# ព្រះគម្ពីរសិក្សា

## សញ្ញាថ្មី

# ព្រះគម្ពីរសិក្សា

## កណ្ឌគម្ពីរ សញ្ញាថ្មី


រៀបរៀងដោយ

ផ្សព្វផ្សាយព្រះបន្ទូលព្រះតាំងពីឆ្នាំ១៩៣៨
Sharing God's Word Since 1938

សម្ព័ន្ធព្រះគម្ពីរកម្ពុជា
SAMPONPRASKUMPI KAMPUCHEA
THE BIBLE LEAGUE CAMBODIA

ប្រអប់សំបុត្រលេខ : ២០៤០ ភ្នំពេញ កម្ពុជា
P.O.Box : 2040 Phnom Penh
Kingdom of Cambodia

# ព្រះគម្ពីរសិក្សា

©អត្ថបទព្រះគម្ពីរ: រក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល អនុញ្ញាតសិទ្ធិប្រើប្រាស់ដោយសមាគមព្រះគម្ពីរកម្ពុជា
©សេចក្ដីពន្យល់ និងខយោង: រក្សាសិទ្ធិដោយសម្ព័ន្ធព្រះគម្ពីរកម្ពុជា
បោះពុម្ពផ្សាយដោយសម្ព័ន្ធព្រះគម្ពីរកម្ពុជា

Scripture Text © United Bible Societies, used by permission from The Bible Society in Cambodia
Study Notes © The Bible League
Published by The Bible League Cambodia

ទស្សនៈរបស់សម្ព័ន្ធព្រះគម្ពីរ

ព្រះអម្ចាស់ទ្រង់បានត្រាស់ហៅយើងទាំងអស់គ្នា ដើម្បីជួយផ្គត់ផ្គង់ព្រះគម្ពីរ និងបណ្ដុះបណ្ដាលមនុស្សទូទាំងពិភពលោក ដែលព្រះវិញ្ញាណបរិសុទ្ធបានដៅចំណាំ ប្រយោជន៍ឱ្យពួកគេបានស្គាល់ទ្រង់ និងបានចូលមកប្រកបគ្នាក្នុងព្រះវិហាររបស់ទ្រង់ ។

កិច្ចការងារបម្រើ

**១. ការជួយផ្គត់ផ្គង់** : ព្រះគម្ពីរ និងសម្ភារៈផ្សាយដំណឹងល្អ បង្កើតសិស្ស បង្កើតព្រះវិហារដល់គ្រប់ស្ថាប័នបម្រើការងារព្រះ និងមនុស្សទាំងឡាយណាដែលត្រូវការក្នុងតម្លៃសមរម្យ ឬតាមសេចក្ដីត្រូវការបែបជាក់ស្ដែងណាមួយ ។ល។

**២. ការជួយលើកទឹកចិត្ត** : បុគ្គល គ្រួសារ និងក្រុមសិក្សាព្រះគម្ពីរ ។

**៣. ការសហការ** : ជាមួយព្រះវិហារគ្រីស្ទបរិស័ទ និកាយ អង្គការផ្សេងៗ ដើម្បីចូលរួមបណ្ដុះបណ្ដាលក្នុងការបង្កើតពួកជំនុំ និងផ្គត់ផ្គង់ ។
ព្រះគម្ពីរ និងសម្ភារៈផ្សេងៗដែលពាក់ព័ន្ធ ក្នុងតម្លៃសមរម្យ ឬអាចជាមធ្យោបាយផ្សេងៗ ។

**៤. ការទទួលខុសត្រូវ** : អ្នករួមចំណែកសម្រាប់ការងារនេះ ត្រូវមានភាពទទួលខុសត្រូវលើវិធានការ និងរបាយការណ៍ក្នុងការផ្ដល់លទ្ធផលដែលយើងទទួលបានគឺ ដោយសារព្រះគុណរបស់ព្រះអម្ចាស់ ។

# អារម្ភកថា

ជាបឋមយើងខ្ញុំជាគណៈកម្មការអភិវឌ្ឍន៍ព្រះគម្ពីរនៃសម្ព័ន្ធព្រះគម្ពីរកម្ពុជា សូមថ្លែងអំណរអរព្រះគុណចំពោះព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានបើកសំដែងអង្គទ្រង់ដល់ប្រជាជនខ្មែរ និងផ្តល់សិទ្ធិគ្រប់គ្រាន់ក្នុងការជួបជុំថ្វាយបង្គំទ្រង់ ហើយក៏សូមអរគុណយ៉ាងខ្លាំងដល់សមាគមព្រះគម្ពីរកម្ពុជាដែលជាគូកនបម្រើព្រះអម្ចាស់យ៉ាងជិតស្និទ្ធនៃយើងខ្ញុំ ក្នុងការអនុញ្ញាតសិទ្ធិបញ្ញា មកសម្ព័ន្ធព្រះគម្ពីរកម្ពុជាប្រើប្រាស់អត្ថបទព្រះគម្ពីរបរិសុទ្ធជាភាសាខ្មែរ បកប្រែចាស់ (ឆ្នាំ១៩៥៤ ដោយ លោកអ័រធើរហាម៉ុង "Old Version by Arthur L Hammond") ដើម្បីរៀបចំជាព្រះគម្ពីរមួយ ដែលមានឈ្មោះថា "**ព្រះគម្ពីរបរិសុទ្ធ សម្រាប់សិក្សា (Khmer Bible Study)**"។

ព្រះគម្ពីរនៅក្នុងដៃរបស់លោកអ្នក គឺជាទ្រព្យសម្បត្តិដ៏សម្បូរបែបខាងឯព្រលឹងវិញ្ញាណ ជាទ្រព្យដ៏មានតម្លៃយ៉ាងពិតប្រាកដ ដែលនាំមកនូវសន្តិភាព អំណរ សុភមង្គល អំណាចព្រះចេស្តារបស់ព្រះ និងគោលដៅថ្មីក្នុងជីវិតរបស់លោកអ្នកនាពេលបច្ចុប្បន្ន និងទៅអនាគត ។ ទ្រព្យសម្បត្តិខាងឯវិញ្ញាណនេះគឺជាមូលដ្ឋានគ្រឹះមួយដែលព្រះអម្ចាស់បានប្រទានមកឱ្យលោកអ្នកមានជីវិតថ្មី ដែលមិនចេះរុះរោយ ដូចព្រះគម្ពីរបានចែងថា: *១២អស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាចឱ្យបានត្រឡប់ជាកូនព្រះ ១៣គឺជាកូនដែលមិនមែនកើតមកពីឈាម ឬតាមប្រាថ្នាខាងរូបសាច់ ឬតាមចំណង់នៃមនុស្សឡើយ គឺកើតមកអំពីព្រះវិញ (យ៉ូហាន ១:១២–១៣)*។ នៅក្នុងព្រះគម្ពីរសិក្សានេះ លោកអ្នកនឹងឃើញទ្រព្យសម្បត្តិខាងឯវិញ្ញាណដែលមានន័យយ៉ាងច្បាស់លាស់ ហើយនាំឱ្យលោកអ្នកទទួលជឿថា ព្រះយេស៊ូវគ្រីស្ទគឺ ជាព្រះរាជបុត្រានៃព្រះ ដោយសេចក្ដីជំនឿនេះហើយដែលដឹកនាំលោកអ្នកឱ្យមានជីវិតនៅក្នុងទ្រង់ (យ៉ូហាន ២០:៣១) ។

យើងខ្ញុំទាំងអស់គ្នាសុទ្ធតែទទួលស្គាល់ថា ឫទ្ធិអំណាចនៃព្រះគម្ពីរគឺជាព្រះបន្ទូលព្រះដ៏ពិតប្រាកដដែលទ្រង់មានបន្ទូលមកកាន់មនុស្សលោក ហេតុដូច្នេះបានជាយើងខ្ញុំប្រឹងប្រែងដោយស្មោះអស់អំពីចិត្តក្នុងការអភិវឌ្ឍន៍ព្រះគម្ពីរខ្មែរនេះឱ្យមានលក្ខណៈកាន់តែងាយស្រួលក្នុងការសិក្សា ហើយមានប្រសិទ្ធិភាពថែមទៀតនៅក្នុងជីវិតជាគ្រីស្ទបរិស័ទនាពេលបច្ចុប្បន្ន ក៏ដូចទៅអនាគត ។ ប៉ុន្តែសួរថា ហេតុអ្វីចាំបាច់ត្រូវការអភិវឌ្ឍន៍ឱ្យមានព្រះគម្ពីរសិក្សានេះនៅពេលដែលអត្ថបទព្រះគម្ពីរមានន័យយ៉ាងច្បាស់លាស់រួចស្រេចទៅហើយនោះ! ពិតហើយ ពុំមានសៀវភៅណាផ្សេងទៀតអាចយកមកជំនួសអត្ថបទគម្ពីរនេះបានឡើយ ។ ជាងនេះទៅទៀត មានតែព្រះវិញ្ញាណមួយអង្គប៉ុណ្ណោះដែលគ្រប់លក្ខណ៍ ហើយមានអំណាចគ្រប់គ្រាន់ក្នុងការបើកចំហរចិត្តមនុស្សឱ្យយល់ពីព្រះបន្ទូលរបស់ទ្រង់បាន ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ព្រះវិញ្ញាណបរិសុទ្ធទ្រង់ប្រើមនុស្សឱ្យបកស្រាយពន្យល់ព្រះបន្ទូលព្រះ ទៅកាន់មនុស្សដទៃទៀតៗផងដែរ ។ គឺព្រះវិញ្ញាណនេះហើយ ដែលបានដឹកនាំសាវ័កភីលីពឱ្យមកជួបនឹងរថរបស់មនុស្សកំរៀវសាសន៍អេធីយ៉ូពីម្នាក់កំពុងតែជិះ ហើយសាវ័ករូបនេះបានសួរទៅគាត់ថា តើលោកមើលយល់ឬទេ? គាត់ក៏ឆ្លើយឡើងថា បើគ្មានអ្នកណាដឹកនាំខ្ញុំ នោះធ្វើដូចម្ដេចឱ្យខ្ញុំយល់បាន?" (កិច្ចការ ៨: ៣០–៣១) ។ បន្ទាប់មក លោកភីលីពក៏ពន្យល់គាត់អំពីទំនាក់ទំនងគ្នារវាងអត្ថបទគម្ពីរសញ្ញាចាស់ និងសេចក្តីដែលចែងអំពីព្រះយេស៊ូវ ។ ទំនាក់ទំនងនេះគឺមានប្រយោជន៍ខ្លាំងណាស់សម្រាប់ជួយពន្យល់អំពីអត្ថន័យនៃទ្រព្យសម្បត្តិខាងឯព្រលឹងវិញ្ញាណនៅក្នុងព្រះគម្ពីរនេះទាំងមូល ។ **តែសូមចាំថា** ជំនួយទាំងនេះគឺគ្រាន់តែជាសេចក្ដីបង្រៀនរបស់គ្រូបង្រៀនព្រះគម្ពីរ ដើម្បីជួយលោកអ្នកឱ្យយល់នូវខ្លឹមសារអត្ថបទព្រះគម្ពីរឱ្យកាន់តែច្បាស់ថែមទៀតប៉ុណ្ណោះ មិនត្រូវបានចាត់ទុកដូចអត្ថបទព្រះគម្ពីរនោះឡើយ ។

## លក្ខណៈពិសេស និងរបៀបប្រើព្រះគម្ពីរសិក្សា

ព្រះគម្ពីរនេះមានអត្ថបទដើមជាព្រះគម្ពីរខ្មែរបកប្រែចាស់ទាំងស្រុង មានទម្រង់ជាលក្ខណៈអន្តរជាតិ មានសេចក្តីផ្តើម ចំណងជើង គម្រោងសង្ខេប ពន្យល់ពាក្យសំខាន់ៗ ខយោង ផែនទី និងតារាងផ្សេងៗ ។

១. អត្ថបទព្រះគម្ពីរមានពីរចន្លោះសងខាង ហើយខយោងនៅចំកណ្ដាល (**ឧ:** *មថ ១:១ "នេះបញ្ជីពង្សាវតារពីព្រះយេស៊ូវគ្រីស្ទ ជាវង្សហ្លួងដាវីឌក..."*) អក្សរ "ក" នៅខាងលើគឺសម្រាប់មើលទៅចំណុចខយោងនៅចន្លោះកណ្ដាល (**ឧ:** ១:១ ក ២សយ ៧:១២–១៦ អស ៩:៦,៧ ១១:១ យរ ២៣:៥,៦ មថ ៩:២៧ លក ១:៣២,៦៩ វវ ២២:១៦) មានន័យថាអត្ថបទនៃព្រះគម្ពីរទាំងអស់នេះគឺនិយាយអំពីហ្លួងដាវីឌ។

២. នៅផ្នែកខាងក្រោមនេះគឺជាសេចក្តីពន្យល់ពាក្យ ឬខណាដែលពិបាកៗ និងខសំខាន់ៗ (**ឧ:** ១:១ បុត្រានៃហ្លួងដាវីឌ) ជាអក្សរទ្រេតសំគាល់ថា ជាពាក្យដកស្រង់ចេញពីព្រះគម្ពីរ ហើយខាងចុងជាសេចក្តីពន្យល់នៃពាក្យនោះ ។

៣. កាលណាឃើញពាក្យថា "មើលការពន្យល់" នោះសូមអានខគម្ពីរនោះជាមុនសិន ទើបងាយយល់នូវសេចក្តីពន្យល់នោះ ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះការគាំទ្រទាំងកម្លាំងកាយ និងកម្លាំងចិត្តពីសំណាក់លោកគ្រូ អ្នកគ្រូគង្វាល អ្នកដឹកនាំ និងគ្រីស្ទបរិស័ទជាច្រើនទាំងនៅភ្នំពេញ និងនៅតាមបណ្ដាខេត្តនានាដែលបានគាំទ្រដល់យើងខ្ញុំក្នុងការធ្វើកិច្ចការនេះ ។

ជាទីបញ្ចប់ សូមលោកអ្នកមេត្តាជួយពិនិត្យផ្តល់មតិ និងសំណូមពរផ្សេងៗ រួចផ្ញើមកយើងខ្ញុំវិញ នោះយើងខ្ញុំរីករាយនឹងទទួលមតិល្អៗ មកអភិវឌ្ឍបន្ថែមទៀត ។ សូមព្រះយេស៊ូវគ្រីស្ទប្រទានពរលោក អ្នកគ្រប់ពេលវេលា!

# បញ្ជីកណ្ឌព្រះគម្ពីរសញ្ញាចាស់


| ឈ្មោះកណ្ឌគម្ពីរ | អក្សរកាត់ | ជំពូក | ទំព័រ |
|---|---|---|---|
| លោកុប្បត្តិ | (លប) | ៥០ | ១ |
| និក្ខមនំ | (នក) | ៤០ | ១១៣ |
| លេវីវិន័យ | (លវ ) | ២៧ | ១៨៩ |
| ជនគណនា | (ជន ) | ៣៦ | ២៣៨ |
| ចោទិយកថា | (ចទ) | ៣៤ | ៣១២ |
| យ៉ូស្វេ | (យស) | ២៤ | ៣៧៤ |
| ពួកចៅហ្វាយ | (ពច) | ២១ | ៤២០ |
| នាងរស់ | (នរ) | ៤ | ៤៧១ |
| សាំយូអែល ទី១ | (១សយ) | ៣១ | ៤៨២ |
| សាំយូអែល ទី២ | (២សយ) | ២៤ | ៥៥៣ |
| ពង្សាវតារក្សត្រ ទី១ | (១ពវ) | ២២ | ៦០៧ |
| ពង្សាវតារក្សត្រ ទី២ | (២ពវ) | ២៥ | ៦៧៦ |
| របាក្សត្រ ទី១ | (១រប) | ២៩ | ៧៤១ |
| របាក្សត្រ ទី២ | (២រប) | ៣៦ | ៧៩៤ |
| អែសរ៉ា | (អរ) | ១០ | ៨៥៣ |
| នេហេមា | (នហ) | ១៣ | ៨៨១ |
| នាងអេសធើរ | (នអ) | ១០ | ៩១៥ |
| យ៉ូប | (យប) | ៤២ | ៩៣១ |
| ទំនុកដំកើង | (ទដ) | ១៥០ | ៩៩២ |
| សុភាសិត | (សភ) | ៣១ | ១២៤៩ |

| ឈ្មោះកណ្ឌគម្ពីរ | អក្សរកាត់ | ជំពូក | ទំព័រ |
|---|---|---|---|
| សាស្ដា | (សស) | ១២ | ១៣១៨ |
| បទចំរៀងសាឡូម៉ូន | (បស) | ៨ | ១៣៣៥ |
| អេសាយ | (អស) | ៦៦ | ១៣៥០ |
| យេរេមា | (យរ) | ៥២ | ១៤៧៩ |
| បរិទេវ | (បទ) | ៥ | ១៦១៨ |
| អេសេគាល | (អគ) | ៤៨ | ១៦៣៣ |
| ដានីយ៉ែល | (ដយ) | ១២ | ១៧៣៩ |
| ហូសេ | (ហស) | ១៤ | ១៧៦៧ |
| យ៉ូអែល | (យអ) | ៣ | ១៧៩០ |
| អេម៉ុស | (អម) | ៩ | ១៨០០ |
| អូបាឌា | (អប) | ១ | ១៨១៩ |
| យ៉ូណាស | (យណ) | ៤ | ១៨២៤ |
| មីកា | (មីក) | ៧ | ១៨៣២ |
| ណាហ៊ុម | (ណហ) | ៣ | ១៨៤៦ |
| ហាបាគុក | (ហប) | ៣ | ១៨៥៣ |
| សេផានា | (សផ) | ៣ | ១៨៦១ |
| ហាកាយ | (ហក) | ២ | ១៨៦៩ |
| សាការី | (សក) | ១៤ | ១៨៧៥ |
| ម៉ាឡាគី | (មឡ) | ៤ | ១៩០០ |


# បញ្ជីកណ្ឌព្រះគម្ពីរសញ្ញាថ្មី


| ឈ្មោះកណ្ឌគម្ពីរ | អក្សរកាត់ | ជំពូក | ទំព័រ |
|---|---|---|---|
| ម៉ាថាយ | (មថ) | ២៨ | ១៩១៤ |
| ម៉ាកុស | (មក) | ១៦ | ១៩៧៦ |
| លូកា | (លក) | ២៤ | ២០២៦ |
| យ៉ូហាន | (យហ) | ២១ | ២១០៨ |
| កិច្ចការ | (កច) | ២៨ | ២១៨៧ |
| រ៉ូម | (រម) | ១៦ | ២២៧៥ |
| កូរិនថូស ទី១ | (១កថ) | ១៦ | ២៣១៩ |
| កូរិនថូស ទី២ | (២កថ) | ១៣ | ២៣៥៦ |
| កាឡាទី | (កទ) | ៦ | ២៣៨១ |
| អេភេសូរ | (អភ) | ៦ | ២៣៩៥ |
| ភីលីព | (ភល) | ៤ | ២៤១៣ |
| កូល៉ុស | (កល) | ៤ | ២៤២៧ |
| ថែស្សាឡូនីច ទី១ | (១ថន) | ៥ | ២៤៣៨ |

| ឈ្មោះកណ្ឌគម្ពីរ | អក្សរកាត់ | ជំពូក | ទំព័រ |
|---|---|---|---|
| ថែស្សាឡូនីច ទី២ | (២ថន) | ៣ | ២៤៤៩ |
| ធីម៉ូថេ ទី១ | (១ធថ) | ៦ | ២៤៥៦ |
| ធីម៉ូថេ ទី២ | (២ធថ) | ៤ | ២៤៦៧ |
| ទីតុស | (ទត) | ៣ | ២៤៧៥ |
| ភីលេម៉ូន | (ភម) | ១ | ២៤៨២ |
| ហេព្រើរ | (ហព) | ១៣ | ២៤៨៥ |
| យ៉ាកុប | (យក) | ៥ | ២៥១៤ |
| ពេត្រុស ទី១ | (១ពត) | ៥ | ២៥២៤ |
| ពេត្រុស ទី២ | (២ពត) | ៣ | ២៥៣៨ |
| យ៉ូហាន ទី១ | (១យហ) | ៥ | ២៥៤៩ |
| យ៉ូហាន ទី២ | (២យហ) | ១ | ២៥៦១ |
| យ៉ូហាន ទី៣ | (៣យហ) | ១ | ២៥៦៣ |
| យូដាស | (យដ) | ១ | ២៥៦៥ |
| វិវរណៈ | (វវ) | ២២ | ២៥៧០ |

# សង្ខេបព្រះគម្ពីរ

ព្រះគម្ពីរសញ្ញាចាស់

ព្រះគម្ពីរសញ្ញាចាស់ត្រូវបានសរសេរឡើងមុនការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ ហើយប្រាប់យើងនូវរបៀបដែលព្រះបានត្រាស់ហៅជនជាតិអ៊ីស្រាអែល និងរបៀបដែលព្រះបានកែឆ្នៃអ៊ីស្រាអែលក្នុងឋានៈពួកគេជារាស្ត្រដ៏ពិសេសរបស់ទ្រង់ ហើយតាមរយៈរាស្ត្រនេះដែលទ្រង់បានប្រទានព្រះរាជបុត្រាទ្រង់តែមួយគត់ឱ្យមកប្រសូត ។ ព្រះគម្ពីរសញ្ញាចាស់ គឺពោរពេញទៅដោយរឿងរ៉ាវនៃអំពើបាបរបស់អ៊ីស្រាអែល ការជំនុំជម្រះ ការអត់ទោស ការនិរទេស និងលាយឡំទៅដោយប្រវត្តិសាស្ត្រ ចំរៀង កំណាព្យក្នុងពេលអ៊ីស្រាអែលថ្វាយបង្គំព្រះ ។ លើសពីនេះទៅទៀតនោះបានប្រាប់នូវរបៀបទទួលព្រះបន្ទូលពីព្រះតាមរយៈពួកហោរា និងក្រឹត្យវិន័យផ្សេងៗសម្រាប់គ្រប់គ្រង និងព្រមានរាស្ត្រអ៊ីស្រាអែល និងជំនុំជំរះនៅពេលគេបានធ្វើបាប ដែលភ្ជាប់មកជាមួយនឹងព្រះបន្ទូលសន្យាអំពីការប្រោសលោះ ការយាងមករបស់ព្រះគ្រីស្ទផង ។

## ព្រះគម្ពីរសញ្ញាចាស់ត្រូវបានចែកជា៤:

### ១. ប្រវត្តិសាស្ត្រ

ព្រះគម្ពីរគឺពោរពេញទៅដោយរឿងរ៉ាវនៃការបង្កើតពិភពលោក ការធ្លាក់ចុះក្នុងអំពើបាបរបស់មនុស្ស ទឹកជំនន់ ដើមកំណើតដំបូងនៃអ៊ីស្រាអែល។ លោកអ្នកនឹងឃើញចាប់ពីលោកុប្បត្តិរហូតដល់នាងអេសធើរ លើកលែងតែលេវីវិន័យ ជនគណនា និងចោទិយកថា។

### ២. ក្រឹត្យវិន័យ

ព្រះគម្ពីរលេវីវិន័យ ជនគណនា និងចោទិយកថា គឺជាព្រះគម្ពីរដំបូងដែលនិយាយអំពីក្រឹត្យវិន័យច្បាប់ស៊ីវិល សម្រាប់គ្រប់គ្រងប្រជារាស្ត្រអ៊ីស្រាអែល និងក្រឹត្យវិន័យខាងសាសនាក្នុងការដឹកនាំការថ្វាយបង្គំ និងក្បួនច្បាប់សម្រាប់ទំនាក់ទំនងផ្សេងៗ មានប្រវត្តិសាស្ត្រ និងក្រឹត្យវិន័យនៅលាយឡំគ្នា ។

### ៣. កំណាព្យ

មាន៥កណ្ឌក្នុងព្រះគម្ពីរសញ្ញាចាស់ដូចជា: យ៉ូប ទំនុកដំកើង សុភាសិត សាស្តា និងបទចំរៀងសាឡូម៉ូន ។ កំណាព្យដែលងាយស្រួលអានជាងគេបំផុតនោះ គឺជាទំនុកដំកើង ដូចជានៅក្នុងទំនុកដំកើងជំពូក២៣ជាដើម សូម្បីតែក្មេងតូចៗ ក៏ចេះកំណាព្យនេះដែរ ហើយពោរពេញទៅដោយសេចក្តីសន្យានៃការថែរក្សាដ៏ផ្អែមល្ហែមរបស់ព្រះដល់អស់អ្នកណាដែលស្រឡាញ់ទ្រង់ ។

### ៤. ទំនាយ

វគ្គចុងក្រោយនៃព្រះគម្ពីរគឺពិបាកអានបន្តិច ដែលសរសេរឡើងដោយពួកហោរានៃសាសន៍អ៊ីស្រាអែល ព្រះគម្ពីរទាំងនេះដោះស្រាយ ជាមួយនឹងការព្រមាននៃអំពើបាប ការជិតមកដល់នៃការជំនុំជម្រះរបស់ព្រះ ការសន្យានៃសេចក្តីសង្គ្រោះ និងទំនាយនៃការយាងមករបស់ព្រះគ្រីស្ទ ដែលចាប់ផ្តើមពីគម្ពីរអេសាយទៅដល់ចុងបញ្ចប់គម្ពីរសញ្ញាចាស់ម៉ាឡាគី ។

ព្រះគម្ពីរសញ្ញាថ្មី

ព្រះគម្ពីរសញ្ញាថ្មីបានពិពណ៌នាអំពីការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ជាព្រះអង្គសង្គ្រោះពិភពលោក លោកអ្នក នឹង ឃើញមានព្រះគម្ពីរ៤ប្រភេទនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។

### អំពីព្រះយេស៊ូវគ្រីស្ទ

ព្រះគម្ពីរ៤កណ្ឌដំបូងត្រូវបានគេហៅថា "ព្រះគម្ពីរដំណឹងល្អ" រួមមានម៉ាថាយ ម៉ាកុស លូកា យ៉ូហាន ព្រះគម្ពីរទាំងនេះបានប្រាប់អំពីកំណើត ការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ ព្រះអង្គបានបើកសំដែងឱ្យមនុស្សទាំងបួននាក់នេះ បានកត់ចុះនូវរឿងរ៉ាវជាច្រើនសម្រាប់អ្នកស្តាប់ អ្នកអានខុសៗគ្នា ហើយគោលបំណងក៏ខុសគ្នាដែរ ព្រមទាំងរបៀបសរសេរក៏ខុសគ្នាទៀត គម្ពីរនិមួយៗបានបញ្ចូលនូវសាច់រឿងសំខាន់ៗនៃដំណើរជីវិតរបស់ព្រះគ្រីស្ទ ។

### អំពីពួកជំនុំ

នៅក្នុងព្រះគម្ពីរកិច្ចការបានប្រាប់យើងអំពីរបៀប និងការរីកចម្រើននៃពួកជំនុំនៅក្នុងគម្ពីរសញ្ញាថ្មី នឹងជាព្រះគម្ពីរដំបូងដែលងាយស្រួលអាន ។

### អំពីសេចក្តីបង្រៀន

ពួកសាវ័កដើមដំបូងបានសរសេរសំបុត្រជាច្រើនផ្ញើទៅកាន់ពួកជំនុំ ហើយនៅក្នុងគម្ពីរសញ្ញាថ្មីត្រូវបានគេហៅថា (សំបុត្រ) សម្រាប់ ជាសេចក្តីបង្រៀនគោលលទ្ធិនៃការរស់នៅជាជីវិតគ្រីស្ទបរិស័ទ ចាប់ផ្តើមពីគម្ពីររ៉ូមដល់យូដាស ។

**អំពីទំនាយ**

ព្រះគម្ពីរវិវរណៈជាគម្ពីរចុងក្រោយ ដែលសំដែងពីទីសំគាល់ចុងក្រោយបំផុតនៃគម្ពីរដំណឹងល្អរបស់គ្រីស្ទបរិស័ទ ហើយនៅពីរជំពូកចុងក្រោយបាននិយាយអំពីរូបភាពយ៉ាងល្អស្អាតនៅឯស្ថានសួគ៌ និងផែនដីថ្មី ដែលព្រះនឹងតាំងឡើងនៅពេលព្រះយេស៊ូវគ្រីស្ទនឹងយាងមកម្តងទៀត ។

ព្រះគម្ពីររបស់គ្រីស្ទបរិស័ទដំណឹងល្អទាំងអស់មាន៦៦កណ្ឌ សញ្ញាចាស់៣៩ និងសញ្ញាថ្មី២៧ បើលើសពីនេះ នោះពុំមែនជាគម្ពីររបស់គ្រីស្ទបរិស័ទ ដំណឹងល្អនោះឡើយ ។

# ដំណឹងល្អ

តាមលោកម៉ាថាយ

សេចក្ដីផ្ដើម

**អ្នកនិពន្ធ**

លោកម៉ាថាយ គឺជាអ្នកដឹកនាំពួកជំនុំដំបូងម្នាក់ ក្នុងចំណោមសិស្សព្រះយេស៊ូវទាំង១២នាក់ ហើយលោកក៏ជាអ្នកនិពន្ធព្រះគម្ពីរដំណឹងល្អម៉ាថាយនេះផងដែរ ។ យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ពួកអ្នកប្រាជ្ញព្រះគម្ពីរមួយចំនួនបានវាយតម្លៃថា គម្ពីរម៉ាថាយនេះត្រូវបានដកស្រង់ចំណុចខ្លះៗពីព្រះគម្ពីរដំណឹងល្អម៉ាកុស ហើយថែមទាំងបានបដិសេធថា លោកម៉ាថាយមិនមែនជាអ្នកនិពន្ធគម្ពីរម៉ាថាយនេះទៀតផង ។ ប៉ុន្តែសួរថា តើលោកម៉ាថាយជាអ្នកបានឃើញនូវព្រឹត្តិការណ៍ទាំងឡាយនៃជីវិតរបស់ព្រះយេស៊ូវដោយផ្ទាល់ ឬក៏គាត់គ្រាន់តែជាអ្នកកត់ត្រាហេតុការណ៍ទាំងនេះ ដោយសំអាងលើព្រះគម្ពីរម៉ាកុសតែប៉ុណ្ណោះឬអី? នោះចម្លើយបានបញ្ជាក់យ៉ាងប្រាកដច្បាស់ថា លោកម៉ាថាយគឺជាសាវ័ក របស់ព្រះយេស៊ូវគ្រីស្ទម្នាក់ដែលបានធ្វើទីបន្ទាល់ពីទ្រង់ដោយផ្ទាល់ ហើយក៏ជាអ្នកបានសរសេរគម្ពីរម៉ាថាយនេះយ៉ាងពិតប្រាកដផងដែរ ។

ម៉ាថាយមានន័យថា "អំណោយរបស់ព្រះអម្ចាស់" លោកម៉ាថាយជាអតីតអ្នកយកពន្ធម្នាក់ដែលបានលះបង់ការងាររបស់ខ្លួនចោល ហើយដើរតាមព្រះយេស៊ូវវិញ(៩:៩-១៣)។ យោងតាមព្រះគម្ពីរម៉ាកុស និងលូកាបានប្រាប់ថា គាត់មានឈ្មោះដើមផ្សេងមួយទៀតគឺ លេវី ។

**ទីកន្លែង និងកាលបរិច្ឆេទនៃការសរសេរ**

ដំណឹងល្អម៉ាថាយប្រហែលជាបានសរសេរឡើងនៅក្នុងប្រទេសភីលីស្ទីន(ប៉ាឡេស្ទីន) តែមានមនុស្សជាច្រើនគិតថាមានប្រភពមកពីស៊ីរី-អាន់ទីយ៉ូក ។ អ្នកខ្លះបានជជែកវែកញែកលើមូលដ្ឋានអំពីចរិតលក្ខណៈនៃសាសន៍យូដាថា កណ្ឌគម្ពីរនេះត្រូវបានសរសេរឡើងក្នុងអំឡុងពេលពួកជំនុំដំបូង គឺប្រហែលជានៅដើមឆ្នាំទី៥០គ.ស ។ ពួកជំនុំ និងដំណឹងល្អភាគច្រើនបានសំដៅទៅសាសន៍យូដាតែមួយប៉ុណ្ណោះ(កិច្ចការ ១១:១៩)។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានអ្នកខ្លះបានសន្និដ្ឋានថា គម្ពីរម៉ាថាយ និងគម្ពីរលូកាភាគច្រើនបានដកស្រង់ចេញពីគម្ពីរម៉ាកុសដែរ ព្រោះគម្ពីរនេះបានផ្សព្វផ្សាយចេញមុនគម្ពីរម៉ាថាយ និងគម្ពីរលូកា ។ អ្នកខ្លះគិតថាគម្ពីរម៉ាថាយបានសរសេរនៅចុងទសវត្សរ៍ទី៥០ឬ៦០គ.ស ។ ចំណែកអ្នកឯទៀតគិតថា ព្រះគម្ពីរម៉ាកុសបានសរសេរនៅចន្លោះឆ្នាំទី៦៥ និង៧០គ.ស ហើយថាព្រះគម្ពីរម៉ាថាយក្នុងទសវត្សរ៍ទី៧០ ឬក្រោយនេះទៅទៀត ។

**អ្នកទទួល**

ដោយព្រោះព្រះគម្ពីរដំណឹងល្អបានសរសេរជាភាសាក្រិក នោះអ្នកអានគម្ពីរម៉ាថាយគឺប្រាកដជាអ្នកនិយាយភាសាក្រិក ហើយក៏ប្រហែលជាជនជាតិយូដាផងដែរ ដោយមានចំណុចសំខាន់ៗជាច្រើនបានបង្ហាញពីសាសន៍១នេះ ។ លោកម៉ាថាយបានយកចិត្តទុកដាក់ជាមួយនឹងការសម្រេចទំនាយនៃព្រះគម្ពីរសញ្ញាចាស់(គាត់ដកស្រង់ និងនិយាយពីព្រះគម្ពីរសញ្ញាចាស់ច្រើនជាងអ្នកនិពន្ធព្រះគម្ពីរសញ្ញាថ្មីផ្សេងៗទៀត)។ លោកម៉ាថាយ បានបញ្ជាក់ពីបញ្ជីពង្សាវតារព្រះយេស៊ូវគ្រីស្ទ ថាមានខ្សែលោហិតចេញពីលោកអ័ប្រាហាំ(១:១-១៧) តែមានការខ្វះខាតនៃការពន្យល់ពីទំនៀមទម្លាប់របស់សាសន៍យូដា(ជាពិសេសវាផ្ទុយទៅនឹងគម្ពីរម៉ាកុស)។ ចំពោះការប្រើពាក្យបច្ចេកទេសរបស់សាសន៍យូដា(ឧទាហរណ៍ "នគរស្ថានសួគ៌" និង "ព្រះវរបិតានៅស្ថានសួគ៌")។ ពាក្យ "ស្ថានសួគ៌" យើងដឹងថាពួកគេស្ទើរតែមិនហ៊ានប្រើពាក្យទាំងនេះ ឬក៏ព្រះនាមព្រះនោះឡើយ(បើគេប្រើ គឺប្រើដោយគោរពបំផុត) គឺប្រើតែពាក្យ "ព្រះរាជបុត្រាហ្លួងដាវីឌ"ជំនួសវិញ(១:១ ៩:២៧ ១២:២៣ ១៥:២២ ២០:៣០-៣១ ២១:៩,១៥ ២២:៤១-៤៥)។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏មិនមែនមានន័យថា ដំណឹងល្អរបស់លោកម៉ាថាយសម្រាប់តែសាសន៍យូដានោះដែរ គាត់បានសរសេរពីការធ្វើដំណើររបស់ហោរា (មិនមែនជាសាសន៍យូដា) បានមកថ្វាយបង្គំព្រះបុត្រតូចយេស៊ូវ(២:១-១២)។ ព្រះយេស៊ូវមានបន្ទូលថា "ចំណែកស្រែនោះ គឺជាតួរបស់លោកីយ" (១៣:៣៨) និងមហាបេសកកម្ម(២៨:១៨-២០)។ ត្រង់នេះបង្ហាញថាគម្ពីរដំណឹងល្អម៉ាថាយគឺសម្រាប់សាសន៍យូដា និងសម្រាប់គ្រប់សាសន៍នៅក្នុងពិភពលោកទាំងមូល ។

**គោលបំណង**

គោលបំណងសំខាន់គឺបង្ហាញភស្តុតាងដល់អ្នកអាន(សាសន៍យូដា)ថា ព្រះយេស៊ូវគឺជាព្រះមែស៊ីរបស់ពួកគេ ។ ដំបូងគាត់បានបង្ហាញអំពីជីវិត និងព្រះរាជកិច្ចរបស់ទ្រង់ដែលបានសម្រេចទំនាយក្នុងគម្ពីរសញ្ញាចាស់ ។ ថ្វីបើអ្នកនិពន្ធទាំងអស់សុទ្ធតែបានដកស្រង់ចេញពីគម្ពីរសញ្ញាចាស់ក៏ដោយ តែចំពោះលោកម៉ាថាយវិញបានបូកបញ្ចូលភស្តុតាង៩ថែមទៀត(១:២២-២៣ ២:១៥ ២:១៧-១៨ ២:២៣

៤:១៤-១៦ ៨:១៧ ១២:១៧-២១ ១៣:៣៥ ២៧:៩-១០) ដើម្បីឆ្លោះតម្រង់ទៅរកតួអង្គព្រះយេស៊ូវថា ទ្រង់គឺជាព្រះមែស៊ីដែលបានសម្រេចតាមទំនាយក្នុងគម្ពីរសញ្ញាចាស់ ។ មិនត្រឹមតែប៉ុណ្ណោះ គាត់ថែមទាំងរកឃើញជីវប្រវត្តិរាស្ត្ររបស់ព្រះអង្គនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ហើយមកសរុបក្នុងទិដ្ឋភាពនៃជីវិតរបស់ទ្រង់ (ហាស ១១:១ មថ ២:១៥)។ ដើម្បីសម្រេចគោលបំណង លោកម៉ាថាយបានបញ្ជាក់ថា ព្រះយេស៊ូវជាវង្សខ្សែលោហិតពិតប្រាកដរបស់ស្តេចដាវីឌ (មើល"អ្នកទទួល")។

**សង្ខេបរចនាបថ**

របៀបតាក់តែងគឺត្រូវបានរៀបចំឡើងដោយបង្ហាញឱ្យឃើញច្បាស់ពីទំនាក់ទំនងយ៉ាងប៉ិនប្រសប់ផ្នែកសិល្បៈនៃការសរសេរ ។ គម្ពីរដំណឹងល្អម៉ាថាយទាំងមូលបានចែកចេញជាប្រាំផ្នែកធំៗ (១).ជំពូក ៥-៧ (២).ជំពូក ១០ (៣).ជំពូក ១៣ (៤).ជំពូក ១៨ និង (៥).ជំពូក ២៤-២៥ ទាំងនេះគឺជាការដែលបានគិតទុកមុនយ៉ាងច្បាស់ ដើម្បីបន្តរនៅពេលបញ្ចប់អត្ថបទនីមួយៗ "កាលព្រះយេស៊ូវទ្រង់មានបន្ទូលពីសេចក្តីទាំងនេះរួចហើយ"(៧:២៨ ១១:១ ១៣:៥៣ ១៩:១ ២៦:១)។ ការរៀបរាប់ពីរឿងរាវទាំងនោះគឺ សម្រាប់នាំឆ្ពោះទៅរកអត្ថន័យដែលមាននៅក្នុងសេចក្តីផ្តើម(ជំពូក១-២) និងសេចក្តីបញ្ចប់ (២៨:១៦-២០) នៃព្រះគម្ពីរដំណឹងល្អម៉ាថាយដែលមានភាពស៊ីចង្វាក់គ្នាយ៉ាងល្អ ។

ព្រះគម្ពីរប្រាំកណ្ឌដំបូង(សញ្ញាចាស់) ប្រហែលជាអាចប្រាប់បានថាលោកម៉ាថាយបានយកមកធ្វើជាគំរូនូវរចនាបថ ហើយអាចជាការបង្ហាញនូវការប្រៀបធៀបនឹងព្រះគម្ពីរដំណឹងល្អម៉ាថាយទៅនឹងក្រឹត្យវិន័យថ្មី ហើយព្រះយេស៊ូវបានយាងមកនោះ គឺវិសេសហើយធំជាងលោកម៉ូសេទៀតផង ។

**គម្រោងសង្ខេប**

**I. កំណើត និងឆ្នាំដំបូងរបស់ព្រះយេស៊ូវ (ជំពូក ១-២)**

ក. ពង្សាវតាររបស់ទ្រង់ (១:១-១៧)

ខ. កំណើតរបស់ទ្រង់ (១:១៨-២:១២)

គ. ការភៀសខ្លួនទៅស្រុកអេស៊ីព្ទ (២:១៣-២៣)

**II. ដើមដំបូងនៃព្រះរាជកិច្ចរបស់ព្រះយេស៊ូវ (៣:១-៤:១១)**

ក. ការរៀបផ្លូវថ្វាយទ្រង់ (៣:១-១២)

ខ. ពិធីបុណ្យជ្រមុជទឹក (៣:១៣-១៧)

គ. ការជួបសេចក្តីល្បួង (៤:១-១១)

**III. ព្រះរាជកិច្ចរបស់ព្រះយេស៊ូវនៅស្រុកកាលីឡេ (៤:១២-១៤:១២)**

ក. ការចាប់ផ្តើមប្រកាសដំណឹងល្អនៅស្រុកកាលីឡេ (៤:១២-២៥)

ខ. សេចក្តីអធិប្បាយនៅលើភ្នំ (ជំពូក ៥-៧)

គ. ការប្រមូលផ្តុំនៃការអស្ចារ្យ (ជំពូក ៨-៩)

ឃ. បេសកកម្មរបស់សាវ័កទាំង១២នាក់ (ជំពូក ១០)

ង. ព្រះរាជកិច្ចទូទាំងស្រុកកាលីឡេ (ជំពូក ១១-១២)

ច. ការប្រៀបប្រដូចនៃនគរព្រះ (ជំពូក ១៣)

ឆ. ប្រតិកម្មរបស់ស្តេចហេរ៉ូឌ ចំពោះព្រះរាជកិច្ចរបស់ព្រះយេស៊ូវ (១៤:១-១២)

**IV. ព្រះយេស៊ូវយាងចេញពីស្រុកកាលីឡេ (១៤:១៣-១៧:២០)**

ក. ការយាងទៅច្រាំងសមុទ្រកាលីឡេភាគខាងជើង (១៤:១៣-១៥:២០)

ខ. ការយាងទៅស្រុកភេនីស(១៥:២១-២៨)

គ. ការយាងទៅស្រុកដេកាប៉ូល (១៥:២៩-១៦:១២)

ឃ. ការយាងទៅស្រុកសេសារា-ភីលីព (១៦:១៣-១៧:២០)

**V. ព្រះរាជកិច្ចចុងក្រោយរបស់ព្រះយេស៊ូវនៅស្រុកកាលីឡេ (១៧:២២-១៨:៣៥)**

ក. ទំនាយពីការសុគតរបស់ព្រះយេស៊ូវ (១៧:២២-២៣)
ខ. ពន្ធព្រះវិហារ (១៧:២៤-២៧)
គ. មេរៀនពីជីវិតនៅឯស្ថានសួគ៌ (ជំពូក ១៨)

**VI. ព្រះរាជកិច្ចរបស់ទ្រង់នៅស្រុកយូដា និងស្រុកពីរេ (ជំពូក ១៩-២០)**

ក. សេចក្ដីបង្រៀនដែលទាក់ទងទៅនឹងការលែងលះប្ដីប្រពន្ធ (១៩:១-១២)
ខ. សេចក្ដីបង្រៀនដែលទាក់ទងទៅនឹងកូនក្មេងតូចៗ (១៩:១៣-១៥)
គ. បុរសអ្នកមានវ័យក្មេង (១៩:១៦-៣០)
ឃ. រឿងប្រៀបប្រដូចអំពីអ្នកធ្វើការនៅចំការទំពាំងបាយជូរ (២០:១-១៦)
ង. បទទំនាយពីការសុគតរបស់ព្រះយេស៊ូវ (២០:១៧-១៩)
ច. សំណូមពររបស់អ្នកម្ដាយ (២០:២០-២៨)
ឆ. មនុស្សខ្វាក់មើលឃើញ (នៅក្រុងយេរីខូរ) (២០:២៩-៣៤)

**VII. សប្ដាហ៍នៃការរងទុក្ខ (ជំពូក ២១-២៧)**

ក. ផ្លូវនៃជ័យជម្នះ (២១:១-១១)
ខ. ការសំអាតព្រះវិហារ (២១:១២-១៧)
គ. ការប្រឈមមុខចុងក្រោយជាមួយនឹងពួកអ្នកដឹកនាំសាសន៍យូដា (២១:១៨-២៣:៣៩)
ឃ. ការបង្រៀននៅលើភ្នំដើមអូលីវអំពីទីអវសាននៃពិភពលោក (ជំពូក ២៤-២៥)
ង. ការចាក់ប្រេងក្រអូបលើព្រះយេស៊ូវនៅភូមិបេថានី (២៦:១-១៣)
ច. ការចាប់ខ្លួន ការកាត់ទោស និងការសុគត (២៦:១៤-២៧:៦៦)

**VIII. ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ (ជំពូក ២៨)**

ក. ការរំជួយផែនដី និងសេចក្ដីប្រកាសរបស់ទេវតា (២៨:១-៧)
ខ. ការជួបគ្នារវាងព្រះយេស៊ូវ និងពួកស្ត្រី (២៨:៨-១០)
គ. របាយការណ៍របស់ពួកអ្នកយាម និងសំណូករបស់ពួកចាស់ទុំសាសន៍យូដា (២៨:១១-១៥)
ឃ. មហាបេសកកម្ម (២៨:១៦-២០)

## ពង្សាវតាររបស់ព្រះយេស៊ូវ

*១:១–១៧ = លក ៣:២៣–៣៨ ១:៣–៦ = នរ ៤:១៨–២២*
*១:៧–១១ = ១ រប ៣:១០–១៧*

**១** ១នេះបញ្ជីពង្សាវតារពីព្រះយេស៊ូវគ្រីស្ទ ជាវង្សាហ្លួង
ដាវីឌ[ក]និងជាជំនួរវង្សនៃលោកអ័ប្រាហាំ[ខ]ដែរ ២អ័ប្រាហាំ
បង្កើតអ៊ីសាក។[គ]បង្កើតយ៉ាកុប។[ឃ]បង្កើតយូដា ហើយនិងបង
ប្អូន[ង]គាត់ ៣យូដាយកនាងតាម៉ារ[ច]បង្កើតបានពេរេស និង
សេរ៉ាស ពេរេសបង្កើតហេស្រុន។បង្កើតអើរ៉ាម ៤អើរ៉ាម
បង្កើតអ័មីនាដាប់។បង្កើតណាសូន។បង្កើតសាលម៉ូន
៥សាលម៉ូនយកនាងរ៉ាហាប[ឆ]បង្កើតបានបូអូស។យកនាង
រស់ បង្កើតបានអូបិឌ។បង្កើតអ៊ីសាយ ៦អ៊ីសាយបង្កើត
ដាវីឌ[ជ]ដ៏ជាស្តេច ស្តេចដាវីឌយកប្រពន្ធរបស់អ៊ូរី[ឈ] បង្កើត
បានសាឡូម៉ូន ៧សាឡូម៉ូនបង្កើតរេហូបោម។បង្កើតអ័របី–
យ៉ាអ័របីយ៉ាបង្កើតអេសា ៨អេសាបង្កើតយ៉ូសាផាត។
បង្កើតយ៉ូរ៉ាម។បង្កើតអូសៀស ៩អូសៀសបង្កើតយ៉ូថាម។
បង្កើតអេហាស។បង្កើតអេសេគាស ១០អេសេគាសបង្កើត
ម៉ានាសេ។[ញ] បង្កើតអាំម៉ូន។បង្កើតយ៉ូសៀស ១១យ៉ូសៀស
បង្កើតយេកូនាស ហើយនិងបងប្អូនគាត់ នៅគ្រាដែលត្រូវ
និរទេសទៅស្រុកបាប៊ីឡូន[ដ] ១២ក្រោយដែលត្រូវនិរទេស
ទៅស្រុកបាប៊ីឡូនហើយ នោះយេកូនាសបង្កើតបាន
សាលធាល។[ឋ] បង្កើតបានសូរ៉ូបាបិល[ឌ] ១៣សូរ៉ូបាបិលបង្កើត
អ័ប៊ីយុឌ។ បង្កើតអេលាគីម។បង្កើតអេសូរ ១៤អេសូរបង្កើត
សាដុក។បង្កើតអេគីម។បង្កើតអេលីយុឌ ១៥អេលីយុឌបង្កើត
អេលាសារ។បង្កើតម៉ាថាន។បង្កើតយ៉ាកុប ១៦យ៉ាកុប
បង្កើតយ៉ូសែប ជាប្តីនាងម៉ារា[ឍ] មាតាព្រះយេស៊ូវ ដែល
ហៅថា «ព្រះគ្រីស្ទ»[ណ] ១៧ដូច្នេះ តាំងពីអ័ប្រាហាំដរាបមក
ដល់ហ្លួងដាវីឌ រួមទាំងអស់មាន១៤ដំណ តាំងពីហ្លួងដាវីឌ
ដរាបមកដល់គ្រាដែលត្រូវនិរទេសទៅស្រុកបាប៊ីឡូន ក៏
មាន១៤ដំណហើយតាំងពីគ្រាដែលត្រូវនិរទេសទៅស្រុកបា
ប៊ីឡូន ដរាបមក ដល់ព្រះគ្រីស្ទ ក៏មាន១៤ដំណដែរ ។

### កំណើតព្រះយេស៊ូវគ្រីស្ទ

១៨រីឯកំណើតព្រះយេស៊ូវគ្រីស្ទ នោះបានកើតមក យ៉ាង
ដូច្នេះ គឺនាងម៉ារា មាតាទ្រង់ កាលដែលយ៉ូសែបបាន
ដណ្តឹងនាងហើយ នោះនាងមានគភ៌ ដោយព្រះវិញ្ញាណ
បរិសុទ្ធ[ត] មុនដែលបាននៅជាមួយគ្នា ១៩ឯយ៉ូសែបប្តីនាងជា

**១:១** ក ២សយ ៧:១២–១៦ អស ៩:៦.៧ ១១:១ យរ ២៣:៥,៦ មថ៩:២៧ លក ១:៣២,៦៩ វវ ២២:១៦ ខ លប ២២:១៨ កទ ៣:១៦ **១:២** គ លប ២១:៣,១២ ឃ លប ២៥:២៦ ង លប ២៩:៣៥ ៤៩:១០ **១:៣** ច លប ៣៨:២៧–៣០ **១:៥** ឆ ហព ១១:៣១ **១:៦** ជ ១សយ ១៦:១ ១៧:១២ ឈ ២សយ ១២:២៤ **១:១០** ញ ២ពវ ២០:២១ **១:១១** ដ ២ពវ ២៤:១៤–១៦ យរ ២៧:២០ ៤០:១ ដយ ១:១,២ **១:១២** ឋ ១រប ៣:១៧ ឌ ១រប ៣:១៩ អរ ៣:២ **១:១៦** ឍ លក ១:២៧ ណ មថ ២៧:១៧ **១:១៨** ត លក ១:៣៥

**១:១–១៦** ចំពោះការប្រៀបធៀបពង្សាវតារក្នុងព្រះគម្ពីរម៉ាថាយទៅនឹងព្រះគម្ពីរលូកា សូមមើលការពន្យល់ "លក ៣:២៣–៣៨" ។ បណ្តាជននៅក្នុងពង្សាវតារដែលបានពោលមកនេះ នឹងបើកសំដែងឱ្យឃើញយ៉ាងច្បាស់ពីបញ្ជីរាស្ត្ររបស់ព្រះ និងពង្សាវតារនៃព្រះយេស៊ូវ ។

**១:១** *ជាវង្សហ្លួងដាវីឌ* ពាក្យនេះត្រូវបានប្រើយ៉ាងច្រើននៅក្នុងគម្ពីរដំណឹងល្អ ដោយជំនួសពាក្យព្រះមែស៊ី (១:២០ ៩:២៧)។ *ជំនួរវង្សនៃលោកអ័ប្រាហាំ* បានជាលោកម៉ាថាយប្រើព្រះនាមព្រះយេស៊ូវដូច្នេះ ពីព្រោះគាត់កំពុងតែសរសេរទៅសាសន៍យូដា(លប ១២:២–៣ ១៥:៩–២១ ជំពូក១៧ និងការពន្យល់ សក ៩:១០)។

**១:៣** *តាម៉ារ* បញ្ជីឈ្មោះក្នុងគម្ពីរម៉ាថាយមានស្ត្រី៤នាក់ឈ្មោះតាម៉ារ រ៉ាហាប (ខ.៥) នាងរស់(ខ.៥) និងបាតសេបា(មិនបានសរសេរចំឈ្មោះទេ គឺដោយការពណ៌នាពី"ម្តាយសាឡូម៉ូនជាអតីតប្រពន្ធអ៊ូរី"ខ.៦)។ យ៉ាងហោចណាស់មានបីនាក់ដែរ ដែលជាសាសន៍ដទៃ(តាម៉ារ រ៉ាហាប នាងរស់)។ នាងបាតសេបា អាចជា សាសន៍យូដា(១រប ៣:៥) ប៉ុន្តែ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសាសន៍ហេតពីព្រោះប្តីដើមរបស់នាងជាសាសន៍ហេត ។ ការរាប់បញ្ចូលស្ត្រីទាំងនេះ (ផ្ទុយនឹងប្រពៃណីសាសន៍យូដា) តែលោកម៉ាថាយបានបង្ហាញប្រាប់តាំងពីដើមដំបូងនៃកណ្ឌគម្ពីរដំណឹងល្អនេះថា ព្រះរាជកិច្ចរបស់ព្រះមិនកំណត់ថា សាសន៍អ៊ីស្រាអែល ឬសាសន៍ដទៃនោះឡើយ ។

**១:៤** *អ័មីនាដាប់* ជាឪពុកក្មេករបស់លោកអើរ៉ុន(នក ៦:២៣) ។

**១:៥** *រ៉ាហាប* នៅជំនាន់ដូនតារបស់រ៉ាហាប និងស្តេចដាវីឌ លោកម៉ាថាយឥតបានកត់ចុះទេ(២ សយ) នេះជារបៀបសរសេររបស់គាត់(មើលការពន្យល់ ខ.១៧)។

**១:៨** *យ៉ូរាម* ជាឪពុកអូសៀស ប៉ុន្តែនៅក្នុង(២រប ២១:៤–២៦:២៣)ឃើញមានតែជំនាន់ខ្លះ ដែលបានរាប់បញ្ចូល(អ័ហាស៊ីយ៉ា យ៉ូអាស និងអ័ម៉ាស៊ីយ៉ា)

**១:១១** *យ៉ូសៀសបង្កើតយេកូនាស* តាមពិតយ៉ូសៀសជាឪពុករបស់យេហូ–យ៉ាគីម ហើយជាជីតារបស់យេកូនាស(ដែលគេហៅថា យ៉ូយ៉ាគីន"២រប ៣៦:១–៩")។

**១:១២** *សាលធាល* មើលការពន្យល់ ១រប ៣:១៩ ។

**១:១៦** លោកម៉ាថាយមិនបាននិយាយថាយ៉ូសែបជាឪពុកព្រះយេស៊ូវទេ គឺគ្រាន់តែថាលោកយ៉ូសែបជាប្តីនាងម៉ារា ហើយព្រះយេស៊ូវជាកូនរបស់នាងម៉ារា ។ តាមពង្សាវតារនេះ លោកម៉ាថាយចង់បង្ហាញថា ទោះបីព្រះយេស៊ូវពុំមែនជាកូនលោកយ៉ូសែបខាងសាច់ឈាមក៏ដោយ ក៏ទ្រង់ជាកូនស្របច្បាប់ដែលមានជាប់នាមត្រកូលរបស់ស្តេចដាវីឌបានដែរ ។

**១:១៧** *១៤ ដំណ. . . ១៤ . . .១៤ . . .* ការបែងចែកនេះបានឆ្លុះបញ្ចាំងអំពីចរិតលក្ខណៈពីរយ៉ាងនៃដំណឹងល្អម៉ាថាយ (១).ការចូលចិត្តខ្លាំង (២).ទាក់ទងនឹងប្រព័ន្ធរៀបចំ។ លេខ១៤ប្រហែលត្រូវបានគេជ្រើសរើស ពីព្រោះ៧ពីរដងស្មើនឹង១៤(ចំនួនគ្រប់លក្ខណៈ) ឬពីព្រោះវាជាតម្លៃលេខនៃឈ្មោះរបស់ស្តេចដាវីឌ (មើលការពន្យល់ វវ ១៣:១៨) (សេចក្តីលំអិតមាននៅក្នុងសេចក្តីផ្តើមនៃព្រះគម្ពីររបាក្សត្រទី១)។

**១:១៨** *ដណ្តឹងនាងហើយ* (ភ្ជាប់ពាក្យហើយ) ចំពោះសាសន៍យូដាគ្មានការរួមរស់ខាងផ្លូវភេទជាមួយគ្នាឡើយ តែត្រូវបានគេហៅថាប្តីប្រពន្ធនឹងគ្នា ។ ពួកគេរស់នៅយ៉ាងស្និទ្ធស្នាលបំផុត ហើយបើគេចង់លែងលះគ្នានោះ គឺធ្វើដូចជាការលែងលះប្តីប្រពន្ធពិតៗដែរ(ខ.១៩) ។ "ចទ ២២:២៤"ស្ត្រីដែល

មនុស្សសុចរិត គាត់មិនចង់បើករឿងនាងឱ្យគេដឹងទេ បាន
ជាគាត់គិតលែង[ថ]នាងចេញ ដោយសំងាត់វិញ ២០កាល
ដែលគាត់កំពុងតែគិតពីការនោះ ស្រាប់តែមានទេវតា[ទ]នៃ
ព្រះអម្ចាស់ លេចមកពន្យល់សប្តិ[ធ] ប្រាប់គាត់ថា យ៉ូសែប
ពូជហ្លួងដាវីឌអើយ កុំឱ្យខ្លាចនឹងយកនាងម៉ារាជាប្រពន្ធ
អ្នកឡើយ ដ្បិតបុត្រដែលមកចាប់ទំផ្ទៃនាង នោះកើតពី
ព្រះវិញ្ញាណបរិសុទ្ធទេ ២១នាងនឹងប្រសូតបុត្រា១ ហើយ
អ្នកត្រូវថ្វាយព្រះនាមថា «យេស៊ូវ»[ន] ព្រោះបុត្រនោះ
នឹងជួយសង្គ្រោះរាស្ត្រទ្រង់ឱ្យរួចពីបាប[ប] ២២ការទាំងនោះ
កើតមកដើម្បីឱ្យបានសំរេច[ផ]សេចក្តី ដែលព្រះអម្ចាស់ទ្រង់
មានបន្ទូល ដោយសារហោរាថា ២៣«មើល នាង
ព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រា១ ហើយព្រះនាមបុត្រ
នោះត្រូវហៅថា អេម៉ាញូអែល»[ព] ដែលប្រែថា ព្រះអង្គ
ទ្រង់គង់ជាមួយនឹងយើងខ្ញុំ ២៤លុះយ៉ូសែបភ្ញាក់ពីដេក
ឡើងនោះគាត់ក៏ធ្វើតាមបង្គាប់ របស់ទេវតា[ភ]នៃព្រះអម្ចាស់
គឺគាត់យកប្រពន្ធមកនៅជាមួយ ២៥តែមិនបានរួមរស់នឹង
នាងសោះ ទាល់តែនាងប្រសូតបុត្រជាចំបងមក រួចគាត់
ថ្វាយព្រះនាមថា «យេស៊ូវ»[ម]។

## ការសួរសុខទុក្ខរបស់ហោរា

**២** ១កាលព្រះយេស៊ូវទ្រង់ប្រសូតមក នៅភូមិបេថ្លេហិម
ស្រុកយូដា[ក] ក្នុងរាជ្យស្តេចហេរ៉ូឌ[ខ] នោះមានពួកហោរ ពី
ទិសខាងកើត មកដល់ក្រុងយេរូសាឡិមសួរថា ២តើព្រះអង្គ
ដែលប្រសូតមក ធ្វើជាស្តេចសាសន៍យូដា[គ] ទ្រង់គង់នៅ
ឯណា ពីព្រោះយើងបានឃើញផ្កាយ[ឃ]របស់ទ្រង់ពីទិស
ខាងកើតមក ហើយយើងមកថ្វាយបង្គំទ្រង់។

៣កាលស្តេចហេរ៉ូឌបានឮ នោះទ្រង់មានសេចក្តីវិតក្ក
ព្រួយ ព្រមទាំងពួកអ្នកនៅក្រុងយេរូសាឡិមទាំងអស់គ្នាផង
៤កាលបានប្រជុំពួកសង្គ្រាជ និងពួកអាចារ្យនៃបណ្តាជនមក

**១:១៩** ថ ចទ ២៤:១
**១:២០** ទ កច ៥:១៩ ធ មថ ២៧:១៩
**១:២១** ន លក ១:៣១ ប ទដ ១៣០:៨ លក ២:១១ យហ ៣:១៧ កច ៥:៣១ រម ១១:១៤ ទត ២:១៤
**១:២២** ផ មថ ២:១៥,១៧,២៣ ៤:១៤ ៨:១៧ ១២:១៧ ២១:៤ ២៦:៥៤,៥៦ ២៧:៩ លក ៤:២១ ២១:២២ ២៤:៤៤ យហ ១៣:១៨ ១៩:២៤,២៨,៣៦
**១:២៣** ព អស ៧:១៤ ៨:៨,១០
**១:២៤** ភ កច ៥:១៩
**១:២៥** ម ខ.២១ លក ១:៣១ **២:១** ក លក ២:៤-៧ ខ លក ១:៥
**២:២** គ យរ ២៣:៥ មថ ២៧:១១ មក ១៥:២ លក ២៣:៣៨ យហ ១:៤៩ ១៨:៣៣–៣៧ ឃ ជន ២៤:១៧

បានភ្ជាប់ពាក្យរួច ត្រូវបានហៅថា "ប្រពន្ធ"។ លោកម៉ាថាយប្រើពាក្យថា ប្តីប្រពន្ធនេះ គឺតាមប្រពៃណីរបស់ពួកយូដា នាងម៉ារាមានគភ៌មុនពេលរៀបការ និងរួមរស់ជាមួយលោកយ៉ូសែបនោះទៅទៀត(ខ.១៩,២៤)។

**១:១៩** *សុចរិត* ចំពោះសាសន៍យូដាសំដៅលើមនុស្សដែលឧស្សាហ៍ព្យាយាមប្រព្រឹត្តតាមក្រឹត្យវិន័យរបស់ព្រះអម្ចាស់ ។ *លែងនាងចេញដោយសំងាត់វិញ* មាន ន័យថា គាត់នឹងចុះហត្ថលេខាលើក្រដាសតាមផ្លូវច្បាប់ណាមួយរបស់រដ្ឋ មិនមែនដោយការ កាត់ក្តីជាសាធារណៈ ហើយចោលនាងនឹងដុំថ្មនោះឡើយ (ចទ ២២:២៣–២៤)។

**១:២០** *មកពន្យល់សប្តិ* ឃ្លានេះមានចំនួន៥ដងនៅក្នុងពីរជំពូកដំបូងនៃគម្ពីរម៉ាថាយ(២:១២–១៣,១៩,២២)បង្ហាញពីការដែលព្រះមានបន្ទូលមកលោកយ៉ូសែប ។ *ពូជហ្លួងដាវីឌ* ប្រហែលជាពាក្យរបស់ទេវតាដែលសំដៅលើព្រះមែស៊ី ។ *កុំឱ្យខ្លាចយកនាងម៉ារាជាប្រពន្ធអ្នកឡើយ* ពួកគេទាំងពីរមានសិទ្ធិជាប្តីប្រពន្ធនៅចំពោះមុខច្បាប់រួចហើយ គឺនៅតែរៀបការ និងរួមរស់ជាប្តីប្រពន្ធមែនទែនតែប៉ុណ្ណោះទេ ។ *ដ្បិតបុត្រដែលបានចាប់ទំផ្ទៃនាង នោះកើតពីព្រះវិញ្ញាណបរិសុទ្ធទេ* ពាក្យនេះដូចគ្នាមួយរយភាគរយទៅនឹងសារប្រកាសជូននាងម៉ារា(លក ១:៣៥) គ្រាន់តែសារនេះមានលក្ខណៈច្បាស់ជាង (មើលការពន្យល់ លក ១:២៦–៣៥)។

**១:២២** *បានសំរេច* មានចំនួន១២ដង (២:១៥,២៣ ៣:១៥ ៤:១៤ ៥:១៧ ៨:១៧ ១២:១៧ ១៣:១៤,៣៥ ២១:៤ ២៧:៩) ម៉ាថាយនិយាយដល់ការសម្រេចនៃទំនាយដែលមាននៅក្នុងគម្ពីរសញ្ញាចាស់ ហើយនិងហេតុការណ៍ដែលបានកើតឡើងក្នុងគម្ពីរសញ្ញាថ្មី ។ អ្នកនិពន្ធបានភ្ជាប់ដំណឹងល្អទៅនឹងគម្ពីរសញ្ញាចាស់ ដោយបង្ហាញពីអំណាចព្រះចេស្តានៃព្រះក្នុងការសម្រេចបទទំនាយ ។

**១:២៣** មើលការពន្យល់ អស ៧:១៤ ។ ត្រង់នេះគឺជាការដកស្រង់លើកដំបូងចំពោះពាក្យថា "ព្រះមែស៊ី" ដោយលោកម៉ាថាយយកចេញពីគម្ពីរសញ្ញាចាស់ ដែលមានយ៉ាងហោចណាស់៤៧ដងដែរ ។

**១:២៥** *តែមិនបានរួមរស់នឹងនាងសោះ ទាល់តែនាងប្រសូតបុត្រជាចំបងមក* លោកម៉ាថាយ និងលោកលូកាបានបញ្ជាក់ច្បាស់ថា ព្រះយេស៊ូវប្រសូតពីស្ត្រីព្រហ្មចារី ។

**២:១** *បេថ្លេហិមស្រុកយូដា* ជាភូមិ១មានចម្ងាយ៨គ.ម ពីភាគខាងត្បូងក្រុងយេរូសាឡិម លោកម៉ាថាយឥតនិយាយពីព្រឹត្តិការណ៍នៅភូមិណាសារ៉ែតទេ (លក ១:២៦–៥៦) គាត់ប្រហែលចង់បញ្ជាក់ពីប្រវត្តិព្រះយេស៊ូវថាជាពូជហ្លួងដាវីឌ ។ បេថ្លេហិមស្រុកយូដាមិនមែនជាកន្លែងល្បីទេ តែវាបញ្ជាក់ថា ព្រះយេស៊ូវមកពីកុលសម្ព័ន្ធ និងទឹកដីដែលបង្កើតពូជស្តេចដាវីឌ ។ សាសន៍យូដាសង្ឃឹមថា ព្រះមែស៊ីនឹងប្រសូតនៅភូមិបេថ្លេហិមតាមខ្សែស្រឡាយស្តេចដាវីឌ (យហ ៧:៤២)។ *ស្តេចហេរ៉ូឌ* (ឆ្នាំទី៣៧–៤មុនគ.ស)ស្តេចហេរ៉ូឌនេះខុសប្លែកពីស្តេចហេរ៉ូឌដទៃទៀត នៅក្នុងព្រះគម្ពីរ ។ ហេរ៉ូឌមិនមែនជាសាសន៍យូដាទេ គឺត្រូវបានតែងតាំងឡើង ដោយរដ្ឋសភារ៉ូម៉ាំងនៅឆ្នាំទី៤០មុនគ.ស ហើយមានអំណាចខ្លាំងនៅឆ្នាំទី៣៧ មុនគ.ស ។ ភាគច្រើនហេរ៉ូឌគ្មានមេត្តាទេគឺសម្លាប់ប្រពន្ធកូនប្រុសបីនាក់ ម្តាយក្មេក បងប្អូនថ្លៃ ពូ និងមនុស្សជាច្រើននាក់ទៀត ថែមទាំងកូនក្មេងនៅភូមិបេថ្លេហិមផង (ខ១៦)។ រជ្ជកាលស្តេចអង្គនេះមានភាពរុងរឿងផ្នែកខាងរោងល្ខោនរង្គ–សាល បូជនីយស្ថាន រូបចម្លាក់ផ្សេងៗ ប៉ម អាគារធំៗ ជាពិសេសគឺបានតុបតែង ព្រះវិហារយេរូសាឡិមឡើងវិញ(ចាប់ផ្តើមឆ្នាំទី១៩មុនគ.ស និងបញ្ចប់បន្ទាប់ពីស្តេចនេះសុគតបាន៦៨ឆ្នាំ)។ *ហោរា* អាចជាអ្នកតារាសាស្ត្រមកពីពើស៊ី ឬ អារ៉ាប់ភាគខាងត្បូង(ប្រទេសទាំងពីរនេះនៅខាងកើតនៃប្រទេសប៉ាឡេស្ទីន)។

**២:២** *ស្តេចសាសន៍យូដា* លោកម៉ាថាយបង្ហាញថា មនុស្សគ្រប់សាសន៍អាចទទួលព្រះយេស៊ូវ(ស្តេចសាសន៍យូដា) និងអាចចូលមកថ្វាយបង្គំទ្រង់បាន (គំរូពួកហោរា)។ *ផ្កាយ* គឺមិនមែនជាផ្កាយ ឬភពព្រហស្បត៍ ឬក៏ភពសៅរ៍ធម្មតានោះទេ ។

**២:៤** *ពួកសង្គ្រាជ* គឺពួកសាឌូស៊ី(៣:៧)ដែលទទួលបន្ទុកផ្នែកថ្វាយបង្គំ និង

សាកសួរពីព្រះគ្រីស្ទ ដែលទ្រង់ត្រូវប្រសូតនៅឯណា ៥នោះ
គេក៏ទូលទ្រង់ថា នៅឯភូមិបេថ្លេហិម[ង]ក្នុងស្រុកយូដា ព្រោះ
ហោរាបានចែងសេចក្ដីទុកមកដូច្នេះថា ៦«ឯងឯងបេថ្លេហិម
ស្រុកយូដាអើយ ឯងមិនមែនតូចជាងគេ ក្នុងពួកចៅហ្វាយ
នៅស្រុកយូដាទេ ដ្បិតនឹងមានចៅហ្វាយ១ ចេញពីឯងមក
ចៅហ្វាយនោះនឹងឃ្វាលអ៊ីស្រាអែល[ច] ជារាស្ត្រអញ»។
៧នោះស្ដេចហេរ៉ូឌ ក៏ហៅពួកហោរនោះមក ដោយ
សំងាត់សាកសួរយ៉ាងម៉ត់ចត់ ពីផ្កាយនោះបានលេចមកពី
កាលណា ៨រួចទ្រង់ចាត់គេឱ្យទៅឯបេថ្លេហិម ដោយ
បង្គាប់ថា ចូរអ្នករាល់គ្នាទៅស៊ើបដំណឹងពីកូនតូចនោះ
ឱ្យច្បាស់លាស់ កាលណាបានឃើញហើយ នោះត្រូវ
មកប្រាប់ដល់យើងវិញ ដើម្បីឱ្យយើងបានទៅថ្វាយបង្គំដែរ
៩កាលគេបានទទួលបង្គាប់នៃស្ដេចស្រេចហើយ នោះក៏នាំ
គ្នាចេញទៅ ឯផ្កាយដែលគេបានឃើញពីទិសខាងកើត
នោះក៏នាំមុខគេ ដរាបដល់ចំពីលើកន្លែងដែលបុត្រតូចនៅ
ទើបឈប់ ១០គេមានសេចក្ដីអំណរជាខ្លាំងក្រៃ ដោយឃើញ
ផ្កាយនោះ ១១ហើយក៏ចូលទៅក្នុងផ្ទះ ឃើញបុត្រតូចនៅជា
មួយនឹងម៉ារា ជាមាតា រួចក៏ក្រាបថ្វាយបង្គំ[ឆ]ព្រមទាំងបើក
យកទ្រព្យដ៏វិសេសរបស់ខ្លួន ថ្វាយដង្វាយ[ជ] ជាមាស ជា
កំញាន ជាជ័រល្វីងទេសដល់បុត្រនោះ ១២រួចវិលទៅស្រុក
គេវិញ តាមផ្លូវមួយទៀតទៅ ដោយព្រោះព្រះទ្រង់ពន្យល់[ឈ]
សប្តិ[ញ]ប្រាប់ មិនឱ្យត្រឡប់ទៅឯហេរ៉ូឌវិញឡើយ ។

**ការភៀសខ្លួនទៅអេស៊ីព្ទ**

១៣កាលគេចេញទៅបាត់ហើយ នោះទេវតា[ដ]នៃព្រះ
អម្ចាស់ក៏លេចមក ពន្យល់សប្តិ[ឋ]ប្រាប់យ៉ូសែបថា ចូរក្រោក
ឡើងនាំបុត្រតូច និងមាតាទ្រង់ រត់ទៅឯស្រុកអេស៊ីព្ទទៅ ឱ្យ
នៅស្រុកនោះទាល់តែយើងប្រាប់ ដ្បិតហេរ៉ូឌនឹងរក
សំឡាប់បុត្រ តូច[ឌ] ១៤គាត់ក៏ក្រោកឡើងទាំងយប់ នាំបុត្រតូច
និងមាតា ទ្រង់ចេញទៅនៅស្រុកអេស៊ីព្ទវិញ ១៥ក៏នៅស្រុក
នោះ ដរាបដល់ហេរ៉ូឌសុគត ដើម្បីឱ្យបានសំរេច[ឍ] សេចក្ដី
ដែលព្រះអម្ចាស់ទ្រង់ប្រាប់ ដោយសារហោរាថា «អញ
បានហៅកូនអញ ចេញពីស្រុកអេស៊ីព្ទមក»[ណ] ១៦លុះហេរ៉ូឌ
ឃើញថា ពួកហោរបានបញ្ឆោតទ្រង់ នោះទ្រង់មាន
សេចក្ដីក្រេវក្រោធជាខ្លាំង ក៏ចាត់គេឱ្យទៅសំឡាប់អស់
ទាំងកូនប្រុសៗនៅបេថ្លេហិម និងក្នុងក្រវល់ស្រុកនោះទាំង
អស់ តាំងពីអាយុ២ឆ្នាំចុះមក តាមកំណត់ថ្ងៃដែលទ្រង់បាន
សួរពួកហោរយ៉ាងម៉ត់ចត់ ១៧នោះបានសំរេច[ត]សេចក្ដី
ទំនាយ ដែលហោរាយេរេមាបានទាយទុកមកថា ១៨«មាន
ឮសំឡេងនៅរ៉ាម៉ា ជាសូរទំនួញយំសោក ហើយ កាន់ទុក្ខ
គឺនាងរ៉ាជែល[ថ]យំនឹងកូននាង ហើយមិនព្រមក្សាន្តចិត្តសោះ
ដ្បិតកូននាងវិនាសបាត់ហើយ»[ទ]។

**ការត្រឡប់ទៅស្រុកណាសារ៉ែតវិញ**

១៩លុះហេរ៉ូឌបានសុគតរួចហើយ នោះទេវតា[ធ]នៃព្រះ
អម្ចាស់លេចមក ពន្យល់សប្តិ[ន]ប្រាប់យ៉ូសែប នៅស្រុកអេស៊ីព្ទ
ថា ២០ចូរក្រោកឡើង នាំបុត្រតូច និងមាតាទ្រង់ទៅនៅឯ
ស្រុកអ៊ីស្រាអែលវិញទៅ ដ្បិតអស់ពួកអ្នកដែលរកសំឡាប់
បុត្រតូច បានស្លាប់អស់ហើយ[ប] ២១គាត់ក៏ក្រោកឡើង នាំបុត្រ
តូច និងមាតាទ្រង់ ទៅឯស្រុកអ៊ីស្រាអែលវិញ ២២ប៉ុន្តែ គាត់

**២:៥** ង យហ ៧:៤២
**២:៦** ច មីក ៥:២ ២សយ ៥:២
**២:១១** ឆ អស ៦០:៣ ជ ទដ ៧២:១០
**២:១២** ឈ ហព ១១:៧ ញ មថ ២:១៣,១៩,២២ មថ ២៧:១៩
**២:១៣** ដ កច ៥:១៩ ឋ មថ ២:១២,១៩, ២២ មថ ២៧:១៩ ឌ វវ ១២:៤
**២:១៥** ឍ ខ ១៧, ២៣ មថ ១:២២ ណ ហស ១១:១ នក ៤:២២,២៣
**២:១៧** ត ខ ១៥, ២៣ មថ ១:២២
**២:១៨** ថ លប ៣៥:១៩ ទ យរ ៣១:១៥
**២:១៩** ធ កច ៥:១៩ ន មថ ២:១២,១៣, ២២ មថ ២៧:១៩
**២:២០** ប នក ៤:១៩

ជាគ្រូបង្រៀនក្រឹត្យវិន័យក្នុងព្រះវិហារនៅក្រុងយេរូសាឡិម ។

**២:៦** នេះជាទំនាយតាមរយៈហោរាមីកាមានតាំងពី៧សតវត្សរ៍មុនមកម្ល៉េះ ។

**២:១១** *ផ្ទះ* ពួកហោរពុំបានមកសួរសុខទុក្ខបុត្រតូច នៅយប់ដែលទ្រង់ប្រសូតក្នុងក្រោលសត្វដូចជាពួកអ្នកគង្វាលចៀមនោះឡើយ គឺនៅខែបន្តបន្ទាប់ពេលទារកតូចគង់នៅក្នុងផ្ទះ ។ *បុត្រតូចនៅជាមួយនឹងម៉ារាជាមាតា* គ្រប់ពេលឃើញពាក្យនេះនៅជាមួយគ្នា (ខ.១១, ១៣–១៤,២០–២១)។ *មាស កំញាន ជ័រល្វីងទេស* ប្រហែលជាតំណាងហោរាបីនាក់ ប៉ុន្តែ ព្រះគម្ពីរឥតបាននិយាយពីចំនួនរបស់ពួកគេទេ ។

**២:១៥** *ដរាបដល់ហេរ៉ូឌសុគត* នៅឆ្នាំទី៤មុន គ.ស ។ "*អញបានហៅកូនអញចេញពីស្រុកអេស៊ីព្ទ*" ដកស្រង់ពី "ហស ១១:១" ជាដើមដំបូងដែលទាក់ទងទៅនឹងការត្រាស់ហៅសាសន៍អ៊ីស្រាអែល ចេញពីប្រទេសអេស៊ីព្ទ នៅក្នុងសម័យលោកម៉ូសេ ។ ចំពោះលោកម៉ាថាយ ដោយមានការបើកសំដែងពីព្រះវិញ្ញាណបរិសុទ្ធបានឱ្យដឹងថា រឿងនេះជាប់ទាក់ទង់នឹងព្រះយេស៊ូវផងដែរ ។ គាត់ដឹងថា ប្រវត្តិសាស្ត្រអ៊ីស្រាអែល (កូននៃព្រះ) បានសរុបនៅក្នុងជីវិតរបស់ព្រះយេស៊ូវ (ជាបុត្រាតែមួយគត់របស់ព្រះ)។ ព្រះបុត្រតូចយេស៊ូវបានភៀសព្រះកាយទៅរស់នៅស្រុកអេស៊ីព្ទ គឺដូចជាជាតិសាសន៍អ៊ីស្រាអែលដ៏ក្មេងខ្ចីធ្លាប់បានរស់នៅទីនោះដែរ ។ ព្រះអម្ចាស់បាននាំព្រះយេស៊ូវចេញពីស្រុកអេស៊ីព្ទដូចដែលទ្រង់បានដឹកនាំសាសន៍អ៊ីស្រាអែលចេញពីទីនោះដែរ ។ គេពុំបានដឹងពីរយៈពេលដែលព្រះយេស៊ូវ និងក្រុមគ្រួសារបានស្នាក់នៅទីនោះទេ ។

**២:១៦** *សំឡាប់អស់ទាំងកូន. . . ពីអាយុ២ឆ្នាំចុះមក* ចំនួននេះត្រូវបានគេដំឡើងរហូតដល់រាប់ពាន់នាក់ ។ ភូមិបេថ្លេហិមដ៏តូចនេះពុំមានក្មេងច្រើនទេ ទោះបីបូកទាំងក្រវល់ស្រុកនោះក៏ដោយ តែក៏មិនតិចដែរចំពោះការសម្លាប់ឥតសំចៃដូច្នេះ ។

**២:១៨** មើលការពន្យល់ យរ ៣១:១៥ ។

**២:២២** *អើខេឡោស* ជាកូនស្ដេចហេរ៉ូឌបានគ្រប់គ្រងលើយូដា និងសាម៉ារីបានតែ១០ឆ្នាំទេ (៤មុនគ.ស–៦គ.ស) ទ្រង់ជានិច្ចជាកាលគឺឃោរឃៅ សង្កត់សង្កិន និងបំបាត់ជាតិសាសន៍ ក្រោយមកស្រុកយូដាបានក្លាយជាប្រទេសចំណុះពួករ៉ូម៉ាំង ។ *កាលីឡេ* តំបន់ភាគខាងជើងប្រទេសប៉ាឡេស្ទីន នាសម័យ

ឮថា អើខេឡោសបានសោយរាជ្យនៅស្រុកយូដា ជំនួស
ហេរ៉ូឌ ជាបិតាទ្រង់ នោះគាត់ខ្លាចមិនហ៊ានទៅឯទីនោះទេ
ក៏ចេញទៅនៅស្រុកកាលីឡេ[ផ]វិញ តាមដែលព្រះទ្រង់បាន
ពន្យល់សប្តិ[ព]ប្រាប់គាត់ ២៣រួចគាត់តាំងទីលំនៅ នៅភូមិ
ណាសារ៉ែត[ភ] ដើម្បីឱ្យបានសំរេច[ម]សេចក្ដីដែលពួកហោរា
បានទាយថា «គេនឹងហៅទ្រង់ជាអ្នកស្រុកណាសារ៉ែត»[យ]។

## យ៉ូហាន–បាទីស្ទរៀបចំផ្លូវ

*៣:១–១២ = មក ១:៣–៨ លក ៣:២–១៧*

**៣** ១នៅគ្រានោះយ៉ូហាន–បាទីស្ទ[ក] គាត់មកនៅក្នុងទីរ–
ហោស្ថានស្រុកយូដា កំពុងតែប្រកាសថា ២ចូរឱ្យប្រែចិត្តចុះ
ដ្បិតនគរស្ថានសួគ៌[ខ]ជិតដល់ហើយ ៣គឺពីអ្នកនេះហើយ ដែល
ហោរាអេសាយបានទាយថា «មានសំឡេងនៃមនុស្សម្នាក់
កំពុងតែស្រែកនៅទីរហោស្ថានថា ចូររៀបចំផ្លូវទទួលព្រះ
អម្ចាស់ ចូរដំរង់ផ្លូវតូចថ្វាយទ្រង់ចុះ»[គ] ៤ឯយ៉ូហាន[ឃ]នេះ
គាត់ពាក់អាវរោមអូដ្ឋ ហើយមានខ្សែក្រវាត់ស្បែកនៅ
ចង្កេះ[ង] ក៏មានកណ្ដូប[ច] និងទឹកឃ្មុំព្រៃជាអាហារ។ ៥នោះ
ពួកក្រុងយេរូសាឡិម និងពួកស្រុកយូដាទាំងអស់ ព្រមទាំង
មនុស្សដែលនៅក្រវល់ជុំវិញទន្លេយ័រដាន់ គេចេញមកឯ
គាត់ ៦ក៏លន់តួបាប ហើយទទួលបុណ្យជ្រមុជ[ឆ]ពីគាត់ក្នុង
ទន្លេយ័រដាន់ទាំងអស់គ្នា ៧តែកាលគាត់ឃើញពួកផារិស៊ី
នឹងពួកសាឌូស៊ី មកទទួលបុណ្យជ្រមុជពីគាត់ជាច្រើនដែរ
នោះក៏សួរគេថា ឱពូជពស់វែក[ជ] អើយតើអ្នកណាបានប្រាប់
ឱ្យអ្នករាល់គ្នារត់ចេញពីសេចក្ដីក្រោធ[ឈ]ដែលត្រូវមកដូច្នេះ
៨បើយ៉ាងនេះ ចូរអ្នករាល់គ្នាបង្កើតផល ដែលសំណាំនឹង
សេចក្ដីប្រែចិត្ត[ញ]នោះចុះ ៩ហើយកុំឱ្យគិតក្នុងចិត្តថា មាន
លោកអ័ប្រាហាំជាឪពុក[ដ]ខ្លួន នោះឡើយ ដ្បិតខ្ញុំប្រាប់អ្នក
រាល់គ្នាថា ព្រះទ្រង់អាចនឹងបង្កើតកូនឱ្យលោកអ័ប្រាហាំ
ពីថ្មទាំងនេះក៏បានដែរ ១០ប៉ុន្តែឥឡូវនេះ ពូថៅបានដាក់នៅ
ឫសដើមឈើហើយ ដូច្នេះអស់ទាំងដើមណាដែលកើតផ្លែ
មិនល្អ នោះត្រូវកាប់បោះចោល ទៅក្នុងភ្លើង[ឋ] ១១ឯខ្ញុំ
ពិតមែនជាធ្វើបុណ្យជ្រមុជឱ្យអ្នករាល់គ្នាដោយទឹក ពីព្រោះ

**២:២២** ផ លក ២:៣៩ ព មថ ២:១២,១៣,១៩ មថ ២៧:១៩ **២:២៣** ភ មក ១:៩ ៦:១ ១:២៤ លក ១:២៦ ២:៣៩,៥១ ៤:១៦,២៣ យហ ១:៤៥,៤៦ ម មថ ២:១៥,១៧ មថ ១:២២ យ មក ១:២៤ **៣:១** ក មថ ៣:១៣, ១៤ មថ ៩:១៤ ១១:២–១៤ ១៤:១–១២ លក ១:១៣,៥៧–៦៦ ៣:២-១៩ កច ១៩:៣,៤ **៣:២** ខ ដយ ៧:១៤ មថ ៤:១៧ ៦:១០ ៧:២១ ២៥:៣៤ លក ១១:២០ ១៧:២០,២១ ១៩:១១
២១:៣១ យហ ៣:៣,៥ កច ១:៣,៦ **៣:៣** គ អស ៤០:៣ មឡ ៣:១ លក ១:៧៦ យហ ១:២៣ **៣:៤** ឃ មថ ៣:១ ង ២ពវ ១:៨ ច លវ ១១:២២ **៣:៦** ឆ ខ.១១ មក ១:៤ **៣:៧** ជ មថ ១២:៣៤ ២៣:៣៣ ឈ រម ១:១៨ **៣:៨** ញ កច ២៦:២០ **៣:៩** ដ លក ៣:៨ **៣:១០** ឋ មថ ៧:១៩ លក ៣:៩ ១៣:៦–៩ យហ ១៥:២,៦ **៣:១១** ឌ ៖៦ មក ១:៤ ឍ មក ១:៨

ព្រះយេស៊ូវ ។

**២:២៣** *ណាសារ៉ែត* ជាភូមិមួយដែលគេមិនសូវស្គាល់ និងមិនឃើញមានសោះក្នុងគម្ពីរសញ្ញាចាស់ ។ វាជាស្រុកកំណើតរបស់ព្រះយេស៊ូវ (១៣:៥៤–៥៧ លក ២:៣៩ ៤:១៦–២៤ យហ ១:៤៥–៤៥)។ ទ្រង់ត្រូវបានគេហៅថា អ្នកស្រុកណាសារ៉ែត ពាក្យចំគ្មានទេក្នុងគម្ពីរសញ្ញាចាស់គ្រាន់តែមានន័យដែលសំដៅលើវា ឬជាទំនាយ "ស្ទើរតែមានន័យថា ជាទីសំអប់" (ទដ ២២:៦ អស ៥៣:៣) និងជាមែកធាង (អស ១១:១)។

**៣:១** *យ៉ូហាន–បាទីស្ទ* គឺជាអ្នកបើកផ្លូវថ្វាយព្រះយេស៊ូវ កើតប្រហែលឆ្នាំទី៧មុន គ.ស ជាកូនសង្ឃសាការី និងនាងអេលីសាបិត (លក ១:៥–៨០)។ *ទីរហោស្ថាន ស្រុកយូដា* មានប្រវែងប្រហែល៣២គ.ម ពីយេរូសាឡិមទៅបេថ្លេហិមជាតំបន់ខ្ពស់ ហូរចាក់ទៅទន្លេយ័រដាន់ និងសមុទ្រស្លាប់ប្រហែលជាកន្លែងយ៉ូហានបានរស់នៅ (លក ១:៨០)។ មានឃើញអ្នកស្រុកគូមរ៉ាន់ (Qumran) បានរស់នៅតំបន់នេះដែរ (តាមឯកសារសមុទ្រស្លាប់)។

**៣:២** *ប្រែចិត្ត* គឺផ្លាស់ប្ដូរដាច់ស្រឡះនូវទង្វើក្នុងជីវិត ។ *នគរស្ថានសួគ៌ជិតដល់ហើយ* ឃ្លានេះមានតែក្នុងគម្ពីរម៉ាថាយទេ (៣៣ដង មើលសេចក្ដីផ្ដើមត្រង់អ្នកទទួល)។ លោកម៉ាកុស និងលូកានិយាយទាក់ទងទៅនឹង "នគរព្រះ" លោកម៉ាថាយប្រើតែ៤ដងទេ (មើលពន្យល់ មក ១១:៣០)។ នគរស្ថានសួគ៌គឺព្រះជាអ្នកគ្រប់គ្រង ហើយជាសេចក្ដីសង្ឃឹមដ៏ពិតប្រាកដទាំងបច្ចុប្បន្ន និងអនាគត ។ នគរព្រះ គឺជាគំនិតស្នូលនៃសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវនៅក្នុងគម្ពីរម៉ាថាយនេះ (មាន៥០ដង)។

**៣:៣** គម្ពីរដំណឹងល្អបីបានដកស្រង់ពី អស ៤០:៣ (លូកា ដកស្រង់ពីខផ្សេងៗទៀត) និងយកមកប្រើជាមួយនឹងលោកយ៉ូហាន–បាទីស្ទ ។ *ចូររៀបចំផ្លូវទទួលព្រះអម្ចាស់* មានន័យដូចគ្នានឹងពាក្យថា "ចូរដំរង់ផ្លូវតូចថ្វាយទ្រង់ចុះ" (លក ៣:៤) ការរៀបចំនេះ គឺសំដៅលើផ្នែកសីលធម៌ និងខាងឯវិញ្ញាណ ។

**៣:៤** *ខ្សែក្រវាត់ស្បែក* ប្រើសម្រាប់ចងរឹត ឬក្រវាត់ខោដែលធូររលុង ។ *កណ្ដូប និងទឹកឃ្មុំព្រៃ* មនុស្សដែលរស់នៅទីរហោស្ថានមិនសាញនឹងបរិភោគសត្វល្អិត កណ្ដូប ដែលជាអាហារមិនស្អាតនោះទេ (លវ ១១:២១–២២)។ សម្លៀកបំពាក់ អាហារ និងជីវិតរបស់លោកយ៉ូហានគឺសាមញ្ញដែលបង្ហាញពីការមិនប្រកាន់ខ្លួន ។

**៣:៦** *ទន្លេយ័រដាន់* មើលការពន្យល់ មក ១:៥ ។

**៣:៧** *ផារិស៊ី* មើលការពន្យល់ មក ២:១៦ លក ៥:១៧ ។ ជាក្រុមអ្នកកាន់ច្បាប់ដ៏តឹងរ៉ឹងមួយ ដែលដាច់ដោយឡែកពីមនុស្សធម្មតា ប៉ុន្តែ ជាញឹកញាប់ពួកគេជាមនុស្សមានពុត ដែលធ្វើជាអ្នកកាន់តាមក្រឹត្យវិន័យរបស់លោកម៉ូសេ និងទំនៀមទម្លាប់នៃពួកចាស់ទុំ (១៥:២)។ *សាឌូស៊ី* មើលការពន្យល់ មក ១២:១៨ លក ២០:២៧ កច ៤:១ ។ ជាអ្នកយកចិត្តទុកដាក់ខាងលោកិយនយោបាយ និងទេវសាស្ត្រខុសឆ្គង ហើយបដិសេធការរស់ឡើងវិញ ទេវតា និងវិញ្ញាណ (កច ២៣:៨)។ *ការជ្រមុជទឹក* មើលការពន្យល់ មក ១:៤ ។ *ចេញពីសេចក្ដីក្រោធ* គឺការយាងមករបស់ព្រះមែស៊ី ដែលនាំមកនូវការប្រែចិត្ត ឬការជំនុំជម្រះ ។

**៣:៩** *លោកអ័ប្រាហាំជាឪពុក* មើលការពន្យល់ យហ ៨:៣៩ ។ ការសង្គ្រោះមិនមែនបានពីកំណើតតៗគ្នាពីដូនតានោះទេ (ទាំងពួកយូដា) គឺបានដោយជឿដល់ព្រះគ្រីស្ទ (រម ២:២៨–២៩ កទ ៣:៧,៩,២៩)។ *ថ្មនេះ* ប្រហែលលោកយ៉ូហានចង្អុលទៅថ្មក្នុងទន្លេយ័រដាន់ ។ *អ័ប្រាហាំ* គឺជារាស្ត្រពិតរបស់ព្រះ មិនកំណត់តែលើពូជពង្សរបស់លោកអ័ប្រាហាំនោះទេ (រម ៩:៦–៨)។

**៣:១០** *ពូថៅបានដាក់នៅឫសដើមឈើ* ការជំនុំជម្រះជិតមកដល់ហើយ ។

**៣:១១** *ជ្រមុជទឹកពីព្រោះមានសេចក្ដីប្រែចិត្ត* លោកយ៉ូហាន–បាទីស្ទសន្មតិ

មានសេចក្តីប្រែចិត្ត[ឌ] តែព្រះអង្គដែលយាងមក ក្រោយខ្ញុំ
ទ្រង់មានអំណាចលើសជាងខ្ញុំទៅទៀត ខ្ញុំមិនគួរនឹងកាន់
សុព័ណ៌បាទទ្រង់ទេ ព្រះអង្គនោះនឹងធ្វើបុណ្យជ្រមុជឱ្យអ្នក
រាល់គ្នា ដោយព្រះវិញ្ញាណបរិសុទ្ធ[ឍ] ហើយនិងភ្លើងវិញ[ណ]
១២ទ្រង់កាន់ចង្អេរនៅព្រះហស្តទ្រង់នឹងបោសរំលីង ទីលាន
ទ្រង់ ហើយនិងប្រមូលស្រូវទ្រង់ មកដាក់ក្នុងជង្រុកតែអង្កាម
ទ្រង់នឹងដុតក្នុងភ្លើង[ត]ដែលពន្លត់មិនបានវិញ ។

## ព្រះយេស៊ូវទទួលពិធីបុណ្យជ្រមុជទឹក

*៣:១៣–១៧ = មក ១:៩–១១ លក ៣:២១,២២ យហ ១:៣១–៣៤*

១៣នោះព្រះយេស៊ូវទ្រង់យាងពីស្រុកកាលីឡេ មកឯយ៉ូ
ហាន[ថ] ត្រង់ទន្លេយ័រដាន់ ដើម្បីនឹងទទួលបុណ្យជ្រមុជពីគាត់
១៤តែយ៉ូហានប្រកែកថា ដូចម្តេចបានជាទ្រង់យាងមកឯ
ទូលបង្គំ គឺទូលបង្គំដែលត្រូវទទួលបុណ្យជ្រមុជពីទ្រង់វិញទេ
តើ ១៥ព្រះយេស៊ូវមានបន្ទូលថា ចូរធ្វើម្តងនេះចុះ ដ្បិតគួរ
ឱ្យយើងធ្វើសំរេចតាមគ្រប់ទាំងសេចក្តីសុចរិតយ៉ាងដូច្នេះ
រួចគាត់ក៏ព្រមធ្វើ ១៦កាលព្រះយេស៊ូវបានទទួលបុណ្យជ្រ
មុជហើយ នោះ ទ្រង់យាងឡើងពីទឹកភ្លាម ស្រាប់តែមេឃ
ក៏របើក[ទ]ឡើងឱ្យទ្រង់ឃើញព្រះវិញ្ញាណនៃព្រះ[ធ] យាងចុះ
មកដូចជាសត្វព្រាប ក៏សណ្ឋិតលើទ្រង់ ១៧នោះមានឮ
សំឡេងចេញពីមេឃ[ន]ថា នេះជាកូន[ប]ស្ងួនភ្ងារបស់អញ ជាទី
ពេញចិត្ត[ផ] អញណាស់។

## ព្រះយេស៊ូវជួបសេចក្តីល្បួង

*៤:១–១១ = មក ១:១២,១៣ លក ៤:១–១៣*

**៤** ១គ្រានោះព្រះវិញ្ញាណក៏នាំព្រះយេស៊ូវ ទៅឯទីរហោ
ស្ថាន ដើម្បីឱ្យត្រូវអារក្ស[ក]ល្បួង[ខ] ២កាលទ្រង់បានតម៤០

ណ អស ៤:៤ កច ២:៣,៤
**៣:១២** ត មថ ១៣:៣០ ២៥:៤១
**៣:១៣** ថ មថ ៣:១ មក ១:៤
**៣:១៦** ទ អគ ១:១ យហ ១:៥១ កច ៧:៥៦ ១០:១១ វវ ៤:១ ១៩:១១ ធ អស ១១:២ ៤២:១
**៣:១៧** ន ចទ ៤:១២ មថ ១៧:៥ យហ ១២:២៨ ប ទដ ២:៧ កច ១៣:៣៣ ហព ១:១–៥ ៥:៥ ២ពត ១:១៧,១៨
មក ផ អស ៤២:១ មថ ១២:១៨ ១៧:៥ ១:១១ ៩:៧ លក ៣:២២ ៩:៣៥ ២ពត ១:១៧ **៤:១** ក លប ៣:១–៧ ខ ហព៤:១៥

ជាមុនពីការប្រែចិត្ត និងមិនជ្រមុជឱ្យពួកផារីស៊ី និងសាឌូស៊ីទេ ពីព្រោះពួកគេមិនប្រែចិត្ត ពិតប្រាកដឡើយ(ខ.៧–៨)។ *កាន់* មក ១:៧ និង លក ៣:១៦ ប្រើពាក្យ"ស្រាយ" ភាសាក្រិកក៏ប្រើពាក្យ "កាន់"មានន័យថា "យកចេញ"។ *ដោយព្រះវិញ្ញាណបរិសុទ្ធ ហើយនិងភ្លើង* បង្ហាញពីការរំភើបខ្លាំងនៅថ្ងៃបុណ្យទី៥០(កច ១:៥,៨ ២:១–១៣ ១១:៦)។ *ដោយភ្លើង* អាចទាក់ទងនឹងការជំនុំជម្រះ (ខ.១២)ការចាក់បង្ហូរព្រះវិញ្ញាណបរិសុទ្ធលើរាស្ត្រព្រះទាំងអស់ដូចបានសន្យានៅក្នុង យអ ២:២៨–២៩ ។

**៣:១២** *កាន់ចង្អេរនៅព្រះហស្ត* ជារបៀបនៃការបោសរំលីង(មើលពន្យល់ នរ ១:២២) សំដៅលើការជំនុំជម្រះនៅថ្ងៃព្រះគ្រីស្ទយាងមកលើកទី២ ។ ហោរានៅក្នុងគម្ពីរសញ្ញាចាស់ និងអ្នកនិពន្ធគម្ពីរសញ្ញាថ្មីមួយចំនួនបានសង្កត់ន័យនៃការយាងមកលើកទី១ និងលើកទី២របស់ព្រះគ្រីស្ទហាក់បីដូចជាព្រឹត្តិការណ៍តែមួយ ។

**៣:១៥** នេះជាការចាប់ផ្តើមភារកិច្ចរបស់ព្រះគ្រីស្ទជាព្រះមែស៊ី ។ ហេតុផលដែលបណ្តាលឱ្យទ្រង់ទទួលបុណ្យជ្រមុជទឹកមាន (១)."ធ្វើតាមគ្រប់ទាំងសេចក្តីសុចរិត" បញ្ជាក់ថាបានថ្វាយដល់ព្រះ និងត្រូវបានទទួលស្គាល់ជាផ្លូវការ ជាពិសេសព្រះវិញ្ញាណបរិសុទ្ធយាងមកសណ្ឋិតលើ(ខ.១៧ ទដ ២:៧ អស ៤២:១)។ សេចក្តីសុចរិតនៃព្រះបានសម្រេចលើតួអង្គព្រះយេស៊ូវ ។ (២).លោកយ៉ូហានបានប្រកាសជាសាធារណៈថា ព្រះមែស៊ី និងការចាប់ផ្តើមភារកិច្ចរបស់ទ្រង់បានមកដល់ហើយ (យហ ១:៣១–៣៤)។ (៣).ព្រះយេស៊ូវ បានធ្វើអង្គទ្រង់ឱ្យដូចជាអ្នកមានបាបពិតៗ ថ្វីបើទ្រង់មិនបាច់ត្រូវការប្រែចិត្ត ឬសំអាតបាបក៏ដោយ តែសម្រាប់ជំនួសអំពើបាបរបស់មនុស្សវិញ (២កថ ៥:២១)។ (៤).ជាគំរូសម្រាប់អ្នកដើរតាមទ្រង់ ។

**៣:១៦–១៧** តួអង្គទាំងបីនៃព្រះត្រៃឯកឃើញយ៉ាងច្បាស់នៅទីនេះ ។

**៣:១៦** *ព្រះវិញ្ញាណនៃព្រះ* ព្រះវិញ្ញាណបរិសុទ្ធយាងចុះមកសណ្ឋិតលើព្រះយេស៊ូវ មិនមែនដើម្បីឱ្យទ្រង់ឈ្នះបាបនោះទេ(ព្រោះទ្រង់គ្មានបាបសោះ) នេះជាការ បន្ថែមដល់ទ្រង់(ពច ៣:១០) កិច្ចការនេះជាលក្ខណៈព្រះផង និងជាមនុស្សផងនៃព្រះមែស៊ី ។ *ការយាងចុះមកដូចជាសត្វព្រាប* មើលនៅក្នុង មក ១:១០ ។

**៣:១៧** *សំឡេងចេញពីមេឃ* (១).បញ្ជាក់បន្ថែមថា ទ្រង់ជាព្រះបុត្រា តែមួយគត់(ទដ ២:៧)។ (២).ទ្រង់ជាអ្នកបម្រើរងទុក្ខលំបាក(អស ៤២:១)។ (៣).ព្រះវរបិតាជាអ្នកជំនួយក្នុងដំណើរបេសកកម្ម របស់ទ្រង់នៅលើផែនដីនេះ និងជាការលើកទឹកចិត្តដល់ទ្រង់(ជាទីពេញចិត្តអញណាស់) ជាភាសាក្រិកមានន័យថា គ្មានទីបញ្ចប់ គឺព្រះសព្វព្រះទ័យនឹងការគាំទ្រព្រះបុត្រារបស់ទ្រង់ជានិច្ចរហូតតទៅ ។

**៤:១–១១** សេចក្តីសំខាន់នៃការល្បួងព្រះយេស៊ូវ ជាពិសេសការល្បួង ទាំងនេះបានកើតឡើងក្នុងការចាប់ផ្តើមដំបូងនៃការងាររបស់ទ្រង់ ហាក់បីដូចជាត្រូវបានយល់ យ៉ាងច្បាស់បំផុតថា ទ្រង់ជាព្រះមែស៊ីដែលត្រូវយាងមក ។ ទ្រង់មិនបានសម្រេចបេសកកម្មទ្រង់ ដោយប្រើអំណាចជាព្រះសម្រាប់សេចក្តីត្រូវការរបស់ទ្រង់ (ល្បួងលើកទី១) មិនប្រើការអស្ចារ្យ ឬមន្តអាគមលើអ្នកដើរតាម(ល្បួងលើកទី២) ឬសម្រុះសម្រួលជាមួយសាតាំងនោះឡើយ (ល្បួងលើកទី៣)។ ព្រះយេស៊ូវមិនមាន ប្រាថ្នានៅក្នុងចិត្ត ឬទោរទន់ទៅរកអំពើបាបឡើយ ដ្បិតការល្បួងទាំងនេះគឺជាអំពើបាប(មថ ៥:២២,២៨)។ ទ្រង់ជាព្រះមិនមានបាប ទោះជាទង្វើខាងក្រៅ ឬការគិតក្នុងចិត្តក៏គ្មានដែរ(២កថ ៥:២១ ហព ៧:២៦ ២ពត ២:២២ ១យហ ៣:៥)។ ការល្បួងព្រះយេស៊ូវមិនមែនគ្រាន់តែជានិមិត្តរូបនោះទេ ទ្រង់ត្រូវល្បួងគ្រប់យ៉ាង ដូចជាយើងនោះដែរ ប៉ុន្តែ ទ្រង់ពុំបានធ្វើបាបណាមួយសោះឡើយ(ហព ៤:១៥)។ ទ្រង់បានប្រឈមមុខនឹងមេល្បួង ដែលមានឱកាសក្នុងការធ្វើបាបបាន ។ ទោះបីទ្រង់ជាព្រះរាជបុត្រានៃព្រះក៏ដោយ ក៏ទ្រង់យកជ័យជម្នះលើសាតាំងដោយសារការប្រើអាវុធដែលមនុស្សគ្រប់គ្នាមាន ហើយបោះបង់ចោលនោះ គឺជាដាវនៃព្រះវិញ្ញាណ ជាព្រះបន្ទូលនៃព្រះ(អភ ៦:១៧) ទ្រង់បានឈ្នះលើសេចក្តីល្បួងទាំងបីនេះ ដោយប្រើនូវព្រះបន្ទូលព្រះ(ខ.៤,៧,១០) ក្នុងកណ្ឌគម្ពីរចោទិយកថា ។

**៤:១** *ព្រះវិញ្ញាណនាំព្រះយេស៊ូវ . . . ដើម្បីឱ្យត្រូវអារក្សល្បួង* ការសាកល្បងនេះជាភាសាក្រិកក៏ប្រើពាក្យ "ល្បួង" ប្រែថា "សាកល្បង" ដែលជាព្រះហឫទ័យព្រះដែលមានប្រវត្តិដំបូងរបស់វានៅក្នុង ចទ ៨:១–៥ ព្រមទាំងការឆ្លើយតបរបស់ ព្រះយេស៊ូវទៅអារក្ស ក៏បានដកស្រង់ចេញពីនេះដែរ

ថ្ងៃ៤០យប់[គ] ហើយ ក្រោយមកទ្រង់ឃ្លាន ៣រួចមេល្បួង[ឃ]ក៏
មកទូលទ្រង់ថា បើអ្នកជាព្រះរាជបុត្រានៃព្រះ[ង]មែន ចូរ
បង្គាប់ឱ្យថ្មទាំងនេះត្រឡប់ជានំបុ័ងទៅ ៤តែទ្រង់មាន
បន្ទូលតបថា មានសេចក្តីចែងទុកមកដូច្នេះ មនុស្សមិន
មែនរស់ ដោយសារតែនំបុ័ងប៉ុណ្ណោះទេ គឺរស់ដោយសារ
គ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ[ច]។
៥នោះអារក្សក៏នាំទ្រង់ទៅឯក្រុងបរិសុទ្ធ[ឆ] ដាក់លើកំពូល
ព្រះវិហារ ទូលថា ៦បើអ្នកជាព្រះរាជបុត្រានៃព្រះមែន[ជ]
ចូរទំលាក់ខ្លួនទៅក្រោមចុះ ដ្បិតមានសេចក្តីចែងទុកមកថា
ទ្រង់នឹងបង្គាប់ពួកទេវតានៃទ្រង់ពីដំណើរអ្នក ទេវតានឹងទ្រ
អ្នកដោយដៃក្រែងលោជើងអ្នកទង្គិចនឹងថ្ម[ឈ] ៧ព្រះយេស៊ូវ
មានបន្ទូលទៅវាថា មានសេចក្តីចែងទុកដូច្នេះទៀត កុំ
ឱ្យឯងល្បួងព្រះអម្ចាស់ ជាព្រះនៃឯងឡើយ[ញ]។
៨មួយទៀត អារក្សបាននាំទ្រង់ទៅលើកំពូលភ្នំយ៉ាងខ្ពស់
ក៏បង្ហាញអស់ទាំងនគរក្នុងលោកីយ និងសិរីលំអរបស់នគរ
ទាំងនោះថ្វាយទ្រង់ទត ៩រួចទូលថា បើសិនជាអ្នកក្រាប
ថ្វាយបង្គំខ្ញុំ នោះខ្ញុំនឹងឱ្យរបស់ទាំងនេះដល់អ្នក ១០នោះព្រះ
យេស៊ូវមានបន្ទូលតបថា នែសាតាំង[ដ]ចូរឯង ថយចេញពី
អញទៅ ដ្បិតមានសេចក្តីចែងទុកមកថា «ឯង ត្រូវថ្វាយបង្គំ
ដល់ព្រះអម្ចាស់ជាព្រះនៃឯង ហើយត្រូវគោរព ដល់ទ្រង់តែ
មួយព្រះអង្គប៉ុណ្ណោះ»[ឋ] ១១ដូច្នេះ អារក្សក៏ថយចេញពីទ្រង់
ទៅ[ឌ] រួចមានពួកទេវតា មកបំរើទ្រង់[ឍ]។

## ព្រះយេស៊ូវចាប់ផ្តើមប្រកាសដំណឹងល្អ

១២កាលព្រះយេស៊ូវឮថា គេបានបញ្ជូនយ៉ូហានទៅ[ណ]
ហើយ នោះទ្រង់យាងថយទៅគង់នៅឯស្រុកកាលីឡេ[ត] វិញ
១៣រួចទ្រង់ចេញពីណាសារ៉ែត ទៅគង់នៅឯក្រុងកាពើ–
ណិម[ថ] វិញ ជាក្រុងនៅមាត់សមុទ្រ ត្រង់ព្រំប្រទល់ដែនខេត្ត

**៤:២** គ នក ៣៤:២៨ ១ពវ ១៩:៨ **៤:៣** ឃ ១ ធម ៣:៥ ង មថ ៣:១៧ ១៤:៣៣ ១៦:១៦ ២៧:៥៤ មក ៣:១១ លក ១:៣៥ ២២:៧០ យហ ១:៣៤,៤៩ ៥:២៥ ១១:២៧ ២០:៣១ កច ៩:២០ រម ១:៤ ១យហ ៥:១០–១៣,២០ វវ ២:១៨ **៤:៤** ច ចទ ៨:៣ យហ ៤:៣៤ **៤:៥** ឆ នហ ១១:១ ដយ ៩:២៤ មថ ២៧:៥៣ **៤:៦** ជ ខ៣ ឈ ទដ ៩១:១១,១២ **៤:៧** ញ ចទ ៦:១៦ **៤:១០** ដ ១របក្ស ២១:១ យប ១:៦–៩ មថ ១៦:២៣ មក ៤:១៥ លក ១០:១៨ ១៣:១៦ ២២:៣,៣១ រម ១៦:២០ ២កថ ២:១១ ១១:១៤ ២ថន ២:៩ វវ ១២:៩ ឋ ចទ ៦:១៣ **៤:១១** ឌ យក ៤:៧ ឍ មថ ២៦:៥៣ លក ២២:៤៣ ហព ១:១៤ **៤:១២** ណ មថ ១៤:៣ ត មក ១:១៤ **៤:១៣** ថ មក ១:២១ ៩:៣៣ លក ៤:២៣,៣១ យហ ២:១២ ៤:៤៦,៤៧

(មើល ខ.៤)។ លោកម៉ូសេបានហៅនូវរបៀបដែលព្រះអម្ចាស់បានដឹកនាំពួកអ៊ីស្រាអែល នៅក្នុងទីរហោស្ថាន អស់រយៈពេល៤០ឆ្នាំថា "ដើម្បីផ្ចាញ់ និងល្បងលោកអ្នក ដើម្បីឱ្យបានដឹងថា តើ ចិត្តលោកអ្នកនោះវាយ៉ាងណា? តើលោកអ្នករក្សាបញ្ញត្តិទ្រង់បានឬក៏អត់" ជាកិច្ចចាប់ផ្តើមភារកិច្ចរបស់ទ្រង់ដំបូង ។ ព្រះយេស៊ូវគឺជាប្រធានបទ ដែលបានសាកល្បងស្រដៀងគ្នានេះដែរ និងបង្ហាញអង្គទ្រង់ផ្ទាល់ថា ជាសាសន៍អ៊ីស្រាអែលពិតៗ ដែលរស់ដោយសារ "គ្រប់ទាំងព្រះបន្ទូលដែលចេញពីព្រះឱស្ឋទ្រង់មក" វាផ្ទុយនឹងអ័ដាមដែលបរាជ័យក្នុងការល្បួងដ៏ធំ ដែលនាំឱ្យយើងគ្រប់គ្នាបានជាប់ក្នុងដាននៃអំពើបាបរហូតមក(លប ៣)។ ព្រះយេស៊ូវគឺស្មោះត្រង់ ហើយបង្ហាញលក្ខណៈសម្បត្តិរបស់ទ្រង់ ដែលជាព្រះអង្គសង្គ្រោះដល់អស់អ្នកណាដែលទទួលជឿទ្រង់ ។ សំខាន់លើសពីនេះទៅទៀតនោះគឺ ព្រះយេស៊ូវជួបល្បួងដូចជាអ៊ីស្រាអែល និងយើងទាំងអស់គ្នាដែរ ដូច្នេះទ្រង់ជាព្រះដែលមានលក្ខណៈជា"សម្តេចសង្ឃ ដែលមានសេចក្តីមេត្តា និងស្មោះត្រង់"(ហព ២:១៧) និង "មានលទ្ធភាពជួយដល់អស់អ្នកដែលត្រូវល្បួងបាន"(ហព ២:១៥ ហព ៤:១៥–១៦)។ ទីបញ្ចប់ទ្រង់ជាព្រះដ៏ស្មោះត្រង់ ទោះនៅក្នុងសេចក្តីល្បួងក៏ដោយ ក៏ទ្រង់នៅតែជាគំរូដល់អ្នកជឿក្នុងការយកជ័យជម្នះលើសេចក្តីល្បួង ។ *អារក្សល្បួង* ប្រាកដហើយព្រះសាកល្បងរាស្ត្រទ្រង់ ប៉ុន្តែ គឺអារក្សដែលល្បួងឱ្យធ្វើការអាក្រក់ (មើលការពន្យល់ លប ២២:១ ១យហ ៣:៨ វវ ២:៩–១០ ១២:៩–១០) ភាសាហេព្រើរប្រើពាក្យ "សាតាំង" ក្រិកប្រើពាក្យ "អារក្ស" មានន័យថា"អ្នកចោទប្រកាន់"ឬ"អ្នកនិយាយបង្ខូច" អារក្សគឺជាការរស់នៅផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗ មិនមែនជាកម្លាំង ឬឥទ្ធិពលអ្វីនោះទេ វាជាសត្រូវធំទី១របស់ព្រះ និងជាមេដឹកនាំនៃម្ចាស់ខាងងងឹត ។

**៤:២** *៤០ថ្ងៃ ៤០យប់* ជាថ្ងៃរំលឹកដល់បទពិសោធន៍នៃលោកម៉ូសេ(នក ២៤:១៨ ៣៤:២៨) និងអេលីយ៉ា (១ពវ ១៩:៨) ព្រមទាំង៤០ឆ្នាំនៃការសាកល្បងពួក អ៊ីស្រាអែលក្នុងទីរហោស្ថាន(ចទ ៨:២–៣)។

**៤:៣** *បើអ្នកជាព្រះរាជបុត្រានៃព្រះមែន* មានន័យថា"ដ្បិតអ្នកជា..."អារក្សមិនបានបោះបង់ការសង្ស័យលើព្រះយេស៊ូវថាជាព្រះបុត្រានៃព្រះឡើយ ពេលនោះវាកំពុងល្បួងទ្រង់ឱ្យប្រើអំណាចក្នុងនាមជាព្រះបុត្រាសម្រាប់ប្រយោជន៍ព្រះអង្គផ្ទាល់ ។

**៤:៤** ដូចគ្នានឹងពេលដែលព្រះប្រទាននំម៉ាន៉ាដល់អ៊ីស្រាអែល ជាអំណាចនៃព្រះ (ចទ ៨:៣) ដូច្នេះមនុស្សក៏ត្រូវពឹងលើព្រះសម្រាប់ចំណីខាង ព្រលឹងវិញ្ញាណដែរ ។ ព្រះយេស៊ូវពឹងលើព្រះវរបិតាទ្រង់ មិនមែនលើការអស្ចារ្យរបស់ព្រះអង្គផ្ទាល់សម្រាប់ការផ្គត់ផ្គង់អាហារនោះឡើយ ។

**៤:៥** មើលពន្យល់ លក ៤:២ ។ *លើកំពូលព្រះវិហារ* មើលពន្យល់ លក ៤:៩ *ព្រះវិហារ* គឺរួមទាំងបរិវេណព្រះវិហារទាំងមូល ដែលបានកសាងឡើងវិញដោយស្តេចហេរ៉ូឌ(មើលការពន្យល់ ២:១ និង យហ ២:២០)។ ទីធ្លានៅខាងមុខបានពង្រីកយ៉ាងធំពី៣០១,៦២ម–៤៥៧ម ។ ការកសាងវេទិការដ៏ធំនេះ ដើម្បីទូទាត់សងនៃការបាត់បង់ទឹកដីនៅភាគអាគ្នេយ៍ ។ ជញ្ជាំងដែលបានធ្វើពីថ្មដុំក្រាស់ធំៗដើម្បី ទ្រវេទិការចំរានហាល និងទីធ្លានៃអាគារព្រះវិហារដែលអមទៅដោយជើងសសរដ៏ស្អាតៗជាច្រើន ។

**៤:១២** នៅត្រង់នេះ លោកយ៉ូហានត្រូវបានបញ្ជូនទៅដាក់គុក(មក ១:១៤ និងការពន្យល់ លក ៣:២០) មូលហេតុ ដែលគេចាប់គាត់ដាក់គុកមាននៅក្នុង ១៤:៣–៤ ។

**៤:១៣** *កាពើណិម* ទោះបីជាមិនបាននិយាយក្នុងព្រះគម្ពីរសញ្ញាចាស់ក៏ដោយក៏វាជាទីក្រុងមួយដែលមានទំហំធំគួរសមដែរនៅក្នុងសម័យព្រះយេស៊ូវ ។ ផ្ទះរបស់ពេត្រុសនៅទីនោះ ទើបបានក្លាយជាមូលដ្ឋាននៃប្រតិបត្តិការក្នុងអំឡុងពេលពង្រីកកិច្ចការរបស់ព្រះយេស៊ូវនៅសមុទ្រកាលីឡេ(មក ២:១ ៩:៣៣)។ នៅសតវត្សរ៍ទី៥ឃើញមានបន្សល់ទុកនៅជើងសសរដែល គេគិតថា ជាផ្ទះរបស់ពេត្រុស ហើយនិងនៅសតវត្សរ៍ទី៤ក៏មានព្រះវិហារមួយនៅក្បែរនោះដែរ ។

សាប់យូល៉ូន និងណែបថាលី ១៤ដើម្បីឱ្យបានសំរេច[ទ]ទំនាយ
ដែលហោរាអេសាយបានទាយថា ១៥ស្រុកសាប់យូល៉ូន
និងណែបថាលី តាមផ្លូវទៅឯសមុទ្រខាងនាយទន្លេយ័រដាន់
គឺជាស្រុកកាលីឡេរបស់សាសន៍ដទៃ ១៦ឯបណ្ដាជនដែល
អង្គុយក្នុងសេចក្ដីងងឹត គេបានឃើញពន្លឺយ៉ាងធំ មានពន្លឺរះ
ឡើង បំភ្លឺដល់ពួកអ្នកដែលអង្គុយក្នុងកំលុង ហើយនិងម្លប់
នៃសេចក្ដីស្លាប់[ធ] ១៧តាំងពីគ្រានោះមក ព្រះយេស៊ូវក៏ចាប់
តាំងប្រកាសដោយបន្ទូលថា ចូរប្រែចិត្តឡើង ដ្បិតនគរ
ស្ថានសួគ៌[ន]ជិតដល់ហើយ។

## ការត្រាស់ហៅពួកសាវ័កលើកដំបូង

*៤:១៨–២២ = មក ១:១៦–២០ លក ៥:២–១១ យហ ១:៣៥–៤២*

១៨កាលព្រះយេស៊ូវទ្រង់កំពុងយាងតាមឆ្នេរសមុទ្រកា
លីឡេ[ប] នោះក៏ទតឃើញបងប្អូន២នាក់ ជាអ្នកនេសាទត្រី គឺ
ស៊ីម៉ូន ដែលហៅថា ពេត្រុស[ផ] និងអនទ្រេជាប្អូនកំពុងតែ
បង់សំណាញ់ក្នុងសមុទ្រ ១៩រួចទ្រង់មានបន្ទូលទៅគេថា
ចូរមកតាមខ្ញុំៗនឹងតាំងអ្នក ឱ្យជាអ្នកនេសាទមនុស្សវិញ
២០គេក៏ទុកសំណាញ់ចោលទៅតាមទ្រង់ភ្លាម[ភ] ២១លុះយាង
ហួសពីនោះបន្តិចទៅ ទ្រង់ទតឃើញបងប្អូន២នាក់ទៀត
គឺយ៉ាកុប ជាកូនសេបេដេ និងយ៉ូហាន[ម]ជាប្អូន ដែលនៅក្នុង
ទូកជាមួយនឹងសេបេដេជាឪពុក គេកំពុងតែជួសជុល[1]សំ
ណាញ់ ហើយទ្រង់មានបន្ទូលហៅអ្នកទាំង២នោះមក ២២គេ
ក៏លះបង់ទូក និងឪពុក ដើរតាម[យ]ទ្រង់ជាមួយរំពេចទៅ ។

**៤:១៤**
ទ មថ ១:២២
**៤:១៦** ធ អស ៩:១,២ លក ២:៣២ យហ ១:៤, ៥,៩
**៤:១៧** ន មថ ៣:២
**៤:១៨** ប មថ ១៥:២៩ មក ៧:៣១ យហ ៦:១
ផ មថ ១៦:១៧,១៨
**៤:១៩**
ព ខ.២០,២២ មថ ៨:២២ មក ១០:២១, ២៨,៥២ លក ៥:២៨ យហ ១:៤៣ ២១:១៩,២២
**៤:២០** ភ ខ១៩
**៤:២១** ម មថ ១៧:១ ២០:២០ ២៦:៣៧ មក ៣:១៧ ១៣:៣ លក ៨:៥១ យហ ២១:២
**៤:២២** យ ខ.១៩
**៤:២៣** រ មក ១:៣៩ លក ៤:១៥,៤៤ ល មថ ៩:៣៥ ១៣:៥៤

## ព្រះយេស៊ូវប្រោសអ្នកជំងឺ

២៣ព្រះយេស៊ូវ ទ្រង់យាងគ្រប់សព្វក្នុងស្រុកកាលីឡេ[រ] ទ្រង់
បង្រៀនក្នុងអស់ទាំងសាលាប្រជុំ[ល] ក៏ប្រកាសដំណឹងល្អ[វ]ពី
នគរ[ស] ព្រមទាំងប្រោសជំងឺគ្រប់មុខ និងអស់ទាំងជរាពិការ
ក្នុងពួកបណ្ដាជន[2]ឱ្យជាផង ២៤ដំណឹងពីទ្រង់បានឮសុស
សាយទូទៅពេញក្នុងស្រុកស៊ីរី[ហ] គេក៏នាំអស់ទាំងមនុស្ស
ដែលមានជំងឺរោគាគ្រាំគ្រាផ្សេងៗ ទាំងមនុស្សអារក្ស
ចូល[ឡ]មនុស្សឆ្កួតជ្រូក[អ] និងមនុស្សស្លាប់ដៃ ស្លាប់ជើង[ក]មកឯ
ទ្រង់ ហើយទ្រង់ក៏ប្រោសឱ្យបានជាទាំងអស់គ្នា ២៥មាន
មនុស្ស[ក]កកកុញ ជាប់តាមទ្រង់[ខ] គឺជាមនុស្សដែលមកពីស្រុក
កាលីឡេ ស្រុកដេកាប៉ូល[3] ពីក្រុងយេរូសាឡិមពីស្រុកយូដា
ហើយពីខាងនាយទន្លេយ័រដាន់ ។

## សុភមង្គលដ៏ពិតប្រាកដ

*៥:៣–១២ = លក ៦:២០–២៣*

**៥** ១កាលបានឃើញហ្វូងមនុស្ស ទ្រង់ក៏យាងឡើងទៅលើ
ភ្នំ រួចកាលបានគង់ចុះហើយ នោះពួកសិស្សចូលមកឯទ្រង់
២ហើយទ្រង់បើកព្រះឱស្ឋបង្រៀនគេថា ៣មានពរហើយ

1. (ខ.២១) ភាសាអង់គ្លេសប្រើពាក្យ "រៀបចំ"
2. (ខ.២៣) មថ ៨:១៦ ១៤:១៤ ១៥:៣០ មក ៣:១០ លក ៧:២២ កថ ១០:៣៨
3. (ខ.២៥) ដេកាប៉ូល គឺជាទីក្រុងសម្ព័ន្ធមិត្តទាំងដប់ ។

មក ១:២១ លក ៤:១៥ យហ ៦:៥៩ ១៨:២០ វ មក ១:១៤ ស មថ ៣:២ កថ ២០:២៥ ២៨:២៣,៣១ **៤:២៤** ហ លក២:២ ឡ មថ៨:១៦, ២៨ ៩:៣២១២:២២ ១៥:២២ មក ១:៣២ ៥:១៥,១៦,១៨ អ មថ ១៧:១៥ ក មថ ៨:៦ ៩:២ មក ២:៣ **៤:២៥** ខ មក ៣:៧,៨ លក ៦:១៧

**៤:១៥–១៦** មានទំនាយមួយទៀតរបស់ហោរាអេសាយអំពីព្រះមែស៊ីថា ព្រះយេស៊ូវបានចំណាយពេលប្រកាសដំណឹងល្អជាសាធារណៈយ៉ាងច្រើននៅក្នុងស្រុកសាប់–យូលូន និងណែបថាលី(ខ.១៣) គឺនៅភាគខាងជើង និងភាគខាងលិចនៃសមុទ្រកាលីឡេ ។

**៤:១៧** *តាំងពីគ្រានោះមក* ពាក្យនេះបានបញ្ជាក់អំពីការផ្លាស់ប្ដូរដ៏សំខាន់មួយនៅក្នុងជីវិតរបស់ព្រះយេស៊ូវ ដែលមានបីដងនៅក្នុងគម្ពីរម៉ាថាយ (១៦:២១ ២៦:១៦) អ្នកខ្លះគិតថា ពាក្យនេះគឺជាសញ្ញាសម្រាប់បញ្ជាក់ថាមានបីវគ្គសំខាន់ៗនៅក្នុងព្រះគម្ពីរនេះ ។ *ប្រែចិត្ត* ព្រះយេស៊ូវបានប្រកាសដំណឹងល្អ ដោយប្រើពាក្យនេះ ដូចគ្នានឹងលោកយ៉ូហាន–បាទីស្ទនោះដែរ (៣:២) "ចូរប្រែចិត្តឡើង ដ្បិតនគរស្ថានសួគ៌ ជិតមកដល់ហើយ"។ ប្រែចិត្តមានន័យជ្រៅជាងការផ្លាស់ប្ដូរចិត្ត ឬអារម្មណ៍សោកស្ដាយចំពោះបាបរបស់ខ្លួននោះទៅទៀត ។ វាជាការលះបង់ដាច់ស្រឡះ ពិតប្រាកដពីនិស្ស័យចាស់ទៅរកឯព្រះដែលចេញជាលទ្ធផលទាំងសកម្មភាព ផ្នែកខាងក្រៅ ខាងក្នុង និងផ្នែកសីលធម៌ ។ *នគរស្ថានសួគ៌* មើលការពន្យល់ ៣:២ ។

**៤:១៨** *សមុទ្រកាលីឡេ* មើលការពន្យល់ មក ១:១៦ ។ *សំណាញ់* ត្រូវបានគេបោះចេញជារង្វង់មូល ដែលអាចឈរនៅលើទូក ឬនៅក្នុងទឹករាក់ៗ ។

**៤:១៩** *នេសាទមនុស្ស* គឺជាការប្រកាសដំណឹងល្អនៃសេចក្ដីសង្គ្រោះរបស់ព្រះដល់មនុស្សទូទៅ ដែលជាការងារដ៏សំខាន់របស់ពួកសាវ័ក ។

**៤:២០** មើលការពន្យល់ មក ១:១៧ ។

**៤:២១** *កំពុងតែជួសជុលសំណាញ់* មានន័យថា កំពុងលាងសំអាតញ្ញូរសម្រក់ទឹក ឬបត់ទុក(ត្រៀមជាស្រេច) សម្រាប់ការងារនៅថ្ងៃស្អែក ។

**៤:២៣** *ទ្រង់បង្រៀន . . . ប្រកាសដំណឹងល្អ . . . ប្រោសជំងឺ* ទាំង៣ចំណុចនេះគឺជាភារកិច្ចដែលព្រះយេស៊ូវធ្វើក្នុងពេលតែមួយ ហើយនៅគ្រប់ទីកន្លែងដែលទ្រង់បាន យាងទៅដល់ ។ *សាលាប្រជុំ* មើលការពន្យល់ មក ១:២១ ។ ជាកន្លែងសម្រាប់ទ្រង់ បង្រៀននៅថ្ងៃឈប់សម្រាកនៃសប្ដាហ៍ ហើយទ្រង់បានប្រកាសដំណឹងល្អនៅចំពោះ មុខហ្វូងមនុស្សជាច្រើន ។ *ដំណឹងល្អ* មើលការពន្យល់ មក ១:១ ។

**៤:២៤** *ស្រុកស៊ីរី* នៅផ្នែកខាងជើងស្រុកកាលីឡេ ចន្លោះក្រុងដាម៉ាស និងសមុទ្រមេឌីទែរ៉ាណេ ។ *មនុស្សឆ្កួតជ្រូក* ពាក្យដើមជាភាសាក្រិកមានន័យថា "ឆ្កួតខែ កន្លង" ពីបុរាណគេមានជំនឿជឿលើអព្ភូតហេតុនៃការបំលាស់ទីរបស់លោកខែ (ខែកន្លង)ដែលអាចធ្វើឱ្យមនុស្សឆ្កួតបាន ។

**៤:២៥** *ស្រុកដេកាប៉ូល* ជាសម្ព័ន្ធមិត្តមួយក្នុងចំណោមទីក្រុងទាំងដប់ ដែលបានចង្អុលចរិតលក្ខណៈដោយវប្បធម៌ក្រិកដ៏រុងរឿងនាសម័យនោះ ។ ការរួមបញ្ចូលគ្នាទាំង១០នេះហៅថា"ក្រុងបេត–សៀន" ស្ថិតនៅខាងកើតនៃសមុទ្រកាលីឡេ និងទន្លេយ័រដាន់ ។ សម្ព័ន្ធភាពនេះបានលាតសន្ធឹងចាប់ពីទិសពាយ័ព្យនៃសមុទ្រកាលីឡេ ឆ្ពោះទៅភាគខាងត្បូងនៃក្រុងភីឡាដិលភា

អស់អ្នកដែលមានសេចក្ដីកំសត់ខាងឯវិញ្ញាណ ដ្បិតនគរ
ស្ថានសួគ៌ជារបស់ផងអ្នកទាំងនោះ[គ] ៤មានពរហើយ អស់
អ្នកដែលយំសោក ដ្បិតអ្នកទាំងនោះនឹងបានសេចក្ដីកំសាន្ត
ចិត្ត[ឃ] ៥មានពរហើយ អស់អ្នកដែលស្លូតត្រង់ ដ្បិតអ្នក
ទាំងនោះនឹងគ្រងផែនដីជាមរដក[ង] ៦មានពរហើយ អស់
អ្នកដែលស្រេកឃ្លាននូវសេចក្ដីសុចរិត ដ្បិតអ្នកទាំងនោះ
នឹងបានឆ្អែត[ច] ៧មានពរហើយអស់អ្នកដែលមានចិត្តមេត្តា
ករុណា ដ្បិតអ្នកទាំងនោះនឹងបានសេចក្ដីមេត្តា ករុណា
វិញ[ឆ] ៨មានពរហើយ អស់អ្នកដែលមានចិត្ត បរិសុទ្ធ[ជ]
ដ្បិតអ្នកទាំងនោះនឹងបានឃើញព្រះ[ឈ] ៩មានពរ ហើយ
អស់អ្នកដែលផ្សះផ្សា[ញ]គេ ដ្បិតអ្នកទាំងនោះនឹងបាន
ហៅជាកូនរបស់ព្រះ[ដ] ១០មានពរហើយ អស់អ្នកដែលត្រូវ
គេបៀតបៀន ដោយព្រោះសេចក្ដីសុចរិត[ឋ] ដ្បិតនគរ
ស្ថានសួគ៌ជារបស់ផងអ្នកទាំងនោះ[ឌ] ១១អ្នករាល់គ្នាមានពរ
ក្នុងកាលដែលគេជេរ[ឍ] បៀតបៀន ហើយនិយាយបង្ខុស
គ្រប់ទាំងសេចក្ដីអាក្រក់ ពីអ្នករាល់គ្នា ដោយព្រោះខ្ញុំ[ណ]
១២ចូរមានចិត្តអំណរ ហើយរីករាយជាខ្លាំងចុះ[ត] ដ្បិតអ្នក
រាល់គ្នាមានរង្វាន់ជាធំនៅឯស្ថានសួគ៌ ពីព្រោះគេក៏បាន
ធ្វើទុក្ខដល់ពួកហោរា ដែលនៅមុនអ្នករាល់គ្នា[ថ] បែប
ដូច្នោះដែរ ។

### អំបិល និងពន្លឺ

១៣អ្នករាល់គ្នាជាអំបិលនៃផែនដី បើអំបិលបាត់ជាតិប្រៃ
ហើយ នោះតើនឹងយកអ្វី ដើម្បីធ្វើឱ្យប្រៃឡើងវិញបាន
ជារបស់គ្មានប្រយោជន៍ទៀតសោះ មានតែបោះបង់ចោល

**៥:៣** គ ខ.១០,១៩ មថ ២៥:៣៤ **៥:៤** ឃ អស ៦១:២,៣ វវ ៧:១៧ **៥:៥** ង ទដ ៣៧:១១ រម ៤:១៣ **៥:៦** ច អស ៥៥:១,២ **៥:៧** ឆ យក ២:១៣ **៥:៨** ជ ទដ ២៤:៣,៤ ៧៣:១ ឈ ទដ ១៧:១៥ ៤២:២ ហព ១២:១៤ វវ ២២:៤ **៥:៩** ញ យក ៣:១៨ រម ១៤:១៩ ដ ខ៤៤,៤៥

រម ៨:១៤ **៥:១០** ឋ ១ពត ៣:១៤ ឌ ខ.៣,១៩ មថ ២៥:៣៤ **៥:១១** ឍ អស ៥១:៧ ណ យហ ១៥:២១ **៥:១២** ត ទដ ៩:២ កច ៥:៤១ ២កថ ៦:១០ ១២:១០ កល ១:២៤ យក ១:២ ១ពត ១:៦ ៤:១៣,១៦ ថ ២រប ៣៦:១៦ មថ ២៣:៣១,៣៧ កច ៧:៥២ ១ថន២:១៥ ហព ១១:៣២–៣៨

(វវ ៣:៧) ។

**៥:១–៧:២៩** សេចក្ដីអធិប្បាយលើភ្នំ គឺជាការលើកទឹកចិត្តមួយក្នុងចំណោមការលើកទឹកចិត្តទាំង៥ក្នុងគម្ពីរម៉ាថាយ (ជំពូក ៥–៧,១០,១៣,១៨,២៤–២៥) ។ នៅក្នុងវគ្គនេះមានសេចក្ដីបង្រៀនបីប្រភេទគឺ (១).សុភមង្គលដ៏ពិតដែលបានពណ៌នាអំពីព្រះពរ (៥:១–១២) ។ (២).ការទូន្មានផ្នែកសីលធម៌ (៥:១៣–២០ ៦:១–៧:២៣) ។ (៣).ជាការផ្ទុយគ្នារវាងការបង្រៀនផ្នែកសីលធម៌របស់ព្រះយេស៊ូវ និងច្បាប់ប្រពៃណីរបស់សាសន៍យូដា (៥:២១–៤៨) ។ ការបញ្ចប់ការអធិប្បាយជាមួយនឹងរឿងប្រដូចខ្លីមួយ ដែលបញ្ជាក់អំពីសារសំខាន់នៃការអនុវត្តន៍នូវអ្វីដែលទ្រង់បានបង្រៀន (៧:២៤–២៧) និងបង្ហាញពីការចាប់អារម្មណ៍របស់បណ្ដាជនលើព្រះបន្ទូលដ៏មានអំណាចព្រះចេស្ដារបស់ព្រះយេស៊ូវ (៧:២៨–២៩) ។

មានមតិផ្សេងទៀតបានឱ្យដឹងពីការសង្ខេបសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវ នៅត្រង់វគ្គនេះថា ជាការបង្រៀនក្នុងឱកាសមួយ ឬជាការបង្រៀនដ៏ស្មុគស្មាញដែលបានបង្ហាញក្នុងឱកាសផ្សេងៗទៀត ។ លោកម៉ាយបានយកសេចក្ដីបង្រៀនតែមួយមកពង្រីក និងបញ្ចូលក្នុងការបង្រៀនដទៃៗទៀតដែល មានជាប់ទាក់ទងគ្នា ។ មាន៣៤ខនៃការបង្រៀនលើភ្នំក្នុងគម្ពីរម៉ាថាយដែលខុសប្លែកពីគម្ពីរលូកា ។ បន្ទាប់មកមានសេចក្ដីបង្រៀនដែលមានសាច់រឿងដូចគ្នានេះដែរនៅក្នុងគម្ពីរ លូកា (លក ៦:១៧–៤៩) ។ អធិប្បាយលើភ្នំរំលឹកដល់ការរស់នៅដោយសីលធម៌ និងចរិយាល្អត្រឹមត្រូវឥតខ្ចោះដែលធ្វើឱ្យអ្នកខ្លះបានបោះបង់ចោលការនេះ ដោយគិតថាគ្មាននណាអាចធ្វើបានទេ វាជាគម្រោងមួយដើម្បីនឹងសម្រេចនៅក្នុងនគរស្ថានសួគ៌ ។ គ្មានអ្វីគួរឱ្យឆ្ងល់ឡើយថា ព្រះយេស៊ូវតាមគម្ពីរ (ម៉ាថាយ) បានប្រទានបញ្ញត្តិនេះជាគំរូដល់គ្រីស្ទបរិស័ទ ដែលយើងដឹងច្បាស់ថា យើងមិនអាចធ្វើដោយខ្លួនឯងបានទេ នេះជាការបញ្ជាក់យ៉ាងច្បាស់របស់ព្រះយេស៊ូវ (មើលការពន្យល់ មថ ៥:២៩–៣០) ។

**៥:១** *ភ្នំ* ជាទីកន្លែង១ដែលមិនបានដឹងប្រាកដទេ ។ ប្រហែលជាជើងភ្នំ ដែលមានជម្រាលតិចៗនៅទិសពាយព្យនៃសមុទ្រកាលីឡេ ក្បែរក្រុងកាពើណិម (មើលការ ពន្យល់ លក ៦:២០–៤៩) ។ ច្បាប់ថ្មីក៏ដូចជាច្បាប់ចាស់ដែរ (នក ១៩:៣) បានយកចេញពីភ្នំមួយ ។ *គង់ចុះ* ជាទម្លាប់របស់ពួកសាសន៍យូដាកាលណាគេបង្រៀន ត្រូវអង្គុយចុះ (មក ៤:១ ៩:៣៥ លក ៤:២០ ៥:៣ យហ ៨:២) ។ *ពួកសិស្ស* "អ្នករៀន" ចប់ពីការអធិប្បាយនៅលើភ្នំ "ហ្វូងមនុស្ស" សំដែងការអស្ចារ្យចំពោះការបង្រៀនរបស់ព្រះយេស៊ូវ (៧:២៨) "សាវ័ក" ប្រហែលអាចត្រូវបានគេប្រើសម្រាប់អ្នកចេះដឹងធំទូលាយ បន្ទាប់មកអ្នកទាំង១២នាក់ ឬប្រហែលការអធិប្បាយនេះដល់សិស្សទាំង១២នាក់ ដែលនៅក្នុងចំណោមបណ្ដាជនកំពុងតែស្ដាប់ជាមួយគ្នាដែរ ។

**៥:៣** *មានពរហើយ* មានន័យលើសពី "សប្បាយ" ពីព្រោះភាពសប្បាយ គឺជាអារម្មណ៍មួយតែងតែអាស្រ័យលើកាលៈទេសៈខាងក្រៅ ។ " មានពរហើយ" នៅទីនេះ គឺសំដៅដល់ការដែលមានសុខុមាលភាពល្អប្រសើរជាទីបំផុត និងមានអំណរខាងវិញ្ញាណ ដោយដឹងច្បាស់ពីសេចក្ដីសង្គ្រោះ ដែលមាននៅក្នុងនគរព្រះ (ទដ ១:១ វវ ១:៣ និងពន្យល់) ។ *កំសត់ខាងឯវិញ្ញាណ* ផ្ទុយទៅនឹងអំនួតខាងវិញ្ញាណ និងការគិតថាខ្លួនគ្រប់គ្រាន់ហើយ ។ *ដ្បិតនគរស្ថានសួគ៌ជារបស់ផងអ្នកនោះ* នគរស្ថានសួគ៌គឺមិនមែនជារបស់ដែលយើងស្វែងរកទិញបាននោះទេ តែវាជាអំណោយទានវិញ មិនមែនជាការសងឬក៏ជារង្វាន់នោះដែរ ។

**៥:៥** *ស្លូតត្រង់* នេះគឺជាព្រះពរមួយ (សុភមង្គល) បានដកស្រង់ចេញពី ទដ ៣៧:១១ ហើយពុំមែននិយាយសំដៅច្រើន ទៅនឹងអាកប្បកិរិយាមនុស្សដូចការរៀបចំចិត្ត ចំពោះព្រះនោះទេ គឺជាការបន្ទាបខ្លួន ។ *ផែនដី* គឺជាទឹកដីសន្យាថ្មី (វវ ២១:១) ។

**៥:៨** *ចិត្ត* (បេះដូង) ជាចំណុចសំខាន់របស់មនុស្ស រួមទាំងគំនិត ឆន្ទៈ អារម្មណ៍ (មើលការពន្យល់ ទដ ៤:៧) ។

**៥:៩** *ផ្សះផ្សាគេ* គឺអស់អ្នកដែលផ្សាយសន្តិភាពនៅកន្លែងណា ដែលពួកគេទៅដល់ (រម ១២:១៨) ។ ការធ្វើដូច្នេះ គឺឆ្លុះបញ្ចាំងពីចរិតលក្ខណៈនៃព្រះវរបិតាគង់នៅស្ថានសួគ៌ និងត្រូវបានគេហៅថា "កូននៃព្រះ" ។

**៥:១០** *នគរស្ថានសួគ៌របស់ផងអ្នកទាំងនោះ* ជាដំណើរពិតប្រាកដក្នុងក្ដីសង្ឃឹមនាពេលអនាគត ។

**៥:១៣** *អំបិល* ប្រើសម្រាប់ធ្វើជាគ្រឿងឱ្យម្ហូបមានរសជាតិ និងសម្រាប់

ទៅក្រៅ ឱ្យមនុស្សដើរជាន់ប៉ុណ្ណោះ[ទ] ១៤អ្នករាល់គ្នាជា
ពន្លឺនៃលោកីយ៍[ធ] ឯទីក្រុងណាដែលនៅលើភ្នំ នោះលាក់មិន
កំបាំងទេ ១៥ក៏គ្មានអ្នកណាអុជចង្កៀង យកទៅដាក់ក្រោម
ថាំងដែរ គេតែងដាក់លើជើងចង្កៀងវិញ នោះទើបភ្លឺដល់
អ្នកដែលនៅក្នុងផ្ទះទាំងអស់គ្នា[ន] ១៦ដូច្នេះ ចូរឱ្យពន្លឺរបស់
អ្នករាល់គ្នា បានភ្លឺនៅមុខមនុស្សលោកយ៉ាងនោះដែរ[ប]
ដើម្បីឱ្យគេឃើញការល្អ ដែលអ្នករាល់គ្នាប្រព្រឹត្ត[ផ] រួចសរ
សើរដំកើង[ព] ដល់ព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅ
ស្ថានសួគ៌ ។

## ការសម្រេចលើក្រឹត្យវិន័យ

១៧កុំឱ្យគិតស្មានថា ខ្ញុំមកដើម្បីនឹងលើកក្រិត្យវិន័យ ឬទំ
នាយពួកហោរាចោលឡើយ ខ្ញុំមិនមែនមកនឹងលើកចោល
ទេ គឺមកនឹងធ្វើឱ្យសំរេចវិញ[ភ] ១៨ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នា
ជាប្រាកដថា នឹងគ្មានបាំងឈើ១ ឬក្បៀស១នៅក្នុងក្រិត្យ
វិន័យ ត្រូវបាត់ឡើយ ដរាបដល់កាលណាមេឃ និងផែនដី
បានកន្លងបាត់ទៅ គឺទាល់តែសេចក្តីទាំងអស់បានសំរេច
ដោយសព្វគ្រប់[ម] ១៩ដូច្នេះ អ្នកណាដែលនឹងរំលងបទណា

**៥:១៣** ទ មក ៩:៥០ លក ១៤:៣៤,៣៥
**៥:១៤** ធ យហ ៨:១២
**៥:១៥** ន មក ៤:២១ លក ៨:១៦ ១១:៣៣
**៥:១៦** ប ១កថ ១០:៣១ ភល ១:១១ ផ ទត ២:១៤ ព មថ ៩:៨
**៥:១៧** ភ យហ ១០:៣៤,៣៥ រម ៣:៣១
**៥:១៨** ម ទដ ១១៩:៨៩ អស ៤០:៨ ៥៥:១១ មថ ២៤:៣៥ មក ១៣:៣១ លក ១៦:១៧ ២១:៣៣
**៥:១៩** យ យក ២:១០

មួយ សូម្បីយ៉ាងតូចបំផុត ក្នុងបញ្ញត្តិ[យ]ទាំងនេះ ហើយ
បង្រៀនមនុស្សឱ្យធ្វើដូច្នោះដែរ នោះនឹងត្រូវហៅជាអ្នក
តូចបំផុតក្នុងនគរស្ថានសួគ៌ តែអ្នកណាដែលកាន់តាមហើយ
បង្រៀនចំពោះបញ្ញត្តិទាំងនេះ នោះនឹងបានហៅជាអ្នកធំ
ក្នុងនគរស្ថានសួគ៌វិញ ២០ខ្ញុំប្រាប់អ្នករាល់គ្នាថា បើសេចក្តី
សុចរិតរបស់អ្នករាល់គ្នា មិនលើសពីសេចក្តីសុចរិត នៃពួក
អាចារ្យ និងពួកផារិស៊ីទេ នោះអ្នករាល់គ្នានឹងចូលទៅក្នុង
នគរស្ថានសួគ៌[រ] ពុំបានឡើយ ។

## ការធ្វើឃាតមនុស្ស

*៥:២៥,២៦ = លក ១២:៥៨,៥៩*

២១អ្នករាល់គ្នាបានឮសេចក្តីដែលសំដែងដល់មនុស្សពី
បុរាណថា «កុំឱ្យសំឡាប់មនុស្សឱ្យសោះ» បើអ្នកណាសំឡាប់
មនុស្ស[ល] នោះក្រែងត្រូវជាប់ជំនុំជំរះហើយ ២២តែខ្ញុំប្រាប់
អ្នករាល់គ្នាដូច្នេះវិញ ថា សូម្បីតែអ្នកណាដែលខឹង[វ]នឹង
បងប្អូន នោះក្រែងត្រូវជាប់ជំនុំជំរះ[ស]ដែរ ហើយអ្នកណា

**៥:២០** រ អស ២៦:២ មថ ១៨:៣ យហ ៣:៥ **៥:២១** ល នក ២០:១៣ ២១:១២ ចទ ៥:១៧ **៥:២២** វ សស ៧:៩ ១កថ ១៣:៥ អភ ៤:២៦ យក ១:១៩,២០ ស ១យហ ៣:១៥

រក្សាចំណីអាហារឱ្យបានយូរ ។ *បាត់ជាតិប្រៃ* ពាក្យនេះសំដៅលើអំបិលមួយប្រភេទដែលពួកអ៊ីស្រាអែលយកមកពីសមុទ្រស្លាប់ដែលជាអំបិលមិនសុទ្ធ មិនល្អ ខ្វះជាតិប្រៃ តែក៏មានឈ្មោះថាជា អំបិលនឹងគេដែរ ។

**៥:១៥** *ចង្កៀង* នៅសម័យព្រះយេស៊ូវ ប្រជាជនប្រើចង្កៀងតូចៗធ្វើពីដីឥដ្ឋ និងដុត ដោយប្រេងអូលីវនៅត្រង់ប្រឆេះរបស់វា (មើលការពន្យល់ នក ២៥:៣៧)។ *ថាំង* គឺស្រដៀងនឹងចាន មានប្រវែងប្រហែលជា៨ស.ម ធ្វើអំពីដីសម្រាប់ដាក់អាហារ ឬម្សៅ ។

**៥:១៦** *ព្រះវរបិតា . . .ដែលគង់នៅស្ថានសួគ៌* លោកម៉ាថាយប្រើពាក្យ "ព្រះវរបិតា គង់នៅស្ថានសួគ៌"ឬ"ព្រះវរបិតានៃស្ថានសួគ៌" ចំនួន១៧ដង ចំណែកឯលោកម៉ាកុស និងលោកលូកា ម្នាក់ៗប្រើពាក្យនេះតែម្តងគត់ ហើយលោកយ៉ូហានវិញមិន បានប្រើពាក្យនេះទាល់តែសោះ ។

**៥:១៧** *ក្រិត្យវិន័យ* គម្ពីរ៥កណ្ឌដំបូងនៃពួកយូដា (សញ្ញាចាស់)។ *ពួកហោរា* គឺ រួមទាំងហោរាធំដូចជា អេសាយ យេរេមា អេសេគាល និងហោរាតូចទាំង១២ (ដែលបានបញ្ចូលគ្នាដោយពួកយូដាហៅថា "ក្រឹត្យវិន័យទាំង១២)។ ប៉ុន្តែ កាលពីមុនត្រូវបានចាត់ទុកជាហោរាផងដែរ នោះគឺ យ៉ូស្វេ ពួកចៅហ្វាយ សាំយូអែល និងពង្សាវតារក្សត្រ ក្រឹត្យវិន័យពេញទាំងគម្ពីរសញ្ញាចាស់ រួមទាំងការសរសេរវគ្គទីបីនៃព្រះគម្ពីរ ហេព្រើរផងដែរ (១៣:៣៥)។ ហោរាទាំងនេះហើយ ដែលលោកម៉ាថាយបានដកស្រង់មកនិយាយ (ទដ ៧៨:២)។ *ឱ្យសំរេច* ព្រះយេស៊ូវបានធ្វើឱ្យក្រឹត្យវិន័យ សម្រេច មានន័យថាទ្រង់បានប្រទានត្រឹត្យវិន័យមក នោះគឺមានន័យ ពេញលេញរួចហើយ ។ ព្រះយេស៊ូវបានសង្កត់ន័យឱ្យកាន់តែជ្រៅថែមទៀត ដែលជាគោលការមូលដ្ឋាន និងការប្រព្រឹត្ត វាប្រសើរជាងគ្រាន់តែមានចំណេះដឹង និងការស្តាប់បង្គាប់តែផ្នែកខាងក្រៅ ។

**៥:១៨–២០** ព្រះយេស៊ូវមិនមានបន្ទូលប្រឆាំងនឹងការពិនិត្យសង្កេតលើតម្រូវការនៃក្រឹត្យវិន័យនោះទេ ប៉ុន្តែប្រឆាំងនឹងពួកអ្នកមានពុត អ្នកច្បាប់និយមផារីស៊ី ។ អ្នកច្បាប់និយមទាំងនេះមិនបានរក្សាគ្រប់ទាំងបញ្ញត្តិរបស់ព្រះឡើយ គឺមានតែសំបកខាងក្រៅដែលមើលទៅហាក់បីដូចជារក្សាបានល្អណាស់ ។ ដើម្បីទទួលបាន ព្រះពរពីព្រះនោះយើងត្រូវរក្សាបញ្ញត្តិទ្រង់នៅខាងក្នុងយ៉ាងពិតប្រាកដវិញ ។ វាមានតួអក្សរជាបន្តបន្ទាប់នៃក្រឹត្យវិន័យខណៈពេលដែលមិនយកចិត្តទុកដាក់នៅ លើគំនិតរបស់វា នោះហើយដែលព្រះយេស៊ូវបានបោះបង់ចោលនូវការកាត់ស្រាយនៃក្រឹត្យវិន័យរបស់ពួកគេ និងទស្សនៈនៃភាពសុចរិតដោយសារការងារ ។ ព្រះយេស៊ូវបានប្រកាសថាបានសុចរិត គឺតាមរយៈសេចក្តីជំនឿលើទ្រង់ និងកិច្ចការរបស់ទ្រង់ ។ នៅខបន្ទាប់ ទ្រង់ប្រទានគំរូប្រាំមួយបែបនៃសំបកខាងក្រៅរបស់ពួកផារីស៊ី ។

**៥:១៨** *បាំងឈើ១* ជាពាក្យមួយក្នុងភាសាក្រិកមានន័យថា តិចបំផុត (iota) ប្រើនៅពេលយើងនិយាយ "គ្មានអ្វីខុសគ្នាទេ" ស្មើនឹងភាសាហេព្រើរថា "yodh"ជាតួអក្សរ តូចជាងគេបំផុតនៅក្នុងភាសាហេព្រើរ ។ *ក្បៀស១ត្រូវបាត់ឡើយ* ឃ្លានេះជាភាសាក្រិកមានន័យថា"ក្បៀស ឬបន្តក់" ដែលប្រើសំគាល់សំលេងវែងខ្លីនៃតួអក្សររបស់ហេព្រើរ ។

**៥:២១** *សេចក្តីដែលសំដែង* ផ្ទុយទៅនឹងអ្វីដែលព្រះយេស៊ូវប្រើក្នុងខ.១២, ២៧,៣១,៣៣,៣៨,៤៣ ហើយមិនមាននៅក្នុងគម្ពីរសញ្ញាចាស់ និងសេចក្តីបង្រៀនរបស់ទ្រង់ទេ (ទ្រង់បានធ្វើឱ្យក្រឹត្យវិន័យក្នុងសញ្ញាចាស់មានសុពលភាព) ជាជាងគ្រាន់តែជាអ្នកដែលកាត់ស្រាយ និងជាអ្នកបង្រៀនច្បាប់ប្រពៃណី ហើយថែមទាំងបានកែតម្រូវនៃការកាត់ស្រាយក្រឹត្យវិន័យទៀតផង ។ ធ្វើឃាតជាច្រើនដងជាភាសាក្រិក និងហេព្រើរគឺមានន័យថា"សម្លាប់" ហើយពាក្យនេះបានប្រើនៅក្នុង នក ២០:១៣ ដែលមានន័យចំគឺ "ធ្វើឃាត"។

**៥:២២** *អាចោលម្សៀត* ប្រហែលជាមកពីពាក្យអារ៉ាប់ មានន័យថា "សីៗ" និង "គ្មានខួរ"។ *ធ្វើទោស* មើលការពន្យល់ មក ១៤:៥៥ ។ *ស្ថាននរក* ជា

ដែលស្ដីឱ្យបងប្អូនថា «អាចោលម្សៀត» នោះក្រែងពួកក្រុម
ជំនុំផ្ដើទោស[ហ] តែចំណែកអ្នកណាដែលថា «អាឆ្កួត» នោះ
ក្រែងធ្លាក់ទៅក្នុងភ្លើងនរក[ឡ] ២៣ដូច្នេះ បើកាលណាអ្នកនាំ
យកដង្វាយមកដល់អាសនាហើយនៅទីនោះអ្នកនឹកឃើញ
ថា បងប្អូនណាមានហេតុអ្វីទាស់នឹងអ្នក ២៤នោះត្រូវទុក
ដង្វាយរបស់អ្នកនៅមុខអាសនា ហើយទៅរកជានឹងបងប្អូន
ជាមុនសិន រួចសឹមមកថ្វាយដង្វាយអ្នកចុះ ២៥ចូរឱ្យអ្នកជា
ស្រុះស្រួល នឹងអ្នកដើមចោទវិញជាប្រញាប់ ដែលកំពុង
តែដើរតាមផ្លូវជាមួយគ្នា ក្រែងគេបញ្ជូនអ្នកទៅឯចៅក្រម
ហើយចៅក្រមប្រគល់អ្នកទៅដល់នាយភូឃុំ រួចអ្នកត្រូវជាប់គុក
២៦ខ្ញុំប្រាប់អ្នកជាប្រាកដថា ដែលអ្នកនៅខ្វះតែ១សេន នឹង
សងគេឱ្យគ្រប់ នោះនឹងចេញពីទីនោះមិនរួចឡើយ ។

## ការផិតក្បត់

២៧អ្នករាល់គ្នាបានឮសេចក្ដី ដែលសំដែងពីដើមថា «កុំ
ផិតឱ្យសោះ»[អ] ២៨ប៉ុន្តែខ្ញុំប្រាប់អ្នករាល់គ្នាថា សូម្បីតែ
អ្នកណាដែលគ្រាន់តែក្រឡេកឃើញស្ត្រី ហើយមានដំរេក
សំរើបចង់បាន នោះឈ្មោះថា បានប្រព្រឹត្តសេចក្ដីកំផិត
នឹងនាងនោះ នៅក្នុងចិត្តខ្លួនហើយ[ក] ២៩បើភ្នែកស្តាំអ្នកនាំឱ្យ
រវាតចិត្ត[ខ] នោះចូរខ្វេះចេញបោះចោលទៅ ដ្បិតដែល
ភ្នែកអ្នក១ត្រូវវិនាស នោះមានប្រយោជន៍ ជាជាងឱ្យរូប
កាយទាំងមូល ត្រូវបោះទៅក្នុងនរក ៣០ហើយបើដៃស្តាំអ្នក
នាំឱ្យរវាតចិត្ត[គ] នោះចូរកាត់ចេញបោះចោលទៅ ដ្បិត
ដែលដៃអ្នកម្ខាងត្រូវវិនាស នោះមានប្រយោជន៍ ជាជាង
ឱ្យរូបកាយទាំងមូល ត្រូវបោះទៅក្នុងនរក ។

## ការលែងលះប្តីប្រពន្ធ

៣១មានសេចក្ដីថ្លែងទុកមកទៀតថា អ្នកណាដែលចង់លែង
ប្រពន្ធ នោះមានតែឱ្យសំបុត្រ[ឃ]លះលែងដល់នាង ៣២ប៉ុន្តែ
ខ្ញុំប្រាប់អ្នករាល់គ្នាថា ស្ត្រីណាដែលមិនផិតប្តី បើប្តីនោះ
លែងចេញ នោះឈ្មោះថា បានធ្វើឱ្យនាងទៅជាស្រីសំផឹង
ហើយ បើអ្នកណាយកស្ត្រីដែលប្តីលែង ធ្វើជាប្រពន្ធ អ្នក
នោះហៅថា ប្រព្រឹត្តសេចក្ដីកំផិតដែរ[ង] ។

## សម្បថ

៣៣មួយទៀត អ្នករាល់គ្នាបានឮសេចក្ដី ដែលសំដែងមក
ដល់មនុស្សពីដើមថា «កុំឱ្យស្បថកុហក[ច]ឡើយ គឺត្រូវឱ្យ
ធ្វើសំរេចតាមគ្រប់ទាំងសេចក្ដីដែលស្បថនឹងព្រះអម្ចាស់»[ឆ]
៣៤ប៉ុន្តែខ្ញុំប្រាប់អ្នករាល់គ្នាថា កុំឱ្យស្បថឱ្យសោះ[ជ] ទោះនឹង
ស្ថានសួគ៌ក្តី ព្រោះជាបល្ល័ង្ក[ឈ]នៃព្រះ ៣៥ទោះនឹងផែនដីក្តី
ព្រោះជាកំណល់កល់ព្រះបាទទ្រង់ ទោះនឹងក្រុងយេរូសា–
ឡិមក្តី ព្រោះជាក្រុងនៃស្តេចធំ[ញ] ៣៦ក៏កុំឱ្យស្បថនឹងក្បាលអ្នក
ដែរ ពីព្រោះអ្នកនឹងធ្វើឱ្យសក់១សរសៃត្រឡប់ទៅជាសឬ
ខ្មៅពុំបានទេ ៣៧ត្រូវឱ្យចេញសំដីថាតែមែនៗ ឬទេៗ[ដ]
ប៉ុណ្ណោះ សេចក្ដីណាដែលលើសអំពីនោះទៅ នោះមកតែ
ពីអាកំណាច[ឋ]ទេ ។

## គំនុំសងសឹក

៣៨អ្នករាល់គ្នាបានឮសេចក្ដីដែលថ្លែងទុកថា «ភ្នែកឱ្យធួន
នឹងភ្នែក ហើយធ្មេញឱ្យធួននឹងធ្មេញ»[ឌ] ៣៩ប៉ុន្តែ ខ្ញុំប្រាប់
អ្នករាល់គ្នាថា កុំឱ្យតតាំងនឹងអំពើអាក្រក់ឡើយ បើអ្នកណា

ហ មថ ២៦:៥៦ យហ ១១:៤៧ កច ៥:២១,២៧,៣៤,៤១ ៦:១២ ឡ មថ ១៨:៩ មក ៩:៤៣,៤៨ លក ១៦:២៤ យក ៣:៦
**៥:២៧** អ នក ២០:១៤ ចទ ៥:១៨
**៥:២៨** ក សភ ៦:២៥ ២ពត ២:១៤
**៥:២៩** ខ មថ ៥:៣០ ១៨:៦,៨,៩ មក ៩:៤២–៤៧ លក ១៧:២ រម ១៤:២១ ១កថ ៨:១៣ ២កថ ៦:៣ ១១:២៩
**៥:៣០** គ ខ ២៩
**៥:៣១** ឃ ចទ ២៤:១–៤
**៥:៣២** ង លក ១៦:១៨
**៥:៣៣** ច លវ ១៩:១២ ឆ ជន ៣០:២ ចទ ២៣:២១ មថ ២៣:១៦–២២
**៥:៣៤** ជ យក ៥:១២ ឈ អស ៦៦:១ មថ ២៣:២២
**៥:៣៥** ញ ទដ ៤៨:២
**៥:៣៧** ដ យស ៥:១២ ឋ មថ ៦:១៣ ១៣:១៩,៣៨ យហ ១៧:១៥ អភ ៦:១៦ ២ថន ៣:៣ ១យហ ២:១៣,១៤ ៣:១២ ៥:១៨,១៩
**៥:៣៨** ឌ នក ២១:២៤ លវ ២៤:២០ ចទ ១៩:២១

ភាសាក្រិកថា *គេហិនណា* (gehenna) ដែលក្លាយមកពីឈ្មោះរបស់ជ្រលងភ្នំដ៏ជ្រៅមួយនៅភាគខាងត្បូងនៃក្រុងយេរូសាឡិម "ជ្រោះនៃកូនប្រុស *ហិនណូម* (Hinnom)" ជាភាសាហេព្រើរ គេហិនណូម (gehinnom) ។ អំឡុងពេលស្ដេចកំណាចអ័រហាស និងម៉ានាសេកាន់អំណាច ពួកគេយកមនុស្សទៅបូជាយញ្ញដល់ព្រះជនជាតិអាម៉ូនឈ្មោះ ព្រះម៉ូលិចនៅទីនោះ ។ យ៉ូសៀស បានបោះបង់ជ្រលងភ្នំនោះចោលដោយសារវាជាកន្លែងថ្វាយបង្គំព្រះដទៃ (២រប ២៣:១០ យរ ៧:៣១–៣២ ១៩:៦) ហើយក្រោយមកបានក្លាយជាទីក្រុងគំនរកប់ខ្មោច និងជាទីកន្លែងកាត់ទោសចុងក្រោយ ។

**៥:២៣–២៦** គំរូឧទាហរណ៍បញ្ជាក់អំពីប្រភេទនៃការដោះស្រាយជាមួយកំហឹង ដោយការផ្សះផ្សា ។

**៥:២៦** *សេន* គឺជាប្រាក់កាក់ធ្វើពីទង់ដែង ដែលមានតម្លៃតូចជាងគេបំផុត នៅសម័យមុន (ពួកចក្រភពរ៉ូម៉ាំងប្រើពាក្យថា "ផិននី" (penny) ។

**៥:២៨** *ឃើញស្ត្រី ហើយមានដំរេក សំរើបចង់បាន* មិនមែនគ្រាន់តែក្រឡេកឃើញមួយភ្លែតហើយចប់នោះទេ គឺមានបំណងប៉ងប្រាថ្នា ដោយសម្លឹងមិនដាក់ភ្នែកក្នុងតម្រេកតណ្ហា ។ តាមព្រះបន្ទូលរបស់ព្រះយេស៊ូវនេះ គឺជាទម្រង់មួយនៃសេចក្ដីកំផិត ទោះបីគ្រាន់តែជា "គិតក្នុងចិត្ត" ក៏ដោយ ។

**៥:២៩–៣០** ព្រះយេស៊ូវគ្រីស្ទពុំបានបង្រៀនឱ្យមនុស្សកាត់អវៈយវៈណាមួយចេញទេនៅត្រង់នេះ ។ មនុស្សគ្រប់គ្នាតែងតែមានចំណង់ (ទោះជាមនុស្សខ្វាក់ក៏ដោយ) ប៉ុន្តែ សំខាន់ត្រូវចេះដោះស្រាយឱ្យច្បាស់លាស់នៅពេលជួបប្រទះអំពើបាប ។

**៥:៣០** *ស្ថាននរក* មើលការពន្យល់ ខ.២២ ។

**៥:៣២** *ស្ត្រីណាដែលមិនផិតប្តី* មើលការពន្យល់ ១៩:៣ មក ១០:១១–១២ និង លក ១៦:១៨ ។

**៥:៣៣–៣៧** បទគម្ពីរសញ្ញាចាស់បានអនុញ្ញាតឱ្យស្បថ លើកលែងតែកិច្ចការណាដែលប្រមាថដល់ព្រះនាមព្រះ ។ ព្រះយេស៊ូវជានិច្ចជាកាលមានបន្ទូលជាសេចក្ដីសន្យាដែលជាការពិតជានិច្ច ។

**៥:៣៨** មើលការពន្យល់ នក ២១:២៣–២៥ លវ ២៤:២០ ។

**៥:៣៩** *តតាំង* នេះប្រហែលជាសកម្មភាពនៅក្នុងតុលាការ ។ *ទះកំផ្លៀងស្តាំ*

ទះកំផ្លៀងស្តាំនៃអ្នក នោះត្រូវតែបែរកំផ្លៀងម្ខាង[ឍ]ទៅឱ្យ
ទៀត ៤០ បើអ្នកណាប្តឹងចង់យកអាវខ្លីរបស់អ្នក នោះត្រូវ
បើកឱ្យគេយកទាំងអាវវែងផង ៤១ បើអ្នកណាបង្ខំឱ្យអ្នកទៅ
អស់១យោជន៍ នោះចូរទៅជាមួយនឹងគេដល់២យោជន៍ផង
៤២ ចូរឱ្យដល់អ្នកណាដែលសូម ហើយកុំឱ្យគេចចេញពីអ្នក
ណាដែលចង់ខ្ចីអ្នក[ណ]ឡើយ ។

## ការស្រឡាញ់ខ្មាំងសត្រូវ

៤៣ អ្នករាល់គ្នាបានឮសេចក្តី ដែលថ្លែងទុកមកថា «ចូរ
ស្រឡាញ់អ្នកជិតខាង[ត]ឯង តែស្អប់ខ្មាំងសត្រូវ[ថ]ឯងវិញ»
៤៤ ប៉ុន្តែខ្ញុំប្រាប់ថា ត្រូវស្រឡាញ់ពួកខ្មាំងសត្រូវ ត្រូវឱ្យពរ
ដល់អ្នកណាដែលប្រទេចផ្តាសា ត្រូវប្រព្រឹត្តល្អនឹងអ្នកណា
ដែលស្អប់អ្នករាល់គ្នា ហើយត្រូវអធិស្ឋាន ឱ្យអ្នកណាដែល
ធ្វើទុក្ខបៀតបៀនដល់អ្នក[ទ]រាល់គ្នាវិញ ៤៥ ដើម្បីឱ្យបានធ្វើ
ជាកូន[ធ]របស់ព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថាន
សួគ៌ ព្រោះទ្រង់ធ្វើឱ្យថ្ងៃរបស់ទ្រង់រះឡើង បំភ្លឺទាំងមនុស្ស
អាក្រក់នឹងមនុស្សល្អ ហើយទ្រង់បង្អុរឱ្យភ្លៀងធ្លាក់មក លើ
ទាំងមនុស្សសុចរិត និងមនុស្សទុច្ចរិត[ន]ផង ៤៦ ដ្បិតបើអ្នក

**៥:៣៩** ឍ លក ៦:២៩ រម ១២:១៧,១៩ ១ពត ៣:៩ **៥:៤២** ណ ចទ ១៥:៨ លក ៦:៣០ **៥:៤៣** ត លវ ១៩:១៨ មថ ១៩:១៩ ២២:៣៩ មក ១២:៣១ លក ១០:២៧ រម ១៣:៩ កទ ៥:១៤ យក ២:៨ ថ ចទ ២៣:៦ ទដ ១៣៩:២១,២២ **៥:៤៤** ទ លក ៦:២៧,២៨ ២៣:៣៤ យហ ១៥:២០ កច ៧:៦០ រម ៨:៣៥ ១២:១៤ ១កថ ៤:១២ ១ពត ២:២៣ **៥:៤៥** ធ ខ៩ លក ៦:៣៥ រម ៨:១៤ ន យប២៥:៣ **៥:៤៦** ប លក ៦:៣២

រាល់គ្នាស្រឡាញ់តែអស់អ្នកណា ដែលស្រឡាញ់ដល់ខ្លួន
នោះតើបានបំណាច់អ្វី[ប] ឯពួកអ្នកយកពន្ធ តើគេមិន
ប្រព្រឹត្តដូច្នោះដែរទេឬអី ៤៧ ហើយបើអ្នករាល់គ្នាគំនាប់
តែបងប្អូនអ្នកប៉ុណ្ណោះ នោះតើបានធ្វើអ្វីប្លែកពីគេ ឯពួក
សាសន៍ដទៃ តើមិនប្រព្រឹត្តដូចគ្នាទេឬអី ៤៨ ដូច្នេះ ចូរឱ្យ
អ្នករាល់គ្នាបានគ្រប់លក្ខណ៍ ដូចជាព្រះវរបិតា នៃអ្នកដែល
គង់នៅស្ថានសួគ៌ ទ្រង់គ្រប់លក្ខណ៍[ផ]ដែរ ។

## ការធ្វើទានដល់ជនក្រីក្រ

**៦** ១ ចូរប្រយ័ត្ន កុំឱ្យអ្នករាល់គ្នាធ្វើទាននៅមុខមនុស្សឱ្យ
តែគេឃើញឡើយ[ព] បើធ្វើដូច្នោះ នោះអ្នករាល់គ្នាគ្មាន
រង្វាន់ នៅនឹងព្រះវរបិតានៃអ្នក ដែលទ្រង់គង់នៅស្ថាន
សួគ៌ទេ ២ ដូច្នេះ កាលណាអ្នកធ្វើទាន នោះកុំឱ្យផ្លុំត្រែនៅ
មុខអ្នក ដូចពួកមានពុត ដែលប្រព្រឹត្តនៅក្នុងសាលាប្រជុំ
ហើយតាមផ្លូវ ដើម្បីឱ្យបានមនុស្សលោកសរសើរខ្លួននោះ
ឡើយ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា គេបានរង្វាន់គេ
ហើយ ៣ ប៉ុន្តែ កាលណាអ្នកធ្វើទាន នោះកុំឱ្យដៃឆ្វេងដឹង

**៥:៤៨** ផ លវ១៩:២ ១ពត ១:១៦ **៦:១** ព មថ ៥:១៦ ២៣:៥

*នៃអ្នកនោះបែរកំផ្លៀងម្ខាងទៅឱ្យទៀត* មានន័យថាការជេរប្រមាថប្រសើរជាងការប្រព្រឹត្តអំពើហឹង្សា ។ នៅត្រង់ចំណុចនេះសំខាន់គឺថា គួរឱ្យគេជេរប្រមាថទ្វេរដង ប្រសើរជាងនាំរឿងរ៉ាវ ទំនាស់នោះទៅតុលាការ ។

**៥:៤០** *អាវខ្លី* អាវនេះសម្រាប់ពាក់នៅខាងក្នុង ឬធ្វើជាទ្រនាប់ ។ *អាវវែង* សម្រាប់ពាក់នៅខាងក្រៅ ឬពីលើមួយជាន់ទៀត ។

**៥:៤១** *បង្ខំ* ភាសាក្រិកជាកិរិយាសព្ទ ដែលមានប្រភពចេញពីពាក្យពើរ៉ែ មានន័យថា "បង្ខំឱ្យបម្រើ" ត្រូវបានគេប្រើនៅក្នុង "មថ ២៧:៣២" នៅពេលទាហានរ៉ូម៉ាំងបញ្ជាដោយបង្ខំដល់លោកស៊ីម៉ូន ឱ្យជួយលីឈើឆ្កាងរបស់ព្រះយេស៊ូវក្នុងពេលកំពុងតែបណ្តើរទ្រង់ទៅធ្វើគុត ។

**៥:៤២** ប្រហែលជាមិនសំដៅចំពោះសេចក្តីតម្រូវការរបស់មនុស្សទូទៅនោះទេ តែសំដៅចំពោះជនក្រីក្រវិញប៉ុណ្ណោះ (ចទ ១៥:៧-១១ ទដ ១១២:៥,៩)។

**៥:៤៣** *ស្អប់ខ្មាំងសត្រូវឯងវិញ* ពាក្យនេះពុំមានក្នុងគម្ពីរសញ្ញាចាស់ទេ ប៉ុន្តែនេះ ជាផ្នែកមួយដែលមាននៅក្នុងចរិយាមារយាទរបស់សាសន៍យូដានាសម័យនោះ ។

**៥:៤៤** *អធិស្ឋាន* គឺជាវិធីបញ្ជាក់នៃសេចក្តីស្រឡាញ់ (យប ៤២:៨-១០)។

**៥:៤៥** *ដើម្បីឱ្យបានធ្វើជាកូនរបស់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌* មានន័យថាការស្រឡាញ់ដល់ខ្មាំងសត្រូវនោះបានធ្វើឱ្យអ្នកដទៃដឹងថាយើងជាកូននៃព្រះដែលគង់នៅស្ថានសួគ៌ ។ *មនុស្សអាក្រក់និងមនុស្សល្អ* ព្រះទ្រង់បានបង្ហាញសេចក្តីស្រឡាញ់ដល់មនុស្សគ្រប់គ្នា ដោយមិនប្រកាន់ថាជាអ្នកណាឡើយ ។

**៥:៤៦** *អ្នកយកពន្ធ* ជាទូទៅត្រូវបានគេហៅថា "អ្នកយកជាស៊ី" ហើយគេស្គាល់យ៉ាងច្បាស់ថា ជាមនុស្សប្រុសក្នុងស្រុកដែលធ្វើការឱ្យអ្នកម៉ៅការផ្នែកប្រមូលពន្ធសម្រាប់ពួករ៉ូម៉ាំង ។ ដោយហេតុតែពួកគេធ្វើការឱ្យពួករ៉ូម៉ាំង នោះជាញឹកញាប់ត្រូវបានគេបញ្ជាឱ្យប្រមូលពន្ធបន្ថែមទៀត ពីព្រោះមិនគ្រប់សម្រាប់ការចំណាយរបស់រាជការរ៉ូម៉ាំង បានជាអ្នកហូតពន្ធត្រូវប្រើវិធីអាក្រក់ជាច្រើន ដើម្បីធ្វើយ៉ាងណាឱ្យតែបានប្រាក់ តាមការកំណត់របស់ពួករ៉ូម៉ាំង ។ ហេតុនេះហើយបានជាគេមានកេរ្តិ៍ឈ្មោះអាក្រក់ និងមានឈ្មោះថាជាអ្នកក្បត់ជាតិទៀតផង ។

**៥:៤៨** *ចូរឱ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍* ព្រះយេស៊ូវទ្រង់បានបង្ហាញនូវគំរូដ៏វិសេសនៃសេចក្តីស្រឡាញ់ដ៏គ្រប់លក្ខណ៍(ខ.៤៣-៤៧) ហើយវាក៏ជាគំរូមួយដែលព្រះទ្រង់ប្រទានឱ្យយើងរាល់គ្នា ។

**៦:១** *ធ្វើទាន* (ភាសាអង់គ្លេសប្រើពាក្យថាទង្វើសុចរិត) នេះគឺជាខមួយដែលលើកឡើងអំពីអត្ថន័យនៃពាក្យថា "ធ្វើទាន ឬទង្វើសុចរិត" (១).ការឱ្យទាន(ខ.២-៤) (២).ការអធិស្ឋាន(ខ.៥-១៥) (៣).ការតមអាហារ(ខ.១៦-១៨)។ *រង្វាន់នៅនឹងព្រះវរបិតានៃអ្នក* គឺការរីកចម្រើន និងចាស់ទុំខាងព្រលឹងវិញ្ញាណ ប្រហែលជាមានការប្រទានជាច្រើនផ្សេងៗទៀតនៅក្នុងអត្ថន័យនេះ ។

**៦:២** *ផ្លុំត្រែ* ប្រហែលទាក់ទងទៅនឹងសំឡេង ដោយការទម្លាក់ប្រាក់កាក់នៅពេល គេដាក់នៅក្នុងឃ្លាំងដង្វាយនៅក្នុងព្រះវិហារ ឬជាឃ្លាអាចត្រូវបានគេប្រើប្រៀបធៀបដែលមានន័យថា "ធ្វើអ្វីមួយជាការបង្ហាញដ៏ធំ" ។ *ពួកមានពុត* ភាសាក្រិក មានន័យថា "តួសំដែង"។ លោកម៉ាថាយបានប្រើពាក្យនេះចំនួន១៣ដង(លោកម៉ាកុសមាន២ដង និងលោកលូកា មាន៣ដង)។ ពាក្យនេះទាក់ទងទៅនឹងមនុស្សណាដែលក្លែងធ្វើជាអ្នកមានជំនឿជឿខ្ជាប់ខ្ជួន ។ *គេបានទទួលរង្វាន់គេហើយ* គឺគ្រាន់តែជាការសរសើររបស់មនុស្សប៉ុណ្ណោះ ។

**៦:៣** *កុំឱ្យដៃឆ្វេងដឹងការដែលដៃស្តាំធ្វើឡើយ* ត្រង់នេះសង្កត់ធ្ងន់លើការដាក់ដង្វាយ គឺមិនចាំបាច់ប្រកាស ឬទាមទារឱ្យអ្នកផ្សេងចាប់អារម្មណ៍លើខ្លួន

ការដែលដៃស្ដាំធ្វើឡើយ ៤ដើម្បីឱ្យអំពើទានរបស់អ្នកបាន
ស្ងាត់កំបាំង នោះព្រះវរបិតានៃអ្នក ដែលទ្រង់ទតឃើញក្នុង
ទីសំងាត់ ទ្រង់នឹងប្រទានរង្វាន់[ក]ដល់អ្នកនៅទីប្រចក្សច្បាស់

## **ការអធិស្ឋាន**

*៦:៩–១៣ = លក ១១:២–៤*

៥កាលណាអ្នកអធិស្ឋាន កុំឱ្យធ្វើដូចមនុស្សមានពុត ដែល
ចូលចិត្តឈរ[ម]អធិស្ឋាននៅក្នុងសាលាប្រជុំ ហើយនៅជ្រុង
ផ្លូវ ឱ្យមនុស្សលោកឃើញនោះឡើយ ខ្ញុំប្រាប់អ្នករាល់គ្នាជា
ប្រាកដថា គេបានរង្វាន់គេហើយ ៦តែឯអ្នក កាលណា
អធិស្ឋាន នោះត្រូវឱ្យចូលទៅក្នុងបន្ទប់ ហើយបិទទ្វារ រួច
អធិស្ឋានដល់ព្រះវរបិតា[យ]នៃអ្នក ដែលទ្រង់គង់នៅទីលាក់
កំបាំងចុះ នោះព្រះវរបិតានៃអ្នក ដែលទតឃើញក្នុងទីលាក់
កំបាំង ទ្រង់នឹងប្រទានរង្វាន់ ដល់អ្នកនៅទីប្រចក្សច្បាស់
៧ហើយកាលណាអធិស្ឋាន នោះកុំឱ្យពោលពាក្យឥត
ប្រយោជន៍ផ្ទួនៗ[រ] ដូចពួកសាសន៍ដទៃឡើយ ដ្បិតគេស្មានថា
ព្រះទ្រង់នឹងស្តាប់គេ ដោយគេពោលពាក្យជាច្រើន[ល] ៨ដូច្នេះ
កុំឱ្យអ្នករាល់គ្នាធ្វើដូចគេឡើយ ដ្បិតព្រះវរបិតានៃអ្នក ទ្រង់
ជ្រាបនូវរបស់អ្វីដែលអ្នកត្រូវការ[វ] មុនដែលអ្នកសូមផង
៩ដូច្នេះ ចូរអធិស្ឋានបែបយ៉ាងនេះវិញថា ឱព្រះវរបិតា[ស]
នៃយើងខ្ញុំ ដែលគង់នៅស្ថានសួគ៌អើយ សូមឱ្យព្រះនាមទ្រង់
បានបរិសុទ្ធ ១០សូមឱ្យរាជ្យទ្រង់[ហ]បានមកដល់ សូមឱ្យព្រះ
ហឫទ័យទ្រង់បានសំរេច[ឡ]នៅផែនដី ដូចនៅស្ថានសួគ៌ដែរ
១១សូមប្រទានអាហារ[អ]ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ
១២សូមអត់ទោសសេចក្តីកំហុសរបស់យើងខ្ញុំ ដូចជាយើងខ្ញុំ
បានអត់ទោស ដល់អស់អ្នកដែលធ្វើខុស[ក]នឹងយើងខ្ញុំដែរ
១៣សូមកុំនាំយើងខ្ញុំទៅក្នុងសេចក្តីល្បួង[ខ]ឡើយ តែសូម
ប្រោស ឱ្យយើងខ្ញុំរួចពីសេចក្តីអាក្រក់វិញ ដ្បិតរាជ្យ ព្រះ
ចេស្តា នឹងសិរីល្អជារបស់ផងទ្រង់ នៅអស់កល្បជានិច្ច
អាម៉ែន[គ] ១៤ដ្បិតបើអ្នករាល់គ្នាអត់ទោសចំពោះការរំលង
ច្បាប់ ដែលមនុស្សលោកប្រព្រឹត្តធ្វើ នោះព្រះវរបិតានៃអ្នក
ដែលគង់នៅស្ថានសួគ៌ ទ្រង់នឹងអត់ទោសឱ្យអ្នក[ឃ]រាល់គ្នា
ដែរ ១៥តែបើអ្នករាល់គ្នាមិនអត់ទោស ចំពោះការរំលង
ច្បាប់ឱ្យគេទេ នោះព្រះវរបិតានៃអ្នក ទ្រង់ក៏មិនអត់ទោស
ចំពោះការរំលង[ង]ច្បាប់ ដែលអ្នករាល់គ្នាប្រព្រឹត្តធ្វើដែរ ។

## **ការតមអាហារ**

១៦កាលណាអ្នករាល់គ្នាតម[ច]អាហារ នោះកុំឱ្យធ្វើទឹកមុខ
ក្រៀម[ឆ] ដូចជាមនុស្សមានពុតឡើយ ដ្បិតគេក្លែងទឹកមុខ
ស្រងូត ឱ្យមនុស្សលោកឃើញថាគេតម ខ្ញុំប្រាប់អ្នករាល់គ្នា
ជាប្រាកដថា គេបានរង្វាន់គេហើយ ១៧តែអ្នកកាលណាតម
នោះចូរឱ្យលាបគ្រឿងក្រអូបនៅលើក្បាល ហើយលប់មុខ
ចេញ ១៨ដើម្បីកុំឱ្យមនុស្សលោកឃើញថាអ្នកតមឡើយ គឺឱ្យ
ព្រះវរបិតានៃអ្នក ដែលគង់នៅទីលាក់កំបាំង បានឃើញ
វិញ នោះព្រះវរបិតានៃអ្នក ដែលទ្រង់ទតឃើញនៅទីលាក់
កំបាំង ទ្រង់នឹងប្រទានរង្វាន់[ជ]ដល់អ្នកនៅទីប្រចក្សច្បាស់ ។

## **ទ្រព្យសម្បត្តិនៅស្ថានសួគ៌**

*៦:២២,២៣ = លក ១១:៣៤–៣៦*

១៩កុំឱ្យប្រមូលទ្រព្យសម្បត្តិ ទុកសំរាប់ខ្លួន នៅផែនដី[ឈ]ជា
កន្លែងដែលមានកន្លាត និងច្រែះស៊ីបំផ្លាញ[ញ] ហើយចោរ
ទំលុះប្លន់នោះឡើយ ២០ត្រូវប្រមូលទ្រព្យសម្បត្តិ ទុកសំរាប់
ខ្លួន នៅឯស្ថានសួគ៌វិញ[ដ] ដែលជាកន្លែងគ្មានកន្លាត ឬច្រែះ

**៦:៤** ក ៦៦,១៨ កល ៣:២៣,២៤
**៦:៥** ម មក ១១:២៥ លក ១៨:១០–១៤
**៦:៦** យ ២ពវ ៤:៣៣
**៦:៧** រ សស ៥:២ ល ១ពវ ១៨:២៦-២៩
**៦:៨** វ ៦៣២
**៦:៩** ស យរ ៣:១៩ មឡ ២:១០ ១ពត ១:១៧
**៦:១០** ហ មថ ៣:២ ឡ មថ ២៦:៣៩
**៦:១១** អ សភ ៣០:៨
**៦:១២** ក មថ ១៨:២១–៣៥
**៦:១៣** ខ យក ១:១៣ គ មថ ៥:៣៧
**៦:១៤** ឃ មថ ១៨:២១–៣៥ មក ១១:២៥,២៦ អភ ៤:៣២ កល ៣:១៣
**៦:១៥** ង មថ ១៨:៣៥
**៦:១៦** ច លវ ១៦:២៩,៣១ ២៣:២៧–៣២ ជន ២៩:៧ ឆ អស ៥៨:៥ សក ៧:៥ ៨:១៩
**៦:១៨** ជ ៦៤,៦
**៦:១៩** ឈ សភ ២៣:៤ លក ១២:១៦–២១ ហព ១៣:៥ ញ យក ៥:២,៣
**៦:២០** ដ មថ ១៩:២១ លក ១២:៣៣ ១៦:៩ ១៨:២២ ១ធថ ៦:១៩

នោះឡើយ។ ការលើកតម្កើងខ្លួនឯង ជានិច្ចជាកាលគឺជារង្វាន់ដ៏គ្រោះថ្នាក់។

**៦:៦** *បន្ទប់* ជាភាសាក្រិកមានន័យថា "ឃ្លាំងដាក់អីវ៉ាន់" វាមិនដូចជាបន្ទប់ធម្មតា នោះទេ គឺមានទ្វារអាចបិទឱ្យជិតបាន ។

**៦:៧** *ពោលពាក្យឥតប្រយោជន៍ផ្ទួនៗ ដូចពួកសាសន៍ដទៃ* គេប្រើតារាងបញ្ជីឈ្មោះនៃព្រះរបស់ពួកគេ ដើម្បីសូត្ររៀបរាប់ដោយសង្ឃឹមថាការឈរពោលពាក្យច្រំដែលៗដូច្នេះ នោះព្រះគេនឹងឮ ហើយអាចជួយពួកគេបាន ។ ព្រះយេស៊ូវមិនមែនកំពុងកាត់ទោសអ្នកដែលអធិស្ឋានយូរនោះទេ ប៉ុន្តែគ្មានប្រយោជន៍អ្វីសោះ ក្នុងការប្រើពាក្យអធិស្ឋានច្រំដែលៗនោះ ។

**៦:១២** *កំហុស* (ភាសាអង់គ្លេសប្រើពាក្យ"បំណុល") គឺជាកំហុសខាងផ្នែកសីលធម៌ ដែលជាអំពើបាប(មើលការពន្យល់ លក ១១:៤)។

**៦:១៦** *តមអាហារ* មើលការពន្យល់ មក ២:១៨ និង លក ១៨:១២ ។

**៦:១៧** *ចូរឱ្យលាបគ្រឿងក្រអូបនៅលើក្បាល ហើយលប់មុខចេញ* ពួកយូដាគេយកផ្ទេះមកដាក់លើក្បាល នៅពេលតមម្តងៗ ។ ការលាបគ្រឿងក្រអូបនេះគឺសំដែងពីផ្ទៃខាងក្រៅ ដែលជាចេតនាមិនបញ្ចេញឱ្យគេដឹងថាខ្លួនតម ។

**៦:១៩–២១** ការគ្រោះថ្នាក់ដោយទ្រព្យសម្បត្តិជាញឹកញាប់បានពោលនៅក្នុងគម្ពីរសញ្ញាថ្មី(ខ.២៤ ១៣:២២ ១៩:២២ មក ១០:១៧–៣០ លក ១២:១៦–២១ ១ធថ ៦:៩–១០,១៧–១៩ ហព ១៣:៥) ប៉ុន្តែ មិនបាននិយាយពីការកាត់ទោសពីទ្រព្យសម្បត្តិនេះទេ ។ អ្វីដែលព្រះយេស៊ូវដាក់ទោសនៅត្រង់នេះ គឺដល់អ្នកដែលលោភលន់ និងការប្រមូលទ្រព្យសម្បត្តិ មកលាក់ទុកសម្រាប់ខ្លួនដោយមិនត្រឹមត្រូវ ។

**៦:១៩** *កន្លាត និងច្រែះស៊ីបំផ្លាញ* តំណាងឱ្យគ្រប់ភ្នាក់ងារ និងដំណើរការផ្សេងៗ សម្រាប់បំផ្លាញទ្រព្យសម្បត្តិនៅលើផែនដីនេះ ។ *ចោរទំលុះប្លន់* ផ្ទះនៅប្រទេសប៉ាឡេស្ទីនបានធ្វើជញ្ជាំងឥដ្ឋអំពីដីភក់ ដែលចោរអាចទំលុះចូលបានដោយងាយ ។

**៦:២០** *ទ្រព្យសម្បត្តិទុកសំរាប់ខ្លួននៅស្ថានសួគ៌* គ្រប់យ៉ាងដែលបានធ្វើនៅជីវិតនេះ គឺមានតម្លៃអស់កល្បជានិច្ច ។ ឃ្លានេះមានន័យថា"សម្បត្តិខាងឯព្រះ" (លក ១២:២១)។ ខនេះប្រហែលសំដៅលើចំណុចសំខាន់ៗជាច្រើនទៀតនៃការប្រើប្រាស់ទ្រព្យសម្បត្តិ សម្រាប់កិច្ចការល្អៗនោះផងដែរ ។

ស៊ីបំផ្លាញឡើយ ក៏គ្មានចោរទំលុះ ឬប្លន់ផង[ឋ] ២១ពីព្រោះ
សម្បត្តិទ្រព្យរបស់អ្នកស្ថិតនៅកន្លែងណា នោះចិត្តអ្នកក៏នឹង
នៅកន្លែងនោះដែរ[ឌ]។
២២ឯចង្កៀងរបស់រូបកាយ គឺជាភ្នែក ដូច្នេះ បើភ្នែកអ្នកល្អ
នោះរូបកាយអ្នកទាំងមូលនឹងបានភ្លឺ ២៣តែបើភ្នែកអ្នកអា
ក្រក់វិញ នោះរូបកាយអ្នកទាំងមូល នឹងត្រូវងងឹតសូន្យ
យ៉ាងនោះ បើពន្លឺដែលនៅក្នុងខ្លួនអ្នក ជាសេចក្តីងងឹតហើយ
ចុះសេចក្តីងងឹតនោះនឹងបានជាខ្លាំងអម្បាលម៉ានទៅហ្ន៎ ។
២៤គ្មានអ្នកណាអាចនឹងបំរើចៅហ្វាយ២នាក់បានទេ ដ្បិត
អ្នកនោះនឹងស្អប់១ ហើយស្រឡាញ់១ ឬស្មោះត្រង់នឹង១
ហើយមើលងាយ១ អ្នករាល់គ្នាពុំអាចនឹងគោរពដល់ព្រះ
និងទ្រព្យសម្បត្តិផងបានទេ[ឍ]។

## ការខ្វល់ខ្វាយ

*៦:២៥–៣៣ = លក ១២:២២–៣១*

២៥ដោយហេតុនេះ បានជាខ្ញុំប្រាប់អ្នករាល់គ្នាថា កុំឱ្យ
ខ្វល់ខ្វាយ[ណ]នឹងជីវិត ដែលនឹងបរិភោគអ្វី ឬនឹងរូបកាយ
ដែលនឹងស្លៀកពាក់អ្វីនោះឡើយ ឯជីវិត តើមិនវិសេសជាង
ចំណីអាហារ ហើយរូបកាយ តើមិនវិសេសជាងសំលៀក
បំពាក់ទេឬអី ២៦ចូរពិចារណាពីសត្វស្លាបនៅលើអាកាស
វាមិនសាបព្រោះ មិនច្រូតកាត់ ឬប្រមូលដាក់ក្នុងជង្រុកផង
តែព្រះវរបិតានៃអ្នក ដែលគង់នៅស្ថានសួគ៌ ទ្រង់ចិញ្ចឹមវា[ត]
ឯអ្នករាល់គ្នា តើគ្មានដំឡៃលើសជាងសត្វទាំងនោះទេឬ
អី[ថ] ២៧ចុះនៅក្នុងពួកអ្នករាល់គ្នា តើមានអ្នកឯណាដែល
អាចនឹងបន្ថែមកំពស់ខ្លួន១ហត្ថ ដោយសារសេចក្តីខ្វល់
ខ្វាយ បានឬទេ[ទ] ២៨ហើយពីដំណើរសំលៀកបំពាក់តើអ្នក
រាល់គ្នាខំខ្វល់ខ្វាយធ្វើអី ចូររំពឹងគិតតែពីផ្កាឈូកនៅក្នុង
បឹង ដែលវាដុះជាយ៉ាងដូចម្តេច គឺវាមិននឿយហត់នឹង
ធ្វើការ ឬស្រាវរវៃទេ ២៩តែខ្ញុំប្រាប់អ្នករាល់គ្នាថា សូម្បី
តែហ្លួងសាឡូម៉ូន ក្នុងគ្រាដែលមានគ្រប់ទាំងសេចក្តីរុង
រឿង[ធ]របស់ទ្រង់ នោះទ្រង់មិនបានតែងអង្គ ដូចជាផ្កា១
នោះផង ៣០រីឯតិណជាតិ ដែលដុះនៅវាលក្នុងថ្ងៃនេះ
ហើយថ្ងៃស្អែកត្រូវគេដុតនៅជើងក្រាន បើព្រះទ្រង់តុបតែង
ស្មៅយ៉ាងដូច្នោះ នោះឱមនុស្សមានជំនឿតិចអើយ[ន] តើទ្រង់
មិនតុបតែងឱ្យអ្នករាល់គ្នា លើសជាងទៅទៀតទេឬអី
៣១ដូច្នេះ កុំឱ្យខ្វល់ខ្វាយថាតើត្រូវបរិភោគអ្វី ឬស្លៀកពាក់
អ្វីនោះឡើយ ៣២ដ្បិតគឺជាសាសន៍ដទៃទេតើ ដែលខំស្វែង
រករបស់ទាំងនោះវិញឯព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់
នៅស្ថានសួគ៌ ទ្រង់ជ្រាបហើយ ថាអ្នករាល់គ្នាត្រូវការ
នឹងរបស់ទាំងនោះដែរ[ប] ៣៣ចូរស្វែងរកនគរ[ផ] នឹងសេច
ក្តីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹង
បានប្រទានមកអ្នករាល់គ្នា ថែមទៀតផង[ព] ៣៤ដូច្នេះ កុំឱ្យ
ខ្វល់ខ្វាយនឹងថ្ងៃស្អែកឡើយ ពីព្រោះថ្ងៃស្អែកនឹងខ្វល់ខ្វាយ
ចំពោះការរបស់ថ្ងៃនោះឯង សេចក្តីលំបាកនៅថ្ងៃណា
នោះគឺល្មមត្រឹមថ្ងៃនោះហើយ ។

## ការកាត់ទោសអ្នកដទៃ

*៧:៣–៥ = លក ៦:៤១,៤២*

**៧** ១កុំឱ្យថ្កោលទោសគេឡើយ ដើម្បីមិនឱ្យមានគេថ្កោល
អ្នកវិញ[ភ] ២ដ្បិតអ្នករាល់គ្នាថ្កោលទោសគេយ៉ាងណា នោះ
គេនឹងថ្កោលអ្នកវិញយ៉ាងនោះដែរ ហើយគេនឹងវាល់ឱ្យ
អ្នករាល់គ្នា តាមរង្វាល់ដែលអ្នកវាល់ឱ្យគេផង[ម] ៣ហេតុអ្វី
បានជាអ្នកមើលឃើញកំទេច ដែលនៅក្នុងភ្នែករបស់បង
ប្អូនអ្នក តែមិនឃើញធ្នឹម ដែលនៅក្នុងភ្នែករបស់ខ្លួនសោះ
ដូច្នេះ ៤ឬធ្វើដូចម្តេចឱ្យអ្នកនិយាយនឹងបងប្អូនថា ចូរឱ្យអញ
យកកំទេចពីភ្នែកឯងចេញ តែមើល មានធ្នឹមនៅក្នុងភ្នែក
ខ្លួនអ្នកវិញ ៥អ្នកមានពុតអើយ ចូរយកធ្នឹមពីភ្នែករបស់ខ្លួន
ចេញជាមុនសិន នោះទើបនឹងបានឃើញច្បាស់ អាចនឹង
យកកំទេចចេញពីភ្នែករបស់បងប្អូនអ្នកបានដែរ ។
៦កុំឱ្យរបស់បរិសុទ្ធដល់ឆ្កែ ឬបោះកែវមុក្តារបស់ខ្លួននៅ

ឋ លក ១២:៣៣
**៦:២១** ឌ លក ១២:៣៤
**៦:២៤** ឍ លក ១៦:១៣
**៦:២៥** ណ ខ.២៧,២៨,៣១,៣៤ លក ១០:៤១ ១២:១១,២២
**៦:២៦** ត យប ៣៨:៤១ ទដ ១០៤:២១ ១៣៦:២៥ ១៤៥:១៥ ១៤៧:៩ ថ មថ ១០:២៩–៣១
**៦:២៧** ទ ទដ ៣៩:៥
**៦:២៩** ធ ១ពវ ១០:៤–៧
**៦:៣០** ន មថ ៨:២៦ ១៤:៣១ ១៦:៨ លក ១២:២៨
**៦:៣២** ប ខ.៨
**៦:៣៣** ផ មថ ៣:២ ព ទដ ៣៧:៤ មថ ១៩:២៩
**៧:១** ភ លក ៦:៣៧ រម ១៤:៤,១០,១៣ ១កថ ៤:៥ ៥:១២ យក ៤:១១,១២
**៧:២** ម អគ ៣៥:១១ មក ៤:២៤ លក ៦:៣៨ រម ២:១

**៦:២៨** *ផ្កាឈូក* តំណាងឱ្យផ្កាទូទៅ ។

**៦:៣០** *ដុតនៅជើងក្រាន* ស្មៅគឺតិណជាតិសាមញ្ញម្យ៉ាងដែលជនជាតិប៉ាឡេស្ទីនយកទៅបង្កាត់ភ្លើងនៅក្នុងឡ(ចង្ក្រានដីឥដ្ឋ)។ *មនុស្សមានជំនឿតិចអើយ* មើល ៨:២៦ ១៤:៣១ ១៦:៨ ១៧:២០ លក ១២:២៨ ។

**៧:១** គ្រីស្ទបរិស័ទមិនត្រូវដាក់ទោសគេថាអ្នកនេះជាមនុស្សកំពុត ឬអ្នកនោះក្លែងធ្វើជាសុចរិតយ៉ាងនេះឬយ៉ាងនោះបានទេ(ខ.៥) សូមមើល ២៣:១៣–៣៩ រម ២:១ ។ នៅក្នុងជំពូកនេះផងដែរក្នុងការគោរព និងបញ្ញត្តិរបស់ព្រះ នោះជាដំបូងត្រូវវាយតម្លៃលើចរិតលក្ខណៈរបស់មនុស្សនោះថាតើពួកគេជាឆ្កែ(ខ.៦) ឬហោរាក្លែងក្លាយ(ខ.១៥) ហើយតើផលផ្លែរបស់គេយ៉ាងដូចម្តេចដែរ(ខ.១៦). ។ ព្រះគម្ពីរបានដាស់តឿនអ្នកជឿឱ្យចេះវាយតម្លៃយ៉ាងប្រុងប្រយ័ត្ន ហើយជ្រើសរើសមនុស្សល្អ និងអាក្រក់ ដោយការប្រព្រឹត្តដែលមានក្នុងបទគម្ពីរដូចតទៅ: សេចក្តីកំផិត(១កថ ៥:៩) អ្នកពាក់ស្បែកមុខធ្វើជាទេវតានៃពន្លឺ (២កថ ១១:១៤) ឆ្កែ (ភល ៣:២) គ្រូក្លែងក្លាយ (១យហ ៤:១)។ ដូច្នេះគ្រីស្ទបរិស័ទត្រូវសម្លឹងមើលគ្រប់ទាំងអស់ហើយប្រកាន់ខ្ជាប់នូវសេចក្តីដែលត្រឹមត្រូវ (១ថស ៥:២១)។

**៧:៣** *មើលឃើញកំទេច . . . តែមិនឃើញធ្នឹម* ជាគំរូនៃការបំផ្លើសព្រះបន្ទូលរបស់ព្រះយេស៊ូវ (១៩:២៤ ត្រង់នេះព្រះយេស៊ូវមានបន្ទូលពីសត្វអូដ្ឋចូលប្រហោងម្ជុល) ហើយគោលបំណងនៃព្រះបន្ទូលនោះ គឺសំដៅចំពោះពួកមនុស្សមានពុត ។

**៧:៦** ការបង្រៀនគួរតែផ្តល់ទៅតាមសមត្ថភាពនៃវិញ្ញាណរបស់អ្នកទទួល ។

មុខជ្រូកឡើយ ក្រែងវាជាន់ឈ្លី រួចត្រឡប់ស្កុះមកខាំអ្នក
វិញ ។

## ការសុំ ការស្វែងរក និងការគោះ

*៧:៧–១១ = លក ១១:៩–១៣*

៧ចូរសូម នោះតែងនឹងឱ្យមកអ្នក[យ] ចូររក នោះតែងនឹង
ឃើញ ចូរគោះ នោះតែងនឹងបើកឱ្យអ្នក ៨ដ្បិតអស់អ្នកណា
ដែលសូម នោះរមែងបាន អ្នកណាដែលរក នោះរមែង
ឃើញ[រ] ហើយនិងបើកឱ្យអ្នកណាដែលគោះដែរ ៩ក្នុងពួក
អ្នករាល់គ្នា បើកូនសូមនំប៉័ង តើមានអ្នកណានឹងឱ្យថ្មដល់វា
១០ឬបើវាសូមត្រី តើនឹងឱ្យពស់វិញឬអី ១១ចុះបើអ្នក
រាល់គ្នាដែលអាក្រក់ អ្នកចេះឱ្យរបស់ល្អដល់កូនខ្លួនដូច្នេះ
នោះចំណង់បើព្រះវរបិតានៃអ្នក ដែលទ្រង់ គង់នៅ
ស្ថានសួគ៌ ទ្រង់នឹងប្រទានរបស់ល្អ[ល] មកអស់អ្នកដែល
សូមតើ ជាងអម្បាលម៉ានទៅទៀត ១២ដូច្នេះ អស់ទាំង ការអ្វី
ដែលអ្នករាល់គ្នាចង់ឱ្យមនុស្សលោកប្រព្រឹត្តនឹងខ្លួន
នោះត្រូវឱ្យអ្នកប្រព្រឹត្តនឹងគេដូច្នោះដែរ[វ] ដ្បិតនេះឯងជា
ក្រិត្យវិន័យ ហើយជាសេចក្តីទំនាយរបស់ពួកហោរា[ស]។

## ទ្វារចង្អៀត និងទ្វារទូលាយ

១៣ចូរឱ្យចូលតាមទ្វារចង្អៀត[ហ] ដ្បិតទ្វារដែលនាំទៅឯ
សេចក្តីហិនវិនាស នោះធំ ហើយទូលាយផង ក៏មានមនុស្ស
ជាច្រើនដែលចូលតាមទ្វារនោះ ១៤តែឯទ្វារដែលនាំទៅឯ
ជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់
ដែលរកផ្លូវនោះឃើញ ។

## ដើមឈើ និងផ្លែរបស់វា

១៥ចូរប្រយ័ត្ននឹងពួកគ្រូក្លែងក្លាយ[ឡ] ដែលគេមកឯអ្នក
រាល់គ្នា ដោយពាក់រោមចៀមបំប្លែងខ្លួន តែខាងក្នុងរបស់
គេ ជាឆ្កែចចក[អ]ដែលឆ្មក់ស៊ីវិញ ១៦អ្នករាល់គ្នានឹងស្គាល់គេ
បាន ដោយសារផល[ក]គេបង្កើត តើដែលបេះផ្លែទំពាំង
បាយជូរពីគុម្ពបន្លា ឬផ្លែល្វាពីដំបងយក្ស[ខ]ឬទេ ១៧ដូច្នេះ
អស់ទាំងដើមឈើល្អ តែងមានផ្លែល្អ ឯដើមអាក្រក់ ក៏តែង
មានផ្លែអាក្រក់ដែរ ១៨ធម្មតាដើមឈើល្អ មិនដែលបញ្ចេញ
ផលអាក្រក់បានទេ ហើយដើមដែលអាក្រក់ ក៏ពុំអាចនឹង
បញ្ចេញផលល្អបានដែរ[គ] ១៩អស់ទាំងដើមឈើណា ដែល
មិនកើតផលផ្លែល្អ នោះត្រូវតែកាប់បោះចោលទៅក្នុង
ភ្លើង[ឃ]ចេញ ២០ដូច្នេះ អ្នករាល់គ្នានឹងស្គាល់គេបានគឺដោយ
សារផលគេបង្កើត ២១មិនមែនអស់អ្នកណាដែលគ្រាន់តែ
និយាយមកខ្ញុំថា ឱព្រះអម្ចាស់ៗអើយ[ង] ដែលនឹងចូលទៅ
ក្នុងនគរស្ថានសួគ៌[ច] នោះទេ គឺជាអស់អ្នកដែលធ្វើតាម
ព្រះហឫទ័យនៃព្រះវរបិតា ដែលគង់នៅស្ថានសួគ៌[ឆ]វិញ
ទេតើ ២២នៅថ្ងៃនោះ[ជ] នឹងមានមនុស្សជាច្រើននិយាយ
មកខ្ញុំថា ឱព្រះអម្ចាស់ៗអើយ តើយើងខ្ញុំមិនបានទាយដោយ
នូវព្រះនាមទ្រង់ ហើយដេញអារក្សដោយនូវព្រះនាមទ្រង់
ព្រមទាំងធ្វើការឫទ្ធិបារមីជាច្រើន ដោយនូវព្រះនាមទ្រង់
ទេឬអី[ឈ] ២៣នោះខ្ញុំ នឹងនិយាយដោយត្រង់ថា អញមិនដែល
បានស្គាល់ឯងរាល់គ្នាទេ នែ ពួកទទឹងច្បាប់អើយ ចូរថយ
ចេញពីអញទៅ[ញ] ។

## មនុស្សពីរនាក់សង់ផ្ទះ

*៧:២៤–២៧ = លក ៦:៤៧–៤៩*

២៤ដូច្នេះ អស់អ្នកណាដែលឮពាក្យរបស់ខ្ញុំទាំងនេះ ហើយ
ប្រព្រឹត្តតាម[ដ] ខ្ញុំនឹងធៀបអ្នកនោះដូចជាមនុស្សប៉ិនប្រយ័ត្ន
ដែលសង់ផ្ទះខ្លួននៅលើថ្ម ២៥រួចភ្លៀងធ្លាក់មក ទឹកក៏ជន់
ឡើង ហើយខ្យល់បក់ប៉ះនឹងផ្ទះនោះ តែមិនបានរលំទេ ពី
ព្រោះបានសង់នៅលើថ្ម ២៦ឯអស់អ្នកណាដែលឮពាក្យ
របស់ខ្ញុំទាំងនេះ តែមិនប្រព្រឹត្តតាម អ្នកនោះត្រូវធៀបដូច
ជាមនុស្សល្ងង់ ដែលសង់ផ្ទះខ្លួននៅលើខ្សាច់វិញ ២៧រួច
ភ្លៀងធ្លាក់មក ទឹកក៏ជន់ឡើង ហើយខ្យល់បក់ប៉ះនឹងផ្ទះនោះ
ផ្ទះនោះក៏រលំទៅ ហើយមានការខូចខាតជាធំ ។

**៧:៧** យ ១ពវ ៣:៥ មថ ១៨:១៩ ២១:២២ យហ ១៤:១៣,១៤ ១៥:៧,១៦ ១៦:២៣,២៤ យក ១:៥–៨ ៤:២–៣ ៥:១៦ ១យហ ៣:២២ ៥:១៤,១៥
**៧:៨** រ សភ ៨:១៧ យរ ២៩:១២,១៣
**៧:១១** ល យក ១:១៧
**៧:១២** វ លក ៦:៣១ ស រម ១៣:៨–១០ កទ ៥:១៤
**៧:១៣** ហ លក ១៣:២៤ យហ ១០:៧,៩
**៧:១៥** ឡ យរ ២៣:១៦ មថ ២៤:២៤ លក ៦:២៦ ២ពត ២:១ ១យហ ៤:១ វវ ១៦:១៣ អ អក ២២:២៧ កច ២០:២៩
**៧:១៦** ក មថ ១២:៣៣ លក ៦:៤៤ ខ យក ៣:១២
**៧:១៨** គ លក ៦:៤៣
**៧:១៩** ឃ មថ ៣:១០
**៧:២១** ង ហស ៨:២ មថ ២៥:១១ យហ ១៣:១៣ ១កថ ១២:៣ ច មថ ៣:២ ឆ មថ ១២:៥០ រម ២:១៣ យក ១:២២ ១យហ ៣:១៨
**៧:២២** ជ មថ១០:១៥ ឈ លក ១០:២០ កច ១៩:១៣ ១កថ ១៣:១–៣
**៧:២៣** ញ ទដ ៦:៨ មថ ២៥:១២,៤១ លក ១៣:២៥–២៧
**៧:២៤** ដ ឌ២១ យក ១:២២–២៥

*ផ្លែ* សំដៅលើប្រភេទផ្លែមិនល្អ មិនស្អាតរស់នៅតាមចិញ្ចើមថ្នល់ជាផ្លែដែលគ្មានម្ចាស់ ហើយគ្មានតម្លៃអ្វីសោះ ។

**៧:៨** *សូម . . . រក . . . គោះ* បង្ហាញពីការស្តាប់បង្គាប់ ហើយត្រូវបានប្រើសម្រាប់ការប្រកាន់ខ្ជាប់នៃការសុំ ការរក ការគោះបញ្ជាក់ពីការព្យាយាមអធិស្ឋាន ។

**៧:១២** ធ្លាប់បានហៅជាក្រាំងមាស និងត្រូវបានគេរកឃើញជាទម្រង់បដិសេធន៍នៅក្នុងលទ្ធិសាសនាយូដា ហិណ្ឌូ ព្រះពុទ្ធ និងខុងជឺ ។ លក្ខណៈនេះហើយ ដែលបញ្ជាក់ពីទម្រង់ច្រើនផ្សេងគ្នានៃសេចក្តីបង្រៀនខាងសីលធម៌របស់សាសន៍ក្រិក និងសាសន៍រ៉ូម ដែលផ្ទុយទៅនឹងសេចក្តីបង្រៀនរបស់ព្រះយេស៊ូវ ។ *ក្រិត្យវិន័យ យើហជាសេចក្តីទំនាយ* មើលការពន្យល់ ៥:១៧ ។

**៧:១៣** *ទ្វារចង្អៀត* គឺជាទ្វារដែលនាំទៅឯស្ថានសួគ៌ ដែលមានន័យដូចទៅនឹងជីវិត (ខ.១៤) ។ *ការហិនវិនាស* គឺការដាច់ចេញពីព្រះទៅឯស្ថាន នរក ។

**៧:១៥** *គ្រូក្លែងក្លាយ* គឺអស់អ្នកដែលព្រះមិនបានបញ្ជូនមក ប៉ុន្តែ គេបានអះអាងថា ខ្លួនគេត្រូវបានព្រះទ្រង់បញ្ជូនមក(២៤:២៤ យរ ២៣:១៦) ។

**៧:២១** *ឱព្រះអម្ចាស់ៗអើយ* គឺចង់បញ្ជាក់ថាព្រះយេស៊ូវជាព្រះ តែមួយអង្គគត់ដែល សម្រេចអំពីជីវិតអស់កល្បជានិច្ច ។ *នគរស្ថានសួគ៌* មើល ៣:២ ។

**៧:២២** *នៅថ្ងៃនោះ* គឺថ្ងៃជំនុំជម្រះ(មឡ ៣:១៧,១៨) ។ *ទាយ* នៅក្នុងគម្ពីរសញ្ញាថ្មី ពាក្យនេះហាក់ដូចជាសំដៅលើការទទួលព្រះរាជសារព្រះមិនចាំ

[២៨]កាលព្រះយេស៊ូវ ទ្រង់មានបន្ទូលសេចក្ដីទាំងនេះរួច
ហើយ[ឋ] នោះបណ្ដាមនុស្សក៏នឹកប្លែក ពីសេចក្ដីដែលទ្រង់
បង្រៀន[ឌ] [២៩]ពីព្រោះទ្រង់បង្រៀន ដូចជាមានអំណាច មិន
មែនដូចពួកអាចារ្យរបស់គេទេ ។

## ការប្រោសមនុស្សឃ្លង់

*៨:២-៤ = មក ១:៤០-៤៤ លក ៥:១២-១៤*

**៨** [១]កាលព្រះយេស៊ូវ ទ្រង់បានយាងចុះពីភ្នំមក នោះមាន
មនុស្សកកកុញដើរតាមទ្រង់ [២]ក៏ឃើញមានមនុស្សឃ្លង់
ម្នាក់[ឍ] មកក្រាបថ្វាយបង្គំ[ណ]ទូលទ្រង់ថា ឱព្រះអម្ចាស់អើយ
បើទ្រង់សព្វព្រះហឫទ័យ ទ្រង់អាចនឹងប្រោសឱ្យទូលបង្គំជា
ស្អាតបាន [៣]ទ្រង់ក៏លូកព្រះហស្ដទៅពាល់គាត់ដោយបន្ទូល
ថា ខ្ញុំចង់ ដែរ ចូរឱ្យជាស្អាតចុះ ស្រាប់តែរោគឃ្លង់ក៏ជា
ស្អាតភ្លាម [៤]រួចព្រះយេស៊ូវទ្រង់ហាមថា នែកុំប្រាប់អ្នក
ឯណាឱ្យ សោះ[ត] ត្រូវទៅបង្ហាញខ្លួនឱ្យពួកសង្ឃ[ថ]ឃើញវិញ
ហើយ ថ្វាយដង្វាយតាមដែលលោកម៉ូសេបានបង្គាប់មក[ទ]
ទុកជាទី បន្ទាល់ដល់លោកទាំងនោះ។

## សេចក្ដីជំនឿរបស់មេទ័ព

*៨:៥-១៣ = លក ៧:១-១០*

[៥]កាលព្រះយេស៊ូវ ទ្រង់បានយាងចូលទៅក្នុងក្រុងកាពើ-
ណិមហើយ នោះមេទ័ពម្នាក់មកឯទ្រង់ទូលអង្វរថា [៦]ព្រះ
អម្ចាស់អើយ បាវទូលបង្គំវាស្លាប់ដៃស្លាប់ជើង[ធ] ដេកនៅ
ផ្ទះវេទនាខ្លាំងណាស់ [៧]ព្រះយេស៊ូវទ្រង់មានបន្ទូលតបថា
ខ្ញុំនឹងទៅប្រោសឱ្យជា [៨]តែមេទ័ពទូលប្រកែកថា ព្រះ
អម្ចាស់អើយ ទូលបង្គំមិនគួរនឹងទទួលទ្រង់នៅក្នុងផ្ទះទូល
បង្គំទេ សូមទ្រង់គ្រាន់តែមានបន្ទូលមួយព្រះឱស្ឋមក
ប៉ុណ្ណោះ នោះបាវទូលបង្គំនឹងបានជាហើយ[ន] [៩]ដ្បិតទូលបង្គំ
ជាមនុស្សនៅក្រោមបង្គាប់គេដែរ ហើយមានទាហាននៅ
ក្រោមឱវាទទូលបង្គំ បើទូលបង្គំប្រាប់ទៅម្នាក់ថា ទៅ
នោះវាក៏ទៅ ប្រាប់ទៅម្នាក់ទៀតថា មក វាក៏មក ហើយ
ប្រាប់ទៅបាវថា ធ្វើការនេះ នោះវាក៏ធ្វើតាម [១០]កាលព្រះ
យេស៊ូវបានឮពាក្យនោះហើយ ទ្រង់មាន សេចក្ដីអស្ចារ្យ
ក្នុងព្រះហឫទ័យ រួចមានបន្ទូលទៅពួកអ្នក ដែលតាម
ទ្រង់ថា ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ខ្ញុំមិន ដែលឃើញ
សេចក្ដីជំនឿជាខ្លាំងដល់ម្ល៉េះទេ[ប] ទោះទាំង នៅក្នុងសាសន៍
អ៊ីស្រាអែលផង [១១]ខ្ញុំប្រាប់អ្នករាល់គ្នាថា នឹងមានមនុស្ស
ជាច្រើន ពីទិសខាងកើត នឹងទិសខាងលិច[ផ] មកអង្គុយជា
មួយនឹងលោកអ័ប្រាហាំ លោកអ៊ីសាក នឹងលោកយ៉ាកុប
នៅក្នុងនគរស្ថានសួគ៌[ព] [១២]តែអស់ទាំង មនុស្សរបស់
នគរនោះ[ភ] នឹងត្រូវបោះចោល ទៅក្នុងសេចក្ដី ងងឹត
ខាងក្រៅវិញ នៅទីនោះនឹងមានយំ ហើយសង្កៀត
ធ្មេញ[ម] [១៣]រួចទ្រង់មានបន្ទូលទៅមេទ័ពនោះថា ចូរទៅចុះ

**៧:២៨** ឋ មថ ១១:១ ១៣:៥៣ ១៩:១ ២៦:១ ឌ មថ ១៣:៥៤ ២២:៣៣ មក ១:២២ ៦:២ ១១:១៨ លក ៤:៣២ យហ ៧:៤៦ **៨:២** ឍ លវ ១៣:៤៥ មថ ១០:៨ ១១:៥ ២៦:៦ លក ៥:១២ ១៧:១២ ណ មថ ៩:១៨ ១៥:២៥ ១៨:២៦ ២០:២០ **៨:៤** ត មថ ៩:៣០ ១២:១៦ មក ៥:៤៣ ៧:៣៦ ៨:៣០ លក ៤:៤១ ថ លក ១៧:១៤ ទ លវ ១៤:២-៣២ **៨:៦** ធ មថ ៤:២៤ **៨:៨** ន ទដ ១០៧:២០ **៨:១០** ប មថ ១៥:២៨ **៨:១១** ផ ទដ ១០៧:៣ អស ៤៩:១២ ៥៩:១៩ មឡ ១:១១ ព លក ១៣:២៩ **៨:១២** ភ មថ ១៣:៣៨ ម មថ ១៣:៤២,៥០ ២២:១៣ ២៤:៥១ ២៥:៣០ លក ១៣:២៨

បាច់តែចំពោះការទាយទំនាយនោះទេ។ *អារក្ស* មើលពន្យល់ មក ១:២៣ ។
**៧:២៩** *មានអំណាច* គ្រូបង្រៀនក្រឹត្យវិន័យជាច្រើនបានដកស្រង់ពីសាសនាយូដាមកបន្ថែមក្នុងសេចក្ដីបង្រៀនរបស់ពួកគេ (មើលការពន្យល់ ២:៤) ប៉ុន្តែ ព្រះយេស៊ូវបានបង្រៀនដោយអំណាចពីព្រះវិញ ។
**៨:២** *មនុស្សឃ្លង់* មើលការពន្យល់ លវ ១៣-១៤ ។ *ព្រះអម្ចាស់* មើលការពន្យល់ ៧:២១ ។ *ប្រោសឱ្យទូលបង្គំជាស្អាត* ជំងឺឃ្លង់បានធ្វើឱ្យមនុស្សមិនស្អាត និងទទួលទណ្ឌកម្មលើរាងកាយ(លក ៥:១២-១៦)។
**៨:៤** *កុំប្រាប់អ្នកឯណាឱ្យសោះ* អាចមានហេតុផលយ៉ាងដូច្នេះ (១).ព្រះយេស៊ូវមិនរវល់តែពីសំដែងការអស្ចារ្យពេកនោះទេ (២).ទ្រង់មិនចង់ឱ្យការបង្រៀនត្រូវបង្អាក់ដោយហ្វូងបណ្ដាជនសុំឱ្យទ្រង់ប្រោសជំងឺ (៣).ទ្រង់មិនចង់សុគតមុនពេល កំណត់(៩:៣០ ១២:១៦ មក ១:៤៤ ៥:៤៣ ៧:៣៦ លក ៨:៥៦)។ *ត្រូវទៅបង្ហាញខ្លួនឱ្យពួកសង្ឃឃើញវិញ* មើលការពន្យល់ លក ៥:១៤
**៨:៥-១៣** នេះជារឿងដោយឡែដន្យដែលស្រដៀងទៅនឹង "យហ ៤:៤៣-៥៤" ប៉ុន្តែប្រហែលជាកើតឡើងផ្សេងពីគ្នានៅក្នុងព្រះជន្មរបស់ព្រះយេស៊ូវ ។
**៨:៥** *កាពើណិម* មើលការពន្យល់ លក ៤:១៣ ។ *មេទ័ព* ជាជនជាតិរ៉ូមម្នាក់ដែលទទួលខុសត្រូវលើទាហាន១០០នាក់ ។ តាមគម្ពីរ "លក ៧:១-៥" ចាស់ទុំ ឬគូកននេះ គឺតំណាងឱ្យមេទ័ពជាច្រើននាក់បានមកឯព្រះយេស៊ូវ តែលោកម៉ាថាយឥតបាននិយាយពីអ្នកតំណាងនោះទេ ។ នៅពេលដែលលោកម៉ាថាយនិយាយថា ពីឡាត់វាយព្រះយេស៊ូវនឹងរំពាត់(២៧:២៦) តែគម្ពីរកិច្ចការបានចែងថាពីឡាត់មិនវាយដោយខ្លួនឯងទេ គឺទាហានរ៉ូម៉ាំងជាអ្នកវាយដោយទទួលបញ្ជាពីគាត់ ។
**៨:៨** *ទូលបង្គំមិនគួរនឹងទទួលទ្រង់នៅក្នុងផ្ទះទូលបង្គំទេ* ជាភាសាក្រិកពាក្យថា "ទូលបង្គំមិនគួរនឹង" គឺដូចគ្នានឹងពាក្យដែលលោកយ៉ូហាន-បាទីស្ទបានប្រើដែរ (៣:១១ ខ្ញុំមិនគួរនឹង)។ នៅក្នុងអត្ថន័យនៃការថ្លែងនេះ គឺសំដែងឱ្យឃើញថា លោកមេទ័ពម្នាក់នេះ គាត់គោរពព្រះយេស៊ូវយ៉ាងខ្ពង់ខ្ពស់ជាទីបំផុត ឬក៏គាត់មានអារម្មណ៍ថាខ្លួនជាមនុស្សមានបាបខ្លាំងណាស់ (នៅក្នុងគំនិតផ្ទាល់របស់គាត់) ពុំគួរនឹងទទួលព្រះវត្តមានរបស់ព្រះយេស៊ូវឱ្យយាងគង់ក្នុងផ្ទះរបស់ ខ្លួននោះទេ ។
**៨:១១** ការប្រកាសដំណឹងល្អពេញទាំងផែនដី គឺជាសាច់រឿងក្នុងចំណោមសាច់រឿងសំខាន់ទាំងឡាយនៃគម្ពីរម៉ាថាយ(មើលសេចក្ដីផ្ដើមត្រង់អ្នកទទួល)។ *មកអង្គុយ . . . នៅក្នុងស្ថានសួគ៌* ជាពិធីជប់លៀងរបស់ព្រះមែស៊ី និងជានិមិត្តរូបនៃព្រះពរ និងទំនាក់ទំនងយ៉ាងស្និទ្ធស្នាលបំផុតជាមួយទ្រង់ (អស ២៥:៦-៩)។
**៨:១២** *អស់ទាំងមនុស្សនៅនគរនោះ* ពួកយូដាគេបានគិតថា តាមរយៈសាសនារបស់ពួកគេ គឺជាលិខិតមរដកមួយសម្រាប់ចូលទៅឯនគរស្ថានសួគ៌ (៣:៩-១០ និង មើលការពន្យល់ ៣:៩)។

ឱ្យបានដូចសេចក្ដីជំនឿរបស់អ្នកចុះ[ឃ] បាវគាត់ក៏បានជា
នៅវេលានោះឯង ។

### ព្រះយេស៊ូវប្រោសមនុស្សមានជំងឺ

*៨:១៤–១៦ = មក ១:២៩–៣៤ លក ៤:៣៨–៤១*

១៤លុះព្រះយេស៊ូវ ទ្រង់យាងទៅក្នុងផ្ទះរបស់ពេត្រុស
ហើយ នោះឃើញម្ដាយក្មេកគាត់កំពុងតែដេកគ្រុន ១៥រួច
ទ្រង់ពាល់ដៃនាង នោះគ្រុនក៏បាត់ទៅ ហើយនាងក្រោក
ឡើងបំរើទ្រង់ ។
១៦ដល់ពេលព្រលប់គេនាំមនុស្សជាច្រើន ដែលមាន
អារក្សចូលមកឯទ្រង់ ហើយទ្រង់ក៏ដេញអារក្សដោយសារ
ព្រះបន្ទូល ឯអស់អ្នកដែលមានជំងឺរោគា ទ្រង់បានប្រោស
ឱ្យជាគ្រប់គ្នាដែរ[រ] ១៧ដើម្បីឱ្យបានសំរេច តាមទំនាយ[ល]
ដែលហោរាអេសាយបានទាយទុកមកថា ទ្រង់បានទទួល
អស់ទាំងរោគា ហើយផ្ទុកអស់ទាំងជំងឺរបស់យើងរាល់គ្នា
«នៅលើព្រះអង្គទ្រង់»[វ] ។

### តម្លៃនៃការដើរតាមព្រះយេស៊ូវ

*៨:១៩–២២ = លក ៩:៥៧–៦០*

១៨កាលព្រះយេស៊ូវ ទ្រង់ឃើញហ្វូងមនុស្សកកកុញនៅជុំ
វិញទ្រង់ នោះទ្រង់បង្គាប់ ឱ្យឆ្លងទៅឯត្រើយម្ខាងទៅ[ស]
១៩ខណៈនោះ មានអាចារ្យម្នាក់ចូលមកទូលទ្រង់ថា លោក
គ្រូអើយ ខ្ញុំនឹងតាមលោកទៅដែរ ទោះបើលោកទៅឯណា
ក៏ដោយ ២០ព្រះយេស៊ូវទ្រង់តបថា កញ្ជ្រោងមានរូងវា
ហើយសត្វហើរលើអាកាស ក៏មានសំបុក តែកូនមនុស្ស[ហ]
គ្មានកន្លែងណានឹងកើយក្បាលទេ ២១មានសិស្សទ្រង់ម្នាក់
ទៀតទូលថា ព្រះអម្ចាស់អើយ សូមទ្រង់អនុញ្ញាតឱ្យទូល
បង្គំ បានទៅកប់ខ្មោចឪពុកទូលបង្គំសិន ២២តែព្រះយេស៊ូវ
មានបន្ទូលទៅអ្នកនោះថា ចូរមកតាមខ្ញុំវិញ[ឡ] ទុកឱ្យពួក
មនុស្សស្លាប់កប់ខ្មោចពួកគេចុះ។

**៨:១៣** ឃ មថ ៩:២២
**៨:១៦** រ មថ ៤:២៣,២៤
**៨:១៧** ល មថ ១:២២
វ អស ៥៣:៤
**៨:១៨** ស មក ៤:៣៥
**៨:២០** ហ ដយ ៧:១៣ មថ ១២:៨, ៣២,៤០ ១៦:១៣, ២៧,២៨ ១៧:៩ ១៩:២៨ មក ២:១០ ៨:៣១
**៨:២២** ឡ មថ ៤:១៩
**៨:២៦** អ មថ ៦:៣០
ក ទដ ៦៥:៧ ៨៩:៩ ១០៧:២៩
**៨:២៨** ខ មថ ៤:២៤
**៨:២៩** គ ពច ១១:១២ ២សយ ១៦:១០ ១ពវ ១៧:១៨ មក ១:២៤ លក ៤:៣៤ យហ ២:៤
ឃ ២ពត ២:៤

### ព្រះយេស៊ូវធ្វើឱ្យព្យុះស្ងប់

*៨:២៣–២៧ = មក ៤:៣៦–៤១ លក ៨:២២–២៥*

*៨:២៣–២៧ = មថ ១៤:២២–៣៣*

២៣កាលទ្រង់បានយាងចុះទូកហើយ នោះពួកសិស្សក៏តាម
ទ្រង់ទៅ ២៤ឯសមុទ្រក៏កំរើកឡើងជាខ្លាំង ដល់ម៉្លេះបានជា
រលកឡើងគ្របលើទូក តែទ្រង់ផ្ទំលក់ ២៥ពួកសិស្សក៏ចូល
ទៅតើនទ្រង់ទូលថា ព្រះអម្ចាស់អើយ សូមជួយសង្គ្រោះផង
យើងខ្ញុំវិនាសហើយ ២៦ទ្រង់មានបន្ទូលថា ឱពួកអ្នកមាន
ជំនឿតិចអើយ[អ] ហេតុអ្វីបានជាភ័យដូច្នេះ រួចទ្រង់ក្រោក
ឡើង កំហែងដល់ខ្យល់ និងសមុទ្រ នោះក៏ស្ងប់ឈឹងអស់ទៅ[ក]
២៧អ្នកទាំងនោះមានសេចក្ដីអស្ចារ្យ ហើយនិយាយគ្នាថា
តើមនុស្សនេះបែបយ៉ាងណា បានជាទាំងខ្យល់ នឹងសមុទ្រក៏
ស្ដាប់បង្គាប់លោកដូច្នេះ ។

### ព្រះយេស៊ូវប្រោសមនុស្សអារក្សចូលពីរនាក់

*៨:២៨–៣៤ = មក ៥:១–១៧ លក ៨:២៦–៣៧*

២៨កាលទ្រង់បានដល់ស្រុកគេរ៉ាស៊ីន នៅត្រើយម្ខាងហើយ
នោះមានមនុស្ស២នាក់ ដែលមានអារក្សចូល[ខ] គេចេញពី
ផ្នូរខ្មោចមកជួបនឹងទ្រង់ វាសាហាវណាស់ ដល់ម៉្លេះបានជា
គ្មានអ្នកណាហ៊ានដើរតាមផ្លូវនោះទេ ២៩នោះវាស្រែក
ឡើងថា ឱព្រះយេស៊ូវ ជាព្រះរាជបុត្រានៃព្រះអើយ តើ
យើងហើយនិងទ្រង់មានការអ្វីនឹងគ្នា[គ] តើទ្រង់បានយាង មក
ទីនេះ ដើម្បីនឹងធ្វើទុក្ខដល់យើងមុនកំណត់ឬអី[ឃ] ៣០រីឯនៅទី
ដែលឆ្ងាយពីវា នោះមានហ្វូងជ្រូកយ៉ាងធំ កំពុងតែរកស៊ី
៣១ហើយពួកអារក្សនោះក៏ទូលអង្វរទ្រង់ថា បើទ្រង់បណ្ដេញ
យើងសូមអនុញ្ញាតឱ្យយើងចូលទៅនៅ ក្នុងហ្វូងជ្រូកនោះ
ចុះ ៣២ទ្រង់មានបន្ទូលតបថា ទៅចុះ វាក៏ចេញទៅចូលក្នុង
ហ្វូងជ្រូក រួចជ្រូកនាំគ្នាបោលម្នីម្នាតាមភ្នំចោត ធ្លាក់ទៅក្នុង

---

**៨:១៤** *ម្ដាយក្មេកគាត់កំពុងតែដេកគ្រុន* មើលការពន្យល់ មក ១:៣០ លក ៤:៣៨
**៨:១៨** *ទៅឯត្រើយម្ខាង* គឺផ្នែកខាងលិច ។
**៨:១៩** *អាចារ្យ* គឺជាគ្រូបង្រៀនខាងក្រឹត្យវិន័យ (មើលការពន្យល់ ២:៤)។
**៨:២០** *កូនមនុស្ស* មើលការពន្យល់ មក ៨:៣១ ។
**៨:២២** *មនុស្សស្លាប់កប់ខ្មោចពួកគេ* គឺឱ្យអ្នកស្លាប់ខាងវិញ្ញាណកប់រូបកាយដែលស្លាប់នោះចុះ ។ ពេលវេលានៃការជ្រើសរើសសិស្សនោះខ្លីណាស់ ឃ្លានេះសង្កត់ធ្ងន់លើការសម្រេចចិត្តរបស់យើង។ ការដែលដើរតាមព្រះយេស៊ូវនៅស្នាក់ស្ទើរ ព្រោះថាកូនចៅរបស់សាសន៍យូដាមានភារកិច្ចមួយដ៏សំខាន់ គឺត្រូវកប់ខ្មោចឪពុកម្ដាយរបស់ខ្លួន ។
**៨:២៤** *សមុទ្រក៏កំរើកជាខ្លាំង* មើលការពន្យល់ មក ៤:៣៧ ។ *ព្រះយេស៊ូវផ្ទំលក់* មើលការពន្យល់ មក ៤:៣៨ ។
**៨:២៨** *ស្រុកគេរ៉ាស៊ីន* គឺជាជាយក្រុងគេរ៉ាស៊ីន ដែលមានចម្ងាយប្រហែល ៩,៦គ.ម ភាគអាគ្នេយ៍នៃសមុទ្រកាលីឡេ ។ លោកម៉ាកុស និងលោកលូកាស្គាល់តំបន់នេះ ដោយសារវាគឺជារាជធានី គេរ៉ាសា ដែលស្ថិតនៅចម្ងាយប្រមាណ ៥៦,២៨គ.ម ពីទិសអាគ្នេយ៍នៃសមុទ្រ ។ *ពីរនាក់ដែលមានអារក្សចូល* គម្ពីរម៉ាកុស ៥:២ និងលូកា ៨:២៧ មានតែម្នាក់ទេនៅគេរ៉ាស៊ីនអ្នកខ្លះហៅថា គេរ៉ាស៊ីន ឬគេដារីនជាកន្លែងតែមួយទេ ។
**៨:២៩** *មុនកំណត់* គឺពេលជំនុំជម្រះរបស់ពួកគេ(មើលការពន្យល់ មក ៥:១០ និង លក ៨:៣១)។
**៨:៣០** *ហ្វូងជ្រូក* ជាចំនួនដ៏ច្រើនមួយដែលសាសន៍ដទៃបានចិញ្ចឹមនៅកាលីឡេ ជាធម្មតាពួកយូដាមិនចិញ្ចឹមជ្រូកទេ តាំងពីគេបានចាត់ទុកសត្វជ្រូកជាសត្វមិនស្អាត ក្នុងចំណោមសត្វទាំងឡាយ ។
**៨:៣២** នៅក្នុងខនេះ មើលទៅហាក់បីដូចជាព្រះយេស៊ូវបានយល់ព្រមនឹងអារក្សដែលអង្វរសុំឱ្យចូលទៅក្នុងសត្វជ្រូកនោះក៏ដោយ ក៏នៅទីបំផុតពួកវា

សមុទ្រ លង់ទឹកស្លាប់ទាំងអស់ទៅ ៣៣ឯពួកអ្នកដែលឃ្វាល
វា គេនាំគ្នារត់ចូលទៅក្នុងទីក្រុង រ៉ាយរ៉ាប់ប្រាប់ពីគ្រប់ការ
ទាំងនោះ ហើយពីមនុស្ស២នាក់ដែលមានអារក្សចូលផង
៣៤ចំណែកពួកអ្នកក្រុងនោះទាំងអស់គ្នា ក៏ចេញមកឯព្រះ
យេស៊ូវ កាលបានឃើញទ្រង់ គេក៏អង្វរឱ្យទ្រង់យាងចេញពី
ក្រវល់ស្រុកគេទៅ[ង] ។

## ព្រះយេស៊ូវប្រោសមនុស្សស្លាប់ដៃស្លាប់ជើង

*៩:២–៨ = មក ២:៣–១២ លក ៥:១៨–២៦*

**៩** ១ព្រះយេស៊ូវ ទ្រង់ក៏យាងចុះទូក ឆ្លងទៅឯក្រុងរបស់
ទ្រង់[ច]វិញ ២នោះមានគេនាំមនុស្សស្លាប់ដៃស្លាប់ជើង[ឆ] ម្នាក់
ដេកលើគ្រែមកឯទ្រង់ កាលទ្រង់ទតឃើញសេចក្ដីជំនឿ[ជ]
របស់អ្នកទាំងនោះ ក៏មានបន្ទូលទៅអ្នកស្លាប់ដៃស្លាប់ជើង
ថា ចូរសង្ឃឹម[ឈ] ឡើង កូនអើយ បាបឯងបានអត់ទោស[ញ]ឱ្យ
ឯងហើយ ៣ដូច្នេះ មានអាចារ្យខ្លះនឹកក្នុងចិត្តថា មនុស្សនេះ
ពោលពាក្យប្រមាថ[ដ]ដល់ព្រះ ៤ឯព្រះយេស៊ូវទ្រង់ឈ្វេង
យល់គំនិត[ឋ]គេ ក៏មានបន្ទូលថា ហេតុអ្វីបានជាអ្នករាល់គ្នា
មានគំនិតអាក្រក់ក្នុងចិត្តដូច្នេះ ៥ដ្បិតដែលថា បាបឯង
បានអត់ទោសឱ្យឯងហើយ ឬថា ឱ្យក្រោកឡើងដើរទៅ
នោះតើពាក្យណាងាយថាជាជាង ៦ប៉ុន្តែ នេះដើម្បីឱ្យអ្នក
រាល់គ្នាបានដឹងថា កូនមនុស្ស[ឌ]មានអំណាច នឹងអត់ទោស
បាបនៅផែនដីបានដែរ នោះទ្រង់មានបន្ទូលទៅ អ្នកស្លាប់
ដៃស្លាប់ជើងថា ចូរក្រោកឡើង យកគ្រែឯងទៅផ្ទះទៅ
៧អ្នកនោះក៏ក្រោកឡើងដើរទៅឯផ្ទះ ៨កាលហ្វូងមនុស្ស
បានឃើញការនោះ គេកើតមានសេចក្ដីអស្ចារ្យ ក៏សរសើរ
ដំកើងដល់ព្រះ[ឍ]ដែលទ្រង់បានប្រទានអំណាច យ៉ាងនេះ
មកមនុស្សលោក ។

## ការត្រាស់ហៅលោកម៉ាថាយ

*៩:៩–១៣ = មក ២:១៤–១៧ លក ៥:២៧–៣២*

៩លុះព្រះយេស៊ូវយាងហួសពីទីនោះទៅ ទ្រង់ក៏ទតឃើញ
មនុស្សម្នាក់ឈ្មោះ ម៉ាថាយ កំពុងអង្គុយនៅកន្លែងយកពន្ធ
នោះទ្រង់មានបន្ទូលហៅគាត់ថា ចូរមកតាមខ្ញុំ[ណ] គាត់ក៏
ក្រោកឡើងដើរតាមទ្រង់ទៅ ១០កាលព្រះយេស៊ូវកំពុងគង់
សោយអាហារនៅក្នុងផ្ទះ នោះមានពួកអ្នកយកពន្ធ នឹង
មនុស្សមានបាបជាច្រើន បានមកអង្គុយជាមួយនឹងទ្រង់ និង
ពួកសិស្សទ្រង់ផង ១១កាលពួកផារិស៊ីបានឃើញដូច្នោះ គេ
ក៏សួរពួកសិស្សទ្រង់ថា ហេតុអ្វីបានជាគ្រូរបស់អ្នករាល់គ្នា
បរិភោគជាមួយនឹងពួកយកពន្ធ ហើយនិងមនុស្សមានបាប
ដូច្នេះ[ត] ១២តែព្រះយេស៊ូវទ្រង់ក៏បានឮ ហើយទ្រង់មាន
បន្ទូលតបថា ពួកអ្នកដែលជាសុខសប្បាយមិនត្រូវការនឹង
គ្រូពេទ្យទេ គឺជាពួកដែលមានជំងឺវិញទេតើ ១៣ចូរឱ្យអ្នក
រាល់គ្នាទៅរៀនន័យបទ ដែលថា « អញចង់បានសេចក្ដី
មេត្តាករុណា មិនមែនយញ្ញបូជាទេ »[ថ] ពីព្រោះខ្ញុំមិនបាន
មក ដើម្បីនឹងហៅមនុស្សសុចរិតទេ គឺមកហៅមនុស្សមាន
បាប ឱ្យប្រែចិត្តវិញ[ទ] ។

## ការតមអាហារ

*៩:១៤–១៧ = មក ២:១៨–២២ លក ៥:៣៣–៣៩*

១៤នៅគ្រានោះ ពួកសិស្សរបស់យ៉ូហាន[ធ] ក៏មកឯទ្រង់ទូលថា
ហេតុអ្វីបានជាយើងខ្ញុំ នឹងពួកផារិស៊ី តម[ន]តែញយៗ តែពួក
សិស្សទ្រង់មិនដែលតមសោះដូច្នេះ ១៥ព្រះយេស៊ូវទ្រង់ឆ្លើយ
ថា កំពុងដែលប្ដីថ្មោងថ្មីនៅជាមួយគ្នា នោះតើសំឡាញ់ នៃ
គាត់នឹងធ្វើទឹកមុខព្រួយបានឬទេ[ប] ប៉ុន្តែនឹងមានគ្រាមកដល់
ដែលប្ដីនឹងត្រូវដកយកចេញពីគេទៅ នៅគ្រានោះ ទើបគេ
នឹងតម[ផ]អាហារវិញ ១៦គ្មានអ្នកណាដែលយកកំណាត់សំពត់
ថ្មីមកប៉ះអាវចាស់ទេ ដ្បិតកំណាត់ថ្មីនោះ នឹងហែកអាវចេញ

**៨:៣៤** ង លក ៥:៨ កច ១៦:៣៩
**៩:១** ច មថ ៤:១៣
**៩:២** ឆ មថ ៤:២៤ ជ ខ.២២ ឈ យហ ១៦:៣៣ ញ លក ៧:៤៨
**៩:៣** ដ មថ ២៦:៦៥ យហ ១០:៣៣
**៩:៤** ឋ ទដ ៩៤:១១ មថ ១២:២៥ លក ៦:៨ ៩:៤៧ ១១:១៧ យហ ២:២៥
**៩:៦** ឌ មថ ៨:២០
**៩:៨** ឍ មថ ៥:១៦ ១៥:៣១ លក ៧:១៦ ១៣:១៣ ១៧:១៥ ២៣:៤៧ យហ ១៥:៨ កច ៤:២១ ១១:១៨ ២១:២០
**៩:៩** ណ មថ ៤:១៩
**៩:១១** ត មថ ១១:១៩ លក ៥:៣០ ១៥:២ ១៩:៧ កទ ២:១៥
**៩:១៣** ថ ហាស ៦:៦ មីក ៦:៦–៨ មថ ១២:៧ ទ លក ១៩:១០ ១ធថ ១:១៥
**៩:១៤** ធ មថ ៣:១ ន មថ ១១:១៨,១៩ លក ១៨:១២
**៩:១៥** ប យហ ៣:២៩ ផ កច ១៣:២,៣ ១៤:២៣

បានធ្លាក់ចូលសមុទ្រលង់ទឹកស្លាប់អស់ដដែល ។ សមុទ្រនៅត្រង់នេះប្រហែលជានិមិត្តរូបនៃជង្ហុក បាតសមុទ្រដ៏ជ្រៅបំផុត(មើលការពន្យល់ លក ៨:៣១) ។

**៨:៣៤** *អង្វរឱ្យទ្រង់យាងចេញ* ប្រហែលជាពួកគេខ្វល់ខ្វាយនឹងការបាត់បង់ទ្រព្យសម្បត្តិរបស់ខ្លួនជាជាងការប្រោសមនុស្សឱ្យរួចពីអំណាចរបស់អារក្ស។

**៩:១** *ឆ្លងទៅ* គឺនៅផ្នែកខាងជើងនៃចុងបំផុតសមុទ្រកាលីឡេ ។ *ក្រុងរបស់ទ្រង់* គឺនិយាយអំពីក្រុងកាពើណិម(មើលការពន្យល់ ៤:១៣) ។

**៩:២** *ជំនឿរបស់អ្នកទាំងនោះ* គឺរបស់អ្នកស្លាប់ដៃស្លាប់ជើង និងអ្នកសែងគាត់ ។

**៩:៣** *ប្រមាថ* មានន័យថាដណ្ដើមអំណាចនៃការអត់ទោសបាប ដែលមានតែព្រះទេទើបអាចធ្វើបាន(មើលការពន្យល់ មក ២:៧) ។

**៩:៥–៦** មើលការពន្យល់ មក ២:៩–១០ និង ១៤:៦៤ ។

**៩:៦** *កូនមនុស្ស* មើលការពន្យល់ មក ៨:៣១ ។

**៩:៩** *ម៉ាថាយ* លោកម៉ាកុស និងលូកាបានហៅសាវ័ករូបនេះថា លេវី នៅក្នុងបញ្ជីប្រៀបប្រដូច(មក ៣:១៨ លក ៦:១៥ កច ១:១៣)។ *អង្គុយកន្លែងយកពន្ធ* មើល ការពន្យល់ មក ២:១៤ ។ *ក្រោកឡើង . . . ទ្រង់* មើលការពន្យល់ លក ៥:២៨ ។

**៩:១០** *អ្នកយកពន្ធ* មើលការពន្យល់ ៥:៤៦ មក ២:១៦ ។ *មនុស្សមានបាប* មើលការពន្យល់ មក ២:១៥ ។

**៩:១១** *ផារិស៊ី* មើលការពន្យល់ មក ២:១៦ ។

**៩:១៣** *ខ្ញុំមិនបានមក ដើម្បីនឹងហៅមនុស្សសុចរិតទេ* គឺមកហៅមនុស្សមានបាបឱ្យប្រែចិត្តវិញ(មើលការពន្យល់ មក ២:១៧) ។

**៩:១៤** *សិស្សរបស់យ៉ូហាន* មើលការពន្យល់ មក ២:១៨ និង លក ៥:៣៣ ។ *តម* មើលការពន្យល់ មក ២:១៨,លក ៥:៣៣ ។

**៩:១៥** មើល មក ២:១៩–២០ ។

ហើយរំហែកនោះនឹងរឹងរឹតតែអាក្រក់ជាងទៅទៀត ១៧ ក៏
មិនដែលមានអ្នកណាដាក់ស្រា ទំពាំងបាយជូរថ្មី ក្នុង
ថង់ស្បែកចាស់ដែរ បើធ្វើដូច្នោះ ថង់ស្បែកនឹងធ្លាយ
ហូរស្រាទំពាំងបាយជូរចេញអស់ ហើយទាំងថង់នោះ
ក៏ត្រូវខូចខាតដែរ គឺគេតែងដាក់ស្រាទំពាំងបាយជូរថ្មី
ក្នុងថង់ស្បែកថ្មីវិញ នោះទើបទាំង២បានគង់នៅ។

## ការប្រោសស្ត្រីមានជំងឺ និងសពក្មេងស្រី

*៩:១៨–២៦ = មក ៥:២២–៤៣ លក ៨:៤១–៥៦*

១៨កំពុងដែលទ្រង់មានបន្ទូលនឹងគេ ពីដំណើរទាំងនោះ
ស្រាប់តែមានមេសាលាម្នាក់ មកក្រាបថ្វាយបង្គំ[ព]ទូលថា
កូនស្រីរបស់ទូលបង្គំទើបនឹងស្លាប់អម្បាញ់មិញ សូមទ្រង់
មេត្តាយាងទៅដាក់ព្រះហស្តលើវា[ភ] នោះវានឹងរស់ឡើង
វិញ ១៩ព្រះយេស៊ូវក៏ក្រោកឡើង យាងទៅតាម ព្រមទាំង
ពួកសិស្សទ្រង់ដែរ ២០រីឯមានស្ត្រីម្នាក់ នាងមានជំងឺធ្លាក់
ឈាមអស់១២ឆ្នាំមកហើយ នាងបានចូលមកពីក្រោយ
ពាល់ជាយព្រះពស្ត្រទ្រង់[ម] ២១ដោយគិតក្នុងចិត្តថា បើគ្រាន់
តែពាល់ជាយព្រះពស្ត្រទ្រង់ប៉ុណ្ណោះ នោះនឹងបានជាហើយ
២២ឯព្រះយេស៊ូវ ទ្រង់បែរទៅឃើញនាង ក៏មានបន្ទូលថា
ចូរសង្ឃឹមឡើង[យ]កូនអើយ សេចក្តីជំនឿរបស់នាងបាន
ជួយសង្គ្រោះ[រ]នាងហើយ នាងក៏បានជា ចាប់តាំងពីវេលា
នោះមក[ល] ២៣រួចមក កាលទ្រង់យាងចូលទៅក្នុងផ្ទះមេសា
លា បានឃើញពួកអ្នកផ្លុំខ្លុយ នឹងមនុស្សសន្ធឹកកំពុងតែឆោ
ឡោ[វ] ២៤នោះទ្រង់មានបន្ទូលថា ចូរថយចេញទៅ ដ្បិតនាង
ក្រមុំនេះមិនមែនស្លាប់ទេ[ស] នាងគ្រាន់តែដេកលក់ប៉ុណ្ណោះ[ហ]
តែគេសើចចំអកឱ្យទ្រង់ ២៥លុះបណ្តេញមនុស្សទាំងនោះ
ទៅក្រៅទាំងអស់ហើយ នោះទ្រង់យាងចូលទៅចាប់ដៃ
នាង រួចនាងក៏ក្រោកឡើង[ឡ] ២៦រឿងនោះបានល្បីខ្ចរខ្ចាយ
ទូទៅ ពេញពាសក្នុងស្រុកនោះឯង[អ]។

## ព្រះយេស៊ូវប្រោសមនុស្សខ្វាក់ និងមនុស្សគ

២៧កំពុងដែលព្រះយេស៊ូវទ្រង់យាងចេញពីទីនោះទៅ
នោះមានមនុស្សខ្វាក់២នាក់តាមទ្រង់ ទាំងស្រែកថា ឱព្រះ
រាជបុត្រាហ្លួងដាវីឌអើយ[ក] សូមទ្រង់ប្រោសមេត្តាដល់
យើងខ្ញុំផង ២៨កាលបានយាងចូលទៅក្នុងផ្ទះ នោះអ្នកខ្វាក់
ទាំង២ក៏មកឯទ្រង់ ហើយទ្រង់មានបន្ទូលសួរថា តើអ្នកជឿ
ថា ខ្ញុំអាចនឹងធ្វើការនេះបានឬទេ អ្នកទាំង២ទូលថា
ជឿហើយ ព្រះអម្ចាស់អើយ[ខ] ២៩នោះទ្រង់ក៏ពាល់ភ្នែកគេ
ដោយបន្ទូលថា ចូរឱ្យបានដូចសេចក្តីជំនឿរបស់អ្នកចុះ[គ]
៣០ភ្នែកគេក៏បានភ្លឺឡើង រួចទ្រង់ហាមផ្តាច់ថា នែ
កុំឱ្យអ្នកណាដឹងការនេះឱ្យសោះហ្ន៎ះ[ឃ] ៣១តែកាលគេ ចេញ
ទៅហើយ នោះក៏ផ្សាយប្រាប់ពីទ្រង់ សុសសាយពេញ ក្នុង
ស្រុកនោះ[ង]។

៣២កំពុងដែលអ្នកទាំង២ចេញទៅ នោះមានគេនាំមនុស្ស
គ[ច] ដែលមានអារក្សចូល[ឆ] មកឯទ្រង់ ៣៣រួចកាលបានដេញ
អារក្សចេញហើយ នោះមនុស្សគបាននិយាយឡើងបាន ឯ
បណ្តាមនុស្សទាំងប៉ុន្មាន គេមានសេចក្តីអស្ចារ្យថា មិន
ដែលឃើញមានយ៉ាងដូច្នេះ នៅក្នុងស្រុកអ៊ីស្រាអែលសោះ
ឡើយ[ជ] ៣៤តែពួកផារិស៊ីនិយាយឡើងថា អ្នកនេះដេញ
អារក្ស ដោយសារតែមេអារក្សទេ[ឈ]។

**៩:១៨** ព មថ ៨:២ ភ មក ៥:២៣ **៩:២០** ម មថ ១៤:៣៦ មក ៣:១០ ៦:៥៦ លក ៦:១៩ **៩:២២** យ ខ.២ យហ ១៦:៣៣ រ ខ.២៩ មថ ៨:១៣ មក ១០:៥២ លក ៧:៥០ ១៧:១៩ ១៨:៤២ ល មថ ១៥:២៨ **៩:២៣** វ ២របា ៣៥:២៥ យរ ៩:១៧,១៨ **៩:២៤** ស កច ២០:១០ ហ ដយ ១២:២ ទដ ៧៦:៥ យហ ១១:១១–១៤ កច ៧:៦០ ១៣:៣៦ ១កថ ១១:៣០ ១៥:៦,១៨,២០ ១ថន ៤:១៣–១៦ **៩:២៥** ឡ លក ៧:១៤ **៩:២៦** អ ខ.៣១ មថ ៤:២៤ ១៤:១ មក ១:២៨,៤៥ លក ៤:១៤,៣៧ ៥:១៥ ៧:១៧ **៩:២៧** ក មថ ១:១ ១២:២៣ ១៥:២២ ២០:៣០,៣១ ២១:៩,១៥ ២២:៤២ មក ១០:៤៧ **៩:២៨** ខ កច ១៤:៩ **៩:២៩** គ ខ.២២ **៩:៣០** ឃ មថ ៨:៤ **៩:៣១** ង ខ.២៦ មក ៧:៣៦ **៩:៣២** ច មថ ១២:២២–២៤ ឆ មថ ៤:២៤ **៩:៣៣** ជ មក ២:១២ **៩:៣៤** ឈ មថ ១២:២៤

**៩:១៧** *ស្រាទំពាំងបាយជូរថ្មី ក្នុងថង់ស្បែកថ្មី* សម័យបុរាណ ថង់ស្បែកពពែត្រូវបានគេ ប្រើសម្រាប់ដាក់ស្រាទំពាំងបាយជូរ ។ ទឹកទំពាំងបាយជូរថ្មីក្រោយពីដាក់មេនោះនឹងឡើង ហើយធ្វើឱ្យថង់ថ្មីអាចយឺតធំបាន ប៉ុន្តែបើសិនជាថង់ចាស់ដែលយឺតអស់ហើយ ហើយយកមកដាក់ស្រាថ្មីម្តងទៀត នោះនឹងត្រូវរហែកនៅពេលមេវាឡើង ។ ព្រះយេស៊ូវប្រទានឱ្យយើងនូវថង់ថ្មីបំផុត ដែលមិនលាយឡំនឹងទម្រង់ចាស់ឡើយ ។ **ម៉ាថាយ** មានន័យថា អំណោយទាននៃព្រះ ។ **មុខងារ** ជាអ្នកយកពន្ធ ជាសាវ័កព្រះយេស៊ូវ ជាអ្នកនិពន្ធ ។ **ល្បីខាង** យកពន្ធគួរឱ្យស្អប់ខ្ពើម ដើរតាមព្រះយេស៊ូវភ្លាម សរសេរដំណឹងល្អ ដែលប្រកាសអំពីព្រះយេស៊ូវថា ព្រះបានសម្រេចទំនាយក្នុងគម្ពីរសញ្ញាចាស់ ។

**៩:១៨** *មេសាលា* តាមគម្ពីរម៉ាកុស និងគម្ពីរលូកាបានឱ្យដឹងថា ជាម្នាក់ដែលមើល ការខុសត្រូវនៅក្នុងសាលាប្រជុំ (ឈ្មោះយ៉ៃរ៉ុស មក ៥:២២) ។

**៩:២០** *ជំងឺធ្លាក់ឈាម១២ឆ្នាំ* មើលការពន្យល់ មក ៥:២៥ ។

**៩:២១** មើលការពន្យល់ មក ៥:២៨ ។

**៩:២២** *កូនស្រី* មើលពន្យល់ លក ៨:៤–៨ ។ *ប្រោសជំងឺ* មើលពន្យល់ មក ៥:៣៤ ។

**៩:២៣** *អ្នកផ្លុំខ្លុយ* គឺជាដន្ត្រីករម្នាក់ ដែលគេជួលមកលេងក្នុងពិធីកាន់ទុក្ខ ។ *មនុស្សសន្ធឹកកំពុងតែឆោឡោ* ក្រុមគ្រួសារសពបានជួលមនុស្សទាំងអស់នេះមក ដើម្បីឱ្យយំត្អូញត្អែរ និងទ្រហោយំរៀបរាប់នៅក្នុងពិធីបុណ្យសពនោះ ។

**៩:២៤** *មិនមែនស្លាប់ទេ នាងគ្រាន់តែដេកលក់* មើលការពន្យល់ លក ៨:៥២

**៩:២៧** *មនុស្សខ្វាក់* លោកអេសាយបានថ្លែងទំនាយអំពីការប្រោសមនុស្សខ្វាក់នេះ នៅសម័យព្រះមែស៊ី (អស ៣៥:៥) ។ *បុត្រហ្លួងដាវីឌ* ជាឈ្មោះដែលមានប្រជាប្រិយភាពបំផុតសម្រាប់ជនជាតិយូដា ក្នុងការហៅជំនួសព្រះនាមរបស់ព្រះយេស៊ូវ ដែលពួកគេរំពឹងគិតទុក និងបានរង់ចាំការយាងមករបស់ព្រះមែស៊ី (១២:២៣ ២០:៣០ ២១:៩ ២២:៤១–៤៥ និងមើលពន្យល់ ១:១) ។

**៩:៣០** មើលការពន្យល់ ៨:៤ ១៦:២០ ។

**៩:៣២** *មនុស្សគ* ហោរាអេសាយក៏បានថ្លែងទំនាយដូចនេះដែរថា មនុស្សគនឹងអាចនិយាយបាននៅក្នុងសម័យព្រះមែស៊ី (អស ៣៥:៦) ។

**៩:៣៤** *មេអារក្ស* មើលការពន្យល់ ១០:២៥ ។

## ចម្រូតធំ តែមានអ្នកច្រូតតិច

៣៥ព្រះយេស៊ូវ ទ្រង់ក៏យាងទៅដល់គ្រប់ក្រុងគ្រប់ភូមិ ព្រម
ទាំងបង្រៀនក្នុងសាលាប្រជុំទាំងប៉ុន្មាន ហើយប្រកាស
ប្រាប់ដំណឹងល្អពីនគរ ទ្រង់ក៏ប្រោសអស់ទាំងជំងឺរោគា និង
ជរាពិការ ក្នុងពួកបណ្ដាជនឱ្យបានជា[ញ] ៣៦កាលទ្រង់
ឃើញហ្វូងមនុស្សហើយ នោះទ្រង់មានព្រះហឫទ័យក្ដួល
អាណិតដល់គេ[ដ] ដ្បិតគេល្វើយ ហើយខ្ចាត់ខ្ចាយ ដូចហ្វូង
ចៀម ដែលឥតអ្នកគង្វាល[ឋ] ៣៧បានជាទ្រង់មានបន្ទូលទៅពួក
សិស្សថា ចំរូតធំណាស់[ឌ] តែមានអ្នកច្រូតតិចទេ[ឍ] ៣៨ដូច្នេះ
ចូរសូមអង្វរដល់ព្រះអម្ចាស់នៃចំរូត ឱ្យទ្រង់ចាត់អ្នកច្រូត
មកក្នុងចំរូតទ្រង់។

## សាវ័កទាំង១២ត្រូវបានបញ្ជូនឱ្យចេញទៅ

*១០:២-៤ = មក ៣:១៦-១៩ លក ៦:១៤-១៦ កច ១:១៣*

*១០:៩-១៥ = មក ៦:៨-១១ លក ៩:៣-៥ ១០:៤-១២*

*១០:១៩-២២ = មក ១៣:១១-១៣ លក ២១:១២-១៧*

*១០:២៦-៣៣ = លក ១២:២-៩*

*១០:៣៤-៣៥ = លក ១២:៥១-៥៣*

**១០** ១កាលទ្រង់បានហៅពួកសិស្សទាំង១២នាក់មកហើយ
នោះក៏ប្រទានឱ្យគេមានអំណាច អាចនឹងដេញអារក្ស
អសោចិ៍[ណ]ហើយនឹងមើលគ្រប់ទាំងជំងឺរោគា នឹងជរាពិ
ការទាំងអស់ឱ្យបានជាផង[ត] ២រីឯពួកសាវ័កទាំង១២នាក់
នោះដូចមានឈ្មោះខាងក្រោមនេះស្រាប់គឺ មុនដំបូងមាន
ស៊ីម៉ូនដែលហៅថាពេត្រុស១ អនទ្រេជាប្អូនគាត់១ យ៉ាកុប
ជាកូនសេបេដេ១ នឹងយ៉ូហាន ជាប្អូនគាត់១ ៣ភីលីព១
បារថូលូមេ១ ថូម៉ាស១ ម៉ាថាយ ជាអ្នកយកពន្ធ១ យ៉ាកុប
ជាកូនអាលផាយ១ លេបេ ដែលហៅថា ថាដេ១ ៤ស៊ីម៉ូន
ជាសាសន៍កាណាន១ ហើយនឹងយូដាស-អ៊ីស្ការីយ៉ុត

**៩:៣៥** ញ មថ ៤:២៣
**៩:៣៦** ដ មថ ១៤:១៤ ១៥:៣២ មក ៨:២ ឋ ជន ២៧:១៧ ១ពវ ២២:១៧ អគ ៣៤:៥,៦ សក ១០:២
**៩:៣៧** ឌ យហ ៤:៣៥ ឍ លក ១០:២
**១០:១** ណ មក ៣:១៣-១៥ ៦:៧ លក ៤:៣៦ ៩:១ ត មថ ៤:២៣
**១០:៤** ថ មថ ២៦:១៤-១៦,២៥, ៤៧ ២៧:៣ មក ១៤:១០ យហ ៦:៧១ ១២:៤ ១៣:២,២៦,២៧ កច ១:១៦
**១០:៥** ទ ១ពវ ១៦:២៤ ២ពវ ១៧:២៤ លក ៩:៥២ ១០:៣៣ ១៧:១៦ យហ ៤:៤-២៦, ៣៩,៤០ ៨:៤៨ កច ៨:៥,២៥
**១០:៦** ធ យរ ៥០:៦ មថ ១៥:២៤
**១០:៧** ន មថ ៣:២
**១០:៩** ប លក ២២:៣៥
**១០:១០** ផ ១ធថ ៥:១៨
**១០:១២** ព ១សយ ២៥:៦

ជា[ថ]អ្នកដែលបញ្ជូនទ្រង់១ ។
៥ព្រះយេស៊ូវ ទ្រង់ចាត់ពួក១២នាក់នេះ ឱ្យទៅដោយផ្ដាំថា
កុំឱ្យអ្នករាល់គ្នាបែរទៅតាមផ្លូវរបស់សាសន៍ដទៃ ឬចូល
ទៅក្នុងទីក្រុងណា១របស់សាសន៍សាម៉ារី[ទ]ឡើយ ៦ចូរទៅ
ឯចៀមបាត់បង់ របស់វង្សានុវង្សនៃពួកអ៊ីស្រាអែល[ធ]វិញ
៧ហើយកំពុងដែលទៅ នោះចូរប្រកាសប្រាប់ថា នគរ
ស្ថានសួគ៌[ន]ជិតដល់ហើយ ៨ចូរប្រោសមនុស្សជំងឺឱ្យជា
មនុស្សស្លាប់ឱ្យរស់ឡើងវិញ មនុស្សឃ្លង់ឱ្យជាស្អាត ហើយ
ដេញអារក្សចេញផង អ្នករាល់គ្នាបានទទួលទទេ ត្រូវឱ្យ
ទទេដែរ ៩កុំឱ្យយកមាសប្រាក់ ឬលុយកាក់ដាក់ក្នុងខ្សែ
ក្រវាត់[ប]របស់អ្នកទៅឡើយ ១០ក៏កុំឱ្យយកយាមសំរាប់តាម
ផ្លូវ ឬអាវ២ ស្បែកជើង ឬដំបងផង ដ្បិតអ្នកដែលធ្វើការ
នោះគួរនឹងបានអាហារចិញ្ចឹមខ្លួន[ផ] ១១នៅក្រុងណា ឬភូមិ
ណា ដែលអ្នករាល់គ្នាចូលទៅ នោះត្រូវឱ្យសួរ រកអ្នកណា
ក្នុងទីនោះដែលគេគួរ រួចឱ្យនៅផ្ទះអ្នកនោះ ដរាបដល់អ្នក
ចេញទៅ ១២កាលណាចូលទៅ ក៏ត្រូវជំរាបសួរ[ព]អ្នកផ្ទះ
នោះដែរ ១៣បើអ្នកផ្ទះនោះគេគួរ នោះចូរឱ្យសេចក្ដីសុខ
សាន្តរបស់អ្នករាល់គ្នានៅផ្ទះនោះចុះ តែបើមិនគួរទេនោះ
ត្រូវឱ្យសេចក្ដីសុខសាន្តត្រឡប់មក លើអ្នករាល់គ្នាវិញ
១៤បើអ្នកណាមិនទទួល ឬមិនស្ដាប់តាមពាក្យអ្នក នោះត្រូវ
ឱ្យអ្នករាល់គ្នាចុះពីផ្ទះនោះ ឬចេញពីក្រុងនោះ រួចរលាស់
ធូលីពីជើងអ្នកចេញ[ភ] ១៥ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
នៅថ្ងៃជំនុំជំរះ[ម] ក្រុងសូដុំម នឹងក្រុងកូម៉ូរា[យ] នឹងទ្រាំបាន
ងាយជាជាងក្រុងនោះវិញ[រ] ។

**១០:១៤** ភ នហ ៥:១៣ មក ៦:១១ លក ៩:៥ ១០:១១ កច ១៣:៥១ ៨:៦
**១០:១៥** ម លប ១៨:២០ ១៩:២៤ ២ពត ២:៦ យដ ៧ យ មថ ១២:៣៦ កច ១៧:៣១ ២ពត ២:៩ ៣:៧ ១យហ ៤:១៧ យដ ៦ រ មថ ១១:២២,២៤

**៩:៣៥** *សាលាប្រជុំ* គឺជាកន្លែងថ្វាយបង្គំព្រះ (មើលពន្យល់ មក ១:២១)។
*ដំណឹងល្អ* មើលការពន្យល់ មក ១:១ ។

**១០:២-៤** មើលការពន្យល់ លក ៦:១៤-១៦ ។

**១០:២** *សាវក* ការប្រើពាក្យនេះមានតែម្ដងគត់នៅក្នុងគម្ពីរដំណឹងល្អម៉ាថាយ (មើលការពន្យល់ មក ៦:៣០)។

**១០:៤** *សាសន៍កាណាន* ជាការពិពណ៌នាមួយនៃភាពឧស្សាហ៍ព្យាយាមរបស់ស៊ីម៉ូនខាងសាសនា ឬជាការទាក់ទងទៅនឹងភាពជាសមាជិករបស់គាត់ក្នុងបក្សជាតិនិយមមួយ ដែលជាក្រុមបះបោរប្រឆាំងនឹងពួករ៉ូម៉ាំងត្រួតត្រាលើប៉ាឡេស្ទីន ។

**១០:៥** *កុំឱ្យអ្នករាល់គ្នាបែរទៅតាម* ការប្រកាសដំណឹងល្អអំពីនគរព្រះត្រូវតែទៅដល់ពួកសាសន៍យូដាជាមុនសិន តែក្រោយពីការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ នោះទ្រង់បង្គាប់ឱ្យនាំព្រះបន្ទូលនេះទៅប្រកាសប្រាប់ដល់មនុស្សគ្រប់ទាំងសាសន៍ (២៨:១៩ ២១:៤៣) ។ សាសន៍សាម៉ារីជាសាសន៍កូនកាត់រវាងសាសន៍ដទៃ និងពួកអ៊ីស្រាអែលដែលនៅសេសសល់ខ្លះពីការនិរទេសឱ្យចេញពីអាណាចក្រខាងជើង ។ គ្រានោះពួកស៊ីរីបាននាំសាសន៍ដទៃមករស់នៅជាមួយពួកនេះ ហើយគេក៏បានរៀបការនឹងគ្នា (២ពវ ១៧:២៤) ។ សម័យកាលព្រះយេស៊ូវ បណ្ដាជម្លោះដ៏ល្វីងជូចត់រវាងពួកសាម៉ារី និងពួកយូដាបានកើតឡើង (យហ ៤:៩) ។

**១០:៧** *នគរស្ថានសួគ៌* មើលការពន្យល់ ៣:២ ។

**១០:៨** *មនុស្សឃ្លង់* មើលការពន្យល់ លវ ១៣:២ ។

**១០:៩-១០** មើលការពន្យល់ មក ៦:៨-៩ ។

**១០:១២** *ជំរាបសួរ* ភាសាហេព្រើរ (shalom សាលូម) មានន័យថា "សន្តិភាព"។

**១០:១៤** *រលាស់ធូលីពីជើងអ្នកចេញ* នេះជានិមិត្តរូបនៃសកម្មភាព ដែលពួកផារីស៊ីបានអនុវត្តនៅពេលពួកគេបានចាកចេញពី "កន្លែងមិនស្អាត" របស់សាសន៍ដទៃ ។ នេះសំដែងពីទង្វើនៃការព្រមានជាដាច់ខាតមួយចំពោះអស់អ្នកដែលបដិសេធព្រះបន្ទូលរបស់ព្រះ (លក ៩:៥ កច ១៣:៥១ កច ១៨:៦) ។

**១០:១៥** *សូដុំម និងក្រុងកូម៉ូរា* (លប ១៩:២៣-២៩) ។

១៦នែ ខ្ញុំចាត់អ្នករាល់គ្នាឱ្យទៅ ដូចជាចៀមនៅកណ្ដាល
ហ្វូងស្វាន[ល] ដូច្នេះ ចូរធ្វើជាអ្នកឆ្លាតដូចជាពស់ ហើយ
សុភាពដូចព្រាប[វ] ១៧ត្រូវឱ្យប្រយ័ត្ននឹងមនុស្សលោក ដ្បិត
គេនឹងបញ្ជូនអ្នករាល់គ្នាទៅពួកក្រុមជំនុំ[ស] ហើយនឹងវាយ
អ្នករាល់គ្នានឹងរំពាត់ នៅក្នុងសាលាប្រជុំ[ហ] ១៨អ្នករាល់គ្នា
នឹងត្រូវគេបញ្ជូនទៅនៅមុខចៅហ្វាយខេត្ត ហើយនៅ
ចំពោះស្ដេច[ឡ] ដោយព្រោះខ្ញុំ ទុកជាទីបន្ទាល់ដល់លោក
ទាំងនោះ ហើយនិងពួកសាសន៍ដទៃដែ ១៩ប៉ុន្តែកាលណា
គេចាប់បញ្ជូនអ្នករាល់គ្នាទៅ នោះកុំឱ្យថប់ព្រួយពីបែប
និយាយ ឬពីពាក្យដែលត្រូវថាឡើយ[អ] ពីព្រោះសេចក្តីដែល
ត្រូវនិយាយ នឹងបានប្រទានមកអ្នករាល់ គ្នានៅវេលានោះ
ឯង ២០ដ្បិតមិនមែនជាអ្នករាល់គ្នាដែល ត្រូវនិយាយទេ
គឺជាព្រះវិញ្ញាណរបស់ព្រះវរបិតានៃអ្នកទេតើ ដែលទ្រង់
មានបន្ទូលក្នុងខ្លួនអ្នកវិញ[ក] ២១បងប្អូននឹងបញ្ជូនគ្នាឱ្យ
ត្រូវស្លាប់ ឪពុកនឹងបញ្ជូនកូន ហើយកូននឹងលើកគ្នាទាស់
នឹងឪពុកម្ដាយ[ខ] ព្រមទាំងសំឡាប់គាត់ផង[គ] ២២មនុស្សទាំង
អស់នឹងស្អប់អ្នករាល់គ្នា ដោយព្រោះឈ្មោះខ្ញុំ[ឃ] ប៉ុន្តែអ្នក
ណាដែលកាន់ខ្ជាប់ ដរាបដល់ចុងបំផុត អ្នកនោះនឹងបាន
សង្គ្រោះ[ង] ២៣កាលណាគេធ្វើទុក្ខបៀតបៀនអ្នករាល់គ្នា
ក្នុងក្រុងនេះ នោះត្រូវរត់ទៅឯក្រុង១ទៀតវិញ ដ្បិតខ្ញុំ
ប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នានឹងដើរ មិនទាន់
ដល់គ្រប់ទាំងទីក្រុងនៃសាសន៍អ៊ីស្រាអែលនៅឡើយ នោះ
កូនមនុស្សនឹងបានមកដល់ហើយ[ច]។
២៤សិស្សមិនមែនលើសជាងគ្រូទេ ហើយបាវក៏មិនលើស
ជាងចៅហ្វាយខ្លួនដែរ[ឆ] ២៥បើសិស្សបានស្មើនឹងគ្រូ ហើយ
បាវបានស្មើនឹងចៅហ្វាយ នោះល្មមហើយ បើសិនជាគេ
ហៅម្ចាស់ផ្ទះថា បេលសេប៊ូល[ជ] នោះចំណង់បើពួកអ្នកនៅ
ផ្ទះនោះទាំងប៉ុន្មាន តើគេនឹងហៅយ៉ាងនោះលើសជាង
អម្បាលម៉ានទៅទៀត ២៦ដូច្នេះ មិនត្រូវឱ្យខ្លាចគេឡើយ ដ្បិត
គ្មានអ្វីគ្របបាំង ដែលមិនត្រូវបើកសំដែងចេញ ឬអ្វីលាក់
លៀម ដែលមិនត្រូវបង្ហាញឱ្យគេស្គាល់នោះទេ[ឈ] ២៧ការអ្វី
ដែលខ្ញុំប្រាប់អ្នករាល់គ្នានៅទីងងឹត នោះចូរសំដែងនៅ ទីភ្លឺ
ហើយការអ្វី ដែលអ្នករាល់គ្នាឮនៅត្រចៀក នោះចូរ
ថ្លែងប្រាប់ពីលើដំបូលផ្ទះវិញចុះ ២៨កុំឱ្យខ្លាចចំពោះពួក
អ្នកដែលសំឡាប់បានតែរូបកាយ តែពុំអាចនឹងសំឡាប់ដល់
ព្រលឹងបាននោះឡើយ ស៊ូឱ្យខ្លាចព្រះអង្គ[ញ]វិញជាជាង
ដែលទ្រង់អាចនឹងធ្វើឱ្យទាំងព្រលឹង នឹងរូបកាយវិនាសទៅ
ក្នុងនរកផង ២៩តើគេមិនលក់ចាប២ថ្លៃ១លុយទេឬអី តែ
គ្មានចាបណាមួយធ្លាក់ទៅដី ឥតព្រះវរបិតានៃអ្នករាល់គ្នា
ជ្រាបឡើយ ៣០សូម្បីតែសក់ក្បាលរបស់អ្នករាល់គ្នា ក៏បាន
រាប់ទាំងអស់ដែរ[ដ] ៣១យ៉ាងនោះមិនត្រូវឱ្យខ្លាចឡើយ អ្នក
រាល់គ្នាមានដំឡៃ លើសជាងចាបជាច្រើន[ឋ] ៣២ដូច្នេះ អស់
អ្នកណាដែលទទួលថ្លែងប្រាប់ពីខ្ញុំ នៅមុខមនុស្សលោក[ឌ]
នោះខ្ញុំនឹងទទួលថ្លែងប្រាប់ពីអ្នកនោះ នៅចំពោះព្រះវរ
បិតាខ្ញុំ ដែលគង់នៅស្ថានសួគ៌ដែរ ៣៣តែអ្នក ណាដែលមិន
ព្រមទទួលស្គាល់ខ្ញុំ នៅមុខមនុស្សលោកទេនោះខ្ញុំក៏មិន
ព្រមទទួលស្គាល់អ្នកនោះ នៅចំពោះព្រះវរបិតាខ្ញុំ ដែល
គង់នៅស្ថានសួគ៌ដែរ[ឍ]។

**១០:១៦** ល លក ១០:៣ កច ២០:២៩ វ ១កថ ១៤:២០
**១០:១៧** ស មថ ៥:២២ ហ មថ ២៣:៣៤ មក ១៣:៩ កច ៥:៤០ ២២:១៩ ២៦:១១
**១០:១៨** ឡ កច ២៥:២៤–២៦
**១០:១៩** អ នក ៤:១២
**១០:២០** ក លក ១២:១១,១២ កច ៤:៨
**១០:២១** ខ មថ ១០:៣៥,៣៦ មីក ៧:៦ គ មក ១៣:១២
**១០:២២** ឃ យហ ១៥:២១ ង មថ ២៤:១៣ មក ១៣:១៣ លក ២១:១៩ វវ ២:១០
**១០:២៣** ច លក ១៧:៣០
**១០:២៤** ឆ យហ ១៣:១៦
**១០:២៥** ជ មក ៣:២២
**១០:២៦** ឈ មក ៤:២២ លក ៨:១៧
**១០:២៨** ញ អស ៨:១២,១៣ ហព ១០:៣១ **១០:៣០** ដ ១សយ ១៤:៤៥ ២សយ ១៤:១១ ១ពវ ១:៥២ លក ២១:១៨ កច ២៧:៣៤
**១០:៣១** ឋ មថ ៦:២៦ ១២:១២

**១០:១៦** មានខយោង"រម ១៦:១៩" ជាពាក្យរបស់លោកប៉ុល "ខ្ញុំចង់ឱ្យអ្នករាល់គ្នាមានប្រាជ្ញាខាងឯសេចក្តីល្អ ហើយល្ងង់ខាងឯសេចក្តីអាក្រក់វិញ"។ ហ្វូងឆ្កែចចកក្នុងព្រះគម្ពីរបកប្រែឆ្នាំ១៩៥៤ គឺ"ហ្វូងស្វាន" ជាឆ្កែព្រៃម្យ៉ាងស៊ីសាច់ជាអាហារ ។

**១០:១៧** *ពួកក្រុមជំនុំ* គឺតុលាការជាន់ទាប នៅក្រោមបង្គាប់សាលាប្រជុំ សម្រាប់ដោះស្រាយបញ្ហាតូចតាច ហើយអាចដាក់ទោស ឬវាយនឹងរំពាត់អ្នកដែលមានកំហុសតិចតួច ។ *សាលាប្រជុំ* មើលការពន្យល់ មក ១:២១ លក ២១:១២ ។

**១០:១៩** *កុំឱ្យថប់ព្រួយពីបែបនិយាយ* កុំឱ្យដូចដែលគ្រូអធិប្បាយខ្លះបានដោះសាដោយព្រោះតែខ្វះការរៀបចំសេចក្តីអធិប្បាយនោះឡើយ (លក ២១:១៤–១៥)។

**១០:២២** *អ្នកណាដែលកាន់ខ្ជាប់ ដរាបដល់ចុងបំផុត អ្នកនោះនឹងបានសង្គ្រោះ* (មើលការពន្យល់ មក ១៣:១៣)។

**១០:២៣** ព្រះបន្ទូលរបស់ព្រះយេស៊ូវត្រង់នេះ ដូចជាសំដៅទៅលើការមកដល់នៃការជំនុំជម្រះពួកយូដានៅពេលក្រុងយេរូសាឡិម និងព្រះវិហារបានបំផ្លាញនៅឆ្នាំទី៧០គ.ស ។

**១០:២៥** *បេលសេប៊ូល* មានន័យថាស្ដេចនៃអារក្ស(១២:២៤) ឈ្មោះភាសាហេព្រើរជារបៀបក្រិកគឺបាល–សេប៊ូល មានន័យថា"ស្ដេចរុយ(lord of flies)"ឬ" ព្រះលាមកសត្វ (lord of dung)"ប្រើសម្រាប់ហៅឈ្មោះសាតាំង (មើលការ ពន្យល់ ១០:៦ ២ពវ ១:២)។

**១០:២៨** *ព្រលឹង* ខ្លួនមនុស្សពិតគឺមានរូបកាយ និងព្រលឹង មានទំនាក់ទំនងយ៉ាងជិតស្និទ្ធនៅក្នុងជីវិតនេះ តែត្រូវបែកចេញពីគ្នានៅពេលអស់ជីវិត រួចមកជួបគ្នាជាថ្មីម្ដងទៀតនៅគ្រារស់ឡើងវិញ(២កថ ៥:១–១០ ភល ១:២៣–២៤)។ *ស៊ូឱ្យខ្លាចព្រះអង្គវិញជាជាង* ទ្រង់តែមួយអង្គគត់ជាអ្នកកំណត់វាសនាចុងក្រោយរបស់មនុស្សទាំងអស់ ។ *នរក* មើលការពន្យល់ ៥:២២ ។

**១០:៣៤** ក្រឡេកមើលមួយភ្លែតទៅ សំដីនេះហាក់បីដូចជាផ្ទុយទៅនឹងបទគម្ពីរ "អស ៩:៦ ថា ស្ដេចនៃមេត្រីភាព" បទគម្ពីរ លក ២:១៤ ថា សេចក្តីសុខសាន្តមាន ដល់មនុស្សនៅផែនដី" និង បទគម្ពីរ យហ ១៤:២៧ ថា សេចក្តីសុខសាន្តដែលខ្ញុំប្រគល់ឱ្យអ្នក"។ នេះជាការពិតណាស់ដែលព្រះគ្រីស្ទយាងមក ដើម្បីនាំមកនូវសេចក្តីសុខសាន្តដល់ អស់អ្នកណាដែលជឿដល់

[៣៤]កុំឱ្យស្មានថា ខ្ញុំមកនឹងតាំងឱ្យមានសេចក្ដីមេត្រីនៅផែន
ដីឡើយ ខ្ញុំមិនមែនមក ដើម្បីតាំងឱ្យមានសេចក្ដីមេត្រីទេ គឺ
ឱ្យមានដាវវិញ [៣៥]ដ្បិតខ្ញុំបានមក ដើម្បីនឹងនាំឱ្យគេទាស់នឹង
ឪពុកខ្លួន ឱ្យកូនស្រីទាស់នឹងម្ដាយ ហើយកូនប្រសាស្រីទាស់
នឹងម្ដាយក្មេក[ណ] [៣៦]ឯពួកសត្រូវរបស់អ្នកណា នោះគឺជាពួក
អ្នកនៅផ្ទះជាមួយនឹងខ្លួននោះឯង[ត] [៣៧]អ្នកណាដែលស្រ
ឡាញ់ឪពុក ឬម្ដាយជាជាងខ្ញុំ នោះមិនគួរនឹងខ្ញុំទេ ហើយ
អ្នកណាដែលស្រឡាញ់កូនប្រុស ឬកូនស្រី ជាជាងខ្ញុំ នោះក៏
មិនគួរនឹងខ្ញុំដែរ[ថ] [៣៨]អ្នកណាដែលមិនយកឈើឆ្កាងខ្លួន
មកតាមខ្ញុំ អ្នកនោះមិនគួរនឹងខ្ញុំឡើយ[1] [៣៩]អ្នក ណាដែលរក
បានជីវិតខ្លួន នោះនឹងត្រូវបាត់ជីវិតទៅ តែអ្នកណាដែល
បាត់ជីវិត ដោយយល់ដល់ខ្ញុំ អ្នកនោះនឹងបានជីវិតវិញ[ទ]។
[៤០]អ្នកណាដែលទទួលអ្នករាល់គ្នា នោះឈ្មោះថាទទួលខ្ញុំ[ធ]
ហើយអ្នកណាដែលទទួលខ្ញុំ នោះក៏ឈ្មោះថា ទទួលព្រះអង្គ
ដែលចាត់ឱ្យខ្ញុំមកដែរ[ន] [៤១]អ្នកណាដែលទទួលហោរា ពី
ព្រោះជាហោរា អ្នកនោះនឹងបានរង្វាន់ដូចជារង្វាន់របស់
ហោរា ឯអ្នកណាដែលទទួលមនុស្សសុចរិត ពីព្រោះជា
មនុស្សសុចរិត នោះនឹងបានរង្វាន់ ដូចជារង្វាន់របស់មនុស្ស
សុចរិតដែរ [៤២]អ្នកណាដែលឱ្យទឹកត្រជាក់តែ១កែវ ទៅកូន
ក្មេងតូច១នេះផឹក ពីព្រោះជាសិស្សខ្ញុំ នោះខ្ញុំប្រាប់អ្នករាល់
គ្នាជាប្រាកដថា អ្នកនោះមិនបាត់រង្វាន់ខ្លួនឡើយ[ប]។

## ព្រះយេស៊ូវ និងយ៉ូហាន–បាទីស្ទ

*១១:២–១៩ = លក ៧:១៨–៣៥*

**១១** [១]កាលព្រះយេស៊ូវបានផ្ដាំពួកសិស្សទាំង១២នាក់[ផ]រួច
ហើយ នោះទ្រង់ក៏យាងចេញពីទីនោះ ដើម្បីនឹងទៅ
បង្រៀន ហើយសំដែង ក្នុងអស់ទាំងក្រុងរបស់គេ ។

[២]រីឯយ៉ូហាន[ព]ដែលជាប់នៅក្នុងគុក[ភ] គាត់បានឮពីការ
ទាំងប៉ុន្មាន ដែលព្រះគ្រីស្ទទ្រង់ធ្វើ ហើយក៏ចាត់សិស្សគាត់
២នាក់ ឱ្យទៅទូលសួរទ្រង់ថា [៣]តើទ្រង់ជាព្រះអង្គដែលត្រូវ
យាងមកនោះ[ម] ឬត្រូវឱ្យយើងខ្ញុំចាំ១អង្គទៅទៀត [៤]ព្រះយេ
ស៊ូវទ្រង់មានបន្ទូលតបថា ចូរទៅប្រាប់យ៉ូហានពីសេចក្ដី
ទាំងប៉ុន្មានដែលអ្នកកំពុងតែឮ ហើយឃើញចុះ [៥]គឺថាមនុស្ស
ខ្វាក់បានភ្លឺ មនុស្សខ្វិនបានដើររួច មនុស្សឃ្លង់បានជាស្អាត
មនុស្សថ្លង់បានឮ មនុស្សស្លាប់បានរស់ឡើងវិញ ហើយមនុស្ស
ទាល់ក្របានឮដំណឹងល្អផង[យ] [៦]មានពរ ហើយ អ្នកណាដែល
មិនរវាតចិត្តដោយព្រោះខ្ញុំ[រ]។

[៧]កំពុងដែលអ្នកទាំង២[ល]នោះចេញទៅហើយ នោះព្រះ
យេស៊ូវទ្រង់ផ្ដើមមានបន្ទូលនឹងហ្វូងមនុស្ស ពីយ៉ូហានថា
តើអ្នករាល់គ្នាបានទៅមើលអ្វីនៅទីរហោស្ថាន[វ]បានទៅ
មើលដើមត្រែងរញ្ជួយដោយខ្យល់ឬអី [៨]តើបានទៅមើល
អ្វី បានទៅមើលមនុស្សពាក់អាវទន់ភ្លន់ឬអី មើលអស់
អ្នកដែលពាក់អាវទន់ភ្លន់ នោះសុទ្ធតែនៅក្នុងដំណាក់ស្ដេច
ទេ [៩]ចុះអ្នករាល់គ្នាបានទៅមើលអ្វី មើលហោរាឬអី[ស]
មែនហើយ ខ្ញុំប្រាប់អ្នករាល់គ្នាថា គាត់ក៏លើសជាងហោរា
ផង [១០]ដ្បិតគឺពីអ្នកនេះហើយ ដែលមានសេចក្ដីចែងទុកមក
ថា «មើល អញចាត់ទូតអញ ឱ្យទៅមុនឯង[ហ]ទូតនោះ នឹង
រៀបចំផ្លូវនៅមុខឯង »[ឡ] [១១]ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដ
ថា ក្នុងបណ្ដាមនុស្សដែលកើតពីស្ត្រីមក នោះគ្មានអ្នកណា
បានធំជាងយ៉ូហាន–បាទីស្ទទេ ប៉ុន្តែអ្នកណាដែលតូចជាង

**១០:៣២** ឱ រម ១០:៩
**១០:៣៣** ឍ មក ៨:៣៨ ២ធថ ២:១២
**១០:៣៥** ណ ខ.២១
**១០:៣៦** ត មីក ៧:៦
**១០:៣៧** ថ លក ១៤:២៦
**១០:៣៨** 1 មថ ១៦:២៤ លក ១៤:២៧
**១០:៣៩** ទ យហ ១២:២៥
**១០:៤០** ធ នក ១៦:៨ មថ ១៨:៥ កទ ៤:១៤ ន លក ៩:៤៨ ១០:១៦ យហ ១២:៤៤ ១៣:២០
**១០:៤២** ប សភ ១៤:៣១ ១៩:១៧ មថ ២៥:៤០ មក ៩:៤១ កថ ១០:៤ ហព ៦:១០
**១១:១** ផ មថ ៧:២៨
**១១:២** ព មថ ៣:១ ភ មថ ១៤:៣
**១១:៣** ម ទដ ១១៨:២៦ យហ ១១:២៧ ហព ១០:៣៧
**១១:៥** យ អស ៣៥:៤–៦ ៦១:១ មថ ១៥:៣១ លក ៤:១៨,១៩ **១១:៦** រ មថ ១៣:២១ ២៦:៣១ **១១:៧** ល មថ ៣:១ វ មថ ៣:១ **១១:៩** ស មថ ១៤:៥ ២១:២៦ លក ១:៧៦ ៧:២៦ **១១:១០** ហ យហ ៣:២៨ ឡ មឡ ៣:១ មក ១:២ លក ៧:២៧

ទ្រង់ ហើយនិងសេចក្ដីសុខសាន្ត ក្នុងចំណោមមនុស្សផងដែរ ។ មិនត្រឹមតែប៉ុណ្ណោះ លទ្ធផលនៃការយាងមករបស់ព្រះគ្រីស្ទក៏នាំមកនូវជម្លោះ ដែលមិនអាចជៀសផុតផងដែរ រវាងកូនព្រះគ្រីស្ទ និងកូនអារក្ស ។ ជម្លោះនេះអាចកើតឡើងគ្រប់គ្នា និងគ្រប់ពេលវេលា សូម្បីតែសមាជិកនៅក្នុងគ្រួសារតែមួយ (ខ.៣៥–៣៦) ។

**១០:៣៨** *យកឈើឆ្កាងខ្លួនមកតាមខ្ញុំ* ជាការនិយាយអំពីឈើឆ្កាងដំបូងបង្អស់នៅក្នុងគម្ពីរដំណឹងល្អម៉ាថាយ ។ ឈើឆ្កាងជាឧបករណ៍តំណាងសេចក្ដីស្លាប់ ហើយនៅខនេះវា ជានិមិត្តរូបយ៉ាងសំខាន់នៃការប្ដេជ្ញាចិត្តធ្វើជាសាវ័ករបស់ព្រះយេស៊ូវ ទោះជាត្រូវស្លាប់ក៏ដោយ (មើលការពន្យល់ មក ៨:៣៤) ។

**១០:៤០–៤២** នៅក្នុងអំឡុងពេលមានការបៀតបៀននោះ ការទទួលអ្នកដទៃឱ្យចូលមកស្នាក់អាស្រ័យនោះ គឺជាការគ្រោះថ្នាក់ខ្លាំងដល់ខ្លួនជាម្ចាស់ផ្ទះ ។ ដូច្នេះព្រះយេស៊ូវមានព្រះបន្ទូលយ៉ាងប្រាកដថា អស់អ្នកដែលផ្ដល់កន្លែង និងសំដែងសេចក្ដីសប្បុរសដល់រាស្ត្ររបស់ទ្រង់ទាំងនេះ នោះនឹងទទួលបានរង្វាន់ ។

**១១:១** នៅខណពេលដែលសិស្សទាំង១២នាក់របស់ទ្រង់ចេញធ្វើបេសកកម្មនោះ ព្រះយេស៊ូវទ្រង់បានបន្តភារកិច្ចរបស់ទ្រង់នៅស្រុកកាលីឡេ ។

**១១:៣** *ព្រះអង្គ...យាងមក* គឺព្រះមែស៊ី ។ *ត្រូវ...១អង្គទៅទៀត* មើល លក ៧:១៩

**១១:៤** *ចូរទៅប្រាប់យ៉ូហានពីសេចក្ដីទាំងប៉ុន្មានដែលអ្នកកំពុងឮ ហើយឃើញចុះ* មើលការពន្យល់ លក ៧:២២ ។

**១១:៥** *មនុស្សឃ្លង់* មើលការពន្យល់ លវ ១៣:២ ។ *មនុស្សទាល់ក្របានឮដំណឹងល្អ* មើលការពន្យល់ លក ៧:២២ ។

**១១:៦** *អ្នកណាដែលមិនរវាតចិត្ត* មើលការពន្យល់ លក ៧:២៣ ។

**១១:១១** *ធំជាងគាត់* លោកយ៉ូហានរស់នៅក្នុងយុគសម័យសញ្ញាចាស់ ដែលជាសម័យកាលរៀបចំផ្លូវថ្វាយព្រះគ្រីស្ទ ។ ពួកបរិសុទ្ធដែលតូចជាងគេបំផុតនៅក្នុង សញ្ញាថ្មី គឺមានឯកសិទ្ធិខ្ពស់ជាងលោក យ៉ូហាន–បាទីស្ទ ដែលគ្រាន់តែជាមិត្តរបស់កូនកំលោះ"ព្រះគ្រីស្ទ (យហ ៣:២៩) "។ ប៉ុន្តែពួកបរិសុទ្ធជាផ្នែកមួយនៃកូនក្រមុំរបស់ព្រះគ្រីស្ទ"ពួកជំនុំ (អភ ៥:២៥–២៧, ៣២) "។ ទស្សនៈមួយទៀតថា "គាត់ជាអ្នកតូចជាងគេបំផុត" ដែលមានន័យ

គេក្នុងនគរស្ថានសួគ៌ នោះធំជាងគាត់ហើយ [១២]តាំងតែពី
ក្រោយ៉ូហាន–បាទីស្ទ ដរាបដល់គ្រាឥឡូវនេះ នោះមានគេ
ខំប្រឹងចាប់បាននគរស្ថានសួគ៌ ហើយគឺជាពួកខំប្រឹងពិត
ដែលចាប់បានផង [១៣]ពីព្រោះអស់ទាំងហោរា និងក្រិត្យ
វិន័យបានទាយ ដរាបមកដល់គ្រាលោកយ៉ូហាន[អ] [១៤]ហើយ
បើសិនជាអ្នករាល់គ្នាព្រមទទួលពាក្យនេះ នោះគឺលោក
នេះហើយ ជាលោកអេលីយ៉ាដែលត្រូវមក[ក] [១៥]អ្នកណា
ដែលមាន ត្រចៀកសំរាប់ស្ដាប់ ឱ្យស្ដាប់ចុះ[ខ] [១៦]តើត្រូវឱ្យខ្ញុំ
ផ្ទៀបដំណមនុស្សនេះជាអ្វី គឺផ្ទៀបដូចជាកូន ក្មេងអង្គុយ
នៅទីផ្សារ ដែលស្រែកទៅគ្នាវាថា [១៧]យើងបានផ្លុំខ្លុយ
ឱ្យឯង តែឯងមិនបានរាំ យើងបានទួញទំនួញឱ្យឯង តែ
ឯងមិនបានយំទេ [១៨]ដ្បិតយ៉ូហានបានមកមិនស៊ី[គ]មិនផឹក[ឃ]
សោះ តែគេថា គាត់មានអារក្សចូល [១៩]ឯកូនមនុស្សបាន
មកទាំងស៊ីទាំងផឹកផង គង់តែគេថា មើលនេះជាអ្នក
ល្មោភស៊ីផឹកច្រើន ជាមិត្រសំឡាញ់របស់ពួកយកពន្ធ នឹង
មនុស្សមានបាប[ង] ប៉ុន្តែប្រាជ្ញាបានរាប់ជាត្រូវដោយផល
ដែលបង្កើត ។

## វេទនាដល់អស់អ្នកដែលមិនប្រែចិត្ត

*១១:២១–២៣ = លក ១០:១៣–១៥*

[២០]នោះទ្រង់ចាប់តាំងបន្ទោសដល់អស់ទាំងក្រុង ជាកន្លែង
ដែលទ្រង់បានធ្វើការឫទ្ធិបារមីជាច្រើន ពីព្រោះគេមិន
បានប្រែចិត្តសោះ គឺទ្រង់មានបន្ទូលថា [២១]វេទនាដល់ឯង
ខូរ៉ាស៊ីនអើយ វេទនាដល់ឯង បេតសៃដា[ច]អើយ ពីព្រោះ
ឯការឫទ្ធិបារមីដែលបានធ្វើនៅកណ្ដាលឯង បើបានធ្វើ
នៅកណ្ដាលក្រុងទីរ៉ុស នឹងស៊ីដូន[ឆ]វិញ នោះគេនឹងបាន
ប្រែចិត្តជាយូរមកហើយ ទាំងស្លៀកសំពត់ធ្មៃ ហើយ
ព្រលាំងដោយផេះផង[ជ] [២២]ប៉ុន្តែខ្ញុំប្រាប់អ្នករាល់គ្នាថា នៅ
ថ្ងៃជំនុំជំរះ ក្រុងទីរ៉ុស នឹងក្រុងស៊ីដូន នឹងទ្រាំបានងាយជា
ជាងឯងរាល់គ្នា[ឈ] [២៣]ហើយឯង កាពើណិម[ញ]អើយ ដែល
ឯងបានដំកើងឡើងស្មើនឹងស្ថានសួគ៌ហើយ ឯងនឹងត្រូវ
ទំលាក់ចុះទៅដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់វិញ[ដ] ពីព្រោះ
ឯការឫទ្ធិបារមី ដែលបានធ្វើនៅកណ្ដាលឯង បើបានធ្វើ
នៅក្រុងសូដុំមវិញ នោះក្រុងគេនឹងបានស្ថិតស្ថេរនៅដរាប
ដល់សព្វថ្ងៃនេះ [២៤]ដូច្នេះ ខ្ញុំប្រាប់ដល់អ្នករាល់គ្នាថា នៅថ្ងៃ
ជំនុំជំរះ នោះក្រុងសូដុំមនឹងទ្រាំបានងាយជាជាងឯង[ឋ] ។

## ព្រះវរបិតា និងព្រះរាជបុត្រា

*១១:២៥–២៧ = លក ១០:២១,២២*

[២៥]នៅវេលានោះ ព្រះយេស៊ូវ ទ្រង់មានបន្ទូលថា ឱព្រះ
វរបិតា ជាព្រះអម្ចាស់នៃស្ថានសួគ៌ និងផែនដីអើយ ទូល

**១១:១៣** អ លក ១៦:១៦
**១១:១៤** ក មឡ ៤:៥ មថ ១៧:១០–១៣ មក ៩:១១–១៣ លក ១:១៧ យហ ១:២១
**១១:១៥** ខ មថ ១៣:៩,៤៣ មក ៤:២៣ លក ១៤:៣៥ វវ ២:៧
**១១:១៨** គ មថ ៣:៤ ឃ លក ១:១៥
**១១:១៩** ង មថ ៩:១១
**១១:២១** ច មក ៦:៤៥ ៨:២២ លក ៩:១០ យហ ១:៤៤ ១២:២១ ឆ យអ ៣:៤ អម ១:៩ មថ ១៥:២១ មក ៣:៨ លក ៦:១៧ កច ១២:២០ ជ យណ ៣:៥–៩
**១១:២២** ឈ ខ.២៤ មថ ១០:១៥
**១១:២៣** ញ មថ ៤:១៣ ដ អស ១៤:១៣–១៥ **១១:២៤** ឋ មថ ១០:១៥

សំខាន់នៅក្នុង ១៨:៤ "អ្នកណាដែលបន្ទាបខ្លួនឱ្យដូចកូនតូចនេះ" នោះព្រះបានរាប់អ្នកនោះឱ្យធំលើសជាងយ៉ូហាន–បាទីស្ទទៅទៀត ។

**១១:១២** *មានគេខំប្រឹងចាប់បាន* ជាភាសាក្រិកត្រូវបានគេប្រើទាំងទម្រង់សកម្ម និងអកម្ម ។ នៅក្នុងទម្រង់អកម្មមានន័យថា "រងទុក្ខពីការបៀតបៀនយ៉ាងខ្លាំង"។ "ពួកខំប្រឹងពិត" ត្រូវបានគេយល់នៅក្នុងន័យបដិសេធន៍ថា "មនុស្សសាហាប់"។ ខនេះបញ្ជាក់ថា ការបៀតបៀនមាននៅបន្តរហូតចំពោះរាស្ត្ររបស់ព្រះ ។

**១១:១៣** *អស់ទាំងហោរា និងក្រិត្យវិន័យ* នៅក្នុងសញ្ញាចាស់ទាំងមូលបានថ្លែងពីការមកដល់នៃនគរព្រះ ហើយយ៉ូហានបានណែនាំម្ដងទៀតនៅទីបញ្ចប់នៃសាច់រឿង ។

**១១:១៤** *លោកនេះជាអេលីយ៉ាដែលត្រូវមក* យោងតាម "មឡ ៤:៥" បានថ្លែងថា អេលីយ៉ានឹងលេចមកម្ដងទៀតមុនថ្ងៃនៃព្រះអម្ចាស់ ដូច្នេះហើយបានជាអ្នកខ្លះសួរថា តើលោកជាអេលីយ៉ាឬ? គាត់ឆ្លើយថា ខ្ញុំមិនមែនទេ! យហ ១:២១ យ៉ូហានមិនមែន ជាអេលីយ៉ាមកចាប់ជាតិនោះទេ តែតាមរយៈគាត់បានធ្វើឱ្យសេចក្តីទំនាយបាន សម្រេច (មើល មថ ១៧: ១០–១៣ និងការពន្យល់ លក ១:១៧)។

**១១:១៦** *ដូចជាកូនក្មេងអង្គុយនៅទីផ្សារ* មើលការពន្យល់ លក ៧:៣២ ។

**១១:១៧** *ផ្លុំខ្លុយ* គឺផ្លុំក្នុងពិធីរៀបការ ។ *ទួញទំនួញ* ធ្វើក្នុងពិធីបុណ្យសពហើយការថ្លែងសេចក្តីនេះ ជានិមិត្តរូបនៃកិច្ចការរបស់លោកយ៉ូហាន និងការចាប់ផ្ដើមរបស់ព្រះយេស៊ូវ ។ ពួកយូដាដូចជាកូនក្មេងដែលបដិសេធមិនព្រមទទួលឱកាសនេះ ។

**១១:១៩** *កូនមនុស្ស* មើលការពន្យល់ មក ៨:៣១ ។ *ប្រាជ្ញាបានរាប់ជាត្រូវដោយផលដែលបង្កើត* គឺជាការសំដែងចេញយ៉ាងច្បាស់ថាព្រះអម្ចាស់ទ្រង់បានបញ្ជូន លោកយ៉ូហាន និងព្រះយេស៊ូវមកដោយមានតួនាទីច្បាស់លាស់ ហើយបញ្ជាក់ថាអ្វី ដែលយ៉ូហាន និងព្រះយេស៊ូវធ្វើនោះត្រឹមត្រូវ (មើលការពន្យល់ លក ៧:៣៥)។

**១១:២១** *ខូរ៉ាស៊ីន* មានតែ២ដងគត់ក្នុងព្រះគម្ពីរ (នៅទីនេះនិង លក ១០:១៣) គឺជាទីក្រុងមួយដែលមានទីតាំងនៅក្បែរសមុទ្រកាលីឡេ និងមានចម្ងាយប្រហែល ជា៣,២គ.មភាគខាងជើងពីក្រុងកាពើណិម ។ *បេតសៃដា* គឺជាទីប្រជុំជនមួយនៅ ទិសឦសាននៃឆ្នេរសមុទ្រកាលីឡេ ។ ស្ដេចភីលីព–អនុរាជបានកសាងក្រុងបេតសៃដានេះឡើងវិញ ហើយបានប្ដូរឈ្មោះពីក្រុងបេត–សៃដាមកដាក់ឈ្មោះថា ទីក្រុង"យូលៀ (Julias)"វិញ ដើម្បីឧទ្ទិសថ្វាយកិត្តិយសដល់បុត្រីស្ដេចសេសា អូគូស ដែលនាមថា "ព្រះនាងយូលៀ"។ *ទីរ៉ុស និងស៊ីដូន* ជាទីក្រុងដែលស្ថិត នៅតាមបណ្ដោយឆ្នេរភេនីស (Phoenician coast) ភាគខាងជើងនៃទឹកដី បរិសុទ្ធ (មើល ការពន្យល់ មក ៧:៣១)។ *ផេះ និងសំពត់ធ្មៃ* វត្ថុទាំងពីរ នៅត្រង់ចំណុចនេះគឺជានិមិត្តសញ្ញានៃការប្រែចិត្ត (មើល វវ ៦:១២ និងការ ពន្យល់ លប ៣៧:៣៤)។

**១១:២៣** *កាពើណិម* មើលការពន្យល់ លក ១០:១៥ ។

**១១:២៥** *សេចក្តីទាំងនេះ* ប្រហែលរួមបញ្ចូលទាំងការយល់ដឹងអំពីបេសកកម្មរបស់ព្រះយេស៊ូវ ។ *ពួកអ្នកប្រាជ្ញ និងពួកអ្នកឈ្លាសវៃ* គឺគ្រូក្រឹត្យវិន័យ និង

បង្គំសរសើរដល់ទ្រង់[ឱ] ដោយព្រោះទ្រង់លាក់សេចក្ដីទាំង
នេះនឹងពួកអ្នកប្រាជ្ញ ហើយនិងពួកឈ្លាសវៃ តែបានសំដែង
ឱ្យពួកកូនក្មេងយល់វិញ[ឃ] ២៦ហ្នឹងហើយ ព្រះវរបិតាអើយ
ដ្បិតទ្រង់បានសព្វព្រះហឫទ័យយ៉ាងដូច្នោះ ២៧គ្រប់សេចក្ដី
ទាំងអស់បានប្រគល់មកខ្ញុំ[ណ]ពីព្រះវរបិតា[ត]នៃខ្ញុំ ហើយគ្មាន
អ្នកណាស្គាល់ព្រះរាជបុត្រាទេ មានតែព្រះវរបិតាតែ១ ក៏គ្មាន
អ្នកណាស្គាល់ព្រះវរបិតាដែរ មានតែព្រះរាជបុត្រា ហើយ
នឹងអ្នកណា ដែលព្រះរាជបុត្រាសព្វព្រះហឫទ័យចង់បើក
ឱ្យស្គាល់ទ្រង់ផងប៉ុណ្ណោះ ។

## ទីសម្រាករបស់អ្នកនឿយព្រួយ

២៨អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯ
ខ្ញុំ[ថ] ខ្ញុំនឹងឱ្យអ្នករាល់គ្នាឈប់សំរាក[ទ] ២៩ចូរទទួលនឹមខ្ញុំ
ហើយរៀននឹងខ្ញុំចុះ[ធ]ដ្បិតខ្ញុំស្លូត ហើយមានចិត្តសុភាព នោះ
អ្នករាល់គ្នានឹងបានសេចក្ដីសំរាកដល់ព្រលឹង[ន] ៣០ពីព្រោះ
នឹមខ្ញុំងាយទេ ហើយបន្ទុកខ្ញុំក៏ស្រាល[ប]។

## ព្រះអម្ចាស់មានអំណាចលើថ្ងៃឈប់សម្រាក

*១២:១–៨ = មក ២:២៣–២៨ លក ៦:១–៥*

*១២:៩–១៤ = មក ៣:១–៦ លក ៦:៦–១១*

**១២** ១នៅគ្រានោះ ព្រះយេស៊ូវទ្រង់យាងកាត់ស្រែនៅថ្ងៃ
ឈប់សំរាក ឯពួកសិស្សទ្រង់គេឃ្លាន ហើយគេចាប់បូតគួរ
ស្រូវ[ផ]បរិភោគទៅ ២ពួកផារិស៊ីក៏ឃើញ ហើយគេទូលទ្រង់
ថា មើលន៎ សិស្សលោកធ្វើអំពើ ដែលគ្មានច្បាប់ធ្វើ នៅថ្ងៃ
ឈប់សំរាកហើយ[ព] ៣តែទ្រង់មានបន្ទូលតបថា តើអ្នក
រាល់គ្នាមិនដែលមើលរឿង ពីការដែលហ្លួងដាវីឌទ្រង់ធ្វើ
ក្នុងកាលដែលទ្រង់ នឹងពួកអ្នកនៅជាមួយបានឃ្លានទេឬ
អី[ភ] ៤គឺដែលទ្រង់បានយាងចូលទៅក្នុងដំណាក់ព្រះ ហើយ
បានសោយនំបុ័ងតាំងទុក ដែលគ្មានច្បាប់ឱ្យទ្រង់សោយ
ឬពួកដែលនៅជាមួយនឹងទ្រង់ផង ជារបស់ទុកសំរាប់
តែពួកសង្ឃ[ម]ប៉ុណ្ណោះ ៥ឬ អ្នករាល់គ្នាមិនបានមើលក្នុង
ក្រិត្យវិន័យទេឬអីថា នៅថ្ងៃឈប់សំរាកនោះពួកសង្ឃ
នៅក្នុងព្រះវិហារ ក៏ប្រព្រឹត្តរំលងច្បាប់នៃថ្ងៃឈប់សំរាក[យ]
ឥតមានទោសវិញ ៦ប៉ុន្តែខ្ញុំប្រាប់អ្នករាល់គ្នាថា នៅទីនេះ
មាន១អង្គ ដែលវិសេសជាងព្រះវិហារទៅទៀត[រ] ៧បើអ្នក
រាល់គ្នាបានយល់ន័យសេចក្ដីដែលថា « អញចង់បានសេចក្ដី
មេត្តាករុណា មិនមែនយញ្ញបូជាទេ » [ល]នោះអ្នករាល់គ្នាមិន
បានបន្ទោស ដល់ពួកអ្នកដែលគ្មានទោសឡើយ ៨ដ្បិតកូន
មនុស្ស[វ]ជាម្ចាស់លើថ្ងៃ ឈប់សំរាកដែរ។

៩ទ្រង់ក៏យាងចេញពីទីនោះ ចូលទៅក្នុងសាលាប្រជុំរបស់
គេ ១០នោះឃើញមនុស្សម្នាក់មានដៃស្វិត ហើយគេទូលសួរ
ទ្រង់ថា តើមានច្បាប់នឹងប្រោសឱ្យជា នៅថ្ងៃឈប់សំរាក
បានឬទេ[ស] នេះគឺដើម្បីឱ្យតែបានរឿងចោទប្រកាន់ទ្រង់
ប៉ុណ្ណោះ[ហ] ១១តែទ្រង់ឆ្លើយថា បើអ្នកណា ក្នុងពួកអ្នករាល់
គ្នាមានចៀមតែ១ ហើយចៀមនោះធ្លាក់ទៅក្នុងរណ្ដៅ នៅ
ថ្ងៃឈប់សំរាក នោះតើមិនទៅចាប់ស្រង់វាមកទេឬអី[ឡ]
១២ឯមនុស្ស តើមានតំឡៃលើសជាងចៀមអម្បាលម៉ានទៅ
ទៀត[អ] ដូច្នេះ មានច្បាប់ឱ្យធ្វើការល្អនៅថ្ងៃឈប់សំរាកដែរ
១៣រួចទ្រង់មានបន្ទូលទៅមនុស្សនោះថា ចូរលាតដៃអ្នក
ទៅ គាត់ក៏លាត ហើយដៃនោះបានជា ដូចដៃម្ខាង ។
១៤កាលពួកផារិស៊ីបានចេញទៅក្រៅ គេក៏ពិគ្រោះគ្នារក
ហេតុនឹងធ្វើឱ្យទ្រង់វិនាស[ក]។

## អ្នកបម្រើដែលព្រះរើសតាំង

១៥តែកាលព្រះយេស៊ូវបានជ្រាប នោះទ្រង់យាងថយ
ចេញពីទីនោះ មានទាំងមនុស្សកកកុញដើរតាមទ្រង់ទៅ
ហើយទ្រង់ក៏ប្រោសគេឱ្យជាគ្រប់គ្នាដែរ[ខ] ១៦ទ្រង់ហាមផ្តាច់

**១១:២៥** ឱ មថ ១៦:១៧ លក ២២:៤២ ២៣:៣៤ យហ ១១:៤១ ១២:២៧,២៨ ឃ មថ ១៣:១១ ១កថ ១:២៦–២៩ **១១:២៧** ណ មថ ២៨:១៨ ត យហ ៣:៣៥ យហ ១០:១៥ ១៧:២៥,២៦ **១១:២៨** ថ យហ ៧:៣៧ ទ នក ៣៣:១៤ **១១:២៩** ធ យហ ១៣:១៥ ភល ២:៥ ១ពត ២:២១ ១យហ ២:៦ ន ទដ ១១៦:៧ យរ ៦:១៦ **១១:៣០** ប ១យហ ៥:៣ **១២:១** ផ ចទ ២៣:២៥ **១២:២** ព ខ.១០ នក ២០:១០ ២៣:១២ ចទ ៥:១៤ លក ១៣:១៤ ១៤:៣ យហ ៥:១០ ៧:២៣ ៩:១៦ **១២:៣** ភ ១សយ ២១:៦ **១២:៤** ម លវ ២៤:៥,៩ **១២:៥** យ ជន ២៨:៩,១០ យហ ៧:២២,២៣ **១២:៦** រ ខ៤១,៤២ **១២:៧** ល ហស ៦:៦ មីក ៦:៦–៨ មថ ៩:១៣

**១២:៨** វ មថ ៨:២០ **១២:១០** ស ខ២ ហ មក ៣:២ ១២:១៣ លក ១១:៥៤ ១៤:១ ២០:២០ **១២:១១** ឡ លក ១៤:៥ **១២:១២** អ មថ ៦:២៦ ១០:៣១ **១២:១៤** ក លប ៣៧:១៨ ទដ ៧១:១០ មថ ២៦:៤ ២៧:១ មក ៣:៦ លក ៦:១១ យហ ៥:១៨ ៧:១,១៩ ១១:៥៣ **១២:១៥** ខ មថ ៤:២៣

ពួកផារិស៊ី ។ *ពួកកូនក្មេង* អ្នកដើរតាមព្រះយេស៊ូវដោយបន្ទាបខ្លួន ។

**១២:១** *ស្រែ* សម្រាប់ស្ទូង ឬព្រោះស្រូវ ហើយគេបានបន្សល់ស្រូវខ្លះក្នុងស្រែសម្រាប់ជនក្រីក្រ ។ *បូតគួរស្រូវ* មើលការពន្យល់ មក ២:២៣ ។

**១២:២** *ផារិស៊ី* មើលការពន្យល់ មក ២:១៦ ។ *ដែលគ្មានច្បាប់ធ្វើនៅថ្ងៃឈប់សំរាក* មើលការពន្យល់ មក ២:២៤ ។

**១២:៣** *ហ្លួងដាវីឌទ្រង់ធ្វើ* មើលការពន្យល់ មក ២:២៥។

**១២:៤** *នំបុ័ងតាំងទុក* គឺជានំបុ័ងថ្មី១២ដុំដែលត្រូវបានគេរៀបចំទុកនៅលើតុក្នុងទីលានបរិសុទ្ធនៅថ្ងៃឈប់សម្រាក ហើយនំបុ័ងដែលបានដាក់យូរមកហើយនោះ គឺសម្រាប់ពួកសង្ឃបរិភោគ(នម ២៥:៣០ លវ ២៤:៥–៩)។

**១២:៥** *ប្រព្រឹត្ត. . .សំរាក* ដោយធ្វើការងារទាក់ទងជាមួយនឹងយញ្ញបូជា។

**១២:៨** *កូនមនុស្សជាម្ចាស់លើថ្ងៃឈប់សំរាក* មើលការពន្យល់ លក ៦:៥ ។

**១២:៩** *សាលាប្រជុំ* មើលការពន្យល់ មក ១:២១ ។

**១២:១០** *ប្រោសឱ្យជា នៅថ្ងៃឈប់សំរាក* អ្នកច្បាប់ដែលជាពួកអាចារ្យ គេបានហាមឃាត់មិនឱ្យប្រោសមនុស្សដែលមានជំងឺនៅថ្ងៃឈប់សម្រាកនោះទេ លុះត្រាតែអ្នកជំងឺធ្ងន់អាចស្លាប់បានក្នុងថ្ងៃឈប់សម្រាក់នោះ តែជាក់ស្តែងបុរស ស្វិតដៃនេះ មិនមានអ្វីគ្រោះថ្នាក់ដល់ជីវិតនោះឡើយ ។

**១២:១៣** *លាតដៃអ្នកទៅគាត់ក៏លាត* បុរសស្វិតដៃនេះបានលាតដៃស្វិតរបស់គាត់បង្ហាញពីទំនាក់ទំនងគ្នារវាងជំនឿ និងអំណាចប្រោសជំងឺរបស់ព្រះយេស៊ូវ ។

**១២:១៦** *មិនឱ្យគេប្រាប់ . . . ស្គាល់ទ្រង់ឡើយ* មើលការពន្យល់ ៨:៤ ។

មិនឱ្យគេប្រាប់ឱ្យបណ្ដាមនុស្សស្គាល់ទ្រង់ឡើយ[គ] ១៧ដើម្បីឱ្យ
បានសំរេច[ឃ]តាមទំនាយ ដែលហោរាអេសាយ បានទាយ
ទុកមកថា ១៨«មើល អ្នកបំរើដែលអញបានរើសតាំង ជា
អ្នកស្ងួនភ្ងាដែលជាទីពេញចិត្តអញ[ង] អញនឹងដាក់វិញ្ញាណ
អញ ឱ្យសណ្ឋិតនៅលើទ្រង់[ច] ហើយទ្រង់នឹងថ្លែងប្រាប់ ពី
សេចក្ដីយុត្តិធម៌ ដល់សាសន៍ដទៃ ១៩ទ្រង់នឹងមិនតតាំងនឹង
គេឬស្រែកសំរែកឡើយ នឹងគ្មានអ្នកណាឮសំឡេងទ្រង់នៅ
ក្នុងផ្លូវទេ ២០ទ្រង់នឹងមិនផ្តាច់ដើមត្រែងដែលបាក់ ក៏មិន
លត់ប្រឆេះដែលនៅហុយឡើយ ទាល់តែបាននាំសេចក្ដី
យុត្តិធម៌ឱ្យមានជ័យជំនះ ២១ហើយអស់ទាំងសាសន៍ដទៃនឹង
មានសេចក្ដីសង្ឃឹម ដោយនូវឈ្មោះទ្រង់»[ឆ]។

## ព្រះយេស៊ូវ និងបេលសេប៊ូល

*១២:២៥–២៩ = មក ៣:២៣–២៧ លក ១១:១៧–២២*

២២នោះគេនាំមនុស្សម្នាក់មានអារក្សចូល ដែលខ្វាក់ ហើយ
គ មកឯទ្រង់ ទ្រង់ក៏ប្រោសឱ្យបានជា គឺឱ្យមនុស្សខ្វាក់ ហើយ
គនោះ បានទាំងនិយាយ ហើយមើលឃើញផង[ជ] ២៣ឯហ្វូង
មនុស្សគេមានសេចក្ដីអស្ចារ្យទាំងអស់គ្នា ក៏និយាយគ្នាថា
អ្នកនេះ តើមិនមែនជាព្រះវង្សហ្លួងដាវីឌនោះទេឬ អី[ឈ]
២៤តែកាលពួកផារិស៊ីបានឮពាក្យនោះ គេក៏ឆ្លើយឡើងថា
មនុស្សនេះដេញអារក្សបាន[ញ] ដោយសារតែបេលសេ–
ប៊ូល[ដ]ជាមេអារក្សទេ ២៥ប៉ុន្តែព្រះយេស៊ូវទ្រង់ជ្រាបគំនិត
គេ[ឋ] ក៏មានបន្ទូលថាអស់ទាំងនគរណាដែលបែកទាស់តែ
គ្នាឯង នោះនឹងត្រូវវិនាសទៅ ហើយអស់ទាំងក្រុងណា ឬ
ផ្ទះណាដែលបែកទាស់តែគ្នាឯង នោះនឹងនៅស្ថិតស្ថេរពុំ
បានទេ ២៦ដូច្នេះ បើអារក្ស[ឌ]ដេញអារក្ស នោះមុខជាវា
បែកទាស់គ្នាវាហើយយ៉ាងនោះ ធ្វើដូចម្តេចឱ្យរាជ្យវាស្ថិត
ស្ថេរនៅបាន ២៧មួយទៀត បើខ្ញុំដេញអារក្ស ដោយអាង
បេលសេប៊ូល[ឍ] ពិត នោះតើកូន[ណ]របស់អ្នករាល់គ្នាដេញ
អារក្ស ដោយសារអ្វីវិញ ដូច្នេះ វានឹងធ្វើជាចៅក្រុមជំនុំ
ជំរះអ្នករាល់គ្នាហើយ ២៨ប៉ុន្តែបើសិនជាខ្ញុំដេញអារក្សដោយ
សារព្រះវិញ្ញាណនៃព្រះវិញ នោះឈ្មោះថា នគរព្រះ[ត]បាន
មកដល់អ្នករាល់គ្នាហើយ ២៩ឬធ្វើដូចម្តេចឱ្យអ្នកណាចូល
ទៅក្នុងផ្ទះ នៃមនុស្សខ្លាំងពូកែ នឹងប្លន់យកទ្រព្យសម្បត្តិ
របស់គេបាន វៀរតែចងអ្នកខ្លាំងពូកែនោះជាមុនសិន នោះ
ទើបនឹងប្លន់ផ្ទះរបស់គេបាន ៣០អ្នកណាដែលមិននៅខាង
ខ្ញុំ អ្នកនោះទាស់នឹងខ្ញុំ ហើយអ្នកណាដែលមិនប្រមូលមក
ខាងខ្ញុំ អ្នកនោះជាអ្នកកំចាត់កំចាយវិញ[ថ] ៣១ហេតុនេះបាន
ជាខ្ញុំប្រាប់អ្នករាល់គ្នាថា អស់ទាំងបាប ហើយពាក្យប្រមាថ
នឹងអត់ទោសឱ្យមនុស្សលោកបាន តែឯពាក្យប្រមាថដល់ព្រះ
វិញ្ញាណវិញ នោះមិនដែលបានអត់ទោស ដល់មនុស្ស
ឡើយ[ទ] ៣២អ្នកណាដែលពោលពាក្យទាស់នឹងកូនមនុស្ស
នោះនឹងអត់ទោសឱ្យបាន តែអ្នកណាដែលពោលទាស់
នឹងព្រះវិញ្ញាណបរិសុទ្ធ នោះនឹងអត់ទោសឱ្យពុំបានឡើយ
ទោះនៅនាលោកីយ[ធ]នេះ ឬនៅបរលោកនាយក្តី[ន] ៣៣ត្រូវតែ
រាប់ថា ដើមឈើល្អ ផ្លែវាក៏ល្អ ឬថាដើមឈើអាក្រក់
ហើយផ្លែវាក៏អាក្រក់ដែរ ដ្បិតគេស្គាល់ដើមឈើ ដោយ
សារផ្លែវា[ប] ៣៤ពូជពស់វែក[ផ]អើយ ដែលអ្នករាល់គ្នា
អាក្រក់ម្ល៉េះ តើធ្វើដូចម្តេចនឹងឱ្យអ្នករាល់គ្នាពោលសេចក្ដី
ល្អបាន ពីព្រោះមាត់តែងនិយាយ តាមសេចក្ដីបរិបូរដែល
នៅក្នុងចិត្ត[ព] ៣៥ធម្មតាមនុស្សល្អ តែងបញ្ចេញសេចក្ដី
ល្អ អំពីកំណប់ដ៏ល្អដែលបានកប់ទុកក្នុងចិត្ត ឯមនុស្សអាក្រក់
វិញ គេក៏បញ្ចេញសេចក្ដីអាក្រក់អំពីកំណប់អាក្រក់របស់
គេដែរ ៣៦ហើយខ្ញុំប្រាប់អ្នករាល់គ្នាថា នៅថ្ងៃជំនុំជំរះ នោះ
មនុស្សលោកនឹងត្រូវរៀបរាប់ប្រាប់ ពីអស់ទាំងហេតុនៃ

**១២:១៦** គ មថ ៨:៤
**១២:១៧** ឃ មថ ១:២២
**១២:១៨** ង មថ ៣:១៧
ច យហ ៣:៣៤
**១២:២១** ឆ អស ៤២:១–៤
**១២:២២** ជ មថ ៤:២៤
**១២:២៣** ឈ មថ ៩:២៧
**១២:២៤** ញ មថ ៩:៣៤
ដ មក ៣:២២
**១២:២៥** ឋ មថ ៩:៤
**១២:២៦** ឌ មថ ៤:១០
**១២:២៧** ឍ ខ.២៤
ណ កច ១៩:១៣
**១២:២៨** ត មថ ៣:២
**១២:៣០** ថ មក ៩:៤០
លក ១១:២៣
**១២:៣១** ទ មក ៣:២៨,២៩ លក ១២:១០
**១២:៣២** ធ ទត ២:១២
ន មក ១០:៣០
លក ២០:៣៤,៣៥
អភ ១:២១
ហព ៦:៥
**១២:៣៣** ប មថ ៧:១៦,១៧
លក ៦:៤៣,៤៤
**១២:៣៤** ផ មថ ៣:៧ ២៣:៣៣
ព មថ ១៥:១៨
លក ៦:៤៥

**១២:១៨–២១** នៅត្រង់នេះម្តងទៀតហើយដើម្បីឱ្យបានសម្រេចតាមបទទំនាយ (មើលការពន្យល់ ១:២២)។ មួយនេះគឺជាចម្រៀងដំបូងរបស់លោកអេសាយ (៤២:១–៤) ហើយនេះជាការដកស្រង់វែងជាងគេមួយក្នុងដំណឹងល្អម៉ាថាយពីគម្ពីរសញ្ញាចាស់ ដែលសង្ខេបពីភារកិច្ចយ៉ាងស្ងៀមស្ងាត់នៃអ្នកបម្រើព្រះអម្ចាស់ ដោយនាំមកនូវយុត្តិធម៌ក្តីសង្ឃឹមដល់មនុស្ស ។

**១២:១៨** *អ្នកបំរើដែលអញ* ព្រះយេស៊ូវត្រូវបានហៅថាអ្នកបម្រើព្រះមានតែនៅទីនេះ និង កច ៣:១៣ (មើលការពន្យល់) ខ.២៦ ៤:២៧,៣០ ។ *ជាអ្នកស្ងួនភ្ងា . . . ចិត្តអញ* មើលការពន្យល់ ៣:១៧ ។ *អញនឹងដាក់វិញ្ញាណអញឱ្យសណ្ឋិតនៅលើទ្រង់* មើលការពន្យល់ អស ១១:២ ៦១:១ ។

**១២:២០** ព្រះយេស៊ូវកែជីវិតជាថ្មី មើលខ.១៥ យហ ៤:៤–៤២ ៨:៣–១១ ។

**១២:២៣** *ព្រះវង្សហ្លួងដាវីឌ* មើលការពន្យល់ ៩:២៧ ។

**១២:២៤** *បេលសេប៊ូល* មើលការពន្យល់ ១០:២៥ ។

**១២:២៨** *នគរព្រះ* មើលការពន្យល់ ៣:២។

**១២:៣១** *ប្រមាថដល់ព្រះវិញ្ញាណ* នោះមិនដែលបានអត់ទោសឡើយ អត្ថបទនៅក្នុង"ខ.២៤,២៨,៣២" ណែនាំថាបាបដែលមិនអាចអត់ទោសឱ្យបាននោះ គឺការបង្ករឡើងដោយសាតាំង ។ ព្រះយេស៊ូវទ្រង់សំដែងសេចក្តីពិត និងការអស្ចារ្យ ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ (មើលការពន្យល់ មក ៣:២៩) ។

ពាក្យឥតប្រយោជន៍ ដែលគេបាននិយាយ ៣៧ដ្បិតអ្នកនឹង
បានរាប់ជាសុចរិត ដោយសារពាក្យសំដីរបស់ខ្លួន ឬនឹងត្រូវ
ទោស ក៏ដោយសារតែពាក្យសំដីនោះដែរ[ភ] ។

## ទីសំគាល់ពីលោកយ៉ូណាស

*១២:៣៨–៤២ = លក ១១:២៩–៣២*

*១២:៤៣–៤៥ = លក ១១:២៤–២៦*

៣៨គ្រានោះ ពួកអាចារ្យ នឹងពួកផារិស៊ីខ្លះ គេទូលទ្រង់ថា
លោកគ្រូ យើងខ្ញុំចង់ឃើញទីសំគាល់[ម]ពីលោក[យ] ៣៩តែ
ទ្រង់មានបន្ទូលតបថា ដំណមនុស្សអាក្រក់ ហើយកំផិត គេ
ចេះតែចង់ឃើញទីសំគាល់ តែនឹងគ្មានទីសំគាល់ណាបាន
ប្រទានមកគេ ក្រៅពីទីសំគាល់របស់ហោរាយ៉ូណាស[រ]
ឡើយ ៤០ដ្បិតដែលលោកយ៉ូណាសបាននៅក្នុងពោះត្រីធំ[ល]
អស់៣ថ្ងៃ៣យប់យ៉ាងណា កូនមនុស្ស[វ]ក៏នឹងនៅក្នុងផ្ទៃផែន
ដី[ស]៣ថ្ងៃ ៣យប់យ៉ាងនោះដែរ ៤១ឯមនុស្សនៅក្រុងនីនីវេ[ហ]
នឹងឈរឡើងជាមួយនឹងមនុស្សដំណនេះ ក្នុងគ្រាជំនុំជំរះ
ហើយនិងកាត់ទោសឱ្យផង ដ្បិតគេបានប្រែចិត្ត ដោយឮ
សេចក្តីដែលលោកយ៉ូណាស[ឡ] បានប្រកាសប្រាប់ ហើយ
មើល នៅទីនេះមាន១អង្គ ដែលវិសេសជាងលោកយ៉ូណាស
ទៅទៀត ៤២មហាក្សត្រីនៅស្រុកខាងត្បូង នឹងឈរឡើងជា
មួយនឹងមនុស្សដំណនេះក្នុងគ្រាជំនុំជំរះ ហើយនឹងកាត់
ទោសឱ្យផង ដោយព្រះនាងបានយាងមក[អ]ពីចុងផែនដី
ដើម្បីនឹងស្តាប់ចំណេះរបស់ហ្លួងសាឡូម៉ូន ហើយមើល នៅ
ទីនេះមាន១អង្គវិសេសជាងហ្លួងសាឡូម៉ូនទៅទៀត ។
៤៣កាលណាអារក្សអសោចិ៍បានចេញពីមនុស្សទៅហើយ
នោះវាដើរចុះឡើង នៅកន្លែងហួតហែង ដើម្បីរកទីឈប់
សំរាក តែរកមិនបានសោះ ៤៤នោះវាគិតថា អញនឹងត្រឡប់
ទៅឯផ្ទះអញ ដែលទើបនឹងចេញមកនោះ រួចកាលវាមក
ដល់ ឃើញផ្ទះនៅទំនេរ បោសស្អាត ហើយតុបតែងយ៉ាងល្អ
៤៥នោះវាចេញទៅនាំយកអារក្ស៧ទៀត ដែលកាចៗជាង
វា មកជាមួយផង ក៏នាំគ្នាចូលទៅនៅទីនោះ ហើយសណ្ឋាន
ក្រោយរបស់មនុស្សនោះ បានអាក្រក់ជាងមុនទៅទៀត[ក] ឯ
មនុស្សដំណអាក្រក់នេះ គេនឹងបានដូច្នោះដែរ ។

## មាតា និងប្អូនរបស់ព្រះយេស៊ូវ

*១២:៤៦–៥០ = មក ៣:៣១–៣៥ លក ៨:១៩–២១*

៤៦កាលទ្រង់កំពុងតែមានបន្ទូលនឹងហ្វូងមនុស្សនៅឡើយ
នោះមាតា[ខ] និងពួកប្អូន[គ]ទ្រង់ក៏ឈរពីខាងក្រៅរកទូលនឹង
ទ្រង់ ៤៧មានម្នាក់ទូលទ្រង់ថា មើលន៍ ម្តាយ នឹងប្អូនលោក
ឈរនៅខាងក្រៅចង់និយាយនឹងលោក ៤៨តែទ្រង់ឆ្លើយ
ទៅអ្នកដែលទូលនឹងទ្រង់ថា តើអ្នកណាជាម្តាយ ហើយជា
ប្អូនខ្ញុំ ៤៩រួចទ្រង់លាតព្រះហស្ត ចង្អុលទៅពួកសិស្ស
ដោយបន្ទូលថា នុ៎ះន៏ ម្តាយ ហើយនិងប្អូនខ្ញុំ ៥០ដ្បិតអ្នកណា
ដែលធ្វើតាមព្រះហឫទ័យនៃព្រះវរបិតាខ្ញុំ ដែលគង់នៅ
ស្ថានសួគ៌[ឃ] គឺអ្នកនោះហើយ ជាប្អូនប្រុសស្រី ហើយជាម្តាយ
ខ្ញុំវិញ ។

## រឿងប្រៀបប្រដូចអំពីអ្នកព្រោះពូជ

*១៣:១–១៥ = មក ៤:១–១២ លក ៨:៤–១០*

*១៣:១៦,១៧ = លក ១០:២៣,២៤*

*១៣:១៨–២៣ = មក ៤:១៣–២០ លក ៨:១១–១៥*

**១៣** ១នៅថ្ងៃនោះ ព្រះយេស៊ូវទ្រង់យាងចេញពីផ្ទះ[ង] ទៅ
គង់នៅមាត់សមុទ្រ ២នោះមានមនុស្សប្រជុំគ្នា មកឯទ្រង់
ណែនណាន់ ដល់ម៉្លេះបានជាទ្រង់យាងចុះទៅគង់ក្នុងទូក
វិញ[ច] ហើយមនុស្សទាំងអស់គ្នាឈរនៅលើមាត់ច្រាំង ៣ទ្រង់
មានបន្ទូលទៅគេ ជាពាក្យប្រៀបប្រដូចអំពីរឿងជាច្រើន

**១២:៣៧** ភ យប ១៥:៦ សភ ១០:១៤ ១៨:២១ យក ៣:២
**១២:៣៨** ម យហ ២:១១ ៤:៤៨ យ មថ ១៦:១ មក ៨:១១,១២ លក ១១:១៦ យហ ២:១៨ ៦:៣០ ១កថ ១:២២
**១២:៣៩** រ មថ ១៦:៤ លក ១១:២៩
**១២:៤០** ល យណ ១:១៧ វ មថ ៨:២០ ស មថ ១៦:២១
**១២:៤១** ហ យណ ១:២ ឡ យណ ៣:៥
**១២:៤២** អ ១ពវ ១០:១ ២រប ៩:១
**១២:៤៥** ក ២ពត ២:២០
**១២:៤៦** ខ មថ ១:១៨ ២:១១,១៣,១៤,២០ លក ១:៤៣ ២:៣៣,៣៤,៤៨,៥១ យហ ២:១,៥ ១៩:២៥,២៦ គ មថ ១៣:៥៥ យហ ២:១២ ៧:៣,៥ កច ១:១៤ ១កថ ៩:៥ កទ ១:១៩
**១២:៥០** ឃ មថ ៦:១០ យហ ១៥:១៤
**១៣:១** ង ខ៣៦ មថ ៩:២៨ **១៣:២** ច លក ៥:៣ **១៣:៨** ឆ លប ២៦:១២
**១៣:៩** ជ មថ ១១:១៥

---

**១២:៣៨** *ទីសំគាល់* ពួកផារិស៊ីចង់ឃើញទីសំគាល់ដ៏ធំមួយនៅលើមេឃ (លក ១១: ១៦) ដែលសំដែងឱ្យដឹងថា ព្រះយេស៊ូវជាព្រះមែស៊ី ។ ផ្ទុយទៅវិញ ទ្រង់ថ្លែងប្រាប់ពួកគេនូវ "ទីសំគាល់" ពីប្រវត្តិសាស្ត្រដែលមានរួចមកហើយវិញ (លក ១១:២៩) ។

**១២:៣៩** *កំផិត* គឺសំដៅខាងឯវិញ្ញាណ ពុំមែនខាងរូបកាយទេ ត្រង់នេះមានន័យថា ដំណរបស់ពួកគេបានក្លាយជាមនុស្សមិនស្មោះត្រង់នឹងប្តីខាងឯវិញ្ញាណ (ព្រះ) ។

**១២:៤០** *៣ថ្ងៃ៣យប់* គឺបូករួមទាំងថ្ងៃដំបូង និងថ្ងៃចុងក្រោយផងដែរ នេះ គឺជាការកំណត់ពេលវេលារបស់ពួកយូដា (លក ២៤:៤៦) ។ *ត្រីធំ* ភាសាក្រិកសំដៅលើសត្វសមុទ្រមិនចំពោះតែ "ត្រីបាឡែន" ទេ (មើលការពន្យល់ យហ ១:១៧) ។

**១២:៤១–៤២** *១អង្គដែលវិសេសជាងយ៉ូណាសទៅទៀត . . . ១អង្គវិសេសជាងហ្លួង សាឡូម៉ូនទៅទៀត* មើលការពន្យល់ លក ១១:៣១–៣២ ។

**១២:៤២** *មហាក្សត្រីនៅស្រុកខាងត្បូង* ក្នុង ១ពវ ១០:១ ព្រះនាងត្រូវបានគេហៅថា មហាក្សត្រីស្រុកសេបាជាប្រទេសមួយនៅភាគនិរតីអារ៉ាប់បច្ចុប្បន្នហៅយែម៉ែន ។

**១២:៤៣–៤៥** មើលការពន្យល់ លក ១១:២៤–២៥) ។

**១២:៤៦** *មាតា និងពួកប្អូន* មើលការពន្យល់ លក ៨:១៩) ។

**១២:៥០** *ដ្បិតអ្នកណាដែល . . . ព្រះវរបិតាខ្ញុំ* មើលការពន្យល់ មក ៣:៣៥ ។

**១៣:២** *គង់ក្នុងទូក* មើលការពន្យល់ មក ៤:១ ។

**១៣:៣–៩** មើលខ.១៨–២៣ សម្រាប់ការកាត់ស្រាយអំពីរឿងប្រៀបប្រដូច ។

**១៣:៣** *ពាក្យប្រៀបប្រដូច* ចេញពីភាសាក្រិក "ការដាក់ជិតគ្នា" មានន័យថា រឿងពីរមកផ្ទៀបនឹងគ្នា ឬការពន្យល់ដោយរូបភាពដែលព្រះយេស៊ូវបានស្រង់ពីធម្មជាតិ និងជីវិតមនុស្សពិតៗប្រចាំថ្ងៃ ។ ក្នុងដំណឹងល្អទាំងបួនមាន

ថា មើល មានអ្នកព្រោះពូជម្នាក់ចេញទៅព្រោះ ៤កំពុង
ដែលគាត់ព្រោះ នោះមានខ្លះធ្លាក់ចុះតាមផ្លូវ ហើយសត្វ
ស្លាបក៏ហើរមកចឹកស៊ីអស់ទៅ ៥មានខ្លះទៀតធ្លាក់ទៅក្នុង
កន្លែងថ្ម ដែលមានដីរាក់ពេក ស្រាប់តែដុះឡើងភ្លាម ព្រោះ
ដីមិនជ្រៅទេ ៦ប៉ុន្តែកាលថ្ងៃរះឡើង នោះក៏ក្រៀមខ្លោច
ទៅ ពីព្រោះគ្មានឫស ៧ហើយខ្លះទៀតធ្លាក់ទៅកណ្ដាល
បន្លាៗក៏ដុះឡើងខ្ទប់ជិត ៨តែមានខ្លះទៀតធ្លាក់ទៅក្នុងដីល្អ
ហើយបង្កើតផលបាន១ជា១រយ[ឆ] មួយទៀតបាន៦០ ហើយ
មួយទៀតបាន៣០ ៩អ្នកណាដែលមានត្រចៀកសំរាប់ស្ដាប់
ឱ្យស្ដាប់ចុះ[ជ] ។

១០រួចពួកសិស្សមកឯទ្រង់ទូលសួរថា ហេតុអ្វីបានជាទ្រង់
មានបន្ទូលនឹងគេ ជាពាក្យប្រៀបប្រដូចដូច្នេះ ១១ទ្រង់មាន
បន្ទូលឆ្លើយថា ពីព្រោះបានប្រទានមកអ្នក រាល់គ្នា[ឈ]
ឱ្យបានស្គាល់ការអាថ៌កំបាំងរបស់នគរស្ថាន សួគ៌[ញ] តែមិន
បានប្រទានឱ្យអ្នកទាំងនោះស្គាល់ទេ ១២ដ្បិតអ្នកណាដែល
មាន គេនឹងឱ្យទៅអ្នកនោះ ហើយអ្នកនោះនឹងមានជា
បរិបូរឡើង តែអ្នកណាដែលគ្មាន នោះគេនឹង យកទាំងអ្វីៗ
ដែលអ្នកនោះមានចេញផង[ដ] ១៣ហេតុនោះបានជាខ្ញុំនិយាយ
នឹងគេ ជាពាក្យប្រៀបប្រដូច ដ្បិតដែល គេមើលនោះមិន
ឃើញវិញ ហើយដែលគេស្ដាប់ នោះក៏ មិនឮ ហើយមិន
យល់ផង[ឋ] ។
១៤ពាក្យទំនាយរបស់ហោរាអេសាយបានសំរេច[ឌ] នៅលើ
អ្នកទាំងនោះហើយ គឺជាសេចក្ដីដែលទាយទុកមកថា
«ដែលឯងរាល់គ្នាឮ នោះនឹងឮមែន តែស្ដាប់មិនបាន
ហើយដែលឃើញ នោះនឹងឃើញមែន តែមិនយល់សោះ
១៥ព្រោះចិត្តរបស់ជនជាតិនេះបានត្រឡប់ជាស្ពឹកវិញ
គេឮដោយត្រចៀកធ្ងន់ ហើយធ្មេចភ្នែក ក្រែងមើលឃើញ
នឹងភ្នែក ស្ដាប់ឮនឹងត្រចៀក ហើយយល់ក្នុងចិត្តរួចគេប្រែ
ចិត្តហើយអញប្រោសឱ្យគេបានជា» [ឍ] ១៦តែអ្នករាល់គ្នាវិញ
ភ្នែកអ្នកមានពរហើយ ដ្បិតមើល ឃើញ ត្រចៀកអ្នកក៏ដែរ
ដ្បិតស្ដាប់ឮ[ត] ១៧ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ពីដើម
មានហោរា នឹងមនុស្សសុចរិតជាច្រើន គេចង់ឃើញ
ការដែលអ្នករាល់គ្នាឃើញ[ថ] តែមិនបានឃើញសោះ ក៏
ចង់ឮសេចក្ដីដែលអ្នករាល់គ្នាឮដែរ តែ មិនបានឮឡើយ ។
១៨ដូច្នេះ ចូរអ្នករាល់គ្នាស្ដាប់ពាក្យប្រៀបប្រដូច ពីអ្នក
ព្រោះពូជនោះ ១៩គឺកាលណាបើអ្នកណាស្ដាប់ព្រះបន្ទូលពី
នគរ[ទ] តែមិនយល់ នោះអាកំណាច[ធ]ក៏មកឆក់យកសេចក្ដី
ដែលបានព្រោះក្នុងចិត្តអ្នកនោះទៅបាត់ នេះគឺជាអ្នកដែល
បានទទួលពូជតាមផ្លូវ ២០ហើយអ្នកដែលបានទទួលពូជ
ក្នុងកន្លែងថ្ម នោះគឺជាអ្នកដែលឮព្រះបន្ទូល រួចទទួលភ្លាម
ដោយអំណរ ២១តែគ្មានចាក់ឫសនៅក្នុងខ្លួន ហើយមិននៅ
ជាប់ជាយូរប៉ុន្មានទេ លុះកាលណាកើតមានសេចក្ដីទុក្ខ
លំបាក ឬសេចក្ដីបៀតបៀនដោយព្រោះព្រះបន្ទូល នោះគេ
រសាយចិត្តចេញភ្លាម[ន] ២២ហើយអ្នកដែលបានទទួលពូជ
នៅក្នុងបន្លា នោះគឺជាអ្នកដែលឮព្រះបន្ទូល រួចសេចក្ដី
ខ្វល់ខ្វាយនៅជីវិតនេះ នឹងសេចក្ដីឆបោករបស់ទ្រព្យ
សម្បត្តិ[ប] មកខ្ទប់ព្រះបន្ទូលជាប់ មិនឱ្យពូជនោះកើតផល
ឡើយ ២៣តែអ្នកដែលទទួលពូជក្នុងដីល្អវិញ នោះគឺជាអ្នក
ដែលឮព្រះបន្ទូល ហើយយល់ ក៏បង្កើតផលផ្លែ[ផ] មួយជា១
រយ មួយជា៦០ ហើយមួយទៀតជា៣០ ។

## រឿងប្រៀបប្រដូចអំពីស្រងែ

២៤ទ្រង់មានបន្ទូល ដោយពាក្យប្រៀបប្រដូច១ទៀតថា នគរ
ស្ថានសួគ៌ប្រៀបដូច[ព]ជាថៅកែម្នាក់ ដែលព្រោះពូជល្អនៅ
ស្រែខ្លួន ២៥ប៉ុន្តែកាលមនុស្សទាំងអស់កំពុងតែដេកលក់

**១៣:១១** ឈ មថ ១១:២៥ ១៦:១៧ ១៩:១១ យហ ៦:៦៥ ១កថ ២:១០,១៤ កល ១:២៧ ១យហ ២:២០,២៧
ញ មថ ៣:២
**១៣:១២** ដ មថ ២៥:២៩
**១៣:១៣** ឋ ចទ ២៩:៤ យរ ៥:២១ អគ ១២:២
**១៣:១៤** ឌ ខ.៣៥ មថ ១:២២
**១៣:១៥** ឍ អស ៦:៩,១០ យហ ១២:៤០ កថ ២៨:២៦,២៧ រម ១១:៨
**១៣:១៦** ត មថ ១៦:១៧
**១៣:១៧** ថ យហ ៨:៥៦ ហព ១១:១៣ ១ពត ១:១០–១២
**១៣:១៩** ទ មថ ៤:២៣
ធ មថ ៥:៣៧
**១៣:២១** ន មថ ១១:៦ ២៦:៣១
**១៣:២២** ប មថ ១៩:២៣ ១ធថ ៦:៩,១០,១៧
**១៣:២៣** ផ ខ.៨
**១៣:២៤** ព ខ.៣១, ៣៣,៤៥,៤៧ មថ ១៨:២៣ ២០:១ ២២:២ ២៥:១ មក ៤:២៦,៣០

រឿងប្រដូចប្រមាណជា៣០រឿង ហើយដំណឹងល្អលោកយ៉ូហានគ្មាននោះទេ តែមានរូបភាពជាសំដី (មើលការពន្យល់ មក ៤:២ លក ៨:៤)។ *ព្រោះពូជ* មើលកាពន្យល់ លក ៨:៥ ។

**១៣:៤–៦** មើលការពន្យល់ មក ៤:៣–៨ ។

**១៣:៤** *សត្វស្លាប* គឺជាអារក្សសាតាំង"អាកំណាច"(ខ.១៩)។

**១៣:៥** *កន្លែងថ្ម* មិនមែនជាដុំថ្មតូចៗដែលក្រាលលើដីនោះទេ តែជាថ្មធំៗ ហើយរឹងដែលមានដីពីលើតិចៗ (មើលការពន្យល់ លក ៨:៦)។

**១៣:៨** *១រយ* មើលការពន្យល់ មក ៤:៨ លក ៨:៨ ។

**១៣:១០** មើលការពន្យល់ លក ៨:៩ ។

**១៣:១១** *អាថ៌កំបាំងរបស់នគរស្ថានសួគ៌* មើលការពន្យល់ មក ៤:១១ លក ៨:១០

**១៣:១៣–១៤** បានជាព្រះយេស៊ូវមានបន្ទូលពាក្យប្រៀបប្រដូច គឺព្រោះតែភាពល្ងង់ខ្លៅខាងឯវិញ្ញាណរបស់បណ្ដាជន (មើលការពន្យល់ លក ៨:៤)។

**១៣:១៣** *គេមើលនោះមិនឃើញ* មើលការពន្យល់ មក ៤:១២ លក ៨:១០

**១៣:១៨** ព្រះយេស៊ូវកម្របកស្រាយរឿងប្រៀបដូចរបស់ទ្រង់ណាស់ តែពាក្យប្រៀបប្រដូចពីអ្នកព្រោះពូជនៅត្រង់នេះ ទ្រង់បានពន្យល់ប្រាប់ ។

**១៣:១៩** *អាកំណាច* គឺអារក្សសាតាំង ។

**១៣:២៤–៣០** មើល ខ.៣៦–៤៣ សម្រាប់ការកាត់ស្រាយ ។

**១៣:២៤** *នគរស្ថានសួគ៌ប្រៀបដូច* ឃ្លានេះមាននៅក្នុងរឿងប្រៀបប្រដូច៦ ក្នុងចំណោមរឿងប្រៀបប្រដូចទាំង៧នៅក្នុងជំពូកនេះ លើកលែងតែរឿងអ្នកព្រោះពូជមួយតែប៉ុណ្ណោះ ។

**១៣:២៥** *ស្រងែ* ប្រហែលជាស្រងែមួយប្រភេទដែលមើលទៅស្រដៀងនឹងស្រូវពេលនៅខ្ចី តែក្រោយមកទើបដឹងថាខុសគ្នា ។ រឿងប្រៀបប្រដូចនេះមិនសំដៅ

នោះសត្រូវរបស់ថៅកែនោះ ក៏មកព្រោះស្រងែនៅក្នុង
ស្រូវសាលីដែរ រួចចេញបាត់ទៅ ២៦លុះពន្លកឡើង ហើយ
ស្រូវចេញ នោះស្រងែក៏លេចមកឱ្យស្គាល់ដែរ ២៧ពួកបាវ
របស់ថៅកែនោះ គេមកជំរាបថា លោកម្ចាស់ តើលោក
មិនបានព្រោះពូជល្អ នៅស្រែរបស់លោកទេឬអី ដូច្នេះ
តើស្រងែនេះកើតពីណាមក ២៨គាត់ក៏ឆ្លើយថា នោះគឺជា
ខ្មាំងសត្រូវហើយ ដែលបានធ្វើការនោះ រួចពួកបាវសួរថា
ដូច្នេះ តើលោកចង់ឱ្យយើងខ្ញុំទៅដកចេញឬទេ ២៩គាត់
ឆ្លើយថា កុំ ក្រែងកាលណាដកស្រងែចេញ នោះស្រូវ
សាលីក៏រលើងទៅដែរ ៣០ទុកឱ្យវាដុះជាមួយគ្នា ដរាបដល់
ពេលច្រូតចុះ ចាំដល់រដូវចំរូត នោះអញនឹងប្រាប់ពួកចំរូត
ថា ចូរច្រូតស្រងែសិន ហើយចងជាកណ្តាប់ ទុកសំរាប់ដុត
ឯស្រូវសាលី ឱ្យប្រមូលដាក់ក្នុងជង្រុកអញវិញ[ភ] ។

## រឿងប្រៀបប្រដូចអំពី គ្រាប់ពូជ និងដំបែ

*១៣:៣១–៣២ = មក ៤:៣០–៣២*

*១៣:៣១–៣៣ = លក ១៣:១៨–២១*

៣១ទ្រង់មានបន្ទូល ជាពាក្យប្រៀបប្រដូច១ទៀតថា
នគរស្ថានសួគ៌ប្រៀបដូច[ម]គ្រាប់ពូជ[យ]ម្យ៉ាង ដែលមនុស្ស
ម្នាក់បានយកទៅព្រោះក្នុងចំការខ្លួន ៣២គ្រាប់នេះល្អិតជាង
គ្រាប់ពូជទាំងអស់ពិតមែន តែកាលណាបានដុះឡើង នោះ
ក៏ធំជាងតិណជាតិទាំងអស់ ហើយក៏ត្រឡប់ជាដើមធំ ដល់
ម៉្លេះបានជាសត្វហើរលើអាកាស មកទំនៅលើមែកផង[រ] ។

៣៣ទ្រង់មានបន្ទូលពាក្យប្រៀបប្រដូចនេះ ឱ្យគេទៀតថា
នគរស្ថានសួគ៌ប្រៀបដូចជា[ល]ដំបែ ដែលស្ត្រីម្នាក់បានយក
មកលាយនឹងម្សៅ[វ]៣រង្វាល់ ទាល់តែម្សៅនោះបានដោរ
ឡើងគ្រប់ទាំងអស់[ស] ។

**១៣:៣០** ភ មថ ៣:១២
**១៣:៣១** ម ខ២៤ យ មថ ១៧:២០ លក ១៧:៦
**១៣:៣២** រ ទដ ១០៤:១២ អគ ១៧:២៣ ៣១:៦ ដយ ៤:១២
**១៣:៣៣** ល ខ.២៤ វ លប ១៨:៦ ស កទ ៥:៩
**១៣:៣៤** ហ យហ ១៦:២៥
**១៣:៣៥** ឡ ខ១៤ មថ ១:២២ អ ទដ ៧៨:២ រម ១៦:២៥,២៦ ១កថ ២:៧ អភ ៣:៩ កល ១:២៦
**១៣:៣៦** ក មថ ១៥:១៥
**១៣:៣៧** ខ មថ ៨:២០
**១៣:៣៨** គ យហ ៨:៤៤,៤៥ ១យហ ៣:១០
**១៣:៣៩** ឃ យអ ៣:១៣ ង មថ ២៤:៣ ២៨:២០ ច វវ ១៤:១៥
**១៣:៤១** ឆ មថ ៨:២០ ជ មថ ២៤:៣១

៣៤ព្រះយេស៊ូវទ្រង់មានបន្ទូលសេចក្តីទាំងនេះ ដោយពាក្យ
ប្រៀបធៀបដល់ហ្វូងមនុស្ស ទ្រង់មិនបានមានបន្ទូលនឹងគេ
ឥតពាក្យប្រៀបធៀបទេ[ហ] ៣៥ដើម្បីឱ្យបានសំរេច[ឡ]តាម
ទំនាយដែលហោរាបានទាយទុកមកថា«អញនឹងបើកមាត់
និយាយ ជាពាក្យប្រៀបប្រដូច អញនឹងសំដែងពីការដែល
លាក់កំបាំង តាំងពីកំណើតលោកីយមក »[អ] ។

## ការពន្យល់ពាក្យប្រៀបប្រដូចអំពីស្រងែ

៣៦នោះទ្រង់ក៏ឱ្យហ្វូងមនុស្សទៅវិញ រួចយាងចូលទៅក្នុង
ផ្ទះ ឯពួកសិស្សមកទូលទ្រង់ថា សូមអធិប្បាយឱ្យយើងខ្ញុំ
យល់ន័យពាក្យប្រៀប[ក] ពីស្មៅស្រងែនៅស្រែផង ។

៣៧ទ្រង់មានបន្ទូលឆ្លើយថា អ្នកដែលព្រោះពូជល្អ នោះ
គឺជាកូនមនុស្ស[ខ] ៣៨ចំណែកស្រែ នោះគឺជាតួលោកីយ ឯ
ពូជល្អ គឺអស់ទាំងមនុស្សរបស់នគរស្ថានសួគ៌ ហើយស្រងែ
គឺជាអស់ទាំងមនុស្សរបស់អាកំណាចវិញ[គ] ៣៩ខ្មាំងសត្រូវ
ដែលបួមព្រោះស្រងែនោះ គឺជាអារក្ស ចំរូត[ឃ]គឺជាបំផុត
កល្ប[ង] ហើយពួកច្រូតនោះ គឺជាពួកទេវតា[ច] ។

៤០ដូច្នេះ ដែលគេច្រូតស្រងែដុតបន្សុសក្នុងភ្លើងជាយ៉ាង
ណា នោះដល់បំផុតកល្បក៏នឹងបានដូច្នោះដែរ ៤១គឺកូន
មនុស្ស[ឆ]នឹងចាត់ពួកទេវតា[ជ] ទៅច្រូតយកអស់ទាំងក្បួន
ដែលនាំឱ្យមនុស្សរវាតចិត្ត នឹងពួកអ្នកដែលប្រព្រឹត្តទទឹង
ច្បាប់ពីនគរចេញ ៤២ហើយនិងបោះគេចោលទៅក្នុងគុក
ភ្លើង នៅទីនោះគេនឹងយំ ហើយសង្កៀតធ្មេញ[ឈ] ៤៣គ្រានោះ
ពួកសុចរិតនឹងភ្លឺដូចជាថ្ងៃ[ញ] នៅក្នុងនគររបស់ព្រះវរបិតា
នៃគេ អ្នកណាដែលមានត្រចៀកសំរាប់ស្តាប់ ឱ្យស្តាប់ចុះ[ដ] ។

**១៣:៤២** ឈ មថ ៨:១២ **១៣:៤៣** ញ ដយ ១២:៣ ដ មថ ១១:១៥

ចំពោះអស់អ្នកមិនជឿនៅតាមវិហារដែលគេស្គាល់ជាសាធារណៈ នោះទេ ។

**១៣:៣១–៣២** នោះមានន័យថា នគរព្រះហាក់បីដូចជាចាប់ផ្តើមឡើង ដោយតូចបំផុត តែក្រោយមកនឹងរីករាលដាលពេញផែនដីទាំងមូល ។

**១៣:៣២** *ល្អិតជាង...ធំជាងតិណជាតិ* វាជាគ្រាប់ពូជរុក្ខជាតិម្យ៉ាង តូចជាងគេបំផុតដែលពុំត្រូវបានគេស្គាល់ទៀតទេនៅសព្វថ្ងៃនេះ ។ ប៉ុន្តែ វាត្រូវបានកសិករ និងអ្នកថែសួនច្បារប្រើនៅប្រទេសប៉ាឡេស្ទីនក្នុងសម័យនោះ ។ បើអាកាសធាតុល្អរុក្ខជាតិនេះអាចមានកំពស់៣ម៉ែត្រ ។ *ដើមធំ. . . ប្រសិនលើមែកផង* គឺ និយាយដូចគ្នានឹង "ដយ ៤:២១" បង្ហាញពីនគរស្ថានសួគ៌នឹងពង្រីកអំណាចគ្រប់គ្រងលើផែនដី និងមនុស្សគ្រប់ជាតិសាសន៍ ដែលអាចនឹងស្វែងរកឃើញការសម្រាកនៅក្រោមម្លប់ដើមឈើនេះ (ដយ ២:៣៥, ៤៤–៤៥ ៧:២៧ វវ ១១:១៥)។

**១៣:៣៣** *ដំបែ* ក្នុងព្រះគម្ពីរជាទូទៅតំណាងឱ្យអ្វីៗដែលអាក្រក់ ឬមិនស្អាត (មើល ការពន្យល់ មក៨:១៥)។ ដំបែក៏តំណាងឱ្យការលូតលាស់ក្នុងខណៈដំបែជ្រាបចូលទៅក្នុងម្សៅ ដូចគ្នាទៅនឹងនគរស្ថានសួគ៌បានរីកលូតលាស់តាមរយៈជីវិតរបស់មនុស្សម្នាក់ៗ ឬអាចមានន័យថា ការរីកលូតលាស់នៃនគរស្ថានសួគ៌ គឺបណ្តាលមកពីព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុងចិត្ត(ដោយប្រើព្រះបន្ទូលព្រះ)។

**១៣:៣៥** *ទំនាយដែលហោរាបានទាយ* ដកស្រង់ចេញពី "ទដ ៧៨" ដែលលើកឡើងដោយលោកអេសាភបើផ្អែកលើ ២រប ២៩:៣០ "អ្នកទាយហេតុការណ៍ទុកមុន"។

**១៣:៣៧** *កូនមនុស្ស* មើលការពន្យល់ មក ៨:៣១ ។

**១៣:៤២** *គុកភ្លើង* បានពោលញឹកញាប់ដែលទាក់ទង់ដល់ការជំនុំជម្រះចុងក្រោយនៅទីបញ្ចប់លោកិយទាំងមូល (វវ ១៩:២០ ២០:១៤)។ *យំហើយសង្កៀតធ្មេញ* ឃ្លានេះមានចំនួន៦ដងនៅក្នុងដំណឹងល្អម៉ាថាយ (៨:១២ ១៣:៥០ ២២:១៣ ២៤:៥១ ២៥:៣០) និងគ្មានកន្លែងណាផ្សេងទៀតឡើយនៅក្នុងគម្ពីរសញ្ញាថ្មី ។

## រឿងប្រៀបប្រដូចពីកំណប់ និងកែវមុក្តា

៤៤មួយទៀត នគរស្ថានសួគ៌ក៏ប្រៀបដូចជា[ឋ]កំណប់កប់ទុក
ក្នុងចំការ ដែលកាលណាមនុស្សម្នាក់បានឃើញ នោះក៏
លាក់ទុក រួចចេញទៅ លក់របស់ទ្រព្យខ្លួនទាំងអស់ ដោយ
អំណរ ដើម្បីនឹងទិញចំការនោះ[ឌ] ។
៤៥មួយទៀត នគរស្ថានសួគ៌ក៏ប្រៀបដូចជា[ឍ]អ្នកឈ្មួញម្នាក់
ដែលរកកែវមុក្តាយ៉ាងល្អ ៤៦កាលណាបានឃើញ១ដែល
មានដំឡៃណាស់ នោះគាត់ទៅលក់របស់ទ្រព្យទាំងអស់ មក
ទិញកែវមុក្តានោះ ។

## រឿងប្រៀបប្រដូចអំពីអួន

៤៧មួយទៀត នគរស្ថានសួគ៌ក៏ប្រៀបដូចជា[ណ]អួន ដែលគេ
ទំលាក់ទៅក្នុងសមុទ្រ ជាប់បានត្រីគ្រប់មុខ[ត] ៤៨កាលបាន
ពេញហើយ នោះគេទាញឡើងមកលើគោក រួចអង្គុយ
ជ្រើសរើសត្រីល្អៗ ដាក់ក្នុងកញ្ជេទុក តែត្រីអាក្រក់ៗ
គេចាក់ចោលចេញ ៤៩ដល់ទីបំផុតកល្ប នឹងបានដូចគ្នាដែរ
គឺពួកទេវតានឹងចេញទៅញែកយកពួកទុច្ចរិតពីពួកសុចរិត
ចេញ[ថ] ៥០ហើយនិងបោះគេចោលទៅក្នុងគុកភ្លើង នៅទី
នោះ គេនឹងយំ ហើយសង្កៀតធ្មេញ[ទ] ។
៥១ព្រះយេស៊ូវទ្រង់មានបន្ទូលសួរដល់គេថា តើអ្នករាល់
គ្នាយល់សេចក្តីទាំងនេះឬទេ គេទូលឆ្លើយថា យើងខ្ញុំ
យល់ហើយ ព្រះអម្ចាស់ ។
៥២ទ្រង់ក៏មានបន្ទូលទៅទៀតថា ដូច្នេះ គ្រប់អស់ទាំង
អាចារ្យណាដែលមានគេបង្ហាត់បង្រៀន ឱ្យធ្វើជាសិស្ស
នៃនគរស្ថានសួគ៌ នោះធៀបដូចជាចៅកែម្នាក់ ដែល

**១៣:៤៤** ឋ ខ២៤ ឌ អស ៥៥:១ មថ ១៩:២១ ភល ៣:៧,៨ **១៣:៤៥** ឍ ខ២៤ **១៣:៤៧** ណ ខ២៤ ត មថ ២២:១០ **១៣:៤៩** ថ មថ ២៥:៣២ **១៣:៥០** ទ មថ ៨:១២ **១៣:៥៣** ធ មថ ៧:២៨ **១៣:៥៤** ន មថ ៤:២៣ ប ៧:២៨ **១៣:៥៥** ផ លក ៣:២៣ យហ ៦:៤២ ព មថ ១២:៤៦ ភ មថ ១២:៤៦ **១៣:៥៧** ម យហ ៦:៦១ យ លក ៤:២៤ យហ ៤:៤៤ **១៤:១** រ មក ៨:១៥ លក ៣:១,១៩ ១៣:៣១ ២៣:៧,៨ កច ៤:២៧ ១២:១ ល លក ៩:៧-៩ **១៤:២** វ មថ ៣:១ **១៤:៣** ស មថ ៤:១២ ១១:២ ហ លក ៣:១៩,២០

បញ្ចេញរបស់ទាំងថ្មីទាំងចាស់ពីឃ្លាំងរបស់ខ្លួន ។

## ហោរាឥតមានគេរាប់អាន

*១៣:៥៤-៥៨ = មក ៦:១-៦*

៥៣កាលព្រះយេស៊ូវ ទ្រង់បានមានបន្ទូលពាក្យប្រៀប
ប្រដូចទាំងនេះ[ធ]ស្រេចហើយ នោះទ្រង់ក៏យាងចេញពីទី
នោះទៅ ៥៤លុះទ្រង់ចូលមកក្នុងស្រុកទ្រង់វិញ នោះក៏
បង្រៀនគេនៅក្នុងសាលាប្រជុំ[ន] ដល់ម៉្លេះបានជាគេនឹក
ប្លែក[ប]ក្នុងចិត្ត ហើយនិយាយថា តើអ្នកនេះបានចំណេះ នឹង
ការឫទ្ធិបារមីទាំងនេះពីណាមក ៥៥តើមិនមែនជាកូន
របស់ជាងឈើទេឬអី[ផ] តើម្តាយមិនមែនឈ្មោះម៉ារា[ព]
ហើយបងប្អូនឈ្មោះ[ភ]យ៉ាកុប យ៉ូសេ ស៊ីម៉ូន ហើយនឹង
យូដាសទេឬអី ៥៦ឯប្អូនស្រី តើមិននៅជាមួយនឹងយើងទេ
ឬអី ដូច្នេះ តើបានសេចក្តីទាំងនេះពីណាមក ៥៧គេក៏
រវាតចិត្ត[ម]ចេញពីទ្រង់ តែព្រះយេស៊ូវមានបន្ទូលទៅគេថា
ហោរាមិនមែនឥតគេរាប់អានទេ លើកតែនៅក្នុងស្រុក ឬ
ក្នុងផ្ទះរបស់ខ្លួនចេញ[យ] ៥៨ទ្រង់មិនបានធ្វើការឫទ្ធិបារមី
ជាច្រើននៅទីនោះទេ ពីព្រោះគេមិនជឿ ។

## ការកាត់ក្បាលយ៉ូហាន-បាទីស្ទ

*១៤:១-១២ = មក ៦:១៤-២៩*

**១៤** ១នៅគ្រានោះ ហេរ៉ូឌ[រ] ជាស្តេចអនុរាជ ទ្រង់បានឮ
ល្បីពីព្រះយេស៊ូវ[ល] ២ទ្រង់ក៏មានបន្ទូលទៅពួកមហាតលិកថា
នោះគឺជាយ៉ូហាន-បាទីស្ទ គាត់បានរស់ពីស្លាប់ឡើងវិញ
ហើយ បានជាមានការឫទ្ធិបារមីកើតមក ដោយសារគាត់
ដូច្នេះ[វ] ៣ដ្បិតហេរ៉ូឌបានចាប់ចងយ៉ូហានដាក់ក្នុងគុក[ស]

---

**១៣:៤៤-៤៦** រឿងប្រៀបប្រដូចទាំងពីរនេះ បានបង្រៀនសេចក្តីពិតដូចគ្នាថា នគរស្ថានសួគ៌ ជាវត្ថុដែលពុំអាចកាត់ថ្លៃបាន យើងទាំងអស់គ្នាគួរតែលះបង់អ្វីៗ គ្រប់យ៉ាងដើម្បីឱ្យបានវា ។ ព្រះយេស៊ូវមិនបានមានបន្ទូលថា មនុស្សអាចទិញ ឬធ្វើការល្អដើម្បីបាននគរស្ថានសួគ៌នោះឡើយ ។

**១៣:៤៤** *កំណប់កប់ទុកក្នុងចំការ* នៅសម័យបុរាណគ្មានធនាគារទេ ដូច្នេះ វាជាការសាមញ្ញមួយ ដែលយកកំណប់ ឬរបស់មានតម្លៃទៅលាក់ទុកទោះបើមានអ្នកចងការប្រាក់ក៏ដោយ(មថ ២៥:២៧) ។

**១៣:៤៧-៥១** ពាក្យប្រៀបប្រដូចពីអួនជាមេរៀនទូទៅដូចនឹងស្រងែដែរ ថានឹងមានការបែងចែកជាពីរគឺមនុស្សសុចរិត និងមនុស្សទុច្ចរិត ។ ពាក្យប្រដូចពីស្រងែ ក៏បានបញ្ជាក់ថាយើងមិនបាច់ព្យាយាមបែងចែកនាពេលនេះទេ ទុកឱ្យព្រះអម្ចាស់ទ្រង់ជាអ្នកចាត់ចែង(ខ.២៨-៣០,៤១-៤២) ។

**១៣:៥៣** នេះជាការសរុបសេចក្តីបង្រៀនវគ្គមុនៗ ហើយបន្តចូលរឿងថ្មីមួយទៀត(៧:២៨-២៩) ។

**១៣:៥៤** *ស្រុកទ្រង់* គឺភូមិណាសារ៉ែត ។ *បង្រៀនគេនៅក្នុងសាលាប្រជុំ* មើល ការពន្យល់ មក ១:២១ ។

**១៣:៥៥** *កូនរបស់ជាងឈើ* ពាក្យ "ជាងឈើ" អាចបកប្រែបានម្យ៉ាងទៀតថា "ជាងកំបោរ" តាមភាសាក្រិកពេលនោះ លោកយ៉ូសែបប្រាកដជាមិនបាននៅក្នុងហេតុការណ៍នេះទេ ។ *បងប្អូន* គឺកូនប្រុសទាំងឡាយរបស់លោកយ៉ូសែប និងនាងម៉ារា ក្រោយពីនាងបានប្រសូតព្រះយេស៊ូវរួចហើយ (មើលការពន្យល់ លក ៨:១៩) ។

**១៣:៥៨** *មិនជឿ* ជាការបញ្ជាក់ច្រើនដងនូវទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ រវាងជំនឿ និងឫទ្ធិបារមីនៃការអស្ចារ្យ (៨:១០,១៣ ៩:២,២២,២៨-២៩) ។

**១៤:១** *អនុរាជ* អ្នកត្រួតត្រាលើផ្នែកទីបួននៃតំបន់មួយ ។ ហេរ៉ូឌអនុរាជ (ហេរ៉ូឌ-អង់ទីប៉ាស) គឺជាបុត្រាមួយក្នុងចំណោមបុត្រាជាច្រើនរបស់ស្តេចហេរ៉ូឌ ។ ក្រោយទ្រង់បានសុគត នោះអាណាចក្រទាំងមូលត្រូវកូនប្រុសទាំងបួនបំបែកចែកគ្នា ។ ហេរ៉ូឌ-អង់ទីប៉ាសគ្រប់គ្រងនៅកាលីឡេ និងពេរ៉ាស៊ី (ឆ្នាំទី៤មុនគ.ស-៣៩គ.ស) ។ លោកម៉ាថាយ និងលូកាសំដៅលើហេរ៉ូឌ-អង់ទីប៉ាសដូចគ្នា(លក ៣:១៩ ៩:៧ កច ១៣:១) ។ ក្នុងខ.៩ លោកម៉ាថាយបានហៅថា "ស្តេច"ដូចលោកម៉ាកុស(មក ៦:១៤) ព្រោះជាឈ្មោះមានប្រជាប្រិយភាពក្នុងចំណោមអ្នកស្រុកកាលីឡេ និងពួករ៉ូម៉ាំង ។

**១៤:២** *យ៉ូហាន-បាទីស្ទ . . . រស់ពីស្លាប់* មើលការពន្យល់ មក ៦:១៦ ។

**១៤:៣** *ហេរ៉ូឌាស* ជាចៅស្រីរបស់ហេរ៉ូឌ-អធិរាជ(ហេរ៉ូឌ-អធិរាជមាន

ដោយព្រោះហេរ៉ូឌាស ជាភរិយា[ហ]ភីលីព អនុជទ្រង់ ៤ពី
ព្រោះយ៉ូហានបានទូលទាស់នឹងស្ដេចថា ទ្រង់គ្មានច្បាប់
នឹងយកនាងនោះទេ[ឡ] ៥ទ្រង់ចង់សំឡាប់គាត់ណាស់ តែ
ខ្លាចហ្វូងមនុស្ស ព្រោះគេរាប់គាត់ទុកជាហោរា[អ]។
៦មានសម័យ១ ជាថ្ងៃធ្វើបុណ្យចំរើនព្រះជន្មហេរ៉ូឌ នោះ
បុត្រីហេរ៉ូឌាស នាងរាំនៅមុខពួកភ្ញៀវ ជាទីគាប់ព្រះទ័យ
ដល់ហេរ៉ូឌណាស់ ៧បានជាទ្រង់ស្បថសន្យានឹងប្រទានគ្រប់
របស់អ្វីដែលនាងនឹងសូម ៨តែមាតានាងបានបញ្ចុះឱ្យ
ទូលថា សូមប្រទានក្បាលយ៉ូហាន-បាទីស្ទ ដាក់លើថាស
មកឱ្យខ្ញុំម្ចាស់នៅទីនេះ ៩នោះស្ដេចទ្រង់ក៏ព្រួយព្រះទ័យ តែ
ដោយព្រោះសម្បថ ហើយនិងពួកភ្ញៀវបានជាទ្រង់បង្គាប់
ឱ្យគេយកក្បាលគាត់មកឱ្យនាង ១០ទ្រង់ក៏ចាត់គេឱ្យទៅកាត់
ក្បាល[ក]យ៉ូហាននៅក្នុងគុក ១១គេយកក្បាលគាត់ដាក់លើ
ថាសមកឱ្យនាង រួចនាងយកទៅថ្វាយដល់មាតា ១២នោះពួក
សិស្សយ៉ូហានក៏មកយកសពទៅកប់[ខ] រួចទៅទូលព្រះយេស៊ូវ។

## ព្រះយេស៊ូវប្រទានអាហារដល់មនុស្សប្រាំពាន់នាក់

*១៤:១៣-២១ = មក ៦:៣២-៤៤ លក ៩:១០-១៧ យហ ៦:១-១៣*

*១៤:១៣-២១ = មថ ១៥:៣២-៣៨*

១៣កាលព្រះយេស៊ូវបានឮហើយ នោះទ្រង់យាងចុះទូក
ចេញពីទីនោះ ទៅឯទីរហោស្ថានដោយឡែក រីឯពួក
បណ្ដាជនក៏បានដឹង ហើយគេចេញពីក្រុងទាំងអស់ដើរតាម
ទ្រង់ទៅ ១៤លុះទ្រង់យាងឡើងពីទូកវិញ ស្រាប់តែឃើញ
មានមនុស្សមីរដេរដាស ទ្រង់ក៏មានព្រះហឫទ័យក្ដួល
អាណិតដល់គេ[គ] ហើយទ្រង់ប្រោសមនុស្សជំងឺទាំងប៉ុន្មាន
ក្នុងពួកគេឱ្យបានជា[ឃ] ។

១៥ដល់ពេលល្ងាច ពួកសិស្សមកឯទ្រង់ទូលថា ទីនេះស្ងាត់
ណាស់ ម៉ោងក៏ជ្រុលហើយ សូមឱ្យហ្វូងមនុស្សត្រឡប់ទៅ
វិញទៅ ដើម្បីឱ្យបានទិញស្បៀងអាហារ នៅក្នុងភូមិជុំវិញ
១៦តែព្រះយេស៊ូវទ្រង់ឆ្លើយថា មិនចាំបាច់ឱ្យគេទៅទេ ចូរ
អ្នករាល់គ្នាឱ្យគេបរិភោគទៅ ១៧ពួកសិស្សក៏ទូលទ្រង់ថា
នៅទីនេះយើងខ្ញុំគ្មានអ្វីទេ មានតែនំបុ័ង៥ដុំ[ង] ហើយនឹង
ត្រី២ប៉ុណ្ណោះ ១៨នោះទ្រង់មានបន្ទូលថា ចូរយកមកឱ្យខ្ញុំ
ឯណេះ ១៩រួចកាលទ្រង់បានបង្គាប់ ឱ្យហ្វូងមនុស្សអង្គុយ
នៅលើស្មៅហើយ នោះទ្រង់យកនំបុ័ង៥ដុំ នឹងត្រី២នោះ
ងើបទតទៅលើមេឃ ទាំងប្រទានពរ រួចកាច់ប្រទាន[ច]
ដល់ពួកសិស្ស ហើយពួកសិស្សក៏ចែកដល់ហ្វូងមនុស្ស
២០គេបានបរិភោគឆ្អែតគ្រប់គ្នា រួចប្រមូលចំណិតដែល
នៅសល់ដាក់ពេញបាន១២កន្ត្រក ២១រីឯពួកមនុស្សដែល
បានបរិភោគ នោះមានចំនួន៥ពាន់នាក់ ឥតរាប់ពួកស្រីៗ
នឹង កូនក្មេងទេ ។

## ព្រះយេស៊ូវយាងលើទឹក

*១៤:២២-៣៣ = មក ៦:៤៥-៥១ យហ ៦:១៦-២១*

*១៤:៣៤-៣៦ = មក ៦:៥៣-៥៦*

២២ស្រាប់តែទ្រង់បង្ខំពួកសិស្ស ឱ្យចុះទូកឆ្លងទៅឯត្រើយ
ម្ខាងមុនទ្រង់ ទាល់តែទ្រង់បានឱ្យហ្វូងមនុស្សវិលទៅវិញ
អស់ ២៣លុះបានឱ្យគេទៅផុតអស់ហើយ នោះទ្រង់យាង
ឡើងលើភ្នំដោយឡែក ដើម្បីនឹងអធិស្ឋាន[ឆ] លុះពេលព្រលប់
ហើយ ទ្រង់ក៏នៅទីនោះតែ១អង្គទ្រង់ ២៤ឯទូកនៅកណ្ដាល
សមុទ្រ ត្រូវរលកបោកជាខ្លាំង ដោយព្រោះច្រាសខ្យល់
២៥ដល់យាម៤យប់ នោះទ្រង់យាងកាត់លើទឹកសមុទ្រទៅឯ

**១៤:៤** ឡ លវ ១៨:១៦ ២០:២១
**១៤:៥** អ មថ ១១:៩
**១៤:១០** ក មថ ១៧:១២
**១៤:១២** ខ កច ៨:២
**១៤:១៤** គ មថ ៩:៣៦
ឃ មថ ៤:២៣
**១៤:១៧** ង មថ ១៦:៩
**១៤:១៩** ច ១សយ ៩:១៣ មថ ២៦:២៦ មក ៨:៦ លក ៩:១៦ ២៤:៣០ កច ២:៤២ ២០:៧,១១ ២៧:៣៥ ១កថ ១០:១៦ ១ធថ ៤:៤
**១៤:២៣** ឆ លក ៣:២១

បុត្រាឈ្មោះភីលីពចំនួនពីរនាក់) មុនដំបូងនាងបានរៀបការជាមួយពូរបស់នាងឈ្មោះហេរ៉ូឌ-ភីលីពដែលរស់នៅទីក្រុងរ៉ូម ។ ខណៈដែលនាងមកលេងនោះហេរ៉ូឌ-អង់ទីប៉ាសបានលួងលោមហេរ៉ូឌាសឱ្យនាងលែងប្ដីហើយមកនៅជាមួយគាត់វិញ ។ ការរៀបការនឹងប្រពន្ធរបស់បងប្រុសខ្លួនដែលមិនទាន់ស្លាប់នោះ គឺត្រូវបានច្បាប់របស់លោកម៉ូសេហាមឃាត់ (លវ ១៨:១៦)។ *ភីលីព* គឺជាបុត្ររបស់ហេរ៉ូឌ-អធិរាជ ជាមួយនឹងនាងម៉ារីយាន ជាកូនស្រីរបស់ស៊ីម៉ូនជាសម្ដេចសង្ឃ ហើយជាបងប្អូនបង្កើតនឹងហេរ៉ូឌ-អង់ទីប៉ាសមានឪពុកតែមួយម្ដាយផ្សេងគ្នា ។ ម្ដាយរបស់ហេរ៉ូឌ-អាន់ទីប៉ាសមានឈ្មោះថានាងម៉ាថាសេ(មើលវង្សត្រកូលស្ដេចហេរ៉ូឌ-អធិរាជ)។

**១៤:៦** *បុត្រីហេរ៉ូឌាស* ឈ្មោះសាលូមបើតាមលោកយ៉ូសែបហ្វីស។ ក្រោយមកនាងបានរៀបការជាមួយអ៊ំប្រុសរបស់នាងម្នាក់ឈ្មោះភីលីព (បុត្រហេរ៉ូឌ-អធិរាជ) ដែលជាអ្នកគ្រប់គ្រងទឹកដីភាគខាងជើង(លក ៣:១)។ នៅពេលនោះនាងសាលូម ជាស្ត្រីក្មេងពេញវ័យស្អាត ថែមទាំងមានក្បាច់រាំល្អឆើតគ្មានទាស់ពេញទៅ ដោយភាពស្រើបស្រាលខាងស្នេហា ហើយជាទីពេញចិតដល់ស្ដេច និងភ្ញៀវ ។

**១៤:៨** *ថាស* ជាប្រភេទចានសំប៉ែតធំម្យ៉ាង ធ្វើពីឈើសម្រាប់ដាក់សាច់ ។

**១៤:១៣-២១** មើលពន្យល់ មក៦:៣២-៤៤ លក៩:១០-១៧ យហ៦:១-១៣

**១៤:២១** *ឥតរាប់ពួកស្រីៗ និងកូនក្មេងទេ* មានតែលោកម៉ាថាយមួយគត់ដែលបញ្ជាក់ការនេះ ។ ត្រង់នេះគាត់កំពុងតែសរសេរទៅសាសន៍យូដា ដែលមិនអនុញ្ញាតឱ្យស្រីៗ និងកូនក្មេងបរិភោគជាមួយនឹងបុរសៗជាសាធារណៈនោះ

**១៤:២២** *បង្ខំ* យោងតាមលោកយ៉ូហានបានឱ្យដឹងថា ក្រោយពីព្រះយេស៊ូវសំដែងឫទ្ធិបារមី(នំបុ័ង៥ដុំ និងត្រី២) នោះបណ្ដាជនក៏គិតនាំគ្នាចាប់ទ្រង់ដោយកម្លាំង ដើម្បីនឹងតាំងទ្រង់ឱ្យធ្វើជាស្ដេច(យហ ៦:១៥)។ នេះជាការយល់ខុសទាំងស្រុងចំពោះបេសកកម្មរបស់ទ្រង់ ហើយពួកសិស្សក៏គិតដូចពួកហ្វូងបណ្ដាជនដែរ ទើបទ្រង់បង្ខំឱ្យពួកសិស្សចេញពីទីនោះ ទៅយ៉ាងលឿនដូច្នេះ(មថ ១៦:៥-១២)។

**១៤:២៣** *ដើម្បីនឹងអធិស្ឋាន* លោកម៉ាថាយនិយាយពីការអធិស្ឋានរបស់ព្រះយេស៊ូវ មានតែនៅទីនេះ និងនៅច្បារគែតសេម៉ានីប៉ុណ្ណោះ(មថ ២៦:៣៦-៤៦)។

**១៤:២៥** *ដល់យាម៤យប់* ចន្លោះម៉ោង៣:00-៦:00 ព្រឹក នេះបើយោងតាមការបែងចែកម៉ោងរបស់ពួករ៉ូម មាន៤យាមនៅសម័យនោះ (១).ម៉ោង

ពួកសិស្ស ២៦កាលគេឃើញទ្រង់យាងលើទឹកដូច្នោះ នោះ
ក៏ភ័យរល់ ហើយនិយាយថា ខ្មោចលងហើយ[ជ] រួចគេ
ស្រែកឡើង ដោយសេចក្ដីតក់ស្លុត ២៧តែព្រះយេស៊ូវទ្រង់
មានបន្ទូលដល់គេភ្លាមថា ចូរ សង្ឃឹមឡើង គឺខ្ញុំទេតើ[ឈ] កុំឱ្យ
ភ័យ[ញ] ឡើយ ២៨ពេត្រុសទូលតបថា ព្រះអម្ចាស់អើយ
បើជាទ្រង់មែននោះសូមឱ្យទូលបង្គំដើរលើទឹកទៅឯទ្រង់
ផង ២៩ទ្រង់មានបន្ទូលថា ចូរមកចុះ ពេត្រុសក៏ចុះចេញពី
ទូកដើរលើទឹក ដើម្បីទៅឯព្រះយេស៊ូវ ៣០តែកាលគាត់
ឃើញខ្យល់បក់ជាខ្លាំង នោះគាត់មានចិត្តភ័យ ហើយដោយ
ព្រោះចាប់តាំងលិចទៅ បានជាគាត់ស្រែកឡើងថា ព្រះ
អម្ចាស់អើយ សូមជួយសង្គ្រោះទូលបង្គំផង ៣១ស្រាប់តែ
ព្រះយេស៊ូវទ្រង់លូកព្រះហស្តទៅចាប់គាត់ភ្លាម ដោយ
បន្ទូលថា ឱមនុស្សមានជំនឿតិចអើយ[ដ] ហេតុអ្វីបានជាអ្នក
សង្ស័យ ៣២រួចកាលទ្រង់នឹងគាត់បានឡើងទៅក្នុងទូក
ហើយ នោះខ្យល់ក៏ស្ងប់ឈឹង ៣៣ឯពួកអ្នកដែលនៅក្នុងទូកក៏
មកថ្វាយបង្គំទ្រង់ទូលថា ទ្រង់ប្រាកដជាព្រះរាជបុត្រានៃ
ព្រះមែន[ឋ] ៣៤លុះបានឆ្លងទៅដល់ត្រើយម្ខាងហើយនោះ
ក៏ចូលទៅ ក្នុងស្រុកគេនេសារ៉ែត ៣៥ពួកមនុស្សនៅទីនោះ
បានចំណាំស្គាល់ទ្រង់ ហើយគេចាត់ឱ្យទៅគ្រប់ក្នុងស្រុក
ជុំវិញនាំយកមនុស្សទាំងប៉ុន្មាន ដែលមានជំងឺមកឯទ្រង់
៣៦ក៏អង្វរឱ្យទ្រង់អនុញ្ញាត ឱ្យអ្នក ទាំងនោះបានគ្រាន់តែ
ពាល់ជាយព្រះពស្ត្រ[ឌ]ទ្រង់ប៉ុណ្ណោះ ឯអស់អ្នកដែលបាន
ពាល់នោះក៏បានជាទាំងអស់គ្នា ។

**របស់ស្អាត និងមិនស្អាត**

*១៥:១-២០ = មក ៧:១-២៣*

**១៥** ១គ្រានោះ ពួកអាចារ្យ និងពួកផារិស៊ីដែលនៅក្រុង
យេរូសាឡិម គេក៏មកឯព្រះយេស៊ូវទូលថា ២ហេតុអ្វីបាន
ជាពួកសិស្សលោកធ្វើខុសនឹងទំនៀមទំលាប់ ដែលពួកចាស់
ទុំបានតាំងទុកពីបុរាណមកដូច្នេះ ដ្បិតកាលណាបរិភោគ
នោះគេមិនលាងដៃសោះ[ឍ] ៣តែទ្រង់មានបន្ទូលតបថា
ឯអ្នករាល់គ្នាវិញ តើហេតុអ្វី បានជាធ្វើខុសនឹងបញ្ញត្ត
ព្រះ ដោយកាន់តាមទំនៀមទំលាប់បុរាណរបស់អ្នករាល់គ្នា
ដូច្នេះដែរ ៤ដ្បិតព្រះទ្រង់ បានបង្គាប់ថា «ចូរគោរពប្រ
តិបត្តិដល់ឪពុកម្ដាយឯង[ណ]» ហើយថា «អ្នកណាដែលនិយាយ
អាក្រក់ពីឪពុកម្ដាយ នោះនឹងត្រូវស្លាប់ជាមិនខាន[ត]» ៥តែអ្នក
រាល់គ្នានិយាយដូច្នេះវិញ បើអ្នកណានឹងនិយាយទៅឪពុក
ម្ដាយថា របស់អ្វីដែលខ្ញុំ អាចនឹងជួយម៉ែឪបាន នោះបាន
ថ្វាយជាដង្វាយហើយ យ៉ាងនោះមិនចាំបាច់ឱ្យអ្នកនោះ
គោរពប្រតិបត្តិ ដល់ឪពុក ម្ដាយទៀតទេ ៦ដូច្នេះឈ្មោះថា
អ្នករាល់គ្នាលើកបញ្ញត្តនៃព្រះចោលហើយ ដោយសារ
ទំនៀមទំលាប់ពីបុរាណ របស់អ្នករាល់គ្នា ៧ឱពួកមនុស្ស
កំពុតអើយ ហោរាអេសាយបានទាយពីអ្នករាល់គ្នាត្រូវ
ណាស់ ថា ៨«បណ្ដាជននេះគេគោរពប្រតិបត្តិដល់អញតែ
បបូរមាត់ទេ ឯចិត្តគេ នោះនៅឆ្ងាយពីអញណាស់ ៩គេ
ថ្វាយបង្គំអញជាឥតប្រយោជន៍ទេ ព្រោះគេបង្រៀនសេចក្ដី
ដែលជាបញ្ញត្តរបស់មនុស្សវិញ»[ថទ] ១០រួចទ្រង់ហៅហ្វូង
មនុស្សមក មានបន្ទូលទៅគេថា ចូរស្ដាប់ហើយយល់ចុះ
១១មិនមែនជារបស់ចូលតាមមាត់ ដែលធ្វើឱ្យមនុស្សស្មោក
គ្រោកនោះទេ[ធ] ឯរបស់ដែលធ្វើឱ្យគេស្មោកគ្រោក នោះ
គឺជាសេចក្ដីដែលចេញពីមាត់វិញ ទេតើ[ន] ។

១២នោះពួកសិស្សក៏មកទូលថា តើទ្រង់ជ្រាបថា ពួកផារិស៊ី
គេអន់ចិត្ត ដោយឮសេចក្ដីនោះឬទេ ១៣តែទ្រង់មាន
បន្ទូលតបថា អស់ទាំងដើមណាដែលព្រះវរបិតាខ្ញុំនៅ
ស្ថានសួគ៌មិនបានដាំ[ប]នោះនឹងត្រូវរំលើងចោល ១៤តាម

**១៤:២៦** ជ លក ២៤:៣៧
**១៤:២៧** ឈ មថ ៩:២ កច ២៣:១១ ញ ដយ ១០:១២ មថ ១៧:៧ ២៨:១០ លក ១:១៣,៣០ ២:១០ កច ១៨:៩ ២៣:១១ វវ ១:១៧
**១៤:៣១** ដ មថ ៦:៣០
**១៤:៣៣** ឋ ទដ ២:៧ មថ ៤:៣
**១៤:៣៦** ឌ មថ ៩:២០
**១៥:២** ឍ លក ១១:៣៨
**១៥:៤** ណ នក ២០:១២ ចទ ៥:១៦ អភ ៦:២ ត នក ២១:១៧ លវ ២០:៩

៦:០០-៩:០០យប់ (២).ម៉ោង៩:០០-១២:០០យប់ (៣).ម៉ោង ១២:០០យប់-៣:០០ព្រឹក (៤).ម៉ោង៣:០០-៦:០០ព្រឹក(មើលការពន្យល់ មក ១៣:៣៥)។ ចំពោះម៉ោងសាសន៍យូដាមានតែបីទេគឺ (១).ពីថ្ងៃលិច-១០:០០យប់ (២).ម៉ោង១០:០០ យប់-២:០០ព្រឹក (៣).ម៉ោង២:០០ព្រឹក-ថ្ងៃរះ(ពច ៧:១៩ ១សយ ១១:១១)។ *យាងកាត់ទឹកសមុទ្រ* មើលការពន្យល់ មក ៦:៤៨ ។

**១៤:៣៤** *គេនេសារ៉ែត* ជាវាលរាបតូចមួយដែលមានបណ្ដោយ៦,៤៣២គ.ម និងទទឹង ៣,២១៦គ.ម ស្ថិតនៅភាគខាងលិចសមុទ្រកាលីឡេផ្នែកខាងជើង រហូតដល់ក្រុងម៉ាកដាឡា(ឬទីប្រជុំជន)វាលរាប ។ វាលរាបនេះត្រូវបានគេចាត់ទុកជា វាលឧទ្យានរបស់ពួកប៉ាឡេស្ទីនដែលជាដីសំបូរជីជាតិ និងមានប្រព័ន្ធធារាសាស្ត្រ ។

**១៤:៣៦** *គ្រាន់តែពាល់ជាយព្រះពស្ត្រទ្រង់* មើលការពន្យល់ មក ៥:២៨ ។

**១៥:២** *ទំនៀមទំលាប់ ពួកចាស់ទុំ* ក្រោយពីការគ្រប់គ្រងរបស់ពួកបាប៊ីឡូននោះមក សាសន៍យូដាបានចាប់ផ្ដើមអនុវត្តច្បាប់នានារបស់រដ្ឋាភិបាលយ៉ាងល្អិតល្អន់នៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ ។ ការកាត់ស្រាយ និងការអនុវត្តន៍នៃក្រឹត្យវិន័យរបស់លោកម៉ូសេគឺតៗគ្នាពីជំនាន់មួយទៅជំនាន់មួយ ។ នៅជំនាន់ព្រះយេស៊ូវទំនៀមទម្លាប់នៃពួកចាស់ទុំនេះគឺជាការចាំមាត់តៗគ្នាទេដល់ឆ្នាំ២០០គ.ស ទើបត្រូវបានគេសរសេរជាអក្សរទុកបង្រៀន ។ *លាង* សូមមើល មក ៧:១-៤ ។

**១៥:៥-៦** មើលការពន្យល់ មក ៧:១១,១៣ ។

**១៥:៧-២០** មើលខគម្ពីរ និងការពន្យល់ក្នុង មក ៧:៦-២៣ ។

តែគេចុះ គេជាមនុស្សខ្វាក់ដែលនាំ[ផ]មនុស្សខ្វាក់ បើមនុស្ស
ខ្វាក់នាំមនុស្សខ្វាក់ដូច្នេះ នោះទាំង២នាក់នឹងធ្លាក់ទៅក្នុង
រណ្ដៅហើយ[ព]។
១៥ រួចពេត្រុសទូលថា សូមស្រាយន័យពាក្យប្រៀបនេះ ឱ្យ
យើងខ្ញុំយល់ផង[ភ] ១៦ទ្រង់មានបន្ទូលថា តើអ្នករាល់គ្នា
នៅតែមិនយល់ទៀតឬអី[ម] ១៧តើមិនទាន់ឃើញទេឬអីថា
របស់អ្វីដែលចូលតាមមាត់ នោះតែងចុះទៅក្នុងពោះ រួច
ចេញទៅក្នុងបង្គន់ ១៨តែឯសេចក្ដីដែលចេញពីមាត់មក
នោះមកអំពីចិត្ត[យ]វិញ គឺសេចក្ដីទាំងនោះហើយ ដែលធ្វើ
ឱ្យមនុស្សស្មោកគ្រោក ១៩ដ្បិតគឺពីក្នុងចិត្តនោះឯងដែល
ចេញអស់ទាំងគំនិតអាក្រក់ គឺការកាប់សំឡាប់គេ ផិតគ្នា
សហាយស្មន់ លួចប្លន់ ធ្វើបន្ទាល់ក្លែងក្លាយ ហើយនិងជេរ
ប្រមាថ[រ] ២០សេចក្ដីទាំងនេះទើបធ្វើឱ្យមនុស្សស្មោកគ្រោក
មែន[ល] តែដែលបរិភោគឥតលាងដៃ នោះមិនមែនធ្វើឱ្យ
ស្មោកគ្រោកទេ។

## សេចក្ដីជំនឿរបស់ស្ត្រីសាសន៍កាណាន

*១៥:២១-២៨ = មក ៧:២៤-៣០*

២១ព្រះយេស៊ូវ ទ្រង់ក៏យាងចេញពីទីនោះ ទៅក្នុងកំលុង
ក្រុងទីរ៉ុស នឹងក្រុងស៊ីដូន[វ] ២២នោះឃើញមានស្ត្រីសាសន៍
កាណានម្នាក់នៅស្រុកនោះ គាត់ចេញមកស្រែកទូលទ្រង់
ថា ឱព្រះអម្ចាស់ ជាពូជហ្លួងដាវីឌអើយ [ស]សូមមេត្តាប្រោស
ខ្ញុំម្ចាស់ផង ដ្បិតកូនស្រីរបស់ខ្ញុំម្ចាស់ មានអារក្សចូល[ហ] ធ្វើ
ទុក្ខ ខ្លាំងណាស់ ។
២៣តែទ្រង់មិនបានឆ្លើយតបទៅស្ត្រីនោះ១ព្រះឱស្ឋសោះ
បានជាពួកសិស្សរបស់ទ្រង់ចូលមកទូលថា សូមឱ្យស្ត្រី
នេះទៅវិញទៅ ដ្បិតគេចេះតែស្រែកតាមយើងខ្ញុំ។
២៤តែទ្រង់មានបន្ទូលឆ្លើយថា ខ្ញុំបានទទួលបង្គាប់នឹង
មកឯពួកកូនចៀម ដែលបាត់បង់របស់ពូជពង្សសាសន៍
អ៊ីស្រាអែលតែប៉ុណ្ណោះទេ[ឡ]។
២៥ប៉ុន្តែ ស្ត្រីនោះមកក្រាប[អ]ថ្វាយបង្គំទូលទ្រង់ថា ឱព្រះ
អម្ចាស់អើយ សូមជួយខ្ញុំម្ចាស់ផង ២៦ទ្រង់មានបន្ទូលថា

**១៥:៩** ថ កល ២:២០-២២ ទ អស ២៩:១៣ មឡ ២:២
**១៥:១១** ធ កច ១០:១៤,១៥ ន មថ ១៥:១៨
**១៥:១៣** ប អស ៦០:២១ ៦១:៣
**១៥:១៤** ផ មថ ២៣:១៦,២៤ រម ២:១៩ ព លក ៦:៣៩
**១៥:១៥** ភ មថ ១៣:៣៦
**១៥:១៦** ម មថ ១៦:៩
**១៥:១៨** យ មថ ១២:៣៤ លក ៦:៤៥ យក ៣:៦
**១៥:១៩** រ កទ ៥:១៩-២១
**១៥:២០** ល រម ១៤:១៤
**១៥:២១** វ មថ ១១:២១
**១៥:២២** ស មថ ៩:២៧ ហ មថ ៤:២៤
**១៥:២៤** ឡ មថ ១០:៦,២៣ រម ១៥:៨
**១៥:២៥** អ មថ ៨:២
**១៥:២៨** ក មថ ៩:២២
**១៥:៣០** ខ មថ ៤:២៣
**១៥:៣១** គ មថ ៩:៨
**១៥:៣២** ឃ មថ ៩:៣៦

ដែលយកនំបុ័ងរបស់កូនក្មេងបោះទៅឱ្យកូនឆ្កែ នោះមិន
ល្អទេ ២៧តែស្ត្រីនោះទូលថា មែនហើយព្រះអម្ចាស់ ប៉ុន្តែ
កូន ឆ្កែវាស៊ីកំទេចដែលធ្លាក់ចុះពីតុម្ចាស់វាមកដែរ
២៨នោះព្រះយេស៊ូវទ្រង់មានបន្ទូលថា នាងស្រីអើយ នាង
មានសេចក្ដីជំនឿជាខ្លាំងមែន[ក] ចូរឱ្យនាងបានដូចសេចក្ដី
ប្រាថ្នាចុះ ស្រាប់តែកូនស្រីរបស់នាងបានជា ចាប់តាំងពី
វេលានោះឯងទៅ ។

## ព្រះយេស៊ូវប្រទានអាហារដល់មនុស្សបួនពាន់នាក់

*១៥:២៩-៣១ = មក ៧:៣១-៣៧ ១៥:៣២-៣៩ = មក ៨:១-១០*
*១៥:៣២-៣៩ = មថ ១៤:១៣-២១*

២៩ព្រះយេស៊ូវ ទ្រង់យាងចេញពីទីនោះ មកខាងសមុទ្រ
កាលីឡេ រួចយាងឡើងទៅលើភ្នំ គង់ចុះនៅទីនោះ ៣០នោះ
មានហ្វូងមនុស្សមកឯទ្រង់កកកុញ នាំទាំងមនុស្ស ខ្វិន ខ្វាក់
គ ពិការ នឹងមនុស្សឯទៀតជាច្រើន មកដាក់នៅទៀបព្រះ
បាទទ្រង់ ហើយទ្រង់ក៏ប្រោសឱ្យគេបានជា[ខ] ៣១ដល់ម្ល៉េះបាន
ជាបណ្ដាមនុស្សទាំងប៉ុន្មានមានសេចក្ដីអស្ចារ្យ ដោយ
ឃើញមនុស្សគនិយាយបាន មនុស្សពិការបានមាំមួន
មនុស្សខ្វិនដើររួច នឹងមនុស្សខ្វាក់មើលឃើញ ហើយគេក៏
សរសើរដំកើងដល់ព្រះនៃសាសន៍អ៊ីស្រាអែលគ្រប់ៗគ្នា[គ] ។
៣២ព្រះយេស៊ូវ ទ្រង់ហៅពួកសិស្សមក មានបន្ទូលថា ខ្ញុំ
មានចិត្តក្តួលអាណិត ដល់ហ្វូងមនុស្សនេះណាស់ [ឃ]ដ្បិតគេ
បាននៅជាមួយនឹងខ្ញុំអស់៣ថ្ងៃមកហើយ គេគ្មានអ្វីនឹង
បរិភោគសោះ ហើយខ្ញុំមិនចង់ឱ្យគេទៅវិញទាំងអត់ឃ្លាន
ទេ ក្រែងហេវតាមផ្លូវ ៣៣ពួកសិស្សទូលទ្រង់ថា នៅទីស្ងាត់
នេះ យើងខ្ញុំនឹងរកនំបុ័ងឱ្យហ្វូងមនុស្សធំដល់ម្លេះ បរិភោគ
ឆ្អែតឯណាបាន ៣៤តែព្រះយេស៊ូវទ្រង់សួរថាតើអ្នករាល់
គ្នាមាននំបុ័ងប៉ុន្មានគេទូលថា មាន៧ហើយនិងត្រីតូចៗខ្លះ
៣៥នោះទ្រង់ក៏ប្រាប់ឱ្យហ្វូងមនុស្សអង្គុយនៅដី ៣៦រួចទ្រង់
យកនំបុ័ង៧ និងត្រីទាំងនោះមកអរព្រះគុណ ហើយកាច់[ង]
ប្រទានដល់ពួកសិស្ស គេក៏ចែកដល់ហ្វូងមនុស្ស ៣៧គ្រប់គ្នា

**១៥:២១** *ក្រុងទីរ៉ុស* មើលការពន្យល់ មក ៧:២៤ ។ *ក្រុងស៊ីដូន* នៅទិសខាងជើងក្រុងទីរ៉ុស ដែលមានចម្ងាយប្រហែល៤០,២ គ.ម ។
**១៥:២២** *សាសន៍កាណាន* ពាក្យនេះឃើញច្រើនដងក្នុងគម្ពីរសញ្ញាចាស់ ប៉ុន្តែ មានតែម្ដងនេះគត់នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ហើយក៏គ្មានប្រទេសឈ្មោះនេះទៀតដែរ ។ បើតាមបូកពា អ្នកខ្លះគិតថាប្រហែលជាអ្នកស្រុកភេនីសកូនកាត់ក្រិក និងអារ៉ាប់ ។ តែបើតាមលោកម៉ាកុសថា ស្ត្រីនោះគឺជាជនជាតិក្រិកដែលបានកើតនៅស៊ីរ៉ូ-ភេនីស (មក ៧:២៦) ។
**១៥:២៦** *របស់កូនក្មេង* "ចៀមដែលបាត់បង់នៃអ៊ីស្រាអែល"ខ.២៤ ។ *កូនឆ្កែ* មានន័យថាឆ្កែចិញ្ចឹមក្នុងផ្ទះ ព្រះយេស៊ូវមានបន្ទូលថា ដំណឹងល្អគឺទៅដល់ពួកយូដាជាមុនសិន ខណៈនោះស្ត្រីយល់ន័យថា"កំទេច" ហើយក៏ដោះស្រាយបាន ពេលនោះព្រះយេស៊ូវក៏ប្រទានរង្វាន់តាមជំនឿរបស់នាង (ខ.២៨) ។
**១៥:២៧** *មែនហើយព្រះអម្ចាស់* មើលការពន្យល់ មក ៧:២៨ ។
**១៥:២៩-៣៩** មើលការពន្យល់ក្នុង មក ៧:៣១-៨:១០ ។
**១៥:៣៧** ការប្រទានអាហារដល់មនុស្ស៥ពាន់នាក់បានកត់ចុះក្នុងដំណឹងល្អ

បានបរិភោគឆ្អែត ហើយគេប្រមូលចំណិតដែលនៅសល់
ដាក់ពេញបាន៧កំប្រោង[ច] [៣៨]ឯពួកប្រុសៗ ដែលបាន
បរិភោគឆ្អែត នោះមាន៤ពាន់នាក់ ឥតរាប់ស្រីៗ ហើយនិង
កូនក្មេងផងទេ [៣៩]រួចកាលទ្រង់បានឱ្យហ្វូងមនុស្សវិលទៅ
វិញនោះទ្រង់យាងចុះទូកឆ្លងទៅដល់ដែនស្រុកម៉ាកាដាន់។

## ការចង់ឃើញទីសំគាល់

*១៦:១-១២ = មក ៨:១១-២១*

**១៦** [១]ពួកផារិស៊ី នឹងពួកសាឌូស៊ី[ឆ] គេមកល្បួងទ្រង់ សូម
ឱ្យសំដែងទីសំគាល់១ពីលើមេឃឱ្យគេឃើញ[ជ] [២]តែ
ទ្រង់មានបន្ទូលឆ្លើយថា ដល់ល្ងាចអ្នករាល់គ្នានិយាយថា
មេឃនឹងល្អ ពីព្រោះក្រហម [៣]ហើយដល់ព្រឹក នោះអ្នក
រាល់គ្នាក៏ថា នៅថ្ងៃនេះនឹងមានព្យុះភ្លៀង ព្រោះមេឃ
ក្រហមស្រទំ ឱមនុស្សកំពុតអើយ អ្នករាល់គ្នាចេះសំគាល់
សណ្ឋានរបស់មេឃមែន តែពុំអាចនឹងស្គាល់ទីសំគាល់នៃ
សម័យ[ឈ]នេះបានទេ [៤]ពូជដំណអាក្រក់ ហើយកំផិត គេចេះ
តែរកទីសំគាល់ តែនឹងគ្មានទីសំគាល់ណាបានប្រទានមក
គេ ក្រៅពីទីសំគាល់តែមួយនោះទេ គឺហោរាយ៉ូណាស[ញ]
រួចទ្រង់យាងចោលគេបាត់ទៅ ។

## ដំបែរបស់ពួកផារិស៊ី និងពួកសាឌូស៊ី

[៥]ពួកសិស្សឆ្លងទៅឯត្រើយម្ខាង តែគេភ្លេចយកនំបុ័ងទៅ
[៦]គ្រានោះ ព្រះយេស៊ូវ ទ្រង់មានបន្ទូលថា ចូរឱ្យពិចារណា
ហើយប្រុងប្រយ័ត្នចំពោះដំបែរបស់ពួកផារិស៊ី នឹងពួក
សាឌូស៊ីឱ្យមែនទែន[ដ]។

**១៥:៣៦** ង មថ ១៤:១៩
**១៥:៣៧** ច មថ ១៦:១០
**១៦:១** ឆ កច ៤:១ ជ មថ ១២:៣៨
**១៦:៣** ឈ លក ១២:៥៤-៥៦
**១៦:៤** ញ មថ ១២:៣៩
**១៦:៦** ដ លក ១២:១
**១៦:៨** ឋ មថ ៦:៣០
**១៦:៩** ឌ មថ ១៤:១៧-២១
**១៦:១០** ឍ មថ ១៥:៣៤-៣៨
**១៦:១២** ណ កច ៤:១
**១៦:១៤** ត មថ ៣:១ ថ មក ៦:១៥ យហ ១:២១
**១៦:១៦** ទ មថ ៤:៣ ទដ ៤២:២ យរ ១០:១០ កច ១៤:១៥ ២កថ ៦:១៦ ១ថន ១:៩ ១ធថ ៣:១៥ ហាព ១០:៣១ ១២:២២

[៧]គេក៏រិះគិតគ្នាថា ប្រហែលជាដោយព្រោះយើងមិនបាន
យកនំបុ័ងមកទេដឹង [៨]កាលព្រះយេស៊ូវទ្រង់ជ្រាប នោះក៏
មានបន្ទូលថា ឱមនុស្សមានជំនឿតិចអើយ[ឋ] ហេតុអ្វីបាន
ជាអ្នករាល់គ្នារិះគិតគ្នា អំពីដំណើរដែលមិនបានយក
នំបុ័ងមកដូច្នេះ [៩]តើអ្នករាល់គ្នានឹកមិនទាន់ឃើញ ឬមិន
ចាំពីនំបុ័ង៥ នឹងមនុស្ស៥ពាន់នាក់ ហើយដែលអ្នករាល់
គ្នាប្រមូលបានប៉ុន្មានកន្ត្រក នោះទេឬអី[ឌ] [១០]ឬពីនំបុ័ង៧
នឹងមនុស្ស៤ពាន់នាក់ ហើយដែលប្រមូលបានប៉ុន្មានកំ
ប្រោងទេឬអី[ឍ] [១១]ហេតុដូចម្តេច បានជាអ្នករាល់គ្នានឹក
មិនទាន់ឃើញថា មិនមែនពីនំបុ័ងដែលខ្ញុំប្រាប់ឱ្យប្រយ័ត្ន
ពីដំបែរបស់ពួកផារិស៊ី និងពួកសាឌូស៊ីនោះទេ [១២]នោះទើប
គេបានយល់ថា មិនមែនពីដំបែនំបុ័ង ដែលទ្រង់មានបន្ទូល
ប្រាប់ឱ្យគេប្រយ័ត្នទេ គឺពីលទ្ធិរបស់ពួកផារិស៊ី និងពួកសា
ឌូស៊ីវិញ[ណ] ។

## សេចក្តីជំនឿរបស់ពេត្រុស

*១៦:១៣-១៦ = មក ៨:២៧-២៩ លក ៩:១៨-២០*

[១៣]កាលព្រះយេស៊ូវបានយាងមកដល់ក្រវល់ក្រុងសេសា-
រា-ភីលីពហើយ នោះទ្រង់មានបន្ទូលសាកសួរពួកសិស្សថា
តើមនុស្សទាំងឡាយ គេថាកូនមនុស្សជាអ្នកណា [១៤]ពួក
សិស្សទូលឆ្លើយថា ខ្លះថាជាយ៉ូហាន-បាទីស្ទ[ត] ខ្លះទៀតថា
ជាអេលីយ៉ា ហើយខ្លះទៀតថា ជាយេរេមា ឬហោរាណា
មួយ[ថ] [១៥]ទ្រង់មានបន្ទូលសួរថា ចុះឯអ្នករាល់គ្នាវិញ តើ
ថាខ្ញុំជាអ្នកណា [១៦]ស៊ីម៉ូន-ពេត្រុសទូលឆ្លើយថា ទ្រង់
ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់[ទ]

---

ទាំងបួន តែការប្រទានដល់មនុស្ស៤ពាន់នាក់មានតែក្នុងគម្ពីរម៉ាថាយ និង ម៉ាកុសទេ ។ នំបុ័ង១២កន្ត្រកនៅសល់ពីការបរិភោគចំនួនមនុស្ស៥ពាន់នាក់ អាចទុកសម្រាប់សិស្សទាំង១២នាក់ ហើយ៧កំប្រោងនៅទីនេះប្រហែលជា ចំនួនដែលច្រើនជាងមុន ហើយមើលទៅ ។

**១៥:៣៩** *ម៉ាកាដាន់* ត្រូវបានគេហៅថាភូមិម៉ាដាឡាផងដែរ ដែលជាស្រុកកំណើតរបស់នាងម៉ារា "មក ៨:១០" ក្រុងដាលម៉ានូថាគឺនៅក្បែរនឹងភូមិម៉ាកាដាន់ ។

**១៦:១** *ទីសំគាល់១ពីលើមេឃ* មើលការពន្យល់ មក ៨:១១។

**១៦:៤** *ហោរាយ៉ូណាស* មើលពន្យល់ ១២:៣៩-៤០ លក ១១:៣០ ។

**១៦:៦** *ដំបែរបស់ពួកផារិស៊ី និងពួកសាឌូស៊ី* មើល ខ.១២ និង ការពន្យល់ ៣:៧ មក ២:១៦ ៨:១៥ ១២:១៨ ។

**១៦:១២** លោកម៉ាថាយជាញឹកញាប់ គាត់ពន្យល់អត្ថន័យព្រះបន្ទូលរបស់ព្រះយេស៊ូវ "១៧:១៣"។

**១៦:១៣** *សេសារា-ភីលីព* ត្រូវបានគេបែងចែកពីក្រុងសេសារាដ៏ល្អឆើតឆាយ ដែលស្តេចហេរ៉ូឌ-អធិរាជបានកសាងឡើងនៅតាមឆ្នេរសមុទ្រមេឌី-ទែរ៉ាណេ ។ ក្រុងសេសារា-ភីលីពបានកសាងឡើងវិញដោយបុត្រាហេរ៉ូឌឈ្មោះភីលីពបានដាក់ឈ្មោះទីក្រុងនោះ ទៅតាមឈ្មោះមនុស្សពីរនាក់ គឺសេសារ-ទីបើរ និងខ្លួនរបស់គាត់ "ភីលីព" ដែលស្ថិតនៅប៉ែកខាងជើងនៃសមុទ្រកាលីឡេជិតទីជម្រាលភ្នំហើម៉ូន ជាកន្លែងសម្រាប់គោរពព្រះរបស់ជនជាតិរ៉ូម ដែលជឿលើព្រះចង្រ្កាន ។ *កូនមនុស្ស* មើលពន្យល់ មក ៨:៣១ ។

**១៦:១៦** *ព្រះគ្រីស្ទ* មើលការពន្យល់ ១:១៧ ។ ក្នុងគម្ពីរសញ្ញាចាស់ហៅថាព្រះមែស៊ី គឺជាម្នាក់ដែលត្រូវបានចាក់ប្រេងតាំងឱ្យធ្វើកិច្ចការអ្វីមួយ ដូចជាពួកហោរា និងពួកស្តេចនៃសាសន៍អ៊ីស្រាអែល(នក ២៩:៧,២១ ១សយ ១០:១,៦ ១៦:១៣ ២សយ ១:១៤,១៦) មានន័យថា ជាម្នាក់ដែលព្រះបានជ្រើសរើស ហើយញែកចេញសម្រាប់បម្រើព្រះ និងត្រូវបានបំពាក់ដោយអំណាចព្រះចេស្តា ដើម្បីសម្រេចការងារ ។ ស្តេចដែលបានចាក់ប្រេងតាំងនោះនឹងមានព្រះចេស្តាពីព្រះ ដើម្បីសង្គ្រោះរាស្ត្ររបស់ទ្រង់ ឱ្យរួចផុតពីកណ្តាប់ដៃខ្មាំងសត្រូវ និងតាំងនគរព្រះឡើង(ដយ ៩:២៥-២៦) នេះបើយោងតាមព្រះគម្ពីរសញ្ញាចាស់ ។ ជុំវិញបរិបទនៃពាក្យថា"ព្រះមែស៊ី" ក្នុងន័យដើមបានលំអៀងទៅរកនយោបាយ និងប្រទេសជាតិ ដូច្នេះហើយបានជាព្រះយេស៊ូវទ្រង់កម្រប្រើពាក្យនេះណាស់ តែបើប្រើនោះគឺជាការត្រៀមបម្រុងទុកសម្រាប់លើអង្គទ្រង់តែប៉ុណ្ណោះ(មក ៨:២៧-៣០ ១៤:៦១-៦៣)។

១៧រួចព្រះយេស៊ូវមានបន្ទូលតបថា អ្នកស៊ីម៉ូន
កូនយ៉ូណាសអើយ អ្នកមានពរ ដ្បិតមិនមែនជាសាច់ឈាម[ធ]
ដែលបានសំដែងឱ្យអ្នកស្គាល់ទេ គឺព្រះវរបិតានៃខ្ញុំដែល
គង់នៅស្ថានសួគ៌វិញ[ន] ១៨ខ្ញុំប្រាប់អ្នកថា អ្នកឈ្មោះពេត្រុស[ប]
ខ្ញុំនឹងតាំងពួកជំនុំខ្ញុំ[ផ]នៅលើថ្មដានេះ ហើយទ្វារស្ថានឃុំ
ព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំឡើយ ១៩ខ្ញុំនឹង
ឱ្យកូនសោរនៃនគរស្ថានសួគ៌[ព]ដល់អ្នក បើអ្នកនឹងចងទុកអ្វីៗ
នៅផែនដី នោះនឹងត្រូវចងទុកនៅស្ថានសួគ៌ដែរ ហើយបើ
អ្នកនឹងស្រាយអ្វីៗនៅផែនដី នោះនឹងត្រូវស្រាយនៅស្ថាន
សួគ៌ដែរ[ភ] ២០រួចទ្រង់ហាមពួកសិស្ស មិនឱ្យគេប្រាប់ដល់
អ្នកណា[ម]ថា ទ្រង់ជាព្រះគ្រីស្ទឡើយ ។

**ព្រះយេស៊ូវថ្លែងទំនាយពីការសុគតរបស់ទ្រង់**

*១៦:២១–២៨ = មក ៨:៣១–៩:១ លក ៩:២២–២៧*

២១តាំងពីគ្រានោះមក ព្រះយេស៊ូវទ្រង់ចាប់ផ្ដើមប្រាប់
ដល់ពួកសិស្សថា ទ្រង់ត្រូវតែយាងទៅឯក្រុងយេរូសាឡិម[យ]
ហើយត្រូវរងទុក្ខជាច្រើន[រ]នៅដៃនៃពួកចាស់ទុំ ពួកសង្គ្រាជ
និងពួកអាចារ្យ[ល] ហើយត្រូវគេធ្វើគុតផង[វ] តែក្រោយ៣ថ្ងៃ[ស]
មកទ្រង់នឹងមានព្រះជន្មរស់ឡើងវិញ[ហ] ២២នោះពេត្រុសក៏
នាំទ្រង់មកជិត ចាប់តាំងទូលចំទាស់ថា ឱព្រះអម្ចាស់អើយ
សូមទ្រង់ប្រណីអង្គទ្រង់វិញ ការនោះមិនត្រូវមកដល់ទ្រង់
ឡើយ ២៣តែទ្រង់បែរទៅមានបន្ទូលនឹងគាត់ថា សាតាំង[ឡ]
អើយ ចូរថយទៅក្រោយអញទៅ ឯងជាសេចក្ដីបង្អាក់
ដល់ចិត្តអញ ព្រោះមិនចេះគិតតាមគំនិតនៃព្រះសោះ គឺគិត
តាមតែគំនិតរបស់មនុស្សលោកវិញ ២៤រួចទ្រង់មានបន្ទូល
ទៅពួកសិស្សទាំងអស់គ្នាថា បើអ្នកណាចង់មកតាមខ្ញុំ នោះ
ត្រូវឱ្យលះកាត់ចិត្តខ្លួនឯងចោលចេញ ហើយផ្ទុកឈើឆ្កាង
ខ្លួនមកតាមខ្ញុំចុះ[អ] ២៥ព្រោះអ្នកណាដែលចង់ឱ្យរួចជីវិត
នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលបាត់ជីវិត ដោយ
ព្រោះខ្ញុំ នោះនឹងបានវិញ[ក] ២៦ដ្បិតបើមនុស្សណានឹងបាន
លោកីយទាំងមូល តែបាត់ព្រលឹងទៅនោះតើមានប្រយោជន៍
អ្វីដល់អ្នកនោះ ឬតើមនុស្សនឹងយកអ្វីទៅដូរ ឱ្យបានព្រលឹង
ខ្លួនវិញ ២៧ព្រោះកូនមនុស្ស[ខ]នឹងមក[គ]ក្នុងសិរីល្អនៃព្រះវរ
បិតា ជាមួយនឹង ពួកទេវតារបស់លោក គ្រានោះលោកនឹង
សងដល់គ្រប់គ្នា តាមការដែលបានធ្វើរៀងខ្លួន[ឃ] ២៨ខ្ញុំ
ប្រាប់អ្នករាល់គ្នាជាប្រាកដថា ក្នុងពួកអ្នកដែលឈរនៅទី
នេះ មានអ្នកខ្លះមិនត្រូវភ្លក់សេចក្ដីស្លាប់ ទាល់តែបាន
ឃើញកូនមនុស្សមក ក្នុង នគររបស់លោក។

**១៦:១៧** ធ ១កថ ១៥:៥០ អភ ៦:១២ ហព ២:១៤ ន មថ ១៣:១១ **១៦:១៨** ប យហ ១:៤២ ផ អភ ២:២០ **១៦:១៩** ព អស ២២:២២ វវ ៣:៧ ភ មថ ១៨:១៨ យហ ២០:២៣ **១៦:២០** ម មក ៨:៣០ **១៦:២១** យ លក ៩:៥១ រ ទដ ២២:៦ អស ៥៣:៣ មថ ២៦:៦៧,៦៨ មក ១០:៣៤ លក ១៧:២៥ យហ ១៨:២២,២៣ ១៩:៣ ល មថ ២៧:១,២ វ កថ ២:២ ៣៣:១៣ ស ហស ៦:២ មថ ១២:៤០ លក ២៤:២១,៤៦ យហ ២:១៩ ១កថ ១៥:៣,៤ ហ មថ ១៧:២២,២៣ ២៧:៦៣ មក ៩:៣១ លក ៩:២២ ១៨:៣១–៣៣ ២៤:៦,៧

**១៦:២៣** ឡ មថ ៤:១០ **១៦:២៤** អ មថ ១០:៣៨ លក ១៤:២៧
**១៦:២៥** ក យហ ១២:២៥ **១៦:២៧** ខ មថ ៨:២០ គ លក ១៧:៣០ យហ ១៤:៣ កច ១:១១ ១កថ ១:៧ ១ថន ២:១៩ ៤:១៦ វវ ១:៧ ២២:៧,១២,២០ ឃ ២របា ៦:២៣ យប ៣៤:១១ ទដ ៦២:១២ យរ ១៧:១០ អគ ១៨:២០ ១កថ ៣:១២–១៥ ២កថ ៥:១០ វវ ២២:១២

**១៦:១៨** *ពេត្រុស . . . ថ្ម . . . ពួកជំនុំ* ពេត្រុសជាភាសាហេព្រើរមានន័យថា "ថ្ម" ដែលបកស្រាយជាច្រើនអំពីថ្មដែលពួកជំនុំបានដាំលើគឺ (១).ព្រះគ្រីស្ទ (២). ពេត្រុសបានជឿថាព្រះយេស៊ូវគឺជាព្រះមែស៊ី (ខ.១៦) (៣).សេចក្ដីបង្រៀនរបស់ព្រះគ្រីស្ទ ដែលបានបញ្ជាក់យ៉ាងច្បាស់ក្នុងដំណឹងល្អម៉ាថាយ (៤).ពេត្រុសបានយល់យ៉ាងច្បាស់ពីតួនាទីរបស់គាត់នៅថ្ងៃទី៥០ (កច ២) កូនេលាសជាមេលើ កងទ័ព (កច ១០) និងជាអ្នកដឹកនាំក្នុងចំណោមសាវ័ក ។ អភ ២:២០ បង្ហាញថា ពួកជំនុំគឺ "បានស្អាង ឡើងលើជញ្ជាំងនៃពួកសាវ័ក និងពួកហោរា" ។ *ពួកជំនុំ* មានតែដំណឹងល្អម៉ាថាយទេ ដែលប្រើពាក្យនេះ (នៅទីនេះ និងពីរដងទៀតនៅ ក្នុង"១៨:១៧") តែក្រោយមកគេប្រើពាក្យសាលាប្រជុំវិញ នាសម័យព្រះយេស៊ូវ (ជាកន្លែងប្រមូលផ្ដុំប្រជុំគ្នា) ជាសាធារណៈ ឬកន្លែងបោះឆ្នោតនៅក្នុងទីក្រុង (កច ១៩:៣២, ៣៨,៤១)។ *ស្ថានឃុំព្រលឹងមនុស្សស្លាប់* តាមភាសាក្រិកមានន័យ ថាជាកន្លែងវិញ្ញាណមនុស្សស្លាប់គឺស្មើនឹងពាក្យ "ស្ថាននរក"(មើលពន្យល់ លប ៣៧:៣៥)។ *ទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់* ប្រហែលមានន័យថា "អំណាចនៃសេចក្ដីស្លាប់" គឺអស់អ្នកដែលទាស់ប្រឆាំងនឹងព្រះគ្រីស្ទ និងនគររបស់ទ្រង់ (មើលការពន្យល់ យប ១៧:១៦)។

**១៦:១៩** *កូនសោ* ប្រហែលជាលោកពេត្រុសបានប្រើកូនសោនៅថ្ងៃទី៥០ (កច ២) ហើយមើលទៅបានជាគាត់ប្រកាសថា ទ្វារនគរស្ថានសួគ៌បានបើកហើយសម្រាប់សាសន៍យូដា និងអ្នកកាន់សាសនាផ្សេងៗទៀត ។ បន្ទាប់មកគាត់បានបង្រៀនថា បើកសម្រាប់សាសន៍ដទៃផងដែរ (កច ១០)។ *ចង . . . ស្រាយ* មិនមែនជាអំណាចដើម្បីសម្រេចចិត្តនោះទេ តែដើម្បីប្រកាសថា មានទោសឬក៏គ្មានទោស (មើលការពន្យល់ ១៨:១៨ និងគម្ពីរយោង កច ៥:៣,៩)។

**១៦:២០** *មិនឱ្យគេប្រាប់* ពីព្រោះពួកយូដាមានទស្សនៈខុសឆ្គង ដោយបានរង់ចាំព្រះមែស៊ីសម្រាប់តែខាងជាតិសាសន៍ និងនយោបាយហេតុនេះបានជាព្រះយេស៊ូវហាមសិស្សទ្រង់មិនឱ្យប្រាប់ដល់សាធារណៈជនថា ទ្រង់ជាព្រះមែស៊ី (ព្រះគ្រីស្ទ) តាមចម្លើយរបស់លោកពេត្រុសនោះឡើយ ដែលអាចជាសន្ទុះកាន់តែលឿន ក្នុងការប្រឆាំងនឹងពួករ៉ូម៉ាំង (មើលការពន្យល់ ៨:៤)។

**១៦:២១** *ចាប់ផ្ដើម* ព្រះយេស៊ូវបានបញ្ជាក់ប្រាប់ពីភារកិច្ចថ្មីមួយទៀត ដែលក្រៅពីបង្រៀនរឿងប្រៀបប្រដូចដល់បណ្ដាជន នោះគឺទ្រង់បានប្រមូលផ្ដុំរៀបចំសិស្ស សម្រាប់ការខិតមកជិតនៃការរងទុក្ខ និងការសុគត ។

**១៦:២៣** *សាតាំង* ជាពាក្យកម្ចីពីភាសាហេព្រើរមានន័យថា "ខ្មាំងសត្រូវ ឬអ្នកចោទប្រកាន់" (មើលការពន្យល់ យប ១:៦ និង វវ ២:៩)។

**១៦:២៤** *ផ្ទុកឈើឆ្កាង* មើលការពន្យល់ ១០:៣៨ មក ៨:៣៤ ។

**១៦:២៧** *កូនមនុស្ស* មើលការពន្យល់ មក ៨:៣១ ។ *នឹងមក* គឺសំដៅលើការយាងមកលើកទីពីររបស់ព្រះយេស៊ូវ ។

**១៦:២៨** មានការបកស្រាយសំខាន់ពីរនៅក្នុងខនេះ (១).ជាទំនាយនៃ

## ការផ្លាស់ប្រែរូបកាយ

*១៧:១-៨ = លក ៩:២៨-៣៦*
*១៧:១-១៣ = មក ៩:២-១៣*

**១៧** ១កន្លងមក៦ថ្ងៃ ព្រះយេស៊ូវទ្រង់យកពេត្រុស យ៉ាកុប
នឹងយ៉ូហាន[ង] ជាប្អូនយ៉ាកុប ទៅជាមួយនឹងទ្រង់ ក៏នាំឡើង
ទៅលើភ្នំខ្ពស់ដោយឡែក ២រួចទ្រង់បានផ្លាស់ប្រែនៅមុខ
អ្នកទាំងនោះ ព្រះភក្ត្រទ្រង់បានភ្លឺដូចព្រះអាទិត្យ ហើយព្រះ
ពស្ត្រទ្រង់ក៏ត្រឡប់ជាស ដូចពន្លឺ ៣នោះឃើញលោកម៉ូសេ
នឹងលោកអេលីយ៉ា លេចមកឯគេ កំពុងតែទូលនឹងទ្រង់ ។
៤ឯពេត្រុស គាត់ទូលទៅព្រះយេស៊ូវថា ព្រះអម្ចាស់ អើយ
ដែលយើងខ្ញុំនៅទីនេះបានល្អណាស់ បើទ្រង់សព្វ ព្រះហឫទ័យ
នោះយើងខ្ញុំនឹងធ្វើត្រសាល៣នៅទីនេះ គឺ១ សំរាប់ទ្រង់
១សំរាប់លោកម៉ូសេ ហើយ១សំរាប់លោក អេលីយ៉ា
៥កាលគាត់កំពុងតែទូលនៅឡើយ នោះមានពពកយ៉ាង
ភ្លឺបានមកបាំងគេ ហើយមានឮសំឡេងចេញពីពពកនោះថា
នេះជាកូនស្ងួនភ្ងាអញ ជាទីពេញចិត្តអញណាស់[ច] ចូរ
ស្តាប់តាមចុះ[ឆ] ៦កាលបានឮហើយ នោះពួកសិស្សក៏ក្រាប
ផ្កាប់មុខនឹងដី ទាំងភ័យស្លុតជាខ្លាំង ៧តែព្រះយេស៊ូវទ្រង់
យាងទៅពាល់គេ ដោយបន្ទូលថា ចូរក្រោកឡើង កុំភ័យ
ឡើយ[ជ] ៨កាលគេបានងើបឡើង នោះមិនបានឃើញអ្នក
ណាសោះ ឃើញតែព្រះយេស៊ូវតែប៉ុណ្ណោះ ។
៩កំពុងដែលនាំគ្នាចុះពីភ្នំមក នោះព្រះយេស៊ូវទ្រង់ហាម
គេថា កុំឱ្យប្រាប់អ្នកណា[ឈ]ពីការជាក់ស្តែងនេះឱ្យសោះ
ទាល់តែកូនមនុស្ស[ញ]បានរស់ពីស្លាប់ឡើងវិញ[ដ] ១០ពួកសិស្ស
ទូលសួរថា ចុះហេតុអ្វីបានជាពួកអាចារ្យប្រាប់ថា លោក
អេលីយ៉ាត្រូវតែមកជាមុន ១១ទ្រង់ឆ្លើយតបថាលោកអេលី
យ៉ាត្រូវមកមុនមែន ដើម្បីនឹងតាំងការទាំងអស់ឡើងវិញ[ឋ]
១២ប៉ុន្តែខ្ញុំប្រាប់អ្នករាល់គ្នាថា លោកអេលីយ៉ាបានមក
ហើយ[ឌ] គេមិនបានស្គាល់លោកទេ ហើយគេប្រព្រឹត្តនឹង
លោកតាមតែចិត្តផង[ឍ] បន្តិចទៀត កូនមនុស្សនឹងត្រូវគេ
ធ្វើទុក្ខ[ណ]ដូច្នោះដែរ ១៣នោះពួកសិស្សក៏យល់ថា ទ្រង់មាន
បន្ទូលពីយ៉ូហាន-បាទីស្ទទេ[ត] ។

**១៧:១** ង មថ ៤:២១
**១៧:៥** ច មថ ៣:១៧
ឆ កច ៣:២២,២៣
**១៧:៧** ជ មថ ១៤:២៧
**១៧:៩** ឈ មក ៨:៣០
ញ មថ ៨:២០
ដ មថ ១៦:២១
**១៧:១១** ឋ មឡ ៤:៦ លក១:១៦,១៧
**១៧:១២** ឌ មថ ១១:១៤
ឍ មថ ១៤:៣,១០
ណ មថ ១៦:២១
**១៧:១៣** ត មថ ៣:១

ការផ្លាស់ប្រែរាងកាយថ្មី ដែលនឹងកើតឡើងមួយសប្តាហ៍ក្រោយ(មក ១៧:១) និងបង្ហាញថា ព្រះយេស៊ូវនឹងយាងមកក្នុងសិរីល្អនៃព្រះវរបិតា (១៦:២៧)។ (២).ទាក់ទង ទៅនឹងអំណាចនៃកូនមនុស្ស និងរាជបល្ល័ង្កស្តេចក្នុងពួកជំនុំក្រោយពីទ្រង់មានព្រះជន្មរស់ឡើងវិញ ។ សិស្សទ្រង់មួយចំនួននឹងធ្វើបន្ទាល់ពីទ្រង់ ព្រមទាំងសហការគ្នាយ៉ាងសកម្ម ដូចបានរៀបរាប់ក្នុងព្រះគម្ពីរកិច្ចការ ដូចក្នុងកាលដែល ព្រះយេស៊ូវកំពុងមានព្រះជន្មរស់នៅជាមួយនឹងពួកគេដែរ (មើលការពន្យល់ ២ពត ១:១៦)។

**១៧:១-៩** ការផ្លាស់ប្រែរូបកាយគឺជា: (១).ការបើកសំដែងនៃសិរីល្អរបស់ព្រះរាជបុត្រាដែលសិរីល្អបានលាក់កំបាំង ឥឡូវនេះត្រូវបានបើកសំដែងនៅពេល ដែលទ្រង់យាងត្រឡប់មកវិញ ។ (២).ការអះអាងបញ្ជាក់បន្ថែមពីការបង្រៀន ដែលពិបាកមួយត្រូវបានបន្ថែមដល់ពួកសិស្សទ្រង់នៅឯសេសារា-ភីលីព (១៦:១៣-២០)។ (៣).ជាបទពិសោធន៍ល្អមួយសម្រាប់ពួកសិស្ស ដែលបានធ្លាក់ទឹកចិត្តក្រោយពីទ្រង់បានរំលឹកពីការរងទុក្ខរហូតដល់សុគត"១៦:២១" (មើលការ ពន្យល់ មក ៩:២-៧ លក ៩:២៨-៣៥) ថ្មីៗនោះ ។

**១៧:១** *៦ថ្ងៃ* ម៉ាកុសក៏បានថា ៦ថ្ងៃដែរ(មក ៩:២) គ្រាន់តែរាប់នៅថ្ងៃចន្លោះ រវាងថ្ងៃដែលពេត្រុសបង្ហាញសេចក្តីជំនឿ (១៦:១៦)និងការផ្លាស់ប្រែ(១៧:២)។ ប៉ុន្តែ លោកលូកាបានរាប់ពីរសងខាងទៀត នោះគឺ៨ថ្ងៃ(លក ៩:២៨)។ *ពេត្រុស យ៉ាកុប និងយ៉ូហាន* មានទំនាក់ទំនងយ៉ាងស្និទ្ធស្នាល ជាពិសេសជាមួយនឹងព្រះយេស៊ូវ(២៦:៣៧ មក៥:៣៧)។ *ភ្នំខ្ពស់* មិនដឹងជានៅទីណានោះទេ តែយោងតាមសេសារា-ភីលីព(១៦:១៣) ប្រហែលជាភ្នំហើម៉ូនដែលនៅជិតសេសារា-ភីលីពភាគខាងជើង (មើលការពន្យល់ លក ៩:២៨)។ *ដោយឡែក* លោកលូកាថា "ទៅអធិស្ឋាន" (លក ៩:២៨)។

**១៧:២** *ទ្រង់បានផ្លាស់ប្រែ* រូបរាងខាងក្រៅរបស់ទ្រង់បានផ្លាស់ប្រែទាំងស្រុង ហើយសិស្សរបស់ទ្រង់ទាំងបីក៏បានឃើញជាក់នឹងភ្នែកថា ព្រះយេស៊ូវបានពេញដោយសិរីរុងរឿងរបស់ព្រះ (យហ ១៧:៥ ២ពត ១:១៧)។

**១៧:៣** *ម៉ូសេ និងលោកអេលីយ៉ា* លោកម៉ូសេលេចមកជាតំណាងនៃការតាំងសញ្ញាចាស់ និងការសន្យានៃសេចក្តីសង្គ្រោះ ដែលបានសម្រេចដោយការសុគតរបស់ព្រះយេស៊ូវ ។ លោកអេលីយ៉ាលេចមកជាតំណាងនៃកាស្តាបនាឡើងវិញនូវគ្រប់អ្វីៗទាំងអស់(មឡ ៤:៥-៦ មក ៩:១១-១៣)។ នៅក្នុង"លក ៩:៣១"និយាយពីការសុគតរបស់ព្រះគ្រីស្ទ(មើលពន្យល់ លក ៩:៣០)។

**១៧:៤** *ត្រសាលបី* មើលការពន្យល់ មក ៩:៥ លក ៩:៣៣ ។

**១៧:៥** *ពពក* គឺព្រះយេស៊ូវ លោកម៉ូសេ និងលោកអេលីយ៉ា ។ *នេះជាកូនស្ងួនភ្ងាអញ ជាទីពេញចិត្តអញណាស់* ដូចពាក្យដែលព្រះអម្ចាស់មានបន្ទូលពីស្ថានសួគ៌នៅពេលព្រះយេស៊ូវទទួលពិធីជ្រមុជទឹកបញ្ជាក់ថា ទ្រង់ជាព្រះបុត្រានៃព្រះ(៣:១៧)។

**១៧:៦** *ភ័យស្លុត* ពេលជួបព្រះវត្តមានព្រះដ៏មានគ្រប់ព្រះចេស្តាជាលើកដំបូង

**១៧:១០** យោងតាម "មឡ ៤:៥-៦" ពួកគ្រូបង្រៀនក្រឹត្យវិន័យបានរំពឹងថាលោកអេលីយ៉ាត្រូវមកមុនការយាងមកដល់របស់ព្រះមែស៊ី ។ ពួកសិស្សទ្រង់បានយល់ថា ការផ្លាស់ប្រែរូបកាយរបស់ព្រះយេស៊ូវ នោះបានបង្ហាញថាទ្រង់ជាព្រះមែស៊ី ហើយចុះហេតុអ្វីបានជាមិនឃើញលោកអេលីយ៉ា?

**១៧:១២** *គេធ្វើទុកដូច្នោះដែរ* គេមិនទទួលស្គាល់លោកយ៉ូហានបាទីស្ទទេថែមទាំងសម្លាប់គាត់ទៀត ព្រះយេស៊ូវក៏ត្រូវបានគេបដិសេធ និងធ្វើគុតទ្រង់ដូច្នោះដែរ ។

**១៧:១៣** មើលការពន្យល់ ១៦:១២ ។

## ការប្រោសក្មេងប្រុសដែលមានអារក្សចូល

*១៧:១៤–១៩ = មក ៩:១៤–២៨ លក ៩:៣៧–៤២*

១៤កាលបានមកដល់ហ្វូងមនុស្សហើយ នោះមានម្នាក់មក
លុតជង្គង់ ក្រាបនៅចំពោះទ្រង់ទូលថា ១៥ព្រះអម្ចាស់
អើយ សូមទ្រង់ប្រោសមេត្តាដល់កូនទូលបង្គំ ដែលឆ្កួតជ្រូក
ផង[ថ] វារវេទនាណាស់ ចេះតែដួលទៅក្នុងភ្លើង នឹងក្នុង
ទឹកជាញយៗ ១៦ទូលបង្គំបាននាំវាមកឯសិស្សទ្រង់ដែរ តែ
គេមើលមិនជាសោះ ១៧ព្រះយេស៊ូវទ្រង់មានបន្ទូល
ឆ្លើយថា ឱដំណមនុស្ស ដែលមិនជឿ ហើយមានចិត្តវៀច
អើយ តើត្រូវឱ្យខ្ញុំនៅជាមួយនឹងអ្នករាល់គ្នាដល់កាលណា
តើត្រូវឱ្យខ្ញុំទ្រាំនឹងអ្នករាល់គ្នាដល់កាលណាទៀត ចូរនាំ
វាមកឯខ្ញុំឯណេះ ១៨នោះព្រះយេស៊ូវទ្រង់បន្ទោសដល់
អារក្ស ហើយវាក៏ ចេញពីក្មេងនោះទៅ រួចក្មេងនោះបាន
ជា ចាប់តាំងពីវេលានោះមក ។
១៩នោះពួកសិស្សមកឯព្រះយេស៊ូវដោយឡែក ទូល
សួរថា ហេតុអ្វីបានជាយើងខ្ញុំ ដេញអារក្សនោះមិនបាន
២០ទ្រង់មានបន្ទូលតបថា គឺដោយព្រោះតែអ្នករាល់គ្នា
មានសេចក្ដីជំនឿតិចពេកប៉ុណ្ណោះ ដ្បិតខ្ញុំប្រាប់ជាប្រាកដថា
បើមានសេចក្ដីជំនឿ[ទ]ដូចគ្រាប់ពូជ១យ៉ាងល្អិត[ធ]នោះអ្នក
រាល់គ្នាអាចនឹងនិយាយទៅភ្នំនេះថា ចូររើចេញពីទីនេះ
ទៅនៅទីនោះចុះ នោះនឹងបានដូច្នោះហើយ ក៏គ្មានការអ្វី
ដែលអ្នករាល់គ្នាធ្វើមិនកើតនោះទេ[ន] ២១តែអារក្សបែប
យ៉ាងនេះ វាចេញទៅដោយសារតែអធិស្ឋាន ហើយនិងតម
អត់ប៉ុណ្ណោះ។
២២កាលគង់នៅស្រុកកាលីឡេ នោះព្រះយេស៊ូវមានបន្ទូល
ទៅពួកសិស្សថា បន្តិចទៀត កូនមនុស្ស[ប]នឹងត្រូវបញ្ជូនទៅ
ក្នុងកណ្ដាប់ដៃនៃមនុស្ស ២៣គេនឹងសំឡាប់លោក[ផ] ហើយ៣
ថ្ងៃ[ព]ក្រោយមក លោកនឹងរស់ឡើងវិញ[ភ] នោះពួកសិស្ស
កើតមានសេចក្ដីព្រួយជាខ្លាំង ។

## ពន្ធព្រះវិហារ

២៤កាលបានមកដល់ក្រុងកាពើណិមហើយ នោះពួកអ្នក
ដែលទារពន្ធ[ម]ព្រះវិហារ គេមកសួរពេត្រុសថា តើគ្រូអ្នក
មិនបង់ពន្ធព្រះវិហារទេឬអី ២៥គាត់ឆ្លើយថា បង់ដែរ
រួចមក កាលគាត់បានចូលទៅក្នុងផ្ទះហើយ នោះព្រះយេ
ស៊ូវទ្រង់មានបន្ទូលជាមុន សួរគាត់ថា នែ ស៊ីម៉ូន អ្នកគិតដូច
ម្ដេច តើអស់ទាំងស្ដេចនៅផែនដីហូតស្ួយរ៉ៃ ឬពន្ធដារ[យ]
ពីអ្នកណា ពីកូនចៅ ឬ ពីអ្នកដទៃ ២៦ពេត្រុសទូលឆ្លើយ
ថា ពីមនុស្សដទៃទេ ទ្រង់មានបន្ទូលថា ដូច្នេះ កូនចៅបាន
រួចហើយ ២៧ប៉ុន្តែ ចូរអ្នកទៅ ឯសមុទ្រ ហើយបោះសន្ទូច
ចាប់យកត្រីដែលជាប់មុនដំបូង មកបើកមាត់វា នោះអ្នក
នឹងឃើញប្រាក់១រៀល ឱ្យយក ប្រាក់នោះទៅបង់សំរាប់ខ្ញុំ
ហើយនិងអ្នកទៅ ដើម្បីកុំឱ្យ យើងបានជាទីអាក់អន់ចិត្ត[រ]
ដល់គេ។

## អ្នកដែលធំជាងគេបំផុតនៅនគរស្ថានសួគ៌

*១៨:១–៥ = មក ៩:៣៣–៣៧ លក ៩:៤៦–៤៨*

**១៨** ១នៅវេលានោះឯង ពួកសិស្សមកឯព្រះយេស៊ូវ
ទូលសួរថា តើអ្នកណាធំជាងគេក្នុងនគរស្ថានសួគ៌ ២តែ
ទ្រង់ហៅកូនក្មេងតូច១មក ដាក់នៅកណ្ដាលពួកគេ
៣រួចមានបន្ទូលថា ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើ
អ្នករាល់គ្នាមិនផ្លាស់គំនិត ហើយត្រឡប់ដូចជាកូនតូច[ល]
នេះនោះនឹងចូលទៅក្នុងនគរស្ថានសួគ៌ពុំបានឡើយ
៤ដូច្នេះអ្នកណាដែលបន្ទាបខ្លួន ឱ្យបានដូចកូនតូចនេះ អ្នក
នោះឯងឈ្មោះថា ធំជាងគេក្នុងនគរស្ថានសួគ៌ហើយ[វ]
៥អ្នកណាដែលទទួលកូនតូចណាមួយដូចកូននេះ ដោយនូវ

**១៧:១៥** ថ មថ ៤:២៤
**១៧:២០** ទ មថ ២១:២១
ធ មថ ១៣:៣១ លក ១៧:៦
ន ១កថ ១៣:២
**១៧:២២** ប មថ ៨:២០
**១៧:២៣** ផ កថ ២:២៣ ៣:១៣
ព មថ ១៦:២១
ភ មថ ១៦:២១
**១៧:២៤** ម នក ៣០:១៣
**១៧:២៥** យ មថ ២២:១៧–២១ រម ១៣:៧
**១៧:២៧** រ យហ ៦:៦១
**១៨:៣** ល មថ ១៩:១៤ ១ពត ២:២ មថ ៣:២
**១៨:៤** វ មក ៩:៣៥

**១៧:១៥** *ឆ្កួតជ្រូក* មើលការពន្យល់ ៤:២៤ ។
**១៧:១៨** មិនមែនគ្រប់ទាំងមនុស្សអារក្សចូល បណ្ដាលឱ្យឆ្កួតជ្រូកនោះទេ តែក្នុងករណីនេះគឺមកពីអារក្ស ។
**១៧:២០** *ជំនឿតិច* ចំនួននៃសេចក្ដីជំនឿមានមិនគ្រប់ទៅនឹងគុណសម្បត្តិនៃសេចក្ដីជំនឿរឹងមាំ នោះគឺដោយការអធិស្ឋាន(មក ៩:២៩)។ *គ្រាប់ពូជ* មើលការពន្យល់ ១៣:៣១–៣២ ។ *និយាយ..."ចូររើ...ទៅ..."* ជាឃ្លាសុភាសិតមានន័យថា ដកចេញនូវបញ្ហាពិបាកៗ(អស ៥៤:១០ ១កថ ១៣:២)។ នេះប្រហែលជាសំដៅទៅលើការដកយកចេញនូវបញ្ហា ទាំងឡាយដែលទាក់ទងនឹងនគរព្រះ ។
**១៧:២១** មើលការការពន្យល់ក្នុង ខ.២០ ។
**១៧:២២** នេះគឺជាទំនាយលើកទី២នៃការសុគតរបស់ព្រះគ្រីស្ទ (ទី១នៅ ១៦:២១)។
**១៧:២៤** *ពន្ធព្រះវិហារ* មនុស្សដែលមានអាយុ២០ឆ្នាំឡើងទៅ(នក ៣០:១៣ ២របា ២៤:៩ នហ ១០:៣២ ត្រូវតម្រូវឱ្យបង់ពន្ធព្រះវិហារជាប្រចាំឆ្នាំ តម្លៃប្រហែលស្មើនឹងកម្លាំងពលកម្មរបស់មនុស្សចំនួន២ថ្ងៃ) សម្រាប់ទំនុកបម្រុងព្រះវិហារ ។
**១៧:២៥** *សួយរ៉ៃ* មានន័យថា សួយសារអាករ ឬពន្ធដារ ។
**១៧:២៦** *កូនចៅបានរួចហើយ* មានន័យថាលោកពេត្រុស និងសិស្សឯទៀតនៅក្នុងដំណាក់នៃព្រះ តែសាសន៍យូដាដែលមិនជឿនោះមិនបាននៅទេ(២១:៤៣)។
**១៨:១** *តើអ្នកណាធំជាងគេក្នុងនគរស្ថានសួគ៌?* មើលពន្យល់ លក ៩:៤៦ ។
**១៨:៣** *ដូចជាកូនតូចនេះ* គឺមានការទុកចិត្ត និងមិនប្រកាន់ថាខ្លួនគ្រាន់បើ ។

ឈ្មោះខ្ញុំ នោះក៏ឈ្មោះថា ទទួលខ្ញុំដែរ[ស] ៦ប៉ុន្តែ បើអ្នកណា
ធ្វើឱ្យកូនតូចណាមួយនេះ ដែលជឿដល់ខ្ញុំ រវាតចិត្តចេញ[ហ]
នោះស៊ូឱ្យគេយកថ្មត្បាល់កិនយ៉ាងធំចងកអ្នកនោះ ហើយ
ពន្លង់ទៅក្នុងសមុទ្រទីជ្រៅវិញ[ឡ] ធ្វើយ៉ាងនោះនឹងមាន
ប្រយោជន៍ដល់អ្នកនោះជាជាង ៧វេទនាដល់លោកីយ
ដោយព្រោះអស់ទាំងហេតុដែលនាំឱ្យរវាតចិត្ត ដ្បិតសេចក្ដី
នោះត្រូវតែមាន តែវេទនាដល់មនុស្សណាដែលបង្កើត
ហេតុឱ្យរវាតចិត្តនោះ[អ] ៨បើសិនជាដៃ ឬជើងអ្នក នាំឱ្យ
គេរវាតចិត្ត[ក] នោះចូរកាត់ចោលទៅ ស៊ូឱ្យអ្នកចូលទៅក្នុង
ជីវិតកំបុតដៃជើងវិញ ជាជាងមានដៃជើងទាំង២ នឹងត្រូវ
បោះទៅក្នុងភ្លើង ដែលឆេះនៅអស់កល្បជានិច្ច ៩ហើយ
បើភ្នែកអ្នកនាំឱ្យគេរវាតចិត្ត[ខ] ចូរខ្វេះវាចោលទៅ ស៊ូឱ្យ
អ្នកចូលទៅក្នុងជីវិតមានភ្នែកតែ១វិញ ជាជាងមានភ្នែក
ទាំង២ នឹងត្រូវបោះទៅក្នុង ភ្លើងនរក[គ]។

## រឿងប្រៀបប្រដូចពីចៀមដែលបាត់

*១៨:១២–១៤ = លក ១៥:៤–៧*

១០ចូរប្រយ័ត្ន កុំឱ្យមើលងាយចំពោះកូនតូចណាមួយនោះ
ឡើយ ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាថា ទេវតា[ឃ]របស់វា ដែល
នៅស្ថានសួគ៌ តែងតែឃើញព្រះភក្ត្រព្រះវរបិតានៃខ្ញុំ
ជានិច្ច ដែលទ្រង់គង់នៅស្ថានសួគ៌ ១១ដ្បិតកូនមនុស្ស
បានមក ដើម្បីនឹងជួយសង្គ្រោះអ្នកណាដែលបាត់បង់
១២បើមនុស្សណាមានចៀម១រយ ហើយមាន១វង្វេងបាត់
តើអ្នករាល់គ្នាគិតដូចម្ដេច តើមិនទុកចៀម៩៩នៅលើ
ភ្នំនឹងទៅរកចៀម១ ដែលវង្វេងបាត់នោះទេឬអី ១៣ខ្ញុំ
ប្រាប់អ្នករាល់គ្នាជាប្រាកដថា បើរកឃើញ នោះមាន
សេចក្ដីអំណរចំពោះចៀមនោះ ជាជាងចៀម៩៩ដែលមិន
បានវង្វេងទៅទៀត ១៤ដូច្នេះ ព្រះវរបិតានៃអ្នករាល់គ្នា
ដែលគង់នៅស្ថានសួគ៌ ទ្រង់ក៏មិនសព្វព្រះហឫទ័យ ឱ្យកូន
តូចណាមួយនេះ ត្រូវវិនាសដូច្នោះដែរ ។

## ការដែលបងប្អូនធ្វើបាបទាស់នឹងអ្នក

១៥បើបងប្អូនធ្វើបាបនឹងអ្នក នោះឱ្យទៅបន្ទោស[ង]គាត់
ក្នុងកាលដែលមានតែអ្នកហើយនិងគាត់ បើគាត់ស្ដាប់អ្នក
នោះអ្នកនឹងបានបងប្អូននោះមកវិញ ១៦តែបើគាត់មិន
ព្រមស្ដាប់ទេ នោះត្រូវយកមនុស្សម្នាក់ឬ២នាក់ទៅជាមួយ
ដើម្បីនឹងបញ្ជាក់គ្រប់ទាំងពាក្យ ដោយសារស្មរ បន្ទាល់[ច]
២ឬ ៣នាក់ ១៧បើគាត់មិនព្រមស្ដាប់អ្នកទាំងនោះ ទេនោះ
ត្រូវតែប្រាប់ដល់ពួកជំនុំ[ឆ] ហើយបើមិនព្រមស្ដាប់ ពួកជំនុំ
ទៀត នោះត្រូវតែរាប់គាត់ទុកជាអ្នកក្រៅសាសន៍ ឬជាអ្នក
យកពន្ធវិញ[ជ] ១៨ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នក
រាល់គ្នាចងទុក អ្វីៗនៅផែនដី នោះនឹងត្រូវចងទុកនៅស្ថាន
សួគ៌ដែរ ហើយបើស្រាយអ្វីៗនៅផែនដី នោះក៏នឹងត្រូវ
ស្រាយនៅស្ថានសួគ៌ ដែរ[ឈ] ១៩មួយទៀត ខ្ញុំប្រាប់ថា បើ
សិនជាមាន២នាក់ក្នុងពួកអ្នករាល់គ្នា ព្រមព្រៀងគ្នានៅ
ផែនដី ពីដំណើរអ្វីដែលគេចង់សូមក៏ដោយ នោះនឹងបាន
សំរេចដល់គេ[ញ] អំពីព្រះវរបិតាខ្ញុំ ដែលគង់នៅស្ថានសួគ៌
២០ដ្បិតកន្លែងណាដែលមាន២ឬ៣នាក់ ប្រជុំជាមួយគ្នាដោយ
នូវឈ្មោះខ្ញុំ នោះខ្ញុំក៏នៅកណ្ដាលចំណោមអ្នកទាំងនោះ
ដែរ[ដ]។

## រឿងប្រៀបប្រដូចអំពីអ្នកបម្រើមិនមានចិត្តមេត្តា

២១ខណៈនោះ ពេត្រុសក៏មកឯទ្រង់ទូលថា ព្រះអម្ចាស់
អើយ បើបងប្អូនធ្វើបាបនឹងខ្ញុំ[ឋ] នោះត្រូវឱ្យខ្ញុំអត់ទោស
ឱ្យគេដល់ប៉ុន្មានដង តើដល់៧ដងឬអី[ឌ] ២២ព្រះយេស៊ូវទ្រង់
មានបន្ទូលតបថា ខ្ញុំមិនថា ឱ្យអ្នកអត់ ទោសត្រឹមតែ៧ដងទេ
គឺដល់៧ចិតសិបដងទៅទៀត[ឍ] ២៣ដូច្នេះ នគរស្ថានសួគ៌ត្រូវ
ប្រៀបដូចជា[ណ]ស្ដេច១អង្គ ដែលចង់គិតបញ្ជី[ត] នឹងពួកបាវ

**១៨:៥** ស មថ ១០:៤០
**១៨:៦** ហ មថ ៥:២៩ ឡ មក ៩:៤២ លក ១៧:២
**១៨:៧** អ លក ១៧:១
**១៨:៨** ក មថ ៥:២៩
**១៨:៩** ខ មថ ៥:២៩ គ មថ ៥:២២
**១៨:១០** ឃ លក ៤៨:១៦ ទដ ៣៤:៧ កថ ១២:១១,១៥ ហព ១:១៤
**១៨:១៥** ង លវ ១៩:១៧ លក ១៧:៣ កទ ៦:១ យក ៥:១៩,២០
**១៨:១៦** ច ជន ៣៥:៣០ ចទ ១៧:៦ ១៩:១៥ យហ ៨:១៧ ២កថ ១៣:១ ១ធថ ៥:១៩ ហព ១០:២៨
**១៨:១៧** ឆ ១កថ ៦:១–៦ ជ រម ១៦:១៧
**១៨:១៨** ឈ មថ ១៦:១៩ យហ ២០:២៣
**១៨:១៩** ញ មថ ៧:៧
**១៨:២០** ដ មថ ២៨:២០
**១៨:២១** ឋ មថ ៦:១៤ ឌ លក ១៧:៤
**១៨:២២** ឍ លប ៤:២៤
**១៨:២៣** ណ មថ ១៣:២៤ ត មថ ២៥:១៩

**១៨:៦** *ថ្មត្បាល់កិន* គឺសំដៅលើថ្មធំសម្បើមពីបុរាណ ដែលប្រើសត្វលាសម្រាប់អូសមិនមែនត្បាល់តូចៗនៅតាមផ្ទះ ដែលប្រើកម្លាំងមនុស្សនោះទេ (២៤:៤១)។

**១៨:៨–៩** មើលការពន្យល់ ៥:២៩–៣០ ។

**១៨:១០** *ទេវតារបស់វា* ទេវតាការពារមិនមែនសម្រាប់តែក្មេងៗនោះទេ គឺសម្រាប់កូនរបស់ព្រះទូទៅ (ទដ ៣៤:៧ ៩១:១១ ហព ១:១៤)។

**១៨:១២–១៤** រឿងប្រៀបប្រដូចពីចៀមដែលបាត់ ក៏មាននៅក្នុង លក ១៥:៣–៧ ប្រើសម្រាប់អ្នកមិនជឿ តែនៅទីនេះគឺសម្រាប់អ្នកជឿ ។ ព្រះយេស៊ូវប្រើរឿងតែមួយ ដើម្បីបង្រៀនពីសេចក្ដីពិតផ្សេងៗគ្នា ក្នុងស្ថានភាពខុសៗគ្នា ។

**១៨:១២** *ចៀម* មើលការពន្យល់ លក ១៥:៤ ។

**១៨:១៥** *បង ប្អូន* គឺអស់អ្នកជឿលើព្រះយេស៊ូវគ្រីស្ទ ។

**១៨:១៧** *ពួកជំនុំ* ទីកន្លែងសម្រាប់ថ្វាយបង្គំព្រះ មានប្រើពាក្យនេះ តែពីរដងប៉ុណ្ណោះក្នុងដំណឹងល្អមួយនៅទីនេះ និងមួយទៀត"១៦:១៨"។ *ក្រៅសាសន៍* សម្រាប់ពួកយូដា និងសាសន៍ដទៃទៀត ។ *អ្នកយកពន្ធ* មើលការពន្យល់ ៥:៤៦ ។ ខនេះជាមូលដ្ឋាន សម្រាប់ការដេញអ្នកណាម្នាក់ចេញពីក្រុម ។

**១៨:១៨** មើលការពន្យល់ ១៦:១៩ ។

**១៨:២២** *៧ចិតសិបដង* មានន័យថា ៧០គុណនឹង៧ជាលេខតំណាង "រាប់មិនអស់"។

**១៨:២៣** *នគរស្ថានសួគ៌* មើលការពន្យល់ ៣:២ ។

ព្រាវ ២៤កាលទ្រង់ចាប់តាំងគិត នោះគេនាំកូនបំណុលម្នាក់
មក ដែលជំពាក់ប្រាក់២ កោដិ ២៥តែដោយព្រោះអ្នកនោះ
គ្មានអ្វីនឹងសង[ថ] បានជាចៅហ្វាយបង្គាប់ឱ្យលក់[ទ]ខ្លួនវា ព្រម
ទាំងប្រពន្ធកូន នឹងរបស់ទាំងអស់ ដើម្បីនឹងសងបំណុល
នោះ ២៦ហេតុដូច្នេះ បាវនោះបានទំលាក់ខ្លួនក្រាបចុះ[ធ]
ថ្វាយបង្គំទូលថា បពិត្រព្រះករុណា សូមទ្រង់មេត្តាបង្អង់
ឱ្យទូលបង្គំសិន ទូលបង្គំនឹងសងថ្វាយទ្រង់គ្រប់ចំនួន
២៧ឯចៅហ្វាយ របស់បាវនោះ មានព្រះទ័យក្តួលអាណិត
ក៏លែងវាឱ្យទៅ ព្រមទាំងលែងទារបំណុលផង ២៨តែ
កាលបាវនោះបានចេញទៅហើយ ក៏ជួបប្រទះនឹងគូកន
ម្នាក់ ដែលជំពាក់ខ្លួន២០រៀល នោះវាចាប់ច្របាច់កអ្នក
នោះ ដោយពាក្យថា ចូរសងប្រាក់ដែលជំពាក់អញនោះ
មក ២៩អ្នកនោះក៏ទំលាក់ខ្លួន ក្រាបចុះនៅទៀបជើង
សូមអង្វរថាសូមមេត្តាបង្អង់ឱ្យខ្ញុំសិន ខ្ញុំនឹងសងជូនអ្នក
៣០តែវាមិនព្រមទេ ត្រឡប់ជាបានចាប់អ្នកនោះ នាំទៅ
ដាក់គុកវិញ ទាល់តែបានសងបំណុលរួច ៣១កាលពួកគូកន
គេបានឃើញការនោះ គេមានចិត្តឈឺឆ្អាលណាស់ ក៏នាំគ្នា
ទៅទូលដល់ចៅហ្វាយ ពីការទាំងប៉ុន្មានដែលកើតមក។
៣២ចៅហ្វាយក៏ឱ្យគេហៅបាវនោះមក រួចមានបន្ទូលថា
នែ៎ អាបំរើអាក្រក់ អញបានលែងទារបំណុលឯងទាំង
អស់ហើយតើ ពីព្រោះឯងបានអង្វរដល់អញ ៣៣ដូច្នេះ
តើមិនគួរឱ្យឯងអាណិតមេត្តាដល់គូកនឯង ដូចជាអញ
បានអាណិតមេត្តាដល់ឯងដែរទេឬអី ៣៤ចៅហ្វាយក៏មាន
សេចក្តីក្រោធ ហើយបញ្ជូនវាទៅឯមេភូឃុំ ទាល់តែបាន
សងបំណុលនោះគ្រប់ចំនួន ៣៥យ៉ាងនោះ បើអ្នករាល់គ្នា
មិនអត់ទោសការរំលងរបស់បងប្អូនដោយស្ម័គ្រពីចិត្តទេ
នោះព្រះវរបិតានៃខ្ញុំ ដែលគង់នៅស្ថានសួគ៌ ទ្រង់ក៏នឹងប្រ
ព្រឹត្តនឹងអ្នករាល់គ្នាដូច្នោះដែរ[ន]។

**១៨:២៥** ថ លក ៧:៤២ ទ លវ ២៥:៣៩ ២ពវ ៤:១ នហ ៥:៥,៨
**១៨:២៦** ធ មថ ៨:២
**១៨:៣៥** ន មថ ៦:១៤ យក ២:១៣
**១៩:១** ប មថ ៧:២៨
**១៩:២** ផ មថ ៤:២៣
**១៩:៣** ព មថ ៥:៣១
**១៩:៤** ភ លប ១:២៧ ៥:២
**១៩:៥** ម លប ២:២៤ ១កថ ៦:១៦ អភ ៥:៣១
**១៩:៧** យ ចទ ២៤:១-៤ មថ ៥:៣១
**១៩:៩** រ លក ១៦:១៨

## ការលែងលះប្តី ប្រពន្ធ

*១៩:១-៩ = មក ១០:១-១២*

**១៩** ១លុះព្រះយេស៊ូវបានមានបន្ទូលពាក្យ[ប]ទាំងនោះរួច
ហើយ នោះទ្រង់ថយចេញពីស្រុកកាលីឡេ ទៅឯព្រំស្រុក
យូដា នៅខាងនាយទន្លេយ័រដាន់វិញ ២ហើយមានហ្វូង
មនុស្សកកកុញតាមទ្រង់ទៅ នៅទីនោះទ្រង់ក៏ប្រោសឱ្យគេ[ផ]
បានជា។

៣រីឯពួកផារិស៊ី គេមកល្បួងទ្រង់ដោយទូលថា តើមនុស្ស
មានច្បាប់នឹងលែងប្រពន្ធ[ព] ដោយហេតុណាក៏ដោយ
បានឬទេ ៤ទ្រង់មានបន្ទូលតបថា តើអ្នករាល់គ្នាមិនបាន
មើល រឿងពីព្រះ ដែលទ្រង់បង្កើតមនុស្សកាលពីដើម
ថាទ្រង់បាន ធ្វើឱ្យមានទាំងប្រុសទាំងស្រីទេឬអី[ភ]
៥រួចក៏មានបន្ទូលថា ដោយហេតុនោះបានជាមនុស្សប្រុស
នឹងលាចេញពីឪពុកម្តាយ ទៅនៅជាប់នឹងប្រពន្ធ ហើយអ្នក
ទាំង២នោះនឹង ត្រឡប់ជាសាច់តែ១សុទ្ធ[ម] ៦យ៉ាងនោះ
គេមិនមែនជា២ទៀត គឺជាសាច់តែ១ទេ ដូច្នេះ កុំឱ្យ
អ្នកណាពង្រាត់មនុស្ស ដែលព្រះទ្រង់បានផ្សំផ្គុំគ្នាឡើយ
៧គេទូលសួរទ្រង់ថាចុះហេតុដូចម្តេចបានជាលោកម៉ូសេ
បង្គាប់ឱ្យធ្វើសំបុត្រលះលែង ហើយឱ្យលែងចេញដូច្នេះ[យ]
៨ទ្រង់ក៏មានបន្ទូលតបថា បានជាលោកម៉ូសេអនុញ្ញាតឱ្យ
អ្នករាល់គ្នាលែងប្រពន្ធទៅ គឺដោយព្រោះតែចិត្តអ្នករាល់
គ្នារឹងរបឹងប៉ុណ្ណោះ តែពីដើមមកមិនមែនដូច្នោះទេ។
៩ហើយខ្ញុំប្រាប់អ្នករាល់គ្នាថា អ្នកណាដែលលែងប្រពន្ធ
មិនមែនដោយព្រោះនាងនោះផិត ហើយទៅយកប្រពន្ធ
មួយទៀត អ្នកនោះឈ្មោះថាប្រព្រឹត្តសេចក្តីកំផិតហើយ ឯ
អ្នកណាដែលយកប្រពន្ធ ជាស្រីដែលប្តីដើមលែង នោះក៏
ប្រព្រឹត្តសេចក្តីកំផិតដែរ[រ] ១០ពួកសិស្សទូលទ្រង់ថា បើ

**១៨:២៥** សម្រាប់ការអនុវត្តន៍ក្នុងខនេះ គឺការលក់ខ្លួនធ្វើជាទាសករ សូមមើល "នក ២១:២ លវ ២៥:៣៩ ២ពវ ៤:១ នហ ៥:៥ អស ៥០:១"។

**១៨:៣៥** *អត់ទោស* គឺជាសេចក្តីបង្រៀនដ៏សំខាន់នៃរឿងប្រៀបប្រដូច ។

**១៩:១** *នៅខាងនាយទន្លេយ័រដាន់* គឺនៅទិសខាងកើត ដែលគេហៅថា ត្រើយទន្លេយ័រដាន់ ឬក៏ពេរ៉េសៗថ្ងៃនេះគេហៅថាតំបន់យ័រដាន់ ជាកន្លែងដែលព្រះយេស៊ូវបំពេញរាជកិច្ចនៅទីនោះ (មើលការពន្យល់ លក ១៣:២២)។

**១៩:៣** *ផារិស៊ី* មើលការពន្យល់ មក ២:១៦ ។ *ដោយហេតុណាក៏ដោយ* ផ្នែកចុងក្រោយនៃសំណួរនេះមិនមាននៅក្នុងរឿងប្រៀបប្រដូចក្នុង"មក ១០:២"នោះទេ ។ លោកម៉ាថាយបញ្ចូលរឿងនេះ ដោយព្រោះគាត់សរសេរទៅកាន់សាសន៍យូដា ដែលបានដឹងរឿងពីការប្រកែកគ្នារវាងសាលាសាមម៉ាយ (shammai) និង ហ៊ីលេល (Hillel) ស្តីពីការបកស្រាយបទគម្ពីរ "ចទ ២៤:១-៤"។ សាមម៉ាយថា "អ្វីមួយដែលមិនសមរម្យ" មានន័យថា "ការផិតក្បត់ប្តីប្រពន្ធ" ដែលអាចបណ្តាល ឱ្យលែងលះគ្នាបាន ។ ចំណែកសាលាហ៊ីលេល (ឆ្នាំ៦០មុនគ.ស-២០គ.ស) ថា ជាប្រយោគពីមុនដែលមានន័យថា "ស្ត្រីដែលក្លាយជាការមិនពេញចិត្តដល់ប្តី" គេអាចអនុញ្ញាតឱ្យបុរសលែងប្រពន្ធបាន បើស្ត្រីនោះបានធ្វើអ្វីមួយដែលប្តីមិនពេញចិត្ត សូម្បីតែចំអិនអាហារខ្លោចក៏ដោយ ។ ព្រះយេស៊ូវបានយល់ស្របតាមសាលាសាមម៉ាយ (ខ.៩) តែចំណុចមុនដំបូងទេ ហើយផ្នែកផ្សេងទៀតគឺត្រឡប់មកគំនិតដើមនៃអាពាហ៍ពិពាហ៍ក្នុងព្រះអម្ចាស់វិញ (លប ១:២៧ ២:២៤)។

របៀបនៃមនុស្សដែលមាន ប្រពន្ធត្រូវជាយ៉ាងនេះ
នោះស៊ូកុំយកគ្នាជាជាង ១១តែទ្រង់មានបន្ទូលថា មនុស្ស
ទាំងអស់ទទួលតាមពាក្យនេះមិនបានទេ ទទួលបានតែ
អស់អ្នកដែលពាក្យនេះបាន ប្រទានមកឱ្យប៉ុណ្ណោះ[ល]
១២ពីព្រោះ មានមនុស្សខ្ទើយ ដែលកើតពីផ្ទៃម្ដាយមក
ខ្ទើយតែម្ដង មានខ្លះដែលមនុស្សលោកបានក្រៀវ ហើយ
មានខ្លះដែលក្រៀវខ្លួនឯងដែរ ដោយយល់ដល់នគរស្ថាន
សួគ៌ ដូច្នេះ អ្នកណាដែលអាចនឹងទទួល បាន ឱ្យទទួលចុះ។

## ព្រះយេស៊ូវ និងកូនក្មេងតូចៗ

*១៩:១៣–១៥ = មក ១០:១៣–១៦ លក ១៨:១៥–១៧*

១៣លំដាប់នោះ មានគេនាំក្មេងតូចៗមកឯទ្រង់ ដើម្បីឱ្យ
ទ្រង់ដាក់ព្រះហស្តអធិស្ឋានឱ្យវា[វ] តែពួកសិស្សបន្ទោសដល់
គេ ១៤នោះព្រះយេស៊ូវទ្រង់មានបន្ទូលថា ទុកឱ្យកូនក្មេង
មកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរស្ថានសួគ៌មាន[ស]សុទ្ធតែ
មនុស្សដូចវារាល់គ្នា[ហ] ១៥ទ្រង់ក៏ដាក់ព្រះហស្តលើវារាល់
គ្នា រួចយាងចេញពីទីនោះទៅ ។

## បុរសអ្នកមានវ័យក្មេង

*១៩:១៦–២៩ = មក ១០:១៧–៣០ លក ១៨:១៨–៣០*

**១៩:១១** ល មថ ១៣:១១ ១កថ ៧:៧–៩,១៧
**១៩:១៣** វ មក ៥:២៣
**១៩:១៤** ស មថ ២៥:៣៤ ហ មថ ១៨:៣ ១ពត ២:២
**១៩:១៦** ឡ មថ ២៥:៤៦ អ លក ១០:២៥
**១៩:១៧** ក លវ ១៨:៥
**១៩:១៨** ខ យក ២:១១
**១៩:១៩** គ នក ២០:១២–១៦ ចទ ៥:១៦–២០ ឃ លវ ១៩:១៨ មថ ៥:៤៣
**១៩:២១** ង មថ ៥:៤៨ ច កច ២:៤៥ ឆ មថ ៦:២០

១៦នោះមានម្នាក់មកទូលសួរទ្រង់ថា លោកគ្រូល្អអើយ
តើត្រូវឱ្យខ្ញុំធ្វើការល្អអ្វី ឱ្យបានជីវិតរស់នៅអស់កល្ប[ឡ]ជា
និច្ច[អ] ១៧ទ្រង់មានបន្ទូលទៅគាត់ថា ហេតុអ្វីបានជាអ្នកហៅខ្ញុំ
ថាជាល្អដូច្នេះ មានតែ១ទេដែលល្អ គឺជាព្រះ តែបើអ្នក
ចង់ចូលទៅក្នុងជីវិត ចូរកាន់តាមបញ្ញត្តទាំងប៉ុន្មានចុះ[ក]
១៨គាត់ទូលសួរថា តើបញ្ញត្តណាខ្លះ នោះព្រះយេស៊ូវ
មានបន្ទូលថា «កុំឱ្យសំឡាប់មនុស្សឱ្យសោះ កុំឱ្យផិតគ្នាឱ្យ
សោះ[ខ] កុំឱ្យលួចឱ្យសោះ កុំឱ្យធ្វើជាទីបន្ទាល់ក្លែងឱ្យសោះ
១៩ចូរគោរពប្រតិបត្តិឪពុកម្ដាយ»[គ] ហើយ «ចូរស្រឡាញ់
អ្នក ជិតខាងដូចខ្លួនឯង»[ឃ] ២០មនុស្សកំឡោះនោះក៏ទូល
ទ្រង់ថា ខ្ញុំបានកាន់តាមគ្រប់ សេចក្ដីទាំងនោះតាំងពីក្មេង
មកហើយ តើនៅខ្វះអ្វីទៀត ២១នោះទ្រង់មានបន្ទូល
ថា បើអ្នកចង់បានជាគ្រប់លក្ខណ៍[ង] ចូរអ្នកទៅលក់របស់
ទ្រព្យខ្លួន ហើយចែកដល់ពួកអ្នកក្រីក្រ[ច]ទៅ នោះអ្នកនឹង
បានទ្រព្យសម្បត្តិ នៅឯស្ថានសួគ៌ វិញ[ឆ] រួចឱ្យមកតាមខ្ញុំចុះ
២២កាលមនុស្សកំឡោះបានឮព្រះបន្ទូលនោះហើយ នោះ
ក៏ចេញទៅទាំងព្រួយចិត្ត ព្រោះមានទ្រព្យសម្បត្តិជាច្រើន ។
២៣នោះព្រះយេស៊ូវ ទ្រង់មានបន្ទូលនឹងពួកសិស្សថា ខ្ញុំ

**១៩:១០–១២** សូមមើល ១កថ ៧:៧–៨,២៦,៣២–៣៥ ។

**១៩:១១** *ពាក្យនេះ* ជាការសរុបសេចក្ដីរបស់សាវ័ក"ខ.១០"។ "ស៊ូកុំយកគ្នា ឬកុំឱ្យរៀបការ វាប្រសើរជាង" មិនមែនគ្រប់គ្នាអាចទទួលសេចក្ដីបង្រៀននេះបានទេ ពីព្រោះវាមិនមានន័យសម្រាប់គ្រប់គ្នាទាំងអស់នោះដែរ ។ ក្រោយមកព្រះយេស៊ូវ បានប្រទានឧទាហរណ៍ពីមនុស្សបីប្រភេទដែលមានអត្ថន័យនៅក្នុងខ.១២ ។

**១៩:១២** នៅវគ្គនេះគាត់បានក្រៀវខ្លួនឯងដោយយល់ដល់នគរស្ថានសួគ៌ គឺជាម្នាក់ដែល ស្ម័គ្រចិត្តលះបង់ដំណើរជីវិតសេចក្ដីសុខផ្ទាល់ខ្លួន ដើម្បីបំពេញកិច្ចការរបស់ព្រះឱ្យបានពេញបរិបូរ ។ ក្នុងករណីលះបង់ដូច្នេះ ត្រូវបានពណ៌នាក្នុងព្រះគម្ពីរ ១កថ ៧:២៥–៣៨ ប៉ុន្តែ មិនបានបង្ហាញពីអាពាហ៍ពិពាហ៍ដ៏ឧត្ដុង្គឧត្ដមនោះទេ ។

**១៩:១៤** *នគរស្ថានសួគ៌* មើលការពន្យល់ ៣:២ ។ *សុទ្ធតែមនុស្សដូចវារាល់គ្នា* មើលការពន្យល់ មក ១០:១៤ ។

**១៩:១៦** *ម្នាក់* មើលការពន្យល់ មក ១០:១៧)។ *តើត្រូវឱ្យខ្ញុំធ្វើការល្អ...?* អ្នកមានម្នាក់នេះ គិតដល់ភាពសុចរិតដែលបានមកពីការប្រព្រឹត្តបានជាព្រះយេស៊ូវកែតម្រង់ការយល់ខុសនោះ មុននឹងទ្រង់ឆ្លើយសំណួរគាត់ ។ *ជីវិតអស់កល្ប* ពាក្យនេះ បានប្រើដំបូងគេនៅក្នុងដំណឹងល្អម៉ាថាយ (ខ.២៩ ២៥:៤៦) ដំណឹងល្អ យ៉ូហាន ក៏មានប្រើញឹកញាប់ណាស់ដែរ តែជាញឹកញាប់ប្រើពាក្យ "នគរព្រះ ឬស្ថានសួគ៌"ជំនួសវិញ តែនៅក្នុងដំណឹងល្អបី (ម៉ាថាយ ម៉ាកុស លូកា) បញ្ជាក់ពី ន័យដូចគ្នា (១).ជីវិតអស់កល្ប(ខ.១៦ មក ១០:១៧ លក ១៨:១៨)។ (២).ចូល នគរស្ថានសួគ៌ (ខ.២៣ មក ១០:២៤ លក ១៨:២៤)។ (៣).ឱ្យបានសង្គ្រោះ (ខ.២៥–២៦ មក ១០:២៦–២៧ លក ១៨:២៦–២៧)។

**១៩:១៧** *មានតែមួយទេដែលល្អ នោះគឺជាព្រះ* ល្អនេះមិនមែនជាទង្វើដែលមនុស្សបានធ្វើនោះទេ គឺមានតែព្រះមួយអង្គគត់ដែលល្អ ហើយការល្អទាំងនោះបានមកពីទ្រង់ សូម្បីតែការប្រព្រឹត្តតាមបញ្ញត្តិព្រះយេស៊ូវ ដែលទ្រង់បានបង្គាប់ក្នុង (ខ.១៨–២០)។ *បើអ្នកចង់ចូលក្នុងជីវិត ចូរកាន់តាមបញ្ញត្តិទាំងនេះចុះ* "ចូលក្នុងជីវិត"ដូចនឹងន័យថា"ឱ្យបានជីវិតអស់កល្បជានិច្ច "ខ.១៦"។ សេចក្ដីតម្រូវគឺ "ឱ្យកាន់តាមបញ្ញត្តិ" មិនមែនធ្វើឡើង ដើម្បីឱ្យបានសគុណពីព្រះនោះទេ គឺដោយជំនឿដ៏ពិតប្រាកដ ។ ព្រះគម្ពីរបង្រៀនយើងថា សេចក្ដីសង្គ្រោះ គឺជាអំណោយទាននៃសេចក្ដីមេត្តាករុណារបស់ព្រះ ដែលបានប្រទានមកតាមរយៈជំនឿ (អភ ២:៨)។

**១៩:២០** *ខ្ញុំបានកាន់តាមគ្រប់...* មើលការពន្យល់ មក ១០:២០ ។

**១៩:២១** *គ្រប់លក្ខណ៍* តាមភាសាក្រិកមានន័យថា"ទៅដល់គោលដៅ" គោលដៅរបស់បុរសនេះគឺឱ្យបានជីវិតអស់កល្បជានិច្ច តែទ្រព្យសម្បត្តិ និងខ្វះការប្ដេជ្ញាចិត្តបានរាំងស្ទះផ្លូវគាត់។ *ចូរទៅ ហើយលក់ទ្រព្យសម្បត្តិ* បើតាមតារាងបញ្ជីបញ្ញត្តិព្រះយេស៊ូវលុបបញ្ញត្តិមួយ "កុំឱ្យលោភឱ្យសោះ" ដែលជាបញ្ហារបស់អ្នកមាននោះ និងកំពង់តែរារាំងគាត់មិនឱ្យចូលក្នុងជីវិត (មើលការពន្យល់ មក ១០:២១)។

**១៩:២២** *ចេញទៅទាំងព្រួយចិត្ត* មើលការពន្យល់ មក ១០:២២ ។

ប្រាប់អ្នករាល់គ្នាជាប្រាកដថា មនុស្សអ្នកមាន[ជ]នឹងចូលទៅ
ក្នុងនគរស្ថានសួគ៌ពិបាកណាស់ ២៤ខ្ញុំប្រាប់អ្នករាល់គ្នាទៀត
ថា ដែលសត្វអូដ្ឋនឹងចូលតាមប្រហោងម្ជុល នោះងាយ ជា
ជាងឱ្យមនុស្សអ្នកមានចូលទៅក្នុងនគរនៃព្រះវិញ។
២៥កាលពួកសិស្សបានឮដូច្នោះ នោះក៏នឹកប្លែកក្នុងចិត្តជា
ខ្លាំងក្រៃលែង ហើយទូលសួរថា ដូច្នេះ តើអ្នកណាអាច
នឹងបានសង្គ្រោះ ២៦ព្រះយេស៊ូវទ្រង់ទតទៅគេ ដោយបន្ទូល
ថា ការនោះមនុស្សលោកធ្វើមិនកើតទេ តែព្រះទ្រង់អាច
នឹងធ្វើកើត ទាំងអស់[ឈ]។
២៧ពេត្រុសទូលទ្រង់ថា មើល យើងខ្ញុំបានលះចោលទាំង
អស់មកតាមទ្រង់ហើយ[ញ] ដូច្នេះ តើយើងខ្ញុំនឹងបានអ្វីខ្លះ
២៨ព្រះយេស៊ូវទ្រង់មានបន្ទូលថា ខ្ញុំប្រាប់អ្នករាល់គ្នាជា
ប្រាកដថា ដល់គ្រាកែជាថ្មីឡើងវិញ កាលណាកូនមនុស្ស
បានឡើងគង់លើបល្ល័ង្កឧត្តម[ដ]របស់លោក នោះអ្នករាល់
គ្នាដែលបានមកតាមខ្ញុំ នឹងបានអង្គុយលើបល្ល័ង្ក១២ដែរ
ហើយនឹងជំនុំជំរះពូជអំបូរអ៊ីស្រាអែលទាំង១២[ឋ] ២៩ឯអស់
អ្នកណាដែលលះចោលផ្ទះសំបែង ឬបងប្អូនប្រុសស្រី ឪពុក
ម្តាយ ប្រពន្ធកូន ឬស្រែចំការ ដោយយល់ដល់ឈ្មោះខ្ញុំ[1]
នោះនឹងបានជា១រយភាគឡើងវិញ ហើយនិងបានគ្រង
ជីវិតអស់កល្បជានិច្ច ទុកជាមរដកដែរ[ឌ] ៣០តែនឹងមាន
មនុស្សមុន ទៅជាក្រោយជាច្រើន ហើយនឹងមានមនុស្ស
ក្រោយ ទៅជាមុនវិញ[ឍ]។

## រឿងប្រៀបប្រដូចអំពីអ្នកធ្វើការនៅចំការទំពាំងបាយជូរ

**២០** ១ដ្បិតនគរស្ថានសួគ៌ប្រៀបដូចជា[ណ]ថៅកែម្នាក់ ដែល
ចេញទៅពីព្រលឹម ដើម្បីនឹងជួលជើងឈ្នួល ឱ្យមកធ្វើការ
ក្នុងចំការទំពាំងបាយជូរ[ត]របស់ខ្លួន ២កាលបានព្រមគ្នានឹង
បើកឱ្យ២កាក់ម្នាក់ក្នុង១ថ្ងៃហើយ នោះក៏បញ្ជូនឱ្យទៅធ្វើ
ក្នុងចំការ ៣ដល់ពេលម៉ោង៩ព្រឹក គាត់ចេញទៅឃើញ
មនុស្សខ្លះ ទៀតឈរទំនេរនៅទីផ្សារ ៤ក៏ប្រាប់គេថា ចូរ
អ្នកទាំងឡាយនាំគ្នាទៅធ្វើការក្នុងចំការ របស់ខ្ញុំទៅខ្ញុំនឹង
បើកឱ្យតាមត្រឹមត្រូវ គេក៏ទៅ ៥ដល់ថ្ងៃត្រង់ ហើយពេល
ម៉ោង៣រសៀល គាត់ក៏ចេញទៅធ្វើ ដូច្នោះទៀត ៦លុះដល់
ពេលម៉ោង៥ គាត់ចេញទៅឃើញ មានមនុស្សខ្លះទៀតនៅ
ទំនេរ ក៏សួរគេថា ហេតុអ្វីបានជាអ្នករាល់គ្នាឈរទំនេរ
នៅទីនេះតាំងពីព្រលឹមមកដូច្នេះ ៧គេឆ្លើយថា ពីព្រោះ
គ្មានអ្នកណាជួលយើងខ្ញុំ រួចគាត់ប្រាប់ថា ចូរអ្នករាល់គ្នា
ទៅធ្វើការក្នុងចំការរបស់ខ្ញុំទៅនោះអ្នក នឹងទទួលឈ្នួល
តាមត្រឹមត្រូវ ៨ដល់ល្ងាច[ថ] ថៅកែចំការនោះ ប្រាប់ទៅ
នាយ ដំរួតការថា ចូរហៅពួកជើងឈ្នួល មកបើកឈ្នួល
ឱ្យគេចាប់តាំងពីមនុស្សក្រោយបង្អស់រៀងទៅដល់អ្នកមុន
ដំបូង ៩កាលពួកអ្នកដែលគាត់ជួលពីម៉ោង៥បានមកដល់
នោះគេបើកបាន២កាក់ម្នាក់ៗ ១០រួចកាលពួកមុនបង្អស់
បានមកដល់ គេស្មានថានឹងបានលើសជាងនោះទៅទៀត
តែអ្នកទាំងនោះក៏បានទទួល២កាក់ម្នាក់ដូចគ្នាដែរ ១១គ្រា
បានបើកប្រាក់ស្រេចហើយ នោះគេត្អូញត្អែរ[ទ]នឹងថៅ
កែថា ១២ពួកអ្នកដែលមកក្រោយនេះ គេធ្វើការតែ១
ម៉ោងសោះ ហើយលោកបានឱ្យគេស្មើនឹងយើងខ្ញុំ ដែល
ទ្រាំធ្វើការធ្ងន់[ធ]ទាំងហាលថ្ងៃតាំងពីព្រលឹមមកដែរ
១៣តែគាត់ឆ្លើយទៅម្នាក់នោះថា សំឡាញ់អើយ[ន] ខ្ញុំមិន
ធ្វើខុសនឹងអ្នកទេ តើអ្នកមិនបានសុខចិត្តព្រមទទួលតែ២
កាក់ទេឬអី ១៤ដូច្នេះចូរយកប្រាក់របស់អ្នកទៅៗ ខ្ញុំបាន
សំរេចនឹងឱ្យដល់ពួកអ្នកដែលមកក្រោយនេះដូចជាបាន
ឱ្យដល់អ្នកដែរ ១៥តើខ្ញុំគ្មានច្បាប់នឹងចាត់ចែងរបស់ខ្ញុំ
តាមអំពើចិត្តទេ តើភ្នែកអ្នកឃើញអាក្រក់ពីព្រោះខ្ញុំល្អឬអី[ប]

**១៩:២៣** ជ មថ ១៣:២២ ១ធថ ៦:៩,១០
**១៩:២៦** ឈ លប ១៨:១៤ យប ៤២:២ យរ ៣២:១៧ លក ១:៣៧ ១៨:២៧ រម ៤:២១
**១៩:២៧** ញ មថ ៤:១៩
**១៩:២៨** ដ មថ ២០:២១, ២៥:៣១ ឋ លក ២២:២៨–៣០ វវ ៣:២១ ៤:៤ ២០:៤
**១៩:២៩** ឌ មថ ៦:៣៣ ២៥:៤៦
**១៩:៣០** ឍ មថ ២០:១៦ មក ១០:៣១ លក ១៣:៣០
**២០:១** ណ មថ ១៣:២៤ ត មថ ២១:២៨,៣៣
**២០:៨** ថ លវ ១៩:១៣ ចទ ២៤:១៥
**២០:១១** ទ យណ ៤:១
**២០:១២** ធ យណ ៤:៨ លក ១២:៥៥ យក ១:១១
**២០:១៣** ន មថ ២២:១២ ២៦:៥០

**១៩:២៣** *នគរស្ថានសួគ៌* មើលការពន្យល់ ៣:២ ។
**១៩:២៤** *សត្វអូដ្ឋនឹងចូលប្រហោងម្ជុល* មើលការពន្យល់ មក ១០:២៥ ។
**១៩:២៦** មើលការពន្យល់ មក ១០:២៧ ។
**១៩:២៨** *ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា* មើលការពន្យល់ មក ១០:២៩ ។ *កូនមនុស្ស* មើលការពន្យល់ មក ៨:៣១ ។ *ជំនុំជំរះ* មើលសេចក្តីផ្តើមក្នុងគម្ពីរពួកចៅហ្វាយ ។
**១៩:២៩** *បានជា១រយភាគ* "មក ១០:៣០" សំដៅដល់អ្នកដែលគេបៀតបៀន ។
**២០:១–១៦** រឿងប្រៀបប្រដូចមួយនេះ មានតែនៅក្នុងដំណឹងល្អម៉ាថាយប៉ុណ្ណោះ ក្នុងអត្ថន័យដើមបានបង្ហាញពីព្រះគុណ និងសេចក្តីមេត្តាករុណានៃព្រះទៅដល់អ្នកដែលមកក្រោយ (អ្នកក្រីក្រ និងមនុស្សដែលសង្គមបដិសេធ) ដើម្បីចូលទៅក្នុងនគរព្រះ ។ អ្នករអ៊ូរទាំ (ខ.១១) ដែលមិនយល់ពីការអស្ចារ្យនៃព្រះគុណរបស់ព្រះ ពួកអ្នកទាំងនោះជាអ្នកដឹកនាំសាសនានានាដែលប្រឆាំងនឹងព្រះយេស៊ូវ ។
**២០:២** *២កាក់* ជាថ្លៃឈ្នួលធម្មតានៃទាហានរ៉ូមទទួលបាន២កាក់ក្នុងមួយថ្ងៃ។
**២០:៣–៦** ម៉ោងរបស់ជនជាតិយូដានៅសម័យមុន មានដូចខាងក្រោម "ម៉ោង៩ព្រឹក=ម៉ោទី៣ ថ្ងៃត្រង់=ម៉ោងទី៦ ម៉ោង៣ល្ងាច=ម៉ោងទី៩ ម៉ោង៥ល្ងាច=ម៉ោងទី១១"។
**២០:៨** *ពេលល្ងាច* កម្មករក្រីក្រ អាចបើកប្រាក់ឈ្នួលជាប្រចាំថ្ងៃបានក្រោយពីចប់ការងារនេះ បើតាមក្រឹត្យវិន័យរបស់ម៉ូសេ (លវ ១៩:១៣ ចទ ២៤:១៤–១៥)។
**២០:១៥** *តើភ្នែកអ្នកឃើញអាក្រក់ ពីព្រោះខ្ញុំចិត្តល្អឬអី?* បង្ហាញពីភ្នែកមនុស្សអាក្រក់ ដោយការច្រណែន និងឈ្នានីសអ្នកដទៃ (១សយ ១៨:៩)។

១៦គឺយ៉ាងនោះដែលអស់អ្នកក្រោយនឹងបានទៅជាមុន
ហើយពួកអ្នកមុននឹងទៅជាក្រោយវិញ[ផ] ដ្បិតបានហៅមនុស្ស
ជាច្រើន តែរើសបានតិចទេ។

## ព្រះយេស៊ូវថ្លែងទំនាយពីការសុគតរបស់ទ្រង់ម្តងទៀត

២០:១៧–១៩ = មក ១០:៣២–៣៤ លក ១៨:៣១–៣៣

១៧កាលព្រះយេស៊ូវទ្រង់កំពុងតែឡើងទៅឯក្រុងយេរូ–
សាឡិម នោះទ្រង់យកពួកសិស្សទាំង១២នាក់ ទៅដោយ
ឡែកតាមផ្លូវ ហើយមានបន្ទូលថា ១៨មើល យើងរាល់គ្នា
ឡើងទៅឯក្រុងយេរូសាឡិម[ព] នោះកូនមនុស្ស[ភ]នឹងត្រូវ
បញ្ជូនទៅដល់ពួកសង្គ្រាជ នឹងពួកអាចារ្យ[ម] ដែលគេនឹង
កាត់ទោសលោកដល់ជីវិត ១៩រួចនឹងបញ្ជូនទៅដល់ពួក
សាសន៍ដទៃ ឱ្យគេចំអកមើលងាយ ព្រមទាំងវាយនឹង
រំពាត់[យ] ហើយឆ្កាង[រ]លោក ក្រោយ៣ថ្ងៃ[ល]មក លោកនឹង
មានជីវិតរស់ឡើងវិញ[វ]។

## សំណូមពររបស់ម្តាយយ៉ាកុប និងយ៉ូហាន

*២០:២០–២៨ = មក ១០:៣៥–៤៥*

២០គ្រានោះ ប្រពន្ធរបស់សេបេដេ គាត់នាំកូនទាំង២[ស]មក
ឯទ្រង់ ក្រាបថ្វាយបង្គំ[ហ]ទូលសូមសេចក្តីមួយ ២១ទ្រង់មាន
បន្ទូលសួរថា តើអ្នកចង់បានអ្វី គាត់ទូលថាសូមអនុញ្ញាត
ឱ្យកូនខ្ញុំម្ចាស់ទាំង២នេះបានអង្គុយ ១ខាងស្តាំ ១ខាងឆ្វេង
ទ្រង់ ក្នុងនគររបស់ទ្រង់[ឡ] ២២តែព្រះយេស៊ូវមានបន្ទូលតប
ថា អ្នករាល់គ្នាមិនយល់សេចក្តីដែលអ្នកសូមទេ តើអ្នកអាច
នឹងផឹកអំពីពែង[អ] ដែលខ្ញុំរៀបនឹងផឹក ហើយទទួលបុណ្យ
ជ្រមុជដែលខ្ញុំទទួលបានឬ ទេ គេទូលឆ្លើយថា ទទួលបាន
២៣នោះទ្រង់មានបន្ទូលថា អ្នករាល់គ្នានឹងផឹកពីពែងខ្ញុំ[ក]
ហើយនឹងទទួលបុណ្យជ្រមុជដែលខ្ញុំទទួលមែន តែដែល
អង្គុយខាងស្តាំឬខាងឆ្វេងខ្ញុំ នោះមិនស្រេចនឹងខ្ញុំទេ គឺសំ
រាប់តែអ្នកណា ដែលព្រះវរបិតាខ្ញុំបានរៀបចំទុកឱ្យវិញ
២៤កាល១០នាក់ឯទៀតបានឮសេចក្តីនោះហើយ គេក៏តូច
ចិត្ត[ខ] នឹងបងប្អូនទាំង២នាក់នោះ ២៥តែព្រះយេស៊ូវទ្រង់ហៅ
អ្នកទាំងនោះមក មានបន្ទូលថា អ្នករាល់គ្នាដឹងថា ពួក
ចៅហ្វាយនៃសាសន៍ដទៃតែងគ្រប់គ្រងលើសាសន៍របស់
ខ្លួន ហើយពួកអ្នកធំក៏មានអំណាចលើគេដែរ ២៦ប៉ុន្តែមិន
ត្រូវឱ្យមានដូច្នោះក្នុងពួកអ្នករាល់គ្នាឡើយ គឺអ្នកណាក្នុង
ពួកអ្នករាល់គ្នា ដែលចង់ធ្វើជាធំ នោះនឹងត្រូវធ្វើជាអ្នក
បំរើ[គ]ដល់អ្នករាល់គ្នាវិញ ២៧ហើយអ្នកណាក្នុងពួកអ្នក
ដែលចង់បានជាលេខ១ អ្នកនោះត្រូវធ្វើជាបាវដល់អ្នក
រាល់គ្នាវិញដែរ ២៨ដូចជាកូនមនុស្ស[ឃ]បានមក មិនមែនឱ្យ
គេបំរើលោកទេ គឺនឹងបំរើគេវិញ[ង] ហើយនិងឱ្យជីវិតខ្លួន
ទុកជាថ្លៃលោះ[ច]មនុស្សជាច្រើនផង។

## មនុស្សខ្វាក់នៅក្រុងយេរីខូរមើលឃើញ

*២០:២៩–៣៤ = មក ១០:៤៦–៥២ លក ១៨:៣៥–៤៣*

២៩កាលកំពុងតែចេញពីក្រុងយេរីខូរមក នោះមានមនុស្ស
មីរដេរដាសដើរតាមទ្រង់ទៅ ៣០ក៏ឃើញមានមនុស្សខ្វាក់
២នាក់ អង្គុយនៅក្បែរផ្លូវ គេឮថាព្រះយេស៊ូវទ្រង់យាង
តាមទីនោះ ក៏ស្រែកឡើងថា ឱព្រះអម្ចាស់ ជាព្រះវង្សហ្លួង
ដាវីឌ[ឆ]អើយ សូមទ្រង់ប្រោសមេត្តាដល់យើងខ្ញុំផង

**២០:១៥** ប ចទ១៥:៩ មក ៧:២២ **២០:១៦** ផ មថ ១៩:៣០ **២០:១៨** ព លក ៩:៥១ ភ មថ ៨:២០ ម មថ ២៧:១,២ **២០:១៩** យ មថ ១៦:២១ រ កច ២:២៣ ល មថ ១៦:២១ វ មថ ១៦:២១ **២០:២០** ស មថ ៤:២១ ហ មថ ៨:២ **២០:២១** ឡ មថ ១៩:២៨ **២០:២២** អ អស ៥១:១៧,២២ យរ ៤៩:១២ មថ ២៦:៣៩,៤២ មក ១៤:៣៦ លក ២២:៤២ យហ ១៨:១១ **២០:២៣** ក កច ១២:២ វវ ១:៩ **២០:២៤** ខ លក ២២:២៤,២៥ **២០:២៦** គ មក ៩:៣៥ **២០:២៨** ឃ មថ ៨:២០ ង អស ៤២:១ លក ១២:៣៧ ២២:២៧ យហ ១៣:១៣–១៦ ២កថ ៨:៩ ភល ២:៧ ច នក ៣០:១២ អស ៤៤:២២ ៥៣:១០ មថ ២៦:២៨ ១ធថ ២:៦ ទត ២:១៤ ហព ៩:២៨ ១ពត ១:១៨,១៩ **២០:៣០** ឆ មថ ៩:២៧

**២០:១៧–១៩** មើលការពន្យល់ មក ១០:៣២–៣៤ លក ១៨:៣១–៣៣ ។

**២០:១៩** បញ្ជូនទៅដល់ពួកសាសន៍ដទៃឱ្យគេចំអកមើលងាយ ព្រមទាំងវាយនឹងរំពាត់ ហើយឆ្កាងលោកផង ទំនាយទី៣នេះបានថ្លែងបន្ថែមពីភាពក្រេវក្រោធរបស់សាសន៍ដទៃ ។ ព្រះយេស៊ូវមិនត្រូវបានពួកយូដាធ្វើគុតដោយចោលនឹងដុំថ្មនោះទេ តែត្រូវឆ្កាងដោយពួករ៉ូម៉ាំងវិញ ។ ទំនាយទាំងបីសុទ្ធតែបានបញ្ជាក់ការមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី(១៦:២១ ១៧:២៣)។

**២០:២០** *ប្រពន្ធរបស់សេបេដេ* តាមគម្ពីរម៉ាកុស ម្នាក់នេះគឺជាម្តាយរបស់លោកយ៉ាកុប និងយ៉ូហានដែលបានស្នើសុំព្រះយេស៊ូវឱ្យកូនរបស់គាត់ (មក ១០:៣៥–៣៧)។

**២០:២១** *ចង់បាន* មើលការពន្យល់ មក ១០:៣៥–៣៦ ។ *អង្គុយ១ខាងស្តាំ ១ខាងឆ្វេងទ្រង់* មើលការពន្យល់ មក ១០:៣៧ ។

**២០:២២** *ផឹកអំពីពែង* ព្រះបន្ទូលនេះសំដៅទៅលើអត្ថន័យថា "ទទួលរងទុក្ខ" ឬ "ឆ្លងកាត់បទពិសោធន៍រងទុក្ខ" (២៦:៣៩)។ ដូចគ្នានឹងសំដីដែលមានចែងក្នុងគម្ពីរ យរ ២៥:១៥ អគ ២៣:៣២ ហប ២:១៦ វវ ១៤:១០ ១៦:១៩ ១៨:៦ និយាយពីសេចក្តីក្រោធ ឬជំនុំជម្រះរបស់ព្រះ(មើលពន្យល់ មក ១០:៣៨)។

**២០:២៣–២៤** *មិនស្រេចនឹងខ្ញុំទេ* មើលការពន្យល់ មក ១០:៤០,៤១ ។

**២០:២៦** *មិនត្រូវឱ្យ . . . អ្នករាល់គ្នា* មើលការពន្យល់ មក ១០:៤៣ ។

**២០:២៨** *ថ្លៃលោះ* ភាសាក្រិកត្រូវបានគេប្រើយ៉ាងសាមញ្ញបំផុតសម្រាប់តម្លៃលោះទាសករ ។ ដូចគ្នានេះដែរព្រះយេស៊ូវទ្រង់បានបង់ថ្លៃលោះយើងទាំងអស់គ្នា ដោយព្រះជន្មរបស់ទ្រង់ ដើម្បីឱ្យយើងរួចផុតពីភាពជាទាសករនៃអំពើបាប ។ *ទុកជា* (សម្រាប់) តាមភាសាក្រិក វាគឺជាធ្នាក់ដែលបញ្ជាក់អំពីការសុគតរបស់ព្រះគ្រីស្ទ ។ *ជាច្រើន* ព្រះគ្រីស្ទបានប្រទានអង្គទ្រង់ជាថ្លៃលោះសម្រាប់មនុស្សទាំងអស់(១ធថ ២:៦)។ សេចក្តីសង្គ្រោះត្រូវបានផ្តល់ឱ្យ "មនុស្សទាំងអស់" ប៉ុន្តែ មានតែមនុស្សមួយចំនួនទេដែលទទួលបាន (មើលការពន្យល់ មក ១០:៤៥)។

**២០:២៩** *ក្រុងយេរីខូរ* មើលការពន្យល់ មក ១០:៤៦ ។

**២០:៣០** *មនុស្សខ្វាក់២នាក់* ដំណឹងល្អបីទៀតមានតែម្នាក់ទេ (មើលការពន្យល់ ៨:២៨)។ *ព្រះវង្សហ្លួងដាវីឌ* ជាងាររបស់ព្រះមែស៊ី(មើលការ

៣១ ឯបណ្ដាមនុស្ស គេហាមអ្នកទាំង២នោះ កុំឱ្យមាត់ តែ
គេស្រែករឹតតែខ្លាំងឡើងថា ឱព្រះអម្ចាស់ ជាព្រះវង្ស
ហ្លួងដាវីឌអើយ សូមទ្រង់ប្រោសមេត្តាដល់យើងខ្ញុំផង
៣២ នោះព្រះយេស៊ូវទ្រង់ឈប់ ក៏ហៅអ្នកទាំង២នោះមក
មានបន្ទូលសួរថា តើចង់ឱ្យខ្ញុំធ្វើអ្វីឱ្យអ្នក ៣៣ គេទូលទ្រង់
ថា ឱព្រះអម្ចាស់អើយ សូមប្រោសឱ្យ ភ្នែកយើងខ្ញុំបាន
ភ្លឺឡើងផង ៣៤ ទ្រង់មានសេចក្ដីក្ដួលក្នុងព្រះហឫទ័យ
ក៏ពាល់ភ្នែកគេ ស្រាប់តែភ្នែកបានភ្លឺឡើង រួចគេដើរតាម
ទ្រង់ទៅ ។

## ផ្លូវនៃជ័យជម្នះ

*២១:១-៩ = មក ១១:១-១០ លក ១៩:២៩-៣៨*

*២១:៤-៩ = យហ ១២:១២-១៥*

**២១** ១ គ្រាបានមកជិតក្រុងយេរូសាឡិមហើយ ដល់ភូមិ
បេតផាសេ ខាងភ្នំដើមអូលីវ[ជ] នោះព្រះយេស៊ូវទ្រង់ចាត់
សិស្ស២នាក់ឱ្យទៅ ២ ដោយបន្ទូលថា ចូរទៅឯភូមិនៅ
ខាងមុខនោះ អ្នកនឹងឃើញមេលា១ គេចងទុក នឹងកូនវា
នៅជាមួយគ្នាចូរស្រាយដឹកនាំវាមកឯខ្ញុំ ៣ បើអ្នកណាថាអ្វី
ឱ្យនោះត្រូវឆ្លើយថា ព្រះអម្ចាស់ទ្រង់ត្រូវការនឹងវា រួចគេ
នឹង ឱ្យវាមកហើយ ៤ ការទាំងនេះកើតមក ដើម្បីឱ្យបាន
សំរេច[ឈ]តាមទំនាយ ដែលហោរាបានទាយទុកមកថា:

**២១:១** ជ មថ ២៤:៣ ២៦:៣០ មក ១៤:២៦ លក ១៩:៣៧ ២១:៣៧ ២២:៣៩ យហ ៨:១ កច ១:១២
**២១:៤** ឈ មថ ១:២២
**២១:៥** ញ សក ៩:៩ អស ៦២:១១
**២១:៨** ដ ២ពវ ៩:១៣
**២១:៩** ឋ ខ.១៥ មថ ៩:២៧ ឌ ទដ ១១៨:២៦ មថ ២៣:៣៩ ឍ លក ២:១៤
**២១:១១** ណ ចទ ១៨:១៥ លក ៧:១៦,៣៩ ២៤:១៩ យហ ១:២១,២៥ ៦:១៤ ៧:៤០
**២១:១២** ត ចទ ១៤:២៦ ថ នក ៣០:១៣ ទ លវ ១:១៤

៥ «ចូរប្រាប់កូនស្រីស៊ីយ៉ូនថា មើល ស្ដេចនៃនាង ទ្រង់
យាងមកឯនាង ទ្រង់សុភាព ហើយគង់លើសត្វលា គឺជាលា
ជំទង់ដែលជាកូនរបស់មេលា»[ញ] ៦ សិស្សនោះក៏ទៅធ្វើ
តាមបង្គាប់ព្រះយេស៊ូវ ៧ ហើយនាំមេលានឹងកូនវាមក រួច
ក្រាលអាវខ្លួនលើខ្នងថ្វាយទ្រង់គង់ ៨ ឯហ្វូងមនុស្សស្ទើរ
តែទាំងអស់ បានក្រាលអាវ[ដ]ខ្លួននៅផ្លូវខ្លះក៏កាប់មែកឈើ
យកមករាយតាមផ្លូវផង ៩ ហើយបណ្ដាមនុស្សដែលដើរ
ហែមុខក្រោយ គេស្រែកឡើងថា ហូសាណា ដល់ព្រះវង្ស
ហ្លួងដាវីឌ[ឋ] ព្រះអង្គដែលយាងមកដោយនូវព្រះនាមព្រះ
អម្ចាស់ ទ្រង់ប្រកបដោយព្រះពរ[ឌ] ហូសាណានៅស្ថាន
ដ៏ខ្ពស់បំផុត[ឍ] ១០ រួចកាលទ្រង់យាងចូលទៅក្នុងក្រុងយេ
រូសាឡិមហើយ នោះកើតមានសេចក្ដីជ្រួលជ្រើមពេញ
ក្នុងទីក្រុង ហើយគេសួរថាលោកនេះជាអ្នកណា ១១ ហ្វូង
មនុស្សឆ្លើយឡើងថា នេះគឺជាហោរា[ណ]យេស៊ូវដែលមកពី
ភូមិណាសារ៉ែត ស្រុកកាលីឡេ។

## ព្រះយេស៊ូវនៅឯព្រះវិហារ

*២១:១២-១៦ = មក ១១:១៥-១៨ លក ១៩:៤៥-៤៧*

១២ ព្រះយេស៊ូវទ្រង់យាងចូលទៅក្នុងព្រះវិហារ ក៏បណ្ដេញ
អស់ទាំងអ្នកដែលលក់ដូរ[ត]ក្នុងព្រះវិហារចេញ ទ្រង់ផ្កាប់តុ
នៃពួកអ្នកដូរប្រាក់[ថ] នឹងជើងម៉ារបស់ពួកអ្នកលក់ព្រាប[ទ]

ពន្យល់ ៩:២៧)។

**២១:១** *ភូមិបេតផាសេ* មានន័យថា "ភូមិដើមល្វា" ឥតមាននិយាយទេក្នុងព្រះគម្ពីរសញ្ញាចាស់ និងមានតែក្នុងគម្ពីរសញ្ញាថ្មីទេ ហើយទាក់ទងទៅនឹងការឈានចូលភាពជ័យជម្នះ ។ តែចំពោះពួកយូដា(សេចក្ដីបង្រៀនមួយចំនួន)វិញ គឺនឹកឃើញការមកជិតដល់ក្រុងយេរូសាឡិម ។ *ភ្នំដើមអូលីវ* មើលការពន្យល់ មក ១១:១ ។

**២១:២** *មេលា១* ជានិមិត្តរូបនៃសត្វដែលសន្តិភាពបន្ទាបខ្លួន និងពួកវង្សត្រកូលស្ដេចដាវីឌ(មើលការពន្យល់ សក ៩:៩ លក ១៩:៣០ មក ១១:២ លក ១៩:៣០)។

**២១:៣** *ព្រះអម្ចាស់* មើលការពន្យល់ លក ១៩:៣១ ។

**២១:៧** *ព្រះយេស៊ូវ . . . ខ្នងថ្វាយទ្រង់* តាមគម្ពីរម៉ាកុស ១១:២ និងលូកា ១៩:៣០ ថាទ្រង់ បានគង់លើខ្នងកូនលា ហើយមេវាក៏បានដើរក្បែរៗគ្នានោះដែរ ខណៈដែល ម៉ាថាយចែងថាមានសត្វលាពីរ តែដំណឹងល្អផ្សេងទៀតថាមានតែមួយទេ ។

**២១:៨** *ក្រាលអាវខ្លួននៅផ្លូវ* ជាការសំដែងការគោរព (២ពវ ៩:១៣)។ *មែកឈើ* មើលការពន្យល់ មក ១១:៨ ។

**២១:៩** *ហូសាណា* មើលការពន្យល់ យរ ៣១:៧ ។ ទាំងអធិស្ឋាន និងសរសើរតម្កើង ។ *ស្ថានដ៏ខ្ពស់បំផុត* នេះអាចជាចម្រៀងស្ថានសួគ៌ "ហូសាណា"(មើល ការពន្យល់ ទដ ១៤៨:១-២ លក ២:១៤)។ *ហ្លួងដាវីឌ* មើលការពន្យល់ ៩:២៧ ។

**២១:១២-១៧** តាមគម្ពីរដំណឹងល្អ ម៉ាថាយ ម៉ាកុស និងលូកា បានឱ្យដឹងថា ការសំអាតព្រះវិហារ កើតឡើងក្រោយអំឡុងពេលមួយសប្ដាហ៍នៃការងាររបស់ព្រះយេស៊ូវ តែគម្ពីរដំណឹងល្អយ៉ូហានមុនពីរឬបីខែ(យហ ២:១២-១៦)។ មានសេចក្ដីពន្យល់ពីរយ៉ាងអំពីហេតុការណ៍នេះ (១).មានការសំអាតព្រះវិហារពីរដងទៀត គឺនៅពេលចាប់ផ្ដើម និងនៅទីបញ្ចប់នៃការ-ងាររបស់ព្រះយេស៊ូវ ។ (២).មាន ការសំអាតតែមួយគត់ដែលបានកើតឡើងនៅសប្ដាហ៍ដំបូង ប៉ុន្តែ នោះជាអ្វីដែលលោកយ៉ូហានបានចាប់ផ្ដើមចុះបញ្ជីសម្រាប់ហេតុផលខាងវិជ្ជាព្រះ ដើម្បីបង្ហាញថា ការជំនុំជម្រះរបស់ព្រះបានធ្វើឡើងតាមរយៈព្រះរាជកិច្ចពីដំបូងរបស់ព្រះមែស៊ី ។ ទោះបីជាយ៉ាងណាក៏ដោយមានសេចក្ដីលំអិតខុសៗគ្នាពីរក្នុង ពេលបច្ចុប្បន្ននេះ (ការលក់ដូរគោក្របី និងសត្វចៀម យហ ២:១៤ ការប្រើរំពាត់ យហ ២:១៥ និងព្រះបន្ទូលរបស់ទ្រង់ មថ ២១:១៣ យហ ២:១៦)។ យោងតាមបទគម្ពីរម៉ាថាយ និងលូកា យើងអាចយល់បានថា ការសំអាតព្រះវិហារ គឺបានធ្វើឡើងនៅថ្ងៃច័ន្ទ ហើយបន្តមកទៀតគេហៅថា ថ្ងៃនៃជ័យជម្នះ(២១:១-១១) ប៉ុន្តែ "មក ១១:១៥-១៩" បានបញ្ជាក់យ៉ាងច្បាស់ថាវាបានកើតឡើងនៅថ្ងៃច័ន្ទ ។ លោកម៉ាថាយ ជាញឹកញាប់បានបញ្ជាក់រឿងឱ្យកាន់តែច្បាស់ ។

**២១:១២** *ក្នុងព្រះវិហារ* មានការលក់ដូរត្រង់កន្លែងសាលប្រជុំនៃសាសន៍ដទៃអង្គុយដែលមានផ្ទៃធំទូលាយ (មើលពន្យល់ មក ១១:១៥ លក ១៩:៤៥)។

[១៣]ហើយទ្រង់មានបន្ទូលទៅគេថា មានសេចក្តីចែងទុក
មកដូច្នេះ «ដំណាក់អញត្រូវហៅថា ជាទីសំរាប់អធិស្ឋាន»[ធ]
តែអ្នករាល់គ្នាបានយកធ្វើជារោងចោរវិញ[ន] [១៤]ឯពួក
មនុស្សខ្វាក់ នឹងមនុស្សខ្វិន គេក៏មកឯទ្រង់ក្នុងព្រះវិហារ
ហើយទ្រង់ប្រោសគេឱ្យបានជាទាំងអស់[ប] [១៥]តែ ពួកសង្គ្រាជ
នឹងពួកអាចារ្យ គេមានចិត្តគ្នាន់ក្នាញ់ណាស់[ផ] ដោយបាន
ឃើញការអស្ចារ្យដែលទ្រង់ធ្វើ នឹងឮកូនក្មេងទាំងប៉ុន្មាន
ស្រែកក្នុងព្រះវិហារថា ហូសាណា ដល់ព្រះវង្សហ្លួង
ដាវីឌដូច្នោះ[ព] [១៦]ហើយគេទូលទ្រង់ថា តើអ្នកឮពាក្យ
ដែលក្មេងទាំងនេះថាឬទេ ព្រះយេស៊ូវទ្រង់ឆ្លើយថា ឮ
ហើយ តើអ្នករាល់គ្នាមិនដែលមើលសេចក្តីទេឬអី ដែល
ថា «ទ្រង់បានធ្វើឱ្យសេចក្តីសរសើរបានគ្រប់លក្ខណ៍ ដោយ
នូវមាត់កូនក្មេង នឹងកូនដែលនៅបៅ»[ភ] [១៧]រួចទ្រង់
លះចោលគេយាងចេញទៅឯភូមិបេថានី[ម]ទៅក៏ផ្ទំនៅទី
នោះ១យប់ ។

## ដើមល្វាត្រូវស្វិតក្រៀម

*២១:១៨–២២ = មក ១១:១២–១៤,២០–២៤*

[១៨]ដល់ព្រលឹមឡើង កំពុងដែលទ្រង់យាងត្រឡប់ទៅឯទី
ក្រុងវិញ នោះទ្រង់ក៏ឃ្លាន [១៩]ទ្រង់ទតឃើញដើមល្វា១ តាម
ផ្លូវ ក៏យាងទៅដល់ ឃើញមានតែស្លឹកទទេ នោះទ្រង់មាន
បន្ទូលថា កុំឱ្យឯងមានផ្លែទៀតឡើយ ស្រាប់តែដើមល្វា
នោះក្រៀមទៅ[យ] [២០]កាលពួកសិស្សបានឃើញដូច្នោះ
នោះគេមានសេចក្តីអស្ចារ្យថា ដើមល្វានេះក្រៀមទៅជា១
រំពេចយ៉ាងណាហ្ន៎ [២១]ព្រះយេស៊ូវទ្រង់មានបន្ទូលថា ខ្ញុំ
ប្រាប់អ្នករាល់គ្នាជាប្រាកដថា បើមានសេចក្តីជំនឿឥត
សង្ស័យសោះ[រ] នោះអ្នករាល់គ្នានឹងអាចធ្វើបាន មិនត្រឹម
តែការដែលកើតឡើងដល់ ដើមល្វាប៉ុណ្ណោះទេ គឺទោះបើ
អ្នកនឹងនិយាយទៅភ្នំនេះថា ឱ្យឯងរើចេញពីទីនេះទៅ
ធ្លាក់ក្នុងសមុទ្រវិញ នោះគង់តែនឹងបានកើតដូច្នោះដែរ
[២២]ហើយគ្រប់ទាំងសេចក្តីអ្វី ដែលអ្នករាល់គ្នានឹងអធិស្ឋាន
សូម[ល] ដោយមានចិត្តជឿ នោះនឹង បានសំរេចទាំងអស់។

## អំណាចរបស់ព្រះយេស៊ូវ

**២១:១៣** ធ អស ៥៦:៧ ន យរ ៧:១១
**២១:១៤** ប មថ ៤:២៣
**២១:១៥** ផ លក ១៩:៣៩
ព ខ.៩ មថ ៩:២៧
**២១:១៦** ភ ទដ ៨:២
**២១:១៧** ម មថ ២៦:៦ មក ១១:១ លក ២៤:៥០ យហ ១១:១, ១៨ ១២:១
**២១:១៩** យ អស ៣៤:៤ យរ ៨:១៣
**២១:២១** រ មថ ១៧:២០ លក ១៧:៦ ១កថ ១៣:២ យក ១:៦
**២១:២២** ល មថ ៧:៧
**២១:២៣** វ កច ៤:៧ ៧:២៧
**២១:២៦** ស មថ ១១:៩
**២១:២៨** ហ ខ.៣៣ មថ ២០:១
**២១:៣១** ឡ លក ៧:២៩
អ លក ៧:៥០
**២១:៣២** ក មថ ៣:១–១២
ខ លក ៣:១២,១៣
គ ៧:២៩ លក ៧:៣៦–៥០ + លក ៧:៣០

*២១:២៣–២៧ = មក ១១:២៧–៣៣ លក ២០:១–៨*

[២៣]កាលទ្រង់បានយាងចូលទៅក្នុងព្រះវិហារ ហើយ នោះ
ពួកសង្គ្រាជ នឹងពួកចាស់ទុំនៃបណ្តាជន គេមកឯទ្រង់ដែល
កំពុងតែបង្រៀន ហើយទូលកាត់សួរថា អ្នកធ្វើការទាំង
នេះ តើអាងអំណាចអ្វី[វ] តើអ្នកណាបានបើកអំណាចនេះ
ឱ្យអ្នក [២៤]ព្រះយេស៊ូវមានបន្ទូលតបថា ខ្ញុំនឹងសួរអ្នក
រាល់គ្នាពីសេចក្តី១ដែរ បើអ្នកឆ្លើយប្រាប់ខ្ញុំ នោះខ្ញុំក៏នឹង
ប្រាប់ឱ្យអ្នកដឹង ពីអំណាចដែលខ្ញុំអាង ដើម្បីនឹងធ្វើការទាំង
នេះដែរ [២៥]ឯបុណ្យជ្រមុជរបស់យ៉ូហាន តើមកពីណា ពី
ស្ថានសួគ៌ ឬពីមនុស្ស នោះគេក៏រិះគិតគ្នាថា បើយើងថា
មកពីស្ថានសួគ៌ នោះវានឹងសួរយើងថា ដូច្នេះហេតុអ្វី
បានជាអ្នករាល់គ្នាមិនបានជឿតាមគាត់ [២៦]តែបើយើងថា
មកពីមនុស្សវិញ នោះខ្លាចហ្វូងមនុស្ស ដ្បិតគេរាប់យ៉ូហាន
ទុកជាហោរាទាំងអស់គ្នា[ស] [២៧]រួចគេទូលឆ្លើយថា យើង
មិនដឹងទេ ហើយទ្រង់ក៏មានបន្ទូលតបថា ដូច្នេះខ្ញុំក៏មិន
ប្រាប់ឱ្យអ្នករាល់គ្នាដឹង ពីអំណាចដែលខ្ញុំអាងនឹងធ្វើការ
ទាំងនេះដែរ ។

## រឿងប្រៀបប្រដូចអំពី កូនប្រុសពីរនាក់

[២៨]ប៉ុន្តែអ្នករាល់គ្នាគិតដូចម្តេច មានមនុស្សម្នាក់មានកូន
ប្រុស២ គាត់ទៅប្រាប់កូនច្បងថា កូនអើយ ថ្ងៃនេះ ចូរ
ឯងទៅធ្វើការក្នុងចំការអញទៅ[ហ] [២៩]កូននោះប្រកែកថា
ខ្ញុំមិនទៅទេ ដល់ក្រោយមក វាប្រែចិត្តជាទៅវិញ [៣០]គាត់
ក៏ទៅប្រាប់ដល់កូនពៅដូចគ្នា ឯកូននោះវាទទួលថា ខ្ញុំទៅ
លោកឪពុក ប៉ុន្តែវាមិនបានទៅទេ [៣១]ដូច្នេះ បណ្តាកូន
ទាំង២នោះ តើកូនណាបានធ្វើតាម ចិត្តរបស់ឪពុក គេ
ឆ្លើយថា កូនច្បង ព្រះយេស៊ូវទ្រង់មានបន្ទូលថា ខ្ញុំ
ប្រាប់អ្នករាល់គ្នាជាប្រាកដថា ពួកអ្នកយកពន្ធ[ឡ] នឹង
ពួកស្រីសំផឹង[អ] គេចូលទៅក្នុងនគរព្រះមុនអ្នករាល់គ្នា
[៣២]ដ្បិតយ៉ូហានបានមកឯអ្នករាល់គ្នាក្នុងផ្លូវសុចរិត[ក] តែ
អ្នករាល់គ្នាមិនបានជឿតាមគាត់ទេ ឯពួកយកពន្ធ[ខ]
នឹងពួកស្រីសំផឹង[គ] គេបានជឿតាមគាត់វិញ លុះកាល

**២១:១៣** *ជាទីសំរាប់អធិស្ឋាន* មើលការពន្យល់ មក ១១:១៧ ។

**២១:១៧** *ភូមិបេថានី* ជាតំបន់ផ្នែកខាងកើតនៃភ្នំដើមអូលីវ ដែលមានចម្ងាយប្រហែលជា៣,២គីឡូម៉ែត្រ នៅតាមកំណាត់ដងផ្លូវពីទីក្រុងយេរូសាឡិមទៅក្រុងយេរីខូ (នេះជាផ្លូវទាល់)។

**២១:១៨–២២** មើលការពន្យល់ ខ.១២–១៧ ។ មានរឿងនិយាយតៗគ្នា មកថា ដើមល្វាត្រូវបណ្តាសានៅព្រឹកថ្ងៃច័ន្ទ (មក ១១:១២–១៤,២០–២៥) ហើយវាបានស្វិតក្រៀមនៅព្រឹកថ្ងៃអង្គារ ។ តែលោកម៉ាថាយថាដើមល្វានេះ បានស្វិតក្រៀម ភ្លាមក្រោយពីត្រូវបណ្តាសាដែលបញ្ជាក់ពីការជំនុំជម្រះភ្លាមៗ (មើលការពន្យល់ មក ១១:១៤)។

**២១:១៨** *ទីក្រុង* គឺទីក្រុងយេរូសាឡិម ។

**២១:២១** *និយាយទៅភ្នំ... ធ្លាក់ក្នុងសមុទ្រវិញ* មើលការពន្យល់ ១៧:២០ ។

**២១:២២** មើល ១យហ ៥:១៤–១៥ និងមើលការពន្យល់ ៥:១៤ ។

**២១:២៣** *ក្នុងព្រះវិហារ* មើលការពន្យល់ មក ១១:២៧ ។

**២១:២៥** *ពីស្ថានសួគ៌ឬពីមនុស្ស* មើលពន្យល់ មក ១១:៣០ លក ២០:៤

អ្នករាល់គ្នាបានឃើញដូច្នោះ នោះក៏នៅតែមិនព្រមប្រែ
ចិត្តជឿតាមគាត់ដែរ។

## រឿងប្រៀបប្រដូចអំពីអ្នកចាំចំការ

*២១:៣៣–៤៦ = មក ១២:១–១២ លក ២០:៩–១៩*

៣៣ចូរស្ដាប់ពាក្យប្រៀបប្រដូច១ទៀត មានថៅកែម្នាក់
ដែលដាំ[ឃ]ចំការទំពាំងបាយជូរ គាត់បានធ្វើរបងព័ទ្ធជុំវិញ
ព្រមទាំងជីកទីជាន់ផ្លែ ហើយសង់ប៉ម[ង] ក៏ប្រវាស់ទៅឱ្យ
ពួកអ្នកធ្វើចំការ រួចចេញពីស្រុកនោះទៅ[ច] ៣៤កាលជិត
ដល់រដូវបេះផ្លែហើយ នោះក៏ប្រើបាវ[ឆ]ខ្លួនឱ្យទៅឯពួក
អ្នកទាំងនោះ ដើម្បីនឹងទទួលផល ជាចំណែករបស់ខ្លួន
៣៥តែពួកធ្វើចំការ គេចាប់បាវទាំងនោះវាយម្នាក់ សំ
ឡាប់ម្នាក់ ហើយម្នាក់ទៀតចោលនឹងថ្មវិញ[ជ] ៣៦ថៅកែក៏
ប្រើបាវ[ឈ]ដទៃជាច្រើនជាងមុនឱ្យទៅទៀត តែគេប្រព្រឹត្ត
នឹងបាវទាំងនោះបែបដូចគ្នា ៣៧ដល់ក្រោយបង្អស់ គាត់ចាត់
កូនខ្លួនឱ្យទៅដោយគិតថា គេនឹងកោតខ្លាចដល់កូនអញ។
៣៨ប៉ុន្តែ កាលពួកចំការបានឃើញ នោះគេនិយាយគ្នាថា
នេះជាកូនគ្រងមរដក[ញ]ហើយ ចូរយើងសំឡាប់វា[ដ]ចេញ
ទៅ រួចយើងនឹងដណ្ដើមយកមរដករបស់វា[ឋ] ៣៩គេក៏ចាប់
កូននោះ បោះចោលទៅខាងក្រៅចំការ ហើយសំឡាប់
ចោលទៅ ៤០ដូច្នេះ កាលណាថៅកែចំការមកដល់ តើ
គាត់នឹងធ្វើអ្វី ដល់ពួកអ្នកដែលធ្វើចំការទាំងនោះ ៤១គេ
ទូលឆ្លើយតបថា គាត់នឹងសំឡាប់ពួកកំណាចទាំង នោះ
យ៉ាងអាក្រក់ណាស់[ឌ] រួចនឹងប្រវាស់ចំការទៅឱ្យពួកឯ
ទៀត[ឍ]វិញ ដែលគេនឹងឱ្យផលដល់គាត់តាមរដូវ ៤២ព្រះ
យេស៊ូវទ្រង់មានបន្ទូលទៅគេថា តើអ្នករាល់គ្នាមិនដែល
មើលក្នុងគម្ពីរទេឬអី ដែលថា «ថ្មដែលពួកជាងសង់ផ្ទះ
បានចោលចេញ នោះបានត្រឡប់ជាថ្មជ្រុងយ៉ាង ឯក
ការនោះគឺព្រះអម្ចាស់ទ្រង់បានធ្វើ ហើយជាការយ៉ាង
អស្ចារ្យ នៅភ្នែកយើងខ្ញុំ»[ណ] ៤៣ដូច្នេះ ខ្ញុំប្រាប់អ្នករាល់
គ្នាថា នគរព្រះនឹងត្រូវហូតចេញ ពីអ្នករាល់គ្នា[ត] ប្រគល់

**២១:៣៣** ឃ ទដ ៨០:៨
ង អស ៥:១–៧
ច មថ ២៥:១៤,១៥
**២១:៣៤** ឆ មថ ២២:៣
**២១:៣៥** ជ ២របា ២៤:២១
មថ ២៣:៣៤,៣៧
ហព ១១:៣៦,៣៧
**២១:៣៦** ឈ មថ ២២:៤
**២១:៣៨** ញ ហព ១:២ ដ មថ ១២:១៤
ឋ ទដ ២:៨
**២១:៤១** ឌ មថ ៨:១១,១២
ឍ កច ១៣:៤៦
**២១:៤២** ណ ទដ ១១៨:២២,២៣
កច ៤:១១
**២១:៤៣** ត មថ ៨:១២
**២១:៤៤** ថ លក ២:៣៤
**២១:៤៦** ទ ខ.១១, ២៦
**២២:២** ធ មថ ១៣:២៤
**២២:៣** ន មថ ២១:៣៤
**២២:៤** ប មថ ២១:៣៦
**២២:៧** ផ លក ១៩:២៧
**២២:៩** ព អគ ២១:២១

ទៅឱ្យសាសន៍១ទៀតដែលគេ នឹងបង្កើតផលរបស់នគរ
នោះ ៤៤អ្នកណាដែលធ្លាក់លើថ្មនោះ នឹងត្រូវបាក់បែក
តែអ្នកណាដែលត្រូវថ្មនោះធ្លាក់មកលើខ្លួន នោះនឹងត្រូវ
កិនខ្ទេចខ្ទីទៅ[ថ] ៤៥កាលពួកសង្គ្រាជ នឹងពួកផារិស៊ីបាន
ឮពាក្យប្រៀបប្រដូចទាំងនោះហើយ គេក៏ដឹងថាទ្រង់មាន
បន្ទូលឆ្ពោះខ្លួនគេ ៤៦រួចគេរកហេតុនឹងចាប់ទ្រង់ ប៉ុន្តែគេ
ខ្លាចហ្វូងមនុស្ស ពីព្រោះបណ្ដាមនុស្សទាំងឡាយរាប់ទ្រង់
ទុកជាហោរា[ទ]។

## រឿងប្រៀបប្រដូចអំពី ពិធីជប់លៀងក្នុងមង្គលការ

*២២:២–១៤ = លក ១៤:១៦–២៤*

**២២** ១ព្រះយេស៊ូវទ្រង់មានបន្ទូលពាក្យប្រៀបប្រដូច១
ទៀតទៅគេថា ២នគរស្ថានសួគ៌ប្រៀបដូចជា[ធ]ស្ដេចមួយ
អង្គ ដែលរៀបវិវាហមង្គលឱ្យព្រះរាជបុត្រា ៣ទ្រង់ចាត់ពួក
មហាតលិក[ន]ឱ្យទៅហៅពួកភ្ញៀវ ដែលទ្រង់បានអញ្ជើញ
មកក្នុងមង្គលការនោះ ប៉ុន្តែអ្នកទាំងនោះមិនព្រមមកទេ។
៤ទ្រង់ក៏ចាត់ពួកមហាតលិក[ប]ឯទៀតឱ្យទៅ ដោយបន្ទូល ថា
ចូរឯងប្រាប់ពួកភ្ញៀវថា ឥឡូវ គ្រឿងជប់លៀងបានរៀប
ជាស្រេចហើយ គេបានសំឡាប់គោ នឹងសត្វបំប៉នយ៉ាង
ធាត់ៗ ហើយក៏រៀបចំគ្រប់ទាំងអស់រួចជាស្រេច ចូរមក
បរិភោគការចុះ ៥តែអ្នកទាំងនោះធ្វេសប្រហែសវិញ
ម្នាក់ក៏ទៅឯចំការខ្លួន ម្នាក់ទៀតទៅឯការជំនួញ ៦អ្នក
ឯទៀតក៏ចាប់ពួកមហាតលិកត្មះតិះដៀល ហើយសំឡាប់
ចោលទៅ ៧កាលស្ដេចបានឮ នោះទ្រង់មានព្រះទ័យ
ក្រេវក្រោធ ក៏ចាត់ទ័ពឱ្យទៅបំផ្លាញពួកមនុស្សដែលសំ
ឡាប់គេនោះ[ផ] ព្រមទាំងដុតទីក្រុងរបស់គេចោលអស់
៨រួចទ្រង់មានបន្ទូលទៅពួកមហាតលិកថា ការបានរៀប
ចំជាស្រេច តែពួកភ្ញៀវមិនគួរនឹងមកបរិភោគទេ ៩ដូច្នេះ
ចូរទៅឯផ្លូវប្រសព្វ[ព] អញ្ជើញអស់អ្នកណាដែលប្រទះឃើញ
ឱ្យគេមកបរិភោគវិញ ១០មហាតលិកទាំងនោះក៏ចេញទៅ
តាមផ្លូវ ប្រមូលអស់អ្នកណាដែលប្រទះឃើញ ទាំងអាក្រក់

---

**២១:៣៣–៤៦** មើលការពន្យល់ មក ១២:១–១២ និង លក ២០:៩–១៩ ។
**២១:៣៣** *ប៉ម* សម្រាប់យាមចំការទំពាំងបាយជូរ ជាពិសេសពេលទំពាំងបាយជូរទុំ ហើយជាម្លប់សម្រាប់ជ្រកផង ធ្វើពីឈើ ខ្ពស់ពីដី ដែលអាចមើលទៅបានឆ្ងាយ ។
**២១:៣៥–៣៧** អ្នកថែរក្សាចំការគឺសាសន៍យូដា ឬអ្នកដឹកនាំពួកគេ អ្នកបម្រើគឺជាពួកហោរាក្នុងសម័យសញ្ញាចាស់ ភាគច្រើនត្រូវបានគេសម្លាប់ ។ កូនប្រុសតំណាង ព្រះគ្រីស្ទដែលត្រូវពួកអ្នកដឹកនាំសាសនាបានកាត់ទោសប្រហារជីវិត ។
**២១:៤១** *ពួកឯទៀត* គឺសាសន៍ដទៃ ។ សាសន៍យូដាភាគច្រើនបដិសេធដំណឹងល្អ ទើបលោកប៉ុលបានផ្សាយដល់សាសន៍ដទៃវិញ (កច ១៣:៤៦ ១៨:៦) នៅសតវត្សរ៍ទី២ ។
**២១:៤៤** *នឹងត្រូវបាក់បែក* មើលការពន្យល់ លក ២០:១៨ ។
**២១:៤៥** *ពួកសង្គ្រាជ* មើលការពន្យល់ ២:៤ មក ៨:៣១ លក ១៩:៤៧ ។
*ពាក្យប្រៀបប្រដូច* មើលការពន្យល់ ១៣:៣ មក ៤:២ លក ៨:៤ ។
**២២:៧** *ដុតទីក្រុងរបស់គេ* ជារឿងធម្មតារបស់ពួកទាហានតែងតែធ្វើ ដូច្នេះត្រង់នេះប្រហែលនិយាយទៅដល់ការបំផ្លាញក្រុងយេរូសាឡិមនៅឆ្នាំទី៧០ ។

ទាំងល្អ[ភ]មក នោះរោងការមានភ្ញៀវពេញព្រៀប [១១]ស្ដេច
ក៏យាងចូលទៅទតមើលពួកភ្ញៀវ ទ្រង់ឃើញមានមនុស្ស
ម្នាក់នៅទីនោះ ដែលមិនបានពាក់អាវផាយ [១២]ក៏មានបន្ទូល
ទៅអ្នកនោះថា សំឡាញ់អើយ[ម] ដូចម្ដេចបានជាអ្នកចូល
មកក្នុងទីនេះ ឥតពាក់អាវផាយដូច្នេះ អ្នកនោះរកឆ្លើយអ្វី
មិនបានឡើយ [១៣]ទើបទ្រង់បង្គាប់ទៅពួកមហាតលិកថា
ចូរចងជើងចងដៃវាបោះចោលទៅឯទីងងឹតខាងក្រៅទៅ
នៅទីនោះនឹងយំ ហើយសង្កៀតធ្មេញ[យ] [១៤]ដ្បិតបានហៅ
មនុស្សជាច្រើន តែរើសបានតិចទេ[រ]។

## ការបង់ពន្ធជូនសេសារ

*២២:១៥-២២ = មក ១២:១៣-១៧ លក ២០:២០-២៦*

[១៥]កាលពួកផារិស៊ីបានចេញទៅ នោះគេពិគ្រោះគ្នាពី
ដំណើរយ៉ាងណានឹងចាប់ទ្រង់ ដោយនូវព្រះបន្ទូល [១៦]រួចក៏
ចាត់ពួកសិស្សរបស់គេឱ្យទៅឯទ្រង់ ជាមួយនឹងពួក
ហេរ៉ូឌ[ល] ដោយពាក្យថា លោកគ្រូ យើងខ្ញុំដឹងថា លោក
ពិតត្រង់ហើយថា លោកបង្រៀនពីផ្លូវព្រះដោយសេចក្ដី
ពិត ឥតមានអំពល់ដល់អ្នកណាឡើយ ព្រោះលោកមិនយល់
មុខមនុស្សណាទេ [១៧]ដូច្នេះ សូមប្រាប់យើងខ្ញុំដែលលោក
គិតដូចម្ដេច តើមានច្បាប់នឹងបង់ពន្ធ[វ] ថ្វាយសេសារឬទេ
[១៨]តែព្រះយេស៊ូវ ទ្រង់ជ្រាបឧបាយកលរបស់គេ ក៏មាន
បន្ទូលតបថា មនុស្សកំពុតអើយ ហេតុអ្វីបានជាអ្នករាល់
គ្នាល្បងខ្ញុំដូច្នេះ [១៩]ចូរបង្ហាញប្រាក់ដែលបង់ពន្ធមកឱ្យខ្ញុំ
មើលចុះ គេក៏យកប្រាក់កាក់ធំមកថ្វាយទ្រង់ទត [២០]រួច
ទ្រង់មានបន្ទូលសួរថា រូបនេះ នឹងឈ្មោះនេះ តើជារបស់
អ្នកណា [២១]គេទូលឆ្លើយថា របស់សេសារ នោះទ្រង់មាន
បន្ទូលឆ្លើយថា ដូច្នេះ ចូរថ្វាយរបស់សេសារ[ស] ទៅ
សេសារទៅ ឯរបស់ព្រះ ចូរថ្វាយទៅព្រះវិញ [២២]កាល
បានឮដូច្នោះ នោះគេមានសេចក្ដីអស្ចារ្យ រួចក៏ដើរ
ចេញពីទ្រង់បាត់ទៅ[ហ]។

## អាពាហ៍ពិពាហ៍នៅគ្រាពីរស់ឡើងវិញ

*២២:២៣-៣៣ = មក ១២:១៨-២៧ លក ២០:២៧-៤០*

[២៣]នៅថ្ងៃនោះឯង ពួកសាឌូស៊ី[ឡ] ដែលគេថា គ្មាន
សេចក្ដីរស់ឡើងវិញទេ[អ] គេក៏មកឯទ្រង់ ទូលសាកសួរថា
[២៤]លោកគ្រូ លោកម៉ូសេបានផ្ដាំថា «បើអ្នកណាស្លាប់ទៅ
ឥតមានកូន នោះប្អូនត្រូវយកប្រពន្ធរបស់បង ដើម្បីនឹង
បង្កើតពូជឱ្យបងខ្លួន»[ក] [២៥]រីឯនៅក្នុងពួកយើងខ្ញុំ មានបង
ប្អូន៧នាក់ បងច្បងបានយកប្រពន្ធ ហើយស្លាប់ទៅគ្មានកូន
សោះ បានទុកប្រពន្ធឱ្យប្អូន [២៦]ប្អូនបន្ទាប់ក៏ធ្វើដូចគ្នា រួចប្អូន
ទី៣ ដរាបដល់ប្អូនពៅបំផុត [២៧]ក្រោយបង្អស់មក ស្ត្រីនោះ
ក៏ស្លាប់ទៅដែរ [២៨]ដូច្នេះ ដល់គ្រារស់ឡើងវិញ តើនាងនោះ
នឹងត្រូវធ្វើជាប្រពន្ធរបស់អ្នកណា ក្នុងបណ្ដាបងប្អូនទាំង៧
នាក់នោះ ដ្បិតសុទ្ធតែបានយកនាងធ្វើជាប្រពន្ធគ្រប់ៗគ្នា

**២២:១០** ភ មថ ១៣:៤៧,៤៨
**២២:១២** ម មថ ២០:១៣ ២៦:៥០
**២២:១៣** យ មថ ៨:១២
**២២:១៤** រ វវ ១៧:១៤
**២២:១៦** ល មក ៣:៦
**២២:១៧** វ មថ ១៧:២៥
**២២:២១** ស រម ១៣:៧
**២២:២២** ហ មក ១២:១២
**២២:២៣** ឡ កច ៤:១ អ កច ២៣:៨ ១កច ១៥:១២
**២២:២៤** ក ចទ ២៥:៥,៦

**២២:១១** *មិនបានពាក់អាវផាយ* វាត្រូវបានគេសន្និដ្ឋានថា ប្រហែលជាទំនៀមទម្លាប់របស់ម្ចាស់ផ្ទះត្រូវផ្ដល់សម្លៀកបំពាក់ដល់ភ្ញៀវ ដែលបានអញ្ជើញមកចូល រួមពិធីនេះជាពិសេសដល់អស់អ្នកដែលខ្លួនបាន ប្រមូលមកពីចិញ្ចើមផ្លូវទៅរោងការផ្ទាល់តែម្ដង(ខ.៩-១០)។ ការខកខានមិនបានពាក់អាវនេះ គឺជាការប្រមាថដល់ម្ចាស់ផ្ទះដែលបានត្រៀមបម្រុងអាវទុកជូនភ្ញៀវរួចជាស្រេចហើយនោះ ។

**២២:១៣** *សង្កៀតធ្មេញ* មើលការពន្យល់ ១៣:៤២ ។

**២២:១៤** ការសង្ខេបន័យពាក្យប្រៀបប្រដូច ព្រះអម្ចាស់បានហៅ "មនុស្សជាច្រើន" ប្រហែលជា"ទាំងអស់គ្នា" ដើម្បីចូលរួមនៅក្នុងនគររបស់ទ្រង់ ប៉ុន្តែមាន "តិចតួច" ប៉ុណ្ណោះដែលព្រះអង្គបានជ្រើសរើស ។ មិនមានន័យថា ព្រះអម្ចាស់បានជ្រើសរើសមនុស្សតាមតែអំពើចិត្តនោះទេ ។ ការអញ្ជើញត្រូវតែបានទទួល ដោយអាកប្បកិរិយាយ៉ាងសមរម្យ ។ ចរិយាមាយាទត្រឹមត្រូវជាភស្តុតាងបង្ហាញថាត្រូវ បានជ្រើសរើស ។

**២២:១៥-១៧** ពួកផារិស៊ីធ្លាប់ជាអ្នកជាតិនិយមដ៏ខ្លាំងក្លាមួយ ក្នុងការប្រឆាំងនឹងរបបគ្រប់គ្រងរ៉ូម៉ាំង តែក្រោយមកដោយបក្សពួកស្ដេចហេរ៉ូឌមិនពេញចិត្តក៏បែរទៅរកពួកស្ដេចហេរ៉ូឌ ដែលគាំទ្រដោយពួករ៉ូម៉ាំងវិញ ។ នៅពេលនោះពួកផារិស៊ីបានចូលរួមជាជំនួយ ដើម្បីរកល្បិចនឹងចាប់ព្រះយេស៊ូវដោយបន្ទូលរបស់ទ្រង់ ។ បន្ទាប់ពីបានបញ្ចើចបញ្ចោរព្រះយេស៊ូវមក ពួកគេបានលើកជាសំណួរថា "តើមានច្បាប់នឹងបង់ពន្ធថ្វាយសេសារឬទេ?" (ខ.១៧)។ ប្រសិនបើទ្រង់ឆ្លើយថា "ទេ" ពួកស្ដេចហេរ៉ូឌនឹង រាយការណ៍ទៅរដ្ឋអំណាចរ៉ូម៉ាំង ដោយចោទថាក្បត់ជាតិ តែបើឆ្លើយ"បាទ"វិញ នោះពួកផារិស៊ីនឹងបានប្រកាសបរិហារទ្រង់ នៅចំពោះមុខមហាជនថាទ្រង់គ្មានភក្តីភាពចំពោះប្រជាជាតិខ្លួនឯងនោះឡើយ ។

**២២:១៩** *ប្រាក់កាក់* នេះជារូបិយវត្ថុរបស់រ៉ូម៉ាំងនៅសម័យនោះ (មើលការពន្យល់ ២០:២)។ រាងមូលដែលមានរូបសេសារ-ទីបេរាសនៅម្ខាង និងម្ខាងទៀតមានសរសេរជាអក្សរឡាតាំងថា "សេសារ-ទីបេរាសអូគូស្ទជាបុត្រស្ដេចអូគូស្ទ ដែលគេចាត់ទុកដូចជាព្រះ"។ ប្រាក់នេះចេញឱ្យប្រើដោយសេសារ-ទី បើរសម្រាប់បង់ ពន្ធដល់ទ្រង់ ។

**២២:២១** *របស់ព្រះ...ទៅព្រះ* មានលក្ខណៈខុសគ្នារវាងសេសារ និងព្រះ ។ ព្រះយេស៊ូវក៏បានតវ៉ាប្រឆាំងនឹងការដាក់រូប និងការប្រកាសឈ្មោះលើប្រាក់កាក់ឱ្យអ្នកដទៃគោរពបូជា(មើលពន្យល់ មក ១២:១៧)នោះផងដែរ ។

**២២:២៣** *សាឌូស៊ី* មើលពន្យល់ ៣:៧ មក ១២:១៨ លក ២០:២៧ កច ៤:១

**២២:២៤** *លោកម៉ូសេបានផ្ដាំថា* ជាពាក្យដែលព្រះយេស៊ូវបានដក ស្រង់ចេញពីព្រះគម្ពីរ៥កណ្ឌដំបូងនៅក្នុងសញ្ញាចាស់ សម្រាប់យកមកជជែកគ្នាជាមួយនឹងពួកសាឌូស៊ីអំពីការរៀបការជាមួយបងថ្លៃស្រីមេម៉ាយ(ចទ ២៥:៥-១០)

**២២:២៥-៤០** មើលការពន្យល់ មក ១២:១៨-៣១ លក ២០:២៧-៤០ ។

29នោះព្រះយេស៊ូវទ្រង់មានបន្ទូលទៅគេថា អ្នករាល់គ្នា
ភាន់ច្រឡំទេ ពីព្រោះមិនយល់គម្ពីរ[ខ] ឬព្រះចេស្តានៃព្រះ
សោះ 30ដ្បិតដល់គ្រារស់ឡើងវិញ នោះគេមិនយកគ្នា
ជាប្ដីប្រពន្ធទៀតទេ[គ] គឺបានដូចជាទេវតានៃព្រះ ដែល
នៅស្ថានសួគ៌វិញ 31តែត្រង់ឯសេចក្ដីរស់ពីស្លាប់ឡើងវិញ
តើអ្នករាល់គ្នាមិនបានមើលសេចក្ដី ដែលព្រះទ្រង់បាន
មានបន្ទូលនឹងអ្នករាល់គ្នាទេឬអី 32គឺថា « អញជាព្រះ
នៃអ័ប្រាហាំ ជាព្រះនៃអ៊ីសាក ហើយជាព្រះនៃយ៉ាកុប[ឃ]
ព្រះអង្គទ្រង់មិនមែនជាព្រះនៃមនុស្សស្លាប់ទេ គឺជាព្រះនៃ
មនុស្សរស់វិញ » 33ឯបណ្ដាមនុស្សគេក៏នឹកប្លែកក្នុងចិត្ត
ដោយឮសេចក្ដី ដែលទ្រង់បង្រៀននោះ[ង]។

### បញ្ញត្តិដែលសំខាន់បំផុត

*២២:៣៤-៤០ = មក ១២:២៨-៣១*

34តែកាលពួកផារិស៊ីបានឮថា ទ្រង់ធ្វើឱ្យពួកសាឌូស៊ី[ច]បាត់
មាត់ដូច្នេះ នោះគេក៏មូលគ្នា 35ហើយពួកគេម្នាក់ ដែលជា
អ្នកប្រាជ្ញខាងច្បាប់[ឆ]ក៏ល្បងសួរទ្រង់ថា 36លោកគ្រូ ក្នុង
បណ្ដាក្រិត្យវិន័យ តើបញ្ញត្តិណាដែលយ៉ាងសំខាន់បំផុត
37នោះព្រះយេស៊ូវឆ្លើយថា «ត្រូវឱ្យស្រឡាញ់ព្រះអម្ចាស់
ជាព្រះនៃឯងឱ្យអស់អំពីចិត្ត អស់អំពីព្រលឹង ហើយអស់
អំពីគំនិតឯង »[ឈ] 38នេះជាបញ្ញត្តិយ៉ាងសំខាន់ទី១ 39ហើយ
បញ្ញត្តិទី២ក៏បែបដូចគ្នា គឺថា «ត្រូវឱ្យស្រឡាញ់អ្នកជិតខាងដូច
ខ្លួនឯង[ញ]» 40បណ្ដាក្រិត្យវិន័យ និងអស់ទាំងទំនាយហោរា
ទាំងប៉ុន្មាន ក៏សំរេចនៅបទបញ្ញត្តិទាំង២ប្រការនេះឯង[ដ]។

### តើព្រះគ្រីស្ទជាវង្សអង្គណា

*២២:៤១-៤៦ = មក ១២:៣៥-៣៧ លក ២០:៤១-៤៤*

41កំពុងដែលពួកផារិស៊ីនៅមូលគ្នានៅឡើយ នោះព្រះ
យេស៊ូវទ្រង់មានបន្ទូលសួរគេថា 42អ្នករាល់គ្នាគិតពី
ព្រះគ្រីស្ទដូចម្ដេច តើទ្រង់ជាព្រះវង្សអ្នកណា នោះគេទូល
ឆ្លើយថា ជាព្រះវង្សហ្លួងដាវីឌ[ឋ] 43ទ្រង់មានបន្ទូលសួរ

**២២:២៩** ខ យហ ២០:៩
**២២:៣០** គ មថ ២៤:៣៨
**២២:៣២** ឃ នក ៣:៦ កច ៧:៣២
**២២:៣៣** ង មថ ៧:២៨
**២២:៣៤** ច កច ៤:១
**២២:៣៥** ឆ លក ៧:៣០ ១០:២៥ ១១:៤៥ ១៤:៣
**២២:៣៧** ឈ ចទ ៦:៥
**២២:៣៩** ញ លវ ១៩:១៨ មថ ៥:៤៣
**២២:៤០** ដ មថ ៧:១២ លក ១០:២៥-២៨
**២២:៤២** ឋ មថ ៩:២៧
**២២:៤៤** ឌ ទដ ១១០:១ ១ពវ ៥:៣ កច ២:៣៤,៣៥ ១កថ ១៥:២៥ ហេ ១:១៣ ១០:១៣
**២២:៤៦** ឍ មក ១២:៣៤ លក ២០:៤០
**២៣:២** ណ អរ ៧:៦,២៥
**២៣:៤** ត លក ១១:៤៦ កច ១៥:១០ កទ ៦:១៣
**២៣:៥** ថ មថ ៦:១,២,៥,១៦ ទ នក ១៣:៩ ចទ ៦:៨ ធ ជន ១៥:៣៨ ចទ ២២:១២
**២៣:៦** ន លក ១១:៤៣ ១៤:៧ ២០:៤៦

ទៀតថា ដូច្នេះ ធ្វើដូចម្ដេចឱ្យហ្លួងដាវីឌមានបន្ទូល ដោយ
នូវព្រះវិញ្ញាណ ហៅទ្រង់ជាព្រះ អម្ចាស់បាន 44ដោយថា
«ព្រះអម្ចាស់ទ្រង់មានបន្ទូលទៅព្រះអម្ចាស់នៃខ្ញុំថា ចូរឯង
អង្គុយខាងស្ដាំអញ ទាល់តែអញ ដាក់ពួកខ្មាំងសត្រូវឯង
នៅក្រោមជើងឯង»[ឌ] 45ដូច្នេះ បើហ្លួងដាវីឌនោះឯង ទ្រង់
ហៅព្រះគ្រីស្ទថាជាព្រះអម្ចាស់ នោះធ្វើ ដូចម្ដេចឱ្យព្រះគ្រីស្ទ
ធ្វើជាព្រះវង្សទ្រង់បាន 46តែគ្មាន អ្នកណាអាចនឹងឆ្លើយ
តបទៅនឹងទ្រង់១ម៉ាត់បានទេ រួចតាំងពីថ្ងៃនោះមក គ្មាន
អ្នកណាហ៊ានទូលសួរទ្រង់ទៀត ឡើយ[ឍ]។

### វេទនាដល់មនុស្សកំពុត

*២៣:១-៧ = មក ១២:៣៨,៣៩ លក ២០:៤៥,៤៦*

*២៣:៣៧-៣៩ = លក ១៣:៣៤,៣៥*

**២៣** 1គ្រានោះ ព្រះយេស៊ូវទ្រង់មានបន្ទូលនឹងហ្វូង
មនុស្ស ហើយនឹងពួកសិស្សទ្រង់ថា 2ពួកអាចារ្យ[ណ] នឹង
ពួកផារិស៊ី គេបានតាំងខ្លួនគេ អង្គុយនៅទីបង្រៀនរបស់
លោកម៉ូសេ 3ដូច្នេះ គ្រប់ទាំងសេចក្ដីណាដែលគេប្រាប់ឱ្យ
អ្នករាល់គ្នាកាន់តាម នោះចូរកាន់ ហើយប្រព្រឹត្តតាមចុះ
ប៉ុន្តែកុំឱ្យប្រព្រឹត្តតាមអំពើរបស់គេឡើយ ដ្បិតគេគ្រាន់តែ
ថា តែមិនធ្វើតាមទេ 4ពីព្រោះគេចងបន្ទុកយ៉ាងធ្ងន់ ដាក់
លើស្មាមនុស្ស ជាបន្ទុកដែលពិបាកទទួល តែខ្លួនគេមិន
ព្រមទាំងយកម្រាមដៃឆ្កឹះបន្ទុកនោះផង[ត] 5គ្រប់ទាំងការ
ដែលគេធ្វើទាំងប៉ុន្មាន នោះសុទ្ធតែធ្វើឱ្យតែមនុស្សមើល
ឃើញទេ[ថ] គឺគេធ្វើស្លាក[ទ]ធំៗកត់ក្រិត្យវិន័យ នឹងរំយោល
អាវ[ធ]គេឱ្យវែងៗ 6គេគាប់ចិត្តនឹងកន្លែងលេខ ១ក្នុងការ
ស៊ីលៀង នឹងកន្លែងដែលមុខគេក្នុងសាលាប្រជុំ[ន] 7ព្រម
ទាំងគាប់ចិត្តឱ្យមនុស្សគំនាប់ខ្លួននៅទីផ្សារ ហើយឱ្យគេ
ហៅខ្លួនថា លោកគ្រូៗផង[ប] 8ប៉ុន្តែ ឯអ្នករាល់គ្នាវិញ
មិនត្រូវឱ្យអ្នកដទៃហៅខ្លួនជាលោកគ្រូឡើយ ដ្បិតអ្នករាល់គ្នា

**២៣:៧** ប ខ.៨ មថ ២៦:២៥,៤៩ មក ៩:៥ ១០:៥១ យហ ១:៣៨,៤៩ ៣:២,២៦ ២០:១៦

---

**២២:៣៧,៣៩** *ស្រឡាញ់* ភាសាក្រិកមានអត្ថន័យពីរគឺ (១).ស្រឡាញ់បែបជាមិត្ត ។ (២).ស្រឡាញ់ដោយប្ដេជ្ញាប្ដូរផ្ដាច់ចេញពីឆន្ទៈក្នុងការបំពេញកិច្ចការអ្វីមួយ ។

**២២:៣៧** *អស់ពីចិត្ត . . . ព្រលឹង . . . គំនិត* គម្ពីរជាភាសាហេព្រើរក្នុង ចទ ៦:៥ "អស់ពីចិត្ត. . . ព្រលឹង. . . កំឡាំង" ភាសាក្រិកមានថែម "គំនិត"។ ព្រះយេស៊ូវបាន ប្រើពាក្យទាំងបួននេះក្នុង "មក ១២:៣០"។ *ព្រលឹង* មើលការពន្យល់ ១០:២៨ ។

**២២:៤០** *ក្រិត្យវិន័យ* គឺជាគម្ពីរសញ្ញាចាស់ទាំងមូល (មើលពន្យល់ ៥:១៧)។

**២២:៤១-៤៦** មើលការពន្យល់ មក ១២:៣៥-៤០ លក ២០:៤៤-៤៧ ។

**២៣:២** *អង្គុយនៅទីបង្រៀនរបស់លោកម៉ូសេ* គឺអ្នកទទួលអំណាច ដើម្បីនឹងស្នងលោកម៉ូសេ ក្នុងមុខតំណែងជាគ្រូបង្រៀនក្រឹត្យវិន័យ ។

**២៣:៥** *ស្លាក* គឺជាប្រអប់តូចៗ មានផ្ទុកក្រឹត្យវិន័យបួន (នក ១៣:១-១០ ១៣:១១-១៦ ចទ ៦:៤-៩ ១១:១៣-២១) ពេលពួកប្រុសៗសាសន៍យូដាចូលអធិស្ឋាន ដោយពាក់នៅនឹងដៃខាងឆ្វេង ឬថ្ងាសដើម្បីបញ្ជាក់ដល់បណ្ដាជនថាពួកគេកាន់ខ្ជាប់ខ្ជួន និងឧស្សាហ៍ព្យាយាមនឹងសាសនារបស់ខ្លួនខ្លាំងណាស់

**២៣:៦** *កន្លែងដែលមុខគេក្នុងសាលាប្រជុំ* មើលការពន្យល់ មក ១២:៣៩ ។

**២៣:៨-១០** ចូរប្រយ័ត្ននឹងការស្វែងរកឋានៈ កិត្តិយស ដើម្បីឱ្យគេកោតសរសើរ ដែលនាំទៅរកសេចក្ដីអំនួតក្នុងជីវិតនោះ ត្រូវតែជៀសវាងឱ្យ

មានសាស្ដាតែ១ ហើយជាបងប្អូននឹងគ្នាទាំងអស់ ៩ក៏កុំឱ្យ
ហៅអ្នកណាជាឪពុក[ផ] នៅផែនដីនេះដែរ ដ្បិតមានឪពុក
តែ១ប៉ុណ្ណោះ គឺជាព្រះដែលគង់នៅស្ថានសួគ៌ ១០ហើយកុំ
ឱ្យអ្នកណាហៅខ្លួនជាសាស្ដាឡើយ ដ្បិតមានសាស្ដាតែ១
ប៉ុណ្ណោះ គឺជាព្រះគ្រីស្ទ ១១តែអ្នកណាដែលធំជាងគេក្នុង
ពួកអ្នករាល់គ្នា នោះត្រូវធ្វើជាអ្នកបំរើដល់អ្នករាល់គ្នា
វិញ[ព] ១២អ្នកណាដែលដំកើងខ្លួន នោះនឹងត្រូវបន្ទាបចុះវិញ
ហើយអ្នកណាដែលបន្ទាបខ្លួន នោះនឹងបានដំកើងឡើង[ភ]។
១៣វេទនាដល់អ្នករាល់គ្នា ពួកអាចារ្យ នឹងពួកផារិស៊ី ជា
មនុស្សកំពុតអើយ[ម] ដ្បិតអ្នករាល់គ្នាបិទនគរស្ថានសួគ៌នៅ
មុខមនុស្ស ខ្លួនអ្នករាល់គ្នាមិនព្រមចូល ហើយក៏មិនបើក
ដល់អស់អ្នក ដែលកំពុងតែចូល ឱ្យគេចូលដែរ[យ] ១៤វេទនា
ដល់អ្នករាល់គ្នា ពួកអាចារ្យ នឹងពួកផារិស៊ី ជាមនុស្សកំ
ពុតអើយ ដ្បិតអ្នករាល់គ្នាខំសូត្រធម៌ឱ្យច្រើន ដើម្បីឱ្យបាន
ឆស៊ីផ្ទះពួកមេម៉ាយ ហេតុដូច្នោះ អ្នករាល់ គ្នានឹងត្រូវ
ទោសធ្ងន់ជាងទៅទៀត ១៥វេទនាដល់អ្នករាល់គ្នា ពួកអា
ចារ្យនឹងពួកផារិស៊ី ជាមនុស្សកំពុតអើយ ដ្បិតអ្នករាល់គ្នា
ដើរជុំជើងទឹក ជើងគោក ដើម្បីនឹងនាំមនុស្សតែម្នាក់ឱ្យចូល
កាន់សាសនា[រ] តែកាលណាគេចូលកាន់ហើយ នោះអ្នក
រាល់គ្នាតែងធ្វើឱ្យគេទៅជាគួរធ្លាក់ទៅនរក[ល] ជាជាងខ្លួន
១ជា២ផង ១៦វេទនាដល់អ្នករាល់គ្នា ពួកកង្វាក់ដែលនាំ
ផ្លូវគេអើយ[វ] អ្នករាល់គ្នាថា បើអ្នកណាស្បថនឹងព្រះវិហារ
នោះមិនជាអ្វីទេ តែបើស្បថនឹងមាសរបស់ព្រះវិហារ
នោះត្រូវជាប់សម្បថខ្លួន[ស]ហើយ ១៧ឱពួកមនុស្សល្ងីល្ងើ
ហើយកង្វាក់អើយ តើរបស់ណាធំជាង មាស ឬព្រះវិហារ
ដែលធ្វើឱ្យមាសនោះបរិសុទ្ធ[ហ] ១៨ហើយក៏ថា បើអ្នកណា

**២៣:៩** ផ មឡ ១:៦ មថ ៦:៩ ៧:១១
**២៣:១១** ព មក ៩:៣៥
**២៣:១២** ភ ១សយ ២:៨ ទដ ១៨:២៧ សភ ៣:៣៤ អស ៥៧:១៥ អគ ២១:២៦ លក ១:៥២ ១៤:១១
**២៣:១៣** ម ខ.១៥, ២៣,២៥,២៧,២៩ យ លក ១១:៥២
**២៣:១៥** រ កច ២:១១ ៦:៥ ៣:៤៣ ល មថ ៥:២២
**២៣:១៦** វ ខ.២៤ អស ៩:១៦ មថ ១៥:១៤ ស មថ ៥:៣៣–៣៥
**២៣:១៧** ហ នក ៣០:២៩
**២៣:១៩** ឡ នក ២៩:៣៧
**២៣:២១** អ ១ពវ ៨:១៣ ទដ ២៦:៨
**២៣:២២** ក ទដ ១១:៤ មថ ៥:៣៤
**២៣:២៣** ខ លវ ២៧:៣០ គ មីក ៦:៨ លក ១១:៤២
**២៣:២៤** ឃ ខ.១៦
**២៣:២៥** ង មក៧:៤ ច លក ១១:៣៩
**២៣:២៧** ជ លក ១១:៤៤ កច ២៣:៣

ស្បថនឹងអាសនា នោះមិនជាអ្វីទេ តែបើស្បថនឹងដង្វាយ
នៅលើអាសនា នោះត្រូវជាប់សម្បថខ្លួនហើយ ១៩ឱពួក
មនុស្សល្ងីល្ងើ ហើយកង្វាក់អើយ តើរបស់ណាធំជាង
ដង្វាយ ឬអាសនាដែលធ្វើឱ្យដង្វាយនោះបានបរិសុទ្ធ[ឡ]
២០ដូច្នេះ អ្នកណាដែលស្បថនឹងអាសនា នោះឈ្មោះថាស្បថ
នឹងអាសនា ហើយនឹងរបស់ទាំងអស់ដែលនៅលើអាសនា
នោះ ២១ឯអ្នកណាដែលស្បថនឹងព្រះវិហារ នោះឈ្មោះថា
ស្បថនឹងព្រះវិហារ ហើយនឹងព្រះដែលគង់[អ]នៅក្នុងព្រះ
វិហារនោះដែរ ២២ហើយអ្នកណាដែលស្បថនឹងស្ថានសួគ៌
នោះឈ្មោះថាស្បថនឹងបល្ល័ង្កនៃព្រះ ហើយនឹងព្រះដែល
គង់លើបល្ល័ង្កនោះផង[ក] ២៣វេទនាដល់អ្នករាល់គ្នា ពួក
អាចារ្យ នឹងពួកផារិស៊ី ជាមនុស្សកំពុតអើយ ដ្បិតអ្នករាល់
គ្នាថ្វាយ១ភាគក្នុង១០[ខ] ទាំងជីរអង្កាម ជីរលីងលាក់
នឹងល្វផង តែបានចោលសេចក្ដីសំខាន់ជាង ដែលនៅក្នុង
ក្រិត្យវិន័យវិញ ដូចជាសេចក្ដីយុត្តិធម៌ សេចក្ដីមេត្តាករុណា
នឹងសេចក្ដីជំនឿ[គ] គួរតែឱ្យអ្នករាល់គ្នាបានប្រព្រឹត្តការទាំង
នេះ ហើយការឯទៀតនោះ ក៏មិនត្រូវចោលផង ២៤ឱពួក
មនុស្សកង្វាក់ ដែលនាំផ្លូវគេអើយ[ឃ] អ្នករាល់គ្នាត្រងសុច
ចេញ តែលេប សត្វអូដ្ឋវិញ ២៥វេទនាដល់អ្នករាល់គ្នា
ពួកអាចារ្យ នឹងពួកផារិស៊ី ជាមនុស្សកំពុតអើយ ដ្បិតអ្នក
រាល់គ្នាលាងចានលាងថាស[ង]តែខាងក្រៅឯខាងក្នុងវិញ
នោះពេញដោយអំពើប្លន់ នឹងសេចក្ដីហួសខ្នាតទទេ[ច]
២៦ឱពួកផារិស៊ីកង្វាក់អើយ ចូរលាងចានលាងថាសខាង
ក្នុងជាមុន ដើម្បីឱ្យខាងក្រៅ បានស្អាតដែរ ២៧វេទនា
ដល់អ្នករាល់គ្នា ពួកអាចារ្យ នឹងពួកផារិស៊ី ជាមនុស្ស
កំពុតអើយ ដ្បិតអ្នករាល់គ្នាដូចជាម៉ុងខ្មោច[ជ]ដែលលាប
ស ឯខាងក្រៅ ល្អមើលពិតមែន តែខាងក្នុងមានពេញ

បាននូវរាល់ការប្រព្រឹត្តទាំងឡាយណាដែលមិនសមហេតុផល ដូចដែលបានបង្គាប់នេះស្រាប់ ។

**២៣:១៤** ព្រះគម្ពីរភាសាអង់គ្លេសមួយចំនួនប្រើពាក្យថា "វេទនា . . . មនុស្សកំពុតអើយ!អ្នកបិទនគរព្រះអ្នកមិនអាចចូលបានទាំងព្យាយាមមិនឱ្យគេចូល។

**២៣:១៥** ព្រះយេស៊ូវមិនរិះគន់ពួកអាចារ្យផារិស៊ីអំពីភាពឧស្សាហ៍ក្នុងការផ្សព្វផ្សាយដំណឹងល្អរបស់ពួកគេនោះទេ តែទ្រង់បានបដិសេធនឹងលទ្ធផលនៃការងារនោះ ពីព្រោះពួកផារិស៊ីទាំងនោះបាននាំមនុស្សឱ្យវង្វេង និងរឹតតែវេទនាខ្លាំងជាងខ្លួន(ពួកផារិស៊ី)ថែមទៀតផង ហើយទីបញ្ចប់ក៏ធ្លាក់ខ្លួនធ្វើជាកូននៃស្ថាននរក ដោយសារសេចក្ដីបង្រៀនមិនត្រឹមត្រូវ ។ *នរក* មើលការពន្យល់ ៥:២២ និង លក ១២:៥ ។

**២៣:២៣** ព្រះយេស៊ូវមិនរិះគន់ ពីការប្រតិបត្តិតាមបញ្ញត្តិព្រះយ៉ាងហ្មត់ចត់នោះទេ ប៉ុន្តែ ទ្រង់មានបន្ទូលអំពីការដែល "បានចោលសេចក្ដីសំខាន់" តែទ្រង់បានរិះគន់ ដល់មនុស្សមានពុត(មើលការពន្យល់ ៥:១៨–២០)។

**២៣:២៤** *ត្រង* ពួកផារិស៊ីដែលកាន់វិន័យតឹងរ៉ឹង និងប្រុងប្រយ័ត្នណាស់នៅពេលផឹកទឹកម្ដងៗ ពួកគេតែងតែយកក្រណាត់មកច្រោះទឹកនោះដើម្បីកុំឱ្យដោយសត្វល្អិតតូចៗដែលមិនស្អាតនៅក្នុងទឹកនោះ តែបែរជាលេបសត្វអូដ្ឋធំមួយទៅវិញ(ជាន័យធៀប)។

**២៣:២៧** *ម៉ុងខ្មោចដែលលាបស* អ្នកណាដែលជាន់លើផ្នូរខ្មោច នោះចាត់ទុកថាមិនស្អាត(ជន ១៩:១៦) ដូច្នេះផ្នូរខ្មោចត្រូវបានលាបពណ៌ស ដើម្បីឱ្យងាយមើលឃើញជាពិសេសនៅពេលយប់ ។ ការលាបពណ៌នេះ មើលទៅឃើញរលោងស្អាតផ្នែកខាងក្រៅ តែចំពោះខាងក្នុងវិញគឺស្អុយរលួយ និងស្មោកគ្រោក ។

ដោយឆ្អឹងខ្មោច នឹងសេចក្ដីស្មោកគ្រោកគ្រប់មុខវិញ ២៨អ្នក
រាល់គ្នាក៏បែបដូច្នោះដែរ ខាងក្រៅមើលទៅដូចជាសុចរិត
ដល់មនុស្សលោកមែន តែខាងក្នុងមានសុទ្ធតែសេចក្ដីកំពុត
នឹងសេចក្ដីទទឹងច្បាប់ទទេ ២៩វេទនាដល់អ្នករាល់គ្នា ពួក
អាចារ្យ នឹងពួកផារិស៊ី ជាមនុស្សកំពុតអើយ ដ្បិតអ្នករាល់
គ្នាធ្វើម៉ុងពួកហោរា[ឈ] ហើយតាក់តែងផ្នូរ របស់ពួកមនុស្ស
សុចរិត ៣០ដោយថា បើយើងបានរស់នៅក្នុងជំនាន់ពួក
ឰយុកោយើង នោះយើងមិនបានចូលដៃនឹងគាត់ ដើម្បីកំ
ចាយឈាមពួកហោរាទេ ៣១ដូច្នេះ អ្នករាល់គ្នាធ្វើជា
បន្ទាល់ទាស់នឹងខ្លួនថា អ្នករាល់គ្នាជាកូនរបស់ពួកអ្នក
ដែលបានសំឡាប់ហោរាទាំងនោះ[ញ] ៣២ឯអ្នករាល់គ្នា
ចូរបំពេញរង្វាល់[ដ]របស់ពួកឰយុកោ នៃអ្នករាល់គ្នាចុះ[ឋ]
៣៣ឱសត្វពស់ ឱពូជពស់វែកអើយ[ឌ] ធ្វើដូចម្ដេចឱ្យអ្នក
រាល់គ្នារួចពីទោសនៅក្នុងនរកបាន[ឍ] ៣៤ដោយហេតុនោះ
បានជាខ្ញុំចាត់ពួកហោរា ពួកអ្នកប្រាជ្ញ នឹងពួកអាចារ្យ
ឱ្យមកឯអ្នករាល់គ្នាៗនឹងសំឡាប់ហើយឆ្កាងខ្លះ[ណ]ក៏វាយខ្លះ
នឹងរំពាត់ នៅក្នុងសាលាប្រជុំ[ត]របស់អ្នករាល់គ្នា ហើយធ្វើ
ទុក្ខបៀតបៀនគេ ពីក្រុង១ទៅដល់ក្រុង១[ថ] ៣៥ដើម្បីឱ្យអស់
ទាំងឈាមរបស់មនុស្សសុចរិត ដែលបានខ្ចាយនៅផែនដី
បានធ្លាក់មកលើអ្នករាល់គ្នាវិញ តាំងពីឈាមរបស់អេបិល[ទ]
ជាអ្នកសុចរិត ដរាបដល់សាការី ជាកូនបារ៉ាគា[ធ] ដែល
អ្នករាល់គ្នាបានសំឡាប់ នៅកណ្ដាលព្រះវិហារ ហើយនឹង
អាសនា[ន] ៣៦ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អំពើទាំង
នោះនឹងធ្លាក់មកលើមនុស្សដំណនេះវិញ[ប]។
៣៧ឱយេរូសាឡិម ក្រុងយេរូសាឡិមអើយ ឯងដែល
សំឡាប់ពួកហោរា ហើយយកថ្មចោលពួកអ្នកដែលបាន
ចាត់មកឯឯង[ផ] តើប៉ុន្មានដងហើយ ដែលអញចង់ប្រមូល

**២៣:២៩** ឈ លក ១១:៤៧,៤៨
**២៣:៣១** ញ មថ ៥:១២
**២៣:៣២** ដ ១ថន ២:១៦ ឋ អគ ២០:៤
**២៣:៣៣** ឌ មថ ៣:៧ ១២:៣៤ ឍ មថ ៥:២២
**២៣:៣៤** ណ ២របា ៣៦:១៥,១៦ លក ១១:៤៩ ត មថ ១០:១៧ ថ មថ ១០:២៣
**២៣:៣៥** ទ លប ៤:៨ ហេព ១១:៤ ធ សក ១:១ ន ២របា ២៤:២១
**២៣:៣៦** ប មថ ១០:២៣ ២៤:៣៤ លក ១១:៥០,៥១
**២៣:៣៧** ផ ២របា ២៤:២១ មថ ៥:១២ ព ទដ ៥៧:១ ៦១:៤ អស ៣១:៥
**២៣:៣៨** ភ ១ពវ ៩:៧,៨ យរ ២២:៥
**២៣:៣៩** ម ទដ ១១៨:២៦ មថ ២១:៩
**២៤:២** យ លក ១៩:៤៤
**២៤:៣** រ មថ ២១:១ ល លក ១៧:៣០ វ មថ ១៣:៣៩ ២៨:២០
**២៤:៤** ស មក ១៣:៥

កូនឯងទាំងប៉ុន្មាន ដូចជាមេមាន់ក្រុងកូនវាឱ្យជ្រកក្រោម
ស្លាប[ព] តែឯងមិនព្រមទេ ៣៨មើល ផ្ទះឯងនឹងត្រូវចោល
ស្ងាត់ទុកឱ្យឯង[ភ] ៣៩ដ្បិតខ្ញុំប្រាប់ អ្នករាល់គ្នាថា ពីនេះទៅមុខ
អ្នករាល់គ្នានឹងលែងឃើញខ្ញុំទៀត ដរាបដល់កាលណា
អ្នករាល់គ្នានិយាយថា ព្រះអង្គដែលយាងមកដោយនូវ
ព្រះនាមព្រះអម្ចាស់ ទ្រង់ប្រកបដោយព្រះពរ[ម]។

### ទីសំគាល់ពីអវសាននៃពិភពលោក

*២៤:១–៥១ = មក ១៣:១–៣៧ លក ២១:៥–៣៦*

**២៤** ១កាលព្រះយេស៊ូវ ទ្រង់កំពុងតែយាងចេញពី
ព្រះវិហារទៅ នោះពួកសិស្សក៏មកចង្អុលបង្ហាញអស់ទាំង
មន្ទីរ នៃព្រះវិហារ ថ្វាយទ្រង់ទត ២តែទ្រង់មានបន្ទូលទៅ
គេថា អ្នករាល់គ្នាឃើញវត្ថុទាំងនេះឬទេ ខ្ញុំប្រាប់អ្នករាល់
គ្នាជាប្រាកដថា នៅទីនេះនឹងគ្មានថ្មនៅត្រួតលើថ្ម[យ] ដែល
មិនត្រូវ ទំលាក់ចុះនោះទេ ៣រួចកាលទ្រង់គង់លើភ្នំដើម
អូលីវ[រ] នោះពួកសិស្សមកឯទ្រង់ដោយឡែក ទូលសួរថា
សូមប្រាប់យើងខ្ញុំ តើការទាំងនេះកាលណានឹងមកដល់[1]
តើមានទីសំគាល់ណាពីទ្រង់យាងមក[ល] ហើយពីបំផុតកល្ប[វ]
៤ព្រះយេស៊ូវទ្រង់មានបន្ទូលឆ្លើយថា ចូរប្រយ័ត ក្រែងអ្នកណា
នាំអ្នករាល់គ្នាឱ្យវង្វេង[ស] ៥ដ្បិតនឹងមានមនុស្សជាច្រើន យក
ឈ្មោះខ្ញុំមកនិយាយថា ខ្ញុំនេះជាព្រះគ្រីស្ទ ហើយអ្នកទាំង
នោះនឹងនាំមនុស្សជាច្រើន ឱ្យវង្វេងចេញផង[ហ] ៦អ្នករាល់
គ្នានឹងឮនិយាយពីចំបាំង នឹងដំណឹងពីចំបាំងនោះកុំឱ្យមាន
ចិត្តថប់បារម្ភឡើយ ដ្បិតការទាំងនោះត្រូវតែមកដល់
តែនោះពុំទាន់ដល់ចុងបំផុតនៅឡើយទេ ៧ពីព្រោះសាសន៍

**២៤:៥** ហ ខ.១១, ២៣,២៤ ១យ៉ូហ ២:១៨ **២៤:៧** ឡ អស ១៩:២ អ កច ១១:២៨

**២៣:៣៣** *នរក* មើលការពន្យល់ ៥:២២ និង លក ១២:៥ ។

**២៣:៣៥** *អេបិល . . . ដល់សាការី* ការស្លាប់របស់អេបិលមានក្នុង"លប ៤:៨" ហើយសាការីជាកូនបារ៉ាគាមានក្នុង "២របា ២៤:២០–២២" ព្រះយេស៊ូវបានបូកសរុបសេចក្ដីឈឺចាប់នៅក្នុងសញ្ញាចាស់ ក៏ដូចជាពណ៌នាសង្ខេបពីលោកុប្បត្តិដល់ វិវរណៈដែរ ។

**២៣:៣៧–៣៩** មើលការពន្យល់ លក ១៣:៣៤–៣៥ ។

**២៤:១–២៥:៤៦** នេះជាសេចក្ដីបង្រៀនលើកទីប្រាំ និងជាលើកចុងក្រោយបង្អស់ក្នុងចំណោមសេចក្ដីបង្រៀនដ៏អស្ចារ្យនានានៃគម្ពីរដំណឹងល្អម៉ាថាយ (មើលការពន្យល់ ៥:១–៧:២៩ និង មក ១៣:១–៣៧)។

**២៤:២** *គ្មានថ្មនៅត្រួតលើថ្ម* តាមន័យនៃពាក្យនេះ គឺបានសម្រេចនៅឆ្នាំ៧០ គ.ស ក្រោមការដឹករបស់ទីតុស ជាអធិរាជរ៉ូម៉ាំង ។ ទីក្រុងយេរូសាឡិម និងព្រះវិហារត្រូវបានគេបំផ្លាញចោល ។ ថ្មទាំងឡាយត្រូវបានគាស់ចេញជាបំណែកៗ ដើម្បីស្វែងរកមាសដែលរលាយហូរពីដំបូលពេលត្រូវកំដៅភ្លើងឆេះព្រះវិហារ ។ *ថ្ម* មើលការពន្យល់ មក ១៣:១ ។ *ត្រូវទំលាក់ចុះ* នៅឆ្នាំ ១៩៦៨ ត្រូវបានគេជីករកឃើញថ្មធំៗទាំងនេះជាច្រើន ដែលរលំចេញពីជញ្ជាំងដោយសារពួកឈ្លានពាន ។

**២៤:៣** *ភ្នំដើមអូលីវ* ជាជួរភ្នំតូចមួយ ដែលមានប្រវែងជិត២គីឡូម៉ែត្រនៅត្រើយ ជ្រោះកេដ្រុនភាគខាងលិចនៃក្រុងយេរូសាឡិម (មើលការពន្យល់ មក ១១:១)។ តើហេតុការណ៍ទាំងនេះនឹងកើតឡើងនៅពេលណា? តើមានអ្វីជាទីសំគាល់ពីព្រះអង្គយាងមក និងពីទីអវសាននៃពិភពលោកដែរឬទេ? ព្រះយេស៊ូវបានឆ្លើយសំណួរទាំងនេះក្នុង"ខ.៤–១៤" ពីអវសាននៃពីភពលោក និង "ខ.១៥–២២" ការបំផ្លាញ ទីក្រុងយេរូសាឡិម(មើលការពន្យល់ លក ២១:២០) និងហើយការយាងមករបស់ ព្រះគ្រីស្ទ"ខ.២៣–៣១"។

**២៤:៥** *ព្រះគ្រីស្ទ* មើលការពន្យល់ ១:១៧ ។

១នឹងលើគ្នាទាស់នឹងសាសន៍១ នគរ១ទាស់នឹងនគរ១[ឱ]
ហើយនឹងកើតមានអំណត់[អ] ជំងឺអាសន្នរោគ និងកក្រើកដី
នៅកន្លែងផ្សេងៗ ៨តែការទាំងនោះជាដើមចម នៃ
សេចក្តីទុក្ខទេ ៩គ្រានោះ គេនឹងបញ្ជូនអ្នករាល់គ្នាទៅឱ្យ
មានសេចក្តីវេទនា[ក] ព្រមទាំងសំឡាប់អ្នករាល់គ្នា[ខ] ហើយ
គ្រប់ទាំង សាសន៍នឹងស្អប់អ្នករាល់គ្នា ដោយព្រោះឈ្មោះខ្ញុំ[គ]
១០នៅគ្រានោះ មនុស្សជាច្រើននឹងរវាតចិត្តចេញ គេនឹង
បញ្ជូន[3]គ្នាហើយនិងស្អប់គ្នាទៅវិញទៅមក ១១ក៏នឹងមានហោ
រាក្លែងក្លាយ[ឃ]ជាច្រើនកើតឡើង នាំឱ្យមនុស្សជាច្រើន
វង្វេងដែរ[ង] ១២រួចដោយព្រោះការទទឹងច្បាប់នឹងចំរើន
ជាច្រើនឡើង បានជាសេចក្តីស្រឡាញ់របស់មនុស្សជាច្រើន
នឹងរសាយអស់ទៅ ១៣តែអ្នកណាដែលកាន់ខ្ជាប់ ដរាប
ដល់ចុងបំផុតវិញ អ្នកនោះនឹងបានសង្គ្រោះ[ច] ១៤ដំណឹងល្អនេះ
ដែលសំដែងពីនគរ[ឆ] នឹងត្រូវប្រកាសប្រាប់ទូទៅគ្រប់ ក្នុង
លោកីយ[ជ] ទុកជាទីបន្ទាល់ដល់អស់ទាំងសាសន៍ នោះទើប
នឹងបានដល់ ចុងបំផុត។

១៥ដូច្នេះ កាលណាអ្នករាល់គ្នាឃើញសេចក្តីដែលហោរា
ដានីយ៉ែលបានទាយទុក គឺជាសេចក្តីស្អប់ខ្ពើមដែលបង្ខូច
បំផ្លាញ[ឈ] វាឈរនៅក្នុងទីបរិសុទ្ធ[ញ] (អ្នកណាដែលអាន
មើលឱ្យយល់ចុះ) ១៦នោះត្រូវឱ្យពួកអ្នកដែលនៅស្រុកយូដា
រត់ចេញទៅឯភ្នំ ១៧កុំឱ្យអ្នកណាដែលនៅលើដំបូលផ្ទះ[ដ]
ចុះមក ដើម្បីនឹងយករបស់អ្វីពីផ្ទះឡើយ ១៨ហើយកុំឱ្យអ្នក
ដែលនៅស្រែចំការ ត្រឡប់មកវិញ ដើម្បីនឹងយកសំលៀក
បំពាក់ ខ្លួនដែរ ១៩នៅគ្រានោះ ស្ត្រីណាដែលមានផ្ទៃពោះ
ហើយស្ត្រីណាដែលបំបៅកូននឹងវេទនាណាស់[ឋ] ២០ចូរ
អធិស្ឋានសូមកុំឱ្យត្រូវរត់នៅរដូវរងា ឬនៅថ្ងៃឈប់សំរាក
ឡើយ ២១ដ្បិតនៅគ្រានោះ នឹងមានសេចក្តីវេទនាជាខ្លាំង
ណាស់ ដល់ម្ល៉េះបានជាតាំងពីដើមកំណើតលោកីយ ដរាប
មកដល់សព្វថ្ងៃនេះ មិនដែលមានយ៉ាងដូច្នោះឡើយ ហើយ
ទៅមុខក៏មិនដែលមានដែរ[ឌ] ២២បើមិនបានបន្ថយថ្ងៃទាំង
នោះឱ្យខ្លីចុះ នោះគ្មានមនុស្សណានឹងបានសង្គ្រោះទេ ប៉ុន្តែ
ថ្ងៃទាំងនោះនឹងត្រូវបន្ថយទៅ ដោយយល់ដល់ពួករើស
តាំង[ឍ] ២៣គ្រានោះ បើមានអ្នកណាប្រាប់អ្នករាល់គ្នាថា
មើលព្រះគ្រីស្ទគង់នៅទីនេះ ឬនៅទីនោះ នោះកុំឱ្យជឿគេ
ឡើយ[ណ] ២៤ដ្បិតនឹងមានព្រះគ្រីស្ទក្លែង ហើយហោរា
ក្លែងកើតឡើង គេនឹងធ្វើទីសំគាល់យ៉ាងធំ ហើយនឹងការ
អស្ចារ្យ[ត] ដើម្បីនឹងនាំទាំងពួកអ្នករើសតាំងឱ្យវង្វេងផង
បើសិនជាបាន ២៥មើល ខ្ញុំបានប្រាប់អ្នករាល់គ្នាជាមុន
២៦ដូច្នេះ បើគេប្រាប់អ្នករាល់គ្នាថា មើល ទ្រង់គង់នៅ
ទីរហោស្ថាន នោះកុំឱ្យចេញទៅឡើយ ឬថា មើលទ្រង់
គង់នៅក្នុងបន្ទប់ នោះក៏កុំឱ្យជឿឱ្យសោះ ២៧ព្រោះដំណើរ
ដែលកូនមនុស្ស[ថ]មក[ទ] នោះនឹងបានដូចជាផ្លេកបន្ទោរ[ធ]
ដែលភ្លឺផ្លេកៗ ពីទិសខាងកើតដល់ទិសខាងលិចដែរ
២៨ដ្បិតខ្មោចមាននៅកន្លែងណា ឥន្ទ្រី[1]នឹងប្រជុំគ្នានៅកន្លែង
នោះ ឯង[ន]។

**២៤:៩** ក មថ ១០:១៧ ខ យហ ១៦:២ គ យហ ១៥:២១ **២៤:១១** ឃ មថ ៧:១៥ ង មក ១៣:៥ **២៤:១៣** ច មថ ១០:២២ **២៤:១៤** ឆ មថ ៤:២៣ ជ រម ១០:១៨ លក ២:១ ៤:៥ កច ១១:២៨ ១៧:៦ **២៤:១៥** ឈ ដយ ៩:២៧ ១១:៣១ ១២:១១ ញ កច ៦:១៣ **២៤:១៧** ដ ១សយ ៩:២៥ មថ ១០:២៧ លក ១២:៣ កច ១០:៩ **២៤:១៩** ឋ លក ២៣:២៩ **២៤:២១** ឌ អគ ៥:៩ ដយ ១២:១ យអ ២:២ **២៤:២២** ឍ ខ.២៤,៣១ **២៤:២៣** ណ លក ១៧:២៣ ២១:៨

**២៤:២៤** ត នក ៧:១១,២២ ២ថន ២:៩–១១ វវ ១៣:១៣ ១៦:១៤ ១៩:២០ **២៤:២៧** ថ មថ ៨:២០ ទ លក ១៧:៣០ ធ លក ១៧:២៤ **២៤:២៨** ន លក ១៧:៣៧

**២៤:៨** *ដើមចមនៃសេចក្តីទុក្ខ* គឺសេចក្តីរងទុក្ខលើកដំបូងសំដៅទៅលើការរងទុក្ខមុននឹងការយាងមកដល់របស់ព្រះមែស៊ី នេះបើតាមប្រពៃណីរបស់សាសន៍យូដា ។

**២៤:១៥** *សេចក្តីស្អប់ខ្ពើមដែលបង្ខូចបំផ្លាញវាឈរនៅក្នុងទីបរិសុទ្ធ* ការនេះហោរាដានីយ៉ែលបានទាយទុកតាំងតែឆ្នាំ១៦៨មុនគ.ស នៅពេលដែលស្តេចអាន់ទីយ៉ូត–អេពីផានបានកសាងអាសនាថ្វាយព្រះសេយូសនៅចំកណ្តាលទីបរិសុទ្ធក្នុងព្រះវិហារយេរូសាឡិម(កច ១៤:១២,១៣)។ មានអ្នកខ្លះយល់ថា មានរឿងពីរទៀត ដែលកំពុងដំណើរការក្នុងការសម្រេចទំនាយនេះ (១).ការបំផ្លិចបំផ្លាញព្រះវិហារនៅឆ្នាំទី៧០ដោយពួករ៉ូម៉ាំង ។ (២).ការលេចរូបរាងនៃការប្រឆាំងនឹងព្រះគ្រីស្ទនៅទីក្រុងយេរូសាឡិម (២ធថ ២:៤ វវ ១៣:១៤–១៥ និងការពន្យល់ ដយ ៩:២៥–២៧ ១១:៣១)។

**២៤:១៦** *ភ្នំ* បើឆ្លងទន្លេយ័រដាន់នឹងមានភ្នំជាច្រើន ជាកន្លែងដែលភីឡាបានបោះទីតាំង ។ គ្រីស្ទបរិស័ទនៅយេរូសាឡិមបានភៀសខ្លួនទៅតំបន់នេះ នៅពេលពួករ៉ូម៉ាំងតាមចាប់មុនឆ្នាំទី៧០ ។ អ្នកខ្លះជឿថាអនាគតនឹងកើតមានការភៀសខ្លួនស្រដៀងគ្នានេះនាអំឡុងពេលមានទុក្ខព្រួយ (ដយ ៩:២៧)។

**២៤:១៩** មើលការពន្យល់ មក ១៣:១៧ ។

**២៤:២០** *រដូវរងា* មើលការពន្យល់ មក ១៣:១៨ ។ *ថ្ងៃឈប់សំរាក* មានតែលោកម៉ាថាយម្នាក់គត់បានបន្ថែមចំណុចនេះ ព្រោះគាត់សរសេរទៅកាន់ពួកយូដាដោយហាមឃាត់ដាច់ខាត សូម្បីតែការដើរក្នុងរយៈចម្ងាយកន្លះគីឡូក៏មិនបានដែរ នៅថ្ងៃឈប់សម្រាកនោះ ។

**២៤:២១** *សេចក្តីវេទនាជាខ្លាំងណាស់* តាមរយៈលោកយ៉ូសែបហ្វីស (Josephus) ជាអ្នកប្រវត្តិសាស្ត្រយូដានៅគ្រានោះ បានពណ៌នាហេតុការណ៍នៃការបំផ្លាញព្រះវិហារនៅក្រុងយេរូសាឡិម ដោយពាក្យនេះស្ទើរតែទាំងអស់គ្នា ។ អ្នកខ្លះជឿថាការវេទនានេះនឹងកើតម្តងទៀតនាពេលអនាគត (ដយ ១២:១)។

**២៤:២២** *ពួករើសតាំង* គឺរាស្ត្ររបស់ព្រះ ។ *បន្ថយថ្ងៃ...ចុះ* អ្នកខ្លះយល់ថាការថ្លែងនេះមានន័យថា សេចក្តីវេទនាមានកម្លាំងខ្លាំងណាស់ បើសិននៅតែបន្តនោះនឹងត្រូវបំផ្លាញគ្រប់គ្នា ។ មានអ្នកខ្លះជឿថា ព្រះគ្រីស្ទកំពុងបញ្ជាក់ពីការកាត់ បន្ថយពេលវេលានៃសេចក្តីទុក្ខវេទនាដែលមានកំណត់នោះ ដូចជា៧០ មកត្រឹម៧ អាទិត្យ (ដយ ៩:២៧) ឬ ៤២ខែ (វវ ១១:២ ១៣:៥)។

២៩ក្រោយសេចក្ដីវេទនារបស់គ្រានោះមក ស្រាប់តែថ្ងៃនឹង
ទៅជាងងឹត ខែនឹងលែងភ្លឺអស់ទាំងផ្កាយនឹងធ្លាក់ចុះពីលើ
មេឃ ហើយអស់ទាំងអំណាចនៅលើមេឃនឹងត្រូវកក្រើក
រំពើក[ប] ៣០នោះទីសំគាល់របស់កូនមនុស្ស នឹងលេចមក
នៅលើមេឃ គ្រប់ទាំងពូជមនុស្សនៅផែនដីនឹងគក់ទ្រូងយំ[ផ]
ក៏នឹងឃើញកូនមនុស្ស មកលើពពកនៅលើមេឃ[ព] មាន
ទាំងព្រះចេស្តា និងសិរីល្អជាខ្លាំង ៣១ហើយលោកនឹងចាត់
ពួកទេវតា[ភ]របស់លោក ឱ្យមកដោយសូរផ្លុំត្រែជាខ្លាំង[ម]
ទេវតាទាំង នោះនឹងប្រមូលពួករើសតាំងរបស់លោកពី
ទិសទាំង៤ចាប់តាំងពីជើងមេឃម្ខាង រហូតដល់ជើងមេឃ
ម្ខាង ។
៣២ប៉ុន្តែ ចូររៀនសេចក្ដីប្រៀបប្រដូចពីដើមល្វា កាល
ណាមែកវាត្រឡប់ជាទន់ ហើយស្លឹកក៏ប៉ិចឡើង នោះអ្នក
រាល់គ្នាដឹងថា រដូវក្ដៅជិតដល់ហើយ ៣៣ដំណើរនេះក៏
បែបដូច្នោះដែរ កាលណាឃើញការទាំងនេះកើតមក
ត្រូវដឹងថា លោកជិតមកដល់ហើយ ក៏នៅមាត់ ទ្វារផង[យ]
៣៤ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា មនុស្សដំណនេះនឹង
មិនទាន់កន្លងហួសបាត់ទៅ ទាល់តែគ្រប់ការទាំង នេះបាន
កើតមកដល់[រ] ៣៥ផ្ទៃមេឃ ហើយផែនដីនឹងកន្លងបាត់ទៅ
តែពាក្យខ្ញុំមិនដែលបាត់ឡើយ[ល]។

## មិនដឹងថ្ងៃ ពេលកំណត់

*២៤:៣៧–៣៩ = លក ១៧:២៦–២៧*

*២៤:៤៥–៥១ = លក ១២:៤២–៤៦*

៣៦ឯត្រង់ថ្ងៃនិងពេលកំណត់ នោះគ្មានអ្នកណាដឹងទេ ទោះ
ទាំងពួកទេវតាដែលនៅលើស្ថានសួគ៌ក៏មិនដឹងដែរ ជ្រាប
តែព្រះវរបិតានៃខ្ញុំប៉ុណ្ណោះ[វ] ៣៧ដ្បិតកាលណាកូនមនុស្សមក
នោះនឹងបានដូចជានៅជំនាន់លោកណូអេដែរ[ស] ៣៨ដ្បិតនៅ
គ្រាមុនទឹកជន់លិច នោះគេកំពុងតែស៊ីផឹក ហើយរៀបការ
ប្ដីប្រពន្ធ[ហ] ដរាបដល់ថ្ងៃដែលលោកណូអេចូលទៅក្នុងទូក
ធំ ៣៩គេឥតបានដឹងខ្លួនឡើយ ទាល់តែទឹកជន់ឡើង យកគេ
ទៅទាំងអស់គ្នា នោះដល់កាលណាកូនមនុស្សមកក៏នឹងមាន
ដូច្នោះដែរ[ឡ] ៤០នៅគ្រានោះ នឹងមានមនុស្ស២នាក់នៅចំការ
ម្នាក់នឹងបានយកទៅ ហើយម្នាក់ទុកនៅ[អ] ៤១ស្ត្រី២នាក់កំពុង
តែកិនម្សៅ ម្នាក់នឹងបានយកទៅ ហើយម្នាក់ទុកនៅ[ក]
៤២ដូច្នេះ ឱ្យចាំយាម ដ្បិតអ្នករាល់គ្នាមិនដឹងជាពេលណា
ដែលព្រះអម្ចាស់នៃអ្នករាល់គ្នានឹងយាងមកទេ[ខ] ៤៣ចូរដឹង
សេចក្ដីនេះចុះ បើម្ចាស់ផ្ទះបានដឹងជាចោរនឹងមកនៅយាម
ណា[គ] នោះគេនឹងបានចាំយាមមិនឱ្យចោរទំលុះចូលផ្ទះបាន
ទេ ៤៤ដូច្នេះ ឱ្យអ្នករាល់គ្នាប្រុងប្រៀបខ្លួនជាស្រេចដែរ[ឃ]
ដ្បិតកូនមនុស្សនឹងមកនៅវេលាដែលអ្នករាល់គ្នាមិនគិត ។
៤៥ដូច្នេះ អ្នកណាជាអ្នកបំរើស្មោះត្រង់[ង] មានមារយាទ
ដែលចៅហ្វាយបានតាំងឱ្យត្រួតលើពួកផ្ទះលោក នឹងឱ្យអា
ហារគេបរិភោគ តាមត្រូវពេល ៤៦បើកាលណាចៅហ្វាយ
មកដល់ ឃើញអ្នកបំរើនោះកំពុងតែធ្វើដូច្នោះ នោះមានពរ
ហើយ[ច] ៤៧ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ចៅហ្វាយនឹង
តាំងអ្នកនោះឡើង ឱ្យត្រួតលើរបស់ទ្រព្យលោកទាំងអស់[ឆ]
៤៨ប៉ុន្តែ បើជាអ្នកបំរើអាក្រក់វិញ ហើយគិតក្នុងចិត្តថា ចៅ
ហ្វាយអញក្រមក ៤៩ក៏តាំងវាយដំពួកគូកនខ្លួន ព្រមទាំងស៊ី
ផឹកជាមួយនឹងពួកមនុស្សប្រមឹកផង[ជ] ៥០ដូច្នេះ នៅថ្ងៃណា
ដែលវាមិននៅចាំ ជាវេលាណាដែលវាមិនដឹង នោះចៅ
ហ្វាយនឹងមកដល់ ៥១ហើយនឹងធ្វើទោសវាជាយ៉ាងធ្ងន់
ទាំងឱ្យវាមានចំណែកជាមួយនឹងពួកមនុស្ស មានពុតផង
នៅទីនោះនឹងយំ ហើយសង្កៀតធ្មេញ[ឈ]។

## រឿងប្រៀបប្រដូចអំពីស្ត្រីព្រហ្មចារី១០នាក់

**២៥** ១គ្រានោះ នគរស្ថានសួគ៌នឹងបានដូចជា[ញ]ស្រីព្រហ្ម
ចារី១០នាក់ ដែលយកចង្កៀង[ដ]រៀងខ្លួន ចេញទៅទទួលប្ដី
ថ្មោងថ្មី[ឋ] ២ក្នុងពួកនាងទាំងនោះ មាន៥នាក់មានគំនិត
ហើយ៥នាក់ល្ងង់[ឌ] ៣នាងល្ងង់ទាំងនោះ គេយកតែចង្កៀង

**២៤:២៩** ប អស ១៣:១០ ៣៤:៤ អគ ៣២:៧ យអ ២:១០,៣១ សផ ១:១៥ វវ ៦:១២,១៣ ៨:១២
**២៤:៣០** ផ វវ ១:៧ ព វវ ១:៧
**២៤:៣១** ភ មថ ១៣:៤១ ម អស ២៧:១៣ សក ៩:១៤ ១កថ ១៥:៥២ ១ថន ៤:១៦ វវ ៨:២ ១០:៧ ១១:១៥
**២៤:៣៣** យ យក ៥:៩
**២៤:៣៤** រ មថ ១៦:២៨ ២៣:៣៦
**២៤:៣៥** ល មថ ៥:១៨
**២៤:៣៦** វ កថ ១:៧
**២៤:៣៧** ស លប ៦:៥ ៧:៦–២៣
**២៤:៣៨** ហ មថ ២២:៣០
**២៤:៣៩** ឡ លក ១៧:៣០
**២៤:៤០** អ លក ១៧:៣៤
**២៤:៤១** ក លក ១៧:៣៥
**២៤:៤២** ខ មថ ២៥:១៣ លក ១២:៤០
**២៤:៤៣** គ លក ១២:៣៩
**២៤:៤៤** ឃ ១ថន ៥:៦

**២៤:៤៥** ង មថ ២៥:២១,២៣ **២៤:៤៦** ច វវ ១៦:១៥ **២៤:៤៧** ឆ មថ ២៥:២១,២៣ **២៤:៤៩** ជ លក ២១:៣៤ **២៤:៥១** ឈ មថ ៨:១២
**២៥:១** ញ មថ ១៣:២៤ ដ លក ១២:៣៥–៣៨ កថ ២០:៨ វវ ៤:៥ ឋ វវ ១៩:៧ ២១:២ **២៥:២** ឌ មថ ២៤:៤៥

**២៤:២៨** *ខ្មោចមាននៅកន្លែងណា ឥន្ទ្រីនឹងប្រជុំគ្នានៅកន្លែងនោះ* ការយាងមករបស់ព្រះគ្រីស្ទនឹងត្រូវបើកសំដែងយ៉ាងច្បាស់ ដូចជាសត្វត្មាតចោមរោមសព (មើលការពន្យល់ លក ១៧:៣៧)។

**២៤:២៩** មើលការពន្យល់ មក ១៣:២៥ ។

**២៤:៣០** *កូនមនុស្ស* មើលការពន្យល់ មក ៨:៣១ ។

**២៤:៣៤** *ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា* មើលការពន្យល់ មក ៣:២៨ ។ *មនុស្សដំណរនេះ* មើលការពន្យល់ លក ២១:៣២ ។

**២៤:៣៥–៣៦** *ផ្ទៃមេឃហើយផែនដីនឹងកន្លងបាត់ទៅ* តែព្រះបន្ទូលរបស់ព្រះយេស៊ូវនឹងឋិតថេរជាដរាបតទៅ ។ *ស្ថានសួគ៌ក៏មិនដឹងដែរ* មើលការ ពន្យល់ មក ១៣:៣២ ។

**២៤:៥១** *នឹងយំ ហើយសង្កៀតធ្មេញ* មើលការពន្យល់ ១៣:៤២ ។

**២៥:១** *ស្រីព្រហ្មចារី១០នាក់* ជាអ្នកកំដរកូនក្រមុំ ហើយមានភារកិច្ចទទួលខុសត្រូវក្នុងការរៀបចំដំណើរកូនក្រមុំឱ្យទៅជួបកូនកំលោះ ។ *ចង្កៀង* ជាឧបករណ៍ម្យ៉ាងដែលធ្វើពីដបឬដែក(កំប៉ុង) ដែលអាចដាក់ប្រេងបាន ហើយភ្ជាប់ក្រណាត់ទៅបំពង់តូចខាងលើបន្ថិចហៅថាបញ្ចោះសម្រាប់អុជបំភ្លឺ ។

**២៥:៣** *ប្រេង* គឺជាប្រេងអូលីវ (ជាដើមឈើមានជាតិប្រេងអាចដុតបាន)។

ទៅ តែមិនបានយកប្រេងជាប់នឹងខ្លួនផងទេ ៤ឯពួកនាង
មានគំនិតវិញ គេបានយកទាំងចង្កៀង ហើយនិងប្រេងដាក់
ក្នុងដបទៅជាមួយផង ៥តែដោយព្រោះប្ដីក្រមកពេក បាន
ជានាងទាំងនោះងោកងុយ ហើយដេកលក់ទៅ[ឍ] ៦លុះដល់
កណ្ដាលអធ្រាត្រ ស្រាប់តែឮសូរសំរែកថា នែ៎ប្ដីមកហើយ
ចូរចេញទៅទទួលចុះ ៧ស្រីព្រហ្មចារីទាំងឡាយក៏ភ្ញាក់ឡើង
រៀបចំចង្កៀងរៀងរាល់ខ្លួន ៨ឯពួកនាងដែលល្ងង់ គេនិ
យាយទៅពួកនាងមានគំនិតថា សូមចែកប្រេងមកឱ្យយើង
ផង ព្រោះចង្កៀងយើងចង់រលត់ហើយ[ណ] ៩តែពួកនាងមាន
គំនិតឆ្លើយឡើងថា ទេ ក្រែងគ្មានល្មមដល់យើង ហើយនិង
នាងរាល់គ្នាផង ស៊ូទៅឯផ្ទះលក់ប្រេង ទិញសំរាប់ខ្លួនវិញ
ទៅ ១០តែកំពុងដែលនាងទាំងនោះទៅទិញ ប្ដីក៏មកដល់
ហើយពួកនាងដែលបានបំរុងជាស្រេច ក៏ចូលទៅក្នុងរោង
ការ[ត] ជាមួយគ្នា រួចគេបិទទ្វារ ១១ឯនាងព្រហ្មចារីឯទៀត
ក៏មកអង្វរថា លោកម្ចាស់ៗអើយ សូមបើកឱ្យយើងខ្ញុំផង
១២តែគាត់ឆ្លើយថា ខ្ញុំប្រាប់នាងរាល់គ្នាជាប្រាកដថា ខ្ញុំ
មិនស្គាល់នាងទេ[ថ] ១៣ដូច្នេះ ចូរចាំយាមចុះ ដ្បិតអ្នករាល់
គ្នាមិនដឹងជាថ្ងៃណា ឬពេលណា ដែលកូនមនុស្សត្រូវមក
នោះទេ[ទ] ។

## រឿងប្រៀបប្រដូចអំពីអ្នកបម្រើល្អ ហើយស្មោះត្រង់

*២៥:១៤–៣០ = លក ១៩:១២–២៧*

១៤ដ្បិតដំណើរនេះបែបដូចជាមនុស្សម្នាក់ ដែលរៀបនឹង
ចេញ[ធ]ពីស្រុកទៅ គាត់ហៅពួកបាវមកប្រគល់របស់ទ្រព្យ
ខ្លួនទុកនឹងគេ ១៥បានឱ្យប្រាក់ទៅម្នាក់៥ពាន់ ម្នាក់ទៀត២
ពាន់ ហើយអ្នកទីបី១ពាន់ គឺឱ្យគ្រប់គ្នាតាមដំរិះគេរៀងខ្លួន[ន]
រួចក៏ចេញទៅ ១៦នោះអ្នកដែលទទួល៥ពាន់ ក៏យក
ប្រាក់ទៅជួញបានចំណេញ៥ពាន់ទៀត ១៧ហើយអ្នកដែល
ទទួល២ពាន់ គាត់ធ្វើដូច្នោះដែរ ក៏បានចំណេញ២ពាន់ ទៀត
១៨តែឯអ្នកដែលទទួលតែ១ពាន់ វាទៅជីកដីកប់ ប្រាក់របស់ចៅ
ហ្វាយវិញ ១៩យូរក្រោយមកចៅហ្វាយរបស់បាវទាំងនោះ
ត្រឡប់ មកវិញ គិតបញ្ជីនឹងគេ[ប] ២០ចំណែកអ្នកដែលបាន
ទទួល៥ពាន់ ក៏យក៥ពាន់ទៀតមកជំរាបចៅហ្វាយថា
លោកចៅហ្វាយ លោកបានប្រគល់៥ពាន់មកខ្ញុំមើល ខ្ញុំបាន
ចំណេញ៥ពាន់ទៀត ២១ចៅហ្វាយនិយាយថាប្រពៃហើយ
បាវល្អស្មោះត្រង់អើយ ឯងមានចិត្តស្មោះនឹងត្រួតរបស់
បន្តិចនេះ ដូច្នេះអញនឹងតាំងឱ្យឯងត្រួតលើរបស់ជាច្រើន
ទៅទៀត[ផ] ចូរឱ្យឯងប្រកបដោយសេចក្ដីអំណរ របស់ចៅ
ហ្វាយឯងចុះ ២២កាលអ្នកដែលទទួល២ពាន់បានមកដល់
នោះក៏ជំរាបថា លោកចៅហ្វាយ លោកបានប្រគល់២ពាន់
មកខ្ញុំ មើល ខ្ញុំបានចំណេញ២ពាន់ទៀត ២៣ចៅហ្វាយ
និយាយថា ប្រពៃហើយ បាវល្អស្មោះត្រង់ អើយ ឯងមាន
ចិត្តស្មោះនឹងត្រួតរបស់បន្តិចនេះ ដូច្នេះ អញនឹងតាំងឱ្យឯង
ត្រួតលើរបស់ជាច្រើន[ព]ទៅទៀត ចូរឱ្យឯងប្រកបដោយ
សេចក្ដីអំណរ របស់ចៅហ្វាយឯងចុះ ២៤ឯអ្នកដែលបាន
ទទួល១ពាន់ វាក៏ចូលមកជំរាបចៅហ្វាយថា លោកចៅ
ហ្វាយ ខ្ញុំដឹងថា លោកជាមនុស្សតឹងរឹងណាស់ លោកច្រូត
នៅកន្លែងដែលមិនបានសាបព្រោះ ហើយប្រមូលនៅកន្លែង
ដែលមិនបានអុំ ២៥ដូច្នេះ ខ្ញុំនឹកខ្លាច ក៏ទៅកប់ប្រាក់១ពាន់
នេះទុកក្នុងដី ហ៎ ខ្ញុំសូមប្រគល់ របស់លោកជូនលោកវិញ
២៦ចៅហ្វាយក៏ឆ្លើយតបថា បាវអាក្រក់ ហើយខ្ជិលច្រអូស
អើយ បើឯងដឹងថា អញច្រូតនៅកន្លែងដែលមិនបានសាប
ព្រោះ ហើយប្រមូលនៅកន្លែងដែលមិនបានអុំ ២៧នោះគួរតែ
ឯងបានយកប្រាក់ទៅ ផ្ញើទុកនឹងអ្នកចងការចុះ លុះដល់
អញមកវិញ នោះនឹងបានប្រាក់អញ ទាំងដើម ទាំងការផង
២៨ដូច្នេះ ចូរដកប្រាក់១ពាន់នោះពីវាចេញ ឱ្យដល់អ្នក
ដែលមាន១ម៉ឺនវិញ ២៩ដ្បិតនឹងឱ្យដល់អស់អ្នកដែលមាន

**២៥:៥** ឍ ១ថ្ន ៥:៦
**២៥:៨** ណ លក ១២:៣៥
**២៥:១០** ត វវ ១៩:៩
**២៥:១២** ថ ខ.៤១ មថ ៧:២៣
**២៥:១៣** ទ មថ ២៤:៤២,៤៤ មក ១៣:៣៥ លក ១២:៤០
**២៥:១៤** ធ មថ ២១:៣៣ លក ១៩:១២
**២៥:១៥** ន មថ ១៨:២៤,២៥
**២៥:១៩** ប មថ ១៨:២៣
**២៥:២១** ផ ខ.២៣ មថ ២៤:៤៥,៤៧ លក ១៦:១០
**២៥:២៣** ព ខ.២១
**២៥:២៩** ភ មថ ១៣:១២ មក ៤:២៥ លក ៨:១៨ ១៩:២៦

**២៥:៧** *រៀបចំ* កងរំប្រឆេះចង្កៀងត្រូវកាត់ចេញ ប្រេងត្រូវចាក់បន្ថែម ។
**២៥:៩** *ទេ ក្រែងគ្មានល្មមដល់យើង* ចង្កៀងនោះប្រហែលទាមទារប្រេង តម្កល់ទុកច្រើនសម្រាប់បន្ថែមវា ដើម្បីរក្សាពន្លឺឱ្យបានយូរ ។
**២៥:១៣** *ចូរចាំយាមចុះ* ជាចំណុចសំខាន់នៃរឿងប្រៀបប្រដូចនេះ ។ *ថ្ងៃណាពេលវេលាណា* គឺសំដៅលើការយាងមករបស់ព្រះគ្រីស្ទ ។
**២៥:១៥** *ប្រាក់* ភាសាក្រិកថា "តាឡិនថុន (talenton)" មុនដំបូងបង្អស់ត្រូវបានគេប្រើដើម្បីកំណត់រង្វាស់ទម្ងន់ ហើយក្រោយមកក៏ក្លាយជារូបិយវត្ថុសម្រាប់ដោះដូរ តែបច្ចុប្បន្ននេះសំដៅលើសមត្ថភាព និងអំណោយទានវិញ ដែលចេញពីរឿងប្រៀបធៀបនេះ (មើលការពន្យល់ លក ១៩:១៣) ។ ឯកសារខ្លះថា "១តាឡិនថុន" មានតម្លៃជាង១ពាន់ដុល្លាអាមេរិកនាពេលបច្ចុប្បន្ននេះ ។
**២៥:២៧** *អ្នកចងការ* ពាក្យដើមគឺ ភ្នាក់ងារធនាគារ តាមភាសាក្រិកពាក្យនេះមានន័យថា តុ គឺសំដៅលើមនុស្សដែលដាក់តុមួយអង្គុយនៅមុខធនាគារដើម្បីប្ដូរប្រាក់ (២១:១២) ។ *ទាំងដើមទាំងការ* ក្នុងភាសាក្រិកប្រើពាក្យ "តូកូស" (tokos) មានន័យថា "ផលកំរៃ ឬអ្វីៗដែលបានមកដោយសារប្រាក់" ។ អ្នកខ្លះហៅថាប្រាក់បង្កើតកូនចៅ ។
**២៥:២៩** ជាខសំខាន់នៃរឿងប្រៀបធៀបនេះ ។ ការត្រៀមខ្លួនជាស្រេច

ហើយអ្នកនោះនឹងមានជាបរិបូរឡើង តែអ្នកណាដែលគ្មាន
នោះនឹងត្រូវហូតយក ទាំងរបស់អ្វី ដែលអ្នកនោះមានផង[ភ]
៣០ឯបាវឥតប្រយោជន៍នោះ ចូរបោះវាចោលទៅឯទីងងឹត
ខាងក្រៅទៅ នៅទីនោះនឹងយំ ហើយសង្កៀតធ្មេញ[ម]។

## សត្វចៀម និងពពែ / ការជំនុំជម្រះចុងក្រោយ

៣១តែកាលណាកូនមនុស្សនឹងមក[យ] ក្នុងសិរីល្អរបស់លោក
មានទាំងពួកទេវតាបរិសុទ្ធទាំងអស់គ្នា មកជាមួយ នោះ
លោកនឹងឡើងគង់លើបល្ល័ង្ករុងរឿង[រ]ឧត្តមរបស់លោក
៣២រួចគ្រប់ទាំងសាសន៍នឹងត្រូវប្រមូលគ្នា នៅចំពោះលោក
ហើយលោកនឹងញែក[ល]គេចេញពីគ្នា ដូចជាអ្នកគង្វាល
ដែលញែកចៀមចេញពីពពែដែរ[វ] ៣៣រួចនឹងដាក់ចៀម
នៅខាងស្តាំ ហើយពពែនៅខាងឆ្វេង ៣៤នោះលោកដ៏ជា
ស្តេច នឹងមានបន្ទូលទៅពួកអ្នកដែលនៅខាងស្តាំថា ឱពួក
អ្នកដែលព្រះវរបិតាយើងបានប្រទានពរអើយ ចូរមក
ទទួលមរដកចុះ គឺជានគរ[ស]ដែលបានរៀបចំទុកសំរាប់
អ្នករាល់គ្នា តាំងពីកំណើតលោកីយមក[ហ] ៣៥ពីព្រោះ
យើងបានឃ្លាន ហើយអ្នករាល់គ្នាបានឱ្យ បរិភោគ
យើងបានស្រេក ហើយអ្នករាល់គ្នាបានឱ្យផឹក យើងជាអ្នក
ដទៃ ហើយអ្នករាល់គ្នាបានទទួលយើង[ឡ] ៣៦យើងនៅ
អាក្រាត ហើយអ្នករាល់គ្នាបានស្លៀកពាក់ឱ្យយើង[អ] យើង
បានឈឺ ហើយអ្នករាល់គ្នាបានមកសួរយើង[ក] ក៏ជាប់គុក
ហើយអ្នករាល់គ្នាបានមកឯយើង[ខ] ៣៧នោះពួកមនុស្ស
សុចរិតនឹងទូលសួរទ្រង់ថា ព្រះអម្ចាស់អើយ តើយើងខ្ញុំ
បានឃើញទ្រង់ស្រេកឃ្លាន ហើយបានថ្វាយទ្រង់សោយ
ពីកាលណា ៣៨តើយើងខ្ញុំបានឃើញទ្រង់ជាអ្នកដទៃ ហើយ
បានទទួលទ្រង់ពីកាលណា ឬទ្រង់អាក្រាតហើយបានបំពាក់
ថ្វាយទ្រង់ពីកាលណា ៣៩តើយើងខ្ញុំបានឃើញទ្រង់ឈឺ ឬ
ជាប់គុក ហើយបានមកឯទ្រង់ពីកាលណា ៤០នោះស្តេច
នឹងឆ្លើយទៅគេថា យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា
ដែលអ្នករាល់គ្នាបានធ្វើការទាំងនោះដល់អ្នក តូចបំផុត
ក្នុងពួកបងប្អូនយើងនេះ នោះឈ្មោះថា បានធ្វើ ដល់យើង
ដែរ[គ] ៤១រួចទ្រង់នឹងមានបន្ទូលទៅពួកខាងឆ្វេងទៀតថាពួក
អ្នករាល់គ្នាដែលត្រូវបណ្តាសាអើយ ចូរថយពីអញចេញ
ទៅ[ឃ]ក្នុងភ្លើងដែលឆេះអស់កល្បជានិច្ច[ង] ដែលបានរៀប
ចំទុកសំរាប់អារក្ស ហើយនឹងពួកទេវតារបស់វាវិញ[ច] ៤២ពី
ព្រោះអញបានឃ្លាន តែឯងរាល់គ្នាមិនបានឱ្យបរិភោគទេ
អញបានស្រេក តែឯងរាល់គ្នាមិនបានឱ្យផឹកទេ ៤៣អញជា
អ្នកដទៃ តែឯងរាល់គ្នាមិនបានទទួលសោះ អញនៅអាក្រាត
តែឯងរាល់គ្នាមិនបានស្លៀកពាក់ឱ្យអញទេ អញក៏ឈឺ
ហើយនៅជាប់គុក តែឯងរាល់គ្នាមិនបានមកសួរសោះ
៤៤រួចគេនឹងទូលសួរទ្រង់ថា ព្រះអម្ចាស់អើយ តើយើងខ្ញុំ
បានឃើញទ្រង់ឃ្លាន ឬស្រេក ឬជាអ្នកដទៃ ឬនៅអាក្រាត
ឬឈឺ ឬជាប់គុក ហើយមិនបានទៅជួយទ្រង់នោះពីកាល
ណា ៤៥នោះទ្រង់នឹងមានបន្ទូលតបថា អញប្រាប់ឯងរាល់គ្នា
ជាប្រាកដថា ដែលមិនបានធ្វើការទាំងនោះ ដល់អ្នក
យ៉ាងតូចបំផុត ក្នុងពួកអ្នកទាំងនេះ នោះឈ្មោះថាមិនបាន
ធ្វើដល់អញដែរ[ឆ] ៤៦ឯពួកអ្នកទាំងនោះនឹងថយទៅ មាន
ទោសអស់កល្បជានិច្ច តែពួកសុចរិតនឹងចូលទៅក្នុងជីវិត
ដ៏នៅអស់កល្បជានិច្ចវិញ[ជឈ]។

## ការឃុបឃិតគ្នាដើម្បីចាប់ព្រះយេស៊ូវ

*២៦:២-៥ = មក ១៤:១,២ លក ២២:១,២*

**២៦** ១កាលព្រះយេស៊ូវទ្រង់មានបន្ទូលសេចក្តីទាំងនេះ[ញ]
រួចហើយ នោះទ្រង់មានបន្ទូលទៅពួកសិស្សថា ២អ្នករាល់
គ្នាដឹងថា នៅ២ថ្ងៃទៀត នឹងចូលបុណ្យរំលង[ដ]ហើយ ឯកូន

**២៥:៣០** ម មថ ៨:១២
**២៥:៣១** យ លក ១៧:៣០
រ មថ ១៩:២៨
**២៥:៣២** ល មឡ ៣:១៨
វ អគ ៣៤:១៧,២០
**២៥:៣៤** ស មថ ៣:២ ៥:៣,១០,១៩ ១៩:១៤
កច ២០:៣២
១កថ ១៥:៥០
កទ ៥:២១
យក ២:៥
ហ ហព ៤:៣ ៩:២៦
វវ ១៣:៨ ១៧:៨
**២៥:៣៥** ឡ យប ៣១:៣២
ហព ១៣:២
**២៥:៣៦** អ អស ៥៨:៧ អគ ១៨:៧
យក ២:១៥,១៦
ក យក ១:២៧
ខ ២ធថ ១:១៦
**២៥:៤០** គ មថ ១០:៤០,៤២
ហព ១៣:២
**២៥:៤១** ឃ មថ ៧:២៣
ង អស ៦៦:២៤
មថ ៣:១២ ៥:២២
មក ៩:៤៣,៤៨
លក ៣:១៧
យដ ខ.៧
ច ២ពត ២:៤
**២៥:៤៥** ឆ សភ ១៤:៣១ ១៧:៥
**២៥:៤៦** ជ មថ ១៩:២៩ យហ ៣:១៥,១៦,៣៦ ១៧:២,៣ រម ២:៧ កទ ៦:៨ ១យហ ១:២ ៥:១១,១៣,២០ ឈ ដយ ១២:២ យហ ៥:២៩ កច ២៤:១៥ រម ២:៧,៨ កទ ៦:៨ **២៦:១** ញ មថ ៧:២៨
**២៦:២** ដ យហ ១១:៥៥

សម្រាប់ការយាងមករបស់ព្រះគ្រីស្ទ ពុំមានន័យថាឱ្យជៀសវាងឧបសគ្គ និងធ្វើកិច្ចការលេងៗ ឬមិនធ្វើអ្វីសោះនោះទេ ។ វាទាមទារឱ្យមានប្រភេទនៃការបម្រើដែលបង្កើតផលផ្លែថ្វាយព្រះអម្ចាស់ ។

**២៥:៣១-៤៦** មានការបកស្រាយពីរដែលគេទទួលស្គាល់ភាគច្រើនអំពីការជំនុំជម្រះនេះ (១).វានឹងកើតឡើងនៅដើមដំបូងនៃអាណាចក្រថ្មី (ខ.៣១, ៣៤) ហើយគោលបំណងសំខាន់នោះគឺកំណត់ថាតើអ្នកណាខ្លះនឹងត្រូវអនុញ្ញាតឱ្យចូលនគរថ្មីនេះ? (ខ.៣៤) ។ (២).ការជំនុំជម្រះបានទាក់ទងនឹងការលេចឡើងបល្ល័ង្កសដ៏អស្ចារ្យនៅទីអវសាននៃពិភពលោក (វវ ២០:១១-១៥) ។ គោលបំណងនោះគឺត្រូវបានកំណត់ថា តើអ្នកណាខ្លះត្រូវចូលនគរដែលមានជីវិតអស់កល្បត្រូវបានសង្គ្រោះ ហើយនិងអ្នកណាខ្លះនឹងត្រូវដាក់ទោសចូលទៅក្នុងស្ថាននរកនោះ (ខ.៣៤,៤៦) ។ មូលដ្ឋានគ្រឹះតំបូងសម្រាប់ជំនុំជម្រះនោះ គឺថាតើត្រូវបានបង្ហាញសេចក្តីស្រឡាញ់ដល់រាស្ត្ររបស់ព្រះដែរឬទេ? (១ យហ ៣:១៤-១៥) ។

**២៥:៣៤-៤០** រង្វាន់ដែលមាននៅក្នុងនគរស្ថានសួគ៌ គឺបានដល់អស់អ្នកណាដែលបម្រើដោយមិនគិតពីរង្វាន់ ។ នៅទីនេះគ្មានតម្រុយណាស្តីពីការទទួលរង្វាន់ឡើយ តែចំពោះព្រះអម្ចាស់គឺទ្រង់ប្រទានមកដោយព្រះគុណមិនមែនដូចជាជំពាក់ទេ ។

**២៦:២** *បុណ្យរំលង* មើលពន្យល់ មក ១៤:១ ។ *កូនមនុស្ស* មក ៨:៣១ ។

មនុស្ស ក៏ត្រូវគេបញ្ជូនទៅ ឱ្យត្រូវជាប់ឆ្កាងដែរ ។
៣នៅគ្រានោះ ពួកសង្គ្រាជ ពួកអាចារ្យ នឹងពួកចាស់ទុំ
នៃបណ្ដាជន គេប្រជុំគ្នានៅទីព្រះលាន[ឋ]នៃសំដេចសង្ឃ ព្រះ
នាមកៃផា[ឌ] ៤ក៏ពិគ្រោះគ្នា ដើម្បីចាប់ព្រះយេស៊ូវដោយ
ឧបាយកល ហើយសំឡាប់បង់[ឍ] ៥តែគេថា កុំធ្វើក្នុងរវាង
ពេលបុណ្យនេះឡើយ ក្រែងបណ្ដាជនកើតកោលាហល[ណ]។

## ការចាក់ប្រេងក្រអូបនៅភូមិបេថានី

*២៦:៦–១៣ = មក ១៤:៣–៩*

*២៦:៦–១៣ = លក ៧:៣៧,៣៨ យហ ១២:១–៨*

៦រីឯកាលព្រះយេស៊ូវទ្រង់គង់ក្នុងផ្ទះស៊ីម៉ូន ជាអ្នកឃ្លង់នៅ
ភូមិបេថានី[ត] ៧នោះមានស្ត្រីម្នាក់មកឯទ្រង់ កាន់ទាំង
ដបថ្មកែវ ដាក់ប្រេងក្រអូបមានដំឡៃដ៏វិសេស នាងក៏
ចាក់ប្រេងនោះលើព្រះសិរទ្រង់ ដែលទ្រង់កំពុងតែគង់
នៅតុ ៨តែកាលពួកសិស្សទ្រង់ឃើញ គេក៏នឹកតូច
ចិត្ត ហើយ និយាយថា ធ្វើបង្ខាតដូច្នេះ តើមានប្រយោជន៍អ្វី
៩ដ្បិតប្រេងនេះនឹងលក់បានប្រាក់ជាច្រើន ដើម្បីនឹងចែក
ឱ្យដល់មនុស្សក្រីក្រ ១០តែព្រះយេស៊ូវទ្រង់ជ្រាប ហើយ
ក៏មានបន្ទូលទៅគេថា ហេតុអ្វីបានជាបង្អាក់ដល់ចិត្តនាង
ដូច្នេះ ដ្បិតនាងបានធ្វើ ការល្អដល់ខ្ញុំណាស់ ១១ពីព្រោះអ្នក
រាល់គ្នាមានពួកអ្នកក្រ នៅជាមួយជាដរាប[ថ] តែខ្ញុំមិននៅ
ជាមួយជាដរាបទេ ១២ដែលនាងនេះបានចាក់ប្រេងក្រអូប
លើខ្លួនខ្ញុំ នោះគឺបាន ធ្វើសំរាប់រៀបកប់ខ្មោចខ្ញុំ[ទ] ១៣ខ្ញុំប្រាប់
អ្នករាល់គ្នាជាប្រាកដថា កន្លែងណាដែលគេនឹងប្រកាស
ប្រាប់ដំណឹងល្អនេះ នៅគ្រប់ក្នុងលោកីយទាំងមូល នោះគេ
នឹងដំណាលពីការដែល នាងបានធ្វើនេះដែរ ទុកសំរាប់ជា
កេរ្តិ៍នាង។

## យូដាស–អ៊ីស្ការីយ៉ុតក្បត់ព្រះយេស៊ូវ

*២៦:១៤–១៦ = មក ១៤:១០,១១ លក ២២:៣–៦*

១៤នៅគ្រានោះ មានម្នាក់ក្នុងពួក១២នាក់ ឈ្មោះយូដាស–
អ៊ីស្ការីយ៉ុត[ធ] វាទៅឯពួកសង្គ្រាជសួរថា ១៥បើខ្ញុំបញ្ជូនអ្នក
នោះមកលោក តើលោកនឹងឱ្យអ្វីដល់ខ្ញុំ រួចគេសំរេច
នឹងឱ្យប្រាក់៣០រៀល[ន]ដល់វា ១៦ចាប់តាំងពីវេលានោះមក
វាក៏ចេះតែរកឱកាសនឹងបញ្ជូនទ្រង់ទៅ ។

## ពិធីលៀងព្រះអម្ចាស់

*២៦:១៧–១៩ = មក ១៤:១២–១៦ លក ២២:៧–១៣*

*២៦:២០–២៤ = មក ១៤:១៧–២១*

*២៦:២៦–២៩ = មក ១៤:២២–២៥ លក ២២:១៧–២០,១កថ ១១:២៣–២៥*

១៧នៅថ្ងៃដំបូង ក្នុងបុណ្យនំបុ័ងឥតដំបែ[ប] នោះពួកសិស្ស
មកឯព្រះយេស៊ូវទូលថា តើទ្រង់សព្វព្រះហឫទ័យឱ្យយើង
ខ្ញុំរៀបបុណ្យរំលងថ្វាយទ្រង់សោយនៅទីណា[ផ] ១៨ទ្រង់ឆ្លើយ
ថាឱ្យចូលទៅក្នុងទីក្រុង ដល់ម្នាក់ណាមួយនោះ ហើយប្រាប់
ថា លោកគ្រូមានប្រសាសន៍ថា កំណត់[ព]ខ្ញុំជិតដល់ហើយ
ខ្ញុំនឹងធ្វើបុណ្យរំលងជាមួយនឹងពួកសិស្សខ្ញុំនៅផ្ទះអ្នក
១៩ដូច្នេះពួកសិស្សក៏ធ្វើតាមបង្គាប់ព្រះយេស៊ូវ ហើយគេ
រៀបចំធ្វើបុណ្យរំលង ។
២០ដល់ល្ងាច ទ្រង់គង់នៅតុជាមួយនឹងពួក១២នាក់ ២១កាល
កំពុងតែបរិភោគ នោះទ្រង់មានបន្ទូលថា ខ្ញុំប្រាប់អ្នក
រាល់គ្នាជាប្រាកដថា ក្នុងពួកអ្នករាល់គ្នា មានម្នាក់នឹង

**២៦:៣** ឋ ដទ ២:២ ឌ ខ.៥៧ លក ៣:២ យហ ១១:៤៧–៥៣ ១៨:១៣,១៤,២៤, ២៨ កច ៤:៦
**២៦:៤** ឍ មថ ១២:១៤
**២៦:៥** ណ មថ ២៧:២៤
**២៦:៦** ត មថ ២១:១៧
**២៦:១១** ថ ចទ ១៥:១១
**២៦:១២** ទ យហ ១៩:៤០
**២៦:១៤** ធ ខ.២៥, ៤៧ មថ ១០:៤
**២៦:១៥** ន នក ២១:៣២ សក ១១:១២
**២៦:១៧** ប នក ១២:១៨–២០ ផ ចទ ១៦:៥–៨
**២៦:១៨** ព មក ១៤:៣៥,៤១ យហ ៧:៦,៨,៣០ ៨:២០ ១២:២៣ ១៣:១ ១៧:១

**២៦:៣** *ពួកសង្គ្រាជ. . .និងពួកចាស់ទុំ* ជាអ្នកជំនួយការរបស់អ្នកដឹកនាំសង្ឃ (មើលការពន្យល់ ២:៤)។ *កៃផា* ជាសម្តេចសង្ឃនៅឆ្នាំទី១៨–៣៦ និងជាកូនប្រសារលោកអាណ (យហ ១៨:១៣) ជាអតីតសម្តេចសង្ឃឆ្នាំទី៦–១៥ ។

**២៦:៥** ក្រែងកើតចលាចលរាប់រយរាប់ពាន់នៃពួកអ្នកធ្វើធម្មយាត្រាសាសន៍យូដាធ្វើដំណើរមកយេរូសាឡិមក្នុងថ្ងៃបុណ្យរំលង ។ មេដឹកនាំសាសនា (ខ.៣) បានដឹងច្បាស់ថាបណ្ដាជនទាំងនោះភាគច្រើន គេពេញចិត្តនឹងព្រះយេស៊ូវខ្លាំងណាស់ ។

**២៦:៦–១៣** មើលការពន្យល់ យហ ១២:១–១១)។

**២៦:៦** *បេថានី* មើលការពន្យល់ ២១:១៧ ។ *ស៊ីម៉ូន ជាអ្នកឃ្លង់* ម្នាក់នេះប្រហែលជាជនរងគ្រោះ បានល្បីឈ្មោះដោយព្រះយេស៊ូវប្រោសឱ្យជាពីឃ្លង់ ។ ឃើញតែមួយកន្លែងទៀតប៉ុណ្ណោះ គឺនៅក្នុង"មក ១៤:១៣"។ ឈ្មោះ "ស៊ីម៉ូន" គឺជាឈ្មោះមួយដែលជនជាតិយូដានិយមចូលចិត្តនៅសតវត្សរ៍ទី១ ។

**២៦:៧** *ដបថ្មកែវ* មានក្នុងសម័យបុរាណ (មើលពន្យល់ មក ១៤:៣)។

**២៦:១០** *ធ្វើការល្អ* ភាសាក្រិកគឺល្អទាំងចរិយាមារយាទ និងសោភ័ណ្ឌភាព ។

**២៦:១៤** *អ៊ីស្ការីយ៉ុត* មើលការពន្យល់ មក ៣:១៩ ។

**២៦:១៥** *ប្រាក់៣០រៀល* ស្មើនឹង១២០ដិនារី (denarii) ជាប្រាក់រ៉ូម៉ាំងដែលមានតម្លៃស្មើនឹងឈ្នួលពលកម្មក្នុងមួយថ្ងៃ ។ ១ដិនារីនៅសម័យនោះស្មើនឹង ២០សេន ដុល្លាអាមេរិកនៅសម័យនេះ (២០:១–១៦)។

**២៦:១៧** *នៅថ្ងៃដំបូង ក្នុងថ្ងៃនំបុ័ងឥតដំបែ* គឺត្រូវនឹងខែខ្មែរយើងខែចេត្រ (មេសា) តែវាជាខែទីមួយនៃឆ្នាំរបស់ពួកយូដា ហើយត្រូវបានហៅថាពេលរៀបចំចូលបុណ្យរំលង ។ អាហារត្រូវបានបរិភោគនៅថ្ងៃលិចក្នុងថ្ងៃទី១៤ និងត្រូវបានបញ្ចប់នៅថ្ងៃលិចទី១៥ ។ នំបុ័ងឥតដំបែនេះអាចទុកបាន៧ថ្ងៃចាប់ពីថ្ងៃទី១៥ដល់ថ្ងៃទី២១ (លវ ២៣:៥–៦) ប៉ុន្តែ នៅសម័យ ព្រះយេស៊ូវត្រូវបានរាប់ពីថ្ងៃទី១៤ដល់ទី២១ បានជាគេហៅថាបុណ្យនំបុ័ងឥតដំបែ (មើលការពន្យល់ មក ១៤:១២)។

**២៦:១៨–៣០** ក្នុងខទាំងនេះបង្ហាញយ៉ាងច្បាស់ថា ព្រះយេស៊ូវទ្រង់បានសោយអាហារនៅថ្ងៃបុណ្យរំលងជាមួយនឹងសិស្សរបស់ទ្រង់នៅពេលយប់មុននឹងទ្រង់ត្រូវបានធ្វើគុត (មើលការពន្យល់ មក ១៤:២២,២៤)។

**២៦:១៨** *កំណត់. . .ដល់ហើយ* សំដៅលើការសុគតរបស់ព្រះយេស៊ូវ។

**២៦:១៩** *រៀបចំធ្វើបុណ្យរំលង* មើលការពន្យល់ មក ១៤:១៥ ។

**២៦:២០** *គង់នៅតុ* មើលការពន្យល់ មក ១៤:១៨ ។

**២៦:២១** *ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា* មើលការពន្យល់ មក ៣:២៨ ។

បញ្ជូនខ្ញុំ[ភ] ។
២២នោះគ្រប់គ្នាមានសេចក្ដីព្រួយជាខ្លាំង ហើយចាប់តាំង
ទូលសួរទ្រង់ថា ព្រះអម្ចាស់អើយ តើទូលបង្គំឬអី ២៣តែទ្រង់
មានបន្ទូលឆ្លើយថា គឺជាអ្នកមួយ ដែលលូកដៃចុះក្នុង
ចានជាមួយនឹងខ្ញុំ អ្នកនោះឯងនឹងបញ្ជូនខ្ញុំទៅ[ម] ២៤ឯកូន
មនុស្ស ត្រូវទៅមែន តាមសេចក្ដីដែលបានចែងទុកពី
ដំណើរលោក[យ] ប៉ុន្តែវេទនាដល់អ្នកនោះ ដែលនឹង បញ្ជូន
កូនមនុស្សទៅ បើវាមិនបានកើតមក នោះល្អដល់វា ជាជាង
២៥នោះយូដាស ជាអ្នកដែលបញ្ជូនទ្រង់[រ] វាចាប់ពាក្យទូល
ថា លោកគ្រូអើយ តើខ្ញុំឬអី[ល] ទ្រង់មានបន្ទូលទៅវាថា
ត្រូវដូចអ្នកនិយាយហើយ។
២៦គ្រាដែលកំពុងតែបរិភោគ នោះព្រះយេស៊ូវទ្រង់យក
នំបុ័ង ហើយកាលទ្រង់បានប្រទានពរ នោះក៏កាច់[វ]ប្រទាន
ទៅពួកសិស្ស ដោយបន្ទូលថា ចូរយកបរិភោគចុះ នេះ
ហើយជារូបកាយខ្ញុំ ២៧រួចទ្រង់យកពែង[ស]មកប្រទានពរក៏
ហុចទៅឱ្យគេ ដោយបន្ទូលថា ចូរបរិភោគពីពែងនេះទាំង
អស់គ្នាចុះ ២៨ដ្បិតនេះជាឈាមខ្ញុំ គឺជាឈាមនៃសញ្ញាថ្មី[ហ]
ដែលបានច្រួចចេញ សំរាប់មនុស្សជាច្រើន ប្រយោជន៍
នឹងផ្ដាច់បាប[ឡ] ២៩តែខ្ញុំប្រាប់អ្នករាល់គ្នាថា ពីនេះតទៅ
មុខ ខ្ញុំមិនផឹកពីផលផ្លែទំពាំងបាយជូរទៀតទេ ដរាបដល់
ថ្ងៃណាដែលខ្ញុំនឹងផឹកជាថ្មី ជាមួយនឹងអ្នករាល់គ្នា[អ]នៅក្នុង
នគរព្រះវរបិតានៃខ្ញុំ ៣០រួចកាលបានច្រៀងទំនុកមួយ
ហើយ នោះក៏នាំគ្នាចេញ ទៅឯភ្នំដើមអូលីវ[ក] ។

## ព្រះយេស៊ូវមានបន្ទូលពីការបដិសេធន៍របស់ពេត្រុស

*២៦:៣១–៣៥ = មក ១៤:២៧–៣១ លក ២២:៣១–៣៤*

៣១ខណនោះ ព្រះយេស៊ូវ ទ្រង់មានបន្ទូលទៅគេថា នៅ
វេលាយប់នេះឯង អ្នករាល់គ្នានឹងមានចិត្តរវាតចេញដោយ
ព្រោះខ្ញុំ[ខ] ដ្បិតមានសេចក្ដីចែងទុកមកថា « អញនឹងវាយអ្នក
គង្វាល ហើយហ្វូងចៀមនឹងត្រូវខ្ចាត់ខ្ចាយទៅ »[គ] ៣២ប៉ុន្តែ
កាលណាខ្ញុំបានរស់ឡើងវិញ នោះខ្ញុំនឹងទៅឯស្រុក
កាលីឡេមុនអ្នករាល់គ្នា[ឃ] ៣៣ពេត្រុសទូលទ្រង់ថា ទោះ
បើមនុស្សទាំងអស់នឹងរវាតចិត្ត ដោយព្រោះទ្រង់ក៏ដោយ
គង់តែទូលបង្គំមិនដូច្នោះទេ ៣៤ព្រះយេស៊ូវទ្រង់មាន
បន្ទូលទៅគាត់ថា ខ្ញុំប្រាប់អ្នកជាប្រាកដថា នៅវេលា
យប់នេះ មុនដែលមាន់រងាវ នោះអ្នកនឹងប្រកែក៣ដងថា
មិនស្គាល់ខ្ញុំ[ង] ៣៥ពេត្រុសទូលតបថា ទោះបើទូលបង្គំត្រូវ
ស្លាប់ជាមួយនឹងទ្រង់[ច]ក៏ដោយ គង់តែមិនព្រមថា មិនស្គាល់
ទ្រង់ឡើយ ហើយពួកសិស្សទាំងអស់ក៏ថាឡើងដូចគ្នា ។

## នៅឯច្បារគែតសេម៉ានី

*២៦:៣៦–៤៦ = មក ១៤:៣២–៤២ លក ២២:៤០–៤៦*

៣៦នោះព្រះយេស៊ូវ ព្រមទាំងពួកសិស្ស ក៏ទៅដល់កន្លែង
ហៅថា ច្បារគែតសេម៉ានី ហើយទ្រង់មានបន្ទូលទៅគេថា
ចូរអង្គុយនៅទីនេះសិន ចាំខ្ញុំនឹងទៅអធិស្ឋាននៅឯណោះ
៣៧រួចទ្រង់យកពេត្រុស នឹងកូនសេបេដេទាំង២នាក់[ឆ]ទៅជា
មួយផង ទ្រង់ចាប់តាំងមានព្រះហឫទ័យព្រួយ ហើយតប់ប្រមល់
ជាខ្លាំង ៣៨ក៏មានបន្ទូលទៅគេថា ចិត្តខ្ញុំព្រួយ[ជ]ពន់ពេក ស្ទើរ

**២៦:២១** ភ លក ២២:២១–២៣ យហ ១៣:២១
**២៦:២៣** ម ទដ ៤១:៩ យហ ១៣:១៨
**២៦:២៤** យ ខ.៣១, ៥៤,៥៦ អស ៥៣ ដយ ៩:២៦ មក ៩:១២ លក ២៤:២៥-២៧, ៤៦ កច ១៧:២,៣ ២៦:២២,២៣ ១ពត ១:១០,១១
**២៦:២៥** រ មថ ១០:៤
ល មថ ២៣:៧
**២៦:២៦** វ មថ ១៤:១៩
**២៦:២៧** ស ១កថ ១០:១៦
**២៦:២៨** ហ នក ២៤:៦–៨ សក ៩:១១ មឡ ២:៥ ហព ៩:២០ ១០:២៩ ១៣:២០
ឡ មថ ២០:២៨ មក ១:៤
**២៦:២៩** អ កច ១០:៤១
**២៦:៣០** ក មថ ២១:១
**២៦:៣១** ខ មថ ១១:៦ ១៣:២១ គ សក ១៣:៧ យហ ១៦:៣២
**២៦:៣២** ឃ មថ ២៨:៧,១០,១៦ **២៦:៣៤** ង ខ.៧៥ យហ ១៣:៣៨
**២៦:៣៥** ច យហ ១៣:៣៧

**២៦:២៣** *លូកដៃចុះក្នុងចានជាមួយនឹងខ្ញុំ* ប្រពៃណីនេះ នៅមានអនុវត្តនៅប្រទេសមជ្ឈិមបូព៌ាខ្លះនាពេលបច្ចុប្បន្ន ដោយយកចំណិតនំបុ័ង ឬសាច់ទៅជ្រលក់ក្នុងចាន ទឹកគ្រឿងរួមគ្នាមួយនៅលើតុ ។ *នឹងបញ្ជូនខ្ញុំ* តាមវប្បធម៌ពួកអារ៉ាប់នាបច្ចុប្បន្ន បានឱ្យដឹងថា កាលណាបរិភោគជាមួយនឹងនរណាម្នាក់ នោះក៏ដូចជាការនិយាយថា "ខ្ញុំជាមិត្តសម្លាញ់របស់អ្នកខ្ញុំនឹងមិនធ្វើបាបអ្នកឡើយ" ។ ហេតុការណ៍នេះ ជាសញ្ញារបស់យូដាស–អ៊ីស្ការីយ៉ុត ជាជាងការដែលធ្វើគួរឱ្យស្អប់(ទដ ៤១:៩) ។

**២៦:២៤** *តាមសេចក្ដី . . . ទុកពីដំណើរលោក* មើលការពន្យល់ មក ១៤:២១ ។ *កូនមនុស្ស* មើលការពន្យល់ មក ៨:៣១ ។

**២៦:២៦–២៨** មើល មក ១៤:២៤ ។ *ប្រទានពរ* គម្ពីរដើមប្រើពាក្យអរព្រះគុណ ។

**២៦:៣០** *ច្រៀងទំនុក* ការប្រកបគ្នាក្នុងពិធីបុណ្យរំលងត្រូវបានលើកមកច្រៀងនៅក្នុងបទព្រះគម្ពីរទំនុកដំកើងជិពូក ១១៥–១១៨ នៅវគ្គទី២ ។

**២៦:៣១** *អ្នករាល់គ្នានឹងមានចិត្តរវាត* មិនមែនគ្រាន់តែពេត្រុសនោះទេ គឺទាំង១១នាក់ យូដាសបានដកចេញហើយ(យហ ១៣:៣០) ។ អត្ថន័យនៃពាក្យរវាតចិត្ត គឺសំដៅលើពេត្រុសបដិសេធព្រះយេស៊ូវ(ខ.៦៩–៧៥) និងការផ្អើលភ័យខ្លាចនៃពួកសិស្ស ដទៃៗទៀត(ខ.៥៦) ។ *អញនឹងវាយអ្នកគង្វាល* មើលការពន្យល់ សក ១៣:៧ ។

**២៦:៣២** *ទៅឯស្រុកកាលីឡេ* មថ ២៨:១០,១៦–២០ មក ១៦:៧ យហ ២១:១–២៣ ។

**២៦:៣៤** *មុនដែលមាន់រងាវ* គឺនៅយាមទី៣នាពេលយប់ ហើយបច្ចុប្បន្ន គឺជិតភ្លឺនាពេលព្រឹក ដែលជាពេលមាន់រងាវ (មើលការពន្យល់ ១៤:២៥ មក ១៣:៣៥) ។

**២៦:៣៦** *គែតសេម៉ានី* ឈ្មោះនេះមានន័យថា "ឃ្នាបប្រេង" ជាកន្លែងមួយសម្រាប់ គាបយកប្រេងពីផ្លែអូលីវ (មើលការពន្យល់ មក ១៤:៣២) ។

**២៦:៣៧** *ពេត្រុស និងកូនសេបេដេទាំង២* គឺយ៉ាកុប និងយ៉ូហាន ៣នាក់នេះ

តែនឹងស្លាប់ ចូរនៅទីនេះចាំយាមជាមួយនឹងខ្ញុំសិន[ឈ]
៣៩កាលទ្រង់បានយាងទៅមុខបន្តិចទៀត នោះទ្រង់ទំលាក់
អង្គ ផ្កាប់ព្រះភក្ត្រចុះអធិស្ឋានថា ឱព្រះវរបិតានៃទូលបង្គំ
អើយ បើសិនជាបាន នោះសូមឱ្យពែង[ញ]នេះកន្លងហួសពី
ទូលបង្គំទៅ ប៉ុន្តែ កុំតាមចិត្តទូលបង្គំឡើយ សូមតាមតែ
ព្រះហឫទ័យទ្រង់វិញ[ដ] ៤០នោះទ្រង់យាងមកដល់ពួកសិស្ស
ឃើញគេដេកលក់ ក៏ មានបន្ទូលទៅពេត្រុសថា ដូច្នេះ
តើអ្នករាល់គ្នាចាំយាមជាមួយនឹងខ្ញុំតែ១ម៉ោងមិនបាន
ទេឬអី ៤១ចូរចាំយាម ហើយអធិស្ឋានចុះ ដើម្បីមិនឱ្យ
កើតសេចក្តីល្បួង[ឌ]នាំចិត្តឡើយ ឯវិញ្ញាណ ក៏ប្រុងជាស្រេច
មែន តែសាច់ឈាមខ្សោយទេ ៤២កាលទ្រង់បានយាងទៅ
ម្តងទៀត នោះក៏អធិស្ឋានថាឱព្រះវរបិតានៃទូលបង្គំអើយ
បើសិនជាពែងនេះកន្លង ហួសពីទូលបង្គំទៅពុំបាន លើក
តែទូលបង្គំទទួល នោះសូម តាមព្រះហឫទ័យទ្រង់ចុះ[ឍ]
៤៣កាលទ្រង់បានយាងមកវិញ នោះក៏ឃើញពួកសិស្សដេក
លក់ទៀត ដ្បិតភ្នែកគេធ្ងន់ជ្រប់ ៤៤រួចទ្រង់យាងចោល
គេទៅម្តងទៀត នឹងអធិស្ឋានជាគំរប់៣ដង ដោយបន្ទូលជា
សេចក្តីដដែល ៤៥នោះទ្រង់យាងមកឯពួកសិស្សមានបន្ទូល
ថា ឥឡូវនេះ អ្នករាល់គ្នាដេកលក់ ហើយសំរាកកំឡាំង
ទៀតឬ មើល កំណត់ជិតដល់ហើយ[ណ] កូនមនុស្សត្រូវគេបញ្ជូន
ទៅក្នុងកណ្តាប់ដៃនៃមនុស្សមានបាប ៤៦ចូរក្រោកឡើង
យើងទៅ នំ អ្នកដែលបញ្ជូនខ្ញុំជិតមកដល់ហើយ ។

## ការចាប់ព្រះយេស៊ូវ

*២៦:៤៧–៥៦ = មក ១៤:៤៣–៥០ លក ២២:៤៧–៥៣*

៤៧កាលទ្រង់កំពុងតែមានបន្ទូលនៅឡើយ នោះឃើញ
យូដាស[ត] ជាម្នាក់ក្នុងពួក១២មកដល់ នាំទាំងហ្វូងមនុស្ស
ជាធំ ដែលកាន់ដាវ កាន់ដំបង មកពីពួកសង្គ្រាជ និងពួក
ចាស់ទុំនៃបណ្តាជន ៤៨ឯអ្នកដែលបញ្ជូនទ្រង់ ក៏ប្រាប់ទីសំ
គាល់នេះដល់គេថា អ្នកណាដែលខ្ញុំថើប គឺអ្នកនោះហើយ
ចូរចាប់វាចុះ ៤៩ស្រាប់តែវាមកដល់ព្រះយេស៊ូវ គំនាប់ទូល
ថា ជំរាបសួរលោកគ្រូ[ថ] រួចក៏ថើបទ្រង់ ៥០តែព្រះយេស៊ូវ
ទ្រង់មានបន្ទូលតបថា សំឡាញ់អើយឯងមកធ្វើអី[ទ] នោះ
គេក៏មកលូកដៃចាប់ព្រះអង្គ ៥១ខណនោះមានម្នាក់ដែល
នៅជាមួយនឹងព្រះយេស៊ូវ គាត់លូកដៃទៅហូតដាវ[ធ] កាប់
ដាច់ស្លឹកត្រចៀក[ន]របស់បាវសំដេចសង្ឃម្នាក់ ៥២តែព្រះ
យេស៊ូវមានបន្ទូលទៅថា ចូរស៊កដាវអ្នកទៅក្នុងស្រោម
វិញទៅ ដ្បិតអស់អ្នកដែលយកដាវ នោះត្រូវស្លាប់ដោយ
ដាវដែរ[ប] ៥៣តើអ្នកស្មានថា ខ្ញុំមិនអាចនឹងសូមដល់ព្រះ
វរបិតាខ្ញុំឥឡូវ ដែលទ្រង់នឹងចាត់ពួកទេវតា១២ កងមកខ្ញុំ
ជា១រំពេចទេឬអី[ផ] ៥៤បើយ៉ាងនោះ ធ្វើដូចម្តេចនឹងបាន
សំរេច[ព]តាមគម្ពីរ ដែលថាត្រូវតែកើតមានដូច្នេះ។
៥៥នៅវេលានោះឯង ព្រះយេស៊ូវមានបន្ទូលទៅហ្វូង
មនុស្សថា តើអ្នករាល់គ្នាបានចេញមកចាប់ខ្ញុំ ដោយកាន់
ដាវ កាន់ដំបង ដូចជាមកចាប់ចោរឬអី ខ្ញុំបានអង្គុយជា
មួយនឹងអ្នករាល់គ្នា ហើយបង្រៀនក្នុងព្រះវិហាររាល់តែ
ថ្ងៃ[ភ] តែអ្នករាល់គ្នាមិនបានចាប់ខ្ញុំទេ ៥៦ប៉ុន្តែ ការទាំងនេះ
បានកើតមក ដើម្បីឱ្យបានសំរេចតាមទំនាយពួកហោរា
វិញ[ម] នោះពួកសិស្សទាំងអស់ក៏រត់ចោលទ្រង់ទៅ ។

## មុនពេលជំនុំជម្រះ

*២៦:៥៧–៦៨ = មក ១៤:៥៣–៦៥ យហ ១៨:១២,១៣,១៩–២៤*

៥៧ឯពួកអ្នកដែលបានចាប់ព្រះយេស៊ូវ គេដឹកនាំទ្រង់ទៅ

**២៦:៣៧** ឆ មថ ៤:២១
**២៦:៣៨** ជ យហ ១២:២៧
ឈ ខ.៤០,៤១
**២៦:៣៩** ញ មថ ២០:២២ ដ ខ.៤២ ទដ ៤០:៦–៨ អស ៥០:៥ មថ ៦:១០ យហ ៤:៣៤ ៥:៣០ ៦:៣៨
**២៦:៤១** ឌ មថ ៦:១៣
**២៦:៤២** ឍ ខ.៣៩
**២៦:៤៥** ណ ខ.១៨
**២៦:៤៧** ត មថ ១០:៤
**២៦:៤៩** ថ ខ.២៥ មថ ២៣:៧
**២៦:៥០** ទ មថ ២០:១៣ ២២:១២
**២៦:៥១** ធ លក ២២:៣៦,៣៨
ន យហ ១៨:១០
**២៦:៥២** ប លប ៩:៦ នក ២១:១២ វវ ១៣:១០
**២៦:៥៣** ផ ២ពវ ៦:១៧ ដយ ៧:១០ មថ ៤:១១
**២៦:៥៤** ព ខ.២៤ មថ ១:២២
**២៦:៥៥** ភ មក ១២:៣៥
លក ២១:៣៧
យហ ៧:១៤,២៨ ១៨:២០
**២៦:៥៦** ម ខ.២៤ មថ ១:២២ **២៦:៥៧** យ ខ.៣

ហាក់បីដូចជាជិតស្និទ្ធនឹងព្រះយេស៊ូវជាងគេ(មើលការពន្យល់ មក ៥:៣៧)។
**២៦:៣៨–៣៩** ព្រះយេស៊ូវទ្រង់មិនបានសុគតដោយស្ងប់ស្ងាត់ ស្រួលបួលដូចមនុស្សដទៃនោះទេ ។ ទ្រង់ជាកូនចៀមនៃព្រះដែលបានយាងមក ទទួលទោសនៃអំពើបាបជំនួសមនុស្សទាំងអស់រហូតដល់សុគត ។ សេចក្តីក្រោធនៃព្រះបានដាក់មកលើអង្គទ្រង់ទាំងអស់ ។ ការនេះល្មមអាចពន្យល់ប្រាប់យើងបានគ្រប់គ្រាន់នូវអ្វីដែលបានកើតឡើង នៅឯច្បារកេតសេម៉ានី ។
**២៦:៣៩** *ពែង* ជានិមិត្តរូបនៃការឈឺចាប់ និងទុក្ខលំបាក ។ ត្រង់នេះគឺទាក់ទងទៅនឹងព្រះវរបិតាដែលកំពុងតែបែរព្រះភក្ត្រចេញពីទ្រង់ ក្នុងពេលដែលទ្រង់គ្មានបាបសោះតែត្រូវទទួលទោស ទុកជាដង្វាយលោះ(មថ ២៧:៤៦ ២កថ ៥:២១)។
**២៦:៤១** មើលការពន្យល់ មក ១៤:៣៨ ។
**២៦:៤៥** *កូនមនុស្ស* មើលការពន្យល់ មក ៨:៣១ ។
**២៦:៤៧** *ហ្វូងមនុស្សជាធំ ដែលកាន់ដាវ កាន់ដំបង* មើលពន្យល់ មក ១៤:៤៣ ។ *ពួកសង្គ្រាជ និងពួកចាស់ទុំ* មើលពន្យល់ ខ.៣ និង មថ ២:៤ ។
**២៦:៤៨** *អ្នកណាដែលខ្ញុំថើប* មើលការពន្យល់ លក ២២:៤៧ ។
**២៦:៤៩** *ជំរាបសួរលោកគ្រូ* មើលពន្យល់ មក ១៤:៤៥ លក ២២:៤៧ ។
**២៦:៥១** *ម្នាក់ដែលនៅជាមួយព្រះយេស៊ូវ* គឺលោកពេត្រុស(យហ ១៨:១០) *បាវសំដេចសង្ឃ* គឺឈ្មោះលោកម៉ាលកុស(យហ ១៨:១០)។
**២៦:៥៣** *កង* នៅសម័យនោះទាហានរ៉ូម៉ាំង១កងមានប្រហែល៦ 000នាក់។
**២៦:៥៤** *សំរេចតាមគម្ពីរ* អាចទាក់ទងជាមួយនឹង សក ១៣:៧ និង ខ.៥៦ ។
**២៦:៥៧–២៧:២៦** ត្រង់នេះគឺជាសេចក្តីសង្ខេបសាច់រឿងពីរ(ពួកអ្នកសាសនា និងប្រជាជន)នៃការកាត់ក្តីដល់ព្រះយេស៊ូវ (មើលការពន្យល់មក

ឯលោកកៃផា[យ] ជាសំដេចសង្ឃ នៅកន្លែងដែលពួក អា
ចារ្យ នឹងពួកចាស់ទុំបានប្រជុំគ្នា ៥៨[រ]រីឯពេត្រុស គាត់តាម
ទ្រង់ពីចំងាយទៅ រហូតដល់ព្រះលាននៃសំដេចសង្ឃ ក៏
ចូលទៅអង្គុយខាងក្នុង ជាមួយនឹងពួកអាជ្ញា[ល] ដើម្បីចង់
ឃើញទីបំផុតនៃការនោះ ។
៥៩ចំណែកពួកសង្គ្រាជ នឹងពួកចាស់ទុំ ហើយក្រុមជំនុំ[វ]ទាំង
អស់គ្នា គេស្វែងរកសេចក្ដីបន្ទាល់ក្លែងទាស់នឹងព្រះយេស៊ូវ
ប្រយោជន៍ឱ្យបានសំឡាប់ទ្រង់ ៦០តែទោះបើមានស្មរ
បន្ទាល់[ស]ក្លែងក្លាយមកជាច្រើននាក់ក៏ដោយ គង់តែរកមិន
បានសោះ ៦១តែក្រោយបង្អស់ មានស្មរបន្ទាល់២នាក់[ហ]មក
ចោទថា អានេះបាននិយាយថា ខ្ញុំអាចនឹងបំផ្លាញព្រះ
វិហារចេញ ហើយនឹងសង់ឡើងវិញ ក្នុងរវាង៣ថ្ងៃបាន[ឡ]
៦២នោះសំដេចសង្ឃក៏ក្រោកឡើងដណ្ដឹងសួរទ្រង់ថា តើ
ឯងមិនព្រមឆ្លើយសោះឬអី សេចក្ដីដែលគេចោទប្រកាន់
ឯងទាំងប៉ុន្មាននេះ តើយ៉ាងដូចម្ដេច ៦៣ឯព្រះយេស៊ូវ
ទ្រង់នៅតែស្ងៀម[អ] រួចសំដេចសង្ឃបង្គាប់ទ្រង់ថា ចូរ
ស្បថ[ក]នឹងព្រះដ៏មានព្រះជន្មរស់ចុះ[ខ] បើឯងជាព្រះគ្រីស្ទ[គ]
ជាព្រះរាជបុត្រានៃព្រះ[ឃ]មែន នោះចូរប្រាប់យើងមក
៦៤ព្រះយេស៊ូវទ្រង់មានបន្ទូលទៅលោកថា ត្រូវដូច លោក
មានប្រសាសន៍ហើយ[ង] ១ទៀតខ្ញុំប្រាប់អ្នករាល់គ្នាថា
អំណឹះទៅមុខ អ្នករាល់គ្នានឹងឃើញកូនមនុស្សអង្គុយ នៅ
ខាងស្តាំនៃព្រះដ៏មានព្រះចេស្តា[ច] ហើយទាំងមកលើពពក
នៅលើមេឃផង[ឆ] ៦៥នោះសំដេចសង្ឃក៏ហែកអាវខ្លួន[ជ]
ហើយនិយាយឡើងថា វាបានពោលពាក្យប្រមាថដល់
ព្រះ ដូច្នេះតើយើងចាំបាច់ត្រូវការនឹងទីបន្ទាល់ណាថែម
ទៀត មើលអ្នករាល់គ្នាទើបនឹងឮពាក្យ ដែលវាប្រមាថ
នោះស្រាប់ហើយ ៦៦តើគិតយ៉ាងដូចម្ដេច អ្នកទាំងនោះ

**២៦:៥៨** រ ខ.៦៩ មក ១៤:៦៦ លក ២២:៥៥ យហ ១៨:១៥ ល មក ១៥:១៦ លក ១១:២១ យហ ៧:៣២,៤៥,៤៦
**២៦:៥៩** វ មថ ៥:២២
**២៦:៦០** ស ទជ ២៧:១២ ៣៥:១១ កច ៦:១៣
**២៦:៦១** ហ ចទ ១៩:១៥ ឡ យហ ២:១៩
**២៦:៦៣** អ មក ១៤:៦១ ក លវ ៥:១ ខ មថ ១៦:១៦ គ លក ២២:៦៧ ឃ មថ ៤:៣
**២៦:៦៤** ង មថ ២៧:១១ លក ២២:៧០ ច មក ១៦:១៩ ឆ វវ ១:៧
**២៦:៦៥** ជ មក ១៤:៦៣
**២៦:៦៦** ឈ លវ ២៤:១៦ យហ ១៩:៧
**២៦:៦៧** ញ មថ ១៦:២១
**២៦:៦៨** ដ លក ២២:៦៣–៦៥
**២៦:៧៥** ឋ ខ.៣៤ យហ ១៣:៣៨

ឆ្លើយឡើងថា វាគួរស្លាប់ហើយ[ឈ] ៦៧គេក៏ស្ដោះដាក់ព្រះ
ភក្ត្រ ហើយដាល់តប់[ញ]ទ្រង់ មានអ្នកខ្លះទះទ្រង់ ទាំងទូលថា
៦៨ចូរទាយប្រាប់យើងចុះ ព្រះគ្រីស្ទអើយ តើអ្នកណាបាន
វាយឯង[ដ] ។

## ពេត្រុសបដិសេធព្រះយេស៊ូវ

*២៦:៦៩–៧៥ = មក ១៤:៦៦–៧២ លក ២២:៥៥–៦២*

*យហ ១៨:១៦–១៨,២៥–២៧*

៦៩ឯពេត្រុស គាត់អង្គុយនៅក្នុងព្រះលានឰដ៏ខាងក្រៅ
នោះមានបាវស្រីម្នាក់មកឯគាត់និយាយថា អ្នកឯងបាននៅ
ជាមួយនឹងយេស៊ូវ ជាអ្នកស្រុកកាលីឡេនេះដែរ ៧០តែគាត់
ប្រកែកនៅមុខអ្នកទាំងអស់ថា ខ្ញុំមិនដឹងជាអ្នកថាអ្វីទេ
៧១កាលគាត់បានចេញទៅដល់មាត់ទ្វារហើយ នោះបាវស្រី
ម្នាក់ទៀតឃើញគាត់ ក៏ប្រាប់ដល់ពួកអ្នកនៅទីនោះថា
អ្នកនេះបាននៅជាមួយនឹងយេស៊ូវ ជាអ្នកស្រុកណាសា
រ៉ែតដែរ ៧២គាត់ក៏ប្រកែកម្ដងទៀត ទាំងស្បថថា ខ្ញុំមិន
ស្គាល់មនុស្ស នោះទេ ៧៣ក្រោយបន្តិចមក ពួកអ្នកដែល
នៅទីនោះ គេមកឯពេត្រុសចោទថា ឯងប្រាកដជាពួក
មនុស្សនោះដែរ ដ្បិតសំដីឯងសពីខ្លួនឯងឱ្យដឹងហើយ
៧៤នោះគាត់ចាប់តាំងប្រមាថ ហើយស្បថថា ខ្ញុំមិនស្គាល់
មនុស្សនោះទេ ស្រាប់តែមាន់ក៏រងាវឡើង ៧៥ពេត្រុសនឹក
ឃើញពីព្រះបន្ទូលនៃព្រះយេស៊ូវ ដែលទ្រង់ប្រាប់គាត់ថា
មុនដែលមាន់រងាវ នោះអ្នកនឹងប្រកែក៣ដងថា មិនស្គាល់
ខ្ញុំ[ឋ] រួចគាត់ក៏ចេញទៅដោយយំក្តួល ។

## យូដាសចងកសំឡាប់ខ្លួន

**២៧** ១ដល់ព្រឹកឡើង ពួកសង្គ្រាជ នឹងពួកចាស់ទុំនៃ
បណ្ដាជន គេពិគ្រោះគ្នាទាស់នឹងព្រះយេស៊ូវ ដើម្បីនឹង

១៤:៥៣–១៥:១៥)។

**២៦:៥៩** *ក្រុមជំនុំ* គឺពួកអ្នកជំនុំជម្រះទោសក្នុងតុលាការ (មក ១៤:៥៥ និង ពន្យល់)។

**២៦:៦១** *ខ្ញុំអាចនឹងបំផ្លាញព្រះវិហារ* គឺជាសំដីបំផ្លើសទៅលើព្រះបន្ទូលព្រះយេស៊ូវ ដោយមានចេតនាយ៉ាងពិតប្រាកដ (យហ ២:១៩)។

**២៦:៦៣** *ចូរស្បថ...*ព្រះយេស៊ូវមិនព្រមឆ្លើយនឹងសំណួរក្នុង"ខ.៦២–៦៣"។ នៅពេលសម្ដេចសង្ឃបានប្រើប្រយោគនេះ បើតាមច្បាប់ នោះចាំបាច់ទ្រង់ត្រូវតែឆ្លើយនឹងសំណួរនោះ ។ *ព្រះគ្រីស្ទ* មើលការពន្យល់ ១៦:១៦ ។

**២៦:៦៤** *មេឃ* ព្រះគម្ពីរភាសាអង់គ្លេសប្រើពាក្យថា "ស្ថានសួគ៌"។

**២៦:៦៥** *ហែកអាវខ្លួន* ធម្មតាសម្ដេចសង្ឃត្រូវបានច្បាប់ហាមមិនឱ្យធ្វើដូច្នេះទេ (លវ ១០:៦ ២១:១០) ប៉ុន្តែនេះជាព្រឹត្តិការណ៍មិនធម្មតាមួយ ។ សម្ដេចសង្ឃបានបកស្រាយចម្លើយរបស់ព្រះយេស៊ូវក្នុង"ខ.៦៤"ថា បានប្រមាថដល់ព្រះ (មើលការពន្យល់ មក ១៤:៦៤)។

**២៦:៦៧–៦៨** ត្រង់វគ្គនេះ បើតាមគម្ពីរម៉ាកុសបានឱ្យដឹងថា ពួកគេបានចងមុខព្រះយេស៊ូវ (មក ១៤:៦៥) និងប្រើពាក្យចំអកឡកឡើយដាក់ទ្រង់ថា "ទាយមើលថា តើនរណាវាយឯង?"

**២៦:៧៣** *សំដីឯងសពីខ្លួនឯង* ពេត្រុសជាអ្នកស្រុកកាលីឡេបានជាសំឡេងខុសពីអ្នកក្រុងយេរូសាឡិម ទើបគេដឹងថាគាត់ជាម្នាក់ក្នុងចំណោមអ្នកនៅជាមួយព្រះយេស៊ូវ ។

**២៧:១** *ព្រឹកព្រលឹម* ក្រុមជំនុំជម្រះក្ដីមិនអាចបើកសាវនាការនៅពេលយប់បានទេ ដូច្នេះពេលទៀបភ្លឺ ទើបពួកគេបើកកិច្ចប្រជុំពិសេសមួយ ដើម្បីរកវិធីកាត់ទោសប្រហារជីវិតព្រះយេស៊ូវ (២៦:៦៦) ជាផ្លូវការតែម្ដង

សំឡាប់ទ្រង់[ឌ] ២ក៏ចងទ្រង់ដឹកបញ្ជូន[ឍ]ទៅឯចៅហ្វាយស្រុក
ឈ្មោះប៉ុនទាស–ពីឡាត់[ណ]។
៣កាលយូដាស ជាអ្នកបញ្ជូនទ្រង់[ត] បានឃើញថាទ្រង់ជាប់
ទោសដូច្នោះ នោះវានឹកស្តាយ ក៏យកប្រាក់៣០[ថ]ទៅឱ្យ
ដល់ពួកសង្គ្រាជ នឹងពួកចាស់ទុំវិញ ៤ដោយពាក្យថា ខ្ញុំបាន
ជាធ្វើបាប ដោយបញ្ជូនឈាមឥតមានទោសហួសទៅហើយ
តែគេឆ្លើយថា តើនោះអំពល់អ្វីដល់យើង ការនោះ ស្រេច
នៅឯងទេតើ[ទ] ៥វាក៏បោះប្រាក់ចោលទៅក្នុងព្រះវិហារ[ធ]
រួចចេញទៅ ក្រៅអួលស្ទះស្លាប់ទៅ[ន] ៦ឯពួកសង្គ្រាជ
គេរើសប្រាក់នោះមកនិយាយថា ប្រាក់នេះគ្មានច្បាប់នឹង
ដាក់ទុកក្នុងឃ្លាំងទេ ពីព្រោះជាថ្លៃឈាម ៧លុះគេបាន
ពិគ្រោះគ្នាហើយ ក៏យកប្រាក់នោះទៅទិញដីវាលរបស់
ជាងស្មូន ទុកសំរាប់ជាទីកប់ខ្មោចនៃសាសន៍ដទៃវិញ
៨ដោយហេតុនោះបានជាគេហៅវាលនោះថា «វាល
ឈាម» [ប]ដរាបដល់សព្វថ្ងៃនេះ ៩នោះបានសំរេចតាម
ទំនាយ ដែលហោរាយេរេមា បានទាយទុកមកថា[ផ] «គេ
បានយកប្រាក់៣០ជាដំឡៃព្រះអង្គ ដែលគេបានកាត់ថ្លៃឱ្យ
គឺដែលពួកកូនចៅសាសន៍អ៊ីស្រាអែលបានកាត់ថ្លៃនោះ
១០ហើយគេឱ្យប្រាក់នោះទៅទិញដីវាលរបស់ជាងស្មូន
ដូចជាព្រះអម្ចាស់ទ្រង់បានបង្គាប់ខ្ញុំ[ព]»។

## ព្រះយេស៊ូវនៅមុខលោកពីឡាត់

*២៧:១១–២៦ = មក ១៥:២–១៥ លក ២៣:២,៣,១៨–២៥*

*យហ ១៨:២៩–១៩:១៦*

១១ឯព្រះយេស៊ូវ ទ្រង់ឈរនៅមុខលោកចៅហ្វាយ ហើយ
លោកក៏ពិចារណាសួរទ្រង់ថា តើអ្នកជាស្តេចរបស់សាសន៍
យូដាឬអី[ភ] ព្រះយេស៊ូវ ទ្រង់មានបន្ទូលទៅលោកថា ត្រូវដូច
លោកមានប្រសាសន៍ហើយ ១២តែកាលពួកសង្គ្រាជ នឹង
ពួកចាស់ទុំចោទប្រកាន់ទ្រង់ នោះទ្រង់មិនបានមានបន្ទូល
ឆ្លើយសោះ[ម] ១៣លោកពីឡាត់ក៏ទូលសួរទ្រង់ថា តើអ្នក
មិនឮរឿងទាំងប៉ុន្មាន ដែលគេចោទប្រកាន់អ្នកទេឬអី[យ]
១៤តែព្រះយេស៊ូវ ទ្រង់មិនមានបន្ទូលឆ្លើយនឹងពាក្យណា
មួយរបស់លោកសោះ[រ] បានជា លោកចៅហ្វាយឆ្ងល់
ខ្លាំងណាស់ ។
១៥ឯនៅបុណ្យនោះ លោកចៅហ្វាយតែងធ្លាប់លែងអ្នក
ទោស[ល]ម្នាក់ ឱ្យដល់ហ្វូងមនុស្ស តាមគេសូម ១៦នៅគ្រា
នោះ គេមានអ្នកទោសម្នាក់ ដែលមានល្បីឈ្មោះៗ បារ៉ា
បាស ១៧ដូច្នេះ កាលគេបានប្រជុំគ្នាជាស្រេច នោះលោក
ពីឡាត់សួរថា តើអ្នករាល់គ្នាចង់ឱ្យខ្ញុំលែងឈ្មោះណា
បារ៉ាបាស ឬយេស៊ូវដែលហៅថា ព្រះគ្រីស្ទ[វ] ១៨ដ្បិត
លោកបានជ្រាបថា គេបញ្ជូនទ្រង់ដោយចិត្តឈ្នានីសទេ
១៩កាលលោកកំពុងតែអង្គុយនៅក្នុងទីកាត់ក្តី[ស] នោះប្រពន្ធ
លោកប្រើបំរើមកជំរាបថា កុំឱ្យធ្វើអ្វីដល់មនុស្សសុចរិត[ហ]
នោះឡើយ ដ្បិតនៅថ្ងៃនេះ ខ្ញុំបានយល់សប្តិ[ឡ]កើតទុក្ខជា
ច្រើន ដោយព្រោះមនុស្សនោះ ២០តែពួកសង្គ្រាជ នឹងពួក
ចាស់ទុំ គេបញ្ចុះហ្វូងមនុស្ស ឱ្យសូមបារ៉ាបាសវិញ ហើយ
ឱ្យបំផ្លាញ[អ]ព្រះយេស៊ូវបង់ ២១នោះលោកចៅហ្វាយចាប់
ពាក្យសួរគេថា ក្នុងមនុស្ស២នាក់នេះ តើចង់ឱ្យខ្ញុំលែងអ្នក
ណា គេឆ្លើយឡើងថា សូមលែងបារ៉ាបាសចុះ ២២លោកពី
ឡាត់សួរគេថា ដូច្នេះ តើឱ្យខ្ញុំធ្វើអ្វីដល់យេស៊ូវដែលហៅ

**២៧:១** ឌ មថ ១២:១៤ មក ១៥:១ លក ២២:៦៦
**២៧:២** ឍ មថ ២០:១៩ ណ មក ១៥:១ លក ១៣:១ កច ៣:១៣ ១ធថ ៦:១៣
**២៧:៣** ត មថ ១០:៤ ថ មថ ២៦:១៤,១៥
**២៧:៤** ទ ខ.២៤
**២៧:៥** ធ លក ១:៩,២១ ន កច ១:១៨
**២៧:៨** ប កច ១:១៩
**២៧:៩** ផ មថ ១:២២
**២៧:១០** ព សក ១១:១២,១៣ យរ ៣២:៦–៩
**២៧:១១** ភ មថ ២:២
**២៧:១២** ម មក ១៤:៦១
**២៧:១៣** យ មថ ២៦:៦២
**២៧:១៤** រ មក ១៤:៦១
**២៧:១៥** ល យហ ១៨:៣៩
**២៧:១៧** វ ខ.២២ មថ ១:១៦
**២៧:១៩** ស យហ ១៩:១៣ ហ ខ.២៤ ឡ លប ២០:៦ ជន ១២:៦ ១ពវ ៣:៥ យប ៣៣:១៤–១៦ មថ ១:២០ ២:១២, ១៣,១៩,២២
**២៧:២០** អ កច ៣:១៤ **២៧:២២** ក មថ ១:១៦

(សូមមើលការពន្យល់ មក ១៥:១)។
**២៧:២** *បញ្ជូនទៅឈ្មោះប៉ុនទាសពីឡាត់* រដ្ឋាភិបាលរ៉ូម៉ាំងមិនបានប្រគល់សិទ្ធិទាំងស្រុងដល់ក្រុមជំនុំជម្រះក្តីក្នុងការកាត់ទោសប្រហារជីវិតជនណាឡើយលើកលែង តែជនបរទេសឈ្លានពានចូលបរិវេណស័ក្តិសិទ្ធិក្នុងព្រះវិហារប៉ុណ្ណោះ ដូច្នេះ ព្រះយេស៊ូវត្រូវបានគេបញ្ជូនទៅឱ្យលោកពីឡាត់សម្រេច។ *ពីឡាត់* មើលពន្យល់ មក ១៥:១ ។
**២៧:៣–១០** មើល កច ១:១៦–១៩ ។
**២៧:៥** *អួលស្ទះស្លាប់* មើលការពន្យល់ កច ១:១៨ ។
**២៧:៨** *វាលឈាម* មានន័យថា "ជ្រោះមរណៈ" (យរ ១៩:៦)។
**២៧:៩** *យេរេមា* ការដកស្រង់ខាងក្រោមនេះ វាហាក់បីដូចជាទាក់ទងនឹងព្រះគម្ពីរ "សក ១១:១២–១៣ និង យរ ១៩:១–១៣ ឬក៏ យរ ១៨:២–១២ យរ ៣២:៦–៩"។ ប៉ុន្តែលោកម៉ាថាយបានសន្មត់ថាជាទំនាយរបស់ហោរាយេរាមាទៅវិញ ដូចដែលលោកម៉ាកុស(មក ១:២–៣) បានដកស្រង់ពី "មឡ ៣:១ និង អស ៤០:៣"ដែរ តែគាត់បែរជាថាដកស្រង់ពីហោរាអេសាយនោះទៅវិញ ។ ត្រង់ចំណុចទាំងពីរនេះ ប្រហែលជាគម្ពីរហោរាអេសាយត្រូវបានគេស្គាល់ច្បាស់ជាងគេហើយមើលទៅ ។
**២៧:១១** *លោកចៅហ្វាយ* គឺជាលោកប៉ុនទាសពីឡាត(មើលការពន្យល់ ខ.២)។ *ស្តេចរបស់សាសន៍យូដា* មើលការពន្យល់ យហ ១៨:៣៣ ។
**២៧:១៥** *ចៅហ្វាយតែងធ្លាប់លែង* ការនេះហាក់បីជាទម្លាប់ស្តេចនៅស្រុកខ្មែរដែរ ដែលតែងតែលែងអ្នកទោសក្នុងពិធីបុណ្យផ្សេងៗនោះដែរ ។
**២៧:១៦** *មានឈ្មោះល្បី* ជាម្នាក់ដែលលេចធ្លោឬជាឥស្សរជន(រម ១៦:៧) ឈ្មោះបារ៉ាបាសត្រូវបានចាប់ខ្លួន ព្រោះបានចូលរួមក្នុងចលនាបះបោរ (លក ២៣:១៩ យហ ១៨:៤០)ប្រឆាំងនឹងពួករ៉ូម៉ាំង ដូច្នេះ គាត់ជាវីរជនរបស់អ្នកស្រុកយូដា ។
**២៧:១៩** ហេតុការណ៍ក្នុងខនេះ ឃើញមានតែក្នុងដំណឹងល្អម៉ាថាយមួយប៉ុណ្ណោះ ។

ជាព្រះគ្រីស្ទនេះ[ក] អ្នកទាំងអស់គ្នាក៏ឆ្លើយឡើងថា ចូរឆ្កាង
វាទៅ ២៣នោះលោកចៅហ្វាយសួរថា តើអ្នកនេះបាន
ធ្វើខុសអ្វី តែគេស្រែកកាន់តែខ្លាំងឡើងថា ចូរឆ្កាងវា
ទៅ ២៤កាលលោកពីឡាត់ឃើញថា មិនឈ្នះទេកើតមាន
កោលាហល[ខ]កាន់តែខ្លាំងឡើងដូច្នោះ នោះលោកយកទឹក
មកលាងដៃ[គ] នៅមុខហ្វូងមនុស្ស ទាំងមានប្រសាសន៍
ថា ខ្ញុំគ្មានទោសនឹងឈាមនៃអ្នកសុចរិតនេះទេ[ឃ] ការនេះ
ស្រេចនៅអ្នករាល់គ្នាចុះ[ង] ២៥បណ្ដាជនទាំងអស់គ្នាក៏ឆ្លើយ
ឡើងថា ចូរឱ្យឈាមវាធ្លាក់មកលើយើងរាល់គ្នា នឹងកូន
ចៅរបស់យើងចុះ[ច] ២៦ដូច្នេះ លោកក៏លែងបារ៉ាបាស
ឱ្យដល់គេ ឯព្រះយេស៊ូវវិញ កាលគេបានវាយ[ឆ] នឹងរំពាត់
រួចហើយ នោះក៏បញ្ជូនទៅឱ្យគេឆ្កាងទ្រង់ ។

## ពួកទាហានរ៉ូម៉ាំងចំអកឱ្យព្រះយេស៊ូវ

*២៧:២៧–៣១ = មក ១៥:១៦–២០*

២៧នោះពួកទាហានរបស់លោកចៅហ្វាយ គេក៏នាំព្រះ
យេស៊ូវទៅក្នុងសាលា[ជ] រួចប្រមូលក្រុមទាហានទាំងអស់មក
ទាស់នឹងទ្រង់ ២៨គេដោះព្រះពស្ត្រទ្រង់ចេញ ហើយយកអាវ
ក្រហមមកបំពាក់វិញ[ឈ] ២៩ក៏ក្រងភ្លូងបន្លាបំពាក់លើព្រះសិរ
ទ្រង់ ហើយយកដើមត្រែងដាក់នៅព្រះហស្តស្តាំ រួចគេលុត
ជង្គង់នៅចំពោះទ្រង់ ទាំងពោលចំអកថា ថ្វាយបង្គំស្តេច
សាសន៍យូដា[ញ] ៣០គេស្តោះដាក់ទ្រង់ ក៏យកដើមត្រែងនោះ
វាយព្រះសិរផង[ដ] ៣១កាលគេបានចំអកមើលងាយទ្រង់
ស្រេចហើយ ក៏ដោះអាវនោះចេញ ហើយបំពាក់ព្រះពស្ត្រ
ទ្រង់ទៅវិញ រួចនាំចេញទៅឆ្កាង[ឋ] ។

## ការឆ្កាងព្រះយេស៊ូវ

*២៧:៣៣–៤៤ = មក ១៥:២២–៣២ លក ២៣:៣៣–៤៣*
*យហ ១៩:១៧–២៤*

៣២កាលបានចេញទៅហើយ[ឌ] នោះគេប្រទះឃើញមនុស្ស
ស្រុកគីរេន[ឍ]ម្នាក់ឈ្មោះស៊ីម៉ូន ក៏ចាប់បង្ខំឱ្យលីឈើឆ្កាង[ណ]
ទ្រង់ទៅ ៣៣លុះបានដល់កន្លែងហៅថា គាល់កូថា ដែល
ស្រាយថា ភ្នំរលាក្បាល[ត] ៣៤នោះគេយកទឹកខ្មេះលាយ
នឹងប្រមាត់[ថ]ថ្វាយទ្រង់សោយ តែកាលទ្រង់បានភ្លក់មើល
នោះទ្រង់មិនព្រមសោយទេ ៣៥គ្រាបានឆ្កាងទ្រង់ហើយ
នោះគេធ្វើឆ្នោតចាប់ចែកព្រះពស្ត្រទ្រង់[ទ] ដើម្បីឱ្យបាន
សំរេចតាមទំនាយ ដែលហោរាបានទាយទុកមកថា «គេ
បានយកអាវខ្ញុំចែកគ្នា ហើយបានធ្វើឆ្នោតចាប់យកអាវ
វែងខ្ញុំ» ៣៦គេអង្គុយចាំយាមទ្រង់នៅទីនោះ[ធ] ៣៧ក៏បិទ
ប្រកាសដែលកាត់ទោសទ្រង់ ដាក់ពីលើព្រះសិរថា «នេះ
ឈ្មោះយេស៊ូវ ជាស្តេចសាសន៍យូដា» ៣៨នៅវេលានោះ
ក៏ឆ្កាងចោរ២នាក់ជាមួយនឹងទ្រង់ដែរ[ន] ១ខាងស្តាំ ហើយ
១ខាងឆ្វេង។
៣៩ឯមនុស្សដែលដើរតាមទីនោះ គេជេរ ប្រមាថដល់ទ្រង់
ទាំងគ្រវីក្បាល[ប] ហើយនិយាយថា ៤០ឯង ដែលបំផ្លាញព្រះ
វិហារ ហើយសង់ឡើងវិញក្នុងរវាង៣ថ្ងៃ អើយ[ផ] ចូរជួយ
សង្គ្រោះខ្លួនចុះ[ព] បើឯងជាព្រះរាជបុត្រា នៃព្រះមែន
នោះឱ្យចុះពីឈើឆ្កាងមក[ភ] ៤១ឯពួកសង្គ្រាជ ព្រមទាំងពួក
អាចារ្យ នឹងពួកចាស់ទុំ គេក៏ចំអកឱ្យទ្រង់បែបដូច្នោះដែរ
ដោយថា ៤២វាជួយសង្គ្រោះមនុស្សឯទៀតបាន តែ
មិនអាចជួយនឹងជួយសង្គ្រោះដល់ខ្លួនវាបានទេ បើសិន

**២៧:២៤** ខ មថ ២៦:៥ គ ទដ ២៦:៦ ឃ ចទ ២១:៦–៨ ង ខ.៤ **២៧:២៥** ច យស ២:១៩ កច ៥:២៨ **២៧:២៦** ឆ អស ៥៣:៥ យហ ១៩:១ **២៧:២៧** ជ យហ ១៨:២៨,៣៣ ១៩:៩ **២៧:២៨** ឈ យហ ១៩:២ **២៧:២៩** ញ អស ៥៣:៣ យហ ១៩:២,៣ **២៧:៣០** ដ មថ ១៦:២១ **២៧:៣១** ឋ អស ៥៣:៧
**២៧:៣២** ឌ ហព ១៣:១២ ឍ កច ២:១០ ៦:៩ ១១:២០ ១៣:១ ណ មក ១៥:២១ លក ២៣:២៦ **២៧:៣៣** ត យហ ១៩:១៧ **២៧:៣៤** ថ ខ.៤៨ ទដ ៦៩:២១ **២៧:៣៥** ទ ទដ ២២:១៨ **២៧:៣៦** ធ ខ.៥៤ **២៧:៣៨** ន អស ៥៣:១២
**២៧:៣៩** ប ទដ ២២:៧ ១០៩:២៥ បទ ២:១៥ **២៧:៤០** ផ យហ ២:១៩ ព ខ.៤២ ភ មថ ៤:៣,៦

**២៧:២៥** ការឆ្លើយតបដ៏សាហាវនៃបណ្ដាជននេះ ជាញឹកញាប់នៅពេលទាមទារយុត្តិធម៌ពីការធ្វើទុក្ខបុកម្នេញដល់សាសន៍យូដាប៉ុណ្ណោះ តែត្រង់នេះបញ្ជាក់ថា ហ្វូងបណ្ដាជនខ្លួនឯងជាអ្នកស្រែកខ្លាំងៗសុំឱ្យធ្វើគុតព្រះយេស៊ូវវិញ។ គ្មានភស្តុតាង ណាបញ្ជាក់ថាព្រះអម្ចាស់យល់ព្រមនឹងសំណូមពរនេះទេ បើសិនសម្រេចតាមទំនាយ នោះគួរតែបានឃើញដូចការបំផ្លាញក្រុងយេរូសាឡិមនៅឆ្នាំ៧០នោះហើយ ។

**២៧:២៦** *វាយនឹងរំពាត់* រំពាត់នេះអាចជាខ្សែតី ឬដំបង ។ ពួករ៉ូមវាយខ្លាំងៗ និងសាហាវណាស់ ជនរងគ្រោះមួយចំនួនអាចស្លាប់បានមុននឹងគេយកទៅឆ្កាងនោះទៅទៀត(មើលការពន្យល់ មក ១៥:១៥)។

**២៧:២៧** *សាលា* គឺជាគេហដ្ឋានផ្លូវការមួយរបស់អភិបាលក្រុងយេរូសាឡិម (មើលការពន្យល់ មក ១៥:១៦)។

**ប៉ុទាស ពីឡាត់** ជាសាសន៍រ៉ូម ជាចៅហ្វាយស្រុកយូដាឆ្នាំទី២៦ ឬ២៧–៣៦ ។

**ល្បីខាង :** – អ្នកធ្វើជាអធិបតីក្នុងការកាត់ទោសព្រះយេស៊ូវ ។
– កាត់ទោសមនុស្សសុចរិតម្នាក់ដល់ស្លាប់ ។
– លាងសំអាតដៃនៃការទទួលខុសត្រូវក្នុងការធ្វើគុតព្រះយេស៊ូវ

**២៧:២៨** *អាវក្រហម* គឺជាអាវវែងខាងក្រៅរបស់ទាហានរ៉ូម៉ាំង ។

**២៧:២៩** *ភ្លូងបន្លា* មើលការពន្យល់ មក ១៥:១៧ ។ *ដើមត្រែង* ប្រើជាដំបងរាជ្យ ឬដំបងអាជ្ញានៅក្នុងអត្ថន័យចំអក និងផ្ដាញ់ផ្ដាល ។

**២៧:៣២** *ស្រុកគីរេន* ជាទីក្រុងមួយនៅអាហ្វ្រិកខាងជើង ។ *ស៊ីម៉ូន . . . លីឈើឆ្កាង* មើលការពន្យល់ មក ១៥:២១ ។

**២៧:៣៣** *គាល់កូថា* មើលការពន្យល់ មក ១៥:២២ ។

**២៧:៣៤** *លាយនឹងប្រមាត់* តាមប្រពៃណី គឺពួកស្ត្រីៗនៅក្រុងយេរូសាឡិមត្រូវផ្តល់ស្រាលាយនឹងប្រមាត់នេះដល់អ្នកទោសដែលកំពុងតែឆ្កាងផឹក ដើម្បីសណ្តំ និងធ្វើឱ្យស្ពឹកសាច់ជៀសវាងការឈឺចាប់ខ្លាំងពេកមុននឹងដាច់ខ្យល់ស្លាប់ ។ ព្រះយេស៊ូវមិនព្រមសោយទេ ព្រោះទ្រង់មានព្រះហឫទ័យរក្សានូវស្មារតីដ៏ពេញលេញរហូតដល់ពេលទ្រង់សុគត(ខ.៥០)។ អង្គធាតុនេះត្រូវបានផ្សំឡើងពីទឹកខ្មេះ ឬស្រាមកលាយទឹកប្រមាត់ ។

**២៧:៣៥** *ឆ្កាង* មើលការពន្យល់ មក ១៥:២៤ ។ *ចាប់ឆ្នោត* មើលការពន្យល់ យហ ១៩:២៣–២៤ ។

**២៧:៣៨** *ចោរ២នាក់* មើលការពន្យល់ មក ១៥:២៧ ។

ណាវាជាស្ដេចសាសន៍អ៊ីស្រាអែលមែន[ម] ចូរឱ្យវាចុះពីឈើ
ឆ្កាងមក នោះយើងនឹងជឿដល់វា[យ] [៤៣]វាបានទុកចិត្តនឹង
ព្រះ ដូច្នេះបើព្រះសព្វព្រះហឫទ័យនឹងវា សូមទ្រង់ជួយ
ដោះវាឥឡូវចុះ[រ] ដ្បិតវាបានថា ខ្ញុំជាព្រះរាជបុត្រានៃព្រះ
[៤៤]ហើយចោរ២នាក់ ដែលត្រូវឆ្កាងជាមួយនឹងទ្រង់ គេក៏
ស្ដីឱ្យទ្រង់ដូច្នោះដែរ ។

## ការសុគតរបស់ព្រះយេស៊ូវ

*២៧:៤៥-៥៦ = មក ១៥:៣៣-៤១ លក ២៣:៤៤-៤៩*

[៤៥]តាំងពីថ្ងៃត្រង់ ដរាបដល់ម៉ោង៣រសៀល នោះមាន
ងងឹតដាប[ល] គ្របពេញលើផែនដី [៤៦]ប្រហែលជាម៉ោង៣
នោះព្រះយេស៊ូវទ្រង់បន្លឺឡើងជាសំឡេងខ្លាំងថា អេលី១
ល៉ាម៉ាសាបាច់ថានី គឺស្រាយថា ឱព្រះអង្គ១ នៃទូល
បង្គំអើយ ហេតុអ្វីបានជាទ្រង់ចោលទូលបង្គំ[វ] [៤៧]មានអ្នក
ខ្លះដែលឈរនៅទីនោះ កាលគេបានឮ នោះក៏និយាយថា
វាស្រែកហៅរកលោកអេលីយ៉ាហើយ [៤៨]ស្រាប់តែមាន
ម្នាក់រត់ទៅ យកសារាយរំហួត ជ្រលក់ទឹកខ្មេះ[ស]ដោក
ដាក់នឹងចុងដើមត្រែង ហុចទៅថ្វាយទ្រង់សោយ [៤៩]តែអ្នក
ឯទៀតនិយាយថា ឈប់សិន ចាំមើល បើលោកអេលីយ៉ា
មកជួយសង្គ្រោះវា។
[៥០]កាលព្រះយេស៊ូវ ទ្រង់បានស្រែកជាខ្លាំងម្ដងទៀត នោះ
ទ្រង់ប្រគល់វិញ្ញាណទ្រង់ទៅវិញ[ហ] ។ [៥១]គ្រានោះ វាំងនន
ក្នុងព្រះវិហារ[ឡ]ក៏រហែកជា២ភាគ ចាប់តាំងពីលើចុះទៅ
ដល់ក្រោម ក៏មានកក្រើកដី ហើយថ្មប្រេះដាច់ពីគ្នា[អ] [៥២]អស់
ទាំងផ្នូរខ្មោចក៏របើកឡើង ឯខ្មោចពួកអ្នកបរិសុទ្ធដែល
ដេកលក់ទៅហើយ បានរស់ឡើងវិញជាច្រើន [៥៣]ទាំងចេញ
ពីផ្នូរ ក្នុងពេលក្រោយដែលទ្រង់មានព្រះជន្មរស់ឡើងវិញ
ហើយចូលទៅក្នុងទីក្រុងបរិសុទ្ធ[ក] លេចមកឱ្យមនុស្សជា
ច្រើនឃើញដែរ ។
[៥៤]ឯមេទ័ពនិងពួកអ្នកដែលចាំយាម[ខ]ព្រះយេស៊ូវជាមួយគ្នា
កាលបានឃើញកក្រើកដី នឹងការទាំងប៉ុន្មាន ដែលកើត
មកដូច្នោះ នោះក៏ភ័យញ័រជាខ្លាំង គាត់និយាយថា នេះពិត
ជាព្រះរាជបុត្រានៃព្រះមែន[គ] [៥៥]នៅទីនោះក៏មានស្ត្រីជា
ច្រើនដែលមកតាមព្រះយេស៊ូវ ពីស្រុកកាលីឡេ ដើម្បីបំរើ
ទ្រង់ គេឈរមើលពីចំងាយ[ឃ] [៥៦]ក្នុងពួកស្ត្រីនោះ មានម៉ា
រា ជាអ្នកស្រុកម៉ាក់ដាឡា១ ម៉ារាជាម្ដាយយ៉ាកុប
និងយ៉ូសេ១ ហើយនឹងប្រពន្ធរបស់សេបេដេ១[ង]។

## ការបញ្ចុះព្រះសពព្រះយេស៊ូវ

*២៧:៥៧-៦១ = មក ១៥:៤២-៤៧ លក ២៣:៥០-៥៦ យហ ១៩:៣៨-៤២*

[៥៧]ដល់ល្ងាច មានមនុស្សអ្នកមានម្នាក់ ជាសិស្សព្រះយេស៊ូវ
ឈ្មោះយ៉ូសែប ដែលនៅភូមិអើរីម៉ាថេ គាត់មកដល់
[៥៨]បានទៅឯលោកពីឡាត់ សូមព្រះសពព្រះយេស៊ូវ លោក
ពីឡាត់ក៏បង្គាប់ឱ្យប្រគល់ព្រះសពដល់គាត់ [៥៩]រួចកាល
យ៉ូសែបបានយកព្រះសពមក នោះក៏រុំនឹងសំពត់ទេសឯក
យ៉ាងស្អាត [៦០]ហើយបញ្ចុះក្នុងផ្នូរថ្មី[ច] ដែលគាត់បានដាប់
ក្នុងថ្ម កាលគាត់បានប្រមៀលថ្ម១យ៉ាងធំទៅបិទមាត់ផ្នូរ
ហើយ នោះក៏ចេញទៅបាត់ [៦១]ឯម៉ារា ជាអ្នកស្រុកម៉ាក់ដាឡា
និងម៉ារា១ទៀត ក៏នៅទីនោះអង្គុយប្រឈមនឹងផ្នូរ ។

## ការយាមផ្នូរព្រះយេស៊ូវ

[៦២]កាលស្អែកឡើង ក្រោយថ្ងៃរៀបបុណ្យ នោះពួកសង្គ្រាជ
នឹងពួកផារិស៊ី គេមូលគ្នាទៅឯលោកពីឡាត់ ជំរាបថា
[៦៣]លោក យើងខ្ញុំនឹកចាំពីពាក្យដែលអាកំភូតនោះបាន
និយាយ ពីកាលនៅរស់នៅឡើយថា ក្រោយមក ៣ថ្ងៃ
ខ្ញុំនឹងរស់ឡើងវិញ[ឆ]។ [៦៤]ដូច្នេះ សូមលោកបង្គាប់ឱ្យគេ
ប្រុងប្រយ័ត្នផ្នូរនោះ ដរាបដល់គំរប់៣ថ្ងៃ ក្រែងពួកសិស្ស

**២៧:៤២** ម យហ ១:៤៩ ១២:១៣ យ យហ ៣:១៥
**២៧:៤៣** រ ទដ ២២:៨
**២៧:៤៥** ល អម ៨:៩
**២៧:៤៦** វ ទដ ២២:១
**២៧:៤៨** ស ឧ.៣៤ ទដ ៦៩:២១
**២៧:៥០** ហ យហ ១៩:៣០
**២៧:៥១** ឡ នក ២៦:៣១-៣៣ ហព ៩:៣,៨ ១០:១៩,២០
**២៧:៤៨** អ ឧ.៥៤
**២៧:៥៣** ក មថ ៤:៥
**២៧:៥៤** ខ ឧ.៣៦ គ មថ ៤:៣ ១៧:៥
**២៧:៥៥** ឃ លក ៨:២,៣
**២៧:៥៦** ង មក ១៥:៤៧ លក ២៤:១០ យហ ១៩:២៥
**២៧:៦០** ច មថ ២៧:៦៦ ២៨:២ មក ១៦:៤ កច ១៣:២៩
**២៧:៦៣** ឆ មថ ១៦:២១

**២៧:៤៦** *អេលី១ល៉ាម៉ាសាបាច់ថានី* គឺភាសាអារ៉ាប់ និងហេព្រើរលាយគ្នា ។ លោកម៉ាថាយបកប្រែដើម្បីអ្នកដទៃទៀតអានបាន (មើលការពន្យល់ មក ១៥:៣៤)។

**២៧:៤៩** មើលការពន្យល់ មក ១៥:៣៥ ។

**២៧:៥១** *វាំងនន* គឺក្រណាត់ក្រាស់ម្យ៉ាងសម្រាប់ខណ្ឌរវាងទីបរិសុទ្ធ និងទីបរិសុទ្ធបំផុត ។ ការរហែកនេះបញ្ជាក់ថា ព្រះគ្រីស្ទកំពុងតែរៀបចំផ្លូវដល់អ្នកជឿលើទ្រង់ទាំងអស់ទៅឯព្រះវត្តមានរបស់ព្រះដោយផ្ទាល់(ហព ៩:១-១៤ ១០:១៤-២២)។

**២៧:៥២-៥៣** ព្រឹត្តិការណ៍នេះមានឃើញតែក្នុងគម្ពីរដំណឹងល្អម៉ាថាយ តែប៉ុណ្ណោះ នេះប្រហែលជានិមិត្តរូបនៃជ័យជម្នះលើសេចក្ដីស្លាប់របស់ព្រះគ្រីស្ទ តាមរយៈការប្រោសលោះរបស់ទ្រង់នៅលើឈើឆ្កាង ។

**២៧:៥៤** *មេទ័ព* មើលការពន្យល់ ៨:៥ ។ *ព្រះរាជបុត្រានៃព្រះ* ពុំអាចកំណត់បានថា មេទ័ពនេះបានលន់តួបាប ឬក៏គ្រាន់តែជាការទទួលស្គាល់ថា គេបានដាក់ទោសដល់ជនម្នាក់នេះ ដោយគ្មានទោសអ្វីសោះនោះទេ ។ ព្រះយេស៊ូវជាម្នាក់ ដែលគេចាប់អារម្មណ៍បំផុតក្នុងចំណោមអ្នកទោសរឿងនេះលោកម៉ាថាយបញ្ជាក់ថាវាគ្រាន់តែជាសំដីចំអក(ខ.៤០) ដូចពីមុនដែរ តែប៉ុណ្ណោះទេ (មើល ការពន្យល់ លក ២៣:៤៧)។

**២៧:៥៦** មើលការពន្យល់ មក ១៥:៤០ ។

**២៧:៥៧** *ភូមិអើរីម៉ាថេ* គឺនៅភ្នំអេប្រាអិម ដែលចម្ងាយប្រហែល៣២គ.ម ពីភាគ ពាយ័ព្យនៃក្រុងយេរូសាឡិម ។

**២៧:៥៨** *សូមព្រះសពព្រះយេស៊ូវ* មើលការពន្យល់ លក ២៣:៥២ ។

**២៧:៥៩-៦០** មើលការពន្យល់ មក ១៥:៤៦ ។

**២៧:៦២** *ស្អែកឡើង . . . ថ្ងៃ* គឺនៅថ្ងៃសៅរ៍ជាថ្ងៃបុណ្យ ថ្ងៃសុក្រជាថ្ងៃរៀបចំចូលថ្ងៃឈប់សម្រាក(ល្ងាចថ្ងៃសុក្រដល់ថ្ងៃសៅរ៍)។

**២៧:៦៤** *អាក្រក់ជាងជាន់មុន* ដំបូងគឺព្រះយេស៊ូវនឹងបានជាព្រះមែស៊ី បន្ទាប់ពីព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ នោះទ្រង់ជាព្រះរាជបុត្រានៃព្រះ ។

របស់វាមកលួចយកខ្មោច[ជ]វាទាំងយប់ទៅ រួចប្រាប់ដល់
បណ្ដាជនថា វាបានរស់ពីស្លាប់ឡើងវិញហើយ បើយ៉ាង
នោះ សេចក្ដីកំភូតជាន់ក្រោយនេះ នឹងបានអាក្រក់ជាង
ជាន់មុនទៅទៀត ៦៥លោកពីឡាត់មានប្រសាសន៍ទៅគេថា
អ្នករាល់គ្នាមានអ្នកយាមល្បាតស្រាប់ហើយ ដូច្នេះចូរទៅ
រក្សាឱ្យមាំមួនតាមចិត្តចុះ[ឈ] ៦៦រួចគេក៏ទៅបិទចំណាំធ្វើឱ្យ
មាំមួន ហើយដាក់គ្នាឱ្យចាំយាមផង ។

## ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ

*២៨:១-៨ = មក ១៦:១-៨ លក ២៤:១-១០, យហ ២០:១-៨*

**២៨** ១ក្រោយថ្ងៃឈប់សំរាក កាលរៀបនឹងចូលថ្ងៃទី១
ក្នុងអាទិត្យនោះ ម៉ារា ជាអ្នកស្រុកម៉ាក់ដាឡា[ញ] នឹងម៉ារា[ដ]១
ទៀត ក៏នាំគ្នាទៅមើលផ្នូរ ២នោះមានកក្រើកដីជាខ្លាំង[ឋ]
ដ្បិតមានទេវតា[ឌ]នៃព្រះអម្ចាស់ ចុះពីលើមេឃមកប្រមៀល
ថ្ម[ឍ]ចេញពីផ្នូរ ហើយក៏អង្គុយលើ ៣សណ្ឋានរបស់ទេវតា
នោះដូចផ្លេកបន្ទោរ ហើយសំលៀកបំពាក់ក៏សស្គុសដូច
ហិមៈ[ណ] ៤ពួកយាមល្បាតក៏ញ័ររន្ធត់ ដោយភ័យខ្លាចទេវតា
ហើយត្រឡប់ដូចជាមនុស្សស្លាប់ ៥តែទេវតានិយាយនឹង
ស្ត្រី២នាក់ថា កុំឱ្យភ័យអី[ត] ដ្បិតខ្ញុំដឹងហើយថា នាងរកព្រះ
យេស៊ូវដែលត្រូវឆ្កាង ៦តែទ្រង់មិនគង់នៅទីនេះទេ ដ្បិត
ទ្រង់មានព្រះជន្មរស់ឡើងវិញហើយ ដូចជាទ្រង់បានមាន
បន្ទូលទុក[ថ] ចូរមកមើលកន្លែង ដែលទ្រង់បានផ្ទំចុះ
៧រួចទៅឱ្យឆាប់ ប្រាប់ដល់ពួកសិស្សទ្រង់ថា ទ្រង់មាន
ព្រះជន្មរស់ពីស្លាប់ឡើងវិញហើយ មើល ទ្រង់យាងទៅឯ
ស្រុកកាលីឡេ[ទ] មុនអ្នករាល់គ្នា។ នឹងឃើញទ្រង់នៅស្រុក
នោះ នែ ខ្ញុំបានប្រាប់អ្នករាល់គ្នាហើយ ៨ស្ត្រី២នាក់នោះ
ក៏ដើរចេញពីផ្នូរជាប្រញាប់ទាំងភ័យ ហើយមានសេចក្ដី
អំណរជាខ្លាំងផង ក៏រត់ទៅប្រាប់ដល់ពួក សិស្សទ្រង់
៩តែកាលនាងកំពុងតែទៅ នោះព្រះយេស៊ូវទ្រង់
យាងមកជួបនឹងនាង[ធ] មានបន្ទូលថា ជំរាបសួរ រួចអ្នក
ទាំង២ក៏ចូលទៅ ឱបព្រះបាទថ្វាយបង្គំទ្រង់ ១០នោះព្រះ
យេស៊ូវទ្រង់មានបន្ទូលទៅនាងថា កុំខ្លាចអី ចូរទៅប្រាប់
ដល់បងប្អូនខ្ញុំផង[ន] ឱ្យគេទៅឯស្រុកកាលីឡេទៅ គេនឹងឃើញខ្ញុំ
នៅស្រុកនោះហើយ។

## សេចក្ដីរាយការណ៍របស់អ្នកយាម

១១កាលនាងកំពុងតែទៅ នោះពួកយាមល្បាតខ្លះ[ប]ក៏ចូល
ទៅក្នុងទីក្រុង ជំរាបដល់ពួកសង្គ្រាជ ពីការទាំងប៉ុន្មានដែល
កើតមក ១២រួចកាលអ្នកទាំងនោះ នឹងពួកចាស់ទុំបានប្រជុំ
ហើយពិគ្រោះគ្នា នោះគេយកប្រាក់ជាច្រើនទៅសូក ដល់
ពួកទាហាន ១៣ដោយពាក្យថា ចូរឯងរាល់គ្នានិយាយថា
ក្នុងកាលដែលយើងខ្ញុំកំពុងតែដេកលក់ នោះពួកសិស្ស
របស់វា បានមកលួចយកខ្មោចវា ទាំងយប់បាត់ទៅហើយ[ផ]
១៤បើសេចក្ដីនោះឮទៅដល់លោកចៅហ្វាយ[ព] នោះយើង
នឹងទៅពន្យល់លោក ឱ្យឯងរាល់គ្នាបានរួចពីទោស ១៥គេ
ទទួលប្រាក់នោះ ហើយក៏ធ្វើតាមបង្គាប់ បានជារឿងនោះឮ
ខ្ចរខ្ចាយ ទូទៅគ្រប់ក្នុងសាសន៍យូដា ដរាបដល់សព្វថ្ងៃនេះ។

## មហាបេសកកម្ម

១៦ឯពួកសិស្សទាំង១១នាក់ គេទៅឯស្រុកកាលីឡេ ដល់ភ្នំ
ដែលព្រះយេស៊ូវបានប្រាប់[ភ] ១៧កាលគេឃើញទ្រង់នោះក៏
ថ្វាយបង្គំ តែមានអ្នកខ្លះមានសេចក្ដីសង្ស័យ ១៨ឯព្រះយេស៊ូវ
ទ្រង់យាងមកមានបន្ទូលនឹងគេថា គ្រប់ទាំងអំណាចបានប្រ
គល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយលើផែនដីផង[ម] ១៩ដូច្នេះ
ចូរទៅបញ្ចុះបញ្ចូលឱ្យមានសិស្សនៅគ្រប់ទាំងសាសន៍[យ]
ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឱ្យ ដោយនូវព្រះនាមព្រះវរ
បិតា ព្រះរាជបុត្រា នឹងព្រះវិញ្ញាណបរិសុទ្ធចុះ[រ] ២០ហើយ
បង្រៀន[ល]ឱ្យគេកាន់តាមគ្រប់ទាំងសេចក្ដីដែលខ្ញុំបានបង្គាប់
មកអ្នករាល់គ្នាផង ហើយមើល ខ្ញុំក៏នៅជាមួយនឹងអ្នករាល់
គ្នាជារាល់ថ្ងៃដែរ[វ] ដរាបដល់បំផុតកល្ប[ស] ។អាម៉ែន។

**២៧:៦៤** ជ មថ ២៨:១៣
**២៧:៦៥** ឈ ខ.៦៦ មថ ២៨:១១
**២៧:៦៦** ដយ ៦:១៧ ខ.៦០ មថ ២៨:២,១១
**២៨:១** ញ លក ៨:២ ដ មថ ២៧:៥៦
**២៨:២** ឋ មថ ២៧:៥១ ឌ យហ ២០:១២ កច ៥:១៩ ឍ មថ ២៧:៦០
**២៨:៣** ណ ដយ ៧:៩ ១០:៦ មក ៩:៣ យហ ២០:១២
**២៨:៥** ត ខ.១០ មថ ១៤:២៧
**២៨:៦** ថ មថ ១៦:២១
**២៨:៧** ទ ខ.១០,១៦ មថ ២៦:៣២
**២៨:៩** ធ យហ ២០:១៤-១៨
**២៨:១០** ន មថ ១២:៥០ ២៥:៤០ មក ៣:៣៤ យហ ២០:១៧ រម ៨:២៩ ហព ២:១១-១៣,១៧
**២៨:១១** ប មថ ២៧:៦៥,៦៦
**២៨:១៣** ផ មថ ២៧:៦៤
**២៨:១៤** ព មថ ២៧:២
**២៨:១៦** ភ ខ.៧,១០ មថ ២៦:៣២
**២៨:១៨** ម ដយ ៧:១៣,១៤ លក ១០:២២ យហ ៣:៣៥ ១៣:១៣ ១៧:២ ១កថ ១៥:២៧ អភ ១:២០-២២ ភល ២:៩,១០
**២៨:១៩** យ អស ៤៩:៦ មក ១៦:១៥,១៦ លក ២៤:៤៧ កច ១:៨ ៤:២១ រ កច ១:៨ ២:៣៨ ៨:១៦ រម ៦:៣,៤ កទ ៣:២៧ កល ២:១២
**២៨:២០** ល យហ ១៤:២៦ កច ២:៤២ វ ចទ ៣១:៦ ១ពវ ៨:៥៧ ហក ១:១៣ មថ ១៨:២០ កច ១៨:១០ ស មថ ១៣:៣៩ ២៤:៣

**២៧:៦៥** *រក្សាឱ្យមាំមួនតាមចិត្តចុះ* លោកពីឡាត់បញ្ជាឱ្យពួកទាហានរ៉ូម៉ាំងជាអ្នកយាមការពារ (២៨:៤,១១-១២)។

**២៨:១** *ថ្ងៃទី១ក្នុងអាទិត្យនោះ* មើលការពន្យល់ លក ២៤:១ ។ *ម៉ារា១ទៀត* ជាប្រពន្ធរបស់លោកក្លូប៉ាស (២៧:៥៦ យហ ១៩:២៥)។

**២៨:២** *នោះមាន* មានន័យថា "ឥឡូវបានកើតមកហើយ" វាបញ្ជាក់យ៉ាងច្បាស់នូវរឿងដែលស្របគ្នាទៅនឹង (មក ១៦:២-៦ លក ២៤:១-៧ យហ ២០:១)។ ព្រឹត្តិការណ៍ក្នុង "ខ.២-៤" ជាហេតុការណ៍ដែលកើតឡើងមុនពួកស្ត្រីបានទៅដល់ផ្នូរនោះទៅទៀត ។ *កក្រើកដី* ពាក្យនេះមានតែក្នុងគម្ពីរម៉ាថាយទេ ហេតុការណ៍ដូចពេលទ្រង់បានសុគតនោះដែរ (២៧:៥១,៥៤)។

**២៨:១១-១៥** មានតែលោកម៉ាថាយទេ បានប្រាប់ពីការដាក់អ្នកយាម (២៧:៦២-៦៦) និងការរាយការណ៍របស់ពួកអ្នកយាមទាំងនេះ ។

**២៨:១៦** *សិស្សទាំង១១* ដោយយូដាសបានសម្លាប់ខ្លួនបាត់ហើយ (២៧:៥)។

**២៨:១៩** *គ្រប់ទាំងសាសន៍* ផ្ទុយទៅនឹង "១០:៥-៦"។ *ធ្វើបុណ្យជ្រមុជទឹកឱ្យគេ* គឺជាសញ្ញានៃការរួបរួម និងការប្ដេជ្ញាចិត្តរបស់ពួកគេផ្ទាល់ៗខ្លួនចំពោះការដើរតាមព្រះយេស៊ូវ (មើលការពន្យល់ កច ២:៣៨ រម ៦:៣-៤)

**២៨:២០** *នៅជាមួយនឹងអ្នក* លោកម៉ាថាយបានបញ្ចប់សំណេររបស់គាត់ដោយពាក្យនៃការធានាអះអាង និងអំណាចព្រះចេស្ដានៃព្រះបន្ទូលរបស់ព្រះម្ដងទៀតថា "ព្រះគង់ជាមួយនឹងយើង" (១:២៣)។

# ដំណឹងល្អ

តាមលោកម៉ាកុស

## សេចក្តីផ្តើម

### អ្នកនិពន្ធ

ទោះបីជាមិនមានភស្តុតាងបញ្ជាក់ដោយផ្ទាល់ថានរណាជាអ្នកនិពន្ធព្រះគម្ពីរនេះក៏ដោយ ក៏មានទីបន្ទាល់នៃពួកជំនុំដំបូងបានបង្ហាញថា ដំណឹងល្អនេះត្រូវបានសរសេរឡើងដោយលោកម៉ាកុស(យ៉ូហាន-ម៉ាកុស)។ មានភស្តុតាងសំខាន់ៗចេញពីឯកសារនៃពួកជំនុំដំបូងនោះថា (១). លោកម៉ាកុសជាមនុស្សជិតស្និទ្ធនឹងលោកពេត្រុស ហើយបានទទួលសេចក្តីបង្រៀនជាច្រើនពីព្រះអម្ចាស់ ទាំងព្រះបន្ទូល និងសកម្មភាពតាមរយៈគាត់នេះឯង។ (២).សេចក្តីបង្រៀននោះមិនបានចប់ត្រឹមលោកម៉ាកុសនោះទេ គឺបានបន្តតម្រង់ឆ្ពោះទៅរកសេចក្តីតម្រូវការរបស់សហគមន៍គ្រីស្ទបរិស័ទដំបូងទៀតផង។ (៣).លោកម៉ាកុសបានរក្សានូវឯកសារទាំងនេះយ៉ាងត្រឹមត្រូវ ។ សរុបសេចក្តីមក លោកម៉ាកុសបានទទួលសេចក្តីបង្រៀនពីលោកពេត្រុស ឬសេចក្តីបង្រៀនរបស់លោកពេត្រុសត្រូវបានចងក្រងឡើងដោយលោកម៉ាកុស ដែលជាព្រះគម្ពីរម៉ាកុសនេះឯង(មើលការពន្យល់ កច ១០:៣៧)។

### យ៉ូហាន-ម៉ាកុស ក្នុងព្រះគម្ពីរសញ្ញាថ្មី

នេះជាការយល់ព្រមទូទៅមួយថា លោកម៉ាកុសជាមនុស្សម្នាក់ដែលមានភាពជិតស្និទ្ធជាមួយនឹងលោកពេត្រុស ក្នុងកាលដែលមិនទាន់មានព្រះគម្ពីរនៅឡើយ ហើយគាត់ក៏ជាមនុស្សម្នាក់ដែលគេហៅថា យ៉ូហាន-ម៉ាកុស នៅក្នុងសញ្ញាថ្មី ក្រោយពីមានព្រះគម្ពីរហើយនោះដែរ ។ ការលេចញពីគាត់មុនដំបូងនោះគឺ ទាក់ទងទៅនឹងម្តាយរបស់គាត់ ដែលមានផ្ទះនៅក្រុងយេរូសាឡិម ថាបានបម្រើនៅកន្លែងប្រជុំសម្រាប់អ្នកជឿ (កច ១២:១២)។ នៅពេលលោកប៉ុល និងលោកបាណាបាសបានត្រឡប់ពីទីក្រុងយេរូសាឡិមទៅឯទីក្រុងអាន់ទីយ៉ូកវិញ ក្រោយពីសួរសុខទុក្ខអ្នកក្រីក្រខ្វះខាត នោះលោកម៉ាកុសក៏បានទៅជាមួយពួកគេ (កច ១២:២៥)។ វត្តមានរបស់គាត់លើកក្រោយនេះ គឺធ្វើជាអ្នកជំនួយដល់លោកប៉ុល និងលោកបាណាបាស ក្នុងដំណើរបេសកកម្មលើកទីមួយរបស់ពួកគេ (កច ១៣:៥)។ ប៉ុន្តែ គាត់បានចាកចោលពួកគេត្រង់ក្រុងពើកា នៅស្រុកប៉ាមភីលា ពេលត្រឡប់មកពីក្រុងយេរូសាឡិមវិញ (កច ១៣:១៣)។ ពេលនោះលោកប៉ុលបានខកចិត្តយ៉ាងខ្លាំងចំពោះអំពើរបស់ម៉ាកុស ពីព្រោះនៅពេលដែលលោកបាណាបាសបានស្នើសុំយកលោកម៉ាកុសទៅជាមួយ ក្នុងដំណើរបេសកកម្មលើកទី២ នោះត្រូវបានលោកប៉ុលបដិសេធចោល។ ការបដិសេធន៍នេះបានធ្វើឱ្យបែកបាក់ទំនាក់ទំនងក្នុងព្រះគម្ពីរកិច្ចការ (កច ១៥:៣៦-៣៩)។ លោកបាណាបាសបានយកលោកម៉ាកុសទៅជាមួយដែលជាបងប្អូនជីដូនមួយនឹងគាត់ ហើយចេញដំណើរទៅស្រុកគីប្រុស គ្មានការពិពណ៌នាណាទៀតឡើយអំពីពួកគាត់នៅក្នុងព្រះគម្ពីរកិច្ចការ។ លោកម៉ាកុសបានលេចញម្តង ទៀតនៅក្នុងសំបុត្ររបស់លោកប៉ុល ដែលបានពីក្រុងរ៉ូម ដើម្បីផ្ញើទៅពួកជំនុំនៅទីក្រុងកូល៉ុស ។ លោកប៉ុលបានផ្ញើពាក្យជម្រាបសួរពីលោកម៉ាកុស ហើយគាត់បន្ថែមទៀតថា: អ្នករាល់គ្នាបានទទួលសេចក្តីបង្រៀនអំពីគាត់ បើគាត់មកឯអ្នករាល់គ្នា នោះសូមស្វាគមន៍គាត់ផង" (កល ៤:១០ និង ភម ២៤ បានសរសេរក្នុងពេលតែមួយ)។ ត្រង់ចំណុចនេះ លោកម៉ាកុសកំពុងតែទទួលបាននូវជ័យជំនះចំពោះការទុកចិត្ត និងជាទីពេញចិត្តយ៉ាងខ្លាំងនៅទីបញ្ចប់នៃជីវិតរបស់លោកប៉ុល(២ធច ៤:១១)។

### កាលបរិច្ឆេទ

អ្នកខ្លះបានគិតថាលោកម៉ាថាយ និងលោកលូកាបានយកគម្ពីរម៉ាកុសធ្វើជាប្រភពធនធានដ៏សំខាន់មួយ ដោយផ្អែកលើគម្ពីរម៉ាកុសត្រូវបានចងក្រងឡើងក្នុងដើមទសវត្សរ៍ទី៥0 ឬ៦0គ.ស ។ ហើយអ្នកផ្សេងបានគិតថា មាតិការឿង និងអត្ថបទនៃដំណឹងល្អម៉ាកុសបានកើតឡើងដោយមានការបញ្ជាក់ពីពួកជំនុំដំបូងថា ព្រះគម្ពីរនេះត្រូវបានសរសេរខ្លីៗ មុនពេលការបំផ្លាញទីក្រុងយេរូសាឡិមនៅឆ្នាំទី៧0 គ.ស (មើលតារាងកាលបរិច្ឆេទ បញ្ជីដំណឹងល្អ)។

### ទីកន្លែងនៃការសរសេរ

អាស្រ័យលើប្រពៃណីនៃពួកជំនុំដំបូង ព្រះគម្ពីរម៉ាកុសត្រូវបានសរសេរឡើងនៅក្នុង "តំបន់នៃប្រទេសអ៊ីតាលី" ឬច្បាស់ជាងនេះទៅទៀត នោះគឺនៅទីក្រុងរ៉ូម ។ អ្នកនិពន្ធទាំងនេះធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងលោកពេត្រុសក្នុងការសរសេរគម្ពីរដំណឹងល្អម៉ាកុស ។ ភស្តុតាងក្នុងការនិយាយខាងលើគឺមានដូចតទៅ :

១. តាមរយៈប្រវត្តិរបស់លោកពេត្រុសបង្ហាញថា គាត់បានចំណាយជីវិតរងទុក្ខចុងក្រោយរបស់គាត់នៅឯទីក្រុងរ៉ូម ។

២. តាមរយៈព្រះគម្ពីរបង្ហាញថា លោកម៉ាកុសក៏បាននៅក្រុងរ៉ូមនោះដែរ ហើយបានធ្វើការរួមជាមួយនឹងលោកពេត្រុសយ៉ាងជិតស្និទ្ធថែមទៀតផង (២ធច ៤:១១ ១ ពត ៥:១៣) ដូចជាការប្រើពាក្យថា "បាប៊ីឡូន" ដែលជាពាក្យសំងាត់មួយបញ្ជាក់ពីទីក្រុងរបស់ចក្រភពរ៉ូម៉ាំង ។

ជិតស្និទ្ធថែមទៀតផង (២ធថ ៤:១១ ១ពត ៥:១៣) ដូចជាការប្រើពាក្យថា បាប៊ីឡូន" ដែលជាពាក្យសម្ងាត់មួយបញ្ជាក់ពីទីក្រុងរបស់ចក្រភពរ៉ូម៉ាំង ។

**អ្នកទទួល**

មានភស្តុតាងបង្ហាញថា ដំណឹងល្អម៉ាកុសបានសំដៅទៅកាន់ពួកជំនុំនៅទីក្រុងរ៉ូម ឬយ៉ាងហោចណាស់ដល់អ្នកអានដែលជាសាសន៍ដទៃនោះដែរ ។ លោកម៉ាកុសបានពន្យល់តាមប្រពៃណីរបស់សាសន៍យូដា (៧:២-៤ ១៥:៤២) បកប្រែទៅជាភាសាអារ៉ាប់ (៣:១៧ ៥:៤១ ៧:១១,៣៤ ១៥:២២) ហើយហាក់បីដូចជាមានការចាប់អារម្មណ៍ជាពិសេសមួយនៅក្នុងការបៀតបៀន និងការរងទុក្ខលំបាក (៨:៣៤-៣៨ ១៣:៩-១៣) ។ ប្រធានបទពិសេសមួយចំនួន ទាក់ទងទៅនឹងអ្នកជឿដែលជាជនជាតិរ៉ូមផងដែរ ហើយភ្លាមៗនោះត្រូវបានគេបន្តផ្សព្វផ្សាយដំណឹងល្អនេះបានលឿនទៀតផង ។

**ស្ថានភាព និងគោលបំណង**

ក្រោយពីដំណឹងល្អរបស់លោកម៉ាកុសបានជ្រាបចូលតាមដំណើរជាមួយសហគមន៍រ៉ូមហើយនោះ ក៏កើតមានការបៀតបៀនចូលមកដល់ពួកជំនុំនៅក្រុងរ៉ូមក្នុងឆ្នាំ៦៤-៦៧ ។ ភាពរំជើបរំជួលខ្លាំងនៅទីក្រុងរ៉ូមគឺចាប់ពីឆ្នាំ៦៤គ.សឡើងទៅ ប្រហែលបង្កើតឡើងដោយពួកនេរ៉ូ តែបែរជាបន្ទោសដល់ពួកគ្រីស្ទបរិស័ទវិញ ។ ជាលទ្ធផលគឺធ្វើឱ្យមានការបៀតបៀនជាសកល ថែមទាំងទទួលការឈឺចាប់ដោយមិនដឹងមូលហេតុក្នុងចំណោម អ្នកជឿជាសាសន៍រ៉ូម ប្រហែលជាលោកម៉ាកុសកំពុងតែសរសេរទៅកាន់អ្នកអានរបស់លោកឱ្យរៀបចំចិត្តសម្រាប់ទទួលការរងទុក្ខដូចជាគ្រីស្ទបរិស័ទមុនៗនៃជីវិតរស់នៅក្នុងព្រះអម្ចាស់របស់យើង ។ មានឧបោងជាច្រើនស្តីអំពីការរងទុក្ខលំបាកទាំងនៅចំពោះមុខ និងនៅក្នុងទីសម្ងាត់(១:១២-១៣ ៣:២២,៣០ ៨:៣៤-៣៨ ១០:៣០,៣៣-៣៤,៤៥ ១៣:៨,១១-១៣)។

**សំគាល់**

១. *ឈើឆ្កាង* មនុស្សបានបង្កហេតុ (១២:១២ ១៤:១-២ ១៥:១០) ហើយព្រះចាំបាច់យាងទៅលើឈើឆ្កាង (៨:៣១ ៩:៣១ ១០:៣៣)។

២. *ភាពជាសាវ័ក* ត្រូវបានយកចិត្តទុកដាក់ជាពិសេសទាំងនេះជាព្រះបន្ទូលស្តីពីទំនាយរបស់ព្រះយេស៊ូវ និងការខ្វាយខ្វល់ក្នុងចិត្ត (៨:៣៤-៩:១ ៩:៣៥-១០:៣១ ១០:៤២-៤៥)។

៣. *សេចក្តីបង្រៀនរបស់ព្រះយេស៊ូវ* លោកម៉ាកុសបានកត់ចុះច្រើនជាងអ្នកនិពន្ធដំណឹងល្អដទៃទៀតនូវសេចក្តីបង្រៀនរបស់ព្រះយេស៊ូវ ។ មានការកត់សំគាល់មួយថា ព្រះយេស៊ូវគឺជាគ្រូបង្រៀន ពាក្យថា លោកគ្រូបង្រៀន ឬការបង្រៀនត្រូវបានគេសំដៅលើព្រះយេស៊ូវនៅក្នុងព្រះគម្ពីរម៉ាកុសមានដល់ទៅ៣៩ដង ។

៤. *ព្រះមែស៊ីជាការសម្ងាត់* ជាច្រើនដងព្រះយេស៊ូវបានហាមសិស្សរបស់ទ្រង់ ឬមនុស្សណាដែលទ្រង់បានប្រោសឱ្យបានជាពីជំងឺមិនឱ្យប្រាប់អ្នកដទៃថាទ្រង់ជាអ្នកណា ឬក៏ការដែលទ្រង់បានធ្វើឡើយ (១:៣៤,៤៤ ៣:១២ ៥:៤៣ ៧:៣៦-៣៧ ៨:២៦,៣០ ៩:៩)។

៥. *ព្រះរាជបុត្រានៃព្រះ* ទោះជាលោកម៉ាកុសបញ្ជាក់ពីភាពជាមនុស្សរបស់ព្រះយេស៊ូវក៏ដោយ ក៏លោកមិនធ្វេសប្រហែសប្រាប់អំពីភាពជាព្រះរបស់ទ្រង់ដែរ (១:១,១១ ៣:១១ ៥:៧ ៩:៧ ១២:១-១១ ១៣:៣២ ១៥:៣៩)។

**លក្ខណៈពិសេស**

ដំណឹងល្អរបស់លោកម៉ាកុសគឺសាមញ្ញ ខ្លី និងមិនមែនជាការតាក់តែង ហើយថែមទាំងមានភាពរស់រវើកនៃព្រះរាជកិច្ចរបស់ព្រះយេស៊ូវ ដោយបញ្ជាក់ពីអ្វីដែលព្រះយេស៊ូវបានធ្វើជាជាងនូវអ្វីដែលទ្រង់បានមានបន្ទូល ។ លោកម៉ាកុសបានប្តូរពីហេតុការណ៍មួយទៅហេតុការណ៍មួយទៀតនៃដំណើរជីវិត និងព្រះរាជកិច្ចរបស់ព្រះយេស៊ូវបានយ៉ាងលឿន ដោយប្រើកិរិយាសព្ទវិសេស "ភ្លាមៗនោះ រំពេចនោះ ឬស្រាប់តែ" (មើលការពន្យល់ ១:១២)។ នៅក្នុងព្រះគម្ពីរម៉ាកុសទាំងមូលហាក់បីដូចជាចង្អុលចរិតលក្ខណៈថា "នេះជាដើមនៃដំណឹងល្អ"(១:១)។ ដំណើរជីវិត ការសុគត និងការរស់ឡើងវិញនៃព្រះគ្រីស្ទបានដាក់បញ្ចូលក្នុងពាក្យ "ដើមដំបូង" ហើយត្រូវបានពួកសាវ័កយកទៅបង្រៀនបន្តក្នុងព្រះគម្ពីរកិច្ចការ ។

ទីលំនៅ: លោកម៉ាកុសរស់នៅក្នុងទីក្រុងយេរូសាឡិម

មុខរបរ: ជាសិស្សរបស់ព្រះគ្រីស្ទ និងជាអ្នកនិពន្ធ

ល្បីខាង: (១). សរសេរសង្ខេបពីដំណើររឿងនៃជីវិតរបស់ព្រះគ្រីស្ទផ្អែកលើសេចក្តីអធិប្បាយរបស់លោកពេត្រុស ។ (២). ចាកចោលលោកប៉ុល និងលោកបាណាបាសពេលបំពេញបេសកកម្មលើកទីមួយ ។ (៣).បានទទួលនូវការទុកចិត្តអំពីលោកប៉ុលឡើងវិញ

(២ធថ ៤:១១)។

**គម្រោងសង្ខេប**

**I. ដើមដំបូងនៃព្រះរាជកិច្ចរបស់ព្រះយេស៊ូវ (១:១–១៣)**

ក. ការរៀបផ្លូវថ្វាយទ្រង់ (១:១–៨)

ខ. ពិធីបុណ្យជ្រមុជទឹក (១:៩–១១)

គ. សេចក្តីល្បួង (១:១២–១៣)

**II. ព្រះរាជកិច្ចរបស់ព្រះយេស៊ូវនៅស្រុកកាលីឡេ (១:១៤–៦:២៩)**

ក. ព្រះរាជកិច្ចនៅស្រុកកាលីឡេលើកដំបូង (១:១៤–៣:១២)

១. ការត្រាស់ហៅសិស្សជាលើកដំបូង (១:១៤–២០)

២. ការអស្ចារ្យនៅក្រុងកាពើណិម (១:២១–៣៤)

៣. ការធ្វើដំណើរនៅក្នុងស្រុកកាលីឡេ (១:៣៥–៤៥)

៤. ព្រះរាជកិច្ចនៅក្រុងកាពើណិម (២:១–២២)

៥. ការប្រឈមមុខដាក់គ្នានៅថ្ងៃឈប់សម្រាក (២:២៣–៣:១២)

ខ. ព្រះរាជកិច្ចនៅស្រុកកាលីឡេបន្តទៀត (៣:១៣–៦:២៩)

១. ការជ្រើសរើសសាវកទាំង១២នាក់ (៣:១៣–១៩)

២. សេចក្តីបង្រៀននៅក្រុងកាពើណិម (៣:២០–៣៥)

៣. រឿងប្រៀបប្រដូចនៃនគរស្ថានសួគ៌ (៤:១–៣៤)

៤. ដំណើរឆ្លងកាត់សមុទ្រកាលីឡេ (៤:៣៥–៥:២០)

៥. មានការអស្ចារ្យថែមទៀតនៅក្នុងស្រុកកាលីឡេ (៥:២១–៤៣)

៦. ពួកអ្នកមិនជឿនៅស្រុករបស់ព្រះយេស៊ូវ (៦:១–៦)

៧. សាវកទាំង៦ក្រុមធ្វើដំណើរនៅក្នុងស្រុកកាលីឡេ (៦:៧–១៣)

៨. ប្រតិកម្មរបស់ស្តេចហេរ៉ូឌ ចំពោះរាជកិច្ចរបស់ព្រះយេស៊ូវ (៦:១៤–២៩)

**III. ការយាងចេញពីស្រុកកាលីឡេរបស់ព្រះយេស៊ូវ (៦:៣០–៩:៣២)**

ក. យាងទៅច្រាំងសមុទ្រកាលីឡេភាគខាងកើត (៦:៣០–៥២)

ខ. យាងទៅច្រាំងសមុទ្រកាលីឡេភាគខាងលិច (៦:៥៣–៧:៣២)

គ. យាងទៅស្រុកភេនីស (៧:២៤–៣០)

ឃ. យាងទៅតំបន់នៃស្រុកដេកាប៉ូល (៧:៣១–៨១០)

ង. យាងទៅសេសារា–ភីលីព (៨:១១–៩:៣២)

**IV. ព្រះរាជកិច្ចចុងក្រោយនៅស្រុកកាលីឡេ (៩:៣៣–៥០)**

**V. ព្រះរាជកិច្ចរបស់ព្រះយេស៊ូវនៅស្រុកយូដា និងពេរ៉េ (ជំពូក ១០)**

ក. សេចក្តីបង្រៀនដែលទាក់ទងនឹងការលែងលះប្តីប្រពន្ធ (១០:១–១២)

ខ. សេចក្តីបង្រៀនដែលទាក់ទងនឹងកូនក្មេង (១០:១៣–១៦)

គ. បុរសអ្នកមានវ័យក្មេងម្នាក់ ១០:១៧–៣១)

ឃ. ទំនាយពីការសុគតរបស់ព្រះយេស៊ូវ (១០:៣២–៣៤)

ង. សំណូមពររបស់បងប្អូនពីរនាក់ (១០:៣៥–៤៥)

ច. មនុស្សខ្វាក់ឈ្មោះបារទីមេបានមើលឃើញ (១០:៤៦–៥២)

**VI. ភាពរំជើបរំជួលពីព្រះយេស៊ូវ (ជំពូក ១១–១៥)**

ក. ផ្លូវនៃជ័យជម្នះ (១១:១–១១)

ខ. ការសម្អាតព្រះវិហារ (១១:១២–១៩)

គ. ការប្រឈមមុខចុងក្រោយជាមួយនឹងពួកអ្នកដឹកនាំសាសន៍យូដា (១១:២០–១២:៤៤)

ឃ. ការបង្រៀននៅលើភ្នំដើមអូលីវអំពីទីអវសាននៃពិភពលោក (ជំពូក ១៣)

ង. ការចាក់ប្រេងតាំងលើព្រះយេស៊ូវ (១៤:១–១១)

ច. ការចាប់ខ្លួន ការកាត់ទោស និងការសុគតរបស់ព្រះយេស៊ូវ (១៤:១២–១៥:៤៧)

**VII. ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ (ជំពូក ១៦)**

## យ៉ូហាន–បាទីស្ទរៀបចំផ្លូវ

*១:២–៨ = មថ ៣:១–១១ លក ៣:២–១៦*

**១** ១ នេះជាដើមដំណឹងល្អពីព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជ
បុត្រានៃព្រះ[ក] ២ ដូចជាបានសរសេរទុក នៅក្នុងគម្ពីរ
ហោរាអេសាយ ថា «មើល អញចាត់ទូតអញឱ្យទៅមុនឯង
គាត់នឹងរៀបចំ ផ្លូវនៅមុខឯង»[ខ] ៣ «មានសំឡេងនៃមនុស្ស
ម្នាក់កំពុងតែស្រែកនៅទីរហោស្ថានថា ឱ្យរៀបចំផ្លូវទទួល
ព្រះអម្ចាស់ ចូរដំរង់ផ្លូវតូចថ្វាយទ្រង់ចុះ»[គ]។
៤ ឯយ៉ូហាន[ឃ]ជាអ្នកដែលធ្វើបុណ្យជ្រមុជទឹក នៅទីរហោ
ស្ថាន ក៏មកដល់ គាត់ប្រកាសប្រាប់ ពីបុណ្យជ្រមុជខាងឯការ
ប្រែចិត្ត[ង] ប្រយោជន៍ឱ្យបានរួចពីបាប[ច] ៥ ពួកមនុស្សនៅ
ស្រុកយូដាទាំងអស់គ្នា នឹងពួកក្រុងយេរូសាឡិម ក៏ចេញទៅ
ទទួលបុណ្យជ្រមុជទឹកពីគាត់ ក្នុងទន្លេយ័រដាន់ទាំងលន់តួ
បាបគ្រប់គ្នា ៦ យ៉ូហានបានប្រដាប់ខ្លួន ដោយសំពត់ធ្វើពី
រោមអូដ្ឋ ហើយមានខ្សែក្រវាត់ស្បែកនៅចង្កេះ[ឆ]ក៏បរិភោគ
កណ្តូប[ជ] និងទឹកឃ្មុំព្រៃជាអាហារ ៧ គាត់ប្រកាសថា ព្រះអង្គ
ដែលយាងមកក្រោយខ្ញុំ ទ្រង់មានអំណាចលើសជាងខ្ញុំ
ខ្ញុំមិនគួរនឹងឱនស្រាយខ្សែសុព័ណ៌បាទទ្រង់ផង[ឈ] ៨ ឯខ្ញុំបាន
ធ្វើបុណ្យជ្រមុជឱ្យអ្នករាល់គ្នាដោយទឹក តែទ្រង់នឹងធ្វើបុណ្យ
ជ្រមុជឱ្យអ្នករាល់គ្នា ដោយព្រះវិញ្ញាណបរិសុទ្ធវិញ[ញ]។

## ពិធីបុណ្យជ្រមុជទឹក នឹងការល្បួងព្រះយេស៊ូវ

*១:៩–១១ = មថ ៣:១៣–១៧ លក ៣:២១,២២*

*១:១២,១៣ = មថ ៤:១–១១ លក ៤:១–១៣*

៩ នៅក្នុងគ្រានោះ ព្រះយេស៊ូវ ទ្រង់យាងមកពីភូមិ
ណាសារ៉ែត[ដ] ស្រុកកាលីឡេ ក៏ទទួលបុណ្យជ្រមុជទឹកពី
យ៉ូហាន[ឋ] នៅក្នុងទន្លេយ័រដាន់ដែរ ១០ កាលកំពុងតែយាង
ឡើងពីទឹកមក ស្រាប់តែឃើញមេឃរបើក នឹងព្រះវិញ្ញាណ
ចុះមកសណ្ឋិតលើទ្រង់ មានរូបដូចជាព្រាប[ឌ] ១១ រួចឮសំឡេង

**១:១** ក មថ ៤:៣ **១:២** ខ មឡ ៣:១ មថ ១១:១០ លក ៧:២៧ **១:៣** គ អស ៤០:៣ យហ ១:២៣ **១:៤** ឃ មថ ៣:១ ង ខ.៨ យហ ១:២៦, ៣៣ កច ១:៥,២២ ១១:៣៦ ១៣:២៤ ១៨:២៥ ១៩:៣,៤ ច លក ១:៧៧ **១:៦** ឆ ២ ពវ ១:៨ ជ លវ ១១:២២ **១:៧** ឈ កច ១៣:២៥ **១:៨** ញ អស ៤៤:៣ យអ ២:២៨ យហ ១:៣៣ កច ១:៥ ២:៤ ១១:១៦ ១៩:៤–៦

**១:៩** ដ មថ ២:២៣ ឋ មថ ៣:១ **១:១០** ឌ យហ ១:៣២

**១:១** *នេះជាដើម* មើលសេចក្តីផ្តើមខាងលើ ជាពិសេសក្នុងការចាប់ផ្តើមព្រះគម្ពីរ (លោកុប្បត្តិ ១:១ និងដំណឹងល្អយ៉ូហាន ១:១) ដោយប្រើពាក្យ "កាលដើមដំបូង"។ *ដំណឹងល្អ* មានន័យថា ព្រះបានផ្តល់សេចក្តីសង្គ្រោះមកមនុស្សលោកតាមរយៈ ការសុគត និងរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ *ព្រះយេស៊ូវ* មើលការ ពន្យល់ មថ ១:២១ ។ *ព្រះគ្រីស្ទ* មើលការពន្យល់ មថ ១:១៧ ។

**១:២–៣** *នៅក្នុងគម្ពីរហោរាអេសាយ* គឺត្រូវដកស្រង់ចេញពីគម្ពីរម៉ាឡាគី ៣:១ ក្នុងពីរបន្ទាត់ដំបូង ហើយផ្សេងទៀតចេញពីអេសាយ ៤០:៣ (មើលការពន្យល់ មថ ២៧:៩) ដើម្បីយល់ពីព្រះរាជកិច្ចរបស់ព្រះយេស៊ូវកាន់តែច្បាស់ នោះត្រូវតែអានពីដើមដំបូងក្នុងគម្ពីរសញ្ញាចាស់ នូវអ្វីដែលហោរាអេសាយបានថែងពី ព្រះអម្ចាស់ដែលមានចំពោះព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ (ខ.១)។ បទគម្ពីរនេះបានសម្រេច ពេលដែលមានសំឡេងទូតនៃព្រះអម្ចាស់ ចេញពីទីរហោស្ថានមកដូចមានថែងនៅក្នុង"ខ.៤–៨"។

**១:៤** *យ៉ូហាន ជាអ្នកដែលធ្វើបុណ្យជ្រមុជទឹក* ដំណឹងល្អរបស់លោកម៉ាកុសដូចជារបស់លោកយ៉ូហានដែរ មិនបានចាប់ផ្តើមតាំងពីកំណើតរបស់ព្រះយេស៊ូវមកនោះទេ គឺចាប់ផ្តើមពីកិច្ចការរបស់លោកយ៉ូហាន–បាទីស្ទ ។ ឈ្មោះយ៉ូហានមានន័យថា "ព្រះគុណនៃព្រះអម្ចាស់"។ *បុណ្យជ្រមុជទឹក* ពិធីបុណ្យជ្រមុជទឹករបស់លោកយ៉ូហាន គឺសម្រាប់អស់អ្នកណាដែលបានប្រែចិត្តពិតប្រាកដបានជាគេស្គាល់គាត់យ៉ាងច្បាស់ថា "អ្នកធ្វើបុណ្យជ្រមុជទឹក"។ *ទីរហោស្ថាន* គឺជាតំបន់សោះកក្រោះ នៅភាគខាងលិចសមុទ្រស្លាប់ អ្នកស្រុកនៅទីនោះបានរួមគ្នាសរសេរ និងថែរក្សាក្រាំងសមុទ្រស្លាប់ ។ *ការប្រែចិត្ត* មានន័យថា ប្តេជ្ញារត់ចេញពីអំពើបាប វិលទៅរកសេចក្តីសុចរិតហើយសេចក្តីបញ្ជាក់របស់លោកយ៉ូហានពីការប្រែចិត្ត នេះថាការប្រកាសហៅឱ្យត្រឡប់មកឯព្រះវិញដោយពួកហោរា (ហស ៣:៤–៥)។ ជានិច្ចជាកាលព្រះបានអត់ទោសដល់មនុស្ស នៅពេលដែលមនុស្សបានប្រែចិត្តមកឯទ្រង់វិញ ។ *ជ្រមុជទឹក* លោកយ៉ូហានកំពុងតែប្រកាសពីបុណ្យជ្រមុជខាងឯការប្រែចិត្ត ។ ឧទាហរណ៍ ពិធីបុណ្យជ្រមុជទឹកដែលមានពីមុនៗ មកពីការប្រែចិត្ត តែធ្វើឡើងសម្រាប់ពួកសាសន៍ដទៃបានផ្លាស់ប្តូរជំនឿ ប៉ុន្តែមិនដែលបាន ឮថាកូនចៅលោកអ័ប្រាហាំ (សាសន៍យូដា) ត្រូវតែប្រែចិត្ត និងត្រូវជ្រមុជទឹកដែរនោះទេ ។

**១:៥** *ទាំងអស់គ្នា* ជាក់ស្តែង មានការបំផ្លើសសំដីក្នុងការបង្កើតឱ្យមានការចាប់អារម្មណ៍នូវសេចក្តីប្រកាសរបស់លោកយ៉ូហាន។ អស់រយៈកាលជាច្រើនសតវត្សរ៍មកហើយ អ៊ីស្រាអែលមិនមានពួកហោរាទេ ។ *ទន្លេយ័រដាន់* កាលដើមដំបូងស្ថិតនៅភ្នំធ្លាក់ព្រិលហើរម៉ូន និងទល់សមុទ្រស្លាប់ ចំណុចដែលជិតជាងគេបំផុតនឹងក្រុងយេរូសាឡិម គឺប្រហែល ៣២ គ.ម ។

**១:៦** *រោមអូដ្ឋ . . . ខ្សែក្រវាត់ស្បែក* ពាក់ដូចហោរាអេលីយ៉ា និងហោរាផ្សេងទៀត (២ពវ ១:៨ សក ១៣:៤)។ *កណ្តូប និងទឹកឃ្មុំព្រៃ* "មើលការពន្យល់ មថ ៣:៤"។

**១:៧-៨** *ប្រកាសថា* ម៉ាកុសសង្ខេបខ្លីៗពីការប្រកាសរបស់យ៉ូហាន (មថ ៣:៧ -១២ លក ៣:៧-១៧) ហើយផ្តោតលើការយាងមករបស់ព្រះដែលមានគ្រប់ព្រះចេស្តា។

**១:៨** *ជ្រមុជ . . . ដោយព្រះវិញ្ញាណបរិសុទ្ធ* មើលការពន្យល់ មថ ៣:១១ ។

**១:៩** *នៅក្នុងគ្រានោះ* ព្រះយេស៊ូវបានចាប់ផ្តើមព្រះរាជកិច្ចរបស់ទ្រង់ជាសាធារណៈ អាចនៅឆ្នាំទី២៧គ.ស នៅពេលទ្រង់មានព្រះជន្ម៣០ឆ្នាំ (លក ៣:២៣)។ ដូចដែលយើងបានដឹងថា ទ្រង់បានចំណាយពេលភាគច្រើនកាលមុននៅភូមិណាសារ៉ែត ។ *ណាសារ៉ែត* មើលការពន្យល់ មថ ២:២៣ ។ ទទួលបុណ្យជ្រមុជ ទឹកពីយ៉ូហានជាទីសំគាល់ពីពិធីបុណ្យជ្រមុជទឹករបស់ព្រះយេស៊ូវ (មើលការពន្យល់ មថ ៣:១៥)។

**១:១០–១១** នៅត្រង់វគ្គនេះ យើងបានឃើញសកម្មភាពព្រះត្រៃឯក មានតួអង្គទាំងបីគឺ (១).ព្រះវរបិតាមានបន្ទូលពីលើស្ថានសួគ៌មក (២).ព្រះរាជបុត្រាទទួលបុណ្យជ្រមុជទឹក (៣).ព្រះវិញ្ញាណបរិសុទ្ធយាងចុះមកសណ្ឋិតលើព្រះរាជបុត្រា ។

ពីលើមេឃថា ឯងជាកូនស្ងួនភ្ងាអញ[ឍ] ជាទីពេញចិត្តអញ
ណាស់[ណ] ១២ស្រាប់តែព្រះវិញ្ញាណបង្ខំទ្រង់ឱ្យយាងទៅ
ឯទីរហោស្ថាន ១៣ទ្រង់ក៏គង់នៅទីនោះ៤០ថ្ងៃ[ត] ជាមួយនឹង
អស់ទាំងសត្វព្រៃ ហើយត្រូវអារក្សសាតាំង[ថ]ល្បួង រួចមាន
ពួកទេវតាមកគាល់បំរើទ្រង់ ។

## ការត្រាស់ហៅសាវ័កជាលើកដំបូង

*១:១៦–២០ = មថ ៤:១៨–២២ លក ៥:២–១១ យហ ១:៣៥–៤២*

១៤គ្រាក្រោយដែលគេបញ្ជូនយ៉ូហាន[ទ]ទៅផុតហើយ នោះ
ព្រះយេស៊ូវទ្រង់យាងមកក្នុងស្រុកកាលីឡេវិញ[ធ] ព្រមទាំង
ប្រកាសប្រាប់ដំណឹងល្អពីនគរព្រះ[ន]ថា ១៥ពេលវេលាបាន
សំរេចហើយ[ប] នគរព្រះជិតមកដល់ ដូច្នេះ ចូរប្រែចិត្ត[ផ]
ហើយជឿដំណឹងល្អចុះ[ព] ។

១៦កាលព្រះយេស៊ូវកំពុងតែយាងទៅតាមឆ្នេរសមុទ្រ
កាលីឡេ នោះទ្រង់ទតឃើញស៊ីម៉ូន នឹងអនទ្រេ ជាប្អូនកំពុង
តែទំលាក់អួនក្នុងសមុទ្រ ដ្បិតគេជាអ្នកនេសាទត្រី ១៧ទ្រង់
មានបន្ទូលហៅថា ចូរមកតាមខ្ញុំ ខ្ញុំនឹងតាំងឱ្យអ្នកនេសាទ
មនុស្សវិញ ១៨គេក៏ទុកអួនចោល ហើយដើរតាមទ្រង់ជា
១រំពេចទៅ[ភ] ១៩លុះទ្រង់យាងហួសពីនោះបន្តិច ក៏ទត
ឃើញយ៉ាកុប ជាកូនសេបេដេ នឹងយ៉ូហាន ជាប្អូននៅក្នុងទូក
កំពុងតែជួស ជុលអួន ២០ហើយទ្រង់មានបន្ទូលហៅគេ
មកភ្លាម គេក៏លះ ចោលសេបេដេ ជាឪពុកនៅក្នុងទូក
ជាមួយនឹងពួកជើង ឈ្នួល រួចដើរតាមទ្រង់ទៅ ។

## ព្រះយេស៊ូវបណ្តេញវិញ្ញាណអាក្រក់

*១:២១–២៨ = លក ៤:៣១–៣៧*

២១នោះក៏នាំគ្នាចូលទៅក្នុងក្រុងកាពើណិម ហើយទ្រង់
ចូលទៅបង្រៀន ក្នុងសាលាប្រជុំរាល់តែថ្ងៃឈប់សំរាក[ម]
២២គេក៏នឹកប្លែកក្នុងចិត្ត ពីសេចក្តីបង្រៀនរបស់ទ្រង់ ដ្បិត
ទ្រង់បង្រៀន ដូចជាមានអំណាច មិនដូចជាពួកអាចារ្យទេ[យ]
២៣[រ]ឯនៅក្នុងសាលាប្រជុំរបស់គេ មានមនុស្សម្នាក់មាន

**១:១១** ឍ មថ ៣:១៧
ណ មថ ៣:១៧
**១:១៣** ត នក ២៤:១៨ ១ពវ ១៩:៨
ថ មថ ៤:១០ ហព ៤:១៥
**១:១៤** ទ មថ ៣:១ ធ មថ ៤:១២
ន មថ ៤:២៣
**១:១៥** ប រម ៥:៦ កទ ៤:៤ អភ ១:១០
ផ យហ ៣:១៥ ព កច ២០:២១
**១:១៨** ភ មថ ៤:១៩
**១:២១** ម ខ.៣៩ មថ ៤:២៣ មក ១០:១
**១:២២** យ មថ ៧:២៨,២៩

---

**១:១០** *ព្រះវិញ្ញាណចុះមកសណ្ឋិតលើទ្រង់* ព្រះយេស៊ូវត្រូវបានចាក់ប្រេងតាំង សម្រាប់បំពេញព្រះរាជកិច្ច ដូចដែលទ្រង់បានប្រកាសនៅក្នុងសាលាប្រជុំនៅភូមិណាសារ៉ែត (លក ៤:១៨)។ *ដូចជាព្រាប* ជានិមិត្តរូបនៃភាពស្លូត បរិសុទ្ធ គ្មានទោស (មថ ១០:១៦)។

**១:១១** ខនេះជាការនិយាយទៅដល់បទគម្ពីរ ទដ ២:៧ អស ៤២:១។ សំឡេងព្រះអម្ចាស់ ពេលខ្លះទ្រង់មានបន្ទូលពីស្ថានសួគ៌ដោយផ្ទាល់តែម្តង(៩:៧ យហ១២:២៨,២៩)។ *ឯងជាកូនស្ងួនភ្ងាអញ* ក្នុង ខ.១ លោកម៉ាកុសប្រកាសថា ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ ហើយពេលនេះព្រះវរបិតាទ្រង់ផ្ទាល់ប្រកាសថាព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះ ។

**១:១២** *ស្រាប់តែ* គឺជាលក្ខណៈប្លែកនៃរបៀបប្រើរបស់លោកម៉ាកុស យើងឃើញមានពាក្យនេះចំនួន៤៧ដង បានប្រែមកដូចជា "ភ្លាមៗនោះ(ភ្លាម) ជា១រំពេច" (មើល ខ.១៨,២០,២៣,២៨–២៩,៤២–៤៣)។

**១:១៣** *៤០* មើលការពន្យល់ មថ ៤:២ ។ *ត្រូវល្បួង* "មើលការពន្យល់ មថ ៤:១–១១"។ *អារក្សសាតាំង* មើលការពន្យល់ លប ៣:១ សក ៣:១ វវ ២:៩–១០ ១២:៩–១០។ *សត្វព្រៃ* នៅសម័យព្រះយេស៊ូវ មានសត្វព្រៃច្រើនជាងបច្ចុប្បន្ននេះ ដូចជាសត្វតោជាដើម ។ មានតែលោកម៉ាកុសទេដែលរាយការណ៍ពីសត្វព្រៃទាំងនេះ គាត់បញ្ជាក់ថា ព្រះយេស៊ូវគ្រីស្ទត្រូវបានថែរក្សាយ៉ាងមានសុវត្ថិភាពនៅឯទីរហោស្ថាន ។ *ទេវតាតាមគាល់បំរើទ្រង់* ដូចគ្នានឹងបម្រើអ៊ីស្រាអែលក្នុងទីរហោស្ថាន (នក ២៣:២០,២៣,៣២,៣៤)។

**១:១៤** *គ្រាក្រោយដែលគេបញ្ជូនយ៉ូហាន* តាមព្រះគម្ពីរភាសាក្រិកថា "ក្រោយពីយ៉ូហានត្រូវបានគេចាប់ដាក់គុក" (មថ ៤:១២ និងការពន្យល់ លក ៣:២០)។

**១:១៥** *នគរព្រះ* មើលការពន្យល់ មថ ៣:២ ។ *ជិតមកដល់* សំដៅលើការយាងមករបស់ព្រះគ្រីស្ទ (ជាស្តេច)។

**១:១៦** *សមុទ្រកាលីឡេ* ជាបឹងមួយដ៏ល្អ មានជម្រៅជិត១៧,៥ម៉ែត្រ មានបណ្តោយ ២២,៥ គ.ម និងទទឹង ៩,៦ គ.ម ហូរចាក់បំពេញដោយទឹកទន្លេយ័រដាន់ ហើយមានឈ្មោះពីរទៀតគឺ សមុទ្រគេនេសារ៉ែត (លក ៥:១) និងទីបេរាស (យហ ៦:១ ២១:១)។ នៅសម័យព្រះគម្ពីរសញ្ញាចាស់មានដែរ (ជន ៣៤:១១ ចទ ៣:១៧ យស ១៩:៣៥)។ *ស៊ីម៉ូន* (មើលការពន្យល់ កច ១៥:១៤) ព្រះយេស៊ូវបានប្តូរឈ្មោះ ស៊ីម៉ូនទៅពេត្រុស (៣:១៦ មថ ១៦:១៨ យហ ១:៤២)។ *សំណាញ់* មើលការ ពន្យល់ មថ ៤:១៨ ។

**១:១៧** *ចូរមកតាមខ្ញុំ* ការត្រាស់ហៅមកធ្វើជាសាវ័ក គឺត្រូវមានភាពច្បាស់លាស់ និងទាមទារការឆ្លើយតបដោយការប្តេជ្ញាចិត្តខ្ពស់ ។ នេះមិនមែនជាលើកទីមួយទេ ដែលព្រះយេស៊ូវបានជួបនិងលោកស៊ីម៉ូន និងលោកអនទ្រេ (យហ ១:៣៥–៤២)។ *នេសាទមនុស្ស* គឺសំដៅទៅលើការផ្សាយដំណឹងល្អ (លក ៥:១០)។

**១:២១** *ក្រុងកាពើណិម* មើលការពន្យល់ មថ ៤:១៣ ។ *សាលាប្រជុំ* ជាវិទ្យាស្ថាន ខាងសាសនាដ៏សំខាន់បំផុតមួយ ក្នុងចំណោមសាសនាផ្សេងៗ នៅសម័យនោះ។ បង្កើតឡើងក្នុងអំឡុងពេលនិរទេសសម្រាប់សាសន៍យូដារៀនព្រះបន្ទូល និងថ្វាយបង្គំព្រះ ។ សាលាប្រជុំអាចត្រូវបានគេកសាងនៅកន្លែងណា ដែលមានបុរសសាសន៍យូដាបានរៀបការរួចយ៉ាងតិច១០នាក់ដែរ។ *ចូលទៅបង្រៀន* ព្រះយេស៊ូវ ដូចជាលោកប៉ុលដែរ (កច ១៣:១៥ ១៤:១ ១៧:២ ១៨:៤) ឆ្លៀតឱកាសដែលប្រពៃណីបានអនុញ្ញាតឱ្យ អ្នកដឹកនាំសាលាប្រជុំអាចអញ្ជើញគ្រូផ្សេងៗទៀតចូលរួមថ្វាយបង្គំព្រះ ។

**១:២២** *ប្លែកក្នុងចិត្ត* ជាញឹកញាប់លោកម៉ាកុសបានរៀបរាប់ពីការអស្ចារ្យនៃសេចក្តីបង្រៀន និងលទ្ធផលរបស់ព្រះយេស៊ូវ (២:១២ ៥:២០,៤២ ៦:២,៥១ ៧:៣៧ ១០:២៦ ១១:១៨ ១៥:៥) ឧទាហរណ៍ទាំងនេះជាអំណាចរបស់ព្រះយេស៊ូវ ដែលមានជាប់ជាមួយនូវការអស្ចារ្យក្នុងចិត្ត ។ ទ្រង់មិនបានយកអំណាចចេញពីមនុស្ស ដូចជាគ្រូក្រឹត្យវិន័យធ្វើនោះឡើយ ពីព្រោះអំណាចរបស់ព្រះអម្ចាស់ គឺមកពីព្រះផ្ទាល់តែម្តង។ *ពួកអាចារ្យ* ជាភាសាក្រិកមានន័យថា "គ្រូក្រឹត្យវិន័យ" (មើលការ ពន្យល់ មថ ២:៤)។

**១:២៣** *មនុស្សម្នាក់នៅក្នុងសាលា... ស្រែកឡើង* ជាធម្មតាកាលណាអារក្ស

អារក្សអសោចិ៍ចូល វាស្រែកឡើងថា ២៤ហឹះ តើយើងនិង
ទ្រង់មានហេតុអ្វីនឹងគ្នា នែ ព្រះយេស៊ូវពីភូមិណាសារ៉ែត
អើយ[រ] តើទ្រង់មកបំផ្លាញយើងឬអី[ល] ខ្ញុំស្គាល់ជាក់ហើយ
ថា ទ្រង់ជាព្រះអង្គបរិសុទ្ធនៃព្រះ[វ] ២៥ព្រះយេស៊ូវទ្រង់ក៏
បន្ទោសដល់វាថា ចូរស្ងៀមទៅហើយថយពីមនុស្សនេះ
ចេញ[ស] ២៦កាលអារក្សអសោចិ៍បានជាន់មនុស្សនោះឱ្យ
ប្រកាច់ប្រកិនជាខ្លាំង ហើយស្រែកឡើង នោះវាក៏ចេញ
ទៅ[ហ] ២៧អ្នកទាំងអស់គ្នាក៏នឹកស្ញើចក្នុងចិត្ត ដល់ម៉្លេះ[ឡ]បាន
ជាគេសួរគ្នាថា នេះជាអ្វីអេះ តើសេចក្ដីបង្រៀនបែបថ្មី
យ៉ាងណាហ្ន៎ បានជាលោកបង្គាប់ដល់អារក្សអសោចិ៍
ដោយអំណាច ហើយវាក៏ស្ដាប់បង្គាប់លោកដូច្នេះ ២៨នោះ
ព្រះនាមទ្រង់ក៏ឮល្បីខ្ចរខ្ចាយជា១រំពេចទូទៅ ពេញក្នុង
ក្រវល់ជុំវិញ[អ]នៃស្រុកកាលីឡេ ។

## ព្រះយេស៊ូវប្រោសអ្នកជំងឺ

*១:២៩–៣១ = មថ ៨:១៤,១៥ លក ៤:៣៨,៣៩*

*១:៣២–៣៤ = មថ ៨:១៦,១៧ លក ៤:៤០,៤១*

២៩កាលបានចេញពីសាលាប្រជុំ[ក]មក ក៏ដំរង់ទៅក្នុងផ្ទះ
ស៊ីម៉ូន នឹងអនទ្រេ នាំទាំងយ៉ាកុប ហើយនឹងយ៉ូហានទៅជា
មួយ ៣០ឯម្ដាយក្មេករបស់ស៊ីម៉ូន នាងកំពុងតែដេកគ្រុន គេក៏
ពិតទូលទ្រង់ជា១រំពេច ពីដំណើរនាង ៣១លុះទ្រង់យាងចូល
ទៅ ក៏ចាប់ដៃនាងលើកឡើង[ខ] ស្រាប់តែគ្រុនបាត់អស់ទៅ
រួចនាងខ្វល់ខ្វាយបំរើទាំងអស់គ្នា ៣២ដល់ពេលល្ងាចជា

**១:២៤** រ មថ ២:២៣ លក ២៤:១៩ យហ ១:៤៥,៤៦ កច ៤:១០ ២៤:៥ ល មថ ៨:២៩ វ ទដ ១៦:១០ អស ៤១:១៤,១៦,២០ លក ១:៣៥ យហ ៦:៦៩ កច ៣:១៤ ១យហ ២:២០
**១:២៥** ស ខ.៣៤
**១:២៦** ហ មក ៩:២០
**១:២៧** ឡ មក ១០:២៤,៣២
**១:២៨** អ មថ ៩:២៦
**១:២៩** ក ខ.២១,២៣
**១:៣១** ខ លក ៧:១៤
**១:៣២** គ មថ ៤:២៤
**១:៣៤** ឃ មថ ៤:២៣ ង មក ៣:១២ កច ១៦:១៧,១៨
**១:៣៥** ច លក ៣:២១
**១:៣៨** ឆ អស ៦១:១
**១:៣៩** ជ មថ ៤:២៣ ឈ មថ ៤:២៤
**១:៤០** ញ មក ១០:១៧

ពេលថ្ងៃលិចហើយ គេនាំអស់ទាំងមនុស្សជំងឺ នឹងមនុស្ស
មានអារក្សចូល[គ]មកឯទ្រង់ ៣៣ឯពួកក្រុងនោះទាំងអស់
គេបានប្រជុំគ្នានៅមាត់ទ្វារ ៣៤ទ្រង់ក៏ប្រោសមនុស្សដែល
មានជំងឺឈឺផ្សេងៗជាច្រើន[ឃ] ឱ្យបានជានឹងដេញអារក្សជា
ច្រើនដែរ តែទ្រង់មិនអនុញ្ញាតឱ្យអារក្ស ទាំងនោះនិយាយ
អ្វីសោះ ពីព្រោះវាស្គាល់ទ្រង់[ង] ។

## ព្រះយេស៊ូវអធិស្ឋាននៅទីស្ងាត់

*១:៣៥–៣៨ = លក ៤:៤២,៤៣*

៣៥កាលនៅងងឹតមិនទាន់ភ្លឺស្រាងនៅឡើយ នោះទ្រង់
តើនឡើងយាងចេញទៅឯទីស្ងាត់ ហើយអធិស្ឋាននៅទី
នោះ[ច] ៣៦ឯស៊ីម៉ូន នឹងពួកអ្នកដែលនៅជាមួយ គេក៏ដើរ
តាមរកទ្រង់ ៣៧គ្រាបានឃើញទ្រង់ហើយ នោះក៏ទូលថា
មនុស្សទាំងអស់កំពុងតែរកទ្រង់ ៣៨តែទ្រង់មានបន្ទូល
តបថា ចូរយើងទៅក្នុងអស់ទាំងភូមិជុំវិញ ដើម្បីឱ្យខ្ញុំបាន
ប្រកាសប្រាប់នៅភូមិទាំងនោះដែរ ដ្បិតគឺដោយហេតុនោះ
ហើយ បានជាខ្ញុំមក[ឆ] ៣៩ទ្រង់ក៏ប្រកាសប្រាប់នៅក្នុងអស់
ទាំងសាលាប្រជុំ[ជ]របស់គេ គ្រប់ក្នុងស្រុកកាលីឡេ ព្រមទាំង
ដេញអារក្សផង[ឈ] ។

## មនុស្សកើតជំងឺឃ្លង់ម្នាក់

*១:៤០–៤៤ = មថ ៨:២–៤ លក ៥:១២–១៤*

៤០គ្រានោះ មានមនុស្សឃ្លង់ម្នាក់[ញ] មកឯព្រះយេស៊ូវ លុត
ជង្គង់ទូលអង្វរថា បើទ្រង់សព្វព្រះហឫទ័យ ទ្រង់អាចនឹង

អសោចិ៍សណ្ឋិតនៅក្នុងខ្លួនមនុស្ស នោះវាជាអ្នកស្រែកឡើង មិនមែនមនុស្សស្រែកនោះទេ ។ *អារក្សអសោចិ៍ចូល* គឺវិញ្ញាណអាក្រក់ ដែលមានបំណងធ្វើទារុណកម្ម និងបំផ្លាញ នូវរូបរាងមនុស្សដែលព្រះអម្ចាស់បានបង្កើតមកឱ្យដូចអង្គទ្រង់ ប៉ុន្តែ អារក្សវាបានដឹងថា ព្រះយេស៊ូវគ្រីស្ទគឺជាសត្រូវរបស់វា ដែលមានអំណាចមានព្រះចេស្ដា អាចកម្ទេចកងកម្លាំងនានារបស់ពួកវា (អារក្សសាតាំង) បាន ។

**១:២៤** *ទ្រង់ជាព្រះអង្គបរិសុទ្ធនៃព្រះ* ជាផ្នែកមួយដែលស្របនឹង លក ៤:៣៤ ពាក្យនេះត្រូវបានប្រើតែម្ដងគត់នៅក្នុង យហ ៦:៦៩ ដែលបង្ហាញថាព្រះគ្រីស្ទគឺជាព្រះ (លក ១:៣៥) ។ នាមនេះប្រហែលជាត្រូវបានប្រើដោយអារក្សសាតាំង ដោយផ្អែកលើជំនឿដែលអាថ៌កំបាំងថា កាលណាប្រើឈ្មោះមនុស្សណាម្នាក់ចំៗឈ្មោះ នោះនឹងមានអំណាចមកលើខ្លួន ។ បុរសនេះមានអារក្សអសោចិ៍ចូលលើសពីមួយ (៥:៩) ប៉ុន្តែ មានតែវិញ្ញាណអាក្រក់មួយទេដែលបាននិយាយ ។

**១:២៥** *ចូរស្ងៀមទៅ* មានន័យថាឃ្លុំ ឬបិទមាត់ទៅ បញ្ជាក់ថា ព្រះយេស៊ូវទ្រង់មានអំណាចធ្វើឱ្យមនុស្សដែលអារក្សចូលស្ងប់ស្ងាត់បាន ។

**១:២៧** *ដោយអំណាច* គឺជាអំណាចរបស់ព្រះយេស៊ូវ ដែលបង្ហាញថាទ្រង់ជាព្រះ ដ៏មានព្រះចេស្ដាទាំងក្នុងពេលបង្រៀន (ខ.២២) និងអ្វីដែលទ្រង់បានធ្វើនៅក្នុងហេតុការណ៍នេះ សម្រាប់បញ្ជាក់ដល់ពួកបណ្ដាជន ។

**១:២៩** *ទៅក្នុងផ្ទះស៊ីម៉ូន និងអនទ្រេ* ព្រះយេស៊ូវ និងសាវ័កទ្រង់ប្រហែលជាបរិភោគនៅទីនោះ បន្ទាប់ពីកម្មវិធីនៃបុណ្យឈប់សម្រាកនៅក្នុងព្រះវិហារបានចប់សព្វគ្រប់ ។

**១:៣០** *ម្ដាយក្មេករបស់ស៊ីម៉ូន* នៅក្នុងបទគម្ពីរ "១ កថ ៩:៥" បានប្រាប់ថាលោកពេត្រុសបានរៀបការហើយ ។

**១:៣២** *គេនាំ...មនុស្សជំងឺ* ពួកបណ្ដាជនបានរង់ចាំរហូតដល់ផុតថ្ងៃឈប់សម្រាក (ក្រោយថ្ងៃលិចទៅ) ទើបអាចធ្វើការបាន (យរ ១៧:២១–២២) ។

**១:៣៤** *ពីព្រោះវាស្គាល់ទ្រង់* លោកលូកានិយាយថា "ពីព្រោះពួកគេបានស្គាល់ថាទ្រង់គឺជាព្រះគ្រីស្ទ" (លក ៤:៤១) ។ ប្រហែលជាព្រះយេស៊ូវចង់បង្ហាញជាពាក្យ និងជាសញ្ញាពីប្រភេទនៃព្រះមែស៊ី (មុននឹងទ្រង់មិនចង់ឱ្យបណ្ដាជនយល់ខុសពីទ្រង់) ប្រកាសពីអង្គទ្រង់ ហើយទ្រង់មិនចង់ឱ្យសាតាំងបំផ្លាញបំណងចិត្តនេះផង ។

**១:៣៦** *ពួកអ្នកដែលនៅជាមួយ* គឺមានអនទ្រេ យ៉ាកុប យ៉ូហាន ហើយអាចមានភីលីព និងណាថាណែល (យហ ១:៤៣–៤៥) ។

**១:៣៩** *គ្រប់ក្នុងស្រុកកាលីឡេ* នេះជាដំណើរលើកទីមួយ តែដូចជាលើកទីបីនៅស្រុកកាលីឡេ (លើកទីពីរ លក ៨:១ លើកទីបី មក ៦:៦ និង មថ ១១:១) ។

**១:៤០** *មនុស្សឃ្លង់ម្នាក់* មើលការពន្យល់ លវ ១៣–១៤ ។

ប្រោសឱ្យទូលបង្គំជាស្អាតបាន ៤១ដូច្នេះទ្រង់មានព្រះហឫទ័យ
ក្តួលអាណិត ក៏លូកព្រះហស្តទៅពាល់គាត់ដោយបន្ទូលថា
ខ្ញុំចង់ដែរ ឱ្យជាស្អាតទៅ ៤២លុះទ្រង់មានបន្ទូលហើយ ស្រាប់
តែរោគឃ្លង់ចេញពីគាត់បាត់ទៅហើយគាត់បានជាស្អាត
៤៣ទ្រង់ក៏ឱ្យគាត់ទៅភ្លាម ដោយហាមផ្តាច់ថា ៤៤ចូរប្រយ័ត
កុំប្រាប់អ្វីដល់អ្នកឯណាឱ្យសោះ[ដ] តែត្រូវទៅបង្ហាញខ្លួន
ឱ្យពួកសង្ឃឃើញវិញ[ឋ] ហើយថ្វាយយញ្ញបូជា ដោយព្រោះ
ការដែលខ្លួនបានស្អាត តាមដែលលោកម៉ូសេបាន
បង្គាប់មក[ឌ] ទុកជាទីបន្ទាល់ដល់លោកទាំងនោះ ៤៥ប៉ុន្តែ
ដល់គាត់បានចេញទៅហើយ នោះក៏តាំងប្រកាសប្រាប់គេ
ឯងរាល់គ្នាតែម្តង ហើយផ្សាយដំណឹងនោះសុសសាយទូទៅ
ដល់ម្ល៉េះបានជាទ្រង់យាងចូលទៅក្នុងក្រុង បែបឱ្យគេឃើញ
ពុំបានទៀត គឺទ្រង់គង់នៅតែខាងក្រៅ ត្រង់កន្លែងស្ងាត់[ឍ]
ទាំងប៉ុន្មានវិញ ហើយគេក៏មកឯទ្រង់ពីគ្រប់ទិសទី[ណ] ។

## ព្រះយេស៊ូវប្រោសមនុស្សស្លាប់ដៃស្លាប់ជើង

*២:៣-១២ = មថ ៩:២-៨ លក ៥:១៨-២៦*

**២** ១រំលងពីរបីថ្ងៃក្រោយមក ទ្រង់យាងចូលមកក្នុងក្រុង
កាពើណិមវិញទៀត ហើយគេឮថា ទ្រង់គង់នៅផ្ទះ ២ស្រាប់
តែមានគេប្រជុំគ្នាជាច្រើន[ត] ដល់ម្ល៉េះបានជាគ្មានកន្លែងណា
ទៀតសោះ សូម្បីនៅមាត់ទ្វារក៏គ្មានដែរ ទ្រង់ក៏សំដែងព្រះ
បន្ទូលឱ្យគេស្តាប់ ៣គ្រានោះ មាន៤នាក់សែងមនុស្ស[ថ]ស្លាប់
ដៃស្លាប់ជើងម្នាក់មកឯទ្រង់ ៤តែពុំអាចនឹងចូលទៅជិតទ្រង់
បានឡើយ ដោយព្រោះហ្វូងមនុស្ស បានជាគេបើកដំបូល
ផ្ទះត្រង់កន្លែងដែលទ្រង់គង់នៅ កាលទំលុះរួចហើយ នោះ
ក៏សំរូតគ្រែដែលមនុស្សស្លាប់ដៃស្លាប់ជើងដេកនោះចុះទៅ
៥ព្រះយេស៊ូវក៏ឃើញសេចក្តីជំនឿរបស់អ្នកទាំងនោះ ហើយ
ទ្រង់មានបន្ទូលទៅអ្នកស្លាប់ដៃស្លាប់ជើងថា កូនអើយ
បាបរបស់ឯងបានអត់ទោសឱ្យឯងហើយ[ទ] ៦នៅទីនោះមាន
អាចារ្យខ្លះអង្គុយរិះគិតក្នុងចិត្តថា ៧ហេតុ អ្វីបានជាមនុស្ស
នេះ ពោលពាក្យប្រមាថដល់ព្រះដូច្នេះ ក្រៅពីព្រះតែ១តើ
មានអ្នកណាអាចនឹងអត់ទោសបាបបាន[ធ] ៨តែព្រះយេស៊ូវ
ទ្រង់ជ្រាបក្នុងវិញ្ញាណទ្រង់ជា១រំពេចថា គេរិះគិតក្នុងចិត្ត
យ៉ាងដូច្នោះ ទើបទ្រង់មានបន្ទូលទៅគេថា ហេតុអ្វីបានជា
អ្នករាល់គ្នាមានគំនិតក្នុងចិត្តយ៉ាងដូច្នេះ ៩ដ្បិតដែលនិយាយ
នឹងមនុស្សស្លាប់ដៃស្លាប់ជើងនេះថា បាបឯងបានអត់ទោស
ឱ្យឯងហើយ ឬថា ឱ្យក្រោកឡើងយកគ្រែឯងដើរទៅ នោះ
តើពាក្យណាងាយថាជាជាង ១០ប៉ុន្តែ ដើម្បីឱ្យអ្នករាល់
គ្នាដឹងថា នៅផែនដីនេះ កូនមនុស្ស[ន]មានអំណាចនឹងអត់
ទោសបាបបាន (នោះទ្រង់មានបន្ទូល ទៅមនុស្សស្លាប់ដៃ
ស្លាប់ជើងថា) ១១អញប្រាប់ឱ្យឯងក្រោកឡើង យកគ្រែឯង

**១:៤៤** ដ មថ ៨:៤
ឋ លវ ១៣:៤៩
ឌ លវ ១៤:១-៣២
**១:៤៥** ឍ លក ៥:១៥,១៦
ណ មក ២:១៣
លក ៥:១៧
យហ ៦:២
**២:២** ត ខ.១៣
មក ១:៤៥
**២:៣** ថ មថ ៤:២៤
**២:៥** ទ លក ៧:៤៨
**២:៧** ធ អស ៤៣:២៥
**២:១០** ន មថ ៨:២០

**១:៤១** *លូកព្រហស្តទៅពាល់គាត់* មានន័យថា ព្រះយេស៊ូវបានលូកព្រះហស្ត ប៉ះមនុស្សឃ្លង់ម្នាក់នោះ ជាទង្វើមួយស្របទៅនឹងក្រឹត្យវិន័យលោកម៉ូសេ (លវ ១៣ ជាពិសេស ខ.៤៥-៤៦ លវ ៥:២) ព្រះយេស៊ូវទ្រង់ មានព្រះទ័យក្តួលអាណិតដល់មនុស្សជាជាងយកចិត្តទុកដាក់លើភាពអ៊ូអរនៃពិធីបុណ្យ ។

**១:៤៤** *កុំប្រាប់អ្វីដល់អ្នកណាឱ្យសោះ* មើលការពន្យល់ មថ ៨:៤ ១៦:២០ ។ *ទៅបង្ហាញខ្លួនឱ្យពួកសង្ឃឃើញវិញ* មើលការពន្យល់ លក ៥:១៤ ។ *ទុកជាទីបន្ទាល់ដល់លោកទាំងនោះ* ការថ្វាយយញ្ញបូជាជាភស្តុតាងដល់ពួកសង្ឃ និងបណ្តាជនថាខ្លួនបានជាមែន ហើយទ្រង់ជាព្រះដ៏ពិត (២ពវ ៥:១-១៤) ។

**១:៤៥** *ចូលទៅក្នុងក្រុង បែបឱ្យគេឃើញពុំបានទៀត* ប្រជាប្រិយភាពរបស់ព្រះយេស៊ូវកាន់តែល្បីទៅៗក្នុងពួកបណ្តាជន (១:២៨ ៣:៧-៨ លក ៧:១៧) និងការបដិសេធន៍ពីសំណាក់ពួកអ្នកដឹកនាំសាសន៍យូដាក៏ច្រើនដែរ (២:៦, ៧,១៦,២៣,២៤ ៣:២,៦,២២) នៅចុងបញ្ចប់ ចាំបាច់ធ្វើឱ្យទ្រង់យាងចេញពីស្រុកកាលីឡេទៅ តំបន់ក្បែរនោះវិញ ។

**២:១** *ផ្ទះ* ប្រហែលជាផ្ទះរបស់លោកពេត្រុស (១:២១,២៩) ។

**២:២** *គេប្រជុំគ្នាជាច្រើន* ពួកគេបានទទួលស្វាគមន៍ព្រះយេស៊ូវកាលពីមុន (១:៣២-៣៣,៣៧) និងក្នុងពេលទ្រង់យាងមកម្តងទៀត ។

**២:៣** *មនុស្សស្លាប់ដៃស្លាប់ជើង* គេមិនដឹងអ្វីផ្សេងទៀតក្រៅតែពីការដែលគាត់មិនអាចដើរបាននោះឡើយ ។ ការប្រឹងប្រែងរបស់បុរសទាំងបួននាក់ក្នុងការនាំអ្នកជម្ងឺមកនេះគឺចង់បង្ហាញថា សភាពរបស់ជម្ងឺរបស់គាត់គ្មានសង្ឃឹមទេ គឺមានតែពឹងដល់ព្រះយេស៊ូវប៉ុណ្ណោះ ។

**២:៤** *បើកដំបូលផ្ទះ* ប្រភេទផ្ទះពួកប៉ាឡេស្ទីនមានដំបូលរាបស្មើ ដែលអាចចូលបានដោយដាក់ជណ្តើរពីខាងក្រៅ ។ *ដំបូល* ជាធម្មតាធ្វើពីដីឥដ្ឋក្រាស់ៗ (បង្ហាប់នឹងថ្ម) ដែលទ្រដោយធ្នឹមធ្វើពីឈើ ។

**២:៥** *ព្រះយេស៊ូវក៏ឃើញជំនឿរបស់អ្នកទាំងនោះ* គឺតាមរយៈកាយវិការដ៏ក្លាហានរបស់មនុស្សស្លាប់ដៃស្លាប់ជើង និងមិត្តភក្តិគាត់ គឺជាភស្តុតាងនៃសេចក្តីជំនឿ ។ *កូនអើយ បាបរបស់ឯងបានអត់ទោសឱ្យឯងហើយ* ព្រះយេស៊ូវបានផ្តល់សេចក្តីត្រូវការបំផុតរបស់មនុស្សនេះ គឺការអត់ទោស ។

**២:៧** *ពោលពាក្យប្រមាថដល់ព្រះដូច្នេះ ក្រៅពីព្រះតែ១ តើមានអ្នកណាអាចនឹងអត់ទោសបាបបាន ?* នៅក្នុងទេវសាស្ត្ររបស់ជនជាតិយូដា សូម្បីតែព្រះមែស៊ីក៏ មិនអាចអត់ទោសបាបឱ្យមនុស្សបានដែរ ហើយពេលនេះព្រះយេស៊ូវបានអត់ទោសបាប ក៏ដូចជាប្រកាសថាទ្រង់ជាព្រះ ដែលពួកគេគិតថាទ្រង់បានប្រមាថដល់ព្រះ (មើលការពន្យល់ ១៤:៦៤) ។

**២:៩** *តើពាក្យណាងាយថាជាង?* គឺរវាងការអត់ទោសបាប និងការប្រោសជំងឺឱ្យ ជាមួយណាងាយស្រួលថាជាង ។ ទាំងពីរយ៉ាងនេះ មនុស្សមិនអាចធ្វើកើតទេ តែចំពោះព្រះមិនពិបាកធ្វើឡើយ ។

**២:១០** *ដើម្បីឱ្យអ្នករាល់គ្នាដឹង* គឺសំដៅទៅលើពួកគ្រូក្រឹត្យវិន័យ ។ ទ្រង់មានបន្ទូលទៅកាន់អ្នកស្លាប់ដៃស្លាប់ជើង ជាពាក្យបន្ទាប់បន្សំ ដើម្បីបង្ហាញនូវការផ្លាស់ប្រែរបស់អ្នកនោះ ។ *កូនមនុស្ស* មើលការពន្យល់ ៨:៣១ ។ ការ

ដើរទៅផ្ទះទៅ ១២គាត់ក៏ក្រោកឡើងភ្លាម យកគ្រែចេញ
ទៅ នៅមុខអ្នកទាំងអស់គ្នា បានជាគ្រប់គ្នាមានសេចក្ដី
អស្ចារ្យ ហើយពណ៌នាសរសើរដំកើងដល់ព្រះ[ប]ដោយពាក្យ
ថា យើងមិនដែលឃើញយ៉ាងដូច្នេះឡើយ[ផ]។

## ការត្រាស់ហៅលោកលេវី

*២:១៤-១៧ = មថ ៩:៩-១៣ លក ៥:២៧-៣២*

១៣ទ្រង់យាងចេញទៅតាមឆ្នេរសមុទ្រម្ដងទៀត ឯហ្វូង
មនុស្សទាំងអស់ ក៏មកឯទ្រង់[ព] ហើយទ្រង់បង្រៀនគេ ១៤លុះ
ទ្រង់យាងហួសពីនោះទៅ ក៏ទតឃើញលេវី ជាកូនអាល់
ផាយ អង្គុយនៅត្រង់កន្លែងយកពន្ធ រួចមានបន្ទូលទៅគាត់
ថា ចូរមកតាមខ្ញុំ[ភ] នោះគាត់ក៏ក្រោកឡើងដើរតាមទ្រង់
១៥កាលព្រះយេស៊ូវទ្រង់គង់នៅតុក្នុងផ្ទះគាត់ នោះមាន
មនុស្សយកពន្ធ និងមនុស្សបាបជាច្រើន មកអង្គុយនៅតុជា
មួយនឹងទ្រង់ ហើយនឹងពួកសិស្ស ដ្បិតមានគ្នាច្រើនណាស់
ដែលតាមទ្រង់មក ១៦ឯពួកអាចារ្យ និងពួកផារិស៊ី[ម] កាលគេ
ឃើញទ្រង់សោយជាមួយនឹងពួកអ្នកយកពន្ធ និងមនុស្សមាន
បាបដូច្នេះ ក៏សួរពួកសិស្សទ្រង់ថា ហេតុអ្វីបានជាលោក
បរិភោគជាមួយនឹងពួកអ្នកយកពន្ធ ហើយនិងមនុស្សមាន
បាបដូច្នេះ[យ] ១៧លុះព្រះយេស៊ូវបានឮ នោះទ្រង់មានបន្ទូល
ថា ពួកអ្នកដែលជាសុខសប្បាយ គេមិនត្រូវការនឹង
គ្រូពេទ្យទេ គឺជាមនុស្សដែលមានជំងឺវិញទេតើ ខ្ញុំមិនបាន
មក ដើម្បីហៅមនុស្សសុចរិតទេ គឺមកហៅតែមនុស្ស
មានបាបប៉ុណ្ណោះ ដើម្បីឱ្យគេប្រែចិត្តឡើង[រ]។

## ព្រះយេស៊ូវពន្យល់អំពីការតម

*២:១៨-២២ = មថ ៩:១៤-១៧ លក ៥:៣៣-៣៨*

១៨រីឯពួកសិស្សយ៉ូហាន នឹងពួកផារិស៊ី គេកំពុងតែតម[ល]
ក៏មកទូលសួរទ្រង់ថា ហេតុអ្វីបានជាសិស្សរបស់យ៉ូហាន
នឹងសិស្សពួកផារិស៊ីគេតម តែពួកសិស្សរបស់លោកមិនតម
សោះ ១៩ព្រះយេស៊ូវទ្រង់មានបន្ទូលតបថា កំពុងដែលប្ដី
ថ្មោងថ្មីនៅជាមួយគ្នា តើពួកសំឡាញ់គាត់នឹងតមអាហារបានឬ

**២:១២** ប មថ ៩:៨
ផ មថ ៩:៣៣
**២:១៣** ព មក ១:៤៥
លក ៥:១៥
យហ ៦:២
**២:១៤** ភ មថ ៤:១៩
**២:១៦** ម កច ២៣:៩
យ មថ ៩:១១
**២:១៧** រ លក
១៩:១០ ១ធថ ១:១៥
**២:១៨** ល មថ
៦:១៦-១៨
កច ១៣:២

អស្ចារ្យបង្ហាញថា ព្រះយេស៊ូវគឺជាព្រះ (យហ ២:១១ ២០:៣០,៣១)។

**២:១២** *គ្រប់គ្នាមានសេចក្ដីអស្ចារ្យ* មើលការពន្យល់ ១:២២ ។

**២:១៤** *លេវី ជាកូនអាល់ផាយ* លោកម៉ាថាយ (មថ ៩:៩ ១០:៣) មានឈ្មោះមួយទៀតថា លេវី ។ ឈ្មោះ"ម៉ាថាយ" មានន័យថា "អំណោយរបស់ព្រះអម្ចាស់"។ *អង្គុយនៅត្រង់កន្លែងយកពន្ធ* ព្រោះលេវីជាអ្នកយកពន្ធ (ពន្យល់ លក ៣:១២) នៅក្រោមអំណាចស្ដេចហេរ៉ូឌ អាន់ទីប៉ាស-អនុរាជ នៃស្រុកកាលីឡេ ។ ព្រះយេស៊ូវបានទតឃើញលោកលេវីប្រហែលជានៅកន្លែងច្រកបង់ពន្ធដែលមានផ្លូវអន្តរជាតិដ៏សំខាន់មួយឆ្លងកាត់តាមពីពីដាណាប៉ាសកាត់ក្រុងកាពើណិម ទៅឆ្នេរសមុទ្រមេឌីទែរ៉ាណេ និងប្រទេសអេស៊ីព្ទ (អស ៩:១)"តាមផ្លូវសមុទ្រ"។ *លេវីក្រោកឡើង ហើយដើរតាមទ្រង់* មើលការពន្យល់ លក ៥:២៨ ។

**២:១៥** *មនុស្សបាប* ជាពួកដែលល្បីខាងការអាក្រក់ ក៏ដូចជាពួកមិនស្ដាប់តាមក្រឹត្យវិន័យរបស់លោកម៉ូសេផងដែរ ។ ជាធម្មតាពាក្យនេះសំដៅលើពួកយកពន្ធ ពួកផិតក្បត់ និងពួកចោរជាដើម ។ *មកអង្គុយនៅតុជាមួយ* គឺកំពុងតែបរិភោគជាមួយគ្នា ដែលជានិមិត្តរូបនៃមិត្តភាព ។

**២:១៦** *ពួកអាចារ្យ និងពួកផារិស៊ី* មិនមែនគ្រប់គ្នាសុទ្ធតែពួកផារិស៊ីនោះទេ ដោយពួកនេះបានចូលរួមជាកម្លាំងជាមួយពួកម៉ាកាប៊ី (maccabees) ក្នុងអំឡុងពេលតស៊ូរំដោះជាតិពីពួកស៊ីរី (១៦៦-១៤២ មុនគ.ស)។ ពួកនេះលេចចេញមុនដំបូងក្រោមឈ្មោះថា ផារិស៊ី ក្នុងរជ្ជកាលនៃស្ដេចយ៉ូហាន-ហ៊ីកាណូស (១៣៥-១០៥ មុនគ.ស) ពួកជឿលើសាសនាយូដា ហើយចូលរួមនឹងពួករ៉ូម៉ាំងប្រឆាំងនឹងពួកស៊ីរី ។ ពួកនេះភាគច្រើនប្រឆាំងនឹងព្រះយេស៊ូវ ពួកមានពុត ច្រណែនតឹងរឹង និងនិយមជ្រុល ។ យោងតាមការនិយមរបស់ពួកផារិស៊ី ព្រះគុណរបស់ព្រះបាន សាយភាយដល់តែអស់អ្នកណាដែលកាន់ តាមក្រឹត្យវិន័យរបស់ទ្រង់ប៉ុណ្ណោះ (មើលការពន្យល់ មថ ៣:៧ លក ៥:១៧)។ *អ្នកយកពន្ធ* អ្នកយកពន្ធជនជាតិយូដាត្រូវបានគេចាត់ទុកដូចជា មនុស្សក្រៅសង្គម ។ ពួកគេមិនអាចធ្វើជាទីបន្ទាល់ ឬជាចៅក្រមបានទេ ហើយត្រូវបានគេបណ្ដេញចេញពីសាលាប្រជុំ (ព្រះវិហារ) ទៀតផង។ នៅក្នុងកែវភ្នែករបស់សហគមន៍យូដា កេរ្ដិ៍ឈ្មោះអាក្រក់របស់ពួកនេះ (អ្នកយកពន្ធ) បានរាលដាលដល់គ្រួសារគេទៀតផង (មើលការពន្យល់ មថ ៥:៤៦)។

**២:១៧** *ខ្ញុំមិនបានមក ដើម្បីហៅមនុស្សសុចរិតទេគឺមកហៅតែមនុស្សមានបាប* មនុស្សដែលថាខ្លួនសុចរិតពុំត្រូវការសេចក្ដីសង្គ្រោះទេ លុះណាតែគេព្រមទទួលថា ខ្លួនមានបាប ។

**២:១៨** *ពួកសិស្សយ៉ូហាន* សិស្សយ៉ូហាន-បាទីស្ទកំពុងតែតមពេលនេះ អាចមកពីយ៉ូហានកំពុងជាប់គុក (១:១៤) ឬជាការអនុវត្តន៍ក្នុងចំណោមពួកគេ ដើម្បីបញ្ជាក់អំពីការប្រែចិត្ត ដោយមានបំណងឱ្យការប្រោសលោះដែលប្រកាសដោយ លោកយ៉ូហាននោះបានឆាប់មកដល់ ។ *សិស្សពួកផារិស៊ី* តាមពិតពួកផារិស៊ី មិនមែនជាគ្រូបង្រៀននោះទេ តែមានខ្លះជាអ្នកនិពន្ធ "ពួកគ្រូក្រឹត្យវិន័យ" ដែលមានសិស្ស ឬប្រហែលមកពីការប្រើឃ្លាដោយគ្មានបច្ចេកទេស ដែលគ្រាន់តែទាក់ទងទៅនឹងមនុស្សខ្លះ ដែលនៅក្រោមឥទ្ធិពលពួកផារិស៊ីតែប៉ុណ្ណោះ ។ *តម* តាមក្រឹត្យវិន័យរបស់លោកម៉ូសេ គឺតម្រូវឱ្យតមនៅក្នុងតែថ្ងៃនៃការលន់តួកំហុសប៉ុណ្ណោះ (លវ ១៦:២៩,៣១ ២៣:២៧-៣២ ជន ២៩:៧)។ ក្រោយពីបាប៊ីឡូនធ្វើនិរទេសមក សាសន៍យូដាបានតម៤ឆ្នាំជាប់ៗគ្នា (សក ៧:៥ ៨:១៩)។ ក្នុងសម័យព្រះយេស៊ូវ ពួកផារិស៊ីបានតមពីរដងក្នុងមួយសប្ដាហ៍ (លក ១៨:១២)។

**២:១៩** *តើពួកសំឡាញ់គាត់នឹងតមអាហារបានឬទេ កាលប្ដីនៅជាមួយនៅឡើយ* ព្រះយេស៊ូវបានប្រៀបធៀបពួកសិស្សរបស់ទ្រង់ ទៅនឹងភ្ញៀវនៃប្ដីថ្មោងថ្មីម្នាក់ ។ អាពាហ៍ពិពាហ៍របស់សាសន៍យូដា គឺជាឱកាសរីករាយយ៉ាងពិសេសមួយ ហើយជាធម្មតាមានភ្ញៀវចូលរួមពិធីនេះរហូតដល់មួយសប្ដាហ៍ឯណោះ ។ វាមិនអាចមានទេថាមនុស្សត្រូវតមក្នុងពិធីដូច្នេះឡើយ

ទេ កាលប្ដីនៅជាមួយនៅឡើយ នោះតមអាហារពុំបាន
ទេ [២០]តែនឹងមានថ្ងៃមកដល់ ដែលប្ដីនឹងត្រូវយកចេញពីពួក
មិត្រសំឡាញ់[រ]ទៅ នៅគ្រានោះគេនឹងតមវិញ [២១]គ្មានអ្នក
ណាដែលយកកំណាត់សំពត់ថ្មី មកប៉ះអាវចាស់ទេ បើ
ធ្វើដូច្នោះ កំណាត់សំពត់ថ្មីនឹងហែកអាវចាស់ ធ្វើឱ្យ
រហែកនោះរឹងរឹតតែអាក្រក់ជាងទៅទៀត [២២]ក៏គ្មានអ្នក
ណាយកស្រាទំពាំងបាយជូរថ្មី ដាក់ក្នុងថង់ស្បែកចាស់ដែរ
បើធ្វើដូច្នោះ ស្រាទំពាំងបាយជូរថ្មីនឹងទំលាយថង់ស្បែក
ហូរចេញអស់ហើយ ឯថង់ស្បែកក៏ត្រូវខូចខាតដែរ តោង
តែដាក់ស្រាទំពាំងបាយជូរថ្មីក្នុងថង់ស្បែកថ្មីវិញ។

## ព្រះអម្ចាស់នៃថ្ងៃឈប់សម្រាក

*២:២៣–២៨ = មថ ១២:១–៨ លក ៦:១–៥*

*៣:១–៦ = មថ ១២:៩–១៤ លក ៦:៦–១១*

[២៣]មានកាល១ថ្ងៃ ជាថ្ងៃឈប់សំរាក ទ្រង់បានយាងកាត់
ស្រែ ហើយពួកសិស្សទ្រង់តាំងចាប់បូតគួរស្រូវ[ស]បណ្ដើរ
[២៤]ពួកផារិស៊ីទូលទ្រង់ថា មើល ហេតុអ្វីបានជាគេធ្វើការ
ដែលគ្មានច្បាប់ធ្វើ នៅថ្ងៃឈប់សំរាកដូច្នេះ[ហ] [២៥]ទ្រង់មាន
បន្ទូលថា តើអ្នករាល់គ្នាមិនដែលមើលរឿងពីការដែល
ហ្លួងដាវីឌទ្រង់ធ្វើ ព្រមទាំងពួកអ្នកនៅជាមួយផង ក្នុងកាល
ដែលគេត្រូវការ ហើយឃ្លានទេឬអី [២៦]គឺដែលទ្រង់បាន
យាងចូលទៅក្នុងដំណាក់ព្រះ នៅក្នុងជាន់ដែលអ័បៀថើរ
ធ្វើជាសម្ដេចសង្ឃ[ឡ] ហើយបានសោយនំបុ័ងតាំងទុក ទាំង
ចែកឱ្យពួកអ្នកដែលនៅជាមួយផង[អ] ដែលគ្មានច្បាប់ឱ្យ
ទ្រង់សោយសោះ ជារបស់ទុកសំរាប់តែពួកសង្ឃប៉ុណ្ណោះ[ក]
[២៧]រួចទ្រង់មានបន្ទូលទៅពួកផារិស៊ីថា ថ្ងៃឈប់សំរាក
បានតាំងសំរាប់ឱ្យមនុស្ស[ខ] មិនមែនជាមនុស្សសំរាប់ថ្ងៃ
ឈប់សំរាកទេ[គ] [២៨]ដូច្នេះ កូនមនុស្ស[ឃ]ជាម្ចាស់នៃថ្ងៃឈប់
សំរាកដែរ។

**៣** [១]ទ្រង់ក៏យាងចូលទៅក្នុងសាលាប្រជុំ[ង]ម្ដងទៀត នៅទី
នោះ មានមនុស្សម្នាក់ស្វិតដៃម្ខាង [២]គេក៏ចាំមើល[ច]ទ្រង់
ក្រែងនឹងប្រោសឱ្យគាត់ជានៅថ្ងៃឈប់សំរាក[ឆ] ដើម្បីឱ្យ
បាន រឿងចោទប្រកាន់ទ្រង់ [៣]ទ្រង់មានបន្ទូលទៅមនុស្ស
ស្វិតដៃ ថា ចូរអ្នកក្រោកឡើង ឈរនៅកណ្ដាលនុ៎ះទៅ
[៤]រួចទ្រង់សួរគេថា នៅថ្ងៃឈប់សំរាក តើបើកឱ្យធ្វើការ
ល្អ ឬឱ្យធ្វើការអាក្រក់ ឱ្យសង្គ្រោះជីវិត ឬឱ្យសំឡាប់បង់
ប៉ុន្តែគេនៅតែស្ងៀម [៥]នោះទ្រង់ងាកទតទៅគេទាំងគ្នាន់

**២:២០** រ លក ១៧:២២
**២:២៣** ស ចទ ២៣:២៥
**២:២៤** ហ មថ ១២:២
**២:២៦** ឡ ១រប ២៤:៦ ២សយ ៨:១៧ លវ ២៤:៥–៩ អ ១សយ ២១:១–៦ ក លវ ២៤:៥–៩
**២:២៧** ខ នក ២៣:១២ ចទ ៥:១៤ គ កល ២:១៦
**២:២៨** ឃ មថ ៨:២០
**៣:១** ង មថ ៤:២៣ មក ១:២១
**៣:២** ច មថ ១២:១០ ឆ លក ១៤:១

ពីព្រោះតមគឺធ្វើឡើងនៅក្នុងពិធីកាន់ទុក្ខតែប៉ុណ្ណោះ ។

**២:២០** *ប្ដីនឹងត្រូវយកចេញពីពួកមិត្តសំឡាញ់* ប្ដីសំដៅលើកូនកំលោះក្នុងថ្ងៃរៀបការ ព្រះយេស៊ូវគឺជាប្ដីដែលនឹងត្រូវយកចេញ ដោយការសុគត ពេលនោះការតមនឹងត្រូវមកដល់ ។

**២:២២** *ថង់ស្បែកថ្មី* មើលការពន្យល់ មថ ៩:១៧ ។

**២:២៣** *ចាប់បូតគួរស្រូវ* ការបរិភោគនោះ គឺមិនខុសទេ (ចទ ២៣:២៥)។

**២:២៤** *ហេតុអ្វីបានជាគេធ្វើការដែលគ្មានច្បាប់ធ្វើ* យោងតាមប្រពៃណីសាសន៍យូដា (អ្វីដែលសិស្សព្រះយេស៊ូវធ្វើនោះ) ត្រូវហាមឃាត់ក្នុងថ្ងៃឈប់សម្រាក (នក ៣៤:២១)។

**២:២៥** *ការដែលហ្លួងដាវីឌទ្រង់ធ្វើ* ១សយ ២១:១–៦ មានទំនាក់ទំនងគ្នាមួយទៅនឹងហេតុការណ៍ក្នុងគម្ពីរសញ្ញាចាស់ ដែលនិយាយអំពីថ្ងៃឈប់សម្រាក ដោយមនុស្សសំណព្វនៃព្រះបានធ្វើការ នៅថ្ងៃដែលគេហាមឃាត់។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ស្ដេចដាវីឌ និងសិស្សព្រះយេស៊ូវមានច្បាប់ធ្វើល្អ និងសង្គ្រោះជីវិតនៅថ្ងៃឈប់សម្រាកដែរ (អស ៥៨:៦–៧ លក ៦:៦–១១ ១៣:១០–១៧ ១៤:១–៦)។

**២:២៦** *ក្នុងជាន់ដែលអ័បៀថើរជាសំដេចសង្ឃ* បើតាមបទគម្ពីរ សយ ២១:១ អាម៉ាលេចជាឪពុកអ័បៀថើរ ដែលបានធ្វើជាសម្ដេចសង្ឃ (មើលពន្យល់ ២សយ ៨:១៧)។ *នំបុ័ងតាំងទុក* នំបុ័ងសម្រាប់ថ្វាយព្រះអម្ចាស់(មថ១២:៤ និងពន្យល់)។

**២:២៧** *ថ្ងៃឈប់សំរាកបានតាំងសំរាប់ឱ្យមនុស្ស មិនមែនជាមនុស្សសំរាប់ថ្ងៃឈប់សម្រាកទេ* ប្រពៃណីសាសន៍យូដាបានតម្រូវ និងបម្រាមជាច្រើនសម្រាប់អនុវត្តនៅក្នុងថ្ងៃឈប់សម្រាកដែលពុំអាចអត់ទ្រាំបាន ។ ព្រះយេស៊ូវបានផ្ដាច់ ចំណងនៃទំនៀមទម្លាប់ទាំងនោះចោល ហើយបញ្ជាក់ថា ថ្ងៃឈប់សម្រាកគឺទុកសម្រាប់មនុស្ស (សម្រាកខាងឯវិញ្ញាណ ខាងខួរក្បាល និងខាងរូបកាយ នក ២០:៨–១១)។

**២:២៨** មើលការពន្យល់ លក ៦:៥ ។

**៣:១–៦** បង្ហាញថា ព្រះយេស៊ូវគឺជាព្រះអម្ចាស់នៃថ្ងៃឈប់សម្រាក(២:២៨)

**៣:២** *គេ* សំដៅលើពួកផារិស៊ី (ខ.៦ និង លក ៦:៧)។ *ចោទប្រកាន់ទ្រង់* ព្រះវត្តមានរបស់ព្រះយេស៊ូវ បានទាមទារនូវការសម្រេចចិត្តក្នុងសេចក្ដីអធិប្បាយអំពីសកម្មភាព និងភាពជាមនុស្សរបស់ទ្រង់ ។ ទំនាស់បានឃើញលើកដំបូងនៅក្នុង ២:៦–៧ នឹងបន្តរាលដាលតទៅទៀតនៅក្នុងខនេះ (មើលការពន្យល់ ខ.៦)។ *គេក៏ចាំមើលទ្រង់* ក្រែងនឹងប្រោសឱ្យគាត់ជានៅថ្ងៃឈប់សម្រាក នេះជាការបង្ហាញ ថាពួកផារិស៊ីបានជឿលើអំណាចរបស់ព្រះយេស៊ូវថា ទ្រង់អាចសំដែងការអស្ចារ្យ បាន ។ សំណួរ មិនមែនថា "តើទ្រង់...?" តែថា "ក្រែងទ្រង់...?" ប្រពៃណីសាសន៍ យូដាបានដាក់បញ្ញត្តិថា ការព្យាបាលជំងឺមានតែក្នុងករណីធ្ងន់ធ្ងរខ្លាំង ដែលអាចគ្រោះថ្នាក់ដល់ជីវិតតែប៉ុណ្ណោះ មិនមែនដូចក្នុងករណីនេះឡើយ (មើលការពន្យល់ ២:២៥ លក ១៣:១៤)។

**៣:៤** *ធ្វើការល្អ ឬឱ្យធ្វើការអាក្រក់ ឱ្យសង្គ្រោះជីវិត ឬឱ្យសំឡាប់?* ព្រះយេស៊ូវទ្រង់សួរ តើមួយណាល្អ ជាងសម្រាប់មនុស្ស ប្រោសឱ្យជា ឬទុកឱ្យវេទនាដល់ស្លាប់? សំណួរនេះ គឺជាការចំអកដល់ពួកផារិស៊ី ដែលកំពុងតែមានគម្រោងធ្វើគុតព្រះអង្គ តែទ្រង់បានរៀបចំស្រេចហើយថានឹងប្រោសជំងឺ ។ វាជាក់ស្ដែងណាស់ ដែលបង្ហាញថា អ្នកណាដែលធ្វើខុសក្នុងថ្ងៃឈប់សម្រាកនេះ ។ *គេនៅតែស្ងៀម* មើលការពន្យល់ ១២:៣៤ ។

ក្នាញ់ ដោយមានព្រះហឫទ័យព្រួយ ព្រោះចិត្តគេរឹងរូស
ក៏មានបន្ទូលទៅមនុស្សនោះថា ចូរអ្នកលាតដៃទៅ អ្នក
នោះក៏លាត ហើយដៃគាត់បានជាដូចម្ខាង ៦រួចកាលពួក
ផារិស៊ីបានចេញផុតទៅ នោះស្រាប់តែគេពិគ្រោះនឹងពួក
ហេរ៉ូឌ[ជ]ទាស់នឹងទ្រង់ ដើម្បីរករឿងធ្វើឱ្យទ្រង់វិនាស[ឈ]។

## ហ្វូងមនុស្សដើរតាមព្រះយេស៊ូវ

*៣:៧–១២ = មថ ១២:១៥,១៦ លក ៦:១៧–១៩*

៧នោះព្រះយេស៊ូវ ទ្រង់ថយទៅឯសមុទ្រ ជាមួយនឹងពួក
សិស្ស ហើយមានហ្វូងមនុស្សកកកុញ ដើរតាមទ្រង់ ជាមនុស្ស
ពីស្រុកកាលីឡេ នឹងស្រុកយូដា[ញ] ៨ពីក្រុងយេរូសាឡិម នឹង
ស្រុកអេដុំម ហើយពីខាងនាយទន្លេយ័រដាន់ នឹងស្រុកនៅ
ជុំវិញក្រុងទីរ៉ុស នឹងស៊ីដូន គឺជាហ្វូងមនុស្សយ៉ាងធំ ដែលមូល
មកឯទ្រង់ ដោយបានឮនិយាយពីការ ទ្រង់ធ្វើទាំងប៉ុន្មាន[ដ]
៩ទ្រង់មានបន្ទូលប្រាប់ពួកសិស្ស ឱ្យមានទូកនៅរង់ចាំ ក្រែង
ហ្វូងមនុស្សប្រជ្រៀតទ្រង់ ១០ដ្បិតទ្រង់កំពុងប្រោសមនុស្សជា
ច្រើនឱ្យបានជា[ឋ] ដល់ម៉្លេះបានជាមនុស្សទាំងអស់ដែលមាន
ជំងឺអ្វីៗ គេប្រឹងរុលចូលទៅដើម្បីនឹងពាល់ទ្រង់[ឌ] ១១កាល
ណាពួកអារក្សអសោចិ៍ឃើញទ្រង់ វាក៏ក្រាបចំពោះទ្រង់
ទាំងស្រែកថា ទ្រង់ជាព្រះរាជបុត្រានៃព្រះមែន[ឍ] ១២ប៉ុន្តែ
ទ្រង់ហាមផ្តាច់ មិនឱ្យវាធ្វើឱ្យគេស្គាល់ទ្រង់ឡើយ[ណ] ។

## ការតែងតាំងសាវ័កទាំង១២នាក់

*៣:១៦–១៩ = មថ ១០:២–៤ លក ៦:១៤–១៦ កច ១:១៣*

១៣ទ្រង់ក៏យាងឡើងទៅលើភ្នំ រួចមានបន្ទូលហៅអស់អ្នក
ដែលទ្រង់សព្វព្រះហឫទ័យចង់ហៅ ហើយអ្នកទាំងនោះក៏
ចូលមកឯទ្រង់[ត] ១៤រួចទ្រង់ដំរូវ១២នាក់[ថ] ឱ្យបាននៅជាមួយ
នឹងទ្រង់ ដើម្បីទ្រង់បានចាត់គេ ឱ្យចេញទៅប្រកាសប្រដៅ
១៥នឹងឱ្យគេមានអំណាចអាចនឹងប្រោសជំងឺឱ្យជា ព្រមទាំង
ដេញអារក្សផង[ទ] ១៦គឺស៊ីម៉ូន១ដែលទ្រង់ប្រទានឱ្យមានឈ្មោះ
ថាពេត្រុស ថែមទៀត[ធ] ១៧ហើយយ៉ាកុប ជាកូនសេបេដេ១
នឹងយ៉ូហាន ជាប្អូនយ៉ាកុប១ ដែលទ្រង់ប្រទានឈ្មោះ
បោនអើកេ ដល់អ្នកទាំង២នោះ គឺស្រាយថាជាកូនផ្គរលាន់
១៨នឹងអនទ្រេ១ ភីលីព១ បារថូល៉ូមេ១ ម៉ាថាយ១ ថូម៉ាស១
នឹងយ៉ាកុប ជាកូនអាល់ផាយ១ ថាដេ១ ស៊ីម៉ូន ជាសាសន៍
កាណាន១ ១៩ហើយយូដាស–អ៊ីស្ការីយ៉ុត ជាអ្នកដែលបញ្ជូន
ទ្រង់១ ។

**៣:៦** ជ មថ ២២:១៦ មក ១២:១៣ ឈ មថ ១២:១៤
**៣:៧** ញ មថ ៤:២៥
**៣:៨** ដ មថ ១១:២១
**៣:១០** ឋ មថ ៤:២៣ ឌ មថ ៩:២០
**៣:១១** ឍ មថ ៤:៣ មក ១:២៣,២៤
**៣:១២** ណ មថ ៨:៤ មក ១:២៤,២៥,៣៤ កច ១៦:១៧,១៨
**៣:១៣** ត មថ ៥:១
**៣:១៤** ថ មក ៦:៣០
**៣:១៥** ទ មថ ១០:១
**៣:១៦** ធ យហ ១:៤២

**៣:៦** *ពួកផារិស៊ី . . . ពិគ្រោះ* ការសម្រេចចិត្តដើម្បីធ្វើគុតព្រះយេស៊ូវ មិនមែនមានរឿងតែមួយនេះទេ គឺមានរឿងជាច្រើនកន្លងមកហើយ (២:៦–៧,១៦–១៧,២៤)។ ការពិគ្រោះរបស់ពួកផារិស៊ី និងពួកស្តេចហេរ៉ូឌត្រូវបានឃើញម្តងទៀត នៅថ្ងៃអង្គារនៃសប្តាហ៍រងទុក្ខ (១២:១៣)។ *ពួកហេរ៉ូឌ* ជារាជវង្សស្តេចយូដា ដែលមានឥទ្ធិពលមួយក្រុម ដោយមានការគាំទ្រពីពួករ៉ូម៉ាំង ។ ពួកនេះចូលរួមជា មួយពួកផារិស៊ី ដើម្បីប្រឆាំងនឹងព្រះយេស៊ូវ ពីព្រោះពួកគេខ្លាចបាត់បង់ឥទ្ធិពល នយោបាយរបស់ខ្លួនលើប្រជាជន (មើលការពន្យល់ មថ ២២:១៥–១៧)។

📖 ខនេះមានន័យថា "រួចហើយពួកផារិស៊ីក៏បានចេញទៅពិគ្រោះគ្នាជាមួយនឹងពួកហេរ៉ូឌភ្លាមមួយរំពេច ដើម្បីរកមធ្យោបាយធ្វើគុតព្រះយេស៊ូវ"។

**៣:៨** ក្នុងខនេះ បានបញ្ជាក់អំពីប្រជាប្រិយភាពរបស់ព្រះយេស៊ូវកាន់តែខ្លាំងឡើងក្នុងចំណោមប្រជាជន ។ តាមបញ្ជីនៃភូមិសាស្ត្របានឱ្យដឹងថាហ្វូងបណ្តាជនមិន គ្រាន់តែមកពីតំបន់ជិតៗក្រុងកាពើណិមនោះទេ គឺមកពីទីឆ្ងាយៗផងដែរ ។ តំបន់ទាំងនោះបានប្រាប់យ៉ាងច្បាស់ ស្ទើរតែទាំងអស់នៃប្រទេសអ៊ីស្រាអែល និងតំបន់ជិតខាងជុំវិញ ។ លោកម៉ាកុសបានប្រាប់ពីព្រះរាជកិច្ចដែលព្រះយេស៊ូវបានធ្វើក្នុងតំបន់ទាំងនេះផងដែរ លើកលែងតែស្រុកអេដុំមប៉ុណ្ណោះ (១:១៤ កាលីឡេ ៥:១ ១០:១ តំបន់ត្រើយខាងនាយទន្លេយ័រដាន់ ៧:២៤,៣១ ទីរ៉ុស និងស៊ីដូន ១០:១ ស្រុកយូដា ១១:១១ ក្រុងយេរូសាឡិម)។ *អេដុំម* នៅទីនេះគឺសំដៅលើតំបន់មួយ នៅក្នុងប្រទេសប៉ាឡេស្ទីនភាគខាងលិចនៅខាងត្បូងស្រុកយូដា ។

**៣:១១** *ពួកអារក្សអសោចិ៍* មើលការពន្យល់ ១:២៣ ។ *ទ្រង់ជាព្រះរាជបុត្រានៃព្រះ* វិញ្ញាណអាក្រក់ ពួកអារក្សអសោចិ៍បានស្គាល់ថាព្រះយេស៊ូវទ្រង់ជានរណា តែមិនទទួលជឿទ្រង់សោះឡើយ (មើលការពន្យល់ ១:២៤)។

**៣:១២** *មិនឱ្យវាធ្វើឱ្យគេស្គាល់ទ្រង់ឡើយ* ពេលនៃការបើកសំដែងពីព្រះយេស៊ូវមិនទាន់មកដល់នៅឡើយ (មើលការពន្យល់ ១:៣៤ មថ ៨:៤ ១៦:២០) អារក្សជាអ្នកបង្កើតព័ត៌មាន និងដំណឹងមិនពិត ។

📖 ខនេះមានន័យថា "ប៉ុន្តែទ្រង់ហាមផ្តាច់មិនឱ្យវាប្រាប់គេថាទ្រង់ជានរណាឡើយ"។

**៣:១៤** *ដំរូវ១២នាក់* គឺតែងតាំងឱ្យធ្វើជាសាវ័ក (មើលការពន្យល់ ៦:៣០)។ *ឱ្យបាននៅជាមួយទ្រង់* ការបង្វឹកសាវ័កទាំង១២នាក់ មិនគ្រាន់តែបង្រៀនជំនាញ អនុវត្តន៍ផ្ទាល់ប៉ុណ្ណោះទេ គឺថែមទាំងបន្តការរួមរស់ និងប្រកបគ្នាយ៉ាងស្និទ្ធស្នាលជាមួយអង្គទ្រង់ដោយផ្ទាល់ទៀតផង ។

📖 ខនេះមានន័យថា "ទ្រង់តម្រូវ១២នាក់ដើម្បីតែងតាំងឱ្យធ្វើជាសាវ័ក ហើយពួកគេនឹងនៅជាមួយទ្រង់ ដើម្បីទ្រង់ចាត់គេឱ្យចេញទៅប្រកាសដំណឹងល្អ"។

**៣:១៦–១៩** មើលការពន្យល់ លក ៦:១៤–១៦ ។

**៣:១៧** *ជាកូនផ្គរលាន់* ប្រហែលជាការពិពណ៌នាពីចរិតរបស់ពួកគេ (មើលការពន្យល់ ១០:៣៧ លក ៩:៥៤–៥៥)។

**៣:១៨** *ថាដេ* ឃើញយ៉ាងច្បាស់ដូចជា "យូដាស ជាកូនយ៉ាកុប" ដែរ (លក ៦:១៦ និង កច ១:១៣)។ *ស៊ីម៉ូន ជាសាសន៍កាណាន* មើលការពន្យល់ មថ ១០:៤ ។

**៣:១៩** *អ៊ីស្ការីយ៉ុត* មានន័យថា "បុរសមកពីក្រុងកេរីយ៉ុត" ក្រុងកេរីយ៉ុត–ហេស្រុន (យស ១៥:២៥) មានចម្ងាយប្រហែល១៩គ.ម ភាគខាងត្បូងនៃក្រុងហេប្រុន (យរ ៤៨:២៤)។ *យូដាសអ៊ីសារីយ៉ុត ជាអ្នកដែលបញ្ជូនទ្រង់* (មើល ១៤:១០–១១,៤៣–៤៦) ។

## ព្រះយេស៊ូវ និងបេលសេប៊ូល

*៣:២០-២៧ = មថ ១២:២៥-២៩ លក ១១:១៧-២២*

២០នោះក៏នាំគ្នាចូលទៅក្នុងផ្ទះ ហើយមានមនុស្សប្រជុំគ្នា[ន]
ទាំងហ្វូងម្ដងទៀត ដល់ម្ល៉េះបានជាទ្រង់ ព្រមទាំងពួកសិស្ស
ពុំអាចនឹងបរិភោគបានឡើយ[ប] ២១កាលពួកបងប្អូនទ្រង់បាន
ឮ គេក៏ចេញទៅរកចាប់ទ្រង់ ដ្បិតគេស្មានថាទ្រង់វង្វេង
ស្មារតីហើយ[ផ] ២២ឯពួកអាចារ្យ ដែលចុះមកពីក្រុង
យេរូសាឡិម[ព] គេនិយាយឡើងថា អ្នកនោះមានអារក្ស
បេលសេប៊ូល[ភ]ចូល វាដេញអារក្ស ដោយអាងមេអារក្ស
ទេ[ម] ២៣តែទ្រង់ហៅគេមកមានបន្ទូល ជាពាក្យប្រៀបប្រ
ដូច[យ] ថា ធ្វើដូចម្ដេចឱ្យអារក្សសាតាំង[រ]បានដេញអារក្សសា
តាំងដូច្នេះ ២៤បើនគរណាបែកទាស់ទែងគ្នាឯងហើយ
នគរ នោះពុំអាចនឹងនៅស្ថិតស្ថេរបានឡើយ ២៥ឬបើផ្ទះ
ណាបែកទាស់ទែងគ្នាឯង ផ្ទះនោះក៏មិនអាចនឹងនៅស្ថិត
ស្ថេរបានដែរ ២៦ឯអារក្សសាតាំងបើកើតបះបោរបែក
ទាស់គ្នាវា នោះវាពុំអាចនឹងនៅស្ថិតស្ថេរបានទេ វាត្រូវ
វិនាសទៅហើយ ២៧គ្មានអ្នកណាអាចនឹងចូលទៅក្នុងផ្ទះ
របស់មនុស្ស ខ្លាំងពូកែ ហើយប្លន់យករបស់ទ្រព្យគេបាន
ទេ លុះត្រាតែបានចងអ្នកនោះជាមុនសិន ទើបនឹងប្លន់
យកបាន[ល] ២៨ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា គ្រប់ទាំង
អំពើបាបនឹងបានអត់ទោសដល់ពួកកូនមនុស្ស ហើយអស់
ទាំងពាក្យដែលគេពោលប្រមាថដែរ ២៩តែអ្នកណាដែល
ពោលពាក្យប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធ នោះមិន
ដែលបានអត់ទោសឱ្យឡើយ អ្នកនោះឯងនឹងត្រូវទោស
នៅអស់កល្បជានិច្ចវិញ[វ]
៣០ដែលទ្រង់មានបន្ទូលដូច្នេះ នោះដោយព្រោះគេថា ទ្រង់
មានអារក្សអសោចិ៍ចូល។

## ម្ដាយ និងបងប្អូនរបស់ព្រះយេស៊ូវ

*៣:៣១-៣៥ = មក ១២:៤៦-៥០ លក ៨:១៩-២១*

៣១គ្រានោះ មាតា និងបងប្អូនទ្រង់មកដល់[ស] ក៏ឈរនៅខាង
ក្រៅ ប្រើគេឱ្យទៅហៅទ្រង់ ៣២ហ្វូងមនុស្សដែលអង្គុយនៅ
ជុំវិញទ្រង់ គេទូលថា នែ៎ មើល ម្ដាយ និងបងប្អូនលោកនៅ
ខាងក្រៅមករកលោក ៣៣ទ្រង់មានបន្ទូលឆ្លើយថា តើអ្នក
ណាជាម្ដាយ ហើយជាបងប្អូនខ្ញុំ ៣៤រួចទ្រង់ងាកទតទៅ
អស់អ្នកដែលអង្គុយនៅជុំវិញទ្រង់ ដោយបន្ទូលថា នុ៎ះ
នែ៎ ម្ដាយ និងបងប្អូនខ្ញុំ ៣៥ពីព្រោះ អ្នកណាដែលធ្វើតាម
ព្រះហឫទ័យព្រះ នោះហើយជាបងប្អូនប្រុសស្រី និងជា
ម្ដាយខ្ញុំ។

## រឿងប្រៀបប្រដូចអំពីគ្រាប់ពូជ

*៤:១-១២ = មថ ១៣:១-១៥ លក ៨:៤-១០*
*៤:១៣-២០ = មថ ១៣:១៨-២៣ លក ៨:១១-១៥*

**៤** ១ខណៈនោះ ទ្រង់តាំងបង្រៀន នៅត្រង់មាត់សមុទ្រ[ហ]ម្ដង
ទៀត ហើយមានមនុស្សទាំងហ្វូងមូលគ្នា មកឯទ្រង់ដល់ម្ល៉េះ
បានជាទ្រង់យាងចុះទៅគង់ក្នុងទូក នៅសមុទ្រវិញហើយ
មនុស្សទាំងអស់នៅលើគោក តាមមាត់ច្រាំង ២ទ្រង់បង្រៀន
សេចក្ដីជាច្រើនដល់គេ ដោយពាក្យប្រៀបធៀប[ឡ] ក៏មាន
បន្ទូលក្នុងន័យដែលទ្រង់បង្រៀនថា ៣ចូរស្ដាប់ចុះមើល
មានអ្នកព្រោះពូជម្នាក់ចេញទៅព្រោះ[អ] ៤កំពុងដែលព្រោះ
មានខ្លះធ្លាក់ចុះតាមផ្លូវ ហើយសត្វហើរលើអាកាស ក៏មក

**៣:២០** ន ខ.៧
ប មក ៦:៣១
**៣:២១** ផ យហ ១០:២០ កច ២៦:២៤
**៣:២២** ព មថ ១៥:១ ភ មថ ១០:២៥ ១១:១៨ ១២:២៤ យហ ៧:២០ ៨:៤៨,៥២ ១០:២០ ម មថ ៩:៣៤
**៣:២៣** យ មក ៤:២ រ មថ ៤:១០
**៣:២៧** ល អស ៤៩:២៤,២៥
**៣:២៩** វ មថ ១២:៣១,៣២ លក ១២:១០
**៣:៣១** ស ខ.២១
**៤:១** ហ មក ២:១៣ ៣:៧
**៤:២** ឡ ខ.១១ មក ៣:២៣
**៤:៣** អ ខ.២៦

**៣:២០** *ផ្ទះ* អាចជាផ្ទះរបស់ពេត្រុស និងអនទ្រេ (១:២៩ ២:១)។
**៣:២១** *កាលពួកបងប្អូនទ្រង់បានឮ គេក៏ចេញទៅ* គឺពួកគេបានធ្វើដំណើរពីស្រុកណាសារ៉ែតទៅក្រុងកាពើណិម ដែលមានចម្ងាយប្រហែល៤៨ គ.ម (ខ.៣១)
**៣:២២** *បេលសេប៊ូល* មើលការពន្យល់ មថ ១០:២៥ ។
**៣:២៣** *ពាក្យប្រៀបប្រដូច* ពាក្យនេះត្រូវបានប្រើក្នុងន័យជាទូទៅអំពីការប្រៀបធៀប (មើលការពន្យល់ ៤:២)។
**៣:២៧** *ចូលទៅក្នុងផ្ទះរបស់មនុស្សខ្លាំងពូកែ ហើយប្លន់យករបស់ទ្រព្យគេបានទេ* ព្រះយេស៊ូវបានមក ដើម្បីរំដោះមនុស្សឱ្យមានសិទ្ធិសេរីភាពពីអំណាចសាតាំង ។
**៣:២៨** *ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា* នេះជាប្រយោគស្រប ដែលព្រះយេស៊ូវបានប្រើដើម្បីពង្រឹងការអះអាងរបស់ទ្រង់ (មើល ៨:១២ ៩:១,៤១ ១០:១៥,២៩ ១១:២៣ ១២:៤៣ ១៣:៣០ ១៤:៩,១៨,២៥,៣០)។
**៣:២៩** *តែអ្នកណាដែលពោលពាក្យប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធ នោះមិនដែលបានអត់ទោសឱ្យឡើយ* ព្រះយេស៊ូវបញ្ជាក់ថា ការប្រមាថ (ខ.៣០ និង ខ.២២) ក្នុងខនេះដោយពួកអាចារ្យបាននិយាយថា ទ្រង់ប្រោសជំងឺនេះដោយអំណាចសាតាំង មិនមែនជាព្រះវិញ្ញាណបរិសុទ្ធទេ (មថ ១២:៣១)។
**៣:៣១** *មាតា និងបងប្អូនព្រះយេស៊ូវ* មើលការពន្យល់ លក ៨:១៩ ។
**៣:៣៥** *អ្នកណាដែលធ្វើតាមព្រះហឫទ័យព្រះ* ជាសមាជិកនៃគ្រួសារព្រះខាងឯវិញ្ញាណ ដែលមានភស្តុតាងដោយការស្តាប់បង្គាប់ដល់ទ្រង់ នោះប្រសើរជាងសមាជិកគ្រួសារខាងសាច់ឈាម (មើលការពន្យល់ ១០:៣០)។
**៤:១** *គង់ក្នុងទូក* ការអង្គុយជាធម្មតារបស់គ្រូបង្រៀនសាសន៍យូដា (មថ ៥:១ លក ៥:៣ យហ ៨:២)។
**៤:២** *ពាក្យប្រៀបធៀប* ជាការនិទានពីរឿងនៃជីវិតសាមញ្ញធម្មតាត្រូវបានគេលើកឡើងដើម្បីពន្យល់ជារូបភាពខាងឯវិញ្ញាណ ឬខាងឯសីលធម៌ ជួនកាលជាទម្រង់សង្ខេបពាក្យប្រៀបធៀប (មើលការពន្យល់ ៣:២៣) ភាពស្រដៀងគ្នា ឬការនិយាយជាសុភាសិតជាដើម ។ ជាធម្មតាវាមានចំណុចសំខាន់បំផុតមួយ ដែលមិនមែនជាសេចក្ដីលំអិតទេ តែមានន័យសំខាន់បំផុត (ពន្យល់ មថ ១៣:៣ លក ៨:៤)។
**៤:៣–៨** នៅថ្ងៃនោះគ្រាប់ពូជត្រូវបានព្រោះដោយដៃ តាមបែបលក្ខណៈធម្មជាតិ មានខ្លះធ្លាក់លើដីមិនល្អ (មើលការពន្យល់ លក ៨:៥)។

ចឹកស៊ី ៥ខ្លះទៀតធ្លាក់ទៅក្នុងកន្លែងថ្ម ដែលមិនសូវមានដី
ប៉ុន្មាន ហើយក៏ដុះឡើងភ្លាម ពីព្រោះគ្មានដីជ្រៅ ៦តែកាល
ថ្ងៃរះឡើង នោះក្រៀមខ្លោចទៅវិញ ពីព្រោះគ្មានឫស
៧ខ្លះទៀតធ្លាក់ទៅក្នុងបន្លា បន្លាក៏ដុះឡើងខ្ទប់ហើយគ្រាប់
នោះមិនកើតផលសោះ ៨តែខ្លះទៀតធ្លាក់ទៅក្នុងដីល្អ ក៏កើត
ផលចំរើនកាន់តែច្រើនឡើង គ្រាប់១បង្កើតបាន៣០ មួយ
បាន៦០ ហើយមួយបាន១រយ[ក] ៩រួចទ្រង់មានបន្ទូលថា
អ្នកណាដែលមានត្រចៀកសំរាប់ស្តាប់ ឱ្យស្តាប់ចុះ[ខ]។
១០កាលទ្រង់គង់នៅដោយឡែក នោះពួកអ្នកដែលនៅ
ជុំវិញទ្រង់ ព្រមទាំងពួក១២នាក់ គេទូលសួរពីពាក្យប្រៀប
ប្រដូចនោះ ១១ទ្រង់មានបន្ទូលថា ពីព្រោះបានប្រទាន
មកឱ្យអ្នករាល់គ្នាបានស្គាល់ការអាថ៌កំបាំងរបស់នគរព្រះ[គ]
ប៉ុន្តែឯមនុស្សក្រៅ ការទាំងអស់បានធ្វើបែបប្រៀបប្រ
ដូចវិញ[ឃ] ១២ដើម្បីកាលណាគេឃើញ នោះឱ្យគេឃើញ
មែន តែឥតយល់ទេ ហើយកាលណាឮ នោះឱ្យគេឮមែន
តែស្តាប់មិនបានសោះ ក្រែងគេប្រែចិត្ត ហើយបាបគេបាន
អត់ទោសឱ្យ[ង] ១៣ទ្រង់មានបន្ទូលសួរថា តើអ្នករាល់គ្នាមិន
យល់ពាក្យប្រៀបនេះទេឬអី ចុះធ្វើដូម្តេចឱ្យអ្នករាល់គ្នា
យល់គ្រប់ទាំងពាក្យប្រៀបប្រដូចបាន ១៤ឯអ្នកព្រោះពូជ
គឺព្រោះព្រះបន្ទូល[ច] ១៥ឯពួកអ្នកតាមផ្លូវ គឺជាកន្លែងដែល
បានព្រោះព្រះបន្ទូលចុះ កាលគេឮ នោះអារក្សសាតាំង[ឆ]
ក៏មកលួចឆក់យកព្រះបន្ទូល ដែលព្រោះក្នុងចិត្តគេទៅ
ភ្លាម ១៦ឯពួកអ្នកដែលទទួលពូជក្នុងកន្លែងថ្មក៏ដូចគ្នាដែរ
កាលណាគេឮព្រះបន្ទូល នោះគេទទួលភ្លាមដោយអំណរ
១៧តែគ្មានចាក់ឫសនៅក្នុងខ្លួនសោះ ហើយក៏នៅជាប់តែ
បន្តិចទេ បើកាលណាកើតមានសេចក្តីទុក្ខលំបាក ឬសេចក្តី
បៀតបៀន ដោយព្រោះព្រះបន្ទូល នោះគេរវាតចិត្ត
ចេញភ្លាម ១៨ឯពួកអ្នកដែលទទួលពូជក្នុងបន្លា គឺអស់អ្នក
ដែលបានឮព្រះបន្ទូលហើយ ១៩តែសេចក្តីខ្វល់ខ្វាយនៅ
ជីវិតនេះ សេចក្តីឆបោករបស់ទ្រព្យសម្បត្តិ[ជ] នឹងសេចក្តី
ប៉ងប្រាថ្នាខាងឯសេចក្តីផ្សេងៗឯទៀត ក៏ចូលមកខ្ទប់ព្រះ
បន្ទូលជិត រួចព្រះបន្ទូលមិនអាចនឹងបង្កើតផលបាន
២០ឯពួកអ្នកដែលទទួលពូជក្នុងដីល្អ គឺអស់ អ្នកដែលបានឮ
ព្រះបន្ទូល ហើយទទួល រួចបង្កើតផល ម្នាក់ បាន៣០ ម្នាក់
បាន៦០ ម្នាក់ទៀតបាន១រយ ។

## រឿងប្រៀបប្រដូចអំពីចង្កៀង

២១ទ្រង់ក៏មានបន្ទូលថា តើគេយកចង្កៀងមក ដើម្បីនឹង
ដាក់នៅក្រោមថាំង ឬក្រោមគ្រែឬអី គេយកមកដាក់លើ
ជើងចង្កៀងវិញទេតើ[ឈ] ២២ដ្បិតគ្មានអ្វីលាក់កំបាំងដែល
មិនត្រូវបើកសំដែងចេញឡើយ ក៏គ្មានអ្វីជាសំងាត់ដែលមិន
ត្រូវដាក់នៅពន្លឺដែរ[ញ] ២៣បើអ្នកណាមានត្រចៀកសំរាប់
ស្តាប់ ឱ្យស្តាប់ចុះ[ដ] ២៤ទ្រង់មានបន្ទូលទៀតថា ចូរប្រយ័ត
ពីសេចក្តីដែលអ្នករាល់គ្នាស្តាប់ចុះ ឯរង្វាល់ណាដែលអ្នក
រាល់គ្នាវាល់ឱ្យគេ នោះគេនឹងវាល់ឱ្យអ្នករាល់គ្នាតាម
រង្វាល់នោះវិញ ហើយនឹងឱ្យជាលើសទៅទៀត ដល់អ្នក
រាល់គ្នាដែលស្តាប់ផង[ឋ] ២៥ដ្បិតអ្នកណាដែលមាន នោះគេ
នឹងឱ្យដល់អ្នកនោះ ប៉ុន្តែអ្នកណាដែលគ្មាន នោះនឹងត្រូវ
ដកចេញ ទាំងរបស់ ដែលអ្នកនោះមានផង[ឌ]។

**៤:៨** ក យហ ១៥:៥ កល ១:៦
**៤:៩** ខ.២៣ មក ៤:២៣ មថ ១១:១៥
**៤:១១** គ មថ ៣:២ ឃ ១កថ ៥:១២,១៣ កល ៤:៥ ១ថន ៤:១២ ១ធថ ៣:៧
**៤:១២** ង អស ៦:៩,១០ មថ ១៣:១៣–១៥
**៤:១៤** ច មក ១៦:២០ លក ១:២ កច ៤:៣១ ៨:៤ ១៦:៦ ១៧:១១ ភល ១:១៤
**៤:១៥** ឆ មថ ៤:១០
**៤:១៩** ជ មថ១៩:២៣ ១ ធថ ៦:៩,១០,១៧ ១ យហ ២:១៥–១៧
**៤:២១** ឈ មថ ៥:១៥
**៤:២២** ញ យរ ១៦:១៧ មថ ១០:២៦ លក ៨:១៧ ១២:២
**៤:២៣** ដ ខ.៩ មថ ១១:១៥
**៤:២៤** ឋ មថ ៧:២

**៤:៨** *ចំរើនកាន់តែច្រើនឡើង...១បានជាមួយរយ* ឱ្យផល១ជាមួយរយគឺជាចម្រូតមួយមិនធម្មតាទេ (លប ២៦:១២)។ ចម្រូតគឺជាសញ្ញាណមួយសាមញ្ញសម្រាប់ប្រើ ជាន័យធៀបពីនគររបស់ព្រះ (យអ ៣:១៣ វវ ១៤:១៤–២០)។
**៤:១១** *អាថ៌កំបាំងរបស់នគរព្រះ* នៅក្នុងព្រះគម្ពីរសញ្ញាថ្មីថែងថា"នគរព្រះគឺជារឿងសំងាត់កាលពីមុន" តែនៅពេលនេះ ព្រះយេស៊ូវបានបើកសំដែងឱ្យរាស្ត្ររបស់ព្រះអង្គបានស្គាល់ហើយ ។ ឈប់ជាការអាថ៌កំបាំងតទៅទៀតហើយ គឺត្រូវបានប្រកាសដល់មនុស្សទាំងអស់ឱ្យឃើញ ប៉ុន្តែ អ្នកដែលអាចយល់អាថ៌កំបាំងនេះ បានលុះត្រាតែមានជំនឿជាមុនសិន ។ ពាក្យអាថ៌កំបាំងត្រង់នេះបានបង្ហាញថានគរ ព្រះនឹងយាងមក គឺជាតួអង្គព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទនេះតែម្តង ។
**៤:១២** *កាលណា* គឺព្រះយេស៊ូវប្រដូចការបង្រៀនរបស់ទ្រង់ទៅនឹងកិច្ចការរបស់ហោរាអេសាយ ខណៈពេលដែលលោកប្រកាសដំណឹងល្អ នោះក៏បានចំណេញដល់សិស្សមួយចំនួន (អស ៨:១៦)ផងដែរ នៅក្នុងចំណោមមនុស្សរឹងទទឹងនឹងការព្រមាន និងការអំពាវនាវរបស់ទ្រង់ ។
**៤:១៤** *ព្រះបន្ទូល* គឺគ្រប់សេចក្តីដែលព្រះយេស៊ូវបង្រៀនតែម្តង ទោះបើមានឧបសគ្គជាច្រើនក៏ដោយ ក៏គង់តែព្រះបន្ទូលរបស់ទ្រង់នឹងសម្រេចគោលដៅដែរ ។
**៤:១៧** *លំបាក ឬសេចក្តីបៀតបៀន* "មើល ៨:៣៤–៣៨ ១០:៣០ ១៣:៩–១៣"។
**៤:១៩** *សេចក្តីឆបោករបស់ទ្រព្យសម្បត្តិ* សុភមង្គលរបស់មនុស្សមិនប្រាកដត្រូវតែមានសុវត្ថិភាព សន្តិសុខ និងទ្រព្យសម្បត្តិថ្កុំថ្កើងនោះទេ គឺត្រូវពឹងផ្អែកលើព្រះអម្ចាស់វិញ (១០:១៧–២៥ ចទ ៨:១៧–១៨ ៣២:១៥ សស ២:៤–១១ យក ៥:១–៦)។
**៤:២១** *តើគេយកចង្កៀងមក...?* ចង្កៀងគឺសម្រាប់បំភ្លឺ មិនត្រូវលាក់ទុកនោះទេ ដូចគ្នា ព្រះយេស៊ូវគឺជាពន្លឺនៃលោកិយ (យហ ៨:១២) ដែលត្រូវបានទុកសម្រាប់បើកសំដែង ។ *ចង្កៀង* មើលការពន្យល់ មថ ៥:១៥ ។
**៤:២៥** *ដ្បិតអ្នកណាដែលមាន* នោះគេនឹងឱ្យដល់អ្នកនោះ បើយើងធ្វើតាមសេចក្តីពិតដែលមាននាពេលបច្ចុប្បន្ន នោះយើងនឹងទទួលថែមទៀតនាពេលអនាគត ប៉ុន្តែ បើយើងមិនបានធ្វើនូវអ្វីដែលខ្លួនបានទទួលបន្តិចបន្តួចនេះទេ នោះយើងដឹងយ៉ាងច្បាស់ថា យើងនឹងមិនបានទទួលអ្វីសោះ សូម្បីតែចាប់ពី

## រឿងប្រៀបប្រដូចអំពីគ្រាប់ពូជ

២៦ ទ្រង់ក៏មានបន្ទូលថា នគរព្រះធៀបដូចជា[ឍ]មនុស្ស
ម្នាក់ ដែលព្រោះពូជនៅដី ២៧ អ្នកនោះក៏ដេករាល់យប់ក្រោក
ឡើងរាល់ថ្ងៃ តែមិនដឹងហេតុដែលពូជពន្លកដុះឡើងជា
យ៉ាងណាទេ ២៨ ដ្បិតដីបង្កើតផលដោយខ្លួនឯង មុនដំបូង
ចេញជាពន្លក រួចបែកជាគួរ ក្រោយទៀតចេញជាគ្រាប់
២៩ លុះដល់កាលណាផ្លែទុំហើយ ក៏ស្រាប់តែគេយកកណ្តៀវ
ទៅច្រូតតែម្តង ព្រោះដល់រដូវច្រូតហើយ[ណ]។

## រឿងប្រៀបប្រដូចអំពីគ្រាប់ពូជតូចល្អិត

*៤:៣០–៣២ = មថ ១៣:៣១,៣២ លក ១៣:១៨,១៩*

៣០ ទ្រង់ក៏មានបន្ទូលថា តើយើងនឹងធៀបនគរព្រះជា អ្វី[ត]
ឬត្រូវយកពាក្យប្រៀបអ្វីមកប្រដូចនឹងនគរនោះ ៣១ គឺ
ដូចជាគ្រាប់ពូជ១ ដែលកាលណាគេព្រោះនៅដី ជាពូជ
យ៉ាងល្អិតជាងគ្រាប់ទាំងអស់នៅផែនដី ៣២ តែកាលណាគេ
ព្រោះចុះទៅ នោះក៏ដុះឡើងត្រឡប់ជាធំ លើសជាងតិណ
ជាតិទាំងអស់វិញ ទាំងបែកមែកជាធំផង ដល់ម៉្លេះបានជា
សត្វហើរនៅលើអាកាស មកទំនៅក្រោមម្លប់បាន ៣៣ ទ្រង់
អធិប្បាយព្រះបន្ទូលឱ្យគេស្តាប់ ដោយពាក្យប្រៀបប្រដូច
យ៉ាងដូច្នេះជាច្រើន តាមដែលគេស្តាប់បាន[ថ] ៣៤ ទ្រង់
មិនបានមានបន្ទូលទៅគេ ដោយឥតពាក្យប្រៀបធៀបទេ[ទ]

**៤:២៥** ឌ មថ ២៥:២៩
**៤:២៦** ឍ មថ ១៣:២៤
**៤:២៩** ណ វវ ១៤:១៥
**៤:៣០** ត មថ ១៣:២៤
**៤:៣៣** ថ យហ ១៦:១២
**៤:៣៤** ទ យហ ១៦:២៥
**៤:៣៦** ធ ខ.១ មក ៣:៩ ៥:២,២១ ៦:៣២,៤៥
**៤:៤០** ន មថ ១៤:៣១ មក ១៦:១៤

តែកាលណានៅដោយឡែក នោះទ្រង់ពន្យល់ទាំងអស់ដល់
ពួកសិស្សវិញ ។

## ព្រះយេស៊ូវធ្វើឱ្យខ្យល់ព្យុះស្ងប់

*៤:៣៥–៤១ = មថ ៨:១៨,២៣–២៧ លក ៨:២២–២៥*

៣៥ លុះពេលល្ងាចថ្ងៃនោះឯង ទ្រង់មានបន្ទូលទៅពួក
សិស្សថា ចូរយើងឆ្លងទៅត្រើយម្ខាង ៣៦ កាលបានឱ្យ
ហ្វូងមនុស្សទៅវិញហើយ នោះពួកសិស្សក៏ទទួលទ្រង់តាម
ភាពដដែលទៅក្នុងទូក[ធ] ហើយមានទូកតូចៗខ្លះទៀតទៅជា
មួយដែរ ៣៧ នោះកើតមានខ្យល់ព្យុះជាខ្លាំង ហើយរលក
បោកចូលក្នុងទូក ដល់ម៉្លេះបានជាទូកពេញហើយ ៣៨ តែ
ទ្រង់ផ្ទំលក់លើខ្នើយ នៅកន្សៃទូក ពួកសិស្សដាស់ទ្រង់ឡើង
ទូលថា លោកគ្រូអើយ យើងវិនាសហើយ លោកមិន
រវល់ទេឬអី ៣៩ កាលតើនឡើង ទ្រង់កំហែងខ្យល់ ក៏បង្គាប់
ទៅសមុទ្រថា ចូរស្ងៀមទៅ ហើយឈប់ចុះ នោះខ្យល់ក៏
ស្ងប់ ហើយស្ងាត់ ឈឹងសូន្យទាំងអស់ទៅ ៤០ រួចទ្រង់មាន
បន្ទូលថា ហេតុអ្វីបានជាអ្នករាល់គ្នាភ័យដល់ម៉្លេះ ម្តេចក៏
គ្មានសេចក្តីជំនឿ[ន] ៤១ នោះគេមានសេចក្តីស្ញែងខ្លាចជា
ខ្លាំង ទាំងសួរគ្នាទៅវិញទៅមកថា ដូច្នេះតើលោកនេះជា
អ្វី បានជាខ្យល់ នឹងសមុទ្រក៏ស្តាប់បង្គាប់លោកដូច្នេះ ។

---

ឥឡូវនេះទៅ ។

**៤:២៦–២៩** មានតែម៉ាកុសទេដែលកត់ត្រារឿងប្រដូចនេះ ផ្ទុយនឹងរឿងប្រដូចអ្នកព្រោះពូជបញ្ជាក់ពីការសំខាន់នៃលទ្ធផលដី ក្នុងការលូតលាស់នៃគ្រាប់ពូជ និងភាពជ័យជម្នះនៃការប្រមូលផល ។ អាថ៌កំបាំងនេះគឺនិយាយពីអំណាចនៃគ្រាប់ពូជរបស់វាផ្ទាល់តែម្តង ដូចជាដំណឹងល្អដែរ គឺមានអំណាចដោយផ្ទាល់នៅក្នុងនោះតែម្តង ។

**៤:២៩** *យកកណ្តៀវទៅច្រូតតែម្តង* ព្រោះដល់រដូវច្រូតហើយ ការនេះគឺនិយាយទៅដល់ "យអ ៣:១៣" ដែលរដូវចម្រូតនោះគឺជាន័យប្រៀបពីនគររបស់ព្រះ ។

**៤:៣០–៣៤** ចំណុចសំខាន់នៃរឿងប្រៀបធៀបគឺថា នគរព្រះហាក់បីដូចជាត្រូវបានចាប់ផ្តើមដំបូងព្រាលៗឡើង ដោយការស្អប់ និងការបដិសេធន៍ព្រះយេស៊ូវ និងសិស្សទាំង១២នាក់របស់ទ្រង់ ។ ប៉ុន្តែ ពិភពលោកនឹងឃើញថ្ងៃនៃសេចក្តីពិត និងអំណាចដ៏អស្ចារ្យដែលត្រូវមកដល់ ។

**៤:៣១** មើលការពន្យល់ មថ ១៣:៣១–៣២ ។

**៤:៣៤** *ទ្រង់មិនបានមានបន្ទូលទៅគេ ដោយឥតពាក្យប្រៀបធៀបទេ* ព្រះយេស៊ូវបានប្រើរឿងប្រៀបប្រដូចជាច្រើន ដើម្បីពន្យល់នូវសេចក្តីពិតដាស់សតិស្មារតី និងបំភ្លឺចំណេះខាងឯវិញ្ញាណ ។ ជាទូទៅមនុស្សមិនបានប្រុងប្រៀបទទួលសេចក្តីពិតនៃដំណឹងល្អទេ ប៉ុន្តែ ពេលដែលព្រះយេស៊ូវនៅដាច់ដោយឡែក នោះទ្រង់បានបង្រៀនសិស្សទ្រង់នូវន័យចំៗជាង តែពួកគេនៅតែត្រូវការឱ្យទ្រង់ជួយពន្យល់ដដែល ។

**៤:៣៥–៤១** ការអស្ចារ្យទាំងនេះគឺពិបាកនឹងធ្វើឱ្យមនុស្សសម័យទំនើបនេះយល់ណាស់ ក្នុងព្រះគម្ពីរសញ្ញាថ្មីប្រាប់យ៉ាងច្បាស់ថា ព្រះយេស៊ូវគឺជាព្រះអម្ចាស់ មិនមែនគ្រាន់តែលើពួកជំនុំរបស់ទ្រង់នោះទេ តែជាព្រះអម្ចាស់លើគ្រប់ទាំងអស់ផងដែរ ។

**៤:៣៥** *ឆ្លងទៅត្រើយម្ខាង* ព្រះយេស៊ូវយាងចេញពីទឹកដីស្រុកកាលីឡេឆ្ពោះទៅតំបន់គេរ៉ាស៊ីន (៥:១) ។

**៤:៣៧** *ខ្យល់ព្យុះជាខ្លាំង* រឿងនេះបានកើតឡើងក្នុងបរិវេណអាងសមុទ្រកាលីឡេមួយ ដែលព័ទ្ធជុំវិញទៅដោយភ្នំជាច្រើន ។ វាគឺជាកន្លែងដែលងាយនឹងទទួលរងនូវខ្យល់ព្យុះខ្លាំងណាស់ ដោយសារតែខ្យល់ត្រជាក់បក់មកពីសមុទ្រមេឌីទែរ៉ាណេ កាត់តាមច្រកភ្នំតូចមួយ ទៅប៉ះនឹងខ្យល់ក្តៅ និងខ្យល់សើមដែលនៅលើផ្ទៃសមុទ្រ នោះក៏ស្រាប់តែបង្កឱ្យមានខ្យល់ព្យុះឡើងទៅ ។

**៤:៣៨** *ផ្ទំលក់លើខ្នើយ* បង្ហាញថាព្រះយេស៊ូវអស់កម្លាំង ហើយផ្ទំលក់ទៅ (តាមទម្លាប់អ្នកបើកទូកតែងតែមានខ្នើយ ឬជាកំណល់អ្វីមួយដាក់នៅក្រោមកៅអីគាត់) ហើយនេះក៏ជាការបង្ហាញពីចរិតលក្ខណៈនៃការសរសេររបស់លោកម៉ាកុស ។

**៤:៤១** *តើលោកនេះជាអ្វី?* ជាសំណួរនូវអ្វីដែលព្រះយេស៊ូវទើបបាន ធ្វើ ដែលមានចម្លើយតែមួយនោះគឺទ្រង់ជាព្រះរាជបុត្រានៃព្រះ! ទាំងព្រះ

## ព្រះយេស៊ូវប្រោសមនុស្សដែលអារក្សចូល

*៥:១-១៧ = មថ ៨:២៨-៣៤ លក ៨:២៦-៣៧*

*៥:១៨-២០ = លក ៨:៣៨,៣៩*

**៥** ១នោះក៏មកដល់ស្រុកគេរ៉ាស៊ីន នៅត្រើយសមុទ្រម្ខាង
២កាលទ្រង់បានយាងឡើងពីទូក[ប] ស្រាប់តែមានមនុស្សម្នាក់
ដែលមានអារក្សអសោចិ៍ចូល[ផ] វាចេញពីក្នុងផ្នូរខ្មោចមក
ជួបនឹងទ្រង់ ៣វានៅតែក្នុងផ្នូរខ្មោច ឥតមានអ្នកណាអាច
នឹងចងវាជាប់ទៀតបានទេ ទោះបើយកច្រវាក់ទៅដាក់ក៏ពុំ
បានផង ៤ដ្បិតគេបានដាក់ខ្នោះដាក់ច្រវាក់វាជាច្រើនដង
ហើយ ប៉ុន្តែវាចេះតែកាច់ច្រវាក់បំបាក់ខ្នោះចោលអស់
ហើយគ្មានអ្នកណាអាចនឹងកំរាបវាបានដែរ ៥វានៅក្នុងផ្នូរ
នៅលើភ្នំ ទាំងស្រែក ហើយយកថ្មមកអារសាច់ខ្លួន ទាំង
យប់ទាំងថ្ងៃជានិច្ច ៦កាលវាឃើញព្រះយេស៊ូវពីចំងាយ
ក៏រត់ទៅក្រាបសំពះទ្រង់ ៧ស្រែកដោយសំរែកជាខ្លាំង
ថា ឱព្រះយេស៊ូវជាព្រះរាជបុត្រាព្រះដ៏ខ្ពស់បំផុតអើយ[ព]
តើទ្រង់ហើយនឹងទូលបង្គំមានរឿងអ្វីនឹងគ្នា[ភ] ទូលបង្គំ
សូមទ្រង់ឱ្យស្បថដោយព្រះថា មិនធ្វើទុក្ខទូលបង្គំទេ
៨វាទូលដូច្នោះពីព្រោះទ្រង់កំពុងតែមានបន្ទូលថា ម្នាល
អារក្សអសោចិ៍ ចូរថយចេញ ពីមនុស្សនេះទៅ
៩រួចទ្រង់សួរវាថា ឯងឈ្មោះអី វាទូលឆ្លើយថា ទូលបង្គំ
ឈ្មោះ «កងទ័ព»[ម] ពីព្រោះយើងខ្ញុំមានគ្នាច្រើន ១០នោះវា
ទទូចអង្វរសូមកុំឱ្យទ្រង់បណ្តេញវារាល់គ្នាចេញពីស្រុក
នោះឡើយ ១១រីឯនៅទីនោះ មានហ្វូងជ្រូកយ៉ាងធំ កំពុង
តែរកស៊ីនៅចង្កេះភ្នំ ១២ហើយអារក្សទាំងនោះទូលអង្វរ
ទ្រង់ថា សូមឱ្យយើងរាល់គ្នាទៅជ្រក នៅក្នុងជ្រូកទាំងនោះ
ចុះ ១៣នោះទ្រង់ក៏អនុញ្ញាតឱ្យភ្លាម រួចកាលវិញ្ញាណអារក្ស
អសោចិ៍ទាំងនោះបានចេញហើយ វាក៏ចូលទៅក្នុងជ្រូក
ហើយហ្វូងជ្រូកប្រហែល២ពាន់រូប ក៏បោលម្នីម្នាតាមភ្នំ
ចោត ចធ្លាក់ទៅក្នុងសមុទ្រ លង់ទឹកស្លាប់ទាំងអស់ទៅ
១៤ឯពួកអ្នកគង្វាលជ្រូក គេរត់ទៅក្នុងទីក្រុង ហើយក្នុង
ស្រុកស្រែសាសព្ទប្រាប់ពីរឿងនោះ រួចមនុស្សទាំងអស់
ចេញមកមើលការដែលបានកើតឡើង ១៥គេមកឯព្រះ
យេស៊ូវ ហើយឃើញមនុស្សដែលពីដើមមានអារក្សចូល
កំពុងតែអង្គុយទាំងស្លៀកពាក់ មានស្មារតីដឹងខ្លួនឡើង
គឺជាអ្នកដែលមាន អារក្សទាំងកង[យ]ចូលនោះឯង រួចគេ

**៥:២** ប មក ៤:១
ផ មក ១:២៣
**៥:៧** ព មថ ៤:៣
លក ១:៣២ ៦:៣៥
កច ១៦:១៧
ហព ៧:១
ភ មថ ៨:២៩
**៥:៩** ម ខ.១៥
**៥:១៥** យ ខ.៩
ខ.១៦,១៨
មថ ៤:២៤

វត្តមាន និងព្រះចេស្តាទ្រង់ត្រូវមនុស្សម្នាបានឃើញ (ទដ ៦៥:៧ ១០៧:២៥-៣០ សភ ៣០:៤)។ លោកម៉ាកុសបានប្រាប់ចម្លើយយ៉ាងច្បាស់ នៅក្នុងបន្ទាត់ដើមដំបូងនៃដំណឹងល្អរបស់លោក (១:១)។ តាមការអស្ចារ្យទាំងនេះ ធ្វើឱ្យសិស្សរបស់ព្រះអង្គបង្កើត និងបង្កើននូវសេចក្តីជំនឿលើភាពជាព្រះរបស់ព្រះអង្គកាន់តែខ្លាំងឡើង ។

**៥:១** *នោះក៏មកដល់* គឺព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់ ។ *ត្រើយសមុទ្រម្ខាង* គឺ ខាងលិចនៃសមុទ្រជាទឹកដីយ៉ាងធំ ដែលមានសាសន៍ដទៃរស់នៅ ដោយបង្ហាញពីហ្វូងសត្វជ្រូក ដែលសាសន៍យូដាចាត់ទុកថា ជាសត្វមិនស្អាត ហើយក៏មិនបរិភោគទៀតផង ។ *ស្រុកគេរ៉ាស៊ីន* ស្ថិតនៅចម្ងាយប្រហែលជា ៥៦ គ.ម ភាគអាគ្នេយ៍នៃសមុទ្រកាលីឡេ ហើយបន្តរហូតដល់ឆកសមុទ្រភាគខាងកើត ដែលគេហៅថា ភូមិតូច បច្ចុប្បន្នមានឈ្មោះថាកើសា ។ ពីទីនេះប្រហែលជាជិត២គ.ម ភាគខាងត្បូងមាន ជម្រាលច្រាំងសមុទ្រចោតគួរសមមួយប្រវែង ៣៧ម៉ែត្រ ពីច្រាំងសមុទ្រ ហើយនិង ចម្ងាយប្រហែល៣គ.ម ពីទីនេះក៏មានរូងគុហាមួយដែលត្រូវបានគេប្រើធ្វើជាលំនៅស្ថាន ។

**៥:៣** *នៅតែក្នុងផ្នូរខ្មោច* វាមិនមែនផ្នូរ (រូង) ធម្មតាសម្រាប់បញ្ចុះសពនោះទេ ហើយក៏មិនជាទីជម្រក ឬរូងគុហាសម្រាប់អ្នកក្រីក្ររស់នោះដែរ ។

**៥:៤** *គេបានដាក់ខ្នោះដាក់ច្រវាក់វាជាច្រើនដង* អ្នកភូមិទាំងនោះមិនញញើតនឹងដាក់ច្រវាក់វានោះឡើយ ព្រោះដើម្បីការពារសុវត្ថិភាពរបស់ពួកគេ និងជាការបំបាក់ ឬបង្ក្រាបវាផងដែរ ។

**៥:៥** *យកថ្មមកអារសាច់ខ្លួន* ពាក្យនិមួយៗនៅក្នុងរឿងនេះបានបញ្ជាក់ពីស្ថានភាពគួរឱ្យអាណិតអាសូរដល់ម្នាក់នេះណាស់ ព្រមទាំងបង្ហាញពីបំណងសាតាំង ដែលចូលមនុស្សនេះ ដើម្បីនឹងធ្វើទារុណកម្ម ហើយបំផ្លាញរូបកាយមនុស្សដែល ព្រះបានបង្កើតមកឱ្យដូចរូបអង្គទ្រង់នោះ ។

**៥:៧** *តើទ្រង់ ហើយនិងទូលបង្គំមានរឿងអ្វីនឹងគ្នា...* របៀបនៃការនិយាយនេះ គឺស្រដៀងគ្នានឹងឃ្លាដែលមាននៅក្នុង ២សយ ១៦:១០ ១៩:២២ "តើយើង បាននិយាយអ្វី" ន័យទាំងនេះបញ្ជាក់ថា "ចូរគិតតែពីរឿងរបស់អ្នកទៅ!" វិញ្ញាណអារក្សនិយាយចេញមកដោយប្រើសំឡេងរបស់មនុស្សដែលវាចូលនោះ។ *ព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត* មើលការពន្យល់ ១:២៤ ។ *ស្បថដោយព្រះថា មិនធ្វើទុក្ខទូលបង្គំទេ* អារក្សបានដឹង ច្បាស់ថាវានឹងត្រូវបានដាក់ទោសបានជាវា ប្រើសម្បថដែលជាការចំអកយ៉ាងខែងរ៉ែងថែមទៅទៀត ។

**៥:៩** *ទូលបង្គំឈ្មោះកងទ័ព ពីព្រោះយើងមានគ្នាច្រើន* មានន័យថាមួយកងពលនៃទាហាន ។ មួយកងពលទាហានរ៉ូម៉ាំងនៅពេលនោះមាន៦០០០នាក់ តាមន័យនៃ ពាក្យនេះបានឱ្យដឹងថា ម្នាក់នេះជាកម្មសិទ្ធរបស់អារក្សអសោចិ៍ដ៏ច្រើន ដែលប្រឆាំងនឹងព្រះយេស៊ូវដែលតំណាងឱ្យអំណាចព្រះចេស្តានៃព្រះ ។

**៥:១០** *សូមកុំឱ្យទ្រង់បណ្តេញវារាល់គ្នាចេញពីស្រុកនោះ* អារក្សភ័យខ្លាចក្រែងពួកវា ត្រូវបានបញ្ជូនទៅកន្លែងដាក់ទណ្ឌកម្មដ៏អស់កល្បជានិច្ច នោះគឺជង្ហុកដ៏ធំ (លក ៨:៣១)។

**៥:១៣** *ទ្រង់ក៏អនុញ្ញាតឱ្យភ្លាម* មើលការពន្យល់ មថ ៨:៣២ ។

**៥:១៦** *ហើយពីដំណើរហ្វូងជ្រូក* ក្រៅពីការចាប់អារម្មណ៍មនុស្សដែលអារក្សចូលបានជាឡើងវិញ នោះពួកគេបាននិយាយពីការងាប់ជ្រូកទាំងហ្វូងផងដែរ ដែលជាការព្រួយបារម្ភសំខាន់របស់ពួកគេ គ្មានអ្វីឆ្ងល់នោះទេពីការនេះ ព្រោះពួកគេបានគិតពីការខាតបង់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់

ស្ញែងខ្លាច ១៦ពួកអ្នកដែលបានឃើញការនោះ ក៏ពណ៌នា
ប្រាប់ដល់ជនគ្រប់គ្នាតាមការដែលកើតឡើង ដល់អ្នកនោះ
ជាយ៉ាងណា ហើយពីដំណើរហ្វូងជ្រូកផង ១៧នោះគេចាប់
តាំងទូលអង្វរ សូមឱ្យទ្រង់យាងចេញពីស្រុកគេទៅ ១៨កាល
ទ្រង់បានយាងចុះទូក នោះអ្នកដែលអារក្សចូលពីដើម
គាត់ក៏សូមទៅជាមួយនឹងទ្រង់ ១៩តែទ្រង់មិនអនុញ្ញាតទេ
ដោយបន្ទូលថាចូរទៅផ្ទះទៅ ហើយប្រាប់បងប្អូនឯង[រ]
ពីការធំទាំងម្លេះ ដែលព្រះអម្ចាស់បានមេត្តាប្រោសដល់ឯង
វិញ ២០គាត់ក៏ចេញទៅ ចាប់តាំងប្រកាសប្រាប់ នៅស្រុក
ដេកាប៉ូល[ល]ពីការធំទាំងម្លេះ ដែលព្រះយេស៊ូវបានប្រោស
ដល់ខ្លួន នោះមនុស្សទាំងអស់ក៏អស្ចារ្យក្នុងចិត្ត ។

## ក្មេងស្រីស្លាប់ម្នាក់ និងស្ត្រីមានជំងឺម្នាក់

*៥:២២–៤៣ = មថ ៩:១៨–២៦ លក ៨:៤១–៥៦*

២១កាលព្រះយេស៊ូវ ទ្រង់បានជិះទូក ឆ្លងដល់ត្រើយម្ខាង[វ]
វិញហើយ ក៏មានហ្វូងមនុស្សយ៉ាងធំប្រជុំគ្នាឯទ្រង់ ហើយ
ទ្រង់គង់នៅទីមាត់សមុទ្រ[ស] ២២នោះមានមេសាលាប្រជុំម្នាក់
ឈ្មោះយ៉ៃរ៉ុស[ហ]មកដល់ឃើញទ្រង់ ក៏ក្រាបនៅទៀបព្រះបាទ
ទ្រង់ ២៣គាត់ទទូចអង្វរទូលថា កូនស្រីទូលបង្គំជិតស្លាប់
ហើយ សូមទ្រង់យាងទៅដាក់ព្រះហស្តលើ[ឡ]វា ឱ្យបានជា
នោះវានឹងបានរស់វិញ ២៤ទ្រង់ក៏ចេញទៅជាមួយនឹងគាត់
ហើយមានមនុស្សកកកុញដើរតាមទៅ ទាំងប្រជ្រៀតទ្រង់
២៥នោះមានស្ត្រីម្នាក់ឈឺធ្លាក់ឈាម[អ] អស់១២ឆ្នាំមកហើយ
២៦នាងបានឈឺសន្ធឹក នៅដៃគ្រូពេទ្យជាច្រើន ហើយបាន
ចំណាយទ្រព្យសម្បត្តិទាំងប៉ុន្មានៗ តែមិនបានគ្រាន់បើសោះ
ជំងឺនោះកាន់តែខ្លាំងឡើងវិញ ២៧នាងបានឮនិយាយពី
ព្រះយេស៊ូវ ក៏ចូលមកក្នុងហ្វូងមនុស្សពីក្រោយ ទៅពាល់
ព្រះពស្ត្រទ្រង់ ២៨ដោយគិតថា បើគ្រាន់តែពាល់ព្រះពស្ត្រ
ទ្រង់ប៉ុណ្ណោះ[ក] នោះនឹងបានជាហើយ ២៩ឯជំងឺធ្លាក់ឈាម
ក៏បាត់ក្នុងខណៈ១រំពេចនោះ ហើយនាងបានដឹងក្នុងខ្លួនថា
នាងរួចពីសេចក្តីវេទនានោះហើយ[ខ] ៣០នោះស្រាប់តែព្រះ
យេស៊ូវជ្រាបក្នុងព្រះអង្គទ្រង់ថា មានព្រះចេស្តា[គ]ចេញពី
ទ្រង់ ក៏ងាកបែរព្រះអង្គក្នុងហ្វូងមនុស្សសួរថា អ្នកណា
ពាល់អាវខ្ញុំ ។
៣១ពួកសិស្សទូលថា ទ្រង់ឃើញថាហ្វូងមនុស្សប្រជ្រៀត
ទ្រង់ដែរ ម្តេចឡើយក៏មានបន្ទូលថា អ្នកណាពាល់ទ្រង់
ដូច្នេះ ៣២ទ្រង់ងាកទតទីជុំវិញ នឹងរកអ្នកណាដែលបានធ្វើ
ការនោះ ៣៣ឯស្ត្រីនោះនាងដឹងការដែលកើតមកក្នុងខ្លួន
ហើយ ក៏មកទាំងភ័យញ័រ ទំលាក់ខ្លួនក្រាបចុះនៅចំពោះ
ទ្រង់ ទូលតាមត្រង់ទាំងអស់ ៣៤ទ្រង់មានបន្ទូលទៅនាងថា
កូនស្រីអើយ សេចក្តីជំនឿនាង បានជួយសង្គ្រោះនាង[ឃ]
ហើយ ចូរទៅឱ្យបានប្រកបដោយសេចក្តីសុខចុះ[ង] ហើយ
ឱ្យនាងបាន រួចពីសេចក្តីវេទនារបស់នាងទៅ។

**៥:១៩** រ មថ ៨:៤
**៥:២០** ល មថ ៤:២៥ មក ៧:៣១
**៥:២១** វ មថ ៩:១ ស មក ៤:១
**៥:២២** ហ ខ.៣៥,៣៦,៣៨ លក ១៣:១៤ កច ១៣:១៥ ១៨:៨,១៧
**៥:២៣** ឡ មថ ១៩:១៣ មក ៦:៥ ៧:៣២ ៨:២៣ ១៦:១៨ លក ៤:៤០ ១៣:១៣ កច ៦:៦
**៥:២៥** អ លវ ១៥:២៥–៣០
**៥:២៨** ក មថ ៩:២០
**៥:២៩** ខ ខ.៣៤
**៥:៣០** គ លក ៥:១៧ ៦:១៩
**៥:៣៤** ឃ មថ ៩:២២ ង កច ១៥:៣៣

ពួកគេ ជាជាងមនុស្សបានសង្គ្រោះ ។

**៥:១៧** *ទូលអង្វរ សូមឱ្យទ្រង់យាងចេញពីស្រុកគេទៅ* ដោយការភ័យខ្លាចខាតបង់ទ្រព្យសម្បត្តិ លើសពីនេះទៅទៀត វាជាកម្លាំងអំណាចនៃសេចក្តីងងឹត ដែលបានធ្វើការនៅក្នុងចំណោមពួកគេមិនឱ្យយល់បាន ។

**៥:១៩** *ប្រាប់បងប្អូនឯងពីការធំ… មេត្តាប្រោសដល់ឯង* នេះជាការផ្ទុយនឹងអ្វីដែលព្រះយេស៊ូវបានធ្លាប់ហាមមនុស្សដែលទ្រង់បានប្រោសឱ្យជាមិនឱ្យទៅប្រាប់ អ្នកណាឡើយ ដូចជាមនុស្សឃ្លង់នៅក្នុងគម្ពីរ (“១:៤៤ ១:៣៤ ៣:១២” និងការពន្យល់ មថ ៨:៤) នេះប្រហែលដោយសារតែ មនុស្សជាពីអារក្សចូលនោះ ជាអ្នករស់នៅលើទឹកដីសាសន៍ដទៃ ជាកន្លែងមានគ្រោះថ្នាក់តិចតួចដល់ការធ្វើដំណើរចុះឡើងរបស់ព្រះយេស៊ូវ ដែលកំពុងតែបើកសំដែងថា ទ្រង់ជាព្រះមែស៊ីនោះ ។

**៥:២០** *ដេកាប៉ូល* មើលការពន្យល់ មថ ៤:២៥ ។

**៥:២១** *ឆ្លងដល់ត្រើយម្ខាងវិញហើយ* ព្រះយេស៊ូវវិលត្រឡប់មកភាគខាងលិចនៃសមុទ្រវិញ ប្រហែលជាទ្រង់យាងទៅក្រុងកាពើណិម ។

**៥:២២** *មេសាលាប្រជុំ* ជាសង្ឃដែលត្រួតត្រាលើសាលាប្រជុំ ដោយទទួលខុសត្រូវផ្នែករដ្ឋបាល ផ្នែកថ្វាយបង្គំ ថែរក្សាអាគារ និងកិច្ចការផ្សេងៗទៀត *សាលាប្រជុំ* ភាគច្រើនមានអ្នកមើលការខុសត្រូវ (អ្នកត្រួតត្រា) តែម្នាក់ទេ លើកលែងតែក្នុង “កច ១៣:១៥” មានគ្នាលើសពីមួយនាក់ ពេលខ្លះតួនាទីនេះ ត្រូវបានលើក តម្កើងដោយមិនបញ្ចូលផ្នែករដ្ឋបាលនោះទេ ។

**៥:២៥** *ឈឺធ្លាក់ឈាមអស់១២ឆ្នាំ* គ្មាននរណាម្នាក់បានដឹងថាស្ត្រីនេះមានជំងឺអ្វីទេ ប៉ុន្តែ អ្វីដែលនាងកំពុងមាននោះ គឺភាពឈឺចាប់ ដោយព្រោះនាងត្រូវបានបណ្តាជនគេចចេញពីនាង ។ ជាទូទៅ បើមានមនុស្សណាម្នាក់មានទំនាក់ទំនងជាមួយនាង នោះត្រូវបានគេចាត់ទុកថាមិនស្អាត (លវ ១៥:២៥–៣៣) ។

**៥:២៦** *នាងបានឈឺសន្ធឹកនៅដៃគ្រូពេទ្យជាច្រើន* គ្រូពេទ្យសាសន៍យូដារក្សានូវកំណត់ត្រានៃថ្នាំពេទ្យ និងវេជ្ជបញ្ជាជាច្រើនសម្រាប់ជំងឺប្រភេទនេះនៅតែមិនជា ។

**៥:២៨** *បើគ្រាន់តែពាល់ព្រះពស្ត្រទ្រង់ប៉ុណ្ណោះ* នាងបានជាដោយសារសេចក្តីជំនឿរបស់នាង (ខ.៣៤ កច ១៩:១២) ។

**៥:៣០** *មានព្រះចេស្តាចេញពីទ្រង់* ស្ត្រីនេះត្រូវបានសង្គ្រោះដោយព្រះគុណរបស់ព្រះអម្ចាស់ដែលបានកំណត់មកថាសង្គ្រោះនាងដោយព្រះចេស្តាទ្រង់។

**៥:៣២** *ទ្រង់ងាកទតទីជុំវិញនឹងរក អ្នករកអ្នកណាបានដែលធ្វើការនោះ* ព្រះយេស៊ូវបានរកស្ត្រីនោះ ដើម្បីនឹងសរសើរពីសេចក្តីជំនឿរបស់នាងជាសាធារណៈ និងដើម្បីធ្វើការអះអាងថា ជំងឺរបស់នាងបានជាហើយចាប់ពីពេលនេះរហូតតទៅ ។

**៥:៣៤** *បានជួយសង្គ្រោះ* មានន័យពីរយ៉ាងជាភាសាក្រិក គឺរូបកាយបានជាពីជំងឺ (នាងបានរួចពីសេចក្តីវេទនារបស់នាង) និងបានទទួលសេចក្តីសង្គ្រោះខាងឯព្រលឹងវិញ្ញាណ (ចូរទៅឱ្យបានប្រកបដោយសេចក្តីសុខចុះ!) ។ ជា

៣៥កំពុងដែលទ្រង់នៅមានបន្ទូលនៅឡើយ នោះមាន
មនុស្សមកពីផ្ទះមេសាលាប្រជុំ[ច] ជំរាបថា កូនស្រីលោក
ស្លាប់ហើយ នៅតែរំខានចិត្តលោកគ្រូធ្វើអីទៀត ៣៦កាល
ព្រះយេស៊ូវបានឮពាក្យគេប្រាប់ ស្រាប់តែទ្រង់មាន
បន្ទូលទៅមេសាលាប្រជុំថា កុំខ្លាចអី ឱ្យគ្រាន់តែ
ជឿប៉ុណ្ណោះ ៣៧ទ្រង់មិនឱ្យអ្នកណាឯទៀតទៅជាមួយ
ឡើយលើកតែពេត្រុស យ៉ាកុប នឹងយ៉ូហាន ជាប្អូនយ៉ាកុប
ប៉ុណ្ណោះ[ឆ] ៣៨លុះដល់ផ្ទះមេសាលាប្រជុំ[ជ] ក៏ឃើញមនុស្ស
កំពុងតែយំស្រែក កើតវឹកវរជាខ្លាំង ៣៩ទ្រង់ក៏យាងចូល
ទៅ មានបន្ទូលថា ហេតុអ្វីបានជាកើតវឹកវរ ហើយយំដូច្នេះ
កូននេះមិនមែនស្លាប់ទេ គឺវាដេកលក់ទេតើ[ឈ] ៤០គេក៏
សើចឡកឱ្យទ្រង់ តែទ្រង់ដេញគេទៅក្រៅអស់ ទុកតែឪ
ពុកម្តាយនៃកូននោះ នឹងពួកអ្នកដែលនៅជាមួយនឹងទ្រង់
នាំគ្នាចូលទៅឯដំណេកវា ៤១រួចទ្រង់ចាប់ដៃ[ញ]វាមាន
បន្ទូលថា «តាលីថាគូមី» ស្រាយថា កូនស្រីអើយ អញ
ប្រាប់ឱ្យឯងក្រោកឡើង[ដ] ៤២ស្រាប់តែកូនស្រីនោះក៏ក្រោក
ឡើងដើរទៅ ដ្បិតមានអាយុ១២ឆ្នាំហើយ ឯមនុស្សរាល់
គ្នាគេមានសេចក្តីអស្ចារ្យជាខ្លាំងក្រៃលែង ៤៣តែទ្រង់ហាម
គេផ្តាច់ មិនឱ្យអ្នកណាដឹងពីរឿងនេះឱ្យសោះ[ឋ] រួចប្រាប់
ឱ្យគេយកអ្វីៗមកឱ្យនាង បរិភោគ ។

**៥:៣៥** ច ខ.២២
**៥:៣៧** ឆ មថ ៤:២១
**៥:៣៨** ជ ខ.២២
**៥:៣៩** ឈ មថ ៩:២៤
**៥:៤១** ញ មក ១:៣១ ដ លក ៧:១៤
**៥:៤៣** ឋ មថ ៨:៤
**៦:១** ឌ មថ ២:២៣
**៦:២** ឍ មក ១:២១ ណ មថ ៤:២៣ ត មថ ៧:២៨
**៦:៣** ថ មថ ១២:៤៦ ទ មថ ១១:៦ យហ ៦:៦១
**៦:៤** ធ លក ៤:២៤ យហ ៤:៤៤
**៦:៥** ន មក ៥:២៣

## ហោរាឥតមានគេរាប់អាន

*៦:១-៦ = មថ ១៣:៥៤-៥៨*

**៦** ១ព្រះយេស៊ូវទ្រង់យាងចេញពីទីនោះ ទៅឯស្រុកទ្រង់[ឌ]
វិញ ហើយពួកសិស្សក៏តាមទ្រង់ទៅ ២ដល់ថ្ងៃឈប់សំរាក[ឍ]
ទ្រង់ចាប់តាំងបង្រៀន នៅក្នុងសាលាប្រជុំ[ណ] ហើយមនុស្ស
ជាច្រើនដែលកំពុងតែស្តាប់ទ្រង់ ក៏នឹកប្លែកក្នុងចិត្ត [ត]ដោយ
ថា អ្នកនេះបានសេចក្តីទាំងនេះពីណាមក ចំណេះណាហ្ន៎
ដែលបានឱ្យមកគាត់ បានជាមានការឫទ្ធិបារមីយ៉ាងនេះ
កើតមក ដោយសារដៃគាត់ដូច្នេះ ៣តើគាត់មិនមែនជា
ជាងឈើ ជាកូននៃនាងម៉ារា ហើយជាបងយ៉ាកុប យ៉ូសែប
យូដាស នឹងស៊ីម៉ូនទេឬអី[ថ] ហើយប្អូនស្រីគាត់ តើមិននៅជា
មួយនឹងយើងនៅទីនេះទេឬអី អ្នកទាំងនោះក៏អាក់អន់ចិត្ត
នឹងទ្រង់[ទ] ៤តែព្រះយេស៊ូវមានបន្ទូលទៅគេថា ហោរាមិន
មែនឥតគេរាប់អានទេ លើកតែនៅក្នុងស្រុកខ្លួន ឬក្នុងពួក
ញាតិសន្តាន ហើយនៅក្នុងផ្ទះខ្លួនចេញ[ធ] ៥នៅទីនោះទ្រង់
ពុំអាចនឹងធ្វើការឫទ្ធិបារមីបានទេ ទ្រង់គ្រាន់តែដាក់
ព្រះហស្ត[ន] ប្រោសមនុស្សពិការខ្លះ ឱ្យបានជាប៉ុណ្ណោះ
៦ទ្រង់ក៏អស្ចារ្យពីដំណើរដែលគេមិនជឿ រួចទ្រង់យាង

ញឹកញាប់ អត្ថន័យទាំងពីរនេះត្រូវបានឃើញនៅជាមួយគ្នាក្នុងដំណឹងល្អរបស់លោកម៉ាកុស (២:១-១២ ៣:១-៦) ។

**៥:៣៧** *ពេត្រុស យ៉ាកុប និងយ៉ូហាន* អ្នកទាំងបីនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងព្រះយេស៊ូវ (មើលការពន្យល់ កច ៣:១) ។

**៥:៣៨** *យំស្រែក កើតវឹកវរជាខ្លាំង* វាជាទម្លាប់សម្រាប់អ្នកយំជាអាជីពដែលត្រូវបានគេនាំមកឱ្យយំនៅកន្លែងបុណ្យសព ។ តែទោះជាយ៉ាងនេះក៏ដោយ ក្នុងករណីនេះ វាមិនទាន់ប្រាកដថាពេលកន្លងមក នោះបានគ្រប់គ្រាន់ឬទេ សម្រាប់ឱ្យអ្នកយំអាជីពបានមកដល់នោះ ។

**៥:៣៩** *មិនមែនស្លាប់ទេ គឺវាដេកលក់ទេតើ* មើលការពន្យល់ លក ៨:៥២។

**៥:៤១** *តាលីថាគូមី* លោកម៉ាកុសម្នាក់ប៉ុណ្ណោះ ដែលសរសេរ ដោយបានរក្សាភាសាកំណើត គឺភាសាអើរ៉ាម ដែលជាភាសាមួយក្នុងចំណោមភាសាជាច្រើនរបស់ប៉ាឡេស្ទីននៅសតវត្សរ៍ទី១ ហើយប្រហែលជាព្រះយេស៊ូវ និងសិស្សរបស់ទ្រង់បានប្រើផងដែរ (ពួកគេអាចប្រើភាសាហេព្រើរ ឬភាសាក្រិក) ។

**៥:៤៣** *មិនឱ្យអ្នកណាដឹងពីរឿងនេះឱ្យសោះ* នៅក្នុងបរិវេណក្នុងស្រុកកាលីឡេជាញឹកញាប់ ព្រះយេស៊ូវបានហាមមនុស្សដែលទ្រង់បានប្រោសមិនឱ្យប្រាប់ពីការអស្ចារ្យនោះឡើយ។ ប្រជាប្រិយភាពរបស់ទ្រង់បានល្បីអស្ចារ្យក្នុងបណ្តាជនហើយ ការប្រឆាំងជំទាស់ក៏កំពុងមានសន្ទុះលឿនបន្តិចម្តងៗ ពីសំណាក់អ្នកដឹកនាំសាសនា ផងដែរមុននឹងព្រះរាជកិច្ចទ្រង់ត្រូវបានបំពេញចប់ (១:៤៤ ៥:១៩ ៧:៣៦ ៨:២៦) ។

**៦:១** *ស្រុកទ្រង់* សំដៅទៅលើទីកន្លែងកំណើតរបស់ព្រះយេស៊ូវ ក្នុងភូមិណាសារ៉ែត ប៉ុន្តែ លោកម៉ាកុសមិនបាននិយាយចំៗនោះទេ (មើលការពន្យល់ ១:៩) ។

**៦:២** *បង្រៀននៅក្នុងសាលាប្រជុំ* (មើលការពន្យល់ ១:២១) ។ *ប្លែកក្នុងចិត្ត* (មើលការពន្យល់ ១:២២) ។

**៦:៣** *ជាងឈើ* តាមសំដីរបស់លោកម៉ាថាយបញ្ជាក់ថា ព្រះយេស៊ូវត្រូវបានគេហៅថា"កូនជាងឈើ" (មថ ១៣:៥៥) ហើយនៅក្នុងកណ្ឌគម្ពីរម៉ាកុសនេះសរសេរថា ព្រះយេស៊ូវទ្រង់ផ្ទាល់ជាជាងឈើ ។ បើតាមភាសាក្រិកពាក្យនេះអាចមានន័យ ថាជាងកំបោរ ឬជាងដែក ប៉ុន្តែ នៅត្រង់ចំណុចនេះគ្រាន់តែមានន័យថាជាងឈើប៉ុណ្ណោះ ។ នេះគឺជាសំណួរមើលងាយ "តើគាត់មិនមែនជាជាងឈើ . . . ? តើមិននៅជាមួយនឹងយើងនៅទីនេះឬអី?" *ជាបងយ៉ាកុប យ៉ូសែប យូដាស និងស៊ីម៉ូន* (មើលពន្យល់ លក ៨:១៩)។ *អ្នកទាំងនោះក៏អាក់អន់ចិត្តនឹងទ្រង់* ព្រោះពួកគេ មិនបានឃើញហេតុផលអ្វីដែលបញ្ជាក់ថា ទ្រង់ខុសប្លែកពីពួកគេនោះសោះ ហើយក៏មិនជឿថាទ្រង់ជាម្នាក់យ៉ាងពិសេស ដែលព្រះបានចាក់ប្រេងតាំងឱ្យនោះដែរ ។ *យ៉ូសែប* គឺជា "យ៉ូសេ" (មថ ១៣:៥៥) ។

**៦:៥** *នៅទីនោះទ្រង់ពុំអាចនឹងធ្វើឫទ្ធិបារមីបានទេ* គឺមិនមែនមានន័យថាព្រះយេស៊ូវគ្មានព្រះចេស្តា ដើម្បីសំដែងការអស្ចារ្យនៅភូមិណាសារ៉ែតនោះទេ ប៉ុន្តែទ្រង់ បានសម្រេចព្រះទ័យមិនធ្វើនៅកន្លែងណាដែលគេមិនជឿនោះឡើយ (ខ.៦) ។

**៦:៦** *ទ្រង់ក៏អស្ចារ្យ* មានន័យថា ទ្រង់នឹកប្លែកក្នុងព្រះទ័យអំពីការដែលពួកគេមិនជឿ (មើលការពន្យល់ លក ៧:៩) ។

ទៅបង្រៀនក្នុងអស់ទាំងភូមិនៅជុំវិញទៅ[ប]។

## ព្រះយេស៊ូវបញ្ជូនសិស្សទាំង១២នាក់ចេញទៅ

*៦:៧–១១ = មថ ១០:១,៩–១៤ លក ៩:១,៣–៥*

៧ទ្រង់ហៅពួក១២នាក់មក[ផ] ចាប់តាំងចាត់ឱ្យគេទៅ
២នាក់ៗ ទ្រង់ប្រទានឱ្យមានអំណាចលើអស់ទាំងអារក្ស
អសោចិ៍ផង[ព] ៨ក៏ហាមមិនឱ្យយកអ្វីសំរាប់តាមផ្លូវសោះ
លើកតែដំបង១ប៉ុណ្ណោះ ឥតយកយាម និំប៉័ង ឬប្រាក់ដាក់
ក្នុងខ្សែក្រវាត់ទេ ៩ពាក់បានតែស្បែកជើងសង្រែក ឥតពាក់
អាវ២ឡើយ ១០រួចមានបន្ទូលទៅគេថា អ្នករាល់គ្នាចូល
ទៅក្នុងផ្ទះណា ចូរឱ្យនៅផ្ទះនោះទាល់តែដើរចេញហួស
ទៅ ១១ឯអស់អ្នកណាដែលមិនទទួល ឬស្តាប់អ្នករាល់គ្នា
នោះកាលណាដើរចេញពីទីនោះ ត្រូវរលាស់ធូលីពីបាត
ជើងអ្នកចេញ[ភ] ទុកជាទីបន្ទាល់ទាស់នឹងគេវិញ ខ្ញុំប្រាប់អ្នក
រាល់គ្នាជាប្រាកដថា នៅថ្ងៃជំនុំជំរះ នោះក្រុងសូដុំម ហើយ
ក្រុងកូម៉ូរ៉ា នឹងទ្រាំបានងាយជាជាងក្រុងនោះ។
១២កាលពួកសិស្សបានចេញទៅ នោះគេប្រកាសប្រាប់
ឱ្យមនុស្សប្រែចិត្តឡើង[ម] ១៣ក៏បណ្តេញអារក្សជាច្រើន ហើយ
លាបប្រេង[យ]ឱ្យមនុស្សជំងឺជាច្រើនបានជាដែរ ។

## ការកាត់ក្បាលយ៉ូហាន–បាទីស្ទ

*៦:១៤–២៩ = មថ ១៤:១–១២*
*៦:១៤–១៦ = លក ៩:៧–៩*

១៤ដំណឹងនោះក៏ឮដល់ស្តេចហេរ៉ូឌ ដ្បិតព្រះនាមទ្រង់
កាន់តែល្បីសុសសាយទៅ ហើយស្តេចមានបន្ទូលថា ច្បាស់
ជាយ៉ូហាន–បាទីស្ទ[រ] បានរស់ពីស្លាប់ឡើងវិញហើយ បាន
ជាមានការឫទ្ធិបារមីសំដែងមក ដោយសារគាត់ដូច្នេះ។
១៥តែអ្នកខ្លះថា ជាអេលីយ៉ា[ល] ខ្លះទៀតថាជាហោរា[វ] ឬដូច
ជាហោរាណាមួយ[ស] ១៦ប៉ុន្តែកាលស្តេចហេរ៉ូឌបានឮ
នោះទ្រង់មានបន្ទូលថា នោះគឺជាយ៉ូហានដែលយើងបាន
កាត់ក្បាលទេ គាត់បាន រស់ពីស្លាប់ឡើងវិញហើយ ១៧ដ្បិត
គឺស្តេចហេរ៉ូឌនេះឯង ដែលបានប្រើគេទៅចាប់ ចងលោក
យ៉ូហានដាក់គុក[ហ]ដោយព្រោះហេរ៉ូឌាសជាភរិយារបស់
ភីលីពអនុជទ្រង់ ព្រោះស្តេចបានយកនាងនោះមកធ្វើជា
ភរិយារបស់ខ្លួនវិញ ១៨ហើយលោកយ៉ូហានបានទូល
ទាស់ថា ទ្រង់គ្មានច្បាប់នឹងយកភរិយារបស់អនុជទ្រង់ទេ[ឡ]
១៩ឯនាងហេរ៉ូឌាស ក៏ចងគំនុំចង់សំឡាប់លោក តែមិនបាន
ឱកាសសោះ ២០ព្រោះស្តេចហេរ៉ូឌកោតខ្លាចលោកយ៉ូហាន
ដោយជ្រាបថា លោកជាមនុស្សសុចរិត ហើយបរិសុទ្ធ ទ្រង់
ក៏ការពារទុកវិញ[អ] កាលទ្រង់បានស្តាប់លោកនោះក៏មាន
ព្រះទ័យរារែកជាខ្លាំង ប៉ុន្តែបានស្តាប់លោកដោយអំណរ
២១លុះថ្ងៃ១ជាថ្ងៃមានឱកាសស្រួល គឺថ្ងៃចំរើនព្រះជន្ម
ស្តេចហេរ៉ូឌ កាលទ្រង់រៀបជប់លៀង[ក]ពួកមន្ត្រី ពួកមេ
ទ័ពធំ នឹងពួកអ្នកមុខអ្នកការនៅស្រុកកាលីឡេ[ខ] ២២នោះ
កូនស្រី របស់ហេរ៉ូឌាសបានចូលមករាំ ជាទីនាំឱ្យគាប់
ព្រះទ័យដល់ស្តេចហេរ៉ូឌ និងពួកភ្ញៀវណាស់ ទ្រង់ក៏មាន
បន្ទូលថា របស់អ្វីដែលនាងចង់បាន ចូរសូមពីយើងចុះ

**៦:៦** ប មថ ៩:៣៥ មក ១:៣៩ លក ១៣:២២
**៦:៧** ផ មក ៣:១៣ ព ចទ ១៧:៦ លក ១០:១ មថ ១០:១
**៦:១១** ភ មថ ១០:១៤
**៦:១២** ម លក ៩:៦
**៦:១៣** យ យក ៥:១៤
**៦:១៤** រ មថ ៣:១
**៦:១៥** ល មឡ ៤:៥ វ មថ ២១:១១ ស មថ ១៦:១៤ មក ៨:២៨
**៦:១៧** ហ មថ ៤:១២ ១១:២ លក ៣:១៩,២០
**៦:១៨** ឡ លវ ១៨:១៦ ២០:២១
**៦:២០** អ មថ ១១:៩
**៦:២១** ក នអ ១:៣ ២:១៨ ខ លក ៣:១

**៦:៧** *២នាក់ៗ* ត្រង់ចំណុចនេះបញ្ជាក់ថា ការដែលទ្រង់ធ្វើយ៉ាងដូច្នោះ គឺដើម្បីងាយស្រួលក្នុងការជួយគ្នាទៅវិញទៅមក នៅពេលប្រកាសដំណឹងល្អ ក៏ដូចជាក្នុងពេលបង្ហាត់បង្រៀន និងពេលធ្វើកិច្ចការផ្សេងៗទៀតផងដែរ (ចទ ១៧:៦)។

**៦:៨** *ឥតយកយាម នំបុ័ង ឬប្រាក់ដាក់ក្នុងខ្សែក្រវាត់ទេ* គឺឱ្យពួកគេពឹងអាងលើព្រះអម្ចាស់ និងមនុស្សដែលពួកគេនឹងធ្វើទីបន្ទាល់ជាមួយនោះតែម្តង (ឧ.១០)។

**៦:៩** *ឥតពាក់អាវ២* ន័យដើមថា"ឥតមានអាវទុកបម្រុង"។អាវនេះសម្រាប់ដណ្តប់ពេលយប់ មានអាកាសធាតុចុះត្រជាក់ ហើយនៅទីនេះគឺជាប់ទាក់ទងទៅនឹងពួកសិស្សទាំងអស់គឺឱ្យទុកចិត្តថា ព្រះនឹងផ្គត់ផ្គង់កន្លែងស្នាក់អាស្រ័យដល់ពួកគេ ។

**៦:១១** *ត្រូវរលាស់ធូលីពីបាតជើងអ្នក* "មើលការពន្យល់ មថ ១០:១៤" ។

**៦:១២–១៣** *ប្រកាសប្រាប់ឱ្យ. . .ក៏បណ្តេញអារក្សជាច្រើន* បេសកកម្មនេះសំគាល់ ពីការចាប់ផ្តើមកិច្ចការដំបូងរបស់ពួកសិស្ស ក្នុងនាមព្រះយេស៊ូវ (៣:១៤–១៥) ហើយការងាររបស់ពួកគេក៏គួរឱ្យកោតសរសើរដូចជាទ្រង់ដែរ (១:១៥)។

**៦:១២** *ប្រែចិត្ត* មើលការពន្យល់ មក ១:៤ ។

**៦:១៣** *លាបប្រេងឱ្យមនុស្សជំងឺជាច្រើនបានជា* ជាទូទៅនៅសម័យបុរាណគេប្រើប្រេងអូលីវជាថ្នាំព្យាបាលជំងឺ(អស ១:៦ លក ១០:៣៤ យក ៥:១៤)។

**៦:១៤** *ស្តេចហេរ៉ូឌ* មើលការពន្យល់ មថ ១៤:១ ។ លោកម៉ាកុសអាចបានប្រើងារនេះ ក្នុងន័យចំអកបញ្ឈឺ (តាំងពីហេរ៉ូឌជាស្តេចអនុរាជ) ឬក៏ប្រើឈ្មោះហេរ៉ូឌដែលមានប្រជាប្រិយភាពមកជាសាមញ្ញ ។

**៦:១៥** *អេលីយ៉ា* មើលការពន្យល់ មឡ ៤:៥ ។

**៦:១៦** *យ៉ូហាន . . . គាត់បានរស់ពីស្លាប់ឡើងវិញហើយ* ការនេះបានធ្វើឱ្យស្តេចហេរ៉ូឌខ្វល់ខ្វាយ និងមានអារម្មណ៍មិនល្អ ដោយខ្លាចខ្មោចយ៉ូហានមកលងគាត់ ។

**៦:១៧** *គេទៅចាប់ចងលោកយ៉ូហានដាក់គុក* តាមសៀវភៅរបស់លោកយ៉ូសែបហ្វីសបានបញ្ជាក់ថា លោកយ៉ូហានត្រូវបានគេចាប់ដាក់គុកនៅឯម៉ាការ៉ុសក្នុងប៉មមួយនៃស្រុកពេរ៉េ នៅភាគខាងកើតនៃសមុទ្រស្លាប់ (មើល ១:១៤ លក ៣:១៩-២០)។ *ហេរ៉ូឌាស* មើលការពន្យល់ មថ ១៤:៣ ។ *ភីលីពអនុជទ្រង់* មើលការពន្យល់ មថ ១៤:៣ ។

**៦:២២** *កូនស្រីរបស់ហេរ៉ូឌាស* មើលការពន្យល់ មថ ១៤:៦ ។

យើងនឹងឱ្យ ២៣ទ្រង់ក៏ស្បថនឹងនាងទៀតថា របស់អ្វីក៏
ដោយ ដែលនាងសូម នោះយើងនឹងឱ្យដោយពិត ទោះ
បើដល់នគរ១ចំហៀងផង[គ] ២៤នាងក៏ចេញទៅសួរមាតាថា
តើត្រូវឱ្យខ្ញុំម្ចាស់សូមអ្វី មាតាឆ្លើយថា ឱ្យសូមក្បាលយ៉ូ
ហាន–បាទីស្ទវិញ ២៥រួចនាងក៏ប្រញាប់ប្រញាល់ចូលទៅ
ឯស្តេចភ្លាម ទូល ថាខ្ញុំម្ចាស់ចង់បានក្បាលយ៉ូហាន–បាទីស្ទ
ដាក់លើថាសមកឥឡូវនេះ ២៦ពាក្យនោះជាហេតុនាំឱ្យស្តេច
មានព្រះទ័យព្រួយខ្លាំងណាស់ តែដោយព្រោះសម្បថ
របស់ទ្រង់ ហើយនឹងពួកភ្ញៀវ បានជាទ្រង់មិនប្រកែកឡើយ
២៧ទ្រង់ចាត់ពេជ្ឈឃាតម្នាក់ទៅភ្លាម ដោយបង្គាប់ឱ្យទៅ
យកក្បាលលោកមក ២៨អ្នកនោះក៏ទៅកាត់ក្បាលលោក
នៅក្នុងគុក ដាក់លើថាសមកជូននាង នាងក៏ថ្វាយដល់មាតា
២៩កាលពួកសិស្សរបស់លោកបានឮ នោះគេមកយកសព
លោកទៅបញ្ចុះក្នុងផ្នូរទៅ ។

## ព្រះយេស៊ូវប្រទានអាហារដល់មនុស្សប្រាំពាន់នាក់

*៦:៣២–៤៤ = មថ ១៤:១៣–២១ លក ៩:១០–១៧ យហ ៦:៥–១៣*

*៦:៣២–៤៤ ឧយោង មក ៨:២–៩*

៣០ឯពួកសាវក[ឃ] ក៏ប្រជុំគ្នាឯព្រះយេស៊ូវ រ៉ាយរឿងទូល
ទ្រង់ពីការដែលខ្លួនបានធ្វើទាំងប៉ុន្មាន ហើយពីសេចក្តី
ដែលបានបង្រៀនដែរ[ង] ៣១រួចទ្រង់មានបន្ទូលទៅគេថា
ចូរអ្នករាល់គ្នាមកឯទីស្ងាត់ដោយឡែក នឹងឈប់សំរាក
បន្តិចសិន ពីព្រោះមានគេដើរទៅដើរមកច្រើនណាស់
ដល់ម្ល៉េះបានជារកពេលគ្រាន់តែបរិភោគក៏មិនបានផង[ច]
៣២នោះក៏នាំគ្នាចុះទូក[ឆ] ចេញទៅឯទីស្ងាត់ដោយឡែកទៅ
៣៣ឯហ្វូងមនុស្សគេឃើញទ្រង់ចេញទៅ ហើយមានគ្នា
ច្រើនបានស្គាល់ទ្រង់ បានជាមានមនុស្សពីគ្រប់ក្រុងទាំង
ប៉ុន្មាន នាំគ្នារត់ទៅមុន ប្រជុំគ្នាឯទ្រង់។
៣៤កាលព្រះយេស៊ូវបានឡើងពីទូកមក នោះទ្រង់ឃើញ
ហ្វូងមនុស្សជាធំ ក៏មានព្រះហឫទ័យក្តួលអាណិតដល់គេ
ពីព្រោះគេធៀបដូចជាចៀមដែលគ្មានអ្នកគង្វាល[ជ] រួចទ្រង់
ចាប់តាំងបង្រៀនគេពីសេចក្តីជាច្រើន ៣៥លុះពេលជ្រុល
ហើយ នោះពួកសិស្សមកទូលទ្រង់ថា ទីនេះជាទីស្ងាត់
ហើយពេលក៏ជ្រុលផង ៣៦សូមទ្រង់ឱ្យគេទៅរកទិញអា
ហារនៅស្រុកស្រែ ហើយក្នុងភូមិនៅជុំវិញចុះ ដ្បិតគេគ្មាន
អ្វីបរិភោគសោះ ៣៧តែទ្រង់មានបន្ទូលឆ្លើយថា ចូរអ្នក
រាល់គ្នាឱ្យគេបរិភោគទៅ[ឈ] ប៉ុន្តែពួកសិស្សទូលថា តើឱ្យ
យើងរាល់គ្នាទៅទិញនំបុ័ងចំនួន៤០រៀល ឱ្យគេបរិភោគ
ឬអី ៣៨ទ្រង់មានបន្ទូលសួរថា តើអ្នករាល់គ្នាមាននំបុ័ង
ប៉ុន្មាន ចូរទៅមើលសិន កាលបានដឹងហើយ ក៏ទូលឆ្លើយ
ថា មាន៥ដុំ និងត្រី២ទេ[ញ] ៣៩នោះទ្រង់បង្គាប់ឱ្យពួកសិស្ស
ប្រាប់គេ ឱ្យអង្គុយលើស្មៅខ្ចីដោយពួកៗ ៤០គេក៏អង្គុយ
ដោយជួរ ក្នុង១ជួរ៥០នាក់ ទាំងអស់មាន១០០ជួរ
៤១រួចទ្រង់យកនំបុ័ង៥ នឹងត្រី២នោះ ងើបទតទៅលើ
មេឃប្រទានពរ ហើយកាច់នំបុ័ង[ដ]ប្រទានដល់ពួកសិស្ស
ឱ្យលើកទៅឱ្យគេ ក៏បែងភាគត្រី២នោះ ចែកទៅមនុស្ស

**៦:២៣** គ នអ ៥:៣,៦ ៧:២
**៦:៣០** ឃ មថ ១០:២ លក ៩:១០ ១៧:៥ ២២:១៤ ២៤:១០ កច ១:២,២៦ ង លក ៩:១០
**៦:៣១** ច មក ៣:២០
**៦:៣២** ឆ ខ.៤៥ មក ៤:៣៦
**៦:៣៤** ជ មថ ៩:៣៦
**៦:៣៧** ឈ ២ពវ ៤:៤២–៤៤
**៦:៣៨** ញ មថ ១៥:៣៤ មក ៨:៥
**៦:៤១** ដ មថ ១៤:១៩

**៦:២៣** *ទោះបើដល់នគរ១ចំហៀង* នេះគឺជាវោហារសំដីដែលបង្ហាញពីចិត្តសប្បុរស ប៉ុន្តែមិនមែននិយាយយកជាផ្លូវការទៅតាមន័យរបស់ពាក្យនោះទេ (នអ ៥:៣,៦)។ ទឹកចិត្តសប្បុរសបែបនេះគឺស័ក្តិសមទៅនឹងឱកាសនាពេលនោះ និងអាចទាក់ទាញចំណាប់អារម្មណ៍របស់ភ្ញៀវកិត្តិយសដែលបានមកចូលរួមទៀតផង ។

**៦:៣០** *ពួកសាវក* មានតែនៅត្រង់នេះនិង៣:១៤ទេ ដែលលោកម៉ាកុសបានប្រើក្នុងដំណឹងល្អម៉ាកុសនេះ ។ សាវកគឺជាមនុស្សដែលមានអំណាចព្រះចេស្តារបស់ព្រះយេស៊ូវ ឬជាអ្នកតំណាងឱ្យទ្រង់ (ហព ៣:១)។ ពេលខ្លះពាក្យនេះត្រូវបានប្រើ ដោយទូទៅនៅក្នុងព្រះគម្ពីរសញ្ញាថ្មីជាភាសាក្រិកនៅក្នុងន័យថា "អ្នកនាំសារ" (យហ ១៣:១៦)។ នៅក្នុងន័យបច្ចេកទេសពាក្យនេះត្រូវបានគេប្រើដូចតទៅ: (១). សាវក១២នាក់(៣:១៤)មានន័យថា បូកបញ្ចូលទាំងលោកប៉ុលផងដែរ (រម ១:១) (២). មួយក្រុមធំ គឺបូកចូលទាំងលោកបាណាបាស (កច ១៤:១៤) លោក យ៉ាកុបជាប្អូនព្រះយេស៊ូវ (កទ ១:១៩) ហើយប្រហែលអាចទាំងអាន់ត្រូនីក និងយូនាស (រម ១៦:៧) ផងដែរ ។ *រាយទូលទ្រង់ពីការដែលខ្លួនបានធ្វើទាំងប៉ុន្មាន ហើយពីសេចក្តីដែលបានបង្រៀនដែរ* ការទាំងអស់នេះបានកើតឡើង ដោយព្រោះព្រះអម្ចាស់ប្រទានដល់ពួកគេ ដែលជាអ្នកតំណាងរបស់ទ្រង់ ។ ពេលនោះពួកគេវិលមកពីប្រកាសដំណឹងល្អបាន១ភាគ៣នៃស្រុកកាលីឡេ (មើលការពន្យល់ មក ១:៣៩)។

**៦:៣២** *នាំគ្នាចុះទូកចេញទៅ* លោកយ៉ូហានបានប្រាប់ថា ពួកគេធ្វើដំណើរទៅត្រើយម្ខាងទៀតនៃសមុទ្រកាលីឡេ(យហ ៦:១)។ ត្រង់ចំណុចនេះលោកលូកាប្រាប់កាន់តែច្បាស់ថែមទៀតថា ពួកគេធ្វើដំណើរឆ្ពោះទៅភូមិបេតសៃដា (លក ៩:១០) ជាកន្លែងដែលព្រះអម្ចាស់បានប្រទានអាហារដល់មនុស្ស៥ពាន់នាក់ នៅភាគខាងជើងច្រាំងសមុទ្រ (មើលការពន្យល់ ៧:២៤)

**៦:៣៣** *នាំគ្នារត់ទៅមុន* មានន័យថាហ្វូងបណ្តាជនបានចេញដំណើតាមក្រោយទូក តែទៅដល់ទីនោះមុន ប្រហែលជាមកពីមានខ្យល់បក់បញ្ច្រាសទូកខ្លាំងទើប បានជាធ្វើឱ្យទូកមកដល់យឺតជាងហ្វូងបណ្តាជន ។

**៦:៣៧** *៤០រៀល* គឺស្មើនឹងប្រាក់ឈ្នួលដែលមនុស្សប្រុសម្នាក់ធ្វើការក្នុងរយៈពេល៨ខែនៅសម័យនោះ (មថ ២០:២)។

**៦:៣៩** *ស្មៅខ្ចី* ស្មៅទើបលូតលាស់ស្រស់បំព្រងពណ៌ខៀវស្រងាត់នាដើមរដូវវស្សា ឬរដូវស្លឹកឈើលាស់ នៅតាមមាត់សមុទ្រកាលីឡេ ។

**៦:៤០** *១ជួរ៥០នាក់ទាំងអស់មាន១០០ជួរ* នេះជាលំនាំតាមលំដាប់ដូចជា

ទាំងអស់ដែរ ៤២គេបានបរិភោគឆ្អែតគ្រប់គ្នា ៤៣រួចប្រ
មូលចំណិតនំប៉័ង នឹងត្រីទាំងប៉ុន្មាន ដែលសល់នៅ
បាន១២កន្ត្រក ៤៤ឯពួកអ្នកដែលបានបរិភោគ នោះមាន
ប្រុសៗ៥ពាន់នាក់ ។

## ព្រះយេស៊ូវយាងកាត់លើទឹក

*៦:៤៥–៥១ = មថ ១៤:២២–៣២ យហ ៦:១៥–២១*

*៦:៥៣–៥៦ = មថ ១៤:៣៤–៣៦*

៤៥ស្រាប់តែទ្រង់បង្ខំពួកសិស្ស ឱ្យចុះទូក[ឋ]ឆ្លងទៅឯ
បេតសៃដា[ឌ] នៅត្រើយម្ខាងជាមុន ដរាបដល់ទ្រង់ឱ្យហ្វូង
មនុស្សទៅវិញអស់ ៤៦កាលទ្រង់បានឱ្យគេទៅអស់ហើយ
នោះក៏យាងឡើងទៅលើភ្នំ ដើម្បីនឹងអធិស្ឋាន[ឍ] ៤៧លុះ
ពេលព្រលប់ នោះទូកនៅកណ្តាលសមុទ្រ តែទ្រង់គង់
នៅលើគោកតែ១ព្រះអង្គទ្រង់ ៤៨ទ្រង់ក៏ឃើញពួកសិស្ស
ចែវទូកទាំងលំបាក ព្រោះច្រាសខ្យល់ លុះពេលប្រហែល
ជាយាម៤យប់ នោះទ្រង់យាងកាត់លើទឹកសមុទ្រទៅឯគេ
ហើយធ្វើហាក់ដូចជាចង់យាងបង្ហួសទៅទៀត ៤៩លុះកាល
គេបានឃើញទ្រង់យាងលើទឹកសមុទ្រដូច្នេះ នោះគេនឹក
ស្មានថាជាខ្មោចលង[ណ] ហើយក៏ស្រែកឡើង ៥០ដ្បិតគ្រប់គ្នា
បានឃើញទ្រង់ ហើយក៏ភ័យស្លុត តែទ្រង់មានបន្ទូលទៅគេ
ជា១រំពេចថា ចូរសង្ឃឹមឡើង គឺខ្ញុំទេតើ កុំភ័យអី[ត]
៥១នោះទ្រង់យាងឡើងទៅឯគេនៅក្នុងទូក[ថ] រួចខ្យល់ក៏ស្ងប់
ឈឹង[ទ] អ្នកទាំងនោះមានសេចក្តីអស្ចារ្យជាខ្លាំងពន់ពេក
ព្រមទាំងវិលវល់ក្នុងចិត្ត ៥២គេមិនបានយល់ដោយសារការ
ដែលបានចំរើននំប៉័ងទេ ដ្បិតគេមានចិត្តរឹងរូស[ធ]។
៥៣លុះបានឆ្លងទៅដល់ស្រុកគេនេសារ៉ែត ត្រើយខាង
នាយហើយ នោះក៏ឈប់ចតទូក[ន] ៥៤កាលបានឡើងពីទូក
នោះមនុស្សទាំងឡាយបានស្គាល់ទ្រង់ជា១រំពេច ៥៥ហើយ
រត់ទៅគ្រប់ក្នុងស្រុកជុំវិញ តាំងសែងមនុស្សជំងឺដេកលើពូក
មកឯទ្រង់ នៅកន្លែងត្រង់ណាដែលគេឮថា ទ្រង់គង់នៅ
៥៦ហើយកន្លែងណាក៏ដោយ ដែលទ្រង់យាងចូល ទោះក្នុង
ភូមិ ក្នុងទីក្រុង ឬស្រុកស្រែក្តី គេក៏បានដាក់មនុស្សជំងឺទាំង
ប៉ុន្មាននៅទីផ្សារ រួចទូលអង្វរទ្រង់ឱ្យគេបានគ្រាន់តែពាល់
ជាយព្រះពស្ត្រ[ប] របស់ទ្រង់តែប៉ុណ្ណោះ ហើយអស់អ្នកណា
ដែលបានពាល់ទ្រង់ នោះក៏បានជាទាំងអស់គ្នា ។

## របស់ស្អាត និងមិនស្អាត

*៧:១–២៣ = មថ ១៥:១–២០*

**៧** ១គ្រានោះពួកផារីស៊ី និងអ្នកខ្លះក្នុងពួកអាចារ្យ ដែល

**៦:៤៥** ឋ ខ.៣២ ឌ មថ ១១:២១
**៦:៤៦** ឍ លក ៣:២១
**៦:៤៩** ណ លក ២៤:៣៧
**៦:៥០** ត មថ ១៤:២៧
**៦:៥១** ថ ខ.៣២ ទ មក ៤:៣៩
**៦:៥២** ធ មក ៨:១៧–២១
**៦:៥៣** ន យហ ៦:២៤,២៥
**៦:៥៦** ប មថ ៩:២០

ការបោះជំរុំរបស់លោកម៉ូសេក្នុងវាលរហោស្ថាន (នក ១៨:២១) ។

**៦:៤២** *គេបានបរិភោគឆ្អែតគ្រប់គ្នា* ជាការពន្យល់ថា ក្រៅពីការអស្ចារ្យនេះ គឺពួកគេមិនបានគ្រប់គ្រាន់ឡើយ (ព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់បានបរិភោគអាហារថ្ងៃត្រង់ជាមួយគ្នា ហើយនិងចែកដល់ហ្វូងបណ្តាជនដែលបានដើរតាមផងដែរ ដែលនេះជាគំរូមួយយ៉ាងល្អ)។ ការសំដែងនូវការអស្ចារ្យពុំមែនជាការពិបាកសម្រាប់ព្រះយេស៊ូវទេ ដូច្នេះបញ្ជាក់ថា ទ្រង់គឺជាព្រះអម្ចាស់ពិតប្រាកដ ។ ព្រះអម្ចាស់ទ្រង់បានសន្យាថា ពេលដែលអ្នកគង្វាលពិតបានមកដល់ នោះវាលរហោស្ថាននឹងត្រឡប់ទៅជាវាលស្មៅខៀវខ្ចី ហើយហ្វូងចៀមអាចប្រមូលគ្នាមក ស៊ី និងបានឆ្អែតគ្រប់ៗគ្នា (អគ ៣៤:២៣–៣១)។ ម្យ៉ាងទៀត នៅត្រង់ចំណុចនេះ គឺជាពិធីជប់លៀងរបស់ព្រះមែស៊ីជាមួយនឹងពួកអ្នកដើរតាមទ្រង់ នៅឯវាលរហោស្ថាន (អស ២៥:៦–៩)។ ព្រះយេស៊ូវគឺជាអ្នកគង្វាលដែលប្រទាននូវសេចក្តី ត្រូវការរបស់យើង ដូច្នេះ យើងនឹងមិនខ្វះអ្វីឡើយ (ទដ ២៣:១)។

**៦:៤៣** *ចំណិតនំប៉័ង និងត្រីទាំងប៉ុន្មានដែលសល់នៅបាន១២កន្ត្រក* សាសន៍យូដាចាត់ទុកនំប៉័ងថាជាអំណោយនៃព្រះអម្ចាស់ ហើយកម្ទេចនំប៉័ងដែលជ្រុះទៅលើដី នៅក្នុងពេលបរិភោគគឺត្រូវរើសយកមកវិញ (៨:៨ និងការពន្យល់ មថ ១៥:៣៧)។

**៦:៤៤** *ប្រុសៗ* សំដៅមនុស្សពេញវ័យ បើតាមលោកម៉ាថាយបញ្ជាក់ថា ក្រៅពីស្ត្រី និងក្មេងៗ (មថ ១៤:២១)។ *៥ពាន់នាក់* ជាហ្វូងមហាជនដ៏ធំអស្ចារ្យ ដោយមានសេចក្តីពិតថា ទីនោះគឺនៅជិតក្រុងកាពើណិម និងបេតសៃដា ដែលមានប្រជាជនប្រហែល២ពាន់ទៅ៣ពាន់នាក់នៅក្នុងក្រុងនិមួយៗ ។

**៦:៤៥** *ទ្រង់...នៅត្រើយម្ខាងជាមុន* លោកយ៉ូហានបង្ហាញថាប្រជាជនបានប្រុងប្រៀបជាស្រេចហើយ ដើម្បីបង្ខំព្រះយេស៊ូវឱ្យធ្វើស្តេច (យហ ៦:១៤–១៥) ដូច្នេះហើយបានជាព្រះយេស៊ូវបញ្ជូនពួកសិស្សទ្រង់ ឱ្យឆ្លងទៅត្រើយម្ខាងមុន ក្នុងខណៈពេលដែលទ្រង់យាងទៅឯភ្នំ ដែលនៅឆ្ងាយពីទីនោះបន្តិច ដើម្បីនឹងអធិស្ឋាន ។

**៦:៤៨** *យាម៤* គឺម៉ោង ៣:០០-៦:០០ព្រឹក (១៣:៣៥ មថ ១៤:២៥ និងពន្យល់)។ *យាងកាត់លើទឹក* ត្រង់ចំណុចនេះគឺជាការបង្ហាញយ៉ាងពិសេសអំពីព្រះវត្តមាន និងអំណាចចេស្តានៃព្រះអម្ចាស់ដ៏ខ្ពស់បំផុត ដែលទ្រង់ជាអ្នកត្រួតត្រាលើសមុទ្រ (ទដ ៨៩:៩ អស ៥១:១០,១៥ យរ ៣១:៣៥)។

**៦:៤៩** *ខ្មោច* ពួកសាសន៍យូដាមានជំនឿថា វិញ្ញាណទាំងឡាយណាដែលចេញមកនៅពេលយប់ គឺនាំមកនូវគ្រោះមហន្តរាយផ្សេងៗ ។ ដោយសារតែការភ័យខ្លាចរបស់ពួកសិស្ស ទើបបណ្តាលឱ្យពួកគេគិតថា នោះជាវិញ្ញាណខ្មោចទឹក ។

**៦:៥២** *គេមិនបានយល់ដោយសារការដែលបានចំរើននំប៉័ងទេ* ពួកគេមិនបានយល់អំពីការប្រទានអាហារដល់មនុស្ស៥ពាន់នាក់ និងមិនមានការអស្ចារ្យក្នុងចិត្តទេ ពេលឃើញព្រះយេស៊ូវយាងដើរនៅលើទឹក ឬការដែលទ្រង់បញ្ជាឱ្យខ្យល់ស្ងាត់នោះ។ *គេមានចិត្តរឹងរូស* ពួកគេកំពុងបង្ហាញថា ខ្លួនគេប្រហាក់ប្រហែល នឹងពួកអ្នកប្រឆាំងនឹងព្រះយេស៊ូវដែរ ដោយបង្ហាញពីចិត្តរឹងទទឹង (៣:៥ ៨:១៧–២១ និងការពន្យល់ នក ៤:២១)។

**៦:៥៣** *គេនេសារ៉ែត* មើលការពន្យល់ មថ ១៤:៣៤ ។

**៦:៥៦** *គេបានគ្រាន់តែពាល់ជាយព្រះពស្ត្ររបស់ទ្រង់* មើលការពន្យល់ ៥:២៨ ។

**៧:១** *ពួកផារិស៊ី និងអ្នកខ្លះក្នុងពួកអាចារ្យដែលមកពីក្រុងយេរូសាឡិម* (៣:២២) ដើម្បីមកស៊ើបអង្កេតមើលសកម្មភាពរបស់ព្រះយេស៊ូវនៅស្រុក

មកពីក្រុងយេរូសាឡិម គេប្រជុំគ្នាឯទ្រង់ ២កាលគេឃើញ
ពួកសិស្សទ្រង់ខ្លះបរិភោគទាំងដៃមិនស្អាត[ផ] គឺមិនបានលាង
ចេញ នោះក៏ចោទប្រកាន់ទោស ៣ដ្បិតពួកផារិស៊ី និងពួក
យូដាទាំងអស់គ្នា គេមិនដែលបរិភោគឡើយ ទាល់តែបាន
ដុសលាងដៃយ៉ាងស្អាតអស់ពីចិត្តជាមុនសិន ដោយកាន់
តាមសណ្តាប់ពីបុរាណរបស់ពួកចាស់ទុំ[ព] ៤ហើយកាលគេ
មកពីផ្សារ នោះគេមិនបរិភោគទេ ទាល់តែបានងូតទឹករួច
សិន ក៏មានសេចក្តីឯទៀតជាច្រើន ដែលគេទទួលកាន់តាម
ដែរ ដូចជាការលាងពែង លាងឆ្នាំង លាងប្រដាប់លង្ហិន
ហើយនិងតុជាដើម[ភ] ៥ដូច្នេះ ពួកផារិស៊ី និងពួកអាចារ្យ
គេពិចារណាសួរទ្រង់ថា ហេតុអ្វីបានជាពួកសិស្សរបស់
លោកមិនកាន់តាម សណ្តាប់បុរាណរបស់ពួកចាស់ទុំ
យ៉ាងនេះ[ម] គឺគេបរិភោគ ឥតលាងដៃទេ ៦តែទ្រង់ឆ្លើយ
តបថា «ពួកអ្នកមានពុតអើយ ហោរាអេសាយបានទាយពី
អ្នករាល់គ្នាត្រូវណាស់» ដូចជាមានសេចក្តីចែងទុកមកថា
« ជនជាតិនេះ គេគោរពប្រតិបត្តិអញតែបបូរមាត់ទេ ឯចិត្ត
គេនៅឆ្ងាយពីអញណាស់ ៧ដែលគេថ្វាយបង្គំអញ ដោយ
បង្រៀនសេចក្តីបញ្ញត្តិជារបស់មនុស្ស នោះជាឥតប្រ
យោជន៍ទេ »[យ] ៨ដ្បិតអ្នករាល់គ្នាលះចោលបញ្ញត្តិរបស់
ព្រះ ទៅកាន់តាមសណ្តាប់មនុស្សវិញ[រ] ដូចជាការលាង
ឆ្នាំង លាងពែងនោះ ហើយនិងរបៀបយ៉ាងនោះជាច្រើន
ទៅទៀត ៩ទ្រង់ក៏មានបន្ទូលទៅគេថា អ្នករាល់គ្នាលះ
បង់ចោលបញ្ញត្តិព្រះមែន ដើម្បីនឹងកាន់តាមសណ្តាប់របស់
ខ្លួនវិញ[ល] ១០ដ្បិតលោកម៉ូសេបានផ្តាំថា «ចូរគោរពប្រតិបត្តិ
ឪពុកម្តាយឯង»[វ] ហើយថា «អ្នកណាដែលនិយាយអាក្រក់
ពីឪពុកម្តាយ នោះនឹងត្រូវស្លាប់ជាមិនខាន»[ស] ១១តែអ្នករាល់
គ្នាថា[ហ] បើមនុស្សណានិយាយទៅឪពុកម្តាយខ្លួនថា របស់
អ្វីដែលខ្ញុំអាចនឹងជួយម៉ែឪបាន នោះជា «គ័របាន់» គឺ
ស្រាយថាជា ដង្វាយថ្វាយព្រះហើយ ១២នោះអ្នករាល់គ្នា
មិនបើកឱ្យអ្នកនោះជួយដល់ឪពុកម្តាយ ក្នុងការអ្វីទៀតសោះ
១៣ក៏លើកព្រះបន្ទូល[ឡ]ចោល ដោយសារសណ្តាប់ផ្ទាប់[អ]
ដែលអ្នករាល់គ្នាបានបង្ហាត់បង្រៀនមក ហើយក៏ធ្វើរបៀប
យ៉ាងនោះជាច្រើនទៅទៀតដែរ ១៤រួចទ្រង់ហៅហ្វូងមនុស្ស
ទាំងអស់មកមានបន្ទូលទៅគេថា ចូរអ្នកទាំងអស់គ្នាស្តាប់
ខ្ញុំសិន ហើយឱ្យយល់ចុះ ១៥គ្មានអ្វីពីខាងក្រៅ ចូលទៅក្នុង
ខ្លួនមនុស្ស ដែលអាចនឹងធ្វើឱ្យស្មោកគ្រោកបានទេ គឺជា
សេចក្តីដែលចេញពីមនុស្សមកទេតើ ដែលធ្វើឱ្យស្មោក
គ្រោកវិញ ១៦បើអ្នកណាមានត្រចៀកសំរាប់ស្តាប់ ឱ្យ
ស្តាប់ចុះ។
១៧កាលទ្រង់បានថយពីហ្វូងមនុស្ស យាងចូលទៅក្នុងផ្ទះ

**៧:២** ផ កច ១០:១៤,២៨ ១១:៨ រម ១៤:១៤
**៧:៣** ព ខ.៥,៨,៩,១៣ លក ១១:៣៨
**៧:៤** ភ មថ ២៣:២៥ លក ១១:៣៩
**៧:៥** ម ខ.៣ កទ ១:១៤ កល ២:៨
**៧:៧** យ អស ២៩:១៣
**៧:៨** រ ខ.៣
**៧:៩** ល ខ.៣
**៧:១០** វ និក ២០:១២ ចទ ៥:១៦ ស និក ២១:១៧ លវ ២០:៩
**៧:១១** ហ មថ ២៣:១៦,១៨
**៧:១៣** ឡ ហព ៤:១២ អ ខ.៣

កាលីឡេ (មើល ការពន្យល់ ២:១៦ មថ ២:៤)។

**៧:៣** *ដុសលាងសំអាត* មើលការពន្យល់ យហ ២:៦ ។ *តាមសណ្តាប់ពីបុរាណរបស់ពួកចាស់ទុំ* ត្រូវបានគេយកមកចងរឹតយ៉ាងជាប់ (ខ.៥ មើលការពន្យល់ មថ ១៥:២)។

**៧:៤** *ផ្សារ* ជាកន្លែងដែលសាសន៍យូដាបានមកជួបជុំគ្នា ហើយប៉ះនឹងសាសន៍ដទៃ ដែលពួកគ្រូក្រឹត្យវិន័យចាត់ទុកថា ជាការមិនស្អាត ។

**៧:៦** *អេសាយបានទាយ* លោកអេសាយនិយាយសំដៅលើអ្នកដឹកនាំសាសនាសម័យនោះ (អស ២៩:១៣)។ ព្រះយេស៊ូវទ្រង់បានដកស្រង់បទគម្ពីរអេសាយមកបញ្ជាក់ថា ទំនៀមទម្លាប់របស់ពួកគ្រូក្រឹត្យវិន័យ ទាំងនោះគឺកើតឡើងដោយសារមនុស្ស ហើយមិនមែនជាបញ្ញត្តិរបស់ព្រះទេ (ខ.៧)។

**៧:៨** *បញ្ញត្តិរបស់ព្រះ. . .តាមសណ្តាប់មនុស្សវិញ* ព្រះយេស៊ូវបានបញ្ជាក់នូវភាពខុសគ្នាថា បញ្ញត្តិរបស់ព្រះគឺមានក្នុងព្រះគម្ពីរ ចំណែកឯប្រពៃណីរបស់ពួកចាស់ទុំ (ខ.៣) គឺមិនមែនជាព្រះគម្ពីរទេ ដូច្នេះប្រពៃណីទាំងនោះមិនមានអំណាចអ្វីមកចងមនុស្សលោកបានឡើយ ។

**៧:១០** បទគម្ពីរនេះគឺជាបញ្ញត្តិទី៥ដែលត្រូវបានលើកឡើង ទាំងក្នុងទម្រង់វិជ្ជមាន និងក្នុងទម្រង់អវិជ្ជមាន ។

**៧:១១** *គ័របាន់* ពាក្យនេះជាភាសាហេព្រើរប្រែថា "ដង្វាយ" (មើលការពន្យល់ លវ ១:២)។ ពួកកូនប្រុសសាសន៍យូដាដែលគ្មានទំនួលខុសត្រូវ បានប្រើប្រាស់ពាក្យនេះនៅក្នុងពិធីស្បថនៃសាសនារបស់ខ្លួនថា ការនិយាយដូច្នេះគឺមានន័យថា បានថ្វាយទៅព្រះនូវទ្រព្យសម្បត្តិដែលខ្លួនរកបាន បើពុំដូច្នោះទេធ្វើឱ្យទ្រព្យសម្បត្តិ ដែលខ្លួនរកបានត្រូវប្រគល់ទៅឱ្យឪពុកម្តាយរបស់ខ្លួនវិញ ។ តាមការពិតគេបាន គេចចេញពីការទទួលខុសត្រូវទាំងនោះហើយ ។ ដូច្នេះពាក្យថា "គ័របាន់" មានន័យយ៉ាងសាមញ្ញថា កូនត្រូវមានទំនួលខុសត្រូវចំពោះឪពុកម្តាយរបស់ខ្លួន ដូចបានចែងទុកក្នុងក្រឹត្យវិន័យស្រាប់ហើយ ។ ពួកគ្រូក្រឹត្យវិន័យចាត់ទុកពាក្យសម្បថ គ័របាន់ថាជាចំណងចងខ្លួនគេយ៉ាងមាំ ។ ការអនុវត្តន៍គឺជាផ្នែកមួយនៃប្រពៃណីជា ច្រើនដែលបានប្រកាន់ខ្ជាប់នូវក្រឹត្យវិន័យ ក្នុងពេលជាមួយគ្នានោះពួកគេភ្លេចគិត អំពីសេចក្តីខាងឯវិញ្ញាណទៅវិញ ។

**៧:១៣** *លើកព្រះបន្ទូលចោល ដោយសារសណ្តាប់ផ្ទាប់* ពួកគ្រូក្រឹត្យវិន័យបានលើកយកបទគម្ពីរនៅក្នុង "ជន ៣០:១-២" ដើម្បីគាំទ្រចំពោះសេចក្តីដែលពួកគេនិយាយអំពី "គ័របាន់" (ដង្វាយថ្វាយព្រះ មក ៧:១១) ប៉ុន្តែព្រះយេស៊ូវគ្រីស្ទបានបដិសេធយ៉ាងដាច់ខាត ចំពោះការអនុវត្តន៍ទាំងឡាយណា ដែលប្រើប្រាស់នូវសេចក្តីបង្រៀនតែមួយផ្នែកនៃព្រះគម្ពីរ ហើយលះបង់ចោលផ្នែកផ្សេងៗទៀត ។ ការបកស្រាយរបស់អ្នកនិពន្ធនៅក្នុង ជន ៣០:១-២ ធ្វើឱ្យមានន័យគ្រប់គ្រាន់ក្នុងវគ្គនោះ តែនៅខ្វះចន្លោះក្នុងក្រឹត្យវិន័យទាំងមូល ។ ព្រះអម្ចាស់មិនសព្វព្រះហឫទ័យ ឱ្យស្តាប់បង្គាប់តែបញ្ញត្តិខ្លះ ហើយលះបង់ចោលខ្លះនោះឡើយ ។

**៧:១៦** បទគម្ពីរនេះដូចជាការបន្ថែមទៅលើ "៤:៩ ឬ ៤:២៣"។

វិញ នោះពួកសិស្សទូលសួរទ្រង់[ក] ពីពាក្យប្រៀបប្រដូចនោះ
១៨ ទ្រង់មានបន្ទូលថា តើអ្នករាល់គ្នានៅតែមិនយល់ដែរឬ
អី តើអ្នករាល់គ្នានឹកមិនឃើញទេឬអីថា របស់អ្វីពីខាង
ក្រៅដែលចូលក្នុងមនុស្ស នោះពុំអាចនឹងធ្វើឱ្យស្មោកគ្រោក
បានទេ ១៩ ដ្បិតរបស់នោះមិនបានចូលទៅក្នុងចិត្ត គឺចូល
ទៅតែក្នុងពោះប៉ុណ្ណោះ រួចចេញទៅក្នុងបង្គន់ ដូច្នេះ
អស់ទាំងអាហារ[ខ]ឈ្មោះថាជារបស់ស្អាតវិញ[គ] ២០ ទ្រង់ក៏
មានបន្ទូលថា គឺជាសេចក្តីដែលចេញពីមនុស្សមកទេ
តើដែលធ្វើឱ្យស្មោកគ្រោកនោះ ២១ ដ្បិតនៅពីខាងក្នុង
ពីក្នុងចិត្តរបស់មនុស្ស មានចេញអស់ទាំងគំនិតអាក្រក់
យ៉ាងនេះ គឺសេចក្តីកំផិត សហាយស្មន់ កាប់សំឡាប់គេ
២២ លួចប្លន់ លោភោ[ឃ] ខិលខូច ឧបាយកល អាសអាភាស
ភ្នែកអាក្រក់ ជេរប្រមាថ ឆ្មើងឆ្មៃ និងសេចក្តីចំកួត ២៣ គឺ
សេចក្តីអាក្រក់ទាំងនេះហើយ ដែលចេញពីខាងក្នុងមក
ហើយធ្វើឱ្យមនុស្សស្មោកគ្រោកវិញ។

## សេចក្តីជំនឿរបស់ស្ត្រីសាសន៍ស៊ីរ៉ូ-ភេនីស

*៧:២៤-៣០ = មថ ១៥:២១-២៨*

២៤ ទ្រង់ក្រោកឡើងយាងចេញពីទីនោះ ទៅឯប្រទល់
ដែនស្រុកទីរ៉ុស[ង]និងស្រុកស៊ីដូន រួចចូលទៅក្នុងផ្ទះ១ មិនចង់
ឱ្យអ្នកណាដឹងសោះ តែទ្រង់នៅកំបាំងពុំបាន ២៥ ដ្បិតមាន
ស្ត្រីម្នាក់មានកូនស្រី១ ដែលអារក្សអសោចិ៍[ច] ចូលនាងបាន
ឮនិយាយពីទ្រង់ ក៏មកទំលាក់ខ្លួនក្រាបនៅទៀបព្រះបាទ
ទ្រង់(២៦ រីឯស្ត្រីនោះ ជាសាសន៍ក្រេក កូនកាត់ស៊ីរ៉ូ-ភេនីស)
នាងក៏ទូលអង្វរឱ្យទ្រង់ដេញអារក្សពីកូនស្រីនាងចេញ
២៧ តែព្រះយេស៊ូវមានបន្ទូលទៅនាងថា ទុកឱ្យកូនក្មេង
ស៊ីឆ្អែតជាមុនសិន ព្រោះមិនគួរនឹងយកនំបុ័ងរបស់កូន
ក្មេងបោះទៅឱ្យឆ្កែស៊ីទេ ២៨ នាងទូលឆ្លើយថា មែនហើយ
ព្រះអម្ចាស់ ប៉ុន្តែឆ្កែនៅក្រោមតុ វាស៊ីកំទេចពីកូនក្មេងដែរ
២៩ នោះទ្រង់មានបន្ទូលថា ដោយព្រោះពាក្យនោះ ចូរ
នាងទៅចុះ អារក្សបានចេញពីកូននាងហើយ ៣០ រួចកាល
នាងបានទៅដល់ផ្ទះវិញ ក៏ឃើញកូនដេកនៅលើគ្រែ
អារក្សបានចេញស្រេចហើយ ។

## ព្រះយេស៊ូវប្រោសមនុស្សថ្លង់ និងមនុស្សគ

*៧:៣១-៣៧ = មថ ១៥:២៩-៣១*

៣១ លំដាប់ពីនោះមក ទ្រង់ចេញពីព្រំដែនស្រុកទីរ៉ុស[ឆ]និង
ស៊ីដូនក៏យាងកាត់ស្រុកដេកាប៉ូល[ជ] មកដល់សមុទ្រកាលីឡេ
វិញ[ឈ] ៣២ នោះមានគេនាំមនុស្សថ្លង់ម្នាក់ ដែលនិយាយទាំង
ពិបាក[ញ]មកឯទ្រង់ ក៏ទូលអង្វរឱ្យទ្រង់ដាក់ព្រះហស្តលើ[ដ]គាត់
៣៣ ទ្រង់ក៏នាំគាត់ចេញពីហ្វូងមនុស្សទៅ ដោយឡែកយក
អង្គុលីព្រះហស្តដាក់ក្នុងត្រចៀកគាត់ រួចស្តោះទឹកព្រះ
ឱស្ឋ[ឋ]ហើយពាល់អណ្តាតគាត់ ៣៤ កាលទ្រង់បានងើបទត
ទៅលើមេឃ[ឌ]ហើយ នោះទ្រង់ថ្ងូរ[ឍ] រួចមានបន្ទូលទៅគាត់

**៧:១៧** ក មក ៩:២៨
**៧:១៩** ខ រម ១៤:១-១២ កល ២:១៦ ១ធថ ៤:៣-៥
គ កច ១០:១៥
**៧:២២** ឃ មថ ២០:១៥
**៧:២៤** ង មថ ១១:២១
**៧:២៥** ច មថ ៤:២៤
**៧:៣១** ឆ ខ.២៤ មថ ១១:២១
ជ មថ ៤:២៥ មក ៥:២០
ឈ មថ ៤:១៨
**៧:៣២** ញ មថ ៩:៣២ លក ១១:១៤
ដ មក ៥:២៣
**៧:៣៣** ឋ មក ៨:២៣
**៧:៣៤** ឌ មក ៦:៤១ យហ ១១:៤១
ឍ មក ៨:១២

**៧:១៩** ព្រះយេស៊ូវបានប្រកាសថា "អាហារជារបស់ស្អាត" ហើយលោកម៉ាកុស លើកយកមកដើម្បីជួយអ្នកអានរបស់គាត់ឱ្យឃើញពីសារៈសំខាន់នៃសេចក្តីប្រកាសរបស់ទ្រង់(កច ១០:៩-១៦)។

**៧:២០** *ស្មោកគ្រោក* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ការនេះកើតចេញពីចិត្តមិនបរិសុទ្ធ មិនមែនមកពីការប្រព្រឹត្តផ្នែកខាងក្រៅ ដូចដែលពួកសាសន៍យូដាយល់ឃើញនោះទេ ។ ការប្រកបជាមួយព្រះមិនត្រូវបានរំខានដោយដៃ ឬអាហារមិនស្អាតនោះទេ ប៉ុន្តែគឺដោយសារអំពើបាបវិញ (ខ.២១-២៣)។

**៧:២៤** *ស្រុកទីរ៉ុស* ជាទីក្រុងមួយនៃសាសន៍ដទៃ ស្ថិតនៅក្នុងស្រុកភេនីស (សព្វថ្ងៃហៅល្បាណូន) ជាប់ព្រំប្រទល់ស្រុកកាលីឡេភាគពាយព្យ ។ ព្រះយេស៊ូវបានធ្វើ ដំណើរប្រហែល៤៨គ.មពីស្រុកកាពើណិមទើបដល់ស្រុកទីរ៉ុស ។ *មិនចង់ឱ្យអ្នកណា ដឹងសោះ* ចាប់ពីផ្តល់អាហារមនុស្ស ៥ពាន់នាក់មក(៦:៣០-៤៤) ព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់បានចំណាយពេលជាច្រើននៅស្រុកកាលីឡេ ។ គោលបំណងគឺដើម្បីជៀសវាងការប្រឆាំងនានា និងយកឱកាសបង្រៀនពួកសិស្សរបស់ទ្រង់ ដោយឡែកផងដែរ (៩:៣០-៣១)។ កន្លែងដែលទ្រង់យាងទៅមាន (១).ច្រាំងសមុទ្រកាលីឡេភាគឦសាន(៦:៣០-៥៣) (២).ភេនីស(៧:២៤-៣០) (៣).ស្រុកដេកាប៉ូល(៧:៣១-៨:១០) និង (៤).សេសារា-ភីលីព(៨:២៧-៩:៣២)។

**៧:២៦** *សាសន៍ក្រិក* ប្រហែលសំដៅលើសាសន៍ដទៃ ។ *ស៊ីរ៉ូ-ភេនីស* មានន័យថាភេនីសនៅក្រោមការត្រួតត្រារបស់ស៊ីរ៉ូក្នុងសម័យនោះ ។ បានជាលោកម៉ាកុសប្រើពាក្យនេះ ប្រហែលដើម្បីបង្ហាញឱ្យឃើញច្បាស់ថាស្ត្រីនោះមកពីលីប៊ី-ភេនីស នៃប្រទេសអាហ្វ្រិចខាងជើង ។

**៧:២៧** *ទុកឱ្យកូនក្មេងស៊ីឆ្អែតជាមុនសិន ព្រោះមិនគួរនឹងយកនំបុ័ងរបស់កូនក្មេងបោះទៅឱ្យឆ្កែស៊ីទេ* "មើលការពន្យល់ មថ ១៥:២៦"។

**៧:២៨** *មែនហើយ ព្រះអម្ចាស់* មានតែម្តងនេះគត់នៅក្នុងដំណឹងល្អនេះដែលព្រះយេស៊ូវមានបន្ទូលថា "ជាព្រះអម្ចាស់"។

**៧:៣១** *ទ្រង់ចេញពីព្រំដែនស្រុកទីរ៉ុស និងស៊ីដូន ក៏យាងកាត់ស្រុកដេកាប៉ូល មកដល់សមុទ្រកាលីឡេវិញ* ការនេះអាចឃើញយ៉ាងច្បាស់ថាព្រះយេស៊ូវយាងទៅទិសខាងជើង ដោយចេញពីស្រុកទីរ៉ុសទៅស្រុកស៊ីដូន (ចម្ងាយប្រហែល ៤០គ.ម)បន្តទៅទិសអាគ្នេយ៍កាត់តាមទឹកដីស្តេចហេរ៉ូឌ-ភីលីពគ្រប់គ្រងនៅត្រើយ ខាងកើតសមុទ្រកាលីឡេ ។ ទ្រង់បានយាងតាមផ្លូវបត់បែនជាច្រើន ដើម្បីជៀសវាងឆ្លងកាត់ទឹកដីកាលីឡេ ដែលគ្រប់គ្រងដោយហេរ៉ូឌ-អនុរាជ(៦:១៧-២៩) និងកន្លែងដែលហ្វូងបណ្តាជនបង្ខំឱ្យព្រះយេស៊ូវធ្វើជាស្តេច (យហ ៦:១៤-១៦)។ *ស្រុកដេកាប៉ូល* មើលការពន្យល់ ខ.២៤ មថ ៤:២៥ ។

**៧:៣៤** *អិបផាថា* ពាក្យនេះជាភាសអើរ៉ាមដែលលោកម៉ាកុសបកប្រែ

ថា «អិបផាថា» គឺថា ឱ្យបើកឡើង ៣៥ស្រាប់តែត្រចៀកក៏បើក
សរសៃអណ្តាតបានធូរ នោះគាត់និយាយបានយ៉ាងច្បាស់[ណ]
៣៦ទ្រង់ហាមមិនឱ្យគេប្រាប់ឱ្យអ្នកណាដឹងឡើយ[ត] ប៉ុន្តែ
ដែលទ្រង់ហាមប៉ុណ្ណា នោះគេចេះតែប្រកាសប្រាប់រឹតតែ
ច្រើនឡើងប៉ុណ្ណោះទៀត ៣៧គេនឹកប្លែកក្នុងចិត្តជាខ្លាំងពន់
ពេក ដោយពាក្យថា លោកបានធ្វើការទាំងអស់សុទ្ធតែល្អ
គឺបានប្រោសទាំងមនុស្សថ្លង់ឱ្យស្តាប់ឮ ហើយមនុស្សគឱ្យ
និយាយបាន។

## ព្រះយេស៊ូវប្រទានអាហារដល់មនុស្ស៤ពាន់នាក់

*៨:១-៩ = មថ ១៥:៣២-៣៩ មក ៦:៣២-៤៤*

*៨:១១-២១ = មថ ១៦:១-១២*

**៨** ១នៅគ្រានោះ មានហ្វូងមនុស្សជាធំណាស់ ហើយគេគ្មាន
អ្វីបរិភោគ បានជាព្រះយេស៊ូវទ្រង់ហៅពួកសិស្សមកមាន
បន្ទូលថា ២ខ្ញុំមានចិត្តក្តួលអាណិតដល់មនុស្សទាំងអស់នេះ[ថ]
ណាស់ ពីព្រោះគេបានមកនៅជាមួយនឹងខ្ញុំ៣ថ្ងៃហើយ តែ
ឥឡូវនេះគ្មានអ្វីបរិភោគទេ ៣បើខ្ញុំឱ្យគេត្រឡប់ទៅផ្ទះវិញ
ទាំងអត់ នោះគេនឹងហេវតាមផ្លូវ ដ្បិតខ្លះបានមកពីឆ្ងាយ
ណាស់ ៤ពួកសិស្សទូលឆ្លើយថា នៅទីស្ងាត់នេះ តើនឹងរក
នំបុ័ងពីណា ដើម្បីចំអែតដល់មនុស្សទាំងនេះបាន ៥ទ្រង់សួរ
គេថា អ្នករាល់គ្នាមាននំបុ័ងប៉ុន្មាន គេទូលឆ្លើយថា មាន៧
៦នោះទ្រង់បង្គាប់ឱ្យហ្វូងមនុស្សអង្គុយនៅដី រួចទ្រង់យក
នំបុ័ង៧នោះមក ក៏អរព្រះគុណ ហើយកាច់ប្រទានដល់ពួក
សិស្ស ឱ្យលើកទៅជូនដល់ហ្វូងមនុស្ស គេក៏លើកទៅ ៧មាន
ត្រីតូចៗខ្លះដែរកាលទ្រង់បានប្រទានពរហើយ នោះក៏
បង្គាប់ឱ្យលើកយកទៅឱ្យគេទៀត[ទ] ៨ហើយទាំងអស់គ្នា
បានបរិភោគឆ្អែត រួចគេប្រមូលចំណិត ដែលសល់នៅបាន៧
កំប្រោង[ធ] ៩ឯពួកអ្នកដែលបានបរិភោគនោះមានចំនួន៤ពាន់
នាក់ រួចទ្រង់ឱ្យគេទៅវិញ ១០ស្រាប់តែទ្រង់យាងចុះទូក
ជាមួយនឹងពួកសិស្សទៅឯស្រុកដាលម៉ានូថាទៅ។
១១នោះពួកផារិស៊ីចេញមក តាំងជជែកដើម្បីនឹងល្បងទ្រង់
ដោយសូមឱ្យទ្រង់សំដែងទីសំគាល់ពីលើមេឃ[ន] ឱ្យគេឃើញ
១២ទ្រង់ក៏ថ្ងូរក្នុងព្រះហឫទ័យ[ប] ហើយមានបន្ទូលថា ហេតុអ្វី
បានជាមនុស្សតំណនេះចង់រកតែទីសំគាល់ដូច្នេះ ខ្ញុំប្រាប់
អ្នករាល់គ្នាជាប្រាកដថា នឹងគ្មានទីសំគាល់ណាប្រទាន
មកមនុស្សតំណនេះឡើយ ១៣រួចទ្រង់យាងចេញពីគេ
ចុះទូកឆ្លងទៅឯត្រើយម្ខាងវិញ ។

## ដំបែរបស់ពួកផារិស៊ី និងពួកហេរ៉ូឌ

១៤ឯពួកសិស្ស គេភ្លេចយកនំបុ័ងទៅ នៅជាប់តែមួយ១

**៧:៣៥** ណ អស ៣៥:៥,៦
**៧:៣៦** ត មថ ៨:៤
**៨:២** ថ មថ ៩:៣៦
**៨:៧** ទ មថ ១៤:១៩
**៨:៨** ធ ខ.២០
**៨:១១** ន មថ ១២:៣៨
**៨:១២** ប មក ៧:៣៤

សម្រាប់ពួកសាសន៍ដទៃ ។

**៧:៣៥** *ស្រាប់តែត្រចៀកក៏បើក...និយាយបានយ៉ាងច្បាស់* ព្រះយេស៊ូវបានកំពុងធ្វើនូវអ្វីដែលទ្រង់បានសន្យាថា នឹងធ្វើនៅពេលទ្រង់បានយាងមក ដើម្បីរំដោះរាស្ត្ររបស់ទ្រង់ (អស ៣៥:៥-៦) ។

**៧:៣៦** *ហាមមិនឱ្យគេប្រាប់ឱ្យអ្នកណាដឹងឡើយ* (១:៤៤ និងការពន្យល់ ៥:១៩,៤៣ មថ ៨:៤ ១៦:២០) ។

**៨:១-១០** ថ្វីបើមានការវាយប្រហារដូចគ្នារវាងរឿងនេះ និងរឿងក្នុង ៦:៣៤-៤៤ ក៏ដោយ ក៏រឿងនេះមានហេតុការណ៍ពីរ ដែលបង្ហាញពិតៗគួរឱ្យកត់សំគាល់ថា អង្គព្រះយេស៊ូវបានជាប់ទាក់ទងទៅនឹងការប្រទានអាហារដល់មនុស្សទាំងពីរ លើកនោះដោយផ្ទាល់ (ខ.១៨-២០) ។ រឿងពិស្តាខុសគ្នាមែន តែមានន័យដូចគ្នា ។

**៨:១** *មានហ្វូងមនុស្សជាធំណាស់* តាំងពីហេតុការណ៍បានកើតឡើងនៅក្នុងតំបន់ដេកាប៉ូល (៧:៣១) ហ្វូងមនុស្សត្រូវបានមកមូលគ្នាទាំងសាសន៍យូដា និងសាសន៍ដទៃ ។

**៨:២** *ខ្ញុំមានចិត្តក្តួលអាណិតដល់មនុស្សទាំងអស់នេះណាស់* ព្រះយេស៊ូវមានចិត្តក្តួលអាណិត ពីព្រោះគេប្រៀបដូចជាហ្វូងចៀម ដែលគ្មានអ្នកគង្វាល (៦:៣៤) ហើយទីនេះទ្រង់ក៏មានចិត្តក្តួលអាណិតទៀត ពីព្រោះពួកគេគ្មានអ្វីបរិភោគ ។

**៨:៤** *តើនឹងរកនំបុ័ងពីណា ដើម្បីចំអែតដល់មនុស្សទាំងនេះបាន?* ពួកសិស្សរបស់ព្រះយេស៊ូវនិយាយយ៉ាងដូច្នេះ ពីព្រោះពួកគេចង់បញ្ជាក់ថា មានតែទ្រង់ប៉ុណ្ណោះ ដែលអាចបំពេញសេចក្តីត្រូវការដល់មនុស្សទាំងនោះបាន ។ ពួកគេក៏មិនបានភ្លេច ដែរនូវការប្រទានអាហារដល់មនុស្ស៥ពាន់នាក់នោះ (៦:៣៤-៤៤) ដូច្នោះហើយ ទើបពួកគេថ្វាយភារកិច្ចក្នុងការរកនំបុ័ងនេះដល់ព្រះយេស៊ូវទ្រង់ជាអ្នកដោះស្រាយវិញ ។ ម្យ៉ាងទៀត សំណួរនេះបង្ហាញអំពីភាពស្ពឹកខាងឯវិញ្ញាណរបស់ពួកសិស្ស ឬថាជាពួកអ្នករៀនស្ពឹក ។

**៨:៨** *៧កំប្រោង* មើលការពន្យល់ មថ ១៥:៣៧ ។

**៨:៩** *៤ពាន់នាក់* មើលការពន្យល់ ៦:៤៤ ។

**៨:១០** *ដាលម៉ានូថា* ជាតំបន់រាបស្មើនៅភាគខាងត្បូងនៃគេនេសារ៉ែតមានគុហា រូងថ្មមួយ ដែលមានឈ្មោះថា "ដាលម៉ានូថា" ប្រហែលជាកន្លែងដែលព្រះយេស៊ូវបានសម្រាកនៅទីនោះ ។ តាមលោកម៉ាថាយនិយាយថា ព្រះយេស៊ូវបានយាងទៅបរិវេណស្រុកម៉ាកាដាន់ (មើលការពន្យល់ មថ ១៥:៣៩) ។ ស្រុកម៉ាកាដាន់ និងស្រុកដាលម៉ានូថាស្ថិតនៅភាគខាងលិចនៃច្រាំងសមុទ្រកាលីឡេ ហើយប្រហែលជាមានឈ្មោះជាច្រើនស្រដៀងគ្នានេះ ឬមានពីរកន្លែងដែលនៅជិតៗនោះ ។

**៨:១១** *ផារិស៊ី* មើលការពន្យល់ ២:១៦ ។ *សំដែងទីសំគាល់ពីលើមេឃ* ពាក្យថា "លើមេឃ" នៅក្នុងភាសាដើមប្រើពាក្យថា "ស្ថានសួគ៌"។ ពួកផារិស៊ីចង់ឃើញភស្តុតាងដែលបង្ហាញថា ព្រះយេស៊ូវមានអំណាចរបស់ព្រះជាជាងការសំដែងភាពអស្ចារ្យ ប៉ុន្តែទ្រង់បានបដិសេធការសំដែងទីសំគាល់នោះ ព្រោះការដែលពួកគេសូមនោះកើតចេញពីការមិនជឿ ។

**៨:១៣** *ត្រើយម្ខាង* គឺនៅច្រាំងសមុទ្រកាលីឡេភាគខាងកើត ។

ដុំក្នុងទូកប៉ុណ្ណោះ ១៥ទ្រង់ក៏ផ្ដាំគេថា ចូរប្រុងមើល ហើយ
ប្រយ័ត្ននឹងដំបែ[ផ]របស់ពួកផារិស៊ី[ព] និងរបស់ហេរ៉ូឌ ឱ្យមែន
ទែន[ភ] ១៦គេរិះគិតគ្នាថា គឺពីព្រោះយើងគ្មាននំបុ័ងទេដឹង
១៧កាលព្រះយេស៊ូវបានជ្រាប នោះទ្រង់មានបន្ទូលថា
ហេតុអ្វីបានជាអ្នករាល់គ្នារិះគិតថា ពីព្រោះគ្មាននំបុ័ង
ដូច្នេះ តើអ្នករាល់គ្នានឹកមិនទាន់ឃើញ ឬមិនយល់ទេឬអី
តើមានចិត្តរឹងរូសឬអី[ម] ១៨អ្នករាល់គ្នាមានភ្នែកតើមើល
មិនឃើញ មានត្រចៀក តើស្ដាប់មិនឮ ហើយមិនចាំទេឬអី
១៩ពីកាលខ្ញុំបានកាច់នំបុ័ង៥ឱ្យដល់៥ពាន់នាក់ នោះតើ
ប្រមូលចំណិត ដែលសល់ដាក់ពេញបានប៉ុន្មានកន្ត្រក គេ
ទូលឆ្លើយថា បាន១២[យ] ២០ហើយកាលកាច់នំបុ័ង៧ឱ្យដល់
៤ពាន់នាក់ នោះបានប្រមូលចំណិតដែលសល់ ដាក់ពេញ
បានប៉ុន្មានកំប្រោង គេទូលឆ្លើយថា បាន៧[រ] ២១នោះទ្រង់
សួរថា ម្ដេចក៏អ្នករាល់គ្នានៅតែមិនយល់ទៀត[ល]។

## ព្រះយេស៊ូវប្រោសមនុស្សខ្វាក់

២២ទ្រង់ក៏យាងមកដល់ក្រុងបេតសៃដា[វ] រួចមានគេនាំ
មនុស្សខ្វាក់ម្នាក់មក[ស]ទូលអង្វរឱ្យទ្រង់ពាល់គាត់ ២៣ទ្រង់ក៏
ចាប់ដៃមនុស្សខ្វាក់នោះនាំចេញទៅក្រៅភូមិ រួចស្ដោះ
ដាក់[ហ]ភ្នែកគាត់ ហើយដាក់ព្រះហស្តលើ[ឡ] ព្រមទាំងសួរបើ
គាត់ឃើញអ្វីឬទេ ២៤គាត់ក៏ងើបភ្នែកឡើងទូលឆ្លើយថា
ខ្ញុំឃើញមនុស្សដើរ មើលទៅដូចជាដើមឈើ ២៥នោះទ្រង់
ដាក់ព្រះហស្តលើភ្នែកគាត់ម្ដងទៀត ប្រាប់ឱ្យងើបឡើង
មើលស្រាប់តែភ្នែកគាត់បានភ្លឺឡើង ឃើញច្បាស់ទាំងអស់
២៦ទ្រង់ឱ្យគាត់ទៅផ្ទះវិញ ទាំងហាមថា កុំឱ្យចូលទៅក្នុង
ភូមិ ឬប្រាប់អ្នកណានៅក្នុងភូមិឡើយ។

## សេចក្ដីជំនឿលោកពេត្រុស

*៨:២៧–២៩ = មថ ១៦:១៣–១៦ លក ៩:១៨–២០*

២៧ព្រះយេស៊ូវ នឹងពួកសិស្ស ក៏ចេញទៅឯភូមិទាំង
ប៉ុន្មាននៅស្រុកសេសារា–ភីលីព ទ្រង់មានបន្ទូលសួរពួក
សិស្ស តាមផ្លូវថា តើមនុស្សទាំងឡាយ គេថាខ្ញុំជាអ្នកណា
២៨ពួកសិស្សទូលឆ្លើយថា ជាយ៉ូហាន–បាទីស្ទ[អ] ខ្លះថាជា
អេលីយ៉ា[ក] ហើយខ្លះទៀតថាជាហោរាណាមួយ ២៩ទ្រង់
សួរថា ចុះឯអ្នករាល់គ្នា តើថាខ្ញុំជាអ្នកណា នោះពេត្រុស
ឆ្លើយឡើងថា ទ្រង់ជាព្រះគ្រីស្ទ[ខ] ៣០ទ្រង់ក៏ហាមផ្ដាច់ មិន
ឱ្យគេប្រាប់អ្នកណាពីដំណើរទ្រង់សោះ[គ]។

## ព្រះយេស៊ូវថ្លែងទំនាយពីការសុគតរបស់ទ្រង់

*៨:៣១–៩:១ = មថ ១៦:២១–២៨ លក ៩:២២–២៧*

៣១រួចទ្រង់ចាប់តាំងបង្រៀនគេថាកូនមនុស្ស[ឃ]ត្រូវរងទុក្ខ
ជាច្រើន[ង] ហើយត្រូវពួកចាស់ទុំ ពួកសង្គ្រាជ នឹងពួក

**៨:១៥** ផ ១កថ ៥:៦–៨
ព លក ១២:១
ភ មថ ១៤:១
មក ១២:១៣
**៨:១៧** ម អស ៦:៩,១០ មក ៦:៥២
**៨:១៩** យ មថ ១៤:២០
មក ៦:៤១–៤៤
លក ៩:១៧
យហ ៦:១៣
**៨:២០** រ ខ.៦–៩
មថ ១៥:៣៧
**៨:២១** ល មក ៦:៥២
**៨:២២** វ មថ ១១:២១
ស មក ១០:៤៦
យហ ៩:១
**៨:២៣** ហ មក ៧:៣៣ ឡ មក ៥:២៣
**៨:២៨** អ មថ ៣:១
ក មឡ ៤:៥
**៨:២៩** ខ យហ ៦:៦៩ ១១:២៧
**៨:៣០** គ មថ ៨:៤ ១៦:២០ ១៧:៩
មក ៩:៩ លក ៩:២១
**៨:៣១** ឃ មថ ៨:២០

**៨:១៥** *ដំបែរបស់ពួកផារិស៊ី និងរបស់ហេរ៉ូឌ* ជាទូទៅនៅក្នុងគម្ពីរសញ្ញាថ្មី ដំបែ តំណាងឱ្យសេចក្ដីអាក្រក់ ឬអំពើពុករលួយ (មថ ១៦:៦,១១ លក ១២:១ ១កថ ៥:៦–៨ កទ ៥:៩ តែ មថ ១៣:៣៣ ហាក់បីដូចជាករណីលើកលែង មើលពន្យល់ ខនេះ)។ ពាក្យប្រៀបប្រដូចនេះរួមទាំងគំនិតផងដែរ កាលដាក់ដំបែបន្តិចចូល នោះអាចធ្វើឱ្យម្សៅឡើងធំបាន ។ នៅក្នុងបទគម្ពីរនេះដំបែមានជាប់ទាក់ទងទៅនឹងអំណាចអាក្រក់ដែលពួកផារិស៊ី និងពួកហេរ៉ូឌបានប្រើតាមចិត្តរបស់ពួកគេ (លក ២៣:៨) ហើយពេលនេះពួកគេបានប្រើអំណាចនោះ ដើម្បីសុំឱ្យព្រះយេស៊ូវធ្វើទីសំគាល់ ដែលបង្ហាញថា ទ្រង់មានអំណាចជាព្រះឱ្យពួកគេមើល(មើលការ ពន្យល់ ខ.១១)។

**៨:១៨–២០** ខទាំងនេះជាប់ទាក់ទងទៅនឹងរឿងប្រទានអាហារឱ្យមនុស្សទាំងពីរលើក (មើលការពន្យល់ ខ.១–១០)។

**៨:២២** *បេតសៃដា* មើលការពន្យល់ មថ ១១:២១ ។

**៨:២៤** *មនុស្សដើរ មើលទៅដូចជាដើមឈើ* បុរសម្នាក់នោះអាចមើលឃើញព្រាលៗហើយ ឥឡូវនេះគាត់មិនបានគិតថា ខ្លួនកំពុងតែដើរបុកដើមឈើដូចកាលនៅងងឹតនោះឡើយ តែហាក់បីដូចជាដើមឈើចេះរត់នោះ ដោយសារតែភ្នែកគាត់មិនទាន់បានភ្លឺច្បាស់ ។

**៨:២៥** *នោះទ្រង់ដាក់ព្រះហស្តលើភ្នែកគាត់ម្ដងទៀត* ការនេះមានតែម្ដងគត់នៅក្នុងព្រះរាជកិច្ចរបស់ព្រះយេស៊ូវ ។ *ភ្នែកគាត់បានភ្លឺឡើងឃើញច្បាស់ទាំងអស់* ការប្រោសមនុស្សខ្វាក់ម្នាក់នេះ ជាការបង្ហាញមួយទៀតថាព្រះយេស៊ូវកំពុងតែធ្វើអ្វីៗទាំងអស់ ដែលព្រះបានសន្យាក្នុងពេលទ្រង់បាននាំមកនូវសេចក្ដីសង្គ្រោះនោះ (អស ៣៥:៥)។

**៨:២៦** *កុំឱ្យចូលទៅក្នុងភូមិ* មានន័យថា កុំឱ្យប្រាប់គេនូវអ្វីដែលព្រះយេស៊ូវជួយគាត់នោះឡើយ ដែលបណ្ដាលឱ្យឆាប់ជួបវិបត្តិមុននឹងទ្រង់បំពេញកិច្ចការរបស់ទ្រង់ចប់សព្វគ្រប់ (១:៤៤ និងការពន្យល់ ៥:១៩,៤៣ មថ ៨:៤ ១៦:២០)។

**៨:២៧** *ស្រុកសេសារា–ភីលីព* មើលការពន្យល់ ៧:២៤ មថ ១៦:១៣ ។

**៨:២៩** *ព្រះគ្រីស្ទ* ជាភាសាក្រិក"ព្រះមែស៊ី"ជាភាសាហេព្រើរ មានន័យដូចគ្នាថា "ម្នាក់ដែលបានចាក់ប្រេងតាំង" ហេតុដូច្នេះហើយបានជាប្រជាជនយូដាភាគច្រើន បានភ្ជាប់ពាក្យ"ព្រះគ្រីស្ទ"នេះទៅក្នុងនយោបាយជាតិ បានជាព្រះយេស៊ូវកម្រប្រើវាណាស់ ។ មាន៧ដងនៅក្នុងដំណឹងល្អម៉ាកុសក្នុងនោះព្រះយេស៊ូវមានបន្ទូលផ្ទាល់តែបីដងទេ(៩:៤១ ១២:៣៥ ១៣:២១) ក្រៅពីនោះទ្រង់មិនបានមានបន្ទូលឡើយ (លើកលែងតែ ៩:៤១)។ លោកម៉ាកុសបានប្រកាសថាព្រះយេស៊ូវគឺជា ព្រះគ្រីស្ទ (១:១)។

**៨:៣០** *មិនឱ្យគេប្រាប់អ្នកណាពីដំណើរទ្រង់សោះ* (១:៤៤ និងការពន្យល់ ៥:១៩, ៤៣ មថ ៨:៤ ១៦:២០)។

**៨:៣១–១០:៥២** វគ្គថ្មីបានចាប់ផ្ដើមពី ៨:៣១ ហើយមានចំណុចសំខាន់៣នៃសេចក្ដីទំនាយអំពីការសុគតរបស់ព្រះយេស៊ូវ (៨:៣១ ៩:៣១ ១០:៣៣–៣៤)។ វាបង្ហាញពីការផ្លាស់ប្ដូរភូមិសាស្ត្រពីស្រុកកាលីឡេ ជាកន្លែងដែលព្រះ

អាចារ្យ[ច] បោះបង់ចោល ហើយសំឡាប់លោក[ឆ] រួច៣ថ្ងៃ[ជ]
ក្រោយដែលលោកស្លាប់ទៅ នោះលោកនឹងរស់ឡើងវិញ[ឈ]
៣២ទ្រង់មានបន្ទូលពីដំណើរនោះយ៉ាងច្បាស់លាស់[ញ] នោះ
ពេត្រុសនាំទ្រង់ទៅ ចាប់តាំងនិយាយចំទាស់ដល់ទ្រង់
៣៣តែទ្រង់បែរមកទតឃើញពួកសិស្ស ក៏បន្ទោសពេត្រុសថា
សាតាំងអើយ ចូរថយទៅក្រោយអញទៅ[ដ] ដ្បិតឯង
មិនគិតតាមគំនិតរបស់ព្រះសោះ គឺតាមតែគំនិតរបស់មនុស្ស
លោកវិញ។

៣៤កាលទ្រង់បានហៅហ្វូងមនុស្ស នឹងពួកសិស្សមកនោះ
ក៏មានបន្ទូលទៅគេថា អ្នកណាដែលចង់មកតាមខ្ញុំ ត្រូវឱ្យ
អ្នកនោះលះកាត់ចិត្តខ្លួនឯងចោល ទាំងផ្ទុកឈើឆ្កាងខ្លួន
មកតាមខ្ញុំចុះ[ឋ] ៣៥ដ្បិតអ្នកណាដែលចង់ឱ្យរួចជីវិត នោះនឹង
បាត់ជីវិតទៅ តែអ្នកណាដែលបាត់ជីវិតដោយព្រោះយល់
ដល់ខ្ញុំ ហើយនឹងដំណឹងល្អ នោះនឹងបានជីវិតវិញ[ឌ] ៣៦ដ្បិត
បើមនុស្សណានឹងបានលោកីយទាំងមូល តែបាត់ព្រលឹងទៅ
នោះតើមានប្រយោជន៍អ្វីដល់អ្នកនោះ ៣៧ឬតើមនុស្សនឹង
យកអ្វីទៅដូរឱ្យបានព្រលឹងខ្លួនវិញ ៣៨ដ្បិតអ្នកណាដែល
មានសេចក្តីខ្មាស ដោយព្រោះខ្ញុំ នឹងពាក្យខ្ញុំ នៅក្នុងតំណ
មនុស្សកំផិត ហើយមានបាបនេះ នោះកូនមនុស្ស[ឍ]នឹងមាន
សេចក្តីខ្មាស ដោយព្រោះអ្នកនោះដែរ[ណ] ក្នុងកាលដែល
លោកមក[ត]ក្នុងសិរីល្អរបស់ព្រះវរបិតា ជាមួយនឹងពួកទេវតា
បរិសុទ្ធ ។

**៩** ១រួចទ្រង់មានបន្ទូលទៅគេថា ខ្ញុំប្រាប់អ្នករាល់គ្នាជា
ប្រាកដថា ក្នុងពួកអ្នកដែលឈរនៅទីនេះ មានខ្លះមិនត្រូវ
ភ្លក់សេចក្តីស្លាប់ ដរាបដល់បានឃើញនគរព្រះមក[ថ] ទាំង
មានព្រះចេស្តា[ទ]។

**៨:៣១** ង មថ ១៦:២១
ច មថ ២៧:១,២
ឆ កច ២:២៣ ៣:១៣
ជ មថ ១៦:២១
ឈ មថ ១៦:២១
**៨:៣២** ញ យហ ១៨:២០
**៨:៣៣** ដ មថ ៤:១០
**៨:៣៤** ឋ មថ ១០:៣៨ លក ១៤:២៧
**៨:៣៥** ឌ យហ ១២:២៥
**៨:៣៨** ឍ មថ ៨:២០
ណ មថ ១០:៣៣ លក ១២:៩
ត ១ថន ២:១៩
**៩:១** ថ មក ១៣:៣០ លក ២២:១៨
ទ មថ ២៤:៣០ ២៥:៣១

សស២៥:៣១

យេស៊ូវបានបំពេញព្រះរាជកិច្ចភាគច្រើន នោះទៅឯក្រុងយេរូសាឡិម និងថ្ងៃចុងក្រោយនៃព្រះជន្មរបស់ទ្រង់ នៅលើផែនដីនេះបានរាយការណ៍ដោយលោកម៉ាកុស ។ ក្នុងវគ្គនេះព្រះយេស៊ូវបានបញ្ជាក់យ៉ាងច្បាស់ អំពីអត្ថន័យពាក្យថា "ព្រះគ្រីស្ទ" ។

**៨:៣១** *កូនមនុស្ស* ការហៅនេះគឺនិយាយពីព្រះយេស៊ូវគ្រីស្ទទ្រង់ផ្ទាល់ ពាក្យនេះមាន៨១ដងនៅក្នុងដំណឹងល្អ ហើយគ្មាននរណាម្នាក់បានប្រើពាក្យនេះឡើយ ក្រៅពីទ្រង់ ។ នៅក្នុងបទគម្ពីរ "ដយ ៧:១៣–១៤" កូនមនុស្សគឺត្រូវបានពិពណ៌នាដូចជារូបភាពស្ថានសួគ៌ ដែលស្ថិតនៅក្នុងទីបញ្ចប់ត្រូវបានទុកចិត្ត ដោយព្រះដ៏មាន ព្រះចេស្តា សិរីរុងរឿង ហើយនិងឫទ្ធិអំណាច ។ ការដែលព្រះយេស៊ូវប្រើពាក្យ "កូនមនុស្ស" នេះក៏ដូចជាប្រើព្រះនាមជាព្រះមែស៊ីដែរ នេះជាភស្តុតាងដោយ ព្រោះទ្រង់បានប្រើដោយទ្រង់ផ្ទាល់ (ខ.៣១) ។ ជាបន្តបន្ទាប់មកទៀតលោកពេត្រុស បានហៅទ្រង់ថា "ព្រះគ្រីស្ទ" (ខ.២៩ មើលការពន្យល់ ដយ ៧:១៣) ។ *ត្រូវរងទុក្ខ* ដូចបានទាយទុកអំពីអ្នកបម្រើរងទុក្ខក្នុង អស ៥២:១៣–៥៣:១២ (មក ៩:៩,១២, ៣១ ១០:៣៣–៣៤ ១៤:២១,៤១) ។ *ពួកចាស់ទុំ* ជាសមាជិកនៃតុលាការជាន់ខ្ពស់របស់សាសន៍យូដា ។ *ពួកសង្គ្រាជ* មើលការពន្យល់ មថ ២:៤ ។ សង្គ្រាជនេះរួមទាំងគ្រប់គ្រងលើសម្តេចសង្ឃ និងគ្រួសារសម្តេចសង្ឃ កាលនោះមានដូចជាលោកកៃផា (ជាអតីតសម្តេចសង្ឃ) លោកអាណផងដែរ ។ *ពួកអាចារ្យ* "មើលការពន្យល់ មថ ២:៤"។ ពួកនេះតំណាងឱ្យមនុស្សបីក្រុមដែលបាននិយាយនៅ ទីនេះ ជាពួកអ្នកតាក់តែងច្បាប់រដ្ឋធម្មនុញ្ញ ។

**៨:៣២** *ពេត្រុស . . . ចាប់តាំងនិយាយជំទាស់ដល់ទ្រង់* នៅក្នុងគំនិតរបស់លោកពេត្រុសគ្មានទេការរងទុក្ខ ការបដិសេធន៍ចំពោះព្រះមែស៊ីនោះ ហើយគាត់ជំទាស់នឹងព្រះយេស៊ូវ ចំពោះការបង្រៀនទាំងឡាយណាដែលគាត់មិនអាចយល់បាន ប៉ុន្តែ នេះជាការយល់ច្រឡំរបស់គាត់ទាំងស្រុង ។

**៨:៣៣** *សាតាំង* បំណងរបស់លោកពេត្រុសគឺដើម្បីឃាត់ព្រះយេស៊ូវកុំឱ្យយាងទៅសុគតលើឈើឆ្កាង ដែលមានដំណើរការប្រព្រឹត្តទៅដូចជាសាតាំងបានល្បួងទ្រង់ ក្នុងពេលទ្រង់ចាប់ផ្តើមបំពេញព្រះរាជកិច្ចជាលើកដំបូងនោះដែរ (មថ ៤:៨–១០) ដូច្នេះ បានជាទ្រង់បន្ទោសដល់គាត់យ៉ាងធ្ងន់ធ្ងរ ។

**៨:៣៤** *លះកាត់ចិត្តខ្លួនឯងចោល* គឺឱ្យឈប់ធ្វើខ្លួនជាម្ចាស់នៃជីវិត និងសកម្មភាពរបស់ខ្លួន ហើយឱ្យព្រះអម្ចាស់គ្រប់គ្រងវិញ។ *ផ្ទុកឈើឆ្កាង* គឺជារូបភាពនៃមនុស្សម្នាក់ត្រូវបានគេកាត់ទោសរួចជាស្រេច ហើយតម្រូវឱ្យលីឈើឆ្កាងរបស់ខ្លួនទៅកន្លែងប្រហារជីវិត (យហ ១៩:១៧) ។ ការលីឈើឆ្កាងគឺជាឆន្ទៈដើម្បីទទួលនូវការរងទុក្ខលំបាក និងស្លាប់សម្រាប់កិច្ចការព្រះអម្ចាស់ ។

**៨:៣៥** *នឹងបានជីវិត* ជីវិតខាងសាច់ឈាមអាចត្រូវរស់ដោយសារការបដិសេធព្រះយេស៊ូវ ប៉ុន្តែជីវិតខាងឯវិញ្ញាណដែលអស់កល្បនោះនឹងត្រូវបាត់បង់ទៅវិញ ។ ដោយរក្សាភាពជាសាវ័ក អាចត្រូវបាត់បង់ជីវិតខាងសាច់ឈាម តែការបាត់បង់នោះគ្មានន័យអ្វីសោះ បើប្រៀបធៀបទៅនឹងការទទួលបានជីវិតអស់កល្បជានិច្ច ។

**៨:៣៦** *លោកីយទាំងមូល* សំដៅលើគ្រប់របស់ទាំងអស់ដែលខ្លួនអាចមានសម្រាប់ជីវិតនេះ ។ *ព្រលឹង* នេះគឺជាជីវិតអស់កល្បជានិច្ច (ខ.៣៧) ។

**៨:៣៨** *មានសេចក្តីខ្មាសដោយព្រោះខ្ញុំ និងពាក្យខ្ញុំ* គឺផ្ទុយនឹង រម ១:១៦ មនុស្ស ដែលគិតតែពីបំពេញចិត្តខ្លួនឯង "នៅក្នុងតំណមនុស្សកំផិតក្បត់ ហើយមានបាប" ជាជាងបំពេញព្រះហឫទ័យព្រះគ្រីស្ទ នោះនឹងគ្មានចំណែកនៅនគរស្ថានសួគ៌ទេ ។ *កូនមនុស្ស* "មើលការពន្យល់ ៨:៣១"។ *កាលដែលលោកមកក្នុងសិរីល្អរបស់ព្រះវរបិតា* "មើលការពន្យល់ ២ថន ១:៦–១០"។ ជាស្ថានភាពក្នុងពេលដែលព្រះយេស៊ូវត្រូវបានគេបដិសេធ ប្រមាថមើលងាយ និងធ្វើគុត តែរឿងនេះនឹងត្រូវ បានត្រឡប់ទៅលើពួកគេវិញ ពេលដែលទ្រង់យាងមកក្នុងសិរីល្អ គឺជាសេចក្តីជំនុំជម្រះដល់មនុស្សទាំងអស់ ។

**៩:១** *ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា* មើលការពន្យល់ ៣:២៨។ *មានខ្លះមិនត្រូវភ្លក់សេចក្តីស្លាប់ ដរាបដល់បានឃើញនគរព្រះមកទាំងមានព្រះចេស្តា* មើលការពន្យល់ មថ ១៦:២៨ ។ *នគរព្រះ* មើលការពន្យល់ មថ

## ការផ្លាស់ប្រែរូបកាយ

*៩:២–៨ = លក ៩:២៨ –៣៦*
*៩:២–១៣ = មថ ១៧:១–១៣*

២ កន្លង៦ថ្ងៃមកទៀត ព្រះយេស៊ូវទ្រង់យកពេត្រុស យ៉ាកុប
នឹងយ៉ូហាន[ធ] ទៅជាមួយ នាំឡើងទៅលើភ្នំខ្ពស់ដោយឡែក
ទ្រង់ក៏ផ្លាស់ប្រែនៅមុខអ្នកទាំងនោះ ៣ ព្រះពស្ត្រទ្រង់ត្រឡប់
ជាភ្លឺសស្គុសដូចហិមៈ[ន] ដល់ម៉្លេះបានជាគ្មានអ្នកប្រមោកណា
នៅផែនដីនេះ ដែលអាចនឹងប្រមោកឱ្យសដូច្នោះបានឡើយ
៤ នោះលោកអេលីយ៉ា ព្រមទាំងលោកម៉ូសេ បានលេចមក
ឱ្យឃើញ កំពុងតែទូលនឹងព្រះយេស៊ូវ ៥ រួចពេត្រុសទូល
ទៅទ្រង់ថា លោកគ្រូ[ប] ដែលយើងខ្ញុំ នៅទីនេះបានល្អ
ណាស់ហើយ សូមឱ្យយើងខ្ញុំធ្វើត្រសាល៣ គឺ១សំរាប់
លោក១សំរាប់លោកម៉ូសេ ហើយ១សំរាប់លោកអេលី
យ៉ា ៦ នេះដ្បិតគាត់មិនដឹងជាត្រូវនិយាយដូចម្តេចទេ ពី
ព្រោះមានសេចក្តីស្ញែងខ្លាចទាំងអស់គ្នា ៧ នោះមាន
ពពកមកគ្របបាំង ហើយមានឮសូរសំឡេងចេញពីពពក
ថា[ផ] នេះជាកូនស្ងួនភ្ងាអញ ចូរស្តាប់តាមចុះ[ព] ៨ ស្រាប់តែ
គេក្រឡេកមើលជុំវិញទៅ ឥតមានឃើញអ្នកណាទៀត
សោះ ឃើញតែព្រះយេស៊ូវគង់ជាមួយប៉ុណ្ណោះ ។
៩ កំពុងដែលចុះពីភ្នំមក នោះទ្រង់ហាមមិនឱ្យប្រាប់អ្នក
ណា[ភ] ពីការដែលបានឃើញនោះឡើយ ដរាបដល់កូន
មនុស្សបានរស់ពីស្លាប់ឡើងវិញ[ម] ១០ អ្នកទាំងនោះក៏រក្សា
ពាក្យនោះទុកនៅតែក្នុងពួកគេ ហើយសួរគ្នាទៅវិញទៅ
មក ពីសេចក្តីរស់ពីស្លាប់ឡើងវិញជាយ៉ាងណា ១១ ក៏ទូល
សួរទ្រង់ថា ចុះហេតុអ្វីបានជាពួកអាចារ្យប្រាប់ថា លោក
អេលីយ៉ាត្រូវតែមកជាមុន ១២ ទ្រង់មានបន្ទូលឆ្លើយថា
លោកអេលីយ៉ាត្រូវមកមុនមែន ដើម្បីនឹងតាំងការទាំង
អស់ឡើងវិញ ប៉ុន្តែធ្វើដូចម្តេចបានជាមានសេចក្តីចែង
ទុកពីកូនមនុស្ស[យ] ថា លោកត្រូវរងទុក្ខជាច្រើន[រ] ព្រមទាំង
ត្រូវគេមើលងាយ[ល] ផង ១៣ ចំណែកលោកអេលីយ៉ា នោះ
ខ្ញុំប្រាប់អ្នករាល់គ្នាថា លោកបានមក[វ] ហើយ គេក៏បានប្រ
ព្រឹត្តនឹងលោកតាមតែអំពើចិត្ត ដូចជាមានសេចក្តីចែង
ទុកពីលោកស្រាប់ ។

**៩:២** ធ មថ ៤:២១
**៩:៣** ន មថ ២៨:៣
**៩:៥** ប មថ ២៣:៧
**៩:៧** ផ នក ២៤:១៦
ព មថ ៣:១៧
**៩:៩** ភ មក ៨:៣០
**៩:៩** ម មថ ៨:២០
**៩:១២** យ មថ ៨:២០
រ មថ ១៦:២១
ល លក ២៣:១១
**៩:១៣** វ មថ ១១:១៤

៣:២ ។
**៩:២** *កន្លង៦ថ្ងៃមកទៀត* មើលការពន្យល់ មថ ១៧:១ ។ *ពេត្រុស យ៉ាកុប និងយ៉ូហាន* មើលការពន្យល់ ៥:៣៧ ។ *ភ្នំខ្ពស់* មើលការពន្យល់ លក ៩:២៨ ។ *ផ្លាស់ប្រែ* មើលការពន្យល់ មថ ១៧:២ ។
**៩:៤** *អេលីយ៉ា ព្រមទាំងម៉ូសេ* មើលការពន្យល់ មថ ១៧:៣ លក ៩:៣០ ។
**៩:៥** *លោកគ្រូ* ក្នុងភាសាហេព្រើរ "គ្រូរបស់ខ្ញុំ"។ *ត្រសាល៣* ប្រហែលពេត្រុសមានបំណងកសាងត្រសាលប្រជុំថ្មី ជាកន្លែងដែលព្រះអាចទំនាក់ទំនងជាមួយនឹងរាស្ត្រទ្រង់ម្តងទៀត(នក ២៩:៤២)។ ម្យ៉ាងទៀត គាត់គិតទៅដល់រោងបារាំដែល គេធ្លាប់បានប្រើក្នុងពេលបុណ្យបារាំនោះ(លវ ២៣:៤២)។ គ្រប់ពេលគាត់ប្រឹង ស្វែងរកការសម្រេចទំនាយ ជាងការដែលព្រះយេស៊ូវមានបន្ទូលពីការរងទុក្ខនោះទៅទៀត ។
**៩:៧** *មានឮសំឡេងចេញពីពពក* ជារឿយៗពពកជានិមិត្តរូបនៃព្រះវត្តមានព្រះសម្រាប់ការពារ និងនាំមុខ(នក ១៦:១០ ១៩:៩ ២៤:១៥–១៨ ៣៣:៩–១០)។ *ចូរស្តាប់តាមចុះ* មានន័យរួមទាំងស្តាប់បង្គាប់ផងដែរ ។ នៅពេលព្រះជាប់ទាក់ទងសំឡេងពិតតែមួយគត់គឺស្តាប់បង្គាប់នូវការឮនោះ (យក ១:២២–២៥)។
**៩:៩** *ហាមមិនឱ្យប្រាប់អ្នកណា* ក្រោយពីព្រះរាជកិច្ចរបស់ព្រះយេស៊ូវចប់ ដោយចាប់ពីព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ នោះនឹងត្រូវបានបើកសំដែងពីការពិត និងចរិតលក្ខណៈពេញលេញនៃព្រះយេស៊ូវដល់មនុស្សគ្រប់គ្នា ដោយពួកសាវ័កនូវអ្វីដែលពួកគេបានបទពិសោធន៍ ថាទ្រង់គឺជាព្រះមែស៊ីយ៉ាងពិតប្រាកដ ។ *កូនមនុស្ស* មើលការពន្យល់ ៨:៣១ ។
**៩:១០** *សេចក្តីរស់ពីស្លាប់ឡើងវិញជាយ៉ាងណា* ព្រោះថាសាសន៍យូដាមានគោលលទ្ធិ ដូចគ្នាចំពោះសេចក្តីរស់ឡើងវិញ នោះគឺជាការរស់ឡើងវិញនៃកូនមនុស្សដែលធ្វើឱ្យពួកគេពិបាកយល់ ពីព្រោះទេវសាស្ត្ររបស់ពួកគេមិនបានចែងពីការរងទុក្ខ និងការសុគតរបស់ព្រះមែស៊ីនោះឡើយ ។
**៩:១១** *លោកអេលីយ៉ាត្រូវតែមកជាមុន* មើលការពន្យល់ មថ ១៧:១០ ។
**៩:១២** *លោកអេលីយ៉ាត្រូវមកមុនមែន ដើម្បីនឹងតាំងការទាំងអស់ឡើងវិញ* យោងតាមការដែលត្រូវមករបស់លោកអេលីយ៉ា ឬក៏មានម្នាក់ដូចគាត់ដើម្បីរៀបចំដំណើរនៃការយាងមករបស់ព្រះមែស៊ី(មើលការពន្យល់ ១៧:១០)។ *កូនមនុស្ស* (មើលការពន្យល់ ៨:៣១)។ *ត្រូវរងទុក្ខជាច្រើន* ព្រមទាំងត្រូវគេមើលងាយ ដូចជា "លោកអេលីយ៉ា"(យ៉ូហាន–បាទីស្ទ មើលការពន្យល់ ខ.១៣) សុទ្ធតែត្រូវបានគេបដិសេធ (មើលការពន្យល់ មថ ១៧:១២)។
**៩:១៣** *លោកអេលីយ៉ា. . .បានមកហើយ* នេះគឺជាសេចក្តីបញ្ជាក់មួយអំពីលោកយ៉ូហាន–បាទីស្ទ (មថ ១៧:១៣)។ *ពួកគេ* សំដៅលើពួកស្តេចហេរ៉ូឌ និងហេរ៉ូឌាស(៦:១៧–២៩)។ លោកយ៉ូហានក៏ដូចជាលោកអេលីយ៉ាត្រូវបានជិទាស់ដោយ អ្នកដឹកនាំម្នាក់ និងមនុស្សអាក្រក់ដែលសេពគប់គាត់ ។ *ដូចជាមានសេចក្តីចែងទុកពីលោកស្រាប់* អ្វីដែលគម្ពីរបានចែងពីលោកអេលីយ៉ាដែលជាប់ទំនាក់ទំនងទៅនឹងស្តេចអ័ហាប់ និងស្តេចយេសិបិល (១ពវ ១៩:១–១០)។ គ្មានទំនាយពីការរង ទុក្ខទេនៅចុងបញ្ចប់នៃភារកិច្ចរបស់លោកអេលីយ៉ានោះ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏រឿងដែលបានកើតឡើងដល់អេលីយ៉ានៅក្រោមការគំរាមកំហែងនៃ ស្តេចយេសិបិល គឺជាប្រផ្នូលមួយសម្រាប់ការដែលត្រូវកើតឡើងចំពោះលោកយ៉ូហាន–បាទីស្ទ ។ ដំណើររឿងនៃព្រឹត្តិការណ៍នេះបានជួយជាយោបល់ផ្សេងៗ ដូចតទៅ: (១).លោកអេលីយ៉ាបានបម្រើការក្នុងសម័យស្តេចអាក្រក់យេសិបិល (២). លោកអេលីយ៉ាក៏ជាមនុស្សម្នាក់ដែលបានរងទុក្ខដូចលោកយ៉ូហាន–បាទីស្ទដែរ ដោយស្នាដៃពួកហេរ៉ូឌាស (៣). ហើយកូនមនុស្សក៏ត្រូវបានរងទុក្ខ និងត្រូវគេមើលងាយដែរ ក្រោយពេលគេកាត់ក្បាលលោកយ៉ូហានតែបន្តិចប៉ុណ្ណោះ ។

## ការប្រោសក្មេងប្រុសដែលមានអារក្សគចូល

*៩:១៤–២៨,៣០–៣២ = មថ ១៧:១៤–១៩,២២,២៣*
*លក ៩:៣៧–៤៥*

១៤ លុះបានមកដល់ពួកសិស្សហើយ នោះទ្រង់ឃើញមាន
ហ្វូងមនុស្សជាធំនៅព័ទ្ធគេជុំវិញ ក៏មានពួកអាចារ្យខ្លះកំពុង
តែដេញដោល ១៥ កាលហ្វូងមនុស្សបានឃើញទ្រង់ ស្រាប់
តែកើតមានសេចក្តីស្រឡាំងកាំង រួចរត់ទៅទទួលទ្រង់
ដោយគោរព ១៦ ទ្រង់មានបន្ទូលសួរពួកអាចារ្យថា តើអ្នក
រាល់គ្នាជជែកពីរឿងអ្វីនឹងអ្នកទាំងនេះ ១៧ នោះមានម្នាក់
ក្នុងហ្វូងមនុស្សទូលកាត់ឆ្លើយថា លោកគ្រូអើយ ខ្ញុំបាននាំ
កូនខ្ញុំមកឯលោក ព្រោះវាមានអារក្សគ ចូល ១៨ នៅកន្លែង
ណាដែលអារក្សជាន់វាម្តងៗ នោះក៏ធ្វើឱ្យវាប្រកាច់ជា
ខ្លាំង វាបែកពពុះមាត់ ព្រមទាំងសង្កៀតធ្មេញ ហើយចេះ
តែហេវទៅៗ ខ្ញុំបានសូមពួកសិស្សលោក ឱ្យដេញអារក្ស
នោះដែរ តែគេពុំអាចនឹងដេញចេញបានទេ ១៩ ទ្រង់
មានបន្ទូលឆ្លើយថា ឱតំណមនុស្សដែលមិនជឿអើយ តើ
ត្រូវឱ្យខ្ញុំនៅជាមួយនឹងអ្នករាល់គ្នាដល់កាលណា តើត្រូវ
ឱ្យខ្ញុំទ្រាំនឹងអ្នករាល់គ្នាដល់កាលណាទៀត ចូរនាំវាមកឯខ្ញុំ
២០ គេក៏នាំវាទៅ កាលបានឃើញទ្រង់ នោះស្រាប់តែ
អារក្សជាន់វា ឱ្យប្រកាច់ដួលននៀលនៅដី ទាំងបែកពពុះ
មាត់[ស] ២១ ទ្រង់មានបន្ទូលសួរឪពុកថា វាបានឈឺដូច្នេះជា
យូរប៉ុន្មានមកហើយ គាត់ទូលឆ្លើយថា តាំងតែពីតូចមក
២២ ជួនកាលក៏បោះវាទៅក្នុងភ្លើងក្នុងទឹកជាញយៗ ដើម្បីនឹង
បំផ្លាញវាទៅ ប៉ុន្តែបើលោកអាចនឹងជួយបាន នោះសូម
អាណិតមេត្តាជួយយើងខ្ញុំផង ២៣ ព្រះយេស៊ូវមានបន្ទូល
ទៅគាត់ថា បើអាចនឹងជឿបាន នោះការទាំងអស់នឹង
សំរេចបាន ដល់អ្នកណាដែលជឿ[ហ] ២៤ ស្រាប់តែឪពុក
របស់កូននោះ ក៏បន្លឺវាចាឡើងទាំងទឹកភ្នែកថា ខ្ញុំជឿហើយ
លោកម្ចាស់អើយ សូមជួយចំពោះសេចក្តីណាដែលខ្ញុំមិន
ជឿផង ២៥ កាលព្រះយេស៊ូវឃើញមនុស្សសន្ធឹកកំពុង
តែរត់មក[ឡ] នោះទ្រង់កំហែងទៅអារក្សអសោចិ៍ថា នែ៎
អារក្សគថ្លង់អើយ អញបង្គាប់ឱ្យឯងចេញពីវាទៅ កុំឱ្យ
ចូលវាទៀតឡើយ ២៦ វាក៏ស្រែកឡើង ទាំងជាន់ក្មេងនោះ
ឱ្យប្រកាច់ជាខ្លាំង រួចក៏ចេញទៅ ក្មេងនោះត្រឡប់ដូចជា
ស្លាប់ ដល់ម្ល៉េះ បានជាមនុស្សជាច្រើនបានថា វាស្លាប់
ហើយ ២៧ ប៉ុន្តែ ព្រះយេស៊ូវទ្រង់ចាប់ដៃលើកវាឡើង
ហើយវាក៏ក្រោក ឈរ ។

២៨ លុះទ្រង់បានយាងចូលទៅក្នុងផ្ទះ នោះពួកសិស្សទូល
សួរទ្រង់ដោយឡែកថា[អ] ហេតុអ្វីបានជាយើងខ្ញុំដេញអារក្ស
នេះពុំបាន ២៩ ទ្រង់មានបន្ទូលថា ដែលនឹងដេញអារក្ស
បែបយ៉ាងនេះបាន នោះគឺដោយសារតែអធិស្ឋាន ហើយ
នឹងតមទេ ៣០ កាលចេញពីទីនោះ ក៏យាងកាត់ស្រុកកាលី
ឡេទៅ ហើយទ្រង់មិនចង់ឱ្យអ្នកណាដឹងសោះ ៣១ ដ្បិត
ទ្រង់កំពុងតែបង្រៀនពួកសិស្សថា កូនមនុស្ស[ក] ត្រូវបញ្ជូន
ទៅក្នុងកណ្តាប់ ដៃនៃមនុស្សលោក គេនឹងសំឡាប់លោក[ខ]
រួចដល់៣ថ្ងៃ ក្រោយ[គ] ដែលគេសំឡាប់ នោះលោកនឹង
រស់ឡើងវិញ[ឃ] ៣២ តែអ្នកទាំងនោះមិនបានយល់សេចក្តី

**៩:២០** ស មក ១:២៦
**៩:២៣** ហ មថ ២១:២១ មក ១១:២៣ យហ ១១:៤០
**៩:២៥** ឡ ខ.១៥
**៩:២៨** អ មក ៧:១៧
**៩:៣១** ក មថ ៨:២០ ខ.១២ ខ កច ២:២៣ ៣:១៣ គ មថ ១៦:២១ ឃ មថ ១៦:២១

---

**៩:១៤** *មកដល់ពួកសិស្ស* គឺជាក្រុមសិស្សទាំង៩នាក់ផ្សេងទៀត ក្រៅពីលោកពេត្រុស លោកយ៉ាកុប និងលោកយ៉ូហាន (ខ.២) ។

**៩:១៨** ការដែលអារក្សអសោចិ៍ចូល ជាការទទួលខុសត្រូវចំពោះស្ថានភាពរបស់ក្មេងប្រុសម្នាក់នោះ (ខ.២០,២៥–២៦) ។

**៩:២២** *បំផ្លាញវា* មានន័យថា "សម្លាប់វា" (មើលការពន្យល់ ៥:៥,១៣) ។

**៩:២៣** *បើអាចនឹងជឿបាន...នឹងសំរេចបានដល់អ្នកណាដែលជឿ* នេះជាសំណួរមិនសំដៅថា តើព្រះយេស៊ូវមានអំណាចប្រោសក្មេងនោះដែរឬទេ ? ប៉ុន្តែ វាសំដៅថា តើឪពុកក្មេងនោះមានជំនឿជឿថាកូនខ្លួនជាឬមិនជា? មនុស្សម្នាក់ដែលជឿពិតប្រាកដ នោះនឹងមិនដាក់កំណត់ចំពោះអ្វីដែលព្រះទ្រង់ធ្វើនោះឡើយ ។

**៩:២៤** *ខ្ញុំជឿហើយលោកម្ចាស់អើយ សូមជួយចំពោះសេចក្តីណាដែលខ្ញុំមិនជឿផង* ព្រោះថាជំនឿមិនទាន់គ្រប់លក្ខណ៍ ហើយជាញឹកញាប់ការជឿ និងការមិនជឿនៅលាយឡំជាមួយគ្នា ។

**៩:២៥** *កាលព្រះយេស៊ូវឃើញមនុស្សសន្ធឹកកំពុងតែរត់មក នោះទ្រង់កំហែងទៅអារក្សអសោចិ៍* គឺយ៉ាងលឿនទៅតាមដែលអាចធ្វើបាន ពីព្រោះព្រះយេស៊ូវមិនរង់ចាំឱ្យមនុស្សឃើញកាន់តែច្រើនឡើងៗនោះទេ ។

**៩:២៩** *បែបយ៉ាងនេះ* មានន័យថាអារក្សមានច្រើនប្រភេទ ។ *ដោយសារតែអធិស្ឋានហើយនិងតម* ពួកសិស្សបានដឹងយ៉ាងច្បាស់ថា ខ្លួនបានទទួលអំណាចហើយ ឬបានជឿថាអំណាចមានជាប់ជាមួយនឹងពួកគេហើយ ។ ខ្វះសេចក្តីអធិស្ឋានបង្ហាញថា ពួកគេភ្លេចថា អំណាចដែលឈ្នះលើវិញ្ញាណអារក្សនោះគឺបានមកពីព្រះយេស៊ូវ (៣:១៥ ៦:៧,១៣) ។

**៩:៣០** *យាងកាត់ស្រុកកាលីឡេ* ព្រះរាជកិច្ចរបស់ព្រះយេស៊ូវនៅជុំវិញស្រុកកាលីឡេបានចប់សព្វគ្រប់ (៧:២៤) ហើយឥឡូវនេះ ទ្រង់កំពុងធ្វើដំណើរតាមផ្លូវ ទៅក្រុងយេរូសាឡិមដើម្បីរងទុក្ខព្រមទាំងសុគតផង (១០:៣២-៣៤) ។ ខណៈពេល ដែលព្រះអម្ចាស់កំពុងបំពេញព្រះរាជកិច្ចអស់រយៈពេលជាច្រើនខែកន្លងមកនេះ ទ្រង់ក៏បានបន្តយកព្រះហឫទ័យទុកដាក់ លើការបង្រៀនពួកសិស្សរបស់ទ្រង់ទាំង១២នាក់ទៀត (ខ.៣១) ។

**៩:៣១** *កូនមនុស្ស* មើលការពន្យល់ ៨:៣១ ។

នោះទេ[ង] ក៏ខ្លាច មិនហ៊ានទូលសួរទ្រង់ផង ។

### អ្នកដែលធំជាងគេបំផុតនៅនគរស្ថានសួគ៌

*៩:៣៣–៣៧ = មថ ១៨:១–៥ លក ៩:៤៦–៤៨*

៣៣ លុះទៅដល់កាពើណិម[ច] កាលកំពុងតែនៅក្នុងផ្ទះ[ឆ]
នោះទ្រង់មានបន្ទូលសួរពួកសិស្សថា តើរឿងអ្វីដែលអ្នក
រាល់គ្នាជជែកគ្នាតាមផ្លូវមកនោះ ៣៤ តែគេនៅតែស្ងៀម
ពីព្រោះតាមផ្លូវ គេបានជជែកគ្នា អំពីអ្នកណាដែលធំជាង[ជ] ។
៣៥ ទ្រង់ក៏គង់ចុះ រួចហៅពួក១២មកមានបន្ទូលថា បើ
អ្នកណាចង់ធ្វើជាលេខ១ នោះត្រូវទៅជាចុងបង្អស់វិញ
ហើយត្រូវបំរើគេទាំងអស់ដែរ[ឈ] ៣៦ ទ្រង់ក៏យកកូនតូច១
ដាក់នៅកណ្តាលជំនុំ រួចទ្រង់បីវា[ញ] មានបន្ទូលទៅគេថា
៣៧ អ្នកណាដែលទទួលកូនតូច១ ដូចជាកូននេះ ដោយនូវ
ឈ្មោះខ្ញុំ នោះក៏ឈ្មោះថាទទួលខ្ញុំ ហើយអ្នកណាដែល
ទទួលខ្ញុំ នោះមិនមែនទទួលខ្ញុំទេ គឺឈ្មោះថាទទួលព្រះ
ដែលបានចាត់ឲ្យខ្ញុំមកវិញ[ដ] ។

### អ្នកដែលកាន់ខាងយើង

*៩:៣៨–៤០ = លក ៩:៤៩,៥០*

៣៨ យ៉ូហានក៏ទូលទ្រង់ថា លោកគ្រូ យើងខ្ញុំបានឃើញ
មនុស្សម្នាក់ ដែលមិនដើរតាមយើងខ្ញុំ គេកំពុងតែដេញ
អារក្ស ដោយនូវឈ្មោះលោក ហើយយើងខ្ញុំបានហាមឃាត់
គេ ពីព្រោះគេមិនដើរជាមួយនឹងយើងខ្ញុំទេ[ឋ] ៣៩ ព្រះយេស៊ូវ
មានបន្ទូលថា កុំឃាត់គេឡើយ ដ្បិតគ្មានអ្នកណាអាចនឹង
ធ្វើការឫទ្ធិបារមី ដោយនូវឈ្មោះខ្ញុំ រួចនិយាយអាក្រក់
ពីខ្ញុំភ្លាម១រំពេចបានទេ ៤០ ដ្បិតអ្នកណាដែលមិនទាស់នឹង
យើង នោះកាន់ខាងយើងវិញ[ឌ] ៤១ អ្នកណាដែលឲ្យទឹក១កែវ
ទៅអ្នករាល់គ្នាផឹក ដោយនូវឈ្មោះខ្ញុំ ដោយព្រោះអ្នក
រាល់គ្នាជារបស់ផងព្រះគ្រីស្ទ នោះខ្ញុំប្រាប់ជាប្រាកដថា អ្នក
នោះមិនបាត់រង្វាន់ខ្លួនឡើយ[ឍ] ។

### លទ្ធផលដែលធ្វើឲ្យបងប្អូនរវាតចិត្ត

៤២ តែអ្នកណាដែលធ្វើឲ្យកូនណាមួយ ដែលជឿដល់ខ្ញុំ
នេះ រវាតចិត្តចេញ[ណ] នោះបើគេយកថ្មត្បាល់កិនយ៉ាងធំ
ចងកអ្នកនោះ ហើយទំលាក់ចុះទៅក្នុងសមុទ្រ យ៉ាងនោះ
មានប្រយោជន៍ដល់អ្នកនោះជាជាង[ត] ៤៣ បើដៃអ្នកនាំឲ្យគេ
រវាតចិត្ត[ថ] នោះចូរកាត់វាចោលទៅ ស៊ូឲ្យអ្នកចូលទៅក្នុង
ជីវិតកំបុតដៃវិញ ជាជាងមានដៃទាំង២ ហើយធ្លាក់ទៅ
នរក[ទ] នៅក្នុងភ្លើងដែលពន្លត់មិនបាន[ធ] ៤៤ ជាកន្លែងដែល
មានដង្កូវមិនដែលស្លាប់ ហើយភ្លើងមិនដែលរលត់ឡើយ
៤៥ បើជើងអ្នកនាំឲ្យគេរវាតចិត្ត[ន] នោះចូរកាត់វាចោលទៅ
ស៊ូឲ្យអ្នកចូលទៅក្នុងជីវិតកំបុតជើងវិញ ជាជាងមានជើង
ទាំង២ ហើយត្រូវបោះចោលទៅនរក[ប] នៅក្នុងភ្លើងដែល
ពន្លត់មិនបាន ៤៦ ជាកន្លែងដែលមានដង្កូវមិនដែលស្លាប់
ហើយភ្លើងមិនដែលរលត់ឡើយ ៤៧ ហើយបើភ្នែកអ្នកនាំឲ្យ
គេរវាតចិត្ត[ផ] នោះចូរខ្វេះចោលទៅ ស៊ូឲ្យអ្នកចូលក្នុងនគរ
ព្រះមានភ្នែកតែ១ ជាជាងមានភ្នែកទាំង២ ហើយត្រូវបោះ

**៩:៣២** ង លក ២:៥០ ៩:៤៥ ១៨:៣៤ យហ ១២:១៦
**៩:៣៣** ច មថ ៤:១៣ ឆ មក ១:២៩
**៩:៣៤** ជ លក ២២:២៤
**៩:៣៥** ឈ មថ ១៨:៤ មក ១០:៤៣ លក ២២:២៦
**៩:៣៦** ញ មក ១០:១៦
**៩:៣៧** ដ មថ ១០:៤០
**៩:៣៨** ឋ ជន ១១:២៧–២៩
**៩:៤០** ឌ មថ ១២:៣០ លក ១១:២៣
**៩:៤១** ឍ មថ ១០:៤២
**៩:៤២** ណ មថ ៥:២៩
**៩:៤២** ត មថ ១៨:៦ លក ១៧:២
**៩:៤៣** ថ មថ ៥:២៩ ទ មថ ៥:៣០ ១៨:៨ ធ មថ ២៥:៤១
**៩:៤៥** ន មថ ៥:២៩ ប មថ ១៨:៨

**៩:៣២** *អ្នកទាំងនោះមិនបានយល់សេចក្តីនោះ* មើល ខ.១០ ៨:៣២–៣៣ ។

**៩:៣៣** *កាពើណិម* មើលការពន្យល់ ១:២១ មថ ៤:១៣ ។ *ផ្ទះ* ប្រហែលជាផ្ទះរបស់លោកពេត្រុស និងលោកអនទ្រេ (១:២៩) ។

**៩:៣៤** *គេនៅតែស្ងៀម* គឺមិនមានអ្វីក្រៅពីសេចក្តីអៀនខ្មាសនោះទេ ។ *អ្នកណាដែលធំជាងគេ* ជាការសួរដេញដោលគ្នាពីឋានៈ បុណ្យសក្តិ ដែលសាសន៍យូដាយកមកនិយាយជាប្រចាំ ហើយចាត់ទុកថាជារឿងសំខាន់ នៅក្នុងជីវិតរបស់ពួកគេនាសម័យនោះ ប៉ុន្តែវាពុំមានតម្លៃអ្វីទេចំពោះព្រះយេស៊ូវ (ខ.៣៥ ១០:៤២–៤៥) ។

**៩:៣៥** *ទ្រង់ក៏គង់ចុះ* មើលការពន្យល់ ៤:១ ។

**៩:៣៨** *មិនដើរជាមួយនឹងយើងខ្ញុំ* មនុស្សនេះជាអ្នកជឿយ៉ាងប្រាកដម្នាក់ ប៉ុន្តែគាត់មិនមែនជាអ្នកដែលនៅក្នុងក្រុមសិស្សទាំង១២នាក់នោះទេ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏គាត់បានធ្វើការងារ ដោយនូវព្រះនាមព្រះយេស៊ូវ ដូចជាពួកសិស្សឯទៀតដែរ តែមានម្តងនោះ គាត់មិនអាចបណ្តេញអារក្សបាន (ខ.១៤–១៨,២៨) ។

**៩:៣៩** *កុំឃាត់គេឡើយ* ការយល់ដឹងរបស់ព្រះយេស៊ូវ គឺមានភាពធំទូលាយជាងការយល់ដឹងរបស់ពួកសិស្សទាំង១២នាក់ ។

**៩:៤១** *ខ្ញុំប្រាប់ជាប្រាកដថា* មើលការពន្យល់ ៣:២៨ ។ *ឲ្យទឹក១កែវ* ព្រះអម្ចាស់បានរំលឹកថា សូម្បីតែចិត្តសប្បុរសដ៏តូចមួយ ក៏បានចម្រើនដល់អ្នកជឿជាច្រើនទៀតដែរ ពីព្រោះគេជាអ្នកជឿពិត ។ *មិនបាត់រង្វាន់ខ្លួន* ព្រះអម្ចាស់ជាអ្នកឲ្យរង្វាន់ទាំងនោះ ។

**៩:៤២** *កូនណាមួយដែលជឿដល់ខ្ញុំ* ប្រហែលកូនតូចដែលនិយាយនៅក្នុង ខ.៣៦–៣៧ ឬជាមនុស្សដែលបានពោលនៅក្នុងខ.៣៨ ។ ចំណុចរបស់ព្រះយេស៊ូវគឺច្បាស់ ណាស់ថា ទោះបើយើងរាប់ថាការនោះជាបាបតូចបំផុតដល់អ្នកជឿនោះក៏ដោយ ក៏ទទួលលទ្ធផលរបស់វាដែរ នោះគឺការជំនុំជម្រះដ៏ធ្ងន់ធ្ងរ ។ *ថ្មត្បាល់កិន* ជាថ្មដែលមានទម្ងន់ធ្ងន់មួយ ត្រូវអូសបង្វិលដោយសត្វលាក្នុងពេលកិនម្សៅ ។

**៩:៤៣** *ចូរកាត់វាចោលទៅ* គឺដើម្បីបញ្ជាក់ន័យឲ្យកាន់តែច្បាស់ឡើងថែមទៀត ដែលទាមទារនូវសកម្មភាពដ៏តឹងរ៉ឹងមួយ ។ ជាញឹកញាប់អំពើបាបត្រូវបានកើតឡើង ដោយគ្រាន់តែច្បាំងដណ្តើម ឲ្យឈ្នះភាពដាច់ខាត នៅក្នុងជីវិតនោះបានហើយ"ការព្យាបាលខាងវិញ្ញាណ"។ *ជីវិត* គឺជាជីវិតអស់កល្បជានិច្ចស្ថិតនៅក្នុងព្រះវត្តមានរបស់ព្រះអម្ចាស់ ។ *នរក* (មើលការពន្យល់ មថ ៥:២២) ។

**៩:៤៤,៤៦** មើលការពន្យល់ ខ.៤៣,៤៥,៤៨ ។

**៩:៤៧** *នគរព្រះ* មើលការពន្យល់ មថ ៣:២ ។

ចោលទៅក្នុងភ្លើងនរកវិញ[ព] ៤៨ជាកន្លែងដែលមានដង្កូវ
មិនដែលស្លាប់ ហើយភ្លើងមិនដែលរលត់ឡើយ[ភ] ៤៩ដ្បិត
គ្រប់គ្នាត្រូវបំប្រៃ[ម]នឹងភ្លើង ហើយគ្រប់ទាំងយញ្ញបូជាត្រូវ
បំប្រៃនឹងអំបិល ៥០អំបិលជារបស់ល្អ តែបើបាត់ជាតិប្រៃ
ហើយ តើនឹងយកអ្វីដើម្បីធ្វើឱ្យប្រៃឡើងវិញបាន[យ] ៥១ដូច្នេះ
ចូរឱ្យអ្នករាល់គ្នាមានអំបិលនៅក្នុងខ្លួន[រ] ហើយនៅជាមួយ
គ្នាដោយមេត្រីចុះ[ល]។

## ការលែងលះប្ដីប្រពន្ធ

**១០** ១ព្រះយេស៊ូវទ្រង់ក៏ក្រោកឡើង យាងចេញពីទីនោះ
ទៅឯព្រំដែនស្រុកយូដា នៅខាងនាយទន្លេយ័រដាន់[វ]នោះ
មានមនុស្សកកកុញប្រជុំគ្នាឯទ្រង់ម្តងទៀត ហើយទ្រង់ក៏
បង្រៀនគេតាមទំលាប់ទ្រង់[ស] ២ពួកផារិស៊ី[ហ]គេមកល្បង
សួរទ្រង់ ពីច្បាប់ដែលនឹងលែងប្រពន្ធបានឬមិនបាន ។
៣តែទ្រង់មានបន្ទូលឆ្លើយថា តើលោកម៉ូសេបានបង្គាប់
មកអ្នករាល់គ្នាថាដូចម្តេច ៤គេទូលថា លោកបានអនុញ្ញាត
ឱ្យធ្វើសំបុត្រលះលែង ហើយឱ្យលែងទៅ[ឡ] ៥ទ្រង់មាន
បន្ទូលឆ្លើយថា ដែលលោកបានតែងច្បាប់នោះឱ្យអ្នក
រាល់គ្នា គឺដោយព្រោះតែចិត្តអ្នករាល់គ្នារឹងរូស ប៉ុណ្ណោះ[អ]
៦ប៉ុន្តែតាំងពីដើមកំណើតមនុស្សមក នោះព្រះទ្រង់បាន
បង្កើតគេជាប្រុសជាស្រី[ក] ៧ដោយហេតុនោះបានជាមនុស្ស
ប្រុសតែងនឹងលាចេញពីឪពុកម្តាយ ទៅនៅជាប់នឹងប្រ
ពន្ធវិញ ៨ហើយអ្នកទាំង២នោះនឹងត្រឡប់ជាសាច់
តែ១[ខ] គេមិនមែនជា២ទៀត គឺជាសាច់តែ១សុទ្ធ ៩ដូច្នេះ
កុំឱ្យអ្នកណាពង្រាត់មនុស្ស ដែលព្រះបានផ្សំផ្គុំគ្នាឡើយ

**៩:៤៧** ផ មថ ៥:២៩ ព មថ ៥:២៩ ១៨:៩
**៩:៤៨** ភ អស ៦៦:២៤ មថ ២៥:៤១
**៩:៤៩** ម លវ ២:១៣
**៩:៥០** យ មថ ៥:១៣ លក ១៤:៣៤,៣៥
**៩:៥១** រ កល ៤:៦ ល រម ១២:១៨ ២កថ ១៣:១១ ១ថន ៥:១៣
**១០:១** វ មក ១:៥ យហ ១០:៤០ ១១:៧ ស មថ ៤:២៣ មក ២:១៣ ៤:២ ៦:៦,៣៤
**១០:២** ហ មក ២:១៦
**១០:៤** ឡ ចទ ២៤:១-៤ មថ ៥:៣១
**១០:៥** អ ទជ ៩៥:៨ ហាព ៣:១៥ **១០:៦** ក លប ១:២៧ ៥:២
**១០:៨** ខ លប ២:២៤ ១កថ ៦:១៦

**៩:៤៨** អស ៦៦:២៤ ជាសំដីនៃទណ្ឌកម្មដល់អ្នកដែលប្រឆាំងនឹងព្រះ ។ ចុងបញ្ចប់នៃទំនាយរបស់ហោរាអេសាយ បានក្លាយជារូបភាពនៃការបំផ្លាញដែលមិនចេះចប់ឡើយ ។ *ដង្កូវមិនដែលស្លាប់* ដង្កូវជានិច្ចជាកាលស្ថិតនៅក្នុងគំនរសំរាម (មើល មថ ៥:២២)។

**៩:៤៩** ខនេះអាចមានន័យថា អ្នកដែលធ្លាក់ទៅក្នុងស្ថាននរកនឹងរងទុក្ខវេទនាដោយភ្លើងនរក ឬអាចមានន័យថា ជីវិតគ្រីស្ទបរិស័ទគ្រប់រូបអាចនឹងត្រូវរងក្នុងភ្លើងនៃទុក្ខវេទនា ដើម្បីបន្សុទ្ធសេចក្តីជំនឿរបស់ខ្លួន ។

**៩:៥០** *អំបិលជារបស់ល្អ* ភាពផ្សេងគ្នានៃសាវ័កត្រូវបានសំគាល់ដោយអំបិលនេះ គឺជាភក្តីភាពនឹងព្រះយេស៊ូវ និងដំណឹងល្អរបស់ទ្រង់ (៨:៣៥,៣៨ និងការពន្យល់ មថ ៥:១៣)។

**៩:៥១** *នៅជាមួយគ្នាដោយមេត្រីចុះ* វិវាទត្រូវបានដោះស្រាយ ហើយមេត្រីភាពត្រូវបានស្អាងឡើង នៅពេលដែលយើងដឹងពីការប្តេជ្ញាចិត្តរួមគ្នាមួយនៅក្នុងដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។ ក្នុងព្រះគម្ពីរភាសាបរទេសខ្លះបានបញ្ចូលខ៥១ និង៥២ជាមួយគ្នា ។

**១០:១** *ព្រំដែនស្រុកយូដា* ភាសាក្រិក និងភាសារ៉ូម៉ាំងមានន័យដូចគ្នាទៅនឹងទឹកដីនៃសាសន៍យូដា ក្នុងព្រះគម្ពីរសញ្ញាចាស់ ជាពិសេសផ្នែកភាគខាងត្បូងនៃប្រទេសប៉ាឡេស្ទីន ព្រមទាំងស្រុកអេដំមផងនាបច្ចុប្បន្ននេះ ដែលកាលពីមុនធ្លាប់ជានគរភាគខាងជើងនោះ ។ សម្រាប់ព្រះរាជកិច្ចរបស់ព្រះយេស៊ូវនៅស្រុកយូដា សូមមើលការពន្យល់ លក ៩:៥១ ។ *ទន្លេយ័រដាន់* មើលការពន្យល់ ១:៥ ។ ព្រះយេស៊ូវបានយាងមកពីក្រុងកាពើណិមភាគខាងត្បូងកាត់តាមភ្នំសាម៉ារីចូលទៅស្រុកយូដា ហើយបន្ទាប់មកទៅទិសខាងកើតឆ្លងកាត់ទន្លេយ័រដាន់ ចូលទៅស្រុកពេរ៉េទៀត ដែលជាទឹកដីរបស់ហេរ៉ូឌ អនុរាជ (មើលការពន្យល់ មថ ១៤:១)។ ព្រះរាជកិច្ចរបស់ព្រះយេស៊ូវនៅស្រុកពេរ៉េ មើលការពន្យល់ លក ១៣:២២ ។

**១០:២** *ផារិស៊ី* មើលការពន្យល់ ២:១៦ ។ *មកល្បងសួរទ្រង់* នេះជាសំណួរចោទប្រកាន់ដើម្បីរករឿងតែម្តង គឺស្រដៀងគ្នាទៅនឹងលោកយ៉ូហានទូលទាស់នឹងស្តេច ហេរ៉ូឌអនុរាជថា៖"ទ្រង់គ្មានច្បាប់នឹងយកភរិយារបស់អនុជទ្រង់ទេ"(៦:១៧-១៨) ដោយហេតុនោះគាត់ត្រូវបានគេចាប់ដាក់គុកម្តង ក្រោយមកត្រូវបានគេកាត់ក្បាលទៀត ។ ចំណុចនេះ ព្រះយេស៊ូវទ្រង់កំពុងតែស្ថិតនៅក្នុងសាលាជំនុំជម្រះក្តីរបស់ស្តេចហេរ៉ូឌ អនុរាជ ហើយពួកផារិស៊ីសង្ឃឹមថា ចម្លើយរបស់ទ្រង់នឹងត្រូវធ្វើឱ្យ ស្តេចអង្គនេះធ្វើគុតទ្រង់ដូចជាលោកយ៉ូហានដែរ ។ *ច្បាប់ដែលនឹងលែងប្រពន្ធបានឬមិនបាន?* ពួកសាសន៍យូដាសម័យនោះ ជាទូទៅបានយល់ថា មានច្បាប់នឹង លែងប្តីប្រពន្ធនោះរួចទៅហើយ តែអ្វីដែលយកមកជជែកទីនេះ គឺជាមូលដ្ឋានដ៏ត្រឹមត្រូវកាលពីដើមរបស់វា (មថ ១៩:៣)។

**១០:៥** *គឺដោយព្រោះតែចិត្តអ្នករាល់គ្នារឹងរូសប៉ុណ្ណោះ* ការលែងលះគឺជាការស្រុះស្រួលគ្នាមួយនៃភាពកម្សោយរបស់មនុស្ស ហើយត្រូវបានប្រើជារបៀបរៀបចំមួយនៅក្នុងសង្គមដែលបានប្រឆាំងនឹងព្រះហឫទ័យព្រះ និងមិនមែនជាខ្នាតគំរូ ដូចដែលព្រះបានបង្កើតមនុស្សពីដំបូង (មក២.៦-៩)។ គំនិតនៅក្នុងបទគម្ពីរ ចទ ២៤:១ មិនមែនធ្វើឱ្យមនុស្សអាចលែងលះគ្នាបាននោះឡើយ តែសម្រាប់បង្ក្រាប ការលែងលះនោះវិញ ។

**១០:៦** *តាំងពីដើមកំណើតមនុស្សមក* ព្រះយេស៊ូវបានពន្យល់ត្រឡប់ទៅក្រោយ មុននឹងមនុស្សបានធ្លាក់ក្នុងអំពើបាប ដើម្បីបង្ហាញពីគោលបំណងដើមរបស់ព្រះដែលបានបង្កើតមនុស្ស ។ អាពាហ៍ពិពាហ៍ ដែលជាព្រះពរនៃការរួបរួមយ៉ាងជិតស្និទ្ធបំផុតរវាងបុរស និងស្ត្រី ដូចជាដើមកំណើតដំបូងដែលទ្រង់បានបង្កើតមនុស្សនោះដែរ ។

**១០:៨** *មិនមែនជា២ទៀត គឺជាសាច់តែ១សុទ្ធ* មនុស្ស២នាក់រួមមកតែ១នេះត្រូវបានអះអាងយ៉ាងច្បាស់ ដោយព្រះយេស៊ូវលើគំនិតនៃអាពាហ៍អាពាហ៍អស់មួយជីវិត ។

**១០:៩** *ព្រះបានផ្សំផ្គុំ* ព្រះយេស៊ូវបានចាប់ផ្តើមដោយថាអាពាហ៍ពិពាហ៍គឺជាព្រះចេស្តាព្រះអង្គផ្ទាល់ដែលប្រទានមក ដោយគ្មាននរណាម្នាក់អាចបំបែកបានឡើយ ហើយក៏គ្មានការលែងគ្នាដែរនៅក្នុងព្រះអម្ចាស់នោះ ។ ការលែងលះគឺជាការបំផ្លាញនូវអ្វីដែលព្រះបានប្រទានមក ដើម្បីបំពេញបំណងផ្ទាល់ខ្លួនរបស់មនុស្ស តែប៉ុណ្ណោះ ។

១០កាលកំពុងនៅក្នុងផ្ទះ នោះពួកសិស្សទូលសួរទ្រង់ ពី
សេចក្ដីដដែលម្ដងទៀត ១១ហើយទ្រង់មានបន្ទូលថា អ្នក
ណាដែលនឹងលែងប្រពន្ធ ទៅយក១ទៀត នោះឈ្មោះថាផិត
ប្រពន្ធហើយ[គ] ១២បើស្ត្រីណាលែងប្ដីទៅយក១ទៀត នោះក៏
ឈ្មោះថាបានផិតប្ដីដែរ[ឃ]។

## ព្រះយេស៊ូវ និងកូនក្មេងតូចៗ

*១០:១៣–១៦ = មថ ១៩:១៣–១៥ លក ១៨:១៥–១៧*

១៣រួចមានគេនាំក្មេងតូចៗមកថ្វាយទ្រង់ពាល់ ប៉ុន្តែពួក
សិស្សបន្ទោសដល់ពួកអ្នកដែលនាំវាមក ១៤កាលព្រះយេស៊ូវ
បានឃើញ នោះទ្រង់គ្នាន់ក្នុងព្រះហឫទ័យ ក៏មានបន្ទូលទៅ
គេថា ទុកឱ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរ
ព្រះមានសុទ្ធតែមនុស្ស ដូចវារាល់គ្នាដែរ[ង] ១៥ហើយខ្ញុំប្រាប់
អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលមិនទទួលនគរព្រះ
ដូចជាកូនក្មេង១នេះ នោះមិនបានចូលទៅក្នុងនគរ នោះ
ឡើយ ១៦ទ្រង់ក៏ឱប[ច]វារាល់គ្នា ហើយដាក់ព្រះហស្តលើ
ទាំងប្រទានពរឱ្យផង ។

## បុរសអ្នកមានម្នាក់

*១០:១៧–៣១ = មថ ១៩:១៦–៣០ លក ១៨:១៨–៣០*

១៧កាលទ្រង់យាងចេញទៅតាមផ្លូវ នោះមានម្នាក់រត់ មក
លុតជង្គង់[ឆ]ក្រាបចុះនៅចំពោះទ្រង់ទូលសួរថា លោក
គ្រូល្អអើយ តើត្រូវឱ្យខ្ញុំធ្វើដូចម្ដេច ប្រយោជន៍ឱ្យបានគ្រង
ជីវិតរស់អស់កល្បជានិច្ច[ជ] ១៨ព្រះយេស៊ូវមានបន្ទូលទៅ
គាត់ថា ហេតុអ្វីបានជាអ្នកហៅខ្ញុំថាល្អដូច្នេះ គ្មានអ្នកណា
ល្អសោះ មានតែ១ គឺជាព្រះប៉ុណ្ណោះ ១៩អ្នកបានស្គាល់
បញ្ញត្តទាំងប៉ុន្មានហើយ ដែលថា «កុំឱ្យផិតឱ្យសោះ កុំឱ្យ
សំឡាប់មនុស្សឱ្យសោះ កុំឱ្យលួចឱ្យសោះ កុំឱ្យធ្វើជាទីបន្ទាល់
ក្លែងឱ្យសោះ កុំឱ្យបំបាត់គេឱ្យសោះ ចូរគោរពប្រតិបត្តិ
ដល់ឪពុកម្ដាយឯង»[ឈ]។
២០តែគាត់ទូលឆ្លើយថា លោកគ្រូ ខ្ញុំបានកាន់តាមសេចក្ដី

**១០:១១** គ លក ១៦:១៸
**១០:១២** ឃ រម ៧:៣ ១កថ ៧:១០,១១
**១០:១៤** ង មថ ២៥:៣៤
**១០:១៥** មថ ១៨:៣
**១០:១៦** មក ៩:៣៦
**១០:១៧** ឆ មក ១:៤០ ជ លក ១០:២៥ កថ ២០:៣២
**១០:១៩** ឈ នក ២០:១២–១៦ ចទ ៥:១៦–២០

**១០:១១** *អ្នកណាដែលនឹងលែងប្រពន្ធ* ការលែងលះដែលបានអនុវត្តនៅក្នុងសាសន៍យូដា គឺប្ដីជាអ្នកមានឥទ្ធិពលខ្លាំង មិនមែនជាអំណាចលើចៅក្រម ឬតុលាការនោះទេ ។ *នោះឈ្មោះថាផិតប្រពន្ធហើយ* នេះជាសេចក្ដីប្រកាសមួយយ៉ាងច្បាស់ពីការលះលែងប្រពន្ធ ។ ប្ដីគ្រប់រូបត្រូវដឹងថា ខ្លួនមិនអាចធ្វើមិនដឹងពីកាតព្វកិច្ចសីលធម៌ និងច្បាប់អាពាហ៍ពិពាហ៍របស់ព្រះនោះឡើយ ហើយនេះជាកម្លាំងនៃចំណង អាពាហ៍ពិពាហ៍ដែលនៅស្ថិតស្ថេរ ដែលមិនត្រូវបានទទួលស្គាល់ដោយកិច្ចការអ្នកបង្រៀនច្បាប់ឡើយ ។ មើលការពន្យល់ មថ ១៩:៣,៩ ជាកន្លែងដែលបញ្ជាក់ពី ករណីលើកលែង ។ បទគម្ពីរ ១កថ ៧:១៥ អាចទាក់ទងនឹងករណីលើកលែងមួយ ទៀត (មើលការពន្យល់ ១កថ ៧:១២,១៥)។

**១០:១២** *ស្ត្រី . . .ឈ្មោះថាផិតប្ដី* ក្នុងអត្ថបទប្រវត្តិសាស្ត្រ និងភូមិវិទ្យា ព្រះយេស៊ូវមានបន្ទូលបញ្ជាក់បន្ថែម នូវសេចក្ដីដែលបានប្រកាសដោយលោកយ៉ូហានបាទីស្ទ ដែលជំទាស់យ៉ាងក្លាហាននឹងស្ដេចហេរ៉ូឌ–អនុរាជ ដែលយកនាងហេរ៉ូឌាស ជាប្រពន្ធរបស់ប្អូនខ្លួនឯងនោះ ទោះជាស្ដេចដាក់ទោសក៏ដោយ ។

**១០:១៤** *នគរព្រះ* មើលការពន្យល់ មថ ៣:២ ។ *ដូចវារាល់គ្នាដែរ* នគរស្ថានសួគ៌ជាកម្មសិទ្ធិដល់អស់អ្នកណាដែលដូចកូនក្មេងទាំងនេះ ដោយពួកគេបានប្រុង ប្រៀបនឹងទទួលនគរព្រះទុកដូចជាអំណោយនៃព្រះអម្ចាស់ (ខ.១៥ និងពន្យល់)។

**១០:១៥** *ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា* មើលការពន្យល់ ៣:២៨ ។ *ដូចជាកូនក្មេង១នេះ* ចំណុចសំខាន់នៃការប្រៀបធៀបនេះគឺ ត្រូវមានការបើកចំហ និងត្រូវទទួលរាក់ទាក់ដល់កូនក្មេងតូចៗផងដែរ ។ នគររបស់ព្រះត្រូវបានផ្ដល់ជូន ដូចជាអំណោយ មិនមែនបានដោយសារការខិតខំរបស់មនុស្សនោះទេ ហើយអ្នកដែលអាចទទួលបាន នោះគឺអស់អ្នកដែលបានដឹងថា ខ្លួនគ្មានទីពំនឹង មិនមែនដោយការទាមទារ ឬក៏ជាសគុណ ដែលខ្លួនសមនឹងបាននោះឡើយ ។

**១០:១៦** *ប្រទានពរ* ត្រង់នេះព្រះយេស៊ូវបានបង្ហាញឱ្យឃើញច្បាស់នឹងភ្នែកថា ព្រះពរទាំងឡាយនៃនគរព្រះគឺត្រូវបានប្រទានឱ្យមនុស្សដោយសេរី ។

**១០:១៧** *នោះមានម្នាក់រត់មក* គម្ពីរម៉ាកុសមិនបានប្រាប់ថាម្នាក់នោះជានរណាទេ ប៉ុន្តែ គម្ពីរលូកា (១៨:១៨) បានប្រាប់ថាម្នាក់នោះគឺ "នាម៉ឺន" និងគម្ពីរម៉ាថាយ (១៩:២០) ប្រាប់ថា "មនុស្សកំលោះ"។ តាមន័យនេះបង្ហាញថាគាត់អាចជាម្នាក់ នៅក្នុងចំណោមមន្ត្រីក្រុមប្រឹក្សា ឬជាមន្ត្រីតុលាការ ។ *តើត្រូវឱ្យខ្ញុំធ្វើដូចម្ដេច...* បុរសអ្នកមានម្នាក់នេះកំពុងគិតដល់ការទិញដូរសេចក្ដីសុចរិត ដើម្បីឱ្យខ្លួនបានជីវិតរស់អស់កល្បជានិច្ច ប៉ុន្តែព្រះយេស៊ូវបានបង្រៀនថា វាជាអំណោយដែលព្រះ បានប្រទានមកនោះទេ (ខ.១៥)។ *ជីវិតរស់អស់កល្បជានិច្ច* (មើល មថ ១៩:១៦)។

**១០:១៨** *ហេតុអ្វីបានជាអ្នកហៅខ្ញុំថាល្អដូច្នេះ* ព្រះយេស៊ូវមិនបានបដិសេធភាពល្អរបស់ទ្រង់នោះទេ តែទ្រង់កំពុងជំរុញឱ្យបុរសនេះយល់ច្បាស់ថា សេចក្ដីសង្ឃឹមគឺ មានតែលើព្រះ១អង្គប៉ុណ្ណោះ ដែលអាចប្រទានជីវិតរស់អស់កល្បជានិច្ចនោះ ។ ទ្រង់ក៏បានលើកទឹកចិត្តដល់មនុស្សកំលោះនេះឱ្យពិចារណា ហើយស្វែងយល់អំពីព្រះ១អង្គដែលទ្រង់កំពុងមានបន្ទូលនេះផងដែរ ។

**១០:១៩** *កុំឱ្យបំបាត់គេឱ្យសោះ* បញ្ញត្តិនេះបូករួមទាំងប្រាក់ដង្វាយ១០ហូត១ផង ដែរ (មិនត្រូវលោភលន់ទេ)។ ដូច្នេះហើយបានជាបញ្ញត្តិទាំង៦របស់ព្រះយេស៊ូវ បានហាមមិនឱ្យប្រព្រឹត្តនូវទង្វើទាំងនេះ (នក ២០:១២–១៦ ចទ ៥:១៦–២១)។

**១០:២០** *ខ្ញុំបានកាន់តាមសេចក្ដីទាំងនោះ* បុរសនេះបាននិយាយដោយស្មោះត្រង់ ពីព្រោះគាត់បានកាន់តាមបញ្ញត្តិដូចគ្នាទាំងនេះ តែសំបកខាងក្រៅប៉ុណ្ណោះ ប៉ុន្តែ បញ្ញត្តិនេះតម្រូវឱ្យស្ដាប់បង្គាប់នៅខាងក្នុងផងដែរ ដែលគ្មានមនុស្សណាពេញចិត្តទាំងស្រុងនោះទេ ដូចជាបុរសនេះក្រោយពីបានញក់ដើរចេញទៅទាំងទុក្ខព្រួយ ។ លោកប៉ុលក៏ធ្លាប់និយាយពីអាកប្បកិរិយាដូចនឹងរឿងនេះដែរ មុនពេលគាត់ប្រែចិត្ត (ភល ៣:៦)។ *តាំងពីក្មេងមក* អាច

ទាំងនោះ តាំងពីក្មេងមកដែរ ២១ព្រះយេស៊ូវទ្រង់ទតទៅ
គាត់ ដោយស្រឡាញ់ ហើយមានបន្ទូលថា អ្នកនៅខ្វះកិច្ច១
ទៀត គឺត្រូវទៅលក់របស់ទ្រព្យអ្នកទាំងប៉ុន្មាន ចែកទានឱ្យ
ដល់ពួកអ្នកក្រទៅ[ញ] នោះអ្នកនឹងបានទ្រព្យសម្បត្តិនៅលើ
ស្ថានសួគ៌វិញ[ដ] រួចឱ្យផ្ទុក ឈើឆ្កាងមកតាមខ្ញុំចុះ[ឋ] ២២តែ
គាត់មានចិត្តព្រួយណាស់ដោយឮពាក្យនោះ ក៏ចេញទៅ
ទាំងក្តីទុក្ខ ព្រោះគាត់មានសម្បត្តិច្រើនណាស់ ។
២៣ព្រះយេស៊ូវទ្រង់ងាកទតជុំវិញ ហើយមានបន្ទូលទៅ
ពួកសិស្សថា ដែលមនុស្សអ្នកមាន[ឌ]ចូលទៅក្នុងនគរព្រះ
នោះពិបាកណាស់ ២៤ឯពួកសិស្ស ក៏នឹកស្ងើចនឹងព្រះបន្ទូល
ទ្រង់ តែទ្រង់មានបន្ទូលទៅគេម្តងទៀតថា កូនអើយ ពួក
អ្នកដែលជាប់ចិត្តនឹងទ្រព្យសម្បត្តិ នោះនឹងចូលទៅក្នុង
នគរព្រះដោយពិបាកណាស់[ឍ] ២៥បើសត្វអូដ្ឋនឹងចូលតាម
ប្រហោងម្ជុល នោះងាយជាជាងមនុស្សអ្នកមានចូលទៅ
ក្នុងនគរព្រះវិញ[ណ] ២៦គេក៏មានសេចក្តីប្លែកក្នុងចិត្តជា
ខ្លាំងទាំងនិយាយគ្នាទៅវិញទៅមកថា ចុះបើដូច្នេះ តើអ្នក
ណាអាចនឹងបានសង្គ្រោះ ២៧ព្រះយេស៊ូវទ្រង់ទតទៅ

**១០:២១** ញ កច ២:៤៥ ដ មថ ៦:២០ លក ១២:៣៣ ឋ មថ ៤:១៩
**១០:២៣** ឌ ទដ ៥២:៧ ៦២:១០ មក ៤:១៩ ១ធថ ៦:៩,១០,១៧
**១០:២៤** ឍ មថ ៧:១៣,១៤ យហ ៣:៥
**១០:២៥** ណ លក ១២:១៦–២០ ១៦:១៩–៣១
**១០:២៧** ត មថ ១៩:២៦
**១០:២៨** ថ មថ ៤:១៩
**១០:៣០** ទ មថ ៦:៣៣ ធ មថ ១២:៣២ ន មថ ២៥:៤៦
**១០:៣១** ប មថ ១៩:៣០

គេ មានបន្ទូលថា ការនោះមនុស្សលោកធ្វើពុំកើតទេ តែ
ព្រះទ្រង់ធ្វើកើត ដ្បិតព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់បាន[ត]
២៨នោះពេត្រុសចាប់តាំងទូលទ្រង់ថា មើល យើងខ្ញុំបានលះ
ចោលទាំងអស់មកតាមទ្រង់ហើយ[ថ] ២៩តែព្រះយេស៊ូវមាន
បន្ទូលឆ្លើយថា ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា មិនដែល
មានអ្នកណាដែលលះចោលផ្ទះសំបែង បងប្អូនប្រុសស្រី
ឪពុកម្តាយ ប្រពន្ធកូន ឬស្រែចំការ ដោយព្រោះយល់ដល់
ខ្ញុំ ហើយនឹងដំណឹងល្អ ៣០ឥតបាន ទទួលជា១រយភាគឡើង[ទ]
ក្នុងសម័យនេះនោះឡើយ[ធ] គឺជាផ្ទះសំបែងបងប្អូនប្រុសស្រី
ម្តាយហើយកូន នឹងស្រែចំការ ព្រមទាំងសេចក្តីបៀតបៀន
ដែរ ហើយដល់បរលោកនាយ នឹងបានជីវិតរស់អស់កល្ប
ជានិច្ចផង[ន] ៣១តែនឹងមានមនុស្សមុនទៅជាក្រោយជាច្រើន
ហើយមនុស្សក្រោយទៅជាមុន វិញ[ប] ។

## ព្រះយេស៊ូវថ្លែងទំនាយពីការសុគតរបស់ទ្រង់ម្តងទៀត

*១០:៣២–៣៤ = មថ ១៧–១៩ លក ១៨:៣១–៣៣*

៣២កំពុងដែលដើរតាមផ្លូវ ឡើងទៅឯក្រុងយេរូសាឡិម
នោះព្រះយេស៊ូវយាងមុខគេ ហើយពួកសិស្សមានចិត្តវិលវល់

តាំងពីអាយុ១៣ឆ្នាំមក ព្រោះក្មេងប្រុសសាសន៍យូដាដែលមានវ័យនេះ ត្រូវទទួលខុសត្រូវក្នុងការស្តាប់បង្គាប់បញ្ញត្តិដោយខ្លួនឯង ។

**១០:២១** *ព្រះយេស៊ូវ . . . ស្រឡាញ់* ព្រះយេស៊ូវទ្រង់ជ្រាបពីទឹកចិត្តដ៏ស្មោះត្រង់របស់បុរសនោះ ។ ការឆ្លើយតបរបស់ព្រះយេស៊ូវមិនមានបំណងធ្វើឱ្យបុរសនេះខ្មាសអៀន ចំពោះការយល់បញ្ញត្តិខុសខាងឯព្រលឹងវិញ្ញាណរបស់គាត់ទេ តែនេះជាការសំដែងសេចក្តីស្រឡាញ់យ៉ាងពិតប្រាកដវិញ ។ *អ្នកនៅខ្វះកិច្ច១ទៀត . . . ទៅលក់របស់ទ្រព្យអ្នកទាំងប៉ុន្មាន* បញ្ហាសំខាន់របស់បុរសនេះគឺទ្រព្យសម្បត្តិ (ខ.២២) ដូច្នេះហើយបានជា ព្រះយេស៊ូវបង្គាប់ឱ្យលក់ទ្រព្យទាំងនោះចេញទៅ ។ សេចក្តីបង្គាប់របស់ព្រះយេស៊ូវដល់បុរសនោះ មិនមានន័យលើគ្រីស្ទបរិស័ទទាំងអស់នោះទេ គឺចំពោះតែអ្នកណាដែលមានបញ្ហាខាងឯវិញ្ញាណដូចនឹងសាច់រឿងនេះតែប៉ុណ្ណោះ ។ *ទ្រព្យសម្បត្តិនៅលើស្ថានសួគ៌* គឺជាអំណោយនៃជីវិតអស់កល្ប ឬសេចក្តីសង្គ្រោះ ។ ទ្រព្យសម្បត្តិនេះមិនអាចនឹងរកបានដោយការបដិសេធន៍ខ្លួនឯង ការធ្វើទាន ឬទង្វើល្អនោះឡើយ តែត្រូវបានទទួលមកដោយសារការដើរតាមព្រះយេស៊ូវ ។ ការលក់ទ្រព្យសម្បត្តិរបស់ខ្លួននោះគឺដូចជាដកឧបសគ្គចេញពីជីវិត ហើយបែរមកជឿទុកចិត្តលើព្រះយេស៊ូវវិញ ។

**១០:២២** *គាត់មានចិត្តព្រួយណាស់ដោយឮពាក្យនោះ ក៏ចេញទៅទាំងក្តីទុក្ខ ព្រោះគាត់មានសម្បត្តិច្រើនណាស់* ការសម្រេចចិត្តដែលនាំឱ្យវិនាស អន្តរាយដោយការស្រឡាញ់ទ្រព្យសម្បត្តិជាងជីវិតអស់កល្បជានិច្ច (៤:១៩) ។

**១០:២៥** *ប្រហោងម្ជុល* អូដ្ឋជាសត្វ១ដែលធំនៅប្រទេសប៉ាឡេស្ទីន ។ ពាក្យផ្ទុយគ្នា រវាងសត្វដ៏ធំ និងអ្វីដែលតំណាងរន្ធតូចបំផុត ដែលឃើញច្បាស់នោះគឺ សំដីរបស់មនុស្សដែលមិនអាចធ្វើកើត ។

**១០:២៧** *ការនោះមនុស្សលោកធ្វើពុំកើតទេ តែព្រះទ្រង់ធ្វើកើត* សេចក្តីសង្គ្រោះ គឺជាព្រះរាជកិច្ចរបស់ព្រះអម្ចាស់ទាំងស្រុង ។ បើមាននរណាម្នាក់ប៉ងប្រាថ្នាចូលនគរព្រះ ដោយពឹងលើការប្រព្រឹត្តរបស់ខ្លួន ឬថាខ្លួនធ្វើល្អដែលសមនឹងបាន នោះគឺជាការឥតប្រយោជន៍ទេ ពីព្រោះបើសិនមិនមែនជាព្រះគុណរបស់ព្រះផ្តល់ឱ្យទេ នោះគ្មាននរណាម្នាក់បានសង្គ្រោះឡើយ ។

**១០:២៩** *ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា* មើលការពន្យល់ ៣:២៨ ។ *ដំណឹងល្អ* មើលការពន្យល់ ១:១ ។

**១០:៣០** *ក្នុងសម័យនេះនោះឡើយ. . . ហើយដល់បរលោកនាយ* ពាក្យទាំង២នេះ បានសរុបតាំងពីការធ្លាក់ចុះរបស់មនុស្ស រហូតដល់ទីអវសាននៃពិភពលោក ។ ក្នុងសម័យកាលនេះ គឺអាក្រក់ (កទ ១:៤) តែសម័យកាលសុចរិតកំពុងធ្វើដំណើរ មកជាមួយនឹងការយាងមកលើកទី២របស់ព្រះគ្រីស្ទ ព្រមទាំងបន្តរហូតអស់កល្បជានិច្ច ។ *ឥតបានទទួលជា១រយភាគឡើង . . . ព្រមទាំងសេចក្តីបៀតបៀនដែរ* ជីវិតនៃភាពជាសាវ័ក គឺជាការភ្ជាប់នៃសេចក្តីសន្យានិងការបៀតបៀន ព្រះពរ និងការរងទុក្ខ។ព្រះមិនបានចំណេញអ្វីពីមនុស្សនោះទេ ឬមិនបានស្អាងនគររបស់ទ្រង់ឡើងវិញ ឱ្យមានសិរីរុងរឿងខ្លាំងជាងមុនដោយសារមនុស្សនោះដែរ ។ ជីវិតរស់អស់កល្ប សម្រាប់អស់អ្នកដែលបានឆ្លងផុតជម្លោះ នៃប្រវត្តិសាស្ត្រគឺជាភាពជោគជ័យដែលអះអាងថា អ្នកនោះជាកម្មសិទ្ធិរបស់ព្រះអម្ចាស់ ។

**១០:៣១** *មនុស្សមុនទៅជាក្រោយ* នេះគឺជាការព្រមានចំពោះភាពមាន អំនួតក្នុងកាលដែលពួកគេលះបង់ថ្វាយព្រះ ដូចករណីលោកពេត្រុសបានបង្ហាញក្នុងនេះ (ខ.២៨) ។

**១០:៣២** *កំពុងដែលដើរតាមផ្លូវ ឡើងទៅឯក្រុងយេរូសាឡិម* នេះជាដំណើរ

ក៏ដើរតាមទ្រង់ទៅទាំងភ័យភិត ទ្រង់ក៏យកពួក១២[ផ] មកម្តង
ទៀត ចាប់តាំងមានបន្ទូលប្រាប់អំពីការដែលត្រូវកើតមក
ដល់ទ្រង់ថា ៣៣ មើល យើងឡើងទៅឯក្រុងយេរូសាឡិម[ព]
នោះកូនមនុស្ស[ភ] នឹងត្រូវបញ្ជូនទៅឯពួកសង្គ្រាជ នឹងពួក
អាចារ្យ[ម] គេនឹងកាត់ទោសលោកដល់ជីវិត ហើយបញ្ជូនទៅ
ដល់ពួកសាសន៍ដទៃ ៣៤ ពួកនោះនឹងចំអកមើលងាយ វាយ
នឹងរំពាត់[យ] ស្តោះដាក់ ហើយសំឡាប់លោក[រ] រួចពីថ្ងៃក្រោយ
ដែលស្លាប់ទៅ[ល] នោះលោកនឹងរស់ឡើងវិញ[វ] ។

## សំណូមពររបស់យ៉ាកុប និងយ៉ូហាន

*១០:៣៥–៤៥ = មថ ២០:២០–២៨*

៣៥ ខណនោះ យ៉ាកុប និងយ៉ូហាន ជាកូនសេបេដេក៏មក
ទូលទ្រង់ថា លោកគ្រូ សូមលោកសំរេចឱ្យយើងខ្ញុំតាម
សេចក្តីសំណូមរបស់យើងខ្ញុំផង ៣៦ ទ្រង់មានបន្ទូលសួរថា
តើចង់ឱ្យខ្ញុំសំរេចអ្វីឱ្យអ្នក ៣៧ គេក៏ទូលឆ្លើយថា សូមឱ្យ
យើងខ្ញុំបានអង្គុយនៅ ម្នាក់ខាងស្តាំ ហើយម្នាក់ខាងឆ្វេង
លោក ក្នុងស្ថាននៃសិរីល្អ របស់លោក[ស] ៣៨ តែព្រះយេស៊ូវ
មានបន្ទូលថា អ្នកមិនយល់សេចក្តីដែលអ្នកសូមនោះទេ[ហ]
តើអ្នកអាចនឹងផឹកអំពីពែង[ឡ] ដែល ខ្ញុំផឹក ហើយទទួល
បុណ្យជ្រមុជដែលខ្ញុំទទួលបានឬទេ[អ] ៣៩ គេទូលឆ្លើយថា
ទទួលបាន នោះព្រះយេស៊ូវមានបន្ទូលតបថា អ្នករាល់គ្នា
នឹងផឹកអំពីពែងខ្ញុំ ហើយទទួលបុណ្យជ្រមុជ ដែលខ្ញុំទទួល
មែន[ក] ៤០ តែដែលអង្គុយខាងស្តាំ ឬខាងឆ្វេងខ្ញុំ នោះមិន
ស្រេចនឹងខ្ញុំទេ គឺសំរាប់តែអ្នកណាដែលទីនោះបានរៀប
ចំទុកឱ្យប៉ុណ្ណោះ ៤១ កាល១០នាក់ឯទៀតបានឮសេចក្តីនោះ
នោះគេក៏នឹក តូចចិត្តនឹងយ៉ាកុប ហើយនឹងយ៉ូហាន
៤២ តែព្រះយេស៊ូវទ្រង់ហៅអ្នកទាំងនោះមក មានបន្ទូលថា
អ្នករាល់គ្នាដឹងថា ពួកអ្នកដែលបានរាប់ជាចៅហ្វាយនៃ
សាសន៍ដទៃ គេគ្រប់គ្រងលើសាសន៍របស់ខ្លួន ហើយពួក
អ្នកធំក៏មានអំណាចលើគេដែរ ៤៣ ប៉ុន្តែមិនត្រូវឱ្យមាន
ដូច្នោះក្នុងពួកអ្នករាល់គ្នាឡើយ អ្នកណាក្នុងពួកអ្នករាល់
គ្នាដែលចង់ធ្វើជាធំ នោះនឹងត្រូវធ្វើជាអ្នកបំរើដល់អ្នក
រាល់គ្នាវិញ[ខ] ៤៤ ឯអ្នកណាក្នុងពួកអ្នករាល់គ្នាដែលចង់
បានជាលេខ១ អ្នកនោះត្រូវធ្វើជាបាវដល់ អ្នកទាំងអស់
វិញ ៤៥ ដ្បិតកូនមនុស្សក៏បានមក មិនមែនឱ្យគេបំរើដែរគឺ
ដើម្បីនឹងបំរើគេវិញ[គ] ហើយនឹងឱ្យជីវិតខ្លួនទុកជាថ្លៃលោះ
មនុស្សជាច្រើនផង[ឃ] ។

**១០:៣២** ផ មក ៣:១៦–១៩
**១០:៣៣** ព លក ៩:៥១ ភ មថ ៨:២០ ម មថ ២៧:១,២
**១០:៣៤** យ មថ ១៦:២១ រ កច ២:២៣ ៣:១៣ ល មថ ១៦:២១ វ មថ ១៦:២១
**១០:៣៧** ស មថ ១៩:២៨
**១០:៣៨** ហ យប ៣៨:២ ឡ មថ ២០:២២ អ លក ១២:៥០
**១០:៣៩** ក កច ១២:២ វវ ១:៩
**១០:៤៣** ខ មក ៩:៣៥
**១០:៤៥** គ មថ ២០:២៨ ឃ មថ ២០:២៨

ចុងក្រោយទៅក្រុងយេរូសាឡិម ដែលចាប់ផ្តើមពីក្រុងអេប្រាអិម (យហ ១១:៥៤) ហើយទ្រង់បន្តទៅស្រុកកាលីឡេ (លក ១៧:១១) ដោយឆ្លងស្រុកពេរ៉េភាគខាងត្បូង ឆ្ពោះទៅក្រុងយេរីខូរ (លក ១៨:៣៥) រួចទៅភូមិបេថានី (លក ១៩:២៩) និងទីបញ្ចប់យាងទៅក្រុងយេរូសាឡិម (លក ១៩:៤១) ។ *ដើរតាមទ្រង់ទៅទាំងភ័យភិត* ប្រហែលជាអ្នកដើរធម្មយាត្រាឡើងទៅក្រុងយេរូសាឡិមទៅក្នុងថ្ងៃបុណ្យរំលង ។ *ពួក១២* ជាពួកសិស្សទាំង១២នាក់ (៣:១៦–១៩ និងពន្យល់ លក ៦:១៤–១៦) ។

**១០:៣៣–៣៤** *ពួកសាសន៍ដទៃ...សំឡាប់លោក* ពាក្យថា "ឆ្កាង" ពុំមានឃើញទេក្នុងទំនាយពីការរងទុក្ខក្នុងដំណឹងល្អរបស់លោកម៉ាកុសនេះ ។ ប៉ុន្តែ ការដែលថ្លែងថា ព្រះយេស៊ូវនឹងត្រូវគេបញ្ជូនទៅពួកសាសន៍ដទៃ ហើយត្រូវពួកគេធ្វើគុត នោះមានន័យថា ពួករ៉ូម៉ាំងសម្លាប់មនុស្សសាសន៍ដទៃ (ក្រៅពីសាសន៍រ៉ូម) ដោយឆ្កាង ។

**១០:៣៣** *កូនមនុស្ស...ពួកសង្គ្រាជ...ពួកអាចារ្យ* មើលការពន្យល់ ៨:៣១ មថ ២:៤ ។ *ពួកអាចារ្យ* ព្រះគម្ពីរជាភាសាក្រិកប្រើពាក្យថា "ពួកគ្រូក្រឹត្យវិន័យ" ។

**១០:៣៥–៤៥** វគ្គនេះបានស្របទៅនឹង ៩:៣៣–៣៧ ។ អត្ថបទទាំងពីរនេះទាក់ទងទៅនឹងសេចក្តីអស្ចារ្យយ៉ាងពិតប្រាកដ និងអំពីទំនាយនៃការរងទុក្ខ និងការសុគតរបស់ព្រះយេស៊ូវ ព្រមទាំងបង្ហាញថា ពួកសិស្សទ្រង់មិនទាន់យល់ពីកិច្ចការរបស់ទ្រង់នៅឡើយទេ ។

**១០:៣៥–៣៦** *សូមលោកសំរេចឱ្យ... សំរេចអ្វីឱ្យអ្នក* បំណងរបស់លោកយ៉ាកុប និងលោកយ៉ូហានគឺចង់បានអំណាច និងតួនាទីធំ ដែលត្រូវបានគេដឹងថា ទាំងពីរនេះបានមកតាមរយៈការបម្រើ (មើលការពន្យល់ ខ.៤៣–៤៤)

**១០:៣៥** *យ៉ាកុប និងយ៉ូហាន* មើលការពន្យល់ ១:១៩ ៣:១៧ ។

**១០:៣៧** *ម្នាក់ខាងស្តាំ ហើយម្នាក់ខាងឆ្វេងលោក* ជាកន្លែងដែលពោរពេញទៅដោយកិត្តិយស និងអំណាច ។

**១០:៣៨** *ផឹកអំពីពែងដែលខ្ញុំផឹក* ជាឃ្លារបស់សាសន៍យូដាដែលមានន័យថា តើអ្នកអាចព្រមស្លាប់រស់ជាមួយខ្ញុំដែរឬទេ? ក្នុងព្រះគម្ពីរសញ្ញាថ្មីឃ្លានេះជាពាក្យប្រៀបធៀប សំដៅលើសេចក្តីក្រោធរបស់ព្រះទាស់នឹងអំពើបាប និងការបះបោររបស់មនុស្ស (ទដ ៧៥:៨ អស ៥១:១៧–២៣ យរ ២៥:១៥–២៨ ៤៩:១២ ៥១:៧) ។ បើតាមពែងដែលព្រះយេស៊ូវត្រូវតែសោយនោះ គឺជាការដាក់ទោសរបស់ព្រះ ចំពោះអំពើបាបដែលទ្រង់បានផ្ទុកជំនួសមនុស្សលោក (១០:៤៥ ១៤:៣៦) ។ *ទទួលបុណ្យជ្រមុជដែលខ្ញុំទទួល* រូបភាពនៃពិធីបុណ្យជ្រមុជទឹកមានន័យដូចគ្នានឹងពែងដែរ គឺជាប់ទាក់ទងទៅនឹងការរងទុក្ខ និងការសុគតរបស់ទ្រង់ (សូមមើល លក ១២:៥០ រម ៦:៣–៤) ។

**១០:៤០** *នោះមិនស្រេចនឹងខ្ញុំទេ* ត្រង់ចំណុចនេះចង់បញ្ជាក់ថា ព្រះយេស៊ូវមិនបាន ដណ្តើមអំណាចព្រះចេស្តាពីព្រះវរបិតារបស់ទ្រង់នោះទេ ។

**១០:៤១** *១០នាក់ឯទៀត* សំដៅលើពួកសិស្សឯទៀតរបស់ព្រះយេស៊ូវ ។ *តូចចិត្ត* ប្រហែលមកពីពួកគេបានគិតទុកថា តំណែងដែលមានកិត្តិយស និងអំណាចនេះជារបស់គេរៀងៗខ្លួន ។

**១០:៤៣** *មិនត្រូវឱ្យមានដូច្នោះក្នុងពួកអ្នករាល់គ្នាឡើយ* ព្រះយេស៊ូវប្តូរពីតម្លៃរចនាសម្ព័ន្ធរបស់លោកិយ ។ ជីវិតនៃភាពជាសិស្សរបស់ទ្រង់គឺត្រូវតែបង្ហាញចរិតលក្ខណៈបន្ទាបខ្លួន និងការបម្រើដោយក្តីស្រឡាញ់ ។

**១០:៤៥** នេះគឺជាខគន្លឹះនៅក្នុងដំណឹងល្អរបស់លោកម៉ាកុស ។ ព្រះយេស៊ូវទ្រង់ បានយាងមកផែនដីនេះក្នុងលក្ខណៈជាអ្នកបម្រើពិតប្រាកដ ហើយអ្នក

## មនុស្សខ្វាក់ឈ្មោះបារទីមេ

*១០:៤៦-៥២ = មថ ២០:២៩-៣៤ លក ១៨:៣៥-៤៣*

៤៦ខណនោះ ក៏មកដល់ក្រុងយេរីខូរ ហើយកំពុងដែល
ទ្រង់យាងចេញពីនោះទៅ ព្រមទាំងពួកសិស្ស នឹងហ្វូង
មនុស្សជាធំផង នោះមានមនុស្សខ្វាក់ឈ្មោះបារទីមេ ជាកូន
ទីមេ កំពុងអង្គុយសូមទាននៅមាត់ផ្លូវ ៤៧កាលគាត់បានឮថា
ជាព្រះយេស៊ូវ ពីណាសារ៉ែត[ង] នោះក៏តាំងស្រែកឡើងថា
ឱព្រះយេស៊ូវ ជាព្រះវង្សហ្លួងដាវីឌអើយ[ច] សូមអាណិត
មេត្តាដល់ទូលបង្គំផង ៤៨មានមនុស្សជាច្រើនកំហែងឱ្យ
គាត់នៅស្ងៀម តែគាត់ស្រែករឹតតែខ្លាំងឡើងថា ឱព្រះអង្គ
ជាព្រះវង្សហ្លួង ដាវីឌអើយ សូមអាណិតមេត្តាទូលបង្គំផង
៤៩នោះព្រះយេស៊ូវទ្រង់ឈប់ ហើយប្រាប់ឱ្យគេហៅគាត់
មក គេក៏ហៅមក ដោយប្រាប់ថា ចូរសង្ឃឹមចុះ ហើយ
ក្រោកឡើង លោកហៅឯង ៥០គាត់បោះអាវធំចោល រួច
ស្ទុះក្រោកឡើង ទៅឯព្រះយេស៊ូវ ៥១ទ្រង់មានបន្ទូលសួរ
គាត់ថា តើចង់ឱ្យខ្ញុំធ្វើអ្វីឱ្យអ្នក អ្នកនោះទូលឆ្លើយថា
លោកគ្រូអើយ[ឆ] សូមប្រោសភ្នែកទូលបង្គំឱ្យបានភ្លឺឡើង
៥២ទ្រង់មានបន្ទូលទៅគាត់ថា ទៅចុះសេចក្ដីជំនឿអ្នកបាន
សង្គ្រោះអ្នកហើយ[ជ] ស្រាប់តែភ្នែកក៏ភ្លឺឡើងភ្លាម រួចគាត់
ដើរតាមទ្រង់ទៅ[ឈ]។

**១០:៤៧** ង មក ១:២៤ ច មថ ៩:២៧
**១០:៥១** ឆ មថ ២៣:៧
**១០:៥២** ជ មថ ៩:២២ ឈ មថ ៤:១៩
**១១:១** ញ មថ ២១:១៧ ដ មថ ២១:១
**១១:២** ឋ ជន ១៩:២ ចទ ២១:៣ ១សយ ៦:៧
**១១:៤** ឌ មក ១៤:១៦

## ផ្លូវនៃជ័យជម្នះ

*១១:១-១០ = មថ ២១:១-៩ លក ១៩:២៩-៣៨*

*១១:៧-១០ = យហ ១២:១២-១៥*

**១១** ១កាលមកជិតដល់ក្រុងយេរូសាឡិម ដល់ភូមិបេតផាសេ
នឹងបេថានី[ញ] ទន្ទឹមនឹងភ្នំដើមអូលីវហើយ[ដ] នោះទ្រង់ចាត់
សិស្ស២នាក់ឱ្យទៅ ២ដោយបន្ទូលថា ចូរទៅឯភូមិខាងមុខ
នុ៎ះ កាលណាចូលទៅដល់ នោះនឹងឃើញកូនលាគេបាន
ចងទុក ដែលឥតមានអ្នកណាទាន់ជិះនៅឡើយ[ឋ] ចូរស្រាយ
ដឹកនាំវាមក ៣បើអ្នកណាសួរថា ស្រាយវាធ្វើអី នោះត្រូវ
ឆ្លើយថា ព្រះអម្ចាស់ទ្រង់ត្រូវការនឹងវា រួចគេនឹងឱ្យវាមក
ហើយ ៤អ្នកទាំង២ក៏ទៅ ឃើញកូនលាគេចងទុកនៅមាត់
ទ្វារ ត្រង់កន្លែងផ្លូវប្រសព្វ[ឌ] រួចក៏ស្រាយវា ៥ឯពួកអ្នកខ្លះ
ដែលឈរនៅទីនោះគេសួរថា អ្នកស្រាយកូនលាធ្វើអី
៦អ្នកទាំងនោះឆ្លើយប្រាប់ ដូចជាព្រះយេស៊ូវទ្រង់បង្គាប់

បម្រើអង្គនេះបានរងទុក្ខ និងសុគតដើម្បីលោះបាបរបស់យើងទាំងអស់គ្នា ដូចដែលហោរាអេសាយបានទាយទុកយ៉ាងច្បាស់រួចមកហើយដែរ (អស ៥២:១៣-៥៣:១២)។ *កូនមនុស្ស* មើលការពន្យល់ ៨:៣១ ។ *ថ្លៃលោះ* មានន័យថា "ថ្លៃដែលបាន ចំណាយសម្រាប់ដោះលែងអ្វីមួយ(ពីចំណង)"។ ព្រះយេស៊ូវទ្រង់បានប្រគល់ជីវិត ទ្រង់ផ្ទាល់ទុកជាថ្លៃលោះយើង ឱ្យបានរួចពីចំណងនៃអំពើបាប និងសេចក្ដីស្លាប់ ។ *ទុកជា* មានន័យថា"ជាជំនួស"។ បង្ហាញថាព្រះគ្រីស្ទសុគតជួសអ្នកដទៃ(មើលការ ពន្យល់មថ ២០:២៨)។ *ជាច្រើន* មានន័យថា ជីវិតជាច្រើនត្រូវបានចេញថ្លៃលោះដោយជីវិតតែមួយ ។

**១០:៤៦** *ក្រុងយេរីខូរ* ជាក្រុងបុរាណវ័យចំណាស់មួយ មានចម្ងាយប្រហែល ៨គ.ម ភាគខាងលិចទន្លេយ័រដាន់ និងប្រហែល២៤គ.ម ទិសឦសាននៃក្រុងយេរូសាឡិម។ ក្នុងព្រះគម្ពីរសញ្ញាចាស់ វាត្រូវបានគេបោះបង់ចោលហើយ តែសម័យព្រះយេស៊ូវ ស្ដេចហេរ៉ូឌបានកសាងទីក្រុងថ្មីមួយនៅភាគខាងត្បូងទីក្រុងនេះ ។ *កំពុងដែលទ្រង់ យាងចេញពីនោះ* តាមគម្ពីរលូកានិយាយថា ព្រះយេស៊ូវ "មកជិតដល់ទីក្រុងយេរីខូរហើយ"(លក ១៨:៣៥) ប្រហែលជាគាត់និយាយពីទីក្រុងយេរីខូរថ្មីនេះ ហើយមើលទៅ តែគម្ពីរម៉ាថាយ (២០:២៩) និងម៉ាកុសនិយាយថា ជាទីក្រុងចាស់ ទេ ។ *មនុស្សខ្វាក់...សូមទានតាមមាត់ផ្លូវ* គឺនៅខាងក្រៅរបងមាត់ទ្វារទីក្រុង តាមដងផ្លូវដែលមនុស្សកំពុងដើរធម្មយាត្រាជាច្រើនទៅកាន់ទីក្រុងយេរូសាឡិមដូចសព្វដង ។

**១០:៤៧** *ណាសារ៉ែត* មើលការពន្យល់ មថ ២:២៣ ។ *ព្រះវង្សហ្លួងដាវីឌ* ជាព្រះ នាមរបស់ព្រះមែស៊ី(អស ១១:១-៣ រយ ២៣:៥-៦ អគ ៣៤:២៣-២៤ និងការពន្យល់ មថ ១:១ ៩:២៧)។ មានតែម្ដងនេះគត់ដែលលោកម៉ាកុសបានប្រើងារនេះ ដើម្បីបង្ហាញអំពីព្រះយេស៊ូវ ។

**១០:៥១** *លោកគ្រូ* ភាសាហេព្រើរប្រើពាក្យថា "គ្រូ(របស់ខ្ញុំ)"។

**១១:១-១១** ចំណុចនេះគឺជាការចាប់ផ្ដើមវគ្គថ្មីមួយផ្សេងទៀត នៅក្នុងដំណឹងល្អតាមរយៈលោកម៉ាកុស ។ ព្រះយេស៊ូវយាងមកដល់ក្រុងយេរូសាឡិម ហើយភារកិច្ចមួយចំនួនទៀតរបស់ទ្រង់នឹងបង្ហើយ នៅក្នុងទីកំណត់នៃទីក្រុងបរិសុទ្ធ ។ ក្បួនដង្ហែនៃជ័យជម្នះដែលចាប់ផ្ដើមនៅក្នុងសប្ដាហ៍នៃការរងទុក្ខ គឺជាការបើកសំដែងអំពីសកម្មភាពរបស់ព្រះមែស៊ី ហើយដើម្បីជាការងាយយល់នោះគឺនៅក្នុងបទគម្ពីរ "សក ៩:៩"(មថ ២១:៥ យហ ១២:១៥)។ គោលបំណងរបស់ព្រះយេស៊ូវ គឺបើកសំដែងអង្គទ្រង់ផ្ទាល់ ដើម្បីឱ្យគេដឹងថាទ្រង់គឺជាព្រះមែស៊ី ទោះទង្វើទាំងនេះនឹង បណ្ដាលឱ្យអ្នកដឹកនាំសាសន៍យូដាមានប្រតិកម្មប្រឆាំងទាស់នឹងទ្រង់យ៉ាងណាក៏ដោយ ។

**១១:១** *បេតផាសេ* មើលការពន្យល់ មថ ២១:១ ។ *បេថានី* មើលការពន្យល់ មថ ២១:១៧ ។ *ភ្នំដើមអូលីវ* នៅទិសខាងកើតក្រុងយេរូសាឡិម មានកំពស់ប្រហែល ៨២៣ម៉ែត្រ អ្នកខ្លះថាវាខ្ពស់ជាងភ្នំស៊ីយ៉ូនប្រហែលជា ៦១ម៉ែត្រទេ ។ បើឡើងទៅដល់កំពូលខ្ពស់ជាងគេរបស់វា នោះនឹងឃើញទេសភាពល្អផើតឆាយនៃទីក្រុងជាពិសេសនោះគឺព្រះវិហារយេរូសាឡិម ។

**១១:២** *ភូមិខាងមុខនុ៎ះ* ប្រហែលជាភូមិបេតផាសេ។ *កូនលា* ជាភាសាក្រិកមានន័យថា កូនសត្វពាហនៈទូទៅ មិនសំដៅលើកូនលានោះទេ ប៉ុន្តែនៅត្រង់ចំណុចនេះ គឺសំដៅលើកូនលាតែប៉ុណ្ណោះ(មថ ២១:២ យហ ១២:១៥)។ *ឥតមានអ្នកណាទាន់ជិះនៅឡើយ* សត្វដែលមិនទាន់ប្រើត្រូវបានគេចាត់ទុកថាជាសត្វដែល សមរម្យបំផុតសម្រាប់ខាងឯសាសនា(ជន ១៩:២ ចទ ២១:៣ ១សយ ៦:៧)។

**១១:៣** *បើអ្នកណាសួរ* បណ្ដាំនេះគឺទាក់ទងទៅនឹងកូនលា និងមនុស្សដទៃផ្សេងទៀតផងដែរ ដែលចាប់អារម្មណ៍នឹងសកម្មភាពរបស់ពួកសាវ័ក មិនមែនគ្រាន់តែ សំដៅលើម្ចាស់សត្វលានោះទេ ។ *ព្រះអម្ចាស់* មើលការ

រួចគេក៏បើកឱ្យ ៧អ្នកទាំង២ដឹកនាំកូនលាមកឯព្រះយេស៊ូវ
រួចក្រាលអាវលើវា ហើយទ្រង់ឡើងគង់ ៨មានមនុស្ស
ជាច្រើន នាំគ្នាក្រាលអាវខ្លួននៅផ្លូវ ហើយខ្លះទៀតកាច់
មែកឈើ យកមករាយតាមផ្លូវដែរ ៩ឯពួកអ្នកដែល
ដើរហែមុខក្រោយ គេស្រែកឡើងថា ហូសាណាព្រះអង្គ
ដែលយាងមក ដោយនូវព្រះនាមព្រះអម្ចាស់ ទ្រង់ប្រកប
ដោយព្រះពរ[ឈ] ១០រាជ្យនៃហ្លួងដាវីឌ ជាព្ធយុកោយើង
រាល់គ្នា ដែលមកដោយនូវព្រះនាមព្រះអម្ចាស់ ក៏ប្រកប
ដោយព្រះពរដែរ ហូសាណា នៅស្ថានដ៏ខ្ពស់បំផុត[ណ]
១១នោះព្រះយេស៊ូវ ទ្រង់យាងចូលទៅក្នុងក្រុងយេរូសាឡិម
ក៏ទៅក្នុងព្រះវិហារ កាលទ្រង់ទតជុំវិញ មើលសព្វគ្រប់
ទាំងអស់ហើយ នោះក៏យាងទៅឯបេថានី ព្រមទាំងពួក
១២ផង[ត] ដ្បិតថ្ងៃកាន់តែ ទាបណាស់ហើយ ។

## ព្រះយេស៊ូវសម្អាតព្រះវិហារ

*១១:១២–១៤ = មថ ២១:១៨–២២ ១១:១៥–១៨ = មថ ២១:១២–១៦*
*លក ១៩:៤៥–៤៧ យហ ២:១៣–១៦*

១២ថ្ងៃស្អែកឡើង កាលបានចេញពីបេថានីមក នោះទ្រង់
ក៏ឃ្លាន ១៣ទ្រង់ទតឃើញដើមល្វា១ពីចំងាយ ដែលមាន
សន្លឹក រួចទ្រង់យាងទៅមើល ក្រែងរកបានផ្លែខ្លះ តែកាល
ទៅដល់ នោះឃើញមានតែស្លឹកទទេ ព្រោះមិនទាន់ដល់
រដូវនៅឡើយ[ថ] ១៤នោះទ្រង់មានបន្ទូលទៅដើមនោះថា កុំ
ឱ្យអ្នកណាស៊ីផ្លែឯងទៀតជារៀងរាបដរាបទៅ ពួកសិស្ស
ទ្រង់ក៏ឮ ។
១៥ព្រះយេស៊ូវ ទ្រង់យាងទៅដល់ក្រុងយេរូសាឡិម កាល
បានចូលទៅក្នុងព្រះវិហារហើយ នោះក៏តាំងដេញពួកអស់
អ្នកដែលលក់ដូរក្នុងព្រះវិហារចេញ ទ្រង់ផ្កាប់តុរបស់
ពួកអ្នកដែលដូរប្រាក់ នឹងជើងម៉ានៃពួកអ្នកលក់ព្រាប។
១៦ក៏មិនព្រមឱ្យអ្នកណាលីសែងអ្វី ដើរកាត់ព្រះវិហារឡើយ
១៧ទ្រង់បង្រៀនគេថា តើគ្មានសេចក្ដីចែងទុកមកទេឬអីថា
«ដំណាក់អញត្រូវហៅជាទីអធិស្ឋាន សំរាប់គ្រប់អស់ទាំង

**១១:៩** ឈ ទដ ១១៨:២៥,២៦ មថ ២៣:៣៩
**១១:១០** ណ លក ២:១៤
**១១:១១** ត មថ ២១:១២,១៧
**១១:១៣** ថ លក ១៣:៦–៩
**១១:១៧** ទ អស ៥៦:៧ ធ យរ ៧:១១

ពន្យល់ លក ១៩:៣១ ។

**១១:៨** *មែកឈើ* មានន័យថា"ស្លឹកឈើ" ឬ"មែកឈើ" ដែលមានដើមរបស់វានៅតាមដងផ្លូវនោះ ។ មានតែក្នុងព្រះគម្ពីរយ៉ូហានប៉ុណ្ណោះដែលនិយាយថាធាងចាក (យហ ១២:១៣) ដែលប្រហែលមានប្រភពមកពីក្រុងយេរីខូ ។

**១១:៩** *ហូសាណា* មើលការពន្យល់ ទដ ១១៨:២៥ ។ *ទ្រង់ប្រកបដោយព្រះពរ* បានដកស្រង់ចេញពី ទដ ១១៨:២៦ ជាបទដំនុកដំកើង "បទសរសើរដំកើង" ដែលបានយកមកច្រៀងនៅថ្ងៃបុណ្យរំលង ពីព្រោះបទនេះត្រូវគ្នាឬស៊ីគ្នានឹងឱកាស បុណ្យនោះ ។

**១១:១០** *រាជ្យនៃហ្លួងដាវីឌ* ជាព្ធយុកោយើងរាល់គ្នា ជានគររបស់ព្រះមែស៊ីដែលបានសន្យាថានឹងយាងមកតាមរាជវង្សនៃស្ដេចដាវីឌ (២សយ ៧:១១–១៤) ។

**១១:១១** *ព្រះវិហារ* មើលការពន្យល់ មថ ៤:៥ ។ *នោះក៏យាងទៅបេថានី* ត្រង់ចំណុចនេះ បញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា ព្រះយេស៊ូវបានចំណាយពេលមួយយប់នាថ្ងៃព្រហស្បតិ៍ នៃសប្ដាហ៍រងទុក្ខនៅភូមិបេថានី ក្នុងផ្ទះរបស់នាងម៉ារា ម៉ាថា និងឡាសារដែលជាមិត្តរបស់ទ្រង់ (១១:១៩ ១៤:១៣ មថ ២១:១៧ យហ ១២:១–៣) ។ *ពួក១២* សូមមើល ៣:១៦–១៩ និងការពន្យល់ លក ៦:១៤–១៦ ។

**១១:១២** *ថ្ងៃស្អែក* គឺនៅថ្ងៃច័ន្ទនៃសប្ដាហ៍រងទុក្ខ ។ *បេថានី* (មថ ២១:១៧)

**១១:១៣** *មិនទាន់ដល់រដូវ* ដើមល្វាដែលដុះជុំវិញក្រុងយេរូសាឡិម តែងតែលាស់ស្លឹករបស់វានៅខែមីនា ឬខែមេសា ប៉ុន្តែវានឹងមានផ្លែរហូតដល់សន្លឹកវារីកធំក្នុងខែមិថុនា ។

**១១:១៤** *កុំឱ្យអ្នកណាស៊ីផ្លែឯងទៀតជារៀងរាបដរាបទៅ* ការនេះអាចជាការប្រៀបធៀបទៅនឹងការជំនុំជម្រះ ដោយយកដើមល្វាមកជាតំណាងឱ្យអ៊ីស្រាអែល (ហស ៩:១០ ណាហ ៣:១២)។ ដើមល្វាដែលមានសន្លឹករីកធំដូចនេះ ជាធម្មតាគួរតែមានផ្លែ តែបែរជាគ្មានផ្លែទៅវិញ ហើយត្រូវបណ្ដាសាទៀត ដោយព្រោះមិនមានផលផ្លែ ។ សាច់រឿងស្ដីពីការសម្អាតព្រះវិហារ (ខ.១៥–១៩) ត្រូវបានយកមកដាក់នៅចំកណ្ដាលរវាង២ផ្នែក នៃរឿងដើមល្វាឥតផ្លែនៅក្នុង ខ.១២–១៤ និង ខ.២០–២៥ ដើម្បីគូសបញ្ជាក់សាច់រឿងនៃការជំនុំជម្រះ (មើលពន្យល់ ខ.២១)។ ទោះបីជាយ៉ាងនេះក៏ដោយ សូមមើលការបកស្រាយរបស់ព្រះយេស៊ូវ ដែលជាគំរូមួយនៃសេចក្ដីជំនឿក្នុងការអធិស្ឋាន (ខ.២១–២៥)។

**១១:១៥–១៩** អ្នកនិពន្ធដំណឹងល្អទាំងអស់បានបញ្ចូលការសរសេររបស់ខ្លួនត្រង់ពេលព្រះយេស៊ូវសម្អាតព្រះវិហារ ។ មានតែលោកយ៉ូហានប៉ុណ្ណោះដែលបានយកចំណុចនេះមកធ្វើជាការចាប់ផ្ដើមវិញនោះ (មើលការពន្យល់ មថ ២១:១២–១៧ យហ ២:១៤–១៧)។

**១១:១៥** *ក្នុងព្រះវិហារ* ទីលាននៃពួកសាសន៍ដទៃគឺមានតែមួយផ្នែកនៃព្រះវិហារ តែប៉ុណ្ណោះដែលសម្រាប់ប្រជុំគ្នាថ្វាយបង្គំ និងអធិស្ឋាន (ខ.១៧) *លក់ដូរ* ត្រង់ចំណុចនេះបណ្ដាជន ដែលធ្វើដំណើរមកចូលរួមក្នុងពិធីបុណ្យរំលងពួកគេត្រូវការសត្វល្អៗដើម្បីធ្វើយញ្ញបូជា បានជាអ្នកលក់រៀបចំទ្រុងសត្វ និងតុដូរប្រាក់នៅក្នុងទីធ្លានៃសាសន៍ដទៃនេះ ។ *ពួកអ្នកដែលដូរប្រាក់* ពួកអ្នកមកពីស្រុកឆ្ងាយត្រូវការដូរប្រាក់របស់ពួកគេដើម្បីងាយស្រួលក្នុងការបង់ពន្ធដល់ព្រះវិហារ ។ សាលាបង្រៀន របស់ទីរ៉ានុស (Mishnah) ក៏ត្រូវការប្រាក់ទីរ៉ុសសម្រាប់ជាដង្វាយខ្លះផងដែរ (មើលការពន្យល់ មថ ១៥:២)។ *អ្នកលក់ព្រាប* សត្វព្រាបគឺជាដង្វាយសម្រាប់ សេចក្ដីបរិសុទ្ធរបស់ស្ត្រី (លវ ១២:៦ លក ២:២២–២៤) ដង្វាយសម្រាប់ជាពីជំងឺសើរស្បែក (លវ ១៤:២២) ហើយក៏សំរាប់ជាដង្វាយផ្សេងៗទៀត (លវ ១៥:១៤-២៩)។ ដង្វាយនេះក៏ត្រូវបានប្រើដោយជនក្រីក្រផងដែរ (លវ ៥:៧)។

**១១:១៦** *មិនព្រមឱ្យអ្នកណាលីសែងអ្វី ដើរកាត់ព្រះវិហារឡើយ* ការរៀបរាប់លំអិតមានតែនៅក្នុងព្រះគម្ពីរម៉ាកុសប៉ុណ្ណោះ ។ ការដើរកាត់បរិវេណព្រះវិហារនេះ គឺជាផ្លូវកាត់ពីទីក្រុងទៅភ្នំដើមអូលីវ (ការពន្យល់ ខ.២៧)។

**១១:១៧** *ដំណាក់អញត្រូវហៅជាទីអធិស្ឋាន សម្រាប់គ្រប់អស់ទាំងសាសន៍* នៅក្នុងបទគម្ពីរ អស ៥៦:៧ សំដៅលើសាសន៍ដទៃដែលមានជំនឿច្បាស់

សាសន៍ »[ទ] ប៉ុន្តែអ្នករាល់គ្នាបានយក ធ្វើជារោងចោរវិញ[ធ]
១៨ ពួកសង្គ្រាជ នឹងពួកអាចារ្យក៏ឮ ហើយគេរកឱកាសធ្វើ
យ៉ាងណានឹងបំផ្លាញទ្រង់ចេញ ដ្បិតគេខ្លាចទ្រង់[ន] ដោយ
ព្រោះបណ្តាមនុស្សទាំងអស់គ្នា មានសេចក្តីអស្ចារ្យក្នុងចិត្ត
ចំពោះសេចក្តីដែលទ្រង់បង្រៀន[ប] ១៩ ដល់ល្ងាច ទ្រង់យាង
ចេញពីទីក្រុងទៅ[ផ]។

## ដើមល្វាក្រៀមស្វិត

*១១:២០–២៤ = មថ ២១:១៩–២២*

២០ លុះព្រឹកឡើង កំពុងដែលដើរតាមផ្លូវទៅ នោះពួក
សិស្សឃើញដើមល្វានោះស្វិតក្រៀម តាំងតែពីឫសឡើង
២១ ពេត្រុសក៏នឹកឃើញ ហើយទូលទ្រង់ថា លោកគ្រូ[ព] មើល
ដើមល្វាដែលលោកដាក់បណ្តាសា នោះក្រៀមស្វិតទៅ
ហើយ ២២ ព្រះយេស៊ូវទ្រង់ឆ្លើយថា ចូរមានសេចក្តីជំនឿ
ដល់ព្រះចុះ ២៣ ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នក
ណានិយាយទៅភ្នំនេះថា ចូររើចេញពីទីនេះទៅធ្លាក់ក្នុង
សមុទ្រចុះ ដោយឥតសង្ស័យក្នុងចិត្ត គឺជឿជាក់ថា សេចក្តី
អ្វីដែលខ្លួនថា នឹងបានកើតមកពិត នោះនឹងបានដូចប្រា
ថ្នាគ្រប់ជំពូកទាំងអស់[ភ] ២៤ ដោយហេតុនោះបានជាខ្ញុំប្រាប់
អ្នករាល់គ្នាថា គ្រប់ទាំងសេចក្តីអ្វីដែលអ្នករាល់គ្នាអធិស្ឋាន
សូម ចូរជឿថា បានហើយ នោះនឹងបានមែន[ម]។
២៥ ហើយកាលណាអ្នកឈរអធិស្ឋាន បើអ្នកមានហេតុអ្វីនឹង
អ្នកណា នោះត្រូវអត់ទោសឱ្យគេសិន ដើម្បីឱ្យព្រះវរបិតា
នៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌ បានអត់ទោសគ្រប់
ទាំងសេចក្តីកំហុសរបស់អ្នករាល់គ្នាដែរ[យ]។
២៦ តែបើអ្នករាល់គ្នាមិនអត់ទោសទេ នោះព្រះវរបិតា
នៃអ្នកដែលគង់នៅស្ថានសួគ៌ ទ្រង់ក៏មិនអត់ទោសសេចក្តីកំ
ហុសរបស់អ្នករាល់គ្នាដែរ។

## អំណាចរបស់ព្រះយេស៊ូវ

*១១:២៧–៣៣ = មថ ២១:២៣–២៧ លក ២០:១–៨*

២៧ នោះក៏មកដល់ក្រុងយេរូសាឡិមម្តងទៀត រួចកាល
ទ្រង់កំពុងតែយាងក្នុងព្រះវិហារ នោះពួកសង្គ្រាជ ពួក
អាចារ្យ នឹងពួកចាស់ទុំ គេមកឯទ្រង់ ២៨ ហើយទូលសួរ
ថា អ្នកធ្វើការទាំងនេះដោយអាងអំណាចអ្វី តើអ្នកណា
បានបើកអំណាចនេះឱ្យអ្នកធ្វើ ២៩ តែព្រះយេស៊ូវទ្រង់មាន
បន្ទូលទៅគេថា ខ្ញុំនឹងសួរអ្នករាល់គ្នាពីសេចក្តី១ដែរ
ចូរឆ្លើយប្រាប់ខ្ញុំសិន នោះខ្ញុំនឹងប្រាប់ឱ្យអ្នកស្គាល់អំណាច
ដែលខ្ញុំអាងនឹងធ្វើការទាំងនេះដែរ ៣០ ឯបុណ្យជ្រមុជរបស់
យ៉ូហាន តើមកពីស្ថានសួគ៌ ឬពីមនុស្ស ចូរឆ្លើយប្រាប់មក
៣១ នោះគេរិះគិតគ្នាថា បើយើងថា មកពីស្ថានសួគ៌នោះ
វានឹងសួរយើងថា ដូច្នេះ ហេតុអ្វីបានជាអ្នករាល់គ្នាមិនបាន
ជឿគាត់ ៣២ តែបើយើងឆ្លើយថា មកពីមនុស្សនោះខ្លាច
ពួកបណ្តាជន ដ្បិតមនុស្សទាំងអស់រាប់យ៉ូហាននេះទុកជា
ហោរាមែន[រ] ៣៣ គេក៏ទូលឆ្លើយថា យើងមិនដឹងទេ ហើយ
ទ្រង់មានបន្ទូលឆ្លើយថា ដូច្នេះ ខ្ញុំក៏មិនប្រាប់ឱ្យអ្នករាល់
គ្នាដឹង ពីអំណាចអ្វីដែលខ្ញុំអាងនឹងធ្វើការទាំងនេះដែរ។

**១១:១៨** ន មថ ២១:៤៦ មក១២:១២ លក ២០:១៩
ប មថ ៧:២៨
**១១:១៩** ផ លក ២១:៣៧
**១១:២១** ព មថ ២៣:៧
**១១:២៣** ភ មថ ២១:២១
**១១:២៤** ម មថ ៧:៧
**១១:២៥** យ មថ ៦:១៤
**១១:៣២** រ មថ ១១:៩

លាស់ក៏ត្រូវបានអនុញ្ញាតឱ្យថ្វាយបង្គំក្នុងព្រះវិហារ ។ ពួកអ្នកដឹកនាំសាសន៍យូដាបានធ្វើអន្តរាគមន៍ ព្រមទាំងអនុញ្ញាតឱ្យមានការលក់ដូរក្នុងបរិវេណសម្រាប់សាសន៍ដទៃ ដោយពួកគេគិតថា នឹងមានការងាយស្រួលក្នុងការទិញរបស់ថ្វាយព្រះ ដូច្នេះហើយបានជា ទីនោះត្រឡប់ទៅជាមានសំឡេងមានក្លិនដូចជាទីផ្សារដែរ ។

**១១:១៨** *ពួកសង្គ្រាជ និងពួកអាចារ្យ* មើលការពន្យល់ មថ ២:៤ ។ *រកឱកាសធ្វើយ៉ាងណានឹងបំផ្លាញទ្រង់* មើលការពន្យល់ ៣:៦ ។ ពួកគេបានចាត់ទុកព្រះយេស៊ូវថាជាការគំរាមកំហែងយ៉ាងគ្រោះថ្នាក់មួយ ក្នុងដំណើរផ្លូវនៃជីវិតរបស់ពួកគេ ។

**១១:១៩** *យាងចេញពីទីក្រុង* គឺឆ្ពោះទៅភូមិបេថានី (ខ.១១) ។

**១១:២០** *លុះព្រឹកឡើង* គឺនៅពេលព្រឹកថ្ងៃអង្គារនៃសប្តាហ៍រងទុក្ខ ។ *ដើមល្វានោះស្វិតក្រៀមតាំងតែពីឫសឡើង* ត្រង់នេះបង្ហាញថា វានឹងជួបការវិនាសទាំងស្រុង (យប ១៨:១៦) ហើយក៏គ្មាននរណាអាចនឹងបរិភោគផ្លែរបស់វាបានទៀតដែរ ។ ការនេះបានសំដែងឱ្យដឹងយ៉ាងច្បាស់ អំពីការជំនុំជម្រះនៅក្នុងឆ្នាំ៧០គ.ស (១៣:២ និងការពន្យល់ មថ ២៤:២) ។

**១១:២១** *លោកគ្រូ* ភាសាក្រិកប្រើពាក្យ "លោកគ្រូ(របស់ខ្ញុំ)"។ *ដើមល្វាដែលលោកដាក់បណ្តាសា* មើលការពន្យល់ ខ.១៤ ។ *ក្រៀមស្វិតទៅហើយ* ការនេះប្រហែលជាទំនាយពីជោគវាសនារបស់សាសន៍យូដា ដោយព្រោះតែពួកគេបានបដិសេធព្រះមែស៊ី ។

**១១:២៣** *ខ្ញុំប្រាប់អ្នក . . . ប្រាកដថា* មើលការពន្យល់ ៣:២៨ ។ *ភ្នំនេះថា . . . ធ្លាក់ក្នុងសមុទ្រចុះ* សំដៅលើភ្នំដើមអូលីវដែលអាចមើលឃើញពីសមុទ្រស្លាប់ ។

**១១:២៦** នៅក្នុងវគ្គនេះមិនមាននៅក្នុងព្រះគម្ពីរសញ្ញាថ្មីកាលពីដំបូងបំផុតនោះទេ (មើលការពន្យល់ ខ.២៥) នេះប្រហែលជាយកមកពី មថ ៦:១៥ ។

**១១:២៧** *ក្នុងព្រះវិហារ* គឺក្នុងទីធ្លានៃបរិវេណព្រះវិហារ ដែលមានច្រើននៅព័ទ្ធជុំវិញអាគារព្រះវិហារមានដូចជា ទីធ្លាសម្រាប់ស្ត្រី និងបុរស (អ៊ីស្រាអែល) និងរបស់សាសន៍ដទៃ(ខ.១៦)។ *ពួកសង្គ្រាជ ពួកអាចារ្យ និង ពួកចាស់ទុំ* មើលការពន្យល់ ៨:៣១ ។

**១១:២៨** *អំណាច* ប្រធាននៃក្រុមប្រឹក្សាម្នាក់បានសួរព្រះយេស៊ូវអំពីការបើកសំដែងនេះ ថាតើមានអ្វីបង្ហាញជាផ្លូវការដែរឬទេ? បើទ្រង់មិនមែនជាអ្នកមានឋានៈអ្វីជាផ្លូវការនោះផង (មើលការពន្យល់ លក ២០:២)។

**១១:៣០** *មកពីស្ថានសួគ៌ ឬមកពីមនុស្ស?* "ស្ថានសួគ៌"គឺជាពាក្យសាមញ្ញមួយដែលយកមកប្រើជំនួសព្រះនាមរបស់ព្រះ ដើម្បីជៀសវាងការប្រើខុស (នក ២០:៧)។ សំណួររបស់ព្រះយេស៊ូវបានបញ្ជាក់ពីចម្លើយថា អំណាចរបស់

## រឿងប្រៀបប្រដូចពី អ្នកស៊ីឈ្នួលធ្វើចំការ

*១២:១-១២ = មថ ២១:៣៣-៤៦ លក ២០:៩-១៩*

**១២** ១ទ្រង់ក៏ចាប់តាំងមានបន្ទូលទៅគេ ជាពាក្យប្រៀប
ប្រដូចថា មានមនុស្សម្នាក់ដែលដាំចំការទំពាំងបាយជូរ[ល]
គាត់បានធ្វើរបងព័ទ្ធជុំវិញ ព្រមទាំងជីកទីជាន់ផ្លែ នឹងសង់
ប៉ម ហើយប្រវាស់ទៅឱ្យពួកអ្នកធ្វើចំការ រួចចេញពីស្រុក
នោះទៅ ២ដល់រដូវហើយ គាត់ចាត់បាវម្នាក់ទៅឯពួក
អ្នកធ្វើចំការ ដើម្បីនឹងទទួលផលខ្លះពីពួកអ្នកទាំងនោះ ៣តែ
គេចាប់បាវនោះវាយ ហើយឱ្យត្រឡប់ទៅវិញទទេ ៤គាត់
ចាត់បាវ១ទៀតឱ្យទៅឯគេ តែគេចោលបាវនោះនឹងថ្ម
ទាំងវាយក្បាល ហើយបណ្តេញឱ្យទៅវិញ ទាំងជេរប្រមាថ
ផង ៥គាត់ក៏ចាត់ម្នាក់ទៀត តែគេសំឡាប់អ្នកនោះបង់ ក៏បាន
ចាត់ជាច្រើននាក់ទៅទៀត ខ្លះត្រូវគេវាយ ខ្លះត្រូវគេសំឡាប់
ចោល ៦គាត់នៅមានកូនសំឡាញ់តែ១ ក៏ចាត់កូននោះឱ្យ
ទៅឯគេក្រោយបង្អស់[វ] ដោយគិតថាគេនឹងកោតខ្លាចដល់
កូនអញ ៧តែពួកអ្នកធ្វើចំការនោះ គេនិយាយគ្នាថា នេះ
ជាកូនគ្រងមរដក ចូរយើងសំឡាប់វាចេញ នោះមរដក
នេះនឹងបានមកលើយើងរាល់គ្នាវិញ ៨រួចគេចាប់កូនគាត់
សំឡាប់ បោះចោលទៅក្រៅចំការទៅ ៩ដូច្នេះ តើម្ចាស់
ចំការនឹងធ្វើដូចម្តេច គឺគាត់នឹងមកបំផ្លាញពួកអ្នកធ្វើ
ចំការនោះ រួចប្រវាស់ទៅឱ្យអ្នកឯទៀតវិញ ១០តើ
អ្នករាល់គ្នាមិនបានមើលបទគម្ពីរនេះផងទេឬអី ដែលថា
«ថ្មដែលពួកជាងសង់ផ្ទះបានចោលចេញ នោះបានត្រឡប់
ជាថ្មជ្រុងយ៉ាងឯក[ស] ១១ការនោះ គឺព្រះអម្ចាស់ទ្រង់ បានធ្វើ
ហើយជាការអស្ចារ្យនៅភ្នែកយើងខ្ញុំ»[ហ] ១២គេក៏រកឱកាស
ចាប់ទ្រង់ ព្រោះដឹងថា ទ្រង់មានបន្ទូលពាក្យប្រៀបនោះ
ដាក់គេ ប៉ុន្តែគេខ្លាចហ្វូងមនុស្ស[ឡ] រួចគេដើរចោលទ្រង់
បាត់ទៅ[អ]។

## ការបង់ពន្ធជូនសេសារ

*១២:១៣-១៧ = មថ ២២:១៥-២២ លក ២០:២០-២៦*

១៣គេបានចាត់ពួកផារិស៊ីខ្លះ នឹងពួកហេរ៉ូឌខ្លះ[ក]ទៅឯ
ព្រះយេស៊ូវ ដើម្បីនឹងចាប់ព្រះបន្ទូល[ខ] ១៤អ្នកទាំងនោះក៏
មកឯទ្រង់ទូលថា លោកគ្រូ យើងខ្ញុំដឹងថា លោកពិតត្រង់
ហើយថា លោកមិនអំពល់ដល់អ្នកណាសោះ ពីព្រោះ
លោកមិនយល់មុខមនុស្សលោកទេ លោកបង្រៀនតែពី
ផ្លូវព្រះ តាមសេចក្តីពិតប៉ុណ្ណោះ ដូច្នេះ តើមានច្បាប់នឹង
បង់ពន្ធ ថ្វាយសេសារឬទេ ១៥តើត្រូវបង់ ឬមិនត្រូវបង់
ប៉ុន្តែទ្រង់ ស្គាល់ពុតមាយារបស់គេ ក៏មានបន្ទូលថា
ហេតុអ្វីបានជា ល្បងលខ្ញុំ ចូរយកប្រាក់កាក់ធំមកឱ្យខ្ញុំ
មើល ១៦គេក៏យកមក រួចទ្រង់មានបន្ទូលសួរថា រូបនេះ នឹង
ឈ្មោះនេះ តើ ជារបស់អ្នកណា គេឆ្លើយថា របស់សេសារ
១៧នោះទ្រង់តបទៅវិញថា ចូរថ្វាយរបស់សេសារទៅ

**១២:១** ល អស ៥:១-៧
**១២:៦** វ ហព ១:១-៣
**១២:១០** ស កច ៤:១១
**១២:១១** ហ ទដ ១១៨:២២,២៣
**១២:១២** ឡ មក ១១:១៨
អ មថ ២២:២២
**១២:១៣** ក មថ ២២:១៦ មក ៣:៦
ខ មថ ១២:១០

ទ្រង់ គឺបានមកពីព្រះ ដូចជាក្នុងពេលពិធីបុណ្យជ្រមុជទឹករបស់លោកយ៉ូហាន-បាទីស្ទដែរ ។

**១២:១-១២** ភាគច្រើននៃរឿងប្រៀបប្រដូចរបស់ព្រះយេស៊ូវ គឺមានចំណុចសំខាន់១ ដែលមិនស្មុកស្មាញ តែច្បាស់លាស់ ហើយស្របនឹងស្ថានភាពសង្គមសាសន៍យូដាក្នុងសតវត្សរ៍ទី១ ។ ម្ចាស់ដីធំៗនៅសម័យនោះ តែងតែប្រវាស់ដីឱ្យកសិករជាអ្នកដាំដំណាំ និងមើលការខុសត្រូវនៅពេលដែលខ្លួនមិននៅ ។ រឿងប្រៀបប្រដូចនេះបានបង្ហាញអំពីអ្នកធ្វើចំការមានបំណងអាក្រក់លើជីវិតរបស់ព្រះយេស៊ូវ និងការជំនុំជម្រះរបស់ព្រះលើអ្នកធ្វើចំការទាំងនោះ (មើលការពន្យល់ មថ ២១:៣៥-៣៧,៤១) ។

**១២:១** *ពាក្យប្រៀបប្រដូច* មើលការពន្យល់ ៤:២ ។ *ម្នាក់ដែលដាំចំការទំពាំងបាយជូរ* ជាការពណ៌នាដល់សំដីមួយនៅក្នុង "អស ៥:១-២" ដែលបង្ហាញយ៉ាងច្បាស់ថា ចំការទំពាំងបាយជូរតំណាងឱ្យអ៊ីស្រាអែល ។ *ប៉ម* មើលពន្យល់ មថ ២១:៣៣ ។

**១២:៧** *នោះមរដកនេះនឹងបានមកលើយើងរាល់គ្នា* ច្បាប់របស់សាសន៍យូដាបានចែងថា ទ្រព្យសម្បត្តិទាំងឡាយដែលគ្មានអ្នកគ្រងមរដក នោះត្រូវបានចាត់ទុកថា "ជារបស់គ្មានម្ចាស់" ហើយប្រជាពលរដ្ឋអាចយករបស់នោះបាន ។ អ្នកធ្វើចំការទាំងនោះបានគិតថា កូនប្រុសនោះហើយជាអ្នកគ្រងមរដក វាបានមកដើម្បីនឹងទាមទារទ្រព្យសម្បត្តិរបស់វា ដូច្នោះបើពួកគេសម្លាប់កូននោះចោល នោះពួកគេនឹងបានទ្រព្យសម្បត្តិទាំងអស់នោះវិញ ។

**១២:៩** *អ្នកឯទៀត* មើលការពន្យល់ មថ ២១:៤១ ។

**១២:១០** *ថ្មជ្រុងយ៉ាងឯក* មើលការពន្យល់ ទដ ១១៨:២២ ។

**១២:១២** *គេ* សំដៅលើពួកសង្គ្រាជ អាចារ្យ និងចាស់ទុំនៅក្នុង "១១:២៧" ។

**១២:១៣-១៧** ព្រឹត្តិការណ៍នេះប្រហែលជាបានកើតឡើងនៅថ្ងៃអង្គារនៃសប្តាហ៍រំដោះរំដួល និងស្ថិតនៅទីធ្លាខាងក្នុងនៃបរិវេណព្រះវិហារ ។

**១២:១៣** *ផារិស៊ី* មើលការពន្យល់ ២:១៦ ។ *ពួកហេរ៉ូឌ* មើលការពន្យល់ ៣:៦ ។ គម្រោងផែនការដើម្បីកម្ចាត់ព្រះយេស៊ូវ មានតាំងពីទ្រង់បំពេញព្រះរាជកិច្ចដំបូង នៅតំបន់សមុទ្រកាលីឡេមកម្ល៉េះ តែឥឡូវផែនការនេះបានលេចចេញមកឱ្យបានឃើញច្បាស់ នៅត្រង់ក្រុងយេរូសាឡិមនេះហើយ ។

**១២:១៤** *បង់ពន្ធថ្វាយសេសារ* ប្រជាជនយូដានៅក្នុងប្រទេសយូដាត្រូវបានគេតម្រូវឱ្យបង់ពន្ធទៅអធិរាជសេសារ ។ ការបង់ពន្ធនេះធ្វើឱ្យប្រជាជនមិនសប្បាយចិត្តសោះ រហូតអ្នកខ្លះបដិសេធមិនព្រមបង់ពន្ធ ដោយយល់ថាប្រាក់ទាំងនេះជាប្រយោជន៍ដល់ពួករ៉ូម៉ាំង ដែលបន្តគ្រប់គ្រងលើសាសន៍យូដា (មើលការពន្យល់ មថ ២២:១៥-១៧) ។

**១២:១៥** *ប្រាក់កាក់* មើលការពន្យល់ ៦:៣៧ និង មថ ២២:១៩ ។

**១២:១៧** *ចូរថ្វាយរបស់សេសារទៅសេសារ* មើលពន្យល់ មថ ២២:២១ ។ មានកាតព្វកិច្ចជាច្រើនដែលគ្រីស្ទបរិស័ទត្រូវមានចំពោះរដ្ឋ និងមិនមានការប្រាសចាកកាតព្វកិច្ចចំពោះព្រះឡើយ (រម ១៣:១-៧ ១ធថ ២:១-៦ ទត ៣:១-២ ១ពត ២:១៣-១៧) ។

សេសារទៅ ហើយរបស់ព្រះទៅព្រះវិញ[គ] គេក៏អស្ចារ្យនឹង
ទ្រង់ ។

## អាពាហ៍ពិពាហ៍ក្រោយពីរស់ឡើងវិញ

*១២:១៨–២៧ = មថ ២២:២៣–៣៣ លក ២០:២៧–៣៨*

១៨ឯពួកសាឌូស៊ី[ឃ]ដែលថា គ្មានសេចក្តីរស់ឡើងវិញ[ង] គេ
ក៏មកទូលសួរទ្រង់ថា ១៩លោកគ្រូ លោកម៉ូសេបានចែង
ទុកឱ្យយើងខ្ញុំថា «បើបងរបស់អ្នកណាស្លាប់ចោលប្រពន្ធឥត
មានកូន នោះត្រូវឱ្យប្អូនយកប្រពន្ធគាត់ ដើម្បីនឹងបង្កើតពូជ
ឱ្យបងខ្លួន»[ច] ២០ឥឡូវ មានបងប្អូន៧នាក់ បងច្បងយក
ប្រពន្ធហើយ ស្លាប់ទៅ ឥតមានកូន ២១ប្អូនបន្ទាប់ក៏យក
នាងនោះ ហើយស្លាប់ទៅ ឥតមានកូនដែរ អ្នកទី៣ក៏ដូចគ្នា
២២អ្នកទាំង៧នោះបានយកនាង តែគ្មានកូន១សោះ ក្រោយ
បង្អស់មក នាង នោះក៏ស្លាប់ទៅដែរ ២៣ដូច្នេះ ដល់គ្រា
ដែលរស់ឡើងវិញ តើនាងនោះត្រូវបានជាប្រពន្ធរបស់
អ្នកណាក្នុងបណ្តាអ្នកទាំងនោះ ពីព្រោះអ្នកទាំង៧បានយក
នាងគ្រប់ៗគ្នា ២៤ព្រះយេស៊ូវមានបន្ទូលឆ្លើយទៅគេថា
ដូច្នេះ អ្នករាល់គ្នាភាន់ច្រឡំទេតើ ពីព្រោះមិនស្គាល់គម្ពីរ[ឆ]
ឬព្រះចេស្តានៃព្រះ ២៥ដ្បិតកាលណាមនុស្សរស់ពីស្លាប់
ឡើងវិញ នោះមិនដែលយកគ្នាជាប្តីប្រពន្ធទៀតទេ គេ
បានដូចជាទេវតានៅស្ថានសួគ៌វិញ[ជ] ២៦ឯដំណើរដែល
មនុស្សស្លាប់រស់ឡើងវិញ នោះតើអ្នករាល់គ្នាមិនបាន
មើលរឿងពីគុម្ពបន្លា ដែលមាននៅក្នុងគម្ពីររបស់លោក
ម៉ូសេទេឬអី ដែលព្រះទ្រង់មានបន្ទូលនឹងលោកថា «អញ
ជាព្រះនៃអ័ប្រាហាំ ជាព្រះនៃអ៊ីសាក ហើយជាព្រះនៃ
យ៉ាកុប»[ឈ] ២៧ទ្រង់មិនមែនជាព្រះនៃមនុស្សស្លាប់ទេ គឺជា
ព្រះនៃមនុស្សរស់វិញទេតើ អ្នករាល់គ្នាភាន់ច្រឡំខ្លាំង
ណាស់។

## បញ្ញត្តិដែលសំខាន់បំផុត

*១២:២៨–៣៤ = មថ ២២:៣៤–៤០*

២៨នោះមានអាចារ្យម្នាក់[ញ] ចូលមកឮជជែកគ្នា ក៏យល់
ឃើញថា ទ្រង់បានឆ្លើយត្រូវចំ រួចគាត់ទូលសួរទ្រង់ថា
ក្នុងបញ្ញត្តទាំងប៉ុន្មាន តើមានបទណាសំខាន់ជាងគេទាំង
អស់ ២៩ព្រះយេស៊ូវមានបន្ទូលឆ្លើយថា ឯបញ្ញតដែល
សំខាន់ជាងគេ នោះគឺថា «ចូរស្តាប់ចុះ អ៊ីស្រាអែលអើយ
ព្រះអម្ចាស់ ជាព្រះនៃយើងខ្ញុំ ទ្រង់ជាព្រះអម្ចាស់តែ១ព្រះអង្គ
ទ្រង់ ៣០ហើយឯងត្រូវស្រឡាញ់ ដល់ព្រះអម្ចាស់ ជាព្រះ
នៃឯង ឱ្យអស់អំពីចិត្ត អស់អំពីព្រលឹង អស់អំពីគំនិត
ហើយអស់អំពីកំឡាំងនៃឯង»[ដ] នោះហើយជាបញ្ញត្តទី១
៣១ឯបញ្ញត្តទី២ ក៏បែបដូចគ្នា គឺថា «ត្រូវឱ្យស្រឡាញ់អ្នក
ជិតខាងដូចខ្លួនឯង»[ឋ] គ្មានបញ្ញត្តិណាទៀតធំជាងបទទាំង
២នេះទេ ៣២អាចារ្យនោះក៏ទូលទ្រង់ថា មែនហើយ
លោកគ្រូ លោកមានប្រសាសន៍ត្រូវណាស់ថា មានព្រះតែ១
ហើយក្រៅពីទ្រង់ គ្មានព្រះណាទៀតសោះ[ឌ] ៣៣ហើយដែល
ស្រឡាញ់ទ្រង់អស់ពីចិត្ត អស់ពីប្រាជ្ញា អស់ពីព្រលឹង
នឹងអស់ពីកំឡាំង ហើយដែលស្រឡាញ់អ្នកជិតខាងដូចខ្លួន

**១២:១៧** គ រម ១៣:៧
**១២:១៨** ឃ កច ៤:១ ង កច ២៣:៨ ១កថ ១៥:១២
**១២:១៩** ច ចទ ២៥:៥
**១២:២៤** ឆ ២ធថ ៣:១៥–១៧
**១២:២៥** ជ ១កថ ១៥:៤២,៤៩,៥២
**១២:២៦** ឈ នក ៣:៦
**១២:២៨** ញ លក ១០:២៥–២៨ ២០:៣៩
**១២:៣០** ដ ចទ ៦:៤,៥
**១២:៣១** ឋ លវ ១៩:១៨ មថ ៥:៤៣
**១២:៣២** ឌ ចទ ៤:៣៥,៣៩ អស ៤៥:៦,១៤ ៤៦:៩

**១២:១៨** *សាឌូស៊ី* គឺជាគណៈបក្សសាសន៍យូដាដែលជាពួកថ្នាក់អ្នកមានទ្រព្យធន និងអ្នកមានចំណេះដឹងខ្ពង់ខ្ពស់ ។ ពួកគេមានទីតាំងយ៉ាងធំនៅក្នុងក្រុងយេរូសាឡិម និងបានយកព្រះវិហារធ្វើជាទីចាត់ការ ដើម្បីជាប្រយោជន៍សម្រាប់ខ្លួនទៀតផង ។ ទោះបីជាពួកនេះមានចំនួនតិចយ៉ាងណាក៏ដោយ ក៏គេនៅតែមានអំណាចខាងផ្នែកនយោបាយ និងមានឥទ្ធិពលផ្នែកសាសនាទៀតផង (មើលការពន្យល់ មថ ៣:៧ លក ២០:២៧ កច ៤:១)។ *គ្មានសេចក្តីរស់ឡើងវិញ* ពួកនេះបានបដិសេធថា គ្មានការរស់ឡើងវិញទេ ហើយមានតែគម្ពីរទាំង៥របស់លោកម៉ូសេប៉ុណ្ណោះ ដែលពួកគេចាត់ទុកថាមានអំណាចចេស្តា និងបានបដិសេធទំនៀមទម្លាប់និយាយតៗគ្នា (មើលការពន្យល់ មថ ១៥:២)។ សេចក្តីជំនឿទាំងនេះបានធ្វើឱ្យពួកគេមានការជំទាស់នឹងពួកផារិស៊ី និងពួកអ្នកដែលគោរពប្រតិបត្តិសាសនាយូដា ។

**១២:១៩** មើលការពន្យល់ មថ ២២:២៤ ។

**១២:២៦** *គម្ពីររបស់លោកម៉ូសេ* គឺជាគម្ពីរ៥កណ្ឌដំបូងនៃគម្ពីរសញ្ញាចាស់។ *រឿងពីគុម្ពបន្លា* គឺជាវិធីយ៉ាងសាមញ្ញ ដែលមានទំនាក់ទំនងទៅនឹង "នក ៣:១–៦ រម ១១:២"និងជាប់ទាក់ទងនឹងរឿងរបស់លោកអេលីយ៉ា (១ពវ ១៩:១–១០)។

**១២:២៨** *តើមានបទណាសំខាន់ជាងគេទាំងអស់?* ពួកអាចារ្យរបស់សាសន៍យូដា បានបែងចែកជា៦១៣បញ្ញត្តិផ្សេងៗពីគ្នា នៅក្នុងក្រឹត្យវិន័យ ហើយព្យាយាមវែកញែកពាក្យដូចជាពាក្យ "ធ្ងន់" (ឬ "ធំ") និងពាក្យ "ស្រាល" (ឬ "តូច") ជាដើម ។

**១២:២៩** ការដកស្រង់ជាលើកដំបូងចេញមកពីក្រុងសេម៉ា ដែលត្រូវបានគេដាក់ឈ្មោះឱ្យបន្ទាប់ពីបទគម្ពីរនៅក្នុង ចទ ៦:៤ បានចែងជាភាសាហេព្រើរ វាមានន័យថា "ឮ"។ ក្រុងសេម៉ាបានក្លាយជាទីកន្លែងលន់តួនៃជំនឿរបស់សាសន៍យូដា និងជាកន្លែងសម្រាប់អ្នកដែលមានជំនឿស៊ប់ សូត្រទន្ទេញចាំមាត់នៅពេលព្រឹក និងពេលល្ងាច ។ សព្វថ្ងៃរាល់កម្មវិធីផ្សេងៗ គេតែងតែធ្វើនៅសាលាប្រជុំវិញ ។

**១២:៣១** ចំពោះក្រុងសេម៉ា ព្រះយេស៊ូវបានដកស្រង់បញ្ញត្តិព្រះពីគម្ពីរ "លវ ១៩:១៨" ដើម្បីបង្ហាញថាការស្រឡាញ់ដល់អ្នកជិតខាង គឺជាការបញ្ជាក់ថាគេក៏ស្រឡាញ់ដល់ព្រះដែរ ។ *អ្នកជិតខាង* សូមមើល លក ១០:២៥–៣៧ ។

**១២:៣៣** *ដង្វាយដុត និងយញ្ញបូជាទាំងប៉ុន្មាន* តាមរយៈការប្រៀបធៀបនេះបានធ្វើឱ្យយើងដឹងថា ការជជែកនេះគឺបានកើតឡើងនៅក្នុងទីលានព្រះវិហារ (១១:២៧)។

ឯង នោះវិសេសលើសជាងអស់ទាំងដង្វាយដុត និងយញ្ញ
បូជាទាំងប៉ុន្មានទៅទៀត[ល] ៣៤កាលព្រះយេស៊ូវបានឃើញ
ថា គាត់ឆ្លើយដោយប្រាជ្ញា នោះក៏មានបន្ទូលទៅគាត់ថា
អ្នកមិនឆ្ងាយពីនគរព្រះទេ[ណ] រួចគ្មានអ្នកណាហ៊ានទូលសួរ
ទ្រង់ទៀតឡើយ[ត]។

## តើព្រះគ្រីស្ទជាវង្សអង្គណា?

*១២:៣៥-៣៧ = មថ ២២:៤១-៤៦ លក ២០:៤១-៤៤*

*១២:៣៨-៤០ = មថ ២៣:១-៧ លក ២០:៤៥-៤៧*

៣៥កំពុងដែលព្រះយេស៊ូវបង្រៀនក្នុងព្រះវិហារ[ថ] នោះ
ទ្រង់មានបន្ទូលសួរថា ហេតុអ្វីបានជាពួកអាចារ្យថា ព្រះ
គ្រីស្ទជាព្រះវង្សហ្លួងដាវីឌ[ទ] ៣៦ដ្បិតហ្លួងដាវីឌមានបន្ទូល
ដោយនូវព្រះវិញ្ញាណបរិសុទ្ធថា[ធ] «ព្រះអម្ចាស់ ទ្រង់មាន
បន្ទូលទៅព្រះអម្ចាស់ខ្ញុំថា ចូរឯងអង្គុយខាងស្តាំអញ ទាល់
តែអញដាក់ពួកខ្មាំងសត្រូវឯង ឱ្យធ្វើជាកំណល់កល់ជើង
ឯង»[ន] ៣៧ដូច្នេះ បើហ្លួងដាវីឌនោះឯង ទ្រង់បានហៅព្រះ
គ្រីស្ទ ជាព្រះអម្ចាស់ នោះធ្វើដូចម្តេចឱ្យព្រះគ្រីស្ទធ្វើជា
ព្រះវង្សទ្រង់បាន ឯហ្វូងមនុស្សដ៏ធំនោះ[ប] គេក៏ស្តាប់ទ្រង់
ដោយអំណរ។

៣៨កំពុងដែលទ្រង់បង្រៀន នោះក៏មានបន្ទូលទៅគេថា
ចូរប្រុងប្រយ័ត្ននឹងពួកអាចារ្យ ដែលគេចូលចិត្តពាក់អាវ
វែងៗដើរចុះឡើង ហើយឱ្យគេគំនាប់ខ្លួននៅទីផ្សារ ៣៩នឹង
អង្គុយទីមុខគេនៅក្នុងសាលាប្រជុំ ហើយនៅកន្លែងលេខ១
ក្នុងការស៊ីលៀង[ផ] ៤០គេឆស៊ីផ្ទះស្ត្រីមេម៉ាយ ដោយសូត្រ
ធម៌ឱ្យច្រើន ដើម្បីដោះសាខ្លួន ពួកអ្នកទាំងនោះនឹងត្រូវ
ទោសធ្ងន់ជាងទៅទៀត។

## ដង្វាយរបស់ស្ត្រីមេម៉ាយ

*១២:៤១-៤៤ = លក ២១:១-៤*

៤១គ្រានោះ ព្រះយេស៊ូវគង់ទល់មុខនឹងឃ្លាំង ក៏ទតមើល
ទៅហ្វូងមនុស្ស ដែលគេដាក់ដង្វាយក្នុងឃ្លាំង[ព]ជាយ៉ាងដូច
ម្តេច មានអ្នកមានជាច្រើន គេដាក់ច្រើន ៤២តែមានស្រី
មេម៉ាយក្រម្នាក់ មកដាក់តែ២ស្លឹង ដែលត្រូវជាកន្លះសេន
៤៣ទ្រង់ហៅពួកសិស្សមកមានបន្ទូលថា ខ្ញុំប្រាប់អ្នករាល់
គ្នាជាប្រាកដថា ស្រីមេម៉ាយក្រនេះបានថ្វាយលើសជាងអ្នក
ទាំងអស់ ដែលដាក់ក្នុងឃ្លាំង ៤៤ដ្បិតគេសុទ្ធតែយកពីរបស់
ជាសំណល់ខ្លួនមកថ្វាយ តែស្ត្រីនេះបានយកពីសេចក្តីកំសត់
ខ្លួនមកថ្វាយវិញ គឺជារបស់ដែលនាងមានទាំងប៉ុន្មានសំរាប់
ចិញ្ចឹមជីវិតខ្លួនផង[ភ]។

## ទីសំគាល់ពីអវសាននៃពិភពលោក

*១៣:១-៣៧ = មថ ២៤:១-៥១ លក ២១:៥-៣៦*

**១៣** ១កាលកំពុងតែចេញពីព្រះវិហារមក នោះពួកសិស្ស

**១២:៣៣** ល ១សយ ១៥:២២ ហស ៦:៦ មីក ៦:៦-៨ ហព ១០:៨
**១២:៣៤** ណ មថ ៣:២ ត មថ ២២:៤៦ លក ២០:៤០
**១២:៣៥** ថ មថ ២៦:៥៥ ទ មថ ៩:២៧
**១២:៣៦** ធ ២សយ ២៣:២ ន ទដ ១១០:១ មថ ២២:៤៤
**១២:៣៧** ប យហ ១២:៩
**១២:៣៩** ផ លក ១១:៤៣
**១២:៤១** ព ២ពវ ១២:៩ យហ ៨:២០
**១២:៤៤** ភ ២កថ ៨:១២

**១២:៣៤** *នគរព្រះ* មើលការពន្យល់ មថ ៣:២ ។

**១២:៣៥** *ក្នុងព្រះវិហារ* មើលការពន្យល់ ១១:២៧ ។ *ព្រះគ្រីស្ទ* មើលការពន្យល់ មថ ១:១៧ ។ *ព្រះវង្សហ្លួងដាវីឌ* មើលការពន្យល់ ១០:៤៧ ។ មានមនុស្សភាគច្រើនបានដឹងថា ព្រះមែស៊ីនឹងប្រសូតមកតាមរយៈរាជវង្សនៃស្តេចដាវីឌ ។

**១២:៣៦** *ព្រះអម្ចាស់ទ្រង់មានបន្ទូលទៅព្រះអម្ចាស់ខ្ញុំ* ព្រះមានបន្ទូលទៅព្រះរបស់ស្តេចដាវីឌ ឧទាហរណ៍: ដាវីឌជាស្តេចដ៏ឧត្តុង្គឧត្តម ហើយដល់រាជ្យវង្សចុងក្រោយនោះគឺព្រះមែស៊ី (មើលការពន្យល់ ទដ ១១០:១)។ គោលបំណងនៃការដកស្រង់នេះ គឺដើម្បីបង្ហាញថា ព្រះមែស៊ីមិនមែនគ្រាន់តែជារាជវង្សរបស់ស្តេចដាវីឌធម្មតានោះទេ តែទ្រង់គឺជាព្រះអម្ចាស់របស់ស្តេចដាវីឌនោះទៀតផង ។

**១២:៣៨** *អាវវែងៗ* គឺជាគ្រូខាងក្រឹត្យវិន័យ (អាចារ្យ) ពួកគេពាក់អាវពណ៌សធ្វើពី ក្រណាត់ទ្បេនដែលមានភ្ជាប់ទៅដោយរំយោលវែងៗស្ទើរតែដល់ដី ។

**១២:៣៩** *នឹងអង្គុយទីមុខគេនៅក្នុងសាលាប្រជុំ* ជាទីកន្លែងដែលនៅខាងមុខគេ ជាប់ទៅនឹង "ហឹប" ដែលដាក់ក្រាំងស័ក្តិសិទ្ធិ ហើយអស់អ្នកណាអង្គុយនៅទីនោះ ត្រូវបានអ្នកដែលមកថ្វាយបង្គំព្រះទាំងអស់នៅក្នុងព្រះវិហារនឹងមើលគេឃើញ ។

**១២:៤០** *ឆស៊ីផ្ទះស្ត្រីមេម៉ាយ* ដោយព្រោះតែគ្រូក្រឹត្យវិន័យ (អាចារ្យ) មិនបានទទួលប្រាក់ឧបត្ថម្ភទៀងទាត់ ដូច្នេះត្រូវពឹងផ្អែកលើសប្បុរសជនសម្រាប់ចិញ្ចឹមជីវិត ។ ដោយសារតែរបៀបគ្រប់គ្រងមិនល្អនោះ នាំឱ្យមានការឆបោកបានកើតឡើងច្រើន ជាពិសេសស្ត្រីមេម៉ាយងាយនឹងរងគ្រោះជាងគេ

**១២:៤១** *ឃ្លាំង* នេះគឺជាប្រអប់ប្រាក់ដង្វាយយ៉ាងធំមួយដែលស្ថិតនៅក្នុងបរិវេណសម្រាប់ស្ត្រី ។ បុរស និងស្ត្រីត្រូវបានគេអនុញ្ញាតឱ្យចូលទៅក្នុងព្រះវិហារ ប៉ុន្តែ ស្ត្រី មិនត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងបរិវេណខាងក្នុងនៃអាគារព្រះវិហារឡើយ ។ ឃ្លាំងនោះមានរាងដូចជាត្រែ១៣ផ្តុំចូលគ្នាសម្រាប់ទទួលអំណោយពីអស់អ្នកដែលមកថ្វាយបង្គំ ។

**១២:៤២** *២ស្លឹង* គឺជាចំនួនទឹកប្រាក់ដែលតិចជាងគេបំផុតនៅប្រទេសប៉ាឡេស្ទីននាសម័យនោះ ។ ប្រាក់ដង្វាយរបស់ស្ត្រីម្នាក់នោះមិនច្រើនទេនៅពេលនោះ តែ ាងបានដាក់ "ប្រាក់ទាំងអស់ដែលនាងមាន"(ខ.៤៤ ២កថ ៨:១២ និងពន្យល់)។

**១២:៤៣** *ខ្ញុំប្រាប់អ្នករាល់ជាប្រាកដថា* មើលការពន្យល់ ៣:២៨ ។

**១៣:១-៣៧** នេះគឺជាសេចក្តីបង្រៀននៅលើភ្នំដើមអូលីវ ដែលលោកម៉ាកុសបានសង្ខេប និងចែកជា៥ផ្នែកដែលមានដូចតទៅ: (១).ទំនាយរបស់ព្រះយេស៊ូវអំពីការបំផ្លាញនៃព្រះវិហារ និងសំណួររបស់ពួកសាវ័ក (ខ.១-៤)។ (២).ការព្រមានចំពោះពួកអ្នកដែលនាំឱ្យគេវង្វេង និងពីទីសំគាល់នៃអវសានពិភពលោក (ខ.៥-២៣)។ (៣).ការយាងមកលើកទី២នៃកូនមនុស្ស (ខ.២៤-២៧)។ (៤).មេរៀន អំពីដើមល្វា (ខ.២៨-៣១) (៥).ការទូន្មានរំឭកឱ្យប្រុងប្រយ័ត្ន (ខ.៣២-៣៧)។

**១៣:១** *ថ្ម* បើតាមឯកសាររបស់លោកយ៉ូសែបហ្វីសបានប្រាប់ថា ថ្មទាំងនេះ

ទ្រង់ម្នាក់ទូលថា លោកគ្រូ មើលន៍ ថ្មហើយនឹងមន្ទីរល្អណាស់
ហ្ន៎ ២ព្រះយេស៊ូវមានបន្ទូលឆ្លើយថា តើឃើញមន្ទីរធំទាំង
នេះឬទេ បន្តិចទៀត នឹងគ្មានថ្មនៅត្រួតលើថ្ម ដែលមិនត្រូវ
ទំលាក់ចុះនោះទេ[ម] ៣រួចកាលទ្រង់គង់លើភ្នំដើមអូលីវ[យ]
ទល់មុខនឹងព្រះវិហារ នោះពេត្រុស យ៉ាកុប យ៉ូហាន[រ] នឹង
អនទ្រេ គេមកទូលសួរទ្រង់ដោយឡែកថា ៤សូមប្រាប់
យើងខ្ញុំ តើកាលណាបានការទាំងនេះនឹងមកដល់ តើមាន
ទីសំគាល់ណាឱ្យដឹង ក្នុងកាលដែលការទាំងនេះជិតកើតមក
៥ព្រះយេស៊ូវចាប់តាំងមានបន្ទូលឆ្លើយទៅគេថា ចូរប្រយ័ត
ក្រែងអ្នកណានាំអ្នករាល់គ្នាឱ្យវង្វេង[ល] ៦ដ្បិតនឹងមាន
មនុស្សជាច្រើនយកឈ្មោះខ្ញុំមកនិយាយថា គឺខ្ញុំនេះហើយ
គេក៏នឹងនាំមនុស្សជាច្រើនឱ្យវង្វេងផង ៧កាលណាអ្នករាល់
គ្នាឮនិយាយពីចំបាំង ហើយពីសូរចំបាំង នោះកុំឱ្យអ្នករាល់
គ្នាមានចិត្តថប់បារម្ភឡើយ ដ្បិតការទាំងនោះត្រូវតែមក
ដល់ តែពុំទាន់ដល់ចុងបំផុតនៅឡើយទេ ៨ពីព្រោះសាសន៍១
នឹងលើកគ្នាទាស់នឹងសាសន៍១ នគរ១ទាស់នឹងនគរ១ ក៏នឹង
មានកក្រើកដីនៅកន្លែងផ្សេងៗ ហើយនឹងមានអំណត់ នឹង
ចលាចលកើតឡើង នេះជាដើមចមនៃសេចក្តីទុក្ខវេទនាទេ
៩ប៉ុន្តែឱ្យអ្នករាល់គ្នាប្រយ័តខ្លួន ពីព្រោះគេនឹងបញ្ជូន
អ្នករាល់គ្នាទៅឯក្រុមជំនុំ គេនឹងវាយអ្នករាល់គ្នា នៅ
ក្នុងសាលាប្រជុំ[វ] ហើយនាំទៅចំពោះចៅហ្វាយខេត្ត និង
ស្តេចដោយព្រោះខ្ញុំ ទុកជាទីបន្ទាល់ដល់លោកទាំងនោះ
១០ឯដំណឹងល្អនឹងត្រូវផ្សាយដល់គ្រប់សាសន៍ជាមុនសិន
១១ប៉ុន្តែ កាលណាគេនាំបញ្ជូនអ្នករាល់គ្នាទៅ នោះកុំ
ឱ្យថប់ព្រួយ ជាមុនពីបែបនិយាយ ឬពីពាក្យដែលត្រូវថា
ឡើយ ត្រូវ និយាយតែសេចក្តីណា ដែលបានប្រទាន
មកអ្នករាល់គ្នា នៅវេលានោះឯង ដ្បិតមិនមែនជាអ្នក
រាល់គ្នាដែលត្រូវនិយាយទេ គឺជាព្រះវិញ្ញាណបរិសុទ្ធ
ទេតើ[ស] ១២បងប្អូននឹងបញ្ជូនគ្នាឱ្យត្រូវស្លាប់ ហើយឪពុកនឹង
បញ្ជូនកូន កូននឹងលើកគ្នាទាស់នឹងឪពុកម្តាយ ហើយនឹង
សំឡាប់គាត់បង់[ហ] ១៣មនុស្សទាំងអស់នឹងស្អប់អ្នករាល់គ្នា
ដោយព្រោះឈ្មោះខ្ញុំ[ឡ] តែអ្នកណាដែលកាន់ខ្ជាប់ដរាបដល់
ចុងបំផុត នោះនឹងបានសង្គ្រោះពិត[អ] ។
១៤កាលណាអ្នករាល់គ្នាឃើញសេចក្តីស្អប់ខ្ពើមដែល បង្ខូច
បំផ្លាញ[ក] ឈរនៅកន្លែងដែលមិនគួរឱ្យឈរ (អ្នកណាដែល
មើល ឱ្យយល់ចុះ) នោះត្រូវឱ្យពួកអ្នកនៅស្រុកយូដារត់
ទៅឯភ្នំទៅ ១៥កុំឱ្យអ្នកណាដែលនៅលើដំបូលផ្ទះចុះមក
ក្នុងផ្ទះឬចូលទៅយកអ្វីចេញពីផ្ទះ ១៦ក៏កុំឱ្យអ្នកដែលនៅ
ស្រែចំការត្រឡប់មកវិញ នឹងយកសំលៀកបំពាក់ខ្លួនឡើយ
១៧នៅគ្រានោះ ស្ត្រីណាដែលមានផ្ទៃពោះ នឹងស្ត្រីណា
ដែលបំបៅកូននឹងវេទនាណាស់[ខ] ១៨ត្រូវឱ្យអធិស្ឋានសូម
កុំឱ្យត្រូវរត់នៅរដូវរងាឡើយ ១៩ដ្បិតនៅគ្រានោះ នឹងមាន

**១៣:២** ម លក ១៩:៤៤
**១៣:៣** យ មថ ២១:១ រ មថ ៤:២១
**១៣:៥** ល ខ.២២ យរ ២៩:៨ អភ ៥:៦ ២ថន ២:៣,១០–១២ ១ធថ ៤:១ ២ធថ ៣:១៣ ១យហ ៤:៦
**១៣:៩** វ មថ ១០:១៧
**១៣:១១** ស មថ ១០:១៩,២០ លក ១២:១១,១២
**១៣:១២** ហ មីក ៧:៦ មថ ១០:២១ លក ១២:៥១–៥៣
**១៣:១៣** ឡ យហ ១៥:២១ អ មថ ១០:២២
**១៣:១៤** ក ដយ ៩:២៧ ១១:៣១ ១២:១១
**១៣:១៧** ខ លក ២៣:២៩

មានពណ៌ស ខ្លះមានបណ្តោយរហូតដល់១១,២៧ម៉ែត្រ កំពស់៣,៦៥ម៉ែត្រ និងទទឹង ៥,៤៨ម៉ែត្រ ។

**១៣:២** មើលការពន្យល់ មថ ២៤:២ ។

**១៣:៣** *ភ្នំដើមអូលីវ* មើលការពន្យល់ ១១:១ ។ *ពេត្រុស យ៉ាកុប យ៉ូហាន និង អនទ្រេ* (សូមមើល ១:១៦–២០) ។

**១៣:៤** ពួកសិស្សបានគិតថា ការបំផ្លាញព្រះវិហារ គឺជាព្រឹត្តិការណ៍មួយនៅក្នុង ចំណោមព្រឹត្តិការណ៍ទាំងឡាយ ស្តីអំពីទីអវសាននៃពិភពលោក (មថ ២៤:៣) ។ *ទីសំគាល់* ពួកសិស្សយល់ថា នៅពេលណាការបំផ្លាញព្រះវិហារបានមកដល់ពេលនោះហើយគឺជាទីអវសាននៃពិភពលោក ។

**១៣:៥** *ចូរប្រយ័ត្ន* វាមានអត្ថន័យយ៉ាងច្បាស់ថា "អ្នកត្រូវតែប្រយ័ត្នខ្លួនរបស់អ្នក" (ខ.៩) ដូច្នេះ "ចូរអ្នករាល់គ្នាប្រុងប្រយ័ត្នឱ្យមែនទែន"(ខ.២៣) "ចូរប្រុងប្រយ័ត្នឱ្យចាំយាមផង"(ខ.៣៣) ដូច្នេះ "ចាំយាមចុះ"(ខ.៣៥) ហើយនិង "ចូរចាំយាម ចុះ!"(ខ.៣៧)ទាំងនេះហើយគឺជាបំណងដ៏សំខាន់នៃសេចក្តីបង្រៀននៅលើភ្នំដើមអូលីវ គឺរំលឹកឱ្យសិស្សទ្រង់ប្រុងប្រយ័ត្នចំពោះពួកបោកបញ្ឆោត ។

**១៣:៦** *គឺខ្ញុំនេះហើយ* មានន័យថា គឺព្រះយេស៊ូវគ្រីស្ទហើយ គឺជាព្រះមែស៊ី

**១៣:៧** *ចុងបំផុត* មិនមែនជាការបំផ្លាញក្រុងយេរូសាឡិមនោះឡើយ ប៉ុន្តែជាទីអវសាននៃពិភពលោកវិញ(មថ ២៤:៣) ។

**១៣:៨** *ជាដើមចមនៃសេចក្តីទុក្ខវេទនា* មើលការពន្យល់ មថ ២៤:៨ ។

**១៣:៩** *ក្រុមជំនុំ* គឺជាទីកន្លែងកាត់ក្តីផ្នែកសាសនាមួយ ដែលមានសមាសភាពពួកចាស់ទុំនៃសាលាប្រជុំជាច្រើននាក់ចូលរួម ។ *វាយ* បទល្មើសនៃច្បាប់របស់សាសន៍យូដា គឺត្រូវដាក់ទោសដោយវាយនឹងខ្សែតី (ខ្លះត្រូវវាយ៣៩ដង ២កថ ១១:២៣–២៤) ។

**១៣:១០** *ជាមុនសិន* គឺមុននឹងដល់ទីអវសាននៃពិភពលោក(មថ ២៤:១៤)

**១៣:១៣** *កាន់ខ្ជាប់ដរាបដល់ចុងបំផុត* ដូច្នេះសេចក្តីខ្ជាប់ខ្ជួនគឺជាការប្រាកដមួយដែលបានបង្ហាញនូវសេចក្តីសង្គ្រោះ (ហព ៣:១៤ ៦:១១–១២ ១០:៣៦) ។

**១៣:១៤** *សេចក្តីស្អប់ខ្ពើមដែលបង្ខូចបំផ្លាញ* មើលការពន្យល់ ដយ ៩:២៥–២៧ និង មថ ២៤:១៥ ។ *ឈរនៅកន្លែងដែលមិនគួរឱ្យឈរ* មើលការពន្យល់ ២ថន ២:៤ ។ *នោះត្រូវឱ្យពួកអ្នកស្រុកយូដារត់ទៅឯភ្នំទៅ* មើលការពន្យល់ មថ ២៤:១៦ ។

**១៣:១៥** *ដំបូលផ្ទះ* មើលការពន្យល់ ២:៤ លក ១៧:៣១ ។

**១៣:១៦** *សំលៀកបំពាក់* មើលការពន្យល់ មថ ៥:៤០ ។

**១៣:១៧** *ស្ត្រីណាដែលមានផ្ទៃពោះ និងស្ត្រីណាដែលបំបៅកូន* សំដៅលើការឈឺចាប់នៅពេលរត់ភៀសខ្លួន និងព្រឹត្តិការណ៍ដ៏សែនលំបាក ។

**១៣:១៨** *រដូវរងារ* គឺជាពេលដែលមានភ្លៀងធ្លាក់ខ្លាំងរហូតបណ្តាលឱ្យ

សេចក្តីវេទនាខ្លាំងណាស់ ដល់ម្ល៉េះបានជាតាំងពីកំណើតលោ
កីយ[គ] ដែលព្រះទ្រង់បានបង្កើត ដរាបដល់សព្វថ្ងៃនេះ
មិនដែលមានយ៉ាងដូច្នោះទេ ហើយទៅមុខក៏មិនដែលមាន
ផង[ឃ] ២០បើព្រះអម្ចាស់មិនបានបន្ថយថ្ងៃទាំងនោះឱ្យខ្លី នោះ
គ្មានមនុស្សណាបានសង្គ្រោះទេ ប៉ុន្តែទ្រង់បានបន្ថយថ្ងៃ
ទាំងនោះ ដោយព្រោះពួកអ្នកដែលទ្រង់បានរើសតាំង
២១នៅគ្រានោះ បើមានអ្នកណាប្រាប់អ្នករាល់គ្នាថា មើល
ព្រះគ្រីស្ទគង់នៅទីនេះ ឬថា មើល ទ្រង់គង់នៅទីនុ៎ះ
នោះកុំឱ្យជឿឡើយ[ង] ២២ដ្បិតនឹងមានព្រះគ្រីស្ទក្លែង ហើយ
ហោរាក្លែងកើតឡើង[ច] គេនឹងធ្វើទីសំគាល់ ព្រមទាំងការ
អស្ចារ្យ[ឆ] ដើម្បីនឹងនាំទាំងពួកអ្នករើសតាំងឱ្យវង្វេងផង បើ
សិនជាបាន ២៣ចូរអ្នករាល់គ្នាប្រុងប្រយ័ត្នឱ្យមែនទែន[ជ]
មើល ខ្ញុំបានប្រាប់អ្នករាល់គ្នាគ្រប់ទាំងអស់ជាមុនហើយ
២៤ប៉ុន្តែនៅគ្រាក្រោយសេចក្តីវេទនានោះ ថ្ងៃនឹងទៅជា
ងងឹត ខែនឹងលែងភ្លឺ ២៥អស់ទាំងផ្កាយនៅលើមេឃនឹង
ធ្លាក់ចុះ ហើយអស់ទាំងអំណាចនៅលើមេឃនឹងត្រូវកក្រើក
រំពើក[ឈ] ២៦នោះគេនឹងឃើញកូនមនុស្សមកក្នុងពពក[ញ]មាន
ទាំងព្រះចេស្តាជាខ្លាំង នឹងសេរីល្អផង ២៧ហើយលោកនឹង
ចាត់ពួកទេវតាឱ្យទៅប្រមូលពួកដែលបានរើសតាំង មក
ពីទិសទាំង៤ តាំងពីទីបំផុតនៃផែនដីម្ខាង រហូតដល់ទីបំផុត
នៃផ្ទៃមេឃ[ដ]។
២៨ប៉ុន្តែត្រូវរៀនសេចក្តីប្រៀបប្រដូច ពីដើមល្វាចុះគឺ
កាលណាមែកវាត្រឡប់ជាទន់ ហើយស្លឹកក៏ប៉ិចឡើងនោះ
អ្នករាល់គ្នាដឹងថា រដូវក្តៅជិតដល់ហើយ ២៩ក៏បែបដូច្នោះ
ដែរ កាលណាឃើញការទាំងនោះកើតមក នោះត្រូវដឹងថា
កូនមនុស្សជិតដល់ហើយ ក៏នៅមាត់ទ្វារផង ៣០ខ្ញុំប្រាប់អ្នក
រាល់គ្នាជាប្រាកដថា មនុស្សតំណនេះ[ឋ]នឹងពុំទាន់កន្លងហួស
បាត់ទៅ ទាល់តែគ្រប់ការទាំងនោះបានកើតមក[ឌ] ៣១ផ្ទៃមេឃ
ហើយផែនដីនឹងកន្លងបាត់ទៅ តែពាក្យខ្ញុំ នឹងមិនដែលកន្លង
បាត់ឡើយ[ឍ]។

## ថ្ងៃ និងពេលកំណត់

៣២ឯត្រង់ថ្ងៃ នឹងពេលកំណត់ នោះគ្មានអ្នកណាដឹងបាន
ទេ ទោះទាំងពួកទេវតាដែលនៅស្ថានសួគ៌ ឬព្រះរាជបុត្រា
ក៏មិនជ្រាបដែរ ជ្រាបតែព្រះវរបិតាប៉ុណ្ណោះ[ណ] ៣៣ចូរប្រុង
ប្រយ័ត ឱ្យចាំយាម[ត]ហើយអធិស្ឋានផង ដ្បិតអ្នករាល់គ្នា
មិនដឹងពេលកំណត់នោះទេ ៣៤នេះដូចជាមនុស្សម្នាក់ ដែល
ចាកចោលផ្ទះចេញពីស្រុកទៅទីឆ្ងាយ ក៏ប្រគល់អំណាច
ដល់ពួកបាវព្រាវ[ថ]ព្រមទាំងដាក់ការឱ្យធ្វើគ្រប់គ្នា ហើយផ្តាំ
អ្នកឆ្មាំទ្វារឱ្យចាំយាមផង ។

**១៣:១៩** គ មក ១០:៦ ឃ ដយ ៩:២៦ ១២:១ យអ ២:២
**១៣:២១** ង លក ១៧:២៣ ២១:៨
**១៣:២២** ច មថ ៧:១៥ ឆ យហ ៤:៤៨ ២ថន ២:៩,១០
**១៣:២៣** ជ ២ពត ៣:១៧
**១៣:២៥** ឈ អស ១៣:១០ ៣៤:៤ មថ ២៤:២៩
**១៣:២៦** ញ វវ ១:៧
**១៣:២៧** ដ សក ២:៦
**១៣:៣០** ឋ លក ១៧:២៥ ឌ មក ៩:១
**១៣:៣១** ឍ មថ ៥:១៨
**១៣:៣២** ណ កច ១:៧ ១ថន ៥:១,២
**១៣:៣៣** ត ១ថន ៥:៦
**១៣:៣៤** ថ មថ ២៥:១៤

មានប្រឡាយទឹកជ្រៅៗ ហើយមិនអាចឆ្លងរួច ជាការរារាំងមិនឱ្យនរណាម្នាក់រត់រួច។

**១៣:១៩** *គ្រានោះនឹងមានសេចក្តីវេទនាខ្លាំងណាស់* មើលការពន្យល់ មថ ២៤:២១។

**១៣:២០** *ពួកអ្នកដែលទ្រង់រើសតាំង* គឺជាប្រជារាស្ត្ររបស់ព្រះ ។

**១៣:២១** *ព្រះគ្រីស្ទ* មើលការពន្យល់ មថ ១:១៧ ។

**១៣:២៤** *នៅគ្រាក្រោយ* គឺសំដៅលើទំនាយក្នុងគម្ពីរសញ្ញាចាស់ ហើយបានកើតឡើងក្នុងសម័យព្រះមែស៊ី យរ ៣:១៦,១៨ ៣១:២៩ ៣៣:១៥–១៦ យអ ៣:១ សក ៨:២៣ ហព ៩:២៦)។ *សេចក្តីវេទនា* មើល ខ.១៩ និងការពន្យល់ មថ ២៤:២១ ។

**១៣:២៥** ការពិពណ៌នានៅក្នុងខ.២៤–២៥ ពុំចាំបាច់តែទាក់ទងទៅនឹងការខ្ទេចខ្ទីនៃពិភពលោកទាំងស្រុងនោះទេ វាគ្រាន់តែជាភាសាសាមញ្ញមួយដែលធ្លាប់ប្រើ ដើម្បីពណ៌នាការជំនុំជម្រះពិភពលោកនេះតែប៉ុណ្ណោះ (អស ១៣:១០ ២៤:២១-២៣ ៣៤:៤ អគ ៣២:៧–៨ យអ ២:១០,៣១ ៣:១៥ អម ៨:៩)។

**១៣:២៦** *កូនមនុស្ស* មើលការពន្យល់ ៨:៣១ ។ *មកក្នុងពពក មានទាំងព្រះចេស្តាជាខ្លាំង* គឺទាក់ទងទៅនឹងការយាងមកលើកទី២របស់ព្រះគ្រីស្ទ (៨:៣៨ ២ថន ១:៦–១០ វវ ១៩:១១–១៦)។

**១៣:២៧** *ទេវតា* មើលការពន្យល់ លប ១៦:៧ វវ ១៤:១៤–១៦ ។ *ប្រមូលពួកដែលបានរើសតាំង* ព្រះមានបន្ទូលនៅក្នុងព្រះគម្ពីរសញ្ញាចាស់បានថែងថា ចូរប្រមូលរាស្ត្រទ្រង់ដែលខ្ចាត់ខ្ចាយនោះមកវិញ (ចទ ៣០:៣–៤ អស ៤៣:៦ យរ ៣២:៣៧ អគ ៣៤:១៣ ៣៦:២៤)។

**១៣:២៨** *ដើមល្វា* មើលការពន្យល់ ១១:១៣ ។

**១៣:២៩** *ការទាំងនោះ* សំដៅលើទីសំគាល់ដែលពណ៌នានៅក្នុងខ.៥–២៣ មុននឹងបំផ្លាញក្រុងយេរូសាឡិម ឬនៅទីអវសានពិភពលោក ។ ហើយវាក៏អាចទាក់ទងទៅនឹងការយាងមកលើកទី២របស់ព្រះគ្រីស្ទផងដែរ (លក ២១:៣១ ការពន្យល់ មថ ២៤:៣៣)។

**១៣:៣០** *ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា* មើលការពន្យល់ ៣:២៨ ។ *មនុស្សតំណនេះ* បើតាមន័យធម្មតា គឺជាជីវិតរបស់មនុស្សដែលរស់នៅក្នុងសម័យកាលនៃព្រះយេស៊ូវ កាលទ្រង់យាងមកនៅលើផែនដីនេះ ឬជាតំណនៃជីវិតពេលដែលទីសំគាល់នេះចាប់ផ្តើមកើតឡើង(លក ២១:៣២)។

**១៣:៣២** *គ្មាននរណាបានដឹងទេ* ទីបញ្ចប់នៃពិភពលោកមិនមានអ្នកណាអាចដឹងបានឡើយ ហើយវាក៏មិនជួយដល់សេចក្តីជំនឿនោះដែរ ។ ទីសំគាល់ជាក់ស្តែងជាច្រើនត្រូវបានបើកសំដែង ប៉ុន្តែមិនលំអិតនោះទេ ។ *ឯត្រង់ថ្ងៃ* សេចក្តីបញ្ជាក់ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ថាគឺជាថ្ងៃនៃព្រះអម្ចាស់យាងមក (អម ៨:៣,៩,១៣ ៩:១១ មីក ៤:៦ ៥:១០ ៧:១១) និងសំដៅលើការយាងមកនៃកូនមនុស្ស(ខ.២៦)។ *ទេវតា* មើលការពន្យល់ លប ១៦:៧ ។ *ឬព្រះរាជបុត្រាក៏មិនជ្រាបដែរ* គឺក្នុងខណៈពេលដែលព្រះយេស៊ូវមានព្រះជន្មនៅលើផែនដី ទោះទាំងទ្រង់ពេញទៅដោយជំនឿ និងការស្តាប់បង្គាប់ក៏ដោយ ។

[៣៥]ដូច្នេះ ចូរចាំយាមចុះ ដ្បិតមិនដឹងជាវេលាណាដែល
ម្ចាស់ផ្ទះនឹងមកវិញទេ ទោះបើល្ងាច កណ្ដាលអធ្រាត្រ
ពេលមាន់រងាវ ឬព្រឹកក្ដី [៣៦]ក្រែងលោលោកមកដល់ភ្លាម
ឃើញអ្នករាល់គ្នាកំពុងតែដេកលក់ [៣៧]ឯសេចក្ដីដែលខ្ញុំ
ប្រាប់ដល់អ្នករាល់គ្នានេះ នោះខ្ញុំក៏ប្រាប់ដល់មនុស្សទាំង
អស់ដែរ គឺថា ចូរចាំយាមចុះ[ថ១]

## ការចាក់ប្រេងតាំងលើព្រះយេស៊ូវនៅភូមិបេថានី

*១៤:១–១១ = មថ ២៦:២–១៦ ១៤:១,២,១០,១១ = លក ២២:១–៦*
*១៤:៣–៨ = យហ ១២:១–៨*

**១៤** [១]ក្រោយ២ថ្ងៃមក នោះជាបុណ្យរំលង[ទ]នឹងបុណ្យនំបុ័ង
ឥតដំបែ ឯពួកសង្គ្រាជ នឹងពួកអាចារ្យ គេរកឱកាសនឹង
ចាប់ទ្រង់ ដោយឧបាយកល ដើម្បីនឹងសំឡាប់ទ្រង់ចោល[ធ]
[២]តែគេថា កុំឱ្យធ្វើក្នុងរវាងបុណ្យឡើយ ក្រែងបណ្ដាជន
កើតកលាហល។
[៣]កំពុងដែលទ្រង់គង់នៅតុ ក្នុងផ្ទះស៊ីម៉ូន ជាមនុស្សឃ្លង់
នៅភូមិបេថានី[ន] នោះមានស្ត្រីម្នាក់កាន់ដបថ្មកែវ ដាក់ប្រេង
ទេព្វិរូសុទ្ធ មានដំឡៃណាស់ យកមកបំបែកដបនោះចាក់
ប្រេងលើព្រះសិរព្រះយេស៊ូវ[ប] [៤]មានអ្នកខ្លះនឹកតូចចិត្ត
ហើយថា តើមានប្រយោជន៍អ្វី នឹងធ្វើបង្ខាតប្រេងនេះដូច្នេះ
[៥]ដ្បិតប្រេងនេះនឹងលក់បានជាង៦០រៀល ដើម្បីចែកទាន
ដល់ពួកអ្នកទ័លក្រវិញ គេក៏រទូរទាំនឹងនាង [៦]ប៉ុន្តែទ្រង់មាន
បន្ទូលថា កុំធ្វើនាង ហេតុអ្វីបានជានាំបង្អាក់ចិត្តនាងដូច្នេះ
នាងបានធ្វើការនេះ ជាការល្អដល់ខ្ញុំណាស់ [៧]ពីព្រោះអ្នក
រាល់គ្នាមានពួកអ្នកក្រនៅជាមួយជាដរាប ហើយកាលណា
អ្នករាល់គ្នាចង់ធ្វើគុណនឹងគេ នោះចេះតែធ្វើបាន[ផ] តែចំ
ណែកខ្ញុំ មិននៅជាមួយជាដរាបទេ [៨]នាងបានធ្វើការអ្វី
ដែលនាងធ្វើបាន គឺបានមកមុនពេលកំណត់ នឹងលាបខ្លួនខ្ញុំ
ជាការសំរាប់កប់ខ្មោចខ្ញុំ[ព] [៩]ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
កន្លែងណាដែលគេនឹងផ្សាយដំណឹងល្អ នេះទូទៅ គ្រប់ក្នុង
លោកីយទាំងមូល[ភ] នោះគេតែងនឹងដំណាលពីការដែល
នាងបានធ្វើហើយនេះ ទុកសំរាប់ជា កេរ្តិ៍នាងតទៅ។

**១៣:៣៧** ថ១ លក ១២:៣៥–៤០
**១៤:១** ទ យហ ១១:៥៥
ធ មថ ១២:១៤
**១៤:៣** ន មថ ២១:១៧
ប លក ៧:៣៧–៣៩
**១៤:៧** ផ ចទ ១៥:១១
**១៤:៨** ព យហ ១៩:៤០
**១៤:៩** ភ មថ២៤:១៤ មក ១៦:១៥

**១៣:៣៥** *ទោះបើល្ងាច កណ្ដាលអធ្រាត្រ ពេលមាន់រងាវ ឬព្រឹកក្ដី* ទាំង៤ យាម ដែលលើកមកនេះ ត្រូវបានប្រើដោយពួករ៉ូម៉ាំង (មើលពន្យល់ មថ ១៤:២៥)។

**១៣:៣៧** *ចូរចាំយាមចុះ* មើលការពន្យល់ ខ.៥ ។

**១៤:១–៩** មើលការពន្យល់ យហ ១២:១–១១ ។

**១៤:១** *បុណ្យរំលង* គឺជាការរំលឹកមួយនៅពេលដែលទេវតានៃព្រះអម្ចាស់បានហោះរំលងផ្ទះរបស់ពួកយូដា ជាជាងការសម្លាប់កូនប្រុសច្បងរបស់ពួកគេ ដូចដែលបានកើតឡើងនៅផ្ទះសាសន៍អេស៊ីព្ទ (នក ១២:១៣,២៣,២៧)។ កូនចៀម ឬកូនពពែ ត្រូវសម្លាប់នៅថ្ងៃទី១៤ខែចេត្រ(មីនា–មេសា) ដើម្បីប្រើក្នុងពិធីបុណ្យនេះហើយគេអាចបរិភោគអាហារបាន តែក្នុងចន្លោះថ្ងៃលិច ដល់ពាក់កណ្ដាលអធ្រាត្រក្នុងយប់នោះតែប៉ុណ្ណោះ ដូច្នេះហើយបានជាសាសន៍យូដានៅសម័យព្រះយេស៊ូវ រៀបចំបុណ្យនេះនៅថ្ងៃទី១៥ខែចេត្រវិញ (មើលការពន្យល់ យហ ២:១៣)។ *បុណ្យនំបុ័ងឥតដំបែ* កើតឡើងក្រោយបុណ្យរំលងតែ៧ថ្ងៃប៉ុណ្ណោះ(នក ១២:១៧ ២៣:១៥ និងការពន្យល់) *ពួកសង្គ្រាជ* មើលការពន្យល់ ៨:៣១ ។ *ពួកអាចារ្យ* មើលការពន្យល់ មថ ២:៤ ។

**១៤:២** *កុំឱ្យធ្វើក្នុងរវាងបុណ្យឡើយ* អំឡុងពេលបុណ្យរំលង និងពេញ១សប្ដាហ៍នៃបុណ្យនំបុ័ងឥតដំបែ ចំនួនប្រជាជននៅក្រុងយេរូសាឡិមបានកើនពី៥០០០០នាក់ ទៅរាប់សែននាក់។ វាគឺជាការប្រថុយនឹងគ្រោះថ្នាក់ខ្លាំងណាស់ក្នុងការចាប់ព្រះយេស៊ូវនៅពេលមានហ្វូងមនុស្សយ៉ាងច្រើនកុះករដូចនោះ ។

**១៤:៣–៩** នៅក្នុងដំណឹងល្អរបស់លោកយ៉ូហាន ព្រឹត្តិការណ៍នេះ បានកើតឡើង មុនពេលចាប់ផ្ដើមនៃសប្ដាហ៍រងទុក្ខ(មើលការពន្យល់ យហ ១២:១–១១)។ តាមលោកម៉ាថាយ និងម៉ាកុស ហេតុការណ៍ដែលកើតឡើងនៅត្រង់នេះ គឺឆ្លើយតបទៅនឹងសម្អប់នៃអ្នកដឹកនាំសាសនា និងការក្បត់របស់យូដាសហើយនិងសេចក្ដីស្រឡាញ់ដ៏ស្មោះរបស់ស្ត្រីដែលបានចាក់ប្រេងក្រអូបលើព្រះយេស៊ូវ ។

**១៤:៣** *ភូមិបេថានី* មើលការពន្យល់ មថ ២១:១៧ ។ *គង់នៅតុ* មានន័យថា ទម្រេតខ្លួន ដែលជាទម្លាប់នៅពេលបរិភោគអាហារជប់លៀង ។ *ស៊ីម៉ូនជាមនុស្សឃ្លង់* មើលការពន្យល់ មថ ២៦:៦ ។ *ស្ត្រី* តាមបទគម្ពីរ យហ ១២:៣ ប្រាប់ថានាង ឈ្មោះម៉ារាជាប្អូនស្រីរបស់ម៉ាថា និងបងស្រីរបស់ឡាសារ ។ *ដបថ្មកែវ* គឺជាដបម្យ៉ាងមានកស្ដួចវែងសម្រាប់បំបែក យកប្រេងមកប្រើ ប្រេងនេះប្រើបានតែម្នាក់ ប៉ុណ្ណោះ។ *ទេព្វិរូ* មើលការពន្យល់ សស ១:១២ យហ ១២:៣ ។ *ចាក់ប្រេងលើ ព្រះសិរ* ជាប្រពៃណីនៅក្នុងថ្ងៃបុណ្យ(មើលការពន្យល់ ទដ ២៣:៥)។ ទង្វើស្ត្រីនោះបញ្ជាក់ពីភក្ដីភាពយ៉ាងខ្លាំងចំពោះព្រះយេស៊ូវ ។

**១៤:៤** *មានអ្នកខ្លះ* នៅក្នុង មថ ២៦:៨ ប្រាប់ថាជាពួកសិស្ស ប៉ុន្តែ នៅក្នុង យហ ១២:៤–៥ ឥតមានវត្តមានយូដាស–អ៊ីស្ការីយ៉ុតទេ ។

**១៤:៥** *ចែកទានដល់ពួកអ្នកទ័លក្រ* នេះគឺជាប្រពៃណីរបស់សាសន៍យូដាដែលចែកអំណោយដល់ពួកអ្នកទ័លក្រនៅល្ងាចថ្ងៃបុណ្យរំលង (យហ ១៣:២៩)។

**១៤:៧** *មានពួកអ្នកក្រនៅជាមួយជាដរាប* (ចទ ១៥:១១ និងពន្យល់)។ ព្រះយេស៊ូវមានបន្ទូលត្រង់នេះ មិនមែនទ្រង់ឥតខ្វល់ខ្វាយនឹងសេចក្ដីត្រូវការរបស់ពួកអ្នកទ័លក្រនោះទេ (មថ ៦:២-៤ លក ៤:១៨ ៦:២០ ១៤:១៣,២១ យហ ១៣:២៩)។ តែទ្រង់កំពុងតែមានបន្ទូលពីការពិតមួយនឹងកើតមានឡើងក្នុងពេលឆាប់ៗនេះ ។

**១៤:៨** *សំរាប់កប់ខ្មោចខ្ញុំ* នេះជាប្រពៃណីនៃសាសន៍យូដាក្នុងការលាបគ្រឿងក្រអូបលើសពមុននឹងបញ្ចុះ(១៦:១ និងការពន្យល់)។

**១៤:៩** *ដំណឹងល្អ* មើលការពន្យល់ ១:១ ។

១០ឯយូដាស–អ៊ីស្ការីយ៉ុត ជាអ្នក១ក្នុងពួក១២[ម] វាក៏ទៅ
ឯពួកសង្គ្រាជ ដើម្បីនឹងបញ្ជូនទ្រង់ទៅគេ[យ] ១១កាលគេបាន
ឮ នោះក៏មានសេចក្តីត្រេកអរណាស់ ហើយសន្យានឹងឱ្យ
ប្រាក់ដល់វា រួចវាខំស្វែងរកឱកាសនឹងបញ្ជូនទ្រង់ទៅ
ដោយស្រួល ។

## ពិធីលៀងព្រះអម្ចាស់

*១៤:១២–២៦ = មថ ២៦:១៧–៣០ លក ២២:៧–២៣*
*១៤:២២–២៥ = ១ កថ ១១:២៣–២៥*

១២នៅថ្ងៃដំបូង ក្នុងបុណ្យនំបុ័ងឥតដំបែនោះ កាលគេ
ត្រូវសំឡាប់កូនចៀម[រ] ធ្វើបុណ្យរំលង នោះពួកសិស្សទូល
សួរទ្រង់ថា តើទ្រង់សព្វព្រះហឫទ័យឱ្យយើងខ្ញុំរៀបចំបុណ្យ
រំលង ថ្វាយទ្រង់សោយនៅទីណា ១៣ទ្រង់ក៏ចាត់សិស្ស
២នាក់ឱ្យទៅ ដោយបន្ទូលថា ចូរទៅក្នុងទីក្រុងនោះនឹង
មានមនុស្សម្នាក់លីក្អមទឹកមកជួបនឹងអ្នក ចូរឱ្យដើរតាមអ្នក
នោះទៅ ១៤នៅកន្លែងណាដែល គាត់ចូល ចូរអ្នកនិយាយ
នឹងម្ចាស់ផ្ទះនោះថា លោកគ្រូមានប្រសាសន៍ថា តើបន្ទប់
ណាដែលលោកនឹងបរិភោគបុណ្យរំលង ជាមួយនឹងពួក
សិស្សរបស់លោក ១៥នោះគាត់នឹងបង្ហាញបន្ទប់១ធំ
ខាងលើដែលរៀបជាស្រេច[ល] ចូររៀបចំនៅទីនោះចុះ
១៦សិស្សទ្រង់២នាក់នោះក៏ចេញទៅ ដល់ទីក្រុងហើយ
នោះក៏ឃើញដូចជាទ្រង់បានមានបន្ទូល រួចគេរៀបចំធ្វើ
បុណ្យរំលង ។

១៧ដល់ពេលល្ងាចហើយ ទ្រង់យាងមក ព្រមទាំងពួក
១២នាក់ ១៨កាលកំពុងតែអង្គុយបរិភោគ នោះព្រះយេស៊ូវ
មានបន្ទូលថា ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ក្នុងពួកអ្នក
រាល់គ្នា ដែលបរិភោគជាមួយនឹងខ្ញុំនេះ នោះមានម្នាក់នឹង
បញ្ជូនខ្ញុំ ១៩គេក៏តាំងព្រួយចិត្ត ហើយទូលទ្រង់ម្តងម្នាក់ៗ
ថា តើទូលបង្គំឬអី រួចម្នាក់ទៀតថា តើទូលបង្គំឬអី
២០ព្រះយេស៊ូវឆ្លើយថា គឺជាម្នាក់ក្នុងពួក១២ដែលលូក
ដៃក្នុងច្រានជាមួយនឹងខ្ញុំ[វ] ២១កូនមនុស្ស[ស] ត្រូវទៅពិត ដូចជា
មានសេចក្តីចែងទុកពីលោកស្រាប់ តែវេទនាដល់មនុស្ស
នោះ ដែលនឹងបញ្ជូនកូនមនុស្សទៅ បើវាមិនបានកើតមក
នោះល្អដល់វាជាជាង។

២២កាលកំពុងតែបរិភោគ នោះព្រះយេស៊ូវទ្រង់យកនំ
បុ័ងប្រទានពរឱ្យ រួចកាច់ប្រទានដល់គេ[ហ] ដោយបន្ទូលថា
ចូរយកបរិភោគចុះ នេះហើយជារូបកាយខ្ញុំ ២៣នោះទ្រង់
យកពែងមកអរព្រះគុណ រួចប្រទានដល់ គេ ហើយគេក៏ផឹក
គ្រប់គ្នា[ឡ] ២៤ទ្រង់មានបន្ទូលថា នេះហើយជាឈាមខ្ញុំ គឺជា
ឈាមនៃសញ្ញាថ្មី[អ] ដែលត្រូវច្រួចសំរាប់មនុស្សជាច្រើន

**១៤:១០** ម មក ៣:១៦–១៩ យ មថ ១០:៤
**១៤:១២** រ នក ១២:១–១១ ចទ ១៦:១–៤ ១កថ ៥:៧
**១៤:១៥** ល កថ ១:១៣
**១៤:២០** វ យហ ១៣:១៨–២៧
**១៤:២១** ស មថ ៨:២០
**១៤:២២** ហ មថ ១៤:១៩
**១៤:២៣** ឡ ១កថ ១០:១៦

---

**១៤:១០** *យូដាស–អ៊ីស្ការីយ៉ុត* មើលការពន្យល់ ៣:១៩ ។ *សង្គ្រាជ* មើលពន្យល់ ៨:៣១ ។ ជាអ្នកមានគម្រោងចាប់ព្រះយេស៊ូវធ្វើគុតក្រៅពីថ្ងៃបុណ្យ (ឧ.២) ។

**១៤:១១** *ឱ្យប្រាក់* (មថ ២៦:១៥ និងការពន្យល់) ។

**១៤:១២** *នៅថ្ងៃដំបូង ក្នុងបុណ្យនំបុ័ងឥតដំបែ* នេះជាថ្ងៃទី១៤ខែចេត្រដែលជាថ្ងៃសម្លាប់កូនចៀម ឬកូនពពែសម្រាប់ក្នុងពិធីបុណ្យរំលង(នក ១២:៦) ។ ពេញទាំង៨ថ្ងៃនៃពិធីបុណ្យពេលខ្លះភ្ជាប់ទៅនឹងបុណ្យនំបុ័ងឥតដំបែផងដែរ *រៀបចំ* គឺរៀបចំអាហារសម្រាប់បរិភោគ មានដូចជានំបុ័ងឥតដំបែសាច់កូនចៀម ពពែ ឬស្រា។ល។

**១៤:១៣** *សិស្ស២នាក់* គឺលោកពេត្រុស និងលោកយ៉ូហាន (លក ២២:៨) ។ *មនុស្សម្នាក់លីក្អម* មើលការពន្យល់ លក ២២:១០ ។

**១៤:១៤** *លោកគ្រូមានប្រសាសន៍ថា* មើលការពន្យល់ លក ២២:១១ ។ *តើបន្ទប់ណាដែលលោក . . . ?* នេះជាប្រពៃណីនៃសាសន៍យូដាដែលផ្ទះនិមួយៗមានបន្ទប់ ទំនេរមួយសម្រាប់ទទួលអ្នកដើរធម្មយាត្រាក្នុងថ្ងៃបុណ្យរំលង ។ ត្រង់នេះ ប្រាកដជាព្រះយេស៊ូវបានរៀបចំមុនរួចស្រេចជាមួយនឹងម្ចាស់ផ្ទះ (មើលការពន្យល់ កថ ១២:១២) ។

**១៤:១៦** *នេះក៏ឃើញដូចជាទ្រង់បានមានបន្ទូល* មើលការពន្យល់ លក ២២:១៣ ។

**១៤:១៧** *ពេលល្ងាច* គឺនៅថ្ងៃព្រហស្បតិ៍នៃសប្តាហ៍រងទុក្ខ ។

**១៤:១៨** *កំពុងអង្គុយតុបរិភោគ* ជាធម្មតានៅថ្ងៃបុណ្យរំលងគេបរិភោគឈរ (នក ១២:១១) តែដល់សម័យព្រះយេស៊ូវ គេបរិភោគដោយទម្រេតខ្លួនវិញ (មើលពន្យល់ ខ.៣)។ *ខ្ញុំប្រាប់អ្នករាល់ជាប្រាកដថា* (មើលពន្យល់ ៣:២៨) ។

**១៤:២០** *ម្នាក់ក្នុងពួក១២ដែលលូកដៃក្នុងចានជាមួយនឹងខ្ញុំ* មើលការពន្យល់ មថ ២៦:២៣ ។

**១៤:២១** *កូនមនុស្ស* មើលការពន្យល់ ៨:៣១ ។ *ដូចជាមានសេចក្តីចែងទុកពីលោកស្រាប់* ព្រះយេស៊ូវនឹកចាំពីទំនាយដែលចែងក្នុង អស ៥៣ ថា"អ្នកបម្រើត្រូវរងទុក្ខ"។

**១៤:២២** នៅក្នុងព្រះគម្ពីរសញ្ញាចាស់បានពណ៌នាពីពិធីលៀងព្រះអម្ចាស់៤កន្លែង គឺ "មក ១៤:១២–២៤ មថ ២៦:២៦–២៨ លក ២២:១៩–២០ ១ កថ ១១:២៣–២៥"។ ការពណ៌នារបស់លោកម៉ាថាយ ម៉ាកុស លូកា និងប៉ុលគឺដូចគ្នាខ្លាំងណាស់ គឺទាំងអស់សុទ្ធតែមាននំបុ័ង អរព្រះគុណ ឬប្រទានពរកាច់នំបុ័ងប្រទានដល់គេ ។ មានតែលោកប៉ុល និងលោកលូកាប៉ុណ្ណោះដែលបានកត់ត្រាអំពីព្រះរាជបញ្ជាឱ្យធ្វើកិច្ចនេះបន្តទៅទៀត ។ *នេះហើយជារូបកាយខ្ញុំ* គឺនំបុ័ងតំណាងរូបសាច់របស់ទ្រង់ដែលកាច់សម្រាប់ពួកគេ (លក ២២:១៩ ១កថ ១១:២៤) ។

**១៤:២៣** *អរព្រះគុណ* ពាក្យដើមជាភាសាក្រិកសម្រាប់ប្រើនៅក្នុងពិធីលៀងព្រះអម្ចាស់ ។

**១៤:២៤** *នេះហើយជាឈាមខ្ញុំ គឺជាឈាមនៃសញ្ញាថ្មី* ពែងតំណាងឱ្យព្រះលោហិតរបស់ព្រះយេស៊ូវ ដែលទ្រង់បានចាក់មក គឺនៅពេលដែលទ្រង់

២៥ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ខ្ញុំមិនផឹកពីផលផ្លែទំ
ពាំងបាយជូរទៀតទេ ដរាបដល់ថ្ងៃណាដែលខ្ញុំនឹងផឹកជាថ្មី
នៅក្នុងនគរព្រះ[ក]។
២៦រួចកាលបានច្រៀងទំនុក១ហើយ នោះក៏ចេញទៅឯ
ភ្នំដើមអូលីវ[ខ]។

## ព្រះយេស៊ូវថ្លែងទំនាយពីការបដិសេធន៍របស់ពេត្រុស

*១៤:២៧-៣១ = មថ ២៦:៣១-៣៥*

២៧ព្រះយេស៊ូវមានបន្ទូលថា នៅវេលាយប់នេះឯង
អ្នករាល់គ្នានឹងរវាតចិត្តដោយព្រោះខ្ញុំ ដ្បិតមានសេចក្ដី
ចែងទុកថា «អញនឹងវាយអ្នកគង្វាល ហើយហ្វូងចៀមនឹង
ត្រូវខ្ចាត់ខ្ចាយទៅ»[គ] ២៨ប៉ុន្តែកាលណាខ្ញុំបានរស់ឡើងវិញ
នោះខ្ញុំនឹងទៅឯស្រុកកាលីឡេមុនអ្នករាល់គ្នា[ឃ] ២៩តែពេ
ត្រុសទូលទ្រង់ថា ទោះបើមនុស្សទាំងអស់រវាតចិត្តចេញ
ក៏ដោយ គង់តែទូលបង្គំមិនដូច្នោះទេ ៣០ព្រះយេស៊ូវទ្រង់
មានបន្ទូលទៅគាត់ថា ខ្ញុំប្រាប់អ្នកជាប្រាកដថា នៅថ្ងៃនេះ
គឺនៅក្នុងពេលយប់នេះឯង មុនដែលមាន់រងាវ២ដង នោះ
អ្នកនឹងប្រកែកគ្រប់៣ដងថា មិនស្គាល់ខ្ញុំ[ង] ៣១តែគាត់ប្រ
កែកយ៉ាងខ្លាំងលើសទៅទៀតថា ទោះបើទូលបង្គំត្រូវស្លាប់
ជាមួយនឹងទ្រង់ក្តី គង់តែមិនព្រមថា មិនស្គាល់ទ្រង់ដូច្នេះ
នោះឡើយ[ច] ហើយទាំងអស់ក៏ថាដូចគ្នា។

## នៅសួនច្បារគែតសេម៉ានី

*១៤:៣២-៤២ = មថ ២៦:៣៦-៤៦ លក ២២:៤០-៤៦*

៣២នោះក៏មកដល់កន្លែងហៅថា ច្បារគែតសេម៉ានី
ហើយទ្រង់មានបន្ទូលទៅពួកសិស្សថា ចូរអង្គុយនៅទីនេះ
សិន ចាំខ្ញុំទៅអធិស្ឋាន ៣៣ទ្រង់ក៏យកពេត្រុស យ៉ាកុប នឹង
យ៉ូហាន[ឆ]ទៅជាមួយដែរ ទ្រង់ចាប់តាំងមានព្រះហឫទ័យ
ភាំងជាខ្លាំង ហើយតប់ប្រមល់ណាស់ ៣៤ក៏មានបន្ទូលទៅ
គេថា ចិត្តខ្ញុំព្រួយជាខ្លាំងសឹងតែនឹងស្លាប់[ជ] ចូរនៅទីនេះ
ចាំយាមចុះ ៣៥រួចកាលទ្រង់បានយាងទៅមុខបន្តិច នោះ
ទ្រង់ទំលាក់ព្រះអង្គ ផ្កាប់ព្រះភក្ត្រចុះអធិស្ឋាន សូមឱ្យ
ពេលវេលា[ញ]នេះបានកន្លងហួសពីទ្រង់ទៅ បើសិនជាបាន
៣៦ទ្រង់មានបន្ទូលថា ឱអ័ប្បា ព្រះវរបិតាអើយ[ឈ] ទ្រង់អាច
នឹងធ្វើការទាំងអស់កើត សូមយកពែងនេះចេញពីទូល
បង្គំផង[ដ] ប៉ុន្តែកុំតាមចិត្តទូលបង្គំឡើយ សូមសំរេចតាម
ព្រះហឫទ័យទ្រង់វិញ ៣៧ទ្រង់ត្រឡប់មកវិញ ឃើញពួកសិស្ស
កំពុងតែដេកលក់ ក៏មានបន្ទូលទៅពេត្រុសថា អ្នកដេក
លក់ឬអី តើនឹងនៅចាំយាម តែ១ម៉ោងមិនបានឬ ៣៨ចូរឱ្យ
ចាំយាម ហើយអធិស្ឋានចុះ ដើម្បីកុំឱ្យកើតមានសេចក្ដី
ល្បួង[ឋ]នាំចិត្តឡើយវិញ្ញាណប្រុងស្រេចមែន តែសាច់ឈាម
ខ្សោយទេ[ឌ] ៣៩រួចទ្រង់ចេញទៅអធិស្ឋានម្តងទៀត ដោយ
បន្ទូលជាសេចក្ដីដដែល ៤០កាលទ្រង់បានយាងត្រឡប់មក
វិញនោះក៏ឃើញគេកំពុងដេកលក់ទៀត ដ្បិតភ្នែកគេធ្ងន់
ជ្រប់ គេមិនដឹងខ្លួនជាទូលឆ្លើយនឹងទ្រង់ថាដូចម្តេចទេ
៤១ទ្រង់បានយាងមកជាគំរប់៣ដង មានបន្ទូលថា ឥឡូវនេះ
នៅតែដេកលក់ ហើយសំរាកកំឡាំងទៀតឬ បុ៉ណ្ណឹងចុះ
កំណត់[ឍ]ដល់ហើយ មើលកូនមនុស្សត្រូវបញ្ជូនទៅក្នុង
កណ្ដាប់ដៃនៃមនុស្សមានបាប ៤២ចូរក្រោកឡើង យើងទៅ

**១៤:២៤** អ មថ ២៦:២៨ ២៦:២៨
**១៤:២៥** ក មថ ៣:២
**១៤:២៦** ខ មថ ២១:១
**១៤:២៧** គ សក ១៣:៧
**១៤:២៨** ឃ មក ១៦:៧
**១៤:៣០** ង ខ.៦៦-៧២ លក ២២:៣៤ យហ ១៣:៣៨
**១៤:៣១** ច លក ២២:៣៣ យហ ១៣:៣៧
**១៤:៣៣** ឆ មថ ៤:២១
**១៤:៣៤** ជ យហ ១២:២៧
**១៤:៣៥** ញ ខ.៤១ មថ ២៦:១៨
**១៤:៣៦** ឈ រម ៨:១៥ កទ ៤:៦ ដ មថ ២០:២២ ២៦:៣៩
**១៤:៣៨** ឋ មថ ៦:១៣ ឌ រម ៧:២២,២៣
**១៤:៤១** ឍ ខ.៣៥ មថ ២៦:១៨

បានថ្វាយជីវិតអង្គទ្រង់នោះ ។ ការតាំងសញ្ញាថ្មីមួយរបស់ព្រះនឹងរាស្ត្ររបស់ទ្រង់នោះគឺតាមរយៈការសុគតរបស់ព្រះយេស៊ូវតែមួយប៉ុណ្ណោះ (នក ២៤:៦,៨ យរ ៣១:៣១-៣៤ លក ២២:២០ ហព ៨:៨-១២ និងការពន្យល់)។ *សំរាប់មនុស្សជាច្រើន* មើលការ ពន្យល់ រម ៥:១៥ ។

**១៤:២៦** *ច្រៀង* មើលពន្យល់ មថ ២៦:៣០ ។ *ភ្នំដើមអូលីវ* មើលពន្យល់ ១១:១ ។

**១៤:២៧** *អ្នករាល់គ្នានឹងរវាតចិត្តដោយព្រោះខ្ញុំ* មិនមែនសិស្សរបស់ទ្រង់បាត់សេចក្ដីជំនឿនោះទេ គ្រាន់តែគេបាត់សេចក្ដីក្លាហាន ហើយទុកទ្រង់ចោលតែម្នាក់ឯងប៉ុណ្ណោះ (មើលការពន្យល់ មថ ២៦:៣១)។

**១៤:២៨** *ខ្ញុំនឹងទៅឯស្រុកកាលីឡេមុនអ្នករាល់គ្នា* (មើល ១៦:៧)។

**១៤:៣០** *ខ្ញុំប្រាប់អ្នកជាប្រាកដថា* មើលការពន្យល់ ៣:២៨ ។ *មាន់រងាវ ២ដង* មើលការពន្យល់ ខ.៧២ ។

**១៤:៣២** *ច្បារគែតសេម៉ានី* គឺជាចំការដើមអូលីវ (យហ ១៨:១) ដែលស្ថិតនៅតាមជើងភ្នំដើមអូលីវ ជាកន្លែង១នៅក្នុងចំណោមកន្លែងជាច្រើនដែលព្រះយេស៊ូវសព្វព្រះហឫទ័យ (លក ២២:៣៩ និងការពន្យល់ យហ ១៨:២)។ នៅក្នុងភាសាហេព្រើរ មានន័យថា "កន្លែងគាបយកប្រេងអូលីវ"។

**១៤:៣៣** *ពេត្រុស យ៉ាកុប និងយ៉ូហាន* មើលការពន្យល់ ៥:៣៧ ។

**១៤:៣៦** *ឱអ័ប្បា ព្រះវរបិតាអើយ* សំដែងពីភាពជិតស្និទ្ធយ៉ាងពិសេសជាមួយនឹងព្រះ ។ *ពែងនេះ* គឺជាពែងនៃសេចក្ដីស្លាប់ និងជាសេចក្ដីក្រោធដែលព្រះវរបិតា បានប្រគល់ឱ្យព្រះយេស៊ូវជាអ្នកសម្រេចនៅក្នុងមហាបេសកកម្មនេះ ។ ព្រះយេស៊ូវមិនញញើតនឹងសុគត ដើម្បីប្រោសលោះយើងចេញពីអំពើបាបឡើយ (មើលការពន្យល់ ១០:៣៨)។

**១៤:៣៧** *ពេត្រុស* មើលការពន្យល់ ១:១៦ ។ ព្រះយេស៊ូវទ្រង់មានបន្ទូលទៅកាន់ តែពេត្រុសប្រហែលមកពីគាត់បានអះអាងយ៉ាងក្លាហានថា នឹងមិនរត់ចោលទ្រង់ទេ ក្នុងពេលមានរឿងរ៉ាវនោះ (ខ.២៩-៣១)។

**១៤:៣៨** *កើតមានសេចក្ដីល្បួង* ជាការល្បួងផ្នែកខាងសេចក្ដីជំនឿ ពីព្រោះបន្តិចទៀតនេះ ពួកគេនឹងប្រឈមមុខនឹងស្ថានភាពគំរាមកំហែងមួយយ៉ាងធ្ងន់ធ្ងរ ។ *វិញ្ញាណប្រុងស្រេចមែន* វិញ្ញាណគឺជាផ្នែកមួយរបស់មនុស្សដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះអម្ចាស់សម្រាប់តតាំងនឹងភាពកម្សោយរបស់យើង។ ម្យ៉ាងទៀត ប្រយោគនេះដកស្រង់ចេញពី ទដ ៥១:១២ ។

ន៍ អ្នកដែលបញ្ជូនខ្ញុំ វាជិតមកដល់ហើយ ។

## ការចាប់ព្រះយេស៊ូវ

*១៤:៤៣-៥០ = មថ ២៦:៤៧-៥៦ លក ២២:៤៧-៥០ យហ ១៨:៣-១១*

[៤៣]កំពុងដែលទ្រង់មានបន្ទូលនៅឡើយ ស្រាប់តែយូដាស[ណ]
ជាម្នាក់ក្នុងពួក១២ ក៏មកដល់ភ្លាម នាំទាំងហ្វូងមនុស្សដ៏ធំ ពី
ពួកសង្គ្រាជ ពួកអាចារ្យ និងពួកចាស់ទុំ មកជាមួយផង ព្រម
ទាំងកាន់ដាវ កាន់ដំបង
[៤៤]អ្នកដែលបញ្ជូនទ្រង់ ក៏ប្រាប់
ទីសំគាល់នេះដល់គេថា អ្នកណាដែលខ្ញុំថើប គឺអ្នកនោះ
ហើយ ចូរចាប់វានាំទៅ ដោយប្រយ័តប្រយែងចុះ
[៤៥]កាលគេបានមកដល់ នោះវា ចូលទៅឯទ្រង់ភ្លាម
ដោយទូលថា លោកគ្រូៗអើយ[ត] ហើយក៏ថើបទ្រង់
[៤៦]នោះគេលូកដៃទៅចាប់ទ្រង់
[៤៧]តែមានម្នាក់ឈរជិតខាង
គាត់ហូតដាវកាប់ដាច់ស្លឹកត្រចៀករបស់បាវសម្តេចសង្ឃ
ម្នាក់
[៤៨]ព្រះយេស៊ូវទ្រង់មានបន្ទូលទៅគេថា តើអ្នករាល់
គ្នាបានចេញមកចាប់ខ្ញុំ ទាំងកាន់ដាវ កាន់ដំបង ដូចជា
មកចាប់ចោរឬអី
[៤៩]ខ្ញុំបាននៅជាមួយនឹងអ្នករាល់គ្នា
ព្រមទាំងបង្រៀនក្នុងព្រះវិហារ[ថ]រាល់តែថ្ងៃផង តែអ្នក
រាល់គ្នាមិនបានចាប់ខ្ញុំសោះ ប៉ុន្តែនេះដើម្បីនឹងធ្វើឱ្យសំរេច
តាមបទ គម្ពីរទេ[ទ]
[៥០]នោះពួកសិស្សក៏រត់ចោលទ្រង់ទាំង
អស់គ្នាទៅ[ធ]
[៥១]មានមនុស្សកំលោះម្នាក់ដែលដើរតាមទ្រង់
មានតែសំពត់ទេសឯកព័ទ្ធនឹងខ្លួន
[៥២]គេក៏ចាប់គាត់ តែគាត់
រត់រួចចោលសំពត់នោះ នៅតែខ្លួនទទេ ។

## នៅមុខក្រុមប្រឹក្សាជាន់ខ្ពស់

*១៤:៥៣-៦៥ = មថ ២៦:៥៧-៦៨ យហ ១៨:១២,១៣,១៩-២៤*

*១៤:៦១-៦៣ = លក ២២:៦៧-៧១*

[៥៣]គេក៏នាំព្រះយេស៊ូវទៅដល់សម្តេចសង្ឃ ឯពួកសង្គ្រាជ
ពួកចាស់ទុំ ហើយពួកអាចារ្យទាំងអស់គ្នា ក៏ប្រជុំគ្នាឯលោក
[៥៤]ចំណែកពេត្រុស គាត់តាមទ្រង់ទៅពីចំងាយ រហូតដល់
ខាងក្នុងព្រះលានសំដេចសង្ឃ[ន] ក៏អង្គុយអាំងភ្លើងជាមួយនឹង
ពួកអាជ្ញា[ប] ។
[៥៥]ពួកសង្គ្រាជ នឹងពួកក្រុមជំនុំទាំងអស់គ្នា[ផ] គេប្រឹងរក
ទីបន្ទាល់ទាស់នឹងព្រះយេស៊ូវ ដើម្បីនឹងសំឡាប់ទ្រង់បង់ តែ

**១៤:៤៣** ណ មថ ១០:៤
**១៤:៤៥** ត មថ ២៣:៧
**១៤:៤៩** ថ មថ ២៦:៥៥
ទ អស ៥៣:៧-១២
មថ ១:២២
**១៤:៥០** ធ ខ.២៧
**១៤:៥៤** ន មថ ២៦:៣
ប យហ ១៨:១៨
**១៤:៥៥** ផ មថ ៥:២២

**១៤:៤១** *កូនមនុស្ស* មើលការពន្យល់ ៨:៣១ ។

**១៤:៤៣** *យូដាស* មើលការពន្យល់ ៣:១៩ ។ *ហ្វូងមនុស្ស... កាន់ដាវ កាន់ដំបង* គឺពួកកងនគរបាលជំនួយ ឬជាពួកអ្នកបម្រើនៅក្នុងតុលាការ ដែលគេចាត់មកឱ្យការពារនិងប្រព្រឹត្តតាមបង្គាប់បញ្ជា សម្រាប់សាធារណៈជននៅខាងក្រៅបរិវេណព្រះវិហារ ។ តាម យហ ១៨:៣ បានឱ្យដឹងថា យ៉ាងហោចណាស់មានក្រុមទាហានរ៉ូម៉ាំងខ្លះដែរ នៅក្នុងក្រុមដែលទៅចាប់ព្រះយេស៊ូវនោះ ។ អ្នកខ្លះយល់ថា ពួកអ្នកទាំងនោះទើបតែត្រូវបានគេកេណ្ឌមកថ្មីៗ ។ *ពួកសង្គ្រាជពួកអាចារ្យ និងពួកចាស់ទុំ* មើលការពន្យល់ ៨:៣១ មថ ២:៤ ។ ដីកាសម្រាប់ចាប់ព្រះយេស៊ូវត្រូវបានចេញ ដោយក្រុមប្រឹក្សាជាន់ខ្ពស់ ។

**១៤:៤៥** *លោកគ្រូៗអើយ* ភាសាហេព្រើរមានន័យថា "លោកគ្រូ(របស់ខ្ញុំ)អើយ"។ *ថើបទ្រង់* ដើម្បីសម្តែងការគោរពដល់គ្រូរបស់ខ្លួន (លក ២២:៤៧ និងពន្យល់)។

**១៤:៤៧** *មានម្នាក់ឈរជិតខាង* តាមដំណឹងល្អលោកយ៉ូហានបានឱ្យដឹងថា ម្នាក់នោះគឺលោកពេត្រុស ហើយបាវបម្រើដែលត្រូវបានគេកាប់ដាច់ស្លឹកត្រចៀកនោះគឺឈ្មោះ ម៉ាលកុស (យហ ១៨:១០)។

**១៤:៤៩** *បង្រៀនក្នុងព្រះវិហារ* មើលការពន្យល់ ១១:២៧ ។ *ដើម្បីឱ្យបានសម្រេច តាមបទគម្ពីរ* ប្រហែលជាជាប់ទាក់ទងនឹង អស ៥៣ ឬច្បាស់ជាងនេះទៅទៀតនោះគឺ សក ១៣:៧ ដកស្រង់ដោយព្រះយេស៊ូវ ខ.២៧ ហើយបានសម្រេច (យ៉ាងហោចណាស់ក្នុងផ្នែកខ្លះដែរ) ក្នុងសម័យព្រះយេស៊ូវ ។

**១៤:៥០** *រត់ចោលទ្រង់* គឺបានសម្រេចដូចដែលមានក្នុងខ.២៧-៣១ ។

**១៤:៥១** *មនុស្សកំលោះម្នាក់* មិនមានអ្វីសម្គាល់ច្បាស់លាស់នោះទេ ប៉ុន្តែការមិនចេញមុខរបស់គាត់នោះ នាំឱ្យគេគិតថាគាត់គឺជាលោកយ៉ូហាន-ម៉ាកុស ជាអ្នកសរសេរដំណឹងល្អម៉ាកុសនេះតែម្តង ។ *សំពត់ទេសឯក* ជាសម្លៀកបំពាក់សាមញ្ញមួយសម្រាប់ស្លៀកពីខាងក្រៅ ដែលធ្វើពីរោមសត្វ ។ សំពត់ទេសឯកបានបន្សល់ក្នុងដៃពួកទាហាន បានបញ្ជាក់ប្រាប់ថា បុរសម្នាក់នេះមកពីត្រកូលអ្នកមាន ។

**១៤:៥២** *នៅតែខ្លួនទទេ* ការដែលមិនមានសម្លៀកបំពាក់ខាងក្នុងនេះអាចមកពីគាត់ស្លៀកពាក់លឿនពេក ដើម្បីដើរតាមព្រះយេស៊ូវនៅពេលនោះ ។

**១៤:៥៣-១៥:១៥** ការកាត់ទោសព្រះយេស៊ូវត្រូវបានគេធ្វើឡើង២ដំណាក់កាលគឺតាមរយៈពួកសាសន៍យូដា និងតាមរយៈពួករ៉ូម៉ាំង ហើយមានរឿងផ្សេងៗបីទៀត នៅក្នុងដំណាក់កាលនីមួយៗ: (១).ដំបូងត្រូវជំនុំជម្រះដោយលោកអាណ ជាអតីតសម្តេចសង្ឃ (យហ ១៨:១២-១៤,១៩-២៣)។ (២).ជំនុំជម្រះ ដោយស្តេចហេរ៉ូឌ-អង់ទីប៉ាសមានតែនៅក្នុង លក ២៣:៦-១២ ។ (៣).បន្តទៅ ដល់លោកពីឡាត់ជាអ្នកជំនុំជម្រះចុង ក្រោយ(១៥:៦-១៥)។ លោកម៉ាកុសមិនបានពណ៌នាអំពីការជំនុំជម្រះ ព្រះយេស៊ូវដោយសាស្តេចហេរ៉ូឌ-អង់ទីប៉ាសនោះទេ ។ សេចក្តីជំនុំជម្រះ ដោយលោកពីឡាត់បានបន្តមានពិពណ៌នាជាហូរហែ នៅក្នុងដំណឹងល្អនេះ (១៥:២-១៥)។

**១៤:៥៣** *សំដេចសង្ឃ* គឺលោកកៃផាស ដែលត្រូវជាកូនប្រសាររបស់អតីតៈសម្តេចសង្ឃឈ្មោះអាណ ។ *ពួកសង្គ្រាជ ពួកចាស់ទុំ ហើយពួកអាចារ្យ* ត្រូវបានហៅឱ្យចូលមក នៅក្នុងសាលាប្រជុំដើម្បីជំនុំជម្រះក្តីរបស់ព្រះយេស៊ូវ ។

**១៤:៥៤** *ព្រះលានសំដេចសង្ឃ* ការជម្រះក្តីនេះប្រហែលបានធ្វើឡើងនៅផ្ទះរបស់លោកកៃផាស ដើម្បីការពារសុវត្ថិភាព ។

**១៤:៥៥** *ពួកក្រុមជំនុំ* គឺជាពួកគណៈវិនិច្ឆ័យជាន់ខ្ពស់របស់សាសន៍យូដា ។ នៅក្នុងសម័យកាលព្រះគម្ពីរសញ្ញាថ្មី ក្រុមនេះត្រូវបានចែកជាបីប្រភេទ គឺពួកសង្គ្រាជ ពួកចាស់ទុំ និងពួកអាចារ្យ(ក្រឹត្យវិន័យ)។ ចំនួនសមាជិកសរុបទាំងអស់មានគ្នា៧១នាក់ ដែលរួមទាំងសម្តេចសង្ឃជាអធិបតីផងដែរ ។ ក្រុមជម្រះក្តីនៃពួករ៉ូម៉ាំង បានប្រគល់អំណាចដ៏ធំ ដល់ពួកសាសន៍យូដាសម្រាប់ដោះស្រាយរាល់បញ្ហាផ្សេងៗ តែពុំមានសិទ្ធិប្រហារជីវិតឡើយ

រកមិនបានសោះ ៥៦ក៏មានមនុស្សជាច្រើន មកធ្វើបន្ទាល់
ក្លែងទាស់នឹងទ្រង់ដែរ តែសេចក្ដីបន្ទាល់របស់គេមិនត្រូវ
គ្នាសោះ ៥៧នោះមានខ្លះឈរឡើង ធ្វើបន្ទាល់ក្លែងទាស់នឹង
ទ្រង់ថា ៥៨យើងខ្ញុំបានឮវាថា ខ្ញុំនឹងបំផ្លាញព្រះវិហារនេះ
ដែលបានធ្វើដោយដៃមនុស្ស ហើយក្នុងរវាង៣ថ្ងៃ ខ្ញុំនឹង
សង់១ទៀត[ព] ដែលមិនមែនធ្វើដោយដៃមនុស្សទេ ៥៩យ៉ាង
នោះ គង់តែសេចក្ដីបន្ទាល់របស់គេមិនត្រូវគ្នាទៀត ៦០ឯសំ
ដេចសង្ឃ ក៏ឈរឡើងនៅកណ្ដាលជំនុំ ដណ្ដឹងសួរព្រះ
យេស៊ូវថា តើឯងមិនព្រមឆ្លើយសោះឬអី សេចក្ដីដែល
គេចោទប្រកាន់ឯងទាំងប៉ុន្មាននេះ តើយ៉ាងដូចម្ដេច ៦១តែ
ទ្រង់នៅតែស្ងៀម មិនបានឆ្លើយអ្វីសោះ[ភ] រួចសំដេចសង្ឃ
ពិចារណាសួរទ្រង់ទៀតថា តើឯងជាព្រះគ្រីស្ទ ជាព្រះរាជ
បុត្រានៃព្រះដ៏មានពរឬអី[ម] ៦២ព្រះយេស៊ូវមានបន្ទូលថា
គឺខ្ញុំនេះហើយ មួយទៀត អ្នករាល់គ្នា នឹងឃើញកូនមនុស្ស
អង្គុយនៅ ខាងស្តាំនៃព្រះចេស្តា ហើយទាំងមកក្នុងពពក
នៅលើមេឃផង[យ] ៦៣នោះសំដេចសង្ឃក៏ហែកព្រះពស្ត្រ
លោក[រ] ដោយពាក្យថា តើយើងចាំបាច់ត្រូវការនឹងទីបន្ទាល់
ណាទៀត ៦៤អ្នករាល់គ្នាបានឮពាក្យប្រមាថនេះហើយ
ចុះតើគិតដូចម្ដេច អ្នកទាំងអស់គ្នាក៏កាត់ទោសទ្រង់ថា
គួរស្លាប់ហើយ[ល] ៦៥អ្នកខ្លះចាប់តាំងស្តោះដាក់ទ្រង់ ក៏ខ្ទប់
ព្រះភក្ត្រ ហើយវាយទ្រង់ រួចទូលប្រាប់ថា ចូរទាយចុះ ឯ
ពួកអាជ្ញា ក៏ទះទ្រង់ ដែរ[វ]។

## ពេត្រុសបដិសេធថាមិនស្គាល់ព្រះយេស៊ូវ

*១៤:៦៦-៧២ = មថ ២៦:៦៩-៧៥ លក ២២:៥៦-៦២*
*យហ ១៨:១៥-១៨,២៥-២៧*

៦៦រីឯពេត្រុស គាត់នៅក្នុងព្រះលាន[ស]ឰដ៏ខាងក្រោម
ហើយមានបាវស្រីរបស់សំដេចសង្ឃម្នាក់មក ៦៧ឃើញ
ពេត្រុសកំពុងតែអាំងភ្លើង[ហ] ក៏សំឡឹងមើលគាត់ ហើយ
និយាយថា អ្នកបាននៅជាមួយនឹងយេស៊ូវ ពីណាសារ៉ែត
នេះដែរ[ឡ] ៦៨តែគាត់ប្រកែកថា ខ្ញុំមិនដឹង មិនយល់ជាអ្នក
និយាយអ្វីទេ[អ] រួចគាត់ចេញទៅឯទីធ្លាខាងក្រៅ នោះមាន់
តាំងរងាវឡើង ៦៩បាវស្រីនោះក៏ឃើញគាត់ម្តងទៀតហើយ
ចាប់តាំងប្រាប់ដល់ពួកអ្នក ដែលឈរនៅទីនោះថាអ្នកនេះ
ជាពួកគេដែរ ៧០គាត់ប្រកែកម្តងទៀត[ក] រួចក្រោយបន្តិចមក
ពួកអ្នកឈរនៅទីនោះនិយាយទៅពេត្រុសថា ឯងប្រាកដ

**១៤:៥៨** ព យហ ២:១៩
**១៤:៦១** ភ អស ៥៣:៧ មថ ២៧:១២-១៤ មក ១៥:៥ លក ២៣:៩ យហ ១៩:៩ ម មថ ១៦:១៦ យហ ៤:២៥,២៦
**១៤:៦២** យ វវ ១:៧
**១៤:៦៣** រ លវ ១០:៦ ២១:១០ ជន ១៤:៦ កច ១៤:១៤
**១៤:៦៤** ល លវ ២៤:១៦
**១៤:៦៥** វ មថ ១៦:២១
**១៤:៦៦** ស ខ.៥៤
**១៤:៦៧** ហ ខ.៥៤ ឡ មក ១:២៤
**១៤:៦៨** អ ខ.៣០,៧២
**១៤:៧០** ក ខ.៣០,៦៨,៧២

(យហ ១៨:៣១ មថ ២៧:២ និងពន្យល់)។

**១៤:៥៦** *ក៏មានមនុស្សជាច្រើន មកធ្វើបន្ទាល់ក្លែងទាស់នឹងទ្រង់* នៅក្នុងប្រព័ន្ធតុលាការរបស់សាសន៍យូដា សាក្សីក៏មានតួនាទីដូចជាអ្នកការពារក្ដីដែរ ។ *មិនត្រូវគ្នាសោះ* យោងទៅតាមបទគម្ពីរ ចទ ១៩:១៥ មនុស្សម្នាក់អាចជាប់ទោស លុះត្រាតែមានសាក្សី២ ឬច្រើនជាងនេះធ្វើជាបន្ទាល់ចោទដល់គាត់ ហើយបន្ទាល់ទាំងនោះក៏ត្រូវដូចគ្នាផងដែរ ។

**១៤:៥៨** ត្រង់ចំណុចនេះប្រហែលជាព្រះបន្ទូលដែលមានចែងនៅក្នុងបទគម្ពីរ យហ ២:១៩ ។

**១៤:៦១** *ព្រះរាជបុត្រានៃព្រះដ៏មានពរ* ការហៅនេះគឺជាមធ្យោបាយមួយនៅក្នុងការហៅជំនួសព្រះនាមព្រះរបស់ខ្លួន (មើលការពន្យល់ ១១:៣០)។ បរមនាមនេះ មានន័យស្មើនឹងពាក្យ "ព្រះរាជបុត្រានៃព្រះ" ដែរ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ន័យរបស់អត្ថបទមិនបានសំដៅលើព្រះទាំងស្រុងនោះទេ គឺលើស្តេចដែលហៅថា "ព្រះមែស៊ី" ដោយសារតែប្រជាជនយូដាបានជឿថា ព្រះមែស៊ី ដែលខ្លួនរង់ចាំនោះ គឺជាមនុស្សមិនមែនជាព្រះនោះទេ ។

**១៤:៦២** *កូនមនុស្ស* មើលការពន្យល់ ៨:៣១ ។ កូនមនុស្សទ្រង់នឹងយាងមក ហើយមនុស្សជាច្រើនបានចូលទៅចំពោះទ្រង់ (ដយ ៧:១៣ ទដ ១១០:១)។

**១៤:៦៣** *ហែកព្រះពស្ត្រ* គឺជាការបង្ហាញពីទុក្ខវេទនា ឬការភ័យតក់ស្លុត (លប ៣៧:២៩ ២ពវ ១៨:៣៧ ១៩:១)។ តែចំពោះសម្ដេចសង្ឃនេះវិញ គ្រាន់តែជាការឆ្លើយតបនឹងចម្លើយរបស់ព្រះយេស៊ូវ ដែលពួកគេបានចាត់ទុកថា ជាការប្រមាថដល់ព្រះនោះតែប៉ុណ្ណោះ (មើលការពន្យល់ មថ ២៦:៦៥)។

**១៤:៦៤** *ពាក្យប្រមាថ* បាបនៃការប្រមាថមិនមែនគ្រាន់តែទាក់ទងនឹងការបញ្ចេញព្រះនាមព្រះនោះទេ (លវ ២៤:១០-១៦) តែវាបូករួមទាំងការមើលងាយដល់ឫទ្ធិបារមី ឬព្រះចេស្ដាទ្រង់ផងដែរ (មក ២:៧ ៣:២៨ យហ ៥:១៨ ១០:៣៣)។ ព្រះយេស៊ូវបានប្រកាសថា ទ្រង់គឺជាព្រះមែស៊ីនោះ គឺមានន័យដូចគ្នាថា ទ្រង់មានគ្រប់ទាំងអំណាចព្រះចេស្ដា ដែលជាកម្មសិទ្ធិរបស់ព្រះតែមួយអង្គគត់នោះដែរ បានជាធ្វើឱ្យលោកកៃផាសចាត់ទុកថា នេះគឺជាការប្រមាថដល់ព្រះ និងត្រូវទទួលទោសប្រហារជីវិតដោយគប់នឹងដុំថ្ម (លវ ២៤:១៦)។

**១៤:៦៥** *ចាប់តាំងស្តោះដាក់...ហើយវាយទ្រង់* នេះគឺជាកាយវិការនៃការដាក់ទោសចំពោះការល្មើសនឹងក្រឹត្យវិន័យនៃព្រះគម្ពីរសញ្ញាចាស់ (ជន ១២:១៤ ចទ ២៥:៩ យប ៣០:១០ អស ៥០:៦)។ *ខ្ទប់ព្រះភក្ត្រ* ក្នុងព្រះគម្ពីរ អស ១១:២-៤ បានចែងថា ទ្រង់អាចជំនុំជម្រះ ឬជ្រាបបាន ដោយមិនចាំបាច់មើលឃើញឡើយ ។

**១៤:៦៦** *ខាងក្រោម* ខណៈពេលដែលគេកំពុងតែវាយព្រះយេស៊ូវនៅខាងលើផ្ទះរបស់លោកកៃផា ចំណែកឯពេត្រុសនៅឯទីព្រះលានខាងក្រោមផ្ទះ។ *មានបាវរបស់ស្រីសំដេចសង្ឃម្នាក់* នាងគឺជាអ្នកចាំទ្វារផ្ទះលោកកៃផា (យហ ១៨:១៦ កច ១២:៣)

**១៤:៦៧** *ណាសារ៉ែត* មើលការពន្យល់ មថ ២:២៣ ។

**១៤:៦៨** *ខ្ញុំមិនដឹង មិនយល់ជាអ្នកនិយាយអ្វីទេ?* ជាពាក្យដ៏សាមញ្ញមួយឃ្លានៅក្នុងក្រឹត្យវិន័យរបស់សាសន៍យូដា សម្រាប់ធ្វើការបដិសេធន៍អ្វីមួយ តាម–ផ្លូវច្បាប់ ។

**១៤:៧០** *អ្នកស្រុកកាលីឡេ* អ្នកស្រុកនេះ គេងាយនឹងចំណាំណាស់ដោយសារតែគ្រាមភាសារបស់ពួកគេ ។ តាមរយៈសំដីរបស់ពេត្រុសបានបង្ហាញ

ជាពួកគេដែរ ដ្បិតឯងជាអ្នកស្រុកកាលីឡេ[ខ] ៧១តែគាត់តាំង
ប្រមាថ ហើយស្បថថា ខ្ញុំមិនស្គាល់មនុស្សនោះដែលអ្នក
រាល់គ្នានិយាយទេ[គ] ៧២នោះមាន់ក៏រងាវឡើងជាគំរប់២
ដង ពេត្រុសក៏នឹកឃើញពីព្រះបន្ទូល ដែលព្រះយេស៊ូវ
បានប្រាប់គាត់ថា មុនដែលមាន់រងាវ២ដង នោះអ្នកនឹង
ប្រកែក៣ដងថា មិនស្គាល់ខ្ញុំ[ឃ] កាលគាត់បានគិតពីសេចក្ដី
នោះហើយ នោះក៏យំ ។

## ព្រះយេស៊ូវប្រឈមមុខនឹងលោកពីឡាត់

*១៥:២-១៥ = មថ ២៧:១១-២៦ លក ២៣:២,៣,១៨-២៥*
*យហ ១៨:២៩-១៩:១៦*

**១៥** ១ដល់ព្រឹកឡើង កាលពួកសង្គ្រាជ ពួកចាស់ទុំ នឹង
ពួកអាចារ្យ[ង] ព្រមទាំងក្រុមជំនុំ[ច] ទាំងអស់បានប្រជុំពិគ្រោះ
គ្នា នោះក៏ចងព្រះយេស៊ូវ នាំបញ្ជូនទៅឯលោកពីឡាត់[ឆ]
២លោកពីឡាត់ពិចារណាសួរទ្រង់ថា តើអ្នកជាស្តេច របស់
សាសន៍យូដាឬអី[ជ] ទ្រង់មានបន្ទូលឆ្លើយថា ត្រូវដូចលោក
មានប្រសាសន៍ហើយ ៣ឯពួកសង្គ្រាជ គេចោទប្រកាន់ទ្រង់
ខ្លាំងណាស់ ៤នោះលោកពីឡាត់ក៏ពិចារណាសួរទ្រង់ម្តង
ទៀត ដោយពាក្យថា តើអ្នកមិនព្រមឆ្លើយសោះទេឬអី
មើលរឿងជាច្រើនទាំងម្ល៉េះ ដែលគេធ្វើបន្ទាល់ទាស់នឹង
អ្នក ៥តែព្រះយេស៊ូវទ្រង់ឥតមានឆ្លើយអ្វីទៀតសោះ[ឈ] បាន
ជាលោកពីឡាត់ក៏ អស្ចារ្យក្នុងចិត្ត។ ។
៦រីឯនៅបុណ្យនោះ លោកតែងធ្លាប់លែងអ្នកទោស ម្នាក់
ឱ្យដល់គេ តាមដែលគេសូម ៧គ្រានោះ មានម្នាក់ឈ្មោះ
បារ៉ាបាស ជាប់គុកជាមួយនឹងពួកអ្នកបះបោរ ជាអ្នកដែល
សំឡាប់គេក្នុងវេលាបះបោរនោះ ៨ហ្វូងមនុស្សក៏ចាប់តាំង
ស្រែកឡើង សូមលោកបើកឱ្យដល់គេ ដូចជាលោកតែង
ធ្លាប់ធ្វើមក ៩លោកពីឡាត់សួរគេថា តើចង់ឱ្យខ្ញុំលែង
ស្តេចសាសន៍យូដា ឱ្យដល់អ្នករាល់គ្នាឬអី[ញ] ១០នេះដ្បិត
លោកជ្រាបថា ពួកសង្គ្រាជបានបញ្ជូនទ្រង់ ដោយឈ្នានីស
ទេ ១១តែពួកសង្គ្រាជបានញុះញង់ហ្វូងមនុស្ស ឱ្យសូមឱ្យ
លោកលែង បារ៉ាបាសវិញ[ដ] ១២លោកពីឡាត់ក៏សួរគេម្តង
ទៀតថា ដូច្នេះ តើចង់ឱ្យខ្ញុំធ្វើអ្វីនឹងអ្នកដែលអ្នករាល់គ្នា
ហៅថា ស្តេចសាសន៍យូដានេះ ១៣គេស្រែកឡើងទៀតថា
ចូរឆ្កាងវាទៅ ១៤លោកពីឡាត់សួរគេថា ដូច្នេះតើគាត់បាន
ធ្វើខុសអ្វី នោះគេស្រែកកាន់តែខ្លាំងឡើងថា ចូរឆ្កាងវាទៅ
១៥ឯពីឡាត់ លោកចង់ធ្វើបំពេញដល់ចិត្តហ្វូងមនុស្សដែរ
បានជាលែងបារ៉ាបាសដល់គេ រួចកាលបានវាយព្រះយេ
ស៊ូវដោយរំពាត់ហើយ[ឋ] នោះក៏បញ្ជូនទៅឱ្យគេឆ្កាងទ្រង់ ។

## ពួកទាហានរ៉ូម៉ាំងចំអកឱ្យព្រះយេស៊ូវ

*១៥:១៦-២០ = មថ ២៧:២៧-៣១*

**១៤:៧០** ខ កច ២:៧
**១៤:៧១** គ ខ.៣០,៧២
**១៤:៧២** ឃ ខ.៣០,៦៨
**១៥:១** ង មថ ២៧:១ លក ២២:៦៦
ច មថ ៥:២២
ឆ មថ ២៧:២
**១៥:២** ជ ខ.៩,១២, ១៨,២៦ មថ ២:២
**១៥:៥** ឈ មក ១៤:៦១
**១៥:៩** ញ ខ.២
**១៥:១១** ដ កច ៣:១៤
**១៥:១៥** ឋ អស ៥៣:៦

ថា លោកគឺជាអ្នកស្រុកកាលីឡេ ហើយជាមនុស្សម្នាក់ក្នុងចំណោមអ្នកដើរតាមព្រះយេស៊ូវយ៉ាងច្បាស់ ទោះជាគាត់នៅឯទីធ្លាខាងក្រៅ ឆ្ងាយពីព្រះយេស៊ូវក៏ដោយ ក៏នៅតែគេស្គាល់ដែរ ។

**១៥:១** *ដល់ព្រឹកឡើង* ម៉ោងចូលធ្វើការជាផ្លូវការរបស់ពួករ៉ូម៉ាំង គឺនៅពេលថ្ងៃរះច្បាស់ពេលព្រឹក ត្រូវនឹងថ្ងៃសុក្រនៃសប្តាហ៍រងទុក្ខ ។ *ក្រុមជំនុំ* មើលការពន្យល់ ១៤:៥៥ ។ *ប្រជុំពិគ្រោះគ្នា* គេកំពុងរកវិធីចោទព្រះយេស៊ូវថា ជាអ្នកក្បត់ជាតិ ជាជាងគ្រាន់តែចោទប្រមាថដល់ព្រះនាមព្រះនោះ (លក ២៣:១-១៤ មើលការពន្យល់ លក ២៣:២) ដើម្បីនឹងបានសម្លាប់ទ្រង់តាមផ្លូវច្បាប់ក្នុងគ្រានេះ ។ *លោកពីឡាត់* ជាជនជាតិរ៉ូម៉ាំង ហើយជាចៅហ្វាយស្រុកយូដាពីឆ្នាំ២៦-៣៦គ.ស ដែលរស់នៅតាមឆ្នេរសមុទ្រមេឌីទែរ៉ាណេ តាមផ្លូវច្បាប់ តាំងពីសម័យស្តេចសេសារមកម្ល៉េះ ។ នៅឆ្នាំ១៩៦១ អ្នកបុរាណវិទ្យាបានជីករកឃើញថ្មមួយផ្ទាំង ដែលបានចារឹកឈ្មោះលោកពីឡាត់ជាមួយនឹងស្តេចសេសារ ។ បន្ទាប់មកគាត់ទៅនៅក្នុងវាំងដ៏ល្អមួយ ដែលកសាងដោយស្តេចហេរ៉ូឌ-អធិរាជ នៅក្រុងយេរូសាឡិមក្បែរបរិវេណព្រះវិហារ ។ លោកម៉ាកុសបានហៅទីកន្លែងនោះថា "ទីកាត់ក្តី" ជំនួសពាក្យថាវាំង (ខ.១៦) ទីនេះហើយដែលតុលាការរ៉ូម៉ាំងបានកាត់ទោសព្រះយេស៊ូវចុងក្រោយ ។

**១៥:២** *លោកពីឡាត់ពិចារណាសួរទ្រង់ថា* ការជំនុំជម្រះក្តីនៅក្នុងតុលាការរ៉ូម៉ាំង គឺមានតែចៅក្រមកំពូលតែមួយគត់ ដែលមានសិទ្ធិសម្រេចរឿងក្តីនេះ ។

**១៥:៣** *រឿងជាច្រើនទាំងម្ល៉េះ* មើលការពន្យល់ លក ២៣:២ ។ ការចោទប្រកាន់ដ៏សន្ធឹកសន្ធាប់ទាំងនេះ វាគឺជារឿងធម្មតាទេចំពោះឧក្រិដ្ឋជននោះ ។

**១៥:៤** *តើអ្នកមិនព្រមឆ្លើយសោះទេឬអី?* ប្រសិនបើព្រះយេស៊ូវមិនព្រមឆ្លើយការពារខ្លួនទេ តាមច្បាប់របស់រ៉ូម៉ាំង លោកពីឡាត់មានសិទ្ធិប្រឆាំងនឹងទ្រង់បាន ។

**១៥:៦** *តែងធ្លាប់លែង* មើលការពន្យល់ យហ ១៨:៣៩ ។

**១៥:៧** *បារ៉ាបាស* គាត់ប្រហែលជាសមាជិករបស់ពួក "ឧស្សាហ៍" ពួកនេះជាក្រុមបដិវត្តន៍យូដា (មើលការពន្យល់ មថ ១០:៤) ។ *ក្នុងវេលាបះបោរនោះ* មិនមានប្រភពណាបញ្ជាក់ពីរឿងនេះច្បាស់ពីការបះបោរនោះទេ លោកម៉ាកុសថា រឿងនេះល្បីណាស់ តែអភិបាលខេត្តរូបនោះថា ការបះបោរនេះជារឿងធម្មតាទេ (លក ១៣:១) ។

**១៥:១៣** *ចូរឆ្កាងវាទៅ* មើលការពន្យល់ ខ.២៤ ។

**១៥:១៥** *វាយ. . .ដោយរំពាត់* ពួករ៉ូម៉ាំងបានធ្វើខ្សែតីមួយពីស្បែកសត្វជាច្រើនខ្សែ ដោយបញ្ចុះឆ្អឹងសត្វចូលក្នុងខ្សែនិមួយៗ ។ អ្នកទោសជនជាតិយូដាត្រូវវាយយ៉ាងច្រើនបំផុតគឺ៤០រំពាត់ តែការកំណត់នេះ មិនត្រូវបានពួករ៉ូម៉ាំងទទួលស្គាល់ឡើយ ជាញឹកញាប់អ្នកទោសមិនអាចរួចជីវិតបានឡើយ

[១៦]ចំណែកពួកទាហាន ក៏នាំទ្រង់ទៅឯទីធ្លា ជាទីកាត់ក្ដី[ឌ] រួច
គេហៅពួកកងទាហានទាំងអស់ ឱ្យមូលគ្នាមក [១៧]ក៏យកអាវ
ពណ៌ស្វាយបំពាក់ទ្រង់ ហើយក្រងភួងបន្លាបំពាក់លើព្រះ
សិរ [១៨]រួចចាប់តាំងសំពះទូលទ្រង់ថា ថ្វាយបង្គំស្ដេចសាសន៍
យូដា[ឍ] [១៩]គេក៏យកដើមត្រែងវាយព្រះសិរ ស្ដោះដាក់
ទ្រង់ ហើយលុតជង្គង់ថ្វាយបង្គំទ្រង់ផង [២០]កាលបានចំអក
មើលងាយទ្រង់ស្រេចហើយ នោះគេដោះអាវពណ៌ស្វាយ
ចេញ ក៏បំពាក់ព្រះពស្ត្រទ្រង់វិញ រួចនាំចេញទៅឆ្កាង[ណ]។

**ការឆ្កាងព្រះយេស៊ូវ**

*១៥:២២-៣២ = មថ ២៧:៣៣-៤៤ លក ២៣:៣៣-៤៣*
*យហ ១៩:១៧-២៤*

[២១]គេចាប់អ្នកស្រុកគីរេន[ត]ម្នាក់ ឈ្មោះស៊ីម៉ូន ជាឪពុក
អ័លេក្សានត្រុស និងរូភូស[ថ]ដែលដើរតាមផ្លូវចុះមកពីចំការ
បង្ខំឱ្យគាត់លីឈើឆ្កាងទ្រង់[ទ] [២២]គេនាំទ្រង់ទៅដល់កន្លែង
ហៅថា«គាល់កូថា» ដែលស្រាយថា ភ្នំរលាក្បាល [២៣]នោះ
គេយកស្រាទំពាំងបាយជូរ លាយនឹងជ័រល្វីងទេស[ធ] ថ្វាយ
ទ្រង់សោយ តែទ្រង់មិនសោយទេ [២៤]កាលបានឆ្កាងទ្រង់រួច
ហើយ នោះគេក៏យកព្រះពស្ត្រទ្រង់ចាប់ឆ្នោតចែកគ្នា[ន] ដើម្បី
ឱ្យដឹងជាអ្នកណាត្រូវបានអ្វី [២៥]ពេលដែលគេឆ្កាងទ្រង់
គឺជាពេលម៉ោង៩ព្រឹក [២៦]គេសរសេរប្រកាសកាត់ទោស
ទ្រង់ថា «នេះស្ដេចសាសន៍យូដា[ប]» [២៧]ហើយក៏ឆ្កាងចោរ២
នាក់ជាមួយនឹងទ្រង់ ម្នាក់ខាងស្ដាំ ម្នាក់ខាងឆ្វេង [២៨]នោះ

**១៥:១៦** ឌ យហ ១៨:២៨,៣៣ ១៩:៩
**១៥:១៨** ឍ ខ.២
**១៥:២០** ណ ហព ១៣:១២
**១៥:២១** ត មថ ២៧:៣២
**១៥:២១** ថ រម ១៦:១៣
ទ មថ ២៧:៣២ លក ២៣:២៦
**១៥:២៣** ធ ខ.៣៦ ទដ ៦៩:២១ សភ ៣១:៦
**១៥:២៤** ន ទដ ២២:១៨
**១៥:២៦** ប ខ.២

កាលត្រូវនឹងខ្សែត្រីនេះ ។

**១៥:១៦** *ទីកាត់ក្ដី* ពាក្យនេះ មានប្រវត្តិដើមរបស់វាមកពីពាក្យ "ទីបញ្ជាការ" ឬទីសំខាន់នៅក្នុងជំរំយោធាមួយ ។ ជាពាក្យដែលយកមកពីសាសន៍ដទៃជាពិសេសជនជាតិប៉ាឡេស្ទីនបានប្រើសម្រាប់ទីចាត់ការយោធារបស់ពួកគេ (១៥:១)។

**១៥:១៧** *អាវពណ៌ស្វាយ* ប្រហែលជាអាវចាស់របស់ទាហាន ដែលមានពណ៌ដូចជាអាវស្ដេច(មថ ២៧:២៨)។ *ភួងបន្លា* ធ្វើឡើងពីរុក្ខជាតិបន្លា (ភាសាក្រិកមានន័យថាជាមែកឈើដែលមានបន្លា) ជាដើមបន្លាដ៏សម្បូរក្នុងប្រទេសប៉ាឡេស្ទីន។ ភួងបន្លា និងអាវពណ៌ស្វាយ សុទ្ធតែជាប្រដាប់តែងខ្លួនដើម្បីប្រមាថព្រះយេស៊ូវ ។

**១៥:១៨** *ថ្វាយបង្គំស្ដេចសាសន៍យូដា* នេះគឺគ្រាន់តែជាការចំអកឡកឡឺយដែលពួកគេធ្វើដូច្នេះចំពោះតែស្ដេចសេសារតែម្នាក់ប៉ុណ្ណោះ មិនមែនព្រះយេស៊ូវទេ ។

**១៥:១៩** *ស្ដោះដាក់ទ្រង់* ប្រហែលជាការធ្វើត្រាប់តាមក្នុងការឱបថើបសំដែងការគោរពចំពោះពួកត្រកូលស្ដេច តាមប្រពៃណីពួកគេ (អ្នកស្រុកខាងកើត)។

**១៥:២១** *ស្រុកគីរេន* ជាទីក្រុងសំខាន់មួយនៃស្រុកលីប៊ីយ៉ានៅប្រទេសអាហ្វ្រិកខាងជើង ដែលមានជនជាតិយូដាមួយចំនួនធំបានរស់នៅទីនោះ ។ *ស៊ីម៉ូន* គាត់ប្រហែលជាជនជាតិយូដា ដែលមកពីស្រុកគីរេន ហើយបានមកធ្វើបុណ្យរំលងនៅក្រុងយេរូសាឡិម(កច ៦:៩)។ *អ័លេក្សានត្រុស និងរូភូស* មាននៅតែក្នុងគម្ពីរម៉ាកុសនេះទេ ។ លោកម៉ាកុសបានសរសេរឡើងដល់អ្នកអានណាដែលបានស្គាល់អ្នកទាំងពីរនេះតែប៉ុណ្ណោះ ។ រូភូសអាចជាមនុស្សតែម្នាក់ដែលបាននិយាយនៅ ក្នុង រម ១៦:១៣។ *លីឈើឆ្កាង* ជាទូទៅ មនុស្សដែលទទួលទោសប្រហារជីវិត ត្រូវតែលីឈើមួកកំណាត់ (ធ្នឹមរបស់ឈើឆ្កាង) ដែលមានទម្ងន់ប្រហែល ១៤ទៅ ១៨គីឡូក្រាម សម្រាប់យកទៅធ្វើឈើឆ្កាងដើម្បីឆ្កាងខ្លួនឯង ។ ព្រះយេស៊ូវទ្រង់បានលីដោយអង្គទ្រង់ពីដំបូងដែរ(យហ ១៩:១៧) តែដោយព្រោះទ្រង់ត្រូវគេវាយ ទ្រោមខ្លាំងពេក ទើបគេបង្ខំលោកស៊ីម៉ូនដែលជាអ្នកស្រុកគីរេនឱ្យជួយលីជំនួសវិញ

**១៥:២២** *ភ្នំរលាក្បាល* វាអាចជាកូនភ្នំតូច ដែលមានរាងដូចជារលាក្បាល ឬក៏ដោយសារតែវាជាកន្លែងប្រហារជីវិតមនុស្សតែប៉ុណ្ណោះ ទើបមានឈ្មោះដូចនេះ (ព្រះគម្ពីរដំណឹងល្អឥតបាននិយាយអ្វីពីភ្នំនេះទេ)។

**១៥:២៣** *ស្រាទំពាំងបាយជូរ លាយនឹងជ័រល្វីងទេស* ជាប្រពៃណីបុណ្យសពនៃជនជាតិយូដាបានបង្ហាញថា វាជាគ្រឿងផ្សំម្យ៉ាងដែលគេលាយនឹងស្រាសម្រាប់បំបាត់ការឈឺចាប់ ឬធ្វើឱ្យស្ពឹក(សភ ៣១:៦)។ *ជ័រល្វីងទេស* ជាគ្រឿងទេសម្យ៉ាងដែលយកមកពីដើមឈើមួយប្រភេទ នៅវាលខ្សាច់អារ៉ាប់ និងតំបន់អាហ្វ្រិក (លប ៣៧:២៥)។

**១៥:២៤** *ឆ្កាង* មានន័យថា យកមនុស្សទៅប្រហារជីវិតដោយបោះដែកគោលជាប់នឹងឈើឆ្កាង ។ ជនរងគ្រោះត្រូវបានគេដំដែកគោលវែងៗនៅត្រង់កដៃ និងឆ្អឹងកែងជើង។ ប្រសិនបើជនរងគ្រោះក្រដាច់ខ្យល់ពេក គេនឹងវាយបំបាក់ជើងទាំងពីររបស់អ្នកនោះ(យហ ១៩:៣៣)។ អ្នកបុរាណវិទ្យាបានរកឃើញឆ្អឹងសពដែលបានស្លាប់ដោយសារគេឆ្កាង ក្បែរក្រុងយេរូសាឡិម ក្នុងចន្លោះឆ្នាំ៧-៦៦គ.ស នៅរប៉ាត់រប៉ាយត្រង់កន្លែងគេឆ្កាងមនុស្សនាសម័យនោះ ។ អ្នកដែលស្លាប់របៀបនេះ គឺជាពួកអ្នកទោសឧក្រិដ្ឋ និងអ្នកប្រឆាំងបះបោរ(ក្រៅពីពួករ៉ូម៉ាំង) នៅសតវត្សរ៍ទី១ អ្នកនិពន្ធបានរៀបរាប់ទិដ្ឋភាពនៃការឈឺចាប់យ៉ាងរស់រវើក ដែលមើលទៅ គួរឱ្យអាម៉ាស់ខ្លាំងណាស់ តាយរយៈការសម្លាប់យ៉ាងដូច្នេះ ។ *យកព្រះពស្ត្រទ្រង់ចាប់ឆ្នោតចែកគ្នា* ត្រង់ចំណុចនេះបញ្ជាក់ថា ក្រុមពេជ្ឈឃាដមានសិទ្ធិរឹបអូសយកទ្រព្យសម្បត្តិពីជនរងគ្រោះ ប៉ុន្តែដោយព្រោះចែកគ្នាមិនដាច់ ទើបពួកគេនាំគ្នាចាប់ឆ្នោតទៅ ។ សម្លៀកបំពាក់របស់ព្រះយេស៊ូវ អាចមានខោអាវខាងក្រៅ ខាងក្នុង ខ្សែក្រវាត់ ស្បែកជើង និងឈ្នួត ។

**១៥:២៥** *ម៉ោង៩ព្រឹក* គឺនៅយាម៣ (លក ២៣:៤៤ យហ ១៩:១៤ និងការពន្យល់)។

**១៥:២៦** *ប្រកាសកាត់ទោសទ្រង់* នេះជាប្រពៃណីដែលត្រូវតែសរសេរអំពីទោសរបស់ជនរងគ្រោះនៅលើបន្ទះក្ដា ដោយមានម្នាក់កាន់ដើរពីមុខជនរងគ្រោះរហូតដល់កន្លែងឆ្កាង ហើយក្រោយពីឆ្កាងរួច បន្ទះក្ដានោះត្រូវដាក់ពីលើជននោះដែរ ។ *នេះស្ដេចសាសន៍យូដា* ពាក្យចោទប្រកាន់នេះប្លែកពីដំណឹងល្អដទៃទៀតបន្តិច ប៉ុន្តែ ដំណឹងល្អទាំងអស់សុទ្ធតែឯកភាពគ្នាថា ព្រះយេស៊ូវត្រូវបានគេឆ្កាងដោយសារតែការប្រកាសថា ទ្រង់ជាស្ដេចនៃសាសន៍យូដានេះឯង ។

**១៥:២៧** *ចោរ២នាក់* យោងតាមច្បាប់របស់ពួករ៉ូម៉ាំងចោរពុំមែនជាជន

បានសំរេចតាមបទគម្ពីរដែលថា គេបានរាប់ទ្រង់ជាពួក
អ្នកទទឹងច្បាប់។
[២៩]ពួកអ្នកដែលដើរតាមទីនោះ ក៏ជេរទ្រង់ ទាំងគ្រវីក្បាល[ផ]
ហើយនិយាយថា អើ ឯងដែលបំផ្លាញព្រះវិហារ ហើយសង់
ឡើងវិញក្នុងរវាង៣ថ្ងៃ [៣០]ឥឡូវ ចូរជួយសង្គ្រោះខ្លួនឯង
ដោយចុះពីឈើឆ្កាងមក [៣១]ពួកសង្គ្រាជ នឹងពួកអាចារ្យ
ក៏ចំអកឱ្យទ្រង់បែបដូចគ្នា[ភ] ទាំងនិយាយគ្នាទៅវិញទៅមក
ថា វាជួយសង្គ្រោះដល់មនុស្សឯទៀតបានតែពុំអាចនឹង
សង្គ្រោះចំពោះខ្លួនឯងបានទេ [៣២]ចូរឱ្យព្រះគ្រីស្ទ[ម] ជាស្តេច
នៃសាសន៍អ៊ីស្រាអែល[យ] ចុះពីឈើឆ្កាងមកឥឡូវចុះ ឱ្យយើង
បានឃើញ ហើយជឿផង ឯ២នាក់ដែលជាប់ឆ្កាងជាមួយ
នឹងទ្រង់ គេក៏ដៀលត្មះទ្រង់ដែរ។

## ការសុគតរបស់ព្រះយេស៊ូវ

*១៥:៣៣–៤១ = មថ ២៧:៤៥–៥៦ លក ២៣:៤៤–៤៩*

[៣៣]ដល់ម៉ោង១២ នោះមានងងឹតជាបគ្របលើផែនដី
ដរាបដល់ម៉ោង៣រសៀល[រ] [៣៤]លុះវេលាម៉ោង៣ នោះ
ព្រះយេស៊ូវ ទ្រង់បន្លឺឧទានជាខ្លាំងថា អេឡយៗល៉ាម៉ាសា
បាច់ថានី គឺស្រាយថា ព្រះអង្គនៃទូលបង្គំអើយ ឱព្រះអង្គ
នៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់លះចោលទូលបង្គំ[ល]
[៣៥]អ្នកខ្លះដែលឈរនៅទីនោះក៏ឮ ហើយគេនិយាយថា
មើល វាស្រែកហៅរកលោកអេលីយ៉ាហើយ [៣៦]រួចម្នាក់
រត់ទៅយកសារាយរំហួតជ្រលក់ទឹកខ្មេះ[វ]ជោក ដាក់នឹងចុង
ដើមត្រែងហុចទៅ ថ្វាយទ្រង់សោយ ដោយពោលថា
ឈប់សិនចាំមើលបើលោកអេលីយ៉ាមកបញ្ចុះវាឬទេ។
[៣៧]រួចព្រះយេស៊ូវ ទ្រង់ស្រែកជាខ្លាំង ហើយក៏ផុតដង្ហើម
ទៅ[ស] [៣៨]គ្រានោះ វាំងននក្នុងព្រះវិហារក៏រហែកជា២ភាគ
ចាប់តាំងពីលើចុះដល់ក្រោម[ហ] [៣៩]ឯមេទ័ព[ឡ]ដែលឈរទល់
មុខនឹងទ្រង់ គាត់ឃើញថា ទ្រង់ស្រែកឡើងហើយផុតដង្ហើម
ទៅយ៉ាងដូច្នោះ ក៏និយាយថា មនុស្សនេះប្រាកដជា ព្រះរាជ
បុត្រានៃព្រះមែន[អ] [៤០]ក៏មានស្ត្រីខ្លះដែលបានតាមបំរើ
ព្រះយេស៊ូវក្នុងគ្រាដែលទ្រង់គង់នៅស្រុកកាលីឡេនៅ
ឡើយគេឈរមើលពី ចំងាយ[ក] [៤១]ក្នុងពួកស្ត្រីទាំងនោះ គឺម៉ា
រាពីស្រុកម៉ាក់ដាឡា១ នឹងម៉ារា ជាម្តាយយ៉ាកុបតូច នឹងយ៉ូ
សេ១ហើយនឹងសាឡូមេ១[ខ]ក៏មានស្ត្រីឯទៀតជាច្រើនដែល
បានឡើងមកឯក្រុងយេរូសាឡិមជាមួយនឹងទ្រង់ដែរ[គ] ។

**១៥:២៩** ផ ទដ ២២:៧ ១០៩:២៥ ៣ យហ ២:១៩
**១៥:៣១** ភ ទដ ២២:៧
**១៥:៣២** ម មក ១៤:៦១ យ ខ.២
**១៥:៣៣** រ អម ៨:៩
**១៥:៣៤** ល ទដ ២២:១
**១៥:៣៦** វ ខ.២៣ ទដ ៦៩:២១
**១៥:៣៧** ស យហ ១៩:៣០
**១៥:៣៨** ហ ហព ១០:១៩,២០
**១៥:៣៩** ឡ ខ.៤៥ អ មក ១:១,១១ ៩:៧ មថ ៤:៣
**១៥:៤០** ក ទដ ៣៨:១១
**១៥:៤១** ខ មក ១៦:១ លក ២៤:១០ យហ ១៩:២៥ គ មថ ២៧:៥៥,៥៦ លក ៨:២,៣

ឧក្រិដ្ឋធ្ងន់ធ្ងរនោះទេ ។ លោកម៉ាកុសបានប្រើពាក្យនេះ (ពួកទទឹងច្បាប់) គឺបានមកពីការកាត់សេចក្តីរបស់តុលាការថា អ្នកទាំងនេះជាជនក្បត់ជាតិ ហើយសមនឹងឆ្កាងប្រហារជីវិត ។

**១៥:២៨** នៅក្នុងព្រះគម្ពីរដើមជាភាសាក្រិក ឥតមានខនេះទេ (អាចយកពី លក ២២:៣៧ និងស្រង់ពី អស ៥៣:១២)។ លោកម៉ាកុសមិនបានដកស្រង់ពីព្រះគម្ពីរសញ្ញាចាស់ច្រើនទេ ។

**១៥:២៩** មើលការពន្យល់ ១៤:៥៨ ។

**១៥:៣២** *ព្រះគ្រីស្ទ* មើលការពន្យល់ មថ ១:១៧ ។ *ឯ២នាក់ដែលជាប់ឆ្កាងជាមួយនឹងទ្រង់* ក្រោយមក ចោរម្នាក់ក្នុងចំណោមចោរ២នាក់បានប្រែចិត្ត ហើយសុំឱ្យព្រះយេស៊ូវទទួលគាត់ទៅឯនគរទ្រង់ផង (លក ២៣:៣៩–៤៣)។

**១៥:៣៣** *ម៉ោង១២* គឺជាម៉ោងទី៦ ហើយម៉ោង៣ គឺជាម៉ោងទី៩ នាសម័យនោះ ។

**១៥:៣៤** ទាំងនេះគឺជាគ្រាមភាសាដ៏សាមញ្ញមួយ ដែលគេនិយាយទូទៅនៅសម័យព្រះយេស៊ូវ ។ នេះជាការបង្ហាញអំពីភាពឈឺចាប់របស់ព្រះយេស៊ូវ ក្នុងគ្រាដែល ទ្រង់មានអារម្មណ៍ថាទ្រង់ត្រូវទទួលការបោះបង់ចោល ដោយសារបាបរបស់ មនុស្សលោក (យហ ១:២៩ ទដ ២២:១)។

**១៥:៣៥** *អេលីយ៉ា* ពួកអ្នកដែលនៅក្នុងហេតុការណ៍នេះបានយល់ច្រឡំព្រះបន្ទូលរបស់ព្រះយេស៊ូវ ពេលទ្រង់ស្រែកលើកដំបូង (អេឡូយៗ) ថាទ្រង់ស្រែករកលោកអេលីយ៉ាវិញ ។ នៅគ្រានោះអ្នកស្រុកជឿថា លោកអេលីយ៉ានឹងមកជួយសង្គ្រោះ ក្នុងគ្រាដែលពួកបរិសុទ្ធ និងពួកសុចរិតត្រូវការ (ខ.៣៦)។

**១៥:៣៦** *ទឹកខ្មេះ* គឺជាប្រភេទស្រាជូរម្យ៉ាង (ស្រដៀងទឹកត្នោតជូរ) សម្រាប់ពួកកម្មករ និងពួកកូនទាហានផឹក (មើលការពន្យល់ លក ២៣:៣៦)។

**១៥:៣៧** *ស្រែកជាខ្លាំង* មើលការពន្យល់ យហ ១៩:៣០ ។ កម្លាំងនៃសូរសំរែកបានបង្ហាញថា ព្រះយេស៊ូវមិនមែនសុគតដូចមនុស្សដែលគេឆ្កាងសម្លាប់ធម្មតាទេ ព្រោះអ្នកផ្សេងៗទៀត ជាធម្មតាអ្នកដែលគេឆ្កាងដូច្នេះ គឺត្រូវឈឺចាប់បន្តិចម្តងៗ ខ្សោះទៅៗ ហើយក៏សន្លប់ បន្ទាប់មកដាច់ខ្យល់ស្លាប់តែម្តង (ការពន្យល់ ខ.២៤)។

**១៥:៣៨** *វាំងននក្នុងព្រះវិហារ* នេះគឺជាវាំងននដែលសម្រាប់ខ័ណ្ឌកន្លែងបរិសុទ្ធ និងកន្លែងបរិសុទ្ធបំផុត(មើលការពន្យល់ នក ២៦:៣១–៣៥ ២៦:៣១)។ ការរហែកវាំងននបង្ហាញថា ព្រះគ្រីស្ទបានចូលដល់ស្ថានសួគ៌ហើយ សម្រាប់នាំអស់អ្នកណាដែលទទួលជឿទ្រង់ ក៏ទៅក្នុងព្រះវត្តមានព្រះដែរ (មើលការពន្យល់ ហព ៩:៨–១០,១២ ១០:១៩–២០)។

**១៥:៣៩** *មេទ័ព* គឺមេទាហានលើ១000នាក់ នៅក្នុងទាហានរ៉ូម៉ាំង(កច ១០:១)។ *គាត់ . . . ឃើញថាទ្រង់ស្រែកឡើងផុតដង្ហើមទៅយ៉ាងដូច្នោះ* មើលការពន្យល់ ខ.៣៧ ។ *ជាព្រះរាជបុត្រានៃព្រះ* មើលការពន្យល់ មថ ២៧:៥៤ ។

**១៥:៤១** *ស្ត្រីឯទៀត. . .ជាមួយនឹងទ្រង់* មើលការពន្យល់ មថ ២៧:៥៥ លក ៨:៣ ។

## ការបញ្ចុះព្រះសពព្រះយេស៊ូវ

*១៥:៤២–៤៧ = មថ ២៧:៥៧–៦១ លក ២៣:៥០–៥៦*
*យហ ១៩:៣៨–៤២*

៤២មានម្នាក់ឈ្មោះយ៉ូសែបនៅស្រុកអើរីម៉ាថេ ដែល
មានកេរ្តិ៍ឈ្មោះក្នុងពួកក្រុមជំនុំ[ឃ]ជាអ្នករង់ចាំនគរព្រះដែរ[ង]
អ្នកនោះបានមកដល់ ក៏ចូលទៅឯលោកពីឡាត់ ដោយចិត្ត
ក្លាហាន សូមព្រះសពព្រះសេយ៊ូវ ៤៣ដោយព្រោះជាថ្ងៃ
រៀបចំហើយ គឺជាថ្ងៃមុនថ្ងៃឈប់សំរាក[ច] ហើយក៏ល្ងាច
ណាស់ផង ៤៤ឯលោកពីឡាត់ មានសេចក្ដីឆ្ងល់ពីទ្រង់ដែល
សុគតជាឆាប់ម្ល៉េះ ក៏ហៅមេទ័ពមកសួរបញ្ជាក់ បើទ្រង់
សុគតជាយូរមកហើយ ឬដូចម្ដេច ៤៥កាលមេទ័ព[ឆ]បាន
ជំរាបឱ្យលោកជ្រាបហើយ នោះលោកក៏អនុញ្ញាតឱ្យព្រះ
សពដល់យ៉ូសែប ៤៦គាត់ក៏ទិញសំពត់ទេសឯក រួចដាក់ព្រះ
សពទ្រង់ចុះមក រុំនឹងសំពត់នោះ នាំទៅបញ្ចុះក្នុងផ្នូរដែល
បានដាប់នៅក្នុងថ្ម រួចប្រមៀលថ្ម១មក សន្ធប់ខ្ទប់មាត់ផ្នូរ
ជិត[ជ] ៤៧ឯម៉ារាជាអ្នកស្រុកម៉ាក់ដាឡា នឹងម៉ារា ជាម្ដាយ
យ៉ូសេ[ឈ]គេក៏ឃើញកន្លែងដែលបញ្ចុះព្រះសពទ្រង់ដែរ ។

## ព្រះយេស៊ូវរស់ឡើងវិញ

*១៦:១–១៨ = មថ ២៨:១–៨ លក ២៤:១–១០*

**១៦** ១កាលផុតថ្ងៃឈប់សំរាកហើយ នោះម៉ារា ជាអ្នក
ស្រុកម៉ាក់ដាឡា ម៉ារា ជាម្ដាយយ៉ាកុប និងសាឡូមេបាននាំ
គ្នាទិញគ្រឿងក្រអូប[ញ]ដើម្បីនឹងទៅអប់ព្រះសពទ្រង់ ២ដល់
ព្រលឹមឡើង នៅថ្ងៃទី១ក្នុងអាទិត្យនោះ កាលថ្ងៃទើបនឹង
រះឡើង គេក៏ទៅឯផ្នូរ ៣ព្រមទាំងនិយាយគ្នាបណ្ដើរថា
តើមានអ្នកណា នឹងប្រមៀលថ្មចេញពីមាត់ផ្នូរឱ្យយើង[ដ]
៤តែកាលបានងើបមើលទៅ នោះឃើញថ្មបានប្រមៀល
ចេញហើយ (ថ្មនោះធំណាស់) ៥លុះកាលបានចូលទៅក្នុង
ផ្នូរ ក៏ឃើញកំឡោះម្នាក់ ពាក់អាវស[ឋ]អង្គុយនៅខាងស្ដាំ
ហើយស្ត្រីទាំងនោះមានសេចក្ដីភាំងស្លុត ៦តែអ្នកនោះ
និយាយថា កុំឱ្យភ័យឡើយ អ្នករាល់គ្នាមករកព្រះយេស៊ូវ
ពីណាសារ៉ែត[ឌ] ដែលត្រូវឆ្កាង ទ្រង់មានព្រះជន្មរស់ឡើង
វិញហើយ ទ្រង់មិនគង់នៅទីនេះទេ មើលនេះជាកន្លែង
ដែលគេបានផ្ដេកព្រះសពទ្រង់ ៧ចូរអ្នករាល់គ្នាទៅប្រាប់
ពួកសិស្សទ្រង់ ព្រមទាំងពេត្រុសផងថា ទ្រង់យាងទៅឯ
ស្រុកកាលីឡេមុនអ្នករាល់គ្នាហើយ អ្នករាល់គ្នានឹងឃើញ
ទ្រង់[ឍ]នៅស្រុកនោះ ដូចជាទ្រង់បានប្រាប់ទុក[ណ] ៨នោះគេ
ប្រញាប់ប្រញាល់ចេញទៅក្រៅ រត់ចោលផ្នូរទៅដោយ
កើតមានសេចក្ដីភ័យញ័រ ទាំងស្រឡាំងកាំង គេមិនបាន
និយាយអ្វីប្រាប់ដល់អ្នកណាឡើយ ព្រោះគេខ្លាច ។

**១៥:៤២** ឃ មថ ៥:២២ ង មថ ៣:២ លក ២:២៥,៣៨
**១៥:៤៣** ច មថ ២៧:៦២ យហ ១៩:៣១
**១៥:៤៥** ឆ ខ.៣៩
**១៥:៤៦** ជ មក ១៦:៣
**១៥:៤៧** ឈ ខ.៤០
**១៦:១** ញ លក ២៣:៥៦ យហ ១៩:៣៩,៤០
**១៦:៣** ដ មក ១៥:៤៦
**១៦:៥** ឋ យហ ២០:១២
**១៦:៦** ឌ មក ១:២៤
**១៦:៧** ឍ យហ ២១:១–២៣ ណ មក ១៤:២៨

**១៥:៤២** *យ៉ូសែប* មើលការពន្យល់ លក ២៣:៥០ ។ *ស្រុកអើរីម៉ាថេ* មើលការពន្យល់ មថ ២៧:៥៧ ។ *ពួកក្រុមជំនុំ* គឺជាក្រុមប្រឹក្សាក្នុងសាលាកាត់ក្ដី (មើលការពន្យល់ ១៤:១៥)។ *នគរព្រះ* មើលការពន្យល់ មថ ៣:២ ។ *លោកពីឡាត់* មើលការពន្យល់ ខ.១ ។ *សូមព្រះសពព្រះយេស៊ូវ* មើលការពន្យល់ លក ២៣:៥២ ។

**១៥:៤៣** *ថ្ងៃរៀបចំ* គឺនៅល្ងាចថ្ងៃសុក្រ ត្រូវតែយកព្រះសពព្រះយេស៊ូវចុះពីលើឈើឆ្កាងឱ្យបានមុនថ្ងៃលិច ដែលជាថ្ងៃចាប់ផ្ដើមបុណ្យឈប់សម្រាក ។

**១៥:៤៤** *សេចក្ដីឆ្ងល់* មនុស្សដែលគេត្រូវឆ្កាង ជាញឹកញាប់អាចមានជីវិតបានតែ ២ឬ៣ថ្ងៃតែប៉ុណ្ណោះ តែចំពោះព្រះយេស៊ូវ គឺមុនកំណត់ខុសពីមនុស្សធម្មតា ។

**១៥:៤៥** *ឱ្យព្រះសពដល់យ៉ូសែប* ការប្រគល់សាកសព ដែលគេកាត់ទោសថាជាជនឧក្រិដ្ឋ ក្បត់ជាតិ ជាពិសេសឱ្យទៅអ្នកដែលមិនមែនជាញាតិនៃសពដូចនេះ គឺជារឿងមិនធម្មតាទេ ។

**១៥:៤៦** *ផ្នូរដែលបានដាប់ក្នុងថ្ម* មថ ២៧:៦០ បានឱ្យដឹងថា ផ្នូរនេះជារបស់លោកយ៉ូសែប ហើយវាជាផ្នូរមួយថ្មី ដែលមិនទាន់ប្រើពីមុនមក ។ ផ្នូរនៅក្នុងសួនច្បារមួយ មិនឆ្ងាយពីកន្លែងគេឆ្កាងទ្រង់ទេ (យហ ១៩:៤១)។ អ្នកបុរាណវិទ្យាបានរកឃើញកន្លែងកប់សពព្រះយេស៊ូវ ក្នុងសតវត្សរ៍ទីមួយ ។ *ថ្ម* គឺជាដុំផ្ទាំងធំ សំប៉ែត រាងមូលមួយ ដែលអាចប្រមៀលបាន ។

**១៦:១** *កាលផុតថ្ងៃឈប់សំរាកហើយ* គឺនៅម៉ោង៦ល្ងាច ។ ក្នុងល្ងាចថ្ងៃសៅរ៍ មិនអាចរកទិញដូរអ្វីបានឡើយក្នុងថ្ងៃឈប់សម្រាក ។ *ម៉ារាជាអ្នកស្រុកម៉ាក់ដាឡា ម៉ារា ជាម្ដាយយ៉ាកុប និងសាឡូមេ* មើលការពន្យល់ ១៥:៤០ ។ *គ្រឿងក្រអូម* សម្រាប់អប់សពពួកសាសន៍យូដាមិនទម្លាប់ធ្វើដូច្នេះទេ ។ គ្រឿងក្រអូបនេះតំណាងឱ្យការគោរព និងក្ដីស្រឡាញ់ (មើលការពន្យល់ លក ២៣:៥៦)។ *ទៅអប់ព្រះសព ព្រះយេស៊ូវ* ស្ត្រីទាំងនេះពុំនឹកស្មានថាព្រះយេស៊ូវគ្រីស្ទបានរស់ឡើងវិញទេ ។

**១៦:៣** *តើមានអ្នកណា នឹងប្រមៀលថ្មចេញពីមាត់ផ្នូរ. . .* ការប្រមៀលថ្មដ៏ធំមួយ ដាក់ទៅក្នុងរូងដែលបានដាប់រួច នោះជាការងាយណាស់ ប៉ុន្តែវាមិនងាយ ស្រួលឡើយក្នុងការប្រមៀលថ្មឡើងចេញពីមាត់រណ្ដៅមកវិញ។

**១៦:៥** *លុះកាលបានចូលទៅក្នុងផ្នូរ* គឺរូងមួយដែលមានរាងជាចតុកោណកែង ដែលបើកចំហដូចជាផ្លូវសំដៅទៅរកផ្នូរព្រះសពព្រះយេស៊ូវ។ *កំលោះម្នាក់ពាក់អាវស* តាមព្រះគម្ពីរ មថ ២៨:២ ថា ជាទេវតា (មើលពន្យល់ លក ២៤:៤)។

**១៦:៦** *ណាសារ៉ែត* មើលការពន្យល់ មថ ២:២៣ ។ *ឆ្កាង* មើលការពន្យល់ ១៥:២៤ ។ *មានព្រះជន្មរស់ឡើងវិញ* ចំណុចសំខាន់នៃដំណឹងល្អម៉ាកុស គឺនិយាយពីការរស់ឡើងវិញរបស់ព្រះយេស៊ូវ បើគ្មានការសុគតរបស់ទ្រង់ទេ នោះសេចក្ដីវេទនានឹងកើតមានឡើងដោយមិនអាចនឹងពណ៌នាបានឡើយ ។ ប៉ុន្តែ ដោយសារទ្រង់រស់ឡើងវិញ នោះទ្រង់ប្រកាសដោយព្រះចេស្ដាថា "ទ្រង់ជាព្រះរាជបុត្រានៃព្រះ"ពិតប្រាកដ (រម ១:៤)។

**១៦:៧** *ព្រមទាំងពេត្រុស* ព្រះយេស៊ូវបានបង្ហាញការយកចិត្តទុកដាក់ជាពិសេសចំពោះលោកពេត្រុស ដោយសារតែលោកបានអួតពីជំនឿ តែក្រោយមកបែរជាបដិសេធទៅវិញ (១៤:២៩–៣១,៦៦–៧២)។ *ដូចជាទ្រង់បានប្រាប់* (១៤:២៨)។

៩រីឯកាលទ្រង់មានព្រះជន្មរស់ឡើងវិញ គឺនៅព្រឹកព្រ
លឹមថ្ងៃទី១ ក្នុងអាទិត្យនោះឯង នោះទ្រង់ក៏លេចមកមុន
ដំបូង ឱ្យម៉ារា ជាអ្នកស្រុកម៉ាក់ដាឡាឃើញ[ត] គឺជាស្ត្រីដែល
ទ្រង់បានបណ្តេញអារក្ស៧ឱ្យចេញនោះ ១០នាងក៏ទៅប្រាប់
ដល់ពួកអ្នកដែលបាននៅជាមួយនឹងទ្រង់ដែរ ដែលគេកំពុង
តែកាន់ទុក្ខ ហើយយំសោក ១១តែកាលគេបានឮថា ទ្រង់រស់
ហើយថានាងបានឃើញទ្រង់ នោះគេមិនជឿទេ[ថ] ១២ក្រោយ
នោះមក ទ្រង់សំដែងមកបែប១ទៀត ឱ្យពួកគេ២នាក់ឃើញ
ក្នុងកាលដែលគេកំពុងតែដើរទៅឯស្រុកស្រែ[ទ] ១៣អ្នកទាំង
២នោះក៏ទៅប្រាប់ដល់ពួកគេឯទៀត តែគេនៅតែមិនជឿ
ទៀត ១៤ក្រោយនោះមក ទ្រង់សំដែងមកឱ្យពួក១១នាក់បាន
ឃើញ ក្នុងកាលដែលកំពុងអង្គុយនៅតុ ហើយទ្រង់បន្ទោស
គេ ដោយព្រោះមានចិត្តរឹងរូស ហើយមិនជឿ ពីព្រោះគេ
មិនបានជឿដល់ពួកអ្នកដែលឃើញទ្រង់ ក្រោយដែលទ្រង់
រស់ឡើងវិញនោះទេ[ធ] ១៥ទ្រង់ផ្តាំគេថា ចូរអ្នករាល់គ្នាទៅ
ពេញសព្វក្នុងលោកីយទាំងមូល ហើយផ្សាយដំណឹងល្អទូ
ទៅដល់គ្រប់មនុស្សទាំងអស់ចុះ[ន] ១៦អ្នកណាដែលជឿ
ហើយទទួលបុណ្យ ជ្រមុជទឹក នោះនឹងបានសង្គ្រោះ តែអ្នក
ណាដែលមិនព្រមជឿ នោះនឹងត្រូវទោសវិញ[ប] ១៧ទីសំ
គាល់[ផ]ទាំងនេះនឹងជាប់តាមអស់អ្នកដែលជឿ គឺថា គេនឹង
ដេញអារក្សដោយនូវឈ្មោះខ្ញុំ[ព] ហើយនិងចេះនិយាយ
ភាសាថ្មី[ភ] ១៨នឹងចាប់កាន់ពស់បាន[ម] ឬបើគេផឹកអ្វីពុល នោះ
មិនធ្វើឱ្យអន្តរាយទេ ហើយគេនឹងដាក់ដៃលើមនុស្សជំងឺ
ឱ្យបានជាផង[យ] ។
១៩ដូច្នេះ ក្រោយដែលព្រះអម្ចាស់បានមានបន្ទូលនឹងគេ
រួចហើយ នោះព្រះវរបិតាបានទទួលទ្រង់ឡើងទៅស្ថាន
សួគ៌វិញ[រ] ឱ្យគង់នៅខាងស្តាំ[ល] ២០ឯពួកសិស្ស គេចេញទៅ
ប្រកាសប្រាប់នៅសព្វគ្រប់អន្លើ ដោយមានព្រះអម្ចាស់ធ្វើ
ការជាមួយ ទាំងបញ្ជាក់ព្រះបន្ទូល ដោយទីសំគាល់[វ]ដែល
កើតមកតាមក្រោយផង ។ អាម៉ែន ។

**១៦:៩** ត មក ១៥:៤៧ យហ ២០:១១–១៨ **១៦:១១** ថ ខ.១៣,១៤ លក ២៤:១១ **១៦:១២** ទ លក ២៤:១៣–៣២ **១៦:១៤** ធ លក ២៤:៣៦–៤៣ **១៦:១៥** ន មថ ២៨:១៨–២០ លក ២៤:៤៧,៤៨ កច ១:៨ **១៦:១៦** ប យហ ៣:១៦,១៨,៣៦ កច ១៦:៣១ **១៦:១៧** ផ យហ ៤:៤៨ ព មក ៩:៣៨ លក ១០:១៧ កច ៥:១៦ ៨:៧ ១៦:១៨ ១៩:១៣–១៦ ភ កច ២:៤ ១០:៤៦ ១៩:៦ ១កថ ១២:១០,២៨, ៣០ ១៣:១ ១៤:២–៣៩ **១៦:១៨** ម លក ១០:១៩ កច ២៨:៣–៥ យ កច ៦:៦ **១៦:១៩** រ លក ២៤:៥០,៥១ យហ ៦:៦២ កច ១:៩–១១ ១ធថ ៣:១៦ ល ទដ ១១០:១ មថ ២៦:៦៤ កច ២:៣៣ ៥:៣១ រម ៨:៣៤ កល ៣:១ ហព ១:៣ ១២:២ **១៦:២០** វ យហ ៤:៤៨

**១៦:៩–២០** មានចម្ងល់ជាច្រើនថា តើវគ្គត្រង់នេះ គឺជាផ្នែកបញ្ចប់នៃដំណឹងល្អម៉ាកុស ឬយ៉ាងណា ។ ដោយសារតែផ្នែកនេះ មិនដូចផ្នែកខាងដើមទេ ហើយពាក្យពេចន៍ របៀបសរសេរ និងផ្នែកទេវសាស្ត្រ ក៏ប្លែកពីផ្នែកផ្សេងៗនៃព្រះគម្ពីរម៉ាកុសនេះដែរ ។ ចុងបញ្ចប់នៃដំណឹងល្អរបស់គាត់ ប្រហែលជាចប់ត្រឹម ១៦:៨ ឬ បានបាត់ច្បាប់ដើម ។
**១៦:៩** *ម៉ារា ជាអ្នកស្រុកម៉ាក់ដាឡា* មើលការពន្យល់ ១៥:៤០ ។
**១៦:១១,១៣** *នោះគេមិនជឿ* មើល ខ.១៤,១៦ យហ ២០:២៤-២៩ និងការពន្យល់ ២០:២៥,២៩ ។
**១៦:១២–១៣** នេះជាការពិពណ៌នាខ្លីមួយ អំពីបុរសពីរនាក់ផ្សេងទៀតដែលកំពុងធ្វើដំណើរទៅឯភូមិអេម៉ោស (លក ២៤:១៣–៣៥) ។
**១៦:១៤** *១១នាក់* ដោយដកយូដាស-អ៊ីស្ការីយ៉ុតចេញ (បានសម្លាប់ខ្លួនបាត់ ហើយមើលការពន្យល់ មថ ២៧:៥) ។
**១៦:១៥–១៦** សូមមើលមហាបេសកកម្មក្នុងព្រះគម្ពីរ មថ ២៨:១៨–២០ និងការពន្យល់ មថ ២៨:១៩–២០ លក ២៤:៤៦–៤៩ យហ ២០:២១–២៣ កច ១:៨ ។
**១៦:១៦** *អ្នកណា. . .បុណ្យជ្រមុជទឹក* ការពន្យល់ មក ១:៤ រម ៦:៣–៤ ។
**១៦:១៨** *ចាប់កាន់ពស់បាន* សូមមើលសំដីរបស់លោកប៉ុល ដែលនិយាយក្នុងព្រះគម្ពីរ កច ២៨:១–៦ ។ *ផឹកអ្វីពុល* មិនមានឃើញនៅកន្លែងណាទៀតទេ ក្នុងព្រះគម្ពីរសញ្ញាថ្មី ដែលនិយាយពីការផឹកថ្នាំពុលដូច្នេះឡើយ ។
**១៦:១៩** *ទ្រង់ឡើងទៅស្ថានសួគ៌* សាក្សីដែលឃើញឡើងទៅស្ថានសួគ៌ មានពួកសាវ័ក (លក ២៤:៥១ កច ១:៩ ១ ធថ ៣:១៦ និងការពន្យល់) ។ *គង់នៅខាងស្តាំ* (មើល ១៤:៦២ ទដ ១១០:១ និងការពន្យល់) ។

# ដំណឹងល្អ

តាមលោកលូកា

សេចក្ដីផ្ដើម

## អ្នកនិពន្ធ

អ្នកនិពន្ធមិនបានបញ្ចេញឈ្មោះរបស់គាត់នៅក្នុងព្រះគម្ពីរនេះទេ ប៉ុន្តែ មានភស្តុតាងជាច្រើនបានបញ្ជាក់យ៉ាងច្បាស់ថា លោកលូកាគឺជា អ្នកនិពន្ធព្រះគម្ពីរដំណឹងល្អនេះ ។ ព្រះគម្ពីរលូកាស្ថិតនៅក្នុងខ្សែជាមួយនឹងព្រះគម្ពីរកិច្ចការ ហើយការប្រើប្រាស់ពាក្យពេចន៍ និងរចនាសម្ព័ន្ធរបស់កណ្ឌគម្ពីរទាំងពីរនេះនាំឱ្យគេដឹងថា អ្នកនិពន្ធរបស់ព្រះគម្ពីរទាំងពីរនេះគឺជាមនុស្សតែមួយ ។ លោកលូកាបានសរសេរព្រះគម្ពីរទាំងពីរផ្ញើជូន លោកថេវភីល ហើយតាមព្រះគម្ពីរកិច្ចការ ១:១ ព្រះគម្ពីរលូកាគឺជាស្នាដៃទីមួយ ហើយព្រះគម្ពីរកិច្ចការគឺជាស្នាដៃទីពីរ ។ ការប្រើសព្វនាម "យើង"នៅក្នុងវគ្គមួយចំនួនរបស់ព្រះគម្ពីរកិច្ចការ (កច ១៦:១០–១៧ ២០:៥–១៥ ២១:១–១៨ ២៧:១–២៨:១៦) គឺបានបង្ហាញថា អ្នកនិពន្ធមានវត្តមានជាមួយនឹងលោកសាវ័កប៉ុលនៅក្នុងព្រឹត្តិការណ៍ដែលមានរៀបរាប់ក្នុងវគ្គទាំងនេះផងដែរ។ អ្នកនិពន្ធគឺជាអ្នកដែលសក្តិសមបំផុតនឹងការដែលលោកប៉ុលបានហៅថា "លោកគ្រូពេទ្យស្ងួនភ្ងា" (កល ៤:១៤)និង"គូកនធ្វើការបម្រើ ព្រះ" (ភល ១.២៤)។ មានទីបន្ទាល់ដូចៗគ្នានៅក្នុងស្នាដៃនិពន្ធពួកជិនុំដំបូងជាច្រើនបានគាំទ្រភាពជាអ្នកនិពន្ធរបស់លោកលូកា ។

លោកលូកាប្រហែលជាមានដើមកំណើតជាសាសន៍ដទៃម្នាក់ ដែលមានការសិក្សាខ្ពស់ផ្នែកវប្បធម៌ក្រិក ជាគ្រូពេទ្យម្នាក់ ជាអ្នករួមដំណើរជាមួយលោកសាវ័កប៉ុលចាប់ពីបេសកកម្មលើកទី២ រហូតដល់ពេលដែលលោកប៉ុលជាប់គុកនៅក្រុងរ៉ូម ហើយនិងជាមិត្តភ័ក្រ្តដ៏ស្មោះត្រង់ម្នាក់ដែលមិនបានបោះបង់ចោលលោកសាវ័កប៉ុល នៅពេលដែលគេរត់ចោលសាវករូបនេះអស់(២ធថ៤:១១)។ គេគិតថាទីកន្លែងកំណើត របស់លោកលូកា ប្រហែល ជានៅទីក្រុងអាន់ទីយ៉ូក(ប្រទេសស៊ីរី) ឬទីក្រុងភីលីព ។

## អ្នកទទួល និងគោលបំណង

ដំណឹងល្អនេះគឺសម្រាប់ផ្ញើជូនជាពិសេសចំពោះព្រះតេជព្រះគុណថេវភីល(១:៣)។ ឈ្មោះ"ថេវភីល"នេះមានន័យថា"អ្នកដែលស្រឡាញ់ព្រះ" ហើយន័យរបស់ឈ្មោះនេះស្ទើរតែសំដៅទៅលើមនុស្សពិសេសតែម្នាក់ ច្រើនជាងមនុស្សទូទៅដែលស្រឡាញ់ព្រះ ។ ការប្រើពាក្យ "ព្រះតេជព្រះគុណ"នៅខាងមុខឈ្មោះនេះ ប្រហែលមកពីលោកលូកាចង់បង្ហាញថា លោកថេវភីលគឺជាមន្ត្រីរ៉ូម៉ាំងមួយរូប ឬយ៉ាងហោចណាស់ក៏ជាអ្នកមានឋានៈខ្ពស់ និងទ្រព្យសម្បត្តិស្តុកស្តម្ភម្នាក់ដែរ ។ លោកអាចជាអ្នកជួយដល់លោកលូកា ក្នុងការមើលការខុសត្រូវលើការចម្លង ហើយការចែកចាយស្នាដៃនេះ ដូចនេះការផ្តល់ការគោរពយ៉ាងដូចនេះចំពោះអ្នកទទួលចម្លងរូបនេះ គឺជារឿងធម្មតាទេនៅសម័យនោះ ។

ទោះបីជាយ៉ាងណាក៏ដោយ លោកថេវភីលមិនត្រឹមតែទទួលចម្លងប៉ុណ្ណោះទេ ពីព្រោះព្រះគម្ពីរដំណឹងល្អនេះគឺជាសេចក្ដីបង្រៀនសម្រាប់រូបលោកផ្ទាល់(១:៤) ក៏ដូចជាសម្រាប់អ្នកឯទៀតដែលទទួលព្រះគម្ពីរនេះបន្តពីលោកផងដែរ ។ ជាការពិតណាស់ដំណឹងល្អនេះគឺមិនមែនកំណត់ថា ត្រូវផ្ញើទៅដល់លោកថេវភីលតែម្នាក់ប៉ុណ្ណោះទេ ។ ដំណឹងល្អនេះត្រូវបានសរសេរឡើងដើម្បីពង្រឹងសេចក្ដីជំនឿរបស់អ្នកជឿទាំងអស់ និងសម្រាប់ឆ្លើយតបចំពោះការបដិសេធន៍ ឬប្រឆាំងរបស់អ្នកមិនជឿព្រះផងដែរ ហើយនិងសម្រាប់ទប់ស្កាត់ដំណឹងដែលមិនសមហេតុផល ហើយអាក្រក់អំពីព្រះយេស៊ូវគ្រីស្ទ(១:១–៤ និងការពន្យល់)។ លោកលូកាចង់បង្ហាញតាមរយៈព្រះគម្ពីររបស់លោកថា សេចក្ដីបង្រៀនរបស់ព្រះយេស៊ូវគឺជាមូលដ្ឋានគ្រឹះនៃកន្លែងរបស់គ្រីស្ទបរិស័ទជាសាសន៍ដទៃនៅក្នុងនគរព្រះ ។ គាត់ចង់ឱ្យដំណឹងល្អបានផ្សាយទៅដល់គ្រប់ទីកន្លែងទាំងអស់ក្នុងពិភពលោក ។

## កាលបរិច្ឆេទ និងទីកន្លែងនិពន្ធ

មានមតិពីរបានសន្និដ្ឋានអំពីកាលបរិច្ឆេទនៃការសរសេរព្រះគម្ពីរដំណឹងល្អលូកានេះ(១).នៅឆ្នាំ៥៩–៦៣ គ.ស និង(២).នៅទសវត្សរ៍ទី៧0 ឬ ៨0 នៃសតវត្សរ៍ទីមួយនៃគ.ស ។

ដំណឹងល្អនេះប្រហែលជាបានសរសេរនៅទីក្រុងរ៉ូម ទោះបីជាមានការសន្និដ្ឋានថានៅក្រុងអាខៃ ក្រុងអេភេសូរ ឬក្រុងសេសារាក៏ដោយ ។ ចំណែកទីកន្លែងទទួលវិញ ប្រាកដជាអាស្រ័យទៅលើទីកន្លែងដែលលោកថេវភីលរស់នៅនោះហើយ ។ បើតាមការដែលដំណឹងល្អនេះមានប្រើ ឈ្មោះទីកន្លែងជាច្រើនដែលមាននៅក្នុងទឹកដីបរិសុទ្ធ ដំណឹងល្អនេះហាក់ដូចជាផ្តោតខ្លាំងទៅលើអ្នកអានដែលមិនសូវស្គាល់ទឹកដីបរិសុទ្ធនេះ ហើយក្រុងអាន់ទីយ៉ូក ក្រុងអេភេសូរ ក្រុងអាខៃ សុទ្ធតែអាចជាទីកន្លែងទទួល ។

**រចនាបថ**

លោកលូកាប្រើភាសាក្រិកនៅក្នុងការនិពន្ធរបស់លោកបានយ៉ាងល្អប្រសើរ ។ ពាក្យពេចន៍ដែលលោកប្រើមានលក្ខណៈទូលំទូលាយ ហើយសំបូរបែប ។ នៅកន្លែងខ្លះ ការនិពន្ធរបស់លោកមានរចនាបថដូចរចនាបថក្រិកបុរាណ (ដូចមាននៅក្នុងបុព្វកថា ១:១-៤) ហើយក្រៅពីនោះគឺលោកច្រើនតាមរចនាបថយូដា (១:៥-២:៥២) គឺច្រើនតែមានលក្ខណៈដូចរចនាបថដែលគេប្រើនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបាន បកប្រែទៅជាភាសាក្រិកនៅមុនសម័យគ្រីស្ទបរិស័ទ ។

**ចរិតលក្ខណៈ**

ព្រះគម្ពីរដំណឹងល្អទីបីនេះនិយាយអំពីព្រះរាជកិច្ច និងសេចក្តីបង្រៀនរបស់ផងព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ដែលមានសារៈសំខាន់យ៉ាងវិសេស ចំពោះការយល់ដឹងអំពីផ្លូវនៃសេចក្តីសង្គ្រោះ ។ សាច់រឿងទាំងមូលដែលចាប់និយាយពីកំណើតរបស់ព្រះគ្រីស្ទ រហូតដល់ការយាងទៅស្ថានសួគ៌វិញមានលក្ខណៈពេញលេញ មានរៀបចំតាមលំដាប់លំដោយយ៉ាងត្រឹមត្រូវ បង្កលក្ខណៈងាយស្រួលដល់ទាំងសាសន៍យូដា និងសាសន៍ដទៃ ។ ចរិតលក្ខណៈនៃស្នាដៃសរសេររបស់លោកមាន ភាពល្អឥតខ្ចោះខាងផ្នែកអក្សរសាស្ត្រ សេចក្តីលំអិតខាងប្រវត្តិសាស្ត្រ និងការយល់ដឹងយ៉ាងត្រឹមត្រូវ និងទូលំទូលាយអំពីតួអង្គព្រះយេស៊ូវ និងអ្នកនៅក្បែរទ្រង់ ។

ព្រះគម្ពីរដំណឹងល្អទាំងបីកណ្ឌដំបូង (ម៉ាថាយ ម៉ាកុស និងលូកា) បាននិយាយស្រដៀងៗគ្នាពីហេតុការណ៍បន្ទាប់បន្សំជាច្រើនស្តីពីព្រះជន្មគង់នៅរបស់ព្រះយេស៊ូវ ដូចនេះអ្នកនិពន្ធនីមួយៗមានការរំពឹងចង់បានលក្ខណៈដែលដូចគ្នានោះខ្លាំងណាស់ ។ លក្ខណៈដែលមិនស្រដៀងគ្នារបស់ព្រះគម្ពីរទាំងបី គឺសង្កត់ធ្ងន់ទៅលើលក្ខណៈពិសេសរបស់អ្នកនិពន្ធទាំងបីរូបដែលមិនមែនជាមនុស្សតែមួយ ។ គោលលក្ខណៈនៃការនិពន្ធព្រះគម្ពីរលូកាគឺ (១).មានលក្ខណសកលដែលទទួលស្គាល់ថា ព្រះទ្រង់មានផែនការសម្រាប់សាសន៍ដទៃ ក៏ដូចជាសាសន៍យូដា (២:៣០-៣២ និងការពន្យល់ ២:៣១ ៣:៦)។ (២).សង្កត់ធ្ងន់លើសេចក្តីអធិស្ឋាន ជាពិសេសគឺសេចក្តីអធិស្ឋានរបស់ព្រះយេស៊ូវ មុនពេលទ្រង់ចាប់ផ្តើមឱកាសសំខាន់ៗ (ការពន្យល់ ៣:២១)។ (៣).សេចក្តីអំណរក្នុងពេលប្រកាសដំណឹងល្អ (ការពន្យល់ ១:១៤)។ (៤).មានការគិតគូជាពិសេសពីតួនាទីរបស់ស្ត្រី (ការពន្យល់ ៨:១-៣)។ (៥).ចំណាប់អារម្មណ៍ជាពិសេសលើមនុស្សក្រីក្រ (មានពួកអ្នកមានមួយចំនួនបានដើរតាមព្រះយេស៊ូវផងដែរ ប៉ុន្តែលោកលូកា និយាយផ្តោតទៅលើពួកអ្នកក្រច្រើនជាង, មើលការពន្យល់ ១២:៣៣)។ (៦).ការយកចិត្តទុកដាក់លើមនុស្សមានបាប (ព្រះយេស៊ូវទ្រង់ជា មិត្តសំឡាញ់នឹងពួកអ្នកមានបាប)។ (៧).សង្កត់ធ្ងន់លើមនុស្សក្នុងក្រុមគ្រួសារតាំងពីក្មេងតូចៗ ដល់មនុស្សចាស់ (មានបុរស ស្ត្រី ក្មេងតូចៗ ដែលជាញឹកញាប់គឺនៅតាមផ្ទះរបស់ពួកគេតែម្តង)។ (៨).មានការលើកជាច្រើនលើកច្រើនសារពីព្រះងាររបស់ព្រះមែស៊ីថាជា "កូនមនុស្ស" (មានប្រើ រហូតដល់២៥ដង ១៩:១០ ដយ ៧:១៣ និងការពន្យល់)។ (៩).មាននិយាយសង្កត់ធ្ងន់អំពីព្រះវិញ្ញាណបរិសុទ្ធ (ការពន្យល់ ៤:១)។ (១០).សរសេរពីរឿងប្រៀបប្រដូចច្រើនជាងដំណឹងល្អដទៃទៀត ។ (១១). សង្កត់ធ្ងន់លើការសរសើរតម្កើងព្រះអម្ចាស់ (១:៦៤ ២៤:៥៣ និងការពន្យល់)។

**ប្រភព**

ទោះបីជាលោកលូកាបានទទួលស្គាល់ថា មានមនុស្សជាច្រើនបានសរសេរអំពីជីវប្រវត្តិរបស់ព្រះយេស៊ូវ (១:១) មុនលោកក៏ដោយ ក៏ការសរសេររបស់លោកមិនបង្ហាញថា លោកបានពឹងផ្អែកទាំងស្រុងទៅលើស្នាដៃទាំងអស់នោះ ក្នុងការនិពន្ធរបស់លោកឡើយ គឺលោកបានធ្វើការស្វែងរក និងរៀបចំដោយខ្លួនលោកផ្ទាល់ ដោយពឹងផ្អែកលើទីបន្ទាល់របស់ "សាក្សីដែលបានឃើញជាក់នឹងភ្នែក និងអ្នកបម្រើផ្សាយព្រះបន្ទូល" (១:២) ដែលរួមមានការអធិប្បាយ និងការនិយាយប្រាប់ផ្ទាល់មាត់របស់ពួកសាវ័កផងដែរ ។ លោកប្រើវិធីសាស្ត្រនិពន្ធផ្សេងពីដំណឹងល្អទាំងពីរកណ្ឌដំបូង ហើយលក្ខណៈពិសេសនៃការសរសេររបស់លោក (១០:១-១៨:១៤ ១៩:១-២៨) បានបង្ហាញពីភាពឯករាជ្យនៃការងាររបស់លោក ទោះបីជាលោកបានប្រើប្រភពមួយចំនួន ដូចប្រភពដែលអ្នកនិពន្ធដំណឹងល្អទាំងពីរកណ្ឌដំបូងប្រើក៏ដោយ ។

**ផែនការ**

ការនិពន្ធរបស់លោកលូកាស្តីពីព្រះរាជកិច្ចរបស់ព្រះយេស៊ូវ ចែកចេញជាបីវគ្គសំខាន់ៗគឺ (១).ព្រឹត្តិការណ៍ដែលកើតមាននៅក្នុងស្រុកកាលីឡេ និងតំបន់ជិតខាង (៤:១៤-៩:៥០)។ (២).ព្រឹត្តិការណ៍នៅស្រុកយូដា និងស្រុកពេរ៉េ (៩:៥១-១៩:២៧)។ (៣).ព្រឹត្តិការណ៍ដែលកើតឡើងក្នុងសប្តាហ៍ចុងក្រោយនៅក្រុងយេរូសាឡិម (១៩:២៨-២៤:៥៣)។ ដំណឹងល្អលូកាបានបង្ហាញឱ្យឃើញជាពិសេសពីលក្ខណៈនៃការសរសេរ នៅត្រង់ថាបានកត់ត្រាជាសរុប អំពីសេចក្តីដែលនិយាយផ្តោតអំពីការបញ្ចប់ព្រះរាជកិច្ចរបស់ព្រះយេស៊ូវនៅស្រុកយូដា និងស្រុកពេរ៉េ ។ សេចក្តីទាំងនោះគឺជាសេចក្តីកំណត់ត្រាយ៉ាងច្រើនបរិបូណ៌អំពីសេចក្តីបង្រៀនរបស់ព្រះយេស៊ូវ ។ នៅក្នុង

១០:៣០–១៩:២៧ ឃើញមានរឿងប្រៀប ប្រដូចរ ហូតដល់ទៅចំនួន២១ ក្នុងចំណោមរឿងប្រៀបប្រដូចទាំងអស់២៨របស់ព្រះគម្ពីរលូកា ។ គ្រាន់តែនៅក្នុង ៩:៥១–១៩:២៧ មានការអស្ចារ្យ រហូតដល់៥ ក្នុងចំណោមការអស្ចារ្យចំនួន២០ដែលបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរលូកាទាំងមូល ។ ទើបតែបាន៩ជំពូកប៉ុណ្ណោះ(មើលការពន្យល់ ៩:៥១) លោកលូកាបានប្រាប់អ្នកអានឱ្យដឹងអំពីការ ផ្ដោតព្រះទ័យរបស់ព្រះយេស៊ូវ ទៅលើការបង្ហាញអង្គទ្រង់ជាលើកចុងក្រោយនៅឯក្រុងយេរូសាឡិម និងការជាប់ឆ្កាងរបស់ទ្រង់(មើលការពន្យល់ ១៣:២២)។

គោលរឿងរបស់ព្រះគម្ពីរដំណឹងល្អលូកាគឺនិយាយសង្កត់ធ្ងន់អំពីលក្ខណៈនៃភាពជាព្រះមែស៊ីរបស់ព្រះយេស៊ូវ និងព្រះរាជកិច្ចទ្រង់ ហើយខគន្លឹះនៃព្រះគម្ពីរនេះគឺ ១៩:១០ ។

**គម្រោងសង្ខេប**

**I. បុព្វកថា ១:១–៤)**

**II. កំណើតរបស់លោកយ៉ូហាន–បាទីស្ទ និងកំណើតរបស់ព្រះយេស៊ូវ (១:៥–២:២៥)**

ក. សេចក្ដីប្រកាសដំណឹង (១:៥–៥៦)

ខ. កំណើតរបស់លោកយ៉ូហាន–បាទីស្ទ (១:៥៧–៨០)

គ. កំណើត និងវ័យកុមាររបស់ព្រះយេស៊ូវ (ជំពូក ២)

**III. ព្រះយេស៊ូវរៀបចំអង្គទ្រង់ដើម្បីបំពេញព្រះរាជកិច្ចជាសាធារណៈ (៣:១–៤:១៣)**

ក. ការរៀបចំផ្លូវថ្វាយព្រះយេស៊ូវ (៣:១–២០)

ខ. ទ្រង់ទទួលបុណ្យជ្រមុជទឹក (៣:២១–២២)

គ. ពង្សាវតាររបស់ព្រះយេស៊ូវ (៣:២៣–៣៨)

ឃ. ព្រះយេស៊ូវជួបនឹងសេចក្ដីល្បួង (៤:១–១៣)

**IV. ព្រះរាជកិច្ចរបស់ព្រះយេស៊ូវនៅស្រុកកាលីឡេ (៤:១៤–៩:៩)**

ក. លើកដំបូងនៃព្រះរាជកិច្ចរបស់ទ្រង់នៅស្រុកកាលីឡេ (៤:១៤–៤១)

ខ. ការធ្វើដំណើរលើកទីមួយនៅស្រុកកាលីឡេ (៤:៤២–៥:៣៩)

គ. បញ្ហាថ្ងៃឈប់សម្រាក(៦:១–១១)

ឃ. ការជ្រើសរើសសិស្សទាំង១២នាក់ (៦:១២–១៦)

ង. សេចក្ដីអធិប្បាយនៅវាលរាប (៦:១៧–៤៩)

ច. ការអស្ចារ្យនៅស្រុកកាពើណិម និងស្រុកណាអ៊ីន (៧:១–១៨)

ឆ. ការស៊ើបសួររបស់លោកយ៉ូហាន–បាទីស្ទ (៧:១៩–២៩)

ជ. ព្រះយេស៊ូវ និងពួកផារិស៊ី (៧:៣០–៥០)

ឈ. ការធ្វើដំណើរលើកទីពីរនៅស្រុកកាលីឡេ (៨:១–៣)

ញ. រឿងប្រៀបប្រដូចអំពីនរគព្រះ (៨:៤–២១)

ដ. ការធ្វើដំណើរឆ្លងកាត់សមុទ្រកាលីឡេ (៨:២២–៣៩)

ឋ. ការធ្វើដំណើរលើកទីបីនៅស្រុកកាលីឡេ (៨:៤០–៩:៩)

**V. ការយាងចេញពីតំបន់ជិតខាងសមុទ្រកាលីឡេ (៩:១០–៥០)**

ក. យាងទៅច្រាំងសមុទ្រកាលីឡេភាគខាងកើត (៩:១០–១៧)

ខ. យាងទៅស្រុកសេសារា–ភីលីព (៩:១៨–៥០)

**VI. ព្រះរាជកិច្ចរបស់ព្រះយេស៊ូវនៅស្រុកយូដា (៩:៥១–១៣:២១)**

ក. ដំណើរយាងកាត់ស្រុកសាម៉ារីទៅសមុទ្រកាលីឡេ (៩:៥១–៦២)

ខ. បេសកកម្មរបស់អ្នកទាំង៧២នាក់ (១០:១–២៤)

គ. អ្នកប្រាជ្ញច្បាប់ម្នាក់ ហើយនិងរឿងប្រៀបប្រដូចអំពីសាសន៍សាម៉ារីល្អម្នាក់ (១០:២៥–៣៧)
ឃ. ព្រះយេស៊ូវ ទ្រង់គង់ជាមួយនឹងនាងម៉ារី និងម៉ាថា (១០:៣៨–៤២)
ង. សេចក្តីបង្រៀនរបស់ទ្រង់នៅស្រុកយូដា (១១:១–១៣:២១)

**VII. ព្រះរាជកិច្ចរបស់ព្រះយេស៊ូវនៅស្រុកពេរ៉េ និងនៅតំបន់ជិតខាង (១៣:២២–១៩:២៧)**

ក. ទ្វារចង្អៀត (១៣:២២–៣០)
ខ. ការព្រមានដែលទាក់ទង ទៅនឹងស្តេចហេរ៉ូឌ (១៣:៣១–៣៥)
គ. ការលះបង់ដើម្បីធ្វើជាសិស្សរបស់ព្រះគ្រីស្ទ(១៤:២៤–៣៥)
ឃ. រឿងប្រៀបប្រដូចអំពីចៀមដែលបាត់ ប្រាក់ដែលបាត់ និងកូនពៅវង្វេង (ជំពូក ១៥)
ង. រឿងប្រៀបប្រដូចអំពីអ្នកត្រួតត្រាមានគំនិតល្បិត (១៦:១–១៨)
ច. អ្នកមាន និងឡាសារ (១៦:១៩–៣១)
ឆ. សេចក្តីបង្រៀនផ្សេងៗ (១៧:១–១០)
ជ. មនុស្សឃ្លង់១០នាក់ត្រូវបានប្រោសឱ្យជា (១៧:១១–១៩)
ឈ. ការយាងមកនៃនរគព្រះ (១៧:២០–៣៧)
ញ. សេចក្តីព្យាយាមរបស់ស្ត្រីម៉េម៉ាយម្នាក់ (១៨:១–៨)
ដ. ពួកផារីស៊ី និងពួកអ្នកយកពន្ធ (១៨:៩–១៤)
ឋ. ព្រះយេស៊ូវ និងក្មេងតូចៗ (១៨:១៥–១៧)
ឌ. នាម៉ឺនវ័យក្មេងម្នាក់ (១៨:១៨–៣០)
ឈ. ព្រះគ្រីស្ទថ្លែងទំនាយពីការសុគតរបស់ទ្រង់ (១៨:៣១–៣៤)
ណ. មនុស្សខ្វាក់ទូលសូមការប្រោសលោះ (១៨:៣៥–៤៣)
ត. ព្រះយេស៊ូវ និងសាខេ (១៩:១–១០)
ថ. រឿងប្រៀបប្រដូចអំពីបាវ១០នាក់ ១៩:១១–២៧)

**VIII. ថ្ងៃចុងក្រោយរបស់ទ្រង់: សុគត និងជ័យជម្នះ (១៩:២៨–២៤:៥៣)**

ក. ក្បួនដង្ហែរនៃជ័យជម្នះ (១៩:២៨–៤៤)
ខ. ការសំអាតព្រះវិហារ (១៩:៤៥–៤៨)
គ. ទំនាស់ចុងក្រោយជាមួយនឹងពួកអ្នកដឹកនាំសាសន៍យូដា (ជំពូក ២០)
ឃ. សេចក្តីបង្រៀននៅលើភ្នំដើមអូលីវ (ជំពូក ២១)
ង. ពិធីលៀងព្រះអម្ចាស់ (២២:១–៣៨)
ច. ព្រះយេស៊ូវអធិស្ឋាននៅក្នុងច្បារគែតសេម៉ានី (២២:៣៩–៤៦)
ឆ. ការចាប់អង្គព្រះយេស៊ូវ (២២:៤៧–៦៥)
ជ. ព្រះយេស៊ូវនៅទីកាត់ក្តី (២២:៦៦–២៣:២៥)
ឈ. ការសុគតរបស់ព្រះយេស៊ូវ (២៣:២៦–៥៦)
ញ. ការរស់ឡើងវិញរបស់ព្រះយេស៊ូវ (២៤:១–១២)
ដ. ព្រះរាជកិច្ចក្រោយពីការមានព្រះជន្មរស់ឡើងវិញ (២៤:១៣–៤៩)
ឋ. ការយាងឡើងទៅស្ថានសួគ៌របស់ព្រះយេស៊ូវ (២៤:៥០–៥៣)

## បុព្វកថា

*១:១–៤ = កច ១:១*

**១** ១មានមនុស្សជាច្រើន បានផ្ដើមតែងរឿង ពីអស់ទាំងការ
ដែលពួកយើងខ្ញុំបានជឿជាក់ ២ដូចជាគេបានប្រាប់មកយើងខ្ញុំ
ដែលគេបានឃើញការទាំងនោះជាក់នឹងភ្នែក[ក]តាំងពីដើម
រៀងមក[ខ] ហើយក៏ធ្វើជាអ្នកបំរើផ្សាយព្រះបន្ទូល[គ] ៣ហេតុនោះ
បានជាខ្ញុំគិតថា គួរគប្បីឱ្យខ្ញុំសរសេរផ្ញើមកជូនលោកដោយ
លំដាប់ដែរ ឱព្រះតេជព្រះគុណ[ឃ]ថេវភីល[ង]អើយ ដ្បិតខ្ញុំបាន
ពិនិត្យពីរឿងទាំងនោះ តាំងតែពីដើមរៀងមក ដោយហ្មត់ចត់
ហើយ[ច] ៤ដើម្បីឱ្យលោកបានជ្រាបពីសេចក្ដីពិតនៃអស់ទាំង
សេចក្ដី ដែលគេបានបង្រៀនលោក[ឆ] ។

## ទំនាយពីកំណើតរបស់លោកយ៉ូហាន–បាទីស្ទ

៥កាលនៅរាជ្យហេរ៉ូឌ ជាស្តេចស្រុកយូដា[ជ] នោះមាន សង្ឃ១
ក្នុងពួកលោកអ័ប៊ីយ៉ា[ឈ] នាមសាការី ប្រពន្ធឈ្មោះ អេលីសាបិត
ជាពូជលោកអើរ៉ុន ៦អ្នកទាំង២នោះជាមនុស្សសុចរិតនៅ
ចំពោះព្រះ បានកាន់តាមក្រិត្យក្រម និងច្បាប់នៃព្រះអម្ចាស់
ទាំងប៉ុន្មាន ឥតកន្លែងបន្ទោសបានទេ[ញ] ៧លោកគ្មានកូនសោះ
ដ្បិតអេលីសាបិតជាស្ត្រីអារ ហើយទាំងប្ដីប្រពន្ធក៏ចាស់
ណាស់ផង។
៨រីឯតាមទំលាប់ការងារពួកសង្ឃ ដែលគេចាប់ឆ្នោត[ដ]នោះ
ត្រូវវេន ឱ្យលោកចូលទៅដុតគ្រឿងក្រអូប នៅក្នុងព្រះវិហារ
នៃព្រះអម្ចាស់[ឋ] ៩កាលកំពុងតែធ្វើការងារនៃពួកសង្ឃនៅ
ចំពោះព្រះ តាមវេនលោក[ឌ] ១០ហើយបណ្ដាមនុស្សដែល
នៅខាងក្រៅកំពុងតែអធិស្ឋាន នៅវេលាដុតគ្រឿងក្រអូប[ឍ]
១១នោះមានទេវតា[ណ]នៃព្រះអម្ចាស់លេចមក ឈរខាងស្តាំ
នៃអាសនាគ្រឿងក្រអូបឱ្យលោកឃើញ[ត] ១២កាលសាការី
ឃើញទេវតាហើយ លោកក៏ភាន់ភាំង ហើយកើតមានសេចក្ដី
ភ័យខ្លាច[ថ] ១៣ប៉ុន្តែទេវតានិយាយថា កុំខ្លាចអី[ទ] សាការីអើយ

**១:២** ក ហព ២:៣ ១ពត ៥:១ ២ពត ១:១៦ ខ មក ១:១ យហ ១៥:២៧ កច ១:២១,២២ ១យហ ១:១ គ មក ៤:១៤ **១:៣** ឃ កច ២៤:៣ ២៦:២៥ ង កច ១:១ ច កច ១១:៤ **១:៤** ឆ យហ ២០:៣១ កច ២:៤២ **១:៥** ជ មថ ២:១ ឈ ១រប ២៤:១០ **១:៦** ញ លប ៦:៩ ចទ ៥:៣៣ ១ពវ ៩:៤ លក ២:២៥ **១:៨** ដ កច ១:២៦ ឋ នក ៣០:៧,៨ ១រប ២៣:១៣ ២រប ២៩:១១ ទដ ១៤១:២ **១:៩** ឌ ១រប ២៤:១៩ ២រប ២:១៤ **១:១០** ឍ លវ ១៦:១៧ **១:១១** ណ កច ៥:១៩ ត នក ៣០:១–១០ **១:១២** ថ ពច ៦:២២,២៣ ១៣:២២ **១:១៣** ទ ខ.៣០ មថ ១៤:២៧

**១:១–៤** ការនិពន្ធរបស់លោកលូកាមានលក្ខណៈដូចគ្នានឹងស្នាដៃនិពន្ធរបស់អ្នកអក្សរសាស្ត្រក្រិកបុរាណ គឺលោកបានចាប់ផ្ដើមបុព្វកថារបស់លោកយ៉ាងមានរបៀបរៀបរយ ដូចស្នាដៃនិពន្ធអំពីប្រវត្តិសាស្ត្រដទៃៗទៀត ដែលស្ថិតក្នុងសម័យកាលជាមួយគ្នាផងដែរ ។ លោកបានបង្ហាញពីគោលបំណងនៃការនិពន្ធព្រះគម្ពីរនេះ និងបានប្រាប់ឈ្មោះអ្នកទទួល ។ លោកបានទទួលស្គាល់ការកត់ត្រារបស់អ្នកដទៃ ដែលមានប្រធានបទដូចការនិពន្ធរបស់លោក និងបានបង្ហាញពីតម្រូវការនៃការនិពន្ធថ្មីមួយនេះ ហើយបានប្រាប់ពីដំណោះស្រាយ និងប្រភពព័ត៌មានផងដែរ ។

**១:១** *ពីអស់ទាំងការដែលពួកយើងខ្ញុំបានជឿជាក់* ជាបទទំនាយដែលមាននៅក្នុងព្រះគម្ពីរសញ្ញាចាស់ ហើយឥឡូវនេះត្រូវបានសម្រេចទាំងស្រុង ។

**១:២** *ដូច...ប្រាប់មកយើងខ្ញុំ* គឺជាទំនៀមទម្លាប់ដ៏ល្អប្រពៃនៃការផ្ទេរដំណឹងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត(ការពន្យល់ ១កថ ១៥:៣)។ *គេបានឃើញការទាំងនោះជាក់នឹងភ្នែក . . . ជាអ្នកបំរើផ្សាយព្រះបន្ទូល* លោកលូកាមិនមែនជាស្មរបន្ទាល់ដែលបានឃើញផ្ទាល់ភ្នែកទេ ប៉ុន្តែលោកបានទទួលទីបន្ទាល់ ពីពួកអ្នកដែលបានឃើញផ្ទាល់ភ្នែក និងជាបាវបម្រើនៃដំណឹងល្អ ។ លោកបានទទួលសេចក្ដីបង្រៀនពីពួកសាវ័ក និងធ្វើបទសម្ភាសជាមួយបុគ្គលដែលជាប់ទាក់ទងនឹងព្រះរាជកិច្ចរបស់ព្រះយេស៊ូវ ។

**១:៣** *ខ្ញុំបានពិនិត្យ . . . ដោយហ្មត់ចត់* ស្នាដៃនិពន្ធនេះមានលក្ខណៈត្រឹមត្រូវហើយច្បាស់លាស់ជាការបកស្រាយលំអិតផ្នែកប្រវត្តិសាស្ត្រ ដែលមានការត្រួតពិនិត្យលើគ្រប់ចំណុចទាំងអស់ ។ លោកលូកាបានទទួលការបើកសំដែងដោយព្រះវិញ្ញាណបរិសុទ្ធ គឺមិនបានប្រើសមត្ថភាពរបស់លោកជាមនុស្សឡើយ ។ លោកបានសរសេរពីជីវប្រវត្តិរបស់ព្រះយេស៊ូវទាំងស្រុង ។ *ព្រះតេជគុណ* លោកប៉ុលក៏បានប្រើពាក្យគោរពនេះជាមួយលោកភេលីច(កច ២៤:៣) និងលោកភេស្ទុស (កច ២៦:២៥)។ *ថេវភីល* មើលសេចក្ដីផ្ដើមត្រង់អ្នកទទួល និងគោលបំណង ។

**១:៤** *ដើម្បីឱ្យលោកបានជ្រាបពីសេចក្ដីពិតសូមប្រៀបធៀបជាមួយនឹង* គោល–បំណងនៃការនិពន្ធរបស់លោកយ៉ូហាន (យហ ២០:៣១ និង ការពន្យល់)។

**១:៥** *ហេរ៉ូឌជាស្តេចស្រុកយូដា* ហេរ៉ូឌ-អធិរាជបានសោយរាជ្យពីឆ្នាំ៣៧–៤មុន គ.ស អាណាចក្ររបស់ស្តេចនេះរួមមាន ស្រុកសាម៉ារី ស្រុកកាលីឡេ ស្រុកពេរ៉េ និងស្រុកត្រាខូនីត(ការពន្យល់ មថ ២:១)។ ខនេះប្រហែលនិយាយសំដៅទៅលើរឿងដែលកើតឡើងនៅឆ្នាំ៧–៦មុន ស.គ ។ *សាការី . . . អេលីសាបិត* លោកទាំងពីរសុទ្ធតែជាពូជរបស់សង្ឃអើរ៉ុន ។ *សង្ឃ១ក្នុងពួកអ័ប៊ីយ៉ា* ចាប់ពីជំនាន់ស្តេចដាវីឌមក ពួកសង្ឃបានចែកជា២៤ក្រុម ហើយលោកអ័ប៊ីយ៉ាជា"មេលើគ្រួសារសង្ឃទាំងឡាយ"(នហ ១២:១២,១៧ និង ការពន្យល់ ១រប ២៤:១០)។

**១:៦** *កាន់តាម . . . ឥតកន្លែងបន្ទោសបាន* មិនមានន័យថាគ្មានបាបនោះទេ ប៉ុន្តែបានកាន់តាមក្រឹត្យវិន័យរបស់ព្រះយ៉ាងស្មោះអស់ពីចិត្ត ។ លោកស៊ីម្មាន (២:២៥) និងលោកយ៉ូសែប(មថ ១:១៩) បានទទួលការសរសើរដូចនេះផងដែរ ។

**១:៧** *លោកគ្មានកូនសោះ* មើលការពន្យល់ ខ.២៥ ។

**១:៩** ការដុតគ្រឿងក្រអូបលើអាសនានៅខាងមុខកន្លែងបរិសុទ្ធបំផុត គឺជាកាតព្វកិច្ចមួយក្នុងចំណោមកាតព្វកិច្ចជាច្រើនរបស់ពួកសង្ឃ គឺត្រូវដុតគ្រឿងក្រអូបស្រស់ មុនពេលថ្វាយដង្វាយពេលព្រឹក ហើយដុតម្តងទៀតក្រោយពេលថ្វាយដង្វាយពេលល្ងាច(នក ៣០:៦–៨)។ តាមធម្មតាពួកសង្ឃម្នាក់ៗកម្រមានអភ័យឯកសិទ្ធិនេះណាស់ ហើយជួនកាលមិនដែលបានអភ័យឯកសិទ្ធនេះសោះ ព្រោះត្រូវចាប់ឆ្នោត ។ *តាមវេន* មើលការពន្យល់ នហ ១១:១ ទដ ១៦:៣៣ យហ ១:៧ កច ១:២៦ ។

**១:១១** *មានទេវតានៃព្រះអម្ចាស់* (ខ.៩ និងមើលការពន្យល់ លប ១៦:៧)។

**១:១២** *សេចក្ដីភ័យខ្លាយ* ជាការឆ្លើយតបជាធម្មតារបស់មនុស្សយើង គឺដូចលោកគេឌាន(ពច ៦:២២–២៣) និងលោកម៉ាណូអា (ពច ១៣:២២)។

**១:១៣** *កុំខ្លាចអី* គឺជាពាក្យធានាដើម្បីបញ្ឈប់ការភ័យខ្លាច ហើយមានប្រើជាច្រើនដងទាំងក្នុងព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី(ខ.៣០ និងការពន្យល់

ព្រោះពាក្យដែលលោកទូលអង្វរ នោះបានទទួលហើយឯង
អេលីសាបិត ប្រពន្ធលោក នឹងបង្កើតកូនប្រុស១ឱ្យលោក
ត្រូវឱ្យវាមានឈ្មោះថា «យ៉ូហាន»[ធ] ១៤លោកនឹងមាន
សេចក្តីរីករាយ និងសេចក្តីអំណរ ហើយមនុស្សជាច្រើន
នឹងអរសាទរ ក្នុងកាលដែលវាកើតមកនោះ[ន] ១៥ដ្បិតវានឹង
បានជាធំនៅចំពោះព្រះអម្ចាស់ វានឹងមិនផឹក[ប]ស្រាទំពាំង
បាយជូរ ឬគ្រឿងស្រវឹងទេ វានឹងបានពេញជាព្រះវិញ្ញាណ
បរិសុទ្ធ[ផ] តាំងតែពីផ្ទៃម្តាយមក[ព] ១៦វានឹងបង្វិលកូនចៅ
សាសន៍អ៊ីស្រាអែលជាច្រើន ឱ្យត្រឡប់វិលមកឯព្រះអម្ចាស់
ជាព្រះនៃគេវិញ ១៧វានឹងនាំមុខទ្រង់[ភ] ដោយនូវវិញ្ញាណ
ហើយនិងអំណាចរបស់លោកអេលីយ៉ា[ម] ដើម្បីនឹងបំបែរ
ចិត្តពួកឪពុកមកឯកូន[យ] នឹងពួកចចេសមកឯប្រាជ្ញារបស់
មនុស្សសុចរិតវិញ ប្រយោជន៍នឹងរៀបចំមនុស្ស១ពួកទុក
ជាស្រេច សំរាប់ជារាស្ត្ររបស់ព្រះអម្ចាស់[រ] ១៨សាការី
សួរទេវតាថា តើខ្ញុំនឹងដឹងសេចក្តីនោះបានដោយសារអ្វី[ល]
ដ្បិតខ្ញុំសោតក៏ចាស់ហើយ ប្រពន្ធខ្ញុំក៏ចាស់ណាស់ដែរ[វ]

ធ ខ៦០,៦៣ មថ ៣:១
**១:១៤** ន ខ.៥៨
**១:១៥** ប ជន ៦:៣
លវ ១០:៩ ពច ១៣:៤
លក ៧:៣៣ ផ ខ.៤១,
៦៧ កច ២:៤ ៤:៨,៣១
៦:៣,៥ ៩:១៧
១១:២៤ អភ ៥:១៨
កច ១០:៤៤
ព យរ ១:៥ កទ ១:១៥
**១:១៧** ភ ខ.៧៦
ម មថ ១១:១៤
យ មឡ ៤:៥,៦
រ មថ ៣:៣
**១:១៨** ល លប ១៥:៨
វ ខ.៣៤ លប ១៧:១៧
**១:១៩** ស ខ.២៦
ដយ ៨:១៦ ៩:២១
**១:២០** ហ នក ៤:១១
អគ ៣:២៦
**១:២២** ឡ ខ.៦២

១៩ទេវតាឆ្លើយតបនឹងលោកថា ខ្ញុំនេះ ឈ្មោះកាព្រីយ៉ែល[ស]
ដែលឈរនៅចំពោះព្រះ ទ្រង់បានចាត់ខ្ញុំឱ្យមកនិយាយនឹង
លោក ហើយប្រកាសប្រាប់ដំណឹងល្អនេះ ២០មើលលោក
នឹងត្រូវគ និយាយមិនបាន[ហ] ដរាបដល់ថ្ងៃដែលការទាំងនេះ
កើតមក ពីព្រោះលោកមិនបានជឿពាក្យខ្ញុំ ដែលនឹងសំរេច
នៅវេលាកំណត់នោះទេ។
២១ឯបណ្តាមនុស្សគេនៅចាំសាការី ក៏នឹកប្លែកពីលោក
ដែលនៅក្នុងព្រះវិហារជាយូរម្ល៉េះ ២២កាលលោកចេញមក
លោកនិយាយនឹងគេមិនបានទេ គេក៏យល់ឃើញថា លោក
បានឃើញការជាក់ស្តែងណាមួយ នៅក្នុងព្រះវិហារជាមិន
ខាន ដោយលោកធ្វើគ្រឿងសំគាល់ឱ្យដឹង[ឡ] ហើយក៏នៅ
តែគ ២៣កាលវេលាដែលការងារលោកបានសំរេចហើយ
នោះលោកក៏ត្រឡប់ទៅផ្ទះវិញ ២៤គ្រាក្រោយនោះ អេលី
សាបិត ជាប្រពន្ធលោក នាងមានផ្ទៃពោះ រួចក៏លាក់
ខ្លួននៅ៥ខែ ដោយថា ២៥ព្រះអម្ចាស់ទ្រង់បានប្រោសខ្ញុំ
យ៉ាងដូច្នេះ ក្នុងគ្រាដែលទ្រង់ទតមកខ្ញុំដើម្បីនឹងដោះសេចក្តី

---

២:១០ ៥:១០ ៨:៥០ ១២:៧,៣២ លប ១៥:១ ២១:១៧ ២៦:២៤ និងការពន្យល់ ចទ ១:២១ យស ១:៩ ៨:១)។ *យ៉ូហាន* ឈ្មោះនេះ (មានប្រភពដើមពីភាសាហេព្រើរ) មានន័យថា "ព្រះអម្ចាស់ប្រកបដោយព្រះគុណ" ឬ "ព្រះអម្ចាស់ប្រទានព្រះគុណ" ។

**១:១៤** *អំណរ* ជាពាក្យគន្លឹះនៃការចាប់ផ្តើមជំពូកដំបូងៗ (ខ.៤៤,៤៧,៥៨ ២:១០)។

**១:១៥** *ស្រាទំពាំងបាយជូរ ឬគ្រឿងស្រវឹង* ត្រង់ចំណុចនេះហាក់ដូចជាបង្ហាញថា លោកយ៉ូហានមានទំនាក់ទំនងជាមួយនឹងការញែកខ្លួនចេញជាបរិសុទ្ធរបស់ពួកណាសារីត ដោយប្តូរប្តេចនឹងការតមគ្រឿងស្រវឹង (ជន ៦:២–១២ និងការពន្យល់) បើរឿងនេះជាការពិតមែន នោះគាត់ជាពួកណា-សារីតម្នាក់ដែលមានអាយុវែង ដូចជាលោកសាំសុន (ពច ១៣:៤–៧) លោកសាំយូអែល (១សយ ១:១១)។ *ពេញជាព្រះវិញ្ញាណបរិសុទ្ធ* លោកលូកាបានអធិប្បាយអំពីការចាប់កំណើត ដោយការសង្កត់ធ្ងន់លើការដែលព្រះវិញ្ញាណបរិសុទ្ធទ្រង់បានធ្វើ (ខ.៣៥,៤១,៦៧ ២:២៥–២៧) គួបផ្សំនឹងការសង្កត់ធ្ងន់ផ្សេងទៀត នៅក្នុងការនិពន្ធព្រះគម្ពីរដំណឹងល្អនេះទាំងមូល និងព្រះគម្ពីរកិច្ចការ (ការពន្យល់ កច ៤:១)។ *តាំងតែពីផ្ទៃម្តាយមក* នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះវិញ្ញាណបរិសុទ្ធទ្រង់យាងមកសណ្ឋិតលើមនុស្សជាតិជាបណ្តោះអាសន្ន សម្រាប់ការងារពិសេសណាមួយ (ពច ៣:១០ និងការពន្យល់) ប៉ុន្តែ លោកយ៉ូហានបានពេញដោយព្រះវិញ្ញាណអស់មួយជីវិតរបស់លោក ។

**១:១៧** *អេលីយ៉ា* លោកយ៉ូហានមិនមែនជាលោកអេលីយ៉ាទេ (មើលការពន្យល់ ១:២១) ប៉ុន្តែ លោកបានបំពេញភារៈកិច្ចដូចពួកអ្នកប្រកាស (ពួកហោរា) ពីការប្រែចិត្ត នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលនាំឱ្យសម្រេចបទគម្ពីរ មឡ ៤:៥–៦ (មើលការពន្យល់ មឡ ៤:៥ មថ ១១:១៤ ១៧:១០)។ *ដើម្បីនឹងបំបែរចិត្តពួកឪពុកមកឯកូន* មើលពន្យល់ មឡ ៤:៦ ។ *សំរាប់ជារាស្ត្ររបស់ព្រះអម្ចាស់* គឺលោកយ៉ូហានបានជួយសម្រេចបទទំនាយរបស់លោកអេសាយ (មើលការពន្យល់ អស ៤០:៣–៥) ដូចដែលបានបង្ហាញនៅក្នុង លក ៣:៤–៦ ។

**១:១៨** *តើខ្ញុំដឹងសេចក្តីនោះបានដោយសារអ្វី...* គឺសួរដូចលោកអ័ប្រាហាំ (មើលការពន្យល់ លប ១៥:៨) និងលោកគេឌានដែរ (និងការ ពន្យល់ ពច ៦:១៧) ចំណែកលោកអេសេគាល (២ពវ ២០:៨) និងសាការីវិញ គឺសុទ្ធតែសួររកទីសំគាល់ (១កថ ១:២២)។

**១:១៩** *កាព្រីយ៉ែល* ឈ្មោះនេះអាចមានន័យថា "ព្រះទ្រង់ជាវីរជនរបស់ខ្ញុំ" ឬ "មនុស្សដ៏អស្ចារ្យរបស់ព្រះ" នៅក្នុងព្រះគម្ពីរមានតែទេវតាពីររូបគត់ដែលគេស្គាល់ឈ្មោះគឺ ទេវតាកាព្រីយ៉ែល (ដយ ៨:១៦ ៩:២១) និងទេវតាមីកែល (ដយ ១០:១៣ និងការពន្យល់ ខ.២១ យដ ៩ វវ ១២:៧)។

**១:២១** *ឯបណ្តាមនុស្សគេនៅចាំសាការី* គឺរង់ចាំគាត់ចេញពីកន្លែងបរិសុទ្ធ និងឱ្យពររបស់លោកអើរ៉ុនដល់ពួកគេ (មើលពន្យល់ ជន ៦:២៤–២៦)។

**១:២៣** *កាលវេលាដែលការងារលោកបានហើយ* ក្នុងពួកសង្ឃម្នាក់ត្រូវមានការទទួលខុសត្រូវចំពោះការងារព្រះវិហារអស់មួយសប្តាហ៍នៅរៀងរាល់៦ខែម្តង ។ *ផ្ទះ* (មើល ខ.៣៩)។

**១:២៤** *រួចក៏លាក់ខ្លួន* គឺលាក់ខ្លួនដោយអំណរ ដោយការលះបង់ និងដោយការអរព្រះគុណចំពោះការដែលព្រះបានដកការគ្មានកូនចេញពីគាត់ ។

**១:២៥** *ព្រះអម្ចាស់ . . . ទ្រង់ទតមកខ្ញុំ ដើម្បីនឹងដោះសេចក្តីអាមាស់ខ្មាសរបស់ខ្ញុំ* ការគ្មានកូនមិនគ្រាន់តែបានធ្វើឱ្យប្តីប្រពន្ធទាំងពីរនាក់បាត់អំណរប៉ុណ្ណោះទេ ប៉ុន្តែ ជាទូទៅវាថែមទាំងបង្ហាញពីបញ្ហាភាពបរិសុទ្ធ ហើយជាញឹកញាប់ត្រូវទទួលការស្តីបន្ទោសពីសង្គមទៀតផង (លប ១៦:២ គឺមាននាងសារ៉ាយ ២៥:២១ នាងរេបិកា ៣០:២៣ នាងរ៉ាដែល ១សយ ១:១–១៨

អាមាស់ខ្មាស[អ]របស់ខ្ញុំ នៅកណ្ដាលមនុស្សចេញ ។

### ទំនាយពីកំណើតរបស់ព្រះយេស៊ូវ

២៦ កន្លង៦ខែក្រោយនោះមក ព្រះទ្រង់ចាត់ទេវតាកាព្រី
យ៉ែល[ក] ឱ្យទៅឯនាងព្រហ្មចារីម្នាក់ ដែលនៅភូមិណា
សារ៉ែត[ខ] ក្នុងស្រុកកាលីឡេ ២៧ ជាស្ត្រីដែលបានបំរុងទុក
ឱ្យមនុស្សម្នាក់ឈ្មោះយ៉ូសែប[គ] ជាពូជហ្លួងដាវីឌ នាងនោះ
ឈ្មោះ ម៉ារា ២៨ ទេវតាក៏ចូលមកឯនាងពោលថា ជំរាប
សួរនាង ឱនាងដែលប្រកបដោយព្រះគុណអើយ ព្រះ
អម្ចាស់ទ្រង់ គង់នៅជាមួយនឹងនាងក្នុងបណ្ដាពួកស្រីៗ នាង
ជាស្ត្រីមានពរពិត ២៩ នាងមានសេចក្ដីភាំង ដោយឮពាក្យ
នោះ ហើយរិះគិតក្នុងចិត្ត ពីពាក្យជំរាបសួរយ៉ាងនោះមាន
ន័យដូចម្ដេច ៣០ តែទេវតានិយាយថា កុំខ្លាចអី[ឃ] ម៉ារាអើយ
ដ្បិតព្រះបានប្រោសមេត្តាដល់នាងហើយ[ង] ៣១ មើលនាង
នឹងមានគភ៌ប្រសូតបានបុត្រា១ ដែលនាងត្រូវថ្វាយព្រះនាមថា
«យេស៊ូវ»[ច] ៣២ បុត្រនោះនឹងបានជាធំឧត្តមហើយគេនឹង
ហៅទ្រង់ ជាព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត[ឆ] ព្រះអម្ចាស់
ដ៏ជាព្រះ ទ្រង់នឹងប្រទានរាជ្យនៃហ្លួងដាវីឌ[ជ] ជាឰយុកោ
ទ្រង់ថ្វាយទ្រង់សោយ ៣៣ ទ្រង់នឹងសោយរាជ្យលើពួកវង្ស
របស់យ៉ាកុប នៅអស់កល្បរៀងទៅ ហើយរាជ្យទ្រង់[ឈ] នឹង
មិនផុតឡើយ[ញ] ៣៤ តែម៉ារាសួរទេវតាថា ខ្ញុំមិនស្គាល់
ប្រុសណាផង ដូច្នេះ តើធ្វើដូម្ដេចនឹងឱ្យការនេះសំរេចបាន
៣៥ ទេវតាក៏ឆ្លើយថា ព្រះវិញ្ញាណបរិសុទ្ធនឹងយាងមក
សណ្ឋិតលើនាង[ដ] ហើយព្រះចេស្ដានៃព្រះដ៏ខ្ពស់បំផុត[ឋ] នឹង
មកគ្របបាំងនាង ដោយស្រមោល ហេតុដូច្នេះបុត្របរិសុទ្ធ[ឌ]
ដែលនឹងប្រសូតមកនោះ ត្រូវហៅថាជាព្រះរាជបុត្រានៃ
ព្រះ[ឍ] ៣៦ មើល ឥឡូវអេលីសាបិត ជាញាតិនាងក៏មានផ្ទៃ
ពោះជាកូនប្រុស[ណ] ក្នុងកាលដែលចាស់ហើយដែរ គឺអ្នក
ដែលគេបានហៅជាស្ត្រីអារ នោះនាងមានផ្ទៃពោះ៦ខែ
មកហើយ ៣៧ ដ្បិតការអ្វីដែលព្រះទ្រង់ធ្វើពុំបាន នោះគ្មាន
សោះឡើយ[ត] ៣៨ នោះម៉ារានិយាយថា មើល ខ្ញុំនេះជាអ្នក
បំរើរបស់ព្រះអម្ចាស់ ដូច្នេះ សូមឱ្យបានសំរេចដូចពាក្យ
លោកចុះ រួចទេវតាក៏ថយចេញពីនាងបាត់ទៅ ។

### នាងម៉ារាមកសួរសុខទុក្ខអាលីសាបិត

៣៩ នៅគ្រានោះ ម៉ារាក៏ក្រោកឡើងទៅឯស្រុកភ្នំជាប្រញាប់
ដល់ភូមិ១ក្នុងខេត្តយូដា[ថ] ៤០ ក៏ចូលទៅក្នុងផ្ទះសាការី ជំរាប
សួរដល់អេលីសាបិត ៤១ កាលអេលីសាបិតបានឮពាក្យ
ម៉ារាជំរាបសួរនោះ កូនក៏បម្រះនៅក្នុងផ្ទៃរួចគាត់បាន
ពេញជាព្រះវិញ្ញាណបរិសុទ្ធ[ទ] ៤២ ក៏បន្លឺសំឡេងយ៉ាងខ្លាំង ថា
ក្នុងបណ្ដាពួកស្រីៗ គឺនាងហើយ ជាស្ត្រីមានពរពិត[ធ]
ព្រមទាំងកូននៅក្នុងផ្ទៃនាងផង ៤៣ ដូចម្ដេចហ្ន៎ បានជាដល់
ទៅព្រះមាតាព្រះអម្ចាស់[ន] នៃខ្ញុំក៏មកសួរដូច្នេះដែរ ៤៤ ដ្បិត
មើលកាលសំឡេងនាងជំរាបសួរឮមកដល់ត្រចៀកខ្ញុំនោះ
កូននៅក្នុងពោះខ្ញុំក៏បម្រះដោយសេចក្ដីអំណរ ៤៥ នាងមាន
ពរហើយ ដោយនាងបានជឿ ដ្បិតសេចក្ដីដែលព្រះអម្ចាស់

**១:២៥** អ លប ៣០:២៣ អស ៤:១
**១:២៦** ក ឌ.១៩ ខ មថ ២:២៣
**១:២៧** គ មថ ១:១៦ ,១៨,២០ លក ២:៤
**១:៣០** ឃ មក ១:១៣ មថ ១៤:២៧
**១:៣០** ង លប ៦:៨
**១:៣១** ច អស ៧:១៤ មថ ១:២១,២៥ លក ២:២១
**១:៣២** ឆ ឌ.៣៥,៧៦ មក ៥:៧ ជ មថ ១:១
**១:៣៣** ឈ មថ២៨:១៨ ញ ២សយ ៧:១៦ ទដ ៨៩:៣,៤ អស ៩:៧ យរ ៣៣:១៧ ដយ ២:៤៤ ៧:១៤,២៧ មីក ៤:៧ ហព ១:៨
**១:៣៥** ដ មថ ១:១៨ ឋ ឌ.៣២,៧៦ មក ៥:៧ ឌ មក ១:២៤ ឍ មថ ៤:៣
**១:៣៦** ណ ឌ.២៤
**១:៣៧** ត មថ ១៩:២៦
**១:៣៩** ថ ឌ.៦៥
**១:៤១** ទ ឌ.១៥
**១:៤២** ធ ពច ៥:២៤
**១:៤៣** ន យហ១៣:១៣

នាងហាណា លវ ២០:២០–២១ ទដ ១២៨:៣ យរ ២២:៣០)។
**១:២៦–៣៥** វគ្គនេះបាននិយាយយ៉ាងច្បាស់ពីកំណើតរបស់ព្រះយេស៊ូវ ពីស្ត្រីព្រហ្មចារី (ឌ.២៧,៣៤–៣៥ មថ ១:១៨–២៥ និងការពន្យល់)។ ការនេះគឺជាព្រះរាជកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលជាអង្គទីបីនៃព្រះត្រៃឯក ។ ព្រះយេស៊ូវទ្រង់គឺជាព្រះ និងជាមនុស្សលោកមួយរយភាគរយ ចាប់តាំងពីទ្រង់បានយកកំណើតជាមនុស្សដោយត្រឡប់ជាសាច់ឈាម (យហ ១:១៤)។
**១:២៦** *កន្លង៦ខែក្រោយនោះមក* មានន័យថាចាប់តាំងពីលោកយ៉ូហានបានចាប់កំណើតក្នុងផ្ទៃម្ដាយមក ។ *ណាសារ៉ែត* មើលការពន្យល់ មថ ២:២៣ ។
**១:២៧** *បំរុងទុកឱ្យមនុស្ស* គឺបានភ្ជាប់ពាក្យជាមួយ (មថ ១:១៨ និងពន្យល់)។
**១:៣១** *យេស៊ូវ* មើលការពន្យល់ មថ ១:២១ ចំពោះអត្ថន័យនៃព្រះនាមនេះ ។
**១:៣២** *រាជ្យបុត្រានៃព្រះដ៏ខ្ពស់បំផុត* ព្រះងារនេះមានន័យពីរយ៉ាងគឺ (១). ព្រះរាជបុត្រាដ៏បរិសុទ្ធរបស់ព្រះ (២).ព្រះមែស៊ីដែលបានចាប់កំណើតហើយ ។ ភាពជាព្រះមែស៊ីរបស់ទ្រង់គឺមាននិយាយយ៉ាងច្បាស់ក្នុងបទគម្ពីរ (ឌ.៣២ខ–៣៣ ទដ ៧:១០,១៧)។ *ព្រះដ៏ខ្ពស់បំផុត* ព្រះងារនេះមានប្រើជាញឹកញាប់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី (ឌ.៣៥,៧៦ ៦:៣៥ ៨:២៨ លប ១៤:១៩ និងការពន្យល់ ២សយ ២២:១៤ ទដ ៧:១០,១៧)។ *រាជ្យ* គឺរាជ្យដែលក្នុងគ្រាសញ្ញាចាស់ ព្រះបានសន្យាប្រទានដល់ព្រះមែស៊ីដែលជាពូជរបស់ស្ដេចដាវីឌ (២សយ ៧:១៣,១៦ ទដ ២:៦–៧ ៨៩:២៥–២៧ អស ៩:៦–៧ និងការពន្យល់)។ *ហ្លួងដាវីឌ ជាឰយុកោទ្រង់* នាងម៉ារាជាពូជស្ដេចដាវីឌដូចលោកយ៉ូសែបដែរ (មថ ១:១៦) ដូចនេះគេអាចហៅព្រះយេស៊ូវដោយស្របច្បាប់បានថា"បុត្រា"ស្ដេចដាវីឌ ។
**១:៣៤** *តើធ្វើដូចម្ដេចនឹងឱ្យការនេះសំរេចបាន ?* នាងម៉ារាមិនបានសួរសំណួររបៀបគ្មានជំនឿ ដូចលោកសាការីឡើយ (ឌ.២០,៤៥)។
**១:៣៥** *បុត្របរិសុទ្ធ* គឺព្រះយេស៊ូវមិនដែលមានបាបទាល់តែសោះ (២កថ ៥:២១ ហព ៤:១៥ "មើលពន្យល់ ៧:២៦" ១ពត ២:២២ ១យហ ៣:៥)។
**១:៣៦** *អេលីសាបិត ជាញាតិនាង* គឺមិនដឹងថានាងអេលីសាបិតត្រូវជាបងប្អូនជីដូនមួយជាម្ដាយមីង ឬជាញាតិអ្វីនឹងនាងម៉ារានោះឡើយ ។
**១:៤៤** *ដោយសេចក្ដីអំណរ* ព្រះវិញ្ញាណទ្រង់បណ្ដាលឱ្យមានការឆ្លើយតបដូចនេះ នៅក្នុងទារកដែលមិនទាន់កើតនេះ តាមវិធីអាថ៌កំបាំងណាមួយ ។
**១:៤៦–៥៥** បទចំរៀងមួយក្នុងចំណោមចម្រៀង៤បទដែលមាននៅក្នុង លក ១–២ (ឌ.៦៨–៧៩ ២:១៤ ២:២៩–៣២)។ គឺជាចម្រៀងសរសើរតម្កើងសិរីល្អរបស់ព្រះ ចម្រៀងនេះប្រៀបបាននឹងបទទំនុកតម្កើងមួយដែរ ហើយគួរតែបានប្រៀបធៀបនឹងបទចម្រៀងរបស់នាងហាណាផងដែរ (១សយ ២:១–១០ និងការពន្យល់ ១សយ ២:១)។

មានបន្ទូលមកនាង នោះនឹងបានសំរេចជាមិនខាន ។

## ចំរៀងរបស់នាងម៉ារា

*១:៤៦–៥៣ = ១ សយ ២:១–១០*

៤៦រួចម៉ារានិយាយឡើងថា ព្រលឹងខ្ញុំលើកដំកើងព្រះអម្ចាស់[ប]
៤៧វិញ្ញាណខ្ញុំក៏រីករាយ នឹងព្រះដ៏ជាព្រះអង្គសង្គ្រោះនៃខ្ញុំ[ផ]
៤៨ដ្បិតទ្រង់បានទតមើលសណ្ឋានទាបថោករបស់ខ្ញុំ ជាបាវ[ព]
បំរើទ្រង់ មើលចុះ ពីនេះទៅមុខ គ្រប់ទាំងដំណមនុស្ស នឹង
រាប់ខ្ញុំថា ជាអ្នកមានពរ[ភ] ៤៩ពីព្រោះព្រះដ៏មានព្រះចេស្តា[ម]
ទ្រង់បានប្រោសសេចក្តី យ៉ាងល្អវិសេសដល់ខ្ញុំ[យ] ព្រះនាម
ទ្រង់បរិសុទ្ធ ៥០ទ្រង់មានសេចក្តីមេត្តាករុណាដល់គ្រប់ទាំង
ដំណមនុស្ស ដែលគេកោតខ្លាចទ្រង់តរៀងទៅ[រ] ៥១ទ្រង់
បានសំដែងឫទ្ធិ ដោយព្រះហស្តទ្រង់[ល] ព្រមទាំងកំចាត់កំ
ចាយមនុស្សអំនួត ដោយសារគំនិតដែលនៅក្នុងចិត្តខ្លួនគេ[វ]
៥២ទាំងទំលាក់ស្តេចពីបល្ល័ង្កចេញ ហើយលើកមនុស្សរាប
សាឡើងវិញ[ស] ៥៣ឯមនុស្សឃ្លាន ទ្រង់បានចំអែតដោយ
របស់ល្អ[ហ] តែពួកអ្នកមាន ទ្រង់បានបណ្តេញឱ្យទៅទទេ
វិញ ៥៤ទ្រង់បានជួយអ៊ីស្រាអែល ជាអ្នកបំរើទ្រង់ ឱ្យបាន
នឹកចាំ ពីសេចក្តីមេត្តាករុណាទ្រង់[ឡ] ៥៥ដូចជាទ្រង់មាន
បន្ទូលនឹងពួកឰយុកោយើង គឺនឹងលោកអ័ប្រាហាំ ហើយ
នឹងពូជលោក[អ]ជារៀងរាបដរាបតមក ៥៦ម៉ារាក៏នៅជា
មួយនឹងអេលីសាបិត ប្រហែលជា៣ខែ ទើបត្រឡប់ទៅផ្ទះ
ខ្លួនវិញ ។

## កំណើតរបស់លោកយ៉ូហាន–បាទីស្ទ

**១:៤៦** ប ទដ ៣៤:២,៣
**១:៤៧** ផ ទដ ១៨:៤៦ អស ១៧:១០ ៦១:១០ ហប ៣:១៨ ១ធថ ១:១ ២:៣ ៤:១០
**១:៤៨** ព ខ.៣៨ ទដ ១៣៨:៦ ភ លក ១១:២៧
**១:៤៩** ម ទដ ១១១:៩ យ ទដ ៧១:១៩
**១:៥០** រ នក ២០:៦ ទដ ១០៣:១៧
**១:៥១** ល ទដ ៩៨:១ អស ៤០:១០ វ លប ១១:៨ នក ១៨:១១ ២សយ ២២:២៨ យរ ១៣:៩ ៤៩:១៦
**១:៥២** ស មថ ២៣:១២
**១:៥៣** ហ ទដ ១០៧:៩
**១:៥៤** ឡ ទដ ៩៨:៣
**១:៥៥** អ កទ ៣:១៦
**១:៥៩** ក លប ១៧:១២ លវ ១២:៣ លក ២:២១ ភល ៣:៥
**១:៦០** ខ ខ.១៣,៦៣ មថ ៣:១
**១:៦២** គ ខ.២២
**១:៦៣** ឃ ខ.១៣,៦០ មថ ៣:១
**១:៦៤** ង ខ.២០ អគ ២៤:២៧

៥៧រីឯពេលដែលអេលីសាបិត ត្រូវសំរាលកូនក៏មកដល់
ហើយនាងសំរាលបានកូនប្រុស ៥៨ចំណែកពួកអ្នកជិតខាង
នឹងញាតិសន្តានគាត់ទាំងប៉ុន្មានក៏ឮថា ព្រះអម្ចាស់បាន
ចំរើនសេចក្តីមេត្តាករុណាដល់គាត់ ហើយគេមានសេចក្តី
រីករាយអរសប្បាយជាមួយនឹងគាត់ ៥៩ដល់ថ្ងៃទី៨ គេមក
ដើម្បីកាត់ស្បែក[ក]ទារកនោះ ក៏ឱ្យឈ្មោះថា សាការី តាម
ឈ្មោះឪពុក ៦០តែម្តាយឆ្លើយឡើងថា ទេត្រូវឱ្យឈ្មោះ
យ៉ូហានវិញ[ខ] ។
៦១គេឆ្លើយទៅគាត់ថា ក្នុងពួកញាតិសន្តានអ្នក គ្មានអ្នក
ណាដែលមានឈ្មោះនោះទេ ៦២គេក៏ធ្វើគ្រឿងសំគាល់[គ]
សួរដល់ឪពុក តើលោកចង់ឱ្យឈ្មោះអ្វីដល់កូន ៦៣លោក
សូមក្តារខៀនមកសរសេរថា វាឈ្មោះយ៉ូហាន[ឃ] នោះគេ
មានសេចក្តីអស្ចារ្យទាំងអស់គ្នា ៦៤ខណនោះ មាត់លោក
បើកឡើងជា១រំពេច អណ្តាតក៏រលាស់បាន ហើយលោក
ពណ៌នា[ង]សរសើរដល់ព្រះ ៦៥ឯមនុស្សដែលនៅជុំវិញទាំង
ប៉ុន្មាន ក៏កើតមានសេចក្តីភ័យខ្លាច រួចគេរ៉ាយរ៉ាប់រឿង
នេះទូទៅពេញក្នុងស្រុកភ្នំរបស់ខេត្តយូដា[ច] ៦៦ហើយអស់
អ្នកដែលឮ ក៏ទុកតែក្នុងពោះដោយថា ដូច្នេះ តើកូននេះនឹង
បានជាអ្វី ព្រះហស្តព្រះអម្ចាស់ក៏នៅជាមួយនឹងវា[ឆ] ។

## ចំរៀងរបស់លោកសាការី

៦៧រីឯសាការីជាឪពុកក៏បានពេញជាព្រះវិញ្ញាណបរិសុទ្ធ[ជ]

**១:៦៥** ច ខ.៣៩ **១:៦៦** ឆ លប ៣៩:២ កច ១១:២១ **១:៦៧** ជ ខ.១៥

**១:៥០** *ដំណមនុស្សដែលគេកោតខ្លាចទ្រង់* គឺពួកអ្នកដែលថ្វាយបង្គំព្រះ និងរស់នៅដោយចុះចូលនឹងព្រះហឫទ័យទ្រង់ (លក ២០:១១ សភ ១:៧ និងការពន្យល់) ។

**១:៥១** *ព្រះហស្តទ្រង់* គឺការពិពណ៌នាជាន័យធៀបអំពីការដែលព្រះទ្រង់ធ្វើព្រះរាជកិច្ចទ្រង់ដោយអំណាចព្រះចេស្តា ។ ព្រះទ្រង់ជាវិញ្ញាណ (មើលការពន្យល់ យហ ៤:២៤) ។

**១:៥៣** *មនុស្សឃ្លាន* គឺឃ្លានទាំងខាងសាច់ឈាម និងព្រលឹងវិញ្ញាណ (មថ ៥:៦ យហ ៦:៣៥) ។ ការយាងមកនៃនគរព្រះនឹងនាំមកនូវការផ្លាស់ប្រែដែលមានឥទ្ធិពលលើគ្រប់ផ្នែកទាំងអស់នៃជីវិត ។

**១:៥៤** *ឱ្យបាននឹកចាំពីសេចក្តីមេត្តាករុណា* បទចម្រៀងនេះបានបញ្ចប់ដោយការធានាថា ព្រះទ្រង់នឹងធ្វើតាមព្រះបន្ទូលសន្យា ដែលទ្រង់មានជាមួយនឹងរាស្ត្ររបស់ទ្រង់ (មើលការពន្យល់ លប ២២:១៦–១៨) ។

**១:៥៦** *ប្រហែលជា៣ខែ* នាងម៉ារាប្រាកដជាបាននៅជាមួយអេលីសាបិតរហូតដល់កំណើតយ៉ូហាន–បាទីស្ទ រួចក៏ត្រឡប់ទៅផ្ទះនាងនៅភូមិណាសារ៉ែតវិញ (ខ.៣៦) ។

**១:៥៧–៦៦** កំណើតរបស់លោកយ៉ូហាន–បាទីស្ទបានសម្រេចបទទំនាយ ខ.៥–២៥ ។

**១:៥៩** *តាមឈ្មោះឪពុក* គឺជាប្រពៃណីដាក់ឈ្មោះនៅសម័យនោះ ។

**១:៦២** *គេក៏ធ្វើគ្រឿងសំគាល់សួរដល់ឪពុក* ត្រង់នេះឃើញថាដោយសារតែគាត់គ នោះគាត់ថ្លង់ផងដែរ ។

**១:៦៣** *លោកសូមក្តារខៀនមកសរសេរ* ប្រហែលជាក្តារខៀនតូចមួយធ្វើអំពីឈើ ហើយមានក្រមួនស្រោបពីខាងលើ ។

**១:៦៤** *សរសើរដល់ព្រះ* គឺគោលរឿងមួយដ៏សំខាន់នៃព្រះគម្ពីរលូកា (២:១៣,២០,២៨ ៥:២៥,២៦ ៧:១៦ ១៣:១៣ ១៧:១៥,១៨ ១៨:៤៣ ១៩:៣៧ ២៣:៤៧ ២៤:៥៣) ។

**១:៦៧** *ពេញជាព្រះវិញ្ញាណបរិសុទ្ធ ហើយទាយថា* សេចក្តីទំនាយមិនគ្រាន់តែជាការថ្លែងទំនាយប៉ុណ្ណោះទេ តែក៏ជាការប្រកាសប្រាប់ពីព្រះបន្ទូលព្រះផងដែរ ។ ព្រះវិញ្ញាណបរិសុទ្ធទ្រង់បានធ្វើឱ្យទាំងលោកសាការី និងនាងអេលីសាបិត (ខ.៤១–៤៥) អាចថ្លែងពីសេចក្តី ដែលពួកគេមិនមានសមត្ថភាពនិយាយសោះ ។

ហើយទាយថា[ឈ] ៦៨សូមឱ្យព្រះអម្ចាស់ ជាព្រះនៃសាសន៍
អ៊ីស្រាអែល[ញ] បានប្រកបដោយព្រះគុណ ពីព្រោះទ្រង់បាន
ទតមើល ហើយប្រោសលោះរាស្ត្រទ្រង់[ដ] ៦៩ព្រមទាំងបង្កើត
ព្រះដ៏មានឥទ្ធិឫទ្ធិ[ឋ] នៅក្នុងពូជហ្លួងដាវីឌ[ឌ] ជាអ្នកបំរើទ្រង់សំ
រាប់នឹងជួយសង្គ្រោះយើងផង ៧០ដូចជាទ្រង់មានបន្ទូល
ដោយមាត់ពួកហោរាបរិសុទ្ធរបស់ទ្រង់តាំងពីបុរាណមក[ឍ]
៧១គឺជាសេចក្ដីសង្គ្រោះ ឱ្យរួចពីខ្មាំងសត្រូវយើង ហើយ
ពីកណ្ដាប់ដៃ នៃអស់អ្នកណាដែលស្អប់យើង ៧២ដើម្បីនឹង
សំរេចសេចក្ដីមេត្តាករុណា ដល់ពួកឰយុកោយើង[ណ] ហើយ
នឹងនឹកចាំ ពីសេចក្ដីសញ្ញាបរិសុទ្ធរបស់ទ្រង់[ត] ៧៣គឺជាសម្បថ
ដែលទ្រង់បានស្បថនឹង លោកអ័ប្រាហាំ[ថ]ជា ឰយុកោយើង
ថា ៧៤នឹងបើកឱ្យយើង បានសង្គ្រោះរួចពីកណ្ដាប់ដៃពួក
ខ្មាំងសត្រូវ ដើម្បីឱ្យបានបំរើទ្រង់[ទ] ឥតភ័យខ្លាច[ធ]
៧៥ដោយសេចក្ដីបរិសុទ្ធ នឹងសេចក្ដីសុចរិត[ន] នៅចំពោះ
ទ្រង់អស់១ជីវិតយើង ៧៦ឯឯងទារកអើយ គេនឹងហៅឯង
ជាហោរា[ប]នៃព្រះដ៏ខ្ពស់បំផុត[ផ] ដ្បិតឯងនឹងដើរចំពោះព្រះ
អម្ចាស់ដើម្បីនឹងរៀបចំផ្លូវថ្វាយទ្រង់[ព] ៧៧ប្រយោជន៍ឱ្យ
រាស្ត្រទ្រង់បានស្គាល់សេចក្ដីសង្គ្រោះ ជាការប្រោសឱ្យគេ
រួចពីបាប[ភ] ៧៨ដោយព្រោះព្រះហឫទ័យមេត្តាករុណារបស់
ព្រះនៃយើង ដែលបណ្ដាលឱ្យបច្ចូសកាល[ម] ភ្លឺមកដល់យើង
ពីស្ថានដ៏ខ្ពស់ ៧៩ដើម្បីនឹងបំភ្លឺដល់ពួកអ្នកដែលអង្គុយក្នុង
សេចក្ដីងងឹត ហើយក្នុងម្លប់នៃសេចក្ដីស្លាប់[យ] ប្រយោជន៍ឱ្យបាន
ដំរង់ជើងយើង តាមផ្លូវសុខសាន្តវិញ[រ] ។
៨០រីឯទារកនោះ ក៏កាន់តែធំឡើង បានចំរើនកំឡាំង
ខាងវិញ្ញាណជាខ្លាំងឡើង[ល] ហើយនៅតែក្នុងទីរហោស្ថាន
ដរាបដល់ថ្ងៃ ដែលបង្ហាញខ្លួន ឱ្យសាសន៍អ៊ីស្រាអែលបាន
ឃើញ ។

## ការប្រសូតរបស់ព្រះយេស៊ូវ

**២** ១នៅគ្រានោះ សេសារ-អូគូស្ទ[វ] បានចេញព្រះរាជក្រម
១ច្បាប់ ឱ្យមនុស្សទាំងអស់ដែលនៅផែនដីបានចុះបញ្ជី[ស]

**១:៦៧** ឈ យអ ២:២៨
**១:៦៨** ញ លប ២៤:២៧ ១ពវ ៨:១៥ ទដ ៧២:១៨ ដ ទដ ១១១:៩ លក ៧:១៦
**១:៦៩** ឋ ១សយ ២:១,១០ ២សយ ២២:៣ ទដ ១៨:២ ៨៩:១៧ ១៣២:១៧ អគ ២៩:២១ ឌ មថ ១:១
**១:៧០** ឍ យរ២៣:៥ កច ៣:២១ រម ១:២
**១:៧២** ណ មីក ៧:២០ ត ទដ ១០៥:៨,៩ ១០៦:៤៥ អស ១៦:៦០
**១:៧៣** ថ លប ២២:១៦-១៨
**១:៧៤** ទ ហព ៩:១៤ ធ ១យហ ៤:១៨
**១:៧៥** ន អភ ៤:២៤
**១:៧៦** ប មថ ១១:៩

ផ ខ.៣២,៣៥ មក ៥:៧ ព ខ.១៧ មថ ៣:៣ **១:៧៧** ភ យរ ៣១:៣៤ មថ ១:២១ មក ១:៤ **១:៧៨** ម មឡ ៤:២ **១:៧៩** យ ទដ ១០៧:១៤ អស ៩:២ ៥៩:៩ មថ ៤:១៦ កច ២៦:១៨ រ លក ២:១៤ **១:៨០** ល លក ២:៤០,៥២
**២:១** វ មថ ២២:១៧ លក ៣:១ ស មថ ២៤:១៤

**១:៦៨-៧៩** វគ្គនេះគឺជាបទទំនុកតម្កើង ដែលបទនេះមានទៅដោយការសរសើរតម្កើងព្រះ និងបទទំនាយពីការប្រោសលោះរបស់ព្រះសម្រាប់រាស្ត្រទ្រង់ ។
**១:៦៨** *ប្រោសលោះរាស្ត្រទ្រង់* គឺមិនមែនសម្រាប់តែសន្តិសុខជាតិប៉ុណ្ណោះទេ (ខ.៧១) ប៉ុន្តែថែមទាំងសម្រាប់សេចក្ដីសង្គ្រោះខាងឯសីលធម៌ និងព្រលឹងវិញ្ញាណផងដែរ (ខ.៧៥,៧៧) ។
**១:៦៩** *មានឥទ្ធិឫទ្ធិ* គឺមានកម្លាំង ។ ព្រះយេស៊ូវទ្រង់ជាព្រះមែស៊ីដែលចេញពីតំណវង្សស្តេចដាវីឌ គឺទ្រង់មានអំណាចក្នុងការសង្គ្រោះ ។
**១:៧៤** *បើកឱ្យយើងបានសង្គ្រោះ* គឺពិតជាការបើកឱ្យមានសេរីភាពរួចផុតពីការគាបសង្កត់ ការជាប់ជាទាសករ ក៏ដូចជាការដោះឱ្យរួចពីបាបផងដែរ ។
**១:៧៦** *ហោរានៃព្រះដ៏ខ្ពស់បំផុត* តែព្រះយេស៊ូវទ្រង់នឹងទទួលងារជា "ព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត" (មើលការពន្យល់ ខ.៣២ ) ។ *រៀបចំផ្លូវ* មើលការពន្យល់ ៣:៤ ។
**១:៧៨** *បច្ចូសកាលភ្លឺ* (ថ្ងៃរះ) គឺសំដៅទៅលើការយាងមកនៃព្រះមែស៊ី (មើលលក្ខណៈស្រដៀងគ្នាក្នុង ជន ២៤:១៧ អស ៩:២ ៦០:១ មឡ ៤:២ និងការពន្យល់) ។ លោកសាការីមិនគ្រាន់តែសរសើរកូនប្រុសរបស់លោកថាជា "ហោរានៃព្រះដ៏ខ្ពស់បំផុត" តែប៉ុណ្ណោះទេ (ខ.៧៦-៧៧) ប៉ុន្តែថែមទាំងបានថ្វាយការគោរពចំពោះការយាងមកនៃព្រះមែស៊ីទៀតផង ។
**១:៧៩** *អ្នកដែលអង្គុយក្នុងសេចក្ដីងងឹត* គឺជាពួកមនុស្សបាត់បង់ ដែលបានដាច់ចេញពីព្រះ ( អស ៩:១-២ មថ ៤:១៥-១៦ និងការពន្យល់) ។ *សុខសាន្ត* មើលការពន្យល់ ២:១៤ ។
**១:៨០** *នៅតែក្នុងទីរហោស្ថាន* ពេលដែលលោកយ៉ូហានចាប់កំណើត ឪពុកម្ដាយគាត់មានវ័យចាស់ណាស់ទៅហើយ ដូចនេះប្រហែលជាពួកគាត់បានស្លាប់នៅពេលគាត់នៅក្មេងនៅឡើយ ។ គេជឿថាគាត់បានចម្រើនវ័យនៅទីរហោស្ថាននៃស្រុកយូដាទីតាំងនៅចន្លោះរវាងទីក្រុងយេរូសាឡិម និងសមុទ្រស្លាប់ ។ *បង្ហាញខ្លួន. . .បានឃើញ* ការដែលលោកយូហាន-បាទីស្ទបានចែកចាយ និងប្រកាសពីការយាងមកនៃព្រះមែស៊ី គឺជាការបញ្ជាក់ថាលោកបានបង្ហាញខ្លួនជាសាធារណៈ ។ លោកមានអាយុប្រហែល៣០ឆ្នាំ នៅពេលដែលលោកចាប់ផ្ដើមធ្វើការបម្រើព្រះ (មើលការពន្យល់ ៣:២៣) ។
**២-៧** ការប្រសូតនៃព្រះយេស៊ូវបានបញ្ជាក់ពីការសម្រេចនៃបទទំនាយក្នុង ខ. ១:២៦-៣៨ ។
**២:១** លោកលូកា គឺជាអ្នកនិពន្ធព្រះគម្ពីរដំណឹងល្អតែម្នាក់គត់ ដែលបានផ្សាភ្ជាប់ការអធិប្បាយរបស់ខ្លួន ទៅនឹងកាលបរិច្ឆេទនៃប្រវត្តិសាស្ត្រពិភពលោក ។ *សេសារ-អូគូស្ទ* ដោយយោងតាមមតិជាច្រើន ស្តេចអង្គនេះគឺជាអធិរាជទីមួយនិងខ្លាំងជាងគេបំផុតរបស់ចក្រភពរ៉ូម៉ាំង (ឆ្នាំ ៣១ មុនគ.ស ដល់ឆ្នាំ១៤ គ.ស) ។ ក្រោយពីបានផ្លាស់ប្ដូរទម្រង់រដ្ឋាភិបាលពីសាធារណរដ្ឋទៅជាចក្រភព ស្តេចអង្គនេះបានពង្រីកអាណាចក្រ ដោយដាក់តំបន់មេឌីទែ-រ៉ាណេទាំងមូល នៅក្រោមការត្រួតត្រានៃអាណាចក្រខ្លួន និងបានស្ថាបនាឡើងនូវ "សន្តិភាពនៃរ៉ូម៉ាំង" ហើយនិងបានត្រួសត្រាយផ្លូវ នៅក្នុងយុគសម័យដ៏រុងរឿងនៃអក្សរសាស្ត្រ និងស្ថាបត្យកម្មរ៉ូម៉ាំង ។ អូគូស (មានន័យថា "ដែលបានតម្កើងឡើង") គឺជាព្រះងារដែលសភារ៉ូម៉ាំងបានបោះឆ្នោតថ្វាយទ្រង់ នៅឆ្នាំ ២៧ មុនគ.ស ។ *ចុះបញ្ជី* ជាពាក្យប្រើសម្រាប់ការងារទាហាន និង

២បញ្ជីមុនដំបូងនោះ បានធ្វើនៅវេលាដែលលោកគីរេនាស
ធ្វើជាចៅហ្វាយនៅស្រុកស៊ីរី[ហ] ៣មនុស្សទាំងអស់ក៏ទៅឯស្រុក
កំណើតរៀងខ្លួន ដើម្បីចុះបញ្ជី ៤ឯយ៉ូសែបគាត់ក៏ចេញពី
ណាសារ៉ែត ស្រុកកាលីឡេឡើងទៅឯស្រុកយូដា ដល់ក្រុង
របស់ហ្លួងដាវីឌ ដែលឈ្មោះថាបេថ្លេហិម[ឡ] ពីព្រោះគាត់
ជាព្រះវង្ស ហើយជាព្រះញាតិនឹងហ្លួងដាវីឌដែរ ៥ដើម្បីនឹង
ចុះបញ្ជីជាមួយនឹងម៉ារា ដែលបានបំរុងទុកឱ្យធ្វើជាប្រពន្ធ
គាត់[អ] ដែលនាងមានគភ៌នោះ ៦កាលកំពុងតែនៅទីនោះ
វេលាដែលនាងត្រូវប្រសូតក៏មកដល់ ៧ហើយនាងប្រសូត
បានបុត្រាជាចំបងមក រួចរុំនឹងសំពត់ ផ្តេកក្នុងស្នូក ពីព្រោះ
ក្នុងផ្ទះសំណាក់គ្មានកន្លែងណានៅទេ ។

## ពួកអ្នកគង្វាល និងទេវតា

៨រីឯនៅស្រុកនោះឯង មានពួកអ្នកគង្វាល ដែលចាំយាម
រក្សាហ្វូងចៀមរបស់ខ្លួន នៅឯវាលក្នុងវេលាយប់ ៩នោះ
មើលមានទេវតា[ក]នៃព្រះអម្ចាស់មកឈរជិតគេ ឯសិរីល្អ
របស់ទ្រង់ក៏ភ្លឺឆ្វាត់ជុំវិញ ហើយគេមានសេចក្តីភ័យខ្លាចជា
ខ្លាំង ១០តែទេវតាប្រាប់ថា កុំខ្លាចអី[ខ] មើល ខ្ញុំមកប្រាប់ដំណឹង
ល្អដល់អ្នករាល់គ្នា ពីសេចក្តីអំណរយ៉ាងអស្ចារ្យ ដែល
សំរាប់បណ្តាជនទាំងអស់គ្នា ១១ដ្បិតនៅថ្ងៃនេះ មានព្រះអង្គ
សង្គ្រោះ[គ]១អង្គ ប្រសូតដល់អ្នករាល់គ្នានៅក្រុងហ្លួងដាវីឌ
គឺជាព្រះគ្រីស្ទ[ឃ]ដ៏ជាព្រះអម្ចាស់[ង] ១២ហើយនេះជាទីសំគាល់[ច]
ដល់អ្នក គឺអ្នករាល់គ្នានឹងឃើញព្រះឱរស១រុំនឹងសំពត់ផ្តេក
ក្នុងស្នូក ១៣នោះស្រាប់តែមានពួកពលបរិវារកកកុញពី
ស្ថានសួគ៌ មកនៅជាមួយនឹងទេវតានោះ ក៏ពោលសរសើរ
ដល់ព្រះថា ១៤សួស្តីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយ
សេចក្តីសុខ[ឆ]សាន្តនៅផែនដីនៅកណ្តាលមនុស្ស ដែល
ជាទីគាប់ព្រះហឫទ័យដល់ទ្រង់ ១៥កាលពួកទេវតាបានឃ្លាត
ចេញ ហោះទៅស្ថានសួគ៌វិញហើយ នោះពួកអ្នកគង្វាល
និយាយគ្នាថា ចូរយើងទៅឯបេថ្លេហិម មើលការដែល
បានកើតមកនោះ ដែលព្រះអម្ចាស់បានប្រាប់ឱ្យយើងដឹង

**២:២** ហ មថ ៤:២៤ កច ១៥:២៣,៤១ ២១:៣ កទ ១:២១
**២:៤** ឡ យហ ៧:៤២
**២:៥** អ លក ១:២៧
**២:៩** ក កច ៥:១៩
**២:១០** ខ មថ ១៤:២៧
**២:១១** គ មថ ១:២១ យហ ៣:១៧ ៤:៤២ កច ៥:៣១ ១៣:២៣ រម ១១:១៤ ១ធថ ៤:១០ ១យហ ៤:១៤ ឃ មថ ១:១៦ ១៦:១៦,២០ យហ ១១:២៧ កច ២:៣៦ ៣:២០ ៩:២២ ង យហ ១៣:១៣
**២:១២** ច ១សយ ២:៣៤ ១០:៧ ២ពវ ១៩:២៩ ទដ ៨៦:១៧ អស ៧:១៤
**២:១៤** ឆ អស ៩:៦ ៥២:៧ ៥៣:៥ មីក ៥:៥ លក ១:៧៩ យហ ១៤:២៧ រម ៥:១ អភ ២:១៤,១៧

ពន្ធដាតែទោះជាយ៉ាងណាក៏ដោយ គេបានលើកលែងការឱ្យពួកយូដាចូលបម្រើការងារទាហានរ៉ូម៉ាំងនោះ ។ ព្រះអម្ចាស់ទ្រង់បានប្រើរាជក្រមរបស់អធិរាជដែលមិនជឿព្រះនេះ ដើម្បីសម្រេចបទទំនាយ មីក ៥:២(មើលការពន្យល់ខនោះ ព្រមទាំង មថ ២:៣–៦)។ *នៅផែនដី* (ព្រះគម្ពីរអង់គ្លេសមួយចំនួនដាក់ថានៅក្នុង "ពិភពរ៉ូម៉ាំង")។

**២:២** *គីរេនាស* នាម៉ឺនរូបនេះប្រហែលជាបានកាន់មុខតំណែងអស់ពីរអាណត្តិ ដែលលើកទីមួយនៅឆ្នាំ៦–៤ មុនគ.ស និងទីពីរនៅឆ្នាំ៦–៩ គ.ស ដែលអាណត្តិនីមួយៗសុទ្ធតែមានការចុះបញ្ជីកត់ត្រារាស្ត្រ ។ ការចុះបញ្ជីក្នុងព្រះគម្ពីរលូកាគឺជាលើកទីមួយ ចំណែកឯនៅក្នុង កច ៥:៣៧ គឺលើកទីពីរ ។

**២:៣** *ស្រុកកំណើត* គឺទំនងជាទឹកដីដូនតា ។

**២:៤** *ណាសារ៉ែត . . . បេថ្លេហិម* បេថ្លេហិមជាក្រុងដែលស្តេចដាវីឌទ្រង់ប្រសូត (១សយ ១៧:១២ ២០:៦)។ ចម្ងាយផ្លូវពីក្រុងណាសារ៉ែតទៅក្រុងបេថ្លេហិម គឺត្រូវចំណាយពេលធ្វើដំណើរយ៉ាងហោចណាស់ក៏បីថ្ងៃដែរ ។

**២:៥** *ជាមួយនឹងម៉ារា* នាងម៉ារាក៏ជាប់ខ្សែស្រឡាយស្តេចដាវីឌដែរ ហើយគេជឿថា នាងក៏តម្រូវឱ្យចុះឈ្មោះនឹងគេដែរ ។ ប្រទេសស៊ីរីជាអាណាខេត្តរបស់ចក្រភពរ៉ូម៉ាំង និងជាទីតាំងរបស់ទឹកដីសន្យា ។ នៅប្រទេសនេះ មនុស្សស្រីដែលមានអាយុចាប់ពី១២ឆ្នាំឡើងទៅគឺបានតម្រូវឱ្យបង់ពន្ធជំរឿន ហើយចុះឈ្មោះផង ។ *បំរុង ទុកឱ្យធ្វើជាប្រពន្ធ* មើល មថ ១:១៨ និងការពន្យល់ ។

**២:៧** គឺជាការបញ្ជាក់ថា ព្រះយេស៊ូវទ្រង់បានប្រសូតក្នុងក្រោលសត្វ ។ តាមប្រពៃណីបុរាណ គេសន្មតថាក្រោលសត្វនោះគឺជារូងភ្នំ ដែលគេប្រើជាក្រោលសត្វ ។

**២:៨** *នៅឯវាល* មិនសំខាន់នៅត្រង់ថា រដូវពេលនោះជារដូវក្តៅ ឬរដូវប្រាំងនោះឡើយ ។ គេបានបម្រុងទុកហ្វូងចៀមទាំងនោះនៅក្នុងទីវាលក្បែរក្រុងបេថ្លេហិមពេញមួយឆ្នាំ សម្រាប់ធ្វើជាយញ្ញបូជារបស់ព្រះវិហារ ។ *ចាំយាមរក្សា* គឺដើម្បីការពារពួកចោរ និងពួកសត្វសាហាវ ។

**២:៩** *ទេវតានៃព្រះអម្ចាស់* ការហៅដូចនេះ មានប្រើនៅក្នុងការអធិប្បាយពីការប្រសូតតាំងពីដើមរហូតដល់ចប់(១:១១ និងការពន្យល់ មថ ១:២០,២៤ ២:១៣,១៩) ដែលគេស្គាល់ទេវតានៅក្នុង ១:១១ ថាជាទេវតាកាព្រីយែល (១:១៩ មើល ១:២៦ លប ១៦:៧ និងការពន្យល់)។

**២:១០** *កុំខ្លាចអី* ការភ័យខ្លាចកើតមានជាធម្មតានៅពេលបានឃើញទេវតា (ការពន្យល់ ១:១៣) ហើយចាំបាច់ត្រូវមានការលើកទឹកចិត្តឱ្យឈប់ខ្លាច ។ *សេចក្តីអំណរយ៉ាងអស្ចារ្យ* មើលការពន្យល់ ១:១៤ ។

**២:១១** *ក្រុងហ្លួងដាវីឌ* គឺក្រុងបេថ្លេហិម ។ *ព្រះអង្គសង្គ្រោះ* ពួកយូដាជាច្រើនកំពុងតែរកអ្នកដឹកនាំនយោបាយ ដែលអាចរំដោះពួកគេឱ្យរួចពីនឹមត្រួតត្រារបស់ចក្រភពរ៉ូម៉ាំង ចំណែកឯអ្នកផ្សេងទៀតក៏កំពុងតែសង្ឃឹមថានឹងមានព្រះសង្គ្រោះមួយអង្គដែលនឹងរំដោះពួកគេឱ្យរួចចាកពីជំងឺ និងទុក្ខលំបាកផ្លូវកាយ ប៉ុន្តែ ការប្រកាសនេះ គឺជាការប្រកាសអំពីព្រះសង្គ្រោះដែលនឹងរំដោះមនុស្សឱ្យរួចពីបាប និងសេចក្តីស្លាប់(មថ ១:២១ យហ ៤:៤២ និងការពន្យល់)។ *ព្រះគ្រីស្ទ* ឬព្រះ មែស៊ី ដែលពាក្យ "គ្រីស្ទ" ជាពាក្យក្រិក និង"មែស៊ី"ជាពាក្យហេព្រើរ ទាំងពីរមានន័យថា "អង្គដែលត្រូវបានចាក់ប្រេងតាំង"។ *ព្រះអម្ចាស់* ជារបៀបហៅដែលពីដំបូងបំផុតគឺប្រើចំពោះព្រះអម្ចាស់ ប៉ុន្តែ ក្រោយមកក៏ចំពោះព្រះមែស៊ីផងដែរ (កច ២:៣៦ ភល ២:១១)។

**២:១៣,២០** *ពោលសរសើរដល់ព្រះ* មើល ១:៦៤ និងការពន្យល់ ។

**២:១៤** មើលការពន្យល់ ១:៤៦–៥៥។ ទេវតាទាំងឡាយបានទទួលស្គាល់ពីសិរីល្អ និងឫទ្ធានុភាពរបស់ព្រះ ដោយការសរសើរតម្កើងដល់ទ្រង់ ។ *នៅស្ថានដ៏ខ្ពស់បំផុត* គឺសំដៅទៅលើស្ថានសួគ៌ ដែលជាដំណាក់របស់ព្រះ (មថ ៦:៩)។ *សេចក្តីសុខសាន្តនៅផែនដីនៅកណ្តាលមនុស្ស ដែលជាទីគាប់ព្រះហឫទ័យដល់ទ្រង់* សេចក្តីសុខមិនធានាថាមានសម្រាប់គ្រប់មនុស្សនោះទេ គឺមានសម្រាប់តែអ្នកដែលធ្វើគាប់ព្រះហឫទ័យព្រះ ដែលជាទីពេញព្រះទ័យដល់

16 គេក៏ទៅជាប្រញាប់ឃើញម៉ារា និងយ៉ូសែបនៅទីនោះ
ព្រមទាំងព្រះឱរសផ្ដេកនៅក្នុងស្នូកផង[ដ] 17 កាលបានឃើញ
ហើយ នោះគេក៏រ៉ាយរ៉ាប់រឿង ពីសេចក្ដីដែលទេវតាបាន
ប្រាប់ពីព្រះឱរស 18 ហើយអស់អ្នកណាដែលឮ ក៏មាន
សេចក្ដីអស្ចារ្យ ពីពាក្យដែលពួកអ្នកគង្វាលបានប្រាប់មក
19 តែម៉ារានាងរក្សាទុករឿងទាំងនេះ ដោយរំពឹងគិតតែ
ក្នុងចិត្ត[ឈ] 20 ឯពួកអ្នកគង្វាលក៏វិលត្រឡប់ទៅវិញ ទាំង
សរសើរដំកើងដល់ព្រះ[ញ] ដោយព្រោះគ្រប់ទាំងការដែល
គេបានឮ ហើយឃើញនោះ ដូចជាទេវតាបានប្រាប់មក ។

## ព្រះយេស៊ូវមានព្រះវត្តមានក្នុងព្រះវិហារ

21 លុះដល់គំរប់៨ថ្ងៃ កាលត្រូវកាត់ស្បែកព្រះឱរសនោះ[ដ]
គេថ្វាយព្រះនាមថា «យេស៊ូវ» ជានាមដែលទេវតាបានប្រាប់
មុនដែលទ្រង់មកចាប់ទំផ្ទៃ[ឋ] ។
22 លុះដល់កំណត់ កាលត្រូវញែកចេញជាបរិសុទ្ធ តាម
ក្រិត្យវិន័យរបស់លោកម៉ូសេ[ឌ] នោះក៏នាំយកព្រះឱរសទៅ
ឯក្រុងយេរូសាឡិម ដើម្បីថ្វាយដល់ព្រះអម្ចាស់ 23 ដូចជា
មានកត់ទុកមក ក្នុងក្រិត្យវិន័យព្រះអម្ចាស់ថា «គ្រប់ទាំង
កូនប្រុសៗ ដែលកើតពីផ្ទៃម្ដាយមកមុនបង្អស់ នោះត្រូវ
រាប់ជាបរិសុទ្ធថ្វាយព្រះអម្ចាស់»[ឍ] 24 ហើយនិងថ្វាយយញ្ញ

**២:១៦** ដ ខ.៧
**២:១៩** ឈ ខ.៥១
**២:២០** ញ មថ ៩:៨
**២:២១** ដ លក ១:៥៩
ឋ លក ១:៣១
**២:២២** ឌ លវ
១២:២–៨
**២:២៣** ឍ នក ១៣:២,
១២,១៥ ជន ៣:១៣
**២:២៤** ណ លវ
១២:៨
**២:២៥** ត លក ១:៦
ថ ខ.៣៨ អស ៥២:៩
លក ២៣:៥១
**២:២៧** ទ ខ.២២
**២:២៩** ធ កច ២:២៤
ន ខ.២៦
**២:៣០** ប អស ៤០:៥
៥២:១០ លក ៣:៦
**២:៣២** ព អស ៤២:៦
៤៩:៦ កច ១៣:៤៧
២៦:២៣

បូជា តាមសេចក្ដីដែលបានកត់ទុកក្នុងក្រិត្យវិន័យរបស់
ព្រះអម្ចាស់ គឺថា «លលក១គូ ឬព្រាបជំទើរ២»[ណ]។
25 នោះមើលនៅក្រុងយេរូសាឡិម មានមនុស្សម្នាក់
ឈ្មោះស៊ីម្មាន ជាអ្នកសុចរិត ដែលកោតខ្លាចដល់ព្រះ[ត] គាត់
រង់ចាំសេចក្ដីដោះទុក្ខ របស់សាសន៍អ៊ីស្រាអែល[ថ] ហើយ
ព្រះវិញ្ញាណបរិសុទ្ធក៏សណ្ឋិតលើគាត់ 26 ព្រះវិញ្ញាណ
បរិសុទ្ធបានសំដែងឱ្យគាត់ដឹងថា គាត់មិនស្លាប់ឡើយ
ទាល់តែបានឃើញព្រះគ្រីស្ទនៃព្រះអម្ចាស់ 27 គាត់ចូល
មកក្នុងព្រះវិហារដោយនូវព្រះវិញ្ញាណ រួចកាលមាតា
បិតានាំយកព្រះយេស៊ូវ ជាឱរសចូលមក ដើម្បីធ្វើតាម
ទំលាប់ក្រិត្យវិន័យដល់ទ្រង់[ទ] 28 នោះគាត់ក៏ទទួលមកបី
ហើយសរសើរដល់ព្រះដោយពាក្យថា 29 ឥឡូវនេះ ឱព្រះ
ដ៏ជាម្ចាស់អើយ សូមបើកឱ្យបាវបំរើទ្រង់ទៅដោយសុខ
សាន្ត[ធ]តាមព្រះបន្ទូលទ្រង់ចុះ[ន] 30 ដ្បិតភ្នែកទូលបង្គំបាន
ឃើញសេចក្ដីសង្គ្រោះរបស់ផងទ្រង់[ប] 31 ដែលទ្រង់បាន
រៀបចំនៅមុខបណ្ដាជនទាំងឡាយ 32 ជាពន្លឺសំរាប់បំភ្លឺ
ដល់សាសន៍ដទៃ ហើយជាសិរីល្អ របស់អ៊ីស្រាអែល ជារាស្ត្រ
ទ្រង់[ព] 33 ឯយ៉ូសែប និងមាតាទ្រង់ ក៏អស្ចារ្យពីសេចក្ដីទាំង

---

ទ្រង់ (មើលការប្រើពាក្យ "រីករាយ" និង "សព្វព្រះទ័យ" របស់លោកលូកា នៅក្នុង ៣:២២ ១០:២១ ១២:៣២)។ ចក្រភពរ៉ូម៉ាំងធ្លាប់មាន "ភាពសុខសាន្តនៃរ៉ូម៉ាំង" ដែលជាសេចក្ដីសុខខាងផ្លូវកាយ ប៉ុន្តែ ទេវតាបានប្រកាសពីសេចក្ដីសុខសាន្តដែលស្ថិតស្ថេរ គឺសេចក្ដីសុខសាន្តខាងផ្លូវចិត្ត និងព្រលឹងវិញ្ញាណ ដែលព្រះសង្គ្រោះទ្រង់បានបណ្ដាល(ខ.១១)។ សេចក្ដីសុខសាន្តដែលមានជាមួយព្រះ គឺកើតមានពីសេចក្ដីជំនឿលើព្រះគ្រីស្ទ (រម ៥:១ និងការពន្យល់) ហើយព្រះទ្រង់សព្វព្រះហឫទ័យចំពោះអ្នកជឿ ។ ព្រះមែស៊ីនៃហ្លួងដាវីឌត្រូវបានហៅថា "ព្រះអម្ចាស់នៃសន្តិភាព"(អស ៩:៦ និងការពន្យល់) ព្រះគ្រីស្ទទ្រង់បានសន្យាប្រទានសន្តិភាព ដល់ពួកសាវ័ករបស់ទ្រង់ (មើល យហ ១៤:២៧ ភល ៤:៧ និងការពន្យល់) ប៉ុន្តែ ទ្រង់បានមកដើម្បីតាំងឱ្យមានសេចក្ដីទាស់ទែង("ដាវ"មើល មថ ១០:៣៤ និងពន្យល់ លក ១២:៤៩) ដើម្បីសេចក្ដីសុខសាន្តជាមួយនឹងព្រះ ដែលមានការប្រឆាំងនឹងសាតាំង និងកិច្ចការរបស់វា(មើល យក ៤:៧ និងការពន្យល់)។

**២:២១** *កាត់ស្បែក* មើល លប ១៧:១០ យហ ៧:២២ និងការពន្យល់ ។

**២:២២** *ជាបរិសុទ្ធ* ក្រោយពីបានឆ្លងទន្លេហើយ ស្ត្រីជាម្ដាយត្រូវតែរង់ចាំឱ្យបាន៤០ថ្ងៃ មុននឹងទៅព្រះវិហារថ្វាយយញ្ញបូជា ដើម្បីឱ្យនាងបានបរិសុទ្ធ ។ ប្រសិនបើនាងមិនអាចថ្វាយចៀមមួយក្បាល និងព្រាប(ឬលលក)មួយក្បាលទេ នាងអាចថ្វាយព្រាប(ឬលលក)ពីរក្បាលក៏បាន(លវ ១២:២–៨ និងការពន្យល់ លវ ៥:១១)។ *ឯក្រុងយេរូសាឡិម* ចម្ងាយផ្លូវពីក្រុងយេរូសាឡិមទៅក្រុងបេថ្លេហិមគឺ ៨,០៤៥ ទៅ ៩,៦៥៤ គម ។ *នាំ . . . ដល់ព្រះអម្ចាស់* កូនប្រុសច្បងដែលទោះជាមនុស្ស ឬសត្វក្ដី ត្រូវតែញែកចេញទុកសម្រាប់ព្រះ (ខ.២៣ នក ១៣:២–១៣ និងការពន្យល់) ។ ចំពោះសត្វត្រូវតែយកទៅធ្វើយញ្ញបូជា រីឯមនុស្សវិញ ត្រូវតែបម្រើព្រះអស់មួយជីវិត ។ ជាការពិតណាស់ ពួកលេវីបានបម្រើព្រះ ជំនួសពួកកូនច្បងទាំងអស់ ក្នុងសាសន៍អ៊ីស្រាអែល (ជន ៣:១១–១៣ ៨:១៧–១៨)។

**២:២៥** *សេចក្ដីដោះទុក្ខ របស់សាសន៍អ៊ីស្រាអែល* គឺសេចក្ដីកម្សាន្តចិត្តដែលព្រះមែស៊ីទ្រង់បានយាងមក ដើម្បីប្រោសប្រទានឱ្យដល់រាស្ត្រទ្រង់ (មើល ខ.២៦,៣៨ ២៣:៥១ ២៤:២១ អស ៤០:១–២ និងការពន្យល់ មថ ៥:៤)។ *ព្រះវិញ្ញាណបរិសុទ្ធក៏សណ្ឋិតលើគាត់* គឺមិនមែនតាមបែបដូចកាលដែលទ្រង់បានយាងមកសណ្ឋិតលើអ្នកជឿនៅថ្ងៃទី៥០នោះឡើយ ។ លោកស៊ីម្មានបានទទួលការបើកសំដែងជាពិសេសពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឱ្យគាត់អាចឃើញ"ព្រះគ្រីស្ទ" ដែលជាព្រះមែស៊ី(ខ.២៦ ១:១៥ និងការពន្យល់)។

**២:២៨** *សរសើរដល់ព្រះ* មើល ១:៦៤ និងការពន្យល់ ។

**២:២៩–៣២** មើលការពន្យល់ ១:៤៦–៥៥ ។ វគ្គនេះគឺជាបទទំនុកតម្កើងមួយបទ ដែលមានន័យថា "ឥឡូវនេះសូមបើកឱ្យបាវបម្រើទ្រង់ទៅ"។

**២:៣១** *បណ្ដាជនទាំងឡាយ* អាស្រ័យដោយខ្លួនលោកជាសាសន៍ដទៃម្នាក់ លោកលូកាមានការប្រុងប្រយ័ត្ន ក្នុងការនិយាយសង្កត់ធ្ងន់លើសេចក្ដីពិតដែលថា សេចក្ដីសង្គ្រោះត្រូវបានប្រទានមកដល់ទាំងសាសន៍ដទៃ(ខ.៣២) ក៏ដូចជាសាសន៍យូដា ។

**២:៣៣** *ឯយ៉ូសែប និងមាតាទ្រង់* (ព្រះគម្ពីរមួយចំនួនដាក់ថា បិតា និងមាតា ទ្រង់) លោកលូកាយល់ពីការដែលព្រះយេស៊ូវទ្រង់បានប្រសូតពីស្ត្រីព្រហ្មចារី (១:២៦–៣៥)ដូចនេះលោកក៏និយាយសំដៅទៅលើលោកយូសែបថា ជាឪពុក

ប៉ុន្មានដែលគេថ្លែងពីទ្រង់ ៣៤ស៊ីម្មានក៏ឱ្យពរ ហើយ និយាយ
ទៅម៉ារា ជាមាតាទ្រង់ថា[ភ] មើលបុត្រនេះបានតាំងឡើង
សំរាប់ធ្វើឱ្យពួកសាសន៍អ៊ីស្រាអែលជាច្រើនដួល[ម] ហើយ
ងើបឡើងវិញ ក៏សំរាប់ជាទីសំគាល់ដែលគេនឹងស្រដី
ទទឹងផង ៣៥ឯនាងវិញ នឹងមានដាវចាក់ទំលុះព្រលឹង
នាងដែរ ដើម្បីឱ្យគំនិតក្នុងចិត្តរបស់មនុស្សជាច្រើនបាន
សំដែងចេញមក ។
៣៦ហើយមានហោរាស្រីម្នាក់[យ] ឈ្មោះ អាណ ជាកូនផា–
ញូអែល ក្នុងពូជអំបូរអេសើរ គាត់មានប្ដី៧ឆ្នាំ តាំងតែពី
ក្រមុំមក ឥឡូវនេះគាត់ចាស់ណាស់ហើយ ៣៧នៅជាមេម៉ាយ
ប្រហែលជា៨៤ឆ្នាំ[រ] ក៏នៅតែក្នុងព្រះវិហារ មិនដែល
ចេញឡើយ គាត់គោរពទាំងយប់ទាំងថ្ងៃ ដោយការតម
ហើយអធិស្ឋាន[ល] ៣៨គាត់បានឡើងមកនៅវេលានោះឯង
ក៏អរព្រះគុណដល់ព្រះ ព្រមទាំងប្រកាសប្រាប់ ពីព្រះឱរស
ដល់អស់អ្នកដែល នៅរង់ចាំសេចក្ដីប្រោសលោះនៅក្រុង
យេរូសាឡិម[វ] ។
៣៩កាលបានធ្វើសំរេចគ្រប់ទាំងអស់ តាមក្រិត្យវិន័យ
ព្រះអម្ចាស់ហើយ នោះក៏នាំគ្នាត្រឡប់ទៅស្រុកវិញ គឺទៅ
ឯភូមិណាសារ៉ែត ក្នុងស្រុកកាលីឡេ[ស] ៤០ឯព្រះឱរសក៏កាន់
តែមានវ័យចំរើនធំឡើង មានកំឡាំងខាងវិញ្ញាណរឹតតែ
ច្រើនឡើងប្រកបដោយប្រាជ្ញាដ៏ពោរពេញ ហើយព្រះគុណ
នៃព្រះក៏សណ្ឋិតលើទ្រង់ផង[ហ]។

## ព្រះកុមារយេស៊ូវនៅឯព្រះវិហារ

៤១រីឯមាតាបិតាទ្រង់ តែងតែទៅឯក្រុងយេរូសាឡិមនៅ
វេលាបុណ្យរំលងរាល់តែឆ្នាំ[ឡ] ៤២លុះទ្រង់មានព្រះជន្មបាន
១២ឆ្នាំ នោះក៏នាំគ្នាឡើងទៅ តាមទំលាប់បុណ្យ ៤៣តែដល់
ថ្ងៃរួចបុណ្យ ក្នុងកាលដែលគេកំពុងតែត្រឡប់ទៅវិញនោះ
ព្រះកុមារយេស៊ូវទ្រង់បានគង់នៅក្រុងយេរូសាឡិមនៅ
ឡើយ ចំណែកឯយ៉ូសែប នឹងមាតាទ្រង់ឥតបានដឹងទេ
៤៤ស្មានថាទ្រង់គង់នៅក្នុងពួកគេ ក៏ដើរទៅបាន១ថ្ងៃ ទើប
ចាប់ភ្លឹកសួររកទ្រង់ក្នុងពួកញាតិសន្ដាន នឹងពួកអ្នកដែល
ស្គាល់គ្នា ៤៥កាលមិនឃើញ នោះក៏ត្រឡប់ទៅរកទ្រង់ឯក្រុង
យេរូសាឡិមវិញ ៤៦លុះកន្លងក្រោយមក៣ថ្ងៃនោះ ទើប
ឃើញទ្រង់ គង់នៅកណ្ដាលពួកអាចារ្យក្នុងព្រះវិហារ កំពុង
តែស្ដាប់ ហើយនឹងសួរគេ ៤៧ពួកអស់អ្នកដែលឮទ្រង់ក៏
អស្ចារ្យ[អ]ក្នុងចិត្តពីប្រាជ្ញា ហើយនឹងពាក្យចំឡើយរបស់ទ្រង់
៤៨លុះមាតាបិតាបានឃើញទ្រង់ នោះក៏នឹកប្លែកក្នុងចិត្ត
ហើយមាតា[ក]សួរថា កូនអើយ ហេតុអ្វីបានជាអ្នកប្រព្រឹត្ត

**២:៣៤** ភ មថ ១២:៤៦
ម អស ៨:១៤
មថ ២១:៤៤
១កថ ១:២៣
២កថ ២:១៦
កទ ៥:១១
១ពត ២:៧,៨
**២:៣៦** យ កច ២១:៩
**២:៣៧** រ ១ធថ ៥:៩
ល កច ១៣:៣
១៤:២៣ ១ធថ ៥:៥
**២:៣៨** វ ខ.២៥
អស ៤០:២ ៥២:៩
លក ១:៦៨ ២៤:២១
**២:៣៩** ស ខ.៥១
មថ ២:២៣
**២:៤០** ហ ខ.៥២
លក ១:៨០
**២:៤១** ឡ នក ២៣:១៥
ចទ ១៦:១–៨
លក ២២:៨
**២:៤៧** អ មថ ៧:២៨
**២:៤៨** ក មថ ១២:៤៦

ដ៏ស្របច្បាប់របស់ព្រះយេស៊ូវ (មើល ខ.៤១ យហ ១:៤៥ និងការពន្យល់)។
**២:៣៤** *ធ្វើឱ្យពួកសាសន៍អ៊ីស្រាអែលជាច្រើនដួល ហើយងើបឡើងវិញ* ព្រះគ្រីស្ទទ្រង់លើកឡើងចំពោះអស់អ្នកណាដែលជឿលើទ្រង់ តែជាឧបស័គ្គរារាំងមិនឱ្យងើបឡើងបានចំពោះអស់អ្នកណាដែលមិនជឿទ្រង់ (២០:១៧–១៨ មើលពន្យល់ ២០:១៨ ១កថ ១:២៣ ១ពត ២:៦–៨ និងការពន្យល់)។ *ទីសំគាល់ . . . ស្រដីទទឹង* ត្រង់នេះអាចមានន័យថា ព្រះយេស៊ូវជាទីសំគាល់ដែលមកអំពីព្រះអម្ចាស់ (ខ.១២ ១១:៣០) គឺជាអង្គដែលនាំឱ្យមានហេតុនៃការទាស់ទែងគ្នា សេចក្ដីទទឹង និងការបដិសេធន៍ ។
**២:៣៥** *ដាវចាក់ទំលុះព្រលឹងនាងដែរ* ពាក្យ"ដែរ"នៅត្រង់កន្លែងនេះ គឺចង់បង្ហាញឱ្យឃើញថា នាងម៉ារាក៏ដូចជាព្រះយេស៊ូវដែរ គឺនឹងកើតទុក្ខជាខ្លាំង (គឺជាពាក្យដំបូងបំផុតនៅក្នុងព្រះគម្ពីរដំណឹងល្អ ដែលនិយាយទាក់ទងនឹងការរងទុក្ខ និងការសុគតរបស់ព្រះគ្រីស្ទ)។
**២:៣៦** *ហោរាស្រី* ហោរាស្រីដទៃទៀតមានដូចជា នាងម៉ារាម (នក ១៥:២០) ដេបូរ៉ា (ពច ៤:៤) នាងហ៊ុលដា (១ពវ ២២:១៤) និងកូនស្រីទាំងបួនរបស់លោកភីលីព (កច ២១:៩)។ *អាណ* គឺឈ្មោះដែលនៅក្នុងគម្ពីរសញ្ញាចាស់ គេហៅថា"ហាណា" (១សយ ១:២) ដែលមានន័យថា "ប្រកបដោយព្រះគុណ"។ នាងអាណាសរសើរដល់ព្រះ ដោយព្រោះព្រះបុត្រតូចយេស៊ូវ ដូចដែលនាងហាណាបានសរសើរព្រះ ដោយព្រោះក្មេងតូចសាំយូអែល (១សយ ២:១–១០) ផងដែរ ។
**២:៣៧** *នៅតែក្នុងព្រះវិហារ មិនដែលចេញឡើយ* ព្រះវិហារស្ដេចហេរ៉ូឌធំគួសមដែរ មានបន្ទប់ជាច្រើនដែលប្រើក្នុងមុខងារផ្សេងៗពីគ្នា ហើយនាងអាណាអាចបានទទួលនូវការអនុញ្ញាត ឱ្យរស់នៅក្នុងបន្ទប់មួយ ក្នុងចំណោមបន្ទប់ទាំងនោះ ។ គេជឿថាឃ្លានេះ មានន័យថានាងបានចំណាយពេលក្រៅពីពេលដំណេក ចូលរួម និងថ្វាយបង្គំនៅក្នុងព្រះវិហារនោះ ។
**២:៣៨** *យេរូសាឡិម* ទីក្រុងបរិសុទ្ធរបស់រាស្ត្ររើសតាំងរបស់ព្រះអម្ចាស់ក្នុងព្រះគម្ពីរ នេះគឺតំណាងឱ្យអ៊ីស្រាអែលទាំងមូល។ មើលសេចក្ដីផ្ដើមគម្ពីរទំនុកតម្កើងត្រង់វិជ្ជាសិក្សាអំពីព្រះ ។
**២:៣៩** *ទៅ . . . ស្រុកកាលីឡេ* លោកលូកាមិនបានបញ្ជាក់ពីការធ្វើដំណើរមកនៃពួកហោរាទិសខាងកើត (ពួកអ្នកប្រាជ្ញ) គ្រោះថ្នាក់ដែលស្ដេចហេរ៉ូឌបានបង្ករ ឬការភាសខ្លួនទៅ និងការត្រឡប់មកពីប្រទេសអេស៊ីព្ទវិញឡើយ (មថ ២:១–២៣)។
**២:៤១** *បុណ្យរំលង* ការចូលរួមជារៀងរាល់ឆ្នាំក្នុងពិធីបុណ្យទាំងបី ដោយពួកកំលោះៗ (តាមធម្មតាមានគ្រួសារពួកគេមកចូលរួមផងដែរ) គឺជាការតម្រូវឱ្យធ្វើតាមក្រឹត្យវិន័យបុណ្យទាំងនោះមាន បុណ្យនំបុ័ងឥតដំបែ បុណ្យថ្ងៃទី៥០ (ឬអាទិត្យទី៧) និងបុណ្យបារាំ (២របា ៨:១៣ មើលការពន្យល់ នក ២៣:១៤–១៧ ចទ ១៦:១៦)។ ចម្ងាយផ្លូវដ៏សែនឆ្ងាយគឺជាមូលហេតុដែលមនុស្សជាច្រើនខកមិនបានចូលរួមពិធីបុណ្យទាំងបីនោះ ប៉ុន្តែ ភាគច្រើននៃពួកយូដាបានព្យាយាមធ្វើដំណើរមកចូលរួមក្នុងពិធីបុណ្យរំលង ។
**២:៤២** *មានព្រះជន្មបាន១២ឆ្នាំ* កាលណាអាយុបាន១២ឆ្នាំ ក្មេងប្រុសៗចាប់ផ្ដើមត្រៀមខ្លួនចូលរួមក្នុងសហគមន៍សាសនានៅពេលឆ្នាំបន្ទាប់ ។
**២:៤៦** *ពួកអាចារ្យ* គឺពួកគ្រូបង្រៀនសាសនា ដែលជំនាញខាងសាសនាយូដា ។

នឹងយើងដូច្នេះ មើលឪពុក[ខ]អ្នក នឹងម្ដាយ បានខំដើររកអ្នក
ទាំងថប់ព្រួយ ៤៩ទ្រង់មានបន្ទូលតបថា អ្នកម្ដាយរកខ្ញុំធ្វើអី
តើមិនជ្រាបថា គួរឱ្យខ្ញុំនៅក្នុងព្រះវិហាររបស់ព្រះវរបិតា
នៃខ្ញុំទេឬអី[គ] ៥០តែគាត់មិនយល់ពាក្យដែលទ្រង់មានបន្ទូល
នោះទេ[ឃ] ៥១ទ្រង់ក៏ចុះទៅឯភូមិណាសារ៉ែត ជាមួយនឹងគាត់
វិញ[ង] ហើយបាននៅក្នុងឱវាទគាត់ ឯមាតាទ្រង់ បានកំណត់
រឿងទាំងនោះទុកនៅតែក្នុងចិត្ត[ច] ៥២ព្រះយេស៊ូវក៏កាន់តែ
ធំប្រកបដោយប្រាជ្ញារឹតតែច្រើនឡើង ហើយជាទីគាប់ព្រះ
ហឫទ័យដល់ព្រះ នឹងចិត្តមនុស្សផង[ឆ]។

## លោកយ៉ូហាន–បាទីស្ទរៀបចំផ្លូវ

*៣:២–១០–មថ ៣:១–១០ មក ១:៣–៥*
*៣:១៦,១៧–មថ ៣:១១,១២ មក ១:៧,៨*

**៣** ១នៅឆ្នាំទី១៥ ក្នុងរាជ្យសេសារ–ទីបេរ កាលលោកប៉ុន
ទាស–ពីឡាត់[ជ] ធ្វើជាចៅហ្វាយនៅស្រុកយូដា ហេរ៉ូឌ[ឈ] ជា
ស្ដេចអនុរាជនៅស្រុកកាលីឡេ ភីលីព អនុជទ្រង់ ជាស្ដេច
អនុរាជនៅស្រុកអ៊ីទូរេ នឹងនៅក្រវល់ស្រុកត្រាខូនីត លី–
សានាស ជាស្ដេចអនុរាជ នៅស្រុកអាប៊ីលេន ២ហើយក្នុង
កាលដែលលោកអាណ នឹងលោកកៃផាធ្វើជាសំដេច
សង្ឃ[ញ] នោះព្រះទ្រង់មានបន្ទូលមកយ៉ូហាន[ដ] ជាកូនសាការី[ឋ]
នៅទីរហោស្ថាន ៣គាត់ក៏ទៅពេញក្នុងស្រុកជុំវិញទន្លេយ័រ
ដាន់ទាំងអស់ ព្រមទាំងប្រកាសប្រាប់ពីបុណ្យជ្រមុជទឹក ខាង
ឯការប្រែចិត្ត ប្រយោជន៍ ឱ្យបានរួចពីបាប[ឌ] ៤ដូចជា
មានសេចក្ដីចែងទុកមក ក្នុងគម្ពីរដែលកត់ពាក្យទំនាយ
របស់ហោរាអេសាយថា «ជាសំឡេងមនុស្សម្នាក់ដែល
កំពុងតែស្រែកនៅទីរហោស្ថានថា ចូររៀបចំផ្លូវទទួលព្រះ

**២:៤៨** ខ លក ៣:២៣ ៤:២២
**២:៤៩** គ យហ ២:១៦
**២:៥០** ឃ មក ៩:៣២
**២:៥១** ង ខ.៣៩ មថ ២:២៣ ច ខ.១៩
**២:៥២** ឆ ខ.៤០ ១សយ ២:២៦ សភ ៣:៤ លក ១:៨០
**៣:១** ជ មថ ២៧:២ ឈ មថ ១៤:១
**៣:២** ញ មថ ២៦:៣ ដ មថ ៣:១ ឋ លក ១:១៣
**៣:៣** ឌ ខ.១៦ មក ១:៤

**២:៤៩** *ក្នុងព្រះវិហាររបស់ព្រះវរបិតានៃខ្ញុំ* ព្រះយេស៊ូវទ្រង់បានបង្ហាញពីករណីកិច្ច ដែលត្រូវធ្វើសម្រាប់ព្រះវរបិតានៃទ្រង់ដែលគង់នៅស្ថានសួគ៌ ។ ទ្រង់បានបង្ហាញពីភាពខុសគ្នារវាង "ព្រះវរបិតានៃខ្ញុំ" និងពាក្យ"ឪពុកអ្នក" ដែលនាងម៉ារាប្រើ(ខ.៤៨)។ ក្នុងព្រះជន្ម១២ឆ្នាំ ទ្រង់ស្គាល់ពីទំនាក់ទំនង (ដែលមានតែមួយ)ជាមួយនឹងព្រះវរបិតា ប៉ុន្តែ ទ្រង់ក៏មានការគោរពប្រតិបត្តិចំពោះឪពុកម្ដាយនៅលោកិយរបស់ទ្រង់ផងដែរ (ខ.៥១)។

**២:៥២** លោកលូកាបានលើកយកបទមួយក្នុងកណ្ឌគម្ពីរសាំយូអែល (១សយ ២:២៦) ដើម្បីពោលពីព្រះយេស៊ូវ(មើលពន្យល់ខនោះ)។ *កាន់តែធំ* ទោះបីព្រះយេស៊ូវទ្រង់ជាព្រះមែនពិត ប៉ុន្តែ មិនមានការចង្អុលបង្ហាញថា ទ្រង់មានគ្រប់ទាំងប្រាជ្ញា និងចំណេះដឹងតាំងពីកំណើតទេ គឺទ្រង់ដូចជាមានការចម្រើនពេញវ័យដូចក្មេងដទៃដែរ ។

**៣:២–១** ការបញ្ជាក់ពីឆ្នាំទីប៉ុន្មានក្នុងរាជស្ដេចអង្គណា ឬមានអ្នកដឹកនាំរូបណាខ្លះ គឺជាវិធីដែលអ្នកប្រវត្តិសាស្ត្រពីសម័យបុរាណបានប្រើជាញឹកញាប់ដើម្បីប្រាប់ឱ្យដឹងពីកាលបរិច្ឆេទនៃព្រឹត្តិការណ៍អ្វីមួយ ។

**៣:១** *ឆ្នាំទី១៥* គេអាចបញ្ជាក់ពីកាលបរិច្ឆេទមួយចំនួន ដែលអាចយកជាការបានដោយអធិប្បាយប្រើពាក្យដូចនេះ ប៉ុន្តែ កាលបរិច្ឆេទនៅឆ្នាំ២៥–២៦គ.ស (ស្ដេចសេសារទីបេរ ចាប់ផ្ដើមមានអំណាចគ្រប់គ្រងលើបណ្ដាអាណាខេត្តរបស់រ៉ូម៉ាំង នៅ ឆ្នាំ១១ គ.ស) គឺសក្ដិសមបំផុតនឹងជីវប្រវត្តិព្រះយេស៊ូវគ្រីស្ទ ។ ឈ្មោះអ្នកដឹកនាំដទៃទៀតមិនបានជួយដល់ការបង្ហាញពីកាលបរិច្ឆេទនៃការចាប់ផ្ដើមការងារបម្រើព្រះរបស់លោកយ៉ូហានទេ ប៉ុន្តែ គ្រាន់តែបានជួយដល់ការបង្ហាញពីសម័យកាលប្រវត្តិសាស្ត្រប៉ុណ្ណោះ ។ *ប៉ុនទាសពីឡាត់* គឺចៅហ្វាយស្រុកសាសន៍រ៉ូម៉ាំងដែលត្រួតលើស្រុកយូដាចាប់ពីឆ្នាំ២៦ ដល់ ៣៦ គ.ស មានភូមិគ្រឹះនៅក្នុងស្រុកសេសារា នៅលើឆ្នេរមេឌីទែរ៉ាណេ ។(នៅឆ្នាំ ១៩៦១ ពួកអ្នកបុរាណវត្ថុវិទ្យាបានធ្វើកំណាយរកឃើញដណ្ដើរថ្មមួយ ក្នុងរោងមហោស្រពរបស់ចក្រភពរ៉ូម៉ាំង នៅស្រុកសេសារា ដែលស្ថិតនៅក្នុងសម័យកាលលោកពីឡាត់ និងមានការចារឹកអក្សរជាភាសាឡាតាំងថា"លោកចៅហ្វាយស្រុកយូដាប៉ុនទាស–ពីឡាត់") នៅពេលគាត់ទៅយេរូសាឡិម គាត់ស្នាក់នៅក្នុងវាំងដ៏ស្រស់ស្អាត ដែលស្ដេចហេរ៉ូឌ–អធិរាជបានសង់ នៅភាគនិរតីនៃតំបន់ព្រះវិហារ ។ លោកម៉ាកុសបានហៅវាំងនោះថា "ទីកាត់ក្ដី" (មក ១៥:១៦ និងការពន្យល់) គឺទីដែលពួករ៉ូម៉ាំង បើកសវនាការកាត់ទោសព្រះយេស៊ូវ (មើលការពន្យល់ មក ១៤:៥៣–១៥:១៥)។ *ហេរ៉ូឌជាស្ដេចអនុរាជនៅស្រុកកាលីឡេ* នៅពេលស្ដេចហេរ៉ូឌ–អធិរាជចូលទីវង្គត(ឆ្នាំ៤មុនគ.ស.) បុត្រារបស់ទ្រង់មានអើខេឡោស ហេរ៉ូឌ–អង់ទីប៉ាស និងហេរ៉ូឌ–ភីលីព បានទទួលនូវសិទ្ធិអំណាចគ្រប់គ្រងលើអាណាចក្រដែលបានបែងចែករបស់ទ្រង់ ។ ស្ដេចហេរ៉ូឌ–អង់ទីប៉ាស់ បានក្លាយទៅជាស្ដេចអនុរាជនៅស្រុក កាលីឡេ និងស្រុកពើរេ (មថ ១៤:១)។

**៣:២** *លោកអាណា និងលោកកៃផាធ្វើជាសម្ដេចសង្ឃ* លោកអាណាបានធ្វើជាសម្ដេចសង្ឃចាប់តាំងពីឆ្នាំទី៦ គ.ស រហូតដល់ពេលដែលមន្ត្រីរ៉ូម៉ាំងឈ្មោះក្រាទូសទម្លាក់គាត់ពីមុខតំណែងនៅឆ្នាំ១៥គ.ស ។ សិស្សរបស់គាត់មាន លោកអេលីសា ដែលជាកូនលោកកៃផាសដែលជាកូនប្រសា ហើយក្រោយមកមានសិស្សដែលជាកូនប្រុសបួននាក់ទៀត ។ ទោះបីពួករ៉ូម៉ាំងបានដកហូតមុខតំណែងរបស់គាត់ក៏ដោយ ក៏ពួកយូដានៅតែបន្តទទួលស្គាល់សិទ្ធិអំណាចរបស់គាត់ដដែល(យហ ១៨:១៣ កច ៤:៦ និងការពន្យល់) ដូចនេះហើយបានជាលោកលូកាបានបញ្ចេញឈ្មោះគាត់ ព្រមទាំងឈ្មោះសម្ដេចសង្ឃថ្មីដែលពួករ៉ូម៉ាំងបានលើកបន្តុបគឺលោកកៃផាស ។ *បន្ទូល* ជាប្រភពនៃការអធិប្បាយព្រះបន្ទូល និងអំណាចធ្វើបុណ្យជ្រមុជទឹករបស់លោកយ៉ូហាន ។ ព្រះមានបន្ទូលមកកាន់លោកយ៉ូហាន ដូចកាលដែលទ្រង់មានបន្ទូលមកកាន់ពួកហោរា ក្នុងគ្រាសញ្ញាចាស់ (យរ ១:២ ហស ១:១ និងការពន្យល់ អគ ១:៣)។ *ទីរហោស្ថាន* គឺជាទីសោះកក្រោះ គ្មានមនុស្សរស់នៅ គឺមិនចំជាវាលខ្សាច់ ឬទីដែលគ្មានទឹកទេ ។

**៣:៣** *បុណ្យជ្រមុជទឹក ខាងឯការប្រែចិត្ត* "មើលការពន្យល់ មថ ៣:១១"។ ពិធីបុណ្យជ្រមុជទឹករបស់លោកយ៉ូហានគឺជាតំណាងឱ្យការប្រែចិត្ត ដែលរួមមានការព្រួយពីអំពើបាប និងការប្ដេជ្ញាចិត្តរស់នៅក្នុងជីវិតបរិសុទ្ធ ។ *រួចពីបាប* ព្រះគ្រីស្ទទ្រង់ដោះអ្នកដែលបានប្រែចិត្ត ឱ្យរួចពីទោសនៃអំពើបាបដោយទ្រង់សុគតលើឈើឆ្កាង ។

**៣:៤** *រៀបចំផ្លូវ* មុននឹងស្ដេចយាងចេញទៅប្រទេសឆ្ងាយៗម្ដងៗ គេរៀបចំផ្លូវទុកជាមុនថ្វាយដល់ទ្រង់ ចំណែកឯលោកយ៉ូហានវិញ លោកបានរៀបចំផ្លូវថ្វាយព្រះមែស៊ី តាមបែបព្រលឹងវិញ្ញាណ និងសីលធម៌ ដោយផ្ដោតទៅលើការប្រែ

អម្ចាស់ ចូរដំរង់ផ្លូវតូចថ្វាយទ្រង់ចុះ ៥គ្រប់ទាំងច្រកភ្នំនឹង
បានលុបឱ្យពេញ គ្រប់ទាំងភ្នំធំតូចនឹងត្រូវបន្ទាបទៅ ផ្លូវ
ក្ងិកក្ងក់នឹងទៅជាត្រង់ ហើយផ្លូវរដិបរដុបនឹងបានរាបស្មើ
ទៅវិញ ៦នោះគ្រប់ទាំងមនុស្សនឹងឃើញសេចក្តីសង្គ្រោះ
របស់ព្រះ»[ឍ]។
៧គាត់ក៏ពោលដល់មនុស្សទាំងហ្វូង ដែលមកទទួលបុណ្យ
ជ្រមុជពីគាត់ថា ឱពូជពស់វែកអើយ[ណ] តើអ្នកណា បានប្រាប់។
ឱ្យអ្នករាល់គ្នារត់ពីសេចក្តីក្រោធ ដែលត្រូវមក ដូច្នេះ[ត]
៨បើដូច្នេះ ចូរបង្កើតផលដែលសំណឹងការប្រែចិត្តចុះ
កុំឱ្យចាប់តាំងនឹកក្នុងចិត្តថា មានលោកអ័ប្រាហាំជាឰយុ
កោខ្លួននោះឡើយ[ថ] ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាថា ព្រះទ្រង់
អាចនឹងបង្កើតកូនឱ្យលោកអ័ប្រាហាំ ពីថ្មទាំងនេះក៏បាន
ដែរ ៩ប៉ុន្តែ ពូថៅបានដាក់នៅឫសដើមឈើហើយ ដូច្នេះ
អស់ទាំងដើមណាដែលមានផ្លែមិនល្អនោះ ត្រូវកាប់បោះ
ចោលទៅក្នុងភ្លើងចេញ[ទ] ១០បណ្តាមនុស្សក៏សួរគាត់ថា
តើត្រូវឱ្យយើងខ្ញុំធ្វើដូចម្តេចវិញ[ធ] ១១គាត់ឆ្លើយថា អ្នកណា
ដែលមានអាវ២ ត្រូវឱ្យអ្នកនោះចែកដល់អ្នកដែលគ្មាន
ផងហើយអ្នកណាដែលមានស្បៀងអាហារ ក៏ត្រូវធ្វើដូច្នោះ
ដែរ[ន] ១២មានពួកអ្នកយកពន្ធមក ដើម្បីទទួលបុណ្យជ្រមុជ
ទឹកដែរ[ប] គេក៏សួរគាត់ថា លោកគ្រូ តើត្រូវឱ្យយើងខ្ញុំធ្វើ
ដូចម្តេច ១៣គាត់ឆ្លើយថា កុំឱ្យទារពន្ធហួសកំរិតដែលបាន
កំណត់មកឡើយ[ផ] ១៤ក៏មានពួកទាហានសួរគាត់ដែរថា ឯ
យើងខ្ញុំ តើត្រូវធ្វើដូចម្តេច គាត់ឆ្លើយថា កុំឱ្យសង្កត់សង្កិន
ឬចោទបង្កាច់អ្នកឯណាឡើយ[ព] ចូរស្កប់ចិត្តតែនឹងប្រាក់ខែ
របស់អ្នករាល់គ្នាប៉ុណ្ណោះ ។
១៥កាលបណ្តាមនុស្សនៅតែចាំមើល ដោយរិះគិតក្នុងចិត្ត
ពីដំណើរយ៉ូហាន[ភ] ដែលគាត់ជាព្រះគ្រីស្ទ ឬមិនមែន[ម]
១៦នោះយ៉ូហានប្រាប់គេគ្រប់គ្នាថា ឯខ្ញុំៗធ្វើបុណ្យជ្រមុជ
ឱ្យអ្នករាល់គ្នាដោយទឹកក៏ពិត[យ] ប៉ុន្តែ មានព្រះ១អង្គមក
ដែលមានអំណាចលើសជាងខ្ញុំទៅទៀត ខ្ញុំមិនគួរនឹងស្រាយ
ខ្សែស្បែកជើងព្រះអង្គទេ ព្រះអង្គនោះនឹងធ្វើបុណ្យជ្រមុជ
ឱ្យអ្នករាល់គ្នា ដោយព្រះវិញ្ញាណបរិសុទ្ធ ហើយនឹង
ភ្លើងវិញ[រ] ១៧ទ្រង់កាន់ចង្អេរ[ល]នៅព្រះហស្ត ទ្រង់នឹងបោស
រំលីងទីលានទ្រង់ ហើយនឹងប្រមូលស្រូវមកដាក់ក្នុងជង្រុក
ទ្រង់ តែអង្កាម ទ្រង់នឹងដុតក្នុងភ្លើងដែលពន្លត់មិនបាន[វ]
១៨នោះគាត់ក៏ ប្រាប់ដំណឹងល្អដល់បណ្តាមនុស្ស ព្រមទាំង
ទូន្មានសេចក្តីជាច្រើនទៀតដែរ ១៩ប៉ុន្តែ កាលគាត់បានបន្ទោស
ហេរ៉ូឌ[ស] ជាស្តេចអនុរាជពីរឿងហេរ៉ូឌាស ជាភរិយារបស់

**៣:៦** ឍ ទដ ៩៨:២ អស ៤០:៣–៥ ៤២:១៦ ៥២:១០ លក ២:៣០
**៣:៧** ណ មថ ១២:៣៤ ២៣:៣៣ ត រម ១:១៨
**៣:៨** ថ អស ៥១:២ លក ១៩:៩ យហ ៨:៣៣,៣៩ កច ១៣:២៦ រម ៤:១,១១,១២, ១៦,១៧ ៩:៧,៨ កទ ៣:៧
**៣:៩** ទ មថ ៣:១០
**៣:១០** ធ ខ.១២,១៤ កច ២:៣៧ ១៦:៣០
**៣:១១** ន អស ៥៨:៧ អគ ១៨:៧
**៣:១២** ប លក ៧:២៩
**៣:១៣** ផ លក ១៩:៨
**៣:១៤** ព នក ២៣:១ លវ ១៩:១១
**៣:១៥** ភ មថ ៣:១ ម យហ ១:១៩,២០ កច ១៣:២៥
**៣:១៦** យ ខ.៣ មក ១:៤ រ យហ ១:២៦,៣៣ កច ១:៥ ២:៣ ១១:១៦ ១៩:៤ **៣:១៧** ល អស ៣០:២៤ វ មថ ១៣:៣០ ២៥:៤១ **៣:១៩** ស ខ.១ មថ ១៤:១

ចិត្ត និងការអត់ទោសបាប និងសេចក្តីត្រូវការព្រះសង្គ្រោះ ។

**៣:៦** *គ្រប់ទាំងមនុស្ស* សេចក្តីសង្គ្រោះរបស់ព្រះត្រូវប្រកាសប្រាប់ដល់ទាំងពួកសាសន៍យូដា និងពួកសាសន៍ដទៃ ដែលនេះគឺជាគោលបំណងសំខាន់របស់ព្រះគម្ពីរដំណឹងល្អលូកា(មើលការពន្យល់ ២:៣១) ។

**៣:៧** *សេចក្តីក្រោធ ដែលត្រូវមក* គឺសំដៅទៅលើការបំផ្លិចបំផ្លាញទីក្រុងយេរូសាឡិម (២១:២០-២៣) ដែលកើតឡើងនៅឆ្នាំ៧០គ.ស និងការជំនុំជម្រះនៅទីអវសាន(យហ ៣:៣៦ ប៉ុន្តែ សូមមើលការពន្យល់ ១ថន ១:១០ ៥:៩) ។

**៣:៩** *ពូថៅ . . . ឫសដើមឈើ* គឺការប្រកាសដោយប្រើនិមិត្តរូបដែលមានន័យថាការជំនុំជម្រះជិតមកដល់អ្នកដែលគ្មានទីបន្ទាល់ពីការប្រែចិត្តហើយ ។ *ភ្លើង* គឺការជំនុំជម្រះរបស់ព្រះ (មថ ៧:៩ ១៣:៤២ និងការពន្យល់ បទ ១:១៣ និងការពន្យល់)។

**៣:១២** *ពួកអ្នកយកពន្ធ* ការប្រមូលពន្ធឱ្យរដ្ឋាភិបាលរ៉ូម៉ាំងជាតួនាទីរបស់ពួកភ្នាក់ងារដែលជាសាសន៍យូដា ។ គេស្អប់ពួកយកពន្ធទាំងនេះយ៉ាងខ្លាំងពីព្រោះពួកគេជួយពួកឈ្លានពានដែលជាសាសន៍ដទៃ ហើយជាញឹកញាប់ថែមទាំងបានគៃបន្លំជនជាតិឯងទៀតផង(មើលការពន្យល់ មថ ៥:៤៦ មក ២:១៦) ។

**៣:១៤** *ពួកទាហាន* គឺកងកម្លាំងទាហានដែលច្បាប់អនុញ្ញាតឱ្យបម្រើពួកអ្នកដឹកនាំសាសន៍យូដានិងស្ថាប័នសំខាន់ៗ(ពួកទាហានស្តេចហេរ៉ូឌ–អង់ទីប៉ាស់ ពួកទាហានយាមព្រះវិហារ និងពួកការពារពួកអ្នកយកពន្ធ)។ ការងារដែលពួកអ្នកយកពន្ធ និងពួកទាហានធ្វើ គឺមិនគួរឱ្យស្អប់ខ្ពើមឡើយ ប៉ុន្តែដែលគួរឱ្យស្អប់ខ្ពើមនោះ គឺជាការអាក្រក់ដែលពួកគេបានប្រព្រឹត្តខុសពីលក្ខខ័ណ្ឌនៃការងារ ។

**៣:១៦** *បុណ្យជ្រមុជ . . . ដោយព្រះវិញ្ញាណបរិសុទ្ធ* ការនេះបានសម្រេចនៅថ្ងៃបុណ្យទី៥០(កច ១:៥ ២:៤,៣៨ និងការពន្យល់)។ *ហើយនឹងភ្លើង* ក្នុងខនេះ គឺទាក់ទងការជំនុំជម្រះ(ខ.១៧ បទ ១:១៣ និងការពន្យល់)។ ភ្លើងនៅថ្ងៃបុណ្យទី៥០ (កច ២:៣ និងការពន្យល់) និងភ្លើងនៃការល្បងមើល(១កថ ៣:១៣)។

**៣:១៧** *ចង្អេរនៅព្រះហស្តទ្រង់* មើលការពន្យល់ នរ ១:២២ ។ អង្កាមគឺតំណាងឱ្យពួកអ្នកមិនប្រែចិត្ត តែស្រូវវិញតំណាងឱ្យពួកអ្នកសុចរិត ។ ពួកយូដាជាច្រើនបានយល់ថា មានតែពួកសាសន៍ដទៃប៉ុណ្ណោះដែលនឹងត្រូវជាប់ជំនុំជម្រះនិងទទួលទោសនៅពេលព្រះមែស៊ីទ្រង់យាងមកប៉ុន្តែលោកយ៉ូហានបានប្រកាសថា អស់អ្នកដែលមិនព្រមប្រែចិត្ត និងជាប់ជំនុំជម្រះ គឺរួមទាំងពួកយូដាផងដែរ ។

**៣:១៩** *បន្ទោសហេរ៉ូឌ . . . ពីរឿងហេរ៉ូឌាស* ស្តេចហេរ៉ូឌ–អង់ទីប៉ាស់បានអភិសេកជាមួយបុត្រីស្តេចអើរេតាសទី៤ នៃប្រទេសអារ៉ាប់ តែទ្រង់បានលែងនាង ហើយយកនាងហេរ៉ូឌាសជាក្មួយស្រីទ្រង់វិញ ដែលនាងជាប្រពន្ធអនុជទ្រង់សោះ (ហេរ៉ូឌ–ភីលីព មើល មថ ១៤:៣ និងមើលការពន្យល់ មក ៦:១៧)។

# ទឹកដីបរិសុទ្ធក្នុងរជ្ជកាលស្តេចហេរ៉ូឌ




ប្រទេសប៉ាឡេស្ទីនជំនាន់ព្រះគ្រីស្ទ

អនុជទ្រង់ ហើយពីគ្រប់ ទាំងការអាក្រក់ ដែលទ្រង់បានធ្វើ
២០ នោះទ្រង់បានបន្ថែម ការនេះទៀត គឺបានចាប់គាត់ដាក់
គុក[ហ] ។

**ការទទួលបុណ្យជ្រមុជទឹក និងពង្សាវតារបស់ព្រះយេស៊ូវ**

*៣:២១,២២–មថ ៣:១៣–១៧ មក ១:៩–១១*

*៣:២៣–៣៨–មថ ១:១–១៧*

២១ លុះកាលបណ្ដាជនទាំងប៉ុន្មាន បានទទួលបុណ្យជ្រមុជហើយ
នោះព្រះយេស៊ូវក៏ទទួលដែរ រួចកំពុងដែលទ្រង់អធិស្ឋាន[ឡ]
នោះស្រាប់តែមេឃរបើកឡើង ២២ ហើយព្រះវិញ្ញាណបរិសុទ្ធ
ក៏យាងចុះមកសណ្ឋិតលើទ្រង់[អ] មានរូបរាងដូចជាសត្វព្រាប
ក៏ឮសំឡេងចេញពីមេឃថា ឯងជាកូនស្ងួនភ្ងាអញ[ក] ជាទី
ពេញចិត្តអញណាស់[ខ] ។
២៣ ឯព្រះយេស៊ូវ កាលទ្រង់ចាប់តាំងប្រារព្ធការ[គ] នោះទ្រង់
មានព្រះជន្មប្រហែលជា៣០ឆ្នាំ ហើយតាមដែលគេគិតស្មាន
នោះថាទ្រង់ជាកូនយ៉ូសែប[ឃ] ដែលជាកូនហេលី ២៤ ហេលីជា
កូនម៉ាត់ថាត់ៗ ជាកូនលេវីៗ ជាកូនម៉ិលគីៗ ជាកូនយ៉ា
ណាយៗ ជាកូនយ៉ូសែប ២៥ យ៉ូសែបជាកូនរបស់ម៉ាតាធាសៗ
ជាកូនហាម៉ូសៗ ជាកូនណាអ៊ូមៗ ជាកូនអែសលីៗ ជាកូន
ណាកៃ ២៦ ណាកៃជាកូនម៉ាអាតៗ ជាកូនម៉ាតាធាសៗ
ជាកូនសេម៉ីៗ ជាកូនយ៉ូសែបៗ ជាកូនយូដា ២៧ យូដាជាកូន
យ៉ូអាណាន់ៗ ជាកូនរេសាៗ ជាកូនសូរ៉ូបាបិល[ង]ៗ ជាកូន
សាលធាលៗ ជាកូននេរី ២៨ នេរីជាកូនម៉ិលគីៗ ជាកូនអ័ត
ឌីៗ ជាកូនកូសាមៗ ជាកូនអែលម៉ូដាម អែលម៉ូដាមជាកូន
អ៊ើរ ២៩ អ៊ើរជាកូនយ៉ូសេៗ ជាកូនអេលាសើរៗ ជាកូនយ៉ូ
រិមៗ ជាកូនម៉ាត់ថាត់ៗជាកូនលេវី ៣០ លេវីជាកូនស៊ីម្មានៗ
ជាកូនយូដាៗ ជាកូនយ៉ូសែបៗ ជាកូនយ៉ូណានៗ ជាកូនអេ
លាគីម ៣១ អេលាគីមជាកូនមេលាសៗ ជាកូនម៉ៃណានៗ
ជាកូនម៉ាតាថាៗ ជាកូនរបស់ណាថាន់[ច]ៗ ជាកូនដាវីឌ
៣២ ដាវីឌជាកូនអ៊ីសាយៗ ជាកូនអូបិឌៗ ជាកូនបូអូសៗ ជាកូន
សាលម៉ូនៗ ជាកូនរបស់ណាសូន ៣៣ ណាសូនជាកូនអេមី
ន៉ាដាប់ៗ ជាកូនអើរ៉ាម អើ- រ៉ាមជាកូនអែសរ៉ូមៗ ជាកូន
ពេរេស[ឆ]ៗ ជាកូនរបស់យូដា ៣៤ យូដាជាកូនយ៉ាកុបៗ ជាកូន

**៣:២០** ហ មថ ១៤:៣,៤
**៣:២១** ឡ មថ ១៤:២៣ មក ១:៣៥ ៦:៤៦ លក ៥:១៦ ៦:១២ ៩:១៨,២៨ ១១:១
**៣:២២** អ អស ៤២:១ យហ ១:៣២,៣៣ កច ១០:៣៨ ក មថ ៣:១៧ ខ មថ ៣:១៧
**៣:២៣** គ មថ ៤:១៧ កច ១:១ ឃ លក ១:២៧
**៣:២៧** ង មថ ១:១២
**៣:៣១** ច សយ ៥:១៤ ១រប ៣:៥
**៣:៣៣** ឆ នរ ៤:១៨–២២ ១រប ២:១០–១២

**៣:២០** *ចាប់គាត់ដាក់គុក* តាមលោកប្រវត្តិវិទូយ៉ូសែបហ្វីស (Josephus) គេបានដាក់គុកលោកយ៉ូហាន ក្នុងបន្ទាយទាហានមាកេរ៉ូស (Machaerus) នៅខាងកើតសមុទ្រស្លាប់ ។ ការនេះមិនទាន់បានកើតឡើងនៅឡើយទេ រហូតដល់ពេលណាមួយក្រោយពេលពីព្រះយេស៊ូវបានចាប់ផ្ដើមព្រះរាជកិច្ចទ្រង់ហើយ (យហ ៣:២២–២៤) ប៉ុន្តែ លោកលូកាបានបញ្ជាក់ពីការនេះ ដើម្បីបញ្ចប់វគ្គបេសកកម្មលោកយ៉ូហានជាមុនសិន មុននឹងចាប់ផ្ដើមវគ្គព្រះរាជកិច្ចទ្រង់ (មថ ៤:១២ មក ១:១៤) ហើយសិមនិយាយសង្ខេបពីការស្លាប់របស់លោកយ៉ូហាន (៩:៧–៩) ។

**៣:២១** *បានទទួលបុណ្យជ្រមុជហើយ* មើលការពន្យល់ មថ ៣:១៥ ។ *កំពុងដែលទ្រង់អធិស្ឋាន* មានតែលោកលូកាម្នាក់គត់បានបញ្ជាក់ថា ព្រះយេស៊ូវទ្រង់បានអធិស្ឋាននៅពេលបុណ្យជ្រមុជទឹក ។ ការនិយាយពីការអធិស្ឋានរបស់ព្រះយេស៊ូវ គឺជាលក្ខណៈពិសេសមួយក្នុងចំណោមលក្ខណៈពិសេសៗរបស់ព្រះគម្ពីរលូកា (៥:១៦ ៦:១២ ៩:១៨,២៨–២៩ ១១:១ ២២:៣២,៤១ ២៣:៣៤,៤៦) ។

**៣:២២** *ព្រះវិញ្ញាណបរិសុទ្ធក៏យាង* លោកលូកាបាននិយាយលំអិតអំពី "សណ្ឋាន" ចំពោះលោកយ៉ូហាន នោះគឺជាសញ្ញា (យហ ១:៣២–៣៤ មើលការពន្យល់ មក ១:១០) ។ *កូនស្ងួនភ្ងាអញ ជាទីពេញចិត្តអញណាស់* មើល ទដ ២:៧–៩ អស ៤២:១ ហាព ១:៥ និងការពន្យល់ ។ មានចំនួនពីរដងទៀត ដែលពួកអ្នកនិពន្ធកណ្ឌព្រះគម្ពីរដំណឹងល្អបានកត់ត្រាទុក នូវការប្រកាសពីព្រះយេស៊ូវ ដោយសំឡេងឮពីស្ថានសួគ៌មក (១).ការផ្លាស់ប្រែនៅលើភ្នំ (៩:៣៥) (២).នៅក្នុងទីធ្លាព្រះវិហារក្នុងអំឡុងពេលនៃសប្ដាហ៍ចុងក្រោយរបស់ទ្រង់ (យហ ១២:២៨) ។

**៣:២៣-៣៨** មានលក្ខណៈខុសគ្នាមួយចំនួនរវាងបញ្ជីពង្សាវតារក្នុងព្រះគម្ពីរលូកា និងម៉ាថាយ (១:២–១៦) ។ ព្រះគម្ពីរម៉ាថាយចាប់រាប់ពីឈ្មោះលោកអ័ប្រាហាំ (ឪពុកសាសន៍យូដា) ផ្ទុយពីព្រះគម្ពីរលូកាដែលបានរាប់បញ្ច្រាសឆ្ពោះទៅរកឈ្មោះលោកអ័ដាមវិញ ដែលជារបៀបបង្ហាញពីទំនាក់ទំនងរវាងព្រះយេស៊ូវជាមួយនឹងពូជពង្សនៃមនុស្សជាតិ (ការពន្យល់ ២:៣១) ។ ពីលោកអ័ប្រាហាំដល់ស្ដេចដាវីឌ បញ្ជីពង្សាវតារទាំងពីរស្ទើតែដូចគ្នាទាំងស្រុង តែចាប់ពីស្ដេចដាវីឌរហូតមកគឺខុសគ្នាវិញ ។ ពួកអ្នកកាត់ស្រាយជាច្រើនយល់ថា ពីព្រោះលោកម៉ាថាយបានយកតាមខ្សែស្រឡាយនៃវង្សានុវង្សដែលជាកូនចៅជំនាន់ក្រោយនៃហ្លួងដាវីឌ ដែលមានតែអ្នកស្នងមរតករាជ្យបល្ល័ង្កប៉ុណ្ណោះ ចំណែកឯលោកលូកាបានយកតាមខ្សែលោហិតផ្ទាល់ពីលោកយ៉ូសែបដល់ស្ដេចដាវីឌ (សេចក្ដីផ្ដើម ១រប) ។ មានការបកស្រាយមួយទៀតថា លោកម៉ាថាយបានយកតាមខ្សែស្រឡាយរបស់លោកយ៉ូសែប (ឪពុកស្របច្បាប់របស់ព្រះយេស៊ូវ សូមមើល មថ ១:៦–៧,១៦) ចំណែកឯលោកលូកាវិញ លោកបានសង្កត់ធ្ងន់លើខ្សែស្រឡាយនាងម៉ារា (ទ្រង់មានខ្សែលោហិតជាប់ជាមួយនឹងលោកណាថាន់ ខ.៣១) ។ ទោះជាការតាមពង្សាវតាររបស់សាច់ឈាមខាងម្ដាយជារឿងមិនធម្មតា ដូចនេះការប្រសូតពីស្ដ្រីព្រហ្មចារីក៏អញ្ចឹងដែរ ។ ការពន្យល់របស់លោកលូកា នៅត្រង់ចំណុចនេះគឺព្រះយេស៊ូវទ្រង់ជាកូនប្រុសរបស់លោកយ៉ូសែប ដែលជាការដែល "គេគិតស្មាន" (ខ.២៣) ។ ការពន្យល់នេះបង្ហាញយ៉ាងច្បាស់លាស់ពីការប្រសូតពីស្ដ្រីព្រហ្មចារីរបស់ព្រះគ្រីស្ទ (១:៣៤–៣៥) ហើយបានលើកឡើងពីសារសំខាន់នៃតួនាទីរបស់នាងម៉ារានៅក្នុងបញ្ជីពង្សាវតា ។

**៣:២៣** *ប្រហែលជា៣០ឆ្នាំ* លោកប្រវត្តិវិទូលូកាបានផ្សាភ្ជាប់ការចាប់ផ្ដើមនៃព្រះរាជកិច្ចរបស់ព្រះយេស៊ូវ ជាមួយនឹងប្រវត្តិសាស្ត្រពិភពលោក និងព្រះជន្មគង់នៅរបស់ទ្រង់ ។ មានអាយុ៣០ឆ្នាំ គឺជាវ័យដែលពួកលេវីត្រូវចូលបម្រើការងារព្រះ (នរ ៤:៤៧) និងជាពេលដែលគេចាត់ទុកមនុស្សប្រុសថាពេញវ័យ ។ *គេគិតស្មាន* មុននេះលោកលូកាបានពោលពីការប្រសូតពីស្ដ្រីព្រហ្មចារី (១:៣៤–៣៥) ហើយនៅត្រង់នេះ គឺលោកបានបញ្ជាក់ឱ្យបានច្បាស់លាស់ម្ដងទៀតថា លោកយ៉ូសែបមិនមែនជាឪពុកខាងសាច់

អ៊ីសាក។ ជាកូនអ័ប្រាហាំ អ័ប្រាហាំជាកូនថេរ៉ា ។ ជាកូនណា
យរ[ជ] ៣៥ណាយរជាកូនសេរូក។ ជាកូនរេហ៊ូវ។ជាកូនផា
លេក។ ជាកូនហេប៊ើរ។ ជាកូនសេឡា ៣៦សេឡាជាកូនកៃ
ណាន។ ជាកូនរបស់អើប៉ាក់សាឌ[ឈ]។ ជាកូនសិម ។ ជាកូនណូ
អេ។ជាកូនឡាមេក[ញ] ៣៧ឡាមេកជាកូនមធូសាឡា។ ជាកូន
ហេណុក។ ជាកូនយ៉ារេឌ។ ជាកូនម៉ាលេលាស។ជាកូន
របស់កៃណាន[ដ] ៣៨កៃណានជាកូនអេណុស។ ជាកូនសេត។
ជាកូនអ័ដាម អ័ដាម ជាកូនព្រះ[ឋ]។

## កាលល្បួងព្រះយេស៊ូវ

*៤:១-១៣-មថ ៤:១-១១ មក ១:១២,១៣*

**៤** ១រីឯព្រះយេស៊ូវទ្រង់បានពេញជាព្រះវិញ្ញាណបរិសុទ្ធ[ឌ]
ក៏វិលពីទន្លេយ័រដាន់មកវិញ[ឍ] នោះព្រះវិញ្ញាណ[ណ] នាំទៅនៅ
ទីរហោស្ថាន ២ទ្រង់ត្រូវអារក្សល្បួង[ត]ក្នុងរវាង៤០ថ្ងៃ[ថ] មិន
បានសោយអ្វីសោះនៅវេលានោះ លុះផុតថ្ងៃទាំងនោះមក
ទ្រង់ក៏ឃ្លាន ៣ហើយអារក្សទូលទ្រង់ថា បើអ្នកជាព្រះរាជ
បុត្រានៃព្រះមែន[ទ] ចូរបង្គាប់ឱ្យថ្មនេះត្រឡប់ជានំបុ័ងទៅ
៤តែព្រះយេស៊ូវមានបន្ទូលតបថា មានសេចក្ដីចែងទុកមក
ថា «មនុស្សមិនមែនរស់ ដោយសារតែនំបុ័ងប៉ុណ្ណោះទេ គឺ
រស់ដោយសារគ្រប់ទាំងព្រះបន្ទូលនៃព្រះវិញ»[ធ]។
៥អារក្សក៏នាំទ្រង់ទៅលើកំពូលភ្នំយ៉ាងខ្ពស់ បង្ហាញនគរនៅ
លោកីយទាំងអស់ក្នុង១ភ្លែតនោះ[ន] ៦ហើយទូលថា ខ្ញុំនឹង
ឱ្យអំណាច នឹងសិរីលំអរនៃនគរទាំងនេះដល់អ្នក ដ្បិតបាន
ប្រគល់មកខ្ញុំហើយ[ប] ខ្ញុំនឹងឱ្យដល់អ្នកណាស្រេចនឹងចិត្តខ្ញុំ
៧ដូច្នេះ បើអ្នកក្រាបថ្វាយបង្គំខ្ញុំ នោះទាំងអស់នឹងបាន
ជា របស់អ្នក ៨តែព្រះយេស៊ូវឆ្លើយតបថា សាតាំងអើយ ចូរ
ថយទៅក្រោយអញទៅ ដ្បិតមានសេចក្ដីចែងទុកមកថា «ត្រូវ
ឱ្យឯងថ្វាយបង្គំដល់ព្រះអម្ចាស់ ជាព្រះនៃឯង ហើយត្រូវ
គោរពដល់ទ្រង់តែ១ព្រះអង្គប៉ុណ្ណោះ»[ផ]។
៩រួចវានាំទ្រង់ទៅឯក្រុងយេរូសាឡិម ដាក់នៅលើកំពូល
ព្រះវិហារទូលថា បើអ្នកជាព្រះរាជបុត្រានៃព្រះមែន ចូរ
ទំលាក់ខ្លួនពីនេះទៅក្រោមចុះ ១០ដ្បិតមានសេចក្ដីចែងទុក
មកថា «ទ្រង់នឹងបង្គាប់ពួកទេវតាទ្រង់ ពីដំណើរអ្នក ឱ្យ
ថែរក្សាអ្នក ១១ទេវតានោះនឹងទ្រអ្នកដោយដៃក្រែងជើង
អ្នកទង្គិចនឹងថ្ម[ព] ១២តែព្រះយេស៊ូវមានបន្ទូលតបថា មាន
បទគម្ពីរដែលថា «កុំឱ្យឯងល្បួងព្រះអម្ចាស់ ជាព្រះនៃឯង
ឡើយ»[ភ] ១៣កាលអារក្សបានល្បួងសព្វគ្រប់ហើយ[ម]នោះក៏
ថយចេញ ពីទ្រង់ទៅ[យ] ទាល់តែមានឱកាសទៀត ។

## ការបដិសេធន៍ព្រះយេស៊ូវនៅភូមិណាសារ៉ែត

១៤ឯព្រះយេស៊ូវទ្រង់វិលទៅស្រុកកាលីឡេវិញ[រ] ទាំងមាន
ព្រះចេស្ដានៃព្រះវិញ្ញាណសណ្ឋិតលើទ្រង់ នោះមានឮល្បឺ
ពីទ្រង់សុសសាយទូទៅក្នុងស្រុកនៅជុំវិញ[ល] ១៥ទ្រង់បង្រៀន
ក្នុងសាលាប្រជុំរបស់គេ[វ] ហើយគេក៏សរសើរដំកើងទ្រង់
ទាំងអស់គ្នា ១៦រួចទ្រង់យាងមកដល់ណាសារ៉ែត[ស] ជាស្រុក

**៣:៣៤** ជ លប ១១:២៤,២៦ **៣:៣៦** ឈ លប ១១:១២ ញ លប ៥:២៨-៣២ **៣:៣៧** ដ លប ៥:១២-២៥ **៣:៣៨** ឋ លប ៥:១,២,៦-៩ **៤:១** ឌ ឧ.១៤,១៨ លក ១:១៥,៣៥ ៣:១៦,២២ ១០:២១ ឍ លក ៣:៣,២១ ណ អគ ៣៧:១ លក ២:២៧ **៤:២** ត ហព ៤:១៥ ថ នក ៣៤:២៨ ១ពវ ១៩:៨ **៤:៣** ទ មថ ៤:៣ **៤:៤** ធ ចទ ៨:៣ **៤:៥** ន មថ ២៤:១៤ **៤:៦** ប យហ ១២:៣១ ១៤:៣០ ១យហ ៥:១៩ **៤:៨** ផ ចទ ៦:១៣ **៤:១១** ព ទដ ៩១:១១,១២ **៤:១២** ភ ចទ ៦:១៦ **៤:១៣** ម ហព ៤:១៥ យ យហ ១៤:៣០ **៤:១៤** រ មថ ៤:១២ ល មថ ៩:២៦ **៤:១៥** វ មថ ៤:២៣ **៤:១៦** ស មថ ២:២៣

ឈាមរបស់ព្រះយេស៊ូវឡើយ ។

**៤:១** *ពេញជាព្រះវិញ្ញាណបរិសុទ្ធ* លោកលូកាមិនគ្រាន់តែបាននិយាយសង្កត់ធ្ងន់ពីព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងព្រះគម្ពីរដំណឹងល្អលូកាប៉ុណ្ណោះទេ (១:៣៥,៤១,៦៧ ២:២៥-២៧ ៣:១៦,២២ ៤:១៤,១៨ ១០:២១ ១១:១៣ ១២:១០,១២) ប៉ុន្តែ ថែមទាំងបាននិយាយនៅក្នុងព្រះគម្ពីរកិច្ចការបានចំនួន ៥៧ដងទៀតផង ។ *នៅទីរហោស្ថាន* គឺទីរហោស្ថាននៃស្រុកយូដា (មើលការពន្យល់ ១:៨០ មថ ៣:១) ។

**៤:៣** *បើអ្នកជាព្រះរាជបុត្រានៃព្រះ* មើលការពន្យល់ មថ ៤:៣ ។

**៤:៦** *អំណាច . . . ប្រគល់មកខ្ញុំហើយ* គេហៅសាតាំងនៅក្នុងបទគម្ពីរដទៃទៀតថា "ចៅហ្វាយរបស់លោកិយ" (យហ ១២:៣១) "ព្រះរបស់លោកិយ" (២កថ ៤:៤) និង "មេគ្រប់គ្រងរាជ្យលើអាកាស" (អភ ២:២) ប៉ុន្តែ ស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងរបស់ព្រះទេ (មើលការពន្យល់ ២សយ ២៤:១ យប ១:១២ ២កថ ៤:៤) ។

**៤:៧** *ក្រាបថ្វាយបង្គំខ្ញុំ* អារក្សកំពុងល្បួងឱ្យព្រះយេស៊ូវជៀសចេញពីការរងទុក្ខនៅលើឈើឆ្កាង ជាការដែលទ្រង់បានយាងមកដើម្បីទទួល (មក ១០:៤៥ និងការពន្យល់) ។ ការល្បួងនេះបានបញ្ជាក់ពីអំណាចគ្រប់គ្រងលោកិយរបស់អារក្ស ។

**៤:៩** *កំពូលព្រះវិហារ* គឺនៅម្តុំជ្រុងខាងត្បូងឆៀងខាងកើតនៃជួរសសរព្រះវិហារដែលមានកម្ពស់៣០ម៉ែត្រពីជ្រោះគីដ្រូន ។

**៤:១០** *ដ្បិតមានសេចក្ដីចែងទុកមកថា* ពេលនេះសាតាំងបានដកស្រង់យកបទគម្ពីរមកប្រើក្នុងផ្លូវអាក្រក់ (ទដ ៩១:១១-១២) ។

**៤:១២** ព្រះយេស៊ូវបានឆ្លើយតបចំពោះសេចក្ដីល្បួងទាំងបីដោយប្រើបទគម្ពីរ ។ ចំពោះសេចក្ដីល្បួងទីបី គឺទ្រង់បានដកស្រង់បទព្រះគម្ពីរចោទិយកថា ៦:១៦ ។

**៤:១៣** *ថយចេញពីទ្រង់ទៅ ទាល់តែមានឱកាសទៀត* អារក្សបានបន្តល្បួងព្រះយេស៊ូវនៅពេលក្រោយៗទៀត (មក ៨:៣៣ និងការពន្យល់) ហើយល្បួងខ្លាំងជាងគេបំផុតគឺនៅច្បារគែតសេម៉ានី ។

**៤:១៤** *ទាំងមានព្រះចេស្ដានៃព្រះវិញ្ញាណសណ្ឋិតលើទ្រង់* មើលពន្យល់ ឧ.១។

**៤:១៥** *ទ្រង់បង្រៀនក្នុងសាលាប្រជុំរបស់គេ* មើលការពន្យល់ មក ១:២១ ។

**៤:១៦** *ទ្រង់យាងមកដល់ណាសារ៉ែត* គឺមិនមែននៅពេលចាប់ផ្តើមព្រះរាជកិច្ចរបស់ទ្រង់ទេ តែប្រហែលនៅពេលបន្ទាប់ពីទ្រង់បានចាប់ផ្តើមព្រះរាជកិច្ចបានមួយឆ្នាំហើយ (តាមឧ.២៣ យើងអាចសន្និដ្ឋានបានថា ព្រះយេស៊ូវទ្រង់កំពុងតែបំពេញព្រះរាជកិច្ច) ។ គេជឿថាហេតុការណ៍ទាំងអស់នៅក្នុង យហ ១:១៩-៤:៤២ កើតឡើងនៅចន្លោះ លក ៤:១៣ និង ៤:១៤ ។ *តាមទំលាប់*

ដែលទ្រង់គង់នៅពីកុមារ ក៏ចូលទៅក្នុងសាលាប្រជុំនៅថ្ងៃ
ឈប់សំរាក[ហ] តាមទំលាប់ទ្រង់ ហើយឈរឡើង ដើម្បីអាន
មើលគម្ពីរ[ឡ] ១៧ គេក៏យកគម្ពីរហោរាអេសាយមកថ្វាយទ្រង់
កាលទ្រង់បានបើកគម្ពីរហើយ នោះទ្រង់រកឃើញត្រង់
កន្លែង ដែលមានសេចក្តីចែងទុកមកថា ១៨ «ព្រះវិញ្ញាណ
ព្រះអម្ចាស់សណ្ឋិតលើខ្ញុំ[អ] ពីព្រោះទ្រង់បានចាក់ប្រេងតាំង
ខ្ញុំ ឱ្យផ្សាយដំណឹងល្អ[ក]ដល់មនុស្សទ័លក្រ ទ្រង់បានចាត់ខ្ញុំ
ឱ្យមក ដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង ហើយ
ប្រកាសប្រាប់ពីសេចក្តីប្រោសលោះដល់ពួកឈ្លើយ នឹង
សេចក្តីភ្លឺឡើងវិញដល់មនុស្សខ្វាក់ ហើយឱ្យដោះមនុស្ស
ដែលត្រូវគេជិះជាន់ឱ្យរួច ១៩ ព្រមទាំងប្រកាសប្រាប់ពីឆ្នាំ
ដែលព្រះអម្ចាស់កំណត់ទុក »[គ] ២០ កាលទ្រង់បានបិទគម្ពីរ
ប្រគល់ដល់អ្នករក្សាសាលាវិញហើយនោះទ្រង់ក៏គង់ចុះ[ឃ]
ឯពួកអ្នកដែលនៅក្នុងសាលា គេក៏សំឡឹងមើលទ្រង់ ២១ ទ្រង់
ចាប់តាំងមានបន្ទូលទៅគេថានៅថ្ងៃនេះ បទគម្ពីរនេះបាន
សំរេច[ង] នៅត្រចៀកអ្នករាល់គ្នាហើយ ២២ គ្រប់គ្នាជាសាក្សី
ពីទ្រង់ ក៏អស្ចារ្យក្នុងចិត្តពីព្រះបន្ទូលដ៏ផ្អែមពីរោះ ដែល
ចេញពីព្រះឱស្ឋទ្រង់មក ហើយគេនិយាយថា តើអ្នកនេះមិន
មែនជាកូនយ៉ូសែបទេឬអី[ច] ២៣ តែទ្រង់មានបន្ទូលទៅគេថា
ពិតប្រាកដជាអ្នករាល់គ្នា នឹងនិយាយពាក្យប្រៀបនេះដាក់
ខ្ញុំថា គ្រូពេទ្យអើយ ចូរមើលខ្លួនអ្នកឱ្យជាសិនចុះ ការអ្វី
ដែលយើងបានឮថា អ្នកធ្វើនៅក្រុងកាពើណិម[ឆ] នោះចូរ
ធ្វើនៅស្រុករបស់ខ្លួននេះដែរ[ជ] ២៤ ទ្រង់ក៏មានបន្ទូលទៀត
ថា ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា គ្មានហោរាណាដែល
គេរាប់អាននៅក្នុងស្រុករបស់ខ្លួននោះទេ[ឈ] ២៥ ខ្ញុំក៏និយាយ
ប្រាកដនឹងអ្នករាល់គ្នាថា នៅជាន់លោកអេលីយ៉ា កាល
រាំង៣ឆ្នាំ ៦ខែ ហើយមានអំណត់អត់ជាខ្លាំង នៅពេញក្នុង
ស្រុកនោះមានមេម៉ាយជាច្រើន នៅស្រុកអ៊ីស្រាអែលដែរ[ញ]
២៦ តែព្រះទ្រង់មិនបានចាត់លោកអេលីយ៉ា ឱ្យទៅឯមេម៉ាយ
ណាមួយនោះសោះ គឺបានចាត់លោកទៅឯស្រីមេម៉ាយម្នាក់

**៤:១៦** ហ មថ ១៣:៥៣
ឡ ១ធថ ៤:១៣
**៤:១៨** អ យហ ៣:៣៤
ក មក ១៦:១៥
**៤:១៩** គ លវ ២៥:១០ អស ៦១:១,២ ទដ ១០២:២០ ១០៣:៦ អស ៤២:៧ ៤៩:៨,៩ ៥៨:៦
**៤:២០** ឃ ខ.១៧ មថ ២៦:៥៥
**៤:២១** ង មថ ១:២២
**៤:២២** ច មថ ១៣:៥៤,៥៥ យហ ៦:៤២, ៧:១៥
**៤:២៣** ឆ មក ១:២១-២៨ ២:១-១២ ជ ខ.១៦ មថ ២:២៣
**៤:២៤** ឈ មថ ១៣:៥៧ យហ ៤:៤៤
**៤:២៥** ញ ១ពវ ១៧:១ ១៨:១ យក ៥:១៧,១៨ វវ ១១:៦

*ទ្រង់* ទម្លាប់នៃការថ្វាយបង្គំរបស់ព្រះយេស៊ូវ គឺជាគំរូសម្រាប់អ្នកដើរតាមទ្រង់ទាំងអស់ ។ *ដើម្បីអានមើលព្រះគម្ពីរ* ទ្រង់ប្រាកដជាអានព្រះគម្ពីរអេសាយដែលបានសរសេរជាភាសារហេព្រើរ បន្ទាប់មកទ្រង់ ឬអ្នកផ្សេងទៀតបានសម្រាយបទនោះជាភាសាអើរ៉ាម (Aramaic) ជាភាសាដែលគេនិយមប្រើនៅសម័យនោះ ។

**៤:១៧** *អេសាយ* ព្រះគម្ពីរសញ្ញាចាស់ដែលនិយាយនេះត្រូវបានសរសេរលើក្រាំង ហើយទុកនៅកន្លែងពិសេសក្នុងសាលាប្រជុំ ។ ការយកព្រះគម្ពីរណាមួយមកឱ្យដល់អ្នកអានជាតួនាទីរបស់អ្នកបម្រើការពិសេស ។ បទគម្ពីរដែលទ្រង់អាននោះអាចជាវគ្គដែលទ្រង់បានជ្រើសរើស ឬវគ្គដែលគេតម្រូវនៅថ្ងៃនោះ ។

**៤:១៨** ខនេះនិយាយពីព្រះរាជកិច្ចរបស់ព្រះយេស៊ូវ ដែលមានការអធិប្បាយព្រះបន្ទូល និងការប្រោសជំងឺ ។ *ទ្រង់បានចាក់ប្រេងតាំងខ្ញុំ* គឺមិនមែនជាប្រេងដែលជាវត្ថុធាតុរាវនោះទេ (នក ៣០:២២-៣១) ប៉ុន្តែជាព្រះវិញ្ញាណបរិសុទ្ធ ។

**៤:១៩** *ឆ្នាំដែលព្រះអម្ចាស់កំណត់ទុក* គឺមិនមែនជាឆ្នាំនៃប្រតិទិននោះទេ ប៉ុន្តែជារយៈពេលនៃការប្រកាសពីសេចក្តីសង្គ្រោះ ឬជាសម័យព្រះមែស៊ី ។ សម្រង់បទគម្ពីរ អស ៦១:១-២ គឺជាការអធិប្បាយដោយប្រយោលអំពីឆ្នាំសោមនស្ស (លវ ២៥:៨-៥៥) ដែលរៀងរាល់៥០ឆ្នាំម្តង គេដោះលែងទាសករ ឱ្យមានសេរីភាព ហើយបំណុលត្រូវលប់ចោល ទ្រព្យសម្បត្តិពីដូនតាក៏ត្រូវប្រគល់ឱ្យទៅគ្រួសារ ដែលជាម្ចាស់ដើមវិញផងដែរ ។ ហោរាអេសាយបានទាយមុនគេ ពីការរំដោះ សាសន៍អ៊ីស្រាអែលពីភាពជាឈ្លើយប្រទេសបាប៊ីឡូន ប៉ុន្តែព្រះយេស៊ូវទ្រង់បានប្រកាសពីការដោះឱ្យរួចពីបាប និងគ្រប់ទាំងផលនៃអំពើបាប ។

**៤:២០** *ក៏គង់ចុះ* នោះគឺជាប្រពៃណីមួយ ដែលត្រូវឈរអានព្រះគម្ពីរ (ខ.១៦) ប៉ុន្តែ ពេលបង្រៀនត្រូវអង្គុយចុះវិញ (៥:៣ មថ ៥:១ និងការពន្យល់ ២៦:៥៥ មក ៤:១ ៩:៣៥ យហ ៨:២ កច ១៦:១៣) ។

**៤:២១** *នៅត្រចៀកអ្នករាល់គ្នា* គឺនៅនឹងការឮរបស់ពួកគេ គឺឮពីការសម្រេចបទទំនាយនៅក្នុងការបង្រៀនរបស់ទ្រង់ ។ គេជឿថាទ្រង់បានមានបន្ទូលច្រើនជាងការកត់ត្រានៅក្នុងព្រះគម្ពីរលូកា ព្រោះលោកលូកាបានកត់ទុកតែអំពីអត្ថន័យនៃការបង្រៀនរបស់ទ្រង់ប៉ុណ្ណោះ ។

**៤:២៣** *ស្រុករបស់ខ្លួននេះ* គឺស្រុកណាសារ៉ែត ។ ព្រះយេស៊ូវទ្រង់បានប្រសូតនៅបេថ្លេហិម ប៉ុន្តែគ្រួសារទ្រង់បាននាំយកទ្រង់ទៅភូមិណាសារ៉ែតស្រុកកាលីឡេវិញ (មើល ១:២៦ ២:៣៩ មថ ២:២៣ និងការពន្យល់) ។ *ក្រុងកាពើណិម* មើលការពន្យល់ មថ ៤:១៣) ។

**៤:២៤** ពួកគេបានប្រមាថដល់ទ្រង់ ដោយមិនពេញចិត្តនឹងការប្រសូតក្នុងគ្រួសារដ៏ក្រីក្ររបស់ទ្រង់ ។ ពួកគេមានអំនួតខ្លាំពេក ដោយមិនចង់ទទួលការបង្រៀនពីគ្រួសារក្រីក្រទេ គឺពួកគេឱ្យតម្លៃទ្រង់ស្មើ ឬទាបជាងខ្លួនពួកគេទៅទៀត ។

**៤:២៦-២៧** ការខ្វាយខ្វល់ដ៏ពិសេសរបស់លោកលូកាចំពោះសាសន៍ដទៃបានឆ្លុះបញ្ចាំងឱ្យឃើញក្នុងការបញ្ជាក់របស់គាត់ អំពីការដែលព្រះយេស៊ូវមានបន្ទូលពីការជួយសង្គ្រោះរបស់ព្រះ ចំពោះអ្នកដែលមិនមែនជាសាសន៍អ៊ីស្រាអែលទាំងពីរនាក់នោះ (១ពវ ១៧:១-១៥ ១ពវ ៥:១-១៤) ។ ខ្លឹមសារនៃព្រះបន្ទូលនេះ គឺដោយសារសាសន៍អ៊ីស្រាអែលបដិសេធទូតនៃការប្រោសលោះរបស់ព្រះ ទើបបានជាព្រះទ្រង់បានបញ្ជូនទូតនោះឱ្យទៅឯសាសន៍ដទៃវិញ ជាមួយគ្នាការនេះនឹងកើតឡើងម្តងទៀត ប្រសិនបើពួកគេបដិសេធមិនព្រមទទួលព្រះយេស៊ូវ (១០:១៣-១៥ និងពន្យល់ រម ៩-១១) ។

**៤:២៦** *ស្រុកស៊ីដូន* គឺក្រុងមួយក្នុងចំណោមក្រុងដែលមានចំណាស់បំផុតរបស់សាសន៍ភេនីស នៅភាគខាងជើង និងមានចម្ងាយ ៣២,១៨គម ពីក្រុង

នៅក្រុងសារិបតាក្នុងស្រុកស៊ីដូនវិញ[ដ] ២៧ហើយនៅជាន់
ហោរាអេលីសេក៏ មានមនុស្សឃ្លង់ជាច្រើន ក្នុងស្រុកអ៊ី
ស្រាអែលដែរ តែគ្មានអ្នកណាមួយបានជាស្អាតសោះ បានជា
តែលោកណាម៉ាន ជាសាសន៍ស៊ីរី១ប៉ុណ្ណោះ[ឋ] ២៨កាលពួក
អ្នកនៅក្នុងសាលាប្រជុំ បានឮសេចក្ដីទាំងនោះហើយ គេ
មានពេញដោយសេចក្ដីក្រោធ ២៩ក៏ក្រោកឡើង ដេញ
ទ្រង់ចេញពីភូមិ[ឌ] បណ្ដើរទៅដល់ចំរែះនៅលើភ្នំដែលគេ
បានកធ្វើភូមិ ដើម្បីនឹងច្រានទំលាក់ចុះទៅក្រោម ៣០ប៉ុន្តែ
ទ្រង់យាងកាត់កណ្ដាលពួកគេចេញបាត់ទៅ[ឍ]។

## ព្រះយេស៊ូវបណ្ដេញវិញ្ញាណអាក្រក់

*៤:៣១–៣៧–មក ១:២១–២៨*

៣១ទ្រង់យាងចុះទៅដល់កាពើណិម[ណ] ជាទីក្រុងស្រុកកាលី
ឡេ ក៏តែងតែបង្រៀនគេរាល់ថ្ងៃឈប់សំរាក ៣២គេក៏នឹក
ប្លែកពីសេចក្ដីដែលទ្រង់បង្រៀនណាស់[ត] ពីព្រោះទ្រង់មាន
បន្ទូលដោយអំណាច[ថ] ៣៣រីឯនៅក្នុងសាលានោះ មាន
មនុស្សម្នាក់ ដែលមានវិញ្ញាណអារក្សអសោចិ៍ចូលវា
ស្រែកឡើងជាខ្លាំងថា ៣៤ហ៊ឺះនែ ព្រះយេស៊ូវពីណាសារ៉ែត[ទ]
អើយ តើយើងហើយនឹងទ្រង់មានហេតុអ្វីនឹងគ្នា[ធ] តើទ្រង់
មកបំផ្លាញយើងឬអី ខ្ញុំស្គាល់ជាក់ហើយ[ន] ទ្រង់ជាព្រះអង្គ
បរិសុទ្ធនៃព្រះ[ប] ៣៥ព្រះយេស៊ូវក៏កំហែងវាថា[ផ] ចូរស្ងៀមចុះ
ហើយចេញពីមនុស្សនេះទៅ លុះអារក្សបានផ្តួលអ្នកនោះ
ទៅកណ្ដាលពួកគេ នោះក៏ចេញទៅឥតមានធ្វើឱ្យឈឺអ្វី
ឡើយ ៣៦គ្រប់គ្នាក៏នឹកស្ញើចក្នុងចិត្ត[ព]ទាំងសួរគ្នាថា តើពាក្យ
បែបយ៉ាងណានេះ ដែលលោកបង្គាប់ដល់វិញ្ញាណអសោចិ៍
ដោយអំណាចនឹងឫទ្ធិបាន[ភ] ហើយវាក៏ចេញទៅដូច្នេះ
៣៧នោះក៏ឮល្បីខ្ចរខ្ចាយពីទ្រង់ សុសសាយទៅគ្រប់ទីកន្លែង
ជុំវិញ[ម]។

## ព្រះយេស៊ូវប្រោសមនុស្សជាច្រើន

*៤:៣៨–៤១–មថ ៨:១៤–១៧ ៤:៣៨–៤៣–មក ១:២៩–៣៨*

៣៨រួចទ្រង់ក្រោកឡើង យាងចេញពីសាលាចូលទៅក្នុង
ផ្ទះស៊ីម៉ូន រីឯម្ដាយក្មេកស៊ីម៉ូន នាងកំពុងគ្រុនជាខ្លាំង ហើយ
គេសូមអង្វរទ្រង់ឱ្យនាង ៣៩ទ្រង់ក៏ឈរឈ្ងោកទៅនាងទាំង
កំហែងដល់គ្រុន[យ] នោះគ្រុនក៏បាត់ទៅ រួចនាងក្រោកឡើង
ភ្លាម បំរើដល់ទាំងអស់គ្នា ។
៤០ដល់ពេលថ្ងៃលិច អស់អ្នកដែលមានបងប្អូនឈឺជំងឺ
ផ្សេងៗ គេនាំអ្នកទាំងនោះមកឯទ្រង់ ហើយទ្រង់ប្រោស
គេគ្រប់គ្នាឱ្យបានជា[រ] ដោយដាក់ព្រះហស្តលើ[ល] ៤១ក៏មាន
អារក្សចេញពីមនុស្សជាច្រើនដែរ វាស្រែកឡើងថា ទ្រង់
ជាព្រះរាជបុត្រានៃព្រះ[វ] តែទ្រង់បន្ទោស[ស] ហាមមិនឱ្យ
វានិយាយសោះ[ហ] ពីព្រោះវាដឹងថា ទ្រង់ជាព្រះគ្រីស្ទពិត។
៤២លុះព្រឹកឡើង ទ្រង់យាងចេញទៅឯកន្លែងស្ងាត់ ឯ
បណ្ដាមនុស្សគេតាមរកទ្រង់ ក៏មកដល់ ហើយឃាត់ទ្រង់
ដើម្បីមិនឱ្យទ្រង់យាងចេញពីគេឡើយ ៤៣តែទ្រង់មានបន្ទូល

**៤:២៦** ដ ១ពវ ១៧:៨–១៦ មថ ១១:២១
**៤:២៧** ឋ ២ពវ ៥:១–១៤
**៤:២៩** ឌ ជន ១៥:៣៥ កច ៧:៥៨ ហព ១៣:១២
**៤:៣០** ឍ យហ ៨:៥៩ ១០:៣៩
**៤:៣១** ណ ខ.២៣ មថ ៤:១៣
**៤:៣២** ត មថ ៧:២៨ ថ ខ.៣៦ មថ ៧:២៩
**៤:៣៤** ទ មក ១:២៤ ធ មថ ៨:២៩ ន យក ២:១៩ ប ខ.៤១ មក ១:២៤
**៤:៣៥** ផ ខ.៣៩,៤១ មថ ៨:២៦ លក ៨:២៤
**៤:៣៦** ព មថ ៧:២៨ ភ ខ.៣២ មថ ៧:២៩ មថ ១០:១
**៤:៣៧** ម ខ.១៤ មថ ៩:២៦ មថ ១០:១
**៤:៣៩** យ ខ.៣៥,៤១
**៤:៤០** រ មថ ៤:២៣ ល មក ៥:២៣ **៤:៤១** វ មថ ៤:៣ ស ខ.៣៥ ហ មថ ៨:៤

ទីរ៉ុស ។ នៅក្នុងតំបន់នេះព្រះយេស៊ូវ ទ្រង់បានដេញអារក្សចេញពីកូនស្រី របស់ស្ត្រីសាសន៍ដទៃម្នាក់ (មថ ១៥:២១–២៨)។

**៤:២៨** *សេចក្ដីក្រោធ* ព្រោះបានឮថាសាសន៍ដទៃជាអ្នកទទួលនូវព្រះពរ ។

**៤:៣០** *យាងកាត់កណ្ដាលពួកគេ* លោកលូកាមិនបានបរិយាយថាតើព្រះយេស៊ូវទ្រង់បានយាងគេចចេញនោះដោយប្រើការអស្ចារ្យ ឬដោយព្រោះមានច្រកផ្លូវសម្រាប់ឱ្យទ្រង់យាងចេញពីពួកគេនោះឡើយ តែយ៉ាងណាក៏ដោយ វេលារបស់ទ្រង់(ដែលត្រូវសុគត) គឺមិនទាន់មកដល់នៅឡើយទេ (មើល យហ ៧:៣០ និងការពន្យល់)។

**៤:៣២** មើលការពន្យល់ មក ១:២២ ។

**៤:៣៣** *វិញ្ញាណអារក្សអសោចិ៍ចូល* សម្រាប់អ្នកមិនជឿព្រះ ពាក្យថា "វិញ្ញាណអារក្ស" គឺជាជីវិតដែលមានលក្ខណៈអធិធម្មជាតិ (ដែលមិនអាចបកស្រាយតាមច្បាប់ធម្មជាតិបាន) ដែលមានល្អមានអាក្រក់ ប៉ុន្តែ ចំពោះគ្រីស្ទបរិស័ទវិញ អារក្សគឺជាវិញ្ញាណអាក្រក់ដែលលោកលូកាបានសរសេរនៅក្នុងព្រះគម្ពីររបស់លោកថា "វិញ្ញាណអារក្សអសោចិ៍"។ វិញ្ញាណអារក្សអសោចិ៍អាចធ្វើឱ្យកើតរោគវិកលចរិត(យហ ១០:២០) សកម្មភាពហិង្សា(លក ៨:២៨–២៩) ជំងឺផ្លូវកាយ(១៣:១១,១៦) ការបះបោរប្រឆាំងនឹងព្រះ (វវ ១៦:១៤)។

**៤:៣៤** *ព្រះអង្គបរិសុទ្ធនៃព្រះ* មើលការពន្យល់ មក ១:២៤ ។

**៤:៣៦** *នឹកស្ញើចក្នុងចិត្ត* មើល ខ.៣២ និងការពន្យល់ មក ១:២២ ។

**៤:៣៨** *សាលា* គឺសាលាប្រជុំ ។ មើលពន្យល់ មថ ៤:១៣ មក ១:២១ ។ *ម្ដាយក្មេកស៊ីម៉ូន* លោកពេត្រុសបានរៀបការហើយ(មើល ១ កថ ៩:៥ និងការពន្យល់)។ *គ្រុនជាខ្លាំង* ព្រះគម្ពីរដំណឹងល្អពីរទៀតក៏មាននិយាយពីការអស្ចារ្យនេះផងដែរ(មថ ៨:១៤–១៥ មក ១:២៩–៣១) ប៉ុន្តែ មានតែលោកវេជ្ជបណ្ឌិតលូកាទេ ដែលប្រើពាក្យ "គ្រុនជាខ្លាំង"។

**៤:៤០** *ដល់ពេលថ្ងៃលិច* ថ្ងៃឈប់សម្រាក(ខ.៣១)ត្រូវបញ្ចប់នៅពេលថ្ងៃលិច (ប្រហែលម៉ោង៦ល្ងាច)។ បើតាមទំនៀមទម្លាប់របស់ពួកចាស់ទុំសាសន៍យូដាមិនអាចជាប់មានបន្ទុកអ្វី ឬធ្វើដំណើរលើសពី ១០៧២,៦៦ ម៉ែត្របានឡើយ គឺមានតែចាំដល់ពេលថ្ងៃលិចសិន ទើបពួកគេអាចនាំអ្នកជំងឺមកឯព្រះយេស៊ូវ ហើយគេអាចមើលឃើញពីតម្រូវការដ៏ខ្លាំងក្លារបស់ពួកគេតាមរយៈការពិត ដែលពួកគេបានចាប់ធ្វើការនោះ ទាំងមិនទាន់ដល់ពេលថ្ងៃលិចផង ។

**៤:៤១** *ពីព្រោះវាដឹងថា ទ្រង់ជាព្រះគ្រីស្ទពិត* ពាក្យ "វា" ដែលប្រើក្នុងខនេះ គឺ "ពួកវា" (មើលការពន្យល់ មក ១:៣៤)។

**៤:៤២** *កន្លែងស្ងាត់* ព្រះគម្ពីរម៉ាកុសមានបន្តដោយពាក្យ "ហើយអធិស្ឋាន

ថា ខ្ញុំត្រូវប្រាប់ដំណឹងល្អពីនគរព្រះ[ឡ] ដល់អស់ទាំងស្រុកឯ
ទៀតដែរ គឺហេតុនោះបានជាព្រះវរបិតាចាត់ឱ្យខ្ញុំមក
៤៤ទ្រង់ក៏ប្រកាសក្នុងអស់ទាំងសាលាប្រជុំនៅស្រុកកាលីឡេ
ទូទៅ[អ] ។

## ការចាប់ផ្ដើមត្រាស់ហៅពួកសាវ័ក

*៥:១–១១–មថ ៤:១៨–២២ មក ១:១៦–២០ យហ ១:៤០–៤២*

**៥** ១កាលទ្រង់កំពុងឈរ នៅមាត់សមុទ្រគេនេសារ៉ែត នោះ
មានមនុស្សកកកុញប្រជ្រៀតគ្នាមកឯទ្រង់ ដើម្បីនឹងស្ដាប់
ព្រះបន្ទូល[ក] ២ហើយទ្រង់ទតឃើញទូក២ ចតនៅមាត់សមុទ្រ
ដែលពួកអ្នកនេសាទបានឡើងទៅលាងអួនហើយ ៣ទ្រង់
យាងចុះទូក១នោះ ជាទូករបស់ស៊ីម៉ូន ក៏សូមឱ្យគាត់ចេញ
ទូកពីដីបន្តិចទៅ រួចទ្រង់គង់បង្រៀនដល់បណ្ដាមនុស្សពីក្នុង
ទូកវិញ[ខ] ៤លុះឈប់អធិប្បាយហើយ នោះទ្រង់មានបន្ទូល
ទៅស៊ីម៉ូនថា ឱ្យចេញទូកទៅឯកន្លែងទឹកជ្រៅទំលាក់អួន
ចាប់ត្រីចុះ[គ] ៥ស៊ីម៉ូនទូលឆ្លើយថា លោកគ្រូអើយ[ឃ] យប់មិញ
យើងខ្ញុំបានខំដឹកអួនទាល់ភ្លឺ គ្មានបានអ្វីសោះ[ង] តែខ្ញុំនឹងទំ
លាក់ អួន តាមពាក្យលោកមើល ៦កាលទំលាក់ទៅ នោះ
ក៏ជាប់បានត្រីសន្ធឹក ដល់ម្ល៉េះបានជាអួនចាប់តាំងធ្លាយ[ច]
៧នោះគេបោយដៃហៅគូកនដែលនៅក្នុងទូក១ទៀត ឱ្យមក
ជួយគ្នា គេក៏មក ហើយចាប់ដាក់បានពេញទូកទាំង២ ទាល់
តែពៀបស្ទើរនឹងលិច ៨កាលស៊ីម៉ូន–ពេត្រុសបានឃើញ
ដូច្នេះ នោះគាត់ក្រាបនៅទៀបព្រះជង្ឃព្រះយេស៊ូវ ទូលថា
ព្រះអម្ចាស់អើយ សូមថយចេញពីទូលបង្គំ ដ្បិតទូលបង្គំជា
មនុស្សមានបាប[ឆ] ៩គាត់ទូលដូច្នោះ ដោយហេតុគាត់ នឹង
ពួកអ្នកនៅជាមួយ នឹកស្ញើចក្នុងចិត្ត ពីត្រីដែលបានច្រើន
ដល់ម្ល៉ោះ ១០ហើយយ៉ាកុប នឹងយ៉ូហាន ជាកូនសេបេដេ
ដែលជាពួកហ៊ុននឹងស៊ីម៉ូន ក៏ដូច្នោះដែរ តែព្រះយេស៊ូវ
មានបន្ទូលទៅស៊ីម៉ូនថា កុំខ្លាចអី[ជ] ពីនេះទៅមុខ អ្នកនឹងចាប់
មនុស្សវិញ ១១រួច កាលទូកបានដល់គោក នោះគេទុករបស់
ទាំងអស់ចោល ហើយដើរតាមទ្រង់ទៅ[ឈ] ។

## បុរសកើតឃ្លង់ម្នាក់

*៥:១២–១៤ មថ ៨:២–៤ មក ១:៤០–៤៤*

១២កាលព្រះយេស៊ូវគង់នៅក្នុងទីក្រុង១ នោះមានមនុស្ស
ម្នាក់កើតឃ្លង់ពេញទាំងខ្លួន[ញ] គាត់ឃើញទ្រង់ ក៏ទំលាក់ខ្លួន

**៤:៤៣** ឡ មថ ៣:២
**៤:៤៤** អ មថ ៤:២៣
**៥:១** ក មក ៤:១៤ ហព ៤:១២
**៥:៣** ខ មថ ១៣:២
**៥:៤** គ យហ ២១:៦
**៥:៥** ឃ លក ៨:២៤, ៤៥ ៩:៣៣,៤៩ ១៧:១៣
ង យហ ២១:៣
**៥:៦** ច យហ ២១:១១
**៥:៨** ឆ លប ១៨:២៧ យប ៤២:៦ អស ៦:៥
**៥:១០** ជ មថ ១៤:២៧
**៥:១១** ឈ ខ.២៨ មថ ៤:១៩
**៥:១២** ញ មថ ៨:២

នៅទីនោះ" (មក ១:៣៥) ។

**៤:៤៣** *នគរព្រះ* នេះជាលើកទីមួយដែលលោកលូកាបានប្រើពាក្យនេះ ដែលមានសរសេរចំនួន៣០ដង នៅក្នុងព្រះគម្ពីរដំណឹងល្អរបស់លោក ហើយនៅក្នុងព្រះគម្ពីរបរិសុទ្ធទាំងមូល ពាក្យនេះមានអត្ថន័យជាច្រើន ដូចជារាជ្យដ៏អស់កល្បជានិច្ច នៃព្រះវត្តមាននគរព្រះ ក្នុងអង្គព្រះយេស៊ូវគ្រីស្ទដ៏ជាស្ដេច សណ្ឋានជាវិញ្ញាណ ដែលជិតមកដល់នៃនគរព្រះ និងនគរព្រះដែលត្រូវមកដល់ (មើលការពន្យល់ មថ ៣:២) ។

**៤:៤៤** គឺសេចក្ដីសង្ខេបដែលមិនត្រឹមតែសម្រាប់សេចក្ដីដែលបានអធិប្បាយរួចមកហើយប៉ុណ្ណោះទេ (ចាប់ពីខ.១៤មក) ប៉ុន្តែ ថែមទាំងសម្រាប់សេចក្ដីអ្វីដែលមានជាបន្តបន្ទាប់ទៀតក្នុងព្រះរាជកិច្ចព្រះយេស៊ូវផងដែរ ។ ការបញ្ជាក់ឱ្យបានច្បាស់លាស់ពីព្រះរាជកិច្ចដំបូងរបស់ទ្រង់ក្នុងស្រុកយូដា ដូចដែលបានកត់ទុកក្នុងព្រះគម្ពីរយ៉ូហាន (២:១៣–៤:៣) គឺមិនមាននៅក្នុងព្រះគម្ពីរនេះទេ ទោះជាអាចឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុង ១៣:៤៣ (មើលការពន្យល់ខនោះ) និងម៉ាថាយ ២៣:៣៧ ក៏ដោយ ។ *ស្រុកកាលីឡេ* ព្រះគម្ពីរមួយចំនួនប្រើពាក្យស្រុកយូដាជាជំនួសវិញ ។ ក្នុងការសរសេរទៅកាន់ពួកសាសន៍ដទៃ (សេចក្ដីផ្ដើមត្រង់អ្នកទទួល និងគោលបំណង) លោកលូកាប្រើពាក្យ "ស្រុកយូដា" សំដៅទៅលើទឹកដីទាំងមូលនៃសាសន៍យូដា (២៣:៥ មើលការពន្យល់ កច ១០:៣៧ ១១:១,២៩ ២៦:២០) ។

**៥:១** *មាត់សមុទ្រគេនេសារ៉ែត* តាមព្រះគម្ពីរដើម គេនេសារ៉ែតគឺជាបឹងមួយដែលនៅជាប់នឹងក្រុងគេនេសារ៉ែតត្រង់ឆ្នេរខាងលិច ។ មានតែលោកលូកាម្នាក់គត់ដែលបានហៅទីនោះថា "បឹងគេនេសារ៉ែត" រីឯអ្នកនិពន្ធព្រះគម្ពីរដំណឹងល្អឯទៀតៗបានហៅថា "សមុទ្រកាលីឡេ" វិញ (មើល មក ១:១៦ និងការពន្យល់) តែលោកយ៉ូហានវិញបានហៅថា "សមុទ្រទីបេរាស" ចំនួចពីរដង (មើល យហ ៦:១ និងការពន្យល់ ២១:១) ។

**៥:២** *លាងអួន* បន្ទាប់ពីនេសាទចប់ គេលាងអួន ហើយសំដិលវា ។

**៥:៣** *គង់* គឺជាឥរិយាបទនៃការបង្រៀន (មើលការពន្យល់ ៤:២០) ។ នៅលើទូកគឺងាយស្រួលដល់ការគង់បង្រៀន ព្រោះក្រោយពីយាងចេញពីការប្រជ្រៀតរបស់ហ្វូងមនុស្សដ៏កកកុញ ហើយចេញទូកពីមាត់ច្រាំងបានបន្តិចទៅនោះ គឺនាំឱ្យមានទីតាំងជិតល្មមឱ្យហ្វូងមនុស្សអាចមើល និងស្ដាប់ការបង្រៀនបាន ។

**៥:៧** *គូកន* មើលខ.១០ ។

**៥:៨** *ព្រះអម្ចាស់អើយ សូមថយចេញពីទូលបង្គំ* កាលណាយើងចូលទៅចំពោះព្រះកាន់តែជិត នោះយើងនឹងដឹងកាន់តែច្បាស់អំពីអំពើបាប និងភាពមិនសក្ដិសមរបស់យើង គឺដូចលោកអ័ប្រាហាំ (មើល លប ១៨:២៧ និងការពន្យល់) លោកយ៉ូប (៤២:៦ និងការពន្យល់) និងហោរាអេសាយ (៦:៥) ។

**៥:១១** *ទុករបស់ទាំងអស់ចោល ហើយដើរតាមទ្រង់* មានការពីរយ៉ាងដែលត្រូវបំពេញដើម្បីចូលទៅចំពោះព្រះ ។ គឺយើងត្រូវទទួលស្គាល់ថា លោកពេត្រុសមានបាប យើងក៏មានបាបដែរ រួចត្រូវដឹងថាយើងមិនអាចសង្គ្រោះខ្លួនឯងបានឡើយ គឺដូចអ្នកនេសាទគំរូទាំងនោះដែរ ។ បើយើងដឹងថាយើងត្រូវការជំនួយ ព្រមទាំងដឹងថា មានតែព្រះយេស៊ូវមួយអង្គគត់ដែលអាចជួយសង្គ្រោះយើងបាន នោះយើងនឹងបានត្រៀមខ្លួនជាស្រេច ដើម្បីលះចោលអ្វីៗទាំងអស់ហើយដើរតាមទ្រង់ ។

**៥:១២–១៦** ការប្រោសបុរសម្នាក់នោះឱ្យជាពីរោគឃ្លង់ មានរៀបរាប់នៅក្នុងព្រះគម្ពីរដំណឹងល្អទាំងបីកណ្ឌដំបូង ប៉ុន្តែរបៀបនៃការរៀបរាប់ទាំងបីនោះមានភាពខុសប្លែកពីគ្នា ។

**៥:១២** *កើតឃ្លង់ពេញទាំងខ្លួន* ន័យតាមព្រះគម្ពីរក្រិក គឺជាពពួកជំងឺឆ្លង

ផ្កាប់មុខទូលអង្វរថា ព្រះអម្ចាស់អើយ បើទ្រង់សព្វព្រះ
ហឫទ័យ នោះទ្រង់អាចនឹងប្រោសឱ្យទូលបង្គំជាស្អាតបាន។
១៣ទ្រង់ក៏លូកព្រះហស្តទៅពាល់គាត់ ដោយបន្ទូលថា ខ្ញុំចង់ដែរ
ឱ្យជាស្អាតចុះ ស្រាប់តែឃ្លង់ចេញពីគាត់ជា១ រំពេចទៅ ។
១៤រួចទ្រង់ហាមមិនឱ្យគាត់ប្រាប់ដល់អ្នកណាឡើយ[ដ] តែត្រូវ
ទៅបង្ហាញខ្លួនឱ្យសង្ឃពិនិត្យមើល ហើយថ្វាយ ដង្វាយ
ដោយព្រោះបានជាស្អាតវិញ ដូចជាលោកម៉ូសេ បាន
បង្គាប់មក[ឋ] ទុកជាទីបន្ទាល់ដល់ពួកលោក ១៥ប៉ុន្តែ ចេះតែ
ឮនិយាយពីទ្រង់កាន់តែខ្លាំងឡើង[ឌ] ក៏មានមនុស្សកកកុញ
មកស្តាប់ផង ហើយឱ្យទ្រង់បានប្រោសជំងឺគេឱ្យជាផង
១៦តែទ្រង់ថយចេញទៅឯទីស្ងាត់ ដើម្បី អធិស្ឋានវិញ[ឍ]។

## ព្រះយេស៊ូវប្រោសមនុស្សស្លាប់ដៃជើងម្នាក់

*៥:១៨–២៦–មថ ៩:២–៨ មក ២:៣–១២*

១៧មានថ្ងៃ១ កាលទ្រង់កំពុងតែបង្រៀន នោះមានពួកផារិស៊ី
នឹងពួកអ្នកប្រាជ្ញច្បាប់[ណ] ដែលចេញពីគ្រប់ទាំងភូមិ
ស្រុកកាលីឡេ ស្រុកយូដា នឹងក្រុងយេរូសាឡិម គេមក
អង្គុយស្តាប់ ហើយព្រះចេស្តានៃព្រះអម្ចាស់ក៏នៅទីនោះ
បំរុងនឹងប្រោសគេឱ្យជាដែរ[ត] ១៨នោះឃើញមានគេសែង
មនុស្សស្លាប់ដៃស្លាប់ជើងម្នាក់ដេកលើគ្រែមក គេរកផ្លូវនាំ
គាត់ចូលទៅដាក់នៅចំពោះទ្រង់ ១៩តែពុំបានសោះ ដោយ
ព្រោះមានមនុស្សសន្ធឹកណាស់ នោះក៏ឡើងទៅលើដំបូល
សំរូតគាត់ទៅទាំងដេកលើគ្រែ នៅកណ្តាលជំនុំ ចំពោះ
ព្រះយេស៊ូវតាមប្រហោងដំបូល ២០លុះទ្រង់បានឃើញ
សេចក្តីជំនឿរបស់គេដូច្នោះ ក៏មានបន្ទូលថា អ្នកអើយ បាប
អ្នកបានអត់ទោសឱ្យអ្នកហើយ[ថ] ២១នោះពួកអាចារ្យ នឹង
ពួកផារិស៊ី ចាប់តាំងរិះគិតគ្នាថា តើអ្នកណានេះ ដែល
ពោលពាក្យប្រមាថព្រះដូច្នេះ ក្រៅពីព្រះ១ តើមានអ្នកណា
អាចនឹងអត់ទោសបាបបាន[ទ] ២២តែព្រះយេស៊ូវបានជ្រាប
គំនិតគេ ក៏មានបន្ទូលសួរថា ហេតុអ្វីបានជារិះគិតក្នុងចិត្ត
ដូច្នេះ ២៣ដ្បិតដែលថា បាបអ្នកបានអត់ទោសឱ្យអ្នកហើយ
ឬថា ចូរអ្នកក្រោកឡើង ដើរទៅ នោះតើពាក្យណាដែល
ងាយថាជាជាង ២៤ប៉ុន្តែ ដើម្បីឱ្យអ្នករាល់គ្នាដឹងថា កូន
មនុស្ស[ធ]មានអំណាចនឹងអត់ទោសបាបនៅផែនដីបាន
(នោះទ្រង់ក៏មានបន្ទូលទៅអ្នក ស្លាប់ដៃស្លាប់ជើងវិញ)
ខ្ញុំប្រាប់អ្នកថា ចូរក្រោកឡើង យកគ្រែអ្នកដើរទៅផ្ទះទៅ
២៥គាត់ក៏ក្រោកឈរឡើងនៅមុខគេជា១រំពេច ហើយលើក
គ្រែ ដែលបានដេក ចេញទៅឯផ្ទះទាំងសរសើរដំកើងដល់
ព្រះបណ្តើរ ២៦នោះបណ្តាមនុស្ស កើតមានសេចក្តីអស្ចារ្យ
ទាំងអស់គ្នា ក៏សរសើរដំកើងព្រះ[ន] ហើយមានសេចក្តីភ័យ
ខ្លាចជាខ្លាំងថា យើងបានឃើញការ ចំឡែកណាស់នៅ
ថ្ងៃនេះ។

## ការត្រាស់ហៅលោកលេវី

*៥:២៧–៣២ មថ ៩:៩–១៣ មក ២:១៤–១៧*

២៧ក្រោយការទាំងនោះ ទ្រង់យាងចេញទៅ ឃើញអ្នកយក

**៥:១៤** ដ មថ ៨:៤
ឋ លវ ១៤:២–៣២
**៥:១៥** ឌ មថ ៩:២៦
**៥:១៦** ឍ លក ៣:២១
**៥:១៧** ណ មថ ១៥:១
លក ២:៤៦
ត មក ៥:៣០
លក ៦:១៩
**៥:២០** ថ លក ៧:៤៨,៤៩
**៥:២១** ទ អស ៤៣:២៥
**៥:២៤** ធ មថ ៨:២០
**៥:២៦** ន មថ ៩:៨

ដែលកើតលើស្បែក គឺមិនទៀងជាជំងឺឃ្លង់នោះទេ ។
**៥:១៤** *មិនឱ្យគាត់ប្រាប់* មើលការពន្យល់ មថ ៨:៤ ១៦:២០ ។ *តែត្រូវទៅបង្ហាញខ្លួនឱ្យសង្ឃពិនិត្យមើល* ព្រះរាជបញ្ជានេះ គឺទ្រង់ជំរុញឱ្យបុរសនោះធ្វើតាមក្រឹត្យវិន័យ ដើម្បីបង្ហាញជាបន្ថែមពីភស្តុតាងនៃការប្រោសជំងឺនោះ ដើម្បីធ្វើបន្ទាល់ពីអំណាចព្រះចេស្តា ដែលមានក្នុងព្រះរាជកិច្ចទ្រង់ និងដើម្បីបញ្ជាក់ពីការដែលបានជាស្អាតពីជំងឺ ប្រយោជន៍ឱ្យបានចូលក្នុងសង្គមឡើងវិញ ។ *ទុកជាទីបន្ទាល់ដល់ពួកលោក* មើលការពន្យល់ មក ១:៤៤ ។
**៥:១៧** *ពួកផារិស៊ី និងពួកអ្នកប្រាជ្ញច្បាប់* មើលការពន្យល់ មថ ២:៤ ៣:៧ មក ២:១៦ ។ ការប្រឆាំងនៅស្រុកកាលីឡេ គឺបានកើតចេញពីពួកអ្នកដឹកនាំសាសនាទាំងអស់នេះ ។ *ផារិស៊ី* បានលេចចេញនៅក្នុងព្រះគម្ពីរលូកាជាលើកទីមួយហើយ ន័យរបស់ពាក្យនេះគឺ "ពួកអ្នកផ្តាច់ខ្លួន"។ ពួកគេមានសមាជិកប្រមាណ៦000នាក់ មាននៅពាសពេញទឹកដីបរិសុទ្ធ ។ ពួកគេធ្វើជាគ្រូបង្រៀននៅក្នុងសាលាប្រជុំ ជាគំរូអ្នកកាន់សាសនានៅក្នុងភ្នែករបស់បណ្តាជន ហើយបានតាំងខ្លួនជាអ្នកថែរក្សាក្រឹត្យវិន័យ និងការប្រព្រឹត្តតាមដែលត្រឹមត្រូវ ។ ពួកគេចាត់ទុកការកាត់ស្រាយ និងច្បាប់ដែលកើតពីទំនៀមទម្លាប់ថាពិតជាមានអំណាចដូចព្រះគម្ពីរដែរ (មក ៧:៨–១៣) ព្រះយេស៊ូវទ្រង់បានប្រឆាំងនឹងពួកអ្នកដឹកនាំសាសន៍យូដា នៅក្រុងយេរូសាឡិមម្តងរួចទៅហើយ (យហ ៥:១៦–១៨) ហើយពេលនេះពួកគេបានមកឯផ្ទះនៅក្រុងកាពើណិម (មក ២:១–៦) ដើម្បីស្តាប់ និងមើលទ្រង់ ។ *ពួកអ្នកប្រាជ្ញច្បាប់* គឺអ្នកសិក្សាកាត់ស្រាយ និងបង្រៀនក្រឹត្យវិន័យ (សរសេរ និងចាំមាត់) (មើលពន្យល់ អរ ៧:៦) ។ ពួកនេះភាគច្រើនជាមនុស្សក្នុងក្រុមរបស់ពួកផារិស៊ី ។
**៥:១៩** *ដំបូល* មើលការពន្យល់ មក ២:៤ ។
**៥:២០** ព្រះយេស៊ូវបានឆ្លើយតប ចំពោះសេចក្តីជំនឿរបស់ក្រុមមនុស្សទាំងនោះពុំមែនចំពោះតែសេចក្តីជំនឿរបស់បុរសស្លាប់ដៃជើងតែម្នាក់នោះទេ។
**៥:២១** *តើអ្នកណា . . . ប្រមាថព្រះដូច្នេះ* មើលការពន្យល់ មក ២:៧ ។ ពួកផារិស៊ីចាត់ទុកការប្រមាថដល់ព្រះ គឺជាបាបដែលធ្ងន់ធ្ងរជាងគេបំផុត ដែលមនុស្សគ្រប់រូបអាចជ្រុលខ្លួនប្រព្រឹត្តបាន (មើលការពន្យល់ មក ១៤:៦៤) ។
**៥:២៣** *តើពាក្យណាដែលងាយថាជាជាង* មើលពន្យល់ មក ២:៩–១០ ។
**៥:២៤** *ដើម្បីឱ្យអ្នករាល់គ្នាដឹងថា* អំណាចដែលព្រះយេស៊ូវទ្រង់មានក្នុងការប្រោសជំងឺ គឺបានបញ្ជាក់ដោយការមើលឃើញច្បាស់នឹងភ្នែកថា ទ្រង់មានអំណាចក្នុងការអត់ទោសបាប ។ *កូនមនុស្ស* មើលការពន្យល់ មក ៨:៣១ ។
**៥:២៥** *សរសើរដំកើងដល់ព្រះ* មើលឧ.២៦ ព្រមទាំង ១:៦៤ និងពន្យល់ ។
**៥:២៧** *អ្នកយកពន្ធ* មើលការពន្យល់ ៣:២១ ។ *លេវី* គឺនាមមួយទៀតរបស់លោកម៉ាថាយ (៦:១៥) ។ *ទីយកពន្ធ* មើលការពន្យល់ មក ២:១៤ ។ ការ

ពន្ធម្នាក់ឈ្មោះលេវី កំពុងអង្គុយនៅទីយកពន្ធ ទ្រង់មាន
បន្ទូលហៅគាត់ថា ចូរមកតាមខ្ញុំឯណេះ[ប] ២៨គាត់ក៏ទុក
របស់ទាំងអស់ចោល ក្រោកតាមទ្រង់ទៅ[ផ] ២៩លេវីបាន
រៀបជប់លៀងជាធំថ្វាយទ្រង់នៅផ្ទះគាត់ ហើយមានអ្នកយក
ពន្ធទាំងហ្វូង[ព] នឹងមនុស្សឯទៀតមកអង្គុយនៅតុជាមួយគ្នា
ដែរ ៣០ពួកអាចារ្យនឹងពួកផារិស៊ី[ភ] គេឧុកដាន់ពួក សិស្ស
ទ្រង់ថា ហេតុអ្វីបានជាបរិភោគជាមួយនឹងពួកអ្នក យកពន្ធ
នឹងមនុស្សមានបាបដូច្នេះ[ម] ៣១តែព្រះយេស៊ូវទ្រង់ឆ្លើយ
ទៅគេថា ពួកអ្នកជាមិនត្រូវការនឹងគ្រូពេទ្យទេ ត្រូវការតែ
ពួកអ្នកដែលឈឺប៉ុណ្ណោះ ៣២ខ្ញុំមិនបានមកហៅពួកមនុស្ស
សុចរិតទេ គឺមកហៅតែមនុស្សមានបាប ឱ្យគេប្រែចិត្ត
វិញទេតើ[យ]។

## ការចោទសួរព្រះយេស៊ូវអំពីការតម

*៥:៣៣–៣៩ មថ ៩:១៤–១៧ មក ២:១៨–២២*

៣៣គេទូលទ្រង់ថា ហេតុអ្វីបានជាពួកសិស្សលោកយ៉ូហាន[រ]
តម ហើយអធិស្ឋានជាញយៗ ដូចជាសិស្សរបស់ពួកផារិស៊ី
ដែរ តែសិស្សលោកតែងតែបរិភោគដូច្នេះវិញ។
៣៤ទ្រង់មានបន្ទូលតបថា កំពុងដែលប្ដីថ្មោងថ្មីនៅជាមួយ
គ្នា តើអាចនឹងឱ្យពួកសំឡាញ់គាត់[ល]តមអាហារបានឬទេ
៣៥តែនឹងមានថ្ងៃមកដល់ កាលណោះប្ដី[វ]នឹងត្រូវដកយក
ចេញពីគេទៅ នៅគ្រានោះគេនឹងតមវិញ ៣៦ទ្រង់ក៏មាន
បន្ទូលទៅគេជាពាក្យប្រៀបប្រដូចថា គ្មានអ្នកណាដែល
យកកំណាត់ថ្មី មកប៉ះអាវចាស់ទេ បើធ្វើដូច្នោះ នឹងនាំឱ្យ

**៥:២៧** ប មថ ៤:១៩
**៥:២៨** ផ ខ.១១ មថ ៤:១៩
**៥:២៩** ព លក ១៥:១
**៥:៣០** ភ កច ២៣:៩ ម មថ ៩:១១
**៥:៣២** យ យហ ៣:១៧
**៥:៣៣** រ លក ៧:១៨ យហ ១:៣៥ ៣:២៥,២៦
**៥:៣៤** ល យហ ៣:២៩
**៥:៣៥** វ លក ៩:២២ ១៧:២២ យហ ១៦:៥–៧
**៦:១** ស ចទ ២៣:២៥
**៦:២** ហ មថ ១២:២
**៦:៣** ឡ ១សយ ២១:៦
**៦:៤** អ លវ ២៤:៥,៩
**៦:៥** ក មថ ៨:២០

រហែកដល់ទាំងកំណាត់ថ្មីដែរ ហើយកំណាត់ដែលយកពី
អាវថ្មី ក៏មិនសមនឹងអាវចាស់ផង ៣៧ក៏គ្មានអ្នកណាដែល
យកស្រាទំពាំងបាយជូរថ្មី ដាក់ក្នុងថង់ស្បែកចាស់ដែរបើ
ធ្វើដូច្នោះ ស្រាទំពាំងបាយជូរថ្មី នឹងទំលាយថង់ស្បែកហូរ
ចេញមក ហើយថង់ស្បែកក៏ត្រូវខូចខាតផង ៣៨តោងតែ
ដាក់ស្រាទំពាំងបាយជូរថ្មីក្នុងថង់ស្បែកថ្មីវិញ នោះទាំង២
យ៉ាងនឹងបានគង់នៅ ៣៩លុះកាលបានផឹកស្រាទំពាំងបាយ
ជូរចាស់ហើយ គ្មានអ្នកណាចង់បានថ្មីទេ ដ្បិតគេថាចាស់
ឆ្ងាញ់ជាង។

## ម្ចាស់នៃថ្ងៃឈប់សម្រាក

*៦:១–១១ មថ ១២:១–១៤ មក ២:២៣–៣:៦*

**៦** ១មានកាល១ថ្ងៃ ជាថ្ងៃឈប់សំរាក ទ្រង់យាងកាត់ស្រែ
ហើយពួកសិស្សបានបូតគួរស្រូវបរិភោគ ដោយញីនឹងដៃ[ស]
២មានពួកផារិស៊ីខ្លះស្តីថា ហេតុអ្វីបានជាអ្នករាល់គ្នាធ្វើ
ការ ដែលគ្មានច្បាប់ធ្វើនៅថ្ងៃឈប់សំរាកដូច្នេះ[ហ] ៣តែព្រះ
យេស៊ូវទ្រង់ឆ្លើយទៅគេថា តើអ្នករាល់គ្នាមិនបានមើល
រឿងនេះផងទេឬអី គឺពីការដែលហ្លួងដាវីឌទ្រង់ធ្វើ ក្នុង
កាលដែលទ្រង់ នឹងពួកអ្នកនៅជាមួយបានឃ្លាន[ឡ] ៤ដែល
ទ្រង់យាងចូលទៅក្នុងដំណាក់ព្រះ យកនំបុ័ងតាំងទុកទៅ
សោយ ទាំងចែកឱ្យពួកអ្នកនៅជាមួយនឹងទ្រង់ផង ដែល
គ្មានច្បាប់ឱ្យបរិភោគសោះ ជារបស់ទុកសំរាប់តែពួកសង្ឃ
ប៉ុណ្ណោះ[អ] ៥រួចទ្រង់មានបន្ទូលទៅគេថា កូនមនុស្ស[ក]ក៏ជា
ម្ចាស់នៃថ្ងៃឈប់សំរាកដែរ។

ត្រាស់ហៅមនុស្សនៅទីសាធារណៈម្នាក់ពីកន្លែងយកពន្ធ មកធ្វើជាសាវ័ក គឺពិតជាភាពអស្ចារ្យនៃព្រះគុណរបស់ទ្រង់ ។

**៥:២៨** *ទុករបស់ទាំងអស់ចោល ក្រោកតាមទ្រង់ទៅ* មើលពន្យល់ ខ.១១ ។

**៥:២៩** *ជប់លៀងជាធំ* គ្រាដែលលោកលេវីចាប់ដើរតាមព្រះយេស៊ូវលោកមិនបានដើរតាមដោយសម្ងាត់ឡើយ (យហ ១៩:៣៨ និងការពន្យល់) ។

**៥:៣០** *ពួកអាចារ្យនិងពួកផារិស៊ី គេឧុកដាន់* ពួកនោះប្រាកដជាឈរនៅខាងក្រៅហើយឧុកដាន់ពីចម្ងាយមក ។ *បរិភោគជាមួយនឹងពួកអ្នកយកពន្ធនិងមនុស្សមានបាប* មើលការពន្យល់ មក ២:១៥ ។

**៥:៣១** *ពួកអ្នកជាមិនត្រូវការនឹងគ្រូពេទ្យទេ . . . អ្នកដែលឈឺប៉ុណ្ណោះ* គឺមិនមែនជាការនិយាយប្រយោលថា ពួកផារិស៊ីជាពួកអ្នកជានោះទេ ប៉ុន្តែមនុស្សយើងត្រូវទទួលស្គាល់ខ្លួនឯងថាជាមនុស្សមានបាបជាមុនសិន ទើបអាចទទួលការប្រោសឱ្យជាខាងវិញ្ញាណបាន (មើលការពន្យល់ មក ២:១៧) ។

**៥:៣៣** *ពួកសិស្សលោកយ៉ូហានតម ហើយអធិស្ឋានជាញយៗ* លោកយ៉ូហាន–បាទីស្ទបានចម្រើនវ័យនៅទីរហោស្ថាន ហើយបានរៀនបន្សាំជីវិតរបស់គាត់ជាមួយនឹងអាហារក្រៀមក្រោះដូចជា កណ្តូប និងទឹកឃ្មុំព្រៃ ។ ចំពោះភាពខុសគ្នារវាងព្រះរាជកិច្ចរបស់ព្រះយេស៊ូវ និងកិច្ចការបម្រើព្រះរបស់លោកយ៉ូហាន–បាទីស្ទសូមមើល ៧:២៤–២៨ មថ ១១:១–១៩ ។ ពួកផារិស៊ីក៏មានរបៀបរស់នៅតឹងរឹងផងដែរ (មើលការពន្យល់ ១៨:១២) ប៉ុន្តែ ព្រះយេស៊ូវបានចូលរួមពិធីស៊ីលៀង ហើយសិស្សរបស់ទ្រង់ ក៏បានអរសប្បាយនឹងសេរីភាពតែពួកផារិស៊ីមិនបានស្គាល់សេរីភាពនោះឡើយ ។ *តម* មើលការពន្យល់ ១៨:១២ មក ២:១៨ អស ៥៨:៣–១១ មថ ៤:២ ៦:៦–១៨ ។

**៥:៣៥** មើលការពន្យល់ មក ២:១៩–២០ ។

**៥:៣៦** *ពាក្យប្រៀបប្រដូច* មើលការពន្យល់ មថ ១៣:៣ មក ៤:២។

**៥:៣៧** អ៊ីស្រាអែលសម័យនេះនិយមប្រើថង់ធ្វើពីស្បែក (ជាទូទៅស្បែកពពែ) ។

**៥:៣៨** *ថង់ស្បែកថ្មី* មើលការពន្យល់ មថ ៩:១៧ ។

**៥:៣៩** *ចាស់ឆ្ងាញ់ជាង* ព្រះយេស៊ូវកំពុងបង្ហាញពីការស្ទាក់ស្ទើររបស់មនុស្សមួយចំនួនក្នុងការផ្លាស់ប្តូរជំនឿសាសនាហើយជឿដល់ដំណឹងល្អវិញ ។

**៦:១** *យាងកាត់ស្រែ* មើលការពន្យល់ មក ២:២៣ ។

**៦:៣** *ការដែលហ្លួងដាវីឌទ្រង់ធ្វើ* មើលការពន្យល់ មក ២:២៥ ។

**៦:៤** *នំបុ័ងតាំងទុក* មើលការពន្យល់ មថ ១២:៤ ។

**៦:៥** *កូនមនុស្ស* មើលការពន្យល់ មក ៨:៣១ ។ *ម្ចាស់នៃថ្ងៃឈប់សំរាក* ព្រះយេស៊ូវ ទ្រង់មានអំណាចលើច្បាប់ស្តីពីថ្ងៃឈប់សម្រាកដែលគ្រាន់តែជាការកាត់ស្រាយរបស់ពួកផារិស៊ី (មថ ១២:៨ មក ២:២៧ និងការពន្យល់)។

៦នៅថ្ងៃឈប់សំរាក១ទៀត[ខ] ទ្រង់ចូលទៅបង្រៀនក្នុងសា
លាប្រជុំ ហើយនៅទីនោះមានមនុស្សម្នាក់ ដែលស្វិតដៃ
ខាងស្តាំ ៧ឯពួកអាចារ្យ នឹងពួកផារិស៊ីក៏សំឡឹងមើល[គ] ក្រែង
ទ្រង់ប្រោសឱ្យគាត់ជានៅថ្ងៃឈប់សំរាកដែរ[ឃ] គឺដើម្បីនឹង
រករឿងចោទប្រកាន់ទ្រង់ ៨តែទ្រង់ស្គាល់គំនិតគេ[ង] ក៏មាន
បន្ទូលទៅមនុស្សស្វិតដៃថា ចូរក្រោកឡើងឈរនៅ
កណ្តាលនុ៎ះទៅ ៩កាលគាត់ក្រោកឈរឡើង នោះព្រះ
យេស៊ូវមានបន្ទូលទៅគេថា ខ្ញុំចង់សួរអ្នករាល់គ្នាថា នៅ
ថ្ងៃឈប់សំរាក តើមានច្បាប់នឹងធ្វើការល្អ ឬអាក្រក់ នឹង
សង្គ្រោះជីវិត ឬបំផ្លាញ ១០ទ្រង់ក៏ងាកជុំវិញ ទតមើលគេ
ទាំងអស់គ្នា រួចមានបន្ទូលទៅមនុស្សនោះថា ចូរអ្នកលាត
ដៃទៅ អ្នកនោះក៏លាត ហើយដៃគាត់បានជាដូចម្ខាង
១១គេមានសេចក្តីឃោរឃៅពោរពេញ[ច] ក៏ពិគ្រោះគ្នាពី
ការអ្វីដែលត្រូវធ្វើដល់ព្រះយេស៊ូវ ។

## សាវ័កទាំង១២

*៦:១៣–១៦ មថ ១០:២–៤ មក ៣:១៦–១៩ កច ១:១៣*

១២នៅគ្រានោះទ្រង់ចេញទៅឯភ្នំ ដើម្បីនឹងអធិស្ឋាន រួច
ទ្រង់អធិស្ឋានដល់ព្រះ[ឆ] ដរាបទាល់ភ្លឺ ១៣លុះភ្លឺឡើងទ្រង់
ហៅពួកសិស្សមក ក៏រើសយក១២នាក់ ដែលទ្រង់ហៅថា
សាវក[ជ] ១៤គឺស៊ីម៉ូន ដែលហៅថា ពេត្រុស១ អនទ្រេ ជាប្អូន
គាត់១ យ៉ាកុប១ យ៉ូហាន១ ភីលីព១ បារថូល៉ូមេ១ ១៥ម៉ា
ថាយ១[ឈ] ថូម៉ាស១ យ៉ាកុប ជាកូនអាល់ផាយ១ ស៊ីម៉ូន
ដែលហៅជាអ្នកឧស្សាហ៍១ ១៦និងយូដាស ជាញាតិនឹងយ៉ាកុប១
ហើយយូដាស–អ៊ីស្ការីយ៉ុត ដែលត្រឡប់ជាអ្នកក្បត់១ ។

## ព្រះពរ និងក្តីវេទនា

*៦:២០–២៣ មថ ៥:៣–១២*

១៧ទ្រង់យាងចុះមកជាមួយនឹងអ្នកទាំងនោះ ក៏ឈប់នៅត្រង់
កន្លែងរាបស្មើ នោះមានសិស្សទ្រង់ជាច្រើន នឹងបណ្តាជន
កកកុញមកពីគ្រប់កន្លែងនៅស្រុកយូដា ក្រុងយេរូសាឡិម
ហើយពីស្រុកទីរ៉ុស ស្រុកស៊ីដូន[ញ] ដែលនៅក្បែរសមុទ្រ
ដើម្បីនឹងស្តាប់ទ្រង់ ហើយប្រយោជន៍ឱ្យបានជាជំងឺគេផង
១៨ក៏មានមនុស្សអារក្សអសោចិ៍ចូលបានជាដែរ ១៩មនុស្សទាំង
អស់រកពាល់ទ្រង់[ដ] ដ្បិតមានព្រះចេស្តាចេញពីទ្រង់មក
ប្រោសឱ្យជាទាំងអស់គ្នា[ឋ] ។

**៦:៦** ខ ឧ.១
**៦:៧** គ មថ ១២:១០
ឃ មថ ១២:២
**៦:៨** ង មថ ៩:៤
**៦:១១** ច យហ ៥:១៨
**៦:១២** ឆ លក ៣:២១
**៦:១៣** ជ មក ៦:៣០
**៦:១៥** ឈ មថ ៩:៩
**៦:១៧** ញ មថ ៤:២៥
មថ ១១:២១
មក ៣:៧,៨
**៦:១៩** ដ មថ ៩:២០
ឋ មក ៥:៣០
លក ៥:១៧

**៦:៧** *ក្រែងទ្រង់ប្រោសឱ្យគាត់ជានៅថ្ងៃឈប់សំរាក* មើលពន្យល់ មក ៣:២ ។
**៦:៨** *ក្រោកឡើងឈរនៅកណ្តាល* ដូចនេះនឹងគ្មានការចោទសួរពីការប្រោសជំងឺទេ ។
**៦:៩** *នៅថ្ងៃឈប់សំរាក តើមានច្បាប់នឹងធ្វើការ . . .* ព្រះយេស៊ូវទ្រង់បានអត់ទ្រាំនឹងការចោទសួរ និងការវាយប្រហារពីពួកផារិស៊ី ហើយដល់ពេលនេះទ្រង់បានផ្តើមសួរទាំងអស់គ្នាដែលមានវត្តមានក្នុងសាលាប្រជុំ(មើលការពន្យល់ មក ៣:៤) ។
**៦:១០** *ទតមើលគេទាំងអស់គ្នា* ព្រះយេស៊ូវទ្រង់ចង់ដឹងថា តើមាននរណាប្រឆាំងនឹងសំណួរទ្រង់ ឬឆ្លើយនឹងសំណួរទ្រង់ ប៉ុន្តែ គ្មាននរណាម្នាក់ហ៊ានឡើយ ។
**៦:១១** *គេមានសេចក្តីឃោរឃៅពោរពេញ* ពីព្រោះពួកគេមិនអាចទ្រាំនឹងហេតុផលរបស់ព្រះយេស៊ូវបានតទៅទៀត ។ ពួកគេបានរៀបគម្រោងធ្វើគុតទ្រង់រួចជាស្រេចហើយ (យហ ៥:១៨) ។ មើលការពន្យល់ មក ៣:៦ ។
**៦:១២** ព្រះយេស៊ូវទ្រង់បានចំណាយពេលពេញមួយយប់អធិស្ឋានមុននឹងជ្រើសរើសសាវ័កទាំង១២ ដែលជាព្រះរាជកិច្ចដ៏សំខាន់មួយ ។
**៦:១៣** *ទ្រង់ហៅពួកសិស្សមក* មនុស្សមួយក្រុមដែលមកស្តាប់ការបង្រៀនរបស់ព្រះយេស៊ូវបានដើរតាមទ្រង់យ៉ាងខ្ជាប់ខ្ជួន ហើយបានប្តេជ្ញាចិត្តចំពោះការបង្រៀនរបស់ទ្រង់ ។ ព្រះយេស៊ូវទ្រង់រើសយកអ្នកទាំង ១២ ជាសាវ័កពីចំណោមពួកគេ ពាក្យថាសាវ័កគឺមានន័យថា "អ្នកដែលត្រូវបញ្ជូនចេញសម្រាប់បេសកកម្មមួយដ៏ពិសេស" (មើលការពន្យល់ មក ៦:៣០ ១កថ ១:១ ហព ៣:១) ។ ពួកសាវ័កទាំង១២ នាក់គឺជាក្រុមមនុស្សដំបូងដែលចាប់ផ្តើមពួកជំនុំ ។
**៦:១៤–១៦** បញ្ជីឈ្មោះរបស់ពួកសាវ័កក៏មានបញ្ជាក់ផងដែរនៅក្នុង មថ ១០:២–៤ មក ៣:១៦–១៩ កច ១:១៣ ទោះបីជាការរៀបឈ្មោះខុសគ្នា ក៏ឈ្មោះលោកពេត្រុសតែងតែនៅមុខគេ ហើយឈ្មោះលោកយូដា–អ៊ីស្ការីយ៉ុតតែងនៅក្រោយគេជានិច្ច ។
**៦:១៤** *បារថូល៉ូមេ* ក្នុងដំណឹងល្អខាងដើមទាំងបី ឈ្មោះនេះហាក់ដូចជាដូចឈ្មោះ"ណាថាណែល" (កណ្ឌគម្ពីរយ៉ូហាន) ផងដែរ ។ លោកណាថាណែលមានការទាក់ទងគ្នាជាមួយនឹងលោកភីលីពក្នុង យហ ១:៤៥ ។
**៦:១៥** *ម៉ាថាយ* គឺឈ្មោះមួយទៀតរបស់លោកលេវី (៥:២៧) ។ *យ៉ាកុបជាកូនអាល់ផាយ* គេអាចហៅបានម្យ៉ាងទៀតថា"យ៉ាកុបតូច" (មក ១៥:៤០) ។ *អ្នកឧស្សាហ៍* មើលការពន្យល់ មថ ១០:៤ ។
**៦:១៦** *យ៉ូដាសជាញាតិនឹងយ៉ាកុប* (កូនយ៉ាកុប) អាចហៅបានម្យ៉ាងទៀតថា "ថាដេ" (មថ ១០:៣ មក ៣:១៨ និងការពន្យល់) ។ *យ៉ូដាស–អ៊ីស្ការីយ៉ុត* អាចជាអ្នកស្រុកយូដា ហើយសិស្សដទៃទៀតជាអ្នកស្រុកកាលីឡេ (មើលការពន្យល់ មក ៣:១៩) ។
**៦:១៧** *ឈប់នៅត្រង់កន្លែងរាបស្មើ* ប្រហែលជានៅក្នុងតំបន់ខ្ពង់រាបដែលសក្តិសមនឹងបរិបទនៃខនេះ ក៏ដូចជាបរិបទក្នុង មថ ៥:១ ផងដែរ (មើលការពន្យល់ មថ ៥:១–៧:២៩) ។ *ស្រុកទីរ៉ុស ស្រុកស៊ីដូន* ឈ្មោះមួយទៀតរបស់ស្រុកភេនីស (ល្បាណូនសព្វថ្ងៃ) មើលការពន្យល់ ៤:២៦ ១០:១៤ មក ៧:២៤,៣១ មើលផែនទី១របស់ព្រះគម្ពីរលូកា ។
**៦:១៨** អ្នកខ្លះមានការពិបាកក្នុងខ្លួន ខ្លះខ្វិចសតិ ខ្លះមានជំងឺ ខ្លះទៀតមានអារក្សចូល តែបានជាដោយជំនឿលើទ្រង់ ព្រោះទ្រង់មានអំណាចលើជំងឺនិងអារក្ស ។

២០ ទ្រង់ងើបព្រះនេត្រឡើង ទតទៅពួកសិស្ស មានបន្ទូល
ថា មានពរហើយ អ្នករាល់គ្នាដែលក្រអើយ ដ្បិតនគរព្រះ
ជារបស់ផងអ្នករាល់គ្នា[ឌ] ២១ មានពរហើយ អ្នករាល់គ្នា
ដែលឃ្លានឥឡូវនេះ ដ្បិតអ្នករាល់គ្នានឹងបានឆ្អែត[ឍ] មាន
ពរហើយ អ្នករាល់គ្នាដែលយំឥឡូវនេះ ដ្បិតអ្នករាល់គ្នា
នឹងបានសើចវិញ[ណ] ២២ មានពរហើយ កាលណាមនុស្សនឹង
ស្អប់អ្នករាល់គ្នា ព្រមទាំងកាត់កាល់[ត] ត្មះតិះដៀល[ថ] ហើយ
ចោលឈ្មោះអ្នករាល់គ្នាចេញ ទុកដូចជាអាក្រក់ដោយ
ព្រោះកូនមនុស្ស[ទ] ២៣ ចូរអ្នករាល់គ្នាអរសប្បាយឡើងនៅ
ថ្ងៃនោះ ហើយលោតកញ្ឆេងចុះ[ធ] ដ្បិតមើល អ្នករាល់គ្នា
មានរង្វាន់ជាយ៉ាងធំនៅឯស្ថានសួគ៌ ឯពួកព្យាយុកោរបស់គេ
ក៏បានប្រព្រឹត្តចំពោះពួកហោរាពីដើមយ៉ាងដូច្នោះដែរ[ន]
២៤ តែវេទនាដល់អ្នករាល់គ្នា ជាអ្នកមាន[ប] ដ្បិតអ្នករាល់គ្នា
កំពុងតែមានសេចក្ដីកំសាន្តចិត្តក្នុងសម័យនេះ[ផ] ២៥ វេទនា
ដល់អ្នករាល់គ្នាដែលឆ្អែត ដ្បិតនឹងត្រូវឃ្លានវិញ[ព] វេទនា
ដល់អ្នករាល់គ្នា ដែលសើចក្នុងជាន់ឥឡូវនេះ ដ្បិតនឹងកើត
ទុក្ខព្រួយ ហើយយំសោកវិញ[ភ] ២៦ វេទនាដល់អ្នករាល់គ្នា
កាលណាមនុស្សទាំងអស់និយាយល្អពីអ្នករាល់គ្នា ពីព្រោះ
កាលពីដើម ពួកព្យាយុកោបានប្រព្រឹត្តនឹងពួកហោរាក្លែង
ក្លាយយ៉ាងដូច្នោះដែរ[ម]។

## ការស្រឡាញ់ខ្មាំងសត្រូវ

*៦:២៩,៣០ មថ ៥:៣៩-៤២*

២៧ ប៉ុន្តែ ខ្ញុំប្រាប់អ្នករាល់គ្នា ដែលកំពុងស្ដាប់ថា ចូរអ្នក
រាល់គ្នាស្រឡាញ់ពួកខ្មាំងសត្រូវ ហើយប្រព្រឹត្តល្អនឹងពួកអ្នក
ដែលស្អប់អ្នករាល់គ្នាវិញ[យ] ២៨ ចូរឱ្យពរដល់អ្នកណាដែល
គេប្រទេចផ្ដាសាអ្នក ហើយអធិស្ឋានឱ្យអ្នកណាដែលធ្វើទុក្ខ
អ្នក[រ] ២៩ ឯអ្នកណាដែលទះកំភ្លៀងអ្នកម្ខាង នោះត្រូវបែរ
ម្ខាងទៅឱ្យគេទៀត ហើយបើអ្នកណាយកអាវវែងរបស់អ្នក
នោះកុំឱ្យឃាត់មិនឱ្យគេយកអាវតូចអ្នកផងឡើយ ៣០ ចូរ
ឱ្យដល់អ្នកណាដែលសូមអ្នក ហើយបើអ្នកណាយករបស់អ្វី
ផងអ្នក នោះកុំទារវិញឡើយ[ល] ៣១ ដែលអ្នករាល់គ្នាចង់
ឱ្យគេប្រព្រឹត្តនឹងខ្លួនជាយ៉ាងណា នោះត្រូវតែប្រព្រឹត្តនឹង
គេយ៉ាងនោះដែរ[វ] ៣២ បើអ្នករាល់គ្នាស្រឡាញ់តែពួកអ្នក
ដែលស្រឡាញ់ដល់អ្នក នោះតើមានគុណបំណាចអ្វី[ស] ដ្បិត
ទាំងមនុស្សមានបាបក៏ស្រឡាញ់ដល់ពួកអ្នក ដែលស្រឡាញ់
គេដូចគ្នាដែរ ៣៣ ហើយបើអ្នករាល់គ្នាប្រព្រឹត្តល្អ ចំពោះ
តែពួកអ្នកដែលប្រព្រឹត្តល្អនឹងខ្លួនអ្នក នោះតើមានគុណ
បំណាច់អ្វី ដ្បិតទាំងមនុស្សមានបាបក៏ប្រព្រឹត្តដូច្នោះដែរ
៣៤ បើអ្នករាល់គ្នាឱ្យគេខ្ចី ដែលសង្ឃឹមនឹងបានវិញ នោះ
តើមានគុណបំណាច់អ្វី[ហ] ដ្បិតទាំងមនុស្សមានបាបក៏ឱ្យ
មនុស្សមានបាបខ្ចីដែរ ដើម្បីឱ្យបានដូចដើមវិញ ៣៥ ចូរ
ស្រឡាញ់ដល់ខ្មាំងសត្រូវរបស់អ្នករាល់គ្នា ឱ្យប្រព្រឹត្តល្អ

**៦:២០** ឌ មថ ២៥:៣៤
**៦:២១** ឍ អស ៥៥:១,២ មថ ៥:៦
ណ អស ៦១:២,៣ មថ ៥:៤ វវ ៧:១៧
**៦:២២** ត យហ ៩:២២ ១៦:២ ថ អស ៥១:៧
ទ យហ ១៥:២១
**៦:២៣** ធ មថ ៥:១២
ន មថ ៥:១២
**៦:២៤** ប យក ៥:១
ផ លក ១៦:២៥
**៦:២៥** ព អស ៦៥:១៣
ភ សភ ១៤:១៣
**៦:២៦** ម មថ ៧:១៥
**៦:២៧** យ ខ.៣៥ មថ ៥:៤៤ រម ១២:២០
**៦:២៨** រ មថ ៥:៤៤
**៦:៣០** ល ចទ ១៥:៧,៨,១០ សភ ២១:២៦
**៦:៣១** វ មថ ៧:១២
**៦:៣២** ស មថ ៥:៤៦
**៦:៣៤** ហ មថ ៥:៤២

**៦:២០-៤៩** ការបង្រៀននៅទីរាបស្មើក្នុងគម្ពីរលូកា គឺត្រូវនឹងការបង្រៀននៅលើទីទួលក្នុងកណ្ឌគម្ពីរម៉ាថាយ (មថ ៥-៧) ។ ទោះជាការបង្រៀនក្នុងព្រះគម្ពីរនេះខ្លីជាងការបង្រៀនក្នុងព្រះគម្ពីរម៉ាថាយមែនពិត ក៏គម្ពីរទាំងពីរនេះបានចាប់ផ្ដើមដូចគ្នា ដោយនិយាយពីព្រះពររបស់ព្រះ ហើយបញ្ចប់ទៅវិញ ដោយនិយាយពីមេរៀនពីអ្នកសង់ផ្ទះដូចគ្នាផងដែរ ។ ការបង្រៀនក្នុងគម្ពីរម៉ាថាយមួយចំនួន គេអាចឃើញនៅក្នុងផ្នែកដទៃៗទៀតរបស់គម្ពីរលូកា (១១:២-៤ ១២:២២-៣១ ៣៣-៣៤) ។

**៦:២០-២៣** មើល មថ ៥:៣-១២ និងការពន្យល់ ។

**៦:២០** ចំពោះព្រះគម្ពីរម៉ាថាយវិញ គឺបាននិយាយអំពី "ការកម្សត់ខាងឯវិញ្ញាណ" (មថ ៥:៣) ។ អ្នកដែលក្រគឺ អ្នកដែលបានលះចោលអ្វីៗទាំងអស់ ដើម្បីដើរតាមព្រះមានការស្កប់ស្កល់ចិត្តនឹងរស់នៅក្នុងព្រះហស្តទ្រង់ ហើយមិនដែលរំពឹងថានឹងបានជម្រើសរបស់លោកិយ ដែលល្អជាងក្នុងការងារបម្រើទ្រង់ឡើយ ។ គឺអ្នកដែលតម្រូវឱ្យធ្វើការដោយលំបាក និងប្រឹងប្រែងសម្រេចគោលដៅដូចជាអ្នកក្រ ប៉ុន្តែ អ្នកនោះមានពរនៅក្នុងសេចក្ដីក្រនោះវិញ ដោយព្រោះនគរព្រះជារបស់ផងអ្នកនោះ ម្យ៉ាងទៀតអ្នកជឿណាដែលក្រនៅលោកិយនេះ ជាអ្នកមានខាងសេចក្ដីជំនឿ" (យក ២:៥) ។

**៦:២១** *ឃ្លានឥឡូវនេះ* ព្រះគម្ពីរម៉ាថាយប្រើពាក្យថា "ការស្រេកឃ្លាននូវសេចក្ដីសុចរិត" (មថ ៥:៦) គឺជាការរៀបរាប់ដែលមានលក្ខណៈពេញលេញជាងគម្ពីរលូកា ប៉ុន្តែ មិនមានភាពខុសគ្នាផ្នែកអត្ថន័យទេ ។

**៦:២២** *ចោលឈ្មោះអ្នករាល់គ្នា* គឺឈ្មោះថាជាសិស្សរបស់ទ្រង់ ។ ដោយព្រោះយ៉ាងហើយនេះ ទើបបានជាពេលខ្លះគេហៅអ្នកជឿថា "ពួកណាសារិន" (ពួកមកពីស្រុកណាសារ៉ែត) ហើយពេលខ្លះថា "ពួកគ្រីស្ទាន" ។ ការហៅឈ្មោះដូចនេះ គឺជាការបន្ទោសបង្អាប់ដែលចេញពីមាត់របស់ពួកខ្មាំងសត្រូវ ។

**៦:២៣** *បានប្រព្រឹត្តចំពោះពួកហោរាពីដើម* មើល ១ពវ ១៨:៤ ១៩:២០ ២របា ២៤:២១ ៣៦:១៦ នហ ៩:២៦ ។

**៦:២៤** អ្នកដែលព្យាយាមស្វែងរកការស្កប់ស្កល់ចិត្តដោយការមានបាន នោះប្រហែលជាមានតែទ្រព្យសម្បត្តិប៉ុណ្ណោះ ដែលសមនឹងទទួលបានជារង្វាន់ តែជារង្វាន់ដែលមិនស្ថិតស្ថេរ ។ ដូចនេះមិនគួរចំណាយអ្វីៗគ្រប់យ៉ាងដើម្បីស្វែងរកភាពស្រណុកស្រួលក្នុងពេលបច្ចុប្បន្ន ដោយមិនស្វែងរកជីវិតពេញបរិបូរណ៍នោះឡើយ ។

**៦:២៥** *ឆ្អែត* គឺឆ្អែតនឹងសាច់ គ្រឿងផឹក និងរបស់របរលោកិយ ។

**៦:២៤-២៦** វគ្គនេះគឺជាការនិយាយផ្ទុយគ្នាដោយចំនុចនឹង ខ.២០-២២ ។

**៦:២៧** យើងត្រូវស្អប់អំពើបាប តែស្រឡាញ់ដល់មនុស្សដែលមានបាបវិញ ។

**៦:២៩** *ត្រូវបែរម្ខាងទៅឱ្យគេទៀត* គឺមិនត្រូវមានចរិតជាអ្នកសងសឹកឡើយ ។ *អាវវែង...អាវតូចអ្នក* អាវវែងគឺជាអាវក្រៅ សម្រាប់ពាក់បន្ថែមពីលើអាវតូច (មើលការពន្យល់ ២ធថ ៤:១៣) ។

**៦:៣៥** ត្រូវស្រឡាញ់ដោយមិនប្រកាន់ថាអ្នកនោះជាអ្វីនឹងយើងទេ ទោះជាគេ

នឹងគេ[ឡ] ហើយឱ្យគេខ្ចី ដោយឥតសង្ឃឹមនឹងបានអ្វីមកវិញ
ចុះនោះ អ្នករាល់គ្នានឹងបានរង្វាន់ជាយ៉ាងធំ ហើយនឹងធ្វើជា
កូន[អ]នៃព្រះដ៏ខ្ពស់បំផុត[ក] ដ្បិតទ្រង់តែងល្អ ដល់ទាំងមនុស្ស
អកត្តញ្ញូ នឹងមនុស្សអាក្រក់ដែរ ៣៦ដូច្នេះ ចូរអ្នករាល់គ្នា
មានចិត្តមេត្តាករុណា[ខ] ដូចជាព្រះវរបិតានៃអ្នក[គ] ទ្រង់មាន
ព្រះហឫទ័យមេត្តាករុណាដែរ ។

## ការថ្កោលទោស

*៦:៣៧–៤២ មថ ៧:១–៥*

៣៧កុំឱ្យថ្កោលទោសគេឱ្យសោះ ដើម្បីកុំឱ្យមានគេថ្កោល
ទោសអ្នកវិញ[ឃ] កុំឱ្យនិន្ទាគេឡើយ ដើម្បីកុំឱ្យមានគេនិន្ទា
អ្នកវិញដែរ ចូរលើកលែងឱ្យគេ នោះគេនឹងលើកលែងឱ្យ
អ្នកវិញ[ង] ៣៨ចូរឱ្យទៅគេ នោះនឹងបានឱ្យមកអ្នកដែរ គេនឹង
វាល់ឱ្យអ្នកយ៉ាងល្អ ទាំងញាត់ ទាំងរលាក់ ហើយដាក់ឱ្យ
ហៀរ នឹងយកមកដាក់បំពេញចិត្តអ្នកផង[ច] ដ្បិតគេនឹងវាល់
ឱ្យអ្នកតាមរង្វាល់ណាដែលអ្នកវាល់ឱ្យគេ[ឆ]។
៣៩ទ្រង់ក៏មានបន្ទូលពាក្យប្រៀបទៅគេថា តើមនុស្សខ្វាក់
អាចនឹងដឹកមនុស្សខ្វាក់បានឬទេ តើមិនធ្លាក់ទៅក្នុងរណ្ដៅ
ទាំង២នាក់ទេឬអី[ជ] ៤០សិស្សមិនមែនលើសជាងគ្រូទេ តែ
អ្នកណាដែលបានគ្រប់លក្ខណ៍ នោះនឹងបានដូចជាគ្រូដែរ[ឈ]
៤១ហេតុអ្វីបានជាមើលឃើញកំទេច ដែលនៅក្នុងភ្នែកប្អូន
អ្នក តែមិនឃើញធ្នឹម ដែលនៅក្នុងភ្នែកខ្លួនវិញសោះ ៤២ធ្វើ
ដូចម្ដេចឱ្យអ្នក ដែលមើលធ្នឹមក្នុងភ្នែកខ្លួនមិនឃើញ អាច
និយាយទៅប្អូនបានថា ប្អូនអើយឱ្យអញយកកំទេច ពីភ្នែក
ឯងចេញដូច្នេះ ឱអ្នកមានពុតអើយ ចូរយកធ្នឹមពីភ្នែក
អ្នកចេញជាមុនសិន នោះទើបនឹងបានឃើញច្បាស់អាច
នឹងយកកំទេចចេញពីភ្នែកប្អូនអ្នកបានដែរ។

## ដើមឈើ និងផ្លែរបស់វា

*៦:៤៣,៤៤ មថ ៧:១៦,១៨,២០*

៤៣ដ្បិតគ្មានដើមឈើល្អណា ដែលមានផលផ្លែអាក្រក់ទេ
ក៏គ្មានដើមអាក្រក់ណា ដែលមានផលផ្លែល្អដែរ ៤៤ពីព្រោះ
គេស្គាល់ដើមឈើនីមួយៗ ដោយសារតែផ្លែទេ[ញ] គេមិន
ដែលបេះផ្លែល្វាពីគុម្ពបន្លា ឬផ្លែទំពាំងបាយជូរពីអញ្ចាញ
ឡើយ ៤៥ឯមនុស្សល្អ គេក៏យកសេចក្ដីល្អ ពីកំណប់ល្អ ដែល
កប់ទុកក្នុងចិត្តគេ ហើយមនុស្សអាក្រក់ក៏យកសេចក្ដីអាក្រក់
ចេញពីកំណប់អាក្រក់ក្នុងចិត្តខ្លួនដែរ ដ្បិតមាត់គេពោល
បញ្ចេញសេចក្ដីបរិបូរដែលនៅក្នុងចិត្តជានិច្ច[ដ]។

## មនុស្សឆ្លាត និងមនុស្សល្ងង់សង់ផ្ទះ

*៦:៤៧–៤៩ មថ ៧:២៤–២៧*

៤៦ហេតុអ្វីបានជាហៅខ្ញុំថា ឱព្រះអម្ចាស់ៗអើយ[ឋ] តែមិន
ធ្វើតាមពាក្យខ្ញុំ វិញដូច្នេះ[ឌ] ៤៧ឯអស់អ្នកដែលមកស្ដាប់
ពាក្យខ្ញុំទាំងនេះ ហើយប្រព្រឹត្តតាមនោះខ្ញុំនឹងបង្ហាញឱ្យ
អ្នករាល់គ្នាដឹងថា អ្នកនោះធៀបដូចជាអ្វី[ឍ] ៤៨គឺធៀបដូច
ជាមនុស្សម្នាក់ដែលសង់ផ្ទះ គាត់បានជីកយ៉ាងជ្រៅដាក់
ជើងសសរនៅលើថ្ម កាលមានទឹកជន់ឡើង ហូរគំហុកមក
ប៉ះ នឹងផ្ទះនោះ នោះធ្វើឱ្យរញ្ជួយមិនបានឡើយ ពីព្រោះ
បានសង់នៅលើថ្ម ៤៩តែអ្នកដែលឮ ហើយមិនប្រព្រឹត្តតាម
នោះប្រៀបដូចជាមនុស្សម្នាក់ដែលសង់ផ្ទះនៅ លើដីឥត
ដាំជើងសសរសោះ លុះទឹកហូរគំហុកមកប៉ះត្រូវ ផ្ទះនោះ
ក៏រលំទៅភ្លាម ហើយត្រូវខូចខាតជាច្រើនផង។

## សេចក្ដីជំនឿរបស់មេទ័ពម្នាក់

*៧:១–១០ មថ ៨:៥–១៣*

**៧** ១កាលទ្រង់មានបន្ទូលសេចក្ដីទាំងនោះ[ណ] ឱ្យបណ្ដាជន
ស្ដាប់រួចហើយ ក៏យាងចូលទៅក្នុងក្រុងកាពើណិមវិញ
២នោះមានបាវសំណប់របស់មេទ័ពម្នាក់ វាឈឺហៀបនឹង

**៦:៣៥** ឡ ខ.២៧
អ រម ៨:១៤
ក មក ៥:៧
**៦:៣៦** ខ យក ២:១៣
គ មថ ៥:៤៨ ៦:១
លក ១១:២ ១២:៣២
រម ៨:១៥ អភ ៤:៦
១ពត ១:១៧
១យហ ១:៣ ៣:១
**៦:៣៧** ឃ មថ ៧:១
ង មថ ៦:១៤
**៦:៣៨** ច ទដ ៧៩:១២
អស ៦៥:៦,៧
ឆ មថ ៧:២
**៦:៣៩** ជ មថ ១៥:១៤
**៦:៤០** ឈ យហ ១៣:១៦
**៦:៤៤** ញ មថ ១២:៣៣
**៦:៤៥** ដ សភ ៤:២៣
មថ ១២:៣៤,៣៥
មក ៧:២០
**៦:៤៦** ឋ យហ
១៣:១៣ ឌ មឡ ១:៦
មថ ៧:២១
**៦:៤៧** ឍ លក ៨:២១
១១:២៨
យក ១:២២–២៥
**៧:១** ណ មថ ៧:២៨

ស្អប់ ឬ មានគម្រោងធ្វើបាបយើងក៏ដោយ ។ ប្រាក់កាសដែលយើងប្រគល់ឱ្យទៅដល់អ្នកណាម្នាក់ហើយ គួរតែចាត់ទុកជាអំណោយវិញ គឺមិនមែនជាប្រាក់កម្ចីដែលមានការប្រាក់ខ្ពស់ ដែលនឹងជួយដល់ខ្លួនឯងជាងជួយគេនោះឡើយ ។ ចូរឱ្យដល់គេដូចជាអ្នកថ្វាយទៅព្រះដែរ ។

**៦:៣៦** *ដូចជាព្រះវរបិតានៃអ្នក ទ្រង់មានព្រះហឫទ័យមេត្តាករុណា* ភាពគ្រប់លក្ខណ៍របស់ព្រះ គឺជាគំរូ និងគោលដៅរបស់យើង (មថ ៥:៤៨ និងការពន្យល់) ។

**៦:៣៧,៣៨** *កុំឱ្យថ្កោលទោសគេឱ្យសោះ* មើលការពន្យល់មថ ៧:១ ។ បើយើងស៊ូរិះគន់គេជាជាងអាណិតអាសូរដល់គេ នោះយើងនឹងទទួលការរិះគន់ដូចគេដែរ ។ បើយើងប្រព្រឹត្តនឹងអ្នកឯទៀតដោយសប្បុរស មេត្តា និងការអាណិតអាសូរ នោះយើងនឹងទទួលបាននូវការតបស្នងមកវិញ តាមរង្វាល់មួយដ៏ត្រឹមត្រូវ ។ យើងត្រូវស្រឡាញ់អ្នកដទៃ គឺមិនមែនថ្កោលទោសគេឡើយ ។

**៦:៤១** ព្រះយេស៊ូវទ្រង់មានបន្ទូលជាពាក្យប្រៀបប្រដូចពីអំពើបាប ឬទោសកំហុសដែលមនុស្សមានពុតដោយល្ងីល្ងើបានលើកពីអ្នកដទៃ ដោយមើលរំលងកំហុសខ្លួនឯង (មថ ៧:៣–៤ និងការពន្យល់ ៧:៣) ។

**៦:៤២** *អ្នកមានពុត* មើលការពន្យល់ ១៣:១៥ មថ ២៣:២៣ កច ៥:៩ ។

**៦:៤៣–៤៥** យក ៣:១១–១២ និងការពន្យល់ ។

**៦:៤៦–៤៩** មើល មថ ៧:២៤–២៧ និងការពន្យល់ ។

**៦:៤៧,៤៩** *ស្ដាប់ពាក្យខ្ញុំ ទាំងនេះ ហើយប្រព្រឹត្តតាម . . . មិនប្រព្រឹត្តតាម* មើល យក ១:២២–២៥ ។

**៧:១** *ក្រុងកាពើណិម* មើលការពន្យល់ មថ ៤:១៣ ។

**៧:២** *បាវសំណប់របស់មេទ័ព* មេទ័ពម្នាក់នេះអាចជាសមាជិកដែលបម្រើការក្នុងជួរទាហានស្ដេចហេរ៉ូឌ–អង់ទីប៉ាស ដែលត្រូវបានរៀបចំតាមរបៀបសាសន៍រ៉ូម៉ាំង តាមធម្មតាក្នុងមួយកងពលមានទាហាន១០០នាក់ (មើលការ

ស្លាប់ ³លោកបានឮនិយាយពីព្រះយេស៊ូវ ក៏ចាត់ពួកចាស់
ទុំសាសន៍យូដាខ្លះ ឱ្យទៅអង្វរអញ្ជើញទ្រង់ មកជួយ
សង្គ្រោះបាវនោះ ⁴កាលគេបានទៅដល់ព្រះយេស៊ូវហើយ
នោះក៏ទទូចអង្វរទ្រង់ថា មេទ័ពនោះមានបំណាច់ណាស់
គួរឱ្យប្រោសមេត្តាដែរ ⁵ដ្បិតគាត់ស្រឡាញ់ដល់សាសន៍
យើង ហើយបានសង់សាលាប្រជុំ១ សំរាប់យើងរាល់គ្នា ។
⁶ព្រះយេស៊ូវក៏យាងទៅជាមួយនឹងគេ ។ កាលហៀបនឹង
ដល់ផ្ទះហើយ នោះមេទ័ពចាត់ពួកសំឡាញ់ឱ្យមកទូលទ្រង់
ថា ព្រះអម្ចាស់អើយ សូមកុំព្រួយព្រះទ័យឡើយ មិនគួរ
នឹងឱ្យទូលបង្គំទទួលទ្រង់នៅក្នុងផ្ទះទូលបង្គំទេ ⁷[ត]គឺដោយ
ហេតុនោះបានជាទូលបង្គំមិនបានរាប់ខ្លួនថា គួរនឹងមក
ឯទ្រង់ដែរ សូមទ្រង់គ្រាន់តែមានបន្ទូល១ព្រះឱស្ឋប៉ុណ្ណោះ
ចុះ នោះបាវទូលបង្គំបានជាហើយ[ត] ⁸ដ្បិតទូលបង្គំនៅ
ក្រោមអំណាចគេដែរ ក៏មានទាហាននៅក្រោម ឱវាទទូល
បង្គំ ទូលបង្គំប្រាប់ទៅម្នាក់ថា ទៅ វាក៏ទៅ ប្រាប់ទៅម្នាក់
ទៀតថា មក វាក៏មក ហើយប្រាប់ទៅបាវថា ធ្វើការ
នេះចុះ នោះវាក៏ធ្វើតាម ⁹កាលព្រះយេស៊ូវបានឮសេចក្ដី
ទាំងនោះ ទ្រង់ក៏មានសេចក្ដីអស្ចារ្យនឹងមេទ័ពនោះណាស់
រួចទ្រង់បែរទៅ មានបន្ទូលនឹងមនុស្សទាំងប៉ុន្មានដែលតាម
ទ្រង់ថា ខ្ញុំប្រាប់អ្នករាល់គ្នាថា ខ្ញុំមិនដែលឃើញសេចក្ដី
ជំនឿណាជាខ្លាំងដល់ម្ល៉េះទេ ទោះបើនៅសាសន៍អ៊ីស្រា
អែលក៏ដោយ ¹⁰ឯពួកអ្នកដែលលោកបានចាត់ឱ្យមក
គេក៏ត្រឡប់ទៅផ្ទះវិញ ឃើញបាវដែលឈឺនោះបានជា
ហើយ ។

**៧:៧** ត ទដ ១០៧:២០
**៧:១៣** ថ ខ.១៩ លក ១០:១ ១៣:១៥ ១៧:៥ ២២:៦១ ២៤:៣៤ យហ ១១:២
**៧:១៤** ទ មថ ៩:២៥ មក ១:៣១ លក ៨:៥៤ យហ ១១:៤៣ កច ៩:៤០
**៧:១៦** ធ លក ១:៦៥ ន មថ ៩:៨ ប ខ.៣៩ មថ ២១:១១ ផ លក ១:៦៨
**៧:១៧** ព មថ ៩:២៦

## ព្រះយេស៊ូវប្រោសកូនរបស់ស្ត្រីមេម៉ាយម្នាក់

*៧:១១-១៦ = ១ ពវ ១៧:១៧-២៤ ២ ពវ ៤:៣២-៣៧*
*មក ៥:២១-២៤,៣៥-៤៣ យហ ១១:១-៤៤*

¹¹ដល់ថ្ងៃក្រោយមក ទ្រង់យាងទៅឯក្រុង១ហៅថា ណាអ៊ីន
មានទាំងពួកសិស្ស នឹងមនុស្សសន្ធឹកទៅដែរ ¹²កាល
ចូលទៅជិតដល់ទ្វារកំផែងក្រុង នោះឃើញគេសែងខ្មោច
ចេញមក ជាខ្មោចកូនតែ១ ដែលម្ដាយនៅមេម៉ាយ ហើយ
មានមនុស្សក្រុងនោះជាច្រើនហែមកជាមួយនឹងគាត់
¹³កាលព្រះអម្ចាស់[ថ]បានឃើញ នោះទ្រង់មានព្រះហឫទ័យ
ក្ដួលអាណិតអាសូរដល់គាត់ណាស់ ក៏មានបន្ទូលថា កុំយំ
អី ¹⁴រួចទ្រង់យាងចូលទៅពាល់ក្ដារមឈូស ឯពួកអ្នក
សែងក៏ឈប់ ហើយទ្រង់មានបន្ទូលថា អ្នកកំលោះអើយ ខ្ញុំ
បង្គាប់អ្នកថា ចូរក្រោកឡើង[ទ] ¹⁵អ្នកដែលស្លាប់នោះក៏
ក្រោកឡើងអង្គុយ ហើយចាប់តាំងនិយាយរួចទ្រង់ប្រគល់
ដល់ម្ដាយវិញ ¹⁶មនុស្សទាំងអស់គ្នាកើតមានសេចក្ដីស្ញែង
ខ្លាច[ធ] ក៏សរសើរដំកើងដល់ព្រះ[ន]ដោយពាក្យថា មានហោរា
១ធំ[ប]បានកើតឡើងក្នុងពួកយើង ហើយថា ព្រះបានប្រោស
រាស្ត្រទ្រង់ហើយ[ផ] ¹⁷ពាក្យគេថ្លែងពីទ្រង់នេះ បានឮសុស
សាយពេញទូទៅក្នុងស្រុកយូដា នឹងស្រុកនៅជុំវិញទាំង
អស់[ព] ។

ពន្យល់ មថ ៨:៥)។ យោងតាមព្រះគម្ពីរសញ្ញាថ្មី បណ្ដាមេទ័ពរ៉ូម៉ាំងបាន បង្ហាញនូវលក្ខណៈសម្បត្តិល្អគួរឱ្យសរសើរ (មើល កច ១០:២និងការពន្យល់ ២៣:១៧-១៨ ២៧:៤៣)។ មេទ័ពម្នាក់នេះ គឺបានបង្ហាញពីការខ្វល់ខ្វាយ យ៉ាងខ្លាំងចំពោះអ្នកបម្រើរបស់ខ្លួន គាត់បានទទួលការកោតសរសើរពី សាសន៍យូដា ដោយពួកគេបាននិយាយល្អពីគាត់ ដោយមិនខ្វល់ថាគាត់ជា សាសន៍ដទៃ (ខ.៥,៩)។

**៧:៣** *ពួកចាស់ទុំសាសន៍យូដា* គឺអ្នកដែលគេផ្ដល់ឱ្យនូវការគោរពដ៏ខ្ពង់ខ្ពស់ នៅក្នុងសហគមន៍របស់ខ្លួន ទោះបីជាពួកគេជាអ្នកដឹកនាំសាលាប្រជុំ ឬមិន មែនក៏ដោយ គឺឱ្យតែជាសាសន៍យូដា ។ នៅក្នុងព្រះគម្ពីរម៉ាថាយ(មថ ៨:៥-១៣) មានមេទ័ពម្នាក់បានទៅទូលព្រះយេស៊ូវដោយខ្លួនគាត់ផ្ទាល់ រីឯនៅក្នុង ព្រះគម្ពីរលូកាវិញ គឺមានមេទ័ពម្នាក់បានទូលសូមដល់ព្រះយេស៊ូវតាមរយៈ ចាស់ទុំសាសន៍យូដា (មើលការពន្យល់ មថ ៨:៥)។

**៧:៦** *មិនគួរនឹងឱ្យទូលបង្គំទទួលទ្រង់នៅក្នុងផ្ទះរបស់ទូលបង្គំ* "មើលកាល ពន្យល់ មថ ៨:៨"។

**៧:៩** មើលការពន្យល់ មថ ៨:១១ ។ *ទ្រង់ក៏មានសេចក្ដីអស្ចារ្យ* មានបញ្ជាក់ ចំនួនតែពីរដងគត់អំពីការដែលព្រះយេស៊ូវទ្រង់មានសេចក្ដីអស្ចារ្យ ។ នៅខ នេះទ្រង់មានសេចក្ដីអស្ចារ្យ ដោយព្រោះសេចក្ដីជំនឿ តែកាលនៅស្រុក ណាសារ៉ែត គឺព្រោះតែការមិនជឿ (មក ៦:៦ និងការពន្យល់ មក ៦:៥)។

**៧:១១,១២** *ណាអ៊ីន* មានបញ្ជាក់តែម្ដងនេះគត់ ។ ណាអ៊ីនជាភូមិមួយមាន ចម្ងាយប្រហែល៦,៤គម ពីភ្នំតាបោរ និងនៅខាងជើងក្រុងកាពើណិមចម្ងាយ ប្រហែល៤០ គម ។ *ទ្វារ* នៅក្រៅទ្វារក្រុងណាអ៊ីន គឺជាទីបញ្ចុះសព ។ តាម ន័យធៀប "ទ្វារ" គឺជាច្រកផ្លូវដែលនាំឆ្ពោះទៅរកជីវិត និងសេចក្ដីហិន វិនាស(មថ ៧:១៣,១៤ លក ១៣:២៤) ឬទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់ (មថ ១៦:១៨)សារសំខាន់ និងកម្លាំងរបស់ទ្វារបង្ហាញថា ទ្វារមានន័យដូចជា "អំណាច"ដែរ ។ ម្យ៉ាងទៀត ទ្វារគឺធៀបដូចជាអ្នកដឹកនាំក្នុងជួររដ្ឋាភិបាល និងអ្នកស្វែងរកយុត្តិធម៌ឱ្យមនុស្សនៅកន្លែងដែលមានទ្វារនោះ ។

**៧:១៤** *ពាល់ក្ដារមឈូស* ដើម្បីប្រោសអ្នកស្លាប់ម្នាក់នោះ ព្រះយេស៊ូវទ្រង់បាន ពាល់ក្ដារមឈូស ដែលតាមក្រឹត្យវិន័យ ត្រូវរាប់ជាមិនស្អាត(ជន ១៩:១៦)។ *ក្ដារមឈូស* ប្រហែលជាគេសែងសាកសពបុរសម្នាក់នោះ នៅក្នុងក្ដារ មឈូសចំហមួយ តាមប្រពៃណីរបស់សាសន៍យូដា និងតាមការពិតដែលអ្នក កំលោះម្នាក់នោះបានងើបអង្គុយ តាមការបង្គាប់របស់ព្រះយេស៊ូវ ។ ការ ប្រោសនេះគឺជាលើកទីមួយ ក្នុងចំណោមការប្រោសមនុស្សស្លាប់ទាំងបី លើក ដែលអ្នកបន្ទាប់មានកូនស្រីរបស់លោកយ៉ៃរ៉ូស(៨:៤០-៥៦) និង ឡាសារ (យហ ១១:៣៨-៤៤)។

**៧:១៥** *ប្រគល់ដល់ម្ដាយវិញ* ១ពវ ១៧:២៣ ២ពវ ៤:៣៦-៣៧ ។

**៧:១៦** *សរសើរដំកើងដល់ព្រះ* មើល ១:៦៤ និងការពន្យល់ ។

## ព្រះយេស៊ូវ និងលោកយ៉ូហាន–បាទីស្ទ

*៧:១៨–៣៥ = មថ ១១:២–១៩*

១៨ពួកសិស្ស[ភ]យ៉ូហាន [ម]ក៏ទៅប្រាប់គាត់ពីគ្រប់ការទាំងនេះ
១៩រួចយ៉ូហានហៅសិស្សគាត់២នាក់មក ប្រើឱ្យទៅទូលសួរ
ព្រះយេស៊ូវថា តើទ្រង់ជាព្រះដែលត្រូវមកពិត ឬត្រូវ
ឱ្យយើងខ្ញុំនៅចាំ១អង្គទៀត ២០កាលអ្នកទាំង២នោះមកដល់
ក៏ទូលទ្រង់ថា លោក យ៉ូហាន–បាទីស្ទបានចាត់យើងខ្ញុំឱ្យ
មកសួរទ្រង់ថា តើទ្រង់ជាព្រះដែលត្រូវមកពិត ឬត្រូវឱ្យ
យើងខ្ញុំនៅចាំ១អង្គទៀត ២១នៅវេលានោះឯង ទ្រង់បាន
ប្រោសមនុស្សជំងឺ[យ]មនុស្សវេទនា នឹងមនុស្សអារក្សអសោចិ៍
ចូលជាច្រើនឱ្យបានជា ហើយមនុស្សខ្វាក់ជាច្រើនឱ្យភ្លឺដែរ
២២រួចទ្រង់ក៏ឆ្លើយថា ចូរទៅប្រាប់យ៉ូហានពីការដែលអ្នក
បានឃើញហើយឮចុះ គឺមនុស្សខ្វាក់បានភ្លឺ មនុស្សខ្វិនដើរ
បាន មនុស្សឃ្លង់បានជាស្អាត មនុស្សថ្លង់ស្តាប់ឮ មនុស្ស
ស្លាប់រស់ឡើងវិញ ហើយមនុស្សទាល់ក្រ[រ]ក៏បានឮដំណឹង
ល្អ ២៣មានពរហើយ អ្នកណាដែលមិនរវាតចិត្តដោយ
ព្រោះខ្ញុំ។

២៤កាលសិស្សដែលយ៉ូហានចាត់ឱ្យមក បានចេញទៅ
ហើយ នោះទ្រង់ចាប់តាំងមានបន្ទូលនឹងបណ្តាមនុស្សពី
យ៉ូហានថា តើអ្នករាល់គ្នាបានទៅមើលអ្វីនៅទីរហោ
ស្ថាន បានទៅមើលដើមត្រែងរញ្ជួយនឹងខ្យល់ឬអី ២៥តើ
អ្នករាល់គ្នាបានទៅមើលអ្វី បានទៅមើលមនុស្សស្លៀក
ពាក់អាវទន់ភ្លន់ឬអី មើល ពួកអ្នកដែលស្លៀកពាក់ល្អ
ប្រសើរ ហើយរស់នៅដោយរុងរឿង នោះសុទ្ធតែនៅក្នុង
ដំណាក់ស្តេចទេ ២៦ចុះអ្នករាល់គ្នាបានទៅមើលអ្វី មើល
ហោរា[ល]ឬអី មែនហើយ ខ្ញុំប្រាប់អ្នករាល់គ្នាថា គាត់ក៏
លើសជាងហោរាផង ២៧ដ្បិតគឺពីអ្នកនេះហើយ ដែលមាន
សេចក្តីចែងទុកមកថា «មើល អញចាត់ទូតអញទៅមុនឯង
ទូតនោះនឹងរៀបចំផ្លូវនៅមុខឯង[វ]» ២៨ដ្បិតខ្ញុំប្រាប់អ្នករាល់
គ្នាថា ក្នុងពួកមនុស្ស ដែលកើតពីស្ត្រីមកនោះគ្មានហោរា
ណាបានធំជាងយ៉ូហាន–បាទីស្ទទេ ប៉ុន្តែអ្នកណាដែលតូច
ជាងគេក្នុងនគរព្រះ[ស] នោះក៏ធំជាងគាត់ហើយ ២៩ឯបណ្តា
ជន នឹងពួកអ្នកយកពន្ធទាំងប៉ុន្មានដែលស្តាប់យ៉ូហាន គេ
ក៏រាប់ព្រះថាជាសុចរិត ដោយបានទទួលបុណ្យជ្រមុជទឹកពី
គាត់[ហ] ៣០តែពួកផារិស៊ី នឹងពួកអ្នកប្រាជ្ញច្បាប់[ឡ] គេបាន
លើកព្រះដំរិះ ដែលដំរូវដល់គេចោលចេញ ដោយមិនបាន
ទទួលបុណ្យជ្រមុជពីគាត់វិញ ៣១នោះព្រះអម្ចាស់មានបន្ទូល
ថា តើត្រូវឱ្យខ្ញុំផ្ទៀបដំណមនុស្សនេះជាអ្វី តើគេដូចជាអ្វី
៣២គឺគេដូចជាកូនក្មេងអង្គុយនៅទីផ្សារ ដែលស្រែកទៅគ្នា
វាថា យើងបានផ្លុំខ្លុយឱ្យឯង តែឯងមិនបានរាំ យើងបានទួញ
ទំនួញឱ្យឯងតែឯងមិនបានយំសោះ ៣៣ដ្បិតយ៉ូហាន–បាទីស្ទ

**៧:១៨** ភ មថ ៣:១ ម លក ៥:៣៣
**៧:២១** យ មថ ៤:២៣
**៧:២២** រ អស ២៩:១៨,១៩ ៣៥:៥,៦ ៦១:១,២ លក ៤:១៨
**៧:២៦** ល មថ ១១:៩
**៧:២៧** វ មឡ ៣:១ មថ ១១:១០ មក ១:២
**៧:២៨** ស មថ ៣:២
**៧:២៩** ហ មថ ២១:៣២ មក ១:៥ លក ៣:១២
**៧:៣០** ឡ មថ ២២:៣៥

**៧:១៨** *ពួកសិស្សយ៉ូហាន* មើល មក ២:១៨ និងការពន្យល់ ៥:៣៣ ។ ទោះជាគេបានដាក់គុកលោកយ៉ូហាន–បាទ្ទីសក៏ដោយ ក៏សិស្សរបស់លោកនៅតែបន្តទាក់ទងជាមួយនឹងលោក ព្រមទាំងនៅតែបន្តបេសកកម្មរបស់លោកទៀតផង ។

**៧:១៩,២០** ចំពោះសេចក្តីជំនឿរបស់លោកយ៉ូហាន ឬសូម្បីតែសេចក្តីជំនឿរបស់សិស្សលោកក៏ដោយ គឺចង់បានការបញ្ជាក់ពីការនេះ ព្រោះព្រះគ្រីស្ទទ្រង់មិនទាន់បានប្រកាសអង្គទ្រង់ជាសាធារណៈថា ទ្រង់ពិតជាព្រះគ្រីស្ទនៅឡើយទេ ឬសូម្បីតែសាវ័កទ្រង់ ដែលស្គាល់ទ្រង់ហើយ ក៏ទ្រង់មិនទាន់ឱ្យនិយាយពីការនេះដែរ គឺទាល់តែដល់ពេលដែលភស្តុតាងនៃភាពជាព្រះគ្រីស្ទរបស់ទ្រង់បានបញ្ជាក់ចប់សព្វគ្រប់នៅក្នុងសេចក្តីដែលទ្រង់រស់ឡើងវិញ ។

**៧:២២** *ទៅប្រាប់យ៉ូហានពីការដែលអ្នកបានឃើញហើយឮចុះ* តាមចម្លើយរបស់ព្រះយេស៊ូវ គឺទ្រង់បានមានបន្ទូលពីការអស្ចារ្យនៅក្នុងការប្រោសឱ្យជានិងរស់ឡើងវិញ និងដំណឹងល្អដល់អ្នកក្រ ជាភស្តុតាងបញ្ជាក់ពីព្រះរាជកិច្ចរបស់ព្រះមែស៊ី ។ បន្ទូលឆ្លើយរបស់ទ្រង់ គឺដើម្បីរំឭកដល់លោកយ៉ូហានថា សេចក្តីទាំងនោះគឺសុទ្ធតែមានចែងនៅក្នុងទំនាយបទគម្ពីរពីព្រះមែស៊ី (អស ២៩:១៨–២១ ៣៥:៥–៦ និងការពន្យល់ ៦១:១ លក ៤:១៨ និងការពន្យល់)។

**៧:២៣** ទ្រង់បានបង្ហាញពីសញ្ញានៃគ្រោះថ្នាក់ ដែលនឹងកើតឡើងចំពោះអ្នកដែលមិនជឿទ្រង់ និងមិនទទួលស្គាល់ភស្តុតាងនៃភាពជាព្រះមែស៊ីរបស់ទ្រង់ តែនឹងមានពរដល់អស់អ្នកដែលមិនរវាតចិត្ត ។

**៧:២៤** *តើអ្នករាល់គ្នាបានទៅមើលអ្វី* លោកយូហានមិនមែនជាទូតទន់ខ្សោយម្នាក់ដែលស្រេចតែនឹងមនុស្សជាអ្នកឱ្យតម្លៃនោះទេ ផ្ទុយទៅវិញលោកគឺជាហោរាដ៏ពិត ។

**៧:២៦** *គាត់ក៏លើសជាងហោរាផង* លោកយ៉ូហានគឺជាហោរាតែម្នាក់គត់ដែលព្រះទ្រង់បានចាត់ឱ្យមករៀបផ្លូវថ្វាយព្រះគ្រីស្ទ(ខ.២៧)។

**៧:២៨** *អ្នកណាដែលតូចជាងគេក្នុងនគរព្រះ* មើលការពន្យល់ មថ ១១:១១ ។

**៧:២៩** *អ្នកយកពន្ធ* មើលការពន្យល់ មថ ៥:៤៦ ។

**៧:៣០** *ពួកអ្នកប្រាជ្ញច្បាប់* គឺការកំណត់ហៅរបស់លោកលូកា ចំពោះពួកអាចារ្យ ឬស្មៀន(គ្រូក្រឹត្យវិន័យ ឬអ្នកចម្លងព្រះគម្ពីរ "តូរ៉ាស់" របស់សាសន៍យូដា និងឯកសារដទៃទៀតរបស់សាសនា ដោយប្រើស្លាបប៉ាកាសរសេរលើស្បែកសត្វ) (មើល ១០:២៥,៣៧ ១១:៤៥–៤៦,៥២ ១៤:៣ មថ ២២:៣៥) ដែលភាគច្រើនជាពួកផារិស៊ី(មើលការពន្យល់ ៥:១៧)។ *លើកព្រះដំរិះ... ចោលចេញ* ពួកអ្នកយកពន្ធបានបង្ហាញនូវការព្រមផ្លាស់ប្រែចិត្ត ដោយទទួលបុណ្យជ្រមុជរបស់លោកយ៉ូហាន–បាទីស្ទ ចំណែកឯពួកផារិស៊ីបានបង្ហាញពីការបដិសេធន៍ព្រះរាជសាររបស់ព្រះ ដោយមិនព្រមទទួលបុណ្យជ្រមុជទឹកឡើយ ។

**៧:៣១,៣៥** ពួកអ្នកដឹកនាំសាសន៍យូដាស្អប់ដល់អ្នកដែលថ្លែងពីសេចក្តីពិតហើយលើកឡើងពីភាពពុតត្បុតរបស់ពួកខ្លួន ។ ពួកគេរិះគន់លោកយ៉ូហាន–

បានមកមិនបរិភោគបាយឬស្រាទំពាំងបាយជូរ[អ]ឡើយ តែ
អ្នករាល់គ្នាថា គាត់មានអារក្សចូល ៣៤ឯកូនមនុស្ស បាន
មកទាំងបរិភោគវិញ ហើយអ្នករាល់គ្នាថា មើល នេះជា
អ្នកល្មោភស៊ីផឹកច្រើន ជាមិត្រសំឡាញ់នឹងពួកអ្នកយកពន្ធ
ហើយនឹងមនុស្សមានបាប[ក] ៣៥ប៉ុន្តែ ប្រាជ្ញាបានរាប់ជាត្រូវ
ដោយផលដែលបង្កើតទាំងប៉ុន្មាន។

## ស្ត្រីមានបាបម្នាក់បានចាក់ប្រេងក្រអូបលើព្រះយេស៊ូវ

*៧:៣៧-៣៩ = មថ ២៦:៦-១៣ មក ១៤:៣-៩ យហ ១២:១-៨*
*៧:៤១,៤២ = មថ ១៨:២៣-៣៤*

៣៦មានពួកផារិស៊ីម្នាក់ទូលសូមទ្រង់ ឱ្យសោយជាមួយ
នឹងគាត់ ទ្រង់ក៏យាងចូលទៅគង់នៅតុ ក្នុងផ្ទះគាត់ ៣៧ហើយ
មើល នៅក្រុងនោះមានស្ត្រីម្នាក់ដែលមានបាប នាងបាន
ដឹងថា ទ្រង់គង់នៅតុក្នុងផ្ទះអ្នកផារិស៊ីនោះ ក៏យកដបថ្ម
កែវដាក់ប្រេងក្រអូបមក ៣៨នាងឈរពីខាងក្រោយទៀប
ព្រះបាទទ្រង់ទាំងយំ ចាប់តាំងសំរក់ទឹកភ្នែកទទឹកព្រះបាទ
ទ្រង់ រួចយកសក់ក្បាលនាងជូត ក៏ថើបព្រះបាទ ដោយ
ស្រឡាញ់ ហើយយកប្រេងក្រអូបលាបផង ៣៩កាលពួក
ផារិស៊ីម្នាក់ដែលអញ្ជើញទ្រង់មកបានឃើញដូច្នោះ ក៏គិត
ក្នុងចិត្តថា បើអ្នកនេះជាហោរាមែន[ខ] នោះនឹងស្គាល់ស្ត្រី
ដែលពាល់ខ្លួន ហើយដឹងថាជាមនុស្សយ៉ាងណា ព្រោះនាង
ជាមនុស្សមានបាប ៤០ព្រះយេស៊ូវក៏មានបន្ទូលថា ស៊ីម៉ូន
អើយ ខ្ញុំចង់និយាយនឹងអ្នកបន្តិច គាត់ក៏ឆ្លើយថា សូមលោក
គ្រូមានប្រសាសន៍មកចុះ ៤១ទ្រង់មានបន្ទូលថា មាន២នាក់
ជំពាក់អ្នកចងការម្នាក់ អ្នក១ជំពាក់១០០រៀល អ្នក១ទៀត
១០រៀល ៤២ដោយព្រោះគេគ្មានអ្វីនឹងសង បានជាគាត់
លែងទារពីអ្នកទាំង២ទៅ ដូច្នេះក្នុង២នាក់នោះ តើអ្នកណា
ស្រឡាញ់គាត់ជាជាង ៤៣ស៊ីម៉ូនទូលឆ្លើយថា ខ្ញុំស្មានថាជា
អ្នកមួយដែលជំពាក់ច្រើនជាងនោះឯង ទ្រង់ក៏មានបន្ទូល
តបថាអ្នកស្មានត្រូវហើយ ៤៤រួចទ្រង់បែរទៅឯស្ត្រីនោះ
តែមានបន្ទូលនឹងស៊ីម៉ូនថា អ្នកឃើញស្ត្រីនេះឬទេ ខ្ញុំបាន
ចូលមកក្នុងផ្ទះអ្នក អ្នកមិនបានឱ្យទឹកសំរាប់លាងជើងខ្ញុំ
ទេ[គ]តែនាងបានសំរក់ទឹកភ្នែកទទឹកជើងខ្ញុំ ហើយយកសក់
ជូតផង ៤៥អ្នកមិនបានថើប[ឃ]ខ្ញុំសោះ តែតាំងពីខ្ញុំចូលមក
នាងចេះតែថើបជើងខ្ញុំដោយស្រឡាញ់ ៤៦អ្នកមិនបានយក
ប្រេងលាបក្បាលខ្ញុំសោះ[ង] តែនាងយកប្រេងក្រអូបមក
លាបជើងខ្ញុំវិញ ៤៧ដោយហេតុនោះបានជាខ្ញុំប្រាប់អ្នក
ថា បាបនាងដែលមានច្រើនទាំងម្ល៉េះ បានអត់ទោសឱ្យ
នាងហើយ ដ្បិតនាងមានសេចក្តីស្រឡាញ់ជាច្រើន ប៉ុន្តែ
អ្នកណាដែលគេអត់ទោសឱ្យតិច នោះក៏ស្រឡាញ់តិច
៤៨រួចទ្រង់មានបន្ទូលទៅនាងថា បាបនាងបានអត់ទោស

**៧:៣៣** អ លក ១:១៥
**៧:៣៤** ក លក ៥:២៩,៣០ ១៥:១,២
**៧:៣៩** ខ ខ.១៦ មថ ២១:១១
**៧:៤៤** គ លប ១៨:៤ ១៩:២ ៤៣:២៤ ពច ១៩:២១ យហ ១៣:៤-១៤ ១ធម ៥:១០
**៧:៤៥** ឃ លក ២២:៤៧,៤៨ រម ១៦:១៦
**៧:៤៦** ង ទដ ២៣:៥ សស ៩:៨

បាទីស្ទ ព្រោះលោកតមហើយមិនផឹកស្រា ហើយពួកគេរិះគន់ព្រះយេស៊ូវ ព្រោះទ្រង់សោយអាហារ និងស្រាយ៉ាងរីករាយជាមួយនឹងពួកយកពន្ធ និងមនុស្សមានបាប ។ ការបដិសេធន៍ទាំងពីរយ៉ាងរបស់ពួកគេ គឺព្រោះទម្លាប់តមទេ ។ អ្វីដែលពួកផារិស៊ី និងពួកអ្នកប្រាជ្ញច្បាប់មិនអាចទ្រាំបាននោះ គឺការលើកឡើងពីភាពពុតត្បុតរបស់ពួកគេតែប៉ុណ្ណោះ ។ *ផ្លុំខ្លុយ* មើលការពន្យល់ មថ ១១:១៧ ។

**៧:៣៣,៣៤** *កូនមនុស្ស* មើលការពន្យល់ មក ៨:៣១ ។ ពួកផារិស៊ីពូកែខាងប្រើប្រាជ្ញារកខុសរកត្រូវ ។ មនុស្សយើងភាគច្រើនអាចធ្វើ ឬជឿលើការអ្វីដែលត្រូវនឹងបំណងចិត្តខ្លួន ដោយសំអាងលើហេតុផលត្រឹមត្រូវ។ បើសិនជាយើងមិនប្រើសេចក្តីពិតរបស់ព្រះអម្ចាស់ជាពន្លឺដល់គំនិតរបស់យើងទេ នោះយើងនឹងអាចរកខុសរកត្រូវតាមតែគំនិតខ្លួនឯង ដូចពួកផារិស៊ីប៉ុណ្ណោះ ។

**៧:៣៥** *ប្រាជ្ញាបានរាប់ជាត្រូវដោយផលដែលបង្កើត* ផ្ទុយពីពួកអ្នកបដិសេធរិះគន់ដោយល្ងីល្ងើ គឺពួកអ្នកមានប្រាជ្ញាខាងព្រលឹងវិញ្ញាណអាចមើលដឹងថាព្រះរាជកិច្ចរបស់ព្រះយេស៊ូវ និងកិច្ចការរបស់លោកយ៉ូហាន គឺសុទ្ធតែសុចរិត ហើយបរិសុទ្ធ ទោះជាមានលក្ខណៈខុសគ្នាក៏ដោយ(មើលការពន្យល់ មថ ១១:១៩)។

**៧:៣៦-៥០** មើលការពន្យល់ យហ ១២:១-១១ ។

**៧:៣៦** *ពួកផារិស៊ីម្នាក់* មើលការពន្យល់ ៥:១៧ ។ ការដែលទ្រង់ព្រមទទួលពាក្យទូលសូមដែលជាល្បិចរបស់ពួកផារិស៊ីម្នាក់នោះ គឺជាការបង្រៀនឱ្យអ្នកដើរតាមទ្រង់ចេះ "ឆ្លាតដូចពស់ សុភាពដូចព្រាប" ។

**៧:៣៧** *ស្ត្រីម្នាក់ដែលមានបាប* នាងប្រាកដជាបានស្តាប់ការអធិប្បាយរបស់ព្រះយេស៊ូវ ហើយនាងបានផ្លាស់ប្រែចិត្ត និងប្តេជ្ញារស់នៅក្នុងជីវិតថ្មី ។ នាងបានបង្ហាញឱ្យឃើញពីសេចក្តីស្រឡាញ់ និងភាពកតញ្ញូ ដោយការដឹងថាខ្លួននាងអាចទទួលការអត់ទោសបាបនេះបាន ។ *ដបថ្មកែវ* គឺដបមូលម្យ៉ាងមានកវែង ។

**៧:៣៨** *នាងឈរពីខាងក្រោយទៀបព្រះបាទទ្រង់* ព្រះយេស៊ូវទ្រង់គង់នៅលើកៅអីទ្រេត(ដូចប៉ោអ៊ី) ព្រះបាទាមិនបានដាក់នៅក្រោមតុ គឺបែរទៅរកជញ្ជាំង ។ ចំណែកកែងព្រះហស្តឆ្វេងដាក់គងលើតុ នាំឱ្យនាងអាចបង្ហាញសេចក្តីស្រឡាញ់ ដោយការប្រតិបត្តិចំពោះព្រះបាទាទ្រង់បាន ដោយគ្មានការរំខានដល់ទ្រង់ ។ *យកប្រេងក្រអូបលាបផង* នាងប្រហែលជាបម្រុងចាក់ប្រេងលើព្រះសិរទ្រង់ តែនាងបានចាក់លើព្រះបាទាទ្រង់វិញ ។ នាងម៉ារានៅភូមិបេថានីបានប្រតិបត្តិស្រដៀងនឹងការនេះ មួយសប្តាហ៍មុននឹងគេយកទ្រង់ទៅឆ្កាង( យល ១២:៣ និងការពន្យល់)។

**៧:៤១** *ជំពាក់១០០រៀល* អ៊ីស្រាអែលនៅសម័យនោះប្រើរូបិយវត្ថុរ៉ូម៉ាំងគឺ "ឌីណារី" (លុយកាក់) ដែល ១ឌីណារីមានតម្លៃប្រហែលប្រាក់ឈ្នួលមួយថ្ងៃ ។

**៧:៤៤** *ឱ្យទឹកសំរាប់លាងជើងខ្ញុំ* គឺជាទំនៀមទម្លាប់នៃការទទួលភ្ញៀវ ។

**៧:៤៧** *នាងមានសេចក្តីស្រឡាញ់ជាច្រើន* សេចក្តីស្រឡាញ់របស់នាងជាភស្តុងតាងបញ្ជាក់ថា នាងបានទទួលការអត់ទោសហើយ តែមិនមែនជាការ

ឱ្យនាងហើយ[ច] ៤៩ឯពួកអ្នកដែលអង្គុយនៅតុជាមួយ ក៏ចាប់
តាំងគិតក្នុងចិត្តថា តើអ្នកនេះជាអ្វីដែលអត់ទោសបាបបាន
ផងដូច្នេះ ៥០តែទ្រង់មានបន្ទូលទៅស្ត្រីនោះថា សេចក្តី
ជំនឿរបស់នាងបានសង្គ្រោះនាងហើយ[ឆ] អញ្ជើញនាងទៅ
ឱ្យបានប្រកបដោយសេចក្តីសុខចុះ[ជ]។

## រឿងប្រៀបប្រដូចពីអ្នកព្រោះពូជ

*៨:៤-១៥ = មថ ១៣:២-២៣ មក ៤:១-២០*

**៨** ១ក្រោយនោះមកទៀត ទ្រង់យាងទៅប្រដៅក្នុងគ្រប់
ក្រុង គ្រប់ភូមិជាមួយនឹងពួក១២នាក់ ព្រមទាំងប្រាប់ដំណឹង
ល្អពីនគរព្រះ[ឈ] ២ក៏មានស្ត្រីខ្លះ ដែលបានជាពីអារក្ស
អសោចិ៍ ហើយពីជំងឺផ្សេងៗបានទៅជាមួយដែរ គឺមាន
ម៉ារា ហៅថាអ្នកស្រុកម៉ាក់ដាឡា[ញ] ដែលមានអារក្ស៧
ចេញពីនាង១ ៣នឹងយ៉ូអាន់ជាប្រពន្ធយូសា មហាតលិក
ស្តេចហេរ៉ូឌ[ដ]១ស៊ូសាន១ ហើយស្ត្រីឯទៀតៗជាច្រើនដែរ
ដែលយកទ្រព្យខ្លួនមកជួយទ្រង់ ។
៤កាលមានមនុស្សមកពីគ្រប់ស្រុក ប្រជុំគ្នាឯទ្រង់ជាណែន
ណាន់តាន់តាប់ហើយ នោះទ្រង់មានបន្ទូលដោយពាក្យ
ប្រៀបប្រដូចថា ៥មានអ្នកព្រោះពូជម្នាក់ចេញទៅព្រោះ
កំពុងដែលគាត់ព្រោះ នោះមានខ្លះធ្លាក់ចុះតាមផ្លូវត្រូវគេ
ដើរជាន់ ហើយសត្វហើរលើអាកាសក៏មកចឹកស៊ី ៦ខ្លះ
ទៀតធ្លាក់ទៅលើថ្ម កាលពន្លកឡើង នោះក៏ក្រៀមស្វិត ទៅ
ពីព្រោះគ្មានធាតុសើមសោះ ៧មានខ្លះទៀតធ្លាក់ទៅ
កណ្តាលបន្លា បន្លាក៏ដុះឡើងជាមួយ ហើយរួចខ្ទប់វា
៨មានខ្លះទៀតធ្លាក់ទៅក្នុងដីល្អ ក៏ពន្លកដុះឡើងបង្កើតផល
ផ្លែបាន១ជា១រយភាគ កាលទ្រង់មានបន្ទូលសេចក្តីទាំង
នោះស្រេចហើយ នោះក៏បន្លឺវាចាថា អ្នកណាដែលមាន

**៧:៤៨** ច មថ ៩:២
**៧:៥០** ឆ មថ ៩:២២
ជ កច ១៥:៣៣
**៨:១** ឈ មថ ៤:២៣
**៨:២** ញ មថ ២៧:៥៥,៥៦
**៨:៣** ដ មថ ១៤:១
**៨:៨** ឋ មថ ១១:១៥

អត់ទោសបាបពីកំណើតរបស់នាងឡើយ ព្រោះខ.៥០បានបញ្ជាក់យ៉ាងច្បាស់ថា នាងបានសង្គ្រោះគឺ ដោយសារតែសេចក្តីជំនឿរបស់នាងទេ (អភ ២:៨ និងការពន្យល់) ។

**៧:៥០** *សេចក្តីជំនឿរបស់នាងបានសង្គ្រោះនាងហើយ* បាបរបស់នាងត្រូវបានអត់ទោសឱ្យហើយ ដូចនេះនាងអាចពិសោធនូវសន្តិភាព (ឬសេចក្តីសុខសាន្ត) របស់ព្រះ (១:៧៩ និងការពន្យល់ ២:១៤) ។

**៨:១** *ទ្រង់យាងទៅប្រដៅក្នុងគ្រប់ក្រុងគ្រប់ភូមិ* មួយផ្នែកធំនៃព្រះរាជកិច្ចព្រះអម្ចាស់គឺបានធ្វើនៅក្រុងកាពើណិម ដែលភាគច្រើនទ្រង់បានចែកចាយនៅក្នុងសាលាប្រជុំ ហើយបន្ទាប់ពីនោះទ្រង់បានយាងពីក្រុងមួយទៅក្រុងមួយ ហើយពីភូមិមួយ ទៅភូមិមួយទៀត នៅក្នុងព្រះរាជដំណើរលើកទីពីរនៅស្រុកកាលីឡេ ។ ចំពោះព្រះរាជដំណើរលើកទីមួយមើល ៤:៤៣-៤៤ មថ ៤:២៣-២៥ មក ១:៣៨-៣៩ ព្រះរាជដំណើរលើកទីបីមើល ៩:១-៦ ។ *នគរព្រះ* មើលការពន្យល់ ៤:៤៣ ។

**៨:២,៣** ព្រះយេស៊ូវទ្រង់លើកកំពស់តម្លៃស្ត្រី ដែលទទួលរងការឈឺចាប់នឹងការបន្ទាបបន្ថោក និងភាពជាខ្ញុំកញ្ជះ ឱ្យពួកគេមានអំណរនឹងការប្រកបស្និទ្ធស្នាល ហើយនិងការបម្រើព្រះ ។ នៅក្នុងវប្បធម៌សាសន៍យូដា ស្ត្រីមិនគួរនឹងសិក្សាពីគ្រូបង្រៀនក្រឹត្យវិន័យឡើយ ។ ទ្រង់បានអនុញ្ញាតឱ្យមានមនុស្សស្រីរួមដំណើរជាមួយនឹងទ្រង់ដែរ ដើម្បីនឹងបង្រៀនថា មនុស្សទាំងពីរភេទសុទ្ធតែស្មើគ្នានៅចំពោះព្រះ ។ ស្ត្រីទាំងនោះបានផ្តល់ប្រាក់ឧបត្ថម្ភដល់ការបំពេញព្រះរាជកិច្ចរបស់ទ្រង់ពួកគេជាប់បំណុលទ្រង់មិនតិចទេ ពីព្រោះទ្រង់បានបណ្តេញអារក្សចេញពីពួកគេខ្លះ ហើយខ្លះទៀតទ្រង់បានប្រោសជំងឺឱ្យបានជាផងដែរ ។

**៨:២** *មានអារក្ស៧* ចំនួនដ៏ច្រើនបែបនេះអាចជាកម្រិតអារក្សចូលដែលខ្លាំងបំផុត ។ ជាធម្មតាគេយល់ថានាងម៉ារា ដែលជាអ្នកស្រុកម៉ាដាឡាគឺជាស្រីសំផឹងម្នាក់មុនពេលដែលនាងទទួលជឿព្រះគ្រីស្ទ ។ ការលន់តួបាបរបស់នាងមានចំណុចដ៏គួរឱ្យកត់សំគាល់ ។ នាងហាក់ដូចជាបានប្រកាន់ខ្ជាប់នូវកាតព្វ-កិច្ច និងការគោរពចំពោះអង្គទ្រង់ លើសពីស្ត្រីឯទៀតៗ ដោយនាងបានបម្រើទ្រង់យ៉ាងជាប់លាប់ នៅពេលដែលទ្រង់នៅមានព្រះជន្ម នៅពេលទ្រង់ជាប់ឆ្កាង និងនៅឯទីផ្នូរបញ្ចុះព្រះសព្វទ្រង់ផងដែរ ។

**៨:៣** *យកទ្រព្យខ្លួនមកជួយទ្រង់* ការផ្គត់ផ្គង់ដល់អង្គទ្រង់ និងពួកសិស្សគឺមិនមែនកើតចេញពីការធ្វើការអស្ចារ្យនោះទេ ប៉ុន្តែបានកើតចេញមកពីការឧបត្ថម្ភរបស់អ្នកដែលមានសណ្តានចិត្តដូចស្ត្រីទាំងនោះ ។

**៨:៤** ជាញឹកញាប់ព្រះយេស៊ូវទ្រង់អធិប្បាយពីសេចក្តីពិតខាងព្រលឹងវិញ្ញាណដោយប្រើពាក្យប្រៀបប្រដូចជារឿង ឬការអធិប្បាយខ្លីៗដែលមានកម្មបទ ឬដំណើររឿងសាមញ្ញ ហើយត្រឡប់ជាមានន័យដ៏អស្ចារ្យ ។ ពាក្យប្រៀបប្រដូចអាចផ្តល់ឱ្យអ្នកស្តាប់នូវសេចក្តីពិតខាងឯព្រលឹងវិញ្ញាណ ដោយភ្ជាប់ន័យត្រង់ជាមួយនឹងន័យធៀបព្រមទាំងជំរុញឱ្យអ្នកស្តាប់មានការគិតពិចារណាស្វែងរកសេចក្តីពិតសម្រាប់ខ្លួនគេ ម្យ៉ាងវិញទៀតពាក្យប្រៀបប្រដូចទាំងនេះក៏លាក់កំបាំងសេចក្តីពិតពីពួកមនុស្សខ្ជិល ឬមនុស្សល្ងីល្ងើ ។ ក្នុងការអានការប្រៀបប្រដូចរបស់ព្រះយេស៊ូវ គឺត្រូវប្រយ័ត្ន មិនត្រូវពិចារណាខ្លាំងជ្រុលពេកទេ ព្រោះការប្រៀបប្រដូចភាគច្រើនសំដៅតែមួយចំណុច ហើយមានន័យតែម្យ៉ាង ។ ការប្រៀបប្រដូចពីអ្នកព្រោះពូជស្ថិតនៅក្នុងចំណោមការប្រៀបប្រដូចទាំងបី ដែលបានកត់ទុកក្នុងព្រះគម្ពីរដំណឹងល្អបីកណ្ឌដំបូង (មថ ១៣:១-២៣ មក ៤:១-២០) ។ ការប្រៀបប្រដូចដទៃទៀតគឺពីគ្រាប់ពូជម្យ៉ាង (១៣:១៩ មថ ១៣:៣១-៣២ មក ៤:៣០-៣២) និងពីដើមទំពាំងបាយជូរ (២០:៩-១៩ មថ ២១:៣៣-៤៦ មក ១២:១-១២) ។

**៨:៥-៨** កសិករម្នាក់នេះមិនមែនមិនមានការទទួលខុសត្រូវ ដោយចេះតែព្រោះគ្រាប់ពូជព្រាវៗនោះទេ ប៉ុន្តែ គាត់បានព្រោះគ្រាប់ពូជនឹងដៃ តាមវិធីសាស្ត្រដ៏ត្រឹមត្រូវគោលដៅរបស់គាត់ គឺដើម្បីឱ្យមានបរិមាណគ្រាប់ពូជច្រើនបំផុតចាក់ឫសចូលជ្រៅទៅក្នុងដី តែជៀសមិនផុតពីការបាត់បង់គ្រាប់មួយចំនួនដែលធ្លាក់ចុះ ឬប៉ើងចូលទៅក្នុងទីដែលមិនអំណោយផលនោះឡើយ ។ ចំពោះគ្រាប់ពូជដែលមិនបង្កើតផល គឺមិនមែនជាកំហុសរបស់អ្នកព្រោះពូជដ៏ស្មោះត្រង់ម្នាក់នេះ ឬជាកំហុសរបស់គ្រាប់ពូជឡើយ ។ ការបង្កើតផលគឺអាស្រ័យទៅលើស្ថានភាពដី ដែលគ្រាប់ពូជនោះបានធ្លាក់ចុះទៅលើ ។ យើងត្រូវមានការទទួលខុសត្រូវចំពោះការព្រោះគ្រាប់ពូជ (ព្រះបន្ទូលព្រះ) តែមិនគួរបោះបង់ចោលនៅពេលដែលយើងបរាជ័យឡើយ ដោយគ្រាន់តែចាំថា

ត្រចៀកសំរាប់ស្តាប់ ឱ្យស្តាប់ចុះ[ប] ។
៩ពួកសិស្សទូលសួរទ្រង់ថា ពាក្យប្រៀបនេះមានន័យដូច
ម្តេច ១០ទ្រង់ឆ្លើយថា ឯអ្នករាល់គ្នា ព្រះបានប្រទានឱ្យ
ស្គាល់អស់ទាំងការអាថ៌កំបាំង របស់នគរទ្រង់ហើយ[ឌ] តែ
បានសំដែងដល់អ្នកឯទៀត ដោយពាក្យប្រៀបប្រដូចវិញ
ដើម្បីកាលណាគេឃើញ នោះមិនឃើញវិញ ហើយ
កាលណាគេឮ នោះមិនយល់ឡើយ[ឍ] ១១រីឯពាក្យប្រៀបប្រ
ដូចនេះ គឺស្រាយយ៉ាងនេះថា ពូជនោះ គឺព្រះបន្ទូល[ណ]
១២ឯពួកអ្នកដែលទទួលតាមផ្លូវ គឺជាអស់អ្នកដែលបានឮ
រួចអារក្សមកឆក់យកព្រះបន្ទូលពីចិត្តគេចេញទៅ ក្រែង
គេជឿហើយបានសង្គ្រោះ ១៣ឯពួកអ្នកដែលទទួលនៅ
លើថ្ម គឺអស់អ្នកដែលកាលណាឮព្រះបន្ទូលហើយ នោះក៏
ទទួលដោយអំណរ តែគ្មានចាក់ឫសសោះ គេជឿនៅតែ១
ស្របក់ប៉ុណ្ណោះ លុះកើតមានសេចក្តីល្បួង នោះគេរសាយ
ចិត្តទៅវិញ[ត] ១៤ឯពូជដែលធ្លាក់ទៅក្នុងបន្លា គឺអស់អ្នកដែល
បានឮ រួចចេញទៅ នោះសេចក្តីខ្វល់ខ្វាយ នឹងទ្រព្យសម្បត្តិ
ហើយនឹងសេចក្តីស្រើបស្រាលនៅជីវិតនេះ ក៏ចូលមក
ខ្ទប់ជិត មិនឱ្យបង្កើតផលផ្លែដ៏ពេញលេញបានឡើយ[ថ]

**៨:១០** ឌ មថ ១៣:១១
ឍ អស ៦:៩
មថ ១៣:១៣,១៤
**៨:១១** ណ ហ៣
៤:១២
**៨:១៣** ត មថ ១១:៦
**៨:១៤** ថ មថ ១៩:២៣
១ធថ ៦:៩,១០,១៧
**៨:១៦** ទ មថ ៥:១៥
**៨:១៧** ធ មថ
១០:២៦ មក ៤:២២
លក ១២:២
**៨:១៨** ន មថ ២៥:២៩

១៥តែពូជដែលនៅដីល្អ គឺពួកអ្នកដែលមានចិត្ត ទៀងត្រង់ល្អ
ក៏ឮព្រះបន្ទូល ហើយយកចិត្តទុកដាក់ រួចបង្កើតផលដោយ
សេចក្តីអត់ធន់វិញ ។

## ចង្កៀង

១៦គ្មានអ្នកណាអុជចង្កៀង រួចយកផើងមកគ្រប ឬយក
ទៅដាក់នៅក្រោមគ្រែឡើយ គេតែងដាក់លើជើងចង្កៀង
វិញ ដើម្បីឱ្យអស់អ្នកណាដែលចូលមកបានឃើញពន្លឺភ្លឺ[ទ]
១៧ដ្បិតគ្មានអ្វីលាក់កំបាំងដែលមិនត្រូវបើកសំដែងចេញ
ឬអ្វីជាសំងាត់ដែលមិនត្រូវឱ្យដឹង ហើយយកទៅដាក់នៅ
ពន្លឺនោះឡើយ[ធ] ១៨ដូច្នេះត្រូវឱ្យប្រយ័ត្នដែលអ្នករាល់គ្នាឮ
ជាយ៉ាងណា ដ្បិតអ្នកណាដែលមាន គេនឹងឱ្យដល់អ្នកនោះ
ប៉ុន្តែអ្នកណាដែលគ្មាន នោះនឹងដកយកទាំងរបស់ដែល
មើលទៅដូចជាអ្នកនោះមានចេញផង[ន] ។

## ម្តាយ និងបងប្អូនរបស់ព្រះយេស៊ូវ

*៨:១៩–២១ = មថ ១២:៤៦–៥០ មក ៣:៣១–៣៥*

១៩នោះមាតា នឹងបងប្អូនទ្រង់ ក៏មករកទ្រង់ តែចូលទៅ
ឯទ្រង់មិនបាន ដោយព្រោះមានមនុស្សច្រើនណាស់ ២០មាន
គេទូលទ្រង់ថា ម្តាយ នឹងបងប្អូន[ប] លោក មកឈរនៅខាង

---

គ្រាប់ពូជទាំងអស់មិនមែនសុទ្ធតែធ្លាក់លើដីល្អឡើយ ។

**៨:៩** *ពួកសិស្សទូលសួរទ្រង់* គឺរួមមាន "សាវ័កទាំង១២ និងសិស្សដទៃៗទៀត" (មក ៤:១០) ។

**៨:១០** *ការអាថ៌កំបាំងរបស់នគរទ្រង់* គឺជាសេចក្តីពិតដែលអាចដឹងបានលុះណាតែមានការបើកសំដែងពីព្រះ (អភ ៣:៣ និងមើលការពន្យល់ ១ពត ១:១០–១២) មើលការពន្យល់ មក ៤:១១ ។ *ដើម្បីកាលណាគេឃើញ នោះមើលមិនឃើញវិញ . . .* មូលហេតុដែលហ្វូងមនុស្សមិនយល់ព្រះបន្ទូលព្រះយេស៊ូវ គឺប្រហែលជាពួកគេកំពុងតែស្វែងរកអ្នកដឹកនាំទ័ព ឬព្រះមែស៊ីដែលជាអ្នកនយោបាយ ហើយនាំឱ្យរបៀបបង្រៀនដ៏សុភាពរបស់ទ្រង់នេះមិនអាចត្រូវនឹងគំនិតពួកគេបានឡើយ ។ ប្រហែលជាពួកគេខ្លាចការគាបសង្កត់របស់ពួកដឹកនាំសាសនាហើយមិនចង់មើលចូលជ្រៅទៅក្នុងបន្ទូលរបស់ទ្រង់ ។ ព្រះមានបន្ទូលមកហោរាអេសាយថា "បណ្តារាស្ត្រទ្រង់នឹងឮតែមិនយល់ ហើយនឹងមើលផងតែឥតដឹងឡើយ" (អស ៦:៩ មថ ១៣:១៤–១៥ និងការពន្យល់ មក ៤:១២) ហើយការឆ្លើយតបនេះក៏បានកើតមានចំពោះព្រះយេស៊ូវ ។ ការប្រៀបប្រដូចពីអ្នកព្រោះពូជតែមួយ គឺគ្រប់គ្រាន់ល្មមនឹងអាចបង្ហាញពីការឆ្លើយតបរបស់បណ្តាជនចំពោះបន្ទូលប្រៀបប្រដូចក្រោយៗទៀតផងដែរ ។

**៨:១១–១៥** *ផ្លូវ* គឺដូចជាពួកអ្នកដឹកនាំសាសនាជាច្រើននាក់ដែលបានបដិសេធមិនព្រមជឿព្រះបន្ទូលព្រះ ។ *ថ្ម* គឺដូចជាមនុស្សជាច្រើននៅក្នុងចំណោមហ្វូងមនុស្សដែលដើរតាមព្រះយេស៊ូវ ពួកគេជឿព្រះបន្ទូលទ្រង់ តែមិនប្រតិបត្តិតាមទេ ។ *បន្លា* គឺអ្នកដែលចាញ់ការបំភ័យ និងសេចក្តីបោកបញ្ឆោតរបស់ទ្រព្យសម្បត្តិ ហើយឥតបានបន្សល់ទុកកន្លែងក្នុងជីវិតរបស់គេសូម្បីតែ១សម្រាប់ព្រះ ។ *ដីល្អ* គឺអ្នកដែលផ្ទុយស្រឡះពីមនុស្សបីក្រុមខាងលើ គឺពួកគេសុខចិត្តដើរតាមព្រះយេស៊ូវ ដោយមិនខ្វល់ថាត្រូវខាតបង់អ្វីទាំងអស់ ។

**៨:១៣** *ជឿនៅតែ១ស្របក់ប៉ុណ្ណោះ* គឺជឿទាំងស្ទាក់ស្ទើរ ហើយមិនអាចសង្គ្រោះបានឡើយគឺដូចជាសេចក្តីអ្វីដែលព្រះគម្ពីរយ៉ាកុបហៅថាជំនឿ "ស្លាប់" (យក ២:១៧,២៦) ឬជំនឿឥតប្រយោជន៍ (យក ២:២០ មើលការពន្យល់ យក ២:១៤–២៦) ។

**៨:១៦,១៧** នៅពេលដែលពន្លឺនៃសេចក្តីពិតបានបំភ្លឺយើងហើយ នោះយើងត្រូវមានកាតព្វកិច្ចបំភ្លឺពន្លឺនោះដល់អ្នកទៀតផងដែរ ។ ក្នុងការធ្វើបន្ទាល់ត្រូវធ្វើជាសាធារណៈមិនត្រូវលាក់កំបាំងឡើយ ។ គឺមិនត្រូវទុកប្រយោជន៍សម្រាប់តែខ្លួនឯងហើយមិនព្រមផ្ទេរឱ្យអ្នកឯទៀតនោះឡើយ ។ យើងចំបាច់ត្រូវត្រៀមខ្លួនជានិច្ច ព្រមទាំងចេះឆ្លៀតឱកាសជួយដល់អ្នកមិនជឿក្នុងគ្រាដែលគេមានបញ្ហាលំបាក ។

**៨:១៨** *ត្រូវប្រយ័ត្នដែលអ្នករាល់គ្នាឮជាយ៉ាងណា* ពួកសាវ័កបានស្តាប់ទ្រង់មិនគ្រាន់តែសម្រាប់ខ្លួនពួកគេផ្ទាល់ខ្លួនម្នាក់ៗប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់អស់អ្នកដែលពួកគេនឹងទំនុកបម្រុងផងដែរ (មក ៤:២៤ យក ១:១៩-២២) ។ សេចក្តីពិតដែលមិនយល់ហើយមិនយកទៅប្រើ នឹងបាត់ទៅវិញជាមិនខាន (១៩:២៦ ភល ៣:១៦ និងការពន្យល់) ប៉ុន្តែ បើបានប្រើវិញនោះនឹងបានកើតផលកើនឡើងជាអតិបរមា ។

**៨:១៩** គ្រួសារដ៏ពិតរបស់ព្រះយេស៊ូវគឺមានអ្នកទាំងឡាយណាដែលឮព្រះបន្ទូលទ្រង់ហើយប្រព្រឹត្តតាម ។ ការឮតែមិនប្រព្រឹត្តតាម នោះមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ ដ្បិតព្រះយេស៊ូវទ្រង់ស្រឡាញ់មាតាទ្រង់ (យហ ១៩:២៥–២៧) នោះទ្រង់ក៏ស្រឡាញ់យើងផងដែរ ។ ព្រះគ្រីស្ទទ្រង់បានប្រទានឱ្យដល់យើងនូវទំនាក់ទំនងជាគ្រួសារដ៏ស្និតរមួតជាមួយនឹងទ្រង់ ។

ក្រោចង់ជួបនឹងលោក ²¹តែទ្រង់ឆ្លើយទៅគេថា ឯអ្នក
ដែលជាម្តាយ នឹងបងប្អូនខ្ញុំ គឺអស់អ្នកដែលស្តាប់ព្រះបន្ទូល
ហើយប្រព្រឹត្តតាមវិញ[ផ]។

## ព្រះយេស៊ូវធ្វើឱ្យខ្យល់ព្យុះស្ងប់

*៨:២២-២៥ = មថ ៨:២៨-៣៤ មក ៤:៣៦-៤១*
*៨:២២-២៥ = មក ៦:៤៧-៥២ យហ ៦:១៦-២១*

២២មានកាល១ថ្ងៃនោះ ទ្រង់ចុះទូកជាមួយនឹងពួកសិស្ស
ហើយមានបន្ទូលទៅគេថា ចូរយើងឆ្លងទៅត្រើយម្ខាង
នោះក៏ចេញទៅ ២៣កាលកំពុងតែបើកក្តោងទៅ នោះទ្រង់
ផ្ទំលក់ រួចមានខ្យល់ព្យុះធ្លាក់មកលើសមុទ្រ ទឹកក៏ចូលស្ទើរ
តែពេញទូក ហើយគេភ័យខ្លាចលិច ២៤គេចូលទៅតើន
ទ្រង់ទូលថា លោកគ្រូៗ[ព]អើយ យើងខ្ញុំស្លាប់ហើយ តែទ្រង់
ក្រោកឡើង កំហែង[ភ]ទៅខ្យល់នឹងទឹក ដែលកំពុងបោកបក់
ជាខ្លាំង នោះក៏ស្ងប់បាត់ឈឹងទៅ[ម] ២៥រួចទ្រង់មានបន្ទូល
ទៅគេថា តើសេចក្តីជំនឿរបស់អ្នករាល់គ្នានៅឯណា គេក៏
ភ័យខ្លាច ហើយមានសេចក្តីអស្ចារ្យក្នុងចិត្ត ទាំងនិយាយគ្នា
ទៅវិញទៅមកថា ចុះលោកនេះជាអ្វីបានជាលោកបង្គាប់
ទៅទាំងខ្យល់ទាំងទឹកបាន ហើយទាំង២យ៉ាងក៏ស្តាប់បង្គាប់
លោកដែរដូច្នេះ។

## ការបណ្តេញអារក្សចេញពីមនុស្ស

*៨:២៦-៣៧ = មថ ៨:២៨-៣៤*
*៨:២៦-៣៩ = មក ៥:១-២០*

២៦ទ្រង់នឹងពួកសិស្សក៏មកដល់ស្រុកគេរ៉ាស៊ីន ដែលប្រ
ទល់មុខនឹងស្រុកកាលីឡេ ២៧កាលឡើងដល់លើគោក
នោះមានមនុស្សម្នាក់ចេញពីក្រុងនោះមកជួបនឹងទ្រង់ គាត់
មានអារក្សចូលជាយូរមកហើយ គ្មានស្លៀកពាក់អ្វីឡើយ
គាត់មិននៅក្នុងផ្ទះទេ គឺអាស្រ័យនៅតែក្នុងផ្នូរខ្មោចវិញ
២៨កាលបានឃើញព្រះយេស៊ូវ នោះគាត់ស្រែកឡើង ក៏
ទំលាក់ខ្លួនក្រាបនៅចំពោះទ្រង់ ទូលជាសំឡេងខ្លាំងថា ឱ
ព្រះយេស៊ូវ ជាព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុតអើយ[យ] តើ
ទ្រង់ហើយនឹងទូលបង្គំមានការអ្វីនឹងគ្នា[រ] ទូលបង្គំសូម
អង្វរទ្រង់កុំឱ្យធ្វើទុក្ខទូលបង្គំឡើយ ២៩ដ្បិតទ្រង់កំពុងតែ
បង្គាប់ដល់វិញ្ញាណអសោចិ៍ ឱ្យចេញពីមនុស្សនោះទៅ
ពីព្រោះវាបានជាន់គាត់ជាយូរមកហើយ គេបានយកច្រវាក់
យកខ្នោះដាក់ ទាំងថែរក្សាគាត់ដែរ តែគាត់ចេះតែផ្តាច់
ចំណងទាំងនោះចេញ ហើយអារក្សវានាំបណ្តាលឱ្យទៅ
នៅទីស្ងាត់ ៣០ព្រះយេស៊ូវមានបន្ទូលសួរគាត់ថា អ្នកឈ្មោះ
អ្វី គាត់ទូលថា ទូលបង្គំឈ្មោះ «កងទ័ព» ព្រោះមានអារក្ស
ជាច្រើន ចូលគាត់ ៣១អារក្សទាំងនោះក៏សូមអង្វរ កុំឱ្យទ្រង់
បង្គាប់វា ឱ្យចុះទៅក្នុងជង្ហុកធំឡើយ[ល] ៣២នៅទីនោះ មាន
ហ្វូងជ្រូកយ៉ាងធំ កំពុងតែរកស៊ីនៅលើភ្នំហើយអារក្សទាំង
នោះក៏សូមអង្វរទ្រង់ ឱ្យបើកឱ្យវាចូល ទៅក្នុងជ្រូកទាំងនោះ
ទ្រង់ក៏បើកឱ្យ ៣៣រួចវាចេញពីមនុស្សនោះ ចូលទៅក្នុង
ហ្វូងជ្រូកៗក៏បោលម្នីម្នា តាមភ្នំចោតធ្លាក់ទៅក្នុងសមុទ្រ[វ]
លង់ទឹកស្លាប់ទាំងអស់ទៅ ៣៤កាលពួកអ្នកគង្វាលជ្រូកបាន
ឃើញដូច្នោះ ក៏នាំគ្នារត់ទៅប្រាប់ដល់ជនក្នុងក្រុង ហើយ

**៨:២០** ប យហ ៧:៥
**៨:២១** ផ លក ៦:៤៧ ១១:២៨ យហ ១៤:២១
**៨:២៤** ព លក ៥:៥ ភ លក ៤:៣៥,៣៩, ៤១ ម ទដ ១០៧:២៩ យហ ១:១៥
**៨:២៨** យ មថ ៨:២៩ រ មក ៥:៧
**៨:៣១** ល វវ ៩:១,២, ១១ ១១:៧ ១៧:៨ ២០:១,៣
**៨:៣៣** វ ខ.២២,២៣

**៨:២១** ព្រះយេស៊ូវមានបន្ទូលឆ្លើយ មិនមែនដើម្បីបដិសេធគ្រួសារខាងសាច់ឈាមរបស់ទ្រង់នោះឡើយ ប៉ុន្តែ គឺដើម្បីសង្កត់ធ្ងន់ពីឯកសិទ្ធិពិសេសដែលអ្នកជឿអាចមានទំនាក់ទំនងខាងវិញ្ញាណជាមួយនឹងទ្រង់ (១១:២៨ និងពន្យល់) ។
**៨:២២** *ត្រើយម្ខាង* មើល ៥:១ និងការពន្យល់ ។
**៨:២៣** *ខ្យល់ព្យុះ* មើលការពន្យល់ មក ៤:៣៧ ។
**៨:២៥** នៅគ្រាប្រទះនឹងព្យុះជីវិតមនុស្សយើងងាយនឹងគិតថាព្រះទ្រង់មិននៅគ្រប់គ្រងហេតុការណ៍ដ៏អាក្រក់នោះទេ ហើយជោគវាសនារបស់យើងក៏ស្រេចតែនឹងព្យុះនោះហើយ ។ តាមការពិត ព្រះទ្រង់មានអំណាចលើគ្រប់ទាំងអស់ ទ្រង់ជាអ្នកគ្រប់គ្រងប្រវិត្តិសាស្ត្រពិភពលោក ក៏ដូចជាជោគវាសនារបស់មនុស្សម្នាក់ៗ ។ ដែលទ្រង់អាចកំហែងទៅខ្យល់ និងទឹកឱ្យស្ងប់បាននោះទ្រង់ក៏អាចកំហែងបានគ្រប់ទាំងព្យុះដែលយើងអាចពើបប្រទះ ។
**៨:២៦** *ស្រុកគេរ៉ាស៊ីន* គឺជាស្រុកសាសន៍ដទៃ ស្ថិតនៅភាគអាគ្នេយ៍នៃសមុទ្រកាលីឡេដែលជាទីតាំងរបស់ទីក្រុងទាំងដប់។ ទីក្រុងទាំងនោះគឺជាទីក្រុងរបស់សាសន៍ក្រិកមិនមែនជាកម្មសិទ្ធប្រទេសណាមួយឡើយ គឺជាទឹកដីឯករាជ្យ ។
**៨:២៧** *គាត់មានអារក្សចូល* មើលការពន្យល់ ៤:៣៣ ។ ព្រះគម្ពីរម៉ាថាយ (៨:២៨) បានបង្ហាញថាមានមនុស្សពីរនាក់ដែលមានអារក្សចូល ប៉ុន្តែចំពោះព្រះគម្ពីរម៉ាកុស (៥:២) និងលូកាប្រហែលជាសង្កត់ធ្ងន់លើតែមនុស្សម្នាក់ដែលសំខាន់ ហើយបានទូលដល់ព្រះយេស៊ូវផង ។ *ផ្នូរ* គឺជាកន្លែងកប់សពដែលនៅឆ្ងាយដាច់ស្រយាល មនុស្សភាគច្រើនដើរគេចពីទីកន្លែងនោះ (មើលការពន្យល់ មក ៥:៣) ។
**៨:២៨** អារក្សទាំងនោះអាចស្គាល់ព្រះយេស៊ូវ និងឫទ្ធិអំណាចទ្រង់ភ្លាមៗ ។ ពួកវាដឹងថាទ្រង់ជានរណា ហើយទ្រង់អាចមានឫទ្ធិអំណាចខ្លាំងប៉ុណ្ណាមកលើពួកវា ។ *កុំធ្វើទុក្ខទូលបង្គំឡើយ* ការអង្វរករយ៉ាងនេះបង្ហាញពីការទទួលស្គាល់ពី ឫទ្ធិអំណាច ដែលទ្រង់មានលើពួកវា ហើយដើម្បីសូមកុំឱ្យទ្រង់រំខានដល់ពួកវា ។
**៨:៣០** *អ្នកឈ្មោះអ្វី* ព្រះយេស៊ូវទ្រង់សួរឈ្មោះបុរសនោះ ប៉ុន្តែ អារក្សវាបានឆ្លើយជំនួសវិញ ជាការបង្ហាញថាពួកវាកំពុងគ្រប់គ្រងបុរសម្នាក់នោះ ។ *កងទ័ព* មើលការពន្យល់ មក ៥:៩ ។
**៨:៣១** *ជង្ហុកធំ* គឺគុកសម្រាប់ដាក់សាតាំង និងបរិវាររបស់វា (ពន្យល់ វវ ៩:១) ។
**៨:៣២** *ជ្រូក* គឺជាសត្វដែលសាសន៍យូដារាប់ថាមិនស្អាត ហើយហាមមិនឱ្យបរិភោគសាច់របស់វា (លវ ១១:៧-៨) ប៉ុន្តែ ហ្វូងជ្រូកនោះគេចិញ្ចឹមនៅស្រុកដេកាប៉ូល ដែលជាដែនដីរបស់សាសន៍ដទៃទេ ។ *ទ្រង់ក៏បើកឱ្យ* មើល

និងស្រុកស្រែ ៣៥រួចមនុស្សទាំងឡាយក៏ចេញមកមើលការ
ដែលកើតមកនោះ គេមកដល់ព្រះយេស៊ូវ ឃើញមនុស្ស
ដែលអារក្សទាំងនោះបានចេញកំពុងតែអង្គុយទៀបព្រះ
បាទទ្រង់[ស] ទាំងស្លៀកពាក់ ហើយដឹងខ្លួន នោះគេមានសេច
ក្តីភ័យខ្លាចគ្រប់គ្នា ៣៦ពួកអ្នកដែលបានឃើញការនោះ ក៏
ប្រាប់គេពីបែបយ៉ាងណាដែលមនុស្សអារក្សចូល[ហ]នោះបាន
ជា ៣៧រួចមនុស្សទាំងប៉ុន្មានដែលនៅជុំវិញស្រុកគេរ៉ាស៊ីន
គេសូមឱ្យទ្រង់ថយចេញ[ឡ]ពីគេទៅ ដ្បិតគេកើតមានសេចក្តី
ស្ញែងខ្លាចជាខ្លាំង នោះទ្រង់យាងចុះទូកត្រឡប់វិលវិញទៅ
៣៨ឯមនុស្សដែលអារក្សបានចេញនោះ គាត់សូមអង្វរទ្រង់
ឱ្យបានទៅជាមួយដែរ ប៉ុន្តែព្រះយេស៊ូវឱ្យគាត់ទៅវិញ
ដោយប្រាប់ថា ៣៩"ចូរវិលទៅឯផ្ទះអ្នកទៅ ហើយប្រាប់ពី
គ្រប់ទាំងការដែលព្រះបានប្រោសដល់អ្នកវិញ គាត់ក៏ទៅ
ផ្សាយប្រាប់ពេញក្នុងទីក្រុង ពីគ្រប់ទាំងការដែលព្រះយេ
ស៊ូវបានប្រោសដល់ខ្លួន ។

## ក្មេងស្រីស្លាប់ និងស្ត្រីមានជំងឺ

*៨:៤០–៥៦ = មថ ៩:១៨–២៦ មក ៥:២២–៤៣*

៤០កាលព្រះយេស៊ូវបានត្រឡប់ទៅវិញហើយ នោះ
បណ្តាលមនុស្សក៏ទទួលទ្រង់ដោយអំណរ ដ្បិតគេទន្ទឹងមើល
តែផ្លូវទ្រង់ទាំងអស់គ្នា ៤១នោះឃើញមានមនុស្សម្នាក់ឈ្មោះ
យៃរ៉ុសជាមេសាលាប្រជុំ[អ] គាត់មកទំលាក់ខ្លួនក្រាបនៅទៀប
ព្រះបាទព្រះយេស៊ូវ សូមអង្វរទ្រង់ ឱ្យយាងទៅផ្ទះគាត់
៤២ព្រោះគាត់មានកូនស្រីតែ១ អាយុប្រហែល១២ឆ្នាំ មាន
ជំងឺឈឺជិតស្លាប់ កាលទ្រង់កំពុងតែយាងទៅ នោះបណ្តា
មនុស្សប្រជ្រៀតគ្នាលើទ្រង់ ។

៤៣ហើយមានស្ត្រីម្នាក់ មានជំងឺធ្លាក់ឈាម[ក]១២ឆ្នាំមក
ហើយ នាងបានចំណាយទ្រព្យខ្លួនទាំងអស់ ដោយរកគ្រូ
ពេទ្យ តែគ្មានគ្រូណាមួយមើលឱ្យជាបានទេ ៤៤នាងមក
ពីក្រោយ ចាប់ពាល់ជាយព្រះពស្ត្រ[ខ]ទ្រង់ នោះឈាមក៏បាត់
ធ្លាក់មកក្នុងខណៈ១រំពេចនោះ ៤៥ព្រះយេស៊ូវមានបន្ទូល
សួរថា តើអ្នកណាពាល់ខ្ញុំ កាលមនុស្សទាំងអស់កំពុងតែ
ប្រកែក នោះពេត្រុស នឹងពួកអ្នកដែលនៅជាមួយទូល
ថា លោកគ្រូ[គ] បណ្តាមនុស្សកំពុងប្រជ្រៀតគ្នាតឿតទ្រង់
ដូច្នេះទ្រង់មានបន្ទូលថា អ្នកណាពាល់ទ្រង់ធ្វើអី ។
៤៦ព្រះយេស៊ូវមានបន្ទូលថា ច្បាស់ជាមានអ្នកណាពាល់ខ្ញុំ
ពិត[ឃ] ដ្បិតខ្ញុំដឹងថា មានឫទ្ធិផ្សាយចេញពីខ្ញុំទៅហើយ[ង]។
៤៧កាលស្ត្រីនោះបានឃើញថា លាក់ខ្លួនមិនកំបាំងទេនោះ
ក៏ចូលមកទាំងញ័ររន្ធត់ ផ្តួលខ្លួននៅចំពោះទ្រង់ ទូលនៅមុខ
មនុស្សទាំងអស់ ពីហេតុដែលនាងបានពាល់ទ្រង់ ហើយពី
បែបដែលនាងបានជាភ្លាម១រំពេចផង ៤៨ទ្រង់មានបន្ទូល
ទៅនាងថា ចូរសង្ឃឹមឡើងកូនស្រីអើយ ដ្បិតសេចក្តី ជំនឿ
នាង[ច]បានសង្គ្រោះនាងហើយ ចូរទៅដោយសុខសាន្ត ចុះ[ឆ]។
៤៩កាលទ្រង់កំពុងតែមានបន្ទូលនៅឡើយ នោះមានម្នាក់
មកពីផ្ទះមេ[ជ]សាលាប្រជុំ ជំរាបគាត់ថា កូនលោកស្លាប់
ហើយ កុំនៅរំខានចិត្តលោកគ្រូទៀត។
៥០ព្រះយេស៊ូវក៏ឮហើយមានបន្ទូលទៅគាត់ថា កុំខ្លាចឡើយ
ឱ្យគ្រាន់តែជឿប៉ុណ្ណោះ នោះនាងនឹងបានរស់វិញ។
៥១រួចទ្រង់យាងចូលទៅក្នុងផ្ទះ មិនឱ្យអ្នកណាទៅជាមួយ
ឡើយ លើកតែពេត្រុស យ៉ាកុប នឹងយ៉ូហាន[ឈ] ហើយឪពុក
ម្តាយរបស់កូននោះប៉ុណ្ណោះ ៥២ឯមនុស្សទាំងអស់ គេកំពុង

**៨:៣៥** ស លក ១០:៣៩
**៨:៣៦** ហ មថ ៤:២៤
**៨:៣៧** ឡ កច ១៦:៣៩
**៨:៤១** អ ខ.៤៩ មក ៥:២២
**៨:៤៣** ក លវ ១៥:២៥–៣០
**៨:៤៤** ខ មថ ៩:២០
**៨:៤៥** គ លក ៥:៥
**៨:៤៦** ឃ មថ ១៤:៣៦ មក ៣:១០ ង លក ៥:១៧ ៦:១៩
**៨:៤៨** ច មថ ៩:២២ ឆ កច ១៥:៣៣
**៨:៤៩** ជ ខ.៤១
**៨:៥១** ឈ មថ ៤:២១

ការពន្យល់ មថ ៨:៣២ ។
**៨:៣៩** *ចូរវិលទៅឯផ្ទះអ្នកទៅ ហើយប្រាប់ពីគ្រប់ទាំងការដែលព្រះបានប្រោសដល់អ្នកវិញ* ទោះបីជាបុរសនោះចង់តាមទ្រង់ក៏ដោយ ក៏ទ្រង់បានបញ្ជាឱ្យគាត់ទៅប្រាប់ពីការអស្ចារ្យនៅស្រុករបស់គាត់វិញ ហើយក៏គ្មានការរំខានដល់ព្រះរាជកិច្ចទ្រង់ដែរ (មើលការពន្យល់ មក ៥:១៩) ។
**៨:៤១** *មេសាលាប្រជុំ* គឺអ្នកទទួលខុសត្រូវលើកិច្ចការបម្រើជ្រើសរើសអ្នកចូលរួមប្រជុំថ្វាយបង្គំ និងថែរក្សាសណ្តាប់ធ្នាប់ (មើលពន្យល់ មក ៥:២២) ។
**៨:៤៣,៤៤** ស្ត្រីម្នាក់នេះបានរស់នៅដោយការរំពឹងទៅលើការព្យាបាលរបស់គ្រូពេទ្យ ហើយជំងឺរបស់នាងមិនបានធូរស្បើយសោះ ។ នាងមិនខ្វល់ថាបណ្តាជនគិតចំពោះនាងយ៉ាងណាទេ (ដោយនាងជាស្រី នាងខ្មាសអៀនក្នុងការដែលនិយាយពីជំងឺរបស់នាង) ដូចនេះនាងបានឆ្លៀតឱកាសចូលទៅកាន់ព្រះយេស៊ូវនៅក្នុងហ្វូងមនុស្ស ។ នាងយល់ថា មនុស្សមានកាន់តែច្រើន នាងកាន់តែងាយស្រួលចូលទៅឯទ្រង់ដោយគ្មានគេដឹង ។ នាងមានជំនឿខ្លាំងណាស់ ពីព្រោះនាងមិនសង្ស័យអ្វីសោះ ផ្ទុយទៅវិញនាងជឿថា នាងអាចជាបានដោយគ្រាន់តែពាល់ជាយព្រះពស្ត្រទ្រង់ប៉ុណ្ណោះ ហើយទ្រង់ជាប្រភពនៃក្តីមេត្តាករុណា ដែលនាងអាចលួចពាល់ជាយព្រះពស្ត្រទ្រង់បាន ។
**៨:៤៥** *តើអ្នកណាពាល់ខ្ញុំ* ព្រះយេស៊ូវទ្រង់សព្វព្រះហឫទ័យឱ្យគេបានដឹងពីការអស្ចារ្យដែលបានកើតមាននោះ គឺដោយសារតែសេចក្តីជំនឿរបស់ស្ត្រីនោះ និងដើម្បីឱ្យហ្វូងមនុស្សបានធ្វើបន្ទាល់ពីការនោះ ។
**៨:៤៦** *ឫទ្ធិផ្សាយចេញ* មើលការពន្យល់ មក ៥:៣០ ។
**៨:៤៨** *កូនស្រីអើយ* នៅក្នុងព្រះគម្ពីរដំណឹងល្អ មានតែស្ត្រីម្នាក់នេះប៉ុណ្ណោះដែលព្រះយេស៊ូវទ្រង់មានបន្ទូលដោយពាក្យស្រទន់ដូចនេះ (២៣:២៨) ។ *ចូរទៅដោយ សុខសាន្ត* មើល ៧:៥០ និងការពន្យល់ ។
**៨:៥០** *នាងនឹងបានរស់វិញ* មើលការពន្យល់ មក ៥:៣៤ ។
**៨:៥២** *យំសោកសង្រេង* មើលការពន្យល់ មក ៥:៣៨ ។ *នាងមិនមែនស្លាប់ទេ គឺនាងដេកលក់ទេតើ* ព្រះយេស៊ូវទ្រង់ចង់មានន័យថា នាងមិនស្លាប់ជារហូត

តែយំសោកសង្រេង[ញ]នឹងនាង តែទ្រង់មានបន្ទូលថា កុំយំ
អី នាងមិនមែនស្លាប់ទេ គឺនាងដេកលក់ទេតើ[ដ] ៥៣គេក៏
សើចចំអកឱ្យទ្រង់ ដ្បិតគេដឹងថា នាងស្លាប់ពិតមែន
៥៤នោះទ្រង់ បណ្ដេញគេចេញអស់ ហើយចាប់ដៃនាង
មានបន្ទូលជាខ្លាំងថា កូនអើយ ចូរក្រោកឡើង[ឋ]
៥៥ខណៈនោះព្រលឹងនាងក៏មកវិញ ហើយនាងក្រោកឡើង
ភ្លាម នោះទ្រង់បង្គាប់ឱ្យគេយកអ្វីៗ មកឱ្យនាងបរិភោគ
៥៦ឪពុកម្ដាយនាងក៏កើតមានសេចក្ដីអស្ចារ្យ តែទ្រង់ហាម
មិនឱ្យ គេប្រាប់ឱ្យអ្នកណាដឹងពីការនោះឡើយ[ឌ]។

## ព្រះយេស៊ូវបញ្ជូនសិស្សទាំង១២ឱ្យចេញទៅ

*៩:៣–៥ = មថ ១០:៩–១៥ មក ៦:៨–១១*
*៩:៧–៩ = មថ ១៤:១,២ មក ៦:១៤–១៦*

**៩** ១លុះទ្រង់បានហៅពួកសិស្សទាំង១២នាក់មក នោះក៏
ប្រទានឱ្យគេមានព្រះចេស្ដា នឹងអំណាចលើអស់ទាំង
អារក្ស[ឍ]ហើយឱ្យអាចមើលជំងឺឱ្យជា[ណ] ២ទ្រង់ចាត់គេឱ្យ
ទៅប្រកាសប្រាប់ពីនគរព្រះ[ត] ហើយឱ្យមើលមនុស្សមាន
ជំងឺឱ្យបានជាផង ៣ទ្រង់មានបន្ទូលប្រាប់ថា កុំឱ្យយកអ្វី
សំរាប់តាមផ្លូវឡើយ ទោះជាដំបង យាម នំបុ័ង ឬប្រាក់ក្តី ក៏
កុំឱ្យមានអាវ២ដែរ[ថ] ៤បើអ្នករាល់គ្នា ចូលទៅក្នុងផ្ទះណា
ចូរស្នាក់នៅផ្ទះនោះ ហើយចេញចូលធ្វើការចុះ ៥ឯអស់
អ្នកណាដែលមិនព្រមរាក់ទាក់ទទួលអ្នករាល់គ្នាទេ នោះ
ចូរចេញពីភូមិនោះទៅ ហើយរលាស់ទាំងធូលីដីពីជើង
អ្នកចេញ ទុកជាទីបន្ទាល់ទាស់នឹងគេវិញ[ទ] ៦កាលគេចេញ
ទៅ នោះក៏ដើរទៅសព្វពេញអស់ទាំងភូមិ ព្រមទាំងផ្សាយ
ដំណឹងល្អ ហើយបានមើលគេឱ្យជា នៅគ្រប់កន្លែងដែរ។
៧ឯហេរ៉ូឌ[ធ] ជាស្ដេចអនុរាជ បានឮនិយាយពីការដែល
ទ្រង់ធ្វើទាំងប៉ុន្មាន ក៏មានព្រះទ័យអល់អែក ពីព្រោះខ្លះ
និយាយថា លោកយ៉ូហាន[ន]បានរស់ពីស្លាប់ឡើងវិញ[ប] ៨ខ្លះ
ថា លោកអេលីយ៉ាបានលេចមកហើយ[ព] ខ្លះទៀតថាមាន
ហោរាណាមួយ ពីចាស់បុរាណបានរស់ឡើងវិញ[ភ] ដូច្នេះ
៩តែហេរ៉ូឌមានបន្ទូលថា យើងបានកាត់ក្បាលយ៉ូហាន
ហើយ ដូច្នេះតើអ្នកណាហ្ន៎ ដែលអញឮថាធ្វើការប្លែក
ទាំងម្ល៉េះនេះ ហើយក៏រកចង់ឃើញទ្រង់[ម]។

**៨:៥២** ញ លក ២៣:២៧ ដ មថ ៩:២៤ **៨:៥៤** ឋ លក ៧:១៤ **៨:៥៦** ឌ មថ ៨:៤ **៩:១** ឍ មថ ១០:១ ណ មថ ៤:២៣ លក ៥:១៧ **៩:២** ត មថ ៣:២ **៩:៣** ថ លក ១០:៤ ២២:៣៥ **៩:៥** ទ មថ ១០:១៤ **៩:៧** ធ មថ ១៤:១ ន មថ ៣:១ ប ខ.១៩
**៩:៨** ព មថ ១១:១៤ ភ ខ.១៩ យហ ១:២១ **៩:៩** ម លក ២៣:៨

ទេ (មើល យហ ១១:១១–១៤ ចំពោះព្រះបន្ទូលដែលទ្រង់មានមកកាន់លោកឡាសារ)។

**៨:៥៦** *ទ្រង់ហាមមិនឱ្យ គេប្រាប់ ឱ្យអ្នកណាដឹងពីការនោះឡើយ* មើលការពន្យល់ មថ ៨:៤ មក ៥:៤៣ ។ បានជាទ្រង់ហាមមិនឱ្យប្រាប់ ពីព្រោះទ្រង់ជ្រាបថា សេចក្ដីពិតគង់តែមានគេដឹង ។ ម្យ៉ាងវិញទៀត ព្រោះទ្រង់ខ្វល់ពីព្រះរាជកិច្ចទ្រង់ ទ្រង់មិនចង់ឱ្យគេគ្រាន់តែស្គាល់ថា ទ្រង់ជាអ្នកធ្វើការអស្ចារ្យម្នាក់នោះទេ តែទ្រង់ចង់ឱ្យបណ្ដាជនស្ដាប់ព្រះបន្ទូលទ្រង់ ដែលអាចប្រោសដល់ជីវិតខ្មោចខ្មាំខាងឯវិញ្ញាណរបស់ពួកគេ ។

**៩:១–៦** ដំណាក់កាលថ្មីមួយទៀតនៃព្រះរាជកិច្ចព្រះយេស៊ូវបានចាប់ផ្ដើមនៅពេល ដែលទ្រង់បញ្ជូនឱ្យសិស្សទ្រង់ចេញផ្សាយដំណឹងល្អ អធិប្បាយ បង្រៀន និងប្រោសជំងឺ ជាកិច្ចការដែលពួកគេបានរៀនពីទ្រង់ ដោយការសង្កេតមើលទ្រង់ (មថ ៩:៣៥) ។ លើកនេះគឺជាលើកទីបីដែលទ្រង់ និងសិស្សរបស់ទ្រង់ធ្វើដំណើរនៅស្រុកកាលីឡេ (មើលពន្យល់ ៨:១)។ ក្នុងព្រះរាជដំណើរលើកទីមួយ ព្រះអម្ចាស់បានធ្វើដំណើរជាមួយនឹងអ្នកនេសាទបួនរូប នៅលើកទីពីរទ្រង់មានសិស្សទាំង១២នាក់ រួមដំណើរជាមួយ ហើយនៅលើកទីបីនេះទៀតទ្រង់យាងតែម្នាក់ឯងទេ បន្ទាប់ពីបានបញ្ជូនឱ្យសិស្សទ្រង់ចេញពីរៗនាក់ ។

**៩:១** *ទាំង១២នាក់* (មើល ៦:១៣ និងការពន្យល់ មក ៦:៣០)។ *ព្រះចេស្ដា និងអំណាច* មើល ៥:១៧ ៨:៤៦ មក ៥:៣០ និងការពន្យល់ ។ *អារក្ស* មើលការពន្យល់ ៤:៣៣ ។

**៩:៣** *កុំឱ្យយកអ្វីសំរាប់តាមផ្លូវ* គឺដើម្បីកុំឱ្យធ្ងន់ពេលធ្វើដំណើរ គឺមិនឱ្យដាក់តាមខ្លួនសូម្បីតែគ្រឿងបម្រុងក៏ដោយ ។ ពួកគេត្រូវពឹងផ្អែកទាំងស្រុងទៅលើអ្នកណាដែលពួកគេស្នាក់នៅជាមួយ (មើលការពន្យល់ មក ៦:៨)។

**៩:៤** *ចូរស្នាក់នៅផ្ទះនោះ* ពួកសាវ័កមិនត្រូវផ្លាស់ពីផ្ទះមួយទៅផ្ទះមួយទៀត ដើម្បីស្វែងរកការស្នាក់នៅស្រួលនោះឡើយ ប៉ុន្តែត្រូវប្រើតែផ្ទះមួយជាទីបញ្ជាការក្នុងពេលកំពុងចែកចាយ នៅក្នុងសហគមន៍ដែលគេទៅដល់នោះបានហើយ ។

**៩:៥** បញ្ហារលាស់ចេញពីជើងនូវធូលីដីរបស់ទឹកដីដែលមិនព្រមទទួល គឺបានចាក់ឫសចូលជ្រៅទៅក្នុងបញ្ហាវប្បធម៌ ។ ចំពោះសាសន៍យូដាណាម្នាក់ដែលមានពុត ពួកគេតែងធ្វើដូចនេះ បន្ទាប់ពីបានដើរកាត់ទីក្រុងនៃសាសន៍ដទៃ ដើម្បីបង្ហាញពីការកាត់ផ្ដាច់ខ្លួនចេញពីសាសន៍ដទៃ ។ ហើយបើកាលណាពួកសាវ័ករលាស់ចេញពីជើង នូវធូលីដីរបស់ទឹកដីសាសន៍យូដា នោះជាការបង្ហាញពីការកាត់ផ្ដាច់ខ្លួនរបស់ពួកគេ ចេញពីសាសន៍យូដាដែលបដិសេធព្រះមែស៊ីរបស់ពួកគេ ។ ការធ្វើដូចនេះក៏បានបង្ហាញផងដែរថា ពួកសាវ័កមិនទទួលខុសត្រូវចំពោះរបៀបយ៉ាងណា ដែលបណ្ដាជនឆ្លើយតបចំពោះដំណឹងល្អ ដែលពួកគេផ្សាយទៅដោយប្រុងប្រយ័ត្នហើយស្មោះត្រង់នោះឡើយ គឺពួកគេត្រូវផ្លាស់ទៅផ្សាយដល់អ្នកផ្សេងទៀត ដែលព្រះទ្រង់សព្វព្រះទ័យឱ្យដំណឹងល្អបានទៅដល់វិញ (១០:១១ មើលការពន្យល់ មថ ១០:១៤ កច ១៣:៥១)។

**៩:៧** *ហេរ៉ូឌ ជាស្ដេចអនុរាជ* មើលការពន្យល់ មថ ១៤:១ ។ *លោកយ៉ូហានបានរស់ពីស្លាប់ឡើយវិញ* មើលការពន្យល់ មក ៦:១៦ លោកលូកាមិនបាននិយាយលំអិតពីកាលបរិច្ឆេទនៃការស្លាប់របស់លោកយ៉ូហាន (មថ ១៤:១–១២ មក ៦:១៧–២៩) ប៉ុន្តែ លោកគ្រាន់តែបានប្រាប់ថាការនេះបានកើត ឡើងប៉ុណ្ណោះ (ខ.៩)។

**៩:៨** *លោកអេលីយ៉ាបានលេចមកហើយ* មើលពន្យល់ ១:១៧ មក ៩:១២ ។

**៩:៩** *រកចង់ឃើញទ្រង់* បំណងដែលស្ដេចហេរ៉ូឌចង់ឃើញព្រះយេស៊ូវបានសម្រេចនៅក្នុងពេលដែលគេកាត់ទោសទ្រង់ (២៣:៨–១២)។

## ព្រះយេស៊ូវប្រទានអាហារដល់មនុស្សប្រាំពាន់នាក់

*៩:១០–១៧ = មថ ១៤:១៣–២១ មក ៦:៣២–៤៤ យហ ៦:៥–១៣*
*៩:១៣–១៧ = ២ពវ ៤:៤២–៤៤*

១០កាលពួកសាវក[យ]បានត្រឡប់មកវិញ ក៏រ៉ាយរឿងទូល
ព្រះយេស៊ូវ ពីការដែលគេបានធ្វើទាំងប៉ុន្មាន នោះទ្រង់នាំ
គេទៅដោយឡែកនៅទីស្ងាត់ ជិតភូមិ១ឈ្មោះបេតសៃដា[រ]
១១កាលបណ្តាមនុស្សបានដឹង ក៏តាមទ្រង់ទៅ ទ្រង់រាក់ទាក់
ទទួលគេ ហើយមានបន្ទូលប្រាប់ពីនគរព្រះ[ល] ទាំងប្រោស
ដល់អស់អ្នកដែលត្រូវការ ឱ្យគេបានជាផង ១២វេលានោះ
ថ្ងៃកាន់តែទាបហើយ នោះពួក១២នាក់មកទូលទ្រង់ថា
សូមឱ្យមនុស្សទាំងឡាយទៅដើម្បីឱ្យទៅរកទីស្នាក់ នឹង
ស្បៀងអាហារ នៅក្នុងភូមិនឹងស្រុកស្រែជុំវិញ ដ្បិតទីនេះ
ស្ងាត់ណាស់ ១៣តែទ្រង់មានបន្ទូលថា ចូរអ្នករាល់គ្នាឱ្យគេ
បរិភោគទៅ ពួកសិស្សទូលថា យើងខ្ញុំមានតែនំបុ័ង៥ដុំ នឹង
ត្រី២ទេ លើកតែយើងខ្ញុំទៅទិញស្បៀងអាហារទៀត សំ
រាប់មនុស្សទាំងនេះវិញ ១៤(រីឯពួកមនុស្សទាំងនោះមាន
ប្រុស។ ចំនួន ៥ពាន់នាក់) តែទ្រង់មានបន្ទូលទៅពួកសិស្ស
ថា ចូរឱ្យគេអង្គុយដោយជួរ។ទៅ ក្នុង១ជួរ៥០នាក់ ១៥ពួក
សិស្សក៏ឱ្យមនុស្សទាំងអស់អង្គុយដូច្នោះ ១៦នោះទ្រង់យក
នំបុ័ង៥ នឹងត្រី២ ងើបទតទៅលើមេឃ ហើយប្រទានពរ
រួចកាច់[វ]ប្រទានដល់ពួកសិស្ស ឱ្យលើកទៅឱ្យបណ្តាមនុស្ស
១៧គេក៏បរិភោគឆ្អែតទាំងអស់គ្នា រួចប្រមូលចំណិតដែល
នៅសល់បាន១២កន្ត្រក ។

## សេចក្តីជំនឿរបស់លោកពេត្រុស

*៩:១៨–២០ = មថ ១៦:១៣–១៦ មក ៨:២៧–២៩*

*៩:២២–២៧ = មថ ១៦:២១–២៨ មក ៨:៣១–៩:១*

១៨គ្រាមួយ កាលទ្រង់កំពុងតែអធិស្ឋានដោយឡែក[ស]
ហើយពួកសិស្សក៏នៅជាមួយ នោះទ្រង់មានបន្ទូលសួរថា
តើហ្វូងមនុស្សទាំងឡាយថាខ្ញុំជាអ្នកណា ១៩គេទូលឆ្លើយថា
ជាយ៉ូហាន–បាទីស្ទ[ហ] ខ្លះថាជាអេ–លីយ៉ា ខ្លះទៀតថាជាហោ
រាណាមួយពីចាស់បុរាណ បានរស់ឡើងវិញ[ឡ] ២០ទ្រង់មាន
បន្ទូលសួរគេថា ចុះឯអ្នករាល់គ្នាវិញ តើថាខ្ញុំជាអ្នកណា
នោះពេត្រុសទូលឆ្លើយថា ទ្រង់ជាព្រះគ្រីស្ទនៃព្រះ[អ] ២១ទ្រង់
ហាមផ្តាច់ មិនឱ្យគេប្រាប់ដល់អ្នកណា ពីសេចក្តីនេះឡើយ[ក]
២២ដោយមានបន្ទូលថា ត្រូវឱ្យកូនមនុស្ស[ខ]រងទុក្ខជាច្រើន[គ]
ត្រូវពួកចាស់ទុំ ពួកសង្គ្រាជ នឹងពួកអាចារ្យ[ឃ]បោះបង់ចោល
ត្រូវគេសំឡាប់[ង] ហើយ៣ថ្ងៃ[ច]ក្រោយមក នឹងរស់ឡើង
វិញ[ឆ] ២៣រួចទ្រង់មានបន្ទូលទៅមនុស្សទាំងអស់ថា បើ
អ្នកណាចង់មកតាមខ្ញុំ[ជ] ត្រូវឱ្យអ្នកនោះលះកាត់ចិត្តខ្លួនឯង
ទាំងផ្ទុក ឈើឆ្កាងខ្លួនរាល់តែថ្ងៃ ហើយមកតាមខ្ញុំចុះ

**៩:១០** យ មក ៦:៣០
រ មថ ១១:២១
**៩:១១** ល ខ.២
មថ ៣:២
**៩:១៦** វ មថ ១៤:១៩
**៩:១៨** ស លក ៣:២១
**៩:១៩** ហ មថ ៣:១
ឡ ខ.៧,៨
**៩:២០** អ យហ ១:៤៩
៦:៦៦–៦៩ ១១:២៧
**៩:២១** ក មក ៨:៣០
**៩:២២** ខ មថ ៨:២០
គ មថ ១៦:២១
ឃ មថ២៧:១,២
ង កថ ២:២៣ ៣:១៣
ច មថ ១៦:២១
ឆ មថ ១៦:២១
**៩:២៣** ជ មថ ១០:៣៨
លក ១៤:២៧

**៩:១០–១៧** ក្រៅពីការអស្ចារ្យនៃការមានព្រះជន្មរស់ឡើងវិញ ការប្រទានអាហារដល់ហ្វូងមនុស្ស(ចំនួនមនុស្សប្រុសមានប្រាំពាន់នាក់) គឺជាការអស្ចារ្យមួយទៀត ដែលព្រះគម្ពីរដំណឹងល្អទាំងបួនសុទ្ធតែបានកត់ទុកដូចគ្នា(មើលការពន្យល់ មក ៦:៣០–៤៤ យហ ៦:១–១៤)។

**៩:១០** *បេតសៃដា* មើលការពន្យល់ មថ ១១:២១ ។ គេជឿថាព្រះយេស៊ូវទ្រង់ប្រាកដជាបានយាងទៅសម្រាកនៅទីស្ងាត់ក្បែរទីប្រជុំជនភូមិបេតសៃដា (ខ.១២)។

**៩:១៣,១៤** នៅពេលដែលពួកសិស្សទ្រង់បានបង្ហាញពីក្តីបារម្ភ អំពីទីស្នាក់អាស្រ័យ និងស្បៀងអាហារសម្រាប់ហ្វូងមនុស្ស ព្រះយេស៊ូវទ្រង់បានប្រទាននូវដំណោះស្រាយមួយដ៏អស្ចារ្យគឺ "ចូរអ្នករាល់គ្នាឱ្យគេបរិភោគទៅ" តែសិស្សទ្រង់បានតវ៉ានឹងទ្រង់ដោយផ្តោតអារម្មណ៍ទៅលើអ្វីដែលពួកគេគ្មានទៅវិញ ។

**៩:១៤** *ក្នុង១ជួរ៥០នាក់* មើលការពន្យល់ មក ៦:៤០ ។

**៩:១៧** *ប្រមូលចំណិតដែលនៅសល់បាន១២កន្ត្រក* ការធ្វើដូចនេះគឺជាគំរូពីការជៀសវាងការខ្ជះខ្ជាយ និងជាការបង្ហាញឱ្យឃើញថា គ្រប់គ្នាបានបរិភោគឆ្អែត (មើលការពន្យល់ មក ៦:៤៣)។

**៩:១៨** *តើហ្វូងមនុស្សទាំងឡាយ ថាខ្ញុំជាអ្នកណា* ចម្លើយរបស់សិស្សទ្រង់គឺដូចអ្វីដែលស្តេចហេរ៉ូឌបានឮអំពីទ្រង់(ខ.៧–៨)។ ហេតុការណ៍នេះបានកើតឡើងនៅភូមិភាគខាងជើង គឺនៅក្រៅទឹកដីរបស់ស្តេចហេរ៉ូឌ និងនៅតំបន់ជិតខាងក្រុងសេសារា–ភីលីព(មថ ១៦:១៣ មក ៧:២៤ និងពន្យល់)។

**៩:២០** *ពេត្រុសទូលឆ្លើយ* គឺឆ្លើយជំនួសពួកសិស្សទាំងអស់គ្នា ។ *ព្រះគ្រីស្ទនៃព្រះ* មើលការពន្យល់ ២:១១ ។ ការរង់ចាំព្រះអង្គរំដោះ(ព្រះមែស៊ី)តាមបទទំនាយគឺ មានរយៈពេលរាប់សតវត្សរ៍(មើលការពន្យល់ មថ ១៦:១៨ មក ៨:២៩ យហ ៤:៥)។

**៩:២១** *ទ្រង់ហាមផ្តាច់ មិនឱ្យគេប្រាប់ដល់អ្នកណា* បណ្តាជនមានការភាន់ច្រឡំពីព្រះមែស៊ី ហើយត្រូវមានការបង្រៀនជាបន្ថែមទៀត មុនពេលដែលព្រះយេស៊ូវបើកបង្ហាញអង្គទ្រង់ឱ្យបណ្តាជនបានស្គាល់ថាទ្រង់ជានរណា ។ ទ្រង់មានការកំណត់ពេលដ៏សុក្រឹត ហើយមិនអាចឱ្យមានរឿងហេតុអ្វីកើតឡើងមុនកាលកំណត់ ដែលនឹងរំខានដល់អង្គទ្រង់នោះឡើយ(មើលការពន្យល់ មថ ៨:៤ ១៦:២០ មក ១:៣៤)។

**៩:២២** *កូនមនុស្ស* មើលការពន្យល់ មក ៨:៣១ ។ *ត្រូវឱ្យ . . . រងទុក្ខ* គឺជាលើកដំបូងដែលទ្រង់ថ្លែងទំនាយយ៉ាងសុក្រឹតពីការសុគតរបស់ទ្រង់(ខ.៤៤ ១២:៥០ ១៧:២៥ ១៨:៣១–៣៣ ២៤:៧,២៥–២៧)។

**៩:២៣** *ទាំងផ្ទុកឈើឆ្កាងខ្លួនរាល់តែថ្ងៃ* ដើម្បីដើរតាមព្រះយេស៊ូវ មនុស្សត្រូវឈប់តាមចិត្តគំនិតខ្លួន លះបង់ទាំងស្រុង ហើយចុះចូលស្តាប់បង្គាប់ ។ លោកលូកាបាននិយាយសង្កត់ធ្ងន់ពីការប្រព្រឹត្តតាមយ៉ាងខ្ជាប់ខ្ជួន ហើយពាក្យ "រាល់តែថ្ងៃ" មិនមានបញ្ជាក់នៅក្នុងព្រះគម្ពីរដំណឹងល្អផ្សេងទៀតទេ

២៤ដ្បិតអ្នកណាដែលចង់ឱ្យរួចជីវិត នោះនឹងបាត់ជីវិតទៅ
តែអ្នកណាដែលបាត់ជីវិត ដោយព្រោះខ្ញុំនោះនឹងបានជី
វិតវិញ[ឈ] ២៥ដ្បិតបើសិនជាមនុស្សណានឹងបានលោកីយទាំង
មូល ប៉ុន្តែធ្វើឱ្យខ្លួនឯងវិនាស ឬឱ្យបាត់បង់នោះតើមាន
ប្រយោជន៍អ្វីដល់អ្នកនោះ។
២៦ដ្បិតអ្នកណាដែលមានសេចក្ដីខ្មាស ដោយព្រោះខ្ញុំ
នឹងពាក្យខ្ញុំនោះកូនមនុស្សនឹងមានសេចក្ដីខ្មាស ដោយ
ព្រោះអ្នកនោះដែរ[ញ] ក្នុងកាល ដែលលោកមកក្នុងសិរីល្អ
របស់លោក របស់ព្រះវរបិតា ហើយនឹងពួកទេវតាបរិ
សុទ្ធ[ដ] ២៧ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ក្នុងពួកអ្នកដែល
ឈរនៅទីនេះ មានអ្នកខ្លះដែលមិនត្រូវភ្លក់សេចក្ដីស្លាប់
ទាល់តែបានឃើញនគរព្រះ។

## ការផ្លាស់ប្រែរូបកាយ

*៩:២៨–៣៦ = មថ ១៧:១–៨ មក ៩:២–៨*

២៨ប្រហែលជា៨ថ្ងៃក្រោយដែលមានបន្ទូលសេចក្ដីទាំង
នោះមក នោះទ្រង់យកពេត្រុស យ៉ូហាន នឹងយ៉ាកុប[ឋ] ឡើង
ទៅលើភ្នំ ដើម្បីអធិស្ឋាន[ឌ] ២៩កាលទ្រង់កំពុងតែអធិស្ឋាន
នោះបែបភាពព្រះភក្ត្រទ្រង់ក៏ផ្លាស់ប្រែ ហើយព្រះពស្ត្រ
ត្រឡប់ជាសព្រាត ៣០នោះឃើញមានមនុស្ស២នាក់កំពុងតែ
ទូលនឹងទ្រង់ គឺលោកម៉ូសេ នឹងលោកអេលីយ៉ា ៣១ដែល
លេចមកក្នុងសិរីល្អ ទូលពីដំណើរ[ឍ]ទ្រង់សុគត ដែលត្រូវ
សំរេចនៅក្រុងយេរូសាឡិម ៣២ឯពេត្រុស នឹងអ្នកទាំង២
ដែលនៅជាមួយនឹងគាត់ គេងងុយជាខ្លាំង[ណ] លុះកាលភ្ញាក់
ដឹងខ្លួនឡើង នោះស្រាប់តែឃើញសិរីល្អទ្រង់ នឹងមនុស្ស២
នាក់ ដែលឈរនៅជាមួយនឹងទ្រង់ដែរ ៣៣កាលមនុស្ស
ទាំង២នោះកំពុងតែថយចេញពីទ្រង់ទៅ នោះពេត្រុសទូល
ថា លោកគ្រូអើយ[ត] ដែលយើងខ្ញុំនៅទីនេះបានល្អណាស់
ហើយ សូមឱ្យយើងខ្ញុំធ្វើត្រសាល៣ គឺ១សំរាប់លោក ១
សំរាប់លោកម៉ូសេ ហើយ១សំរាប់លោកអេលីយ៉ា ដោយ
មិនដឹងខ្លួនជាថាដូចម្ដេចទេ ៣៤កំពុងដែលទូលសេចក្ដីទាំង
នេះនៅឡើយ នោះមានពពកមកគ្របបាំងគេ គេក៏ភ័យខ្លាច
ទាំងអស់គ្នាដោយចូលខ្លួនក្នុងពពកនោះ ៣៥ហើយមាន
សំឡេងចេញពីពពកមកថា នេះជាកូនស្ងួនភ្ងាអញ[ថ] ចូរឱ្យ
ស្ដាប់តាមចុះ!”[ទ] ៣៦ក្រោយសំឡេងនោះមក ក៏ឃើញមាន
តែព្រះយេស៊ូវ១អង្គទ្រង់ប៉ុណ្ណោះ ក្នុងគ្រានោះគេនៅតែ

**៩:២៤** ឈ យហ ១២:២៥
**៩:២៦** ញ មថ ១០:៣៣ លក ១២:៩ ២ធថ ២:១២ ដ មថ ១៦:២៧
**៩:២៨** ឋ មថ ៤:២១ ឌ លក ៣:២១
**៩:៣១** ឍ ២ពត ១:១៥
**៩:៣២** ណ មថ ២៦:៤៣
**៩:៣៣** ត លក ៥:៥
**៩:៣៥** ថ អស ៤២:១ ទ មថ ៣:១៧

(មថ ១៦:២៤–២៦ មក ៨:៣៤)។ ពួកសាវ័កដែលមកពីស្រុកកាលីឡេ ប្រាកដជាស្គាល់ឈើឆ្កាងព្រោះនៅក្នុងស្រុករបស់ពួកគេ មានមនុស្សរាប់រយនាក់ត្រូវទទួលទោសប្រហារជីវិតនៅលើឈើឆ្កាង ។

**៩:២៤** *អ្នកណាដែលបាត់ជីវិត ដោយព្រោះខ្ញុំ* ឃ្លានេះមាននៅក្នុងគ្រប់ដំណឹងល្អទាំងបួន ហើយមានលើសពីមួយដងនៅក្នុងព្រះគម្ពីរដំណឹងល្អពីរ (១៤:២៦–២៧ ១៧:៣៣ មថ ១០:៣៨–៣៩ ១៦:២៤–២៥ មក ៨:៣៤–៣៥ យហ ១២:២៥)។ ព្រះបន្ទូលមួយឃ្លានេះមានការសង្កត់ធ្ងន់ខ្លាំងជាងគេបំផុត ។

**៩:២៦** *អ្នកណាដែលមានសេចក្ដីខ្មាស* មើលពន្យល់ ១២:៩ មក ៨:៣៨ ។

**៩:២៧** មើលពន្យល់ មថ ១៦:២៨ ។ *នគរព្រះ* មើលពន្យល់ មថ ៣:២ ។

**៩:២៨** *ប្រហែលជា៨ថ្ងៃ* ពាក្យនេះជាញឹកញាប់គេប្រើដើម្បីបង្ហាញពីរយៈពេលមួយសប្ដាហ៍(យហ ២០:២៦ មើលការពន្យល់ មថ ១៧:១)។ *ពេត្រុស យ៉ូហាន និងយ៉ាកុប* សាវ័កបីនាក់នេះក៏បាននៅជាមួយនឹងទ្រង់ដែរនៅពេលដែលទ្រង់ប្រោសកូនលោកយៃរ៉ូស(៨:៥១) និងក្នុងពេលដែលទ្រង់យាងទៅច្បារគែតសេម៉ានី(មក ១៤:៣៣)។ *ទៅលើភ្នំ* ទោះជាគេបានកំណត់យកភ្នំតាបោរជាកន្លែង ដែលព្រះភក្ត្រទ្រង់ផ្លាស់ប្រែក៏ដោយ ក៏ការកំណត់យកនេះហាក់ដូចជាមិនទាន់ត្រឹមត្រូវនៅឡើយទេ បើគេគិតពីចម្ងាយពីភ្នំនេះ ទៅក្រុងសេសារា–ភីលីព (ក្រវល់ក្រុងដែលបាននិយាយក្នុងវគ្គមុន) កំពស់របស់វា(ប្រហែល ៥៤៨,៦៤ ម៉ែត្រ) ហើយនិងបន្ទាយមួយដែលសង់នៅពីលើភ្នំនោះថែមទៀតនោះ ។ ភ្នំហ៊ើម៉ូនមាន លក្ខណៈសក្តិសមនឹងព្រឹត្ត–ការណ៍នោះជាង ព្រោះមានចម្ងាយជិតជាង និងកម្ពស់ខ្ពស់ជាង (គឺកម្ពស់ជាង ២៧៤៣,២ម៉ែត្រ មើល មក ៩:២)។ *អធិស្ឋាន* លោកលូកាបានលើកឡើងម្ដងទៀតពីទីកន្លែងអធិស្ឋាននៅក្នុងព្រឹត្តិការណ៍ដ៏សំខាន់ ។

**៩:៣០** *លោកម៉ូសេ និងលោកអេលីយ៉ា* លោកម៉ូសេ គឺជាអ្នករំដោះក្នុងគ្រាសញ្ញាចាស់ និងអ្នកដែលតែងច្បាប់លោកអេលីយ៉ា គឺជាតំណាងរបស់ពួកហោរា ។ កិច្ចការរបស់លោកម៉ូសេ មានលោកយ៉ូស្វេជាអ្នកបញ្ចប់ រីឯកិច្ចការរបស់លោកអេលីយ៉ា មានលោកអេលីសេជាអ្នកបញ្ចប់ ។ នៅពេលនេះ លោកទាំងពីរកំពុងទូលព្រះយេស៊ូវ (ព្រះនាមទ្រង់ជាភាសាហេព្រើរគឺ "យ៉ូស្វេ") អំពីសេចក្ដីសង្គ្រោះ ដែលជិតបានសម្រេចហើយ ដោយទ្រង់នឹងដោះរាស្ត្រទ្រង់ឱ្យរួចពីភាពជាទាសករនៃអំពើបាបព្រមទាំងសម្រេចកិច្ចការរបស់លោក និងលោកអេលីយ៉ា (ការពន្យល់ ១ពវ ១៩:១៦ មថ ១៧:៣)។

**៩:៣១** *ដំណើរទ្រង់សុគត* ដំណើរនេះប្រហែលជាអាចតភ្ជាប់ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ដើម្បីសង្គ្រោះមនុស្ស ជាមួយនឹងការដែលព្រះនាំរាស្ត្រទ្រង់ចេញពីប្រទេសអេស៊ីព្ទ ។

**៩:៣២** *ងងុយជាខ្លាំង* ការអស្ចារ្យនេះប្រហែលជាបានកើតឡើងនៅពេលយប់ ។ *ឃើញសិរីល្អទ្រង់* មើលការពន្យល់ នក ៣៣:១៨ ។

**៩:៣៣** *ត្រសាល៣* ជាសំណង់បណ្ដោះអាសន្ន សម្រាប់ឱ្យបុគ្គលសំខាន់ទាំងបីរូបស្នាក់នៅបានយូរបន្តិចទៀត គឺមានអ្នកតែងច្បាប់ ហោរា និងព្រះមែស៊ី។ ទោះជាយ៉ាងណាក៏ដោយ គំនិតរបស់សិស្សទ្រង់មិនប្រាកដទេ ពីព្រោះទ្រង់មានកិច្ចការមួយ ដែលត្រូវបញ្ចប់ក្នុងរយៈពេលសេសសល់ពីរបីថ្ងៃទៀត (មើលការពន្យល់ មក ៩:៥)។

**៩:៣៤–៣៥** *ពពក* មើល មថ ១៧:៥ និងការពន្យល់ ។

**៩:៣៥** *កូនស្ងួនភ្ងាអញ* ពាក្យស្ងួនភ្ងានេះមានន័យត្រូវនឹងពាក្យ "ដែលអញបានជ្រើសតាំង"(មថ ១៧:៥ មថ ៣:១៧ និងការពន្យល់ ២ពត ១:១៧)។

ស្មៀម ឥតមានប្រាប់ដល់អ្នកណាពីការអ្វីដែលគេឃើញ
នោះឡើយ[ធ] ។

## ការប្រោសក្មេងប្រុសដែលមានអារក្សចូល

*៩:៣៧-៤៥ = មថ ១៧:១៤-១៨,២២,២៣ មក ៩:១៤-២៧,៣០-៣២*

៣៧ដល់ថ្ងៃក្រោយ កាលចុះពីភ្នំមក នោះមានមនុស្សសន្ធឹក
មកជួបនឹងទ្រង់ ៣៨ហើយមើល មានម្នាក់ស្រែកឡើងពីក្នុង
ពួកមនុស្សទាំងនោះថា លោកគ្រូអើយ សូមអាណិតកូនខ្ញុំ
ផង ដ្បិតជាកូនតែ១របស់ខ្ញុំ ៣៩ហើយមើល មានវិញ្ញាណ
អារក្សចេះតែជាន់វា ហើយលោតែវាស្រែកឡើង ធ្វើឱ្យ
ប្រកាច់បែកពពុះមាត់ នឹងហើមជាំអស់ទាំងខ្លួន រួចចេញពី
វាទៅដោយពិបាក ៤០ខ្ញុំបានសូមអង្វរឱ្យពួកសិស្ស លោក
ដេញចេញដែរ តែគេដេញមិនបានសោះ។
៤១ព្រះយេស៊ូវមានបន្ទូលឆ្លើយថា ឱដំណមនុស្សដែល
មិនជឿ ហើយមានចិត្តវៀចអើយ[ន] តើត្រូវឱ្យខ្ញុំនៅជាមួយ
ហើយទ្រាំនឹងអ្នករាល់គ្នាដល់កាលណាទៀត ចូរនាំកូនអ្នក
មកឯណេះ ៤២កាលវាកំពុងតែដើរចូរមកនោះអារក្ស
បានផ្តួលវា ហើយធ្វើឱ្យប្រកាច់ប្រកិនជាខ្លាំង តែព្រះ
យេស៊ូវទ្រង់កំហែងទៅវិញ្ញាណអសោចិ៍ ហើយប្រោសក្មេង
នោះឱ្យជា រួចប្រគល់ដល់ឪពុកវិញ ឯមនុស្សទាំងឡាយ
ក៏អស្ចារ្យចំពោះឥទ្ធិឫទ្ធិរបស់ព្រះទាំងអស់គ្នា ។
៤៣កាលមនុស្សទាំងអស់ កំពុងតែនឹកប្លែកក្នុងចិត្តពីអស់
ទាំងការដែលព្រះយេស៊ូវទ្រង់ធ្វើ នោះទ្រង់មានបន្ទូលទៅ
ពួកសិស្សថា ៤៤ចូរអ្នករាល់គ្នាចាំពាក្យទាំងនេះ ទុកនៅក្នុង
ត្រចៀកចុះ ដ្បិតបន្តិចទៀត កូនមនុស្សត្រូវបញ្ជូនទៅក្នុង
កណ្តាប់ដៃនៃមនុស្សលោកហើយ[ប] ៤៥ប៉ុន្តែគេមិនបាន
យល់សេចក្តីនោះទេ ព្រោះជាសេចក្តីលាក់កំបាំងដល់គេ
ដើម្បីមិនឱ្យគេគិតឃើញ[ផ] ហើយគេក៏ខ្លាចមិនហ៊ានទូលសួរ
ទ្រង់ពីសេចក្តីនោះដែរ ។

## តើអ្នកណាធំជាងគេ?

*៩:៤៦-៤៨ = មថ ១៨:១-៥ ៩:៤៦-៥០ = មក ៩:៣៣-៤០*

៤៦ខណៈនោះ គេកើតមានសេចក្តីជជែកគ្នាពីអ្នកណា
ដែលធំជាងក្នុងពួកគេវិញ[ព] ៤៧កាលព្រះយេស៊ូវបានជ្រាប
គំនិត[ភ]ក្នុងចិត្តគេហើយ នោះទ្រង់យកក្មេងតូច១ មកដាក់នៅ
ជិតទ្រង់ ៤៨រួចមានបន្ទូលថា អ្នកណាដែលទទួលក្មេងតូច
នេះ ដោយនូវឈ្មោះខ្ញុំ នោះឈ្មោះថាទទួលខ្ញុំ ហើយអ្នក
ណាដែលទទួលខ្ញុំ[ម] នោះឈ្មោះថាទទួលព្រះដែលចាត់
ឱ្យខ្ញុំមកដែរ ព្រោះអ្នកណាដែលតូចជាងគេក្នុងពួកអ្នករាល់
គ្នា គឺអ្នកនោះហើយជាអ្នកធំវិញ[យ] ៤៩យ៉ូហានទូលឆ្លើយថា
លោកគ្រូ[រ] យើងខ្ញុំបានឃើញមនុស្សម្នាក់កំពុងតែដេញអា
រក្ស ដោយឈ្មោះលោក តែយើងខ្ញុំបានឃាត់ដល់អ្នកនោះ
ដោយព្រោះគេមិនតាមយើងរាល់គ្នា ៥០នោះព្រះយេស៊ូវ
មានបន្ទូលទៅគាត់ថា កុំឃាត់គេឡើយ ដ្បិតអ្នកណាដែល
មិនទាស់នឹងយើង នោះកាន់ខាងយើងហើយ[ល] ។

## ការបដិសេធន៍របស់សាសន៍សាម៉ារី

៥១កាលជិតដល់កំណត់ ដែលទ្រង់ត្រូវឡើងទៅស្ថានសួគ៌[វ]
នោះទ្រង់ដំរង់ព្រះភក្ត្រ យាងឆ្ពោះត្រង់ទៅឯក្រុងយេរូសសឡិម

**៩:៣៦** ធ មថ ១៧:៩
**៩:៤១** ន ចទ ៣២:៥
**៩:៤៤** ប ខ.២២
**៩:៤៥** ផ មក ៩:៣២
**៩:៤៦** ព លក ២២:២៤
**៩:៤៧** ភ មថ ៩:៤
**៩:៤៨** ម មថ ១០:៤០ យ មក ៩:៣៥
**៩:៤៩** រ លក ៥:៥
**៩:៥០** ល មថ ១២:៣០ លក ១១:២៣
**៩:៥១** វ មក ១៦:១៩

**៩:៣៩** *អារក្សចេះតែជាន់វា* គឺវិញ្ញាណអារក្សអាចធ្វើឱ្យមនុស្សប្រកាច់ប្រកិន (មថ ១៧:១៥ មើលការពន្យល់ មថ ៤:២៤) និងនិយាយមិនរួច(មក ៩:១៧)។ វិញ្ញាណអារក្សមានការទទួលខុសត្រូវលើការបង្កការឈឺចាប់ជាច្រើនប្រភេទ (មើលការពន្យល់ ៤:៣៣)។

**៩:៤៤** គឺការថ្លែងទំនាយមួយទៀត អំពីការសុគតដែលត្រូវមកដល់អង្គព្រះគ្រីស្ទយេស៊ូវ(មើលការពន្យល់ខ.២២) ដែលជាការបង្ហាញពីរបៀបដែលការនោះនឹងកើតឡើង(២២:២១)។

**៩:៤៦** *សេចក្តីជជែក . . . អ្នកណាដែលធំជាងក្នុងពួកគេ* គឺប្រធានបទដែលពួកសិស្សទ្រង់បានលើកមកជជែកគ្នាជាច្រើនដង(មើល ២២:២៤ មក ១០:៣៥-៤៥ និងការពន្យល់ មក ៩:៣៤)។

**៩:៤៨** *អ្នកណាដែលតូចជាងគេ . . . អ្នកធំវិញ* មនុស្សម្នាក់ៗនឹងបានជាធំនៅចំពោះព្រះវិញ បើកាលណាពួកគេបន្ទាបខ្លួនថ្វាយបង្គំទ្រង់ ដោយចិត្តស្មោះត្រង់(មើល មក ១០:៤៣ និងការពន្យល់)។

**៩:៤៩,៥០** គឺពួកសាវ័កមានចិត្តច្រណែននឹងបុរសម្នាក់នោះ ។ មានសាវ័ក៩នាក់ ដែលមិនអាចដេញអារក្សចេញបានសូម្បីតែមួយ(លក ៩:៤០) ប៉ុន្តែនៅពេលដែលពួកគេឃើញបុរសម្នាក់នោះ ដែលមិននៅក្នុងក្រុមជាមួយពួកខ្លួនដេញអារក្ស ពួកគេបានប្រាប់ឱ្យគាត់ឈប់ ។ សេចក្តីអំនួតរបស់មនុស្សម្នាក់ៗ តែងនាំឱ្យខ្លួនគេមានការមិនពេញចិត្តនឹងអ្នកដទៃ ដែលបានទទួលជោគជ័យក្នុងការអ្វីដែលខ្លួនបរាជ័យ ។

**៩:៥០** *ដ្បិតអ្នកណាដែលមិនទាស់នឹងយើង នោះកាន់ខាងយើងហើយ* ដោយសារគ្មាននរណាម្នាក់អាចកាន់ ឬមិនកាន់ខាងព្រះផង និងអារក្សផងបានដូចនេះអ្នក ដែលមិនទាស់ប្រឆាំងនឹងទ្រង់ គឺនៅខាងទ្រង់ហើយ ។ គ្រាន់តែថាពួកគេអាចមានបែបបទនៃការបម្រើផ្សេងពីយើង គឺអាចនៅក្នុងក្រុម ឬនិកាយផ្សេងពីយើង ប៉ុន្តែបើសិនជាពួកគេធ្វើការក្នុងព្រះនាមទ្រង់ នោះត្រូវឱ្យយើងទទួលពួកគេដូចជាបងប្អូន និងគូកនការងារនៅក្នុងព្រះគ្រីស្ទ(មថ ១២:៣០ មក ៣:២៧ ១១:២៣ និងការពន្យល់)។

**៩:៥១** *ឡើងទៅស្ថានសួគ៌* មើល ២៤:៥១ កច ១:៩ ។ *ទ្រង់ដំរង់ព្រះភក្ត្រយាងឆ្ពោះត្រង់ទៅឯក្រុងយេរូសាឡិម* ទោះជាយ៉ាងណាក៏ដោយ ការចេញដំណើរទៅក្រុងយេរូសាឡិមលើកនេះ គឺមិនមែនជាការចេញដំណើរឆ្ពោះទៅរកការសុគតលើឈើឆ្កាងតែម្តងនោះទេ ប៉ុន្តែ វាជាដំណើរចាប់ផ្តើមព្រះរាជកិច្ចមួយរយៈនៅស្រុកយូដា ដែលមានទីក្រុងយេរូសាឡិមជាចំណុចកណ្តាល ។ ដំណើរតម្រង់ឆ្ពោះទៅស្រុកយូដាមានបញ្ជាក់នៅក្នុង មក ១០:១

តែម្តង[ស] ៥២ទ្រង់ចាត់ប្រើអ្នកខ្លះឱ្យទៅជាមុន គេក៏ទៅ
ហើយបានចូលទៅក្នុងភូមិ១របស់សាសន៍សាម៉ារី[ហ] ដើម្បី
នឹងរៀបចំថ្វាយទ្រង់ ៥៣តែពួកភូមិនោះមិនទទួលទ្រង់ទេ
ពីព្រោះទ្រង់ដូចជាមានព្រះភក្ត្រឆ្ពោះត្រង់យាងទៅឯក្រុង
យេរូសាឡិម ៥៤កាលយ៉ាកុប នឹងយ៉ូហាន[ឡ] ជាសិស្សទ្រង់
បានឃើញដូច្នោះ នោះក៏ទូលថា ព្រះអម្ចាស់អើយ តើ
ទ្រង់សព្វព្រះហឫទ័យឱ្យយើងខ្ញុំ ហៅភ្លើងឱ្យធ្លាក់ ពីមេឃ
មកបញ្ឆេះគេ ដូចជាលោកអេលីយ៉ាបានធ្វើដែរឬអី[អ]
៥៥តែទ្រង់បែរទៅបន្ទោសគេថា អ្នករាល់គ្នាមិនដឹងជា
មានវិញ្ញាណបែបយ៉ាងណាទេ ៥៦ពីព្រោះកូនមនុស្សមិន
មែនមកបំផ្លាញជីវិតមនុស្សទេ គឺមកដើម្បីនឹងជួយ
សង្គ្រោះវិញ រួចក៏នាំគ្នាទៅឯភូមិមួយទៀតទៅ ។

## តម្លៃនៃការដើរតាមព្រះយេស៊ូវ

*៩:៥៧–៦០ = មថ ៨:១៩–២២*

៥៧កាលកំពុងតែទៅតាមផ្លូវ[ក] នោះមានម្នាក់ទូលទ្រង់ថា
ព្រះអម្ចាស់អើយ ទូលបង្គំនឹងតាមទ្រង់ ទោះបើទ្រង់យាង
ទៅក្នុងទីណាក៏ដោយ ៥៨ព្រះយេស៊ូវមានបន្ទូលតបថា
កញ្ជ្រោងមានរូងវា ហើយសត្វហើរលើអាកាសក៏មាន
សំបុកដែរ តែកូនមនុស្ស[ខ]គ្មានកន្លែងណានឹងកើយក្បាល
ទេ ៥៩ទ្រង់មានបន្ទូលទៅម្នាក់ទៀតថា ចូរមកតាមខ្ញុំ[គ]
អ្នកនោះទូលឆ្លើយថា "ព្រះអម្ចាស់អើយ! សូមទ្រង់
អនុញ្ញាតឱ្យទូលបង្គំ ទៅកប់ខ្មោចឪពុកទូលបង្គំសិន
៦០តែទ្រង់មានបន្ទូលទៅអ្នកនោះថា "ទុកឱ្យពួកមនុស្ស
ស្លាប់កប់ខ្មោចពួកគេចុះ ឯអ្នក ចូរទៅផ្សាយដំណឹងពី
នគរព្រះវិញ"[ឃ] ៦១មានម្នាក់ទៀតទូលថា "ព្រះអម្ចាស់
អើយ! ទូលបង្គំនឹងតាមទ្រង់ទៅដែរ តែសូម អនុញ្ញាត
ឱ្យទូលបង្គំ ទៅលាពួកផ្ទះទូលបង្គំសិន"[ង] ៦២ទ្រង់មាន
បន្ទូលទៅអ្នកនោះថា "អ្នកណាដែលដាក់ ដៃកាន់នង្គ័ល
ហើយងាកបែរទៅមើលក្រោយ អ្នកនោះមិនគួរនឹង
នគរព្រះទេ" ។

## ការបញ្ជូនសិស្ស៧០នាក់ទៅប្រកាសដំណឹងល្អ

*១០:៤–១២ = លក ៩:៣–៥*

*១០:១៣–១៥,២១,២២ = មថ ១១:២១–២៣,២៥–២៧*

*១០:២៣,២៤ = មថ ១៣:១៦,១៧*

**១០** ១លុះក្រោយការទាំងនោះមក ព្រះអម្ចាស់[ច]ទ្រង់ដំរូវ
៧០នាក់ទៀត[ឆ] ហើយចាត់គេឱ្យទៅមុនទ្រង់ មួយគូៗ[ជ]ក្នុង

**៩:៥១** ស លក ១៣:២២ ១៧:១១ ១៨:៣១ ១៩:២៨
**៩:៥២** ហ មថ ១០:៥
**៩:៥៤** ឡ មថ ៤:២១ អ ២ពវ ១:១០,១២
**៩:៥៧** ក ខ.៥១
**៩:៥៨** ខ មថ ៨:២០
**៩:៥៩** គ មថ ៤:១៩
**៩:៦០** ឃ មថ ៣:២
**៩:៦១** ង ១ពវ ១៩:២០
**១០:១** ច លក ៧:១៣ ឆ លក ៩:១,២,៥១ ,៥២ ជ មក ៦:៧

ចំណែកឯលោកយ៉ូហាន ក៏បានបកស្រាយពីការនេះផងដែរថា នោះគឺជាការធ្វើដំណើរទៅក្រុងយេរូសាឡិមក្នុងថ្ងៃបុណ្យបារាំ(យហ ៧:១–១០)។ ការបកស្រាយពីបេសកកម្មនៅស្រុកយូដានេះ (សូមមើលសេចក្តីផ្តើម ត្រង់គម្រោង) មាននៅក្នុង ៩:៥១–១៣:២១ យហ ៧:១០–១០:៣៩ និងការពន្យល់ មក ១០:៣២ ។

**៩:៥២** *ភូមិ១របស់សាសន៍សាម៉ារី* សាសន៍សាម៉ារីគឺជាសត្រូវរបស់សាសន៍យូដា ហើយពួកសាសន៍យូដាខ្លះ ត្រូវធ្វើដំណើរទៅធ្វើពិធីបុណ្យនៅក្រុងយេរ៉ូសាឡិម ដោយកាត់តាមទឹកដីរបស់សាសន៍សាម៉ារី ។ ដំណើរពីស្រុកកាលីឡេ ទៅក្រុងយេរូសាឡិមដែលកាត់តាមភូមិរបស់សាស៍សាម៉ារី យ៉ាងហោចណាស់ក៏ត្រូវចំណាយពេលបីថ្ងៃដែរ ហើយសាសន៍សាម៉ារីមានការបដិសេធន៍មិនព្រមផ្តល់កន្លែងស្នាក់ នៅពេលយប់ដល់សាសន៍យូដាឡើយ ។ ដោយសារតែការបដិសេធន៍នេះ សាសន៍យូដាដែលពីដើមធ្លាប់ធ្វើដំណើរពីស្រុកកាលីឡេ ទៅកាន់ក្រុងយេរូសាឡិម ជាញឹកញាប់ធ្វើដំណើរតាមភាគខាងកើតនៃទន្លេយ័រដាន់វិញ ។

**៩:៥៤** ពេលដែលសាសន៍សាម៉ារីបដិសេធលោកយ៉ាកុប និងលោកយ៉ូហាន នៅក្នុងភូមិរបស់ពួកគេនោះ សាវ័កទាំងពីរមិនចង់ឆ្លើយតប ដោយគ្រាន់តែរលាស់ធូលីដីពីជើងប៉ុណ្ណោះទេ (លក ៩:៥)។ ពួកគេចង់ធ្វើតបទៅវិញ ដោយហៅភ្លើងឱ្យធ្លាក់ពីលើមេឃមក ដូចដែលលោកអេលីយ៉ាបានធ្វើដែរ (២ពវ ១:៩–១៦) ប៉ុន្តែ ពួកគេត្រូវចាំថាការជំនុំជម្រះ គឺស្រេចតែលើព្រះវិញ ហើយក៏មិនត្រូវរំពឹងថា ទ្រង់នឹងប្រើអំណាចតាមចិត្តដែលពួកគេចង់ធ្វើតបដាក់គេវិញនោះឡើយ ។

**៩:៥៥** *បន្ទោសគេ* មើលការពន្យល់ ២ពវ ១:១០ ។

**៩:៥៧–៦២** វគ្គនេះគឺនិយាយពីការលះបង់ ដើម្បីឱ្យបានក្លាយជាអ្នកដើរតាមព្រះគ្រីស្ទពិតប្រាកដ ។ មិនត្រូវឱ្យទុក្ខលំបាក(ខ.៥៧–៥៨)ការបាត់បង់មនុស្សជាទីស្រឡាញ់(ខ.៥៩–៦០) ឬចំណងគ្រួសារ(ខ.៦១) បញ្ឈប់ការដើរតាមព្រះបានឱ្យសោះ(ខ.៦២)។

**៩:៥៧** *កាលកំពុងតែទៅតាមផ្លូវ* គឺពួកគេកំពុងធ្វើដំណើរទៅឯក្រុងយេរូសាឡិមបន្តទៀត ដោយកាត់តាមភូមិរបស់សាសន៍សាម៉ារី ។

**៩:៥៩** លោកលូកាមិនបានបញ្ជាក់ប្រាប់យើងថា តើឪពុកសិស្សម្នាក់នោះបានស្លាប់ទៅហើយ ឬមានជំងឺឈឺរ៉ាំរ៉ៃនោះទេ ។ បើសិនជាឪពុកគាត់បានស្លាប់ទៅហើយមែន នោះគាត់គួរតែកំពុងនៅបំពេញកិច្ចបញ្ចុះសពឪពុករបស់គាត់ហើយ ព្រះយេស៊ូវទ្រង់បានប្រកាសថា សិស្សពិតប្រាកដគឺតម្រូវឱ្យនៅសកម្មជាប់ជានិច្ច ។ ព្រះយេស៊ូវទ្រង់មិនបានបង្រៀនឱ្យមនុស្សបោះបង់ចោលការទទួលខុសត្រូវចំពោះគ្រួសារឡើយ ។ ប្រហែលសិស្សម្នាក់នេះចង់ពន្យាពេលដើរតាមទ្រង់ ហើយចង់ឱ្យទ្រង់អត់ទោសឱ្យ ដោយព្រោះឪពុករបស់គាត់ ។

**៩:៦២** *ងាកបែរទៅក្រោយ* មើល យហ ៦:៦៦ ភល ៣:១៣ និងការពន្យល់ ។

**១០:១** *ដំរូវ៧០នាក់ទៀត* មាននិយាយតែក្នុងព្រះគម្ពីរលូកាប៉ុណ្ណោះ (មើល មថ ៩:៣៧–៣៨ ១០:៧–១៦ មក ៦:៧–១១ លក ៩:៣–៥)។ ព្រះគម្ពីរភាសាអង់គ្លេសមួយចំនួនប្រើ ចំនួន៧២នាក់ ប៉ុន្តែ ដោយសារព្រះគម្ពីរច្បាប់ដើមទាំងឡាយបានប្រើចំនួនខុសគ្នា ធ្វើឱ្យចំនួននេះមិនច្បាស់ជាមួយណាឡើយ ។ *មួយគូៗ* កាលបំពេញព្រះរាជកិច្ចនៅស្រុកកាលីឡេ ទ្រង់ក៏បានចាត់ពួកទាំង១២ឱ្យទៅមួយគូៗផងដែរ (៩:១–៦ មក ៦:៧ និងការពន្យល់) ដែលនោះជាគំរូដែលពួកជំនុំដើមដំបូងបានអនុវត្តតាមផងដែរ (កច ១៣:២ ១៥:២៧,

គ្រប់ក្រុង គ្រប់កន្លែងដែលទ្រង់គិតយាងទៅ[ឈ] ២ទ្រង់ក៏មាន
បន្ទូលទៅគេថា ចំរូតធំណាស់ តែមានអ្នកច្រូតតិចទេ
ដូច្នេះ ឱ្យសូមអង្វរដល់ព្រះអម្ចាស់ចំរូត ឱ្យទ្រង់ចាត់អ្នក
ច្រូតមកក្នុងចំរូតទ្រង់[ញ] ៣ទៅចុះ មើល ខ្ញុំប្រើអ្នករាល់គ្នា
ទៅ ដូចជាកូនចៀម នៅកណ្ដាលហ្វូងស្វាន[ដ] ៤កុំឱ្យយក
កាបូប ឬយាម ឬស្បែកជើងឡើយ ក៏កុំឱ្យគំនាប់អ្នកណាតាម
ផ្លូវផង ៥ឯផ្ទះណា ដែលអ្នករាល់គ្នាចូលទៅនោះមុនដំបូង
ត្រូវថា សូមឱ្យផ្ទះនេះបានសេចក្ដីសុខសាន្ត ៦បើនៅផ្ទះនោះ
មានមនុស្សណាចូលចិត្តនឹងសេចក្ដីសុខសាន្ត នោះសេចក្ដី
សុខរបស់អ្នករាល់គ្នា នឹងនៅជាប់នឹងផ្ទះនោះ បើគ្មានទេ
នោះសេចក្ដីសុខនឹងត្រឡប់មកអ្នករាល់គ្នាវិញ ៧ហើយត្រូវ
ស្នាក់នៅផ្ទះនោះឯង ទាំងទទួលបរិភោគរបស់អ្វីៗដែល
គេឱ្យចុះ ពីព្រោះអ្នកដែលធ្វើការនោះគួរនឹងបានឈ្នួល[ឋ]
វិញកុំ ឱ្យផ្លាស់ពីផ្ទះ១ទៅផ្ទះ១ឡើយ ៨ឯភូមិណាដែលអ្នក
រាល់គ្នាចូលទៅ ហើយគេរាក់ទាក់ទទួលនោះឱ្យទទួល
បរិភោគរបស់អ្វីៗ ដែលគេលើក មកឱ្យចុះ[ឌ] ៩ទាំងមើល
ពួកអ្នកឈឺក្នុងភូមិនោះឱ្យជាផង ហើយប្រាប់គេថា នគរ
ព្រះ[ឍ]ជិតមកដល់អ្នករាល់គ្នាហើយ ១០តែភូមិណាដែលអ្នក
រាល់គ្នាចូលទៅ ហើយគេមិនទទួលទេ នោះចូរចេញទៅ
ឯផ្លូវ ហើយនិយាយថា ១១នែ៎ ទោះទាំងធូលីដីក្នុងភូមិអ្នក
រាល់គ្នា ដែលជាប់នៅជើងយើង នោះយើងក៏ជូតចេញ
ទាស់នឹងអ្នករាល់គ្នាដែរ[ណ] ប៉ុន្តែ ត្រូវដឹងសេចក្ដីនេះថា
នគរព្រះជិតដល់ហើយ[ត] ១២ខ្ញុំប្រាប់អ្នករាល់គ្នាថា នៅថ្ងៃ
នោះ ក្រុងសូដុំម[ថ]នឹងទ្រាំបានងាយ ជាជាងភូមិនោះ[ទ]
១៣វេទនាដល់ឯង[ធ] ក្រុងខូរ៉ាស៊ីនអើយ វេទនាដល់ឯង
ក្រុងបេតសៃដាអើយ ពីព្រោះការឫទ្ធិបារមីដែលបានធ្វើ
នៅកណ្ដាលឯង បើបានធ្វើនៅកណ្ដាលក្រុងទីរ៉ុស នឹងស៊ីដូន
វិញ នោះគេនឹងបានប្រែចិត្ត ជាយូរមកហើយ ទាំងស្លៀកសំ
ពត់ធ្មៃ[ន] អង្គុយក្នុងផេះផង ១៤ដូច្នេះ នៅថ្ងៃជំនុំជំរះ ក្រុង
ទីរ៉ុស នឹងស៊ីដូន នឹងទ្រាំបានងាយ ជាជាងឯអ្នករាល់គ្នា
១៥ហើយក្រុងកាពើណិម[ប]អើយ គឺឯងដែលបានដំកើង
ឡើងស្មើស្ថានសួគ៌ហើយ ឯងនឹងត្រូវទំលាក់ទៅដល់ស្ថាន
ឃុំព្រលឹងមនុស្សស្លាប់វិញ ១៦ឯអ្នកណាដែលស្ដាប់អ្នក
រាល់គ្នា នោះឈ្មោះថាស្ដាប់ខ្ញុំ តែអ្នកណាដែលមើលងាយ
អ្នករាល់គ្នា នោះឈ្មោះថាមើលងាយដល់ខ្ញុំ ហើយអ្នកណា
ដែលមើលងាយខ្ញុំ នោះក៏ឈ្មោះថាមើលងាយ ដល់ព្រះ
ដែលចាត់ឱ្យខ្ញុំមកដែរ[ផ] ១៧ពួក៧០នាក់[ព]នោះក៏មកវិញដោយ
អំណរ ហើយទូលថា ព្រះអម្ចាស់អើយ ទោះទាំងពួកអារក្ស
ក៏ចុះចូលចំពោះយើងរាល់គ្នា ដោយព្រះនាមទ្រង់ដែរ[ភ]
១៨នោះទ្រង់មានបន្ទូលទៅគេថា ខ្ញុំបានឃើញអារក្សសា
តាំង[ម]ធ្លាក់ពីលើមេឃ[យ] មកដូចជាផ្លេកបន្ទោរ ១៩មើល ខ្ញុំ

**១០:១** ឈ មថ ១០:១ លក ៧:១៣ លក ៩:១,២,៥១,៥២ មថ ៦:៧
**១០:២** ញ មថ ៩:៣៧,៣៨ យហ ៤:៣៥
**១០:៣** ដ មថ ១០:១៦
**១០:៧** ឋ ១ធថ ៥:១៨
**១០:៨** ឌ ១កថ ១០:២៧
**១០:៩** ឍ មថ ៣:២
**១០:១១** ណ មថ ១០:១៤ ត ខ.៩
**១០:១២** ថ មថ ១០:១៥ ទ មថ ១១:២៤
**១០:១៣** ធ លក ៦:២៤-២៦ ន វវ ១១:៣
**១០:១៥** ប មថ ៤:១៣
**១០:១៦** ផ មថ ១០:៤០
**១០:១៧** ព ខ.១ ភ មក ១៦:១៧
**១០:១៨** ម មថ ៤:១០ យ អស ១៤:១២ វវ ៩:១ ១២:៨,៩

៣៩-៤០ ១៧:១៤ ១៩:២២)។

**១០:៣** *កូនចៀមនៅកណ្ដាលហ្វូងស្វាន* មើល មថ ៧:១៥ ១០:១៦ កច ២០:២៩ ។

**១០:៤** *កុំឱ្យយកកាបូប ឬយាម ឬស្បែកជើងឡើយ* ពួកគេមិនត្រូវផ្ទុកខ្លួនពួកគេឱ្យធ្ងន់ដោយកាបូប(ដាក់ប្រាក់)ឥវ៉ាន់ ឬស្បែកជើង(ស្បែកជើងសង្រែក)បម្រុង(ការពន្យល់ ៩:៣)។ *កុំឱ្យគំនាប់អ្នកណាតាមផ្លូវ* ពួកគេមិនត្រូវឈប់តាមផ្លូវ ដើម្បីសួរសុខទុក្ខ និងធ្វើការវះកិច្ចតាមប្រពៃណី នាំឱ្យយឺតយ៉ាវដល់បេសកកម្មនោះឡើយ ។

**១០:៧** *អ្នកដែលធ្វើការ នោះគួរនឹងបានឈ្នួលវិញ* មើល ១កថ ៩:៣-១២ ១ធថ ៥:១៨ និងពន្យល់ ។ *ផ្លាស់ពីផ្ទះ១ទៅផ្ទះ១* មើលពន្យល់ ៩:៤ ។

**១០:៨,៩** ព្រះយេស៊ូវទ្រង់ប្រទាននូវបញ្ញត្តិពីរ សម្រាប់ឱ្យពួកសិស្សប្រតិបត្តិតាម ក្នុងពេលធ្វើដំណើរ ។ គឺពួកគេត្រូវបរិភោគនូវអាហារដែលគេលើកមកឱ្យ គឺមិនត្រូវរើសឡើយ ហើយពួកគេត្រូវមើលជំងឺផងដែរ ព្រោះការប្រោសជំងឺអាចជួយឱ្យគេព្រមស្ដាប់ដំណឹងល្អបានដែរ ។

**១០:១១** *ធូលីដី . . . ជូតចេញ* មើលការពន្យល់ ៩:៥ ។

**១០:១២** *ក្រុងសូដុំមនឹងទ្រាំបានងាយ* ព្រះទ្រង់បានបំផ្លាញក្រុងសូដុំម ព្រោះក្រុងនេះមានពេញដោយបាប(លប ១៨:២០ និងការពន្យល់ ១៩:២៤-២៨ យដ ៧ និងការពន្យល់) រីឯអស់អ្នកដែលបានឮព្រះបន្ទូលដែលព្រះយេស៊ូវនិងសាវ័កទ្រង់បានប្រកាសទៅនោះ ត្រូវមានការទទួលខុសត្រូវខ្លាំងជាងនោះទៅទៀត ពីព្រោះនោះគឺជាការប្រកាសពីនគរព្រះ។ *នៅថ្ងៃនោះ* គឺថ្ងៃជំនុំជម្រះ ។

**១០:១៣** *ក្រុងខូរ៉ាស៊ីន . . . ក្រុងបេតសៃដា* មើលពន្យល់ មថ ១១:២១ ។ *ស្លៀកសំពត់ធ្មៃ អង្គុយក្នុងផេះ* មើល មថ ១១:២១ វវ ១១:៣ និងពន្យល់ ។

**១០:១៤** *ក្រុងទីរ៉ុស និងស៊ីដូន* ព្រះទ្រង់បានបំផ្លាញក្រុងទាំងពីរ ដោយសារតែសេចក្ដីអាក្រក់(អគ ២៦-២៨)។

**១០:១៥** *ក្រុងកាពើណិម* បន្ទាប់ពីគេបានបណ្ដេញព្រះយេស៊ូវចេញពីស្រុកណាសារ៉ែត(មថ ៤:១៣-១៦ លក ៤:១៦-៣១) ក្រុងកាពើណិមបានក្លាយជាទីតាំងដ៏សំខាន់ចំពោះព្រះរាជកិច្ចរបស់ទ្រង់ ។ មានការឫទ្ធិបារមីជាច្រើនដែលទ្រង់បានធ្វើនៅក្រុងនោះ(មថ ៨:៥,១៤,១៥ ៩:២-៦ ១០:១៧ ១៥:១-២០ មថ ១៥:១-២០ មក ១:៣២-៣៤)។ ការដែលអ្នកក្រុងនេះមិនជឿពីសេចក្ដីប្រកាសរបស់ព្រះយេស៊ូវពីនគរព្រះ គឺជាហេតុដែលនាំឱ្យពួកគេត្រូវទទួលការជំនុំជម្រះខ្លាំងជាងក្រុងដែលមិនបានឮ ។

**១០:១៨,១៩** ព្រះយេស៊ូវទ្រង់ជ្រាបជាមុន ពីជ័យជម្នះលើអារក្សសាតាំងដោយការសុគតលើឈើឆ្កាង(យហ ១២:៣១,៣២)។ម្យ៉ាងទៀតព្រះយេស៊ូវទ្រង់បានព្រមានពួកសិស្សទ្រង់អំពីសេចក្ដីអំនួត ។ ខ.១៨ ប្រហែលជាសំដៅទៅលើ អស ១៤:១២-១៧ (ដែលផ្ដើមឡើងថា"ឱតារាប្រចាំថ្ងៃ ជាផ្កាយ

ឱ្យអ្នករាល់គ្នាមានអំណាចនឹងដើរជាន់ទាំងពស់[រ] នឹង
ខ្យាដំរី ហើយលើគ្រប់ទាំងឥទ្ធិឫទ្ធិរបស់ខ្មាំងសត្រូវផង គ្មាន
អ្វីនឹងធ្វើទុក្ខអ្នករាល់គ្នាឡើយ ២០ប៉ុន្តែកុំឱ្យអរសប្បាយ
ដោយព្រោះអារក្សចុះចូលអ្នករាល់គ្នានោះឡើយ ត្រូវឱ្យ
រីករាយ ដោយព្រោះឈ្មោះអ្នករាល់គ្នាបានកត់ទុក នៅ
ស្ថានសួគ៌វិញ[ល]។
២១នៅវេលានោះឯង ព្រះយេស៊ូវទ្រង់កំពង់តែរីករាយ
ដោយព្រះវិញ្ញាណ ក៏មានបន្ទូលថា ឱព្រះវរបិតាជាព្រះ
អម្ចាស់នៃស្ថានសួគ៌ និងផែនដីអើយ ទូលបង្គំសរសើរ
ដល់ទ្រង់ ពីព្រោះទ្រង់បានលាក់សេចក្តីទាំងនេះ នឹងពួក
អ្នកប្រាជ្ញ ហើយនឹងពួកឈ្លាសវៃ តែបានសំដែងឱ្យពួក
កូនក្មេង[វ]យល់វិញ អើ ព្រះវរបិតាអើយ ដ្បិតទ្រង់បានសព្វ
ព្រះហឫទ័យយ៉ាងដូច្នេះ ២២រួចទ្រង់បែរទៅមានបន្ទូលនឹង
ពួកសិស្សថា គ្រប់សេចក្តីទាំងអស់សុទ្ធតែបានប្រទានមកខ្ញុំ
ពីព្រះវរបិតានៃខ្ញុំ[ស] គ្មានអ្នកណាស្គាល់ព្រះរាជបុត្រាទេ
មានតែព្រះវរបិតាតែ១ ក៏គ្មានអ្នកណាស្គាល់ព្រះវរបិតា
ដែរ មានតែព្រះរាជបុត្រា ហើយនឹងអ្នកណា ដែលព្រះ
រាជបុត្រាសព្វព្រះហឫទ័យ បើកឱ្យស្គាល់ទ្រង់ផងប៉ុណ្ណោះ[ហ]
២៣ទ្រង់ក៏បែរទៅមានបន្ទូលនឹងពួកសិស្សដោយឡែកថា
មានពរហើយ ភ្នែកណាដែលឃើញអស់ទាំងការដែល
អ្នករាល់គ្នាឃើញ ២៤ពីព្រោះខ្ញុំប្រាប់អ្នករាល់គ្នាថា មាន
ហោរានឹងស្តេចជាច្រើនបានប្រាថ្នាចង់ឃើញការដែល

**១០:១៩** រ មក ១៦:១៨ កច ២៨:៣–៥
**១០:២០** ល វវ ២០:១២
**១០:២១** វ ១កថ ១:២៦–២៩
**១០:២២** ស មថ ២៨:១៨ ហ យហ ១:១៨
**១០:២៤** ឡ ១ពត ១:១០–១២
**១០:២៥** អ មថ ១៩:១៦ លក ១៨:១៨
**១០:២៧** ក ចទ ៦:៥ ខ លវ ១៩:១៨ មថ ៥:៤៣
**១០:២៨** គ រម ៧:១០
**១០:២៩** ឃ លក ១៦:១៥
**១០:៣១** ង លវ ២១:១–៣

អ្នករាល់គ្នាឃើញដែរ តែមិនបានឃើញទេ ក៏ចង់ឮសេចក្តី
ដែលអ្នករាល់គ្នាឮដែរ តែមិនបានឮសោះ[ឡ]។

## រឿងប្រៀបប្រដូចពីសាសន៍សាម៉ារីល្អម្នាក់

*១០:២៥–២៨ = មថ ២២:៣៤–៤០ មក ១២:២៨–៣១*

២៥នៅគ្រានោះ មានអ្នកប្រាជ្ញច្បាប់ម្នាក់ឈរឡើងទូល
ល្បងទ្រង់ថា លោកគ្រូ តើត្រូវឱ្យខ្ញុំធ្វើដូចម្តេច ដើម្បីឱ្យ
បានជីវិតអស់កល្បជានិច្ច[អ] ២៦ទ្រង់មានបន្ទូលឆ្លើយថា ក្នុង
ក្រិត្យវិន័យ តើមានកត់ទុកយ៉ាងដូចម្តេចខ្លះ តើអ្នកមើល
យល់ដូចម្តេច
២៧អ្នកនោះទូលថា «ឯងត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃ
ឯង ឱ្យអស់អំពីចិត្ត អស់អំពីព្រលឹង អស់អំពីកំឡាំង ហើយ
អស់អំពីគំនិតឯង[ក] ព្រមទាំងអ្នកជិតខាង ដូចខ្លួនឯងដែរ»[ខ]
២៨ទ្រង់មានបន្ទូលតបថា អ្នកបានឆ្លើយត្រូវហើយ ចូរអ្នក
ធ្វើដូច្នោះចុះ នោះអ្នកនឹងរស់នៅពិត[គ]។
២៩តែអ្នកនោះចង់សំដែងខ្លួនជាអ្នកសុចរិត ក៏ទូលសួរទៀតថា
តើអ្នកណាជាអ្នកជិតខាងខ្ញុំ[ឃ] ៣០ព្រះយេស៊ូវមានបន្ទូលថា
មានមនុស្សម្នាក់កំពុងតែធ្វើដំណើរ ពីក្រុងយេរូសាឡិម
ចុះទៅឯក្រុងយេរីខូរ ក៏ធ្លាក់ខ្លួនទៅក្នុងកណ្តាប់ដៃនៃពួក
ចោរ វាប្លន់គាត់ ព្រមទាំងវាយឱ្យត្រូវរបួស រួចចេញបាត់
ទៅ ចោលគាត់ឱ្យទ្រមនៅ ៣១ចួនជាមានសង្ឃ១អង្គ ចុះ
មកតាមផ្លូវនោះ កាលបានឃើញគាត់ នោះក៏វាងតាមម្ខាង
ហួសទៅ[ង] ៣២ហើយមានពួកលេវីម្នាក់មកដល់កន្លែងនោះ

ព្រឹកអើយ ឯងបានធ្លាក់ចុះមកពីលើមេឃហើយ")។ សេចក្តីអំនួតរបស់អារក្សសាតាំង គឺជាដើមចមនៃគ្រប់ទាំងអំពើអាក្រក់នៅលើផែនដីនេះ ។

**១០:១៩** *ពស់និងខ្យាដំរី . . . ខ្មាំងសត្រូវ* សត្វពស់ និងខ្យាដំរីអាចតំណាងឱ្យវិញ្ញាណអារក្ស និងខ្មាំងសត្រូវដែលជាអារក្សសាតាំង ។

**១០:២០** សេចក្តីសង្គ្រោះ គឺសំខាន់ជាងអំណាចលើវិញ្ញាណអាក្រក់ ឬអំណាចរួចពីការធ្វើទុក្ខរបស់វាទៅទៀត ។ *ឈ្មោះអ្នករាល់គ្នាបានកត់ទុក* (ទដ ៦៩:២៨ និងការពន្យល់ ដយ ១២:១)។

**១០:២១–២២** មើល មថ ១១:២៥–២៧ និងការពន្យល់ ។

**១០:២៣** *ឃើញអស់ទាំងការដែលអ្នករាល់គ្នាឃើញ* គឺឃើញព្រះមែស៊ី និងព្រះរាជកិច្ចសង្គ្រោះរបស់ទ្រង់ ។

**១០:២៥** *អ្នកប្រាជ្ញច្បាប់* គឺអ្នកប្រាជ្ញដែលមានចំណេះដឹងខ្ពង់ខ្ពស់ខាងគម្ពីរ (១៨:១៨ មថ ២២:៣៥)។ ម្នាក់នោះគ្រាន់តែទូលសួរទ្រង់ក្នុងន័យផ្ចាញ់ផ្ចាល ឬល្បងលចំណេះទ្រង់ប៉ុណ្ណោះ (មើលការពន្យល់ ៧:៣០)។

**១០:២៧** *ស្រឡាញ់ព្រះអម្ចាស់ . . .អ្នកជិតខាងដូចខ្លួនឯង* ព្រះយេស៊ូវទ្រង់បានមានបន្ទូលឆ្លើយយ៉ាងដូចនេះ នៅក្នុងបទគម្ពីរដទៃៗទៀត (មើល មថ ២២:៣៥–៤០ មក ១២:២៨–៣១ និងការពន្យល់) ដោយបង្រួមបទគម្ពីរពីរឱ្យត្រឡប់ជាតែមួយ (ចទ ៦:៥ លវ ១៩:១៨)។ ទោះជាការស្រឡាញ់នោះអស់ពីកម្លាំងទាំងបួន (ចិត្ត ព្រលឹង កម្លាំង និងគំនិត ដែលមានក្នុងខនេះ និង មក ១២:៣០) ឬអស់អំពីកម្លាំង ទាំងបីក៏ដោយ (ចទ ៦:៥) ក៏សេចក្តីស្រឡាញ់ដែលពេញលក្ខណៈនោះ គឺតម្រូវឱ្យមានការលះបង់ទាំងស្រុង ។

**១០:២៨** *នឹងរស់នៅ* គឺរស់នៅអស់កល្បជានិច្ច (ខ.២៥)។

**១០:២៩** *ចង់សំដែងខ្លួន* អ្នកប្រាជ្ញច្បាប់ម្នាក់នេះបានដឹងជាមុនពីចម្លើយនៃសំណួរដំបូងរបស់គាត់រួចស្រេចហើយ ដូចនេះដើម្បីធ្វើឱ្យគេជឿជាក់ថាគាត់ជាមនុស្សសុចរិត គាត់ក៏សួរបន្តទៀតថា "តើអ្នកណាជាអ្នកជិតខាងខ្ញុំ?"

**១០:៣០** *ក្រុងយេរីខូរ* ក្រុងនេះស្ថិតនៅចម្ងាយ២៤,១៣៥គម ពីក្រុងយេរូ-សាឡិមនៅប៉ែកពាយ័ព្យ និង ១២,៨៧២ គម ពីទន្លេយ័រដាន់ នៅភាគខាងលិច ។ ផ្លូវសម្រាប់ធ្វើដំណើរនោះ គឺពាសពេញដោយថ្ម និងត្រូវឆ្លងកាត់ប្រទេសសមុទ្រខ្សាច់ទៀតផង ហើយពួកចោរប្លន់មានកន្លែងសម្រាប់ពួនស្ទាក់អ្នកដំណើរដែលគ្មានលទ្ធភាពការពារខ្លួន ។

**១០:៣១–៣៣** *សង្ឃ . . . ពួកលេវី . . . សាសន៍សាម៉ារី* អ្នកដំណើរម្នាក់នេះមិនមែនជាអ្នកដឹកនាំសាសនា ឬអ្នកកាន់សាសនាណាមួយទេ ប៉ុន្តែ គាត់ជាជនបរទេសម្នាក់ដែលគេស្អប់ ។ សាសន៍យូដាបានចាត់ទុកសាសន៍សាម៉ារីថា ជាពួកកូនកាត់ទាំងខាងសាច់ឈាម (មើលការពន្យល់ មថ ១០:៥) និងខាងព្រលឹងវិញ្ញាណ (មើលពន្យល់ យហ ៤:២០,២២)។ សាសន៍សាម៉ារី

ដែរ កាលបានឃើញ ក៏វាងតាមម្ខាងហួសទៅទៀត
៣៣តែមានសាសន៍សាម៉ារីម្នាក់[ច] ដើរដំណើរមកដល់ កាល
បានឃើញហើយ នោះក៏មានចិត្តក្តួលអាណិតដល់គាត់
៣៤ទើបចូលទៅរុំរបួសឱ្យ ព្រមទាំយកប្រេង នឹងស្រា ចាក់
លាប រួចលើកដាក់លើសត្វជាជំនិះរបស់ខ្លួន ដឹកនាំទៅឯ
ផ្ទះសំណាក់ ថែទាំរក្សាគាត់ ៣៥ស្អែកឡើង កាលគាត់រៀប
នឹងចេញទៅនោះក៏យកប្រាក់៤កាក់ ហុចដល់ម្ចាស់ផ្ទះនោះ
ដោយប្រាប់ថា ចូរថែរក្សាអ្នកនេះផង បើចួនជាអ្នកចាយ
លើសពីនេះទៅ នោះដល់ខ្ញុំមកវិញ ខ្ញុំនឹងសងអ្នក
៣៦ដូច្នេះក្នុង៣នាក់នោះ តើអ្នកស្មានថាអ្នកណាជាអ្នកជិត
ខាងនឹងមនុស្សដែលធ្លាក់ទៅក្នុងកណ្តាប់ដៃពួកចោរ នោះ
៣៧អ្នកនោះឆ្លើយថា គឺអ្នក១ដែលមានចិត្តអាណិតដល់គាត់
នោះឯង ដូច្នេះព្រះយេស៊ូវមានបន្ទូលថាទៅចុះ ចូរអ្នកប្រ
ព្រឹត្តបែបយ៉ាងដូច្នោះដែរ ។

**នៅផ្ទះរបស់នាងម៉ាថា និងនាងម៉ារា**

៣៨កាលកំពុងតែនាំគ្នាទៅ នោះទ្រង់យាងចូលទៅក្នុងភូមិ
១ ហើយមានស្ត្រីម្នាក់ឈ្មោះម៉ាថា[ឆ] បានទទួលអញ្ជើញទ្រង់
ទៅក្នុងផ្ទះ ៣៩នាងមានប្អូនស្រី១ឈ្មោះម៉ារា[ជ] នាងនោះបាន
អង្គុយស្តាប់ព្រះបន្ទូលនៅទៀបព្រះបាទព្រះអម្ចាស់[ឈ]
៤០ឯម៉ាថា នាងមានការរវល់ជាច្រើនក៏ចូលមកទូលថា
ព្រះអម្ចាស់អើយ តើទ្រង់មិនគិតឃើញថា ប្អូនខ្ញុំម្ចាស់ វា
ទុកខ្ញុំម្ចាស់ ឱ្យខ្វល់ខ្វាយ[ញ]បំរើតែម្នាក់ឯងទេឬអី សូមទ្រង់
ប្រាប់ឱ្យវាមកជួយខ្ញុំម្ចាស់ផង ៤១ប៉ុន្តែព្រះយេស៊ូវមានបន្ទូល
ឆ្លើយថា ម៉ាថាៗអើយ នាងព្រួយចិត្តខំប្រឹង[ដ]រៀបចំធ្វើអី
ច្រើនម្ល៉េះ ៤២មានសេចក្តីតែ១ទេ ដែលសំរាប់ត្រូវការ[ឋ]
ឯម៉ារា នាងបានរើសចំណែកយ៉ាងល្អ ដែលមិនត្រូវយក
ចេញពីនាងឡើយ។

**ព្រះយេស៊ូវបង្រៀនពីសេចក្តីអធិស្ឋាន**

*១១:២–៤ = មថ ៦:៩–១៣*

*១១:៩–១៣ = មថ ៧:៧–១១*

**១១** ១ក្រោយមក កាលទ្រង់កំពុងតែអធិស្ឋាន[ឌ] នៅកន្លែង
១លុះទ្រង់ឈប់ហើយ នោះសិស្សម្នាក់ទូលថា ព្រះអម្ចាស់
អើយ[ឍ] សូមទ្រង់បង្រៀនយើងខ្ញុំ ឱ្យចេះអធិស្ឋានផង ដូច
ជាលោកយ៉ូហានបានបង្រៀនដល់សិស្សលោកដែរ ២ទ្រង់ក៏
មានបន្ទូលទៅគេថា កាលណាអ្នករាល់គ្នាអធិស្ឋាន នោះត្រូវ
ថា ឱព្រះវរបិតា[ណ]នៃយើងខ្ញុំដែលគង់នៅស្ថានសួគ៌អើយ
សូមឱ្យព្រះនាមទ្រង់បានបរិសុទ្ធ សូមឱ្យរាជទ្រង់បានមក
ដល់ សូមឱ្យព្រះហឫទ័យទ្រង់បានសំរេចនៅផែនដី ដូចនៅ
ស្ថានសួគ៌ដែរ ៣សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការ
មកជារៀងរាល់ថ្ងៃ ៤សូមអត់ទោសបាបយើងខ្ញុំ ដ្បិតយើង
ខ្ញុំក៏អត់ទោសដល់ អស់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ[ត]
ហើយសូមកុំនាំយើងខ្ញុំទៅក្នុងសេចក្តីល្បួងឡើយ តែសូម
ប្រោសឱ្យយើងខ្ញុំ បានរួចពីសេចក្តីអាក្រក់វិញ[ថ]។
៥ទ្រង់ក៏មានបន្ទូលទៅគេថា ក្នុងពួកអ្នករាល់គ្នា បើអ្នក
ណាមានមិត្រសំឡាញ់ម្នាក់ ហើយទៅនិយាយនឹងអ្នកនោះ
ទាំងពាក់កណ្តាលអាធ្រាត្រថាសំឡាញ់អើយ សូមឱ្យអញ

**១០:៣៣** ច មថ ១០:៥
**១០:៣៨** ឆ យហ ១១:១ ១២:២
**១០:៣៩** ជ យហ ១១:១ ១២:៣ ឈ លក ៨:៣៥
**១០:៤០** ញ មក ៤:៣៨
**១០:៤១** ដ មថ ៦:២៥–៣៤ លក ១២:១១,២២
**១០:៤២** ឋ ទដ ២៧:៤
**១១:១** ឌ លក ៣:២១ ឍ យហ ១៣:១៣
**១១:២** ណ មថ ៣:២
**១១:៤** ត មថ ១៨:៣៥ មក ១១:២៥ ថ មថ ២៦:៤១ យក ១:១៣

និងសាសន៍យូដាបានបង្ហាញពីការស្អប់ខ្ពើម ចំពោះគ្នាទៅវិញទៅមកជារបៀបបើកចំហ (មើលពន្យល់ ៩:៥២) ប៉ុន្តែ ព្រះយេស៊ូវទ្រង់បានបង្រៀនថា សេចក្តីស្រឡាញ់មិនប្រកាន់ខ្សែបន្ទាត់ព្រំដែននៃជាតិសាសន៍ឡើយ ។

**១០:៣៤** ខនេះបង្ហាញពី "ការស្រឡាញ់អ្នកជិតខាងខ្លួន" (ខ.២៧) ។ *ប្រេង និងស្រា* គេប្រើសម្រាប់ព្យាបាលរបួស (អស ១:៦ មក ៦:១៣ យក ៥:១៤ និងការពន្យល់) ។

**១០:៣៥** *ប្រាក់បួនកាក់* គឺស្មើនឹងប្រាក់ឈ្នួលពីរថ្ងៃ ដែលអាចឱ្យបុរសរងគ្រោះម្នាក់នេះ បន្តស្នាក់នៅក្នុងផ្ទះសំណាក់បានរហូតដល់ពីរខែ ។

**១០:៣៦** *អ្នកណាជាអ្នកជិតខាងនឹងមនុស្ស ដែលធ្លាក់ . . .* គឺមានន័យថា តើអ្នកណាដែលបានធ្វើខ្លួនជាអ្នកជិតខាងដ៏ល្អនឹងបុរសដែលធ្លាក់ទៅក្នុងកណ្តាប់ដៃពួកចោរ នោះ ?

**១០:៣៨** *ភូមិ១* គឺភូមិបេថានី ដែលនៅឆ្ងាយពីក្រុងយេរូសាឡិមប្រមាណជា ៣គម និងជាទីតាំងរបស់ផ្ទះនាងម៉ារា និងនាងម៉ាថា (យហ ១២:១–៣ និងការពន្យល់ មក ២១:១៧) ។

**១១:១** *កាលទ្រង់កំពុងតែអធិស្ឋាន* ព្រះយេស៊ូវទ្រង់អធិស្ឋានក្នុងឱកាសពិសេសៗ (បុណ្យជ្រមុជទឹក ៣:២១ និងការពន្យល់ ការជ្រើសរើសសាវ័កទាំង ១២ នាក់ ៦:១២ នៅច្បារគែតសេម៉ានី ២២:៤១) ហើយនោះថែមទាំងជាទម្លាប់របស់ទ្រង់ផងដែរ (៥:១៦ មថ ១៤:២៣ មក ១:៣៥ សូមមើលសេចក្តីផ្តើមត្រង់ចំណុចចរិតលក្ខណៈ) ។ *បង្រៀនយើងខ្ញុំ ឱ្យចេះអធិស្ឋាន* ព្រះយេស៊ូវទ្រង់បានប្រទាននូវគំរូសេចក្តីអធិស្ឋានដល់ពួកសិស្ស ដើម្បីឆ្លើយតបតាមការទូលសូមរបស់ពួកគេ ។ សេចក្តីអធិស្ឋាននោះមានលក្ខណៈដូចគ្នានឹងផ្នែកមួយនៃសេចក្តីបង្រៀនរបស់ទ្រង់ក្នុង មថ ៦:៩–១៣ ។ ក្នុងកណ្ឌគម្ពីរម៉ាថាយ សេចក្តីអធិស្ឋានមានសេចក្តីសំណូមចំនួនប្រាំមួយ ហើយនៅក្នុងព្រះគម្ពីរលូកាមានសេចក្តីសំណូមចំនួនប្រាំ ។

**១១:៤** *សូមអត់ទោសបាបយើងខ្ញុំ* មថ ៦:១២ បានប្រើពាក្យ "សេចក្តីកំហុស" ប៉ុន្តែ អត្ថន័យគឺដូចគ្នានឹងពាក្យ "ទោសបាប" ផងដែរ ។ ព្រះយេស៊ូវទ្រង់ក៏បានបង្រៀនពីសេចក្តីពិតនេះ នៅក្នុងឱកាសផ្សេងទៀតផងដែរ (មថ ១៨:៣៥ មក ១១:២៥ អភ ៤:៣២ និងការពន្យល់) ។

**១១:៥–១៣** ក្នុងបទគម្ពីរនេះ សេចក្តីបង្រៀនរបស់ព្រះយេស៊ូវ គឺបានជំរុញទឹកចិត្តឱ្យអធិស្ឋានដោយទទូចអង្វរ (ខ.៥–៨) និងបានផ្តល់នូវការធានាមួយ

ខ្ញុំនំបុ័ង៣ដុំសិន ៦ដ្បិតមានសំឡាញ់អញម្នាក់មានដំណើរ
មកឯផ្ទះ អញគ្មានអ្វីទទួលគេសោះ ។
៧តែអ្នកនោះនឹងឆ្លើយពីក្នុងផ្ទះមកថា កុំមករំខានចិត្តអញ
អី ព្រោះទ្វារបិទហើយ កូនអញក៏ដេកនៅគ្រែជាមួយនឹង
អញផង អញក្រោកទៅយកឱ្យឯងពុំបានទេ ៨ខ្ញុំប្រាប់អ្នក
រាល់គ្នាថា ទោះបើអ្នកនោះមិនក្រោកឡើង យកទៅឱ្យ
ដោយព្រោះជាសំឡាញ់ក៏ដោយ គង់តែនឹងក្រោឡើងយក
ឱ្យតាមអ្នកនោះត្រូវការជាមិនខាន ដោយព្រោះអ្នកនោះ
ចេះតែទទូចអង្វរជានិច្ច[ទ] ៩បានជាខ្ញុំប្រាប់អ្នករាល់គ្នាថា
ចូរសូមនោះតែងនឹង ឱ្យមកអ្នក[ធ] ចូររកនោះតែងនឹងឃើញ
ចូរគោះនោះ តែងនឹងបើកឱ្យអ្នក ១០ដ្បិតអស់អ្នកដែលសូម
នោះរមែងបាន អ្នកណាដែលរក នោះរមែងឃើញ ក៏
បើកឱ្យអ្នកណា ដែលគោះដែរ ១១ឯអ្នករាល់គ្នាដែលជាឪ
ពុក បើកូនសូមនំបុ័ង តើអ្នកណានឹងឱ្យថ្មទៅវា ឬបើសូមត្រី
តើនឹងឱ្យពស់វិញឬ ១២បើវាសូមពងមាន់ តើនឹងឱ្យខ្យាដំរី
ឬអី ១៣បើអ្នករាល់គ្នាដែលជាមនុស្សអាក្រក់ អ្នកចេះឱ្យ
របស់ល្អទៅកូនយ៉ាងដូច្នេះ នោះចំណង់បើព្រះវរបិតា
ដែលគង់ស្ថានសួគ៌ តើទ្រង់នឹងប្រទានព្រះវិញ្ញាណបរិសុទ្ធ
មកអស់អ្នកដែលសូម ជាជាងអម្បាលម៉ានទៅទៀត ។

## ព្រះយេស៊ូវ និងមេអារក្សបេលសេប៊ូល

*១១:១៤,១៥,១៧–២២,២៤–២៦ = មថ ១២:២២,២៤–២៩,៤៣–៤៥*

**១១:៨** ទ លក ១៨:១–៦
**១១:៩** ធ មថ ៧:៧
**១១:១៤** ន មថ ៩:៣២,៣៣
**១១:១៥** ប មក ៣:២២ ផ មថ ៩:៣៤
**១១:១៦** ព មថ ១២:៣៨
**១១:១៧** ភ មថ ៩:៤
**១១:១៨** ម មថ ៤:១០
**១១:២០** យ នក ៨:១៩ រ មថ ៣:២

*១១:១៧–២២ = មក ៣:២៣–២៧*

១៤គ្រានោះទ្រង់កំពុងតែដេញអារក្សគពីមនុស្សម្នាក់ កាល
វាបានចេញទៅបាត់ហើយ នោះមនុស្សគក៏និយាយឡើង
បាន ហើយបណ្ដាមនុស្សគេកើតមានសេចក្ដីអស្ចារ្យ[ន] ១៥តែ
ខ្លះនិយាយថា អ្នកនេះដេញអារក្សដោយសារតែបេលសេ
ប៊ូល[ប]ជាមេអារក្សទេ[ផ] ១៦អ្នកខ្លះទៀតល្បងទ្រង់ ដោយសូម
ទីសំគាល់១មកពីលើមេឃ[ព] ១៧តែទ្រង់ជ្រាបគំនិតគេ[ភ]ក៏
មានបន្ទូលថា អស់ទាំងនគរណា ដែលបែកខ្ញែកទាស់តែ
គ្នាឯង នោះនឹងត្រូវវិនាសទៅហើយផ្ទះណាដែលទាស់ទែង
គ្នាឯង នោះនឹងត្រូវរលំទៅជាមិនខាន ១៨បើសាតាំង[ម]បែក
ទាស់គ្នាវាហើយ នោះធ្វើដូចម្ដេច ឱ្យនគរវានៅស្ថិតស្ថេរ
បាន នេះព្រោះដ្បិត អ្នករាល់គ្នាថា ខ្ញុំដេញអារក្ស ដោយ
អាងបេលសេប៊ូល ១៩បើសិនជាខ្ញុំដេញអារក្ស ដោយអាង
បេលសេប៊ូលមែន នោះតើកូនចៅអ្នករាល់គ្នាដេញវា
ដោយសារអ្វីវិញ ដូច្នេះ វារាល់គ្នានឹងធ្វើជាចៅក្រមជំនុំជំ
រះអ្នករាល់គ្នាហើយ ២០ប៉ុន្តែ បើខ្ញុំដេញអារក្ស ដោយសារ
អង្គុលីព្រះហស្តនៃព្រះវិញ[យ] នោះច្បាស់ជានគរព្រះ[រ]បាន
មកដល់អ្នករាល់គ្នាហើយ ២១កាលណាមនុស្សខ្លាំងពូកែ
កាន់គ្រឿងអាវុធ ប្រុងប្រៀបនឹងការពារផ្ទះរបស់ខ្លួន នោះ
ទ្រព្យសម្បត្តិក៏បានគង់វង់នៅ ២២តែបើមានមនុស្សខ្លាំង
ជាង មកបង្ក្រាបឱ្យឈ្នះគាត់កាលណា នោះក៏ដណ្ដើមយក

ចំពោះការឆ្លើយតបរបស់ព្រះចំពោះសេចក្ដីអធិស្ឋាន (ខ.៩–១៣) ។ ក្នុងចំណោមអំណោយទានសំខាន់បំផុត គឺមានព្រះវិញ្ញាណបរិសុទ្ធ (កច ២:១–៤) ដែលព្រះយេស៊ូវទ្រង់បានសន្យាប្រទានឱ្យដល់គ្រប់អ្នកជឿ បន្ទាប់ពីទ្រង់សុគត និងរស់ឡើងវិញ ហើយយាងត្រឡប់ទៅឯស្ថានសួគ៌របស់ទ្រង់វិញ (យហ ១៥:២៦) ។

**១១:១៣** *ប្រទានព្រះវិញ្ញាណបរិសុទ្ធ* មថ ៧:១១ បានប្រើពាក្យ "ប្រទានរបស់ល្អ" គឺមានន័យថា"អំណោយទានខាងវិញ្ញាណ"។ព្រះគម្ពីរលូកាសង្កត់ធ្ងន់លើ "ព្រះរាជកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធ" ហើយព្រះវិញ្ញាណបរិសុទ្ធជាអំណោយទានមួយក្នុងចំណោមអំណោយទានដែលសំខាន់បំផុតនៃព្រះ ។

**១១:១៤** *អារក្សគ* មើលពន្យល់ ៤:៣៣ ។ អារក្សប្រភេទនេះមានអំណាចធ្វើឱ្យមនុស្សគ ។ នៅក្នុងព្រះគម្ពីរម៉ាថាយ (មថ ១២:២២–៣០ និង មក ៣:២០–២៧) បទគម្ពីរដែលមានលក្ខណៈដូចខនេះបានបង្ហាញថា បុរសម្នាក់នេះមិនមែនគតែម្យ៉ាងនោះទេ ប៉ុន្តែ ថែមទាំងមានជំងឺខ្វាក់ផងដែរ ។

**១១:១៥** *បេលសេប៊ូល ជាមេអារក្ស* បេលសេប៊ូលគឺសាតាំង (ខ.១៨ មើលការពន្យល់ មថ ១០:២៥) ។

**១១:១៦** *ទីសំគាល់១មកពីលើមេឃ* ព្រះយេស៊ូវទ្រង់ទើបតែបានប្រោសមនុស្សគម្នាក់ឱ្យជា ដែលនោះជាទីសំគាល់សម្រាប់ពួកគេហើយ តែពួកគេមិនអាចស្គាល់ថា ការនេះជាការអ្វីទេ (មក ៨:១១ និងការពន្យល់) ។

**១១:១៧** *នគរណាដែលបែកខ្ញែកទាស់តែគ្នាឯង* ព្រះយេស៊ូវទ្រង់ទាស់ប្រឆាំងនឹងអារក្សនៅក្នុងគ្រប់ទាំងផ្លូវ ដូចនេះប្រសិនបើសាតាំងថ្វាយអំណាចដល់ព្រះយេស៊ូវ នោះវាកំពុងតែជួយគាំទ្រការវាយប្រហារមកលើខ្លួនវាហើយ ។

**១១:១៩** *តើកូនចៅអ្នករាល់គ្នាដេញវា ដោយសារអ្វីវិញ* ព្រះយេស៊ូវទ្រង់មិនបានមានបន្ទូលថាតើកូនចៅរបស់ពួកផារិស៊ី (មថ ១២:២៤) ពិតជាបានដេញអារក្ស ឬអត់នោះទេ (មើលការពន្យល់ ខ.២៤) ប៉ុន្តែ ពួកនេះបានអះអាងថា ពួកគេបានដេញអារក្ស ដោយសារអំណាចព្រះអម្ចាស់ ហើយព្រះយេស៊ូវបានមានបន្ទូលយ៉ាងដូច្នោះផងដែរ ។ ដូចនេះការដែលពួកគេចោទប្រកាន់ថា ព្រះយេស៊ូវទ្រង់បានប្រើអំណាចអារក្សសាតាំង គឺដូចជាពួកគេបានថ្កោលទោសកូនចៅខ្លួនឯងចំៗផងដែរ ។ *វារាល់គ្នានឹងធ្វើជាចៅក្រមជំនុំជំរះអ្នករាល់គ្នា* មានន័យថាកូនចៅរបស់ពួកផារិស៊ីនឹងថ្កោលទោសពួកផារិស៊ី ដោយព្រោះពាក្យចោទប្រកាន់មកលើកូនចៅរបស់ខ្លួនឯងនេះ ។

**១១:២០** *នគរព្រះបានមកដល់អ្នករាល់គ្នា* គឺមានន័យថា នគរព្រះមានព្រះវត្តមាននៅក្នុងអង្គព្រះយេស៊ូវ (មើលការពន្យល់ ៤:៤៣ ១៧:២១) ហើយអំណាចនៃសេចក្ដីអាក្រក់កំពុងតែត្រូវបានផ្ដួលរំលំហើយ ។

**១១:២២** *មនុស្សខ្លាំងជាង* ព្រះយេស៊ូវមានអំណាចខ្លាំងជាងបេលសេប៊ូល

អស់ទាំងគ្រឿងអាវុធ ដែលគាត់ទុកចិត្តនោះចេញ រួចប្លន់
យករបឹបទៅចែកគ្នាវិញ ២៣អ្នកណាដែលមិននៅខាង
ខ្ញុំ អ្នកនោះគឺទាស់នឹងខ្ញុំ ហើយអ្នកណាដែលមិនប្រមូល
មកខាងខ្ញុំ អ្នកនោះឈ្មោះថាជាអ្នកកំចាត់កំចាយវិញ[ល]
២៤កាលណាអារក្សអសោចិ៍បានចេញពីមនុស្សណា នោះ
វាដើរកាត់កន្លែងហួតហែង ទៅរកទីឈប់សំរាក តែដោយ
រកមិនបានសោះ បានជាវាគិតថាអញនឹងត្រឡប់ទៅឯផ្ទះ
អញវិញ ដែលទើបនឹងចេញមកនោះ ២៥រួចកាលណាវា
មកដល់ ឃើញផ្ទះបោសស្អាត ហើយបានតុបតែងយ៉ាងល្អ
២៦នោះវាក៏ចេញទៅនាំយកអារក្ស៧ទៀត ដែលកាចៗ
ជាងវា ចូលទៅនៅទីនោះផង ហើយសណ្ឋានក្រោយរបស់
មនុស្សនោះក៏រឹងរិតតែអាក្រក់ជាងមុនទៅទៀត[វ] ។
២៧កាលទ្រង់កំពុងតែមានបន្ទូលសេចក្តីទាំងនេះនៅឡើយ
នោះមានស្ត្រីម្នាក់ស្រែកឡើងពីក្នុងហ្វូងមនុស្សថា មានពរ
ហើយ ផ្ទៃណាដែលបានរក្សាលោក ហើយដោះណាដែល
លោកបានបៅ[ស] ២៨តែទ្រង់មានបន្ទូលតបថា ស៊ូថាដូច្នេះ
វិញ មានពរហើយ អស់អ្នកដែលស្តាប់ព្រះបន្ទូល[ហ] ហើយ
កាន់តាម [ឡ]។

**១១:២៣** ល មថ ១២:៣០ មក ៩:៤០ លក ៩:៥០
**១១:២៦** វ ២ពត ២:២០
**១១:២៧** ស លក ២៣:២៩
**១១:២៨** ហ ហត ៤:១២ ឡ សក ៨:៣២ លក ៦:៤៧ ៨:២១ យហ ១៤:២១
**១១:២៩** អ ខ.១៦ មថ ១២:៣៨ ក យណ ១:១៧ មថ ១៦:៤

## ទីសំគាល់ពីលោកយ៉ូណាស

*១១:២៩-៣២ = មថ ១២:៣៩-៤២*

២៩កាលណោះ មានមនុស្សប្រជុំគ្នាតាន់តាប់ជាខ្លាំង ហើយ
ទ្រង់ចាប់តាំងមានបន្ទូលថា មនុស្សដំណនេះអាក្រក់ណាស់
គេរកតែទីសំគាល់[អ]ទេ តែគ្មានទីសំគាល់ណានឹងបាន
ប្រទានមកគេ ក្រៅពីទីសំគាល់នៃហោរាយ៉ូណាសឡើយ[ក]
៣០ពីព្រោះ ដូចជាលោកយ៉ូណាសជាទីសំគាល់ដល់មនុស្ស
នៅក្រុងនីនីវេយ៉ាងណា នោះកូនមនុស្សក៏នឹងបានជាទី
សំគាល់ដល់មនុស្សដំណនេះយ៉ាងដូច្នេះដែរ ៣១នៅថ្ងៃជំនុំ
ជំរះមហាក្សត្រីស្រុកខាងត្បូង នឹងឈរឡើងជំនុំជំរះមនុស្ស
ដំណនេះ ហើយនឹងកាត់ទោសឱ្យផង ពីព្រោះព្រះនាងបាន
យាងមកពីចុងផែនដី ដើម្បីនឹងស្តាប់ចំណេះហ្លួងសាឡូម៉ូន[ខ]
ហើយមើលនៅទីនេះមាន១អង្គដ៏វិសេសលើស ជាងហ្លួង
សាឡូម៉ូនទៅទៀត ៣២នៅថ្ងៃជំនុំជំរះមនុស្សនៅក្រុងនីនីវេ
នឹងឈរឡើងជំនុំជំរះមនុស្សដំណនេះ ហើយនឹងកាត់ទោស
ឱ្យផង ពីព្រោះគេបានប្រែចិត្តដោយសារពាក្យ លោក
យ៉ូណាសប្រដៅ[គ] ហើយមើលនៅទីនេះមាន១អង្គដ៏វិសេស
លើសជាងលោកយ៉ូណាសទៅទៀត ។

**១១:៣១** ខ ១ពវ ១០:១ ២ រប ៩:១ **១១:៣២** គ យណ ៣:៥

ហើយតាមរយៈការដែលទ្រង់បណ្តេញវិញ្ញាណអាក្រក់ ទ្រង់បានបង្ហាញថា ទ្រង់មានអំណាចលើសាតាំង ហើយទ្រង់ក៏អាចដកហូតអំណាច ឬកម្លាំងពីវាបានដែរ ដូចនេះ ការដែលយល់ថាព្រះយេស៊ូវទ្រង់ដេញអារក្ស ដោយអំណាចសាតាំង គឺពិតជាទស្សនៈមួយដ៏ល្ងីល្ងើ ហើយខុសឆ្គងបំផុត ។

**១១:២៣** អ្នកណាដែលមិនកាន់ខាងព្រះយេស៊ូវ គឺបានទាស់ប្រឆាំងនឹងទ្រង់ ហើយដូចនេះការដែលនៅជាអព្យាក្រឹត ដោយមិនកាន់ទាំងខាងព្រះ និងខាងអារក្ស គឺមិនអាចទៅរួចឡើយ(មើលការពន្យល់ មថ ១២:៣០)។ សូម្បីតែអ្នកធ្វើការក្នុង៩:៥០ ដែលពួកសាវ័កបានបកស្រាយថា "គាត់មិនតាមពួកគេ"(៩:៤៩) ក៏ជាអ្នកដែលគេជឿថាជាអ្នកជឿដែលធ្វើការក្នុងព្រះនាមព្រះយេស៊ូវផងដែរ (មើលពន្យល់ មក ៩:៣៨) ហើយព្រះយេស៊ូវទ្រង់ក៏មិនបានថ្កោលទោសបុរសម្នាក់នោះឡើយ ។

**១១:២៤** *អារក្សអាសោចិ៍បានចេញ* ព្រះយេស៊ូវទ្រង់ប្រហែលជាមានបន្ទូលសំដៅទៅលើការងារដេញអារក្សរបស់ពួកសាសន៍យូដា ដែលអះអាងថាបានដេញអារក្ស(ខ.១៩ និងការពន្យល់) តែបានបដិសេធនគរព្រះ ហេតុដូចនេះហើយបានជាការដេញអារក្សរបស់ពួកគេ គ្មានប្រសិទ្ធភាពអ្វីទាល់តែសោះ ។ សូមមើល មថ ១២:៤៣-៤៥ ជាវគ្គដែលព្រះយេស៊ូវមានបន្ទូលដូចគ្នាពីសណ្ឋានរបស់ជាតិសាសន៍យូដាក្នុងសម័យនោះ ។

**១១:២៥** *ផ្ទះបោសស្អាត* គឺមានន័យថាផ្ទះនោះបានបោសសំអាតស្អាតហើយ ប៉ុន្តែ គ្មានម្ចាស់នៅគ្រប់គ្រងទេ ។ ជីវិតដែលត្រូវបានសំអាតហើយ ប៉ុន្តែ បើគ្មានព្រះវត្តមាន និងព្រះចេស្តាព្រះសណ្ឋិតនៅក្នុងជីវិតនោះទេ នោះនឹងបើកឱកាសឱ្យអារក្សចូលមកគ្រប់គ្រងលើជីវិតនោះសារជាថ្មីជាមិនខាន ។

**១១:២៨** *មានពរហើយ* ព្រះយេស៊ូវទ្រង់មិនមែនកំពុងបដិសេធការមានពររបស់នាងម៉ារាទេ ប៉ុន្តែ ទ្រង់កំពុងសង្កត់ធ្ងន់ថាអ្នកដើរតាមទ្រង់នឹងមានពរជាង ។

**១១:២៩** *រកតែទីសំគាល់* មានច្រើនដងមកហើយដែលពួកសាសន៍យូដាបានទូលសូមទីសំគាល់(ខ.១៦ មថ ១២:៣៨ មក ៨:១១ និងការពន្យល់) ប៉ុន្តែព្រះយេស៊ូវបានបដិសេធការទូលសូមរបស់ពួកគេពីព្រោះពួកគេមានបំណងអាក្រក់ ។

**១១:៣០** *ដូចជាលោកយ៉ូណាសជាទីសំគាល់* លោកយ៉ូណាសបាននៅក្នុងពោះត្រីធំអស់បីថ្ងៃបីយប់(មថ ១២:៤០ និងពន្យល់ )យ៉ាងណា ព្រះយេស៊ូវទ្រង់ក៏នឹងនៅក្នុងផ្ទៃផែនដី៣ថ្ងៃបីយប់យ៉ាងនោះដែរ មុនដែលទ្រង់មានព្រះជន្មរស់ឡើងវិញ ។

**១១:៣១-៣២** អ្នកក្រុងនីនីវេ និងក្សត្រីស្រុកខាងត្បូងបានបែរមកព្រះ តាមរយៈការប្រកាសឱ្យប្រែចិត្ត ដែលមិនអាចប្រៀបផ្ទឹមនឹងការប្រកាសរបស់ព្រះយេស៊ូវដល់អ្នកដែលស្តាប់ទ្រង់បានឡើយ ហើយក៏មិនអាចផ្ទឹមនឹងការប្រកាសដែលមនុស្សយើងបានទទួលក្នុងសម័យនេះដែរ ។ គ្រីស្ទបរិស័ទគឺជាស្មរបន្ទាល់ពីសេចក្តីដែលព្រះគ្រីស្ទទ្រង់រស់ឡើងវិញ ពីអំណាចព្រះវិញ្ញាណដែលបានបញ្ជូនមកនៅថ្ងៃបុណ្យទី៥០ ពីការមានឱកាសទទួលព្រះគម្ពីរបរិសុទ្ធបានដោយងាយ និងពីការយល់ដឹងពីព្រះរាជកិច្ច ដែលព្រះគ្រីស្ទទ្រង់បានធ្វើតាមរយៈពួកជំនុំរបស់ទ្រង់ ។

**១១:៣១** *មហាក្សត្រីស្រុកខាងត្បូង* គឺមហាក្សត្រីស្រុកសេបា(១ពវ ១០:១-១០ និងការពន្យល់)។

## ចង្កៀងរបស់រូបកាយ

*១១:៣៤–៣៥ = មថ ៦:២២,២៣*

៣៣គ្មានអ្នកណាដែលអុជចង្កៀង យកទៅដាក់នៅទីកំបាំង
ឬគ្របនឹងថាំងឡើយ គេតែងដាក់លើជើងចង្កៀងវិញ ដើម្បី
ឱ្យអស់អ្នកដែលចូលបានឃើញពន្លឺភ្លឺ[ឃ] ៣៤ឯចង្កៀងរូបកាយ
គឺជាភ្នែក ដូច្នេះកាលណាភ្នែកអ្នកល្អ នោះរូបកាយអ្នក
ទាំងមូលនឹងបានភ្លឺដែរ តែកាលណាភ្នែកអាក្រក់ នោះរូប
កាយអ្នកនឹងងងឹតវិញ ៣៥ដូច្នេះ ចូរប្រយ័ត្ន ក្រែងមានពន្លឺ
ដែលនៅក្នុងខ្លួនអ្នកជាសេចក្ដីងងឹតវិញ ៣៦បើសិនជារូប
កាយអ្នកទាំងមូលបានភ្លឺ ឥតមានងងឹតត្រង់ណាសោះ នោះ
នឹងបានភ្លឺទាំអស់ដូចកាលចង្កៀងបំភ្លឺអ្នកដែរ។

## សេចក្ដីវេទនាដល់មនុស្សពុតត្បុត

៣៧កាលទ្រង់កំពុងតែមានបន្ទូលនៅឡើយ នោះមានពួក
ផារិស៊ីម្នាក់ទូលសូមទ្រង់ឱ្យយាងទៅសោយជាមួយ ទ្រង់ក៏
យាងចូលទៅគង់នៅតុ[ង] ៣៨កាលអ្នកផារិស៊ីនោះបាន ឃើញ
ក៏នឹកប្លែកណាស់ ដែលទ្រង់មិនបានលាងព្រះហស្ដមុន
នឹងសោយ[ច] ៣៩ប៉ុន្តែ ព្រះអម្ចាស់[ឆ] មានបន្ទូលទៅគាត់ថា
ឯអ្នករាល់គ្នាជាពួកផារិស៊ី អ្នករាល់គ្នាលាងចានលាង
ថាស តែខាងក្រៅទេ តែចំណែកខាងក្នុងរបស់អ្នករាល់គ្នា
មានពេញដោយការឆស៊ី នឹងអំពើអាក្រក់វិញ[ជ] ៤០ឱមនុស្ស
ល្ងីល្ងើអើយ[ឈ] ព្រះដែលបង្កើតខាងក្រៅ តើមិនបានបង្កើត
ខាងក្នុងដែរទេឬអី ៤១ត្រូវឱ្យទាន[ញ]ពីរបស់ដែលនៅខាង
ក្នុងវិញ នោះគ្រប់ទាំងអស់នឹងស្អាតដល់អ្នករាល់គ្នា[ដ]។
៤២តែវេទនាដល់អ្នករាល់គ្នា ពួកផារិស៊ីអើយ ដ្បិតអ្នក
រាល់គ្នា តែងថ្វាយ១ភាគក្នុង១០[ឋ]ទាំងជីរអង្កាម ជីរលីង
លាក់ នឹងបន្លែគ្រប់មុខ តែលះចោលសេចក្ដីយុត្តិធម៌ នឹង
សេចក្ដីស្រឡាញ់នៃព្រះវិញ[ឌ] គួរតែឱ្យអ្នករាល់គ្នាបាន
ប្រព្រឹត្តសេចក្ដីទាំងនេះវិញ ហើយឥតចោលការខាងដើម
នោះផង[ឍ] ៤៣វេទនាដល់អ្នករាល់គ្នា ពួកផារិស៊ីអើយ
ដ្បិតអ្នករាល់ គ្នាចូលចិត្តនឹងកន្លែងមុខគេក្នុងសាលាប្រជុំ
ហើយឱ្យគេ គំនាប់ខ្លួននៅទីផ្សារ[ណ] ៤៤វេទនាដល់អ្នករាល់
គ្នា ពួកអាចារ្យ នឹងពួកផារិស៊ីជាអ្នកមានពុតអើយ ដ្បិតអ្នក
រាល់គ្នាដូចជាផ្នូរខ្មោច[ត]ដែលមើលមិនឃើញ ហើយមនុស្ស
ដើរជាន់ឥតដឹងទេ។

**១១:៣៣** ឃ មថ ៥:១៥
**១១:៣៧** ង លក ៧:៣៦ ១៤:១
**១១:៣៨** ច មក ៧:៣,៤
**១១:៣៩** ឆ លក ៧:១៣
ជ មថ ២៣:២៥,២៦ មក ៧:២០–២៣
**១១:៤០** ឈ លក ១២:២០ ១កថ ១៥:៣៦
**១១:៤១** ញ លក ១២:៣៣ ដ កច ១០:១៥
**១១:៤២** ឋ លក ១៨:១២ ឌ ចទ ៦:៥ មីក ៦:៨ ឍ មថ ២៣:២៣
**១១:៤៣** ណ មថ ២៣:៦,៧ លក ១៤:៧ ២០:៤៦

**១១:៣៣** *បានឃើញពន្លឺ* អត្ថន័យនៃការអុចចង្កៀង គឺដើម្បីផ្ដល់ពន្លឺដល់អ្នកដែលនៅក្បែរពន្លឺចង្កៀង(ខ.៣៦)។ ព្រះយេស៊ូវទ្រង់បានប្រទានដោយបើកចំហនូវពន្លឺនៃដំណឹងល្អប៉ុន្តែ"មនុស្សតំណដែលអាក្រក់នោះ" (ខ.២៩) បានទូលសូម ពីទ្រង់នូវទីសំគាល់ដែលអស្ចារ្យជាងនោះទៅវិញ ។ គ្មានកំហុសឆ្គងអ្វីកើតមាននៅក្នុងការដែលព្រះយេស៊ូវទ្រង់ប្រទានពន្លឺនោះទេ ប៉ុន្តែបញ្ហាគឺមកពីអ្នកដែលមិនចេះស្ដាប់ទ្រង់ ឬទទួលពន្លឺតែប៉ុណ្ណោះ ។

**១១:៣៤** *ចង្កៀងរូបកាយ* មើលការពន្យល់ មថ ៦:២២ ។ *ភ្នែកអ្នកល្អ* អ្នកដែលទារកទីសំគាល់មិនត្រូវការពន្លឺបន្ថែមទេ ប៉ុន្តែ ពួកគេត្រូវការភ្នែកល្អវិញ ដើម្បីឱ្យអាចមើលឃើញពន្លឺបានច្បាស់ ។

**១១:៣៨** *លាងព្រះហស្ដមុននឹងសោយ* ចំពោះការលាងដៃដែលត្រូវធ្វើជាពិសេសសម្រាប់ជាពិធីលាងសំអាតនោះ ក្រឹត្យវិន័យមិនបានចែងទេ ប៉ុន្តែគ្រាន់តែជាសេចក្ដីដែលពួកផារិស៊ីបានបន្ថែមឱ្យមាន នៅក្នុងទំនៀមទម្លាប់របស់ពួកខ្លួនប៉ុណ្ណោះ (មថ ១៥:៩ និងការពន្យល់ យហ ២:៦)។

**១១:៣៩** *លាងថាសតែខាងក្រៅ* ជាការលាងជម្រះកាយក្នុងពិធីបុណ្យ ។ *ឆស៊ី និងអំពើអាក្រក់* ពួកផារិស៊ីទាំងនោះគិតតែពីកាន់តាមពិធីបុណ្យ ជាងគិតធ្វើចិត្តឱ្យបានល្អ (មក ៧:២០ និងការពន្យល់) ។

**១១:៤០** *មិនបានបង្កើតខាងក្នុងដែរទេឬអី* ខាងក្នុងមនុស្ស(គឺចិត្ត និងសេចក្ដីសុចរិតនៅខាងក្នុង) គឺសំខាន់ជាងខាងក្រៅ (ការលាងសំអាតតាមពិធីបុណ្យ)។

**១១:៤១** ពួកផារិស៊ីចូលចិត្តគិតថាពួកខ្លួន"ស្អាត" ប៉ុន្តែ ភាពម៉ៅស្មិតរបស់ពួកគេចំពោះព្រះ និងចំពោះអ្នកក្របង្ហាញថា ពួកគេមិនមែនស្អាតដូចដែលពួកគេគិតនោះឡើយ ។ តើអ្នកប្រើធនធានដែលព្រះប្រទានមកយ៉ាងដូចម្ដេចខ្លះ? តើអ្នកមានក្ដីសប្បុរសក្នុងការបំពេញសេចក្ដីត្រូវការរបស់មនុស្សដែលនៅក្បែរអ្នកដែរឬទេ ? សេចក្ដីសប្បុរសរបស់អ្នកគឺបង្ហាញពីភាពបរិសុទ្ធនៃចិត្តរបស់អ្នក ។

**១១:៤២–៥២** គឺសេចក្ដីវេទនាទាំងប្រាំមួយដែលព្រះយេស៊ូវទ្រង់មានបន្ទូលសំដៅលើពួកមេដឹកនាំសាសនា(មថ ២៣:១៣–៣២)។ ព្រះយេស៊ូវទ្រង់រិះគន់ពួកផារិស៊ី និងពួកអ្នកប្រាជ្ញក្រឹត្យវិន័យធ្ងន់ៗយ៉ាងនេះ ពីព្រោះ (១).ពួកគេសំអាតតែខាងក្រៅ តែមិនមែនខាងក្នុងរបស់ពួកគេ (២).ពួកគេចងចាំការថ្វាយ១ភាគក្នុង១០ តែប្រមាថសេចក្ដីយុត្តិធម៌ (៣).ពួកគេចូលចិត្តឱ្យអ្នកដទៃកោតសរសើរ និងចាប់អារម្មណ៍មកលើខ្លួន (៤).ពួកគេដាក់បន្ទុកនៃសេចក្ដីតម្រូវរបស់សាសនាលើបណ្ដាជន (៥).ពួកគេមិនព្រមទទួលសេចក្ដីពិតពីព្រះយេស៊ូវហើយ (៦).ក៏បានរារាំងមិនឱ្យអ្នកដទៃជឿលើសេចក្ដីពិតនោះផងដែរ។ ពួកគេបានធ្វើខុសដោយផ្ដោតតែលើអាការៈខាងក្រៅ និងព្រងើយកន្តើយនឹងសភាពខាងក្នុងរបស់ចិត្តពួកគេ ។ មនុស្សមានពេលខ្លះអាចចាញ់ការបោកបញ្ឆោត ប៉ុន្តែ ព្រះទ្រង់មិនដូច្នោះទេ ។

**១១:៤២** *១ភាគក្នុង១០* កសិផល១ភាគក្នុង១០ គឺមានការតម្រូវឱ្យថ្វាយនៅក្នុងក្រឹត្យវិន័យសញ្ញាចាស់(ចទ ១៤:២២–២៩ និងការពន្យល់)។ វាជាការងាយ ដែលលើកហេតុផលថាមិនជួយអ្នកដទៃ ពីព្រោះបានជួយព្រះវិហារទៅហើយនោះ ប៉ុន្តែ អ្នកដើរតាមព្រះយេស៊ូវត្រូវជួយបំពេញតម្រូវការរបស់អ្នកជិតខាងរបស់ពួកគេ ។ ដង្វាយ១ភាគក្នុង១០ពិតជាមានសារៈសំខាន់ចំពោះព្រះវិហារមែនហើយ ប៉ុន្តែយើងមិនត្រូវឱ្យសេចក្ដីអាណិតស្រឡាញ់របស់យើងមានតែប៉ុណ្ណឹងឡើយ។បើអាចជួយបានគឺត្រូវតែជួយ ។

**១១:៤៣** *កន្លែងមុខគេក្នុងសាលាប្រជុំ* មើល មក ១២:៣៩ និងពន្យល់ ។

**១១:៤៤** *ផ្នូរខ្មោច ដែលមើលមិនឃើញ* (មថ ២៣:២៧)។ ក្រឹត្យវិន័យសញ្ញាចាស់បានចែងថា អ្នកណាដែលពាល់ផ្នូរខ្មោច នោះត្រូវរាប់ជាមិន

[៤៥]មានអ្នកប្រាជ្ញច្បាប់ម្នាក់[ច] ឆ្លើយឡើងថា លោកគ្រូ
ដែលលោកមានប្រសាសន៍យ៉ាងនេះ នោះឈ្មោះថា ត្មះតិះ
ដៀលដល់ពួកយើងខ្ញុំហើយ [៤៦]ទ្រង់មានបន្ទូលឆ្លើយថា
វេទនាដល់អ្នករាល់គ្នា ដែលជាអ្នកប្រាជ្ញច្បាប់ដែរ ដ្បិត
អ្នករាល់គ្នាដាក់បន្ទុកយ៉ាងធ្ងន់ ដែលពិបាកទទួល ទៅលើ
មនុស្ស តែខ្លួនអ្នករាល់គ្នាមិនព្រមទាំងយកម្រាមដៃ១ផ្ទឹះ
បន្ទុកនោះផង[ទ] [៤៧]វេទនាដល់អ្នករាល់គ្នា ដ្បិតអ្នករាល់
គ្នាធ្វើម៉ុងឱ្យពួកហោរា ដែលពួកឰយុកោអ្នករាល់គ្នាបាន
សំឡាប់បង់ [៤៨]ដូច្នេះអ្នករាល់គ្នាធ្វើបន្ទាល់ថា អ្នករាល់
គ្នាយល់ព្រមតាមការ ដែលពួកឰយុកោបានធ្វើហើយនោះ
ដ្បិតពួកឰយុកោបានសំឡាប់គេមែន ហើយអ្នករាល់គ្នាធ្វើ
ម៉ុងឱ្យដែរ[ធ] [៤៩]ដោយហេតុនោះបានជាប្រាជ្ញា[ន]នៃព្រះបាន
សំដែងថា អញចាត់ពួកហោរា ហើយពួកសាវកទៅឯគេ
គេនឹងសំឡាប់ខ្លះ ហើយបណ្តេញខ្លះ[ប] [៥០]ដើម្បីឱ្យឈាម
របស់ពួកហោរាទាំងអស់ ដែលបានខ្ចាយ តាំងពីកំណើត
លោកីយរៀងមកនោះ បានត្រូវទារពីមនុស្សដំណនេះវិញ
[៥១]គឺចាប់តាំងពីឈាមរបស់អេបិល[ផ] ទៅដល់ឈាមរបស់
សាការី[ព] ដែលគេសំឡាប់នៅកណ្តាលអាសនា នឹងវិហារ
ផង អើ ខ្ញុំប្រាប់ថាឈាមទាំងនោះនឹងត្រូវទារពីមនុស្ស
ដំណនេះវិញ[ភ] [៥២]វេទនាដល់អ្នករាល់គ្នា ពួកប្រាជ្ញច្បាប់
អើយ ដ្បិតអ្នករាល់គ្នាបានដកកូនសោនៃចំណេះចេញទៅ
ហើយ ខ្លួនអ្នករាល់គ្នាមិនបានចូល ហើយក៏ហាមឃាត់ដល់
ពួកអ្នក ដែលកំពុងតែរកចូល មិនឱ្យគេចូលដែរ[ម]។
[៥៣]កាលទ្រង់មានបន្ទូលសេចក្តីទាំងនោះដល់គេរួចហើយ
នោះពួកអាចារ្យ នឹងពួកផារិស៊ី គេចាប់តាំងជិរុញទ្រង់
ជាខ្លាំងពន់ពេក ឱ្យមានបន្ទូលពីសេចក្តីជាច្រើនទៅទៀត
[៥៤]ដោយចាំពិនិត្យពិចារណាមើល ទាំងរកហេតុនឹងចាប់
ព្រះបន្ទូលពីព្រះឱស្ឋទ្រង់ ដើម្បីឱ្យបានរឿងចោទប្រកាន់
ទ្រង់[យ]។

**១១:៤៤** ត មថ ២៣:២៧
**១១:៤៥** ថ មថ ២២:៣៥
**១១:៤៦** ទ មថ ២៣:៤
**១១:៤៨** ធ មថ ២៣:២៩–៣២ កច ៧:៥១–៥៣
**១១:៤៩** ន ១កថ ១:២៤,៣០ កល ២:៣ ប មថ ២៣:៣៤
**១១:៥១** ផ លប ៤:៨ ព ២របា ២៤:២០,២១ ភ មថ ២៣:៣៥, ៣៦
**១១:៥២** ម មថ ២៣:១៣
**១១:៥៤** យ មថ ១២:១០
**១២:១** រ មថ ១៦:៦, ១១,១២
**១២:២** ល មក ៤:២២

## ការព្រមាន និងការលើកទឹកចិត្ត

*១២:២–៩ = មថ ១០:២៦–៣៣*

**១២** [១]កាលទ្រង់កំពុងតែមានបន្ទូល នោះមានមនុស្ស
ប្រជុំគ្នាមីរដេរដាសស្មើរតែនឹងជាន់គ្នាឯង ទ្រង់ក៏ចាប់តាំង
មានបន្ទូលនឹងពួកសិស្សជាមុនដំបូងថា ចូរអ្នករាល់គ្នា
ប្រយ័ត្ននឹងដំបែពួកផារិស៊ី ដែលជាសេចក្តីកំពុត[រ] [២]គ្មានអ្វី
គ្របបាំងដែលមិនត្រូវបើកឱ្យឃើញ ឬអ្វីលាក់លៀម ដែល
មិនត្រូវបើកឱ្យស្គាល់នោះឡើយ[ល] [៣]ដូច្នេះគ្រប់ទាំងសេចក្តី
ដែលអ្នករាល់គ្នាបាននិយាយក្នុងទីងងឹតនោះ នឹងបានឮនៅ

ស្អាត (ជន ១៩:១៦) ។ ព្រះយេស៊ូវបានចោទពួកផារិស៊ីថា បានធ្វើឱ្យអ្នកដទៃមិនស្អាតដោយភាពពុករលួយខាងវិញ្ញាណរបស់ពួកគេ ។ ពួកផារិស៊ីបាននាំឱ្យខូចដល់អស់អ្នកណាដែលមកទាក់ទងពួកគេ គឺដូចជាផ្នូរខ្មោចដែលគ្មានការគូសសំគាល់ ហើយលាក់កំបាំងនៅក្នុងទីវាលអញ្ចឹងដែរ ។

**១១:៤៥** *អ្នកប្រាជ្ញច្បាប់ម្នាក់* មើលការពន្យល់ ៧:៣០ ។

**១១:៤៦** *ដាក់បន្ទុកយ៉ាងធ្ងន់ ដែលពិបាកទទួលលើមនុស្ស* ពួកផារិស៊ីបានប្រឌិតឡើងនូវវិធី ដែលអាចជួយឱ្យពួកខ្លួនជៀសផុតពីការកាន់តាមក្រឹត្យ–វិន័យ (មថ ១១:២៨ និងមើលការពន្យល់) ។ ពួកផារិស៊ីក៏បានដាក់បន្ទុកលើបណ្តាជន ដោយបន្ថែមពីលើក្រឹត្យវិន័យដ៏សំខាន់របស់លោកម៉ូសេនូវវិន័យនិងបទបញ្ញា (មើលការពន្យល់ មថ ១៥:២) ហើយមិនបានធ្វើអ្វីម្យ៉ាង ដើម្បីជួយឱ្យអ្នកដទៃអាចកាន់តាមនោះឡើយ (មថ ២៣:៤) ។

**១១:៤៧** *ធ្វើម៉ុងឱ្យពួកហោរា* តាមសំបកក្រៅ "ពួកអ្នកប្រាជ្ញច្បាប់" (ខ.៤៦) មើលទៅហាក់ដូចជាគោរពពួកហោរា ដោយបានសាងសង់ ឬជួសជុលទីរំឭក ប៉ុន្តែ ខាងក្នុងវិញគឺពួកគេបានបដិសេធព្រះមែស៊ីដែលពួកហោរាបានប្រកាស ។ ពួកគេរស់នៅដោយការទាស់ប្រឆាំងនឹងពួកហោរា ដូចដែលពួកឰយុកោរបស់ពួកគេបានធ្វើផងដែរ ។

**១១:៤៩** ហោរារបស់ព្រះត្រូវគេបដិសេធ ដោយការបៀតបៀន និងសម្លាប់ ប៉ុន្តែ មនុស្សក្នុងតំណក្រោយនេះកំពុងតែបដិសេធហោរាដែលលើសពីមនុស្សលោកគឺពួកគេកំពុងតែបដិសេធព្រះ ។ ខនេះមិនបានដកស្រង់ពីព្រះគម្ពីរសញ្ញាចាស់ឡើយ ព្រះយេស៊ូវទ្រង់ជាហោរាលើអស់ទាំងហោរា គឺទ្រង់កំពុងប្រទានឱ្យពួកគេនូវព្រះរាជសាររបស់ព្រះ ។

**១១:៥១** *ឈាមរបស់អេបិល . . . សាការី* មើលពន្យល់ មថ ២៣:៣៥ ។

**១១:៥២** តើពួកអ្នកប្រាជ្ញច្បាប់ដកយកកូនសោនៃចំណេះដោយរបៀបណា? ដើម្បីធ្វើឱ្យសេចក្តីពិតរបស់ព្រះពិបាកយល់ និងប្រតិបត្តិតាមពួកអ្នកប្រាជ្ញច្បាប់បានប្រើការកាត់ស្រាយខុសឆ្គង ហើយបន្ថែមក្រឹត្យវិន័យ ។ ជាងនេះទៅទៀតពួកគេបានធ្វើជាគំរូអាក្រក់ ដោយពួកគេបានរុករកវិធីគេចពីក្រឹត្យវិន័យដោយផ្ទុកបន្ទុកយ៉ាងធ្ងន់លើអ្នកដទៃ។ ពួកគេមិនអាចនាំបណ្តាជនទៅឯព្រះបានឡើយ ព្រោះពួកគេមានចំណងសាសនាដែលពួកគេបានបង្កើតខ្លួនឯងទៅហើយ ។ ពួកគេបានបិទទ្វារនៃសេចក្តីស្រឡាញ់ ដែលព្រះទ្រង់មានសម្រាប់មនុស្សលោក ហើយថែមទាំងបោះកូនសោនៃចំណេះចោលទៀតផង ។

**១១:៥៣,៥៤** ពួកអាចារ្យ និងពួកផារិស៊ីសង្ឃឹមថា នឹងបានចាប់ព្រះយេស៊ូវដោយចោទថាពាក្យប្រមាថដល់ព្រះ ជំនឿខុសឆ្គង និងការបំពានក្រឹត្យវិន័យ ប៉ុន្តែ ពួកគេមិនអាចចាប់ទ្រង់បានឡើយព្រោះបន្ទូលទ្រង់ជាព្រះបន្ទូលព្រះ ។ ដូចនេះពួកគេបានសម្រេចស្វែងរកនីតិវិធីដើម្បីកម្ចាត់ទ្រង់វិញ ។ សូមមើល ៦:១១ និងការពន្យល់ ១៩:៤៧–៤៨ ២០:១៩–២០ ២២:២ ។

**១២:១** *ដំបែពួកផារិស៊ី* មើលការពន្យល់ មក ៨:១៥ ។

**១២:២** *គ្មានអ្វីគ្របបាំង ដែលមិនត្រូវបើកឱ្យឃើញ* មានន័យថាគ្មានការអ្វីដែលគ្របបាំងដោយសេចក្តីកំពុត ដែលមិនត្រូវបើកឱ្យគេដឹងនោះឡើយ (មើលការពន្យល់ ៨:១៧) ។

**១២:៣** នៅស្រុកយូដា គេសង់ផ្ទះដែលមានដំបូលផ្តេក ដែលមានបង្កាន់ដៃជុំវិញ សម្រាប់ស្រូបយកខ្យល់អាកាស សម្រាក និងអធិស្ឋាន ហើយផ្ទះនោះ

ទីភ្លឺ ហើយសេចក្ដីអ្វីដែលអ្នករាល់គ្នាបានខ្សឹបដាក់ត្រចៀក
នៅក្នុងបន្ទប់ នោះនឹងបានប្រកាសប្រាប់ពីលើដំបូលផ្ទះវិញ
៤តែពួកសំឡាញ់អើយ ខ្ញុំប្រាប់អ្នករាល់គ្នាថា កុំឱ្យខ្លាច
អ្នកណាដែលសំឡាប់បានតែរូបកាយ រួចក្រោយមកពុំ
អាចធ្វើអ្វីទៀតបាននោះឡើយ ៥ខ្ញុំនឹងបង្ហាញ ឱ្យអ្នកដឹងជា
ត្រូវខ្លាចដល់អ្នកណា គឺត្រូវឱ្យខ្លាចដល់ព្រះវិញ ដែល
កាលណាទ្រង់សំឡាប់ នោះក៏មានអំណាចអាចបោះចោល
ទៅក្នុងនរកបានផង អើ ខ្ញុំប្រាប់អ្នករាល់គ្នាថា ត្រូវឱ្យ
ខ្លាចដល់ព្រះអង្គចុះ[ស] ៦តើគេមិនលក់ចាប ៥ ថ្លៃ២ លុយទេ
ឬអី តែគ្មានចាបណាមួយ ដែលព្រះទ្រង់ ភ្លេចទេ ៧សូម្បី
ទាំងសក់ក្បាលរបស់អ្នករាល់គ្នា ក៏បានរាប់ទាំងអស់ដែរ[ហ]
ដូច្នេះកុំឱ្យខ្លាចឡើយ អ្នករាល់គ្នាមានដំឡៃលើសជាង
ចាបជាច្រើន[ឡ] ៨ខ្ញុំប្រាប់អ្នករាល់គ្នាថា អស់អ្នកណាដែល
ទទួលស្គាល់ខ្ញុំ នៅមុខមនុស្សលោក នោះកូនមនុស្សនឹង
ទទួលស្គាល់អ្នកនោះ នៅចំពោះមុខពួកទេវតានៃព្រះដែរ[អ]
៩តែអ្នកណាដែលមិនព្រមទទួលស្គាល់ខ្ញុំ នៅមុខមនុស្ស
លោក នោះខ្ញុំក៏មិនទទួលស្គាល់អ្នកនោះ[ក] នៅចំពោះមុខពួក
ទេវតានៃព្រះដែរ ១០ឯអស់អ្នកណា ដែលពោលពាក្យ
ទាស់នឹងកូនមនុស្ស[ខ] នោះនឹងបានអត់ទោសឱ្យ តែអ្នកណា
ដែលប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធវិញ នោះមិនបានអត់
ទោសឱ្យឡើយ[ឃ] ១១កាលណាគេបណ្ដើរអ្នករាល់គ្នាទៅ
នៅមុខពួកជំនុំគេ ឬចំពោះចៅក្រម ឬពួកនាម៉ឺន នោះកុំឱ្យ
បារម្ភព្រួយ ពីបែបយ៉ាងណា ឬពីពាក្យអ្វី ដែលនឹងត្រូវ
ឆ្លើយដោះសា ឬ និយាយនោះឡើយ[ង] ១២ដ្បិតគឺព្រះវិញ្ញាណ
បរិសុទ្ធទ្រង់ នឹងបង្រៀនសេចក្ដីដែលអ្នករាល់គ្នាត្រូវ
និយាយនៅវេលានោះឯង[ច]។

## រឿងប្រៀបប្រដូចពីអ្នកមានល្ងីល្ងើម្នាក់

១៣មានម្នាក់ក្នុងហ្វូងមនុស្សទូលទ្រង់ថា លោកគ្រូសូម

**១២:៤** វ យហ ១៥:១៤,១៥
**១២:៥** ស ហព ១០:៣១
**១២:៧** ហ មថ ១០:៣០
ឡ មថ ១២:១២
**១២:៨** អ លក ១៥:១០
**១២:៩** ក មក ៨:៣៨ ២ធថ ២:១២
**១២:១០** ខ មថ ៨:២០ ឃ មថ ១២:៣១,៣២ ១យហ ៥:១៦
**១២:១១** ង មថ ១០:១៧,១៩ លក ២១:១២,១៤
**១២:១២** ច នក ៤:១២ មថ ១០:២០ មក ១៣:១១ លក ២១:១៥

ហាក់ដូចជាសម្រាប់ធ្វើសេចក្ដីប្រកាសផ្សេងៗ ដល់សាធារណៈជន ។ ពួកបណ្ឌិតរបស់សាសន៍យូដាមានទម្លាប់ថ្វាយបង្គំ ខ្សឹបដាក់ត្រចៀកពួកសិស្ស ហើយឱ្យពួកគេថាតាម លឺៗឱ្យបណ្ដាជនស្ដាប់ ។ ជួនកាលពួកគេអធិប្បាយឱ្យដល់បណ្ដាជនពីលើដំបូលផ្ទះដែលទាបហើយមានដំបូលផ្តេកនោះ ។

**១២:៤,៥** ការភ័យខ្លាចការប្រឆាំង ឬការសើចចំអក អាចនាំឱ្យចុះខ្សោយដល់ការធ្វើបន្ទាល់របស់យើងថ្វាយព្រះគ្រីស្ទ ។ ទោះបីជាស្ថិតក្នុងពេលលះ-បង់ដើម្បីដើរតាមព្រះក៏ដោយ ជាញឹកញាប់យើងមិនចង់ឱ្យបាត់សេចក្ដីសុខសាន្ត និងភាពស្រណុករបស់យើងឡើយ ។ ប៉ុន្តែ ព្រះយេស៊ូវទ្រង់បានរំឭកដល់យើងនៅក្នុងបទនេះថា យើងត្រូវកោតខ្លាចព្រះវិញ ដែលទ្រង់អាចឱ្យទាំងព្រលឹងទាំងរូបកាយធ្លាក់ទៅក្នុងនរកអស់កល្បជានិច្ច(មថ ១០:២៨ និងការពន្យល់)។

**១២:៥** *អំណាចអាចបោះចោលទៅក្នុងនរកបាន* គឺមានតែព្រះទេដែលទ្រង់មានអំណាចនេះ ។ ពាក្យ "នរក" ជាភាសាក្រិកគឺ"គេហិណា" (មើលការពន្យល់ មថ ៥:២២) កុំឱ្យច្រឡំនឹងពាក្យ "ស្ថានឃុំព្រលឹងមនុស្សស្លាប់"។ *ខ្លាចដល់ព្រះ* គឺត្រូវស្រឡាញ់ទ្រង់ គោរពអំណាចទ្រង់ ឈរនៅក្នុងភាពស្ញែងខ្លាចព្រះចេស្ដាទ្រង់ និងជឿលើទ្រង់ ។ ខ.៦–៧ ជាខស្ដីពីមូលដ្ឋានគ្រឹះនៃការជឿជាក់លើទ្រង់ ។

**១២:៦** *ចាប៥ថ្លៃ២លុយ* សត្វចាបលក់បានក្នុងតម្លៃថោកជាងគេក្នុងចំណោមប្រភេទបក្សីទាំងអស់ ។ ដូចនេះព្រះទ្រង់យកព្រះទ័យទុកដាក់សូម្បីតែចំពោះបក្សីដ៏តូច ដែលមនុស្សអាចលក់បានក្នុងតម្លៃថោក ដើម្បីទិញអាហារ ។

**១២:៨** *ទទួលស្គាល់ខ្ញុំ* ពេលដែលបុគ្គលណាដែលទទួលស្គាល់ព្រះយេស៊ូវថាជាព្រះមែស៊ី ដែលជាព្រះរាជបុត្រានៃព្រះ (មថ ១៦:១៦ ១យហ ២:២២ និងការពន្យល់) ព្រះយេស៊ូវទ្រង់ក៏នឹងទទួលស្គាល់បុគ្គលនោះ ថាជាអ្នកដើរតាមទ្រង់ដ៏ស្មោះត្រង់ផងដែរ(មថ ៧:២១)។

**១២:៩** *មិនព្រមទទួលស្គាល់អ្នកនោះ* មើល មក ៨:៣៨ ២ធថ ២:១២ និងការពន្យល់ មថ ៧:២១ ២៥:៤១–៤៦ ។ ព្រះយេស៊ូវទ្រង់ក៏បានមានបន្ទូលដូចនេះផងដែរចំពោះទំនាយពីការបដិសេធន៍របស់លោកពេត្រុស (២២:៣៤ ២២:៦១"ប្រកែកថា មិនស្គាល់")។

**១២:១០** ពួកផារិស៊ីបានពោលពាក្យប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធ ដោយចាត់ទុកថាព្រះយេស៊ូវធ្វើការអស្ចារ្យដោយអំណាចសាតាំង(មថ ១២:២៤) តែមិនមែនព្រះវិញ្ញាណទៅវិញ ។ បាបដែលមិនអាចអត់ទោសឱ្យបាន គឺការបដិសេធន៍អំណាចរបស់ព្រះ ដែលមានក្នុងព្រះគ្រីស្ទដោយចេតនា ។ ការប្រព្រឹត្តបាបនោះបង្ហាញពីចិត្តរឹងរូសដែលចង់ប្រព្រឹត្តឥតរាថយឡើយ ។ ពេលខ្លះអ្នកជឿដល់ព្រះអម្ចាស់មានការព្រួយបារម្ភថា ខ្លួនបានភ្លាត់ប្រព្រឹត្តអំពើបាបដែលមិនអាចអត់ទោសឱ្យនេះហើយ ប៉ុន្តែ អ្នកដែលចាំបាច់ត្រូវព្រួយបារម្ភនោះ គឺជាអ្នកដែលបែរខ្នងដាក់ព្រះ ហើយបដិសេធគ្រប់ទាំងសេចក្ដីជំនឿទៅវិញទេ ។ ដែលព្រះយេស៊ូវទ្រង់មានបន្ទូលថាពួកគេមិនអាចអត់ទោសឱ្យបាននោះ គឺមិនមែនព្រោះតែបាបរបស់ពួកគេមានសភាពអាក្រក់ជាងបាបអ្នកដទៃនោះទេ ប៉ុន្តែ ពីព្រោះតែពួកគេនោះនឹងមិនដែលលន់តួបាបសោះឡើយ ។ ការដែលអ្នកណាម្នាក់បដិសេធការដាស់តឿនរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺដូចជាការដែលអ្នកនោះដោះខ្លួនចេញពីកម្លាំងជំរុញឱ្យលន់តួបាប ឬឱ្យមានទំនាក់ទំនងឡើងវិញជាមួយនឹងព្រះ ។ មើលការពន្យល់ មថ ១២:៣១ មក ៣:២៩ ។

**១២:១២** *ព្រះវិញ្ញាណបរិសុទ្ធ . . . អ្នករាល់គ្នាត្រូវនិយាយ* មើល មថ ១០:១៩ និងការពន្យល់ ។

**១២:១៣** *ចែកមរដក* តាម ចទ ២១:១៧(ការពន្យល់ខនោះ) ច្បាប់បានកំណត់ថា កូនច្បងត្រូវទទួលមរដកឱ្យលើសកូនប្អូន១ជា២ ។ តាមធម្មតាពួកគ្រូបង្រៀនខាងសាសនាយូដា ជាអ្នកដោះស្រាយបញ្ហាជម្លោះរឿងមរដក ។ ការទូលសូមរបស់បុរសម្នាក់នេះ គឺទូលសូមឱ្យទ្រង់ជួយបំពេញបំណងចិត្តអាត្មានិយម និងសម្ភារៈនិយមរបស់គាត់តែប៉ុណ្ណោះ ។ គ្មានការបញ្ជាក់ថាគាត់ពិតជាស្ដាប់សេចក្ដីដែលព្រះយេស៊ូវមានបន្ទូលនោះឡើយ(ខ.១-១១)។

លោកប្រាប់បងខ្ញុំឱ្យគាត់ចែកមរដកមកខ្ញុំផង ១៤ទ្រង់ឆ្លើយ
តបថា ឱអ្នកអើយ តើអ្នកណាបានតាំងខ្ញុំ ឱ្យធ្វើជាចៅក្រម
សំរាប់ចែករបស់ទ្រព្យដល់អ្នករាល់គ្នា ១៥រួចទ្រង់មាន
បន្ទូលទៅគ្រប់គ្នាថា ចូរប្រយ័ត្ន ហើយខំចៀសពីសេចក្ដី
លោភចេញ ដ្បិតជីវិតនៃមនុស្សមិនស្រេចនឹងបានទ្រព្យ
សម្បត្តិជាបរិបូរទេ[ឆ] ១៦ទ្រង់ក៏មានបន្ទូលជាពាក្យប្រៀប
ធៀបទៅគេថា មានស្រែចំការរបស់អ្នកមានម្នាក់បានកើត
ផលចំរើនជាបរិបូរ ១៧ហើយអ្នកនោះរិះគិតក្នុងចិត្តថា តើ
ត្រូវឱ្យអញធ្វើដូចម្ដេច ដ្បិតអញគ្មានកន្លែងណានឹងដាក់
ផលរបស់អញទាំងនេះទេ ១៨ទើបយល់ថាអញត្រូវធ្វើយ៉ាង
នេះ គឺអញនឹងរុះជង្រុកអញ ពង្រីកឱ្យធំជាងទៅទៀត រួច
ប្រមូលផល នឹងទ្រព្យសម្បត្តិទៅផ្ទុកនៅទីនោះ ១៩នោះអញ
នឹងប្រាប់ដល់ចិត្តថា ចិត្តអើយឯងមានទ្រព្យសម្បត្តិជាច្រើន
ល្មមទុកសំរាប់ជាយូរឆ្នាំទៅមុខទៀតបានហើយ ចូរឯង
ឈប់សំរាកទៅ ហើយស៊ីផឹកសប្បាយចុះ ២០ប៉ុន្តែព្រះទ្រង់
មានបន្ទូលទៅអ្នកនោះថា ឱមនុស្សល្ងីល្ងើអើយ[ជ] នៅវេលា
យប់នេះឯង អញនឹងដកយកព្រលឹងឯងទៅវិញ[ឈ] ដូច្នេះ តើ
ទ្រព្យសម្បត្តិទាំងប៉ុន្មានដែលឯងបានប្រមូលទុកនេះ នឹង
ទៅជារបស់អ្នកណាវិញ[ញ] ២១អ្នកណាដែលប្រមូលទ្រព្យ
សម្បត្តិ ទុកបំរុងតែខ្លួនឯង តែឥតមានខាងឯព្រះសោះ
នោះក៏ដូច្នោះដែរ[ដ]។

## កុំឱ្យព្រួយបារម្ភ

*១២:២២-៣១ = មថ ៦:២៥-៣៣*

២២ទ្រង់ក៏មានបន្ទូលទៅពួកសិស្សថា ហេតុនោះបានជាខ្ញុំ
ប្រាប់អ្នករាល់គ្នាថា កុំឱ្យខ្វល់ខ្វាយនឹងជីវិត ដែលនឹង
បរិភោគអ្វី ឬនឹងរូបកាយ ដែលនឹងស្លៀកពាក់អ្វីនោះ
ឡើយ ២៣ឯជីវិតនោះវិសេសជាងអាហារចំណី ហើយ
រូបកាយ ក៏វិសេសជាងសំលៀកបំពាក់ដែរ ២៤ចូរពិចារ
ណាពីក្អែក ដ្បិតវាមិនដែលសាបព្រោះ ឬច្រូតកាត់ឡើយ
ក៏គ្មានឃ្លាំង គ្មានជង្រុកអ្វីផង តែព្រះទ្រង់ចិញ្ចឹមវា[ឋ] ចំណង់
បើអ្នករាល់គ្នា តើមានដំឡៃលើសជាងសត្វស្លាបអម្បាល
ម៉ានទៅទៀត ២៥តើមានអ្នកណាក្នុងពួកអ្នករាល់គ្នាអាច
នឹងបន្ថែមកំពស់ខ្លួនឡើង១ហត្ថ ដោយសារសេចក្ដីខ្វល់
ខ្វាយបានឬទេ ២៦ដូច្នេះ បើការតូចបំផុតពុំអាចនឹងធ្វើ
បានទៅហើយ នោះហេតុអ្វីបានជាចង់ខ្វល់ខ្វាយពីការឯ
ទៀតធ្វើអី ២៧ចូរពិចារណាពីផ្កាឈូកដែរ ដែលវាដុះ តើ
មានសភាពដូចម្ដេច វាមិនដែលនឿយធ្វើការងារ ឬស្រាវ
រវៃទេ ប៉ុន្តែខ្ញុំប្រាប់អ្នករាល់គ្នាថា សូម្បីតែហ្លួងសាឡូម៉ូន
ក្នុងគ្រាដែលមានគ្រប់ទាំងសេចក្ដីរុងរឿងរបស់ទ្រង់[ឌ] នោះ
មិនបានតែងអង្គដូចជាផ្កា១នោះផង ២៨ឯតិណជាតិដែល
ដុះឡើងដូច្នេះ ហើយថ្ងៃនេះមាន តែថ្ងៃស្អែកត្រូវបោះទៅ
ក្នុងជើងក្រាន នោះបើព្រះទ្រង់តុបតែងវាយ៉ាងដូច្នោះ ឱ
មនុស្សមានជំនឿតិចអើយ តើទ្រង់នឹងបំពាក់ឱ្យអ្នករាល់គ្នា
លើសជាងអម្បាម៉ានទៅទៀត[ឍ] ២៩កុំឱ្យស្វែងរកតែគ្រឿង
សំរាប់បរិភោគ ហើយកុំថប់បារម្ភឡើយ ៣០ដ្បិតអស់ទាំង
សាសន៍ដទៃ នៅលោកីយនេះ តែងស្វែងរករបស់ទាំងនោះ
ឯអ្នករាល់គ្នាវិញ នោះព្រះវរបិតា[ណ]នៃអ្នកទ្រង់ជ្រាបហើយ
ថាអ្នករាល់គ្នាត្រូវការនឹងរបស់ទាំងនោះ[ត] ៣១ចូរខំស្វែង
រកនគរព្រះវិញ[ថ] នោះគ្រប់របស់ទាំងនោះនឹងបានប្រទាន
មកអ្នករាល់គ្នាផង[ទ] ៣២កុំឱ្យខ្លាច[ធ]ហ្វូងតូចអើយ ព្រោះព្រះ
វរបិតានៃអ្នករាល់គ្នា ទ្រង់សព្វព្រះហឫទ័យ នឹងប្រទាន
នគរមកអ្នករាល់គ្នាពិត[ន] ៣៣ចូរលក់របស់ដែលអ្នករាល់គ្នា
មានទាំងប៉ុន្មានហើយចែកឱ្យទៅជាទានចុះ[ប] ចូរធ្វើថង់

**១២:១៥** ឆ យបប ២០:២០ ៣១:២៤ ទដ ៦២:១០
**១២:២០** ជ យរ ១៧:១១ លក ១១:៤០ ឈ យបប ២៧:៨ ញ ទដ ៣៩:៦ ៤៩:១០
**១២:២១** ដ ខ.៣៣
**១២:២៤** ឋ យបប ៣៨:៤១ ទដ ១៤៧:៩
**១២:២៧** ឌ ១ពវ ១០:៤-៧
**១២:២៨** ឍ មថ ៦:៣០
**១២:៣០** ណ លក ៦:៣៦ ត មថ ៦:៨
**១២:៣១** ថ មថ ៣:២ ទ មថ ១៩:២៩
**១២:៣២** ធ មថ ១៤:២៧
ន មថ ២៥:៣៤

បន្ទូលឆ្លើយតបរបស់ព្រះយេស៊ូវចំពោះការទូលសូមរបស់គាត់ គឺពាក្យប្រៀបប្រដូចពីផលនៃសេចក្ដីលោភលន់ ។

**១២:១៦** *ពាក្យប្រៀបធៀប* មើលការពន្យល់ ៨:៤ ។

**១២:១៩** *ស៊ីផឹកសប្បាយ* មើល អស ២២:១៣ និងការពន្យល់ ។

**១២:២១** *មានខាងឯព្រះ* គឺមាន "ទ្រព្យសម្បត្តិនៅនគរស្ថានសួគ៌" (មថ ៦:២០ និងការពន្យល់ លក ១២:៣៤) ។

**១២:២២** *កុំឱ្យខ្វល់ខ្វាយ* មើលខ.២៩ មើល ភល ៤:៦-៧ និងការពន្យល់ ។

**១២:២៧** *ផ្កាឈូក* មើលការពន្យល់ មថ ៦:២៨ ។

**១២:២៨** មើល មថ ៦:៣០ និងការពន្យល់ ។

**១២:៣១** ការស្វែងរកនគរព្រះមានន័យថា អនុញ្ញាតឱ្យព្រះយេស៊ូវធ្វើជាព្រះអម្ចាស់ និងជាព្រះសង្គ្រោះផ្ទាល់ខ្លួនបុគ្គលម្នាក់ៗ ។ ទ្រង់ប្រាកដជាគ្រប់គ្រងលើផ្នែកនីមួយៗនៃជីវិតរបស់អ្នកដែលស្វែងរកទ្រង់ដូចជា កិច្ចការ ការកម្សាន្ត ផែនការ និងទំនាក់ទំនង ។ ដោយសារទ្រង់ជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះផងនោះ ទ្រង់មានព្រះហឫទ័យចង់ជួយយើង ដោយប្រទានឱ្យអ្វីៗតាមត្រូវការ ក៏ដូចជាដឹកនាំយើងនៅក្នុងការដែលយើងត្រូវប្រើប្រាស់នូវអ្វីៗដែលទ្រង់បានប្រទានមកនោះផងដែរ ។

**១២:៣៣** *លក់របស់ដែលអ្នករាល់គ្នាមានទាំងប៉ុន្មាន* ព្រះយេស៊ូវទ្រង់មិនមែនបង្រៀនសិស្សទ្រង់ ឱ្យលក់របស់ដែលពួកគេមានទាំងអស់នោះឡើយ (សូមមើល មក ១០:២១) ។ នៅក្នុងព្រះគម្ពីរដំណឹងល្អនេះទាំងមូល សេចក្ដីបង្រៀននេះ គឺសង្កត់ធ្ងន់លើការចែករំលែកទ្រព្យសម្បត្តិឱ្យដល់អ្នកក្រដោយចិត្តសប្បុរសទេ (ខ.២១-២៦) ។ *ចែកឱ្យទៅជាទាន* លក្ខណៈសំខាន់របស់ព្រះគម្ពីរលូកាគឺមាននិយាយពីគ្រោះថ្នាក់របស់អ្នកមាន និងការតម្រូវឱ្យចេះ

ដែលមិនចេះចាស់សំរាប់ខ្លួនជាទ្រព្យដែលមិនចេះអស់នៅ
ឯស្ថានសួគ៌វិញ[ផ] ដែលជាស្ថានគ្មានចោរចូលទៅជិតឡើយ
ហើយកន្លាតក៏មិនកាត់បំផ្លាញដែរ[ព] ៣៤ព្រោះសម្បត្តិទ្រព្យ
អ្នកនៅកន្លែងណា នោះចិត្តអ្នកក៏នឹងស្ថិតនៅកន្លែងនោះ
ឯង[ភ]។

## ការដែលត្រូវប្រុងប្រយ័ត្ន

*១២:៣៥–៣៦ = មថ ២៥:១–១៣ មក ១៣:៣៣–៣៧*

*១២:៣៩,៤០,៤២–៤៦ = មថ ២៤:៤៣–៥១*

៣៥ចូរឱ្យចង្កេះអ្នករាល់គ្នានៅជាក្រវាត់ ហើយចង្កៀង
នៅឆេះ ៣៦ចូរអ្នករាល់គ្នាធ្វើដូចជាមនុស្សដែល នៅរង់ចាំ
ចៅហ្វាយខ្លួនត្រឡប់មកពីស៊ីការវិញ ដើម្បីកាលណា
លោកមកគោះទ្វារហៅ នោះឱ្យបានបើកឱ្យជា១រំពេច
៣៧បើកាលណាចៅហ្វាយមកដល់ ឃើញពួកបាវកំពុងតែ
ចាំយាមដូច្នោះ នោះគេមានពរណាស់[ម] ខ្ញុំប្រាប់អ្នករាល់
គ្នាជាប្រាកដថា លោកនឹងឱ្យ អ្នកទាំងនោះអង្គុយនៅតុ
ហើយលោកនឹងក្រវាត់ខ្លួនលោក មកបំរើគេវិញ[យ] ៣៨បើ
លោកមកដល់ក្នុងយាមទី២ ឬយាមទី៣ ហើយឃើញពួក
បាវនៅចាំយាមដូច្នោះដដែល នោះគេមានពរហើយ
៣៩តែត្រូវដឹងសេចក្ដីនេះថា បើម្ចាស់ផ្ទះ ដឹងជាចោរ[រ]នឹង
មកនៅវេលាថ្មើរម៉ោន នោះគាត់នឹងចាំយាម មិនឱ្យចោរ
ទំលុះផ្ទះបានទេ ៤០ដូច្នេះចូរអ្នករាល់គ្នាបំរុងខ្លួនជាស្រេច
ដែរ[ល] ដ្បិតកូនមនុស្សនឹងមក នៅវេលាដែលអ្នករាល់គ្នា
មិនគិត។
៤១ពេត្រុសទូលសួរទ្រង់ថា ព្រះអម្ចាស់អើយ ទ្រង់ មានបន្ទូល
ពាក្យប្រៀបប្រដូចនេះ ដល់ត្រឹមយើងខ្ញុំប៉ុណ្ណោះ ឬដល់មនុស្ស
គ្រប់គ្នាដែរ ៤២ព្រះអម្ចាស់[វ]ទ្រង់មានបន្ទូលតបថា ចុះតើអ្នក
ណាជានាយដំរួតការដែលស្មោះត្រង់ មានមារយាទល្អ
ដែលចៅហ្វាយនឹងតាំងឱ្យត្រួតលើពួកផ្ទះលោក ដើម្បី
នឹងបើក អាហារឱ្យគេបរិភោគតាមត្រូវពេល ៤៣បើកាល
ណាចៅហ្វាយមកដល់ ឃើញអ្នកបំរើនោះកំពុងតែធ្វើ
ដូច្នោះ នោះវាមានពរហើយ ៤៤ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រា
កដថា លោកនឹងតាំងអ្នកនោះ ឱ្យត្រួតត្រា លើរបស់ទ្រព្យ
លោកទាំងអស់ ៤៥ប៉ុន្តែ បើអ្នកបំរើនោះគិតស្មានក្នុងចិត្តថា
ចៅហ្វាយអញក្រមក ហើយក៏តាំងវាយពួកបាវប្រុសស្រី
ទាំងស៊ីផឹកស្រវឹងវិញ ៤៦ដូច្នេះដល់ថ្ងៃដែលអ្នកបំរើនោះ
មិននៅចាំ ហើយវេលាណាដែលមិនដឹង[ស] នោះចៅហ្វាយ
នឹងមកដល់ ក៏នឹងធ្វើទោសជាយ៉ាងធ្ងន់ ព្រមទាំងឱ្យមានចំ
ណែកជាមួយនឹងពួកមនុស្សមិនជឿផង ៤៧អ្នកបំរើណាដែល
ស្គាល់ចិត្តចៅហ្វាយ តែមិនបានរៀបចំ ឬធ្វើតាមចិត្ត
លោកសោះ នោះនឹងត្រូវរំពាត់ជាយ៉ាងច្រើន[ហ] ៤៨ឯអ្នក
ណាដែលមិនបានស្គាល់ តែបានប្រព្រឹត្តគួរនឹងត្រូវរំពាត់

**១២:៣៣** ប កច ២:៤៥
ផ មថ ៦:២០
ព យក ៥:២
**១២:៣៤** ភ មថ ៦:២១
**១២:៣៧** ម មថ ២៤:៤២,៤៦ ២៥:១៣
យ មថ ២០:២៨
**១២:៣៩** រ មថ ៦:១៩ ១ថន ៥:២ ២ពត ៣:១០ វវ ៣:៣ ១៦:១៥
**១២:៤០** ល មក ១៣:៣៣ លក ២១:៣៦
**១២:៤២** វ លក ៧:១៣
**១២:៤៦** ស ខ.៤០
ហ ចទ ២៥:២
១២:៤៧ ហចទ ២៥:២

ធ្វើអំណោយផងដែរ (៣:១១ ៦:៣០ ១១:៤១ និងការពន្យល់ ១៤:១៣–១៤ ១៦:៩ និងពន្យល់ ១៨:២២ ១៩:៨)។ *ទ្រព្យដែលមិនចេះអស់នៅឯស្ថានសួគ៌* មើល ខ.២១ និងការពន្យល់ ។

**១២:៣៧** *ក្រវាត់ខ្លួនលោក មកបំរើគេវិញ* មានន័យថា ចៅហ្វាយនោះនឹងបង្ហាញពីសេចក្ដីស្រឡាញ់របស់គាត់(២២:២៧ និងការពន្យល់ ២២:២៦ មក ១០:៤៥ យហ ១៣:៥–១៤ និងការពន្យល់)។

**១២:៣៨** *យាមទី២ ឬយាមទី៣* ពួករ៉ូម៉ាំងបានបែងចែកម៉ោងពេលយប់ជាបួនយាម(មក ១៣:៣៥) ចំណែកឯពួកយូដាបានចែកជាបីយាម (ពច ៧:១៩ មថ ១៤:២៥ មើលការពន្យល់)។ ក្នុងសម័យនោះ ពួកយូដាប្រហែលជាអាចប្រើម៉ោងតែពីរប្រភេទនេះទេ ។ ពិធីស៊ីលាងនោះអាចចាប់ផ្ដើមនៅយាមទីមួយ ។

**១២:៤០** ការយាងត្រឡប់មកវិញរបស់ព្រះគ្រីស្ទគឺជាការពិត ប៉ុន្តែគ្មាននរណាដឹងថានៅពេលណាទេ(មថ ២៤:៣៦ មក ១៣:៣២ និងពន្យល់)។ អ្នកដែលបានត្រៀមខ្លួនសម្រាប់ការយាងមកវិញនៃព្រះអម្ចាស់ (១).គឺមិនមែនមានពុត ប៉ុន្តែ មានភក្ដីភាព (លក ១២:១) (២).មិនមានការភ័យខ្លាច ប៉ុន្តែ បានត្រៀមខ្លួនធ្វើបន្ទាល់(លក ១២:៤–៩) (៣).មិនព្រួយបារម្ភ ប៉ុន្តែ មានជំនឿ(លក ១២:២៥,២៦) (៤).មិនលោភលន់ ប៉ុន្តែ មានក្ដីសប្បុរស (លក ១២:៣៤) (៥).មិនខ្ជិល ប៉ុន្តែ រវាសរវៃ(លក ១២:៣៧)។

**១២:៤១** *ដល់ត្រឹមយើងខ្ញុំប៉ុណ្ណោះ ឬដល់មនុស្សគ្រប់គ្នាដែរ* ពាក្យ"យើងខ្ញុំ" គឺមានន័យថា"យើងខ្ញុំដែលជាសាវ័ក"។ ព្រះបន្ទូលជាពាក្យប្រដូចពីនាយតម្រួតការ ដែលត្រួតមើលពួកផ្ទះឱ្យចៅហ្វាយគាត់នោះ គឺសង្កត់ធ្ងន់ខ្លាំងបំផុតលើពួកអ្នកជំនួយ និងពួកអ្នកដឹកនាំព្រះវិហារ ប៉ុន្តែ ចុងបញ្ចប់នៃវគ្គនេះ (ខ.៤៨) បានបង្ហាញថា ពាក្យប្រៀបប្រដូចនេះគឺសម្រាប់មនុស្សគ្រប់គ្នា ទៅតាមចំណេះដឹង និងមុខងារដែលបានប្រទានឱ្យគេរៀងៗខ្លួន ។

**១២:៤២** *នាយដំរួតការដែលស្មោះត្រង់* មើល លក ១៦:១ និងការពន្យល់ ។ ព្រះយេស៊ូវទ្រង់បានសន្យាប្រទានរង្វាន់ដល់អ្នកដែលស្មោះត្រង់ចំពោះម្ចាស់ខ្លួន ។ ជួនកាលគ្រីស្ទបរិស័ទបានពិសោធជាមួយនឹងរង្វាន់ដែលទទួលបានភ្លាមៗ និងរង្វាន់ជាសម្ភារៈសម្រាប់ការស្ដាប់បង្គាប់ព្រះ ប៉ុន្តែ រង្វាន់ទាំងអស់នោះមិនមែនសុទ្ធតែជារង្វាន់ក្នុងករណីខាងលើនោះទេ ហើយបើសិនជាអញ្ចឹងមែន នោះគ្រីស្ទបរិស័ទនឹងត្រូវល្បួងឱ្យមានសេចក្ដីអំនួតចំពោះស្នាដៃរបស់ខ្លួន ហើយនិងធ្វើល្អដើម្បីតែផលប្រយោជន៍ប៉ុណ្ណោះ ។ រង្វាន់ដែលគ្រីស្ទបរិស័ទនឹងទទួលនៅស្ថានសួគ៌ នឹងបញ្ជាក់ពីការអ្វីខ្លះដែលពួកគេបានធ្វើនៅលោកិយ ហើយរង្វាន់ទាំងនោះនឹងអស្ចារ្យហួសពីក្ដីស្រមៃរបស់ពួកគេទៅទៀត ។

**១២:៤៦–៤៨** គឺជាវគ្គដែលនិយាយពីការកាត់ទោស តាមអភ័យឯកសិទ្ធក្នុងការដែលបានដឹង បានស្គាល់ហើយ តែបែរជាមិនព្រមប្រតិបត្តិតាមសេចក្ដីដែលបានដឹងនោះទៅវិញ(រម ២:១២–១៦)។

**១២:៤៨** ព្រះយេស៊ូវបានមានបន្ទូលពីរបៀបដែលយើងត្រូវរស់នៅ រហូត

នោះនឹងត្រូវវាយតិចវិញ[ឡ] ឯអស់អ្នកណាដែលគេប្រគល់
ទុកជាច្រើនឱ្យ នោះគេនឹងទារជាច្រើនពីអ្នកនោះវិញ គេ
នឹងសូមលើសទៅទៀតពីអ្នកណា ដែលគេបានផ្ញើទុកជា
ច្រើនផង ។

### ពេលដែលត្រូវបាក់បែកគ្នា

*១២:៥១-៥៣ = មថ ១០:៣៤-៣៦*

៤៩ខ្ញុំបានមកដើម្បី នឹងបោះភ្លើងនៅលើផែនដី បើភ្លើង
នោះឆេះហើយ តើខ្ញុំនៅចង់បានអ្វីទៀត ៥០តែខ្ញុំត្រូវ
ទទួលបុណ្យជ្រមុជ១សិន[អ] ហើយខ្ញុំត្រូវចង្អៀតចង្អល់យ៉ាង
ដូចម្តេចទៅហ្ន៎ ទំរាំតែបុណ្យនោះបានសំរេច[ក] ៥១តើអ្នក
រាល់គ្នាស្មានថា ខ្ញុំមកដើម្បីឱ្យមានសេចក្តីសុខសាន្តនៅ
ផែនដីឬអី ខ្ញុំប្រាប់អ្នករាល់គ្នាថាមិនមែនទេ គឺមកដើម្បី
ឱ្យកើតប្រដិបក្សវិញទេតើ ៥២ដ្បិតពីនេះទៅមុខ នឹងមាន
៥នាក់ក្នុងផ្ទះ១បាក់បែកគ្នា គឺ៣នាក់ទាស់នឹង២នាក់ ហើយ
២នាក់ទាស់នឹង៣នាក់ ៥៣ឯឪពុកនឹងបាក់បែក ទាស់នឹង
កូនប្រុស ហើយកូនប្រុសទាស់នឹងឪពុក ម្តាយទាស់ នឹងកូន
ស្រី ហើយកូនស្រីទាស់នឹងម្តាយ ម្តាយក្មេកទាស់នឹង កូន
ប្រសាស្រី ហើយកូនប្រសាស្រីទាស់នឹងម្តាយក្មេកដែរ[ខ] ។

### ការបកស្រាយពេលវេលា

៥៤ទ្រង់ក៏មានបន្ទូលទៅបណ្តាមនុស្សដែរថា កាលណា
អ្នករាល់គ្នាឃើញពពកឡើងពីទិសខាងលិច ស្រាប់តែអ្នក
រាល់គ្នាថាចង់ភ្លៀងហើយ រួចក៏មានដូច្នោះមែន[គ] ៥៥ហើយ
កាលណាខ្យល់បក់ពីទិសខាងត្បូង នោះអ្នករាល់គ្នាថា
ថ្ងៃនេះមុខជាក្តៅ នោះក៏មានដែរ ៥៦ឱមនុស្សកំពុត
អើយ អ្នករាល់គ្នាចេះសំគាល់សភាពដី ហើយនឹងមេឃ
បានចុះ ហេតុដូចម្តេចបានជាមិនស្គាល់ពេលវេលានេះ[ឃ]
៥៧ហើយហេតុអ្វីបានជាមិនពិចារណាក្នុងខ្លួនអ្នករាល់គ្នា
ពីសេចក្តីណាដែលសុចរិត ៥៨ដ្បិតដែលអ្នកកំពុងតែដើរ
តាមផ្លូវទៅឯចៅហ្វាយជាមួយនឹងសត្រូវអ្នក នោះចូរខំ
ប្រឹងដោះខ្លួនឱ្យរួចចេញ ក្រែងគេទាញអូសអ្នកទៅឯ
ចៅក្រម ចៅក្រមប្រគល់អ្នកដល់នាយភូឃុំ ហើយនាយ
ភូឃុំនឹងដាក់អ្នកជាប់គុក[ង] ៥៩ខ្ញុំប្រាប់អ្នកថា ដែលអ្នកនៅខ្វះ
តែកន្លះសេននឹងសងគេឱ្យគ្រប់ នោះនឹងចេញពីទីនោះ
មិនរួចឡើយ[ច] ។

### ការប្រែចិត្ត ឬត្រូវវិនាស

**១៣** ១នៅវេលានោះឯងមានអ្នកខ្លះនៅទីនោះ គេទូល
ព្រះយេស៊ូវពីរឿងពួកសាសន៍កាលីឡេ ដែលលោកពី

**១២:៤៨** ឡ លវ ៥:១៧ ជន ១៥:២៧-៣០
**១២:៥០** អ មក ១០:៣៨ ក យហ ១៩:៣០
**១២:៥៣** ខ មីក ៧:៦ មថ ១០:២១
**១២:៥៤** គ មថ ១៦:២
**១២:៥៦** ឃ មថ ១៦:៣
**១២:៥៨** ង មថ ៥:២៥
**១២:៥៩** ច មថ ៥:២៦ មក ១២:៤២
**១៣:១** ឆ មថ ២៧:២

ដល់ពេលទ្រង់យាងមកវិញគឺ យើងត្រូវចាំយាម ត្រូវធ្វើការយ៉ាងរវាសរវៃ និងត្រូវស្តាប់បង្គាប់ទ្រង់ ។ ការប្រតិបត្តិនេះមានសារសំខាន់ជាពិសេសចំពោះអ្នកដឹកនាំ ។ អ្នកដឹកនាំដែលចាំយាម ហើយស្មោះត្រង់នឹងបានទទួលនូវឱកាស និងការទទួលខុសត្រូវជាបន្ថែមទៀត ។ យើងមានធនធានប្រាជ្ញា និងចំណេះដឹងកាន់តែច្រើនប៉ុណ្ណា នោះយើងត្រូវមានការទទួលខុសត្រូវក្នុងការប្រើរបស់ទាំងនោះ ឱ្យមានប្រសិទ្ធភាពកាន់តែច្រើនប៉ុណ្ណោះដែរ ។

**១២:៤៩** *ភ្លើង* នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ពាក្យនេះមានប្រើជាន័យធៀបតាមរបៀបខុសៗគ្នា (មើលការពន្យល់ ៣:១៦) ។ ក្នុងខនេះ ពាក្យនេះជាប់ទាក់ទងនឹងការកាត់ទោស (ខ.៤៩) និងការបង្កើតប្រដិបក្ស (បក្សឬក្រុមពីរផ្ទុយគ្នា ទាស់ទែង ឬបែកបាក់គ្នា) (ខ.៥១) ។ ការជំនុំជម្រះត្រូវធ្លាក់ទៅលើអ្នកដែលអាក្រក់ គឺអ្នកដែលបានផ្តាច់ខ្លួនចេញពីពួកបរិសុទ្ធ ។

**១២:៥០** *បុណ្យជ្រមុជ* គឺការរងទុក្ខដែលព្រះយេស៊ូវទ្រង់ត្រូវទទួលនៅលើឈើឆ្កាង (មើលការពន្យល់ មក ១០:៣៨) ។ *ទំរាំតែបុណ្យនោះបានសំរេច* ព្រះបន្ទូលដែលទ្រង់មានពីលើឈើឆ្កាងមក គឺជាការប្រកាសពីការសម្រេចនោះឯង (យហ ១៩:២៨,៣០ និងការពន្យល់) ។ ព្រះយេស៊ូវមានព្រះទ័យចង់ឱ្យពេលដែលត្រូវរងទុក្ខនោះត្រូវកន្លងទៅបាត់ ។

**១២:៥៤-៥៦** ខ្យល់ដែលបក់មកពីទិសខាងលិច គឺបក់មកពីសមុទ្រមេឌីទែ-រ៉ាណេ តែបើបក់មកពីខាងត្បូង គឺបក់មកពីតំបន់សមុទ្រខ្សាច់ ។ ទោះជាបណ្តាជនអាចប្រើការសំគាល់នេះ ដើម្បីព្យាករណ៍ធាតុអាកាសក៏ដោយ ក៏ពួកគេមិនអាចស្គាល់ទីសំគាល់នៃវិបត្តិខាងឯព្រលឹងវិញ្ញាណដែលមានដូចជាការយាងត្រឡប់មកវិញនៃព្រះមែស៊ី ការគំរាមកំហែងនៃសេចក្តីស្លាប់ ការប្រឈមមុខដាក់ពួករ៉ូម៉ាំងដែលត្រូវមកដល់ និងផលដែលត្រូវទទួលអស់កល្បជានិច្ច ។

**១២:៥៧** *មិនពិចារណាក្នុងខ្លួន* ទោះបីជាមានការគាបសង្កត់ពីសំណាក់ពួកផារិស៊ីដ៏រឹងរូស ពីការគ្រប់គ្រងរបស់ចក្រភពរ៉ូម៉ាំង និងពីគ្រួសារក៏ដោយ ក៏ពួកអ្នកទាំងនោះនៅតែត្រូវទទួលព្រះ ដោយការសម្រេចចិត្តផ្ទាល់ខ្លួនគេម្នាក់ដែរ ។ ទីសំគាល់ដែលកើតមាននៅសម័យនោះបានអំពាវនាវឱ្យសាសន៍យូដាសម្រេចចិត្តភ្លាមៗ មុនពេលដែលការកាត់ទោសត្រូវធ្លាក់មកលើជាតិសាសន៍នេះទាំងមូល ។

**១២:៥៨** *ចូរខំប្រឹងដោះខ្លួនឱ្យរួចចេញ* មានន័យថាត្រូវមានសេចក្តីសុខសាន្តជាមួយនឹងព្រះជាបន្ទាន់ ប្រយោជន៍កុំឱ្យយឺតពេល ។

**១៣:១-៥** លោកពីឡាត់ប្រហែលជាបានសម្លាប់សាសន៍កាលីឡេ ពីព្រោះគាត់គិតថា ពួកគេបានបះបោរប្រឆាំងនឹងចក្រភពរ៉ូម៉ាំង ។ ចំពោះអ្នកដែលបានស្លាប់នៅក្នុងការដួលរលំប៉មស៊ីឡោមនោះ គឺប្រហែលអ្នកដែលធ្វើការឱ្យពួករ៉ូម៉ាំងនៅក្នុងជលមាគ៌ានោះ ។ ពួកផារិស៊ីបានបដិសេធមិនព្រមប្រើកម្លាំងទ័ពក្នុងការដោះស្រាយជាមួយពួករ៉ូម៉ាំងទេ ហើយពួកគេបាននិយាយថា ពួកសាសន៍ការលីឡេសមនឹងស្លាប់ នៅក្នុងការបះបោរនោះ ។ ពួកឧស្សាហ៍ ដែលជាពួកភេរវជនមួយក្រុមប្រឆាំងនឹងពួករ៉ូម៉ាំងបាននិយាយថា ពួកកម្មករជលមាគ៌ាទាំងនោះសមនឹងស្លាប់ ពីព្រោះពួកគេបានសហការជាមួយពួករ៉ូម៉ាំង ។ ប៉ុន្តែ ព្រះយេស៊ូវទ្រង់មានបន្ទូលថា សាសន៍កាលីឡេក្តី ពួកកម្មករក្តី គឺមិនគួរទទួលការស្តីបន្ទោស ពីទុក្ខលំបាកដែលពួកគេទទួលរងនោះឡើយ ។ ម្នាក់ៗគួរដែលសម្លឹងមើលទៅថ្ងៃជំនុំជម្រះរបស់ខ្លួនវិញ ជា

ឡាត់[ឆ]បានយកឈាមគេលាយនឹងយញ្ញបូជា ដែលគេ
កំពុងតែថ្វាយ ២តែទ្រង់មានបន្ទូលឆ្លើយទៅអ្នកទាំងនោះ
ថា តើអ្នករាល់គ្នាស្មានថា ពួកកាលីឡេទាំងនោះមាន
បាបលើសជាងសាសន៍កាលីឡេឯទៀត ដោយព្រោះគេ
បានរងទុក្ខលំបាកយ៉ាងនោះឬអី[ជ] ៣ខ្ញុំប្រាប់អ្នករាល់គ្នា
ថាមិនមែនទេ ប៉ុន្តែបើអ្នករាល់គ្នាមិនប្រែចិត្តទេ នោះនឹង
ត្រូវវិនាសទាំងអស់គ្នាយ៉ាងដូច្នោះដែរ ៤ឬស្មានថាពួក១៨
នាក់ដែលប៉មស៊ីឡោម[ឈ]បានរលំមកលើកិនស្លាប់នោះ គេ
មានទោសលើសជាងមនុស្សទាំងប៉ុន្មាន ដែលនៅក្រុង
យេរូសាឡិមឬអី ៥ខ្ញុំប្រាប់អ្នករាល់គ្នាថាមិនមែនទេ ប៉ុន្តែ
បើអ្នករាល់គ្នាមិនប្រែចិត្តទេ[ញ] នោះនឹងត្រូវវិនាសទាំងអស់
គ្នាដូច្នោះដែរ។
៦រួចទ្រង់មានបន្ទូលពាក្យប្រៀបប្រដូចនេះថា មានបុរស
ម្នាក់មានដើមល្វាដុះក្នុងចំការខ្លួន គាត់បានមករកផល
ផ្លែពីដើមនោះ តែគ្មានសោះ[ដ] ៧ក៏និយាយទៅអ្នករក្សា
ចំការថា មើល៣ឆ្នាំមកហើយ ខ្ញុំមករកផលផ្លែពីដើមល្វា
នេះមិនដែលបានសោះ ដូច្នេះ ចូរកាប់ចោលទៅ[ឋ] ទុកឱ្យ
នៅបង្ខាតដីធ្វើអី ៨តែអ្នកនោះឆ្លើយថា សូមលោកទុកនៅ១
ឆ្នាំទៀតសិន ចាំខ្ញុំជ្រួយដីហើយដាក់ជីលមើល ៩ក្រែងកើត
មានផលផ្លែឡើង បើគ្មានទេ នោះសូមកាប់ចោលទៅចុះ។

**ស្ត្រីពិការម្នាក់បានជានៅថ្ងៃឈប់សំរាក**

១០កាលព្រះយេស៊ូវ ទ្រង់កំពុងតែបង្រៀនក្នុងសាលាប្រ
ជុំ[ឌ]១ នៅថ្ងៃឈប់សំរាក ១១នោះឃើញមានស្ត្រីម្នាក់ដែល
អារក្សធ្វើឱ្យពិការ អស់១៨ឆ្នាំមកហើយ[ឍ] មានខ្នងកោង
ងើបត្រង់ពុំបានសោះ ១២លុះទ្រង់បានឃើញគាត់ក៏មាន
បន្ទូលហៅគាត់មកប្រាប់ថា នាងអើយ នាងបានរួចពី
ជរាពិការហើយ ១៣រួចទ្រង់ដាក់ព្រហស្តលើគាត់[ណ] នោះ
គាត់ក៏ងើបត្រង់ឡើងជា១រំពេច ហើយពោលពណ៌នា
សរសើរដល់ព្រះ ១៤ឯមេសាលាប្រជុំ[ត] គាត់នឹកគ្នាន់ក្នុង
ចិត្តណាស់ ដោយព្រោះព្រះយេស៊ូវបានប្រោសឱ្យជា នៅ
ថ្ងៃឈប់សំរាក[ថ] ក៏និយាយទៅមនុស្សទាំងនោះថា មានតែ៦
ថ្ងៃទេ ដែលគួរធ្វើការបាន[ទ] ដូច្នេះ ចូរមកក្នុងរវាងថ្ងៃទាំង
នោះវិញ ដើម្បីឱ្យបានជាចុះ កុំឱ្យមកក្នុងថ្ងៃឈប់សំរាក
ឡើយ ១៥នោះព្រះអម្ចាស់ ទ្រង់មានបន្ទូលឆ្លើយ ទៅគាត់ថា
មនុស្សមានពុតអើយ តើអ្នករាល់គ្នាមិនស្រាយគោស្រាយ
លាពីចំណង ដឹកទៅឱ្យផឹកទឹកនៅថ្ងៃឈប់សំរាកទេឬអី[ធ]
១៦ឯស្ត្រីនេះជាពូជលោកអ័ប្រាហាំ[ន] ដែលអារក្សសាតាំង[ប]

**១៣:២** ជ យហ ៩:២,៣
**១៣:៤** ឈ យហ ៩:៧,១១
**១៣:៥** ញ មថ ៣:២ កច ២:៣៨
**១៣:៦** ដ អស ៥:២ យរ ៨:១៣ មថ ២១:១៩
**១៣:៧** ឋ មថ ៣:១០
**១៣:១០** ឌ មថ ៤:២៣
**១៣:១១** ឍ ខ.១៦
**១៣:១៣** ណ មក ៥:២៣
**១៣:១៤** ត មថ ១២:២ ថ មក ៥:២២ ទ នក ២០:៩
**១៣:១៥** ធ លក ១៤:៥
**១៣:១៦** ន លក ៣:៨ ប មថ ៤:១០

ជាងស្ដីបន្ទោសឱ្យអ្នកដទៃ ។

**១៣:២,៤** *បាបលើសជាង . . . មានទោសលើសជាង* នៅសម័យបុរាណ ជាញឹកញាប់គេសន្និដ្ឋានថា សេចក្ដីវេទនានឹងកើតមានចំពោះតែអ្នកដែលមានបាបធ្ងន់ប៉ុណ្ណោះ(យហ ៩:២ និងការពន្យល់ និង យប ៤:៧,២២:៥ ដែលលោកអេលីផាសចោទប្រកាន់ខុសមកលើលោកយ៉ូប (មើលការពន្យល់ យប ២២:៥–១១) ប៉ុន្តែ ព្រះយេស៊ូវទ្រង់បានបញ្ជាក់ថា មនុស្សយើងគ្រប់គ្នាសុទ្ធតែជាមនុស្សមានបាប ដែលត្រូវតែលន់តួបាប មិនដូច្នោះទេមនុស្សយើងនឹងត្រូវជួបប្រទះនឹងទីបញ្ចប់ដ៏គួរឱ្យភ័យខ្លាច ។

**១៣:៤** *ប៉មស៊ីឡោម* គឺជាប៉មដែលគេសង់នៅភាគអាគ្នេយ៍នៃកំផែងក្រុងយេរូសាឡិម (មើលការពន្យល់ យហ ៩:៧)។

**១៣:៦** *ដើមល្វា* គឺជាតំណាងឱ្យសាសន៍យូដា (មើលពន្យល់ មក ១១:១៤) ប៉ុន្តែ ក៏អាចតំណាងឱ្យបុគ្គលម្នាក់ៗផងដែរ ។

**១៣:៧** *៣ឆ្នាំមកហើយ* គឺជារយៈពេលមួយដែលដើមល្វាត្រូវបញ្ចេញផលផ្លែរបស់វាជាបរិបូរ ។

**១៣:១១** *អារក្សធ្វើឱ្យពិការ* មានជំងឺផ្សេងៗជាច្រើនដែលអារក្សសាតាំងជាអ្នកបណ្ដាល(មើលការពន្យល់ ៤:៣៣)។ តាមការរៀបរាប់ពីពិការភាពរបស់ស្ត្រីម្នាក់នេះ បង្ហាញថាឆ្អឹងខ្នងរបស់គាត់ត្រូវជាប់គ្នាយ៉ាងណែន ។

**១៣:១២** *នាងអើយ* មើលការពន្យល់ យហ ២:៤ ។ *បានរួចពីជរាពិការ* ពីព្រោះទ្រង់បានដេញវិញ្ញាណអារក្សរួចរាល់ហើយ ហើយស្ត្រីម្នាក់នេះក៏មានសេរីភាពរួចពីភាពពិការខាងសាច់ឈាមនោះហើយដែរ ។

**១៣:១៣** *សរសើរដល់ព្រះ* មើល ១:៦៤ និងការពន្យល់ ។

**១៣:១៤** *ប្រោសឱ្យជានៅថ្ងៃឈប់សំរាក* ពួកមេដឹកនាំសាសនាយូដាបានចាត់ទុកការប្រោសឱ្យជាថាជាមុខនាទីរបស់ពួកពេទ្យ ហើយការធ្វើការងារនៅថ្ងៃឈប់សម្រាកគឺត្រូវហាមឃាត់(មើល ៦:៥ ១៤:៥ និងការពន្យល់ មថ ១២:១–៨ ១១–១២ យហ ៥:១០ និងការពន្យល់ និងមើល នក ២០:៩–១០)។ *មេសាលាប្រជុំ* មើលការពន្យល់ ៨:៤១ ។

**១៣:១៥** *មនុស្សមានពុត* មើលការពន្យល់ មថ ៦:២ ។ *ស្រាយគោស្រាយលាពីចំណង* ពួកគេយកចិត្តទុកដាក់នឹងតម្រូវការរបស់សត្វធាតុខ្លាំងជាងតម្រូវការរបស់មនុស្សជាតិ ។ ព្រះយេស៊ូវទ្រង់បានហៅអ្នករិះគន់ទ្រង់ថា "មនុស្សមានពុត" ពីព្រោះពួកគេធ្វើពុតជាឧស្សាហ៍ខាងឯក្រឹត្យវិន័យ ប៉ុន្តែគំនិតរបស់ពួកគេ គឺបែរជាចង់វាយប្រហារមកលើទ្រង់ និងការប្រោសឱ្យជារបស់ទ្រង់ទៅវិញ ។

**១៣:១៦** ការដែលក្នុងលោកិយយើងនេះ មានពេញទៅដោយបាប បញ្ហាជំងឺនិងពិការគឺជាបញ្ហាធម្មតាទេ ហើយបុព្វហេតុនៃបញ្ហាទាំងនោះគឺបណ្ដាលមកពីកត្តាផ្សេងៗជាច្រើន ។ បុព្វហេតុនៃបញ្ហាភាគច្រើនក៏បណ្ដាលមកពីកត្តាជាច្រើនរួមផ្សំគ្នាផងដែរ ដែលរួមមានការខ្វះជីវជាតិ ការចម្លង ការបង្ការខ្សោយ និងសូម្បីតែការវាយប្រហារដោយផ្ទាល់របស់អារក្សក៏ជាបុព្វហេតុផងដែរ ។ ពេលណាដែលមានបញ្ហាទាំងនោះ យើងអាចរកឃើញប្រភពនៃបញ្ហាជំងឺទាំងនោះបានថា ជាសាតាំង ដែលជាដើមចមនៃគ្រប់សេចក្ដីអាក្រក់ទាំងអស់នៅលើលោកិយ ប៉ុន្តែ ដំណឹងល្អបានប្រកាសប្រាប់ពីសេចក្ដីសង្ឃឹមថា ព្រះយេស៊ូវទ្រង់មានអំណាចលើគ្រប់ទាំងសេចក្ដីអាក្រក់ព្រមទាំងជំងឺទៀតផង គឺទ្រង់អាចប្រោសឱ្យជាបានក្នុងពេលឥឡូវនេះ ហើយ

បានចងគាត់១៨ឆ្នាំមកហើយ ដូច្នេះ តើមិនគួរនឹងស្រាយ
ឱ្យរួចពីចំណងនេះ នៅថ្ងៃឈប់សំរាកដែរទេឬអី ១៧កាល
ទ្រង់មានបន្ទូលសេចក្តីទាំងនេះហើយ នោះអស់អ្នកដែល
ទាស់នឹងទ្រង់ ក៏អៀនខ្មាស[ផ]គ្រប់គ្នា តែបណ្តាមនុស្ស គេ
កើតមានសេចក្តីអំណរ ចំពោះគ្រប់ទាំងការឧត្តម ដែល
ទ្រង់ធ្វើនោះវិញ ។

## រឿងប្រៀបប្រដូចពីគ្រាប់ពូជ និងដំបែ

*១៣:១៨,១៩ = មក ៤:៣០–៣២*
*១៣:១៨–២១ = មថ ១៣:៣១–៣៣*

១៨ទ្រង់មានបន្ទូលថា តើនគរព្រះ[ព]ធៀបដូចជាអ្វី[ភ] តើ
ត្រូវយកអ្វីមកផ្ទឹមនឹងនគរនោះ ១៩គឺធៀបដូចជាគ្រាប់
ពូជម្យ៉ាងដែលមនុស្សម្នាក់យកទៅដាំក្នុងសួនច្បារ ខ្លួនវា
ដុះឡើងទៅជាដើមឈើយ៉ាងធំ[ម] ហើយសត្វហើរលើមេឃ
ក៏មកទំលើមែកបាន[យ] ២០ទ្រង់ក៏មានបន្ទូលទៀតថា តើគួរ
ឱ្យខ្ញុំធៀបនគរ ព្រះដូចជាអ្វី ២១នោះត្រូវធៀបដូចជាដំបែ
ដែលស្ត្រីម្នាក់យកទៅលាយនឹងម្សៅ៣រង្វាល់ ទាល់តែដោរ
ឡើងសព្វ ទាំងអស់[រ] ។

២២ទ្រង់ក៏យាងកាត់អស់ទាំងក្រុង អស់ទាំងភូមិ ទាំង
បង្រៀនបណ្តើរ ហើយចេះតែដំរង់ត្រង់ ឆ្ពោះទៅឯក្រុង

**១៣:១៧** ផ អស ៦៦:៥
**១៣:១៨** ព មថ ៣:២ ភ មថ ១៣:២៤
**១៣:១៩** ម លក ១៧:៦ យ មថ ១៣:៣២
**១៣:២១** រ ១កថ ៥:៦
**១៣:២២** ល លក ៩:៥១
**១៣:២៤** វ មថ ៧:១៣
**១៣:២៥** ស មថ ៧:២៣ ២៥:១០–១២
**១៣:២៧** ហ មថ ៧:២៣
**១៣:២៨** ឡ មថ ៨:១២

យេរូសាឡិម[ល] ២៣ក៏មានម្នាក់ទូលសួរថា ព្រះអម្ចាស់អើយ
តើមនុស្សដែលបានសង្គ្រោះ មានគ្នាតែបន្តិចទេឬអី តែ
ទ្រង់មានបន្ទូលទៅគេថា ២៤ចូរខំប្រឹងយ៉ាងអស់ពីចិត្ត
ឱ្យបានចូលទៅតាមទ្វារចង្អៀត[វ] ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាថា
នឹងមានមនុស្សជាច្រើនខំប្រឹងរកចូលដែរ តែចូលមិន
បានទេ ២៥កាលណាម្ចាស់ផ្ទះបានក្រោកឡើងបិទទ្វារ នោះ
អ្នករាល់គ្នានឹងចាប់តាំងឈរពីខាងក្រៅ គោះទ្វារទូលថា ឱ
ព្រះអម្ចាស់ៗអើយ សូមបើកឱ្យយើងខ្ញុំផង នោះទ្រង់នឹងមាន
បន្ទូលឆ្លើយថា អញមិនស្គាល់ឯងរាល់គ្នាដែលមកពីណា
ទេ[ស] ២៦រួចអ្នករាល់គ្នានឹងតាំងទូលថា យើងខ្ញុំបានទទួល
ទាននៅចំពោះទ្រង់ ហើយទ្រង់បានបង្រៀនតាមផ្លូវ
យើងខ្ញុំដែរ ២៧តែទ្រង់នឹងមានបន្ទូលថា អញប្រាប់ឯងរាល់
គ្នាថា អញមិនស្គាល់ឯងរាល់គ្នាដែលមកពីណាទេនែ អស់
អ្នកដែលប្រព្រឹត្តសេចក្តីទុច្ចរិតអើយ ចូរថយចេញពីអញ
ទៅ[ហ] ២៨ដូច្នេះ កាលណាឯងរាល់គ្នាត្រូវបោះទៅក្រៅនោះ
នឹងយំ ហើយសង្កៀតធ្មេញ[ឡ] នៅទីនោះ ដោយឃើញលោក
អ័ប្រាហាំ លោកអ៊ីសាក នឹងលោកយ៉ាកុប ហើយអស់ទាំង
ហោរានៅក្នុងនគរព្រះ ២៩ដ្បិតនឹងមានមនុស្សពីទិសខាង

---

នៅពេលដែលទ្រង់យាងមកវិញជាលើកទីពីរ ទ្រង់នឹងបញ្ចប់គ្រប់ទាំងជំងឺ និងពិការ ។

**១៣:១៩** *គ្រាប់ពូជម្យ៉ាង* មើលការពន្យល់ មថ ១៣:៣១–៣២ មក ៤:៣១ ។ ជួនកាលដើមឈើ នៅក្នុងព្រះគម្ពីរ គឺជានិមិត្តរូបតំណាងឱ្យជាតិសាសន៍ (មើល អគ ១៧:២៣ ៣១:៦ ដយ ៤:១១ និងការពន្យល់) ។

**១៣:២១** *ដំបែ* មើលការពន្យល់ មថ ១៣:៣៣ ។ ខនេះបានសង្កត់ធ្ងន់ថា ដំបែបានធ្វើឱ្យម្សៅឡើង ចាប់ពីផ្នែកខាងក្នុងម្សៅ រហូតដល់ផ្នែកខាងក្រៅម្សៅទាំងស្រុងតែម្តង ។ ពាក្យប្រៀបប្រដូចនេះ គឺនិយាយអំពីការជះឥទ្ធិពលដ៏ខ្លាំងក្លានៃនគរព្រះ ។ *៣រង្វាល់* តាមព្រះគម្ពីរដើមជាភាសាក្រិក៣រង្វាល់នោះត្រូវជា "៣ សាតាស (Satas)" (ប្រហែល២២លីត្រ) គឺដូចគ្នានឹងរង្វាល់ដែលនាងសារ៉ាប្រើក្នុង លប ១៨:៦ ដែរ (មើលការពន្យល់ខនោះ) ។

**១៣:២២** *អស់ទាំងក្រុង អស់ទាំងភូមិ* គឺទីកន្លែងនៃហេតុការណ៍ក្នុង ១១:១ និង ១៣:២១ ។ ព្រះយេស៊ូវទ្រង់បានយាងចេញពីស្រុកយូដា ហើយទ្រង់បានចាប់ផ្តើមព្រះរាជកិច្ចទ្រង់ជាបន្តទៀតនៅក្នុងស្រុកពេរ៉េ និងក្នុងក្រវល់ស្រុកនោះ ដែលមានកត់ទុកក្នុង ១៣:២២–១៩:២៧ មថ ១៩:១–២០:២៨ មក ១០ (មើលពន្យល់ ១០:៣២) និង យហ ១០:៤០–៤២ ។ គេជឿថា ព្រះយេស៊ូវទ្រង់បានយាងទៅស្រុកកាលីឡេ គឺយាងទៅកាន់ភាគជើងក្នុងអំឡុងពេលចុងក្រោយនៃព្រះរាជកិច្ចនៅស្រុកពេរ៉េរួចទ្រង់យាងទៅក្រុងយេរីខូ ដោយកាត់តាមស្រុកពេរ៉េ គឺទ្រង់យាងទៅភាគត្បូងម្តងទៀត ។ ការសន្និដ្ឋានរបស់ព្រះគម្ពីរលូកា អំពីព្រះបន្ទូលមួយចំនួនដែលព្រះយេស៊ូវទ្រង់មានបន្ទូល នៅក្នុងពេលដែលទ្រង់បំពេញព្រះរាជកិច្ចនៅស្រុកពេរ៉េនោះ មានលក្ខណៈខុសគ្នាពីការសន្និដ្ឋានរបស់ព្រះគម្ពីរម៉ាថាយ ដោយទីកន្លែង (៧:១៣–១៤,២២–២៣) ។ ការនេះប្រហែលជាព្រះយេស៊ូវទ្រង់មានបន្ទូលពីសេចក្តីតែមួយ តែនៅក្នុងឱកាសផ្សេងៗពីគ្នា ។ *យេរូសាឡិម* គឺទីកន្លែងដែលព្រះយេស៊ូវនឹងត្រូវសុគត ។ ទោះបីជាព្រះយេស៊ូវទ្រង់កំពុងបំពេញព្រះរាជកិច្ចនៅក្នុងស្រុកពេរ៉េក៏ដោយ ក៏ព្រះនេត្រទ្រង់នៅតែសម្លឹងឆ្ពោះទៅរកទីក្រុងបរិសុទ្ធ និងគោលដៅជាទីបញ្ចប់របស់ទ្រង់ជានិច្ច ។

**១៣:២៦–២៧** សាសន៍យូដាសម័យនោះ នឹងទូលទៅព្រះយេស៊ូវថា "ពួកយើងជាសាសន៍យូដាដូចលោកដែរ ជាពូជរបស់លោកអាប្រាហាំ ជារាស្ត្រដែលព្រះទ្រង់បានជ្រើសតាំង ហើយយើងប្រាកដជាមានកន្លែងនៅក្នុងនគរព្រះហើយ" ប៉ុន្តែ ព្រះយេស៊ូវទ្រង់នឹងមានបន្ទូលតបទៅពួកគេវិញថា "ពួកអ្នករាល់គ្នាពិតជាមិនបានជឿខ្ញុំទេ ដូចនេះខ្ញុំមិនស្គាល់អ្នករាល់គ្នាទេ" ។

**១៣:២៣** *មនុស្សដែលបានសង្គ្រោះ មានគ្នាតែបន្តិចទេឬអី ?* នេះប្រហែលជាសំណួរមួយដែលកើតចេញពីការសង្កេតឃើញថា ទោះជាមានមនុស្សទាំងហ្វូងៗ មកស្តាប់ព្រះយេស៊ូវមានបន្ទូល និងឱ្យទ្រង់ប្រោសជំងឺក៏ដោយ ក៏មានអ្នកតាមទ្រង់តែពីរបីនាក់ប៉ុណ្ណោះដែលមានចិត្តស្មោះត្រង់។ ព្រះយេស៊ូវទ្រង់មិនបានមានបន្ទូលឆ្លើយចំៗតែម្តងនោះទេ ប៉ុន្តែ ទ្រង់មានបន្ទូលព្រមានថា មានមនុស្សជាច្រើននឹងព្យាយាមចូលទៅក្នុងនគរព្រះ នៅពេលដែលហួសពេលទៅហើយ ។

**១៣:២៧** *អញមិនស្គាល់ឯងរាល់គ្នា* មើល មថ ៧:២៣ ២៥:១២ ។

កើត ខាងលិច[អ] ខាងជើង ហើយខាងត្បូងមកអង្គុយក្នុង
នគរព្រះដែរ ៣០ហើយមើលនឹងមានមនុស្ស ក្រោយទៅជា
មុន នឹងមនុស្សមុនទៅជាក្រោយវិញ[ក]។

## ព្រះយេស៊ូវសោកស្តាយក្រុងយេរូសាឡិម

*១៣:៣៤,៣៥ = មថ ២៣:៣៧–៣៩*
*១៣:៣៤,៣៥ = លក ១៩:៤១*

៣១នៅថ្ងៃនោះឯង មានពួកផារិស៊ីខ្លះមកទូលទ្រង់ថា ចូរ
ថយចេញពីនេះទៅ ដ្បិតស្តេចហេរ៉ូឌ[ខ]រកចង់សំឡាប់លោក
៣២តែទ្រង់មានបន្ទូលទៅគេថា ចូរអ្នករាល់គ្នាទៅប្រាប់
សត្វកញ្ជ្រោងនោះថា មើល ខ្ញុំដេញអារក្ស ហើយប្រោស
មនុស្សឱ្យជា នៅថ្ងៃនេះហើយថ្ងៃស្អែក លុះដល់ថ្ងៃទី៣
ខ្ញុំនឹងបានសំរេចការ[គ] ៣៣ប៉ុន្តែ ត្រូវឱ្យខ្ញុំដើរតាមផ្លូវ ខ្ញុំទៅ
នៅក្នុងថ្ងៃនេះ ថ្ងៃស្អែក ហើយខានស្អែកទៀត ដ្បិតគ្មាន
ទំនងឱ្យហោរា[ឃ]ណាវិនាសក្រៅពីក្រុងយេរូសាឡិមទេ ។
៣៤ឱយេរូសាឡិម ក្រុងយេរូសាឡិម ជាទីក្រុងដែល
សំឡាប់ពួកហោរា ហើយចោលថ្មទៅអស់អ្នក ដែលបាន
ចាត់មកឯឯងអើយ តើប៉ុន្មានដងហើយ ដែលអញចង់
ប្រមូលកូនឯងរាល់គ្នា ដូចជាមេមាន់ប្រមូលកូនក្រុងក្រោម

**១៣:២៩** អ មថ ៨:១១
**១៣:៣០** ក មថ ១៩:៣០
**១៣:៣១** ខ មថ ១៤:១
**១៣:៣២** គ ហព ២:១០
**១៣:៣៣** ឃ មថ ២១:១១
**១៣:៣៤** ង មថ ២៣:៣៧
**១៣:៣៥** ច យរ ១២:១៧ ២២:៥ ឆ ទដ ១១៨:២៦ លក ១៩:៣៨
**១៤:១** ជ លក ៧:៣៦ ១១:៣៧ ឈ មថ ១២:១០
**១៤:៣** ញ មថ ២២:៣៥ ដ មថ ១២:២
**១៤:៥** ឋ លក ១៣:១៥

ស្លាប[ង] តែឯងមិនព្រមសោះនោះ ៣៥មើលផ្ទះឯងរាល់គ្នា
ត្រូវចោលនៅស្ងាត់ឈឹង[ច] ហើយអញប្រាប់ឯងរាល់គ្នាថា
មិនឃើញអញទៀតទាល់តែឯងនិយាយថា ព្រះអង្គដែល
យាងមក ដោយនូវព្រះនាមព្រះអម្ចាស់ទ្រង់ប្រកបដោយ
ព្រះពរ[ឆ]។

## ព្រះយេស៊ូវគង់នៅផ្ទះពួកផារិស៊ី

*១៤:៨–១០ = សភ ២៥:៦,៧*

**១៤** ១មានកាល១ថ្ងៃ ជាថ្ងៃឈប់សំរាក ព្រះយេស៊ូវយាង
ចូលទៅសោយព្រះស្ងោយក្នុងផ្ទះនាម៉ឺនម្នាក់ ដែលជាពួក
ផារិស៊ី[ជ] ពួកនោះក៏រិះគន់មើលទ្រង់[ឈ] ២គ្រានោះឃើញ
មានមនុស្សកើតទាចម្នាក់ នៅចំពោះទ្រង់ ៣ទ្រង់មានបន្ទូល
សួរពួកអ្នកប្រាជ្ញច្បាប់[ញ] នឹងពួកផារិស៊ីថា តើមានច្បាប់
នឹងមើលឱ្យជា នៅថ្ងៃឈប់សំរាកឬទេ[ដ] ៤តែគេនៅតែ
ស្ងៀម នោះទ្រង់ក៏យកគាត់មកប្រោសឱ្យជា រួចឱ្យគាត់
ទៅវិញ ៥ហើយទ្រង់មានបន្ទូលទៅគេថា ក្នុងពួកអ្នករាល់
គ្នា បើអ្នកណាមានលា ឬគោ ធ្លាក់ចុះក្នុងរណ្តៅ នៅថ្ងៃ
ឈប់សំរាក តើមិនស្រង់យកចេញ ក្នុង១រំពេចនោះទេឬអី[ឋ]

**១៣:២៩** *មនុស្សពីទិសខាងកើត . . . ខាងត្បូង* គឺមកពីគ្រប់ទិសទី (ទដ ១០៧:៣) និងមកពីគ្រប់ចំណោមមនុស្សទាំងអស់ ដោយរាប់បញ្ចូលទាំងសាសន៍ដទៃផងដែរ ។ *មកអង្គុយក្នុងនគរព្រះ* មើល ១៤:១៥ មថ ៨:១១ និងការពន្យល់ ។

**១៣:៣០** មើល មថ ១៩:៣០ និងការពន្យល់ ។

**១៣:៣១** *ស្តេចហេរ៉ូឌរកចង់សំឡាប់លោក* មើលការពន្យល់ មថ ១៤:១ ។ គេជឿថាព្រះយេស៊ូវទ្រង់កំពុងតែស្ថិតនៅក្នុងស្រុកពេរ៉េ ជាស្រុកដែលស្តេចហេរ៉ូឌត្រួតត្រា (មើលការពន្យល់ ៣:១)។ ពួកផារិស៊ីម្នាក់នេះចង់ធ្វើឱ្យព្រះយេស៊ូវមានការភ័យខ្លាច ហើយយាងចេញពីតំបន់នេះទៅឯស្រុកយូដាវិញ ។

**១៣:៣២** *សត្វកញ្ជ្រោង* ជាសត្វសាហាវ ។ *ថ្ងៃនេះ ហើយថ្ងៃស្អែក* តាមវប្បធម៌យូដា ឃ្លាមួយនេះអាចប្រើសំដៅទៅលើរយៈពេលមួយ ដែលមិនច្បាស់លាស់ តែមានព្រំដែនកំណត់ ។ *ខ្ញុំនឹងបានសំរេចការ* ព្រះទ្រង់បានរៀបផែនការទុកជា មុនសម្រាប់ព្រះជន្មគង់នៅរបស់ព្រះយេស៊ូវ ហើយគ្មានការរងទុក្ខណាមួយអាចកើតឡើងចំពោះទ្រង់បានឡើយ ដរាបណាមិនទាន់ដល់ពេលដែលត្រូវសម្រេចទេនោះ (៤:៤៣ ៩:២២)។

**១៣:៣៣** *ក្រៅពីក្រុងយេរូសាឡិម* គឺវេលារបស់ទ្រង់មិនទាន់ដល់ទេ (លក ២:៣៨ យហ ២:៤ និងការពន្យល់ យហ ៨:៥៩ ១០:៣៩ ១១:៥៤)។ ទ្រង់នឹងសុគតក្នុងក្រុងយេរូសាឡិម ដូចពួកហោរាមួយចំនួនដែលបានមកមុនទ្រង់ដែរ ។

**១៣:៣៤–៣៥** មើល មថ ២៣:៣៧–៣៩ ។

**១៣:៣៤** មូលហេតុដែលព្រះយេស៊ូវយកព្រះទ័យទុកដាក់នឹងក្រុងយេរូសាឡិមខ្លាំងយ៉ាងនេះ ពីព្រោះទីក្រុងយេរូសាឡិម (ទីក្រុងរបស់ព្រះ) គឺជានិមិត្តរូបតំណាងឱ្យជាតិសាសន៍អ៊ីស្រាអែលទាំងមូល ប៉ុន្តែ ទីក្រុងយេរូសាឡិមមានប្រវត្តិបដិសេធហោរារបស់ព្រះ (១ពរ ១៩:១០ ២រប ២៤:១៩ យរ ២:៣០ ២៦:២០–២៣) ហើយទីក្រុងនេះនឹងបដិសេធព្រះមែស៊ីថែមទៀត ដូចដែលបានបដិសេធអ្នកដែលព្រះទ្រង់បានចាត់ឱ្យមកមុនទ្រង់ដែរ ។

**១៣:៣៥** *ផ្ទះ . . .ចោលនៅស្ងាត់ឈឹង* គឺព្រះអម្ចាស់ទ្រង់នឹងបោះបង់ចោលព្រះវិហារ និងទីក្រុងរបស់ទ្រង់(២១:២០,២៤ យរ ១២:៧ ២២:៥ និងការពន្យល់)។ *មិនឃើញអញទៀតទាល់តែ* មើល សក ១២:១០ និងការពន្យល់ វវ ១:៧ អស ៤៥:២៣ រម ១៤:១១ ភល ២:១០–១១ ។

**១៤:១** ក្នុងចំណោមការអស្ចារ្យនៅថ្ងៃឈប់សម្រាកដែលបានកត់ត្រាទុកចំនួន៧ លោកលូកាបានកត់ត្រាទុកចំនួនប្រាំ(៤:៣១,៣៨ ៦:៦ ១៣:១៤ និង ១៤:១) ហើយពីរទៀតគឺនៅក្នុង យហ ៥:១០ (មើលពន្យល់ ខនេះ) ៩:១៤ ។ ចំពោះការឃ្លាំ មើលរបស់ពួកផារិស៊ី សូមមើលការពន្យល់ ១៣:១៤ ។ គេរៀបចំអាហារថ្ងៃឈប់សម្រាកទុកមុនថ្ងៃនោះមួយថ្ងៃ ។

**១៤:២** *កើតទាច* គឺកើតរោគដែលកើតមកពីមានសារធាតុរាវហួសកំរិតក្នុងជាលិកា ហើយអវៈយវៈ និងខ្លួនត្រូវហើមប៉ោងដោយសារធាតុរាវនោះ ។ មានភស្តុតាងបញ្ជាក់ថា បុរសកើតទាចនោះអាចផ្លាស់ទីបាន គឺនៅពេលដែលគាត់ចូលទៅខាងក្នុងផ្ទះរបស់ពួកផារិស៊ីម្នាក់នោះ ។

**១៤:៣** *អ្នកប្រាជ្ញច្បាប់* មើលការពន្យល់ ៥:១៧ ៧:៣០ ។ ដើម្បីធ្វើឱ្យពួកអ្នកប្រាជ្ញច្បាប់ពិបាកក្នុងការប្រឆាំងនឹងទ្រង់ ក្រោយពេលដែលទ្រង់ធ្វើការអស្ចារ្យ ព្រះយេស៊ូវបានមានបន្ទូលសួរពួកគេមុនពេលទ្រង់ធ្វើការអស្ចារ្យ ។

**១៤:៥** *លា* ព្រះគម្ពីរជាភាសាអង់គ្លេសមួយចំនួនប្រើពាក្យ "កូន" (របស់អ្នករាល់គ្នា)។ ក្នុងខនេះព្រះយេស៊ូវទ្រង់មានបន្ទូលការពារក្រឹត្យវិន័យម្តងទៀត

៦តែគេពុំអាចនឹងឆ្លើយអ្វីទូលទ្រង់ពីដំណើរនោះបានទេ។
៧កាលទ្រង់ឃើញពួកភ្ញៀវ ដែលគេរើសយកកន្លែងប្រសើរៗ[ឌ]
នោះក៏មានបន្ទូលជាពាក្យប្រៀបធៀបទៅគេថា ៨បើមាន
អ្នកណាអញ្ជើញអ្នករាល់គ្នាទៅបរិភោគការ នោះកុំឱ្យ
អង្គុយត្រង់កន្លែងដ៏ប្រសើរឡើយ ក្រែងចួនជាគេបាន
អញ្ជើញអ្នកណាដែលធំជាងអ្នក ៩ហើយកាលណាអ្នកមង្គល
ការដែលបានអញ្ជើញអ្នក នឹងអ្នកនោះផង គាត់មកនិយាយ
នឹងអ្នកថា ទុកកន្លែងនេះឱ្យអ្នកនេះអង្គុយវិញ នោះអ្នក
នឹងថយ ទៅអង្គុយនៅកន្លែងក្រោយបង្អស់ ទាំងខ្មាសគេផង
១០ដូច្នេះកាលណាគេអញ្ជើញអ្នក នោះត្រូវទៅអង្គុយ នៅ
កន្លែងក្រោយបង្អស់សិន ដើម្បីកាលណាអ្នកមង្គលការមក
ដល់ នោះគាត់នឹងនិយាយថា សំឡាញ់អើយ សូមអញ្ជើញ
មកអង្គុយនៅខាងមុខវិញ នោះអ្នកនឹងបានថ្កើងឡើង នៅ
មុខពួកអ្នកដែលអង្គុយនៅតុជាមួយគ្នា ១១ដ្បិតអស់អ្នកណា
ដែលដំកើងខ្លួន នោះនឹងត្រូវបន្ទាបចុះ តែអ្នកណាដែល
បន្ទាបខ្លួន នោះនឹងបានដំកើងឡើងវិញ[ឍ]។
១២ទ្រង់ក៏មានបន្ទូលទៅអ្នក ដែលបានអញ្ជើញទ្រង់ថា
កាលណាអ្នកលៀងភ្ញៀវពេលថ្ងៃត្រង់ ឬពេលល្ងាចនោះ
កុំឱ្យអញ្ជើញពួកសំឡាញ់ បងប្អូនសាច់ញាតិ ឬអ្នកមាន
ដែលនៅជិតខាងឡើយ ក្រែងគេក៏អញ្ជើញអ្នកទៅសង
ដូច្នោះវិញដែរ ១៣បើកាលណាអ្នករៀបលៀងភ្ញៀវ នោះ
ចូរអញ្ជើញពួកអ្នកក្រ អ្នកពិការ អ្នកខ្វិច និងអ្នកខ្វាក់វិញ[ណ]
១៤យ៉ាងនោះអ្នកនឹងបានពរពិត ដ្បិតមនុស្សទាំងនោះគ្មានអ្វី
នឹងសងអ្នកវិញទេ លុះកាលណាពួកមនុស្សសុចរិតរស់
ឡើងវិញ នោះអ្នកនឹងបានរង្វាន់ហើយ[ត]។

## រឿងប្រៀបប្រដូចពីពិធីជប់លៀង

*១៤:១៦-២៤ = មថ ២២:២-១៤*

១៥កាលម្នាក់ដែលអង្គុយនៅតុជាមួយ បានឮពាក្យទាំង
នោះ គាត់ក៏ទូលទ្រង់ថា មានពរហើយ អ្នកណាដែលនឹង
បរិភោគ[ថ]ក្នុងនគរព្រះ[ទ] ១៦តែទ្រង់មានបន្ទូលថា មានបុរស
ម្នាក់រៀបជប់លៀងជាយ៉ាងធំ ក៏អញ្ជើញមនុស្សជាច្រើន
១៧ដល់ពេលជិតស៊ីលៀង គាត់ប្រើបាវឱ្យទៅប្រាប់ពួកភ្ញៀវ
ថា សូមអញ្ជើញមក ដ្បិតទាំងអស់បានរៀបប្រុងជាស្រេច
ហើយ ១៨តែគេចាប់តាំងដោះសាដូចគ្នាទាំងអស់ អ្នកមុន
និយាយថា ខ្ញុំបានទិញចំការ ហើយខ្ញុំត្រូវទៅមើលចំការ
នោះ សូមឱ្យលោកអត់ទោស ១៩ម្នាក់ទៀតថា ខ្ញុំបានទិញ
គោ៥នឹម ខ្ញុំត្រូវទៅលវាមើល សូមឱ្យលោកអត់ទោស
២០ម្នាក់ទៀតក៏ថា ខ្ញុំទើបនឹងការប្រពន្ធហើយ ដោយហេតុ
នោះបានជាខ្ញុំទៅមិនបាន ២១បាវនោះក៏ត្រឡប់ទៅវិញ ជំ
រាបចៅហ្វាយខ្លួនតាមដំណើរនោះ ដូច្នេះលោកប្រាប់ទៅ
បាវ ទាំងកំហឹងថា ចូរប្រញាប់ចេញទៅឯផ្លូវតូចធំនៅទី
ក្រុង នាំអស់ពួកមនុស្សក្រ ពិការ ខ្វាក់ នឹងខ្វិច ចូលមកឱ្យ
ឆាប់[ធ]២២បាវនោះក៏ជំរាបថា លោក ការដែលលោកបង្គាប់

**១៤:៧** ឌ លក ១១:៤៣
**១៤:១១** ឍ មថ ២៣:១២
**១៤:១៣** ណ ខ.២១
**១៤:១៤** ត កច ២៤:១៥
**១៤:១៥** ថ អស ២៥:៦ មថ ២៦:២៩ លក ១៣:២៩ វវ ១៩:៩ ទ មថ ៣:២
**១៤:២១** ធ ខ.១៣

ចំពោះការធ្វើអំពើ ដោយក្ដីមេត្តាករុណា (សូមមើល មថ ១២:៧ ១២ មក ២:២៨ ៣:៤)។

**១៤:៧** *កន្លែងប្រសើរ* ការរើសយកតែកន្លែងល្អៗនេះ ប្រហែលអាចជាបុព្វហេតុនៃបញ្ហាដែលពួកសាវ័កមានក្នុងថ្ងៃលៀងព្រះអម្ចាស់ (២២:២៤ និង ២០:៤៦ មក ១២:៣៩ និងការពន្យល់)។

**១៤:១១** *អ្នកណាដែលបន្ទាបខ្លួន នោះនឹងបានដំកើងឡើង* គឺជាបញ្ញត្តិដែលមាននិយាយជាច្រើនដងនៅក្នុងព្រះគម្ពីរ (១១:៤៣ ១៨:១៤ ២០:៤៦ ២របា ៧:១៤-១៥ ទដ ៣:៣៤ ២៥:៦-៧ មថ ១៨:៤ ២៣:១២ យក ៤:១០ ១ពត ៥:៦)។

**១៤:១៤** *ពួកមនុស្សសុចរិតរស់ឡើងវិញ* គឺក្នុងពេលដែលមនុស្សទាំងអស់ត្រូវរស់ឡើងវិញ (ដយ ១២:២ យហ ៥:២៨-២៩ និងការពន្យល់ កច ២៤:១៥)។ អ្នកកាត់ស្រាយមួយចំនួនជឿថា ការរស់ឡើងវិញរបស់ពួកមនុស្សសុចរិត (១កថ ១៥:២៣ ១ធថ ៤:១៦ វវ ២០:៤-៦) គឺជារឿងដោយឡែកពីការរស់ឡើងវិញ "ជាសា កល" (១កថ ១៥:១២,២១ ហព ៦:២ វវ ២០:១១-១៥)។ *ពួកសុចរិត* គឺជាពួកអ្នកដែលព្រះអម្ចាស់ទ្រង់បានហៅយ៉ាងដូចនេះ ព្រោះពួកគេមានសេចក្ដីជំនឿលើព្រះគ្រីស្ទ ដែលបានសុគតជួសគេ (រម ១:១៧ និងការពន្យល់) និងជាពួកអ្នកដែល បានធ្វើបន្ទាល់ពីសេចក្ដីជំនឿរបស់ពួកគេដោយការដែលពួកគេបានធ្វើ (មថ ២៥:៣៤-៤០)។

**១៤:១៥** *បរិភោគក្នុងនគរព្រះ* គឺបរិភោគក្នុងពិធីស៊ីលៀងដ៏ធំអស្ចារ្យរបស់ព្រះមែស៊ី ។ ទំនាក់ទំនងរវាងនគរព្រះជាមួយនឹងពិធីស៊ីលៀងគឺជារឿងធម្មតាទេ (១៣:២៩ អស ២៥:៦ មថ ៨:១១ ២៥:១-១០ ២៦:២៩ វវ ១៩:៩ និងការពន្យល់)។

**១៤:១៦** *ទ្រង់មានបន្ទូល* (តបទៅវិញ) ព្រះយេស៊ូវទ្រង់បានតបនឹងយោបល់របស់បុរសម្នាក់នេះ ជាឱកាសមានបន្ទូលជាពាក្យប្រៀបប្រដូច ដែលព្រមានថា មិនមែនគ្រប់គ្នាសុទ្ធតែបានចូលនគរព្រះទេ ហើយនគរព្រះក៏មិនមែនសម្រាប់តែសាសន៍យូដាតែមួយ ដូចអ្វីដែលបុរសម្នាក់នោះចង់មានន័យនោះឡើយ ។

**១៤:១៨** *គេចាប់តាំងដោះសាដូចគ្នាទាំងអស់* (សូមប្រៀបធៀបជាមួយនឹង មថ ២២:៥) ការដោះសាទាំងបីយ៉ាងគឺបានបញ្ជាក់អំពី "ការខ្វល់ខ្វាយអំពីជីវិតនៅលើលោកិយ" (ខ.១៨) "សេចក្ដីឆបោករបស់ទ្រព្យសម្បត្តិ" (ខ.១៩) និង "សេចក្ដីត្រេកត្រអាលនៅក្នុងជីវិតរស់នៅ" (ខ.២០) ហើយសេចក្ដីទាំងនោះ "ខ្ទប់ព្រះបន្ទូលជាប់" (មថ ១៣:២២ លក ៨:១៤)។ ទោះជាពួកគេម្នាក់ៗមានការដោះសាផ្សេងៗពីគ្នាក៏ដោយ ក៏ពួកគេគង់តែនឹងទទួលលទ្ធផលដូចៗគ្នា ។

នោះ បានធ្វើហើយ តែនៅតែមានសល់កន្លែងទៀត ។
២៣ រួចចៅហ្វាយប្រាប់ថា ចូរចេញទៅតាមផ្លូវច្រកល្ហក
តាមរបង ហើយបង្ខំគេឱ្យចូលមក ដើម្បីឱ្យផ្ទះអញបាន
ពេញ ២៤ ដ្បិតអញប្រាប់ថា ឯពួកមនុស្សទាំងប៉ុន្មាន ដែល
អញបានអញ្ជើញមកមុននោះ អញលែងឱ្យអ្នកណា១ភ្លក់
ម្ហូបរបស់អញហើយ[ន] ។

## ការលះបង់ដើម្បីធ្វើជាសិស្សព្រះយេស៊ូវ

២៥ មានមនុស្សសន្ធឹកណាស់ ដើរទៅជាមួយនឹងទ្រង់នោះ
ទ្រង់បែរទៅមានបន្ទូលនឹងគេថា ២៦ បើអ្នកណាមកឯខ្ញុំ
ដោយមិនបានលះអាល័យពីឪពុកម្តាយ ប្រពន្ធកូន បងប្អូន
ប្រុសស្រី នឹងជីវិតខ្លួនឯងផង អ្នកនោះនឹងធ្វើជាសិស្សខ្ញុំមិន
បានទេ[ប] ២៧ ហើយអ្នកណាដែលមិនផ្ទុកឈើឆ្កាងខ្លួនមក
តាមខ្ញុំ នោះក៏ធ្វើជាសិស្សខ្ញុំមិនបានដែរ[ផ] ២៨ ដ្បិតក្នុងពួក
អ្នករាល់គ្នា បើមានអ្នកណាចង់សង់ផ្ទះពីថ្ម តើមិនអង្គុយ
លៃលកមើលជាមុនទេឬអី ដើម្បីឱ្យដឹងជា មានល្មមនឹងធ្វើ
បង្ហើយបានឬមិនបាន ២៩ ក្រែងកាលណាដាក់ជើងជញ្ជាំង
រួចបង្ហើយមិនបាន នោះអស់អ្នកណាដែលឃើញ ក៏នឹង
សើចចំអកឱ្យ ៣០ ដោយពាក្យថា អ្នកនេះបានចាប់ផ្តើមសង់
ផ្ទះ តែបង្ហើយមិនបាន ៣១ ឬតើមានស្តេចឯណា ដែលរៀប
ចេញទៅច្បាំងនឹងស្តេច១ទៀត ឥតអង្គុយពិគ្រោះមើលជា
មុនសិន ដើម្បីឱ្យដឹងជាខ្លួននាំពល១ម៉ឺនទៅតទល់នឹងស្តេច
ដែលនាំពល២ម៉ឺន មកច្បាំងបានឬមិនបាន ៣២ បើឃើញ
ថាមិនបានទេ នោះទ្រង់នឹងចាត់រាជទូត ឱ្យទៅស៊ើបសួរពី
កិច្ច ដែលចងស្ពានមេត្រីនឹងគ្នាជាយ៉ាងណា ក្នុងកាលដែល
ស្តេចនោះនៅឆ្ងាយនៅឡើយ ៣៣ ដូច្នេះ អស់អ្នកណាក្នុង
ពួកអ្នករាល់គ្នា ដែលមិនលះអាល័យពីរបស់ទ្រព្យខ្លួនទាំង
អស់ នោះធ្វើជាសិស្សខ្ញុំមិនបានទេ[ព] ៣៤ អំបិលជារបស់ល្អ
តែបើបាត់ជាតិប្រៃហើយ តើនឹងយកអ្វីធ្វើឱ្យប្រៃឡើងវិញ
បាន[ភ] ៣៥ គ្មានប្រយោជន៍ដល់ដីឬជីទេ គេនឹងចោលទៅក្រៅ
វិញ[ម] អ្នកណាដែលមានត្រចៀកសំរាប់ស្តាប់ ឱ្យស្តាប់ចុះ[យ] ។

## រឿងប្រៀបប្រដូចអំពីចៀមដែលបាត់

*១៥:៤–៧ = មថ ១៨:១២–១៤*

**១៥** ១ អស់ទាំងអ្នកយកពន្ធ[រ] នឹងអ្នកមានបាប គេក៏ចូលមក
ជិត ដើម្បីស្តាប់ទ្រង់ ២ នោះពួកផារិស៊ី នឹងពួកអាចារ្យ គេ
ឌុកដាន់ថា អ្នកនេះទទួលមនុស្សបាប ហើយក៏ស៊ីជាមួយ
នឹងគេផង[ល] ៣ តែទ្រង់មានបន្ទូល ជាពាក្យប្រៀបប្រដូចនេះ
ដល់គេថា[វ] ៤ ក្នុងពួកអ្នករាល់គ្នា បើអ្នកណាមានចៀម១រយ
តែបាត់១ តើមិនទុកចៀម៩៩ឱ្យនៅទីរហោស្ថាន ដើម្បី
នឹងទៅតាមរកចៀម១ដែលបាត់ ទាល់តែឃើញទេឬអី[ស]
៥ កាលណារកឃើញហើយ នោះក៏លើកព្រនរមក ដោយអំ
ណរ ៦ លុះមកដល់ផ្ទះវិញ អ្នកនោះនឹងហៅពួកសំឡាញ់

**១៤:២៤** ន មថ ២១:៤៣ កច ១៣:៤៦
**១៤:២៦** ប មថ ១០:៣៧ យហ ១២:២៥
**១៤:២៧** ផ មថ ១០:៣៨ លក ៩:២៣
**១៤:៣៣** ព ភល ៣:៧,៨
**១៤:៣៤** ភ មក ៩:៥០
**១៤:៣៥** ម មថ ៥:១៣ យ មថ ១១:១៥
**១៥:១** រ លក ៥:២៩
**១៥:២** ល មថ ៩:១១
**១៥:៣** វ មថ ១៣:៣
**១៥:៤** ស ទដ ២៣, ១១៩:១៧៦ យរ ៣១:១០ អគ ៣៤:១១–១៦ លក ៥:៣២ ១៩:១០

**១៤:២៤** *ពួកមនុស្សទាំងប៉ុន្មាន ដែលអញបានអញ្ជើញ* ព្រះយេស៊ូវទ្រង់បានព្រមានពួកអ្នកដឹកនាំសាសន៍យូដាថា អ្នកដែលបដិសេធការអញ្ជើញរបស់ព្រះយេស៊ូវ ឱ្យចូលរួមពិធីស៊ីលៀងរបស់ព្រះមែស៊ី នឹងមិនបានភ្លក់ម្ហូបរបស់នគរព្រះសោះឡើយ (២០:៩–១៩ និងការពន្យល់ មថ ២១:៤១) ។

**១៤:២៦** *លះអាល័យពីឪពុកម្តាយ* គឺមានន័យថាម្នាក់ៗត្រូវស្រឡាញ់ព្រះឱ្យបានខ្លាំងជាងអ្វីៗទាំងអស់ គឺទោះជាគ្រួសាររបស់ផងខ្លួនក៏ដោយ (មឡ ១:២–៣) ។ មើល មថ ១០:៣៧ និងការពន្យល់ មឡ ១:៣ ។

**១៤:២៧** *ផ្ទុកឈើឆ្កាងខ្លួន* មើល ៩:២៣ មថ ១០:៣៨ និងការពន្យល់ ។

**១៤:២៨** *លៃលកមើលជាមុន* ព្រះយេស៊ូវទ្រង់មិនសព្វព្រះទ័យនឹងជំនឿដែលគ្មានការប្តេជ្ញាត្រឹមត្រូវ ដែលគ្រាន់តែរំពឹងថានឹងបានព្រះពរនោះឡើយ ។ ជាងសង់ផ្ទះជាមនុស្សដែលលៃលកមើលខ្ទង់ចំណាយមុនសង់ផ្ទះ ចំណែកស្តេចក៏ប្រមាណកម្លាំងទាហានមុននឹងច្បាំង (ខ.៣១) ផងដែរ ដូចនេះមនុស្សយើងក៏ត្រូវតែពិចារណាយ៉ាងហ្មត់ចត់ ពីសេចក្តីអ្វីដែលព្រះយេស៊ូវទ្រង់សព្វព្រះទ័យឱ្យលះបង់ថ្វាយទ្រង់មុននឹងទុកដាក់ជីវិតនឹងទ្រង់ផងដែរ ។

**១៤:៣៣** *លះអាល័យពីរបស់ទ្រព្យខ្លួនទាំងអស់* ព្រះយេស៊ូវទ្រង់បានព្រមានដល់អ្នកដើរតាមទ្រង់ទាំងអស់ ឱ្យធ្វើការលះបង់ទាំងស្រុងថ្វាយទ្រង់ (ភល ៣:៧–៨) គឺត្រូវរៀបចំខ្លួនលះបង់ដោយអំណរ នូវគ្រប់ទាំងអ្វីៗទាំងអស់ថ្វាយទ្រង់ដូចជា ទ្រព្យសម្បត្តិ សេចក្តីសុខ គ្រួសារ ហើយសូម្បីតែជីវិតរបស់ខ្លួនក៏ដោយ បើមិនដូច្នោះទេមិនអាចធ្វើជាសិស្សរបស់ទ្រង់បានឡើយ (មើល មថ ១០:៣៧ មក ៨:៣៤ លក ១៤:២៦–២៧) ។

**១៤:៣៤** *អំបិលជារបស់ល្អ* មើលការពន្យល់ មក ៩:៥០ ។

**១៥:១** *អ្នកយកពន្ធ និងអ្នកមានបាប* មើលការពន្យល់ ៣:១២ មក ២:១៥ ។

**១៥:២** *ដុកដាន់* មានន័យថា រំអុកឱ្យ និយាយកកែកករ រករឿងរកហេតុ និយាយរុកកួន និយាយចាក់រុក ញុះញង់ ។ ព្រះគម្ពីរអង់គ្លេសប្រើពាក្យ "ខ្សិប ឬ រអ៊ូ" ។ ក្នុងពេលនោះពួកផារិស៊ី និងពួកអាចារ្យបានធ្វើរឿងនេះតែក្នុងចំណោមគ្នា ពួកខ្លួនប៉ុណ្ណោះ ពួកគេមិននិយាយបើកចំហនោះឡើយ ។ *ស៊ីជាមួយនឹងគេ* ការបរិភោគអាហារជាមួយគ្នា គឺមានន័យលើសពីទំនាក់ទំនងធម្មតាទៅទៀត ព្រោះជាការបង្ហាញពីការព្រមទទួលស្គាល់ (ទដ ៤១:៩ យហ ១៣:១៨ កច ១១:៣ ១កថ ៥:១១ និងការពន្យល់ កទ ២:១២) ។

**១៥:៣** *ពាក្យប្រៀបប្រដូចនេះ* ព្រះយេស៊ូវទ្រង់បានមានបន្ទូលតបទៅវិញ ដោយយករឿងមួយមកបង្ហាញពីភាពផ្ទុយគ្នា រវាងសេចក្តីស្រឡាញ់របស់ព្រះ និងការរើសអើងរបស់ពួកផារិស៊ី ។

**១៥:៤** *ចៀម១ដែលបាត់* សេចក្តីនេះមានទំនាក់ទំនងជិតស្និទ្ធ នឹងសេចក្តីអំពីការគង្វាល (ទដ ២៣ អស ៤០:១១ អស ៣៤:១១–១៦ និងការពន្យល់) ។ ការតាមរកចៀម១ដែលបាត់នេះ គឺជាការដែលព្រះទ្រង់តាមរកមនុស្សដែលបាត់បង់ ដើម្បីសង្គ្រោះពួកគេឱ្យរួចពីបាប ។

នឹងពួកអ្នកជិតខាងមក ប្រាប់ថាសូមអរសប្បាយជាមួយនឹង
ខ្ញុំ ដ្បិតចៀមខ្ញុំដែលបាត់ នោះឃើញវិញហើយ[ហ] ៧ខ្ញុំប្រាប់
អ្នករាល់គ្នាថា នៅស្ថានសួគ៌នឹងមានសេចក្តីអំណរយ៉ាង
នោះដែរ ដោយសារមនុស្សបាបតែ១នាក់ដែលប្រែចិត្ត
វិញ ជាជាងមនុស្សសុចរិត៩៩នាក់ ដែលមិនត្រូវការប្រែ
ចិត្តទេ[ឡ]។

## រឿងប្រៀបប្រដូចពីប្រាក់ដែលបាត់

៨ឬមានស្ត្រីឯណា ដែលមានប្រាក់១០ដួង បើបាត់១តើ
មិនអុជចង្កៀង ហើយបោសផ្ទះរកអស់ពីចិត្ត ទាល់តែបាន
ឃើញទេឬអី ៩កាលរកឃើញ នោះក៏ហៅពួកសំឡាញ់
នឹងអ្នកជិតខាងមកប្រាប់ថា សូមអរសប្បាយជាមួយនឹង
ខ្ញុំចុះ ដ្បិតប្រាក់ខ្ញុំដែលបាត់ នោះរកឃើញវិញហើយ[អ]
១០ដូច្នេះ ខ្ញុំប្រាប់អ្នករាល់គ្នាថា ក៏មានសេចក្តីអំណរនៅ
មុខពួកទេវតានៃព្រះយ៉ាងនោះដែរ ដោយសារមនុស្ស
បាបតែ១នាក់ដែលប្រែចិត្តវិញ[ក]។

## រឿងប្រៀបប្រដូចពីកូនពៅវង្វេង

១១រួចទ្រង់ក៏មានបន្ទូលថា មានបុរសម្នាក់មានកូនប្រុស២[ខ]
១២កូនពៅនិយាយទៅឪពុកថា សូមលោកឪពុកប្រគល់
ចំណែកមរដក[គ] ដែលត្រូវចែកដល់ខ្ញុំនោះមក គាត់ក៏ចែក
ទ្រព្យ[ឃ]នោះដល់កូន ១៣ក្រោយបន្តិចមក កូនពៅប្រមូល
ទាំងអស់ ចេញទៅឯស្រុកឆ្ងាយ ហើយក៏បង្ហិនទ្រព្យទៅ[ង]
ដោយល្បែងដ៏ហួសខ្នាត ១៤កាលបានចាយអស់រលីងហើយ
នោះកើតមានអំណត់ ជាខ្លាំងនៅស្រុកនោះ វាក៏មានសេច
ក្តីទ័លក្រ ១៥រួចទៅបំរើអ្នកស្រុកនោះម្នាក់ ហើយគេប្រើ
ឱ្យទៅឯវាលឃ្វាលហ្វូងជ្រូក[ច] ១៦វាមានចិត្តចង់ចំអែតពោះ
ដោយសំបកដែល ជ្រូកស៊ីណាស់ តែគ្មានអ្នកណាឱ្យសោះ
១៧កាលវាភ្ញាក់ដឹងខ្លួន នោះក៏គិតថា ឪពុកអញមានជើង
ឈ្នួលប៉ុន្មានៗ សុទ្ធតែមានអាហារបរិបូរគ្រប់គ្នា តែនៅ
ទីនេះ អញជិតដាច់ពោះស្លាប់ហើយ ១៨អញនឹងក្រោក
ឡើងទៅនិយាយនឹងគាត់ថា លោកឪពុក ខ្ញុំបានធ្វើបាប[ឆ]
នឹងព្រះ ហើយនឹងលោកឪពុកមែន ១៩ខ្ញុំនេះមិនគួរឱ្យគេ
ហៅជាកូនលោកឪពុកទៀតទេ សូមទទួលខ្ញុំទុកដូចជាជើង
ឈ្នួលលោកឪពុកវិញចុះ ២០នោះវា ក៏ក្រោកឡើងដើរទៅ
លុះឪពុកឃើញពីចំងាយហើយ ក៏មានចិត្តអាណិត មេត្តា
ហើយរត់ទៅឱបថើបវា[ជ] ២១ទើបវានិយាយថា លោកឪពុក
ខ្ញុំបានធ្វើបាបនឹងព្រះ ហើយនឹងលោកឪពុក[ឈ] ខ្ញុំមិនគួរឱ្យ
គេហៅជាកូនរបស់លោកឪពុកទៀតទេ ២២តែឪពុកប្រាប់
ទៅពួកបាវគាត់ថា ចូរយកអាវ[ញ]ល្អបំផុតចេញមកបំពាក់
ឱ្យវា ហើយយកចិញ្ចៀន[ដ] នឹងស្បែកជើងមកឱ្យផង ២៣រួច
យកកូនគោដែលបំប៉នមកសំឡាប់ចុះ យើងនឹងបរិភោគ
ឱ្យសប្បាយចិត្ត ២៤ដ្បិតកូនអញនេះបានស្លាប់ ឥឡូវ
រស់ឡើងវិញ[ឋ] ក៏បាត់ទៅ ហើយបានឃើញមកវិញ នោះ
គេក៏បរិភោគសប្បាយទាំងអស់គ្នាទៅ[ឌ] ២៥ឯកូនច្បង
នៅឯចំការ កាលត្រឡប់មកជិតដល់ផ្ទះនោះក៏ឮសូរភ្លេង
នឹងរបាំ ២៦គាត់ហៅពួកបាវម្នាក់មកសួរថា គេធ្វើអ្វីហ្នឹង

**១៥:៦** ហ ខ.៩
**១៥:៧** ឡ ខ.១០
**១៥:៩** អ ខ.៦
**១៥:១០** ក ខ.៧
**១៥:១១** ខ មថ ២១:២៨
**១៥:១២** គ ចទ ២១:១៧ ឃ ខ.៣០
**១៥:១៣** ងខ ៣០ លក ១៦:១
**១៥:១៥** ច លវ ១១:១៧
**១៥:១៨** ឆ លវ ២៦:៤០ មថ ៣:២
**១៥:២០** ជ លប ៤៥:១៤,១៥ ៤៦:២៩ កច ២០:៣៧
**១៥:២១** ឈ ទដ ៥១:៤
**១៥:២២** ញ សក ៣:៤ វវ ៦:១១ ដ លប ៤១:៤២
**១៥:២៤** ឋ អភ ២:១,៥ ៥:១៤ ១ធថ ៥:៦ ឌ ខ.៣២

---

**១៥:៧** *នៅស្ថានសួគ៌នឹងមានសេចក្តីអំណរយ៉ាងនោះដែរ* សេចក្តីអំណររបស់ព្រះ ចំពោះការប្រែចិត្តរបស់មនុស្សមានបាប គឺផ្ទុយស្រឡះពីអាកប្ប–កិរិយារបស់ពួកផារិស៊ី និងពួកអាចារ្យ(ខ.២)។ *មនុស្សសុចរិត . . .មិនត្រូវការប្រែចិត្ត* អាចជាការចំអកឱ្យអ្នកដែលគិតថាខ្លួនជាមនុស្សសុចរិត (ដូចជាពួកផារិស៊ី និងអាចារ្យជាដើម) ហើយគិតថាខ្លួនមិនត្រូវការប្រែចិត្តទេ ។
**១៥:៨** *ប្រាក់១០ដួង* ព្រះគម្ពីរភាសាក្រិកប្រើពាក្យ "ប្រាក់១០ដ្រាចម៉ាស" (Drach- mas )"។ ដ្រាចម៉ាសគឺជាប្រភេទលុយកាក់ដែលមានតម្លៃស្មើប្រាក់ឈ្នួលមួយថ្ងៃ និងលុយកាក់ "ឌិណារី" របស់រ៉ូម៉ាំងផងដែរ (មថ ២០:២)។ *រកអស់ពីចិត្ត* នៅមជ្ឈិមបូព៌ាផ្ទះភាគច្រើនសង់ផ្ទាល់ដីហើយគ្មានបង្អួចទេ ធ្វើឱ្យពិបាកក្នុងការរកប្រាក់កាក់តែមួយឱ្យឃើញ ។
**១៥:១២** *ចែកទ្រព្យ* កូនពៅនោះត្រូវទទួលមួយភាគបីនៃចំណែកមរដក ហើយកូនបងត្រូវទទួលពីភាគបី(១២:១៣ ចទ ២១:១៧ និងការពន្យល់)។ ជាញឹកញាប់ កូនពៅត្រូវទទួលចំណែកនោះ នៅពេលដែលឪពុកបានស្លាប់ទៅ ទោះបីជាជួនកាលឪពុកអាចសម្រេចចិត្តថា ត្រូវចែកឱ្យបានមុនពេលស្លាប់ និងសម្រេចលាឈប់ពីការគ្រប់គ្រងលើទ្រព្យសម្បត្តិក៏ដោយ ប៉ុន្តែក្នុងវគ្គនេះរឿងដែលមិនធម្មតាគឺកូនពៅជាអ្នកផ្តើមគំនិតចែកមរដក ជាទង្វើមួយបង្ហាញពីការមិនគោរពយ៉ាងក្រអើត ចំពោះអំណាចរបស់ឪពុកដែលជាមេគ្រួសារ ។
**១៥:១៣** *ប្រមូលទាំងអស់* នៅពេលដែលកូនពៅម្នាក់នេះចាកចេញទៅ គេអាចមើលដឹងយ៉ាងច្បាស់ពីហេតុផលរបស់គាត់ ព្រោះគាត់បានប្រមូលយកសម្បត្តិរបស់គាត់ចេញទៅទាំងអស់ ដោយគ្មានបន្សល់ទុករបស់អ្វីសម្រាប់ពេលត្រឡប់មកវិញឡើយ។ គាត់ចង់ឱ្យខ្លួនគាត់រស់នៅដោយសេរីដោយគ្មានអាណាព្យាបាល និងចង់ចាយវាយចំណែក ដែលគាត់បានពីទ្រព្យសម្បត្តិគ្រួសាររបស់គាត់តាមទំនើងចិត្ត ។ *ដ៏ហួសខ្នាត* គឺទង្វើដែលបានបង្ហាញឱ្យកាន់តែច្បាស់នៅក្នុងខ.៣០ ទោះបីជាកូនច្បងប្រហែលជាបាននិយាយពន្លើសដោយសារសេចក្តីកំហឹងក៏ដោយ ។
**១៥:១៥** *ឃ្វាលហ្វូងជ្រូក* គឺជាការងារថោកទាប ហើយគួរឱ្យស្អប់ខ្ពើមបំផុតសម្រាប់សាសន៍យូដាពីព្រោះសត្វជ្រូកជាសត្វដែល"មិនស្អាត" (លវ១១:៧)។
**១៥:១៦** *សំបក* គឺគ្រាប់របស់ផ្លែ"ការូប(Carob )" មានដើមដុះនៅតំបន់សមុទ្រមេឌីទែរ៉ាណេ ដែលផ្លែរបស់វាមានរស់ជាតិស្រដៀងស្ករសូកូឡា ។
**១៥:២២–២៣** *អាវល្អបំផុត . . . ចិញ្ចៀន . . . ស្បែកជើង . . . បរិភោគឱ្យសប្បាយ* ទង្វើនីមួយៗសុទ្ធតែជាសញ្ញាបញ្ជាក់ពីការរាប់រក និងទទួលស្គាល់ (លប ៤១:៤២ និងការពន្យល់ សក ៣:៤)។ អាវល្អគឺសម្រាប់ភាពសមរម្យ ចិញ្ចៀន សម្រាប់អំណាច ស្បែកជើងសម្រាប់កូនប្រុស(ពួកទាសករដើរជើង

| សេចក្តីបង្រៀនរបស់ព្រះយេស៊ូវជារឿងប្រៀបប្រដូច | | | |
|---|---|---|---|
| រឿងប្រៀបប្រដូច | គម្ពីរម៉ាថាយ | គម្ពីរម៉ាកុស | គម្ពីរលូកា |
| ចង្កៀងដែលគ្របនឹងថាំង | ៥:១៤–១៥ | ៤:២១–២២ | ៨:១៦, ១១:៣៣ |
| មនុស្សល្ងង់ និងមនុស្សឆ្លាតសង់ផ្ទះ | ៧:២៤–២៧ | | ៦:៤៧–៤៩ |
| ក្រណាត់ថ្មីប៉ះអាវចាស់ | ៩:១៦ | ២:២១ | ៥:៣៦ |
| ស្រាថ្មីដាក់ក្នុងថង់ចាស់ | ៩:១៧ | ២:២២ | ៥:៣៧–៣៨ |
| អ្នកព្រោះគ្រាប់ពូជ | ១៣:៣–៨,១៨–២៣ | ៤:៣–៨,១៤–២០ | ៨:៥–៨,១១–១៥ |
| ស្រងែ | ១៣:២៤–៣០,៣៦–៤៣ | | |
| គ្រាប់ពូជតូចល្អិត | ១៣:៣១–៣២ | ៤:៣០–៣២ | ១៣:១៨–១៩ |
| ដំបែ | ១៣:៣៣ | | ១៣:២០–២១ |
| កំណប់ដែលបានកប់ទុក | ១៣:៤៤ | | |
| កែវមុក្តា | ១៣:៤៥–៤៦ | | |
| សំណាញ់ | ១៣:៤៧–៥០ | | |
| ថៅកែម្នាក់ | ១៣:៥២ | | |
| ចៀមដែលបាត់ | ១៨:១២–១៤ | | ១៥:៤–៧ |
| បាវបម្រើដែលគ្មានក្តីមេត្តា | ១៨:២៣–៣៤ | | |
| ពួកអ្នកស៊ីឈ្នួលធ្វើចំការទំពាំងបាយជូរ | ២០:១–១៦ | | |
| កូនប្រុសពីរនាក់ | ២១:២៨–៣២ | | |
| ពួកអ្នកជួលចំការទំពាំងបាយជូរ | ២១:៣៣–៤៤ | ១២:១–១១ | ២០:៩–១៨ |
| ពិធីជប់លៀងក្នុងមង្គលការ | ២២:២–១៤ | | |
| ដើមល្វា | ២៤:៣២–៣៥ | ១៣:២៨–២៩ | ២១:២៩–៣១ |
| បាវបម្រើវៃឆ្លាត ហើយស្មោះត្រង់ | ២៤:៤៥–៥១ | | ១២:៤២–៤៨ |
| ស្ត្រីព្រហ្មចារីទាំង១០នាក់ | ២៥:១–១៣ | | |
| បាវបម្រើល្អ ហើយស្មោះត្រង់ | ២៥:១៤–៣០ | | ១៩:១២–២៧ |
| ចៀម និងពពែ | ២៥:៣១–៤៦ | | |
| គ្រាប់ពូជ | | ៤:២៦–២៩ | |
| បាវបម្រើដែលចាំយាម | | ១៣:៣៥–៣៧ | ១២:៣៥–៤០ |
| អ្នកឱ្យប្រាក់គេខ្ចី | | | ៧:៤១–៤៣ |
| សាសន៍សាម៉ារីដ៏ល្អ | | | ១០:៣០–៣៧ |
| មិត្តសំឡាញ់ក្នុងពេលខ្វះខាត | | | ១១:៥–៨ |
| អ្នកចងការ | | | ១២:១៦–២១ |
| ដើមល្វាដែលមិនបង្កើតផលផ្លែ | | | ១៣:៦–៩ |
| កន្លែងក្រោយបង្អស់ក្នុងពិធីបរិភោគការ | | | ១៤:៧–១៤ |
| ពិធីជប់លៀងដ៏ធំ | | | ១៤:១៦–២៤ |
| ការលះបង់ដើម្បីធ្វើជាសិស្សព្រះយេស៊ូវ | | | ១៤:២៨–៣៣ |
| ប្រាក់ដែលបាត់ | | | ១៥:៨–១០ |
| កូនពៅវង្វេង (ខ្ជះខ្ជាយ) | | | ១៥:១១–៣២ |
| អ្នកត្រួតត្រាដែលមានប្រាជ្ញាល្អិត | | | ១៦:១–៨ |
| អ្នកមាន និងឡាសារ | | | ១៦:១៩–៣១ |
| ចៅហ្វាយ និងបាវបម្រើ | | | ១៧:៧–១០ |
| ស្ត្រីមេម៉ាយម្នាក់មានចិត្តស៊ូ | | | ១៨:២–៨ |
| ពួកផារិស៊ី និងពួកអ្នកយកពន្ធ | | | ១៨:១០–១៤ |

២៧បាវនោះជំរាបថា ប្អូនលោកត្រឡប់មកវិញហើយ
លោកឪពុកបានសំឡាប់កូនគោដែលបំប៉ន ដោយព្រោះ
បានកូនមកវិញដោយសុខសាន្ត ២៨ដូច្នេះ គាត់ក៏ខឹង[ឈ] មិន
ព្រមចូលទៅសោះ បានជាឪពុកចេញមកអង្វរដល់គាត់
២៩តែគាត់ឆ្លើយថា មើល ខ្ញុំបានបំរើលោកឪពុកប៉ុន្មានឆ្នាំ
នេះមកហើយ មិនដែលធ្វើខុសអ្វីនឹងបង្គាប់សោះ តែលោក
ឪពុកមិនដែលឱ្យកូនពពែ សូម្បីតែ១ ឱ្យខ្ញុំបានអរសប្បាយ
ជាមួយនឹងពួកមិត្រសំឡាញ់ខ្ញុំឡើយ ៣០ឯកូនលោកឪពុក
ដែលវាបង្ហិនបំផ្លាញសម្បត្តិ[ណ]លោកឪពុកអស់ ដោយនូវ
ស្រីអ្នកលេងនេះ[ត] កាលវាបានមកដល់ នោះលោកឪពុកសំ
ឡាប់កូនគោ ដែលបំប៉នឱ្យវាភ្លាម ៣១ឪពុកក៏តបថា កូន
អើយ ឯងបាននៅជាមួយនឹងអញជាដរាប ឯរបស់អញទាំង
ប៉ុន្មាន ក៏ជារបស់ឯងដែរ ៣២គួរឱ្យយើងស៊ីលៀង ដោយអរ
សប្បាយទៅ ពីព្រោះប្អូនឯងនេះបានស្លាប់ ឥឡូវរស់ឡើង
វិញ ក៏បាត់បង់តែបានឃើញមកវិញហើយ[ថ] ។

## រឿងប្រៀបប្រដូចពីអ្នកត្រួតត្រាដែលមានប្រាជ្ញាល្អិត

**១៦** ១ទ្រង់ក៏មានបន្ទូលទៅពួកសិស្សថា មានសេដ្ឋីម្នាក់
ដែលគេមកប្តឹងលោក ពីអ្នកត្រួតត្រាលើរបស់ទ្រព្យលោក
ថា គាត់ចាយបង្ហិនបង្ខោចទ្រព្យសម្បត្តិលោកជាច្រើន[ទ]
២លោកក៏ហៅអ្នកនោះមកសួរថា តើរឿងអ្វីដែលអញឮ
និយាយពីឯង ចូររៀបរាប់ប្រាប់ពីការឯងត្រួតត្រានោះ
មកមើល ពីព្រោះឯងនៅត្រួតត្រាការទៀតពុំបានទេ ។
៣អ្នកដំរួតនោះគិតក្នុងចិត្តថា តើអញនឹងធ្វើអ្វី ដ្បិតចៅ
ហ្វាយអញគិតដកការត្រួតត្រានេះពីអញចេញហើយ អញ
ទៅកាប់ដីមិនកើតទេ និងទៅសូមទាន ក៏ខ្មាសគេដែរ
៤អញដឹងការដែលអញនឹងធ្វើហើយ ដើម្បីបើកាលណា
លោកបណ្តេញអញ ពីការត្រួតត្រាចេញ នោះនឹងមានគេ
ទទួលអញ ឱ្យទៅនៅផ្ទះគេមិនខាន ៥គាត់ក៏ហៅពួកកូន
បំណុលរបស់ចៅហ្វាយគាត់មក គាត់សួរអ្នកដែលមកមុន
ថា តើអ្នកជំពាក់ចៅហ្វាយខ្ញុំប៉ុន្មាន ៦អ្នកនោះឆ្លើយថាជំ
ពាក់ប្រេង១រយប៉ោត រួចគាត់ប្រាប់អ្នកនោះថា ចូរយក
សំបុត្រអ្នក ទៅអង្គុយសរសេរដាក់៥០វិញ ជាប្រញាប់ទៅ
៧រួចគាត់សួរទៅម្នាក់ទៀតថា ឯអ្នក តើជំពាក់ប៉ុន្មាន អ្នក
នោះឆ្លើយថា ជំពាក់ស្រូវ១រយហាប គាត់ប្រាប់អ្នកនោះ
ថា ចូរយកសំបុត្រអ្នកទៅសរសេរ ដាក់៨០វិញទៅ ៨ចៅ
ហ្វាយក៏សរសើរដល់អ្នកត្រួតត្រាទុច្ចរិតនោះ ពីព្រោះគាត់
បានប្រព្រឹត្តដោយឆ្លៀវឆ្លាត ដ្បិតមនុស្សរបស់ផងលោកីយ

**១៥:២៨** ឈ យណ ៤:១
**១៥:៣០** ណ ខ.១២,១៣ ត សភ ២៩:៣
**១៥:៣២** ថ ខ.២៤ មទ្ឡ ៣:១៧
**១៦:១** ទ លក ១៥:១៣,៣០

ទទេ) ហើយកូនគោបំប៉នគឺសម្រាប់ឱកាសពិសេស ។

**១៥:២៨** *គាត់* សេចក្តីស្រឡាញ់ដោយការអត់ទោសរបស់ឪពុកម្នាក់នេះតំណាងឱ្យសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់ ហើយកំហឹងដោយការអាក់អន់ចិត្តរបស់កូនច្បង គឺដូចជាអាកប្បកិរិយារបស់ពួកផារិស៊ី និងពួកអាចារ្យដែលទាស់ប្រឆាំងនឹងព្រះយេស៊ូវ (ខ.២) ។

**១៥:២៩** *កូនពពែ* ជាអាហារថ្នាក់ទាបជាងកូនគោបំប៉ន ។

**១៥:៣១** *របស់អញទាំងប៉ុន្មាន ក៏ជារបស់ឯងដែរ* ឪពុកម្នាក់នេះមានសេចក្តីស្រឡាញ់ចំពោះកូនទាំងពីរនាក់ ។ រឿងប្រៀបប្រដូចនេះបានបង្ហាញពីភាពផ្ទុយគ្នារវាងការមិនរាប់រកដោយចិត្តអាត្មានិយមរបស់ពួកផារិស៊ី ដែលមិនបានយល់ពីសេចក្តីស្រឡាញ់របស់ព្រះ និងសេចក្តីអំណររបស់ព្រះយេស៊ូវចំពោះការប្រែចិត្តរបស់មនុស្សមានបាប ។

**១៥:៣២** *បានស្លាប់ ឥឡូវរស់ឡើងវិញ* គឺទិដ្ឋភាពដ៏ស្រស់ស្អាតនៃការវិលត្រឡប់របស់កូនពៅ ដែលជារូបភាពនៃការផ្លាស់ប្រែចិត្តទទួលជឿព្រះផងដែរ (រម ៦:១២-១៣ និងការពន្យល់ អភ ២:១,៥)។ ឃ្លាថា "បានបាត់ហើយរកឃើញវិញ" ជាញឹកញាប់គេប្រើក្នុងន័យថា "បានវិនាសទៅ ហើយបានសង្គ្រោះវិញ" (១៩:១០ មថ ១០:៦ ១៨:១២-១៤ និងការពន្យល់)។

**១៦:១** *ពួកសិស្ស* ប្រហែលជារាប់បញ្ចូលទាំងពួកសិស្សទាំង១២នាក់ និងពួកសិស្សដទៃទៀត (៦:១៣ និងការពន្យល់ ១០:១)។ *អ្នកត្រួតត្រាលើរបស់ទ្រព្យ* គឺអ្នកបម្រើម្នាក់ ដែលកាន់កាប់គ្រប់គ្រងកិច្ចការរកស៊ីទាំងអស់របស់ម្ចាស់គាត់ (១កថ ៤:១-២ និងការពន្យល់ ៤:១)។ *បង្ហិនបង្ខោច* គាត់បានចាយវាយខ្ជះខ្ជាយទ្រព្យសម្បត្តិរបស់ម្ចាស់គាត់ ដូចជាកូនពៅកញ្ជះកញ្ជាយម្នាក់នោះដែរ (១៥:១៣)។

**១៦:៣** *តើអញនឹងធ្វើអ្វី* អ្នកត្រួតត្រាដែលមិនស្មោះត្រង់ម្នាក់នេះ (ខ.៨) ពុំមានការនឹករអែងទេ នៅពេលដែលគាត់ប្រើមុខនាទីរបស់គាត់ដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួននោះ ទោះជាគាត់ដឹងហើយថាការនោះជាការបោកប្រាស់ម្ចាស់គាត់ក៏ដោយ ។ ដោយដឹងថាគាត់នឹងបាត់បង់ការងារ គាត់ក៏រៀបគម្រោងសម្រាប់ពេលខាងមុខ ដោយកាត់បន្ថយបំណុលដែលគេជំពាក់ម្ចាស់គាត់ ដើម្បីឱ្យពួកកូនបំណុលត្រូវជាប់កាតព្វកិច្ចសងគុណដល់គាត់វិញ ។ បណ្តាអ្នកកាត់ស្រាយទាំងឡាយមានមតិមិនយល់ស្របជុំវិញបញ្ហាទង្វើមិនស្មោះត្រង់ ដែលគាត់មានគម្រោងកាត់បន្ថយបំណុលនោះ ។ តើគាត់បានកាត់នូវអ្វីដែលពិតជារបស់ម្ចាស់គាត់ ឬគាត់លះចោលការប្រាក់ដែលម្ចាស់គាត់គ្មានសិទ្ធិគិតពីពួកកូនបំណុល ? ជាដំបូងអ្នកត្រួតត្រាម្នាក់នេះប្រហែលជាបានគិតបំណុលលើស ដែលជាការបំពានក្រឹត្យវិន័យរបស់លោកម៉ូសេ ដែលហាមប្រាមមិនឱ្យយកការប្រាក់ពីរាស្ត្ររបស់ព្រះ (នក ២២:២៥-២៧ លវ ២៥:៣៦ និងការពន្យល់ ចទ ២៣:១៩-២០)។ ដូចនេះដើម្បីកាត់បន្ថយបំណុល គាត់ប្រហែលជាគិតតែបំណុលដើមវិញ ដែលនឹងបានបំពេញចិត្តម្ចាស់គាត់ផង និងបានអនុគ្រោះឱ្យពួកកូនបំណុលផង ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាទាំងពីរខាងលើគឺមិនខុសពីគ្នាប៉ុន្មានទេ ព្រោះគាត់មានប្រាជ្ញាល្អិតល្អន់ល្មមនឹងអាចធ្វើការមួយណាក៏បាន ដើម្បីរៀបគម្រោងសម្រាប់សុវត្ថិភាពរបស់គាត់នៅពេលខាងមុខនោះ ។

នេះ[ធ] គេមានប្រាជ្ញា[ន]ចំពោះជំនាន់គេ ជាជាងមនុស្សរបស់
ផងពន្លឺទៅទៀត[ប] [៩]ខ្ញុំក៏ប្រាប់អ្នករាល់គ្នាថា ចូរប្រើទ្រព្យ
សម្បត្តិលោកីយនេះ[ផ] ឱ្យបានមិត្រសំឡាញ់ដល់ខ្លួន ដើម្បី
កាលណាអ្នករាល់គ្នាខាននៅ នោះនឹងមានគេទទួលអ្នក
រាល់គ្នា ឱ្យនៅក្នុងទីលំនៅដ៏ស្ថិតស្ថេរអស់កល្បជានិច្ច វិញ[ព]
[១០]អ្នកណាដែលស្មោះត្រង់ក្នុងការតូចបំផុត នោះក៏ឈ្មោះ
ថា ស្មោះត្រង់ក្នុងការធំ[ភ] ហើយអ្នកណាដែលទុច្ចរិតក្នុង
ការតូចបំផុត នោះក៏ឈ្មោះថាទុច្ចរិតក្នុងការដ៏ធំដែរ
[១១]ដូច្នេះ បើអ្នករាល់គ្នាមិនស្មោះត្រង់ ចំពោះទ្រព្យសម្បត្តិ
របស់លោកីយទេ[ម] តើអ្នកណាហ៊ានផ្ញើសម្បត្តិដ៏ពិតទុកនឹង
អ្នករាល់គ្នាបាន [១២]ហើយបើអ្នករាល់គ្នាមិនស្មោះត្រង់
នឹងរបស់គេទេ តើអ្នកណានឹងហ៊ានឱ្យរបស់អ្វីដាច់ជា
របស់ផងអ្នកបាន [១៣]គ្មានបាវណាដែលបំរើចៅហ្វាយ២
បានទេ ពីព្រោះបាវនោះនឹងស្អប់១ស្រឡាញ់១ ឬនឹងកាន់
ខាង១ ហើយមើលងាយ១ ដូច្នេះ អ្នករាល់គ្នាក៏បំរើព្រះផង
ទ្រព្យសម្បត្តិ ផងពុំបានដែរ[យ]។
[១៤]ឯពួកផារិស៊ី ដែលជាពួកអ្នកមានចិត្តលោភ[រ] គេក៏បាន
ស្តាប់គ្រប់សេចក្តីទាំងនោះដែរ ហើយគេចំអកឱ្យទ្រង់[ល]
[១៥]នោះទ្រង់មានបន្ទូលទៅគេថា អ្នករាល់គ្នាជាពួកដែល
សំដែងខ្លួនជាសុចរិត[វ]នៅចំពោះមុខមនុស្ស តែព្រះទ្រង់
ជ្រាបចិត្ត[ស]អ្នករាល់គ្នាហើយ ដ្បិតរបស់ណាដែលមនុស្ស
គាប់ចិត្តរាប់អានជាច្រើន នោះជាទីស្អប់ខ្ពើមនៅចំពោះ
ព្រះវិញ ។

## សេចក្តីបង្រៀនបន្ថែម

[១៦]មានក្រិត្យវិន័យ នឹងទំនាយនៃពួកហោរា ដរាបមកដល់
យ៉ូហាន[ហ] តាំងពីនោះមក គេបានផ្សាយ[ឡ]ដំណឹងពីនគរព្រះ
ទូទៅ ហើយមនុស្សទាំងអស់កំពុងតែខំប្រឹងចូល [១៧]ប៉ុន្តែ
ដែលផ្ទៃមេឃ នឹងផែនដីបាត់ទៅ នោះងាយជាជាងបាត់
ក្បៀស១ក្នុងក្រិត្យវិន័យទៅទៀត[អ]។
[១៨]អស់អ្នកណាដែលលែងប្រពន្ធ ទៅយក១ទៀតនោះ
ឈ្មោះថាប្រព្រឹត្តអំពើកំផិត ហើយអស់អ្នកណាដែលយក
ស្ត្រីប្តីលែង នោះក៏ឈ្មោះថាប្រព្រឹត្តសេចក្តីកំផិតដែរ[ក]។

## អ្នកមាន និងឡាសារ

[១៩]មានបុរសម្នាក់មានទ្រព្យសម្បត្តិច្រើន គាត់ស្លៀកពាក់
សំពត់ពណ៌ស្វាយ នឹងសំពត់ទេសឯកយ៉ាងម៉ដ្ត តែងតែ
ស៊ីលៀងដ៏ឧត្តមប្រសើររាល់តែថ្ងៃ[ខ] [២០]ក៏មានបុរសក្រ[គ]ម្នាក់

**១៦:៨** ធ ទដ ១៧:១៤ ន ទដ ១៨:២៦ ប យហ ១២:៣៦ អភ ៥:៨ ១ថន ៥:៥
**១៦:៩** ផ ខ.១១,១៣ ព មថ ១៩:២១ លក ១២:៣៣
**១៦:១០** ភ មថ ២៥:២១,២៣ លក ១៩:១៧
**១៦:១១** ម ខ.៩,១៣
**១៦:១៣** យ ខ.៩,១១ មថ ៦:២៤
**១៦:១៤** រ ១ធថ ៣:៣ ល លក ២៣:៣៥
**១៦:១៥** វ លក ១០:២៩ ស វវ ២:២៣
**១៦:១៦** ហ មថ ៥:១៧ ១១:១២,១៣ ឡ មថ ៤:២៣
**១៦:១៧** អ មថ ៥:១៨
**១៦:១៨** ក មថ ៥:៣១,៣២ ១៩:៩ មក ១០:១១ រម ៧:២,៣ ១កថ ៧:១០,១១
**១៦:១៩** ខ អគ ១៦:៤៩
**១៦:២០** គ កថ ៣:២

**១៦:៨** *មនុស្សរបស់ផងពន្លឺ* គឺរាស្ត្ររបស់ព្រះ (មើល យហ ១២:៣៥–៣៦ អភ ៥:៨ ១ធថ ៥:៥ និងការពន្យល់)។

**១៦:៩** *ប្រើទ្រព្យសម្បត្តិលោកីយ* រាស្ត្ររបស់ព្រះត្រូវប្រើអ្វីដែលព្រះបានប្រទានដោយប្រុងប្រយ័ត្ននិងឈ្លាសវៃ មិនមែនដើម្បីឱ្យបាននគរព្រះ (ផ្ទះដែលនៅអស់កល្បជានិច្ច) ទេ ប៉ុន្តែ ដើម្បីឱ្យអ្នកដែលត្រូវជួយនោះបានទទួលស្វាគមន៍រាស្ត្ររបស់ព្រះនៅក្នុងនគរទ្រង់ ។ បើសិនជារាស្ត្ររបស់ព្រះប្រើទ្រព្យសម្បត្តិដើម្បីជួយដល់តម្រូវការរបស់អ្នកដទៃ ឬជួយឱ្យអ្នកឯទៀតបានស្វែងរកព្រះគ្រីស្ទ នោះការលះបង់របស់ពួកគេ នៅលើផែនដីនេះនឹងនាំឱ្យពួកគេបានទទួលព្រះពរដ៏នៅអស់កល្បជានិច្ច ។

**១៦:១០** *ស្មោះត្រង់ក្នុងការធំ* មើល ១៩:១៧ មថ ២៥:២១ ។ ភាពស្មោះត្រង់គឺមិនត្រូវកំណត់ដោយបរិមាណរបស់ដែលបានផ្ទុកផ្តាក់នោះទេ ប៉ុន្តែ ដោយចារិតលក្ខណៈរបស់អ្នកដែលប្រើរបស់ទាំងនោះ ។

**១៦:១១** *សម្បត្តិដ៏ពិត* គឺសម្បត្តិដែលជាកម្មសិទ្ធរបស់នគរព្រះហើយផ្ទុយនឹង "សម្បត្តិរបស់លោកិយ"។

**១៦:១៣** *ចៅហ្វាយពីរ* មើល មថ ៦:២៤ សូមផ្ទៀបនឹង យក ៤:៤ និងការពន្យល់ ។

**១៦:១៦** *ដរាបមកដល់យ៉ូហាន* កិច្ចការបម្រើព្រះរបស់លោកយ៉ូហាន–បាទីស្ទ គឺរៀបចំផ្លូវថ្វាយព្រះយេស៊ូវដ៏ជាព្រះមែស៊ី ។ កិច្ចការរបស់លោកគឺជាបន្ទាត់ពុះចែករវាងសញ្ញាចាស់ (ក្រឹត្យវិន័យ និងពួកហោរា) និងសញ្ញាថ្មី (មើលការពន្យល់ យរ ៣១:៣១–៣៤ ហព ៨:៦–១២)។ *ខំប្រឹងចូល* មានការជជែកបដិសេធគ្នា អំពីអត្ថន័យរបស់ពាក្យនេះ ប៉ុន្តែ ន័យរបស់វាប្រាកដជាសំដៅទៅលើបណ្តាជន ដែលឆ្លើយតបចំពោះដំណឹងល្អពីនគរព្រះ ដោយការខំប្រឹងប្រែងយ៉ាងខ្លាំងអស់ពីចិត្ត ។ មានមនុស្សទាំងហ្វូងៗមកស្តាប់ព្រះយេស៊ូវ និងទទួលព្រះបន្ទូលទ្រង់ ។

**១៦:១៧** ព្រះរាជកិច្ចរបស់ព្រះយេស៊ូវ (ដែលចាប់ផ្តើមគ្រាសេចក្តីសញ្ញាថ្មី) គឺជាការសម្រេចក្រឹត្យវិន័យ (ដោយប្រកាសពីព្រំដែននៃគ្រាសេចក្តីសញ្ញាចាស់) ដែលមានរៀបរាប់លម្អិតក្នុងរយៈពេលដ៏ខ្លី (២១:៣៣)។ *ផ្ទៃមេឃ និងផែនដីបាត់ទៅ* មើល មក ១៣:២៤–២៥ ២ពត ៣:៧ និងការពន្យល់ ។ *ងាយជាជាងបាត់ក្បៀស១* មើល មថ ៥:១៧–១៨ និងការពន្យល់ ។

**១៦:១៨** *លែងប្រពន្ធ* មើល មថ ៥:៣២ ១៩:៣ មក ១០:១១–១២ ១កថ ៧:១០–១១ និងការពន្យល់ ។ ព្រះយេស៊ូវទ្រង់បញ្ជាក់ពីអំណាចដែលក្រឹត្យវិន័យនៅតែមានលើមនុស្សដូចជា សេចក្តីកំផិតគឺនៅតែជាសេចក្តីកំផិត នៅតែប្រាសចាកក្រឹត្យវិន័យ ហើយនៅតែជាអំពើបាបដដែល ។ ការបកស្រាយនៅក្នុងព្រះគម្ពីរម៉ាថាយមានលក្ខណៈពេលលេញជាងនេះគឺ (១).ក្រឹត្យវិន័យស្តីពីការលែងលះនេះបានបង្កើតឡើង គឺព្រោះតែចិត្តរឹងរូសតែប៉ុណ្ណោះ (២).ក្រឹត្យវិន័យនោះបានរាប់បញ្ចូលករណីលើកលែង ចំពោះការលែងលះដោយសារតែមានអំពើផិតក្បត់ (មថ ១៩:៩)។

**១៦:១៩** *បុរសម្នាក់មានទ្រព្យសម្បត្តិច្រើន* នៅអ៊ីស្រាអែលក្នុងសម័យនោះជួនកាលគេហៅគាត់ថា "ឌីវេស" (Dives) ជាពាក្យឡាតាំងមានន័យថា "អ្នកមាន"។ *សំពត់ពណ៌ស្វាយ...ទេសឯកយ៉ាងម៉ដ្ត* ជាលក្ខណៈសំពត់ដែលមានតម្លៃថ្លៃ ។

**១៦:២០** *ឡាសារ* មិនមែនជាឡាសារម្នាក់ដែលព្រះយេស៊ូវបានប្រោសឱ្យ

ឈ្មោះឡាសារ កើតដំបៅពេញទាំងខ្លួន គេនាំយកមកផ្ដេក
នៅមាត់ទ្វាររបស់អ្នកមាននោះ ២១គាត់មានប្រាថ្នាចង់
ចំអែតពោះ ដោយចំណិតដែលធ្លាក់ចុះពីតុ[ឃ]អ្នកមានមក
ណាស់ ក៏មានឆ្កែមកលិទ្ធដំបៅគាត់ដែរ ២២ចំណេរក្រោយ
មក អ្នកក្រនោះក៏ស្លាប់ទៅ ហើយពួកទេវតានាំយកគាត់
ទៅដាក់នៅស្ថានបរមសុខ នាដើមទ្រូងលោកអ័ប្រាហាំ
ឯអ្នកមាននោះ ក៏ស្លាប់ទៅដែរ ហើយគេនាំយកទៅកប់
២៣គាត់រងទុក្ខវេទនា នៅស្ថានឃុំព្រលឹង មនុស្សស្លាប់
ក៏ងើបភ្នែកឡើង ឃើញលោកអ័ប្រាហាំពី ចំងាយ
នឹងឡាសារនៅដើមទ្រូងលោក ២៤នោះគាត់ស្រែក
ឡើងថា ឱលោកអ័ប្រាហាំ[ង] ជាឪពុកអើយ សូមអាណិត
មេត្តាខ្ញុំផង សូមឱ្យឡាសារមកជ្រលក់ចុងម្រាមដៃទៅក្នុង
ទឹក ដាក់លើអណ្ដាតខ្ញុំឱ្យត្រជាក់បានបន្តិចផង ដ្បិតខ្ញុំវេទនា
នៅក្នុងភ្លើងនេះ[ច] ២៥តែលោកអ័ប្រាហាំឆ្លើយថា កូនអើយ
ចូរនឹកចាំថា កាលឯងនៅរស់នៅឡើយ ឯងបានទទួលសុទ្ធ
តែសេចក្ដីល្អ ឯឡាសារគាត់បានតែសេចក្ដីអាក្រក់ទេ[ឆ]
ឥឡូវនេះ គាត់បានសេចក្ដីកំសាន្តចិត្តវិញ ហើយឯងត្រូវ
វេទនា[ជ] ២៦មួយវិញសោត មានជង្ហុកមួយយ៉ាងធំ តាំងនៅ
ជាកណ្ដាលយើង ហើយនឹងឯងរាល់គ្នា បានជាអស់អ្នក
ណា ដែលចង់ឆ្លងពីទីនេះទៅឯឯង ឬពីនោះមកឯយើង
នោះមិនបានឡើយ ២៧គាត់ក៏និយាយថា លោកឪពុកអើយ
បើដូច្នេះ សូមលោកចាត់ឱ្យគាត់ទៅឯផ្ទះឪពុកខ្ញុំបន្តិច

**១៦:២១** ឃ មថ ១៥:២៧ លក ១៥:១៦
**១៦:២៤** ង ខ.៣០ លក ៣:៨
ច មថ ៥:២២
**១៦:២៥** ឆ ទដ ១៧:១៤ ជ លក ៦:២១,២៤,២៥
**១៦:២៨** ឈ កច ២:៤០ ២០:២៣ ១ថន ៤:៦
**១៦:២៩** ញ លក ២៤:២៧,៤៤ យហ ១:៤៥, ៥:៤៥–៤៧ កច ១៥:២១
ដ លក ៤:១៧ ២៤:២៧,៤៤ យហ ១:៤៥
**១៦:៣០** ឋ ខ.២៤ លក ៣:៨
**១៧:១** ឌ មថ ៥:២៩
ឍ មថ ១៨:៧
**១៧:២** ណ មក ១០:២៤ លក ១០:២១
ត មថ ៥:២៩
**១៧:៣** ថ មថ ១៨:១៥
ទ អភ ៤:៣២ កល ៣:១៣
**១៧:៤** ធ មថ ១៨:២១,២២
**១៧:៥** ន មក ៦:៣០
ប លក ៧:១៣

២៨ដ្បិតខ្ញុំមានបងប្អូន៥នាក់ សូមឱ្យគាត់ទៅធ្វើបន្ទាល់ប្រាប់
គេផង[ឈ] ក្រែងលោគេភ្លាត់មកក្នុងស្ថានវេទនានេះដែរ
២៩លោកអ័ប្រាហាំឆ្លើយថា គេមានលោកម៉ូសេ[ញ] នឹងពួក
ហោរា[ដ]ហើយ ចូរឱ្យគេស្ដាប់តាមលោកទាំងនោះចុះ
៣០តែគាត់ប្រកែកថា ទេ លោកអ័ប្រាហាំ[ឋ] ឪពុកអើយ បើ
មានអ្នកណាពីពួកមនុស្សស្លាប់ទៅឯគេវិញ នោះគេនឹងប្រែ
ចិត្តជាមិនខាន ៣១លោកឆ្លើយទៅថា បើគេមិនព្រមស្ដាប់
លោកម៉ូសេ នឹងពួកហោរាទេ នោះទោះបើមានអ្នកណា
រស់ពីស្លាប់ឡើងវិញក៏ដោយ គង់តែគេមិនព្រមជឿដែរ ។

## បាប ជំនឿ និងកាតព្វកិច្ច

**១៧** ១ទ្រង់មានបន្ទូលទៅពួកសិស្សថា នឹងធ្វើឱ្យបាត់
ហេតុ ដែលនាំឱ្យរវាតចិត្ត[ឌ] នោះមិនបានឡើយ តែវេទនា
ដល់អ្នកណាដែលបង្កើតហេតុនោះឡើង[ឍ] ២បើគេយកថ្ម
ត្បាល់កិនយ៉ាងធំ ទៅចងកអ្នកនោះ ទំលាក់ចុះទៅក្នុង
សមុទ្រ នោះមានប្រយោជន៍ដល់អ្នកនោះ ជាជាងទុកឱ្យនៅ
ធ្វើ ហេតុនាំឱ្យកូនតូច[ណ]ណាមួយនេះរវាតចិត្តវិញ[ត] ៣ចូរ
ប្រយ័ត្នខ្លួន បើបងប្អូនធ្វើបាបនឹងអ្នកត្រូវឱ្យអ្នកបន្ទោសដល់
គាត់[ថ] បើគាត់ប្រែចិត្តមកវិញ នោះចូរអត់ទោសដល់គាត់
ចុះ[ទ] ៤បើគាត់ធ្វើបាបនឹងអ្នក៧ដងក្នុង១ថ្ងៃ ហើយត្រឡប់
មកនិយាយនឹងអ្នក៧ដងថា ខ្ញុំប្រែចិត្ត ហើយនោះត្រូវឱ្យអ្នក
អត់ទោសដល់គាត់ជាកុំខាន[ធ] ៥ដូច្នេះ ពួកសាវក[ន]ទូលដល់
ព្រះអម្ចាស់[ប]ថា សូមទ្រង់ចំរើនសេចក្ដីជំនឿដល់យើងខ្ញុំ

---

រស់ពីស្លាប់នោះទេ (យហ ១១:៤៣-៤៤) ។ ប្រសិនបើរឿងមួយនេះគឺជារឿងប្រៀបប្រដូច នោះមានតែរឿងមួយនេះប៉ុណ្ណោះ ដែលព្រះយេស៊ូវទ្រង់បានបញ្ចេញឈ្មោះសម្រាប់ចារិតលក្ខណៈមួយក្នុងចំណោមចរិតលក្ខណៈសំខាន់ៗទាំងពីរនោះ ។ *កើតដំបៅពេញទាំងខ្លួន* ឃ្លានេះនៅក្នុងព្រះគម្ពីរក្រិកគឺជាពាក្យវេជ្ជសាស្ត្រមួយដ៏សាមញ្ញ ដែលមានឃើញនៅក្នុងព្រះគម្ពីរនេះតែមួយប៉ុណ្ណោះ ចំពោះព្រះគម្ពីរសញ្ញាថ្មី (មើលសេចក្ដីផ្ដើមព្រះគម្ពីរលូកាត្រង់អ្នកនិពន្ធ) ។

**១៦:២២** *នាដើមទ្រូងលោកអ័ប្រាហាំ* តាមជំនឿពួកសាសន៍យូដា ដើមទ្រូងលោកអ័ប្រាហាំគឺជាស្ថានបរមសុខ សម្រាប់ព្រលឹងវិញ្ញាណមនុស្សល្អនៅចាប់ពីពេលដែលគេស្លាប់ដល់រស់ឡើងវិញ ។

**១៦:២៣** *ស្ថានឃុំព្រលឹងមនុស្សស្លាប់* នៅក្នុងបទគម្ពីរនេះស្ថានឃុំព្រលឹងមនុស្សស្លាប់គឺ កន្លែងដែលមនុស្សអាក្រក់ត្រូវធ្លាក់ទៅ ហើយរងទុក្ខវេទនាបន្ទាប់ពីបានស្លាប់ទៅនោះ ។

**១៦:២៨** *មានបងប្អូន៥នាក់* នេះជាលើកទីមួយ ដែលបុរសអ្នកមានបង្ហាញពីការព្រួយបារម្ភចំពោះអ្នកដទៃ ។

**១៦:២៩** *ស្ដាប់តាម* គឺស្ដាប់ឮហើយប្រព្រឹត្តតាម ។ *លោកម៉ូសេ និងពួកហោរា* គឺជាវិធីបកស្រាយអំពីព្រះគម្ពីរសញ្ញាចាស់ទាំងមូល ។ បុរសអ្នកមានបានខកមិនបានចាប់អារម្មណ៍ចំពោះព្រះគម្ពីរ និងអ្វីដែលព្រះគម្ពីរបង្រៀន ដូចនេះហើយបានជាគាត់ខ្លាចបងប្អូនរបស់គាត់ទាំងប៉ុន្មានប្រព្រឹត្តបែបយ៉ាងនេះដែរ ។

**១៦:៣០** *អ្នកណាពីពួកមនុស្សស្លាប់* រឿងនេះប្រហែលជាចង់បង្ហាញថា បុរសអ្នកមានបាននិយាយសំដៅទៅឡាសារ ប៉ុន្តែ លោកលូកាហាក់ដូចជានិយាយប្រយោលថា ព្រះយេស៊ូវទ្រង់ក៏កំពុងតែមានបន្ទូលពីការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ផងដែរ (ខ.៣១ ៩:២២) ។ ប្រសិនបើចិត្តរបស់មនុស្សបានបិទមិនព្រមចំហ ហើយបដិសេធព្រះគម្ពីរទៅហើយ នោះគ្មានបន្ទាល់អ្វីទៀត សូម្បីតែសេចក្ដីរស់ឡើងវិញ ក៏មិនអាចបំផ្លាស់បំប្រែចិត្តរបស់គេបានដែរ ។

**១៧:២** *ថ្មត្បាល់កិន* គឺថ្មធ្ងន់សម្រាប់កិនគ្រាប់ពូជផ្សេងៗឱ្យទៅជាម្សៅ ។ *កូនតូច* មើល មថ ១៨:៦,១០,១៤ មក ៩:៤២ និងការពន្យល់ ។

**១៧:៣** *បងប្អូន* មើល មថ ១៨:១៥,១៧ មក ៣:៣៥ និងការពន្យល់ ។

**១៧:៤** *៧ដង* គឺជាការបង្រៀនពីការអត់ទោសដែលគ្មានព្រំដែន (មើលការពន្យល់ ទដ ១១៩:១៦៤ មថ ១៨:២២) ។

**១៧:៥** *ចំរើនសេចក្ដីជំនឿ* ពួកសិស្សមានអារម្មណ៍ថា ពួកគេមិនមានលទ្ធភាពប្រតិបត្តិតាមការបង្រៀនពីខ.១–៤ ឡើយ ។ ពួកគេចង់បានសេចក្ដីជំនឿ

ទៀតផង ៦តែព្រះអម្ចាស់មានបន្ទូលថា បើអ្នករាល់គ្នាមាន
សេចក្ដីជំនឿដូចគ្រាប់ពូជ១យ៉ាងល្អិត[ផ] នោះនឹងនិយាយ
ទៅដើមមននេះថា ចូរឯងរលើងទៅដុះក្នុងសមុទ្រទៅ
នោះគង់តែនឹងស្ដាប់បង្គាប់អ្នកដែរ[ព] ៧ក្នុងពួកអ្នករាល់គ្នា
បើអ្នកណាមានបាវកំពុងតែភ្ជួរ ឬឃ្វាលសត្វលុះកាលណា
វាវិលមកពីចំការ តើនឹងនិយាយទៅវាភ្លាមថា មកអង្គុយ
ស៊ីបាយសិន ឬអី ៨គឺនឹងប្រាប់វាយ៉ាងនេះវិញទេតើ ថា
ចូររៀបចំអាហារឱ្យអញ រួចក្រវាត់ខ្លួនមកបំរើអញ[ភ] ដែល
កំពុងតែស៊ី រួចសឹមឯងស៊ីជាក្រោយចុះ ៩តើចៅហ្វាយដឹង
គុណបាវនោះ ដោយព្រោះវាធ្វើតាមបង្គាប់ឬដូចម្ដេច
ខ្ញុំយល់ថា មិនមែនទេ ១០ឯអ្នករាល់គ្នា ក៏ដូច្នោះដែរ កាល
ណាអ្នករាល់គ្នាបានធ្វើតាមបង្គាប់គ្រប់ជំពូកហើយ នោះ
ត្រូវរាប់ថា យើងជាបាវបំរើឥតកំរៃដល់ម្ចាស់ទេ ដ្បិត
យើងបានធ្វើត្រឹមតែការដែលយើងត្រូវធ្វើប៉ុណ្ណោះ[ម]។

## ការប្រោសជម្ងឺឃ្លង់

១១កាលទ្រង់កំពុងឡើងទៅឯក្រុងយេរូសាឡិម[យ] នោះក៏
យាង តាមព្រំដែនស្រុកសាម៉ារី ហើយនឹងស្រុកកាលីឡេ[រ]
១២លុះយាងចូលទៅក្នុងភូមិមួយ ក៏មានមនុស្សឃ្លង់[ល]១០នាក់
មកជួបនឹងទ្រង់ ឈរនៅពីចំងាយ[វ] ស្រែកទូលថា ១៣ឱព្រះ
យេស៊ូវជាម្ចាស់អើយ[ស] សូមមេត្តាប្រោសយើងខ្ញុំផង
១៤ទ្រង់ទតឃើញគេ ហើយក៏មានបន្ទូលថា ចូរអ្នករាល់គ្នាទៅ
បង្ហាញខ្លួន ឱ្យពួកសង្ឃពិនិត្យមើលចុះ[ហ] លុះគេកំពុងតែដើរ
ទៅ នោះក៏បានជាស្អាតទាំងអស់គ្នា ១៥មានម្នាក់កាលឃើញ
ថា ខ្លួនបានជាហើយ ក៏វិលមកវិញ ទាំងសរសើរដំកើង
ព្រះ[ឡ] ដោយសំឡេងជាខ្លាំង ១៦គាត់ទំលាក់ខ្លួនផ្កាប់មុខ នៅ
ទៀបព្រះបាទព្រះយេស៊ូវ ទាំងអរព្រះគុណដល់ទ្រង់ផង អ្នក
នោះជាសាសន៍សាម៉ារី[អ] ១៧ទ្រង់មានបន្ទូលសួរថា តើអ្នក
ទាំង១០នោះមិនបានជាស្អាតទេឬអី ចុះ៩នាក់ឯទៀតនៅ
ឯណា ១៨តើឃើញមានតែសាសន៍ដទៃ១នេះ វិលមកសរ
សើរដំកើងដល់ព្រះឬទេ ១៩រួចទ្រង់មានបន្ទូលទៅអ្នកនោះ
ថាចូរក្រោកឡើងទៅចុះ សេចក្ដីជំនឿអ្នកបានសង្គ្រោះអ្នក
ហើយ[ក] ។
២០ឯពួកផារិស៊ី គេទូលសួរទ្រង់ពីនគរព្រះ ដែលត្រូវមកដល់
នៅវេលាណា[ខ] នោះទ្រង់មានបន្ទូលឆ្លើយថា នគរព្រះមិន
មែនមកបែបឱ្យមើលឃើញទេ ២១គ្មានអ្នកណានឹងថា មើល
នៅទីនេះ ឬថា មើល នៅទីនោះបានឡើយ[គ] ដ្បិតមើលនគរ
ព្រះក៏នៅកណ្ដាលអ្នករាល់គ្នាហើយ ។
២២រួចទ្រង់មានបន្ទូលទៅពួកសិស្សថា នឹងមានគ្រាមក
ដល់ ដែលអ្នករាល់គ្នានឹងចង់ឃើញថ្ងៃមួយ របស់កូន

**១៧:៦** ផ មថ ១៣:៣១, ១៧:២០ លក ១៣:១៩ ព មថ ២១:២១ មក ៩:២៣
**១៧:៨** ភ លក ១២:៣៧
**១៧:១០** ម ១កថ ៩:១៦
**១៧:១១** យ លក ៩:៥១ រ លក ៩:៥១,៥២ យហ ៤:៣,៤
**១៧:១២** ល មថ ៨:២ វ លវ ១៣:៤៥,៤៦
**១៧:១៣** ស លក ៥:៥
**១៧:១៤** ហ លវ ១៤:២ មថ ៨:៤
**១៧:១៥** ឡ មថ ៩:៨
**១៧:១៦** អ មថ ១០:៥
**១៧:១៩** ក មថ ៩:២២
**១៧:២០** ខ មថ ៣:២
**១៧:២១** គ ខ.២៣

ខ្លាំងជាងមុន ដើម្បីមានអំណាចក្នុងការរស់នៅតាមគំរូរបស់ព្រះយេស៊ូវ ។

**១៧:៦** មើល មថ ១៧:២០ មក ស១១:២៣ មថ ១៣:៣១–៣២ មក ៤:៣១ និងការពន្យល់ ។

**១៧:៧** *បាវ* គឺទាសករ ។ ការប្រើពាក្យនេះគឺដើម្បីបង្ហាញពីការបំពេញតួនាទី (១២:៣៧ និងការពន្យល់) ។

**១៧:១១** *ព្រំដែនស្រុកសាម៉ារីហើយនិងស្រុកកាលីឡេ* តាមខនេះព្រះយេស៊ូវហាក់ដូចជាបានធ្វើដំណើរទៅស្រុកពេរ៉េ ជាកន្លែងដែលទ្រង់បំពេញព្រះរាជកិច្ច តាមទិសខាងត្បូងឆ្ពោះទៅរកក្រុងយេរូសាឡិម (មើលការពន្យល់ ៩:៥១ ១៣:២២) ។

**១៧:១៤** *ទៅបង្ហាញខ្លួន ឱ្យពួកសង្ឃពិនិត្យមើល* វិធីនេះគេអនុវត្តជាធម្មតាបន្ទាប់ពីបានជាស្អាតហើយ (លវ ១៣:២–៣ ១៤:២–៣២) ។

**១៧:១៥** *សរសើរដំកើងព្រះ* មើល ខ.១៨ និង ១:៦៤ និងការពន្យល់ ។

**១៧:១៦** *សាសន៍សាម៉ារី* មើលការពន្យល់ ១០:៣១–៣៣ ។ តាមធម្មតាសាសន៍យូដាមិនរាប់អានសាសន៍សាម៉ារីទេ (យហ ៤:៩ និងការពន្យល់) ប៉ុន្តែ ការរើសអើងដោយព្រោះជំងឺឃ្លង់បានបណ្ដាលឱ្យអ្នកជំងឺ ដែលមកពីសាសន៍ទាំងពីរអាចនៅជាមួយគ្នាបាន (លវ១៣:២,៤,៤៥–៤៦ និងពន្យល់) ។

**១៧:១៩** *សេចក្ដីជំនឿអ្នកបានសង្គ្រោះអ្នកហើយ* មើល មថ ៩:២២ មក ៥:៣៤ និងការពន្យល់ លក ៧:៥០ ។ ការដែលសាសន៍សាម៉ារីម្នាក់នោះត្រឡប់មកវិញ ដើម្បីអរព្រះគុណដល់ព្រះយេស៊ូវ ប្រហែលជាបង្ហាញថាគាត់បានទទួលនូវសេចក្ដីសង្គ្រោះ ជាការបន្ថែមពីលើការប្រោសឱ្យជាខាងរូបកាយរបស់គាត់ ដែលអ្នកទាំង៩នាក់នោះបានទទួលជាមួយគាត់ (៧:៥០ ៨:៤៨,៥០ និងការពន្យល់) ។

**១៧:២០** *ពួកផារិស៊ី* មើលការពន្យល់ ៥:១៧ ។

**១៧:២១** *នគរព្រះក៏នៅកណ្ដាលអ្នករាល់គ្នា* ជាការបង្ហាញថា នគរព្រះគឺជានគរខាងព្រលឹងវិញ្ញាណ ហើយមាននៅក្នុងចិត្តមនុស្ស (មថ ២៣:២៦ និងការពន្យល់) ប៉ុន្តែ មិនមែនជានគរខាងសាច់ឈាម និងនៅសំបកខាងក្រៅឡើយ (យហ ១៨:៣៦ និងការពន្យល់)។ ព្រះគម្ពីរអង់គ្លេសប្រើឃ្លា "នគរព្រះក៏នៅក្នុងអ្នករាល់គ្នា" (១៩:១១ ២១:៧ កថ ១:៦ និងការពន្យល់) ដែលមានន័យថា នគរព្រះគឺមានវត្តមាននៅក្នុងអង្គព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ ៤:៤៣)។ តែ ខ២០ បានបង្ហាញថា នគរព្រះគឺជានគរខាងឯវិញ្ញាណដែលមិនអាចមើលឃើញបានឡើយ ហើយពាក្យ "អ្នករាល់គ្នា" គឺសំដៅទៅលើមនុស្សទូទៅ តែមិនសំដៅទៅលើបុគ្គលពួកផារិស៊ីដែលមិនមែនជាអ្នកជឿព្រះនោះឡើយ ។ ជាការពិតណាស់ នគរព្រះមិនស្ថិតនៅក្នុងពួកគេឡើយ ។

**១៧:២២** *ចង់ឃើញ* ដល់គ្រាលំបាកវេទនា អ្នកជឿនឹងចង់ឱ្យថ្ងៃដែលព្រះគ្រីស្ទយាងមកក្នុងសិរីល្អរបស់ទ្រង់មកដល់ ដែលពេលនោះទ្រង់នឹងដោះឱ្យរាស្ត្រទ្រង់រួចពីសេចក្ដីវេទនា ។

**១៧:២៣** *នោះកុំឱ្យចេញទៅតាមឡើយ* គឺកុំទុកការងាររបស់ខ្លួនចោល ដើម្បីដើរតាមការទស្សទាយ ពីការយាងមកជាលើកទីពីរ របស់ព្រះគ្រីស្ទនោះឡើយ (មើលការពន្យល់ ១ធថ ៤:១១) ។

មនុស្ស[ឃ] តែមិនឃើញទេ[ង] ២៣ហើយគេនឹងប្រាប់អ្នករាល់គ្នា
ថាមើលនៅទីនេះ ឬថាមើលនៅទីនោះ នោះកុំឱ្យចេញ
ទៅតាមឡើយ[ច] ២៤ដ្បិតនៅថ្ងៃ[ឆ]របស់កូនមនុស្ស នោះលោក
នឹងបានដូចជាផ្លេកបន្ទោរ ដែលភ្លឺផ្លេកៗពីជើងមេឃម្ខាង
ដល់ជើងមេឃម្ខាងដូច្នោះដែរ ២៥ប៉ុន្តែមុនដំបូងត្រូវឱ្យ
លោករងទុក្ខលំបាកជាច្រើន[ជ] ហើយត្រូវមនុស្សជំណាន់នេះ[ឈ]
បោះបង់ចោល[ញ]លោកផង ២៦នៅគ្រារបស់កូនមនុស្សនោះ
នឹងកើតមានដូចជានៅជំនាន់លោកណូអេដែរ[ដ] ២៧ដ្បិតនៅ
ជំនាន់នោះ គេកំពុងតែស៊ីផឹក រៀបការប្ដីប្រពន្ធដរាបដល់
ថ្ងៃដែលលោកណូអេបានចូលទៅក្នុងទូកធំ នោះទឹកក៏ជន់
មកលិចបំផ្លាញគ្រប់គ្នាទៅ ២៨ក៏ដូចជានៅជំនាន់លោកឡុត
ដែរ[ឋ] គេកំពុងតែស៊ីផឹក លក់ដូរ ដាំដំណាំ ហើយសង់ផ្ទះ
២៩តែនៅថ្ងៃដែលលោកឡុត ចេញពីក្រុងសូដុំមមក នោះ
មានភ្លៀង ជាភ្លើងនឹងស្ពាន់ធ័រ ធ្លាក់ពីលើមេឃមកបំផ្លាញ
គេទាំងអស់គ្នាបង់ ៣០នៅថ្ងៃដែលកូនមនុស្សលេចមក[ឌ]នោះ
ក៏នឹងកើតមានដូច្នោះដែរ ៣១ថ្ងៃនោះឯង បើអ្នកណានៅ
លើដំបូល ហើយមានទ្រព្យសម្បត្តិនៅក្នុងផ្ទះ នោះកុំឱ្យ
ចុះមកយកឡើយ ឯអ្នកណាដែលនៅចំការក៏ដូច្នោះដែរ កុំ
ឱ្យត្រឡប់មកវិញឱ្យសោះ[ឍ] ៣២ចូរនឹកចាំពីប្រពន្ធលោក
ឡុត[ណ] ៣៣អ្នកណាដែលរកចង់ឱ្យរួចជីវិត នោះនឹងបាត់
ជីវិតទៅ ហើយអ្នកណាដែលបាត់ជីវិត នោះនឹងបានគង់
នៅវិញ[ត] ៣៤ខ្ញុំប្រាប់អ្នករាល់គ្នាថា នៅយប់នោះនឹងមាន
មនុស្សពីរនាក់ដេកនៅដំណេកជាមួយគ្នា ម្នាក់នឹងបានយក
ទៅ ម្នាក់ត្រូវទុកនៅ ៣៥នឹងមានស្ត្រី២នាក់កិនម្សៅជាមួយ
គ្នាម្នាក់នឹងបានយកទៅ ម្នាក់ត្រូវទុកនៅ ៣៦នឹងមានមនុស្ស
២នាក់នៅចំការ ម្នាក់នឹងបានយកទៅ ហើយម្នាក់ត្រូវទុក
នៅ[ថ] ៣៧នោះគេទូលសួរថា ព្រះអម្ចាស់អើយ តើនៅ
ឯណា ទ្រង់មានបន្ទូលឆ្លើយថា ខ្មោចនៅកន្លែងណា ឥន្ទ្រី
នឹងប្រជុំគ្នានៅទីនោះឯង[ទ]។

## រឿងប្រៀបប្រដូចពីស្ត្រីមេម៉ាយមានចិត្តតស៊ូ

**១៨** ១នោះព្រះអម្ចាស់ទ្រង់មានបន្ទូលជាពាក្យប្រៀបប្រ
ដូចទៅគេដើម្បីនឹងបង្ហាញថា ត្រូវតែអធិស្ឋានជានិច្ចឥត
រសាយចិត្តឡើយ[ធ] ២ទ្រង់មានបន្ទូលថា នៅក្នុងក្រុង១មាន
ចៅក្រមម្នាក់ ដែលមិនកោតខ្លាចដល់ព្រះ ក៏មិនព្រឹម
ញញើតចំពោះមនុស្សណាផង ៣ហើយមានស្ត្រីមេម៉ាយម្នាក់
នៅក្នុងក្រុងនោះដែរ នាងចេះតែមកនិយាយនឹងលោក
នោះថា សូមលោកកាត់ទោស[ន]ដល់ខ្មាំងសត្រូវឱ្យខ្ញុំផង
៤តែលោកមិនទទួលព្រមជាយូរក្រែលហើយ លុះក្រោយ
មកក៏គិតក្នុងចិត្តថា ទោះបើអញមិនខ្លាចដល់ព្រះ ឬព្រម

**១៧:២២** ឃ មថ ៨:២០ ង លក ៥:៣៥ **១៧:២៣** ច មថ ២៤:២៣ លក ២១:៨ **១៧:២៤** ឆ មថ ២៤:២៧ **១៧:២៥** ជ មថ ១៦:២១ ឈ លក ៩:២២,១៨:៣២ ញ មក ១៣:៣០ លក ២១:៣២ **១៧:២៦** ដ លប ៦:៥–៨ ៧:៦–២៤ **១៧:២៨** ឋ លប ១៩:១–២៨ **១៧:៣០** ឌ មថ ១០:២៣ ១៦:២៧ ២៤:៣,២៧,៣៧,៣៩ ២៥:៣១ ១កថ ១:៧ ១ថន ២:១៩ ២ថន ១:៧ ២:៨ ២ពត ៣:៤ វវ ១:៧ **១៧:៣១** ឍ មថ ២៤:១៧,១៨ **១៧:៣២** ណ លប ១៩:២៦

**១៧:៣៣** ត យហ ១២:២៥ **១៧:៣៥** ថ មថ ២៤:៤១ **១៧:៣៧** ទ មថ ២៤:២៨ **១៨:១** ធ អស ៤០:៣១ លក ១១:៥–៨ កច ១:១៤ រម ១:១០, ១២:១២ អភ ៦:១៨ កល ៤:២ ១ថន ៥:១៧ **១៨:៣** ន អស ១:១៧

**១៧:២៤** *ដូចជាផ្លេកបន្ទោរ* ដល់ពេលកំណត់មកដល់ការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទនឹងប្រព្រឹត្តទៅភ្លាមៗ គួរឱ្យភ្ញាក់ផ្អើល ហើយគ្រប់គ្នានឹងដឹងជាក់ពីព្រឹត្តិការណ៍នេះ (១២:៤០ និងការពន្យល់) ។

**១៧:២៥** *លោករងទុក្ខលំបាកជាច្រើន* ព្រះយេស៊ូវទ្រង់មានបន្ទូលប្រាប់ឱ្យដឹងជាមុនជាច្រើនដង អំពីការសុគតរបស់ទ្រង់ដែលត្រូវមកដល់ (៥:៣៥ ៩:២២ និងការពន្យល់ ៤៣–៤៥ ១២:៥០ ១៣:៣២–៣៣ ១៨:៣២ ២៤:៧ មថ ១៦:២១ មក ២:២០ និងការពន្យល់) មុនពេលដែលទ្រង់យាងមកវិញក្នុងសិរីល្អរបស់ទ្រង់ ។

**១៧:២៨** *នៅជំនាន់លោកឡុត* មើល លប ១៨:១៦–១៩:២៨ ។

**១៧:៣០** *ថ្ងៃដែលកូនមនុស្សលេចមក* នៅពេលដែលព្រះយេស៊ូវទ្រង់យាងត្រឡប់មកវិញ មនុស្សទាំងអស់នឹងបានឃើញទ្រង់ច្បាស់នឹងភ្នែក(១កថ ១:៧ ២ថន ១:៧ និងការពន្យល់ ១ពត ១:៧ ១៣ ៤:១៣ វវ ១:៧) ។

**១៧:៣១** *អ្នកណានៅលើដំបូល* ពេលដែលនាទីចុងក្រោយមកដល់បុគ្គលដែលនៅលើដំបូលមិនត្រូវគិតចុះក្រោមដើម្បីយករបស់អ្វីឡើយ ។ ព្រះគម្ពីរម៉ាកុសនិយាយស្រដៀងគ្នានឹងព្រះគម្ពីរលូកាពីសេចក្ដីនេះសំដៅទៅលើការភាសខ្លួន នៅពេលដែលក្រុងយេរូសាឡិមត្រូវបំផ្លាញ ហើយក៏និយាយប្រយោលសំដៅទៅលើថ្ងៃអវសាននៃលោកិយ (មថ ២៤:១៧–១៨ មក ១៣:១៥) ប៉ុន្តែខនេះប្រាកដជា និយាយសំដៅទៅលើការយាងត្រឡប់មកវិញរបស់ផងព្រះយេស៊ូវគ្រីស្ទ (ខ.៣០ ២១:២១) ។

**១៧:៣៣** *អ្នកណាដែលបាត់ជីវិត នោះនឹងបានគង់នៅវិញ* មើលការពន្យល់ ៩:២៤ (មថ ១០:៣៩) ។

**១៧:៣៥** *បានយកទៅ* គឺអាចសំដៅទៅលើការដែល "បានយកទៅ ឬចេញពីសេចក្ដីហិនវិនាស" ឬ"បានយកទៅឯនគរព្រះ"។ ខនេះបានបង្ហាញយ៉ាងច្បាស់ថា ទោះជាមនុស្សពីរនាក់មានទំនាក់ទំនងជិតស្និទ្ធក្នុងជីវិតរស់នៅយ៉ាងណាក៏ដោយ ក៏គ្មានការធានាពីភាពដូចគ្នា រវាងវាសនាដ៏អស់កល្បជានិច្ចរបស់ពួកគេទាំងពីរឡើយ ។ នឹងមានម្នាក់ត្រូវទទួលទោសអស់កល្បជានិច្ច ហើយម្នាក់ទៀតអាចត្រូវទទួលសេចក្ដីសង្គ្រោះរង្វាន់ និងព្រះពរអស់កល្បជានិច្ច ។

**១៧:៣៦** ខនេះមានន័យថា នឹងមានមនុស្សពីរនាក់នៅចំការ ម្នាក់នឹងត្រូវយកទៅហើយម្នាក់ត្រូវទុកនៅ (សម្រង់ មថ ២៤:៤០) ។

**១៧:៣៧** *ខ្មោចនៅកន្លែងណា ឥន្ទ្រីនឹងប្រជុំគ្នានៅទីនោះ* ឃ្លានេះគឺជាសុភាសិតមួយ (ពាក្យ "ឥន្ទ្រី" ច្រើនប្រើដោយព្រះគម្ពីរអង់គ្លេសបកប្រែចាស់ ចំណែកព្រះគម្ពីរអង់គ្លេសបកប្រែថ្មីនិយមប្រើពាក្យ "ត្មាត"ជំនួសវិញ) (មើលការពន្យល់ មថ ២៤:២៨) ។

**១៨:២** *ក៏មិនព្រឹមញញើតចំពោះមនុស្សណាផង* ចៅក្រមរូបនេះមិនខ្វល់ពីតម្រូវការរបស់អ្នកណាម្នាក់ឬចិត្តគំនិតដែលពួកគេមានចំពោះលោកឡើយ។

**១៨:៣** *ស្ត្រីមេម៉ាយ* ដែលគ្មានទីពំនឹង និងងាយរងគ្រោះបំផុត ពីព្រោះគ្មានគ្រួសារជួយរកយុត្តិធម៌ឱ្យគាត់ឡើយ។ មានតែយុត្តិធម៌ និងការតស៊ូរបស់គាត់

ញញើត ចំពោះមនុស្សណាក៏ដោយ ៥គង់តែអញនឹងជំនុំ
ជំរះឱ្យស្ត្រីមេម៉ាយនេះជាមិនខាន ដោយព្រោះនាងនាំ
ឱ្យរំខានចិត្តអញខ្លាំងណាស់ ក្រែងនាងចេះតែមករំអុក
ជានិច្ចដូច្នេះទៅ នឹងនាំឱ្យអញពិបាកចិត្តទៅទៀត[ប] ។
៦នោះទ្រង់[ផ]មានបន្ទូលថា ចូរពិចារណាសេចក្ដី ដែល
ចៅក្រមទុច្ចរិតនោះនិយាយចុះ ៧ចំណែកព្រះវិញ ដែល
ទ្រង់មានព្រះហឫទ័យអត់ធ្មត់ ដល់ពួករើសតាំងរបស់ទ្រង់
ដែលគេអំពាវនាវ[ព]រកទ្រង់ទាំងយប់ទាំងថ្ងៃ នោះតើទ្រង់
មិនសងសឹកជំនួសគេដែរទេឬអី ៨ខ្ញុំប្រាប់អ្នករាល់គ្នាថា
ទ្រង់នឹងសងសឹកជំនួសអ្នកទាំងនោះជាប្រញាប់មិនខាន
ប៉ុន្តែ កាលណាកូនមនុស្ស[ភ]នឹងមក[ម]តើនឹងឃើញមានសេចក្ដី
ជំនឿនៅផែនដីដែរឬដូម្ដេច ។

## រឿងប្រៀបប្រដូចពីពួកផារិស៊ី និងអ្នកយកពន្ធ

៩ឯពួកអ្នកខ្លះដែលទុកចិត្តនឹងខ្លួនគេថា គេសុចរិត[យ]ហើយ
ក៏មើលងាយដល់មនុស្សឯទៀតផង[រ] នោះទ្រង់មានបន្ទូលជា
ពាក្យប្រៀបប្រដូចនេះថា ១០មានបុរស ២នាក់ឡើងទៅ
អធិស្ឋាន[ល]ក្នុងព្រះវិហារ មួយជាពួកផារិស៊ី មួយទៀតជាអ្នក
យកពន្ធ ១១អ្នកផារិស៊ីក៏ឈរ[វ]តាំងអធិដ្ឋាន តែម្នាក់ឯង
ដូច្នេះថា ឱព្រះអង្គអើយ ទូលបង្គំអរព្រះគុណដល់ទ្រង់
ព្រោះទូលបង្គំមិនដូចជាមនុស្សឯទៀត ដែលជាមនុស្សប្លន់
ទុច្ចរិត ហើយកំផិត ឬដូចជាអ្នកយកពន្ធនេះទេ ១២ទូលបង្គំ
តម[ស]ក្នុង១អាទិត្យ២ដង ហើយក៏ថ្វាយ១ភាគក្នុង១០[ហ]ពីរបស់
ទាំងអម្បាលម៉ានដែលទូលបង្គំបានចំណេញផង ១៣ឯអ្នក
យកពន្ធគាត់ឈរនៅទីឆ្ងាយ មិនទាំងងើបមើលទៅលើ
មេឃផង ក៏គក់ដើមទ្រូង[ឡ]ទូលថា ឱព្រះអង្គអើយ សូមទ្រង់
មេត្តាអត់ទោសដល់ទូលបង្គំ ដែលជាអ្នកមានបាបផង[អ] ១៤ខ្ញុំ

**១៨:៥** ប លក ១១:៨
**១៨:៦** ផ លក ៧:១៣
**១៨:៧** ព នក ២២:២៣ ទដ ៨៨:១ វវ ៦:២០
**១៨:៨** ភ មថ ៨:២០ ម មថ ១៦:២៧
**១៨:៩** យ លក ១៦:១៥ រ អស ៦៥:៥
**១៨:១០** ល កច ៣:១
**១៨:១១** វ មថ ៥:៦ មក ១១:២៥
**១៨:១២** ស អស ៥៨:៣ មថ ៩:១៤ មឡ ៣:៨ លក ១១:៤២
**១៨:១៣** ហ អស ៦៦:២ យរ ៣១:១៩ លក ២៣:៤៨ ឡ លក ៥:៣២ ១ធថ ១:១៥
**១៨:១៤** អ មថ ២៣:១២
**១៨:១៧** ក មថ ១១:២៥ ១៨:៣
**១៨:១៨** ខ លក ១០:២៥
**១៨:២០** គ នក ២០:១២–១៦ ចទ ៥:១៦–២០ រម ១៣:៩
**១៨:២២** ឃ កច ២:៤៥

ប្រាប់អ្នករាល់គ្នាថា កាលចុះទៅដល់ផ្ទះ អ្នកនេះបានរាប់
ជាសុចរិតជាជាងអ្នក១នោះ ដ្បិតអស់អ្នកណាដែលដំកើង
ខ្លួន នោះនឹងត្រូវបន្ទាបវិញ ហើយអ្នកណាដែលបន្ទាបខ្លួន
នោះនឹងបានដំកើងឡើង ។

## ក្មេងតូចៗ និងព្រះយេស៊ូវ

១៨:១៥–១៧ = មថ ១៩:១៣–១៥ មក ១០:១៣–១៦

១៥មានគេនាំកូនតូចៗមកឯព្រះយេស៊ូវដែរ ដើម្បីឱ្យទ្រង់
បានពាល់វា តែកាលពួកសិស្សបានឃើញ នោះក៏បន្ទោស
ដល់គេ ១៦ប៉ុន្តែទ្រង់ហៅពួកសិស្សមកមានបន្ទូលថា ទុកឱ្យ
កូនតូចមកឯខ្ញុំចុះ កុំឃាត់វាឡើយ ព្រោះនគរព្រះមាន
សុទ្ធតែមនុស្សដូចវារាល់គ្នាដែរ ១៧ខ្ញុំប្រាប់អ្នករាល់គ្នាជា
ប្រាកដថា អ្នកណាដែលមិនទទួលនគរព្រះ ដូចជាកូនតូចៗ[ក]
នោះមិនបានចូលទៅក្នុងនគរនោះឡើយ ។

## នាម៉ឺនជាអ្នកមានម្នាក់

*១៨:១៨–៣០ = មថ ១៩:១៦–២៩ មក ១០:១៧–៣០*

១៨មាននាម៉ឺនម្នាក់ទូលសួរទ្រង់ថា ឱលោកគ្រូល្អអើយ
តើត្រូវឱ្យខ្ញុំធ្វើដូចម្ដេច ឱ្យបានជីវិតរស់អស់កល្បជានិច្ច[ខ]
១៩ព្រះយេស៊ូវមានបន្ទូលតបថា ហេតុអ្វីបានជាអ្នកហៅ
ខ្ញុំថាល្អដូច្នេះ គ្មានអ្នកណាល្អឡើយ មានតែមួយ ប៉ុណ្ណោះ
គឺជាព្រះ ២០អ្នកបានស្គាល់បញ្ញត្តទាំប៉ុន្មានហើយ ដែលថា
កុំឱ្យផិតឱ្យសោះ កុំឱ្យសំឡាប់មនុស្សឱ្យសោះ កុំឱ្យលួច
ឱ្យសោះ កុំឱ្យធ្វើជាទីបន្ទាល់ក្លែងក្លាយឱ្យសោះ ចូរគោរព
ប្រតិបត្តិដល់ឪពុកម្ដាយ[គ] ២១តែគាត់ទូលឆ្លើយថា ខ្ញុំបាន
កាន់តាមសេចក្ដីទាំងនេះ តាំងតែពីក្មេងមកហើយ ២២កាល
ព្រះយេស៊ូវបានឮដូច្នោះ នោះក៏មានបន្ទូលទៅគាត់ថា អ្នក
នៅខ្វះសេចក្ដី១ទៀត ដូច្នេះ ចូរទៅលក់របស់ទ្រព្យអ្នក

---

ប៉ុណ្ណោះដែលអាចជួយដល់គាត់បាន (១ធថ ៥:៣ និងការពន្យល់) ។
**១៨:៧** *ចំណែកព្រះវិញ ដែលទ្រង់ . . .* ចៅក្រមម្នាក់ដែលមិនសមធ្វើជាចៅក្រម ហើយមិនស្រឡាញ់យុត្តិធម៌ទេ នៅតែមានមនុស្សគ្មានទីពឹងម្នាក់អាចជំរុញយ៉ាងខ្ជាប់ខ្ជួន ឱ្យចៅក្រមនោះរកយុត្តិធម៌ឱ្យគាត់បាន ដូចនេះតើព្រះទ្រង់នឹងឆ្លើយតបចំពោះការអធិស្ឋានសូមដល់ទ្រង់ខ្លាំងជាងប៉ុន្មានដង? *សងសឹកជំនួសគេ* ព្រះទ្រង់នឹងមិនពន្យាពេលជួយពួកជ្រើសតាំង នៅពេលដែលពួកគេធ្វើត្រូវនោះឡើយ ព្រះទ្រង់មិនដូចចៅក្រមអយុត្តិធម៌ម្នាក់នោះដែលទាល់តែទទូចសុំឥតឈប់ឈរ ទើបយល់ព្រមរកយុត្តិធម៌ឱ្យនោះទេ ។
**១៨:៨** *តើនឹងឃើញនៅមានសេចក្ដីជំនឿ . . . ?* ជាពិសេសគឺសេចក្ដីជំនឿនៅក្នុងសេចក្ដីអធិស្ឋាន និងភាពស្មោះត្រង់ (មថ ២៤:១២–១៣) ។ ព្រះគ្រីស្ទទ្រង់មានបន្ទូលពីសេចក្ដីប្រតិបត្តិទីពីរ ដែលផ្ដោតឆ្ពោះទៅរកការយាងមកជាលើកទីពីររបស់ទ្រង់ ។ ការសន្និដ្ឋានសម្រាប់គ្រានៃភាពអន់ថយខាងព្រលឹងវិញ្ញាណ និងការបៀតបៀននោះគឺ គ្រានោះតម្រូវឱ្យមានសេចក្ដីខ្ជាប់ខ្ជួន ដូចដែលស្ត្រីមេម៉ាយម្នាក់នោះមានសេចក្ដីខ្ជាប់ខ្ជួនជាគំរូស្រាប់ ។
**១៨:១០** *អធិស្ឋាន* ព្រះវិហារនោះមានពេលសម្រាប់អធិស្ឋានជារៀងរាល់ថ្ងៃ ដែលផ្សាភ្ជាប់នឹងពេលថ្វាយយញ្ញបូជាដែលមាននៅពេលព្រឹក និងពេលល្ងាច ។ បណ្ដាជនអាចទៅអធិស្ឋានជាលក្ខណៈបុគ្គលនៅក្នុងព្រះវិហារតាមពេលណាមួយក៏បាន ។ *អ្នកយកពន្ធ* មើលការពន្យល់ មថ ៥:៤៦ ។
**១៨:១៧** *ដូចជាកូនតូចៗ* គឺត្រូវពឹងផ្អែកទាំងស្រុងជឿទាំងស្រុងនិងស្មោះត្រង់ទាំងស្រុង (មថ ១៨:៣ ១៩:១៤ មក ១០:១៤–១៥ ១ពត ២:២ និងពន្យល់) ។
**១៨:១៨–២៧** សម្រាប់វគ្គនេះសូមមើល មក ១០:១៧–២៧ ។
**១៨:១៨** *ជីវិតអស់កល្បជានិច្ច* មើលការពន្យល់ មថ ១៩:១៦ ។
**១៨:២០** *អ្នកបានស្គាល់បញ្ញត្តិទាំងប៉ុន្មាន* មើល នក ២០:១–១៧ ២០:២ និងការពន្យល់ ។

ទាំងប៉ុន្មាន ចែកទានឱ្យដល់ពួកអ្នកក្រីក្រទៅ[ឃ] នោះអ្នកនឹង
បានព្រទ្យសម្បត្តិ នៅលើស្ថានសួគ៌វិញ[ង] រួចចូរមកតាម
ខ្ញុំចុះ ២៣កាលគាត់ បានឮសេចក្ដីទាំងនេះហើយ នោះក៏កើត
មានចិត្តព្រួយជាខ្លាំង ព្រោះគាត់មានសម្បត្តិទ្រព្យច្រើន
ណាស់។

២៤ព្រះយេស៊ូវក៏ឃើញថា គាត់កើតមានចិត្តព្រួយ បានជាទ្រង់
មានបន្ទូលថា មនុស្សអ្នកមានចូលទៅក្នុងនគរ ព្រះពិបាក
ណាស់[ច] ២៥ដ្បិតដែលសត្វអូដ្ឋនឹងចូលទៅតាមប្រហោងម្ជុល
នោះងាយជាជាងអ្នកមានចូលទៅក្នុងនគរព្រះ ទៅទៀត
២៦ពួកអ្នកដែលឮក៏ទូលសួរថា ដូច្នេះតើអ្នកណាអាចនឹង
បានសង្គ្រោះ ២៧ទ្រង់មានបន្ទូលថា ការដែលមនុស្សធ្វើ
មិនកើត នោះព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់[ឆ] ២៨នោះ
ពេត្រុសទូលថា មើល យើងខ្ញុំបានលះចោល ទាំងអស់ មក
តាមទ្រង់ហើយ[ជ] ២៩ទ្រង់មានបន្ទូលទៅពួកសិស្សថា ខ្ញុំ
ប្រាប់អ្នករាល់គ្នាជាប្រាកដថា គ្មានអ្នកណា ដែលលះចោល
ផ្ទះសំបែង ឪពុកម្ដាយ បងប្អូន ឬប្រពន្ធកូន ដោយយល់ដល់
នគរព្រះ ៣០ឥតបានចំរើនកាន់តែច្រើនឡើង ក្នុងសម័យ
នេះនោះឡើយ ហើយលុះដល់បរលោកនាយ[ឈ] ក៏នឹងបាន
ជីវិតរស់អស់កល្បជានិច្ចថែមទៀតផង[ញ]។

## ព្រះយេស៊ូវថ្លែងទំនាយពីការសុគតរបស់ទ្រង់ម្ដងទៀត

*១៨:៣១–៣៣ = មថ ២០:១៧–១៩ មក ១០:៣២–៣៤*

៣១ទ្រង់ក៏យកពួក១២នាក់មកមានបន្ទូលថា មើល យើង
រាល់គ្នានឹងឡើងទៅឯក្រុងយេរូសាឡិម[ដ] នោះគ្រប់សេចក្ដី
ដែលពួកហោរា[ឋ]បានចែងទុកពីកូនមនុស្ស[ឌ] នឹងបានសំរេច
ពិត ៣២ដ្បិតគេនឹងបញ្ជូនលោកទៅពួកសាសន៍ដទៃ[ឍ] គេនឹង
សើចចំអកឱ្យ ត្មះតិះដៀល ហើយស្តោះដាក់លោក ៣៣រួច
កាលគេបានវាយនឹងរំពាត់[ណ] ហើយនោះគេនឹងសំឡាប់[ត]
លោកបង់ តែក្រោយ៣ថ្ងៃ[ថ]មក លោកនឹងរស់ឡើង វិញ[ទ]។
៣៤តែពួកសាវកមិនបានយល់សេចក្ដីទាំងនោះសោះ ពាក្យ
នោះជាពាក្យលាក់កំបាំងដល់គេ ហើយគេមិនបាន យល់ជា
ថាដូចម្តេចទេ[ធ] ។

## អ្នកសុំទានខ្វាក់ម្នាក់បានមើលឃើញ

*១៨:៣៥–៤៣ = មថ ២០:២៩–៣៤ មក ១០:៤៦–៥២*

៣៥កាលជិតដល់ក្រុងយេរីខូរ[ន]ហើយ នោះមានមនុស្សខ្វាក់
ម្នាក់អង្គុយសូមទាននៅមាត់ផ្លូវ ៣៦គាត់ឮសូរសន្ធឹកមនុស្ស
ទាំងហ្វូង ដែលដើរតាមនោះ ក៏សួរគេថា តើមានការ
អ្វី ៣៧គេប្រាប់គាត់ថា គឺព្រះយេស៊ូវ ពីស្រុកណាសារ៉ែត
ទ្រង់យាងមក[ប] ៣៨រួចគាត់ស្រែកឡើងថា ឱព្រះយេស៊ូវ
ជាព្រះវង្សហ្លួង ដាវីឌអើយ[ផ] សូមអាណិតមេត្តាដល់ទូល
បង្គំផង[ព] ៣៩ឯពួកអ្នកដែលដើរមុន គេកំហែងគាត់ឱ្យនៅ
ស្ងៀម តែគាត់ស្រែករឹតតែខ្លាំងឡើងថា ឱព្រះវង្សហ្លួង
ដាវីឌអើយ សូមអាណិតមេត្តាដល់ទូលបង្គំផង[ភ] ៤០នោះ
ព្រះយេស៊ូវទ្រង់ក៏ឈប់ ហើយបង្គាប់ឱ្យគេនាំគាត់មក កាល
គាត់មកជិតហើយ នោះទ្រង់មានបន្ទូលសួរថា ៤១តើចង់ឱ្យ
ខ្ញុំធ្វើអ្វីឱ្យអ្នក គាត់ទូលថា ឱព្រះអម្ចាស់អើយសូមឱ្យភ្នែកទូល
បង្គំបានភ្លឺឡើង ៤២ព្រះយេស៊ូវមានបន្ទូលទៅគាត់ថា ឱ្យ
ភ្លឺចុះ សេចក្ដីជំនឿអ្នកបានជួយសង្គ្រោះអ្នកហើយ[ម] ៤៣ស្រាប់
តែភ្នែកគាត់បានភ្លឺភ្លាម ហើយគាត់ដើរតាមទ្រង់ ទាំងពណ៌
នាសរសើរដំកើងព្រះ ឯមនុស្សទាំអស់ដែលឃើញក៏សរ

ង មថ ៦:២០
**១៨:២៤** ច សភ ១១:២៨
**១៨:២៧** ឆ មថ ១៩:២៦
**១៨:២៨** ជ មថ ៤:១៩
**១៨:៣០** ឈ មថ ១២:៣២
ញ មថ ២៥:៤៦
**១៨:៣១** ដ លក ៩:៥១
ឋ មថ ៨:២០
ឌ ទដ ២២ អស ៥៣
**១៨:៣២** ឍ លក ២៣:១
**១៨:៣៣** ណ មថ ១៦:២១
ត កថ ២:២៣
ថ មថ ១៦:២១
ទ មថ ១៦:២១
**១៨:៣៤** ធ មក ៩:៣២
**១៨:៣៥** ន លក ១៩:១
**១៨:៣៧** ប លក ១៩:៤
**១៨:៣៨** ផ ខ.៣៩ មថ ៩:២៧ ព មថ ១៧:១៥ លក១៨:១៣
**១៨:៣៩** ភ ខ.៣៨
**១៨:៤២** ម មថ ៩:២២

**១៨:២៤** *នគរព្រះ* មើលការពន្យល់ មថ ៣:២ ។
**១៨:៣០** *សម័យនេះ . . .ដល់បរលោកនាយ* គឺក្នុងសម័យបច្ចុប្បន្នដែលមានពេញដោយអំពើបាប និងសេចក្ដីទុក្ខវេទនា និងពេលអនាគតដែលចាប់ផ្ដើមដោយការយាងត្រឡប់មកវិញរបស់ព្រះមែស៊ី(មក ១០:៣០ និងពន្យល់)។
**១៨:៣១** *សេចក្ដីដែលពួកហោរាបានចែងទុកពីកូនមនុស្ស* ជួនកាលសេចក្ដីនេះគឺសំដៅទៅលើសេចក្ដីទំនាយទីបី អំពីការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ ទោះបីជាចំនួនបទទំនាយមានច្រើនលើសពីបីក៏ដោយ (១៧:២៥ និងមើលការពន្យល់)។ បទទំនាយទីមួយគឺនៅក្នុង ៩:២២ (មើលការពន្យល់ខនេះ) ទីពីរគឺនៅក្នុង ៩:៤៤(មើលការពន្យល់ខនេះ)។ មានការថ្លែងបទទំនាយ ឬប្រាប់ឱ្យដឹងជាមុនរាប់សតវត្សរ៍អំពីការសុគតរបស់ព្រះមែស៊ី(២៤:២៥–២៧ សេចក្ដីផ្ដើម ទដ ២២ អស ៥២:១៣–៥៣:១២ សក ១៣:៧ និងការពន្យល់ មថ ២៦:២៤,៣១,៥៤)។ *កូនមនុស្ស* មើលការពន្យល់ មថ ៨:៣១ ។
**១៨:៣៥** *ជិតដល់ក្រុងយេរីខូរ* មើលការពន្យល់ មក ១០:៤៦ ។ *មនុស្សខ្វាក់ម្នាក់* បុរសខ្វាក់នោះមានឈ្មោះ"បារទីមេ"(មក ១០:៤៦)។ ព្រះគម្ពីរម៉ាថាយបានប្រាប់ឱ្យដឹងថា មានបុរសខ្វាក់ពីរនាក់ ដែលបានប្រោសឱ្យភ្លឺ (មើលការពន្យល់ មថ ២០:៣០)។ ព្រះគម្ពីរម៉ាកុសនិងព្រះគម្ពីលូកាមិនបានកត់ទុកពីវត្តមានរបស់បុរសខ្វាក់ដទៃទៀតឡើយ ប្រហែលបណ្ដាលមកពីមានតែម្នាក់ដែលទូលព្រះយេស៊ូវធ្វើឱ្យគាត់លេចធ្លោជាងអ្នកមួយទៀត ។
**១៨:៣៨–៣៩** *ព្រះវង្សហ្លួងដាវីឌ* គឺជាងារមួយរបស់ព្រះមែស៊ី (មថ ១:១ ២២:៤១–៤៥ មក ១០:៤៧ ១២:៣៥ យហ ៧:៤២ និង ២សយ ៧:១២–១៣ ទដ ៨៩:៣–៤ អម ៩:១១ មថ ១២:២៣ និងការពន្យល់)។
**១៨:៤២** *សេចក្ដីជំនឿអ្នក* មើលការពន្យល់ ១៧:១៩ ។
**១៨:៤៣** *ពណ៌នាសរសើរដំកើងព្រះ . . . ក៏សរសើរដល់ព្រះដែរ* មើល ១:៦៤ និងការពន្យល់ ។

សើរដល់ព្រះដែរ[យ] ។

## អ្នកយកពន្ធម្នាក់ឈ្មោះសាខេ

**១៩** ១លុះទ្រង់បានចូលទៅក្នុងក្រុងយេរីខូរ[រ] ក៏យាងកាត់
ទីក្រុងទៅ ២នោះឃើញមានបុរសអ្នកមានម្នាក់ឈ្មោះ
សាខេ ជាមេលើពួកអ្នកយកពន្ធ ៣គាត់ខំរកមើលព្រះ
យេស៊ូវ ដែលទ្រង់មានបែបភាពជាយ៉ាងណា តែមិនឃើញ
សោះ ដោយព្រោះមានមនុស្សសន្ធឹកណាស់ ហើយគាត់ក៏តូច
ទាបផង ៤ដូច្នេះគាត់រត់ទៅពីខាងមុខ ឡើងលើដើម
ឧទុម្ពរ[ល]ឱ្យបានឃើញទ្រង់ ព្រោះទ្រង់ត្រូវយាងមកតាម
នោះ[វ] ៥កាលព្រះយេស៊ូវយាងមកដល់ នោះទ្រង់ងើបព្រះ
នេត្រឡើងឃើញ ហើយមានបន្ទូលទៅគាត់ថា សាខេ
ចូរអ្នក ចុះមកជាប្រញាប់ ដ្បិតថ្ងៃនេះ ខ្ញុំត្រូវស្នាក់នៅផ្ទះអ្នក
៦គាត់ក៏ចុះមកជាប្រញាប់ ហើយទទួលទ្រង់ដោយអំណរ ។
៧កាលមនុស្សទាំងអស់បានឃើញដូច្នោះ នោះគេរទូរទាំ
ថា លោកបានចូលទៅស្នាក់នៅក្នុងផ្ទះរបស់មនុស្សមាន
បាប[ស] ៨ឯសាខេក៏ឈរទូលទ្រង់ថា[ហ] មើលព្រះអម្ចាស់
អើយ ទូលបង្គំចែកទ្រព្យទូលបង្គំពាក់កណ្ដាលឱ្យដល់មនុស្ស
ក្រីក្រ ហើយបើទូលបង្គំបានហូតពន្ធបំបាត់ចំពោះ អ្នកណា[ឡ]
នោះទូលបង្គំនឹងសងគេ១ជា៤វិញ[អ] ។
៩ព្រះយេស៊ូវទ្រង់មានបន្ទូលទៅគាត់ថា ថ្ងៃនេះសេចក្ដី
សង្គ្រោះបានមកដល់ផ្ទះនេះហើយ ពីព្រោះអ្នកនេះជាពូជ
លោកអ័ប្រាហាំដែរ[ក] ១០ដ្បិតកូនមនុស្ស បានមកដើម្បីនឹងរក
ហើយជួយសង្គ្រោះដល់មនុស្សបាត់បង់[ខ] ។

## រឿងប្រៀបប្រដូចពីអ្នកបំរើល្អ ហើយស្មោះត្រង់

*១៩:១២–២៧ = មថ ២៥:១៤–៣០*

១១កាលគេកំពុងតែស្ដាប់សេចក្ដីទាំងនោះនៅឡើយ នោះ
ទ្រង់មានបន្ទូលថា ជាពាក្យប្រៀបប្រដូច១ថែមទៀត ដោយ
ព្រោះជិតដល់ក្រុងយេរូសាឡិមហើយ គេក៏ស្មានថានគរ
ព្រះ[គ] រៀបនឹងលេចមកភ្លាម[ឃ] ១២ដូច្នេះ ទ្រង់មានបន្ទូលថា
មានបុរសត្រកូលខ្ពស់ម្នាក់រៀបនឹងចេញទៅឯស្រុកឆ្ងាយ
ដើម្បីគ្រងរាជ្យ រួចត្រឡប់មកវិញ ១៣ក៏ហៅពួកបាវ[ង]១០
នាក់ មកប្រគល់ប្រាក់១០ណែនដល់គេ ដោយថា ចូរឯង
រាល់គ្នាធ្វើជំនួញដរាបដល់អញត្រឡប់មកវិញ ១៤ប៉ុន្តែ ពួក
អ្នកស្រុករបស់លោក គេស្អប់លោកណាស់ ក៏ចាត់សារឱ្យ
ទៅតាមក្រោយលោក ទូលថា យើងរាល់គ្នាមិនចង់ឱ្យ
មនុស្សនេះ សោយរាជ្យលើយើងទេ ១៥លុះត្រឡប់មកវិញ
ក្រោយដែលបានគ្រងរាជ្យហើយ នោះទ្រង់បង្គាប់ឱ្យហៅ

**១៨:៤៣** យ មថ ៩:៨ លក ១៣:១៧
**១៩:១** រ លក១៨:៣៥
**១៩:៤** ល ១ពវ ១០:២៧ ១របា ២៧:២៨ អស ៩:១០
វ លក ១៨:៣៧
**១៩:៧** ស មថ ៩:១១
**១៩:៨** ហ លក ៧:១៣
ឡ លក ៣:១២,១៣
អ នក ២២:១ លវ ៦:៤,៥ ជន ៥:៧ ២សយ ១២:៦ អគ ៣៣:១៤,១៥
**១៩:៩** ក លក ៣:៨
**១៩:១០** ខ អគ ៣៤:១២,១៦ យហ ៣:១៧
**១៩:១១** គ មថ ៣:២
ឃ លក ១៧:២០ កច ១:៦
**១៩:១៣** ង មក ១៣:៣៤

**១៩:១** *ចូលទៅក្នុងក្រុងយេរីខូរ* មើលការពន្យល់ មក ១០:៤៦ ។

**១៩:២** *មេលើពួកអ្នកយកពន្ធ* នៅក្នុងព្រះគម្ពីរទាំងមូល មុខតំណែងនេះមានឃើញតែនៅក្នុងខនេះប៉ុណ្ណោះ ។ តំណែងនេះប្រហែលជាបង្ហាញថា គាត់មើលការខុសត្រូវលើអ្នកយកពន្ធមួយស្រុក ។ នៅសម័យនោះ ភាពសម្បូណ៌សប្បាយក្នុងតំបន់នោះ អាចជាមូលហេតុដែលលោកសាខេអាចធ្វើជាអ្នកមានបានយ៉ាងងាយ (មើលការពន្យល់ ៣:១២ មថ ៥:៤៦ មក ២:១៤–១៦) ។

**១៩:៤** *ដើមឧទុម្ពរ* គឺដើមឈើមាំមានកម្ពស់ពី៩ ទៅ ១២ ម៉ែត្រ ដើមវាខ្លីអាចទ្រទម្ងន់ខ្លួនមនុស្សពេញវ័យម្នាក់បាន ហើយមានមែកបែកសាខា។ មើលការពន្យល់ អម ៧:១៤ ។

**១៩:៥** *ខ្ញុំត្រូវស្នាក់នៅផ្ទះអ្នក* គឺជាព្រះបន្ទូលប្រយោលអំពីភាពចាំបាច់នៃការមានព្រះវត្តមានរបស់ព្រះ ។

**១៩:៨** *១ជា៤វិញ* គឺជាការសងប្រាក់ឱ្យគ្រប់តាមក្រឹត្យវិន័យស្ដីអំពើចោរលួច (នក ២២:១ ២សយ ១២:៦ និងការពន្យល់) ។

**១៩:៩** *ពូជលោកអ័ប្រាហាំ* គឺសាសន៍យូដាសុទ្ធ ដែលមិនត្រឹមតែជាអ្នកមានខ្សែលោហិតជាប់លោកអ័ប្រាហាំប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងជាអ្នកដែល "ដើរតាមដាននៃសេចក្ដីជំនឿលោកអ័ប្រាហាំ" ទៀតផង (រម ៤:១២) ។ ព្រះយេស៊ូវទ្រង់ទទួលស្គាល់គាត់យ៉ាងដូចនេះ ទោះបីជាសង្គមយូដាបានកាត់គាត់ចេញក៏ដោយ ។

**១៩:១០** គឺជាខគន្លឹះនៅក្នុងដំណឹងល្អលូកា ។ *កូនមនុស្ស* គឺជាងារមួយរបស់ព្រះមែស៊ី (មើលសេចក្ដីផ្ដើមត្រង់ ផែនការ និងការពន្យល់ មក ៨:៣១ ផងដែរ) ។ *ដើម្បីនឹងរក ហើយជួយសង្គ្រោះ* គឺគោលបំណងជាសង្ខេបរបស់ព្រះយេស៊ូវ ដែលទ្រង់បានយាងមក ដើម្បីប្រទាននូវសេចក្ដីសង្គ្រោះ ដែលមានន័យថាប្រទានជីវិតអស់កល្បជានិច្ច (១៨:១៨) និងប្រទាននូវនគរព្រះ (១៨:២៥) ។ មើលការពន្យល់ ១៥:៣២ ។

**១៩:១១** *នគរព្រះរៀបនឹងលេចមកភ្លាម* ពួកគេមានសង្ឃឹមថាព្រះមែស៊ីទ្រង់នឹងបង្ហាញអង្គទ្រង់ដោយអំណាច និងសិរីល្អ ដើម្បីបង្កើតនគររបស់ទ្រង់នៅលើលោកិយ ដោយយកជ័យជម្នះ លើគ្រប់ទាំងពួកខ្មាំងសត្រូវខាងផ្នែកនយោបាយ និងទាហានរបស់ពួកគេ ។

**១៩:១២** *ដើម្បីគ្រងរាជ្យ* ពួកស្ដេចត្រកូលហេរ៉ូឌបានទៅទីក្រុងរ៉ូមដើម្បីទទួលការជ្រើសតាំងជាស្ដេចលើសាសន៍យូដា ។ ការនេះស្រដៀងគ្នានឹងការដែលព្រះយេស៊ូវទ្រង់នឹងត្រូវយាងចេញទៅឆ្ងាយក្នុងពេលឆាប់ៗ ហើយនៅពេលអនាគតទ្រង់នឹងយាងមកវិញក្នុងរូបភាពជាស្ដេចមួយអង្គ ។ ក្នុងអំឡុងពេលដែលទ្រង់មិននៅ អ្នកបម្រើទ្រង់ត្រូវទទួលការផ្ទុកផ្ដាក់នឹងកិច្ចការរបស់ទ្រង់ដែលជាម្ចាស់លើពួកគេ (ចំពោះរឿងប្រៀបប្រដូចដែលស្រដៀងនឹងរឿងនេះ សូមមើល មថ ២៥:១៤–៣០) ។

**១៩:១៣** *១០ណែន* ព្រះគម្ពីរអង់គ្លេសប្រើ១០មីណា (Mina) ដែល១មីណាមានតម្លៃស្មើប្រាក់ឈ្នួលបីខែ ។

**១៩:១៤** *ចាត់សារឱ្យទៅតាមក្រោយ* ហេតុការណ៍ដូចនេះកើតឡើងក្នុងរាជ្យស្ដេចអើខេឡោសជាង៣០ឆ្នាំមុនពេលដែលព្រះយេស៊ូវទ្រង់មានបន្ទូលក្នុងខនេះហើយក៏មានហេតុការណ៍មួយចំនួនទៀតកើតឡើងដូចនេះផងដែរ ។ ការដែលព្រះយេស៊ូវទ្រង់មានបន្ទូលជាពាក្យប្រៀបប្រដូច ដែលឃើញមានក្នុងវគ្គនេះអាចជាការព្រមានដល់ពួកយូដា ចំពោះការបដិសេធន៍មិនព្រម

ពួកបាវទាំងនោះ ដែលទ្រង់បានប្រគល់ប្រាក់ដល់គេឱ្យ
មក ដើម្បីចង់ដឹង ពីអ្នកនិមួយៗ ដែលជួញបានចំណេញ
ប៉ុន្មានម្នាក់ ១៦អ្នកមុនដំបូងក៏មកទូលថា ព្រះអម្ចាស់អើយ
ប្រាក់ណែនរបស់ទ្រង់បានចំណេញ១០ណែនទៀត ១៧រួច
ទ្រង់មានបន្ទូលថា ប្រពៃហើយបាវល្អអើយ[ច] ដោយព្រោះ
ឯងមានចិត្តស្មោះចំពោះ ក្នុងការបន្តិចបន្តួចនេះ នោះចូរ
ឯងត្រួតលើទីក្រុង១០ចុះ[ឆ] ១៨អ្នកទី២ក៏មកទូលថា ព្រះ
អម្ចាស់អើយ ប្រាក់ណែនរបស់ទ្រង់បានចំណេញ៥ណែន
ទៀត ១៩រួចទ្រង់មានបន្ទូលទៅអ្នកនេះដែរថា ឯឯង ចូរ
ឯងត្រួតលើទីក្រុង៥ចុះ ២០អ្នក១ទៀតមកទូលថា ព្រះ
អម្ចាស់អើយ នេះនែ៎ប្រាក់ណែនរបស់ទ្រង់ ដែលទូលបង្គំ
បានវេចទុកក្នុងកន្សែង ២១ដ្បិតទូលបង្គំនឹកខ្លាចទ្រង់
ព្រោះទ្រង់ជាមនុស្សប្រិតប្រៀប ទ្រង់លើកយករបស់ដែល
ទ្រង់មិនបានដាក់ ហើយច្រូតចំរូតដែលទ្រង់មិនបានសាប
ព្រោះ[ជ] ២២នោះទ្រង់មានបន្ទូលទៅអ្នកនោះថា បាវអាក្រក់
អើយ អញនឹងជំនុំជំរះឯង តាមសំដីឯង[ឈ] ចុះបើឯងដឹងថា
អញជា មនុស្សប្រិតប្រៀប ទាំងលើកយករបស់ដែលអញ
មិនបានដាក់ ហើយច្រូតចំរូតដែលអញមិនបានសាប
ព្រោះ[ញ] ២៣ដូច្នេះ តើហេតុអ្វីបានជាឯងមិនបានយកប្រាក់
អញនោះ ទៅដាក់នៅឯផ្ទះចងការវិញ ដើម្បីដល់អញត្រ
ឡប់មកវិញ នោះអញនឹងបានទាំងដើមទាំងការផង ២៤ទ្រង់
ក៏មានបន្ទូលទៅពួកអ្នក ដែលឈរនៅមុខលោកថា ចូរដក
យកប្រាក់១ណែនពីវាចេញ ហើយឱ្យដល់អ្នកដែលមាន១០
ណែនវិញ ២៥(អ្នកទាំងនោះទូលទ្រង់ថា ព្រះអម្ចាស់អើយ
អ្នកនោះ មាន១០ណែនហើយ) ២៦ដ្បិតអញប្រាប់ឯងរាល់
គ្នាថា គេនឹងឱ្យដល់អស់អ្នកណាដែលមាន តែអ្នកណាដែល
គ្មាន នោះគេនឹងហូតយក ទាំងរបស់ដែលអ្នកនោះមាន
ចេញផង[ដ] ២៧មួយទៀត ឯពួកខ្មាំងសត្រូវ ដែលមិនចង់ឱ្យ
អញសោយរាជ្យលើគេ នោះចូរនាំគេមកសំឡាប់ទាំងអស់
នៅមុខអញនេះវិញ។

## ក្បួនដង្ហែរនៃជ័យជម្នះ

*១៩:២៩–៣៨ = មថ ២១:១–៩ មក ១១:១–១០*

*១៩:៣៥–៣៨ = យហ ១២:១២–១៥*

២៨លុះទ្រង់មានបន្ទូលសេចក្ដីទាំងនេះរួចហើយ នោះទ្រង់
យាងទៅខាងមុខ ឡើងសំដៅទៅឯក្រុងយេរូសាឡិម[ឋ]
២៩កាលយាងទៅជិតដល់ភូមិបេតផាសេ នឹងភូមិបេថានី[ឌ]
នៅក្បែរភ្នំ ដែលហៅថាភ្នំដើមអូលីវ[ឍ]ហើយ នោះទ្រង់
ចាត់សិស្ស២នាក់ឱ្យទៅដោយថា ៣០ត្រូវចូលទៅក្នុងភូមិ
នៅខាងមុខ នុ៎ះកាលណាចូលដល់ហើយ នោះនឹងឃើញកូន
លា១គេចងទុក ដែលមិនទាន់មានអ្នកណាជិះនៅឡើយចូរ
ស្រាយវាដឹកនាំមក ៣១បើអ្នកណាសួរអ្នកថា ស្រាយវាធ្វើអី
នោះត្រូវឆ្លើយថា ពីព្រោះព្រះអម្ចាស់ទ្រង់ត្រូវការនឹងវា

**១៩:១៧** ច សក ២៧:១៨
ឆ លក ១៦:១០
**១៩:២១** ជ មថ ២៥:២៤
**១៩:២២** ឈ ២សយ ១:១៦ យប ១៥:៦
ញ មថ ២៥:២៦
**១៩:២៦** ដ មថ ២៥:២៩
**១៩:២៨** ឋ មក ១០:៣២ លក ៩:៥១
**១៩:២៩** ឌ មថ ២១:១៧
ឍ មថ ២១:១

ទទួលព្រះយេស៊ូវជាស្តេច ។

**១៩:២២** *ចុះបើឯងដឹងថា អញជាមនុស្សប្រិតប្រៀប...* គឺមិនមានន័យថា ស្តេចទទួលស្គាល់ពាក្យសំដីរបស់បាវអាក្រក់នោះឡើយ ប៉ុន្តែ ទ្រង់គ្រាន់តែមានបន្ទូលតាមហើយសួរជាសំណួរទៅវិញប៉ុណ្ណោះ ។ បើបាវនោះពិតជាមានគំនិតយោបល់ដូចនេះមែន នោះគួរតែគាត់បានប្រព្រឹត្តតាមគំនិតនោះ ។

**១៩:២៦** មើល ៨:១៨ ១៧:៣៣ និងការពន្យល់ មថ ១៣:១២ ។ អ្នកណាដែលស្វែងរកផលចំណេញខាងវិញ្ញាណនៅក្នុងដំណឹងល្អ សម្រាប់ខ្លួនឯង ហើយក៏សម្រាប់អ្នកដទៃផងដែរ អ្នកនោះនឹងមានជាងមុន ហើយអ្នកណាដែលមិនយកចិត្តទុកដាក់ ឬខ្ជះខ្ជាយនឹងអ្វីដែលបានទទួលអ្នកនោះនឹងចុះក្រដោយបាត់បង់សូម្បីតែអ្វីៗដែលខ្លួនមានក៏ដោយ ។

**១៩:២៧** *ពួកខ្មាំងសត្រូវ . . . នាំគេមកសំឡាប់ទាំងអស់* ប្រហែលជាការនិយាយសំដៅទៅលើការបំផ្លិចបំផ្លាញទីក្រុងយេរូសាឡិមនៅក្នុងឆ្នាំ៧០ ។ ការកាត់ទោសអ្នកដែលបះបោរប្រឆាំងនឹងស្តេចយ៉ាងសកម្ម(ខ.១៤) នឹងមានកម្រិតធ្ងន់ជាងការកាត់ទោសបាវបម្រើធ្វេសប្រហែសម្នាក់នោះ ។

**១៩:២៨–៤៤** គឺជាក្បួនដង្ហែរនៃជ័យជម្នះ ដែលកើតឡើងនៅថ្ងៃអាទិត្យក្នុងសប្តាហ៍នៃបុណ្យរំលង(មើលការពន្យល់ មថ ២១:១–៩ មក ១១:១–១០ យហ ១២:១២–១៥)។

**១៩:២៩** *បេតផាសេ* គឺជាភូមិមួយស្ថិតនៅក្បែរផ្លូវ ពីក្រុងយេរីខូទៅក្រុងយេរូសាឡិម ។ *បេថានី* គឺភូមិមួយទៀត នៅភាគអាគ្នេយ៍ និងមានចម្ងាយជាង៣គម ពីក្រុងយេរូសាឡិម (យហ ១១:១៨) ហើយផ្ទះរបស់នាងម៉ារា នាងម៉ាថា និងឡាសារស្ថិតនៅក្នុងភូមិនោះ ។ *ភ្នំដើមអូលីវ* គឺជួរភ្នំតូចមួយដែលមានប្រវែងជាងមួយគីឡូម៉ែត្រកន្លះ(មើលការពន្យល់ មក ១១:១)។ ចំពោះភ្នំដើមអូលីវ ភូមិបេថានី ភូមិបេផាសេ ទាក់ទងនឹងទីក្រុងយេរូសាឡិម មើលផែនទីក្នុងព្រះគម្ពីរម៉ាកុស ។ *សិស្ស២នាក់* មិនមានបញ្ចេញឈ្មោះក្នុងវគ្គនេះ និងបទគម្ពីរដទៃទៀតដែលត្រូវនឹងខនេះឡើយ(មើល មថ ២១:១ មក ១១:១ យហ ១២:១៤)។

**១៩:៣០** *ភូមិ* ប្រហែលជាភូមិបេថានី ។ *កូនលា* (យហ ១២:១៥) ចំពោះការដែលកូនលានៅជាមួយនឹងមេវា មើល មថ ២១:៧ និងការពន្យល់ ។ ព្រះយេស៊ូវទ្រង់សម្រេចព្រះទ័យចូលក្រុងយេរូសាឡិមក្នុងពេលនេះ ដោយគង់លើខ្នងលា ដើម្បីប្រកាសជាសាធារណៈថា ទ្រង់ជាព្រះរាជបុត្រានៃស្តេចដាវីឌ ដែលបានជ្រើសតាំង ឱ្យគង់លើបល្ល័ង្ករបស់ស្តេចដាវីឌ (មើលការពន្យល់ ១ពវ ១:៣៣) គឺជាអង្គដែលពួកហោរាបានថ្លែងទំនាយពីទ្រង់ (សក ៩:៩ និងការពន្យល់)។ *មិនទាន់មានអ្នកណាជិះនៅឡើយ* គឺអាចយកទៅប្រើក្នុងកិច្ចការបរិសុទ្ធបាន (មើលការពន្យល់ មក ១១:២)។

**១៩:៣១** *ព្រះអម្ចាស់* គឺព្រះវរបិតា ឬអង្គព្រះយេស៊ូវ(ទំនងជាទ្រង់ជាងក្នុងវគ្គនេះ) ដែលការបង្គាប់ឱ្យប្រើពាក្យនេះ គឺជាការប្រកាស់ប្រាប់ពីឋានៈជា

៣២ ពួកអ្នកដែលទ្រង់បានចាត់នោះក៏ទៅ ឃើញមានដូចជា
ទ្រង់ប្រាប់[ណ] ៣៣ កំពុងដែលគេស្រាយកូនលា ម្ចាស់វាក៏សួរ
ថា អ្នកស្រាយវាធ្វើអី ៣៤ គេឆ្លើយថា ព្រះអម្ចាស់ទ្រង់ត្រូវ
ការនឹងវា ៣៥ រួចគេដឹកវាទៅ ថ្វាយព្រះយេស៊ូវ ក៏ក្រាលអាវ
គេលើខ្នង ហើយថ្វាយទ្រង់គង់ ៣៦ កំពុងដែលទ្រង់យាង
ទៅ គេក៏នាំគ្នាយកអាវរបស់ខ្លួនក្រាលតាមផ្លូវ[ត] ៣៧ លុះទ្រង់
យាងជិតដល់ហើយ គឺត្រង់ផ្លូវចុះពីភ្នំដើមអូលីវ[ថ]មក នោះ
ពួកសិស្សទ្រង់ទាំងហ្វូងចាប់តាំងមានសេចក្តីរីករាយ ក៏
ពោលសរសើរដល់ព្រះ ដោយសំឡេងយ៉ាងខ្លាំង ដោយ
ព្រោះអស់ទាំងការឫទ្ធិបារមីដែលគេបានឃើញនោះ ៣៨ គឺ[ទ]
ពោលថា ស្តេចដែលយាងមក ដោយនូវ ព្រះនាមព្រះ
អម្ចាស់ ទ្រង់ប្រកបដោយព្រះពរ[ទ] សូមឱ្យបានសេចក្តី
ក្សេមក្សាន្តនៅស្ថានសួគ៌ នឹងសិរីល្អនៅស្ថានដ៏ខ្ពស់បំផុត[ធ]
៣៩ នោះពួកផារិស៊ីខ្លះ ដែលនៅក្នុងបណ្តាមនុស្ស គេទូល
ទ្រង់ថា លោកគ្រូត្រូវស្តីបន្ទោសដល់ពួកសិស្សលោកផង[ន]
៤០ តែទ្រង់មានបន្ទូលទៅគេថា ខ្ញុំប្រាប់អ្នករាល់គ្នាថា
បើអ្នកទាំងនេះនៅស្ងៀម នោះថ្មនឹងស្រែកឡើងវិញ[ប]
៤១ កាលទ្រង់យាងទៅបង្កើយ នឹងឃើញទីក្រុងហើយ នោះ
ក៏ទ្រង់ព្រះកន្សែងនឹងក្រុងនោះថា[ផ] ៤២ ឱឯង ឯងអើយ
នៅថ្ងៃរបស់ឯងនេះ គួរណាស់តែឯងបានស្គាល់សេចក្តី
ដែលសំរាប់ឱ្យឯងបានសុខសាន្តទៅអេះ ប៉ុន្តែឥឡូវនេះ
សេចក្តីទាំងនោះបានកំបាំងនឹងភ្នែកឯងហើយ ៤៣ ដ្បិតនឹង
មានថ្ងៃមកដល់ ដែលពួកខ្មាំងសត្រូវឯងនឹងធ្វើបន្ទាយនៅ
ជុំវិញឯង ព្រមទាំងឡោមព័ទ្ធ ហើយបិទផ្លូវគ្រប់ទិស[ព] ៤៤ គេ
នឹងពង្រាបឯងឱ្យស្មើនឹងដី ព្រមទាំងកូនចៅដែលមាន ក្នុង
ឯងផង[ភ] ឥតទុកថ្មណាមួយឱ្យនៅត្រួតលើថ្មណា[ម] នៅក្នុង
ឯងឡើយ ពីព្រោះឯងមិនបានស្គាល់ពេលដែលព្រះយាង
មក[យ] ប្រោសឯងសោះ។

## ព្រះយេស៊ូវនៅឯព្រះវិហារ

*១៩:៤៥,៤៦ = មថ ២១:១២–១៦ មក ១១:១៥–១៨ យហ ២:១៣–១៦*

៤៥ កាលទ្រង់យាងចូលដល់ក្នុងព្រះវិហារហើយ នោះទ្រង់
ចាប់តាំងដេញពួកអ្នកដែលលក់ដូរចេញ ៤៦ ដោយបន្ទូលថា
មានសេចក្តីចែងទុកមកថា ដំណាក់អញជាទីសំរាប់អធិ–
ស្ឋាន តែអ្នករាល់គ្នាបានយកធ្វើជារោងចោរវិញ[រ]។
៤៧ ទ្រង់ក៏បង្រៀនក្នុងព្រះវិហាររាល់តែថ្ងៃ តែពួក
សង្គ្រាជ ពួកអាចារ្យ នឹងពួកអ្នកធំក្នុងបណ្តាជន គេខំស្វែង
រកឱកាស នឹងបំផ្លាញទ្រង់ចេញ[ល] ៤៨ តែរកហេតុអ្វីមិនបាន
សោះ ពីព្រោះបណ្តាជនកំពុងប្រុងស្តាប់ទ្រង់ណាស់ ។

**១៩:៣២** ណ លក ២២:១៣
**១៩:៣៦** ត ២ពវ ៩:១៣
**១៩:៣៧** ថ មថ ២១:១
**១៩:៣៨** ទ ទដ ១១៨:២៦ លក ១៣:៣៥ ធ លក ២:១៤
**១៩:៣៩** ន មថ ២១:១៥,១៦
**១៩:៤០** ប ហប ២:១១
**១៩:៤១** ផ អស ២២:៤ លក ១៣:៣៤,៣៥
**១៩:៤៣** ព អស ២៩:៣ យរ ៦:៦ អគ ៤:២ ២៦:៨ លក ២១:២០
**១៩:៤៤** ភ ទដ ១៣៧:៩ ម លក ២១:៦ យ ១ពត ២:១២
**១៩:៤៦** រ អស ៥៦:៧ យរ ៧:១១
**១៩:៤៧** ល មថ ១២:១៤ មថ ២៦:៥៥ មក ១១:១៨

"ព្រះអម្ចាស់នៃសាសន៍អ៊ីស្រាអែល"។

**១៩:៣៧** *អស់ទាំងការឫទ្ធិបារមី* ការប្រោសឡាសារឱ្យរស់ឡើងវិញ និងការប្រោសលោកបាទីមេឱ្យជាពីរោគខ្វាក់ គឺជាការឫទ្ធិបារមីដែលទ្រង់ទើបតែបានធ្វើ ប៉ុន្តែ ក៏មានរាប់បញ្ចូលការឫទ្ធិបារមីផ្សេងៗទៀត ដែលព្រះគម្ពីរយ៉ូហានបានកត់ទុកថា ទ្រង់បានធ្វើនៅក្រុងយេរូសាឡិម ព្រមទាំងនៅស្រុកកាលីឡេផងដែរ (មថ ២១:១៤ យហ ១២:១៧)។ *ពោលសរសើរដល់ព្រះ* មើល ១:៦៤ និងការពន្យល់ ។

**១៩:៣៩,៤០** ពួកផារិស៊ីគិតថា ហ្វូងមនុស្សកំពុងពោលពាក្យប្រមាថដល់ព្រះហើយ ពួកគេមិនចង់ឱ្យមាននរណាប្រជែងជាមួយនឹងអំណាចរបស់ពួកគេ ហើយក៏មិនចង់ឱ្យមានការបះបោរណាមួយកើតឡើង ជាហេតុនាំឱ្យពួករ៉ូម៉ាំងដកហូតសិទ្ធិអំណាចរបស់ពួកគេឡើយ ។ ហេតុដូចនេះបានជាពួកគេទូលព្រះយេស៊ូវឱ្យស្តីបន្ទោសសិស្សទ្រង់ឱ្យពួកគេនៅស្ងៀមវិញ ។

**១៩:៤០** ខយោងប្រហែលជានៅ ហព ២:១១ ។

**១៩:៤២** *សុខសាន្ត* គឺសេចក្តីសុខសាន្តដែលព្រះមែស៊ីបានយាងមក ដើម្បីផ្តល់ឱ្យ (មើល ១៨:៣៤)។

**១៩:៤៣** *ពួកខ្មាំងសត្រូវឯង នឹងធ្វើបន្ទាយនៅជុំវិញឯង* មើល ២១:២០ និងការពន្យល់ ។ បទទំនាយនេះបានសម្រេចនៅពេលដែលចក្រភពរ៉ូម៉ាំងចូលកាន់កាប់ក្រុងយេរូសាឡិមនៅឆ្នាំ៧០គ.ស ដោយសង់បន្ទាយដើម្បីឡោមព័ទ្ធយកទីក្រុងទាំងមូល ។ ព្រះបន្ទូលអធិប្បាយនេះគឺជាការរំឭកពីបទទំនាយក្នុងព្រះគម្ពីរសញ្ញាចាស់ ស្តីពីការបំផ្លិចបំផ្លាញទីក្រុងយេរូសាឡិម (អស ២៩:៣ ៣៧:៣៣ អគ ៤:១–៣)។

**១៩:៤៤** *ពេលដែលព្រះយាងមកប្រោសឯង* ព្រះទ្រង់បានយាងមកប្រោសសាសន៍យូដាតាមរយៈអង្គព្រះយេស៊ូវដែលជាព្រះមែស៊ី ប៉ុន្តែ ពួកគេមិនបានទទួលស្គាល់ ហើយបដិសេធទ្រង់ថែមទៀត(សូមមើល យហ ១:១០–១១ លក ២០:១៣–១៦)។

**១៩:៤៥** ព្រះគម្ពីរម៉ាកុស(១១:១១–១៧) បានបំភ្លឺថា ការបោសសំអាតព្រះវិហារនេះកើតឡើងនៅថ្ងៃបន្ទាប់ពីក្បួនដង្ហែរនៃជ័យជម្នះ គឺនៅថ្ងៃច័ន្ទនៃសប្តាហ៍ដែលទ្រង់រងទុក្ខ ។ *ដល់ក្នុងព្រះវិហារ* គឺទីធ្លាខាងក្រៅ(សម្រាប់សាសន៍ដទៃ)ដែលមានលក់សត្វសម្រាប់ថ្វាយយញ្ញបូជា ក្នុងតម្លៃមិនត្រឹមត្រូវ (មើលការពន្យល់ មក ១១:១៥)។ ព្រះគម្ពីរយ៉ូហាននិយាយពីការបោសសំអាតព្រះវិហារដែលព្រះ យេស៊ូវទ្រង់ធ្វើនៅពេលចាប់ផ្តើមព្រះរាជកិច្ចទ្រង់(យហ ២:១៣–២៥) ប៉ុន្តែ ព្រះគម្ពីរទាំងបីកណ្ឌដំបូង (មថ ២១:១២–១៣ មក ១១:១៥–១៧)និយាយតែអំពីការបោសសំអាតព្រះវិហារ ដែលទ្រង់ធ្វើនៅជិតចុងបញ្ចប់នៃព្រះរាជកិច្ចទ្រង់ប៉ុណ្ណោះ(មថ ២១:១២–១៧ យហ ២:១៤–១៧ និងការពន្យល់)។

**១៩:៤៧** *ពួកសង្គ្រាជ* មើល ៣:២ ២២:៥២ ២៣:៤ ២៤:២០ និងមើលការពន្យល់ មថ ២:៤ ។ ពួកសង្គ្រាជគឺជាផ្នែកមួយនៃក្រុមជំនុំ ដែលជាក្រុមប្រឹក្សាខាងការដឹកនាំសាសនាយូដា(មើលការពន្យល់ មក ១៤:៥៥)។ *ស្វែងរក* –

## អំណាចរបស់ព្រះយេស៊ូវ

*២០:១-៨ = មថ ២១:២៣-២៧ មក ១១:២៧-៣៣*

**២០** ១មានកាល១ថ្ងៃនោះ កំពុងដែលព្រះយេស៊ូវទ្រង់
បង្រៀនដល់ពួកជន ព្រមទាំងប្រាប់ដំណឹងល្អ[រ] នៅក្នុងព្រះ
វិហារ[ស] នោះពួកសង្គ្រាជ ពួកអាចារ្យ នឹងពួកចាស់ទុំ ក៏មក
ដល់ ២គេទូលទ្រង់ថា សូមប្រាប់យើងខ្ញុំ តើអ្នកធ្វើការទាំង
នេះ ដោយអាងអំណាចអ្វី អ្នកណាបានបើកអំណាចនេះ
ឱ្យអ្នក[ហ] ៣តែទ្រង់មានបន្ទូលឆ្លើយថា ខ្ញុំនឹងសួរអ្នករាល់
គ្នាពីសេចក្តី១ដែរ ចូរប្រាប់មកខ្ញុំសិន ៤ឯបុណ្យជ្រមុជ
របស់យ៉ូហាន[ឡ] តើមកពីស្ថានសួគ៌ ឬពីមនុស្ស ៥គេក៏រិះគិត
គ្នាថា បើយើងថា មកពីស្ថានសួគ៌ នោះវានឹងសួរយើង
វិញថា ដូច្នេះ ហេតុអ្វីបានជាអ្នករាល់គ្នាមិនបានជឿគាត់
៦តែបើយើងឆ្លើយថា មកពីមនុស្ស នោះបណ្តាជន[អ] នឹង
ចោលយើងនឹងថ្ម ពីព្រោះគេជឿប្រាកដថាយ៉ូហាននេះ
ជាហោរាមែន[ក] ៧រួចគេទូលឆ្លើយថា មិនដឹងជាមកពី
ណាទេ ៨ទ្រង់ក៏មានបន្ទូលសបដល់គេថា ដូច្នេះខ្ញុំមិនប្រាប់
ឱ្យអ្នករាល់គ្នាដឹង ដែលខ្ញុំអាងអំណាចអ្វីនឹងធ្វើការទាំងនេះ
ដែរ។

## រឿងប្រៀបប្រដូចពីអ្នកស៊ីឈ្នួលធ្វើចំការ

*២០:៩-១៩ = មថ ២១:៣៣-៤៦ មក ១២:១-១២*

៩ទ្រង់ក៏ចាប់តាំងមានបន្ទូលទៅបណ្តាជន ជាពាក្យប្រដូច
នេះថា មានបុរសម្នាក់បានដាំចំការទំពាំងបាយជូរ[ខ] ហើយ
ប្រវាស់ទៅឱ្យពួកអ្នកធ្វើចំការ រួចក៏ចេញពីស្រុកនោះទៅ
ជាយូរ[គ] ១០លុះដល់រដូវហើយ គាត់ក៏ចាត់បាវទៅឯពួកធ្វើ
ចំការ ដើម្បីឱ្យគេចែកផលទំពាំងបាយជូរមកគាត់ តែពួក
អ្នកទាំងនោះ គេវាយបណ្តេញបាវនោះឱ្យមកវិញទទេ
១១គាត់ចាត់បាវ១ទៅទៀត តែគេវាយបាវនោះដែរ ទាំង
ជៀលត្មះ ហើយបណ្តេញឱ្យមកវិញទទេ ១២គាត់ក៏ចាត់អ្នក
ទី៣ឱ្យទៅទៀត តែគេវាយអ្នកនោះឱ្យមានរបួស រួចបោះ
ចោលទៅក្រៅទៅ ១៣នោះថៅកែចំការគិតថា តើត្រូវឱ្យ
អញធ្វើដូចម្តេច អញនឹងចាត់កូនសំឡាញ់[ឃ] របស់អញឱ្យ
ទៅទៀត ក្រែងកាលណាគេឃើញ នោះគេនឹងកោតខ្លាច
ដល់វា ១៤តែកាលពួកធ្វើចំការបានឃើញ នោះគេរិះគិត
គ្នាថា នេះជាកូនគ្រងមរដក ចូរយើងសំឡាប់វាចោលទៅ
ដើម្បីឱ្យបានមរដកមកយើងវិញ ១៥គេក៏បោះទៅក្រៅចំការ
ហើយសំឡាប់ចោលទៅ ដូច្នេះ តើថៅកែចំការនោះនឹងធ្វើ
ដូចម្តេច ១៦គឺគាត់នឹងមកបំផ្លាញដល់ពួកធ្វើការ[ង] នោះ រួច
ប្រវាស់ទៅឱ្យអ្នកឯទៀតវិញ កាលបានឮសេចក្តីនោះហើយ

**២០:១** រ មថ ២៦:៥៥
ស លក ៨:១
**២០:២** ហ យហ ២:១៨
កច ៤:៧ ៧:២៧
**២០:៤** ឡ មក ១:៤
**២០:៦** អ លក ៧:២៩
ក មថ ១១:៩
**២០:៩** ខ អស ៥:១-៧ គ មថ ២៥:១៤
**២០:១៣** ឃ មថ ៣:១៧
**២០:១៦** ង លក ១៩:២៧

---

*ឱកាសនឹងបំផ្លាញទ្រង់* មើល ២០:១៩-២០ (យហ ៧:១ ១១:៥៣-៥៧)។

**២០:១** ហេតុការណ៍ទាំងអស់ចាប់ពី ២០:១-២១:៣៦ សុទ្ធតែកើតឡើងនៅថ្ងៃអង្គារនៃសប្តាហ៍រងទុក្ខ ដែលពោរពេញទៅដោយការស្វែងរកកំហុសព្រះយេស៊ូវ ។ *មានកាល១ថ្ងៃ* ព្រះគម្ពីរលូកាមិនបានប្រាប់ឱ្យចំៗថាថ្ងៃនោះជាថ្ងៃអ្វីឡើយ ប៉ុន្តែ ខយោងក្នុងព្រះគម្ពីរម៉ាកុស(មក ១១:១៩-២០,២៧-៣៣) បញ្ជាក់ថាថ្ងៃនោះ (ថ្ងៃអង្គារ) គឺជាថ្ងៃបន្ទាប់ពីថ្ងៃបោសសំអាតព្រះវិហារ(ថ្ងៃច័ន្ទ) ដែលបន្ទាប់ពីថ្ងៃក្បួនដង្ហែរនៃជ័យជម្នះ(ថ្ងៃអាទិត្យ)។ មើលផែនទីចុងក្រោយក្នុងព្រះគម្ពីរម៉ាកុស ។ *ពួកសង្គ្រាជ* មើល ១៩:៤៧ និងការពន្យល់ ។ *ពួកអាចារ្យ* មើល ៥:៣០ និងការពន្យល់ ៥:១៧ ។ *ពួកចាស់ទុំ* មើលការពន្យល់ មថ ១៥:២ ។ ក្រុមនីមួយៗសុទ្ធតែមានតំណាងរបស់ខ្លួននៅក្នុងក្រុមប្រឹក្សាសាសនាយូដាដែលហៅថា ក្រុមជំនុំ(២២:៦៦)។

**២០:២** *អ្នកណាបានបើកអំណាចនេះឱ្យអ្នក* ពួកគេធ្លាប់សួរសំណួរដូចនេះដល់លោកយូហាន-បាទីស្ទ(យហ ១:១៩-២៥) បន្ទាប់មកក៏បានសួរព្រះយេស៊ូវ ក្នុងគ្រាដែលព្រះរាជកិច្ចទ្រង់ទើបតែបានចាប់ផ្តើមផងដែរ(យហ ២:១៨-២២)។ ការចោទសួរនេះប្រហែលជាសំដៅទៅលើការដែលទ្រង់បោសសំអាតព្រះវិហារ ដែលមិនត្រឹមតែប៉ះពាល់ដល់អំណាចរបស់ពួកមេដឹកនាំសាសនាយូដាទាំងអស់នោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានធ្វើឱ្យពួកគេបាត់បង់ប្រាក់ចំណេញទៀតផង ។ មេដឹកនាំទាំងនោះប្រហែលជាកំពុងស្វែងរកវិធីធ្វើយ៉ាងណាឱ្យបណ្តាជនអស់ជំនឿលើព្រះយេស៊ូវ ឬធ្វើឱ្យពួកគេមានការសង្ស័យថាទ្រង់ គឺជាទីគំរាមកំហែងចំពោះអំណាចគ្រប់គ្រងរបស់ចក្រភពរ៉ូម៉ាំង ។

**២០:៤** ព្រះយេស៊ូវទ្រង់បានដាក់បន្ទុកលើពួកអ្នកដែលប្រឆាំងនឹងទ្រង់ ដោយឆ្លើយតបសំណួរពួកគេដោយការសួរសំណួរមួយបកទៅវិញ ដែលបង្កប់ទៅដោយជម្រើសពីរគឺ ថាតើការងាររបស់លោកយ៉ូហានគឺមានព្រះជាអ្នកបណ្តាល ឬមនុស្សជាអ្នកផ្តើមគំនិតធ្វើ ។ ពួកគេបានធ្វើខ្លួនជាមនុស្សល្ងង់ដើម្បីគេចមិនព្រមឆ្លើយសំណួរទ្រង់។*ពីស្ថានសួគ៌* មក ១១:៣០ និងពន្យល់។

**២០:១០** *គាត់ក៏ចាត់បាវទៅ* រឿងប្រៀបប្រដូចនេះ(ខ.៩)រំឮកពី អស ៥:១-៧ (មើលការពន្យល់ អស ៥:១)។ បាវដែលត្រូវចាត់ទៅឯពួកធ្វើចំការតំណាងឱ្យពួកហោរារបស់ព្រះដែលបានចាត់ពីអតីតកាល ហើយត្រូវគេបដិសេធ(នហ ៩:២៦ យរ ៧:២៥ និងការពន្យល់ ២៥:៤-៧ មថ ២៣:៣៤ កច ៧:៥២ ហព ១១:៣៦-៣៨)។ *ចែកផលទំពាំងបាយជូរ* តាមកិច្ចព្រមព្រៀងនៃការចែកផលដំណាំម្ចាស់ចំការត្រូវទទួល ថ្លៃជួលចំការរបស់គាត់ជាចំណែកផលដំណាំ ហើយដល់ពេលកំណត់ម្ចាស់ចំការតែងមានសង្ឃឹមថា នឹងបានទទួលចំណែកនោះ ។

**២០:១៣** *កូនសំឡាញ់រស់អញ* គឺសំដៅទៅលើព្រះរាជបុត្រានៃព្រះ ដែលជាព្រះយេស៊ូវគ្រីស្ទ (៣:២២ មថ ១៧:៥ និងការពន្យល់)។

**២០:១៤** *បានមរដកមកយើងវិញ* មើលការពន្យល់ មក ១២:៧ ។

**២០:១៦** *ប្រវាស់ទៅឱ្យអ្នកឯទៀតវិញ* មើលការពន្យល់ មក ១២:៤១ ។

គេក៏ទូលថា សូមកុំឱ្យបានដូច្នោះឡើយ ១៧តែទ្រង់ទតទៅ
គេ មានបន្ទូលថា ឯសេចក្តីដែលចែងទុកមកថា «ថ្មដែល
ជាងសង់ផ្ទះបានចោលចេញនោះ បានត្រឡប់ជាថ្មជ្រុង
យ៉ាងឯក» តើមានន័យ ដូចម្តេច[ច] ១៨អសអ្នកណាដែលធ្លាក់
លើថ្មនោះនឹងត្រូវបាក់បែក តែអ្នកណាដែលថ្មនោះធ្លាក់
លើ នោះនឹងត្រូវកិនខ្ទេចខ្ទីទៅ[ឆ] ១៩នៅវេលានោះឯង ពួក
សង្គ្រាជនឹងពួកអាចារ្យក៏រកចាប់ទ្រង់[ជ] ដ្បិតគេដឹងថា ទ្រង់
មានបន្ទូលពាក្យប្រៀបនោះដាក់គេ តែគេនឹកខ្លាចបណ្តា
ជន[ឈ]។

## ការបង់ពន្ធទៅស្តេចសេសារ

*២០:២០–២៦ = មថ ២២:១៥–២២ មក ១២:១៣–១៧*

២០គេឃ្លាំមើលទ្រង់ ហើយក៏ចាត់ពួកសិងាត់ខ្លះទៅ ដែល
ធ្វើឫកជាត្រឹមត្រូវ ដើម្បីនឹងចាប់ទ្រង់ ដោយនូវព្រះបន្ទូល[ញ]
ប្រយោជន៍នឹងបញ្ជូនទ្រង់ទៅក្នុងកំឡាំង នឹងអំណាចនៃចៅ
ហ្វាយខេត្ត[ដ] ២១អ្នកទាំងនោះទូលសួរទ្រង់ថា លោកគ្រូ
យើងខ្ញុំដឹងថា លោកមានប្រសាសន៍ ហើយបង្រៀន សុទ្ធតែ
ដោយត្រឹមត្រូវទាំងអស់ ហើយលោកមិនយល់មុខអ្នកណា
សោះ លោកបង្រៀនពីផ្លូវព្រះ តាមតែសេចក្តីពិត[ឋ] ២២ដូច្នេះ
តើបើកឱ្យយើងខ្ញុំបង់ពន្ធថ្វាយសេសារឬទេ ២៣តែទ្រង់ជ្រាប
ឧបាយកលរបស់គេ ក៏មានបន្ទូលថា ហេតុអ្វីបានជាល្បួង
លខ្ញុំដូច្នេះ ២៤ចូរបង្ហាញកាក់ធំ១មកឱ្យខ្ញុំមើល តើមានរូប
នឹងឈ្មោះនេះ ជារបស់អ្នកណា គេទូលឆ្លើយថា ជារបស់
សេសារ ២៥នោះទ្រង់មានបន្ទូលថា បើដូច្នេះចូរថ្វាយរបស់

**២០:១៧** ច ទដ ១១៨:២២ កច ៤:១១
**២០:១៨** ឆ អស ៨:១៤,១៥
**២០:១៩** ជ លក ១៩:៤៧ ឈ មក ១១:១៨
**២០:២០** ញ មថ ១២:១០ ដ មថ ២៧:២
**២០:២១** ឋ យហ ៣:២
**២០:២៥** ឌ លក ២៣:២ រម ១៣:៧
**២០:២៧** ឍ កច ៤:១ ណ កច ២៣:៨ ១កថ ១៥:១២
**២០:២៨** ត ចទ ២៥:៥
**២០:៣៥** ថ មថ ១២:៣២

សេសារទៅសេសារទៅ[ឌ] ហើយរបស់ព្រះទៅព្រះវិញ
២៦ខណនោះ គេចាប់ព្រះបន្ទូលទ្រង់នៅមុខជនទាំងឡាយ
មិនបាន ហើយក៏ស្ងៀមនៅ ដោយអស្ចារ្យពីចំឡើយរបស់ទ្រង់។

## ការរស់ឡើងវិញ ហើយនិងការរៀបការ

*២០:២៧–៤០ = មថ ២២:២៣–៣៣ មក ១២:១៨–២៧*

២៧នោះមានពួកសាឌូស៊ីខ្លះ[ឍ] ដែលប្រកាន់ថា គ្មានសេចក្តី
រស់ឡើងវិញ[ណ] គេមកទូលសួរដល់ព្រះយេស៊ូវថា ២៨លោក
គ្រូ លោកម៉ូសេបានចែងទុកឱ្យយើងខ្ញុំថា បើបងអ្នកណា
មានប្រពន្ធ ហើយស្លាប់ទៅឥតមានកូន នោះប្អូនត្រូវយក
នាងនោះ ដើម្បីនឹងបង្កើតពូជឱ្យបង[ត] ២៩ដូច្នេះមានបងប្អូន
៧នាក់ បងច្បងបានយកប្រពន្ធ ហើយស្លាប់ទៅគ្មានកូន
សោះ ៣០ប្អូនបន្ទាប់ក៏យកនាង ហើយស្លាប់ទៅ ឥតកូនដែរ
៣១អ្នកទី៣ក៏យកនាងទៀត បណ្តាទាំង៧នាក់នោះក៏យកនាង
គ្រប់ៗគ្នា ហើយស្លាប់ទៅឥតមានកូនដូចគ្នាទាំងអស់
៣២ក្រោយបង្អស់មក នាងនោះស្លាប់ទៅដែរ ៣៣ដូច្នេះដល់
គ្រាដែលរស់ឡើងវិញតើនាងនោះនឹងធ្វើជាប្រពន្ធរបស់អ្នក
ណា ដ្បិតអ្នកទាំង៧នោះបានយកនាងធ្វើជាប្រពន្ធគ្រប់ៗគ្នា។
៣៤នោះទ្រង់មានបន្ទូលឆ្លើយថា ធម្មតាមនុស្សនៅលោ
កីយនេះ គេតែងយកប្តីប្រពន្ធ ៣៥តែអស់អ្នកដែលបាន
រាប់ជាគួរ ឱ្យបានទៅឯបរលោកនាយ[ថ] ហើយឱ្យបាន
រស់ពីស្លាប់ឡើងវិញនៅស្ថាននោះគេមិនដែលយកប្តីប្រពន្ធ
ទៀតទេ ៣៦ពីព្រោះគេមិនចេះស្លាប់ទៀត គឺដូចជាទេវតា

**២០:១៧** *ថ្មជ្រុងយ៉ាងឯក* មើល កច ៤:១១ រម ៩:៣៣ ១ពត ២:៧ និងការពន្យល់ ទដ ១១៨:២២ ។

**២០:១៨** *នឹងត្រូវបាក់បែក* ឆ្នាំងដែលបោកនឹងថ្មត្រូវបែក ហើយឆ្នាំងដែលថ្មធ្លាក់លើក៏ត្រូវខ្ទេច ដូចនេះអ្នកដែលបដិសេធព្រះយេស៊ូវនឹងជួបសេចក្តីហិនវិនាសផងដែរ (អស ៨:១៤ និងពន្យល់ ដយ ២:៣៤-៣៥,៤៤ លក ២:៣៤) ។

**២០:១៩** *ពួកអាចារ្យ* មើលការពន្យល់ មថ ២:៤ ។ ចំពោះការប្រឆាំងរបស់ពួកគេ សូមមើល ៥:១៧ និងការពន្យល់ ខ.៣០ ៩:២០ ១៩:៤៧ ២២:២ ២៣:១០ ។

**២០:២០** *អំណាចនៃចៅហ្វាយខេត្ត* ដោយខ្លាចមិនហ៊ានធ្វើសកម្មភាពខ្លួនឯង ពួកមេដឹកនាំសាសន៍យូដាមានសង្ឃឹមថា ពួកគេអាចចាប់កំហុសព្រះយេស៊ូវដោយនូវបន្ទូលដែលប្រឆាំងនឹងពួកមន្ត្រីរ៉ូម៉ាំង ហើយធ្វើឱ្យពួកនេះចាត់វិធានការដកព្រះវត្តមានទ្រង់ចេញ ដើម្បីកាត់ផ្តាច់ទំនាក់ទំនងដែលទ្រង់មានជាមួយបណ្តាជន ។

**២០:២២** *បង់ពន្ធថ្វាយសេសារ* មើលការពន្យល់ មក ១២:១៤ ។ ការគាំទ្រការតម្រូវឱ្យបង់ពន្ធរបស់ស្តេចសេសារ នឹងនាំឱ្យបណ្តាជនខកចិត្ត ប៉ុន្តែ ការបង្រៀនមិនឱ្យបង់ពន្ធ នឹងនាំឱ្យប៉ះពាល់ដល់រាជការរ៉ូម៉ាំង ។ អ្នកដែលសួរនោះ សង្ឃឹមថានឹងបានចាប់ព្រះយេស៊ូវ ដោយប្រើជម្រើសទាំងពីរនេះ (មើលការពន្យល់ មថ ២២:១៥–១៧) ។

**២០:២៤** *កាក់ធំ១* គឺលុយកាក់ "ឌីណារី (Dinarius) "របស់រ៉ូម៉ាំង ។ ១ឌីណារីមានតម្លៃស្មើប្រាក់ឈ្នួលមួយថ្ងៃ (មើលការពន្យល់ មថ ២២:១៩) ។

**២០:២៥** *របស់ព្រះទៅព្រះ* មើលការពន្យល់ មថ ២២:២១ មក ១២:១៧។

**២០:២៧** *ពួកសាឌូស៊ី* គឺជាក្រុមមួយនៃពួកអភិជន និងមានគំនិតជាអ្នកនយោបាយ ដែលព្រមធ្វើការសម្រុះសម្រួលគ្នាជាមួយនឹងអ្នកដឹកនាំមិនមែនខាងសាសនា និងអ្នកដឹកនាំសាសន៍ដទៃ ។ នៅសម័យនោះពួកសាឌូស៊ីបានគ្រប់គ្រងលើនាទីរបស់សម្តេចសង្ឃ ហើយកៅអីភាគច្រើនបំផុតនៅក្នុងក្រុមជំនុំជារបស់ពួកគេ ។ ពួកសាឌូស៊ីមិនជឿលើការរស់ពីស្លាប់ឡើងវិញ ឬសេចក្តីបន្ទាប់ពីការស្លាប់ឡើយ ហើយពួកគេបដិសេធមិនព្រមទទួលស្គាល់ទំនៀមទម្លាប់កើតពីមាត់របស់ពួកផារិស៊ីឡើយ (តាមប្រវត្តិវិទូ យ៉ូសែប–ហ្វីស) ។ មើលការពន្យល់ អរ ៧:២ មថ ២:៤ ៣:៧ ២២:២៣ មថ ១២:១៨ កច ៤:១ និងតារាងនិកាយសាសនាយូដា ក្នុងព្រះគម្ពីរម៉ាថាយ ។

**២០:២៨** *ប្អូនត្រូវយកនាងនោះ* គឺតាមក្រឹត្យវិន័យស្តីពីអាពាហ៍ពិពាហ៍ (ការពន្យល់ មថ ២២:២៤ លប ៣៨:៨ និងការពន្យល់) ។

**២០:៣៤–៣៥** *លោកីយនេះ... បរលោកនាយ* មើលការពន្យល់ ១៨:៣០។

**២០:៣៦** *ដូចជាទេវតា* សេចក្តីដែលមានជាបន្តបន្ទាប់ពីការរស់ឡើយវិញ

ហើយជាពួកកូនរបស់ព្រះផង[ទ] ដោយបានរស់ពីស្លាប់ឡើង
វិញ ៣៧រីឯដំណើរដែលមនុស្សរស់ពីស្លាប់ឡើងវិញ នោះ
ទាំងលោកម៉ូសេក៏បានបង្ហាញ ក្នុងរឿងពីគុម្ពបន្លាហើយ
ក្នុងកាលដែលលោកហៅព្រះអម្ចាស់ ថាជាព្រះនៃលោក
អ័ប្រាហាំនៃលោកអ៊ីសាក ហើយនៃលោកយ៉ាកុប[ធ] ៣៨ដ្បិត
ទ្រង់មិនមែនជាព្រះនៃមនុស្សស្លាប់ទេ គឺជាព្រះនៃមនុស្ស
រស់វិញ ព្រោះមនុស្សទាំងអស់រស់សំរាប់ទ្រង់ ៣៩នោះមាន
ពួកអាចារ្យខ្លះឆ្លើយឡើងថា លោកគ្រូ លោកមានប្រសាសន៍
ត្រូវណាស់ ៤០រួចគេមិនហ៊ានទូលសួរទ្រង់ទៀតឡើយ[ន]។

**តើព្រះគ្រីស្ទមានវង្សត្រកូលពីណា?**

*២០:៤១-៤៧ = មថ ២២:៤១-២៣:៧ មក ១២:៣៥-៤០*

៤១ទ្រង់ក៏មានបន្ទូលសួរគេថា ដូចម្តេចបានជាគេថា ព្រះ
គ្រីស្ទជាព្រះវង្សហ្លួងដាវីឌ[ប] ៤២ព្រោះហ្លួងដាវីឌនោះ ឯង
ទ្រង់បានមានបន្ទូលក្នុងគម្ពីរទំនុកដំកើងថា «ព្រះអម្ចាស់ ទ្រង់
មានបន្ទូលទៅព្រះអម្ចាស់ខ្ញុំថា ចូរឯងអង្គុយខាងស្តាំអញ
៤៣ទាល់តែអញដាក់ពួកខ្មាំងសត្រូវឯង ឱ្យធ្វើជាកំណល់
កល់ជើងឯង[ផ]» ៤៤ដូច្នេះ បើហ្លួងដាវីឌនោះឯង ទ្រង់ហៅព្រះ
គ្រីស្ទជាព្រះអម្ចាស់ នោះធ្វើដូចម្តេចឱ្យព្រះគ្រីស្ទធ្វើជា
ព្រះវង្សទ្រង់បាន។

៤៥កាលបណ្តាជនកំពុងតែស្តាប់ទ្រង់ នោះទ្រង់មានបន្ទូល
ទៅពួកសិស្សថា ៤៦ចូរប្រុងប្រយ័ត្ននឹងពួកអាចារ្យដែល
គេចូលចិត្តពាក់អាវវែងដើរចុះឡើង ក៏គាប់ចិត្តឱ្យមនុស្ស
គំនាប់គេនៅទីផ្សារ ហើយចង់អង្គុយកន្លែងមុខគេក្នុង
សាលាប្រជុំ នឹងកន្លែងដ៏ប្រសើរបំផុតក្នុងការស៊ីលៀង[ព]
៤៧តែគេឆស៊ីផ្ទះស្រីមេម៉ាយទាំងដោះសាខ្លួនដោយសូត្រ
ធម៌ឱ្យច្រើន អ្នកទាំងនោះឯងនឹងត្រូវទោសធ្ងន់ជាងទៅ
ទៀត។

**ដង្វាយរបស់ស្ត្រីមេម៉ាយ**

*២១:១-៤ = មក ១២:៤១-៤៤*

**២១** ១នោះទ្រង់ក្រឡេកព្រះនេត្រទតទៅ ឃើញពួកអ្នក
មានកំពុងតែដាក់ប្រាក់ដង្វាយក្នុងឃ្លាំង[ភ] ២ទ្រង់ក៏ឃើញស្រី
មេម៉ាយក្រម្នាក់ ដាក់ថ្វាយតែ២ស្លឹងគត់ ៣រួចទ្រង់មាន
បន្ទូលថា ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ស្រីមេម៉ាយទ័ល
ក្រនេះ បានដាក់ដង្វាយលើសជាងគេទាំងអស់ ៤ដ្បិតអ្នក
ទាំងនោះ សុទ្ធតែយកពីរបស់សំណល់ខ្លួនមកថ្វាយ តែឯស្ត្រី
នេះ នាងបានយកពីសេចក្តីកំសត់របស់ខ្លួនមក ថ្វាយវិញ គឺ
នាងបានថ្វាយរបស់ទាំងប៉ុន្មាន ដែលមានសំរាប់នឹងចិញ្ចឹម
ជីវិតខ្លួនផង[ម]។

**សញ្ញានៃទីអវសាននៃពិភពលោក**

*២១:៥-៣៦ = មថ ២៤: មក ១៣*

*២១:១២-១៧ = មថ ១០:១៧-២២*

៥កាលអ្នកខ្លះកំពុងតែនិយាយពីព្រះវិហារ ដែលធ្វើនឹងថ្ម
យ៉ាងល្អ ហើយតាក់តែងដោយដង្វាយទាំងប៉ុន្មាន នោះទ្រង់

**២០:៣៦** ទ យហ ១:១២
**២០:៣៧** ធ នក ៣:៦
**២០:៤០** ន មថ ២២:៤៦ មក ១២:៣៤
**២០:៤១** ប មថ ១:១
**២០:៤៣** ផ ទដ ១១០:១ មថ ២២:៤៤
**២០:៤៦** ព លក ១១:៤៣
**២១:១** ភ មថ ២៧:៦ យហ ៨:២០
**២១:៤** ម ២កថ ៨:១២

មិនអាចចាប់ផ្តើម ដោយបន្តពីខ្សែជីវិតនៅលើលោកិយនេះបានឡើយ ។ នៅឯបរលោកនាយនឹងគ្មានអាពាហ៍ពិពាហ៍ គ្មានការបន្តពូជ ហើយក៏គ្មានសេចក្តីស្លាប់ដែរ (មើលការពន្យល់ មក ១២:២៥)។ *ពួកកូនរបស់ព្រះផង ដោយបានរស់ពីស្លាប់ឡើងវិញ* គឺពួកអ្នកដែលត្រូវមានចំណែកនៅក្នុងការរស់ឡើងវិញរបស់ពួកសុចរិត (មក ១២:១៨ កថ ៤:១ ២៣:៦ និងពន្យល់)។

**២០:៣៧** *ក្នុងរឿងពីគុម្ពបន្លា* មើល នក ៣:២-៦ និងការពន្យល់ ។

**២០:៣៩** *លោកគ្រូលោកមានប្រសាសន៍ត្រូវណាស់* ពួកអាចារ្យមានសេចក្តីសម្អប់និងកំហឹងចំពោះព្រះយេស៊ូវខ្លាំងមែនពិត ប៉ុន្តែ ពួកអាចារ្យ (ដែលជាពួកផារិស៊ី) បានកាន់ខាងព្រះយេស៊ូវប្រឆាំងនឹងពួកសាឌូស៊ី ចំពោះករណីរស់ពីស្លាប់ឡើងវិញ ។

**២០:៤៤** *ហ្លួងដាវីឌនោះឯង ទ្រង់ហៅព្រះគ្រីស្ទជាព្រះអម្ចាស់* ព្រះបន្ទូលជិទាស់ដែលយេស៊ូវទ្រង់មាននឹងពួកមេដឹកនាំសាសនាយូដា គឺព្រោះព្រះមែស៊ីទ្រង់ជាពូជរបស់ហ្លួងដាវីឌ តើហ្លួងដាវីឌដ៏ជាក្សត្រដែលគេគោរពនោះអាច ហៅកូនចៅរបស់ទ្រង់ថា ជាព្រះអម្ចាស់បានដោយរបៀបណា? នោះពួកអ្នកប្រឆាំងនឹងទ្រង់មិនអាចឆ្លើយសំណួរនេះបានឡើយ បើពួកគេមិនទាន់បានទទួលស្គាល់នៅឡើយទេ ថាព្រះមែស៊ីទ្រង់គឺជាព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុតទៀតផង (មើលការពន្យល់ ទដ ១១០:១ មថ ២២:៤៤ មក ១២:៣៦)។

**២០:៤៦** *អាវវែង... កន្លែងមុខគេ* មើលការពន្យល់ មក ១២:៣៨-៣៩ ។

**២០:៤៧** *ឆស៊ីផ្ទះស្ត្រីមេម៉ាយ* គឺពួកអាចារ្យបានបោកប្រាស់និងរៀបគម្រោងរកប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីឆ្លៀតយកប្រយោជន៍ពីក្រុមអ្នកដែលគ្មានទីបង្អែកនេះ ។ *ទោសធ្ងន់ជាងទៅទៀត* (សូមផ្ទៀបនឹង ១២:៤៦-៤៨ និងការពន្យល់)។ ទទួលបាននូវទំនុកចិត្តកាន់តែច្រើនត្រូវប្រកាន់នូវយុត្តិធម៌ពិតប្រាកដកាន់តែម៉ឺងម៉ាត់ ហើយមានពុតត្បុតកាន់តែខ្លាំង(មថ ២៣:១-៣៦) នោះត្រូវក៏ទទួលទោសកាន់តែធ្ងន់ផងដែរ។

**២១:១** *ឃ្លាំង* កន្លែងស្ត្រីដែលនៅភាគខាងកើតនៃវិហារស្តេចហេរ៉ូឌ មានដាក់ប្រអប់ចំនួន១៣ មានរាងដូចជាមេក្រូផ្កាប់ ប្រើសម្រាប់ដាក់ដង្វាយរបស់អ្នកដែលមកថ្វាយបង្គំ(មើលការពន្យល់ មក ១២:៤១)។

**២១:២** *តែពីស្លឹងគត់* មើលការពន្យល់ មក ១២:៤២ ។

**២១:៣-៤** មើលការពន្យល់ ២កថ ៨:១២ ។

**២១:៣** *ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា* មើលការពន្យល់ មក ៣:២៨ ។

**២១:៥-៣៦** មើលការពន្យល់ មក ១៣:១-៣៧ ។

**២១:៥** *ព្រះវិហារ ដែលធ្វើនឹងថ្ម* ស្តេចហេរ៉ូឌបានប្រទានរូបចម្លាក់ទំពាំងបាយជូរមួយធ្វើពីមាស សម្រាប់តុបតែងលំអរព្រះវិហារនេះ ។ គ្រាន់តែចង្កោមរបស់ទំពាំងបាយជូរនោះ មានកំពស់ស្មើមនុស្សប្រុសម្នាក់ ។ ភាពស្រស់ស្អាតទាំងមូលរបស់ព្រះវិហារ ដែលស្តេចហេរ៉ូឌបានសាងសង់ និង

មានបន្ទូលថា ៦ឯរបស់ទាំងនេះ ដែលអ្នករាល់គ្នាកំពុងតែ
មើល នោះនឹងមានថ្ងៃមកដល់ ដែលនឹងគ្មានថ្មនៅត្រួតលើ
ថ្មទៀត ឥតត្រូវទំលាក់ចុះនោះទេ[យ] ៧នោះគេទូលសួរទ្រង់
ថា លោកគ្រូ តើកាលណាការទាំងនេះនឹងកើតឡើង តើ
មានទីសំគាល់ណា ឱ្យដឹងក្នុងកាលដែលការទាំងនេះជិត
មកដល់ ៨ទ្រង់មានបន្ទូលថា ចូរប្រយ័តក្រែងអ្នកណានាំ
ឱ្យអ្នករាល់គ្នាវង្វេង ដ្បិតនឹងមានមនុស្សជាច្រើនយកឈ្មោះ
ខ្ញុំ មកនិយាយថា គឺខ្ញុំនេះហើយ ក៏នឹងថា វេលាជិតដល់
ហើយ ដូច្នេះកុំឱ្យទៅតាមគេឡើយ[រ] ៩កាលណាអ្នករាល់គ្នា
ឮ និយាយពីចំបាំង នឹងចលាចលនោះកុំឱ្យភ័យស្លុតឡើយ
ដ្បិតការទាំងនោះត្រូវតែមកជាមុន តែនោះពុំទាន់ដល់ចុង
បំផុតជាឆាប់ម្ល៉េះទេ។
១០ទ្រង់ក៏មានបន្ទូលទៅគេថា សាសន៍១នឹងលើកគ្នាទាស់
នឹងសាសន៍១ ហើយនគរ១ទាស់នឹងនគរ១[ល] ១១ក៏នឹងមាន
កក្រើកដីជាខ្លាំង និងអំណត់ ហើយអាសន្នរោគនៅកន្លែង
ផ្សេងៗ ទាំងមានហេតុនាំឱ្យភ័យ នឹងទីសំគាល់យ៉ាងធំពី
លើមេឃផង[វ]។
១២តែមុនការទាំងនោះ គេនឹងចាប់អ្នករាល់គ្នាធ្វើទុក្ខ
បញ្ជូនទៅសាលាប្រជុំ ហើយដាក់គុក ព្រមទាំងនាំអ្នករាល់
គ្នាទៅចំពោះស្តេច និងចៅហ្វាយខេត្ត ដោយព្រោះឈ្មោះ
ខ្ញុំផង ១៣ប៉ុន្តែការនោះនឹងត្រឡប់ប្រែជាឱកាស ឱ្យអ្នក
រាល់គ្នាធ្វើបន្ទាល់វិញ[ស] ១៤ដូច្នេះ ចូរសំរេចក្នុងចិត្តថា អ្នក
រាល់គ្នានឹងមិនគិតជាមុន អំពីពាក្យដែលត្រូវដោះសាទេ[ហ]
១៥ដ្បិតខ្ញុំនឹងឱ្យអ្នករាល់គ្នាមានថ្វីមាត់[ឡ] ហើយនិងប្រាជ្ញាវិញ
ដែលពួកអ្នកតតាំងពុំអាចនឹងឆ្លើយឆ្លង ឬទទឹងទាស់បាន
ឡើយ ១៦ប៉ុន្តែទោះទាំងឪពុកម្តាយ បងប្អូន ញាតិសន្តាន
ហើយមិត្រ[អ]សំឡាញ់ក៏នឹងបញ្ជូនអ្នករាល់គ្នា ហើយនឹងសំ
ឡាប់អ្នករាល់គ្នាខ្លះដែរ ១៧មនុស្សទាំងអស់នឹងស្អប់អ្នករាល់
គ្នា ដោយព្រោះឈ្មោះខ្ញុំ[ក] ១៨តែសូម្បីសក់១សរសៃលើក្បាល
អ្នករាល់គ្នា ក៏មិនត្រូវវិនាសបាត់ផង[ខ] ១៩អ្នករាល់គ្នានឹង
បានជីវិតគង់នៅវិញដោយមានចិត្តខ្ជាប់ខ្ជួន[គ]។
២០ប៉ុន្តែ កាលណាឃើញពលទ័ពឡោមព័ទ្ធក្រុងយេរូសា
ឡិម[ឃ] នោះត្រូវឱ្យដឹងថា សេចក្តីហិនវិនាសនៃក្រុងនោះ
ជិតដល់ហើយ ២១គ្រានោះ ត្រូវឱ្យអស់អ្នកនៅស្រុកយូដារត់
ទៅឯភ្នំ ហើយពួកអ្នកនៅកណ្តាលទីក្រុង ត្រូវរត់ចេញទៅ
ឱ្យផុត ក៏កុំឱ្យពួកអ្នកដែលនៅស្រុកស្រែ ចូលទៅក្នុង
ទីក្រុងឡើយ[ង] ២២ដ្បិតគ្រានោះជាគ្រាសងសឹក[ច] ដើម្បីនឹង

**២១:៦** យ លក ១៩:៤៤
**២១:៨** រ លក ១៧:២៣
**២១:១០** ល ២រប ១៥:៦ អស ១៩:២
**២១:១១** វ អស ២៩:៦ យអ ២:៣០
**២១:១៣** ស ភល ១:១២
**២១:១៤** ហ លក ១២:១១
**២១:១៥** ឡ លក ១២:១២
**២១:១៦** អ លក ១២:៥២,៥៣
**២១:១៧** ក យហ ១៥:២១
**២១:១៨** ខ មថ ១០:៣០
**២១:១៩** គ មថ ១០:២២
**២១:២០** ឃ លក ១៩:៤៣
**២១:២១** ង លក ១៧:៣១

សំអិតសំអាង គឺទើបតែមានការដឹងឮក្នុងពេលថ្មីៗនេះប៉ុណ្ណោះ តាមរយៈការស្រាវជ្រាវបុរាណវត្ថុវិទ្យានៅទីទួលរបស់ព្រះវិហារនេះ ។

**២១:៦** *នឹងគ្មានថ្មនៅត្រួតលើថ្មទៀត . . . ចុះនោះទេ* គឺបានសម្រេចនៅឆ្នាំ ៧០គ.ស នៅពេលដែលចក្រភពរ៉ូម៉ាំងចូលកាន់កាប់ទីក្រុងយេរ៉ូសាឡិម ព្រមទាំងដុតបំផ្លាញព្រះវិហារនោះផង(មថ ២៤:២ និងការពន្យល់)។

**២១:៧** *តើកាលណា . . .* នៅក្នុងព្រះគម្ពីរម៉ាកុសមានសិស្សបួននាក់ដែលបានទូលសួរទ្រង់នូវសំណួរនេះគឺ ពេត្រុស យ៉ាកុប យ៉ូហាន និងអនទ្រេ (មក ១៣:៣)។ នៅក្នុងព្រះគម្ពីរម៉ាថាយ សំណួរនេះរួមមានការទូលសួរពីទីសំគាល់នៃការយាងមករបស់ព្រះយេស៊ូវ និងចុងបំផុតកល្ប(ទីអវសាននៃលោកិយ) (មថ ២៤:៣ និងការពន្យល់)។

**២១:៨** *គឺខ្ញុំនេះហើយ* គឺខ្ញុំនេះហើយជាព្រះមែស៊ី(ដែលត្រូវយាងមកជាលើកទីពីរ)។ *វេលា* គឺពេលចុងក្រោយ ។

**២១:៩** *ពុំទាន់ដល់ចុងបំផុតជាឆាប់ម្ល៉េះទេ* គឺសំដៅទៅលើសម័យចុងក្រោយបំផុតនៃមនុស្សជាតិ(មថ ២៤:៣,៦)។ ហេតុការណ៍ទាំងអស់ដែលមាននិយាយចាប់ពី ខ.៨–១៨ ជាចរិតលក្ខណៈនៃសម័យបច្ចុប្បន្នទាំងមូល គឺមិនគ្រាន់តែជាទីសំគាល់នៃទីអវសានប៉ុណ្ណោះទេ ។

**២១:១១** *ទីសំគាល់យ៉ាងធំពីលើមេឃ* មើលខ.២៥ ។ ចំពោះសេចក្តីអធិប្បាយពីបទទំនាយពីទីសំគាល់ពីលើមេឃ ដែលនឹងកើតមាននៅថ្ងៃនៃព្រះអម្ចាស់ សូមមើលការពន្យល់ មក ១៣:២៤–២៥ ។

**២១:១២** *បញ្ជូនទៅសាលាប្រជុំ* គេមិនគ្រាន់តែយកសាលាប្រជុំធ្វើជាកន្លែងថ្វាយបង្គំ និងសាលារៀនប៉ុណ្ណោះទេ ប៉ុន្តែគេថែមទាំងប្រើវានៅក្នុងផ្នែកគ្រប់គ្រងសហគមន៍ និងសម្រាប់ឃុំឃាំងជនជាប់ចោទ ក្នុងអំឡុងពេលរង់ចាំការកាត់ទោសទៀតផង(មើលការពន្យល់ មក ១៣:៩ មថ ២៣:៣៤)។

**២១:១៥** *ពុំអាចនឹងឆ្លើយឆ្លង ឬទទឹងទាស់បានឡើយ* មើល កច ៦:៩–១០ ។

**២១:១៨** ទោះជាការបៀតបៀន និងសេចក្តីស្លាប់អាចមកដល់ក៏ដោយ ក៏ព្រះទ្រង់នៅគ្រប់គ្រងការទាំងនោះ ហើយលទ្ធផលចុងក្រោយបំផុតគឺជាជ័យជម្នះអស់កល្បជានិច្ច ។ *សូម្បីតែសក់១សរសៃលើក្បាលអ្នករាល់គ្នា ក៏មិនត្រូវវិនាសបាត់ផង* តាមការបង្ហាញនៅក្នុងខ.១៦ ការនេះមិនអាចសំដៅទៅលើសេចក្តីសុខខាងឯរូបកាយបានឡើយ ។ ន័យធៀបរបស់ខនេះគឺចង់បង្ហាញថានឹងគ្មានការបាត់បង់ពិតប្រាកដ ដែលជាការបាត់បង់ខាងឯវិញ្ញាណ និងអស់កល្បជានិច្ចឡើយ ។

**២១:១៩** មើលការពន្យល់ មក ១៣:១៣ ។

**២១:២០** *ពលទ័ពឡោមព័ទ្ធ* មើល ១៩:៤៣ និងការពន្យល់ ។ ទីសំគាល់នៃទីបញ្ចប់ដែលជិតមកដល់(ខ.៧ និងមើលការពន្យល់) គឺការឡោមព័ទ្ធទីក្រុងយេរូសាឡិមដោយពលទ័ព ដែលមានការទាក់ទងនឹង"សេចក្តីស្អប់ខ្ពើមដែលបង្ខូចបំផ្លាញ" (មថ ២៤:១៥ និងការពន្យល់)។

**២១:២១** *រត់ទៅឯភ្នំ* នៅពេលដែលទីក្រុងមួយត្រូវពលទ័ពឡោមព័ទ្ធ ជាធម្មតាគេ នាំគ្នាស្វែងរកការការពារខ្លួននៅក្នុងកំផែង ប៉ុន្តែព្រះយេស៊ូវទ្រង់បានបង្រៀន ឱ្យអ្នកដើរតាមទ្រង់ស្វែងរកការជ្រកកោននៅឯភ្នំវិញ ពីព្រោះទីក្រុងនោះនឹងត្រូវទទួលកាត់ទោសឱ្យវិនាស(មើលពន្យល់ មថ ២៤:១៦)។

**២១:២២** *គ្រាសងសឹក* គឺសេចក្តីយុត្តិធម៌ដែលបង្ហាញចេញតាមរយៈការកាត់ទោសរបស់ព្រះចំពោះការគ្មានជំនឿ(អស ៦៣:៤ យរ ៥:២៩ ហស ៩:៧)។

សំរេចតាមគ្រប់ទាំងសេចក្តីដែលបានចែងទុកមក[ឆ] ២៣ឯពួក
ស្រីៗដែលមានផ្ទៃពោះ ហើយពួកដែលបំបៅកូន នៅគ្រា
នោះ នឹងវេទនាណាស់ ដ្បិតនឹងមានសេចក្តីវេទនាជាខ្លាំង
នៅក្នុងស្រុក ហើយនឹងសេចក្តីក្រោធដល់បណ្តាជននេះ ២៤គេ
នឹងដួលនៅក្រោមមុខដាវ ហើយនឹងត្រូវដឹកនាំទៅជាឈ្លើយ
ដល់អស់ទាំងនគរ ក្រុងយេរូសាឡិមនឹងត្រូវសាសន៍ដទៃជាន់
ឈ្លី[ជ] ដរាបដល់គ្រារបស់សាសន៍ដទៃបានសំរេច ២៥កាល
ណោះ នឹងមានទីសំគាល់នៅក្នុងព្រះអាទិត្យក្នុង ព្រះចន្ទ
នឹងក្នុងអស់ទាំងផ្កាយ ហើយនៅលើផែនដី នឹងមាន
សេចក្តីលំបាកនៅគ្រប់ទាំងសាសន៍ នឹងសេចក្តីទ័លគំនិត
ដោយព្រោះសូរសន្ធឹករបស់សមុទ្រ នឹងរលក[ឈ] ២៦មនុស្ស
នឹងស្រយុតចិត្តដោយភ័យ ហើយដោយទន្ទឹងចាំ ការដែល
ត្រូវមកលើផែនដី ដ្បិតអស់ទាំងអំណាចនៅលើ មេឃនឹង
ត្រូវកក្រើករំពើក[ញ] ២៧នោះគេនឹងឃើញកូនមនុស្ស[ដ] មក
លើពពក[ឋ]មានទាំងព្រះចេស្តា នឹងសិរីល្អជាខ្លាំង ២៨កាល
ណាការទាំងនេះចាប់តាំងកើតមក នោះឱ្យអ្នករាល់គ្នាងើប
មើលទៅលើ ពីព្រោះសេចក្តីប្រោសលោះរបស់អ្នករាល់គ្នា
ជិតដល់ហើយ[ឌ]។
២៩រួចទ្រង់មានបន្ទូលជាពាក្យប្រៀបប្រដូចទៅគេថា ចូរ
មើលដើមល្វា នឹងអស់ទាំងដើមឈើចុះ ៣០កាលណាវា
លាស់ឡើង នោះអ្នករាល់គ្នាយល់ឃើញដោយខ្លួនឯងថា
រដូវក្តៅជិតដល់ហើយ ៣១កាលណាអ្នករាល់គ្នា ឃើញការ
ទាំងនេះកើតមក នោះត្រូវដឹងថា នគរព្រះ[ឍ]ជិតដល់ហើយ
យ៉ាងដូច្នោះដែរ ៣២ខ្ញុំក៏ប្រាប់អ្នករាល់គ្នាជាប្រាកដថា មនុស្ស
ដំណនេះ[ណ]នឹង មិនទាន់កន្លងហួសបាត់ទៅឡើយ ទាល់តែ
គ្រប់ការទាំងនេះបានកើតមក ៣៣ឯផ្ទៃមេឃ និងផែនដី
នោះនឹងកន្លងបាត់ទៅ តែឯពាក្យខ្ញុំ មិនដែលកន្លងបាត់
ឡើយ[ត] ៣៤ចូរអ្នករាល់គ្នាប្រយ័ត្នខ្លួន ក្រែងចិត្តអ្នករាល់គ្នា
កំពុងតែផ្ទុកនូវសេចក្តីវក់នឹងស៊ីផឹក ហើយនិងសេចក្តីខ្វល់
ខ្វាយនៅជីវិត[ថ] នោះលោតែថ្ងៃនោះ[ទ]មកដល់អ្នករាល់គ្នា
ភ្លាម ៣៥ដ្បិតថ្ងៃនោះនឹងមកដូចជាលប់ គ្របលើអស់ទាំង
មនុស្សដែលនៅគ្រប់លើផែនដី ៣៦ដូច្នេះ ចូរចាំយាមចុះ
ហើយអធិស្ឋានជានិច្ច[ធ] ដើម្បីឱ្យបានរាប់ជាគួរនឹងរួចពី
ការទាំង នេះដែលត្រូវមក ហើយឱ្យបានឈរនៅមុខកូន
មនុស្សផង ។
៣៧នៅពេលថ្ងៃ ទ្រង់តែងបង្រៀនក្នុងព្រះវិហារ[ន] លុះដល់
ពេលយប់ ទ្រង់តែងតែយាងចេញ[ប]ទៅស្នាក់នៅលើភ្នំដែល
ហៅថា ភ្នំដើមអូលីវ[ផ] ៣៨ព្រលឹមៗឡើង បណ្តាជនក៏មក
ស្តាប់ទ្រង់នៅក្នុងព្រះវិហារជានិច្ច[ព]។

**២១:២២** ច អស ៦៣:៤ ដយ ៩:២៤–២៧ ហស ៩:៧ ឆ មថ ១:២២
**២១:២៤** ជ អស ៥:៥, ៦៣:១៨ ដយ ៨:១៣ វវ ១១:២
**២១:២៥** ឈ ២ពត ៣:១០,១២
**២១:២៦** ញ មថ ២៤:២៩
**២១:២៧** ដ មថ ៨:២០ ឋ វវ ១:៧
**២១:២៨** ឌ លក ១៨:៧
**២១:៣១** ឍ មថ ៣:២
**២១:៣២** ណ លក ១១:៥០ ១៧:២៥
**២១:៣៣** ត មថ ៥:១៨
**២១:៣៤** ថ មក ៤:១៩ ទ លក ១២:៤០,៤៦ ១ថន ៥:២–៣
**២១:៣៦** ធ មថ ២៦:៤១
**២១:៣៧** ន មថ ២៦:៥៥ ប មក ១១:១៩ ផ មថ ២១:១
**២១:៣៨** ព យហ ៨:២

## យូដាសក្បត់ព្រះយេស៊ូវ

*២២:១,២ = មថ ២៦:២–៥ មក ១៤:១,២,១០,១១*

**២២** ១រីឯបុណ្យនំបុ័ងឥតដំបែ ដែលហៅថាបុណ្យរំលង

**២១:២៤** *គ្រារបស់សាសន៍ដទៃ* សាសន៍ដទៃនឹងមានទាំងឱកាសខាងឯវិញ្ញាណ (មថ ២៤:១៤ មក ១៣:១០ លក ២០:១៦ រម ១១:២៥ និងការពន្យល់) និងឱកាសកាន់កាប់ទីក្រុងយេរូសាឡិម ប៉ុន្តែគ្រានោះនឹងត្រូវបញ្ចប់នៅពេលដែលបំណងព្រហប្ញទ័យរបស់ព្រះសម្រាប់សាសន៍ដទៃបានសម្រេចហើយ ។

**២១:២៧** មើល មថ ២៤:៣០ និងការពន្យល់ ។

**២១:២៨** *ងើបមើលទៅលើ* គឺមិនត្រូវបាក់ទឹកចិត្តក្នុងពេលដែលទីសំគាល់ទាំងនោះលេចចេញមកឡើយ ប៉ុន្តែ ចូរឱ្យសម្លឹងមើលទៅលើដោយអំណរសង្ឃឹម និងជំនឿ (ទដ ២៤:៧) ។*សេចក្តីប្រោសលោះ* គឺសេចក្តីប្រោសលោះនៅទីអវសាន ដែលត្រូវចប់ជាស្ថាពរ (ហព ៩:២៨ និងការពន្យល់) ។

**២១:២៩** *ចូរមើលដើមល្វា* ការកើនឡើងនៃពណ៌បៃតងនៅលើដើមឈើគឺជាការប្រកាសប្រាប់ពីការឈានមកដល់នៃរដូវផ្ការីក (សូមផ្ទៀបជាមួយ មថ ៤:៣២–៣៥ មក ១១:១៣ និងការពន្យល់ ១៣:២៨–៣១) ។ គឺដូចគ្នានៅពេលដែលកើតមានទីសំគាល់ មនុស្សជាទូទៅអាចស្មានដឹងជាមុនពីការមកដល់នៃនគរព្រះ ។ ប៉ុន្តែ "ពាក្យនគរព្រះ" មានការប្រើខុសៗគ្នាជាច្រើន (មើលពន្យល់ ៤:៤៣) ។ សេចក្តីយោងក្នុងខ.៣១ គឺសំដៅទៅលើអនាគតនគរព្រះ ។

**២១:៣២** *មនុស្សដំណនេះ* បើព្រះយេស៊ូវទ្រង់មានបន្ទូលពីខនេះ សំដៅទៅលើការបំផ្លិចបំផ្លាញទីក្រុងយេរូសាឡិម ដែលនឹងកើតឡើងប្រហែល៤០ឆ្នាំទៀតនោះ ពាក្យ"ដំណ"នេះ ត្រូវប្រើតាមន័យតាមធម្មតារបស់វាដែលមានន័យថា មួយជំនាន់របស់មនុស្ស(ចាប់ពីកើតដល់ស្លាប់)។ គ្រប់ការទាំងនេះនឹងបានសម្រេចនៅពេល ដែលទីក្រុងយេរូសាឡិមត្រូវបំផ្លាញនៅឆ្នាំ ៧០ គ.ស ។ ម្យ៉ាងវិញទៀតបើខនេះសំដៅទៅលើការយាងមកវិញនៃព្រះគ្រីស្ទ នោះពាក្យ"ដំណ"នេះអាចសំដៅទៅលើតំណ ឬជំនាន់មនុស្សដែលនៅមានជីវិតនៅពេលដែល "ការទាំងនេះ" ចាប់ផ្តើមកើតមាន ។

**២១:៣៤** *ថ្ងៃនោះ* គឺថ្ងៃដែលព្រះគ្រីស្ទទ្រង់យាងត្រឡប់មកវិញ ហើយទិដ្ឋភាពនៃអនាគតនគរព្រះត្រូវចាប់ផ្តើមមានឡើង (ផ្ទៀបនឹង ខ.៣១) ។ *មកដល់អ្នករាល់គ្នាភ្លាម* គឺពុំមានន័យថាការយាងត្រឡប់មកវិញជាលើកទីពីររបស់ព្រះគ្រីស្ទ នឹងត្រូវប្រកាសឱ្យដឹងទាំងស្រុងនោះទេ ពីព្រោះនឹងកើតមានទីសំគាល់ជាមុនសិន (ខ.២៨,៣១ ១ថន ៥:១–៣) ។

**២១:៣៥** *នៅគ្រប់លើផែនដី* ការយាងមកវិញនៃព្រះគ្រីស្ទនឹងមានជាប់ទាក់ទងនឹងមនុស្សជាតិទាំងអស់ ចំណែកឯការដួលរលំនៃទីក្រុងយេរូសាឡិមគឺមិនដូច្នោះទេ ។

**២១:៣៧** *នៅពេលថ្ងៃ* គឺនៅថ្ងៃនីមួយៗក្នុងសប្តាហ៍ចុងក្រោយរបស់ទ្រង់ គឺគិតចាប់ពីថ្ងៃក្បួនដង្ហែរនៃជ័យជម្នះរបស់ទ្រង់ រហូតដល់ពេលបុណ្យរំលង (ពីថ្ងៃអាទិត្យដល់ថ្ងៃព្រហស្បតិ៍)។ *ភ្នំដើមអូលីវ* មើលការពន្យល់ ១៩:២៩ មថ ២១:១៧ ។

**២២:១** *បុណ្យនំបុ័ងឥតដំបែ...រំលង* មានការប្រើប្រាស់ពាក្យ"បុណ្យរំលង" តាមពីររបៀបផ្សេងៗពីគ្នាគឺ (១).គឺជាឱកាសបរិភោគអាហារជុំគ្នាដែល

នោះក៏ជិតមកដល់[ក] ២ហើយពួកសង្គ្រាជ នឹងពួកអាចារ្យ គេ
រកវិធីយ៉ាងណានឹងសំឡាប់ទ្រង់ចេញ[ម] ព្រោះគេខ្លាចបណ្តា
ជន ៣នោះអារក្សសាំតាំង[យ]វាចូលយូដាសដែលហៅថាអ៊ីស្ការី
រីយ៉ុត[រ] ជាម្នាក់ក្នុងពួក១២ ៤រួចវាទៅនិយាយនឹងពួកសង្គ្រាជ
ហើយពួកមេទ័ពរក្សាព្រះវិហារ[ល] ពីបែបដែលនឹងបញ្ជូន
ទ្រង់ឱ្យដល់គេ ៥គេក៏ត្រេកអរណាស់ ហើយសន្យានឹង
ឱ្យប្រាក់ដល់វា[វ] ៦វាយល់ព្រម រួចក៏ទៅរកឱកាសនឹងបញ្ជូន
ទ្រង់ដល់គេ ក្នុងកាលដែលឃ្លាតពីបណ្តាមនុស្ស ។

## ពិធីលៀងព្រះអម្ចាស់

*២២:៧–១៣ = មថ ២៦:១៧–១៩ មក ១៤:១២–១៦*

*២២:១៧–២០= មថ ២៦:២៦–២៩ មក ១៤:២២–២៥ ១កថ ១១:២៣–២៥*

*២២:២១–២៣ មថ ២៦:២១–២៤ មក ១៤:១៨–២១ យហ ១៣:២១–៣០*

*២២:២៥–២៧ មថ ២០:២៥–២៨ មក ១០:៤២–៤៥*

*២២:៣៣,៣៤ = មថ ២៦:៣៣–៣៥ មក ១៤:២៩–៣១ យហ ១៣:៣៧,៣៨*

៧ឯថ្ងៃបុណ្យនំបុ័ងឥតដំបែក៏មកដល់ គឺជាថ្ងៃដែលគេត្រូវ
សំឡាប់កូនចៀមធ្វើបុណ្យរំលង[ស] ៨នោះទ្រង់ចាត់ពេត្រុស
នឹងយ៉ូហាន[ហ]ឱ្យទៅ ដោយបន្ទូលថា ចូរទៅរៀបចំបុណ្យរំ
លងសំរាប់យើងរាល់គ្នាបរិភោគ ៩តែគេទូលសួរថាតើ
ទ្រង់តើទ្រង់សព្វព្រះហឫទ័យឱ្យយើងខ្ញុំ រៀបចំនៅកន្លែងណា
១០ទ្រង់ក៏ប្រាប់ថា មើល កាលណាចូលទៅក្នុងទីក្រុង នោះ
នឹងឃើញមនុស្សម្នាក់កំពុងតែលីក្អមទឹក ចូរតាមអ្នក នោះ
ទៅក្នុងផ្ទះណាដែលគាត់ចូល ១១ហើយនិយាយនឹង
ម្ចាស់ផ្ទះនោះថា លោកគ្រូមានប្រសាសន៍សួរមកអ្នកថា តើ
បន្ទប់ដែលខ្ញុំនឹងទទួលទានបុណ្យរំលង ជាមួយនឹងពួកសិស្ស
ខ្ញុំនៅឯណា ១២នោះគាត់នឹងបង្ហាញបន្ទប់១ធំនៅខាងលើ
ដែលមានគ្រប់ប្រដាប់ប្រដា ចូររៀបចំនៅទីនោះចុះ។
១៣គេក៏ទៅឃើញ ដូចជាទ្រង់បានមានបន្ទូល[ឡ] ហើយគេ
រៀបចំបុណ្យរំលង ។
១៤លុះដល់ពេលហើយ ទ្រង់[អ]ក៏គង់នៅតុ[ក]ជាមួយនឹងពួក
សាវក ១៥ទ្រង់មានបន្ទូលថា មុនដែលខ្ញុំរងទុក្ខលំបាក ខ្ញុំ
បានចង់ទទួលទានបុណ្យរំលងនេះជាមួយនឹងអ្នករាល់គ្នា
យ៉ាងអស់ពីចិត្ត[ខ] ១៦ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាថា ខ្ញុំមិនបាន
ទទួលទានបុណ្យនេះទៀតទេ ទាល់តែបុណ្យនេះបានសំរេច

**២២:១** ភ យហ ១១:៥៥
**២២:២** ម មថ ១២:១៤
**២២:៣** យ មថ ៤:១០ រ មថ ១០:៤
**២២:៤** ល ខ.៥២ កច ៤:១ ៥:២៤
**២២:៥** វ សក ១១:១២
**២២:៧** ស នក ១២:១៨–២០ ចទ ១៦:៥–៨ មក ១៤:១២
**២២:៨** ហ កច ៣:១,១១ ៤:១៣,១៩ ៨:១៤
**២២:១៣** ឡ លក ១៩:៣២
**២២:១៤** អ មក ៦:៣០ ក មថ ២៦:២០ មក ១៤:១៧,១៨
**២២:១៥** ខ មថ ១៦:២១ **២២:១៦** គ លក ១៤:១៥

ចាប់ផ្តើមពីពេលថ្ងៃលិចនៅថ្ងៃទី១៤ នៃខែនីសាន់ (Nisan ) (គឺខែដំបូងរបស់សាសន៍យូដាដែលប្រហាក់ប្រហែលនឹងខែផល្គុនរបស់ខ្មែរយើងដែរ) (លវ ២៣:៤–៥) (២). គឺជាសប្តាហ៍បន្ទាប់ពីឱកាសបរិភោគអាហារបុណ្យរំលង (អគ ៤៥:២១)។ គេអាចហៅបានម្យ៉ាងទៀតថា "បុណ្យនំបុ័ងឥតដំបែ"ដែលក្នុងរយៈពេលបុណ្យនេះមួយសប្តាហ៍ ការប្រើដំបែត្រូវហាមឃាត់ (នក ១២:១៥ ១៣:៣–៧ និងការពន្យល់ មក ១៤:១ យហ ២:១៣)។ នៅគ្រាសញ្ញាថ្មីឈ្មោះទាំងពីរយ៉ាង របស់ពិធីបុណ្យដែលធ្វើពេញមួយសប្តាហ៍នេះស្ទើរតែអាចហៅជំនួសគ្នាទៅវិញទៅមកបានទៅហើយ ។

**២២:២** *ពួកសង្គ្រាជ និងពួកអាចារ្យ* មើល ២០:១ និងការពន្យល់ ។

**២២:៣** *អារក្សសាតាំងវាចូលយូដាស* នៅក្នុងដំណឹងល្អទាំងបួន គេប្រើឃ្លានេះនៅក្នុងឱកាសពីរផ្សេងគ្នា (១).មុនពេលយូដាសទៅឯពួកសង្គ្រាជហើយសន្យាបញ្ជូនព្រះយេស៊ូវ (ក្នុងខនេះ) (២).ក្នុងអំឡុងពេលពិធីលៀងព្រះអម្ចាស់ (យហ ១៣:២៧ និងការពន្យល់)។ ដូចនេះហើយបានជាអ្នកនិពន្ធព្រះគម្ពីរដំណឹងល្អ បង្ហាញពីការគ្រប់គ្រងរបស់អារក្សលើយូដាស ជាអ្នកមិនដែលមានការកាន់ខ្ជាប់ជាមួយនឹងព្រះយេស៊ូវ (យហ ១៣:២ និងការពន្យល់ យហ ១៧:១២ ១កថ ១៥:២)។ *ដែលហៅថា អ៊ីស្ការីយ៉ុត* មើល យហ ៦:៧១ និងការពន្យល់ ។

**២២:៤** *ពួកមេទ័ពរក្សាព្រះវិហារ* ជាសាសន៍យូដាដែលភាគច្រើនគេជ្រើសរើសពីពួកលេវី ។

**២២:៧** *សំឡាប់កូនចៀមធ្វើបុណ្យរំលង* គឺត្រូវធ្វើនៅថ្ងៃទី១៤ នៃខែនីសាន់ (មើលការពន្យល់ ២២:១) នៅចន្លោះម៉ោង ២:៣០ ដល់ ៥:៣០ នៅក្នុងកន្លែងពួកសង្ឃ គឺនៅថ្ងៃព្រហស្បតិ៍នៃសប្តាហ៍រងទុក្ខរបស់ទ្រង់ ។

**២២:១០** *មនុស្សម្នាក់កំពុងតែលីក្អមទឹក* ព្រះគម្ពីរអង់គ្លេសមានបញ្ជាក់ថាអ្នកលីក្អមទឹកនោះគឺជាមនុស្សប្រុសម្នាក់ ។ ការដែលបុរសម្នាក់នោះលីក្អមទឹក គឺជារឿងប្លែកណាស់ ពីព្រោះជាធម្មតាកិច្ចការនោះមានស្ត្រីជាអ្នកធ្វើ ។

**២២:១១** *លោកគ្រូមានប្រសាសន៍សួរ* ការដែលត្រូវនិយាយដូចនេះ អាចមកពីបុរសម្ចាស់ផ្ទះនោះជាអ្នកដើរតាមព្រះយេស៊ូវ ហើយទ្រង់ក៏ស្គាល់គាត់ផងដែរ ។

**២២:១៣** *ដូចជាទ្រង់បានមានបន្ទូល* ប្រហែលព្រះយេស៊ូវទ្រង់បានបង្គាប់ឱ្យបុរសម្នាក់នោះរៀបចំឱ្យទ្រង់ទុកជាមុន ដើម្បីធានាថានឹងគ្មានការរំខានដល់អាហារបុណ្យរំលងឡើយ ។ ដោយសារព្រះយេស៊ូវទ្រង់មិនបានមានបន្ទូលចំៗតែម្តងពីកន្លែងដែលនឹងត្រូវរៀបចំបុណ្យរំលង យូដាសមិនអាចឱ្យដំណឹងដល់ពួកសត្រូវទាំងនោះបាន ហើយពួកទាំងនោះក៏មិនអាចទៅរំខានឱកាសដ៏សំខាន់មួយនេះបានដែរ ។

**២២:១៤–៣០** តាមវគ្គនេះ ការបកស្រាយរបស់លោកលូកាពីពិធីលៀងព្រះអម្ចាស់ ហាក់ដូចជាមិនតឹងរឹងខ្លាំង នៅក្នុងការរៀបរាប់តាមបែបប្រវត្តិសាស្ត្រឡើយ ។ គឺជាបឋមលោកនិយាយពីការប្រទាននំបុ័ង និងទឹកទំពាំងបាយជូរដែលផ្នែកសំខាន់បំផុតនៃឱកាសនោះ ។ រួចហើយលោកក៏បាននិយាយពីបន្ទូលរបស់ព្រះយេស៊ូវអំពីអ្នកដែលក្បត់ទ្រង់ ហើយនិយាយពីសេចក្តីទាស់ទែងគ្នា ពីរឿងអ្នកណាដែលរាប់ជាធំជាងគេ ទោះបីជាចំណុចទាំងពីរនេះគួរតែនិយាយពីដំបូងក៏ដោយ។ដំណឹងល្អយ៉ូហាន (១៣:២៦–៣០) បានបង្ហាញថា យូដាសបានចេញទៅបាត់ មុនពេលដែលព្រះអម្ចាស់ទ្រង់ប្រទាននំបុ័ង និងទឹកទំពាំងបាយជូរ ប៉ុន្តែ ព្រះគម្ពីរលូកាមិនបានបញ្ជាក់ពីពេលណាដែលយូដាសចាកចេញទៅឡើយ ។

**២២:១៤** *គង់នៅតុជាមួយ* មើលការពន្យល់ មក ១៤:១៨ ។

**២២:១៦** *ទាល់តែបុណ្យនេះបានសំរេច* ព្រះយេស៊ូវទ្រង់ចង់ធ្វើបុណ្យរំលង

នៅក្នុងនគរព្រះវិញ[គ] ១៧ កាលទ្រង់បានទទួលពែង នោះក៏
អរព្រះគុណ រួចមានបន្ទូលថា ចូរយកពែងនេះចែកគ្នាផឹក
១៨ ដ្បិតខ្ញុំ ប្រាប់អ្នក រាល់គ្នាថា ខ្ញុំមិនផឹកពីផលផ្លែទំពាំង
បាយជូរទៀតទេ ដរាប ដល់នគរព្រះបានមកដល់ ១៩ រួច
ទ្រង់ក៏យកនំបុ័ងមកអរព្រះគុណ ហើយកាច់[ឃ]ប្រទានទៅ
គេដោយបន្ទូលថា នេះហើយជារូបកាយខ្ញុំដែលបានប្រទាន
មកសំរាប់អ្នករាល់គ្នា ចូរធ្វើបុណ្យនេះ ដើម្បីរំឭកពីខ្ញុំចុះ
២០ ក្រោយដែលបានបរិភោគហើយ នោះទ្រង់យកពែងមក
ធ្វើបែបដូច្នោះដែរ ដោយបន្ទូលថា ពែងនេះជាសញ្ញាថ្មី[ង]
ដែលតាំងដោយនូវឈាមខ្ញុំ គឺជាឈាមដែលត្រូវច្រួចចេញ
សំរាប់អ្នករាល់គ្នា ២១ មួយទៀត មើលដៃនៃអ្នកដែលបញ្ជូន
ខ្ញុំក៏នៅតុជាមួយនឹងខ្ញុំដែរ[ច] ២២ កូនមនុស្ស[ឆ]ត្រូវទៅមែនតាម
សេចក្តីដែលសំរេចមក[ជ] ប៉ុន្តែ វេទនាដល់មនុស្សនោះ ដែល
បញ្ជូនខ្ញុំទៅ ២៣ នោះគេចាប់តាំងសួរគ្នាទៅវិញទៅមក ពី
អ្នកណាក្នុងពួកគេ ដែលនឹងធ្វើការនោះ ។
២៤ គេក៏កើតមានសេចក្តីទាស់ទែងគ្នា អំពីអ្នកណាដែល

**២២:១៩** ឃ មថ ១៤:១៩
**២២:២០** ង នក ២៤:៨ អស ៤២:៦ យរ ៣១:៣១–៣៤ សក ៩:១១ ២កថ ៣:៦ ហេ ៨:៦ ៩:១៥
**២២:២១** ច ទដ ៤១:៩
**២២:២២** ឆ មថ ៨:២០ ជ កច ២:២៣ ៤:២៨
**២២:២៤** ឈ មក ៩:៣៤ លក ៩:៤៦
**២២:២៦** ញ ១ពត ៥:៥ ដ មក ៩:៣៥
**២២:២៧** ឋ មថ ២០:២៨
**២២:២៩** ឌ មថ ២៥:៣៤ ២ធថ ២:១២

រាប់ជាធំជាងគេ[ឈ] ២៥ តែទ្រង់មានបន្ទូលថា អស់ទាំងស្តេច
នៃសាសន៍ដទៃ គេតែងសោយរាជ្យលើបណ្តារាស្រ្ត ហើយ
បណ្តាជនហៅពួកអ្នកមានអំណាចលើគេ ថាជាអ្នកមាន
គុណដែរ ២៦ ប៉ុន្តែ មិនត្រូវឱ្យមានដូច្នោះក្នុងពួកអ្នករាល់
គ្នាឡើយ ឯអ្នកណាដែលធំជាងគេ ក្នុងពួកអ្នករាល់គ្នានោះ
ត្រូវប្រព្រឹត្តដូចជាតូចជាងគេវិញ[ញ] ហើយអ្នកណាដែលនាំ
មុខគេ នោះដូចជាអ្នកបំរើដែរ[ដ] ២៧ ដ្បិតតើអ្នកណា ធំជាង
អ្នកដែលអង្គុយនៅតុ ឬអ្នកដែលបំរើ តើមិនមែនជា
អ្នកដែលអង្គុយនៅតុទេឬអី ប៉ុន្តែ ខ្ញុំនៅកណ្តាលពួកអ្នករាល់
គ្នា ទុកដូចជាអ្នកបំរើវិញ[ឋ] ២៨ ឯអ្នករាល់គ្នា គឺជាពួក
ដែលបានកាន់ខ្ជាប់ជាមួយនឹងខ្ញុំ ក្នុងអស់ទាំងសេចក្តីល្បួង
លខ្ញុំ ២៩ ខ្ញុំក៏ដំរូវនគរ១ឱ្យអ្នករាល់គ្នា ដូចជាព្រះវរបិតានៃខ្ញុំ
បានដំរូវនគរ[ឌ]ឱ្យខ្ញុំដែរ ៣០ ដើម្បីឱ្យអ្នករាល់គ្នាបានបរិភោគ
នៅតុខ្ញុំ ក្នុងនគររបស់ខ្ញុំ[ឍ] ហើយឱ្យបានអង្គុយ លើបល្ល័ង្កជំ
នុំជំរះពូជអំបូរអ៊ីស្រាអែលទាំង១២ផង[ណ]។
៣១ ព្រះអម្ចាស់ក៏មានបន្ទូលថា ស៊ីម៉ូនៗអើយ មើលសាតាំង

**២២:៣០** ឍ លក ១៤:១៥ ណ មថ ១៩:២៨ **២២:៣១** ត យប ១:៦–១២

ជាមួយនឹងពួកសិស្សទ្រង់ខ្លាំងណាស់ ពីព្រោះនោះជាឱកាសចុងក្រោយ មុនពេលទ្រង់ត្រូវគេធ្វើគុតដូចជា "កូនចៀមបុណ្យរំលង" ដ៏គ្រប់លក្ខណ៍(១កថ ៥:៧ និងមើលការពន្យល់) ហើយការថ្វាយយញ្ញបូជានោះត្រូវសម្រេច។ ព្រះយេស៊ូវនឹងមិនសោយអាហារបុណ្យរំលងទៀតឡើយ ដរាបណាអនាគតនគរព្រះមិនទាន់មកដល់ ។ បន្ទាប់ពីនោះទ្រង់នឹងធ្វើឱ្យការប្រកបបានថ្មីឡើងជាមួយនឹងអស់អ្នកដែលបានរំឭកពិធីលៀងព្រះអម្ចាស់កាលនៅលោកិយ ។ នៅទីបញ្ចប់ការប្រកបគ្នានឹងបានគ្រប់លក្ខណ៍ នៅក្នុងពិធីរៀបវិវាហមង្គលដ៏អស្ចារ្យនៃព្រះមែស៊ី ដែលនឹងត្រូវមកដល់ (វវ ១៩:៩)។

**២២:១៧** *កាលទ្រង់បានទទួលពែង* គឺជាពែងទីមួយ ឬពែងទី៣នៃពែងទាំងបួន ដែលត្រូវចែកឱ្យប្រើក្នុងឱកាសបរិភោគអាហារបុណ្យរំលង ។

**២២:១៨** *ដរាបដល់នគរព្រះបានមកដល់* (៤:៤៣ មើលពន្យល់ ខ.១៦)។

**២២:១៩** *ជា* គឺមានន័យថា"ជាតំណាង" ឬ"សញ្ញា" ។ *ដែលបានប្រទានមកសំរាប់អ្នករាល់គ្នា* គឺបន្ទូលប្រាប់ឱ្យដឹងជាមុន ពីការដែលទ្រង់ត្រូវប្រទានព្រះអង្គទ្រង់ជាយញ្ញបូជានៅលើឈើឆ្កាងជំនួសមនុស្សរាល់គ្នា ។ *ដើម្បីរំឭកពីខ្ញុំ* បុណ្យរំលងគឺជាពិធីរំឭកដែលត្រូវបន្តប្រារពធ្វើជានិច្ច និងជាការប្រកាសពីការដែលព្រះទ្រង់ប្រោសលោះរាស្ត្រអ៊ីស្រាអែល ឱ្យរួចពីភាពជាទាសករនៅប្រទេសអេស៊ីព្ទ ដូចនេះការកាន់តាមព្រះរាជបញ្ញាព្រះគ្រីស្ទនឹងបានជាការរំឭក និងការប្រកាសពីការដោះអ្នកជឿគ្រប់រូប ឱ្យរួចពីភាពជាទាសករនៃអំពើបាប តាមរយៈការរងទុក្ខរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាងផងដែរ ។

**២២:២០** *ក្រោយដែលបានបរិភោគហើយ* ឃ្លានេះមានប្រើនៅតែក្នុងខនេះ និង ១កថ ១១:២៥ មើលការពន្យល់ ១កថ ១១:២៣–២៦ ។ *ទ្រង់យកពែងមកធ្វើបែបដូច្នោះ* មើលការពន្យល់ មក ១៤:២៤ ។ *សញ្ញាថ្មី* គឺពាក្យសន្យាដែលព្រះទ្រង់មានបន្ទូល តាមរយៈហោរាយេរេមា (៣១:៣១–៣៤ និងការពន្យល់) គឺអំណាចគ្រប់គ្រងនៃព្រះគុណដែលជួយសង្គ្រោះរបស់ព្រះដែលបានបង្កើតឱ្យមានឡើង និងបានធានាដោយការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ("ក្នុងឈាមរបស់ទ្រង់") មើលការពន្យល់ ១កថ ១១:២៥ ។

**២២:២១** *ដៃនៃអ្នកដែលបញ្ជូនខ្ញុំ ក៏នៅតុជាមួយនឹងខ្ញុំដែរ* តាមខនេះ ព្រះយេស៊ូវទ្រង់ប្រាកដជាមានព្រះបន្ទូលនេះ មុនពេលទ្រង់ចាប់ប្រារព្ធពិធីលៀងព្រះអម្ចាស់ ។ យូដាសបានចាកចេញទៅ ហើយមិនបានត្រឡប់មកវិញរហូតដល់ពេលដែលគាត់បញ្ជូនព្រះយេស៊ូវនៅក្នុងសួនច្បារនោះ ។

**២២:២២** *តាមសេចក្តីដែលសំរេចមក* មើល មក ១៤:២១ និងពន្យល់ ។

**២២:២៥** *អ្នកមានគុណ* គឺជាងារដែលគេសម្រេចដាក់ឱ្យ ឬបោះឆ្នោតជ្រើសរើសឱ្យដល់អ្នកដឹកនាំនៅប្រទេសអេស៊ីព្ទ ប្រទេសស៊ីរី និងចក្រភពរ៉ូម៉ាំង ដែលតំណាងឱ្យការគោរព ប៉ុន្តែជាញឹកញាប់តំណាងឱ្យការជួយយកអាសាដែលមានពិតជាក់ស្តែង ។

**២២:២៦** *ដូចជាអ្នកបំរើ* គឺជាសេចក្តីដែលព្រះយេស៊ូវទ្រង់បង្រៀន ហើយទ្រង់បានធ្វើជាគំរូអ្នកដឹកនាំដែលបន្ទាបខ្លួនបម្រើ ដែលលក្ខណៈនេះនៅតែពិតជាអស្ចារ្យជានិច្ចនិរន្ត (មក ១០:៤៥ ភល ២:៥,៧ និងការពន្យល់)។

**២២:២៨** *ក្នុងអស់ទាំងសេចក្តីល្បួងលខ្ញុំ* រួមមានសេចក្តីល្បួង(៤:១៣)ការរងទុក្ខ (៩:៥៨) និងការបដិសេធន៍ (យហ ១:១១)។

**២២:២៩** *ដំរូវនគរ១ឱ្យអ្នករាល់គ្នា* តាមខ.៣០ នគរព្រះដែលទ្រង់មានបន្ទូលនេះគឺជាអនាគតនគរព្រះ (មើលការពន្យល់ ៤:៤៣ មថ ៣:២)។

**២២:៣០** *បានអង្គុយលើបល្ល័ង្ក* ដោយពួកគេមានចំណែកនៅក្នុងសេចក្តីល្បួងលរបស់ព្រះគ្រីស្ទ ដូចនេះពួកគេក៏នឹងបានសោយរាជ្យជាមួយនឹងទ្រង់ផងដែរ(២ធថ ២:១២)។ *ជំនុំជំរះ* គឺគ្រប់គ្រង ឬដឹកនាំ(មើលការពន្យល់ ពច ២:១៦)។ *ពូជ អំបូរអ៊ីស្រាអែល* មើល មថ ១៩:២៨ ។

**២២:៣១** *វែងអ្នករាល់គ្នា* សាតាំងចង់ល្បួងលពួកសាវ័ក ដោយសង្ឃឹមថា

បានសូមចង់[ត]បានអ្នករាល់គ្នា ប្រយោជន៍នឹងរែងអ្នករាល់
គ្នាដូចជារែងអង្ករ[ថ] ៣២ប៉ុន្តែ ខ្ញុំបានអធិស្ឋានឱ្យអ្នក[ទ]
ដើម្បីមិនឱ្យសេចក្តីជំនឿរបស់អ្នកវិនាសបាត់ឡើយ កាល
ណាអ្នកបានប្រែចិត្តវិលមកវិញ នោះចូរចំរើនឱ្យបងប្អូន
អ្នកបានខ្ជាប់ខ្ជួនឡើង[ធ] ៣៣តែគាត់ទូលទ្រង់ថា ព្រះអម្ចាស់
អើយ ទូលបង្គំប្រុងប្រៀបជាស្រេច នឹងទៅជាមួយនឹង
ទ្រង់ដែរ ទោះបើជាប់គុក ឬដល់ស្លាប់ក្តី[ន] ៣៤នោះទ្រង់
មានបន្ទូលថា ពេត្រុសអើយ ខ្ញុំប្រាប់អ្នកថា នៅថ្ងៃ
នេះមាន់មិនរងាវឡើយ ទាល់តែអ្នកបានប្រកែក ៣ដងថា
មិនស្គាល់ខ្ញុំ។

៣៥រួចមក ទ្រង់មានបន្ទូលទៅពួកសិស្សទាំងអស់ថា កាល
ខ្ញុំចាត់អ្នករាល់គ្នា ឱ្យទៅឥតកាបូប ឥតយាម ហើយឥត
ស្បែកជើង[ប] នោះតើមានខ្វះអ្វីឬទេ គេទូលឆ្លើយថាគ្មាន
ខ្វះអ្វីទេ ៣៦ដូច្នេះ ទ្រង់មានបន្ទូលថា ឥឡូវនេះវិញអ្នកណា
ដែលមានកាបូប មានយាម នោះត្រូវតែយកទៅកុំខាន
ហើយអ្នកណាដែលគ្មានដាវ ក៏ឱ្យអ្នកនោះលក់អាវខ្លួនទៅ
ទិញមួយមក ៣៧ខ្ញុំប្រាប់អ្នករាល់គ្នាថា សេចក្តីនេះដែលបាន
ចែងទុកមកថា គេបានរាប់ទ្រង់ ជាពួកទទឹងច្បាប់[ផ] នោះ
ត្រូវសំរេចលើខ្លួនខ្ញុំ ដ្បិតគ្រប់សេចក្តីដែលដំរូវមកខ្ញុំ ត្រូវតែ
បានសំរេចទាំងអស់ ៣៨រួចគេទូលថា ព្រះអម្ចាស់អើយ
មើល នេះមានដាវ២ហើយ ទ្រង់ក៏មានបន្ទូលថាអើល្មម
ហើយ ។

## ព្រះយេស៊ូវអធិស្ឋាននៅលើភ្នំដើមអូលីវ

*២២:៤០–៤៦ = មថ ២៦:៣៦–៤៦ មក ១៤:៣២–៤២*

៣៩កាលទ្រង់យាងចេញទៅ នោះទ្រង់ទៅឯភ្នំដើមអូលីវ[ព]
តាមទំលាប់[ភ] ហើយពួកសិស្សក៏តាមទៅដែរ ៤០លុះដល់
កន្លែងហើយ ទ្រង់មានបន្ទូលថា ចូរអធិស្ឋានទៅ ដើម្បីកុំ
ឱ្យត្រូវសេចក្តីល្បួងឡើយ[ម] ៤១រួចទ្រង់ថយចេញពីគេទៅ
ចំងាយទីប្រហែលជាគេចោលថ្ម១ទំហឹងដៃ ក៏លុតព្រះជង្ឃ
ក្រាបចុះ[យ]អធិស្ឋានថា ៤២ឱព្រះវរបិតាអើយ បើសិនជាទ្រង់សព្វ
ព្រះហឫទ័យ នោះសូមយកពែងនេះចេញពីទូល[រ]បង្គំទៅ
ប៉ុន្តែ កុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់
វិញ[ល] ៤៣នោះមានទេវតាលេចមកឯទ្រង់ អំពីស្ថានសួគ៌មក
ចំរើនកំឡាំងថ្វាយ[វ] ៤៤ហើយដោយទ្រង់កើតទុក្ខជាខ្លាំង បាន
ជាទ្រង់អធិស្ឋានទទូចរឹតតែខ្លាំងឡើង ញើសទ្រង់ក៏ត្រឡប់
ដូចជាដំណក់ឈាមដ៏ធំៗស្រក់ទៅដី ៤៥រួចទ្រង់ក្រោកពីទី
អធិស្ឋាន វិលទៅឯពួកសិស្សវិញ ក៏ឃើញគេដេកលក់ដោយ
ព្រួយចិត្ត ៤៦ទ្រង់មានបន្ទូលថា ហេតុអ្វីបានជាដេកលក់
ដូច្នេះ ចូរក្រោកឡើងអធិស្ឋានចុះ ដើម្បីកុំឱ្យត្រូវសេចក្តីល្បួង
ឡើយ[ស] ។

## ការចាប់អង្គព្រះយេស៊ូវ

*២២:៤៧–៥៣ = មថ ២៦:៤៧–៥៦ មក ១៤:៤៣–៥០ យហ ១៨:៣–១១*

៤៧កំពុងដែលព្រះយេស៊ូវ ទ្រង់មានបន្ទូលនៅឡើយ នោះ
ឃើញមានមនុស្សទាំងហ្វូងមក ហើយអ្នកដែលមានឈ្មោះ

**២២:៣១** ថ អម ៩:៩
**២២:៣២** ទ យហ ១៧:៩,១៥ រម ៨:៣៤ ធ យហ ២១:១៥–១៧
**២២:៣៣** ន យហ ១១:១៦
**២២:៣៥** ប មថ ១០:៩,១០ លក ៩:៣ ១០:៤
**២២:៣៧** ផ អស ៥៣:១២
**២២:៣៩** ព មថ ២១:១ ភ លក ២១:៣៧
**២២:៤០** ម មថ ៦:១៣
**២២:៤១** យ លក ១៨:១១
**២២:៤២** រ មថ ២០:២២ ល មថ ២៦:៣៩
**២២:៤៣** វ មថ ៤:១១ មក ១:១៣
**២២:៤៦** ស ខ.៤០

នឹងបានធ្វើឱ្យពួកគេជួបសេចក្តីហិនវិនាសខាងវិញ្ញាណ ។

**២២:៣៤** មើល មថ ២៦:៣៤ យហ ១៣:៣៨ និងការពន្យល់ ។

**២២:៣៦** *កាបូប . . . យាម* គឺមាននៅក្នុងសេចក្តីបង្រៀនកាលពីលើកមុន (៩:៣ ១០:៤) ។ រហូតមកទល់ពេលនេះ ពួកគេមានការពឹងផ្អែកលើម្ចាស់ផ្ទះដែលទទួលពួកគេដោយចិត្តសប្បុរស ប៉ុន្តែ ការប្រឆាំងនៅពេលអនាគតនឹងតម្រូវឱ្យពួកគេត្រៀមខ្លួនចេញថ្លៃចំណាយខ្លួនឯង ។ *ទិញមួយមក* គឺជាព្រះបន្ទូលធ្ងន់ដែលប្រើក្នុងន័យធៀប ដើម្បីព្រមានពួកសិស្សពីគ្រោះថ្នាក់ដែលរៀបនឹងមកដល់ ។ ពួកគេនឹងត្រូវការដោះសារ និងការការពារដូចជាការអ្វីដែលសាវ័កប៉ុលបានធ្វើ នៅពេលដែលលោកធ្វើសំណើថ្វាយទៅស្តេចសេសារ (កច ២៥:១១ និងការពន្យល់) និងដូចជាអ្នកដែល "ស្ពាយដាវ" នោះផងដែរ (រម ១៣:៤) ។

**២២:៣៧** *រាប់ទ្រង់ជាពួកទទឹងច្បាប់* ព្រះយេស៊ូវទ្រង់នឹងត្រូវគេចាប់ខ្លួនដូចជាឧក្រិដ្ឋជនម្នាក់នៅក្នុងពេលដ៏ខ្លីខាងមុខ ដែលការនេះត្រូវសម្រេចតាមបទទំនាយពួកហោរា ហើយសិស្សរបស់ទ្រង់ក៏នឹងត្រូវប្រឈមមុខនឹងគ្រោះថ្នាក់នៃការធ្វើជាសិស្សរបស់ទ្រង់ ។

**២២:៣៨** *"... ដាវ២" ... "ល្មមហើយ"* មានន័យថាពួកសិស្សបានជឿថាការដែលទ្រង់មានបន្ទូលពីដាវនោះជាន័យត្រង់ ។ ព្រះយេស៊ូវទ្រង់បានបញ្ចប់ការសន្ទនាដោយបន្ទូលដ៏ខ្លីគឺ "ល្មមហើយ"។ មិនយូរប៉ុន្មានសាវ័កពេត្រុសក៏ប្រើដាវហើយត្រូវទទួលការបន្ទោស (ខ.៥០) ។

**២២:៣៩** *ភ្នំដើមអូលីវ* មើល ១៩:២៩ និងការពន្យល់ ។ ព្រះគម្ពីរម៉ាថាយប្រាប់ឈ្មោះចំតែម្តងគឺ "គែតសេម៉ានី" (មថ ២៦:៣៦ និងមើលការពន្យល់) ព្រះគម្ពីរយ៉ូហានប្រើពាក្យ "ច្បារ១" (យហ ១៨:១) ។ គេជឿថាទ្រង់អធិស្ឋាននៅត្រង់ទីជម្រាលទាបៗរបស់ភ្នំដើមអូលីវ ។

**២២:៤០** *សេចក្តីល្បួង* សេចក្តីល្បួងដែលនិយាយក្នុងខនេះ គឺសំដៅទៅលើការល្បួងដែលមានចាប់ពីខ.២៨–៣៨ដែលអាចនាំឱ្យពួកគេបាក់ជំនឿបាន ។

**២២:៤២** *ពែងនេះ* គឺពែងនៃការរងទុក្ខ (មថ ២០:២២ មក ១៤:៣៦ អស ៥១:១៧ អក ២៣:៣១ និងការពន្យល់) ។

**២២:៤៣** *ទេវតា* ព្រះគម្ពីរម៉ាថាយ និងម៉ាកុសមាននិយាយពីពួកទេវតាដែលមកបម្រើទ្រង់នៅពេលបញ្ចប់ការតមនិងការល្បួង (មថ ៤:១១ មក ១:១៣) ។

**២២:៤៤** *ដំណក់ឈាមដ៏ធំៗស្រក់* អាចជាញើសដែលបែកចេញមកជាដំណក់ធំៗ ឬអាចជាដំណក់ឈាមលាយឡំជាមួយនឹងញើស ដែលកើតឡើងពីភាពតានតឹងការថប់បារម្ភ ឬការកើតទុក្ខយ៉ាងខ្លាំង ។ មានតែលោកវេជ្ជបណ្ឌិតលូកាម្នាក់គត់ ដែលរៀបរាប់អំពីដំណក់ឈាមយ៉ាងដូចនេះ ។

**២២:៤៧** *មនុស្សទាំងហ្វូងមក* គឺពួកគេត្រូវបានសម្តេចសង្ឃ ពួកចាស់ទុំ

យូដាស ជាម្នាក់ក្នុងពួក១២ ក៏នាំមុខគេ វាចូលមកជិត ដើម្បី
ថើបព្រះយេស៊ូវ ៤៨តែទ្រង់មានបន្ទូលទៅវាថាយូដាស
អើយ អ្នកបញ្ជូនកូនមនុស្សទៅ ដោយថើប១ខ្សឺតឬអី
៤៩កាលពួកអ្នកដែលនៅជុំវិញទ្រង់ ឃើញការដែលហៀប
នឹងកើតមកដូច្នេះ នោះក៏ទូលទ្រង់ថា ព្រះអម្ចាស់អើយ
តើត្រូវឱ្យយើងខ្ញុំកាប់នឹងដាវឬអី[ហ] ៥០មានម្នាក់ក្នុងពួកគេ
ក៏កាប់ដាច់ត្រចៀកស្តាំរបស់បាវសំដេចសង្ឃម្នាក់ ៥១ព្រះ
យេស៊ូវមានបន្ទូលថា ចូរឈប់ប៉ុណ្ណឹងចុះរួច ទ្រង់ពាល់
ត្រចៀកអ្នកនោះឱ្យជាវិញ ៥២នោះព្រះយេស៊ូវមានបន្ទូល
ទៅពួកសង្គ្រាជ ពួកមេទ័ព[ឡ]រក្សាព្រះវិហារ នឹងពួកចាស់
ទុំដែលមកចាប់ទ្រង់ថា តើអ្នករាល់គ្នាចេញមកទាំងកាន់
ដាវកាន់ដំបង ដូចជាមកចាប់ចោរឬអី ៥៣កាលខ្ញុំនៅជា
មួយនឹងអ្នករាល់គ្នា ក្នុងព្រះវិហារ[អ]រាល់តែថ្ងៃ នោះអ្នក
រាល់គ្នាមិនបានលូកដៃមកចាប់ខ្ញុំសោះ ប៉ុន្តែ នេះជាពេល
វេលា[ក]របស់ផងអ្នករាល់គ្នាទេ ហើយជាអំណាចនៃសេចក្តី
ងងឹតផង[ខ]។

### ពេត្រុសបដិសេធព្រះយេស៊ូវ

*២២:៥៥-៦២ = មថ ២៦:៦៩-៧៥ មក ១៤:៦៦-៧២*

៥៤គេក៏ចាប់ទ្រង់ដឹកនាំទៅដល់ដំណាក់សំដេចសង្ឃ[គ] ឯ
ពេត្រុស គាត់តាមទៅពីចំងាយដែរ[ឃ] ៥៥កាលគេបានបង្កាត់
ភ្លើងនៅកណ្តាលព្រះលាន ហើយអង្គុយជាមួយគ្នា នោះ
ពេត្រុសក៏អង្គុយជាមួយនឹងគេដែរ ៥៦មានស្រីបំរើម្នាក់
ឃើញគាត់អង្គុយនៅជិតភ្លើង ក៏សំឡឹងមើល ហើយនិយាយ
ថា អ្នកនេះបាននៅជាមួយនឹងមនុស្សនោះដែរ។
៥៧តែគាត់ប្រកែកថា នាងអើយ ខ្ញុំមិនស្គាល់មនុស្សនោះទេ
៥៨ក្រោយបន្តិចមក មានម្នាក់ទៀតឃើញគាត់ ហើយក៏ថា
អ្នកឯងជាពួកនោះដែរ តែពេត្រុសឆ្លើយថា អ្នកអើយខ្ញុំ
មិនមែនទេ ៥៩រួចប្រហែលជា១ម៉ោងក្រោយមក មានម្នាក់
ទៀតថា អ្នកនេះប្រាកដជាបាននៅជាមួយនឹងមនុស្សនោះ
ដែរ ដ្បិតជាសាសន៍កាលីឡេដូចគ្នា[ឃ] ៦០តែពេត្រុសប្រកែក
ថា អ្នកអើយ ខ្ញុំមិនដឹងជាអ្នកថាដូចម្តេចទេ កាលគាត់កំ
ពុងតែនិយាយនៅឡើយ នោះស្រាប់តែមាន់រងាវឡើង
៦១ហើយព្រះអម្ចាស់[ង]ទ្រង់បែរមកទតមើលពេត្រុស នោះពេ
ត្រុសក៏នឹកឃើញ ពីព្រះបន្ទូលនៃព្រះអម្ចាស់ ដែលមាន
បន្ទូលនឹងគាត់ថា មុនដែលមាន់រងាវនោះអ្នកនឹងប្រ
កែក៣ដងថា មិនស្គាល់ខ្ញុំ[ច] ៦២រួចគាត់ចេញទៅក្រៅដោយ
យំក្តួល។

### ការចំអកឱ្យព្រះយេស៊ូវ

*២២:៦៣-៦៥ = មថ ២៦:៦៧,៦៨*
*មក ១៤:៦៥ យហ ១៨:២២,២៣*

៦៣ឯពួកមនុស្សដែលរក្សាព្រះយេស៊ូវ គេចំអកឱ្យហើយ
វាយទ្រង់ ៦៤ក៏ខ្ទប់ព្រះនេត្រ ហើយទះកំផ្លៀងទ្រង់ ដោយ
ទូលថា ចូរទាយចុះ តើអ្នកណាបានទះឯង ៦៥គេក៏
ពោលពាក្យប្រមាថទ្រង់ជាច្រើនទៅទៀតដែរ[ឆ]។

**២២:៤៩** ហ ខ.៣៨
**២២:៥២** ឡ ខ.៤
**២២:៥៣** អ មថ ២៦:៥៥
ក យហ ១២:២៧
ខ មថ ៨:១២
យហ ១:៥ ៣:២០
**២២:៥៤** គ មថ ២៦:៥៧ មក ១៤:៥៣
ឃ មថ ២៦:៥៨
មក ១៤:៥៤
យហ ១៨:១៥
**២២:៥៩** ឃ លក ២៣:៦
**២២:៦១** ង លក ៧:១៣ ច ខ.៣៤
**២២:៦៥** ឆ មថ ១៦:២១

(មថ ២៦:៤៧) និងពួកអាចារ្យ(មក ១៤:៤៣ និងការពន្យល់) ចាត់ឱ្យមកចាប់ទ្រង់ ដោយមានកាន់ដាវ និងដំបងជាប់មកជាមួយផង ។ អ្នកទាំងនេះរួមមានទាហានមួយក្រុមដែលមកជាមួយពួកមន្ត្រីសាសន៍យូដា (ខ.៥២ យហ ១៨:៣)។ *ដើម្បីថើប* គឺជាការឱ្យសញ្ញាទៅពួកនោះ ដើម្បីឱ្យស្គាល់ថាជាទ្រង់ ហើយចូលចាប់តែម្តង(មថ ២៦:៤៨)។ ការធ្វើដូចនេះគ្មានប្រយោជន៍ទេ ពីព្រោះព្រះយេស៊ូវទ្រង់បានបង្ហាញអង្គទ្រង់ឱ្យពួកនេះបានឃើញរួចទៅហើយ(១៨:៥) តែទោះបីជាយ៉ាងណាក៏ដោយ យូដាសនៅតែត្រូវធ្វើតាមផែនការរបស់ខ្លួនដដែល ។

**២២:៥០** *បាវសំដេចសង្ឃ* គឺមានឈ្មោះម៉ាលកុស ដែលស៊ីម៉ូនកាប់ត្រូវមួយដាវ (យហ ១៨:១០ និងការពន្យល់)។

**២២:៥១** *ពាល់ . . . ឱ្យជាវិញ* ការនេះឃើញមាននៅតែក្នុងព្រះគម្ពីរលូកាប៉ុណ្ណោះ ។ ព្រះយេស៊ូវទ្រង់កែតម្រូវសេចក្តីកំហុសដែលសិស្សទ្រង់ទើបតែបានធ្វើនោះ ។ ក្នុងរឿងនេះលោកម៉ាលកុសមិនបានប្រើសេចក្តីជំនឿរបស់គាត់ឡើយ ប៉ុន្តែ ការបណ្តោយឱ្យមានការឈឺចាប់យ៉ាងដូចនោះ នឹងនាំឱ្យមានការប្រាសចាកពីការបង្រៀនរបស់ទ្រង់ ។

**២២:៥២** មើលការពន្យល់ មថ ២៦:៥៥ ។

**២២:៥៣** *ពេលវេលារបស់ផងអ្នករាល់គ្នា* គឺពេលវេលាដែលបានកំណត់ឱ្យពួកអ្នកប្រឆាំងនឹងទ្រង់ទាំងនោះនាំគ្នាមកចាប់ចងទ្រង់ ក៏ដូចជាពេលវេលាដែលអំណាចនៃសេចក្តីងងឹត(អំណាចអារក្សសាតាំង) ធ្វើការអាក្រក់បំផុតរបស់វា ដោយចង់យកឈ្នះលើផែនការរបស់ព្រះ ។

**២២:៥៤** *ដំណាក់សំដេចសង្ឃ* មើលការពន្យល់ ៣:២ មក ១៤:៥៣ ។

**២២:៥៧** *នាងអើយ* សូមផ្ទៀបនឹងការពន្យល់ យហ ២:៤ ។

**២២:៥៩** *ដ្បិតជាសាសន៍កាលីឡេដូចគ្នា* គឺគេសំគាល់គាត់បានតាមរយៈពាក្យសំដីរបស់គាត់(មថ ២៦:៧៣ និងការពន្យល់) ហើយសាច់ញាតិរបស់ម៉ាលកុស (បាវសំដេចសង្ឃ)ក៏មើលដឹងថាជាគាត់ផងដែរ (យហ ១៨:២៦ និងការពន្យល់)។

**២២:៦១** *ព្រះអម្ចាស់ទ្រង់ . . .មើលពេត្រុស* ពេត្រុសកំពុងស្ថិតនៅបរិវេណខាងក្រៅ គឺនៅក្នុងទីធ្លាដែលមានអាគារជុំជិត ហើយព្រះយេស៊ូវ និងសាវ័កពេត្រុសបានឃើញគ្នាទៅវិញទៅមក ប្រហែលនៅក្នុងពេលដែលគេកំពុងបណ្តើរទ្រង់ពីកន្លែងកាត់ក្តី(ដោយលោកកៃផាស)ទៅឯក្រុមជំនុំ។ *ព្រះបន្ទូលនៃព្រះអម្ចាស់ដែលមានបន្ទូលនឹងគាត់* មើលខ.៣៤ ។

**២២:៦៤** *ខ្ទប់ព្រះនេត្រ* មើលការពន្យល់ មក ១៤:៦៥ ។

**២២:៦៦** *ដល់ព្រឹកឡើង* បើមិនទាន់ដល់ពេលទៀបភ្លឺទេ ក្រុមប្រឹក្សា(ក្រុមជំនុំ) មិនអាចបើកការជំនុំជម្រះទោស ដើម្បីសម្រេចទោសប្រហារជីវិតបាន

### ព្រះយេស៊ូវនៅចំពោះមុខលោកពីឡាត់ និងស្ដេចហេរ៉ូឌ

*២២:៦៧-៧១ = មថ ២៦:៦៣-៦៦ មក ១៤:៦១-៦៣ យហ ១៨:១៩-២១*
*២៣:២,៣ = មថ ២៧:១១-១៤ មក ១៥:២-៥ យហ ១៨:២៩-៣៧*
*២៣:១៨-២៥ = មថ ២៧:១៥-២៦ មក ១៥:៦-១៥ យហ ១៨:៣៩-១៩:១៦*

៦៦ដល់ព្រឹកឡើង នោះពួកចាស់ទុំនៃបណ្ដាជន[ជ] ព្រមទាំង
ពួកសង្គ្រាជ នឹងពួកអាចារ្យក៏ប្រជុំគ្នា[ឈ] ហើយគេនាំទ្រង់មក
ក្នុងក្រុមជំនុំសួរថា ៦៧បើឯងជាព្រះគ្រីស្ទមែន ចូរប្រាប់
មកយើងចុះតែទ្រង់មានបន្ទូលទៅគេថា បើសិនជាខ្ញុំជំរាប
ដល់ លោករាល់គ្នា នោះលោកក៏មិនព្រមជឿ ៦៨ហើយបើ
ខ្ញុំសួរលោកវិញ នោះក៏មិនព្រមឆ្លើយមកខ្ញុំ ឬលែងឱ្យខ្ញុំទៅ
ដែរ[ញ] ៦៩អំណឹះទៅមុខ កូនមនុស្សនឹងអង្គុយខាងស្ដាំព្រះ
ចេស្ដានៃព្រះ[ដ] ៧០នោះទាំងអស់គ្នានិយាយឡើងថា ដូច្នេះ
ឯងជាព្រះ រាជបុត្រានៃព្រះឬអី[ឋ] ទ្រង់មានបន្ទូលឆ្លើយថា
លោករាល់ គ្នាមានប្រសាសន៍ ដូច្នោះ នោះគឺខ្ញុំនេះហើយ[ឌ]
៧១គេក៏និយាយថា តើចាំបាច់ត្រូវការនឹងទីបន្ទាល់អ្វីទៀត
ព្រោះយើងបានឮចេញពីមាត់ខ្លួនវាមកស្រាប់ហើយ។
**២៣** ១បណ្ដាមនុស្សទាំងអស់គ្នា ក៏ក្រោកឡើងនាំទ្រង់
ទៅឯលោកពីឡាត់[ឍ] ២ចាប់តាំងចោទប្រកាន់ទ្រង់ថា យើង
ខ្ញុំបានឃើញមនុស្សនេះ នាំបំភាន់សាសន៍យើង[ណ]ឱ្យវង្វេង
ចេញ ក៏ហាមមិនឱ្យបង់ពន្ធថ្វាយសេសារផង[ត] ដោយ
លើកខ្លួនថាជាព្រះគ្រីស្ទ គឺជាស្ដេចដែរ[ថ] ៣លោកពីឡាត់ក៏
ពិចារណាសួរទ្រង់ថា តើអ្នកជាស្ដេច សាសន៍យូដាមែនឬ
អីទ្រង់ឆ្លើយថា ត្រូវដូចលោកមានប្រសាសន៍ហើយ ៤នោះ
លោកពីឡាត់មានប្រសាសន៍ដល់ពួកសង្គ្រាជ នឹងបណ្ដា
មនុស្សថា ខ្ញុំមិនឃើញជាមនុស្សនេះមានទោសអ្វីសោះ[ទ]
៥ប៉ុន្តែ គេនិយាយទទូចថា វាញុះញង់បណ្ដាជន ហើយក៏
បង្រៀនពេញក្នុងស្រុកយូដាទាំងមូល ចាប់តាំងពីស្រុក
កាលីឡេ[ធ]រហូតមកដល់ទីនេះ ៦កាលលោកពីឡាត់ឮនិយាយ
ពីស្រុកកាលីឡេ នោះលោកសួរថា មនុស្សនេះជាអ្នកស្រុក
កាលីឡេឬអី[ន] ៧លុះបានជ្រាបថា ទ្រង់នៅក្នុងអំណាចនៃ
ស្ដេចហេរ៉ូឌ នោះលោកក៏បញ្ជូនទ្រង់ទៅឯស្ដេចហេរ៉ូឌ
ទៅ[ប] ដ្បិតគ្រានោះស្ដេចគង់នៅក្រុងយេរូសាឡិមដែរ។
៨កាលស្ដេចហេរ៉ូឌបានឃើញព្រះយេស៊ូវ នោះក៏អរ
ណាស់ ដ្បិតស្ដេចចង់ឃើញទ្រង់ជាយូរមកហើយ[ផ] ព្រោះ
បានឮរឿងពីទ្រង់ជាច្រើន ហើយបានសង្ឃឹមថានឹងឃើញ

**២២:៦៦** ជ មថ ៥:២២ ឈ មថ ២៧:១ មក ១៥:១
**២២:៦៨** ញ លក ២០:៣-៨
**២២:៦៩** ដ មក ១៦:១៩
**២២:៧០** ឋ មថ ៤:៣ ឌ មថ ២៧:១១ លក ២៣:៣
**២៣:១** ឍ មថ ២៧:២
**២៣:២** ណ ខ.១៤ ត លក ២០:២២ ថ យហ ១៩:១២
**២៣:៤** ទ ខ.១៤,២២, ៤១ មថ ២៧:២៣ យហ ១៨:៣៨ ១ធថ ៦:១៣ ២ កថ ៥:២១
**២៣:៥** ធ មក ១:១៤
**២៣:៦** ន លក ២២:៥៩
**២៣:៧** ប មថ ១៤:១

ឡើយ(មើលការពន្យល់ មក ១៤:៥៣-១៥:១៥)។
**២២:៦៧** *បើឯងជាព្រះគ្រីស្ទមែន* ការបង្គាប់ក្នុងខនេះមានការជាប់ទាក់ទងនឹងសំណួរដែលមានសួរនៅពេលក្រោយទៀតថា "ឯងជាព្រះរាជបុត្រានៃព្រះឬអី" (ខ.៧០)។
**២២:៦៩** *កូនមនុស្ស* មើលការពន្យល់ មក ៨:៣១ ។
**២២:៧១** *ឮចេញពីមាត់ខ្លួនវា* ការមានប្រតិកម្មចំពោះព្រះបន្ទូលឆ្លើយរបស់ព្រះយេស៊ូវបង្ហាញយ៉ាងច្បាស់ថា ព្រះបន្ទូលឆ្លើយរបស់ទ្រង់ជាការបញ្ជាក់យ៉ាងខ្លាំង ។ ព្រះគម្ពីរម៉ាកុសមានពាក្យ "គឺខ្ញុំនេះហើយ" (មក ១៤:៦២)។ ការកុហកដោយហ៊ានអះអាងថាខ្លួនជាព្រះមែស៊ី និងព្រះរាជបុត្រានៃព្រះពិតប្រាកដជាការពោលពាក្យប្រមាថព្រះ(មើលការពន្យល់ មក ១៤:៦៤)។
**២៣:១** *បណ្ដាមនុស្សទាំងអស់* គឺជាសមាជិកក្រុមជំនុំ(មថ ២៦:៥៩ ២៧:១ មក ១៤:៥៥ និងការពន្យល់) ដែលបានជួបប្រជុំគ្នាតាំងតែពីព្រលឹមស្រាង។ (២២:៦៦ និងការពន្យល់)។ *នាំទ្រង់ទៅឯលោកពីឡាត់* មើលការពន្យល់ លក ៣:១ ។ *ពីឡាត់* (មើលការពន្យល់ មក ១៥:១)ជាសាសន៍រ៉ូម៉ាំងដែលមានឋានៈជាចៅហ្វាយមានទីបញ្ជាការនៅក្រុងសេសារា ប៉ុន្តែ លោកនៅក្នុងក្រុងយេរូសាឡិម ក្នុងអំឡុងពេលបុណ្យរំលង ដើម្បីការពារកុំឱ្យមានបញ្ហាដែលអាចបង្ក ឡើងដោយសាសន៍យូដាដ៏ច្រើនលើសលប់ ដែលមកផ្តុំគ្នាប្រារព្ធធ្វើពិធីនោះ ។
**២៣:២** *បំភាន់សាសន៍យើងឱ្យវង្វេង* មានមនុស្សទាំងហ្វូងៗដើរតាមព្រះយេស៊ូវ ប៉ុន្តែ ទ្រង់មិនបានបំភាន់ពួកគេ ឬដឹកនាំពួកគេឱ្យប្រឆាំងនឹងចក្រភពរ៉ូម៉ាំងនោះឡើយ។ *ហាមមិនឱ្យបង់ពន្ធថ្វាយសេសារ* គឺជាការចោទប្រកាន់មិនត្រឹមត្រូវមួយទៀត(២០:២៥ និងការពន្យល់ មថ ២២:២១)។ *លើកខ្លួនថាជាព្រះគ្រីស្ទគឺជាស្ដេចដែរ* ព្រះយេស៊ូវទ្រង់បានប្រកាសថា ទ្រង់គឺជាព្រះមែស៊ី ប៉ុន្តែ ទ្រង់មិនបានប្រកាសថាទ្រង់ជាស្ដេចដែលធ្វើនយោបាយ ឬដឹកនាំទ័ព ដែលនឹងនាំឱ្យចក្រភពរ៉ូម៉ាំងអន្ទះសារចង់កម្ចាត់ចោលនោះឡើយ ។
**២៣:៣** *ត្រូវ . . . ហើយ* ព្រះយេស៊ូវទ្រង់បញ្ជាក់ថាទ្រង់គឺជាក្សត្រប៉ុន្តែបន្ទាប់មកទៀតទ្រង់ក៏បានបកស្រាយថា នគររបស់ទ្រង់មិនមែនជានគរនៃលោកិយនេះឡើយ(យហ ១៨:៣៣-៣៨ និងការពន្យល់)។
**២៣:៥** *ស្រុកយូដា* អាចសំដៅទៅលើទឹកដីទាំងអស់របស់សាសន៍យូដា (រួមទាំងស្រុកកាលីឡេផង) ឬអាចសំដៅទៅលើទឹកដីភាគខាងត្បូងតែម្យ៉ាងដែលមានតំបន់ដែលលោកពីឡាត់គ្រប់គ្រង (មើលការពន្យល់ ៤:៤៤)។
**២៣:៧** *អំណាចនៃស្ដេចហេរ៉ូឌ* មើលការពន្យល់ ៣:១ ។ ទោះបីជាលោកពីឡាត់ និងស្ដេចហេរ៉ូឌជាគូប្រជែងនឹងគ្នាក៏ដោយ ក៏លោកពីឡាត់មិនចង់សម្រេចរឿងក្តីនេះឡើយ ដូចនេះហើយបានជាគាត់ឱ្យគេបញ្ជូនទ្រង់ទៅស្ដេចហេរ៉ូឌ(ខ.១២)។ *នៅក្រុងយេរូសាឡិម* ទីបញ្ជាការរបស់ស្ដេចហេរ៉ូឌស្ថិតនៅស្រុកទីបេរាស ដែលនៅជាប់សមុទ្រកាលីឡេទេ ប៉ុន្តែ ដោយសារតែហ្វូងមនុស្សដែលមកផ្តុំគ្នានៅយេរូសាឡិម ទ្រង់ក៏យាងទៅគង់នៅក្រុងយេរូសាឡិម គឺដូចគ្នានឹងលោកពីឡាត់ដែរ ។
**២៣:៨** *ចង់ឃើញទ្រង់* ស្ដេចហេរ៉ូឌមានការបារម្ភថា តើព្រះយេស៊ូវជា

ទ្រង់ធ្វើទីសំគាល់ណាមួយ ៩ នោះស្ដេចមានបន្ទូលសួរទ្រង់
ជាច្រើន ប៉ុន្តែទ្រង់មិនព្រមឆ្លើយសោះ[ព] ១០ ឯពួកសង្គ្រាជ
និងពួកអាចារ្យ គេឈរនៅទីនោះកំពុងតែចោទ ប្រកាន់
ទ្រង់ជាខ្លាំង ១១ លុះស្ដេចហេរ៉ូឌ ព្រមទាំងពួកទាហានបាន
ចំអកមើលងាយព្រះយេស៊ូវរួចហើយ នោះក៏យកអាវដ៏រុង
រឿង[ភ] មកបំពាក់ទ្រង់ រួចបញ្ជូនត្រឡប់ទៅឯលោកពីឡាត់
វិញ ១២ នៅថ្ងៃនោះ លោកពីឡាត់ និងស្ដេចហេរ៉ូឌក៏បាន
ជានឹងគ្នា[ម] ដ្បិតពីមុនលោកទាំង២នោះបានទាស់ទែងគ្នា ។
១៣ កាលលោកពីឡាត់បានប្រមូលពួកសង្គ្រាជ ពួកនាម៉ឺន
និងបណ្ដាមនុស្សទាំងអស់មក ១៤ នោះលោកមានប្រសាសន៍
ទៅគេថា អ្នករាល់គ្នាបាននាំមនុស្សនេះមកឯខ្ញុំ ទុកជា
មនុស្សដែលនាំបណ្ដាជនឱ្យវង្វេង តែមើល ខ្ញុំបានពិចារ
ណាសួរនៅមុខអ្នករាល់គ្នាហើយ មិនឃើញជាមាន
ទោសអ្វី តាមដែលអ្នករាល់គ្នាចោទប្រកាន់នោះសោះ[យ]
១៥ ទាំងស្ដេចហេរ៉ូឌក៏រកគ្មានដែរ ដ្បិតខ្ញុំបានឱ្យអ្នករាល់គ្នា
ទៅឯទ្រង់ ហើយមើល ទ្រង់មិនថាជាអ្នកនេះមានទោសអ្វី
ដែលគួរឱ្យស្លាប់ទេ ១៦ ដូច្នេះ ខ្ញុំនឹងគ្រាន់តែវាយប្រដៅ[រ]
រួចលែងឱ្យទៅចុះ ១៧ ដ្បិតនៅបុណ្យនោះ លោកត្រូវតែ
លែងអ្នកទោសម្នាក់ឱ្យដល់គេ ១៨ តែគេស្រែកឡើងព្រមគ្នា
ថាសូមយកមនុស្សនេះទៅ ហើយលែងបារ៉ាបាសឱ្យយើង

**២៣:៨** ផ លក ៩:៩
**២៣:៩** ព មក ១៤:៦១
**២៣:១១** ភ មក ១៥:១៧–១៩ យហ ១៩:២,៣
**២៣:១២** ម កច ៤:២៧
**២៣:១៤** យ ខ.៤
**២៣:១៦** រ ខ.២២ មថ ២៧:២៦ យហ ១៩:១ កច ១៦:៣៧ ២កថ ១១:២៣,២៤
**២៣:១៨** ល កច ៣:១៣,១៤
**២៣:២២** វ ខ.១៦
**២៣:២៦** ស មថ ២៧:៣២ ហ មក ១៥:២១ យហ ១៩:១៧
**២៣:២៧** ឡ លក ៨:៥២

វិញ[ល] ១៩ ឯបារ៉ាបាសនេះ វាជាប់គុកដោយព្រោះការបះ
បោរ ដែលវាបង្កើតនៅក្នុងទីក្រុង ហើយនិងការសំឡាប់
គេ ២០ បានជាលោកពីឡាត់ មានប្រសាសន៍ទៅគេម្ដងទៀត
ដោយចង់លែងព្រះយេស៊ូវវិញ ២១ ប៉ុន្តែគេស្រែកឡើងថា
ឱ្យឆ្កាងវា១ទៅ ២២ លោកមានប្រសាសន៍ទៅគេជាគំរប់
៣ដងថា តើមនុស្សនេះបានធ្វើអាក្រក់អ្វី ខ្ញុំមិនឃើញជាមាន
ហេតុអ្វីគួរឱ្យស្លាប់ទេ ដូច្នេះ ខ្ញុំនឹងវាយប្រដៅ រួចលែងវា
ទៅ[វ] ២៣ តែគេស្រែកទទូចជាខ្លាំង ទាំងសូមឱ្យឆ្កាងទ្រង់វិញ
ហើយសំរែករបស់ជនទាំងនោះ និងពួកសង្គ្រាជ ក៏បានឈ្នះ
២៤ លោកពីឡាត់កាត់សំរេចទោសតាមគេសូម ២៥ រួចលែង
អ្នកនោះដែលជាប់គុក ដោយព្រោះការបះបោរ នឹងការ
សំឡាប់មនុស្ស ឱ្យដល់ពួកគេ តាមគេសូម ហើយប្រគល់
ព្រះយេស៊ូវទៅតាមចិត្តគេប្រាថ្នាវិញ។

## ការធ្វើគត់ព្រះយេស៊ូវដោយឆ្កាង

*២៣:៣៣–៤៣ = មថ ២៧:៣៣–៤៤ មក ១៥:២២–៣២ យហ ១៩:១៧–២៤*

២៦ កាលគេនាំព្រះយេស៊ូវទៅ នោះគេចាប់មនុស្សសាសន៍
គីរេន[ស] ម្នាក់ ឈ្មោះស៊ីម៉ូន ដែលកំពុងតែវិលមកពីចំការ ក៏
ដាក់ឱ្យគាត់លីឈើឆ្កាងតាមទ្រង់ទៅ[ហ] ២៧ មានមនុស្ស
ដើរតាមទ្រង់ដ៏ណែនណាន់ ក៏មានពួកស្រីៗដែលគក់ដើម
ទ្រូង ហើយយំទួញផង[ឡ] ២៨ ព្រះយេស៊ូវទ្រង់ងាកបែរទៅ

នរណា (៩:៩ និងការពន្យល់) ហើយបានប៉ងធ្វើគុតព្រះយេស៊ូវ (១៣:៣១ និងការពន្យល់) ចាប់តាំងពេលដែលមិនទាន់បានជួបទ្រង់ម្ល៉េះ ។ គ្មានការកត់ត្រាថាព្រះយេស៊ូវទ្រង់ធ្លាប់បានបង្រៀននៅស្រុកទីបេរាស ដែលជាទីតាំងរបស់ដំណាក់ស្ដេចហេរ៉ូឌនោះឡើយ ។

**២៣:១១** *អាវដ៏រុងរឿង* មើលការពន្យល់ មក ១៥:១៧ ។

**២៣:១៦** *ខ្ញុំនឹងគ្រាន់តែវាយប្រដៅ* ទោះជាលោកពីឡាត់រកមិនឃើញទោសកំហុសដែលគេបានចោទព្រះយេស៊ូវក៏ដោយ ក៏គាត់បានសម្រេចឱ្យគេយកទ្រង់ទៅវាយដោយមិនស្របច្បាប់ ដើម្បីផ្គាប់ចិត្តពួកសង្គ្រាជ និងបណ្ដាជន និងដើម្បីព្រមានកុំឱ្យកើតមានបញ្ហានៅថ្ងៃមុខទៀត ។ ទោះជាពួករ៉ូម៉ាំងមិនចង់វាយដល់ស្លាប់ ក៏ជួនកាលអាចបណ្ដាលឱ្យស្លាប់បានដែរ (មើលការពន្យល់ មក ១៥:១៥) ។

**២៣:១៧** ព្រះគម្ពីរអង់គ្លេសបកប្រែថ្មីមួយចំនួនពុំមានខនេះទេ ។ ខនេះគឺត្រូវនឹង មថ ២៧:១៥ និង មក ១៥:៦ ។

**២៣:១៨** *បារ៉ាបាស* មានន័យថា "កូនរបស់ឪពុក" (មើលការពន្យល់ មថ ២៧:១៦) ។ លោកពីឡាត់បានឱ្យគេជ្រើសរើសរវាងព្រះយេស៊ូវ និងជនឧក្រិដ្ឋម្នាក់ដែលពិតជាអាក្រក់ហើយគ្រោះថ្នាក់ ។

**២៣:១៩** *ការបះបោរ ...សំឡាប់គេ* បច្ចុប្បន្នពុំមានគេដឹងថាការបះបោរនេះជាការបះបោរអ្វីទេ ប៉ុន្តែ គ្រាន់តែដឹងថាមានការសម្លាប់មនុស្សនៅក្នុងការបះបោរនោះ ដែលបង្ហាញពីកម្រិតនៃទោសរបស់គាត់ (យហ ១៨:៤០ និងការពន្យល់) ។

**២៣:២២** *៣ដង* មើលខ.៤,១៤ ។

**២៣:២៥** *ប្រគល់ព្រះយេស៊ូវទៅតាមចិត្តគេប្រាថ្នាវិញ* រហូតមកដល់ខនេះ លោកពីឡាត់បានប្រគល់ព្រះយេស៊ូវឱ្យទៅពួកទាហាន ដើម្បីធ្វើទារុណកម្មរួចទៅហើយ មុនពេលដែលទ្រង់ត្រូវគេកាត់ទោស (យហ ១៩:១–៥) ។ ហើយខនេះបង្ហាញថា លោកពីឡាត់បានប្រគល់ព្រះយេសូវឱ្យគេយកទ្រង់ទៅឆ្កាងហើយ ។

**២៣:២៦** *ស៊ីម៉ូន* កូនរបស់គាត់មានអ័លេក្សានត្រុស និងរូភូស (មក ១៥:២១ និងការពន្យល់) ប្រាកដជាមានលឺឈ្មោះក្នុងចំណោមគ្រីស្ទបរិស័ទនៅពេលក្រោយមកទៀត ហើយប្រហែលជាមានទំនាក់ទំនងជាមួយនឹងព្រះវិហារនៅក្រុងរ៉ូម (រម ១៦:១៣) ។ *សាសន៍គីរេន* ឬអ្នកគីរេន ។ គីរេនគឺជាក្រុងឈានមុខរបស់ស្រុកលីប៊ី ដែលនៅភូមិភាគខាងលិចនៃប្រទេសអេស៊ីព្ទ (មើលការពន្យល់ កច ៦:៩) ។ *ដាក់ ឱ្យគាត់លីឈើឆ្កាង* មើលការពន្យល់ មក ១៥:២១ ។

**២៣:២៧–២៨** វគ្គនេះឃើញមានតែក្នុងដំណឹងល្អនេះប៉ុណ្ណោះ ។ ព្រះគម្ពីរលូកាមាននិយាយសង្កត់ធ្ងន់ ពីតួនាទីរបស់ស្ត្រី ក្នុងរឿងដំណឹងល្អផងដែរ (មើលសេចក្ដីផ្ដើមត្រង់ ចរិតលក្ខណៈ) ។

មានបន្ទូលនឹងពួកស្ត្រីទាំងនោះថា កូនស្រីក្រុងយេរូសា
ឡិមអើយ កុំយំនឹងខ្ញុំឡើយ ឱ្យយំនឹងខ្លួនអ្នករាល់គ្នា ហើយ
និងកូនចៅរបស់អ្នករាល់គ្នាវិញចុះ[អ] ២៩ដ្បិតមើលនឹងមាន
គ្រាមកដល់ ដែលគេនឹងថា មានពរហើយ ពួកស្រីអារ
និងពោះដែលមិនកើតកូន ហើយដោះដែលមិនបំបៅកូន[ក]
៣០នៅគ្រានោះ គេនឹងចាប់តាំងនិយាយទៅភ្នំធំថា សូមឱ្យ
រលំមកលើយើងវិញហើយទៅភ្នំតូចថា សូមគ្របមកលើ
យើងចុះ[ខ] ៣១ព្រោះបើគេធ្វើការទាំងនេះ ដល់ដើមឈើ
ស្រស់នោះតើនឹងកើតអ្វីដល់ដើមឈើស្ងួតវិញ[គ] ។
៣២គេក៏នាំចោរកំណាច២នាក់ ទៅសំឡាប់ជាមួយនឹងទ្រង់
ដែរ[ឃ] ៣៣កាលមកដល់កន្លែងដែលហៅថា ភ្នំរលាក្បាល
ហើយ គេឆ្កាងទ្រង់នៅទីនោះ ព្រមទាំងចោរកំណាចផង
ម្នាក់ខាងស្តាំ ម្នាក់ខាងឆ្វេងទ្រង់ ៣៤ឯព្រះយេស៊ូវ ទ្រង់មាន
បន្ទូលថា ឱព្រះវរបិតាអើយ[ង] សូមអត់ទោសដល់អ្នកទាំង
នេះផង ដ្បិតគេមិនដឹងជាគេធ្វើអ្វីទេ[ច] គេក៏នាំគ្នាធ្វើ
ឆ្នោតចាប់ព្រះពស្ត្រទ្រង់ចែកគ្នា[ឆ] ៣៥ឯបណ្តាជនដែល
ឈរមើល នឹងពួកនាម៉ឺន ដែលឈរជាមួយ ក៏បន្តុះទ្រង់[ជ]ថា
វាបានជួយសង្គ្រោះមនុស្សឯទៀត បើវាជាព្រះគ្រីស្ទ ជា
អ្នករើសតាំងរបស់ព្រះមែន នោះឱ្យវាជួយសង្គ្រោះខ្លួន
វាទៅ[ឈ] ៣៦ពួកទាហានក៏បង្អាប់ទ្រង់ដែរ[ញ] ហើយគេយក
ទឹកខ្មេះ[ដ] ចូលទៅជិតថ្វាយទ្រង់ ដោយថា ៣៧បើឯងជាស្តេច
សាសន៍យូដាមែន[ឋ] ចូរជួយសង្គ្រោះខ្លួនចុះ ៣៨ហើយនៅពី
លើទ្រង់មានអក្សរជាភាសាក្រេក ឡាតាំង នឹងហេព្រើរថា
«នេះជាស្តេចសាសន៍យូដា[ឌ]» ។
៣៩រីឯចោរកំណាចម្នាក់ដែលជាប់ឆ្កាង វាប្រមាថមើល
ងាយដល់ទ្រង់ថា បើឯងជាព្រះគ្រីស្ទពិត នោះចូរជួយ
សង្គ្រោះខ្លួនឯង ហើយនឹងយើងផង[ឍ] ៤០ប៉ុន្តែម្នាក់ទៀត
ឆ្លើយបន្ទោសវាថា តើឯងមិនខ្លាចព្រះ ទេឬអី ដ្បិតឯងក៏
ជាប់ទោសដូចគ្នា ៤១គេធ្វើទោសយើងត្រូវហើយ ដ្បិត
យើងត្រូវទោសចំពោះការដែលយើងបានប្រព្រឹត្ត ប៉ុន្តែ
ព្រះអង្គនេះមិនបានធ្វើខុសអ្វីសោះ[ណ] ៤២រួចអ្នកនោះទូល
ព្រះយេស៊ូវថា ព្រះអម្ចាស់អើយ កាលណាចូលទៅក្នុងនគរ
ទ្រង់ សូមនឹកចាំពីទូលបង្គំផង[ត] ៤៣ព្រះយេស៊ូវមានបន្ទូល
ទៅថា ខ្ញុំប្រាប់អ្នកជាប្រាកដថា ថ្ងៃនេះ អ្នកនឹងនៅក្នុងស្ថាន

**២៣:២៨** អ លក ១៩:៤១–៤៤ ២១:២៣,២៤
**២៣:២៩** ក មថ ២៤:១៩
**២៣:៣០** ខ អស ២:១៩ ហស ១០:៨ វវ ៦:១៦
**២៣:៣១** គ អគ ២០:៤៧
**២៣:៣២** ឃ អស ៥៣:១២ មថ ២៧:៣៨ មក ១៥:២៧ យហ ១៩:១៨
**២៣:៣៤** ង មថ ១១:២៥ ច មថ ៥:៤៤ ឆ ទដ ២២:១៨
**២៣:៣៥** ជ ទដ ២២:១៧ ឈ អស ៤២:១
**២៣:៣៦** ញ ទដ ២២:៧ ដ ទដ ៦៩:២១ មថ ២៧:៤៨
**២៣:៣៧** ឋ លក ៤:៣,៩ **២៣:៣៨** ឌ មថ ២:២ **២៣:៣៩** ឍ ខ.៣៥,៣៧
**២៣:៤១** ណ ខ.៤ **២៣:៤២** ត មថ ១៦:២៧

**២៣:២៨** *យំនឹងខ្លួនអ្នករាល់គ្នា ហើយនឹងកូនចៅរបស់អ្នករាល់គ្នា* ពីព្រោះប្រមាណជា៤០ឆ្នាំទៀតនឹងកើតមានទុក្ខវេទាយ៉ាងខ្លាំង នៅពេលដែលចក្រភពរ៉ូម៉ាំងឡោមព័ទ្ធទីក្រុងយេរូសាឡិម ព្រមទាំងកម្ទេចព្រះវិហារនោះចោលផង ។

**២៣:២៩** *មានពរហើយពួកស្រី* ពេលនោះការគ្មានកូនប្រសើរជាងការដែលមានកូនដែលត្រូវរងការឈឺចាប់(យហ ១៦:១–៤ ១កថ ៧:២៥–៣៥)

**២៣:៣០** *រលំមកលើយើងវិញ* គឺនៅពេលនោះបណ្តាជននឹងស្វែងរកការបំផ្លិចបំផ្លាញខ្លួនឯងនៅក្នុងសេចក្តីស្លាប់ ជាជាងនៅទ្រាំឈឺចាប់ និងការទទួលទោសបែបនោះ (ហស ១០:៨ វវ ៦:១៦ និងការពន្យល់)។

**២៣:៣១** *ដើមឈើស្រស់ . . . ស្ងួត* បើគេប្រព្រឹត្តបែបយ៉ាងនេះចំពោះព្រះមែស៊ី តើសេចក្តីវេទនានឹងត្រូវត្រឡប់មករកពួកគេវិញខ្លាំងប៉ុណ្ណា នៅពេលដែលទ្រង់ត្រូវដកចេញពីពួកគេទៅ ហើយពួកគេត្រូវឈឺចាប់ដោយសារការបដិសេធ នៅក្នុងរយៈពេលស្ងួតនោះ ?

**២៣:៣៣** *ភ្នំរលាក្បាល* ឈ្មោះជាភាសាឡាតាំងគឺ "កាល់វ៉ារី" ហើយជាភាសាក្រិកគឺ "គាល់កូថា" (មថ ២៧:៣៣ មក ១៥:២២)។ *ឆ្កាង* មើលការពន្យល់ មក ១៥:២៤ ។

**២៣:៣៤** *គេមិនដឹងជាគេធ្វើអ្វីទេ* សូមធៀបជាមួយ កច ៣:១៧ និងការពន្យល់ ។ *ចែកគ្នា* ពិជ្ឈឃាតអាចយករបស់ទ្រព្យអ្វីដែលអ្នកទោសដែលត្រូវឆ្កាងមានជាប់នឹងខ្លួន ។ ការចាប់ឆ្នោតចាប់ព្រះពស្ត្រទ្រង់ចែកគ្នានេះបង្ហាញថា ពួកទាហាន (យហ ១៩:២៣–២៤) កំពុងតែធ្វើឱ្យសម្រេចព្រះបន្ទូលនៅក្នុង ទដ ២២:១៨ (ប៉ុន្តែ សូមមើលការពន្យល់ ទដ ២២ និងការពន្យល់ ទដ ២២:១៧,២០–២១)។

**២៣:៣៥** *អ្នករើសតាំងរបស់ព្រះ* មើលការពន្យល់ ៩:៣៥ ។

**២៣:៣៦** *ទឹកខ្មេះ* ទឹកខ្មេះដែលគេប្រើនៅពេលនោះ ផលិតពីស្រាទំពាំងបាយជូរ ហើយស្រាទំពាំងបាយជូរ (ប្រភេទជូរ) របស់ពួកកម្មករ និងពួកទាហានសាមញ្ញ។ ព្រះយេស៊ូវបានបដិសេធមិនព្រមទទួលភេសជ្ជៈដែលជាថ្នាំបំបាត់ការឈឺចាប់នោះទេ(មថ ២៧:៣៤ មក ១៥:២៣ និងការពន្យល់) ប៉ុន្តែក្រោយមកគេបានថ្វាយវាទៅទ្រង់ នៅពេលដែលទ្រង់មានបន្ទូលថា ទ្រង់ស្រេកទឹកណាស់(យហ ១៩:២៨–៣០ និងការពន្យល់)។ លោកលូកាបានបង្ហាញថា ពួកគេបានថ្វាយទៅទ្រង់ក្នុងន័យចំអកឱ្យតែប៉ុណ្ណោះ ។

**២៣:៣៨** *មានអក្សរ* គឺអក្សរដែលគេចារនៅលើក្តារបន្ទះតូចមួយ សម្រាប់ប្រាប់ពីបទឧក្រិដ្ឋ ដែលអ្នកទោសនោះត្រូវទទួលទោសប្រហារជីវិត ។ ការចារអក្សរ នេះគឺជាវិធីដែលលោកពីឡាត់ប្រើដើម្បីចំអកឱ្យមេដឹកនាំសាសន៍យូដាក៏ដូចជាប្រកាសពីបទអ្វីដែលគេចោទព្រះយេស៊ូវ ។ *នេះជាស្តេចសាសន៍យូដា* មើលការពន្យល់ មក ១៥:២៦ ។

**២៣:៣៩** *ចោរកំណាចម្នាក់* មើលការពន្យល់ មក ១៥:៣២ ។

**២៣:៤៣** *ស្ថានបរមសុខ* នៅក្នុងព្រះគម្ពីរសេបទូអាជិន ([Septuagint] ព្រះគម្ពីរសញ្ញាចាស់ បកប្រែជាភាសាក្រិក មុនសម័យគ្រីស្ទបរិស័ទ) គេប្រើពាក្យនេះសំដៅទៅលើសួនច្បារ (លប ២:៨–១០ និងពន្យល់ លប ២:៨) ឬព្រៃ(នហ ២:៨ និងការពន្យល់) ប៉ុន្តែនៅក្នុងព្រះគម្ពីរសញ្ញាថ្មីវិញ (មានប្រើតែក្នុងខនេះ និង ២កថ ១២:៤ វវ ២:៧ [មើលការពន្យល់]) គេប្រើពាក្យនេះសំដៅទៅលើទីកន្លែងនៃព្រះពរ និងការសម្រាកនៅក្នុងចន្លោះសេចក្តីស្លាប់ និងការរស់ឡើងវិញ (សូមធៀបនឹង លក ១៦:២២ ២កថ ១២:២)។

បរមសុខជាមួយនឹងខ្ញុំដែរ[ច]។

## ការសុគតរបស់ព្រះយេស៊ូវ

*២៣:៤៤-៤៩ = មថ ២៧:៤៥-៥៦ មក ១៥:៣៣-៤១ យហ ១៩:២៩-៣០*

៤៤ពេលនោះ ប្រហែលជាថ្ងៃត្រង់ហើយ ស្រាប់តែកើត
មានងងឹត នៅគ្របពេញលើផែនដី ដរាបដល់ម៉ោង៣
រសៀល[ទ] ៤៥ថ្ងៃត្រឡប់ទៅជាងងឹត ហើយវាំងនន[ធ]ក្នុងព្រះ
វិហារ ក៏រហែកចំពាក់កណ្ដាល[ន] ៤៦នោះព្រះយេស៊ូវស្រែក
ឡើងជាខ្លាំង[ប]ថា ឱព្រះវរបិតាអើយ ទូលបង្គំសូមប្រគល់
វិញ្ញាណដល់ព្រះហស្តទ្រង់វិញ[ផ] កាលមានបន្ទូលពាក្យ
ទាំងនេះរួចហើយ នោះទ្រង់ផុតដង្ហើមទៅ[ព]។
៤៧កាលមេទ័ពបានឃើញការដែលកើតមក នោះក៏ពោល
សរសើរដល់ព្រះ[ភ] ហើយថា មនុស្សនេះសុចរិតពិតមែន
៤៨ឯបណ្ដាមនុស្សទាំងហ្វូង ដែលប្រជុំគ្នាមើលការនោះ
កាលគេបានឃើញការដែលកើតឡើងដូច្នោះ ក៏វិលទៅវិញ
ទាំងគក់ដើមទ្រូងបណ្ដើរ[ម] ៤៩ឯពួកអ្នកដែលស្គាល់ទ្រង់ នឹង
ពួកស្រីៗដែលតាមទ្រង់មកពីស្រុកកាលីឡេ[យ] គេក៏ឈរ
មើលពីចំងាយ[រ]។

## ការបញ្ចុះព្រះសពព្រះយេស៊ូវ

*២៣:៥០-៥៦ = មថ ២៧:៥៧-៦១ មក ១៥:៤២-៤៧ យហ ១៩:៣៨-៤២*

៥០ហើយមើល មានមនុស្សម្នាក់ឈ្មោះយ៉ូសែប ជាពួក
ក្រុមជំនុំ ជាមនុស្សល្អ ត្រឹមត្រូវ សុចរិត ៥១(លោកនេះ
មិនបានចូលដៃ ចូលគំនិត ជាមួយនឹងគេទេ) លោកនៅឯ
អើរីម៉ាថេ ជាភូមិសាសន៍យូដា ហើយក៏រង់ចាំនគរព្រះ
ដែរ[ល] ៥២លោកទៅឯលោកពីឡាត់ ដើម្បីនឹងសូមព្រះសព
ព្រះយេស៊ូវ ៥៣កាលបានយកព្រះសពចុះមកហើយ នោះក៏រុំ
នឹងសំពត់ ទេសឯក នាំទៅបញ្ចុះក្នុងផ្នូរដាប់ក្នុងថ្ម ដែលមិន
ទាន់មាន បញ្ចុះខ្មោចណានៅឡើយ ៥៤ថ្ងៃនោះជាថ្ងៃរៀប
ចំ[វ]ហៀប នឹងចូលថ្ងៃឈប់សំរាកហើយ ។

**២៣:៤៣** ច ២កថ ១២:៣,៤ វវ ២:៧
**២៣:៤៤** ទ អម ៨:៩
**២៣:៤៥** ធ នក ២៦:៣១-៣៣ ហាព ៩:៣,៨ ន ហាព ១០:១៩,២០
**២៣:៤៦** ប មថ ២៧:៥០ ផ ទដ ៣១:៥ ១ពត ២:២៣ ព យហ ១៩:៣០
**២៣:៤៧** ភ មថ ៩:៨
**២៣:៤៨** ម លក ១៨:១៣
**២៣:៤៩** យ លក ៨:២ រ ទដ ៣៨:១១
**២៣:៥១** ល លក ២:២៥,៣៨
**២៣:៥៤** វ មថ ២៧:៦២

**២៣:៤៤** *ប្រហែលជាថ្ងៃត្រង់... ម៉ោង៣រសៀល* គឺត្រូវនឹងម៉ោងទី៦រហូតដល់ម៉ោងទី៩(ម៉ោងរបស់ពួកយូដា)។ ព្រះគម្ពីរយ៉ូហានបានប្រាប់ឱ្យដឹងថា លោកពីឡាត់បានធ្វើការសម្រេចទោសព្រះយេស៊ូវ នៅពេលប្រហែលជាថ្ងៃត្រង់ (មិនទាន់ដល់ពេលថ្ងៃត្រង់ដែលត្រូវនឹងម៉ោងទី៦ ម៉ោងរបស់ពួកយូដានៅឡើយទេ) (យហ ១៩:១៤ និងការពន្យល់) ហើយព្រះយេស៊ូវត្រូវគេឆ្កាងនៅម៉ោងទី៣ (ម៉ោង៩ ព្រឹក [មក ១៥:២៥])។

**២៣:៤៥** *វាំងននក្នុងព្រះវិហារ* គឺវាំងននដែលខ័ណ្ឌចែករវាងកន្លែងបរិសុទ្ធ និងកន្លែងបរិសុទ្ធបំផុតរបស់ព្រះវិហារ ។ ការរហែកវាំងននេះជានិមិត្តរូបតំណាង ឱ្យសេចក្ដីដែលថា ព្រះគ្រីស្ទទ្រង់បានបើកផ្លូវឱ្យមនុស្សលោកចូលទៅចំពោះព្រះដោយផ្ទាល់ខ្លួនគេម្នាក់ហើយ(ហាព ៩:៣,៨ ១០:១៩-២២ និងការពន្យល់ ១០:១៩-២០)។

**២៣:៤៧** *ពោលសរសើរដល់ព្រះ* (១:៦៤ និងការពន្យល់) អាចមានន័យថា ពីព្រោះមេទ័ពម្នាក់នេះបានឃើញព្រះនៅទីសាធារណៈ គាត់ក៏បានប្រកាសថាព្រះយេស៊ូវទ្រង់គ្មានទោស ដោយសារទីសំគាល់ពីលើមេឃប្រកបដោយព្រះចេស្ដា ឬអាចថា ដោយគាត់មានការភ័យខ្លាចយ៉ាងខ្លាំងចំពោះព្រះ(មថ ២៧:៥៤) ដែលជាចៅក្រមដ៏ខ្ពស់បំផុត គាត់ក៏ពោលសរសើរព្រះដើម្បីឱ្យខ្លួនគាត់រួចពីការដាក់ទោស ពីបទប្រហារជីវិតដោយអយុត្តិធម៌ ។ *មនុស្សនេះសុចរិតពិតមែន* ឬ"មនុស្សនេះពិតជាមនុស្សសុចរិតមែន"។ កណ្ឌគម្ពីរម៉ាថាយ និងព្រះគម្ពីរម៉ាកុសបានកត់ត្រាទុកពាក្យសំដីរបស់មេទ័ពម្នាក់នោះដែលថា "មនុស្សនេះពិតជាព្រះរាជបុត្រានៃព្រះមែន" ហើយឃ្លានេះមានអត្ថន័យមិនខុសពីឃ្លា "មនុស្សនេះសុចរិតពិតមែន" ដែលមានប្រើនៅក្នុងព្រះគម្ពីរលូកានេះឡើយ ដូចនេះការសំខាន់មិនស្ថិតនៅត្រង់ថា តើមេទ័ពម្នាក់នោះចង់ប្រើឃ្លាមួយណានោះឡើយ (មើលពន្យល់ មថ ២៧:៥៤)។ អ្នកនិពន្ធព្រះគម្ពីរដំណឹងល្អទាំងឡាយបានបង្ហាញថា ការប្រកាសរបស់មេទ័ពម្នាក់នោះ គឺជាការប្រកាសពីភាពបរិសុទ្ធរបស់ព្រះយេស៊ូវគ្រីស្ទ ហើយដោយសារគាត់គឺជាមន្ត្រីរាជការនៃចក្រភពរ៉ូម៉ាំង ដែលទទួលខុសត្រូវលើការឆ្កាងនោះ ការធ្វើបន្ទាល់របស់គាត់ពិតជាមានសារៈសំខាន់ណាស់ (មើលសេចក្ដីប្រកាសរបស់លោកពីឡាត់ ខ.៤,១៤ មថ ២៧:២៣-២៤)។

**២៣:៤៨** *គក់ដើមទ្រូងបណ្ដើរ* គឺពួកគេកំពុងបង្ហាញពីការឈឺចាប់ក្នុងចិត្ត ការកើតទុក្ខ ឬការស្ដាយក្រោយ (១៨:១៣)។

**២៣:៤៩** *ពួកស្រីៗ... ស្រុកកាលីឡេ* មើល មក ១៥:៤០ យហ ១៩:២៥ លក ២៤:១០ និងការពន្យល់ ។

**២៣:៥០** *យ៉ូសែប ជាពួកក្រុមជំនុំ* គាត់មិនបានចូលរួមប្រជុំជាមួយនឹងក្រុមជំនុំ (២២:៦៦) ឬគាំទ្រការយកព្រះយេស៊ូវទៅឆ្កាងឡើយ(ខ.៥១)។ តាម មក ១៤:៦៤ គេអាចសន្និដ្ឋានបានថា គាត់ពុំមានវត្តមានទេ នៅពេលដែលគេទាំងអស់គ្នាបាន "ស្រុះគ្នា"សម្រេចទោសព្រះយេស៊ូវនោះ ។

**២៣:៥១** *អើរីម៉ាថេ* មើលការពន្យល់ មថ ២៧:៥៧ ។ *រង់ចាំនគរព្រះ* មើល ២:២៥ និងការពន្យល់ ។

**២៣:៥២** សាកសពរបស់អ្នកទោសដែលបានប្រហារជីវិតហើយជាញឹកញាប់ត្រូវគេទុកចោលកណ្ដាលវាល ឬនៅក្នុងកន្លែងថោកទាបរបស់វាលអ្នកក្រ ។ ចំពោះសាច់ញាតិដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងសព ដូចជាម្ដាយជាដើម ប្រហែលជាទៅសូមសាកសពនោះ ។ ដូចនេះការដែលលោកយ៉ូសែប ដែលជាពួកក្រុមជំនុំបានទៅឯលោកពីឡាត់ ដើម្បីសូមព្រះសពព្រះយេស៊ូវបានបង្ហាញពីសេចក្ដីក្លាហានរបស់គាត់ហើយ ។

**២៣:៥៣** *មិនទាន់មានបញ្ចុះខ្មោចណានៅឡើយ* គេធ្វើផ្នូរនោះដោយដាប់ចូល ជ្រៅទៅក្នុងកូនភ្នំថ្មកំបោរមួយ ក្នុងចំណោមកូនភ្នំថ្មកំបោរជាច្រើននៅក្បែរក្រុងយេរូសាឡិម ហើយតាមធម្មតាគេធ្វើផ្នូរប្រភេទនោះសម្រាប់ដាក់សាកសពច្រើន ចំពោះផ្នូរមួយនេះគេបានធ្វើវាហើយមែន ប៉ុន្តែ មិនទាន់បានប្រើវានៅឡើយទេ (មើលការពន្យល់ ១៩:៣០ មក ១៥:៤៦)។

**២៣:៥៤** *ថ្ងៃរៀបចំ* គឺនៅថ្ងៃសុក្រជាថ្ងៃរៀបចំចូលថ្ងៃឈប់សម្រាក ដែលជាថ្ងៃបន្ទាប់ ។ គេអាចធ្វើការរៀបចំនេះសម្រាប់ថ្ងៃបុណ្យរំលងផងដែរ ប៉ុន្តែ ដោយថ្ងៃបន្ទាប់ជាថ្ងៃឈប់សម្រាក នោះបានសេចក្ដីថាថ្ងៃរៀបចំនោះ

៥៥ឯពួកស្រីៗ ដែលមកពីស្រុកកាលីឡេ[ស]ជាមួយនឹងទ្រង់
គេក៏តាមទៅឃើញផ្នូរ និងសណ្ឋានដែលគេបញ្ចុះព្រះសព
ទ្រង់ដែរ ៥៦រួចគេវិលទៅវិញរៀបគ្រឿងក្រអូប[ហ] និងប្រេង
អប់ តែគេឈប់នៅថ្ងៃឈប់សំរាកតាមបញ្ញត្តិសិន[ឡ] ។

### ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ

*២៤:១–១០ = មថ ២៨:១–៨ មក ១៦:១–៨ យហ ២០:១–៨*

**២៤** ១លុះដល់ថ្ងៃទី១ក្នុងអាទិត្យ កាលភ្លឺស្រាងៗ នោះគេ
យកគ្រឿងក្រអូបដែលរៀបចំនោះ[អ] នាំគ្នាទៅឯផ្នូរ មាន
អ្នកខ្លះទៀតទៅជាមួយដែរ ២គេក៏ឃើញថ្មបានរមៀល
ចេញពីមាត់ផ្នូរហើយ ៣តែកាលចូលទៅ នោះមិនឃើញ
ព្រះសពព្រះអម្ចាស់យេស៊ូវទេ[ក] ៤កំពុងដែលមានសេចក្តី
ងឿងឆ្ងល់អំពីការនោះ ស្រាប់តែឃើញមាន២នាក់ស្លៀក
ពាក់ភ្លឺព្រោងព្រាយ[ខ]ឈរជិតគេ ៥គេក៏ភ័យស្លុត ហើយក្រាប
ផ្កាប់មុខនឹងដី រួចអ្នកនោះនិយាយមកគេថា ហេតុអ្វីបានជា
មករកព្រះអង្គ ដែលមានព្រះជន្មរស់ នៅក្នុងទីខ្មោចស្លាប់
ដូច្នេះ ៦ទ្រង់មានព្រះជន្មរស់ឡើងវិញហើយមិនគង់នៅទី
នេះទេ ចូរនឹកចាំពីព្រះបន្ទូល ដែលទ្រង់មានបន្ទូលនឹងអ្នក
រាល់គ្នា ក្នុងកាលដែលនៅស្រុកកាលីឡេ[គ]នៅឡើយថា
៧កូនមនុស្ស[ឃ]ត្រូវគេបញ្ជូនទៅក្នុងកណ្តាប់ដៃនៃមនុស្ស
មានបាបឱ្យគេឆ្កាង ហើយ៣ថ្ងៃក្រោយមកនឹងរស់ឡើង
វិញ[ង] ៨នោះគេក៏នឹកឃើញពីព្រះបន្ទូលទ្រង់[ច] ៩លុះវិលមកពី
ផ្នូរវិញ នោះក៏ប្រាប់ពីការទាំងនោះដល់ពួក១១នាក់ នឹង
អ្នកឯទៀតទាំងប៉ុន្មានដែរ ១០រីឯពួកស្ត្រីដែលប្រាប់ពីការ
ទាំងនោះដល់ពួកសាវក[ឆ] នោះគឺ ម៉ារា ពីស្រុកម៉ាក់ដាឡា១

**២៣:៥៥** ស ខ.៤៩
**២៣:៥៦** ហ មក ១៦:១ លក ២៤:១
ឡ ឯក ១២:១៦ ២០:១០
**២៤:១** អ លក ២៣:៥៦
**២៤:៣** ក ខ.២៣,២៤
**២៤:៤** ខ យហ ២០:១២
**២៤:៦** គ មថ ១៧:២២,២៣ លក ៩:២២ ២៤:៤៤
**២៤:៧** ឃ មថ ៨:២០
ង មថ ១៦:២១
**២៤:៨** ច យហ២:២២
**២៤:១០** ឆ មក ៦:៣០

ជាថ្ងៃសុក្រ (មើលការពន្យល់ មថ ២៧:៦២) ។

**២៣:៥៥** *ពួកស្រីៗ* មើលខ.៤៩ និងការពន្យល់ និងសូមផ្ទៀបនឹង ៨:២–៣ និងការពន្យល់ ។ ពួកស្រីៗស្រុកកាលីឡេទាំងនោះបានតាមលោកយ៉ូសែបទៅមើលផ្នូរព្រះយេស៊ូវផ្ទាល់ភ្នែក ដូចនេះពួកគេប្រាកដជាដឹងយ៉ាងច្បាស់ពីកន្លែងដែលត្រូវរកព្រះសព នៅពេលដែលពួកគេត្រឡប់មកឯផ្នូរទ្រង់វិញបន្ទាប់ពីថ្ងៃឈប់សម្រាក ដោយមានគ្រឿងក្រអូប និងប្រេអប់មកជាមួយផង។ ពួកស្ត្រីទាំងនេះមិនអាចធ្វើការ "ធំ" សម្រាប់ព្រះយេស៊ូវបានឡើយ គឺពួកគេគ្មានការអនុញ្ញាតឱ្យធ្វើ បន្ទាល់ឱ្យទ្រង់នៅចំពោះមុខពួកក្រុមជំនុំយូដា និងពួកអភិបាលរ៉ូម៉ាំងឡើយ ប៉ុន្តែពួកគេបានធ្វើនូវអ្វីដែលពួកគេអាចធ្វើបាន គឺពួកគេបាននៅកន្លែងឆ្កាងទ្រង់ នៅពេលដែលពួកសិស្សភាគច្រើនបានរត់គេចខ្លួនបាត់ស្រមោលអស់ ហើយថែមទាំងបានត្រៀមខ្លួនរួចជាស្រេច ដើម្បីចាក់ប្រេងលើព្រះសពព្រះអម្ចាស់នៃពួកគេទៀតផង ។ ដោយសារតែការលះបង់របស់ពួកគេ ទើបធ្វើឱ្យពួកគេជាពួកមនុស្សដំបូង ដែលបានដឹងពីការរស់ពីសុគតឡើងវិញ ។

**២៣:៥៦** *គ្រឿងក្រអូប និងប្រេងអប់* គេប្រើក្រណាត់រាប់ម៉ែត្រ ហើយគ្រឿងក្រអូបដ៏ច្រើនសន្ធឹកសន្ធាប់ ដើម្បីរៀបចំបញ្ចុះសពនីមួយៗ។ គេប្រើជ័រល្វីងទេស និងក្រិស្នារាប់សិបគីឡូ នៅល្ងាចទ្រង់សុគត(យហ ១៩:៣៩ និងការពន្យល់)។ គ្រឿងក្រអូបទាំងនោះត្រូវបានទិញបន្ថែមទៀត សម្រាប់ការត្រឡប់របស់ពួកស្ត្រី ទៅឯផ្នូទ្រង់នៅក្រោយថ្ងៃឈប់សម្រាក (មើលការពន្យល់ មក ១៦:១)។

**២៤:១** *ថ្ងៃទី១ក្នុងអាទិត្យ* ពួកសាសន៍យូដាមានប្រពៃណីរាប់ថ្ងៃអាទិត្យចាប់ពីពេលថ្ងៃលិចនៅថ្ងៃសៅរ៍ ។ ពួកស្ត្រីទាំងនោះបានចាត់ចែងគ្រឿងក្រអូបនៅពេលថ្ងៃលិចនៅថ្ងៃសៅរ៍(មក ១៦:១ និងការពន្យល់) និងត្រៀមខ្លួនជាស្រេចដើម្បីនឹងទៅឯផ្នូរទ្រង់នៅថ្ងៃស្អែកឱ្យបានពីព្រលឹម ។ ពួកគេចាប់ផ្តើមចេញដំណើរ កាលកំពុងនៅងងឹតនៅឡើយ (យហ ២០:១ និងការពន្យល់) ហើយពួកគេបានទៅដល់ផ្នូរនៅពេលភ្លឺស្រាងៗ(មថ ២៨:១ មក ១៦:២)។

**២៤:២** *ថ្មបានរមៀលចេញពីមាត់ផ្នូរ* តាមធម្មតាគេបិទមាត់ផ្នូរ ដើម្បីការពារកុំឱ្យពួកបំផ្លាញទ្រព្យឯកជន ឬសាធារណៈ និងសត្វតិរិច្ឆានរំខានដល់សាកសព។ ប៉ុន្តែ ចំពោះពួករ៉ូម៉ាំងវិញ ពួកគេបានចាត់ឱ្យមានទាហាននៅយាមមាត់ផ្នូរព្រះយេស៊ូវ ដោយមានមូលហេតុផ្សេងពីនេះ (មថ ២៧:៦២–៦៦)។

**២៤:៤** *មាន២នាក់* អ្នកទាំងពីរនាក់នោះដូចមនុស្សប្រុស ប៉ុន្តែ គេអាចសំគាល់សម្លៀកបំពាក់របស់ពួកគេបាន(៩:២៩ កច១:១០ និងការពន្យល់)។ បទគម្ពីរដទៃៗទៀត បានហៅអ្នកទាំងពីរនោះថា ទេវតា (ខ.២៣ យហ ២០:១២ និងការពន្យល់) ទោះជាព្រះគម្ពីរម៉ាថាយគ្រាន់តែនិយាយថា "មានទេវតានៃព្រះអម្ចាស់"(ចំនួនមួយគឺមិនមែនពីរ មថ ២៨:២) ហើយព្រះគម្ពីរម៉ាកុសថា "ឃើញអ្នកកំលោះម្នាក់ពាក់អាវស"(មក ១៦:៥ និងការពន្យល់) ក៏គ្មានអ្វីចម្លែកទេ ពីព្រោះជាញឹកញាប់គេធ្វើការកត់សំគាល់ តែអំពីអ្នកដែលបាននិយាយប៉ុណ្ណោះ ។ ចំពោះការបកស្រាយខុសគ្នា អំពីឥរិយាបទនៃការដែលទេវតាអង្គុយក្នុង យហ ២០:១២ និងឈរក្នុង លក ២៤:៤ មិនបណ្តាលឱ្យបទគម្ពីរទាំងពីរប្រឆាំងគ្នាឡើយ គឺគ្រាន់តែបង្ហាញពីភាពមានម្ចាស់ការនៅក្នុងការនិពន្ធរៀងៗខ្លួនប៉ុណ្ណោះ ។

**២៤:៦** *កាលដែលនៅស្រុកកាលីឡេនៅឡើយ* ព្រះយេស៊ូវទ្រង់បានថ្លែងទំនាយពីការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ជាច្រើនលើកច្រើនសារមកហើយ(៩:២២ និងការពន្យល់) ប៉ុន្តែពួកសាវ័កមិនបានយល់ឬទទួលបានថា តើទ្រង់មានបន្ទូលពីអ្វីនោះឡើយ ។

**២៤:៩** *ដល់ពួក១១នាក់ នឹងអ្នកឯទៀតទាំងប៉ុន្មាន* ជួនកាលគេប្រើពាក្យ "ពួក១១នាក់" សំដៅទៅលើក្រុមរបស់ពួកសាវ័ក(កច ១:២៦ ២:១៤) នៅក្រោយពេលដែលយូដាសបានក្បត់ ។ យូដាសមិនមានជីវិតរស់នៅទៀតទេ នៅពេលដែលពួកសាវ័កជួបព្រះគ្រីស្ទដែលបានមានព្រះជន្មរស់ឡើងវិញ ប៉ុន្តែ ពួកសាវ័កនៅតែត្រូវហៅថា "ពួក១២"ដដែល (យហ ២០:២៤)។ *អ្នកឯទៀត* គឺពួកសិស្សដទៃទៀត ដែលភាគច្រើនមកពីស្រុកកាលីឡេ ។

**២៤:១០** *ម៉ារា ពីស្រុកម៉ាក់ដាឡា* មើលការពន្យល់ ៨:២ ។ ឈ្មោះនាងត្រូវគេដាក់មុនគេ នៅក្នុងបញ្ជីឈ្មោះស្ត្រីភាគច្រើន (មថ ២៧:៥៦ មក ១៥:៤០ និងការពន្យល់ ប៉ុន្តែ សូមផ្ទៀបនឹង យហ ១៩:២៥) និងជាអ្នកដែលបានឃើញព្រះយេស៊ូវមុនគេបង្អស់ បន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញ(យហ ២០:១៣–១៨)។ *យ៉ូអាន់* មើល ៨:៣ ។ ឈ្មោះនេះមាននិយាយតែក្នុងព្រះគម្ពីរលូកាត្រង់ចំនុចនេះប៉ុណ្ណោះ (មានតែព្រះគម្ពីរម៉ាកុសទេដែលមាន

ម៉ារា ជាម្ដាយយ៉ាកុប១ ហើយស្ត្រីឯទៀត[ដ] ដែលនៅជា
មួយគ្នាផង ១១ពួកសាវកមិនបានជឿទេ[ឈ] ដ្បិតពាក្យសំដី
របស់ស្រីៗនោះ មើលទៅដូចជារឿងលេងសុទ្ធ ១២តែ
ពេត្រុស គាត់ក្រោកឡើងរត់ទៅឯផ្នូរ ក៏ឱនមើលទៅ
ឃើញតែសំពត់ស្នបទទេ[ញ] រួចវិលទៅផ្ទះ[ដ]ទាំងអស្ចារ្យក្នុង
ចិត្តពីការដែលកើតមានមក ។

## តាមផ្លូវឆ្ពោះទៅភូមិអេម៉ោស

១៣រីឯនៅថ្ងៃនោះឯង មានពួកសិស្ស២នាក់កំពុងតែ
ដើរទៅឯភូមិអេម៉ោស ចំងាយ១១គីឡូម៉ែត្រពីក្រុងយេរូ
សាឡិមទៅ[ឋ] ១៤គេកំពុងតែនិយាយគ្នា ពីអស់ទាំងការដែល
កើតមានមកនោះ ១៥កាលគេកំពុងតែនិយាយគ្នា ហើយរិះ
គិតដូច្នេះ នោះព្រះយេស៊ូវក៏ចូលមក យាងជាមួយនឹងគេ
ដែរ[ឌ] ១៦តែភ្នែកគេត្រូវថ្លឹន មិនឱ្យស្គាល់ទ្រង់ទេ[ឍ]។
១៧ទ្រង់មានបន្ទូលទៅគេថា តើរឿងអ្វីដែលអ្នកនិយាយ
គ្នាកំពុងដែលដើរទៅ ដោយមានមុខស្រងូតដូច្នេះ ១៨ឯ
ម្នាក់ដែលឈ្មោះក្លេវប៉ាស[ណ] គាត់ឆ្លើយថា តើអ្នកស្នាក់នៅ
ក្នុងក្រុងយេរូសាឡិមតែម្នាក់ឯងទេឬអី បានជាមិនដឹងការ
ដែលកើតមកនៅគ្រានេះ ១៩ទ្រង់មានបន្ទូលថា តើការអ្វី
ហ្នឹង នោះគេឆ្លើយថា ដំណើរលោកយេស៊ូវ ពីស្រុកណា
សារ៉ែត[ត] ជាហោរា[ថ] ដែលការលោកធ្វើ នឹងពាក្យសំដីរបស់
លោក សុទ្ធតែមានឫទ្ធិ នៅចំពោះព្រះ នឹងបណ្ដាជនទាំង
ឡាយផង ២០ហើយពីបែបយ៉ាងណា ដែលពួកសង្គ្រាជ នឹង
ពួកនាម៉ឺនយើងខ្ញុំ បានបញ្ជូន[ទ]លោកទៅ ឱ្យជាប់ទោសដល់
ជីវិត ហើយឆ្កាងលោកផង ២១តែយើងខ្ញុំបានសង្ឃឹមថា គឺ
លោកនេះ ហើយជាព្រះដែលរៀបនឹងប្រោសលោះសាសន៍
អ៊ីស្រាអែលទាំងប៉ុន្មាន[ធ] ឥឡូវនេះ ក៏មានការនេះថែមទៀត
ដ្បិតនេះគំរប់៣ថ្ងៃហើយ[ន] តាំងពីការទាំងនោះកើតមក
២២ហើយមានស្ត្រីខ្លះក្នុងពួកយើងខ្ញុំបាននាំឱ្យឆ្ងល់ដែរ[ប]
ដោយបានទៅឯផ្នូរពីព្រលឹម ២៣តែរកសពលោកមិន
ឃើញសោះ ហើយគេមកប្រាប់យើងថា ឃើញទេវតាលេច
មកប្រាប់ថា លោករស់ឡើងវិញហើយ ២៤មានពួកយើង
ខ្ញុំខ្លះបានទៅឯផ្នូរដែរ ក៏ឃើញដូចជាពួកស្រីបានថាមែន
តែមិនបានឃើញរូបលោកទេ[ផ] ២៥នោះទ្រង់មានបន្ទូល
ទៅគេថា ឱមនុស្សឥតពិចារណា ហើយក្រនឹងជឿអស់
ទាំងសេចក្ដី ដែលពួកហោរាបានទាយទុកមកអើយ ២៦តើ
មិនគួរឱ្យព្រះគ្រីស្ទរងទុក្ខទាំងនោះ ហើយចូលទៅក្នុងសិរី
ល្អនៃទ្រង់វិញទេឬអី[ព] ២៧រួចទ្រង់ក៏ស្រាយន័យសេចក្ដី ដែល
ដំរូវដល់ទ្រង់[ភ] ពីក្នុងគម្ពីរទាំងឡាយ ឱ្យគេស្ដាចាប់តាំងពី

**២៤:១០** ដ លក ៨:១–៣
**២៤:១១** ឈ មក ១៦:១១
**២៤:១២** ញ យហ ២០:៣–៧
ដ យហ ២០:១០
**២៤:១៣** ឋ មក ១៦:១២
**២៤:១៥** ឌ ខ.៣៦
**២៤:១៦** ឍ យហ ២០:១៤ ២១:៤
**២៤:១៨** ណ យហ ១៩:២៥
**២៤:១៩** ត មក ១:២៤ ថ មថ ២១:១១
**២៤:២០** ទ លក ២៣:១៣
**២៤:២១** ធ លក ១:៦៨ ២:៣៨ ២១:២៨
ន មថ ១៦:២១
**២៤:២២** ប ខ.១–១០
**២៤:២៤** ផ ខ.១២
**២៤:២៦** ព ហព ២:១០ ១ពត ១:១១
**២៤:២៧** ភ មឡ ៣:១ យហ ១:៤៥

និយាយពីឈ្មោះសាឡូមេត្រង់ចំនុចនេះផងដែរ មក ១៦:១ និងការពន្យល់ មក ១៥:៤០)។ *ម៉ារា ជាម្ដាយយ៉ាកុប* មើល មក ១៦:១ ។ គាត់គឺជា"ម៉ារាម្នាក់ទៀត" នៃ មថ ២៨:១ (មើលការពន្យល់)។ អវត្តមានរបស់មាតាព្រះយេស៊ូវ ប្រហែលមកពីគាត់កំពុងនៅជាមួយសាវ័កយ៉ូហាន (សូមធៀបជាមួយនឹង យហ ១៩:២៧ និងការពន្យល់)។

**២៤:១២** *ពេត្រុស . . . រត់ទៅ* ដំណឹងល្អយ៉ូហាន(២០:៣–៩)បានប្រាប់ថា មានសាវ័ក ឬសិស្សម្នាក់ទៀតទៅជាមួយពេត្រុស គឺសាវ័កយ៉ូហាន ។

**២៤:១៣** *ពួកសិស្ស២នាក់* មានម្នាក់ឈ្មោះក្លេវប៉ាស(ខ.១៨)។

**២៤:១៥** *ព្រះយេស៊ូវទ្រង់យាង . . . យាងជាមួយនឹងគេដែរ* សូមមើលតារាងខាងក្រោម ។

**២៤:១៦** *មិនឱ្យស្គាល់ទ្រង់ទេ* គឺដោយអំណាចរបស់ព្រះអម្ចាស់ ដែលធ្វើឱ្យពួកគេមិនអាចមើលដឹងថាជាទ្រង់ ។

**២៤:១៨** ដំណឹងអំពីការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាងបានលេចឮពាសពេញទីក្រុងយេរូសាឡិមទាំងមូល ។ មកដល់ពេលនៃសប្ដាហ៍នៃបុណ្យរំលងនេះ ពួកសាសន៍យូដាដែលធ្វើដំណើរពីតំបន់ដែលស្ថិតនៅក្រោមចំណុះចក្រភពរ៉ូម៉ាំង មកកាន់ទីក្រុងនេះ បានដឹងពីការសុគតរបស់ទ្រង់ ពីព្រោះការសុគតរបស់ព្រះ យេស៊ូវមិនមែនជាព្រឹត្តការណ៍ដ៏តូចមួយនោះឡើយ ប៉ុន្តែគឺជាព្រឹត្តិការណ៍ដ៏សំខាន់បំផុតមួយ ដែលមិនត្រឹមតែមានឥទ្ធិពលលើពួកសិស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានធ្វើឱ្យជាតិសាសន៍ទាំងមូលមានចំណាប់អារម្មណ៍យ៉ាងខ្លាំង ។

**២៤:១៩** *ជាហោរា* ពួកគេបានទទួលស្គាល់ថា ព្រះយេស៊ូវទ្រង់គឺជាមនុស្សម្នាក់ដែលមកពីព្រះ ប៉ុន្តែ ក្រោយពីទ្រង់បានរស់ពីសុគតឡើងវិញហើយ ពួកគេទំនងជាមានការស្ទាក់ស្ទើរក្នុងការហៅទ្រង់ថាព្រះមែស៊ី ។

**២៤:២១** *ប្រោសលោះសាសន៍អ៊ីស្រាអែល* គឺពួកគេចង់មានន័យថា"ប្រោសលោះសាសន៍យូដាឱ្យរួចពីនឹមត្រួតត្រារបស់ចក្រភពរ៉ូម៉ាំង ហើយដឹកនាំសាសន៍យូដាចូលទៅក្នុងនគរព្រះ"(១:៦៨ ២:៣៨ ២១:២៨ និងការពន្យល់ ២:៣១ ទត ២:១៤ ១ពត ១:១៨ និងការពន្យល់)។ *គរប់៣ថ្ងៃ* គឺពួកគេចង់សំដៅលើជំនឿរបស់សាសនាយូដាដែលថា បន្ទាប់ពីស្លាប់បានបីថ្ងៃ ហើយព្រលឹងនឹងចាកចេញពីរូបកាយ ឬចង់សំដៅលើព្រះបន្ទូលរបស់ព្រះយេស៊ូវ ដែលទ្រង់មានបន្ទូលថាទ្រង់នឹងរស់ឡើងវិញនៅថ្ងៃទីបី(៩:២២)។

**២៤:២៣** *ឃើញទេវតា* មើលការពន្យល់ខ.៤ ។

**២៤:២៤** *ពួកយើងខ្ញុំខ្លះ* មើល ខ.១២ និងការពន្យល់ ។

**២៤:២៦** *ចូលទៅក្នុងសិរីល្អនៃទ្រង់* មើល ភល ២:៩–១១ ១ធថ ៣:១៦ និងធៀបនឹង ៩:២៦ ២១:២៧ ។

**២៤:២៧** *គម្ពីរលោកម៉ូសេ និងគម្ពីរពួកហោរា* គឺជារបៀបហៅព្រះគម្ពីរសញ្ញាចាស់ទាំងមូល(ខ.៤៤ និងការពន្យល់ ១៦:១៦,២៩)។ ព្រះយេស៊ូវទ្រង់បានមានបន្ទូលម្ដងទៀត ដល់ពួកសិស្សទាំងនោះអំពីព្រះគម្ពីរសញ្ញាចាស់ ដោយចាប់ផ្ដើមពីព្រះបន្ទូលសន្យាអំពីពូជ(៣:១៥) ហើយបាវបម្រើដែលរងទុក្ខនៅក្នុងព្រះគម្ពីរអេសាយ(ជំពូក៥៣) ហើយនិងចិត្តប្រកបដោយគុណនៅក្នុងព្រះគម្ពីរសាការី(សក ១២:១០) រហូតដល់ទូតនៃសេចក្ដីសញ្ញា

លោកម៉ូសេ[ម] និងគម្ពីរពួកហោរា[យ]រៀងមក ២៨នោះក៏ជិត
ដល់ភូមិដែលគេគិតទៅ ហើយទ្រង់ធ្វើដូចជាចង់យាង
បង្ហួស ២៩តែគេឃាត់ទ្រង់ ដោយពាក្យថា សូមនៅជាមួយ
នឹងយើងខ្ញុំសិន ពីព្រោះល្ងាច ថ្ងៃទាបណាស់ហើយ ដូច្នេះ
ទ្រង់ក៏យាងចូលទៅគង់ជាមួយនឹងគេ ៣០កាលគង់នៅតុជា
មួយគ្នា នោះទ្រង់យកនំបុ័ងមកប្រទានពរ រួចកាច់[រ]ប្រទាន
ទៅឱ្យគេ ៣១នោះភ្នែកគេបានបើកភ្លឺឡើង ហើយគេបាន
ស្គាល់ទ្រង់[ល] តែទ្រង់បាត់ពីមុខគេទៅភ្លាម ៣២នោះគេ
និយាយគ្នាថា តើយើងមិនមានសេចក្តីខ្វល់ខ្វាញ់នៅក្នុងចិត្ត[វ]
ក្នុងពេលដែលទ្រង់កំពុងតែមានបន្ទូលនឹងយើង ហើយ
សំដែងពីគម្ពីរ[ស] តាមផ្លូវនោះទេឬអី ៣៣នៅវេលានោះឯង
គេក៏ក្រោកឡើងត្រឡប់ទៅឯក្រុងយេរូសាឡិមវិញ ឃើញ
ពួកសាវក១១នាក់ នឹងអស់អ្នកដែលនៅជាមួយបានប្រជុំ
គ្នា កំពុងតែនិយាយថា ៣៤ព្រះអម្ចាស់[ហ] ទ្រង់មានព្រះជន្មរស់
ឡើងវិញមែន ក៏បានលេចមកឱ្យស៊ីម៉ូនឃើញ[ឡ] ៣៥នោះគេ
ក៏និយាយប្រាប់ពីការដែលកើតមានមកតាមផ្លូវ ហើយដែល
គេបានស្គាល់ទ្រង់ជាក់ ដោយទ្រង់កាច់នំបុ័ងឱ្យ[អ]។

## ព្រះយេស៊ូវលេចមកឯពួកសាវក

៣៦កាលកំពុងតែប្រាប់រឿងទាំងនោះ ស្រាប់តែព្រះ
យេស៊ូវទ្រង់ឈរនៅកណ្តាលគេ មានបន្ទូលថា សូមឱ្យ
អ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្តចុះ[ក] ៣៧តែគេ
ភ័យញ័រ ទាំងមានសេចក្តីស្ញែងខ្លាចជាខ្លាំង ដោយស្មាន
ថាជាខ្មោចលងវិញ[ខ] ៣៨ទ្រង់មានបន្ទូលទៅគេថា ហេតុអ្វី
បានជាវិលវល់ ហើយសង្ស័យក្នុងចិត្តដូច្នេះ ៣៩ចូរមើលមក
ដៃនឹងជើងខ្ញុំ[គ] ឱ្យបានដឹងថា នេះគឺខ្ញុំពិតមែន ចូរពាល់ខ្ញុំ
មើល ដ្បិតខ្មោចគ្មានសាច់ឬឆ្អឹង ដូចជាឃើញខ្ញុំនេះទេ
៤០លុះទ្រង់មានបន្ទូលដូច្នោះរួចហើយ នោះក៏បង្ហាញ
ព្រះហស្ត នឹងព្រះបាទទ្រង់ដល់គេ ៤១កាលគេមិនទាន់ជឿ
នៅឡើយ ដោយព្រោះមានសេចក្តីអំណរ នឹងសេចក្តី
អស្ចារ្យ នោះទ្រង់មានបន្ទូលថា នៅទីនេះ អ្នករាល់គ្នា
មានអ្វីបរិភោគឬទេ ៤២គេក៏យកត្រីអាំង១ដុំ នឹងសំណុំ
ឃ្មុំមកថ្វាយទ្រង់ ៤៣រួចទ្រង់យកទៅសោយនៅមុខគេ[ឃ]
៤៤ក៏មានបន្ទូលថា នេះហើយជាសេចក្តីដែលខ្ញុំបានប្រាប់
អ្នករាល់គ្នា កាលនៅជាមួយគ្នានៅឡើយ[ង] គឺថា ត្រូវតែ
សំរេច[ច]គ្រប់ទាំងសេចក្តីដែលបានចែងទុកពីខ្ញុំ ទោះក្នុង
ក្រិត្យវិន័យលោកម៉ូសេ[ឆ] ក្នុងទំនាយពួកហោរា[ជ] ឬក្នុងបទទំ
នុកដំកើងផង[ឈ] ៤៥នោះទ្រង់ក៏បើកបំភ្លឺសតិស្មារតីគេ ឱ្យបាន
យល់ក្នុងគម្ពីរ ៤៦ទ្រង់មានបន្ទូលទៅគេថា គឺសេចក្តីនេះហើយ
ដែលបានចែងទុកមក គឺថា ព្រះគ្រីស្ទត្រូវរងទុក្ខលំបាក[ញ]
ហើយនៅថ្ងៃទី៣ទ្រង់នឹងរស់ពីស្លាប់ឡើងវិញ[ដ] ៤៧ហើយត្រូវ
ឱ្យការប្រែចិត្ត នឹងសេចក្តីប្រោសឱ្យរួច បានប្រកាសប្រាប់

**២៤:២៧** ម អស ៧:១៤ ៩:៦ ៤០:១០, ១១,៥៣ អគ ៣៤:២៣ ដយ ៩:២៤ មីក ៧:២០ មឡ ៣:១ យ លប ៣:១៥ ជន ២១:៩ ចទ ១៨:១៥ **២៤:៣០** រ មថ ១៤:១៩ **២៤:៣១** ល ខ.១៦ **២៤:៣២** វ ទដ ៣៩:៣ ស ខ.២៧,៤៥ **២៤:៣៤** ហ លក ៧:១៣ ឡ ១កថ ១៥:៥ **២៤:៣៥** អ ខ.៣០:៣១ **២៤:៣៦** ក យហ ២០:១៩,២១,២៦ ១៤:២៧ **២៤:៣៧** ខ មក ៦:៤៩ **២៤:៣៩** គ យហ ២០:២៧ ១យហ ១:១ **២៤:៤៣** ឃ កច ១០:៤១ **២៤:៤៤** ង លក ៩:៤៥ ១៨:៣៤ ច មថ ១:២២ ១៦:២១ លក ៩:២២,៤៤ ១៨:៣១–៣៣ ២២:៣៧ ឆ ខ.២៧ ជ ខ.២៧ ឈ ទដ (ជំពូក ២,១៦,២២, ៦៩,៧២,១១០,១១៨) **២៤:៤៦** ញ មថ ១៦:២១ដ មថ ១៦:២១

(មឡ ៣:១)។ ព្រះគ្រីស្ទទ្រង់គឺជាប្រធានបទមួយដែលកណ្ឌគម្ពីរទាំងអស់បានលើកមកនិយាយ និងធ្វើឱ្យកណ្ឌគម្ពីរទាំងអស់មានទំនាក់ទំនងជាមួយគ្នា។ ព្រះយេស៊ូវប្រហែលជាមានបន្ទូលនៅតាមផ្លូវឆ្ពោះទៅកាន់ភូមិអេម៉ោស អំពីបទគម្ពីរមានដូចជា លប ៣,១២ ទដ ២២, ៦៩, ១១០ អស ៥៣ យរ ៣១ សក ៩,១៣ មឡ ៣ ។

**២៤:២៨** *ទ្រង់ធ្វើដូចជាចង់យាងបង្ហួស* បើសិនជាពួកគេមិនឃាងទ្រង់ទេ នោះទ្រង់នឹងបន្តទៅមុខទៀតដោយអង្គទ្រង់ ។

**២៤:៣១** *ភ្នែកគេបានបើកភ្លឺឡើង* គឺឃើញពីការអស្ចារ្យ (សូមផ្ទៀប ខ.១៦)។

**២៤:៣៣** *ពួកសាវក១១នាក់ និងអស់អ្នកដែលនៅជាមួយ* មើលពន្យល់ខ.៩។

**២៤:៣៦** *ព្រះយេស៊ូវទ្រង់ឈរនៅកណ្តាលគេ* គឺនៅក្នុងបន្ទប់បិទជិត(សូមមើល យហ ២០:១៩ និងតារាងក្នុងទំព័រខាងមុខ)។ គឺទ្រង់បង្ហាញព្រះកាយដែលរស់ឡើងវិញប្រកបដោយសិរីល្អ ។ *សូមឱ្យអ្នករាល់គ្នាប្រកបដោយសេចក្តីសុខសាន្ត* កាលពីមុនគេនិយាយពាក្យគួរសមដូចនេះតាមប្រពៃណី តែនៅពេលនេះ ការមានព្រះជន្មរស់ឡើងវិញបានធ្វើឱ្យសេចក្តីនេះមានអត្ថន័យថ្មីស្រឡាង ។

**២៤:៣៩** *ដៃនិងជើងខ្ញុំ* ជាភស្តុតាងបញ្ជាក់ថា ព្រះបាទ និងព្រះហស្តរបស់ទ្រង់បានត្រូវគេដំដែកគោលភ្ជាប់នឹងឈើឆ្កាង(មក ១៥:២៤ និងសូមផ្ទៀបនឹង យហ ២០:២០ និងការពន្យល់ យហ ២០:២៧)។

**២៤:៤២** *ត្រីអាំង១ដុំ* បង្ហាញថាទ្រង់មានសាច់ឈាមអាចទទួលអាហារបាន។

**២៤:៤៤** *ក្រិត្យវិន័យលោកម៉ូសេ ក្នុងទំនាយពួកហោរា ឬក្នុងបទទំនុកដំកើង* ផ្នែកទាំងបី នៃព្រះគម្ពីរសញ្ញាចាស់របស់សាសន៍ហេព្រើរ (កណ្ឌគម្ពីរទំនុកដំកើង ជាផ្នែកទីបីដែលសំខាន់បំផុត ដែលហៅថា"ប្រជុំការនិពន្ធ")បង្ហាញថា បទទំនាយអំពីព្រះគ្រីស្ទមាននិយាយនៅក្នុងគម្ពីរសញ្ញាចាស់ទាំងមូល ។

**២៤:៤៥** *បើកបំភ្លឺសតិស្មារតី* ដោយពន្យល់ពីគម្ពីរសញ្ញាចាស់(ខ.២៧)។

**២៤:៤៦** *រងទុក្ខលំបាក... នៅថ្ងៃទីបី... រស់ពីស្លាប់ឡើងវិញ* មើល ១កថ ១៥:៣–៤។ ព្រះគម្ពីរសញ្ញាចាស់បានអធិប្បាយអំពីព្រះមែស៊ីថា ជាអង្គដែលនឹងត្រូវរងទុក្ខដល់អស់ព្រះជន្ម(មើលការពន្យល់ ទដ ២២ និង អស ៥៣) ហើយរស់ពីសុគតឡើងវិញនៅថ្ងៃទី៣(សូមផ្ទៀប ទដ ១៦:៨–១១ ជាមួយនឹង កច ២:២៣–៣៣ និងការពន្យល់ មើល អស ៥៣:១០–១១ និងការពន្យល់ ផ្ទៀប យហ ១:១៧ ជាមួយ នឹង មថ ១២:៤០ និងការពន្យល់)។

**២៤:៤៧** *ការប្រែចិត្ត និងសេចក្តីប្រោសឱ្យរួច* មើល កច ៥:៣១ ១០:៤៣ ១៣:៣៨ ២៦:១៨ ។ *អស់ទាំងសាសន៍* ពាក្យនេះក៏មានផងដែរនៅក្នុងបទទំនាយក្នុង មក ១៣:១០ សូមផ្ទៀបនឹង មថ ២៨:១៩–២០ និងការពន្យល់ មក ១០:៣៤–៣៥ ១៥:១៦–១៧ រម ១:១៣–១៤ ៤:១៦–១៧ ១៥:៧–១២)។

ដល់អស់ទាំងសាសន៍[ឋ] ដោយនូវព្រះនាម[ឌ]ទ្រង់ចាប់តាំង
ពីក្រុងយេរូសាឡិមទៅ[ឍ] ៤៨អ្នករាល់គ្នាជាស្មរបន្ទាល់[ណ]ពី
ការទាំងនេះ ៤៩ហើយមើល ខ្ញុំនឹងឱ្យសេចក្ដីសន្យា[ត]របស់
ព្រះវរបិតា មកសណ្ឋិតលើអ្នករាល់គ្នា ចូរអ្នករាល់គ្នានៅ
តែក្នុងក្រុងយេរូសាឡិម ដរាបដល់ព្រះចេស្ដាពីស្ថានលើ
បានមកគ្របដណ្ដប់លើអ្នករាល់គ្នា ។

## ព្រះយេស៊ូវយាងឡើងទៅស្ថានសួគ៌

៥០នោះទ្រង់នាំគេចេញទៅត្រឹមបេថានី[ថ] រួចទ្រង់លើក
ព្រះហស្តឡើងប្រទានពរឱ្យ ៥១កំពុងដែលទ្រង់ប្រទានពរ
នោះព្រះវរបិតាបានញែកទ្រង់ចេញពីគេ លើកឡើងទៅ
ស្ថានសួគ៌[ទ]ទៅ ៥២គេក៏ក្រាបថ្វាយបង្គំទ្រង់ រួចត្រឡប់ទៅឯ
ក្រុងយេរូសាឡិមវិញ ដោយអំណរជាខ្លាំង ៥៣ក៏នៅក្នុង
ព្រះវិហារ[ធ]ជានិច្ច ទាំងសរសើរ ហើយលើកដំកើងព្រះ។
អាម៉ែន ។

**២៤:៤៧** ឋ មថ ២៨:១៩ មក ១៣:១០ ឌ កច ៥:៣១ ១០:៤៣ ១៣:៣៨ ឍ អស ២:៣ **២៤:៤៨** ណ យហ ១៥:២៧ កច ១:៨ ២:៣២ ៤:២០ ៥:៣២ ១៣:៣១ ១ពត ៥:១

**២៤:៤៩** ត យហ ១៤:១៦ កច ១:៤ **២៤:៥០** ថ មថ ២១:១៧ **២៤:៥១** ទ ២ពវ ២:១១ **២៤:៥៣** ធ កច ២:៤៦

*ចាប់តាំងពី ក្រុងយេរូសាឡិមទៅ* មើល កច ១:៨ និងការពន្យល់ ។
**២៤:៤៩** *សេចក្ដីសន្យារបស់ព្រះវរបិតា* មើល យអ ២:២៨–៣២ និងការពន្យល់ ។ ឃ្លានេះគឺសំដៅទៅលើអំណាចនៃព្រះវិញ្ញាណដែលត្រូវយាងមក និងបានសម្រេច នៅក្នុង កច ២:៤(កច ២:១៧–២២ និងការពន្យល់)។
**២៤:៥០** *បេថានី* គឺជាភូមិមួយនៅលើភ្នំដើមអូលីវ(ការពន្យល់ ១៩:២៩ មថ ២១:១៧ និងផែនទីចុងក្រោយរបស់ព្រះគម្ពីរម៉ាកុស)។
**២៤:៥១** *លើកឡើងទៅស្ថានសួគ៌* គឺខុសពីលើកមុនៗ(៤:៣០ ២៤:៣ យហ ៨:៥៩) ពួកគេបានឃើញទ្រង់ត្រូវលើកឡើងកាត់ពពកមួយផ្ទាំង (កច ១:៩ និង កច ១:១១–១២ និងការពន្យល់)។
**២៤:៥៣** *នៅក្នុងព្រះវិហារ* បន្ទាប់ពីព្រះគ្រីស្ទទ្រង់ទើបតែត្រូវបានលើកឡើងទៅឯស្ថានសួគ៌វិញ អ្នកជឿទាំងឡាយបានជួបជុំគ្នាយ៉ាងខ្ជាប់ខ្ជួននៅក្នុងព្រះវិហារ (កច ២:៤៦ ៣:១ ៥:២១,៤២)។*សរសើរហើយដំកើង* ព្រះគម្ពីរដំណឹងល្អលូកាមានការចាប់ផ្ដើម(១:៦៤ និងការពន្យល់) និងបញ្ចប់ទៅវិញ (ខ.នេះ)ដោយការសរសើរតម្កើងព្រះនៅក្នុងព្រះវិហាររបស់ទ្រង់ ។

### ការបង្ហាញអង្គទ្រង់ក្រោយពីមានព្រះជន្មរស់ឡើងវិញ

| ការបង្ហាញ | ទីកន្លែង | ពេលវេលា | ម៉ាថាយ | ម៉ាកុស | លូកា | | | |
|---|---|---|---|---|---|---|---|---|
| ផ្នូរនៅទទេ | ក្រុងយេរូសាឡិម | ថ្ងៃអាទិត្យ | ២៨:១–១០ | ១៦:១–៨ | ២៤:១–១២ | ២០:១–៩ | | |
| ដល់ម៉ារាអ្នកស្រុកម៉ាក់ដាឡាត្រង់សួនច្បារ | ក្រុងយេរូសាឡិម | ថ្ងៃអាទិត្យ | | ១៦:៩–១១ | | ២០:១១–១៨ | | |
| ដល់ស្ត្រី២នាក់ផ្សេងទៀត | ក្រុងយេរូសាឡិម | ថ្ងៃអាទិត្យ | ២៨:៩–១០ | | | | | |
| ដល់មនុស្ស២នាក់កំពុងធ្វើដំណើរទៅភូមិអេម៉ោស | តាមផ្លូវទៅភូមិអេម៉ោស | ថ្ងៃអាទិត្យ | | ១៦:១២–១៣ | ២៤:១៣–៣២ | | | |
| ដល់លោកពេត្រុស | ក្រុងយេរូសាឡិម | ថ្ងៃអាទិត្យ | | | ២៤:៣៤ | | | ១៥:៥ |
| ដល់សិស្សទាំង១០នាក់នៅបន្ទប់ខាងលើ | ក្រុងយេរូសាឡិម | ថ្ងៃអាទិត្យ | | | ២៤:៣៦–៤៣ | ២០:១៩–២៥ | | |
| ដល់សិស្ស១១នាក់នៅបន្ទប់ខាងលើ | ក្រុងយេរូសាឡិម | បន្ទាប់ពីថ្ងៃអាទិត្យ | | ១៦:១៤ | | ២០:២៦–៣១ | | ១៥:៥ |
| ដល់សិស្សជាអ្នកនេសាទទាំង៧នាក់ | សមុទ្រកាលីឡេ | ពេលបន្ទាប់មកទៀត | | | | ២១:១–២៣ | | |
| ដល់សិស្សទាំង១១នាក់នៅលើភ្នំ | ស្រុកកាលីឡេ | ពេលបនផ្ទាប់មកទៀត | ២៨:១៦–២០ | ១៦:១៥–១៨ | | | | |
| ដល់មនុស្សជាង៥០០០នាក់ | មិនដឹង | ពេលបន្ទាប់មកទៀត | | | | | | ១៥:៦ |
| ដល់លោកយ៉ាកុប | មិនដឹង | ពេលបន្ទាប់មកទៀត | | | | | | ១៥:៧ |
| ដល់សិស្សជាច្រើនពេលយាងទៅស្ថានសួគ៌ | នៅលើភ្នំដើមអូលីវ | ៤០ថ្ងៃក្រោយការមានព្រះជន្មរស់ឡើងវិញ | | | ២៤:៤៤–៤៩ | | ១:៣–៨ | |
| ដល់សាវ័កប៉ុល | ក្រុងដាម៉ាស់ | ច្រើនឆ្នាំក្រោយមកទៀត | | | | | ៩:១–១៩ ២២:៣–១៦ ២៦:៩–១៨ | ៩:១ |

# ដំណឹងល្អ

តាមលោកយ៉ូហាន

សេចក្ដីផ្ដើម

## អ្នកនិពន្ធ

អ្នកនិពន្ធព្រះគម្ពីរដំណឹងល្អយ៉ូហានគឺលោកយ៉ូហាន ។ គាត់ជាសិស្សម្នាក់ដែលព្រះយេស៊ូវស្រឡាញ់ (១៩:២៦ ២០:២ ២១:៧,២០,២៤ មើលការពន្យល់ ១៣:២៣) ។ ឈ្មោះរបស់គាត់ត្រូវបានគេស្គាល់យ៉ាងច្បាស់នៅក្នុងពួកជំនុំដំបូង ប៉ុន្តែ គាត់មិនបានប្រាប់ថាគាត់ជាអ្នកនិពន្ធកណ្ឌគម្ពីរនេះដោយត្រង់ៗតែម្ដងទេ ។ លោកយ៉ូហានមានការយល់ដឹងយ៉ាងទូលំទូលាយអំពីជីវិត និងរបៀបរបបរស់នៅរបស់ពួកសាសន៍យូដា ។ ការទាំងនេះ បានបង្ហាញឱ្យឃើញយ៉ាងច្បាស់ នៅក្នុងកំណត់ត្រារបស់គាត់ស្ដីអំពីព្រះមែស៊ី (១:២១ មើលការពន្យល់ ៧:៤០-៤២) ជម្លោះរវាងសាសន៍យូដា ជាមួយសាសន៍សាម៉ារី (មើលការពន្យល់ ៤:៩) និងប្រពៃណីរបស់សាសន៍យូដា ដែលតម្រូវឱ្យកាត់ស្បែកនៅថ្ងៃទីប្រាំបី ទោះបីថ្ងៃនោះជាថ្ងៃឈប់សម្រាកក៏ដោយ (មើលការពន្យល់ ៧:២២) ។ លោកយ៉ូហានក៏ស្គាល់ពីទីតាំងភូមិសាស្ត្រ នៃទឹកដីសន្យាយ៉ាងច្បាស់ផងដែរ ព្រោះគាត់បានកត់ត្រាទុកនូវទីតាំងភូមិបេថានី ដែលមានចម្ងាយ៣គីឡូម៉ែត្រពីទីក្រុងយេរូសាឡិម (១១:១៨) និងភូមិកាណា ដែលមិនឃើញមាននៅក្នុងស្នាដៃនិពន្ធមុនៗឡើយ (មើលការពន្យល់ ២:១ ២១:២) ។ ព្រះគម្ពីរដំណឹងល្អនេះមានការបកស្រាយយ៉ាងលម្អិតជាច្រើន ដូចជាការរៀបរាប់អំពីក្លិនក្រអូប ដែលភាយ ចេញពីប្រេងក្រអូបទេព្វិរូសុទ្ធ ពេញក្នុងផ្ទះនៅភូមិបេថានីជាដើម (មើលការពន្យល់ ១២:៣) ។ អ្នកនិពន្ធសម័យដើម ដូចជាលោកអ៊ីរ៉េនណាស (Iranaeus) និងលោកធ័រធូលាន (Tertullian) បាននិយាយថា លោកយ៉ូហានគឺជាអ្នកនិពន្ធព្រះគម្ពីរដំណឹងល្អយ៉ូហាននេះតែម្ដង ។ មានភស្ដុងតាង ផ្សេងៗទៀតជាច្រើនសុទ្ធតែបានទទួលស្គាល់ថា លោកយ៉ូហានគឺជាអ្នកនិពន្ធកណ្ឌព្រះគម្ពីរនេះឡើង (សូមមើលសេចក្ដីផ្ដើមកណ្ឌគម្ពីរ ១យហ ត្រង់ចំណុចអ្នកនិពន្ធ) ។

## កាលបរិច្ឆេទ

មានទស្សនៈពីរដែលត្រូវបានទទួលស្គាល់ នៅក្នុងការកំណត់យកកាលបរិច្ឆេទ នៃការនិពន្ធព្រះគម្ពីរដំណឹងល្អយ៉ូហាននេះគឺ

១. ទស្សនៈទំនៀមទម្លាប់: ទស្សនៈនេះយល់ឃើញថា កណ្ឌគម្ពីរដំណឹងល្អយ៉ូហានត្រូវបានសរសេរឡើងនៅចុងសតវត្សទី១ គឺប្រហែលឆ្នាំទី ៨៥គ.ស ឬនៅឆ្នាំក្រោយៗមកទៀត (មើលសេចក្ដីផ្ដើមកណ្ឌគម្ពីរ ១យហ ត្រង់ចំណុចកាលបរិច្ឆេទ) ។

២. ទស្សនៈសម័យថ្មី: ទស្សនៈនេះយល់ឃើញថា កណ្ឌព្រះគម្ពីរនេះត្រូវបានសរសេរឡើង ប្រហែលនៅក្នុងឆ្នាំទី៥០គ.ស គឺនៅមុនឆ្នាំ៧០គ.ស ទៅទៀត ។

ទស្សនៈទីមួយប្រហែលជាបានទទួលការគាំទ្រដោយលោកក្លេមីន ជាអ្នកក្រុងអ័លេក្សានឌ្រា (Clement of Alexandria ស្លាប់នៅចន្លោះឆ្នាំទី ២១១គ.ស និង២១៦គ.ស) ។ លោកក្លេមីនបានបញ្ជាក់ថា លោកយ៉ូហានបានសរសេរកណ្ឌគម្ពីរនេះ គឺដើម្បីរួមចំណែកជាមួយនឹងស្នាដៃនិពន្ធនៃព្រះគម្ពីរដំណឹងល្អដទៃទៀត ។ ម្យ៉ាងទៀត គាត់យល់ថា កណ្ឌគម្ពីរនេះត្រូវបានសរសេរឡើងក្រោយកណ្ឌគម្ពីរដំណឹងល្អបីកណ្ឌដំបូង ។ មានមតិខ្លះទៀតយល់ថា ដោយព្រោះព្រះគម្ពីរដំណឹងល្អយ៉ូហាននេះមានការសិក្សាអំពីព្រះ ច្រើនជាងព្រះគម្ពីរដំណឹងល្អបីកណ្ឌដំបូង ដូច្នេះមានន័យថា កណ្ឌគម្ពីរនេះត្រូវបានសរសេរឡើងក្រោយព្រះគម្ពីរដំណឹងល្អបីទៀត ។

ទស្សនៈទីពីរត្រូវបានទទួលការគាំទ្រ ពីព្រោះគេយល់ឃើញថា ការនិពន្ធព្រះគម្ពីរដំណឹងល្អយ៉ូហាន មានលក្ខណៈឯករាជ្យពីព្រះគម្ពីរដំណឹងល្អបីទៀត ។ ការយល់ឃើញយ៉ាងដូច្នេះ មិនបានប្រឆាំងនឹងយោបល់របស់លោកក្លេមីនខាងលើទេ ។ ម្យ៉ាងវិញទៀត អ្នកដែលប្រកាន់យកទស្សនៈនេះយល់ថា ភាពចម្រើនឡើងខាងឯវិជ្ជាសិក្សាអំពីព្រះនៅក្នុងព្រះគម្ពីរយ៉ូហាន ពុំមានន័យថា កណ្ឌគម្ពីរនេះត្រូវបានសរសេរឡើងក្រោយកណ្ឌគម្ពីរដំណឹងល្អបីផ្សេងទៀតទេ ។ គួរកត់សំគាល់ផងដែរថា ផ្នែកសាសនាវិទ្យារបស់ពួករ៉ូម៉ាំងនៅពេលនោះ (ឆ្នាំទី ៥៧គ.ស) ក៏មានការរីកចម្រើនដែរ ។ នៅក្នុង "យហ ៥:២" លោកយ៉ូហាននិយាយថា "មានស្រះមួយ" ជិត "ទ្វារចៀម"។ ត្រង់ចំណុចនេះ ព្រះគម្ពីរបរិសុទ្ធជាភាសាក្រេក ប្រើទម្រង់វេយ្យាករណ៍ជាបច្ចុប្បន្នកាល ដូច្នេះ អាចបញ្ជាក់ថា លោកយ៉ូហានសរសេរកណ្ឌគម្ពីរនេះឡើងនៅមុនឆ្នាំទី៧០គ.ស ជាពេលដែលទីក្រុងយេរូសាឡិមត្រូវបំផ្លាញ ។ ទោះជាយ៉ាងណាក៏ដោយ ក៏លោកយ៉ូហានបានប្រើទម្រង់វេយ្យាករណ៍ជាបច្ចុប្បន្នកាល នៅចំណុចផ្សេងៗទៀត ដើម្បីរៀបរាប់អំពីហេតុការណ៍នៅក្នុងអតីតកាលផងដែរ ។

## គោលបំណង និងសារៈសំខាន់

ព្រះគម្ពីរយ៉ូហានមានលក្ខណៈ និងរចនាបទខុសប្លែកពីព្រះគម្ពីរដំណឹងល្អបីកណ្ឌដំបូង ។ រហូតមកដល់សព្វថ្ងៃនេះ នៅតែមានសំណួរថា

"តើលោកយ៉ូហានបានអានព្រះគម្ពីរដំណឹងល្អបីកណ្ឌដំបូងនោះដែរ ឬទេ?"

ព្រះគម្ពីរយ៉ូហានបានចាប់ផ្តើមដោយបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះបន្ទូល ដែលគង់នៅតាំងពីដើមដំបូងមក ។ ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម និងធ្វើជាពន្លឺនៃជីវិតសម្រាប់ពិភពលោកទាំងមូល ។ ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ ដែលមកពីព្រះវរបិតា ។ ការយាងមករបស់ទ្រង់នៅលើផែនដី គឺដើម្បីបង្ហើយព្រះរាជកិច្ចរបស់ព្រះវរបិតា (មើលការពន្យល់ ៤:៣៤)។ សិរីល្អនៃព្រះវរបិតាបានសំដែងឱ្យឃើញយ៉ាងច្បាស់នៅក្នុងអង្គព្រះយេស៊ូវគ្រីស្ទ (១៤:៩) ។ គ្រប់ព្រះរាជកិច្ចដែលព្រះយេស៊ូវទ្រង់ធ្វើ គឺដើម្បីតម្កើងដល់ព្រះវរបិតា ។ នៅក្នុងទ្រង់ គឺពេញដោយព្រះគុណ និងសេចក្តីពិតនៃព្រះ ។ ម្យ៉ាងទៀត នៅក្នុងព្រះគម្ពីរដំណឹងល្អយ៉ូហាន បានបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់គង់នៅជាមួយព្រះវរបិតា តាំងពីអស់កល្បជានិច្ចមក (៦:៣៥ ៨:១២ ៩:៥ ១០:៧,៩,១៤ ១១:២៥ ១៤:៦ ១៥:១,៥) ។

ព្រះបន្ទូលរបស់ព្រះយេស៊ូវទៅកាន់លោកនីកូដេម បានសង្ខេបនូវគោលបំណងដ៏សំខាន់ នៃព្រះគម្ពីរដំណឹងល្អយ៉ូហាននេះ គឺថា *"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឱ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឱ្យមានជីវិតអស់កល្បជានិច្ចវិញ" (៣:១៦)* ។ ទោះជាយ៉ាងណាក៏ដោយ ក៏គោលបំណងសំខាន់នៃកណ្ឌគម្ពីរ នេះ នៅមានការប្រែប្រួលទៅតាមការបកស្រាយរបស់អ្នកសិក្សាព្រះគម្ពីរផងដែរ ។ លោកយ៉ូហានបានបញ្ជាក់អំពីគោលបំណងរបស់គាត់យ៉ាងច្បាស់នៅក្នុង "២០:៣១"ថា *"បានចែងទុកតែប៉ុណ្ណោះ ដើម្បីឱ្យអ្នករាល់គ្នាបានជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះពិត ហើយអ្នករាល់គ្នាបានជីវិត ដោយសារព្រះនាមទ្រង់ ដោយនៃសេចក្តីជំនឿ"* ។

ចំពោះសារៈសំខាន់នៃកណ្ឌគម្ពីរនេះ សូមមើលសេចក្តីពន្យល់ "១:៤,៧,៩,១៤,១៩,៤៩ ២:៤,១១ ៣:២៧ ៤:៣៤ ៦:៣៥ ១៣:១–១៧:២៦ ១៣:៣១ ១៧:១–២,៥ ២០:៣១" ។

**គម្រោងសង្ខេប**

**I. បុព្វកថាៈ ព្រះបន្ទូលត្រឡប់ជាសាច់ឈាម (១:១–១៨)**

**II. ការចាប់ផ្តើមព្រះរាជកិច្ចរបស់ព្រះយេស៊ូវ (១:១៩–៥១)**

ក. សេចក្តីបន្ទាល់របស់លោកយ៉ូហាន–បាទីស្ទអំពីព្រះយេស៊ូវ (១:១៩–៣៤)
ខ. សិស្សរបស់លោកយ៉ូហាន–បាទីស្ទដើរតាមព្រះយេស៊ូវ (១:៣៥–៤២)
គ. ការត្រាស់ហៅលោកភីលីព និងលោកណាថាណែល (១:៤៣–៥១)

**III. ព្រះរាជកិច្ចរបស់ព្រះយេស៊ូវនៅមុខពួកបណ្តាជន ការអស្ចារ្យ និងការថ្លែងព្រះបន្ទូល (ជំពូក ២–១១)**

ក. ទឹកប្រែទៅជាស្រាទំពាំងបាយជូរ (២:១–១១)
ខ. ការសម្អាតព្រះវិហារ (២:១២–២៥)
គ. ព្រះយេស៊ូវមានបន្ទូលពន្យល់លោកនីកូដេម (៣:១–២១)
ឃ. សេចក្តីបន្ទាល់ចុងក្រោយរបស់លោកយ៉ូហាន–បាទីស្ទអំពីព្រះយេស៊ូវ (៣:២២–៣៦)
ង. ព្រះយេស៊ូវ និងស្ត្រីសាសន៍សាម៉ារី (៤:១–៤២)
ច. ការប្រោសជំងឺកូនរបស់នាម៉ឺនម្នាក់ (៤:៤៣–៥៤)
ឆ. ព្រះយេស៊ូវយាងទៅឯទីក្រុងយេរូសាឡិម (ជំពូក ៥)
ជ. ព្រះយេស៊ូវជានំបុ័ងជីវិត និងការប្រទានអាហារដល់មនុស្សប្រាំពាន់នាក់ (ជំពូក ៦)
ឈ. ព្រះយេស៊ូវយាងទៅឯពិធីបុណ្យបារាំ និងសំណួរថា "តើទ្រង់ជាអ្នកណា?" (ជំពូក ៧–៨)
ញ. ការប្រោសបុរសម្នាក់ដែលខ្វាក់ពីកំណើតឱ្យបានភ្លឺ (ជំពូក ៩)
ដ. ព្រះយេស៊ូវជាអ្នកគង្វាលល្អ (១០:១–២១)
ឋ. បញ្ហាទំនាស់នៅក្នុងពិធីបុណ្យឆ្លង (១០:២២–៤២)
ឌ. ការប្រោសឡាសារឱ្យរស់ឡើងវិញ (ជំពូក ១១)

**IV. សប្តាហ៍នៃការរងទុក្ខ (ជំពូក ១២–១៩)**

ក. ការចាក់ប្រេងលាបព្រះបាទព្រះយេស៊ូវ (១២:១–១១)

ខ. ព្រះយេស៊ូវយាងចូលទីក្រុងយេរូសាឡិមក្នុងលក្ខណៈជាស្តេច (១២:១២–១៩)

គ. ព្រះយេស៊ូវថ្លែងទំនាយអំពីការសុគតរបស់ទ្រង់ (១២:២០–៣៦)

ឃ. អ្នកជឿ និងអ្នកមិនជឿក្នុងចំណោមពួកសាសន៍យូដា (១២:៣៧–៥០)

ង. ព្រះបន្ទូលអំពីការយាងចាកចេញ និងការអធិស្ឋាន (ជំពូក ១៣–១៧)

១. នៅក្នុងពិធីលៀងចុងក្រោយ (ជំពូក ១៣–១៤)

១.ក. ព្រះយេស៊ូវលាងជើងឱ្យពួកសាវ័ក (១៣:១–១៧)

១.ខ. ព្រះយេស៊ូវមានបន្ទូលអំពីអ្នកដែលបញ្ជូនទ្រង់ (១៣:១៨–៣០)

១.គ. ព្រះយេស៊ូវថ្លែងទំនាយអំពីការបដិសេធន៍របស់លោកពេត្រុស (១៤:៣១–៣៨)

ខ.ឃ. ព្រះយេស៊ូវកម្សាន្តចិត្តពួកសិស្សទ្រង់ (១៤:១–៤)

១.ង. ព្រះយេស៊ូវជាផ្លូវទៅឯព្រះវរបិតា (១៤:៥–១៤)

១.ច. ព្រះយេស៊ូវមានបន្ទូលសន្យាអំពីការប្រទានព្រះវិញ្ញាណបរិសុទ្ធ (១៤:១៥–៣០)

២. នៅតាមផ្លូវទៅកាន់ច្បារគែតសេម៉ានី (ជំពូក ១៥–១៦)

២.ក. ដើមទំពាំងបាយជូរ និងខ្នែងរបស់វា (១៥:១–១៧)

២.ខ. លោកីយស្អប់ពួកសិស្សរបស់ព្រះយេស៊ូវ (១៥:១៨–២៥)

២.គ. ព្រះរាជកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធ (១៥:២៦–១៦:១៥)

២.ឃ. ការសោកសង្រេងរបស់ពួកសិស្សក្លាយជាសេចក្តីអំណរ (១៦:១៦–៣៣)

៣. សេចក្តីអធិស្ឋានរបស់ព្រះយេស៊ូវ (ជំពូក ១៧)

៣.ក. អធិស្ឋានសម្រាប់ព្រះអង្គទ្រង់ (១៧:១–៥)

៣.ខ. អធិស្ឋានសម្រាប់ពួកសិស្សទ្រង់ (១៧:៦–១៩)

៣.គ. អធិស្ឋានសម្រាប់គ្រប់អ្នកជឿទាំងអស់ (១៧:២០–២៦)

ច. ការបញ្ជូនព្រះយេស៊ូវ និងការឃាត់ព្រះកាយទ្រង់ (១៨:១–១១)

ឆ. ការកាត់ទោសព្រះយេស៊ូវនៅមុខពួកសាសន៍យូដា និងពួកអភិបាលរ៉ូម៉ាំង (១៨:១២–៤០)

ជ. ការឆ្កាងព្រះយេស៊ូវ (១៩:១–២៧)

ឈ. ការសុគតរបស់ព្រះយេស៊ូវ និងការបញ្ចុះព្រះសព (១៩:២៨–៤២)

**V. ព្រះយេស៊ូវមានព្រះជន្មរស់ពីសុគតឡើងវិញ (២០:១–២៩)**

**VI. ការថ្លែងអំពីគោលបំណងនៃដំណឹងល្អ (២០:៣០–៣១)**

**VII. អវសានកថា : ព្រះយេស៊ូវប្រទានមហាបេសកកម្មដល់ពួកសិស្សទ្រង់ (ជំពូក ២១)**

## ព្រះបន្ទូលបានត្រឡប់ជាសាច់ឈាម

**១** ១កាលដើមដំបូងមានព្រះបន្ទូល[ក] ព្រះបន្ទូលក៏គង់នៅជា
មួយនឹងព្រះ[ខ] ហើយព្រះបន្ទូលនោះឯងជាព្រះ[គ] ២ទ្រង់គង់
នៅជាមួយនឹងព្រះ តាំងអំពីដើមមក[ឃ] ៣គ្រប់របស់ទាំងអស់
បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្ដារបស់ដែល
បានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមក
ក្រៅពីទ្រង់ឡើយ[ង] ៤នៅក្នុងទ្រង់មានជីវិត[ច] ហើយជីវិតនោះ
ជាពន្លឺ[ឆ]នៃមនុស្សលោក ៥ពន្លឺនោះក៏ភ្លឺមកក្នុងសេចក្ដី
ងងឹត[ជ] តែសេចក្ដីងងឹតយល់មិនដល់ពន្លឺទេ[ឈ] ។
៦មានម្នាក់ឈ្មោះយ៉ូហាន ដែលព្រះទ្រង់ចាត់ឱ្យមក[ញ]
៧អ្នកនោះបានមកសំរាប់ជាទីបន្ទាល់[ដ] ដើម្បីនឹងធ្វើបន្ទាល់
ពីពន្លឺ ប្រយោជន៍ឱ្យមនុស្សទាំងអស់បានជឿ ដោយសារ
គាត់[ឋ] ៨គាត់មិនមែនជាពន្លឺនោះទេ គឺមកគ្រាន់តែនឹង
ធ្វើបន្ទាល់ពីពន្លឺតែប៉ុណ្ណោះ ៩ឯពន្លឺដ៏ពិត[ឌ] នោះគឺជាពន្លឺ
ដែល បំភ្លឺដល់មនុស្សទាំងអស់[ឍ] ដែលកើតមកក្នុងលោកីយ
១០ទ្រង់បានគង់ក្នុងលោកីយ ហើយលោកកីយក៏កើតមក
ដោយសារទ្រង់[ណ] តែមិនស្គាល់ទ្រង់ទេ ១១ទ្រង់បានយាងមក
គង់នៅផែនដីរបស់ទ្រង់ តែរាស្ត្រទ្រង់មិនបានទទួលទ្រង់
សោះ[ត] ១២ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែល
ជឿ[ថ]ដល់ព្រះនាមទ្រង់[ទ] នោះទ្រង់បានប្រទានអំណាច ឱ្យបាន
ត្រឡប់ជាកូនព្រះ[ធ] ១៣គឺជាកូនដែលមិនមែនកើតមកពីឈាម

**១:១** ក អស ៥៥:១១ វវ ១៩:១៣ ខ យហ ១៧:៥ ១យហ ១:២ គ ភល ២:៦ **១:២** ឃ លប ១:១ យហ ៨:៥៨ ១៧:៥,២៤ ១យហ ១:១ វវ ១:៨ **១:៣** ង ខ.១០ ១កថ ៨:៦ កល ១:១៦ ហត ១:២ **១:៤** ច យហ ៥:២៦ ៦:៥៧ ១១:២៥ ១៤:៦ កច ៣:១៥ ហត ៧:១៦ ១យហ ១:១-២ ៥:២០ វវ ១:១៨ ឆ ទដ ៣៦:៩ យហ ៣:១៩ ៨:១២ ៩:៥ ១២:៤៦ **១:៥** ជ ទដ ១៨:២៨ ឈ យហ ៣:១៩ **១:៦** ញ មថ ៣:១ **១:៧** ដ ខ.១៥,១៩,៣២ យហ ៣:២៦ ៥:៣៣ ឋ ខ.១២ យហ ៣:១៥ **១:៩** ឌ ១យហ ២:៨ ឍ អស ៤៩:៦ **១:១០** ណ ខ.៣ **១:១១** ត អស ៥៣:៣ **១:១២** ថ ខ.៧ យហ ៣:១៥ ទ ១យហ ៣:២៣ ធ ចទ ១៤:១ រម ៨:១៤,១៦, ២១ អភ ៥:១ ១យហ ៣:១,២

**១:១** *កាលដើមដំបូង* ត្រង់ចំណុចនេះមានលក្ខណៈដូចគ្នាទៅនឹងបទគម្ពីរ "លប ១:១" ដែរ (មើលការពន្យល់ លប ១:១) ។ លោកយ៉ូហានប្រើពាក្យថា "កាលដើមដំបូង" ចង់បញ្ជាក់ថា ព្រះរាជកិច្ចដំបូងបំផុត ដែលព្រះយេស៊ូវគ្រីស្ទទ្រង់ធ្វើគឺបង្កើតពិភពលោកនេះឡើង (ប្រៀបធៀប យហ ៣:១៦)។ *ព្រះបន្ទូល* មានន័យថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះបន្ទូល ។ នៅក្នុងភាសាក្រិក ពាក្យនេះសំដៅលើព្រះដែលទ្រង់គ្រប់គ្រងលើរបស់ទាំងអស់ នៅលើពិភពលោកនេះតែម្ដង (ទដ ៣៣:៦ ១១៩:៨៩ ១៤៧:១៥,១៨)។ ចំពោះពួកសាសន៍យូដាវិញយល់ថា ព្រះបន្ទូលនោះហើយ ដែលបានបង្កើត និងគ្រប់គ្រងពិភពលោក ។ ម្យ៉ាងទៀត ពាក្យនេះក៏សំដៅលើក្រឹត្យវិន័យ ដែលព្រះអម្ចាស់បានប្រទានមកពួកអ៊ីស្រាអែល ដើម្បីជាផ្លូវនាំពួកគេឱ្យទទួលបាននូវមរតក ដែលជាជីវិតអស់កល្បជានិច្ច (ចទ ៣២:៤៧ មើលការពន្យល់ ៣០:២០)។ ព្រះបន្ទូលគង់នៅជាមួយព្រះ តាំងពីអស់កល្បជានិច្ចមក ។ គ្រប់អ្វីៗទាំងអស់ នៅលើពិភពលោកនេះ កើតឡើងដោយសារព្រះបន្ទូល ។ ព្រះបន្ទូលគឺជាពន្លឺ និងជាសេចក្ដីពិតមកពីព្រះ ។ *ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ* មានន័យថា ព្រះយេស៊ូវគឺជាព្រះបន្ទូល ដែលគង់នៅជាមួយព្រះតាំងពីអស់កល្បជានិច្ចមក ។ *ព្រះបន្ទូលនោះឯងជាព្រះ* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះដ៏ពិត (មើលការពន្យល់ ខ.១៨ រម ៩:៥)។

**១:៤** *ជីវិត* លោកយ៉ូហានប្រើពាក្យថា "ជីវិត" នៅក្នុងគម្ពីរដំណឹងល្អយ៉ូហាននេះ រហូតដល់៣៦ដង ។ រីឯក្នុងកណ្ឌគម្ពីរផ្សេងៗទៀត នៃព្រះគម្ពីរសញ្ញាថ្មីមានប្រើពាក្យនេះមិនលើសពី១៧ដងទេ ។ ដូច្នេះ បញ្ជាក់ថា គោលបំណងដ៏សំខាន់នៃកណ្ឌគម្ពីរដំណឹងល្អយ៉ូហានគឺនិយាយអំពីជីវិត ដែលព្រះអម្ចាស់ប្រទានមកមនុស្សនៅលើពិភពលោកនេះទាំងមូល ។ ព្រះយេស៊ូវគ្រីស្ទគឺជាពន្លឺ (១០:២៨) និងជាជីវិត (១៤:៦)។ *ពន្លឺនៃមនុស្សលោក* មានន័យថា ព្រះយេស៊ូវគឺជាពន្លឺនិងជាសេចក្ដី សង្ឃឹមសម្រាប់មនុស្សទាំងអស់ (មើលការពន្យល់ ៣:១៦ ៨:១២ ទដ ៣៦:៩)។

**១:៥** *សេចក្ដីងងឹត* ពាក្យថា "សេចក្ដីងងឹត" គឺសំដៅលើសេចក្ដីទាំងឡាយណាដែលប្រឆាំងនឹងព្រះបន្ទូលរបស់ព្រះអម្ចាស់ (ទដ ៨២:៥ ១០៧:១០ សភ ២០:២០ មថ ៨:១២ រម ១៣:១២)។

**១:៦** *យ៉ូហាន* គឺសំដៅលើលោកយ៉ូហាន–បាទីស្ទ ។

**១:៧** *អ្នកនោះបានមកសំរាប់ជាទីបន្ទាល់* មានន័យថា លោកយ៉ូហាន–បាទីស្ទបានមក ដើម្បីធ្វើបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះមែស៊ី ដែលត្រូវយាងមកយ៉ាងពិតប្រាកដ (១០:៤១)។ *ឱ្យមនុស្សទាំងអស់បានជឿដោយសារគាត់* ត្រង់ចំណុចនេះពុំមានន័យថា ឱ្យមនុស្សទាំងអស់ជឿលើលោកយ៉ូហាន–បាទីស្ទនោះទេ គឺឱ្យជឿលើព្រះយេស៊ូវគ្រីស្ទវិញ ។ លោកយ៉ូហាន-បាទីស្ទគឺជាអ្នកប្រកាសប្រាប់ អំពីការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ ហើយមានមនុស្សជាច្រើនបានជឿដល់ទ្រង់ តាមរយៈគាត់ (២០:៣១)។ លោកយ៉ូហានប្រើពាក្យថា "ជឿ ឬជំនឿ" ចំនួន ៩៨ដងក្នុងដំណឹងល្អយ៉ូហាន ដូច្នេះ បញ្ជាក់ថា គោលបំណងដ៏សំខាន់មួយទៀត របស់គាត់គឺចង់ឱ្យមនុស្សទាំងអស់មានសេចក្ដីជំនឿលើព្រះយេស៊ូវ ប្រយោជន៍ ឱ្យបានការសង្គ្រោះមកអំពីទ្រង់ ។

**១:៨** *គាត់មិនមែនជាពន្លឺនោះទេ* ដោយព្រោះតែលោកយ៉ូហាន–បាទីស្ទមានកេរ្តិ៍ ឈ្មោះល្បីល្បាញខ្លាំង ទើបធ្វើឱ្យពួកសិស្សរបស់គាត់មួយចំនួន មានការយល់ច្រឡំថា គាត់គឺជាព្រះគ្រីស្ទ ឬជាអ្នកធំណាមួយទៅវិញ (ខ.២១ មើលការពន្យល់ មថ ១១:១១)។ ប៉ុន្តែ ក្នុងពេលដែលព្រះគ្រីស្ទ បានសំដែងអង្គទ្រង់ឱ្យមនុស្សលោកស្គាល់ នោះទ្រង់មានព្រះបន្ទូលបញ្ជាក់យ៉ាងច្បាស់ថា លោកយ៉ូហាន (យ៉ូហាន-បាទីស្ទ) ពុំមែនជាពន្លឺនៃជីវិតទេ (៥:៣៥)។

**១:៩** សេចក្ដីនៅក្នុងបទគម្ពីរនេះ គឺសំដៅលើការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ ដើម្បីធ្វើជាពន្លឺដ៏ពិតប្រាកដ ដល់មនុស្សទាំងអស់នៅលើពិភពលោកនេះ ។ *លោកីយ* ពាក្យនេះអាចមានន័យថា ពិភពលោកទាំងមូល ផែនដីមនុស្សរស់នៅលើផែនដី ឬសំដៅលើការទាំងអស់ ដែលមនុស្សបង្កើតឡើងដើម្បីប្រឆាំងនឹងព្រះអម្ចាស់ ។ នៅក្នុងព្រះគម្ពីរដំណឹងល្អយ៉ូហានជាភាសាក្រិក មានប្រើពាក្យថា "លោកិយ" ចំនួន៧៨ដង ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងកណ្ឌគម្ពីរនេះ លោកយ៉ូហានមិនបានពន្យល់អំពីអត្ថន័យរបស់ពាក្យនេះទេ (មើលការពន្យល់ ១៧:៥,១៤–១៥)។

**១:១២** *ទ្រង់បានប្រទានអំណាច* មានន័យថា ព្រះអម្ចាស់ទ្រង់ប្រទានឱ្យអស់អ្នកណា ដែលជឿដល់ព្រះនាមទ្រង់នូវអំណាចឱ្យបានត្រឡប់ជាកូនរបស់ទ្រង់យ៉ាងពិតប្រាកដ (មើលការពន្យល់ អភ ២:៨,៩)។ ការនេះកើតឡើងបានដោយសារតែព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ (ខ.១៣)។

ឬតាមប្រាថ្នាខាងរូបសាច់ ឬតាមចំណង់នៃមនុស្សឡើយ
គឺកើតមកអំពីព្រះវិញ[ន]។
១៤ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម[ប] ហើយបានស្នាក់
នៅជាមួយនឹងយើងរាល់គ្នា យើងរាល់គ្នាបានឃើញសិរីល្អ
ទ្រង់[ផ] គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមកពីព្រះវរបិតា
មានពេញជាព្រះគុណ[ព] នឹងសេចក្ដីពិត[ភ] ១៥ឯយ៉ូហានបាន
ធ្វើបន្ទាល់[ម]ពីទ្រង់ ដោយបន្លឺឧទានឡើងថា គឺពីព្រះអង្គ
នេះហើយ ដែលខ្ញុំប្រាប់ថា ព្រះអង្គ ដែលយាងមកក្រោយខ្ញុំ
ទ្រង់បានត្រឡប់ជាមុនខ្ញុំវិញ ដ្បិត ទ្រង់គង់នៅមុនខ្ញុំ[យ]
១៦ហើយយើងទាំងអស់គ្នា បានទទួល អំពីសេចក្ដីពោរ
ពេញ[រ] របស់ទ្រង់មក គឺជាព្រះគុណ[ល] ថែម លើព្រះគុណផង
១៧ដ្បិតបណ្ដាក្រិត្យវិន័យទាំងប៉ុន្មាន បានប្រទានមក ដោយ
សារលោកម៉ូសេ[វ] តែឯព្រះគុណ និងសេចក្ដីពិត នោះ
បានមកដោយសារព្រះយេស៊ូវគ្រីស្ទវិញ[ស] ១៨គ្មានអ្នកណា
ដែលឃើញព្រះឡើយ[ហ]មានតែព្រះរាជបុត្រាតែ១[ឡ] ដែល
គង់នៅក្នុងឱរាព្រះវរបិតាប៉ុណ្ណោះ ទ្រង់បានសំដែងឱ្យ
ស្គាល់ព្រះអង្គ ។

## លោកយ៉ូហាន-បាទីស្ទមិនមែនជាព្រះគ្រីស្ទទេ

១៩កាលពួកសាសន៍យូដា[អ] ចាត់ពួកសង្ឃ និងពួកលេវី
ពីក្រុងយេរូសាឡិម ឱ្យមកសួរយ៉ូហានថា តើលោកជា
អ្នកណា នោះគាត់ធ្វើបន្ទាល់យ៉ាងនេះ[ក] ២០គឺគាត់ប្រាប់តាម
ត្រង់ ឥតមានលាក់អ្វីឡើយថា ខ្ញុំមិនមែនជាព្រះគ្រីស្ទទេ[ខ]
២១នោះគេសួរថា ចុះលោកជាអ្នកណា ជាលោកអេលីយ៉ា

**១:១៣** ន យហ ៣:៦ ទត ៣:៥ យក ១:១៨ ១ពត ១:២៣ ១យហ ៣:៩ ៤:៧ ៥:១,៤
**១:១៤** ប កទ ៤:៤ ភល ២:៧,៨ ១ធថ ៣:១៦ ហព ២:១៤ ១យហ ១:១,២ ៤:២ ផ ឯក ៣៣:១៨ ផ នក ៤០:៣៤ ព រម ៣:២៤ ភ យហ ១៤:៦
**១:១៥** ម ឧ.៧ យ ឧ.៣០ មថ ៣:១១
**១:១៦** រ អភ ១:២៣ កល ១:១៩ ២:៩ ល រម ៣:២៤ **១:១៧** វ ចទ ៣២:៤៦ យហ ៧:១៩ ស ឧ.១៤
**១:១៨** ហ នក ៣៣:២០ យហ ៦:៤៦ កល ១:១៥ ១ធថ ៦:១៦ ១យហ ៤:១២ ឡ យហ ៣:១៦,១៨ ១យហ ៤:៩ **១:១៩** អ យហ ២:១៨ ៥:១០,១៦ ៦:៤១,៥២ ៧:១ ១០:២៤ ក មថ ៣:១ **១:២០** ខ យហ ៣:២៨ លក ៣:១៥,១៦
**១:២១** គ មថ ១១:១៤ ឃ ចទ ១៨:១៥

**១:១៣** *កើតមកអំពីព្រះ* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា នៅពេលអ្នកណាម្នាក់ទទួលជឿដល់ព្រះនាមព្រះអម្ចាស់ នោះគេពិតជាបានកើតជាថ្មីខាងឯវិញ្ញាណ និងបានត្រឡប់ជាកូនរបស់ទ្រង់យ៉ាងពិតប្រាកដ (៣:៣,៥ ២កថ ៥:១៧ កទ ៦:១៥ មើលការពន្យល់ ទត ៣:៥)។ ដូច្នេះ អស់អ្នកណាដែលទទួលជឿដល់ព្រះយេស៊ូវ នោះពិតជាបានកើតជាថ្មីខាងឯវិញ្ញាណ និងទទួលបានជីវិតរស់អស់កល្បជានិច្ច ។

**១:១៤** *ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម* ឃ្លានេះនិយាយសំដៅលើព្រះយេស៊ូវ គឺនៅពេលដែលទ្រង់យាងមកប្រសូតជាមនុស្សនៅលើផែនដីកាលពីជាងពីរពាន់ឆ្នាំមុន ។ *បានស្នាក់នៅជាមួយនឹងយើងរាល់គ្នា* ឃ្លានេះនៅក្នុងព្រះគម្ពីរបរិសុទ្ធជាភាសាក្រិក ច្រើនមានទំនាក់ទំនងនឹងពាក្យថា "រោងឧបោសថ (នក ២៧:៩)"។ មានន័យថា ព្រះយេស៊ូវគង់នៅក្នុងចំណោមពួកគេ និងជាទីជម្រកសម្រាប់ពួកគេទាំងអស់គ្នាផង ។ ម្យ៉ាងទៀត លោកយ៉ូហានប្រើពាក្យនេះ គឺចង់ប្រាប់ពួកអ្នកអាន ជាសាសន៍យូដាទាំងអស់ឱ្យនឹកចាំនូវរោងឧបោសថ ដែលពេញដោយសិរីល្អរបស់ព្រះអម្ចាស់ (នក ៤០:៣៤,៣៥)។ *យើងរាល់គ្នាបានឃើញសិរីល្អទ្រង់* បញ្ជាក់ថា ព្រះយេស៊ូវទ្រង់បានបើកសំដែង ឱ្យពួកសិស្សទ្រង់ឃើញសិរីល្អរបស់ទ្រង់ តាមរយៈការអស្ចារ្យ (មើលការពន្យល់ ២:១១) និងការសុគត ហើយរស់ឡើងវិញ របស់ទ្រង់ ។ *ពេញជាព្រះគុណ និងសេចក្ដីពិត* ឃ្លានេះនៅក្នុងព្រះគម្ពីរបរិសុទ្ធជាភាសាហេព្រើរ ច្រើនប្រែថា "សេចក្ដីស្រឡាញ់ និងសេចក្ដីសុចរិត (របស់ព្រះ)" (មើលការពន្យល់ ទជ ២៦:៣ សភ ១៦:៦)។ *ព្រះគុណ* ពាក្យថា "ព្រះគុណ" មានន័យសំខាន់ណាស់ សម្រាប់អ្នកជឿដល់ព្រះនាមព្រះយេស៊ូវ (មើលការពន្យល់ យណ ៤:២ កទ ១:៣ អភ ១:២)។ ពាក្យនេះអាចមានន័យថា ជាអ្វីដែលមនុស្សលោកមិនសក្តិសម និងគ្មានសមត្ថភាព នឹងទទួលបានទាល់តែសោះ ប៉ុន្តែ ព្រះអម្ចាស់ទ្រង់ប្រទានឱ្យ ។ *សេចក្ដីពិត* លោកយ៉ូហានប្រើពាក្យនេះច្រើនមានទំនាក់ទំនងទៅនឹង ព្រះយេស៊ូវគ្រីស្ទ ព្រោះថា ទ្រង់គឺជាសេចក្ដីពិត (មើលការពន្យល់ ១៤:៦)។

**១:១៥** *ទ្រង់គង់នៅមុនខ្ញុំ* នៅសម័យនោះ ជាទូទៅគេតែងតែគោរពមនុស្សដែលមានវ័យចាស់ ជាងអ្នកដែលមានវ័យក្មេង ។ លោកយ៉ូហាន-បាទីស្ទមានអាយុខាងឯសាច់ឈាមច្រើនជាងព្រះយេស៊ូវប្រហែលជា៦ខែ ។ ដូច្នេះ មានន័យថា នៅពេលដែលពួកគេមិនទាន់ស្គាល់ព្រះយេស៊ូវនៅឡើយ ពួកគេប្រហែលជាគោរពលោកយ៉ូហាន-បាទីស្ទជាងទ្រង់ ។ ប៉ុន្តែ គាត់បានពន្យល់ប្រាប់ពួកគេទាំងនោះយ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទ ជាព្រះបន្ទូល ដែលមានព្រះជន្មគង់នៅ តាំងពីអស់កល្បជានិច្ចមក គឺមុនពេលដែលទ្រង់បានបង្កើតពិភពលោកនេះទៅទៀត ។

**១:១៦** *ព្រះគុណថែមលើព្រះគុណ* ព្រះគុណបានប្រទានមកតាំងពីមុនពេលដែលព្រះយេស៊ូវយាងមកទៅទៀត ។ នៅពេលដែលព្រះយេស៊ូវយាងមក ទ្រង់ក៏បានប្រទានព្រះគុណ ថែមលើព្រះគុណដែលបានប្រទានមកពីមុននោះទៀត (ឧ.១៧ មើលការពន្យល់ ហព ១:១-៤) ដូច្នេះ មានន័យថា ព្រះគុណថែមលើព្រះគុណ ។

**១:១៨** *មានតែព្រះរាជបុត្រាតែ១* ឃ្លានេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រាតែ១នៃព្រះ (៣:១៦ មើលការពន្យល់ ឧ.១,១៤ រម ៩:៥)។ *ទ្រង់បានសំដែងឱ្យស្គាល់ព្រះអង្គ* បញ្ជាក់ថា អស់អ្នកណាដែលទទួលជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ នោះទ្រង់ពិតជាបើកសំដែង ឱ្យគេស្គាល់ទ្រង់ជាក់ជាមិនខាន (២កថ ៤:៤ កល ១:១៥,១៩ មើលការពន្យល់ កល ២:៩)។

**១:១៩** *ពួកសាសន៍យូដា* ជាទូទៅ ពាក្យនេះ គេប្រើសម្រាប់សំដៅលើពួកសាសន៍យូដាទាំងអស់តែម្ដង ។ នៅក្នុងកណ្ឌគម្ពីរដំណឹងល្អយ៉ូហាន មានប្រើពាក្យនេះចំនួន ៧០ដង ហើយច្រើនតែសំដៅលើក្រុមអ្នកដឹកនាំនៃពួកយូដា និងជាអ្នកដែលប្រឆាំងនឹងព្រះយេស៊ូវ (៨:៤៨)។ *ពួកលេវី* គឺសំដៅលើពូជពង្សរបស់លោកលេវី ។ ពួកនេះមាននាទីចាត់ចែងនៅក្នុងរោងឧបោសថ (នក ៣:១៧-៣៧) និងក្នុងព្រះវិហារ ហើយក៏មានទំនួលខុសត្រូវក្នុងការបង្រៀនផងដែរ (២របា ៣៥:៣ នហ ៨:៧-៩)។

**១:២០** *ខ្ញុំមិនមែនជាព្រះគ្រីស្ទទេ* ត្រង់ចំណុចនេះ លោកយ៉ូហាន-បាទីស្ទធ្វើការបញ្ជាក់យ៉ាងច្បាស់ថា គាត់មិនមែនជាព្រះមែស៊ី ដែលត្រូវយាងមកសង្គ្រោះពួកអ៊ីស្រាអែលនោះទេ ។ គាត់គ្រាន់តែជាអ្នករៀបចំផ្លូវថ្វាយទ្រង់តែប៉ុណ្ណោះ ។

ឬអី[គ] គាត់ឆ្លើយថា មិនមែនទេ តើលោកជាហោរា នោះ
ឬអី[ឃ] នោះគាត់ឆ្លើយថា ទេ ២២ដូច្នេះ គេសួរគាត់ទៀតថា
តើលោកជាអ្នកណាទៅវិញ លោកនឹងមានប្រសាសន៍ពី
ខ្លួនលោកដូចម្ដេច ដើម្បី ឱ្យយើងរាល់គ្នា បាននាំពាក្យទៅ
ជំរាបដល់លោកដែល ចាត់ឱ្យយើងខ្ញុំមកផង ២៣នោះគាត់
ក៏ប្រាប់ថា ខ្ញុំជាសំឡេង ដែលបន្លឺឡើង នៅទីរហោស្ថាន[ង]
ថា ចូរដំរង់ផ្លូវថ្វាយ ព្រះអម្ចាស់ ដូចជាហោរាអេសាយ
បានទាយទុក[ច] ២៤ឯពួកអ្នក ដែលបានចាត់មកនោះគេជា
ពួកផារិស៊ី ២៥គេក៏សួរគាត់ថាបើលោកមិនមែនជាព្រះ
គ្រីស្ទឬលោក អេលីយ៉ា ឬហោរានោះទេ ចុះហេតុអ្វីបាន
ជាលោកធ្វើ បុណ្យជ្រមុជទឹកដូច្នេះ ២៦យ៉ូហានឆ្លើយថា
ឯខ្ញុំៗធ្វើបុណ្យជ្រមុជដោយទឹក[ឆ] ប៉ុន្តែ នៅកណ្ដាលពួកអ្នក
រាល់គ្នា នោះមានព្រះ១អង្គ ដែលអ្នករាល់គ្នាមិនស្គាល់
២៧គឺព្រះអង្គនោះហើយ ដែលមកក្រោយខ្ញុំ[ជ] តែបានគង់
នៅមុនខ្ញុំ ខ្ញុំមិនគួរនឹងស្រាយខ្សែ សុព័ណ៌បាទទ្រង់ទេ[ឈ]
២៨រឹងការទាំងនេះ បានកើតមកនៅភូមិបេថានី ខាងនាយ
ទន្លេយ័រដាន់[ញ] ជាកន្លែងដែលយ៉ូហានកំពុងតែធ្វើបុណ្យ
ជ្រមុជទឹក ។

### ព្រះយេស៊ូវជាកូនចៀមនៃព្រះ

២៩លុះស្អែកឡើង យ៉ូហានឃើញព្រះយេស៊ូវ ដែលទ្រង់
កំពុងតែយាងមកឯគាត់ នោះក៏ពោលថា នុ៎ះន៏ កូនចៀម
នៃព្រះ[ដ] ដែលដោះបាបមនុស្សលោក[ឋ] ៣០គឺពីព្រះអង្គនេះ
ហើយ ដែលខ្ញុំប្រាប់ថា ក្រោយខ្ញុំមានព្រះ១អង្គយាងមក
ដែលបានត្រឡប់ជាមុនខ្ញុំ ដ្បិតទ្រង់គង់នៅមុនខ្ញុំ[ឌ] ៣១ខ្ញុំមិន
បានស្គាល់ទ្រង់ទេ តែខ្ញុំមកធ្វើបុណ្យជ្រមុជនេះ គឺដើម្បីនឹង
សំដែងឱ្យសាសន៍អ៊ីស្រាអែលបានស្គាល់ទ្រង់ប៉ុណ្ណោះ ។
៣២យ៉ូហានក៏ធ្វើបន្ទាល់ថា ខ្ញុំបានឃើញព្រះវិញ្ញាណ យាង
ចុះពីលើមេឃ មានរូបដូចជាព្រាប មកសណ្ឋិតលើ ទ្រង់[ឍ]
៣៣ខ្ញុំមិនបានស្គាល់ទ្រង់ទេ ប៉ុន្តែព្រះដែលចាត់ឱ្យខ្ញុំមក
ធ្វើបុណ្យជ្រមុជដោយទឹក[ណ] ទ្រង់មានបន្ទូលមកខ្ញុំថា ដែល

**១:២៣** ង មថ ៣:១ ច អស ៤០:៣
**១:២៦** ឆ មក ១:៤
**១:២៧** ជ ខ.១៥,៣០ ឈ មក ១:៧
**១:២៨** ញ យហ ៣:២៦ ១០:៤០
**១:២៩** ដ ខ.៣៦ លប ២២:៨ អស ៥៣:៧ ១ពត ១:១៩ វវ ៥:៦ ១៣:៨ ឋ យហ ៣:១៧
**១:៣០** ឌ ខ.១៥,២៧
**១:៣២** ឍ មថ ៣:១៦
**១:៣៣** ណ មក ១:៤

**១:២១** *អេលីយ៉ាឬអី...មិនមែនទេ* ពួកសាសន៍យូដាជឿថា លោកអេលីយ៉ា មិនទាន់ស្លាប់ទេ (២ពវ ២:១១) ហើយថា គាត់នឹងត្រឡប់មកវិញ ដើម្បីប្រកាសអំពីថ្ងៃចុងបំផុតដែលត្រូវមកដល់ ។ ប៉ុន្តែ លោកយ៉ូហាន–បាទីស្ទ បានបដិសេធថា គាត់មិនមែនជាលោកអេលីយ៉ាទេ ។ ព្រះយេស៊ូវទ្រង់មានបន្ទូលថា លោកអេលីយ៉ាបាន មករួចហើយ (មថ ១១:១៤ មើលការពន្យល់ មថ ១៧:១០)។ ដូច្នេះ បញ្ជាក់ថា សេចក្ដីទំនាយនៅក្នុងបទគម្ពីរ "មឡ ៤:៥ (មើលការពន្យល់)" បានសម្រេចហើយ ។ *តើលោកជាហោរានោះឬអី* ឃ្លានេះសំដៅលើហោរាម្នាក់ដែលថ្លែងទំនាយនៅ ក្នុងបទគម្ពីរ "ចទ ១៨:១៥"។ លោកយ៉ូហាន–បាទីស្ទ បានបដិសេធចំពោះពួកយូដាទាំងនោះថា គាត់មិនមែនជាហោរាទេ ។ គាត់មកដើម្បីធ្វើបន្ទាល់ពីព្រះយេស៊ូវថា ទ្រង់គឺជាព្រះមែស៊ីពិតប្រាកដមែន ។

**១:២៣** លោកយ៉ូហាន–បាទីស្ទ បានលើកយកសេចក្ដីទំនាយ នៅក្នុងបទគម្ពីរ "អស ៤០:៣" មកបញ្ជាក់ប្រាប់ពួកគេឱ្យដឹងថា ការងារដែលគាត់ត្រូវបំពេញថ្វាយព្រះអម្ចាស់ គឺប្រកាសប្រាប់ពួកគេឱ្យប្រែចិត្តចេញពីអំពើបាប ហើយរៀបចំខ្លួនទទួលព្រះមែស៊ីជាព្រះសង្គ្រោះ ។

**១:២៤** *ពួកផារិស៊ី* គឺជាក្រុមអ្នកកាន់សាសនាយូដា ដែលប្រតិបត្តិតាមក្រឹត្យវិន័យ និងទំនៀមទម្លាប់ដ៏តឹងរ៉ឹង ។ ពួកនេះជឿថា មានការរស់ឡើងវិញ មានទេវតា និងមានវិញ្ញាណ (ការពន្យល់ មថ ៣:៧ មក ២:១៦ លក ៥:១៧)។

**១:២៥** *ព្រះគ្រីស្ទ* មានន័យថា អង្គដែលព្រះអម្ចាស់ចាក់ប្រេងតាំង ។ នៅក្នុងគម្ពីរសញ្ញាចាស់ ការចាក់ប្រេងតាំង ធ្វើឡើងដើម្បីតែងតាំងអ្នកណាម្នាក់ឱ្យធ្វើជាស្ដេច (១សយ ១៦:១,១៣) ឬជាសង្ឃ (នក ២៨:៤១ ២៩:៧ ៤០:១៣, ១៥ ៣០:៣០)។

**១:២៧** *ខ្ញុំមិនគួរនឹងស្រាយខ្សែសុព័ណ៌បាទទ្រង់ទេ* ពាក្យថា "សុព័ណ៌បាទ" មានន័យថា "ទ្រនាប់ជើង"។ លោកយ៉ូហាន-បាទីស្ទនិយាយយ៉ាងដូច្នេះ ពីព្រោះគាត់ចង់បញ្ជាក់ប្រាប់ពួកគេថា គាត់គ្រាន់តែជាអ្នកបម្រើម្នាក់របស់ព្រះអម្ចាស់ប៉ុណ្ណោះ ។

**១:២៨** *ភូមិបេថានី* ភូមិនេះស្ថិតនៅភាគខាងកើតនៃទីក្រុងយេរូសាឡិម ប្រហែល ៣,២គ.ម (មើលការពន្យល់ មថ ២១:១៧)។

**១:២៩** *កូនចៀមនៃព្រះ* គឺសំដៅលើព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ លប ២២:៨ អស ៥៣:៧ យរ ១១:១៩ ១យហ ២:២ វវ ៥:៦)។ លោកយ៉ូហាននិយាយយ៉ាងដូច្នេះ ព្រោះគាត់ចង់បញ្ជាក់ថា ព្រះយេស៊ូវគ្រីស្ទគឺជាកូនចៀមដែលត្រូវសម្លាប់ដើម្បីលោះបាបមនុស្សលោក (ខ.៣៦)។

**១:៣១** *ខ្ញុំមិនបានស្គាល់ទ្រង់ទេ* លោកយ៉ូហាន–បាទីស្ទរស់នៅឯទីរហោស្ថានរហូតដល់ថ្ងៃដែលគាត់បង្ហាញខ្លួន ឱ្យសាសន៍អ៊ីស្រាអែលបានឃើញ នាឆ្នាំ ២៦ ឬ ២៧គ.ស (មើលការពន្យល់ លក ១:៨០)។ ត្រង់ចំណុចនេះ អាចបញ្ជាក់ថា នៅមុនពេលដែលព្រះយេស៊ូវគ្រីស្ទ បានសំដែងការអស្ចារ្យឱ្យពួកគេឃើញ លោកយ៉ូហាន-បាទីស្ទ មិនបានដឹងថាទ្រង់គឺជាព្រះមែស៊ីនោះទេ (ខ.៣២-៣៣)។

**១:៣២,៣៣** "មើលការពន្យល់ មថ ៣:១៥"។ *ធ្វើបុណ្យជ្រមុជ ដោយព្រះវិញ្ញាណបរិសុទ្ធ* លោកយ៉ូហាន–បាទីស្ទធ្វើបុណ្យជ្រមុជដោយទឹក ប៉ុន្តែព្រះយេស៊ូវគ្រីស្ទ ធ្វើបុណ្យជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធវិញ ហើយអស់អ្នកណាដែលជឿដល់ព្រះនាមទ្រង់ នោះពិតជាបានកើតជាថ្មីខាងឯវិញ្ញាណ និងមិនត្រូវវិនាសឡើយ (២០:២២ កច ១:៥ ២:៤ ១១:១៥,១៦ ១៩:៤–៦ ១កថ ១២–១៤ កទ ៣:៥,១៤ ៤:៦ ៥:១៦–២៥ អភ ១:១៣ ៣:១៦ ៥:១៨ ភល ៣:៣ ១ថន ៤:៨)។ *ព្រះវិញ្ញាណបរិសុទ្ធ* គឺជាព្រះវិញ្ញាណនៃព្រះអម្ចាស់ (១៤:២៦ ២០:២២)។ ព្រះវិញ្ញាណបរិសុទ្ធបានយាងមកសណ្ឋិតលើព្រះយេស៊ូវគ្រីស្ទ ដូច្នេះ បញ្ជាក់យ៉ាងច្បាស់ថា ទ្រង់គឺជាព្រះបរិសុទ្ធ និងមានគ្រប់អំណាចព្រះចេស្ដាទាំងអស់ ។

ឯងឃើញព្រះវិញ្ញាណ យាងចុះមក សណ្ឋិតលើអ្នកណា
គឺអ្នកនោះហើយ ដែលធ្វើបុណ្យជ្រមុជ ដោយព្រះវិញ្ញាណ
បរិសុទ្ធ[ត] ៣៤ខ្ញុំបានឃើញមែន ហើយក៏ធ្វើបន្ទាល់ពីព្រះអង្គ
នោះថា ទ្រង់ជាព្រះរាជបុត្រានៃព្រះពិតមែន[ថ]។

## សាវ័កដំបូងរបស់ព្រះយេស៊ូវ

*១:៤០–៤២ = មថ ៤:១៨–២២ មក ១:១៦ លក ៥:២–១១*

៣៥លុះស្អែកឡើងទៀត យ៉ូហាន[ទ] ឈរនៅជាមួយនឹង
សិស្សគាត់២នាក់ ៣៦គាត់មើលទៅព្រះយេស៊ូវ ដែលទ្រង់
កំពុងតែយាងទៅ ក៏ពោលថា នុ៎ះន៏ កូនចៀមនៃព្រះ[ធ]។
៣៧សិស្សគាត់ទាំង២នាក់នោះក៏ឮដែរ រួចគេដើរតាម
ព្រះយេស៊ូវទៅ ៣៨ឯព្រះយេស៊ូវទ្រង់ងាកបែរមក ឃើញ
អ្នកទាំង២កំពុងតែដើរតាម ក៏មានបន្ទូលទៅគេថា អ្នកមក
រកអី គេទូលឆ្លើយថា រ៉ាប៊ី[ន] (គឺប្រែថា លោកគ្រូ) តើលោក
នៅឯណា ៣៩ទ្រង់មានបន្ទូលថា ចូរតាមខ្ញុំទៅមើល គេក៏ទៅ
ឃើញកន្លែងដែលទ្រង់គង់នៅ រួចនៅជាមួយនឹងទ្រង់
ក្នុងថ្ងៃនោះ ពេលនោះប្រហែលជាម៉ោង៤ល្ងាចហើយ
៤០ក្នុងអ្នក២នាក់ ដែលឮយ៉ូហានពោលនោះ ហើយ
ក៏តាមទ្រង់ទៅ នោះមានម្នាក់ឈ្មោះអនទ្រេ ជាប្អូន
ស៊ីម៉ូន–ពេត្រុស ៤១មុនដំបូងគាត់រកស៊ីម៉ូន ជាបងបង្កើត
ក៏ប្រាប់ថា យើងបានឃើញព្រះមែស៊ីហើយ (គឺប្រែថា
ព្រះគ្រីស្ទ)[ប] ៤២រួចគាត់នាំបង ទៅឯព្រះយេស៊ូវ ឯទ្រង់ក៏
ទតមើលគាត់ ហើយមានបន្ទូលថា អ្នកឈ្មោះស៊ីម៉ូន ជាកូន
យ៉ូណាស តែត្រូវហៅថា[ផ] កេផាសវិញ (គឺប្រែថាថ្ម)[ព]។
៤៣លុះដល់ស្អែកឡើង ព្រះយេស៊ូវសព្វព្រះហឫទ័យ ចង់
យាងទៅឯស្រុកកាលីឡេ ទ្រង់ក៏រកភីលីព[ភ] កាលបានឃើញ
ហើយ នោះទ្រង់មានបន្ទូលទៅគាត់ថា ចូរតាមខ្ញុំមក[ម]
៤៤ឯភីលីពនេះ គាត់នៅបេតសៃដា ជាទីក្រុងរបស់អន
ទ្រេ នឹងពេត្រុស[យ] ៤៥ភីលីពក៏រកណាថាណែល[រ] រួចប្រាប់
ថា យើងបានឃើញព្រះអង្គនោះហើយ គឺជាព្រះដែលលោក
ម៉ូសេ បានចែងទុកពីទ្រង់ នៅក្នុងក្រិត្យវិន័យ[ល] ហើយពួក
ហោរាក៏បានទាយពីទ្រង់ផង[វ] ទ្រង់ព្រះនាមជា យេស៊ូវជា
បុត្រយ៉ូសែប[ស] នៅភូមិណាសារ៉ែត[ហ] ៤៦តែណាថាណែល
និយាយថា តើមានអ្វីដ៏ល្អអាចចេញ ពីណាសារ៉ែតមក
បានឬទេ[ឡ] ភីលីពឆ្លើយឡើងថា ចូរតាមខ្ញុំទៅមើលចុះ
៤៧ព្រះយេស៊ូវ ទ្រង់ឃើញណាថាណែលមកឯទ្រង់ ក៏មាន
បន្ទូលពីគាត់ថា នុ៎ះន៏ ជាសាសន៍អ៊ីស្រាអែលពិតមែន[អ] ដែល
ឥតមានចិត្តឧបាយ[ក] ៤៨នោះណាថាណែលទូលសួរថា
លោកស្គាល់ខ្ញុំពីណាមក ព្រះយេស៊ូវមានបន្ទូលឆ្លើយថា

**១:៣៣** ត មក ១:៨
**១:៣៤** ថ ខ.៤៩ មថ ៤:៣
**១:៣៥** ទ មថ ៣:១
**១:៣៦** ធ ខ.២៩
**១:៣៨** ន ខ.៤៩ មថ ២៣:៧
**១:៤១** ប យហ ៤:២៥
**១:៤២** ផ លប ១៧:៥,១៥ ៣២:២៨ ៣៥:១០ ព មថ ១៦:១៨
**១:៤៣** ភ មថ ១០:៣ យហ ៦:៥–៧ ១២:២១,២២ ១៤:៨,៩ ម មថ ៤:១៩
**១:៤៤** យ មថ ១១:២១
**១:៤៥** រ យហ២១:២ ល លក ២៤:២៧ វ លក ២៤:២៧ ស លក ៣:២៣ ហ មក ១:២៤
**១:៤៦** ឡ យហ ៧:៤១,៤២,៥២
**១:៤៧** អ រម ៩:៤,៦

ក ទដ ៣២:២

**១:៣៤** *ទ្រង់ជាព្រះរាជបុត្រានៃព្រះពិតមែន* (ខ.១៤,១៨ ២០:៣១) "មើលការពន្យល់ ៣:១៦"។

**១:៣៥** *សិស្សគាត់២នាក់* សិស្សរបស់លោកយ៉ូហាន–បាទីស្ទទាំងពីរនាក់នោះគឺលោកអនទ្រេ (ខ.៤០) ហើយម្នាក់ទៀតពុំបានបញ្ជាក់ឈ្មោះទេ ។ សិស្សម្នាក់ទៀត ដែលមិនបានបញ្ជាក់ឈ្មោះនោះ ប្រហែលជាលោកយ៉ូហាន ជាអ្នកនិពន្ធព្រះគម្ពីរដំណឹងល្អយ៉ូហាននេះតែម្តង ។ អ្នកទាំងនោះបានចាត់ទុកលោកយ៉ូហាន–បាទីស្ទ ថាជាគ្រូម្នាក់ដែលបង្រៀនព្រះបន្ទូលព្រះដល់ពួកគេ។

**១:៣៦** *កូនចៀមនៃព្រះ* "មើលការពន្យល់ ខ.២៩"។ ត្រង់ចំណុចនេះមានន័យថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ ដែលត្រូវយាងមកសុគត ដើម្បីសង្គ្រោះមនុស្សនៅលើពិភពលោកនេះឱ្យបានរួចពីបាប ហើយទ្រង់នឹងបង្រៀនពួកគេឱ្យបានស្គាល់ច្បាស់អំពីផ្លូវនៃសេចក្តីពិត ។

**១:៤០** *អនទ្រេ* គឺជាសាវ័កម្នាក់ ក្នុងចំណោមសាវ័កទាំង១២នាក់ របស់ព្រះយេស៊ូវ (មថ ១០:២)។ គាត់រស់នៅក្នុងក្រុងបេតសៃដា (ខ.៤៤) ប៉ុន្តែក្រោយមក គាត់បានមកប្រកបរបរនេសាទជាមួយនឹងលោកពេត្រុស នៅឯទីក្រុងកាពើណិមវិញ (មថ ៤:១៨ មក ១:២៩)។

**១:៤១** *ព្រះមែស៊ី* "មើលការពន្យល់ ខ.២៥"។ ពាក្យនេះមាននិយាយនៅក្នុងព្រះគម្ពីរបរិសុទ្ធសញ្ញាថ្មីចំនួន ៥១៤ដង ។

**១:៤២** *ស៊ីម៉ូន ជាកូនយ៉ូណាស* នៅក្នុងព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសខ្លះប្រើពាក្យថា "ស៊ីម៉ូន ជាកូនយ៉ូហាន"។ *ស៊ីម៉ូន* គឺជាឈ្មោះដើមរបស់លោកពេត្រុសជាបងរបស់លោកអនទ្រេ និងជាកូនរបស់លោកយ៉ូណាស ។ គាត់រស់នៅក្នុងក្រុងបេតសៃដា នៃស្រុកកាលីឡេ ។ ក្រោយមកទៀត គាត់បានប្តូរទីលំនៅទៅរស់នៅជាមួយក្រុមគ្រួសាររបស់គាត់ នៅឯទីក្រុងកាពើណិមវិញ (មថ ៤:១៨ ៨:១៤ ១០:២ ១៦:១៦,១៧ មក ១:១៦,២៩,៣០ មើលការពន្យល់ មថ ១៦:១៨)។

**១:៤៤** *បេតសៃដា* គឺជាក្រុង ឬភូមិមួយដែលស្ថិតនៅឆ្នេរភាគខាងជើងនៃសមុទ្រ កាលីឡេ (មើលការពន្យល់ មថ ១១:២១)។

**១:៤៥** *យេស៊ូវ ជាបុត្រយ៉ូសែប* ត្រង់ចំណុចនេះបញ្ជាក់ថា បើគិតតាមច្បាប់និងទំនៀមទម្លាប់របស់ពួកយូដា នោះព្រះយេស៊ូវគ្រីស្ទ គឺជាកូនរបស់លោកយ៉ូសែបខាងឯសាច់ឈាម ទោះបីទ្រង់បានប្រសូតពីស្ត្រីក្រមុំព្រហ្មចារីក៏ដោយ (មើលការពន្យល់ មថ ១:១៨,២០,២៣,២៥ លក ១:២៦–៣៥)។

**១:៤៦** *ណាសារ៉ែត* គឺជាភូមិមួយនៃស្រុកកាលីឡេ ។ ភូមិនេះស្ថិតនៅភាគខាងលិច (ឆៀងខាងត្បូង) នៃសមុទ្រកាលីឡេ ចម្ងាយប្រហែល ២២,៤គ.ម (៧:៥២ មើលការពន្យល់ មថ ២:២៣)។

**១:៤៧** *ជាសាសន៍អ៊ីស្រាអែលពិតមែន* ឃ្លានេះបញ្ជាក់ថា លោកណាថាណែល គឺជាសាសន៍អ៊ីស្រាអែលម្នាក់ ដែលប្រតិបត្តិតាមក្រឹត្យវិន័យ របស់ព្រះអម្ចាស់យ៉ាងខ្ជាប់ខ្ជួន (២:២៤–២៥ រម ៩:៦ ២:២៨–២៩)។

**១:៤៨** *នៅក្រោមដើមល្វា* បញ្ជាក់ថា នៅមុនពេលដែលលោកណាថាណែលបានមកជួបនឹងព្រះយេស៊ូវគ្រីស្ទប្រហែលជាគាត់កំពុងអធិស្ឋាន ឬកំពុងតែ

មុនដែលភីលីពហៅមក កាលអ្នកនៅក្រោមដើមល្វានៅ
ឡើយ នោះខ្ញុំបានឃើញហើយ ៤៩ណាថាណែលក៏ទូលទ្រង់
ថា លោកគ្រូ[ខ] លោកជាព្រះរាជបុត្រានៃព្រះ[គ] លោកប្រាកដ
ជាស្តេច នៃសាសន៍អ៊ីស្រាអែលមែន[ឃ] ៥០ព្រះយេស៊ូវមាន
បន្ទូលឆ្លើយថា ដោយព្រោះតែខ្ញុំបាននិយាយប្រាប់អ្នកថា
ខ្ញុំឃើញអ្នកនៅក្រោមដើមល្វានោះ បានជាអ្នកជឿឬអី
អ្នកនឹងឃើញការដ៏ធំវិសេស លើសជាងនេះទៅទៀត
៥១រួចទ្រង់មានបន្ទូលទៀតថា ប្រាកដមែន ខ្ញុំប្រាប់អ្នកជា
ប្រាកដថា អ្នករាល់គ្នានឹងឃើញមេឃបើកចំហ[ង] និងពួក
ទេវតានៃព្រះហោះឡើង ហោះចុះ[ច]លើកូនមនុស្ស[ឆ]។

**ទឹកបានប្រែទៅជាស្រាទំពាំងបាយជូរ**

**២** ១លុះ៣ថ្ងៃក្រោយមក មានវិវាហមង្គល នៅភូមិកាណា
ក្នុងស្រុកកាលីឡេ[ជ] ហើយមាតា[ឈ]ព្រះយេស៊ូវ ក៏នៅឯណោះ
ស្រាប់ ២គេបានអញ្ជើញព្រះយេស៊ូវ ព្រមទាំងពួកសិស្ស
ទ្រង់ ទៅឯការនោះដែរ ៣កាលស្រាទំពាំងបាយជូរអស់
ហើយ នោះមាតាព្រះយេស៊ូវទូលទ្រង់ថា គេអស់ស្រាទំពាំង
បាយជូរហើយ ៤តែព្រះយេស៊ូវមានបន្ទូលតបថា មាតា
អើយ[ញ] តើការនោះអំពល់អ្វីដល់យើង[ដ] ពេលវេលាខ្ញុំ[ឋ]
មិនទាន់មកដល់នៅឡើយ ៥មាតាទ្រង់ ក៏ប្រាប់ដល់ពួកបាវ
ថា ការអ្វីដែលលោកប្រាប់ឱ្យធ្វើ នោះត្រូវធ្វើចុះ[ឌ] ៦រីឯ
នៅទីនោះ មានពាងថ្ម៦ តាមទំនៀមការលាងសំអាត[ឍ]
របស់សាសន៍យូដា ពាងមួយៗនោះចំណុះទឹកបាន ២ ឬ
៣អម្រែក ៧ព្រះយេស៊ូវមានបន្ទូលទៅគេថា ចូរចាក់ទឹក
ឱ្យពេញពាងទាំងនេះទៅ គេក៏ចាក់ទឹកពេញដល់មាត់ពាង
៨រួចទ្រង់មានបន្ទូលប្រាប់គេថា ឥឡូវនេះ ចូរដងយកទៅជូន

**១:៤៩** ខ ខ.៣៨ មថ ២៣:៧
គ ខ.៣៤ មថ ៤:៣
ឃ មថ ២:២ ២៧:៤២ យហ ១២:១៣
**១:៥១** ង មថ ៣:១៦
ច លប ២៨:១២
ឆ មថ ៨:២០
**២:១** ជ យហ ៤:៤៦ ២១:២
ឈ មថ ១២:៤៦
**២:៤** ញ យហ ១៩:២៦
ដ មថ ៨:២៩
ឋ មថ ២៦:១៨
**២:៥** ឌ លប ៤១:៥៥
**២:៦** ឍ មក ៧:៣,៤ យហ ៣:២៥

សិក្សាព្រះគម្ពីរ (គម្ពីរសញ្ញាចាស់) នៅក្រោមដើមល្វានោះ ។

**១:៤៩** *លោកជាព្រះរាជបុត្រានៃព្រះ* (ខ.១៤,១៨,៣៤ ២០:៣១ មើលការពន្យល់ ៣:១៦)។ លោកអនទ្រេបានហៅព្រះនាមព្រះយេស៊ូវថា "ព្រះមែស៊ី (ខ.៤១)"។ រីឯលោកពេត្រុសវិញ បានហៅព្រះនាមទ្រង់ថា "ព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ (មថ ១៦:១៦)"។ *ជាស្តេចនៃសាសន៍អ៊ីស្រាអែល* ត្រង់ចំណុចនេះ ប្រហែលជាលោកណាថាណែលគិតថា ព្រះយេស៊ូវគ្រីស្ទយាងមកដើម្បីធ្វើជា ស្តេចរបស់សាសន៍អ៊ីស្រាអែលតែមួយប៉ុណ្ណោះ ប៉ុន្តែ ក្រោយមកទើបគាត់ដឹងយ៉ាងច្បាស់ថា ទ្រង់គឺជាស្តេចលើគ្រប់សាសន៍ទាំងអស់ (មក ១៥:៣២ មើលការពន្យល់ មថ ១២:១៣)។

**១:៥១** *អ្នករាល់គ្នានឹងឃើញមេឃបើកចំហ* ឃ្លានេះ ព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសសរសេរថា "អ្នករាល់គ្នានឹងឃើញស្ថានសួគ៌បើកចំហ"។ មានន័យថា ទ្វារនៃនគរស្ថានសួគ៌កំពុងតែបើកចំហ ហើយព្រះយេស៊ូវគ្រីស្ទគឺជាផ្លូវ និងជាសេចក្តីសង្គ្រោះតែមួយគត់ សម្រាប់មនុស្សនៅលើពិភពលោកនេះ (១៤:៦)។ *កូនមនុស្ស* សំដៅលើព្រះយេស៊ូវគ្រីស្ទ ។ ចំពោះពួកសាសន៍យូដា ពាក្យនេះមានអត្ថន័យសំខាន់ណាស់ ព្រោះមានជាប់ទាក់ទងទៅនឹងបទទំនាយ តាមរយៈលោកហោរាដានីយ៉ែលដែលថា កូនមនុស្សមានសិរីល្អ និងមានអំណាចគ្រប់គ្រង ហើយរាជ្យរបស់ទ្រង់ស្ថិតស្ថេរនៅអស់កល្បជានិច្ច (ដយ ៧:១៣-១៤ មក ១៣:២៦-២៧ មើលការពន្យល់ មក ៨:៣១)។

**២:១,២** *លុះ៣ថ្ងៃក្រោយមក* គឺ៣ថ្ងៃបន្ទាប់ពីពេលដែលព្រះយេស៊ូវទ្រង់បានជួបជាមួយនឹងលោកណាថាណែល (១:៤៧–៥១)។ នៅថ្ងៃទី៣នោះទ្រង់បានយាងមកដល់ស្រុកកាលីឡេ ជាមួយនឹងពួកសិស្សរបស់ទ្រង់ រួមមានពេត្រុស អនទ្រេ ភីលីព ណាថាណែល យ៉ាកុប និងយ៉ូហាន ។ ក្នុងពេលនោះដែរ គេបានសូមយាងទ្រង់ ឱ្យទៅចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍មួយនៅឯភូមិកាណា ដែលស្ថិតនៅភាគ ខាងជើងភូមិណាសារ៉ែត ប្រហែល ១៤គ.ម ។ លោកណាថាណែលរស់នៅក្នុងភូមិកាណានោះតែម្តង (២:១១ ៤:៤៦ ២១:១–២)។

**២:៣** *កាលស្រាទំពាំងបាយជូរអស់ហើយ* ត្រង់ចំណុចនេះបញ្ជាក់ថា នៅក្នុងពិធីមង្គលការអ្នកម្ចាស់កម្មវិធីមានទំនួលខុសត្រូវ ក្នុងការផ្គត់ផ្គង់ដល់ភ្ញៀវទាំងអស់ឱ្យបានសមរម្យ និងគ្រប់គ្រាន់ ។ ដូច្នោះហើយ បានជានៅពេលដែលស្រាទំពាំងបាយជូរសម្រាប់ទទួលភ្ញៀវបានអស់ ក្នុងខណៈពេលដែលមិនចប់កម្មវិធីនៅឡើយ នោះពួកគេក៏មានការព្រួយបារម្ភជាខ្លាំង ។ ប៉ុន្តែ មាតារបស់ព្រះយេស៊ូវបានទូលសូមទ្រង់ឱ្យជួយដល់ពួកគេ ព្រោះគាត់ដឹងថា ទ្រង់គឺជាព្រះដ៏ពិត ។

**២:៤** ក្នុងបទគម្ពីរនេះបញ្ជាក់ថា ព្រះយេស៊ូវគ្រីស្ទយាងមក មិនមែនដើម្បីធ្វើតាមបំណងចិត្តរបស់អ្នកណាម្នាក់ឡើយ គឺធ្វើតាមព្រះហឫទ័យរបស់ព្រះវរបិតាដែលចាត់ទ្រង់ឱ្យមកវិញ ។ *ពេលវេលាខ្ញុំមិនទាន់មកដល់នៅឡើយ* ឃ្លានេះមានន័យថា ពុំទាន់ដល់ពេលដែលព្រះយេស៊ូវសំដែងអង្គទ្រង់ ឱ្យពួកគេស្គាល់ថា ទ្រង់ជា ព្រះមែស៊ី ដែលត្រូវយាងមកនៅឡើយទេ ។ ម្យ៉ាងទៀត ការយាងមករបស់ទ្រង់ មិនមែនដើម្បីធ្វើការអស្ចារ្យប៉ុណ្ណោះទេ គឺទ្រង់ចង់ឱ្យពួកគេយកចិត្តទុកដាក់ស្តាប់ និងប្រតិបត្តិតាមសេចក្តីបង្រៀនរបស់ទ្រង់វិញ (មក ៥:៤៣ ៦:៤៥)។ អ្នកខ្លះយល់ថា ពេលវេលារបស់ព្រះយេស៊ូវគ្រីស្ទបានមកយ៉ាងពិតប្រាកដ គឺនៅពេលដែលទ្រង់សុគតនៅលើឈើឆ្កាង និងរស់ឡើងវិញ (៧:៦,៨,៣០ ១៣:១ ១៦:៣២ ១៧:១ មើលការពន្យល់ ៨:២០ ១២:២៣,២៧)។

**២:៦** *តាមទំនៀមការលាងសំអាត* ត្រង់ចំណុចនេះបញ្ជាក់ថា តាមទំនៀមទម្លាប់របស់ពួកសាសន៍យូដា គឺត្រូវតែធ្វើពិធីលាងសម្អាតដោយលាងដៃ (ដងទឹកមកចាក់ស្រោចលើដៃ) នៅមុន និងក្រោយពេលដែលបរិភោគអាហារ (មថ ១៥:២ មក ៧:៣,៤)។ ដូច្នេះនៅក្នុងពិធីមង្គលការនោះគេពិតជាត្រូវការទឹកយ៉ាងច្រើន ។

**២:៧** ក្នុងបទគម្ពីរនេះ ព្រះយេស៊ូវពុំមែនមានបន្ទូលទៅកាន់ពួកសិស្សរបស់ទ្រង់ទេ គឺទ្រង់មានបន្ទូលទៅពួកបាវបម្រើ ដែលគេជួលមកឱ្យធ្វើកិច្ចការនៅក្នុងពិធីមង្គលការនោះតែម្តង ។ ព្រះយេស៊ូវមានបន្ទូលទៅពួកអ្នកបម្រើទាំងនោះឱ្យដងទឹកមកចាក់ក្នុងពាងថ្មទាំង៦នោះ រហូតបានពេញទាំងអស់ ។ ប៉ុន្តែ ព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់ទាំងអស់ មិនបានប៉ះពាល់ទឹក

ដល់លោកជាមង្គលការចុះ គេក៏ដងយកទៅ ៩កាលអ្នក
មង្គលការបានភ្លក់ទឹក ដែលបានប្រែទៅជាស្រាទំពាំង
បាយជូរហើយ[ណ] ឥតមានដឹងជាមកពីណា (តែពួកបាវបំរើ
ដែលដងទឹកនោះ គេដឹង) នោះអ្នកមង្គលការក៏ហៅប្ដី
ថ្មោងថ្មីមកនិយាយថា ១០មនុស្សទាំងឡាយ គេតែងតែលើក
ស្រាទំពាំងបាយជូរល្អមកជាមុន លុះកាលបានផឹកជាច្រើន
ហើយ នោះទើបលើកស្រាទំពាំងបាយជូរ ដែលមិនសូវ
ល្អមកជាក្រោយ តែនេះ អ្នកបានទុកស្រាទំពាំងបាយជូរ
យ៉ាងល្អ ដរាបដល់ឥឡូវនេះវិញ ១១ព្រះយេស៊ូវទ្រង់ធ្វើ
ទីសំគាល់[ត]មុនដំបូងនេះ នៅភូមិកាណា ក្នុងស្រុកកាលីឡេ
ទាំងសំដែងសិរីល្អរបស់ទ្រង់[ថ] ហើយពួកសិស្សក៏ជឿដល់
ទ្រង់[ទ] ។

## ព្រះយេស៊ូវសម្អាតព្រះវិហារ

*២:១៤–១៦ = មថ ២១:១២,១៣ មក ១១:១៥–១៧*
*លក ១៩:៤៥,៤៦*

១២លុះក្រោយមក ទ្រង់យាងចុះទៅឯក្រុងកាពើណិម[ធ]
មានទាំងមាតា[ន០] បងប្អូន[ប] និងពួកសិស្សទ្រង់ទៅជាមួយផង
តែនៅឯណោះមិនយូរប៉ុន្មានទេ ១៣រីឯបុណ្យរំលង[ផ] របស់
សាសន៍យូដាក៏ជិតដល់ នោះព្រះយេស៊ូវទ្រង់យាងឡើង
ទៅឯក្រុងយេរូសាឡិម[ព] ១៤កាលទ្រង់ឃើញពួកអ្នកលក់គោ
លក់ចៀម លក់ព្រាប[ភ] នឹងពួកអ្នកដូរប្រាក់ អង្គុយនៅ
ក្នុងព្រះវិហារ[ម] ១៥នោះទ្រង់ក៏យកខ្សែធ្វើជារំពាត់ ដេញ
គេចេញពីព្រះវិហារទាំងអស់ទៅ គឺដេញទាំងចៀម ទាំង
គោ ហើយក៏ចាក់ប្រាក់របស់ពួកអ្នកដូរចេញដែរ ព្រម
ទាំងផ្កាប់តុគេផង ១៦រួចមាន បន្ទូលទៅពួកអ្នកលក់ព្រាប
ថា ចូរយករបស់ទាំងនេះចេញទៅ កុំឱ្យយកដំណាក់ នៃ
ព្រះវរបិតាខ្ញុំ[យ] ធ្វើជាផ្ទះជំនួញឡើយ ១៧ពួកសិស្សទ្រង់ក៏
នឹកឃើញពីសេចក្ដី ដែលចែងទុកមកថា «សេចក្ដីឧស្សាហ៍
ដល់ដំណាក់ទ្រង់ បានស៊ីបង្ហិនទូលបង្គំ[រ]» ១៨ដូច្នេះ ពួកសា
សន៍យូដា[ល] គេទូលសួរទ្រង់ថា ដែលលោកធ្វើយ៉ាង
ដូច្នេះនោះតើនឹងសំដែងទីសំគាល់ណា[វ] ឱ្យយើងខ្ញុំឃើញ
ផង[ស] ១៩ព្រះយេស៊ូវទ្រង់ឆ្លើយទៅគេថា ចូរបំផ្លាញ
ព្រះវិហារនេះចុះ រួចក្នុងរវាង៣ថ្ងៃខ្ញុំនឹងសង់ឡើងវិញ[ហ]

**២:៩** ណ យហ ៤:៤៦
**២:១១** ត ខ.២៣ មថ ១២:៣៨ យហ ៣:២ ៤:៤៨ ៦:២,១៤,២៦,៣០ ១២:៣៧ ២០:៣០ ថ យហ ១:១៤ ទ នក ១៤:៣១
**២:១២** ធ មថ ៤:១៣ ន មថ ១២:៤៦ ប មថ ១២:៤៦
**២:១៣** ផ យហ ១១:៥៥ ព ចទ ១៦:១–៦ លក ២:៤១
**២:១៤** ភ លវ ១:១៤ ចទ ១៤:២៦ ម ចទ ១៤:២៥
**២:១៦** យ លក ២:៤៩
**២:១៧** រ ទដ ៦៩:៩
**២:១៨** ល យហ ១:១៩ វ ខ.១១ ស មថ ១២:៣៨

ដែលនៅក្នុងពាងទាំងនោះទេ ។ ដូច្នេះ បញ្ជាក់ថា ការអស្ចារ្យនោះ មិនមែនកើតឡើងដោយក្លែងបន្លំទេ គឺពិតជាបានកើតឡើង ដោយសារព្រះចេស្ដារបស់ទ្រង់យ៉ាងពិតប្រាកដ ។

**២:៨–៩** *អ្នកមង្គលការ* ពាក្យនេះសំដៅលើអ្នកចាត់ចែង ឬអ្នកដឹកនាំកម្មវិធីដូចជានៅក្នុងពិធីមង្គលការជាដើម ។ ម្យ៉ាងទៀត អ្នកនេះមាននាទីចាត់ចែងអ្នកបម្រើ និងទទួលខុសត្រូវក្នុងការផ្គត់ផ្គង់ម្ហូបអាហារដល់ភ្ញៀវទាំងអស់ដែលមកចូលរួម ។

**២:១០** នៅក្នុងបទគម្ពីរនេះបញ្ជាក់ថា ជាទូទៅ គេតែងតែយកស្រាទំពាំង–បាយជូរ ដែលល្អមកបម្រើភ្ញៀវជាមុន ។ បន្ទាប់មក នៅពេលដែលពួកភ្ញៀវបានស្រវឹងហើយ ទើបគេយកស្រាដែលមិនល្អមកជាក្រោយ ។ ដូច្នោះហើយ បានជាក្នុងខណៈពេលដែលអ្នកមង្គលការ បានភ្លក់ទឹកដែលបានប្រែទៅជាស្រាទំពាំងបាយជូរនោះហើយ គាត់មានការចម្លែកក្នុងចិត្តជាខ្លាំង ព្រោះថាវាជាស្រាទំពាំងបាយជូរដ៏ល្អវិសេសពិតៗ ។

**២:១១** *ទីសំគាល់* សំដៅលើការអស្ចារ្យទាំងឡាយ ដែលកើតឡើងដោយសារអំណាចព្រះចេស្ដារបស់ព្រះយេស៊ូវគ្រីស្ទ ។ ការទាំងនោះកើតឡើងដើម្បីសំដែងនូវសិរីល្អដល់ទ្រង់ និងបញ្ជាក់ថា ទ្រង់គឺជាព្រះរាជបុត្រានៃព្រះដ៏ពិត ។ បន្ទាប់ពីបានឃើញទីសំគាល់នោះមក ពួកសិស្សរបស់ទ្រង់ ក៏មានសេចក្ដីជំនឿលើទ្រង់កាន់តែខ្លាំងឡើង ។

**២:១២** *ក្រុងកាពើណិម* ជាទីក្រុងមួយស្ថិតនៅឆ្នេរភាគខាងជើងឆៀងខាងលិច នៃសមុទ្រកាលីឡេ (មើលពន្យល់ មថ ៤:១៣ លក ១០:១៥) ។ *បងប្អូន* ត្រង់ចំណុចនេះប្រហែលជាសំដៅលើពួកកូនរបស់លោកយ៉ូសែប និងនាងម៉ារា ហើយនៅក្នុងចំណោមអ្នកទាំងនោះមានលោកយ៉ាកុបម្នាក់ដែរ ។

**២:១៣** *បុណ្យរំលង* ពួកយូដាតែងតែប្រារព្ធធ្វើពិធីបុណ្យនេះឡើងនៅពាក់កណ្ដាលខែចេត្រ (ត្រូវនឹងខែមេសា) ជារៀងរាល់ឆ្នាំ (នក ១២ មើលការពន្យល់ នក ១២:១១–២៣ លក ២២:១ មថ ២៦:១៧,១៨–៣០ មក ១៤:១,១២) ។ តាមទំនៀមទម្លាប់ពួកប្រុសៗជាសាសន៍យូដា ត្រូវតែធ្វើដំណើរទៅចូលរួមក្នុងពិធីបុណ្យនេះ នៅឯទីក្រុងយេរូសាឡិម (៥:១ ចទ ១៦:១៦) ។

**២:១៤** *លក់គោ លក់ចៀម លក់ព្រាប* សត្វទាំងអស់នេះពួកគេប្រើសម្រាប់ធ្វើជាយញ្ញបូជាលោះបាប និងមានលក់នៅក្បែរព្រះវិហារតែម្ដង ។ ប៉ុន្តែក្រោយមក ពួកឈ្មួញបានយកសត្វទាំងនេះ ទៅលក់នៅក្នុងព្រះវិហារ ត្រង់ទីលានសម្រាប់សាសន៍ដទៃតែម្ដង ។ *ក៏ចាក់ប្រាក់របស់ពួកអ្នកដូរចេញដែរ* ត្រង់ចំណុចនេះ បញ្ជាក់ថា ការដែលចូលទៅក្នុងព្រះវិហារគឺត្រូវតែបង់ពន្ធដោយប្រើប្រាស់ប្រាក់របស់ពួកយូដា ។ អស់អ្នកដែលមានប្រាក់បរទេស ត្រូវតែដូរយកប្រាក់យូដា ដូច្នោះហើយ ទើបបណ្ដាលឱ្យមានកន្លែងដូរប្រាក់នៅទីនោះ (មើលការពន្យល់ មក ១១:១៥) ។ នៅពេលដែលព្រះយេស៊ូវឃើញពួកគេធ្វើយ៉ាងដូច្នោះ ទ្រង់ក៏ដេញពួកគេទាំងអស់ ឱ្យចេញពីព្រះវិហារ ព្រមទាំងចាក់ប្រាក់របស់ពួកគេចោលផង (ខ.១៥) ។

**២:១៧** ត្រង់ចំណុចនេះបញ្ជាក់ថា ពួកសិស្សរបស់ព្រះយេស៊ូវបាននឹកឃើញអំពីសេចក្ដីទំនាយនៅក្នុងបទគម្ពីរ "ទដ ៦៩:៩" ដែលមានន័យថា ទ្រង់មានព្រះហឫទ័យឧស្សាហ៍ដល់ដំណាក់របស់ទ្រង់ណាស់ ។ ម្យ៉ាងទៀត បទគម្ពីរនេះក៏បានបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទគឺពិតជាព្រះមែស៊ីដែលត្រូវយាងមកនោះមែន ។

**២:១៩** ពួកសាសន៍យូដាយល់ច្រឡំថា ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលសំដៅលើព្រះវិហារ នៅឯទីក្រុងយេរូសាឡិមនោះតែម្ដង ។ ប៉ុន្តែ លោកយ៉ូហានបានប្រាប់យ៉ាងច្បាស់ថា ព្រះយេស៊ូវមានបន្ទូលយ៉ាងដូច្នោះ គឺសំដៅលើ

[២០]ដូច្នេះ ពួកសាសន៍យូដាទូលថា គេសង់ព្រះវិហារនេះ
ពេញ៤៦ឆ្នាំគត់ តែលោកនឹងសង់ឡើងវិញ ក្នុងរវាង៣ថ្ងៃ
ឬ [២១]ប៉ុន្តែ គឺទ្រង់មានបន្ទូល ពីព្រះវិហារ ដែលជារូបអង្គ
ទ្រង់ទេ[ឡ] [២២]ដូច្នេះ កាលទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើង
វិញ នោះពួកសិស្សនឹកឃើញថា ទ្រង់បានមានបន្ទូលពាក្យ
នោះ[អ]ហើយគេក៏ជឿគម្ពីរ[ក] និងព្រះបន្ទូលរបស់ព្រះយេស៊ូវ
[២៣]កាលទ្រង់គង់នៅក្រុងយេរូសាឡិម នៅក្នុងវេលាបុណ្យ
រំលង[ខ] នោះមានមនុស្សជាច្រើនជឿ[គ]ដល់ព្រះនាមទ្រង់
ដោយឃើញទីសំគាល់[ឃ]ដែលទ្រង់ធ្វើមក [២៤]តែព្រះយេស៊ូវ
ទ្រង់មិនទុកចិត្តនឹងគេទេ ពីព្រោះទ្រង់ស្គាល់ដល់គ្រប់ទាំង
មនុស្ស [២៥]ហើយទ្រង់មិនត្រូវការឱ្យ អ្នកណាធ្វើបន្ទាល់
ពីមនុស្សណាទេ[ង] ដ្បិតទ្រង់ជ្រាបហើយពីសេចក្តី ដែលនៅ
ក្នុងមនុស្សទាំងឡាយ[ច]។

## ព្រះយេស៊ូវ និងលោកនីកូដេម

**៣** [១]រីឯនៅក្នុងពួកផារិស៊ី មានចៅហ្វាយ សាសន៍យូដា
ម្នាក់[ឆ] ឈ្មោះនីកូដេម[ជ] [២]លោកក៏មកឯព្រះយេស៊ូវទាំងយប់
ទូលថា លោកគ្រូ[ឈ] យើងខ្ញុំដឹងថា[ញ]លោកជាគ្រូមកពីព្រះពិត
ដ្បិតគ្មានអ្នកណា អាចនឹងធ្វើទីសំគាល់[ដ] ដែលលោកធ្វើទាំង
នេះបានទេ លើកតែព្រះគង់នៅជាមួយប៉ុណ្ណោះ[ឋ] [៣]ព្រះយេ
ស៊ូវមានបន្ទូលឆ្លើយថា ប្រាកដមែន ខ្ញុំប្រាប់ អ្នកជាប្រាកដថា
បើមិនបានកើតជាថ្មី នោះគ្មានអ្នកណាអាច នឹងឃើញនគរ
ព្រះបានទេ[ឌ ឍ] [៤]លោកនីកូដេមទូលសួរថា ធ្វើដូចម្តេចនឹង
កើតឡើងបាន ក្នុងកាលដែលចាស់ហើយ តើអាចនឹង
ចូលទៅក្នុងពោះម្តាយម្តងទៀត ហើយកើតឡើងវិញបានឬ
[៥]ព្រះយេស៊ូវមានបន្ទូលឆ្លើយថា ប្រាកដមែនខ្ញុំប្រាប់អ្នក
ជាប្រាកដថា បើមិនបានកើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ
នោះគ្មានអ្នកណា អាចនឹងចូលទៅក្នុងនគរព្រះបានទេ[ណ ត]
[៦]របស់អ្វីដែលកើតពីសាច់ នោះជាសាច់ទេ ហើយដែល
កើតពីព្រះវិញ្ញាណ នោះជាវិញ្ញាណវិញ[ថ] [៧]កុំឱ្យឆ្ងល់ពី

**២:១៩** ហ មថ ១៦:២១ ២៦:៦១ ២៧:៤០ មក ១៤:៥៨ ១៥:២៩ កច ៦:១៤ **២:២១** ឡ ១កថ ៦:១៩ **២:២២** អ លក ២៤:៥–៨ យហ ១២:១៦ ១៤:២៦ ក ទដ ១៦:១០ លក ២៤:២៧ **២:២៣** ខ ខ.១៣ គ យហ ៣:១៥ ឃ ខ.១១ **២:២៥** ង អស ១១:៣ ច ចទ ៣១:២១ ១ពវ ៨:៣៩ មថ ៩:៤ យហ ៦:៦១,៦៤ ១៣:១១ **៣:១** ឆ លក ២៣:១៣ ជ យហ ៧:៥០ ១៩:៣៩ **៣:២** ឈ មថ ២៣:៧ ញ ខ.១១ ដ យហ ២:១១ ឋ យហ ១០:៣៨ ១៤:១០,១១ កច ២:២២ **៣:៣** ឌ យហ ១:១៣ ឍ មថ៣:២ **៣:៥** ណ កច ២២:១៦ ត ទត ៣:៥ **៣:៦** ថ យហ ១:១៣ ១កថ ១៥:៥០

ព្រះវិហារដែលជារូបអង្គទ្រង់ផ្ទាល់ ដែលត្រូវសុគត ហើយ៣ថ្ងៃក្រោយមក ទ្រង់នឹងរស់ឡើងវិញ (ខ.២១)។ ក្រោយមកទៀត ពួកសាសន៍យូដាបានយកសេចក្តីដែលទ្រង់មានបន្ទូលនោះ មកសម្រាប់ចោទប្រកាន់ទ្រង់តែម្តង (មថ ២៧:៤០ មក ១៥:២៩ មើលការពន្យល់ មថ ២៦:៦១ មក ១៤:៥៨)។ ពួកគេក៏បានចោទប្រកាន់លោកស្ទេផាន តាមរបៀបដូចគ្នានេះដែរ (មើលការពន្យល់ កច ៦:១៣)។

**២:២០** *ពេញ៤៦ឆ្នាំគត់* ស្តេចហេរ៉ូឌបានចាប់ផ្តើមសាងសង់ព្រះវិហារនៅទីក្រុងយេរូសាឡិមឡើងវិញនៅឆ្នាំទី១៩ ឬ២០មុនគ.ស ។ ការសាងសង់នោះបានបន្តរហូតដល់ឆ្នាំទី៤៦គ.ស ។ ព្រះយេស៊ូវទ្រង់មានបន្ទូលទៅពួកគេ អំពីការបំផ្លាញព្រះវិហារនោះប្រហែលជានៅឆ្នាំទី២៧គ.ស។ ដូច្នេះ រយៈពេលចាប់ពីឆ្នាំទី១៩ មុនគ.ស រហូតដល់ឆ្នាំទី២៧គ.ស គឺស្មើនឹង៤៦ឆ្នាំ ។

**២:២២** ត្រង់ចំណុចនេះបញ្ជាក់ថា នៅពេលដែលពួកសិស្សរបស់ព្រះយេស៊ូវបានឮសេចក្តី ដែលទ្រង់មានបន្ទូលអំពីការបំផ្លាញព្រះវិហារនោះ ពួកគេមិនទាន់បានយល់ច្បាស់នៅឡើយទេ ។ ពួកគេបានយល់សេចក្តីនោះយ៉ាងច្បាស់ នៅពេលដែលទ្រង់រស់ពីសុគតឡើងវិញ និងបានសំដែងអង្គទ្រង់ ឱ្យពួកគេឃើញដោយផ្ទាល់តែម្តង (យហ ១៤:២៦ មក ៨:៣១ ៩:៣១)។ *ហើយគេក៏ជឿគម្ពីរ* មានន័យថា ពួកសិស្សរបស់ព្រះយេស៊ូវ ក៏ជឿសេចក្តីដែលចែងអំពីការសុគត និងការរស់ឡើងវិញរបស់ទ្រង់ (១កថ ១៥:៤ មើលការពន្យល់ ទដ ១៦:១០ ១៧:១៥ យហ ២០:៩)។

**២:២៣–២៥** នៅពេលនោះមានមនុស្សជាច្រើនគ្រាន់តែជឿថា ព្រះយេស៊ូវគ្រីស្ទ គឺជាគ្រូបង្រៀនដែលមកពីព្រះ ឬជាព្រះមែស៊ីប៉ុណ្ណោះ ។ ពួកគេមិនបានយល់ថា ទ្រង់ជាព្រះសង្គ្រោះរបស់ខ្លួនទេ ដូច្នេះហើយបានជាទ្រង់មិនទុកចិត្តនឹងពួកគេទេ ។

**៣:១** *ពួកផារិស៊ី* ជាពួកអ្នកកាន់សាសនាយូដាដែលជឿថាមានការរស់ឡើងវិញ មានទេវតា និងមានវិញ្ញាណ (មើលការពន្យល់ មថ ៣:៧ មក ២:១៦ លក ៥:១៧ កច ២៣:៦–៨)។

**៣:២** *ទាំងយប់* ត្រង់ចំណុចនេះបញ្ជាក់ថា ប្រហែលជាលោកនីកូដេមមានកិច្ចការច្រើនត្រូវធ្វើ ព្រោះគាត់គឺជាសមាជិកម្នាក់នៃពួកក្រុមជំនុំ ដូច្នោះហើយទើបមិនអាចមកជួបព្រះយេស៊ូវនៅពេលថ្ងៃបាន ។ ម្យ៉ាងទៀតប្រហែលជាគាត់ ចង់មានពេលច្រើន ដើម្បីពិភាក្សាជាមួយនឹងព្រះយេស៊ូវ ព្រោះថានាពេលថ្ងៃមានមនុស្សជាច្រើននៅជាមួយទ្រង់ ។

**៣:៣,៧** *កើតជាថ្មី* សំដៅលើការកើតជាថ្មីខាងឯវិញ្ញាណ និងការទទួលបានជីវិតថ្មី ដែលព្រះយេស៊ូវគ្រីស្ទទ្រង់ប្រទានឱ្យ ។ នៅក្នុងភាសាក្រិក ពាក្យនេះអាចមានន័យថា "កើតមកពីស្ថានសួគ៌" (មើលការពន្យល់ ១:១៣)។

**៣:៥** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា គ្មានអ្នកណាម្នាក់អាចចូលទៅក្នុងនគរព្រះបានទេ បើមិនបានកើតជាថ្មីខាងឯវិញ្ញាណនោះទេ ។ *កើតអំពីទឹក* សំដៅលើការជ្រមុជដោយទឹក ដែលជា "និមិត្តរូប" នៃការលាងសម្អាតអំពើបាប។ ចូរចងចាំថា អំពើបាបរបស់មនុស្សម្នាក់ៗត្រូវបានលាងសម្អាត ដោយសារអំណាច ព្រះចេស្តានៃព្រះលោហិតរបស់ព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ មិនមែនដោយសារទឹកទេ ។ *ហើយអំពីព្រះវិញ្ញាណ* ឃ្លាថា "កើតអំពីព្រះវិញ្ញាណ" គឺមានន័យដូចគ្នា នឹងឃ្លាថា "កើតអំពីព្រះអម្ចាស់"។ នៅក្នុងខណៈពេលដែលអ្នកណាម្នាក់ទទួល ព្រះយេស៊ូវគ្រីស្ទជាព្រះសង្គ្រោះនៅក្នុងជីវិតរបស់ខ្លួន នោះព្រះវិញ្ញាណបរិសុទ្ធយាងចូលគង់នៅក្នុងអ្នកនោះ ហើយក៏មានន័យថា អ្នកនោះបានកើតជាថ្មីខាងឯវិញ្ញាណយ៉ាងពិតប្រាកដ (ខ.៨ ១:៣១ មើលការពន្យល់ ទត ៣:៥)។

**៣:៦–៧** ត្រង់ចំណុចនេះបញ្ជាក់ថា មនុស្សកើតមកនៅក្នុងលោកិយនេះ គឺបានកើតមកខាងឯសាច់ឈាម ហើយដោយសារបាបនោះមិនអាចចូលទៅឯនគរព្រះបានទេ ដូច្នេះ ដើម្បីចូលទៅក្នុងនគរព្រះបាននោះត្រូវតែកើត

ពាក្យដែលខ្ញុំប្រាប់ថា ត្រូវតែកើតជាថ្មីនោះឡើយ ៨ឯខ្យល់
ចង់បក់ទៅឯណា ក៏ចេះតែបាន ហើយអ្នកឮសូរសព្ទតែមិន
ដឹងជាមកពីណា ឬទៅឯណាទេ អស់អ្នកណាដែលកើតមក
ពីព្រះវិញ្ញាណនោះក៏ដូច្នោះដែរ[ទ] ៩លោកនីកូដេមទូលសួរ
ថា ធ្វើដូចម្ដេច ឱ្យការទាំងនេះ កើតបាន[ធ] ១០ព្រះយេស៊ូវ
ទ្រង់ឆ្លើយថា អ្នកជាគ្រូនៃសាសន៍អ៊ីស្រាអែល[ន] តែមិនដឹង
ការទាំងនេះទេឬ ១១ប្រាកដមែន ខ្ញុំប្រាប់អ្នកជាប្រាកដថា
យើងប្រាប់ពីការដែលយើងដឹង[ប] ហើយធ្វើបន្ទាល់ពីការ
ដែលយើងបានឃើញ តែអ្នករាល់គ្នាមិនទទួលសេចក្ដី
បន្ទាល់របស់យើងទេ[ផ] ១២បើខ្ញុំនិយាយប្រាប់អ្នករាល់
គ្នា ពីការដែលត្រូវខាងផែនដី តែអ្នករាល់គ្នាមិនជឿទៅ
ហើយ នោះចំណង់បើខ្ញុំប្រាប់ពីការ ដែលត្រូវខាងស្ថាន
សួគ៌វិញ តើធ្វើដូចម្ដេចនឹងឱ្យជឿទៅបាន ១៣គ្មានអ្នកណា
បានឡើងទៅស្ថានសួគ៌ឡើយ[ព] មានតែព្រះអង្គ ដែលយាង
ចុះពីស្ថានសួគ៌មកប៉ុណ្ណោះ[ភ] គឺជាកូនមនុស្សដែលនៅស្ថាន
សួគ៌នោះឯង[ម] ១៤ហើយដែលលោកម៉ូសេបានលើកសត្វ
ពស់ឡើង នៅទីរហោស្ថាន[យ]ជាយ៉ាងណា នោះកូនមនុស្ស
នឹងត្រូវគេលើកលោកឡើងយ៉ាងនោះដែរ[រ] ១៥ដើម្បីឱ្យ

**៣:៨** ទ ១កថ
២:១៤-១៦
**៣:៩** ធ យហ
៦:៥២,៦០
**៣:១០** ន លក ២:៤៦
**៣:១១** ប យហ
១:១៨ ៧:១៦,១៧
**៣:១១** ផ ខ.៣២
**៣:១៣** ព សភ
៣០:៤ កថ ២:៣៤
អភ ៤:៨-១០
ភ ខ.៣១
យហ ៦:៣៨,៤២
ហព ៤:១៤ ៩:២៤
ម មថ ៨:២០
**៣:១៤** យ ជន
២១:៨,៩ រ ១២:៣២
**៣:១៥** ល ខ.១៦,៣៦
លប ១៥:៦
ជន ១៤:១១
មថ ២៧:៤២
មក ១:១៥
យហ ១:៧,១២
២:២៣ ៥:២៤

អ្នកណាដែលជឿ[ល] ដល់កូនមនុស្សនោះ មិនត្រូវវិនាសឡើយ
គឺឱ្យមានជីវិត អស់កល្បជានិច្ចវិញ[វ] ១៦ដ្បិតព្រះទ្រង់ស្រ
ឡាញ់[ស]មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទាន[ហ]ព្រះរាជ
បុត្រាទ្រង់តែ១[ឡ] ដើម្បី ឱ្យអ្នកណាដែលជឿ[អ]ដល់ព្រះរាជ
បុត្រានោះ មិនត្រូវវិនាសឡើយ គឺឱ្យមានជីវិតអស់កល្ប
ជានិច្ចវិញ[ក] ១៧ពីព្រោះ ព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រា
ទ្រង់ ឱ្យមកក្នុងលោកីយ[ខ] ដើម្បីនឹងជំនុំជំរះលោកីយនោះទេ
គឺឱ្យលោកីយបានសង្គ្រោះ ដោយសារទ្រង់វិញ[គ] ១៨ឯអ្នក
ណាដែលជឿដល់ទ្រង់ នោះមិនជាប់មានទោសទេ[ឃ] តែអ្នក
ណាដែលមិនជឿវិញ នោះត្រូវមានទោសហើយពីព្រោះ
មិនបានជឿដល់ព្រះនាមនៃ ព្រះរាជបុត្រាតែ១របស់ព្រះ[ង]

៧:៣៨ ២០:២៩ កថ ១៣:៣៩ ១៦:៣១ រម ៣:២២ ១០:៩,១០ ១យហ ៥:១,៥,
១០ វ ខ.១៦,៣៦ មថ ២៥:៤៦ យហ ២០:៣១ **៣:១៦** ស រម ៥:៨ អភ ២:៤
១យហ ៤:៩,១០ ហ អស ៩:៦ រម ៨:៣២ ឡ លប ២២:១២ យហ ១:១៨ អ
ខ.១៥ ក ខ.៣៦ យហ ៦:២៩,៤០ ១១:២៥,២៦ **៣:១៧** ខ យហ ៦:២៩,៥៧
១០:៣៦ ១១:៤២ ១៧:៨,២១ ២០:២១ គ អស ៥៣:១១ មថ ១:២១
លក ២:១១ ១៩:១០ យហ ១:២៩ ១២:៤៧ រម ១១:១៤ ១ធថ ១:១៥
២:៥,៦ ១យហ ២:២ ៣:៥ **៣:១៨** ឃ យហ ៥:២៤

ជាថ្មីខាងឯវិញ្ញាណ (ខ.៣)។

**៣:៨** នៅក្នុងបទគម្ពីរនេះបញ្ជាក់ថា ព្រះវិញ្ញាណបរិសុទ្ធទ្រង់គង់នៅគ្រប់ទីកន្លែងទាំងអស់ ។ ម្យ៉ាងទៀត ព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទទាំងអស់ ប៉ុន្តែ គ្មានអ្នកណាអាចមើលឃើញទ្រង់ដែលគង់នៅក្នុងពួកគេនោះទេ ។

**៣:៩-១០** លោកនីកូដេមគឺជាគ្រូនៃសាសន៍អ៊ីស្រាអែល ប៉ុន្តែ គាត់នៅតែពុំយល់សេចក្ដីដែលព្រះយេស៊ូវមានបន្ទូលនៅពេលនោះទេ ។ ការនេះបញ្ជាក់យ៉ាងច្បាស់ថា មនុស្សមិនអាចយល់ព្រះបន្ទូលព្រះអម្ចាស់ ដោយប្រើប្រាជ្ញារបស់ខ្លួនបានឡើយ លុះណាតែមានការបើកសំដែងអំពីទ្រង់ ។

**៣:១១** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ទោះជាព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់ បានធ្វើបន្ទាល់អំពីសេចក្ដីពិត ដែលនាំឱ្យពួកគេបានការសង្គ្រោះក៏ដោយ ក៏មានពួកគេជាច្រើននៅតែមិនព្រមជឿដដែល ។ *សេចក្ដីបន្ទាល់* "មើលការពន្យល់ ១:៧"។

**៣:១២** *ការដែលត្រូវខាងផែនដី* សំដៅលើការទាំងឡាយណាដែលកើតឡើង នៅលើពិភពលោកនេះ និងអ្វីៗដែលមនុស្សអាចយល់បាន ។ *ពីការដែលត្រូវខាងស្ថានសួគ៌* សំដៅទៅលើការទាំងឡាយ ដែលទាក់ទងខាងឯវិញ្ញាណ និងសេចក្ដីពិតមកពីព្រះអម្ចាស់ ។

**៣:១៣** *មានតែព្រះអង្គ ដែលយាងចុះពីស្ថានសួគ៌មកប៉ុណ្ណោះ* ឃ្លានេះមានន័យថា ព្រះយេស៊ូវគ្រីស្ទបានយាងចុះពីស្ថានសួគ៌ មកគង់នៅក្នុងចំណោមមនុស្សនៅលើផែនដីនេះ និងបានបង្រៀនពួកគេនូវសេចក្ដីពិត អំពីការសង្គ្រោះដ៏ពិតប្រាកដ។ *កូនមនុស្ស* សំដៅលើព្រះយេស៊ូវ "មើលការពន្យល់ មក ៨:៣១ លក ១៩:១០"។

**៣:១៤** *លោកម៉ូសេបានលើកសត្វពស់ឡើង . . . នោះកូនមនុស្សនឹងត្រូវគេលើកលោកឡើងយ៉ាងនោះដែរ* ការដែលលោកម៉ូសេបានលើកសត្វពស់ឡើងនោះ គឺជាតំណាងអំពីការយាងមកសុគតរបស់ព្រះយេស៊ូវគ្រីស្ទ ដើម្បីនាំសេចក្ដីសង្គ្រោះដល់មនុស្សទាំងអស់ ដែលកំពុងរស់នៅក្រោមអំណាចបាប ប្រយោជន៍ឱ្យអស់អ្នកណាដែលទទួលជឿដល់ព្រះនាមទ្រង់ បានទៅឯទ្រង់វិញ (មើលការពន្យល់ ៨:២៨ ១២:៣២ ជន ២១:៨-៩ ២ពវ ១៨:៤)។

**៣:១៥,១៦** ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវសុគតគឺដើម្បីជួយសង្គ្រោះមនុស្សលោក ឱ្យមានជីវិតយ៉ាងពិតប្រាកដ និងរស់នៅមានទំនាក់ទំនងជាមួយទ្រង់អស់កល្បជានិច្ច (រម ៥:៨ វវ ២១:១-៤)។

**៣:១៦** *ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក* ព្រះយេស៊ូវគ្រីស្ទជាសេចក្ដីស្រឡាញ់ (១យហ ៤:៨-១០) ហើយទ្រង់ស្រឡាញ់មនុស្សទាំងអស់ដោយមិនរើសមុខ ។ ភស្តុតាងដែលបញ្ជាក់ថា ទ្រង់ស្រឡាញ់មនុស្សលោក គឺបានសំដែងយ៉ាងច្បាស់ ដោយការសុគតរបស់ទ្រង់នៅលើឈើឆ្កាង ដើម្បីសង្គ្រោះពួកគេមិនឱ្យវិនាសឡើយ ។ *មនុស្សលោក* គឺមនុស្សទាំងអស់នៅលើពិភពលោកនេះ (១:១៩)។ *ព្រះរាជបុត្រាទ្រង់តែ១* គឺព្រះយេស៊ូវគ្រីស្ទ (អស ៩:៦ មើលពន្យល់ លប ២២:២,១៦ ២សយ ៧:១៤ យហ ១:១៤,១៨ ២០:៣១ រម ៨:៣២)។ ម្យ៉ាងទៀត អស់អ្នកដែលជឿដល់ព្រះនាមព្រះអម្ចាស់ក៏ត្រូវបានហៅថា កូនប្រុសកូនស្រីរបស់ទ្រង់ (២កថ ៦:១៨ កទ ៤:៤-៦)។

**៣:១៧** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវទ្រង់យាងមកដើម្បីសង្គ្រោះមនុស្សលោក មិនមែនមកដើម្បីជំនុំជម្រះពួកគេទេ (លក ១៩:១០ រម ៨:១)។

**៣:១៨** ត្រង់ចំណុចនេះមានន័យថា អស់អ្នកណាដែលជឿដល់ព្រះយេស៊ូវគ្រីស្ទនោះមិនជាប់មានទោសទេ ប៉ុន្តែ ចំពោះពួកអ្នកដែលមិនព្រមជឿដល់ទ្រង់ នោះនឹងត្រូវមានទោស ។

១៩ហើយទោសនេះ គឺថា ពន្លឺ[ច]បានមកក្នុងលោកីយ តែមនុស្ស
លោកចូលចិត្តនឹងសេចក្ដីងងឹត ជាជាងពន្លឺ ពីព្រោះអំពើ
ដែលគេធ្វើទាំងប៉ុន្មាន សុទ្ធតែអាក្រក់[ឆ] ២០ដ្បិតអ្នកណា
ដែលប្រព្រឹត្តអាក្រក់ នោះតែងស្អប់ដល់ពន្លឺ ហើយមិនមក
ឯពន្លឺទេ ក្រែងអំពើដែលខ្លួនប្រព្រឹត្តទាំងប៉ុន្មាន បានបើក
ឱ្យឃើញ[ជ] ២១តែអ្នកណាដែល ប្រព្រឹត្តតាមសេចក្ដីពិតវិញ
នោះតែងមកឯពន្លឺ ដើម្បីឱ្យ អំពើដែលខ្លួនប្រព្រឹត្ត
បានសំដែងមកឱ្យដឹងថា បានធ្វើ ដោយនូវព្រះ។

## លោកយ៉ូហាន–បាទីស្ទធ្វើបន្ទាល់អំពីព្រះយេស៊ូវ

២២ក្រោយនោះមក ព្រះយេស៊ូវ និងពួកសិស្សទ្រង់ ក៏មក
ក្នុងស្រុកយូដា ទ្រង់គង់នៅទីនោះជាមួយនឹងគេ ព្រមទាំង
ធ្វើបុណ្យជ្រមុជទឹកផង[ឈ] ២៣ឯយ៉ូហាន[ញ] គាត់កំពុងតែធ្វើ
បុណ្យជ្រមុជទឹកនៅស្រុកអេណូន ជិតភូមិសាលិម ព្រោះនៅ
ទីនោះមានទឹកច្រើន ហើយចេះតែមានគេមក ដើម្បីទទួល
បុណ្យជ្រមុជទឹកផង ២៤ដ្បិត យ៉ូហានមិនទាន់ជាប់គុកនៅ
ឡើយ[ដ] ២៥វេលានោះ ពួកសិស្សយ៉ូហាន នឹងសាសន៍យូដា
ម្នាក់ កើតជជែកគ្នា ពីដំណើរលាងសំអាត[ឋ] ២៦រួចគេមកឯ
យ៉ូហាន ជំរាបថា លោកគ្រូ[ឌ] លោកនោះដែលនៅជាមួយ
នឹងលោក ខាងនាយទន្លេយ័រដាន់ ដែលលោកបានធ្វើ
បន្ទាល់ឱ្យ[ឍ] មើល លោកក៏ធ្វើបុណ្យជ្រមុជដែរ ហើយបណ្ដា
មនុស្សទាំងប៉ុន្មាន គេទៅឯលោកវិញ ២៧យ៉ូហានឆ្លើយថា
គ្មានមនុស្សណា អាចនឹងទទួលអ្វីបានទេ លើកតែបានប្រទាន
ពីស្ថានសួគ៌មកឱ្យប៉ុណ្ណោះ ២៨ខ្លួនអ្នករាល់គ្នាជាទីបន្ទាល់
ពីខ្ញុំ ដែលខ្ញុំថា ខ្ញុំមិនមែនជាព្រះគ្រីស្ទទេ គឺគ្រាន់តែទទួល
បង្គាប់នឹងមកនាំមុខទ្រង់ប៉ុណ្ណោះ[ណ] ២៩អ្នកណាដែលយកប្រ
ពន្ធ នោះឈ្មោះថាជាប្ដី[ត]ហើយ ឯពួកមិត្រសំឡាញ់ ដែល
ឈរស្ដាប់គាត់ កំពុងដែលរៀបការ នោះក៏មានសេចក្ដី
អំណរអរឡើង ដោយសារសំឡេងប្ដី គឺយ៉ាងនោះឯង
ដែលសេចក្ដីអំណររបស់ខ្ញុំបាន ពោរពេញហើយ[ថ] ៣០ត្រូវ
ឱ្យព្រះអង្គនោះ បានចំរើនឡើង ហើយខ្ញុំត្រូវថយវិញចុះ
៣១ព្រះអង្គ ដែលមកពីស្ថានលើ[ទ] នោះខ្ពស់លើសទាំង អស់
ឯមនុស្សដែលនៅផែនដី នោះកើតពីផែនដីមក ហើយ
ក៏និយាយ តាមរបៀបផែនដី[ធ] តែព្រះអង្គដែលយាងមកពី
ស្ថានសួគ៌ នោះខ្ពស់លើសជាងទាំងអស់ ៣២ទ្រង់ធ្វើបន្ទាល់
ពីការដែលទ្រង់បានឃើញ ហើយឮ[ន] តែគ្មានអ្នកណាដែល
ទទួលសេចក្ដីបន្ទាល់របស់ទ្រង់ទេ[ប] ៣៣អ្នកណាដែលទទួល
សេចក្ដីបន្ទាល់របស់ទ្រង់ នោះបានបោះត្រា យល់ព្រមថា
ព្រះទ្រង់ពិតត្រង់មែន ៣៤ដ្បិតព្រះអង្គ ដែលព្រះបានចាត់

**៣:១៨** ង យហ ១:១៨ ១យហ ៤:៩
**៣:១៩** ច យហ ១:៤ ឆ ទដ ៥២:៣ យហ ៧:៧
**៣:២០** ជ អភ ៥:១១,១៣
**៣:២២** ឈ យហ ៤:២
**៣:២៣** ញ មថ ៣:១
**៣:២៤** ដ មថ ៤:១២ ១៤:៣
**៣:២៥** ឋ យហ ២:៦
**៣:២៦** ឌ មថ ២៣:៧ ឍ យហ ១:៧
**៣:២៨** ណ យហ ១:២០,២៣
**៣:២៩** ត មថ ៩:១៥ ថ យហ ១៦:២៤ ១៧:១៣ ភល ២:២ ១យហ ១:៤ ២យហ ១២
**៣:៣១** ទ ខ.១៣ ធ យហ ៨:២៣ ១យហ ៤:៥
**៣:៣២** ន យហ ៨:២៦ ១៥:១៥

ប ខ.១១

**៣:២២** *ព្រមទាំងធ្វើបុណ្យជ្រមុជទឹកផង* យោងតាមបទគម្ពីរ "យហ ៤:២" បញ្ជាក់ យ៉ាងច្បាស់ថា ពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាអ្នកធ្វើបុណ្យជ្រមុជទឹកឱ្យពួកបណ្ដាជនទាំងឡាយដែលមកឯទ្រង់ មិនមែនទ្រង់ធ្វើដោយផ្ទាល់ទេ ។

**៣:២៣,២៤** ពេលដែលព្រះយេស៊ូវគង់នៅស្រុកអេណូន លោកយ៉ូហាន–បាទីស្ទ ក៏កំពុងតែធ្វើបុណ្យជ្រមុជទឹក ឱ្យបណ្ដាជននៅតំបន់ក្បែរនោះដែរ ។

**៣:២៥** *ពីដំណើរលាងសំអាត* គឺសំដៅលើពិធីបុណ្យជ្រមុជទឹក ។ ម្យ៉ាងទៀត ការនេះមានទំនាក់ទំនងទៅនឹងពិធីលាងសម្អាតរបស់ពួកសាសន៍យូដាផងដែរ (មើលការពន្យល់ ២:៦)។

**៣:២៦** *លោកនោះ... ដែលលោកបានធ្វើបន្ទាល់ឱ្យ* ពេលនោះ ពួកសិស្សរបស់លោកយ៉ូហាន–បាទីស្ទបានដឹងថា គាត់ធ្វើបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ប៉ុន្តែ ដោយពួកគេឃើញមនុស្សជាច្រើនមកឯទ្រង់ ទើបពួកគេកើតមានចិត្តច្រណែន ។

**៣:២៧,២៨** លោកយ៉ូហាន–បាទីស្ទមិនបានលើកខ្លួន ហើយក៏មិនព្រមទទួលការសរសើរតម្កើងពីសំណាក់ពួកសិស្សរបស់គាត់ និងពីអ្នកណាម្នាក់ទេ ។ ការងាររបស់គាត់ គឺនាំមនុស្សឱ្យបានស្គាល់ព្រះយេស៊ូវគ្រីស្ទ មិនមែននាំគេឱ្យស្គាល់គាត់ទេ ។ នេះគឺជាគំរូដ៏ល្អមួយ សម្រាប់គ្រប់អ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទទាំងអស់ ។

**៣:២៩** *ប្ដី* ពាក្យថា "ប្ដី" នៅក្នុងបទគម្ពីរនេះ គឺសំដៅលើព្រះយេស៊ូវគ្រីស្ទ ។ *មិត្រសំឡាញ់* សំដៅលើលោកយ៉ូហាន-បាទីស្ទ ។ *សេចក្ដីអំណររបស់ខ្ញុំបាន ពោរពេញហើយ* លោកយ៉ូហាន–បាទីស្ទមានអំណរ ព្រោះគាត់បានឃើញព្រះអម្ចាស់ ជាព្រះសង្គ្រោះ និងជ័យជម្នះរបស់ទ្រង់ដោយផ្ទាល់ ។

**៣:៣០** លោកយ៉ូហាន-បាទីស្ទដឹងយ៉ាងច្បាស់ អំពីការងាររបស់គាត់ គឺត្រូវប្រកាសប្រាប់មនុស្សអំពីព្រះនាមព្រះអម្ចាស់ ។ គាត់ចង់ឱ្យព្រះយេស៊ូវបានចម្រើនឡើង ហើយឱ្យខ្លួនគាត់ថយចុះវិញ ។ ទាំងនេះគឺជាគំរូល្អសម្រាប់អ្នកជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទគ្រប់ៗគ្នា ។

**៣:៣១** *ព្រះអង្គដែលមកពីស្ថានលើ* មានន័យថា ព្រះយេស៊ូវគ្រីស្ទទ្រង់យាងមកពីស្ថានសួគ៌ (ខ.១៣ ១កថ ១៥:៤៧)។ *មនុស្សដែលនៅផែនដី* ឃ្លានេះគឺសំដៅលើមនុស្សទូទៅដែលរស់នៅលើពិភពលោកនេះ ។ ប៉ុន្តែ ក្នុងបទគម្ពីរនេះ គឺនិយាយសំដៅចំពោះលោកយ៉ូហាន–បាទីស្ទតែម្តង ។

**៣:៣២** *ទ្រង់ធ្វើបន្ទាល់ពីការដែលទ្រង់បានឃើញហើយឮ* បញ្ជាក់ថា គ្រប់សេចក្ដីបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ គឺសុទ្ធតែជាសេចក្ដីពិត ដែលមកពីព្រះវរបិតានៅឯស្ថានសួគ៌ ។ *តែគ្មានអ្នកណាដែលទទួលសេចក្ដីបន្ទាល់របស់ទ្រង់ទេ* ត្រង់ចំណុចនេះ គ្រាន់តែនិយាយជាលក្ខណៈទូទៅតែប៉ុណ្ណោះ ហើយពុំមែនមានន័យថា មនុស្សទាំងអស់បដិសេធព្រះបន្ទូលរបស់ព្រះអម្ចាស់នោះទេ (ខ.៣៣)។

**៣:៣៣** *ទទួលសេចក្ដីបន្ទាល់របស់ទ្រង់* នៅពេលមនុស្សម្នាក់ទទួលយកព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ នោះមានន័យថាគេទទួលសេចក្ដីបន្ទាល់របស់ទ្រង់ហើយ ។

**៣:៣៤** *ព្រះអង្គ ដែលព្រះបានចាត់ឱ្យមក* គឺព្រះយេស៊ូវគ្រីស្ទ ។ *ព្រះទ្រង់មិន*

ឱ្យមក[ផ] ទ្រង់មានបន្ទូលតាមព្រះបន្ទូលនៃព្រះ ពីព្រោះ
ព្រះទ្រង់មិនប្រទានព្រះវិញ្ញាណ[ព]មក ដោយមានកំរិតទេ
៣៥ឯព្រះវរបិតា ទ្រង់ស្រឡាញ់ព្រះរាជបុត្រា ហើយបាន
ប្រគល់គ្រប់ទាំងអស់ មកក្នុងព្រះហស្តទ្រង់[ភ] ៣៦ឯអ្នកណា
ដែលជឿដល់ព្រះរាជបុត្រា នោះមានជីវិតដ៏នៅអស់កល្ប
ជានិច្ចហើយ[ម] តែអ្នកណាដែលមិនព្រមជឿដល់ព្រះរាជ
បុត្រាវិញ នោះនឹងមិនឃើញជីវិតសោះឡើយ គឺសេចក្ដី
ក្រោធរបស់ព្រះ តែងនៅជាប់លើអ្នកនោះឯង ។

## ព្រះយេស៊ូវមានបន្ទូលនឹងស្ត្រីសាសន៍សាម៉ារី

**៤** ១ដូច្នេះ កាលព្រះអម្ចាស់ទ្រង់ជ្រាបពីពួកផារិស៊ី ដែលគេ
បានឮនិយាយថា ទ្រង់បានសិស្ស ហើយក៏ធ្វើបុណ្យជ្រមុជទឹក
ឱ្យជាច្រើន លើសជាងយ៉ូហានទៅទៀត[យ] ២(តែមិនមែន
ព្រះយេស៊ូវ ដែលធ្វើបុណ្យជ្រមុជព្រះអង្គទ្រង់ទេ គឺជា
ពួកសិស្សទ្រង់វិញ) ៣នោះទ្រង់[រ] ក៏យាងចេញពីស្រុកយូដា[ល]
ត្រឡប់ទៅឯស្រុកកាលីឡេវិញ ៤ហើយទ្រង់ត្រូវតែ
យាងកាត់ស្រុកសាម៉ារី[វ] ៥ដូច្នេះ ទ្រង់ យាងទៅដល់ក្រុង១
នៅស្រុកសាម៉ារី ហៅថា ស៊ូខារ ជិតដីដែលលោកយ៉ាកុប
បានឱ្យដល់យ៉ូសែបជាកូន[ស] ៦នៅទី នោះក៏មានអណ្តូង
យ៉ាកុប ដូច្នេះ ព្រះយេស៊ូវទ្រង់អស់កំឡាំង ដោយយាងមក
ក៏គង់នៅមាត់អណ្តូងនោះ ពេលនោះ ប្រហែលជាថ្ងៃត្រង់
ហើយ ៧មានស្ត្រីសាសន៍សាម៉ារីម្នាក់មកដងទឹក ហើយ
ព្រះយេស៊ូវ មានបន្ទូលទៅនាងថា សូម ឱ្យខ្ញុំផឹកផង[ហ]
៨ព្រោះពួកសិស្សទ្រង់ បានទៅផ្សារ[ឡ]អស់ ដើម្បីនឹងរក
ទិញស្បៀងអាហារ ៩ស្ត្រីសាសន៍សាម៉ារីនោះក៏ ទូលថា
លោកជាសាសន៍ យូដា ម្តេចឡើយក៏លោកសូមទឹកខ្ញុំពិសា
ដែលខ្ញុំជាស្រី សាសន៍សាម៉ារី[អ]ដូច្នេះ (នេះដ្បិតសាសន៍យូដា

**៣:៣៤** ផ ខ.១៧ ព អស ៤២:១ មថ ១២:១៨ លក ៤:១៨ កច ១០:៣៨ **៣:៣៥** ភ មថ ២៨:១៨ **៣:៣៦** ម ខ.១៥ យហ ៥:២៤ ៦:៤៧ **៤:១** យ យហ ៣:២២,២៦ **៤:៣** រ លក ៧:១៣ ល យហ ៣:២២ **៤:៤** វ មថ ១០:៥ **៤:៥** ស លប ៣៣:១៩ យស ២៤:៣២ **៤:៧** ហ លប ២៤:១៧ ១ពវ ១៧:១០ **៤:៨** ឡ ខ.៥,៣៩ **៤:៩** អ មថ ១០:៥

*ប្រទានព្រះវិញ្ញាណមក ដោយមានកំរិតទេ* មានន័យថា ព្រះវិញ្ញាណបរិសុទ្ធត្រូវប្រទានមកព្រះយេស៊ូវគ្រីស្ទ ដោយមិនមានកម្រិតទេ ។ ម្យ៉ាងទៀត មានន័យថា ព្រះវិញ្ញាណបរិសុទ្ធបានប្រទានមកជាបរិបូរដល់អ្នកជឿលើព្រះយេស៊ូវទាំងអស់ ។

**៣:៣៥** បទគម្ពីរនេះបញ្ជាក់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់មានគ្រប់អំណាចព្រះចេស្តាទាំងអស់ ។

**៣:៣៦** *នោះមានជីវិតដ៏នៅអស់កល្បជានិច្ច* ក្នុងខណៈពេលដែលមនុស្សណាម្នាក់ទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះសង្គ្រោះនៅក្នុងជីវិត នោះគេទទួលបានជីវិតថ្មីខាងឯវិញ្ញាណយ៉ាងពិតប្រាកដ ហើយគេនឹងមិនត្រូវវិនាសឡើយ (ខ.១៥) ។ *សេចក្តីក្រោធរបស់ព្រះ* គឺសំដៅលើការជំនុំជម្រះរបស់ព្រះអម្ចាស់ ។ នៅក្នុងបទគម្ពីរនេះដែរ ក៏បញ្ជាក់យ៉ាងច្បាស់ថា សេចក្តីក្រោធរបស់ព្រះអម្ចាស់នឹងមិន កើតមានចំពោះអស់អ្នកដែលទទួលជឿដល់ព្រះនាមទ្រង់ទេ (រម ១:១៨) ។

**៤:១** *ព្រះអម្ចាស់ទ្រង់ជ្រាប* មានន័យថា ព្រះយេស៊ូវទ្រង់ជ្រាបនូវហេតុការណ៍ទាំងអស់ដែលកើតឡើង ដោយពុំចាំបាច់មានអ្នកណាប្រាប់ទ្រង់ឡើយ (២:២៥) ។ *ពួកផារិស៊ី* គឺជាក្រុមអ្នកកាន់សាសនាយូដា ដែលប្រតិបត្តិតាមក្រឹត្យវិន័យ និងទំនៀមទម្លាប់ដ៏តឹងរ៉ឹង ។ នៅពេលដែលពួកនេះឃើញថា មានមនុស្សជាច្រើនមកឯព្រះយេស៊ូវគ្រីស្ទ នោះក៏ចាប់ផ្តើមសង្កេតតាមដាន ដើម្បីរកកំហុសទ្រង់ គឺដូចការដែលពួកគេបានធ្វើចំពោះលោកយ៉ូហាន-បាទីស្ទដូច្នោះដែរ (១:២៤) ។

**៤:២** នៅក្នុងបទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់ពុំបានធ្វើពិធីបុណ្យជ្រមុជទឹក ឱ្យពួកអ្នកជឿដល់ព្រះនាមទ្រង់ដោយផ្ទាល់ទេ គឺទ្រង់ដឹកនាំពួកសិស្សរបស់ទ្រង់ឱ្យធ្វើវិញ ។ ម្យ៉ាងទៀត ពួកសិស្សរបស់ទ្រង់ធ្វើការទាំងនោះ គឺតាមតែព្រះបន្ទូលទ្រង់ប៉ុណ្ណោះ ។

**៤:៣** *ទ្រង់ក៏យាងចេញពីស្រុកយូដា* ព្រះយេស៊ូវយាងចេញពីស្រុកយូដា ពីព្រោះព្រះរាជកិច្ចរបស់ទ្រង់នៅទីនោះបានជោគជ័យ មិនមែនដោយព្រោះបរាជ័យទេ (មើលការពន្យល់ ៧:១-៨:៥៩) ។

**៤:៤** ត្រង់ចំណុចនេះបញ្ជាក់ថា មហាបេសកកម្មរបស់ព្រះយេស៊ូវ មិនមែនសម្រាប់ តែពួកសាសន៍យូដានោះទេ គឺសម្រាប់មនុស្សទាំងអស់នៅលើពិភពលោកនេះ ។ *ស្រុកសាម៉ារី* ស្ថិតនៅភាគខាងលិចទន្លេយ័រដាន់ ចន្លោះស្រុកយូដា និងស្រុកកាលីឡេ ។ ពួកសាសន៍យូដាមិនធ្វើដំណើរពីស្រុកយូដា ទៅកាន់ស្រុកកាលីឡេ ដោយឆ្លងកាត់ស្រុកសាម៉ារីទេ គឺពួកគេវាងតាមភាគខាងកើតទន្លេយ័រដាន់វិញ (មើលការពន្យល់ មថ ១០:៥ លក ៩:៥២) ។ ការដែលពួកសាសន៍យូដាធ្វើដូច្នោះ ប្រហែលជាពួកគេយល់ថា សាសន៍សាម៉ារីគឺជាសាសន៍មិនបរិសុទ្ធ ។ ព្រះយេស៊ូវបានយាងកាត់ស្រុកសាម៉ារី មិនមែនដោយព្រោះតែមានចម្ងាយផ្លូវជិតនោះទេ គឺទ្រង់មានព្រះហឫទ័យទៅសង្គ្រោះពួកគេតែម្តង ។

**៤:៥** *ស៊ូខារ* ជាភូមិមួយស្ថិតនៅតំបន់ក្បែរស្រុកស៊ីគែម ។ លោកយ៉ាកុបបានទិញដីនៅតំបន់ជិតខាងនៃស្រុកស៊ីគែម (លប ៣៣:១៨-១៩) ហើយបានប្រគល់ឱ្យទៅលោកយ៉ូសែបជាកូនរបស់គាត់ (លប ៤៨:២១-២២) ។

**៤:៦** *អណ្តូងយ៉ាកុប* អណ្តូងនោះស្ថិតនៅក្នុងដី ដែលលោកយ៉ាកុបបានឱ្យទៅលោកយ៉ូសែប ។ ពួកអ្នកដឹកនាំនៃព្រះវិហារក្រិកបានទិញដីដែលមានអណ្តូងនោះ ហើយបានសង់ព្រះវិហារដ៏ធំមួយនៅក្បែរនោះ និងមានធ្វើរបងព័ទ្ធជុំវិញផង ។

**៤:៧** ជាទូទៅ នៅសម័យនោះ ពួកសាម៉ារីតែងតែមកដងទឹកនៅពេលល្ងាច ប៉ុន្តែ មានពេលខ្លះ ពួកគេក៏មកដងទឹកនៅពេលថ្ងៃត្រង់ផងដែរ (នក ២:១៥-១៧) ។ ការដែលធ្វើឱ្យស្ត្រីសាសន៍សាម៉ារីម្នាក់នោះ មកដងទឹកនៅពេលថ្ងៃត្រង់ ប្រហែលមកពីនាងមានការអៀនខ្មាសមិនចង់ជួបនឹងអ្នកដទៃ ព្រោះនាងបានប្រព្រឹត្តការមិនល្អជាច្រើននៅក្នុងជីវិតរបស់នាង ។

**៤:៩** *សាសន៍យូដាមិនដែលប្រកបនឹងសាសន៍សាម៉ារីទេ* ពួកសាសន៍យូដាយល់ថា ពួកសាសន៍សាម៉ារីជាសាសន៍មិនបរិសុទ្ធ ហើយអ្វីៗទាំងអស់ដែលពួកគេ (សាសន៍សាម៉ារី) មាន ក៏មិនបរិសុទ្ធដែរ ។ ដូច្នោះហើយ បានជានៅពេលដែលស្ត្រីសាសន៍សាម៉ារីឃើញព្រះយេស៊ូវ មានបន្ទូលសូមទឹកពីនាងនោះធ្វើឱ្យនាងមានការចម្លែកចិត្តជាខ្លាំង ។

មិនដែលប្រកបនឹងសាសន៍សាម៉ារីទេ) ១០ព្រះយេស៊ូវមាន
បន្ទូលឆ្លើយថា បើសិនជានាងបានស្គាល់អំណោយទាន
នៃព្រះ និងអ្នកដែលនិយាយនឹងនាងថា សូមឱ្យខ្ញុំផឹកផង
នោះនាងនឹងបានសូមពីអ្នកនោះវិញ រួចអ្នកនោះនឹងឱ្យ
ទឹករស់ដល់នាង[ក] ១១ស្ត្រីនោះក៏ទូលទ្រង់ថា លោកម្ចាស់
លោកគ្មានអ្វីនឹងដងទេ ហើយអណ្តូងក៏ជ្រៅផង ដូច្នេះ
លោកបានទឹករស់នោះពីណាមក ១២តើលោកធំជាង
យ៉ាកុប ជាព្ធយុកោយើងខ្ញុំ ដែលឱ្យអណ្តូង[ខ]នេះមកយើងខ្ញុំ
ហើយទាំងខ្លួនលោក កូនចៅ និងហ្វូងសត្វរបស់លោក
ក៏បានផឹកផងឬអី ១៣ព្រះយេស៊ូវមានបន្ទូលឆ្លើយថា អស់
អ្នកណាដែលផឹកទឹកនេះ នឹងត្រូវស្រេកទៀត ១៤តែអ្នកណា
ដែលផឹកទឹកខ្ញុំឱ្យ នោះនឹងមិនស្រេកទៀតឡើយ[គ] ទឹកដែល
ខ្ញុំឱ្យ នឹងត្រឡប់ជារន្ធទឹក[ឃ]នៅក្នុងអ្នកនោះ ដែលផុសឡើង
ដល់ទៅបាន ជីវិតអស់កល្បជានិច្ច[ង] ១៥ស្ត្រីនោះក៏ទូលទ្រង់
ថា លោកម្ចាស់អើយ សូមឱ្យទឹកនោះមកខ្ញុំផង ដើម្បីកុំឱ្យ
ខ្ញុំស្រេក[ច] ឬមកដងនៅទីនេះទៀត ១៦ព្រះយេស៊ូវមានបន្ទូល
ថា ចូរទៅហៅប្តីនាងមកឯណេះ ១៧ស្ត្រីនោះទូលឆ្លើយថា
ខ្ញុំគ្មានប្តីទេ រួចព្រះយេស៊ូវមានបន្ទូលថា ដែលនាងថា
គ្មានប្តី នោះថាត្រូវហើយ ១៨ដ្បិតនាងបានមានប្តី៥មក
ហើយ ឯអ្នកដែលនៅជាមួយសព្វថ្ងៃនេះ មិនមែនជាប្តីនាង
ទេ ពាក្យនោះនាងនិយាយត្រូវប្រាកដ ១៩ស្ត្រីនោះទូលទ្រង់
ថា លោកម្ចាស់អើយ ខ្ញុំយល់ឃើញថា លោកជាហោរា[ឆ]
២០ឯពួកព្ធយុកោយើងខ្ញុំ បានថ្វាយបង្គំនៅលើភ្នំនេះ[ជ] តែ
ពួកលោកថា ក្រុងយេរូសាឡិមជាកន្លែង ដែលត្រូវថ្វាយបង្គំ
វិញ[ឈ] ២១ព្រះយេស៊ូវមានបន្ទូលថា នាងស្រីអើយ ចូរជឿខ្ញុំ
ថា នឹងមានពេលវេលាមក[ញ] ដែលអ្នករាល់គ្នា នឹងមិន
ថ្វាយបង្គំ ព្រះវរបិតានៅលើភ្នំនេះ ឬនៅក្រុងយេរូសាឡិម

**៤:១០** ក អស ៤៤:៣ ៥៥:១ យរ ២:១៣ ១៧:១៣ សក ១៤:៨ យហ ៧:៣៧,៣៨ វវ ៧:១៧ ២១:៦ ២២:១,១៧
**៤:១២** ខ ខ.៦
**៤:១៤** គ យហ ៦:៣៥
ឃ អស ១២:៣ ៥៨:១១ យហ ៧:៣៨
ង មថ ២៥:៤៦
**៤:១៥** ច យហ ៦:៣៤
**៤:១៩** ឆ មថ ២១:១១
**៤:២០** ជ ចទ ១១:២៩ យស ៨:៣៣
ឈ លក ៩:៥៣
**៤:២១** ញ យហ ៥:២៨ ១៦:២

ដ មឡ ១:១១ ១ធថ ២:៨

**៤:១០** *អំណោយទាននៃព្រះ* នៅក្នុងព្រះគម្ពីរយ៉ូហាន ឃ្លានេះសំដៅលើព្រះគុណនៃព្រះតាមរយៈព្រះយេស៊ូវគ្រីស្ទ ។ ម្យ៉ាងទៀត អំណោយទាននៃព្រះ គឺសំដៅលើព្រះយេស៊ូវគ្រីស្ទ ឬព្រះវិញ្ញាណបរិសុទ្ធតែម្តង ។ *ទឹករស់* ពាក្យនេះនៅក្នុងបទគម្ពីរ "យហ ៧:៣៨–៣៩" គឺសំដៅលើព្រះវិញ្ញាណបរិសុទ្ធ (ខ.១៤)។

**៤:១១** *អណ្តូងក៏ជ្រៅផង* យោងតាមកំណត់ត្រាមួយចំនួនបង្ហាញថា កាលពីសតវត្សទី៤គ.ស អណ្តូងទឹកនៅក្នុងតំបន់នោះ (ស្រុកសាម៉ារី) មានជម្រៅជាមធ្យម គឺ៣០,៤៨ម៉ែត្រ ។ នៅឆ្នាំ១៩៣៥គ.ស គេបានស្តារអណ្តូងនោះ ឃើញមានជម្រៅដល់ទៅ ៤២,០៥ម៉ែត្រ ។

**៤:១២** *យ៉ាកុប ជាព្ធយុកោយើងខ្ញុំ* ឃ្លានេះបញ្ជាក់ថា ពួកសាសន៍សាម៉ារីក៏ជាពូជពង្សរបស់លោកយ៉ាកុបដែរ ។ ប៉ុន្តែ ក្រោយមក ដោយមានចលនាល្បាយជាតិសាសន៍ បានកើតឡើងក្នុងចំណោមពួកសាម៉ារីនោះ ដូច្នោះ បានជាពួកគេនៅពេលនោះ លែងជាសាសន៍អ៊ីស្រាអែលសុទ្ធទៀតហើយ ។

**៤:១៣–១៤** ត្រង់ចំណុចនេះពុំមានន័យថា នៅពេលដែលមនុស្សណាម្នាក់ទទួលជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទហើយ គេលែងត្រូវការអាហារខាងឯវិញ្ញាណទៀតនោះទេ គឺគេត្រូវតែបន្តទូលសូមទ្រង់ឱ្យបំពេញគេ រហូតបានពេញជាបរិបូរ (មថ ៥:៦)។

**៤:១៥** បទគម្ពីរនេះបញ្ជាក់ថា ស្ត្រីសាសន៍សាម៉ារីនោះនៅពុំទាន់យល់នូវសេចក្តីដែលព្រះយេស៊ូវ មានបន្ទូលទៅកាន់នាងនៅឡើយទេ ព្រោះនាងនៅតែយល់ថា ទ្រង់មានបន្ទូលអំពីទឹកធម្មតាប៉ុណ្ណោះ ។ ការនេះមានលក្ខណៈដូចគ្នាទៅនឹងករណីរបស់លោកនីកូដេមដែរ (៣:៤)។

**៤:១៨** *នាងបានមានប្តី៥មកហើយ* ក្នុងបទគម្ពីរនេះមិនបានបញ្ជាក់ថា ការដែលនាងមានប្តីដល់ទៅប្រាំ គឺមកពីប្តីនាងស្លាប់ ឬយ៉ាងណានោះទេ ។ ក្នុងក្រឹត្យវិន័យរបស់សាសន៍យូដា ស្ត្រីណាម្នាក់លែងលះប្តីរបស់ខ្លួន ហើយបើប្តីដើមនោះមានជីវិតរស់នៅឡើយ នោះបុរសណាដែលយកនាងធ្វើជាប្រពន្ធពុំត្រូវបានចាត់ទុកថា ជាប្តីរបស់នាងទេ ។ រីឯនៅក្នុងក្រឹត្យវិន័យរបស់ពួកសាសន៍សាម៉ារីវិញ ប្រសិនបើស្ត្រីណាម្នាក់លែងប្តីត្រឹមតែ៣ដងប៉ុណ្ណោះ នោះគឺមានន័យថា នាងបានប្រព្រឹត្តអំពើផិតក្បត់ហើយ ។ ព្រះយេស៊ូវទ្រង់មានបន្ទូលនៅកាន់ស្ត្រីសាសន៍សាម៉ារីយ៉ាងដូច្នោះ ធ្វើឱ្យនាងដឹងថា នាងកំពុងតែរស់នៅក្នុងអំពើបាប (មក ១០:១២)។

**៤:១៩** *ខ្ញុំយល់ឃើញថា លោកជាហោរា* ស្ត្រីសាសន៍សាម៉ារីនោះនិយាយយ៉ាងដូច្នេះ ព្រោះនាងដឹងយ៉ាងច្បាស់ថា អ្វីដែលព្រះយេស៊ូវមានបន្ទូលអំពីនាង សុទ្ធតែជាការពិតទាំងអស់ ។ ម្យ៉ាងទៀត ពួកសាសន៍សាម៉ារីជឿថា ព្រះអម្ចាស់ទ្រង់នឹងបណ្តាលឱ្យមានហោរាម្នាក់កើតឡើង (ចទ ១៨:១៥) ហើយដែលពួកគេជឿថា ហោរានោះគឺជាព្រះមែស៊ីតែម្តង ។

**៤:២០** *នៅលើភ្នំនេះ* គឺភ្នំកេរិស៊ីម (ចទ ១១:២៩)។ ការជជែកគ្នាអំពីទីកន្លែងដែលត្រូវថ្វាយបង្គំព្រះ គឺជាបញ្ហាមួយ ដែលបានកើតឡើងអស់រយៈពេលជាយូរមកហើយរវាងពួកយូដា និងពួកសាម៉ារី ។ ពួកសាម៉ារីប្រកាន់ថា ត្រូវតែថ្វាយបង្គំនៅលើភ្នំកេរិស៊ីម ដោយព្រោះពួកគេយល់ថា លោកអ័ប្រាហាំ និងលោកយ៉ាកុប បានសង់អាសនានៅទីនោះ (លប ១២:៦–៧ ៣៣:១៨–២០) ហើយព្រះពរក៏បានប្រទានមកនៅលើភ្នំនោះដែរ (ចទ ១១:២៩ ២៧:១២)។ នៅក្នុងគម្ពីររបស់ពួកសាម៉ារីសរសេរថា លោកម៉ូសេបានបញ្ជាឱ្យគេសង់អាសនាមួយ នៅលើភ្នំកេរិស៊ីមនោះ (ចទ ២៧:៤–៦)។ នៅឆ្នាំទី៤០០មុនគ.ស ពួកសាម៉ារីបានសង់ព្រះវិហារមួយនៅលើភ្នំនោះ ប៉ុន្តែ ពួកយូដាបានបំផ្លាញចោលវិញ ប្រហែលនៅឆ្នាំទី១២៨មុនគ.ស ។ ដោយព្រោះតែហេតុការណ៍នោះ បានជាធ្វើឱ្យមានទំនាស់ កាន់តែខ្លាំងឡើងរវាងសាសន៍យូដា និងសាសន៍សាម៉ារី ។

**៤:២២** *អ្នករាល់គ្នាមិនដឹងជាខ្លួនថ្វាយបង្គំអ្វីទេ* ដោយសារតែសាសន៍សាម៉ារីមិនព្រមទទួលយកព្រះបន្ទូលនៃព្រះអម្ចាស់ តាមរយៈពួកហោរបរិសុទ្ធរបស់ទ្រង់ ទើបធ្វើឱ្យពួកគេពុំបានស្គាល់ទ្រង់ច្បាស់ទេ (កច ១៧:២៣)។ *សេចក្តី*

ទេ[ដ] ២២អ្នករាល់គ្នាមិនដឹងជាខ្លួនថ្វាយបង្គំអ្វីទេ[ឋ] ឯយើងវិញ
យើងស្គាល់ព្រះដែលយើងថ្វាយបង្គំ ដ្បិតសេចក្តីសង្គ្រោះ
កើតមកពីសាសន៍យូដា[ឌ] ២៣តែនឹងមានពេលវេលាមក
ក៏នៅឥឡូវនេះហើយ[ឍ] នោះពួកអ្នកដែលថ្វាយបង្គំដោយ
ពិតត្រង់ គេនឹងថ្វាយបង្គំព្រះវរបិតា ដោយវិញ្ញាណ[ណ] នឹង
សេចក្តីពិត ពីព្រោះព្រះវរបិតា ទ្រង់រកពួកអ្នកយ៉ាងនោះ
ឱ្យបានថ្វាយបង្គំទ្រង់ ២៤ឯព្រះ ទ្រង់ជាវិញ្ញាណ[ត] ហើយអ្នក
ណាដែលថ្វាយបង្គំទ្រង់ នោះត្រូវតែថ្វាយបង្គំដោយវិញ្ញាណ
នឹងសេចក្តីពិតដែរ ២៥ស្ត្រីនោះទូលទ្រង់ថា ខ្ញុំដឹងហើយ
ថា ព្រះមែស៊ី ដែលហៅជាព្រះគ្រីស្ទ[ថ] ទ្រង់នឹងយាងមក
កាលណាមកហើយ នោះទ្រង់នឹងប្រាប់ឱ្យយើងខ្ញុំដឹងគ្រប់
ទាំងអស់ ២៦ព្រះយេស៊ូវមានបន្ទូលថា នោះគឺខ្ញុំនេះហើយ
ដែលនិយាយនឹងនាង[ទ]។

## ពួកសិស្សនឹកប្លែកពីព្រះយេស៊ូវ

២៧ខណៈនោះ ពួកសិស្សទ្រង់មកដល់[ធ] ក៏នឹកប្លែកពីទ្រង់
មានបន្ទូលនឹងស្ត្រីនោះ ប៉ុន្តែ គ្មានអ្នកណាទូលសួរថា ទ្រង់
សួររកអ្វី ឬថា ទ្រង់មានបន្ទូលនឹងស្ត្រីនេះធ្វើអីនោះទេ
២៨ឯស្ត្រីនោះ នាងទុកក្អមចោល ក៏ចូលក្នុងក្រុងដំណាល
ប្រាប់គេថា ២៩ចូរមកមើល មានមនុស្សម្នាក់ដែលប្រាប់ខ្ញុំ
ពីគ្រប់អំពើទាំងអស់ ដែលខ្ញុំបានប្រព្រឹត្ត[ន] តើអ្នកនោះមិន
មែន ជាព្រះគ្រីស្ទទេឬអី[ប] ៣០គេក៏ចេញពីទីក្រុងទៅឯទ្រង់
៣១ក្នុងរវាងនោះ ពួកសិស្សទូលទ្រង់ថា លោកគ្រូ[ផ] អញ្ជើញ
ពិសា ៣២តែទ្រង់មានបន្ទូលថា ខ្ញុំមានអាហារសំរាប់
ទទួលទាន[ព]ហើយ គឺជាអាហារដែលអ្នករាល់គ្នាមិនស្គាល់
៣៣ដូច្នេះ ពួកសិស្សសួរគ្នាទៅវិញទៅមកថា មានអ្នកណា
យកអ្វីមកជូនលោកពិសាដែរឬអី ៣៤នោះព្រះយេស៊ូវមាន
បន្ទូលទៅគេថា ឯអាហារខ្ញុំ គឺត្រង់ដែលខ្ញុំធ្វើ តាមព្រះ
ហឫទ័យ[ភ]នៃព្រះ ដែលចាត់ឱ្យខ្ញុំមក ព្រមទាំងបង្ហើយការ
របស់ទ្រង់នោះឯង[ម] ៣៥តើអ្នករាល់គ្នាមិនថា នៅ៤ខែទៀត
ទើបដល់រដូវចំរូតទេឬអី ខ្ញុំប្រាប់អ្នករាល់គ្នាថា ចូរងើប
ឡើងមើលទៅស្រែមើល ដ្បិតបានក្រហមល្មមច្រូតហើយ[យ]

**៤:២២** ឋ ២ពវ ១៧:២៨–៤១
ឌ អស ២:៣ រម ៣:១,២ ៩:៤,៥ ១៥:៨,៩
**៤:២៣** ឍ យហ ៥:២៥ ១៦:៣២
ណ ភល ៣:៣
**៤:២៤** ត ភល ៣:៣
**៤:២៥** ថ មថ ១:១៦ យហ ១:៤១
**៤:២៦** ទ យហ ៨:២៤ ៩:៣៥–៣៧
**៤:២៧** ធ ខ.៨
**៤:២៩** ន ខ.១៧,១៨
ប មថ ១២:២៣ យហ ៧:២៦,៣១
**៤:៣១** ផ មថ ២៣:៧
**៤:៣២** ព យប ២៣:១២ មថ ៤:៤ យហ ៦:២៧
**៤:៣៤** ភ មថ ២៦:៣៩
**៤:៣៤** ម យហ ១៩:៣០ **៤:៣៥** យ មថ ៩:៣៧ លក ១០:២
**៤:៣៦** រ រម ១:១៣

---

*សង្គ្រោះ កើតមកពីសាសន៍យូដា* មានន័យថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះមែស៊ី ដែលត្រូវយាងមកកើតជាមនុស្ស នៅក្នុងពួកសាសន៍យូដា ដើម្បីសង្គ្រោះមនុស្សនៅលើពិភពលោកនេះ ប្រយោជន៍ឱ្យពួកគេបានរួចផុតពីអំណាចបាប និងទៅឯទ្រង់វិញ ហើយទទួលបានជីវិតអស់កល្បជានិច្ច (មើលពន្យល់ រម ១:១៦ ១១:១៨)។

**៤:២៤** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ការថ្វាយបង្គំព្រះអម្ចាស់អាចធ្វើបាននៅគ្រប់ទីកន្លែង ឱ្យតែការនោះសរសើរតម្កើងទ្រង់ ព្រោះទ្រង់ជាវិញ្ញាណ និងគង់នៅគ្រប់ទីកន្លែងទាំងអស់ក្នុងពេលតែមួយ (១:១៤)។

**៤:២៥** ស្ត្រីសាសន៍សាម៉ារីនោះនៅតែពុំបានយល់ អំពីសេចក្តីខាងឯវិញ្ញាណ ដែលព្រះយេស៊ូវមានបន្ទូលទៅកាន់នាងនៅឡើយ ។ ប៉ុន្តែ ក្នុងពេលជាមួយគ្នានោះ នាងក៏មានការជឿងឆ្ងល់ថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះមែស៊ី ដែលត្រូវយាងមកនោះហើយ (១:២៥)។ ពួកសាសន៍សាម៉ារីសង្ឃឹមថា ព្រះមែស៊ីនឹងយាងមក ប៉ុន្តែ ដោយព្រោះពួកគេបានបដិសេធព្រះបន្ទូលតាមរយៈពួកហោរាបរិសុទ្ធរបស់ទ្រង់ ទើប ធ្វើឱ្យពួកគេពុំអាចយល់ច្បាស់នូវសេចក្តីដែលចែងអំពីទ្រង់ទេ ។ ម្យ៉ាងទៀត ពួកគេគ្រាន់តែយល់ថា ព្រះមែស៊ីគឺជាគ្រូបង្រៀនម្នាក់ប៉ុណ្ណោះ ។

**៤:២៦** *នោះគឺខ្ញុំនេះហើយ* ត្រង់ចំណុចនេះ ព្រះយេស៊ូវគ្រីស្ទមានបន្ទូលពីអង្គទ្រង់ យ៉ាងច្បាស់ថា ទ្រង់គឺជាព្រះមែស៊ីពិតប្រាកដមែន ។ ប៉ុន្តែ ទ្រង់មិនមានបន្ទូលប្រាប់ពួកសាសន៍យូដាជាទូទៅថា ទ្រង់ជាព្រះមែស៊ីទេ ។

**៤:២៧** *ក៏នឹកប្លែក* តាមធម្មតា ពួកគ្រូក្រឹត្យវិន័យសាសន៍យូដាកម្រនឹងនិយាយជាមួយស្ត្រីនៅឯទីសាធារណៈណាស់ ដូច្នោះហើយ បានជានៅពេលដែលពួកសិស្សរបស់ព្រះយេស៊ូវ ឃើញទ្រង់និយាយជាមួយនឹងស្ត្រីសាសន៍សាម៉ារីនោះ ពួកគេក៏នឹកប្លែកក្នុងចិត្តជាខ្លាំង ។

**៤:២៩** *ប្រាប់ខ្ញុំ ពីគ្រប់អំពើទាំងអស់ ដែលខ្ញុំបានប្រព្រឹត្ត* ត្រង់ចំណុចនេះបញ្ជាក់ថា ព្រះយេស៊ូវមានបន្ទូលប្រាប់ស្ត្រីសាសន៍សាម៉ារីនោះ នូវបញ្ហាខ្លះៗប៉ុណ្ណោះ ប៉ុន្តែ ព្រះបន្ទូលនោះបានបណ្តាលចិត្តនាងឱ្យដឹងថា ទ្រង់ពិតជាអាចប្រាប់នាងអំពីការទាំងអស់នៅក្នុងជីវិតរបស់នាងបាន ។

**៤:៣១–៣៣** បន្ទាប់ពីស្ត្រីសាសន៍សាម៉ារី បានចាកចេញទៅប្រកាស់ប្រាប់គេអំពីព្រះយេស៊ូវ នោះពួកសិស្សរបស់ទ្រង់ក៏គិតថា ប្រហែលជាមានអ្នកណាយកអាហារមកថ្វាយទ្រង់សោយរួចហើយ ព្រោះទ្រង់មានបន្ទូលថា ទ្រង់មានអាហារសម្រាប់ទទួលទានហើយ ។ ព្រះយេស៊ូវមានបន្ទូលអំពីអាហារខាងឯវិញ្ញាណ ប៉ុន្តែ នៅក្នុងខណៈពេលនោះ ពួកសិស្សរបស់ទ្រង់ពុំបានយល់ទេ (ខ.១៥ ៤:៤)។

**៤:៣៤** *ខ្ញុំធ្វើតាមព្រះហឫទ័យនៃព្រះ ដែលចាត់ឱ្យខ្ញុំមក* មានន័យថា គ្រប់ការទាំងអស់ដែលព្រះយេស៊ូវទ្រង់ធ្វើ គឺធ្វើតាមបំណងព្រះហឫទ័យនៃព្រះវរបិតា ។ ម្យ៉ាងទៀត នៅក្នុងកណ្ឌគម្ពីរយ៉ូហានបញ្ជាក់យ៉ាងច្បាស់ថា គ្រប់ព្រះរាជកិច្ចរបស់ព្រះយេស៊ូវគ្រីស្ទ គឺធ្វើតាមបំណងព្រះហឫទ័យនៃព្រះវរបិតាទាំងស្រុង (មើលការ ពន្យល់ ៥:៣០ ៦:៣៨ ៨:២៦ ៩:៤ ១០:៣៧,៣៨ ១២:៥០ ១៤:៣១ ១៥:១០ ១៧:៤)។

**៤:៣៥** បទគម្ពីរនេះបញ្ជាក់ថា ជាទូទៅគេតែងតែព្រោះគ្រាប់ពូជ ហើយត្រូវរង់ចាំរដូវចម្រូតមកដល់ ប៉ុន្តែ ចំពោះចម្រូតខាងឯវិញ្ញាណវិញ គឺបានមកដល់ហើយ ដូច្នេះមិនត្រូវបង្អង់ចាំតទៅទៀតទេ (មថ ៩:៣៦–៣៨)។

**៤:៣៦** *នោះបានរង្វាន់* មានន័យថា អស់អ្នកដែលធ្វើការងារថ្វាយព្រះយេស៊ូវនោះនឹងបានរង្វាន់មកអំពីទ្រង់ ។ *ដើម្បីឱ្យអ្នកដែលព្រោះ និងអ្នកដែលច្រូតបានអរសប្បាយផងគ្នា* ព្រះយេស៊ូវមានព្រះបន្ទូលយ៉ាងដូច្នេះ គឺឱ្យអស់អ្នកដែលបានជឿដល់ព្រះនាមទ្រង់ទាំងអស់ ធ្វើការងារថ្វាយទ្រង់ដោយចិត្ត

៣៦អ្នកណាដែលច្រូត៍ នោះបានរង្វាន់ ក៏ប្រមូលផលសំរាប់
ជីវិតដ៏នៅអស់កល្បជានិច្ច[ល] ដើម្បីឱ្យអ្នកដែលព្រោះ និង
អ្នកដែលច្រូត បានអរសប្បាយផងគ្នា ៣៧ដ្បិតចំពោះដំ
ណើរនេះ នោះពាក្យទំនៀមនេះត្រូវណាស់ថា ម្នាក់ព្រោះ
ម្នាក់ទៀតច្រូត[វ] ៣៨ខ្ញុំបានចាត់អ្នករាល់គ្នាទៅច្រូតចំរូត
ដែលមិនបាននឿយនឹងធ្វើសោះ មានអ្នកឯទៀតបាននឿយ
ហត់ ហើយអ្នករាល់គ្នាបានចូលទៅក្នុងការរបស់គេ ។

## សាសន៍សាម៉ារីជាច្រើនបានជឿព្រះយេស៊ូវ

៣៩នៅក្រុងនោះ ក៏មានសាសន៍សាម៉ារីជាច្រើន[ស] បាន
ជឿដល់ទ្រង់ ដោយព្រោះពាក្យ ដែលស្ត្រីនោះធ្វើបន្ទាល់ថា
លោកប្រាប់ខ្ញុំ ពីគ្រប់អំពើទាំងអស់ ដែលខ្ញុំបានប្រព្រឹត្ត[ហ]
៤០ដូច្នេះ កាលពួកសាសន៍សាម៉ារី បានមកដល់ទ្រង់ហើយ
នោះគេសូមទ្រង់ ឱ្យនៅជាមួយនឹងគេ ទ្រង់ក៏គង់នៅទី
នោះអស់២ថ្ងៃ ៤១ហើយមានមនុស្សជាច្រើនទៀតបានជឿ
ដោយសារព្រះបន្ទូលទ្រង់ ៤២រួចគេនិយាយទៅស្ត្រីនោះថា
ឥឡូវនេះ យើងជឿមិនមែនដោយព្រោះពាក្យសំដី របស់
អ្នកទៀតទេ គឺជឿដោយព្រោះបានឮទ្រង់ផ្ទាល់ខ្លួនយើង
វិញ ហើយយើងដឹងថា ទ្រង់ជាព្រះគ្រីស្ទ ជាព្រះដ៏ជួយ
សង្គ្រោះមនុស្សលោកពិតប្រាកដមែន[ឡ]។

**៤:៣៦** ល មថ ២៥:៤៦
**៤:៣៧** វ យប ៣១:៨ មីក ៦:១៥
**៤:៣៩** ស ខ.៥ ហ ខ.២៩
**៤:៤២** ឡ លក ២:១១
**៤:៤៣** អ ខ.៤០
**៤:៤៤** ក មថ ១៣:៥៧ លក ៤:២៤
**៤:៤៥** ខ យហ ២:២៣
**៤:៤៦** គ យហ ២:១-១១
**៤:៤៧** ឃ ខ.៣,៥៤
**៤:៤៨** ង ដយ ៤:២,៣ យហ ២:១១ កច ២:៤៣ ១៤:៣ រម ១៥:១៩ ២កថ ១២:១២ ហព ២:៤

## កូនប្រុសរបស់នាម៉ឺនម្នាក់បានជាពីជំងឺ

៤៣កន្លង២ថ្ងៃនោះមក[អ] ព្រះយេស៊ូវក៏ចេញពីទីនោះ ទៅឯ
ស្រុកកាលីឡេវិញ ៤៤ដ្បិតទ្រង់ធ្វើបន្ទាល់ ដោយព្រះអង្គ
ទ្រង់ថា គេមិនរាប់អានហោរា នៅក្នុងស្រុករបស់ខ្លួនទេ[ក]
៤៥ដូច្នេះ កាលទ្រង់បានយាងមកដល់ស្រុកកាលីឡេហើយ
នោះពួកអ្នកនៅស្រុកនោះ ក៏ទទួលទ្រង់ ដោយបានឃើញ
អស់ទាំងការដែលទ្រង់ធ្វើ នៅក្រុងយេរូសាឡិម ក្នុងវេលា
បុណ្យ[ខ] ពីព្រោះគេក៏បានទៅឯបុណ្យនោះដែរ ។
៤៦រួចមកទ្រង់យាងមកដល់ភូមិកាណា ក្នុងស្រុកកាលីឡេ
ម្តងទៀត គឺនៅភូមិនោះហើយ ដែលទ្រង់ធ្វើទឹកឱ្យប្រែ
ទៅជាស្រាទំពាំងបាយជូរ[គ] នោះមាននាម៉ឺនម្នាក់មានកូនឈឺ
នៅឯកាពើណិម ៤៧កាលលោកបានឮថា ព្រះយេស៊ូវបាន
យាងពីស្រុកយូដា[ឃ] មកដល់ស្រុកកាលីឡេហើយ នោះលោក
ក៏ទៅសូមទ្រង់ ឱ្យយាងចុះទៅប្រោសកូនឱ្យជា ដ្បិតកូននោះ
ជិតស្លាប់ហើយ ៤៨ព្រះយេស៊ូវទ្រង់មានបន្ទូលទៅលោកថា
បើអ្នករាល់គ្នា មិនឃើញទីសំគាល់ នឹងការអស្ចារ្យ[ង] នោះ
មិនព្រមជឿទេ ៤៩នាម៉ឺននោះទូលទ្រង់ថា លោកម្ចាស់
សូមអញ្ជើញចុះ ទៅជាប្រញាប់ ក្រែងកូនខ្ញុំស្លាប់ ៥០ព្រះ
យេស៊ូវមានបន្ទូលទៅលោកថា អញ្ជើញទៅចុះ កូនលោក

---

ស្មោះត្រង់ និងមិនត្រូវប្រកួតប្រជែងគ្នាយកឈ្នះចាញ់ឡើយ គឺត្រូវឱ្យអរសប្បាយជាមួយគ្នាជានិច្ចវិញ ។

**៤:៣៧** *ម្នាក់ព្រោះម្នាក់ទៀតច្រូត* មានន័យថា មិនអាចខ្វះអ្នកណាម្នាក់បានទេ គឺត្រូវតែមានទាំងអ្នកព្រោះ និងអ្នកច្រូត (មើលការពន្យល់ ១កថ ៣:៦-៩)

**៤:៣៨** *មានអ្នកឯទៀតបាននឿយហត់* ឃ្លានេះប្រហែលជាសំដៅលើលោកយ៉ូហាន-បាទីស្ទ និងពួកគូកនរបស់គាត់ ឬពួកអ្នកបម្រើបរិសុទ្ធដទៃទៀត ដែលបានធ្វើការយ៉ាងនឿយហត់ថ្វាយព្រះអម្ចាស់ មុនពេលដែលទ្រង់បានយាងមក ។

**៤:៣៩** *ក្រុងនោះ* គឺក្រុងស៊ីខារ (ខ.៥)។

**៤:៤២** *ជាព្រះដ៏ជួយសង្គ្រោះមនុស្សលោក* មានន័យថា ព្រះយេស៊ូវទ្រង់ប្រទានសេចក្តីសង្គ្រោះសម្រាប់មនុស្សនៅលើពិភពលោកនេះទាំងមូល មិនមែនសម្រាប់តែជាតិសាសន៍ណាមួយទេ (១យហ ៤:១៤ មើលការពន្យល់ ៣:១៦)។

**៤:៤៣** *កន្លង២ថ្ងៃនោះមក* គឺរយៈ២ថ្ងៃដែលព្រះយេស៊ូវទ្រង់បានគង់នៅក្រុងស៊ីខារនៃស្រុកសាម៉ារី (ខ.៤០)។

**៤:៤៤** *គេមិនរាប់អានហោរា នៅក្នុងស្រុករបស់ខ្លួនទេ* ត្រង់ចំណុចនេះមិនមែនមានន័យថា ហោរាទាំងអស់គ្មានគេរាប់អាននោះទេ ប៉ុន្តែ បើតាមបទពិសោធន៍ដែលមានចែងនៅក្នុងព្រះគម្ពីរបរិសុទ្ធឃើញថា ពួកគេភាគច្រើនមិនបានទទួលការរាប់អានអំពីបងប្អូន ឬជាតិសាសន៍របស់ខ្លួនទេ ដូចជាលោកយ៉ូសែប ស្តេចដាវីឌ (១សយ ១៧:២៨) លោកយេរេមា (យរ ១១:២១) ជាដើម (លក ៤:២៤ មថ ១៣:៥៧)។

**៤:៤៥** *ពួកអ្នកនៅស្រុកនោះក៏ទទួលទ្រង់* ពួកគេពុំមែនទទួលព្រះយេស៊ូវដោយព្រោះទ្រង់ជាព្រះមែស៊ីនោះទេ គឺដោយព្រោះតែចង់ឃើញការអស្ចារ្យដែលទ្រង់ធ្វើប៉ុណ្ណោះ ព្រោះមានពួកគេមួយចំនួន ធ្លាប់បានឃើញការអស្ចារ្យដែលទ្រង់ធ្វើនៅឯទីក្រុងយេរូសាឡិមរួចហើយ (២០:៣០)។ *ក្នុងវេលាបុណ្យ* គឺសំដៅលើ បុណ្យរំលងដែលពួកសាសន៍យូដាទើបតែប្រារព្ធធ្វើនៅឯទីក្រុងយេរូសាឡិមនោះ (២:១៣-២៥)។

**៤:៤៦** *នាម៉ឺនម្នាក់* នាម៉ឺនម្នាក់នោះ គឺជាមន្ត្រីបម្រើការថ្វាយស្តេចហេរ៉ូឌ-អាន់ទីប៉ាស់ ជាស្តេចនៅស្រុកកាលីឡេ និងស្រុកពើរេ (Peraea) (១០:៤០ លក ២៣:៧)។ ក្នុងកណ្ឌគម្ពីរយ៉ូហានពុំបានបញ្ជាក់ថា នាម៉ឺននោះឈ្មោះអ្វីទេ ។

**៤:៤៨** *បើអ្នករាល់គ្នាមិនឃើញ . . . នោះមិនព្រមជឿទេ* ព្រះយេស៊ូវមានបន្ទូលយ៉ាងដូច្នេះ ពុំសំដៅលើលោកនាម៉ឺននោះទេ គឺសំដៅលើពួកអ្នកស្រុកកាលីឡេទូទៅតែម្តង ។

**៤:៤៩-៥០** ត្រង់ចំណុចនេះបញ្ជាក់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់គង់នៅឯភូមិកាណា ហើយកូនប្រុសរបស់លោកនាម៉ឺននោះ កំពុងតែមានជំងឺនៅឯក្រុងកាពើណិម ។ ម្យ៉ាងទៀត ចម្ងាយពីភូមិកាណាទៅក្រុងកាពើណិម គឺប្រហែល ២៥,៧៤គ.ម ។ នៅពេលដែលព្រះយេស៊ូវ មានបន្ទូលទៅកាន់លោកនាម៉ឺននោះ នៅឯភូមិកាណាថា "កូនលោកនឹងរស់នៅទេ" នោះកូនប្រុសរបស់គាត់ដែលកំពុងតែមានជំងឺនៅឯក្រុងកាពើណិមក៏បានជាភ្លាម (ខ.៥១,៥៣)។

នឹងរស់នៅទេ លោកក៏ជឿព្រះបន្ទូល នៃព្រះយេស៊ូវ ហើយ
ចេញទៅ ៥១ កំពុងដែលលោកចុះទៅ ស្រាប់តែពួកបាវ
លោកមកជំរាបថា កូនលោកជាហើយ ៥២ ដូច្នេះ លោក
ក៏សួរគេ ពីពេលណាដែលកូនបានគ្រាន់បើ គេជំរាបថា
បាត់គ្រុនពីម៉ោង១ម្សិលមិញ ៥៣ នោះឪពុកបានដឹងថា
គឺជាពេលនោះឯង ដែលព្រះយេស៊ូវមានបន្ទូលថា កូនរស់
នៅទេ ហើយលោកក៏ជឿ ព្រមទាំងពួកផ្ទះ[ច] លោកទាំង
អស់ដែរ ៥៤ នេះជាទីសំគាល់ទី២[ឆ] ដែលព្រះយេស៊ូវទ្រង់
ធ្វើ ក្នុងកាលដែលទ្រង់យាងត្រឡប់ពីស្រុកយូដា មកក្នុង
ស្រុកកាលីឡេវិញ ។

## ការប្រោសអ្នកជំងឺនៅឯស្រះបេថែសដា

**៥** ១ ក្រោយនោះមក មានបុណ្យ១របស់សាសន៍យូដា
ហើយព្រះយេស៊ូវ ទ្រង់យាងឡើងទៅឯ ក្រុងយេរូសាឡិម
២ រីឯ នៅក្រុងយេរូសាឡិម ជិតទ្វារចៀម[ជ] នោះមានស្រះ១
ដែលភាសាហេព្រើរ[ឈ] ហៅថា បេថែសដា មានសាលា
សំណាក់ ៥ ៣ មានមនុស្សសន្ធឹក ដេកនៅក្នុងសាលាទាំង
នោះ ខ្លះឈឺ ខ្លះខ្វាក់ ខ្លះខ្វិន ខ្លះស្វិត គេរង់ចាំទឹកកំរើកឡើង
៤ ដ្បិតចួនណាមានទេវតាចុះមកកូរទឹកក្នុងស្រះនោះ លុះ
ក្រោយដែលបានកូរស្រេចហើយ នោះអ្នកណាដែលចុះទៅ
មុនគេ ក៏បានជាស្អាត ទោះបើឈឺរោគអ្វីក៏ដោយ ៥ នៅ
ទីនោះ មានមនុស្សម្នាក់ដែលឈឺ៣៨ឆ្នាំមកហើយ ៦ កាល
ព្រះយេស៊ូវឃើញគាត់ដេកនៅ ហើយបានជ្រាបថាគាត់
នៅយ៉ាងនោះជាយូរមកហើយ នោះទ្រង់មានបន្ទូលថា តើ
អ្នកចង់បានជាឬទេ ៧ អ្នកជំងឺនោះទូលឆ្លើយថា លោកម្ចាស់
អើយ ខ្ញុំគ្មានអ្នកណានឹងដាក់ខ្ញុំទៅក្នុងស្រះ ក្នុងកាលដែល
ទឹកបានកំរើកឡើងនោះទេ ហើយកំពុងដែលខ្ញុំចុះទៅ
នោះក៏មានម្នាក់ទៀតចុះទៅមុនខ្ញុំ ៨ ព្រះយេស៊ូវមានបន្ទូល
ទៅគាត់ថា ចូរក្រោកឡើង យកគ្រែអ្នកដើរទៅ[ញ] ៩ ស្រាប់
តែអ្នកនោះបានជាភ្លាម ក៏យកគ្រែដើរទៅ ឯថ្ងៃនោះ
ជាថ្ងៃឈប់សំរាក[ដ] ១០ ដូច្នេះ ពួកសាសន៍យូដា[ឋ] គេស្តីឱ្យអ្នក
ដែលបានជាថា ថ្ងៃនេះជាថ្ងៃឈប់សំរាក អ្នកគ្មានច្បាប់
នឹងលីគ្រែទៅទេ[ឌ] ១១ គាត់ឆ្លើយទៅគេថា លោកដែលធ្វើ

**៤:៥៣** ច កច ១១:១៤
**៤:៥៤** ឆ ខ.៤៨ យហ ២:១១
**៥:២** ជ នហ ៣:១ ១២:៣៩ ឈ យហ ១៩:១៣, ១៧,២០ ២០:១៦ កច ២១:៤០ ២២:២ ២៦:១៤
**៥:៨** ញ មថ ៩:៥,៦
**៥:៩** ដ មថ ១២:១–១៤ យហ ៩:១៤
**៥:១០** ឋ ខ.១៦ ឌ នហ ១៣:១៥–២២ យរ ១៧:២១ មថ ១២:២

**៤:៥៣** *ជឿ* ត្រង់ចំណុចនេះបញ្ជាក់ថា តាមកណ្ឌគម្ពីរយ៉ូហាន សេចក្តីជំនឿមានសារសំខាន់ណាស់ សម្រាប់អ្នកជឿព្រះយេស៊ូវ (ការពន្យល់ ២០:៣១) ។
**៤:៥៤** *ជាទីសំគាល់ទី២* មានន័យថា ការប្រោសកូនរបស់លោកនាម៉ឺនម្នាក់នោះឱ្យបានជាពីជំងឺ គឺជាទីសំគាល់ទី២ ដែលព្រះយេស៊ូវគ្រីស្ទទ្រង់ធ្វើ នៅក្នុងស្រុកកាលីឡេ ។ ទីសំគាល់ទី១ គឺទ្រង់ធ្វើឱ្យទឹកបានប្រែទៅជាស្រាទំពាំងបាយជូរ (មើលការពន្យល់ ២:១១) ។
**៥:១** *បុណ្យ១របស់សាសន៍យូដា* ប្រហែលជាសំដៅលើបុណ្យរំលងឬបុណ្យថ្ងៃទី ៥០ ឬក៏បុណ្យចម្រូត (នក ២៣:១៦) ។ នៅក្នុងកណ្ឌគម្ពីរយ៉ូហាន មាននិយាយអំពីបុណ្យរំលងយ៉ាងតិចក៏៣ដងដែរគឺ ទី១នៅក្នុង "២:១៣,២៣ (មើលការពន្យល់)" ទី២នៅក្នុង"៦:៤" និងទី៣មានលើកឡើងច្រើនដង ដូចជានៅក្នុង"១១:៥៥"និង "១២:១" ជាដើម ។ ដោយព្រោះពិធីបុណ្យរំលងត្រូវបានពួកសាសន៍យូដាប្រារព្ធធ្វើ ១ឆ្នាំម្តង ដូច្នេះ អាចសន្និដ្ឋានបានថា ព្រះរាជកិច្ចរបស់ព្រះយេស៊ូវ ចាប់ពីពេលដែលទ្រង់ទទួលពិធីបុណ្យជ្រមុជទឹក ដោយលោកយ៉ូហាន-បាទីស្ទ រហូតដល់ពេលដែលទ្រង់សុគតនិងរស់ឡើងវិញ គឺមានរយៈពេលសរុបជាង៣ឆ្នាំ ។
**៥:២** *ទ្វារចៀម* គឺទ្វារក្រុងមួយ ស្ថិតនៅក្បែរព្រះវិហារទីក្រុងយេរូសាឡិម ភាគខាងជើង ។ គេប្រើទ្វារនេះសម្រាប់ដឹកនាំចៀម និងគោ ចូលទៅក្នុងទីក្រុង ។ *បេថែសដា* គឺជាឈ្មោះស្រះមួយ ស្ថិតនៅភាគខាងជើងឆៀងខាងកើតនៃទីក្រុងយេរូសាឡិម ។ មានរឿងដំណាលថា ទឹកនៅក្នុងស្រះបេថែសដានេះ មានអំណាចព្យាបាលមនុស្សឱ្យជាពីជំងឺបាន ។ ដូច្នេះ បានជានៅពេលដែលព្រះយេស៊ូវយាង ទៅដល់ទីនោះ ទ្រង់ឃើញមានអ្នកជំងឺជាច្រើន ។ *សាលាសំណាក់៥* គេបានសង់សាលាសំណាក់ទាំងនេះ នៅជុំវិញស្រះបេថែសដា សម្រាប់ជាជម្រកដល់អ្នកជំងឺ ដែលមករង់ចាំនៅទីនោះ ។
**៥:៤** *ទេវតា* ត្រង់ចំណុចនេះមិនបានបញ្ជាក់ថា ពួកគេអាចមើលឃើញទេវតាដែលចុះមកកូរទឹកក្នុងស្រះនោះទេ ។
**៥:៥** *ឈឺ៣៨ឆ្នាំមកហើយ* ក្នុងបទគម្ពីរនេះមិនបានប្រាប់ថា បុរសនោះមានជំងឺអ្វីទេ គ្រាន់តែបញ្ជាក់ថា គាត់មានជំងឺ និងពុំអាចដើរបាន អស់រយៈពេល ៣៨ឆ្នាំមកហើយ ។
**៥:៦** *តើអ្នកចង់បានជាឬទេ?* ត្រង់ចំណុចនេះបញ្ជាក់ថា ព្រះយេស៊ូវទ្រង់បានយាងទៅរកបុរសមានជំងឺម្នាក់នោះ ហើយមានបន្ទូលសួរគាត់ជាមុន ។ ម្យ៉ាងទៀត បុរសនោះពុំបានដឹងថា ព្រះយេស៊ូវទ្រង់ជាអ្នកណាទេ ។
**៥:៧** បទគម្ពីរនេះបញ្ជាក់ថា បុរសម្នាក់នោះពុំទាន់បានដឹងថា ព្រះយេស៊ូវទ្រង់មានអំណាចក្នុងការប្រោសគាត់ ឱ្យបានជាពីជំងឺនៅឡើយទេ ពីព្រោះគាត់នៅតែ សង្ឃឹមទៅលើទឹកដែលបានកម្រើកឡើងនៅក្នុងស្រះនោះដដែល ។
**៥:៩** *អ្នកនោះបានជាភ្លាម* ការដែលបុរសនោះបានជាពីជំងឺ គឺដោយសារតែសេចក្តីជំនឿលើព្រះនាមព្រះយេស៊ូវគ្រីស្ទ (៥:៣៤) ។ នៅពេលដែលព្រះយេស៊ូវមានបន្ទូលទៅកាន់បុរសនោះថា "ចូរក្រោកឡើង" នោះគាត់ក៏ធ្វើតាម ដូច្នេះ អាចបញ្ជាក់បានថា គាត់មានជំនឿលើទ្រង់ ។
**៥:១០** *អ្នកគ្មានច្បាប់នឹងលីគ្រែទៅទេ* នៅក្នុងក្រឹត្យវិន័យលោកម៉ូសេមិនបានចែងមកយ៉ាងដូច្នេះទេ គឺពួកគេបានបង្កើតឡើងដោយខ្លួនឯងតែម្តង ។ ពួកសាសន៍យូដា តែងតែកាន់តាមក្រឹត្យវិន័យយ៉ាងតឹងរ៉ឹងបំផុត ប៉ុន្តែពួកគេមានការយល់ខុសជាច្រើន ដែលផ្ទុយនឹងព្រះបន្ទូលនៃព្រះអម្ចាស់ (មថ ២៣:៣–៤) ។ ព្រះយេស៊ូវទ្រង់បានបញ្ជាក់យ៉ាងច្បាស់ថា មនុស្សអាចធ្វើការល្អគ្រប់យ៉ាង តាមព្រះបន្ទូលទ្រង់ រួមទាំងការជួយសង្គ្រោះជីវិតផងដែរ ទោះជានៅថ្ងៃឈប់សម្រាកក៏ដោយ (ខ.១៧ ៧:២៣ លក ៦:៩ ១៣:១៥ ១៤:៥) ។
**៥:១១–១៣** នៅពេលដែលពួកអ្នកដឹកនាំសាសន៍យូដាបានឃើញបុរសដែលមានជំងឺ៣៨ឆ្នាំនោះលីគ្រែដើរដូច្នោះ ពួកគេក៏បន្ទោសគាត់ ហើយថែមទាំង

ឱ្យខ្ញុំជា លោកបង្គាប់ថា ចូរយកគ្រែឯងដើរទៅ
១២នោះគេសួរគាត់ថា តើអ្នកណា បានប្រាប់ឱ្យអ្នកយកគ្រែដើរទៅ
ដូច្នេះ
១៣តែអ្នកដែលបានជាមិនស្គាល់ជាអ្នកណាទេ ពីព្រោះព្រះយេស៊ូវទ្រង់យាងទៅបាត់ហើយ ក៏មានមនុស្សសន្ធឹកនៅទីនោះដែរ
១៤ក្រោយនោះមក ព្រះយេស៊ូវឃើញគាត់នៅក្នុងព្រះវិហារ ក៏មានបន្ទូលទៅថា មើល ឥឡូវអ្នកបានជាហើយ កុំឱ្យធ្វើបាបទៀត[ល] ក្រែងអ្នកកើតមានសេចក្តីអាក្រក់ជាងនេះទៅទៀត
១៥មនុស្សនោះក៏ចេញទៅប្រាប់ដល់ពួកសាសន៍យូដា[ណ] ឱ្យដឹងថាជាព្រះយេស៊ូវ ដែលប្រោសឱ្យខ្លួនបានជា ។

## ជីវិតតាមរយៈព្រះរាជបុត្រា

១៦ហេតុនោះបានជាពួកសាសន៍យូដា គេបៀតបៀនដល់ព្រះយេស៊ូវ ហើយរកសំឡាប់ទ្រង់ ដោយព្រោះទ្រង់ធ្វើការនោះ នៅថ្ងៃឈប់សំរាក
១៧ប៉ុន្តែ ព្រះយេស៊ូវមានបន្ទូលទៅគេថា ព្រះវរបិតាខ្ញុំ[ត] ទ្រង់ធ្វើការដរាបមកដល់ឥឡូវនេះ[ថ] ហើយខ្ញុំក៏ធ្វើការដែរ
១៨ដោយហេតុពាក្យនោះ បានជាពួកសាសន៍យូដា គេរកសំឡាប់ទ្រង់ រឹតតែខ្លាំងឡើង[ទ] ពីព្រោះ ទ្រង់មិនមែនគ្រាន់តែរំលងច្បាប់ នៃថ្ងៃឈប់សំរាកតែប៉ុណ្ណោះ គឺបានទាំងហៅព្រះថា ជាព្រះវរបិតានៃទ្រង់ថែមទៀត ហើយលើកអង្គទ្រង់ស្មើនឹងព្រះផង[ធ] ។
១៩ដូច្នេះ ព្រះយេស៊ូវទ្រង់មានបន្ទូលឆ្លើយទៅគេថា ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ព្រះរាជបុត្រាពុំអាចនឹងធ្វើការអ្វី ដោយព្រះអង្គទ្រង់បានទេ[ន] ធ្វើបានតែការអ្វីដែលឃើញព្រះវរបិតាធ្វើ ដ្បិតការអ្វីដែលព្រះវរបិតាធ្វើ នោះព្រះរាជបុត្រាក៏ធ្វើដូច្នោះដែរ
២០ពីព្រោះព្រះវរបិតាទ្រង់ស្រឡាញ់ព្រះរាជបុត្រា[ប] ហើយក៏បង្ហាញឱ្យព្រះរាជបុត្រាឃើញអស់ទាំងការដែលទ្រង់ធ្វើដែរ ទ្រង់នឹងបង្ហាញឱ្យឃើញការធំ លើសជាងការទាំងនេះទៅទៀត ដើម្បីឱ្យអ្នករាល់គ្នាមានសេចក្តីអស្ចារ្យ[ផ]
២១ដ្បិតដែលព្រះវរបិតាទ្រង់ប្រោសមនុស្សស្លាប់ ឱ្យមានជីវិតរស់ឡើងវិញយ៉ាងណា[ព] នោះព្រះរាជបុត្រា នឹងប្រោសដល់អ្នកណា[ភ] ដែលទ្រង់សព្វព្រះហឫទ័យក៏យ៉ាងដូច្នោះដែរ
២២ព្រះវរបិតាទ្រង់មិនជំនុំជំរះអ្នកណាទេ ទ្រង់បានប្រគល់គ្រប់ការជំនុំជំរះ ដល់ព្រះរាជបុត្រាវិញ[ម]
២៣ដើម្បីឱ្យមនុស្សទាំងអស់បានគោរពប្រតិបត្តិដល់ព្រះរាជបុត្រា ដូច

**៥:១៤** ល មក ២:៥ យហ ៨:១១
**៥:១៥** ណ យហ ១:១៩
**៥:១៧** ត លក ២:៤៩ ថ យហ ៩:៤ ១៤:១០
**៥:១៨** ទ មថ ១២:១៤ ធ យហ ១០:៣០,៣៣ ១៩:៧
**៥:១៩** ន ខ.៣០ យហ ១៤:២៤
**៥:២០** ប យហ ៣:៣៥ ផ យហ ១៤:១២
**៥:២១** ព រម ៤:១៧ ៨:១១ ២កថ ១:៩ ហព ១១:១៩ ភ យហ ១១:២៥
**៥:២២** ម ខ.២៧ លប ១៨:២៥ ពថ ១១:២៧ យហ ៩:៣៩ កថ ១០:៤២

សួររកអ្នកដែលជួយគាត់ឱ្យបានជាអំពីជំងឺនោះផង ។ ទង្វើរបស់ពួកគេទាំងនោះ គឺប្រឆាំង នឹងក្រឹត្យវិន័យរបស់ព្រះអម្ចាស់ទាំងស្រុង ។

**៥:១៤** *កុំឱ្យធ្វើបាបទៀត* ឃ្លានេះបញ្ជាក់ថា បុរសនោះមានជំងឺ គឺប្រហែលមកពីគាត់បានធ្វើបាបហើយ ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅក្នុងព្រះគម្ពីរប្រាប់យ៉ាងច្បាស់ថា មានជំងឺខ្លះកើតឡើងដោយសារតែអំពើបាប (មក ២:៥) ហើយជំងឺខ្លះទៀតមិនមែនមកពីអំពើបាបទេ (យហ ៩:១–៣)។ *សេចក្តីអាក្រក់ជាងនេះ* គឺអាចសំដៅលើការឈឺចាប់អស់កល្បជានិច្ចនៅក្នុងភ្លើងនរក (មថ ៥:២២)។

**៥:១៦** *គេបៀតបៀនដល់ព្រះយេស៊ូវ* ត្រង់ចំណុចនេះ លោកយ៉ូហានមិនបានបញ្ជាក់ថា នៅពេលនោះ ពួកអ្នកដឹកនាំសាសន៍យូដា បានធ្វើការអាក្រក់អ្វីខ្លះដល់ព្រះយេស៊ូវទេ ។

**៥:១៧** *ព្រះវរបិតាខ្ញុំ* ព្រះយេស៊ូវមានព្រះបន្ទូលយ៉ាងដូច្នេះ បញ្ជាក់ថា ទ្រង់គង់នៅជាមួយព្រះវរបិតាយ៉ាងជិតស្និទ្ធ តាំងពីអស់កល្បជានិច្ចមក ។ ពួកសាសន៍យូដាមិនហ៊ានប្រើពាក្យថា "ព្រះវរបិតាខ្ញុំ" ក្នុងការនិយាយទៅកាន់ព្រះអម្ចាស់ទេ ។ ពួកគេអាចនិយាយទៅកាន់ទ្រង់ ដោយប្រើពាក្យថា "ព្រះវរបិតានៃយើងខ្ញុំ" ឬព្រះវរបិតាដែលគង់នៅស្ថានសួគ៌"។ *ទ្រង់ធ្វើការដរាបមកដល់ឥឡូវនេះ* ឃ្លានេះមានន័យថា ព្រះអម្ចាស់ទ្រង់ពុំបានឈប់សម្រាកទេ ទោះជានៅថ្ងៃឈប់សម្រាកក៏ដោយ ។ នៅថ្ងៃទី៦ ព្រះអម្ចាស់បានបញ្ចប់ការបង្កើតពិភពលោករុក្ខជាតិ សត្វ និងមនុស្ស ។ នៅថ្ងៃទី៧ ព្រះអម្ចាស់នៅតែបន្តព្រះរាជកិច្ចរបស់ទ្រង់ដដែល គឺទ្រង់បន្តគ្រប់គ្រង និងថែរក្សានូវអ្វីៗដែលទ្រង់បានបង្កើតមក ដូច្នេះបញ្ជាក់យ៉ាងច្បាស់ថា ទ្រង់បានធ្វើការដរាបដល់សព្វថ្ងៃនេះ ។

**៥:១៨** *គេរកសំឡាប់ទ្រង់រឹតតែខ្លាំងឡើង* នៅពេលដែលព្រះយេស៊ូវមានបន្ទូលដោយប្រើពាក្យថា "ព្រះវរបិតានៃខ្ញុំ" នោះធ្វើឱ្យពួកអ្នកដឹកនាំសាសន៍យូដាកាន់តែមានកំហឹងខ្លាំងឡើង រហូតរកសម្លាប់ទ្រង់ ។ ពួកគេនាំគ្នាប្រឆាំង ហើយរកសម្លាប់ព្រះយេស៊ូវ ដោយចោទថា ទ្រង់បានលើកអង្គទ្រង់ស្មើនឹងព្រះ ។

**៥:១៩** នៅក្នុងបទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះរាជបុត្រាយាងមកគឺដើម្បី ធ្វើតាមព្រះហឫទ័យ នៃព្រះវរបិតាតែប៉ុណ្ណោះ (មើលការពន្យល់ ៤:៣៤)។

**៥:២០** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថាសេចក្តីស្រលាញ់ និងបំណងព្រះហឫទ័យរបស់ព្រះវរបិតា គឺមាននៅក្នុងព្រះរាជបុត្រាតាំងពីអស់កល្បជានិច្ចមក ។ ម្យ៉ាងទៀត ផែនការ និងបំណងព្រះហឫទ័យរបស់ព្រះវរបិតាត្រូវបានសម្រេចតាមរយៈព្រះរាជបុត្រា (១៧:៤)។ *ទ្រង់នឹងបង្ហាញឱ្យឃើញការធំ* ពាក្យថា "ការធំ" នៅត្រង់ចំណុចនេះ គឺសំដៅលើការអស្ចារ្យដែលព្រះយេស៊ូវទ្រង់ធ្វើ ដូចជាការប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញជាដើម ។

**៥:២១** *ព្រះវរបិតាទ្រង់ប្រោសមនុស្សស្លាប់* ត្រង់ចំណុចនេះ ពួកសាសន៍យូដាយល់ថា មានតែព្រះប៉ុណ្ណោះ ដែលមានអំណាចក្នុងការប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញ ។ ម្យ៉ាងទៀត ពួកគេយល់ថា ក្រៅពីព្រះ គ្មានអ្នកណាអាចប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញបានទេ ។ នៅក្នុងព្រះគម្ពីរប្រាប់យ៉ាងច្បាស់ថា អំណាចនៃការប្រោសមនុស្សស្លាប់ ឱ្យរស់ឡើងវិញនេះ ក៏ត្រូវបានប្រទានមកលោកអេលីយ៉ា (១ពវ ១៧:២២) និងលោកអេលីសេ (២ពវ ៤:៣២–៣៥) ផងដែរ ។ *ព្រះរាជបុត្រា នឹងប្រោសដល់អ្នកណា ដែលទ្រង់សព្វព្រះហឫទ័យ* មានន័យថា ព្រះយេស៊ូវមានអំណាចប្រទានជីវិតដល់អស់អ្នកណាដែលជឿដល់ព្រះនាមទ្រង់ (១០:១០ មើលការពន្យល់ ១១:២៥)។

**៥:២២** *ព្រះវរបិតា . . . ទ្រង់បានប្រគល់ការជំនុំជំរះ ដល់ព្រះរាជបុត្រាវិញ*

ជាគោរពប្រតិបត្តិដល់ព្រះវរបិតាដែរ អ្នកណាដែលមិន
គោរពប្រតិបត្តិដល់ព្រះរាជបុត្រា នោះក៏មិនគោរពប្រតិបត្តិ
ដល់ព្រះវរបិតា ដែលចាត់ឱ្យទ្រង់មកដែរ[យ] ។
២៤ ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណា
ដែលស្តាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គ ដែលចាត់ខ្ញុំឱ្យ
មក[រ] អ្នកនោះមានជីវិត ដ៏នៅអស់កល្បជានិច្ច[ល] ហើយមិន
ដែលត្រូវជំនុំជំរះឡើយ[វ] គឺបានកន្លងហួសពីសេចក្តីស្លាប់
ទៅដល់ជីវិតវិញ[ស] ២៥ ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជា
ប្រាកដថា នឹងមានពេលវេលាមក ក៏មកដល់ហើយ[ហ] ដែល
មនុស្សស្លាប់នឹងឮសំឡេង[ឡ]ព្រះរាជបុត្រានៃព្រះ ហើយ
អស់អ្នកណាដែលឮនឹងបានរស់វិញ ២៦ ពីព្រោះដែល
ព្រះវរបិតាមានជីវិតក្នុងព្រះអង្គទ្រង់យ៉ាងណា នោះទ្រង់ក៏
បានប្រទានឱ្យព្រះរាជបុត្រាមានជីវិត[អ] ក្នុងព្រះអង្គទ្រង់
យ៉ាងនោះដែរ ២៧ ហើយបានប្រទានអំណាចមកទ្រង់ ឱ្យ
ជំនុំជំរះផង[ក] ពីព្រោះទ្រង់ជាកូនមនុស្ស ។

**៥:២៣** យ លក ១០:១៦ ១យហ ២:២៣
**៥:២៤** រ មថ ១០:៤០ យហ ៣:១៥,១៧ ល មថ ២៥:៤៦ វ យហ ៣:១៨ ស ១យហ ៣:១៤
**៥:២៥** ហ យហ ៤:២៣ ១៦:៣២ ឡ យហ ៨:៤៣,៤៧
**៥:២៦** អ ចទ ៣០:២០ យប ១០:១២ ៣៣:៤ ទដ ៣៦:៩ យហ ១:៤
**៥:២៧** ក ខ.២២
**៥:២៨** ខ យហ ៤:២១ ១៦:២
**៥:២៩** គ មថ

២៨ កុំឱ្យឆ្ងល់ពីសេចក្តីនេះឡើយ ដ្បិតមានពេលវេលា
មក[ខ] ដែលអស់ទាំងខ្មោចនៅក្នុងផ្នូរនឹងឮសំឡេងទ្រង់ ហើយ
និងចេញមក ២៩ គឺពួកអ្នកដែលបានប្រព្រឹត្តល្អ គេនឹងរស់
ឡើងវិញ ឱ្យបានជីវិត ឯពួកអ្នកដែលបានប្រព្រឹត្តអាក្រក់វិញ
គេនឹងរស់ឡើង ឱ្យជាប់មានទោស[គ] ៣០ ខ្ញុំពុំអាចនឹងធ្វើ
ការអ្វី ដោយខ្លួនខ្ញុំបានទេ[ឃ] ខ្ញុំជំនុំជំរះតាមដែលខ្ញុំឮ ហើយ
សេចក្តីជំនុំជំរះរបស់ខ្ញុំក៏សុចរិត[ង] ពីព្រោះខ្ញុំមិនរកតាមតែ
ចិត្តខ្ញុំទេ គឺតាមព្រះហឫទ័យនៃព្រះវិញ ដែលទ្រង់ចាត់ឱ្យ
ខ្ញុំមក[ច] ។

## ទីបន្ទាល់អំពីព្រះយេស៊ូវ

៣១ បើសិនជា ខ្ញុំធ្វើបន្ទាល់ពីខ្លួនខ្ញុំ នោះសេចក្តីបន្ទាល់
របស់ខ្ញុំមិនពិតទេ[ឆ] ៣២ មានម្នាក់ទៀតដែលធ្វើបន្ទាល់ពីខ្ញុំ[ជ]

២៥:៤៦ **៥:៣០** ឃ ខ.១៩ ង អស ២៨:៦ យហ ៨:១៦ ច មថ ២៦:៣៩
**៥:៣១** ឆ យហ ៨:១៤ **៥:៣២** ជ ខ.៣៧ យហ ៨:១៨

ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះវរបិតាទ្រង់បានប្រទានអំណាចគ្រប់ទាំងអស់ ដល់ព្រះយេស៊ូវគ្រីស្ទក្នុងការជំនុំជម្រះ (មថ ២៥:៣១–៣២ កច ១០:៤២ ១៧:៣១ ២កថ ៥:១០ ២ធថ ៤:១ ១ពត ៤:៥)។ រីឯពួកសាសន៍យូដាវិញយល់ថា មានតែព្រះវរបិតាប៉ុណ្ណោះ ដែលមានអំណាចក្នុងការជំនុំជម្រះ ។ ដូច្នោះហើយ បានជានៅពេលដែលបានឮសេចក្តីបង្រៀនរបស់ព្រះយេស៊ូវ ពួកគេក៏យល់ថា សេចក្តីបង្រៀននោះគឺប្រឆាំងនឹងក្រឹត្យវិន័យរបស់ខ្លួន ។

**៥:២៤** *ជឿដល់ព្រះអង្គ . . . មានជីវិតដ៏នៅអស់កល្បជានិច្ច* មានន័យថា ដើម្បីឱ្យបានជីវិត នោះត្រូវតែមានសេចក្តីជំនឿដល់ព្រះអម្ចាស់ (មើលការពន្យល់ ២០:៣១)។ *មានជីវិតដ៏នៅអស់កល្បជានិច្ច* ជីវិតអស់កល្បនេះត្រូវប្រទានដល់អស់អ្នកណាដែលព្រមទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ ៣:១៥,៣៦)។ ក្នុងខណៈពេល ដែលមនុស្សណាម្នាក់ប្រែចិត្តចេញពីអំពើបាប ហើយទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះសង្គ្រោះនៅក្នុងជីវិត នោះគេទទួលបានជីវិតខាងឯវិញ្ញាណដ៏នៅរស់អស់កល្បជានិច្ច ។ *បានកន្លងហួសពីសេចក្តីស្លាប់ទៅដល់ជីវិត* មានន័យថា សេចក្តីស្លាប់ខាងឯវិញ្ញាណ លែងមានអំណាចលើអស់អ្នកណាដែល ទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទទៀតឡើយ ផ្ទុយទៅវិញគេមានជីវិតរស់ជាមួយ ទ្រង់អស់កល្បជានិច្ចវិញ ។

**៥:២៥** *នឹងមានពេលវេលាមក ក៏មកដល់ហើយ* មានន័យថា ពេលវេលាដែលព្រះយេស៊ូវគ្រីស្ទប្រទានជីវិត ដ៏នៅរស់អស់កល្បជានិច្ចខាងឯវិញ្ញាណដល់មនុស្សលោកបានមកដល់ហើយ ។

**៥:២៦** *ព្រះវរបិតាមានជីវិត* បញ្ជាក់ថា ព្រះអម្ចាស់ទ្រង់ជាព្រះដ៏មានព្រះជន្មរស់ និងជាប្រភពនៃគ្រប់ជីវិតទាំងអស់ (យស ៣:១០ ១យស ១៧:២៦ យរ ១០:១០ មើលការពន្យល់ ចទ ៣០:២០ យប ១០:១២ ៣៣:៤ ទដ ១៦:១១ ២៧:១ ៣៦:៩)។ *ព្រះរាជបុត្រាមានជីវិត* មានន័យថា ព្រះយេស៊ូវគ្រីស្ទទ្រង់មានព្រះជន្មរស់ជាមួយព្រះវរបិតាតាំងពីអស់កល្បជានិច្ចមក ។ម្យ៉ាងទៀត ព្រះយេស៊ូវគ្រីស្ទទ្រង់មានអំណាច ក្នុងការប្រទានជីវិត ដល់អស់អ្នកណាដែលជឿដល់ព្រះនាមទ្រង់ ។

**៥:២៧** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះវរបិតាបានប្រទានគ្រប់អំណាចព្រះចេស្តាទាំងអស់ ដល់ព្រះយេស៊ូវគ្រីស្ទ ក្នុងការជំនុំជម្រះ (មើលការពន្យល់ខ.២២)។ *ទ្រង់ជាកូនមនុស្ស* សំដៅលើព្រះយេស៊ូវ (មើលការពន្យល់ ១:៥១)។

**៥:២៨-២៩** សេចក្តីដែលព្រះយេស៊ូវទ្រង់មានបន្ទូល នៅក្នុងបទគម្ពីរទាំងនេះ គឺ សំដៅលើហេតុការណ៍ ដែលនឹងកើតឡើងនៅថ្ងៃចុងបំផុត (ដយ ១២:២)

**៥:២៩** *ប្រព្រឹត្តល្អ . . . រស់ . . . ប្រព្រឹត្តអាក្រក់ . . . ជាប់មានទោស* មានន័យថា ព្រះអម្ចាស់នឹងជំនុំជម្រះមនុស្សទាំងអស់ ទៅតាមទង្វើដែលគេម្នាក់ៗបានប្រព្រឹត្តនៅក្នុងជីវិត (មើលការពន្យល់ រម ២:៦–៨ វវ ២០:១២)។ ចូរចងចាំថា សេចក្តីសង្គ្រោះមិនមែនបានមក ដោយសារការប្រព្រឹត្តិរបស់មនុស្សម្នាក់ៗនោះទេ គឺបានមកដោយសារតែសេចក្តីជំនឿ លើព្រះយេស៊ូវគ្រីស្ទតែមួយអង្គគត់ (មើលការពន្យល់ យក ២:១៤-២៦)។

**៥:៣០** *ខ្ញុំមិនរកតាមតែចិត្តខ្ញុំទេ គឺតាមព្រះហឫទ័យនៃព្រះវិញ* ត្រង់ចំណុចនេះបញ្ជាក់ថា គ្រប់ព្រះរាជកិច្ចរបស់ព្រះយេស៊ូវគ្រីស្ទ គឺទ្រង់ធ្វើតាមព្រះហឫទ័យនៃព្រះវរបិតា (មើលការពន្យល់ខ.១៩)។

**៥:៣១-៤៧** ក្នុងវគ្គនេះច្រើននិយាយសំដៅលើទីបន្ទាល់ (មើលការពន្យល់ ១:៧) របស់លោកយ៉ូហាន-បាទីស្ទ (ខ.៣៣) អំពីព្រះរាជកិច្ចរបស់ព្រះយេស៊ូវគ្រីស្ទ (ខ.៣៦,៣៧) ដែលមានចែងនៅក្នុងព្រះគម្ពីរបរិសុទ្ធ (ខ.៣៩) និងក្នុងក្រឹត្យវិន័យ លោកម៉ូសេ (ខ.៤៦)។

**៥:៣១** ក្នុងបទគម្ពីរនេះបញ្ជាក់ថា ព្រះយេស៊ូវមិនបានធ្វើបន្ទាល់ពីអង្គទ្រង់ផ្ទាល់ថា ទ្រង់ជាព្រះមែស៊ីនោះទេ ប៉ុន្តែ មានពួកហោរាបរិសុទ្ធ និងពួកអ្នកបម្រើរបស់ទ្រង់ ជាអ្នកធ្វើបន្ទាល់អំពីទ្រង់វិញ ។

**៥:៣២** *មានម្នាក់ទៀត ដែលធ្វើបន្ទាល់ពីខ្ញុំ* ពាក្យថា "ម្នាក់ទៀត" ត្រង់ចំណុចនេះ គឺសំដៅលើព្រះវរបិតា ដែលទ្រង់បានធ្វើបន្ទាល់ដោយផ្ទាល់ថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រានៃទ្រង់ប្រាកដមែន (មក ១:១១ ៩:៧ យហ ៨:១៧–១៨)។

ហើយខ្ញុំដឹងថា សេចក្តីបន្ទាល់ ដែលអ្នកនោះធ្វើពីខ្ញុំក៏ពិត
ប្រាកដមែន ៣៣អ្នករាល់គ្នាបានចាត់គេ ឱ្យទៅឯលោក
យ៉ូហាន លោកក៏ធ្វើបន្ទាល់[ឈ]តាមសេចក្តីពិត ៣៤ប៉ុន្តែ
សេចក្តីបន្ទាល់ដែលខ្ញុំទទួល នោះមិនមែនមកពីមនុស្ស
ទេ[ញ] ខ្ញុំគ្រាន់តែនិយាយសេចក្តីទាំងនេះ ប្រយោជន៍ឱ្យអ្នក
រាល់គ្នាបាន សង្គ្រោះប៉ុណ្ណោះ[ដ] ៣៥ឯលោកយ៉ូហាន
លោកជាចង្កៀងដែលឆេះ ហើយភ្លឺ[ឋ] អ្នករាល់គ្នាក៏ចូលចិត្ត
ឱ្យបានអរសប្បាយក្នុងពន្លឺរបស់លោក ក្នុង១គ្រានោះដែរ
៣៦ប៉ុន្តែ ខ្ញុំមានទីបន្ទាល់វិសេសជាងទីបន្ទាល់ របស់លោក
យ៉ូហានទៅទៀត[ឌ] ពីព្រោះការទាំងប៉ុន្មាន ដែលព្រះវរ
បិតាបានប្រគល់មកឱ្យខ្ញុំធ្វើបង្ហើយ គឺការដែលខ្ញុំធ្វើ
ទាំងប៉ុន្មាននេះឯង[ឍ] នោះបានធ្វើបន្ទាល់ពីខ្ញុំហើយ ថា
ព្រះវរបិតាបានចាត់ឱ្យខ្ញុំមក[ណ] ៣៧ឯព្រះវរបិតា ដែល
ចាត់ឱ្យខ្ញុំមក ទ្រង់ក៏ធ្វើបន្ទាល់ពីខ្ញុំដែរ[ត] អ្នករាល់គ្នាមិន
ដែលឮសំឡេងទ្រង់ឡើយ ក៏មិនដែលឃើញរូបអង្គទ្រង់
ផង[ថ] ៣៨អ្នករាល់គ្នាគ្មានព្រះបន្ទូលទ្រង់នៅក្នុងខ្លួនសោះ[ទ]
ពីព្រោះអ្នករាល់គ្នាមិនជឿ[ធ]ដល់ព្រះអង្គ ដែលទ្រង់ចាត់
ឱ្យមកនេះ[ន] ៣៩អ្នករាល់គ្នាស្ទង់មើលគម្ពីរ[ប] ដោយស្មាន
ថា បានជីវិតដ៏នៅអស់កល្បជានិច្ចអំពីគម្ពីរនោះមក[ផ] គឺជា
គម្ពីរនោះឯង ដែលធ្វើបន្ទាល់ពីខ្ញុំ[ព] ៤០តែអ្នករាល់គ្នាមិន
សុខចិត្តមកឯខ្ញុំ[ភ] ឱ្យបានជីវិតទេ ។
៤១ខ្ញុំមិនទទួលកិត្តិសព្ទអំពីមនុស្សទេ[ម] ៤២ខ្ញុំស្គាល់អ្នក
រាល់គ្នាហើយ ថាគ្មានសេចក្តីស្រឡាញ់របស់ព្រះ នៅក្នុង
ខ្លួនអ្នករាល់គ្នាសោះ ៤៣ខ្ញុំបានមកដោយនូវព្រះនាមរបស់
ព្រះវរបិតាខ្ញុំ តែអ្នករាល់គ្នាមិនទទួលខ្ញុំទេ បើសិនជាមាន
អ្នកណាទៀតមក ដោយនូវឈ្មោះរបស់ខ្លួនគេ នោះអ្នក
រាល់គ្នានឹងទទួលអ្នកនោះវិញ ៤៤ធ្វើដូចម្តេចឱ្យអ្នករាល់គ្នា
ជឿបាន ដែលទទួលកិត្តិសព្ទតែពីគ្នាឯង ឥតស្វែងរកកិត្តិសព្ទ
ដែលមកពីព្រះអង្គដ៏ជាព្រះតែ១អង្គទ្រង់ដូច្នេះ[យ] ។
៤៥កុំឱ្យស្មានថា ខ្ញុំនឹងប្តឹងដល់ព្រះវរបិតា ពីអ្នករាល់

**៥:៣៣** ឈ យហ ១:៧
**៥:៣៤** ញ ១យហ ៥:៩ ដ កច ១៦:៣០,៣១ អភ ២:៨ ទត ៣:៥
**៥:៣៥** ឋ ដយ ១២:៣ ២ពត ១:១៩
**៥:៣៦** ឌ ១យហ ៥:៩ ឍ យហ ១៤:១១ ១៥:២៤ ណ យហ ៣:១៧
**៥:៣៧** ត យហ ៨:១៨ ថ ចទ ៤:១២ ១ធថ ១:១៧ យហ ១:១៨
**៥:៣៨** ទ ១យហ ១:១០ ២:១៤ ធ អស ២៦:១០ ន យហ ៣:១៧
**៥:៣៩** ប រម ២:១៧,១៨ ផ មថ ២៥:៤៦ ព លក ២៤:២៧,៤៤ កច ១៣:២៧ **៥:៤០** ភ យហ ៦:៤៤
**៥:៤១** ម ខ.៤៤ **៥:៤៤** យ រម ២:២៩

**៥:៣៣** *អ្នករាល់គ្នាបានចាត់គេ ឱ្យទៅឯលោកយ៉ូហាន* ពួកសាសន៍យូដាបានចាត់គេ ឱ្យទៅឯលោកយ៉ូហាន-បាទីស្ទ ដើម្បីសួរគាត់ថា តើគាត់ជាអ្នកណា (មើលការពន្យល់ ១:១៩) ។ *លោកក៏ធ្វើបន្ទាល់ តាមសេចក្តីពិត* មានន័យថា លោកយ៉ូហាន-បាទីស្ទត្រូវបានបញ្ជូនមក ដើម្បីធ្វើបន្ទាល់ដល់ពួកសាសន៍យូដាថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះប្រាកដមែន ។ ដូច្នេះ បើពួកគេជឿដល់សេចក្តីបន្ទាល់របស់លោកយ៉ូហាន-បាទីស្ទ នោះពួកគេក៏ជឿដល់ព្រះគ្រីស្ទ និងទទួលបានការសង្គ្រោះមកពីទ្រង់ដែរ ។

**៥:៣៤** *សេចក្តីបន្ទាល់ដែលខ្ញុំទទួល នោះមិនមែនមកពីមនុស្សទេ* បញ្ជាក់ថា ទោះបីជាសេចក្តីបន្ទាល់របស់មនុស្សអាចមានកំហុស ឬអាចប្រែប្រួល ក៏សេចក្តីបន្ទាល់របស់ព្រះអម្ចាស់ នៅតែជាសេចក្តីពិតអស់កល្បជានិច្ច (១យហ ៥:៩) ។

**៥:៣៥** *លោកយ៉ូហាន* គឺលោកយ៉ូហាន-បាទីស្ទ ។ ពេលនោះគាត់ប្រហែលជានៅក្នុងពន្ធនាគារ ។ *លោកជាចង្កៀង* ពាក្យថា "ចង្កៀង" ត្រង់ចំណុចនេះអាចមានន័យថា "គ្រូបង្រៀន"។ *ភ្លឺ* បញ្ជាក់ថាលោកយ៉ូហាន–បាទីស្ទជាគ្រូម្នាក់ដែលពួកគេគោរព ។ ម្យ៉ាងទៀត សេចក្តីបង្រៀនរបស់គាត់គឺត្រឹមត្រូវច្បាស់លាស់ និងមិនប្រែប្រួល ព្រោះគាត់និយាយសេចក្តីដែលមកអំពីព្រះអម្ចាស់ ។

**៥:៣៦** *ការដែលខ្ញុំធ្វើ* សំដៅលើការអស្ចារ្យទាំងឡាយ ដែលព្រះយេស៊ូវទ្រង់ធ្វើ និងបញ្ជាក់ថា ព្រះវរបិតាបានចាត់ទ្រង់ឱ្យមកប្រាកដមែន (មើលការពន្យល់ ១០:២៥) ។

**៥:៣៧** *សំឡេងទ្រង់* ប្រហែលសំដៅលើសម្លេងដែលព្រះវរបិតាទ្រង់មានបន្ទូល នៅពេលដែលព្រះយេស៊ូវគ្រីស្ទទទួលពិធីជ្រមុជទឹក ដោយលោកយ៉ូហាន-បាទីស្ទ (ខ.៣៨–៣៩ មើលការពន្យល់ មថ ៣:១៧) ។

**៥:៣៨** *ព្រោះអ្នករាល់គ្នាមិនជឿ* មានន័យថា នៅពេលនោះពួកគេមិនបានទទួលជឿដល់ព្រះបន្ទូលនៃព្រះអម្ចាស់ទេ ។ ដូច្នេះបញ្ជាក់ថា អស់អ្នកណាដែលមិនជឿដល់ព្រះនាមព្រះអម្ចាស់ នោះក៏គ្មានព្រះបន្ទូលទ្រង់នៅក្នុងខ្លួនដែរ ។

**៥:៣៩** *អ្នករាល់គ្នាស្ទង់មើលគម្ពីរ* បញ្ជាក់ថា ពួកអ្នកដឹកនាំសាសន៍យូដាតែងតែសិក្សាព្រះគម្ពីរ (សញ្ញាចាស់) ដោយយកចិត្តទុកដាក់ និងដោយប្រុងប្រយ័ត្ន ប៉ុន្តែពួកគេមិនបានយល់ នូវសេចក្តីដ៏សំខាន់បំផុត ដែលថែងអំពីព្រះម្ចាស់ទេ ។

**៥:៤១** *ខ្ញុំមិនទទួលកិត្តិសព្ទអំពីមនុស្សទេ* បញ្ជាក់ថា ព្រះអម្ចាស់មិនទទួលការសរសើរបែបចំអកពីមនុស្សអាក្រក់ និងមនុស្សមានពុតទេ ប៉ុន្តែ ទ្រង់ទទួលការសរសើរអំពីអ្នកបម្រើបរិសុទ្ធ សុចរិត និងស្មោះត្រង់របស់ទ្រង់ (ខ.៤៤) ។

**៥:៤២** បទគម្ពីរនេះបញ្ជាក់ថា ដោយព្រោះពួកគេមិនព្រមទទួលព្រះយេស៊ូវគ្រីស្ទជាព្រះសង្គ្រោះ និងជាព្រះនៃសេចក្តីស្រលាញ់ ដូច្នោះហើយបានជាពួកគេមិនមានសេចក្តីស្រលាញ់របស់ទ្រង់នៅក្នុងខ្លួនទេ (១យហ ៤:៨) ។

**៥:៤៣-៤៤** ពួកអ្នកដឹកនាំសាសន៍យូដានៅពេលនោះ តែងតែចង់បានការសរសើរ និងការលើកតម្កើងពីមនុស្ស រហូតធ្វើឱ្យពួកគេបដិសេធព្រះយេស៊ូវ ដែលមកពីព្រះវរបិតា ដូច្នោះហើយ ទើបពួកគេមិនបានទទួលកិត្តិសព្ទមកអំពីទ្រង់ទេ ។

**៥:៤៣** *បើសិនជាមានអ្នកណាទៀតមក . . . អ្នករាល់គ្នានឹងទទួលអ្នកនោះ* មានន័យថា ប្រសិនបើមានគ្រូបង្រៀនខុសឆ្គងមកដោយឈ្មោះរបស់គេផ្ទាល់ ពួកគេនឹងទទួលអ្នកនោះ (សក ១១:១៥,១៧) ។

**៥:៤៥-៤៧** បទគម្ពីរត្រង់ចំណុចនេះបញ្ជាក់ថា សេចក្តីដែលបានប្រទានមកលោកម៉ូសេនិងសេចក្តីដែលព្រះយេស៊ូវមានបន្ទូលគឺសុទ្ធតែមកពីព្រះវរបិតា (មើលការពន្យល់ លក ១៦:៣១ រម ១០:៤) ។ អស់អ្នកណាដែលមិនព្រមទទួលទីបន្ទាល់របស់លោកម៉ូសេក៏មិនទទួលទីបន្ទាល់របស់ព្រះយេស៊ូវដែរ ។ ព្រះយេស៊ូវទ្រង់មានបន្ទូលទៅពួកអ្នកដែលកំពុងស្តាប់ទ្រង់ នៅពេលនោះថា

គ្នានោះឡើយ មានម្នាក់ដែលប្ដឹងពីអ្នករាល់គ្នាហើយ គឺជា
លោកម៉ូសេ ដែលអ្នករាល់គ្នាយកជាទីសង្ឃឹម[ល] ៤៦បើសិន
ជាអ្នករាល់គ្នាជឿដល់លោកម៉ូសេពិត នោះនឹងបានជឿ
ដល់ខ្ញុំដែរ ពីព្រោះលោកបានចែងទុកពីខ្ញុំ[វ] ៤៧ប៉ុន្តែបើអ្នក
រាល់គ្នាមិនជឿសេចក្ដី ដែលលោកបានចែងទុកមកទេនោះ
ធ្វើដូចម្ដេចឱ្យជឿពាក្យខ្ញុំទៅបាន[ស]។

**ព្រះយេស៊ូវប្រទាននំប៉័ងដល់មនុស្ស៥ពាន់នាក់**

*៦:១-១៣ មថ ១៤:១៣-២១ មក ៦:៣២-៤៤ លក ៩:១០-១៧*

**៦** ១លុះក្រោយមក ព្រះយេស៊ូវទ្រង់ឆ្លងសមុទ្រកាលីឡេ គឺ
ជាសមុទ្រទីបេរាស ២ហើយមានហ្វូងមនុស្សជាធំតាមទ្រង់
ទៅ ដោយបានឃើញទីសំគាល់ទាំងប៉ុន្មាន[ហ] ដែលទ្រង់
ប្រោសដល់ពួកជំងឺ ៣នោះព្រះយេស៊ូវទ្រង់យាងឡើងទៅ
លើភ្នំ[ឡ] គង់ជាមួយនឹងពួកសិស្សនៅទីនោះ ៤រីឯបុណ្យរំលង
ជាបុណ្យរបស់សាសន៍យូដា[អ] ក៏ជិតដល់ហើយ ៥ឯព្រះយេ
ស៊ូវទ្រង់ងើបព្រះនេត្រឡើង ឃើញមនុស្សកកកុញមក
ឯទ្រង់ នោះទ្រង់មានបន្ទូលទៅភីលីពថា[ក] យើងនឹងទិញ
នំប៉័ងពីណាមក ឱ្យមនុស្សទាំងអស់នេះបានបរិភោគ
៦ទ្រង់មានបន្ទូលសួរដូច្នេះ ដើម្បីនឹងល្បងលគាត់ទេ ព្រោះ
ទ្រង់ជ្រាបការ ដែលទ្រង់គិតធ្វើហើយ ៧ភីលីពទូលឆ្លើយ
ថា ទោះបើទិញនំប៉័ងអស់៤០រៀល ក៏មិនគ្រាន់ឱ្យគ្រប់គ្នា
សូម្បីតែបន្តិចបន្តួចផង ៨មានសិស្សទ្រង់ម្នាក់ ឈ្មោះអនទ្រេ
ជាប្អូនស៊ីម៉ូន-ពេត្រុស[ខ] គាត់ទូលទ្រង់ថា ៩នៅទីនេះមាន
ក្មេងម្នាក់ មាននំប៉័ងម្សៅឱក៥ និងត្រីតូច២ ប៉ុន្តែដែលមាន
តែប៉ុណ្ណោះ តើមានប្រយោជន៍អ្វី ដល់មនុស្សច្រើនទាំង
ម្ល៉េះ[គ] ១០ព្រះយេស៊ូវមានបន្ទូលថា ចូរឱ្យមនុស្សទាំងអស់
អង្គុយទៅ រីឯនៅទីនោះ មានស្មៅច្រើន ដូច្នេះ គេក៏នាំគ្នា
អង្គុយ មានចំនួនប្រហែលជា៥ពាន់នាក់ ១១រួចព្រះយេស៊ូវ
ទ្រង់យកនំប៉័ងនោះមកអរព្រះគុណ[ឃ] រួចចែកទៅឱ្យពួក
សិស្ស គេក៏ចែកដល់ពួកអ្នកដែលអង្គុយ បានចែកទាំង
ត្រីតូចនោះបែបដូច្នោះដែរ តាមតែគេចង់បាន ១២លុះគេ
បានឆ្អែតគ្រប់គ្នាហើយ នោះទ្រង់មានបន្ទូលទៅពួកសិស្ស
ថា ចូរប្រមូលចំណិតដែលសល់នៅ ដើម្បីកុំឱ្យបាត់អ្វីឡើយ
១៣ក្រោយដែលបរិភោគរួចហើយ នោះគេប្រមូលចំណិតនំ
ប៉័ងម្សៅឱក ដែលសល់ពី៥ដុំនោះ ដាក់ពេញបាន ១២កន្ត្រក
១៤កាលមនុស្សទាំងប៉ុន្មាន បានឃើញទីសំគាល់[ង] ដែល

**៥:៤៥** រ យហ ៩:២៨ ល រម ២:១៧
**៥:៤៦** វ លប ៣:១៥ លក ២៤:២៧,៤៤ កច ២៦:២២
**៥:៤៧** ស លក ១៦:២៩,៣១
**៦:២** ហ យហ ២:១១
**៦:៣** ឡ ខ.១៥
**៦:៤** អ យហ ១១:៥៥
**៦:៥** ក យហ ១:៤៣
**៦:៨** ខ យហ ១:៤០
**៦:៩** គ ២ពវ ៤:៤៣
**៦:១១** ឃ ខ.២៣ មថ ១៤:១៩
**៦:១៤** ង យហ ២:១១ ច ចទ ១៨:១៥,១៨ មថ ១១:៣ ២១:១១

ពួកគេបានបដិសេធទាំងទីបន្ទាល់របស់លោកម៉ូសេ និងទីបន្ទាល់របស់ទ្រង់ផង ។ ដូច្នេះ អ្នកដែលប្ដឹងពីពួកគេរាល់គ្នា នៅចំពោះព្រះអម្ចាស់ គឺលោកម៉ូសេ ។

**៥:៤៦** *ពីព្រោះលោកបានចែងទុកពីខ្ញុំ* ត្រង់ចំណុចនេះ អ្នកនិពន្ធព្រះគម្ពីរបរិសុទ្ធសញ្ញាថ្មី តែងតែបញ្ជាក់ថា សេចក្ដីដ៏សំខាន់បំផុតដែលចែងនៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺនិយាយអំពីព្រះគ្រីស្ទ (មើលការពន្យល់ លក ២៤:២៥-២៧,៤៤) ។ ក្នុងខណៈពេល ដែលព្រះយេស៊ូវមានបន្ទូលទៅកាន់ពួកបណ្ដាជនទាំងនោះ ទ្រង់បានបញ្ជាក់យ៉ាងច្បាស់ថា លោកម៉ូសេបានចែងទុកអំពីទ្រង់ (ចទ ១៨:១៥,១៨) ។ ម្យ៉ាងទៀត មានសេចក្ដីជាច្រើន ដែលបានចែងទុកនៅក្នុងក្រឹត្យវិន័យ និងតាមរយៈពួកហោរាបរិសុទ្ធ អំពីព្រះយេស៊ូវគ្រីស្ទ ថាទ្រង់គឺជាព្រះមែស៊ីពិតប្រាកដមែន ។

**៦:១-១៥** នៅក្នុងព្រះគម្ពីរដំណឹងល្អទាំងអស់ សុទ្ធតែមាននិយាយអំពីការប្រទានអាហារដល់មនុស្ស៥ពាន់អ្នក និងអំពីការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ ការដែលទ្រង់ប្រទាននំប៉័ងដល់ពួកគេ បង្ហាញអំពីការផ្គត់ផ្គង់ដល់សេចក្ដីត្រូវការរបស់ពួកគេ និងជាទីបន្ទាល់មួយដែលបញ្ជាក់ថា ទ្រង់គឺជាអាហារដែលផ្ដល់ជីវិត ដ៏ពិតប្រាកដ (ខ.៣៥) ។

**៦:១** *ឆ្លង* កន្លែងដែលព្រះយេស៊ូវឆ្លងនោះ ប្រហែលជានៅក្បែរភូមិបេតសៃដា (លក ៩:១០) ។ *សមុទ្រទីបេរាស* ប្រហែលជាឈ្មោះផ្លូវការរបស់សមុទ្រកាលីឡេសម្រាប់ពួករ៉ូម៉ាំង ។ នៅឆ្នាំទី២០គ.ស គេបានយកឈ្មោះទីក្រុងទីបេរាសធ្វើជាឈ្មោះរបស់សមុទ្រនេះតែម្ដង ។

**៦:២** *ទីសំគាល់* សំដៅលើការអស្ចារ្យរបស់ព្រះយេស៊ូវ (ពន្យល់ ២:១១) ។

**៦:៤** *បុណ្យរំលង* ពួកយូដាតែងតែប្រារព្ធធ្វើពិធីបុណ្យនេះឡើងនៅពាក់កណ្ដាល ខែចេត្រ (ត្រូវនឹងខែមេសា) ជារៀងរាល់ឆ្នាំ (នក ១២ មើលការពន្យល់ នក ១២:១១-២៣ លក ២២:១ មថ ២៦:១៧,១៨-៣០ មក ១៤:១,១២) ។ តាមទំនៀមទម្លាប់ ពួកប្រុសៗជាសាសន៍យូដា ត្រូវតែធ្វើដំណើរទៅចូលរួមក្នុងពិធីបុណ្យនេះ នៅឯទីក្រុងយេរូសាឡិម (២:១៣ ៥:១ ចទ ១៦:១៦) ។

**៦:៥** *ភីលីព* លោកភីលីពរស់នៅក្បែរភូមិបេតសៃដា (មើលការពន្យល់ ១:៤៤) ដូច្នោះ បានជាព្រះយេស៊ូវទ្រង់មានបន្ទូលសួរគាត់ អំពីទីកន្លែងដែលអាចរកទិញអាហារឱ្យមនុស្សដែលមកតាមទ្រង់បរិភោគ ។

**៦:៩** *នំប៉័ងម្សៅឱក* គឺជានំប៉័ងដែលមានតម្លៃថោក ។

**៥:១០** *មានចំនួនប្រហែលជា៥ពាន់នាក់* ចំនួន៥ពាន់នាក់នោះ គឺរាប់តែប្រុសៗប៉ុណ្ណោះ មិនរាប់ចំនួនក្មេងៗ និងស្រីៗទេ (មើលការពន្យល់ មថ ១៤:២១) ។

**៦:១២** *ចូរប្រមូលចំណិតដែលនៅសល់* ការដែលព្រះយេស៊ូវទ្រង់មានបន្ទូលទៅពួកសិស្ស ឱ្យប្រមូលចំណិតនំប៉័ងដែលនៅសល់ទាំងនោះ បញ្ជាក់ថា មិនត្រូវខ្ជះខ្ជាយ ឬមើលងាយព្រះពរ ដែលទ្រង់ប្រទានឱ្យទេ (មក ៦:៤៣) ។

**៦:១៣** *ដាក់ពេញបាន១២កន្ត្រក* បញ្ជាក់ថា សិស្សទាំង១២នាក់របស់ព្រះយេស៊ូវម្នាក់ៗប្រមូលបានមួយកន្ត្រក ។ ម្យ៉ាងទៀត ការដែលមាននំប៉័ងនៅសល់ច្រើន យ៉ាងនេះមានន័យថា ព្រះយេស៊ូវបានផ្គត់ផ្គង់ពួកគេយ៉ាងបរិបូរ (មក ៦:៤៣) ។

**៦:១៤** បទគម្ពីរនេះបញ្ជាក់ថា នៅពេលដែលពួកអ្នកដើរតាមព្រះយេស៊ូវបានឃើញការអស្ចារ្យដែលទ្រង់ធ្វើ នោះពួកគេក៏យល់ថា ទ្រង់គឺជាហោរា

ព្រះយេស៊ូវធ្វើនោះ គេក៏និយាយថា លោកនេះប្រាកដជា
ហោរានោះ ដែលត្រូវមកក្នុងលោកីយមែន[ច] ១៥ដូច្នេះ
ព្រះយេស៊ូវក៏ថយឡើងទៅលើភ្នំតែ១អង្គទ្រង់វិញទៀត[ឆ]
ពីព្រោះទ្រង់ជ្រាបថា គេគិតមកចាប់ទ្រង់ដោយកំឡាំង
ដើម្បីនឹងតាំងឡើងជាស្តេច[ជ]។

### ព្រះយេស៊ូវយាងលើទឹក

*៦:១៦–២១ មថ ១៤:២២–៣៣ មក ៦:៤៧–៥១*

១៦លុះព្រលប់ហើយ ពួកសិស្សទ្រង់ចុះទៅឯសមុទ្រ
១៧ក៏ចុះទូកឆ្លងទៅឯកាពើណិម ពេលនោះងងឹតហើយ
តែព្រះយេស៊ូវមិនទាន់មកដល់នៅឡើយ ១៨សមុទ្រក៏មាន
រលក បោកដោយខ្យល់បក់ជាខ្លាំង ១៩កាលគេបានចែវទៅ
ប្រហែលជា៥ឬ៦គីឡូម៉ែត្រហើយ នោះស្រាប់តែគេ
ឃើញព្រះយេស៊ូវ ទ្រង់យាងលើសមុទ្រ[ឈ]មកជិតទូក ហើយ
គេមានសេចក្តីភ័យខ្លាច ២០តែទ្រង់មានបន្ទូលថា កុំភ័យអី
គឺខ្ញុំទេតើ[ញ] ២១នោះគេក៏ព្រមទទួលទ្រង់ មកក្នុងទូក ស្រាប់
តែទូកបានដល់ស្រុកដែលគេប៉ងនឹងទៅ ។

២២ស្អែកឡើង កាលហ្វូងមនុស្ស ដែលនៅត្រើយសមុទ្រ
ម្ខាង បានឃើញថា នៅទីនោះគ្មានទូកណាទៀត[ដ] ក្រៅពី
ទូក១ ដែលពួកសិស្សទ្រង់បានជិះ ហើយថា ព្រះយេស៊ូវមិន
បានជិះទូកនោះ ទៅជាមួយនឹងពួកសិស្សទេ គឺពួកសិស្សបាន
ចេញទៅតែគ្នាគេ[ឋ] ២៣(ប៉ុន្តែមានទូកខ្លះទៀត មកពីស្រុក
ទីបេរាស[ឌ] ជិតកន្លែងដែលគេបានបរិភោគនំបុ័ង ក្រោយ
ដែលព្រះអម្ចាស់បានអរព្រះគុណរួចហើយ[ឍ]) ២៤ដូច្នេះ
កាលហ្វូងមនុស្ស មិនឃើញព្រះយេស៊ូវ ឬពួកសិស្សទ្រង់
នៅទីនោះ គេក៏ជិះទូកទៅឯកាពើណិម ដើម្បីនឹងរក
ទ្រង់ ២៥កាលឃើញទ្រង់នៅឯត្រើយម្ខាងហើយនោះគេ
ទូលសួរថា លោកគ្រូ[ណ] លោកមកដល់ទីនេះពីកាលណា
២៦ព្រះយេស៊ូវមានបន្ទូលឆ្លើយទៅគេថា ប្រាកដមែន ខ្ញុំ
ប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នារកខ្ញុំ[ត] មិនមែន
ដោយព្រោះបានឃើញទីសំគាល់ទេ[ថ] គឺដោយព្រោះតែ
បានបរិភោគនំបុ័ងឆ្អែតប៉ុណ្ណោះ ២៧កុំឱ្យខំប្រឹងឱ្យបាន
តែអាហារ ដែលតែងតែពុករលួយនោះឡើយ ចូរខំឱ្យ
បានអាហារ ដែលនៅស្ថិតស្ថេរ[ទ] ដរាបដល់ជីវិតអស់កល្ប
ជានិច្ចវិញ[ធ] ជាអាហារដែលកូនមនុស្ស[ន]នឹងឱ្យមកអ្នករាល់
គ្នា ដ្បិតគឺកូនមនុស្សនេះហើយ ដែលព្រះវរបិតាដ៏ជាព្រះ
ទ្រង់បានដៅ[ប]ចំណាំទុក ២៨ដូច្នេះ គេទូលសួរទ្រង់ថា ដែល
នឹងធ្វើការរបស់ព្រះ តើត្រូវធ្វើដូចម្តេចខ្លះ ២៩ព្រះយេស៊ូវ
មានបន្ទូលឆ្លើយថា ឯការរបស់ព្រះ គឺឱ្យអ្នករាល់គ្នាបាន
ជឿ[ផ]ដល់អ្នកដែលព្រះបានចាត់ឱ្យមក[ព] ៣០នោះគេទូលសួរ
ទ្រង់ថា បើដូច្នេះ តើលោកនឹងធ្វើទីសំគាល់[ភ]ណាឱ្យយើង
ខ្ញុំឃើញផង ដើម្បីឱ្យបានជឿដល់លោក[ម] តើលោកធ្វើការ
អ្វីខ្លះ ៣១ពួកព្វយុកោយើងខ្ញុំ បានបរិភោគនំម៉ាន៉ា[យ]

**៦:១៥** ឆ មថ ១៤:២៣ មក ៦:៤៦ ជ យហ ១៨:៣៦
**៦:១៩** ឈ យប ៩:៨
**៦:២០** ញ មថ ១៤:២៧
**៦:២២** ដ ខ.២
**៦:២២** ឋ ខ.១៥–២១
**៦:២៣** ឌ ខ.១ ឍ ខ.១១
**៦:២៥** ណ មថ ២៣:៧
**៦:២៦** ត ខ.២៤ ថ ខ.៣០ យហ ២:១១
**៦:២៧** ទ អស ៥៥:២ ធ ខ.៥៤ មថ ២៥:៤៦ ន មថ ៨:២០ ប រម ៤:១១ ១កថ ៩:២ ២កថ ១:២២ អភ ១:១៣ ៤:៣០ ២ធថ ២:១៩ វវ ៧:៣
**៦:២៩** ផ ១យហ ៣:២៣ ព យហ ៣:១៧
**៦:៣០** ភ យហ ២:១១ ម មថ ១២:២៨

ម្នាក់ដែលមានចែងទុកនៅក្នុងបទគម្ពីរ "ចទ ១៨:១៥,១៨" (មើលការពន្យល់ ១:២១)។ ព្រះអម្ចាស់បានប្រទានទឹក និងអាហារ ដល់រាស្ត្ររបស់ទ្រង់ នៅឯទីរហោស្ថាន តាមរយៈលោកម៉ូសេ ហើយពួកគេសង្ឃឹមថា នឹងមានហោរាដែលធ្វើការអស្ចារ្យធំជាងគាត់(ម៉ូសេ) ទៅទៀត ។

**៦:១៥** *គេគិតមកចាប់ទ្រង់ដោយកំឡាំង* មានន័យថា ពួកគេមានគំនិតចង់បង្ខំឱ្យព្រះយេស៊ូវធ្វើជាស្តេចលើពួកគេ គឺដូចជាស្តេចផ្សេងៗទៀតនៅលើផែនដីនេះតែម្តង (មើលការពន្យល់ ១៨:៣៦ លក ២៤:២១)។ ព្រះយេស៊ូវទ្រង់ជ្រាបពីគំនិតរបស់ពួកគេ ដូច្នោះបានជាទ្រង់បដិសេធ និងបានយាងចេញពីពួកគេទៅ ។

**៦:១៩** *៥ ឬ ៦ គីឡូម៉ែត្រ* ត្រង់ចំណុចនេះ លោកម៉ាកុសសរសេរថា ទូកនោះនៅកណ្តាលសមុទ្រតែម្តង (មើលការពន្យល់ មក ៦:៤៧)។ *គេមានសេចក្តីភ័យខ្លាច* មានន័យថា នៅពេលដែលពួកសិស្សរបស់ព្រះយេស៊ូវបានឃើញទ្រង់យាងនៅ លើទឹកសមុទ្រ នោះក៏មានសេចក្តីភ័យខ្លាចជាខ្លាំង ហើយនិយាយគ្នាថា ខ្មោចលង ពួកគេហើយ (មថ ១៤:២៦)។

**៦:២២–២៤** ពួកបណ្តាជនមិនបានដឹងថា មានហេតុការណ៍អ្វីកើតឡើងចំពោះព្រះយេស៊ូវទេ ប៉ុន្តែ នៅពេលដែលមិនឃើញទ្រង់ នោះក៏នាំគ្នាស្វែងរកទ្រង់នៅឯក្រុងកាពើណិមតែម្តង (មើលការពន្យល់ ២:១២)។

**៦:២៧** *ជីវិតអស់កល្បជានិច្ច* គឺជាជីវិតដែលបានមកដោយសារសេចក្តីជំនឿលើព្រះនាមព្រះយេស៊ូវគ្រីស្ទ (ខ.២៨–២៩ មើលការពន្យល់ ៣:១៥)។ *កូនមនុស្ស* សំដៅលើព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ មក ៨:៣១)។ គោលបំណងមួយនៃកណ្ឌគម្ពីរដំណឹងល្អយ៉ូហានគឺ និយាយអំពីការស្តាប់បង្គាប់របស់ព្រះរាជបុត្រាចំពោះព្រះវរបិតា (មើលការពន្យល់ ៤:៣៤)។

**៦:២៨** *តើត្រូវធ្វើដូចម្តេចខ្លះ ?* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកគេនៅមិនទាន់បានយល់នៅឡើយទេថា ការសង្គ្រោះគឺជាអំណោយទានរបស់ព្រះយេស៊ូវគ្រីស្ទ និងទទួលបានដោយសារសេចក្តីជំនឿលើព្រះនាមទ្រង់ ។ ពួកគេនៅតែយល់ច្រឡំថា ប្រហែលជាត្រូវធ្វើកិច្ចការអ្វីម្យ៉ាង ដើម្បីបានការសង្គ្រោះមកអំពីព្រះអម្ចាស់ (អភ ២:៨–៩ ទត ៣:៥)។

**៦:២៩** ក្នុងបទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ការដ៏សំខាន់បំផុតដែលមនុស្សត្រូវធ្វើ ដើម្បីឱ្យបានជីវិតអស់កល្បជានិច្ច មកអំពីព្រះអម្ចាស់ គឺត្រូវទទួលជឿលើព្រះនាមទ្រង់ (មើលការពន្យល់ ៩:៤)។

**៦:៣០** *តើលោកធ្វើការអ្វីខ្លះ ?* ឃ្លានេះបញ្ជាក់ថា នៅពេលនោះ ពួកគេចង់ឱ្យព្រះយេស៊ូវធ្វើទីសំគាល់ណាមួយ ដើម្បីបង្ហាញថា ទ្រង់ពិតជាអាចធ្វើការអស្ចារ្យធំជាងការប្រទាននំម៉ាន៉ា នៅសម័យលោកម៉ូសេនោះទៅទៀត ។

**៦:៣១** *នំម៉ាន៉ា* ពួកសាសន៍យូដាសង្ឃឹមថា នៅពេលដែលព្រះមែស៊ីយាងមកនោះទ្រង់នឹងប្រទាននំម៉ាន៉ាឱ្យដល់ពួកគេ ។ ម្យ៉ាងទៀត ប្រហែលជាពួកគេគិតថា ព្រះយេស៊ូវមិនបានធ្វើការអស្ចារ្យធំៗ ដូចលោកម៉ូសេទេ ។

នៅទីរហោស្ថាន ដូចជាមានសេចក្តីចែងទុកមកថា
«លោកបានឱ្យនំបុ័ងពីស្ថានសួគ៌ មកឱ្យគេបរិភោគ»[រ]
៣២ឯព្រះយេស៊ូវទ្រង់មានបន្ទូលតបថា ប្រាកដមែន ខ្ញុំប្រាប់
អ្នករាល់គ្នាជាប្រាកដថា មិនមែនលោកម៉ូសេ ដែលឱ្យ
នំបុ័ង ពីស្ថានសួគ៌នោះ មកអ្នករាល់គ្នាទេ តែឯនំបុ័ងដ៏ពិត
ដែលមកពីស្ថានសួគ៌ នោះគឺព្រះវរបិតាខ្ញុំ ដែលប្រទាន
មកអ្នករាល់គ្នាវិញ ៣៣ដ្បិតនំបុ័ងរបស់ព្រះ គឺជាព្រះអង្គ
ដែលយាងចុះពីស្ថានសួគ៌មក[ល] ព្រមទាំងប្រទានឱ្យមនុស្ស
លោកបានជីវិតផង ៣៤ដូច្នេះ គេទូលទ្រង់ថា លោកម្ចាស់
អើយ សូមឱ្យនំបុ័ងនោះមកយើងខ្ញុំជានិច្ច[វ]។
៣៥ព្រះយេស៊ូវមានបន្ទូលថា ខ្ញុំជា[ស]នំបុ័ងជីវិត[ហ]អ្នកណា
ដែលមកឯខ្ញុំ នោះនឹងមិនឃ្លានទៀតឡើយ ហើយអ្នកណា
ដែលជឿ[ឡ]ដល់ខ្ញុំ ក៏មិនត្រូវស្រេកដែរ[អ] ៣៦ប៉ុន្តែខ្ញុំបានប្រាប់
អ្នករាល់គ្នារួចហើយថា អ្នករាល់គ្នាបានឃើញខ្ញុំតែមិន
ជឿទេ ៣៧អស់អ្នកណាដែលព្រះវរបិតាប្រទានមកខ្ញុំ[ក] នោះ
នឹងមកឯខ្ញុំ ហើយអ្នកណាដែលមកឯខ្ញុំ ខ្ញុំក៏មិនដែលចោល
ទៅក្រៅឡើយ ៣៨ពីព្រោះខ្ញុំបានចុះពីស្ថានសួគ៌មក[ខ] មិន
មែននឹងធ្វើតាមចិត្តខ្ញុំទេ គឺតាមបំណងព្រះហឫទ័យ[គ] នៃ
ព្រះវិញ ដែលទ្រង់ចាត់ឱ្យខ្ញុំមក[ឃ] ៣៩ឯបំណងព្រះហឫទ័យ
នៃព្រះវរបិតា ដែលចាត់ឱ្យខ្ញុំមក នោះគឺមិនចង់ឱ្យខ្ញុំបាត់
អ្នកណា ក្នុងគ្រប់អស់ទាំងមនុស្ស ដែលទ្រង់ប្រទានមកខ្ញុំ
នោះឡើយ[ង] គឺទ្រង់ចង់ឱ្យខ្ញុំប្រោសទាំងអស់ ឱ្យរស់ឡើង[ច]
នៅថ្ងៃចុងបំផុតវិញ ៤០នេះហើយជាបំណងព្រះហឫទ័យ
នៃព្រះវរបិតាខ្ញុំ គឺឱ្យអស់អ្នកណាដែលឃើញព្រះរាជ
បុត្រា[ឆ] ហើយក៏ជឿដល់ទ្រង់ បានជីវិតដ៏នៅអស់កល្ប
ជានិច្ច[ជ] ហើយខ្ញុំនឹងឱ្យអ្នកនោះរស់ឡើងវិញ នៅថ្ងៃចុង
បំផុត។
៤១នោះពួកសាសន៍យូដា គេឌុកដាន់ទ្រង់ ពីព្រោះទ្រង់
មានបន្ទូលថា ខ្ញុំជានំបុ័ង ដែលចុះពីស្ថានសួគ៌មក ៤២គេ
និយាយថា អ្នកនេះ តើមិនមែនឈ្មោះយេស៊ូវ ជាកូន
យ៉ូសែប[ឈ] ដែលយើងស្គាល់ឪពុកម្តាយគាត់ទេឬអី[ញ] ចុះ
ដូចម្តេចឡើយបានជាគាត់និយាយថា គាត់ចុះពីស្ថានសួគ៌
មកដូច្នេះ[ដ] ៤៣នោះព្រះយេស៊ូវមានបន្ទូលទៅគេថា
កុំឱ្យរទូរទាំក្នុងពួកអ្នករាល់គ្នាឡើយ ៤៤គ្មានអ្នកណា

**៦:៣១** យ ជន ១១:៧–៩ រ នក ១៦:៤,១៥ នហ ៩:១៥ ទដ ៧៨:២៤ ១០៥:៤០ **៦:៣៣** ល ខ.៥០ យហ ៣:១៣,៣១ **៦:៣៤** វ យហ ៤:១៥ **៦:៣៥** ស នក ៣:១៤ យហ ៨:១២ ១០:៧,១១ ១១:២៥ ១៤:៦ ១៥:១ ហ ខ.៤៨,៥១ ឡ យហ ៣:១៥ អ យហ ៤:១៤ **៦:៣៧** ក ខ.៣៩ យហ ១៧:២,៦,៩,២៤ **៦:៣៨** ខ យហ ៣:១៣,៣១ គ មថ ២៦:៣៩ ឃ យហ ៣:១៧ **៦:៣៩** ង អស ២៧:៣ យរ ២៣:៤ យហ ១០:២៨ ១៧:១២ ១៨:៩ ច ខ.៤០,៤៤,៥៤ **៦:៤០** ឆ យហ ១២:៤៥ ជ មថ ២៥:៤៦ **៦:៤២** ឈ លក ៤:២២ ញ យហ ៧:២៧,២៨ ដ ខ.៣៨,៦២

ព្រះយេស៊ូវប្រទានអាហារដល់មនុស្ស៥ពាន់នាក់ ប៉ុន្តែ លោកម៉ូសេបានឱ្យអាហារដល់ប្រជាជាតិអ៊ីស្រាអែលទាំងមូល ។ ព្រះយេស៊ូវប្រទានមកតែម្តងប៉ុណ្ណោះ ប៉ុន្តែ លោកម៉ូសេបានឱ្យអាហារដល់ពួកអ៊ីស្រាអែល៤០ឆ្នាំ ។ ព្រះយេស៊ូវប្រទានឱ្យពួកគេនូវនំបុ័ងធម្មតា (មើលការពន្យល់ ខ.១–១៥ និងខ.១៤) ប៉ុន្តែ លោកម៉ូសេបានឱ្យនំម៉ាន៉ា ដែលមកពីស្ថានសួគ៌ដល់ពួកអ៊ីស្រាអែលវិញ (មើលការពន្យល់ នក ១៦:៤ ជន ១១:៧)។ ពួកគេប្រហែលជាយល់យ៉ាងដូច្នេះ ព្រោះថា ពកគេមិនទាន់បានយល់នូវសេចក្តីពិតរបស់ព្រះអម្ចាស់នៅឡើយទេ ។

**៦:៣២** បទគម្ពីរនេះ បញ្ជាក់យ៉ាងច្បាស់ថា លោកម៉ូសេមិនបានឱ្យនំម៉ាន៉ាដល់ពួកអ៊ីស្រាអែលទេ គឺពួកគេទទួលមកពីព្រះអម្ចាស់វិញ ។ ម្យ៉ាងទៀត ព្រះវរបិតាប្រទានអាហារដ៏ពិតដែលផ្តល់ជីវិត មកពីស្ថានសួគ៌ តាមរយៈព្រះរាជបុត្រាទ្រង់ ។

**៦:៣៣** *នំបុ័ងរបស់ព្រះ* សំដៅលើព្រះយេស៊ូវគ្រីស្ទ ។ *ព្រះអង្គដែលយាងចុះពីស្ថានសួគ៌* គឺព្រះយេស៊ូវគ្រីស្ទ (ខ.៣៨,៤១,៥០–៥១,៥៨)។

**៦:៣៤** ក្នុងបទគម្ពីរនេះបញ្ជាក់ថា ពួកគេមានការយល់ច្រឡំនូវសេចក្តីដែលព្រះយេស៊ូវមានបន្ទូលទៅកាន់ពួកគេ គឺដូចជាស្ត្រីសាសន៍សាម៉ារីម្នាក់ ដែលទ្រង់បានជួបនៅក្បែរអណ្តូងយ៉ាកុបនោះដែរ (មើលការពន្យល់ ៣:៤ ៤:១៥)។ ពួកគេយល់ថា ទ្រង់មានបន្ទូលអំពីសេចក្តីដែលត្រូវខាងឯសាច់ឈាមប៉ុណ្ណោះ ។

**៦:៣៥** ព្រះយេស៊ូវគឺជានំបុ័ងជីវិត (១:៤ ៣:៣៦ ១យហ ៥:១១–១២)។ អ្នកណាដែលមកឯទ្រង់ នោះទ្រង់នឹងឱ្យគេមានជីវិតរស់អស់កល្បជានិច្ច (មើលការពន្យល់ ៤:១៤)។ មានន័យថា អស់អ្នកណាដែលទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ នោះទ្រង់ប្រទានជីវិតដ៏នៅរស់អស់កល្បជានិច្ចដល់អ្នកនោះ (ខ.៤០ ៣:១៦)។

**៦:៣៦** *តែមិនជឿទេ* ត្រង់ចំណុចនេះបញ្ជាក់ថា ទោះបីពួកសាសន៍យូដាបានឃើញការអស្ចារ្យ ដែលព្រះយេស៊ូវទ្រង់ធ្វើដោយផ្ទាល់ភ្នែកក៏ដោយ ក៏ពួកគេនៅតែមិនព្រមជឿដល់ទ្រង់ដដែល ។

**៦:៣៧** បទគម្ពីរនេះបញ្ជាក់ថា ព្រះយេស៊ូវទ្រង់មិនចាកចោលអ្នកដែលជឿដល់ព្រះនាមទ្រង់ទេ (១០:២៨ មើលការពន្យល់ ១៧:៩,១២,១៥,១៩ ១៨:៩)។

**៦:៣៨** "មើលការពន្យល់ ៤:៣៤"។

**៦:៣៩** *នោះគឺមិនចង់ឱ្យខ្ញុំបាត់អ្នកណា . . . ឡើយ* មានន័យថា ព្រះយេស៊ូវទ្រង់ថែរក្សាពួកអ្នក ដែលជឿដល់ព្រះនាមទ្រង់ ហើយមិនឱ្យពួកគេត្រូវវិនាសឡើយ គឺឱ្យពួកគេមានជីវិតរស់អស់កល្បជានិច្ចវិញ (១០:២៨–២៩ មើលការពន្យល់ ភល ១:៦ ហាព ៣:៦,១៤)។ *ថ្ងៃចុងបំផុត* សំដៅលើថ្ងៃដែលព្រះយេស៊ូវយាងមកផែនដីជាលើទី២ ឬថ្ងៃដែលមនុស្សទាំងអស់នឹងរស់ឡើងវិញ ឬក៏ថ្ងៃជំនុំជម្រះ (ខ.៤០,៤៤,៥៤ ៥:២៥–៣០ ១១:២៤ ១២:៤៨)។

**៦:៤០** *ជីវិតដ៏នៅអស់កល្បជានិច្ច* "មើលការពន្យល់ ៣:១៥"។ *ឱ្យអ្នកនោះរស់ឡើងវិញ នៅថ្ងៃចុងបំផុត* មានន័យថា ព្រះយេស៊ូវនឹងប្រោសអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ ឱ្យមានជីវិតរស់ឡើងវិញ ហើយសេចក្តីស្លាប់ក៏គ្មានអំណាចលើគេឡើយ (១១:២៥ មើលការពន្យល់ ខ.២៦)។

**៦:៤១** *ពួកសាសន៍យូដា* "មើលការពន្យល់ ១:៩"។

**៦:៤៤** *ទ្រង់ទាញនាំគេ* ឃ្លានេះអាចមានន័យថា បើមិនមែនដោយសារ

អាចនឹងមកឯខ្ញុំបានទេ លើកតែព្រះវរបិតា ដែលចាត់ខ្ញុំ
ឱ្យមក ទ្រង់ទាញនាំគេប៉ុណ្ណោះ[ឋ] ហើយខ្ញុំនឹងឱ្យអ្នកនោះ
រស់ឡើងវិញនៅថ្ងៃចុងបំផុតដែរ ៤៥នៅក្នុងគម្ពីរ ពួក
ហោរាមានសេចក្តីចែងទុកមកថា «ព្រះទ្រង់នឹងបង្រៀន
គេទាំងអស់គ្នា» [ឌ] ដូច្នេះ អស់អ្នកណាដែលឮព្រះវរបិតា
ហើយបានរៀនពីទ្រង់ នោះក៏មកឯខ្ញុំ ៤៦នេះមិនមែនថា
មានអ្នកណា ដែលឃើញព្រះវរបិតានោះឡើយ មានតែ
ព្រះអង្គ ដែលយាងមកពីព្រះប៉ុណ្ណោះ[ឍ] ព្រះអង្គនោះទើប
ទ្រង់បានឃើញព្រះវរបិតាមែន ៤៧ប្រាកដមែន ខ្ញុំប្រាប់
អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលជឿដល់ខ្ញុំ នោះ
មានជីវិតអស់កល្បជានិច្ច[ណ] ៤៨ខ្ញុំជានំបុ័ងជីវិត[ត] ៤៩ពួក
ឰយុកោអ្នករាល់គ្នាបានបរិភោគនំម៉ានា នៅទីរហោស្ថាន
ហើយក៏ស្លាប់អស់ទៅ[ថ] ៥០ឯនំបុ័ងដែលខ្ញុំនិយាយនេះ គឺជា
នំបុ័ងដែលចុះពីស្ថានសួគ៌មក[ទ] ដើម្បីឱ្យអ្នកណា ដែល
បរិភោគ មិនត្រូវស្លាប់ឡើយ ៥១ខ្ញុំជានំបុ័ងដ៏រស់[ធ] ដែលចុះ
ពីស្ថានសួគ៌មក[ន] បើអ្នកណាបរិភោគនំបុ័ងនេះ នោះនឹង
រស់នៅអស់កល្បជានិច្ច ឯនំបុ័ងដែលខ្ញុំឱ្យ គឺជារូបសាច់
ខ្ញុំ ដែលខ្ញុំនឹងឱ្យជំនួសជីវិតមនុស្សលោក[ប] ៥២ដូច្នេះ ពួក
សាសន៍យូដា[ផ]គេជជែកគ្នា[ព]ថា ធ្វើដូចម្តេចឱ្យអ្នកនេះអាច
នឹងឱ្យសាច់ខ្លួនមកយើងបរិភោគបាន ។

៥៣នោះព្រះយេស៊ូវមានបន្ទូលទៅគេថា ប្រាកដមែន
ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នករាល់គ្នាមិនពិសា
សាច់[ភ] ហើយមិនផឹកឈាម[ម]របស់កូនមនុស្ស[យ] នោះអ្នក
រាល់គ្នាគ្មានជីវិតនៅក្នុងខ្លួនទេ ៥៤អ្នកណាដែលបរិភោគ
សាច់ នឹងឈាមរបស់ខ្ញុំ នោះមានជីវិតដ៏នៅអស់កល្ប
ជានិច្ច ហើយខ្ញុំនឹងឱ្យអ្នកនោះរស់ឡើងវិញ នៅថ្ងៃចុង
បំផុត[រ] ៥៥ពីព្រោះសាច់ខ្ញុំជាអាហារពិត ហើយឈាម
ខ្ញុំក៏ជាគ្រឿងផឹកពិតប្រាកដ ៥៦អ្នកណាដែលបរិភោគ
សាច់ នឹងឈាមរបស់ខ្ញុំ នោះនៅក្នុងខ្ញុំ ហើយខ្ញុំក៏នៅក្នុង
អ្នកនោះដែរ[ល] ៥៧អ្នកណាដែលបរិភោគខ្ញុំ អ្នកនោះនឹង
រស់ដោយសារខ្ញុំដូចជាព្រះវរបិតាដ៏មានព្រះជន្មរស់
ទ្រង់បានចាត់ឱ្យខ្ញុំមក[វ] ហើយខ្ញុំក៏រស់នៅ ដោយសារ
ទ្រង់ដែរ ៥៨នំបុ័ងនេះជានំបុ័ង ដែលចុះពីស្ថានសួគ៌មកជា
ពិត មិនមែនដូចជាពួកឰយុកោអ្នករាល់គ្នា បានបរិភោគ
នំម៉ានា ហើយក៏ស្លាប់ទៅនោះទេ គឺអ្នកណាដែលបរិភោគ
នំបុ័ងនេះ នឹងរស់នៅអស់កល្បជានិច្ចវិញ[ស] ៥៩ទ្រង់មាន
បន្ទូលសេចក្តីទាំងនេះ ក្នុងសាលាប្រជុំ នៅកាពើណិម
កំពុងដែលទ្រង់បង្រៀនគេ ។

## សិស្សជាច្រើនចាកចេញពីព្រះយេស៊ូវ

៦០ពួកសិស្សទ្រង់ជាច្រើន[ហ] ដែលឮសេចក្តីនោះ ក៏
និយាយថា ពាក្យនេះពិបាកស្តាប់ណាស់ តើអ្នកណាយល់
បាន [ឡ] ៦១ប៉ុន្តែ ព្រះយេស៊ូវទ្រង់ជ្រាបក្នុងព្រះអង្គទ្រង់ថា
ពួកសិស្សរទូរទាំពីសេចក្តីនោះ បានជាទ្រង់មានបន្ទូលថា
តើសេចក្តីនេះនាំបង្អាក់ដល់ចិត្តអ្នករាល់គ្នាឬអី[អ] ៦២ចុះ
បើអ្នករាល់គ្នាបានឃើញកូនមនុស្ស[ក]ឡើងទៅឯស្ថាន
ដែលលោកនៅពីដើម នោះតើនឹងគិតដូចម្តេចទៅ[ខ] ៦៣គឺ

**៦:៤៤** ឋ ខ.៦៥ យរ ៣១:៣ យហ ១២:៣២ **៦:៤៥** ឌ អស ៥៤:១៣ យរ ៣១:៣៣,៣៤ ១កថ ២:១៣ ១ថន ៤:៩ ហព ៨:១០,១១ ១០:១៦ ១យហ ២:២៧ **៦:៤៦** ឍ យហ ១:១៨ ៥:៣៧ ៧:២៩ **៦:៤៧** ណ មថ ២៥:៤៦ **៦:៤៨** ត ខ.៣៥,៥១ **៦:៤៩** ថ ខ.៣១,៥៨ **៦:៥០** ទ ខ.៣៣ **៦:៥១** ធ ខ.៣៥,៤៨ ន ខ.៤១,៥៨ ប ហព ១០:១០ **៦:៥២** ផ យហ ១:១៩ ព យហ ៧:៤៣ ៩:១៦ ១០:១៩ **៦:៥៣** ភ មថ ២៦:២៦ ម មថ ២៦:២៨ យ មថ ៨:២០ **៦:៥៤** រ ខ.៣៩ **៦:៥៦** ល យហ ១៥:៤-៧ ១យហ ២:២៤ ៣:២៤ ៤:១៥ **៦:៥៧** វ យហ ៣:១៧ **៦:៥៨** ស ខ.៤៩-៥១ យហ ៣:៣៦ ៥:២៤ **៦:៦០** ហ ខ.៦៦ ឡ ខ.៥២ **៦:៦១** អ មថ ១៣:៥៧ **៦:៦២** ក មថ ៨:២០ ខ មក ១៦:១៩ យហ ៣:១៣ ១៧:៥

ព្រះគុណរបស់ព្រះអម្ចាស់ទេ នោះគ្មានអ្នកណាម្នាក់អាចមកឯទ្រង់បានឡើយ ។

**៦:៤៥** *ពួកហោរា* សំដៅលើពួកហោរា ដែលមានចែងនៅក្នុងព្រះគម្ពីរបរិសុទ្ធសញ្ញាចាស់ (មើលការពន្យល់ ៥:១៧) ។

**៦:៤៨-៥០** ត្រង់ចំណុចនេះព្រះយេស៊ូវបញ្ជាក់យ៉ាងច្បាស់ថា ទ្រង់គឺជានំបុ័ងដែលផ្តល់ជីវិតដ៏ពិត ។ ពួកសាសន៍យូដាយល់ថា មានតែនំម៉ានាទេ ដែលជាអាហារប្រសើរជាងអាហារណាៗទាំងអស់ ។ ប៉ុន្តែ ព្រះយេស៊ូវមានបន្ទូលប្រាប់ពួកគេយ៉ាងច្បាស់ថា នំម៉ានាមិនអាចផ្តល់ឱ្យពួកគេ មានជីវិតដ៏នៅរស់អស់កល្បជានិច្ចទេ (ខ.៣១) ។ ដូច្នេះ អស់អ្នកណាដែលទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ នោះមិនត្រូវវិនាសឡើយ ។

**៦:៥១** *មនុស្សលោក* សំដៅលើមនុស្សទាំងអស់នៅលើពិភពលោកនេះ (មើលការពន្យល់ ១:៩ ៤:៤២) ។

**៦:៥៣-៥៨** ពាក្យថា "សាច់" និង "ឈាម" ត្រង់ចំណុចនេះ គឺសំដៅលើព្រះគ្រីស្ទ ដែលត្រូវគេឆ្កាង និងបង្ហូរព្រះលោហិតសម្រាប់សង្គ្រោះមនុស្សទាំងអស់ ។ ម្យ៉ាងទៀត ព្រះគ្រីស្ទគឺជាប្រភពនៃជីវិត ដូច្នេះ អស់អ្នកដែលជឿដល់ទ្រង់ នោះទទួលបាននូវជីវិតរស់ជាមួយទ្រង់អស់កល្បជានិច្ច ។

**៦:៥៨** *នំបុ័ងដែលចុះពីស្ថានសួគ៌មក* មានន័យថា ព្រះយេស៊ូវទ្រង់ជានំបុ័ងដែលចុះពីស្ថានសួគ៌ ដើម្បីផ្តល់ជីវិតអស់កល្បជានិច្ច ដល់អស់អ្នកណាដែលទទួលជឿដល់ព្រះនាមទ្រង់ ។

**៦:៦០** *ពិបាកស្តាប់* ត្រង់ចំណុចនេះ ពុំមានន័យថា ពួកគេពិបាកយល់នោះទេ ផ្ទុយទៅវិញគឺ ពួកគេពិបាកនឹងទទួលយកសេចក្តីដែលព្រះយេស៊ូវទ្រង់មានបន្ទូលទៅកាន់ពួកគេតែម្តង ។ សម្រាប់ពួកសាសន៍យូដា ការដែលព្រះយេស៊ូវទ្រង់មានបន្ទូលអំពីការបរិភោគសាច់ និងផឹកឈាមរបស់ទ្រង់នោះ ពួកគេប្រាកដជាយល់ (មើលការពន្យល់ ខ.៥៣-៥៨) ។

**៦:៦២** ក្នុងបទគម្ពីរនេះ អាចសំដៅលើការដែលព្រះយេស៊ូវត្រូវគេឆ្កាង ឬសំដៅលើការដែលទ្រង់យាងឡើងទៅឯស្ថានសួគ៌ បន្ទាប់ពីទ្រង់រស់ពីសុគតឡើងវិញ (មើលការពន្យល់ ៧:៣៩) ។ *កូនមនុស្ស* "មើលការពន្យល់ មក ៨:៣១ លក ៦:៥ ១៩:១០" ។ *ដែលលោកនៅពីដើម* មានន័យថា ព្រះយេស៊ូវទ្រង់គង់នៅស្ថានសួគ៌ តាំងពីអស់កល្បជានិច្ចមក (មើលការពន្យល់ ៨:៥៨ ១៧:៥) ។

ជាវិញ្ញាណដែលឱ្យមានជីវិត[គ] រូបសាច់គ្មានប្រយោជន៍
អ្វីទេ ឯពាក្យដែលខ្ញុំនិយាយនឹងអ្នករាល់គ្នា នោះត្រូវខាង
វិញ្ញាណនិងជីវិតវិញ ៦៤ប៉ុន្តែ មានអ្នករាល់គ្នាខ្លះមិនជឿ
ទេ នេះដ្បិតព្រះយេស៊ូវទ្រង់ជ្រាប[ឃ] តាំងតែពីដើមមក
អំពីអ្នកណា ដែលមិនបានជឿ ហើយអំពីអ្នកណា ដែលនឹង
បញ្ជូនទ្រង់[ង] ៦៥ទ្រង់ក៏មានបន្ទូលថា គឺហេតុនោះបានជា
ខ្ញុំប្រាប់អ្នករាល់គ្នាថា គ្មានអ្នកណាអាចនឹងមកឯខ្ញុំបានទេ
លើកតែព្រះវរបិតាទ្រង់ប្រោសប្រទានឱ្យប៉ុណ្ណោះ[ច]។
៦៦តាំងពីនោះមក មានសិស្ស[ឆ]ទ្រង់ជាច្រើនដកខ្លួនថយ
ចេញ មិនតាមទ្រង់ទៀតទេ ៦៧នោះព្រះយេស៊ូវមាន
បន្ទូលទៅពួក១២នាក់ថា អ្នក រាល់គ្នាចង់ថយទៅដែរឬ[ជ]
៦៨ស៊ីម៉ូន–ពេត្រុសទូល ឆ្លើយថា[ឈ] ព្រះអម្ចាស់អើយ
តើយើងខ្ញុំនឹងទៅឯអ្នកណាវិញ គឺទ្រង់ហើយ ដែលមាន
ព្រះបន្ទូលនៃជីវិតដ៏នៅអស់កល្បជានិច្ច[ញ] ៦៩យើងខ្ញុំក៏
បានជឿ ហើយដឹងថា ទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រា
នៃព្រះដ៏មានព្រះជន្មរស់ពិត[ដ] ៧០ព្រះយេស៊ូវមានបន្ទូល
ទៅគេថា តើខ្ញុំមិនបានរើសអ្នករាល់គ្នា[ឋ] ជាពួក១២នាក់
ទេឬអី តែមានម្នាក់ក្នុងពួក អ្នករាល់គ្នាជាអារក្សវិញ[ឌ]
៧១នេះគឺទ្រង់មានបន្ទូលពី យូដាស-អ៊ីស្ការីយ៉ុត ជាកូន
ស៊ីម៉ូន[ឍ] ដែលនៅក្នុងពួក១២នាក់នោះ ដ្បិតវារៀបនឹង
បញ្ជូនទ្រង់ទៅ[ណ]។

## ព្រះយេស៊ូវយាងទៅឯបុណ្យបារាំ

**៧** ១ក្រោយនោះមក ព្រះយេស៊ូវ ទ្រង់យាងនៅតែក្នុងស្រុក
កាលីឡេប៉ុណ្ណោះ ទ្រង់មិនសព្វព្រះហឫទ័យនឹងយាងក្នុង
ស្រុកយូដាទេ ពីព្រោះសាសន៍យូដា[ត]រកសំឡាប់ទ្រង់[ថ] ២រីឯ
បុណ្យរបស់សាសន៍យូដា ដែលហៅថាបុណ្យបារាំ[ទ] នោះជិត
ដល់ហើយ ៣ដូច្នេះ ពួកប្អូនទ្រង់[ធ] ទូលថា ចូរចេញពីទីនេះ
ទៅឯស្រុកយូដាទៅ ដើម្បីឱ្យពួកសិស្សរបស់បងបានឃើញ
ការដែលបងធ្វើផង ៤ដ្បិតអ្នកណាដែលចង់ឱ្យគេស្គាល់
ខ្លួន នោះមិនដែលធ្វើការដោយសំងាត់ទេ បើបងធ្វើការ
ទាំងនេះ ចូរសំដែងខ្លួនឱ្យមនុស្សលោកស្គាល់ដែរ ៥ដ្បិត
ពួកប្អូនទ្រង់មិនបានជឿដល់ទ្រង់ទេ[ន] ៦ដូច្នេះ ព្រះយេស៊ូវ
មានបន្ទូលតបថា ឯពេលវេលារបស់ឯងរាល់គ្នា នោះចេះ
តែមានជានិច្ច តែពេលវេលា[ប]របស់អញមិនទាន់ដល់នៅ

**៦:៦៣** គ ២កថ ៣:៦
**៦:៦៤** ឃ យហ ២:២៥ ង មថ ១០:៤
**៦:៦៥** ច ខ.៣៧,៤៤ មថ ១៣:១១
**៦:៦៦** ឆ ខ.៦០
**៦:៦៧** ជ មថ ១០:២
**៦:៦៨** ឈ មថ ១៦:១៦ ញ ខ.៦៣ មថ ២៥:៤៦
**៦:៦៩** ដ មក ១:២៤ ៨:២៩ លក ៩:២០
**៦:៧០** ឋ យហ ១៥:១៦,១៩ ឌ យហ ១៣:២៧ ១៧:១២
**៦:៧១** ឍ មថ ២៦:១៤ ណ មថ ១០:៤
**៧:១** ត យហ ១:១៩ ថ ខ.១៩,២៥ មថ ១២:១៤
**៧:២** ទ លវ ២៣:៣៤ ចទ ១៦:១៦

**៧:៣** ធ មថ ១២:៤៦ **៧:៥** ន ទដ ៦៩:៨ មក ៣:២១ **៧:៦** ប មថ ២៦:១៨

**៦:៦៣** *ជាវិញ្ញាណដែលឱ្យមានជីវិត* ព្រះអម្ចាស់ទ្រង់ជាវិញ្ញាណ ដែលផ្តល់ជីវិតដល់អស់អ្នកណាដែលទទួលជឿដល់ព្រះនាមទ្រង់ (៣:៥–៦,៨ ៤:២៤)។

**៦:៦៥** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា គ្មានអ្នកណាអាចមកឯព្រះអម្ចាស់ និងទទួលការសង្គ្រោះបានទេ បើមិនដោយសារព្រះគុណរបស់ទ្រង់ឱ្យ (មើលការពន្យល់ ខ.៣៧,៣៩,៤៤,៤៥)។

**៦:៦៦** ពួកយូដាមួយចំនួនបានដើរតាមព្រះយេស៊ូវ ដោយគិតថានឹងបានប្រយោជន៍ជាទ្រព្យសម្បត្តិ ឬកិត្តយសមកអំពីទ្រង់ ។ ពួកគេធ្វើយ៉ាងដូច្នោះ ព្រោះពួកគេធ្លាប់ទទួលការបង្រៀនថា ថ្ងៃណាមួយព្រះមែស៊ីនឹងយាងមក ហើយធ្វើជាស្តេចលើពួកគេ គឺដូចជាស្តេចដទៃទៀតនៅលើផែនដីនេះដែរ។ ដូច្នេះ នៅពេលដែល ពួកគេដឹងថា សេចក្តីបង្រៀនរបស់ព្រះយេស៊ូវ និងការធ្វើជាសិស្សរបស់ទ្រង់ គឺមានភាពខុសគ្នាពីអ្វីដែលពួកគេធ្លាប់រៀន នោះក៏នាំគ្នាចាកចេញពីទ្រង់ទៅ ។

**៦:៦៨** *ព្រះបន្ទូលនៃជីវិតដ៏នៅអស់កល្បជានិច្ច* លោកពេត្រុសនិយាយយ៉ាងដូច្នេះ ព្រោះគាត់ជឿលើព្រះបន្ទូលរបស់ព្រះយេស៊ូវ ថាជាសេចក្តីពិត ដែលផ្តល់ជីវិតអស់កល្បជានិច្ច (ខ.៦៣)។

**៦:៦៩** *ព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ* ឃ្លានេះគឺសំដៅលើព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ មក ១:២៤ លក ៤:៣៤ កច ២:២៧)។

**៦:៧០** *មានម្នាក់ . . . ជាអារក្សវិញ* សំដៅលើ យូដាស–អ៊ីស្ការីយ៉ុត (ខ.៧១)។

**៦:៧១** *យូដាស–អ៊ីស្ការីយ៉ុត* អាចមានន័យថា យូដាសម្នាក់នេះ គឺជាមនុស្សមកពីក្រុងកេរីយ៉ុត (Kerioth នៅស្រុកយូដា យស ១៥:២៥)។ ម្យ៉ាងទៀត ក្នុងចំណោមសិស្សទាំង១២នាក់របស់ព្រះយេស៊ូវគ្រីស្ទ ប្រហែលជាមានតែយូដាស-អ៊ីស្ការីយ៉ុតម្នាក់ទេ ដែលមិនមែនជាអ្នកស្រុកកាលីឡេ ។

**៧:១–៨:៥៩** ក្នុងជំពូក៧ និង៨នេះ លោកយ៉ូហានបានកត់ត្រានូវការបៀតបៀន និងការប្រមាថជាច្រើន ដែលពួកសាសន៍យូដាបានធ្វើដល់ព្រះយេស៊ូវ (៧:១,១៣,១៩,២៥,៣០,៣២,៤៤ ៨:៣៧,៤០,៥៩)។ ម្យ៉ាងទៀត នៅត្រង់ចំណុចនេះក៏មានសេចក្តីជាច្រើន ដែលបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះមែស៊ីពិតប្រាកដមែន ។

**៧:១** *ក្រោយនោះមក* មានន័យថា ក្រោយពីហេតុការណ៍ដែលបានកើតឡើងនៅចុងជំពូក៦ ។

**៧:២** *បុណ្យបារាំ* ជាពិធីបុណ្យមួយរបស់ពួកសាសន៍យូដា ដែលប្រារព្ធធ្វើឡើង នៅចុងខែកញ្ញា ឬដើមខែតុលា ជារៀងរាល់ឆ្នាំ ។ ចាប់ពីបុណ្យរំលង រហូតដល់បុណ្យបារាំ គឺមានរយៈពេល៦ខែ (៦:៤ មើលការពន្យល់ លវ ២៣:២៣–៤៣ ចទ ១៦:១៣–១៥ សក ១៤:១៦)។

**៧:៣** *ពួកប្អូនទ្រង់* ប្រហែលជាសំដៅលើពួកកូនរបស់នាងម៉ារា និងលោកយ៉ូសែប (មក ៦:៣ មើលការពន្យល់ លក ៨:១៩)។

**៧:៤** បទគម្ពីរនេះអាចបញ្ជាក់ថា នៅពេលនោះ ពួកប្អូនរបស់ព្រះយេស៊ូវមិនទាន់ជឿថា ទ្រង់គឺជាព្រះមែស៊ីនៅឡើយទេ (ខ.៥)។

**៧:៦** *ពេលវេលារបស់អញ មិនទាន់ដល់នៅឡើយ* ព្រះយេស៊ូវមានបន្ទូលយ៉ាងដូច្នេះ បញ្ជាក់ថា ទ្រង់យាងមក គឺធ្វើតាមបំណងព្រះហឫទ័យ នៃព្រះវរបិតាទ្រង់ទាំងស្រុង (មើលការពន្យល់ ២:៤ រម ៥:៦)។

**៧:៧** *លោកីយ* ពាក្យនេះអាចសំដៅលើ (១)អស់អ្នកដែលប្រឆាំងនឹងព្រះ (២)គ្រប់ប្រព័ន្ធទាំងឡាយណាដែលមនុស្សបង្កើតឡើង ប្រឆាំងនឹងព្រះ

ឡើយ ៧ លោកិយពុំអាចនឹងស្អប់ឯងរាល់គ្នាបានទេ តែគេ
ស្អប់អញវិញ[ផ] ពីព្រោះអញធ្វើបន្ទាល់ពីគេថា ការគេប្រ
ព្រឹត្តសុទ្ធតែអាក្រក់[ព] ៨ ចូរឯងរាល់គ្នាឡើងទៅឯបុណ្យ
នេះចុះ ឯអញមិនទាន់ទៅទេ ព្រោះកំណត់អញ[ភ] មិនទាន់សំ
រេចនៅឡើយ ៩ កាលទ្រង់មានបន្ទូលសេចក្ដីទាំងនោះរួច
ហើយ នោះក៏គង់នៅស្រុកកាលីឡេដដែល ១០ ប៉ុន្តែ កាល
ពួកប្អូនទ្រង់ឡើងទៅឯបុណ្យនោះផុតហើយ នោះទ្រង់ក៏
យាងទៅដែរ តែមិនទៅជាមួយនឹងអ្នកណាទេ គឺទៅដោយ
សំងាត់វិញ ១១ រីឯពួកសាសន៍យូដា គេសួររកទ្រង់[ម] នៅឯទី
បុណ្យថា តើលោកនៅឯណា ១២ ហើយក្នុងហ្វូងមនុស្ស
ក៏ព្រួឌឹបខ្សៀវពីដំណើរទ្រង់ជាច្រើន ខ្លះថា លោកជាមនុស្ស
ល្អ ខ្លះទៀតថា ទេ អ្នកនោះ ជាអ្នកបញ្ឆោតប្រជាជនទេតើ[យ]
១៣ ប៉ុន្តែ គ្មានអ្នកឯណាហ៊ាន និយាយពីដំណើរទ្រង់
ឱ្យបណ្ដាជនដឹងឡើយ ព្រោះខ្លាច សាសន៍យូដា[រ] ។

## សេចក្ដីបង្រៀនរបស់ព្រះយេស៊ូវ

១៤ នៅពាក់កណ្ដាលពេលបុណ្យ នោះព្រះយេស៊ូវទ្រង់
ឡើងទៅ បង្រៀនក្នុងព្រះវិហារ[ល] ១៥ ហើយពួកសាសន៍យូដា[វ]
នឹកឆ្ងល់ថា ធ្វើដូចម្ដេចឱ្យអ្នកនេះចេះគម្ពីរដូច្នេះ[ស]
ពីព្រោះគាត់មិនដែលរៀនសូត្រសោះ[ហ] ១៦ ព្រះយេស៊ូវ
មានបន្ទូលឆ្លើយថា សេចក្ដីដែលខ្ញុំបង្រៀននេះ មិនមែនជា
របស់ខ្ញុំទេ គឺជារបស់ផងព្រះ ដែលចាត់ ឱ្យខ្ញុំមកនោះវិញ[ឡ]
១៧ បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបាន
ដឹង[អ] ជាសេចក្ដីបង្រៀននេះមកពីព្រះ ឬជាខ្ញុំនិយាយដោយ
អាងខ្លួនខ្ញុំ ១៨ អ្នកណាដែលនិយាយដោយអាងខ្លួនឯង នោះ
ចង់តែលើកដំកើងដល់ខ្លួនទេ[ក] តែអ្នកដែលចង់លើកដំកើង
ថ្វាយព្រះ ដែលចាត់ឱ្យខ្លួនមក នោះទើបពិតវិញ ហើយឥត
មានសេចក្ដីទុច្ចរិតណានៅក្នុងខ្លួនឡើយ ១៩ ឯលោកម៉ូសេ
តើមិនបានឱ្យក្រិត្យវិន័យមកអ្នករាល់គ្នាទេឬអី[ខ] ប៉ុន្តែក្នុង
ពួកអ្នករាល់គ្នា គ្មានអ្នកណាមួយប្រព្រឹត្តតាមក្រិត្យវិន័យ
នោះទេ ហេតុអ្វីបានជាអ្នករាល់គ្នារកសំឡាប់ខ្ញុំដូច្នេះ[គ]
២០ ហ្វូងមនុស្សក៏ឆ្លើយឡើងថា អ្នកឯងមានអារក្សចូល ទេ[ឃ]
តើមានអ្នកណារកសំឡាប់ឯង ២១ ព្រះយេស៊ូវមានបន្ទូល
ទៅគេថា ខ្ញុំបានធ្វើការ១[ង] ហើយអ្នករាល់គ្នាមានសេចក្ដី
អស្ចារ្យទាំងអស់គ្នា ២២ លោកម៉ូសេក៏ឱ្យពិធីកាត់ស្បែក[ច] មក
អ្នករាល់គ្នា (មិនមែនថា កើតពីលោកម៉ូសេទេ គឺពីពួក
ឰយុកោវិញ)[ឆ] ហើយអ្នករាល់គ្នាកាត់ស្បែកឱ្យមនុស្សនៅ

**៧:៧** ផ យហ ១៥:១៨,១៩ ព យហ ៣:១៩,២០
**៧:៨** ភ ខ.៦ មថ ២៦:១៨
**៧:១១** ម យហ ១១:៥៦
**៧:១២** យ ខ.៤០,៤៣
**៧:១៣** រ យហ ៩:២២ ១២:៤២ ១៩:៣៨ ២០:១៩
**៧:១៤** ល ខ.២៨ មថ ២៦:៥៥
**៧:១៥** វ យហ ១:១៩ ស កច ២៦:២៤ ហ មថ ១៣:៥៤
**៧:១៦** ឡ យហ ១៤:២៤
**៧:១៧** អ ទដ ២៥:១៤
**៧:១៨** ក យហ ៥:៤១ ៨:៥០,៥៤
**៧:១៩** ខ ចទ ៣២:៤៦ យហ ១:១៧ គ ខ.១ មថ ១២:១៤
**៧:២០** ឃ មក ៣:២២ **៧:២១** ង ខ.២៣ យហ ៥:២-៩
**៧:២២** ច លវ ១២:៣ ឆ លប ១៧:១០-១៤

ហឫទ័យនៃព្រះអម្ចាស់ (មើលការពន្យល់ ១យហ ២:១៥) ។

**៧:៨** ព្រះយេស៊ូវមិនបានបដិសេធ ក្នុងការយាងទៅឯបុណ្យនោះទេ ប៉ុន្តែ គឺទ្រង់បដិសេធមិនយាងទៅ តាមរបៀបដែលពួកប្អូនរបស់ទ្រង់ បានស្នើសូមនោះទេ ។ ការដែលព្រះយេស៊ូវយាងទៅឯបុណ្យនោះ គឺដើម្បីប្រកាសព្រះបន្ទូលដូច្នោះ បានជាទ្រង់រង់ចាំពេលវេលារបស់ទ្រង់ (ខ.៦) ។

**៧:១០** *គឺទៅដោយសំងាត់វិញ* មានន័យថា ព្រះយេស៊ូវមិនបានយាងទៅឯបុណ្យបារាំនោះជាមួយនឹងពួកប្អូនរបស់ទ្រង់ទេ (ខ.៤) ។

**៧:១២** *ខ្សឹបខ្សៀវ* បញ្ជាក់ថា ពួកគេពុំហ៊ាននិយាយដោយចំហនៅទីសាធារណៈទេ ព្រោះខ្លាចមានរឿងអាក្រក់កើតឡើងចំពោះខ្លួន (ខ.១៣) ។

**៧:១៤** *នៅពាក់កណ្ដាលពេលបុណ្យ* ឃ្លានេះបញ្ជាក់ថា នៅពាក់កណ្ដាលពេលបុណ្យនោះ មានមនុស្សជាច្រើនបានមកចូលរួម ដូច្នេះ ការដែលព្រះយេស៊ូវទ្រង់បង្រៀននៅក្នុងអំឡុងពេលនោះ ធ្វើឱ្យពួកគេជាច្រើនបានឮ ។

**៧:១៥** *ពួកសាសន៍យូដា* នៅត្រង់ចំណុចនេះ ជាទូទៅគឺសំដៅលើពួកអ្នកដឹកនាំពួកផារិស៊ី និងពួកគ្រូបង្រៀនក្រឹត្យវិន័យរបស់ពួកសាសន៍យូដា (មថ ៧:២៨-២៩ មក ៦:២-៣ មើលការពន្យល់ យហ ១:១៩ កច ៤:១៣) ។

**៧:១៦** *មិនមែនជារបស់ខ្ញុំទេ* មានន័យថា សេចក្ដីបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ គឺមកពីព្រះវរបិតាដែលចាត់ឱ្យទ្រង់មក (មើលការពន្យល់ ៤:៣៤) ។

**៧:១៧** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា អស់អ្នកណាដែលធ្វើតាមព្រះហឫទ័យនៃព្រះអម្ចាស់ នោះពិតជាទទួលស្គាល់ថា សេចក្ដីបង្រៀនរបស់ទ្រង់ គឺពិតជាត្រឹមត្រូវ ។ ពួកអ្នកដឹកនាំសាសន៍យូដា មិនបានធ្វើតាមព្រះហឫទ័យនៃព្រះអម្ចាស់ទេ ដូច្នោះបានជាពួកគេមិនដឹងថា សេចក្ដីបង្រៀនរបស់ទ្រង់ពិត ឬមិនពិតនោះទេ (មើលការពន្យល់ ៦:២៩) ។

**៧:១៨** ព្រះយេស៊ូវយាងមក មិនមែនដើម្បីបំពេញបំណងព្រះហឫទ័យទ្រង់ទេ ។ គ្រប់ការទាំងអស់ ដែលព្រះយេស៊ូវទ្រង់ធ្វើ គឺទ្រង់លើកតម្កើង ដល់ព្រះវរបិតា ។ ក្នុងព្រះគម្ពីរបរិសុទ្ធទាំងមូល បញ្ជាក់យ៉ាងច្បាស់ថា មានតែព្រះអម្ចាស់ទេ ដែលជាសេចក្ដីពិត (៣:៣៣ មើលការពន្យល់ ៨:២៦) ។

**៧:១៩** *ក្រិត្យវិន័យ* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកសាសន៍យូដាបានលើកតម្កើងខ្លួនឯង ដោយយល់ថា ពួកគេជាអ្នកដែលព្រះអម្ចាស់ជ្រើសរើសឱ្យទទួលនូវក្រឹត្យវិន័យមកអំពីទ្រង់ ។ ប៉ុន្តែ ព្រះយេស៊ូវមានបន្ទូលទៅពួកគេថា ពួកគេមិនបានប្រព្រឹត្តតាមក្រឹត្យវិន័យ ដែលខ្លួនបានទទួលនោះទេ ដូច្នេះហើយបានជាពួកគេក្លាយទៅជាមានអំនួតយ៉ាងខ្លាំង (រម ២:១៧-២៩) ។

**៧:២០** *ហ្វូងមនុស្សក៏ឆ្លើយឡើងថា អ្នកឯងមានអារក្សចូលទេ* ពួកអ្នកដែលនិយាយដូច្នេះ គឺសុទ្ធតែជាពួកអ្នកដែលបៀតបៀនដល់ព្រះយេស៊ូវ និងមិនបានស្គាល់ថា ទ្រង់ជាព្រះសង្គ្រោះរបស់ខ្លួនទេ (ខ.១ ៨:៤៨-៥២ ១០:២០-២១ មថ ១២:២៤-៣២ មក ៣:២២-៣០ មើលការពន្យល់ ខ.២៥) ។

**៧:២១** *ខ្ញុំបានធ្វើការ១* ពាក្យថា "ធ្វើការ១" ក្នុងបទគម្ពីរនេះ គឺសំដៅលើការដែលព្រះយេស៊ូវប្រោសមនុស្សមានជំងឺ៣៨ឆ្នាំម្នាក់ ឱ្យបានជាក្នុងថ្ងៃឈប់សម្រាក នៅឯស្រះបេថែសដា (៥:១-៥) ។

**៧:២២** *ពិធីកាត់ស្បែក* ពាក្យថា "កាត់ស្បែក" សំដៅលើការកាត់ស្បែកនៅចុងលិង្គរបស់បុរស ឬក្មេងប្រុស ។ ក្នុងក្រឹត្យវិន័យលោកម៉ូសេមានតម្រូវឱ្យមានពិធីកាត់ស្បែក (លវ ១២:៣ មើលការពន្យល់ នក ១២:៤៤, ៤៨) ។ លោកម៉ូសេមិនបានបង្គាប់ឱ្យពួកអ៊ីស្រាអែលធ្វើពិធីនេះទេ ។ អ្នក

ថ្ងៃឈប់សំរាកផង ២៣ដូច្នេះបើមនុស្សទទួលកាត់ស្បែក នៅ
ថ្ងៃឈប់សំរាក ដើម្បីមិនឱ្យរំលងក្រិត្យវិន័យរបស់លោក
ម៉ូសេ នោះតើអ្នករាល់គ្នាខឹងនឹងខ្ញុំ ដោយព្រោះខ្ញុំបានធ្វើ
ឱ្យមនុស្សម្នាក់បានជាស្រឡះ នៅថ្ងៃឈប់សំរាកឬអី ២៤កុំឱ្យ
ជំនុំជំរះតាមភាពដែលមើលឃើញតែខាងក្រៅឡើយ ត្រូវជំ
នុំជំរះតាមសេចក្តីសុចរិតវិញ[ជ]។

## ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ

២៥នោះមានពួកក្រុងយេរូសាឡិមខ្លះនិយាយថា គឺអ្នក
នេះទេតើ ដែលគេរកសំឡាប់នោះ[ឈ] ២៦ហើយមើលគាត់
និយាយនៅកណ្តាលចំណោម តែគ្មានអ្នកណាថាអ្វីឱ្យសោះ
តើពួកនាម៉ឺន[ញ]បានយល់ឃើញហើយថា អ្នកនេះជាព្រះគ្រីស្ទ
មែនឬអី[ដ] ២៧ឯអ្នកនេះ យើងដឹងជាមកពីណា[ឋ]តែព្រះគ្រីស្ទ
វិញ កាលណាទ្រង់យាងមក នោះគ្មានអ្នកណាដឹងជាមកពី
ណាទេ ២៨ដូច្នេះ កំពុងដែលព្រះយេស៊ូវបង្រៀនក្នុងព្រះ
វិហារ[ឌ] នោះក៏បន្លឺឧទានឡើងថា អ្នករាល់គ្នាស្គាល់ខ្ញុំ
ហើយដឹងជាខ្ញុំមកពីណាផង[ឍ] តែខ្ញុំមិនបានមក ដោយអាង
ខ្លួនខ្ញុំទេ ឯព្រះដែលចាត់ឱ្យខ្ញុំមក ទ្រង់ពិតត្រង់ហើយ[ណ]
អ្នករាល់គ្នាមិន ស្គាល់ទ្រង់ទេ ២៩តែខ្ញុំស្គាល់ទ្រង់[ត] ពីព្រោះ
ខ្ញុំមកពីទ្រង់ គឺ ទ្រង់ពិត ដែលចាត់ឱ្យខ្ញុំមក[ថ] ៣០ដូច្នេះគេ
រកចាប់ទ្រង់ ប៉ុន្តែគ្មានអ្នកណាលូកដៃទៅចាប់សោះ[ទ] ពីព្រោះ
កំណត់ទ្រង់មិនទាន់មកដល់នៅឡើយ[ធ] ៣១នៅក្នុងបណ្តា
មនុស្សនោះ មានគ្នាច្រើនបានជឿដល់ទ្រង់[ន] ហើយគេ
និយាយថា កាលណាព្រះគ្រីស្ទយាងមក តើទ្រង់នឹងធ្វើទីសំ
គាល់ច្រើន[ប]ជាងលោកនេះឬអី ៣២ឯពួកផារិស៊ី ក៏ឮគេខ្សឹប
ខ្សៀវរឿងទាំងនេះពីទ្រង់ រួចពួកសង្គ្រាជ និងពួកផារិស៊ីគេ
ចាត់ពួកអាជ្ញា ឱ្យទៅចាប់ទ្រង់ ៣៣ដូច្នេះ ព្រះយេស៊ូវមាន
បន្ទូលថា ខ្ញុំនៅជាមួយនឹងអ្នករាល់គ្នាតែបន្តិចទៀតទេ[ផ]
រួចខ្ញុំទៅឯព្រះ ដែលចាត់ឱ្យខ្ញុំមកនោះវិញ[ព] ៣៤អ្នករាល់
គ្នានឹងរកខ្ញុំ តែរកមិនឃើញទេ ហើយកន្លែងដែលខ្ញុំ
ទៅ នោះអ្នករាល់គ្នាពុំអាចនឹងទៅបានឡើយ[ភ] ៣៥នោះ
ពួកសាសន៍យូដានិយាយគ្នាគេថា តើអ្នកនេះគិតទៅឯណា
ដែលយើងនឹងរកមិនឃើញ តើគិតទៅឯពួកអ្នកខ្ចាត់ខ្ចាយ[ម]

**៧:២៤** ជ ១សយ ១៦:៧ អស ១១:៣,៤ យហ ៨:១៥ ២កថ ១០:៧
**៧:២៥** ឈ ខ.១ មថ ១២:១៤
**៧:២៦** ញ ខ.៤៨ ដ យហ ៤:២៩
**៧:២៧** ឋ មថ ១៣:៥៥ លក ៤:២២ យហ ៦:៤២
**៧:២៨** ឌ ខ.១៤ ឍ យហ ៨:១៤ ណ យហ ៨:២៦,៤២
**៧:២៩** ត មថ ១១:២៧ ថ យហ ៣:១៧
**៧:៣០** ទ ខ.៣២,៤៤ យហ ១០:៣៩ ធ មថ ២៦:១៨
**៧:៣១** ន យហ ៨:៣០ ១០:៤២ ១១:៤៥ ២:១១,៤២ ប យហ ២:១១
**៧:៣៣** ផ យហ ១២:៣៥ ១៣:៣៣ ១៦:១៦ ព យហ ១៦:៥,១០,១៧,២៨
**៧:៣៤** ភ ខ.៣៦ យហ ៨:២១ ១៣:៣៣

ដែលផ្តើមធ្វើពិធីនេះគឺលោកអ័ប្រាហាំ (មើលការពន្យល់ លប ១៧:១០–១២)។ ពួកសាសន៍យូដាបានតម្រូវឱ្យមានការកាត់ស្បែកនៅថ្ងៃទី៨ បន្ទាប់ពីទារកប្រសូត ទោះបីជានៅថ្ងៃឈប់សម្រាកក៏ដោយ ។ ព្រះយេស៊ូវមិនបានឱ្យពួកគេឈប់គោរពប្រតិបត្តិ ដល់ថ្ងៃឈប់សម្រាកទេ ប៉ុន្តែ ទ្រង់មានព្រះហឫទ័យចង់ឱ្យពួកគេយល់អំពីអត្ថន័យនៃថ្ងៃនេះ ។ មានន័យថា នៅពេលខ្លះ មានការងារមួយចំនួនដែលត្រូវតែបំពេញ នៅថ្ងៃឈប់សម្រាក ដូចជាការសង្គ្រោះជីវិតមនុស្សជាដើម (ខ.២៣ មើលការ ពន្យល់ ៥:១០ មក ៣:២)។

**៧:២៥** *ពួកក្រុងយេរូសាឡិម* សំដៅលើពួកអ្នកដែលកំពុងតែស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូវនៅពេលនោះ ឬអស់អ្នកដែលរស់នៅក្នុងទីក្រុងយេរូសាឡិមទាំងមូល (មក ១:៥ មើលការពន្យល់ ខ.២០)។

**៧:២៦** បទគម្ពីរនេះបញ្ជាក់ថា ពួកបណ្តាជនមួយចំនួនបានដឹងថា ពួកអ្នកដឹកនាំសាសន៍យូដាចង់រកសម្លាប់ព្រះយេស៊ូវ ។ ដូច្នេះហើយ បានជានៅពេលដែលពួកបណ្តាជនបានឃើញព្រះយេស៊ូវបង្រៀននៅទីសាធារណៈ ក៏នឹកឆ្ងល់ថា ប្រហែលជាពួកអ្នកដឹកនាំសាសន៍យូដាកែប្រែគំនិត និងឈប់រកសម្លាប់ទ្រង់ទៀតហើយ ។

**៧:២៧** បទគម្ពីរនេះបញ្ជាក់ថា មានពួកសាសន៍យូដាមួយចំនួនយល់ថា ព្រះគម្ពីរសញ្ញាចាស់បានប្រាប់ពួកគេ ឱ្យដឹងអំពីទីកន្លែង ដែលព្រះមែស៊ីនឹងយាងមក (ខ.៤២ មថ ២:៤–៦) ប៉ុន្តែ មានពួកគេខ្លះទៀតយល់ថា គ្មានអ្នកណាអាចដឹងពីទីកន្លែងដែលទ្រង់យាងមកទេ ។

**៧:២៨** ពួកអ្នកដឹកនាំសាសន៍យូដាដឹងថា ព្រះយេស៊ូវទ្រង់យាងមកពីភូមិណាសារ៉ែតនៃស្រុកកាលីឡេ ប៉ុន្តែ ពួកគេពុំទទួលស្គាល់ថា ទ្រង់បានយាងមកពីព្រះវរបិតាដែលគង់នៅឯស្ថានសួគ៌ទេ (មើលការពន្យល់ ៨:១៩)។ម្យ៉ាងទៀត ក្នុងបទគម្ពីរនេះ បញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវបានយាងមកពីព្រះវរបិតា និងធ្វើតាមព្រះហឫទ័យទ្រង់ (ព្រះវរបិតា) ទាំងស្រុង (មើលពន្យល់ ៤:៣៤)។ ដូច្នេះ គ្រប់ទាំងព្រះបន្ទូល និងព្រះរាជកិច្ចរបស់ព្រះយេស៊ូវ គឺមកពីព្រះវរបិតាដែលចាត់ឱ្យទ្រង់មក ។

**៧:៣០** ត្រង់ចំណុចនេះមានន័យថា ពួកអ្នកដែលប្រឆាំងនឹងព្រះយេស៊ូវ ពុំអាចធ្វើការអាក្រក់អ្វីដល់ទ្រង់ នៅមុនពេលកំណត់របស់ទ្រង់បានឡើយ (មើលការពន្យល់ ២:៤)។

**៧:៣១** បទគម្ពីរនេះបញ្ជាក់ថា មានមនុស្សជាច្រើនបានជឿលើការអស្ចារ្យដែលព្រះយេស៊ូវទ្រង់ធ្វើ ប៉ុន្តែ ពួកគេមិនទាន់ជឿថា ទ្រង់គឺជាព្រះមែស៊ីដែលត្រូវយាងមកនៅឡើយទេ (ខ.២០ ៦:២៦)។ ទោះជាយ៉ាងណា ក៏ពួកគេបានចាប់ផ្តើមមានសេចក្តីជំនឿលើទ្រង់ដែរ ។

**៧:៣២** *ពួកសង្គ្រាជ* ត្រង់ចំណុចនេះបញ្ជាក់ តាមទម្លាប់របស់ពួកសាសន៍យូដា គឺមានសង្គ្រាជតែម្នាក់ប៉ុណ្ណោះ ប៉ុន្តែ ក្រោយមក ពួករ៉ូម៉ាំងបានតែងតាំងឱ្យមានមនុស្សមួយចំនួនទៀត ដែលមានឋានៈជាសង្គ្រាជ (មើលការពន្យល់ មថ ២:៤ មក ៨:៣១) ដូច្នេះ បានជាបទគម្ពីរនេះប្រើពាក្យថា "ពួកសង្គ្រាជ"។

**៧:៣៣** ក្នុងបទគម្ពីរនេះ និយាយសំដៅលើការសុគតរបស់ព្រះយេស៊ូវនៅលើ ឈើឆ្កាង (ខ.៣៤)។

**៧:៣៥** *ពួកអ្នកខ្ចាត់ខ្ចាយ នៅក្នុងសាសន៍ក្រិក* ឃ្លានេះសំដៅលើពួកយូដាដែលត្រូវបានគេនិរទេសចេញពីទឹកដីអ៊ីស្រាអែល ហើយភាគច្រើនបានទៅរស់នៅតាមទីក្រុងដែលស្ថិតនៅក្រោមការត្រួតត្រារបស់ចក្រភពរ៉ូម៉ាំង ។

នៅក្នុងសាសន៍ក្រិក[យ] ដើម្បីនឹងបង្រៀនដល់ សាសន៍នោះ
ឬអី ៣៦ពាក្យដែលគាត់ថា «អ្នករាល់គ្នានឹងរកខ្ញុំ តែរកមិន
ឃើញទេ» ហើយថា «កន្លែងដែលខ្ញុំទៅ អ្នក រាល់គ្នាពុំ
អាចនឹងទៅបានទេ» នេះតើមានន័យដូចម្ដេច[រ] ។
៣៧នៅថ្ងៃក្រោយបង្អស់ ជាថ្ងៃបុណ្យ[ល]យ៉ាងសំខាន់ នោះ
ព្រះយេស៊ូវទ្រង់ឈរបន្លឺឧទានប្រកាសឡើងថា បើអ្នកណា
ស្រេក ចូរឱ្យអ្នកនោះមកឯខ្ញុំ ហើយផឹកចុះ[វ] ៣៨អ្នកណា
ដែលជឿ[ស]ដល់ខ្ញុំ នោះនឹងមានទន្លេទឹករស់[ហ]ហូរចេញពី
ពោះខ្លួនមក ដូចជាគម្ពីរសំដែង[ឡ]ហើយ[អ] ៣៩តែសេចក្ដីនេះ
គឺទ្រង់មានបន្ទូល ពីព្រះវិញ្ញាណ[ក] ដែលអស់អ្នកជឿដល់ទ្រង់
នឹងត្រូវទទួល[ខ] ដ្បិតព្រះវិញ្ញាណបរិសុទ្ធ មិនទាន់យាងមក
ដោយព្រោះ ព្រះយេស៊ូវមិនទាន់បានដំកើងឡើងនៅឡើយ[គ]
៤០ដូច្នេះ កាលបណ្ដាមនុស្សបានឮ នោះមានគ្នាច្រើន
និយាយថា លោកនេះពិតប្រាកដជាហោរានោះហើយ[ឃ]
៤១អ្នកខ្លះទៀតថា នេះជាព្រះគ្រីស្ទហើយ ខ្លះទៀតថា
ចុះព្រះគ្រីស្ទយាងមកពីស្រុកកាលីឡេដែរឬ[ង] ៤២តើគម្ពីរ
មិនថា ព្រះគ្រីស្ទត្រូវកើត ពីព្រះវង្សហ្លួងដាវីឌ[ច] ហើយក៏
យាងមកពីភូមិបេថ្លេហិម[ឆ] ជាកន្លែងដែលហ្លួងដាវីឌបាន
គង់នៅទេឬអី ៤៣ដូច្នេះ គេក៏បាក់បែកទាស់គ្នា[ជ] ដោយ
ព្រោះទ្រង់ ៤៤មានខ្លះចង់ចាប់ទ្រង់ តែគ្មានអ្នកណាលូកដៃ
ទៅចាប់ទេ[ឈ] ។

## ការមិនជឿរបស់ពួកអ្នកដឹកនាំសាសនាយូដា

៤៥នោះពួកអាជ្ញា ក៏ត្រឡប់ទៅឯពួកសង្គ្រាជ នឹងពួក ផា
រិស៊ីវិញ លោកទាំងនោះសួរគេថា ហេតុអ្វីបានជាមិន
ចាប់អ្នកនោះមក ៤៦ពួកអាជ្ញាឆ្លើយថា មិនដែលមានអ្នក
ណានិយាយដូចអ្នកនោះទេ[ញ] ៤៧ដូច្នេះ ពួកផារិស៊ីស្ដីឱ្យថា
អ្នករាល់គ្នា ត្រូវបញ្ឆោតដែរឬ[ដ] ៤៨តើមានអ្នកឯណា
ក្នុងពួកនាម៉ឺន ឬក្នុងពួកផារិស៊ី ដែលជឿដល់អ្នកនោះឬទេ[ឋ]
៤៩ឯហ្វូងមនុស្សនេះ ដែលមិនស្គាល់ក្រិត្យវិន័យ គេជា
មនុស្សត្រូវបណ្ដាសាវិញ ៥០ឯលោកនីកូដេម[ឌ] ជាអ្នកដែល
មកឯទ្រង់ទាំងយប់ ដែលជាពួកផារិស៊ីដែរ លោក
និយាយទៅគេថា ៥១តើក្រិត្យវិន័យ យើងកាត់ទោសដល់
មនុស្សណា មុនដែលបានឮពាក្យ ចំឡើយពីខ្លួនអ្នកនោះ
ហើយដឹងជាធ្វើខុសយ៉ាងណាឬអី ៥២នោះគេឆ្លើយទៅ

**៧:៣៥** ម យក ១:១ យ យហ ១២:២០ កច ១៧:៤ ១៨:៤ **៧:៣៦** រ ខ.៣៤ **៧:៣៧** ល លវ ២៣:៣៦ **៧:៣៧** វ អស ៥៥:១ វវ ២២:១៧ **៧:៣៨** ស យហ ៣:១៥ ហ យហ ៤:១០ ឡ អស ៥៨:១១ អ យហ ៤:១៤ **៧:៣៩** ក យអ ២:២៨ យហ ១:៣៣ កច ២:១៧,៣៣ ខ យហ ២០:២២ គ យហ ១២:២៣ ១៣:៣១,៣២ **៧:៤០** ឃ មថ ២១:១១ **៧:៤១** ង ខ.៥២ យហ ១:៤៦ **៧:៤២** ច មថ ១:១ ឆ មីក ៥:២ មថ ២:៥,៦ លក ២:៤

**៧:៤៣** ជ យហ ៦:៥២ ៩:១៦ ១០:១៩ **៧:៤៤** ឈ ខ.៣០
**៧:៤៦** ញ មថ ៧:២៨ **៧:៤៧** ដ ខ.១២ **៧:៤៨** ឋ យហ ១២:៤២
**៧:៥០** ឌ យហ ៣:១ ១៩:៣៩

**៧:៣៧** *នៅថ្ងៃក្រោយបង្អស់* គឺនៅថ្ងៃទី៧ ឬទី៨នៃបុណ្យបារាំនោះ ។ បុណ្យនោះមានរយៈពេល៧ថ្ងៃ (លវ ២៣:៣៤ ចទ ១៦:១៣,១៥) ប៉ុន្តែ ថ្ងៃបុណ្យចុងក្រោយបង្អស់ គឺហាក់ដូចជានៅថ្ងៃទី៨ (លវ ២៣:៣៦ មើលការពន្យល់ មក ១៤:១២)។ *ព្រះយេស៊ូវទ្រង់ឈរបន្លឺឧទាន* ត្រង់ចំណុចនេះបញ្ជាក់ថា ជាទូទៅគ្រូបង្រៀនតែងតែអង្គុយ ប៉ុន្តែ ព្រះយេស៊ូវទ្រង់បែរជាឈរបង្រៀនដល់ពួកគេវិញ ដូច្នេះ មានន័យថា ទ្រង់មានព្រះហឫទ័យចង់ឱ្យពួកអ្នកដែលមានវត្តមាននៅពេលនោះ ស្ដាប់ព្រះបន្ទូលទ្រង់ដោយយកចិត្តទុកដាក់បំផុត ។

**៧:៣៨** *ទន្លេទឹករស់* សំដៅលើព្រះវិញ្ញាណបរិសុទ្ធ (ខ.៣៩ មើលពន្យល់ ៤:១០)។

**៧:៣៩** *ដ្បិតព្រះវិញ្ញាណបរិសុទ្ធមិនទាន់យាងមក* ឃ្លានេះបញ្ជាក់ថា ព្រះយេស៊ូវនឹងចាត់ព្រះវិញ្ញាណបរិសុទ្ធឱ្យមក បន្ទាប់ពីទ្រង់យាងទៅឯព្រះវរបិតាវិញ ។ ការយាងមកនៃព្រះវិញ្ញាណបរិសុទ្ធ បានសំដែងឱ្យពួកគេឃើញយ៉ាងច្បាស់នៅថ្ងៃបុណ្យទី៥០ (មើលការពន្យល់ កច ២:១,២,៤)។ *មិនទាន់បានដំកើងឡើង* ត្រង់ចំណុចនេះ អាចសំដៅលើការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង ការរស់ពីសុគតឡើងវិញ និងការដែលទ្រង់យាងទៅឯស្ថានសួគ៌វិញ (មើលការពន្យល់ ១៣:១៣)។

**៧:៤០** *បណ្ដាមនុស្ស* "មើលពន្យល់ ខ.២០"។ *ហោរា* "មើលពន្យល់ ១:២១"។

**៧:៤២** *ព្រះគ្រីស្ទត្រូវកើតពីព្រះវង្សហ្លួងដាវីឌ . . . មកពីភូមិបេថ្លេហិម* "ទដ ៨៩:៣,៤ មីក ៥:២ មើលការពន្យល់ ខ.២៧ ១សយ ២០:៦ ២សយ ៧:១២-១៦"។

**៧:៤៦** *ពួកអាជ្ញា* ត្រង់ចំណុចនេះបញ្ជាក់ថា នៅពេលដែលពួកអាជ្ញាកំពុងរង់ចាំដើម្បីចាប់ព្រះយេស៊ូវ នោះពួកគេក៏បានស្ដាប់ឮសេចក្ដីបង្រៀនរបស់ទ្រង់ ហើយក៏មានការប៉ះពាល់ចិត្ត ដូច្នោះហើយទើបពួកគេមិនព្រមចាប់ទ្រង់ទេ ។

**៧:៤៧** *ពួកផារិស៊ីស្ដីឱ្យ* មានន័យថា នៅពេលដែលពួកផារិស៊ីបានឮចម្លើយរបស់ពួកអាជ្ញាភ្លាម នោះក៏មានកំហឹងយ៉ាងខ្លាំង ។

**៧:៤៩** *ហ្វូងមនុស្សនេះ* សំដៅលើពួកអ្នកដែលកំពុងស្ដាប់សេចក្ដីបង្រៀនរបស់ព្រះយេស៊ូវនៅថ្ងៃបុណ្យចុងក្រោយនោះ (ខ.២០)។ *មិនស្គាល់ក្រិត្យវិន័យ* ពួកផារិស៊ីនិយាយយ៉ាងដូច្នេះ គឺពួកគេចង់មានន័យថា ហ្វូងមនុស្សទាំងនោះមិនបានរៀនសូត្រក្រឹត្យវិន័យនៅក្នុងសាលា (របស់ពួកផារិស៊ី) និងមិនបានយល់ពីសេចក្ដី ដែលមានចែងនៅក្នុងព្រះគម្ពីរសញ្ញាចាស់ទេ ។

**៧:៥០-៥១** ពួកផារិស៊ីនិយាយថា ក្នុងចំណោមពួកអ្នកដឹកនាំសាសន៍យូដា គ្មានអ្នកណាម្នាក់យល់ស្របតាមសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវទេ ។ ប៉ុន្តែ ក្នុងព្រះគម្ពីរបានបញ្ជាក់យ៉ាងច្បាស់ថា លោកនីកូដេម ដែលជាអ្នកដឹកនាំម្នាក់ក្នុងពួកផារិស៊ីបាននិយាយការពារព្រះយេស៊ូវ និងសេចក្ដីបង្រៀនរបស់ទ្រង់ផង ។

**៧:៥២** *គតដែលមានហោរាណា កើតមកពីស្រុកកាលីឡេឡើយ* "១:៤៦ មើលការពន្យល់ មថ ២:២៣"។ ពួកផារិស៊ីនិយាយយ៉ាងដូច្នេះ គឺខុសទាំងស្រុង ព្រោះថា លោកយ៉ូណាសក៏ជាហោរាម្នាក់ ដែលកើតនៅក្នុងក្រុងកាថ-ហេភើរ (២ពវ ១៤:២៥) នៃស្រុកកាលីឡេដែរ ។

លោកថា តើលោកមកពីស្រុកកាលីឡេដែរឬ ចូរពិចារណា
មើលចុះ ឥតដែលមានហោរាណា កើតមកពីស្រុកកាលី
ឡេឡើយ[ឍ] ៥៣ គេក៏ត្រឡប់ទៅផ្ទះវិញរៀងខ្លួន ១ តែព្រះ
យេស៊ូវទ្រង់យាងទៅឯភ្នំដើម អូលីវវិញ[ណ]។
**៨** ២ ដល់ព្រលឹមឡើង ទ្រង់យាងត្រឡប់ ទៅក្នុងព្រះវិហារ
ហើយបណ្ដាជនក៏មកឯទ្រង់ នោះទ្រង់គង់ចុះបង្រៀនគេ[ត]
៣ រួចពួកអាចារ្យនឹងពួកផារិស៊ី គេនាំស្ត្រីម្នាក់ដែលបានទាន់
នៅដំណេកមកឯទ្រង់ កាលគេដាក់ស្ត្រីនោះនៅកណ្ដាលជំនុំ
ហើយ នោះក៏ទូលថា ៤ លោកគ្រូ ស្ត្រីនេះគេចាប់បានកំពុង
ដែលសហាយស្មន់នឹងគ្នា ៥ រីឯក្នុងក្រិត្យវិន័យ លោកម៉ូសេ
បានបង្គាប់ឱ្យយើងខ្ញុំ ចោលស្ត្រីយ៉ាងនេះនឹងថ្ម[ថ] ដូច្នេះ តើ
លោកគិតដូចម្ដេច ៦ គេទូលដូច្នោះ ដើម្បីនឹងល្បងលទ្រង់
ទេ[ទ] ប្រយោជន៍ ឱ្យតែបានរឿងចោទប្រកាន់ទ្រង់ប៉ុណ្ណោះ[ធ]
ប៉ុន្តែ ព្រះយេស៊ូវទ្រង់ឱនទៅសរសេរនៅដីដោយព្រះអង្គុលី
វិញ ៧ តែដោយព្រោះគេ ចេះតែសួរ បានជាទ្រង់ងើបឡើង
មានបន្ទូលថា អ្នកណាដែលគ្មានបាបសោះ[ន] ចូរឱ្យអ្នកនោះ
ចោលនាងនឹងថ្មជាមុនចុះ[ប] ៨ រួចទ្រង់ក៏ឱនសរសេរនៅដី
ម្ដងទៀត ៩ កាលបានឮពាក្យទាំងនោះ ហើយបញ្ញាចិត្តគេ
បានចោទប្រកាន់ទោសខ្លួន នោះគេក៏ថយចេញទៅ ម្នាក់
ម្ដងៗ ចាប់តាំងពីមនុស្សចាស់ជាងគេ ដរាបដល់អ្នកក្រោយ
បង្អស់ សល់នៅតែព្រះយេស៊ូវ នឹងស្ត្រីនោះ ដែលនៅ
ចំពោះទ្រង់ប៉ុណ្ណោះ ១០ ព្រះយេស៊ូវងើបឡើងវិញ ឃើញតែ
ស្ត្រីនោះ ក៏មានបន្ទូលទៅថា នាងអើយ ពួកដែលចោទប្រ
កាន់នាង តើនៅឯណា គ្មានអ្នកណាកាត់ទោសនាងទេឬអី
១១ នាងទូលឆ្លើយថា គ្មានទេ លោកម្ចាស់ រួចព្រះយេស៊ូវ
មានបន្ទូលទៅថា ខ្ញុំក៏មិនកាត់ទោសនាងដែរ[ផ] អញ្ជើញទៅ
ចុះ តែកុំធ្វើបាបទៀតឡើយ[ព]។

## ទីបន្ទាល់របស់ព្រះយេស៊ូវ

១២ ព្រះយេស៊ូវទ្រង់មានបន្ទូលទៅគេម្ដងទៀតថា ខ្ញុំជា[ភ]

**៧:៥២** ឍ ខ.៤១
**៨:១** ណ មថ ២១:១
**៨:២** ត ខ.២០ មថ ២៦:៥៥
**៨:៥** ថ លវ ២០:១០ ចទ ២២:២២ យប ៣១:១១
**៨:៦** ទ មថ ២២:១៥,១៨ ធ មថ ១២:១០
**៨:៧** ន ចទ ១៧:៧ អគ ១៦:៤០ ប រម ២:១,២២
**៨:១១** ផ យហ ៣:១៧ ព យហ ៥:១៤
**៨:១២** ភ យហ ៦:៣៥ ម យហ ១:៤ យ សភ ៤:១៨ មថ ៥:១៤

**៧:៥៣** *គេក៏ត្រឡប់ទៅផ្ទះវិញរៀងខ្លួន* បទគម្ពីរនេះបញ្ជាក់ថា លោកនីកូដេម គឺជាអ្នកដឹកនាំដែលមានឥទ្ធិពលម្នាក់ នៅក្នុងពួកអ្នកដឹកនាំសាសន៍យូដា ពីព្រោះបន្ទាប់ពីគាត់និយាយហើយ ធ្វើឱ្យពួកគេត្រឡប់ទៅផ្ទះរៀងៗខ្លួនអស់ទៅ ។

**៨:១** *ភ្នំដើមអូលីវ* ស្ថិតនៅភាគខាងកើត (ឆៀងខាងជើង) នៃទីក្រុងយេរូសាឡិម (មើលការពន្យល់ សក ១៤:៤ មក ១១:១ លក ១៩:២៩ កច ១:១២) ។

**៨:៣** *ពួកអាចារ្យ* ពាក្យនេះនៅក្នុងព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសមួយចំនួនសរសេរថា "គ្រូបង្រៀនក្រឹត្យវិន័យ" (មើលការពន្យល់ មថ ២:៤ មក ២:១៦)។ *ស្ត្រីម្នាក់ដែលបានទាន់នៅដំណេក* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ពួកសាសន៍យូដាចង់ល្បងលដល់ព្រះយេស៊ូវ និងចង់ចាប់កំហុសទ្រង់ទាំងស្រុង ព្រោះថា គ្រប់អំពើសហាយស្មន់មិនអាចកើតឡើងដោយបុគ្គលតែម្នាក់ទេ ប៉ុន្តែ ពួកគេចាប់យកតែស្ត្រីម្នាក់មក រីឯបុរសដែលប្រព្រឹតការនោះបែរជារួចខ្លួនទៅវិញ ។ ដូច្នេះ មានន័យថា ពួកសាសន៍យូដាទាំងនោះ គឺជាអ្នករៀបចំឱ្យមានការនោះ ដើម្បីនឹងរករឿងចោទប្រកាន់ព្រះយេស៊ូវ ។

**៨:៤** *ចាប់បានកំពុងដែលសហាយស្មន់នឹងគ្នា* បទគម្ពីរនេះមិនបានបញ្ជាក់ថា មានអ្នកណាធ្វើជាសាក្សី ថាបានឃើញហេតុការណ៍នោះទេ ។ ដូច្នេះ មានន័យថា អ្វីដែលបានកើតឡើងនោះ គឺជាគម្រោងការណ៍របស់ពួកសាសន៍យូដាតែម្ដង ។

**៨:៥** *ចោលស្ត្រីយ៉ាងនេះនឹងថ្ម* ត្រង់ចំណុចនេះមិនបញ្ជាក់ថា ស្ត្រីនោះមានគេដណ្ដឹងហើយឬនៅទេ ។ បើសិនជានាងមិនទាន់មានគេដណ្ដឹងទេ មានន័យថា ទង្វើរបស់ពួកសាសន៍យូដានៅពេលនោះ គឺប្រឆាំងនឹងក្រឹត្យវិន័យទាំងស្រុង ព្រោះនៅក្នុង "ចទ ២២:២៣-២៤" បានចែងថា "បើមានស្ត្រីក្រមុំណា ដែលមានគេដណ្ដឹង ហើយ" នោះទើបឱ្យចោលសម្លាប់ ។ ម្យ៉ាងទៀតត្រូវយកទាំងបុរសដែលប្រព្រឹត្ត អំពើនោះជាមួយនាងទៅចោលសម្លាប់ដែរ (លវ ២០:១០ ចទ ២២:២២) គឺពុំមែនយកតែស្ត្រីម្នាក់ទៅសម្លាប់ទេ ។

**៨:៦** បទគម្ពីរនេះបញ្ជាក់ថា ប្រសិនបើព្រះយេស៊ូវមានបន្ទូល ឱ្យពួកគេចោលសម្លាប់ស្ត្រីនោះ គឺមានន័យថា ទ្រង់ប្រឆាំងនឹងច្បាប់របស់ចក្រភពរ៉ូម៉ាំង ។ ព្រោះនៅក្នុងច្បាប់របស់ពួករ៉ូម៉ាំង មិនអនុញ្ញាតឱ្យពួកយូដា មានសិទ្ធិសម្រេចក្នុងការកាត់ទោសប្រហារជីវិតអ្នកណាម្នាក់ទេ (មើលការពន្យល់ ១៨:៣១) ។ ប៉ុន្តែ ប្រសិនបើព្រះយេស៊ូវមានបន្ទូលមិនឱ្យចោលសម្លាប់នាងវិញ នោះពួកសាសន៍យូដានឹងចោទទ្រង់ថា មិនបានគោរពប្រតិបត្តិដល់ក្រឹត្យវិន័យ ។

**៨:៧** *អ្នកណាដែលគ្មានបាបសោះ* ព្រះយេស៊ូវមានបន្ទូលដូច្នេះ គឺសំដៅលើអំពើបាបទូទៅ មិនចំពោះតែអំពើបាបដែលស្ត្រីនោះបានប្រព្រឹត្តទេ ។ ម្យ៉ាងទៀត បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា មនុស្សគ្រប់រូបសុទ្ធតែមានបាប ។

**៨:៨** ការដែលព្រះយេស៊ូវទ្រង់ឱនទៅសរសេរនៅដីម្ដងទៀត គឺជាឱកាសសម្រាប់ពួកសាសន៍យូដាដែលល្បងលដល់ទ្រង់ ថយចេញពីទីនោះ ។

**៨:៩** *ថយចេញទៅម្នាក់ម្ដងៗ* ត្រង់ចំណុចនេះបញ្ជាក់ថា បន្ទាប់ពីពួកសាសន៍យូដាបានឮព្រះបន្ទូលរបស់ព្រះយេស៊ូវរួចហើយ ពួកគេក៏ដឹងថាខ្លួនសុទ្ធតែជាមនុស្សមានបាប ដូច្នេះ ក៏នាំគ្នាថយចេញពីទីនោះអស់ទៅ (ខ.៧) ។ *មនុស្សចាស់ជាងគេ* សំដៅលើពួកគ្រូក្រឹត្យវិន័យ ពួកផារិស៊ី និងពួកអ្នកដឹកនាំសាសន៍យូដាដទៃទៀត ។

**៨:១១** *តែកុំធ្វើបាបទៀតឡើយ* មានន័យថា កុំឱ្យប្រព្រឹត្តអំពើដែលប្រឆាំងនឹងព្រះបន្ទូលរបស់ព្រះអម្ចាស់ទៀត ។

**៨:១២** *ខ្ញុំជាពន្លឺលោកីយ* "១យហ ១:៥ មើលពន្យល់ ១:៤ ៦:៣៥ ៩:៥ ១២:៤៦"។ ពួកសិស្សរបស់ព្រះយេស៊ូវទាំងអស់ គឺទទួលពន្លឺមកអំពីទ្រង់ ដូច្នេះ ពួកគេជាពន្លឺនៅ ក្នុងលោកិយនេះ (មថ ៥:១៤ ភល ២:១៥)។ *សេចក្ដីងងឹត* សំដៅលើការអាក្រក់របស់លោកិយ និងសេចក្ដីអាក្រក់ទាំងឡាយរបស់អារក្សសាតាំង។ *ពន្លឺនៃជីវិត* មានន័យថា ព្រះយេស៊ូវជាពន្លឺបំភ្លឺមនុស្សលោកឱ្យបានស្គាល់ផ្លូវនៃជីវិតដ៏ពិតប្រាកដ គឺដូចជាបង្គោលភ្លើង ដែលបំភ្លឺពួក

ពន្លឺលោកីយ[ម] អ្នកណាដែលតាមខ្ញុំ នោះមិនដែលដើរក្នុង
សេចក្ដីងងឹតឡើយ គឺនឹងមានពន្លឺនៃជីវិតវិញ[យ] ១៣នោះពួក
ផារិស៊ីទូលថា អ្នកធ្វើបន្ទាល់ពីខ្លួនអ្នក ដូច្នេះ សេចក្ដីបន្ទាល់
របស់អ្នកមិនពិតទេ[រ] ១៤ព្រះយេស៊ូវមានបន្ទូលឆ្លើយថា
ទោះបើខ្ញុំធ្វើបន្ទាល់ពីខ្លួនខ្ញុំ គង់តែសេចក្ដីបន្ទាល់នោះ
ក៏ពិតដែរ ព្រោះខ្ញុំដឹងជាខ្ញុំមកពីណា ហើយទៅឯណាផង[ល]
តែអ្នករាល់គ្នាមិនដឹងជាខ្ញុំមកពីណា[វ] ឬទៅឯណាទេ
១៥អ្នករាល់គ្នាជំនុំជំរះតាមសាច់ឈាម[ស] ឯខ្ញុំមិនជំនុំជំរះអ្នក
ណាទេ[ហ] ១៦តែបើខ្ញុំជំនុំជំរះដែរ នោះសេចក្ដីជំនុំជំរះរបស់
ខ្ញុំជាពិតវិញ ពីព្រោះខ្ញុំមិននៅតែឯងទេ គឺមានព្រះវរបិតា
ដែលចាត់ឱ្យខ្ញុំមក ទ្រង់គង់ជាមួយផង[ឡ] ១៧ហើយក្នុងក្រឹត្យ
វិន័យរបស់អ្នករាល់គ្នា ក៏មានពាក្យចែងទុកមកថា សេចក្ដី
បន្ទាល់របស់មនុស្ស២នាក់ នោះពិតហើយ[អ] ១៨ដូច្នេះ មាន
ខ្ញុំនេះ១ដែលធ្វើបន្ទាល់ពីខ្លួនខ្ញុំ ហើយមានព្រះវរបិតា១
ដែលចាត់ឱ្យខ្ញុំមក ទ្រង់ក៏ធ្វើបន្ទាល់ពីខ្ញុំដែរ[ក] ១៩នោះគេ
ទូលសួរថា តើព្រះវរបិតាអ្នកនៅឯណា ព្រះយេស៊ូវទ្រង់
ឆ្លើយថា អ្នករាល់គ្នាមិនស្គាល់ខ្ញុំ ឬព្រះវរបិតាខ្ញុំទេ[ខ] បើ
សិនជាអ្នករាល់គ្នាបានស្គាល់ខ្ញុំ នោះនឹងស្គាល់ដល់ព្រះ
វរបិតាខ្ញុំដែរ[គ] ២០ព្រះយេស៊ូវទ្រង់មានបន្ទូលពាក្យទាំងនេះ
នៅត្រង់ឃ្លាំង[ឃ] កំពុងដែលទ្រង់បង្រៀន[ង] នៅក្នុងព្រះវិហារ
តែគ្មានអ្នកណាចាប់ទ្រង់ទេ ព្រោះកំណត់របស់ទ្រង់ មិន
ទាន់ដល់នៅឡើយ[ច]។
២១ព្រះយេស៊ូវមានបន្ទូលទៅគេម្តងទៀតថា ខ្ញុំនឹងទៅបាត់
ឯកន្លែងដែលខ្ញុំទៅ នោះអ្នករាល់គ្នាពុំអាចនឹងទៅបានទេ
អ្នករាល់គ្នានឹងរកខ្ញុំ ហើយនឹងស្លាប់[ឆ]ក្នុងអំពើបាបរបស់អ្នក
រាល់គ្នាវិញ[ជ] ២២ពួកសាសន៍យូដាក៏និយាយគ្នាថា តើអ្នក
នេះនឹងសំឡាប់ខ្លួនឯងឬអី បានជាថា កន្លែងដែលខ្ញុំទៅ
នោះអ្នករាល់គ្នាពុំអាចនឹងទៅបានទេ ២៣ទ្រង់មានបន្ទូលថា
អ្នករាល់គ្នាមកពីស្ថានក្រោម ឯខ្ញុំៗមកពីស្ថានលើវិញ អ្នក
រាល់គ្នាកើតពីលោកីយនេះ តែខ្ញុំមិនកើតពីលោកីយនេះ
ទេ[ឈ] ២៤ហេតុនោះបានជាខ្ញុំប្រាប់ថា អ្នករាល់គ្នានឹងស្លាប់
ក្នុងអំពើបាបរបស់ខ្លួន ពីព្រោះបើមិនជឿថា ខ្ញុំនេះជាព្រះ[ញ]
នោះអ្នក រាល់គ្នា នឹងស្លាប់ក្នុងអំពើបាប របស់ខ្លួនពិតមែន
២៥ដូច្នេះ គេទូលសួរទ្រង់ថា តើអ្នកជាអ្វី ព្រះយេស៊ូវមាន
បន្ទូលឆ្លើយថា គឺដូចជាខ្ញុំបានប្រាប់អ្នករាល់គ្នា ពីដើម
រៀងមកនោះឯង ២៦ខ្ញុំមានសេចក្ដីជាច្រើន ដែលត្រូវ
និយាយ ហើយជំនុំជំរះ ពីដំណើរអ្នករាល់គ្នា ប៉ុន្តែ ព្រះ
អង្គដែលចាត់ឱ្យខ្ញុំមក ទ្រង់ពិតប្រាកដ[ដ] ហើយសេចក្ដីអ្វី
ដែលខ្ញុំបានឮពីទ្រង់ នោះខ្ញុំក៏ប្រាប់ ដល់មនុស្សលោកដែរ[ឋ]

**៨:១៣** រ យហ ៥:៣១
**៨:១៤** ល យហ ១៣:៣ ១៦:២៨ វ យហ ៧:២៨ ៩:២៩
**៨:១៥** ស យហ ៧:២៤ ហ យហ ៣:១៧
**៨:១៦** ឡ យហ ៥:៣០
**៨:១៧** អ មថ ១៨:១៦
**៨:១៨** ក យហ ៥:៣៧
**៨:១៩** គ ១យហ ២:២៣ យហ ១៦:៣
**៨:២០** ឃ មក ១២:៤១ ង មថ ២៦:៥៥
ច មថ ២៦:១៨
**៨:២១** ឆ អគ ៣:១៨ ជ យហ ៧:៣៤ ១៣:៣៣
**៨:២៣** ឈ យហ ៣:៣១ ១៧:១៤
**៨:២៤** ញ យហ ៤:២៦ ១៣:១៩
**៨:២៦** ដ យហ ៧:២៨ ឋ យហ ៣:៣២ ១៥:១៥

អ៊ីស្រាអែលទៅកាន់ទឹកដីសន្យានាពេលយប់នោះដែរ (នហ ៩:១២ មើលការពន្យល់ នក ១៣:២១)។

**៨:១៣** បទគម្ពីរនេះបញ្ជាក់ថា នៅក្នុងសាលាជម្រះក្តី នាសម័យកាលសញ្ញាចាស់ ពាក្យសំដីរបស់អ្នកចុងចោទ ពុំត្រូវបានគេចាត់ទុកថាត្រឹមត្រូវទេ លុះណាតែមានសាក្សីចាប់ពី២នាក់ឡើងទៅ (ចទ ១៩:១៥)។

**៨:១៥** ត្រង់ចំណុចនេះបញ្ជាក់ថា សេចក្តីជំនុំជម្រះរបស់ពួកផារិស៊ី គឺធ្វើតាមតែការយល់ឃើញរបស់ខ្លួន និងតាមតែសាច់ឈាមប៉ុណ្ណោះ។ *ឯខ្ញុំ ខ្ញុំមិនជំនុំជម្រះអ្នកណាទេ* មានន័យថា ការដែលព្រះយេស៊ូវយាងមកនៅពេលនោះមិនមែន ដើម្បីជំនុំជម្រះមនុស្សលោកទេ គឺដើម្បីជួយសង្គ្រោះពួកគេ ឱ្យរួចពីសេចក្តីស្លាប់វិញ (ខ.២៦)។

**៨:១៦-១៨** ព្រះយេស៊ូវគ្រីស្ទមានបន្ទូលទៅកាន់ពួកសាសន៍យូដាយ៉ាងច្បាស់ថា ព្រះវរបិតាគង់នៅជាមួយទ្រង់ជានិច្ច ហើយក៏ធ្វើបន្ទាល់ពីទ្រង់ដែរ (មថ ៣:១៧)។ ដូច្នេះ ព្រះយេស៊ូវមិនបានធ្វើបន្ទាល់តែមួយអង្គទ្រង់ទេ គឺមានព្រះវរបិតាទៀត ដែលធ្វើបន្ទាល់អំពីទ្រង់ ។ ម្យ៉ាងទៀត បញ្ជាក់ថា សេចក្តីបន្ទាល់របស់ព្រះយេស៊ូវ គឺស្របនឹងក្រឹត្យវិន័យដែលមានចែងទុកទៀតផង (ចទ ១៧:៦ ១៩:១៥)។

**៨:១៦** បទគម្ពីរនេះបញ្ជាក់ថា ព្រះយេស៊ូវទ្រង់គង់នៅជាមួយព្រះវរបិតា តាំងពីអស់កល្បជានិច្ចមក ។ ម្យ៉ាងទៀត គ្រប់ព្រះរាជកិច្ចទាំងអស់ ដែលព្រះយេស៊ូវទ្រង់ធ្វើ រួមទាំងការជំនុំជម្រះផង គឺសុទ្ធតែជាបំណងព្រះហឫទ័យ នៃព្រះវរបិតា ដែលចាត់ឱ្យទ្រង់មកទាំងស្រុង (មើលការពន្យល់ ៤:៣៤)។

**៨:១៩** ព្រះយេស៊ូវមានបន្ទូលប្រាប់ពួកផារិស៊ីថា ព្រះវរបិតាជាស្មរបន្ទាល់របស់ទ្រង់ ប៉ុន្តែ ពួកគេបែរជានិយាយចំអកដាក់ទ្រង់ ដោយសួរទ្រង់ថា "តើព្រះវរបិតាអ្នកនៅឯណា?"។ ពួកគេគិតថា ព្រះយេស៊ូវមានបន្ទូលសំដៅលើលោកយ៉ូសែបជាប្តីរបស់នាងម៉ារា ។ ផ្ទុយទៅវិញ គឺទ្រង់មានបន្ទូលសំដៅលើព្រះវរបិតា ដែលគង់នៅឯស្ថានសួគ៌វិញ ។ លោកយ៉ូហាន បានបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវគឺជា ព្រះបន្ទូល ដែលគង់នៅជាមួយព្រះវរបិតាតាំងពីអស់កល្បជានិច្ចមក (មើលការពន្យល់ ១:១,១៨)។ ម្យ៉ាងទៀត បទគម្ពីរនេះបញ្ជាក់ថា មនុស្សលោកមិនអាចស្គាល់ព្រះវរបិតាបានទេ លុះណាតែតាមរយៈព្រះរាជបុត្រានៃទ្រង់ (មើលការពន្យល់ ១៤:៧,១១-១១)។

**៨:២០** *កំណត់របស់ទ្រង់* "មើលការពន្យល់ ២:៤"។

**៨:២១** ពួកអ្នកដឹកនាំសាសន៍យូដា បានបដិសេធព្រះយេស៊ូវ ថាទ្រង់មិនមែនជាព្រះមែស៊ីដែលត្រូវយាងមកនោះទេ ។ ដូច្នេះ ជាលទ្ធផល ពួកគេត្រូវស្លាប់នៅក្នុងអំពើបាបរបស់ខ្លួន ។

**៨:២៣** *មកពីស្ថានក្រោម* អាចមានន័យថា កើតពីលោកិយ ឬជារបស់លោកិយ ។ *មកពីស្ថានលើ* គឺមកពីព្រះអម្ចាស់ ឬជារបស់ព្រះអម្ចាស់ ។ ក្នុងព្រះគម្ពីរបរិសុទ្ធ បញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវបានយាងមកប្រសូតនៅលើផែនដី ប៉ុន្តែ ទ្រង់មិនមែនជារបស់លោកិយនេះទេ ។ ពួកសាសន៍យូដាដែលប្រឆាំងនឹងព្រះយេស៊ូវ ពួកគេគឺជារបស់លោកិយ ដូច្នេះ ទើបពួកគេបដិសេធមិនព្រមទទួលទ្រង់ (យហ ១២:៣១ ១៤:៣០ ១៦:១១ ១យហ ៥:១៩)

**៨:២៤** *ជឿ* មើលការពន្យល់ ១:៧ ។ *ខ្ញុំនេះជាព្រះ* ត្រង់ចំណុចនេះព្រះ

២៧ តែគេមិនដឹងជាទ្រង់ មានបន្ទូលនឹងគេ ពីព្រះវរបិតាទេ
២៨ ដូច្នេះ ព្រះយេស៊ូវមានបន្ទូលថា កាលណាអ្នក រាល់គ្នា
បានលើកកូនមនុស្ស[ឃ] ឡើង នោះទើបនឹងដឹងថា គឺខ្ញុំនេះ
ហើយជាព្រះ ហើយថា ខ្ញុំមិនធ្វើការអ្វី ដោយអាងខ្លួនខ្ញុំ
គឺខ្ញុំនិយាយសេចក្ដីទាំងនេះ តាមដែលព្រះវរបិតាបាន
បង្រៀនខ្ញុំវិញ[ឈ] ២៩ ព្រះអង្គនោះ ដែលចាត់ឱ្យខ្ញុំមក ក៏គង់
ជាមួយនឹងខ្ញុំ ទ្រង់មិនទុកឱ្យខ្ញុំ នៅតែឯងទេ[ណ] ពីព្រោះ
ខ្ញុំចេះតែធ្វើការ ដែលគាប់ដល់ព្រះហឫទ័យទ្រង់ជាដរាប[ត]
៣០ កំពុងដែលទ្រង់ មានបន្ទូលសេចក្ដីទាំងនេះ នោះមាន
មនុស្សជាច្រើនបានជឿដល់ទ្រង់[ថ]។

## ពូជរបស់លោកអ័ប្រាហាំ

៣១ នោះព្រះយេស៊ូវមានបន្ទូល ទៅពួកសាសន៍យូដាដែល
ជឿដល់ទ្រង់ថា បើអ្នករាល់គ្នា នៅជាប់ក្នុងពាក្យខ្ញុំ[ទ] នោះ
អ្នករាល់គ្នាជាសិស្សខ្ញុំមែន ៣២ អ្នករាល់គ្នា នឹងស្គាល់សេចក្ដី
ពិត ហើយសេចក្ដីពិតនោះ នឹងប្រោសឱ្យអ្នករាល់គ្នាបាន
រួច[ធ] ៣៣ គេទូលឆ្លើយថា យើងរាល់គ្នាជាពូជលោកអ័ប្រា
ហាំ[ន] ក៏មិនដែលធ្វើជាបាវបំរើរបស់អ្នកណាឡើយ ម្ដេច
ក៏អ្នកថា យើងនឹងបានរួចដូច្នេះ ៣៤ ព្រះយេស៊ូវមាន
បន្ទូលតបថា ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដ
ថា អស់អ្នកណាដែលប្រព្រឹត្តអំពើបាប នោះជាបាវបំរើ
របស់អំពើបាបនោះហើយ[ប] ៣៥ រីឯបាវបំរើ គេមិននៅ
ជាប់ក្នុងផ្ទះជាដរាបទេ តែព្រះរាជបុត្រា ទ្រង់នៅជាប់
អស់កល្បជានិច្ចវិញ ៣៦ ដូច្នេះ បើព្រះរាជបុត្រាប្រោសឱ្យ
អ្នករាល់គ្នាបានរួច[ព] នោះនឹងបានរួចជាពិត[ភ] ៣៧ ខ្ញុំដឹងហើយ
ថា អ្នករាល់គ្នាជាពូជលោកអ័ប្រាហាំ ប៉ុន្តែអ្នករាល់គ្នារក
សំឡាប់ខ្ញុំ[ភ] ពីព្រោះពាក្យខ្ញុំ គ្មានកន្លែងដក់នៅក្នុងចិត្តរបស់
អ្នករាល់គ្នាទេ ៣៨ ឯខ្ញុំៗ និយាយតែសេចក្ដីណាដែលខ្ញុំ
បានឃើញនៅឯព្រះវរបិតាខ្ញុំ[ម] តែអ្នករាល់គ្នាធ្វើតែការ
ដែលបានឃើញ នៅឯឪពុករបស់អ្នករាល់គ្នាវិញ[យ] ៣៩ គេ
ទូលឆ្លើយថា គឺលោកអ័ប្រាហាំជាឪពុកនៃយើងរាល់គ្នា[រ]
ព្រះយេស៊ូវមានបន្ទូលថា បើអ្នករាល់គ្នាជាពូជលោក
អ័ប្រាហាំពិត នោះនឹងធ្វើតាមលោកជាប្រាកដ ៤០ តែឥឡូវ
នេះ អ្នករាល់គ្នារកចង់សំឡាប់ខ្ញុំវិញ[ល] ជាមនុស្សដែលយក
សេចក្ដីពិត ដែលបានឮពីព្រះ[វ] មកប្រាប់ដល់អ្នករាល់គ្នា
លោកអ័ប្រាហាំមិនបានធ្វើដូច្នោះទេ ៤១ អ្នករាល់គ្នាធ្វើតាម
តែឪពុករបស់ខ្លួន[ស] ដូច្នេះ គេទូលថា យើងរាល់គ្នាមិនមែន
ជាកូនសហាយទេ យើងមានព្រះវរបិតាតែ១ គឺជាព្រះ[ហ]

## កូនរបស់អារក្សសាតាំង

៤២ ព្រះយេស៊ូវមានបន្ទូលថា បើព្រះ ជាព្រះវរបិតានៃអ្នក

**៨:២៨** ឃ យហ ១២:៣២
ឈ យហ ១៤:២៤
**៨:២៩** ណ ខ.១៦
យហ ១៦:៣២
ត អស ៥០:៥
យហ ៤:៣៤ ៥:៣០
៦:៣៨
**៨:៣០** ថ យហ ៧:៣១
**៨:៣១** ទ យហ ១៥:៧
២យហ ៩
**៨:៣២** ធ ខ.៣៦
រម ៨:២ ២កថ ៣:១៧
កទ ៥:១,១៣
**៨:៣៣** ន ខ.៣៧,៣៩
លក ៣:៨
**៨:៣៤** ប រម ៦:១៦
**៨:៣៥** ផ កទ ៤:៣០
**៨:៣៦** ព ខ.៣២
**៨:៣៧** ភ ខ.៣៩,៤០
**៨:៣៨** ម យហ ៥:១៩,៣០ ១៤:១០,
២៤ យ ខ.៤១,៤៤
**៨:៣៩** រ ខ.៣៧
លក ៣:៨
**៨:៤០** ល មថ ១២:១៤ វ ខ.២៦
**៨:៤១** ស ខ.៣៨,៤៤
ហ អស ៦៣:១៦ ៦៤:៨

យេស៊ូវមានបន្ទូលយ៉ាងច្បាស់ថា ទ្រង់គឺជាព្រះ (ខ.៥៨ ៦:៣៥ នក ៣:១៤)។

**៨:២៨** *កាលណាអ្នករាល់គ្នាបានលើកកូនមនុស្សឡើង* ឃ្លានេះសំដៅលើការដែលព្រះយេស៊ូវត្រូវគេយកឆ្កាង (មើលការពន្យល់ ៣:១៤ ១២:៣២)។ *កូនមនុស្ស* គឺព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ មក ៨:៣១)។

**៨:៣០** បទគម្ពីរនេះបញ្ជាក់ថា នៅពេលនោះ ទោះបីមានមនុស្សជាច្រើនបដិសេធ និងមិនព្រមទទួលយកព្រះបន្ទូលរបស់ព្រះយេស៊ូវក៏ដោយ ក៏នៅមានពួកគេជាច្រើនបានទទួលជឿដល់ទ្រង់ដែរ (១:៧ ២០:៣១)។

**៨:៣១** *នៅជាប់ក្នុងពាក្យខ្ញុំ នោះអ្នករាល់គ្នាជាសិស្សរបស់ខ្ញុំមែន* មានន័យថា អ្នកណាដែលជឿ និងប្រតិបត្តិតាមសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវ អ្នកនោះគឺជាសិស្សរបស់ទ្រង់ពិតប្រាកដមែន ។

**៨:៣២** *សេចក្ដីពិត* ពាក្យថា "សេចក្ដីពិត" ត្រង់ចំណុចនេះគឺសំដៅលើព្រះយេស៊ូវ (មើលការពន្យល់ ខ.៣៦ ១៤:៦)។ *ប្រោសឱ្យអ្នករាល់គ្នាបានរួច* មានន័យថា ព្រះយេស៊ូវគឺជាសេចក្ដីពិត ដែលប្រោសមនុស្សនៅលើពិភពលោកនេះ ឱ្យបានរួចពីអំណាចនៃសេចក្ដីស្លាប់ (ខ.៣៦)។

**៨:៣៣** *ក៏មិនដែលធ្វើជាបាវបំរើរបស់អ្នកណាឡើយ* ពួកសាសន៍យូដានិយាយដូច្នេះ គឺមិនបានគិតថា ពួកគេកំពុងតែស្ថិតនៅក្រោមការត្រួតត្រា របស់ចក្រភពរ៉ូម៉ាំងទេ ។ ម្យ៉ាងទៀត ពួកគេក៏ធ្លាប់ស្ថិតនៅក្រោមការត្រួតត្រារបស់ប្រទេសជ ច្រើនទៀតដូចជា អេស៊ីព្ទ អាសស៊ើរ បាប៊ីឡូន ពើស៊ី និងស៊ីរី ។ ពួកគេប្រហែលជានិយាយយ៉ាងដូច្នេះ ដោយសំអាងថា ពួកគេជាកូនចៅរបស់លោកអ័ប្រាហាំ ហើយដែលព្រះអម្ចាស់បានសន្យានឹងលោកថា ពូជពង្សរបស់លោកនឹងមិនធ្លាក់ទៅជាបាវបម្រើរបស់អ្នកណាទេ (កទ ៤:២១-២៣)។

**៨:៣៤** *បាវបំរើរបស់អំពើបាប* ឃ្លានេះបញ្ជាក់ថាមនុស្សគ្រប់ៗរូបសុទ្ធតែមានបាប ហើយមិនអាចពឹងអាងលើការប្រព្រឹត្ត និងកម្លាំងរបស់ខ្លួន ដើម្បីឱ្យបានរួចពីអំណាចរបស់វាឡើយ (មើលការពន្យល់ រម ៦:១៨)។

**៨:៣៧** ក្នុងបទគម្ពីរនេះព្រះយេស៊ូវមានបន្ទូលថា ពួកសាសសន៍យូដា ជាកូនចៅរបស់លោកអ័ប្រាហាំខាងឯសាច់ឈាម ប៉ុន្តែ ពួកគេមិនបានប្រព្រឹត្តឱ្យដូចជាលោកទេ (ខ.៣៩,៤០)។ ម្យ៉ាងទៀត ការដែលពួកគេមិនទទួលយកសេចក្ដីបង្រៀនរបស់ទ្រង់ ក៏មានន័យថា ពួកគេបដិសេធទ្រង់ដែរ (មើលការពន្យល់ ៧:១–៨:៥៩)។

**៨:៣៨** *ឪពុករបស់អ្នករាល់គ្នា* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកសាសន៍យូដាដែលប្រឆាំងនឹងព្រះយេស៊ូវនៅពេលនោះ គឺមានអារក្សសាតាំងជាឪពុករបស់ពួកគេ ដូច្នោះហើយបានជានាំគ្នារកសម្លាប់ទ្រង់ ។

**៨:៣៩–៤១** បទគម្ពីរទាំងនេះបញ្ជាក់ថា ទង្វើរបស់ពួកសាសន៍យូដានៅពេលនោះបានសំដែងឱ្យឃើញយ៉ាងច្បាស់ថា ពួកគេគឺជាកូនរបស់អារក្សសាតាំង ។

**៨:៤១** *អ្នករាល់គ្នាធ្វើតាមតែឪពុករបស់ខ្លួន* ព្រះយេស៊ូវទ្រង់មានបន្ទូលទៅកាន់ពួកសាសន៍យូដា ដែលប្រឆាំងនឹងទ្រង់យ៉ាងដូច្នេះ ដើម្បីឱ្យពួកគេដឹងថា ឪពុករបស់ពួកគេមិនមែនជាលោកអ័ប្រាហាំទេ គឺជាអារក្សសាតាំង ដែលជាអ្នកប្រឆាំង និងជាអ្នកសម្លាប់គេតាំងពីដើមរៀងមកវិញ ។

រាល់គ្នាមែន នោះអ្នកនឹងបានស្រឡាញ់ខ្ញុំ[ឡ] ដ្បិតខ្ញុំចេញពី
ព្រះមក[អ] ហើយក៏មកដល់ មិនមែនមកដោយអាងខ្លួនខ្ញុំទេ[ក]
គឺព្រះអង្គបានចាត់ឱ្យខ្ញុំមកទេតើ[ខ] ៤៣ហេតុអ្វីបានជាអ្នករាល់
គ្នាមិនយល់សំដីខ្ញុំ គឺមកតែពីស្តាប់ពាក្យខ្ញុំមិនបានប៉ុណ្ណោះ
៤៤អ្នករាល់គ្នាមានអារក្សសាតាំងជាឪពុក[គ] ហើយអ្នករាល់
គ្នាចូលចិត្តធ្វើតាមតណ្ហា ដែលគាប់ចិត្តដល់ឪពុករបស់អ្នក[ឃ]
វាជាអ្នកសំឡាប់គេតាំងពីដើមមក វាមិនបាននៅជាប់ក្នុង
សេចក្តីពិត ព្រោះគ្មានសេចក្តីពិតនៅក្នុងវាទេ កាលណាវា
ពោលពាក្យភូតភរ នោះដុះចេញពីចិត្តវាមក ដ្បិតវាជាអ្នក
កំភូតហើយជាឪពុកនៃសេចក្តីនោះឯង[ង] ៤៥ដោយព្រោះតែ
ខ្ញុំនិយាយសេចក្តីពិត[ច] បានជាអ្នករាល់គ្នាមិនជឿខ្ញុំ ៤៦តើមាន
ពួកអ្នករាល់គ្នាណាមួយចាប់ប្រកាន់ខ្ញុំ ពីអំពើបាបបានឬទេ
តែបើខ្ញុំនិយាយសេចក្តីពិតវិញ ហេតុអ្វីបានជា មិនជឿដល់
ខ្ញុំសោះ ៤៧អ្នកណាដែលកើតអំពីព្រះ នោះក៏ស្តាប់តាមព្រះ
បន្ទូលនៃព្រះដែរ[ឆ] ឯអ្នករាល់គ្នា មិនបានកើតមកពីព្រះទេ
បានជាមិនស្តាប់តាមដូច្នេះ។

## ព្រះយេស៊ូវធ្វើបន្ទាល់អំពីអង្គទ្រង់

៤៨នោះពួកសាសន៍យូដា ទូលទ្រង់ថា តើយើងមិននិយាយ
ត្រូវថា អ្នកជាសាសន៍សាម៉ារី[ជ] ហើយមានអារក្សចូលទេឬអី[ឈ]
៤៩ព្រះយេស៊ូវទ្រង់ឆ្លើយថា ខ្ញុំគ្មានអារក្សចូលទេ ខ្ញុំគោរព
ប្រតិបត្តិចំពោះព្រះវរបិតាខ្ញុំ តែអ្នករាល់គ្នាត្មះតិះដៀលខ្ញុំវិញ
៥០ឯខ្ញុំ មិនមែនរកកិត្តិសព្ទ ចំពោះខ្លួនទេ[ញ] មានព្រះ១អង្គ
ដែលរកឱ្យខ្ញុំវិញ ហើយទ្រង់ក៏ជំនុំជំរះផង ៥១ប្រាកដមែន
ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នកណា កាន់តាមពាក្យខ្ញុំ
អ្នកនោះមិនត្រូវឃើញសេចក្តីស្លាប់ នៅអស់កល្បរៀងទៅ[ដ]។
៥២ដូច្នេះ ពួកសាសន៍យូដាទូលថា ឥឡូវនេះ យើងដឹងជា
ប្រាកដថា អ្នកមានអារក្សចូលពិតមែន[ឋ] ព្រោះលោកអ័ប្រាហាំ
នឹងពួកហោរា បានស្លាប់អស់ហើយ តែអ្នកថា បើអ្នកណាកាន់
តាមពាក្យអ្នក នោះមិនដែលភ្លក់សេចក្តីស្លាប់ នៅអស់កល្ប
រៀងទៅវិញ ៥៣តើអ្នកធំជាងលោកអ័ប្រាហាំ ជាព្ធយុកោ
យើង[ឌ] នឹងពួកហោរា ដែលស្លាប់ទៅហើយនោះឬអី តើអ្នក
តាំងខ្លួនធ្វើជាអ្វី ៥៤ព្រះយេស៊ូវមានបន្ទូលឆ្លើយថា បើសិនជា
ខ្ញុំដំកើងខ្លួនខ្ញុំ[ឍ] នោះកិត្តិសព្ទរបស់ខ្ញុំឥតមានប្រយោជន៍ទេ
គឺព្រះវរបិតាខ្ញុំទេតើ ទ្រង់លើកដំកើងខ្ញុំ ដែលអ្នករាល់គ្នាថា
ទ្រង់ជាព្រះនៃ អ្នក[ណ] ៥៥តែអ្នករាល់គ្នាមិនស្គាល់ទ្រង់ទេ[ត] ឯ
ខ្ញុំៗស្គាល់ទ្រង់[ថ] បើខ្ញុំថាមិនស្គាល់ទ្រង់វិញ នោះខ្ញុំនឹងទៅជា
អ្នកភូតភរដូចអ្នករាល់គ្នាដែរ ប៉ុន្តែខ្ញុំស្គាល់ទ្រង់ពិត ហើយ
ក៏កាន់តាមព្រះបន្ទូលទ្រង់ផង[ទ] ៥៦លោកអ័ប្រាហាំ ជាព្ធយុកោ
អ្នករាល់គ្នា[ធ] លោកបានត្រេកអរដោយឃើញគ្រាខ្ញុំ លោកក៏

**៨:៤២** ឡ ១យហ ៥:១ អ យហ ១៣:៣ ក យហ ៧:២៨ ខ យហ ៣:១៧ **៨:៤៤** គ ១យហ ៣:៨ ឃ ខ.៣៨,៤១ ង លប ៣:៤ ៤:៩ ២របា ១៨:២១ ទដ ៥:៦ ១២:២ **៨:៤៥** ច យហ ១៨:៣៧ **៨:៤៧** ឆ យហ ១៨:៣៧ ១យហ ៤:៦ **៨:៤៨** ជ មថ ១០:៥ ឈ ខ.៥២ មក ៣:២២ **៨:៥០** ញ ខ.៥៤ យហ ៥:៤១ **៨:៥១** ដ យហ ១១:២៦ **៨:៥២** ឋ ខ.៤៨ មក ៣:២២ **៨:៥៣** ឌ ខ.៣៩ យហ ៤:១២ **៨:៥៤** ឍ ខ.៥០ ណ យហ ១៦:១៤ ១៧:១,៥ **៨:៥៥** ត ខ.១៩ ថ យហ ៧:២៨,២៩ ទ យហ ១៥:១០ **៨:៥៦** ធ ខ.៣៧,៣៩ លប ១៨:១៨ ន មថ ១៣:១៧

**៨:៤២–៤៣** ពួកសាសន៍យូដានិយាយថា ពួកគេមានព្រះវរបិតាតែ១ គឺជាព្រះ (ខ.៤១)។ ប៉ុន្តែ ព្រះយេស៊ូវមានបន្ទូលទៅពួកគេថា បើព្រះជាព្រះវរបិតារបស់ពួកគេមែន នោះពួកគេពិតជាទទួលទ្រង់ហើយ ។

**៨:៤៤** *អ្នករាល់គ្នាមានអារក្សសាតាំងជាឪពុក* ត្រង់ចំណុចនេះ ព្រះយេស៊ូវទ្រង់ព្រមានដល់ពួកសាសន៍យូដាដែលប្រឆាំងនឹងទ្រង់ ចំពោះទង្វើរបស់ពួកគេថាបានទទួលឥទ្ធិពលពីអារក្សសាតាំងដែលជាមេបះបោរ ជាអ្នកប្រឆាំង និងជាអ្នកសម្លាប់គេតាំងតែពីដើមមក ។ ម្យ៉ាងទៀត ព្រះហឫទ័យទ្រង់គឺ ឱ្យពួកសាសន៍យូដា និងពួកសាសន៍ដទៃបានយកលោកអ័ប្រាហាំជាគំរូ (ខ.៣៩–៤០ រម ៤:១៦)។

**៨:៤៦** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ពួកសាសន៍យូដាមិនអាចរកកំហុសរបស់ព្រះយេស៊ូវបានឡើយ ពីព្រោះទ្រង់មិនដែលប្រព្រឹត្តបាបទាល់តែសោះ (ហព ៤:១៥ ១យហ ៣:៥)។

**៨:៤៧** *ស្តាប់តាមព្រះបន្ទូលនៃព្រះ* ឃ្លានេះបញ្ជាក់ថា អស់អ្នកណាដែលកើតមកពីព្រះអម្ចាស់ នោះនឹងស្តាប់តាមព្រះបន្ទូលរបស់ទ្រង់ ។ រីឯអស់អ្នកដែលមិនកើតមកពីព្រះអម្ចាស់ នោះពុំអាចយល់នូវព្រះបន្ទូលរបស់ទ្រង់ទេ (៨:២៣ ១កថ ២:១២,១៤ មើលការពន្យល់ ១០:៣–៤ ១យហ ៤:៦)។ អ្នកដែលទទួលជឿដល់ព្រះយេស៊ូវនោះ គឺត្រូវបានរាប់ជាសុចរិត ហើយទ្រង់ប្រទានឱ្យគេនូវជីវិតអស់កល្បជានិច្ច (យហ ៣:១៦–១៧)។

**៨:៤៨** *ពួកសាសន៍យូដា* "មើលការពន្យល់ ១:១៩"។ *សាសន៍សាម៉ារី* ត្រង់ចំណុចនេះ ប្រហែលជាពួកសាសន៍យូដាចង់បង្ហាញថា ព្រះយេស៊ូវមិនមានការយល់ដឹងអំពីក្រឹត្យវិន័យ ឬសេចក្តីផ្សេងៗទៀតរបស់ពួកគេទេ ។ ប៉ុន្តែ អ្វីដែលគួរតែកត់សំគាល់នោះគឺ នៅពេលពួកសាសន៍យូដានិយាយពាក្យថា "សាសន៍សាម៉ារី" ទៅកាន់អ្នកណាម្នាក់ គឺមានន័យថា ពួកគេកំពុងតែចាត់ទុកអ្នកនោះជាមនុស្សទាបថោក ។ ដូច្នេះ នៅពេលពួកសាសន៍យូដា ដែលប្រឆាំងនឹងព្រះយេស៊ូវ និយាយយ៉ាងដូច្នេះទៅកាន់ទ្រង់ បញ្ជាក់ថាពួកគេបានសំដែងនូវការបន្ទាបបន្ថោកដល់ទ្រង់តែម្តង ។ *មានអារក្សចូលទេឬអី?* "១០:២០ មើលការពន្យល់ ៧:២០"។

**៨:៥១** *ពាក្យខ្ញុំ* សំដៅលើព្រះបន្ទូល និងសេចក្តីបង្រៀនរបស់ព្រះយេស៊ូវ ដែលនាំមកនូវជីវិតដ៏ពិតប្រាកដ ។

**៨:៥២–៥៣** ត្រង់ចំណុចនេះ ពួកសាសន៍យូដាមានការយល់ខុសទាំងស្រុង ព្រោះថា លោកអ័ប្រាហាំ និងពួកហោរារបស់ព្រះអម្ចាស់ បានស្លាប់តែរូបកាយប៉ុណ្ណោះ រីឯព្រលឹងវិញ្ញាណរបស់ពួកគាត់មិនបានស្លាប់ទេ (មក ១២:២៦–២៧)។ ក្នុងព្រះគម្ពីរសញ្ញាចាស់បានបញ្ជាក់យ៉ាងច្បាស់ថា មានម្នាក់ដែលធំជាងលោកអ័ប្រាហាំ និងពួកហោរារបស់ព្រះអម្ចាស់ទៅទៀត (មើលការពន្យល់ ៦:៣០–៣៥)។

**៨:៥៦** *គ្រាខ្ញុំ* ត្រង់ចំណុចនេះប្រហែលជាសំដៅលើថ្ងៃដែលព្រះយេស៊ូវយាងមកសុគត ហើយរស់ឡើងវិញ ដើម្បីឱ្យមនុស្សលោកបានទទួលការសង្គ្រោះ ដោយសារសេចក្តីជំនឿលើព្រះនាមទ្រង់ (លប ១២:២–៣)។

បានឃើញមែន[ន] ហើយមានសេចក្ដីរីករាយ ៥៧ដូច្នេះ ពួក
សាសន៍យូដាទូលទ្រង់ថា អាយុអ្នកមិនទាន់ដល់ ៥០ឆ្នាំផង
ហើយអ្នកថា បានឃើញលោកអ័ប្រាហាំដែរឬ ៥៨ព្រះយេ
ស៊ូវទ្រង់មានបន្ទូលតបថា ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់
គ្នាជាប្រាកដថា មុនដែលលោកអ័ប្រាហាំកើតមក[ប] នោះមាន
ខ្ញុំហើយ[ផ] ៥៩ដូច្នេះ គេរើសថ្មនឹងចោលព្រះយេស៊ូវ[ព] តែទ្រង់
បានបំបាំងដល់គេ[ភ] រួចយាងកាត់កណ្ដាលពួកគេ ចេញពី
ព្រះវិហារផុតទៅ ។

## ព្រះយេស៊ូវទ្រង់ប្រោសបុរសខ្វាក់ពីកំណើតម្នាក់

**៩** ១លុះទ្រង់យាងហួសទៅ ក៏ទតឃើញមនុស្សម្នាក់ ដែល
ខ្វាក់ពីកំណើត ២ពួកសិស្សទូលសួរទ្រង់ថា លោកគ្រូ[ម] តើអ្នក
ណាបានធ្វើបាប[យ] មនុស្សនេះ[រ] ឬឪពុកម្ដាយរបស់គាត់[ល] បាន
ជាគាត់កើតមកខ្វាក់ដូច្នេះ ៣ព្រះយេស៊ូវមានបន្ទូលឆ្លើយថា
មិនមែនដោយព្រោះអ្នកនេះ ឬឪពុកម្ដាយគាត់បានធ្វើ
បាបទេ គឺដើម្បីឱ្យការរបស់ព្រះបានសំដែងមក ក្នុងខ្លួន
គាត់វិញ[វ] ៤កំពុងដែលថ្ងៃនៅភ្លឺនៅឡើយ[ស] នោះត្រូវតែ
ខ្ញុំធ្វើការរបស់ព្រះ ដែលចាត់ឱ្យខ្ញុំមក ដ្បិតយប់ដល់មក
នោះគ្មានអ្នកណាអាចនឹងធ្វើការ បានទេ ៥កាលខ្ញុំកំពុងតែ
នៅក្នុងលោកីយនៅឡើយ នោះខ្ញុំជាពន្លឺនៃលោកីយ[ហ] ៦លុះ
បន្ទូលសេចក្ដីទាំងនោះរួចហើយ ទ្រង់ក៏ស្ដោះ[ឡ]ដាក់នៅដី
ហើយយកទឹកព្រះឱស្ឋទ្រង់ធ្វើជាភក់ ទៅលាបភ្នែកនៃ
មនុស្សខ្វាក់នោះ ៧រួចមានបន្ទូលទៅគាត់ថា ចូរទៅលាង
ក្នុងស្រះស៊ីឡោមទៅ[អ] (ស៊ីឡោម គឺស្រាយថា ចាត់ឱ្យទៅ)
ដូច្នេះគាត់ក៏ទៅលាង ហើយត្រឡប់មកវិញ ទាំងមើលឃើញ[ក]
៨នោះពួកអ្នកជិតខាង នឹងពួកអ្នក ដែលពីដើមបានឃើញ
ថា គាត់ជាអ្នកសុំទាន គេនិយាយថា អ្នកនេះទេតើដែល
ធ្លាប់តែអង្គុយសុំទានគេ[ខ] ៩ខ្លះថា គឺអ្នកហ្នឹងហើយ ខ្លះទៀត
ថា គាត់ដូចជាអ្នកនោះទេ តែគាត់ឆ្លើយថា គឺខ្ញុំនេះឯង

**៨:៥៨** ប យហ ១:២ ផ នក ៣:១៤ ៦:៣ **៨:៥៩** ព នក ១៧:៤ លវ ២៤:១៦ ១សយ ៣០:៦ យហ ១០:៣១ ១១:៨ ភ យហ ១២:៣៦ **៩:២** ម មថ ២៣:៧ យ ខ.៣៤ លក ១៣:២ កច ២៨:៤ រ អគ ១៨:២០ ល នក ២០:៥ យប ២១:១៩ **៩:៣** វ យហ ១១:៤ **៩:៤** ស យហ ១១:៩ ១២:៣៥ **៩:៥** ហ យហ ១:៤ **៩:៦** ឡ មក ៧:៣៣ ៨:២៣ **៩:៧** អ ខ.១១ ២ពវ ៥:១០ លក ១៣:៤ ក អស ៣៥:៥ យហ ១១:៣៧ **៩:៨** ខ កច ៣:២,១០

**៨:៥៧** *អ្នកមិនទាន់ដល់៥០ឆ្នាំផង ហើយអ្នកថា បានឃើញលោកអ័ប្រាហាំដែរឬ?* ពួកសាសន៍យូដានិយាយយ៉ាងដូច្នេះ គឺដើម្បីចំអកដាក់ព្រះយេស៊ូវតែម្ដង ព្រោះថា នៅពេលនោះ ទ្រង់មានព្រះជន្មប្រហែលជា៣២ឆ្នាំប៉ុណ្ណោះ (មើលការពន្យល់ លក ៣:២៣)។

**៨:៥៨** *ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដ* ព្រះយេស៊ូវទ្រង់មានបន្ទូលយ៉ាងដូច្នេះ គឺដើម្បីបញ្ជាក់ និងអះអាងថា ព្រះបន្ទូលរបស់ទ្រង់គឺជាសេចក្ដីពិត (មក ៣:២៨)។ ម្យ៉ាងទៀត នៅក្នុងខនេះ ព្រះយេស៊ូវមានបន្ទូលយ៉ាងច្បាស់ថា ទ្រង់មានព្រះជន្មរស់តាំងពីអស់កល្បជានិច្ចមក គឺតាំងពីមុនពេលដែលលោកអ័ប្រាហាំបានកើតមកម្ល៉េះ ។

**៨:៥៩** *គេរើសថ្មនឹងចោលព្រះយេស៊ូវ* នៅពេលនោះពួកសាសន៍យូដាបានដឹងថា ព្រះយេស៊ូវប្រកាសអង្គទ្រង់ថាជាព្រះ ទើបបានជាពួកគេនាំគ្នារើសថ្មដើម្បីចោលសម្លាប់ទ្រង់ ។ ពួកគេធ្វើដូច្នេះ ព្រោះថា តាមក្រឹត្យវិន័យរបស់ពួកគេ គឺត្រូវតែសម្លាប់ដោយចោលនឹងថ្ម ចំពោះអ្នកដែលប្រមាថដល់ព្រះ (លវ ២៤:១៦)។

**៩:១-១២** ក្នុងវគ្គនេះព្រះយេស៊ូវទ្រង់សំដែងការអស្ចារ្យជាច្រើន ។ ការដែលទ្រង់ប្រោសមនុស្សខ្វាក់ឱ្យបានភ្លឺ គឺស្របនឹងសេចក្ដីទំនាយ ដែលចែងទុកមកថា ទ្រង់គឺជាព្រះមែស៊ី (អស ២៩:១៨ ៣៥:៥ មើលការពន្យល់ ៤២:៧)។ ការអស្ចារ្យទាំងឡាយ ដែលព្រះយេស៊ូវទ្រង់ធ្វើ គឺជាភស្តុតាងបញ្ជាក់ថា ទ្រង់គឺជាព្រះមែស៊ី ដែលត្រូវយាងមកយ៉ាងពិតប្រាកដ (មើលការពន្យល់ ២០:៣១)។

**៩:២** *តើអ្នកណាបានធ្វើបាប ?* ពួកសិស្សរបស់ព្រះយេស៊ូវបានសួរទ្រង់យ៉ាងដូច្នេះ ព្រោះពួកគេធ្លាប់បានឮសេចក្ដីបង្រៀន របស់ពួកគ្រូក្រឹត្យវិន័យសាសន៍យូដាថា ការដែលមនុស្សស្លាប់គឺមកពីអំពើបាប ហើយទុក្ខវេទនាទាំងឡាយ គឺកើតឡើងដោយសារតែអំពើទុច្ចរិតដែលគេប្រព្រឹត្ត ។ ពួកគ្រូក្រឹត្យវិន័យរបស់សាសន៍យូដាយល់ថា មនុស្សម្នាក់ៗសុទ្ធតែបានប្រព្រឹត្តអំពើបាប ឬព្រលឹងវិញ្ញាណរបស់គេបានប្រព្រឹត្តអំពើបាប តាំងពីមុនពេលចាប់កំណើត នៅក្នុងផ្ទៃម្ដាយមកម្ល៉េះ ។ ពួកគ្រូទាំងនោះយល់ទៀតថា ទុក្ខវេទនាដែលមនុស្សម្នាក់ៗមាន គឺកើតឡើងដោយសារតែអំពើបាបរបស់ឪពុកម្ដាយគេ ។ ប៉ុន្តែ ព្រះយេស៊ូវមានបន្ទូលបដិសេធទាំងស្រុង ចំពោះសេចក្ដីបង្រៀនរបស់ពួកគ្រូក្រឹត្យវិន័យសាសន៍យូដាទាំងនោះ ។

**៩:៣** *ដើម្បីឱ្យការរបស់ព្រះ បានសំដែងមក* ឃ្លានេះបញ្ជាក់ថា ពេលខ្លះមានទុក្ខវេទនាបានកើតឡើង ហើយក្នុងពេលជាមួយគ្នានោះ ការអស្ចារ្យរបស់ព្រះអម្ចាស់ក៏បានសំដែងឡើងផងដែរ (ខ.៤០ ១១:៤)។

**៩:៤** *នោះត្រូវតែខ្ញុំធ្វើការរបស់ព្រះ* ឃ្លានេះ ព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសខ្លះ សរសេរថា "នោះត្រូវតែយើងធ្វើការរបស់ព្រះ"។ មានន័យថា ព្រះយេស៊ូវបានរាប់បញ្ចូលទាំងពួកសិស្ស និងពួកអ្នកដែលជឿលើព្រះនាមទ្រង់ទាំងអស់ផងដែរ នៅក្នុងមហាបេសកកម្មរបស់ទ្រង់នៅលើផែនដីនេះ ។ *ដ្បិតយប់ដល់មក* ព្រះយេស៊ូវជាពន្លឺ សម្រាប់លោកិយនេះ (ខ.៥) ហើយនៅពេលដែលទ្រង់មានបន្ទូលយ៉ាងដូច្នេះ ទៅកាន់ពួកសិស្សរបស់ទ្រង់ ប្រហែលជាសំដៅលើការសុគតរបស់ទ្រង់ ដែលប្រៀបបានទៅនឹងយប់ដែលត្រូវមកដល់ ។

**៩:៥** *ខ្ញុំជាពន្លឺនៃលោកិយ* "មើលការពន្យល់ ៨:១២"។

**៩:៦** បទគម្ពីរនេះបញ្ជាក់ថា ព្រះយេស៊ូវមានរបៀបច្រើនយ៉ាង ក្នុងការប្រោសមនុស្សឱ្យបានជាពីជំងឺ ។ ម្យ៉ាងទៀត ទ្រង់មានអំណាចព្រះចេស្ដា ធ្វើឱ្យអ្វីៗទាំងអស់ ដែលទ្រង់បង្កើតមក បានល្អប្រសើរឡើងវិញ (មក ៨:២២-២៥)។

**៩:៧** *ស្រះស៊ីឡោម* ស្រះនេះស្ថិតនៅក្នុងក្រុងយេរូសាឡិមភាគខាងត្បូង ត្រង់ចំណុចចុងបំផុតនៃប្រព័ន្ធធារាសាស្ត្រមួយ ដែលបានកសាងឡើង នៅសម័យកាលស្ដេចហេសេគា (២ពវ ២០:២០ នហ ២:១៤ យប ២៨:១០ អស ៨:៦)។

**៩:៨** *សុំទានគេ* បញ្ជាក់ថា អ្នកសុំទានភាគច្រើន នៅសម័យនោះ ចិញ្ចឹមជីវិតដោយសារការសុំទានគេ ។

១០គេសួរថា ធ្វើដូចម្ដេចបានជាភ្នែកឯងបានភ្លឺដូច្នេះ
១១គាត់ឆ្លើយថា មានម្នាក់ឈ្មោះ យេស៊ូវ បានធ្វើភក់មក
លាបភ្នែកខ្ញុំ រួចប្រាប់ឱ្យទៅលាងនៅស្រះស៊ីឡោម ខ្ញុំក៏
ទៅលាង ហើយបានភ្លឺឡើង[គ] ១២គេសួរទៀតថា
អ្នកនោះនៅឯណា គាត់ឆ្លើយថាខ្ញុំមិនដឹងទេ។

## ពួកផារិស៊ីសង្កេតមើលការប្រោសជំងឺរបស់ព្រះយេស៊ូវ

១៣គេក៏នាំមនុស្សដែលពីដើមខ្វាក់នោះ ទៅឯពួកផារិស៊ី
១៤រីឯថ្ងៃ ដែលព្រះយេស៊ូវទ្រង់ធ្វើភក់ ប្រោសឱ្យគាត់ភ្លឺ
ភ្នែកនោះ គឺជាថ្ងៃឈប់សំរាក[ឃ] ១៥ដូច្នេះ ពួកផារិស៊ីក៏សួរ
គាត់ ពីដំណើរដែលបានភ្លឺភ្នែកជាយ៉ាងដូចម្ដេចដែរ[ង]
នោះគាត់ជំរាបថា លោកយកភក់មកលាបភ្នែកខ្ញុំ រួចខ្ញុំ
ទៅលាង ហើយក៏មើលឃើញ ១៦ដូច្នេះ ពួកផារិស៊ីខ្លះ
និយាយថា មនុស្សនោះមិនមែនមកពីព្រះទេ ព្រោះមិន
កាន់ថ្ងៃឈប់សំរាកសោះ[ច] ខ្លះទៀតថា ធ្វើដូចម្ដេចឱ្យ
មនុស្សមានបាបអាចធ្វើទីសំគាល់យ៉ាងនេះបាន[ឆ] នោះក៏
កើតបាក់បែកគ្នា[ជ] ១៧រួចគេសួរមនុស្សខ្វាក់ម្ដងទៀត
ថា តើឯងថាដូចម្ដេច ពីដំណើរអ្នកដែលធ្វើឱ្យភ្នែកឯង
ភ្លឺនោះ គាត់ឆ្លើយថា លោកជាហោរា[ឈ] ១៨តែពួកសាសន៍
យូដា[ញ]មិនជឿថា គាត់ខ្វាក់ភ្នែក ហើយបានភ្លឺឡើងវិញទេ
ទាល់តែបានហៅឪពុកម្ដាយរបស់អ្នក ដែលបានភ្លឺភ្នែក
នោះមក សួរថា ១៩តើអ្នកនេះជាកូនរបស់អ្នក ដែលអ្នកថា
បានកើតមកខ្វាក់នោះឬអី ចុះឥឡូវនេះ ធ្វើដូចម្ដេចបាន
ជាវាភ្លឺឡើងវិញ ២០ឪពុកម្ដាយគាត់ឆ្លើយថា យើងខ្ញុំដឹង
ថា នេះជាកូនយើងខ្ញុំពិត ហើយថា វាកើតមកខ្វាក់មែន
២១តែឥឡូវនេះ ដែលវាភ្លឺជាយ៉ាងដូចម្ដេច នោះយើងខ្ញុំមិន
ដឹងទេ ក៏មិនដឹងជាអ្នកណាបានធ្វើឱ្យភ្លឺផងដែរ វាពេញ
អាយុហើយ សូមសួរវាចុះ វានឹងជំរាបពីដំណើរខ្លួនវា
២២ឪពុកម្ដាយគាត់និយាយដូច្នេះ ព្រោះខ្លាចសាសន៍យូដា[ដ]
ដ្បិតពួកសាសន៍យូដាបានព្រមព្រៀងគ្នាហើយ ថាបើអ្នកណា
នឹងទទួលទ្រង់ទុកជាព្រះគ្រីស្ទ នោះត្រូវកាត់[ឋ]ពីពួកជំនុំគេ
ចេញ[ឌ] ២៣ហេតុនោះបានជាឪពុកម្ដាយគាត់និយាយថា
វាពេញអាយុហើយ សូមសួរវាចុះ[ឍ] ២៤គេក៏ហៅមនុស្ស
ដែលពីដើមខ្វាក់នោះ មកម្ដងទៀតប្រាប់ថា ចូរសរសើរដំ
កើងដល់ព្រះវិញ[ណ] ឯមនុស្សនោះ យើងដឹងថាជាអ្នកមានបាប
ទេ[ត] ២៥គាត់ឆ្លើយទៅថា បើលោកជាមនុស្សមានបាប នោះ
ខ្ញុំមិនដឹងទេ ខ្ញុំដឹងតែប៉ុណ្ណោះថា ពីដើមខ្ញុំខ្វាក់ តែឥឡូវនេះខ្ញុំ
មើលឃើញ ២៦នោះគេសួរគាត់ម្ដងទៀតថា អ្នកនោះបាន
ធ្វើអ្វីដល់ ឯង តើបានធ្វើដូចម្ដេចខ្លះ ឱ្យភ្នែកឯងបានភ្លឺឡើង
២៧គាត់ឆ្លើយថា ខ្ញុំបានជំរាបហើយ[ថ] តែលោកមិនស្ដាប់
ហេតុអ្វីបានជាចង់ស្ដាប់ម្ដងទៀត តើលោកចង់ធ្វើជាសិស្ស
របស់លោកនោះដែរឬអី ២៨នោះគេជេរប្រមាថគាត់ថា គឺ

**៩:១១** គ ខ.៧
**៩:១៤** ឃ មថ ១២:១-១៤ យហ ៥:៩
**៩:១៥** ង ខ.១០
**៩:១៦** ច មថ ១២:២ ឆ យហ ២:១១ ជ យហ ៦:៥២
**៩:១៧** ឈ មថ ២១:១១
**៩:១៨** ញ យហ ១:១៩
**៩:២២** ដ យហ ៧:១៣ ឋ ខ.៣៤ លក ៦:២២ ឌ យហ ១២:៤២ ១៦:២
**៩:២៣** ឍ ខ.២១
**៩:២៤** ណ យស ៧:១៩ ត ខ.១៦
**៩:២៧** ថ ខ.១៥

**៩:១៣** *ពួកផារិស៊ី* "មើលការពន្យល់ ៧:៣២"។

**៩:១៤** *ថ្ងៃឈប់សំរាក* សំដៅលើថ្ងៃទី៧នៃសប្ដាហ៍ (ថ្ងៃសៅរ៍)។ ពួកផារិស៊ីបានចោទប្រកាន់ព្រះយេស៊ូវថា បានប្រឆាំងនឹងក្រឹត្យវិន័យ ព្រោះទ្រង់បានប្រោសមនុស្សមានជំងឺឱ្យបានជា នៅថ្ងៃឈប់សម្រាក (មើលការពន្យល់ ៥:១០)។

**៩:១៦** ត្រង់ចំណុចនេះ មានពួកផារិស៊ីពីរក្រុម ដែលមានការយល់ឃើញផ្សេងគ្នា ។ ក្រុមទីមួយយល់ថា ការដែលព្រះយេស៊ូវប្រោសមនុស្សខ្វាក់ពីកំណើតឱ្យបានជានោះ គឺមកពីព្រះ ។ រីឯក្រុមទីពីរវិញគិតថា ការអស្ចារ្យដែលព្រះយេស៊ូវទ្រង់ធ្វើពុំមែនមកពីព្រះទេ ពីព្រោះតែទ្រង់បានធ្វើការនោះ នៅថ្ងៃឈប់សម្រាក (មើលការពន្យល់ ខ.៣០–៣៣)។

**៩:១៧** *តើឯងថាដូចម្ដេច ពីដំណើរអ្នកដែលធ្វើឱ្យភ្នែកឯងភ្លឺនោះ?* សំណួរដែលពួកផារិស៊ីសួរទៅបុរសដែលបានភ្លឺភ្នែកនោះ មានលក្ខណៈគំរាមកំហែងលើរូបគាត់ទាំងស្រុង ។ ការដែលពួកគេសួរគាត់យ៉ាងដូច្នេះ គឺក្នុងគោលបំណងចង់ឱ្យគាត់ឆ្លើយ នូវចម្លើយអវិជ្ជមាន អំពីព្រះយេស៊ូវតែម្ដង ។ ចម្លើយរបស់បុរសនោះ បានសំដែងអំពីសេចក្ដីជំនឿរបស់គាត់ លើទ្រង់កាន់តែខ្លាំងឡើង ដោយយោងតាមលក្ខណៈពាក្យពេចន៍ដែលគាត់ប្រើ (ខ.១១,១៧,២៧,៣៣,៣៨)។

**៩:១៨** *ពួកសាសន៍យូដា* "មើលការពន្យល់ ១:១៩"។ ត្រង់ចំណុចនេះ ពួកសាសន៍យូដាមិនព្រមជឿលើទីសំគាល់នៃការអស្ចារ្យ ដែលព្រះអម្ចាស់ទ្រង់ធ្វើទេ ប៉ុន្តែ ផ្ទុយទៅវិញ ពួកគេបែរជាព្យាយាមប្រឆាំងនឹងទ្រង់វិញ ។

**៨:២១** ក្នុងបទគម្ពីរនេះ បញ្ជាក់ថា ឪពុកម្ដាយរបស់បុរសដែលបានភ្លឺភ្នែកនោះ មានការភ័យខ្លាច ចំពោះពួកផារិស៊ី ដូច្នោះ បានជាពួកគាត់ មិនហ៊ានឆ្លើយដោយត្រង់ៗទេ ។

**៩:២២** *នោះត្រូវកាត់ពីពួកជំនុំគេចេញ* សេចក្ដីនេះមានចែងនៅក្នុងកណ្ឌព្រះគម្ពីរអែសរ៉ា (១០:៨) ប៉ុន្តែ ពុំបានបញ្ជាក់ថា មានអនុវត្តក្នុងសម័យកាលសញ្ញាថ្មីទេ ។ ប្រសិនបើពួកសាសន៍យូដាណា ត្រូវកាត់ចេញពីពួកជំនុំរបស់ខ្លួននោះគឺមានន័យថា គេលែងមានទំនាក់ទំនងជាមួយសហគមន៍របស់ពួកសាសន៍យូដាទៀតហើយ ។

**៩:២៤** *យើងដឹងថាជាអ្នកមានបាបទេ* ពួកសាសន៍យូដាដឹងថា ព្រះយេស៊ូវបានធ្វើការអស្ចារ្យនៅថ្ងៃឈប់សម្រាក ដូច្នោះហើយបានជាពួកគេនិយាយថាទ្រង់ជាអ្នក មានបាប ។

**៩:២៧** *លោកចង់ធ្វើជាសិស្សរបស់លោកនោះដែរឬអី?* បុរសដែលបានភ្លឺភ្នែក នោះនិយាយយ៉ាងដូច្នេះ បញ្ជាក់ថា គាត់បានរាប់ខ្លួនគាត់ជាសិស្សរបស់ព្រះយេស៊ូវរួចទៅហើយ ។

ឯងជាសិស្សអ្នកនោះហើយ ឯយើង ជាសិស្សរបស់លោកម៉ូ
សេវិញ[ទ] ២៩យើងដឹងថា ព្រះបានមានបន្ទូលនឹងលោកម៉ូសេ
ពិត តែអ្នកនោះ យើងមិនដឹង ជាមកពីណាទេ[ធ] ៣០មនុស្សនោះ
ឆ្លើយថា នេះចំឡែកណាស់មែន លោករាល់គ្នាមិនដឹងជា
លោកនោះមកពីណា ដែលលោកបានធ្វើឱ្យភ្នែកខ្ញុំភ្លឺផង
៣១យើងខ្ញុំដឹងថា ព្រះមិនស្ដាប់តាមមនុស្សមានបាបទេ ប៉ុន្តែ
បើអ្នកណាកោតខ្លាចដល់ព្រះ ហើយប្រព្រឹត្តតាមព្រះហឫទ័យ
ទ្រង់ ទើបទ្រង់នឹងស្ដាប់តាមអ្នកនោះឯង[ន] ៣២ចាប់តាំងពីអស់
កល្បរៀងមក មិនដែលឮនិយាយពីអ្នកណាដែលធ្វើឱ្យភ្នែក
មនុស្សខ្វាក់ពីកំណើតបានភ្លឺទេ ៣៣បើលោកនោះមិនមែន
មកពីព្រះទេ[ប] នោះលោកពុំអាចនឹងធ្វើអ្វីបាន ឡើយ ៣៤គេ
ឆ្លើយតបទៅគាត់ថា ឯងជាមនុស្សកើតមកក្នុង អំពើបាប
សុទ្ធ[ផ] ហើយឯងបង្រៀនយើងឬ រួចគេបណ្ដេញ គាត់ទៅ[ព]។

## ការខ្វាក់ខាងឯវិញ្ញាណ

៣៥ព្រះយេស៊ូវទ្រង់ឮថា គេបានបណ្ដេញគាត់ហើយ រួច
កាលទ្រង់បានឃើញគាត់ នោះក៏មានបន្ទូលទៅថា តើអ្នក
ជឿ[ភ]ដល់ព្រះរាជបុត្រានៃព្រះឬទេ[ម] ៣៦គាត់ទូលឆ្លើយថា
លោកម្ចាស់អើយ តើអ្នកណាជាព្រះរាជបុត្រានោះ ដើម្បី
ឱ្យខ្ញុំបានជឿដល់ទ្រង់ផង[យ] ៣៧ព្រះយេស៊ូវមានបន្ទូលទៅ
គាត់ថា អ្នកបានឃើញទ្រង់ហើយ គឺជាខ្ញុំដែលនិយាយនឹង
អ្នកនេះឯង[រ] ៣៨គាត់ទូលថា ខ្ញុំជឿហើយ ព្រះអម្ចាស់អើយ
រួចគាត់ក៏ក្រាបថ្វាយបង្គំទ្រង់[ល]។

៣៩ព្រះយេស៊ូវ មានបន្ទូលថា ខ្ញុំបានមកក្នុងលោកីយនេះ
ដើម្បីនឹងជំនុំជំរះ[វ] ឱ្យពួកអ្នកដែលមើលមិនឃើញ បានភ្លឺ
ឡើង[ស] ហើយឱ្យពួកអ្នកដែលមើលឃើញ[ហ] បានទៅជាខ្វាក់
វិញ[ឡ] ៤០ពួកផារិស៊ី ដែលនៅជាមួយនឹងទ្រង់ បានឮពាក្យ
នោះ ក៏ទូលសួរថា តើយើងខ្ញុំខ្វាក់ដែរឬអី[អ] ៤១ព្រះយេស៊ូវ
មានបន្ទូលទៅគេថា បើសិនជាអ្នករាល់គ្នាខ្វាក់មែន នោះ
អ្នករាល់គ្នាឥតមានបាបទេ តែឥឡូវនេះ អ្នករាល់គ្នាអាង
ថាភ្លឺ បានជាជាប់មានបាបនៅឡើយ[ក]។

## អ្នកគង្វាលចៀម និងចៀម

**១០** ១ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នក
ណា ដែលចូលទៅក្នុងក្រោលចៀម មិនមែនតាមទ្វារ
គឺឡើងចូលតាមកន្លែងណាឯទៀតវិញ អ្នកនោះឈ្មោះថា

**៩:២៨** ទ យហ ៥:៤៥ **៩:២៩** ធ យហ ៨:១៤ **៩:៣១** ន លប ១៨:២៣–៣២ ទដ ៣៤:១៥,១៦ ៦៦:១៨ ១៤៥:១៩,២០ សភ ១៥:២៩ អស ១:១៥ ៥៩:១,២ យហ ១៥:៧ យក ៥:១៦–១៨ ១យហ ៥:១៤,១៥ **៩:៣៣** ប ខ.១៦ យហ ៣:២ **៩:៣៤** ផ ខ.២ ព ខ.២២,៣៥ អស ៦៦:៥ **៩:៣៥** ភ យហ ៣:១៥ ម មថ ៨:២០ **៩:៣៦** យ រម ១០:១៤ **៩:៣៧** រ យហ ៤:២៦ **៩:៣៨** ល មថ ២៨:៩ **៩:៣៩** វ យហ ៥:២២ ស យហ ៣:១៩ ១២:៤៧ ហ លក ៤:១៨ ឡ មថ ១៣:១៣ **៩:៤០** អ រម ២:១៩ **៩:៤១** ក យហ ១៥:២២,២៤

**៩:៣០–៣៣** ត្រង់ចំណុចនេះ បញ្ជាក់យ៉ាងច្បាស់ថា ទោះជាមនុស្សពុំមានការសិក្សាជ្រៅជ្រះក៏ដោយ ក៏ព្រះអម្ចាស់ទ្រង់ប្រទានឱ្យគេ នូវប្រាជ្ញាក្នុងការបម្រើទ្រង់ ប្រកបដោយជោគជ័យដែរ ។

**៩:៣១** បទគម្ពីរនេះ បញ្ជាក់ថា ព្រះអម្ចាស់ទ្រង់ស្ដាប់នូវសេចក្ដីអធិស្ឋាននៃពួកអ្នកដែលធ្វើតាមព្រះហឫទ័យទ្រង់ ។

**៩:៣៤** *រួចគេបណ្ដេញគាត់ទៅ* មានន័យថា ពេលដែលពួកសាសន៍យូដាទាំងនោះបានដឹងថា បុរសដែលបានភ្លឺភ្នែកនោះ ជឿលើសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវ ក៏បណ្ដេញគាត់ចេញពីពួកជំនុំ និងកាត់គាត់ចេញពីសហគមន៍របស់ពួកគេទៀតផង (មើលការពន្យល់ ខ.២២ ១កថ ៥:៥)។

**៩:៣៥** *រួចកាលទ្រង់បានឃើញគាត់* ឃ្លានេះបញ្ជាក់ថា ក្នុងពេលនោះព្រះយេស៊ូវក៏កំពុងតែរកមើលបុរសនោះដែរ ។ *ព្រះរាជបុត្រានៃព្រះ* ព្រះយេស៊ូវមានបន្ទូលនូវពាក្យនេះ គឺសំដៅលើព្រះអង្គទ្រង់ផ្ទាល់ (មើលការពន្យល់ មក ៨:៣១)។

**៩:៣៦** បទគម្ពីរនេះបញ្ជាក់ថា បុរសដែលព្រះយេស៊ូវបានប្រោសឱ្យជានោះគាត់ត្រៀមខ្លួនជាស្រេច ដើម្បីទទួលយកព្រះបន្ទូលទ្រង់ ។

**៩:៣៨** *ខ្ញុំជឿ* "មើលការពន្យល់ ១:៧ ២០:៣១"។ *រួចគាត់ក៏ក្រាបថ្វាយបង្គំទ្រង់* បញ្ជាក់ថា បុរសនោះព្រមទទួលជឿដល់ព្រះយេស៊ូវថាទ្រង់គឺជាព្រះមែស៊ីដែលត្រូវយាងមកសង្គ្រោះមនុស្សលោកពិតមែន ។

**៩:៣៩** ហេតុការណ៍ដែលកើតឡើងនៅក្នុង "ខ.៣៥–៣៨" ហាក់ដូចជាបានកើតឡើងនៅក្នុងចំណោមពួកផារិស៊ី ។ រីឯហេតុការណ៍នៅក្នុង "ខ.៣៩–៤១" ប្រហែលជា បានកើតឡើងក្រោយហេតុការណ៍នៅក្នុង "ខ.៣៥–៣៨" នោះបន្តិច ។ *ដើម្បីនឹងជំនុំជំរះ* ត្រង់ចំណុចនេះ អត្ថន័យនៅក្នុងព្រះគម្ពីរទាំងមូលបញ្ជាក់ថា ការយាងមករបស់ព្រះយេស៊ូវនៅពេលនោះមិនមែនដើម្បីជំនុំជម្រះមនុស្សលោកទេ (មើលការពន្យល់ ៣:១៧ ១២:៤៧)។

**៩:៤០** *តើយើងខ្ញុំខ្វាក់ដែរឬអី?* បញ្ជាក់ថា ពួកផារិស៊ីតែងតែគិតថាខ្លួនជាអ្នកនាំផ្លូវ និងជាអ្នកដឹកនាំដល់ពួកបណ្ដាជន ។ ដូច្នេះ នៅពេលដែលពួកគេបានឮសេចក្ដីដែលព្រះយេស៊ូវមានបន្ទូលនៅក្នុង "ខ.៣៩" នោះក៏សួរទ្រង់នូវសំណួរនេះតែម្ដង (មើលការពន្យល់ ខ.១៣)។

**៩:៤១** បទគម្ពីរនេះបញ្ជាក់ថា ពួកផារិស៊ីមានភ្នែកភ្លឺមែន ប៉ុន្តែពួកគេខ្វាក់ខាងឯវិញ្ញាណ ព្រោះពួកគេមិនមានសេចក្ដីពិតរបស់ព្រះអម្ចាស់ទេ ។

**១០:១–៣០** ត្រង់ចំណុចនេះ ច្រើននិយាយអំពីភាពជាអ្នកគង្វាល ដែលនៅសម័យកាលសញ្ញាចាស់ សំដៅលើអ្នកដែលថែរក្សាការពារ និងដឹកនាំប្រជារាស្ត្ររបស់ព្រះអម្ចាស់ ។ ព្រះអម្ចាស់ទ្រង់ជាអ្នកគង្វាលដ៏ពិតប្រាកដរបស់ពួកអ៊ីស្រាអែល (ទដ ២៣:១ ៨០:១ អស ៤០:១០–១១ អគ ៣៤:២,១១–១៦ សក ១០:២)។ ទ្រង់បាន ប្រទានតួនាទីជាអ្នកគង្វាលនេះ ទៅពួកអ្នកដឹកនាំរបស់អ៊ីស្រាអែល ប៉ុន្តែពួកគេមិនបានប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួនទេ ។ ដូច្នេះហើយ បានជាព្រះអម្ចាស់មានបន្ទូលថា ពួកគេជាអ្នកគង្វាលមិនល្អ (អស ៥៦:៩–១២ អគ ៣៤) ហើយទ្រង់បានសន្យាថា នឹង ប្រទានមកពួកគេនូវអ្នកគង្វាលដ៏ពិតប្រាកដ គឺជាព្រះមែស៊ី ដើម្បីថែរក្សាការពារនិងដឹកនាំពួកគេ (អគ ៣៤:២៣)។

**១០:១** *ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដ* "មើលការពន្យល់ មក ៣:២៨"។ *ចោរលួច ចោរប្លន់* បញ្ជាក់ថា ពេលដែលពួកអ្នកដឹកនាំសាសន៍យូដា ដែលមាន

ជាចោរលួច ចោរប្លន់ហើយ[ខ] ២ឯអ្នកដែលចូលតាមទ្វារ
នោះជាអ្នកគង្វាលចៀមពិត[គ] ៣អ្នកឆ្មាំទ្វារ ក៏បើកឱ្យអ្នក
នោះ ហើយហ្វូងចៀមស្តាប់តាមសំឡេងគាត់ដែរ[ឃ] ឯចៀម
របស់គាត់ នោះគាត់ហៅតាមឈ្មោះវានិមួយៗ នាំចេញ
ទៅក្រៅ[ង] ៤កាលបានបញ្ចេញចៀមខ្លួន ទៅក្រៅអស់ហើយ
នោះគាត់ដើរមុនវា ហើយចៀមក៏ដើរ តាមក្រោយទៅ
ដ្បិតវាស្គាល់សំឡេងគាត់[ច] ៥វាមិនព្រមតាមមនុស្សដទៃទេ
វានឹងរត់ចេញពីគេវិញ ពីព្រោះវាមិនស្គាល់សំឡេងរបស់
មនុស្សដទៃណាសោះ ៦ព្រះយេស៊ូវទ្រង់មានបន្ទូលពាក្យ
ប្រៀបប្រដូចនេះទៅគេ[ឆ] តែគេមិនដឹងជាទ្រង់មានបន្ទូលពី
ដំណើរអ្វីទេ[ជ]។
៧ដូច្នេះ ព្រះយេស៊ូវទ្រង់មានបន្ទូលទៅគេម្តងទៀតថា
ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ខ្ញុំជា[ឈ]ទ្វារ[ញ]
ចៀម ៨អស់អ្នកដែលមកមុនខ្ញុំ[ដ] នោះសុទ្ធតែជាចោរលួច
ចោរប្លន់ទេ[ឋ] តែចៀមមិនបានស្តាប់តាមអ្នកទាំងនោះឡើយ
៩ខ្ញុំជាទ្វារ បើអ្នកណាចូលតាមខ្ញុំ នោះនឹងបានសង្គ្រោះ រួច
នឹងចេញចូល ហើយនឹងរកបានវាលស្មៅដ៏ស្រួល ១០ឯចោរ
វាមកប្រយោជន៍តែនឹងលួច សំឡាប់ ហើយបំផ្លាញប៉ុណ្ណោះ
តែឯខ្ញុំវិញ ខ្ញុំបានមកដើម្បីឱ្យវារាល់គ្នាមានជីវិត[ឌ] ហើយ
ឱ្យមានជីវិតនោះពេញបរិបូរផង[ឍ]។
១១ខ្ញុំជា[ណ]អ្នកគង្វាលល្អ[ត]ឯអ្នកគង្វាលល្អ ក៏ស៊ូតែប្តូរជីវិត
ជំនួសចៀម[ថ] ១២តែអ្នកស៊ីឈ្នួល ដែលមិនមែនជាអ្នកគង្វាល
ពិត ហើយចៀមក៏មិនមែនជារបស់ផងវា លុះវាឃើញឆ្កែ
ព្រៃមក ក៏រត់ចេញចោលចៀម[ទ] នោះឆ្កែព្រៃឆក់យកទៅ
ទាំងដេញកំចាត់កំចាយហ្វូងចៀមផង ១៣អ្នកស៊ីឈ្នួលនោះ
រត់ទៅ ពីព្រោះវាគ្រាន់តែ ស៊ីឈ្នួលប៉ុណ្ណោះ វាមិនយកចិត្ត
ទុកដាក់នឹងចៀមឡើយ។
១៤ឯខ្ញុំជាអ្នកគង្វាលល្អ[ធ]ខ្ញុំស្គាល់ចៀមរបស់ខ្ញុំ ហើយ
ចៀមក៏ស្គាល់ខ្ញុំ[ន] ១៥ដូចជាព្រះវរបិតា ទ្រង់ស្គាល់ខ្ញុំ ហើយខ្ញុំ
ក៏ស្គាល់ទ្រង់ដែរ[ប] ខ្ញុំស៊ូប្តូរជីវិតខ្ញុំនឹងចៀម[ផ] ១៦ខ្ញុំក៏មានចៀម
ឯទៀត[ព] ដែលមិនទាន់នៅក្នុងក្រោលនេះនៅឡើយ ត្រូវតែ

**១០:១** ខ ខ.៨,១០ **១០:២** គ ខ.១១,១៤ មក ៦:៣៤ **១០:៣** ឃ ខ.៤,៥,១៤, ១៦,២៧ ង ខ.៤, ៥, ១៤,១៦,២៧ **១០:៤** ច ខ.៣ **១០:៦** ឆ យហ ១៦:២៥ ជ មក ៩:៣២ **១០:៧** ឈ យហ ៦:៣៥ ញ ខ.៩ **១០:៨** ដ យរ ២៣:១,២ អគ ៣៤:២ ឋ ខ.១ **១០:១០** ឌ យហ ១:៤ ៣:១៥,១៦ ៥:៤០ ២០:៣១ ឍ ទដ ៦៥:១១ រម ៥:១៧ **១០:១១** ណ យហ ៦:៣៥ ត ខ.១៤ ទដ ២៣:១ អស ៤០:១១ អគ ៣៤:១១–១៦, ២៣ មថ ២:៦ លក ១២:៣២ ហព ១៣:២០ ១ពត ២:២៥ ៥:៤ វវ ៧:១៧ ថ ខ.១៥,១៧,១៨ យហ ១៥:១៣ ១យហ ៣:១៦ **១០:១២** ទ សក ១១:១៦,១៧ **១០:១៤** ធ ខ.១១ ន ខ.២៧ នក ៣៣:១២ **១០:១៥** ប មថ ១១:២៧ ផ ខ.១១,១៧,១៨ **១០:១៦** ព អស ៥៦:៨ កច ១០:៣៤,៣៥

ពួកផារិស៊ីជាដើម បានធ្វេសប្រហែស មិនគោរពប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ទើបធ្វើឱ្យពួកគេក្លាយទៅជាអ្នកដឹកនាំមិនល្អ ដូច្នោះហើយបានជាទ្រង់មានបន្ទូលថា ពួកគេជាមនុស្សខ្ជាក់ និងមានលក្ខណៈដូចជាចោរលួច ចោរប្លន់ ដែលមិនដើរចូលក្រោលចៀមតាមច្រកទ្វារទេ ។

**១០:៣** *អ្នកឆ្មាំទ្វារ* ពាក្យនេះសំដៅលើអ្នកដែលទទួលខុសត្រូវមើលថែរក្សាចៀមយ៉ាងច្រើន នៅក្នុងក្រោលចៀមដ៏ធំមួយ ។ *ហ្វូងចៀមស្តាប់តាមសំឡេងគាត់* មានន័យថា ចៀមស្តាប់ និងឆ្លើយតប តែចំពោះសំឡេងនៃអ្នកគង្វាលវាប៉ុណ្ណោះ ។ *ចៀមរបស់គាត់ នោះគាត់ហៅតាមឈ្មោះវានិមួយៗ* បញ្ជាក់ថា អ្នកគង្វាលល្អ មិនចេះតែហៅឈ្មោះចៀមដោយព្រាវៗទេ ប៉ុន្តែ គឺហៅដោយចំឈ្មោះ ហើយហៅតែចៀមរបស់ខ្លួនប៉ុណ្ណោះ ។

**១០:៤** *នោះគាត់ដើរមុន* មានន័យថា អ្នកគង្វាលគឺជាអ្នកដែលនាំផ្លូវដល់ហ្វូងចៀម ដោយធ្វើសំឡេងជាសញ្ញា ហើយពួកវាក៏ដើរតាម (សត្វចៀមតែងតែស្តាប់សំឡេងរបស់អ្នកគង្វាលវា) ។

**១០:៦** *គេមិនដឹងជាទ្រង់មានបន្ទូលពីដំណើរអ្វីទេ* "មើលពន្យល់ ៨:២៧ ១២:១៦ មក ៨:១៦ លក ២:៥០ ៩:៤៥ ១៨:៣៤"។

**១០:៧,៩** *ខ្ញុំជាទ្វារ* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវទ្រង់ជាផ្លូវ ឬជាទ្វារនៃសេចក្តីសង្គ្រោះ (១៤:៦)។

**១០:៨** *អស់អ្នកដែលមកមុនខ្ញុំ នោះសុទ្ធតែជាចោរលួច ចោរប្លន់ទេ* ការដែលព្រះយេស៊ូវមានបន្ទូលយ៉ាងដូច្នេះ មិនមែនសំដៅលើពួកហោរាស្មោះត្រង់នៅក្នុងសម័យកាលសញ្ញាចាស់ទេ ប៉ុន្តែ គឺសំដៅលើពួកអ្នកដឹកនាំរបស់ពួកសាសន៍យូដា (មានពួកសម្តេចសង្ឃ និងពួកផារិស៊ីជាដើម) ដែលមិនប្រតិបត្តិតាមព្រះបន្ទូល (មើលការពន្យល់ ខ.១–៣០ សក ១១:៥,៨)។

**១០:១០** *ចោរ* គឺបញ្ជាក់ថា ពួកចោរធ្វើអ្វីៗដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ ។ រីឯព្រះយេស៊ូវទ្រង់យាងមក គឺដើម្បីប្រទានជីវិតដល់ពួកអ្នកដែលបាត់បង់ (១:៤)។

**១០:១១** *ស៊ូតែប្តូរជីវិតជំនួសចៀម* មានន័យថា អ្នកគង្វាលល្អតែងតែពុះពារឧបសគ្គដើម្បីចៀមរបស់ខ្លួន (លប ៣១:៣៩ ១យស ១៧:៣៤–៣៧)។ ព្រះយេស៊ូវគ្រីស្ទជាអ្នកគង្វាលដែលបានស៊ូប្តូរជីវិត និងសុគត ដើម្បីសង្គ្រោះហ្វូងចៀមរបស់ទ្រង់ឱ្យរួចផុតពីអំណាចនៃសេចក្តីស្លាប់ ។

**១០:១២–១៣** ត្រង់ចំណុចនេះបញ្ជាក់ថា ពួកអ្នកគង្វាលពិតប្រាកដ គឺជាម្ចាស់ និងតែងតែយកចិត្តទុកដាក់ ចំពោះហ្វូងចៀម ជាងអ្នកដែលស៊ីឈ្នួល ។ អ្នកស៊ីឈ្នួល តែងតែរត់ចេញពីហ្វូងចៀម នៅពេលដែលមានហ្វូងចចក ឬពេលដែលមានបញ្ហាមកដល់ ។ ក្នុងចំណោមអ្នកដឹកនាំរបស់ប្រជាជាតិនិមួយៗក៏ដូច្នេះដែរ ពួកគេតែងតែរត់គេចយករួចខ្លួន នៅពេលដែលមានបញ្ហា ឬឧបសគ្គមកដល់ ។ ដូច្នេះ យើងជាអ្នកមានជំនឿលើព្រះយេស៊ូវគ្រីស្ទត្រូវតែយកទ្រង់ជាគំរូ ដោយសុខចិត្តស៊ូប្តូរជីវិត ជំនួសហ្វូងចៀម ដែលទ្រង់បានប្រទានឱ្យយើងថែរក្សា ។

**១០:១៤** *ខ្ញុំស្គាល់ចៀមរបស់ខ្ញុំ ហើយចៀមក៏ស្គាល់ខ្ញុំ* មានន័យថា ព្រះអម្ចាស់ទ្រង់ស្គាល់ពួកអ្នកដែលជឿដល់ព្រះនាមទ្រង់យ៉ាងច្បាស់ ហើយក៏បើកសំដែងឱ្យពួកគេស្គាល់ទ្រង់ដែរ (ខ.៤ ២ធថ ១:១២ ២:១៩)។

**១០:១៥** *ខ្ញុំស៊ូប្តូរជីវិតខ្ញុំនឹងចៀម* ឃ្លានេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវទ្រង់មានព្រះហឫទ័យស្រលាញ់ ដល់ចៀមរបស់ទ្រង់ខ្លាំងណាស់ ហើយក៏ស៊ូប្តូរព្រះជន្មដើម្បីពួកគេទៀតផង ។

**១០:១៦** បទគម្ពីរនេះបញ្ជាក់ថា មានចៀមរបស់ព្រះអម្ចាស់ជាច្រើនទៀត ដែលមិនទាន់បាននាំចូលមកក្នុងក្រោលរបស់ទ្រង់នៅឡើយ ។ ពួកគេទាំងនោះគឺជាអ្នកដែលនឹងទទួលជឿដល់ព្រះនាមទ្រង់ (១៧:២០–២៣)។

ខ្ញុំនាំចៀមទាំងនោះមកដែរ វានឹងស្ដាប់តាមសំឡេងខ្ញុំ
នោះនឹងមានហ្វូងតែ១[ភ] នឹងអ្នកគង្វាលតែ១វិញ[ម] ១៧ ហេតុ
នោះបានជាព្រះវរបិតាទ្រង់ស្រឡាញ់ខ្ញុំ ពីព្រោះខ្ញុំដាក់ជីវិត
ខ្ញុំចុះ[យ] ដើម្បីឱ្យបានយកមកវិញ ១៨ គ្មានអ្នកណាដកយកជីវិត
ពីខ្ញុំបានទេ គឺខ្ញុំដាក់ជីវិតចុះដោយខ្លួនខ្ញុំ ខ្ញុំអាចនឹងដាក់
ជីវិតនេះចុះ ហើយក៏អាចនឹងយកមកវិញបានដែរ[រ] ខ្ញុំបាន
ទទួលអំណាចនេះ ពីព្រះវរបិតាខ្ញុំមក[ល] ១៩ នោះពួកសាសន៍
យូដាក៏កើតបែកបាក់ទាស់គ្នាម្តងទៀត ដោយព្រោះពាក្យ
នេះ[វ] ២០ ក៏មានពួកគេជាច្រើននិយាយថា អ្នកនោះមាន
អារក្សចូលមែន[ស] ហើយក៏ឆ្កួតផង[ហ] ហេតុអ្វី បានជាស្ដាប់វា
២១ ខ្លះទៀតថា នេះមិនមែនជាពាក្យសំដីរបស់មនុស្សមាន
អារក្សចូលទេ[ឡ] តើអារក្សអាចនឹងធ្វើឱ្យមនុស្សខ្វាក់
ភ្នែកបានភ្លឺដែរឬ[អ]។

## ការមិនជឿរបស់សាសន៍យូដា

២២ គ្រានោះជារដូវរងា ហើយនៅក្រុងយេរូសាឡិមគេ
កំពុងតែធ្វើបុណ្យឆ្លង ២៣ ឯព្រះយេស៊ូវទ្រង់យាងចុះឡើង
ក្នុងព្រះវិហារ ត្រង់បាំងសាចហ្លួងសាឡូម៉ូន[ក] ២៤ នោះមាន
ពួកសាសន៍យូដា[ខ] ចោមព័ទ្ធទ្រង់ទូលសួរថា តើលោកទុក
ឱ្យយើងខ្ញុំនៅស្ទាក់ស្ទើរ ដល់កាលណាទៀត បើលោកជា
ព្រះគ្រីស្ទពិត នោះសូមប្រាប់យើងខ្ញុំ ឱ្យច្បាស់មកចុះ[គ]។
២៥ ព្រះយេស៊ូវទ្រង់ឆ្លើយទៅគេថា ខ្ញុំបានប្រាប់អ្នករាល់
គ្នាហើយ[ឃ] តែអ្នករាល់គ្នាមិនជឿ ឯការទាំងប៉ុន្មានដែលខ្ញុំ
ធ្វើ ដោយនូវព្រះនាមព្រះវរបិតាខ្ញុំ ការទាំងនោះឯងធ្វើ
បន្ទាល់ពីខ្ញុំហើយ[ង] ២៦ ប៉ុន្តែ អ្នករាល់គ្នាមិនជឿ ដ្បិតអ្នក
រាល់គ្នាមិនមែនជាចៀមរបស់ខ្ញុំទេ[ច] ដូចជាខ្ញុំបានប្រាប់
ស្រេចហើយ ២៧ ចៀមខ្ញុំទាំងប៉ុន្មានវាស្ដាប់ខ្ញុំ[ឆ] ហើយមក
តាម[ជ] ខ្ញុំក៏ស្គាល់វាដែរ ២៨ ខ្ញុំឱ្យជីវិតអស់កល្បជានិច្ច ដល់
វា[ឈ] វាមិនត្រូវវិនាសនៅអស់កល្បរៀងទៅ[ញ] ក៏គ្មានអ្នកណា
ឆក់យកវាពីដៃខ្ញុំបានទេ[ដ] ២៩ ព្រះវរបិតានៃខ្ញុំ ដែលប្រទានវា
មកខ្ញុំ[ឋ] ទ្រង់ធំលើសជាងទាំងអស់[ឌ] គ្មានអ្នកណាអាចនឹងឆក់

**១០:១៦** ភ យហ ១១:៥២ ១៧:២០,២១ អភ ២:១១-១៩ ម អគ ៣៤:២៣ ៣៧:២៤
**១០:១៧** យ ខ.១១, ១៥,១៨
**១០:១៨** រ មថ ២៦:៥៣ ល យហ ១៥:១០ ភល ២:៨ ហព ៥:៨
**១០:១៩** វ យហ ៦:៥២
**១០:២០** ស មក ៣:២២ ហ ២ពរ ៩:១១ យរ ២៩:២៦ មក ៣:២១
**១០:២១** ឡ មថ ៤:២៤ អ នក ៤:១១ យហ ៩:៣២,៣៣
**១០:២៣** ក កច ៣:១១ ៥:១២
**១០:២៤** ខ យហ ១:១៩ គ លក ២២:៦៧ យហ ១៦:២៥,២៩
**១០:២៥** ឃ យហ ៤:២៦ ៨:៥៨ ង យហ ៥:៣៦ ១៤:១១
**១០:២៦** ច យហ ៨:៤៧ **១០:២៧** ឆ ខ.១៤ ជ ខ.៤ **១០:២៨** ឈ មថ ២៥:៤៦ ញ អស ៦៦:២២ ដ យហ ៦:៣៩ **១០:២៩** ឋ យហ ១៧:២,៦,២៤ ឌ យហ ១៤:២៨

**១០:១៧** *ខ្ញុំដាក់ជីវិតខ្ញុំចុះ* មានន័យថា ព្រះយេស៊ូវបានលះព្រះជន្ម ដើម្បីសង្គ្រោះមនុស្សលោកតាមព្រះហឫទ័យនៃព្រះវរបិតាទ្រង់ ។

**១០:១៨** *គ្មានអ្នកណាដកយកជីវិតពីខ្ញុំបានទេ គឺខ្ញុំដាក់ជីវិតចុះដោយខ្លួនខ្ញុំ* ឃ្លានេះបញ្ជាក់ថា ការដែលព្រះយេស៊ូវគ្រីស្ទសុគត គឺដោយព្រោះទ្រង់ស្ម័គ្រព្រះទ័យដាក់ព្រះជន្មទ្រង់ចុះដោយផ្ទាល់ មិនមែនដោយសារអំណាចរបស់អ្នកណាឡើយ ។

**១០:១៩** *ពួកសាសន៍យូដាក៏កើតបែកបាក់ទាស់គ្នាម្តងទៀត* ពួកសាសន៍យូដាទាំងនោះកើតបែកបាក់ ដោយសារតែមានការយល់ឃើញផ្សេងគ្នា ។ ម្ខាងទទួលយកសេចក្តីបង្រៀនរបស់ព្រះយេស៊ូវ រីឯម្ខាងទៀតបដិសេធទាំងស្រុង (៧:៤៣ ៩:១៦) ។

**១០:២០** *អ្នកនោះមានអារក្សចូលមែន* "មើលការពន្យល់ ៧:២០"។

**១០:២១** "មើលការពន្យល់ ៩:១៦"។

**១០:២២** *បុណ្យឆ្លង* សំដៅលើបុណ្យមួយរបស់ពួកយូដា មានរយៈពេល៨ថ្ងៃ ត្រូវបានគេប្រារព្ធធ្វើនៅពាក់កណ្តាលខែធ្នូ ជារៀងរាល់ឆ្នាំ ដើម្បីរំឭកដល់ការសម្អាតព្រះវិហារកាលពីឆ្នាំទី១៦៤មុនគ.ស ឱ្យបានជ្រះពីភាពកខ្វក់របស់ពួក អាន់ទីយ៉ូក អេពីហ្វាន (Antiochus Epiphanes ) ។

**១០:២៣** *បាំងសាចហ្លួងសាឡូម៉ូន* គឺបាំងសាច (រានហាល) ស្ថិតនៅផ្នែកខាងក្នុងនៃជញ្ជាំងដែលព័ទ្ធជុំវិញទីលានខាងក្រៅ ។ បាំងសាចនោះទ្រដោយសសរថ្ម កំពស់៨,២២ម៉ែត្រ តំរៀបជាជួរ និងមានពិតានធ្វើអំពីឈើតាត្រៅ (ជន១៩:៦ ២៤:៦ យហ ៥:១២ កច ៣:១១) ។

**១០:២៤** *បើលោកជាព្រះគ្រីស្ទពិត នោះសូមប្រាប់យើងខ្ញុំឱ្យច្បាស់មកចុះ* ពួកសាសន៍យូដានិយាយយ៉ាងដូច្នេះ គឺក្នុងគោលបំណងចង់ឱ្យព្រះយេស៊ូវធ្វើការអស្ចារ្យណាមួយ ដើម្បីបញ្ជាក់ឱ្យពួកគេឃើញថា ទ្រង់គឺជាព្រះមែស៊ីដែលត្រូវយាងមកមែន ព្រោះមានគំនិតប្រឆាំងគ្នាជាខ្លាំង នៅក្នុងចំណោមពួកគេទាំងនោះ (មើលការពន្យល់ ១:២៥ ២០:៣១) ។

**១០:២៥** *ខ្ញុំបានប្រាប់អ្នករាល់គ្នាហើយ* ចំណុចដែលព្រះយេស៊ូវមានបន្ទូលថា ទ្រង់ជាព្រះគ្រីស្ទ មានដូចជា ពេលទ្រង់ជួបជាមួយនឹងស្ត្រីសាសន៍សាម៉ារី (៤:២៦) និងបុរសម្នាក់ ដែលទ្រង់ប្រោសឱ្យបានភ្លឺភ្នែក (៩:៣៥-៣៧) ។ នៅក្នុងពេលដែលព្រះយេស៊ូវមានបន្ទូលទៅកាន់បុរស ដែលទ្រង់ប្រោសឱ្យបានភ្លឺភ្នែកនោះ ក៏មានពួកសាសន៍យូដាជាច្រើនបានឮដែរ ដូច្នេះហើយទើបទ្រង់មានបន្ទូលទៅកាន់ពួកគេថា ទ្រង់បានប្រាប់ពួកគេរួចហើយ ។ ម្យ៉ាងទៀត មានការអស្ចារ្យជាច្រើនដែលបញ្ជាក់ឱ្យពួកគេដឹងថា ទ្រង់ពិតជាព្រះគ្រីស្ទមែន (មើលការពន្យល់ ២:២៣) ។

**១០:២៦** *អ្នករាល់គ្នាមិនមែនជាចៀមរបស់ខ្ញុំទេ* មានន័យថា អស់អ្នកដែលមិនទទួល និងប្រតិបត្តិតាមសេចក្តីបង្រៀនរបស់ព្រះយេស៊ូវ នោះមិនមែនជាសិស្សរបស់ទ្រង់ទេ ។

**១០:២៧** *វាស្ដាប់ខ្ញុំ* "មើលការពន្យល់ ខ.៣"។ *ហើយមកតាម* "មើលការពន្យល់ ខ.៤"។ *ខ្ញុំក៏ស្គាល់វាដែរ* "មើលការពន្យល់ ខ.១៤"។

**១០:២៨** *ជីវិតអស់កល្បជានិច្ច* ត្រង់ចំណុចនេះបញ្ជាក់ថា ជីវិតអស់កល្បជានិច្ចគឺ ជាអំណោយទាន ដែលព្រះយេស៊ូវទ្រង់ប្រទានឱ្យ (៣:១៥) ។ *មិនត្រូវវិនាស* មានន័យថា ព្រះយេស៊ូវស្ម័គ្រព្រះទ័យប្តូរព្រះជន្មជំនួសចៀមទ្រង់ មិនឱ្យពួកគេណាមួយត្រូវវិនាសឡើយ ។

**១០:២៩** ក្នុងបទគម្ពីរនេះ ព្រះយេស៊ូវមានបន្ទូលយ៉ាងច្បាស់ថា អារក្សសាតាំងមិនអាចនឹងឆក់យកចៀមរបស់ទ្រង់បានទេ ព្រោះព្រះវរបិតាបានប្រទានឱ្យទ្រង់ នូវគ្រប់អំណាចព្រះចេស្តាទាំងអស់ ដើម្បីការពារពួកគេមិនឱ្យបាត់បង់ឡើយ (៥:១៧, ៣៧ ៦:៣៩ មើលការពន្យល់ ១៧:១១-១២) ។

យកវា ចេញពីព្រះហស្តរបស់ព្រះវរបិតាខ្ញុំបានឡើយ ៣០ខ្ញុំ
ហើយនឹងព្រះវរបិតា គឺតែ១អង្គទេ[ល]។
៣១នោះពួកសាសន៍យូដាក៏រើសថ្មម្ដងទៀត ដើម្បីនឹង
ចោលព្រះយេស៊ូវ[ណ] ៣២តែទ្រង់មានបន្ទូលសួរគេថា ខ្ញុំបាន
សំដែងឱ្យអ្នករាល់គ្នា ឃើញការល្អជាច្រើន ដែលមកពី
ព្រះវរបិតាខ្ញុំ តើអ្នករាល់គ្នាចោលខ្ញុំនឹងថ្ម ដោយព្រោះការ
ណាមួយនោះ ៣៣ពួកសាសន៍យូដាទូលឆ្លើយថា យើង
ចោលអ្នកនឹងថ្ម មិនមែនដោយព្រោះការល្អណាទេ គឺ
ដោយព្រោះពាក្យប្រមាថដល់ព្រះ ហើយពីព្រោះអ្នក
ដែលជាមនុស្ស បានតាំងខ្លួនឡើងជាព្រះវិញប៉ុណ្ណោះ[ត]
៣៤ព្រះយេស៊ូវមានបន្ទូលឆ្លើយថា តើគ្មានសេចក្ដី
ចែងទុកមកក្នុងក្រិត្យវិន័យរបស់អ្នករាល់គ្នាថា[ថ] « អញបាន
និយាយថា ឯងរាល់គ្នាជាព្រះ » ទេឬអី[ទ] ៣៥ដូច្នេះ បើទ្រង់
បានហៅអ្នកទាំងនោះជាព្រះ ដែលព្រះបន្ទូល[ធ]របស់ព្រះ
អង្គបានឮទៅដល់គេ ហើយបើលើកចោលបទគម្ពីរណា
មិនបាន[ន] ៣៦នោះតើអ្នករាល់គ្នានិយាយមកខ្ញុំនេះ ដែលព្រះ
វរបិតាញែក[ប]ជាបរិសុទ្ធ[ផ] ហើយចាត់មកក្នុងលោកីយ[ព]ថា
ខ្ញុំពោលពាក្យប្រមាថដល់ព្រះ ដោយព្រោះតែខ្ញុំនិយាយថា
ខ្ញុំជាព្រះរាជបុត្រានៃព្រះដូច្នេះឬអី[ភ] ៣៧បើសិនជាខ្ញុំ
មិនធ្វើការរបស់ព្រះវរបិតាខ្ញុំទេ នោះកុំឱ្យជឿដល់ខ្ញុំ
ឡើយ[ម] ៣៨ប៉ុន្តែ បើខ្ញុំធ្វើការរបស់ទ្រង់វិញ នោះទោះបើ
អ្នករាល់គ្នាមិនជឿខ្ញុំ គង់តែត្រូវជឿដល់ការទាំងនោះ
ដែរ ដើម្បីឱ្យអ្នករាល់គ្នាបានដឹង ហើយជឿថាព្រះវរបិតា
ទ្រង់គង់នៅក្នុងខ្ញុំ ហើយខ្ញុំក្នុងទ្រង់ដែរ[យ]។
៣៩គេក៏រកចាប់ទ្រង់ម្ដងទៀត[រ] តែទ្រង់គេចចេញរួចពី
កណ្ដាប់ដៃគេទៅ[ល] ៤០រួចយាងទៅខាងនាយទន្លេយ័រដាន់[វ]
វិញទៀត គឺជាកន្លែងដែលលោកយ៉ូហានធ្វើបុណ្យជ្រមុជ
ជាន់មុនដំបូង ហើយទ្រង់គង់នៅទីនោះ ៤១នោះមានមនុស្ស
ជាច្រើនមកឯទ្រង់ ក៏និយាយថា លោកយ៉ូហានគ្មានធ្វើទី
សំគាល់ណាទេ[ស] តែសេចក្ដីទាំងប៉ុន្មាន ដែលលោកមាន
ប្រសាសន៍ពីអ្នកនេះ នោះសុទ្ធតែពិតទាំងអស់[ហ] ៤២នៅទី
នោះ មានមនុស្សជាច្រើនជឿដល់ទ្រង់ដែរ[ឡ]។

## ការស្លាប់របស់ឡាសារ

**១១** ១មានបុរសម្នាក់ ឈ្មោះឡាសារ មានជំងឺឈឺ គាត់
នៅភូមិបេថានី[អ] ជាភូមិរបស់នាងម៉ារា នឹងបងនាងឈ្មោះ

**១០:៣០** ល ចទ ៦:៤ យហ ១៧:២១-២៣ **១០:៣១** ណ យហ ៨:៥៩ **១០:៣៣** ត លវ ២៤:១៦ មថ ២៦:៦៣-៦៦ យហ ៥:១៨ **១០:៣៤** ថ យហ ៨:១៧ ១២:៣៤ ១៥:២៥ រម ៣:១៩ ១កថ ១៤:២១ ទ ទដ ៨២:៦ **១០:៣៥** ធ ហព ៤:១២ ន មថ ៥:១៨ **១០:៣៦** ប យរ ១:៥ ផ យហ ៦:៦៩ ព យហ ៣:១៧ ភ យហ ៥:១៧,១៨ **១០:៣៧** ម ខ.២៥ **១០:៣៨** យ យហ ១៤:១០,១១, ២០ ១៧:២១ **១០:៣៩** រ យហ ៧:៣០ ល លក ៤:៣០ យហ ៨:៥៩

**១០:៤០** វ យហ ១:២៨ **១០:៤១** ស យហ ២:១១ ហ យហ ១:២៦,២៧,៣០, ៣៤ **១០:៤២** ឡ យហ ៧:៣១ **១១:១** អ មថ ២១:១៧ ក លក ១០:៣៨

**១០:៣០** ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទ និងព្រះវរបិតាគឺ តែ១អង្គទេ (៦:៣៥ ៨:២៤,៥៨ ១៧:២១-២២)។

**១០:៣១** *ពួកសាសន៍យូដា* "មើលការពន្យល់ ១:១៩"។ *ក៏រើសថ្មម្ដងទៀតដើម្បីនឹងចោលព្រះយេស៊ូវ* ពួកសាសន៍យូដារើសថ្មចោលព្រះយេស៊ូវដោយចោទថា ទ្រង់បានប្រមាថដល់ព្រះ (លវ ២៤:១៦ មក ១៤:៦៤ យហ ៥:១៨ ៨:៥៩)។

**១០:៣២** *ការល្អជាច្រើន* ពាក្យនេះនៅក្នុងព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសខ្លះប្រើពាក្យថា "ការអស្ចារ្យជាច្រើន" (មថ ៥:១៦ ១ធថ ៥:១០,២៥ ៦:១៨)។

**១០:៣៣** *ប្រមាថដល់ព្រះ* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកអ្នកដឹកនាំសាសន៍យូដាក៏បានយល់នូវព្រះបន្ទូលអំពីសេចក្ដីពិតរបស់ព្រះយេស៊ូវដែរ ប៉ុន្តែ ពួកគេមិនព្រមជឿ និងទទួលស្គាល់ថា ទ្រង់គឺជាព្រះមែស៊ីទេ ។

**១០:៣៤** *ក្រិត្យវិន័យ* ពាក្យថា"ក្រឹត្យវិន័យ"ត្រង់ចំណុចនេះគឺសំដៅលើក្រឹត្យវិន័យលោកម៉ូសេ ឬអាចសំដៅលើសេចក្ដី ដែលមានចែងនៅក្នុងព្រះគម្ពីរសញ្ញាចាស់ទាំងមូលតែម្ដង ។ *ឯងរាល់គ្នាជាព្រះ* សេចក្ដីនេះមានចែងនៅក្នុងបទគម្ពីរ "នក ៤:១៦ ៧:១" (ចទ ១:១៧ ១៦:១៨ ២របា ១៩:៦ ទដ ៨២:៦)។

**១០:៣៥** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវទ្រង់មិនបានបដិសេធនូវសេចក្ដីណាមួយដែលមានចែងនៅក្នុងព្រះគម្ពីរសញ្ញាចាស់ទេ ។

**១០:៣៦** យោងតាម"នក ៤:១៦ ៧:១ ទដ ៨២:៦" អាចមានន័យថា ព្រះអម្ចាស់ចាត់ទុកមនុស្សលោកជាព្រះមួយដែរ ។ ប៉ុន្តែ នៅពេលដែល ព្រះយេស៊ូវគ្រាន់តែមានបន្ទូលថា ទ្រង់ជាព្រះរាជបុត្រានៃព្រះប៉ុណ្ណោះ ពួក សាសន៍យូដាបែរជារកសម្លាប់ទ្រង់ទៅវិញ ។

**១០:៣៧-៣៨** ព្រះយេស៊ូវមានបន្ទូលប្រាប់ពួកសាសន៍យូដា ឱ្យសង្កេត និងពិនិត្យមើលគ្រប់ព្រះរាជកិច្ចដែលទ្រង់ធ្វើ រួចទ្រង់មានបន្ទូលសួរពួកគេថា តើការទាំងអស់នោះមកពីព្រះ ឬយ៉ាងណា (៩:៣២-៣៣ ១០:៣,៣២ ១៧:២១)។

**១០:៣៩** *គេក៏រកចាប់ទ្រង់ម្ដងទៀត* ត្រង់ចំណុចនេះមិនបានបញ្ជាក់ថា ពួកសាសន៍យូដាចង់ចាប់ព្រះយេស៊ូវ យកទៅកាត់ទោសនៅឯសាលាជំនុំជម្រះក្តី ឬមួយចង់ចាប់ទ្រង់យកទៅចោលនឹងថ្មសម្លាប់នោះទេ ។ *តែទ្រង់គេចចេញរួច* ឃ្លានេះ លោកយ៉ូហានពុំបានប្រាប់ថា តើព្រះយេស៊ូវគេចចេញពីពួកសាសន៍យូដាទាំងនោះ ដោយរបៀបណាទេ ប៉ុន្តែ គោលបំណងដ៏សំខាន់ដែលលោកចង់បញ្ជាក់ប្រាប់នោះគឺ គ្មានអ្នកណាអាចធ្វើអ្វីដល់ទ្រង់នៅមុនកំណត់របស់ទ្រង់បានឡើយ (២:៤ មើលការពន្យល់ លក ៤:៣០)។

**១០:៤០** *កន្លែងដែលលោកយ៉ូហានធ្វើបុណ្យជ្រមុជ* ទីន្លែងលោកយ៉ូហាន-បាទីស្ទ ធ្វើបុណ្យជ្រមុជទឹកឱ្យពួកបណ្ដាជន គឺត្រង់ចំណុចក្បែរភូមិបេថានី (១:២៨)។

**១០:៤១-៤២** ត្រង់ចំណុចនេះបញ្ជាក់ថា លោកយ៉ូហាន-បាទីស្ទបានមកដើម្បីធ្វើបន្ទាល់អំពីព្រះយេស៊ូវថា ទ្រង់គឺជាព្រះសង្គ្រោះមនុស្សលោកពិតប្រាកដមែន ហើយក៏មានពួកគេជាច្រើនបានជឿដល់ទ្រង់ ។

**១១:១** *ឡាសារ* ឈ្មោះរបស់ឡាសារម្នាក់នេះ មាននិយាយតែនៅក្នុងដំណឹងល្អយ៉ូហានជំពូក១១-១២ប៉ុណ្ណោះ (ឈ្មោះឡាសារម្នាក់ទៀត ក្នុងពាក្យប្រៀប

ម៉ាថា[ក] ២ឯនាងម៉ារា ដែលប្អូននាងឈ្មោះឡាសារ មានជំងឺ
នេះ គឺនាងនេះហើយ ដែលបានចាក់ប្រេងក្រអូបលាបថ្វាយ
ព្រះអម្ចាស់ រួចយក សក់នាងជូតព្រះបាទទ្រង់[ខ] ៣បងប្អូនស្រី
២នាក់នោះ ក៏ចាត់គេឱ្យទៅឯព្រះយេស៊ូវទូលថា ព្រះ
អម្ចាស់អើយ មើលអ្នកដែលទ្រង់ស្រឡាញ់[គ]នោះគាត់ឈឺ។
៤កាលទ្រង់បានឮដូច្នេះ នោះក៏មានបន្ទូលថា ជំងឺនេះ
មិនមែនដល់ស្លាប់ទេ គឺសំរាប់ជាកិត្តិសព្ទដល់ព្រះវិញ ដើម្បី
នឹងលើកដំកើងដល់[ឃ] ព្រះរាជបុត្រានៃព្រះ ដោយសារជំងឺ
នេះឯង ៥រីឯព្រះយេស៊ូវ ទ្រង់ស្រឡាញ់នាងម៉ាថា នឹងប្អូន
ស្រីនាង ហើយនឹងឡាសារផង ៦ដូច្នេះ កាលទ្រង់បានឮថា
គាត់ឈឺ នោះទ្រង់ក៏គង់នៅកន្លែងដដែល២ថ្ងៃទៀត ។
៧ក្រោយនោះមក ទ្រង់មានបន្ទូលទៅពួកសិស្សថា ចូរ
យើងត្រឡប់ទៅឯស្រុកយូដាវិញ[ង]។
៨ពួកសិស្សទូលទ្រង់ថា លោកគ្រូ[ច]ពួកសាសន៍យូដាទើប
នឹងរកចោលលោកនឹងថ្ម ពីមុននោះ[ឆ] ដូច្នេះ តើលោកគិត
ទៅឯណោះទៀតឬ ៩ព្រះយេស៊ូវមានបន្ទូលឆ្លើយថា
ក្នុង១ថ្ងៃ មាន១២ ម៉ោងទេតើ បើអ្នកណាដើរនៅពេលថ្ងៃ
នោះមិនជំពប់ ជើងទេ ព្រោះឃើញពន្លឺលោកីយនេះ[ជ]
១០តែបើអ្នកណា ដើរនៅពេលយប់ នោះត្រូវជំពប់ជើង
វិញពីព្រោះគ្មានពន្លឺ នៅក្នុងខ្លួនសោះ ១១ក្រោយដែលទ្រង់
មានបន្ទូលសេចក្តីទាំងនេះហើយ នោះក៏មានបន្ទូលទៀតថា
ឡាសារ ជាសំឡាញ់[ឈ]យើង គាត់បានដេកលក់ទៅហើយ[ញ]
ខ្ញុំទៅដើម្បីនឹងដាស់គាត់ឡើង ១២ដូច្នេះ ពួកសិស្សទូលថា
ព្រះអម្ចាស់អើយ បើគាត់ដេកលក់ នោះគាត់នឹងបានជាវិញ
១៣ឯព្រះយេស៊ូវ ទ្រង់មានបន្ទូលពីគាត់ស្លាប់ទេ តែគេស្មាន
ថា ទ្រង់មានបន្ទូលអំពីគាត់គ្រាន់តែដេកសំរាកប៉ុណ្ណោះ[ដ]
១៤ព្រះយេស៊ូវមានបន្ទូលទៅគេជាយ៉ាងច្បាស់ថា ឡា
សារស្លាប់ហើយ ១៥ខ្ញុំក៏អរណាស់ ដោយយល់ដល់អ្នក
រាល់គ្នា ព្រោះខ្ញុំមិនបានទៅឯណោះ ដើម្បីឱ្យអ្នករាល់គ្នា
បានជឿឥឡូវ ចូរយើងទៅឯគាត់ចុះ ១៦ដូច្នេះ ថូម៉ាស[ឋ]
ដែលហៅថា ឌីឌីម គាត់និយាយទៅពួកសិស្ស ជាគូកន
គាត់ថា ចូរយើងរាល់គ្នាទៅដែរ ដើម្បីនឹងប្តូរស្លាប់ជា
មួយនឹងលោក។

### ព្រះយេស៊ូវទ្រង់កម្សាន្តចិត្ត

១៧កាលព្រះយេស៊ូវយាងទៅដល់ហើយ នោះបានឮថា
ឡាសារនៅក្នុងផ្នូរអស់៤ថ្ងៃហើយ[ឌ] ១៨រីឯភូមិបេថានី[ឍ]នោះ
នៅជិតក្រុងយេរូសាឡិម ប្រហែលជា៣គីឡូម៉ែត្រទេ

**១១:២** ខ មក ១៤:៣ លក ៧:៣៨ យហ ១២:៣
**១១:៣** គ ខ.៥,៣៦
**១១:៤** ឃ ខ.៤០
**១១:៧** ង យហ ១០:៤០
**១១:៨** ច មថ ២៣:៧ ឆ យហ ៨:៥៩ ១០:៣១
**១១:៩** ជ យហ ៩:៤ ១២:៣៥
**១១:១១** ឈ ខ.៣ ញ មថ ៩:២៤
**១១:១៣** ដ មថ ៩:២៤
**១១:១៦** ឋ មថ ១០:៣ យហ ១៤:៥ ២០:២៤–២៨ ២១:២ កច ១:១៣
**១១:១៧** ឌ ខ.៦,៣៩
**១១:១៨** ឍ ខ.១ មថ ២១:១៧

ប្រដូចរបស់ព្រះយេស៊ូវ នៅក្នុង "លក ១០:៣៨–៤២")។ រីឯបងស្រីរបស់គាត់វិញ គឺមាននិយាយនៅក្នុងដំណឹងល្អលូកាផងដែរ (លក ១០:៣៨–៤២) ។

**១១:២** *ចាក់ប្រេងក្រអូប* "មើលការពន្យល់ ១២:៣"។

**១១:៣** *អ្នកដែលទ្រង់ស្រឡាញ់* ត្រង់ចំណុចនេះបញ្ជាក់ថាទំនាក់ទំនងរបស់ពួកគេ នឹងព្រះអម្ចាស់ពិតជាមានភាពជិតស្និទ្ធជាខ្លាំង ។

**១១:៤** *ជំងឺនេះមិនមែនដល់ស្លាប់ទេ* ការដែលព្រះយេស៊ូវមានបន្ទូលអំពីការរស់ឡើងវិញរបស់ឡាសារ (ខ.៤៤) ក៏បញ្ជាក់នូវការដែលទ្រង់នឹងត្រូវសុគតហើយរស់ឡើងវិញផងដែរ (ខ.១៤) ។ គាត់ប្រហែលជាបានស្លាប់បន្ទាប់ពីអ្នកនាំដំណឹងទៅប្រាប់ព្រះយេស៊ូវ បានចាកចេញទៅពីភូមិបេថានីបន្តិច ។ អ្នកនាំដំណឹងចាកចេញពីភូមិបេថានី ទៅដល់កន្លែងដែលព្រះយេស៊ូវគង់នៅ គឺមានរយៈពេល១ថ្ងៃ ។ បន្ទាប់អំពីព្រះយេស៊ូវ បានទទួលដំណឹងនោះហើយទ្រង់ក៏គង់នៅកន្លែងដដែល អស់រយៈពេល២ថ្ងៃទៀត (មើលការពន្យល់ ខ.៦) ។ ការធ្វើដំណើររបស់ទ្រង់មក ភូមិបេថានី គឺមានរយៈពេល១ថ្ងៃទៀត ។ ដូច្នេះបញ្ជាក់ថា រយៈពេលដែលឡាសារ ស្លាប់គឺ៤ថ្ងៃ (ខ.១៧,៣៩ មើលការពន្យល់ ខ.១៧) ។ *សំរាប់ជាកិត្តិសព្ទដល់ព្រះវិញ* "មើលពន្យល់ ៧:៣៩ ១២:៤១ ១៣:៣១"។ ត្រង់ចំណុចនេះបញ្ជាក់ថា ឡាសារ រស់ឡើងវិញ គឺដើម្បីឱ្យព្រះវរបិតា ដែលគង់នៅក្នុងព្រះរាជបុត្រាបានតម្កើងឡើង (មើលការពន្យល់ ខ.៤០ ៤៦–៥៣ ៥:២១) ។

**១១:៦** *ទ្រង់ក៏គង់នៅកន្លែងដដែល២ថ្ងៃទៀត* ព្រះយេស៊ូវបន្តគង់នៅទីនោះទៀត ព្រោះទ្រង់ជ្រាបរួចជាស្រេចថា ឡាសារបានស្លាប់ហើយ ។ ម្យ៉ាងទៀត ទ្រង់មានគម្រោងប្រោសគាត់ឱ្យរស់ឡើងវិញរួចជាស្រេចហើយ ប៉ុន្តែទ្រង់នៅរង់ចាំពេល វេលារបស់ទ្រង់មកដល់ (មើលការពន្យល់ ២:៤ ១០:៤០) ។

**១១:៨** *ពួកសាសន៍យូដា* "មើលពន្យល់ ១:១៩"។ *រកចោលលោកនឹងថ្ម* "មើលពន្យល់ ១០:៣១"។ ម្យ៉ាងទៀត បទគម្ពីរនេះបញ្ជាក់ថា ការដែលព្រះយេស៊ូវយាងទៅឯស្រុកយូដា គឺត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ជាច្រើន ។

**១១:៩** *ក្នុង១ថ្ងៃមាន១២ម៉ោងទេតើ* មានន័យថាក្នុងពេលថ្ងៃមាន១២ម៉ោងដែលមនុស្សអាចធ្វើការងារ ដោយអាស្រ័យលើពន្លឺថ្ងៃ ។ ដូច្នេះ ពួកគេត្រូវតែប្រើប្រាស់ពេលវេលាទាំងនេះដោយយកចិត្តទុកដាក់បំផុត (៩:៤) ។ ជីវិតមនុស្សប្រៀបដូចជារយៈពេល១២ម៉ោងនៅពេលថ្ងៃដែរ គឺត្រូវតែខំប្រឹងធ្វើកិច្ចការរបស់ខ្លួនឱ្យបានចប់សព្វគ្រប់ រួចហើយសេចក្តីស្លាប់ត្រូវមកដល់ដែលប្រៀបបាននឹងពេលយប់ ដែលត្រូវមកដល់នោះដែរ ។

**១១:១១** *គាត់បានដេកលក់ទៅហើយ* មានន័យថា គាត់បានស្លាប់ទៅហើយ

**១១:១៦** *ថូម៉ាស . . . ឌីឌីម* ពាក្យថា "ថូម៉ាស" គឺជាភាសាហេព្រើរ រីឯ "ឌីឌីម" គឺជាភាសាក្រិក ។ ពាក្យទាំងពីរនេះមានន័យថា "ភ្លោះ" ដូចគ្នា ។

**១១:១៧** *៤ថ្ងៃ* "មើលការពន្យល់ ខ.៤"។ ពួកសាសន៍យូដាជាច្រើនជឿថាព្រលឹងរបស់មនុស្សគឺស្ថិតនៅជិតៗសាកសព្វ ក្នុងអំឡុងពេល៣ថ្ងៃបន្ទាប់ពីគេបានស្លាប់ ។ ហើយពួកគេអាចនៅមានសង្ឃឹមថា ព្រលឹងនោះនឹងចូលមកក្នុងរូបកាយវិញ ។ ដូច្នេះ បានជានៅពេលដែលឡាសារស្លាប់បាន៤ថ្ងៃ នោះក៏ធ្វើឱ្យពួកគេលែងមានសង្ឃឹម និងយល់ថា គាត់ពិតជាមិនអាចរស់ឡើងវិញបានទេ ។

**១១:១៨** *ភូមិបេថានី* ស្ថិតនៅភាគខាងកើតទីក្រុងយេរូសាឡិមចម្ងាយ

១៩ហើយមានពួកសាសន៍យូដាជាច្រើនបានមក ដើម្បីជួយ
កំសាន្តទុក្ខនាងម៉ាថា និងម៉ារា ពីដំណើរប្អូនស្លាប់[ណ] ២០កាល
ម៉ាថាបានឮថា ព្រះយេស៊ូវយាងមកហើយ នោះនាងក៏ទៅ
ទទួលទ្រង់ តែម៉ារាអង្គុយនៅឯផ្ទះ[ត] ២១ម៉ាថាទូលព្រះយេ
ស៊ូវថា ព្រះអម្ចាស់អើយ បើសិនជាទ្រង់បានគង់នៅទីនេះ
នោះប្អូនខ្ញុំម្ចាស់មិនបានស្លាប់ទេ[ថ] ២២ប៉ុន្តែខ្ញុំម្ចាស់ដឹងថា
ទោះទាំងនៅគ្រាឥឡូវនេះ នោះការអ្វីដែលទ្រង់នឹងសូម
ពីព្រះ គង់តែព្រះនឹងប្រទានមកទ្រង់ជាមិនខាន[ទ] ២៣ព្រះយេ
ស៊ូវមានបន្ទូលទៅនាងថា ប្អូននាងនឹងរស់ឡើងវិញ ២៤ម៉ា
ថាទូលទ្រង់ថា ខ្ញុំដឹងថា នៅថ្ងៃចុងបំផុត កាលណាមនុស្ស
ត្រូវរស់ពីស្លាប់ឡើងវិញ[ធ] នោះប្អូនខ្ញុំម្ចាស់នឹងរស់ឡើង
ដែរ[ន] ២៥ព្រះយេស៊ូវមានបន្ទូលទៅនាងថា ខ្ញុំជា[ប]សេចក្តី
រស់ឡើងវិញ ហើយជាជីវិត[ផ] អ្នកណាដែលជឿដល់ខ្ញុំ[ព]
ទោះបើបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ
២៦ឯអ្នកណាដែលរស់នៅ ហើយជឿដល់ខ្ញុំ[ភ] នោះមិនត្រូវ
ស្លាប់ឡើយ[ម] នាងជឿសេចក្តីនេះឬទេ ២៧នាងទូលឆ្លើយថា
ព្រះពរព្រះអម្ចាស់ ខ្ញុំម្ចាស់ជឿ ហើយថាទ្រង់ជាព្រះគ្រីស្ទ
[យ]គឺជាព្រះរាជបុត្រានៃព្រះ[រ]ដែល ត្រូវយាងមកក្នុងលោ
កីយមែន[ល]។
២៨កាលនាងបានពោលពាក្យដូច្នោះហើយ នោះក៏ទៅ
ហៅម៉ារា ប្អូននាង មកដោយសំងាត់ ប្រាប់ថា លោកគ្រូ[វ]
អញ្ជើញមកដល់ហើយ លោកហៅរកឯង ២៩កាលនាង
ម៉ារាបានឮពាក្យនោះ ក៏ក្រោកឡើងជាប្រញាប់ទៅឯទ្រង់
៣០ឯព្រះយេស៊ូវទ្រង់មិនទាន់យាងចូលក្នុងភូមិនៅឡើយ
គឺទ្រង់គង់នៅត្រង់កន្លែងដែលម៉ាថាបានចួបនោះ[ស] ៣១កាល
ពួកសាសន៍យូដា ដែលនៅក្នុងផ្ទះ កំពុងតែជួយកំសាន្តចិត្ត
នាងម៉ារា[ហ] បានឃើញថា នាងក្រោកឡើងចេញទៅជា
ប្រញាប់ដូច្នេះ គេក៏តាមនាងទៅ ដោយនិយាយគ្នាថា នាង
គិតទៅយំឯផ្នូរហើយ ។
៣២នាងម៉ារាក៏ទៅដល់កន្លែង ដែលព្រះយេស៊ូវគង់នៅ
កាលបានឃើញទ្រង់ នោះនាងក្រាប នៅទៀបព្រះបាទទូល
ថា ព្រះអម្ចាស់អើយ បើទ្រង់បានគង់នៅទីនេះ នោះប្អូនខ្ញុំ
ម្ចាស់មិនបានស្លាប់ទេ[ឡ]។

**១១:១៩** ណ ខ.៣១ យប ២:១១ **១១:២០** ត លក ១០:៣៨–៤២ **១១:២១** ថ ខ.៣២,៣៧ **១១:២២** ទ ខ.៤១,៤២ **១១:២៤** ធ ដយ ១២:២ យហ ៥:២៨,២៩ កច ២៤:១៥ ន យហ ៦:៣៩,៤០ **១១:២៥** ប យហ ៦:៣៥ ផ យហ ១:៤ ព យហ ៣:១៥ **១១:២៦** ភ យហ ៣:១៥ ម មថ ២៥:៤៦ **១១:២៧** យ លក ២:១១ រ មថ ៤:៣ ល យហ ៦:១៤ **១១:២៨** វ មថ ២៦:១៨ យហ ១៣:១៣

**១១:៣០** ស ខ.២០ **១១:៣១** ហ ខ.១៩ **១១:៣២** ឡ ខ.២១

ប្រហែល ៣គ.ម (មើលការពន្យល់ មថ ២១:១៧)។

**១១:១៩** *ដើម្បីជួយកំសាន្តទុក្ខ* តាមទំនៀមទម្លាប់របស់ពួកយូដា ការជួយរំលែកទុក្ខក្រុមគ្រួសារសពមានចែកចេញជាបីដំណាក់កាល (១)រយៈពេល ៣ថ្ងៃដំបូងសម្រាប់ការរំលែកទុក្ខដ៏ធ្ងន់ (២)រយៈពេល៤ថ្ងៃបន្តទៀតសម្រាប់ការរំលែកទុក្ខធ្ងន់ (៣)ហើយបន្តរយៈពេល៣០ថ្ងៃទៀត សម្រាប់ការរំលែកទុក្ខមានលក្ខណៈជាធម្មតា ។

**១១:២០** *នោះនាងក៏ទៅទទួលទ្រង់* ត្រង់ចំណុចនេះបញ្ជាក់ថា នាងម៉ាថាចេញទៅទទួលព្រះយេស៊ូវ ប្រហែលព្រោះនាងជាបងគេនៅក្នុងគ្រួសារ ដូច្នេះត្រូវមាននាទីទៅទទួលភ្ញៀវ ។

**១១:២១** នៅក្នុងពេលដែលរង់ចាំការយាងមករបស់ព្រះយេស៊ូវ នោះបងប្អូនស្រីទាំងពីរនាក់តែងតែនិយាយគ្នាថា "បើសិនជាទ្រង់បានគង់នៅទីនេះ នោះប្អូនរបស់ខ្លួនមិនស្លាប់ទេ"។

**១១:២២** *ការអ្វីដែលទ្រង់នឹងសូមពីព្រះ* ត្រង់ចំណុចនេះ នាងម៉ាថាមិនសង្ឃឹមថាប្អូនរបស់នាងអាចរស់វិញបានទេ គឺនាងគិតថាគាត់ (ឡាសារ) នឹងរស់ឡើងវិញនៅថ្ងៃចុងបំផុត ព្រោះសពនោះធុំក្លិនហើយ ។ ការអ្វីដែលមនុស្សលោកធ្វើមិនកើត តែព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់ (មថ ១៩:២៦ លប ១៨:១៤ យរ ៣២:១៧,២៧)។

**១១:២៥** *ខ្ញុំជាសេចក្តីរស់ឡើងវិញ* បញ្ជាក់ថា ព្រះយេស៊ូវមានអំណាចប្រទានឱ្យមនុស្សដែលស្លាប់រស់ឡើងវិញបានមិនតែប៉ុណ្ណោះ ទ្រង់ប្រទានឱ្យគេមានជីវិតរស់អស់កល្បជានិច្ចខាងឯវិញ្ញាណផង (១:៤ ៥:២៦)។ ដើម្បីទទួលជីវិតអស់កល្បអំពីព្រះយេស៊ូវ គឺត្រូវទទួលជឿដល់ព្រះនាមទ្រង់ និងត្រូវតែកើតជាថ្មី (៣:៣ ១២:២៤ រម ៦:៣–៥)។ *ជីវិត* ព្រះយេស៊ូវគឺជាជីវិត (១៤:៦ កច ៣:១៥ ហព ៧:១៦ មើលការពន្យល់ ១:៤)។ *អ្នកណាដែលជឿដល់ខ្ញុំ ទោះបើស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ* ឃ្លានេះបញ្ជាក់ថា ព្រះយេស៊ូវមិនគ្រាន់តែជាជីវិតទេ ប៉ុន្តែទ្រង់ផ្តល់ជីវិត ដល់អស់អ្នកណាដែលជឿដល់ព្រះនាមទ្រង់ និងប្រទានឱ្យពួកគេបានឈ្នះអំណាចនៃសេចក្តីស្លាប់ដោយសារតែព្រះគុណផងទ្រង់ (មើលពន្យល់ ១កថ ១៥:៥៧)។

**១១:២៦** *នោះមិនត្រូវស្លាប់ឡើយ* ត្រង់ចំណុចនេះ ពុំមានន័យថា អស់អ្នកជឿលើព្រះនាមព្រះយេស៊ូវគ្រីស្ទទាំងអស់ រូបកាយរបស់គេមិនស្លាប់នោះទេ (ខ.២៥)។

**១១:២៧** *ខ្ញុំម្ចាស់ជឿហើយ* គឺនាងជឿថា ព្រះយេស៊ូវគ្រីស្ទជា ព្រះមែស៊ី និងជាព្រះរាជបុត្រានៃព្រះ ហើយជាព្រះសង្គ្រោះមនុស្សលោក (លក ១០:៤០–៤២)។

**១១:២៨** *លោកគ្រូ* បញ្ជាក់ថា ពួកស្រីៗសាសន៍យូដា តែងហៅព្រះយេស៊ូវថា "លោកគ្រូ" ព្រោះទ្រង់បានបង្រៀនពួកគេទាំងប្រុស ទាំងស្រី (លក ១០:៣៨-៤២) គឺផ្ទុយពីពួកគ្រូក្រឹត្យវិន័យរបស់ពួកគេ ដែលបង្រៀនតែពួកប្រុសៗប៉ុណ្ណោះ (មើលការពន្យល់ ៤:២៧)។

**១១:៣១** *នាងគិតទៅយំឯផ្នូរហើយ* ឃ្លានេះបញ្ជាក់ថា ជាធម្មតាសមាជិកគ្រួសារសពតែងតែទៅយំនៅឯផ្នូរ ដូច្នេះ បានជានៅពេលដែលនាងម៉ារាចេញពីផ្ទះនោះ ពួកសាសន៍យូដាក៏គិតថា នាងទៅយំឯផ្នូរហើយ ។ ម្យ៉ាងទៀត ពួកអ្នកដែលទៅតាម នាងម៉ារា ក៏បានជួបនឹងព្រះយេស៊ូវដែរ ដូច្នេះ មានន័យថា មានមនុស្សជាច្រើន បានជួបទ្រង់ ។

**១១:៣២** *នាងក្រាបនៅទៀបព្រះបាទ* ការដែលនាងម៉ារាធ្វើដូច្នេះ ប្រហែលជាបញ្ជាក់ថា នាងសូមឱ្យព្រះយេស៊ូវអត់ទោសក្នុងការដែលនាង

៣៣កាលព្រះយេស៊ូវឃើញនាងយំ ព្រមទាំងពួកសាសន៍
យូដា ដែលមកជាមួយនឹងនាងផង នោះទ្រង់មានសេចក្តី
រំជួល[អ] ទាំងក្នាញ់ក្នុងព្រះហឫទ័យ[ក] ៣៤ហើយមានបន្ទូល
សួរថា អ្នករាល់គ្នាបានយករូបបុគ្គលទៅទុកឯណា គេ
ទូលឆ្លើយថា ព្រះអម្ចាស់សូមយាងទៅទតមើល ៣៥ព្រះយេ
ស៊ូវក៏ទ្រង់ព្រះកន្សែង[ខ] ៣៦ដូច្នេះ ពួកសាសន៍ យូដានិយាយ
ថា មើល លោកស្រឡាញ់គាត់ណាស់ហ្ន៎[គ] ៣៧ហើយពួកគេ
ខ្លះនិយាយថា លោកនេះដែលបានប្រោសមនុស្សខ្វាក់ឱ្យភ្លឺ[ឃ]
តើពុំអាចនឹងឃាត់មិនឱ្យមនុស្ស នេះស្លាប់បានដែរឬ[ង] ។

## ព្រះយេស៊ូវប្រោសឡាសារឱ្យរស់ឡើងវិញ

៣៨នោះព្រះយេស៊ូវយាងទៅដល់ផ្នូរ[ច] ទាំងមានសេចក្តី
ក្នាញ់ក្នុងព្រះហឫទ័យម្តងទៀត ឯផ្នូរនោះជារអាងភ្នំ ហើយ
មានថ្ម១បិទសន្ទប់[ឆ] ៣៩ព្រះយេស៊ូវមានបន្ទូលថា ចូរយក
ថ្មចេញ តែម៉ាថា ជាបងរបស់រូបបុគ្គលនោះ ទូលថា
ព្រះអម្ចាស់អើយ ខ្មោចនេះធុំក្លិនហើយ ព្រោះស្លាប់កន្លង
មកបាន៤ថ្ងៃ[ជ] ៤០ព្រះយេស៊ូវមានបន្ទូលទៅនាងថា តើខ្ញុំ
មិនបានប្រាប់នាងថា បើសិនជានាងជឿ[ឈ] នោះនាងនឹង
ឃើញសិរីល្អនៃព្រះទេឬអី[ញ] ៤១ដូច្នេះ គេក៏យកថ្មចេញ រួច
ព្រះយេស៊ូវងើបព្រះនេត្រទៅលើ[ដ] ទូលថា ឱព្រះវរបិតា[ឋ]
អើយ ទូលបង្គំអរព្រះគុណដល់ព្រះអង្គ ដោយព្រោះទ្រង់
បានអនុញ្ញាតតាមទូលបង្គំ ៤២ទូលបង្គំដឹងថា ទ្រង់អនុញ្ញាត
តាមទូលបង្គំជាដរាប តែដែលទូលបង្គំទូលដូច្នេះ គឺដោយ
ព្រោះតែបណ្តាមនុស្សដែលឈរនៅជុំវិញទេ[ឌ] ដើម្បីឱ្យគេ
ជឿថា ទ្រង់បានចាត់ឱ្យទូលបង្គំមកមែន[ឍ] ៤៣កាលទ្រង់មាន
បន្ទូលដូច្នេះហើយក៏បន្លឺវាចាថា ឡាសារអើយ ចូរចេញ
មក[ណ] ៤៤នោះអ្នកដែលបានស្លាប់ ក៏ចេញមក មានទាំងសំ
ពត់ស្នបរុំជាប់នៅជើងដៃផង[ត] ហើយមានកន្សែងគ្រប
មុខដែរ[ថ] ព្រះយេស៊ូវមានបន្ទូលទៅគេថា ចូរស្រាយគាត់ឱ្យ
ទៅចុះ។

## គម្រោងការធ្វើគុតព្រះយេស៊ូវ

៤៥ដូច្នេះ កាលពួកសាសន៍យូដាដែលមកតាមនាងម៉ារា[ទ]
បានឃើញការដែលព្រះយេស៊ូវធ្វើ[ធ] នោះមានគ្នាជាច្រើន
ជឿដល់ទ្រង់[ន] ៤៦តែមានខ្លះ ទៅជំរាបដល់ពួកផារិស៊ី
ពីការ ដែលព្រះយេស៊ូវបានធ្វើ ៤៧នោះពួកសង្គ្រាជ នឹង
ពួកផារិស៊ី[ប] គេប្រមូល[ផ]ក្រុមប្រឹក្សា[ព] មកនិយាយថា តើ
យើងត្រូវធ្វើដូចម្តេច ព្រោះមនុស្សនេះធ្វើទីសំគាល់ច្រើន
ណាស់[ភ] ៤៨បើយើងទុកឱ្យធ្វើតែយ៉ាងដូច្នេះទៅ នោះ
មុខជាមនុស្សទាំងអស់ នឹងជឿតាមវាហើយ រួចសាសន៍រ៉ូម

**១១:៣៣** អ ខ.៣៨ ក យហ ១២:២៧
**១១:៣៥** ខ លក ១៩:៤១
**១១:៣៦** គ ខ.៣
**១១:៣៧** ឃ យហ ៩:៦,៧ ង ខ.២១,៣២
**១១:៣៨** ច ខ.៣៣ ឆ មថ ២៧:៦០ លក ២៤:២ យហ ២០:១
**១១:៣៩** ជ ខ.១៧
**១១:៤០** ឈ ខ.២៣–២៥ ញ ខ.៤
**១១:៤១** ដ យហ ១៧:១ ឋ មថ ១១:២៥
**១១:៤២** ឌ យហ ១២:៣០ ឍ យហ ៣:១៧
**១១:៤៣** ណ លក ៧:១៤
**១១:៤៤** ត យហ ១៩:៤០ ថ យហ ២០:៧
**១១:៤៥** ទ ខ.១៩ ធ យហ ២:២៣ ន នក ១៤:៣១ យហ ៧:៣១
**១១:៤៧** ប ខ.៥៧ ផ មថ ២៦:៣ ព មថ ៥:២២ ភ យហ ២:១១

មិនបានមកទទួល ទ្រង់ នៅក្នុងខណៈពេលដែលទ្រង់យាងមកដល់ទីនោះភ្លាម

**១១:៣៣** *នាងយំ* ចំណុចនេះបញ្ជាក់ថា នាងទ្រហោយំយ៉ាងខ្លាំង ។ *ទាំងក្នាញ់ក្នុងព្រះហឫទ័យ* ឃ្លានេះមានន័យថា ដោយព្រោះព្រះយេស៊ូវជាព្រះមួយរយភាគរយ និងជាមនុស្សមួយរយភាគរយ ដូច្នេះបានជានៅពេលដែលទ្រង់ឃើញពួកអ្នក ដែលជឿដល់ព្រះនាមទ្រង់មានការឈឺចាប់ នោះទ្រង់ក៏ព្រួយក្នុងព្រះទ័យជាខ្លាំង (មើលការពន្យល់ ១២:២៧ ១៣:២១) ។

**១១:៣៥** *ទ្រង់ព្រះកន្សែង* មានន័យថា "ទ្រង់យំ"។ នៅក្នុងភាសាក្រិកប្រើពាក្យថា "យំដោយស្ងាត់ស្ងៀម"។

**១១:៣៦** បទគម្ពីរនេះបញ្ជាក់ថា នៅពេលដែលពួកយូដាបានឃើញព្រះយេស៊ូវ ទ្រង់ព្រះកន្សែង ពួកគេដឹងថាទ្រង់ស្រឡាញ់ឡាសារខ្លាំងណាស់ ។ ដូច្នេះ នៅពេលដែលទ្រង់បង្ហូរព្រះលោហិតនៅលើឈើឆ្កាង តើបញ្ជាក់ថាទ្រង់ស្រឡាញ់មនុស្ស លោកយ៉ាងណា ?

**១១:៣៧** ខនេះបញ្ជាក់ថា មានពួកយូដាជាច្រើនបានឃើញ និងដឹងថា ព្រះយេស៊ូវ មានអំណាចព្រះចេស្តា ក្នុងការប្រោសមនុស្សខ្វាក់ឱ្យបានភ្លឺវិញ ដូច្នោះហើយ បានជាពួកគេនិយាយគ្នាថា តើទ្រង់អាចប្រោសឡាសារ ឱ្យរស់ឡើងវិញបានដែរឬទេ?

**១១:៣៨** *ផ្នូរនោះជារអាងភ្នំ ហើយមានថ្ម១បិទសន្ទប់* ជាធម្មតា នៅសម័យនោះ គេតែងតែធ្វើផ្នូរមានលក្ខណៈយ៉ាងដូច្នេះ សម្រាប់បញ្ចុះសព ជាពិសេសចំពោះគ្រួសារដែលមានជីវភាពសមរម្យ (២០:១ មក ១៥:៤៦ លក ២៤:២) ។

**១១:៣៩** *៤ថ្ងៃ* "មើលការពន្យល់ ខ.៤,១៧"។

**១១:៤០** *សិរីល្អនៃព្រះ* "មើលការពន្យល់ ខ.៤"។

**១១:៤៤** *សំពត់ស្នប* គឺសំពត់ដែលរុំសព (មើលការពន្យល់ ១៩:៤០) ។

**១១:៤៥** *នោះមានគ្នាជាច្រើនជឿដល់ទ្រង់* ត្រង់ចំណុចនេះបញ្ជាក់ថា នៅពេលបានឃើញព្រះយេស៊ូវប្រោសឡាសារ ឱ្យបានរស់ពីស្លាប់ឡើងវិញ នោះមានពួកសាសន៍យូដាជាច្រើន ដែលពីមុនមិនព្រមទទួលជឿ និងប្រហែលខ្លះទៀតធ្លាប់តែប្រឆាំងនឹងទ្រង់ ក៏បានទទួលជឿដល់ទ្រង់ (មើលការពន្យល់ ១:៧,១៩ ២០:៣១) ។

**១១:៤៦** *ពួកផារិស៊ី* "មើលការពន្យល់ ៧:៣២"។

**១១:៤៧** *ពួកសង្គ្រាជ និងពួកផារិស៊ី* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកផារិស៊ីគឺជាអ្នកតំណាងសម្រាប់ការប្រឆាំងនឹងព្រះយេស៊ូវ ក្នុងដំណើរមហាបេសកកម្មរបស់ទ្រង់នៅលើផែនដី ។ ពួកនេះពុំមានអំណាចគ្រប់គ្រាន់ នៅក្នុងហេតុការណ៍ឆ្កាងព្រះយេស៊ូវទេ ប៉ុន្តែ មានពួកសង្គ្រាជជាអ្នកជួយជ្រោមជ្រែង (មើលការពន្យល់ មថ ២:៤) ។ ពួកទាំងនេះពុំអាចបដិសេធចំពោះសេចក្តីពិត និងការអស្ចារ្យទាំងឡាយ ដែលព្រះយេស៊ូវទ្រង់ធ្វើបានទេ (មើលការពន្យល់ ២:១១) ។ ម្យ៉ាងទៀត ពួកគេពុំយល់នូវទង្វើរបស់ខ្លួន ថាជាការត្រឹមត្រូវ ឬជាការខុសនោះទេ ព្រោះពួកគេមិនព្រមជឿដល់ទ្រង់ ហើយក៏គ្មានសេចក្តីពិតនៅក្នុងខ្លួនដែរ ។

**១១:៤៨** ពួកអ្នកដឹកនាំសាសន៍យូដាមានការភ័យខ្លាចថា នៅពេលដែលមានមនុស្សច្រើនបានទទួលជឿដល់ព្រះយេស៊ូវ ជាព្រះមែស៊ីដែលត្រូវយាងមក

នឹងមកចាប់យកទាំងស្រុក នឹងជាតិយើងផង ៤៩មានក្រុម
ជំនុំម្នាក់ឈ្មោះកៃផា[ម] ដែលធ្វើជាសំដេចសង្ឃក្នុងឆ្នាំនោះ[យ]
លោកមានប្រសាសន៍ថា អ្នករាល់គ្នាមិនដឹងអ្វីសោះ ៥០ក៏
មិនគិតពិចារណាឃើញថា បើមានមនុស្សម្នាក់ស្លាប់ជំនួស
បណ្ដាជន នោះមានប្រយោជន៍ ដល់អ្នករាល់គ្នាជា
ជាង ដើម្បីកុំឱ្យជាតិយើងនេះត្រូវវិនាសទាំងអស់ឡើយ[រ]
៥១តែលោកមិននិយាយសេចក្ដីនោះ ដោយអាងតែខ្លួន
លោកទេ គឺដោយព្រោះលោកជាសំដេចសង្ឃនៅឆ្នាំនោះ
បានជាលោកទាយថា ព្រះយេស៊ូវត្រូវសុគតជំនួសសាសន៍
នោះ ៥២ហើយមិនជំនួសត្រឹមតែសាសន៍នោះប៉ុណ្ណោះ គឺ
សុគតដើម្បីឱ្យអស់ទាំងកូននៃព្រះ ដែលខ្ចាត់ខ្ចាយទៅបាន
ប្រមូលរួមមកជាសាសន៍តែ១ដែរ[ល] ៥៣ដូច្នេះ ចាប់តាំង
ពីថ្ងៃនោះមក គេក៏ពិគ្រោះគ្នានឹងសំឡាប់ទ្រង់ចេញ[វ]។
៥៤ហេតុនោះបានជាព្រះយេស៊ូវ មិនបានយាងនៅក្នុង
ពួកសាសន៍យូដា[ស] ឱ្យគេឃើញទៀតទេ គឺទ្រង់យាងទៅ
ឯស្រុកស្រែ ក្បែរទីរហោស្ថានវិញ ដល់ភូមិ១ហៅថា
អេប្រាអិម ក៏គង់នៅទីនោះជាមួយនឹងពួកសិស្ស ។
៥៥រីឯបុណ្យរំលង[ហ] របស់សាសន៍យូដា នោះជិតដល់
ហើយ ក៏មានមនុស្សជាច្រើនចេញពីស្រុកស្រែ ឡើងទៅឯ

**១១:៤៩** ម មថ ២៦:៣
យ ខ.៥១
យហ ១៨:១៣,១៤
**១១:៥០** រ យហ
១៨:១៤
**១១:៥២** ល អស
៤៩:៦ យហ ១០:១៦
**១១:៥៣** វ មថ
១២:១៤
**១១:៥៤** ស យហ
៧:១
**១១:៥៥** ហ នក
១២:១៣,២៣,២៧
មថ ២៦:១,២
មក ១៤:១
យហ ១៣:១
ឡ ២របា ៣០:១៧,១៨
**១១:៥៦** អ យហ
៧:១១
**១២:១** ក យហ
១១:៥៥
ខ មថ ២១:១៧
**១២:២** គ លក
១០:៣៨-៤២
**១២:៣** ឃ មក ១៤:៣

ក្រុងយេរូសាឡិម មុនបុណ្យនោះ ដើម្បីឱ្យបានញែកខ្លួន
ជាបរិសុទ្ធ[ឡ] ៥៦ពួកអ្នកទាំងនោះកំពុងតែឈរនៅក្នុងព្រះ
វិហារ សួរគ្នារកព្រះយេស៊ូវ[អ]ថា លោកនោះមិនមកឯ
បុណ្យនេះទេឬអី តើគិតដូចម្ដេច ៥៧ឯពួកសង្គ្រាជ នឹង
ពួកផារិស៊ីបានបង្គាប់មកថា បើអ្នកណាដឹងជាទ្រង់គង់ នៅ
ឯណា នោះត្រូវប្រាប់ឱ្យគេដឹងផង ដើម្បីឱ្យគេបានទៅចាប់
ទ្រង់ ។

## ព្រះយេស៊ូវទទួលការចាក់ប្រេងនៅភូមិបេថានី

*១២:១-៨ មថ ២៦:៦-១៣ មក ១៤:៣-៩ លក ៧:៣៧-៣៩*

**១២** ១កាលមុនបុណ្យរំលង៦ថ្ងៃ[ក] នោះព្រះយេស៊ូវទ្រង់
យាងមកដល់ភូមិបេថានី[ខ] ជាកន្លែងឡាសារនៅ គឺជាអ្នក
ដែលទ្រង់បានប្រោសឱ្យរស់ពីស្លាប់ឡើងវិញ ២នៅទីនោះ
គេរៀបចំព្រះស្ងោយថ្វាយទ្រង់ ហើយនាងម៉ាថា ក៏ខ្វល់
ខ្វាយបំរើ[គ] ឯឡាសារ គាត់នៅក្នុងពួកអ្នកដែលអង្គុយនៅតុ
ជាមួយនឹងទ្រង់ដែរ ៣នោះនាងម៉ារា យកប្រេងក្រអូប[ឃ]
ទេព្វិរូសុទ្ធ១នាឡិ មានដំឡៃណាស់ មកចាក់លាបព្រះបាទ
ទ្រង់ រួចយកសក់នាងជូត[ង] ក្លិនក្រអូបនោះក៏សាយឡើង
ពេញក្នុងផ្ទះ ។

ង យហ ១១:២

មែននោះ ពួកគេនឹងនាំគ្នាលើកទ្រង់ធ្វើជាស្ដេច ជាហេតុនាំឱ្យមានចលាចលនៅក្នុងស្រុក និងធ្វើឱ្យពួករ៉ូម៉ាំងគិតថា ពួកគេ (ពួកយូដា) ចង់បះបោរប្រឆាំង ។ ជាលទ្ធផល គឺពួករ៉ូម៉ាំងនឹងដកយកសិទ្ធិគ្រប់គ្រងលើទឹកដី និងព្រះវិហារក្នុងក្រុងយេរូសាឡិម ចេញពីពួកគេទាំងស្រុង ។ ម្យ៉ាងទៀត ប្រសិនបើហេតុការណ៍ទាំងនោះកើតឡើងមែន ពួកអ្នកដឹកនាំសាសន៍យូដានឹងបាត់បង់នូវផលប្រយោជន៍ ឋានៈ និងកិត្តិយសរបស់ខ្លួនជាមិនខាន ។

**១១:៤៩** *កៃផា* ជាសម្ដេចសង្ឃនៅឆ្នាំទី ១៨-៣៦គ.ស ។ គាត់ជាកូនប្រសាររបស់លោកអាណ (ជាសម្ដេចសង្ឃនៅឆ្នាំ ៦-១៥ គ.ស ហើយត្រូវបានពួករ៉ូម៉ាំងទម្លាក់ពីតំណែងនៅឆ្នាំទី១៦គ.ស មើលការពន្យល់ ១៨:១៣ កថ ៤:៦) ។ *អ្នករាល់គ្នាមិនដឹងអ្វីសោះ* ចំណុចនេះបង្ហាញឱ្យឃើញ នូវគំនិតដ៏អាក្រក់របស់លោកកៃផា និងពួកសាឌូស៊ី ។ លោកយ៉ូសែបហ្វីស (Jusephus ) បានសរសេរថា ពួកសាឌូស៊ី តែងមានគំនិតអាក្រក់ ទាំងចំពោះគូកនខ្លួន និងអ្នកដទៃ (មើលពន្យល់ មថ ៣:៧) ។

**១១:៥០** លោកកៃផាមិនខ្វល់អំពីភាពសុចរិត និងទុច្ចរិតទេ គឺគាត់គិតតែពីរឿងនយោបាយប៉ុណ្ណោះ ។ គាត់ជឿថា មនុស្សម្នាក់ មិនថា អ្នកនោះសុចរិតប៉ុនណាទេ គឺត្រូវវិនាសដូចគ្នា នៅពេលដែលប្រទេសជាតិត្រូវអន្តរាយ ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅឆ្នាំទី៧0គ.ស ពួកគេនៅតែត្រូវវិនាសដដែល។

**១១:៥២** *កូននៃព្រះ ដែលខ្ចាត់ខ្ចាយទៅ* ឃ្លានេះបញ្ជាក់ថា ព្រះយេស៊ូវទ្រង់សុគត សម្រាប់មនុស្សបាត់បង់ ដែលរស់នៅក្នុងប្រជាជាតិឆ្ងាយៗដែរ (១:២៩ ៣:១៦ ៤:៤២ ១០:១៦) ។

**១១:៥៤** *មិនបានយាង . . . ឱ្យគេឃើញទៀតទេ* មានន័យថា ព្រះយេស៊ូវទ្រង់មិនបានបង្រៀនពួកបណ្ដាជននៅតាមទីសាធារណៈ ឬតាមទីក្រុងនានាទៀតទេ ។

**១១:៥៥** *បុណ្យរំលង* "មើលការពន្យល់ ២:១៣ ៥:១"។ *ដើម្បីឱ្យបានញែកខ្លួនជាបរិសុទ្ធ* បញ្ជាក់ថា ពួកសាសន៍យូដា តែងតែឡើងទៅឯទីក្រុងយេរូសាឡិម ដើម្បីញែកខ្លួនជាបរិសុទ្ធ មុនពេលថ្ងៃបុណ្យរំលងមកដល់ (មើលការពន្យល់ ២:៦ ១៨:២៨) ។

**១១:៥៦** *លោកនោះមិនមកឯបុណ្យនេះទេឬអី តើគិតដូចម្ដេច?* ពួកគេសួរគ្នាទៅវិញទៅមកយ៉ាងដូច្នេះ ដោយគិតថា ព្រះយេស៊ូវមិនយាងមកក្នុងពិធីបុណ្យរំលងនោះទេ ។

**១២:១-១១** នៅក្នុងព្រះគម្ពីរដំណឹងល្អទាំងបួន សុទ្ធតែមាននិយាយអំពីការដែលស្ត្រីចាក់ប្រេងក្រអូបលាបថ្វាយព្រះយេស៊ូវ ។ សេចក្ដីដែលលោកយ៉ូហានលើក ឡើងនៅត្រង់ចំណុចនេះ មានលក្ខណៈស្រដៀងគ្នានឹងសេចក្ដីដែលមានចែងនៅ ក្នុង"មថ ២៦:៦-១៣ និង មក ១៤:៣-៩"ដែរ ។ រីឯសេចក្ដីដែលនិយាយអំពីការចាក់ប្រេងក្រអូបលាបថ្វាយព្រះយេស៊ូវ នៅក្នុងព្រះគម្ពីរដំណឹងល្អលូកាវិញ មានលក្ខណៈប្លែកអំពីព្រះគម្ពីរដំណឹងល្អ៣ផ្សេងទៀត ។

**១២:១** *ភូមិបេថានី* "មើលការពន្យល់ មថ ២១:១៧"។

**១២:៣** *ទេព្វិរូ* ជាឈ្មោះឈើមួយប្រភេទ ដែលសំបក និងប្រេងរបស់វាមានក្លិនក្រអូប ។ ប្រេងរបស់វាឈ្មោះថា ប្រេងទេព្វិរូ និងមានតម្លៃណាស់ ។ ដូច្នេះការដែលនាងម៉ារាធ្វើនោះ មានអត្ថន័យសំខាន់ណាស់ ។ ម្យ៉ាងទៀត អ្វីដែលនាងធ្វើ គឺមានលក្ខណៈខុសប្លែកពីអ្នកដទៃ ពីព្រោះធម្មតាគេយកប្រេងនោះទៅលាបក្បាល ប៉ុន្តែ នាងបែរជាយកទៅលាបព្រះបាទរបស់ព្រះយេស៊ូវ ហើយថែមទាំងយកសក់របស់នាងទៅជូតទៀត (ជាទូទៅពួក

៤ដូច្នេះ ពួកសិស្សទ្រង់ម្នាក់ ឈ្មោះយូដាស-អ៊ីស្ការីយ៉ុត
ជាកូនស៊ីម៉ូន ដែលរៀបនឹងបញ្ជូនទ្រង់[ច] ក៏និយាយឡើងថា
៥ម្តេចឡើយក៏មិនបានលក់ប្រេងក្រអូបនេះ ជាដំឡៃ៦០
រៀល ដើម្បីចែកឱ្យដល់មនុស្សក្រីក្រវិញ ៦វានិយាយ
ដូច្នោះ មិនមែនដោយព្រោះវាយកចិត្តទុកដាក់នឹងមនុស្ស
ក្រីក្រទេ គឺដោយព្រោះវាជាចោរ វាកាន់ថង់ប្រាក់[ឆ]
ហើយ ក៏លួចយករបស់ដែលដាក់នៅក្នុងថង់នោះផង
៧ព្រះយេស៊ូវមានបន្ទូលថា កុំឱ្យធ្វើនាងឡើយ ដ្បិត
នាងបានទុកប្រេងក្រអូបនេះ សំរាប់ដល់ថ្ងៃបញ្ចុះខ្មោចខ្ញុំ[ជ]
៨ឯអ្នករាល់គ្នា តែងតែមានពួកអ្នកក្រនៅជាមួយជាដរាប[ឈ]
តែខ្ញុំមិននៅជាមួយជាដរាបទេ។
៩មានពួកសាសន៍យូដាសន្ធឹកណាស់បានដឹងថា ទ្រង់គង់
នៅទីនោះ ដូច្នេះ គេក៏នាំគ្នាមក តែមិនមែនដោយព្រោះ
ព្រះយេស៊ូវប៉ុណ្ណោះ គឺមកចង់ឃើញឡាសារ ដែលទ្រង់
ប្រោសឱ្យរស់ពីស្លាប់ឡើងវិញផង[ញ] ១០តែពួកសង្គ្រាជ គេ
ជំនុំគ្នា នឹងសំឡាប់ទាំងឡាសារដែរ ១១ដ្បិតដោយព្រោះ
តែគាត់[ដ] បានជាមានសាសន៍យូដាជាច្រើន ដកខ្លួនចេញពី
ពួកគេ ទៅជឿដល់ព្រះយេស៊ូវវិញ[ឋ]។

**ក្បួនដង្ហែរនៃជ័យជម្នះ**

*១២:១២-១៥- មថ ២១:៤-៩ មក ១១:៧-១០ លក ១៩:៣៥-៣៨*

១២លុះថ្ងៃស្អែកឡើង កាលបណ្តាមនុស្ស ដែលមកឯ
បុណ្យ បានឮថា ព្រះយេស៊ូវកំពុងយាងចូលមកក្នុងក្រុង
យេរូសាឡិម ១៣នោះមានគ្នាសន្ធឹក យកធាងចាកចេញ[ឌ]
ទៅទទួលទ្រង់ ទាំងស្រែកថា ហូសាណា ព្រះអង្គដែល
យាងមកដោយព្រះនាមព្រះអម្ចាស់[ឍ] គឺជាស្តេចនៃសាសន៍
អ៊ីស្រាអែល ទ្រង់ប្រកបដោយព្រះពរ[ណ]។
១៤កាលព្រះយេស៊ូវ រកបានកូនលា ១ នោះក៏គង់លើវា
តាមសេចក្តីដែលចែងទុកមកថា ១៥កុំខ្លាចអ្វី កូនស្រីស៊ី
យ៉ូនអើយ មើលស្តេចឯងទ្រង់យាងមក ទាំងគង់លើកូន
លា[ត] ១៦មុនដំបូង ពួកសិស្សទ្រង់មិនបានយល់សេចក្តី
ទាំងនោះទេ[ថ] តែកាលព្រះយេស៊ូវបានដំកើងឡើងហើយ[ទ]
នោះគេនឹកឃើញថា មានសេចក្តីទាំងនោះចែងទុកពី
ទ្រង់ហើយថា គេបានសំរេចការទាំងនោះថ្វាយទ្រង់ដែរ
១៧រីឯហ្វូងមនុស្ស ដែលនៅជាមួយនឹងទ្រង់[ធ] គេក៏ធ្វើ

**១២:៤** ច មថ ១០:៤
**១២:៦** ឆ យហ ១៣:២៩
**១២:៧** ជ យហ ១៩:៤០
**១២:៨** ឈ ចទ ១៥:១១
**១២:៩** ញ យហ ១១:៤៣,៤៤
**១២:១១** ដ ខ.១៧,១៨ យហ ១១:៤៥
ឋ យហ ៧:៣១
**១២:១៣** ឌ លវ ២៣:៤០
ឍ ទដ ១១៨:២៥,២៦
ណ យហ ១:៤៩
**១២:១៥** ត សក ៩:៩
**១២:១៦** ថ មក ៩:៣២ ទ ខ.២៣ យហ ២:២២ ៧:៣៩
**១២:១៧** ធ យហ ១១:៤២

ស្ត្រីមានកិត្តិយសភាគច្រើន មិនទម្លាក់សក់នៅតាមទីសាធារណៈទេ)។ ការនេះបញ្ជាក់អំពីការបន្ទាបខ្លួន និងភាពជាអ្នកបម្រើដ៏ពិតប្រាកដ (១:២៧ ១៣:៥)។

**១២:៤** *យូដាស-អ៊ីស្ការីយ៉ុត* "មើលការពន្យល់ ៦:៧១ ១៧:១២"។

**១២:៥** *ដើម្បីចែកឱ្យដល់មនុស្សក្រីក្រវិញ* "មើលការពន្យល់ មក ១៤:៥"។

**១២:៦** *ដោយព្រោះវាជាចោរ* ឃ្លានេះបញ្ជាក់ថា យូដាស-អ៊ីស្ការីយ៉ុតគឺជាមនុស្សមិនស្មោះត្រង់ទេ ប៉ុន្តែដោយព្រោះគាត់ជាអ្នកកាន់ថង់ប្រាក់ ប្រហែលជាអាចបញ្ជាក់ថា គាត់ក៏ត្រូវបានគេទុកចិត្តដែរ ។

**១២:៧** *នាងបានទុកប្រេងក្រអូបនេះ សំរាប់ដល់ថ្ងៃបញ្ចុះខ្មោចខ្ញុំ* ត្រង់ចំណុចនេះបញ្ជាក់ថា នាងម៉ារាគ្មានចេតនា និងគំនិតរក្សាប្រេងក្រអូបនោះ ដើម្បីទុកសម្រាប់ថ្ងៃបញ្ចុះសពរបស់ព្រះយេស៊ូវទេ (១៩:៣៩-៤០)។

**១២:៨** *តែងតែមានពួកអ្នកក្រនៅជាមួយជាដរាប* មើលពន្យល់ មក ១៤:៧

**១២:៩** នៅមុនបុណ្យរំលង៦ថ្ងៃ ព្រះយេស៊ូវទ្រង់បានយាងទៅឯភូមិបេថានី ជាភូមិដែលឡាសាររស់នៅ(ខ.១)។ នៅពេលដែលពួកបណ្តាជននៅទីក្រុងយេរូសាឡិមបានឮថា ព្រះយេស៊ូវយាងទៅឯភូមិបេថានី ពួកគេក៏ទៅទីនោះដើម្បីជួបទ្រង់ និងចង់ឃើញឡាសារ ដែលទ្រង់បានប្រោសឱ្យរស់ឡើងវិញផង ។

**១២:១០** ក្នុងបទគម្ពីរនេះបញ្ជាក់ថា ពួកអ្នកដឹកនាំសាសន៍យូដា ពីមុនចង់សម្លាប់តែព្រះយេស៊ូវទេ (មើលការពន្យល់ ១១:៥០) ប៉ុន្តែឥឡូវពួកគេចង់សម្លាប់ទាំងឡាសារទៀត ។ ដូច្នេះមានន័យថា អំពើបាបកាន់តែរីកធំឡើងនៅក្នុងពួកគេ (យក ១:១៥)។

**១២:១២** *បណ្តាមនុស្ស* សំដៅលើពួកអ្នកដែលមកចូលរួមក្នុងពិធីបុណ្យរំលង ។ ក្នុងចំណោមពួកទាំងនោះ ពិតជាមានអ្នកដែលបានឃើញព្រះយេស៊ូវនៅឯស្រុកកាលីឡេ ហើយពួកគេចង់ឃើញទ្រង់សម្តែងអង្គទ្រង់ថាទ្រង់គឺជាព្រះមែស៊ីដែលត្រូវយាងមកនោះមែន ។

**១២:១៣** *ធាងចាក* "មើលការពន្យល់ មក ១១:៨"។ គេប្រើធាងចាកនៅក្នុងពិធីអបអរសាទរនៃជ័យជម្នះ ។ លោកយ៉ូហានបានឃើញមនុស្សមួយហ្វូងយ៉ាងធំនៅស្ថានសួគ៌ កាន់ធាងចាកនៅដៃ (វវ ៧:៩)។ *ហូសាណា* មានន័យថា "សូមទ្រង់ សង្គ្រោះឥឡូវ" ឬ "សូមទ្រង់ជួយសង្គ្រោះទូលបង្គំ" (មើលពន្យល់ មថ ២១:៩)។ *ព្រះនាមព្រះអម្ចាស់* "មើលការពន្យល់ ២:២៣"។ *ជាស្តេចនៃសាសន៍អ៊ីស្រាអែល ទ្រង់ប្រកបដោយព្រះពរ* ឃ្លានេះមាននិយាយតែក្នុងព្រះគម្ពីរដំណឹងល្អយ៉ូហានប៉ុណ្ណោះ ។ ពួកបណ្តាជនពោលយ៉ាងដូច្នេះគឺបន្ថែមលើព្រះបន្ទូលនៅក្នុងបទគម្ពីរ ទំនុកដំកើង ដើម្បីសំដែងនូវការពេញចិត្តចំពោះព្រះយេស៊ូវ ដែលនាំមកនូវការផ្លាស់ប្រែសម្រាប់ប្រជាជាតិរបស់ខ្លួន ។

**១២:១៤** *កូនលា* "មើលការពន្យល់ សក ៩:៩ មថ ២១:២,៧ មក ១១:២ លក ១៩:៣០"។

**១២:១៥** *កូនស្រីស៊ីយ៉ូន* សំដៅលើពួកអ្នកដែលរស់នៅក្នុងទីក្រុងយេរូសាឡិម (២ពវ ១៩:២១)។

**១២:១៦** ត្រង់ចំណុចនេះបញ្ជាក់ថា ពួកសិស្សរបស់ព្រះយេស៊ូវពុំបានយល់ច្បាស់ នូវសេចក្តីដែលទ្រង់មានបន្ទូលទៅកាន់ពួកគេនាពេលនោះទេ ប៉ុន្តែបន្ទាប់ពីទ្រង់បានតម្កើងឡើង នោះពួកគេក៏បានយល់ ដោយមានការបើកសំដែងអំពីព្រះវិញ្ញាណ បរិសុទ្ធ (១៦:១៣)។ *ដំកើងឡើង* "មើលការពន្យល់ ខ.៤១ ១១:៤ ១៣:៣១"។ បន្ទាប់ពីព្រះយេស៊ូវសុគត ហើយរស់ឡើងវិញ និងបានប្រទានព្រះវិញ្ញាណបរិសុទ្ធមក ទើបពួកសាវ័ករបស់ទ្រង់ បានយល់នូវសេចក្តីទំនាយ ដែលចែងថា ទ្រង់ត្រូវ តម្កើងឡើង ។

**១២:១៧-១៩** ត្រង់ចំណុចនេះបញ្ជាក់ថា មានមនុស្សជាច្រើនដើរតាមព្រះយេស៊ូវ ព្រោះបានឃើញទ្រង់ប្រោសឡាសារឱ្យរស់ឡើងវិញ និងការ

បន្ទាល់ពីកាលទ្រង់ហៅឡាសារចេញពីផ្នូរមក ហើយប្រោស
ឱ្យគាត់រស់ពីស្លាប់ឡើងវិញ ១៨គឺដោយហេតុនោះ បាន
ជាមានហ្វូងមនុស្សទៅទទួលទ្រង់ ពីព្រោះគេឮថាទ្រង់បាន
ធ្វើទីសំគាល់នោះ[ន] ១៩ដូច្នេះ ពួកផារិស៊ីនិយាយគ្នាគេថា
មើល ពួកយើងមិនឈ្នះទេ ឃើញឬទេ លោកិយទាំងស្រុង
ទៅតាមអ្នកនោះហើយ[ប]។

## ព្រះយេស៊ូវថ្លែងទំនាយពីការសុគតរបស់ទ្រង់

២០ក្នុងពួកអ្នកដែលឡើងទៅថ្វាយបង្គំ នៅក្នុងវេលា
បុណ្យនោះ ក៏មានសាសន៍ក្រេកខ្លះដែរ[ផ] ២១គេមកឯភីលីព
ជាអ្នកនៅភូមិបេតសៃដា[ព] ស្រុកកាលីឡេ គេសូមគាត់ថា
លោកម្ចាស់ យើងខ្ញុំចង់ឃើញព្រះយេស៊ូវ ២២ភីលីពក៏ទៅ
ប្រាប់អនទ្រេ រួចអនទ្រេ នឹងភីលីពទៅទូលដល់ព្រះយេស៊ូវ
២៣តែទ្រង់មានបន្ទូលឆ្លើយថា កំណត់[ភ]ដែលកូនមនុស្សត្រូវ
ដំកើងឡើង បានមកដល់ហើយ[ម] ២៤ប្រាកដមែន ខ្ញុំប្រាប់អ្នក
រាល់គ្នាជាប្រាកដថា បើគ្រាប់ស្រូវ ដែលធ្លាក់ចុះទៅដីមិន
ងាប់ទេ[យ] នោះក៏នៅតែ១ដដែល តែបើងាប់វិញ នោះក៏
បង្កើតផលជាច្រើនឡើង ២៥អ្នកណាដែលស្រឡាញ់ជីវិតខ្លួន
នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលស្អប់ជីវិតខ្លួននៅ
លោកិយនេះវិញ នោះនឹងរក្សាជីវិតទុក[រ] ដរាបដល់អស់
កល្បរៀងទៅ[ល] ២៦បើអ្នកណាបំរើខ្ញុំ ត្រូវឱ្យអ្នកនោះ
មកតាមខ្ញុំចុះ យ៉ាងនោះ ទោះបើខ្ញុំនៅឯណាក្តី អ្នកបំរើ
ខ្ញុំក៏នឹងនៅទីនោះដែរ[វ] បើអ្នកណាបំរើខ្ញុំ ព្រះវរបិតានឹង
លើកមុខអ្នកនោះ។

២៧ឥឡូវនេះខ្ញុំមានចិត្តតប់ប្រមល់[ស] តើត្រូវឱ្យខ្ញុំទូល
ដូចម្តេច ឱព្រះវរបិតាអើយ[ហ] សូមជួយសង្គ្រោះទូលបង្គំ
ឱ្យរួចពីពេលនេះផង[ឡ] ប៉ុន្តែ គឺដោយហេតុនេះឯង បាន
ជាទូលបង្គំមកដល់ពេលនេះ ២៨ឱព្រះវិរបិតាអើយ សូម
ដំកើងព្រះនាមទ្រង់ឡើង នោះស្រាប់តែមានឮសំឡេង
ពីលើមេឃ[អ]ថា អញបានដំកើងហើយ ក៏នឹងដំកើងឡើង
ទៀតដែរ ២៩ដូច្នេះ បណ្តាមនុស្ស ដែលឈរនៅទីនោះ
ហើយឮ ក៏និយាយថា ឮផ្គរលាន់ ខ្លះទៀតថា មានទេវតា
ទូលនឹងទ្រង់ ៣០តែព្រះយេស៊ូវទ្រង់ឆ្លើយថា សំឡេងនេះ
មិនមែនឮ ដោយព្រោះខ្ញុំទេ គឺដោយយល់ដល់អ្នករាល់គ្នា
វិញ[ក] ៣១ឥឡូវ លោកិយនេះត្រូវជាប់ទោសហើយ[ខ] ឥឡូវ

**១២:១៨** ន ខ.១១ លក ១៩:៣៧
**១២:១៩** ប យហ ១១:៤៧,៤៨
**១២:២០** ផ យហ ៧:៣៥ កច ១១:២០
**១២:២១** ព មថ ១១:២១
**១២:២៣** ភ មថ ២៦:១៨ ម យហ ១៣:៣២ ១៧:១
**១២:២៤** យ ១កថ ១៥:៣៦
**១២:២៥** រ មថ ១០:៣៩ មក ៨:៣៥ លក ១៤:២៦ ១៧:៣៣ ល មថ ២៥:៤៦
**១២:២៦** វ យហ ១៤:៣ ១៧:២៤ ២កថ ៥:៨ ភល ១:២៣ ១ថន ៤:១៧
**១២:២៧** ស មថ ២៦:៣៨,៣៩ ហ មថ ១១:២៥ ឡ ខ.២៣
**១២:២៨** អ មថ ៣:១៧

អស្ចារ្យផ្សេងៗដែលកើតឡើងដោយសារទ្រង់ ។ ក្នុងពេលជាមួយគ្នានោះដែរ ពួកអ្នកដឹកនាំសាសន៍យូដាមិនសប្បាយចិត្តនឹងទ្រង់ទេ ព្រោះបានឃើញពួកបណ្តាជនពេញចិត្តនឹងសេចក្តីបង្រៀនរបស់ទ្រង់ ដូច្នេះបានជាពួក គេនិយាយគ្នាថា លោកិយទាំងស្រុងទៅតាមទ្រង់ហើយ (យហ ១១:៤៧–៤៨) ។ ម្យ៉ាងទៀត ដោយព្រោះមានមនុស្សច្រើនមកឯព្រះយេស៊ូវ ធ្វើឱ្យគម្រោងការដែលពួកផារិស៊ីចង់សម្លាប់ទ្រង់នោះ កាន់តែមានភាពលំបាក ដូច្នេះ ទើបធ្វើឱ្យពួកគេកាន់តែមានកំហឹងខ្លាំងឡើង ។ *ពួកផារិស៊ី* "មើលការពន្យល់ ៧:៣២"។

**១២:២០** *ក៏មានសាសន៍ក្រិកខ្លះដែរ* គឺសំដៅលើពួកសាសន៍ក្រេកដែលគោរពប្រតិបត្តិដល់ព្រះអម្ចាស់ ឬពួកអ្នកដែលប្រតិបត្តិតាមសេចក្តីសញ្ញាចាស់ ។ ពួកនេះថ្វាយបង្គំនៅតាមសាលាប្រជុំ ប៉ុន្តែ ពុំត្រូវបានពួកសាសន៍យូដារាប់ថា ជាអ្នកចូលសាសន៍ទេ (កច ១៦:១៤) ។

**១២:២១** ដោយព្រោះឈ្មោះរបស់លោកភីលីពគឺជាភាសាក្រិក នេះប្រហែលជាមូលហេតុ ដែលធ្វើឱ្យពួកសាសន៍ក្រិកទាំងនោះមកឯគាត់ ដើម្បីសួរគាត់ថា តើព្រះយេស៊ូវគង់នៅឯណា ។ *ខ្ញុំចង់ឃើញព្រះយេស៊ូវ* ឃ្លានេះអាចបញ្ជាក់ថា ពួកសាសន៍ក្រិកទាំងនោះ មិនគ្រាន់តែចង់ឃើញព្រះយេស៊ូវប៉ុណ្ណោះទេ គឺពួកគេចង់ដឹងសេចក្តីផ្សេងៗជាច្រើនពីទ្រង់ថែមទៀតផង (មើលការពន្យល់ ខ.៣២) ។ ការដែលពួកសាសន៍ក្រិកទាំងនោះ មកឯព្រះយេស៊ូវ គឺជាជោគជ័យរបស់ទ្រង់ និងបញ្ជាក់ឱ្យឃើញថា ការសុគតរបស់ទ្រង់ គឺសម្រាប់មនុស្សទាំងអស់នៅលើ ពិភពលោកនេះ ។ *ភូមិបេតសៃដា* "មើលការពន្យល់ មថ ១១:២១"។

**១២:២២** *អនទ្រេ* "មើលការពន្យល់ ១:៤"។

**១២:២៣** *កំណត់ដែលកូនមនុស្សត្រូវដំកើងឡើង បានមកដល់ហើយ* នៅពេលដែលព្រះយេស៊ូវជ្រាបថា មានពួកសាសន៍ដទៃ (សាសន៍ក្រិក) បានមករកទ្រង់ នោះទ្រង់ក៏មានបន្ទូលថា កំណត់ដែលទ្រង់ត្រូវតម្កើងឡើង បានមកដល់ហើយ (១៧:១) ។ *កូនមនុស្សត្រូវដំកើងឡើង* សំដៅលើការដែលព្រះយេស៊ូវត្រូវសុគត និងរស់ឡើងវិញ ហើយនិងត្រូវលើកឡើងទៅស្ថានសួគ៌ (មើលការពន្យល់ ខ.៤១ ១១:៤ ១៣:៣១) ។

**១២:២៤** *តែបើងាប់វិញ នោះក៏បង្កើតផល* ឃ្លានេះគឺជាការប្រៀបធៀបទៅនឹង ជីវិតដែលបានមក ដោយសារតែការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ ។

**១២:២៥** *អ្នកណាដែលស្អប់ជីវិតខ្លួន នៅលោកីយនេះវិញ នោះនឹងរក្សាជីវិតទុក* ត្រង់ចំណុចនេះ ពុំមែនមានន័យថា ឱ្យយើងស្អប់រូបកាយ ឬជីវិតរបស់យើងទេ ប៉ុន្តែ គឺមិនឱ្យយើងស្រលាញ់ជីវិតដែលរស់នៅតាមរបៀបលោកិយ និងជីវិតដែលស្ថិតនៅក្រោមអំណាចនៃអំពើបាបវិញ (មក ៨:៣៤,៣៥ លក ៩:២៣,២៤ មឡ ១:៣ លក ១៤:២៦)។ *ជីវិត . . . អស់កល្ប* "មើលការពន្យល់ ៣:១៥"។

**១២:២៧** *ខ្ញុំមានចិត្តតប់ប្រមល់* ឃ្លានេះមានលក្ខណៈស្រដៀងគ្នានឹងសេចក្តីដែលមានចែងនៅក្នុងព្រះគម្ពីរដំណឹងល្អម៉ាកុស និងលូកាដែរ (មើលការពន្យល់ មក ១៤:៣៤–៣៦ លក ២២:៤២) ។ ម្យ៉ាងទៀត ព្រះយេស៊ូវគឺជាព្រះមួយរយភាគរយ និងជាមនុស្សមួយរយភាគរយ ។ ដូច្នេះ បញ្ជាក់ថា ក្នុងភាពជាមនុស្ស ទ្រង់ក៏មានការឈឺចាប់ និងទុក្ខលំបាកផ្សេងៗដែរ (មក ១៤:៣២–៣៤ ២កថ ៥:២១) ។ *ឱ្យរួចពីពេលនេះផង* ពាក្យថា "ពេល" ត្រង់ចំណុចនេះ គឺសំដៅលើពេលវេលា ដែលព្រះយេស៊ូវត្រូវសុគត ដើម្បីសង្គ្រោះមនុស្សលោកឱ្យរួចផុតពីអំណាចនៃសេចក្តីស្លាប់ (មើលការពន្យល់ ២កថ ៥:២១)

**១២:២៨** *ឱព្រះវរបិតាអើយ សូមដំកើងព្រះនាមទ្រង់ឡើង* ឃ្លានេះមានន័យថា ព្រះវរបិតាបានតម្កើងឡើង តាមរយៈការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ

នេះ ចៅហ្វាយរបស់លោកីយនេះ[ក] ក៏ត្រូវបោះចោលចេញ
៣២ឯខ្ញុំ បើសិនជាខ្ញុំត្រូវលើកពីដីឡើង[ខ] នោះខ្ញុំនឹងទាញ
មនុស្សទាំងអស់មកឯខ្ញុំ[ង] ៣៣ទ្រង់មានបន្ទូលសេចក្ដីទាំងនេះ
ដើម្បីនឹងបង្ហាញ ពីទ្រង់ត្រូវសុគតជាបែបយ៉ាងណា[ច]។
៣៤ហ្វូងមនុស្សទូលឆ្លើយថា យើងខ្ញុំបានឮ ក្នុងក្រិត្យ
វិន័យ[ឆ]ថា ព្រះគ្រីស្ទទ្រង់គង់នៅអស់កល្បជានិច្ច[ជ] ចុះធ្វើ
ដូចម្ដេចបានជាថា កូនមនុស្ស[ឈ]ត្រូវលើកឡើងដូច្នេះ[ញ] តើ
អ្នកណាជាកូនមនុស្សនេះ ៣៥នោះព្រះយេស៊ូវមានបន្ទូល
ទៅគេថា ពន្លឺ[ដ]នៅជាមួយនឹងអ្នករាល់គ្នាតែបន្តិចទៀតទេ
ចូរដើរកំពុងដែលនៅមានពន្លឺចុះ [ឋ]ក្រែងលោសេចក្ដី
ងងឹតតាមអ្នករាល់គ្នាទាន់[ឌ] អ្នកណាដែលដើរក្នុងសេចក្ដី
ងងឹត នោះមិនដឹងជាទៅឯណាទេ ៣៦ចូរអ្នករាល់គ្នាជឿ
ដល់ពន្លឺ កំពុងដែលនៅមាន នៅឡើយចុះ ដើម្បីឱ្យបានធ្វើ
ជាកូននៃពន្លឺ[ឍ]។

## សាសន៍យូដាមិនព្រមជឿព្រះយេស៊ូវ

៣៧លុះព្រះយេស៊ូវមានបន្ទូលសេចក្ដីទាំងនេះហើយនោះ
ទ្រង់ក៏យាងចេញទៅ ហើយបានកំបាំងពីគេ[ណ] ប៉ុន្តែទោះ
បើទ្រង់បានធ្វើទីសំគាល់[ត] នៅមុខគេជាច្រើនទាំងម្ល៉េះក៏
ដោយ គង់តែគេមិនបានជឿដល់ទ្រង់ដែរ ៣៨ដើម្បីឱ្យ
ពាក្យរបស់ហោរាអេសាយបានសំរេច ដែលទាយថា «ព្រះ
អម្ចាស់អើយ តើអ្នកណាបានជឿសេចក្ដី ដែលយើងខ្ញុំប្រាប់
ហើយតើព្រះហស្តព្រះអម្ចាស់ បានបើកសំដែងមក ឱ្យអ្នក
ណាឃើញ[ថ]» ៣៩គឺដោយហេតុនោះ បានជាគេជឿពុំបាន
ពីព្រោះលោកអេសាយក៏ទាយទៀតថា ៤០«ទ្រង់បានធ្វើឱ្យ
ភ្នែកគេខ្វាក់ ហើយឱ្យចិត្តគេរឹង ក្រែងភ្នែកគេមើលឃើញ
ចិត្តគេយល់ ហើយគេប្រែគំនិត ដើម្បីឱ្យអញបានប្រោសឱ្យ
ជា[ទ]» ៤១លោកអេសាយ មានប្រសាសន៍សេចក្ដីទាំងនេះ
ពីព្រោះលោកបានឃើញសិរីល្អទ្រង់[ធ] ហើយក៏ទាយពីទ្រង់[ន]
៤២ប៉ុន្តែ នៅក្នុងពួកនាម៉ឺន ក៏មានជាច្រើននាក់បានជឿ
ដល់ទ្រង់ដែរ[ប] តែគេមិនហ៊ានប្រាប់ដល់អ្នកណាសោះ ដោយ
ព្រោះពួកផារិស៊ី[ផ] ក្រែងត្រូវកាត់ចេញពីពួកជំនុំគេទៅ[ព]
៤៣ពីព្រោះ គេចូលចិត្តនឹងសេចក្ដីសរសើររបស់មនុស្ស[ភ]

**១២:៣០** ក នក ១៩:៩ យហ ១១:៤២ **១២:៣១** ខ យហ ១៦:១១ គ យហ ១៤:៣០ ១៦:១១ ២កថ ៤:៤ អភ ២:២ ១យហ ៤:៤ ៥:១៩ **១២:៣២** ឃ ខ.៣៤ អស ១១:១០ យហ ៣:១៤,៨:២៨ ង យហ ៦:៤៤ **១២:៣៣** ច យហ ១៨:៣២ ២១:១៩ **១២:៣៤** ឆ យហ ១០:៣៤ ជ ទដ ១១០:៤ អស ៩:៧ អគ ៣៧:២៥ ដយ ៧:១៤ ឈ មថ ៨:២០ ញ យហ ៣:១៤ **១២:៣៥** ដ ខ.៤៦ ឋ អភ ៥:៨ ឌ ១យហ ១:៦ ២:១១ **១២:៣៦** ឍ ខ.៤៦ លក ១៦:៨ **១២:៣៧** ណ យហ ៨:៥៩ ត យហ ២:១១ **១២:៣៨** ថ អស ៥៣:១ រម ១០:១៦ **១២:៤០** ទ អស ៦:១០ មថ ១៣:១៣,១៥ **១២:៤១** ធ អស ៦:១–៤ ន លក ២៤:២៧ **១២:៤២** ប ខ.១១ យហ ៧:៤៨ ផ យហ ៧:១៣ ព យហ ៩:២២

(មើលការពន្យល់ ២:២៣ ១៧:១,៤ មថ ៦:៩)។

**១២:៣១** *លោកីយនេះត្រូវជាប់ទោសហើយ* ឃ្លានេះពុំមានន័យថា ការជំនុំជម្រះនៅថ្ងៃចុងបំផុតបានមកហើយនោះទេ ព្រោះព្រះយេស៊ូវទ្រង់មានព្រះបន្ទូលយ៉ាងច្បាស់ថា ទ្រង់យាងមកនៅពេលនោះ គឺមិនមែនដើម្បីជំនុំជម្រះមនុស្សលោកទេ (១២:៤៧ ៨:១៥)។ ទ្រង់នឹងយាងមកជំនុំជម្រះមនុស្សលោកទាំងអស់ នៅថ្ងៃចុងបំផុត ។ ម្យ៉ាងទៀត ការដែលព្រះយេស៊ូវសុគតនៅលើឈើឆ្កាង គឺបានបញ្ជាក់យ៉ាងច្បាស់ថា លោកិយ និងចៅហ្វាយលោកីយត្រូវជាប់ទោសហើយ (១៤:៣០ ១៦:១១)។ *ចៅហ្វាយរបស់លោកិយនេះ* សំដៅលើអារក្សសាតាំង ។ ការសុគត របស់ព្រះយេស៊ូវគ្រីស្ទនៅលើឈើឆ្កាង និងការរស់ឡើងវិញរបស់ទ្រង់ បានធ្វើឱ្យអារក្សសាតាំងត្រូវបរាជ័យទាំងស្រុង ។

**១២:៣២** *ខ្ញុំត្រូវលើកពីដីឡើង* ឃ្លានេះសំដៅលើ (១) ព្រះយេស៊ូវត្រូវគេឆ្កាងឡើង (ខ.៣៣) (២) ទ្រង់រស់ឡើងវិញ (៣) ទ្រង់ត្រូវលើកឡើងទៅស្ថានសួគ៌ (ខ.៤១ ៣:១៤ ៨:២៨ កថ ២:៣៣ ៥:៣១)។ *មនុស្សទាំងអស់មកឯខ្ញុំ* មានន័យថា ទាំងសាសន៍យូដា និងសាសន៍ដទៃនឹងមកឯព្រះយេស៊ូវ (មើលពន្យល់ ខ.២០)។

**១២:៣៤** *ក្រិត្យវិន័យ* ពាក្យនេះ សំដៅលើសេចក្ដីទាំងឡាយ ដែលមានចែងទុកនៅក្នុងព្រះគម្ពីរសញ្ញាចាស់ (១០:៣៤ ទដ ៨៩:៣០–៣៧ ១១០:៤ អស ៩:៧)។ *ព្រះគ្រីស្ទ* "មើលការពន្យល់ ១:២៥"។ *កូនមនុស្ស* "មើលការពន្យល់ ៨:៣១"។

**១២:៣៥-៣៦** *ពន្លឺ* សំដៅលើព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ ៨:១២)

**១២:៣៧-៣៨** ទោះបីពួកសាសន៍យូដា បានឃើញការអស្ចារ្យជាច្រើន ដែលព្រះយេស៊ូវទ្រង់ធ្វើ និងបញ្ជាក់ថា ទ្រង់គឺជាព្រះមែស៊ី ដែលត្រូវយាងមកក៏ដោយ ក៏មានពួកគេជាច្រើនមិនព្រមទទួលជឿដល់ទ្រង់ដែរ (អស ៥៣:១)។

**១២:៣៩** *ហេតុនោះបានជាគេជឿពុំបាន* ត្រង់ចំណុចនេះមិនមានន័យថា គ្មានអ្នកណាជឿដល់ព្រះយេស៊ូវនោះទេ ព្រោះថា នៅក្នុងដំណើរបេសកកម្មរបស់ទ្រង់ មានមនុស្សជាច្រើនបានទទួលជឿដល់ទ្រង់ ។ ម្យ៉ាងទៀត ក៏មានពួកអ្នកដឹកនាំ សាសន៍យូដាបានជឿដល់ទ្រង់ដែរ (មើលការពន្យល់ ខ.៤២)

**១២:៤០** ព្រះបន្ទូលនៅត្រង់ចំណុចនេះ គឺបានលើកយកពីបទគម្ពីរ "អស ៦:១០" (មថ ១៣:១៣–១៤ មក ៤:១២ លក ៨:១០–១១ និងការពន្យល់)។ លោកប៉ុល ក៏បានលើកយកបទគម្ពីរនេះ មកធ្វើការពន្យល់ នៅក្នុងសេចក្ដីអធិប្បាយរបស់គាត់ដែរ (កថ ២៨:២៦–២៧)។

**១២:៤១** *លោកបានឃើញសិរីល្អទ្រង់* ឃ្លានេះបញ្ជាក់ថា លោកអេសាយបានឃើញសិរីល្អរបស់ព្រះយេស៊ូវគ្រីស្ទ តាំងពីទ្រង់មិនទាន់យាងមកសុគត ដើម្បីលោះបាបមនុស្សលោកទៅទៀត ហើយក៏ទាយទុកពីទ្រង់រួចជាស្រេច (អស ៦:៣)។ សិរីល្អរបស់ព្រះយេស៊ូវ បានសម្ដែងឱ្យឃើញតាមរយៈអំណាចព្រះចេស្ដា ការសុគតនិងរស់ឡើងវិញ ហើយនិងការតម្កើងឡើងរបស់ទ្រង់ (អស ៥៣:១ ៦:១០ ហាព ១:៦,១០ និងការពន្យល់)។

**១២:៤២** *នៅក្នុងពួកនាម៉ឺន ក៏មានជាច្រើននាក់បានជឿដល់ទ្រង់ដែរ* លោកយ៉ូហានមិនបានពណ៌នាអំពីដំណើរ ដែលធ្វើឱ្យពួកអ្នកដឹកនាំសាសន៍យូដាទាំងនោះទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទទេ ប៉ុន្តែ លោកគ្រាន់តែបានបញ្ជាក់យ៉ាងច្បាស់ថា មានពួកគេជាច្រើនបានទទួលជឿដល់ទ្រង់ (មើលការពន្យល់ ១:៧)។ ទោះជាយ៉ាងណាក៏ដោយ ក៏ពួកគេទាំងនោះមិនហ៊ានប្រកាសជាចំហថាខ្លួនជា អ្នកជឿដល់ទ្រង់ទេ ព្រោះពួកគេភ័យខ្លាចត្រូវកាត់ចេញពី

ជាជាងសេចក្ដីសរសើររបស់ព្រះវិញ[ម]។
៤៤ព្រះយេស៊ូវទ្រង់បន្លឺឡើងថា អ្នកណាដែលជឿដល់ខ្ញុំ
នោះមិនមែនជឿដល់ខ្ញុំ គឺជឿដល់ព្រះអង្គ ដែលចាត់ឱ្យ
ខ្ញុំមកនោះវិញ[យ] ៤៥ហើយអ្នកណាដែលឃើញខ្ញុំ នោះក៏
ឃើញព្រះអង្គ ដែលចាត់ឱ្យខ្ញុំមកដែរ[រ] ៤៦ខ្ញុំបានមកក្នុង
លោកិយជាពន្លឺភ្លឺ[ល] ដើម្បីកុំឱ្យអ្នកណាដែលជឿដល់ខ្ញុំ ត្រូវ
នៅក្នុងសេចក្ដីងងឹតឡើយ ៤៧បើអ្នកណាឮពាក្យខ្ញុំ តែ
មិនជឿ នោះខ្ញុំមិនកាត់ទោសគេ ដ្បិតខ្ញុំមិនបានមក ដើម្បី
នឹងកាត់ទោសដល់លោកិយទេ គឺមកប្រយោជន៍នឹងសង្គ្រោះ
វិញ[វ] ៤៨អ្នកណាដែលវៀរបង់ចោលខ្ញុំ ហើយមិនទទួល
ពាក្យខ្ញុំ អ្នកនោះមានចៅក្រម ដែលកាត់ទោសខ្លួនហើយ
គឺជាពាក្យដែលខ្ញុំបាននិយាយនោះឯង ពាក្យនោះនឹងកាត់
ទោសដល់គេ[ស] នៅថ្ងៃចុងបំផុត ៤៩ដ្បិតខ្ញុំមិនបាននិយាយ
ដោយអាងខ្លួនខ្ញុំទេ គឺជាព្រះវរបិតា ដែលចាត់ឱ្យខ្ញុំមក
ទ្រង់បានបង្គាប់ខ្ញុំ[ហ] ពីសេចក្ដីដែលខ្ញុំត្រូវនិយាយ ហើយពី
ពាក្យដែលខ្ញុំត្រូវប្រាប់វិញ ៥០ខ្ញុំក៏ដឹងថា សេចក្ដីដែលទ្រង់
បង្គាប់មកនោះ ជាជីវិតដ៏នៅអស់កល្បជានិច្ច[ឡ] ដូច្នេះសេចក្ដី
អ្វីដែលខ្ញុំនិយាយ នោះខ្ញុំនិយាយតាមដែលព្រះវរបិតាបាន
ប្រាប់មក[អ]។

## ព្រះយេស៊ូវលាងជើងឱ្យពួកសិស្សទ្រង់

**១៣** ១កាលមុនបុណ្យរំលង[អ] នោះព្រះយេស៊ូវទ្រង់ជ្រាប
ថា ពេលកំណត់ដែលទ្រង់ត្រូវចេញពីលោកិយនេះ ទៅឯ
ព្រះវរបិតាវិញ[ក] បានមកដល់ហើយ[ខ] ដូច្នេះ ដែលទ្រង់បាន
ស្រឡាញ់ដល់ពួកទ្រង់ នៅក្នុងលោកិយនេះ នោះទ្រង់ក៏ចេះ
តែស្រឡាញ់គេ ដរាបដល់ចុងបំផុត ២កំពុងពេលបាយយប់
នោះឯង កាលអារក្សបានបញ្ចូលចិត្តយូដាស-អ៊ីស្ការីយ៉ុត
ជាកូនស៊ីម៉ូន ឱ្យបញ្ជូនទ្រង់ហើយ[គ] ៣នោះដោយព្រោះព្រះ
យេស៊ូវបានជ្រាបថា ព្រះវរបិតាបានប្រគល់ការទាំងអស់
មកក្នុងព្រះហស្តទ្រង់[ឃ] ហើយថា ទ្រង់មកពីព្រះ[ង] ក៏ត្រូវទៅ
ឯព្រះវិញ ៤បានជាទ្រង់ក្រោកពីសោយ ឡើងដោះព្រះពស្ត្រ
ចេញ[ច] រួចយកក្រមាមកក្រវាត់អង្គ ៥ក្រោយនោះទ្រង់ចាក់
ទឹកក្នុងចានក្លាំ ចាប់តាំងលាងជើង[ឆ]ពួកសិស្ស ហើយយក
ក្រមាដែលទ្រង់ក្រវាត់នោះ មកជូត ៦កាលទ្រង់មកដល់ស៊ី
ម៉ូន-ពេត្រុស នោះគាត់ទូលថា ព្រះអម្ចាស់អើយ ទ្រង់លាង
ជើងឱ្យទូលបង្គំឬ ៧ព្រះយេស៊ូវទ្រង់ឆ្លើយថា ការដែលខ្ញុំ
ធ្វើ នោះអ្នកមិនយល់ក្នុងពេលឥឡូវនេះទេ តែទៅមុខទើប
នឹងបានយល់ វិញ[ជ] ៨ពេត្រុសទូលប្រកែកថា ទ្រង់មិនត្រូវ
លាងជើងឱ្យទូលបង្គំសោះឡើយ ព្រះយេស៊ូវមានបន្ទូលថា
បើខ្ញុំមិនលាងឱ្យអ្នក នោះអ្នកគ្មានចំណែកជាមួយនឹងខ្ញុំទេ

**១២:៤៣** ភ ១សយ ១៥:៣០ ម រម ២:២៩ **១២:៤៤** យ មថ ១០:៤០ យហ ៥:២៤ **១២:៤៥** រ យហ ១៤:៩ **១២:៤៦** ល យហ ១:៤ **១២:៤៧** វ យហ ៣:១៧ **១២:៤៨** ស យហ ៥:៤៥ **១២:៤៩** ហ យហ ១៤:៣១ **១២:៥០** ឡ មថ ២៥:៤៦ អ យហ ១៤:២៤ **១៣:១** អ យហ ១១:៥៥ ក យហ ១៦:២៨ ខ មថ ២៦:១៨ **១៣:២** គ មថ ១០:៤ **១៣:៣** ឃ មថ ២៨:១៨ ង យហ ៨:៤២ ១៦:២៧,២៨,៣០ ១៧:៨ **១៣:៤** ច មថ ២០:២៨ **១៣:៥** ឆ លក ៧:៤៤ **១៣:៧** ជ ខ.១២

សហគមន៍របស់ខ្លួន (មើលការពន្យល់ ៣:១–២ ៩:២២ ១៩:៣៨–៣៩)។

**១២:៤៤** *ព្រះយេស៊ូវទ្រង់បន្លឺឡើង* គឺទ្រង់បន្លឺសំឡេងខ្លាំងៗតែម្ដង។ *អ្នកណាដែលជឿដល់ខ្ញុំ... គឺជឿដល់ព្រះអង្គ ដែលចាត់ឱ្យខ្ញុំមកវិញ* ត្រង់ចំណុចនេះបញ្ជាក់ថា រហូតដល់ទីបញ្ចប់នៃព្រះរាជកិច្ចរបស់ព្រះយេស៊ូវគ្រីស្ទ គឺទ្រង់ធ្វើតាម ព្រះហឫទ័យនៃព្រះវរបិតាទាំងស្រុង (១:៧ ៤:៣៤ ២០:៣១ និងការពន្យល់)។

**១២:៤៦** ក្នុងបទគម្ពីរនេះព្រះយេស៊ូវមានបន្ទូលយ៉ាងច្បាស់ថា ទ្រង់គឺជាពន្លឺដ៏ពិតប្រាកដ ហើយអស់អ្នកណាដែលជឿដល់ព្រះនាមទ្រង់ នោះមិនស្ថិតនៅក្រោមអំណាចនៃសេចក្ដីងងឹតឡើយ (មើលការពន្យល់ ខ.៣៥–៣៦)។

**១២:៤៧** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់បានយាងមកដើម្បីសង្គ្រោះមនុស្សលោក មិនមែនដើម្បីកាត់ទោសពួកគេទេ (៣:១៧–១៨)។

**១២:៤៩** *គឺជាព្រះវរបិតា... ទ្រង់បានបង្គាប់ខ្ញុំ ពីសេចក្ដីដែលខ្ញុំត្រូវនិយាយ* មានន័យថា គ្រប់សេចក្ដីទាំងអស់ដែលព្រះយេស៊ូវមានបន្ទូល គឺមកពីព្រះវរបិតា (ខ.៤៨)។ ដូច្នេះ អស់អ្នកណាដែលបដិសេធព្រះបន្ទូលរបស់ព្រះយេស៊ូវ គឺមានន័យថា បដិសេធព្រះបន្ទូលរបស់ព្រះវរបិតាដែលចាត់ឱ្យទ្រង់មកហើយ ។

**១២:៥០** *ជីវិតដ៏នៅអស់កល្បជានិច្ច* "មើលការពន្យល់ ៣:១៥"។ អស់អ្នកណាដែលទទួលជឿដល់ព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទ នោះទទួលបានជីវិតអស់កល្ប ជានិច្ច (ខ.៤៤ ៣:១៦ ១យហ ៣:២២ និងការពន្យល់)។

**១៣:១-១៧:២៦** នៅក្នុងវគ្គនេះ គឺជាសេចក្ដីសំខាន់ៗ ដែលព្រះយេស៊ូវមានបន្ទូលទៅកាន់ពួកសិស្សទ្រង់ នាពេលបាយនៅយប់មុនថ្ងៃបុណ្យរំលង ។

**១៣:១** *បុណ្យរំលង* មើលការពន្យល់ ២:១៣ ៥:១ ។ *ពេលកំណត់* មើលការពន្យល់ ២:៤"។

**១៣:២** *ពេលបាយយប់នោះ* ត្រង់ចំណុចនេះ មានមតិរបស់អ្នកជឿខ្លះយល់ថា ការពិសាអាហារជុំគ្នានាពេលយប់នោះ គឺជាការប្រកបគ្នា និងជាពិធីលៀងនៃព្រះអម្ចាស់ ដែលធ្វើឡើងនៅមុនថ្ងៃបុណ្យរំលង ។ ដូច្នេះ អាចមានន័យថា វាមិនមែនជាការពិសាអាហារ នៅក្នុងថ្ងៃបុណ្យរំលងទេ ។ *អារក្ស* វិញ្ញាណអាក្រក់ ឬសាតាំង (មើលពន្យល់ ខ.២៧)។ *យូដាស-អ៊ីស្ការីយ៉ុត* "មើលពន្យល់ ៦:៧១"។

**១៣:៣** *ព្រះវរបិតាបានប្រគល់ការទាំងអស់ មកក្នុងព្រះហស្តទ្រង់* មានន័យថា ព្រះវរបិតាប្រទានគ្រប់អំណាចព្រះចេស្ដា និងការទាំងអស់មកក្នុងព្រះហស្តរបស់ព្រះយេស៊ូវ ។ *ទ្រង់មកពីព្រះ ក៏ត្រូវទៅឯព្រះវិញ* "មើលការពន្យល់ ២០:១៧"។

**១៣:៥** *ចាប់តាំងលាងជើងពួកសិស្ស* ការលាងជើងឱ្យអ្នកណាម្នាក់ គឺជានាទីរបស់បាវបម្រើប៉ុណ្ណោះ (១:២៧)។ ព្រះយេស៊ូវលាងជើងឱ្យពួកសិស្សទ្រង់ក្នុងខណៈពេលដែលកំពុងបរិភោគអាហារតែម្ដង ។ ការនេះគឺជាគំរូដ៏សំខាន់ ដែលបង្ហាញអំពីការបន្ទាបខ្លួន ភាពជាអ្នកបម្រើ និងភាពមិនអាត្មានិយម (មើលការពន្យល់ លក ២២:២៧ ភល ២:៥–៨)។

**១៣:៨** *ទ្រង់មិនត្រូវលាងជើងឱ្យទូលបង្គំសោះឡើយ* បញ្ជាក់ថា លោក

៩សីម៉ូន–ពេត្រុសទូលទ្រង់ថា ឱព្រះអម្ចាស់អើយ បើដូច្នោះ
សូមកុំលាងត្រឹមតែជើងទូលបង្គំប៉ុណ្ណោះឡើយ គឺ សូមលាង
ដល់ទាំងដៃ ទាំងក្បាលផងចុះ ១០ព្រះយេស៊ូវមានបន្ទូលទៅ
គាត់ថា អ្នកណាដែលងូតទឹកហើយ នោះត្រូវការលាងតែ
ជើងប៉ុណ្ណោះ ឱ្យបានស្អាតទាំងអស់ ឯអ្នករាល់គ្នា ក៏បាន
ស្អាតហើយ[ឈ] តែមិនមែនទាំងអស់គ្នាទេ[ញ] ១១នេះព្រោះទ្រង់
ជ្រាបនូវអ្នកណាដែលនឹងបញ្ជូនទ្រង់[ដ] ហេតុនោះបានជា
ទ្រង់មានបន្ទូលថា អ្នករាល់គ្នាមិនមែនស្អាតគ្រប់គ្នាទេ ។
១២កាលទ្រង់បានលាងជើងគេរួច ហើយបានពាក់ព្រះ
ពស្ត្រទ្រង់វិញ នោះក៏គង់នៅតុ មានបន្ទូលទៅគេថា តើ
អ្នករាល់គ្នាយល់ការ ដែលខ្ញុំទើបនឹងធ្វើនេះឬទេ ១៣អ្នក
រាល់គ្នាហៅខ្ញុំជាលោកគ្រូ[ឋ] ហើយជាព្រះអម្ចាស់[ឌ] នោះក៏
ត្រូវមែន ពីព្រោះគឺខ្ញុំនេះហើយ ១៤ដូច្នេះ បើខ្ញុំ ដែលជា
ព្រះអម្ចាស់ ហើយជាគ្រូ បានលាងជើង ឱ្យអ្នករាល់គ្នា
នោះគួរតែឱ្យអ្នករាល់គ្នា លាងជើងដល់គ្នានឹងគ្នាដែរ[ឍ]
១៥ដ្បិតខ្ញុំបានធ្វើដំរាប់ ទុកឱ្យអ្នករាល់គ្នាហើយ ដើម្បី
ឱ្យអ្នករាល់គ្នាត្រាប់តាមការ ដែលខ្ញុំបានធ្វើឱ្យនោះ[ណ]
១៦ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បាវមិនមែន
ធំជាងចៅហ្វាយទេ[ត] ហើយអ្នកបំរើ ក៏មិនធំជាងអ្នកដែល
ប្រើដែរ ១៧បើអ្នករាល់គ្នាដឹងសេចក្តីទាំងនេះ ហើយប្រព្រឹត្ត
តាម នោះមានពរហើយ[ថ] ។

## ព្រះយេស៊ូវមានបន្ទូលអំពីអ្នកដែលបញ្ជូនទ្រង់

១៨ខ្ញុំមិនមែននិយាយពីអ្នករាល់គ្នាទាំងអស់ទេ[ទ] ខ្ញុំស្គាល់
អស់អ្នកដែលខ្ញុំបានរើស[ធ] ប៉ុន្តែបទគម្ពីរដែលថា «អ្នកដែល
បរិភោគនំបុ័ង[ន] ជាមួយនឹងទូលបង្គំ នោះបានលើកកែង
ជើង[ប]ទាស់នឹងទូលបង្គំវិញ»[ផ] ពាក្យនោះត្រូវតែបានសំរេច[ព]

**១៣:១០** ឈ យហ ១៥:៣ ញ ខ.១៨ **១៣:១១** ដ មថ ១០:៤ **១៣:១៣** ឋ មថ ២៦:១៨ យហ ១១:២៨ ឌ មថ ២៨:១៨ លក ១:៤៣ ២:១១ ៦:៤៦ ១១:១ កថ ១០:៣៦ រម ១០:៩,១២ ១៤:៩ ១កថ ១២:៣ ភល ២:១១ កល ២:៦ **១៣:១៤** ឍ ១ពត ៥:៥ **១៣:១៥** ណ មថ ១១:២៩ ១ធថ ៤:១២ **១៣:១៦** ត មថ ១០:២៤ លក ៦:៤០ យហ ១៥:២០ **១៣:១៧** ថ មថ ៧:២៤,២៥ លក ១១:២៨ យក ១:២៥ **១៣:១៨** ទ ខ.១០ ធ យហ ១៥:១៦,១៩ ន មថ ២៦:២៣

ពេត្រុសបានបដិសេធទាំងស្រុង មិនឱ្យព្រះយេស៊ូវលាងជើងរបស់គាត់ទេ ។ ការដែលលោកពេត្រុសប្រកែកយ៉ាងដូច្នេះ បង្ហាញថា គាត់ជាមនុស្សម្នាក់បន្ទាបខ្លួន (ព្រោះគាត់មិនចង់ឱ្យទ្រង់ធ្វើការនោះចំពោះខ្លួន) ប៉ុន្តែសកម្មភាពរបស់គាត់ ក៏បានបង្ហាញអំពីអំនួតផងដែរ (ព្រោះគាត់បានព្យាយាមប្រឆាំងនឹងព្រះបន្ទូលទ្រង់) (មថ ១៦:២១–២៣)។ *បើខ្ញុំមិនលាងឱ្យអ្នក នោះអ្នកគ្មានចំណែកជាមួយនឹងខ្ញុំទេ* មានន័យថា បើទ្រង់មិនលាងគាត់ឱ្យស្អាតពីបាបទេ នោះគាត់គ្មានចំណែកជាមួយនឹងទ្រង់ទេ ។ ព្រះយេស៊ូវលាងជើងឱ្យពួកសិស្សរបស់ទ្រង់ ក៏ជានិមិត្តរូបបញ្ជាក់អំពីការសម្អាតពួកគេឱ្យស្អាតពីបាបដែរ ។

**១៣:៩** *គឺសូមលាងដល់ទាំងដៃទាំងក្បាលផងចុះ* ឃ្លានេះបញ្ជាក់អំពីការឆ្លើយតបរបស់លោកពេត្រុសដោយអស់ពីចិត្ត ប៉ុន្តែ ពាក្យសម្តីរបស់គាត់នៅតែមានលក្ខណៈបង្គាប់បញ្ជាដល់ព្រះយេស៊ូវដដែល ។

**១៣:១០** ចំពោះពួកសាសន៍យូដានៅសម័យនោះ ប្រសិនបើអ្នកណាម្នាក់ទទួលការអញ្ជើញ ឱ្យទៅចូលរួមក្នុងពិធីជប់លៀងផ្សេងៗ នោះត្រូវងូតទឹកជម្រះកាយនៅឯផ្ទះរបស់ខ្លួនជាមុន ។ បន្ទាប់មក ពេលដែលទៅដល់ផ្ទះអ្នករៀបចំពិធីលាងជើងរបស់គេអាចត្រូវប្រឡាក់ធូលី ដូច្នេះ អ្នកទទួលត្រូវផ្តល់ទឹកលាងជើងឱ្យអ្នកនោះ ។ នៅពេលដែលព្រះយេស៊ូវមានបន្ទូលទៅកាន់លោកពេត្រុសថា គាត់ត្រូវលាងតែជើងប៉ុណ្ណោះ បញ្ជាក់ថា គាត់បានងូតទឹករួចហើយ ។ ទ្រង់មានបន្ទូលយ៉ាងដូច្នេះ គឺមានន័យថា បាបរបស់លោកពេត្រុសបានលាងសម្អាតរួចហើយ រីឯខ្លួនរបស់គាត់ក៏បានស្អាតហើយដែរ ប៉ុន្តែ គាត់ត្រូវលាងជើងរបស់គាត់ទៀត មានន័យថា ការដើរតាមទ្រង់ និងការរស់នៅប្រចាំថ្ងៃ ត្រូវជួបប្រទះនឹងការល្បួងល ឬឧបសគ្គ ឬក៏បញ្ហាផ្សេងៗ ហើយពេលខ្លះអាចប្រព្រឹត្តអំពើបាប ទោះបីដោយចេតនា ឬអចេតនាក្តី ។ ដូច្នេះ ត្រូវទូលសូមទ្រង់ ឱ្យលាងសម្អាត ដូចជាជើងដែលប្រឡាក់ក្នុងពេលធ្វើដំណើរ ហើយត្រូវលាងសម្អាតនោះដែរ ។

**១៣:១១** បទគម្ពីរនេះបញ្ជាក់ថា ពួកសិស្សរបស់ព្រះយេស៊ូវ គ្រប់គ្នាបានលាងសម្អាតឱ្យស្អាតហើយ លើកលែងតែម្នាក់ប៉ុណ្ណោះដែលមិនបានស្អាត។ ម្នាក់នោះ គឺសំដៅលើយ៉ូដាស–អ៊ីស្ការីយ៉ុត ។

**១៣:១៣** *លោកគ្រូ ហើយជាព្រះអម្ចាស់* ពាក្យថា "លោកគ្រូ" សំដៅលើអ្នកណែនាំ ឬប្រៀនប្រដៅ ។ រីឯពាក្យ "ព្រះអម្ចាស់" គឺសំដៅលើអ្នកដែលមានឋានៈខ្ពង់ខ្ពស់ជាងគេ ។ ព្រះយេស៊ូវគ្រីស្ទទ្រង់គឺជាគ្រូ និងជាព្រះអម្ចាស់ (ខ.១៤)។

**១៣:១៤–១៥** ត្រង់ចំណុចនេះ មានមតិរបស់គ្រីស្ទបរិស័ទខ្លះយល់ថា គួរតែធ្វើពិធីលាងជើនេះឱ្យបានទៀងទាត់ ។ ប៉ុន្តែ គ្រីស្ទបរិស័ទខ្លះទៀតយល់ថា អត្ថន័យដ៏សំខាន់បំផុត នៃការដែលព្រះយេស៊ូវលាងជើងឱ្យពួកសិស្ស គឺដើម្បីធ្វើជាគំរូបង្ហាញអំពីការបម្រើដោយបន្ទាបខ្លួនដ៏ពិតប្រាកដ ។

**១៣:១៤** *នោះគួរតែឱ្យអ្នករាល់គ្នាលាងជើងដល់គ្នានឹងគ្នាដែរ* មានន័យថា គ្រីស្ទបរិស័ទគ្រប់រូបត្រូវបម្រើគ្នាទៅវិញទៅមក ដោយមិនប្រកាន់តួនាទី ឬឋានៈរបស់ខ្លួនឡើយ ។

**១៣:១៦** ត្រង់ចំណុចនេះបញ្ជាក់ថា ត្រូវឱ្យយើងជាអ្នកជឿដល់ព្រះអម្ចាស់មានការបន្ទាបខ្លួនដោយពិតប្រាកដ ព្រោះទ្រង់បានបន្ទាបអង្គទ្រង់ ជាគំរូដល់យើងគ្រប់គ្នាស្រាប់ហើយ ។ ម្យ៉ាងទៀត ព្រះអម្ចាស់សព្វព្រះហឫទ័យនឹងអស់អ្នកដែលបន្ទាបខ្លួនដ៏ពិតប្រាកដ (១៥:២០ មថ ១០:២៤ លក ៦:៤០ ២២:២៧)។

**១៣:១៨** ព្រះយេស៊ូវមានបន្ទូលទៅពួកសិស្សទ្រង់ថា មិនមែនពួកគេទាំងអស់បានស្អាតទេ (ខ.១០) ព្រោះទ្រង់ជ្រាបតាំងពីមុនពេលដែលទ្រង់រើសពួកគេទៀតថា យូដាស–អ៊ីស្ការីយ៉ុតនឹងបញ្ជូនទ្រង់ទៅឱ្យគេឆ្កាង ។ សេចក្តីទំនាយដែលទាក់ទងទៅនឹងអ្នកដែលបញ្ជូនព្រះយេស៊ូវទៅឱ្យគេឆ្កាង បានចែងទុកជាស្រេចនៅក្នុង "ទដ ៤១:៩" (ខ.២១)។ *បរិភោគនំបុ័ង* ត្រង់ចំណុចនេះបញ្ជាក់ថា ការពិសាអាហារជាមួយគ្នា គឺសំដែងអំពីទំនាក់ទំនងរវាងគ្នា និងការប្រកបគ្នាយ៉ាងជិតស្និទ្ធ (ទដ ៤១:៩)។ *លើកកែងជើង* គឺជាពាក្យប្រៀបធៀបដែលមានន័យថា "ទាស់ប្រឆាំង" គឺមានលក្ខណៈដូចជាលើកជើងបម្រុងនឹងធាក់ ឬរលាស់ធូលីដី ចេញដូច្នោះដែរ (មើលការពន្យល់ លក ៩:៥)។

១៩ខ្ញុំប្រាប់អ្នករាល់គ្នា តាំងពីឥឡូវនេះ មុនដែលការ
នោះកើតមក ដើម្បីកាលណាបានកើតមកដល់ នោះឱ្យអ្នក
រាល់គ្នាបានជឿ[ភ]ថា គឺខ្ញុំនេះហើយ[ម] ២០ប្រាកដមែន ខ្ញុំ
ប្រាប់អ្នករាល់គ្នា ជាប្រាកដថា អ្នកណាទទួលអ្នកដែលខ្ញុំ
នឹងចាត់ឱ្យទៅ នោះឈ្មោះថាទទួលខ្ញុំ ហើយអ្នកណាដែល
ទទួលខ្ញុំ នោះក៏ឈ្មោះថា ទទួលព្រះអង្គ ដែលចាត់ឱ្យខ្ញុំមក
ដែរ[យ]។

២១កាលព្រះយេស៊ូវទ្រង់មានបន្ទូលសេចក្តីទាំងនោះរួច
ហើយ នោះទ្រង់មានព្រះហឫទ័យតប់ប្រមល់[រ] ហើយក៏ធ្វើ
បន្ទាល់ថា ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
មានពួកអ្នករាល់គ្នាម្នាក់ នឹងបញ្ជូនខ្ញុំ[ល] ២២ដូច្នេះ ពួកសិស្ស
ក៏ងាកមើលគ្នាទៅវិញទៅមក មិនដឹងជាទ្រង់មានបន្ទូល
ពីអ្នកណាទេ ២៣មានសិស្សម្នាក់ដែលព្រះយេស៊ូវស្រ
ឡាញ់[វ]គាត់អង្គុយនៅតុ ផ្អែកលើព្រះឧរាទ្រង់ ២៤ដូច្នេះ
ស៊ីម៉ូន-ពេត្រុសក៏ធ្វើគ្រឿងសំគាល់ ឱ្យអ្នកនោះ ទូលសួរព្រះ
យេស៊ូវ អំពីអ្នកណាដែលទ្រង់មាន បន្ទូលនោះ ២៥អ្នកនោះ
ក៏ទូលសួរព្រះយេស៊ូវ ទាំងទំរេតលើព្រះឱរាទ្រង់ថា ព្រះ
អម្ចាស់អើយ តើអ្នកណា[ស] ២៦ព្រះយេស៊ូវមានបន្ទូលឆ្លើយថា
គឺជាអ្នកដែលខ្ញុំនឹងជ្រលក់ចំណិតនំប៉័ង ហុចទៅឱ្យ រួចទ្រង់
ជ្រលក់នំប៉័ង ១ចំណិត ប្រទានទៅឱ្យយូដាស-អ៊ីស្ការីយ៉ុត[ហ]
ជាកូនស៊ីម៉ូន ២៧ក្រោយដែលទទួលចំណិតនោះហើយ នោះ
អារក្សសាតាំងក៏ចូលវា[ឡ] រួចព្រះយេស៊ូវមានបន្ទូលទៅ
វាថា ការអ្វីដែលអ្នកគិតធ្វើ នោះចូរធ្វើជាប្រញាប់ទៅចុះ
២៨ប៉ុន្តែ ក្នុងពួកអ្នកដែលអង្គុយនៅតុ គ្មានអ្នកណាដឹង
ជាទ្រង់មានបន្ទូលទៅវា ដោយហេតុអ្វីទេ ២៩ខ្លះស្មាន
ថា ដោយព្រោះយូដាសកាន់ថង់ប្រាក់[អ] បានជាព្រះយេស៊ូវ
ទ្រង់ប្រាប់ឱ្យវាទៅទិញអីវ៉ាន់អ្វីនិមួយ ដែលត្រូវការសំរាប់
បុណ្យនោះ[ក] ឬឱ្យវាចែកទានអ្វីដល់ពួកអ្នកក្រីក្រ[ខ] ៣០កាល
វាបានទទួលចំណិតនំនោះ វាក៏ចេញទៅជា១រំពេច ពេល
នោះយប់ហើយ[គ]។

## ព្រះយេស៊ូវមានបន្ទូលអំពីការបដិសេធន៍របស់ពេត្រុស

*១៣:៣៧,៣៨ – មថ ២៦:៣៣–៣៥ មក ១៤:២៩–៣១ លក ២២:៣៣,៣៤*

៣១កាលវាចេញផុតទៅ នោះព្រះយេស៊ូវមានបន្ទូលថា
ឥឡូវនេះ កូនមនុស្ស[ឃ] បានដំកើងឡើងហើយ[ង] ព្រះក៏បាន

**១៣:១៨** ប យហ ៦:៧០ ផ ទដ ៤១:៩ ព មថ ១:២២
**១៣:១៩** ភ យហ ១៤:២៩ ១៦:៤ ម យហ ៤:២៦ ៨:២៤
**១៣:២០** យ មថ ១០:៤០
**១៣:២១** រ យហ ១២:២៧ ល មថ ២៦:២១
**១៣:២៣** វ យហ ១៩:២៦ ២០:២ ២១:៧,២០
**១៣:២៥** ស មថ ២៦:២២ យហ ២១:២០
**១៣:២៦** ហ មថ ១០:៤
**១៣:២៧** ឡ លក ២២:៣
**១៣:២៩** អ យហ ១២:៦ ក ឧ.១ ខ យហ ១២:៥
**១៣:៣០** គ លក ២២:៥៣ **១៣:៣១** ឃ មថ ៨:២០ ង យហ ៧:៣៩ ១២:២៣

**១៣:១៩** ព្រះយេស៊ូវមានបន្ទូលប្រាប់ពួកសិស្សទ្រង់ជាមុន អំពីការសុគត និងហេតុការណ៍ទាំងឡាយ ដែលនឹងកើតមានឡើងចំពោះទ្រង់ ដើម្បីកាលណាការទាំងនោះកើតឡើង ពួកគេនឹងដឹងយ៉ាងច្បាស់ថា ទ្រង់មិនគ្រាន់តែជាព្រះមែស៊ីប៉ុណ្ណោះទេ គឺទ្រង់ជ្រាបគ្រប់ការទាំងអស់ផង (មថ ១១:២២,២៣ កច ១៥:១៨ ១យយ ១:៥)។ *គឺខ្ញុំនេះហើយ* មានន័យថា ពួកសិស្សរបស់ព្រះយេស៊ូវនឹងបានដឹងច្បាស់ថា គឺទ្រង់ហើយជាព្រះដ៏ពិត (មើលការពន្យល់ ៨:៥៨ ១២:៤៤)។

**១៣:២០** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ អំពីលក្ខណៈនៃមហាបេសកកម្មរបស់ព្រះយេស៊ូវ និងការចូលរួមពីសំណាក់ពួកសិស្សរបស់ទ្រង់ (មើលការពន្យល់ ៤:៣៤ ១២:៤៤ ១៧:៣–៤,១៨ ២០:២១)។

**១៣:២១** *ទ្រង់មានព្រះហឫទ័យតប់ប្រមល់* ឃ្លានេះមានលក្ខណៈស្រដៀងគ្នានឹង សេចក្តីដែលមានចែងនៅក្នុងព្រះគម្ពីរដំណឹងល្អម៉ាកុស និងលូកាដែរ (មើលការពន្យល់ មក ១៤:៣៤–៣៦ លក ២២:៤២)។ ព្រះយេស៊ូវគឺជាព្រះមួយរយភាគរយ និងជាមនុស្សមួយរយភាគរយ ។ ដូច្នេះ បញ្ជាក់ថា ក្នុងភាពជាមនុស្ស ទ្រង់ក៏មានការឈឺចាប់ និងទុក្ខលំបាកផ្សេងៗដែរ (មក ១៤:៣២–៣៤ ២កថ ៥:២១)។ ទ្រង់មានព្រះហឫទ័យតប់ប្រមល់ ក៏ដោយព្រោះទ្រង់ជ្រាបជាមុនថា អ្នកដែលក្បត់គឺជាសិស្សរបស់ទ្រង់ផ្ទាល់ ។

**១៣:២២** ដោយសារតែពួកសិស្សនាំគ្នាភ្ញាក់ផ្អើល និងសួរគ្នាទៅវិញទៅមក ដូច្នេះ ពួកគេមិនបានដឹងថា យូដាស-អ៊ីស្ការីយ៉ុត គឺជាអ្នកដែលមានទំនាក់ទំនងជាមួយនឹងពួកសម្តេចសង្ឃ និងជាអ្នកក្បត់នឹងព្រះយេស៊ូវទេ (ឧ.២៨ មក ១៤:១៩)។

**១៣:២៣** *សិស្សម្នាក់ដែលព្រះយេស៊ូវស្រឡាញ់* គឺសំដៅលើលោកយ៉ូហាន ដែលជាអ្នកនិពន្ធកណ្ឌព្រះគម្ពីរយ៉ូហាននេះតែម្តង ។ ឃ្លានេះមិនមានន័យថា ព្រះយេស៊ូវមានព្រះហឫទ័យលំអៀងនោះទេ គឺទ្រង់ស្រលាញ់ពួកគេទាំងអស់ស្មើៗគ្នា ប៉ុន្តែ ត្រង់ចំណុចនេះ វាបញ្ជាក់អំពីទំនាក់ទំនងពិសេសមួយរបស់ទ្រង់ចំពោះគាត់ ។

**១៣:២៦** យូដាស-អ៊ីស្ការីយ៉ុតប្រហែលជាអង្គុយនៅក្បែរព្រះយេស៊ូវ និងប្រហែលជានៅកន្លែងកិត្តិយសផង ។ ម្យ៉ាងទៀត ដោយព្រោះពេលនោះគឺជាឱកាសប្រកបគ្នាដ៏វិសេស ទើបលោកយ៉ូហានហៅឈ្មោះ យូដាស-អ៊ីស្ការីយ៉ុត ដោយចំៗតែម្តង (មើលការពន្យល់ ៦:៧១)។

**១៣:២៧-២៨** ពេលព្រះយេស៊ូវមានបន្ទូលទៅកាន់លោកយ៉ូហាន អំពីអ្នកដែលក្បត់នឹងទ្រង់ នោះគាត់ពុំទាន់បានយល់នៅឡើយទេ ថាជាយូដាស-អ៊ីស្ការីយ៉ុត ។ ម្យ៉ាងទៀត លោយ៉ូហានមិននឹកស្មានថា យូដាស-អ៊ីស្ការីយ៉ុត ជាអ្នកបញ្ជូនទ្រង់ ឱ្យពួកសម្តេចសង្ឃ យកទៅសម្លាប់នោះទេ ។ *អារក្សសាតាំង* (ឧ.២ មើលការ ពន្យល់ យប ១:៦ សក ៣:១ វវ ១២:៩,១០)។

**១៣:២៩** *បុណ្យនោះ* "មើលការពន្យល់ ឧ.១,២"។ *អ្នកក្រីក្រ* "មើលការពន្យល់ មក ១៤:៥"។

**១៣:៣០** *ពេលនោះយប់ហើយ* ពាក្យថា "យប់" នៅត្រង់ចំណុចនេះអាចមានន័យពីរយ៉ាងគឺ (១) ពេលនោះជាពេលយប់ពិតមែន (២) សំដៅលើសេចក្តីងងឹង ដែលបានមកគ្របបាំងលើ យូដាស-អ៊ីស្ការីយ៉ុត ក្នុងខណៈពេលដែលបានទទួលចំណិតនំប៉័ងពីព្រះយេស៊ូវ (មើលការពន្យល់ ១:៤ ៨:១២ អស ៦០:២)។

**១៣:៣១** *កូនមនុស្ស* សំដៅលើព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ មក ៨:៣១)។ *ដំកើងឡើង* សំដៅលើការសុគតរបស់ព្រះយេស៊ូវ នៅលើឈើ

ដំកើងឡើងក្នុងកូនមនុស្សដែរ[ច] ៣២ បើសិនជាព្រះបានដំកើង
ឡើងក្នុងកូនមនុស្ស នោះទ្រង់នឹងដំកើងកូនមនុស្សឡើង ក្នុង
ព្រះអង្គទ្រង់ដែរ[ឆ] ក៏នឹងដំកើងកូនមនុស្សឡើងជា១រំពេច
ផង។

៣៣ ឱកូនរាល់គ្នាអើយ ខ្ញុំនៅជាមួយនឹងអ្នករាល់គ្នាតែ
បន្តិចទៀតទេ អ្នករាល់គ្នានឹងរកខ្ញុំ តែដូចជាខ្ញុំបានប្រាប់
ដល់ពួកសាសន៍យូដារួចហើយថា កន្លែងដែលខ្ញុំទៅនោះ
អ្នករាល់គ្នាពុំអាចនឹងទៅបានទេឥឡូវនេះ ខ្ញុំក៏ប្រាប់ដល់
អ្នករាល់គ្នាដូច្នោះដែរ[ជ] ៣៤ ខ្ញុំឱ្យសេចក្តីបញ្ញត្តិ[ឈ]១ថ្មី ដល់
អ្នករាល់គ្នា គឺឱ្យអ្នករាល់គ្នា ស្រឡាញ់គ្នាទៅវិញទៅមក[ញ]
ត្រូវឱ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ[ដ]
៣៥ គេនឹងដឹងថា អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ ដោយសារ
សេចក្តីនេះឯង គឺដោយអ្នករាល់គ្នា មានសេចក្តីស្រឡាញ់
ដល់គ្នាទៅវិញទៅមក[ឋ] ៣៦ ស៊ីម៉ូន-ពេត្រុសទូលសួរទ្រង់ថា
ព្រះអម្ចាស់អើយ តើទ្រង់យាងទៅឯណា[ឌ] ព្រះយេស៊ូវទ្រង់
ឆ្លើយថា កន្លែងដែលខ្ញុំទៅ នោះអ្នកពុំអាចនឹងទៅតាម
ក្នុងគ្រាឥឡូវនេះបានទេ[ឍ] លុះគ្រាក្រោយ ទើបអ្នកនឹងទៅ
បាន[ណ] ៣៧ ពេត្រុសទូលទ្រង់ថា ព្រះអម្ចាស់អើយ ហេតុអ្វីបាន
ជាទូលបង្គំទៅតាម ក្នុងគ្រានេះពុំបាន ទូលបង្គំស៊ូតែប្តូរ
ជីវិតជំនួសទ្រង់ ៣៨ ព្រះយេស៊ូវមានបន្ទូលឆ្លើយទៅគាត់ថា
តើអ្នកនឹងប្តូរជីវិតជំនួសខ្ញុំឬ ប្រាកដមែន ខ្ញុំប្រាប់អ្នកជាប្រា
កដថា មាន់មិនរងាវទៀត ទាល់តែអ្នកបានប្រកែក៣ដង
ថាមិនស្គាល់ខ្ញុំ[ត]។

## ព្រះយេស៊ូវកម្សាន្តចិត្តពួកសិស្សទ្រង់

**១៤** ១ កុំឱ្យចិត្តអ្នករាល់គ្នាថប់បារម្ភឡើយ[ថ] អ្នករាល់គ្នា
ជឿ[ទ]ដល់ព្រះ[ធ]ហើយ ចូរជឿដល់ខ្ញុំដែរ ២ នៅក្នុងដំណាក់
នៃព្រះវរបិតាខ្ញុំ មានទីលំនៅជាច្រើន ពុំនោះ ខ្ញុំបានប្រាប់
អ្នករាល់គ្នាហើយ ខ្ញុំទៅ[ន]រៀបកន្លែងឱ្យអ្នករាល់គ្នា ៣ បើខ្ញុំ
ទៅរៀបកន្លែងឱ្យអ្នករាល់គ្នា នោះខ្ញុំនឹងត្រឡប់មកវិញ[ប]នឹង
ទទួលអ្នករាល់គ្នាទៅឯខ្ញុំ ប្រយោជន៍ឱ្យអ្នករាល់គ្នា បាននៅ
កន្លែងដែលខ្ញុំនៅនោះដែរ[ផ] ៤ ឯកន្លែងដែលខ្ញុំទៅ នោះអ្នក
រាល់គ្នាក៏ដឹង ហើយក៏ស្គាល់ផ្លូវទៅដែរ។

៥ ថូម៉ាស[ព]ទូលទ្រង់ថា ព្រះអម្ចាស់អើយ យើងខ្ញុំមិនដឹង
ជាទ្រង់យាងទៅឯណាទេ ដូច្នេះ ធ្វើដូចម្តេចឱ្យយើងខ្ញុំ

**១៣:៣១** ច យហ ១៤:១៣ ១៧:៤ ១ពត ៤:១១
**១៣:៣២** ឆ យហ ១៧:១
**១៣:៣៣** ជ យហ ៧:៣៣,៣៤
**១៣:៣៤** ឈ យហ ១៥:១២ ១យហ ២:៧-១១ ៣:១១ ញ លវ ១៩:១៨ ១ថន ៤:៩ ១ពត ១:២២ ដ យហ ១៥:១២ អភ ៥:២ ១យហ ៤:១០,១១
**១៣:៣៥** ឋ ១យហ ៣:១៤ ៤:២០
**១៣:៣៦** ឌ យហ ១៦:៥ ឍ ខ.៣៣ យហ ១៤:២ ណ យហ ២១:១៨,១៩ ២ពត ១:១៤
**១៣:៣៨** ត យហ ១៨:២៧
**១៤:១** ថ ខ.២៧ ទ យហ ៣:១៥ ធ ទដ ៤:៥ **១៤:២** ន យហ ១៣:៣៣,៣៦ ១៦:៥ **១៤:៣** ប ខ.១៨,២៨ មថ ១៦:២៧ ផ យហ ១២:២៦
**១៤:៥** ព យហ ១១:១៦

ឆ្កាង ដើម្បីសង្គ្រោះមនុស្សលោកឱ្យរួចពីបាប ។ *ព្រះក៏បានដំកើងឡើងក្នុងកូនមនុស្សដែរ* ឃ្លានេះអាចសរសេរថា ព្រះវរបិតាក៏បានតម្កើងឡើងក្នុងព្រះយេស៊ូវគ្រីស្ទដែរ ។

**១៣:៣៤** *សេចក្តីបញ្ញត្តិ១ថ្មី* សេចក្តីនេះមានចែងនៅក្នុង "លវ ១៩:១៨" រួចហើយ ប៉ុន្តែគឺជាបញ្ញត្តិមួយថ្មីសម្រាប់ពួកសិស្សរបស់ព្រះយេស៊ូវ ព្រោះពួកគេបានទទួលនូវបទពិសោធន៍ នៃសេចក្តីស្រលាញ់ដ៏ពិតប្រាកដអំពីទ្រង់ (មថ ២២:៣៧,៣៩ មក ១២:៣១ លក ១០:២៧ និងការពន្យល់)។ *ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ* ត្រង់ចំណុចនេះបញ្ជាក់ថា សេចក្តីស្រលាញ់របស់ព្រះយេស៊ូវ គឺជាគំរូសម្រាប់គ្រប់អ្នកជឿដល់ព្រះនាមទ្រង់ទាំងអស់ ។

**១៣:៣៥** *មានសេចក្តីស្រឡាញ់ដល់គ្នាទៅវិញទៅមក* ឃ្លានេះបញ្ជាក់យ៉ាងច្បាស់ថា អស់អ្នកដែលមានសេចក្តីស្រលាញ់មកអំពីព្រះអម្ចាស់ នោះក៏ស្រលាញ់ដល់គ្នាទៅវិញទៅមកដោយឥតមានពុត និងពិតជាសិស្សរបស់ទ្រង់មែន (១យហ ៣:២៣ ៤:៧-៨,១១-១២,១៩-២១)។

**១៣:៣៦** *តើទ្រង់យាងទៅឯណា?* ការដែលលោកពេត្រុសសួរព្រះយេស៊ូវដូច្នេះ ហាក់ដូចជាគាត់មិនសូវយកចិត្តទុកដាក់ ចំពោះព្រះបន្ទូលរបស់ទ្រង់អំពីសេចក្តីស្រលាញ់ប៉ុន្មានទេ ប៉ុន្តែ គាត់បែរជាបារម្ភអំពីការចាកចេញរបស់ទ្រង់វិញ ។

**១៣:៣៧** *ទូលបង្គំស៊ូតែប្តូរជីវិតជំនួសទ្រង់* ឃ្លានេះមានលក្ខណៈដូចគ្នានឹងអ្នកគង្វាលល្អដែលមានចែងនៅក្នុង "១០:១១" ដែរ ។ កាយវិការរបស់លោកពេត្រុសបានសំដែងចេញនូវស្មារតីហ៊ានប្តូរជីវិត ថ្វាយព្រះយេស៊ូវប្រាកដមែន ។ ប៉ុន្តែ អ្វីដែលគាត់ចង់ធ្វើនៅពេលនោះ មិនបានសម្រេចជោគជ័យឡើយ ព្រោះមិនមែនជាព្រះហឫទ័យនៃព្រះអម្ចាស់ទេ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ក្រោយមកទៀត គាត់ពិតជាបានប្តូរជីវិត ដើម្បីព្រះនាមទ្រង់ប្រាកដមែន ។

**១៣:៣៨** *ទាល់តែអ្នកបានប្រកែក៣ដង ថាមិនស្គាល់ខ្ញុំ* ត្រង់ចំណុចនេះបញ្ជាក់ថា ការដែលលោកពេត្រុសប្រកែក មិនព្រមទទួលស្គាល់ព្រះយេស៊ូវបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរដំណឹងល្អទាំងបួន (មថ ២៦:៣៣-៣៥ មក ១៤:២៩-៣១ លក ២២:៣១-៣៤)។

**១៤:១** *កុំឱ្យចិត្តអ្នករាល់គ្នាថប់បារម្ភឡើយ* គឺមិនឱ្យពួកសិស្សរបស់ទ្រង់ថប់បារម្ភនឹងការដែលទ្រង់ត្រូវចាកចេញពីពួកគេនោះឡើយ (១៣:៣៣,៣៦ ទដ ៥៦:៣,៤ អស ២៦:៣,៤)។

**១៤:២** *ដំណាក់នៃព្រះវរបិតាខ្ញុំ* ពាក្យថា "ដំណាក់" ត្រង់ចំណុចនេះគឺសំដៅលើ ស្ថានសួគ៌ ដែលជាទីព្រះអម្ចាស់គង់នៅ ។

**១៤:៣** *ខ្ញុំនឹងត្រឡប់មកវិញ* អាចសំដៅលើការដែលព្រះយេស៊ូវយាងមកជួបពួកសិស្សទ្រង់បន្ទាប់ពីទ្រង់រស់ពីសុគតឡើងវិញ ឬសំដៅលើការយាងមកជាលើកទីពីររបស់ទ្រង់ (វវ ២២:៧,១២,២០)។

**១៤:៤** *ផ្លូវ* ពាក្យថា "ផ្លូវ" នៅក្នុងបទគម្ពីរនេះគឺសំដៅលើព្រះយេស៊ូវ មានន័យថា ទ្រង់ជាផ្លូវតែមួយគត់ទៅឯព្រះវរបិតា (កច ៤:១២ ៩:២ ហព ១០:១៩-២០)។

**១៤:៥** *យើងខ្ញុំមិនដឹងជាទ្រង់យាងទៅឯណាទេ* ត្រង់ចំណុចនេះបញ្ជាក់ថា លោកថូម៉ាសជាសិស្សស្មោះត្រង់ម្នាក់របស់ព្រះយេស៊ូវ ព្រោះនៅពេលដែលគាត់មិនយល់នូវសេចក្តីដែលទ្រង់មានបន្ទូល នោះគាត់ក៏សួរដល់ទ្រង់ ដោយ

ស្គាល់ផ្លូវទៅបាន។

## ព្រះយេស៊ូវជាផ្លូវទៅឯព្រះវរបិតា

៦ព្រះយេស៊ូវមានបន្ទូលទៅគាត់ថា ខ្ញុំជា[ភ]ផ្លូវ[ម] ជាសេចក្តី
ពិត[យ] ហើយជាជីវិត[រ] បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅ
ឯព្រះវរបិតាបានឡើយ[ល] ៧បើអ្នករាល់គ្នាបានស្គាល់ខ្ញុំ នោះ
បានស្គាល់ព្រះវរបិតាដែរ[វ] អំពីនេះទៅមុខ អ្នករាល់គ្នាក៏
ស្គាល់ ហើយបានឃើញទ្រង់ផង ៨ភីលីព[ស]ទូលទ្រង់ថា
ព្រះអម្ចាស់អើយ សូមបង្ហាញព្រះវរបិតា ឱ្យយើងខ្ញុំឃើញ
ផង នោះយើងខ្ញុំពេញចិត្ត ហើយ ៩ព្រះយេស៊ូវមានបន្ទូល
ទៅថា ភីលីពអើយ ខ្ញុំបាននៅជាមួយនឹងអ្នករាល់គ្នា
ជាយូរដល់ម្ល៉េះ ហើយអ្នកមិនទាន់ស្គាល់ខ្ញុំឬ អ្នកណាដែល
ឃើញខ្ញុំ នោះក៏បានឃើញព្រះវរបិតាដែរ[ហ] ចុះធ្វើដូចម្តេច
បានជាអ្នកថា សូមបង្ហាញឱ្យឃើញព្រះវរបិតាផងដូច្នេះ
១០តើអ្នកមិនជឿថា ខ្ញុំនៅ ក្នុងព្រះវរបិតា ហើយព្រះវរបិតា
គង់នៅក្នុងខ្ញុំទេឬអី[ឡ] អស់ទាំងពាក្យដែលខ្ញុំប្រាប់ដល់អ្នក
រាល់គ្នា នោះខ្ញុំមិនមែនប្រាប់ ដោយអាងខ្លួនខ្ញុំទេ[អ] គឺជា
ព្រះវរបិតាដែលគង់ក្នុងខ្ញុំ ទ្រង់ធ្វើការទាំងនោះវិញ ១១ចូរ
ជឿខ្ញុំថា ខ្ញុំនៅក្នុងព្រះវរបិតា ហើយព្រះវរបិតាក៏គង់ក្នុង
ខ្ញុំ ពុំនោះសោត ឱ្យជឿខ្ញុំដោយព្រោះការទាំង នោះឯង
ចុះ[ក] ១២ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
អ្នកណាដែលជឿ[ខ]ដល់ខ្ញុំ នោះនឹងធ្វើការដែលខ្ញុំធ្វើដែរ[គ]
ក៏នឹងធ្វើការធំជាងការទាំងនោះទៅទៀត ពីព្រោះខ្ញុំទៅឯ
ព្រះវរបិតា ១៣ហើយការអ្វីក៏ដោយ ដែលអ្នករាល់គ្នានឹង
សូម[ឃ] ដោយនូវឈ្មោះខ្ញុំ នោះខ្ញុំនឹងសំរេចឱ្យ ដើម្បីឱ្យព្រះ
វរបិតាបានដំកើងឡើងក្នុងព្រះរាជបុត្រា ១៤បើអ្នករាល់គ្នា
នឹងសូមអ្វី ដោយនូវឈ្មោះខ្ញុំ នោះខ្ញុំនឹង សំរេចឱ្យ។

## ព្រះបន្ទូលសន្យាអំពីព្រះវិញ្ញាណបរិសុទ្ធ

១៥បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់
ខ្ញុំចុះ[ង] ១៦នោះខ្ញុំនឹងទូលសូមដល់ព្រះវរបិតា ហើយទ្រង់នឹង
ប្រទានព្រះដ៏ជាជំនួយ[ច]១អង្គទៀត មកអ្នករាល់គ្នា ឱ្យបាន
គង់នៅជាមួយ នៅអស់កល្បរៀងទៅ ១៧គឺជាព្រះវិញ្ញាណ
នៃសេចក្តីពិត[ឆ] ដែលលោកិយទទួលពុំបាន[ជ] ព្រោះមិនឃើញ
ហើយមិនស្គាល់ទ្រង់សោះ តែអ្នករាល់គ្នាស្គាល់ទ្រង់ ដ្បិតទ្រង់
គង់ជាមួយ ក៏នឹងសណ្ឋិតនៅក្នុងអ្នករាល់គ្នាដែរ ១៨ខ្ញុំមិនចោល
អ្នករាល់គ្នា ឱ្យនៅកំព្រាទេ[ឈ] ខ្ញុំនឹងមកឯអ្នករាល់គ្នាវិញ[ញ]

**១៤:៦** ភ យហ ៦:៣៥ ម យហ ១០:៩ អភ ២:១៨ ហព ១០:២០ យ យហ ១:១៤ រ យហ ១:៤ ល កច ៤:១២ **១៤:៧** វ យហ ១:១៨ ១យហ ២:២៣ **១៤:៨** ស យហ ១:៤៣ **១៤:៩** ហ អស ៩:៦ យហ ១:១៤ ១២:៤៥ ២កថ ៤:៤ ភល ២:៦ កល ១:១៥ ហព ១:៣ **១៤:១០** ឡ ខ.១១,២០ យហ ១០:៣៨ ១៧:២១ អ ខ.២៤ **១៤:១១** ក យហ ៥:៣៦ ១០:៣៨ **១៤:១២** ខ មថ ២១:២១ គ លក ១០:១៧ **១៤:១៣** ឃ មថ ៧:៧ **១៤:១៥** ង ខ.២១,២៣ ទដ ១០៣:១៨ យហ ១៥:១០ ១យហ ២:៣-៥ ៣:២២,២៤ ៥:៣ ២យហ ៦ វវ ១២:១៧ ១៤:១២ **១៤:១៦** ច ខ.២៦ យហ ១៥:២៦ ១៦:៧ **១៤:១៧** ឆ យហ ១៥:២៦ ១៦:១៣ ១យហ ៤:៦ ៥:៦ ជ ១កថ ២:១៤ **១៤:១៨** ឈ ១ពវ ៦:១៣

មិនលាក់ទុកនៅក្នុងចិត្តទេ (មើលការពន្យល់ ១១:១៦)។

**១៤:៦** *ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត* បញ្ជាក់ថា ព្រះយេស៊ូវមិនគ្រាន់តែបង្រៀនដល់ពួកសិស្សទ្រង់ អំពីផ្លូវ អំពីសេចក្តីពិត និងអំពីជីវិត ប៉ុណ្ណោះទេ គឺទ្រង់មានបន្ទូលប្រាប់ពួកគេយ៉ាងច្បាស់ថា ទ្រង់គឺជាផ្លូវ ជាសេចក្តីពិត និងជាជីវិតនោះតែម្តង (១:៤ ៥:២៦ ៨:៣១-៣២ ១៧:៣)។

**១៤:៧** *អ្នករាល់គ្នាបានស្គាល់ខ្ញុំ នោះបានស្គាល់ព្រះវរបិតាដែរ* ព្រះយេស៊ូវមានបន្ទូលដូច្នេះ ព្រោះទ្រង់ និងព្រះវរបិតាគឺតែ១អង្គទេ (១០:៣០ មើលការពន្យល់ ១:១៨)។

**១៤:១០** *នោះខ្ញុំមិនមែនប្រាប់ ដោយអាងខ្លួនខ្ញុំទេ* ត្រង់ចំណុចនេះបញ្ជាក់ថា គ្រប់ សេចក្តីបង្រៀនទាំងអស់របស់ព្រះយេស៊ូវគ្រីស្ទ មិនមែនមកពីមនុស្សទេ គឺមកអំពី ព្រះវរបិតា ដែលចាត់ទ្រង់ឱ្យមកវិញ ។

**១៤:១១** *ចូរជឿខ្ញុំថា ខ្ញុំនៅក្នុងព្រះវរបិតា ហើយព្រះវរបិតាក៏គង់ក្នុងខ្ញុំ* មានន័យថា អស់អ្នកដែលជឿដល់ព្រះយេស៊ូវគ្រីស្ទ នោះត្រូវជឿថា ទ្រង់គង់ក្នុងព្រះវរបិតា ហើយព្រះវរបិតាគង់ក្នុងទ្រង់ (មើលការពន្យល់ ១៧:២១-២២)។

**១៤:១២** *ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដ* ព្រះយេស៊ូវប្រើឃ្លានេះក្នុងការអះអាងបញ្ជាក់សេចក្តីពិតនៃព្រះបន្ទូលរបស់ទ្រង់ (មើលការពន្យល់ មក ៣:២៨)។ *ក៏នឹង ធ្វើការធំជាងការទាំងនោះទៅទៀត* ពាក្យថា "ការធំ" គឺសំដៅលើការអស្ចារ្យទាំងឡាយ ដែលកើតឡើង ដោយសារអំណាចព្រះចេស្តារបស់ព្រះយេស៊ូវគ្រីស្ទ (ខ.១៦-១៧ មើលការពន្យល់ ១៥:២៦)។

**១៤:១៣** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា គ្រប់ការទាំងអស់ដែលពួកសិស្សរបស់ព្រះអម្ចាស់ទូលសូមតាមបំណងព្រះហឫទ័យទ្រង់ និងដោយនូវព្រះនាមទ្រង់នោះ នឹងត្រូវប្រទានមកមិនខាន (ខ.១៤ ២:២៣ យក ១:៦ ១យហ ៥:១៤)។

**១៤:១៥** *បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ* ត្រង់ចំណុចនេះបញ្ជាក់ថា សេចក្តីស្រឡាញ់ ក៏ដូចជាជំនឿដែរ គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការស្តាប់បង្គាប់ ។

**១៤:១៦** *ព្រះដ៏ជាជំនួយ១អង្គទៀត* គឺព្រះវិញ្ញាណបរិសុទ្ធ (ខ.២៦ ១៥:២៦ មើលការពន្យល់ ១៦:៧-១៥ ១យហ ២:១)។ ព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយនឹង អស់អ្នកដែលទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទជានិច្ច ។

**១៤:១៧** *ព្រះវិញ្ញាណនៃសេចក្តីពិត* សំដៅលើព្រះវិញ្ញាណបរិសុទ្ធដែលទ្រង់នាំមនុស្សលោកឱ្យស្គាល់សេចក្តីពិត (មើលការពន្យល់ ខ.៦ ៤:២៤ ទដ ៣១:៥ អស ៦៥:១៦)។ *លោកិយ* សំដៅលើមនុស្សរស់នៅលើពិភពលោកនេះ និងការទាំងឡាយ ដែលគេបង្កើតឡើងប្រឆាំងនឹងព្រះអម្ចាស់ (មើលការពន្យល់ ១:៩ ១៧:៥,១៤,១៥ កច ១:២ ២:៤,១៧,៣៨ រម ៨:៩ ១កថ ២:៤)។

**១៤:១៨** *ខ្ញុំនឹងមកឯអ្នករាល់គ្នាវិញ* ឃ្លានេះអាចសំដៅលើការដែល ព្រះយេស៊ូវយាងមកជួបពួកសិស្សទ្រង់ បន្ទាប់ពីទ្រង់រស់ពីសុគតឡើងវិញ ឬអាច

១៩បន្តិចទៀត លោកិយនឹងលែងឃើញខ្ញុំ តែអ្នករាល់គ្នា
នឹងឃើញខ្ញុំវិញ[ដ] ហើយដោយព្រោះខ្ញុំរស់ នោះអ្នករាល់
គ្នានឹងរស់ដែរ[ឋ] ២០នៅថ្ងៃនោះ[ឌ]អ្នករាល់គ្នានឹងដឹងថា
ខ្ញុំនៅក្នុងព្រះវរបិតាខ្ញុំ[ឍ] អ្នករាល់គ្នាក៏នៅក្នុងខ្ញុំ ហើយខ្ញុំ
នៅក្នុងអ្នករាល់គ្នាដែរ[ណ] ២១អ្នកណាដែលមានបញ្ញត្តិ
របស់ខ្ញុំ ហើយកាន់តាម គឺអ្នកនោះហើយដែលស្រឡាញ់ខ្ញុំ[ត]
ឯអ្នកណាដែលស្រឡាញ់ខ្ញុំ នោះជាទីស្រឡាញ់នៃព្រះ
វរបិតាខ្ញុំហើយ[ថ] ខ្ញុំនឹងស្រឡាញ់អ្នកនោះដែរ ក៏នឹងសំដែង
ខ្លួនឱ្យអ្នកនោះស្គាល់ផង ២២យូដាស[ទ] (មិនមែនអ៊ីស្ការីយ៉ុត)
គាត់ទូលទ្រង់ថា ព្រះអម្ចាស់អើយតើកើតមានហេតុដូច
ម្ដេច បានជាទ្រង់នឹងសំដែងមកឱ្យយើងខ្ញុំស្គាល់ទ្រង់ តែមិន
ឱ្យលោកិយស្គាល់ផង[ធ] ២៣ព្រះយេស៊ូវមានបន្ទូលឆ្លើយថា
បើអ្នកណាស្រឡាញ់ខ្ញុំ អ្នកនោះនឹងកាន់តាមពាក្យខ្ញុំ[ន] នោះ
ព្រះវរបិតាខ្ញុំនឹងស្រឡាញ់អ្នកនោះ ហើយយើងនឹងមកឯ
អ្នកនោះ ក៏នឹងតាំងទីលំនៅ នៅជាមួយដែរ[ប] ២៤អ្នកណា
ដែលមិនស្រឡាញ់ខ្ញុំ នោះមិនកាន់តាមពាក្យខ្ញុំទេ ឯពាក្យ
ដែលអ្នករាល់គ្នាឮ នោះមិនមែនជាពាក្យខ្ញុំ គឺជាព្រះបន្ទូល
របស់ព្រះវរបិតា ដែលទ្រង់ចាត់ឱ្យខ្ញុំមកទេតើ[ផ] ។
២៥ខ្ញុំប្រាប់សេចក្ដីទាំងនេះដល់អ្នករាល់គ្នា កំពុងដែល
នៅជាមួយគ្នានៅឡើយ ២៦តែព្រះដ៏ជាជំនួយ[ព] គឺជាព្រះ
វិញ្ញាណបរិសុទ្ធ ដែលព្រះវរបិតា នឹងចាត់មក ដោយនូវ
ឈ្មោះខ្ញុំ[ភ] ទ្រង់នឹងបង្រៀនអ្នករាល់គ្នា ពីគ្រប់សេចក្ដីទាំង
អស់[ម] ក៏នឹងរំឭកពីគ្រប់ទាំងសេចក្ដី ដែលខ្ញុំបានប្រាប់ដល់
អ្នករាល់គ្នាដែរ[យ] ២៧ខ្ញុំទុកសេចក្ដីសុខ នៅនឹងអ្នករាល់គ្នា[រ]
គឺខ្ញុំឱ្យសេចក្ដីសុខសាន្តរបស់ខ្ញុំ ដល់អ្នករាល់គ្នា ហើយដែល
ខ្ញុំឱ្យនោះ មិនមែនដូចជាលោកិយឱ្យទេ កុំឱ្យចិត្ត អ្នករាល់គ្នា
ថប់បារម្ភ[ល] ឬភ័យឡើយ ២៨អ្នករាល់គ្នាបានឮពាក្យ ដែលខ្ញុំ
ប្រាប់ថា ខ្ញុំទៅ ហើយនិងមកឯអ្នករាល់គ្នាវិញ[វ] បើសិនជា
អ្នករាល់គ្នាស្រឡាញ់ដល់ខ្ញុំ នោះនឹងមានសេចក្ដីអំណរ ឡើង
ដោយព្រោះខ្ញុំទៅឯព្រះវរបិតា[ស] ដ្បិតព្រះវរបិតាទ្រង់ធំ
លើសជាងខ្ញុំ[ហ] ២៩ឥឡូវនេះ ខ្ញុំបានប្រាប់អ្នករាល់គ្នា មុន
ដែលការនោះមកដល់ ដើម្បីកាលណាមកហើយ នោះឱ្យ
អ្នករាល់គ្នាបានជឿ[ឡ] ៣០ពីនេះទៅមុខ ខ្ញុំមិនបាននិយាយ
នឹងអ្នករាល់គ្នាប៉ុន្មានទៀតទេ ដ្បិតចៅហ្វាយរបស់លោកិយ
នេះ[អ] ជិតមកដល់ហើយ តែវាគ្មានអ្វីនៅក្នុងខ្ញុំទេ ៣១គឺខ្ញុំ
ធ្វើតាមបង្គាប់ព្រះវរបិតាវិញ[ក] ដើម្បីឱ្យលោកិយបានដឹងថា

**១៤:១៨** ញ ខ.៣,២៨ មថ ១៦:២៧
**១៤:១៩** ដ យហ ៧:៣៣,៣៤ ១៦:១៦ ឋ យហ ៦:៥៧
**១៤:២០** ឌ យហ ១៦:២៣,២៦ ឍ ខ.១០,១១ យហ ១០:៣៨ ១៧:២១ ណ រម ៨:១០
**១៤:២១** ត ខ.១៥ ថ ចទ ៧:១៣ យហ ១៦:២៧ ១យហ ២:៥
**១៤:២២** ទ លក ៦:១៦ កច ១:១៣ ធ កច ១០:៤១
**១៤:២៣** ន ខ.១៥ ប រម ៨:១០
**១៤:២៤** ផ ខ.១០ ចទ ១៨:១៨ យហ ៥:១៩ ៧:១៦ ៨:២៨ ១២:៤៩,៥០
**១៤:២៦** ព ខ.១៦ យហ ១៥:២៦ ១៦:៧

ភ កច ២:៣៣ ម យហ ១៦:១៣ ១យហ ២:២០,២៧ យ យហ ២:២២
**១៤:២៧** រ ជន ៦:២៦ ទដ ៨៥:៨ មឡ ២:៦ លក ២:១៤ ២៤:៣៦ យហ ១៦:៣៣ ភល ៤:៧ កល ៣:១៥ ល ខ.១ **១៤:២៨** វ ខ.២–៤,១៨ មថ ១៦:២៧ ស យហ ៥:១៨ ហ យហ ១០:២៩ **១៤:២៩** ឡ យហ ១៣:១៩ ១៦:៤ **១៤:៣០** អ យហ ១២:៣១

សំដៅលើការយាងមកជាលើកទីពីររបស់ទ្រង់ (មើលការពន្យល់ ខ.៣,១៩, ២៨ ១៦:២២) ។

**១៤:១៩** *លោកិយនឹងលែងឃើញខ្ញុំ តែអ្នករាល់គ្នានឹងឃើញខ្ញុំវិញ* មានន័យថា អស់អ្នកដែលទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ នោះនឹងបានឃើញទ្រង់ ប៉ុន្តែ អស់អ្នកដែលមិនទទួលជឿដល់ទ្រង់ នោះនឹងមិនបានឃើញទ្រង់ទេ ។ ម្យ៉ាងទៀត ការសុគតរបស់ព្រះយេស៊ូវគ្រីស្ទនៅលើឈើឆ្កាង បានញែកពួកសិស្សទ្រង់ជាបរិសុទ្ធ និងដាច់ចេញស្រឡះពីលោកិយ ។ *ដោយព្រោះខ្ញុំរស់ នោះអ្នករាល់គ្នានឹងរស់ដែរ* ឃ្លានេះបញ្ជាក់ថា ជីវិតអ្នកជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទគ្រប់រូប គឺបានរស់ដោយសារទ្រង់ (១:៤ ៣:១៥ ១០:១០ ភល ១:២១ និងការពន្យល់) ។

**១៤:២០** *នៅថ្ងៃនោះ* សំដៅលើថ្ងៃដែលព្រះយេស៊ូវរស់ពីសុគតឡើងវិញ ដែលធ្វើឱ្យពួកសិស្សទ្រង់ដឹងច្បាស់ នូវសេចក្ដីដែលទ្រង់មានបន្ទូលទៅកាន់ពួកគេ ។

**១៤:២៣** "មើលការពន្យល់ ខ.១៥,២១ ១៥:១០"។

**១៤:២៤** *គឺជាព្រះបន្ទូលរបស់ព្រះវរបិតា ដែលទ្រង់ចាត់ឱ្យខ្ញុំមក* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា គ្រប់សេចក្ដីទាំងអស់ដែលព្រះយេស៊ូវគ្រីស្ទមានបន្ទូល គឺជាព្រះបន្ទូលរបស់ព្រះវរបិតា (ខ.១០ ៧:១៦) ។

**១៤:២៦** *ព្រះដ៏ជាជំនួយ* "មើលការពន្យល់ ខ.១៦"។ *ព្រះវិញ្ញាណបរិសុទ្ធដែលព្រះវរបិតានឹងចាត់មក* ឃ្លានេះបញ្ជាក់ថា គឺព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ ចាត់ព្រះវិញ្ញាណបរិសុទ្ធ ឱ្យមកគង់ជាមួយយើងគ្រប់ៗគ្នា (មើលការពន្យល់ ១:១៣ ១៥:២៦) ។ *ដោយនូវឈ្មោះខ្ញុំ* "មើលការពន្យល់ ខ.១៣ ២:២៣"។ *ទ្រង់នឹងបង្រៀនអ្នករាល់គ្នា ពីគ្រប់សេចក្ដីទាំងអស់* មានន័យថា ព្រះយេស៊ូវទ្រង់ចាត់ព្រះវិញ្ញាណបរិសុទ្ធមក ដើម្បីពន្យល់ និងបង្រៀនពួកសិស្សរបស់ទ្រង់បន្ថែមទៀត ប្រយោជន៍ឱ្យពួកគេយល់ច្បាស់ នូវគ្រប់សេចក្ដីទាំងអស់ ដែលទ្រង់មានបន្ទូលមកកាន់ពួកគេ ។

**១៤:២៧** *ខ្ញុំទុកសេចក្ដីសុខនៅនឹងអ្នករាល់គ្នា* ពាក្យថា "សេចក្ដីសុខ" ត្រង់ចំណុចនេះ គឺសំដៅលើសេចក្ដីសុខដ៏ពិត ខាងឯវិញ្ញាណ និងជាអំណោយទានមកអំពីព្រះអម្ចាស់ នៅក្នុងការប្រកបជាមួយទ្រង់ (២០:១៩ មើលពន្យល់ ខ.២១,២៦) ។ *មិនមែនដូចជាលោកិយឱ្យទេ* មានន័យថា សេចក្ដីសុខដែលព្រះយេស៊ូវប្រទានមកយើងរាល់គ្នា គឺជាសេចក្ដីសុខពិតប្រាកដ និងមិនប្រែប្រួលដូចជារបស់លោកិយ ដែលតែងតែប្រែប្រួលនោះឡើយ (មើលការពន្យល់ ១៦:៣៣) ។ *កុំឱ្យចិត្តអ្នករាល់គ្នាថប់បារម្ភ ឬភ័យឡើយ* ព្រះយេស៊ូវគង់នៅជាមួយនឹងពួកសិស្សរបស់ទ្រង់គ្រប់ពេលវេលាទាំងអស់ ដូច្នេះ ទើបទ្រង់មិនឱ្យពួកគេថប់បារម្ភ ឬភ័យឡើយ (មើលការពន្យល់ ខ.១) ។

**១៤:២៨** *មានសេចក្ដីអំណរ ឡើង* មានន័យថា ព្រះយេស៊ូវមានព្រះហឫទ័យឱ្យពួកសិស្សរបស់ទ្រង់ទាំងអស់មានអំណរ ឡើង ពីព្រោះសិរីល្អ និងអំណាចព្រះចេស្ដាទាំងអស់ បានប្រទានមកទ្រង់អស់កល្បជានិច្ចហើយ ។ *ដ្បិតព្រះវរបិតា ទ្រង់ធំលើសជាងខ្ញុំ* ព្រះវរបិតាទ្រង់ចាត់ព្រះយេស៊ូវ ឱ្យមកសង្គ្រោះមនុស្សលោក ដោយការសុគតនៅលើឈើឆ្កាង ។ ដូច្នេះ បានជាព្រះយេស៊ូវមានបន្ទូលថា ព្រះវរបិតា ធំជាងទ្រង់ (ព្រះយេស៊ូវ) (១០:៣០ ១៣:១៦) ។

**១៤:៣០** *ចៅហ្វាយរបស់លោកិយ* សំដៅលើសាតាំង (១២:៣១) ។ *តែវាគ្មានអ្វី នៅក្នុងខ្ញុំទេ* មានន័យថា សាតាំងគ្មានអំណាចអ្វីលើព្រះយេស៊ូវទេ ។

ខ្ញុំស្រឡាញ់ដល់ទ្រង់ ចូរយើងក្រោកឡើងចេញពីទីនេះ
ទៅ។

## រឿងប្រៀបប្រដូចអំពីដើមទំពាំងបាយជូរ

**១៥** ១ ខ្ញុំជា[ខ]ដើមទំពាំងបាយជូរដ៏ពិត[គ] ហើយព្រះវរបិតាខ្ញុំ
ជាអ្នកដាំ ២ អស់ទាំងខ្នែងណាដុះចេញពីខ្ញុំ ដែលមិនបង្កើត
ផលផ្លែ[ឃ] នោះទ្រង់កាត់ចោល តែអស់ទាំងខ្នែងណា ដែល
បង្កើតផលផ្លែ[ង] នោះទ្រង់លួសខ្នែងនោះវិញ ដើម្បីឱ្យ
បានផលផ្លែជាច្រើនឡើង ៣ ឯអ្នករាល់គ្នា បានស្អាតហើយ
ដោយសារពាក្យ ដែលខ្ញុំបានប្រាប់[ច] ៤ ចូរនៅជាប់នឹងខ្ញុំ
ហើយខ្ញុំជាប់នឹងអ្នករាល់គ្នាចុះ[ឆ] ប្រៀបដូចជាខ្នែង បើមិន
នៅជាប់នឹងគល់ នោះពុំអាចនឹងបង្កើតផល ដោយឯកឯង
បានទេ ដូច្នេះ អ្នករាល់គ្នាក៏ពុំបានដែរ លើកតែនៅជាប់
នឹងខ្ញុំ ៥ ខ្ញុំជាគល់ អ្នករាល់គ្នាជាខ្នែង អ្នកណាដែលនៅ
ជាប់នឹងខ្ញុំ ហើយខ្ញុំជាប់នឹងអ្នកនោះ នោះទើបនឹងបង្កើត
ផលឡើងជាច្រើន[ជ] ដ្បិតបើដាច់ពីខ្ញុំចេញនោះអ្នករាល់គ្នា
ពុំអាចនឹងធ្វើអ្វីបានទេ ៦ បើអ្នកណាមិននៅជាប់នឹងខ្ញុំ អ្នក
នោះត្រូវបោះចោលទៅខាងក្រៅ ហើយក៏ក្រៀមទៅដូច
ជាខ្នែងដែរ រួចគេប្រមូលបោះទៅក្នុងភ្លើងឆេះអស់ទៅ[ឈ]
៧ បើអ្នករាល់គ្នានៅជាប់នឹងខ្ញុំ[ញ] ហើយពាក្យខ្ញុំនៅជាប់ក្នុង
អ្នករាល់គ្នា នោះចូរសូមអ្វីតាមតែប្រាថ្នាចុះ សេចក្ដីនោះ
នឹងបានសំរេចដល់អ្នករាល់គ្នាជាមិនខាន[ដ] ៨ ព្រះវរបិតាខ្ញុំ
បានដំកើងឡើង[ឋ] ដោយសេចក្ដីនេះឯង គឺដោយអ្នករាល់
គ្នាបង្កើតផលជាច្រើន យ៉ាងនោះអ្នករាល់គ្នានឹងធ្វើជាសិស្ស
ខ្ញុំមែន[ឌ]។

៩ ខ្ញុំបានស្រឡាញ់អ្នករាល់គ្នា ដូចជាព្រះវរបិតាទ្រង់
ស្រឡាញ់ខ្ញុំដែរ[ឍ] ចូរនៅជាប់ក្នុងសេចក្ដីស្រឡាញ់របស់ខ្ញុំ
ចុះ ១០ បើអ្នករាល់គ្នាកាន់តាមបញ្ញត្តិខ្ញុំ[ណ] នោះនឹងនៅជាប់

**១៤:៣១** ក យហ ១០:១៨ ១២:៤៩
**១៥:១** ខ យហ ៦:៣៥ គ ទដ ៨០:៨-១១ អស ៥:១-៧
**១៥:២** ឃ ខ.៦ មថ ៣:១០ ង ទដ ៩២:១៤ មថ ៣:៨ ៧:២០ កទ ៥:២២ អភ ៥:៩ ភល ១:១១ ង មថ ៣:៨ ៧:២០ កទ ៥:២២ អភ ៥:៩ ភល ១:១១
**១៥:៣** ច យហ ១៣:១០ ១៧:១៧ អភ ៥:២៦
**១៥:៤** ឆ យហ ៦:៥៦
**១៥:៥** ជ ខ.១៦
**១៥:៦** ឈ ខ.២ អគ ១៥:៤ មថ ៣:១០ **១៥:៧** ញ ខ.៤ យហ ៦:៥៦ ដ មថ ៧:៧
**១៥:៨** ឋ មថ ៩:៨ ឌ យហ ៨:៣១ **១៥:៩** ឍ យហ ១៧:២៣,២៤,២៦
**១៥:១០** ណ យហ ១៤:១៥

**១៤:៣១** *គឺខ្ញុំធ្វើតាមបង្គាប់ព្រះវរបិតាវិញ* ត្រង់ចំណុចនេះបង្ហាញយ៉ាងច្បាស់អំពីគំរូ និងសារសំខាន់នៃការស្ដាប់បង្គាប់របស់ព្រះយេស៊ូវ ចំពោះព្រះវរបិតា (មើលការពន្យល់ ខ.១៥,២១,២៣)។ ម្យ៉ាងទៀត ការទាំងនេះគឺជាជំនួយដ៏សំខាន់បំផុត សម្រាប់ពួកសិស្សរបស់ទ្រង់ទាំងអស់ (ប្រៀបធៀប ជំពូក ១៨-១៩)។

**១៥:១** *ខ្ញុំជាដើមទំពាំងបាយជូរដ៏ពិត* នៅក្នុងសម័យកាលសញ្ញាចាស់ ដើមទំពាំងបាយជូរ ជានិមិត្តរូបតំណាងឱ្យសាសន៍អ៊ីស្រាអែល (៦:៣៥ ទដ ៨០:៨-១៦ អស ៥:១-៧ យរ ២:២១ និងការពន្យល់)។ ម្យ៉ាងទៀត នៅពេលដែលមាននិយាយអំពីការប្រៀបធៀបជាមួយដើមទំពាំងបាយជូរ នោះបញ្ជាក់ថា ពួកអ៊ីស្រាអែល តែងតែមានចំណុចខ្សោយ និងកំហុសឆ្គង នៅក្នុងផ្នែកណាមួយជាក់ជាមិនខាន ។ ដូច្នេះ បានជាព្រះយេស៊ូវមានព្រះបន្ទូលថា ទ្រង់គឺជាដើមទំពាំងបាយជូរដ៏ពិត មានន័យថា ទ្រង់គ្មានចំណុចបន្ទោសបានឡើយ ។

**១៥:២** *នោះទ្រង់កាត់ចោល* ពាក្យថា "កាត់ចោល" ត្រង់ចំណុចនេះ គឺសំដៅលើការជំនុំជម្រះរបស់ព្រះអម្ចាស់ (មើលការពន្យល់ ខ.៦)។ *លួស* មានន័យថា កាត់ ឬច្រាស់ទ្រួសៗ ឱ្យដាច់មែកតូចៗ ដែលមិនល្អចេញ (ឧ: លួសមែកឈើ)។ *ដើម្បីឱ្យបានផលផ្លែជាច្រើនឡើង* ក្នុងសម័យកាលសញ្ញាថ្មី ពាក្យថា "ផលផ្លែ" គឺសំដៅ លើផលផ្លែខាងឯវិញ្ញាណ និងជីវិតដែលរស់នៅតាមព្រះហឫទ័យនៃព្រះអម្ចាស់ (មថ ៣:៨ ៧:១៦-២០ កទ ៥:២២-២៣ អភ ៥:៩ ភល ១:១១ និងការពន្យល់)។

**១៥:៣** *ឯអ្នករាល់គ្នា បានស្អាតហើយ* ឃ្លានេះពុំមែនមានន័យថា ពួកសិស្សរបស់ព្រះយេស៊ូវទាំងនោះ បានល្អស្អាតឥតខ្ចោះហើយនោះទេ ប៉ុន្តែ បញ្ជាក់ថា ពួកគេពិតជាបានរួចផុតពីអំណាចនៃសេចក្ដីងងឹត និងកំពុងស្ថិតនៅក្នុងការដឹកនាំរបស់ទ្រង់ជានិច្ច ។ *ពាក្យដែលខ្ញុំបានប្រាប់* សំដៅលើគ្រប់សេចក្ដីដែលព្រះយេស៊ូវទ្រង់មានព្រះបន្ទូល ។

**១៥:៤** *ចូរនៅជាប់នឹងខ្ញុំ* ត្រង់ចំណុចនេះបញ្ជាក់ថា គ្រប់អ្នកជឿដល់ព្រះយេស៊ូវទាំងអស់នឹងបង្កើតផលផ្លែ ប្រសិនបើនៅជាប់ក្នុងការប្រកបជាមួយទ្រង់ ។ រីឯអស់អ្នកណាដែលដាច់ចេញពីទ្រង់ នោះមិនអាចបង្កើតផលផ្លែបានទេ គឺប្រៀបដូចជាមែកទំពាំងបាយជូរ ដែលដាច់ចេញពីដើមរបស់វាដូច្នោះដែរ ។

**១៥:៥** *អ្នកណាដែលនៅជាប់នឹងខ្ញុំ ហើយខ្ញុំជាប់នឹងអ្នកនោះ* ឃ្លានេះបញ្ជាក់យ៉ាងច្បាស់ថា ការប្រកបជាមួយព្រះគ្រីស្ទគឺមានសារសំខាន់ណាស់ ព្រោះបើគ្មានទំនាក់ទំនងជាមួយទ្រង់ទេ នោះជីវិតរបស់យើងក៏គ្មានន័យអ្វីដែរ ។

**១៥:៦** *រួចគេប្រមូលបោះទៅក្នុងភ្លើងឆេះអស់ទៅ* ឃ្លានេះគឺសំដៅលើការជំនុំជម្រះរបស់ព្រះអម្ចាស់ (មើលការពន្យល់ ខ.២)។ នៅក្នុងបទគម្ពីរ "យហ ៦:៣៩ និង ១០:២៧-២៩" បញ្ជាក់ថា ខ្នែងដែលបង្កើតផលផ្លែ គឺសំដៅលើអ្នកជឿដល់ព្រះនាមព្រះអម្ចាស់ពិតប្រាកដ (មថ ៧:១៩-២៣ មើលការពន្យល់ យហ ១៥:២,៤,១០ ហព ៦:៩)។

**១៥:៧** បទគម្ពីរនេះបញ្ជាក់ថា ប្រសិនបើយើងស្ថិតនៅជាប់នឹងព្រះគ្រីស្ទ នោះទ្រង់ក៏ស្ថិតនៅក្នុងយើងដែរ ។ ហើយបើទ្រង់គង់នៅក្នុងយើង នោះព្រះបន្ទូលទ្រង់ក៏ស្ថិតនៅក្នុងយើងដែរ ។ យើងមិនអាចប្រកបជាមួយព្រះអម្ចាស់ដោយគ្មានព្រះបន្ទូលទ្រង់នៅក្នុងយើងបានទេ ។ ម្យ៉ាងទៀត យើងមិនអាចអធិស្ឋានបានត្រឹមត្រូវ ដោយគ្មានជំនឿ និងព្រះបន្ទូលទ្រង់នៅក្នុងយើងទេ (មើលការពន្យល់ ១៤:១៣ ១យហ ៥:១៤)។

**១៥:៨** *ព្រះវរបិតាខ្ញុំបានដំកើងឡើង* មានន័យថា ព្រះវរបិតាបានតម្កើងឡើងតាមរយៈព្រះរាជកិច្ចរបស់ព្រះរាជបុត្រា (មើលការពន្យល់ ១៣:៣១) និងផលផ្លែនៃពួកសិស្សរបស់ទ្រង់ (មថ ៧:២០ លក ៦:៤៣-៤៥)។

**១៥:១០** *កាន់តាមបញ្ញត្តិខ្ញុំ . . . ដូចជាខ្ញុំបានកាន់តាមបញ្ញត្តិនៃព្រះវរបិតាខ្ញុំ* តាមរយៈព្រះបន្ទូលនៅត្រង់ចំណុចនេះបញ្ជាក់ថា គំរូ និងការប្រតិបត្តិតាមបញ្ញត្តិរបស់ព្រះអម្ចាស់ មានសារសំខាន់ណាស់ សម្រាប់ជីវិតគ្រីស្ទបរិស័ទគ្រប់ៗរូប (១៤:១៥,២១,២៣ មើលពន្យល់ ១៤:៣១)។ *ក៏នៅជាប់ក្នុងសេចក្ដីស្រឡាញ់របស់ទ្រង់ដែរ* មានន័យថា សេចក្ដីស្រឡាញ់និងការស្ដាប់បង្គាប់ ត្រូវតែដើរទន្ទឹមគ្នាជានិច្ច (១៤:១៥,២១,២៣ ៥:២-៣ និងការ

ក្នុងសេចក្ដីស្រឡាញ់របស់ខ្ញុំ ដូចជាខ្ញុំបានកាន់តាមបញ្ញត្តិ
នៃព្រះវរបិតាខ្ញុំ ហើយក៏នៅជាប់ក្នុងសេចក្ដីស្រឡាញ់របស់
ទ្រង់ដែរ ១១ ខ្ញុំបាននិយាយសេចក្ដីទាំងនេះ ប្រាប់ដល់អ្នក
រាល់គ្នា ដើម្បីឱ្យសេចក្ដីអំណររបស់ខ្ញុំ បាននៅជាប់ក្នុង
អ្នករាល់គ្នា ហើយឱ្យសេចក្ដីអំណរ របស់អ្នករាល់គ្នា
បានពោរពេញផង[ត] ១២ នេះជាសេចក្ដីបញ្ញត្តិរបស់ខ្ញុំ គឺ
ឱ្យអ្នករាល់គ្នា ស្រឡាញ់ដល់គ្នាទៅវិញទៅមក ដូចជាខ្ញុំ
បានស្រឡាញ់អ្នករាល់គ្នាដែរ[ថ] ១៣ គ្មានអ្នកណាមានសេចក្ដី
ស្រឡាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្តូរជីវិត ជំនួសពួក
សំឡាញ់របស់ខ្លួននោះទេ[ទ] ១៤ បើអ្នករាល់គ្នាធ្វើតាមសេចក្ដី
ដែលខ្ញុំបង្គាប់[ធ] នោះអ្នករាល់គ្នា ជាពួកសំឡាញ់ខ្ញុំហើយ[ន]
១៥ ខ្ញុំមិនហៅជាអ្នកបំរើទៀត ពីព្រោះអ្នកបំរើ គេមិនដឹងជា
ចៅហ្វាយធ្វើអ្វីទេ គឺខ្ញុំហៅអ្នករាល់គ្នាថា ជាសំឡាញ់វិញ
ពីព្រោះ ខ្ញុំបានឱ្យអ្នករាល់គ្នា ដឹងគ្រប់ការទាំងអស់ ដែល
ខ្ញុំឮ ពីព្រះវរបិតាខ្ញុំមក[ប] ១៦ មិនមែនអ្នករាល់គ្នា ដែល
បានរើសខ្ញុំទេ គឺខ្ញុំទេតើ ដែលរើសអ្នករាល់គ្នាវិញ[ផ] ទាំង
តាំងអ្នករាល់គ្នា ឱ្យទៅបង្កើតផល[ព] ហើយឱ្យផលរបស់អ្នក
រាល់គ្នាបាននៅជាប់ផង ដើម្បីឱ្យព្រះវរបិតា បានប្រោស
ប្រទានឱ្យអ្នករាល់គ្នាបានអ្វីៗ ដែលនឹងសូមពីទ្រង់ដោយនូវ

**១៥:១១** ត យហ ៣:២៩
**១៥:១២** ថ ខ.១៧ យហ ១៣:៣៤
**១៥:១៣** ទ លប ៤៤:៣៣ យហ ១០:១១ រម ៥:៧,៨
**១៥:១៤** ធ មថ ១២:៥០ ន យប ១៦:២០ សភ ១៨:២៤ លក ១២:៤
**១៥:១៥** ប យហ ៨:២៦
**១៥:១៦** ផ ខ.១៩ ព យហ ១៣:១៨ ខ.៥ ភ មថ ៧:៧
**១៥:១៧** ម ខ.១២
**១៥:១៨** យ អស ៦៦:៥ យហ ៧:៧ ១យហ ៣:១៣
**១៥:១៩** រ ខ.១៦ ល យហ ១៧:១៤
**១៥:២០** វ យហ ១៣:១៦ ស ២ថន ៣:១២

ឈ្មោះខ្ញុំ[ភ] ១៧ ខ្ញុំបង្គាប់សេចក្ដីនេះ ដល់អ្នករាល់គ្នា គឺឱ្យ
ស្រឡាញ់គ្នាទៅវិញទៅមកចុះ[ម]។

### លោកីយស្អប់ពួកសិស្សរបស់ព្រះយេស៊ូវ

១៨ បើសិនជាលោកីយស្អប់អ្នករាល់គ្នា[យ] នោះអ្នករាល់គ្នា
ដឹងហើយ ថាគេបានស្អប់ខ្ញុំជាមុន ១៩ បើអ្នករាល់គ្នាជារបស់
ផងលោកីយ នោះលោកីយនឹងស្រឡាញ់អ្នករាល់គ្នា តែ
ដោយព្រោះខ្ញុំបានរើស[រ]ចេញ ពីលោកីយមក ហើយអ្នក
រាល់គ្នា មិនមែនជារបស់ផងលោកីយទៀត នោះបានជា
លោកីយស្អប់អ្នករាល់គ្នាវិញ[ល] ២០ ចូរនឹកចាំពីពាក្យដែល
ខ្ញុំបានប្រាប់រួចហើយថា បាវមិនមែនធំជាងចៅហ្វាយទេ[វ]
បើគេបានបៀតបៀនដល់ខ្ញុំ នោះគេនឹងបៀតបៀនដល់អ្នក
រាល់គ្នា[ស] ហើយបើគេបានកាន់តាមពាក្យខ្ញុំ នោះគេនឹងកាន់
តាមពាក្យរបស់អ្នករាល់គ្នាដែរ ២១ គេនឹងប្រព្រឹត្តការទាំង
នោះដល់អ្នករាល់គ្នា ដោយយល់ដល់ឈ្មោះខ្ញុំ[ហ] ពីព្រោះ
គេមិនស្គាល់ព្រះដែលចាត់ឱ្យខ្ញុំមកទេ[ឡ] ២២ បើសិនជាខ្ញុំមិន
បានមកនិយាយនឹងគេ[អ] នោះគេឥតមានបាបទេ តែឥឡូវ
នេះ គេគ្មានសេចក្ដីដោះសា ចំពោះបាបរបស់ខ្លួនសោះ[ក]

**១៥:២១** ហ អស ៦៦:៥ មថ ៥:១០,១១ ១០:២២ លក ៦:២២ កថ ៥:៤១ ១ពត ៤:១៤ វវ ២:៣ ឡ យហ ១៦:៣ **១៥:២២** អ អគ ២:៥ ៣:៧ ក យហ ៩:៤១ រម ១:២០ ២:១

ពន្យល់ ១យហ ២:៥)។

**១៥:១១** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវមានព្រះហឫទ័យចង់ឱ្យអ្នកជឿដល់ព្រះនាមទ្រង់គ្រប់ៗគ្នា មានអំណរពេញជាបរិបូរ (៣:២៩ ១៦:២២,២៤ ១៧:១៣ ភល ៤:៤ ១ថន ៥:១៦ ១យហ ១:៤)។

**១៥:១៣** សេចក្ដីស្រលាញ់របស់ព្រះយេស៊ូវគ្រីស្ទ មិនមែនមាននៅតែក្នុងព្រះបន្ទូលរបស់ទ្រង់ប៉ុណ្ណោះទេ គឺបានសំដែងឱ្យឃើញយ៉ាងច្បាស់ ដោយការសុគតរបស់ទ្រង់ទៀតផង (មើលការពន្យល់ អភ ៥:២៥)។

**១៥:១៥** *ខ្ញុំមិនហៅជាអ្នកបំរើទៀត . . . គឺខ្ញុំហៅអ្នករាល់គ្នាថាជាសំឡាញ់វិញ* ព្រះយេស៊ូវមានបន្ទូលយ៉ាងដូច្នេះ ព្រោះថា អ្នកបម្រើគ្រាន់តែមាននាទីបំពេញកិច្ចការ ដែលចៅហ្វាយដាក់ឱ្យធ្វើប៉ុណ្ណោះ ហើយមិនបានដឹងអំពីគោលបំណងរបស់ចៅហ្វាយខ្លួនទេ ។ *ខ្ញុំបានឱ្យអ្នករាល់គ្នាដឹងគ្រប់ការទាំងអស់* ត្រង់ចំណុចនេះមិនមានន័យថា ព្រះអម្ចាស់ទ្រង់បើកសំដែងឱ្យអ្នកជឿដល់ព្រះនាមទ្រង់ នូវគ្រប់ការទាំងអស់នោះទេ គឺទ្រង់មានព្រះហឫទ័យឱ្យគេដឹងទៅតាមសមត្ថភាពដែលគេអាចទទួលយកបាន ។ ទោះជាយ៉ាងណាក៏ដោយ ក៏អ្នកជឿដល់ព្រះនាមព្រះអម្ចាស់គ្រប់ៗរូប គឺមានព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយ និងជួយណែនាំបំភ្លឺគ្រប់ពេលវេលា (មើលការពន្យល់ ១៦:១២-១៣)។

**១៥:១៦** *មិនមែនអ្នករាល់គ្នាដែលបានរើសខ្ញុំទេ គឺខ្ញុំទេតើដែលរើសអ្នករាល់គ្នា* ត្រង់ចំណុចនេះបញ្ជាក់ថា ចំពោះពួកសាសន៍យូដាជាទូទៅ តែងតែរកគ្រូដែលខ្លួនពេញចិត្តឱ្យមកបង្រៀន ។ ប៉ុន្តែ ព្រះយេស៊ូវមានបន្ទូលទៅកាន់ពួកសិស្សទ្រង់ថា ទ្រង់បានជ្រើសរើសពួកគេជាមុន ដោយមានគោលបំណងយ៉ាងច្បាស់លាស់បំផុត គឺឱ្យពួកគេបង្កើតផលផ្លែ (មើលការពន្យល់ ខ.២ ២:២៣ ១៤:១៣)។

**១៥:១៨-១៩** *លោកីយ* ពាក្យថា"លោកីយ"ត្រង់ចំណុចនេះ សំដៅលើគ្រប់ប្រព័ន្ធទាំងអស់ ដែលមនុស្សបង្កើតឡើងប្រឆាំងនឹងព្រះអម្ចាស់ និងព្រះហឫទ័យទ្រង់ (៧:៧ ៨:២៣ ១៤:៣០ ១កថ ២:១២ មើលការពន្យល់ ១:៩)។

**១៥:២១** *គេនឹងប្រព្រឹត្តការទាំងនោះដល់អ្នករាល់គ្នា ដោយយល់ដល់ឈ្មោះខ្ញុំ* ឃ្លានេះ នៅក្នុងព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេស សរសេរថា "*គេនឹងប្រព្រឹត្តការទាំងនោះដល់អ្នករាល់គ្នា ដោយព្រោះឈ្មោះខ្ញុំ*" មានន័យថា ពួកអ្នកជឿដល់ព្រះនាមព្រះអម្ចាស់ទាំងអស់ មិនមែនជារបស់លោកិយទេ ដូច្នេះ ការបៀតបៀន (ពីសំណាក់លោកិយ) តែងតែកើតមានឡើងចំពោះពួកគេ ។ លោកិយព្យាយាម ធ្វើទុក្ខបៀតបៀនដល់ពួកអ្នកជឿដល់ព្រះអម្ចាស់ ពីព្រោះគេ (លោកិយ) បដិសេធមិនទទួលស្គាល់ទ្រង់តែម្តង (២:២៣ ១៦:៣)។

**១៥:២២** *គេគ្មានសេចក្ដីដោះសា ចំពោះបាបរបស់ខ្លួនសោះ* ត្រង់ចំណុចនេះបញ្ជាក់ថា ព្រះអម្ចាស់បានប្រទានព្រះបន្ទូល (ព្រះគម្ពីរសញ្ញាចាស់) ហើយថែមទាំងបានចាត់ព្រះរាជបុត្រាទ្រង់ ឱ្យយាងមកប្រសូត និងរស់នៅក្នុងចំណោមពួកយូដាដោយផ្ទាល់ ។ ដូច្នេះ បើពួកគេណាម្នាក់បដិសេធ និងមិនទទួលព្រះរាជបុត្រានោះនឹងមិនអាចដោះសា ចំពោះអំពើបាបរបស់ខ្លួនបានទេ ។ បើព្រះរាជបុត្រាមិនបានយាងមក នៅក្នុងចំណោមពួកគេទេ នោះពួកគេនឹងស្ថិតនៅក្នុងអំពើបាបរបស់ខ្លួនដដែល ប៉ុន្តែ ពួកគេមិនមានឈ្មោះថា បានបដិសេធទ្រង់ដោយផ្ទាល់ទេ (ខ.២៤)។

២៣អ្នកណាដែលស្អប់ខ្ញុំ នោះក៏ស្អប់ដល់ព្រះវរបិតាខ្ញុំដែរ
២៤បើខ្ញុំមិនបានធ្វើការនៅក្នុងពួកគេ ដែលគ្មានអ្នកណា
ទៀតបានធ្វើឡើយ[ខ] នោះគេឥតមានបាបទេ[គ] តែឥឡូវនេះ
គេបានទាំងឃើញ ហើយទាំងស្អប់ខ្ញុំ នឹងព្រះវរបិតារបស់ខ្ញុំ
ដែរ ២៥នោះដើម្បីឱ្យសេចក្ដី ដែលចែងទុកមក ក្នុងក្រិត្យ
វិន័យរបស់គេបានសំរេច[ឃ] ដែលថា «គេបានស្អប់ខ្ញុំ ដោយ
ឥតហេតុ»[ង] ២៦ប៉ុន្តែកាលណាព្រះដ៏ជាជំនួយទ្រង់យាងមក[ច]
ដែលខ្ញុំនឹងចាត់មកពីព្រះវរបិតា[ឆ] គឺជាព្រះវិញ្ញាណនៃសេចក្ដី
ពិត[ជ] ដែលចេញពីព្រះវរបិតាមក ព្រះអង្គនោះ ទ្រង់នឹងធ្វើ
បន្ទាល់ពីខ្ញុំ[ឈ] ២៧ហើយអ្នករាល់គ្នានឹងធ្វើបន្ទាល់ដែរ[ញ] ពី
ព្រោះអ្នករាល់គ្នាបាននៅជាមួយនឹងខ្ញុំ តាំងតែពីដើមមក[ដ]។
**១៦** ១ខ្ញុំបាននិយាយសេចក្ដីទាំងនេះ[ឋ]ប្រាប់ដល់អ្នករាល់គ្នា
ដើម្បីកុំឱ្យអ្នករាល់គ្នា រវាតចិត្តឡើយ[ឌ] ២គេនឹងកាត់អ្នក
រាល់គ្នា ចេញពីពួកជំនុំរបស់គេ[ឍ] ក៏នឹងមានពេលវេលាមក
នោះអស់អ្នកណា ដែលសំឡាប់អ្នករាល់គ្នា នឹងគិតស្មានថា
ខ្លួនបំរើដល់ព្រះដែរ[ណ] ៣គេនឹងប្រព្រឹត្តការទាំងនោះ ដល់
អ្នករាល់គ្នា ដោយព្រោះគេមិនស្គាល់ព្រះវរបិតា ឬខ្ញុំទេ[ត]
៤តែខ្ញុំនិយាយសេចក្ដីទាំងនេះ ប្រាប់ដល់អ្នករាល់គ្នា ដើម្បី
កាលណាពេលវេលានោះមកដល់ នោះឱ្យអ្នករាល់គ្នាបាន
នឹកឃើញថា[ថ] ខ្ញុំប្រាប់ហើយ ខ្ញុំមិនបានប្រាប់កាលពីដើមទេ
ពីព្រោះ ខ្ញុំកំពុងនៅជាមួយនឹងអ្នករាល់គ្នា នៅឡើយ[ទ]។

## ព្រះរាជកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធ

៥តែឥឡូវនេះ ខ្ញុំទៅឯព្រះអង្គ ដែលចាត់ឱ្យខ្ញុំមក[ធ]
ហើយក្នុងពួកអ្នករាល់គ្នា គ្មានអ្នកណាសួរខ្ញុំថា លោក
អញ្ជើញទៅឯណានោះទេ[ន] ៦ប៉ុន្តែ អ្នករាល់គ្នាមានចិត្ត
ពេញដោយសេចក្ដីព្រួយ ដោយព្រោះខ្ញុំបានប្រាប់សេចក្ដី
ទាំងនេះ[ប] ៧ខ្ញុំប្រាប់តាមត្រង់ថា ដែលខ្ញុំទៅ នោះមាន
ប្រយោជន៍ដល់អ្នករាល់គ្នាវិញ ដ្បិតបើខ្ញុំមិនទៅទេ នោះ
ព្រះដ៏ជាជំនួយ[ផ] ក៏មិនមកឯអ្នករាល់គ្នាដែរ តែបើខ្ញុំទៅ

**១៥:២៤** ខ យហ ៥:៣៦ គ យហ ៩:៤១ **១៥:២៥** ឃ យហ ១០:៣៤ ង ទដ ៣៥:១៩ ៦៩:៤ ១០៩:៣ **១៥:២៦** ច យហ ១៤:១៦ ឆ យហ ១៤:២៦ ១៦:៧ ជ យហ ១៤:១៧ ឈ ១យហ ៥:៧ **១៥:២៧** ញ យក ២៤:៤៨ យហ ២១:២៤ ១យហ ១:២ ៤:១៤ ដ លក ១:២ **១៦:១** ឋ យហ ១៥:១៨–២៧ ឌ មថ ១១:៦ **១៦:២** ឍ យហ ៩:២២ ១២:៤២ ណ អស ៦៦:៥ កច ២៦:៩,១០ វវ ៦:៩ **១៦:៣** ត យហ ១៥:២១ ១៧:២៥ ១យហ ៣:១ **១៦:៤** ថ យហ ១៣:១៩ ១៤:២៩ ទ យហ ១៥:២៧ **១៦:៥** ធ ខ.១០,១៧,២៨ យហ ៧:៣៣ ន យហ ១៣:៣៦ ១៤:៥ **១៦:៦** ប ខ.២២ **១៦:៧** ផ យហ ១៤:១៦ ១៥:២៦

**១៥:២៣** *អ្នកណាដែលស្អប់ខ្ញុំ នោះក៏ស្អប់ដល់ព្រះវរបិតាខ្ញុំដែរ* ឃ្លានេះបញ្ជាក់ថា អ្នកណាដែលបដិសេធព្រះយេស៊ូវ គឺមានន័យថា ស្អប់ទ្រង់ ។ ហើយអ្នកណាដែលស្អប់ព្រះយេស៊ូវ នោះក៏មានន័យថា ស្អប់ដល់ព្រះវរបិតាដែលចាត់ឱ្យទ្រង់មកដែរ (១៣:២០) ។

**១៥:២៥** *ដើម្បីឱ្យសេចក្ដី ដែលចែងទុកមកក្នុងក្រិត្យវិន័យរបស់គេបានសំរេច* មានន័យថា ការបៀតបៀន ការប្រឆាំងទាស់នឹងព្រះយេស៊ូវ និងសេចក្ដីផ្សេងៗជាច្រើនទៀត ដែលចែងទុកអំពីទ្រង់ ត្រូវបានសម្រេចទាំងអស់ (ទដ ៣៥:១៩) ។ *ក្រិត្យវិន័យ* សំដៅលើក្រឹត្យវិន័យលោកម៉ូសេ ឬគ្រប់សេចក្ដីដែលមានចែងនៅ ក្នុងព្រះគម្ពីរសញ្ញាចាស់ទាំងមូល (មើលការពន្យល់ ១០:៣៤ ១២:៣៤) ។

**១៥:២៦** *ព្រះដ៏ជាជំនួយ* គឺព្រះវិញ្ញាណបរិសុទ្ធ (មើលពន្យល់ ១៤:១៦, ២៦) ។ ព្រះរាជកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺធ្វើឱ្យព្រះហឫទ័យរបស់ព្រះវរបិតានៅលើផែនដីនេះបានសម្រេច ។ *ទ្រង់នឹងធ្វើបន្ទាល់ពីខ្ញុំ* ឃ្លានេះមានន័យថា ព្រះវិញ្ញាណបរិសុទ្ធធ្វើបន្ទាល់ អំពីព្រះយេស៊ូវគ្រីស្ទថា ទ្រង់គឺជាព្រះរាជបុត្រានៃព្រះ និងជាព្រះអង្គសង្គ្រោះមនុស្សលោកពិតប្រាកដមែន (មើលពន្យល់ ១:៧) ។

**១៥:២៧** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ទីបន្ទាល់របស់អ្នកជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ គឺមានសារសំខាន់ណាស់ ក្នុងការនាំដំណឹងល្អរបស់ទ្រង់ ទៅអ្នកដែលមិនទាន់ស្គាល់ទ្រង់នៅឡើយ (លក ២៤:៤៨ កច ១០:៣៩,៤១ រម ១០:១៤ មើលការពន្យល់ កច ១:៨) ។

**១៦:២** *កាត់អ្នករាល់គ្នាចេញពីពួកជំនុំរបស់ពួកគេ* "មើលការពន្យល់ ៩:២២"។ *នោះអស់អ្នកណា . . . ខ្លួនបំរើដល់ព្រះដែរ* ឃ្លានេះសំដៅលើពួកអ្នកកាន់សាសនាដែលយល់ថា ព្រះសព្វព្រះទ័យ ឱ្យពួកគេធ្វើទុក្ខបៀតបៀនដល់គ្រីស្ទបរិស័ទ ។ លោកសុល (ក្រោយមកហៅថា"ប៉ុល") បានព្យាយាមធ្វើការបៀតបៀន និងតាមចាប់គ្រីស្ទបរិស័ទជាច្រើន ដោយយល់ថា ធ្វើដូច្នោះគឺត្រឹមត្រូវតាមព្រះហឫទ័យនៃព្រះអម្ចាស់ (កច ៩:១,២ ២៦:៩–១១ កទ ១:១៣–១៤) ។

**១៦:៣** *ព្រះវរបិតា* "មើលការពន្យល់ ៥:១៧"។ ព្រះវរបិតា និងព្រះរាជបុត្រា គឺតែមួយអង្គទេ (យហ ១០:៣០) ។ ការដែលមិនស្គាល់ព្រះយេស៊ូវគ្រីស្ទ ក៏មានន័យថា មិនស្គាល់ព្រះវរបិតាដែរ (១៤:៧,១០-១១ ១៧:៦-៧, ២២-២៣,២៦ និងការ ពន្យល់) ។

**១៦:៥** *គ្មានអ្នកណាសួរខ្ញុំ លោកអញ្ជើញទៅឯណានោះទេ* ត្រង់ចំណុចនេះបញ្ជាក់ថា លោកពេត្រុសធ្លាប់បានសួរអំពីដំណើរដែលថា តើព្រះយេស៊ូវនឹងយាងទៅឯណា (១៣:៣៦) ប៉ុន្តែ ក្នុងខណៈនោះ គាត់បែរជាចាប់អារម្មណ៍ទៅលើរឿងផ្សេងទៅវិញ ។ មានន័យថា គាត់បែរជាបារម្ភអំពីហេតុការណ៍ដែលនឹងកើតឡើង ចំពោះអ្នកដទៃ និងខ្លួនគាត់ផ្ទាល់តែម្ដង គឺមិនមែនអំពីទីកន្លែងដែលព្រះយេស៊ូវនឹងយាងទៅនោះទេ ។

**១៦:៦** *ចិត្តពេញទៅដោយសេចក្ដីព្រួយ* ពួកសិស្សរបស់ព្រះយេស៊ូវមានចិត្តពេញទៅដោយសេចក្ដីព្រួយ ព្រោះតែទ្រង់មានបន្ទូលថា ទ្រង់នឹងចាកចេញពីពួកគេ ។

**១៦:៧** *បើខ្ញុំមិនទៅទេ នោះព្រះដ៏ជាជំនួយក៏មិនមកឯអ្នករាល់គ្នាដែរ* ត្រង់ចំណុចនេះ ព្រះយេស៊ូវមិនបានបញ្ជាក់ទេថា ហេតុអ្វីបានជាព្រះវិញ្ញាណមិនយាងមកនៅ មុនពេលដែលទ្រង់យាងចេញទៅ ។ ប៉ុន្តែ នៅក្នុងសេចក្ដីបង្រៀនរបស់ទ្រង់បាន បញ្ជាក់យ៉ាងច្បាស់ អំពីសារសំខាន់នៃព្រះរាជកិច្ចរបស់ទ្រង់នៅមុនការយាងមក របស់ព្រះវិញ្ញាណបរិសុទ្ធ ។ ការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង ដើម្បីសង្គ្រោះមនុស្សលោក ក៏ជាព្រះរាជកិច្ចដែលទ្រង់ត្រូវបំពេញ នៅមុនការយាងមករបស់ព្រះវិញ្ញាណបរិសុទ្ធដែរ ។ *ព្រះដ៏ជាជំនួយ* គឺព្រះវិញ្ញាណបរិសុទ្ធ (មើលការពន្យល់ ១៤:៦)។ *ខ្ញុំនឹង*

នោះខ្ញុំនឹងចាត់ទ្រង់ឱ្យមក[ព] ៨កាលណាទ្រង់បានយាងមក
ហើយ នោះទ្រង់នឹងសំដែង ឱ្យមនុស្សលោកដឹងច្បាស់ពី
អំពើបាប ពីសេចក្តីសុចរិត ហើយពីសេចក្តីជំនុំជំរះ ៩គឺ
ពីអំពើបាប[ភ] ដោយព្រោះគេមិនជឿដល់ខ្ញុំ ១០ពីសេចក្តី
សុចរិត[ម] ដោយព្រោះខ្ញុំទៅឯព្រះវរបិតាខ្ញុំ[យ] ហើយអ្នក
រាល់គ្នាមិនឃើញខ្ញុំទៀតទេ ១១នឹងពីសេចក្តីជំនុំជំរះ ដោយ
ព្រោះចៅហ្វាយ របស់លោកីយនេះ[រ] ត្រូវទោសហើយ។
១២ខ្ញុំនៅមានសេចក្តីជាច្រើនទៀត នឹងប្រាប់ដល់អ្នក
រាល់គ្នា តែឥឡូវនេះ អ្នករាល់គ្នាពុំអាចនឹងទទួលបានទេ[ល]
១៣កាលណាព្រះអង្គនោះ គឺជាព្រះវិញ្ញាណនៃសេចក្តីពិត[វ]
បានមកដល់ នោះទ្រង់នឹងនាំអ្នករាល់គ្នា ចូលក្នុងគ្រប់ទាំង
សេចក្តីពិត[ស] ដ្បិតទ្រង់នឹងមានបន្ទូល មិនមែនដោយអាង
ព្រះអង្គទ្រង់ទេ គឺនឹងមានបន្ទូល ចំពោះតែសេចក្តីណា
ដែលទ្រង់ឮ ហើយនឹងសំដែង ឱ្យអ្នករាល់គ្នាដឹងការដែល
ត្រូវមក ១៤ទ្រង់នឹងដំកើងខ្ញុំ ដ្បិតទ្រង់នឹងយកសេចក្តី ដែល
ដំរូវពីខ្ញុំ មកប្រាប់ដល់អ្នករាល់គ្នា ១៥គ្រប់ទាំងអស់ដែល
ព្រះវរបិតាមាន នោះជារបស់ផងខ្ញុំដែរ[ហ] ហេតុនោះ បាន
ជាខ្ញុំប្រាប់ថា ទ្រង់នឹងយកសេចក្តីដែលដំរូវពីខ្ញុំ មកប្រាប់
អ្នករាល់គ្នា។
១៦នៅបន្តិចទៀត[ឡ] អ្នករាល់គ្នានឹងលែងឃើញខ្ញុំ រួច
បន្តិចទៅទៀត នឹងឃើញខ្ញុំវិញ ដ្បិតខ្ញុំទៅឯព្រះវរបិតា[អ]។

## ទុក្ខលំបាកនៃពួកសាវ័កប្រែទៅជាអំណរ

១៧ដូច្នេះ មានពួកសិស្សទ្រង់ខ្លះនិយាយគ្នាថា ពាក្យនេះ
ដែលទ្រង់មានបន្ទូល មកយើងថា នៅបន្តិចទៀត អ្នក
រាល់គ្នានឹងលែងឃើញខ្ញុំ រួចបន្តិចទៅទៀត នឹងឃើញខ្ញុំ
វិញ[អ] ហើយដែលថា «ដ្បិតខ្ញុំទៅឯព្រះវរបិតា»[ក] នេះតើ
មានន័យដូចម្តេច ១៨ហេតុនោះបានជាគេនិយាយថា
ពាក្យនេះ ដែលទ្រង់មានបន្ទូលថា «នៅបន្តិចទៀត» ដូច្នេះ
នោះចង់ថាដូចម្តេច យើងស្តាប់មិនបានទេ ១៩ព្រះយេស៊ូវ
ក៏ជ្រាបថា គេចង់សួរទ្រង់ បានជាទ្រង់មានបន្ទូលទៅគេថា
តើអ្នករាល់គ្នាសាកសួរគ្នាពីពាក្យដែលខ្ញុំថា នៅបន្តិចទៀត
នឹងលែងឃើញខ្ញុំ រួចបន្តិចទៅទៀត នឹងឃើញខ្ញុំវិញ ឬអី
២០ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់

**១៦:៧** ព យហ ៧:៣៩ ១៤:២៦
**១៦:៩** ភ យហ ១៥:២២
**១៦:១០** ម កច ៣:១៤ ៧:៥២ រម ១:១៧ ៣:២១,២២ ១ពត ៣:១៨ យ ខ.៥
**១៦:១១** រ យហ ១២:៣១
**១៦:១២** ល មក ៤:៣៣ ១កថ ៣:២
**១៦:១៣** វ យហ ១៤:១៧ ស ទដ ២៥:៥ យហ ១៤:២៦
**១៦:១៥** ហ យហ ១៧:១០
**១៦:១៦** ឡ យហ ៧:៣៣ អ ខ.២២ យហ ១៤:១៨-២៤
**១៦:១៧** អ ខ.១៦ ក ខ.៥

*ចាត់ទ្រង់ឱ្យមក* "មើលការពន្យល់ ១៤:២៦"។
**១៦:៨** *ទ្រង់នឹងសំដែង ឱ្យមនុស្សលោកបានដឹងច្បាស់ ពីអំពើបាប* ឃ្លានេះបញ្ជាក់ថា ព្រះរាជកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺសំដែងឱ្យមនុស្សលោកដឹងថា គេពិតជាមានបាប ។ តាមធម្មតា នៅក្នុងព្រះគម្ពីរសញ្ញាថ្មី កាលណានិយាយអំពីព្រះរាជកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធ ច្រើនតែសំដៅលើព្រះរាជកិច្ចរបស់ទ្រង់នៅក្នុងអ្នកជឿ ។
**១៦:៩** *ពីអំពើបាប* ត្រង់ចំណុចនេះ បញ្ជាក់ថា បើមិនមានការបើកសំដែងពីព្រះវិញ្ញាណបរិសុទ្ធទេ នោះគ្មានអ្នកណាអាចទទួលស្គាល់ថា ខ្លួនមានបាបឡើយ ។ ម្យ៉ាងទៀត បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ការដែលមិនជឿដល់ព្រះអម្ចាស់ គឺជាអំពើបាប ។
**១៦:១០** *សេចក្តីសុចរិត* ការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ បាននាំមកនូវសេចក្តីសុចរិតដ៏ពិតប្រាកដ (រម ១:១៧ ៣:២១-២៤)។ មានតែព្រះវិញ្ញាណបរិសុទ្ធទេ ដែលបើកសំដែង ឱ្យមនុស្សលោកដឹង និងទទួលស្គាល់ថា សេចក្តីសុចរិត (នៅចំពោះព្រះ) មិនមែនកើតឡើងពីទង្វើរបស់ពួកគេទេ គឺបានមកដោយសារការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ នៅលើឈើឆ្កាងវិញ ។
**១៦:១១** *ពីសេចក្តីជំនុំជំរះ* បញ្ជាក់ថា ព្រះរាជកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធធ្វើឱ្យមនុស្សដឹងអំពីសេចក្តីជំនុំជម្រះរបស់ព្រះអម្ចាស់ ។ ម្យ៉ាងទៀត ទ្រង់បានបើកសម្តែងឱ្យមនុស្សលោកដឹងច្បាស់ថា សាតាំងដែលជាចៅហ្វាយលោកិយត្រូវជាប់ទោសហើយ (១២:៣១)។
**១៦:១២** *អ្នករាល់គ្នាពុំអាចនឹងទទួលបាន* ឃ្លានេះអាចមានន័យថា "លើសពីការយល់ដឹងរបស់អ្នករាល់គ្នាទៅទៀត" ឬ "អ្នករាល់គ្នាពុំអាចធ្វើអ្វីបានដោយគ្មានជំនួយពីព្រះវិញ្ញាណទេ"។ ដូច្នេះ ដើម្បីឱ្យការអនុវត្តន៍ព្រះបន្ទូលព្រះអម្ចាស់ទទួលបានជោគជ័យ នោះត្រូវតែមានជំនួយពីព្រះវិញ្ញាណបរិសុទ្ធ
**១៦:១៣** *ព្រះវិញ្ញាណនៃសេចក្តីពិត* "មើលការពន្យល់ ១៤:១៧"។ *ដ្បិតទ្រង់នឹងមានបន្ទូល . . . តែសេចក្តីណាដែលទ្រង់ឮ* មានន័យថា ព្រះវិញ្ញាណបរិសុទ្ធទ្រង់ មានបន្ទូលតែសេចក្តីណាដែលទ្រង់ឮពីព្រះអម្ចាស់ប៉ុណ្ណោះ ។ *ការដែលត្រូវមក* អាចសំដៅលើសេចក្តីទាំងឡាយ ដែលព្រះអម្ចាស់ប្រទានមក សម្រាប់ឱ្យគ្រីស្ទបរិស័ទប្រតិបត្តិតាម និងការបើកសម្តែងផ្សេងៗ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។
**១៦:១៤** *ទ្រង់នឹងដំកើងខ្ញុំ* មានន័យថា ការយាងមករបស់ព្រះវិញ្ញាណបរិសុទ្ធ គឺដើម្បីតម្កើងព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ ១:១៤)។
**១៦:១៥** *គ្រប់ទាំងអស់ដែលព្រះវរបិតាមាន នោះជារបស់ផងខ្ញុំដែរ* ត្រង់ចំណុចនេះ បញ្ជាក់យ៉ាងច្បាស់ថា ព្រះវរបិតាប្រទានគ្រប់ទាំងអស់មកព្រះយេស៊ូវគ្រីស្ទ ។
**១៦:១៦** ព្រះយេស៊ូវមានបន្ទូលទៅកាន់ពួកសិស្សរបស់ទ្រង់ថា បន្តិចទៀតទ្រង់នឹងត្រូវគេធ្វើគុត ប៉ុន្តែ ទ្រង់នឹងរស់ឡើងវិញនៅថ្ងៃទីបី ។ ទ្រង់មានបន្ទូលយ៉ាងដូច្នេះជាច្រើនដងដល់ពួកសិស្សរបស់ទ្រង់ ប៉ុន្តែ ក្នុងខណៈពេលនោះ ពួកគេមិនបានយល់នៅឡើយទេ (មើលការពន្យល់ ខ.២២ មក ៨:៣១ ៩:៣១-៣២ ១០:៣២-៣៤)។
**១៦:១៧** ក្នុងបទគម្ពីរនេះបញ្ជាក់ថា នៅពេលនោះ ពួកសិស្សព្រះយេស៊ូវនៅតែយល់ថា ទ្រង់នឹងតាំងនគររបស់ទ្រង់នៅលើផែនដីនេះ គឺដូចជាការយល់ឃើញរបស់ពួកសាសន៍យូដាដែរ ។ ដូច្នោះ បានជាពេលដែលឮទ្រង់មានបន្ទូលថា ពួកគេនឹងមិនឃើញទ្រង់ទៀតទេ នោះក៏ចាប់ផ្តើមសួរគ្នាទៅវិញទៅមក និងមានចម្ងល់ជាខ្លាំង អំពីសេចក្តីដែលទ្រង់មានបន្ទូលនោះ ព្រោះពួកគេយល់ច្រឡំថា ព្រះរាជកិច្ចរបស់ទ្រង់មិនទាន់បានសម្រេចនៅឡើយ (មើលពន្យល់ ខ.១០)។
**១៦:២០** *អ្នករាល់គ្នានឹងយំ* ពាក្យថា "យំ" ត្រង់ចំណុចនេះ គឺសំដៅលើការយំខ្លាំងៗ ដែលសម្តែងចេញឱ្យឃើញថា ពិតជាមានទុក្ខព្រួយដ៏លំបាកបំផុតមែន

គ្នានឹងយំ ហើយសោកសង្រេង[ខ] តែលោកិយនឹងអរសប្បាយ
ឡើង អ្នករាល់គ្នានឹងព្រួយចិត្ត តែសេចក្តីព្រួយរបស់អ្នក
រាល់គ្នា នឹងប្រែទៅជាសេចក្តីអំណរទៅវិញ[គ] ២១ឯស្ត្រី
កាលណាហៀបនឹងសំរាលកូន នោះតែងព្រួយចិត្ត[ឃ] ព្រោះ
ដល់កំណត់ហើយ តែកាលណាសំរាលរួចមក នោះលែង
នឹកពីសេចក្តីវេទនានោះហើយ ពីព្រោះមានសេចក្តីអំណរ
ដោយព្រោះមានកូនមួយកើតមកក្នុងលោក ២២ឥឡូវនេះ
អ្នករាល់គ្នាមានសេចក្តីព្រួយដូច្នោះមែន[ង] ប៉ុន្តែ ខ្ញុំនឹង
ឃើញអ្នករាល់គ្នាម្តងទៀត[ច] នោះអ្នករាល់គ្នានឹងមានចិត្ត
អរសប្បាយវិញ ក៏នឹងឥតមានអ្នកណាដកយកសេចក្តីអំណរ
នោះ ចេញពីអ្នករាល់គ្នាបានឡើយ[ឆ] ២៣នៅថ្ងៃនោះ[ជ] អ្នក
រាល់គ្នា នឹងមិនសូមអ្វីពីខ្ញុំទៀត ប្រាកដមែន ខ្ញុំប្រាប់អ្នក
រាល់គ្នាជាប្រាកដថា អ្វីៗដែលអ្នករាល់គ្នា នឹងសូមដល់
ព្រះវរបិតា ដោយនូវឈ្មោះខ្ញុំ នោះទ្រង់នឹងប្រទានឱ្យ[ឈ]
២៤តាំងពីដើមមក អ្នករាល់គ្នាមិនបានសូមអ្វី ដោយនូវ
ឈ្មោះខ្ញុំទេ ឥឡូវចូរសូមចុះ នោះអ្នករាល់គ្នានឹងបាន[ញ]
ដើម្បីឱ្យសេចក្តីអំណររបស់អ្នករាល់គ្នា បានពោរពេញ
ពិត[ដ] ២៥ខ្ញុំនិយាយសេចក្តីទាំងនេះដល់អ្នករាល់គ្នា ដោយ
ពាក្យប្រៀបធៀប[ឋ] តែនឹងមានពេលវេលាមក[ឌ] ដែលខ្ញុំនឹង
មិននិយាយនឹងអ្នករាល់គ្នា ដោយពាក្យប្រៀបធៀបទៀតទេ
គឺនឹងនិយាយនឹងអ្នករាល់គ្នាពីព្រះវរបិតាយ៉ាងច្បាស់លាស់
វិញ ២៦នៅថ្ងៃនោះ អ្នករាល់គ្នានឹងសូមដោយនូវឈ្មោះខ្ញុំ[ឍ]
ហើយខ្ញុំមិនថា ខ្ញុំនឹងទូលអង្វរដល់ព្រះវរបិតា ជំនួសអ្នក
រាល់គ្នានោះទេ ២៧ដ្បិតព្រះវរបិតា ទ្រង់ក៏ស្រឡាញ់អ្នក
រាល់គ្នាដែរ ដោយព្រោះអ្នករាល់គ្នាស្រឡាញ់ខ្ញុំ[ណ] ហើយក៏
ជឿថា ខ្ញុំបានចេញពីព្រះមក[ត] ២៨ខ្ញុំបានចេញពីព្រះវរបិតា
មកមែន ហើយបានមកក្នុងលោកិយ ក៏នឹងចេញពីលោកិយ
ទៅឯព្រះវរបិតាវិញទៀត[ថ]។
២៩ពួកសិស្សទូលទ្រង់ថា ហ្ន៎ ម្តងណេះទ្រង់មានបន្ទូល
ច្បាស់ហើយ មិនមែនដោយពាក្យប្រៀបធៀបទៀតទេ[ទ]
៣០ឥឡូវនេះ យើងខ្ញុំដឹងថា ទ្រង់ជ្រាបគ្រប់ទាំងអស់ ហើយ
មិនត្រូវការ ឱ្យអ្នកណាសួរទ្រង់ទេ ដោយហេតុនេះ យើង
ខ្ញុំ ជឿថា[ធ] ទ្រង់បានចេញពីព្រះមកមែន[ន] ៣១ព្រះយេស៊ូវ
ទ្រង់មានបន្ទូលឆ្លើយថា ឥឡូវនេះ អ្នករាល់គ្នាជឿហើយឬ
៣២មើល នឹងមានពេលវេលាមក ក៏មកដល់ហើយ[ប] នោះ

**១៦:២០** ខ មក ១៦:១០ លក ២៣:២៧ គ យហ ២០:២០ **១៦:២១** ឃ អស ១៣:៨ ២១:៣ ២៦:១៧ មីក ៤:៩ ១ថន ៥:៣ **១៦:២២** ង ខ.៦ ច ខ.១៦ ឆ ខ.២០ យរ ៣១:១២ **១៦:២៣** ជ ខ.២៦ យហ ១៤:២០ ឈ មថ ៧:៧ **១៦:២៤** ញ មថ ៧:៧ ដ យហ ៣:២៩ **១៦:២៥** ឋ ខ.២៩ ទដ ៧៨:២ អក ២០:៤៩ មថ ១៣:៣៤ មក ៤:៣៣,៣៤ យហ ១០:៦ ឌ ខ.២ **១៦:២៦** ឍ ខ.២៣, ២៤ **១៦:២៧** ណ យហ ១៤:២១,២៣ ត ខ.៣០ យហ ១៣:៣ **១៦:២៨** ថ ខ.៥,១០, ១៧ យហ ១៣:៣ **១៦:២៩** ទ ខ.២៥ **១៦:៣០** ធ ១ពវ ១៧:២៤ ន ខ.២៧ យហ ១៣:៣

(មើលការពន្យល់ ១១:៣៣)។

**១៦:២១** បទគម្ពីរនេះបញ្ជាក់ថា ពួកអ្នកជឿដល់ព្រះនាមព្រះអម្ចាស់នឹងត្រូវជួបនូវការបៀតបៀនជាមិនខាន ប៉ុន្តែ ទ្រង់នឹងប្រទានឱ្យពួកគេនូវអំណរ ដែលលោកិយមិនអាចយល់បានឡើយ (អស ២៦:១៧–១៩ ៦៦:៧–១៤ ហស ១៣:១៣–១៤)។

**១៦:២២** *ខ្ញុំនឹងឃើញអ្នករាល់គ្នាម្តងទៀត* ឃ្លានេះមានលក្ខណៈដូចគ្នានឹង ខ.១៦ដែរ ហើយអាចសំដៅលើការដែលព្រះយេស៊ូវ នឹងយាងមកជួបពួកសិស្សទ្រង់ បន្ទាប់ពីទ្រង់រស់ពីសុគតឡើងវិញ ។ *ឥតមានអ្នកណាដកយកសេចក្តីអំណរនោះ ចេញពីអ្នករាល់គ្នាបានឡើយ* ឃ្លានេះបញ្ជាក់ថាការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូវ បានធ្វើឱ្យពួកសិស្សទ្រង់យល់ច្បាស់ នូវសេចក្តីទាំងឡាយដែលទ្រង់មានបន្ទូលទៅកាន់ពួកគេ និងធ្វើឱ្យពួកគេមានអំណរ ដែលលោកិយមិនអាចដកចេញពីពួកគេបានឡើយ (មើលការពន្យល់ ១៥:១១)។

**១៦:២៣** *អ្នករាល់គ្នានឹងមិនសូមអ្វីពីខ្ញុំទៀត* អាចមានន័យថា ពួកសិស្សរបស់ព្រះយេស៊ូវនឹងទូលសូមដល់ព្រះវរបិតា នូវគ្រប់ការទាំងអស់ ដោយនូវព្រះនាមទ្រង់ (ព្រះនាមព្រះយេស៊ូវ) (មើលពន្យល់ ខ.២៤,២៦–២៧ ២:២៣ ១៤:១៣)។

**១៦:២៤** នៅក្នុងបទគម្ពីរនេះបញ្ជាក់ថា រហូតមកដល់ពេលនោះ ពួកសិស្សរបស់ព្រះយេស៊ូវពុំបានទូលសូមអ្វី ដោយនូវព្រះនាមទ្រង់ទេ ។ *សេចក្តីអំណរ* "មើលការពន្យល់ ១៥:១១"។

**១៦:២៥** បទគម្ពីរនេះបញ្ជាក់ថា ពួកសិស្សរបស់ព្រះយេស៊ូវ ពុំបានយល់ច្បាស់នូវគ្រប់ទាំងព្រះបន្ទូលទ្រង់ទេ ព្រោះមានសេចក្តីជាច្រើន គឺជាការប្រៀបធៀប ។ ប៉ុន្តែ បន្ទាប់ពីទ្រង់រស់ពីសុគតឡើងវិញ ទ្រង់បានប្រទានព្រះវិញ្ញាណបរិសុទ្ធមក ដើម្បីពន្យល់ដល់ពួកគេ ឱ្យបានយល់នូវគ្រប់សេចក្តីទាំងឡាយ ដែលពួកគេនៅមានមន្ទិលសង្ស័យ ។ *តែនឹងមានពេលវេលាមក* សំដៅលើពេលបន្ទាប់ពីព្រះយេស៊ូវរស់ពីសុគតឡើងវិញ ។

**១៦:២៦** បទគម្ពីរនេះបញ្ជាក់ថា ក្នុងខណៈពេលដែលព្រះយេស៊ូវគង់នៅជាមួយពួកសិស្សរបស់ទ្រង់នៅលើផែនដីនៅឡើយ ទ្រង់តែងតែអធិស្ឋានដល់ព្រះវរបិតាសម្រាប់ពួកគេជានិច្ច ។ ប៉ុន្តែ បន្ទាប់ពីទ្រង់បានយាងទៅឯស្ថានសួគ៌វិញ នោះទ្រង់បានប្រទានព្រះវិញ្ញាណបរិសុទ្ធមក ដើម្បីដឹកនាំ និងជួយពួកសិស្សទ្រង់ឱ្យអធិស្ឋាន ក្នុងព្រះនាមទ្រង់ ដល់ព្រះវរបិតាដោយផ្ទាល់ៗខ្លួនតែម្តង (រម ៨:៣៤ ហព ៧:២៥ ១យហ ២:១ និងការពន្យល់)។ *ដោយនូវឈ្មោះខ្ញុំ* "មើលការពន្យល់ ២:២៣"។

**១៦:២៧** *ដ្បិតព្រះវរបិតា ទ្រង់ក៏ស្រឡាញ់អ្នករាល់គ្នាដែរ* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ អំពីសេចក្តីស្រលាញ់របស់ព្រះវរបិតា ។ ម្យ៉ាងទៀត ពួកអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទទាំងអស់ អាចអធិស្ឋានដោយនូវព្រះនាមទ្រង់ដល់ព្រះវរបិតាដោយផ្ទាល់ៗខ្លួនបាន ។ ព្រះវរបិតាទ្រង់ស្តាប់សេចក្តីអធិស្ឋានរបស់ពួកគេ ព្រោះពួកគេបានជឿ និងស្រលាញ់ព្រះយេស៊ូវគ្រីស្ទ ។

**១៦:២៩** *មិនមែនដោយពាក្យប្រៀបធៀបទៀតទេ* មើលការពន្យល់ ខ.២៥។

**១៦:៣០** *យើងខ្ញុំជឿថា ទ្រង់បានចេញពីព្រះមកមែន* ត្រង់ចំណុចនេះបញ្ជាក់ថា នៅក្នុងព្រះគម្ពីរដំណឹងល្អយ៉ូហាន ច្រើននិយាយអំពីជំនឿ លើព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ ១:៧) និងការដែលទ្រង់យាងមកពីព្រះវរបិតា (មើលការពន្យល់ ៤:៣៤ ១៧:៣,៨)។

**១៦:៣២** *អ្នករាល់គ្នានឹងត្រូវខ្ចាត់ខ្ចាយ* បញ្ជាក់ថា នៅពេលនោះ ពួកសិស្ស

អ្នករាល់គ្នានឹងត្រូវខ្ចាត់ខ្ចាយទៅ ដោយខ្លួនៗ[ផ] ទាំងទុក
ខ្ញុំចោលឱ្យនៅតែឯកឯង[ព] តែខ្ញុំមិននៅតែឯកឯងទេ គឺមាន
ព្រះវរបិតាគង់ជាមួយនឹងខ្ញុំដែរ[ភ] ៣៣ខ្ញុំប្រាប់សេចក្ដីទាំងនេះ
ដើម្បីឱ្យអ្នករាល់គ្នា បានសេចក្ដីសុខសាន្ត[ម] ដោយសារខ្ញុំ
នៅលោកីយនេះ នោះអ្នករាល់គ្នាមានសេចក្ដីវេទនាមែន[យ]
ប៉ុន្តែ ត្រូវសង្ឃឹមឡើង ដ្បិតខ្ញុំបានឈ្នះ[រ] លោកីយហើយ។

## ព្រះយេស៊ូវអធិស្ឋានសម្រាប់ព្រះអង្គទ្រង់

**១៧** ១កាលព្រះយេស៊ូវ មានបន្ទូលសេចក្ដីទាំងនោះរួច
ហើយ នោះក៏ងើបព្រះនេត្រទៅលើមេឃ[ល] ទូលថាឱព្រះវរ
បិតាអើយ កំណត់បានមកដល់ហើយ[វ] សូមដំកើង ព្រះរាជ
បុត្រាទ្រង់ ដើម្បីឱ្យព្រះរាជបុត្រា បានដំកើងទ្រង់ ដែរ[ស]
២ដូចជាទ្រង់បានប្រទានឱ្យព្រះរាជបុត្រាមានអំណាច លើ
គ្រប់ទាំងមនុស្ស[ហ] ដើម្បីនឹងប្រទានជីវិត ដ៏នៅអស់កល្ប
ជានិច្ច[ឡ] ដល់អស់អ្នកដែលទ្រង់បានប្រទាន មកព្រះរាជបុត្រា
ដែរ[អ] ៣នេះជាជីវិតដ៏នៅអស់កល្បជានិច្ច គឺឱ្យគេបានស្គាល់

**១៦:៣២** ប ខ.២,២៥
ផ មថ ២៦:៣១
ព មថ ២៦:៥៦
ភ យហ ៨:១៦,២៩
**១៦:៣៣** ម យហ ១៤:២៧
យ យហ ១៥:១៨-២១
រ រម ៨:៣៧
១យហ ៤:៤ ៥:៤
វវ ២:៧,១១,១៧,២៦
៣:៥,១២,២១ ២១:៧
**១៧:១** ល យហ ១១:៤១
វ មថ ២៦:១៨
ស យហ ១២:២៣
១៣:៣១,៣២
**១៧:២** ហ មថ ២៨:១៨
ឡ មថ ២៥:៤៦
អ ខ.៦,៩,២៤
ដយ ៧:១៤
យហ ៦:៣៧,៣៩

ដល់ទ្រង់[ក] ដ៏ជាព្រះពិតតែ១ នឹងព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់
បានចាត់ឱ្យមកផង[ខ] ៤ទូលបង្គំបានដំកើងទ្រង់[គ] នៅផែនដី
ទូលបង្គំបានបង្ហើយការ ដែលទ្រង់ប្រគល់មកឱ្យធ្វើ[ឃ]
៥ឥឡូវនេះ ឱព្រះវរបិតាអើយ សូមដំកើងទូលបង្គំ[ង] ឡើង
ជាមួយនឹងទ្រង់ផង ដោយសិរីល្អដែលទូលបង្គំមាន ជាមួយ
នឹងទ្រង់[ច] ក្នុងកាលដែលលោកីយ មិនទាន់បានកើតនៅ
ឡើយ[ឆ]។

## ព្រះយេស៊ូវអធិស្ឋានសម្រាប់ពួកសិស្សទ្រង់

៦ឯពួកអ្នក ដែលទ្រង់បានប្រទានមកទូលបង្គំ អំពី
មនុស្សលោក នោះទូលបង្គំបានបើកសំដែង ឱ្យគេស្គាល់
ព្រះនាមទ្រង់[ជ] អ្នកទាំងនោះជារបស់ផងទ្រង់ ហើយទ្រង់
បានប្រទានគេមកទូលបង្គំ[ឈ] គេក៏កាន់តាមព្រះបន្ទូលទ្រង់
៧ឥឡូវនេះ គេដឹងថា គ្រប់ទាំងអស់ ដែលទ្រង់ប្រទានមក

**១៧:៣** ក ភល ៣:៨ ខ ខ.៨,១៨,២១,២៣, ២៥ យហ ៣:១៧
**១៧:៤** គ យហ ១៣:៣១ ឃ យហ ១៩:៣០ **១៧:៥** ង ខ.១ ច ភល ២:៦
ឆ យហ ១:២ **១៧:៦** ជ ខ.២៦ យហ ១:១៨ ឈ ខ.២

របស់ព្រះយេស៊ូវមានជំនឿ ប៉ុន្តែ មិនរឹងមាំទេក្នុងពេលមានទុក្ខលំបាក ។ ព្រះយេស៊ូវ ទ្រង់ជ្រាបយ៉ាងច្បាស់ថា ពួកគេនៅខ្សោយ (មថ ២៦:៣១ សក ១៣:៧ និងការពន្យល់)។ ទោះជាយ៉ាងណាក៏ដោយ ក៏ពួកជំនុំដែលជាព្រះកាយទ្រង់ពុំមែនបង្កើត ឡើងដោយសារកម្លាំងរបស់មនុស្សទេ គឺដោយសារអំណាចព្រះចេស្ដាទ្រង់វិញ ។ ដូច្នេះ ទោះបីពួកសិស្សរបស់ទ្រង់ខ្សោយ ក៏ទ្រង់គង់នៅជាមួយនឹងពួកគេ និងជួយពួកគេ ឱ្យទទួលបានជោគជ័យនៅទីបំផុតដែរ ។

**១៦:៣៣** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា សេចក្ដីសុខសាន្តដ៏ពិត គឺបានមកអំពីព្រះយេស៊ូវ ។ ម្យ៉ាងទៀត ទ្រង់មានបន្ទូលយ៉ាងច្បាស់ថា ពួកអ្នកជឿដល់ព្រះនាមទ្រង់ទាំងអស់ ដែលកំពុងរស់នៅលើផែនដីនេះ ក៏ជួបនឹងទុក្ខលំបាក និងការបៀតបៀនផ្សេងៗ ពីសំណាក់លោកិយដែរ ។ ប៉ុន្តែ ត្រូវចងចាំថា ព្រះយេស៊ូវទ្រង់មានជ័យជម្នះរួចជាស្រេចហើយ ទ្រង់ក៏ប្រទាន ឱ្យពួកអ្នកជឿដល់ព្រះនាមទ្រង់ទាំងអស់ មានជ័យជម្នះជាមួយនឹងទ្រង់ដែរ (មើលការពន្យល់ ១:៩)។

**១៧:១-២៦** ក្នុងវគ្គនេះ ច្រើននិយាយអំពីសេចក្ដីអធិស្ឋានរបស់ព្រះយេស៊ូវគ្រីស្ទ ។

**១៧:១** *ងើបព្រះនេត្រទៅលើមេឃ* ចំណុចនេះបញ្ជាក់ថា ទម្លាប់ក្នុងការអធិស្ឋាន គេតែងតែងើបមុខឡើងសម្លឹងទៅលើ (១១:៤១ ទដ ១២៣:១ មក ៧:៣៤) ប៉ុន្តែ ទោះជាយ៉ាងណា មានពេលខ្លះ ព្រះយេស៊ូវទ្រង់ក៏អធិស្ឋានដោយផ្កាប់ព្រះភក្ត្រចុះផងដែរ (មថ ២៦:៣៩)។ *ព្រះវរបិតា* ពាក្យនេះមានប្រើនៅក្នុងគម្ពីរដំណឹងល្អយ៉ូហានចំនួន១២០ដង ។ *កំណត់* សំដៅលើពេលវេលានៃការសុគត និងរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ (មើលពន្យល់ ២:៤)។ *សូមដំកើង . . . ដំកើងទ្រង់ដែរ* ត្រង់ចំណុចនេះបញ្ជាក់ថា ព្រះវរបិតាត្រូវបានតម្កើងឡើងនៅក្នុងព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ ១:១៤ ៧:៣៩ ១៣:៣១)។ ហើយព្រះយេស៊ូវគ្រីស្ទ ក៏បានតម្កើង ឡើងនៅក្នុងព្រះវរបិតាដែរ ។ ការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ បានថ្វាយសិរីល្អ ដល់ព្រះវរបិតា និងបាននាំមកនូវជីវិតពេញបរិបូរ ដល់អស់អ្នកជឿដល់ព្រះនាមទ្រង់ផងដែរ (ខ.២)។

**១៧:២** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះវរបិតាបានប្រទានគ្រប់អំណាចព្រះចេស្ដាទាំងអស់ដល់ព្រះយេស៊ូវ (ខ.៤,៦-៩ ទដ ១២៣:២ មក ៧:៣៤ មើលការពន្យល់ ៣:២៧)។ *ជីវិតដ៏នៅអស់កល្បជានិច្ច* "មើលការពន្យល់ ៣:១៥"។ *អ្នកដែលទ្រង់បានប្រទានមកព្រះរាជបុត្រា* ត្រង់ចំណុចនេះ បញ្ជាក់យ៉ាងច្បាស់ អំពីផែនការរបស់ព្រះអម្ចាស់ ក្នុងការសង្គ្រោះមនុស្សលោកឱ្យរួចពីបាប ។

**១៧:៣** *ទ្រង់បានចាត់ឱ្យមក* ឃ្លានេះបញ្ជាក់អំពីមហាបេសកកម្មរបស់ព្រះអម្ចាស់ ដើម្បីសង្គ្រោះមនុស្សលោក (មើលការពន្យល់ ១៣:២០)។

**១៧:៤** *ទូលបង្គំបានដំកើងទ្រង់* បញ្ជាក់ថា មហាបេសកកម្មរបស់ព្រះយេស៊ូវគ្រីស្ទ ពុំមែនដើម្បីតម្កើងព្រះអង្គទ្រង់ផ្ទាល់ទេ គឺតម្កើងដល់ព្រះវរបិតា ដែលចាត់ឱ្យទ្រង់មកវិញ ។ ការនេះគឺជាគំរូសម្រាប់គ្រីស្ទបរិស័ទគ្រប់ៗរូប យកទៅអនុវត្តនៅក្នុងជីវិតជាអ្នកបម្រើព្រះអម្ចាស់ ។

**១៧:៥** ក្នុងបទគម្ពីរនេះ ព្រះយេស៊ូវបានទូលសូម នូវសិរីល្អដែលទ្រង់មានជាមួយនឹងព្រះវរបិតា តាំងពីមុនពេលដែលទ្រង់បានបង្កើតពិភពលោកនេះទៅទៀត ។ ព្រះយេស៊ូវបានទទួលនូវសិរីល្អ នៅពេលដែលទ្រង់មានព្រះជន្មរស់ពីសុគត និងត្រូវបានលើកឡើងទៅឯព្រះវរបិតាវិញ ។ *លោកិយ* ពាក្យថា "លោកិយ" ត្រង់ ចំណុចនេះ គឺសំដៅលើសកលលោកទាំងមូល (មើលការពន្យល់ ខ.១៤,១:៩)។ នៅក្នុងវគ្គនៃសេចក្ដីអធិស្ឋាននេះ ព្រះគម្ពីរបរិសុទ្ធជាភាសាក្រិក មានប្រើពាក្យថា "លោកិយ" ចំនួន១៨ដង ។

**១៧:៦** *ទូលបង្គំបានបើកសំដែងឱ្យគេស្គាល់ព្រះនាមទ្រង់* មានន័យថា ព្រះយេស៊ូវបានបើកសំដែង ឱ្យពួកសិស្សទ្រង់ស្គាល់ព្រះវរបិតា ដែលចាត់ឱ្យទ្រង់មក (មើលការពន្យល់ ខ.២ ២:២៣,១៤:១៣ ប្រៀបធៀបនឹង ១:១៨)។

ទូលបង្គំ នោះសុទ្ធតែកើតពីទ្រង់មក ៨ដ្បិតអស់ទាំងព្រះ
បន្ទូលដែលទ្រង់បានប្រទានមក នោះទូលបង្គំបានឱ្យដល់
គេហើយ[ញ] គេក៏ទទួលយក ហើយដឹងជាប្រាកដថា ទូលបង្គំ
ចេញពីទ្រង់មក[ដ] ក៏ជឿថា ទ្រង់ចាត់ឱ្យទូលបង្គំមកមែន[ឋ]
៩ទូលបង្គំអធិស្ឋានឱ្យគេ[ឌ] មិនមែនអធិស្ឋានឱ្យលោកិយទេ
គឺឱ្យអស់អ្នកដែលទ្រង់បានប្រទាន មកទូលបង្គំវិញ[ឍ] ពីព្រោះ
គេជារបស់ផងទ្រង់ ១០(របស់ទូលបង្គំទាំងអស់ ជារបស់
ផងទ្រង់ ហើយរបស់ទ្រង់ទាំងប៉ុន្មាន ក៏ជារបស់ផងទូលបង្គំ
ដែរ)[ណ] ទូលបង្គំបានថ្កើងឡើងក្នុងគេ ១១អ្នកទាំងនេះនៅ
ក្នុងលោកិយ តែទូលបង្គំ មិននៅក្នុងលោកិយទៀតទេ[ត]
ទូលបង្គំនឹងទៅឯទ្រង់[ថ] ឱព្រះវរបិតាដ៏បរិសុទ្ធអើយ ឯពួក
អ្នកដែលទ្រង់បានប្រទានមកទូលបង្គំ នោះសូមទ្រង់រក្សាគេ
ដោយព្រះនាមទ្រង់ផង ដើម្បីឱ្យគេបានរួមគ្នាតែ១[ទ] ដូចជា
យើងដែរ[ធ] ១២កាលទូលបង្គំនៅក្នុងលោកិយ ជាមួយនឹងគេ
នោះទូលបង្គំបានរក្សាគេ ដោយព្រះនាមទ្រង់ដែរ ទូលបង្គំ
បានរក្សាទុកនូវអស់អ្នក ដែលទ្រង់ប្រទានមកទូលបង្គំ គ្មាន
អ្នកណាមួយត្រូវវិនាសឡើយ[ន] បានវិនាសតែ១នាក់នោះ[ប]
ដែលបានដំរូវឱ្យត្រូវវិនាសប៉ុណ្ណោះ ដើម្បីឱ្យបានសំរេច
តាមបទគម្ពីរ[ផ] ១៣ឥឡូវនេះ ទូលបង្គំទៅឯទ្រង់[ព] តែទូល
បង្គំថ្លែងសេចក្ដីទាំងនេះ នៅក្នុងលោកិយ ដើម្បីឱ្យគេបាន
សេចក្ដីអំណររបស់ទូលបង្គំ[ភ] ឱ្យនៅពោរពេញក្នុងខ្លួនគេ
១៤ទូលបង្គំ បានឱ្យព្រះបន្ទូលទ្រង់ដល់គេ ហើយលោកិយ
បានស្អប់គេ[ម] ពីព្រោះគេមិនមែនជារបស់លោកិយទេ ដូច
ជាទូលបង្គំក៏មិនមែនជារបស់លោកិយដែរ[យ] ១៥ទូលបង្គំមិន
សូមឱ្យយកគេចេញពីលោកិយទេ គឺសូមឱ្យទ្រង់រក្សាគេ ឱ្យ
រួចពីសេចក្ដីអាក្រក់វិញ[រ] ១៦គេមិនមែនជារបស់ផងលោកិយ
ដូចជាទូលបង្គំក៏មិនមែនជារបស់លោកិយដែរ[ល] ១៧សូមញែក
គេចេញជាបរិសុទ្ធ ដោយសារសេចក្ដីពិតរបស់ទ្រង់ឯសេច
ក្ដីពិត គឺជាព្រះបន្ទូលរបស់ទ្រង់[វ] ១៨ទូលបង្គំបានចាត់គេឱ្យទៅ

**១៧:៨** ញ ខ.១៤,២៦ យហ ១៤:២៤ ដ យហ ១៣:៣ ឋ ខ.៣,១៨,២១,២៣,២៥ យហ ៣:១៧ **១៧:៩** ឌ លក ២២:៣២ ឍ ខ.២ **១៧:១០** ណ យហ ១៦:១៥ **១៧:១១** ត យហ ១៣:១ ថ ខ.១៣ យហ៧:៣៣ ទ ខ.២១-២៣ ទដ ១៣៣:១ ធ យហ ១០:៣០ **១៧:១២** ន យហ ៦:៣៩ ប យហ ៦:៧០ ផ មថ ១:២២ **១៧:១៣** ព ខ.១១ ភ យហ ៣:២៩ **១៧:១៤** ម យហ ១៥:១៩ យ ខ.១៦ យហ ៨:២៣ **១៧:១៥** រ មថ ៥:៣៧ **១៧:១៦** ល ខ.១៤ **១៧:១៧** វ យហ ១៥:៣ ២សយ ៧:២៨ ១ពវ ១៧:២៤

**១៧:៧** *គ្រប់ទាំងអស់ . . . កើតពីទ្រង់* ត្រង់ចំណុចនេះបញ្ជាក់ថា ទាល់តែមនុស្សលោកបានឃើញការ ដែលព្រះវរបិតាធ្វើនៅក្នុងព្រះយេស៊ូវគ្រីស្ទ ដូចដែលពួកសិស្សរបស់ទ្រង់បានឃើញ ទើបពួកគេ (មនុស្សលោក) មានគំនិតយល់ដឹងដ៏ត្រឹមត្រូវអំពីទ្រង់ (សូមប្រៀបធៀបនឹង យក ១:១៧)។

**១៧:៨** បទគម្ពីរនេះមាននិយាយអំពីសេចក្ដីបីយ៉ាងរបស់ពួកសាវ័កៈ (១).ពួកគេបានទទួលយកការបង្រៀន (ផ្ទុយពីពួកផារិស៊ី និងអ្នកដទៃទៀត ដែលគ្រាន់តែបានស្ដាប់ការបង្រៀន ប៉ុន្តែមិនបានជឿ និងប្រតិបត្តិតាមទេ) (២).ពួកគេបានដឹងយ៉ាងច្បាស់ថា ព្រះយេស៊ូវទ្រង់គឺជាព្រះ ។ ការដែលពួកគេទទួលយកការបើកសំដែងអំពីទ្រង់ ធ្វើឱ្យពួកគេចូលកាន់តែជ្រៅទៅក្នុងសេចក្ដីពិត ។ (៣).ពួកគេ មានជំនឿលើទ្រង់ (មើលការពន្យល់ ១:៧,១២ ២០:៣១)។

**១៧:៩** *មិនមែនអធិស្ឋានឱ្យលោកីយទេ* ឃ្លានេះពុំមែនមានន័យថា ព្រះយេស៊ូវមិនស្រលាញ់មនុស្សលោកទេ គឺទ្រង់ស្រលាញ់ពួកគេទាំងអស់ ហើយក៏អធិស្ឋានឱ្យអស់អ្នកដែលព្រមទទួលយកការសង្គ្រោះអំពីទ្រង់ និងអស់អ្នកដែលព្រមទទួលជឿដំណឹងល្អ តាមរយៈពួកសិស្សរបស់ទ្រង់ផងដែរ (ខ.២១, ២៣)។

**១៧:១០** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា អ្វីៗទាំងអស់ដែលព្រះយេស៊ូវទ្រង់មាន គឺជារបស់ព្រះវរបិតា ។ ម្យ៉ាងទៀត អ្វីៗទាំងអស់ដែលជារបស់ព្រះវរបិតា ក៏ជារបស់ព្រះយេស៊ូវដែរ (យហ ៣:៣៥)។ ដូច្នេះ មានន័យថា គ្រប់សិរីល្អគឺជារបស់ផងទ្រង់ (ព្រះយេស៊ូវ)។

**១៧:១១** *ព្រះវរបិតាដ៏បរិសុទ្ធ* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះទ្រង់បរិសុទ្ធ (លវ ១១:៤៤ និងការពន្យល់) និងពេញដោយសេចក្ដីស្រលាញ់ ។ ក្នុងព្រះគម្ពីរសញ្ញាថ្មី ពាក្យនេះមានប្រើតែនៅក្នុងខនេះប៉ុណ្ណោះ (ប្រៀបធៀបនឹង ១ពត ១:១៦ វវ ៤:៨ និងការពន្យល់)។ *ដើម្បីឱ្យគេបានរួមគ្នាតែ១* នៅផ្នែកខាងចុងវគ្គនៃសេចក្ដីអធិស្ឋាននេះ ច្រើននិយាយសង្កត់ធ្ងន់លើការរួបរួមគ្នា ។ ព្រះអម្ចាស់បានប្រទាននូវការរួបរួមនេះ មកពួកអ្នកជឿដល់ព្រះនាមទ្រង់រួចជាស្រេចហើយ ដើម្បីឱ្យ "ពួកគេរួបរួមគ្នាតែមួយជានិច្ច" គឺដូចគ្នានឹងការរួបរួមដែល ទ្រង់មាននៅក្នុងព្រះវរបិតាដូច្នោះដែរ ។

**១៧:១២** *ទូលបង្គំបានរក្សាគេ* មានន័យថា ព្រះយេស៊ូវទ្រង់ថែរក្សាអ្នកជឿដល់ព្រះនាមទ្រង់ទាំងអស់ ដោយអំណាចព្រះចេស្ដាទ្រង់ (ប្រៀបធៀបនឹង ១ពត ១:៥ និងការពន្យល់)។ *បានវិនាសតែ១នាក់នោះ* គឺសំដៅលើយូដាស-អ៊ីស្ការីយ៉ុត (២ធថ ២:៣ និងការពន្យល់)។

**១៧:១៣** *សេចក្ដីអំណររបស់ទូលបង្គំ* "មើលការពន្យល់ ១៥:១១"។

**១៧:១៤** *លោកីយ* ពាក្យថា "លោកីយ" ត្រង់ចំណុចនេះគឺសំដៅលើគ្រប់ទាំងអស់ដែលប្រឆាំងនឹងព្រះអម្ចាស់ និងរាស្ត្ររបស់ទ្រង់ (មើលការពន្យល់ ខ.៥,១:៩)។ *មិនមែនជារបស់លោកីយទេ* មានន័យថា ពួកអ្នកជឿដល់ព្រះយេស៊ូវទាំងអស់សុទ្ធតែបានកើតពីព្រះវិញ្ញាណបរិសុទ្ធ ដូច្នេះ ពួកគេមិនមែនជារបស់លោកិយទេ (៣:៨)។ ម្យ៉ាងទៀត មានន័យថា ពួកគេគឺជា "កូនរបស់ព្រះ" (១:១២)។

**១៧:១៥** *មិនសូមឱ្យយកគេចេញពីលោកីយទេ* ព្រះយេស៊ូវមិនសូមឱ្យព្រះវរបិតា យកពួកសិស្សរបស់ទ្រង់ចេញពីលោកិយនេះទេ គឺទុកឱ្យបំពេញកិច្ចការថ្វាយទ្រង់បន្តទៀត ដរាបដល់ការងាររបស់ពួកគេត្រូវបានបញ្ចប់ (ខ.១៨)។ *សេចក្ដីអាក្រក់* ជាពិសេសគឺសេចក្ដីអាក្រក់ ដែលកំពុងតែមានសកម្មភាព នៅក្នុងលោកិយនេះ (មថ ៦:១៣ ១យហ ៥:១៩)។

**១៧:១៧** *ញែកគេចេញជាបរិសុទ្ធ* គឺញែកគេចេញសម្រាប់ការងារបរិសុទ្ធ ឬធ្វើ ឱ្យគេទៅជាបរិសុទ្ធ (មើលការពន្យល់ ខ.១៩)។ ការញែកជាបរិសុទ្ធ និងការបើកសំដែងពីព្រះអម្ចាស់ តែងតែដើរទន្ទឹមគ្នាជានិច្ច និងមិនអាចកាត់ផ្ដាច់ចេញពីគ្នាបានឡើយ (១ពត ២:២ ៨:៣១-៣២ ៨:៣២ និងការពន្យល់)។

**១៧:១៨** *ទូលបង្គំបានចាត់គេ . . . ដូចជាទ្រង់ចាត់ទូលបង្គំ ឱ្យមកក្នុងលោកីយដែរ* ព្រះរាជបេសកកម្មរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាគំរូដ៏សំខាន់បំផុត

ក្នុងលោកិយ[ស] ដូចជាទ្រង់ចាត់ទូលបង្គំ ឱ្យមកក្នុងលោកិយ
ដែរ[ហ] ១៩ឯទូលបង្គំ ក៏ញែកខ្លួនចេញជាបរិសុទ្ធ ដោយយល់
ដល់គេ ដើម្បីឱ្យគេបានញែកចេញជាបរិសុទ្ធ ដោយសារ
សេចក្តីពិតដែរ[ឡ]។

## ព្រះយេស៊ូវអធិស្ឋានសម្រាប់អ្នកជឿគ្រប់គ្នា

២០ទូលបង្គំមិនអធិស្ឋាន ឱ្យអ្នកទាំងនេះតែប៉ុណ្ណោះ គឺ
ឱ្យដល់ទាំងអ្នកណា ដែលនឹងជឿដល់ទូលបង្គំ ដោយសារ
ពាក្យរបស់គេថែមទៀតដែរ ២១ដើម្បីឱ្យទាំងអស់ បានរួម
មកតែមួយ[អ] ឱព្រះវរបិតាអើយ ដូចជាទ្រង់គង់ក្នុងទូលបង្គំ
ហើយទូលបង្គំនៅក្នុងទ្រង់ដែរ[ក] គឺឱ្យអ្នកទាំងនោះ បានរួម
គ្នាតែមួយនៅក្នុងយើង ប្រយោជន៍ឱ្យលោកិយបានជឿថា
ទ្រង់ចាត់ឱ្យទូលបង្គំមកពិត[ខ] ២២ឯសិរីល្អ ដែលទ្រង់ប្រទាន
មកទូលបង្គំ[គ] នោះទូលបង្គំបានឱ្យដល់គេហើយ ដើម្បីឱ្យគេ
បានរួមគ្នាតែមួយ ដូចជាយើងក៏រួមតែមួយដែរ[ឃ] ២៣គឺ
ទូលបង្គំនៅក្នុងគេ ហើយទ្រង់គង់ក្នុងទូលបង្គំ ដើម្បីឱ្យគេ
បានគ្រប់លក្ខណ៍ឡើង ដរាបដល់រួមគ្នាតែមួយជាស្រេច
ប្រយោជន៍ ឱ្យលោកិយ បានដឹងថា គឺទ្រង់ដែលចាត់ឱ្យ
ទូលបង្គំមកមែន[ង] ហើយថា ទ្រង់ស្រឡាញ់គេ[ច] ដូចជា
ស្រឡាញ់ទូលបង្គំដែរ។
២៤ឱព្រះវរបិតាអើយ ឯពួកអ្នកដែលទ្រង់ប្រទានមក
ទូលបង្គំ[ឆ] នោះទូលបង្គំចង់ឱ្យគេនៅជាមួយនឹងទូលបង្គំ ក្នុង
កន្លែងដែលទូលបង្គំនៅដែរ[ជ] ដើម្បីឱ្យបានឃើញសិរីល្អ[ឈ]
ដែលទ្រង់បានប្រទានមកទូលបង្គំ ដ្បិតទ្រង់បានស្រឡាញ់
ទូលបង្គំ តាំងតែពីមុនកំណើតលោកិយរៀងមក[ញ]។
២៥ឱព្រះវរបិតាដ៏សុចរិតអើយ លោកិយមិនស្គាល់
ទ្រង់ទេ[ដ] តែទូលបង្គំស្គាល់ទ្រង់ ហើយពួកអ្នកនេះក៏ដឹងថា
ទ្រង់បានចាត់ឱ្យទូលបង្គំមកដែរ[ឋ] ២៦ទូលបង្គំបានឱ្យគេស្គាល់
ព្រះនាមទ្រង់[ឌ] ក៏នឹងសំដែងឱ្យគេស្គាល់តទៅទៀត ដើម្បីឱ្យ
សេចក្តីស្រឡាញ់ ដែលទ្រង់ស្រឡាញ់ដល់ទូលបង្គំ បាននៅ
ក្នុងគេ[ឍ] ហើយឱ្យទូលបង្គំនៅក្នុងគេដែរ។

**១៧:១៨** ស យហ ២០:២១ ហ ខ.៣,៨, ២១,២៣,២៥ យហ ៣:១៧
**១៧:១៩** ឡ ខ.១៧
**១៧:២១** អ យរ ៣២:៣៩ ក ខ.១១ យហ ១០:៣៨ ខ ខ.៣,៨,១៨,២៣, ២៥ យហ ៣:១៧
**១៧:២២** គ យហ ១:១៤ ឃ យហ ១៤:២០
**១៧:២៣** ង ខ.៣,៨, ១៨,២១,២៥ យហ ៣:១៧ ច យហ ១៦:២៧
**១៧:២៤** ឆ ខ.២ ជ យហ ១២:២៦ ឈ យហ ១:១៤ ញ ខ.៥ មថ ២៥:៣៤ យហ ១:២
**១៧:២៥** ដ យហ ១៥:២១ ១៦:៣ ឋ ខ.៣,៨,១៨,២១, ២៣ យហ ៣:១៧ ១៦:២៧ **១៧:២៦** ឌ ខ.៦ ឍ យហ ១៥:៩

សម្រាប់អ្នកជឿដល់ព្រះនាមទ្រង់គ្រប់ៗគ្នា និងជាសេចក្តីដ៏សំខាន់បំផុត ដែលមានចែងទុកនៅក្នុង ព្រះគម្ពីរដំណឹងល្អនេះ (ខ.៣ និងការពន្យល់)។ *មកក្នុងលោកីយ* ត្រង់ចំណុចនេះ បញ្ជាក់ថា ការងារដែលព្រះអម្ចាស់ប្រទានមកពួកអ្នកជឿដល់ព្រះនាមទ្រង់ធ្វើ គឺនៅលើផែនដីនេះ។ រីឯទីកន្លែងដែលពួកគេត្រូវទៅ គឺស្ថានសួគ៌ដែលជាកន្លែង ព្រះអម្ចាស់គង់នៅអស់កល្បជានិច្ចវិញមិនមែននៅផែនដីនេះទេ ។

**១៧:១៩** *ទូលបង្គំញែកខ្លួនចេញជាបរិសុទ្ធ* នៅក្នុងព្រះគម្ពីរបរិសុទ្ធជាភាសាក្រិក (គម្ពីរសញ្ញាចាស់បកប្រែដំបូង) មានប្រើពាក្យថា "ញែកជាបរិសុទ្ធ" សម្រាប់ពួកសង្ឃ (នក ២៨:៤១) និងនៅក្នុងការថ្វាយដង្វាយ (នក ២៨:៣៨ ជន ១៨:៩)។ ព្រះយេស៊ូវគ្រីស្ទបាន "ញែកព្រះអង្គទ្រង់ជាបរិសុទ្ធ" ដើម្បីធ្វើតាមព្រះហឫទ័យនៃព្រះវរបិតា ។ម្យ៉ាងទៀត ការញែកចេញជាបរិសុទ្ធនៅក្នុងបទគម្ពីរនេះ គឺសំដៅលើការសុគត របស់ព្រះយេស៊ូវគ្រីស្ទនៅលើឈើឆ្កាងតែម្តង។ *ដើម្បីឱ្យគេបាន ញែកចេញជាបរិសុទ្ធ ដោយសារសេចក្តីពិតដែរ* ការដែលព្រះយេស៊ូវសុគតនៅ លើឈើឆ្កាងមិនគ្រាន់តែដើម្បីសង្គ្រោះយើងរាល់គ្នាប៉ុណ្ណោះទេ គឺថែមទាំងញែក យើងចេញជាបរិសុទ្ធ សម្រាប់ការងាររបស់ទ្រង់ផង (មើលការពន្យល់ ខ.១៧)។

**១៧:២០** *ទូលបង្គំមិនអធិស្ឋាន ឱ្យអ្នកទាំងនេះតែប៉ុណ្ណោះ គឺឱ្យអ្នកណាដែលនឹងជឿដល់ទូលបង្គំ ដោយសារពាក្យរបស់គេថែមទៀតដែរ* មានន័យថា ព្រះយេស៊ូវអធិស្ឋានឱ្យពួកអ្នកដែលទទួលជឿដំណឹងល្អរបស់ទ្រង់គ្រប់ៗគ្នា (ខ.១៨,១៩)។

**១៧:២១** *អ្នកទាំងនោះបានរួមគ្នាតែមួយ* គឺឱ្យពួកអ្នកជឿដល់ព្រះនាមព្រះយេស៊ូវទាំងអស់ បានរួមគ្នាតែមួយនៅក្នុងទ្រង់ (មើលការពន្យល់ ខ.១១)។ *ប្រយោជន៍ឱ្យលោកីយបានជឿ* ការរួបរួមរបស់អ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទមានឥទ្ធិពលខ្លាំងណាស់ ទៅលើពួកអ្នកដែលកំពុងរស់នៅមជ្ឈដ្ឋានជុំវិញពួកគេ ។

**១៧:២២** *សិរីល្អ* ត្រង់ចំណុចនេះបញ្ជាក់ថា គ្រីស្ទបរិស័ទត្រូវតែជាអ្នកបន្ទាបខ្លួន និងជាអ្នកបម្រើ ដើម្បីថ្វាយសិរីល្អដល់ព្រះអម្ចាស់ (មើលការពន្យល់ ខ.១)។ *ដើម្បីឱ្យគេបានរួមគ្នាតែមួយ ដូចជាយើងក៏រួមគ្នាតែមួយដែរ* ត្រង់ចំណុចនេះ ព្រះយេស៊ូវមានព្រះបន្ទូលយ៉ាងច្បាស់ អំពីសារសំខាន់នៃការរួបរួមគ្នារបស់ពួកអ្នកដែលដើរតាមទ្រង់។ ម្យ៉ាងទៀត ការរួបរួមរបស់ទ្រង់ និងព្រះវរបិតា គឺជាគំរូសម្រាប់គ្រីស្ទបរិស័ទគ្រប់ៗរូប ។

**១៧:២៣** *ទូលបង្គំនៅក្នុងគេ* មានន័យថា ព្រះយេស៊ូវគង់នៅក្នុងគ្រប់អ្នកជឿដល់ព្រះនាមទ្រង់ទាំងអស់ ។ *ហើយទ្រង់គង់ក្នុងទូលបង្គំ* ឃ្លានេះញ្ជាក់ថា ព្រះវរបិតាគង់នៅក្នុងព្រះយេស៊ូវគ្រីស្ទ ។ *ដរាបដល់រួមគ្នាតែមួយជាស្រេច* ឃ្លានេះសំដៅលើការរួបរួមរបស់គ្រីស្ទបរិស័ទ ដោយមានគោលដៅតែមួយ គឺបម្រើព្រះអម្ចាស់ និងដំណឹងល្អរបស់ទ្រង់ ។ ការរួបរួមនេះ មិនមែនគ្រាន់តែមានទំនាក់ទំនងជាមួយ នឹងព្រះរាជបេសកកម្មរបស់ព្រះអម្ចាស់ប៉ុណ្ណោះទេ គឺថែមទាំងមានទំនាក់ទំនងនឹងសេចក្តីស្រលាញ់ ដែលទ្រង់មានចំពោះមនុស្សលោកទៀតផង ។

**១៧:២៤** នៅពេលដែលព្រះយេស៊ូវមានព្រះហឫទ័យថប់បារម្ភ ទ្រង់ក៏អធិស្ឋានថា "កុំតាមចិត្តទូលបង្គំឡើយ សូមសម្រេចតាមព្រះហឫទ័យទ្រង់វិញ" (មក ១៤:៣៦)។ *នៅជាមួយនឹងទូលបង្គំ* ការដែលបាននៅជាមួយនឹងព្រះអម្ចាស់ គឺជាព្រះពរដ៏ធំបំផុតសម្រាប់គ្រីស្ទបរិស័ទ (១៤:៣ ១ថន ៤:១៧ និងការពន្យល់)។ *សិរីល្អដែលទ្រង់បានប្រទានមកទូលបង្គំ* ឃ្លានេះសំដៅលើសិរីល្អដែលព្រះយេស៊ូវទ្រង់មានជាមួយនឹងព្រះវរបិតា តាំងពីអស់កល្បជានិច្ចមក (១យហ ៣:២ អភ ២:៧)។

**១៧:២៥** *ព្រះវរបិតាដ៏សុចរិត* នៅក្នុងព្រះគម្ពីរបរិសុទ្ធសញ្ញាថ្មី ពាក្យនេះមានប្រើតែក្នុងខនេះប៉ុណ្ណោះ (សូមប្រៀបធៀបនឹងពាក្យថា "ព្រះវរបិតាដ៏បរិសុទ្ធ" ក្នុងខ.១១)។ *លោកិយមិនស្គាល់ទ្រង់* មានន័យថា លោកិយមិនស្គាល់ព្រះអម្ចាស់ទេ ។ ប៉ុន្តែ លោកីយអាចដឹងថា ព្រះវរបិតាពិតជាគង់នៅ

## ការចាប់ព្រះយេស៊ូវ

*១៨:៣-១១ – មថ ២៦:៤៧-៥៦ មក ១៤:៤៣-៥០*
*លក ២២:៤៧-៥៣*

**១៨** ១កាលព្រះយេស៊ូវ មានបន្ទូលសេចក្ដីទាំងនោះរួច
ហើយ នោះទ្រង់យាងទៅខាងនាយជ្រោះកេដ្រុន[ណ] បាននាំ
ទាំងពួកសិស្សទៅផង ហើយទ្រង់ នឹងពួកសិស្ស ក៏ចូល[ត]ទៅ
ក្នុងច្បារ១[ថ]ដែលនៅទីនោះ ២ឯយូដាស ដែលជាអ្នកបញ្ជូន
ទ្រង់ ក៏ស្គាល់កន្លែងនោះដែរ ពីព្រោះព្រះយេស៊ូវនឹងពួក
សិស្ស តែងប្រជុំនៅទីនោះជាញឹកញយ[ទ] ៣ដូច្នេះកាលយូ
ដាសបានទទួលពួកទាហាន នឹងពួកអាជ្ញាខ្លះ ពីពួកសង្គ្រាជ
នឹងពួកផារិស៊ី[ធ]ហើយ នោះក៏នាំគ្នា[ន]ទៅឯទីនោះ មានទាំង
កាន់គោម ចន្លុះ នឹងគ្រឿង សាស្ត្រាវុធផង ៤ព្រះយេស៊ូវ
ទ្រង់ជ្រាបការទាំងអស់ ដែលត្រូវមកដល់ទ្រង់[ប] បានជា
ទ្រង់យាងចេញទៅសួរគេថា តើមករកអ្នកណា[ផ] ៥គេទូល
ឆ្លើយថា រកយេស៊ូវ ជាអ្នកស្រុកណាសារ៉ែត[ព] ព្រះយេស៊ូវ
មានបន្ទូលទៅគេថា គឺខ្ញុំនេះហើយ ឯយូដាសដែលបញ្ជូន
ទ្រង់ ក៏ឈរនៅជាមួយនឹងគេដែរ ៦កាលទ្រង់មានបន្ទូល
ទៅគេថា គឺខ្ញុំនេះហើយ នោះគេក៏ថយក្រោយដួលផ្ងារ
ទាំងអស់គ្នា ៧ដូច្នេះ ទ្រង់មានបន្ទូលសួរគេម្តងទៀតថា
តើរកអ្នកណា[ភ] គេទូលឆ្លើយថា រកយេស៊ូវ ជាអ្នកស្រុក
ណាសារ៉ែត ៨ព្រះយេស៊ូវមានបន្ទូលឆ្លើយថា ខ្ញុំបានប្រាប់
អ្នករាល់គ្នាថា គឺខ្ញុំនេះហើយ ដូច្នេះ បើអ្នករាល់គ្នារកខ្ញុំ
នោះចូរបើកឱ្យអ្នកទាំងនេះទៅចុះ ៩នោះគឺដើម្បីឱ្យបាន
សំរេចពាក្យ ដែលទ្រង់មានបន្ទូលថា ក្នុងពួកអ្នក ដែល
ទ្រង់បានប្រទានមកទូលបង្គំ នោះសូម្បីម្នាក់ក៏មិនបាត់ផង[ម]
១០រីឯស៊ីម៉ូន-ពេត្រុស គាត់មានដាវ ហើយក៏ហូតមក កាប់
ដាច់ត្រចៀកស្តាំរបស់បាវសំដេចសង្ឃម្នាក់ បាវនោះឈ្មោះ
ម៉ាលកុស ១១នោះព្រះយេស៊ូវមានបន្ទូលទៅពេត្រុសថា
ចូរស៊កដាវទៅក្នុងស្រោមវិញទៅ តើមិនត្រូវឱ្យខ្ញុំទទួលពែង[យ]
ដែលព្រះវរបិតាបានប្រទានមកខ្ញុំទេឬអី ។

## ព្រះយេស៊ូវនៅមុខលោកអាណ

*១៨:១២,១៣ – មថ ២៦:៥៧*

១២នោះពួកទាហាន នឹងមេទ័ព ហើយពួកអាជ្ញារបស់
សាសន៍យូដា[រ] ក៏ចាប់ព្រះយេស៊ូវចង ១៣រួចនាំទៅឯលោក
អាណ ជាមុនដំបូង ដ្បិតលោកជាឪពុកក្មេករបស់កៃផា[ល]
ដែលធ្វើជាសំដេចសង្ឃក្នុងឆ្នាំនោះ ១៤គឺលោកកៃផានេះ

**១៨:១** ណ ២សយ ១៥:២៣ ត ខ.២៦ មថ ២១:១ ថ មថ ២៦:៣៦
**១៨:២** ទ លក ២១:៣៧ ២២:៣៩
**១៨:៣** ធ ខ.១២ ន កច ១:១៦
**១៨:៤** ប យហ ៦:៦៤ ១៣:១,១១ ផ ខ.៧
**១៨:៥** ព មក ១:២៤
**១៨:៧** ភ ខ.៤
**១៨:៩** ម យហ ៦:៣៩
**១៨:១១** យ មថ ២០:២២
**១៨:១២** រ ខ.៣
**១៨:១៣** ល ខ.២៤ មថ ២៦:៣

ក្នុងព្រះយេស៊ូវតាមរយៈព្រះរាជបេសកកម្មរបស់ទ្រង់ ។
**១៧:២៦** *បានឱ្យគេស្គាល់ព្រះនាមទ្រង់* "មើលការពន្យល់ ១៦:៣"។
**១៨:១** *ជ្រោះកេដ្រុន* ស្ថិតនៅភាគខាងកើតនៃទីក្រុងយេរូសាឡិម ។ ជ្រោះនេះមានទឹកតែនៅក្នុងរដូវវស្សាប៉ុណ្ណោះ ។
**១៨:៣** *យូដាស* "មើលការពន្យល់ ៦:៧១"។ *ពួកទាហាន និងពួកអាជ្ញាខ្លះ* ពួកអ្នកទាំងនេះស្ថិតនៅក្រោមបញ្ជារបស់ពួកក្រុមជំនុំ និងមានឋានៈស្មើនឹងពួកអ្នកយាមព្រះវិហារដែរ (មើលពន្យល់ មថ ២:៤ ៣:៧ មក ១៤:៥៥)។ *គោម* គឺជាគោមដៃម្យ៉ាង ដែលមានដាក់ចង្កៀងនៅខាងក្នុង ។ *ចន្លុះ* នៅសម័យនោះ គេធ្វើចន្លុះដោយយកឈើជ័រម្យ៉ាងមកចងផ្គោបគ្នា ។
**១៨:៤,៥** លោកយ៉ូហានមិនបាននិយាយ អំពីការដែលយូដាស-អ៊ីស្ការីយ៉ុតចូលមកគំនាប់ព្រះយេស៊ូវដោយថើបទ្រង់ទេ (មថ ២៦:៤៩ លក ២២:៤៧-៤៨ មក ១៤:៤៥)។
**១៨:៤** ក្នុងបទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទជ្រាបជាមុននូវគ្រប់ហេតុការណ៍ទាំងអស់ ដែលនឹងកើតមានឡើងចំពោះព្រះអង្គទ្រង់ និងពួកសិស្ស របស់ទ្រង់ ។
**១៨:៥** *ស្រុកណាសារ៉ែត* ជាភូមិមួយស្ថិតនៅក្នុងស្រុកកាលីឡេ និងមានចម្ងាយប្រហែល៩,៦គ.ម ភាគខាងលិចនៃភ្នំតាបោរ និងចម្ងាយប្រហែល ២២,៥គ.មភាគ ខាងលិចឆៀងខាងត្បូងនៃសមុទ្រកាលីឡេ ។
**១៨:៦** *នោះគេក៏ថយក្រោយ ដួលផ្ងារទាំងអស់គ្នា* ត្រង់ចំណុចនេះ ពួកអ្នកប្រឆាំង គិតថា ពួកគេមកចាប់ឃាត់ខ្លួនមនុស្សដ៏សាមញ្ញម្នាក់ប៉ុណ្ណោះ ។ ប៉ុន្តែអ្នកដែលពួកគេចង់ចាប់ខ្លួន គឺជាព្រះអម្ចាស់ ដែលមានគ្រប់អំណាចព្រះចេស្តាទាំងអស់ទៅវិញ ។ ដូច្នោះហើយ បានជានៅពេលដែលពួកគេបានជួបនឹងទ្រង់ នោះក៏មានចិត្តភ័យខ្លាចយ៉ាងខ្លាំង ។
**១៨:៨** *នោះចូរបើកឱ្យអ្នកទាំងនេះទៅចុះ* ព្រះយេស៊ូវមានបន្ទូលទៅពួកអ្នកដែលមកចាប់ទ្រង់ថា ត្រូវដោះលែងពួកសិស្សរបស់ទ្រង់ឱ្យទៅចុះ គឺចាប់តែទ្រង់បានហើយ (ខ.៤-៥,៧)។
**១៨:៩** "មើលការពន្យល់ ៦:៣៩ ១៧:១២"។
**១៨:១០** *ស៊ីម៉ូន-ពេត្រុស* នៅក្នុងគម្ពីរដំណឹងល្អយ៉ូហានបានបញ្ជាក់យ៉ាងច្បាស់ថា លោកពេត្រុសគឺជាអ្នកមានដាវ និងបានកាត់ដាច់ត្រចៀកស្តាំរបស់បាវសម្តេចសង្ឃ ។ លោកយ៉ូហានបានបញ្ជាក់បន្ថែមទៀតថា បាវនោះឈ្មោះ "ម៉ាលកុស"។ *ដាវ* នៅក្នុងភាសាក្រិក ពាក្យនេះសំដៅលើដាវដែលមានប្រវែងខ្លី ។
**១៨:១១** *ពែង* ពាក្យនេះនៅក្នុងព្រះគម្ពីរបរិសុទ្ធច្រើនសំដៅលើទុក្ខលំបាក (មើលការពន្យល់ ទដ ៧៥:៨ អគ ២៣:៣១) និងសេចក្តីក្រោធនៃព្រះអម្ចាស់ (មើលការពន្យល់ មថ ២៦:៣៩ មក ១៤:៣៦ លក ២២:៤២ ទដ ១៦:៥ អស ៥១:១៧ យរ ២៥:១៥ រម ១:១៨ វវ ១៤:១០)។
**១៨:១២** *ក៏ចាប់ព្រះយេស៊ូវចង* បទគម្ពីរនេះមិនបានបញ្ជាក់ច្បាស់ អំពីមូលហេតុដែលបណ្តាលឱ្យពួកទាហានចាប់ចងព្រះយេស៊ូវទេ ។ ការចាប់ចងអ្នកណាម្នាក់ ប្រហែលជាធ្វើតាមច្បាប់របស់ពួកគេ និងមានលក្ខណៈស្រដៀងគ្នានឹងការដាក់ខ្នោះដៃអ្នកទោសនៅសម័យនេះដែរ ។
**១៨:១៣** *លោកអាណ* គឺជាសម្តេចសង្ឃនៅឆ្នាំ៦-១៥គ.ស ។ គាត់ត្រូវពួករ៉ូម៉ាំងទម្លាក់ពីតំណែងនៅឆ្នាំទី១៥គ.ស ដោយឱ្យកូនប្រុសបង្កើតរបស់គាត់

ឯង ដែលទូន្មានដល់ពួកសាសន៍យូដាថា មានប្រយោជន៍ឱ្យ
មានមនុស្សម្នាក់ស្លាប់ជំនួសបណ្ដាជន[វ] ។

## ការបដិសេធន៍របស់លោកពេត្រុស

*១៨:១៦–១៨ – មថ ២៦:៦៩,៧០ មក ១៤:៦៦–៦៨*
*លក ២២:៥៥–៥៧*

១៥ ឯស៊ីម៉ូន–ពេត្រុស នឹងសិស្សម្នាក់ទៀត ក៏តាម
ព្រះយេស៊ូវទៅ សំដេចសង្ឃបានស្គាល់សិស្ស១នោះដែរ[ស]
ហើយគាត់ក៏ចូលទៅក្នុងព្រះលានសំដេចសង្ឃ ជាមួយនឹង
ព្រះយេស៊ូវ[ហ]
១៦ ឯពេត្រុស គាត់ឈរនៅឯមាត់ទ្វារខាង
ក្រៅ ដូច្នេះសិស្សម្នាក់ ដែលសំដេចសង្ឃស្គាល់នោះ គាត់
ក៏ចេញទៅនិយាយនឹងអ្នកឆ្មាំទ្វារ រួចនាំពេត្រុសចូលមក ។
១៧ នោះបាវស្រីដែលចាំទ្វារ និយាយទៅពេត្រុសថា
អ្នកឯងជាសិស្សរបស់មនុស្សនោះដែរឬ គាត់ឆ្លើយថា
ខ្ញុំមិនមែនទេ[ឡ]
១៨ ពួកបាវ នឹងពួកអាជ្ញា ក៏ឈរនៅទីនោះ
ដែរ គេបាន ដុតភ្លើងអាំង[អ] ព្រោះរងា ហើយពេត្រុសក៏
ឈរអាំងនៅ ជាមួយនឹងគេ[ក] ។

## សម្ដេចសង្ឃចោទសួរព្រះយេស៊ូវ

*១៨:១៩–២៤ – មថ ២៦:៥៩–៦៨ មក ១៤:៥៥–៦៥*
*លក ២២:៦៣–៧១*

១៩ នោះសំដេចសង្ឃក៏ពិចារណាសួរព្រះយេស៊ូវ ពីដំ
ណើរពួកសិស្ស និងសេចក្ដីដែលទ្រង់បង្រៀន
២០ ព្រះយេ
ស៊ូវមានបន្ទូលឆ្លើយទៅលោកថា ខ្ញុំបាននិយាយនឹងបណ្ដា
មនុស្ស នៅកណ្ដាលជំនុំ ខ្ញុំតែងតែបង្រៀនក្នុងសាលាប្រជុំ[ខ]
ហើយក្នុងព្រះវិហារ[គ] ជាកន្លែងដែលពួកសាសន៍យូដាប្រជុំ
គ្នា ខ្ញុំមិនដែលនិយាយដោយសំងាត់ទេ[ឃ]
២១ ហេតុអ្វីបានជា
លោកសួរខ្ញុំ ចូរសួរដល់ពួកអ្នកដែលបានស្ដាប់ខ្ញុំ ពីសេចក្ដី
ដែលខ្ញុំនិយាយនោះវិញ មើល គេដឹងសេចក្ដីដែលខ្ញុំនិយាយ
ដែរ
២២ កាលទ្រង់មានបន្ទូលដូច្នេះហើយនោះមានពួកអាជ្ញា
ម្នាក់[ង] ដែលឈរនៅទីនោះ បានទះកំផ្លៀងព្រះយេស៊ូវ[ច]
ដោយពាក្យថា ឯងឆ្លើយទៅសំដេចសង្ឃយ៉ាងដូច្នេះឬ
២៣ ព្រះយេស៊ូវ មានបន្ទូលទៅអ្នកនោះថា បើខ្ញុំបាននិយាយ
អាក្រក់ នោះចូរធ្វើបន្ទាល់ពីសេចក្ដីអាក្រក់នោះចុះ តែបើ
ខ្ញុំបាននិយាយល្អវិញ ហេតុអ្វីបានជាវាយខ្ញុំ[ឆ]
២៤ នោះលោក
អាណ ឱ្យគេនាំទ្រង់ទាំងជាប់ចំណងទៅ ឯលោកកៃផា[ជ]
ជាសំដេចសង្ឃវិញ ។

## ការបដិសេធន៍លើកទីពីរ និងទីបីរបស់លោកពេត្រុស

*១៨:២៥–២៧ – មថ ២៦:៧១–៧៥ មក ១៤:៦៩–៧២*
*លក ២២:៥៨–៦២*

២៥ ឯស៊ីម៉ូន–ពេត្រុស គាត់កំពុងឈរអាំងភ្លើង[ឈ] ដូច្នេះ

**១៨:១៤** វ យហ ១១:៤៩–៥១
**១៨:១៥** ស មថ ២៦:៣
ហ មថ ២៦:៥៨ មក ១៤:៥៤ លក ២២:៥៤
**១៨:១៧** ឡ ខ.២៥
**១៨:១៨** អ យហ ២១:៩
ក មក ១៤:៥៤,៦៧
**១៨:២០** ខ មថ ៤:២៣
គ មថ ២៦:៥៥
ឃ យហ ៧:២៦
**១៨:២២** ង ខ.៣
ច មថ ១៦:២១ យហ ១៩:៣
**១៨:២៣** ឆ មថ ៥:៣៩ កច ២៣:២–៥
**១៨:២៤** ជ ខ.១៣ មថ ២៦:៣
**១៨:២៥** ឈ ខ.១៨

ឈ្មោះលោកអេលាសារឡើងជំនួស ។ បន្ទាប់មកទៀត គឺឱ្យកូនប្រសាររបស់លោកអាណ ឈ្មោះលោកកៃផា ហៅយ៉ូសែប (ខ.១៨-៣៦) ឡើងបន្តពីលោកអេលាសារ ។ ទោះជាយ៉ាងណា ក៏ពួកយូដាជាច្រើន នៅតែចាត់ទុកលោកអាណ ថាជាសម្ដេចសង្ឃពិតប្រាកដរបស់ពួកគេដដែល (មើលការពន្យល់ ១១:៤៩ លក ៣:២ កច ៤:៦) ។

**១៨:១៩** *កៃផា* គាត់គឺជាសមាជិកម្នាក់នៃពួកសាឌូស៊ី និងជាសម្ដេចសង្ឃនៅឆ្នាំទី ២៧-៣៦ គ.ស (លក ៣:២ មថ ២៦:៣,៥៧ កច ៥:១៧) ។

**១៨:១៥** *សិស្សម្នាក់ទៀត* ប្រហែលជាលោកយ៉ូហាន ដែលជាអ្នកនិពន្ធកណ្ឌគម្ពីរយ៉ូហាននេះតែម្ដង ។ សិស្សម្នាក់ទៀតនោះ ពិតជាមានទំនាក់ទំនងល្អ ជាមួយនឹងសម្ដេចសង្ឃ ព្រោះគាត់មានសិទ្ធិចូលទៅក្នុងផ្ទះរបស់សម្ដេចសង្ឃបាន ហើយថែមទាំងអាចនាំលោកពេត្រុសទៅជាមួយទៀតផង ។

**១៨:១៧** *បាវស្រីដែលចាំទ្វារ* ត្រង់ចំណុចនេះបញ្ជាក់ថា នៅក្នុងគម្ពីរដំណឹងល្អទាំងបួន សុទ្ធតែមាននិយាយអំពីការដែលលោកពេត្រុសបានជួបជាមួយនឹងបាវស្រីដែលចាំទ្វារនោះ ។ សំណួរដែលស្ត្រីនោះបានសួរទៅលោកពេត្រុស គឺជាសំណួរមួយដែលធ្វើឱ្យគាត់ឆ្លើយនូវចម្លើយបដិសេធន៍ (លក ២២:៥៨-៥៩) ។

**១៨:១៨** *ពេត្រុសក៏ឈរអាំងនៅជាមួយនឹងគេ* ត្រង់ចំណុចនេះបញ្ជាក់ថាការដែលលោកពេត្រុសឈរអាំងភ្លើងជាមួយនឹងគេ ពីព្រោះខណៈនោះជាពេលយប់ ហើយត្រជាក់ទៀតផង ដូច្នោះបើសិនជាគាត់ឈរនៅឆ្ងាយពីគេ នោះធ្វើឱ្យគេសង្ស័យលើរូបគាត់មិនខាន ។

**១៨:១៩** *ពិចារណាសួរ* ការដែលសម្ដេចសង្ឃពិចារណាសួរព្រះយេស៊ូវនៅពេលនោះ ពុំត្រឹមត្រូវតាមច្បាប់ទេ ព្រោះការចោទប្រកាន់អ្នកណាម្នាក់ថាមានទោស គឺតម្រូវឱ្យនាំសាក្សីមកជាមុន ។ ទង្វើយ៉ាងដូច្នេះ ពុំតម្រូវឱ្យចុងចោទបង្ហាញនូវភស្តុតាងថាខ្លួនគ្មានទោសនោះទេ ។ លោកកៃផាសួរព្រះយេស៊ូវនៅពេលនោះ ប្រហែលគ្រាន់តែដើម្បីសង្កេតមើលទ្រង់ នៅមុនពេលជំនុំជម្រះប៉ុណ្ណោះ មិនមែនជាការសួរដើម្បីកាត់ទោសទេ ។

**១៨:២០** *ខ្ញុំមិនដែលនិយាយដោយសំងាត់ទេ* ឃ្លានេះបញ្ជាក់ថា ព្រះយេស៊ូវគ្រីស្ទមិនដែលមានព្រះបន្ទូលដោយសម្ងាត់ទេ ដូច្នេះ បើពួកអ្នកប្រឆាំងនឹងទ្រង់ចង់រកសាក្សីដើម្បីឱ្យមកចោទប្រកាន់ទ្រង់ នោះមិនមែនជាការពិបាកទេ (ខ.២១) ។

**១៨:២២** *ទះកំផ្លៀង* ត្រង់ចំណុចនេះបញ្ជាក់ថាការដែលពួកអាជ្ញាទះកំផ្លៀងព្រះយេស៊ូវគ្រីស្ទនៅក្នុងខណៈនោះ គឺជាការមិនត្រឹមត្រូវ និងបានបំពានលើច្បាប់ទាំងស្រុង ។

**១៨:២៣** *ធ្វើបន្ទាល់* មានន័យថា ធ្វើសាក្សី ឬបង្ហាញភស្តុតាង ឬក៏ឆ្លើយអះអាង ។ ការដែលតម្រូវឱ្យមានសាក្សីមកធ្វើបន្ទាល់ អំពីការអាក្រក់របស់ចុងចោទ គឺជាការត្រឹមត្រូវតាមច្បាប់ ។ ម្យ៉ាងទៀត នៅក្នុងដំណឹងល្អយ៉ូហានច្រើននិយាយអំពីសារសំខាន់នៃការធ្វើបន្ទាល់ (មើលការពន្យល់ ១:៧) ។

**១៨:២៥** *គេសួរគាត់* ត្រង់ចំណុចនេះ នៅក្នុងគម្ពីរដំណឹងល្អបីផ្សេងទៀត

គេសួរគាត់ថា អ្នកឯងជាសិស្សរបស់អ្នកនោះដែរឬ តែ
គាត់ប្រកែកថា ខ្ញុំមិនមែនទេ[ញ] ២៦មានពួកបាវសំដេចសង្ឃ
ម្នាក់ គឺជាសាច់ញាតិនឹងអ្នកដែលពេត្រុស បានកាប់ដាច់
ត្រចៀកនោះ[ដ] ក៏និយាយថា តើអញមិនបានឃើញឯង
នៅក្នុងច្បារជាមួយនឹងអ្នកនោះទេឬអី[ឋ] ២៧ពេត្រុសក៏ប្រ
កែកម្ដងទៀត ស្រាប់តែមាន់រងាវឡើង[ឌ]។

## ព្រះយេស៊ូវនៅមុខលោកពីឡាត់

*១៨:២៨-៤០ – មថ ២៧:១១-១៨ ២០-២៣ មក ១៥:២-១៥*

*លក ២៣:២,៣,១៨-២៥*

២៨គេនាំព្រះយេស៊ូវ ពីលោកកៃផា ទៅក្នុងសាលាជំនុំ[ឍ]
ពេលនោះព្រលឹមស្រាងហើយ គេមិនបានចូលទៅក្នុង
សាលាទេ[ណ] ក្រែងគេត្រូវសៅហ្មង នឹងបរិភោគបុណ្យរំលង
មិនបាន[ត] ២៩ដូច្នេះ លោកពីឡាត់ចេញទៅឯគេ សួរថា

**១៨:២៥** ញ ខ.១៧-១៨
**១៨:២៦** ដ ខ.១០
ឋ ខ.១
**១៨:២៧** ឌ យហ ១៣:៣៨
**១៨:២៨** ឍ មថ ២៧:២ ណ ខ.៣៣
យហ ១៩:៩
ត យហ ១១:៥៥
**១៨:៣២** ថ មថ ២០:១៩ ២៦:២
យហ ៣:១៤ ៨:២៨
១២:៣២,៣៣
**១៨:៣៣** ទ ខ.២៨,២៩
យហ ១៩:៩
ធ លក ២៣:៣
មថ ២:២

តើអ្នករាល់គ្នាចោទប្រកាន់មនុស្សនេះពីរឿងអ្វី ៣០គេឆ្លើយ
ទៅលោកថា បើវាមិនមែនជាមនុស្សអាក្រក់ នោះយើងខ្ញុំ
មិន បានបញ្ជូនវាមកទេ ៣១ដូច្នេះ លោកពីឡាត់មាន
ប្រសាសន៍ថា ចូរយកទៅជំនុំជំរះតាមច្បាប់របស់អ្នករាល់
គ្នាចុះ តែពួកសាសន៍យូដាជំរាបលោកថា យើងខ្ញុំគ្មាន
ច្បាប់នឹងសំឡាប់អ្នកណាទេ ៣២គេនិយាយដូច្នោះដើម្បីឱ្យ
បានសំរេចពាក្យ ដែលព្រះយេស៊ូវមានបន្ទូល នឹងបង្ហាញ
ពីទ្រង់ត្រូវសុគត[ថ] បែបយ៉ាងណា ៣៣នោះលោកពីឡាត់ក៏
ចូលទៅក្នុងសាលាជំនុំវិញ[ទ] រួចហៅព្រះយេស៊ូវមកដណ្ដឹង
សួរថា តើអ្នកជាស្ដេចសាសន៍យូដាឬអី[ធ] ៣៤ព្រះយេស៊ូវ
មានបន្ទូលឆ្លើយថា តើលោកមានប្រសាសន៍ដូច្នេះ ដោយ
ខ្លួនលោក ឬមានអ្នកណាជំរាបលោកពីខ្ញុំ ៣៥លោកពីឡាត់

បញ្ជាក់ថា ទីកន្លែងដែលគេសួរលោកពេត្រុស និងទីកន្លែងដែលគាត់ឆ្លើយបដិសេធថា មិនបានស្គាល់ព្រះយេស៊ូវ គឺនៅក្បែរកន្លែងដែលគាត់ឈរអាំងភ្លើងជិតមាត់ទ្វារ ខាងក្រៅផ្ទះរបស់លោកកៃផា ។ រីឯលោកយ៉ូហានវិញនិយាយថា ការបដិសេធរបស់គាត់លើកទី១ គឺនៅខាងក្រៅផ្ទះរបស់លោកអាណ ហើយការបដិសេធន៍២លើកទៀត កើតឡើងនៅខាងក្រៅផ្ទះរបស់លោកកៃផា ។ ដោយព្រោះផ្ទះរបស់លោកអាណ និងផ្ទះរបស់លោកកៃផាស្ថិតនៅក្បែរគ្នា ដូច្នេះ អាចបញ្ជាក់បានថា ទីកន្លែង ដែលលោកពេត្រុសបដិសេធមិនស្គាល់ព្រះយេស៊ូវ នៅក្នុងគម្ពីរដំណឹងល្អយ៉ូហាន និងនៅក្នុងដំណឹងល្អបីផ្សេងទៀត គឺជាទីកន្លែងតែមួយ ។

**១៨:២៦** បទគម្ពីរនេះ លោកយ៉ូហានបានបញ្ជាក់យ៉ាងច្បាស់ អំពីសាច់ញាតិរបស់អ្នកដែលលោកពេត្រុសកាប់ដាច់ត្រចៀក ។ សាច់ញាតិម្នាក់នោះប្រហែលជាចាប់អារម្មណ៍លើលោកពេត្រុសជាងគេ ពីព្រោះគាត់មានដាវនៅនឹងដៃ កាលនៅក្នុងច្បានាពេលយប់ដែលគេចាប់ព្រះយេស៊ូវនោះ ។

**១៨:២៧** *ស្រាប់តែមាន់រងាវឡើង* ការដែលមាន់រងាវ គឺស្របនឹងសេចក្ដីដែលព្រះយេស៊ូវនៅក្នុង "១៣:៣៨" (មើលការពន្យល់) ។

**១៨:២៨** *សាលាជំនុំ* សំដៅលើសាលាជម្រះក្ដីរបស់ពួករ៉ូម៉ាំង ។ លោកយ៉ូហានបានលើកយកសេចក្ដីជាច្រើន ស្ដីអំពីការកាត់ទោសព្រះយេស៊ូវគ្រីស្ទនៅមុខពួកអភិបាលរ៉ូម៉ាំង ។ ដូច្នេះ អាចបញ្ជាក់ថា លោកយ៉ូហានក៏បានចូលទៅក្នុងសាលាជំនុំជម្រះក្ដីរបស់ពួករ៉ូម៉ាំងនោះដែរ (មក ១៤:៥៣-១៥:១៥) *ពេលនោះព្រលឹមស្រាងហើយ* គឺប្រហែលនៅម៉ោង៦ទៅម៉ោង៧ព្រឹក ។ *ក្រែងគេត្រូវសៅហ្មង* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកគេមិនហ៊ានចូលទៅក្នុងសាលាជំនុំជម្រះក្ដីរបស់ពួករ៉ូម៉ាំងដែលជាសាសន៍ដទៃទេ ព្រោះពួកគេខ្លាចត្រូវសៅហ្មង (ឬមិនបរិសុទ្ធ) និងមិនអាចបរិភោគអាហារនៅថ្ងៃបុណ្យរំលង ។ *បុណ្យរំលង* សំដៅលើរយៈ ពេលប្រាំពីរថ្ងៃនៃបុណ្យរំលងតែម្ដង។

**១៨:២៩** *លោកពីឡាត់* គឺជាចៅហ្វាយស្រុកយូដា (មថ ២៧:២ មើលការពន្យល់ មក ១៥:១) ។ គាត់បានបង្ហាញនូវលក្ខណៈលំអៀង ទៅខាងពួកអ្នកដឹកនាំសាសន៍យូដា ។ *តើអ្នករាល់គ្នាចោទប្រកាន់មនុស្សនេះពីរឿងអ្វី ?* ឃ្លានេះជាសំណួរធម្មតា ដែលគេសួរទៅដើមចោទ ជាដំបូងបង្អស់ នៅពេលចាប់ផ្ដើមការជំនុំជម្រះ ប៉ុន្តែ សម្រាប់ពួកមេដឹកនាំសាសន៍យូដា គឺជាសំណួរដ៏ពិបាក ព្រោះពួកគេគ្មានមូលហេតុច្បាស់លាស់ ដើម្បីចោទប្រកាន់ព្រះយេស៊ូវ នៅមុខទីជំនុំជម្រះរបស់ពួករ៉ូម៉ាំងទេ ។

**១៨:៣១** *ចូរយកទៅជំនុំជំរះតាមច្បាប់របស់អ្នករាល់គ្នាចុះ* លោកពីឡាត់និយាយ ដូច្នេះ មានន័យថា មិនចាំបាច់ត្រូវជំនុំជម្រះព្រះយេស៊ូវ តាមច្បាប់របស់ពួករ៉ូម៉ាំងទេ គឺឱ្យជំនុំជម្រះតាមច្បាប់របស់ពួកសាសន៍យូដាវិញ ។ *យើងខ្ញុំគ្មានច្បាប់នឹងសំឡាប់អ្នកណាទេ* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ពួកអ្នកដឹកនាំសាសន៍ យូដាពិតជាចង់ធ្វើគុតព្រះយេស៊ូវដោយគ្មានហេតុផល ប៉ុន្តែ ពួកគេគ្មានសិទ្ធិក្នុងការធ្វើគុតទ្រង់ទេ ។ ម្យ៉ាងទៀត បើអ្នកដឹកនាំសាសន៍យូដាណាម្នាក់ហ៊ានគាំទ្រពួករ៉ូម៉ាំង នៅក្នុងការកាត់ទោសព្រះយេស៊ូវ អ្នកដឹកនាំនោះនឹងត្រូវគេដកចេញពីតំណែង និងសម្លាប់ជាសម្ងាត់បំផុត ។ ពេលខ្លះការជំនុំជម្រះក្ដីរបស់ពួករ៉ូម៉ាំងហាក់ដូចជាមានលក្ខណៈលំអៀង ទៅខាងពួកអ្នកដឹកនាំសាសន៍យូដា (កច ៧:១-៦០) ។ ទោះជាយ៉ាងណាក៏ដោយ ក៏ការដាក់ទោសប្រហារជីវិតអ្នកណាម្នាក់ គឺជាសិទ្ធិសម្រេចរបស់ពួករ៉ូម៉ាំង ។

**១៨:៣២** *បង្ហាញពីទ្រង់ត្រូវសុគតបែបយ៉ាងណា* ឃ្លានេះបញ្ជាក់ថា តាមច្បាប់របស់ពួកសាសន៍យូដា អ្នកណាដែលមានទោសដល់ស្លាប់ គឺត្រូវសម្លាប់ដោយចោលនឹងថ្ម ប៉ុន្តែ ព្រះយេស៊ូវគ្រីស្ទសុគតដោយគេឆ្កាងវិញ ដើម្បីទទួលយកនូវបណ្ដាសាទាំងអស់ជំនួសមនុស្សលោក (ចទ ២១:២២-២៣ ប្រៀបធៀបនឹង យហ ១២:៣២-៣៤) ។

**១៨:៣៣** *តើអ្នកជាស្ដេចសាសន៍យូដាឬអី ?* ឃ្លានេះជាសំណួរដំបូង ដែលលោកពីឡាត់សួរទៅព្រះយេស៊ូវ មានកត់ត្រាទុកនៅក្នុងព្រះគម្ពីរដំណឹងល្អទាំងបួន ។ ម្យ៉ាងទៀត បញ្ជាក់ថា គ្រាន់តែលោកពីឡាត់បានជួបនឹងព្រះយេស៊ូវភ្លាម នោះគាត់អាចដឹងថា ពាក្យសម្ដីចោទប្រកាន់របស់ពួកអ្នកប្រឆាំងនឹងទ្រង់ ដែលថាទ្រង់ជាអ្នកបះបោរ គឺគ្រាន់តែជារឿងដែលពួកគេនាំគ្នាប្រឌិតឡើង ដើម្បីរកសម្លាប់ទ្រង់ប៉ុណ្ណោះ និងមិនមែនជាការពិតទេ

**១៨:៣៤** *តើលោកមានប្រសាសន៍ដូច្នេះដោយខ្លួនលោក ឬមានអ្នកណា*

ឆ្លើយថា តើខ្ញុំជាសាសន៍យូដាឬអី គឺសាសន៍របស់អ្នកឯង
និងពួកសង្គ្រាជទេតើ ដែលបញ្ជូនអ្នកមកខ្ញុំ ចុះអ្នកបានធ្វើអ្វី
36 ព្រះយេស៊ូវមានបន្ទូលថា នគរ[ន]ខ្ញុំ មិនមែនត្រូវខាង
លោកិយនេះទេ បើសិនជានគរខ្ញុំ ត្រូវខាងលោកិយនេះ
នោះពួកអ្នកបំរើខ្ញុំ គេនឹងបានតយុទ្ធហើយ ដើម្បីមិនឱ្យខ្ញុំ
ត្រូវបញ្ជូនទៅសាសន៍យូដាឡើយ[ប] តែឥឡូវនេះ នគរខ្ញុំមិន
មែនត្រូវខាងស្ថាននេះទេ[ផ] 37 លោកពីឡាត់ក៏សួរទ្រង់ថា
ដូច្នេះ អ្នកជាស្តេចមែនឬ ព្រះយេស៊ូវមានបន្ទូលឆ្លើយ
ថា លោកមានប្រសាសន៍ថា ខ្ញុំជាស្តេច នោះត្រូវហើយ
ខ្ញុំបានកើតមក ហើយក៏ចូលក្នុងលោកីយនេះសំរាប់តែការ
នោះឯង ដើម្បីឱ្យខ្ញុំបានធ្វើបន្ទាល់ពីសេចក្តីពិត[ព] អស់អ្នក
ណាដែលកើតពីសេចក្តីពិត នោះក៏ឮសំឡេងខ្ញុំ[ភ] 38 លោក
ពីឡាត់ទូលសួរទ្រង់ថា តើយ៉ាងណាដែលហៅថាសេចក្តី
ពិតនោះ កាលបានទូលដូច្នោះរួចហើយ នោះលោកចេញ
ទៅឯពួកសាសន៍យូដាម្តងទៀត ក៏មានប្រសាសន៍ថា ខ្ញុំមិន
ឃើញជាអ្នកនោះ មានទោសខុសអ្វីសោះ[ម] 39 អ្នករាល់គ្នា
មានទំលាប់ធ្លាប់ឱ្យខ្ញុំលែងម្នាក់ ដល់អ្នករាល់គ្នានៅវេលា
បុណ្យរំលង ដូច្នេះ តើចង់ឱ្យខ្ញុំលែង ស្តេចនៃសាសន៍យូដា
ឬអី 40 គេក៏ស្រែកឡើងទាំងអស់គ្នាម្តងទៀតថា កុំលែងអ្នក
នោះឡើយ សូមលែងបារ៉ាបាសវិញ រីឯបារ៉ាបាស វាជា
ចោរប្លន់[យ]។

**១៨:៣៦** ន មថ ៣:២ ប មថ ២៦:៥៣ ផ លក ១៧:២១ យហ ៦:១៥ **១៨:៣៧** ព យហ ៣:៣២ ភ យហ ៨:៤៧ ១យហ ៤:៦ **១៨:៣៨** ម លក ២៣:៤ **១៨:៤០** យ កច ៣:១៤ **១៩:១** ង ចទ ២៥:៣ អស ៥០:៦ ៥៣:៥ មថ ២៧:២៦ **១៩:៣** ច មថ ២៧:២៩ ឆ យហ ១៨:២២ **១៩:៤** ជ យហ ១៨:៣៨ ឈ ខ.៦ លក ២៣:៤ **១៩:៥** ញ ខ.២ **១៩:៦** ដ កច ៣:១៣ ឋ ខ.៤ លក ២៣:៤

## ការកាត់ទោសឱ្យព្រះយេស៊ូវជាប់ឆ្កាង

*១៩:១-១៦ – មថ ២៧:២៧-៣១ មក ១៥:១៦-២០*

**១៩** 1 ខណៈនោះ លោកពីឡាត់នាំយកព្រះយេស៊ូវទៅវាយ
នឹងរំពាត់[ង] 2 ពួកទាហានក៏ក្រងភួងបន្លាបំពាក់លើព្រះសិរ
ហើយយកអាវពណ៌ស្វាយមកបំពាក់ទ្រង់ 3 ទាំងទូលថា សូម
ថ្វាយបង្គំស្តេចសាសន៍យូដា[ច] រួចគេទះទ្រង់[ឆ] 4 លោកពីឡាត់
ក៏ចេញទៅ មានប្រសាសន៍នឹងគេម្តងទៀតថា មើល ខ្ញុំនាំអ្នក
នេះចេញ[ជ]មកឯអ្នករាល់គ្នា ដើម្បីឱ្យអ្នករាល់គ្នាដឹងថា
ខ្ញុំមិនឃើញជាគាត់មានទោសយ៉ាងណាសោះ[ឈ] 5 ដូច្នេះ
ព្រះយេស៊ូវក៏យាងចេញទៅក្រៅ ទាំងពាក់ភួងបន្លា នឹង
អាវពណ៌ស្វាយនោះ[ញ] រួចលោកពីឡាត់មានប្រសាសន៍ទៅ
គេថា មើលចុះ មនុស្សនេះហើយ 6 កាលពួកសង្គ្រាជ នឹង
ពួកអាជ្ញាបានឃើញទ្រង់ នោះក៏ស្រែកឡើងថា ឆ្កាងវា
ឆ្កាងវាទៅ លោកពីឡាត់មានប្រសាសន៍ទៅគេថា ត្រូវ
ឱ្យអ្នករាល់គ្នាយកគាត់ទៅឆ្កាងវិញ[ដ] ដ្បិតខ្ញុំមិនឃើញជាមាន
ទោសអ្វីទេ[ឋ] 7 ពួកសាសន៍យូដាឆ្លើយថា យើងខ្ញុំមានក្រឹត្យ
វិន័យ ហើយតាមក្រិត្យវិន័យនោះ វាត្រូវស្លាប់[ឌ] ពីព្រោះវា
បានតាំងខ្លួនឡើងជាព្រះរាជបុត្រានៃព្រះ[ឍ]។

*ជិរាបលោកពីខ្ញុំ?* ចំណុចនេះបញ្ជាក់ថា សំណួរដែលលោកពីឡាត់សួរទៅព្រះយេស៊ូវ នៅពេលនោះ អាចមកពីខ្លួនគាត់ផ្ទាល់ ឬអាចមកពីពួកមេដឹកនាំសាសន៍យូដា ។

**១៨:៣៦** *នគរខ្ញុំមិនមែនត្រូវខាងលោកីយនេះទេ* មានន័យថា នគរដែលព្រះគ្រីស្ទតាំងឡើង មិនមែនជានគរដូចដែលលោកិយគិតនោះទេ ប៉ុន្តែ ជានគរស្ថានសួគ៌ដែលនៅអស់កល្បជានិច្ចវិញ ។

**១៨:៣៧** *ធ្វើបន្ទាល់ . . . សេចក្តីពិត* សេចក្តីទាំងពីរនេះមានសារសំខាន់ណាស់ នៅក្នុងព្រះគម្ពីរដំណឹងល្អយ៉ូហាន (១:៧ ១:១៤ ១៤:៦ និងការពន្យល់)។

**១៨:៣៨** *តើយ៉ាងណាដែលហៅថាសេចក្តីពិតនោះ* ឃ្លានេះនៅក្នុងព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសសរសេរថា "តើអ្វីជាសេចក្តីពិត ?" ព្រះយេស៊ូវគ្រីស្ទគឺជាសេចក្តីពិត (១៤:៦)។ នៅក្នុងទ្រង់មានពេញដោយព្រះគុណ និងសេចក្តីពិត (១:១៤ ៨:៣២)។ *ខ្ញុំមិនឃើញជាអ្នកនោះមានទោសខុសអ្វីសោះ* ត្រង់ចំណុចនេះ បញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវទ្រង់គ្មានទោសអ្វីទាល់តែសោះ (១៩:៤,៦)។

**១៨:៣៩-៤០** តាមទម្លាប់ ពួករ៉ូម៉ាំងតែងតែដោះលែងអ្នកទោសសាសន៍យូដាម្នាក់ នៅថ្ងៃបុណ្យរំលង ដើម្បីជានិមិត្តរូបនៃចំណងមិត្តភាពជាមួយនឹងសាសន៍យូដា ។ ដោយសារពួកបណ្តាជនទទួលឥទ្ធិពលពីពួកសម្តេចសង្ឃ (មក ១៥:១១) ដូច្នេះ បានជាពួកគេនាំគ្នាសូមឱ្យលោកពីឡាត់ដោះលែងបារ៉ាបាស ដែលជាចោរប្លន់ទៅឱ្យពួកខ្លួនវិញ (មើលការពន្យល់ មថ ២៧:១៦ លក ២៣:១៨,១៩)។

**១៩:១** លោកពីឡាត់មានសង្ឃឹមថា ការនាំយកព្រះយេស៊ូវទៅវាយនឹងរំពាត់ អាចបំពេញចិត្តដល់ពួកសាសន៍យូដា និងអាចជួយឱ្យគាត់មានឱកាសដោះលែងទ្រង់បានផង (មើលការពន្យល់ មក ១៥:១៥)។

**១៩:២** *ភួងបន្លា* "មើលការពន្យល់ មក ១៥:១៧"។ *ពណ៌ស្វាយ* ជាទូទៅពណ៌ស្វាយ គឺជាពណ៌សម្រាប់ស្តេច ។

**១៩:៦** លោកពីឡាត់បាននិយាយទៅកាន់ពួកសាសន៍យូដាថា "គឺអ្នករាល់គ្នាយកគាត់ទៅឆ្កាងវិញ ដ្បិតខ្ញុំមិនឃើញមានទោសអ្វីទេ"។ នៅក្នុងឃ្លាដែលលោកពីឡាត់ និយាយទៅកាន់ពួកសាសន៍យូដាទាំងនោះ មានប្រើពាក្យថា "អ្នករាល់គ្នា" និងពាក្យថា "ខ្ញុំ"។ ការដែលគាត់ប្រើពាក្យយ៉ាងដូច្នេះ ពីព្រោះគាត់ចង់បង្ហាញអំពីភាពផ្ទុយគ្នា រវាងខ្លួនគាត់ និងពួកសាសន៍យូដា ។ ម្យ៉ាងទៀត បញ្ជាក់ថា គាត់មិនបានអនុញ្ញាត ឱ្យពួកសាសន៍យូដាឆ្កាងព្រះយេស៊ូវនោះឡើយ ប៉ុន្តែពាក្យសម្តី របស់គាត់ដូចជាចង់និយាយថា "ក្នុងនាមខ្ញុំជាអ្នកកាត់ក្តី ខ្ញុំបានសម្រេចថា គាត់គ្មានទោសទេ តែពួកអ្នករាល់គ្នាដូចជាមិនដឹងថា រឿងក្តីនេះចប់ហើយទេ ។ បើអ្នករាល់គ្នាពិតជាមានសមត្ថភាពបដិសេធសេចក្តីសម្រេចរបស់ខ្ញុំ ហើយនៅតែបន្ត រឿងក្តីនេះដោយគ្មានខ្ញុំដូច្នេះ យកគាត់ទៅឆ្កាងដោយខ្លួនឯងទៅ"។ *ខ្ញុំមិនឃើញ ជាមានទោសអ្វីទេ* នេះគឺជាលើកទីបីហើយ ដែលលោកពីឡាត់បានប្រកាសថា ព្រះយេស៊ូវ

៨កាលលោកពីឡាត់ បានឮពាក្យនោះ ក៏ភ័យរឹតតែខ្លាំង
ឡើង ៩លោកត្រឡប់ទៅក្នុងសាលាជំនុំ[ណ] ទូលសួរព្រះយេស៊ូវ
ថា តើអ្នកមកពីណា តែព្រះយេស៊ូវទ្រង់មិនឆ្លើយសោះ[ត]
១០ដូច្នេះ លោកពីឡាត់សួរទ្រង់ថា តើអ្នកមិនឆ្លើយទេឬអី
អ្នកមិនដឹងទេឬថា ខ្ញុំមានអំណាចនឹងឆ្កាងអ្នក ឬលែងអ្នកក៏
បាន ១១ព្រះយេស៊ូវមានបន្ទូលថា បើមិនបានប្រទានមកពី
ស្ថានលើ[ថ] នោះលោកឥតមានអំណាចលើខ្ញុំសោះ ហេតុ
នោះ បានជាអ្នកដែលបញ្ជូនខ្ញុំមកលោក អ្នកនោះមានបាប
ធ្ងន់ជាង[ទ] ១២តាំងពីនោះមក លោកពីឡាត់រកទំនង
នឹងលែងទ្រង់ដែរ តែពួកសាសន៍យូដាស្រែកកងឡើងថា
បើលោកលែងអ្នកនេះទៅ នោះលោកមិនមែនជាទីស្រ
ឡាញ់នឹងសេសារទេ ព្រោះអ្នកណាដែលតាំងខ្លួនធ្វើជា
ស្តេច[ធ] នោះក្បត់នឹង សេសារហើយ ១៣កាលលោកពីឡាត់
បានឮពាក្យនោះ ក៏នាំព្រះយេស៊ូវចេញទៅឯកន្លែងហៅ
ថា ទីក្រាលថ្ម ដែលភាសាហេព្រើរហៅថា កាបាថា
រួចលោកអង្គុយនៅទីជំនុំជំរះ[ន] ១៤(រីឯ ថ្ងៃនោះ ជាថ្ងៃរៀប
ចំ[ប]បុណ្យរំលង ប្រហែលជាថ្ងៃត្រង់ហើយ)[ផ] លោកក៏មាន
ប្រសាសន៍ ទៅពួកសាសន៍យូដាថា មើល នេះស្តេចនៃអ្នក
រាល់គ្នា[ព] ១៥តែគេស្រែកឡើងថា យកវាចេញ យកវាចេញ
ឱ្យឆ្កាងវាទៅ លោកពីឡាត់សួរគេថា តើឱ្យខ្ញុំឆ្កាងស្តេចនៃ
អ្នករាល់គ្នាឬអី ពួកសង្គ្រាជឆ្លើយថា យើងខ្ញុំមានស្តេច
តែសេសារទេ ១៦ដូច្នេះ លោកក៏បញ្ជូនទ្រង់ទៅឱ្យគេឆ្កាង
ហើយគេនាំទ្រង់យកទៅ[ភ]។

## ការឆ្កាង

*១៩:១៧-២៤ – មថ ២៧:៣៣-៤៤ មក ១៥:២២-៣២*
*លក ២៣:៣៣-៤៣*

១៧ព្រះយេស៊ូវ ទ្រង់យាងចេញទៅ ទាំងលីឈើឆ្កាងទៅ[ម]
ដល់កន្លែងហៅថា ភ្នំរលាក្បាល[យ]ដែលភាសាហេព្រើរ[រ]
ហៅថា គាល់កូថា ១៨គេក៏ឆ្កាងទ្រង់នៅទីនោះ ព្រមទាំង២
នាក់ទៀត[ល]ជាមួយនឹងទ្រង់ដែរម្នាក់ម្ខាងៗ ហើយព្រះយេស៊ូវ

**១៩:៧** ឌ លវ ២៤:១៦
ឍ មថ ២៦:៦៣-៦៦ យហ ៥:១៨ ១០:៣៣
**១៩:៩** ណ យហ ១៨:៣៣
**១៩:៩** ត មក ១៤:៦១
**១៩:១១** ថ រម ១៣:១ ទ យហ ១៨:២៨-៣០ កច ៣:១៣
**១៩:១២** ធ លក ២៣:២
**១៩:១៣** ន មថ ២៧:១៩
**១៩:១៤** ប មថ ២៧:៦២ ផ មក ១៥:២៥ ព ឧ.១៩,២១
**១៩:១៦** ភ មថ ២៧:២៦ មក ១៥:១៥ លក ២៣:២៥
**១៩:១៧** ម លប ២២:៦ លក ១៤:២៧ ២៣:២៦

គ្មានទោសទេ (១៨:៣៨ មើលការពន្យល់ ១៩:៤)។ ព្រះគម្ពីរលូកាក៏មាននិយាយ អំពីការប្រកាសរបស់លោកពីឡាត់ ទាំងបីលើកនេះផងដែរ (លក ២៣:៤ ១៤:២២)។

**១៩:៧** *វាត្រូវស្លាប់* ពួកសាសន៍យូដានិយាយយ៉ាងដូច្នេះគឺសំដៅលើការដែលពួកគេចោទប្រកាន់ព្រះយេស៊ូវថា ទ្រង់ត្រូវតែទទួលទោស ពីបទពោលពាក្យប្រមាថដល់ព្រះ (លវ ២៤:១៦)។

**១៩:៨** បទគម្ពីរនេះបញ្ជាក់ថា លោកពីឡាត់ក៏ជឿលើរឿងអបិយជំនឿដែរ ដូច្នោះ បានជានៅពេលដែលគាត់បានឮ សេចក្តីទាំងឡាយអំពីព្រះយេស៊ូវ នោះគាត់ក៏មាន ការភិតភ័យរឹតតែខ្លាំងឡើង ។

**១៩:៩** *ព្រះយេស៊ូវទ្រង់មិនឆ្លើយសោះ* ត្រង់ចំណុចនេះមិនបានបញ្ជាក់ច្បាស់ទេថា តើមូលហេតុអ្វីបានជាព្រះយេស៊ូវទ្រង់មិនឆ្លើយសំណួររបស់ពួកគេ ។

**១៩:១០** *ខ្ញុំមានអំណាច* លោកពីឡាត់មានការជឿជាក់លើសិទ្ធិអំណាចដែលគាត់មាននៅក្នុងចក្រភពរ៉ូម៉ាំង ។ សំណួរទីពីររបស់គាត់បានបង្ហាញនូវការទទួលខុសត្រូវរបស់គាត់ ចំពោះការយកព្រះយេស៊ូវទៅឆ្កាង ។

**១៩:១១** បទគម្ពីរនេះ គឺជាសេចក្តីដែលព្រះយេស៊ូវទ្រង់មានបន្ទូលទៅកាន់លោកពីឡាត់ជាលើកចុងក្រោយបង្អស់ហើយ ។ *មកពីស្ថានលើ* មានន័យថា មកពីព្រះ (រម ១៣:១៤ និងការពន្យល់)។ *មានបាបធ្ងន់ជាង* លោកកៃផា និងពួកមេដឹកនាំសាសន៍យូដាដទៃៗទៀត មានបាបធ្ងន់ជាងគេ ពីព្រោះពួកគេជាអ្នករៀបចំគម្រោងការធ្វើគុតព្រះយេស៊ូវ ។ ព្រះយេស៊ូវមិនបានមានបន្ទូលចោទប្រកាន់លោកពីឡាត់អំពីបញ្ហាអ្វីទេ ។

**១៩:១២** *មិនមែនជាទីស្រឡាញ់នឹងសេសារទេ* ឃ្លានេះនៅក្នុងព្រះគម្ពីរបរិសុទ្ធជា ភាសាអង់គ្លេសសរសេរថា "មិនមែនជាមិត្តរបស់សេសារទេ"។ មានមនុស្សមួយចំនួនមានឋានៈជា "មិត្តរបស់សេសារ"។ មានការគំរាមដោយប្រយោលថា ប្រសិនបើលោកពីឡាត់ដោះលែងព្រះយេស៊ូវ នោះគាត់នឹងត្រូវប្រឈមមុខ ចំពោះការចោទប្រកាន់ នៅមុខស្តេចអធិរាជសេសារមិនខាន ។

**១៩:១៣** *ទីក្រាលថ្ម* ស្ថិតនៅក្នុងកន្លែងប៉មអាន់តូនា (Antonia) ដែលនៅជាប់នឹងកាច់ជ្រុងនៃបរិវេណព្រះវិហារក្រុងយេរូសាឡិម ។ ទីក្រាលថ្មនេះមានឈ្មោះម្យ៉ាងទៀតថា "ហ្គាប់បាថា (Gabbatha)"។

**១៩:១៤** *ជាថ្ងៃរៀបចំបុណ្យរំលង* ឃ្លានេះនិយាយសំដៅលើ ថ្ងៃសុក្រនៃសប្តាហ៍បុណ្យរំលង ។ តាមធម្មតា ថ្ងៃសុក្រគឺជាថ្ងៃដែលបណ្តាជនត្រៀមខ្លួនសម្រាប់ថ្ងៃឈប់សម្រាក ។ *ប្រហែលថ្ងៃត្រង់ហើយ* "មើលការពន្យល់ មក ១៥:២៥ មថ ២៧:៤៥-៤៦ មក ១៥:៣៣-៣៤ លក ២៣:៤៤)។ *ពួកសាសន៍យូដា* "មើលការ ពន្យល់ ១:១៩"។ *នេះស្តេចនៃអ្នករាល់គ្នា* ការដែលលោកពីឡាត់និយាយយ៉ាងដូច្នេះ ប្រហែលមកពីគាត់ចង់ឱ្យពួកសាសន៍យូដាឈប់ប៉ុនប៉ងកាត់ទោសសម្លាប់ព្រះយេស៊ូវ ដោយគ្រាន់តែចំអកឱ្យទ្រង់វិញ ហើយប្រហែលជាគាត់នៅតែសង្ឃឹម ថានឹងអាចដោះលែងទ្រង់បាន ។

**១៩:១៥** *យើងខ្ញុំមានស្តេចតែសេសារទេ* ពួកសង្គ្រាជបាននិយាយឃ្លានេះគឺនៅ ក្នុងន័យផ្សេងវិញ ។ ពួកមេដឹកនាំសាសន៍យូដាអស់សង្ឃឹមយ៉ាងខ្លាំងនៅក្នុងការធ្វើគុតព្រះយេស៊ូវ ។ ទោះជាពួកគេស្អប់ពួករ៉ូម៉ាំងខ្លាំងយ៉ាងណាក៏ដោយ ក៏ពួកគេនៅតែស្រែកថា "យើងខ្ញុំមានតែស្តេចសេសារទេ"។ ពួកគេបានធ្វើពុតជាស្មោះស្ម័គ្រនឹងពួករ៉ូម៉ាំង ហើយបដិសេធព្រះមែស៊ីរបស់ខ្លួន ។ ពាក្យសម្តីរបស់ពួកគេបានថ្កោលទោសពួកគេហើយ ពីព្រោះព្រះអម្ចាស់ទ្រង់ទើបជាស្តេចដ៏ពិតប្រាកដរបស់ពួកគេ ដូច្នេះការដែលពួកគេធ្វើនោះគឺមិនស្មោះត្រង់នឹងទ្រង់ទេ ។

**១៩:១៧** *លីឈើឆ្កាង* តាមធម្មតា អ្នកទោសដែលត្រូវឆ្កាង ត្រូវលីឈើឆ្កាងដោយខ្លួនឯងផ្ទាល់ទៅកន្លែងឆ្កាង ។ នៅតាមផ្លូវទៅកន្លែងឆ្កាង គេបានបង្ខំ

នៅជាកណ្ដាល ១៩លោកពីឡាត់ធ្វើប្រកាស ១ បិទនៅលើ
ឈើឆ្កាង មានសេចក្ដីថា «នេះឈ្មោះយេស៊ូវ ជាអ្នកស្រុក
ណាសារ៉ែត[វ] ស្ដេចនៃសាសន៍យូដា»[ស] ២០មានសាសន៍យូដា
ជាច្រើនបានមើលប្រកាសនោះ ដ្បិតកន្លែងដែលគេឆ្កាង
ព្រះយេស៊ូវនោះនៅជិតទីក្រុង[ហ] ហើយប្រកាសនោះ គេបាន
សរសេរជាភាសាហេព្រើរ ក្រេក និងឡាតាំង ២១ដូច្នេះ
ពួកសង្គ្រាជរបស់សាសន៍យូដា គេជិរាបដល់លោកពីឡាត់
ថា សូមលោកកុំសរសេរថា នេះជាស្ដេចនៃសាសន៍យូដា
ឡើយ សូមសរសេរតាមវានិយាយវិញថា ខ្ញុំជាស្ដេចនៃ
សាសន៍ យូដា[ឡ] ២២លោកពីឡាត់ឆ្លើយថា ឯសេចក្ដី
ដែលខ្ញុំបានសរសេរ នោះបានសរសេរស្រេចទៅហើយ
២៣ឯពួកទាហាន កាលបានឆ្កាងព្រះយេស៊ូវរួចហើយ
នោះគេយកព្រះពស្ត្រទ្រង់ ចែកជា៤ចំណែក ឱ្យម្នាក់ៗបាន
១ចំណែក ក៏យកអាវវែងទ្រង់ដែរ តែអាវនោះបានត្បាញ
ពីលើជាសំពត់តែ១ គ្មានថ្នេរសោះ ២៤ដូច្នេះ គេនិយាយ
គ្នាថា កុំហែកអាវនេះឡើយ ចូរយើងចាប់ឆ្នោតវិញ ឱ្យ

**១៩:១៧** យ លក លប ២២:៦ លក ១៤:២៧,២៣,២៦ ២៣:៣៣
វ យហ ៥:២
**១៩:១៨** ល លក ២៣:៣២
**១៩:១៩** វ មក ១:២៤ ស ខ.១៤,២១
**១៩:២០** ហ ហព ១៣:១២
**១៩:២១** ឡ ខ.១៤
**១៩:២៤** អ ខ.២៨, ៣៦,៣៧ មថ ១:២២ ក ទដ ២២:១៨
**១៩:២៥** ខ មថ ១២:៤៦
គ លក ២៤:១៨
ឃ មថ ២៧:៥៥,៥៦
**១៩:២៦** ង មថ ១២:៤៦
ច យហ ១៣:២៣
**១៩:២៨** ឆ ខ.៣០ យហ ១៣:១
ជ ខ.២៤,៣៦,៣៧ មថ ១:២២

បានដឹងជាអាវនេះនឹងទៅជារបស់រូបអ្នកណា នោះដើម្បី
ឱ្យបានសំរេច[អ]បទគម្ពីរដែលថា «គេបានយកសំលៀកបំ
ពាក់ទូលបង្គំចែកគ្នា ឯអាវវែងរបស់ទូលបង្គំ គេយកដោយ
ចាប់ជាឆ្នោត»[ក] ពួកទាហាន ក៏ធ្វើដូច្នោះ ។
២៥ឯមាតាព្រះយេស៊ូវ ប្អូនស្រីមាតាទ្រង់[ខ] ម៉ារា ជាប្រ
ពន្ធក្លូប៉ាស និងម៉ារាជាអ្នកស្រុកម៉ាក់ដាឡា[គ] គេឈរនៅ
ជិតឈើឆ្កាងទ្រង់[ឃ] ២៦ព្រះយេស៊ូវក៏ឃើញមាតាទ្រង់[ង] នឹង
សិស្សម្នាក់ដែលទ្រង់ស្រឡាញ់[ច] កំពុងឈរនៅទីនោះ រួច
ទ្រង់មានបន្ទូលទៅមាតាថា មាតាអើយ នុ៎ះន៏ កូនរបស់
មាតា ២៧រួចទ្រង់មានបន្ទូលទៅសិស្សនោះថា នុ៎ះន៎ ម្ដាយ
អ្នក តាំងពីនោះមក សិស្សនោះក៏នាំយកគាត់ទៅនៅផ្ទះខ្លួន។

## ការសុគតរបស់ព្រះយេស៊ូវ

១៩:២៩,៣០–មថ ២៧:៤៨,៥០ មក ១៥:៣៦,៣៧ លក ២៣:៣៦

២៨ក្រោយនោះព្រះយេស៊ូវទ្រង់ជ្រាបថា ការទាំងអស់
បានសំរេចហើយ[ឆ] តែដើម្បីឱ្យបានសំរេចតាមបទគម្ពីរ[ជ]
នោះទ្រង់មានបន្ទូលថា ខ្ញុំស្រេកទឹកណាស់ ២៩[ឈ]រីឯនៅទី

លោកស៊ីម៉ូន ជាអ្នកស្រុកគីរេនឱ្យលីឈើឆ្កាងព្រះយេស៊ូវ (មក១៥:២១និង ការពន្យល់) ប្រហែលមកពីទ្រង់ខ្សោយកម្លាំង ដោយសារការវាយដំរបស់ពួករ៉ូម៉ាំង ។ *គាល់កូថា* ពាក្យនេះនៅក្នុងភាសាឡាតាំងគឺ "កាល់វ៉ារី" (Calvaria) ដែលមានន័យដូចគ្នានឹងពាក្យថា "គាល់កូថា" នេះដែរ (មើលការពន្យល់មក១៥:២២)។

**១៩:១៨** *ឆ្កាងទ្រង់នៅទីនោះ* "មើលការពន្យល់ មក ១៥:២៤"។ ការឆ្កាងគឺជាទម្រង់នៃការកាត់ទោសប្រហារជីវិតរបស់ពួករ៉ូម៉ាំង ។ អ្នកទោសត្រូវគេបង្ខំឱ្យលីឈើឆ្កាង តាមផ្លូវទៅកាន់កន្លែងប្រហារជីវិត ដើម្បីទុកជាការព្រមានដល់បណ្ដាជន ។ មានប្រភេទឈើឆ្កាង និងវិធីឆ្កាងជាច្រើនយ៉ាង ។ គេបានឆ្កាងព្រះយេស៊ូវ ដោយដំដែកគោលភ្ជាប់នឹងឈើឆ្កាង ។ អ្នកទោសខ្លះទៀតត្រូវគេឆ្កាង ដោយយកខ្សែចងភ្ជាប់នឹងឈើឆ្កាង ។ អ្នកទោសត្រូវថប់ដង្ហើមស្លាប់នៅលើឈើឆ្កាង ព្រោះទម្ងន់ខ្លួនរបស់ពួកគេ ធ្វើឱ្យពួកគេពិបាកដកដង្ហើម ហើយអស់កម្លាំងយ៉ាងខ្លាំង ។ ការស្លាប់នៅលើឈើឆ្កាងមានដំណើរយឺតៗ និងឈឺចាប់យ៉ាងខ្លាំងបំផុត ។

**១៩:១៩** *ប្រកាស១បិទនៅលើឈើឆ្កាង* គឺជាប្រកាសអំពីបទឧក្រិដ្ឋរបស់អ្នកទោស ។ *ស្ដេចនៃសាសន៍យូដា* ទោះជាគេបានសរសេរនៅក្នុងគោលបំណងអ្វីក៏ដោយ ក៏សេចក្ដីពិតគឺព្រះយេស៊ូវទ្រង់ពិតជាស្ដេចនៃសាសន៍យូដា ហើយក៏ជាស្ដេចលើគ្រប់សាសន៍ទាំងអស់ផងដែរ ។

**១៩:២០** *ភាសាហេព្រើរ* គឺជាភាសាសម្រាប់ពួកសាសន៍យូដាដែលរស់នៅក្នុងស្រុកយូដា ។ *ក្រិក* ជាភាសាដែលគេប្រើជាទូទៅនៅក្នុងចក្រភពរ៉ូម៉ាំងទាំងមូល។ *ឡាតាំង* ជាភាសាផ្លូវការរបស់ចក្រភពរ៉ូម៉ាំង ។

**១៩:២២** លោកពីឡាត់មានហេតុផលគ្រប់គ្រាន់ នៅក្នុងការឆ្កាងនេះ ហើយការដែលគាត់និយាយនៅក្នុងខនេះ មិនមែនមានន័យថា គាត់កំពុងតែសើចចំអកឱ្យពួកសាសន៍យូដាទាំងនោះឡើយ ។

**១៩:២៣** តាមប្រពៃណី សំលៀកបំពាក់របស់អ្នកទោស ត្រូវបានជាកម្មសិទ្ធរបស់ពួកទាហានរ៉ូម៉ាំង ដែលទទួលខុសត្រូវលើការឆ្កាងអ្នកទោសនោះ ។ ពួកទាហានទាំងនោះ បានយកអាវវែងព្រះយេស៊ូវចែកគ្នា ដោយការចាប់ឆ្នោត ដើម្បីឱ្យដឹងថា អ្នកណាបានអាវវែងនោះ (គឺអាវវែងគ្មានថ្នេរ ដែលមានតម្លៃខ្ពស់)។ ការនេះធ្វើឱ្យសេចក្ដីទំនាយនៅក្នុង "ទដ ២២:១៨" បានសម្រេច ។

**១៩:២៤** "មើលការពន្យល់ ទដ ២២ និង ២២:១៧,២០–២១"។

**១៩:២៥** *ក្លូប៉ាស* ឈ្មោះរបស់គាត់មាននិយាយតែនៅក្នុងខនេះប៉ុណ្ណោះ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ *ម៉ារាជាអ្នកស្រុកម៉ាក់ដាឡា* ឈ្មោះនេះឃើញមាននៅគ្រប់ព្រះគម្ពីរដំណឹងល្អទាំង៤ ក្នុងវគ្គឆ្កាងព្រះយេស៊ូវ និងវគ្គព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ និងមាននៅក្នុង "លក ៨:២–៣" ប៉ុណ្ណោះ (ការពន្យល់ ៨:២)។

**៩:២៦** *សិស្សម្នាក់ដែលទ្រង់ស្រឡាញ់* គឺសាវ័កយ៉ូហានដែលជាអ្នកនិពន្ធព្រះគម្ពីរដំណឹងល្អនេះ (ការពន្យល់ ១៣:២៣)។ *មាតាអើយ* "មើលការពន្យល់ ២:៤"។

**១៩:២៧** *នាំយកគាត់ទៅនៅផ្ទះខ្លួន* ដូចនេះសាវ័កយ៉ូហានមានការទទួលខុសត្រូវលើជីវភាពរបស់នាងម៉ារា ។ ប្រហែលជានៅពេលនោះ លោកយ៉ូសែបជាប្ដីរបស់នាងម៉ារា បានស្លាប់បាត់ហើយ ។ ព្រះយេស៊ូវទ្រង់មិនបានប្រគល់កិច្ចការថែរក្សានេះទៅពួកប្អូនរបស់ទ្រង់ទេ ពីព្រោះទ្រង់ជាបុត្រច្បងនៅក្នុងគ្រួសារ ដូច្នេះបានជាទ្រង់ផ្ទុកផ្ដាក់មាតាទ្រង់ ជាមួយនឹងលោកយ៉ូហាន ព្រោះនៅពេលនោះ គាត់ក៏នៅកន្លែងឆ្កាងជាមួយនឹងទ្រង់ដែរ ។

**១៩:២៨** *ខ្ញុំស្រេកទឹកណាស់* ត្រង់ចំណុចនេះ អាចឆ្លើយតបទៅនឹងសេចក្ដី

នោះ មានក្រឡដាក់ទឹកខ្មេះ[ឈ] ពេញ គេក៏យកសារាយរំហួត
ជ្រលក់ទឹកខ្មេះជោគ រួចចងភ្ជាប់នឹងមែកហីសុប ហុចទៅ
ដល់ព្រះឱស្ឋទ្រង់ ៣០កាលព្រះយេស៊ូវបានទទួលទឹកខ្មេះរួច
ហើយ ក៏មានបន្ទូលថា ការស្រេចហើយ[ញ] នោះទ្រង់ឱន
ព្រះសិរប្រគល់វិញ្ញាណទ្រង់ទៅ ។
៣១ពួកសាសន៍យូដា ក៏សូមលោកពីឡាត់ ឱ្យបានបំបាក់
ជើងពួកជាប់ឆ្កាង ហើយយកចេញទៅ ដើម្បីកុំឱ្យខ្មោចនៅ
ជាប់លើឈើឆ្កាង[ដ] ក្នុងថ្ងៃឈប់សំរាក ពីព្រោះជាថ្ងៃរៀប
ចំហើយ[ឋ] ឯថ្ងៃឈប់សំរាកនោះ គឺជាថ្ងៃបុណ្យធំ ៣២ដូច្នេះ
ពួកទាហានក៏មកបំបាក់ជើងអ្នក១ រួចអ្នក១ទៀត[ឌ] ដែលជាប់
ឆ្កាងជាមួយនឹងទ្រង់ ៣៣តែកាលគេមកដល់ព្រះយេស៊ូវ ក៏
ឃើញថា ទ្រង់សុគតផុតហើយ បានជាគេមិនបំបាក់ព្រះបាទ
ទ្រង់ទេ ៣៤ប៉ុន្តែទាហានម្នាក់យកលំពែងចាក់[ឍ] ត្រង់ចំហៀង
ទ្រង់ នោះក៏ចេញឈាម ហើយនិងទឹកមក[ណ] ៣៥អ្នកដែល
ឃើញ[ត] បានធ្វើបន្ទាល់ ហើយសេចក្ដីបន្ទាល់របស់អ្នកនោះ
ក៏ពិតប្រាកដ[ថ] អ្នកនោះដឹងថាខ្លួននិយាយត្រូវ ដើម្បីឱ្យអ្នក
រាល់គ្នាបានជឿ ៣៦ដ្បិតការទាំងនោះបានកើតមក ដើម្បីឱ្យ
បទគម្ពីរបានសំរេច[ទ] ដែលថា «គ្មានឆ្អឹងទ្រង់ណាមួយត្រូវ
បាក់សោះ» [ធ] ៣៧ក៏មានបទ១ទៀតថា «គេនឹងមើលព្រះអង្គ
ដែលគេបានចាក់» [ន]។

## ការបញ្ចុះព្រះសពព្រះយេស៊ូវ

*១៩:៣៨–៤២ – មថ ២៧:៥៧–៦១ មក ១៥:៤២–៤៧ លក ២៣:៥០–៥៦*

៣៨ក្រោយនោះមក យ៉ូសែប ជាអ្នកស្រុកអើរីម៉ាថេ
ដែលជាសិស្សរបស់ព្រះយេស៊ូវដោយសំងាត់ ព្រោះខ្លាច
ពួកយូដា[ប] លោកបានសូមដល់លោកពីឡាត់ ឱ្យមានច្បាប់
នឹងយកព្រះសពព្រះយេស៊ូវចុះមក លោកពីឡាត់ក៏បើកឱ្យ
ដូច្នេះ លោកមកយកព្រះសពព្រះយេស៊ូវទៅ ៣៩ហើយ
លោកនីកូដេម[ផ] ដែលពីមុន បានទៅឯព្រះយេស៊ូវទាំងយប់
ក៏មកដែរ លោកយកជ័រល្វីងទេស លាយនឹងក្រឹស្នា បាន
ប្រហែលជា១រយនាលិមក ៤០លោកទាំង២នោះ ក៏យក
ព្រះសពព្រះយេស៊ូវមក រុំនឹងសំពត់ទេសឯក[ព] ជាមួយនឹង
គ្រឿងក្រអូបទាំងនោះ តាមទំលាប់ របស់សាសន៍យូដា[ភ]
ដែលគេធ្លាប់រៀបចំកប់ខ្មោច ៤១មានច្បារ១នៅត្រង់កន្លែង

**១៩:២៩** ឈ ទដ ៦៩:២១ **១៩:៣០** ញ លក ១២:៥០ យហ ៤:៣៤ ១៧:៤ **១៩:៣១** ដ ចទ ២១:២៣ យស ៨:២៩ ១០:២៦,២៧ ឋ ខ.១៤,៤២ **១៩:៣២** ឌ ខ.១៨ **១៩:៣៤** ឍ សក ១២:១០ វវ ១:៧ ណ ១យហ ៥:៦,៨ **១៩:៣៥** ត លក ២៤:៤៨ ថ យហ ១៥:២៧ ២១:២៤ **១៩:៣៦** ទ ខ.២៤,២៨,៣៧ មថ ១:២២ ធ នក ១២:៤៦ ជន ៩:១២ ទដ ៣៤:២០ **១៩:៣៧** ន សក ១២:១០ វវ ១:៧

**១៩:៣៨** ប យហ ៧:១៣ **១៩:៣៩** ផ យហ ៣:១ ៧:៥០ **១៩:៤០** ព លក ២៤:១២ យហ ១១:៤៤ ២០:៥,៧ ភ មថ ២៦:១២

ដែលមានចែងទុកនៅក្នុង "ទដ ៦៩:២១ (មើលពន្យល់)" (ប្រៀបធៀប ទដ ២២:១៥) ។

**១៩:២៩** *ទឹកខ្មេះ* គឺស្មើនឹងស្រាថោកៗ របស់មនុស្សធម្មតា (មើលការពន្យល់ មក ១៥:៣៦ លក ២៣:៣៦) ។

**១៩:៣០** *ការស្រេចហើយ* ត្រង់ចំណុចនេះបញ្ជាក់ថា ការសុគតរបស់ព្រះយេស៊ូវ គឺទ្រង់មានជ័យជម្នះ ព្រោះទ្រង់បានបញ្ចប់ព្រះរាជកិច្ច ដែលទ្រង់ត្រូវយាងមកបំពេញ (១៧:៤) ។ *ប្រគល់ព្រះវិញ្ញាណទ្រង់ទៅ* ឃ្លានេះបញ្ជាក់អំពីរបៀបដែលព្រះយេស៊ូវទ្រង់សុគត (មើលពន្យល់ មថ ២៧:៥០ មក ១៥:៣៧ ១០:១៧–១៨) ។

**១៩:៣១** *រៀបចំ* "មើលការពន្យល់ ខ.១៤"។ *ជាថ្ងៃបុណ្យធំ* សំដៅលើថ្ងៃឈប់សម្រាកដែលស្ថិតនៅក្នុងថ្ងៃបុណ្យរំលង ។ គេពិសាអាហារបុណ្យរំលងនៅល្ងាចថ្ងៃព្រហស្បតិ៍ ។ ថ្ងៃរៀបចំសម្រាប់បុណ្យរំលងគឺថ្ងៃសុក្រ ហើយថ្ងៃឈប់សម្រាក គឺនៅថ្ងៃសៅរ៍ ។ *ពួកសាសន៍យូដា* "មើលការពន្យល់ ១:១៩" *បំបាក់ជើងពួកជាប់ឆ្កាង* ការធ្វើយ៉ាងដូច្នេះ គឺដើម្បីឱ្យអ្នកទោសដែលជាប់ឆ្កាងនោះឆាប់ស្លាប់ ដោយព្រោះមិនអាចទ្រទម្ងន់ខ្លួនបាន និងពិបាកដកដង្ហើម ។

**១៩:៣៤** *យកលំពែងចាក់ត្រង់ចំហៀងទ្រង់* ការដែលពួកគេធ្វើចំពោះទ្រង់យ៉ាងដូច្នេះ គឺជាអំពើមួយដ៏យង់ឃ្នង និងដើម្បីឱ្យដឹងច្បាស់ថា ទ្រង់ពិតជាសុគតមែន (ខ.៣៧ អស ៥៣:៥ សក ១២:១០ ប្រៀបធៀបនឹង ទដ ២២:១៦) *ឈាម ហើយនិងទឹកមក* ដោយសារលំពែងបានចាក់ទម្លុះសន្ទះទ្រូង រហូតដល់បេះដូងទ្រង់ ។

**១៩:៣៥** *អ្នកដែលឃើញ* គឺសំដៅលើលោកយ៉ូហាន ឬអ្នកដែលបានឃើញការសុគតរបស់ព្រះយេស៊ូវ និងធ្វើបន្ទាល់ពីទ្រង់ ។ *ធ្វើបន្ទាល់ . . . បានជឿ* "មើលការពន្យល់ ១:៧"។

**១៩:៣៦,៣៧** ព្រះយេស៊ូវទ្រង់សុគត ដូចជាកូនចៀម ដែលគេសម្លាប់នៅក្នុងបុណ្យរំលងដូច្នោះដែរ ។ កូនចៀមដែលត្រូវបូជា មិនមានបាក់ឆ្អឹងណាមួយឡើយ (នក ១២:៤៦ ជន ៩:១២) ។ ព្រះយេស៊ូវ គឺជាកូនចៀមនៃព្រះ និងជាយញ្ញបូជាដ៏គ្រប់លក្ខណ៍សម្រាប់លោះបាបមនុស្សលោក (១កថ ៥:៧) ។

**១៩:៣៨** "មើលការពន្យល់ លក ២៣:៥២"។ *យ៉ូសែប* ជាសិស្សរបស់ព្រះយេស៊ូវ និងជាអ្នកមានទ្រព្យសម្បត្តិម្នាក់ (មថ ២៧:៥៧) ។ គាត់ជាសមាជិកម្នាក់របស់ពួកក្រុមជំនុំ ប៉ុន្តែ គាត់មិនបានយល់ស្របនឹងការថ្កោលទោសព្រះយេស៊ូវទេ (លក ២៣:៥១ មើលការពន្យល់ ២៣:៥០) ។ *អ្នកស្រុកអើរីម៉ាថេ* "មើលការពន្យល់ មថ ២៧:៥៧"។ *ដោយសំងាត់* ព្រោះគាត់មានការលំបាកក្នុងការគាំទ្រព្រះរាជកិច្ច ព្រះយេស៊ូវដោយចំហ ។ ពួកសិស្សដែលស្និទ្ធស្នាលនឹងព្រះយេស៊ូវបានរត់ចោលទ្រង់ (មក ១៤:៥០ និងការពន្យល់) ដូច្នេះ ការបញ្ចុះព្រះសពព្រះយេស៊ូវត្រូវធ្លាក់ ទៅលើលោកយ៉ូសែប និងលោកនីកូដេមវិញ ។ *លោកពីឡាត់ក៏បើកឱ្យ* ញាតិមិត្តរបស់អ្នកទោសជាប់ឆ្កាង អាចយកសពអ្នកទោសនោះ ទៅបញ្ចុះក្នុងផ្នូរបានកាលណាមានការអនុញ្ញាត ។

**១៩:៣៩** *លោកនីកូដេម* មានតែក្នុងព្រះគម្ពីរយ៉ូហានប៉ុណ្ណោះ ដែលបញ្ជាក់ថា លោកនីកូដេមបានចូលរួមជាមួយនឹងលោកយ៉ូសែប នៅក្នុងការបញ្ចុះព្រះសពព្រះយេស៊ូវ ។ *ប្រហែលជា១រយនាលិ* គឺជាបរិមាណដ៏ច្រើន (ប្រៀបធៀបនឹង ២កថ ១៦:១៤) ។

**១៩:៤០** *សំពត់ទេសឯក* គឺក្រណាត់សំពត់ស្ដើងដូចបង់រុំរបួសដែរ ។ ម្យ៉ាងទៀត ក៏សំដៅលើសំពត់ធំៗសម្រាប់រុំសពផងដែរ ។

**១៩:៤១** *ផ្នូរថ្មី* គឺជាកម្មសិទ្ធិរបស់លោកយ៉ូសែប (មថ ២៧:៦០) ។

ដែលគេឆ្កាងទ្រង់ ហើយក្នុងច្បារនោះ មានផ្នូរ១ថ្មី ដែល
មិនទាន់ដាក់ខ្មោចណានៅឡើយ ៤២ដូច្នេះ លោកក៏បញ្ចុះ
ព្រះសពព្រះយេស៊ូវនៅទីនោះ ពីព្រោះជាថ្ងៃរៀបចំបុណ្យ[ម]
របស់សាសន៍យូដា ហើយផ្នូរនោះក៏នៅជិតស្រាប់[យ] ។

## ផ្នូរទទេ

*២០:១-៨ មថ ២៨:១-៨ មក ១៦:១-៨ លក ២៤:១-១០*

**២០** ១នៅថ្ងៃទី ១ ក្នុងអាទិត្យនោះ ម៉ារា ជាអ្នកស្រុក
ម៉ាក់ដាឡា[ង] នាងទៅឯផ្នូរពីព្រលឹម កាលកំពុងនៅងងឹត
នៅឡើយ ក៏ឃើញថ្មបានយកចេញពីមាត់ផ្នូរហើយ[ច] ២នោះ
នាងរត់ទៅប្រាប់ដល់ ស៊ីម៉ូន-ពេត្រុស នឹងសិស្ស១នោះ
ដែលទ្រង់ស្រឡាញ់[ឆ]ថា គេបានយកព្រះអម្ចាស់ចេញពីផ្នូរ
ហើយ យើងខ្ញុំមិនដឹងជាគេយកទៅទុកឯណាទេ[ជ] ។
៣នោះពេត្រុស នឹងសិស្ស១នោះ ក៏ចេញទៅឯផ្នូរ[ឈ]
៤អ្នកទាំង២រត់ទៅជាមួយគ្នា តែសិស្ស១នោះរត់លឿនជាង
ពេត្រុសបានដល់ផ្នូរមុន ៥រួចគាត់ឱនខ្លួនទៅមើល[ញ] ឃើញ
មានតែសំពត់ស្នប[ដ]នៅក្នុងនោះ តែគាត់មិនបានចូលទេ
៦ឯស៊ីម៉ូន-ពេត្រុស ដែលមកតាមក្រោយ គាត់ក៏ចូលទៅក្នុង
ផ្នូរ ឃើញសំពត់ស្នបនៅក្នុងនោះដែរ ៧ហើយឃើញកន្សែង
ដែលគ្របព្រះសិរទ្រង់[ឋ] មិននៅជាមួយនឹងសំពត់ស្នបនោះ
ទេ គឺបានបត់ដាក់នៅទីកន្លែងដោយខ្លួនវិញ ៨សិស្សមួយ
នោះដែលមកដល់ផ្នូរមុន[ឌ] គាត់ក៏ចូលទៅឃើញដូច្នោះដែរ
រួចគាត់ជឿ ៩ដ្បិតគេមិនទាន់យល់បទគម្ពីរ[ឍ]នៅឡើយដែល
ថា ទ្រង់ត្រូវរស់ពីស្លាប់ឡើងវិញ[ណ] ។

## ព្រះយេស៊ូវបង្ហាញព្រះអង្គទ្រង់ដល់នាងម៉ារា

១០សិស្សទាំង ២ ក៏ត្រឡប់ទៅឯផ្ទះគេវិញ ១១ឯម៉ារា
នាងឈរយំពីខាងក្រៅផ្នូរ ហើយកំពុងដែលនាងយំ នោះក៏
ឱនខ្លួនមើលទៅក្នុងផ្នូរ[ត] ១២ឃើញទេវតា២រូប ស្លៀកពាក់
ស[ថ] អង្គុយ១ខាងក្បាល ១ចុងជើង ត្រង់កន្លែងដែលបាន
ផ្ដេកព្រះសពព្រះយេស៊ូវ ១៣ទេវតានោះសួរថា នាងអើយ
ហេតុអ្វីបានជាយំ[ទ] នាងឆ្លើយថា ពីព្រោះគេបានយកព្រះ
អម្ចាស់ខ្ញុំទៅបាត់ ហើយខ្ញុំមិនដឹងជាគេទុកទ្រង់នៅឯណា
ទេ[ធ] ១៤នាងនិយាយដូច្នោះ រួចបែរខ្លួនទៅក្រោយ ឃើញ
ព្រះយេស៊ូវទ្រង់ឈរ[ន] តែមិនដឹងជាព្រះយេស៊ូវទេ[ប] ១៥ព្រះ
យេស៊ូវមានបន្ទូលថា នាងអើយហេតុអ្វីបានជាយំ[ផ] នាង
រកអ្នកណា ឯនាង ក៏ស្មានថាជាអ្នកថែច្បារ ទើបនិយាយ

**១៩:៤២** ម ខ.១៤,៣១ យ ខ.២០,៤១ **២០:១** ង ខ.១៨ លក ៨:២ យហ ១៩:២៥ ច មថ ២៧:៦០,៦៦ **២០:២** ឆ យហ ១៣:២៣ ជ ខ.១៣ **២០:៣** ឈ លក ២៤:១២ **២០:៥** ញ ខ.១១ ដ យហ ១៩:៤០ **២០:៧** ឋ យហ ១១:៤៤ **២០:៨** ឌ ខ.៤ **២០:៩** ឍ មថ ២២:២៩ យហ ២:២២ ណ លក ២៤:២៦,៤៦ កច ២:២៤ **២០:១១** ត ខ.៥ **២០:១២** ថ មថ ២៨:២,៣ មក ១៦:៥ លក ២៤:៤
កច ១:១០ ៥:១៩ ១០:៣០ **២០:១៣** ទ ខ.១៥ ធ ខ.២ **២០:១៤** ន មក ១៦:៩ ប លក ២៤:១៦ យហ ២១:៤ **២០:១៥** ផ ខ.១៣

**១៩:៤២** *ថ្ងៃរៀបចំបុណ្យ* "មើលការពន្យល់ ខ.១៤"។ កាលណាថ្ងៃបុណ្យឈប់សម្រាកបានចាប់ផ្ដើមហើយ នោះគ្មានការអ្វីដែលអាចធ្វើបានឡើយ ។

**២០:១** *ការកំពុងនៅងងឹតនៅឡើយ* ត្រង់ចំណុចនេះ ព្រះគម្ពីរម៉ាកុស-និយាយថា "កាលថ្ងៃទើបរះនៅឡើយ" (មក ១៦:២) ។ ពួកស្រីៗប្រហែលជាបានទៅឯផ្នូរនាពេលព្រលឹម ជាមួយនឹងនាងម៉ារាជាអ្នកស្រុកម៉ាក់ដាឡាដែរ ការដែលព្រះគម្ពីរទាំងពីរនិយាយពីពេលវេលាមិនដូចគ្នា ប្រហែលមកពីព្រះគម្ពីរយ៉ូហាន និយាយសំដៅលើពេលវេលាចាកចេញពីផ្ទះ រីឯព្រះគម្ពីរម៉ាកុសនិយាយសំដៅលើពេលវេលាទៅដល់ផ្នូរវិញ ។ *ម៉ារាជាអ្នកស្រុកម៉ាក់ដាឡា* "មើលការពន្យល់ ១៩:២៥ ប្រៀបធៀបនឹង មក ១៦:៩"។

**២០:២** *ស៊ីម៉ូន-ពេត្រុស* ទោះបីជាលោកពេត្រុសធ្លាប់បានបដិសេធព្រះយេស៊ូវក៏ដោយ ក៏គាត់នៅតែជាគំរូនាំមុខគេ ក្នុងចំនោមពួកសិស្សដដែល ។ *សិស្ស១នោះ ដែលទ្រង់ស្រឡាញ់* គឺសំដៅលើលោកយ៉ូហាន (មើលការពន្យល់ ១៣:២៣) ។ *យើងខ្ញុំ* ទោះបីជាលោកយ៉ូហានមិនបានប្រាប់ពីឈ្មោះរបស់ពួកគេក៏ដោយ ក៏ការប្រើសព្វនាមថា "យើងខ្ញុំ" នេះ បញ្ជាក់ថា មានអ្នកដទៃទៀតនៅជាមួយនឹងនាងម៉ារាផងដែរ (មថ ២៨:១ មក ១៦:១ លក ២៤:១០) ។ *គេយកទៅទុកឯណា* ឃ្លានេះបញ្ជាក់ថា នាងម៉ារា មិនបានគិតទៅដល់ការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូវទេ ។

**២០:៧** *បានបត់ដាក់* ចំណុចនេះបញ្ជាក់អំពីការរៀបចំយ៉ាងមានសណ្ដាប់ធ្នាប់ គឺមិនមែនគ្មានសណ្ដាប់ធ្នាប់ ដោយសារត្រូវចោរលួចឡើយ ។

**២០:៨** *ឃើញដូច្នោះដែរ រួចគាត់ជឿ* "ប្រៀបធៀប ខ.២៩"។ លោកយ៉ូហានមិនបានបញ្ជាក់ថា សិស្សម្នាក់នោះបានជឿ ដោយព្រោះបានឃើញការអ្វីនោះទេ គ្រាន់តែប្រាប់ថា គាត់ប្រាកដជាជឿថា ព្រះយេស៊ូវគ្រីស្ទពិតជាមានព្រះជន្មរស់ឡើងវិញ ។

**២០:៩** ក្នុងបទគម្ពីរ ទដ ១៦:១០ និង អស ៥៣:១០ ហើយនិងបទគម្ពីរជាច្រើនទៀត បានចែងទុករួចជាស្រេច អំពីការមានព្រះជន្មរស់ពីសុគតឡើងវិញរបស់ព្រះគ្រីស្ទ ហើយទ្រង់ផ្ទាល់ក៏មានបន្ទូលយ៉ាងច្បាស់អំពីការនេះដែរ ប៉ុន្តែ ពួកសិស្សរបស់ទ្រង់ នៅតែមិនយល់ពីអត្ថន័យនៃបទទំនាយទាំងនេះដដែល ដរាបដល់ព្រឹត្តិការណ៍ទាំងអស់នោះបានកើតឡើង ទើបពួកគេបានយល់ច្បាស់ ។ រីឯពួកសាសន៍យូដាវិញ នៅតែយកសេចក្ដីទាំងនេះធ្វើជាលេស ដើម្បីចោទប្រកាន់ថា ការមានព្រះជន្មរស់ ពីសុគតឡើងវិញរបស់ព្រះគ្រីស្ទ គឺជារឿងប្រឌិតទៅវិញ ។

**២០:១១** *ម៉ារា* ព្រះយេស៊ូវប្រហែលជាបានបង្ហាញព្រះអង្គទ្រង់ឱ្យនាងម៉ារាឃើញមុនគេ ។ *យំ* គឺនាងបានទ្រហោយំយ៉ាងខ្លាំង ដែលបង្ហាញពីទុក្ខសោកជាពន់ពេក (មើលការពន្យល់ ១១:៣៣) ។

**២០:១២** *ទេវតា២រូប* ត្រង់ចំណុចនេះ ព្រះគម្ពីរម៉ាថាយសរសេរថា មានទេវតាតែម្នាក់ (មថ ២៨:២) ព្រះគម្ពីរម៉ាកុសនិយាយថា អ្នកកំលោះម្នាក់ (មក ១៦:៥) ព្រះគម្ពីរលូកានិយាយថា មាន២នាក់ ដែលជាទេវតា (លក ២៤:៤,២៣ មើលការពន្យល់ លក ២៤:៤) ។ ការដែលលោកម៉ាថាយ និងលោកម៉ាកុសសរសេរថា មានទេវតាតែម្នាក់ បញ្ជាក់ថា ពួកគាត់បានកត់សម្គាល់តែតួអង្គដែលនិយាយទៅកាន់នាងម៉ារាប៉ុណ្ណោះ រីឯទេវតាម្នាក់ទៀត ពួកគាត់មិនបានរាប់បញ្ចូលទេ ។

**២០:១៣** *ស្ត្រី* "ខ.១៥ មើលការពន្យល់ ២:៤"។

**២០:១៤** *មិនដឹងជាព្រះយេស៊ូវទេ* បញ្ជាក់ថា មានពេលជាច្រើនដង ដែលគេមើលព្រះយេស៊ូវមិនស្គាល់ បន្ទាប់ពីទ្រង់មានព្រះជន្មរស់ពីសុគតឡើងវិញ

ទៅថា លោកនាយអើយ បើលោកបានយកព្រះសពចេញ
ទៅឯណា នោះសូមប្រាប់ខ្ញុំ ឱ្យដឹងកន្លែងដែលបានទុកផង
ខ្ញុំនឹងទៅនាំយកទៅ ១៦ព្រះយេស៊ូវមានបន្ទូលទៅនាងថា
ម៉ារាអើយ នោះនាងបែរខ្លួនទៅទូលទ្រង់ ជាភាសា
ហេព្រើរថា[ព] រ៉ាបូនី[ភ] ដែលស្រាយថា លោកគ្រូអើយ
១៧ព្រះយេស៊ូវមានបន្ទូលទៅនាងថា កុំពាល់ខ្ញុំ ព្រោះខ្ញុំមិន
ទាន់ឡើងទៅឯព្រះវរបិតាខ្ញុំនៅឡើយ ចូរនាងទៅឯពួក
បងប្អូន[ម]ខ្ញុំប្រាប់គេថា ខ្ញុំឡើងទៅឯព្រះវរបិតាខ្ញុំ[យ] ជាព្រះ
វរបិតានៃអ្នករាល់គ្នា គឺជាព្រះនៃខ្ញុំហើយជាព្រះនៃអ្នក
រាល់គ្នាដែរ ១៨នោះម៉ារា-ម៉ាក់ដាឡា[រ]ក៏នាំដំណឹងទៅ
ប្រាប់ដល់ពួកសិស្ស[ល]ថា នាងបានឃើញព្រះអម្ចាស់ ហើយ
ទ្រង់បានមានបន្ទូលសេចក្ដីទាំងនេះមកនាង ។

## ព្រះយេស៊ូវបង្ហាញអង្គទ្រង់ដល់ពួកសិស្ស

១៩នៅថ្ងៃដំបូងក្នុងអាទិត្យនោះឯង លុះព្រលប់ហើយ
កាលទ្វារទាំងអស់ នៅកន្លែងដែលពួកសិស្សប្រជុំគ្នា បាន
បិទ ដោយព្រោះខ្លាចសាសន៍យូដា[វ] នោះព្រះយេស៊ូវ
ទ្រង់ យាងមកឈរនៅកណ្ដាលពួកសិស្ស មានបន្ទូល
ថា សូមឱ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខ[ស]ចុះ[ហ]
២០កាលទ្រង់មានបន្ទូលដូច្នោះហើយ នោះក៏បង្ហាញព្រះ
ហស្ត និងចំហៀងទ្រង់ឱ្យគេមើល[ឡ] ដូច្នេះ ពួកសិស្សមានចិត្ត
ត្រេកអរ[អ] ដោយបានឃើញព្រះអម្ចាស់ ២១រួចព្រះយេស៊ូវ
មានបន្ទូលទៅគេម្ដងទៀតថា សូមឱ្យអ្នករាល់គ្នាបានប្រកប
ដោយសេចក្ដីសុខសាន្ត[ក] ខ្ញុំចាត់អ្នករាល់គ្នាឱ្យទៅ[ខ] ដូចជា
ព្រះវរបិតាបានចាត់ឱ្យខ្ញុំមកដែរ[គ] ២២ទ្រង់មានបន្ទូលដូច្នោះ
រួចក៏ផ្លុំលើគេទាំងមានបន្ទូលថា ចូរទទួលព្រះវិញ្ញាណ
បរិសុទ្ធចុះ[ឃ] ២៣បើអ្នករាល់គ្នានឹងអត់ទោសបាបដល់អ្នក
ណា នោះបាបគេនឹងបានអត់ទោសឱ្យ តែបើអ្នករាល់គ្នា
នឹងប្រកាន់ទោសបាបចំពោះអ្នកណា នោះបាបគេនឹងត្រូវ
ប្រកាន់ជាប់វិញ[ង]។

## ព្រះយេស៊ូវបង្ហាញអង្គទ្រង់ដល់ថូម៉ាស

២៤រីឯថូម៉ាស[ច] ជាម្នាក់ក្នុងពួក១២ ដែលគេហៅថាឌីឌីម
គាត់មិននៅជាមួយ ក្នុងកាលដែលព្រះយេស៊ូវយាងមកនោះ

**២០:១៦** ព យហ ៥:២ ភ មថ ២៣:៧ **២០:១៧** ម មថ ២៨:១០ យ យហ ៧:៣៣ **២០:១៨** រ ខ.១ ល លក ២៤:១០, ២២,២៣ **២០:១៩** វ យហ ៧:១៣ ស យហ ១៤:២៧ ហ ខ.២១,២៦ លក ២៤:៣៦–៣៩ **២០:២០** ឡ លក ២៤:៣៩,៤០ យហ ១៩:៣៤ អ យហ ១៦:២០,២២ **២០:២១** ក ខ.១៩ ខ មថ ២៨:១៩ យហ ១៧:១៨ គ យហ ៣:១៧ **២០:២២** ឃ យហ ៧:៣៩ កច ២:៣៨ ៨:១៥–១៧ ១៩:២ កទ ៣:២ **២០:២៣** ង មថ ១៦:១៩ ១៨:១៨ **២០:២៤** ច យហ ១១:១៦

(២១:៤ មថ ២៨:១៧ លក ២៤:១៦,៣៧ មើលការពន្យល់ លក ២៤:១៦)។

**២០:១៦** *ម៉ារា* (ប្រៀបធៀបនឹង ១០:៣-៤)។ *រ៉ាបូនី* ពួកសាសន៍យូដាពីសម័យដើមប្រើពាក្យនេះ ក្នុងការស្រែកអំពាវនាវទៅរកព្រះជាម្ចាស់ និងនៅក្នុងការនិយាយទៅកាន់ពួកគ្រូបង្រៀនក្រឹត្យវិន័យរបស់ពួកគេ ។

**២០:១៧** *ខ្ញុំឡើងទៅឯព្រះវរបិតាខ្ញុំ* "មើលការពន្យល់ ១៣:៣"។ នាងម៉ារាមិនចង់ឱ្យព្រះយេស៊ូវយាងចោលពួកនាងទេ ។ នាងពុំទាន់បានយល់ពីការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់នៅឡើយទេ (យហ ១៤:៣)។ ប្រសិនបើទ្រង់មិនយាងទៅឯនគរស្ថានសួគ៌វិញទេ នោះព្រះវិញ្ញាណបរិសុទ្ធនឹងមិនយាងមកឡើយ ។ *ពួកបងប្អូនខ្ញុំ* សំដៅលើពួកសិស្សរបស់ព្រះយេស៊ូវ (ខ.១៨ មក ៣:៣៥ ៧:៤,៥ កច ១:១៤ និងការពន្យល់)។ *ព្រះវរបិតាខ្ញុំជាព្រះវរបិតានៃអ្នករាល់គ្នា* ត្រង់ចំណុចនេះ បញ្ជាក់ថា ព្រះវរបិតាដែលគង់នៅឯស្ថានសួគ៌គឺជាព្រះវរបិតានៃអ្នកជឿដល់ ព្រះនាមព្រះយេស៊ូវគ្រីស្ទគ្រប់ៗគ្នា (១:១២,១៤,១៨,៣៤ ៣:១៦ និងការពន្យល់)។

**២០:១៨** ពេលដែលនាងម៉ារាបានជួបព្រះយេស៊ូវភ្លាម នោះនាងមើលមិនស្គាល់ទ្រង់ទេ ព្រោះភាពសោកសង្រេងរបស់នាងបានធ្វើឱ្យភ្នែកនាងងងឹត។ ម្យ៉ាងទៀត នាងមិនបានរំពឹងគិតថា នឹងបានឃើញទ្រង់ទៀតទេ ។ ប៉ុន្តែ នៅពេលដែលទ្រង់ហៅឈ្មោះនាង នោះក៏ធ្វើឱ្យនាងចំណាំទ្រង់បានភ្លាម ។ ការនេះបង្ហាញថា នៅពេលដែលព្រះសង្គ្រោះរបស់នាង ហៅឈ្មោះនាងនោះសេចក្ដីស្រលាញ់ក៏បានពោរពេញនៅក្នុងចិត្តរបស់នាង ។

**២០:១៩** "មើលការពន្យល់ លក ២៤:៣៦"។ *ពួកសិស្ស* គឺពួកសិស្សទាំង ១២នាក់ និងពួកសិស្សដទៃទៀត(ខ.២៤)។ *សាសន៍យូដា* "មើលការពន្យល់ ១:១៩"។ *សូមឱ្យអ្នករាល់គ្នាប្រកបដោយសេចក្ដីសុខចុះ* ពួកយូដាប្រើពាក្យនេះនៅក្នុងការគួរសម ឬនៅក្នុងការស្វាគមន៍គ្នាទៅវិញទៅមក (ប្រៀបធៀប ដយ ១០:១៩)។ ពួកសិស្សរបស់ព្រះយេស៊ូវ ប្រហែលជានឹកស្មានថាទ្រង់នឹងស្ដីបន្ទោសឱ្យពួកគេ ចំពោះអាកប្បកិរិយារបស់ពួកគេ កាលពីថ្ងៃសុក្រនោះហើយ ប៉ុន្តែ ទ្រង់មិនបានធ្វើឱ្យពួកគេភ័យបារម្ភទេ (មើលការពន្យល់ ១៤:២៧)។

**២០:២០** *ព្រះហស្ត និងចំហៀងទ្រង់* គឺកន្លែងដែលត្រូវរបួស (ព្រះគម្ពីរយ៉ូហានមិនបាននិយាយអំពីរបួស នៅត្រង់ព្រះបាទព្រះយេស៊ូវទេ)។ យោងតាមបទគម្ពីរ "លក ២៤:៣៧" នៅពេលដែលព្រះយេស៊ូវបានបង្ហាញព្រះអង្គទ្រង់នៅកណ្ដាល ចំណោមពួកសិស្សរបស់ទ្រង់ នោះពួកគេបែជាស្មានថាខ្មោចលងទៅវិញ ។ ទោះជាយ៉ាងណា ក៏ទ្រង់បានបង្ហាញព្រះអង្គទ្រង់ឱ្យពួកគេមើលឃើញយ៉ាងច្បាស់ ដោយឥតសង្ស័យឡើយ ។

**២០:២១** *សូមឱ្យអ្នករាល់គ្នាបានប្រកប ដោយសេចក្ដីសុខសាន្ត* "មើលការពន្យល់ ខ.១៩"។ *ខ្ញុំចាត់អ្នករាល់គ្នាឱ្យទៅ* "មើលការពន្យល់ ១៧:១៨"។

**២០:២២** *ចូរទទួលព្រះវិញ្ញាណបរិសុទ្ធចុះ* ក្នុងខនេះ ព្រះយេស៊ូវទ្រង់មានបន្ទូលឱ្យដឹងជាមុន អំពីការដែលនឹងកើតឡើងនៅថ្ងៃបុណ្យទី៥០ (មើលការពន្យល់ កច ២:២,៤,១៤,១៧,៣៣,៣៨)។ ពួកសិស្សរបស់ទ្រង់ទាំងអស់ ត្រូវការជំនួយមកអំពីទ្រង់ ដើម្បីបំពេញមហាបេសកកម្មដែលទ្រង់ប្រទានឱ្យពួកគេធ្វើ ។

**២០:២៣** *"បើអ្នករាល់គ្នានឹងអត់ទោសបាបដល់អ្នកណា នោះបាបគេនឹងបានអត់ទោសឱ្យ តែបើអ្នករាល់គ្នានឹងប្រកាន់ទោសបាបចំពោះអ្នកណា នោះបាបគេនឹងត្រូវប្រកាន់ជាប់វិញ"* ត្រង់ចំណុចនេះមិនមានន័យថា ការអត់ទោសបាបអាស្រ័យលើមនុស្សនោះទេ គឺអាស្រ័យលើព្រះយេស៊ូវគ្រីស្ទវិញ (ប្រៀបធៀប មថ ១៦:១៩ ១៨:១៨ និងការពន្យល់)។

**២០:២៤** *ថូម៉ាស* "មើលការពន្យល់ ១១:១៦"។

ទេ 25ដូច្នេះ ពួកសិស្សឯទៀតប្រាប់គាត់ថា យើងបាន
ឃើញព្រះអម្ចាស់ តែគាត់ឆ្លើយថា បើខ្ញុំមិនឃើញស្នាម
ដែកគោល នៅព្រះហស្តទ្រង់ ទាំងលូកម្រាមទៅក្នុងស្នាម
ដែកគោលនោះ ហើយលូកដៃខ្ញុំទៅក្នុងចំហៀងទ្រង់[ឆ] នោះ
ខ្ញុំមិនព្រមជឿទេ[ជ] 26ដល់៨ថ្ងៃក្រោយមក ពួកសិស្សទ្រង់នៅ
ក្នុងផ្ទះម្តងទៀត ហើយថូម៉ាសក៏នៅជាមួយដែរ នោះព្រះ
យេស៊ូវទ្រង់យាងមក ឈរកណ្តាលពួកគេ ទាំងទ្វារនៅបិទ
ហើយមានបន្ទូលថា សូមឱ្យអ្នករាល់គ្នាបានប្រកបដោយ
សេចក្តីសុខសាន្ត[ឈ ញ] 27រួចទ្រង់មានបន្ទូលទៅថូម៉ាសថា
ចូរលូកម្រាមដៃអ្នកមក ស្ទាបមើលដៃខ្ញុំឯណេះ ហើយលូក
ដៃមកក្នុងចំហៀងខ្ញុំផង កុំឱ្យមានចិត្តមិនជឿឡើយ ត្រូវឱ្យ
ជឿចុះ[ដ] 28នោះថូម៉ាសទូលឆ្លើយថា ឱព្រះអម្ចាស់ ទូលបង្គំ
ឱព្រះនៃទូលបង្គំអើយ 29ព្រះយេស៊ូវមានបន្ទូលទៅគាត់ថា
ថូម៉ាសអើយ អ្នកជឿដោយព្រោះបានឃើញ ខ្ញុំទេតើ[ឋ]
មានពរ ហើយ អ្នកណាដែលជឿឥតឃើញសោះ[ឌ]។

30ព្រះយេស៊ូវក៏ធ្វើទីសំគាល់ជាច្រើនទៀត[ឍ] នៅមុខ
ពួកសិស្សទ្រង់ ដែលមិនបានចែងទុកក្នុងសៀវភៅនេះទេ[ណ]
31បានចែងទុកតែប៉ុណ្ណោះ ដើម្បីឱ្យអ្នករាល់គ្នាបានជឿ[ត]ថា
ព្រះយេស៊ូវជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះពិត[ថ]
ហើយឱ្យអ្នករាល់គ្នាបានជីវិត ដោយសារព្រះនាមទ្រង់
ដោយមានសេចក្តីជំនឿ[ទ]។

**២០:២៥** ឆ ខ.២០ ជ មក ១៦:១១
**២០:២៦** ឈ យហ ១៤:២៧ ញ ខ.២១
**២០:២៧** ដ ខ.២៥ លក ២៤:៤០
**២០:២៩** ឋ យហ ៣:១៥ ឌ ១ពត ១:៨
**២០:៣០** ឍ យហ ២:១១ ណ យហ ២១:២៥
**២០:៣១** ត យហ ៣:១៥ ១៩:៣៥ ថ មថ ៤:៣ ទ មថ ២៥:៤៦
**២១:១** ធ ខ.១៤ យហ ២០:១៩,២៦ ន យហ ៦:១
**២១:២** ប យហ ១១:១៦ ផ យហ ១:៤៥ ព យហ ២:១ ភ មថ ៤:២១
**២១:៣** ម លក ៥:៥
**២១:៤** យ លក ២៤:១៦ យហ ២០:១៤
**២១:៦** រ លក ៥:៤-៧
**២១:៧** ល យហ ១៣:២៣

## ព្រះយេស៊ូវ និងការអស្ចារ្យ

**២១** 1ក្រោយនោះមក ព្រះយេស៊ូវទ្រង់សំដែងអង្គទ្រង់
ឱ្យពួកសិស្សឃើញម្តងទៀត[ធ] ត្រង់សមុទ្រទីបេរាស[ន] គឺទ្រង់
សំដែងមកបែបយ៉ាងនេះ 2មានស៊ីម៉ូន-ពេត្រុស ថូម៉ាស[ប]
ដែលហៅថា ឌីឌីម ណាថាណែល[ផ] ដែលនៅភូមិកាណា
ស្រុកកាលីឡេ[ព] កូនសេបេដេទាំង២[ភ] នឹងពួកសិស្ស២នាក់
ទៀតនៅជាមួយគ្នា 3នោះស៊ីម៉ូន-ពេត្រុសនិយាយទៅគេ ថា
ខ្ញុំទៅនេសាទត្រី គេក៏ឆ្លើយថា យើងទៅដែរ
ស្រាប់តែគេនាំគ្នាចេញទៅចុះទូក តែយប់នោះគេចាប់មិន
បានអ្វីសោះ[ម] 4ដល់ព្រលឹមឡើង ព្រះយេស៊ូវទ្រង់ឈរនៅ
ឆ្នេរសមុទ្រ តែពួកសិស្សមិនដឹងជាព្រះយេស៊ូវទេ[យ] 5ទ្រង់
មានបន្ទូលទៅគេថា កូនរាល់គ្នាអើយ តើមានអ្វី បរិភោគ
ឬទេ គេទូលឆ្លើយថា គ្មានទេ 6រួចទ្រង់មានបន្ទូលប្រាប់ថា
ចូរទំលាក់អួនទៅខាងស្តាំទូក នោះទើបបាន ដូច្នេះ
គេក៏ទំលាក់អួនទៅ តែទាញមកវិញមិនរួច ព្រោះជាប់ត្រី
សន្ធឹកណាស់[រ] 7នោះសិស្ស១ ដែលព្រះយេស៊ូវស្រឡាញ់[ល]
គាត់និយាយនឹងពេត្រុសថា នេះគឺជាព្រះអម្ចាស់ហើយកាល
ស៊ីម៉ូន-ពេត្រុសបានឮថាជាព្រះអម្ចាស់ នោះគាត់ពាក់អាវ
ក្រវាត់ខ្លួន ព្រោះគាត់នៅខ្លួនទទេ ក៏លោតចុះទៅក្នុងទឹក
8ពួក សិស្សឯទៀតបានមកក្នុងទូកតូចទាំងដឹកអួនជាប់បានត្រី
ដ្បិតគេមិនសូវនៅឆ្ងាយពីគោកទេ ប្រហែលជា ២០០ហត្ថ

**២០:២៥** *បើខ្ញុំមិនឃើញ . . . ទាំងលូកម្រាម . . . ខ្ញុំមិនជឿទ្រង់ទេ* ការនិយាយយ៉ាងដូច្នេះ បានបង្ហាញឱ្យឃើញអំពីការមិនព្រមជឿ និងមានចិត្តមានះយ៉ាងខ្លាំង (មើលការពន្យល់ មក ១៦:១៤)។

**២០:២៦** *សេចក្តីសុខសាន្ត* (ខ.១៩,២១ មើលការពន្យល់ ១៤:២៧)។

**២០:២៨** *ឱព្រះអម្ចាស់ទូលបង្គំ ឱព្រះនៃទូលបង្គំអើយ* ការដែលទទួលស្គាល់ថា ព្រះយេស៊ូវគឺជាព្រះអម្ចាស់ និងយាងទ្រង់មកគង់នៅក្នុងជីវិត បង្ហាញឱ្យឃើញនូវសេចក្តីជំនឿដ៏ពិតប្រាកដ (មើលការពន្យល់ ១:១)។

**២០:៣០** *ទីសំគាល់* "មើលការពន្យល់ ២:១១"។ *នៅមុខពួកសិស្សទ្រង់* គឺនៅ មុខពួកអ្នកដែលអាចធ្វើបន្ទាល់ អំពីអ្វីដែលព្រះយេស៊ូវបានធ្វើ ។ ព្រះគម្ពីរយ៉ូហានបាននិយាយសង្កត់ធ្ងន់ម្តងទៀតអំពីការ ធ្វើបន្ទាល់ (មើលការពន្យល់ ១:៧)។

**២០:៣១** *ដើម្បីឱ្យអ្នករាល់គ្នាបានជឿ* ឃ្លានេះបង្ហាញអំពីគោលបំណងរបស់លោកយ៉ូហាន នៅក្នុងការផ្សាយដំណឹងល្អ ។ *ជឿ* "មើលការពន្យល់ ១:៧"។ *ជាព្រះគ្រីស្ទ* "មើលការពន្យល់ ១:២៥"។ លោកយ៉ូហានបានសរសេរព្រះគម្ពីរដំណឹងល្អនេះ ដើម្បីឱ្យអ្នកអានទទួលជឿដល់ព្រះយេស៊ូវ ថាទ្រង់គឺជាព្រះមែស៊ី និងជាព្រះរាជបុត្រានៃព្រះប្រាកដមែន ។ *ព្រះរាជបុត្រានៃព្រះ* "មើលការពន្យល់ ៣:១៦"។ *អ្នករាល់គ្នាបានជីវិត . . . ដោយមានសេចក្តីជំនឿ* ត្រង់ចំណុចនេះ បង្ហាញឱ្យឃើញម្តងទៀត នូវគោលបំណងរបស់លោកយ៉ូហាន គឺដើម្បីនាំឱ្យអ្នកអាន មានសេចក្តីជំនឿ ដែលនាំមកនូវជីវិត (មើលការពន្យល់ ១:៤ ៣:១៥,១៦)។

**២១:១** *សមុទ្រទីបេរាស* "មើលការពន្យល់ ៦:១"។

**២១:២** *ស៊ីម៉ូន-ពេត្រុស* "មើលការពន្យល់ មក ១:១៦"។ *ថូម៉ាស* "មើលការពន្យល់ ១១:១៦"។ *កូនសេបេដេ* ឈ្មោះរបស់អ្នកទាំងពីរនោះ មិនមានកត់ត្រាទុកនៅក្នុងដំណឹងល្អនេះទេ (មថ ៤:២១)។

**២១:៣** *យប់នោះ* នាសម័យបុរាណ ពួកអ្នកនេសាទនិយមនេសាទពេលយប់

**២១:៤** *មិនដឹងជាព្រះយេស៊ូវទេ* សូមប្រៀបធៀបទៅនឹងករណីរបស់នាងម៉ារា (មើលការពន្យល់ ២០:១៤)។

**២១:៧** *សិស្ស១ដែលព្រះយេស៊ូវ* "មើលការពន្យល់ ១៣:២៣"។ *អាវក្រវាត់ខ្លួន* គឺគាត់ក្រវាត់ខ្លួនយ៉ាងប្រញាប់ប្រញាល់ ដើម្បីរៀបចំខ្លួនលោតចុះទៅក្នុងទឹក ។ ពួកសាសន៍យូដាយល់ថា ការគោរពគឺអាចធ្វើទៅបានតែនៅពេលមានសំលៀកបំពាក់ជាប់ខ្លួនប៉ុណ្ណោះ ។ ក្នុងបទគម្ពីរនេះ លោកពេត្រុសប្រហែលជាកំពុងរៀបចំខ្លួនគោរពព្រះអម្ចាស់ ។

ប៉ុណ្ណោះ ៩កាលបានឡើងទៅលើគោកវិញ នោះគេឃើញ
រងើកភ្លើង[រ] ហើយមានត្រីអាំងនៅពីលើ[ស] នឹងនំបុ័ងដែរ ។
១០ព្រះយេស៊ូវមានបន្ទូលទៅគេថា ចូរយកត្រីខ្លះ ដែល
ទើបនឹងចាប់នោះមក ១១ស៊ីម៉ូន–ពេត្រុសក៏ឡើងមកទាំង
ទាញអួន ដាក់លើគោក បានពេញដោយត្រីធំៗ ១៥៣
ហើយទោះបើមានត្រីច្រើនដល់ម្លេះ គង់តែអួនមិនបាន
ធ្លាយដែរ ១២ព្រះយេស៊ូវទ្រង់ហៅគេមកថា ចូរមកពិសា
សិន ប៉ុន្តែ គ្មានសិស្សណាមួយហ៊ានទូលសួរទ្រង់ថា តើអ្នក
ណានុ៎ះ ដោយគេដឹងថាជាព្រះអម្ចាស់ហើយ ១៣ព្រះយេស៊ូវ
ក៏យាងមក យកនំបុ័ង នឹងត្រី ប្រទានដល់គេ[ហ] ១៤នោះជាគំ
រប់៣ដងហើយ ដែលព្រះយេស៊ូវសំដែងមក ឱ្យពួកសិស្ស[ឡ]
ឃើញ ក្នុងពេលក្រោយដែលមានព្រះជន្មរស់ពីស្លាប់ឡើង
វិញ ។

## ព្រះយេស៊ូវសួរបញ្ជាក់ពេត្រុសជាច្រើនលើក

១៥កាលគេបានបរិភោគរួចហើយ នោះព្រះយេស៊ូវ
មានបន្ទូលនឹងស៊ីម៉ូន–ពេត្រុសថា ស៊ីម៉ូន ជាកូនយ៉ូណាស
អើយ តើអ្នកស្រឡាញ់ខ្ញុំជាជាងរបស់ទាំងនេះឬអី គាត់ទូល
ឆ្លើយថា ព្រះករុណាវិសេសព្រះអម្ចាស់ ទ្រង់ ជ្រាបថា
ទូលបង្គំពេញចិត្តនឹងទ្រង់ហើយ[អ] ទ្រង់មានបន្ទូលថា ចូរឱ្យ
ចំណីដល់កូនចៀមខ្ញុំស៊ីផង[ក] ១៦រួចទ្រង់មានបន្ទូលទៅគាត់
ម្តងទៀតថា ស៊ីម៉ូន កូនយ៉ូណាសអើយ តើស្រឡាញ់ខ្ញុំ ឬអី
គាត់ទូលឆ្លើយថា ព្រះករុណាវិសេសព្រះអម្ចាស់ទ្រង់ជ្រាប
ថា ទូលបង្គំពេញចិត្តនឹងទ្រង់ហើយ ទ្រង់មានបន្ទូល ជាគំរប់
៣ដងថា ស៊ីម៉ូន កូនយ៉ូណាសអើយ តើពេញចិត្តនឹងខ្ញុំ

**២១:៩** រ យហ ១៨:១៨ ស ខ.១០,១៣
**២១:១៣** ហ ខ.៩
**២១:១៤** ឡ យហ ២០:១៩,២៦
**២១:១៥** អ មថ ២៦:៣៣,៣៥ យហ ១៣:៣៧ ក លក ១២:៣២
**២១:១៦** ខ ២សយ ៥:២ អក ៣៤:២ មថ ២:៦ យហ ១០:១១ កច ២០:២៨ ១ពត ៥:២,៣
**២១:១៧** គ យហ ១៣:៣៨ ឃ យហ ១៦:៣០ ង ខ.១៦
**២១:១៨** ច យហ ១២:៣៣ ១៨:៣២ ឆ យហ ១៣:៣៦ ២ពត ១:១៤ ជ ៤:១៩
**២១:២០** ឈ ខ.៧ យហ ១៣:២៣ ញ យហ ១៣:២៥
**២១:២២** ដ មថ ១៦:២៧ ឋ ខ.១៩ មថ ៤:១៩
**២១:២៣** ឌ កច ១:១៦

មែនឬអី ពេត្រុសមានចិត្តព្រួយដោយទ្រង់មានបន្ទូលជា
គំរប់៣ដងថា តើពេញចិត្តនឹងខ្ញុំឬអីដូច្នេះ[គ] បានជាគាត់
ទូលឆ្លើយថា ព្រះអម្ចាស់អើយ ទ្រង់ជ្រាបគ្រប់ការទាំង
អស់[ឃ] គឺទ្រង់ជ្រាបថា ទូលបង្គំពេញចិត្តនឹងទ្រង់ហើយ ព្រះ
យេស៊ូវមានបន្ទូលទៅគាត់ថា ចូរឱ្យចំណីដល់ហ្វូងចៀមខ្ញុំស៊ី
ផង[ង] ១៨ប្រាកដមែន ខ្ញុំប្រាប់អ្នកជាប្រាកដថា កាលអ្នកនៅពី
ក្មេងនៅឡើយ នោះបានក្រវាត់ខ្លួនឯង ទាំងដើរទៅមក
តាមតែចិត្ត តែកាលណាចាស់ហើយ នោះអ្នកនឹងសន្ធឹងដៃ
ទៅ ហើយម្នាក់ទៀតនឹងក្រវាត់ឱ្យអ្នកវិញ ទាំងនាំអ្នកទៅឯ
កន្លែង ដែលអ្នកមិនចង់ទៅផង ១៩ទ្រង់មានបន្ទូលដូច្នេះ
ដើម្បីនឹងបង្ហាញពីបែបយ៉ាងណាដែលគាត់ត្រូវស្លាប់[ច]
ប្រយោជន៍ដើម្បីនឹងលើកដំកើងព្រះ[ឆ] កាលទ្រង់មានបន្ទូល
ដូច្នោះរួចហើយ នោះក៏ប្រាប់គាត់ថា ចូរមកតាមខ្ញុំចុះ[ជ]
២០ប៉ុន្តែ ពេត្រុសបែរខ្លួនទៅឃើញសិស្ស១នោះ ដែលព្រះ
យេស៊ូវទ្រង់ស្រឡាញ់[ឈ] កំពុងដើរមកតាមក្រោយ គឺជាអ្នក
ដែលផ្អែកលើព្រះឱរាទ្រង់ ក្នុងកាលដែលបរិភោគ នៅ
ពេលយប់នោះ ហើយបានទូលសួរថា ព្រះអម្ចាស់អើយ តើ
អ្នកណានោះដែលបញ្ជូនទ្រង់[ញ] ២១កាលពេត្រុសបានឃើញ
គាត់ នោះក៏ទូលសួរដល់ទ្រង់ថា ព្រះអម្ចាស់អើយ តើអ្នក
នោះនឹងបានដូចម្តេចទៅ ២២ព្រះយេស៊ូវមានបន្ទូលឆ្លើយ
ទៅគាត់ថា បើសិនជាខ្ញុំចង់ឱ្យអ្នកនោះនៅ ទាល់តែខ្ញុំមក
នោះតើអំពល់អ្វីដល់អ្នក ចូរឱ្យអ្នកមកតាមខ្ញុំចុះ[ឋ] ២៣ដូច្នេះ
ពាក្យនោះក៏ឮខ្ចរខ្ចាយទូទៅ ក្នុងពួកបងប្អូន[ឌ]ថា សិស្សនោះ
មិនត្រូវស្លាប់ទេ ប៉ុន្តែ ព្រះយេស៊ូវមិនបានមានបន្ទូលថា

---

**២១:៩** *រងើកភ្លើង* ត្រង់ចំណុចនេះមិនបានបញ្ជាក់ថា តើរងើកភ្លើងនោះកើតមានឡើង ដោយសារការអស្ចារ្យ ឬដោយសារពួកអ្នកនេសាទផ្សេងទៀតបានបង្កាត់ទុកសម្រាប់ចម្អិនត្រីដែលនេសាទបាននោះទេ (មើលការពន្យល់ ១៨:១៨ ហើយ ចំពោះពាក្យ "ភ្លើង" សូមមើល ១៨:២៦)។

**២១:១១** *គង់តែអួនមិនបានធ្លាយដែរ* ឃ្លានេះបញ្ជាក់ថា អួនដែលពួកគេប្រើនាពេលនោះ គឺខុសពីអួនដែលបាននិយាយនៅក្នុង "លក ៥:៦"។

**២១:១៤** *ជាគំរប់៣ដង* មានន័យថា ជាលើកទីបីហើយ ដែលព្រះយេស៊ូវបង្ហាញព្រះអង្គទ្រង់ឱ្យពួកសិស្សរបស់ទ្រង់បានឃើញ (២០:១៩–២៣,២៤–២៩)។

**២១:១៥** *ជាជាងរបស់ទាំងនេះ* ឃ្លានេះអាចមានន័យថា "ជាជាងអ្នកទាំងនេះ" ឬ "ជាជាងអ្នកទាំងនេះដែលស្រលាញ់ខ្ញុំ" ឬក៏ "ជាជាងរបស់ទាំងនេះ" (ដូចជាឧបករណ៍នេសាទជាដើម)។ អត្ថន័យទីពីរហាក់ដូចជាសមរម្យជាងគេ ពីព្រោះលោកពេត្រុសធ្លាប់បានអះអាងអំពីសេចក្តីស្រលាញ់ដែលគាត់មាន (មថ ២៦:៣៣ មក ១៤:២៩ ប្រៀបធៀប យហ ១៣:៣៧)។ *ឱ្យចំណីដល់កូនចៀមខ្ញុំស៊ីផង* សូមប្រៀបធៀបជាមួយនឹងឃ្លាថា "ចូរឃ្វាលហ្វូងចៀមរបស់ខ្ញុំចុះ" (ខ.១៦) និងឃ្លាថា "ចូរឱ្យចំណីដល់ហ្វូងចៀមខ្ញុំស៊ីផង" (ខ.១៧)។

**២១:១៨** *ខ្ញុំប្រាប់ជាប្រាកដថា* "មើលការពន្យល់ មក ៣:២៨"។ *អ្នកនឹងសន្ធឹងដៃទៅ* ពួកជំនុំដំបូងយល់ឃើញថា ព្រះបន្ទូលត្រង់ចំណុចនេះ គឺជាបទទំនាយអំពីការដែលលោកពេត្រុសត្រូវគេយកទៅឆ្កាង ។

**២១:១៩** *បែបយ៉ាងណា ដែលគាត់ត្រូវស្លាប់* លោកពេត្រុសនឹងត្រូវស្លាប់ ដោយការធ្វើបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ។ មានការអះអាងថា លោកពេត្រុសត្រូវបាន គេឆ្កាងក្បាលចុះក្រោម ។

**២១:២០** *សិស្ស១នោះ ដែលព្រះយេស៊ូវទ្រង់ស្រឡាញ់* "មើលពន្យល់ ១៣:២៣"។ *បរិភោគនៅពេលយប់នោះ* "មើលការពន្យល់ ១៣:២៣–២៥"។

**២១:២២** *ទាល់តែខ្ញុំមក* ត្រង់ចំណុចនេះ ព្រះយេស៊ូវមានបន្ទូលយ៉ាងច្បាស់អំពីការយាងមកជាលើកទីពីររបស់ទ្រង់ (១៤:៣ និងការពន្យល់)។

គាត់មិនស្លាប់នោះទេគឺគ្រាន់តែថាបើសិនជាខ្ញុំចង់ឱ្យអ្នក
នោះនៅទាល់តែខ្ញុំមក នោះតើអំពល់អ្វីដល់អ្នកវិញ
ប៉ុណ្ណោះ ។
២៤គឺសិស្សនោះឯង ដែលធ្វើបន្ទាល់ពីសេចក្ដីទាំងនេះ[ល]
ព្រមទាំងចែងរឿងទាំងនេះទុកផង យើងរាល់គ្នាដឹងថា
សេចក្ដីបន្ទាល់របស់គាត់ នោះពិតហើយ[ណ]
២៥មានការ
ជាច្រើនទៀត[ត] ដែលព្រះយេស៊ូវបានធ្វើដែរ ខ្ញុំស្មានថា
បើនឹងសរសេរទុក ដោយលំដាប់តមក នោះលោកីយទាំង
មូលក៏មិនល្មមគ្រាន់ ដើម្បីនឹងដាក់អស់ទាំងសៀវភៅ
ដែលត្រូវសរសេរនោះផង ។ អាម៉ែន ។

**២១:២៤** ល យហ ១៥:២៧
ណ យហ ១៩:៣៥
**២១:២៥** ត យហ ២០:៣០

**២១:២៤** *សិស្សនោះឯងដែលធ្វើបន្ទាល់* សិស្សដែលធ្វើបន្ទាល់នោះគឺសំដៅលើលោកយ៉ូហាន ។ ម្យ៉ាងទៀត គោលបំណងសំខាន់នៃព្រះគម្ពីរដំណឹងល្អនេះ គឺដើម្បីធ្វើបន្ទាល់អំពីព្រះយេស៊ូវ (មើលការពន្យល់ ១:៧)។ *រឿងទាំងនេះ* សំដៅលើ សេចក្ដីដែលមានចែងនៅក្នុងព្រះគម្ពីរដំណឹងល្អនេះទាំងមូលតែម្ដង ។ *ចែងរឿងទាំងនេះទុក* សិស្សម្នាក់នោះមិនត្រឹមតែជាស្មរបន្ទាល់ប៉ុណ្ណោះទេ គឺថែមទាំងជាអ្នកនិពន្ធកណ្ឌគម្ពីរនេះទៀតផង ។
**២១:២៥** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវទ្រង់បានធ្វើការអស្ចារ្យជាច្រើន ហើយដែលមិនបានកត់ត្រាទុកទាំងអស់ នៅក្នុងព្រះគម្ពីរទេ លោកយ៉ូហាន គ្រាន់តែបានកត់ត្រាទុក នូវផ្នែកខ្លះៗ នៃព្រះរាជកិច្ចរបស់ទ្រង់ប៉ុណ្ណោះ (២០:៣០)។ ដូច្នេះហើយ បានជាគាត់ប្រើឃ្លាជាចុងក្រោយ នៅក្នុងគម្ពីរដំណឹងល្អនេះថា *"បើនឹងសរសេរទុកដោយលំដាប់តមក នោះលោកិយទាំងមូលក៏មិនល្មមគ្រាន់ ដើម្បីនឹងដាក់អស់ទាំងសៀវភៅ ដែលត្រូវសរសេរនោះផង"*។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏សេចក្ដីដែលបានកត់ត្រាទុកអំពីព្រះយេស៊ូវ គឺល្មមគ្រប់គ្រាន់សម្រាប់យើងក្នុងការស្គាល់ទ្រង់ដែរ *(ទំនុកដំកើង ២៥:១១ ចែងថា ពាក្យសំដី ដែលនិយាយចំពេល នោះធៀបដូចជាផ្លែសារីមាសឆ្លាក់ភ្ជាប់នឹងក្បាច់ប្រាក់)* ។

| **ស្ថានីយបុរាណសំខាន់ៗដែលទាក់ទងទៅនឹងគម្ពីរសញ្ញាថ្មី** | | |
|---|---|---|
| ស្ថានីយបុរាណ | ទីកន្លែង | ខគម្ពីរ |
| **នៅប្រទេសអ៊ីស្រាអែល** | | |
| ផ្ទះសម្ដេចសង្ឃកៃផា | ក្រុងយេរូសាឡិម | មថ ២៦:៣ |
| ព្រះវិហារស្ដេចហេរ៉ូឌ | ក្រុងយេរូសាឡិម | លក ១:៩ |
| វាំងរដូវរំហើយស្ដេចហេរ៉ូឌ | ក្រុងយេរីខូរ | មថ ២:៤ |
| ហេរ៉ូឌាម (អាចជាផ្នូររបស់ស្ដេចហេរ៉ូឌ) | ជិតភូមិបេថ្លេហិម | មថ ២:១៩ |
| ស្រុកម៉ាសេដា | ជិតច្រាំងសមុទ្រស្លាប់ | លក ២១:២០ |
| ព្រះវិហារដំបូង | ក្រុងកាពើណិម | មក ១:២១ |
| ស្រះទឹកស៊ីឡោម | ក្រុងយេរូសាឡិម | យហ ៩:៧ |
| ស្រះទឹកបេថែសដា | ក្រុងយេរូសាឡិម | យហ ៥:២ |
| សិលាចារឹកពីឡាត់ | ក្រុងសេសារា | លក ៣:១ |
| សិលាចារឹក លើខ្លោងទ្វារព្រះវិហារសាសន៍ដទៃ | ក្រុងយេរូសាឡិម | កច ២១:២៧–២៩ |
| សំណល់ឆ្អឹងរបស់មនុស្សដែលបានស្លាប់ដោយសារគេឆ្កាង | ក្រុងយេរូសាឡិម | លក ២៣:៣៣ |
| ផ្ទះសាវ័កពេត្រុស | ក្រុងកាពើណិម | មថ ៨:១៤ |
| អណ្ដូងទឹកលោកយ៉ាកុប | ស្រុកណាប្លូស | យហ ៤:៥–៦ |
| **នៅតំបន់អាស៊ីមីន័រ** | | |
| សិលាចារឹកស្រុកឌើបេ | កេទី ហ៊ុយយុគ | កច ១៤:២០ |
| សិលាចារឹកសើគាស–ប៉ូល៉ូស | កោះគីរាយៃ៉/កោះគីប្រុស | កច ១៣:៦–៧ |
| អាសនាសេអូស (បល្ល័ង្ករបស់សាតាំង?) | ពើកាណិម | វវ ២:១៣ |
| កំផែងជញ្ជាំងក្នុងសតវត្សទី៤មុនគ.ស | អាសុស | កច ២០:១៣–១៤ |
| ព្រះវិហារ និងអាសនាព្រះឌីអាន | ក្រុងអេភេសូរ | កច ១៩:២៧–២៨ |
| រោងល្ខោនអេភេសូរ | ក្រុងអេភេសូរ | កច ១៩:២៩ |

| ស្ថានីយបុរាណសំខាន់ៗដែលទាក់ទងនៅនឹងគម្ពីរសញ្ញាថ្មី | | |
|---|---|---|
| ហាងជាងធ្វើប្រាក់ | ក្រុងអេភេសូរ | កច ១៩:២៤ |
| រូបចម្លាក់របស់ព្រះឌីអាន | ក្រុងអេភេសូរ | កច ១៩:៣៥ |
| | **ប្រទេសក្រិក** | |
| សិលាចារឹកអេរ៉ាស្ទុស | ក្រុងកូរិនថូស | រម ១៦:២៣ |
| សិលាចារឹកនៅលើព្រះវិហារ | ក្រុងកូរិនថូស | កច ១៨:៤ |
| សិលាចារឹកនៅផ្សារលក់សាច់ | ក្រុងកូរិនថូស | ១កថ ១០:២៥ |
| បន្ទប់បរិភោគអាហាររបស់មេដឹកនាំសាសនា<br>(នៅព្រះវិហារអាស្កាលីពូស និងឌីម៉េទើ) | ក្រុងកូរិនថូស | ១កថ ៨:១០ |
| ទីលានកាត់ក្តី (បេម៉ា) | ក្រុងកូរិនថូស | កច ១៨:១២ |
| ទីផ្សារ (បេម៉ា) | ក្រុងភីលីព | កច ១៦:១៩ |
| ទីលានរត់ប្រណាំង | ក្រុងអ៊ីស្មាយ | ១កថ ៩:២៤,២៦ |
| សិលាចារឹកកាលីយ៉ូ | ក្រុងដេហ្វី | កច ១៨:១២ |
| ផ្លូវអេណាទាន | កោះនេប៉ូល (កាវ៉ាឡា)<br>ក្រុងភីលីព ក្រុងអាំភីប៉ូលី<br>ក្រុងអ័ប៉ុឡូនា ក្រុងថែស្សាឡូនីច | កច ១៦:១១-១២, ១៧:១ |
| សិលាចារឹកប៉ូលីតាស | ថែស្សាឡូនីច | កច ១៧:៦ |
| | **នៅប្រទេសអ៊ីតាលី** | |
| ផ្ទះរបស់ស្តេចសេសារ-អូគូស | ក្រុងរ៉ូម | លក ២:១ |
| ទីឃុំឃាំងម៉ាមើទីន | ក្រុងរ៉ូម | ២ធថ ១:១៦-១៧ ២:៩ ៤:៦-៨ |
| ផ្លូវអ័ផៃន | ពីក្រុងពូទីយ៉ូលីទៅក្រុងរ៉ូម | កច ២៨:១៣-១៦ |
| វិមានមាសរបស់ស្តេចអធិរាជនេរ៉ូ | ក្រុងរ៉ូម | កច ២៥:១០ ១ពត ២:១៣ |
| របងផ្ទះរបស់លោកទីតុស | ក្រុងរ៉ូម | លក ១៩:៤៣-៤៤ ២១:៦,២០ |

# ភាពស៊ីសង្វាក់គ្នានៃគម្ពីរដំណឹងល្អ

| | ម៉ាថាយ | ម៉ាកុស | លូកា | យ៉ូហាន |
|---|---|---|---|---|
| **សង្ខេបអំពីព្រះយេស៊ូវ** | | | | |
| គោលបំណងនៃការសរសេរដំណឹងល្អរបស់លោកលូកា | | | ១:១–៤ | |
| ចំណុចចាប់ផ្តើមរបស់លោកយ៉ូហាន : ព្រះយេស៊ូវ និងព្រះបន្ទូលមុនពេលត្រឡប់ជាសាច់ឈាម | | | ១:១–១៨ | |
| ពង្សាវតាស្របច្បាប់របស់ព្រះយេស៊ូវតាមរយៈយ៉ូសែប និងតាមរយៈនាងម៉ារា | ១:១–១៧ | | ៣:២៣–៣៨ | |
| **ឆ្នាំដំបូងនៃការងាររបស់លោកយ៉ូហាន-បាទីស្ទ** | | | | |
| ទំនាយពីកំណើតយ៉ូហានប្រាប់ដល់លោកសាការី | | | ១:៥–២៥ | |
| ទំនាយពីកំណើតព្រះយេស៊ូវប្រាប់ដល់នាងម៉ារា | | | ១:២៦–៣៨ | |
| នាងម៉ារាទៅលេងអេលីសាបិត និងចម្រៀងអេលីសាបិត | | | ១:៣៩–៤៥ | |
| អំណរនៃបទចម្រៀងនាងម៉ារា | | | ១:៤៦–៥៦ | |
| កំណើតរបស់លោកយ៉ូហាន–បាទីស្ទ | | | ១:៥៧–៦៦ | |
| ទំនាយជាបទចម្រៀងរបស់លោកសាការី | | | ១:៦៧–៧៩ | |
| ការចម្រើនវ័យ និងជីវិតដំបូងរបស់លោកយ៉ូហាន–បាទីស្ទ | | | ១:៨០ | |
| **ឆ្នាំដំបូងនៃព្រះរាជកិច្ចរបស់ព្រះយេស៊ូវគ្រីស្ទ** | | | | |
| ការពន្យល់ពីកំណើតព្រះយេស៊ូវដល់លោកយ៉ូសែប | ១:១៨–២៥ | | | |
| កំណើតព្រះយេស៊ូវ | | | ២:១–៧ | |
| ចម្រៀងសរសើររបស់ពួកទេវតា និងទីបន្ទាល់របស់អ្នកគង្វាលចៀម | | | ២:៨–២០ | |
| ការកាត់ស្បែកព្រះឱរសយេស៊ូវ | | | ២:២១ | |
| ព្រះយេស៊ូវត្រូវបាននាំទៅព្រះវិហារ បង្ហាញដល់លោកស៊ីម្មាន និងនាងអាណ | | | ២:២២–៣៨ | |
| ការសួរសុខទុក្ខរបស់ពួកហោរា | ២:១–១២ | | | |
| ការភៀសខ្លួនទៅប្រទេសអេស៊ីព្ទ និងការសម្លាប់ក្មេងប្រុសនៅភូមិបេថ្លេហិម | ២:១៣–១៨ | | | |
| ការត្រឡប់មកភូមិណាសារ៉ែតវិញ | ២:១៩–២៣ | | ២:៣៩ | |
| ដំណើរជីវិតដំបូងរបស់ព្រះយេស៊ូវ | | | ២:៤០ | |
| ការធ្វើបុណ្យរំលងលើកទី១របស់ព្រះយេស៊ូវនៅក្រុងយេរូសាឡិម | | | ២:៤១–៥០ | |
| ការធំពេញវ័យរបស់ព្រះយេស៊ូវ | | | ២:៥១–៥២ | |
| **ការចាប់ផ្តើមការងារជាសាធារណៈរបស់លោកយ៉ូហាន-បាទីស្ទ** | | | | |
| ការចាប់ផ្តើមការងាររបស់គាត់ | | ១:១ | ៣:១–២ | |
| សេចក្តីប្រកាស និងការធ្វើបុណ្យជ្រមុជទឹករបស់គាត់ | ៣:១–៦ | ១:២–៦ | ៣:៣–៦ | |
| សេចក្តីបង្រៀនរបស់គាត់ដល់ពួក ផារិស៊ី សាឌូស៊ី បណ្តាជន | | | | |
| អ្នកយកពន្ធ និងពួកទាហាន | ៣:៧–១០ | | ៣:៧–១៤ | |
| ការពិពណ៌នាពីព្រះគ្រីស្ទរបស់គាត់ | ៣:១១–១២ | ១:៧–៨ | ៣:១៥–១៨ | |
| **ចុងបញ្ចប់នៃការងារយ៉ូហាន-បាទីស្ទ និងការចាប់ផ្តើម** | | | | |
| **នៃព្រះរាជកិច្ចរបស់ព្រះយេស៊ូវ** | | | | |
| ព្រះយេស៊ូវទទួលបុណ្យជ្រមុជទឹកពីលោកយ៉ូហាន | ៣:១៣–១៧ | ១:៩–១១ | ៣:២១–២៣ | |
| ព្រះយេស៊ូវជួបនឹងការល្បួងនៅវាលរហោស្ថាន | ៤:១–១១ | ១:១២–១៣ | ៤:១–១៣ | |
| ទីបន្ទាល់លោកយ៉ូហានអំពីខ្លួនរបស់គាត់នៅមុខពួកសង្ឃ និងពួកលេវី | | | | ១:១៩–២៨ |
| ទីបន្ទាល់លោកយ៉ូហានថាព្រះយេស៊ូវជាព្រះរាជបុត្រាព្រះ | | | | ១:២៩–៣៤ |
| អ្នកដើរតាមព្រះយេស៊ូវទីមួយ | | | | ១:៣៥–៥១ |
| ការអស្ចារ្យរបស់ព្រះយេស៊ូវលើទី១: ទឹកប្រែជាស្រាទំពាំងបាយជូរ | | | | ២:១–១១ |
| ការស្នាក់លើកទី១នៅក្រុងកាពើណិមជាមួយញាតិសន្តាន និងសិស្សទ្រង់ដំបូងគេ | | | | ២:១២ |
| ការសម្អាតព្រះវិហារលើកទី១នៅថ្ងៃបុណ្យរំលង | | | | ២:១៣–២២ |
| ការឆ្លើយតបចំពោះការអស្ចារ្យរបស់ព្រះយេស៊ូវលើកដំបូង | | | | ២:២៣–២៥ |
| ការសម្ភាសរបស់លោកនីកូដេមជាមួយនឹងព្រះយេស៊ូវ | | | | ៣:១–២១ |
| ព្រះយេស៊ូវយាងមកជិតនួសលោកយ៉ូហាន–បាទីស្ទ | | | | ៣:២២–៣៦ |
| ការចាកចេញពីស្រុកយូដា | ៤:១២ | ១:១៤ | ៣:១៩–២០,៤:១៤ | ៤:១–៤ |
| ការពិភាក្សាគ្នាជាមួយនឹងស្ត្រីសាសន៍សាម៉ារី | | | | ៤:៥–២៦ |
| ឧបសគ្គនៃចម្រូតព្រលឹងវិញ្ញាណ | | | | ៤:២៧–៣៨ |
| ការផ្សាយដំណឹងល្អនៅស្រុកស៊ូខារ | | | | ៤:៣៩–៤២ |
| ការមកដល់ស្រុកកាលីឡេ | | | | ៤:៤៣–៤៥ |

## ភាពស៊ីសង្វាក់គ្នានៃគម្ពីរដំណឹងល្អ

| | ម៉ាថាយ | ម៉ាកុស | លូកា | យ៉ូហាន |
|---|---|---|---|---|
| ព្រះរាជកិច្ចរបស់ព្រះគ្រីស្ទនៅស្រុកកាលីឡេ | | | | |
| *ការបៀតបៀននៅក្នុងស្រុកកំណើត និងទីតាំងថ្មី* | | | | |
| ការចាប់ផ្តើមរាជកិច្ចនៅស្រុកកាលីឡេ | ៤:១៧ | ១:១៤ខ-១៥ | ៤:១៤ខ-១៥ | |
| កូនក្មេងនៅស្រុកកាពើណិមបានជា ខណៈពេលទ្រង់គង់នៅភូមិកាណា | | | | ៤:៤៦-៥៤ |
| រាជកិច្ច និងការបដិសេធនៅភូមិណាសារ៉ែត | | | ៤:១៦-៣១ក | |
| ការយាងមកស្រុកកាពើណិមវិញ | ៤:១៣-១៦ | | | |
| *ការត្រាស់ហៅសិស្ស និងព្រះរាជកិច្ចព្រះគ្រីស្ទនៅស្រុកកាលីឡេ* | | | | |
| ការត្រាស់ហៅសិស្ស៤នាក់ | ៤:១៨-២២ | ១:១៦-២០ | ៥:១-១១ | |
| ការបង្រៀនក្នុងព្រះវិហារ នៅក្រុងកាពើណិម | | | | |
| បញ្ជាក់ការពិតដោយប្រោសមនុស្សអារក្សចូល | | ១:២១-២៨ | ៤:៣១ខ-៣៧ | |
| ម្តាយក្មេករបស់ពេត្រុស និងអ្នកដទៃទៀតបានជាពីជំងឺ | ៨:១៤-១៧ | ១:២៩-៣៤ | ៤:៣៨-៤១ | |
| ដំណើរយាងទៅកាលីឡេជាមួយស៊ីម៉ូន និងអ្នកផ្សេងទៀត | ៤:២៣-២៥ | ១:៣៥-៣៩ | ៤:៤២-៤៤ | |
| ការប្រោសមនុស្សឃ្លង់ | ៨:២-៤ | ១:៤០-៤៥ | ៥:១២-១៦ | |
| ការអត់ទោស និងការប្រោសជំងឺដល់មនុស្សឃ្លង់ | ៩:១-៨ | ២:១-១២ | ៥:១៧-២៦ | |
| ការត្រាស់ហៅលោកម៉ាថាយ | ៩:៩ | ២:១៣-១៤ | ៥:២៧-២៨ | |
| ពិធីជប់លៀងនៅផ្ទះលោកម៉ាថាយ | ៩:១០-១៣ | ២:១៥-១៧ | ៥:២៩-៣២ | |
| ព្រះយេស៊ូវមានបន្ទូលការពារសិស្សទ្រង់ពីការបរិភោគ និងតមអាហារ | | | | |
| ដោយលើករឿងប្រៀបធៀប៣ប្រការ | ៩:១៤-១៧ | ២:១៨-២២ | ៥:៣៣-៣៩ | |
| *ទំនាស់នៅថ្ងៃឈប់សម្រាក និងការចាកចេញ* | | | | |
| ព្រះយេស៊ូវមានសិទ្ធិប្រោសជំងឺនៅថ្ងៃឈប់សម្រាក | | | | ៥:១-៩ |
| គម្រោងសម្លាប់ព្រះយេស៊ូវ ដោយចោទថាទ្រង់ធ្វើខុស | | | | |
| នៅថ្ងៃឈប់សម្រាក ហើយថាទ្រង់ស្មើនឹងព្រះ | | | | ៥:១០-១៨ |
| ការបង្ហាញពីសេចក្តីបង្រៀនពីភាពស្មើគ្នារវាងព្រះបុត្រា និងព្រះវរបិតា | | | | ៥:១៩-៤៧ |
| ជម្លោះដោយសារពួកសិស្សបូតស្រូវបរិភោគនៅថ្ងៃឈប់សម្រាក | ១២:១-៨ | ២:២៣-២៨ | ៦:១-៥ | |
| ការប្រោសមនុស្សស្វិតដៃនៅថ្ងៃឈប់សម្រាក | ១២:៩-១៤ | ៣:១-៦ | ៦:៦-១១ | |
| ការយាងចេញពីតំបន់សមុទ្រកាលីឡេដោយមានមនុស្សដើរតាមកកកុញ | ១២:១៥-២១ | ៣:៧-១២ | | |
| *ការជួបគ្នានៃសិស្សទាំង១២នាក់ និងសេចក្តីបង្រៀននៅលើភ្នំ* | | | | |
| ការជ្រើសរើសសិស្សទាំង១២នាក់ | | ៣:១៣-១៩ | ៦:១២-១៦ | |
| ការចាប់ផ្តើមរៀបចំបង្រៀន | ៥:១-២ | | ៦:១៧-១៩ | |
| មានពរ ហើយអស់ដែលគ្រងនគរព្រះជាមរដក | | | | |
| ហើយវេទនាដល់អស់អ្នកពុំបាននោះវិញ | ៥:៣-១២ | | ៦:២០-២៦ | |
| ការទទួលខុសត្រូវក្នុងអំឡុងពេលរង់ចាំនគរព្រះ | ៥:១៣-១៦ | | | |
| ក្រឹត្យវិន័យ សេចក្តីសុចរិត ហើយនិងនគរព្រះ | ៥:១៧-២០ | | | |
| ភាពផ្ទុយគ្នាទាំង៦ក្នុងការបកស្រាយអំពីក្រឹត្យវិន័យ | ៥:២១-៤៨ | | ៦:២៧-៣០,៣២-៣៦ | |
| អំពើពុតត្បុត៣យ៉ាងថា"ជាសេចក្តីសុចរិត"ដែលត្រូវជាសវាង | ៦:១-១៨ | | | |
| បម្រាម៣យ៉ាង: កុំឱ្យលោភលន់ កុំឱ្យថ្កោលទោសគេ | | | | |
| និងការបង្ហាញភាពល្ងង់ខ្លៅនៃការស្តាប់បង្គាប់ព្រះ | ៦:១៩-៧:៦ | | ៦:៣៧-៤២ | |
| ការអនុវត្តន៍ និងសេចក្តីសន្និដ្ឋាន | ៧:៧-២៧ | | ៦:៣១, ៤៣-៤៩ | |
| ប្រតិកម្មឆ្លើយតបនៃពួកបណ្តាជន | ៧:២៨-៨:១ | | | |
| *ព្រះកិត្តិនាមរបស់ព្រះយេស៊ូវ និងការប្រែចិត្ត* | | | | |
| សេចក្តីជំនឿរបស់មេសាលាប្រជុំ និងការប្រោសជំងឺអ្នកបម្រើគាត់ | ៨:៥-១៣ | | ៧:១-១០ | |
| កូនប្រុសស្ត្រីមេម៉ាយម្នាក់បានរស់ឡើងវិញនៅក្រុងណាអ៊ីន | | | ៧:១១-១៧ | |
| សំណួររបស់លោកយ៉ូហាន-បាទីស្ទអំពីនគរព្រះ | ១១:២-១៩ | | ៧:១៨-៣៥ | |
| វេទនាដល់ក្រុងខូរ៉ាស៊ីន និងបេតសៃដាដែលមិនបានប្រែចិត្ត | ១១:២០-៣០ | | | |
| ស្ត្រីដែលបានប្រែចិត្តពីបាបម្នាក់ចាក់ប្រេងក្រអូបលើជើងព្រះគ្រីស្ទ | | | ៧:៣៦-៥០ | |
| *ការបដិសេធន៍ជាសាធារណៈដោយមេដឹកនាំសាសន៍យូដា* | | | | |
| ការធ្វើដំណើរជាមួយនឹងសិស្ស១២នាក់ និងអ្នកដទៃទៀត | | | ៨:១-៣ | |
| ការចោទប្រមាថដោយពួកគ្រូក្រឹត្យវិន័យ និងពួកផារិស៊ី | ១២:២២-៣៧ | ៣:២០-៣០ | | |
| ការមិនព្រមធ្វើទីសំគាល់ | ១២:៣៨-៤៥ | | | |
| សេចក្តីប្រកាសនៃសាច់ញាតិថ្មីខាងព្រលឹងវិញ្ញាណ | ១២:៤៦-៥០ | ៣:៣១-៣៥ | ៨:១៩-២១ | |

## ភាពស៊ីសង្វាក់គ្នានៃព្រះគម្ពីរដំណឹងល្អ

| | ម៉ាថាយ | ម៉ាកុស | លូកា | យ៉ូហាន |
|---|---|---|---|---|
| *អាថ៌កំបាំងអំពីនគរព្រះតាមរយៈរឿងប្រៀបប្រដូច* | | | | |
| **ដល់ហ្វូងមហាជននៅក្បែរមាត់សមុទ្រ** | | | | |
| ការចាប់ផ្តើមនៃរឿងប្រៀបប្រដូច | ១៣:១–៣ក | ៤:១–២ | ៨:៤ | |
| អំពីដីមានជីជាតិ | ១៣:៣ខ–២៣ | ៤:៣–២៥ | ៨:៥–១៨ | |
| អំពីគ្រាប់ពូជ | | ៤:២៦–២៩ | | |
| អំពីស្រងែ | ១៣:២៤–៣០ | | | |
| អំពីគ្រាប់ពូជតូចល្អិត | ១៣:៣១–៣២ | ៤:៣០–៣២ | | |
| អំពីដំបែរ | ១៣:៣៣–៣៥ | ៤:៣៣–៣៤ | | |
| **ដល់ពួកសិស្សនៅក្នុងផ្ទះ** | | | | |
| ពន្យល់ន័យអំពីស្រងែ | ១៣:៣៦–៤៣ | | | |
| អំពីការលាក់កំណប់ | ១៣:៤៤ | | | |
| អំពីកែវមុក្តា | ១៣:៤៥–៤៦ | | | |
| អំពីអួន | ១៣:៤៧–៥០ | | | |
| អំពីម្ចាស់ផ្ទះ | ១៣:៥១–៥៣ | | | |
| *ការទាស់ប្រឆាំងចេះតែបន្តទៀត* | | | | |
| ការយាងកាត់សមុទ្រ និងការបង្គាប់ឱ្យខ្យល់ព្យុះស្ងប់ | ៨:១៨,២៣–២៧ | ៤:៣៥–៤១ | ៨:២២–២៥ | |
| ការប្រោសមនុស្សខ្មោចចូលនៅស្រុកគេរ៉ាស៊ីន និងការបដិសេធន៍លទ្ធផល | ៨:២៨–៣៤ | ៥:១–២០ | ៨:២៦–៣៩ | |
| ត្រឡប់មកស្រុកកាលីឡេវិញ ការប្រោសស្ត្រីម្នាក់ដោយគ្រាន់តែប៉ះព្រះពស្ត្រ ព្រះយេស៊ូវ និងប្រោសកូនស្រីលោកយៃរ៉ុសឱ្យរស់ឡើងវិញ | ៩:១៨–២៦ | ៥:២១–៤៣ | ៨:៤០–៥៦ | |
| ការប្រោសលោះដ៏អស្ចារ្យបី និងការចោទប្រមាថមួយផ្សេងទៀត | ៩:២៧–៣៤ | | | |
| ការសួរសុខទុក្ខអ្នកមិនជឿចុងក្រោយនៅភូមណាសារ៉ែត | ១៣:៥៤–៥៨ | ៦:១–៦ក | | |
| *ការប្រកាសដំណឹងល្អចុងក្រោយដល់អ្នកស្រុកកាលីឡេ* | | | | |
| អ្នកធ្វើការមានគ្នាតិច | ៩:៣៥–៣៨ | ៦:៦ខ | | |
| បេសកកម្មរបស់សិស្សទាំង១២នាក់ | ១០:១–៤២ | ៦:៧–១១ | ៩:១–៥ | |
| ការបញ្ជូនអ្នកធ្វើការចេញទៅ | ១១:១ | ៦:១២–១៣ | ៩:៦ | |
| កំហុសរបស់ស្តេចហេរ៉ូឌ–អាន់ទីប៉ាសជាទីសំគាល់ពីព្រះយេស៊ូវ | ១៤:១–២ | ៦:១៤–១៦ | ៩:៧–៩ | |
| ការដាក់គុក និងការកាត់ក្បាលលោកយ៉ូហាន–បាទីស្ទ | ១៤:៣–១២ | ៦:១៧–២៩ | | |
| ព្រះរាជកិច្ចរបស់ព្រះគ្រីស្ទនៅជុំវិញស្រុកកាលីឡេ | | | | |
| *មេរៀនអំពីនំបុ័ងជីវិត* | | | | |
| ការវិលត្រឡប់មកវិញនៃអ្នកធ្វើការ | | ៦:៣០ | ៩:១០ក | |
| ការយាងចេញពីស្រុកកាលីឡេ | ១៤:១៣–១៤ | ៦:៣១–៣៤ | ៩:១០ខ–១១ | ៦:១–៣ |
| ការប្រទានអាហារដល់មនុស្សប្រាំពាន់នាក់ | ១៤:១៥–២១ | ៦:៣៥–៤៤ | ៩:១២–១៧ | ៦:៤–១៣ |
| ការប៉ុនប៉ងធ្វើឱ្យរាំងស្ទះការងារព្រះយេស៊ូវមុនពេលកំណត់ | ១៤:២២–២៣ | ៦:៤៥–៤៦ | | ៦:១៤–១៥ |
| ការយាងលើទឹកក្នុងពេលមានខ្យល់ព្យុះ | ១៤:២៤–៣៣ | ៦:៤៧–៥២ | | |
| ការប្រោសជំងឺនៅស្រុកគេនេសារ៉ែត | ១៤:៣៤–៣៦ | ៦:៥៣–៥៦ | | |
| សេចក្តីបង្រៀនអំពីនំបុ័ងជីវិតដ៏ពិត | | | | ៦:២២–៥៩ |
| សេចក្តីខ្វះខាតនៅក្នុងចំណោមពួកសិស្ស | | | | ៦:៦០–៧១ |
| *មេរៀនស្តីពីដំបែនៃពួកផារិស៊ី សាឌូស៊ី និងពួកហេរ៉ូឌ* | | | | |
| ជម្លោះស្តីពីទំនៀមទម្លាប់នៃភាពមិនស្អាតនៅក្នុងពិធីបុណ្យ | ១៥:១–៣ក, ៧–៩ខ,៣ខ–៦,១០–២០ | ៧:១–២៣ | | ៧:១ |
| ដំណឹងល្អទៅដល់ស្ត្រីសាសន៍ក្រិកនៅក្រុងទីរ៉ុស និងស៊ីដូន | ១៥:២១–២៨ | ៧:២៤–៣០ | | |
| ការប្រោសជំងឺនៅស្រុកដេកាប៉ូល | ១៥:២៩–៣១ | ៧:៣១–៣៧ | | |
| ការប្រទានអាហារដល់មនុស្សបួនពាន់នាក់នៅស្រុកដេកាប៉ូល | ១៥:៣២–៣៨ | ៨:១–៩ក | | |
| ការយាងមកស្រុកកាលីឡេវិញ និងការប្រទះនឹងពួកផារិស៊ី និងសាឌូស៊ី | ១៥:៣៩–១៦:៤ | ៨:៩ខ–១២ | | |
| ការព្រមានពីកំហុសខុសឆ្គងរបស់ពួកផារិស៊ី សាឌូស៊ី និងពួកហេរ៉ូឌ | ១៦:៥–១២ | ៨:១៣–២១ | | |
| ការប្រោសមនុស្សខ្វាក់នៅស្រុកបេតសៃដា | | ៨:២២–២៦ | | |
| *មេរៀនអំពីភាពជាព្រះមែស៊ីត្រូវបានរៀន និងអះអាង* | | | | |
| ការបញ្ជាក់របស់លោកពេត្រុសថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទ និងទំនាយពីពួកជំនុំលើកដំបូង | ១៦:១៣–២០ | ៨:២៧–៣០ | ៩:១៨–២១ | |
| ទំនាយលើកទី១អំពីការបដិសេធន៍ចំពោះការសុគត និងរស់ឡើងវិញ | ១៦:២១–២៦ | ៨:៣១–៣៧ | ៩:២២–២៥ | |

# ភាពស៊ីសង្វាក់គ្នានៃព្រះគម្ពីរដំណឹងល្អ

| | ម៉ាថាយ | ម៉ាកុស | លូកា | យ៉ូហាន |
|---|---|---|---|---|
| ការយាងមកនៃកូនមនុស្ស និងការជំនុំជម្រះ | ១៦:២៧-២៨ | ៨:៣៨-៩:១ | ៩:២៦-២៧ | |
| ការផ្លាស់ព្រះកាយនៃព្រះយេស៊ូវ | ១៧:១-៨ | ៩:២-៨ | ៩:២៨-៣៦ក | |
| ការពិភាក្សាគ្នាអំពីការរស់ឡើងវិញរបស់អេលីយ៉ា និងយ៉ូហាន-បាទីស្ទ | ១៧:៩-១៣ | ៩:៩-១៣ | ៩:៣៦ខ | |
| *មេរៀនអំពីការទទួលខុសត្រូវចំពោះអ្នកដទៃ* | | | | |
| ការប្រោសក្មេងដែលអារក្សចូលម្នាក់ និងការស្តីបន្ទោសពីអ្នកមិនជឿ | ១៧:១៤-២០ | ៩:១៤-២៩ | ៩:៣៧-៤៣ក | |
| ទំនាយលើកទី២នៃការសុគត និងរស់ឡើងវិញ | ១៧:២២-២៣ | ៩:៣០-៣២ | ៩:៤៣ខ-៤៥ | |
| ការបង់ពន្ធព្រះវិហារ | ១៧:២៤-២៧ | | | |
| ការជជែករកអ្នកដែលធំជាងគេនៅនគរព្រះ | ១៨:១-៥ | ៩:៣៣-៣៧ | ៩:៤៦-៤៨ | |
| ការព្រមានអំពីការដែលធ្វើឱ្យអ្នកជឿជំពប់ដួល | ១៨:៦-១៤ | ៩:៣៨-៥០ | ៩:៤៩-៥០ | |
| ការប្រព្រឹត្ត និងការអត់ទោសដល់បងប្អូនដែលបានធ្វើខុស | ១៨:១៥-៣៥ | | | |
| *ដំណើរមកចូលរួមបុណ្យបារាំនៅក្រុងយេរូសាឡិម* | | | | |
| ការតម្រូវឱ្យមានការប្តេជ្ញាចិត្តខ្ពស់ចំពោះអ្នកដើរតាម | ៨:១៩-២២ | | ៩:៥៧-៦២ | |
| ការចំអកនៃប្អូនប្រុសព្រះយេស៊ូវ | | | | ៧:២-៩ |
| ការយាងកាត់ស្រុកសាម៉ារី | | | ៩:៥១-៥៦ | ៧:១០ |
| ព្រះរាជកិច្ចព្រះគ្រីស្ទនៅស្រុកកាលីឡេ | | | | |
| *ព្រះរាជកិច្ចចាប់ផ្តើមនៅថ្ងៃបុណ្យបារាំ* | | | | |
| ប្រតិកម្មតបតចំពោះសេចក្តីបង្រៀន និងការអស្ចារ្យរបស់ព្រះយេស៊ូវ | | | | ៧:១១-៣១ |
| ការប៉ុនប៉ងចាប់ព្រះយេស៊ូវមិនបានសម្រេច | | | | ៧:៣២-៥២ |
| ព្រះយេស៊ូវបានអត់ទោសដល់ស្ត្រីកំផិតម្នាក់ | | | | ៧:៥៣-៨:១១ |
| ជម្លោះអំពីការអះអាងរបស់ព្រះយេស៊ូវថាជាពន្លឺនៃពិភពលោក | | | | ៨:១២-២០ |
| ទំនាក់ទំនងរបស់ព្រះយេស៊ូវចំពោះព្រះវរបិតា | | | | ៨:២១-៣០ |
| ទំនាក់ទំនងរបស់ព្រះយេស៊ូវចំពោះលោកអ័ប្រាហាំ និងការប៉ងគប់ដុំថ្ម | | | | ៨:៣១-៥៩ |
| ការប្រោសបុរសខ្វាក់ពីកំណើតម្នាក់ | | | | ៩:១-៧ |
| ការឆ្លើយតបនៃអ្នកជិតខាងរបស់បុរសខ្វាក់ពីកំណើត | | | | ៩:៨-១២ |
| បុរសខ្វាក់ម្នាក់ដែលបានភ្លឺ ត្រូវបានពួកផារិស៊ីពិនិត្យមើល និងកាត់ចេញពីពួកជំនុំសាសន៍យូដា | | | | ៩:១៣-៣៤ |
| ព្រះយេស៊ូវបានបង្ហាញអង្គទ្រង់ដល់មនុស្សខ្វាក់ | | | | ៩:៣៥-៣៨ |
| ការខ្វាក់ខាងវិញ្ញាណនៃពួកផារិស៊ី | | | | ៩:៣៩-៤១ |
| ការអធិប្បាយប្រៀបធៀបនៃអ្នកគង្វាលចៀមល្អ | | | | ១០:១-១៨ |
| ការបែងចែកបក្សពួកនៅក្នុងចំណោមសាសន៍យូដា | | | | ១០:១៩-២១ |
| *មេរៀនអំពីសេចក្តីស្រឡាញ់ ការបម្រើ និងការអធិស្ឋាន* | | | | |
| បេសកកម្មនៃសិស្សទាំង៧០នាក់ | | | ១០:១-១៦ | |
| ការវិលត្រឡប់មកវិញនៃសិស្សទាំង៧០នាក់ | | | ១០:១៧-២៤ | |
| រឿងអំពីសាសន៍សាម៉ារីដ៏ល្អ | | | ១០:២៥-៣៧ | |
| ព្រះយេស៊ូវសួរសុខទុក្ខនាងម៉ារា និងម៉ាថា | | | ១០:៣៨-៤២ | |
| មេរៀនអំពីរបៀបអធិស្ឋាន និងរឿងប្រៀបប្រដូចពីមិត្តក្លាហាន | | | ១១:១-១៣ | |
| *ការជជែកវែកញែកជាមួយគ្រូក្រឹត្យវិន័យ និងពួកផារិស៊ី* | | | | |
| ការចោទប្រមាថលើកទី៣ និងការជជែកវែកញែកលើកទី២ | | | ១១:១៤-៣៦ | |
| វេទនាដល់ពួកផារិស៊ី និងគ្រូក្រឹត្យវិន័យខណៈពេលបរិភោគ ជាមួយពួកអាចារ្យផារិស៊ី | | | ១១:៣៧-៥៤ | |
| ការព្រមានដល់សិស្សពីភាពកំពុត | | | ១២:១-១២ | |
| ការព្រមានអំពីភាពលោភលន់ និងការទុកចិត្តលើទ្រព្យសម្បត្តិ | | | ១២:១៣-៣៤ | |
| ការព្រមានពីការដែលមិនរៀបចំសម្រាប់ការយាងមកនៃកូនមនុស្ស | | | ១២:៣៥-៤៨ | |
| ការព្រមានពីការបែងចែកបក្សពួក | | | ១២:៤៩-៥៣ | |
| ការព្រមានពីការដែលខ្វះខាតចំណេះដឹងនាពេលបច្ចុប្បន្ន | | | ១២:៥៤-៥៩ | |
| មានជម្រើសពីរៈ ប្រែចិត្ត ឬ ត្រូវវិនាស | | | ១៣:១-៩ | |
| ការទាស់ប្រឆាំងពីមេសាលាប្រជុំសម្រាប់ការប្រោសស្ត្រីម្នាក់នៅថ្ងៃឈប់សម្រាក | | | ១៣:១០-២១ | |
| ការប៉ងគប់នឹងដុំថ្ម ឬចាប់ព្រះយេស៊ូវ ដោយចោទថា បានប្រមាថដល់ព្រះនៅថ្ងៃបុណ្យ | | | ១០:២២-៣៩ | |

## ភាពស៊ីសង្វាក់គ្នានៃព្រះគម្ពីរដំណឹងល្អ

| | ម៉ាថាយ | ម៉ាកុស | លូកា | យ៉ូហាន |
|---|---|---|---|---|
| ព្រះរាជកិច្ចរបស់ព្រះគ្រីស្ទនៅស្រុកពេរ៉េ និងតំបន់ជុំវិញនោះ | | | | |
| *គោលការណ៍នៃពួកសាវ័ក* | | | | |
| ពីទីក្រុងយេរូសាឡិមទៅស្រុកពេរ៉េ | | | | ១០:៤–៤២ |
| ការចោទសួរអំពីសេចក្ដីសង្គ្រោះ និងការចូលទៅក្នុងនគរព្រះ | | | ១៣:២២–៣០ | |
| ព្រះយេស៊ូវបានដឹងមុនពីការសុគត និងភាពសោកសង្រេងដល់ក្រុងយេរូសាឡិម | | | ១៣:៣១–៣៥ | |
| ពួកផារិស៊ីរិះគន់ព្រះយេស៊ូវក្នុងការដែលទ្រង់ប្រោសមនុស្សកើតទាចនៅថ្ងៃឈប់សម្រាក និងរឿងប្រៀបប្រដូច | | | ១៤:១–២៤ | |
| តម្លៃនៃភាពជាសាវ័ក | | | ១៤:២៥–៣៥ | |
| រឿងប្រៀបប្រដូចក្នុងន័យការពារអ្នកមានបាប | | | ១៥:១–៣២ | |
| រឿងប្រៀបប្រដូចពីការប្រើប្រាស់ប្រាក់ឱ្យបានត្រឹមត្រូវ | | | ១៦:១–១៣ | |
| សេចក្ដីបង្រៀនអំពីគ្រោះថ្នាក់នៃទ្រព្យសម្បត្តិ | | | ១៦:១៤–៣១ | |
| មេរៀនទាំង៤ស្ដីអំពីភាពជាសាវ័ក | | | ១៧:១–១០ | |
| ជម្ងឺ និងមរណភាពរបស់ឡាសារ | | | | ១១:១–១៦ |
| ឡាសាររស់ពីស្លាប់ឡើងវិញ | | | | ១១:១៧–៤៤ |
| ការសម្រេចចិត្តធ្វើគុតព្រះយេស៊ូវរបស់មេសាលាប្រជុំ | | | | ១១:៤៥–៥៤ |
| *សេចក្ដីបង្រៀនចុងក្រោយក្នុងដំណើរទៅក្រុងយេរូសាឡិម* | | | | |
| ការប្រោសមនុស្សឃ្លង់១០នាក់ក្នុងដំណើរឆ្លងកាត់ស្រុកសាម៉ារី និងកាលីឡេ | | | ១៧:១១–២១ | |
| សេចក្ដីបង្រៀនទាក់ទងទៅនឹងការយាងមករបស់កូនមនុស្ស | | | ១៧:២២–៣៧ | |
| រឿងប្រៀបប្រដូចពីរស្ដីអំពីការអធិស្ឋាន : ស្ត្រីមេម៉ាយដែលមានការព្យាយាម និងការអធិស្ឋានរបស់ពួកផារិស៊ី និងពួកអ្នកយកពន្ធ | | | ១៨:១–១៤ | |
| បញ្ហាទំនាស់ជាមួយសេចក្ដីបង្រៀនរបស់ពួកផារិស៊ីអំពីការលែងលះប្ដីប្រពន្ធ | ១៩:១–១២ | ១០:១–១២ | | |
| គំរូរបស់ក្មេងតូចៗដែលទាក់ទងទៅនឹងនគរព្រះ | ១៩:១៣–១៥ | ១០:១៣–១៦ | ១៨:១៥–១៧ | |
| អ្នកមាន និងនគរព្រះ | ១៩:១៦–៣០ | ១០:១៧–៣១ | ១៨:១៨–៣០ | |
| រឿងប្រៀបប្រដូចអំពីថៅកែម្នាក់ | ២០:១–១៦ | | | |
| ទំនាយពីការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ | ២០:១៧–១៩ | ១០:៣២–៣៤ | ១៨:៣១–៣៤ | |
| ការព្រមានអំពីភាពមានអំនួត | ២០:២០–២៨ | ១០:៣៥–៤៥ | | |
| ការប្រោសមនុស្សខ្វាក់ឈ្មោះបារទីមេ និងគូកនរបស់គាត់ | ២០:២៩–៣៤ | ១០:៤៦–៥២ | ១៨:៣៥–៤៣ | |
| សេចក្ដីសង្គ្រោះបានមកដល់លោកសាខេ | | | ១៩:១–១០ | |
| រឿងប្រៀបប្រដូចពីការទទួលខុសត្រូវក្នុងវេលាដែលនគរព្រះមិនទាន់មកដល់ | | | ១៩:១១–២៨ | |
| ***ការបង្ហាញជាផ្លូវការរបស់ព្រះគ្រីស្ទចំពោះរាស្ត្រអ៊ីស្រាអែល និងលទ្ធផលនៃជម្លោះ*** | | | | |
| *ផ្លូវនៃជ័យជម្នះ និងដើមល្វា* | | | | |
| ការយាងមកដល់ភូមិបេថានី | | | | ១១:៥៥–១២:១, ៩–១១ |
| ដំណើរជ័យជម្នះឆ្ពោះទៅទីក្រុងយេរូសាឡិម | ២១:១–៣,៦–៧ ៤–៥,៨–១១,១៤–១៧ | ១១:១–១១ | ១៩:២៩–៤៤ | ១២:១២–១៩ |
| ដើមល្វាមានស្លឹកតែគ្មានផ្លែ | ២១:១៨–១៩ក | ១១:១២–១៤ | | |
| ការសំអាតព្រះវិហារលើកទី២ | ២១:១២–១៣ | ១១:១៥–១៨ | ១៩:៤៥–៤៨ | |
| សំណូមពររបស់ពួកក្រិកចង់ឃើញព្រះយេស៊ូវ និងការលើកឡើងរបស់កូនមនុស្ស | | | | ១២:២០–៣៦ |
| ការឆ្លើយតបផ្សេងៗរបស់ពួកបណ្ដាជនចំពោះព្រះយេស៊ូវ និងការឆ្លើយតបរបស់ទ្រង់ | | | | ១២:៣៦–៥០ |
| ដើមល្វាដែលក្រៀមស្វិត និងមេរៀនពីសេចក្ដីជំនឿ | ២១:១៩ខ–២២ | ១១:១៩–២៥ | ២១:៣៧–៣៨ | |
| *ការជំទាស់ជាផ្លូវការទៅនឹងអំណាចព្រះគ្រីស្ទ* | | | | |
| ការចោទសួរពីអំណាចព្រះយេស៊ូវពីសំណាក់ពួកសម្ដេចសង្ឃ គ្រូក្រឹត្យវិន័យ និងពួកចាស់ទុំ | ២១:២៣–២៧ | ១១:២៧–៣៣ | ២០:១–៨ | |
| ការឆ្លើយតបរបស់ព្រះយេស៊ូវជាសំណួរ និងរឿងប្រៀបប្រដូច៣ប្រការ | ២១:២៨–២២:១៤ | ១២:១–១២ | ២០:៩–១៩ | |
| ពួកផារិស៊ី និងពួកហេរ៉ូឌប៉ងចាប់ព្រះយេស៊ូវដោយចោទសួរ អំពីការបង់ពន្ធដារឱ្យស្ដេចសេសារ | ២២:១៥–២២ | ១២:១៣–១៧ | ២០:២០–២៦ | |
| សំណួរល្បងរបស់ពួកសាឌូស៊ីអំពីការរស់ឡើងវិញ | ២២:២៣–៣៣ | ១២:១៨–២៧ | ២០:២៧–៤០ | |
| សំណួរជាផ្លូវច្បាប់របស់ពួកផារិស៊ី | ២២:៣៤–៤០ | ១២:២៨–៣៤ | | |

## ភាពស៊ីសង្វាក់គ្នានៃព្រះគម្ពីរដំណឹងល្អ

| | ម៉ាថាយ | ម៉ាកុស | លូកា | យ៉ូហាន |
|---|---|---|---|---|
| *ការឆ្លើយតបរបស់ព្រះគ្រីស្ទចំពោះពួកអ្នកប្រឆាំងនឹងទ្រង់* | | | | |
| ទំនាក់ទំនងរវាងព្រះគ្រីស្ទ និងស្តេចដាវីឌ ក្នុងលក្ខណៈជាព្រះអម្ចាស់ និងបុត្រា | ២២:៤១–៤៦ | ១២:៣៥–៣៧ | ២០:៤១–៤៤ | |
| សេចក្តីវេទនាទាំង៧ ចំពោះពួកគ្រូក្រឹត្យវិន័យ និងផារិស៊ី | ២៣:១–៣៦ | ១២:៣៨–៤០ | ២០:៤៥–៤៧ | |
| ការសោកស្តាយព្រះយេស៊ូវចំពោះក្រុងយេរូសាឡិម | ២៣:៣៧–៣៩ | | | |
| ស្ត្រីមេម៉ាយក្រីក្រម្នាក់ដាក់ដង្វាយទាំងអស់ដែលខ្លួនមាន | | ១២:៤១–៤៤ | ២១:១–៤ | |
| **ទំនាយអំពីការរៀបចំសម្រាប់ការសុគតរបស់ព្រះគ្រីស្ទ** | | | | |
| *ព្រះយេស៊ូវថ្លែងទំនាយនៅលើភ្នំដើមអូលីវ* | | | | |
| *អំពីព្រះវិហារ និងការយាងមកលើកទី២* | | | | |
| ការចាប់ផ្តើមថ្លែងទំនាយ | ២៤:១–៣ | ១៣:១–៤ | ២១:៥–៧ | |
| ដើមដំបូងនៃសេចក្តីវេទនា | ២៤:៤–១៤ | ១៣:៥–១៣ | ២១:៨–១៩ | |
| ការស្អប់ខ្ពើមនៃការបង្ខូចបំផ្លាញ និងទុក្ខព្រួយជាបន្តបន្ទាប់ | ២៤:១៥–២៨ | ១៣:១៤–២៣ | ២១:២០–២៤ | |
| ការយាងមករបស់កូនមនុស្ស | ២៤:២៩–៣១ | ១៣:២៤–២៧ | ២១:២៥–២៧ | |
| សញ្ញានៃការជិតមកដល់របស់កូនមនុស្ស តែពុំដឹងវេលាពិតប្រាកដ | ២៤:៣២–៤១ | ១៣:២៨–៣២ | ២១:២៨–៣៣ | |
| រឿងប្រៀបប្រដូច៥ដើម្បីបង្រៀនពីការចាំយាម និងការស្មោះត្រង់ | ២៤:៤២–២៥:៣០ | ១៣:៣៣–៣៧ | ២១:៣៤–៣៦ | |
| ការជំនុំជម្រះនៅពេលកូនមនុស្សយាងមក | ២៥:៣១–៤៦ | | | |
| *គម្រោងការធ្វើគុតព្រះយេស៊ូវ* | | | | |
| ពួកមេសាលាប្រជុំដាក់ផែនការចាប់ និងសម្លាប់ព្រះយេស៊ូវ | ២៦:១–៥ | ១៤:១–២ | ២២:១–២ | |
| នាងម៉ារាចាក់ប្រេងក្រអូបសម្រាប់ការបញ្ចុះព្រះសពព្រះយេស៊ូវ | ២៦:៦–១៣ | ១៤:៣–៩ | | ១២:២–៨ |
| ការព្រមព្រៀងរបស់យូដាស-អ៊ីស្ការីយ៉ុត ដើម្បីក្បត់ព្រះយេស៊ូវ | ២៦:១៤–១៦ | ១៤:១០–១១ | ២២:៣–៦ | |
| *ពិធីលៀងព្រះអម្ចាស់* | | | | |
| ការរៀបអាហារបុណ្យរំលង | ២៦:១៧–១៩ | ១៤:១២–១៦ | ២២:៧–១៣ | |
| ការចាប់ផ្តើមបរិភោគអាហារបុណ្យរំលង | ២៦:២០ | ១៤:១៧ | ២២:១៤–១៦,២៤–៣០ | |
| ការលាងជើងពួកសាវ័ក | | | | ១៣:១–២០ |
| ទីសំគាល់អំពីអ្នកដែលក្បត់ | ២៦:២១–២៥ | ១៤:១៨–២១ | ២២:២១–២៣ | ១៣:២១–៣០ |
| ទំនាយអំពីការបដិសេធន៍របស់ពេត្រុស | ២៦:៣១–៣៥ | ១៤:២៧–៣១ | ២២:៣១–៣៨ | ១៣:៣១–៣៨ |
| ទីបញ្ចប់នៃការបរិភោគអាហារ និងសេចក្តីបង្រៀន | | | | |
| អំពីពិធីលៀងព្រះអម្ចាស់(១កថ ១១:២៣–២៦) | ២៦:២៦–២៩ | ១៤:២២–២៥ | ២២:១៧–២០ | |
| *សេចក្តីបង្រៀន និងសេចក្តីអធិស្ឋាននៅលើភ្នំគែតសេម៉ានី* | | | | |
| សំណួរ និងចម្លើយអំពី ព្រះយេស៊ូវ ព្រះវរបិតា និងព្រះវិញ្ញាណបរិសុទ្ធ | | | | ១៤:១–៣១ |
| ដើមទំពាំងបាយជូរ ហើយនិងខ្នែងរបស់វា | | | | ១៥:១–១៧ |
| ការប្រឆាំងពីសំណាក់លោកិយ | | | | ១៥:១៨–១៦:៤ |
| ការយាងមក និងព្រះរាជកិច្ចនៃព្រះវិញ្ញាណបរិសុទ្ធ | | | | ១៦:៥–១៥ |
| ទំនាយពីសេចក្តីអំណរបន្ទាប់ពីព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ | | | | ១៦:១៦–២២ |
| ការសន្យាប្រទានសេចក្តីសុខសាន្ត និងឆ្លើយតបចំពោះសេចក្តីអធិស្ឋាន | | | | ១៦:២៣–៣៣ |
| សេចក្តីអធិស្ឋានរបស់ព្រះយេស៊ូវសម្រាប់ពួកសិស្ស និងអ្នកជឿលើទ្រង់ទាំងអស់ | | | | ១៧:១–២៦ |
| សេចក្តីអធិស្ឋានរបស់ព្រះយេស៊ូវនៅច្បារគែតសេម៉ានី | ២៦:៣០,៣៦–៤៦ | ១៤:២៦,៣២–៤២ | ២២:៣៩–៤៦ | ១៨:១ |
| **ការសុគតរបស់ព្រះយេស៊ូវ** | | | | |
| *ការក្បត់ និងការចាប់ខ្លួន* | | | | |
| ការក្បត់ ការចាប់ព្រះកាយ និងការបោះបង់ចោលព្រះយេស៊ូវ | ២៦:៤៧–៥៦ | ១៤:៤៣–៥២ | ២២:៤៧–៥៣ | ១៨:២–១២ |
| *ការកាត់ទោស* | | | | |
| វគ្គទី១ នៅមុខសាសន៍យូដាឈ្មោះអាណ | | | | ១៨:១៣– |
| ១៤,១៩–២៣ | | | | |
| វគ្គទី២ នៅមុខសាសន៍យូដា មុនដល់លោកកៃផា និងមេសាលាប្រជុំ | ២៦:៥៧,៥៩–៦៨ | ១៤:៥៣,៥៥–៦៥ | ២២:៥៤,៦៣–៦៥ | ១៨:២៤ |
| ការបដិសេធន៍របស់ពេត្រុស | ២៦:៥៨,៦៩–៧៥ | ១៤:៥៤,៦៦–៧២ | ២២:៥៤–៦២ | ១៨:១៥– |
| ១៨,២៥–២៧ | | | | |
| វគ្គទី៣ នៅមុខសាសន៍យូដាមុននឹងទៅឯមេសាលាប្រជុំ | ២៧:១ | ១៥:១ | ២២:៦៦–៧១ | |
| ការសោកស្តាយ និងការសម្លាប់ខ្លួនរបស់យូដាស(កច ១:១៨–១៩) | ២៧:៣–១០ | | | |
| វគ្គទី១ នៅមុខសាសន៍រ៉ូម៉ាំង មុនទៅដល់លោកពីឡាត់ | ២៧:២,១១–១៤ | ១៥:១–៥ | ២៣:១–៥ | ១៨:២៨–៣៨ |
| វគ្គទី២ នៅមុខសាសន៍រ៉ូម៉ាំងមុនទៅដល់ស្តេចហេរ៉ូឌអាន់ទីប៉ាស | | | ២៣:៦–១២ | |

| ភាពស៊ីសង្វាក់គ្នានៃព្រះគម្ពីរដំណឹងល្អ | | | | |
|---|---|---|---|---|
| | ម៉ាថាយ | ម៉ាកុស | លូកា | យ៉ូហាន |
| វគ្គទី៣ នៅមុខលោកពីឡាត់ | ២៧:១៥–២៦ | ១៥:៦–១៥ | ២៣:១៣–២៥ | ១៨:៣៩–១៩:១៦ |
| *ការធ្វើគុតព្រះយេស៊ូវ* | | | | |
| ការប្រមាថមើលងាយពីសំណាក់ពួកទាហានរ៉ូម៉ាំង | ២៧:២៧–៣០ | ១៥:១៦–១៩ | | |
| ការបណ្ដើរព្រះយេស៊ូវទៅកាន់ភ្នំគាល់កូថា | ២៧:៣១–៣៤ | ១៥:២០–២៣ | ២៣:២៦–៣៣ | ១៩:១៦–១៧ |
| បីម៉ោងដំបូងនៃការឆ្កាងព្រះយេស៊ូវ | ២៧:៣៥–៤៤ | ១៥:២៤–៣២ | ២៣:៣៣–៤៣ | ១៩:១៨,២៣–២៤<br>១៩:២២,២៥–២៧ |
| បីម៉ោងចុងក្រោយនៃការឆ្កាងព្រះយេស៊ូវ | ២៧:៤៥–៥០ | ១៥:៣៣–៣៧ | ២៣:៤៤–៤៥,៤៦ | ១៩:២៨–៣០ |
| ទីបន្ទាល់នៃការសុគតរបស់ព្រះយេស៊ូវ | ២៧:៥១–៥៦ | ១៥:៣៨–៤១ | ២៣:៤៥,៤៧–៤៩ | |
| *ការបញ្ចុះសពព្រះយេស៊ូវ* | | | | |
| លិខិតបញ្ជាក់នៃព្រះសពព្រះយេស៊ូវ និងការប្រគល់សព | ២៧:៥៧–៥៨ | ១៥:៤២–៤៥ | ២៣:៥០–៥២ | ១៩:៣១–៣៨ |
| ការបញ្ចុះព្រះសពព្រះយេស៊ូវទៅក្នុងផ្នូរ | ២៧:៥៩–៦០ | ១៥:៤៦ | ២៣:៥៣–៥៤ | ១៩:៣៩–៤២ |
| ផ្នូរត្រូវបានយាមដោយពួកស្ត្រី និងពួកទាហ៊ាន | ២៧:៦១–៦៦ | ១៥:៤៧ | ២៣:៥៥–៥៦ | |
| ការរស់ឡើងវិញ និងការយាងទៅស្ថានសួគ៌ | | | | |
| *ផ្នូរនៅទទេ* | | | | |
| ពួកស្រីៗបានមកដល់ផ្នូរ | ២៨:១ | ១៦:១ | | |
| ការប្រមៀលថ្មចេញ | ២៨:២–៤ | | | |
| ពួកស្រីៗបានមកឃើញផ្នូរនៅទទេ | ២៨:៥–៨ | ១៦:២–៨ | ២៤:១–៨ | ២០:១ |
| ពេត្រុស និងយ៉ូហានបានមកឃើញផ្នូរនៅទទេ | | | ២៤:៩–១២ | ២០:២–១០ |
| *ការបង្ហាញព្រះកាយក្រោយពេលមានព្រះជន្មរស់ឡើងវិញ* | | | | |
| បង្ហាញដល់នាងម៉ារាអ្នកស្រុកម៉ាក់ដាឡា | | ១៦:៩–១១ | | ២០:១១–១៨ |
| បង្ហាញដល់ស្ត្រីជាច្រើននាក់ផ្សេងទៀត | ២៨:៩–១០ | | | |
| ការរាយការណ៍ដល់ពួកទាហ៊ាន និងរដ្ឋអំណាចយូដា | ២៨:១១–១៥ | | | |
| បង្ហាញដល់សិស្ស២នាក់កំពុងធ្វើដំណើរទៅភូមិអេម្មូស | | ១៦:១២–១៣ | ២៤:១៣–៣២ | |
| ការរាយការណ៍ដល់សិស្ស២នាក់ និងអ្នកផ្សេងទៀត (១កថ ១៥:៥ក) | | | ២៤:៣៣–៣៥ | |
| បង្ហាញដល់សិស្ស១០នាក់ពេលកំពុងប្រជុំ | | ១៦:១៤ | ២៤:៣៦–៤៣ | ២០:១៩–២៥ |
| បង្ហាញដល់សិស្ស១១នាក់ពេលកំពុងប្រជុំ (១កថ ១៥:៥ខ) | | | | ២០:២៦–៣១ |
| បង្ហាញដល់សិស្ស៧នាក់ខណៈពេលកំពុងចាប់ត្រី | | | | ២១:១–២៥ |
| បង្ហាញដល់សិស្ស១១នាក់នៅស្រុកកាលីឡេ (១កថ ១៥:៦) | ២៨:១៦–២០ | ១៦:១៥–១៨ | | |
| បង្ហាញដល់យ៉ាកុប ប្អូនប្រុសព្រះយេស៊ូវ (១កថ ១៥:៧) | | | | |
| បង្ហាញដល់សិស្សនៅក្រុងយេរូសាឡិម (កថ ១:៣–៨) | | | ២៤:៤៤–៤៩ | |
| *ការយាងឡើងទៅស្ថានសួគ៌* | | | | |
| ការប្រទានពរ និងការចេញដំណើររបស់ព្រះគ្រីស្ទ (កថ ១:៩–១២) | | ១៦:១៩–២០ | ២៤:៥០–៥៣ | |

# កិច្ចការ

របស់ពួកសាវក

សេចក្ដីផ្ដើម

## អ្នកនិពន្ធ

ទោះជាអ្នកនិពន្ធមិនបានបញ្ជាក់ឈ្មោះរបស់ខ្លួនក៏ដោយ ក៏នៅមានភស្តុតាងពីខាងក្រៅបទគម្ពីរនេះជាច្រើន និងសេចក្ដីពិតដែលមានចែងនៅក្នុងកណ្ឌគម្ពីរកិច្ចការផ្ទាល់ បានឈានទៅដល់ការសន្និដ្ឋានមួយថាលោក "លូកា" គឺជាអ្នកនិពន្ធកណ្ឌគម្ពីរនេះឡើង ។ មានស្នាមបន្ទាល់ខាងក្រៅព្រះគម្ពីរដំបូងបំផុតនៅក្នុងសៀវភៅ *មុយរ៉ាតូរាន កាណុន* (Muratorian Canon ប្រហែលឆ្នាំទី ១៧០ គ.ស) បានបញ្ជាក់យ៉ាងច្បាស់ថា លោកលូកាជាអ្នកនិពន្ធកណ្ឌគម្ពីរដំណឹងល្អលូកា និងកណ្ឌគម្ពីរកិច្ចការ ។ *អឺសីប៊ីស* (Eusebius ប្រហែលឆ្នាំទី ៣២៥ គ.ស) បានរក្សាទុកនូវកំណត់ត្រា និងព័ត៌មានពីប្រភពជាច្រើន ដែលបញ្ជាក់ថា លោកលូកាគឺជាអ្នកនិពន្ធកណ្ឌគម្ពីរទាំងពីរនេះឡើង ។

តាមរយៈកណ្ឌគម្ពីរនេះផ្ទាល់មានគន្លឹះខ្លះៗដែលបញ្ជាក់អំពីអ្នកនិពន្ធ:

១. លោកលូកា ជា *"គូកនលោកប៉ុល"* ។ ក្នុងការពិពណ៌នាអំពីហេតុការណ៍ ដែលកើតមានឡើងនៅក្នុងគម្ពីរកិច្ចការ មានវគ្គខ្លះប្រើសព្វនាម "យើង" ។ ត្រង់ចំណុចដែលមានប្រើសព្វនាម "យើង" អ្នកនិពន្ធពិតជាបានរាប់បញ្ចូលខ្លួនគាត់ផ្ទាល់ ថាជាគូកនរបស់លោកប៉ុលម្នាក់ដែរ (១៦:១០-១៧ ២០:៥-២១:១៨ ២៧:១-២៨:១៦ មើលការពន្យល់ កច ១៦:១០,១៧ ២៧:១) ។ ចំពោះប្រវត្តិវិទូ ក៏ដូចជាអ្នកនិពន្ធរូបនេះដែរ ដើម្បីបង្ហាញនូវលក្ខណៈត្រឹមត្រូវក្នុងការតែងនិពន្ធ ពួកគេច្រើនប្រើប្រាស់សព្វនាម "យើង" នៅកន្លែងមួយចំនួន ហើយសព្វនាម "ពួកគេ" នៅកន្លែងផ្សេងៗទៀត ។ ដោយសំអាងលើសព្វនាម "យើង" អ្នកនិពន្ធប្រហែលជាមានវត្តមានជាមួយលោកប៉ុលនៅក្នុងហេតុការណ៍ណាមួយច្បាស់លាស់ជាមិនខាន ។

វគ្គដែលមានប្រើសព្វនាម "យើង" គឺរួមបញ្ចូលទាំងរយៈពេលដែលលោកប៉ុលជាប់ក្នុងពន្ធនាគារ២ឆ្នាំ នៅទីក្រុងរ៉ូមផងដែរ (ជំពូក២៨) ។ ក្នុងរយៈពេលនោះ លោកប៉ុលបានសរសេរសំបុត្រមួយចំនួន រួមទាំងសំបុត្រភីលេម៉ូន និងកូល៉ុសផងដែរ ។ នៅក្នុងសំបុត្រទាំងពីរនោះ គាត់បានផ្ញើក្ដីនឹករឭកពីគូកនរួមការងាររបស់គាត់ ដែលក្នុងនោះមានលោក "លូកា" ម្នាក់ដែរ (កល ៤:៩-១៧ និងមើលការពន្យល់ ភម ២៣-២៤) ។ ដូច្នេះ លោកលូកាម្នាក់នេះស័ក្ដិសមជាអ្នកនិពន្ធកណ្ឌគម្ពីរកិច្ចការនេះជាងគេ ។

២. លោកលូកា ជា *"គ្រូពេទ្យ"* ។ ទោះបីមិនអាចបញ្ជាក់ថា អ្នកនិពន្ធកណ្ឌព្រះគម្ពីរកិច្ចការគឺជាគ្រូពេទ្យ ដោយសំអាងលើវាក្យសព្ទដែលគាត់ប្រើនោះក៏ដោយ ក៏លក្ខណៈពាក្យពេចន៍ដែលគាត់ប្រើ និងការអប់រំក្នុងនាមជាគ្រូពេទ្យមានឥទ្ធិពលយ៉ាងខ្លាំងចំពោះការសរសេររបស់គាត់ (មើលការពន្យល់ កច ២៨:៦) ។ ម្យ៉ាងទៀត ថ្វីបើគ្រូពេទ្យនាសតវត្សរ៍ទី១ មិនមានឯកទេសផ្នែកវាក្យសព្ទដូចជាគ្រូពេទ្យនាពេលបច្ចុប្បន្នក៏ដោយ ក៏នៅមានការមួយចំនួនក្នុងព្រះគម្ពីរដំណឹងល្អលូកា និងព្រះគម្ពីរកិច្ចការ ហាក់ដូចជាបង្ហាញថាគ្រូពេទ្យម្នាក់នេះជាអ្នកនិពន្ធកណ្ឌគម្ពីរទាំងពីរនេះឡើង ។ គួរចងចាំផងដែរថា លោកប៉ុលបានប្រើពាក្យ "គ្រូពេទ្យ" ក្នុងការពិពណ៌នាអំពីលោកលូកា (មើលការពន្យល់ កល ៤:១៤) ។

## កាលបរិច្ឆេទ

មានកាលបរិច្ឆេទ២ត្រូវបានលើកឡើង: (១).ប្រហែលឆ្នាំ៦៣គ.ស គឺបន្ទាប់ពីហេតុការណ៍ចុងក្រោយបង្អស់ត្រូវបានកត់ចូលក្នុងកណ្ឌគម្ពីរកិច្ចការនេះតែម្ដង (២).ប្រហែលឆ្នាំ៧០ គ.ស ឬក្រោយជាងនេះទៅទៀត ។

កាលបរិច្ឆេទទី១ត្រូវបានគាំទ្រដោយសារ:

*១. ពុំបាននិយាយអំពីហេតុការណ៍បន្ទាប់:* ហេតុការណ៍ដែលបានកើតឡើងនៅក្រោយឆ្នាំទី៦៣គ.ស មិនត្រូវបានកត់ត្រាចូលនេះ ប្រហែលជាកណ្ឌគម្ពីរកិច្ចការមិនបាននិយាយដល់រឿងរ៉ាវ ដែលកើតមានឡើងចំពោះលោកប៉ុល បន្ទាប់ពីរយៈពេល២ឆ្នាំក្នុងពន្ធនាគារនៅទីក្រុងរ៉ូមនោះទេ [ឧ: ការឆេះទីក្រុងរ៉ូម និងការរងទុក្ខនៃគ្រីស្ទបរិស័ទនៅទីនោះ (ឆ្នាំ៦៤គ.ស) ការស្លាប់របស់លោកពេត្រុស និងលោកប៉ុល (ឆ្នាំ៦៧គ.ស) ហើយនិងការវិនាសនៃទីក្រុងយេរូសាឡិម (ឆ្នាំ៧០ គ.ស)]។

*២. ពុំមានលទ្ធផលអំពីការវិនិច្ឆ័យទោសកំហុសរបស់លោកប៉ុល:* ប្រសិនបើលោកលូកាដឹងអំពីលទ្ធផល នៃទោសកំហុសដែលលោកប៉ុលត្រូវទទួល (២៨:៣០) ហេតុអ្វីបានជាគាត់មិនកត់ត្រាហេតុការណ៍ទាំងនោះ ? ប្រហែលជាគាត់ចង់ទុកឱ្យហេតុការណ៍ទាំងអស់នោះនៅតែថ្មីជានិច្ច ។

រីឯអស់អ្នកដែលពេញចិត្តនឹងកាលបរិច្ឆេទទី២បានអះអាងថា បទគម្ពីរ "កច ១:៨" (មើលការពន្យល់) គឺជាគោលបំណងមួយ

របស់លោកលូកា ។ គោលបំណងនោះហើយដែលធ្វើឱ្យការបញ្ចប់កណ្ឌគម្ពីរកិច្ចការតាមរបៀបយ៉ាងដូច្នេះ ។ គាត់ចង់បង្ហាញអំពីរបៀបដែលពួកជំនុំជ្រៀតចូលទៅក្នុងពិភពលោកនាសម័យនោះ ដោយមានលក្ខណៈជារង្វង់សាកល (ដំណើរជាជុំ) មួយ (ទីក្រុងយេរូសាឡិម ស្រុកសាម៉ារី ស្រុកយូដា និងចុងបំផុតនៃពិភពលោក) និងរហូតបានទៅដល់ទីក្រុងរ៉ូម ដែលជាមជ្ឈមណ្ឌលនយោបាយ និងវប្បធម៌ពិភពលោក។ តាមការយល់ឃើញរបស់មតិទី២នេះ បានអះអាងថា មូលហេតុដែលធ្វើឱ្យលោកលូកាមិននិយាយអំពីការស្លាប់របស់លោកប៉ុល (ប្រហែលឆ្នាំ ៧០ គ.ស) និងការវិនាសនៃទីក្រុងយេរូសាឡិម (៧០ គ.ស) ព្រោះហេតុការណ៍ទាំងនោះមិនមានទំនាក់ទំនងទៅនឹងគោលបំណងនៃកណ្ឌគម្ពីរកិច្ចការទេ ។ ដូច្នេះ កណ្ឌគម្ពីរ កិច្ចការ" ត្រូវបានសរសេរឡើងប្រហែលជានៅឆ្នាំទី ៧០ គ.ស ឬក្រោយមកទៀត ។

**អ្នកទទួល**

អ្នកទទួលកណ្ឌគម្ពីរកិច្ចការ និងដំណឹងល្អលូកាដំបូងគេគឺ លោក "ថេវភីល" (សូមមើលសេចក្តីផ្តើមគម្ពីរលូកា ចំណុចអ្នកទទួល និងគោលបំណង) ។

**សារៈសំខាន់**

កណ្ឌគម្ពីរកិច្ចការផ្តល់ជាស្ពានសម្រាប់ការសរសេរព្រះគម្ពីរសញ្ញាថ្មី ដោយបានបញ្ជាក់យ៉ាងច្បាស់ អំពីព្រះរាជកិច្ចដែលព្រះយេស៊ូវគ្រីស្ទ "បានចាប់ផ្តើមធ្វើ និងបង្រៀន" (មើលការពន្យល់ កច ១:១) ហើយបន្តធ្វើ និងបង្រៀន តាមរយៈពួកសាវក និងពួកជំនុំរបស់ទ្រង់ ។ ព្រះគម្ពីរកិច្ចការបានធ្វើឱ្យកណ្ឌគម្ពីរដំណឹងល្អទាំងអស់ និងសំបុត្ររបស់ពួកសាវកមានទំនាក់ទំនងគ្នា ។ ម្យ៉ាងទៀតកណ្ឌគម្ពីរនេះបានផ្តល់នូវរឿងរ៉ាវជីវិតរបស់លោកប៉ុល ដែលធ្វើឱ្យយើងអាចយល់ដឹងអំពីសេចក្តីពិតជាច្រើន នៅក្នុងសំបុត្ររបស់គាត់ ។ យោងតាមទីតាំងភូមិសាស្ត្រ ហេតុការណ៍ទាំងឡាយនៅក្នុងគម្ពីរកិច្ចការត្រូវបានគេដឹងឮសុសសាយ ចាប់ពីក្រុងយេរូសាឡិម ជាកន្លែងពួកជំនុំចាប់ផ្តើមដំបូង រហូតដល់ទីក្រុងរ៉ូម ដែលជាមជ្ឈមណ្ឌលនយោបាយនៃចក្រភពរ៉ូម៉ាំង ។ រីឯតាមលក្ខណៈប្រវត្តិសាស្ត្រវិញ ព្រះគម្ពីរកិច្ចការបានប្រាប់អំពីហេតុការណ៍ ដែលបានកើតឡើងចំពោះពួកជំនុំ ក្នុងអំឡុងពេល៣០ឆ្នាំដំបូង ។ វាក៏ជាស្ពានដែលភ្ជាប់ទំនាក់ទំនងរវាងពួកជំនុំដំបូង និងពួកជំនុំនៅសម័យកាលបន្តបន្ទាប់មកទៀតផងដែរ ។ កណ្ឌគម្ពីរនេះជាជំនួយដ៏សំខាន់សម្រាប់សិក្សាបង្កើននូវការយល់ដឹង ដើម្បីយកទៅអនុវត្តក្នុងការគ្រប់គ្រង និងដឹកនាំពួកជំនុំនៅគ្រប់សម័យកាលទាំងអស់ ។

**គោលរឿង និងគោលបំណង**

គោលរឿងនៃកណ្ឌគម្ពីរកិច្ចការគឺបានសង្ខេបយ៉ាងច្បាស់នៅក្នុង "កច ១:៨ (មើលការពន្យល់)"។ ជារបៀបសាមញ្ញមួយដែលអ្នកនិពន្ធសម័យនេះចាប់ផ្តើមផ្នែកទី២ ដោយសង្ខេបផ្នែកទី១ និងបង្ហាញនូវមាតិកាសម្រាប់ផ្នែកទី២របស់គេជាមុន ។ លោកលូកាបានសង្ខេបផ្នែកទី១ នៅក្នុង"កច ១:១–៣" ហើយគោលរឿងនៃផ្នែកទី២របស់គាត់បានផ្តើមដោយព្រះបន្ទូលរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទគឺ *"នោះអ្នករាល់គ្នានឹងបានព្រះចេស្តា ហើយនិងធ្វើបន្ទាល់ពីខ្ញុំ នៅក្រុងយេរូសាឡិម ព្រមទាំងស្រុកយូដា និងស្រុកសាម៉ារីទាំងមូល ហើយរហូតដល់ចុងផែនដីបំផុតផង"*(១:៨) ។

គោលបំណងសំខាន់ៗរួមមាន:

*១. ដើម្បីបង្ហាញនូវហេតុការណ៍ប្រវត្តិសាស្ត្រ ។* សារៈសំខាន់នៃព្រះគម្ពីរកិច្ចការគឺ បានប្រាប់អំពីការបង្កើត ការចាប់ផ្តើមនៃពួកជំនុំ ការចម្រើនឡើងនៃដំណឹងល្អ និងការខំប្រឹងប្រែងរបស់ពួកសាវកក្នុងការប្រកាសដំណឹងល្អ ។ ទិដ្ឋភាពពិសេសដោយឡែកមួយទៀតនៃភាពជាគ្រីស្ទបរិស័ទគឺ "មូលដ្ឋានគ្រឹះនៃប្រវត្តិសាស្ត្រដ៏រឹងមាំ" ។ ព្រះជន្មរបស់ព្រះយេស៊ូវគ្រីស្ទ និងសេចក្តីបង្រៀនរបស់ទ្រង់ត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងព្រះគម្ពីរដំណឹងល្អ ។ ចំណែកឯកណ្ឌគម្ពីរកិច្ចការវិញ បានផ្តល់នូវភាពពិតនៃការចាប់ផ្តើម និងការចម្រើនឡើងនៃពួកជំនុំ ដែលជាលទ្ធផលនៃព្រះរាជកិច្ចរបស់ព្រះយេស៊ូវគ្រីស្ទ បន្ទាប់ពីទ្រង់រស់ពីសុគតឡើងវិញ ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ និងតាមរយៈពួកសាវករបស់ទ្រង់ ។

*២. ដើម្បីផ្តល់នូវគ្រឿងការពារ ។* កណ្ឌគម្ពីរកិច្ចការបានកត់ត្រានូវរបៀបការពាររបស់គ្រីស្ទបរិស័ទចំពោះពួកយូដា (៤:៨–១២) និងសាសន៍ដទៃ(២៥:៨–១១) ដោយមានគោលបំណងច្បាស់លាស់គឺ "ការប្រែចិត្ត"។ វាបានបង្ហាញអំពីរបៀបដែលពួកជំនុំដំបូងតស៊ូប្រឆាំងនឹងពួកប៉ាកាន (pagan ឬហៅថាសាសន៍ដទៃ) និងផ្តត់គំនិតរបស់ពួកយូដារដ្ឋាភិបាលរ៉ូម៉ាំង ហើយនិងពួកហេលេន ។ លោកលូកាប្រហែលជាសរសេរកណ្ឌគម្ពីរនេះឡើង ក្នុងពេលដែលលោកប៉ុលកំពុងទទួលការវិនិច្ឆ័យទោសនៅទីក្រុងរ៉ូម ។

*៣. ដើម្បីផ្តល់នូវការណែនាំ ។* លោកលូកាពុំបានដឹងពីអាយុកាល នៃការចម្រើនឡើងរបស់ពួកជំនុំ នៅលើផែនដីនេះទេ។ ប៉ុន្តែដរាបណាពួកជំនុំនៅតែបន្តការងាររបស់ខ្លួន នោះកណ្ឌគម្ពីរកិច្ចការ នៅតែជាមគ្គុទ្ទេសក៍មួយដ៏សំខាន់ជានិច្ច ។ ក្នុងគម្ពីរកិច្ចការ យើងឃើញមានចំណុចសំខាន់ៗ ដែលជាមូលដ្ឋានសម្រាប់អនុវត្ត ចំពោះស្ថានការណ៍ជាក់ស្តែងនៃបញ្ហា និងការបៀតបៀនផ្សេងៗ ។ ហើយគោលការណ៍ដដែលនេះនឹងនៅតែបន្តអនុវត្ត បានរហូតដល់ថ្ងៃព្រះគ្រីស្ទយាងមកវិញ ។

*៤. ដើម្បីពណ៌នាអំពីជ័យជម្នះរបស់គ្រីស្ទបរិស័ទ ។* ជ័យជម្នះរបស់ពួកជំនុំក្នុងការនាំដំណឹងល្អពីក្រុងយេរូសាឡិម ទៅទីក្រុងរ៉ូម និងក្នុងការបង្កើតពួកជំនុំ ឆ្លងកាត់តំបន់គ្រប់គ្រងដោយចក្រភពរ៉ូម៉ាំង បានបង្ហាញឱ្យឃើញថា ការងារទាំងអស់នោះមិនមែនមកពីមនុស្សទេ ប៉ុន្តែ ជ័យជម្នះទាំងនោះ គឺស្ថិតនៅក្រោមការដឹកនាំរបស់ព្រះយេស៊ូវគ្រីស្ទ និងតាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។

**លក្ខណៈពិសេស**

*១. ប្រវត្តិសាស្ត្រពិតពិស្តារ ។* អ្នកប្រវត្តិសាស្ត្រយល់ឃើញថា គ្រប់ទំព័រនៅក្នុងគម្ពីរកិច្ចការ មានពេញដោយការពណ៌នាដ៏ជាក់លាក់ និងច្បាស់លាស់ ។ ហេតុការណ៍ទាំងឡាយក្នុងអំឡុងពេលប្រហែល៣០ឆ្នាំ បានឮសុសសាយឆ្លងកាត់ក្រុងយេរូសាឡិម រហូតដល់ទីក្រុងរ៉ូម ។ ការរៀបរាប់របស់លោកលូកាចំពោះពេលវេលា និងកន្លែងទាំងនោះ គឺមានបញ្ចូលនូវគ្រប់ប្រភេទនៃមនុស្សនិងវប្បធម៌ របបគ្រប់គ្រងរដ្ឋបាលផ្សេងៗគ្នា រូបភាពតុលាការនៅក្រុងសេសារា និងហេតុការណ៍វិនាសកម្ម ដូចជានៅក្រុងអាន់ទីយ៉ូក ក្រុងអេភេសូរ ក្រុងអាថែន ក្រុងកូរិនថូស ក្រុងរ៉ូម ហើយមានរាប់បញ្ចូលនូវស្រុកនៃពួកសាសន៍ដទៃ និងសាសន៍យូដាផង ។ គ្រប់ករណីទាំងអស់ ការស្រាវជ្រាវផ្នែកបុរាណវត្ថុវិទ្យាបានអះអាងថា លោកលូកាពិតជាបានប្រើប្រាស់ពាក្យពេចន៍ដ៏ត្រឹមត្រូវចំពោះពេលវេលា និងទីកន្លែងដែលគាត់បានលើកឡើង ។

*២. ភាពឥតខ្ចោះនៃអក្សរសាស្ត្រ ។* លោកលូកាមិនត្រឹមតែមានវាក្យសព្ទទូលំទូលាយ ធៀបនឹងអ្នកនិពន្ធសញ្ញាថ្មីផ្សេងៗទៀតប៉ុណ្ណោះទេ គឺគាត់ថែមទាំងបានប្រើនូវទម្រង់អក្សរសាស្ត្រ ត្រូវនឹងហេតុការណ៍ដែលគាត់កត់ត្រានោះទៀតផង ដូចជា ពេលខ្លះគាត់ប្រើភាសាក្រេកបុរាណ ហើយពេលខ្លះទៀតគាត់ប្រើភាសា "អើរ៉ាម-ប៉ាឡេស្ទីន"(Palestinian Aramaic ឬហៅថាភាសាហេព្រើរ) នៅដើមសតវត្សរ៍ទី១ ដើម្បីបង្ហាញអំពីលក្ខណៈដ៏ត្រឹមត្រូវនៃការសរសេររបស់គាត់ ។ នេះគឺជាលក្ខណៈពិសេសមួយនៃការអនុវត្តន៍ដោយប្រុងប្រយ័ត្នរបស់លោកលូកា ពីព្រោះគាត់បានប្រើប្រាស់ភាសាត្រូវនឹងពេលវេលា និងទីកន្លែងដែលគាត់បានលើកឡើង ។ លក្ខណៈជាអើរ៉ាម (ឬហៅថាហេព្រើរ) ត្រូវបានប្រើ នៅពេលគាត់ពណ៌នាអំពីហេតុការណ៍ ដែលកើតឡើងនៅដែនដីបរិសុទ្ធ (ឬហៅថាទឹកដីសន្យាជំពូក១-១២)។ លក្ខណៈទាំងនោះ បានបាត់បង់អស់ទៅហើយ ពេលដែលលោកប៉ុលធ្វើដំណើរទៅតំបន់មួយចំនួននៃប្រទេសក្រេក ជាកន្លែងដែលមានប្រជាជននិយាយភាសាអើរ៉ាម (ឬហេព្រើរ) រស់នៅនោះ ។

*៣. ការពណ៌នាប្រកបដោយទេពកោសល្យខ្ពស់ ។* ការប្រើទេព្យកោសល្យក្នុងការនិយាយរបស់លោកលូកា គឺជាជំនួយយ៉ាងច្រើនសម្រាប់ការតែងនិពន្ធរបស់គាត់ និងធ្វើឱ្យសកម្មភាពទាំងឡាយមានភាពរស់រវើកគ្រប់ទីកន្លែង ។

*៤. គោលដៅពិតប្រាកដ ។* លោកលូកាបានរៀបចំឯកសារយ៉ាងត្រឹមត្រូវ និងមានភាពសុក្រឹតបំផុត ។ គាត់បានបង្ហាញនូវការពិតទាំងឡាយដែលបានកើតឡើងនៅក្នុងពួកជំនុំដំបូង ដោយកត់ត្រាទុករាល់កំហុស ជ័យជម្នះ ការល្អ និងការអាក្រក់របស់ពួកគេ ។ មិនគ្រាន់តែទំនាស់រវាងពួកហេលេន និងពួកហេព្រើរប៉ុណ្ណោះទេ សូម្បីតែភាពមិនចុះសម្រុងគ្នារវាងលោកប៉ុល និងលោកបាណាបាស ក៏ត្រូវបានគាត់កត់ត្រាទុកផងដែរ (មើលការពន្យល់ ១៥:៣៩)។

*៥. ការថ្លែងព្រះបន្ទូលដ៏មានប្រសិទ្ធិភាព ។* លក្ខណៈពិសេសគួរឱ្យកត់សំគាល់មួយទៀតនៃព្រះគម្ពីរកិច្ចការ នោះគឺការថ្លែងព្រះបន្ទូលដែលចែកជា (១).ការប្រកាសដំណឹងល្អ ទី១សម្រាប់ពួកយូដា ទី២សម្រាប់អស់អ្នកដែលគោរពកោតខ្លាចដល់ព្រះអម្ចាស់ (២:១៤-៤០ ៣:១២-២៦ ៤:៨-១២ ៥:២៩-៣២ ១០:៣៤-៤៣ ១៣:១៦-៤១) និងចំពោះពួកអ្នកកាន់សាសនា អ្នកកាន់ក្រឹត្យវិន័យ (១៧:២២-៣១) (២).សេចក្ដីសង្គ្រោះ (១:១៦-១៧,២០-២២, ១៥:៧-១១,១៣-២១) (៣).ការលន់តួបាប (៧:២-៥២ ២២:១-២១ ២៣:១-៦ ២៤:១០-២១ ២៥:៨,១០ ២៦:២-២៣ ២៨:១៧-២០,២១-២២,២៥-២៨) (៤).ការប្រៀនប្រដៅ (២០:១៨-៣៥)។ ប្រយោគមួយចំនួនមិនបាននិយាយត្រង់ៗតែម្តងទេ គឺទាមទារឱ្យមានពេលវេលាក្នុងការសញ្ជឹងគិត ទើបអាចយល់បានគ្រប់ជ្រុងជ្រោយ ។ ដូច្នេះ ការសិក្សាអំពីសម្រង់សេចក្ដីទាំងនេះ (អ្នកនិយាយ អ្នកស្តាប់ ព្រឹត្តិការណ៍ ភាសា របៀបនៃការសរសេរ) ផ្តល់ឱ្យយើងនូវភស្តុតាង និងជំនឿថា អត្ថបទគម្ពីរកិច្ចការ មានភាពសុក្រឹតត្រឹមត្រូវបំផុត ។

**គម្រោងសង្ខេប**

លោកលូកាបានដាក់បញ្ចូលគ្នានូវចំណាប់អារម្មណ៍ និងចំណុចសំខាន់ៗទាំងឡាយ ក្នុងការរៀបរាប់អំពីការចាប់ផ្តើម និងការចម្រើនឡើងនៃពួកជំនុំ ។ ប្លង់សម្រាប់កណ្ឌគម្ពីរនេះរួមមាន: (១).បុគ្គលសំខាន់ៗ: លោកពេត្រុស និងលោកប៉ុល (២).ដើមរឿង និងហេតុការណ៍សំខាន់ៗ: ព្រះរាជកិច្ចនៃព្រះវិញ្ញាណបរិសុទ្ធ បេសកកម្មឈានមុខទៅទីចម្រូតថ្មីៗ ការប្រែចិត្ត ការចម្រើនឡើងនៃពួកជំនុំ ជីវិតក្នុងសហគមន៍គ្រីស្ទបរិស័ទ (៣).ទីតាំងភូមិសាស្ត្រ ។

**I. លោកពេត្រុស និងការចាប់ផ្ដើមនៃពួកជំនុំនៅទឹកដីសន្យា (ដែនដីបរិសុទ្ធ) (ជំពូក ១–១២)**

ក. ស្រុកយូដា ស្រុកកាលីឡេ និងស្រុកសាម៉ារី (១:១–៩:៣១ មើលការពន្យល់ ៩:៣១)

១. សេចក្ដីផ្ដើម (១:១–២)

២. ព្រះរាជកិច្ចរបស់ព្រះយេស៊ូវគ្រីស្ទបន្ទាប់ពីទ្រង់មានព្រះជន្មរស់ពីសុគតឡើងវិញ (១:៣–១១)

៣. រយៈពេលរង់ចាំព្រះវិញ្ញាណបរិសុទ្ធ (១:១២–២៦)

៤. ការពេញដោយព្រះវិញ្ញាណបរិសុទ្ធ (ជំពូក២)

៥. ការប្រោសមនុស្សខ្វិន និងលទ្ធផលនៃការចាប់ខ្លួនលោកពេត្រុស និងលោកយ៉ូហាន (៣:១–៤:៣១)

៦. សហគមន៍នៃការល្អ (៤:៣២–៥:១១)

៧. ការចាប់ខ្លួនពួកសាវ័កទាំង១២ (៥:១២–៤២)

៨. ការជ្រើសរើសអ្នកទាំង៧នាក់ (៦:១–៧)

៩. ការចាប់ខ្លួនលោកស្ទេផាន និងការស្លាប់របស់គាត់ (៦:៨–៧:៦០)

១០. ការខ្ចាត់ខ្ចាយនៃពួកជំនុំនៅទីក្រុងយេរូសាឡិម (៨:១–៤)

១១. កិច្ចការរបស់លោកភីលីព (៨:៥–៤០)

១១.ក. នៅស្រុកសាម៉ារី (៨:៥–២៥)

១១.ខ. ជួបជាមួយអ្នកកម្រៀវជាតិអេធីយ៉ូពីម្នាក់ (៨:២៦–៤០)

១២. ការប្រែចិត្តរបស់លោកសុល (៩:១–៣១)

ខ. ស្រុកភេនីស កោះគីប្រុស ក្រុងអាន់ទីយ៉ូក (៩:៣២–១២:២៥ មើលការពន្យល់ ១១:១៩)

១. កិច្ចការរបស់លោកពេត្រុស នៅឆ្នេរសមុទ្រមេឌីទែរ៉ាណេ (៩:៣២–១១:១៨)

ក. ជួបជាមួយ លោកអេនាស និងនាងតេប៊ីថា (៩:៣២–៤៣)

ខ. ជួបជាមួយលោកកូនេលាស (១០:១–១១:១៨)

២. ពួកជំនុំសាសន៍ដទៃដំបូងនៅទីក្រុងអាន់ទីយ៉ូក (១១:១៩–៣០)

៣. ការបៀតបៀនរបស់ស្ដេចហេរ៉ូឌ និងក្រោយពីការសុគត (ជំពូក១២)

**II. លោកប៉ុល និងការចម្រើនឡើងនៃពួកជំនុំ ពីក្រុងអាន់ទីយ៉ូក រហូតដល់ទីក្រុងរ៉ូម (ជំពូក១៣–២៨)**

ក. នៅក្នុងតំបន់នៃស្រុកពីស៊ីឌា និងស្រុកកាឡាទី (១៣:១–១៥:៣៥ មើលការពន្យល់ ១៦:៦)

១. ដំណើរបេសកកម្មលើកទី១របស់លោកប៉ុល (ជំពូក១៣–១៤)

២. ការប្រជុំគ្នានៅក្រុងយេរូសាឡិម (១៥:១–៣៥)

ខ. ជុំវិញស្រុកម៉ាសេដូន (១៥:៣៦–២១:១៦ និងមើលការពន្យល់ ១៦:៩)

១. ដំណើរបេសកកម្មលើកទី២របស់លោកប៉ុល (១៥:៣៦–១៨:២២)

២. ដំណើរបេសកកម្មលើកទី៣របស់លោកប៉ុល (១៨:២៣–២១:១៦)

គ. នៅឯទីក្រុងរ៉ូម (២១:១៧–២៨:៣១ និងមើលការពន្យល់ ២៨:១៤)

១. ការជាប់គុករបស់លោកប៉ុលនៅទីក្រុងយេរូសាឡិម (២១:១៧–២៣:៣៥)

ក. ការចាប់ខ្លួន (២១:១៧–២២:២៩)

ខ. ការកាត់ទោសមុខក្រុមជំនុំ (២២:៣០–២៣:១១)

គ. ការផ្ទេរទៅឯទីក្រុងសេសារា (២៣:១២–៣៥)

២. ការជាប់គុករបស់លោកប៉ុលនៅទីក្រុងសេសារា (ជំពូក២៤–២៦)

ក. ការកាត់ទោសនៅមុខលោកភេលីច (ជំពូក២៤)

ខ. ការកាត់ទោសនៅមុខលោកភេស្ទុស (២៥:១–១២)

គ. ការថ្លែងនៅមុខលោកភេស្ទុស និងព្រះរាជាអ័គ្រីប៉ា (២៥:១៣–២៦:៣២)

៣. ការធ្វើដំណើរទៅទីក្រុងរ៉ូម (២៧:១–២៨:១៥)

៤. ពីរឆ្នាំជាប់ឃុំក្នុងផ្ទះនៅទីក្រុងរ៉ូម (២៨:១៦–៣១)

## ព្រះយេស៊ូវបានលើកឡើងទៅស្ថានសួគ៌

**១** ១ឱលោកថេវភីលអើយ ខ្ញុំបានតែងរឿង១ច្បាប់មុន
នោះ[ក] ពីអស់ទាំងការដែលព្រះយេស៊ូវ បានចាប់តាំងធ្វើ
ហើយបង្រៀន[ខ] ២ដរាបដល់ថ្ងៃ ដែលព្រះបានលើកទ្រង់
ឡើងផុតទៅហើយ[គ] គឺក្រោយដែលទ្រង់បានផ្ដាំ[ឃ] ដោយនូវ
ព្រះវិញ្ញាណបរិសុទ្ធ ដល់ពួកសាវក[ង] ជាពួកអ្នកដែលទ្រង់
បានរើស[ច] ៣ហើយកាលទ្រង់បានរងទុក្ខរួចហើយ នោះក៏
បានសំដែងអង្គទ្រង់មកទាំងរស់ ឱ្យពួកសាវកនោះឃើញ[ឆ]
ដោយសារភស្តុតាងជាច្រើន ព្រមទាំងលេចមកឯគេ ក៏
សំដែងពីអស់ទាំងសេចក្ដីខាងឯនគរព្រះ[ជ] ក្នុងរវាង៤០ថ្ងៃ
៤រួចមក កាលបានប្រជុំទាំងអស់គ្នាហើយ នោះទ្រង់ហាម
មិនឱ្យគេចេញពីក្រុងយេរូសាឡិមឡើយ ដោយបន្ទូលថា
ត្រូវឱ្យនៅចាំ[ឈ] សេចក្ដីសន្យានៃព្រះវរបិតា ដែលអ្នក
រាល់គ្នាបានឮខ្ញុំថ្លែងប្រាប់ហើយ[ញ] ៥ដ្បិតពិតជាលោក
យ៉ូហានបានធ្វើបុណ្យជ្រមុជដោយទឹក[ដ] ប៉ុន្តែ នៅបន្តិចទៀត
អ្នករាល់គ្នានឹងទទួលបុណ្យជ្រមុជ ដោយព្រះវិញ្ញាណ
បរិសុទ្ធវិញ[ឋ] ។
៦ដូច្នេះ កាលពួកសាវកបានប្រជុំគ្នា នោះក៏ទូលសួរថា
ព្រះអម្ចាស់អើយ តើនៅគ្រានេះឬអី ដែលទ្រង់នឹងតាំង
នគរ[ឌ] ឱ្យសាសន៍អ៊ីស្រាអែលឡើងវិញនោះ ៧តែទ្រង់មាន
បន្ទូលឆ្លើយថា មិនត្រូវឱ្យអ្នករាល់គ្នាដឹងពេល ដឹងកំណត់
ដែលព្រះវរបិតាបានទុកនៅ ក្នុងអំណាច របស់ទ្រង់នោះ
ឡើយ[ឍ] ៨ប៉ុន្តែ កាលណាព្រះវិញ្ញាណបរិសុទ្ធបានមកសណ្ឋិត
លើអ្នករាល់គ្នា[ណ] នោះអ្នករាល់គ្នានឹងបានព្រះចេស្ដា ហើយ
និងធ្វើជាទីបន្ទាល់[ត]ពីខ្ញុំ នៅក្រុងយេរូ-សាឡិមព្រមទាំង
ស្រុកយូដា និងស្រុកសាម៉ារី[ថ]ទាំងមូល ហើយរហូតដល់
ចុងផែនដីបំផុតផង[ទ] ៩កាលទ្រង់បានមានបន្ទូលសេចក្ដីទាំង
នោះរួចជាស្រេច ហើយពួកសាវកកំពុងតែមើល នោះព្រះ
បានលើកទ្រង់[ធ]ឡើងទៅ រួចមានពពកមកបំបាំងទ្រង់ ពី
ភ្នែកគេ ។
១០កំពុងដែលគេងើយសំឡឹងមើលទៅលើមេឃ ក្នុង

**១:១** ក លក ១:១–៤ ខ លក ៣:២៣ **១:២** គ ខ.៩,១១ មក ១៦:១៩ ឃ មថ ២៨:១៩–២០ ង កម ៦:៣០ ច យហ ១៣:១៨ ១៥:១៦,១៩ **១:៣** ឆ មថ ២៨:១៧ លក ២៤:៣៤,៣៦ យហ ២០:១៩,២៦ ២១:១,១៤ ១កថ ១៥:៥–៧ ជ មថ ៣:២ **១:៤** ឈ ទដ ២៧:១៤ ញ លក ២៤:៤៩ យហ ១៤:១៦ កច ២:៣៣ **១:៥** ដ មក ១:៤ ឋ មក ១:៨ **១:៦** ឌ មថ ១៧:១១ កច ៣:២១ **១:៧** ឍ ចទ ២៩:២៩ ទដ ១០២:១៣ មថ ២៤:៣៦ **១:៨** ណ កច ២:១–៤ ត លក ២៤:៤៨ ថ កច ៨:១–២៥ ទ មថ ២៨:១៩ **១:៩** ធ ខ.២ មក ១៦:១៩

**១:១** *រឿង១ច្បាប់មុន* រឿង១ច្បាប់មុននោះ គឺសំដៅលើព្រះគម្ពីរដំណឹងល្អលូកា ។ លោកថេវភីលជាអ្នកដែលទទួលព្រះគម្ពីរកិច្ចការនេះដំបូងគេបង្អស់ (សូមមើលសេចក្ដីផ្ដើមគម្ពីរលូកា ត្រង់ចំណុចអ្នកទទួល និងគោលបំណង) ។ *ចាប់តាំងធ្វើ ហើយបង្រៀន* ដោយសង្ខេបព្រះគម្ពីរ "ដំណឹងល្អលូកា" បានបញ្ជាក់យ៉ាងច្បាស់ថា ព្រះរាជកិច្ចរបស់ព្រះយេស៊ូវគ្រីស្ទ នៅតែមានបន្តក្នុង "ព្រះគម្ពីរកិច្ចការ" តាមរយៈការអស្ចារ្យ និងព្រះរាជកិច្ចនៃព្រះវិញ្ញាណបរិសុទ្ធ ។

**១:២** *ព្រះបានលើកទ្រង់ឡើងផុតទៅហើយ* ឃ្លានេះគឺជាសេចក្ដីបញ្ចប់នៅក្នុងព្រះគម្ពីរដំណឹងល្អលូកា (លក ២៤:៥០-៥២) ប៉ុន្តែ ជាសេចក្ដីផ្ដើមនៃកណ្ឌគម្ពីរកិច្ចការ (កច ១:៦-១១) ។ ព្រះយេស៊ូវបានលើកទៅស្ថានសួគ៌វិញ បន្ទាប់ពីទ្រង់រស់ពីសុគត៤០ថ្ងៃ (ខ.៣) ។ *ដោយនូវព្រះវិញ្ញាណបរិសុទ្ធ* ត្រង់ចំណុចនេះមានន័យថា ព្រះយេស៊ូវនៅតែបន្តបង្រៀនដល់ពួកសិស្សរបស់ទ្រង់ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ ម្យ៉ាងទៀត ព្រះយេស៊ូវប្រទានព្រះវិញ្ញាណបរិសុទ្ធមកដើម្បីដឹកនាំពួកសិស្សរបស់ទ្រង់ ក្នុងគ្រប់កិច្ចការដែលពួកគេបំពេញថ្វាយទ្រង់ (ខ.៤,៥,៨ យហ ២០:២២ មើលការពន្យល់ លក ២៤:៤៩ និងសេចក្ដីផ្ដើមព្រះគម្ពីរយូដាស) ។ ការអស្ចារ្យបន្ទាប់អំពីព្រះយេស៊ូវយាងទៅស្ថានសួគ៌វិញគឺជាព្រះរាជកិច្ច និងអំណាចព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ (ខ.៨ ២:៤,១៧ ៤:៨,៣១ ៥:៣ ៦:៣,៥ ៧:៥៥ ៨:១៦ ៩:១៧,៣១ ១០:៤៤ ១៣:២,៤ ១៥:២៨ ១៦:៦ ១៩:២,៦ មើលការពន្យល់ លក ៤:១) ។

**១:៣** *ដោយសារភស្តុតាងជាច្រើន* ភស្តុតាងទាំងនោះមានដូចជាទ្រង់សំដែងអង្គទ្រង់ឱ្យមនុស្សមួយចំនួនបានឃើញ សោយអាហារជាមួយពួកសិស្ស ជួបពួកគេនៅស្រុកកាលីឡេ ពួកសិស្សស្ទាបព្រះកាយទ្រង់ដោយផ្ទាល់ មនុស្ស៥០០នាក់បានឃើញ (១កថ ១៥:៦) និងការសំដែងអង្គទ្រង់នៅទីសាធារណៈចំនួន៤០ថ្ងៃ (មថ ២៨:១-២០ លក ២៤:១-៥៣ យហ ២០:១-២៩) ។ *នគរព្រះ* នេះជាសេចក្ដីសំខាន់ជាងគេ នៅក្នុងការបង្រៀនរបស់ព្រះយេស៊ូវ (មថ ៣:២ លក ៤:៤៣) ។

**១:៤** *សេចក្ដីសន្យានៃព្រះវរបិតា* សេចក្ដីសន្យានោះគឺ ព្រះវិញ្ញាណបរិសុទ្ធ (លក ២៤:៤៩ និង យហ ១៤:២៦ ១៥:២៦–២៧ ១៦:១២–១៣) ។

**១:៥** *យ៉ូហានធ្វើបុណ្យជ្រមុជដោយទឹក* "មើលពន្យល់ លក ៣:១៦"។ *បន្តិចទៀត* ពាក្យនេះសំដៅលើបុណ្យថ្ងៃទី៥០ ដែលត្រូវមកដល់១០ថ្ងៃបន្ទាប់ និងជាពេលដែលព្រះវិញ្ញាណបរិសុទ្ធយាងមកសណ្ឋិតលើពួកគេ (កច ២:១–៤) ។

**១:៦** *តាំងនគរឱ្យអ៊ីស្រាអែល?* ពួកសិស្ស ក៏ដូចពួកបណ្ដាជនដទៃទៀតដែរ គឺបានរង់ចាំជនជាតិអ៊ីស្រាអែលមកពីបរទេស ដើម្បីរំដោះពួកគេ ឱ្យរួចអំពីការគាបសង្កត់របស់បរទេស និងតាំងអាណាចក្រអ៊ីស្រាអែលនៅលើផែនដីនេះឡើងវិញ ។ ការសំដែងនៃព្រះវិញ្ញាណនេះ ក៏បានធ្វើឱ្យពួកសាវកនៅសង្ស័យ និងភាន់ច្រឡំថា អាណាចក្រនៅផែនដីរបស់អ៊ីស្រាអែលប្រហែលជិតមានពន្លឺហើយ ។

**១:៧** *ពេលនឹងកំណត់* សំដៅលើពេលវេលាដែលព្រះយេស៊ូវគ្រីស្ទយាងមកជាលើកទីពីរ (មក ១៣:៣២ មើលការពន្យល់ ១ថន ៥:១) ។

**១:៨** នៅក្នុងកណ្ឌគម្ពីរកិច្ចការគឺពួកសាវកត្រូវធ្វើបន្ទាល់នៅក្រុងយេរូសាឡិម (ជំពូក ១-៧) ស្រុកយូដា និងស្រុកសាម៉ារី (ជំពូក ៨-៩) និងចុងផែនដីបំផុតរួមទាំងក្រុងសេសារា ស្រុកអាន់ទីយ៉ូក ស្រុកអាស៊ី ប្រទេសក្រេក និងក្រុងរ៉ូម (ជំពូក១០–២៨) ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេត្រូវរង់ចាំទទួលអំណាចមកពីព្រះវិញ្ញាណបរិសុទ្ធសិនទើបចាប់ផ្ដើមកិច្ចការរបស់ខ្លួន ។ *ជាទីបន្ទាល់ពីខ្ញុំ* គោលបំណងសំខាន់មួយនៃកណ្ឌគម្ពីរកិច្ចការគឺបង្ហាញពីទីបន្ទាល់របស់អ្នកជឿ (២:៣២ ៣:១៥ ៥:៣២ ១០:៣៩ ១៣:៣១ ២២:១៥) ។ *សាម៉ារី* ជាស្រុកមួយស្ថិតនៅភាគខាងជើងនៃទីក្រុងយេរូសាឡិម ។

**១:៩** *ព្រះបានលើកទ្រង់ឡើងទៅ* "មើលការពន្យល់ ខ.២"។ *ពពកមកបំបាំងទ្រង់* "មើលការពន្យល់ មថ ១៧:៥"។

**១:១០** *២នាក់ស្លៀកពាក់ស* (ប្រៀបធៀប យហ ២០:១២) ។

កាលដែលទ្រង់យាងទៅ នោះឃើញមាន២នាក់ ស្លៀកពាក់
ស[ន] ឈរនៅជិត និយាយថា ១១ពួកអ្នកស្រុកកាលីឡេអើយ[ប]
ហេតុអ្វីបានជាឈរងើយមើលទៅលើមេឃដូច្នេះ ព្រះយេ
ស៊ូវនេះឯង ដែលព្រះបានលើកពីអ្នករាល់គ្នា ឡើង
ទៅលើស្ថានសួគ៌ ទ្រង់នឹងយាងមកវិញ[ផ] តាមបែបដដែល
ដូចជាអ្នករាល់គ្នាបានឃើញទ្រង់ទៅនោះដែរ ។

## ការជ្រើសរើសម៉ាត់ធាសជំនួសយូដាស

១២ពួកអ្នកទាំងនោះក៏វិលពីភ្នំដែលហៅថា ភ្នំដើមអូលីវ[ព]
ត្រឡប់ទៅឯក្រុងយេរូសាឡិម[ភ]វិញ រីឯភ្នំនោះនៅជិត
ក្រុងយេរូសាឡិម ចំងាយផ្លូវដើរអស់១ថ្ងៃឈប់សំរាក
១៣កាលគេចូលទៅដល់ហើយ នោះក៏ឡើងទៅឯបន្ទប់[ម]
ខាងលើ ជាលំនៅរបស់ពេត្រុស យ៉ូហាន យ៉ាកុប អនទ្រេ
ភីលីព ថូម៉ាស បារថូល៉ូមេ ម៉ាថាយ យ៉ាកុបជាកូន
អាល់ផាយ ស៊ីម៉ូន ជាពួកឧស្សាហ៍ នឹងយូដាស ជាញាតិនឹង
យ៉ាកុប[យ] ១៤ពួកអ្នកទាំងនេះ មានចិត្តព្រមព្រៀងគ្នា ដោយ
ព្យាយាមក្នុងសេចក្ដីអធិស្ឋាន[រ] ជាមួយនឹងពួកស្រីៗ[ល] ព្រម
ទាំងម៉ារា ជាមាតាព្រះយេស៊ូវ នឹងបងប្អូន[វ]ទ្រង់ដែរ ។

**១:១០** ន យហ ២០:១២ **១:១១** ប កច ២:៧ ផ មថ ១៦:២៧ **១:១២** ព មថ ២១:១ ភ លក ២៤:៥២ **១:១៣** ម កច ៩:៣៧ ២០:៨ យ មថ ១០:២-៤ មក ៣:១៦-១៩ លក ៦:១៤-១៦ **១:១៤** រ ២៣:៤៩,៥៥ វ មថ ១២:៤៦ **១:១៦** ស កច ៦:៣ ១១:១,១២,២៩ ១៤:២ ១៨:១៨,២៧ ២១:៧ ២២:៥ រម

១៥នៅគ្រានោះ ពេត្រុសឈរឡើងកណ្ដាលពួកបងប្អូន
ដែលមានឈ្មោះប្រហែលជា១២០នាក់ ប្រកាសថា ១៦បង
ប្អូន[ស]រាល់គ្នាអើយ បទគម្ពីរដែលព្រះវិញ្ញាណបរិសុទ្ធបាន
ទាយ ដោយសារព្រះឱស្ឋហ្លួងដាវីឌ ពីដំណើរយូដាស[ហ] ជា
អ្នកដែលនាំគេទៅចាប់ព្រះយេស៊ូវ បទនោះត្រូវតែបាន
សំរេច[ឡ] ១៧ដ្បិតវាបានរាប់ក្នុងពួកយើងរាល់គ្នា[អ]ហើយបាន
ទទួល១ចំណែកក្នុងការងារ[ក]នេះដែរ ១៨(រីឯមនុស្សនេះ
បានទិញដីវាល[ខ] ដោយសាររង្វាន់[គ]នៃការ ទុច្ចរិតរបស់ខ្លួន
វាប៉ុន្តែវាដួលទៅមុខធ្លាយពោះ ហើយពោះវៀនក៏ចេញ
ទ្រោល ១៩រឿងនោះបានឮ ទៅដល់មនុស្សទាំងឡាយ
ដែលនៅក្រុងយេរូសាឡិម បានជាគេហៅវាលនោះតាម
ភាសា[ឃ]គេថា អាកិលដាម៉ា គឺប្រែថា វាលឈាម)
២០ព្រោះមានសេចក្ដីចែងទុកមក ក្នុងគម្ពីរទំនុកដំកើងថា
ចូរឱ្យទីលំនៅវាត្រូវចោលស្ងាត់ចុះ កុំឱ្យមានអ្នកណានៅ
ទីនោះឡើយ[ង] ហើយថា ត្រូវឱ្យម្នាក់ទៀតទទួលការងារ

៧:១ ហ មថ ១០:៤ ឡ ខ.២០ មថ ១:២២ **១:១៧** អ យហ ៦:៧០,៧១ ក ខ.២៥ **១:១៨** ខ មថ ២៧:៣-១០ គ មថ ២៦:១៤,១៥ **១:១៩** ឃ យហ ៥:២ **១:២០** ង ទដ ៦៩:២៥ ច ទដ ១០៩:៨

**១:១១** *អ្នកស្រុកកាលីឡេ* សាវកទាំង១២មកពីស្រុកកាលីឡេ លើកលែងយូដាសមួយចេញ ហើយពេលនោះយូដាសមិនមានវត្តមានជាមួយពួកគេទៀតទេ គឺស្លាប់បាត់ទៅហើយ ។ *តាមបែបដដែល* គឺមានរូបកាយដូចកាលពីទ្រង់រស់ពីសុគតឡើងវិញ និងនៅក្នុងពពក ហើយនិងពេញដោយសិរីល្អ (មថ ២៤:៣០) ។

**១:១២** *ភ្នំដើមអូលីវ* ការយាងទៅស្ថានសួគ៌វិញ គឺនៅភាគខាងកើតជម្រាលភ្នំនេះ ត្រង់ចន្លោះក្រុងយេរូសាឡិម និងភូមិបេថានី (លក ១៩:២៨-២៩,៣៧ មើលការពន្យល់ សក ១៤:៤ មក ១១:១ លក ១៩:២៩) ។ *ដើរអស់១ថ្ងៃឈប់សំរាក* គឺជាចម្ងាយកំណត់មួយ មានចែងនៅក្នុងសេចក្ដីបង្រៀនរបស់ពួកយូដា (នក ១៦:២៩ ជន ៣៥:៥ យស ៣:៤) ។ តាមរយៈសេចក្ដីបង្រៀននោះ ក្នុងថ្ងៃឈប់សម្រាកមនុស្សសុចរិតមិនអាចដើរឱ្យឆ្ងាយជាងចម្ងាយ ដែលបានកំណត់នោះឡើយ ។

**១:១៣** *បន្ទប់* ប្រហែលជាបន្ទប់ជាន់ខាងលើនៃផ្ទះធំមួយ ហើយអាចជាផ្ទះរបស់ម៉ារាម្ដាយរបស់ម៉ាកុស (មើលការពន្យល់ កច ១២:១២) ។ ពិធីលៀងចុងក្រោយនៃព្រះអម្ចាស់ ក៏ប្រហែលជាធ្វើនៅទីនោះដែរ (មក ១៤:១៥) ។ *បារថូល៉ូមេ* លោកយ៉ូហានហៅគាត់ថា "ណាថាណែល" (យហ ១:៤៥-៤៩ ២១:២) ។ *យ៉ាកុប ជាកូនអាល់ផាយ* គឺយ៉ាកុបតូច (មក ១៥:៤០) ។ *ពួកឧស្សាហ៍* (មើលពន្យល់ មថ ១០:៤) ។ *យូដាស ជាញាតិនឹងយ៉ាកុប* យូដាសម្នាក់នេះគឺជា "ថាដេ" (មថ ១០:៣) ពុំមែនជា យូដាស-អ៊ីស្ការីយ៉ុតទេ ។

**១:១៤** *ជាមួយនឹងពួកស្រីៗ* គឺប្រហែលជាប្រពន្ធរបស់ពួកសាវក (ប្រៀបធៀបការពន្យល់ ១កថ ៩:៥) និងអស់អ្នកតាមបម្រើព្រះយេស៊ូវ (មថ ២៧:៥៥ លក ៨:២-៣ ២៤:២២) ។ *ម៉ារា ជាមាតាព្រះយេស៊ូវ* ឈ្មោះគាត់ត្រូវបានលើកយកមកនិយាយចុងក្រោយបង្អស់ហើយ នៅក្នុងព្រះគម្ពីរ ។ *បងប្អូនទ្រង់* (មើលការពន្យល់ លក ៨:១៩) ។ លោកយ៉ាកុប ក៏ជាបងប្អូនម្នាក់របស់ព្រះយេស៊ូវដែរ ដែលក្រោយមកក្លាយជាអ្នកដឹកនាំពួកជំនុំ នៅឯទីក្រុងយេរូសាឡិម (១២:១៧ ១៥:១៣ ២១:១៨ កទ ១:១៩ ២:៩ និងសេចក្ដីផ្ដើមព្រះគម្ពីរយ៉ាកុប) ។

**១:១៦** *បទនោះត្រូវតែបានសំរេច* "ខ.២០" ។ នៅក្នុងកណ្ឌគម្ពីរទំនុកដំកើងមានវគ្គជាច្រើន និយាយអំពីព្រះមែស៊ី ទាំងនៅមុនពេលព្រះយេស៊ូវគ្រីស្ទទ្រង់យាងមក និងក្រោយដែលទ្រង់យាងមក ។ អ្វីដែលបានកើតឡើងជាបទពិសោធន៍របស់អ្នកនិពន្ធទំនុកដំកើង គឺជាបទពិសោធន៍តាមបែបព្រះមែស៊ី ។ ហើយគ្មានអ្វីដែលត្រូវសង្ស័យនោះទេព្រោះសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវបានបញ្ជាក់យ៉ាងច្បាស់ថា ទ្រង់គឺជាព្រះមែស៊ីដែលត្រូវយាងមក (លក ២៤:២៧,៤៥-៤៧) ។

**១:១៨** *មនុស្សនេះបានទិញដីវាល* យូដាសបានទិញដីវាលនោះដោយប្រយោល ដោយសារប្រាក់ដែលគាត់ផ្ញើរឱ្យទៅពួកសម្ដេចសង្ឃនោះហើយ ដែលប្រើសម្រាប់ទិញដីវាលរបស់ជាងស្មូន ដើម្បីកប់សពគាត់ (មថ ២៧:៣,៧) ។ *វាដួលទៅមុខធ្លាយពោះ* (ព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសខ្លះ ប្រើពាក្យថា "ដួលបោកក្បាលស្លាប់") ។ នៅក្នុង "មថ ២៧:៥" ប្រាប់ថា គាត់អួលស្ទះស្លាប់ (ភាសាអង់គ្លេសខ្លះប្រើពាក្យថា "ចងកខ្លួនឯង") ។ នៅពេលដែលរូបកាយដួលទៅដីហើយ ទោះបីដោយពុកផុយ ឬដោយគេកាត់ក្ដី ក៏នៅពេលដែលរលួយ នោះផ្នែកពោះពិតជាធ្លាយចំហ ។ នៅក្នុង "មថ ២៧:៥" ព្រះគម្ពីរជាភាសាអង់គ្លេសខ្លះ អាចមានន័យថា "ចាក់សម្លាប់" ក្នុងការពណ៌នាអំពីលទ្ធផលនៃការសម្លាប់ខ្លួនឯងរបស់យូដាសដែលក្បត់ម្នាក់នោះ ។

**១:២០** *មានសេចក្ដីចែងទុកមក* ឃ្លានេះមានន័យថា បទទំនាយដែលបានថ្លែងតាមរយៈពួកហោរាបរិសុទ្ធរបស់ព្រះអម្ចាស់ស្ដីអំពីយូដាសនោះត្រូវ

ជិនួសវា[ច] ២១ដូច្នេះ ក្នុងពួកអ្នកដែលដើរជាមួយនឹងយើង
គ្រប់វេលាដែលព្រះអម្ចាស់យេស៊ូវយាងចេញចូល ក្នុងពួក
យើង ២២ចាប់តាំងពីគ្រាលោកយ៉ូហានធ្វើបុណ្យជ្រមុជទឹក[ឆ]
ដរាបមកដល់ថ្ងៃ ដែលព្រះបានលើកទ្រង់ឡើង ពីយើង
រាល់គ្នាទៅ នោះត្រូវឱ្យមានម្នាក់ទៀតធ្វើជាទីបន្ទាល់[ជ]
ជាមួយនឹងយើង ពីដំណើរដែលទ្រង់មានព្រះជន្មរស់ឡើង
វិញ ២៣ដូច្នេះ គេក៏ដំរូវលើរូប២នាក់ គឺយ៉ូសែបដែលហៅ
ថាបារសាបាស ដែលមានឈ្មោះយូស្ទុសផងនោះ១ និង
ម៉ាត់ធាស១ ។
២៤រួចគេអធិស្ឋាន[ឈ]ទូលថា ឱព្រះអម្ចាស់ ជាព្រះដ៏ជ្រាបនូវ
ចិត្ត[ញ]មនុស្សទាំងឡាយអើយ សូមបង្ហាញឱ្យយើង[ដ]ខ្ញុំដឹងថា
ទ្រង់រើសអ្នកណាក្នុងបណ្តាអ្នកទាំង២នេះ ២៥ឱ្យបានទទួល

**១:២២** ឆ មក ១:៤ ជ ខ.៨ លក ២៤:៤៨
**១:២៤** ឈ កច ៦:៦ ១៣:៣ ១៤:២៣ ញ វវ ២:២៣ ដ ១សយ ១៤:៤១
**១:២៦** ឋ កច ២:១៤
**២:១** ឌ លវ ២៣:១៥,១៦ កច ២០:១៦ ១កថ ១៦:៨ ឍ កច ១:១៤
**២:២** ណ កច ៤:៣១
**២:៤** ត លក ១:១៥ ថ មក ១៦:១៧

ចំណែក ក្នុងកិច្ចការ និងងារជាសាវកនេះ ជិនួសយូដាស
ដែលបានធ្លាក់ចេញពីងារនេះ ហើយដើម្បីនឹងទៅឯកន្លែង
របស់វា ២៦នោះគេចាប់ឆ្នោតត្រូវលើរូបម៉ាត់ធាស រួចគេ
ក៏រាប់គាត់បញ្ចូលជាមួយនឹងពួកសាវកទាំង១១នាក់[ឋ] ។

## ការយាងមកនៃព្រះវិញ្ញាណបរិសុទ្ធនៅថ្ងៃបុណ្យទី៥០

**២** ១កាលបុណ្យថ្ងៃទី៥០[ឌ]បានមកដល់ នោះគេមានចិត្តព្រម
ព្រៀងប្រជុំទាំងអស់គ្នា[ឍ] នៅកន្លែងតែ១ ២ស្រាប់តែមានឮ
សូរពីលើមេឃ ដូចជាខ្យល់បក់គំហុកយ៉ាងខ្លាំង មកពេញ
ក្នុងផ្ទះដែលគេអង្គុយនៅ[ណ] ៣ក៏មានអណ្តាត ដូចជាអណ្តាត
ភ្លើង ដែលបែកចេញពីគ្នា លេចមកឱ្យគេឃើញហើយ
មកសណ្ឋិតលើគេគ្រប់គ្នា ៤រួចគេបានពេញជាព្រះវិញ្ញាណ
បរិសុទ្ធ[ត]ទាំងអស់ ក៏តាំងនិយាយភាសា[ថ]ផ្សេងៗ តាមដែល

បានសម្រេចហើយ (មើលការពន្យល់ ទដ ៦៩:២៥ ១០៩:៨) ។

**១:២១** *យាងចេញចូល ក្នុងពួកយើង* នេះបញ្ជាក់ថាព្រះយេស៊ូវគ្រីស្ទទ្រង់គង់នៅជាមួយយើងរាល់គ្នាគ្រប់ពេលវេលាទាំងអស់ (៩:២៨) ។

**១:២២** *ជាទីបន្ទាល់ជាមួយនឹងយើង ពីដំណើរដែលទ្រង់មានព្រះជន្មរស់ឡើងវិញ* ត្រង់ចំណុចនេះបង្ហាញថា គ្រីស្ទបរិស័ទនៅពេលនោះចង់ជ្រើសរើសមនុស្សម្នាក់ ដើម្បីធ្វើបន្ទាល់ជាផ្លូវការ អំពីសេចក្តីរស់ឡើងវិញរបស់ព្រះយេស៊ូវ (ខ.២៥) ។

**១:២៣** *បារសាបាស* មានន័យថា "កូននៃថ្ងៃឈប់សម្រាក"។ ឈ្មោះនេះប្រើចំពោះគ្រីស្ទបរិស័ទជាតិយូដា២នាក់ ដែលប្រហែលជាបងប្អូននឹងគ្នាផង ។ ម្នាក់គឺលោកយ៉ូសែប និងម្នាក់ទៀតគឺលោកយូដាសដែលជាហោរានៅក្រុងយេរូសាឡិម និងត្រូវបញ្ជូនទៅទីក្រុងអាន់ទីយ៉ូក ជាមួយនឹងលោកស៊ីឡាស (១៥:២២,៣២)។ លោកយ៉ូសែបមានឈ្មោះមួយទៀត ជាភាសាក្រិកគឺ "យូស្ទុស"។

**១:២៣-២៤** ដំបូងពួកសាវកទាំង១១នាក់ជ្រើសរើសមនុស្ស២នាក់ ដែលស័ក្តិសមធ្វើជាសាវកទី១២ ។ បន្ទាប់មក ពួកគេនាំគ្នាអធិស្ឋានទូលសូមឱ្យព្រះអម្ចាស់ បង្ហាញថា ក្នុងចំណោមអ្នកទាំង២នាក់នោះ តើអ្នកណាម្នាក់ដែលទ្រង់ជ្រើសរើស។ ពួកគេក៏នាំគ្នាចាប់ឆ្នោតដោយទុកចិត្ត និងសង្ឃឹមថាឆ្នោតនោះនឹងបានទៅលើអ្នក ដែលព្រះអម្ចាស់សព្វព្រះហឫទ័យ (សភ ១៦:៣៣)។ ការនេះបានកើតឡើងតែម្តងគត់នៅក្នុងគម្ពីរសញ្ញាថ្មី ក្នុងគោលបំណងស្វែងរកព្រះហឫទ័យព្រះអម្ចាស់ ។ មានគ្រីស្ទបរិស័ទជាច្រើនជឿថា ចាប់តាំងពីពេលដែលព្រះអម្ចាស់ទ្រង់បានប្រទានព្រះវិញ្ញាណបរិសុទ្ធ នៅថ្ងៃបុណ្យទី៥០នោះមក ការចាប់ឆ្នោតដើម្បីស្វែងរកព្រះហឫទ័យទ្រង់ លែងជាការសំខាន់ទៀតហើយ ។ ពួកគេនិយាយយ៉ាងដូច្នោះ ព្រោះយល់ថា មានព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយពួកគេគ្រប់គ្នា ហើយទ្រង់នឹងបើកសំដែងឱ្យពួកគេដឹងនូវគ្រប់កិច្ចការដែលជាបំណងព្រះហឫទ័យទ្រង់ ។

**១:២៦** *ចាប់ឆ្នោត* "មើលការពន្យល់ សភ ១៦:៣៣"។ ដោយសារការចាប់ឆ្នោត ពួកគេបានប្រគល់ការសម្រេចចិត្តទៅព្រះអម្ចាស់ ។ ការប្រើថ្ម ឬកំណាត់ឈើដើម្បី ធ្វើការសម្រេចចិត្តគឺជាការមួយគួរឱ្យកត់សំគាល់ (១រប ២៦:១៣-១៦ និងមើលការពន្យល់ នហ ១១:១ យណ ១:៧)។ នេះគឺជាការចាប់ឆ្នោតលើកចុងក្រោយបង្អស់ ដែលមានចែងនៅក្នុងព្រះគម្ពីរបរិសុទ្ធ ។

**២:១** *បុណ្យថ្ងៃទី៥០* គឺថ្ងៃទី៥០បន្ទាប់អំពីការឈប់សម្រាកនៃបុណ្យរំលង (លវ ២៣:១៥-១៦)។ បុណ្យថ្ងៃទី៥០ក៏ត្រូវបានហៅថា បុណ្យអាទិត្យទី៧ (ចទ ១៦:១០) ឬបុណ្យចម្រូត (នក ២៣:១៦) ឬក៏បុណ្យផលដំបូង (ជន ២៨:២៦)។ *គេមានចិត្តព្រមព្រៀងប្រជុំទាំងអស់គ្នា* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកគេមានការរួបរួមគ្នាយ៉ាងល្អ ដែលចាប់ផ្តើមពីពួកសាវកទាំង១១នាក់ និងម៉ាត់ធាស ហើយបន្ទាប់មក គឺពួកអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទគ្រប់ៗគ្នា (១:១៣-១៥)។ *នៅកន្លែងតែ១* ត្រង់ចំណុចនេះ មិនមែនសំដៅលើបន្ទប់ដែលពួកគេស្នាក់នៅនោះទេ (១:១៣) ប៉ុន្តែ ប្រហែលជានៅឯបរិវេណព្រះវិហារ ព្រោះថាពួកសាវកតែងតែនៅទីនោះជានិច្ច គឺគ្រប់ពេលដែលព្រះវិហារបើកទ្វារ (មើលការពន្យល់ លក ២៤:៥៣)។

**២:២** *ខ្យល់បក់គំហុកយ៉ាងខ្លាំង* ដង្ហើម ឬខ្យល់ ជានិមិត្តរូបនៃព្រះវិញ្ញាណបរិសុទ្ធ (អគ៣៧:៩,១៤យហ៣:៨)។ ការយាងមករបស់ព្រះវិញ្ញាណបរិសុទ្ធអាចសំដែងឡើងឱ្យមើលឃើញ (ភ្លើង) ឬមិនអាចមើលឃើញ (ខ្យល់)។ *ពេញក្នុងផ្ទះ* ពាក្យថា "ផ្ទះ" ត្រង់ចំណុចនេះ អាចសំដៅលើព្រះវិហារ (ប្រៀបធៀប ៧:៤៧)។

**២:៣** *អណ្តាត* ពាក្យថា "អណ្តាត" ជាពាក្យប្រៀបធៀប ដែលមានន័យដូចគ្នានឹងពាក្យថា "ភាសា" និងបញ្ជាក់ថា ពួកគេនឹងនិយាយភាសាផ្សេងៗ ។ *ភ្លើង* គឺជានិមិត្តរូបនៃព្រះវត្តមាន និងការជំនុំជម្រះរបស់ព្រះអម្ចាស់ (នក ៣:២ មថ ៣:១២)។

**២:៤** *ទាំងអស់* ពាក្យថា "ទាំងអស់"នេះ អាចសំដៅលើពួកសាវក ឬមនុស្សទាំង១២០នាក់ ។ អ្នកខ្លះយល់ថា គឺសំដៅលើមនុស្សទាំង១២០នាក់ ដោយអះអាងថា សេចក្តីទំនាយតាមរយៈហោរាយ៉ូអែលនោះ បានសម្រេចហើយ (ខ.១៧-១៨) ដូច្នេះពាក្យថា "គេទាំងអស់"នៅទីនេះ ពុំសំដៅលើតែពួកសាវកប៉ុណ្ណោះទេ ។ ប៉ុន្តែ បើតាមសេចក្តីបញ្ជាក់នៅក្នុង "ខ.១" គឺសំដៅចំពោះតែពួកសាវកប៉ុណ្ណោះ រួមមានលោកពេត្រុស និងសាវកទាំង១១នាក់ ដែលឈរឡើងជាមួយគាត់ ក្នុងការថ្លែងទៅកាន់បណ្តាជន (ខ.១៤)។ *បានពេញជាព្រះវិញ្ញាណបរិសុទ្ធ* នេះជាសេចក្តីសន្យារបស់ព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ លក ២៤:៤៩ យហ ១៤:១៦-១៨ ២០:២២) ដែលត្រូវ

ព្រះវិញ្ញាណប្រទានឱ្យ ។
៥ រីឯនៅក្រុងយេរូសាឡិម មានពួកសាសន៍យូដា ជាអ្នក
កោតខ្លាច[ទ]ដល់ព្រះ ដែលមកពីគ្រប់នគរ នៅក្រោមមេឃ
៦ កាលសូរសព្ទពីការ នោះបានឮសុសសាយទៅ នោះបណ្ដា
មនុស្សក៏ប្រជុំគ្នា ហើយគេមានសេចក្ដីស្រឡាំងកាំង ដោយ
គ្រប់គ្នាឮភាសាជាតិរបស់ខ្លួន ដែលពួកសាវកកំពុងតែ
អធិប្បាយ ៧ គេមានសេចក្ដីអស្ចារ្យក្នុងចិត្ត[ធ] ហើយនិយាយ
គ្នាទៅវិញទៅមក ដោយឆ្ងល់ថា អ្នកទាំងនេះ ដែល
អធិប្បាយ តើមិនមែនជាពួកអ្នកស្រុកកាលីឡេ[ន]ទាំងអស់គ្នា
ទេឬអី ៨ ចុះដូចម្ដេចបានជាយើងឮ គេនិយាយតាមភាសា
កំណើតរបស់យើងរៀងខ្លួនដូច្នេះ ៩ គឺជាសាសន៍ផារថុស
មេឌី អេឡាំ នឹងពួកអ្នកស្រុកមេសូប៉ូតាមា ស្រុកយូដា
ស្រុកកាប៉ាដូគា[ប] ស្រុកប៉ុនតុស[ផ] ស្រុកអាស៊ី[ព] ១០ ព្រមទាំងស្រុក
ព្រីគា[ភ] ស្រុកប៉ាមភីលា[ម] ស្រុកអេស៊ីព្ទ និងដែនស្រុកលីប៊ី
ដែលនៅជុំវិញស្រុកគីរេន[យ] ហើយពួកអ្នកស្រុករ៉ូម ដែល
ស្នាក់នៅទីនេះ ទោះទាំងសាសន៍យូដា និងអ្នកចូលសាសន៍
ផង ១១ ហើយសាសន៍ក្រេត នឹងសាសន៍អារ៉ាប់ដែរ យើងទាំង
អស់គ្នាឮគេនិយាយ ពីអស់ទាំងការអស្ចារ្យរបស់ព្រះ តាម
ភាសារបស់យើងរៀងខ្លួន ១២ អ្នកទាំងនោះមានសេចក្ដី
អស្ចារ្យ ព្រមទាំងវល់ក្នុងចិត្ត ក៏សួរគ្នាទៅវិញទៅមកថា
តើការនេះដូចម្ដេចហ្ន៎ ១៣ តែមានអ្នកខ្លះចំអកឱ្យថា
ពួកនេះស្រវឹងស្រាថ្មីទេ[រ] ។

### ពេត្រុសថ្លែងទៅកាន់ហ្វូងមនុស្ស

១៤ នោះពេត្រុសក៏ឈរឡើង ជាមួយនឹងពួក១១នាក់ ក៏បន្លឺ
សំឡេងនិយាយទៅគេថា ឱពួកសាសន៍យូដា និងពួកអ្នកនៅ
ក្រុងយេរូសាឡិមទាំងអស់គ្នាអើយ សូមឱ្យអ្នករាល់គ្នាដឹង

**២:៥** ទ លក ២:២៥ កច ៨:២
**២:៧** ធ ខ.១២ ន កច ១:១១
**២:៩** ប ១ពត ១:១ ផ កច ១៨:២ ១ពត ១:១ ព កច ១៦:៦ ១៩:១០ រម ១៦:៥ ១កថ ១៦:១៩ ២កថ ១:៨ វវ ១:៤
**២:១០** ភ កច ១៦:៦ ១៨:២៣ ម កច ១៣:១៣ ១៤:២៤ ១៥:៣៨ យ មថ ២៧:៣២
**២:១៣** រ ១កថ ១៤:២៣ អភ ៥:១៨

បានសម្រេច ដូចមានចែងនៅក្នុង "១:៤–៥,៨" ដូច្នោះដែរ ។ វិញ្ញាណរបស់ពួកគេទាំងអស់គ្នា គឺស្ថិតនៅក្រោមការដឹកនាំនៃព្រះវិញ្ញាណបរិសុទ្ធ ហើយពាក្យសំដីរបស់ពួកគេក៏ទទួលមកពីទ្រង់ដែរ ។ *ភាសាផ្សេងៗ* ព្រះវិញ្ញាណបរិសុទ្ធប្រទានឱ្យពួកគេ ចេះនិយាយភាសាផ្សេងៗទៀត ដែលពួកគេមិនចេះនិយាយនិងពុំធ្លាប់បានរៀនសូត្រពីមុនមក (មើលពន្យល់ ១០:៤៦ ១៩:៦) ។ ពុំមានមតិណាមួយដែលអះអាងថា ពួកសាវកនិយាយភាសា ដែលខ្លួនចេះនិយាយហើយនោះទេ ។ ដូច្នេះ មានន័យថាពួកគេនិយាយភាសាថ្មីទាំងស្រុង ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ច្រើនចែងអំពីអំណោយទានខាងឯវិញ្ញាណ (១កថ ១២-១៤) ។

**២:៥** *ពួកសាសន៍យូដា ជាអ្នកកោតខ្លាចដល់ព្រះ* គឺសាសន៍យូដាដែលគោរពកោតខ្លាចដល់ព្រះ មកពីតំបន់ផ្សេងៗនៃពិភពលោក ហើយមកផ្ដុំគ្នានៅក្រុងយេរូសាឡិម ដើម្បីចូលរួមបុណ្យថ្ងៃទី៥0 ឬមកដើម្បីតាំងលំនៅថ្មីនៅទីនោះ (លក ២:២៥) ។

**២:៦** *ភាសាជាតិរបស់ខ្លួន* ពួកយូដាដែលទៅរស់នៅស្រុកក្រៅ បានប្រើប្រាស់ភាសាផ្សេងៗ តាមតំបន់ដែលពួកគេរស់នៅនោះ ដូចជាភាសាកំណើតរបស់ខ្លួន ។ ដូច្នោះ ពេលឮពួកសាវកនិយាយភាសារបស់ខ្លួន នោះពួកគេភ្ញាក់ផ្អើលជាខ្លាំង ។

**២:៩** *សាសន៍ផារថុស* ជាក្រុមមនុស្សដែលរស់នៅតាមតំបន់ចាប់ពីទន្លេទីគ្រីសរហូតដល់ប្រទេសឥណ្ឌា ។ *មេឌី* ជាតំបន់មួយស្ថិតនៅភាគខាងលិចនៃប្រទេសមេសូប៉ូតាមា (Mesopotamia) ភាគខាងជើងឆៀងខាងលិចនៃនគរពើស៊ី (Persia) និងភាគខាងត្បូងឆៀងខាងលិចនៃសមុទ្រកាស្ពៀន (Caspin sea) ។ *អេឡាំ* គឺជាខេត្តមួយស្ថិតនៅភាគខាងជើងនៃឈូងសមុទ្រពើស៊ី (Persian Gulf) ហើយខាងលិចជាប់ជាមួយនឹងទន្លេទីគ្រីស ។ *មេសូប៉ូតាមា* ជាប្រទេសមួយ ស្ថិតនៅចន្លោះទន្លេអឺប្រាត និងទន្លេទីគ្រីស ។ *ស្រុកយូដា* ជាទឹកដីកំណើតរបស់សាសន៍យូដា ។ នៅក្នុងសញ្ញាចាស់ ទឹកដីនោះប្រហែលជាលាតសន្ធឹងពីទន្លេអេស៊ីព្ទ រហូតដល់ទន្លេអឺប្រាត (លប ១៥:១៨) រួមបញ្ចូលទាំងស្រុកកាលីឡេផង ។ *ស្រុកកាប៉ាដូគា ស្រុកប៉ុនតុស ស្រុកអាស៊ី* (មើលការពន្យល់ ២កថ ១:៨) តំបន់ទាំងអស់នេះស្ថិតនៅទ្វីបអាស៊ី ភាគខាងលិចបំផុត (ឬហៅថា អាស៊ីមីន័រ Asia Minor) ។

**២:១០** *ស្រុកព្រីគានិងស្រុកប៉ាមភីលា* តំបន់ទាំង២នេះស្ថិតនៅទ្វីបអាស៊ីភាគខាងលិចបំផុត ។ *ស្រុកអេស៊ីព្ទ* ជាប្រទេសមួយស្ថិតនៅភាគខាងជើងឆៀងខាងកើតនៃទ្វីបអាហ្វ្រិក ។ ពួកសាសន៍យូដាបាននាំគ្នាមករស់នៅប្រទេសនេះនាសតវត្សរ៍ទី៦មុនគ.ស ។ *ស្រុកលីប៊ី* ជាប្រទេសមួយស្ថិតនៅភាគខាងលិចនៃប្រទេសអេស៊ីព្ទ ។ *ស្រុកគីរេន* ជាស្រុកមួយនៃប្រទេសលីប៊ី ។ *រ៉ូម* ជារាជធានីនៃប្រទេសអ៊ីតាលី។ មានជនជាតិយូដារាប់ពាន់នាក់រស់នៅទីនោះ ។ *អ្នកចូលសាសន៍* គឺអស់អ្នកដែលទទួលយក និងប្រតិបត្តិតាមក្រឹត្យវិន័យរបស់លោកម៉ូសេ ។ ពួកនោះក៏ត្រូវបានគេអនុញ្ញាត ឱ្យមានសិទ្ធិចូលរួមក្នុងពិធីផ្សេងៗជាមួយនឹងសាសន៍យូដាពិតប្រាកដផងដែរ ។

**២:១១** *សាសន៍ក្រេត* គឺជាជាតិសាសន៍មួយក្រុមដែលរស់នៅលើដីកោះ តាមភាគខាងត្បូងនៃប្រទេសក្រេក ។ *សាសន៍អារ៉ាប់* សំដៅលើជាតិសាសន៍ទាំងឡាយរស់នៅក្នុងអាណាចក្រណាបាទីន–អារ៉ាប់ (Nabatean Arabs) ដែលស្ថិតនៅចន្លោះសមុទ្រក្រហម និងទន្លេអឺប្រាត ហើយមានទីក្រុងធំមួយឈ្មោះថា "ពេត្រា"។ *យើងទាំងអស់គ្នាឮគេនិយាយ* ត្រង់ចំណុចនេះមានន័យថា ពួកអ្នកដំណើរដែលមកពីស្រុកក្រៅទាំងនោះ បានឮពួកសាវក និយាយភាសាកំណើតរបស់ខ្លួនដោយផ្ទាល់ ហើយក៏មានការចម្លែកក្នុងចិត្តជាខ្លាំង ។

**២:១៤-៤០** នៅក្នុងទបគម្ពីរទាំងនេះ មានហេតុការណ៍សំខាន់ដែលបានកើតឡើងនៅក្នុងពួកជំនុំដំបូងដូចជា (១).ការពន្យល់អំពីហេតុការណ៍ទាំងឡាយដែលកើតមាននៅក្នុងពួកជំនុំ (ខ.១៤–២១) (២).ដំណឹងល្អអំពីការសុគតការរស់ឡើងវិញ និងការយាងទៅស្ថានសួគ៌របស់ព្រះយេស៊ូវគ្រីស្ទ (ខ.២២–៣៦) (៣).សេចក្ដីពិតអំពីការប្រែចិត្ត និងពិធីបុណ្យជ្រមុជទឹក (ខ.៣៧-៤0) ។

**២:១៤** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ អំពីសេចក្ដីក្លាហានរបស់ពួកសាវកនៅក្នុងការថ្លែងព្រះបន្ទូលរបស់ព្រះអម្ចាស់ ។ ពួកសាវកធ្វើការទាំងនោះមិនមែនពឹងអាងលើកម្លាំងរបស់ខ្លួនទេ ប៉ុន្តែគឺដោយសារអំណាចព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអម្ចាស់វិញ ។

សេចក្តីនេះ ហើយប្រុងស្តាប់ពាក្យខ្ញុំចុះ ១៥ដ្បិតអ្នកទាំងនេះ
មិនមែនស្រវឹង ដូចជាអ្នករាល់គ្នាគិតស្មាននោះទេ ព្រោះ
ទើបនឹងម៉ោង៩ព្រឹកនៅឡើយ[ល] ១៦នេះគឺជាសេចក្តីទំ
នាយរបស់ហោរាយ៉ូអែលវិញ ដែលលោកទាយទុកមកថា
១៧ព្រះទ្រង់មានបន្ទូលថា ដល់ថ្ងៃជាន់ក្រោយបង្អស់ អញ
នឹងចាក់ព្រះវិញ្ញាណអញ ទៅលើគ្រប់ទាំងមនុស្ស[វ] នោះកូន
ប្រុសកូនស្រីឯងរាល់គ្នានឹងទាយទំនាយ[ស] ពួកកំឡោះឯង
រាល់គ្នា នឹងឃើញការជាក់ស្តែង ហើយពួកចាស់ៗរបស់
ឯងរាល់គ្នានឹងយល់សប្តិ ១៨នៅគ្រានោះ អញនឹងចាក់
ព្រះវិញ្ញាណអញ ទៅលើទាំងពួកអ្នកបំរើប្រុសស្រីផង
ហើយគេនឹងទាយទំនាយដែរ[ហ]។ ១៩អញនឹងសំដែងការ
អស្ចារ្យ នៅលើមេឃ នឹងទីសំគាល់ នៅផែនដី[ឡ] គឺជាឈាម
ភ្លើង ហើយនឹងកំសួលផ្សែង ២០ថ្ងៃនឹងប្រែទៅជាងងឹត
ហើយខែនឹងទៅជាឈាម[អ] មុនដែលថ្ងៃធំឧត្តមរបស់ព្រះ
អម្ចាស់មកដល់ ២១នោះអស់អ្នកណាដែលអំពាវនាវដល់
ព្រះនាមព្រះអម្ចាស់[ក] គេនឹងបានសង្គ្រោះ[ខ] ២២ឱពួកសាសន៍
អ៊ីស្រាអែលអើយ សូមស្តាប់ពាក្យនេះចុះ ព្រះយេស៊ូវ ជា
អ្នកស្រុកណាសារ៉ែត[គ] ដែលព្រះបានសំដែងបង្ហាញមកអ្នក
រាល់គ្នា ដោយការឫទ្ធិបារមី ការអស្ចារ្យ នឹងទីសំគាល់[ឃ]
ដែលព្រះទ្រង់បានធ្វើ នៅកណ្តាលអ្នករាល់គ្នា ដោយសារ
ទ្រង់[ង] ដូចជាអ្នករាល់គ្នាដឹងស្រាប់ហើយ ២៣ព្រះអង្គនោះ
ទ្រង់ត្រូវបញ្ជូនទៅ តាមការសំរេច នឹងបព្វញាណ[ច]នៃព្រះ
ហើយអ្នករាល់គ្នាបានចាប់ទ្រង់ ដោយសារដៃមនុស្សទទឹង
ច្បាប់ ព្រមទាំងឆ្កាង[ឆ]សំឡាប់ទ្រង់ផង ២៤ប៉ុន្តែ ព្រះបាន
ប្រោសទ្រង់ ឱ្យមានព្រះជន្មរស់ឡើងវិញ ដោយបានស្រាយ
ចំណងនៃសេចក្តីស្លាប់ចេញ ពីព្រោះសេចក្តីស្លាប់[ជ] គ្មាន
អំណាចនឹងឃុំឃាំងទ្រង់[ឈ]ទុកបានឡើយ ២៥ដ្បិតហ្លួងដាវីឌ
មានបន្ទូលពីទ្រង់ថា«ទូលបង្គំបានឃើញព្រះអម្ចាស់ នៅមុខ
ទូលបង្គំជានិច្ច ពីព្រោះទ្រង់សណ្ឋិតនៅ ខាងដៃស្តាំទូលបង្គំ
ដើម្បីមិនឱ្យទូលបង្គំត្រូវរង្កើឡើយ ២៦ហេតុនោះបានជាចិត្ត
ទូលបង្គំមានសេចក្តីអំណរ ហើយអណ្តាតទូលបង្គំក៏ថ្លែង
ដោយសេចក្តីត្រេកអរ ១ទៀត រូបសាច់ទូលបង្គំនឹងស្នាក់
នៅ ដោយសេចក្តីសង្ឃឹមដែរ ២៧ដ្បិតទ្រង់នឹងមិនទុកព្រលឹង
ទូលបង្គំ ឱ្យជាប់នៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់ទេ ក៏មិន
ឱ្យអ្នកបរិសុទ្ធរបស់ទ្រង់ឃើញសេចក្តីពុករលួយ[ញ]ដែរ ២៨ទ្រង់
បានឱ្យទូលបង្គំស្គាល់អស់ទាំងផ្លូវនៃជីវិត ក៏នឹងឱ្យទូលបង្គំ
បានពេញជាសេចក្តីអំណរ ដោយភាពនៃព្រះភក្រ្តទ្រង់[ដ]»

**២:១៥** ល ថន ១ ៥:៧
**២:១៧** វ ជន ១១:២៥ អស ៤៤:៣ អគ ៣៩:២៩ យហ ៧:៣៧-៣៩ កច ១០:៤៥ ស កច ២១:៩
**២:១៨** ហ កច ២១:៩-១២
**២:១៩** ឡ លក ២១:១១
**២:២០** អ មថ ២៤:២៩
**២:២១** ក លប ៤:២៦ ២៦:២៥ ទដ ១០៥:១ កច ៩:១៤ ១កថ ១:២ ២ធថ ២:២២ ខ យអ ២:២៨-៣២ រម ១០:១៣
**២:២២** គ មក ១:២៤ ឃ យហ ៤:៤៨ ង យហ ៣:២
**២:២៣** ច អស ៥៣:១០ កច ៣:១៨ ៤:២៨ ឆ មថ ១៦:២១ លក ២៤:២០ កច ៣:១៣ **២:២៤** ជ ខ.៣២ កច ១៣:៣០,៣៣,៣៤,៣៧ ១៧:៣១ រម ៦:៤ ៨:១១ ១០:៩ ១កថ ៦:១៤ ១៥:១៥ អភ ១:២០ កល ២:១២ ហព ១៣:២០ ១ពត ១:២១ ឈ យហ ២០:៩
**២:២៧** ញ ខ.៣១ កច ១៣:៣៥ **២:២៨** ដ ទដ ១៦:៨-១១

**២:១៥** *ព្រោះទើបនឹងម៉ោង៩ព្រឹកនៅឡើយ* ក្នុងពិធីបុណ្យ ដូចជាបុណ្យថ្ងៃទី៥០ ពួកយូដាមិនអាចបញ្ឈប់តំណមរបស់ខ្លួនបានទេ គឺត្រូវទ្រាំអត់រហូតដល់ម៉ោង១០ព្រឹក ទើបអាចបរិភោគអាហារ ឬផឹកស្រាបាន ។ ដូច្នេះ មានន័យថា ពួកសាវ័ក មិនមែនស្រវឹងស្រាដូចពាក្យពួកគេចោទប្រកាន់នោះទេ ។

**២:១៧-១៨** *គ្រប់ទាំងមនុស្ស . . . កូនប្រុស . . . កូនស្រី. . . ពួកកំឡោះ. . .ពួកចាស់ៗ . . . ប្រុស . . . ស្រី* បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះអម្ចាស់ទ្រង់ចាក់ព្រះវិញ្ញាណបរិសុទ្ធ ទៅលើអស់អ្នកណាដែលជឿដល់ព្រះនាមទ្រង់ គឺពុំគិតអំពីភេទ អាយុ និងឋានៈ អ្វីឡើយ ។

**២:១៧** *ថ្ងៃជាន់ក្រោយ* "មើលការពន្យល់ អស ២:២ ១ធថ ៤:១ ២ធថ ៣:១ ហព ១:២ ១ពត ១:២០ ១យហ ២:១៨ និង ហស ៣:៥ មីក ៤:១"។ ក្នុងបទគម្ពីរយ៉ូអែល ជាភាសាហេព្រើ ប្រើពាក្យថា "ពេលក្រោយទៀត" ហើយព្រះគម្ពីរដែលបកប្រែជាភាសាក្រិកដំបូងបង្អស់ប្រើពាក្យថា "បន្ទាប់អំពីការទាំងនេះ"។ លោកពេត្រុស លើកយកបទគម្ពីរ "យអ ២:២៨-៣២" មកថ្លែងប្រាប់ពួកបណ្តាជនថា សេចក្តីទំនាយនោះបានសម្រេចហើយ (យរ ៣១:៣៣-៣៤ អគ ៣៦:២៦-២៧ ៣៩:២៩)។ *ព្រះវិញ្ញាណអញ* គឺព្រះវិញ្ញាណបរិសុទ្ធ (មើលការពន្យល់ ១:២)។

**២:១៨** *គេនឹងទាយទំនាយ* "មើលការពន្យល់ ១កថ ១២:១០"។

**២:១៩-២០** "មើលការពន្យល់ យអ ២:៣០-៣១ មក ១៣:២៤-២៥"។

**២:២១** *អស់អ្នកណាដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់* គឺសំដៅលើអស់អ្នកដែលជឿលើព្រះនាមព្រះយេស៊ូវ និងប្រតិបត្តិតាមព្រះបន្ទូលទ្រង់ពុំមែនគ្រាន់តែប្រើពាក្យសំដីធម្មតានោះទេ (ធៀប ខ.៣៩ មថ ៧:២១)។

**២:២២** *ដែលព្រះបានសំដែងបង្ហាញមកអ្នករាល់គ្នា ដោយការឫទ្ធិបារមី ការ អស្ចារ្យ និងទីសំគាល់* ព្រះរាជកិច្ចដ៏អស្ចារ្យទាំងនោះ មានមនុស្សស្ទើរតែទាំងអស់ដែលរស់នៅប្រទេសអ៊ីស្រាអែល កាលពីជាងពីរពាន់ឆ្នាំមុនបានដឹងឮ និងបានបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះសង្គ្រោះមនុស្សនៅលើពិភពលោកនេះឱ្យរួចពីបាប(មក ១:២៨ លក ៧:១៤-១៧)។

**២:២៣** *បព្វញាណនៃព្រះ* មានន័យថាព្រះអម្ចាស់ទ្រង់ជ្រាបគ្រប់ការទាំងអស់តាំងពីមុនពេលដែលទ្រង់បានបង្កើតពិភពលោកនេះទៅទៀត ។ម្យ៉ាងទៀត ខនេះបញ្ជាក់ថា ព្រះមែស៊ីត្រូវតែរងទុក្ខ និងសុគត ហើយបន្ទាប់មកទ្រង់នឹងរស់ឡើងវិញ (កច ១៧:២,៣ ២៦:២២,២៣ លក ២៤:២៥,២៦,៤៥,៤៦ មើលការពន្យល់ ១ពត ១:១១)។

**២:២៤** ពួកទទឹងច្បាប់បានធ្វើគុតព្រះយេស៊ូវគ្រីស្ទ តែព្រះបានលើកទ្រង់ឡើង និងប្រទានឱ្យទ្រង់មានអំណាចលើទាំងអស់ ទាំងនៅស្ថានសួគ៌ និងនៅផែនដីហើយសេចក្តីស្លាប់គ្មានអំណាចលើទ្រង់ឡើយ ។

**២:២៧** *មិនទុកព្រលឹងទូលបង្គំ ឱ្យជាប់នៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់ទេ* ហ្លួងដាវីឌថ្លែងបទគម្ពីរនេះ គឺសំដៅលើព្រះមែស៊ី (ខ.៣១) និងមានន័យថាព្រះអម្ចាស់មិនបណ្តោយឱ្យរូបកាយទ្រង់ ទៅជារលួយនោះឡើយ (មើលការពន្យល់ ទដ ១៦:៩-១១)។

## ប្រទេសរបស់ជាតិសាសន៍ដែលមកចូលរួមនៅថ្ងៃបុណ្យទី៥០



***ស្រុកអាស៊ី*** ជាខេត្តរបស់ចក្រភពរ៉ូម៉ាំង
***ស្រុកមេឌី*** ជាខេត្តរបស់ចក្រភពផារថុស
***(១) (២) (៣)*** . . . គឺជាលេខលំដាប់នៅក្នុង "កច ២:៩-១១"។

## ព្រះវិហារនៅសម័យស្តេចហេរ៉ូឌ

**នៅឆ្នាំទី២០មុនគ.ស–៧០គ.ស**

ចាប់ផ្តើមកសាងក្នុងឆ្នាំទី២០មុនគ.ស តាមរចនាសម្ព័ន្ធថ្មីរបស់ស្តេចហេរ៉ូឌ ដែលមានកម្ពស់១៥ជាន់យ៉ាងខ្ពស់ត្រដែត ដោយប្រើកម្រាលចាស់ដដែលត្រង់ទីបរិសុទ្ធ និងទីបរិសុទ្ធបំផុត ។ កន្លែងដែលស័ក្តិសិទ្ធបំផុត ត្រូវបានសង់ឡើង នៅកន្លែងអតីតប្រាសាទនៃស្តេចសាឡូម៉ូន និងស្តេចយេរូបាបិល ដោយចប់សព្វគ្រប់ត្រឹមតែរយៈពេល១៨ខែប៉ុណ្ណោះ ។



ផ្នែកបរិវេណខាងក្រៅមិនបានសង់ចប់ សព្វគ្រប់នោះទេ រហូតដល់ឆ្នាំទី៦៤គ.ស ។ គម្រោងសាងសង់ទាំងមូលត្រូវរើចេញ និងកំទេចចោលដោយពួករ៉ូម៉ាំងនៅឆ្នាំទី ៧០គ.ស ។ ទំហំនៃបន្ទប់ ជណ្តើរ ទ្វារ ក្បាំងក្បាល ជញ្ជាំង និងរង្វាស់បរិវេណ ខាងក្រៅត្រូវបានកត់ទុកជា ប្រវត្តិសាស្ត្រ (ក្នុងឯសាររបស់លោកយ៉ូសែបហ្វីស និងមីសណា Josephus and theMishnah) ប៉ុន្តែ អាស្រ័យលើការបកស្រាយ និងមានគំនូស (គំរូប្លង់) ទាំងអស់ប្លែកៗគ្នា ។

២៩ឱបងប្អូន[ឋ]រាល់គ្នាអើយ ខ្ញុំមានច្បាប់ នឹងថ្លែងប្រាប់
ដល់អ្នករាល់គ្នាយ៉ាងច្បាស់ ពីហ្លួងដាវីឌ ជាព្វយុកោ[ឌ]ថា
លោកបានទាំងសុគត ហើយគេបានបញ្ចុះ[ឍ]សពលោកដែរ
ផ្នូរលោកក៏នៅជាមួយនឹងយើងរាល់គ្នា ដរាបដល់សព្វថ្ងៃ
នេះ[ណ] ៣០ដូច្នេះ ដោយព្រោះលោកជាហោរា ហើយក៏
ជ្រាបថាព្រះបានស្បថសន្យានឹងលោកថា ទ្រង់នឹងបង្កើត
ព្រះគ្រីស្ទ ពីពូជរបស់លោកខាងសាច់ឈាម ឱ្យបានគង់
លើបល្ល័ង្ក[ត]របស់លោក ៣១គឺដោយព្រោះលោកបានឃើញ
ការនោះជាមុន បានជាលោកសំដែង ពីព្រះគ្រីស្ទត្រូវរស់
ឡើងវិញថា ព្រលឹងទ្រង់មិនត្រូវទុកចោល នៅក្នុងស្ថានឃុំ
ព្រលឹងមនុស្សស្លាប់ទេ ហើយរូបសាច់ទ្រង់មិនត្រូវឃើញ
សេចក្ដីពុករលួយ[ថ]ឡើយ ៣២ឯព្រះយេស៊ូវនេះ ព្រះបាន
ប្រោសឱ្យទ្រង់មានព្រះជន្មរស់ឡើងវិញ[ទ] ហើយពួកយើង
នេះជាទីបន្ទាល់[ធ]ពីទ្រង់ទាំងអស់គ្នា ៣៣ដូច្នេះ ដែលទ្រង់បាន
ដំកើងឡើង[ន] ដោយសារព្រះហស្តស្តាំនៃព្រះ[ប] ហើយបាន
ទទួលសេចក្ដីសន្យា គឺជាព្រះវិញ្ញាណបរិសុទ្ធ[ផ] ពីព្រះវរ
បិតា[ព] នោះទ្រង់បានចាក់[ភ]សេចក្ដីនេះមក ដែលអ្នករាល់គ្នា
កំពុងតែមើល ហើយស្តាប់ ៣៤ដ្បិតហ្លួងដាវីឌមិនបានឡើង
ទៅស្ថានសួគ៌ទេ ប៉ុន្តែលោកបាននិយាយថា «ព្រះអម្ចាស់
ទ្រង់មានបន្ទូលនឹងព្រះអម្ចាស់នៃទូលបង្គំថា ចូរឯងអង្គុយ
ខាងស្តាំអញ ៣៥ដរាបដល់អញយកពួកខ្មាំងសត្រូវឯងដាក់ធ្វើ
ជាកំណល់កល់ជើងឯង»[ម]។
៣៦ដូច្នេះ ចូរឱ្យពួកវង្សអ៊ីស្រាអែលទាំងអស់ ដឹងជា
ប្រាកដថា ព្រះទ្រង់បានលើកព្រះយេស៊ូវនេះ ដែលអ្នក
រាល់គ្នាបានឆ្កាង ឱ្យទ្រង់ធ្វើជាព្រះអម្ចាស់[យ] ហើយជា
ព្រះគ្រីស្ទផង[រ]។
៣៧កាលគេបានឮ នោះគេមានសេចក្ដីចាក់ចុចក្នុងចិត្ត
ក៏សួរពេត្រុស នឹងពួកសាវកឯទៀតថា បងប្អូនអើយ តើ
យើងខ្ញុំត្រូវធ្វើដូចម្ដេច[ល] ៣៨ពេត្រុសឆ្លើយតបថា ចូរអ្នករាល់
គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹក[វ]ទាំងអស់គ្នា
ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ប្រយោជន៍ឱ្យបានរួច
ពីបាប[ស] នោះអ្នករាល់គ្នានឹងទទួលអំណោយទាន ជាព្រះ
វិញ្ញាណបរិសុទ្ធ[ហ] ៣៩ដ្បិតសេចក្ដីសន្យានោះ គឺសន្យាដល់

**២:២៩** ឋ កច ២២:៥ ឌ កច ៧:៨–៩ ឍ ១ពវ ២:១០ កច ១៣:៣៦ ណ នហ ៣:១៦
**២:៣០** ត មថ ១:១
**២:៣១** ថ ទដ ១៦:១០
**២:៣២** ទ ខ.២៤ ធ លក ២៤:៤៨
**២:៣៣** ន ភល ២:៩ ប មក ១៦:១៩ ផ យហ ៧:៣៩ ១៤:២៦ ១៥:២៦ ព កច ១:៤ ភ កច ១០:៤៥
**២:៣៥** ម ទដ ១១០:១ មថ ២២:៤៤
**២:៣៦** យ មថ ២៨:១៨ រ លក ២:១១

**២:៣៧** ល លក ៣:១០,១២,១៤ កច ១៦:៣០ **២:៣៨** វ ខ.៤១ កច ៨:១២, ១៦, ៣៦,៣៨ ៩:១៨ ១០:៤៨ ១៦:១៥,៣៣ ១៩:៥ ២២:១៦ កល ២:១២ ស យរ ៣៦:៣ មក ១:៤ លក ២៤:៤៧ កច ៣:១៩ ហ យហ ២០:២២

**២:២៩** *ផ្នូរលោកក៏នៅជាមួយនឹងយើងរាល់គ្នា ដរាបដល់សព្វថ្ងៃនេះ* គឺផ្នូររបស់ហ្លួងដាវីឌ នៅក្នុងទីក្រុងយេរូសាឡិម ដែលគេអាចមើលឃើញ ។ ហើយក្នុងផ្នូរនោះក៏នៅមានបំណែកសពរបស់ទ្រង់ខ្លះៗផងដែរ ។ អត្ថន័យនៅក្នុងបទគម្ពីរ "ទដ ១៦:៨-១១" គឺសំដៅលើព្រះយេស៊ូវតែម្តងពុំមែនសំដៅលើហ្លួងដាវីឌទេ ។

**២:៣៣** *ទ្រង់បានដំកើងឡើង ដោយសារព្រះហស្តស្តាំនៃព្រះ* "មើលការពន្យល់ អព ១:២,៣"។ *សេចក្ដីសន្យាគឺជាព្រះវិញ្ញាណបរិសុទ្ធ* "មើលការពន្យល់ ១:៤"។ *បានចាក់សេចក្ដីទាំងនេះមក* (ខ.១៧ យអ ២:២៨)។

**២:៣៤** *ព្រះអម្ចាស់ទ្រង់មានបន្ទូលនឹងព្រះអម្ចាស់នៃទូលបង្គំ* ពាក្យថា "*ព្រះអម្ចាស់នៃទូលបង្គំ*" ក្នុងខនេះគឺសំដៅលើព្រះយេស៊ូវ ។ ព្រះវិញ្ញាណបរិសុទ្ធនៃព្រះអម្ចាស់បានបើកសំដែង ឱ្យហ្លួងដាវីឌដឹងថា នឹងមានព្រះសង្គ្រោះមកប្រសូតនៅក្នុងរាជវង្សរបស់ទ្រង់ ។ ដូច្នោះហើយ បានជាហ្លួងដាវីឌមានអំណរជាខ្លាំង ព្រោះទ្រង់ដឹងយ៉ាងច្បាស់ថា ព្រះអម្ចាស់ធំអស្ចារ្យណាស់ (មថ ២២:៤១–៤៥)។ ព្រះអម្ចាស់នៃយើងទ្រង់មិនគ្រាន់តែរស់ពីសុគតប៉ុណ្ណោះទេ (ខ.៣១–៣២) គឺទ្រង់ត្រូវបានតម្កើងឡើង នៅខាងស្តាំនៃព្រះដ៏ខ្ពស់បំផុតផង (ខ.៣៣-៣៥)។ ហើយព្រះវត្តមានរបស់ទ្រង់បានសំដែងឱ្យដឹង តាមរយៈព្រះវិញ្ញាណបរិសុទ្ធ (ខ.៣៣ យហ ១៦:៧ មើលសេចក្ដីផ្ដើម ទំនុកដំកើង និងការពន្យល់ ទដ ១១០:១)។

**២:៣៧** *សេចក្ដីចាក់ចុចក្នុងចិត្ត* ការនេះកើតឡើងបានគឺដោយសារតែព្រះបន្ទូលដែលលោកពេត្រុសថ្លែងទៅកាន់ពួកគេ មានអំណាចព្រះចេស្ដា និងការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ។ ព្រះបន្ទូលព្រះអម្ចាស់ដូចជាដាវ (អភ ៦:១៧) ដែលកាត់ព្រលឹង និងវិញ្ញាណ ហើយសន្លាក់ និងខួរឆ្អឹងដាច់ពីគ្នាទាំងពិចារណាអស់ទាំងគំនិតដែលគិត (ហព ៤:១២)។

**២:៣៨** *ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា* ការប្រែចិត្តមានសារសំខាន់ណាស់ ដូចមានចែងនៅក្នុងសេចក្ដីបង្រៀនរបស់លោកយ៉ូហាន–បាទីស្ទ (មក ១:៤ លក ៣:៣) ក្នុងសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ (មក ១:១៥ លក ១៣:៣) ក្នុងសេចក្ដីបង្រៀននៅមុនពេលដែលទ្រង់យាងទៅស្ថានសួគ៌វិញ (មថ ២៨:១៨,១៩) និងនៅក្នុងសេចក្ដីបង្រៀននៃព្រះគម្ពីរកិច្ចការ ទាក់ទងទៅនឹងសេចក្ដីជំនឿ (៨:១២ ១៨:៨) ការទទួលយកព្រះបន្ទូល (ខ.៤១) និងការប្រែចិត្ត ។ *ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ* សេចក្ដីនេះមានន័យដូចគ្នា នឹង "មថ ២៨:១៩"។ ក្នុងគម្ពីរកិច្ចការទម្រង់សង្ខេបនេះ ត្រូវបានប្រើក្នុងពិធីបុណ្យជ្រមុជទឹក (១៩:៤–៥)។ *ប្រយោជន៍ឱ្យបានរួចពីបាប* ត្រង់ចំណុចនេះត្រូវចាំថា ពិធីជ្រមុជទឹកពុំមែនមានន័យថា ធ្វើឱ្យមនុស្សបានរួចពីបាបនោះទេ ។ ដើម្បីឱ្យបានរួចពីបាបគឺមានតែការទទួលជឿព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ ។ ចំណែកឯពិធីបុណ្យជ្រមុជទឹកគឺគ្រាន់តែជានិមិត្តរូបមួយនៃការអត់ទោសបាប និងសំដែងអំពីការស្លាប់បង្ហាប់ទ្រង់ បន្ទាប់ពីទទួលជឿដល់ទ្រង់ហើយប៉ុណ្ណោះ (មើលការពន្យល់ រម ៦:៣–៤)។ *ព្រះវិញ្ញាណបរិសុទ្ធ* ព្រះវិញ្ញាណបរិសុទ្ធ និងការអត់ទោសបាប (២២:១៦) គឺជាការប្រទានមកពីព្រះអម្ចាស់ ។ សេចក្ដីសន្យាទាំងនេះ គឺត្រូវប្រទានទៅដល់អស់អ្នកណា ដែលទទួលជឿដល់ព្រះនាមព្រះយេស៊ូវ (រម ៨:៩–១១ និងមើលការពន្យល់ កច ៨:៩ ១កថ ១២:១៣)។

**២:៣៩** ទោះបីលោកពេត្រុសជាសាសន៍យូដា និងនិយាយទៅកាន់ហ្វូងមនុស្សដែលភាគច្រើនជាជនជាតិយូដាក៏ដោយ ក៏គាត់ប្រាប់ពួកគេថា សេចក្ដីសន្យាជាព្រះវិញ្ញាណបរិសុទ្ធមិនមែនសម្រាប់តែសាសន៍យូដាប៉ុណ្ណោះទេ គឺសម្រាប់

អ្នករាល់គ្នា និងកូនចៅអ្នករាល់គ្នា[ឡ] ព្រមទាំងអស់អ្នកដែល
នៅឆ្ងាយដែរ[អ] គឺដល់អស់អ្នកណាដែលព្រះអម្ចាស់ជាព្រះ
នៃយើងរាល់គ្នាទ្រង់នឹងហៅ ៤០គាត់ក៏ធ្វើបន្ទាល់អស់ពី
ចិត្ត ហើយទូន្មានដោយពាក្យជាច្រើនទៀតថា ចូរឱ្យអ្នក
រាល់គ្នាបានសង្គ្រោះ រួចពីពូជដំណវៀច[ក]នេះ ៤១នោះពួក
អ្នកដែលទទួលពាក្យរបស់គាត់ដោយអំណរ ក៏បានទទួល
បុណ្យជ្រមុជទឹក ហើយនៅថ្ងៃដដែលនោះ មានប្រហែល
ជា៣ពាន់នាក់ ថែមកើនឡើងទៀត[ខ]។

## ការប្រកបគ្នានៃពួកអ្នកជឿ

៤២អ្នកទាំងនោះ ក៏នៅតែព្យាយាមក្នុងសេចក្ដីបង្រៀន[គ]
របស់ពួកសាវក ហើយក្នុងសេចក្ដីប្រកបគ្នា ព្រមទាំងការ
កាច់នំបុ័ង[ឃ] នឹងសេចក្ដីអធិស្ឋាន[ង]ផង ៤៣គ្រប់គ្នាកើតមាន
ចិត្តកោតខ្លាច ហើយមានការអស្ចារ្យ នឹងទីសំគាល់ជា
ច្រើនកើតមកដោយសារពួកសាវកដែរ[ច] ៤៤ពួកអ្នកដែល
ជឿទាំងប៉ុន្មាន ក៏នៅជាមួយគ្នា ហើយមានរបស់ទាំងអស់
នៅមូលព្រមគ្នា[ឆ] ៤៥គេក៏លក់ទ្រព្យសម្បត្តិ និងរបស់គេទាំង
ប៉ុន្មានចែកដល់គ្នា តាមដែលគ្រប់គ្នាត្រូវការ[ជ] ៤៦រាល់តែថ្ងៃ
គេនៅតែព្យាយាមក្នុងព្រះវិហារ[ឈ] ដោយមានចិត្តព្រម

**២:៣៩** ឡ អស ៤៤:៣ ៦៥:២៣ ៥៧:១៩
អ កច ១០:៤៥ អភ ២:១៣
**២:៤០** ក ចទ ៣២:៥ ភល២:១៥
**២:៤១** ខ ខ.៤៧ ៤:៤,៥ ៥:១៤ ៦:១,៧ ៩:៣១,៣៥,៤២ ១១:២១ ២៤ ១៤:១, ២១ ១៦:៥ ១៧:១២
**២:៤២** គ មថ ២៨:២០
ឃ មថ ១៤:១៩
ង កច ១:១៤
**២:៤៣** ច កច ៥:១២
**២:៤៤** ឆ កច ៤:៣២
**២:៤៥** ជ មថ ១៩:២១ លក ១២:៣៣ ១៨:២២ កច ៤:៣៤,៣៥ ៦:១

ព្រៀងគ្នា ឯកាលនៅផ្ទះក៏កាច់នំបុ័ង[ញ] ហើយបរិភោគ
អាហារដោយអំណរនឹងចិត្តស្មោះត្រង់ ៤៧ព្រមទាំងសរសើរ
ដល់ព្រះ ហើយបណ្ដាជនទាំងអស់គ្នាក៏រាប់អានគេ[ដ] ចំណែក
ព្រះអម្ចាស់ទ្រង់ក៏បន្ថែម នូវអស់អ្នកដែលកំពុងតែបាន
សង្គ្រោះរាល់តែថ្ងៃទៅក្នុងពួកជំនុំថែមទៀត[ឋ]។

## មនុស្សខ្វិនពីកំណើតម្នាក់បានជាពីជំងឺ

៣ ១នៅពេលអធិស្ឋាន ជាពេលម៉ោង៣រសៀល[ឌ] នោះ
ពេត្រុស និងយ៉ូហាន[ឍ] ឡើងទៅក្នុងព្រះវិហារ[ណ]ជាមួយគ្នា
២រីឯនៅត្រង់មាត់ទ្វារ[ត]ព្រះវិហារ ដែលហៅថា ទ្វារលំអ
នោះមានមនុស្សម្នាក់ដែលខ្វិនពីកំណើត[ថ] គេតែងសែងគាត់
យកមកដាក់នៅទីនោះរាល់តែថ្ងៃ ដើម្បីឱ្យបានសូមទាន[ទ]
ចំពោះអស់អ្នកដែលចូលទៅក្នុងព្រះវិហារ ៣កាលគាត់
ឃើញពេត្រុស និងយ៉ូហាន កំពុងតែដើរចូលទៅក្នុង
ព្រះវិហារនោះគាត់សូមទាន ៤តែពេត្រុសព្រមទាំងយ៉ូហាន
ក៏សំឡឹងមើលទៅគាត់ ប្រាប់ថា ចូរមើលមកយើងឯ
ណេះ ៥គាត់ក៏ស្ដាប់តាម ដោយសង្ឃឹមថានឹងបានអ្វីខ្លះ ។

**២:៤៦** ឈ លក ២៤:៥៣ កច ៣:១ ៥:២១,៤២ ញ ខ.៤២ មថ ១៤:១៩
**២:៤៧** ដ រម ១៤:១៨ ឋ ខ.៤១ **៣:១** ឌ ទដ ៥៥:១៧ កច ១០:៣០ ឍ លក ២២:៨ ណ កច ២:៤៦ **៣:២** ត លក ១៦:២០ ថ កច ១៤:៨ ទ យហ ៩:៨

អស់អ្នកដែលនៅឆ្ងាយដែរ (អ្នកនៅឆ្ងាយគឺសាសន៍ដទៃ អភ ២:១១–១៣)។ សេចក្ដីសន្យានេះមានចំពោះអ្នកដែលព្រះអម្ចាស់ទ្រង់ត្រាស់ហៅ ។ ព្រះទ្រង់ជ្រើសរើស និងបានត្រាស់ហៅយើងតាំងពីមុនកំណើតពិភពលោកមកម៉្លេះ (អភ ១:៤) ហើយទ្រង់ក៏ជ្រាបទាំងអស់ថា អ្នកណានឹងជឿលើព្រះនាមទ្រង់ និងបានសេចក្ដីសង្គ្រោះមកពីទ្រង់ ។ ដូច្នេះ អស់អ្នកដែលជឿលើព្រះនាមព្រះយេស៊ូវគ្រីស្ទ នោះពិតជាបានសង្គ្រោះ (ខ.២១) និងទទួលបាននូវសេចក្ដីសន្យាជាព្រះវិញ្ញាណបរិសុទ្ធ ។

**២:៤១** *កើនឡើងទៀត* គឺជាចំនួននៃអ្នកជឿលើព្រះយេស៊ូវគ្រីស្ទ ដែលបានចូលរួមជាមួយនឹងពួកសាវក ក្នុងការសរសើរ និងថ្វាយបង្គំទ្រង់ ។

**២:៤២** *សេចក្ដីបង្រៀនរបស់ពួកសាវក* សេចក្ដីបង្រៀនរបស់ពួកសាវកនាពេលនោះច្រើននិយាយអំពីការសុគត ការបញ្ចុះព្រះសព និងការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ (ខ.២៣–២៤ ៣:១៥ ៤:១០ ១កថ ១៥:១–៤ មថ ២៨:២០)។ លក្ខណៈពិសេសមួយដែលគួរឱ្យកត់សំគាល់គឺ ពួកគេទាំងនោះបានពេញដោយអំណាចដ៏អស្ចារ្យមកអំពីព្រះអម្ចាស់ (២កថ ១៣:១០ ១ធថ ៤:២)។ *សេចក្ដីប្រកបគ្នា* គឺសំដៅលើការរួបរួមគ្នា រវាងពួកអ្នកជឿលើព្រះនាមព្រះយេស៊ូវក្នុងការថ្វាយបង្គំទ្រង់ ។ *ការកាច់នំបុ័ង* ត្រង់ចំណុចនេះប្រហែលជាពួកគេធ្វើពិធីលៀងព្រះអម្ចាស់ (ខ.៤៦ ១កថ ១០:១៦ ១១:២០)។ *សេចក្ដីអធិស្ឋាន* នៅក្នុងព្រះគម្ពីរកិច្ចការ បានបញ្ជាក់យ៉ាងច្បាស់ អំពីសារសំខាន់នៃសេចក្ដីអធិស្ឋាន ក្នុងជីវិតអ្នកជឿដល់ព្រះយេស៊ូវ ទាំងសម្រាប់ខ្លួនឯងនិងសម្រាប់អ្នកដទៃ (១:១៤ ៣:១ ៦:៤ ១០:៤,៣១ ១២:៥ ១៦:១៣,១៦)។

**២:៤៤** *ពួកអ្នកដែលជឿទាំងប៉ុន្មាន ក៏នៅជាមួយគ្នា* ត្រង់ចំណុចនេះបង្ហាញអំពីការរួបរួមគ្នាដ៏ពិតប្រាកដនៃពួកជំនុំដំបូង (មើលការពន្យល់ កច ៤:៣២ យហ ១៧:១១,២១–២៣ រម ១៥:៥ អភ ៤:១–១៦ ភល២:១–៤)។ *មានរបស់ទាំងអស់ នៅមូលព្រមគ្នា* ពួកគេធ្វើយ៉ាងដូច្នោះគឺសំដែងអំពីការចែកចាយដោយស្ម័គ្រចិត្ត ដើម្បីផ្គត់ផ្គង់ដល់អស់អ្នកដែលមានតម្រូវការចាំបាច់សម្រាប់ការរស់នៅប្រចាំថ្ងៃ (ធៀប "៤:៣៤–៣៥" និង "៤:៣៦-៥:៩")។

**២:៤៦** *ក្នុងព្រះវិហារ* ប្រហែលជានៅត្រង់បាំងសាចសាឡូម៉ូន (មើលការពន្យល់ ៣:១១ ៥:១២)។ *ឯកាលនៅផ្ទះ ក៏កាច់នំបុ័ង* ត្រង់ចំណុចនេះបានបង្ហាញអំពីជីវិត អំណរ សេចក្ដីសប្បុរស និងសកម្មភាពដ៏ពិតប្រាកដរបស់គ្រីស្ទបរិស័ទនៅក្នុងពួកជំនុំដំបូង ។ *ដោយអំណរ និងចិត្តស្មោះត្រង់* ទាំងនេះគឺជាផលផ្លែខាងឯវិញ្ញាណ ដែលព្រះអម្ចាស់ទ្រង់ប្រទានមកពួកជំនុំរបស់ទ្រង់ (មើលការពន្យល់ ១៦:៣៤)។

**៣:១** *ពេត្រុស និងយ៉ូហាន* ក្នុងខណៈនោះ អ្នកទាំងពីរនេះក៏ស្ថិតនៅក្នុងចំណោមពួកសាវកដទៃទៀតដែរ (កទ ២:៩)។ លោកយ៉ាកុប ជាប្អូនរបស់លោកយ៉ូហាន និងជាអ្នកដែលនៅជិតស្និទ្ធនឹងព្រះយេស៊ូវ ក៏នៅជាមួយពួកសាវកទាំងនោះដែរ (មក ៩:២ ១៣:៣ ១៤:៣៣ លក ២២:៨)។ ពួកសាវកទាំងនោះត្រូវបានគេចាប់ខ្លួនជាមួយគ្នា (៤:៣) និងទៅឯស្រុកសាម៉ារីជាមួយគ្នា (៨:១៤)។ *ពេលអធិស្ឋាន* គ្រានោះ ពួកអ្នកកាន់សាសនាយូដាតែងតែអធិស្ឋាន១ថ្ងៃ៣ដងគឺនៅម៉ោង៩ព្រឹក ម៉ោង៣រសៀល និងពេលថ្ងៃលិច ។

**៣:២** *ទ្វារលំអ* ជាទ្វារដ៏ប្រណិតនៅក្នុងព្រះវិហារ ស្ថិតនៅចន្លោះទីលានសម្រាប់សាសន៍ដទៃ និងទីលានសម្រាប់ស្ត្រី ។ ទ្វារនេះប្រហែលជាស្រោបដោយទង់ដែងពីខាងក្រៅ។ ពេលខ្លះគេហៅទ្វារនេះថា ទ្វារនីកាន័រ (៦:៥)។

៦តែពេត្រុសនិយាយថា ឯប្រាក់ ហើយនិងមាសខ្ញុំគ្មានទេ
តែរបស់ដែលខ្ញុំមាន នោះខ្ញុំនឹងឱ្យដល់អ្នក គឺដោយសារ
ព្រះនាមព្រះយេស៊ូវគ្រីស្ទ ពីស្រុកណាសារ៉ែត[ធ] ចូរអ្នក
ក្រោកឡើងដើរទៅចុះ ៧រួចក៏ចាប់ដៃស្ដាំ លើកគាត់ឡើង
ស្រាប់តែប្រអប់ជើង នឹងភ្នែកគោររបស់គាត់មានកំឡាំង
ឡើងភ្លាម ៨គាត់ក៏ស្ទុះឈរឡើង ដើរទៅមក ហើយចូលទៅ
ក្នុងព្រះវិហារ ជាមួយនឹងអ្នកទាំង២នោះ ទាំងដើរ ទាំង
លោត[ន] ទាំងសរសើរដល់ព្រះផង ៩បណ្ដាជន[ប]ទាំងអស់គ្នា
ក៏ឃើញគាត់ដើរ ទាំងសរសើរព្រះដូច្នោះ ១០ហើយគេ
ស្គាល់គាត់ ថាជាអ្នកដែលតែងតែអង្គុយសូមទានគេ នៅ
ត្រង់មាត់ទ្វារលំអ[ផ]របស់ព្រះវិហារ នោះគេក៏មានពេញជា
សេចក្ដីអស្ចារ្យ ហើយមមិងមមាំងពីការដែលកើតមកនោះ

## ពេត្រុសថ្លែងទៅកាន់បណ្ដាជន

១១ដូច្នេះ កំពុងដែលគាត់ចាប់តោងឃាត់ពេត្រុស និង
យ៉ូហាន[ព] នោះបណ្ដាជនទាំងអស់ក៏រត់មូលមកឯគេ នៅត្រង់
បាំងសាចដែលហៅថា បាំងសាចសាឡូម៉ូន[ភ] ហើយគេ
មានសេចក្ដីអស្ចារ្យក្នុងចិត្តណាស់ ១២កាលពេត្រុសបាន
ឃើញដូច្នោះ នោះគាត់និយាយទៅប្រជាជនថា ឱសាសន៍
អ៊ីស្រាអែលរាល់គ្នាអើយ ហេតុអ្វីបានជាមានសេចក្ដីប្លែក
ក្នុងចិត្តពីការនេះ ហើយសំឡឹងមើលមកយើងខ្ញុំ ហាក់ដូចជា
យើងខ្ញុំបានធ្វើឱ្យមនុស្សនេះដើររួច ដោយអាងអំណាច
ឬគុណានុភាព របស់ខ្លួនយើងខ្ញុំដូច្នេះ ១៣ព្រះនៃលោក
អ័ប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប[ម] ជាព្រះនៃពួក
ឰយុកោ[យ]យើងរាល់គ្នា ទ្រង់បានដំកើងអ្នកបំរើទ្រង់ នោះគឺ
ព្រះយេស៊ូវ ដែលអ្នករាល់គ្នាបានបញ្ជូនទៅ[រ] ហើយក្នុង
កាលដែលលោកពីឡាត់[ល] សំរេចសេចក្ដីថានឹងលែងទ្រង់
នោះអ្នករាល់គ្នាបានប្រកែក បដិសេធនៅមុខលោក មិន
ព្រមទទួលទ្រង់ទេ[វ] ១៤គឺជាមិនព្រមទទួលព្រះដ៏បរិសុទ្ធ[ស]
ហើយសុចរិត[ហ]នោះឯង បែរជាសូមឱ្យលោកលែងមនុស្ស
ដែលសំឡាប់គេ ដល់អ្នករាល់គ្នាវិញ[ឡ] ១៥អ្នករាល់គ្នាបាន
សំឡាប់ព្រះអម្ចាស់ជីវិតនោះទៅ តែព្រះបានប្រោសឱ្យ
ទ្រង់មានព្រះជន្មរស់ពីស្លាប់[អ]ឡើងវិញ យើងខ្ញុំនេះជា
ទីបន្ទាល់[ក] ពីការនោះឯង ១៦ហើយគឺដោយសារសេចក្ដី
ជំនឿជឿដល់ព្រះនាមទ្រង់[ខ] នោះព្រះនាមទ្រង់បានប្រោស
មនុស្សនេះ ដែលអ្នករាល់គ្នាឃើញ ហើយស្គាល់ ឱ្យមាន
កំឡាំងឡើង គឺជាសេចក្ដីជំនឿ ដែលកើតមកដោយសារ
ព្រះអង្គនោះឯង បានធ្វើឱ្យគាត់ជាស្រឡះ នៅមុខអ្នក

**៣:៦** ធ ខ.១៦ មក ១:២៤
**៣:៨** ន អស ៣៥:៦ កច ១៤:១០
**៣:៩** ប កច ៤:១៦,២១
**៣:១០** ផ ខ.២
**៣:១១** ព លក ២២:៨ ភ យហ ១០:២៣ កច ៥:១២
**៣:១៣** ម នក ៣:៦ យ កច ៥:៣០ ៧:៣២ ២២:១៤ រ កច ២:២៣ ល មថ ២៧:២ វ លក ២៣:៤
**៣:១៤** ស មក ១:២៤ កច ៤:២៧ ហ កច ៧:៥២ ឡ មក ១៥:១១ លក ៣២:១៨–២៥
**៣:១៥** អ កច ២:២៤ ក លក ២៤:៤៨
**៣:១៦** ខ ខ.៦

**៣:៦** *ដោយសារព្រះនាមព្រះយេស៊ូវគ្រីស្ទ* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ពួកសាវកធ្វើការអស្ចារ្យទាំងនោះបាន គឺដោយសារព្រះចេស្ដារបស់ព្រះយេស៊ូវ ។

**៣:៧** *រួចក៏ចាប់ដៃស្ដាំ លើកគាត់ឡើង* បុរសម្នាក់នោះជាពីជំងឺ គឺដោយសារតែសេចក្ដីជំនឿ និងព្រះគុណនៃព្រះអម្ចាស់ (ខ.១៦)។

**៣:៨** *ចូលទៅក្នុងព្រះវិហារ* នៅក្នុងខណៈនោះ សាវ័កទាំងពីរនាក់បានចូលទៅក្នុងព្រះវិហារ តាមទីលានខាងក្រៅ (សម្រាប់សាសន៍ដទៃ) រួចចូលទៅទីលានសម្រាប់ស្ត្រី ជាកន្លែងមានផ្ទុកនូវវត្ថុដែលមានតម្លៃ (មក ១២:៤១–៤៤) បន្ទាប់មកទើបទៅដល់ទីលានសម្រាប់ពួកអ៊ីស្រាអែល ។ ពីទីលានខាងក្រៅបំផុតរហូតទៅដល់ទីលានខាងក្នុងបំផុត ត្រូវឆ្លងកាត់ទ្វារចំនួន៩ ។

**៣:១១** *បាំងសាចសាឡូម៉ូន* គឺបាំងសាច (រានហាល) ស្ថិតនៅផ្នែកខាងក្នុងនៃជញ្ជាំងដែលព័ទ្ធជុំវិញទីលានខាងក្រៅ ។ បាំងសាចនោះទ្រដោយសសរថ្មកម្ពស់៨,២២ម៉ែត្រ តម្រៀបជាជួរ និងមានពិតានធ្វើអំពីឈើតាត្រៅ (ជន ១៩:៦ ២៤:៦ មើលការពន្យល់ យហ ១០:២៣)។

**៣:១២** លោកពេត្រុសបានបដិសេធមិនព្រមទទួលការសរសើរ និងកិត្តិយស សម្រាប់ខ្លួនឯងទេ ប៉ុន្តែ គាត់បានថ្វាយគ្រប់ការទាំងអស់នោះទៅឯព្រះអម្ចាស់វិញ (មើលការពន្យល់ ២:១៤–៤០)។ ទាំងនោះគឺជាគំរូដ៏ល្អសម្រាប់ពួកអ្នកជឿលើព្រះយេស៊ូវគ្រីស្ទគ្រប់ៗគ្នានាពេលបច្ចុប្បន្ន ។

**៣:១៣** បទគម្ពីរនេះ បានរំឭកពួកគេឱ្យដឹងថា ព្រះយេស៊ូវត្រូវរងទុក្ខជាច្រើនតាមសេចក្ដីទំនាយនៅក្នុងគម្ពីរ "អស ៥២:១៣–៥៣:១២" (មើលការពន្យល់ មថ ១២:១៨ កច ៤:២៧,៣០)។ *មិនព្រមទទួលទ្រង់ទេ* គឺពួកគេបាននាំគ្នាបដិសេធព្រះយេស៊ូវគ្រីស្ទ ដោយនិយាយថា ទ្រង់មិនមែនជាព្រះមែស៊ី ដែលត្រូវយាងមកសង្គ្រោះពួកគេទេ ។ *លោកពីឡាត់សំរេចសេចក្ដីថានឹងលែងទ្រង់* "មើលការពន្យល់ យហ ១៩:១២"។

**៣:១៤** *ព្រះដ៏បរិសុទ្ធ* មើលការពន្យល់ លវ ១១:១៤ ។ *សុចរិត* ពួកគេប្រើពាក្យនេះសម្រាប់ពណ៌នាអំពីលក្ខណៈរបស់ព្រះមែស៊ី "កច ៧:៥២ ២២:១៤ ១យហ ២:១)។ *មនុស្សដែលសំឡាប់គេ* គឺសំដៅលើបុរសម្នាក់ឈ្មោះ "បារ៉ាបាស" ដែលជាអ្នកបះបោរប្រឆាំងនឹងចក្រភពរ៉ូម៉ាំង (មើលការពន្យល់ លក ២៣:១៨)។

**៣:១៥** *អ្នករាល់គ្នាបានសំឡាប់. . .ព្រះបានប្រោសឱ្យទ្រង់. . .យើងខ្ញុំនេះជាទីបន្ទាល់* សេចក្ដីទាំងនេះគឺជាគោលបំណងដ៏សំខាន់នៅក្នុងព្រះគម្ពីរកិច្ចការ (២:២៣-២៤ ៤:១០ ៥:៣០–៣២ ១០:៣៩–៤១ ១៣:២៨–២៩ ១កថ ១៥:១–៤)។

**៣:១៦** លោកពេត្រុសថ្លែងប្រាប់ពួកបណ្ដាជនយ៉ាងច្បាស់ថា មនុស្សខ្វិនពីកំណើតម្នាក់នោះបានជា គឺដោយសារតែជំនឿលើព្រះយេស៊ូវគ្រីស្ទ ។ ឃ្លាថា "មានជំនឿលើព្រះនាមព្រះយេស៊ូវ"មានន័យដូចគ្នានឹងឃ្លាថា "មានជំនឿលើព្រះយេស៊ូវ"។ ម្យ៉ាងទៀតនៅពេលដែលលោកពេត្រុសនិយាយថា "*គឺដោយសារសេចក្ដីជំនឿ ជឿដល់ព្រះនាមទ្រង់ នោះព្រះនាមទ្រង់បានប្រោសមនុស្សនេះ ដែលអ្នករាល់គ្នាឃើញ ហើយស្គាល់ ឱ្យមានកំឡាំងឡើង គឺជាសេចក្ដីជំនឿ ដែលកើតមកដោយ សារព្រះអង្គនោះឯង បានធ្វើឱ្យគាត់ជាស្រឡះនៅមុខអ្នករាល់គ្នាដូច្នេះ*" នោះឃើញថា "ព្រះនាមព្រះយេស៊ូវគឺសំដៅលើអង្គព្រះយេស៊ូវតែម្ដង" (កច ២:៦)។

រាល់គ្នាដូច្នេះ ១៧ឥឡូវនេះ បងប្អូនអើយ[គ] ខ្ញុំដឹងថាអ្នក
រាល់គ្នា ព្រមទាំងពួកនាម៉ឺននៃអ្នករាល់គ្នា[ឃ] បានប្រព្រឹត្ត
ការនោះ ដោយមិនបានយល់ទេ[ង] ១៨ប៉ុន្តែ សេចក្តីដែលព្រះ
បានប្រកាសប្រាប់ជាមុន[ច] ដោយសារមាត់នៃអស់ទាំង
ហោរារបស់ទ្រង់[ឆ] ពីដំណើរព្រះគ្រីស្ទថា ទ្រង់ត្រូវរងទុក្ខ
លំបាក[ជ] នោះព្រះទ្រង់ក៏បានសំរេច[ឈ] តាមយ៉ាងដូច្នោះឯង
១៩ដូច្នេះ ចូរប្រែចិត្ត ហើយវិលមកចុះ ដើម្បីឱ្យបាបរបស់
អ្នករាល់គ្នាបានលុបចេញ[ញ] ប្រយោជន៍ឱ្យមានពេលលំហើយ
មកពីចំពោះព្រះអម្ចាស់ ២០ហើយឱ្យទ្រង់បានចាត់ព្រះអង្គ
នោះ[ដ] ដែលបានដំរូវទុកជាមុន មកឯអ្នករាល់គ្នា គឺជា
ព្រះយេស៊ូវគ្រីស្ទ ២១ដែលស្ថានសួគ៌[ឋ] ត្រូវទទួល ដរាបដល់
គ្រាតាំងរបស់ទាំងអស់ឡើងវិញ[ឌ] ដែលព្រះបានមានបន្ទូល
ប្រាប់ពីគ្រានោះ ដោយសារមាត់នៃពួកហោរាបរិសុទ្ធ[ឍ]
របស់ទ្រង់តាំងពីបុរាណមក ២២ដ្បិតលោកម៉ូសេបានមាន
ប្រសាសន៍ដល់ពួកព្វយុកោថា «ព្រះអម្ចាស់ជាព្រះនៃអ្នក
រាល់គ្នា ទ្រង់នឹងបង្កើតហោរាម្នាក់ ពីបងប្អូនអ្នករាល់គ្នា
មកឱ្យដូចខ្ញុំ ត្រូវឱ្យអ្នករាល់គ្នាស្តាប់តាមហោរានោះ ក្នុង
គ្រប់ការទាំងអស់ដែលលោកនឹងប្រាប់មកចុះ[ណ] ២៣ឯអស់
អ្នកណាដែលមិនព្រមស្តាប់តាមវិញ នោះនឹងត្រូវវិនាស
បាត់ពីសាសន៍ខ្លួនចេញ»[ត] ២៤ហើយអស់ទាំងហោរា[ថ] ចាប់
តាំងពីលោកសាំយូអែល គឺអស់អ្នកដែលបានទាយតមក
ក៏បានប្រាប់ជាមុនពីគ្រានេះដែរ ២៥អ្នករាល់គ្នាជាដំណ[ទ]វង្ស
នៃពួកហោរា នឹងសេចក្តីសញ្ញា[ធ] ដែលព្រះបានតាំងនឹងពួក
ព្វយុកោយើងរាល់គ្នា ដោយមានបន្ទូលនឹងលោកអ័ប្រាហាំ
ថា «អស់ទាំងគ្រួសារនៅផែនដីនឹងបានពរ ដោយសារពូជ
ឯង»[ន] ២៦រីឯ ដែលព្រះបានតាំងព្រះយេស៊ូវជាអ្នកបំរើទ្រង់
ឡើង[ប] នោះគឺសំរាប់អ្នករាល់គ្នាជាដើម[ផ] ហើយក៏ចាត់ទ្រង់
មក ដើម្បីនឹងប្រទានពរដល់អ្នករាល់គ្នា ដោយបង្វែរអ្នក
រាល់គ្នាពីសេចក្តីអាក្រក់របស់ខ្លួនចេញ ។

## លោកពេត្រុស និងលោកយ៉ូហាននៅមុខពួកក្រុមជំនុំ

**៤** ១កាលអ្នកទាំង២កំពុងតែនិយាយនឹងបណ្តាជននៅឡើយ
នោះពួកសង្ឃ និងពួកសាឌូស៊ី[ព] ព្រមទាំងមេទ័ព[ភ]រក្សាព្រះ

**៣:១៧** គ កច ២២:៥ ឃ កច ១៣:២៧ ង លក ២៣:៣៤ **៣:១៨** ច កច ២:២៣ ឆ លក ២៤:២៧ ជ កច ១៧:២-៣ ២៦:២២-២៣ ឈ មថ ១:២២ **៣:១៩** ញ ទដ ៥១:១ អស ៤៣:២៥ ៤៤:២២ កច ២:៣៨ **៣:២០** ដ លក ២:១១ **៣:២១** ឋ កច ១:១១ ឌ មថ ១៧:១១ កច ១:៦ ឍ លក ១:៧០ **៣:២២** ណ ចទ ១៨:១៥,១៨ កច ៧:៣៧

**៣:២៣** ត ចទ ១៨:១៩ **៣:២៤** ថ លក ២៤:២៧ **៣:២៥** ទ កច ២:៣៩ ធ រម ៩:៤,៥ ន លប ១២:៣ ២២:១៨ ២៦:៤ ២៨:១៤ **៣:២៦** ប ខ.២២ កច ២:២៤ ផ កច ១៣:៤៦ រម ១:១៦ **៤:១** ព មថ ៣:៧ ១៦:១,៦ ២២:២៣, ៣៤ កច ៥:១៧ ២៣:៦-៨ ភ លក ២២:៤

**៣:១៧** *បងប្អូនអើយ* លោកពេត្រុសនិយាយពាក្យនេះគឺសំដៅលើពួកសាសន៍អ៊ីស្រាអែល" (ខ.១២) ។ *អ្នករាល់គ្នាបានប្រព្រឹត្តការ នោះដោយមិនបានយល់ទេ* គឺពួកគេពុំបានដឹងថាព្រះយេស៊ូវគឺជាព្រះមែស៊ីទេ (លក២៣:៣៤) ។ ត្រង់ចំណុចនេះក៏អាចមានន័យថា ពួកគេទាំងនោះក៏នៅតែមានឱកាសទទួលបានការសង្គ្រោះ ប្រសិនបើពួកគេប្រែចិត្ត និងជឿដល់ព្រះនាមព្រះអម្ចាស់ (មើលការពន្យល់ ខ.១៩) ។

**៣:១៨** *ព្រះបានប្រកាសប្រាប់ជាមុន ដោយសារមាត់នៃអស់ទាំងហោរារបស់ទ្រង់* មានន័យថា ព្រះអម្ចាស់មានព្រះបន្ទូលប្រាប់ពួកគេរួចជាស្រេចតាមរយៈពួកហោរាបរិសុទ្ធរបស់ទ្រង់ អំពីសេចក្តីទាំងឡាយ ដែលទាក់ទងនឹងការរងទុក្ខជាច្រើនរបស់ព្រះយេស៊ូវគ្រីស្ទ (អស ៥៣:៧-៨ កច ៤:២៥-២៦ ៨:៣២-៣៣ ទដ ២:១-២ ២២:១ មថ ២៧:៤៦ ១ពត ១:១១ លក ២៤:២៦-២៧) ។

**៣:១៩** *ប្រែចិត្ត* ជាការផ្លាស់ចិត្ត និងគំនិតចេញពីអំពើបាប (មើលការពន្យល់ ២:៣៨ លក ៣:៣) ។ *ហើយវិលមកចុះ* មានន័យថា ត្រូវវិលមកឯព្រះអម្ចាស់វិញ (កច ៩:៣៥ ១១:២១ ១៤:១៥ ១៥:១៩ ២៦:១៨,២០ ២៨:២៧) ។ មានសេចក្តីពន្យល់ផ្សេងទៀតថា ការប្រែចិត្តគឺ "ការងាកចេញពីអំពើបាប" ចំណែកឯសេចក្តីជំនឿគឺ "ការងាកបែរមកឯព្រះ" ។ *បាបរបស់អ្នករាល់គ្នាបានលុបចេញ* មានន័យថាមនុស្សម្នាក់បានទទួលសេចក្តីសង្គ្រោះភ្លាម នៅក្នុងខណៈពេលដែលទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ ។

**៣:២០-២១** ពួកសាសន៍យូដាមានជំនឿថា ថ្ងៃណាមួយព្រះមែស៊ីទ្រង់នឹងយាងមក ប៉ុន្តែនៅពេលដែលទ្រង់បានយាងមកនោះ ពួកគេភាគច្រើនពុំបានទទួលទ្រង់ទេ ។

**៣:២២-២៦** *ទ្រង់នឹងបង្កើត..តាំងព្រះយេស៊ូវជាអ្នកបំរើទ្រង់ឡើង* បទគម្ពីរទាំងនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទគឺជាចម្លើយទៅនឹងសេចក្តីទំនាយតាមរយៈលោកម៉ូសេ ហ្លួងដាវីឌ និងលោកអ័ប្រាហាំ ។ ព្រះគ្រីស្ទទ្រង់ជាព្រះ និងជាហោរាម្នាក់ដូចលោកម៉ូសេដែរ (ខ.២២-២៣) ។ លោកសាំយូអែលបានថ្លែងថា ព្រះអម្ចាស់បាននាំមកនូវព្រះពរដល់គ្រប់មនុស្សទាំងអស់ គឺដូចជាការដែលទ្រង់បានសន្យានឹងលោកអ័ប្រាហាំដូច្នោះ ដែរ (មើលការពន្យល់ ខ.២៤,២៥,២៦) ។

**៣:២៤** *អស់ទាំងហោរា ចាប់តាំងពីលោកសាំយូអែល* លោកសាំយូអែលបានចាក់ប្រេងលើដាវីឌឱ្យធ្វើជាស្តេច និងថ្លែងអំពីការចាប់ផ្តើមនៃអាណាចក្ររបស់ទ្រង់ (១សយ ១៦:១៣ ១៣:១៤ ១៥:២៨ ២៨:១៧) ។ រីឯសេចក្តីទំនាយតាមរយៈលោកហោរាណាថាន់នៅក្នុង "២ សយ ៧:១២-១៦" វិញគឺសំដៅលើព្រះមែស៊ីយ៉ាងពិតប្រាកដ (កច ១៣:២២-២៣ ហព ១:៥) ។

**៣:២៥** *ដោយសារពូជឯង* ពាក្យថា "ពូជឯង" នៅក្នុងខនេះគឺសំដៅលើព្រះគ្រីស្ទ (ពាក្យនេះនៅក្នុងភាសាក្រិក និងហេព្រើរ ក៏ដូចជានៅក្នុងភាសាអង់គ្លេសដែរសរសេរជាឯកវចនៈ) (កទ ៣:១៦) ។

**៣:២៦** ព្រះអម្ចាស់បានប្រទានព្រះគ្រីស្ទ ឱ្យមកក្នុងចំណោមពួកយូដាមុនគេ ។ ហើយពួកគេមានឱកាសច្រើន ក្នុងការទទួលសេចក្តីសង្គ្រោះពីទ្រង់ (មថ ១០:៥-៦ លក ២៤:៤៧ កច ១៣:៤៥-៤៦ រម ១:១៦) ។ ដោយហេតុនោះបានជាលោកពេត្រុសទូន្មានដល់ពួកសាសន៍យូដាឱ្យប្រែចិត្ត ហើយបែរមកឯព្រះអម្ចាស់វិញ ប្រយោជន៍កុំឱ្យបាត់បង់ឱកាសទទួលការសង្គ្រោះ ដែលទ្រង់បានប្រទានមក ។

**៤:១** *ពួកសង្ឃ* គឺអ្នកបម្រើការនៅទីលានព្រះវិហារ (មើលការពន្យល់ លក ១:២៣) ។ *មេទ័ពរក្សាព្រះវិហារ* គឺជាក្រុមអ្នកដឹកនាំមកពីគ្រួសារពួកសង្ឃ ហើយមានឋានៈ បន្ទាប់ពីសម្តេចសង្ឃ (៥:២៤,២៦ លក ២២:៤,៥២) ។

វិហារក៏មកដល់ [២]គេមានសេចក្ដីអាក់អន់ចិត្តពីដំណើរដែល
គាត់បង្រៀនដល់ពួកជន ហើយក៏សំដែងប្រាប់ដល់បណ្ដាជន
ពីសេចក្ដីរស់ពីស្លាប់ឡើងវិញ[ម]ដោយសារព្រះយេស៊ូវ [៣]គេ
ក៏ចាប់អ្នកទាំង២នាំទៅឃុំទុក[យ] ដរាបដល់ស្អែក ដ្បិតពេល
នោះល្ងាចហើយ [៤]ប៉ុន្តែឯពួកអ្នកដែលឮព្រះបន្ទូល នោះ
មានគ្នាជាច្រើន[រ]បានជឿ ហើយពួកដែលជឿក៏បានកើន
ឡើង មានប្រុសៗប្រហែលជា៥ពាន់នាក់ ។
[៥]ដល់ស្អែកឡើង ពួកនាម៉ឺន[ល] ពួកចាស់ទុំ នឹងពួកអាចារ្យ
ក៏ប្រជុំគ្នានៅក្រុងយេរូសាឡិម [៦]ព្រមទាំងលោកអាណា ជា
សំដេចសង្ឃ លោកកៃផា[វ] លោកយ៉ូហាន នឹងលោក
អ័លេក្សានត្រុស ហើយអស់អ្នកដែលជាគ្រួសារនៃសំដេច
សង្ឃដែរ [៧]កាលបាននាំអ្នកទាំង២ មកដាក់នៅកណ្ដាល
ចំណោមហើយ នោះក៏ពិចារណាសួរថា ឯងបានធ្វើ
ការនោះដោយអាងអំណាចអ្វី ឬដោយអាងឈ្មោះណា
[៨]នោះពេត្រុស ដែលពេញជាព្រះវិញ្ញាណបរិសុទ្ធ[ស] ក៏

**៤:២** ម កច ១៧:១៨
**៤:៣** យ កច ៥:១៨
**៤:៤** រ កច ២:៤១
**៤:៥** ល លក ២៣:១៣
**៤:៦** វ មថ ២៦:៣
**៤:៨** ស លក ១:១៥
ហ ខ.៥ លក ២៣:១៣
**៤:៩** ឡ កច ៣:៦
**៤:១០** អ មក ១:២៤
ក កច ២:២៤
**៤:១១** ខ ទដ ១១៨:២២ អស ២៨:១៦ សក ១០:៤ មថ ២១:៤២ អភ ២:២០ ១ពត ២:៧
**៤:១២** គ មថ ១:២១ យហ ១៤:៦ កច ១០:៤៣ រម ១១:១៤ ១ធថ ២:៥
**៤:១៣** ឃ លក ២២:៨

ជំរាបថា ឱលោកដ៏ធំលើបណ្ដាជន[ហ] និងពួកលោកចាស់ទុំ
ទាំងឡាយនៃសាសន៍អ៊ីស្រាអែលអើយ [៩]នៅថ្ងៃនេះ បើសិន
ជាលោកអ្នករាល់គ្នា គិតពិចារណាសួរយើងខ្ញុំ ពីដំណើរ
ការល្អ ដែលបានធ្វើដល់មនុស្សពិការ[ឡ]នោះថា គាត់បាន
ជាដោយសារអ្វី [១០]នោះសូមឲ្យលោករាល់គ្នាជ្រាបដូច្នេះ
ហើយឲ្យសាសន៍អ៊ីស្រាអែលទាំងអស់ដឹងផង ថាដែលមនុស្ស
នេះបានជាស្រឡះ ហើយឈរនៅមុខលោករាល់គ្នាដូច្នេះ
គឺដោយសារព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ពីស្រុកណាសា
រ៉ែត[អ] ដែលលោករាល់គ្នាបានឆ្កាងទ្រង់ តែព្រះបានប្រោស
ឲ្យមានព្រះជន្មរស់ពីស្លាប់[ក]ឡើងវិញ [១១]ព្រះអង្គនោះ ជា
ថ្មដែលលោករាល់គ្នា ជាជាងសង់ផ្ទះ បានមើលងាយ
ប៉ុន្តែទ្រង់បានត្រឡប់ជាថ្មជ្រុងយ៉ាងឯកវិញ[ខ] [១២]ហើយគ្មាន
សេចក្ដីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅ
ក្រោមមេឃ គ្មាននាមឈ្មោះណាទៀតបានប្រទានមក
មនុស្សលោក ឲ្យយើងរាល់គ្នាបានសង្គ្រោះ នោះឡើយ[គ]
[១៣]កាលបានឃើញថា ពេត្រុស និងយ៉ូហាន[ឃ] មានចិត្ត

---

*ពួកសាឌូស៊ី* គឺពួកយូដា១ក្រុមដែលមានសមាជិកមកពីត្រកូលពួកសង្ឃ និងមាននាទីគ្រប់គ្រងព្រះវិហារ ។ ពួកនេះមិនជឿលើការរស់ឡើងវិញ និងមិនទទួលស្គាល់ព្រះយេស៊ូវគ្រីស្ទទេ ។ ពួកសាឌូស៊ីជឿថា ព្រះមែស៊ីមិនទាន់យាងមកនៅឡើយទេ ហើយនៅតែរង់ចាំការយាងមករបស់ទ្រង់ដដែល ។ សម្ដេចសង្ឃដែលជាអ្នកមានតួនាទីជាប្រធាននៃពួកក្រុមជំនុំ ក៏មកពីពួកសាឌូស៊ីនេះដែរ (៥:១៧ ២៣:៦–៨ មថ ២២:២៣–៣៣ មើល ការពន្យល់ អរ ៧:២ មថ ៣:៧ មក ១២:១៨ លក ២០:២៧) ។

**៤:២** *ពីសេចក្ដីរស់ពីស្លាប់ឡើងវិញ ដោយសារព្រះយេស៊ូវ* មានន័យថា ពួកគេបានបង្រៀនដល់ពួកបណ្ដាជន ដោយឈរលើមូលដ្ឋានគ្រឹះដ៏សំខាន់គឺការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។

**៤:៣** *ពេលនោះល្ងាចហើយ* ក្នុងខណៈពេលនោះគឺ ប្រហែលជាម៉ោង៤ល្ងាច ហើយព្រះវិហារក៏ត្រូវបិទទ្វារដែរ ។ ដូច្នោះ ការកាត់ទោស ដែលទាក់ទងនឹងអាយុជីវិតត្រូវចាប់ផ្ដើម និងសម្រេចសេចក្ដីនៅថ្ងៃបន្ទាប់ ។

**៤:៤** *ប្រុសៗប្រហែល៥ពាន់នាក់* ជាចំនួនអ្នកជឿដែលបានកើនឡើងថែមលើចំនួនមនុស្ស៣ពាន់នាក់នៅថ្ងៃបុណ្យទី៥០ (២:៤១) ។ ហើយក្រោយមកទៀត ចំនួនមនុស្សដែលទទួលជឿដល់ព្រះអម្ចាស់ បានកើនឡើងជាច្រើន (៥:១៤ ៦:៧) ។

**៤:៥** *ពួកនាម៉ឺន ពួកចាស់ទុំ នឹងពួកអាចារ្យ* ទាំង៣ពួកនេះបញ្ចូលគ្នាបង្កើតបានជាពួកក្រុមជំនុំ ដែលជាតុលាការជាន់ខ្ពស់នៃប្រជាជនអ៊ីស្រាអែល (លក ២២:៦៦ មើលការពន្យល់ មថ ២:៤ ១៥:២ មក ២:១៦ ១៤:៥៥ លក ៥:១៧) ។

**៤:៦** *លោក អាណា* គឺជាសម្ដេចសង្ឃនៅឆ្នាំ៦–១៥គ.ស ហើយត្រូវពួករ៉ូម៉ាំងទម្លាក់ពីតំណែង ដោយឲ្យកូនរបស់គាត់ឈ្មោះលោកអេលាសារ ឡើងជំនួសវិញ បន្ទាប់មកទៀត គឺឲ្យកូនប្រសាររបស់គាត់ឈ្មោះ លោកកៃផា ហៅយ៉ូសែប (ឆ.១៨–៣៦) ឡើងបន្តពីអេលាសារ ។ ប៉ុន្តែ ពួកយូដានៅតែចាត់ទុកលោកអាណា ជាសម្ដេចសង្ឃដដែល (លក ៣:២ យហ ១៨:១៣,២៤) ។ *យ៉ូហាន* ប្រហែលជាលោកយ៉ូណាថាន ដែលជាកូនរបស់លោកអាណា ហើយដែលត្រូវគេចាត់តាំងឲ្យ ធ្វើជាសម្ដេចសង្ឃនៅឆ្នាំ៣៦គ.ស ។ មានអ្នកខ្លះយល់ថាគាត់គឺជាយ៉ូហាណាន ដែលជាកូនរបស់លោកសាកាយ និងជាមេសាលាប្រជុំដ៏ធំបន្ទាប់ពីការរលំនៃក្រុងយេរូសាឡិម ។

**៤:៨** *ពេញជាព្រះវិញ្ញាណបរិសុទ្ធ* "មើលការពន្យល់ ២:៤" ។

**៤:១០** *ព្រះយេស៊ូវគ្រីស្ទ ពីស្រុកណាសារ៉ែត* "មើលពន្យល់ មថ ២:២៣" ។

**៤:១១** *ជាថ្ម... បានមើលងាយ* បទគម្ពីរនេះនិយាយសំដៅលើព្រះយេស៊ូវ ។ សេចក្ដីទំនាយនេះបានសម្រេច នៅពេលដែលព្រះយេស៊ូវគ្រីស្ទទ្រង់សុគតនៅលើឈើឆ្កាង ។ ម្យ៉ាងទៀត សេចក្ដីទំនាយនេះ ក៏ជាកត្តាដ៏សំខាន់ នៅក្នុងសេចក្ដីអធិប្បាយ និងក្នុងការពង្រឹងជំនឿ នៃពួកជំនុំដំបូងផងដែរ ។ ព្រះយេស៊ូវទ្រង់ក៏បានលើកយកព្រះបន្ទូលនៅក្នុង "ទដ ១១៨:២២" មកបង្ហាញអំពីសេចក្ដីពិតរបស់ទ្រង់ផងដែរ (មថ ២១:៤២ ១ពត ២:៧ រម ៩:៣៣ អស ២៨:១៦) ។

**៤:១២** *គ្មាននាមឈ្មោះណាទៀត* (១០:៤៣ យហ ១៤:៦ ១ធថ ២:៥ និងមើលការពន្យល់ មថ ១:២១) ។

**៤:១៣** *ក្លាហាន* គឺជាសេចក្ដីក្លាហានពិតប្រាកដ ដែលបង្ហាញពីការធានាអំណាច និងភាពស្មោះត្រង់របស់ពួកសាវ័ក (២:២៩ ៤:២៩ ២៨:៣១) ។ ការទាំងអស់នេះត្រូវប្រទានមកអស់អ្នកដែលជឿព្រះយេស៊ូវគ្រីស្ទ (៤:៣១) ។ *មិនសូវចេះជ្រៅជ្រះ ហើយឥតបាន រៀនសូត្រប៉ុន្មាន* លោកពេត្រុស និងលោកយ៉ូហានមិនធ្លាប់បានទទួលការហ្វឹកហ្វឺនធ្វើជាគ្រូបង្រៀន ហើយក៏គ្មានតួនាទីនៅក្នុងក្រុមសាសនាដែលជាហេតុធ្វើឲ្យគេស្គាល់ពួកគាត់ទេ ។ *គេធ្លាប់នៅជាមួយនឹងព្រះយេស៊ូវ* ពួកគេនិយាយដូច្នេះព្រោះពួកគេឃើញពួកសាវ័កធ្វើការអស្ចារ្យទាំងនោះ ដោយនូវព្រះនាមព្រះយេស៊ូវ (មក ១:២២ មើល ការពន្យល់ កច ៣:១៤) ។

ក្លាហាន នោះពួកលោកទាំងនោះ ក៏មានសេចក្ដីអស្ចារ្យ
ដោយដឹងថា គេជាមនុស្សមិនសូវចេះជ្រៅជ្រះ[ង] ហើយឥត
បានរៀនសូត្រប៉ុន្មានផង បានជាលោកយល់ឃើញថាគេ
ធ្លាប់នៅជាមួយនឹងព្រះយេស៊ូវ[ច] [១៤]តែលោកគ្មានពាក្យណា
នឹងឆ្លើយតបមកវិញសោះ ដោយឃើញមនុស្សដែលបាន
ជាគាត់ឈរជាមួយនឹងគេ [១៥]ដូច្នេះ កាលបានបង្គាប់ឱ្យគេ
ចេញពីពួកក្រុមជំនុំ[ឆ]ទៅបន្ដិច នោះក៏ពិគ្រោះគ្នាថា [១៦]តើ
ត្រូវឱ្យយើងធ្វើអ្វីដល់មនុស្សទាំង២នេះ[ជ] ដ្បិតដែលគេ
បានធ្វើទីសំគាល់[ឈ] យ៉ាងអស្ចារ្យ នោះក៏ច្បាស់ដល់គ្រប់
មនុស្សនៅក្រុងយេរូសាឡិម ហើយយើងក៏ប្រកែកមិនបាន
ផង [១៧]ប៉ុន្ដែ ចូរយើងកំហែងហាមគេ មិនឱ្យនិយាយនឹង
អ្នកណាទៀតដោយឈ្មោះនោះទៀតឡើយ ដើម្បីកុំឱ្យរឿង
នេះផ្សាយទៅក្នុងពួកជនទៀត [១៨]រួចលោកហៅមកវិញ
ហាមផ្ដាច់មិនឱ្យនិយាយ ឬបង្រៀន ដោយនូវព្រះនាមព្រះ
យេស៊ូវទៀតឡើយ[ញ] [១៩]តែ ពេត្រុស និងយ៉ូហាន ឆ្លើយតប
ថា បើគួរគប្បីនៅចំពោះព្រះ ឱ្យយើងខ្ញុំស្ដាប់តាមលោក
រាល់គ្នា ជាជាងស្ដាប់តាមព្រះ[ដ] នោះសូមពិចារណាចុះ
[២០]ដ្បិតយើងខ្ញុំនឹងលែងនិយាយ[ឋ]ពីការដែលយើងខ្ញុំបាន
ឃើញ ហើយឮ[ឌ] ពុំបានទេ [២១]តែលោកកំហែងទៀត រួច
លែងឱ្យទៅ ដោយមិនឃើញជាមានហេតុអ្វីនឹងធ្វើទោស
សោះ ដោយព្រោះបណ្ដាជន ដ្បិតទាំងអស់គ្នា[ឍ] កំពុងតែ
សរសើរដំកើងដល់ព្រះ[ណ] ពីការនោះ ដែលទើបនឹងកើត
មក [២២]ពីព្រោះមនុស្សដែលបានជា ដោយសារទីសំគាល់
នោះ គាត់មានអាយុជាង៤០ឆ្នាំហើយ ។

## សេចក្ដីអធិស្ឋាននៃពួកអ្នកជឿ

[២៣]លុះបានលែងស្រេចហើយ នោះក៏នាំគ្នាទៅឯពួក
របស់ខ្លួនវិញ ទាំងរ៉ាយរឿងប្រាប់ ពីសេចក្ដីទាំងប៉ុន្មាន
ដែលពួកសង្គ្រាជ និងពួកចាស់ទុំបានហាមប្រាម [២៤]កាល
ពួកជំនុំបានឮដូច្នោះ នោះក៏បន្លឺឧទានព្រមគ្នាទូលដល់ព្រះ[ត]
ថា ឱព្រះដ៏ជាម្ចាស់ធំបំផុតអើយ គឺទ្រង់ជាព្រះដែល
បង្កើតផ្ទៃមេឃ ផែនដី និងសមុទ្រ ហើយរបស់ទាំងអស់
ដែលនៅស្ថានទាំងនោះ[ថ]ផង [២៥]ទ្រង់បានមានបន្ទូល ដោយ
សារព្រះឱស្ឋហ្លួងដាវីឌ[ទ] ជាអ្នកបំរើទ្រង់ថា: «ហេតុអ្វីបាន
ជាអស់ទាំងសាសន៍ជ្រួលជ្រើមឡើង ហើយជនជាតិទាំង
ប៉ុន្មាន មានគំនិតជាអសារឥតការដូច្នេះ [២៦]ពួកមហាក្សត្រ
នៅផែនដីលើកគ្នាឡើង ពួកគ្រប់គ្រង ទាំងប៉ុន្មានក៏ប្រឹក្សា
គ្នាទាស់នឹងព្រះអម្ចាស់ ហើយទាស់នឹង ព្រះគ្រីស្ទ[ធ]នៃទ្រង់»
[២៧]ប្រាកដមែនហើយ ដ្បិតនៅក្រុងនេះ ស្ដេចហេរ៉ូឌ[ន]
និងលោក ប៉ុនទាស-ពីឡាត់[ប] បានប្រជុំគ្នា ព្រមទាំងពួក
សាសន៍ដទៃ និងសាសន៍អ៊ីស្រាអែល ទាស់នឹងព្រះយេស៊ូវជា
អ្នកបំរើបរិសុទ្ធរបស់ទ្រង់[ផ] ដែលទ្រង់បានចាក់ប្រេងតាំង
ឱ្យ [២៨]ដើម្បីនឹងធ្វើអស់ទាំងការដែលព្រះហស្តទ្រង់ និងព្រះ
ដំរិះទ្រង់ បានគិតសំរេចជាមុន[ព] [២៩]ឥឡូវនេះ ឱព្រះអម្ចាស់
អើយ សូមទតមើលសេចក្ដីកំហែងរបស់គេ ហើយសូម
ប្រទានឱ្យពួកអ្នកបំរើទ្រង់ បានផ្សាយព្រះបន្ទូល ដោយ
សេចក្ដីក្លាហានដ៏ពេញលេញ[ភ] [៣០]ដោយទ្រង់លូកព្រះ
ហស្តមក សំរាប់នឹងប្រោសមនុស្សឱ្យបានជា ហើយនិងធ្វើ
ទីសំគាល់ និងការអស្ចារ្យ[ម] ដោយសារព្រះនាមព្រះយេស៊ូវ
ជាអ្នកបំរើបរិសុទ្ធរបស់ទ្រង់[យ] [៣១]កាលបានអធិស្ឋានរួច
ហើយ នោះកន្លែងដែលគេប្រជុំគ្នាក៏រញ្ជួយ[រ] ហើយគេបាន
ពេញជាព្រះវិញ្ញាណបរិសុទ្ធ[ល]ទាំងអស់គ្នា រួចក៏ផ្សាយព្រះ
បន្ទូល[វ] ដោយចិត្តក្លាហាន[ស]។

**៤:១៣** ង មថ ១១:២៥ ច មក ៣:១៤
**៤:១៥** ឆ មថ ៥:២២
**៤:១៦** ជ យហ ១១:៤៧ ឈ កច ៣:៦–១០
**៤:១៨** ញ អម ៧:១៣ កច ៥:៤០
**៤:១៩** ដ កច ៥:២៩
**៤:២០** ឋ យប ៣២:១៨ យរ ២០:៩ អម ៣:៨ ឌ លក ២៤:៤៨
**៤:២១** ឍ កច ៥:២៦ ណ មថ ៩:៨
**៤:២៤** ត កច ១:១៤ ថ នហ ៩:៦ យប ៤១:១១ អស ៣៧:៦
**៤:២៥** ទ កច ១:១៦
**៤:២៦** ធ ទដ ២:១–២ ដយ ៩:២៥ លក ៤:១៨ កច ១០:៣៨ ហេ ១:៩
**៤:២៧** ន មថ ១៤:១ ប មថ ២៧:២ លក ២៣:១២ ផ ខ.៣០ កច ៣:១៣–១៤
**៤:២៨** ព កច ២:២៣
**៤:២៩** ភ ខ.១៣,៣១ ទដ ១៣៨:៣ កច ៩:២៧ ១៣:៤៦ ១៤:៣ ២៨:៣១ អភ ៦:១៩ ភល ១:១៤
**៤:៣០** ម យហ ៤:៤៨ យ ខ.២៧
**៤:៣១** រ កច ២:២ ល លក១:១៥ វ ហេ ៤:១២ ស ខ.២៩

---

**៤:១៥** *ពួកក្រុមជំនុំ* ពាក្យនេះមានន័យថា "ក្រុមជម្រះក្ដី ក្រុមជំនុំជម្រះ ក្រុមកាត់ក្ដី ចៅក្រម ឬតុលាការ" (មើលការពន្យល់ មក ១៤:៥៥) ។

**៤:១៩** "មើលការពន្យល់ រម ១៣:៣" ។

**៤:២០** *នឹងលែងនិយាយ . . . ពុំបានទេ* (៥:២៩ យរ ២០:៩) ។

**៤:២២** *គាត់មានអាយុជាង៤០ឆ្នាំហើយ* ត្រង់ចំណុចនេះបង្ហាញថា នៅសម័យនោះ ពុំមានវិធីព្យាបាលមនុស្សវ័យចំណាស់ដូចគាត់ ឱ្យបានជាសះស្បើយទេ ។

**៤:២៣** *នោះក៏នាំគ្នាទៅឯពួករបស់ខ្លួនវិញ* ប្រហែលជាពួកគេទៅកន្លែងដែលពួកសាវក និងពួកជំនុំធ្លាប់ជួបប្រជុំគ្នាកាលពីពេលមុន (មើល ១:១៣ ១២:១២) ។

**៤:២៤** *ព្រះដ៏ជាម្ចាស់ធំបំផុត* គឺសំដៅលើព្រះយេស៊ូវគ្រីស្ទ (លក ២:២៩) ។

**៤:២៧** *ស្ដេចហេរ៉ូឌ* គឺហេរ៉ូឌ អាន់ទីប៉ាស ជាស្ដេចអនុរាជនៅស្រុកកាលីឡេ និងពេរេ (ស្ថិតនៅតាមបណ្ដោយទន្លេយ័រដាន់ភាគខាងកើត លក ២៣:៧–១៥) ។ *ប៉ុនទាស-ពីឡាត់* គឺជាអភិបាលរ៉ូម៉ាំងនៅស្រុកយូដា (មើលការពន្យល់ លក ៣:១) ។

**៤:២៨** *បានគិតសំរេចជាមុន* មានន័យថា គ្រប់ព្រះរាជកិច្ច ដែលព្រះអម្ចាស់ទ្រង់ធ្វើ តាមរយៈពួកអ្នកបម្រើរបស់ទ្រង់នៅពេលនោះ គឺជាផែនការដែលទ្រង់បានរៀបចំទុកជាស្រេច ដើម្បីសង្គ្រោះមនុស្សនៅលើពិភពលោកនេះ (២:២៣) ។

**៤:៣០** *អ្នកបំរើបរិសុទ្ធ* "មើលការពន្យល់ ៣:១៣" ។

**៤:៣១** *កន្លែងដែលគេប្រជុំគ្នាក៏រញ្ជួយ* នេះគឺជាទីសំគាល់ដែលព្រះទ្រង់ឆ្លើយតបភ្លាមៗចំពោះសេចក្ដីអធិស្ឋានរបស់ពួកគេ (១៦:២៦) ។ *បានពេញជាព្រះវិញ្ញាណបរិសុទ្ធ* "មើលពន្យល់ ២:៤" ។ *ផ្សាយព្រះបន្ទូលព្រះ* ពួកគេនៅតែបន្តអធិប្បាយព្រះបន្ទូល ទោះបីមានការព្រមានពីពួកក្រុមជំនុំក៏ដោយ

## ពួកអ្នកជឿចែកចាយរបស់ដែលខ្លួនមាន

៣២ឯមនុស្សទាំងហ្វូងដែលបានជឿ គេក៏មានចិត្ត មាន
គំនិតតែ១ គ្មានអ្នកណាប្រកាន់ថា អ្វីៗដែលខ្លួនមានជារបស់
ផងខ្លួននោះទេ គឺគ្រប់របស់ទាំងប៉ុន្មាន ជារបស់សំរាប់ប្រើ
ជាមួយគ្នាទាំងអស់[ហ] ៣៣ពួកសាវកក៏ធ្វើបន្ទាល់[ឡ] ដោយព្រះ
ចេស្តាដ៏ធំ ពីដំណើរដែលព្រះអម្ចាស់យេស៊ូវមានព្រះជន្ម
រស់ឡើងវិញ[អ] ហើយមានព្រះគុណ[ក]ជាធំ សណ្ឋិតលើគេ
ទាំងអស់គ្នាដែរ ៣៤នៅក្នុងពួកគេ គ្មានអ្នកណាខ្វះខាតអ្វី
សោះ ដ្បិតអស់អ្នកណាដែលមានដី មានផ្ទះ នោះក៏លក់[ខ]
យកប្រាក់ដែលជាថ្លៃរបស់ទាំងនោះមក ៣៥ដាក់នៅទៀប
ជើងពួកសាវក[គ] ហើយគេក៏ចែកដល់គ្រប់គ្នា តាមត្រូវការ[ឃ]
៣៦រីឯយ៉ូសេ ដែលពួកសាវកហៅថា បាណាបាស[ង]
(ប្រែថាជាអ្នកជំនួយ) ជាពួកលេវី ដែលកើតនៅកោះ
គីប្រុស ៣៧គាត់មានដីដែរ ហើយក៏លក់យកប្រាក់មកដាក់
នៅទៀបជើងពួកសាវក[ច]។

## អាន៉្នានាស និងសាភីរ៉ា

**៥** ១តែមានមនុស្សម្នាក់ទៀតឈ្មោះ អាន៉្នានាស ប្រពន្ធ
ឈ្មោះសាភីរ៉ា បាននាំគ្នាលក់របស់ទ្រព្យខ្លួនដែរ ២ហើយ
បានកែដំឡៃនោះទុកខ្លះ[ឆ] ដោយប្រពន្ធយល់ព្រមដែរ រួចនាំ
យក១ចំណែក មកដាក់នៅទៀបជើងពួកសាវក[ជ] ៣តែពេ
ត្រុសសួរថា អាន៉្នានាសអើយ ហេតុអ្វីបានជា អារក្សសា
តាំង[ឈ]មកនៅពេញក្នុងចិត្តអ្នក[ញ] ឱ្យអ្នកហ៊ានកុហក ដល់
ព្រះវិញ្ញាណបរិសុទ្ធ[ដ] ដោយកែទុកដំឡៃដី១ចំណែក ដូច្នេះ[ឋ]
៤កាលនៅៗឡើយ តើមិនមែនជារបស់ផងអ្នកទេ ឬអី
ហើយដែលលក់ទៅ តើប្រាក់មិននៅក្នុងអំណាចអ្នក
ដែរទេឬអី [ឌ] ហេតុអ្វីបានជាអ្នកកាត់ចិត្តធ្វើដូច្នេះ នេះ
មិនមែនកុហកដល់មនុស្សទេ គឺឈ្មោះថាកុហកដល់ព្រះ[ឍ]
វិញ ៥កាលអាន៉្នានាសបានឮពាក្យនោះ គាត់ក៏ដួលដាច់
ខ្យល់ទៅ[ណ] ហើយអស់អ្នកដែលឮនិយាយពីការនោះ ក៏កើត
មានសេចក្តីស្ញែងខ្លាច[ត] ៦នោះពួកកំឡោះៗក្រោកឡើង
រុំខ្មោច[ថ]យកទៅកប់ ៧នៅគ្រាប្រហែលជា៣ម៉ោងក្រោយ
មកប្រពន្ធគាត់ក៏ចូលមក ឥតដឹងការដែលកើតមកនោះ
សោះ ៨ពេត្រុសសួរថា សូមប្រាប់ខ្ញុំ តើបានលក់ដីថ្លៃ
ប៉ុណ្ណោះ មែនឬ នាងឆ្លើយតបថា ចាស ពិតមែនហើយ[ទ]
៩រួចពេត្រុសនិយាយថា ហេតុអ្វីបានជាព្រមព្រៀងគ្នា នឹង

**៤:៣២** ហ កច ២:៤៤
**៤:៣៣** ឡ លក ២៤:៤៨ អ កច ១:២២ ក រម ៣:២៤
**៤:៣៤** ខ មថ ១៩:២១ កច ២:៤៥
**៤:៣៥** គ ខ.៣៧ កច ៥:២ ឃ កច ២:៤៥ ៦:១
**៤:៣៦** ង កច ៩:២៧ ១១:២២,៣០ ១៣:២ ១កថ ៩:៦ កទ ២:១,៩,១៣
**៤:៣៧** ច ខ.៣៥ កច ៥:២
**៥:២** ឆ យស ៧:១១ ជ កច ៤:៣៥,៣៧
**៥:៣** ឈ មថ ៤:១០ ញ យហ ១៣:២,២៧ ដ ខ.៩ ឋ ចទ ២៣:២១
**៥:៤** ឌ ចទ ២៣:២២ ឍ លវ ៦:២
**៥:៥** ណ ខ.១០ ទដ ៥:៦ ត ខ.១១ **៥:៦** ថ យហ ១៩:៤០ **៥:៨** ទ ខ.២

(មើលការពន្យល់ ខ.១៣)។

**៤:៣២** *មានចិត្ត មានគំនិតតែ១* មានន័យថា ពួកគេមានការឯកភាពគ្នាទាំងស្រុង ទាំងផ្នែកចិត្តគំនិត និងទ្រព្យសម្បត្តិ (មើលការពន្យល់ ២:៤៤)។

**៤:៣៣** *ក៏ធ្វើបន្ទាល់. . . មានព្រះជន្មរស់ឡើងវិញ* ត្រង់ចំណុចនេះបញ្ជាក់ថា នៅក្នុងការប្រកាសដំណឹងល្អ ពួកសាវកតែងតែថ្លែងអំពីការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។

**៤:៣៤** *អស់អ្នកណាដែលមានដី មានផ្ទះ នោះក៏លក់* "មើលពន្យល់ ២:៤៤"។

**៤:៣៦** *ពួកលេវី* បើតាមក្រិត្យវិន័យដែលចែងតាមរយៈពួកហោរា ពួកលេវីពុំមានដីជាមរតកនៅលើទឹកដីសន្យាទេ ។ ប៉ុន្តែ ច្បាប់នោះពុំអាចអនុវត្តចំពោះពួក លេវីដែលរស់នៅប្រទេសផ្សេងៗទៀតទេ ដូចជានៅស្រុកគីប្រុសជាដើម ។ ដូច្នេះ លោកបាណាបាស ប្រហែលជាលក់ដីរបស់គាត់នៅស្រុកគីប្រុស ហើយបានយកប្រាក់មកប្រគល់ឱ្យពួកសាវក (ខ.៣៧)។ ម្យ៉ាងទៀត ប្រហែលជាគាត់បានរៀបការ ហើយដីដែលគាត់លក់នោះ គឺជាដីចំណែករបស់ប្រពន្ធគាត់ ។ មានមតិខ្លះយល់ថា ពេលនោះ ច្បាប់ដែលចែងអំពីពួកលេវីពុំមានប្រសិទ្ធភាពទៀតទេ ។ *កោះគីប្រុស* ជាកោះមួយ ស្ថិតនៅភាគខាងលិចនៃឆ្នេរសមុទ្រ (មេឌីទែរ៉ាណេ) ប្រទេសស៊ីរី ប្រហែល៩៦គ.ម ។ *បាណាបាស* គាត់គឺជាគំរូល្អម្នាក់នៅក្នុងពួកជំនុំដំបូង ។ លោកលូកាបានបញ្ជាក់ថា លោកបាណាបាស គឺជាគូកនដ៏សំខាន់របស់លោកប៉ុល (១៣:១–៤ ៩:២៧ ១១:២២,២៥ ១៥:៣៧–៣៩)។

**៥:១** *អាន៉្នានាស. . . សាភីរ៉ា* ពីរនាក់ប្តីប្រពន្ធនេះគឺជាគំរូអាក្រក់ ផ្ទុយអំពីលោកបាណាបាសដែលជាគំរូល្អ (មើលការពន្យល់ ៤:៣៦)។ ពាក្យសំដីកុហកបោកប្រាស់ ដើម្បីឱ្យបានប្រយោជន៍ពីអ្នកដទៃ និងការស្រលាញ់ប្រាក់គឺជាអំពើបាប ដែលបានកត់ត្រាយ៉ាងច្បាស់ នៅក្នុងព្រះគម្ពីរកិច្ចការ ។ ម្យ៉ាងទៀត យើងក៏បានឃើញយ៉ាងច្បាស់អំពីការព្រមានរបស់ព្រះអម្ចាស់ចំពោះពួកអ្នកដែលប្រព្រឹត្តការទាំងអស់នោះ (កទ ៦:៧)។ សូមមើលអំពីការវិនិច្ឆ័យទោស ដែលកើតមានចំពោះ ណាដាប (លវ ១០:២) អេកាន (យស ៧:២៥) និង អ៊ុសា (២សយ ៦:៧)។

**៥:២** *បានកែដំឡៃនោះទុកខ្លះ* ពួកគេមានសិទ្ធិយកទៅវិញនូវអ្វីដែលខ្លួនចង់បាន ប៉ុន្តែ ត្រូវបង្ហាញរបស់ទាំងអស់នោះជាមុនសិន ដើម្បីបញ្ជាក់ថាខ្លួនមិនបានប្រព្រឹត្តបាបទេ ។ ផ្ទុយទៅវិញ ទាំងពីរនាក់ប្តីប្រពន្ធនោះមិនបានប្រតិបត្តិតាមទេ ។

**៥:៣–៤** ត្រង់ចំណុចនេះ មានសំណួរមួយចោទឡើងថា តើហេតុដូចម្តេចបានជាលោកពេត្រុសដឹងថា អាន៉្នានាស និងសាភីរ៉ានិយាយកុហក? ចម្លើយគឺគាត់ដឹងដោយសារការបើកសំដែងពីព្រះវិញ្ញាណបរិសុទ្ធ ។ ព្រះវិញ្ញាណបរិសុទ្ធប្រទានឱ្យលោកនូវពាក្យសំដីនៃប្រាជ្ញាវាងវៃ (១កថ ១២:៨)។

**៥:៣** *អារក្សសាតាំងមកនៅពេញក្នុងចិត្តអ្នក* ត្រង់ចំណុចនេះបង្ហាញថា សកម្មភាពរបស់សាតាំងនៅតែមានបន្ត (លក ២២:៣ យហ ១៣:២,២៧ ១ពត៥:៨)។ *កុហកដល់ព្រះវិញ្ញាណបរិសុទ្ធ* បញ្ជាក់ថា ព្រះអម្ចាស់គង់នៅក្នុងចំណោមពួកជំនុំរបស់ទ្រង់ ទាំងបើកសំដែងឱ្យពួកគេដឹងកាន់តែច្បាស់នូវសេចក្តីពិត (ខ.៤)។

**៥:៥-៦** ការស្លាប់របស់អាន៉្នានាសមិនមែនជាកំហុសរបស់លោកពេត្រុសទេ ប៉ុន្តែ វាជាលទ្ធផលនៃការប្រឆាំងនឹងព្រះវិញ្ញាណបរិសុទ្ធ ។

**៥:៩** *ល្បងដល់ព្រះវិញ្ញាណនៃព្រះអម្ចាស់* ការកុហកបោកប្រាស់គឺជាបញ្ហាមួយដែលអាចកើតឡើងក្នុងចំណោមអ្នកជឿ ប្រសិនបើគ្មានលទ្ធផលដ៏ធ្ងន់ធ្ងរ

ល្បួងដល់ព្រះវិញ្ញាណនៃព្រះអម្ចាស់ដូច្នេះ[ធ]មើល ពួកអ្នក
ដែលកប់ខ្មោចប្ដីអ្នក គេមកដល់មាត់ទ្វារ ហើយ គេនឹងសែង
អ្នកយកទៅដែរ ១០នោះស្រាប់តែនាងដួលដាច់ខ្យល់១រំ
ពេច[ន] នៅទៀបជើងពេត្រុសទៀត កាលពួកកំឡោះៗបាន
ចូលមក ឃើញនាងស្លាប់ នោះគេក៏សែងយកទៅកប់ នៅ
ជិតខ្មោចប្ដី[ប]ទៅ ១១រួចពួកជំនុំទាំងប៉ុន្មាន នឹងអស់អ្នកណា
ដែលឮនិយាយពីការនោះ ក៏កើតមានសេចក្ដីស្ញែងខ្លាច[ផ]
ទាំងអស់គ្នា ។

## ពួកសាវ័កប្រោសអ្នកជំងឺជាច្រើន

១២មានទីសំគាល់ នឹងការអស្ចារ្យ[ព] ជាច្រើនទៀត ដែល
កើតមកក្នុងពួកជន ដោយសារដៃពួកសាវក (គេបានស្រុះ
ចិត្តទាំងអស់គ្នា[ភ]នឹងនៅក្នុងបាំងសាចសាឡូម៉ូន[ម] ១៣ឯអ្នក
ឯទៀតមិនហ៊ានចូលក្នុងពួកគេឡើយ តែប្រជាជនសរសើរ
ដល់គេ[យ] ១៤ហើយពួកអ្នកដែលជឿដល់ព្រះអម្ចាស់ ក៏បាន
ចំរើនកាន់តែច្រើនឡើង មានមនុស្សសន្ធឹក ទាំងប្រុស ទាំង
ស្រី)[រ] ១៥ដល់ម្ល៉េះ បានជាគេយកមនុស្ស ដែលមានជំងឺ
ផ្សេងៗ ចេញមកនៅផ្លូវ ផ្ដេកលើគ្រែនឹងពូក ដើម្បី
កាលណាពេត្រុសដើរមក នោះសូម្បីហោចណាស់ ឱ្យគ្រាន់
តែស្រមោលគាត់ ចោលទៅលើពួកនោះខ្លះប៉ុណ្ណោះ[ល] ១៦ឯ
បណ្ដាមនុស្សដែលនៅអស់ទាំងស្រុកជុំវិញក្រុងយេរូសាឡិម
គេក៏មូលគ្នា នាំទាំងមនុស្សមានជំងឺមក ព្រមទាំងមនុស្ស
អារក្សអសោចិ៍ចូលផង ហើយគេបានជាទាំងអស់គ្នា[វ] ។

## ពួកសាវ័កត្រូវគេបៀតបៀន

១៧រីឯសំដេចសង្ឃ នឹងអស់អ្នកនៅជាមួយនឹងលោក
ដែលនៅខាងពួក[ស]សាឌូស៊ី[ហ] គេលើកគ្នាឡើង ដោយមាន
សេចក្ដីកំហឹងដ៏ពោរពេញ ១៨ក៏ចាប់ពួកសាវក យកទៅឃុំ
ទុក[ឡ] ១៩ប៉ុន្តែនៅវេលាយប់នោះ មានទេវតា[អ]នៃព្រះអម្ចាស់
បើកទ្វារគុក[ក]នាំចេញមក[ខ]ប្រាប់ថា ២០ចូរទៅឈរអធិប្បាយ
នៅក្នុងព្រះវិហារ ឱ្យបណ្ដាជនស្ដាប់ អស់ទាំងព្រះបន្ទូល
ពីជីវិតថ្មី[គ]នេះទៅ ២១កាលគេបានឮហើយ នោះក៏នាំគ្នា
ចូលទៅបង្រៀន ក្នុងព្រះវិហារពីព្រលឹម ឯសំដេចសង្ឃ
និងពួកអ្នកដែលនៅជាមួយនឹងលោក[ឃ] ក៏មកហៅពួកក្រុមជំ

**៥:៩** ធ ខ.៣
**៥:១០** ន ខ.៥ ប ខ.៦
**៥:១១** ផ ខ.៥ កច ១៩:១៧
**៥:១២** ព យហ ៤:៤៨ កច ២:៤៣ ភ កច ៤:៣២ ម យហ ១០:២៣ កច ៣:១១
**៥:១៣** យ កច ២:៤៧ ៤:២១
**៥:១៤** រ កច ២:៤១
**៥:១៥** ល កច ១៩:១២
**៥:១៦** វ មថ ៨:១៦ មក ១៦:១៧
**៥:១៧** ស កច ១៥:៥ ហ កច ៤:១

**៥:១៨** ឡ កច ៤:៣ **៥:១៩** អ លប ១៦:៧ នក ៣:២ មថ ១:២០ ២:១៣,១៩ ២៨:២ លក ១:១១ ២:៩ យហ ២០:១២ កច ៨:២៦ ១០:៣ ១២:៧,២៣ ២៧:២៣ ក កច ១៦:២៦ ខ ទដ ៣៤:៧ **៥:២០** គ យហ ៦:៦៣,៦៨
**៥:២១** ឃ កច ៤:៥,៦ ង ខ.២៧,៣៤,៤១ មថ ៥:២២

ចំពោះការនេះទេ ។ ម្យ៉ាងទៀត មិនត្រឹមតែមានភាពមិនស្មោះត្រង់ បានកើតឡើងប៉ុណ្ណោះទេ គឺពួកគេនឹងហ៊ានកុហកដល់ព្រះវិញ្ញាណបរិសុទ្ធទៀតផង ។ ដូច្នេះការសំខាន់គឺត្រូវតែកែតម្រង់ជាមុន ដើម្បីកុំឱ្យមានការសង្ស័យ ដោយដឹងច្បាស់ថា ព្រះទ្រង់មិនលើកលែងចំពោះអំពើពុតត្បុត និងទង្វើបោកប្រាស់ណាមួយនោះទេ ។

**៥:១១** *ពួកជំនុំ* អាចជាពួកជំនុំតូចៗនៅតាមតំបន់ (៨:១ ១១:២២ ១៣:១) ឬជាពួកជំនុំជាសាកល (២០:២៨) ។ នៅក្នុងភាសាក្រិកពាក្យថា "ពួកជំនុំ" ត្រូវបានប្រើនៅក្នុងវិស័យនយោបាយ និងចំពោះការប្រជុំផ្សេងៗ (១៩:៣២, ៤១) ។ ពាក្យនេះក៏មានប្រើក្នុងព្រះគម្ពីរ "សញ្ញាចាស់ " ដែលបកប្រែជាភាសាក្រិកដំបូងបង្អស់ និងក្នុងការប្រជុំសាសនានៃពួកអ៊ីស្រាអែលមួយចំនួនផងដែរ ។

**៥:១២** *បាំងសាចសាឡូម៉ូន* "មើលការពន្យល់ ៣:១១"។

**៥:១៣** *អ្នកឯទៀតមិនហ៊ានចូលក្នុងពួកគេឡើយ* ដោយព្រោះតែលទ្ធផលរបស់អាន្នានាស និងប្រពន្ធរបស់គាត់បានធ្វើឱ្យមនុស្សមានពុត ឬពួកអ្នកស្ទាក់ស្ទើរមិនហ៊ានចូលរួមជាមួយពួកអ្នកជឿឡើយ ។ នេះពុំមានន័យថា គ្មានអ្នកណាមកចូលរួមជាមួយអ្នកជឿនោះទេ ព្រោះនៅក្នុង"ខ.១៤"បានបញ្ជាក់យ៉ាងច្បាស់ថាមានមនុស្សជាច្រើនទទួលជឿព្រះយេស៊ូវគ្រីស្ទ ។

**៥:១៤** *ពួកអ្នកដែលជឿដល់ព្រះអម្ចាស់. . . កាន់តែច្រើនឡើង. . . ទាំងប្រុសទាំងស្រី* នេះជាលើកទី១ហើយ ដែលបានបញ្ជាក់យ៉ាងច្បាស់អំពីការជឿរបស់ស្ត្រី (១:១៤ ៤:៤ ៨:៣,១២ ៩:២ ១៣:៥០ ១៦:១,១៣-១៤ ១៧:៤, ១២,៣៤ ១៨:២ ២១:៥) ។

**៥:១៥** *ស្រមោលគាត់* ដូចគ្នានឹងកន្សែងរបស់លោកប៉ុល (១៩:១២) និងព្រះពស្ត្រព្រះយេស៊ូវដែរ (មថ ៩:២០) របស់ទាំងនោះពុំមានលក្ខណៈពិសេស ឬឥទ្ធិពលអ្វីទេ ប៉ុន្តែវាបង្ហាញនូវទំនាក់ទំនងផ្ទាល់ជាមួយនឹងទ្រង់ ឬពួកសាវករបស់ទ្រង់ ។

**៥:១៧** *សំដេចសង្ឃ* សម្ដេចសង្ឃដែលពួករ៉ូម៉ាំងទទួលស្គាល់ជាផ្លូវការគឺលោកកៃផា ប៉ុន្តែពួកយូដាចាត់ទុកលោកអាណ ដែលជាឪពុកក្មេកលោកកៃផាជាសម្ដេចសង្ឃពិតប្រាកដរបស់ខ្លួនវិញ ព្រោះថាតួនាទីជាសម្ដេចសង្ឃត្រូវតែកាន់ខ្ជាប់រហូតអស់មួយជីវិត (មើលការពន្យល់ ៤:៦) ។ *អស់អ្នកនៅជាមួយនឹងលោក* សំដៅលើសមាជិកគ្រួសាររបស់គាត់ ។ *នៅខាងពួកសាឌូស៊ី* "មើលការពន្យល់ ៤:១"។

**៥:១៨** *ក៏ចាប់ពួកសាវកយកទៅឃុំទុក* ការដែលគេចាប់ពួកសាវ័កទៅនោះគឺដើម្បីរង់ចាំទទួលការវិនិច្ឆ័យទោសនៅថ្ងៃបន្ទាប់ ។

**៥:១៩** *ទេវតានៃព្រះអម្ចាស់* ឃ្លានេះមាននិយាយ៤កន្លែងទៀតនៅក្នុងគម្ពីរកិច្ចការ (១).លោកស្ទេផានថ្លែងពីទ្រង់(៧:៣០-៣៨) (២).ទ្រង់បង្ហាញផ្លូវលោកភីលីព (៨:២៦) (៣).ទ្រង់រំដោះលោកពេត្រុស (១២:៧-១០) (៤).ទ្រង់ប្រហារស្ដេចហេរ៉ូឌ (១២:២៣)(មថ ១:២០-២៤ ២:១៣,១៩ ២៨:២ លក ១:១១-៣៨ ២:៩ និងមើលការពន្យល់ លប ១៦:៧ ២ពវ ១:៣ ទដ ៣៤:៧ សក ១:៨) ។

**៥:២០** *អស់ទាំងព្រះបន្ទូលពីជីវិតថ្មី* គឺដំណឹងល្អនៃជីវិតអស់កល្ប និងគ្រប់លក្ខណ៍ (មើលពន្យល់ យហ ៦:៦៨ រម ៦:៤ ២កថ ៥:១៧ ភល ១:២១) ។

**៥:២១** *ពួកក្រុមជំនុំ* គឺជាតុលាការជាន់ខ្ពស់របស់ពួកយូដា មានសមាជិកពី៧០ទៅ១០០នាក់ (ចំនួនសមរម្យគឺ ៧១នាក់) ។ ពួកគេជាមនុស្សដែលមានចំណេះវិជ្ជាជ្រៅជ្រះ អង្គុយជារាងពាក់កណ្ដាលរង្វង់ មាន៣ជួរ និងមាន

នុំ[ង] នឹងពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែលទាំងអស់ ឱ្យប្រជុំ
គ្នា រួចចាត់ពួកអាជ្ញាទៅឯគុក ដើម្បីនឹងនាំយកពួកសាវក
មក ២២ គេក៏បានទៅ ដល់គុក តែមិនឃើញពួកសាវកនៅ
ក្នុងគុកទេ[ច] រួចត្រឡប់ មកវិញ ជំរាបថា ២៣ យើងខ្ញុំបាន
ឃើញគុកនៅបិទទ្វារជាប់ ទាំងប្រយ័ត្នគ្រប់ជំពូកព្រមទាំង
មានពួកយាមល្បាតឈរនៅមាត់ទ្វារផង តែកាលបានបើក
ទៅ នោះមិនឃើញមានអ្នកណាមួយនៅក្នុងទីនោះសោះ
២៤ កាលមេទ័ពរក្សាព្រះវិហារ នឹងពួកសង្គ្រាជ[ឆ]បានឮ
ដូច្នោះ នោះក៏វល់ក្នុងចិត្ត ពីដំណើរពួកនោះ ដែលកើតជា
យ៉ាងណា ២៥ តែមានម្នាក់ទៀតមកជំរាបថាមើល ពួកមនុស្ស
ដែលលោកបានដាក់គុកនោះ ឥឡូវនេះគេកំពុងតែឈរ
បង្រៀនដល់ពួកជននៅ ក្នុងព្រះវិហារវិញ ២៦ នោះមេទ័ព
នឹងពួកអាជ្ញា ក៏ទៅនាំគេមក ដោយឥតមានគំហកកំហែង
សោះ ដ្បិតខ្លាចក្រែងបណ្ដាជន[ជ]ចោលខ្លួននឹងថ្ម ២៧ កាល
បាននាំមកដាក់នៅមុខក្រុមជំនុំ[ឈ] ហើយនោះសំដេចសង្ឃ
ស្តីថា ២៨ តើយើងមិនបានហាមផ្តាច់មិនឱ្យ ឯងរាល់គ្នា
បង្រៀនពីឈ្មោះនោះទៀតទេឬអី[ញ] តែមើលឯងរាល់គ្នា
បានបង្រៀនសេចក្តីនោះ នៅពេញក្រុងយេរូសាឡិមទាំង
មូលវិញ ព្រមទាំងគិតទំលាក់ទោសពីឈាមមនុស្សនោះ
មកលើយើងផង[ដ] ២៩ តែពេត្រុស នឹងពួកសាវកឯទៀត
ឆ្លើយឡើងថា ត្រូវតែស្តាប់បង្គាប់របស់ព្រះជាជាងមនុស្ស[ឋ]
៣០ រីឯព្រះនៃពួកឰយុកោ[ឌ] យើងរាល់គ្នា ទ្រង់បានប្រោស
ព្រះយេស៊ូវ[ឍ] ដែលលោករាល់គ្នាបានសំឡាប់ ដោយ
ព្យួរនៅជាប់លើឈើ[ណ] ឱ្យទ្រង់មានព្រះជន្មរស់ឡើងវិញ
៣១ ហើយព្រះបានដំកើងទ្រង់ឡើង ដោយសារព្រះហស្តស្តាំ[ត]
ឱ្យធ្វើជាព្រះអម្ចាស់ នឹងជាព្រះអង្គសង្គ្រោះ[ថ] ដើម្បីនឹងប្រោស
ប្រទានការប្រែចិត្ត ដល់សាសន៍អ៊ីស្រាអែល[ទ] ប្រយោជន៍
ឱ្យបានរួចពីបាប ៣២ យើងខ្ញុំនេះ ព្រមទាំងព្រះវិញ្ញាណបរិ
សុទ្ធ[ធ] ដែលព្រះបានប្រទានដល់អស់អ្នកដែលស្តាប់បង្គាប់
ទ្រង់ដែរ ជាស្មរបន្ទាល់[ន] របស់ទ្រង់ពីការទាំងនោះ ។
៣៣ លុះកាលពួកក្រុមជំនុំបានឮ នោះគេមានចិត្តក្តៅ
ក្រហាយជាខ្លាំង[ប] ក៏ពិគ្រោះគ្នា នឹងសំឡាប់ពួកសាវកចេញ
៣៤ ប៉ុន្តែ មានពួកផារិស៊ីម្នាក់ឈ្មោះ កាម៉ាលាល[ផ]ជាអ្នកប្រាជ្ញ
ច្បាប់[ព] ដែលមនុស្សទាំងអស់រាប់អាន លោកឈរឡើងក្នុង
ក្រុមជំនុំ បង្គាប់ឱ្យបញ្ចេញពួកសាវក ទៅខាងក្រៅបន្តិច
សិន ៣៥ រួចលោកមានប្រសាសន៍ទៅពួកក្រុមជំនុំថា ពួកសាសន៍
អ៊ីស្រាអែលអើយ ចូរប្រយ័ត្នខ្លួន ពីដំណើរមនុស្សទាំងនេះ
ដែលអ្នករាល់គ្នាគិតធ្វើអ្វីដល់គេ ៣៦ ដ្បិតពីដើម មានឈ្មោះ
ធើដាស លើកខ្លួនឡើងថាជាអ្វីៗ ក៏មានមនុស្សចំនួនជា៤រយ
នាក់បានចូលពួកវា តែវាត្រូវគេសំឡាប់ទៅ ហើយពួកអ្នក
ទាំងប៉ុន្មាន ដែលចុះចូលចំពោះវា ក៏ត្រូវខ្ចាត់ខ្ចាយសូន្យអស់
ទៅដែរ ៣៧ ក្រោយនោះមកនៅវេលាធ្វើបញ្ជីកត់ត្រារាស្ត្រ[ភ]
នោះមានឈ្មោះយូដាស ជាអ្នកស្រុកកាលីឡេទៀត បាន
លើកខ្លួនឡើង បញ្ចុះបញ្ចូលមនុស្សជាច្រើន ឱ្យទៅតាមខ្លួន
វាក៏វិនាសបាត់ទៅដែរ ហើយពួកអ្នកដែលចុះចូលតាម ក៏

**៥:២២** ច កច ១២:១៨,១៩
**៥:២៤** ឆ កច ៤:១
**៥:២៦** ជ កច ៤:២១
**៥:២៧** ឈ មថ ៥:២២
**៥:២៨** ញ កច ៤:១៨ ដ មថ ២៣:៣៥ ២៧:២៥ កច ២:២៣,៣៦ ៣:១៤,១៥ ៧:៥២
**៥:២៩** ឋ នក ១:១៧ កច ៤:១៩
**៥:៣០** ឌ កច ៣:១៣ ឍ កច ២:២៤ ណ កច ១០:៣៩ ១៣:២៩ កទ ៣:១៣
**៥:៣១** ត មក ១៦:១៩ ថ លក ២:១១ ទ មថ ១:២១ មក ១:៤ លក ២៤:៤៧ កច ២:៣៨ ៣:១៩ ១០:៤៣
**៥:៣២** ធ យហ ១៥:២៦ ន លក ២៤:៤៨
**៥:៣៣** ប កច ២:៣៧ ៧:៥៤
**៥:៣៤** ផ កច ២២:៣ ព លក ២:៤៦ ៥:១៧
**៥:៣៧** ភ លក ២:១,២

មន្ត្រីតុលាការឈរនៅខាងមុខ (មើលការពន្យល់ មក ១៤:៥៥) ។
**៥:២៤** *មេទ័ពរក្សាព្រះវិហារ* "មើលការពន្យល់ ៤:១" ។
**៥:២៨** *គិតទំលាក់ទោស ពីឈាមមនុស្សនោះមកលើយើង* ប្រហែលជាពួកសាវកបានប្រកាសម្តងហើយម្តងទៀតថា ពួកយូដា និងអ្នកដឹកនាំរបស់គេមួយចំនួនបានធ្វើគុតព្រះយេស៊ូវគ្រីស្ទ (២:២៣ ៣:១៣–១៥ ៤:១០–១១ មថ ២៧:២៥) ។
**៥:២៩** "មើលការពន្យល់ ៤:១៩" ។
**៥:៣០** *ឈើ* គឺប្រើក្នុងការពណ៌នាអំពីឈើឆ្កាង (មើលការពន្យល់ ១ពត ២:២៤ ចទ ២១:២២,២៣) ។ ពួកហេព្រើរក៏ប្រើពាក្យនេះសំដៅលើដើមឈើឈើវែង ធ្នឹមឈើ ឬវត្ថុផ្សេងៗដែលស្រដៀងគ្នានេះផងដែរ ។
**៥:៣២** *ព្រមទាំងព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះបានប្រទានដល់អស់អ្នកដែលស្តាប់បង្គាប់ទ្រង់ដែរ* (យហ ១៥:២៦–២៧) ព្រះវិញ្ញាណបរិសុទ្ធទ្រង់បានដឹកនាំ និងធានាអះអាងនូវទីបន្ទាល់របស់ពួកសាវក ។ គឺទ្រង់ហើយដែលផ្លាស់ប្រែចិត្តមនុស្ស លោកតាមរយៈព្រះបន្ទូល (យហ ១៦:៨–១១) និងត្រូវប្រទានទៅអស់អ្នកដែលឆ្លើយតបដោយការស្តាប់បង្គាប់ និងជំនឿលើអង្គព្រះយេស៊ូវគ្រីស្ទ (រម ១:៥ និងមើលការពន្យល់ ៦:៧) ។
**៥:៣៤** *ពួកផារិស៊ីម្នាក់ឈ្មោះ កាម៉ាលាល* គាត់គឺជាគ្រូបង្រៀនសាសន៍យូដាម្នាក់ដែលមានឈ្មោះល្បីខ្លាំងនាសម័យគាត់ ។ តាមទំនៀមទម្លាប់ពួកយូដា ឈ្មោះរបស់គាត់ត្រូវបានរាប់ចូលក្នុងបញ្ជីនៃពួកប្រធានសាលា ។ លោកកាម៉ាលាលម្នាក់នេះ ប្រហែលជាចៅរបស់លោកហ៊ីលេល ។ ហើយក៏ដូចគ្នានឹងលោកហ៊ីលេលដែរ (មើលការពន្យល់ មថ ១៩:៣) លោកកាម៉ាលាលចេះប្រមាណនូវការយល់ឃើញ ប្រកបដោយលក្ខណៈច្បាស់លាស់ និងប្រុងប្រយ័ត្នរាល់ពាក្យសំដីរបស់ខ្លួន ។ លោកសុល (ប៉ុល) ក៏ធ្លាប់ជាសិស្សម្នាក់របស់លោកកាម៉ាលាលនេះដែរ (២២:៣) ។
**៥:៣៦** *ធើដាស* គ្មានប្រភពឯកសារប្រវត្តិសាស្ត្រណាផ្សេងទៀតនិយាយពីគាត់ទេ ។
**៥:៣៧** *យូដាស ជាអ្នកស្រុកកាលីឡេ* យោងតាមអ្នកប្រវត្តិសាស្ត្រជាតិយូដាម្នាក់ឈ្មោះយ៉ូសែបហ្វីស (Josephus) បានសរសេរថា យូដាសម្នាក់នេះគឺជាបុរសម្នាក់នៅឯកាម៉ាឡា (Gamala) នៃកូឡានីទីស (Gaulanitis) និងជាអ្នកប្រឆាំងមិនព្រមបង់ពន្ធទៅអធិរាជសេសារ ។ ការបះបោរនោះត្រូវទទួលបរាជ័យ ប៉ុន្តែ ចលនាតស៊ូអាចនៅមានបន្តទៅក្រុមនៃពួកឧស្សាហ៍ (១:១៣ មើលការពន្យល់ មថ ១០:៤) ។ *វេលាធ្វើបញ្ជីកត់ត្រារាស្ត្រ* គឺជាការចុះ

ត្រូវខ្ចាត់ខ្ចាយទាំងអស់គ្នាទៅ ៣៨ដូច្នេះ ខ្ញុំទូន្មានអ្នករាល់គ្នា
ថា ចូរដកខ្លួនពីមនុស្សទាំងនេះចេញ កុំឱ្យធ្វើអ្វីដល់គេ
ឡើយ ដ្បិតបើសិនជាគំនិតគេ ឬការគេធ្វើនេះ កើតឡើង
ពីមនុស្ស នោះនឹងត្រូវវិនាសទៅជាមិនខាន[ម] ៣៩តែបើកើត
មកពីព្រះវិញ នោះអ្នករាល់គ្នា ពុំអាចនឹងធ្វើឱ្យវិនាសបាន
ទេ ក្រែងអ្នករាល់គ្នាជាប់ទោស ជាពួកអ្នកតយុទ្ធនឹងព្រះ
ដែរ[យ] ៤០ពួកក្រុមជំនុំក៏យល់ព្រមតាមគំនិតលោក រួចកាល
បានហៅពួកសាវកមកវិញ នោះក៏វាយនឹងរំពាត់[រ] ព្រមទាំង
ហាមឃាត់ មិនឱ្យនិយាយពីព្រះនាមព្រះយេស៊ូវទៀត រួច
លែងឱ្យទៅ ។

៤១ពួកសាវកក៏ចេញពីពួកក្រុមជំនុំ ទៅដោយអរសប្បាយ[ល]
ពីព្រោះព្រះបានរាប់ជាអ្នកគួរនឹងទ្រាំសេចក្ដីដំនៀលដោយ
ព្រោះព្រះនាម[វ]ទ្រង់ ៤២ហើយអ្នកទាំងនោះចេះតែបង្រៀន
ព្រមទាំងប្រាប់ដំណឹងល្អ[ស] ពីព្រះយេស៊ូវគ្រីស្ទ[ហ] នៅក្នុង
ព្រះវិហារ[ឡ] ហើយនៅអស់ទាំងផ្ទះរាល់តែថ្ងៃជានិច្ច ។

**៥:៣៨** ម មថ ១៥:១៣
**៥:៣៩** យ ២របា ១៣:១២ សភ ២១:៣០ អស ៤៦:១០ កច ៧:៥១ ១១:១៧
**៥:៤០** រ មថ ១០:១៧
**៥:៤១** ល មថ ៥:១២ វ យហ ១៥:២១
**៥:៤២** ស កច ១៣:៣២ ហ ចក ៩:២២ ឡ កច ២:៤៦
**៦:១** អ កច ២:៤១ ក កច ៩:២៩ ខ កច ៩:៣៩,៤១ ១ធថ ៥:៣ គ កច ៤:៣៥

## ការជ្រើសរើសអ្នកទាំង៧នាក់

៦ ១នៅគ្រានោះ កាលពួកសិស្សបានចំរើនច្រើនឡើង[អ]
នោះពួកហេលេន[ក] ចាប់តាំងរទូរទាំទាស់នឹងពួកហេព្រើរ
អំពីការចែកចាយរាល់តែថ្ងៃ ដោយព្រោះគេតែងធ្វេស
ការនឹងស្រីមេម៉ាយ[ខ]របស់ពួកហេលេននោះ[គ] ២ពួកសាវក
១២នាក់ក៏ហៅសិស្ស[ឃ]ទាំងអស់មកនិយាយថា មិនគួរគប្បី
ឱ្យយើងខ្ញុំ ទុកព្រះបន្ទូល[ង]ចោល ដើម្បីនឹងទៅបំរើតុទេ
៣ដូច្នេះបងប្អូន[ច]អើយ ចូររើសយក៧នាក់ក្នុងពួកអ្នករាល់គ្នា
ជាអ្នកមានឈ្មោះល្អ ពេញជាព្រះវិញ្ញាណបរិសុទ្ធ[ឆ] នឹង
ប្រាជ្ញា នោះយើងខ្ញុំនឹងតាំងគេ ឱ្យត្រួតត្រាលើការងារនេះ[ជ]
៤ឯយើងខ្ញុំ នឹងខំព្យាយាមក្នុងសេចក្ដីអធិស្ឋាន[ឈ] និងការ
ផ្សាយព្រះបន្ទូលវិញ ៥សេចក្ដីនោះក៏ពេញចិត្តដល់ពួកជំនុំ
ទាំងអស់គ្នា ហើយគេរើសយកស្ទេផាន១[ញ] ជាមនុស្សពេញ
ដោយសេចក្ដីជំនឿ និងព្រះវិញ្ញាណបរិសុទ្ធ[ដ] ព្រមទាំងភី
លីព១[ឋ] ប្រូខូរ៉ូស១នីកាន័រ១ ទីម៉ូន១ ប៉ាមេណា១ និង

**៦:២** ឃ កច១១:២៦ ង ហព ៤:១២ **៦:៣** ច កច ១:១៦ ឆ លក ១:១៥ ជ នក ១៨:២១ នហ ១៣:១៣ **៦:៤** ឈ កច ១:១៤ **៦:៥** ញ ខ.៨ កច ៧:៥៥–៦០ ១១:១៩ ២២:២០ ដ លក ១:១៥ ឋ កច ៨:៥–៤០ ២១:៨

បញ្ជីដែលធ្វើឡើងនៅឆ្នាំ ៦ គ.ស ពុំមែនជាការចុះបញ្ជីដំបូង ដែលលោកលូកាលើកឡើងក្នុង"លូកា២:១,២"នោះទេ ។

**៥:៣៨–៣៩** លោកកាម៉ាលាល បានណែនាំពួកយូដា ឱ្យដោះលែងពួកសាវក ហើយបានធ្វើការពន្យល់ដល់ពួកក្រុមជំនុំ និងសាសន៍ពួកយូដាថា ប្រសិនបើការដែលពួកសាវកធ្វើនោះមកពីចិត្ត និងគំនិតរបស់ខ្លួនផ្ទាល់ នោះវាពិតជានឹងវិនាសបាត់ទៅជាមិនខាន ។ ប៉ុន្តែ បើការដែលពួកសាវកធ្វើនោះមកអំពីព្រះវិញ គ្មានមនុស្សណាម្នាក់អាចបញ្ឈប់បានឡើយ ។

**៥:៤០** *វាយនឹងរំពាត់* ទណ្ឌកម្មសម្រាប់ពួកយូដាគឺត្រូវវាយ ៤០ រំពាត់ខ្វះ១ (មើលការពន្យល់ ២កថ ១១:២៤)។ ទោះបីត្រូវគេវាយនឹងរំពាត់ក៏ដោយក៏ពួកសាវក នៅតែបន្តព្យាយាមផ្សាយដំណឹងល្អ ពីការសង្គ្រោះរបស់ព្រះអម្ចាស់ដដែល ។

**៦:១** *ពួកសិស្សបានចំរើនច្រើនឡើង* រយៈពេលនៃការរីកចម្រើននេះ គឺចាប់ផ្ដើមរាប់ចាប់ពីចុងជំពូក៥មកម្ល៉េះ ។ ពួកជំនុំនៅតែបន្តចម្រើនឡើង ប៉ុន្តែទន្ទឹមនឹងនោះ ក៏មានកើតឡើងនូវបញ្ហា ទាំងពីខាងក្រៅ និងខាងក្នុងចំណោមពួកគេផ្ទាល់ (៦:៨–៧:៦០)។ ក្នុងរយៈពេលនៃការចម្រើនឡើងនេះ ពួកជំនុំត្រូវបានរៀបចំតាមរបៀបពួកយូដា ។ ហើយចំពោះពួកយូដា ក៏ត្រូវបានចែកជា២ក្រុមទៀតគឺ ពួកហេលេន និងពួកហេព្រើរ ។ ពួកហេលេនជាអ្នកដែលពុំបានកើតនៅលើទឹកដីសន្យា និយាយភាសាក្រិក និងមានទំនោរទៅពួកក្រេកផ្នែកប្ញកពា និងចរិយាមាយាទ ។ ពួកហេព្រើរជាក្រុមនិយាយភាសាអើរ៉ាម ឬហេព្រើរ ហើយប្រកាន់នូវទំនៀមទម្លាប់ និងវប្បធម៌យូដា ។ *អំពីការចែកចាយរាល់តែថ្ងៃ* នៅពេលនោះពួកជំនុំមានទំនួលខុសត្រូវចំពោះការចែកចាយដល់ពួកស្ត្រីមេម៉ាយទាំងឡាយណាដែលខ្វះខាត និងគ្មានអ្នកថែរក្សា (៤:៣៥ ១១:២៨–២៩ ១ធថ ៥:៣–១៦)។

**៦:២** *ពួកសាវក១២នាក់* ក្នុងដំណាក់កាលរីកចម្រើននោះ ពួកសាវកជាអ្នកទទួលខុសត្រូវចំពោះជីវិតពួកជំនុំទាំងមូល រួមមានការចែកចាយព្រះបន្ទូល និងការថែរក្សាពួកជំនុំ ។ *ដើម្បីនឹងទៅបំរើតុទេ* គឺឱ្យពួកគេមើលការខុសត្រូវលើការចែកចាយអំណោយសប្បុរសផ្សេងៗ។ ពួកជំនុំដំបូងមានការយកចិត្តទុកដាក់ ទាំងតម្រូវការខាងឯវិញ្ញាណ (ព្រះបន្ទូលព្រះ និងការអធិស្ឋាន ខ.៤) និងរាល់តម្រូវការសម្រាប់រស់នៅខាងរូបកាយ ។

**៦:៣** *ចូររើសយក៧នាក់* ពួកជំនុំបានជ្រើសរើសពួកទាំង៧នាក់នោះ (ខ.៥) ហើយពួកសាវកទាំង១២ក៏តែងតាំងពួកគេឡើង (ខ.៦)។ តាមរបៀបយ៉ាងដូច្នេះ ពួកគេត្រូវបានតែងតាំង ឱ្យបំពេញមុខងារតាមតួនាទីរៀងៗខ្លួន ។ *ពេញជាព្រះវិញ្ញាណបរិសុទ្ធ* "មើលការពន្យល់ ២:៤"។

**៦:៤** គំរូដ៏សំខាន់មួយគឺ កាលណាមានភារកិច្ចច្រើន រហូតមិនអាចបំពេញឱ្យចប់គ្រប់ជ្រុងជ្រោយល្អ នោះត្រូវផ្ទេរការងារខ្លះ ទៅមនុស្សសុចរិតរបស់ព្រះអម្ចាស់ ។

**៦:៥** *ហើយគេរើសយកស្ទេផាន១...នីកុឡាស* ការដែលសំខាន់បំផុតគឺអ្នកទាំង៧ដែលត្រូវបានជ្រើសរើសនោះមានឈ្មោះជាក្រិក ។ ពាក្យសំដីរទូររទាំបានកើតឡើងនៅក្នុងពួកជំនុំ ដោយក្រុមអ្នកដែលនិយាយភាសាក្រិក ដូច្នេះ ៧នាក់ដែលជ្រើសតាំងឡើងនោះត្រូវតែមកពីក្រុមនេះ គឺដើម្បីបង្ហាញនូវភាពស្មើគ្នានៃចំណង់ចំណូលចិត្តរបស់ពួកគេ ។ ក្នុងចំណោមអ្នកទាំង៧នោះ មានតែលោកភីលីព និងលោកស្ទេផានប៉ុណ្ណោះ ដែលត្រូវបានកត់សំគាល់បន្តបន្ទាប់មកទៀត (ស្ទេផាន ៦:៨–៧:៦០ ភីលីព ៨:៥–៤០ ២១:៨–៩)។ *ជាអ្នកស្រុកអាន់ទីយ៉ូក ដែលចូលសាសន៍១* ការដ៏សំខាន់នោះគឺសាសន៍ដទៃម្នាក់នេះបានរាប់បញ្ចូលទៅក្នុងចំនួន ពួកទាំង៧នាក់ ហើយលោកលូកាបានបង្ហាញពីទីកន្លែងកំណើតរបស់បុរសម្នាក់នេះថាគាត់មកពីស្រុកអាន់ទីយ៉ូកជាទីកន្លែងដែលទទួលដំណឹងល្អបានឆាប់រហ័សនាពេលនោះ ហើយបានក្លាយទៅជាចំណុចដ៏សំខាន់មួយសម្រាប់នាំដំណឹងល្អទៅសាសន៍ដទៃ ។

នីកុឡាស ជាអ្នកស្រុកអាន់ទីយ៉ូក ដែលចូលសាសន៍១
៦ក៏នាំអ្នកទាំងនោះមកនៅចំពោះមុខពួកសាវក កាលពួក
សាវកបានអធិស្ឋាន[ឌ]រួចហើយ នោះក៏ដាក់ដៃលើអ្នកទាំង
៧នាក់នោះ[ឍ] ៧ព្រះបន្ទូលក៏បានផ្សាយទៅកាន់តែច្រើន
ឡើង[ណ] ហើយចំនួនពួកសិស្ស បានចំរើនឡើងក្រៃលែង[ត]
នៅក្រុងយេរូសាឡិម ឯពួកសង្ឃ ក៏មានសន្ធឹកចុះចូល
ជឿដែរ ។

## ការឃាត់ខ្លួនលោកស្ទេផាន

៨ឯស្ទេផាន ដែលពេញដោយសេចក្ដីជំនឿ និងព្រះចេស្ដា
គាត់ក៏ធ្វើការអស្ចារ្យ និងទីសំគាល់យ៉ាងធំ[ថ] នៅក្នុងពួកជន
៩គ្រានោះ មានអ្នកខ្លះក្នុងពួកដែលហៅថា ពួកអ្នកបំរោស
និងពួកស្រុកគីរេន[ទ] ពួកស្រុកអ័លេក្សានទ្រា ពួកអ្នកមកពី
ស្រុកគីលីគា[ធ] ហើយស្រុកអាស៊ី[ន] គេលើកគ្នាមកជជែកនឹង
ស្ទេផាន ១០តែគេពុំអាចដើម្បីទប់ទល់នឹងប្រាជ្ញា ហើយនិង
ព្រះវិញ្ញាណ ដែលគាត់អាងនឹងនិយាយនោះបានទេ[ប] ។
១១នោះគេសូក[ផ]មនុស្សខ្លះឱ្យនិយាយបង្កាច់ថា យើងបាន
ឮអ្នកនេះ ពោលពាក្យប្រមាថដល់លោកម៉ូសេ ហើយដល់ព្រះ
ផង[ព] ១២អ្នកទាំងនោះក៏ញុះញង់ដល់បណ្ដាជន ពួកចាស់ទុំ និង
ពួកអាចារ្យ រួចនាំគ្នាទៅចាប់គាត់យកទៅដល់ពួកក្រុមជំនុំ[ភ]
១៣គេតាំងឱ្យមានសាក្សីក្លែង[ម]និយាយថា មនុស្សនេះចេះតែ

**៦:៦** ឌ កច ១:២៤ ឍ ជន ៨:១០ ២៧:១៨ កច ៩:១៧ ១៩:៦ ២៨:៨ ១ធថ ៤:១៤ មក ៥:២៣
**៦:៧** ណ កច ១២:២៤ ១៩:២០ ត កច ២:៤១
**៦:៨** ថ យហ ៤:៤៨
**៦:៩** ទ មថ ២៧:៣២ ធ កច ១៥:២៣,៤១ ២២:៣ ២៣:៣៤ ន កច ២:៩
**៦:១០** ប លក ២១:១៥
**៦:១១** ផ ១ពវ ២១:១០ ព មថ ២៦:៥៩–៦១
**៦:១២** ភ មថ ៥:២២ **៦:១៣** ម នក ២៣:១ ទជ ២៧:១២

**៦:៦** *ពួកសាវកបានអធិស្ឋានរួចហើយ នោះក៏ដាក់ដៃលើអ្នកទាំង៧នាក់នោះ* ការដែលអធិស្ឋានដាក់ដៃលើ មានប្រើនៅក្នុងគម្ពីរសញ្ញាចាស់ដើម្បីឱ្យពរ (លក ៤៨:១៣–២០) ផ្ទេរអំពើបាបទៅឯយញ្ញបូជា (លវ ១:៤) តាំងអ្នកណាម្នាក់ឱ្យទទួលនូវភារកិច្ចថ្មី (ជន ២៧:២៣) ។ ក្នុងសម័យកាលសញ្ញាថ្មីវិញការដាក់ដៃលើត្រូវបានប្រើក្នុងការប្រោសជំងឺ (២៨:៨ មក ១:៤១) ការឱ្យពរ (មក ១០:១៦) ការចាក់ប្រេងតាំង ឬប្រគល់មុខតំណែង (កច ៦:៦ ១៣:៣ ១ធថ ៥:២២) និង ពង្រឹងអំណោយទានខាងឯវិញ្ញាណរបស់អ្នកជឿណាម្នាក់ (កច ៨:១៧ ១៩:៦ ១ធថ ៤:១៤ ២ធថ ១:៦) ។ ពួកសាវកបានតាំងអ្នកទាំង៧នាក់នោះ ឱ្យទទួលនូវភារកិច្ចជំនួសពួកខ្លួន ។ ភាសាក្រិកប្រើពាក្យថា "អ្នកជំនួយ" ក្នុងការពណ៌នាពីទំនួល ខុសត្រូវដែលអ្នកទាំង៧នោះត្រូវទទួល ។ ពាក្យនេះ នៅក្នុងភាសាក្រិកដដែលក៏អាចប្រែថា "អ្នកបម្រើ" ផងដែរ (ភល ១:១ ១ធថ ៣:៨–១៣) ។ អ្នកទាំង៧នោះ ត្រូវបានគេហៅថា "ពួកទាំង៧នាក់" (២១:៨) គឺដូចដែលគេហៅពួកសាវកថា "ពួកទាំង១២នាក់" យ៉ាងដូច្នោះដែរ ។ មានសំណួរចោទឡើងថា តើអ្នកទាំង៧នាក់នោះជាអ្នកជំនួយ ឬមានអ្នកផ្សេងទៀតជាអ្នកជំនួយ (មើលការពន្យល់ ១ធថ ៣:៨) ។

**៦:៧** របាយការណ៍ស្ដីអំពីការរីកចម្រើននៃពួកជំនុំ បានផ្ដល់យ៉ាងជាក់លាក់តាមរយៈព្រះគម្ពីរកិច្ចការ (១:១៥ ២:៤១ ៤:៤ ៥:១៤ ៦:៧ ៩:៣១ ១២:២៤ ១៦:៥ ១៩:២០ ២៨:៣១) ។ *ឯពួកសង្ឃ* ទោះបីពួកនេះមានជាប់វង្សត្រកូល និងការបម្រើជាសង្ឃ កាន់តាមបញ្ញត្តិនៃសញ្ញាចាស់ក៏ដោយ ក៏ពួកគេព្រមទទួលយកការបង្រៀនរបស់ពួកសាវក ដែលប្រកាសថា យញ្ញបូជានៃសញ្ញាចាស់មិនសំខាន់ទៀតទេ (ហព ៨:១៣ មើលពន្យល់ ១០:១–៤,១១-១៤) ។ *ក៏មានសន្ធឹកចុះចូលជឿដែរ* ការនេះកើតឡើងដោយការឆ្លើយតបទៅនឹងបញ្ញត្តិនៃដំណឹងល្អ ។ ជឿគឺត្រូវស្ដាប់បង្គាប់ ។ ជំនឿគឺត្រូវមានការស្ដាប់បង្គាប់ ហើយវាក៏បង្កើតឱ្យមានការស្ដាប់បង្គាប់ផងដែរ (រម ១:៥ អភ ២:៨–១០ យក ២:១៤–២៦) ។

**៦:៨** *ការអស្ចារ្យ និងទីសំគាល់យ៉ាងធំ* រហូតមកដល់ចំណុចនេះ គម្ពីរកិច្ចការបាននិយាយតែការអស្ចារ្យ ដែលកើតឡើងតាមរយៈពួកសាវកប៉ុណ្ណោះ (២:៤៣ ៣:៤-៨ ៥:១២) ប៉ុន្តែ បន្ទាប់ពីពួកសាវកបានអធិស្ឋានដាក់ដៃលើលោកស្ទេផាន នោះគាត់ក៏ចាប់ផ្ដើមធ្វើការអស្ចារ្យយ៉ាងធំ ។ ការអស្ចារ្យរបស់ព្រះអម្ចាស់ ក៏បានសំដែងតាមរយៈលោកភីលីពផងដែរ (៨:៦) ។

**៦:៩** *ពួកអ្នកបំរោស* គឺក្រុមមនុស្សដែលបានរួចខ្លួនអំពីទាសភាពមកវិញ និងមកពីតំបន់ផ្សេងៗនៃប្រទេសក្រិក ។ *ស្រុកគីរេន* ជាទីក្រុងសំខាន់មួយនៃស្រុកលីប៊ី (ស្ថិតនៅអាហ្វ្រិកខាងជើង) (មើលការពន្យល់ ២:១០ មក ១៥:២១) ។ ស្រុកនេះស្ថិតនៅចន្លោះស្រុកអ័លេក្សានទ្រា និងទីក្រុងកាថាច (Cartage) ។ ប្រជាជនរស់នៅទីនោះមានមួយក្រុមជាពួកយូដា (១១:១៩–២១) ។ *អ័លេក្សានទ្រា* ជារាជធានីនៃប្រទេសអេស៊ីព្ទ ហើយបានក្លាយទៅជាទីក្រុងទី២វិញនៅក្នុងសម័យកាល ដែលត្រួតត្រាដោយចក្រភពរ៉ូម៉ាំង ។ មានជនជាតិយូដារស់នៅក្នុងសង្កាត់ចំនួន២ក្នុង ចំណោមសង្កាត់ចំនួន៥ នៅអ័លេក្សានទ្រា ។ *គីលីគា* ជាខេត្តមួយរបស់ចក្រភពរ៉ូម៉ាំង ។ ខេត្តនេះស្ថិតនៅភាគអាគ្នេយ៍នៃទ្វីបអាស៊ីខាងលិចបំផុត ជាប់ជាមួយនឹងប្រទេសស៊ីរី ។ ក្រុងតើសុស ដែលជាទីកន្លែងកំណើតរបស់លោកប៉ុល គឺជាក្រុងសំខាន់មួយនៃខេត្តនេះ ។ *ស្រុកអាស៊ី* ជាខេត្តមួយរបស់ចក្រភពរ៉ូម៉ាំង ស្ថិតនៅភាគខាងលិចបំផុតនៃទ្វីបអាស៊ី (សព្វថ្ងៃជាតំបន់១នៅទ្វីបអឺរ៉ុប) ។ ទីក្រុងអេភេសូរជាទីក្រុងធំនៃស្រុកនេះ ហើយវាក៏ជាកន្លែង ដែលលោកប៉ុលធ្លាប់បម្រើការងារថ្វាយព្រះអម្ចាស់ដែរ ។ *គេលើកគ្នាមកជជែក* ដោយលោកសុលជាមនុស្សម្នាក់មកពីក្រុងតើសុស ដូច្នេះ អាចសន្និដ្ឋានបានថា គាត់ប្រហែលមកចូលរួមនៅថ្ងៃបុណ្យទី៥០នោះដែរ ។ ម្យ៉ាងទៀត ប្រហែលជាគាត់នៅក្នុងចំណោមអ្នកដែលជជែកនឹងលោកស្ទេផានផងដែរ ។ គាត់មានវត្តមានយ៉ាងច្បាស់នៅពេលដែលគេគប់ដុំថ្មសម្លាប់លោកស្ទេផាន (៧:៥៨) ។

**៦:១១** *ប្រមាថដល់លោកម៉ូសេ ហើយដល់ព្រះផង* ដោយព្រោះលោកស្ទេផានបានប្រកាសថា ការថ្វាយបង្គំព្រះអម្ចាស់ មិនចាំបាច់តែនៅឯព្រះវិហារទៀតទេ (៧:៤៨–៤៩) នោះធ្វើឱ្យពួកអ្នកប្រឆាំងមូលបង្កាច់ និងចោទប្រកាន់ពាក្យសំដីគាត់ ថាបានព្យាយាមបំផ្លាញព្រះវិហារ ហើយប្រឆាំងនឹងក្រឹត្យវិន័យលោកម៉ូសេ និងព្រះផង ។

**៦:១២** *ពួកចាស់ទុំ និងពួកអាចារ្យ* "មើលការពន្យល់ មថ ២:៤ ១៥:២ មក ២:១៦ លក ៥:១៧"។ *ពួកក្រុមជំនុំ* "មើលការពន្យល់ មក ១៤:៥៥"។

**៦:១៣** *ពោលពាក្យប្រមាថដល់ទីបរិសុទ្ធ និងក្រឹត្យវិន័យ* ស្រដៀងនឹងពាក្យសំដីដែលពួកគេបានចោទប្រកាន់ព្រះយេស៊ូវគ្រីស្ទដែរ (មើលពន្យល់ មក

ពោលពាក្យប្រមាថដល់ទីបរិសុទ្ធ[យ] នឹងក្រិត្យវិន័យ ១៤ដ្បិត
យើងខ្ញុំបានឮវាថា ឈ្មោះយេស៊ូវ ពីស្រុកណាសារ៉ែតនោះ
នឹងបំផ្លាញទីនេះបង់[រ] ព្រមទាំងបំផ្លាស់បំប្រែទំនៀមទំលាប់
ដែលលោកម៉ូសេ បានទុកឱ្យយើងរាល់គ្នាចេញ[ល] ១៥តែអស់
អ្នកដែលអង្គុយ នៅក្នុងក្រុមជំនុំ[វ] ក៏ជាប់ភ្នែកមើលមុខគាត់
ឃើញដូចជាមុខទេវតា ។

## លោកស្ទេផានថ្លែងទៅកាន់ពួកក្រុមជំនុំ

**៧** ១នោះសំដេចសង្ឃសួរថា សេចក្ដីទាំងនេះត្រូវឬទេ
២ស្ទេផានឆ្លើយថា ឱអ្នករាល់គ្នាជាបងប្អូន ជាឪពុកអើយ[ស]
សូមស្ដាប់សិន ព្រះដ៏មានសិរីល្អ[ហ] ទ្រង់លេចមកឱ្យលោក
អ័ប្រាហាំ ជាព្ធយុកោយើងរាល់គ្នាឃើញ ក្នុងកាលដែល
លោកនៅស្រុកមេសូប៉ូតាមា មុនដែលនៅស្រុកខារ៉ាន[ឡ]
៣ហើយមានបន្ទូលប្រាប់លោកថា «ចូរឯងចេញពីស្រុក
ហើយពីញាតិសន្តានឯង ទៅនៅស្រុក១ដែលអញនឹងបង្ហាញ
វិញ »[អ] ៤នោះលោកក៏ចេញពីស្រុករបស់សាសន៍ខាល់ដេ
ទៅនៅស្រុកខារ៉ានទៅ លុះក្រោយដែលឪពុកលោកស្លាប់
ហើយ នោះទ្រង់ផ្លាស់លោកពីទីនោះ ឱ្យមកនៅស្រុក ដែល
លោករាល់គ្នានៅសព្វថ្ងៃនេះវិញ[ក] ៥ទ្រង់មិនបានប្រទាន ឱ្យ
លោកមានមរដកអ្វី នៅស្រុកនេះទេ[ខ] សូម្បីឱ្យល្មមនឹងដាក់
ជើងចុះក៏គ្មានដែរ តែទ្រង់សន្យានឹងប្រទានស្រុកនេះ ទុកជា
ស្រុកកំណាន់ដល់លោក នឹងពូជលោកតទៅវិញ[គ] ថ្វីបើ
លោកមិនទាន់មានកូននៅឡើយផង ៦ហើយព្រះទ្រង់មាន
បន្ទូលបែបដូច្នេះ គឺពូជលោកនឹងត្រូវអាស្រ័យនៅក្នុងស្រុក
ដទៃ អ្នកស្រុកនោះនឹងចាប់គេធ្វើជាខ្ញុំកំដរ ព្រមទាំងធ្វើទុក្ខ
គេគ្រប់៤០០ឆ្នាំ[ឃ] ៧ព្រះទ្រង់មានបន្ទូលទៀតថា «អញនឹង
ជំនុំជំរះសាសន៍នោះ ដែលចាប់គេទៅបំរើ ក្រោយនោះ
គេនឹងចេញមកគោរពប្រតិបត្តិដល់អញ នៅទីនេះវិញ»[ង]
៨ទ្រង់ក៏តាំងសេចក្ដីសញ្ញាខាងឯការកាត់ស្បែក[ច] ដល់លោក

**៦:១៣** យ មថ ២៤:១៥ កច ៧:៤៨ ២១:២៨
**៦:១៤** រ យហ ២:១៩ ល កច ១៥:១ ២១:២១ ២៦:៣ ២៨:១៧
**៦:១៥** វ មថ ៥:២២
**៧:២** ស កច ២២:១ ហ ទដ ២៩:៣ ឡ លប ១១:៣១ ១៥:៧
**៧:៣** អ លប ១២:១
**៧:៤** ក លប ១២:៥
**៧:៥** ខ ហព ១១:១៣ គ លប ១២:៧ ១៧:៨ ២៦:៣
**៧:៦** ឃ នក ១:៨-១១ នក ១២:៤០
**៧:៧** ង លប ១៥:១៣ ,១៤ នក ៣:១២

២៦:៦១)។ លោកស្ទេផានប្រហែលជាសំដៅលើព្រះបន្ទូលនៅក្នុង "យហ ២:១៩" (មើលការពន្យល់) ហើយអាចថាពួកគេពុំយល់ ឬក៏ធ្វើជាមិនយល់តែម្ដង(ខ.១៤) គឺដូចកាលដែលពួកគេបានធ្វើចំពោះព្រះយេស៊ូវដែរ ។ *ទីបរិសុទ្ធ* ពាក្យថា"ទីបរិសុទ្ធ" នៅត្រង់ចំណុចនេះ ពួកគេចង់សំដៅទៅលើព្រះវិហារ នៅឯទីក្រុងយេរូសាឡិម ។

**៧:១** *សំដេចសង្ឃ* ប្រហែលជាលោកកៃផា (មថ ២៦:៥៧-៦៦ មើលការពន្យល់ ៤:៦ យហ ១៨:១៩,២៤)។ *សេចក្ដីទាំងនេះត្រូវឬទេ?* "មើលការពន្យល់ ៦:១១,១៣"។

**៧:២-៥៣** សូមមើលសេចក្ដីផ្ដើមគម្ពីរកិច្ចការ ត្រង់ចំណុចលក្ខណៈពិសេសនៃការថ្លែងព្រះបន្ទូលដ៏មានប្រសិទ្ធភាព ។ អ្នកនិពន្ធគម្ពីរកិច្ចការទុកចន្លោះច្រើនសម្រាប់ការថ្លែងរបស់លោកស្ទេផាន ដូច្នេះ អាចសន្និដ្ឋានថាវាពិតជាមានសារសំខាន់ដ៏វិសេសជាមិនខាន ។ ការនិយាយដោយបើកចំហ នោះមិនមានន័យថាជាការដោះសារយករួចខ្លួន ដោយសង្ឃឹមថាអាចផ្សះផ្សាជាមួយនឹងពួកអ្នកប្រឆាំងនោះទេ(ខ.៥១-៥២) ប៉ុន្ដែជាការវាយប្រហារមួយទៅលើមូលដ្ឋានគ្រឹះនៃសាសនាយូដា ដោយការរំឭកឡើងវិញនូវប្រវត្តិខុសឆ្គងទាំងឡាយរបស់លទ្ធិនោះ ទាក់ទងទៅនឹងចំណុចសំខាន់៣ ដែលពួកយូដាយកចិត្តទុកដាក់គោរព (១).ទឹកដី (ខ.២-៣៦) (២).ក្រឹត្យវិន័យ (ខ.៣៧-៤៣) (៣).ព្រះវិហារ (ខ.៤៤-៥០) និងបញ្ចប់ដោយ សូរកងរំពងនៃពួកអ្នកប្រឆាំង(ខ.៥១-៥២)។ ការថ្លែងរបស់លោកស្ទេផានបានបញ្ជាក់យ៉ាងច្បាស់អំពីភាពខុសគ្នារវាងសាសនាយូដា និងជំនឿលើព្រះគ្រីស្ទ ហើយបន្តពន្យល់ពីភាពខុសគ្នារវាងជំនឿចាស់ និងជំនឿថ្មី ដែលមានបង្ហាញនៅក្នុងសំបុត្ររបស់លោកប៉ុល និងក្នុងគម្ពីរហេព្រើរ ។

**៧:២** *លោកអ័ប្រាហាំ. . . នៅស្រុកមេសូប៉ូតាមា មុនដែលនៅស្រុកខារ៉ាន* ព្រះអម្ចាស់ទ្រង់បានត្រាស់ហៅលោកអ័ប្រាហាំនៅស្រុកអើរ មិនមែននៅស្រុកខារ៉ាននោះទេ (លប ១២:១ មើលពន្យល់ លប ១៥:៧ នហ ៩:៧)។ ម្យ៉ាងទៀត ប្រហែលជាគាត់ត្រូវបានព្រះអម្ចាស់ត្រាស់ហៅនៅស្រុកអើរ ហើយរំឭកឡើងវិញនៅស្រុកខារ៉ាន (មើលពន្យល់ យរ ១៥:១៩-២១)។

**៧:៤** *ស្រុករបស់សាសន៍ខាល់ដេ* ស្រុកមួយស្ថិតនៅភាគខាងត្បូងនៃស្រុកបាប៊ីឡូន ហើយក្រោយមកក្លាយជាតំបន់មួយ ដែលរួមបញ្ចូលទាំងស្រុកបាប៊ីឡូននេះទាំងមូលផង ។ *លុះក្រោយដែលឪពុកលោកស្លាប់ហើយ* នៅក្នុង "លប ១១:២៦" ពុំមានន័យថាលោកថេរ៉ាបានបង្កើតកូនទាំង៣នាក់ (លោកអ័ប្រាហាំ លោកណាឃរ និងលោកហារ៉ាន) នៅក្នុងឆ្នាំតែមួយក្នុងពេលដែលគាត់មានអាយុ៧០ឆ្នាំនោះទេ (លប ១១:២៦-១២:១)។ លោកថេរ៉ាប្រហែលជាបានបង្កើតកូនទីមួយឈ្មោះលោកហារ៉ាន ហើយ៦០ឆ្នាំក្រោយមក ទើបគាត់បង្កើតបានលោកអ័ប្រាហាំម្នាក់ទៀត ។ ដូច្នេះ លោកអ័ប្រាហាំបានចាកចេញពីស្រុកខារ៉ានក្នុងវ័យ៧៥ឆ្នាំ គឺក្រោយពេលដែលលោកថេរ៉ាជាឪពុករបស់គាត់បានស្លាប់ក្នុងអាយុ២០៥ឆ្នាំ ។

**៧:៦** *គ្រប់៤០០ឆ្នាំ* នេះជារយៈពេលមធ្យមដែលជនជាតិអ៊ីស្រាអែលបានស្នាក់នៅប្រទេសអេស៊ីព្ទ (ក្នុង នក ១២:៤០,៤១ មានរយៈពេល៤៣០ឆ្នាំ)។ ការដែលសន្មតថា៤ជំនាន់គឺតំណាងឱ្យ៤០០ឆ្នាំ នោះពុំមែនជាការសំខាន់ទេ (មើលការពន្យល់ លប ១៥:១៦)។ នៅក្នុង"នក ៦:១៦-២០" បញ្ជាក់ថាលោកម៉ូសេជាចៅទួតរបស់លោកលេវី ដែលជាកូនរបស់លោកយ៉ាកុប និងជាបងប្អូនរបស់លោកយ៉ូសែប ។ ចាប់ពីលោកលេវី រហូតមកដល់លោកម៉ូសេអាចជាបួនជំនាន់ ។ ប៉ុន្តែនៅក្នុង "១ រប ៧:២២-២៧" មានឈ្មោះមនុស្ស១០នាក់ ដែលតំណាងឱ្យ១០ជំនាន់ គឺចន្លោះលោកអេប្រាអិមជាកូនរបស់លោកយ៉ូសែប និងលោកយ៉ូស្វេ ។ បើមួយជំនាន់មានអាយុ៤០ឆ្នាំ ដូច្នេះ ១០ជំនាន់ស្មើនឹង៤០០ឆ្នាំ ដូចគ្នានឹងរយៈពេលដែល បានកត់ត្រាចំពោះ៤ជំនាន់ពីមុនដែរ គ្រាន់តែមួយផ្ដល់នូវព័ត៌មានលំអិត ហើយមួយទៀតនិយាយបែបសង្ខេបតែប៉ុណ្ណោះ ។

**៧:៨** *តាំងសេចក្ដីសញ្ញា ខាងឯការកាត់ស្បែក* (មើលការពន្យល់ លប ១៧:១០,១១) ល័ក្ខខ័ណ្ឌសំខាន់ៗនៃគោលលទ្ធិសម្រាប់ពួកអ៊ីស្រាអែលបានសម្រេចសព្វគ្រប់តាំងពីមុនការសាងសង់ព្រះវិហារ និងទំនៀមទម្លាប់របស់

ដូច្នេះ លោកបង្កើតបានអ៊ីសាក ហើយបានកាត់ស្បែកឱ្យ
នៅថ្ងៃទី៨[ឆ] ឯអ៊ីសាកក៏បង្កើតបាន យ៉ាកុប[ជ] ហើយយ៉ាកុប
បង្កើតពួកព្ធយុកោទាំង១២នាក់[ឈ]។
៩ឯពួកព្ធយុកោទាំងនោះ[ញ] ក៏លក់យ៉ូសែបឱ្យទៅឯស្រុក
អេស៊ីព្ទទៅ[ដ] ដោយមានចិត្តឈ្នានីស តែព្រះទ្រង់គង់ជាមួយ
នឹងលោក[ឋ] ១០ហើយក៏ប្រោសឱ្យលោករួចពីគ្រប់ទាំងសេចក្ដី
វេទនាទាំងអស់វិញ ព្រមទាំងប្រទានឱ្យលោកមានប្រា
ជ្ញាវាងវៃ ហើយឱ្យជាទីគាប់ព្រះទ័យដល់ផារ៉ោន ជា
ស្ដេចស្រុកអេស៊ីព្ទ ដែលតាំងឱ្យលោកធ្វើជាចៅហ្វាយលើ
ស្រុកនោះ នឹងលើព្រះរាជវាំងទាំងមូលផង[ឌ] ១១រីឯនៅ
ស្រុក អេស៊ីព្ទ នឹងស្រុកកាណាន ក៏កើតមានអំណត់អត់បាយ
គ្រប់ កន្លែង មានសេចក្ដីវេទនាជាខ្លាំង ហើយពួកព្ធយុ
កោនៃ យើងរាល់គ្នាគេរកអ្វីនឹងចិញ្ចឹមជីវិតមិនបាន[ឍ]
១២នោះលោកយ៉ាកុបឮថា មានស្រូវនៅស្រុកអេស៊ីព្ទ ក៏ចាត់
ប្រើពួកព្ធយុកោយើង ឱ្យទៅជាជាន់មុនដំបូង[ណ] ១៣លុះដល់
លើកទី២ ទើបលោកយ៉ូសែប បានឱ្យបងប្អូនស្គាល់ខ្លួន[ត]
ហើយផារ៉ោន ក៏បានស្គាល់គ្រួសារ នៃលោកយ៉ូសែប[ថ] ដែរ
១៤រួចលោកយ៉ូសែបប្រើពួកបងប្អូន ឱ្យទៅអញ្ជើញលោក
យ៉ាកុបជាឪពុក នឹងញាតិសន្ដានទាំងប៉ុន្មាន[ទ] មានចំនួន៧៥
នាក់ឱ្យមក[ធ] ១៥ដូច្នេះ លោកយ៉ាកុបក៏ចុះទៅនៅស្រុកអេស៊ីព្ទ
ហើយបានស្លាប់នៅទីនោះ ព្រមទាំងពួកព្ធយុកោយើងដែរ[ន]
១៦គេដង្ហែសពលោក ទៅឯស្រុកស៊ីគែម បញ្ចុះក្នុងផ្នូរដែល
លោកអ័ប្រាហាំបានទិញ ពីពួកកូនចៅហេម័រ ជាអ្នកស្រុក
ស៊ីគែមនោះ[ប]។
១៧កាលជិតដល់កំណត់ នៃសេចក្ដីសន្យា ដែលព្រះបាន
ស្បថនឹងលោកអ័ប្រាហាំហើយ នោះសាសន៍យើងក៏ចំរើន
ជាច្រើនឡើង នៅស្រុកអេស៊ីព្ទ[ផ] ១៨ដរាបដល់មានស្ដេច១
ទៀតសោយរាជ្យឡើង[ព] ដែលមិនបានស្គាល់លោកយ៉ូសែប
ទេ ១៩ស្ដេចនោះប្រព្រឹត្តនឹងសាសន៍យើងដោយឆ្លៀវឆ្លាត
ទាំងធ្វើទុក្ខដល់ពួកព្ធយុកោយើង ដោយបង្ខំឱ្យគេចោល
អស់ទាំងកូនង៉ែតរបស់គេចេញ មិនឱ្យមាននៅរស់ឡើយ[ភ]
២០នៅគ្រានោះ លោកម៉ូសេបានកើតមក ជាកូនយ៉ាង
ស្រស់ល្អដល់ព្រះ គេក៏ចិញ្ចឹមនៅក្នុងផ្ទះឪពុក[ម] អស់៣ខែ
២១កាលគេត្រូវដាក់នៅខាងក្រៅវិញ នោះព្រះរាជបុត្រី
ផារ៉ោនក៏យកទៅចិញ្ចឹមទុកជាកូនបង្កើត[យ] ២២លោកបាន
រៀនសូត្រ គ្រប់អស់ទាំងចំណេះវិជ្ជា នៃសាសន៍អេស៊ីព្ទ[រ]

**៧:៨** ច លប ១៧:៩–១៤ ឆ លប ២១:២–៤ ជ លប ២៥:២៦ ឈ ២៩:៣១–៣៥ ៣០:៥-១៣,១៧–២៤ ៣៥:១៦-១៨,២២-២៦ **៧:៩** ញ លប ៣៧:៤,១១ ដ លប ៣៧:២៨ ទដ ១០៥:១៧ ឋ លប ៣៩:២,២១,២៣ ហក ២:៤ **៧:១០** ឌ លប ៤១:៣៧–៤៣ ទដ ១០៥:២០–២២ **៧:១១** ឍ លប ៤១:៥៤ **៧:១២** ណ លប ៤២:១-២ **៧:១៣** ត លប ៤៥:១–៤ ថ លប ៤៥:១៦ **៧:១៤** ទ លប ៤៥:៩,១០

ធ លប ៤៦:២៦,២៧ នក ១:៥ ចទ ១០:២២ **៧:១៥** ន លប ៤៦:៥–៧ ៤៩:៣៣ នក ១:៦ **៧:១៦** ប លប ២៣:១៦–២០ ៣៣:១៨,១៩ ៥០:១៣ យស ២៤:៣២ **៧:១៧** ផ នក ១:៧ ទដ ១០៥:២៤ **៧:១៨** ព នក ១:៨ **៧:១៩** ភ នក ១:១០–២២ **៧:២០** ម នក ២:២ ហព ១១:២៣ **៧:២១** យ នក ២:៣–១០ **៧:២២** រ ១ពវ ៤:៣០ អស ១៩:១១

ពួកគេនាពេលនោះបានចាប់ផ្ដើមឡើងទៅទៀត ។ *ពួកព្ធយុកោទាំង១២នាក់* (លប ៣៥:២៣–២៦)។

**៧:៩** *ពួកព្ធយុកោទាំងនោះក៏លក់យ៉ូសែប* ពួកអ៊ីស្រាអែលតែងតែបដិសេធអស់អ្នកដែលព្រះអម្ចាស់ទ្រង់ជ្រើសរើស ។ លោកស្ទេផានបានលើកយករឿងរ៉ាវរបស់លោកយ៉ូសែប ដែលត្រូវបងប្អូនបដិសេធ មកធ្វើជាមូលដ្ឋានដើម្បីបង្ហាញអំពីទង្វើដែលពួកគេបដិសេធព្រះយេស៊ូវគ្រីស្ទ (លប ៣៧:១២–៣៦)។

**៧:១៣** *លុះដល់លើកទី២* "មើលការពន្យល់ លប ៤៣"។

**៧:១៤** *យ៉ាកុបជាឪពុក និងញាតិសន្ដានទាំងប៉ុន្មាន មានចំនួន៧៥នាក់* នៅក្នុងព្រះគម្ពីរបរិសុទ្ធ ជាភាសាហេព្រើរ មានចំនួន៧០នាក់ (មើលការពន្យល់ លប ៤៦:២៦–២៧) ប៉ុន្តែ ក្នុងព្រះគម្ពីរបរិសុទ្ធជាភាសាក្រិកដំបូងមានចំនួន៧៥នាក់ ដោយមានរាប់បញ្ចូលត្រង់ "លប ៤៦:២០" នូវឈ្មោះកូនរបស់លោកម៉ាន៉ាសេម្នាក់ និងកូនរបស់លោកអេប្រាអិម២នាក់ ដែលម្នាក់ៗមានកូនមួយ ។ ដូច្នេះចំនួនសរុបគឺ៧៥នាក់ ជាចំនួនដែលលោកស្ទេផានលើកយកមកនិយាយ ។

**៧:១៥–១៦** លោកយ៉ាកុប និងកូនរបស់គាត់ទាំង១២នាក់បានស្លាប់នៅឯប្រទេសអេស៊ីព្ទ ប៉ុន្តែ ធាតុរបស់ពួកគាត់បាននាំមកបញ្ចុះនៅទឹកដីសន្យា (លប ៥០:៤–៩)។

**៧:១៦** លោកស្ទេផានលើកឡើងព្រមគ្នា នូវការពិតក្នុងគម្ពីរសញ្ញាចាស់អំពីដីទិញ២កន្លែង (ដោយលោកអ័ប្រាហាំ និងលោកយ៉ាកុប) និងកន្លែងបញ្ចុះសព២កន្លែង (នៅអេប្រុន និងនៅស៊ីគែម)។ យោងតាមព្រះគម្ពីរសញ្ញាចាស់បានបញ្ជាក់ឱ្យដឹងថា លោកអ័ប្រាហាំបានទិញដីនៅអេប្រុន (លប ២៣:១៧–១៨) ជាកន្លែងដែលគេបញ្ចុះសពគាត់ (លប ២៥:៩–១១) និងអ៊ីសាក (លប ៣៥:២៩) ហើយនិងយ៉ាកុប (លប ៥០:១៣)។ លោកយ៉ាកុបបានទិញដីនៅស៊ីគែម ដែលក្រោយមក យកធ្វើជាកន្លែងបញ្ចុះសពរបស់លោកយ៉ូសែប (យស ២៤:៣២)។ យោងតាមមតិរបស់លោកយ៉ូសែបហ្វីស (Josephus ជាអ្នកប្រវត្តិសាស្ត្រម្នាក់ កើតនៅឆ្នាំ ៣៧ ឬ ៣៨ គស នៅទីក្រុងយេរូសាឡិម) បានអះអាងថា តាមទំនៀមទម្លាប់ បងប្អូនរបស់លោកយ៉ូសែប (កូនលោកយ៉ាកុប) ត្រូវបានគេបញ្ចុះនៅឯអេប្រុនដែរ ។ ការថ្លែងរបស់លោកស្ទេផាន (ដែលថាលោកយ៉ាកុប និងពួកព្ធយុកោទាំង១២ មិនត្រូវបានគេបញ្ចុះនៅប្រទេសអេស៊ីព្ទទេ គឺនៅស្រុកកាណាន) ប្រហែលជាចម្លែកសម្រាប់អ្នកស្ដាប់នាសម័យបច្ចុប្បន្ន ប៉ុន្តែ វាអាចងាយយល់ចំពោះអ្នកស្ដាប់គាត់នាពេលនោះ ។

**៧:១៨** *ស្ដេចមួយទៀត ...មិនបានស្គាល់លោកយ៉ូសែប* "មើលពន្យល់ នក ១:៨"។

**៧:២២** *លោកបានរៀនសូត្រគ្រប់អស់ទាំងចំណេះវិជ្ជា នៃសាសន៍អេស៊ីព្ទ* សេចក្ដីនេះពុំបានបញ្ជាក់ច្បាស់ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ទេ ប៉ុន្តែទោះជាយ៉ាងណាក៏ ដោយក៏អាចសន្និដ្ឋានបានថា លោកម៉ូសេពិតជាមានលក្ខណៈទាំងនោះពិតប្រាកដមែន ព្រោះគាត់បានធំដឹងក្ដីនៅក្នុងគ្រួសាររបស់បុត្រីស្ដេចផារ៉ោន ។ មានប្រវត្តិវិទូ២រូបគឺ លោកភីឡូ និងលោកយ៉ូសែបហ្វីស

ហើយក៏មានពាក្យសំដី និងការធ្វើយ៉ាងចំណាន ។
២៣កាលលោកបានអាយុ៤០ឆ្នាំហើយ នោះមានចិត្តភ្នក
នឹករឭក ចង់ទៅសួរពួកកូនចៅអ៊ីស្រាអែល ជាបងប្អូនខ្លួន
២៤លុះបានឃើញសាសន៍អេស៊ីព្ទម្នាក់ កំពុងតែធ្វើទុក្ខដល់
បងប្អូនខ្លួនម្នាក់ នោះក៏ជួយការពារ ហើយសងសឹកជំនួស
អ្នកដែលត្រូវគេសង្កត់សង្កិន ដោយសំឡាប់សាសន៍អេស៊ីព្ទ
ម្នាក់នោះបង់ ២៥ដ្បិតលោកស្មានថា បងប្អូនលោកនឹងយល់
ថា ព្រះទ្រង់ប្រទានសេចក្ដីសង្គ្រោះមក ដោយសារដៃលោក
តែគេមិនបានយល់ទេ ២៦លុះថ្ងៃក្រោយមក កំពុងដែលមាន
គេប្រឈ្លោះគ្នា នោះលោកមកដល់ ក៏ទូន្មានឱ្យស្រុះស្រួល
នឹងគ្នាវិញ ដោយថា អ្នករាល់គ្នាជាបងប្អូននឹងគ្នា ហេតុអ្វី
បានជាធ្វើបាបគ្នាដូច្នេះ ២៧តែអ្នក១ ដែលកំពុងតែធ្វើ
បាបដល់អ្នកជិតខាង ក៏ច្រានលោកចេញ ដោយពាក្យថា
តើអ្នកណាបានតាំងឱ្យ ឯងធ្វើជាចៅហ្វាយ ហើយជាចៅ
ក្រមលើយើង[ល] ២៨តើចង់សំឡាប់អញ ដូចជាសំឡាប់
សាសន៍អេស៊ីព្ទម្នាក់នោះពីថ្ងៃម្សិលមិញឬអី ២៩កាលឮ
ពាក្យនោះ លោកម៉ូសេក៏រត់ភៀសទៅស្នាក់នៅស្រុកម៉ា
ឌាងទៅ ហើយបង្កើតបានកូនប្រុស២[វ] នៅស្រុកនោះឯង ។
៣០លុះក្រោយមក៤០ឆ្នាំ នោះទេវតានៃព្រះអម្ចាស់
លេចមក ឱ្យលោកម៉ូសេឃើញក្នុងអណ្ដាតភ្លើងដែលឆេះ
នៅគុម្ពបន្លា ត្រង់ទីរហោស្ថានភ្នំស៊ីណាយ ៣១កាលលោក
ឃើញ នោះក៏ឆ្ងល់នឹងការជាក់ស្ដែងនោះ រួចលោក
ចូលទៅជិត ដើម្បីនឹងពិនិត្យមើល ស្រាប់តែឮសំឡេងព្រះ
អម្ចាស់មានបន្ទូលមក[ស]ថា ៣២«អញជាព្រះនៃពួកឰយុកោ
ឯង[ហ] គឺជាព្រះនៃអ័ប្រាហាំ ជាព្រះនៃអ៊ីសាក ហើយជាព្រះ
នៃយ៉ាកុប» ម៉ូសេក៏ញ័ររន្ធត់ មិនហ៊ានមើលឡើយ[ឡ]
៣៣រួចព្រះអម្ចាស់ទ្រង់មានបន្ទូលទៅលោកថា «ចូរដោះ
ស្បែកជើងឯងចេញ ដ្បិតកន្លែងដែលឯងឈរនោះ ជាដី
បរិសុទ្ធ[អ] ៣៤អញបានឃើញសេចក្ដីទុក្ខលំបាក ដែលគេធ្វើ
ដល់រាស្ត្រអញនៅស្រុកអេស៊ីព្ទ ហើយក៏ឮសូរដំងូររបស់គេ
ដែរ ហេតុនោះបានជាអញចុះមក ដើម្បីប្រោសឱ្យគេ
រួច ចូរមកឥឡូវ អញនឹងចាត់ឯងឱ្យទៅឯស្រុកអេស៊ីព្ទ»[ក]
៣៥ឯលោកម៉ូសេនេះ ដែលគេមិនព្រមទទួល ដោយថា
«តើអ្នកណាបានតាំងឱ្យឯងធ្វើជាចៅហ្វាយ ហើយជាចៅ
ក្រមដូច្នេះ»[ខ] គឺលោកនេះហើយ ដែលព្រះបានចាត់ឱ្យ
ទៅធ្វើជាចៅហ្វាយ ហើយជាអ្នកជួយឱ្យរួច ដោយសារ
ព្រះហស្តនៃទេវតា ដែលលេចមកឱ្យលោកឃើញ ក្នុងគុម្ព
បន្លានោះ ៣៦លោកនេះបាននាំគេចេញ ដោយធ្វើការ
អស្ចារ្យ និងទីសំគាល់[គ]នៅស្រុកអេស៊ីព្ទ[ឃ]នៅសមុទ្រក្រហម[ង]
ហើយនៅទីរហោស្ថាន[ច]ក្នុងរវាង៤០ឆ្នាំ ៣៧គឺលោកម៉ូសេ
នេះហើយ ដែលមានប្រសាសន៍ដល់ពួកកូនចៅសាសន៍
អ៊ីស្រាអែលថា ព្រះអម្ចាស់ ដ៏ជាព្រះនៃអ្នករាល់គ្នា ទ្រង់នឹង
បង្កើតហោរាម្នាក់ ពីពួកបងប្អូនអ្នករាល់គ្នាមក ឱ្យដូចជាខ្ញុំ[ឆ]
ត្រូវឱ្យអ្នករាល់គ្នាស្ដាប់តាមហោរានោះចុះ ៣៨គឺលោកនេះ
ឯងដែលបាននៅក្នុងពួកជំនុំ នៅទីរហោស្ថានជាមួយនឹង

**៧:២៧** ល លប ១៩:៩ ជន ១៦:១៣
**៧:២៩** វ នក ២:១១–១៥
**៧:៣១** ស នក ៣:១–៤
**៧:៣២** ហ កច ៣:១៣ ឡ នក ៣:៦
**៧:៣៣** អ នក ៣:៥ យស ៥:១៥
**៧:៣៤** ក នក ៣:៧–១០
**៧:៣៥** ខ ខ.២៧
**៧:៣៦** គ នក ១១:១០ យហ ៤:៤៨ ឃ នក ១២:៤១ ៣៣:១ ង នក ១៤:២១ ច នក ១៥:២៥ ១៧:៥–៦
**៧:៣៧** ឆ ចទ ១៨:១៥,១៨ កច ៣:២២

(Philo and Josephus) បាននិយាយ សរសើរអំពីចំណេះដឹងដ៏ប្រសើររបស់លោកម៉ូសេ ។ *ហើយក៏មានពាក្យសំដី និងការធ្វើយ៉ាងចំណាន* "មើលការពន្យល់ នក ៤:១០"។

**៧:២៣** *កាលលោកបានអាយុ៤០ឆ្នាំហើយ* លោកម៉ូសេមានអាយុ៨០ឆ្នាំនៅពេលដែលព្រះបញ្ជូនគាត់ ឱ្យទៅនិយាយនៅមុខស្ដេចផារ៉ោន (នក ៧:៧)។ គាត់ស្លាប់នៅអាយុ១២០ឆ្នាំ (ចទ ៣៤:៧)។ ពាក្យសំដីរបស់លោកស្ទេផាន ដែលថាលោកម៉ូសេមានអាយុ៤០ឆ្នាំ នៅពេលគាត់ភៀសចេញពីប្រទេសអេស៊ីព្ទជាលើកទី១ គឺជាការត្រឹមត្រូវ ព្រមទាំងស្របគ្នានឹងទំនៀមទម្លាប់របស់ពួកយូដាទៀតផង ។

**៧:២៩** *ភៀសទៅស្នាក់នៅស្រុកម៉ាឌា* លោកម៉ូសេគិតថាពួកគេនឹងនាំយកដំណឹងអំពីការដែលគាត់បានសម្លាប់មនុស្សនោះ ទៅប្រាប់ជនជាតិអេស៊ីព្ទ ដូច្នោះគាត់ក៏ភៀសខ្លួនទៅស្រុកម៉ាឌា ដែលនៅតាមបណ្ដោយសងខាងនៃឈូងសមុទ្រអាកាបា (Aqaba) (មើលការពន្យល់ នក ២:១៥)។ *បង្កើតបានកូនប្រុស២* គឺលោកគើសំម និងលោកអេលាស៊ើរ (១របា ២៣:១៥ នក ២:២២ ១៨:៣–៤)។

**៧:៣០–៣៤** *លុះក្រោយមក៤០ឆ្នាំ* បន្ថែម៤០ឆ្នាំនៅ "ខ.២៣"បានជា៨០ឆ្នាំនៅក្នុង"នក ៧:៧"។ *ភ្នំស៊ីណាយ* ភ្នំនេះនៅក្នុង"នក ៣:១" ហៅថាភ្នំហូរែប (មើលពន្យល់ នក ៣:១)។ លោកម៉ូសេរស់នៅស្រុកម៉ាឌាអស់រយៈពេល ៤០ឆ្នាំ ។ ហើយនៅចុងឆ្នាំទី៤០នោះ គាត់មានអាយុ៨០ឆ្នាំ ។ ទេវតានៃព្រះបានលេចមកឱ្យលោកម៉ូសេឃើញ នាពេលគាត់មានអាយុ៨០ឆ្នាំ (ខ.៣០)។

**៧:៣៥** *ឯលោកម៉ូសេនេះ. . . ដែលព្រះបានចាត់ឱ្យទៅធ្វើជាចៅហ្វាយ ហើយជា អ្នកជួយឱ្យរួច* នាសម័យកាលដែលលោកស្ទេផានថ្លែងការទាំងនោះពួកយូដាបានបដិសេធព្រះគ្រីស្ទ ដូចការដែលពួកអ៊ីស្រាអែលបានបដិសេធលោកម៉ូសេ ជាអ្នកជួយពួកគេឱ្យរួចដូច្នោះដែរ ។ ការដែលត្រូវចងចាំ នោះគឺ លោកម៉ូសេ និង ព្រះគ្រីស្ទត្រូវបានព្រះអម្ចាស់ទ្រង់បញ្ជូនឱ្យមក។ *ទេវតា ដែលលេចមកឱ្យលោក ឃើញក្នុងគុម្ពបន្លា* "មើលការពន្យល់ នក ៣:២"។

**៧:៣៧** *ហោរាម្នាក់ ពីពួកបងប្អូនអ្នករាល់គ្នាមកឱ្យដូចខ្ញុំ* លោកស្ទេផានបានពន្យល់ប្រាប់ពួកក្រុមជំនុំសាសន៍យូដាថា ព្រះយេស៊ូវនេះហើយដែលព្រះបញ្ជូនមក ដើម្បីសង្គ្រោះពួកគេឱ្យរួចផុតពីអំពើបាប ហើយទៅឯទ្រង់វិញ (៣:២២–២៣ មើលការពន្យល់ ចទ ១៨:១៥ ៣៤:១០,១២)។

**៧:៣៨** *ពួកជំនុំ* ពាក្យថា "ពួកជំនុំ" នៅត្រង់ចំណុចនេះសំដៅលើពួកអ៊ីស្រាអែល ។ *ទេវតាដែលមានបន្ទូលនឹងលោក* ពួកយូដាយល់ថាព្រះអម្ចាស់ប្រទានក្រឹត្យវិន័យមកលោកម៉ូសេ តាមរយៈទេវតារបស់ទ្រង់ ទើបក្រោយ

ទេវតា[ជ] ដែលមានបន្ទូលនឹងលោក នៅលើភ្នំស៊ីណាយ
ហើយជាមួយនឹងពួកព្ធយុកោ[ឈ] យើងរាល់គ្នា ដែលបាន
ទទួលព្រះបន្ទូលរស់[ញ] សំរាប់នឹងបន្តមកដល់យើងរាល់គ្នា
ដែរ[ដ] ៣៩តែពួកព្ធយុកោយើងមិនព្រមចុះចូលនឹងលោកទេ
គេ ផាត់លោកចោល ហើយនឹករឭកដល់ស្រុកអេស៊ីព្ទវិញ[ឋ]
៤០ដោយនិយាយនឹងអើរ៉ុនថា «ចូរធ្វើព្រះឱ្យយើងរាល់គ្នា
ដែលនឹងនាំមុខយើងផង ដ្បិតឯលោកម៉ូសេនោះ ដែលនាំ
យើងរាល់គ្នាចេញពីស្រុកអេស៊ីព្ទមក យើងមិនដឹងជាមាន
កើតគ្រោះថ្នាក់អ្វីដល់លោកទេ»[ឌ] ៤១នៅគ្រានោះ គេក៏ធ្វើ
រូបកូនគោ១ រួចថ្វាយយញ្ញបូជាដល់រូបនោះ ហើយនាំ
គ្នាអរសប្បាយចំពោះរបស់ដែលដៃខ្លួនគេបានធ្វើ[ឍ] ៤២នោះ
ព្រះទ្រង់ផ្លាស់ប្រែទៅជាបញ្ជូនគេ[ណ] ឱ្យគោរពប្រតិបត្តិដល់
ពួកបរិវារដែលនៅលើមេឃវិញ[ត] ដូចជាមានសេចក្តីចែង
ទុកមកក្នុងគម្ពីរពួកហោរាថា «ឱពួកវង្សអ៊ីស្រាអែលអើយ
ដែលឯងរាល់គ្នាបានសំឡាប់សត្វ ថ្វាយជាយញ្ញបូជានៅទី
រហោស្ថានក្នុងរវាង៤០ឆ្នាំនោះ ៤៣ព្រមទាំងរើសយកបារាំ
របស់ព្រះម៉ូឡុក នឹងផ្កាយរបស់ព្រះរេមផាន់ ជារូបដែល
ឯងបានធ្វើសំរាប់នឹងថ្វាយបង្គំផង នោះតើបានថ្វាយដល់
អញឬ ដូច្នេះ អញនឹងនិរទេសឯងរាល់គ្នា ឱ្យទៅនៅ
ខាងនាយស្រុកបាប៊ីឡូនវិញ»[ថ]។
៤៤រីឯរោងឧបោសថនៃសេចក្តីបន្ទាល់[ទ] នោះ បាននៅជា
មួយនឹងពួកព្ធយុកោយើងរាល់គ្នានៅទីរហោស្ថាន ដូចជា
ព្រះបានបង្គាប់មក ឱ្យលោកម៉ូសេធ្វើតាមគំរូដែលលោក
បានឃើញ[ធ] ៤៥ពួកព្ធយុកោយើង ក៏ទទួលរោងនោះតៗមក
ហើយបាននាំចូលមកក្នុងស្រុក ជាមួយនឹងលោកយ៉ូស្វេ ក្នុង
កាលដែលគេចាប់យក អស់ទាំងនគររបស់ពួកសាសន៍ដទៃ
ដែលព្រះបានបណ្តេញពីមុខពួកព្ធយុកោយើងចេញ[ន] ដរាប
ដល់រាជ្យហ្លួងដាវីឌ[ប] ៤៦រីឯហ្លួងដាវីឌនេះ ព្រះទ្រង់សព្វព្រះ
ហឫទ័យនឹងទ្រង់ ហើយស្តេចទ្រង់មានព្រះទ័យប្រាថ្នាចង់
រកទីលំនៅសំរាប់ព្រះនៃយ៉ាកុប[ផ] ៤៧តែគឺហ្លួងសាឡូម៉ូន វិញ
ដែលស្អាងដំណាក់១ថ្វាយដល់ព្រះ[ព]។
៤៨ប៉ុន្តែ ឯព្រះដ៏ខ្ពស់បំផុត[ភ] ទ្រង់មិនគង់នៅក្នុងព្រះវិហារ
ដែលដៃមនុស្សធ្វើនោះឡើយ[ម] ដូចជាហោរាបានទាយថា
៤៩«ស្ថានសួគ៌ជាបល្ល័ង្កអញ ហើយផែនដីជាកំណល់កល់ជើង
អញ[យ] ព្រះអម្ចាស់មានបន្ទូលថា តើឯងរាល់គ្នានឹងស្អាង
ដំណាក់ណាឱ្យអញ ឬកន្លែងណា ឱ្យអញឈប់សំរាកបាន
៥០តើមិនមែនដៃអញ ដែលបង្កើតរបស់ទាំងនេះទេ ឬអី»[រ]
៥១ឱពួកមនុស្សក្បាលរឹង[ល] ដែលមានចិត្ត មានត្រចៀកមិន
កាត់ស្បែកអើយ[វ] អ្នករាល់គ្នាចេះតែទាស់ទទឹងនឹងព្រះ
វិញ្ញាណបរិសុទ្ធជាដរាប ពួកព្ធយុកោអ្នករាល់គ្នាយ៉ាង
ណា នោះអ្នករាល់គ្នាក៏យ៉ាងនោះដែរ ៥២តើមានហោរា

**៧:៣៨** ជ ខ.៥៣ ឈ នក ១៩:១៧ លវ ២៧:៣៤ ញ ចទ ៣២:៤៥–៤៧ ហព ៤:១២ ដ រម ៣:២
**៧:៣៩** ឋ ជន ១៤:៣–៤
**៧:៤០** ឌ នក ៣២:១,២៣
**៧:៤១** ឍ នក ៣២:៤–៦ ទដ ១០៦:១៩,២០ វវ ៩:២០
**៧:៤២** ណ យស ២៤:២០ អស ៦៣:១០ ត យរ ១៩:១៣
**៧:៤៣** ថ អម ៥:២៥–២៧
**៧:៤៤** ទ នក ៣៨:២១ ជន ១:៥០ ១៧:៧ ធ នក ២៥:៨,៩,៤០
**៧:៤៥** ន យស ៣:១៤–១៧ ១៨:១ ២៣:៩ ២៤:១៨ ទដ ៤៤:២ ប ២សយ ៧:២,៦
**៧:៤៦** ផ ២សយ ៧:៨–១៦ ១ពវ ៨:១៧ ទដ ១៣២:១–៥
**៧:៤៧** ព ១ពវ ៦:១–៣៨ **៧:៤៨** ភ មក ៥:៧ ម ១ពវ ៨:២៧ ២របា ២:៦
**៧:៤៩** យ មថ ៥:៣៤,៣៥ **៧:៥០** រ អស ៦៦:១,២
**៧:៥១** ល នក ៣២:៩ ៣៣:៣,៥ វ លវ ២៦:៤១ ចទ ១០:១៦ យរ ៤:៤ ៩:២៦

មកហៅថា ក្រឹត្យវិន័យលោកម៉ូសេ (នក ៣:២,៥៣ កទ ៣:១៩ ហព ២:២)។ *បានទទួលព្រះបន្ទូលរស់ សំរាប់នឹងបន្តមកដល់យើងរាល់គ្នា* មានន័យថា ក្រិត្យវិន័យដែលលោកម៉ូសេបានទទួលនៅភ្នំស៊ីណាយ គឺជាព្រះបន្ទូលរស់ ដែលមកអំពីព្រះអម្ចាស់ ។

**៧:៣៩** *ពួកព្ធយុកោយើងមិនព្រមចុះចូលនឹងលោកទេ* មានន័យថាពួកគេទាំងនោះបានបដិសេធបញ្ញត្តិព្រះអម្ចាស់ និងអ្នកបម្រើដែលទ្រង់បញ្ជូនមក ។

**៧:៤០** *ចូរធ្វើព្រះឱ្យយើងរាល់គ្នា* នៅពេលដែលលោកម៉ូសេឡើងទៅលើភ្នំស៊ីណាយ ដើម្បីទទួលក្រឹត្យវិន័យពីព្រះអម្ចាស់ នោះពួកគេនាំគ្នាធ្វើរូបព្រះមួយ (រូបកូនគោមាស)។ ទង្វើនោះជាភស្តុតាងបង្ហាញយ៉ាងច្បាស់ថា ពួកគេពិតជាបានបដិសេធព្រះអម្ចាស់ និងមនុស្សដែលទ្រង់បានចាត់ឱ្យមក (នក ៣២:១)។

**៧:៤២** *ព្រះទ្រង់ផ្លាស់ប្រែទៅជាបញ្ជូនគេ* "មើលពន្យល់ រម ១:២៤"។ *ពួកបរិវារដែលនៅលើមេឃ* "មើលការពន្យល់ យរ ១៩:១៣"។

**៧:៤៣** *ព្រះម៉ូឡុក... ព្រះរេមផាន់* "មើលការពន្យល់ លវ ១៨:២១ អម ៥:២៦"។

**៧:៤៤-៥០** ពួកអ្នកប្រឆាំងបានបៀតបៀនលោកស្ទេផានដោយចោទថា គាត់ពោលពាក្យប្រមាថដល់ទីបរិសុទ្ធ (៦:១៣)។ ដូច្នេះ អាចសន្និដ្ឋានបានថា សេចក្តីដែលលោកស្ទេផានថ្លែងទៅកាន់ពួកគេទាំងនោះ គឺនិយាយអំពីទីបរិសុទ្ធ ។ លោកបាននិយាយថា ការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ គឺជំនួសឱ្យព្រះវិហារដែលសង់ឡើងដោយដៃមនុស្ស ។ ព្រះយេស៊ូវគ្រីស្ទទ្រង់គង់នៅជាមួយរាស្ត្ររបស់ទ្រង់គ្រប់ទីកន្លែង និងគ្រប់ពេលវេលាទាំងអស់ ដូច្នេះ ពួកគេអាចថ្វាយបង្គំទ្រង់នៅទីកន្លែងណាក៏បាន ឱ្យតែសរសើរតម្កើងដល់ព្រះនាមទ្រង់ គឺមិនចាំបាច់តែនៅក្នុងព្រះវិហារនៅឯទីក្រុងយេរូសាឡិមនោះទេ (មើលការពន្យល់ ៦:១៣)។

**៧:៤៤** *រោងឧបោសថនៃសេចក្តីបន្ទាល់* នៅក្នុង "នក ២៥:១៦,២១" ប្រើពាក្យថា "ហឹបនៃសេចក្តីសញ្ញា"។ នៅក្នុងហឹបនៃសេចក្តីសញ្ញានោះមានផ្ទុកបន្ទះថ្មនៃសេចក្តីសញ្ញាពីរ ។

**៧:៤៦** ស្តេចដាវីឌមានបំណងសង់ព្រះវិហារមួយថ្វាយដល់ព្រះអម្ចាស់ (២សយ ៧:១-២) ប៉ុន្តែទ្រង់មានបន្ទូលតាមរយៈលោកហោរាណាថាន់ថា ទ្រង់មិនគង់នៅក្នុងព្រះវិហារនោះទេ ។

**៧:៤៩** លោកស្ទេផានថ្លែងបទគម្ពីរ "អស ៦៦:១,២"នេះ ដើម្បីរំឭកពួកអ៊ីស្រាអែលថា ព្រះអម្ចាស់ទ្រង់បង្កើតព្រះវិហារដោយព្រះហស្តទ្រង់ផ្ទាល់ ។

**៧:៥១** *មានចិត្តមានត្រចៀកមិនកាត់ស្បែក* មានន័យថា ទោះបីពួកគេបានកាត់ស្បែកហើយក៏ដោយ ក៏ទង្វើរបស់ពួកគេទាំងនោះ ដូចជាសាសន៍ដទៃដែលពុំបានកាត់ស្បែកដូច្នោះដែរ ។

**៧:៥២** *ព្រះដ៏សុចរិត* "មើលការពន្យល់ ៣:១៤"។

ណាមួយ ដែលពួកឰយុកោអ្នករាល់គ្នា មិនបានធ្វើទុក្ខ
បៀតបៀន[ស] ហើយគេបានសំឡាប់ពួកអ្នកដែលទាយពី
ដំណើរព្រះដ៏សុចរិតត្រូវយាងមកដែរ ឥឡូវនេះអ្នករាល់
គ្នាក៏បានក្បត់ ហើយសំឡាប់ព្រះអង្គនោះ[ហ] ៥៣អ្នករាល់គ្នា
ជាអ្នកដែលបានទទួលក្រិត្យវិន័យ ដោយព្រះចាត់ថែងពួក
ទេវតា[ឡ]មក តែមិនបានកាន់តាមសោះ ។

## ការចោលលោកស្ទេផានទឹងថ្ម

៥៤កាលបានឮសេចក្ដីទាំងនោះហើយ គេកើតមានចិត្តក្ដៅ
ក្រហាយណាស់[អ] ទាំងសង្កៀតធ្មេញដាក់គាត់ផង ៥៥តែដែល
គាត់បានពេញជាព្រះវិញ្ញាណបរិសុទ្ធ[ក] នោះក៏សំឡឹងមើល
ទៅលើមេឃ ឃើញសិរីល្អនៃព្រះ នឹងព្រះយេស៊ូវឈរនៅ
ខាងព្រះហស្តស្តាំ[ខ] ៥៦រួចគាត់មានវាចាថា មើល ខ្ញុំឃើញ
មេឃចំហ[គ]នឹងកូនមនុស្ស[ឃ]ឈរនៅខាងព្រះហស្តស្តាំនៃព្រះ
៥៧នោះគេក៏ស្រែកឡើងជាខ្លាំង ទាំងចុកត្រចៀក ហើយ
ស្ទុះចូលព្រមគ្នាទៅលើគាត់ ៥៨គេកញ្ឆក់នាំគាត់ចេញទៅ
ខាងក្រៅទីក្រុង[ង]រួចចោលនឹងថ្ម[ច]ឯពួកស្មរបន្ទាល់[ឆ] គេក៏ផ្ញើ
អាវ[ជ]គេដាក់នៅទៀបជើងមនុស្សកំឡោះម្នាក់ឈ្មោះសុល[ឈ]
៥៩គេចោលស្ទេផាននឹងថ្ម កំពុងដែលគាត់ទូលអង្វរដល់
ព្រះថា ឱព្រះអម្ចាស់យេស៊ូវអើយ សូមទទួលវិញ្ញាណ
ទូលបង្គំផង[ញ] ៦០នោះគាត់លុតជង្គង់ចុះ[ដ]រួចស្រែកឡើងជា
សំឡេងខ្លាំងថា ឱព្រះអម្ចាស់អើយ សូមកុំរាប់បាបនេះ
ដល់គេឡើយ[ឋ] កាលគាត់បានពោលដូច្នោះហើយ នោះក៏
ដេកលក់ទៅ[ឌ]ឯសុលក៏យល់ព្រមក្នុងការសំឡាប់គាត់ដែរ ។

## ការបៀតបៀន និងការបែកខ្ញែកនៃពួកជំនុំ

៨ ១នៅថ្ងៃនោះឯង ក៏កើតមានសេចក្ដីបៀតបៀនជាខ្លាំង
ទាស់នឹងពួកជំនុំនៅក្រុងយេរូសាឡិម ហើយពួកជំនុំត្រូវ
ខ្ចាត់ខ្ចាយ[ឍ]ទៅនៅតែពាសក្នុងស្រុកយូដា នឹងស្រុកសាម៉ារី[ណ]
លើកតែពួកសាវកចេញ ២រីឯខ្មោចស្ទេផាន នោះមានពួក
មនុស្សខ្លះដែលកោតខ្លាចដល់ព្រះ បាននាំយកទៅកប់ ព្រម
ទាំងយំសោកនឹងគាត់ជាខ្លាំងផង ៣ឯសុល[ត]បានធ្វើទុក្ខដល់
ពួកជំនុំ[ថ]ខ្លាំងណាស់ ដោយចូលគ្រប់តែផ្ទះ ចាប់ទាញអូស
ទាំងប្រុសទាំងស្រី បញ្ជូនទៅដាក់គុក ។

## លោកភីលីពនៅស្រុកសាម៉ារី

៤ចំណែកអស់អ្នកដែលត្រូវខ្ចាត់ខ្ចាយ[ទ] នោះគេដើរចុះឡើង
ទាំងផ្សាយដំណឹងល្អ[ធ] គឺជាព្រះបន្ទូល ៥ឯភីលីព[ន]គាត់ចុះទៅ
ឯទីក្រុង១នៅស្រុកសាម៉ារី ប្រាប់គេពីព្រះគ្រីស្ទ ៦ហើយ
បណ្ដាមនុស្សក៏ស្រុះចិត្តគ្នា នឹងប្រុងស្ដាប់អស់ទាំងសេចក្ដី
ដែលភីលីពនិយាយ ដោយគេឮ ហើយឃើញទីសំគាល់ដែល
គាត់ធ្វើ ៧ព្រោះ មានអារក្សអសោចិ៍ ដែលបានចូលមនុស្ស
ជាច្រើន[ប] វាស្រែកឡើងជាខ្លាំង រួចចេញមក ក៏មានមនុស្ស
ស្លាប់ដៃ ស្លាប់ជើង នឹងមនុស្សខ្វិនជាច្រើនបានជាដែរ[ផ]
៨ហើយនៅទីក្រុងនោះ គេមានសេចក្ដីអំណរជាខ្លាំង ។

## លោកស៊ីម៉ូនជាគ្រូមន្តអាគម

៩រីឯនៅក្រុងនោះ មានមនុស្សម្នាក់ឈ្មោះ ស៊ីម៉ូន ជា
អ្នកដែលពីដើមនាំឱ្យសាសន៍សាម៉ារីភាន់ភាំង ដោយវិធី

**៧:៥២** ស មថ ៥:១២ ហ កច ៣:១៤ ១ថន ២:១៥ **៧:៥៣** ឡ ខ.៣៨ កទ ៣:១៩ ហព ២:២ **៧:៥៤** អ កច ៥:៣៣ **៧:៥៥** ក លក ១:១៥ ខ មក ១៦:១៩ **៧:៥៦** គ មថ ៣:១៦ ឃ មថ ៨:២០ **៧:៥៨** ង លក ៤:២៩ ច លវ ២៤:១៤,១៦ ឆ ចទ ១៧:៧ ជ កច ២២:២០ ឈ កច ៨:១ **៧:៥៩** ញ ទដ ៣១:៥ លក ២៣:៤៦ **៧:៦០** ដ លក ២២:៤១ កច ៩:៤០ ឋ មថ ៥:៤៤ ឌ មថ ៩:២៤

**៨:១** ឍ ខ.៤ កច ១១:១៩ ណ កច ៩:៣១ **៨:៣** ត កច ៧:៥៨ ថ កច ៩:១,១៣,២១ ២២:៤,១៩ ២៦:១០,១១ ១កថ ១៥:៩ កទ ១:១៣,២៣ ភល ៣:៦ ១ធថ ១:១៣ **៨:៤** ទ ខ.១ ធ កច ១៥:៣៥

**៨:៥** ន កច ៦:៥ ២១:៨ **៨:៧** ប មក ១៦:១៧ ផ មថ ៤:២៤

**៧:៥៣** *ក្រិត្យវិន័យ ដោយព្រះចាត់ថែងពួកទេវតាមក* "មើលពន្យល់ ខ.៣៨"។

**៧:៥៥** *បានពេញជាព្រះវិញ្ញាណបរិសុទ្ធ* "មើលការពន្យល់ ២:៤ ៦:៥"។ *សិរីល្អនៃព្រះ* "មើលការពន្យល់ លក ២:៩"។

**៧:៥៦** *កូនមនុស្ស* "មើលការពន្យល់ មក ៨:៣១"។ *ឈរនៅខាងព្រះហស្តស្តាំព្រះ* "មើលការពន្យល់ ទដ ១១០:១ មក ១៤:៦២ លក ២២:៦៩ ហព ១:២–៣"។

**៧:៥៨** *គេក៏ផ្ញើអាវគេ. . . ឈ្មោះសុល* អ្នកខ្លះយល់ថា លោកសុលជាអ្នកទទួលខុសត្រូវចំពោះការសម្លាប់លោកស្ទេផាន ។ ត្រង់ចំណុចនេះ គឺជាការចាប់ផ្ដើមផ្នែកទី២នៃកណ្ឌគម្ពីរកិច្ចការ (ជំពូក ១៣–២៨)។

**៧:៦០** *សូមកុំរាប់បាបនេះដល់គេ* "សូមប្រៀបធៀបនឹងព្រះបន្ទូលព្រះយេស៊ូវនៅក្នុង "លក ២៣:៣៤"។ *ក៏ដេកលក់ទៅ* "មើលការពន្យល់ យហ ១១:១១"។ *យល់ព្រមក្នុងការសំឡាប់* "មើលការពន្យល់ ២២:២០"។

**៨:១** *ពួកជំនុំត្រូវខ្ចាត់ខ្ចាយ ទៅនៅតែពាស ក្នុងស្រុកយូដា និងស្រុកសាម៉ារី* ព្រះបន្ទូលនៅក្នុង"កច ១:៨"ស្ដីអំពីមហាបេសកកម្ម បានសម្រេចមិនមែនមកអំពីគម្រោងការណ៍របស់ពួកជំនុំទេ ប៉ុន្តែ គឺដោយសារការដឹកនាំរបស់ព្រះអម្ចាស់ ។ *លើកតែពួកសាវកចេញ* មានន័យថា ពួកសាវកត្រូវតែបន្តស្នាក់នៅក្នុងទីក្រុងយេរូសាឡិម ដើម្បីជាការលើកទឹកចិត្តដល់ពួកអ្នកដែលជាប់នៅក្នុងពន្ធនាគារ និងអស់អ្នកដែលត្រូវគេបៀតបៀន ។ ពួកជំនុំនៅគ្រានោះពុំមានបញ្ចេញឈ្មោះឱ្យគេដឹងជាទូទៅទេ ។

**៨:៣** *បានធ្វើទុក្ខដល់ពួកជំនុំខ្លាំងណាស់* ឃ្លានេះនៅក្នុងភាសាក្រិកអាចមានន័យថា "ការបំផ្លាញដ៏សាហាវ" (២២:៤)។

**៨:៤** *ផ្សាយដំណឹងល្អ* មានស្មរបន្ទាល់ជាច្រើនបានចេញទៅប្រកាសដំណឹងល្អនៃសេចក្ដីសង្គ្រោះរបស់ព្រះអម្ចាស់នៅគ្រប់ទីកន្លែង ហើយចំនួនរបស់ពួកគេមានការកើនឡើងជាលំដាប់ ។ ក្រោយមកទៀត ពួកគេបានចេញទៅប្រកាសប្រាប់មនុស្សនៅតាមតំបន់ផ្សេងៗទៀតជាច្រើន (១១:១៩–២០)។

**៨:៥** *ភីលីព* ជាម្នាក់ក្នុងចំណោមពួកទាំង៧នាក់នៃពួកជំនុំនៅទីក្រុងយេរូសាឡិម (៦:៣,៥ មើលការពន្យល់ ៦:៦)។ ក្រោយមក គាត់គឺជាអ្នកប្រកាសដំណឹងល្អម្នាក់ ដែលត្រូវគេបៀបបៀនជាខ្លាំងដែរ (២១:៨)។ *ទីក្រុង១នៅស្រុកសាម៉ារី* នៅក្នុងឯកសារយោងខ្លះប្រើពាក្យថា "រាជធានីនៃស្រុកសាម៉ារី" គឺសំដៅលើរាជធានីចាស់របស់ស្រុកសាម៉ារី ។ ក្រោយមកទីក្រុងនោះមានឈ្មោះថាសីបេស ឬនាប៉ូល (Sebaste or Neapolis កច ១៦:១១)។

**៨:៩** *ស៊ីម៉ូន* ស៊ីម៉ូនម្នាក់នេះត្រូវបានពួកជំនុំដំបូងហៅថា ជាមេប្រឆាំងនឹងអ្នកជឿលើព្រះយេស៊ូវគ្រីស្ទ និងជាគ្រូម្នាក់ ដែលបង្រៀនសេចក្ដីខុសឆ្គង ។ *មន្តអាគម* "មើលការពន្យល់ ២ពវ ១៧:១៧"។

មន្តអាគម[ព] របស់ខ្លួន ទាំងប្រកាសខ្លួនថាជាអ្នកធំណាមួយ[ភ]
១០មនុស្សទាំងឡាយ ចាប់តាំងពីអ្នកតូច រហូតដល់អ្នកធំ
ក៏ប្រុងផ្ទង់ស្ដាប់គាត់ទាំងអស់គ្នា ដោយថា អ្នកនេះពិតជាតួ
ព្រះចេស្ដានៃព្រះដ៏ធំហើយ[ម] ១១គេប្រុងស្ដាប់គាត់ ពីព្រោះ
គាត់នាំឱ្យភាន់ជាយូរមកហើយ ដោយមន្តអាគមរបស់គាត់
១២តែកាលមនុស្សទាំងអស់បានជឿតាមភីលីព ដែលគាត់
ប្រាប់ដំណឹងល្អពីនគរនៃព្រះ[យ] ហើយពីព្រះនាមព្រះយេស៊ូវ
គ្រីស្ទវិញ នោះគេក៏ទទួលបុណ្យជ្រមុជទឹក[រ] ទាំងប្រុសទាំង
ស្រី ១៣ហើយស៊ីម៉ូននោះក៏ជឿដែរ លុះគាត់ទទួលបុណ្យ
ជ្រមុជរួចហើយ នោះក៏នៅជាប់នឹងភីលីព ជាដរាបទៅ
ហើយគាត់កើតមានសេចក្ដីអស្ចារ្យ ដោយបានឃើញទី
សំគាល់ នឹងការឫទ្ធិបារមីជាធំដែលកើតមក[ល]។

១៤កាលពួកសាវក នៅក្រុងយេរូសាឡិមបានឮថា ស្រុក
សាម៉ារី[វ] ទទួលព្រះបន្ទូល[ស] ហើយ នោះគេក៏ចាត់ពេត្រុស
នឹងយ៉ូហាន[ហ] ឱ្យទៅឯពួកអ្នកនោះ ១៥លុះអ្នកទាំង២បាន
ចុះទៅដល់ហើយ នោះក៏អធិស្ឋានឱ្យគេ ប្រយោជន៍ឱ្យគេ
បានទទួលព្រះវិញ្ញាណបរិសុទ្ធ[ឡ] ១៦ដ្បិតព្រះវិញ្ញាណមិនទាន់
ចុះមកសណ្ឋិតលើពួកគេណាមួយនៅឡើយ[អ] គេគ្រាន់តែ
បានទទួលបុណ្យជ្រមុជទឹក ដោយនូវព្រះនាមព្រះអម្ចាស់
យេស៊ូវ[ក] ប៉ុណ្ណោះ ១៧ដូច្នេះ អ្នកទាំង២ក៏ដាក់ដៃលើ[ខ] គេ
ហើយគេបានទទួលព្រះវិញ្ញាណបរិសុទ្ធ[គ] ដែរ ។

១៨កាលស៊ីម៉ូនបានឃើញថា ព្រះវិញ្ញាណបរិសុទ្ធបាន
មកសណ្ឋិត ដោយពួកសាវកដាក់ដៃលើគេដូច្នោះ នោះគាត់
យកប្រាក់មកជូន ដោយពាក្យថា ១៩ សូមឱ្យខ្ញុំមានអំណាច
នេះផង ដើម្បីឱ្យខ្ញុំដាក់ដៃលើអ្នកណា ឱ្យអ្នកនោះបានទទួល
ព្រះវិញ្ញាណបរិសុទ្ធដែរ ២០តែពេត្រុសឆ្លើយតបថា ចូរឱ្យ
ប្រាក់អ្នកវិនាសទៅជាមួយនឹងអ្នកចុះ ព្រោះអ្នកស្មានថា
នឹងយកប្រាក់មកទិញអំណោយទានរបស់ព្រះបានដូច្នេះ[ឃ]
២១អ្នកគ្មានភាគគ្មានចំណែក[ង] ក្នុងការនេះឡើយ ព្រោះចិត្ត
អ្នកមិនស្មោះត្រង់[ច] ចំពោះព្រះទេ ២២ដូច្នេះ ចូរប្រែចិត្ត[ឆ]
ចេញពីសេចក្ដីអាក្រក់នេះចុះ ហើយសូមអង្វរដល់ព្រះ
អម្ចាស់វិញ ក្រែងទ្រង់នឹងអត់ទោសដល់គំនិតក្នុងចិត្ត
អ្នកបាន ២៣ដ្បិតខ្ញុំយល់ឃើញថា អ្នកនៅក្នុងសេចក្ដីជូរ
ល្វីង ហើយក៏ជាប់ដោយចំណងនៃសេចក្ដីទុច្ចរិតផង
២៤ស៊ីម៉ូនឆ្លើយឡើងថា សូមលោកជួយ អង្វរដល់ព្រះអម្ចាស់
ឱ្យខ្ញុំផង[ជ] ដើម្បីកុំឱ្យមានការអ្វីមួយ ដូចលោកមានប្រសាសន៍
នោះ បានកើតមកដល់ខ្ញុំឡើយ ២៥កាលអ្នកទាំង២បានប្រឹង
ធ្វើបន្ទាល់អស់ពីចិត្ត ហើយប្រាប់ព្រះបន្ទូលនៃព្រះអម្ចាស់[ឈ]
រួចហើយ នោះក៏ត្រឡប់ទៅឯក្រុងយេរូសាឡិមវិញ ទាំង
ប្រកាសប្រាប់ដំណឹងល្អ នៅក្នុងភូមិរបស់សាសន៍សាម៉ារី[ញ]
ជាច្រើនតាមផ្លូវរៀងទៅ ។

### លោកភីលីព និងអ្នកកម្រៀវសាសន៍អេធីយ៉ូពី

២៦នោះទេវតា[ដ] នៃព្រះអម្ចាស់ មានបន្ទូលទៅភីលីព[ឋ] ថា
ចូរក្រោកឡើង ទៅឯខាងត្បូង តាមផ្លូវដែលចុះពីក្រុង
យេរូសាឡិម ទៅឯក្រុងកាសា ដែលជាទីរហោស្ថានទៅ។
២៧គាត់ក៏ក្រោកឡើង ដើរទៅ នោះឃើញមានសាសន៍

**៨:៩** ព កច ១៣:៦ ភ កច ៥:៣៦
**៨:១០** ម កច ១៤:១១ ២៨:៦
**៨:១២** យ មថ ៣:២ រ កច ២:៣៨
**៨:១៣** ល ខ.៦ កច ១៩:១១
**៨:១៤** វ ខ.១ ស ហព ៤:១២ ហ លក ២២:៨
**៨:១៥** ឡ យហ ២០:២២
**៨:១៦** អ កច ១០:៤៤ ១៩:២ ក មថ ២៨:១៩ កច ២:៣៨
**៨:១៧** ខ កច ៦:៦ គ យហ ២០:២២
**៨:២០** ឃ ២ពវ ៥:១៦ ដយ ៥:១៧ មថ ១០:៨ កច ២:៣៨
**៨:២១** ង នហ ២:២០ ច ទដ ៧៨:៣៧
**៨:២២** ឆ កច ២:៣៨
**៨:២៤** ជ នក ៨:៨ ជន ២១:៧ ១ពវ ១៣:៦ យរ ៤២:២
**៨:២៥** ឈ កច ១៣:៤៨ ញ ខ.៤០
**៨:២៦** ដ កច ៥:១៩ ឋ កច ៦:៥

**៨:១០** *តួព្រះចេស្ដានៃព្រះដ៏ធំ* មានន័យថា ស៊ីម៉ូនដែលជាគ្រូមន្តអាគមម្នាក់នេះ បានលើកខ្លួនឯងជាអ្នកតំណាងរបស់ព្រះ ឬជាព្រះតែម្ដង ។

**៨:១៣** *ហើយស៊ីម៉ូននោះក៏ជឿដែរ លុះគាត់ទទួលបុណ្យជ្រមុជ* ត្រង់ចំណុចនេះពិបាកនឹងសន្និដ្ឋានអំពីសេចក្ដីជំនឿរបស់គាត់ណាស់ ថាតើជាជំនឿពិតឬមិនពិត ។ លោកលូកានិយាយថា គាត់បានជឿ ។ ប៉ុន្តែ លោកពេត្រុសថា គាត់គ្មានចំណែកអ្វីជាមួយនឹងពួកសាវកទេ ព្រោះចិត្តគាត់មិនស្មោះត្រង់ចំពោះព្រះ (ខ.២១) ។

**៨:១៤** *ស្រុកសាម៉ារី* គឺសំដៅលើពួកអ្នកស្រុកសាម៉ារី (១:៨)។ *ទទួលព្រះបន្ទូល* មានន័យថា ពួកអ្នកស្រុកសាម៉ារី បានទទួលជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ និងស្ដាប់បង្គាប់ព្រះបន្ទូលទ្រង់ តាមរយៈលោកភីលីព ។ *គេចាត់ពេត្រុស និងយ៉ូហាន* ត្រង់ចំណុចនេះបញ្ជាក់ថា នៅក្នុងដំណាក់កាលនោះ ពួកជំនុំនៅឯទីក្រុងយេរូសាឡិម មានទំនួលខុសត្រូវក្នុងការពិនិត្យមើលសកម្មភាពនៃការផ្សាយដំណឹងល្អ និងពួកអ្នកជឿតាមរយៈពួកគេនៅតាមតំបន់ផ្សេងៗ (១១:២២) ។

**៨:១៦** *មិនទាន់ចុះមកសណ្ឋិតលើគេណាមួយនៅឡើយ* ចាប់តាំងពីថ្ងៃបុណ្យទី៥០អស់អ្នកដែលជឿលើព្រះយេស៊ូវគ្រីស្ទ នោះមានព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងគេរួចទៅហើយ (រម ៨:៩) ។ ប៉ុន្តែ នៅពេលនោះ ទីបន្ទាល់នៃព្រះវិញ្ញាណបរិសុទ្ធមិនទាន់បានសំដែងឱ្យពួកអ្នកជឿនៅស្រុកសាម៉ារីឃើញផ្ទាល់នឹងភ្នែកពួកគេនៅឡើយទេ ។

**៨:១៧** *ក៏ដាក់ដៃលើគេ* "មើលពន្យល់ ៦:៦" (ខ.១៨ ១៩:១-៧ ១ធថ ១:៦) ។

**៨:១៨** *នោះគាត់យកប្រាក់មកជូន* ស៊ីម៉ូនម្នាក់នោះធ្លាប់អួតថា ខ្លួនមានព្រះចេស្ដានៃព្រះដ៏ធំ (មើលពន្យល់ ខ.១០) ហើយពេលដែលឃើញពួកសាវកធ្វើការអស្ចារ្យ នោះគាត់ក៏គិតថាពួកគេចេះមន្តអាគម ដូច្នោះហើយទើបគាត់ព្យាយាមយកប្រាក់មកទិញ ដើម្បីឱ្យខ្លួនមានអំណាចដូចពួកគេដែរ ។

**៨:២៣** *នៅក្នុងសេចក្ដីជូរល្វីង* "មើលការពន្យល់ ចទ ២៩:១៨"។ *ក៏ជាប់ដោយចំណងនៃសេចក្ដីទុច្ចរិតផង* "មើលការពន្យល់ រម ៦:២០"។

**៨:២៤** នៅពេលដែលបានឮសំដីរបស់លោកពេត្រុស នោះស៊ីម៉ូនក៏សូមអង្វរឱ្យគាត់ (ពេត្រុស) អធិស្ឋានឱ្យទាំងមានសេចក្ដីភ័យខ្លាចជាខ្លាំង ។

**៨:២៦** *ទេវតានៃព្រះអម្ចាស់* "ខ.២៩ មើលការពន្យល់ ៥:១៩"។ *ពីក្រុងយេរូសាឡិមទៅឯក្រុងកាសា* ពីទីក្រុងយេរូសាឡិមទៅទីក្រុងកាសាមានចម្ងាយប្រហែល៨០,៤គ.ម ។

**៨:២៧** *សាសន៍អេធីយ៉ូពីម្នាក់* ប្រទេសអេធីយ៉ូពីស្ថិតនៅទ្វីបអាហ្វ្រិក (ភាគខាងជើងឆៀងខាងកើត)។ *កានដេស* ពាក្យនេះគ្រាន់តែជាងារមួយរបស់ម្ចាស់ក្សត្រីយ៍នៃប្រទេសអេធីយ៉ូពីនាសម័យនោះប៉ុណ្ណោះ ។ ម្ចាស់ក្សត្រីយ៍

អេធីយ៉ូពីម្នាក់[ឌ] ជាមនុស្សកំរៀវ[ឍ] ដែលមានអំណាចក្រោម
ព្រះនាងកានដេស មហាក្សត្រី ដែលសោយរាជ្យក្នុងស្រុក
អេធីយ៉ូពី លោកជាអ្នកត្រួតត្រាលើអស់ទាំងព្រះរាជទ្រព្យ
របស់ស្ដេច ហើយបានមកឯក្រុងយេរូសាឡិម ដើម្បីនឹង
ថ្វាយបង្គំ[ណ] ២៨លោកកំពុងតែជិះរថត្រឡប់ទៅវិញ ក៏មើល
គម្ពីរហោរាអេសាយ ២៩ខណៈនោះ ព្រះវិញ្ញាណទ្រង់
មានបន្ទូល[ត]ទៅភីលីពថា ឱ្យចូលប្រកៀកនឹងរថនោះទៅ
៣០ភីលីពក៏រត់ទៅតាម ឮលោកកំពុងតែអានមើលគម្ពីរ
ហោរាអេសាយ រួចសួរថា លោកមើលយល់ឬទេ ៣១ឯលោក
ក៏ឆ្លើយឡើងថា បើគ្មានអ្នកណាដឹកនាំខ្ញុំ នោះធ្វើដូចម្ដេច
ឱ្យខ្ញុំយល់បាន រួចលោកក៏សូមឱ្យភីលីពឡើងជិះរថជា
មួយគ្នា ៣២ឯបទគម្ពីរដែលលោកកំពុងតែមើលនោះគឺ
ត្រង់បទនេះថា «ទ្រង់ត្រូវគេដឹកនាំទៅ ដូចជាដឹកចៀម
ទៅសំឡាប់ ទ្រង់មិនបានហើបព្រះឱស្ឋសោះ ដូចជា
កូនចៀមដែលគ នៅមុខអ្នកកាត់រោមវា ៣៣នៅគ្រាដែល
ទ្រង់ត្រូវបន្ទាបបន្ថោក នោះគេបានដកសេចក្ដីយុត្តិធម៌
ចេញពីទ្រង់ទៅ តើអ្នកណានឹងថ្លែងពីព្រះវង្សាទ្រង់
បាន ដ្បិតគេ បានដកព្រះជន្មទ្រង់ ពីផែនដីចេញហើយ»[ថ]
៣៤អ្នកកំរៀវនោះ សួរភីលីពថា ខ្ញុំសូមសួរអ្នក តើហោរា
និយាយដូច្នេះ គឺនិយាយពីអ្នកណា ពីខ្លួនលោក ឬពីអ្នក
ដទៃ ៣៥នោះភីលីព បើកមាត់[ទ] សំដែងប្រាប់ដំណឹងល្អ[ធ] ពី
ព្រះយេស៊ូវចាប់តាំងពីបទគម្ពីរ[ន]នោះរៀងទៅ ៣៦កាលកំ
ពុងតែទៅតាមផ្លូវ នោះឃើញមានទីទឹក ហើយអ្នកកំរៀវ
និយាយថា មើល នុ៎ះន៏ទឹក តើមានអ្វីឃាត់មិនឱ្យខ្ញុំទទួល
បុណ្យជ្រមុជទឹកបាន[ប] ៣៧ភីលីពឆ្លើយថា បើលោកជឿអស់
ពីចិត្ត នោះទទួលបានលោកឆ្លើយឡើងថា ខ្ញុំជឿហើយ
ថាព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ៣៨នោះលោក
បង្គាប់ឱ្យបញ្ឈប់រថ រួចភីលីព នឹងអ្នកកំរៀវ ក៏ចុះទៅក្នុង
ទឹកទាំង២នាក់ ហើយភីលីព គាត់ធ្វើបុណ្យជ្រមុជទឹកឱ្យ
៣៩លុះឡើងពីទឹកមកនោះព្រះវិញ្ញាណនៃព្រះអម្ចាស់ ទ្រង់
ឆក់យកភីលីពបាត់ទៅ[ផ]ហើយអ្នកកំរៀវមិនបានឃើញគាត់
ទៀតទេ ក៏ទៅតាមផ្លូវទៅដោយអរសប្បាយ ៤០ឯភីលីព
គេបានឃើញគាត់នៅក្រុងអាសូតវិញ គាត់ក៏ដើរទៅទាំង
ផ្សាយដំណឹងល្អនៅគ្រប់អស់ទាំងទីក្រុងរៀងទៅ[ព] រហូតទៅ
ដល់ក្រុងសេសារា[ភ]។

## ការប្រែចិត្តរបស់លោកសុល

*៩:១–១៩ = កច ២២:៣–១៦ ២៦:៩–១៨*

**៩** ១ឯសុល គាត់នៅតែបញ្ចេញសេចក្ដីគំរាម និងពាក្យ
កំហែង ព្រមទាំងការសំឡាប់ដល់ពួកសិស្ស[ម]នៃព្រះអម្ចាស់
នៅឡើយ ២ក៏ទៅឯសំដេចសង្ឃ សូមសំបុត្រកាន់យកទៅឯ
សាលាប្រជុំទាំងប៉ុន្មាននៅក្រុងដាម៉ាស[យ]ប្រយោជន៍ដើម្បី

**៨:២៧** ឌ ទដ ៦៨:៣១ ៨៧:៤ សផ ៣:១០ ឍ អស ៥៦:៣–៥ ណ ១ពវ ៨:៤១–៤៣ យហ ១២:២០
**៨:២៩** ត កច ១០:១៩ ១១:១២ ១៣:២ ២០:២៣ ២១:១១
**៨:៣៣** ថ អស ៥៣:៧–៨
**៨:៣៥** ទ មថ ៥:២ ធ កច ១៣:៣២ ន លក ២៤:២៧ កច ១៧:២ ១៨:២៨ ២៨:២៣
**៨:៣៦** ប កច ២:៣៨ ១០:៤៧
**៨:៣៩** ផ ១ពវ ១៨:១២ ២ពវ ២:១៦ អគ ៣:១២, ១៤ ៨:៣ ១១:១,២៤ ៤៣:៥ ២កថ ១២:២ ១ថន ៤:១៧ វវ ១២:៥
**៨:៤០** ព ខ.២៥ ភ កច ១០:១,២៤ ១២:១៩ ២១:៨,១៦ ២៣:២៣,៣៣ ២៥:១,៤,៦,១៣
**៩:១** ម កច ៨:៣ **៩:២** យ អស ១៧:១ យរ ៤៩:២៣

នោះមាននាទីចាត់ចែងរាជកិច្ច (សកម្មភាព ដែលក្សត្រីយ៍ចាត់ចែង ពុំមានអ្នកណាដឹងទេ) ថ្វាយមហាក្សត្រដែលគ្រងរាជ្យ ។ *មកឯក្រុងយេរូសាឡិម ដើម្បីនឹងថ្វាយបង្គំ* ត្រង់ចំណុចនេះបញ្ជាក់ច្បាស់ថា គាត់ជាមនុស្សកម្រៀវ (ចទ ២៣:១) និងជាសាសន៍ដទៃម្នាក់ ដែលគោរពកោតខ្លាចដល់ព្រះអម្ចាស់ (មើលការពន្យល់ ១០:២) ។

**៨:៣០** *ឮលោកកំពុងតែអាន* នៅសម័យនោះ គេមានទម្លាប់អានអក្សរឮសូរសំឡេងខ្លាំងៗ ដូច្នោះហើយបានជាលោកភីលីពអាចឮបទគម្ពីរ ដែលសាសន៍អេធីយ៉ូពីម្នាក់នោះកំពុងតែអាន ។

**៨:៣៤** *តើហោរានិយាយដូច្នេះ គឺនិយាយពីអ្នកណា. . . ?* ត្រង់ចំណុចនេះប្រហែលជាលោកភីលីពថ្លែង ពីការរងទុក្ខរបស់ព្រះមែស៊ីក្នុងបទគម្ពីរ "អស ១១" ដោយយកបទគម្ពីរ "អស ៥៣" ធ្វើជាសេចក្ដីផ្ដើមនៃការសន្ទនារបស់គាត់ជាមួយនឹងអ្នកកម្រៀវនោះ (ខ.៣៥ ដយ ៧:១៣) ។

**៨:៣៥** *ដំណឹងល្អពីព្រះយេស៊ូវ* លោកភីលីពប្រាប់សាសន៍អេធីយ៉ូពីម្នាក់នោះអំពីរបៀបដែលទទួលបានការសង្គ្រោះ គឺតាមរយៈព្រះយេស៊ូវគ្រីស្ទ តែមួយប៉ុណ្ណោះ (មើលការពន្យល់ មក ១:១) ។

**៨:៣៦** *ឃើញមានទីទឹក* ទីកន្លែងដែលលោកភីលីពជ្រមុជទឹកឱ្យអ្នកកម្រៀវនោះអាចជាប្រឡាយនៅតាមជ្រលងភ្នំអេឡា (គឺជាទីកន្លែងដែលស្ដេចដាវីឌឆ្លងទៅប្រយុទ្ធនឹងកូលីយ៉ាត ១សយ ១៧:៤០) ឬប្រហែលជាទីកន្លែងណាមួយដែលមានទឹក នៅក្នុងតំបន់នោះតែម្ដង ។

**៨:៣៩** *ដោយអរសប្បាយ* ក្នុងកណ្ឌគម្ពីរកិច្ចការ "សេចក្ដីអំណរ" មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹង "សេចក្ដីសង្គ្រោះ" (មើលពន្យល់ ១៦:៣៤) ។

**៨:៤០** *ក្រុងអាសូត* ក្នុងសញ្ញាចាស់ប្រើពាក្យថា "អាសដូឌ" (១សយ ៥:១) គឺជាទីក្រុង១ ក្នុងចំណោមទីក្រុង៥ នៃប្រទេសភីលីស្ទីន ។ ទីក្រុងនេះស្ថិតនៅតាមបណ្ដោយឆ្នេរសមុទ្រមេឌីទែរ៉ាណេ ភាគខាងត្បូងក្រុងសេសារា ចម្ងាយប្រហែល ៩៦,៥ គ.ម និងភាគខាងជើងទីក្រុងកាសា ប្រហែល ៣០,៥ គ.ម ។ *ក្រុងសេសារា* ស្ដេចហេរ៉ូឌបានសាងសង់ទីក្រុងនេះឡើងវិញធ្វើជាទីបញ្ជាការធំសម្រាប់ពួកអភិបាលរ៉ូម៉ាំង ។ លោកលូកាពុំបានបញ្ជាក់ថា លោកភីលីពបានធ្វើដំណើរទៅទីកន្លែងណាទៀតទេ ។ ប៉ុន្តែ លោកលូកាបានប្រាប់ថា ២០ឆ្នាំក្រោយមកទៀត លោកភីលីពរស់នៅក្នុងទីក្រុងនេះដដែល (២១:៨) ។

**៩:១** *សុល* លោកសុលបានបង្ហាញខ្លួនច្បាស់ក្នុងពេលដែលគេគប់ដុំថ្មសម្លាប់លោកស្ទេផាន (៧:៥៨) ។ គាត់ជាសាសន៍យូដា កើតនៅក្រុងតើសុស ស្រុកគីលីគា និងជាសិស្សរបស់លោកកាម៉ាលាល (២២:៣ មើលការពន្យល់ ភល ៣:៤–១៤) ។ ក្រៅពីករណីលោកស្ទេផាន ពុំមានអ្នកណាដឹងថា តើលោកសុលពិតជាបានចូលរួមដោយផ្ទាល់ក្នុងគ្រប់ហេតុការណ៍សម្លាប់គ្រីស្ទបរិស័ទដទៃៗទៀត ឬយ៉ាងណានោះទេ (៨:១ ២២:៤ ២៦:១០) ។

**៩:២** *សំដេចសង្ឃ* ប្រហែលសំដៅលើលោកកៃផា (មើលការពន្យល់ ៤:៦) និងពួកក្រុមជំនុំ ដែលមានអំណាចលើពួកយូដា នៅស្រុកយូដា និងតំបន់

បេឃើញមានអ្នកណាខ្លះ ដែលប្រតិបត្តិតាមផ្លូវនោះ[រ] ទោះ
ប្រុសឬស្រីក្តី នោះនឹងចាប់ចងគេ នាំមកឯក្រុងយេរូសាឡិម
៣ប៉ុន្តែ កំពុងដែលគាត់ដើរតាមផ្លូវ ទៅជិតនឹងដល់ក្រុង
ដាម៉ាសហើយ នោះស្រាប់តែមានពន្លឺពីលើមេឃ ភ្លឺមកនៅ
ជុំវិញខ្លួន[ល] ៤គាត់ក៏ដួលដល់ដី រួចឮសំឡេង[វ]មានបន្ទូលមក
ថា សុល នែសុល ហេតុអ្វីបានជាអ្នកបៀតបៀនដល់ខ្ញុំ
ដូច្នេះ ៥គាត់ទូលឆ្លើយថា ឱព្រះអម្ចាស់អើយ ព្រះអង្គណា
នុ៎ះ រួចព្រះអម្ចាស់ទ្រង់តបថា ខ្ញុំនេះជាព្រះយេស៊ូវដែល
អ្នកបៀតបៀន អ្នកធាក់ជល់នឹងជន្លួញដូច្នេះ នោះពិបាក
ដល់អ្នកណាស់ ៦នោះគាត់ក៏ញាប់ញ័រ ទាំងអស្ចារ្យក្នុងចិត្ត
ហើយទូលថា ព្រះអម្ចាស់អើយ តើទ្រង់សព្វព្រះហឫទ័យ
ឱ្យទូលបង្គំធ្វើដូចម្តេចព្រះអម្ចាស់មានបន្ទូលថា ចូរ ក្រោក
ឡើងចូលទៅក្នុងទីក្រុងទៅ នោះគេនឹងប្រាប់អ្នកឱ្យដឹង
ពីការដែលអ្នកត្រូវធ្វើ[ស] ៧ឯពួកអ្នកដែលដើរជាមួយនឹង
គាត់ គេក៏ឈរស្រឡាំងកាំងនៅ ដោយបានឮសំឡេងមែន[ហ]
តែមិនឃើញអ្នកណាសោះ[ឡ] ៨រួចសុលក៏ក្រោកពីដីឡើង
តែកាលគាត់បើកភ្នែកហើយ នោះមើលមិនឃើញអ្វីទេ[អ]
គេក៏ដឹកដៃគាត់នាំទៅឯដាម៉ាស ៩ក្នុងរវាង៣ថ្ងៃគាត់
មើលមិនឃើញឡើយ ក៏មិនបរិភោគអ្វីផង។
១០រីឯនៅក្រុងដាម៉ាស នោះមានសិស្សម្នាក់ឈ្មោះអា
ន៉ានាស ហើយព្រះអម្ចាស់ទ្រង់មានបន្ទូលហៅគាត់ ក្នុង
ការជាក់ស្តែង[ក]ថា នែ អាន៉ានាសអើយ គាត់ទូលឆ្លើយ
ថា ព្រះករុណាវិសេសព្រះអម្ចាស់ ១១ព្រះអម្ចាស់មានបន្ទូល
ថា ចូរក្រោកឡើង ទៅឯផ្លូវដែលហៅថា ផ្លូវត្រង់ ហើយ
រកមនុស្សម្នាក់ឈ្មោះសុល ជាអ្នកស្រុកតើសុស[ខ] នៅក្នុងផ្ទះ
យូដាស ដ្បិតមើល គាត់កំពុងតែអធិស្ឋាន ១២ហើយក្នុងការ
ជាក់ស្តែង គាត់បានឃើញថា មានមនុស្សម្នាក់ ឈ្មោះ
អាន៉ានាស ចូលមកដាក់ដៃលើ[គ]គាត់ ឱ្យបានភ្លឺភ្នែកឡើង
១៣អាន៉ានាសទូលឆ្លើយថា ព្រះអម្ចាស់អើយ ទូលបង្គំបានឮ
មនុស្សជាច្រើន និយាយពីការអាក្រក់ទាំងប៉ុន្មាន ដែល
អ្នកនោះបានប្រព្រឹត្ត ដល់ពួកបរិសុទ្ធ[ឃ]របស់ទ្រង់ នៅក្រុង
យេរូសាឡិម[ង] ១៤ហើយនៅទីនេះ គាត់ក៏មានអំណាចពីពួក
សង្គ្រាជ[ច] អាចនឹងទៅចាប់ចងនូវអ្នកណា ដែលអំពាវនាវ
ដល់ព្រះនាមទ្រង់ដែរ[ឆ] ១៥ប៉ុន្តែ ព្រះអម្ចាស់មានបន្ទូលថា
ចូរទៅចុះ ពីព្រោះអ្នកនោះជាប្រដាប់រើសតាំងដល់ខ្ញុំ[ជ]
សំរាប់នឹងប្រកាសឈ្មោះខ្ញុំ ដល់ពួកសាសន៍ដទៃ[ឈ] និងពួក
ស្តេច[ញ] ហើយនិងពួកកូនចៅសាសន៍អ៊ីស្រាអែលផង ១៦ដ្បិត
ខ្ញុំនឹងបង្ហាញ ឱ្យគាត់ដឹងជាត្រូវរងទុក្ខលំបាកទាំងអម្បាលម៉ាន

**៩:២** រ កច ១៩:៩,២៣ អស ១៧:១ យរ ៤៩:២៣ ២២:៤ ២៤:១៤,២២ **៩:៣** ល ១កថ ១៥:៨ **៩:៤** វ អស ៦:៨ **៩:៦** ស ខ.១៦ អគ ៣:២២ **៩:៧** ហ យហ ១២:២៩ ឡ ដយ ១០:៧ **៩:៨** អ ខ.១៨ **៩:១០** ក កច ១០:៣,១៧,១៩ ១២:៩ ១៦:៩–១០ ១៨:៩ **៩:១១** ខ ខ.៣០ កច ១១:២៥ ២១:៣៩ ២២:៣ **០:១២** គ មថ ៥:២៣ **៩:១៣** ឃ ខ.៣២ កច ២៦:១០ រម ១:៧ ១៥:២៥,២៦,៣១ ១៦:២,១៥ អភ ១:១ ភល ១:១ ង កច ៨:៣ **៩:១៤** ច ខ.២,២១ ឆ កច ២:២១ **៩:១៥** ជ កច ១៣:២ រម ១:១ កទ ១:១៥ ១ធថ ១:១២ ឈ រម ១១:១៣ ១៥:១៥–១៦ កទ ១:១៦ ២:៧,៨ ញ កច ២៥:២២, ២៣ ២៦:១

ផ្សេងៗទៀត ។ *ក្រុងដាម៉ាស* ទីក្រុងនេះពីមុនស្ថិតនៅក្នុងប្រទេសស៊ីរី ក្រោមការត្រួតត្រារបស់ចក្រភពរ៉ូម៉ាំង និងមានជនជាតិយូដារស់នៅច្រើន ។ ពីទីក្រុងដាម៉ាសទៅទីក្រុងយេរូសាឡិមមានចម្ងាយប្រហែល ២៤១ គ.ម ។ *ប្រតិបត្តិតាមផ្លូវនោះ* នេះជាងារមួយដែលគេប្រើសំដៅចំពោះគ្រីស្ទបរិស័ទ (១៦:១៧ ១៨:២៥–២៦ ១៩:៩,២៣ ២២:៤ ២៤:១៤,២២ ២ពត ២:២)។ ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលថាទ្រង់គឺជា "ផ្លូវ" (យហ ១៤:៦)។ *ចាប់ចងគេនាំមកឯក្រុងយេរូសាឡិម* នៅគ្រានោះទីក្រុងយេរូសាឡិមជាកន្លែងដែលពួកក្រុមជំនុំមានអំណាចគ្រប់គ្រាន់ ក្នុងការកាត់សេចក្តីអ្នកទោស ថាគេត្រូវបានរួចខ្លួន ឬត្រូវស្លាប់ ។

**៩:៣** *ពន្លឺពីលើមេឃ* ហេតុការណ៍នេះកើតឡើង ប្រហែលជានៅពេលថ្ងៃត្រង់ (២៦:១៣)។

**៩:៤** *ហេតុអ្វីបានជាអ្នកបៀតបៀនដល់ខ្ញុំដូច្នេះ?* បៀតបៀនពួកជំនុំរបស់ព្រះគ្រីស្ទ គឺមានន័យថាបៀតបៀនដល់ទ្រង់ ព្រោះថាពួកជំនុំទ្រង់គឺជាព្រះកាយទ្រង់ផ្ទាល់ (១កថ ១២:២៧ អភ ១:២២–២៣)។

**៩:៥** *ឱព្រះអម្ចាស់អើយ ព្រះអង្គណានុ៎ះ ?* សំឡេងដែលមានបន្ទូលមកលោកសុល គឺជាសំឡេងរបស់ព្រះអម្ចាស់ ។ ពន្លឺពីលើមេឃដែលភ្លឺមកជុំវិញខ្លួនលោកសុល ធ្វើឱ្យគាត់ដឹងថា គាត់ស្ថិតនៅក្នុងព្រះវត្តមានព្រះអម្ចាស់ ។

**៩:៧** *ឮសំឡេង* ពួកអ្នកនៅជាមួយនឹងលោកសុសក៏បានឮសំឡេងដែលព្រះអម្ចាស់មានព្រះបន្ទូលមកលោកដែរ ប៉ុន្តែ ពុំបានយល់ពីអត្ថន័យដែលទ្រង់មានព្រះបន្ទូលនោះទេ (២២:៩ ដយ ១០:៧)។

**៩:១០** *អាន៉ានាស* នៅសម័យនោះមានគេប្រើឈ្មោះនេះច្រើន ប៉ុន្តែ អាន៉ានាសម្នាក់នេះ ត្រូវបានលើកយកមកនិយាយតែម្តងទៀតប៉ុណ្ណោះ គឺនៅក្នុង "២២:១២"។ ពាក្យនេះមានប្រភពដើមមកពីភាសាហេព្រើរថា "ហាណានា" ដែលមានន័យថា "ព្រះអម្ចាស់ទ្រង់ល្អ" (១ពត ២:៣ មើលការពន្យល់ ដយ ១:៦)។

**៩:១១** *ផ្លូវត្រង់* ប្រហែលជាផ្លូវ (មានបណ្តោយពីលិចទៅកើត) ដែលគាត់ធ្វើដំណើរឆ្ពោះទៅទីក្រុងដាម៉ាសនោះតែម្តង ។ *ស្រុកតើសុស* "មើលការពន្យល់ ២២:៣"។ *អធិស្ឋាន* ក្នុងគម្ពីរលូកា និងគម្ពីរកិច្ចការ សេចក្តីអធិស្ឋានច្រើនមានទំនាក់ទំនងជាមួយនឹងការជាក់ស្តែង (១០:៩–១១ លក ១:១០ ៣:២១ ៩:២៨)។

**៩:១៣,៣២** *ពួកបរិសុទ្ធ* "មើលការពន្យល់ រម ១:៧ ភល ១:១"។

**៩:១៥** *ប្រកាសឈ្មោះខ្ញុំ ដល់ពួកសាសន៍ដទៃ* "មើលការពន្យល់ រម ១:១៣–១៤"។ *ពួកស្តេច* គឺសំដៅលើស្តេចអ័គ្រីប៉ា (២៦:១) និងស្តេចសេសារ នៅឯទីក្រុងរ៉ូម (២៥:១១–១២ ២៨:១៩)។

**៩:១៦** *ឱ្យគាត់ដឹងជាត្រូវរងទុក្ខលំបាកទាំងអម្បាលម៉ាន* "មើលការពន្យល់ ២កថ ១១:១៣-២៨"។

ដោយព្រោះឈ្មោះខ្ញុំ[ដ] [១៧]ដូច្នេះ អាន្នានាសក៏ទៅ ហើយ
ចូលក្នុងផ្ទះនោះ ដាក់ដៃលើ[ឋ]គាត់ និយាយថា អ្នកសុលអើយ
ព្រះអម្ចាស់ គឺព្រះយេស៊ូវ ដែលលេចមកឱ្យអ្នកឃើញ
តាមផ្លូវ ទ្រង់បានចាត់ខ្ញុំមក ដើម្បីឱ្យអ្នកបានភ្លឺភ្នែក ហើយ
ឱ្យអ្នកបានពេញជាព្រះវិញ្ញាណបរិសុទ្ធ[ឌ] [១៨]ស្រាប់តែមាន
ដូចជាស្រកា ជ្រុះចុះពីភ្នែកគាត់មក ហើយគាត់ក៏បានភ្លឺជា
១រំពេច រួចក្រោកឡើងទទួលបុណ្យជ្រមុជទឹក[ឍ] [១៩]ហើយ
ក្រោយដែលគាត់បានបរិភោគ នោះក៏មានកំឡាំងឡើង
វិញ ។

## លោកសុលនៅក្រុងដាម៉ាស និងក្រុងយេរូសាឡិម

[២០]សុលក៏នៅក្រុងដាម៉ាស[ណ]ជាមួយនឹងពួកសិស្ស[ត]ជាយូរ
ថ្ងៃ នោះស្រាប់តែគាត់ប្រកាសប្រាប់ពីព្រះយេស៊ូវ នៅក្នុង
សាលាប្រជុំ[ថ]ទាំងប៉ុន្មានថា ទ្រង់ជាព្រះរាជបុត្រានៃព្រះ[ទ]
[២១]ឯអស់អ្នកដែលឮ ក៏មានសេចក្តីងឿងឆ្ងល់ ហើយគេ
និយាយថា តើមិនមែនអ្នកនេះទេឬអី ដែលបំផ្លាញពួក
អ្នកអំពាវនាវដល់ព្រះនាមនោះ[ធ] នៅក្រុងយេរូសាឡិម
ហើយគាត់បានមកទីនេះ ដើម្បីនឹងចាប់ចងគេ បញ្ជូនទៅ
ឱ្យពួកសង្គ្រាជ[ន]ដែរ [២២]តែសុល គាត់មានកំឡាំងកាន់តែ
ខ្លាំងឡើង ក៏ផ្ចុញផ្ចាល់ដល់ពួកសាសន៍យូដា ដែលនៅក្រុង
ដាម៉ាសវិញ ដោយសំដែងបញ្ជាក់ពីព្រះអង្គនេះថា ទ្រង់ជា

**៩:១៦** ដ កច ២០:២៣ ២១:១១ ២កថ ៦:៤–១០ ១១:២៣–២៧ ២ធថ ១:៨ ២:៣,៩
**៩:១៧** ឋ កច ៦:៦ ឌ លក ១:១៥
**៩:១៨** ឍ កច ២:៣៨
**៩:២០** ណ កច ២៦:២០ ត កច ១១:២៦
**៩:២០** ថ កច ១៣:៥,១៤ ១៤:១ ១៧:២,១០,១៧ ១៨:៤,១៩ ១៩:៨ ទ មថ ៤:៣
**៩:២១** ធ កច ៨:៣ ន ខ.១៤
**៩:២២** ប លក ២:១១ កច ៥:៤២ ១៧:៣ ១៨:៥,២៨
**៩:២៣** ផ កច ២០:៣
**៩:២៤** ព កច ២០:៣,១៩ ២៣:១៦,៣០
**៩:២៥** ភ ១សយ ១៩:១២ ២កថ ១១:៣២–៣៣

ព្រះគ្រីស្ទ[ប]ពិតមែន [២៣]លុះយូរថ្ងៃក្រោយមក ពួកសាសន៍
យូដា គេពិគ្រោះគ្នានឹងសំឡាប់គាត់ចេញ[ផ] [២៤]គេក៏ចាំទ្វារ
ក្រុងទាំងយប់ទាំងថ្ងៃ ដើម្បីនឹងសំឡាប់គាត់ តែសុលបាន
ដឹងពីឧបាយកលរបស់គេដែរ[ព] [២៥]ហើយក្នុងវេលាយប់ ពួក
សិស្សយកកញ្ច្រឹ មកដាក់គាត់ សំរូតចុះតាមកំផែងក្រុងទៅ[ភ]។
[២៦]កាលសុលបានមកដល់ក្រុងយេរូសាឡិម[ម] នោះគាត់
ខំចូលទៅឯពួកសិស្ស តែគេខ្លាចគាត់ទាំងអស់គ្នា គេមិន
ជឿថា គាត់ជាសិស្សទេ [២៧]តែបាណាបាស[យ] នាំគាត់ទៅឯ
ពួកសាវក រ៉ាយរឿងប្រាប់គេ ពីដំណើរដែលគាត់បាន
ឃើញព្រះអម្ចាស់តាមផ្លូវ ហើយទ្រង់បានមានបន្ទូលនឹង
គាត់[រ] ក៏និយាយពីបែបយ៉ាងណា ដែលគាត់មានចិត្តក្លាហាន
នឹងអធិប្បាយ ដោយនូវព្រះនាមព្រះយេស៊ូវ[ល] នៅក្រុង
ដាម៉ាសផង [២៨]គាត់ក៏នៅជាមួយនឹងគេក្នុងក្រុងយេរូសាឡិម
ទាំងចេញចូល ហើយបានអធិប្បាយ ដោយនូវព្រះនាមនៃ
ព្រះអម្ចាស់យេស៊ូវដោយក្លាហាន [២៩]គាត់សំដែង ហើយ
ជជែកជាមួយនឹងពួកហេលេន[វ] តែពួកនោះរករឿងសំ
ឡាប់គាត់វិញ[ស] [៣០]បានជាកាលពួកបងប្អូន[ហ]បានដឹង
នោះគេជូន គាត់ទៅត្រឹមសេសារា[ឡ] រួចឱ្យទៅឯតើសុស[អ]

**៩:២៦** ម កច ២២:១៧ ២៦:២០ កទ ១:១៧–១៨ **៩:២៧** យ កច ៤:៣៦ រ ខ.៣–៦ ល ខ.២០,២២ **៩:២៩** វ កច ៦:១ ស ២កថ ១១:២៦ **៩:៣០** ហ កច ១:១៦ ឡ កច ៨:៤០ អ ខ.១១

**៩:១៧** *គឺព្រះយេស៊ូវ ដែលលេចមកឱ្យអ្នកឃើញ* បទពិសោធន៍ដែលលោកសុលបានទទួល ក្នុងខណៈពេលធ្វើដំណើរទៅទីក្រុងដាម៉ាស ជាព្រះពរមួយសម្រាប់ជីវិតគាត់ ព្រោះព្រះគ្រីស្ទដែលមានព្រះជន្មរស់ពីស្លាប់ឡើងវិញ ទ្រង់បានលេចមកឱ្យគាត់ឃើញ ។ ការនោះហើយ ដែលធ្វើឱ្យគាត់ពិតជាស័ក្តិសមទទួលងារជាសាវ័ករបស់ទ្រង់ (១កថ ១៥:៨ មើលការពន្យល់ ១កថ ៩:១) ។

**៩:១៨-១៩** ក្នុងអំឡុងពេលតែ៣ថ្ងៃប៉ុណ្ណោះ ធ្វើឱ្យលោកសុល ដែលធ្លាប់ជាសត្រូវរបស់ព្រះយេស៊ូវគ្រីស្ទ បានក្លាយជាសាវ័កម្នាក់ដ៏ប្រសើររបស់ទ្រង់ ។

**៩:២០** *នោះស្រាប់តែគាត់ប្រកាសប្រាប់ពីព្រះយេស៊ូវ* ការនេះកើតឡើងបន្ទាប់ពីគាត់បានទទួលបុណ្យជ្រមុជទឹករួចហើយ (ខ.១៨) ។ *សាលាប្រជុំទាំងប៉ុន្មាន* ត្រង់ចំណុចនេះ បញ្ជាក់យ៉ាងច្បាស់ថា លោកសុលបានចាប់ផ្តើមអធិប្បាយព្រះបន្ទូលនៅតាមសាលាប្រជុំនានា (១៣:៥ ១៤:១ ១៧:១,២,១០ ១៨:៤,១៩ ១៩:៨) ។ *ទ្រង់ជាព្រះរាជបុត្រានៃព្រះ* លោកសុលច្រើនអធិប្បាយអំពីហេតុការណ៍កើតឡើងចំពោះរូបគាត់ ក្នុងខណៈពេលធ្វើដំណើរទៅក្រុងដាម៉ាស ដោយប្រកាសយ៉ាងប្រាកដថា ព្រះគ្រីស្ទគឺជាព្រះមែស៊ី ដែលត្រូវយាងមក ដើម្បីសង្គ្រោះមនុស្សនៅលើផែនដីនេះ ឱ្យរួចផុតពីអំណាចនៃសេចក្តីស្លាប់ ។

**៩:២៣** *យូរថ្ងៃក្រោយមក* គឺមានរយៈពេល៣ឆ្នាំ (កទ ១:១៧,១៨) ។ ពេលនោះ ប្រហែលជាលោកសុលចំណាយពេលជាច្រើន នៅក្នុងតំបន់ផ្សេងៗនៃប្រទេសអារ៉ាប់ ព្រោះព្រំប្រទល់នៃប្រទេសនោះមួយផ្នែកជាប់នឹងតំបន់នៃទីក្រុងដាម៉ាស ។ *ពួកសាសន៍យូដា គេពិគ្រោះគ្នានឹងសំឡាប់គាត់ចេញ* ចៅហ្វាយស្រុករបស់ស្តេចអើរេតាស បានឱ្យគេចាំយាមទីក្រុង ក្នុងគោលបំណងចង់ចាប់លោកប៉ុល នៅតាមផ្លូវដែលគាត់ធ្វើដំណើរ ទៅឯទីក្រុងដាម៉ាសនោះ ។ នៅឆ្នាំទី ៣៤ គ.ស រហូតដល់ឆ្នាំទី ៦២ គ.ស គេពុំឃើញមានប្រើប្រាស់ប្រាក់សេនរបស់ពួករ៉ូមុាំង នៅក្នុងទីក្រុងដាម៉ាសទេ ។ ដូច្នេះ នៅក្នុងអំឡុងពេលនោះ ស្តេចអើរេតាសប្រហែលជានៅ មានអំណាចនៅឡើយ ។

**៩:២៥** *ពួកសិស្សយកកញ្ច្រឹមកដាក់គាត់ សំរូតចុះ* (២កថ ១១:៣៣ យស ២:១៥ ១សយ ១៩:១២) ។

**៩:២៦** *សុលបានមកដល់ក្រុងយេរូសាឡិម* តាមរយៈ"កទ ១:១៨-១៩" ឱ្យដឹងថា នៅពេលនោះ ក្នុងចំណោមពួកសាវ័ក មានតែលោកពេត្រុសម្នាក់ទេ ដែលនៅទីក្រុងយេរូសាឡិមដោយមានលោកយ៉ាកុបជាប្អូនរបស់ព្រះយេស៊ូវនៅជាមួយ ។ លោកយ៉ាកុបម្នាក់នេះ មិនមែនជាលោកយ៉ាកុប ដែលនៅក្នុងចំណោមពួកសិស្សទាំង១២នាក់ ដែលព្រះយេស៊ូវបានជ្រើសរើសនោះទេ ប៉ុន្តែ គាត់ក៏ស័ក្តិសមទទួលងារជាសាវ័កម្នាក់ដ៏ល្អផងដែរ (កទ ២:៩) ។

**៩:២៧** *បាណាបាស* "មើលការពន្យល់ ៤:៣៦"។

**៩:២៩** *គាត់សំដែង ហើយជជែក* ពីមុនលោកសុលធ្លាប់ប្រឆាំងនឹងព្រះគ្រីស្ទ ប៉ុន្តែ ឥឡូវនេះគាត់ប្រកាសយ៉ាងក្លាហានថា ទ្រង់ពិតជាព្រះមែស៊ី ។

**៩:៣០** *សេសារា* "មើលការពន្យល់ ៨:៤០"។ *តើសុស* ជាទីកន្លែងកំណើត

៣១ នៅគ្រានោះ ពួកជំនុំទាំងប៉ុន្មាននៅគ្រប់ក្នុងស្រុកយូដា
ស្រុកកាលីឡេ និងស្រុកសាម៉ារី[ក] ក៏មានសេចក្ដីសុខសាន្ត
ហើយមានចិត្តស្អាងឡើង ក៏បានចំរើនជាច្រើនឡើងដែរ[ខ]
ដោយជឿនទៅមុខ ក្នុងសេចក្ដីកោតខ្លាចដល់ព្រះអម្ចាស់
នឹងក្នុងសេចក្ដីកំសាន្តចិត្ត របស់ព្រះវិញ្ញាណបរិសុទ្ធ ។

## អេនាស និងតេប៊ីថា

៣២ រីឯពេត្រុស កំពុងដែលគាត់ដើរចុះឡើងគ្រប់កន្លែង
នោះក៏ចុះទៅឯពួកបរិសុទ្ធ[គ] នៅភូមិលីដាដែរ ៣៣ នៅទីនោះ
គាត់ឃើញមនុស្សម្នាក់ឈ្មោះ អេនាស មានជំងឺឈើស្លាប់ដៃ
ជើង ដេកនៅតែលើគ្រែ អស់៨ឆ្នាំមកហើយ ៣៤ ក៏និយាយ
ទៅគាត់ថា អ្នកអេនាសអើយ ព្រះយេស៊ូវដ៏ជាព្រះគ្រីស្ទទ្រង់
ប្រោសឱ្យអ្នកបានជាហើយ[ឃ] ចូរក្រោកឡើង រៀបគ្រែអ្នក
ទៅ ស្រាប់តែគាត់ក៏ក្រោកឡើងភ្លាម ៣៥ ឯមនុស្សទាំង
ប៉ុន្មាន ដែលនៅភូមិលីដា នឹងស្រុកសារ៉ូន[ង] ក៏ឃើញគាត់
ហើយគេប្រែចិត្តជឿដល់ព្រះអម្ចាស់[ច] ៣៦ នៅក្រុងយ៉ុបប៉េ[ឆ]
ក៏ដែរ មានសិស្សស្រីម្នាក់ ឈ្មោះ តេប៊ីថា (ស្រាយថា នាង
ក្តាន់) នាងនោះបានធ្វើគុណ ហើយដាក់ទានជាច្រើន[ជ]
៣៧ នៅគ្រានោះ នាងមានជំងឺ ឈឺហើយស្លាប់ទៅ កាលគេ
បានផ្ងូតទឹករូបនាងហើយ នោះក៏យកទៅដាក់នៅឯបន្ទប់
ខាងលើ[ឈ] ៣៨ រួចដោយព្រោះ ភូមិលីដានៅជិតយ៉ុបប៉េ
ហើយពួកសិស្ស[ញ] បានឮថា ពេត្រុសនៅទីនោះ បានជាគេ
ប្រើ២នាក់ឱ្យទៅរកគាត់ ដើម្បីនឹងសូមអង្វរ ឱ្យមកឯគេ
ដោយឥតបង្អង់ ៣៩ ពេត្រុសក៏ក្រោកឡើងទៅជាមួយ កាល
បានដល់ហើយ នោះគេនាំគាត់ទៅឯបន្ទប់ខាងលើនោះ
ហើយពួកស្រីមេម៉ាយ[ដ] ក៏ឈរជិតគាត់ ទាំងយំ ព្រមទាំង
បង្ហាញអាវ នឹងសំលៀកបំពាក់ទាំងប៉ុន្មាន ដែលតេប៊ីថា
បានធ្វើឱ្យ ពីកាលនាងនៅជាមួយនៅឡើយ ៤០ តែពេត្រុស
បណ្តេញគេទៅក្រៅទាំងអស់[ឋ] ក៏លុតជង្គង់[ឌ] អធិស្ឋាន រួច
គាត់បែរខ្លួនទៅឯរូបបុគ្គលនោះ និយាយថា តេប៊ីថាអើយ
ចូរនាងក្រោកឡើង[ឍ] នាងក៏បើកភ្នែក ឃើញពេត្រុស រួច
ឡើងអង្គុយ ៤១ គាត់ក៏ហុចដៃទៅឱ្យនាងតោងឡើង រួច
គាត់ហៅពួកបរិសុទ្ធ នឹងពួកស្រីមេម៉ាយមក ប្រគល់នាង
ទៅគេទាំងរស់ ៤២ មនុស្សទាំងឡាយ បានដឹងដំណឹងពីការ
នោះ នៅពេញពាសក្នុងក្រុងយ៉ុបប៉េ ហើយមានមនុស្សជា
ច្រើនបានជឿដល់ព្រះអម្ចាស់[ណ] ៤៣ រួចគាត់ក៏អាស្រ័យនៅ
យ៉ុបប៉េ ក្នុងផ្ទះជាងសំឡាប់ស្បែក ឈ្មោះស៊ីម៉ូនជាយូវថ្ងៃ[ត] ។

**៩:៣១** ក កច ៨:១ ខ កច ២:៤១
**៩:៣២** គ ខ.១៣
**៩:៣៤** ឃ កច ៣:៦,១៦ ៤:១០
**៩:៣៥** ង ១របរ ៥:១៦ ២៧:២៩ បស ២:១ អស ៣៣:៩ ៣៥:២ ៦៥:១០
**៩:៣៥** ច កច ២:៤១
**៩:៣៦** ឆ យស ១៩:៤៦ ២រប ២:១៦ អរ ៣:៧ យណ ១:៣ កច ១០:៥ ជ ១ធថ ២:១០ ទត ៣:៨
**៩:៣៧** ឈ កច ១:១៣ ២០:៨
**៩:៣៨** ញ កច ១១:២៦
**៩:៣៩** ដ កច ៦:១ ១ធថ ៥:៣
**៩:៤០** ឋ មថ ៩:២៥ ឌ លក ២២:៤១ កច ៧:៦០ ឍ លក ៧:១៤
**៩:៤២** ណ កច ២:៤១ **៩:៤៣** ត កច ១០:៦

របស់លោកសុល "មើលការពន្យល់ ២២:៣"។

**៩:៣១** *ពួកជំនុំ* សំដៅលើព្រះកាយរបស់ព្រះគ្រីស្ទទាំងមូល រួមមានគ្រីស្ទបរិស័ទ នៅស្រុកយូដា ស្រុកកាលីឡេ និងស្រុកសាម៉ារីជាដើម (មើលពន្យល់ ៥:១១)។ *សេចក្ដីកំសាន្តចិត្តរបស់ព្រះវិញ្ញាណបរិសុទ្ធ* ព្រះរាជកិច្ចនៃព្រះវិញ្ញាណបរិសុទ្ធ ត្រូវបានកត់សំគាល់ តាមរយៈព្រះគម្ពីរកិច្ចការទាំងមូល (១៣:២ មើលការពន្យល់ ១:២)។ ដូច្នេះហើយ ទើបពេលខ្លះ ព្រះគម្ពីរកិច្ចការ ត្រូវបានគេហៅថាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ។

**៩:៣២** *លីដា* ជាភូមិមួយ ស្ថិតនៅប្រហែល ៤គ.ម ភាគខាងជើងនៃផ្លូវដែលភ្ជាប់រវាងស្រុកយ៉ុបប៉េ និងទីក្រុងយេរូសាឡិម ។ ពីភូមិលីដា (ស្ថិតនៅភាគខាងកើត ស្រុកយ៉ុបប៉េ) ទៅឯស្រុកយ៉ុបប៉េ មានចម្ងាយប្រហែល ១៩,៣ គ.ម ។

**៩:៣៣** *អេនាស* ត្រង់ចំណុចនេះបង្ហាញថា លោកអេនាសប្រហែលជាគ្រីស្ទបរិស័ទម្នាក់ដែរ ។

**៩:៣៥** *ស្រុកសារ៉ូន* គឺជាតំបន់វាលរាបមួយកន្លែងដែលដីមានជីជាតិ ស្ថិតនៅតាមបណ្ដោយឆ្នេរសមុទ្រមេឌីទែរ៉ាណេ និងមានបណ្ដោយប្រហែល ៨០,៤គ.ម ។ សណ្ឋានដីនៅតំបន់នេះ មានសភាពរដិបរដុបចាប់ពីស្រុកយ៉ុបប៉េរហូតដល់ស្រុកសេសារា ។ ឯកសារយោងខ្លះសរសេរថា វាពុំមែនជាស្រុកទេ ប៉ុន្តែជាភូមិមួយស្ថិតនៅក្បែរភូមិលីដា ខ្លះទៀតថា ជាទីក្រុងមួយស្ថិតនៅក្នុងទឹកដីសន្យា ។

**៩:៣៦** *ក្រុងយ៉ុបប៉េ* ជាកំពង់ផែសមុទ្រនៃស្រុកយូដា ស្ថិតនៅប្រហែល៦១ គ.ម ពីទីក្រុងយេរូសាឡិម ។ សព្វថ្ងៃមានឈ្មោះថា ហ្យាហ្វា (Jaffa) ដែលជាតំបន់ជាយក្រុងនៃទីក្រុងតែលអាវៀវ (Tel Aviv ជាទីក្រុងធំទីពីរ នៃប្រទេសអ៊ីស្រាអែល បន្ទាប់ពីទីក្រុងយេរូសាឡិម) ។

**៩:៣៧** *គេបានផ្ងូតទឹករូបនាងហើយ* នេះជាទំនៀមទម្លាប់របស់សាសន៍យូដា និងសាសន៍ក្រិក នៅមុនពេលដែលយកសពទៅបញ្ចុះ ។ *បន្ទប់ខាងលើ* មានន័យថា ប្រសិនបើការបញ្ចុះសពត្រូវពន្យាពេល នោះពួកគេមានទម្លាប់យកសាកសពទៅរក្សាទុកដាក់នៅឯបន្ទប់ខាងលើ ។ នៅឯទីក្រុងយេរូសាឡិម សាកសពត្រូវតែយកទៅបញ្ចុះ នៅក្នុងថ្ងៃដែលបុគ្គលនោះស្លាប់តែម្ដង ប៉ុន្តែនៅតំបន់ផ្សេងៗវិញ គេអាចពន្យាពេលសម្រាប់ការបញ្ចុះសពនោះបានរហូតដល់៣ថ្ងៃ ។

**៩:៣៨** *នៅជិតយ៉ុបប៉េ* "មើលពន្យល់ ខ.៣២"។ *ដោយឥតបង្អង់* ពួកសិស្សបានសូមឱ្យលោកពេត្រុសមកជាប្រញាប់ ឱ្យទាន់មុនពេលបញ្ចុះសព ដើម្បីជាការលើកទឹកចិត្ត ឬធ្វើការអស្ចារ្យ បើជាបំណងព្រះហឫទ័យព្រះអម្ចាស់ ។

**៩:៤០** *ពេត្រុសបណ្តេញគេទៅក្រៅទាំងអស់* (ប្រៀបធៀប ១ពវ ១៧:២៣ ២ពវ ៤:៣៣)។ លោកពេត្រុសបានឃើញហេតុការណ៍៣ដងទាក់ទងនឹងការអស្ចារ្យដែលព្រះយេស៊ូវប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញ ដូចមានចែងទុកក្នុងព្រះគម្ពីរបរិសុទ្ធ (មថ ៩:២៥ លក ៧:១១–១៧ យហ ១១:១–៤៤)។ លោកពេត្រុសបានឱ្យមនុស្សទាំងអស់ចេញពីបន្ទប់ ដូចគ្នានឹងការដែលព្រះយេស៊ូវប្រោសកូនស្រីរបស់លោកយ៉ៃរ៉ុស ឱ្យរស់ពីស្លាប់ឡើងវិញដូច្នោះដែរ ប៉ុន្តែ ចំណុចខុសគ្នាគឺ គាត់ (ពេត្រុស) លុតជង្គង់អធិស្ឋាន ។

**៩:៤២** *មនុស្សជាច្រើនបានជឿដល់ព្រះអម្ចាស់* (ធៀប យហ ១២:១១)។

**៩:៤៣** *ជាងសំឡាប់ស្បែក* ការប្រើប្រាស់ឈ្មោះមុខរបរភ្ជាប់ជាមួយឈ្មោះ

## លោកពេត្រុសជួបជាមួយលោកកូនេលាស

**១០** ១វីឯ នៅក្រុងសេសារា[ថ] មានមនុស្សម្នាក់ ឈ្មោះ
កូនេលាស ជាមេលើកងទ័ព ដែលហៅថា កងទ័ពអ៊ីតាលី
២ជាអ្នកគោរព ហើយកោតខ្លាចដល់ព្រះ[ទ] ព្រមទាំងពួកគ្រួ
លោកទាំងអស់ផង លោកក៏ដាក់ទានជាច្រើនដល់ពួក
ជន ហើយអំពាវនាវដល់ព្រះជានិច្ច ៣លោកបានឃើញ
ការ ជាក់ស្តែង[ធ]យ៉ាងច្បាស់ ប្រហែលជាម៉ោង៣រសៀល[ន]
គឺ បានឃើញទេវតា[ប]នៃព្រះ មកឯលោក ពោលថា កូនេ
លាស អើយ ៤លោកក៏សំឡឹងមើលទៅទេវតា ទាំងភ័យ
ហើយ ឆ្លើយថា ព្រះអម្ចាស់អើយ តើមានការអ្វី ទេវតាប្រាប់
ថា សេចក្តីអធិស្ឋាន នឹងការដាក់ទានរបស់អ្នកបានឡើង
ទៅទុកជាសេចក្តីរំឭក[ផ] នៅចំពោះព្រះ[ព]ហើយ ៥ដូច្នេះ
ចូរអ្នកប្រើគេឱ្យទៅឯយ៉ុបប៉េ[ភ] ហៅស៊ីម៉ូន ដែលមាន
ឈ្មោះថាពេត្រុស ឱ្យមកឥឡូវ ៦គាត់ស្នាក់នៅផ្ទះរបស់
ជាងសំឡាប់ស្បែក[ម]ម្នាក់ឈ្មោះ ស៊ីម៉ូន ដែលនៅក្បែរមាត់
សមុទ្រ អ្នកនោះនឹងប្រាប់ឱ្យអ្នកដឹង ពីការ ដែលអ្នកត្រូវធ្វើ
ជាយ៉ាងណា ៧កាលទេវតា ដែលនិយាយមកលោក
បានចេញទៅបាត់ហើយ នោះលោកហៅអ្នកបំរើ២នាក់
នឹងទាហានម្នាក់ ដែលកោតខ្លាចដល់ព្រះ ពីពួកមនុស្សដែល
តែងតែបំរើលោកឱ្យមក ៨រួចប្រាប់រឿងរ៉ាវសព្វគ្រប់ ហើយ
ប្រើ ឱ្យទៅឯយ៉ុបប៉េ[យ]។

## លោកពេត្រុសឃើញការជាក់ស្តែង

*១០:៩–៣២ = កច ១១:៥–១៤*

៩ដល់ស្អែកឡើង កំពុងដែលពួកអ្នកទាំងនោះដើរទៅជិត
ដល់ទីក្រុងហើយ នោះពេត្រុសក៏ឡើង ទៅលើដំបូលផ្ទះ[រ]
ដើម្បីនឹងអធិស្ឋាន ក្នុងពេលប្រហែលជា ថ្ងៃត្រង់ហើយ
១០គាត់ក៏នឹកឃ្លានជាខ្លាំងចង់បរិភោគ តែកំពុងដែលគេ
ចាត់ចែងឱ្យ នោះគាត់លង់ស្មារតីទៅ[ល] ១១គាត់ឃើញមេឃ
ចំហ[វ] ហើយមានប្រដាប់ ដូចជាសំពត់កំរាលយ៉ាងធំ បាន
ចុះមកចងទាំង៤ជ្រុង សំរូតមកដល់ដី ១២នៅក្នុងសំពត់នោះ
មានសត្វជើង៤ សត្វព្រៃ សត្វលូនវារគ្រប់មុខ ដែលនៅ
លើដី និងសត្វហើរលើអាកាសដែរ ១៣ក៏ឮសំឡេង មាន
បន្ទូលមកថា ពេត្រុសអើយ ចូរក្រោកឡើងសំឡាប់ ហើយ

**១០:១** ថ កច ៨:៤០
**១០:២** ទ ខ.២២,៣៥ កច ១៣:១៦,២៦
**១០:៣** ធ កច ៩:១០ ន ទដ ៥៥:១៧ កច ៣:១ ប កច ៥:១៩
**១០:៤** ផ ទដ ២០:៣ មថ ១០:៤២ ២៦:១៣ ព វវ ៨:៤
**១០:៥** ភ កច ៩:៣៦
**១០:៦** ម កច ៩:៤៣
**១០:៨** យ កច ៩:៣៦
**១០:៩** រ មថ ២៤:១៧
**១០:១០** ល កច ២២:១៧
**១០:១១** វ មថ ៣:១៦

របស់មនុស្ស គឺដើម្បីងាយស្រួលក្នុងការចំណាំបុគ្គលនោះ (១៦:១៤ ១៨:៣ ១៩:២៤ ២ធថ ៤:១៤)។ ប៉ុន្តែ នៅត្រង់ចំណុចនេះ មានការមួយដ៏សំខាន់ ដែលគួរតែគិតពិចារណា ។ មុខរបរជាជាងសម្លាប់ស្បែក ពិតជាមានការ ពាក់ព័ន្ធនឹងការដឹកជញ្ជូនស្បែកសត្វដែលស្លាប់ ហើយមានន័យថា បានទាក់ទងជាមួយនឹងរបស់មិនបរិសុទ្ធ ដូច្នេះ អស់អ្នកដែលប្រកបមុខរបរនេះ មានមនុស្សជាច្រើនស្អប់ខ្ពើម ។ លោកពេត្រុសបានសម្រេចចិត្តស្នាក់នៅជាមួយ ជាងសម្លាប់ស្បែក គឺបង្ហាញអំពីគំនិត ដែលបដិសេធការវិនិច្ឆ័យខុសឆ្គង របស់ពួកសាសន៍យូដារួចទៅហើយ ។ ម្យ៉ាងទៀត វាក៏ជាជំនួយដល់គាត់ផង ដែរ សម្រាប់បេសកកម្មទៅឯសាសន៍ដទៃ ។

**១០:១** *ក្រុងសេសារា* ស្ថិតនៅភាគខាងជើងទីក្រុងយ៉ុបប៉េ ចម្ងាយ៤៨គ.ម ។ គេដាក់ឈ្មោះទីក្រុងនេះយ៉ាងដូច្នេះ គឺដើម្បីថ្វាយកិត្តិយស ដល់អធិរាជសេសារ-អូគូស្ទ ។ ទីក្រុងនេះជាទីបញ្ជាការកងទ័ព និងជាកន្លែងសម្រាប់ពួកអភិបាលរ៉ូម៉ាំង (មើលការពន្យល់ ៨:៤០)។ *កូនេលាស* គឺឈ្មោះជាភាសាឡាតាំង និងត្រូវបានគេនិយមប្រើ នៅពេលដែលលោកកូនេលាស-ស៊ូលឡា (Cornelius Sulla) បានរំដោះទាសករប្រហែល ១០ ០០០ នាក់ ឱ្យមានសេរីភាពឡើងវិញ កាលពី១០០ឆ្នាំមុននោះ ។ ក្រោយមក មានមនុស្សមួយចំនួនបានយកនាមត្រកូលរបស់គាត់មកប្រើ ដូចជាលោកកូនេលាស នៅក្នុងខគម្ពីរនេះជាដើម ។ *ជាមេលើកងទ័ព* គឺជាមេបញ្ជាការដែលមានកងទ័ពយ៉ាងតិចបំផុត ១០០នាក់ (មើលការពន្យល់ មថ ៨:៥)។ កងទ័ពរ៉ូម៉ាំង (ប្រហែល ៦ ០០០ នាក់) ត្រូវបែងចែកជា១០កងវរសេនាធំ ដែលនីមួយៗ មានឈ្មោះសំគាល់ដោយឡែក១ ។ អ្នកដែលមានឋានៈជាមេលើកងទ័ពគឺ ត្រូវមានសមត្ថភាពសមរម្យ និងត្រូវបានជ្រើសរើសដោយប្រុងប្រយ័ត្នបំផុត (លក ៧:៥)។ ភារកិច្ចដ៏សំខាន់របស់ពួកនេះគឺ ផ្តល់នូវស្ថេរភាពឱ្យចក្រភពរ៉ូម៉ាំងគ្រប់ផ្នែកទាំងអស់ ។

**១០:២** *ជាអ្នកគោរព ហើយកោតខ្លាចដល់ព្រះ* មានន័យថា លោកកូនេលាស មិនមែនជាសាសន៍យូដាទេ ប៉ុន្តែ គាត់គឺជាអ្នកជឿ និងគោរពកោតខ្លាចដល់ព្រះ ។ ម្យ៉ាងទៀត ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ទោះបីលោកកូនេលាលបានប្រព្រឹត្តនូវអំពើដ៏សប្បុរសក៏ដោយក៏គាត់ត្រូវការផ្លូវនៃសេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់ តាមរយៈមនុស្សដែលទ្រង់ចាត់ឱ្យមកប្រាប់គាត់ដែរ ។ តួនាទីរបស់ទេវតានាពេលនោះគឺ នាំគាត់ឱ្យបានជួបលោកពេត្រុស (ខ.៣ ៨:២៦ ៩:១០)។

**១០:៣** *ប្រហែលជាម៉ោង៣រសៀល* សម្រាប់សាសន៍យូដា នៅម៉ោង៣រសៀល គឺជាពេលអធិស្ឋាន និងដុតគ្រឿងក្រអូប (៣:១ លក ១:១០)។ *ការជាក់ស្តែង* មិនមែនជាការយល់សប្តិ ឬជាការលង់ស្មារតីនោះទេ ប៉ុន្តែ ជាការបើកសំដែងមកអំពីព្រះអម្ចាស់ ធ្វើឱ្យលោកកូនេលាសដឹងច្បាស់នៅខណៈពេលដែលគាត់កំពុងអធិស្ឋាននោះ (ខ.៣០ មើលការពន្យល់ ៩:១១)។

**១០:៤** *បានឡើងទៅ ទុកជាសេចក្តីរំឭកនៅចំពោះព្រះ* មានន័យថា ការប្រព្រឹត្តិរបស់លោក ប្រៀបបាននឹងក្លិននៃយញ្ញបូជា នៅចំពោះព្រះអម្ចាស់ (ទដ ១៤១:២ ហព ១៣:១៥–១៦ មើលការពន្យល់ ភល ៤:១៨)។

**១០:៥–៦** *ឯយ៉ុបប៉េ.ឈ្មោះស៊ីម៉ូន* "មើលការពន្យល់ ៩:៣៦,៤៣"។

**១០:៩** *ឡើងទៅលើដំបូលផ្ទះ ដើម្បីនឹងអធិស្ឋាន* ពួកគេមានទម្លាប់សង់ផ្ទះ ដែលមានដំបូលរាបស្មើ និងមានជណ្តើរនៅខាងក្រៅផ្ទះ សម្រាប់ឡើងទៅលើដំបូលនោះ ដើម្បីសម្រាក ឬជួបជុំគ្នា (មើលការពន្យល់ មក ២:៤)។

**១០:១០** *លង់ស្មារតីទៅ* នេះជារបៀបមួយដែលព្រះអម្ចាស់មានបន្ទូលមកកាន់លោកពេត្រុស ។ ត្រង់ចំណុចនេះ មិនមែនជាអារម្មណ៍ស្រមើលស្រមៃ ឬជាការយល់សប្តិនោះទេ ប៉ុន្តែ គឺជាការជាក់ស្តែង ដែលព្រះអម្ចាស់ទ្រង់បើកសំដែងឱ្យលោកពេត្រុសបានដឹងជាមុន ។

**១០:១២** *មានសត្វជើងបួន* យោងតាម "លវ ១១" ចំពោះសត្វជើងបួន គឺមាន

# ផែនការនៅក្នុងជីវិតរបស់លោកប៉ុល

គំនូសបំព្រួញនេះបង្ហាញអំពីហេតុការណ៍ដែល
បានកើតឡើងនៅក្នុងជីវិតរបស់លោកប៉ុល



បរិភោគទៅ ១៤តែពេត្រុសប្រកែកថា ទេ ព្រះអម្ចាស់[ស]
ដ្បិតទូលបង្គំ មិនដែលទទួលទានអ្វី ដែលមិនស្អាត មិន
បរិសុទ្ធនោះសោះ[ហ] ១៥រួចឮសំឡេងនោះ មកម្ដងទៀតថា
របស់អ្វី ដែលព្រះបានសំអាតហើយ នោះកុំឱ្យអ្នករាប់ថា
ជាមិនស្អាតឡើយ[ឡ] ១៦ការនោះមានមកគ្រប់៣ដង រួច
បានលើកប្រដាប់នោះ ឡើងទៅលើមេឃវិញ ។
១៧កំពុងដែលពេត្រុសនៅងោងក្នុងខ្លួន ពីន័យការ
ជាក់ស្ដែង[អ] ដែលបានឃើញនោះនៅឡើយ នោះមនុស្ស
៣នាក់ ដែលកូនេលាស[ក]ចាត់ឱ្យមក បានសួររកផ្ទះស៊ីម៉ូន
ក៏ឈរនៅមាត់ទ្វារហើយ ១៨គេកំពុងតែហៅសួរ បើ
មានឈ្មោះស៊ីម៉ូន ដែលហៅថាពេត្រុស នៅផ្ទះនោះឬទេ
១៩ដូច្នេះ កំពុងដែលពេត្រុសគិតរំពឹងពីការជាក់ស្ដែង[ខ]នោះ
ព្រះវិញ្ញាណមានបន្ទូល[គ]មកគាត់ថា មើល មានមនុស្ស៣នាក់
មករកអ្នក ២០ចូរក្រោកឡើងចុះទៅ ហើយទៅជាមួយនឹង
គេចុះ កុំប្រកាន់ឡើយ ពីព្រោះគឺខ្ញុំហើយ ដែលចាត់ ឱ្យគេ
មក[ឃ] ២១ដូច្នេះពេត្រុសក៏ចុះទៅទទួលគេ ដោយពាក្យថា គឺខ្ញុំ
នេះហើយ ដែលអ្នករាល់គ្នារក តើមានការអ្វី ២២គេឆ្លើយ
ឡើងថា លោកមេទ័ពកូនេលាស ដែលជាមនុស្សសុចរិត
ហើយកោតខ្លាចដល់ព្រះ[ង] មានសាសន៍យូដាទាំងអស់ ធ្វើ
បន្ទាល់ល្អឱ្យ លោកបានទទួលបង្គាប់នៃព្រះ ដោយសារ
ទេវតាបរិសុទ្ធ ឱ្យចាត់មកអញ្ជើញលោកគ្រូ ទៅឯផ្ទះលោក
ដើម្បីនឹងបានស្ដាប់លោកគ្រូអធិប្បាយខ្លះ[ច] ២៣ដូច្នេះពេត្រុស
ក៏អញ្ជើញគេ ចូលមកស្នាក់នៅសិន លុះដល់ស្អែក គាត់
ក្រោកឡើងទៅជាមួយនឹងគេ ហើយមានពួកបងប្អូនខ្លះ[ឆ]
ដែលនៅយ៉ុបប៉េ ក៏ទៅជាមួយដែរ[ជ]។

## លោកពេត្រុសនៅឯផ្ទះលោកកូនេលាស

២៤ដល់ស្អែកឡើង គេចូលទៅក្នុងសេសារា[ឈ] ឯកូនេលាស
ក៏ទន្ទឹងមើលផ្លូវគេបានទាំងប្រមូលញាតិសន្តាននិងសំឡាញ់
ស្និទ្ធស្នាលរបស់លោកមកផង ២៥កាលពេត្រុសកំពុងតែ
ចូលទៅ កូនេលាសក៏មករាក់ទាក់ទទួល ដោយក្រាបថ្វាយ
បង្គំនៅទៀបជើងគាត់ ២៦តែ ពេត្រុសលើកលោកឡើង
ដោយពាក្យថា សូមក្រោកឡើង ខ្លួនខ្ញុំជាមនុស្សដូចគ្នា
ដែរ[ញ] ២៧នោះក៏ចូលទៅ ទាំងចរចាគ្នា ហើយឃើញមាន
មនុស្សជាច្រើន[ដ]ប្រជុំចាំ ២៨រួចគាត់និយាយទៅគេថា
អ្នករាល់គ្នាដឹងថា មនុស្សសាសន៍យូដាគ្មានច្បាប់នឹងសេព
គប់នឹងសាសន៍ដទៃ ឬនឹងចូលទៅជិតគេឡើយ[ឋ] តែព្រះ
ទ្រង់បានសំដែងឱ្យខ្ញុំដឹង ថាមិនត្រូវរាប់អ្នកណាថាមិន
ស្អាត ឬមិនបរិសុទ្ធឡើយ[ឌ] ២៩ហេតុនោះបានជាកាល
លោកចាត់គេឱ្យទៅហៅខ្ញុំ នោះខ្ញុំបានមកដោយឥតប្រ
កែកសោះ ដូច្នេះខ្ញុំសូមសួរលោក តើលោកឱ្យខ្ញុំមកមាន
ការអ្វី ៣០កូនេលាសឆ្លើយថា កន្លងមក៤ថ្ងៃហើយ ពេល
ថ្មើរណេះ កាលខ្ញុំកំពុងតែតមហើយអធិស្ឋាននៅផ្ទះខ្ញុំ
ក្នុងពេលម៉ោង៣រសៀល នោះឃើញមានម្នាក់ពាក់អាវ

**១០:១៤** ស កច ៩:៥ ហ លវ ១១:៤–៨, ១៣–២០ ២០:២៥ ចទ ១៤:៣–២០ អគ ៤:១៤
**១០:១៥** ឡ ខ.២៨ លប ៩:៣ មថ ១៥:១១ លក ១១:៤១ កច ១១:៩ រម ១៤:១៤,១៧,២០ ១កថ ១០:២៥ ១ធថ ៤:៣–៤ ទត ១:១៥
**១០:១៧** អ កច ៩:១០ ក ខ.៧,៨
**១០:១៩** ខ កច ៩:១០ គ កច ៨:២៩
**១០:២០** ឃ កច ១៥:៧–៩
**១០:២២** ង ខ.២ ច កច ១១:១៤
**១០:២៣** ឆ កច ១:១៦ ជ ខ.៤៥ កច ១១:១២
**១០:២៤** ឈ កច ៨:៤០
**១០:២៦** ញ កច ១៤:១៥ វវ ១៩:១០ ២២:៨–៩
**១០:២៧** ដ ខ.២៤ **១០:២៨** ឋ យហ ៤:៩ ១៨:២៨ កច ១១:៣ ឌ ខ.១៤,១៥
**១០:៣០** ឍ យហ ២០:១២

ទាំងសត្វស្អាតបរិសុទ្ធ និងសត្វដែលមិនស្អាតមិនបរិសុទ្ធ ។

**១០:១៤** *ទេ ព្រះអម្ចាស់* លោកពេត្រុសធ្លាប់បានប្រតិបត្តិតាមក្រិត្យវិន័យដែលថែងអំពីភាពបរិសុទ្ធ និងមិនបរិសុទ្ធ ហើយសេចក្ដីទាំងនោះបានដក់ជាប់នៅក្នុងចិត្តគំនិតរបស់គាត់ពិបាកនឹងកែប្រែ ដូច្នោះហើយបានជាគាត់ភ្លេចខ្លួន និងនិយាយពាក្យបដិសេធន៍ទៅកាន់ព្រះអម្ចាស់ ។ *មិនស្អាត មិនបរិសុទ្ធ* សំដៅលើអ្វីៗដែលក្រឹត្យវិន័យពុំអនុញ្ញាតឱ្យបរិភោគ (អរ ៤:១៤) ។

**១០:១៥** *អ្វីដែលព្រះបានសំអាតហើយ* មានន័យថា ព្រះយេស៊ូវទ្រង់បានសំអាតរួចជាស្រេចហើយ (មថ ១៥:១១ ១ធថ ៤:៣–៥) ។

**១០:១៦** *គ្រប់៣ដង* គឺធ្វើឱ្យលោកព្រេត្រុសបានដឹងកាន់តែច្បាស់ ។

**១០:២៣** *ពេត្រុសក៏អញ្ជើញគេចូលមកស្នាក់នៅសិន* ដោយការទទួលពួកគេឱ្យស្នាក់អាស្រ័យជាមួយ នោះបង្ហាញថា លោកពេត្រុស បានចាប់ផ្ដើមជំហានទីមួយរបស់គាត់ ទៅឯពួកសាសន៍ដទៃរួចស្រេចទៅហើយ ។ ទង្វើដែលគាត់ធ្វើនោះគឺផ្ទុយនឹងការប្រតិបត្តិរបស់សាសន៍យូដាទាំងស្រុង ។ *លុះដល់ស្អែក* ព្រោះថានៅថ្ងៃនោះជ្រុលពេលណាស់ទៅហើយ សម្រាប់ការធ្វើដំណើរទៅឯទីក្រុងសេសារា (មើលការពន្យល់ ខ.១) ។ *មានពួកបងប្អូនខ្លះ* ពួកទាំងនោះមានចំនួន៦នាក់ (១១:១២) ជាអ្នកជឿដែលកាត់ស្បែក (១០:៤៥ មើលការពន្យល់ ១១:១) ។

**១០:២៦** *ខ្លួនខ្ញុំជាមនុស្សដូចគ្នាដែរ* នៅពេលនោះប្រហែលជាលោកកូនេលាសគ្រាន់តែចង់សំដែងការគោរព ដល់លោកពេត្រុសតែប៉ុណ្ណោះ ។ លោកកូនេលាសធ្វើយ៉ាងដូច្នេះ ព្រោះគាត់ដឹងច្បាស់ថា លោកពេត្រុសគឺជាអ្នកបម្រើដ៏ល្អរបស់ព្រះអម្ចាស់ ។ ប៉ុន្តែ លោកពេត្រុសមិនបណ្ដោយឱ្យមានការភាន់ច្រឡំឡើយ ដោយបញ្ជាក់ថា គាត់ក៏ជាមនុស្ស ដែលព្រះទ្រង់បង្កើតមកដូចគ្នាដែរ (១៤:១១–១៥) ។

**១០:២៨** *ព្រះទ្រង់បានសំដែង ឱ្យខ្ញុំដឹង* ព្រះអម្ចាស់បើកសំដែងឱ្យលោកពេត្រុសដឹងថា សាច់សត្វដែលទ្រង់សំអាតរួចហើយ នោះពិតជាបានជាបរិសុទ្ធ ហើយរនាំងខណ្ឌរវាងសាសន៍យូដា និងសាសន៍ដទៃ ក៏ត្រូវបានកាត់ផ្ដាច់ចេញដែរ (អភ ២:១១–២២) ។

**១០:៣០** *កន្លងមក៤ថ្ងៃហើយ* (១).ថ្ងៃដែលទេវតានៃព្រះមកឯលោកកូនេលាស (២).ថ្ងៃដែលលោកកូនេលាលប្រើគេឱ្យទៅឯទីក្រុងយ៉ុបប៉េ និងជាថ្ងៃដែលលោកពេត្រុសឃើញការជាក់ស្ដែងមកពីព្រះ (៣).ថ្ងៃដែលពួកគេធ្វើដំណើរចេញពីទីក្រុងយ៉ុបប៉េ (៤).ថ្ងៃដែលពួកគេមកដល់ផ្ទះរបស់លោកកូនេលាស ។ *មានម្នាក់ ពាក់អាវដ៏ភ្លឺ* សំដៅលើទេវតា នៅពេលលេចមកឱ្យឃើញក្នុងលក្ខណៈជាមនុស្ស (មថ ២៨:៣ មក ១៦:៥ យហ ២០:១២ មើលការពន្យល់ កច ១:១០) ។

ដ៏ភ្លឺ[ឃ] ឈរនៅមុខខ្ញុំ [៣១]ប្រាប់ថា កូនេលាសអើយ ព្រះបាន
ទទួលសេចក្ដីអធិស្ឋានរបស់អ្នកហើយ ក៏នឹកចាំពីទាន
របស់អ្នកដែរ [៣២]ដូច្នេះ ចូរប្រើគេឱ្យទៅឯយ៉ុបប៉េ អញ្ជើញ
ស៊ីម៉ូន ដែលហៅថាពេត្រុសមក លោកនោះនៅក្នុងផ្ទះ
របស់ជាងសំឡាប់ស្បែកឈ្មោះស៊ីម៉ូន នៅក្បែរមាត់សមុទ្រ
កាលណាលោកបានមកដល់នោះនឹងអធិប្បាយឱ្យអ្នកស្ដាប់
[៣៣]ដូច្នេះ ខ្ញុំបានចាត់គេឱ្យទៅឯលោកភ្លាម ដែលលោក
អញ្ជើញមកនេះក៏ល្អហើយឥឡូវនេះ យើងទាំងអស់នៅ
ចំពោះព្រះ ដើម្បីនឹងស្ដាប់គ្រប់ទាំងសេចក្ដី ដែលព្រះបាន
បង្គាប់មកលោក។

[៣៤]ពេត្រុសក៏បើកមាត់និយាយថា ប្រាកដមែន ខ្ញុំយល់
ឃើញថា ព្រះមិនរើសមុខអ្នកណាទេ[ណ] [៣៥]គឺនៅក្នុងគ្រប់
ទាំងសាសន៍ អស់អ្នកណាដែលកោតខ្លាចដល់ទ្រង់ ព្រមទាំង
ប្រព្រឹត្តសេចក្ដីសុចរិត[ត] នោះគាប់ដល់ព្រះហឫទ័យទ្រង់ដែរ
[៣៦]ឯព្រះបន្ទូល[ថ] ដែលទ្រង់បានផ្សាយ មកដល់ពួកជនជាតិ
អ៊ីស្រាអែល ដោយប្រកាសប្រាប់ដំណឹងល្អ[ទ] ជាសេចក្ដី
មេត្រី[ធ] ដែលមកដោយសារព្រះយេស៊ូវគ្រីស្ទ ដ៏ជាព្រះ
អម្ចាស់លើទាំងអស់[ន] [៣៧]នោះអ្នករាល់គ្នាដឹងស្រាប់ហើយ
គឺជារឿង ដែលបានថ្លែងប្រាប់ ចាប់តាំងពីស្រុកកាលីឡេ
ក្នុងគ្រាក្រោយដែលលោកយ៉ូហាន បានប្រកាសប្រាប់ពី
បុណ្យជ្រមុជទឹក ក៏ផ្សាយមកគ្រប់ក្នុងស្រុកយូដាផង [៣៨]គឺ
ពីព្រះយេស៊ូវ ពីស្រុកណាសារ៉ែត ដែលព្រះបានចាក់[ប]
ព្រះវិញ្ញាណបរិសុទ្ធ និងព្រះចេស្ដា ឱ្យមកសណ្ឋិតលើទ្រង់
ហើយទ្រង់បានយាងចុះឡើងធ្វើការល្អ ព្រមទាំងប្រោស[ផ]
ឱ្យអស់អ្នកដែលត្រូវអារក្សសង្កត់សង្កិនបានជាផង ដ្បិតព្រះ
បានគង់ជាមួយនឹងទ្រង់[ព] [៣៩]ឯយើងរាល់គ្នា ជាទីបន្ទាល់[ភ]
ពីអស់ទាំងការដែលទ្រង់ធ្វើ នៅក្នុងស្រុករបស់ពួកសាសន៍
យូដា ហើយនៅក្រុងយេរូសាឡិម [៤០]គេបានធ្វើគុតទ្រង់
ដោយព្យួរនៅលើឈើ[ម] តែព្រះបានប្រោសឱ្យទ្រង់រស់
ឡើងវិញ[យ] នៅថ្ងៃទី៣ ព្រមទាំងអនុញ្ញាតិឱ្យទ្រង់សំដែងមក
ឱ្យឃើញផង [៤១]មិនមែនឱ្យប្រជាជនទាំងអស់[រ] ឃើញទេ
គឺឱ្យពួកស្មរបន្ទាល់ដែលព្រះបានរើសអំពីមុនមកវិញ គឺ
ជាពួកយើងរាល់គ្នា ដែលបានទទួលទាន[ល] ជាមួយនឹងទ្រង់
ក្នុងពេលក្រោយដែលទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើង
វិញ [៤២]ទ្រង់ក៏ផ្ដាំមកយើងរាល់គ្នា ឱ្យប្រកាសប្រាប់ដល់
បណ្ដាជនទាំងឡាយ[វ] ហើយឱ្យធ្វើបន្ទាល់សព្វគ្រប់ថា គឺ
ព្រះអង្គនេះហើយ ដែលព្រះបានតាំងឡើង ឱ្យជំនុំជំរះ
ដល់ទាំងមនុស្សរស់នឹងមនុស្សស្លាប់ផង[ស] [៤៣]ពួកហោរាសុទ្ធ
តែធ្វើបន្ទាល់ពីទ្រង់[ហ] ថា អស់អ្នកណា[ឡ] ដែលជឿ[អ] ដល់ទ្រង់
នោះបានរួចពីបាប ដោយសារព្រះនាមទ្រង់[ក] [៤៤]កាល
ពេត្រុសកំពុងតែអធិប្បាយនៅឡើយ នោះព្រះវិញ្ញាណ

**១០:៣៤** ណ ចទ ១០:១៧ ២របា ១៩:៧ យប ៣៤:១៩ មក ១២:១៤ រម ២:១១ កទ ២:៦ អភ ៦:៩ កល ៣:២៥ យក ២:១ ១ពត ១:១៧ **១០:៣៥** ត កច ១៥:៩ **១០:៣៦** ថ ១យហ ១:៥ ទ កច ១៣:៣២ ធ លក ២:១៤ ន មថ ២៨:១៨ **១០:៣៨** ប កច ៤:២៦ ផ មថ ៤:២៣ ព យហ ៣:២ **១០:៣៩** ភ ខ.៤១ លក ២៤:៤៨ **១០:៤០** ម កច ៥:៣០ យ កច ២:២៤ **១០:៤១** រ យហ ១៤:១៧,២២ ល លក ២៤:៤៣ យហ ២១:១៣ កច ១:៤ **១០:៤២** វ មថ ២៨:១៩,២០ ស យហ ៥:២២ កច ១៧:៣១ រម ១៤:៩ ២កថ ៥:១០ ២ធថ ៤:១ ១ពត ៤:៥ **១០:៤៣** ហ អស ៥៣:១១ កច២៦:២២ ឡ កច ១៥:៩ អ យហ ៣:១៥ ក លក ២៤:២៧

**១០:៣៤** *ព្រះមិនរើសមុខអ្នកណាទេ* ព្រះអម្ចាស់សព្វព្រះហឫទ័យមនុស្សម្នាក់ៗមិនមែនដោយព្រោះគេមានឋានៈខ្ពស់ក្នុងសង្គម ឬមានទ្រព្យសម្បត្តិនោះទេ (រម ២:១១ ចទ ១០:១៧-១៩ ២កថ ១៩:១៧ យប ៣៤:១៩ អភ ៦:៩ កល ៣:២៥ ១ពត ១:១៧ មើលការពន្យល់ យក ២:១)។ ផ្ទុយទៅវិញគឺទ្រង់សព្វព្រះហឫទ័យ ចំពោះចរិតលក្ខណៈ និងការប្រព្រឹត្តិរបស់ពួកគេម្នាក់ៗវិញ ។ ទាំងនេះជាភស្តុតាងដែលបញ្ជាក់ថា អ្នកណាគោរពកោតខ្លាចដល់ព្រះអម្ចាស់ និងប្រព្រឹត្តតាមផ្លូវសុចរិតនៃទ្រង់ នោះពិតជាបានគាប់ព្រះហឫទ័យទ្រង់ហើយ(ខ.៣៥)។ លោកកូនេលាស បានថ្វាយបង្គំព្រះដ៏ពិតរៀងរហូតមក ប៉ុន្តែ នៅខ្វះការមួយទៀតនៅក្នុងជីវិតរបស់គាត់ ដើម្បីឱ្យបានសង្គ្រោះនោះគឺសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ (ខ.៣៦)។

**១០:៣៦** *ពួកជនជាតិអ៊ីស្រាអែល* ជាជាតិសាសន៍ដែលបានទទួលព្រះបន្ទូលព្រះមុនគេ។ ព្រះបន្ទូលនោះមិនមែនសម្រាប់ ឬចំពោះតែពួកអ៊ីស្រាអែលទេ គឺសម្រាប់មនុស្សទាំងអស់ ដូចមានចែងនៅក្នុងបទគម្ពីរ "យហ ៣:១៦ និង រម ១:១៦" ថា "ព្រះអម្ចាស់លើទាំងអស់"។ *សេចក្ដីមេត្រី* នៅក្នុងព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេស ប្រើពាក្យថា "សេចក្ដីសុខសាន្ត ឬសន្តិភាព"។ មានន័យថា ព្រះអម្ចាស់ទ្រង់មានព្រះហឫទ័យចង់ឱ្យមនុស្សដែលទ្រង់បង្កើតមក មានសេចក្ដីសុខសាន្ត ក្រោមការដឹកនាំរបស់ទ្រង់ (មើលការពន្យល់ រម ៥:១)។ *ព្រះអម្ចាស់ លើទាំងអស់* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់ជាព្រះលើគ្រប់ទាំងអស់ គឺទាំងសាសន៍យូដា និងសាសន៍ដទៃផង (ខ.៣៤-៣៥)។

**១០:៣៧** *ក្រោយដែលលោកយ៉ូហាន បានប្រកាសប្រាប់ពីបុណ្យជ្រមុជទឹក* ការអធិប្បាយរបស់លោកពេត្រុសនៅត្រង់ចំណុចនេះ មានភាពស្រដៀងគ្នាទៅនឹងគម្ពីរដំណឹងល្អម៉ាកុសដែរ គឺចាប់ផ្ដើមដោយនិយាយអំពីពិធីជ្រមុជទឹករបស់លោកយ៉ូហាន ហើយបន្តទៅនិយាយអំពីការរស់ពីសុគតវិញរបស់ព្រះយេស៊ូវ ។ តាមរយៈការយល់ឃើញរបស់ពួកជំនុំដំបូងថា លោកម៉ាកុសគឺជាអ្នកបកប្រែឱ្យលោកពេត្រុស (មើលសេចក្ដីផ្ដើមគម្ពីរម៉ាកុស ចំណុចអ្នកនិពន្ធ)។ ចំពោះសេចក្ដីសង្ខេបនៃការអធិប្បាយរបស់លោកពេត្រុស សូមមើល "២:១៤-៤១ ៣:១២-២៦ និងការពន្យល់ ២:១៤-៤០"។

**១០:៣៨** *ដែលព្រះបានចាក់ព្រះវិញ្ញាណបរិសុទ្ធ នឹងព្រះចេស្ដាឱ្យមកសណ្ឋិតលើទ្រង់* "មើលការពន្យល់ អស ៦១:១-៣ លក ៤:១៨-២១"។

**១០:៤០** *គេបានធ្វើគុតទ្រង់ ដោយព្យួរនៅលើឈើ* "មើលពន្យល់ ៥:៣០"។

**១០:៤១** *ដែលបានទទួលទានជាមួយនឹងទ្រង់* សំដៅលើពួកអ្នកដែលបានទទួលទានជាមួយព្រះយេស៊ូវ និងបានឃើញព្រះកាយទ្រង់ បន្ទាប់ពីទ្រង់រស់ពីសុគតឡើងវិញ (លក ២៤:៤២-៤៣ យហ ២១:១២-១៥)។

**១០:៤៤** *ព្រះវិញ្ញាណបរិសុទ្ធក៏យាងចុះមកសណ្ឋិតលើ* "មើលការពន្យល់ ៨:១៦"។

បរិសុទ្ធ ក៏យាងចុះមកសណ្ឋិត[ខ] លើអស់អ្នកដែលកំពុងតែ
ស្តាប់ព្រះបន្ទូល ៤៥ឯពួកអ្នកជឿ ក្នុងពួកកាត់ស្បែកទាំង
ប៉ុន្មានដែលមកជាមួយនឹងពេត្រុស[គ] គេក៏មានសេចក្តីអស្ចារ្យ
ជាខ្លាំង ពីដំណើរដែលអំណោយទាន ជាព្រះវិញ្ញាណ
បរិសុទ្ធ បានចាក់មកលើ[ឃ] ពួកសាសន៍ដទៃ[ង] ដូច្នេះដែរ
៤៦ដ្បិតគេឮអ្នកទាំងនោះនិយាយភាសាដទៃ[ច] ហើយសរសើរ
ដំកើងដល់ព្រះ ៤៧នោះពេត្រុសសួរថា តើមានអ្នកណាអាច
នឹងឃាត់ មិនឱ្យធ្វើបុណ្យជ្រមុជទឹក ដល់អ្នកទាំងនេះបាន
ឬទេ[ឆ] ដែលពួកគេបានទទួលព្រះវិញ្ញាណបរិសុទ្ធ ដូចជា
យើងដែរ[ជ] ៤៨គាត់ក៏បង្គាប់ ឱ្យធ្វើបុណ្យជ្រមុជឱ្យគេ ដោយ
នូវព្រះនាមព្រះអម្ចាស់[ឈ] រួចគេសូមអង្វរគាត់ ឱ្យនៅជា
មួយ ពីរបីថ្ងៃទៀត ។

## សេចក្តីពន្យល់របស់លោកពេត្រុស

**១១** ១ឯពួកសាវក នឹងពួកបងប្អូន[ញ] ដែលនៅស្រុកយូដា
គេក៏ឮថា សាសន៍ដទៃបានទទួលព្រះបន្ទូល[ដ]ដែរ ២រួចកាល
ពេត្រុសឡើងទៅឯក្រុងយេរូសាឡិម នោះអស់អ្នកខាងពួក
កាត់ស្បែក[ឋ] គេមានសេចក្តីប្រកាន់ចំពោះគាត់ថា ៣លោក
បានចូលទៅឯពួកមនុស្សដែលមិនកាត់ស្បែក ក៏បានពិសា
ជាមួយនឹងគេផង[ឌ] ៤តែពេត្រុសចាប់ផ្តើមរ៉ាយរឿងប្រាប់
គេ ដោយលំដាប់ថា ៥កំពុងដែលខ្ញុំអធិស្ឋាននៅក្រុងយ៉ុបប៉េ
នោះខ្ញុំលង់ស្មារតីទៅ ឃើញការជាក់ស្តែង[ឍ] ជាប្រដាប់
ដូចជាសំពត់កំរាលយ៉ាងធំ ចងទាំង៤ជ្រុង សំរូតចុះពីលើ
មេឃមកត្រឹមខ្ញុំ ៦កាលខ្ញុំសំឡឹងគិតពិចារណាមើល នោះ
ក៏ឃើញមានសត្វជើង៤ សត្វព្រៃ នឹងសត្វលូនវារដែល
នៅលើដី ព្រមទាំងសត្វស្លាបនៅលើអាកាសផង ៧រួចខ្ញុំ
ឮសំឡេងមានបន្ទូលមកខ្ញុំថា ពេត្រុសអើយ ចូរក្រោក
ឡើងសំឡាប់ហើយបរិភោគទៅ ៨តែខ្ញុំប្រកែកថា ទេ
ព្រះអម្ចាស់ ព្រោះមិនដែលមានអ្វីដែលមិនស្អាតមិនបរិ
សុទ្ធ ចូលមកក្នុងមាត់ទូលបង្គំឡើយ ៩ក៏មានឮសំឡេងពី
លើមេឃនោះម្តងទៀតថា របស់អ្វីដែលព្រះបានសំអាត
ហើយ នោះកុំឱ្យអ្នកថាជាមិនស្អាតឡើយ[ណ] ១០ការនោះមាន
មកគ្រប់៣ដង រួចបានលើកទាំងអស់ទៅលើមេឃវិញ
១១ទីបំផុតនោះ ស្រាប់តែមានមនុស្ស៣នាក់ ដែលលោក
នោះចាត់ពីសេសារា[ត] មករកខ្ញុំ គេឈរនៅមុខផ្ទះតែម្តង
១២ហើយព្រះវិញ្ញាណទ្រង់មានបន្ទូល[ថ] ប្រាប់ឱ្យខ្ញុំទៅជា
មួយនឹងគេឥតប្រកាន់ឡើយ[ទ] ក៏មានបងប្អូនទាំង៦នាក់នេះ[ធ]
បានទៅជាមួយនឹងខ្ញុំដែរ យើងរាល់គ្នា បានចូលទៅក្នុងផ្ទះ
របស់លោក ១៣ហើយលោករ៉ាយរឿងប្រាប់យើងពីដំណើរ
ដែលឃើញទេវតា[ន] ឈរក្នុងផ្ទះ ប្រាប់លោកថា ចូរចាត់គេ
ឱ្យទៅឯយ៉ុបប៉េ ហៅស៊ីម៉ូនដែលហៅថា ពេត្រុសឱ្យមក
១៤គាត់នឹងអធិប្បាយ ឱ្យលោកស្តាប់សេចក្តី[ប] ដែលនឹងជួយ
សង្គ្រោះដល់លោក ព្រមទាំងពួកគ្រួ[ផ] លោកទាំង អស់ផង
១៥កាលខ្ញុំចាប់តាំងនិយាយទៅ នោះព្រះវិញ្ញាណបរិសុទ្ធក៏

**១០:៤៤** ខ កច ៨:១៥,១៦ ១១:១៥ ១៥:៨ ១៩:៦ លក ១:១៥
**១០:៤៥** គ ឧ.២៣ ឃ កច ២:៣៣,៣៨ ង កច ១១:១៨ ១៥:៨
**១០:៤៦** ច មក ១៦:១៧
**១០:៤៧** ឆ កច ៨:៣៦ ជ យហ ២០:២២ កច ១១:១៧
**១០:៤៨** ឈ កច ២:៣៨
**១១:១** ញ កច ១:១៦ ដ ហព ៤:១២
**១១:២** ឋ កច ១០:៤៥
**១១:៣** ឌ កច ១០:២៥,២៨ កទ ២:១២
**១១:៥** ឍ កច ៩:១០ ១០:៩–៣២
**១១:៩** ណ កច ១០:១៥
**១១:១១** ត កច ៨:៤០
**១១:១២** ថ កច ៨:២៩ ទ កច ១៥:៩ រម ៣:២២ ធ ឧ.១,២៩ កច ១:១៦ **១១:១៣** ន កច ៥:១៩ **១១:១៤** ប កច ១០:៣៦ ផ យហ ៤:៥៣ កច ១៦:១៥,៣១–៣៤ ១៨:៨ ១កថ ១:១១,១៦

**១០:៤៥** *បានចាក់មកលើពួកសាសន៍ដទៃដូច្នេះដែរ* ត្រង់ចំណុចនេះ ពួកជំនុំដំបូងជាសាសន៍យូដា ពុំបានយល់ច្បាស់ទេថា ដំណឹងល្អនៃសេចក្តីសង្គ្រោះ និងការប្រោសលោះ គឺសម្រាប់ទាំងសាសន៍ដទៃ និងសាសន៍យូដា ។ ពួកគេយល់ច្រឡំថា ចំពោះសាសន៍ដទៃ ទាល់តែចូលសាសន៍ ទើបអាចទទួលការទាំងនេះបាន (៦:៥) ។

**១០:៤៦** *និយាយភាសាដទៃ* គឺដូចគ្នាទៅនឹងបទពិសោធន៍ដែលពួកសាវកបានទទួលនៅថ្ងៃបុណ្យទី៥០ (២:៤,១១) និងហេតុការណ៍ដែលកើតមានចំពោះពួកសិស្សមួយចំនួនទៀតនៅទីក្រុងអេភេសូរដែរ (១៩:១,៦) ។

**១០:៤៧** *តើមានអ្នកណាអាចនឹងឃាត់ មិនឱ្យធ្វើបុណ្យជ្រមុជទឹកដល់អ្នកទាំងនេះបានឬទេ?* ពួកអ្នកជឿជាសាសន៍ដទៃ និងអ្នកជឿជាសាសន៍យូដាទទួលបាននូវអំណោយទានដូចគ្នា ដូចជាការនិយាយភាសាដទៃជាដើម ។ ម្យ៉ាងទៀតនៅ ត្រង់ចំណុចនេះ ក៏ជាភស្តុតាងមួយបញ្ជាក់យ៉ាងច្បាស់ថា នគរព្រះបើកចំហចំពោះមនុស្សគ្រប់ៗគ្នា គឺទាំងសាសន៍ដទៃ និងសាសន៍យូដា ។

**១១:១** *ពួកសាវក និងពួកបងប្អូន* នៅសម័យកាលនោះ ពាក្យថា "បងប្អូន" សំដៅលើមនុស្សទាំងឡាយណាដែលជាប់ពូជពង្សនឹងគ្នា (២:២៩ ៧:២) ប៉ុន្តែ ចំពោះគ្រីស្ទបរិស័ទវិញ សំដៅលើអស់អ្នកដែលរួមគ្នានៅក្នុងព្រះគ្រីស្ទ (៦:៣ ១០:២៣) ។ ពេលជួបបញ្ហាធំៗ ពួកសាវកតែងចែកចាយយោបល់ជាមួយពួកជំនុំ ។ ហើយដោយមានការដឹកនាំមកអំពីព្រះអម្ចាស់ ពួកសាវកទាំងនោះទទួលនាទីជាអ្នកកាត់ស្រាយ ន័យព្រះបន្ទូល និងអធិប្បាយទូន្មាន ប៉ុន្តែពួកជំនុំទាំងមូលត្រូវបានលើកទឹកចិត្ត ឱ្យបញ្ចេញយោបល់ (ពួកជំនុំទាំងអស់ "៦:៥" ពួកសាវកនិងពួកបងប្អូន "១១:១" ពួកជំនុំ "១១:២២" ពួកជំនុំ ពួកសាវក និងពួកចាស់ទុំ "១៥:៤,២២") ។

**១១:២** *អស់អ្នកខាងពួកកាត់ស្បែក* សំដៅលើពួកអ្នកជឿដែលជាសាសន៍យូដា ។

**១១:៣** *ពួកមនុស្សដែលមិនកាត់ស្បែក* គឺពួកសាសន៍ដទៃ ។ ពួកអ្នកជឿដែលជាសាសន៍យូដាបានចោទពួកសាសន៍ដទៃថា ពុំបានប្រតិបត្តិតាមក្រិត្យវិន័យដែលចែងអំពីអាហារបរិសុទ្ធ និងមិនបរិសុទ្ធទេ ហើយថែមទាំងបំពានទៅលើច្បាប់ទម្លាប់របស់ពួកគេ (ពួកយូដា) ទៀតផង ។ *ពិសាជាមួយនឹងគេផង* "មើលការពន្យល់ លក ១៥:២" ។

**១១:៤–១៧** "មើលការពន្យល់ ១០:១–២៣,២៨–៣៣" ។

**១១:១៤** *ព្រមទាំងពួកគ្រួលោកទាំងអស់ផង* មានន័យថា មិនមែនគ្រាន់តែក្រុមគ្រួសាររបស់លោកកូនេលាសប៉ុណ្ណោះទេ គឺរួមទាំងពួកអ្នកបម្រើ និងអស់អ្នកដែលនៅក្រោមបង្គាប់លោកទាំងអស់ផង (មើលការពន្យល់ លប ៦:១៨) ។

ក៏យាងមកសណ្ឋិតលើ[ព]គេ ដូចជាបានសណ្ឋិតលើយើងរាល់
គ្នាកាលពីដើមដែរ[ភ] ១៦នោះខ្ញុំបាននឹកឃើញពីសេចក្តីដែល
ព្រះអម្ចាស់ទ្រង់មានបន្ទូលថា លោកយ៉ូហានបានធ្វើបុណ្យ
ជ្រមុជដោយទឹក[ម] តែអ្នករាល់គ្នា នឹងទទួលបុណ្យជ្រមុជ
ដោយព្រះវិញ្ញាណបរិសុទ្ធវិញ[យ] ១៧ដូច្នេះ បើសិនជាព្រះ
បានប្រទានអំណោយទានទៅគេ[រ] ដូចជាបានប្រទានមក
យើង[ល]ដែរ ដោយជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ចុះតើខ្ញុំ
ជាអ្វីដែលអាចនឹងឃាត់ព្រះបាន ១៨កាលបានឮសេចក្តី
នោះហើយ នោះគេបាត់មាត់ ក៏ត្រឡប់ជាសរសើរដល់
ព្រះវិញថា ដូច្នេះ ព្រះទ្រង់ក៏ប្រោសប្រទានការប្រែចិត្ត
ដល់ពួកសាសន៍ដទៃ ឱ្យគេមានជីវិតដែរហ្ន៎[វ] ។

## ពួកជំនុំនៅទីក្រុងអាន់ទីយ៉ូក

១៩រីឯពួកអ្នកដែលត្រូវខ្ចាត់ខ្ចាយដោយព្រោះសេចក្តីបៀត
បៀន ដែលកើតមកពីដំណើរស្ទេផាន[ស] នោះក៏ដើររៀង
រហូតទៅដល់ស្រុកភេនីស ស្រុកគីប្រុសនឹងក្រុងអាន់ទីយ៉ូក[ហ]
តែបានផ្សាយព្រះបន្ទូល ដល់ចំពោះតែពួកសាសន៍យូដា
ប៉ុណ្ណោះទេ ២០ប៉ុន្តែក្នុងពួកអ្នកនោះ មានអ្នកខ្លះពីកោះ
គីប្រុស[ឡ] និងស្រុកគីរេន[អ] គេបានទៅដល់ក្រុងអាន់ទីយ៉ូក[ក]
ក៏ផ្សាយដំណឹងល្អ[ខ] ពីព្រះអម្ចាស់យេស៊ូវ ដល់ពួកសាសន៍
ក្រេកដែរ ២១ព្រះហស្តព្រះអម្ចាស់ ក៏នៅជាមួយនឹងគេ[គ]
ហើយមានមនុស្សជាច្រើន បែរមកឯព្រះអម្ចាស់វិញ[ឃ]
ដោយមានសេចក្តីជំនឿ ២២រឿងនោះបានឮដល់ត្រចៀក
ពួកជំនុំនៅក្រុងយេរូសាឡិម រួចគេចាត់បាណាបាស[ង]
ឱ្យទៅត្រឹមអាន់ទីយ៉ូក ២៣កាលគាត់ទៅដល់ ហើយបាន
ឃើញព្រះគុណនៃព្រះ[ច] នោះគាត់មានសេចក្តីអំណរ ក៏
ទូន្មានគេគ្រប់គ្នាឱ្យសំរេចចិត្ត[ឆ]នឹងនៅជាប់ក្នុងព្រះអម្ចាស់[ជ]
២៤ដ្បិតគាត់ជាមនុស្សល្អ ពេញជាព្រះវិញ្ញាណបរិសុទ្ធ[ឈ]
នឹងសេចក្តីជំនឿ ហើយមានមនុស្សសន្ធឹកណាស់ បានចំរើន
ដល់ព្រះអម្ចាស់[ញ] ២៥នោះបាណាបាស ក៏ទៅឯក្រុងតើសុស[ដ]
ដើម្បីនឹងរកសុល ២៦កាលបានឃើញហើយ នោះក៏នាំគាត់
មកឯអាន់ទីយ៉ូកវិញ រួចអ្នកទាំង២នោះ បានប្រជុំគ្នានឹង

**១១:១៥** ព កច ១០:៤៤ ភ កច ២:៤ **១១:១៦** ម មក ១:៤ យ មក ១:៨ **១១:១៧** រ កច ២:៣៨ ល កច ១០:៤៥,៤៧ **១១:១៨** វ រម ១០:១២,១៣ ២កថ ៧:១០ **១១:១៩** ស កច ៨:១,៤ ហ ខ.២៦,២៧ កច ១៣:១ ១៤:២៦ ១៨:២២ កទ ២:១១ **១១:២០** ឡ កច ៤:៣៦ អ មថ ២៧:៣២ ក ខ.១៩ ខ កច ១៣:៣២ **១១:២១** គ លក ១:៦៦ ឃ កច ២:៤១ **១១:២២** ង កច ៤:៣៦ **១១:២៣** ច កច ១៣:៤៣ ១៤:២៦ ១៥:៤០ ២០:២៤ ឆ កច ១៤:២២ ជ លក ១:១៥ **១១:២៤** ឈ កច ២:៤១ ញ កច ៩:១១ **១១:២៥** ដ ខ.២៩ កច ៦:១,២ ៩:១៩, ២៦,៣៨ ១៣:៥២

**១១:១៧** *ចុះតើខ្ញុំជាអ្វី ដែលអាចនឹងឃាត់ព្រះបាន* លោកពេត្រុសនិយាយយ៉ាងដូច្នេះ បញ្ជាក់ថា គាត់ពុំអាចហាមឃាត់ពួកអ្នកជឿដែលជាសាសន៍ដទៃមិនឱ្យទទួលបុណ្យជ្រមុជទឹក និងប្រកបសេចក្តីអំណរក្នុងព្រះគ្រីស្ទ ជាមួយនឹងគ្រីស្ទបរិស័ទផ្សេងៗទៀតបានទេ ។ ក្នុងខណៈនោះ ពួកយូដាក៏ទទួលស្គាល់ថាព្រះអម្ចាស់ពិតជា ប្រោសប្រទានការសង្គ្រោះដល់សាសន៍ដទៃ ដូចជាពួកគេផងដែរ ។

**១១:១៨** *ប្រោសប្រទានការប្រែចិត្ត ដល់ពួកសាសន៍ដទៃ* គឺបែរចេញពីអំពើបាប ហើយវិលមកឯព្រះអម្ចាស់វិញ (មើលការពន្យល់ ២:៣៨) ។

**១១:១៩** *ព្រោះសេចក្តីបៀតបៀន ដែលកើតមកពីដំណើរស្ទេផាន* "មើលការពន្យល់ ៨:១-៤"។ *ស្រុកភេនីស* ជាតំបន់មួយ ស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រមេឌីទែរ៉ាណេភាគខាងកើត មានបណ្តោយប្រហែល ១៩៣ គ.ម និងទទឹងប្រហែល២៤គ.ម ព្រំប្រទល់ខាងជើងជាប់នឹងប្រទេសស៊ីរី ខាងត្បូងជាប់ជាមួយស្រុកយូដា ។ ទីក្រុងសំខាន់ៗនៅក្នុងតំបន់នេះគឺ ទីក្រុងទីរ៉ុស និងទីក្រុងស៊ីដូន ។ *ស្រុកគីប្រុស* ជាកោះមួយដែលស្ថិតនៅភាគខាងជើងឆៀងខាងកើតនៃសមុទ្រមេឌីទែរ៉ាណេ ។ កោះនេះគឺជាកន្លែងកំណើតរបស់លោកបាណាបាស (៤:៣៦) ។ *ក្រុងអាន់ទីយ៉ូក* គឺជាទីក្រុងលំដាប់ថ្នាក់ទី៣របស់ចក្រភពរ៉ូម៉ាំង (បន្ទាប់ពីទីក្រុងរ៉ូម និងទីក្រុងអ័លេក្សានទ្រា) ។ ទីក្រុងនេះស្ថិតនៅភាគខាងជើងឆៀងខាងកើតនៃសមុទ្រមេឌីទែរ៉ាណេ ។ ពួកជំនុំដែលជាសាសន៍ដទៃធំជាងគេ ដំបូងមានដើមកំណើតនៅក្នុងទីក្រុងនេះ ។ ដំណើរបេសកកម្មរបស់លោកប៉ុល ក៏មានជាប់ទាក់ទងនឹងពួកជំនុំនៅក្នុងតំបន់នោះដែរ (១៣:១-៤ ១៥:៤០ ១៨:២៣) ។

**១១:២០** *ស្រុកគីរេន* "មើលការពន្យល់ ២:១០"។ *ពួកសាសន៍ក្រេក* គឺសំដៅលើពួកសាសន៍ដទៃ ពុំមែនជាពួកសាសន៍យូដានិយាយភាសាក្រិកនោះទេ ។

**១១:២១** *ព្រះហស្តព្រះអម្ចាស់* បង្ហាញពីព្រះវត្តមាននៃព្រះចេស្តារបស់ទ្រង់ដើម្បី ជួយ និងប្រទានពរដល់ពួកជំនុំ (៤:៣០ លក ១:១៦ មើលការពន្យល់ កច ១៣:១១) ពេលខ្លះទ្រង់សំដែងឱ្យឃើញតាមរយៈទីសំគាល់ និងការអស្ចារ្យ (នក៨:១៩) ។

**១១:២២** *បាណាបាស* ពាក្យថា"បាណាបាស"មានន័យថា"អ្នកលើកទឹកចិត្ត" (មើលការពន្យល់ ៤:៣៦ ៩:២៧) ។ ការដែលបញ្ជូនគាត់ ឱ្យទៅឯទីក្រុងអាន់ទីយ៉ូក គឺជាទំនួលខុសត្រូវមួយរបស់ពួកជំនុំនៅទីក្រុងយេរូសាឡិម ដើម្បីពិនិត្យមើលការងារថ្មីៗនៅទីនោះ (៨:១៤) ។

**១១:២៣** *គាត់...ក៏ទូន្មានគេគ្រប់គ្នា* គឺបង្រៀនពួកគេអំពីសេចក្តីពិតរបស់ព្រះអម្ចាស់ ។

**១១:២៤** *ពេញជាព្រះវិញ្ញាណបរិសុទ្ធ និងសេចក្តីជំនឿ* ត្រង់ចំណុចនេះបញ្ជាក់ថា លោកបាណាបាសពិតជាមនុស្សដែលព្រះអម្ចាស់សព្វព្រះហឫទ័យ (៦:៥) ។

**១១:២៥-២៦** លោកបាណាបាសត្រូវការគូកនធ្វើដំណើរទៅក្រុងអាន់ទីយ៉ូកដើម្បីជួយអធិប្បាយ និងបង្រៀនពួកជំនុំនៅទីនោះ ។ ដូច្នោះគាត់ក៏ធ្វើដំណើរទៅទីក្រុងតើសុស ក្នុងគោលបំណងរកលោកសុលឱ្យទៅជាមួយនឹងគាត់ ។ កាលបានជួបលោកសុលហើយ ក៏នាំគាត់ធ្វើដំណើរទៅទីក្រុងអាន់ទីយ៉ូកនិងធ្វើការជាមួយគ្នានៅទីនោះអស់រយៈពេល១ឆ្នាំ ។

**១១:២៥** *ក្រុងតើសុស* (៩:១១,៣០ មើលការពន្យល់ ២២:៣) ។

**១១:២៦** *ក្នុងរវាង១ឆ្នាំ* ត្រង់ចំណុចនេះ ជាភស្តុតាងមួយបញ្ជាក់ថា លោកលូកាពិតជាបានកត់ត្រាទុកនូវពេលវេលាយ៉ាងច្បាស់លាស់បំផុត (១៨:១១ ១៩:៨,១០ ២៤:២៧ ២៨:៣០) ។ *ពួកគ្រីស្ទាន* ជាងារមួយដែលគេប្រើដំបូងបំផុតនៅឯទីក្រុងអាន់ទីយ៉ូក សំដៅលើអស់អ្នកណាដែលជឿលើព្រះយេស៊ូវ

ពួកជំនុំ ព្រមទាំងបង្រៀនដល់មនុស្សសន្ធឹកណាស់ ក្នុង
រវាង១ឆ្នាំ គឺនៅអាន់ទីយ៉ូកនេះឯង ដែលគេហៅពួកសិស្ស
ថា«ពួកគ្រីស្ទាន» ជាមុនដំបូង[ប] ។
២៧ នៅគ្រានោះ មានហោរាខ្លះ[ឌ] ចុះពីក្រុងយេរូសាឡិម
មកដល់អាន់ទីយ៉ូក ២៨ ក្នុងពួកហោរានោះ មានម្នាក់ឈ្មោះ
អ័ក្កាបុស[ឍ] គាត់ក្រោកឡើងទាយដោយព្រះវិញ្ញាណថា នឹង
មានអំណត់អត់ជាខ្លាំងនៅគ្រប់លើផែនដី[ណ] នោះក៏កើតមក
ក្នុងប្រវត្តិនៃមហារាជក្លូឌាសមែន[ត] ២៩ ដូច្នេះ ពួកសិស្ស[ថ]
ក៏គិតសំរេចនឹងផ្ញើទៅជួយ[ទ] ដល់ពួកបងប្អូន[ធ] ដែលនៅស្រុក
យូដា តាមកំឡាំងរៀងខ្លួន ៣០ ហើយក៏បានធ្វើការនោះមែន
ព្រមទាំងផ្ញើទៅដល់ពួកចាស់ទុំ[ន] ដោយសារបាណាបាស[ប]
នឹងសុល[ផ] ។

## លោកពេត្រុសចេញពីគុកដោយការអស្ចារ្យ

**១២** ១ នៅគ្រានោះ ស្តេចហេរ៉ូឌ[ព] ទ្រង់លូកព្រះហស្តទៅ
ចាប់ធ្វើទុក្ខដល់ពួកជំនុំខ្លះ ២ ក៏សំឡាប់យ៉ាកុបជាបងយ៉ូហាន
ដោយដាវផង[ម] ៣ លុះទ្រង់យល់ឃើញថា ការនោះជាទី
គាប់ចិត្តដល់ពួកសាសន៍យូដា[យ] នោះក៏ចាប់ពេត្រុសថែម
ទៀត (រីឯវេលានោះជាបុណ្យនំបុ័ងឥតដំបែ)[រ] ៤ កាល
ចាប់បានហើយ នោះក៏ដាក់គុក ព្រមទាំងប្រគល់ដល់ទា
ហាន៤សង្កាត់ ឲ្យឃុំរក្សាទុក ដោយប្រាថ្នានឹងនាំគាត់មក
នៅមុខបណ្តាជន ក្រោយថ្ងៃបុណ្យរំលង[ល] ៥ ដូច្នេះ គេ
ក៏ឃុំពេត្រុស ទុកនៅក្នុងគុក តែចំណែកខាងពួកជំនុំ គេខំ
ប្រឹង អធិស្ឋានដល់ព្រះឲ្យគាត់អស់ពីចិត្ត[វ] ៦ រីឯក្នុងកាលដែល
ស្តេចហេរ៉ូឌគិតនាំពេត្រុសមក នៅវេលាយប់នោះឯង
គាត់ដេកនៅជាកណ្តាលទាហាន២នាក់ មានទាំងច្រវាក់
២ខ្សែ[ស] ជាប់នៅខ្លួន ហើយមានពួកទាហានចាំយាមនៅ

**១១:២៦** ប កច ២៦:២៨ ១ពត ៤:១៦ **១១:២៧** ឌ កច ១៣:១ ១៥:៣២ ១កថ ១១:៤ ១២:២៨,២៩ ១៤:២៩,៣២,៣៧ អភ ៤:១១ **១១:២៨** ឍ កច ២១:១០ ណ មថ ២៤:១៤ ត កច ១៨:២ **១១:២៩** ថ ខ.២៦ ទ រម ១៥:២៦ ២កថ ៨:១-៤ ៩:២ ធ ខ.១,១២ កច ១:១៦ **១១:៣០** ន កច ១៤:២៣ ១៥:២,២២ ២០:១៧ ១ធថ៥:១៧ ទត ១:៥ យក ៥:១៤ ១ពត ៥:១ ២យហ ១ ប កច ៤:៣៦ ផ កច ១២:២៥ **១២:១** ព មថ ១៤:១ **១២:២** ភ មថ ៤:២១ ម មក ១០:៣៩ **១២:៣** យ កច ២៤:២៧ ២៥:៩ រ នក ១២:១៥ ២៣:១៥ កច ២០:៦ **១២:៤** ល យហ ១១:៥៥ **១២:៥** វ កច ១:១៤ រម ១៥:៣០,៣១ អភ ៦:១៨ **១២:៦** ស កច ២១:៣៣

គ្រីស្ទ (២៦:២៨ ១ពត ៤:១៦) ។

**១១:២៧** *ហោរាខ្លះ* មានន័យថា ព្រះអម្ចាស់ទ្រង់នៅតែប្រទានអំណោយទាន ក្នុងការថ្លែងទំនាយដល់ពួកជំនុំរបស់ទ្រង់ដដែល ។ ហោរាទាំងនោះមានតួនាទីអធិប្បាយ ទូន្មានពន្យល់ និងថ្លែងទំនាយតាមការដែលព្រះអម្ចាស់ទ្រង់បើកសំដែងឲ្យដឹង (១៣:១ ១៥:៣២ ១៩:៦ ២១:៩–១០ រម ១២:៦ ១កថ ១២:១០ ១៣:២,៨ ១៤:៣, ៦,២៩–៣៧ មើលការពន្យល់ យហ ៣:២ សក ១:១ អភ ៤:១១) ។

**១១:២៨** *អ័ក្កាបុស* គាត់ជាហោរាម្នាក់ថ្លែងទំនាយអំពីការដែលលោកប៉ុលត្រូវរងទុក្ខនៅក្នុងពន្ធនាគារ (ខ.២៧ ២១:១០ ២១:៩–១០ ១៥:៣២) ។ *ក្លូឌាស* គឺជាអធិរាជនៃចក្រភពរ៉ូម៉ាំង នៅឆ្នាំទី៤១គ.ស រហូតដល់ឆ្នាំទី៥៤គ.ស ។

**១១:៣០** *ពួកចាស់ទុំ* "មើលការពន្យល់ ១ធថ ៣:១ ៥:១៧"។ ត្រង់ចំណុចនេះមិនបាននិយាយអំពីពួកសាវ័ក ដូច្នោះ មានន័យថា ក្នុងខណៈនោះ ពួកគេប្រហែលជាមិននៅក្នុងទីក្រុងយេរូសាឡិមទេ ។

**១២:១** *នៅគ្រានោះ* ត្រង់ចំណុចនេះ អ្នកខ្លះយល់ថា ហេតុការណ៍បានកត់ត្រានៅក្នុងជំពូក១២ទាំងមូល ដែលទាក់ទងទៅនឹងស្តេចហេរ៉ូឌ–អ័គ្រីប៉ា មិនបានរៀបតាមលំដាប់លំដោយនៃកាលបរិច្ឆេទទេ ។ មានមតិខ្លះយល់ថា លោកបាណាបាស និងលោកប៉ុលមកដល់ទីក្រុងយេរូសាឡិម បន្ទាប់ពីលោកពេត្រុសចេញពីពន្ធនាគារ (១១:៣០) គឺប្រហែលជាពេលដែលស្តេចហេរ៉ូឌចាប់ផ្តើមធ្វើការបៀតបៀនគ្រីស្ទបរិស័ទតែម្តង ។ ហេតុការណ៍ទាំងនេះប្រហែលជាបានកើតឡើងនៅឆ្នាំទី៤៣គ.ស ព្រោះថាស្តេចហេរ៉ូឌនោះសុគតនៅឆ្នាំទី៤៤គ.ស ។ តាមការយល់ឃើញខាងលើនេះ គ្រោះទុរ្ភិក្សនៅក្នុង "១១:២៨" ប្រហែលជាបានកើតឡើងនៅឆ្នាំទី ៤៦គ.ស គឺក្រោយពីការសុគតរបស់ស្តេចហេរ៉ូឌ (ខ.២៣) ។ ដូច្នេះ អំណោយដែលផ្ញើទៅស្រុកយូដានៅក្នុង "១១:៣០" គឺនៅមុនការសុគតរបស់ស្តេចហេរ៉ូឌ នៅឆ្នាំទី៤៤គ.ស ។ តាមទស្សនៈពីបុរាណយល់ថា លោកប៉ុលធ្វើដំណើរទៅដល់ទីក្រុងយេរូសាឡិមដូចមានចែងនៅក្នុង "កទ ២:១–១០" គឺត្រូវនឹងពេលមាន គ្រោះទុរភិក្សដែលចែងនៅក្នុង "ខ.២៥ ១១:៣០"។ ក្រោយមក មានទស្សនៈខ្លះយល់ថា បទគម្ពីរ "កទ ២:១" ដែលចែងថា លោកប៉ុលបានមកដល់ទីក្រុងយេរូសាឡិមនោះ គឺមកដើម្បីប្រជុំប្រឹក្សាគ្នា ដូចមានចែងក្នុង "១៥:១–២៩"។ *ស្តេចហេរ៉ូឌ* គឺហេរ៉ូឌ-អ័គ្រីបាទី១ ជាចៅរបស់ស្តេចហេរ៉ូឌ-អធិរាជ (មើលការពន្យល់ មថ ២:១ ១៤:១) និងជាបុត្រារបស់អើរីស្តូប៊ូល ។ ស្តេចហេរ៉ូឌអង្គនេះ គឺជាបងប្អូនជីដូនមួយរបស់ស្តេច ហេរ៉ូឌ–អាន់ទីប៉ាស ។ ស្តេចហេរ៉ូឌ-អាន់ទីប៉ាស នោះហើយ ជាអ្នកសម្លាប់លោក យ៉ូហាន–បាទីស្ទ (មថ ១៤:៣–១២) និងជាអ្នកល្បងល និងចំអកដាក់ព្រះយេស៊ូវ (មើល លក ២៣:៨–១២) ។ ក្នុងពេលដែលស្តេចហេរ៉ូឌ អាន់ទីប៉ាស មិនបានគង់នៅក្នុងប្រទេស នោះស្តេចហេរ៉ូឌ អ័គ្រីប៉ាត្រូវទទួលនាទីជាស្តេចអនុរាជរបស់ទ្រង់ ដូចគ្នានឹងស្តេចភីលីព និងស្តេចលីសានាសដែរ (មើលពន្យល់ លក ៣:១) ។ ស្រុកយូដា និងស្រុកសាម៉ារី ត្រូវបានដាក់បញ្ចូលទៅក្រោមការត្រួតត្រារបស់ស្តេចហេរ៉ូឌ អាន់ទីប៉ាសទី១ នៅឆ្នាំទី៤១ គ.ស ។

**១២:២** *យ៉ាកុប* ជាបងរបស់សាវ័កយ៉ូហាន និងជាកូនរបស់លោកសេបេដេ (មថ ៤:២១) ។ ហេតុការណ៍សម្លាប់លោកយ៉ាកុប កើតឡើងប្រហែលជា១០ ឆ្នាំបន្ទាប់ ពីព្រះយេស៊ូវគ្រីស្ទទ្រង់សុគត និងរស់ឡើងវិញ ។ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលរួចជាស្រេច អំពីទុក្ខវេទនាដែលពួកសិស្សទ្រង់ត្រូវទទួល (មថ ២២:២០-២៣) ។ *ដោយដាវផង* ត្រង់ចំណុចនេះ មានន័យថា ពួកគេសម្លាប់លោកយ៉ាកុប ដោយកាត់ក្បាលរបស់គាត់ គឺដូចគ្នានឹងការសម្លាប់លោកយ៉ូហាន–បាទីស្ទដែរ ។

**១២:៣** *បុណ្យនំបុ័ងឥតដំបែ* "មើលការពន្យល់ មក ១៤:១ លក ២២:១"។

**១២:៤** *ទាហាន៤សង្កាត់* គេបែងចែកទាហាន៤ក្រុម ដែល១ក្រុមៗមានគ្នា៤នាក់ និងទទួលខុសត្រូវចាំយាមក្នុងរយៈពេល១យាម (១យប់មាន៤យាម មើលការពន្យល់ មថ ១៤:២៥) ។ *ថ្ងៃបុណ្យរំលង* គឺសំដៅលើរយៈពេល

មាត់ទ្វាររក្សាគុកដែរ ៧នោះមើល មានទេវតា[ហ] នៃព្រះ
អម្ចាស់ ឈរខាងគាត់ ក៏មានពន្លឺផ្សាយមកក្នុងគុក ទេវ
តានោះក៏គោះពីខាងចំហៀង ដាស់គាត់ឡើងថា ចូរ
ក្រោកឡើងជាប្រញាប់ នោះច្រវាក់ក៏ជ្រុះពីដៃគាត់ចេញ[ឡ]
៨រួចទេវតាប្រាប់ថា ចូរក្រវាត់ខ្លួន ហើយពាក់ស្បែកជើង
ទៅ គាត់ក៏ធ្វើដូច្នោះ ហើយទេវតាប្រាប់ទៀតថា ចូរពាក់
អាវមកតាមខ្ញុំចុះ ៩នោះគាត់ចេញទៅតាមទេវតា ឥតមាន
ដឹងជាការ ដែលកើតមកដោយសារទេវតានោះ ជាពិតឬ
មិនពិតទេ គឺគាត់ស្មានថា បានឃើញការជាក់ស្តែងវិញ[អ]
១០កាលបានដើរផុតពីអ្នកយាមទី១ រួចទី២ នោះក៏មកដល់[ក]
ទ្វារដែក ដែលនាំចេញទៅខាងក្រៅ ទ្វារនោះក៏របើកឯង
កាលបានចេញទៅផុតផ្លូវ១ហើយ នោះស្រាប់តែទេវតា
ឃ្លាតចេញពីគាត់បាត់ទៅ ១១លុះពេត្រុសដឹងខ្លួនឡើង[ខ] ក៏
នឹកឃើញថា ឥឡូវនេះ អញដឹងប្រាកដថា ព្រះអម្ចាស់បាន
ចាត់ទេវតានៃទ្រង់ ឱ្យមកដោះអញ[គ]ឱ្យរួចពីកណ្តាប់ដៃ
នៃស្តេចហេរ៉ូឌ ហើយពីគ្រប់ទាំងបំណង ដែលសាសន៍
យូដាបានរង់ចាំដែរ ១២លុះគាត់ពិចារណាហើយ នោះ
ក៏ទៅឯផ្ទះម៉ារា ជាម្តាយយ៉ូហាន-ម៉ាកុស[ឃ] ជាកន្លែងដែល
មនុស្សជាច្រើនបានប្រជុំគ្នាអធិស្ឋាន[ង] ១៣គាត់ក៏គោះទ្វារ
មុខ នោះមានស្រីបំរើម្នាក់ ឈ្មោះរ៉ូដា មកផ្ទៀងស្តាប់[ច]
១៤លុះស្គាល់សំឡេងពេត្រុសហើយ នោះនាងមានសេចក្តី
អំណរដ៏ពន្លឹក[ឆ] ដល់ម្លេះបានជាភ្លេចទាំងបើកទ្វារ រត់
ចូលទៅប្រាប់គេវិញថា លោកពេត្រុសឈរនៅមាត់ទ្វារ
១៥តែគេស្តីថា ឯងវង្វេងហើយ តែនាងនៅតែថា ប្រាកដ
មែនៗ រួចគេថាជាទេវតារបស់គាត់ទេ[ជ] ១៦ឯពេត្រុស គាត់
ចេះតែគោះទ្វារថែម កាលគេបានបើកទ្វារឃើញ នោះ
គេមានសេចក្តីស្រឡាំងកាំង ១៧តែគាត់ធ្វើគ្រឿងសំគាល់
នឹងដៃ[ឈ]ឱ្យគេស្ងៀមទៅ រួចក៏រ៉ាយរឿងប្រាប់គេ ពីដំណើរ
ដែលព្រះអម្ចាស់បាននាំគាត់ចេញពីគុកជាយ៉ាងណា ហើយ
គាត់ផ្តាំគេថា សូមប្រាប់រឿងនេះដល់យ៉ាកុប[ញ] នឹងពួកបង
ប្អូន[ដ]ឱ្យដឹងផង នោះគាត់ ចេញទៅឯកន្លែង១ទៀតទៅ ។

## ការសុគតរបស់ស្តេចហេរ៉ូឌ

១៨លុះភ្លឺឡើង ក៏កើតមានវឹកវរជាធំ នៅក្នុងពួកកង
ទាហាន ពីដំណើរពេត្រុស ដែលទៅឯណាបាត់ ១៩កាល
ស្តេចហេរ៉ូឌបានរកគាត់មិនឃើញ នោះក៏ពិចារណាសួរ
ពួកអ្នកយាមល្បាត ហើយបង្គាប់ឱ្យនាំគេទៅសំឡាប់បង់[ឋ]
រួចស្តេចក៏យាងចុះពីស្រុកយូដា ទៅឯសេសារា[ឌ] គង់នៅ
ទីនោះ។
២០រីឯស្តេចហេរ៉ូឌ ទ្រង់មានព្រះទ័យចងគំនុំនឹងពួក អ្នកនៅ
ស្រុកទីរ៉ុស និងស៊ីដូន[ឍ]ជាខ្លាំង តែគេស្រុះចិត្តគ្នានឹងមកគាល់
ស្តេច លុះបានបញ្ចុះបញ្ចូលប្លាតុស ជាមន្ត្រីសេវកាមាត្យ
របស់ស្តេចហើយ នោះក៏សូមចងជាស្ពានមេត្រីវិញ ពី
ព្រោះគេតែងតែបានស្បៀងអាហារពីស្រុកស្តេចមក[ណ]

**១២:៧** ហ កច ៥:១៩ ឡ ទដ ១០៧:១៤ កច ១៦:២៦
**១២:៩** អ កច ៩:១០
**១២:១០** ក កច ៥:១៩ ១៦:២៦
**១២:១១** ខ លក ១៥:១៧ គ ទដ ៣៤:៧ ដយ ៣:២៨ ៦:២២ ២កថ ១:១០ ២ពត ២:៩
**១២:១២** ឃ ខ.២៥ កច ១៣:៥,១៣ ១៥:៣៧,៣៩ កល ៤:១០ ២ធថ ៤:១១ ភម ២៤ ១ពត ៥:១៣ ង ខ.៥
**១២:១៣** ច យហ ១៨:១៦,១៧
**១២:១៤** ឆ លក ២៤:៤១
**១២:១៥** ជ មថ ១៨:១០
**១២:១៧** ឈ កច ១៣:១៦ ១៩:៣៣ ២១:៤០ ញ កច ១៥:១៣ ដ កច ១:១៦
**១២:១៩** ឋ កច ១៦:២៧ ឌ កច ៨:៤០
**១២:២០** ឍ មថ ១១:២១ ណ ១ពវ ៥:៩,១១ អគ ២៧:១៧

ពេញមួយសប្តាហ៍នៃពិធី បុណ្យនោះតែម្តង (មើលពន្យល់ លក ២២:១)។
**១២:៧** *ទេវតានៃព្រះអម្ចាស់* "មើលការពន្យល់ ៥:១៩"។ *ក៏មានពន្លឺផ្សាយមក* គឺបង្ហាញអំពីសិរីល្អនៃព្រះអម្ចាស់ (មើលការពន្យល់ ៧:៥៥)។
**១២:៩** *នោះគាត់ចេញទៅតាមទេវតា* ប្រហែលជានៅបន្ទាយអាន់តូនី (Antonia) ដែលស្ថិតនៅជ្រុងខាងជើងឆៀងខាងកើតនៃព្រះវិហារ និងជាកន្លែងដែលគេយកលោកប៉ុលទៅឃុំដែរ (២១:៣៤)។
**១២:១២** *ម៉ារា* ជាមីងរបស់លោកបាណាបាស (កល ៤:១០)។ ផ្ទះរបស់គាត់ជាកន្លែងជួបជុំគ្នានៃគ្រីស្ទបរិស័ទ ។ ពិធីលៀងចុងក្រោយនៃព្រះអម្ចាស់ ប្រហែលជាធ្វើនៅបន្ទប់ខាងលើនោះ (មក ១៤:១៣-១៥ កច ១:៣) ហើយកន្លែងអធិស្ឋាន ដូចមានចែងនៅក្នុង"៤:៣១"ក៏នៅបន្ទប់ខាងលើនោះដែរ ។ *យ៉ូហាន–ម៉ាកុស* គឺជាក្មួយម្នាក់របស់លោកបាណាបាស និងសុល ។ ហើយក្រោយមក គាត់គឺជាអ្នកសរសេរគម្ពីរដំណឹងល្អម៉ាកុស (មើលការពន្យល់ ខ.២៥)។
**១២:១៣** *រ៉ូដា* គាត់ជាអ្នកបម្រើម្នាក់ ដែលមានសន្តានចិត្តល្អចំពោះក្រុមគ្រួសាររបស់នាងម៉ារា និងពួកជំនុំនៅទីនោះ ។
**១២:១៥** *ទេវតារបស់គាត់* នៅសម័យនោះ ពួកយូដាមានជំនឿថា បុគ្គលម្នាក់ៗមានទេវតានៅជាមួយ (ហព ១:១៤ មើលការពន្យល់ មថ ១៨:១០)។
**១២:១៦** *នោះគេមានសេចក្តីស្រឡាំងកាំង* មានន័យថា ទោះបីពួកគេបានអធិស្ឋានទៅព្រះអម្ចាស់ ឱ្យលោកពេត្រុសយ៉ាងអស់ពីចិត្តក៏ដោយ ក៏នៅពេលដែលឃើញគាត់ភ្លាម ពួកគេបែរជាស្រឡាំងកាំងទៅវិញ (ខ.៥)។
**១២:១៧** *យ៉ាកុប* គឺយ៉ាកុបជាប្អូនរបស់ព្រះអម្ចាស់យេស៊ូវ និងជាអ្នកដឹកនាំពួកជំនុំនៅក្រុងយេរូសាឡិម(មើលការពន្យល់ កទ ១:១៩)។ នៅពេលនោះ លោកយ៉ាកុប ដែលជាបងរបស់លោកយ៉ូហានត្រូវបានគេសម្លាប់ទៅហើយ (ខ.២)។ *ពួកបងប្អូន* "មើលការពន្យល់ ១១:១"។
**១២:១៩** *សេសារា* ក្រុងនេះមិនគ្រាន់តែជាទីបញ្ជាការសម្រាប់ពួកអភិបាលរ៉ូម៉ាំងប៉ុណ្ណោះទេ ប៉ុន្តែ នៅពេលដែលស្រុកយូដាគ្មានអភិបាលគ្រប់គ្រង ស្តេចអ័គ្រីបា បានយកទីក្រុងនេះធ្វើជារាជធានីរបស់ទ្រង់តែម្តង (មើលការពន្យល់ ៨:៤០ ១០:១)។
**១២:២០** *ទីរ៉ុស និងស៊ីដូន* គឺជាទីក្រុងសំខាន់នៃស្រុកភេនីស (សព្វថ្ងៃហៅថា លេបាណូន Lebanon)។ ម្ហូបអាហារសម្រាប់អស់អ្នកដែលរស់នៅក្នុងទីក្រុងទាំងពីរនេះ គឺអាស្រ័យលើវាលដំណាំនៃស្រុកកាលីឡេ ។ *ប្លាសតុស* ជាអ្នកចាត់ចែងរាជកិច្ច នៅក្នុងដំណាក់របស់ស្តេច ហេរ៉ូឌ អ័គ្រីបាទី១ ។

២១ លុះដល់ថ្ងៃកំណត់ ស្ដេចហេរ៉ូឌទ្រង់ព្រះពស្ត្រារាជ្យ
កំពុងតែគង់នៅលើបល្ល័ង្ក អធិប្បាយឱ្យគេស្ដាប់ ២២ ហើយ
រាស្ត្រគ្រប់គ្នាចេះតែបន្លឺវាចាថា នេះជាសំឡេងព្រះទេវ៉ីយ
មិនមែនជាសំឡេងមនុស្សទេ ២៣ នោះស្រាប់តែទេវតានៃ
ព្រះអម្ចាស់ ប្រហារស្ដេចឱ្យសុគតទៅ[ថ] ដោយដង្កូវចុះ
ពីព្រោះ ស្ដេចមិនបានផ្ទេរ សេចក្ដីសរសើរ នោះ ថ្វាយដល់
ព្រះវិញ ។
២៤ ឯព្រះបន្ទូល[ទ] ក៏ដុះដាលចំរើន កាន់តែច្រើនឡើង[ធ]
២៥ កាលបាណាបាស[ន] និងសុល បានធ្វើការងាររបស់ខ្លួន
រួចសព្វគ្រប់ហើយ[ប] នោះក៏ត្រឡប់ពីក្រុងយេរូសាឡិមមក
វិញ នាំទាំងយ៉ូហាន-ម៉ាកុសមកជាមួយផង[ផ]។

**ការជូនដំណើរលោកសុល និងបាណាបាស**

**១៣** ១ រីឯក្នុងពួកជំនុំនៅក្រុងអាន់ទីយ៉ូក[ព] នោះ មានគ្រូ
អធិប្បាយ[ភ] នឹងគ្រូបង្រៀនខ្លះ[ម] គឺបាណាបាស១[យ] ស៊ីម្មានដែល
ហៅថានីគើរ១ លូគាស ជាសាសន៍គីរេន១[រ] ម៉ាន៉ាអេន ជា
កូនចិញ្ចឹមជាមួយនឹងហេរ៉ូឌ[ល] ស្ដេចអនុរាជ១ នឹងសុល១
២ កំពុងដែលអ្នកទាំងនោះ ធ្វើការងារថ្វាយព្រះអម្ចាស់
ទាំងតម នោះព្រះវិញ្ញាណបរិសុទ្ធ មានបន្ទូលប្រាប់ថា[វ]
ចូរញែកបាណាបាស នឹងសុលចេញឱ្យខ្ញុំ សំរាប់ការងារ[ស]
ដែលខ្ញុំហៅគេឱ្យធ្វើ[ហ] ៣ ដូច្នេះ ក្រោយដែលបានតម ហើយ
អធិស្ឋាន ព្រមទាំងដាក់ដៃលើអ្នកទាំង២[ឡ]នោះ ក៏បើកឱ្យ
គេទៅ[អ] ៤ ឯអ្នកទាំង២នោះក៏ចុះទៅដល់សេលើស៊ា ដោយ
ព្រះវិញ្ញាណបរិសុទ្ធចាត់ឱ្យទៅ[ក] នៅទីនោះ គេចុះសំពៅ

**១២:២៣** ត កច ៥:១៩ ថ ១សយ ២៥:៣៨ ២សយ ២៤:១៦,១៧ ២ពវ ១៩:៣៥
**១២:២៤** ទ ហព ៤:១២ ធ កច ៦:៧ ១៩:២០
**១២:២៥** ន កច ៤:៣៦ ប កច ១១:៣០ ផ ខ.១២
**១៣:១** ព កច១១:១៩ ភ កច ១១:២៧ ម អភ ៤:១១ យ កច ៤:៣៦ រ មថ ២៧:៣២ ល មថ ១៤:១
**១៣:២** វ កច ៨:២៩ ស កច ១៤:២៦ ហ កច ៩:១៥ ២២:២១
**១៣:៣** ឡ កច ៦:៦ អ កច ១៤:២៦ **១៣:៤** ក ខ.២,៣

**១២:២១** *លុះដល់ថ្ងៃកំណត់* សំដៅលើថ្ងៃបុណ្យមួយដែលស្ដេចហេរ៉ូឌប្រារព្ធធ្វើដើម្បីថ្វាយជាកិត្តិយសដល់ស្ដេច ក្លូឌាស-សេសារ ។ *ហេរ៉ូឌទ្រង់ព្រះពស្ត្រារាជ្យ* លោកយ៉ូសែបហ្វីស (Josephus) បានសរសេរទុកថា សម្លៀកបំពាក់របស់ស្ដេចហេរ៉ូឌនៅក្នុងពិធីបុណ្យនោះ គឺធ្វើអំពីលោហៈប្រាក់ និងមានពន្លឺចាំងខ្លាំង ។ ពេលប្រជារាស្ត្រប្រកាសថា ទ្រង់ជាព្រះ ទ្រង់មិនបានបដិសេធទេភ្លាមៗនោះ សេចក្ដីវេទនាដ៏ឈឺចាប់បំផុត ក៏កើតមានចំពោះទ្រង់ ហើយក៏សុគតក្រោយពីពិធីបុណ្យនោះប្រាំថ្ងៃ ។

**១២:២៣** *ទេវតានៃព្រះអម្ចាស់* "មើលការពន្យល់ ៥.៧"។ *សុគតទៅដោយដង្កូវចុះ* ការស្លាប់ដ៏វេទនាបំផុតរបស់ស្ដេចហេរ៉ូឌ គឺជាប់ទាក់ទងនឹងការទទួលយកនូវសេចក្ដីសរសើរដែលថាទ្រង់ផ្ទាល់ជាព្រះ។ ហើយការនោះក៏ជារង្វាន់ដែលស្ដេចអង្គនេះទទួលបាន អំពីការបៀតបៀនពួកជំនុំព្រះអម្ចាស់ផងដែរ ។

**១២:២៤** *ព្រះបន្ទូល ក៏ដុះដាលចំរើន កាន់តែច្រើនឡើង* នេះជាលើកទី៣ហើយ ដែលនិយាយអំពីការចម្រើនឡើងនៃពួកជំនុំ (៦:៧ ៩:៣១)។ ការនេះមាននិយាយ៣ដងទៀត គឺនៅក្នុង "១៦:៥ ១៩:២០ ២៨:៣១"។

**១២:២៥** *យ៉ូហាន-ម៉ាកុស* គាត់ប្រហែលជាមនុស្សកំលោះម្នាក់ដែលបានរត់នៅពេលដែលគេចាប់ព្រះយេស៊ូវ (មក ១៤:៥១,៥២)។ គាត់ក៏ជាអ្នកសរសេរព្រះគម្ពីរដំណឹងល្អម៉ាកុស (សេចក្ដីផ្ដើមគម្ពីរម៉ាកុស) ហើយជាគូកនរបស់លោកបាណាបាសនិងលោកសុល នៅផ្នែកទីមួយនៃដំណើរបេសកកម្មរបស់ពួកគេផងដែរ (មើលការពន្យល់ ១៥:៣៨-៣៩)។

**១៣:១** *គ្រូអធិប្បាយ* (ខនេះភាសាអង់គ្លេសប្រើពាក្យថា "ហោរា" មើលការពន្យល់ ១១:២៧)។ នេះជាអំណោយទានដ៏វិសេស ដែលព្រះអម្ចាស់ទ្រង់ប្រទានឱ្យពួកហោរារបស់ទ្រង់ ទាំងនៅក្នុងសម័យកាលសញ្ញាថ្មី (២:១៧-១៨ ១កថ ១៤:២៩-៣២ អភ ៣:៥) និងសម័យកាលសញ្ញាចាស់ (ចទ ១៨:១៨-២០ ២ពត ១:២១)។ នៅក្នុងសេចក្ដីអធិប្បាយរបស់លោកប៉ុល អំណោយទានជាហោរានេះស្ថិតនៅក្នុងលំដាប់ទី២ (១កថ ១២:២៨-២៩ អភ ២:២០ ៤:១១ ប្រៀបធៀប លក ១១:៤៩ រម ១២:៦ ១កថ ១២:១០)។ *គ្រូបង្រៀនខ្លះ* (១១:២៦ ១៥:៣៥ ១៨:១១ ២០:២០ ២៨:៣១ ១កថ ១២:២៨-២៩ អភ ៤:១១)។ *បាណាបាស. . . សុល* ទាំងនេះជាអ្នកដឹកនាំពួកជំនុំនៅទីក្រុងអាន់ទីយ៉ូក ។ *បាណាបាស* (មើលការពន្យល់ ៤:៣៦) គាត់ត្រូវបានពួកជំនុំនៅទីក្រុងយេរូសាឡិម បញ្ជូនឱ្យទៅឯទីក្រុងអាន់ទីយ៉ូក (១១:២២)។ នៅគ្រាមានអំណត់អត់នោះ គាត់បាននាំយកជង្វាយពីពួកជំនុំនៅក្រុងអាន់ទីយ៉ូក មកជួយពួកបងប្អូននៅឯក្រុងយេរូសាឡិម (១២:២៥)។ ក្រោយមក គាត់ត្រូវបានគេស្គាល់ថា ជាអ្នកដឹកនាំម្នាក់ នៃពួកជំនុំនៅទីក្រុងអាន់ទីយ៉ូក ។ *ស៊ីម្មាន ដែលហៅថានីគើរ* ពាក្យថា "ស៊ីម្មាន" បញ្ជាក់ថាគាត់មានដើមកំណើតមកពីសាសន៍យូដា ។ រីឯពាក្យ នីគើរ វិញ (ភាសាឡាតាំង នីគើរ មានន័យថា ខ្មៅ) អាចបញ្ជាក់ប្រាប់ថា គាត់មានសម្បុរខ្មៅ ។ *លូគាស ជាសាសន៍គីរេន* ពាក្យថា "លូគាស" គឺឈ្មោះជាភាសាឡាតាំង ។ ក្នុងចំណោមក្រុមទី២ នៃពួកគ្រូអធិប្បាយដែលមកឯទីក្រុងអាន់ទីយ៉ូក មានខ្លះមកពីក្រុងគីរេន (១១:២០) ដែលជាទីក្រុងធំ នៃប្រទេសលីប៊ី (មើលពន្យល់ ៦:៩)។ *ម៉ាន៉ាអេន* ឈ្មោះនេះជាភាសាហេព្រើរថា "ម៉ាន៉ាហែន"។ គាត់គឺជាបងប្អូនចិញ្ចឹម ឬជាមិត្តភ័ក្តិស្និទ្ធស្នាលរបស់ស្ដេចហេរ៉ូឌ-អាន់ទីប៉ាស ។

**១៣:២** *ធ្វើការងារថ្វាយព្រះអម្ចាស់ទាំងតម* ដំណើរបេសកកម្មលើកទី១ របស់លោកប៉ុលពុំមែនកើតឡើងដោយផែនការរបស់អ្នកណា ឬក្រុមណាមួយឡើយ គឺមកពីការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលបានតាំងគាត់ឡើងជាអ្នកដឹកនាំម្នាក់ក្នុងការថ្វាយបង្គំ (ខ.៤)។ ទំនាក់ទំនងជាមួយនឹងព្រះអម្ចាស់ ក៏អាចកើតមានឡើងតាមរយៈពួកហោរាបរិសុទ្ធ ដែលទ្រង់បានតាំងឡើងដែរ ។

**១៣:៣** *ដាក់ដៃលើអ្នកទាំង២* គោលបំណងនៃការធ្វើយ៉ាងដូច្នេះគឺ ញែកអ្នកទាំង២នោះសម្រាប់ការងារ ដែលព្រះអម្ចាស់ទ្រង់ត្រាស់ហៅជាពិសេស (ចំពោះបេសកកម្មរបស់អ្នកទាំង២ សូមមើល ១៤:២៦)។ ការអធិស្ឋានតម និងការតាំងអ្នកទាំង២នោះ បានកើតឡើងនៅក្នុងពេលជាមួយគ្នា (១៤:២៣ លក ២:៣៧)។

**១៣:៤-១៤:២៨** ដំណើរបេសកកម្មរបស់លោកប៉ុល (សូមមើលផែនទី)។

**១៣:៤** *សេលើស៊ា* ជាកំពង់ផែសមុទ្រ (ស្ថិតនៅភាគខាងលិចទីក្រុងអាន់ទីយ៉ូក ប្រហែល២៥,៦ គ.ម និងខាងជើងទន្លេអូរ៉ូនប្រហែល ៨ គ.ម) នៃក្រុងអាន់ទីយ៉ូក។ *កោះគីប្រុស* ទីនោះមានពួកសាសន៍យូដាជាច្រើនរស់នៅហើយ ដំណឹងល្អក៏ត្រូវបានប្រកាសហើយដែរ (១១:១៩,២០ មើលពន្យល់ ១១:១៩)។

ចេញទៅឯកោះគីប្រុស[ខ] ៥ដល់សាឡាមីនហើយ គេក៏ផ្សាយ
ព្រះបន្ទូល[គ] នៅក្នុងសាលាប្រជុំទាំងប៉ុន្មានរបស់ពួកសាសន៍
យូដា[ឃ] មានទាំងយ៉ូហាន[ង] ជាអ្នកជំនួយដែរ ៦កាលបានដើរ
កាត់កោះ ទៅត្រឹមប៉ាផុសហើយ នោះក៏ប្រទះនឹងសាសន៍
យូដាម្នាក់ ដែលធ្វើជាគ្រូអាបធ្មប់[ច] ជាហោរាក្លែងក្លាយ[ឆ]
ឈ្មោះ បារ-យេស៊ូវ ៧គ្រូនោះនៅជាមួយនឹងអ្នកដំ
ណាង[ជ] ជាតិរ៉ូមម្នាក់ ឈ្មោះសើគាស-ប៉ូល៉ូស ជាអ្នកឆ្លៀវ
ឆ្លាត លោកក៏ហៅបាណាបាស នឹងសុលមក ដើម្បីចង់
ស្តាប់ព្រះបន្ទូល ៨តែអេលីម៉ាស ជាគ្រូអាបធ្មប់នោះ[ឈ]
(ដ្បិតឈ្មោះនោះប្រែមកដូច្នេះ) ក៏តាំងខ្លួនទាស់[ញ]
នឹងគេដើម្បីបង្វែរលោកមិនឱ្យជឿ[ដ] ៩តែសុលដែលហៅថា
ប៉ុលដែរ គាត់បានពេញជាព្រះវិញ្ញាណបរិសុទ្ធ[ឋ] ក៏សំឡឹង
មើលទៅគ្រូនោះ ដោយនិយាយថា ១០នែមនុស្សដែលពេញ
ដោយកិច្ចកល នឹងសេចក្តីល្បិចគ្រប់យ៉ាង ជាកូននៃអារក្ស[ឌ]
ហើយជាខ្មាំងសត្រូវ ដល់គ្រប់ទាំងសេចក្តីសុចរិតអើយ
តើមិនព្រមឈប់បង្ខូចផ្លូវត្រង់ របស់ព្រះអម្ចាស់ទេ ឬអី[ឍ]
១១មើល ឥឡូវនេះ ព្រះហស្តនៃព្រះអម្ចាស់ បានមកលើឯង
ហើយ[ណ] ឯងនឹងត្រូវខ្វាក់ភ្នែក មើលមិនឃើញពន្លឺថ្ងៃ ជាយូរ
បន្តិច[ត] នោះស្រាប់តែភ្នែករបស់គ្រូនោះ បានទៅជាព្រិលៗ
ហើយងងឹតសូន្យទៅ រួចក៏ដើរវិលវល់ រកអ្នកណាឱ្យដឹក ដៃ
១២កាលលោកដំណាង[ថ]ជាតិ ឃើញការដែលកើតមក
ដូច្នោះ នោះក៏ជឿ ព្រមទាំងមានសេចក្តីអស្ចារ្យក្នុងចិត្ត
អំពីសេចក្តីបង្រៀនរបស់ព្រះអម្ចាស់ផង ។

## នៅស្រុកពីស៊ីឌា អាន់ទីយ៉ូក

១៣ប៉ុល នឹងពួកគូកនគាត់ ក៏ចុះសំពៅចេញពីប៉ាផុស[ទ]
ទៅដល់ពើកា នៅស្រុកប៉ាមភីលា[ធ] ឯយ៉ូហាន[ន] គាត់បែកពី
គេត្រឡប់ទៅឯក្រុងយេរូសាឡិមវិញ ១៤តែគេចេញពីពើកា
ដើរកាត់ទៅឯអាន់ទីយ៉ូក[ប] នៅស្រុកពីស៊ីឌា ក៏ចូលទៅអង្គុយ
ក្នុងសាលាប្រជុំ[ផ] នៅថ្ងៃឈប់សំរាក[ព] ១៥ក្រោយការដែល

ខ កច ៤:៣៦ **១៣:៥** គ ហព ៤:១២ ឃ កច ៩:២០ ង កច ១២:១២ **១៣:៦** ច កច ៨:៩ ឆ មថ ៧:១៥ **១៣:៧** ជ ខ.៨,១២ កច ១៨:១២ ១៩:៣៨ **១៣:៨** ឈ កច ៨:៩ ញ ខ.៧ ដ អស ៣០:១១ កច ៦:៧ **១៣:៩** ឋ លក ១:១៥ **១៣:១០** ឌ មថ ១៣:៣៨ យហ ៨:៤៤ ឍ ហស ១៤:៩ **១៣:១១** ណ នក ៩:៣ ១សយ ៥:៦,៧ ទដ ៣២:៤ ត លប ១៩:១០,១១ ២ពរ ៦:១៨ **១៣:១២** ថ ខ.៧ **១៣:១៣** ទ ខ.៦ ធ កច ២:១០ ន កច ១២:១២ **១៣:១៤** ប កច ១៤:១៩,២១ ផ កច ៩:២០ ព ខ.២៧,៤២,៤៤ កច ១៦:១៣ ១៨:៤

**១៣:៥** *សាឡាមីន* ជាទីក្រុងមួយ ស្ថិតនៅឆ្នេរសមុទ្រកោះគីប្រុសភាគខាងកើត ។ *យ៉ូហាន* គឺលោកយ៉ូហាន–ម៉ាកុស ជាបងប្អូនជីដូនមួយរបស់លោកបាណាបាស (១២:២៥ មើលការពន្យល់ កល ៤:១០)។ *ជាអ្នកជំនួយ* ត្រង់ចំណុចនេះមិនបានប្រាប់ច្បាស់ថា គាត់ជួយទៅលើផ្នែកអ្វីទេ ។ មានមតិខ្លះយល់ថា គាត់ជួយបង្រៀនដល់ពួកអ្នកដែលជឿថ្មី ។ ប៉ុន្តែ បើតាមទស្សនៈរបស់លោកលូកាបញ្ជាក់ថា លោកយ៉ូហានបានជួយច្រើនជាងនេះទៅទៀត (២៦:១៦ លក ១:២ "អ្នកបម្រើ")។

**១៣:៦** *ប៉ាផុស* ជាទីក្រុងមួយ ស្ថិតនៅតាមឆ្នេរសមុទ្រកោះគីប្រុសភាគខាងលិច ហើយមានចម្ងាយប្រហែល ១៦០គ.ម ពីទីក្រុងសាឡាមីន ។ ទីក្រុងប៉ាផុសគឺជាទីបញ្ជាការ សម្រាប់ពួកអ្នកគ្រប់គ្រងចក្រភពរ៉ូម៉ាំង ។ *បារ-យេស៊ូវ* ពាក្យថា "បារ" ជាភាសាអើរ៉ាម មានន័យថា "កូនរបស់" ហើយពាក្យថា "យេស៊ូវ" មានប្រភពដើមពីភាសាហេព្រើរថា "យ៉ូស្វេ"។

**១៣:៧** *អ្នកដំណាង* ដោយព្រោះកោះគីប្រុសជាខេត្តសំខាន់មួយនៃចក្រភពរ៉ូម៉ាំង ដូច្នោះត្រូវមានអ្នកតំណាងប្រចាំការ នៅទីនោះ ។

**១៣:៨** *អេលីម៉ាស* គឺឈ្មោះជាភាសាអារ៉ាប់ មានន័យថា "គ្រូធ្មប់ ឬ គ្រូមន្តអាគម ឬក៏ អ្នកប្រាជ្ញ"។

**១៣:៩** *សុល... ដែលហៅថាប៉ុល* សុល មានន័យថា "ត្រូវបានត្រាស់ហៅ (មកពីព្រះអម្ចាស់)"។ ប៉ុល មានន័យថា "តូច ឬ តិចតួច"។ កាលណាប្រើឈ្មោះថា សុល នោះមានន័យថា គាត់ជាសាសន៍យូដា ។ ប៉ុន្តែ នៅពេលដែលគាត់ប្រើឈ្មោះថា ប៉ុល នោះបញ្ជាក់ថា គាត់ជាជាតិរ៉ូម និងមានដើមកំណើតជាក្រិក ។ ចាប់ពីចំណុចនេះតទៅ នៅក្នុងគម្ពីរកិច្ចការ ឈ្មោះរបស់លោកសុលត្រូវប្តូរទៅជា ប៉ុល វិញ ។ ការដែលប្តូរឈ្មោះនេះ ប្រហែលព្រោះតែជ័យជម្នះរបស់លោកសុល ក្នុងការប្រកាសដំណឹងល្អប្រាប់លោក សើគាស–ប៉ូល៉ូស ឬដោយសារគាត់បានចាប់ ផ្តើមបេសកកម្មទៅសាសន៍ដទៃ ។ លំដាប់ឈ្មោះនៃពួកគាត់ទាំង២ (បាណាបាស និងសុល) ត្រូវបានប្តូរពី "បាណាបាស និងសុល" ទៅជា "ប៉ុល និងបាណាបាស" វិញ ។ ប៉ុន្តែ នៅពេលដែលអ្នកទាំង២ត្រឡប់ទៅពួកជំនុំ នៅឯទីក្រុងយេរូសាឡិមវិញ លំដាប់នៃឈ្មោះនេះគឺ "បាណាបាស និងប៉ុល" (១៥:១២)។

**១៣:១១** *ព្រះហស្តនៃព្រះ* "មើលការពន្យល់ ១១:២១"។ *ឯងនឹងត្រូវខ្វាក់ភ្នែក* "សូមប្រៀបធៀប ទៅនឹងហេតុការណ៍ ដែលកើតឡើងចំពោះលោកសុល នៅក្នុង ៩:៨–១៨"។

**១៣:១២** *នោះក៏ជឿ* គាត់បានប្រែចិត្តជឿដោយសារការអស្ចារ្យ និងព្រះ–បន្ទូល ។

**១៣:១៣** *ពើកានៅស្រុកប៉ាមភីលា* ពើកាជាទីក្រុងធំមួយនៃស្រុកប៉ាមភីលា ។ ប៉ាមភីលាគឺជាប្រទេសមួយ ស្ថិតនៅភាគខាងលិចបំផុតនៃទ្វីបអាស៊ី តាមបណ្តោយឆ្នេរសមុទ្រមេឌីទែរ៉ាណេ ចន្លោះស្រុកគីលីគា និងប្រទេសលីគា (Lycia) ចម្ងាយ១៩,៣គ.ម ពីកំពង់ផែអាតាលា ។ *ឯយ៉ូហាន គាត់បែកពីគេ* ត្រង់ចំណុចនេះ លោកលូកាពុំបានបញ្ជាក់អំពីមូលហេតុ ដែលនាំឱ្យលោកយ៉ូហាន–ម៉ាកុសបែកចេញពីពួកគេនោះទេ ។ ប៉ុន្តែ ក្រោយមកទៀត លោកលូកាបានប្រាប់ថា លោកយ៉ូហាន–ម៉ាកុស គឺជាគូកនដ៏ល្អម្នាក់របស់លោកប៉ុល ។

**១៣:១៤–៤១** លោកប៉ុល និងបាណាបាសនៅសាលាប្រជុំនៃទីក្រុងអាន់ទីយ៉ូកស្រុកពីស៊ីឌា ។ សម្រាប់ព័ត៌មានបន្ថែម ស្តីអំពីរឿងរ៉ាវនៅក្នុងសាលាប្រជុំសូមមើល "លក ៤:១៦–២១"។

**១៣:១៤** *ស្រុកពីស៊ីឌា* "មើលការពន្យល់ ១៤:២៤"។ *អាន់ទីយ៉ូក* ឈ្មោះទីក្រុងនេះបានដាក់តាមឈ្មោះរបស់ស្តេចអាន់ទីយ៉ូក ជាស្តេចនៃប្រទេសស៊ីរីសោយរាជ្យ បន្ទាប់អំពីការសុគតរបស់អធិរាជអ័លេក្សានត្រុស ។ ទីក្រុងនេះគឺជាដែនដីចំណុះរបស់ចក្រភពរ៉ូម៉ាំង និងជាមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏សំខាន់ស្ថិតនៅចម្ងាយ ១៧៦,៨គ.ម ពីទីក្រុងពើកា ។ មានសាសន៍យូដាជាច្រើនរស់នៅក្នុងទីក្រុងនេះ ។ ម្យ៉ាងទៀត ពួកទាហានដែលចូលនិវត្តត្រូវបាន

# ដំណើរបេសកកម្មលើកទី១របស់លោកប៉ុល




**ឆ្នាំទី៤៦–៤៨គ.ស**

កច ១៣:៤–១៤:២៨

# ដំណើរបេសកកម្មលើកទី២របស់លោកប៉ុល



អានមើលក្រិត្យវិន័យ[ភ] នឹងគម្ពីរពួកហោរាហើយ នោះមេ
សាលាក៏ប្រើមនុស្ស ឱ្យទៅប្រាប់ថា បងប្អូនអើយ បើមាន
សេចក្ដីអ្វី នឹងទូន្មានដល់ពួកជន នោះសូមបងប្អូនមាន
ប្រសាសន៍ចុះ ១៦លំដាប់នោះ ប៉ុលក៏ក្រោកឡើង ធ្វើគ្រឿង
សំគាល់នឹងដៃ[ម] និយាយថា ពួកសាសន៍អ៊ីស្រាអែល នឹងអស់
អ្នកដែលកោតខ្លាចដល់ព្រះអើយ សូមស្ដាប់ចុះ ១៧ព្រះនៃ
សាសន៍អ៊ីស្រាអែលយើងនេះ ទ្រង់បានរើសពួកឰយុកោ
យើងរាល់គ្នា ក៏លើកដំកើងសាសន៍យើង ក្នុងកាលដែលគេ
អាស្រ័យនៅស្រុកអេស៊ីព្ទនៅឡើយ រួចទ្រង់នាំគេចេញពី
ស្រុកនោះ[យ] ដោយព្រះហស្តដ៏មានព្រះចេស្ដា ១៨ហើយទ្រង់
បានទ្រាំទ្រនឹងកិរិយារបស់គេ[រ] នៅទីរហោស្ថាន[ល] ក្នុងរវាង
ប្រហែលជា៤០ឆ្នាំ ១៩ក្រោយដែលទ្រង់បានបំផ្លាញសាសន៍
ទាំង៧នគរ នៅស្រុកកាណាន[វ] នោះក៏ចែកស្រុករបស់គេ
ដល់ពួកឰយុកោយើង[ស]ដោយចាប់ឆ្នោត ២០ក្រោយការ
ទាំងនោះមក ទ្រង់ប្រទានឱ្យមានចៅហ្វាយ[ហ] ក្នុងរវាង
ប្រហែលជា៤៥០ឆ្នាំ ដរាបដល់គ្រាហោរាសាំយូអែល[ឡ]
២១នោះគេសូមឱ្យមានស្ដេច[អ] រួចព្រះទ្រង់តាំងសូល[ក] ជា
បុត្រគីស ក្នុងពូជអំបូរបេនយ៉ាមីន[ខ] ឱ្យធ្វើជាស្ដេចលើ
គេ នៅរវាង៤០ឆ្នាំ ២២កាលដកស្ដេចនោះចេញ
ហើយ[គ] នោះទ្រង់លើកដាវីឌ តាំងឡើងជាស្ដេចវិញ[ឃ] ក៏ធ្វើប
ន្ទាល់ពី ស្ដេចដាវីឌថា«អញរកបានដាវីឌ កូនអ៊ីសាយ ជាទី
គាប់ចិត្តដល់អញ[ង] ដែលនឹងធ្វើតាមចិត្តអញគ្រប់ជំពូក»[ច]
២៣គឺពីព្រះវង្សាស្ដេចនោះហើយ[ឆ] ដែលព្រះបានបង្កើត
ព្រះអង្គសង្គ្រោះ[ជ]១អង្គ ដល់សាសន៍អ៊ីស្រាអែលតាមសេចក្ដី
សន្យា[ឈ]គឺជាព្រះយេស៊ូវ[ញ] ២៤តែមុនដែលទ្រង់យាងមកនោះ
លោកយ៉ូហាន បានប្រកាសប្រាប់ពីបុណ្យជ្រមុជទឹក ខាងឯ
ការប្រែចិត្ត ដល់សាសន៍អ៊ីស្រាអែលទាំងអស់គ្នាជាស្រេច
ហើយ[ដ] ២៥កាលលោកយ៉ូហានកំពុងតែធ្វើសំរេចការងារ[ឋ]
នោះលោកមានប្រសាសន៍ថា តើអ្នករាល់គ្នា ស្មានថា ខ្ញុំជា
អ្នកណា ខ្ញុំមិនមែនជាព្រះអង្គនោះទេ[ឌ] តែមើល ព្រះអង្គ
នោះយាងមកក្រោយខ្ញុំ ខ្ញុំមិនគួរនឹងស្រាយខ្សែសុព៌ណ៌បាទ
ទ្រង់ផង[ឍ]។
២៦ឱបងប្អូន[ណ]ជាកូនចៅពូជអ័ប្រាហាំ[ត]នឹងអស់អ្នកក្នុងពួក
អ្នករាល់គ្នា ដែលកោតខ្លាចដល់ព្រះអើយ ទ្រង់បានផ្ញើ
ព្រះបន្ទូល ពីសេចក្ដីសង្គ្រោះនេះ[ថ] មកដល់អ្នករាល់គ្នា
២៧ដ្បិតដោយព្រោះពួកមនុស្សនៅក្រុងយេរូសាឡិម ព្រម
ទាំងពួកមេរបស់គេមិនបានស្គាល់ទ្រង់ទេ[ទ] ក៏មិនបានយល់
សេចក្ដីទំនាយរបស់ពួកហោរា[ធ] ដែលគេមើលរាល់តែថ្ងៃ
ឈប់សំរាកដែរ បានជាគេធ្វើសំរេចតាមសេចក្ដីទំនាយ
នោះឯង ដោយគេបានកាត់ទោសដល់ទ្រង់ ២៨ហើយទោះ
បើគេរកហេតុអ្វី នឹងសំឡាប់ទ្រង់មិនបានក៏ដោយ គង់តែ
គេសូមអង្វរដល់លោកពីឡាត់ ឱ្យបានសំឡាប់ទ្រង់ដែរ[ន]
២៩ក្រោយដែលគេធ្វើសំរេច គ្រប់សេចក្ដី ដែលចែងទុកពី
ទ្រង់រួចហើយ[ប] នោះគេក៏យកទ្រង់ចុះពីឈើឆ្កាង[ផ] មក
បញ្ចុះក្នុងផ្នូរ[ព] ៣០តែព្រះបានប្រោស ឱ្យទ្រង់មានព្រះជន្ម
រស់ពីស្លាប់ឡើងវិញ[ភ] ៣១ហើយទ្រង់លេចមក ឱ្យពួកអ្នក
ដែលបានឡើងពីស្រុកកាលីឡេ មកឯក្រុងយេរូសាឡិម[ម]

**១៣:១៥** ភ កច ១៥:២១
**១៣:១៦** ម កច ១២:១៧
**១៣:១៧** យ នក ៦:៦,៧ ចទ ៧:៦-៨
**១៣:១៨** រ ចទ ១:៣១ ល ជន ១៤:៣៣ ទដ ៩៥:១០ កច ៧:៣៦
**១៣:១៩** វ ចទ ៧:១ ស យស ១៩:៥១ កច ៧:៤៥ ទដ ៧៨:៥៥
**១៣:២០** ហ ពច ២:១៦ ឡ ១សយ ៣:១៩,២០ កច ៣:២៤
**១៣:២១** អ ១សយ ៨:៥,១៩ ក ១សយ ១០:១ ខ ១សយ ៩:១,២
**១៣:២២** គ ១សយ ១៥:២៣,២៦ ឃ ១សយ ១៦:១៣ ទដ ៨៩:២០ ង ១សយ ១៣:១៤ យរ ៣:១៥ ច អស ៤៤:២៨
**១៣:២៣** ឆ មថ ១:១ ជ លក ២:១១ ឈ ខ.៣២ ២សយ ៧:១១ ២២:៥១ យរ ៣០:៩ ញ មថ ១:២១
**១៣:២៤** ដ មក ១:៤ **១៣:២៥** ឋ កច ២០:២៤ ឌ យហ ១:២០ ឍ មថ ៣:១១ យហ ១:២៧ **១៣:២៦** ណ កច ២២:៥ ត លក ៣:៨ ថ កច ៤:១២ ២៨:២៨ **១៣:២៧** ទ កច ៣:១៧ ធ លក ២៤:២៧ មថ ១:២២ **១៣:២៨** ន មថ ២៧:២០-២៥ កច ៣:១៤ **១៣:២៩** ប មថ ១:២២ លក ១៨:៣១ ផ កច ៥:៣០ ព លក ២៣:៥៣ **១៣:៣០** ភ មថ ១៦:២១ ២៨:៦ កច ២:២៤ **១៣:៣១** ម មថ ២៨:១៦

បញ្ជូនឱ្យមករស់នៅក្នុងទីក្រុងនេះ ដោយទទួលបានដីធ្លី និងសិទ្ធិជាប្រជាពលរដ្ឋនៃទីក្រុងរ៉ូម ។ *សាលាប្រជុំ* ត្រង់ចំណុចនេះបញ្ជាក់ថា លោកប៉ុលតែងអធិប្បាយនៅក្នុងសាលាប្រជុំគ្រប់ខណៈ ពេលដែលពួកយូដាអនុញ្ញាត (ខ.៥ ១៤:១ ១៧:១,១០,១៧ ១៨:៤,១៩ ១៩:៨)។ មូលហេតុដែលលោកប៉ុលធ្វើយ៉ាងដូច្នោះ ព្រោះគាត់ចង់ឱ្យពួកគេយល់ច្បាស់អំពីផែនការប្រោសលោះរបស់ព្រះអម្ចាស់ (ខ.៤៦ រម ២:៩-១០ ៩-១១ មើលពន្យល់ រម ១:១៦ ២:១០)។ ទាំងអស់នោះបង្ហាញថា គាត់ពុំបានធ្វេសប្រហែសនៅក្នុងការបម្រើព្រះអម្ចាស់ទេ (ខ.១៦ មើលការពន្យល់ ១០:២)។ ជាងនេះទៅទៀត នៅក្នុងសាលាប្រជុំ ក៏បានផ្ដល់ឱ្យគាត់ នូវការយល់ដឹងអំពីស្ថានភាព នៃការអធិប្បាយ ការបង្កើតគម្រោងសម្រាប់ជួបប្រជុំ និងមានឱកាសជួបអស់អ្នកដែលមានការយល់ដឹងច្បាស់លាស់អំពីព្រះគម្ពីរសញ្ញាចាស់ផងដែរ ។

**១៣:១៥** *ក្រិត្យវិន័យ និងគម្ពីរពួកហោរា* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកគេមានទម្លាប់លើកយកបទគម្ពីរសញ្ញាចាស់មកអាន និងអធិប្បាយ ហើយបញ្ចប់ដោយការទូន្មានផ្សេងៗ ។ *មេសាលា* "មើលការពន្យល់ មក ៥:២២"។ *សេចក្ដីអ្វីនឹងទូន្មាន* "មើលសេចក្ដីផ្ដើមព្រះគម្ពីរហេព្រើរ"។

**១៣:២០** *ប្រហែលជា៤៥០ឆ្នាំ* គឺសំដៅលើរយៈពេល៤០០ឆ្នាំដែលប្រជាជនអ៊ីស្រាអែលបានរស់នៅប្រទេសអេស៊ីព្ទ (ខ.១៧ មើលការពន្យល់ ៧:៦) បន្ថែម៤០ឆ្នាំនៅទីរហោស្ថាន និងរយៈពេលចាប់អំពីការឆ្លងទន្លេយ័រដាន់រហូតដល់ការបែងចែកស្រុកឱ្យពួកកូនចៅអ៊ីស្រាអែល (យស ១៤-១៩)។

**១៣:២៣** *តាមសេចក្ដីសន្យា* "សូមមើល អស ១១:១-១៦"។

**១៣:២៥** *លោកយ៉ូហាន . . . មានប្រសាន៍ថា* "សូមមើល មថ ៣:១១ មក ១:៧ លក ៣:១៦ យហ ១:២០,២៧"។

**១៣:២៦** *ក្នុងពួកអ្នករាល់គ្នា ដែលកោតខ្លាចដល់ព្រះ* "មើលពន្យល់ ខ.១៤"។

**១៣:២៨** *ទោះបើគេរកហេតុអ្វី នឹងសំឡាប់ទ្រង់មិនបានក៏ដោយ* "មើលការពន្យល់ យហ ១៩:៤"។

**១៣:២៩-៣១** *ឈើឆ្កាង. . . ផ្នូរ. . . ព្រះបានប្រោស . . .* (មើលពន្យល់ ៣:១៥)។

**១៣:៣១** *ជាយូរថ្ងៃ* គឺមានរយៈពេល៤០ថ្ងៃ (១:៣)។

ជាមួយនឹងទ្រង់បានឃើញជាយូរថ្ងៃ អ្នកទាំងនោះជាស្មរ
បន្ទាល់[យ]ពីទ្រង់ ដល់ពួកជនទាំងឡាយ ។
៣២ យើងខ្ញុំក៏ប្រាប់ដំណឹងល្អនេះ ដល់អ្នករាល់គ្នា[រ] គឺជា
សេចក្ដីសន្យា[ល] ដែលបានតាំងនឹង ពួកព្ធយុកោយើងថា
៣៣ ព្រះបានធ្វើសំរេចតាមសេចក្ដីសន្យាទ្រង់ ដល់យើងជា
ពូជនៃពួកព្ធយុកោនោះហើយ ដោយទ្រង់បានប្រោសឱ្យ
ព្រះយេស៊ូវ[វ] មានព្រះជន្មរស់ឡើងវិញ ដូចមានសេចក្ដី
ចែងទុកមក ក្នុងទំនុកដំកើង បទទី២ថា «ឯងជាកូនអញ
អញបានបង្កើតឯងនៅថ្ងៃនេះ»[ស] ៣៤ ហើយដែលព្រះបាន
ប្រោសឱ្យទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ ដើម្បីមិន
ឱ្យទ្រង់ត្រឡប់ទៅឯសេចក្ដីពុករលួយទៀតឡើយ នោះទ្រង់
មានបន្ទូលដូច្នេះថា «អញនឹងផ្ដល់សេចក្ដីមេត្តាករុណា
ស្មោះត្រង់ ដែលឱ្យដល់ដាវីឌ ដល់ឯងរាល់គ្នាដែរ»[ហ]
៣៥ ហេតុដូច្នេះ បានជាទ្រង់មានបន្ទូល ក្នុងបទ១ទៀតថា
«ទ្រង់មិនទុកឱ្យអ្នកបរិសុទ្ធនៃទ្រង់ឃើញ សេចក្ដីពុករលួយ
ឡើយ»[ឡ] ៣៦ រីឯហ្លួងដាវីឌ កាលទ្រង់បានធ្វើការងារ
ចំពោះមនុស្សជំនាន់ទ្រង់ តាមព្រះហឫទ័យព្រះរួចស្រេច
ហើយ នោះក៏ផុតលក់ទៅ[អ] ហើយបានប្រមូលទៅមូលនឹង
ពួកព្ធយុកោទ្រង់[ក] ក៏ឃើញសេចក្ដីពុករលួយដែរ ៣៧ តែ
ព្រះអង្គនោះ ដែលព្រះបានប្រោសឱ្យរស់ឡើងវិញ[ខ] ទ្រង់
មិនបានឃើញសេចក្ដីពុករលួយឡើយ ៣៨ ដូច្នេះ អ្នករាល់
គ្នាជាបងប្អូនអើយ សូមជ្រាបថាដែលមានសេចក្ដីប្រោស
ឱ្យរួចពីបាប បានប្រកាសប្រាប់ ដល់អ្នករាល់គ្នានោះគឺ
ដោយសារព្រះអង្គនោះឯង[គ] ៣៩ មួយទៀត ដោយសារទ្រង់
អស់អ្នកណាដែលជឿ[ឃ]បាន រាប់ជាសុចរិត រួចពីគ្រប់ការ
ទាំងអស់ ដែលពុំអាចនឹងបានរាប់ជាសុចរិតដោយសារ
ក្រិត្យវិន័យលោកម៉ូសេ បានឡើយ[ង] ៤០ ដូច្នេះ ត្រូវប្រយ័ត្ន
ក្រែងអ្នករាល់គ្នាកើតមាន សេចក្ដីដែលពួកហោរាបាន
ទាយទុកថា ៤១ «នែ អស់អ្នក ដែលមើលងាយអើយ ចូរ
ភាំងឆ្ងល់ ហើយវិនាសទៅចុះ ដ្បិតអញធ្វើការ១នៅជំនាន់
ឯងរាល់គ្នា គឺជាការដែលឯងរាល់គ្នាមិនព្រមជឿឡើយ
ទោះបើមានគេប្រាប់មកឯង រាល់គ្នាក៏ដោយ»[ច]។
៤២ កាលពួកសាសន៍យូដា បានចេញពីសាលាប្រជុំទៅ
ហើយ[ឆ] នោះពួកសាសន៍ដទៃ ក៏សូមឱ្យប៉ុលអធិប្បាយ តាម
សេចក្ដីទាំងនោះ នៅថ្ងៃឈប់សំរាក មួយក្រោយទៀត
៤៣ កាលពួកអ្នកប្រជុំនោះបានបែកចេញពីគ្នាទៅ នោះមាន
ពួកសាសន៍យូដា នឹងពួកចូលសាសន៍ជាច្រើន ដែលមក
ថ្វាយបង្គំ គេដើរតាមប៉ុល នឹងបាណាបាស ដែលទូន្មានឱ្យ
គេកាន់ខ្ជាប់ក្នុងព្រះគុណនៃព្រះ[ជ]។
៤៤ ដល់ថ្ងៃឈប់សំរាកក្រោយ នោះពួកអ្នកក្រុងស្ទើរតែ
ទាំងអស់ក៏មកប្រជុំគ្នា ដើម្បីនឹងស្ដាប់ព្រះបន្ទូល ៤៥ តែកាល
ពួកសាសន៍យូដាបានឃើញមនុស្សទាំងហ្វូងដូច្នេះ នោះ
កើតមានចិត្តពេញដោយសេចក្ដីច្រណែន ហើយក៏ឆ្លើយ
ទទឹងទាស់[ឈ]នឹងសេចក្ដីដែលប៉ុលអធិប្បាយនោះ ទាំងជំនះ
ហើយប្រមាថផង[ញ] ៤៦ ប៉ុន្តែប៉ុល នឹងបាណាបាសនិយាយ
ដោយក្លាហានថា មុខគួរឱ្យយើងខ្ញុំ ថ្លែងប្រាប់ព្រះបន្ទូល
ដល់អ្នករាល់គ្នាជាមុនដំបូង[ដ] ប៉ុន្តែដោយព្រោះអ្នករាល់គ្នា
បោះបង់ចោលព្រះបន្ទូលនោះ ហើយជំនុំជំរះកាត់ទោស
ដល់ខ្លួនឯងថា មិនគួរនឹងទទួលបានជីវិតដ៏នៅអស់កល្ប
ជានិច្ចនោះទេ ហេតុដូច្នេះបានជាយើងខ្ញុំបែរទៅឯពួក
សាសន៍ដទៃវិញ[ឋ] ៤៧ ដ្បិតព្រះអម្ចាស់ ទ្រង់បានបង្គាប់មក
យើងខ្ញុំដូច្នេះថា «អញបានតាំងឯងសំរាប់ជាពន្លឺដល់សា
សន៍ដទៃ[ឌ] ដើម្បីឱ្យឯងបានសំរាប់ជាសេចក្ដីសង្គ្រោះ
ដល់ចុងផែនដីបំផុត»[ឍ]។
៤៨ កាលពួកសាសន៍ដទៃបានឮដូច្នោះ នោះគេមាន

**១៣:៣១** យ លក ២៤:៤៨
**១៣:៣២** រ អស ៤០:៩ ៥២:៧ កច ៥:៤២ ៨:៣៥ ១០:៣៦ ១៤:៧,១៥,២១ ១៧:១៨ ល កច ២៦:៦ រម ១:២ ៤:១៣ ៩:៤
**១៣:៣៣** វ កច ២:២៤ ស ទដ ២:៧ មថ ៣:១៧
**១៣:៣៤** ហ អស ៥៥:៣
**១៣:៣៥** ឡ ទដ ១៦:១០ កច ២:២៧
**១៣:៣៦** អ មថ ៩:២៤ ក ២សយ ៧:១២ ១ពវ ២:១០ ២របា ២៩:២៨ កច ២:២៩
**១៣:៣៧** ខ កច ២:២៤
**១៣:៣៨** គ លក ២៤:៤៧ កច ២:៣៨
**១៣:៣៩** ឃ យហ ៣:១៥ ង រម ៣:២៨
**១៣:៤១** ច ហប ១:៥
**១៣:៤២** ឆ ខ.១៤
**១៣:៤៣** ជ កច ១១:២៣ ១៤:២២ រម ៣:២៤
**១៣:៤៥** ឈ កច ១៨:៦ ១ពត ៤:៤ យដ ១០ ញ ១ថន ២:១៦
**១៣:៤៦** ដ ខ.២៦ កច ៣:២៦
ឋ មថ ២១:៤១ កច ១៨:៦ ២២:២១ ២៦:២០ ២៨:២៨ រម ១១:១១
**១៣:៤៧** ឌ លក ២:៣២ ឍ អស ៤៩:៦

**១៣:៣៣** *ឯងជាកូនអញ អញបានបង្កើតឯងនៅថ្ងៃនេះ* គឺសំដៅទៅលើការរស់ពីសុគតឡើងវិញនៃព្រះយេស៊ូវគ្រីស្ទ (ទដ២:៧-៩ រម ១:៤ និងពន្យល់)។
**១៣:៣៥** *ទ្រង់មិនទុកឱ្យអ្នកបរិសុទ្ធនៃទ្រង់ ឃើញសេចក្ដីពុករលួយឡើយ* សេចក្ដីនេះ ក៏មាននៅក្នុងការអធិប្បាយរបស់លោកពេត្រុស នៅថ្ងៃបុណ្យទី៥០ដែរ (មើលការពន្យល់ ២:២៧ ទដ ១៦:១០)។
**១៣:៣៩** *បានរាប់ជាសុចរិត* ត្រង់ចំណុចនេះបញ្ជាក់ថា មនុស្សបានរាប់ជាសុចរិត គឺមានជាប់ទាក់ទងទៅនឹងការពីរយ៉ាង (១). ការអត់ទោសបាប (២).ការប្រទានសេចក្ដីសុចរិតមកអំពីព្រះអម្ចាស់ (រម ៣:២១-២២)។
**១៣:៤៣** *ខ្ជាប់ក្នុងព្រះគុណនៃព្រះ* "មើលការពន្យល់ ទត ២:១១-១២"។
**១៣:៤៦** *ថ្លែងប្រាប់ព្រះបន្ទូល ដល់អ្នករាល់គ្នាជាមុនដំបូង* លោកប៉ុលនិយាយយ៉ាងដូច្នោះ ព្រោះថាដំណឹងល្អបានប្រទានមកពួកយូដាជាដំបូង ហើយគាត់ក៏ជាសាសន៍យូដា ដែលមានចិត្តក្តួលអាណិតចំពោះប្រជាជាតិខ្លួនដែរ (រម ១:១៦ ៩:១-៥ ១០:១-៣ មើលការពន្យល់ ខ.១៤)។
**១៣:៤៧** *ឯង* ពាក្យថា "ឯង" នៅត្រង់ចំណុចនេះ គឺសំដៅលើព្រះមែស៊ី (៩:១៥,១៦ ២២:១៤-១៥,២១ ២៦:១៥-១៨)។ សេចក្ដីទំនាយ ដែលលោកប៉ុលបានលើកឡើង ស្ដីអំពីភាពជាអ្នកបម្រើរបស់ព្រះមែស៊ី (អស ៤៩:៦) គឺសំដៅលើអស់អ្នកដែលបន្តបេសកកម្មថ្វាយទ្រង់ ក្នុងភាពជាអ្នកបម្រើ (មើលការពន្យល់ អស ៥៤:១៧)។
**១៣:៤៨** *ចំណែកអស់អ្នកដែលត្រូវបានជីវិតអស់កល្បជានិច្ច នោះក៏បានជឿ* មានន័យថា សេចក្ដីសង្គ្រោះដែលព្រះអម្ចាស់ប្រទានមក គឺទាក់ទងទៅនឹង

សេចក្ដីអំណរ ហើយក៏សរសើរព្រះបន្ទូលនៃព្រះអម្ចាស់[ណ]
ចំណែកអស់អ្នកដែលត្រូវបានជីវិតអស់កល្បជានិច្ចនោះ
ក៏បានជឿ ៤៩ឯព្រះបន្ទូលនៃព្រះអម្ចាស់[ត] បានផ្សាយសុស
សាយ ទូទៅពេញក្នុងស្រុកនោះ ៥០តែពួកសាសន៍យូដា
គេញុះញង់ពួកស្ត្រីអ្នកមុខអ្នកការ ដែលមកថ្វាយបង្គំ នឹង
ពួកអ្នកធំនៅក្នុងទីក្រុងនោះ បណ្ដាលឱ្យមានសេចក្ដីបៀត
បៀនដល់ប៉ុល នឹងបាណាបាស ក៏ដេញអ្នកទាំង២នោះ
ចេញពីស្រុកគេទៅ[ថ] ៥១ដូច្នេះ អ្នកទាំង២ក៏រលាស់ធូលី
ដីពីជើងចេញទាស់នឹងគេ[ទ] រួចចេញទៅឯក្រុងអ៊ីកូនាម[ធ]
៥២ឯពួកសិស្ស[ន] គេមានចិត្តពេញ ដោយសេចក្ដីអំណរ
ហើយនឹងព្រះវិញ្ញាណបរិសុទ្ធ[ប]។

## នៅឯទីក្រុងអ៊ីកូនាម

**១៤** ១កាលនៅក្រុងអ៊ីកូនាម[ផ] ក៏នាំគ្នាចូលទៅក្នុងសាលា
ប្រជុំរបស់សាសន៍យូដា[ព] បានអធិប្បាយ នាំឱ្យទាំងពួក
សាសន៍យូដា នឹងសាសន៍ក្រេកយ៉ាងសន្ធឹក[ភ]បានជឿ ២ប៉ុន្តែ
ឯពួកសាសន៍យូដាដែលមិនព្រមជឿ គេញុះញង់ ហើយចាក់
រុកពួកសាសន៍ដទៃ ឱ្យគេទាស់នឹងពួកជំនុំវិញ[ម] ៣ចំណែក
ប៉ុល នឹងបាណាបាស ក៏នៅទីនោះជាយូរថ្ងៃ គេអធិប្បាយ
យ៉ាងក្លៀវក្លា[យ]ដោយនូវព្រះអម្ចាស់ ហើយទ្រង់ក៏ធ្វើបន្ទាល់
អំពីព្រះបន្ទូលនៃព្រះគុណទ្រង់ ដោយទ្រង់ប្រោសប្រទាន
ឱ្យមានទីសំគាល់ នឹងការអស្ចារ្យកើតមក ដោយសារដៃ
អ្នកទាំង២នោះ[រ] ៤ឯមនុស្សទាំងឡាយនៅទីក្រុងនោះ គេ
បែកបាក់គ្នា អ្នកខ្លះកាន់ខាងសាសន៍យូដា ខ្លះខាងពួក
សាវក[ល] ៥តែកាលពួកសាសន៍ដទៃ នឹងពួកសាសន៍យូដា[វ]
ព្រមទាំងពួកនាម៉ឺនរបស់គេ បានលើកព្រួតគ្នានឹងទៅត្មះតិះ
ដៀល ហើយចោលនឹងថ្ម[ស] ៦នោះអ្នកទាំង២បានដឹង ហើយក៏
រត់[ហ]ទៅឯទីក្រុងនៅស្រុកលូកៅនាវិញ គឺលីស្ត្រា នឹងឌើបេ
ហើយនឹងស្រុកនៅជុំវិញ ៧ក៏ប្រកាសប្រាប់[ឡ]ដំណឹងល្អ[អ]នៅ
កន្លែងទាំងនោះ ។

## នៅទីក្រុងលីស្ត្រា និងឌើបេ

៨រីឯនៅក្រុងលីស្ត្រា មានមនុស្សម្នាក់ មានជើងពិការ
គាត់អង្គុយនៅដោយខ្វិនតាំងតែពីផ្ទៃម្ដាយមក[ក] មិនដែល
ដើរសោះឡើយ ៩អ្នកនោះបានឮប៉ុលអធិប្បាយ ហើយប៉ុល
ក៏សំឡឹងមើលទៅគាត់ ឃើញថាគាត់មានសេចក្ដីជំនឿល្មម
ដើម្បីឱ្យបានជា[ខ] ១០នោះក៏បន្លឺជាសំឡេងខ្លាំងថា ចូរក្រោក
ឈរឱ្យត្រង់ឡើង[គ] រួចអ្នកនោះក៏ស្ទុះឡើងដើរ[ឃ] ១១កាល
ហ្វូងមនុស្ស បានឃើញការដែលប៉ុលធ្វើ នោះ គេបន្លឺឡើង
ជាភាសាលូកៅនាថា ពួកព្រះបានកាឡានិម្មិតជាមនុស្ស ចុះ
មកឯយើងហើយ[ង] ១២គេក៏ហៅបាណាបាសជា ព្រះសេយូស
ហើយប៉ុលជាព្រះហ៊ើមេស ពីព្រោះគាត់ជា មេសំដែង[ច]

**១៣:៤៨** ណ ខ.៤៩ កច ៨:២៥ ១៥:៣៥,៣៦ ១៩:១០,២០ **១៣:៤៩** ត ខ.៤៨ **១៣:៥០** ថ ១ថន ២:១៦ **១៣:៥១** ទ មថ ១០:១៤ ធ កច ៤:១,១៩,២១ ១៦:២ ២ធថ ៣:១១ **១៣:៥២** ន កច ១១:២៦ ប លក ១:១៥ **១៤:១** ផ កច ១៣:៥១ ព កច ៩:២០ ភ កច ២:៤១ **១៤:២** ម កច ១:១៦ **១៤:៣** យ កច ៤:២៩ រ យហ ៤:៤៨ **១៤:៤** ល កច ១៧:៤,៥ ២៨:២៤ **១៤:៥** វ កច ២០:៣ ស ខ.១៩ **១៤:៦** ហ មថ ១០:២៣ **១៤:៧** ឡ កច ១៦:១០ អ ខ.១៥,២១ កច ១៣:៣២

**១៤:៨** ក កច ៣:២ **១៤:៩** ខ មថ ៩:២៨,២៩ ១៣:៥៨ **១៤:១០** គ អគ ២:១ ឃ កច ៣:៨ **១៤:១១** ង កច ៨:១០ ២៨:៦ **១៤:១២** ច នក ៧:១

ព្រះគុណ និងសេចក្ដីជំនឿដែលពួកគេមានចំពោះទ្រង់ ។

**១៣:៥១** *រលាស់ធូលីដី* ទង្វើយ៉ាងដូច្នេះ គឺបង្ហាញអំពីការឈប់ទទួលខុសត្រូវចំពោះអ្នកទាំងឡាយណាដែលបដិសេធព្រះបន្ទូល និងនាំឱ្យមានសេចក្ដីវេទនាដល់អ្នកបម្រើរបស់ព្រះអម្ចាស់ (មើលការពន្យល់ លក ៩:៥)។ *ក្រុងអ៊ីកូនាម* (បច្ចុប្បន្នឈ្មោះថា កុនយ៉ា Konya) ទីក្រុងនេះជាមជ្ឈមណ្ឌលកសិកម្មមួយដ៏សំខាន់នៅកណ្ដាលវាលទំនាបនៃស្រុកកាឡាទី ។

**១៣:៥២** *ពេញ. . . ហើយនិងព្រះវិញ្ញាណបរិសុទ្ធ* "មើលពន្យល់ ២:៤"។

**១៤:១** *ចូលទៅក្នុងសាលាប្រជុំ* "មើលការពន្យល់ ១៣:១៤"។ *យ៉ាងសន្ធឹក* ដំបូងមានពួកសិស្សជាច្រើនបានចម្រើនឡើង បន្ទាប់មកមានការបៀតបៀនដ៏ខ្លាំងក្លាពីសំណាក់ពួកសាសន៍យូដា (ខ.២)។ ប៉ុន្តែ ការប្រឆាំងលើកទី១មិនបានសម្រេចទេ ព្រោះមានភស្តុតាងបញ្ជាក់ថា លោកប៉ុល និងបាណាបាសនៅតែបន្តការងាររបស់ខ្លួននៅទីនោះដដែល (ខ.៣)។ រីឯផែនការប្រឆាំងលើកទី២របស់ពួកគេវិញ មានសភាពរឹតតែធ្ងន់ធ្ងរ និងឃោរឃៅជាងមុន (ខ.៥)។

**១៤:៣** *ទ្រង់ក៏ធ្វើបន្ទាល់...ឱ្យមានទីសំគាល់ និងការអស្ចារ្យ* គោលបំណងសំខាន់នៃការប្រទានឱ្យមានទីសំគាល់ និងការអស្ចារ្យ គឺដើម្បីបញ្ជាក់សេចក្ដីពិតនៃព្រះបន្ទូលរបស់ព្រះអម្ចាស់ និងសេចក្ដីស្រលាញ់របស់ទ្រង់ (មើលការពន្យល់ ២:២២)។

**១៤:៤** *ពួកសាវក* នៅពេលនោះ គេហៅលោកប៉ុល និងបាណាបាស ថា "សាវក" (ខ.១៤ មើលការពន្យល់ មក ៦:៣០)។ ទាំងពីរនាក់នេះត្រូវបានហៅយ៉ាងដូច្នេះ ពុំមែនមានន័យថា ពួកគាត់ជាសាវកក្នុងចំណោមពួកទាំង ១២នោះទេ ប៉ុន្តែ ព្រោះពួកគាត់ត្រូវបានបញ្ជូនឱ្យទៅបំពេញបេសកកម្មថ្វាយព្រះអម្ចាស់ (១៣:២-៣)។

**១៤:៥** *ចោលនឹងថ្ម* នេះជារបៀបដាក់ទោសប្រហារជីវិតរបស់ពួកយូដាចំពោះអស់អ្នកណា ដែលប្រមាថដល់ព្រះអម្ចាស់ (មើលការពន្យល់ យហ ១០:៣១)។ សកម្មភាពដែលពួកយូដាចង់សម្លាប់លោកប៉ុល និងបាណាបាសប្រហែលជាចាប់ផ្ដើមឡើងនៅក្នុងខណៈពេលនោះតែម្ដង ។

**១៤:៦** *ទីក្រុងនៅស្រុកលូកៅនា* ស្រុកលូកៅនាស្ថិតនៅភាគខាងកើតនៃស្រុកពីស៊ីឌានិងភាគខាងជើងនៃជួរភ្នំតូរូស (Taurus)។ ស្រុកនេះគឺជាផ្នែកមួយនៃខេត្តកាឡាទី ដែលនៅក្រោមការគ្រប់គ្រងរបស់ចក្រភពរ៉ូម៉ាំង ។ *លីស្ត្រា* ជាទីក្រុងមួយស្ថិតនៅចម្ងាយប្រហែល៣២គ.មពីទីក្រុងអ៊ីកូនាម និង២០៩គ.មពីទីក្រុងអាន់ទីយ៉ូក ។ ទីក្រុងនេះជាដែនដីអាណានិគមរបស់ចក្រភពរ៉ូម៉ាំង (មើលការពន្យល់ ១៣:១៤) និងជាទីកន្លែងដែលលោកធីម៉ូថេរស់នៅ (មើលការពន្យល់ ១៦:១,២ គាត់ត្រូវបានគេស្គាល់នៅឯទីក្រុងអ៊ីកូនាមផងដែរ)។ *ឌើបេ* ជាទីក្រុងមួយស្ថិតនៅចម្ងាយប្រហែល ៩៦,៥ គ.ម ភាគខាងកើតនៃទីក្រុងលីស្ត្រា ហើយក៏ជាទីកន្លែងដែលលោកកៃយុសរស់នៅផងដែរ (២០:៤ មើលការពន្យល់ ១៤:២០)។

**១៤:១២** *ព្រះសេយូស. . . ព្រះហ៊ើមេស* សេយូសជាព្រះរបស់ពួកលីស្ត្រា

## សេចក្ដីបង្រៀនរបស់ព្រះយេស៊ូវជារឿងប្រៀបប្រដូច

| រឿងប្រៀបប្រដូច | គម្ពីរម៉ាថាយ | គម្ពីរម៉ាកុស | គម្ពីរលូកា |
|---|---|---|---|
| ចង្កៀងដែលគ្របនឹងថាំង | ៥:១៤–១៥ | ៤:២១–២២ | ៨:១៦, ១១:៣៣ |
| មនុស្សល្ងង់ និងមនុស្សឆ្លាតសង់ផ្ទះ | ៧:២៤–២៧ | | ៦:៤៧–៤៩ |
| ក្រណាត់ថ្មីប៉ះអាវចាស់ | ៩:១៦ | ២:២១ | ៥:៣៦ |
| ស្រាថ្មីដាក់ក្នុងថង់ចាស់ | ៩:១៧ | ២:២២ | ៥:៣៧–៣៨ |
| អ្នកព្រោះគ្រាប់ពូជ | ១៣:៣–៨,១៨–២៣ | ៤:៣–៨,១៤–២០ | ៨:៥–៨,១១–១៥ |
| ស្រងែ | ១៣:២៤–៣០,៣៦–៤៣ | | |
| គ្រាប់ពូជតូចល្អិត | ១៣:៣១–៣២ | ៤:៣០–៣២ | ១៣:១៨–១៩ |
| ដំបែ | ១៣:៣៣ | | ១៣:២០–២១ |
| កំណប់ដែលបានកប់ទុក | ១៣:៤៤ | | |
| កែវមុក្តា | ១៣:៤៥–៤៦ | | |
| សំណាញ់ | ១៣:៤៧–៥០ | | |
| ចៅកែម្នាក់ | ១៣:៥២ | | |
| ចៀមដែលបាត់ | ១៨:១២–១៤ | | ១៥:៤–៧ |
| បាវបម្រើដែលគ្មានក្ដីមេត្តា | ១៨:២៣–៣៤ | | |
| ពួកអ្នកស៊ីឈ្នួលធ្វើចំការទំពាំងបាយជូរ | ២០:១–១៦ | | |
| កូនប្រុសពីរនាក់ | ២១:២៨–៣២ | | |
| ពួកអ្នកជួលចំការទំពាំងបាយជូរ | ២១:៣៣–៤៤ | ១២:១–១១ | ២០:៩–១៨ |
| ពិធីជប់លៀងក្នុងមង្គលការ | ២២:២–១៤ | | |
| ដើមល្វា | ២៤:៣២–៣៥ | ១៣:២៨–២៩ | ២១:២៩–៣១ |
| បាវបម្រើវៃឆ្លាត ហើយស្មោះត្រង់ | ២៤:៤៥–៥១ | | ១២:៤២–៤៨ |
| ស្ត្រីព្រហ្មចារីទាំង១០នាក់ | ២៥:១–១៣ | | |
| បាវបម្រើល្អ ហើយស្មោះត្រង់ | ២៥:១៤–៣០ | | ១៩:១២–២៧ |
| ចៀម និងពពែ | ២៥:៣១–៤៦ | | |
| គ្រាប់ពូជ | | ៤:២៦–២៩ | |
| បាវបម្រើដែលចាំយាម | | ១៣:៣៥–៣៧ | ១២:៣៥–៤០ |
| អ្នកឱ្យប្រាក់គេខ្ចី | | | ៧:៤១–៤៣ |
| សាសន៍សាម៉ារីដ៏ល្អ | | | ១០:៣០–៣៧ |
| មិត្តសំឡាញ់ក្នុងពេលខ្វះខាត | | | ១១:៥–៨ |
| អ្នកចងការ | | | ១២:១៦–២១ |
| ដើមល្វាដែលមិនបង្កើតផលផ្លែ | | | ១៣:៦–៩ |
| កន្លែងក្រោយបង្អស់ក្នុងពិធីបរិភោគការ | | | ១៤:៧–១៤ |
| ពិធីជប់លៀងដ៏ធំ | | | ១៤:១៦–២៤ |
| ការលះបង់ដើម្បីធ្វើជាសិស្សព្រះយេស៊ូវ | | | ១៤:២៨–៣៣ |
| ប្រាក់ដែលបាត់ | | | ១៥:៨–១០ |
| កូនពៅវង្វេង (ខ្ជះខ្ជាយ) | | | ១៥:១១–៣២ |
| អ្នកត្រួតត្រាដែលមានប្រាជ្ញាល្អិត | | | ១៦:១–៨ |
| អ្នកមាន និងឡាសារ | | | ១៦:១៩–៣១ |
| ចៅហ្វាយ និងបាវបម្រើ | | | ១៧:៧–១០ |
| ស្ត្រីមេម៉ាយម្នាក់មានចិត្តតស៊ូ | | | ១៨:២–៨ |
| ពួកផារិស៊ី និងពួកអ្នកយកពន្ធ | | | ១៨:១០–១៤ |

១៣ហើយសង្ឃរបស់ព្រះសេយូស ដែលនៅមុខក្រុងគេ ក៏នាំ
យកគោឈ្មោល ហើយនឹងភួងទៅដល់ខ្លោងទ្វារក្រុង ចង់
ថ្វាយយញ្ញបូជា ជាមួយនឹងបណ្ដាមនុស្ស ១៤កាលបាណា
បាស នឹងប៉ុល ជាសាវកបានដឹង នោះក៏ហែកអាវ
ខ្លួន[ឆ] រត់ចូលទៅកណ្ដាលហ្វូងមនុស្ស ស្រែកឡើងថា
១៥អ្នករាល់គ្នាអើយ ហេតុអ្វីបានជាធ្វើដូច្នេះ យើងខ្ញុំជា
មនុស្ស[ជ] វិស័យដូចជាអ្នករាល់គ្នាដែរ មួយទៀត យើងក៏
ប្រកាសប្រាប់ដំណឹងល្អ[ឈ] ដល់អ្នករាល់គ្នា ឱ្យបានបែរចេញ
ពីអស់ទាំងការ ដែលឥតប្រយោជន៍យ៉ាងនេះ[ញ] ទៅឯព្រះដ៏
មានព្រះជន្មរស់វិញ[ដ] ដែលទ្រង់បង្កើតផ្ទៃមេឃ ផែនដី[ឋ]
សមុទ្រ នឹងរបស់ទាំងអស់ ដែលនៅស្ថានទាំងនោះផង[ឌ]
១៦ក្នុងកាលជិនាន់មនុស្សពីបុរាណនោះ ទ្រង់បានអនុញ្ញាត[ឍ]
ឱ្យគ្រប់ទាំងសាសន៍ ដើរតាមផ្លូវរបស់គេរៀងខ្លួន[ណ] ១៧ប៉ុន្តែ
ទ្រង់មិនដែលលែងមានទីបន្ទាល់ពីព្រះអង្គទ្រង់ទេ[ត] ដោយ
ទ្រង់តែងតែផ្សាយព្រះគុណមក គឺទ្រង់ប្រោសប្រទាន ឱ្យ
ភ្លៀងធ្លាក់ចុះពីលើមេឃ ឱ្យមានរដូវដ៏សំបូរ[ថ] ដើម្បីនឹង
បំពេញចិត្តយើង ដោយអាហារ នឹងសេចក្ដីអំណរ[ទ] ១៨តែ
ដែលគាត់អធិប្បាយសេចក្ដីទាំងនោះដល់គេ នោះឃាត់គេ
មិនឱ្យថ្វាយយញ្ញបូជាដល់ខ្លួនសឹងតែមិនបានផង ។
១៩មានពួកសាសន៍យូដាខ្លះ[ធ]មកពីអាន់ទីយ៉ូក នឹងអ៊ីកូនាម[ន]
គេបញ្ចុះបញ្ចូលហ្វូងមនុស្ស ឱ្យចោលប៉ុលនឹងថ្ម[ប] រួចគេ
អូសគាត់ចេញទៅក្រៅទុកចោល ដោយស្មានថាបានស្លាប់
ហើយ ២០ប៉ុន្តែ ពួកសិស្ស[ផ]មកចោមព័ទ្ធគាត់ រួចគាត់ក្រោក
ឡើង ចូលទៅក្នុងទីក្រុងវិញ ហើយដល់ថ្ងៃស្អែក គាត់និង
បាណាបាសក៏ចេញទៅឯឌើបេ ។

**ការវិលត្រឡប់ទៅឯទីក្រុងអាន់ទីយ៉ូក**

២១ក្រោយដែលប្រកាសប្រាប់ដំណឹងល្អ[ព] ហើយបានសិស្ស
ជាច្រើន[ភ]នៅក្រុងនោះ នោះក៏ត្រឡប់ទៅឯលីស្ត្រា អ៊ីកូនាម[ម]
នឹងអាន់ទីយ៉ូកវិញ ២២ព្រមទាំងចំរើនកំឡាំងដល់ពួកសិស្ស
ឱ្យមានចិត្តរឹងប៉ឹងឡើង ហើយទូន្មាន ឱ្យនៅស្ថិតស្ថេរក្នុង
សេចក្ដីជំនឿ[យ] ដោយពាក្យថា ត្រូវតែទ្រាំរងទុក្ខវេទនា
ជាច្រើន[រ] ទើបនឹងចូលទៅក្នុងនគរព្រះបាន ២៣កាលបាន
រើសពួកចាស់ទុំ តាំងឡើង[ល] ក្នុងគ្រប់ទាំងពួកជំនុំហើយ
អធិស្ឋានទាំងតម[វ]នោះក៏ប្រគល់គេទុកនឹងព្រះអម្ចាស់[ស]ដែល

**១៤:១៤** ឆ មក ១៤:៦៣
**១៤:១៥** ជ កច ១០:២៦ ឈ ខ.៧,២១ កច ១៣:៣២ ញ ១សយ ១២:២១ ១ធថ ១:៩ ដ មថ ១៦:១៦ ឋ លប ១:១ ឌ ទដ ១៤៦:៦ វវ ១៤:៧
**១៤:១៦** ឍ កច ១៧:៣០ ណ ទដ ៨១:១២ មីក ៤:៥
**១៤:១៧** ត រម ១:២០ ថ ចទ ១១:១៤ យប ៥:១០ ទដ ៦៥:១០ ទ ទដ ៤:៧
**១៤:១៩** ធ កច ១៣:៤៥ ន កច ១៣:៥១ ប ២កថ ១១:២៥ ២ធថ ៣:១១
**១៤:២០** ផ ខ.២២, ២៨ កច ១១:២៦
**១៤:២១** ព កច ១៣:៣២ ភ កច ២:៤១ ម កច ១៣:៥១
**១៤:២២** យ កច ១១:២៣ ១៣:៤៣ រ យហ ១៦:៣៣ ១ថន ៣:៣ ២ធថ ៣:១២ **១៤:២៣** ល កច ១១:៣០ វ កច ១៣:៣ ស កច ២០:៣២

ហើយមានទាំងវិហារនៅទីនោះផង ។ ក្រោយមក អស់អ្នកដែលបាននាំយញ្ញបូជាដល់ព្រះសេយូស បានសម្រេចចិត្តនាំដង្វាយមកជូនលោកប៉ុល និង បាណាបាសវិញ ដោយពួកគេចាត់ទុកលោកបាណាបាសដូចជាព្រះសេយូស (ប្រហែលមកពីគាត់មានលក្ខណៈគួរឱ្យគោរព) ហើយលោកប៉ុលដូចជាព្រះហើមេស ពីព្រោះគាត់ជាអ្នកនាំពាក្យ (២៨:៦) ។ ហេតុការណ៍ទាំងនេះប្រហែលជាបានកើតឡើងជូនគ្នានឹងរឿងព្រេងបុរាណមួយ ដែលនិយាយថា នៅក្នុងពេលណាមួយព្រះសេយូស និងព្រះហើមេសនឹងមកទីកន្លែងដែលពួកគេកំពុងរស់នៅនោះ ។ រីឯលោកប៉ុល និង បាណាបាស ក៏ព្រមានពួកគេថា មិនត្រូវឱ្យមានហេតុការណ៍ទាំងនេះកើតឡើងទៀតឡើយ ។

**១៤:១៣** *ខ្លោងទ្វារក្រុង* ពាក្យនេះនៅក្នុងភាសាក្រិកអាចសំដៅលើទ្វារព្រះវិហារ ទ្វារទីក្រុង ឬទ្វារផ្ទះ ។

**១៤:១៤** *ក៏ហែកអាវខ្លួន* សម្រាប់ពួកសាសន៍យូដា ទង្វើបែបនេះជានិមិត្តរូបមួយបង្ហាញថា ពួកគេមានសេចក្ដីទុក្ខលំបាកជាខ្លាំង ដែលមិនអាចរៀបរាប់បាន (លប ៣៧:២៩,៣៤) ។ លោកប៉ុល និងបាណាបាសធ្វើយ៉ាងដូច្នោះបញ្ជាក់ថា ពួកគាត់បដិសេធមិនព្រមទទួលនូវការសរសើរណាមួយសម្រាប់ខ្លួនទេ ។

**១៤:១៥** *អស់ទាំងការដែលឥតប្រយោជន៍* ពាក្យនេះប្រើនៅក្នុងគម្ពីរសញ្ញាចាស់ច្រើនសំដៅទៅលើរូបព្រះឬព្រះរបស់សាសន៍ដទៃ (១សយ ១២:២១) ។

**១៤:១៦** "មើលការពន្យល់ ១៧:៣០" ។

**១៤:១៩** *ឱ្យចោលប៉ុលនឹងថ្ម* គេចង់ចោលសម្លាប់លោកប៉ុលនឹងថ្ម នៅខាងក្នុងទីក្រុងតែម្ដង គឺមិនមែនជាកន្លែងដែលគេធ្លាប់តែសម្លាប់មនុស្ស នៅឯខាងក្រៅជញ្ជាំងទីក្រុងនោះទេ (៧:៥៨ មើលការពន្យល់ កទ ៦:១៧) ។

**១៤:២០** *ពួកសិស្សមកចោមព័ទ្ធគាត់* នៅក្នុងខណៈពេលនោះ ប្រហែលជាយុវជនឈ្មោះធីម៉ូថេក៏មានវត្តមាននៅទីនោះដែរ (២ធថ ៣:១០-១១ មើលការពន្យល់ ៣:១១) ។ *រួចគាត់ក្រោកឡើង. . . ដល់ស្អែក. . .ក៏ចេញ* គោលបំណងដែលលោកលូកាពិពណ៌នា អំពីការជាសះស្បើយយ៉ាងឆាប់រហ័សរបស់លោកប៉ុល គឺចង់បញ្ជាក់ថា នោះគឺជាការអស្ចារ្យមកអំពីព្រះអម្ចាស់ (២៨:៥-៦) ។ *ឌើបេ* ជាទីក្រុងមួយ ដែលមានព្រំប្រទល់ជាប់នឹងស្រុកលូកៅនាភាគខាងជើង (មើលការពន្យល់ ខ.៦) ។ សិលាចារឹកដែលនិយាយអំពីឈ្មោះនៃទីក្រុងឌើបេ ត្រូវបានគេរកឃើញ នៅចម្ងាយប្រហែល ៤៨គមភាគខាងកើតនៃតំបន់ទីក្រុងនោះតែម្ដង ។

**១៤:២១** *ក៏ត្រឡប់ទៅឯលីស្ត្រា. . . វិញ* ពុំមែនធ្វើដំណើរតាមផ្លូវកាត់នៃជួរភ្នំតូរូសទេ ប៉ុន្តែ ទៅតាមទីក្រុងមួយចំនួនដែលពួកគេបានបង្កើតពួកជំនុំ (ខ.២២) ។

**១៤:២២** *ត្រូវតែទ្រាំរងទុក្ខវេទនាជាច្រើន* "មើលពន្យល់ ភល ១:២៩" ។

**១៤:២៣** *តាំងឡើង* ពាក្យនេះជាភាសាក្រិក (ត្រូវបានប្រើនៅក្នុង ២កថ ៨:១៩ ផងដែរ) អាចមានន័យថា (១).លាតសន្ធឹងដៃ (២).តាំងឡើងដោយលើកដៃ (៣).តែងតាំង ឬជ្រើសរើស ដោយមិនពឹងអាងទៅលើទ្រឹស្ដី ឬប្រព័ន្ធណាមួយឡើយ ។ ការតែងតាំងពួកទាំង៧នាក់នៅក្នុង "៦:៦" កើតឡើងដោយការជ្រើសរើសរបស់ពួកជំនុំ និងការតែងតាំងរបស់ពួកសាវ័កដែលជាអ្នកអធិស្ឋានដាក់ដៃលើពួកគេ ។ លោកប៉ុល និងលោកបាណាបាសប្រហែលជាជ្រើសរើសឱ្យមានពួកចាស់ទុំ ហើយតែងតាំងពួកគេតែម្ដង

គេបានជឿដល់ទ្រង់ហើយ [២៤]រួចនាំគ្នាដើរកាត់ស្រុកពីស៊ីឌា
ទៅរហូតដល់ស្រុកប៉ាមភីលា [២៥]ក្រោយដែលអធិប្បាយតាម
ព្រះបន្ទូលនៅក្រុងពើការួចហើយ នោះក៏ចុះទៅឯអាតាលា
[២៦]ក៏ចុះសំពៅពីទីនោះ ត្រឡប់ទៅឯអាន់ទីយ៉ូកវិញ[ឡ] ជា
កន្លែង ដែលគេបានទុកដាក់អ្នកទាំង២ ក្នុងព្រះគុណនៃព្រះ[អ]
សំរាប់ការ ដែលទើបនឹងធ្វើសំរេច[ក] [២៧]លុះដល់ហើយ ក៏
ប្រមូលពួកជំនុំមក ថ្លែងប្រាប់ពីការដែលព្រះបានធ្វើដោយ
សារខ្លួន[ខ] ហើយពីទ្រង់បានបើកទ្វារ[គ] នៃសេចក្ដីជំនឿដល់
សាសន៍ដទៃដែរ [២៨]រួចក៏នៅទីនោះជាមួយនឹងពួកសិស្សជា
យូរក្រៃល[ឃ]។

## ការប្រឹក្សាយោបល់នៅឯទីក្រុងយេរូសាឡិម

**១៥** [១]មានមនុស្សខ្លះ[ង] ចុះពីស្រុកយូដា មកបង្រៀនដល់
ពួកជំនុំ[ច]ថា បើមិនបានកាត់ស្បែក[ឆ] តាមទំលាប់របស់លោក
ម៉ូសេ[ជ] នោះពុំអាចនឹងបានសង្គ្រោះឡើយ [២]ដូច្នេះកាលប៉ុល
នឹងបាណាបាស បានជជែកនឹងគេ ហើយមានសេចក្ដីដេញ
ដោលគ្នាជាខ្លាំងរួចហើយ នោះពួកជំនុំបានដំរូវឱ្យប៉ុល និង
បាណាបាស ព្រមទាំងអ្នកខ្លះទៀតក្នុងពួកគេ ឡើងទៅឯពួក
សាវក និងពួកចាស់ទុំ[ឈ] នៅក្រុងយេរូសាឡិម[ញ] ដើម្បីនឹង
សួរបញ្ជាក់ពីដំណើរនោះ [៣]ដូច្នេះពួកជំនុំក៏ចេញជូនដំណើរ
អ្នកទាំងនោះទៅ រួចគេដើរកាត់ស្រុកភេនីស[ដ] និងស្រុក
សាម៉ារី ទាំងថ្លែងប្រាប់ពីរឿង ដែលសាសន៍ដទៃបានប្រែ
ចិត្តជឿ[ឋ] គេក៏នាំឱ្យពួកជំនុំទាំងអស់ មានសេចក្ដីអំណរជា
ខ្លាំង [៤]លុះដល់ក្រុងយេរូសាឡិមហើយ នោះពួកជំនុំ ពួក
សាវក និងពួកចាស់ទុំក៏រាក់ទាក់ទទួលគេ រួចគេថ្លែងប្រាប់
ពីគ្រប់ការទាំងអស់ ដែលព្រះបានធ្វើ ដោយសារខ្លួន[ឌ]
[៥]នោះមានអ្នកខ្លះក្នុងពួក[ឍ]ផារិស៊ី[ណ] ដែលជឿគេឈរឡើង
និយាយថា ត្រូវតែកាត់ស្បែកឱ្យពួកសាសន៍ដទៃនោះ ហើយ
បង្គាប់ឱ្យកាន់តាមក្រិត្យវិន័យរបស់លោកម៉ូសេដែរ[ត]។

**១៤:២៤** ហ កច ២:១០
**១៤:២៦** ឡ កច ១១:១៩
អ កច ១១:២៣
ក កច ១៣:១,៣
**១៤:២៧** ខ កច ១៥:៤,១២ ២១:១៩
គ ១កថ ១៦:៩ ២កថ ២:១២ កល ៤:៣ វវ ៣:៨
**១៤:២៨** ឃ កច ១១:២៦
**១៥:១** ង ខ.២៤ កទ ២:១២ ច កច ១:១៦ ឆ ខ.៥ កទ ៥:២,៣ ជ កច ៦:១៤
**១៥:២** ឈ កច ១១:៣០ ញ កទ ២:២
**១៥:៣** ដ កច ១១:១៩ ឋ កច ១៤:២៧ **១៥:៤** ឌ ខ.១២ កច ១៤:២៧ ២១:១៩ **១៥:៥** ឍ កច ៥:១៧ ណ មថ ៣:៧ ត ខ.១

ព្រោះថាពួកជំនុំទាំងនោះទើបចាប់ផ្ដើម ។

**១៤:២៤** *ស្រុកពីស៊ីឌា* ជាស្រុកមួយមានបណ្ដោយប្រហែល ១៩៣ គ.ម និងទទឹងប្រហែល ៨០,៤គ.ម និងស្ថិតនៅភាគខាងជើងនៃស្រុកប៉ាមភីលា (១៣:១៣-១៤)។ អំពើចោរកម្មកើតមានជារឿយៗនៅក្នុងស្រុកនោះ (២កថ ១១:២៦)។ *ស្រុកប៉ាម ភីលា* ជាស្រុកមួយស្ថិតនៅភាគខាងលិចបំផុតនៃទ្វីបអាស៊ី (ឆៀងខាងត្បូង) មានបណ្ដោយប្រហែល ១២៨,៦ គ.ម និងទទឹងប្រហែល៣២គ.ម (ត្រង់កន្លែងធំបំផុត)។ ក្រោយពីឆ្នាំ៧៤គ.ស ស្រុកពីស៊ីឌាត្រូវបានដាក់បញ្ចូលទៅជាផ្នែកមួយនៃស្រុកប៉ាមភីលា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ចក្រភពរ៉ូម៉ាំងវិញ (១៣:១៣)។

**១៤:២៥** *ក្រុងពើកា* "មើលការពន្យល់ ១៣:១៣"។ *អាតាលា* ជាកំពង់ផែសមុទ្រដ៏សំខាន់បំផុតនៃស្រុកប៉ាមភីលា (១៣:១៣–១៤)។

**១៤:២៦** *អាន់ទីយ៉ូក* "១១:២០ មើលការពន្យល់ ១១:១៩"។

**១៤:២៧** *ទ្រង់បានបើកទ្វារនៃសេចក្ដីជំនឿ* មានន័យថា ព្រះអម្ចាស់ទ្រង់ប្រោសប្រទានឱ្យពួកសាសន៍ដទៃទទួលបាននូវសេចក្ដីជំនឿ (១១:១៨)។

**១៤:២៨** *ជាយូរក្រៃល* គឺប្រហែលជាមានរយៈពេលជាង១ឆ្នាំ ។

**១៥:១** *មានមនុស្សខ្លះ* ក្រុមនេះប្រហែលជាអ្នកជឿមកពីពួកផារិស៊ី (ខ.៥) ដែលប្រកាន់ថា លុះណាតែកាន់តាមក្រឹត្យវិន័យរបស់លោកម៉ូសេ ទើបអាចទទួលបានភាពជាគ្រីស្ទបរិស័ទពិតប្រាកដ ហើយរបៀបដែលបញ្ជាក់អំពីការនេះគឺប្រុសៗទាំងអស់ត្រូវតែកាត់ស្បែក ។ *ចុះពីស្រុកយូដា* មានន័យថា ពួកនេះជាអ្នកជឿ ដែលកាន់តាមក្រឹត្យវិន័យ និងមានសិទ្ធិក្នុងការបញ្ចេញយោបល់ ប៉ុន្តែ មិនមែនជាអ្នកតំណាងរបស់ពួកសាវក និងពួកចាស់ទុំនៅទីក្រុងយេរូសាឡិមទេ (១១:១៨)។

**១៥:២** *ឡើងទៅ. . . ក្រុងយេរូសាឡិម* "មើលពន្យល់ ១២:១ កទ ២:១"។ អ្នកខ្លះយល់ថា បទគម្ពីរ "កទ ២:១–១០" និយាយដូចគ្នាទៅនឹង "១១:២៧–៣០ ១២:២៥" ហើយពិតជាស្របនឹងសេចក្ដីទំនាយតាមរយៈលោកអ័ក្កាបុស អំពីគ្រោះទុរ្ភិក្សដែលត្រូវកើតមាន (១១:២៧–២៨) ព្រោះនៅក្នុង "កទ ២:២" បានថែងថា ព្រះអម្ចាស់ទ្រង់បើកសំដែងការទាំងនោះឱ្យពួកគេដឹងជាមុន ។ អ្នកផ្សេងទៀតយល់ថា "កទ ២:១–១០" គឺសំដៅលើការប្រជុំប្រឹក្សាគ្នានៅទីក្រុងយេរូសាឡិម ដូចដែលមានចែងនៅក្នុង "១៥:១–២២" ដូច្នោះដែរ ។ ហើយលោកប៉ុល និងបាណាបាសធ្វើដំណើរទៅសួរសុខទុក្ខពួកជំនុំ នៅក្រុងយេរូសាឡិមក្នុងគ្រាដែលមានគ្រោះទុរ្ភិក្សកើតឡើងនោះ គឺនៅឆ្នាំទី៤៤គ.ស ជាឆ្នាំដែលស្ដេចហេរ៉ូឌ–អ័គ្រីប៉ាសុគត (១១:២៧–៣០ ១២:២៥)។ ការប្រែចិត្តរបស់លោកប៉ុល ប្រហែលជាកើតឡើងក្នុងឆ្នាំដែលគេឆ្កាងព្រះយេស៊ូវតែម្ដង គឺប្រហែលជានៅឆ្នាំទី៣០គ.ស ត្រូវនឹងរយៈពេល១៤ឆ្នាំមុនការសុគតនៃស្ដេចអ័គ្រីប៉ា (កទ ២:១)។

**១៥:៤–២២** កម្មវិធីនៃការជួបប្រជុំដែលមានចែងនៅក្នុង "ខ.៤-២២" មានដូចជា: (១).ការជួបប្រជុំជាទូទៅ ដែលមានការស្វាគមន៍និងរបាយការណ៍ (ខ.៤–៥) (២).ការជួបប្រជុំគ្នានៃពួកអ្នកដឹកនាំ (ប្រហែលជានៅកន្លែងមួយដោយឡែក) ក្នុងពេលដែលពួកជំនុំនៅជួបប្រជុំគ្នានៅឡើយ (ខ.៦–១១) (៣)ការជួបប្រជុំគ្នានៃពួកសាវក ពួកចាស់ទុំ និងពួកជំនុំទាំងមូល (ខ.១២–២២)។

**១៥:៤** ត្រង់ចំណុចនេះគឺជាការជួបប្រជុំលើកទីមួយ ដែលមាននិយាយអំពីលទ្ធផលការងារ ដែលបានធ្វើនៅក្នុងចំណោមពួកសាសន៍ដទៃ ។

**១៥:៥** *អ្នកខ្លះក្នុងពួកផារិស៊ីដែលជឿ* នៅពេលនោះ មានពួកផារិស៊ីខ្លះបានទទួលជឿដំណឹងល្អ ហើយនាំទាំងលទ្ធិសាសនាយូដាមកជាមួយផង ។ ពួកគេយល់ថា សាសន៍ដទៃត្រូវតែទទួលយកលទ្ធិនេះ និងកាត់ស្បែកជាមុន (ខ.១) ទើបទទួលបាន នូវសេចក្ដីសង្គ្រោះដោយជំនឿដ៏ស្របច្បាប់ ។ ក្នុងចំណោមពួកនេះប្រហែលជាមានអ្នកខ្លះបានធ្វើដំណើរទៅឯទីក្រុងអាន់ទីយ៉ូក ហើយបានត្រឡប់មកវិញ ដើម្បីនាំមកនូវព័ត៌មានអំពីហេតុការណ៍ ដែលខ្លួនបានជួបប្រទះនៅទីនោះ ។

៦ពួកសាវក នឹងពួកចាស់ទុំ ក៏ប្រជុំគ្នាប្រឹក្សាពីដំណើរ
នោះ ៧លុះបានជជែកគ្នាជាយូរទៅ នោះពេត្រុសក្រោក
ឡើង និយាយថា បងប្អូនអើយ អ្នករាល់គ្នាដឹងហើយថា
កាលពីដើមព្រះបានរើស ក្នុងពួកយើងរាល់គ្នា ដើម្បីឱ្យពួក
សាសន៍ដទៃ បានឮព្រះបន្ទូលនៃដំណឹងល្អ ហើយឱ្យបាន
ជឿ[ថ] ដោយសារមាត់ខ្ញុំ ៨នោះព្រះដ៏ជ្រាបនូវចិត្ត[ទ]មនុស្ស
ទាំងឡាយ ទ្រង់បានធ្វើបន្ទាល់ពីគេ ដោយទ្រង់ ប្រទាន
ព្រះវិញ្ញាណបរិសុទ្ធដល់គេ[ធ] ដូចជាដល់យើងរាល់គ្នាដែរ
៩ទ្រង់មិនបានរាប់ពួកយើង និងពួកគេខុសពីគ្នាទេ[ន] គឺបាន
សំអាតចិត្តគេ ដោយសារសេចក្ដីជំនឿជឿដែរ[ប] ១០ចុះហេតុ
អ្វីបានជាល្បងព្រះ[ផ] ដោយបំពាក់នឹមនៅកពួកសិស្សដូច្នេះ[ព]
ដែលទោះទាំងពួកឰយុកោយើង ឬយើងរាល់គ្នាក៏ពុំអាច
នឹងទ្រទ្រាំបានផង ១១យើងជឿថា បានសង្គ្រោះដោយ
ព្រះគុណ[ភ]នៃព្រះអម្ចាស់យេស៊ូវ ដូចជាគេដែរ ១២ឯពួកជំនុំ
ទាំងអស់គ្នា ក៏នៅស្ងៀមស្ដាប់បាណាបាស និងប៉ុល ដែល
គេរ៉ាយរឿងប្រាប់ពីទីសំគាល់ និងការអស្ចារ្យ[ម]ទាំងប៉ុន្មាន

**១៥:៧** ថ កច ១០:១-៤៨
**១៥:៨** ទ វវ ២:២៣ ធ កច ១០:៤៤,៤៧
**១៥:៩** ន កច ១០:២៨,៣៤ ១១:១២ ប កច ១០:៤៣
**១៥:១០** ផ កច ៥:៩ ព មថ ២៣:៤ កទ ៥:១
**១៥:១១** ភ រម ៣:២៤ កទ ២:១៦ អភ ២:៥-៨
**១៥:១២** ម យហ ៤:៤៨ យ ខ.៤ កច ១៤:២៧ ២១:១៩
**១៥:១៣** រ កច ១២:១៧ ២១:១៨ ១កថ ១៥:៧ កទ ១:១៩ ២:៩,១២

ដែលព្រះបានធ្វើក្នុងពួកសាសន៍ដទៃដោយសារខ្លួន[យ]
១៣កាលឈប់អធិប្បាយហើយ នោះយ៉ាកុប[រ] ឆ្លើយឡើងថា
អ្នករាល់គ្នាជាបងប្អូនអើយ សូមស្ដាប់ខ្ញុំសិន ១៤ស៊ីម៉ូន បាន
ថ្លែងប្រាប់ពីបែបយ៉ាងណា ដែលព្រះទ្រង់ប្រោសដល់ពួក
សាសន៍ដទៃជាមុនដំបូង ដើម្បីរើសយករាស្ត្រ១ពួកពីគេ
ទុកសំរាប់ព្រះនាមទ្រង់[ល] ១៥ហើយសេចក្ដីទំនាយរបស់ពួក
ហោរា ក៏ត្រូវនឹងដំណើរនោះដែរ ដូចជាមានសេចក្ដីចែង
ទុកមកថា ១៦«ក្រោយនោះ អញនឹងត្រឡប់មក លើកទីលំ
នៅរបស់ហ្លួងដាវីឌ ដែលរលំនោះឡើង អញនឹងសង់ត្រង់
កន្លែងបាក់បែក ហើយដំឡើងឱ្យត្រង់ឡើងវិញ ១៧ដើម្បីឱ្យ
សំណល់មនុស្ស បានស្វះស្វែងរកព្រះអម្ចាស់ ព្រមទាំងសាសន៍
ដទៃទាំងប៉ុន្មាន ដែលបានហៅតាមឈ្មោះអញនោះផង នេះ
ហើយជាព្រះបន្ទូលនៃព្រះអម្ចាស់ ជាព្រះដែលធ្វើការទាំង
នោះ»[វ] ១៨គ្រប់ការដែលព្រះទ្រង់ធ្វើ នោះទ្រង់បានជ្រាប
តាំងពីអស់កល្បរៀងមក[ស] ១៩ដូច្នេះបើតាមគំនិតខ្ញុំ នោះមិន

**១៥:១៤** ល ២ពត ១:១ **១៥:១៧** វ អម ៩:១១-១២
**១៥:១៨** ស អស ៤៥:២១

**១៥:៧** *ពេត្រុសក្រោកឡើង* បន្ទាប់ពីពួកសាវកនិងពួកចាស់ទុំបានពិភាក្សាគ្នាអស់រយៈពេលយ៉ាងយូរ នោះលោកពេត្រុសក៏ចាប់ផ្ដើមថ្លែងទៅកាន់ពួកគេ ។ *ពួកសាសន៍ដទៃបានឮព្រះបន្ទូល* លោកពេត្រុសបានថ្លែងជំទាស់នឹងពួកជំនុំ និងពួកចាស់ទុំ ដោយសំអាងលើបទពិសោធន៍ដែលខ្លួនទទួលបាន នៅក្នុងពេលដែលព្រះអម្ចាស់ត្រាស់ហៅគាត់ ឱ្យទៅប្រកាសដំណឹងល្អដល់ពួកសាសន៍ដទៃ (១០:២៨-២៩ មើលការពន្យល់ ១០:២៨) ។

**១៥:៨** *ទ្រង់ប្រទានព្រះវិញ្ញាណបរិសុទ្ធដល់គេ* ចំណុចនេះគឺជាភស្តុតាងបញ្ជាក់ថា ព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យនឹងពួកជំនុំទ្រង់ណាស់ (១០:៤៤, ៤៧ មើលការពន្យល់ ១១:១៧,១៨) ។

**១៥:៩** *បានសំអាតចិត្តគេ ដោយសារសេចក្ដីជំនឿ* ត្រង់ចំណុចនេះបញ្ជាក់ថា អ្នកណាមានសេចក្ដីជំនឿ នៅក្នុងព្រះយេស៊ូវគ្រីស្ទ នោះទ្រង់នឹងសំអាតចិត្តគេឱ្យបានបរិសុទ្ធ (រម៥:១ កទ ២:១៥,១៦) ។

**១៥:១០** *នឹម* គឺសំដៅលើក្រឹត្យវិន័យទាំងឡាយ (មើលការពន្យល់ កទ ៥:១ មថ ១១:២៨-២៩) ។

**១៥:១១** *ដោយព្រះគុណនៃព្រះអម្ចាស់យេស៊ូវ* បទគម្ពីរនេះបញ្ជាក់ថា ពុំតម្រូវឱ្យមានការកាត់ស្បែកទៀតទេ ។ *បានសង្គ្រោះ. . . ដូចជាគេដែរ* "មើលការពន្យល់ រម ៣:៩"។

**១៥:១២** *ពួកជំនុំទាំងអស់គ្នាក៏នៅស្ងៀម* "មើលការពន្យល់ ខ.៤-២២"។ ក្នុងខណៈពេលដែលពួកសាវក និងពួកចាស់ទុំកំពុងជួបប្រជុំគ្នានោះ ពួកជំនុំនាំគ្នាជជែកនៅតាមកន្លែងរៀងៗខ្លួន ប៉ុន្តែ ក្រោយពីបានស្ដាប់សំដីរបស់លោកពេត្រុសរួចហើយ ពួកគេក៏នៅស្ងៀម ។ *បាណាបាស និងប៉ុល* ត្រង់ចំណុចនេះ ឈ្មោះរបស់លោកបាណាបាស ត្រូវបានសរសេរនៅខាងមុខឈ្មោះរបស់លោកប៉ុល (ប្រហែលជាចង់បញ្ជាក់ថា លោកបាណាបាសជាមនុស្សសំខាន់ម្នាក់នៅឯក្រុងយេរូសាឡិម) ។ ប៉ុន្តែ ក្នុងដំណើរបេសកកម្មបន្ទាប់អំពីហេតុការណ៍ដែលបានកើតឡើង នៅឯកោះគីប្រុសនោះមកលំដាប់នៃឈ្មោះ រវាងពួកគាត់ទាំងពីរនាក់គឺ "ប៉ុល និងបាណាបាស" (១៣:៤២-៤៣,៤៦,៥០ ១៤:១,៣,២០,២៣) ។ *ទីសំគាល់ និងការអស្ចារ្យ* "សូមមើល ៨:១៩-២០ ១៤:៣"។

**១៥:១៣** *យ៉ាកុប* ជាប្អូនរបស់ព្រះយេស៊ូវ (មើលពន្យល់ ១២:១៧ និងសេចក្ដីផ្ដើមគម្ពីរយ៉ាកុប ត្រង់ចំណុចអ្នកនិពន្ធ) ។ គាត់គឺជាអ្នកដឹកនាំម្នាក់ នៅក្នុងពួកជំនុំនៅឯទីក្រុងយេរូសាឡិម ។

**១៥:១៤** *ស៊ីម៉ូន* លោកពេត្រុសមានឈ្មោះជាភាសាហេព្រើរថា "ស៊ីម៉ូន" (ខ.៧) ។ *ទុកសំរាប់ព្រះនាមទ្រង់* មានន័យថា ព្រះអម្ចាស់ត្រាស់ហៅទាំងសាសន៍ដទៃ និងសាសន៍យូដា (១ពត ២:៩-១០ យហ ១០:១៦ និងពន្យល់) ។

**១៥:១៥** *ពួកហោរា* សំដៅលើ "អម ៩:១១-១២" (មើលការពន្យល់ អម ៩:១២) ។

**១៥:១៦** *ក្រោយនោះ អញនឹងត្រឡប់មក* បទគម្ពីរនេះបានដកស្រង់ចេញពីគម្ពីរអេម៉ុស ដែលអ្នកខ្លះយល់ថាសំដៅលើហេតុការណ៍ ដែលនឹងកើតឡើងនៅគ្រាចុងក្រោយ រួមមាន (១).អាយុកាលនៃពួកជំនុំ (ព្រះអម្ចាស់នឹងលើករាស្ត្រទ្រង់ឡើង ខ.១៤) (២).ការតាំងអាណាចក្រអ៊ីស្រាអែលឡើងវិញ (ខ.១៦) (៣).ការប្រទានសេចក្ដីសង្គ្រោះដល់មនុស្សគ្រប់ទាំងសាសន៍ (ខ. ១៧,១៨) ។ រីឯអ្នកផ្សេងទៀតយល់ថា បទគម្ពីរនេះជាការសំដែងនូវព្រះ-ហឫទ័យករុណារបស់ព្រះអម្ចាស់ចំពោះពួកសាសន៍ដទៃ ។

**១៥:១៨** *តាំងពីអស់កល្បរៀងមក* គឺតាំងពីមុនពេលដែលព្រះអម្ចាស់បានបង្កើតពិភពលោកនេះទៅទៀត (មើលការពន្យល់ រម ១៥:៩) ។

**១៥:១៩** *មិនត្រូវធ្វើឱ្យ . . . មានចិត្តខ្វល់ឡើយ* ការកាត់ស្បែកមិនតម្រូវឱ្យ

ត្រូវធ្វើឱ្យពួកសាសន៍ដទៃ ដែលងាកបែរមកឯព្រះវិញ មាន
ចិត្តខ្វល់ឡើយ ២០គឺ ត្រូវសរសេរផ្ញើទៅ ឱ្យគេគ្រាន់តែចៀស
វាងចេញពីរូបព្រះ ដែលនាំឱ្យស្មោកគ្រោក១[ហ] ពីសេចក្តី
កំផិត១[ឡ] ពីសត្វដែលសំឡាប់ដោយច្របាច់ក១ ហើយពីឈាម
១[អ]ប៉ុណ្ណោះ ២១ព្រោះតាំងពីចាស់បុរាណមក មានគេប្រ
កាសប្រាប់ពីលោកម៉ូសេនៅគ្រប់ទីក្រុងទាំងអស់ ហើយគេ
មើលគម្ពីរលោក នៅអស់ទាំងសាលាប្រជុំ រាល់តែថ្ងៃឈប់
សំរាក ដែរ[ក]។

## សំបុត្រផ្ញើទៅពួកបងប្អូនសាសន៍ដទៃ

២២នោះពួកសាវក នឹងពួកចាស់ទុំ[ខ] ព្រមទាំងពួកជំនុំ
គ្រប់គ្នាក៏យល់ព្រមថា គួរនឹងរើសយកអ្នកខ្លះក្នុងពួកគេ គឺ
យូដាស ដែលហៅថា បាសាបាស១ និងស៊ីឡាស១[គ] ជាពួក
អ្នកមុខក្នុងពួកជំនុំ ដើម្បីនឹងចាត់ឱ្យទៅឯអាន់ទីយ៉ូក[ឃ] ជា
មួយនឹងប៉ុល ហើយនិងបាណាបាស ២៣គេក៏ធ្វើសំបុត្រ
ផ្ញើដោយសារអ្នកទាំងនោះ បែបដូច្នេះថា សំបុត្រយើងខ្ញុំ
ជាពួកសាវក ពួកចាស់ទុំ និងពួកបងប្អូនទាំងអស់គ្នា ផ្ញើមក
ជំរាបសួរដល់ពួកបងប្អូនសាសន៍ដទៃ ដែលនៅក្រុងអាន់
ទីយ៉ូក[ង] ស្រុកស៊ីរី[ច] និងស្រុកគីលីគា[ឆ] ឱ្យបានជ្រាប[ជ]
២៤ដ្បិតយើងខ្ញុំបានឮថា មានអ្នកខ្លះចេញពីពួកយើងខ្ញុំ
មកនាំឱ្យអ្នករាល់គ្នាខ្វល់ចិត្ត ហើយឱ្យវល់គំនិត ដោយ
ពាក្យសំដីដែលគេថា ត្រូវតែកាត់ស្បែក ហើយកាន់តាម
ក្រិត្យវិន័យផង តែយើងខ្ញុំមិនបានបង្គាប់គេទេ[ឈ] ២៥ដូច្នេះ
យើងខ្ញុំបានព្រមព្រៀងគ្នា យល់ឃើញថា គួរនឹងរើសអ្នកខ្លះ
ចាត់មកឯអ្នករាល់គ្នា ជាមួយនឹងបាណាបាស ហើយនិង
ប៉ុល ជាសំឡាញ់ស្ងួនភ្ងានៃយើងខ្ញុំ ២៦ដែលបានប្រថុយ
ជីវិត[ញ] ដោយយល់ដល់ព្រះនាម នៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ
នៃយើងរាល់គ្នា ២៧ដូច្នេះ យើងខ្ញុំបានចាត់យូដាស និង
ស៊ីឡាស[ដ]មក ឱ្យជំរាបដល់អ្នករាល់គ្នាផ្ទាល់មាត់ ពីសេចក្តី
នោះឯង ២៨ពីព្រោះព្រះវិញ្ញាណបរិសុទ្ធ[ឋ] នឹងយើងខ្ញុំ
រាល់គ្នាបានយល់ឃើញថា មិនគួរគប្បីនឹងដាក់បន្ទុកអ្វីទៀត
លើអ្នករាល់គ្នា ក្រៅពីសេចក្តីទាំងនេះ ដែលត្រូវតែកាន់
នោះឡើយ ២៩គឺឱ្យចៀសវាងចំពោះរបស់ដែលបានថ្វាយ
ដល់រូបព្រះ១ ឈាម១ សត្វដែលសំឡាប់ដោយច្របាច់ក១
និងសេចក្តីកំផិត១ បើអ្នករាល់គ្នាចៀសវាងពីរបស់ទាំងនេះ
នោះបានល្អហើយ[ឌ] សូមឱ្យអ្នករាល់គ្នា បានប្រកបដោយ
សេចក្តីសុខចុះ ។

៣០កាលពួកជំនុំបានឱ្យអ្នកទាំងនោះទៅហើយ នោះ
គេទៅដល់អាន់ទីយ៉ូក ក៏ប្រជុំពួកសិស្សទាំងប៉ុន្មាន ហើយ
ប្រគល់សំបុត្រនោះដល់ពួកជំនុំ ៣១លុះបានអានមើលសំបុត្រ
ស្រេចហើយ ពួកនោះក៏មានសេចក្តីរីករាយ ដោយពាក្យ
កំសាន្តនោះ ៣២ឯយូដាស និងស៊ីឡាស[ឍ]ដែលជាគ្រូអធិប្បាយ
ដែរ[ណ] គេបានប្រដៅទូន្មានជាច្រើនដល់ពួកជំនុំ ព្រមទាំង
តាំងឱ្យគេមានចិត្តខ្ជាប់ខ្ជួនឡើង ៣៣កាលនៅទីនោះជាយូរ
បន្តិច នោះពួកជំនុំឱ្យគេត្រឡប់ទៅឯពួកសាវកវិញដោយ

**១៥:២០** ហ ១កថ ៨:៧–១៣ ១០:១៤–២៨ វវ ២:១៤,២០ ឡ ១កថ ១០:៧,៨ វវ ២:១៤,២០ អ ខ.២៩ លប ៩:៤ លវ ៣:១៧ ៧:២៦ ១៧:១០–១៣ ១៩:២៦ ចទ ១២:១៦,២៣ **១៥:២១** ក កច ១៣:១៥ ២កថ ៣:១៤,១៥ **១៥:២២** ខ កច ១១:៣០ គ ខ.២៧,៣២,៤០ កច ១៦:១៩,២៥,២៩ ២កថ ១:១៩ ១ថន ១:១ ២ថន ១:១ ១ពត ៥:១២ ឃ កច ១១:១៩ **១៥:២៣** ង ខ.១ កច ១១:១៩ ច លក ២:២ ឆ ខ.៤១ កច ៦:៩ ជ កច ២៣:២៥,២៦ យក ១:១ **១៥:២៤** ឈ ខ.១ កទ ១:៧ ៥:១០ **១៥:២៦** ញ កច ៩:២៣–២៥ ១៤:១៩ ១កថ ១៥:៣០ **១៥:២៧** ដ ខ.២២ **១៥:២៨** ឋ កច ៥:៣២ **១៥:២៩** ឌ ខ.២០ កច ២១:២៥ **១៥:៣២** ឍ ខ.២២ ណ កច ១១:២៧

មានទៀតទេ ប៉ុន្តែ មានសេចក្តី៤យ៉ាងដែលពួកអ្នកនៅទីក្រុងអាន់ទីយ៉ូកត្រូវប្រតិបត្តិតាម (ខ.២០)។ សេចក្តីទាំងអស់នោះបានប្រទានមកពួកយូដាតាំងពីមុនក្រឹត្យវិន័យរបស់លោកម៉ូសេទៅទៀត ។ ហើយទំនាក់ទំនងរវាងពួកសាសន៍ដទៃ និងសាសន៍យូដា ពិតជាបានល្អប្រសើរឡើងវិញ ប្រសិនបើពួកគេ (សាសន៍ដទៃ) ព្រមប្រតិបត្តិតាមសេចក្តីទាំងនោះ ។

**១៥:២០** *ចៀសវាងចេញពីរូបព្រះដែលនាំឱ្យស្មោកគ្រោក* "សូមមើល ខ.២៩ ១កថ ៨:៧-១៣ វវ ២:១៤,២០"។ *សេចក្តីកំផិត* គឺជាទង្វើមួយដែលពួកហេលេនតែងតែប្រព្រឹត្ត ។ ម្យ៉ាងទៀត ពួកសាវកលើកយកសេចក្តីកំផិតមកនិយាយ ព្រោះនៅពេលនោះ ពួកហេលេនមានពិធីបុណ្យសាសនាមួយ ដែលមានជាប់ទាក់ទងនឹងសេចក្តីនេះ ។ *សត្វដែលសំឡាប់ដោយច្របាច់ក* ត្រង់ចំណុចនេះបញ្ជាក់ថា នៅក្នុងក្រឹត្យវិន័យលោកម៉ូសេ បានចែងមិនឱ្យបរិភោគសាច់សត្វណាដែលនៅមានឈាមនោះទេ ។ *ឈាម* ពាក្យនេះប្រហែលជាសំដៅលើឈាមសុទ្ធ ដែលនៅក្នុងក្រឹត្យវិន័យរបស់ពួកសាសន៍យូដាបានហាមផ្តាច់មិនឱ្យបរិភោគទេ (លវ ១៧:១០–១២)។

**១៥:២២** *ពួកសាវក និងពួកចាស់ទុំ ព្រមទាំងពួកជំនុំ* បន្ទាប់ពីបានប្រជុំប្រឹក្សា និងមានការព្រមព្រៀងទាំងអស់គ្នាយ៉ាងច្បាស់លាស់មក ពួកគេក៏ជ្រើសតាំងឱ្យមានអ្នកនាំសំបុត្រទៅឯក្រុងអាន់ទីយ៉ូក ជាមួយនឹងលោកប៉ុល និងលោកបាណាបាស(ខ.២៣–២៩)។ *យូដាស ដែលហៅថា បាសាបាស* "បាសាបាស" គឺជានាមត្រកូលរបស់លោកយូដាស និងលោកយូសែប ដូច្នេះ អ្នកទាំងពីរនេះប្រហែលជាបងប្អូននឹងគ្នាផង(មើលពន្យល់ ១:២៣)។ *ស៊ីឡាស* គឺជាហោរា (ខ.៣២) និងជាអ្នកដឹកនាំម្នាក់ នៃពួកជំនុំនៅទីក្រុងយេរូសាឡិម ហើយជាគូកនរបស់លោកប៉ុល ក្នុងដំណើរបេសកកម្មលើកទីពីររបស់គាត់ (១៥:៤០)។ គាត់មានសញ្ជាតិរ៉ូម៉ាំង (១៦:៣៧–៣៨)។

**១៥:២៣** *ក្រុងអាន់ទីយ៉ូក* ជាទីក្រុងសំខាន់មួយស្ថិតនៅរវាងស្រុកស៊ីរី និងស្រុកគីលីគា ។

**១៥:២៦** *បានប្រថុយជីវិត* "សូមមើល ១៣:១៥ ១៤:២,៥,១៩"។

**១៥:២៨** *ព្រះវិញ្ញាណបរិសុទ្ធ និងយើងខ្ញុំរាល់គ្នា* ព្រះវិញ្ញាណបរិសុទ្ធទ្រង់មានគ្រប់ព្រះចេស្តាទាំងអស់ ហើយពួកសាវក ពួកចាស់ទុំ និងពួកជំនុំទាំងមូលក៏បានយល់ព្រមចំពោះសេចក្តីសម្រេចនោះដែរ (ខ.២២–២៣)។

**១៥:៣២** *គ្រូអធិប្បាយ* (ភាសាអង់គ្លេសប្រើពាក្យថា"ហោរា") ភារកិច្ចចម្បងរបស់គ្រូអធិប្បាយនៅក្នុងពួកជំនុំដំបូងគឺ ទូន្មានប្រដៅ និងស្អាងទឹកចិត្តអស់អ្នកដែលជឿលើព្រះនាមព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ ១១:២៧

សុខសាន្ត[ត] ៣៤តែស៊ីឡាស គាត់គាប់ចិត្តនៅទីនោះតទៅ
ទៀត ៣៥ឯប៉ុល និងបាណាបាស បានបង្អង់នៅឯក្រុង
អាន់ទីយ៉ូកនោះដែរ ទាំងបង្រៀន ហើយប្រកាសប្រាប់[ថ]
ដំណឹងល្អ គឺជាព្រះបន្ទូលនៃព្រះអម្ចាស់ ជាមួយនឹងមនុស្ស
ឯទៀតជាច្រើន[ទ]។

## ការខ្វែងគំនិតគ្នារវាងលោកប៉ុល និងបាណាបាស

៣៦កាលក្រោយបន្តិចថ្ងៃមក នោះប៉ុលនិយាយនឹងបាណា-
បាស ថា ចូរយើងត្រឡប់ទៅសួរពួកបងប្អូន នៅអស់ទាំង
ក្រុង[ធ] ជាទីដែលយើងបានផ្សាយព្រះបន្ទូលនៃព្រះអម្ចាស់[ន]
ផង ដើម្បីឱ្យដឹងពីគេថាជាយ៉ាងដូម្តេច ៣៧ឯបាណាបាស
គាត់គិតចង់យកយ៉ូហាន ដែលហៅថាម៉ាកុស[ប] ទៅជាមួយ
ផង ៣៨តែប៉ុលមិនចូលចិត្តនឹងយកគាត់ទៅទេ ពីព្រោះជាន់
មុន គាត់បានចាកចោលគេ[ផ] ពីកាលនៅស្រុកប៉ាមភីលាម្តង
ហើយ មិនបានទៅធ្វើការជាមួយគ្នាតទៅឡើយ ៣៩ដូច្នេះ
គេមានការណ៍ទាស់ទែងគ្នាជាខ្លាំង ដល់ម្ល៉េះបានជាបែក
ចេញពីគ្នា ឯបាណាបាស គាត់យកម៉ាកុស ចុះសំពៅទៅឯ
កោះគីប្រុស ៤០តែប៉ុល គាត់រើសយកស៊ីឡាសវិញ[ព] ហើយ
ចេញដំណើរទៅ ដោយមានពួកជំនុំផ្ទុកផ្តាក់ក្នុងព្រះគុណ
នៃព្រះអម្ចាស់[ភ] ៤១នោះគាត់ដើរកាត់ស្រុកស៊ីរី[ម] និងស្រុក
គីលីគា[យ] ក៏តាំងឱ្យពួកជំនុំទាំងប៉ុន្មានបានខ្ជាប់ខ្ជួនឡើង[រ]។

## លោកធីម៉ូថេចូលរួមជាមួយលោកប៉ុល និងស៊ីឡាស

**១៦** ១រីឯប៉ុល បានទៅដល់ក្រុងឌើបេ និងលីស្ត្រា[ល] ហើយ
នៅទីនោះ ក៏ប្រទះឃើញសិស្សម្នាក់ ឈ្មោះ ធីម៉ូថេ[វ] ជាកូន
របស់ស្ត្រីសាសន៍យូដាម្នាក់ដែលបានជឿ[ស] តែឪពុកជា
សាសន៍ក្រេក ២គាត់ជាអ្នកមានកេរ្តិ៍ឈ្មោះល្អក្នុងពួកជំនុំ[ហ]
នៅលីស្ត្រា និងអ៊ីកូនាម[ឡ] ៣ឯប៉ុលចង់ឱ្យអ្នកនោះទៅជាមួយ
ផង បានជាគាត់នាំយកទៅកាត់ស្បែកឱ្យ ដោយព្រោះពួក
សាសន៍យូដាដែលនៅស្រុកទាំងនោះ ដ្បិតគេដឹងគ្រប់គ្នា ថា
ឪពុកគាត់ជាសាសន៍ក្រេក[អ] ៤កំពុងដែលដើរកាត់ អស់
ទាំងទីក្រុង នោះក៏ប្រគល់សេចក្តីបញ្ញត្តិទាំងប៉ុន្មានដល់គេ
ជាសេចក្តីដែលពួកសាវក និងពួកចាស់ទុំ[ក] ដែលនៅក្រុង

**១៥:៣៣** ត ១យស ១:១៧ មក ៥:៣៤ លក ៧:៥០ កច ១៦:៣៦ ១កថ ១៦:១១
**១៥:៣៥** ថ កច ៨:៤ ទ កច ១៣:៤៨
**១៥:៣៦** ធ កច ១៣:៤,១៣,១៤,៥១ ១៤:១,៦,២៤,២៥ ន កច ១៣:៤៨
**១៥:៣៧** ប កច ១២:១២
**១៥:៣៨** ផ កច ១៣:១៣
**១៥:៤០** ព ខ.២២ ភ កច ១១:២៣
**១៥:៤១** ម ខ.២៣ លក ២:២ យ កច ៦:៩ រ កច ១៦:៥
**១៦:១** ល កច ១៤:៦ វ កច ១៧:១៤ ១៨:៥ ១៩:២២ ២០:៤ រម ១៦:២១ ១កថ ៤:១៧ ១៦:១០ ២កថ ១:១,១៩ ភល ១:១ ២:១៩ កល ១:១ ១ថន ១:១ ៣:២,៦ ២ថន ១:១ ១ធថ ១:២,១៨ ២ធថ ១:២,៥,៦ ភម ១ ស ២ធថ ១:៥ **១៦:២** ហ ខ.៤០ កច ១:១៦ ឡ កច ១៣:៥១ **១៦:៣** អ កទ ២:៣ **១៦:៤** ក កច ១១:៣០

១កថ ១៤:៣)។

**១៥:៣៣** *ឱ្យគេត្រឡប់ទៅឯពួកសាវក* មានន័យថា ឱ្យគេត្រឡប់ទៅឯពួកជំនុំនៅទីក្រុងយេរូសាឡិមវិញ (ខ.២២)។

**១៥:៣៤** *នៅទីនោះតទៅទៀត* គឺនៅជាមួយពួកជំនុំក្រុងអាន់ទីយ៉ូកបន្តទៀត។

**១៥:៣៦** *នៅអស់ទាំងក្រុង* សំដៅលើទីក្រុងទាំងប៉ុន្មានដែលពួកគេបានទៅប្រកាសដំណឹងល្អនៅក្នុងដំណើរបេសកកម្មលើកទី១ (១៣:៤–១៤:២៦)។

**១៥:៣៨** *គាត់បានចាកចោលគេ* លោកម៉ាកុសបានចាកចេញពីពួកគេនៅត្រង់ក្រុងពើកា ហើយមិនបានទៅឯក្រុងអាន់ទីយ៉ូក ក្រុងអ៊ីកូនាម លីស្ត្រា និងក្រុងឌើបេនោះទេ (មើលការពន្យល់ ១៣:១៣)។

**១៥:៣៩–១៨:២២** គឺនិយាយអំពីដំណើរបេសកកម្មលើកទី២របស់លោកប៉ុល ។

**១៥:៣៩** *ដល់ម្ល៉េះបានជាបែកចេញពីគ្នា* ចាប់ពីចំណុចនេះទៅមុខ នៅក្នុងគម្ពីរកិច្ចការពុំមាននិយាយអំពីលោកបាណាបាស និងលោកម៉ាកុសទៀតទេ ។ ទោះជាយ៉ាងណា ក៏នៅក្នុង "១កថ ៩:៦" លោកប៉ុលបានហៅលោកបាណាបាសថា ជាគំរូដ៏ល្អម្នាក់សម្រាប់ពួកជំនុំ ។ រីឯនៅក្នុង "កទ ២:១១–១៣" លោកប៉ុលក៏បាននិយាយអំពីលោកបាណាបាស នៅក្រុងអាន់ទីយ៉ូកផងដែរ ។ ក្រោយមកទៀត មានភស្តុតាងបញ្ជាក់ថា លោកម៉ាកុសបានត្រឡប់ទៅបំពេញការងារជាមួយនឹងលោកពេត្រុសវិញ (មើលការពន្យល់ ១ពត ៥:១៣)។ នៅក្នុងរយៈពេលដែលលោកប៉ុលជាប់ក្នុងពន្ធនាគារ លោកម៉ាកុសក៏ជាម្នាក់ដែលនៅជាមួយនឹងគាត់ដែរ (កល ៤:១០ ភល ២៤)។ ទីបំផុត លោកប៉ុលបានកោតសរសើរលោកម៉ាកុសយ៉ាងខ្លាំង រហូតសូមឱ្យគាត់ធ្វើដំណើរទៅជាមួយ ក្នុងដំណើរចុងក្រោយបំផុតផង (មើលការពន្យល់ ២ធថ ៤:១១ និងសេចក្តីផ្តើមគម្ពីរម៉ាកុស)។ *កោះគីប្រុស* កោះនេះជាទីកន្លែងកំណើតរបស់លោកបាណាបាស (៤:៣៦)។

**១៥:៤០** *ស៊ីឡាស* គាត់បានត្រឡប់ទៅឯក្រុងយេរូសាឡិមវិញ បន្ទាប់ពីបានប្រគល់សំបុត្រឱ្យទៅពួកជំនុំនៅក្រុងអាន់ទីយ៉ូក ស្រុកស៊ីរី និងស្រុកគីលីគាហើយនោះ (ខ.៣២–៣៣)។ បន្ទាប់ពីបានផ្តល់លទ្ធផលទៅពួកជំនុំនៅក្រុងយេរូសាឡិមរួចហើយ គាត់ក៏ត្រឡប់មកធ្វើកិច្ចការជាមួយពួកជំនុំនៅក្រុងអាន់ទីយ៉ូកនោះវិញ ។

**១៦:១** *ក្រុងឌើបេ* "មើលការពន្យល់ ១៤:៦,២០"។ ត្រង់ចំណុចនេះលំដាប់ឈ្មោះនៃទីក្រុងទាំងពីរត្រូវប្តូរជា "ឌើបេ និងលីស្ត្រា" វិញ ពីព្រោះដំណើរបេសកកម្មលើកទី២របស់លោកប៉ុលមកដល់ទីនេះ តាមទិសដៅផ្ទុយគ្នានឹងដំណើរលើកទី១របស់គាត់ (១៥:៦)។ *លីស្ត្រា* "មើលការពន្យល់ ១៤:៦"។ *ធីម៉ូថេ* (សេចក្តីផ្តើម គម្ពីរ "១ធថ" ត្រង់ចំណុចអ្នកទទួល)។ ខណៈពេលនោះ ប្រហែលជាលោកធីម៉ូថេ ជាមនុស្សមានវ័យជំទង់នៅឡើយ ព្រោះថារយៈពេល១៥ឆ្នាំក្រោយមកទៀត លោកប៉ុលនៅតែហៅគាត់ថា "ក្មេង" (១ធថ ៤:១២)។ *ឪពុកជាសាសន៍ក្រេក* សេចក្តីជំនឿរបស់ម្តាយលោកធីម៉ូថេត្រូវបានបញ្ជាក់យ៉ាងច្បាស់ (២ធថ ១:៥) ប៉ុន្តែ មិនបាននិយាយអំពីឪពុករបស់គាត់ទេប្រហែលគាត់ក៏ជាអ្នកជឿម្នាក់ដែរ ។

**១៦:៣** *គាត់នាំយកទៅកាត់ស្បែកឱ្យ* លោកប៉ុលធ្វើដូច្នេះ ព្រោះចង់ឱ្យបេសកកម្មរបស់គាត់ក្នុងចំណោមសាសន៍យូដា កាន់តែមានប្រសិទ្ធិភាព ។ រីឯលោកទីតុសវិញ (កទ ២:៣) គាត់បដិសេធមិនឱ្យមានការកាត់ស្បែកទេ ព្រោះមានអ្នកខ្លះបែរជាយល់ច្រឡំថា ការនេះមានសារសំខាន់ សម្រាប់ទទួលសេចក្តីសង្គ្រោះមកអំពីព្រះអម្ចាស់ទៅវិញ ។

យេរូសាឡិម[ខ] បានជំនុំសំរេចឱ្យគេកាន់តាម[គ] ៥យ៉ាងនោះ
ពួកជំនុំទាំងប៉ុន្មាន មានសេចក្ដីជំនឿរឹតតែខ្លាំង[ឃ] ហើយ
ចំនួននៃពួកសិស្ស ចេះតែចំរើនកើនឡើង[ង] ជារាល់ថ្ងៃ
៦កាលបានដើរកាត់ស្រុកព្រីគា[ច] និងដែនខេត្តកាឡាទី[ឆ]
នោះព្រះវិញ្ញាណបរិសុទ្ធ ទ្រង់ឃាត់មិនឱ្យផ្សាយព្រះបន្ទូល
នៅស្រុកអាស៊ីទេ[ជ] ៧បានជានាំគ្នាចុះទៅឯស្រុកមីស៊ាវិញ
ហើយខំចូលទៅក្នុងស្រុកប៊ីធូនា ប៉ុន្តែ ព្រះវិញ្ញាណនៃ
ព្រះយេស៊ូវ[ឈ] មិនអនុញ្ញាតឱ្យចូលទេ ៨រួចគេដើរហួសពី
ស្រុកមីស៊ា ចុះទៅឯទ្រអាសវិញ[ញ] ៩នៅយប់នោះ ប៉ុលបាន
ឃើញក្នុងការជាក់ស្តែង[ដ] ជាមនុស្សពីស្រុកម៉ាសេដូនម្នាក់[ឋ]
ឈរអង្វរគាត់ថា សូមអញ្ជើញឆ្លងមកជួយយើងខ្ញុំដែលនៅ
ស្រុកម៉ាសេដូននេះផង ១០លុះគាត់បានឃើញការជាក់ស្តែង
នោះរួចហើយ នោះយើង[ឌ] ក៏រកឱកាស នឹងទៅឯស្រុក

**១៦:៤** ខ កច ១៥:២ គ កច ១៥:២៨,២៩ **១៦:៥** ឃ កច ៩:៣១ ១៥:៤១ ង កច ២:៤១ **១៦:៦** ច កច ២:១០ ១៨:២៣ ឆ កច ១៨:២៣ កទ ១:២ ៣:១ ជ កច ២:៩ **១៦:៧** ឈ រម ៨:៩ កទ ៤:៦ ភល ១:១៩ ១ពត ១:១១ **១៦:៨** ញ ខ.១១ កច ២០:៥ ២កថ ២:១២ ២ធថ ៤:១៣ **១៦:៩** ដ កច ៩:១០ ឋ កច ១៩:២១,២៩ ២០:១,៣

ម៉ាសេដូនភ្លាម ដោយយល់ឃើញថា ព្រះអម្ចាស់ទ្រង់ហៅ
យើងឱ្យទៅផ្សាយដំណឹងល្អ[ឍ] ដល់គេ ។

## សេចក្ដីសន្ទនារបស់នាងលីឌានៅទីក្រុងភីលីព

១១កាលបានចុះសំពៅចេញពីទ្រអាស[ណ] ទៅ នោះក៏ដំរង់
ទៅឯកោះសាម៉ូត្រាស ហើយថ្ងៃក្រោយបានដល់នាប៉ូល
១២ពីទីនោះ យើងក៏ទៅដល់ក្រុងភីលីព[ត] ជាទីក្រុងលេខ១ក្នុង
ខេត្តម៉ាសេដូន[ថ] ដែលជាស្រុកចំណុះ ហើយយើងសំចតនៅ
ទីនោះបានបួនដប់ថ្ងៃ ។

១៣ដល់ថ្ងៃឈប់សំរាក[ទ] យើងដើរចេញពីទីក្រុង ទៅឯ
មាត់ទន្លេ ជាកន្លែងដែលគេធ្លាប់អធិស្ឋាន ក៏អង្គុយនិយាយ

រម ១៥:២៦ ១កថ ១៦:៥ ១ថន ១:៧,៨ **១៦:១០** ឌ ខ.១០-១៧ កច ២០:៥-១៥ ២១:១-១៨ ២៧:១-២៨:១៦ ឍ កច ១៤:៧ **១៦:១១** ណ ខ.៨ **១៦:១២** ត កច ២០:៦ ភល ១:១ ១ថន ២:២ ថ ខ.៩ **១៦:១៣** ទ កច១៣:១៤

**១៦:៦** *ស្រុកព្រីគា* ជាស្រុកមួយ(ស្ថិតនៅភាគខាងលិចបំផុតនៃទ្វីបអាស៊ី) ដែលមានព្រំប្រទល់ជាប់ជាមួយនឹងស្រុកមីស៊ា ស្រុកកាឡាទី ស្រុកលូកៅនា ស្រុកពីស៊ីឌា និងស្រុកលីឌា ។ ក្រោយមក ស្រុកនេះត្រូវបានគេបែងចែកជាពីរគឺ ព្រីគាខាងជើង (ធំជាង) និងព្រីគាខាងត្បូង (តូចជាង) ។ ទីក្រុងអ៊ីកូនាម និងអាន់ទីយ៉ូកស្ថិតនៅព្រីគាខាងត្បូង ។ *កាឡាទី* កាលពីមុនឆ្នាំទី២៥មុនគ.ស គឺសំដៅលើអាណាចក្ររបស់ក្រិក ប៉ុន្តែចាប់ពីឆ្នាំនោះមក ត្រូវបានដាក់បញ្ចូលទៅជាខេត្តមួយរបស់ចក្រភពរ៉ូម៉ាំង ។ *ស្រុកអាស៊ី* ជាខេត្តមួយរបស់រ៉ូម៉ាំង រួមមានដូចជា ស្រុកមីស៊ា ស្រុកលីឌា ស្រុកការា និងផ្នែក ខ្លះនៃស្រុកព្រីគា ។
**១៦:៧** *មីស៊ា* ជាខេត្តមួយ ស្ថិតនៅភាគខាងជើងឆៀងខាងលិចនៃទ្វីបអាស៊ី (ភាគខាងលិចបំផុត) តាមបណ្ដោយឆ្នេរសមុទ្រអេជីន (Aegean Sea) ចន្លោះស្រុកលីឌា និងស្រុកប៊ូប៊ុនទីស ។ លោកប៉ុលបានឆ្លងកាត់ទីនោះក្នុងដំណើរបេសកកម្មលើកទី១របស់គាត់ (កច ១៦:៧,៨) ។ *ប៊ីធូនា* ជាខេត្តមួយដ៏សំខាន់សម្រាប់ពួកអភិបាលរ៉ូម៉ាំង ស្ថិតនៅភាគខាងកើតនៃខេត្តមីស៊ា និងបានបង្កើតឡើងបន្ទាប់ពីឆ្នាំទី៧៤មុនគ.ស ។ *ព្រះវិញ្ញាណនៃព្រះយេស៊ូវ* គឺព្រះវិញ្ញាណបរិសុទ្ធ (៥:៣,៤) ។ *មិនអនុញ្ញាតឱ្យ* ត្រង់ចំណុចនេះ បញ្ជាក់ថា ការដឹកនាំរបស់ព្រះអម្ចាស់អាចសំដែងឱ្យដឹងបាន តាមរយៈការជាក់ស្តែង កាលៈទេសៈ ការថ្លែងទំនាយ ។ល។
**១៦:៨** *ទ្រអាស* ជាទីក្រុងមួយ (នៅភាគខាងជើងឆៀងខាងលិចនៃទ្វីបអាស៊ីប៉ែកខាងលិចបំផុត) ស្ថិតនៅចម្ងាយ ១៦,០៨ គ.ម ពី ទីក្រុង"ត្រយ (Troy)"។ ទីក្រុងនេះមានឈ្មោះពេញថា"អ័លេក្សានត្រុស ទ្រអាស" ជាដែនដីអាណានិគមរបស់ចក្រភពរ៉ូម៉ាំង ហើយជាកំពង់ផែសមុទ្រដ៏សំខាន់ដែលភ្ជាប់រវាងខេត្តម៉ាសេដូន ប្រទេសក្រេក និងប្រទេសដែលស្ថិតនៅទ្វីបអាស៊ីភាគខាងលិច ។ បន្ទាប់ពីបានបំពេញបេសកកម្មរបស់ខ្លួន នៅឯទីក្រុងអេភេសូររួចរាល់ហើយ (២កថ ២:១២) លោកប៉ុលក៏បានត្រឡប់មកឯទីក្រុងទ្រអាសនោះវិញ ។ ពួកជំនុំនៅក្នុងទីក្រុងនោះបានចាប់ផ្ដើមឡើង ក្នុងដំណើរបេសកកម្មលើកទី២ ឬលើកទី៣របស់គាត់ព្រោះថាក្នុងដំណើរលើកទី៣តាមផ្លូវត្រឡប់ទៅទីក្រុងយេរូសាឡិមវិញ (២០:៥-១២) គាត់បានចូលទូន្មានដល់ពួកគេ ឱ្យបានខ្ជាប់ខ្ជួនឡើងនៅក្នុងសេចក្ដីជំនឿ ។

**១៦:៩** *ការជាក់ស្តែង* គឺជារបៀបមួយ ដែលព្រះអម្ចាស់បង្ហាញឱ្យដឹងពីបំណងព្រះហឫទ័យទ្រង់ (១០:៣) ។ *មនុស្សពីស្រុកម៉ាសេដូនម្នាក់* នៅឆ្នាំ១៤៨មុនគ.ស ខេត្តម៉ាសេដូនត្រូវបានដាក់ជាដែនដីអាណានិគមរបស់ចក្រភពរ៉ូម៉ាំង ។ ក្នុងដំណើរបេសកកម្មរបស់លោកប៉ុលនៅទីនោះ លោកលូកាក៏នៅជាមួយនឹងគាត់ផងដែរ ។
**១៦:១០** *នោះយើងក៏រកឱកាស. . . ភ្លាម* ត្រង់ចំណុចនេះ បញ្ជាក់យ៉ាងច្បាស់ថា លោកលូកាដែលជាអ្នកនិពន្ធកណ្ឌព្រះគម្ពីរកិច្ចការ ពិតជាមានវត្តមានជាមួយលោកប៉ុលនៅឯទីក្រុងទ្រអាសនោះ ។
**១៦:១១** *សាម៉ូត្រាស* ជាកោះមួយស្ថិតនៅភាគខាងជើងឆៀងខាងកើតនៃសមុទ្រអេជីន (Aegean Sea) ។ កោះនេះជាទីកន្លែងមួយដ៏សមរម្យសម្រាប់ចតទូក ដើម្បីជៀសវាងគ្រោះថ្នាក់ ដែលអាចកើតមានឡើងក្នុងការធ្វើដំណើរនៅពេលយប់ ។ *នាប៉ូល* ជាកំពង់ផែសមុទ្រនៃទីក្រុងភីលីព និងមានចម្ងាយ១៦,០៨ គ.ម ពីទីក្រុងនេះ ហើយបច្ចុប្បន្នត្រូវបានហៅថា "កាវ៉ាឡា (Kavalla)"។
**១៦:១២** *ក្រុងភីលីព* ស្ថិតនៅភាគខាងកើតខេត្តម៉ាសេដូន ។ គេបានយកឈ្មោះរបស់ស្តេចភីលីពទី២ ដែលជាបិតារបស់ស្តេចអធិរាជ អ័លេក្សានត្រុស មកដាក់ជាឈ្មោះទីក្រុងនេះ ។ ម្យ៉ាងទៀត ទីក្រុងនេះជាដែនដីអាណានិគមរបស់ចក្រ-ភពរ៉ូម៉ាំង ដូច្នេះ រាល់ប្រព័ន្ធរដ្ឋបាល និងប្រព័ន្ធគ្រប់គ្រងទាំងអស់ ត្រូវយកគំរូតាមទីក្រុងរ៉ូម (មើលការពន្យល់ ១៣:១៤) ។ ពួកទាហានរ៉ូម៉ាំងជាច្រើនដែលចូលនិវត្តន៍បានមក តាំងទីលំនៅក្នុងទីក្រុងនេះ ប៉ុន្តែ ពុំសូវមានពួកយូដាទេ (មើលសេចក្ដីផ្ដើមគម្ពីរ ភីលីព ត្រង់ចំណុចអ្នកទទួល) ។ *ជាទីក្រុងលេខ១* ខេត្តម៉ាសេដូនមានទីក្រុងធំមួយឈ្មោះក្រុងថែស្សាឡូនីចនិងមានស្រុកចំនួន៤ ។ ទីក្រុងភីលីពស្ថិតនៅក្នុងស្រុកលំដាប់ ទី១នៃខេត្តម៉ាសេដូន ។ ហើយស្រុកដែលក្រុងភីលីពស្ថិតនៅនោះ មានក្រុងធំមួយឈ្មោះថា "ក្រុងអំប៉ុឡូនា"។ ប៉ុន្តែ នៅត្រង់ចំណុចនេះ លោកលូកាប្រើពាក្យថា "ទីក្រុងលេខ១" ព្រោះទីក្រុងភីលីពស្ថិតនៅជិតព្រំប្រទល់ជាងគេក្នុងចំណោមទីក្រុងទាំងប៉ុន្មាននៅក្នុងតំបន់នោះ ។
**១៦:១៣** *កន្លែងដែលគេធ្លាប់អធិស្ឋាន* គេកម្រឃើញសាសន៍យូដាណាដែលគ្មានសាលាប្រជុំណាស់ (បុរសជាតិយូដាដែលរៀបការហើយ ចាប់ពី១០នាក់ឡើងទៅ អាចបង្កើតឱ្យមានសាលាប្រជុំមួយ) ដូច្នេះហើយ បានជាមានពួកអ្នក

និងពួកស្រីៗដែលប្រជុំគ្នា ១៤ នោះមានស្ត្រីម្នាក់ ជាអ្នកជំនួញ
ល័ខពណ៌ស្វាយ ឈ្មោះលីឌា ពីក្រុងធាទេរ៉ា[ធ] ជាអ្នកដែល
ថ្វាយបង្គំព្រះ នាងប្រុងស្តាប់ ហើយព្រះអម្ចាស់ទ្រង់បើក
ចិត្តនាង[ន] ឱ្យយកចិត្តទុកដាក់តាមសេចក្តីដែលប៉ុលអធិប្បាយ
១៥ កាលនាងបានទទួលបុណ្យជ្រមុជទឹក[ប] ព្រមទាំងពួកគ្រួ[ផ]
នាងរួចហើយ នោះក៏អញ្ជើញយើងថា បើអស់លោកយល់
ឃើញថា ខ្ញុំស្មោះត្រង់ចំពោះព្រះអម្ចាស់ពិត នោះសូម
លោកអញ្ជើញទៅនៅឯផ្ទះខ្ញុំកុំខាន នាងក៏បង្ខំដល់យើង ។

## លោកប៉ុល និងសីឡាសនៅក្នុងគុក

១៦ រួចកាលយើងកំពុងតែទៅឯទីអធិស្ឋាន[ព] នោះមានបាវស្រី
ម្នាក់មកចួបនឹងយើង នាងនោះមានអារក្សភីថង់ចូល[ភ] ក៏
បានចំរើនឱ្យចៅហ្វាយនាងជាច្រើនដោយការទាយ ១៧ នាង
ដើរតាមប៉ុល និងយើងខ្ញុំ ទាំងស្រែកថា អ្នកទាំងនេះជាអ្នក
បំរើនៃព្រះដ៏ខ្ពស់បំផុត[ម] ដែលប្រាប់យើង ពីផ្លូវសង្គ្រោះ
១៨ នាងក៏ធ្វើដូច្នោះជាយូរថ្ងៃ ទាល់តែប៉ុលមានសេចក្តីរំខាន
ចិត្ត ហើយបែរទៅនិយាយនឹងអារក្សនោះថា អញបង្គាប់
ឯង ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ឱ្យឯងចេញពីនាង
នេះទៅ វាក៏ចេញទៅនៅវេលានោះឯង[យ] ។
១៩ កាលពួកចៅហ្វាយរបស់នាងឃើញថាទីសង្ឃឹម ដែល
នឹងបានកំរៃ[រ] បានបាត់អស់ទៅហើយ នោះគេក៏ចាប់ប៉ុល
និងសីឡាស[ល] ដោយកន្ត្រាក់កន្ត្រែង[វ] នាំទៅឯទីផ្សារ នៅ
ចំពោះមុខមេនគរបាល ២០ រួចកាលនាំទៅដល់នាយកដំរួត
នគរបាល គេជំរាបថា ពួកសាសន៍យូដាទាំងនេះ នាំឱ្យ
ទីក្រុងយើងកើតវឹកវរជាខ្លាំណាស់[ស] ២១ គេប្រកាសប្រាប់
ពីទំនៀមទំលាប់ ដែលយើងខ្ញុំជាសាសន៍រ៉ូម[ហ] គ្មានច្បាប់
ទទួល ឬកាន់តាមឡើយ[ឡ] ២២ហ្វូងមនុស្សក៏លើកគ្នា
ទាស់នឹងប៉ុល ហើយនិងសីឡាសដែរ រួចមេនគរបាលបាន
កន្ត្រាក់ហែកអាវគេចេញ ហើយបង្គាប់ឱ្យវាយនឹងរំពាត់[អ]
២៣ ក្រោយដែលវាយ មានស្នាមជាច្រើនហើយនោះក៏យក
ទៅដាក់គុក បង្គាប់មេភូឃុំ[ក] ឱ្យរក្សាដោយប្រយ័ត្នប្រយែង
២៤ មេភូឃុំទទួលបង្គាប់យ៉ាងដូច្នោះហើយ ក៏នាំយកគេទៅ
ដាក់ក្នុងគុកជ្រៅ ព្រមទាំងដាក់ខ្នោះភ្ជាប់នៅជើងផង[ខ]
២៥ លុះពេលប្រហែលជាកណ្តាលអធ្រាត្រ[គ] ប៉ុល និងសីឡាស[ឃ]
កំពុងតែអធិស្ឋាន ហើយច្រៀងសរសើរ[ង]ដល់ព្រះ ឯពួកអ្នក
ទោសក៏ស្តាប់ដែរ ២៦ នោះស្រាប់តែកើតមានកក្រើកដី
ជាខ្លាំង ដល់ម្លេះបានជារញ្ជួយ[ច]ដល់ជើងជញ្ជាំងគុកផង
ហើយទ្វារទាំងប៉ុន្មានរបើកចេញភ្លាម[ឆ] ខ្នោះក៏របេះ
ចេញទាំងអស់ទៅ[ជ] ២៧ កាលមេភូឃុំភ្ញាក់ឡើង ឃើញ
ទ្វារគុកនៅចំហដូច្នោះ ក៏ហូតដាវបំរុងនឹងសំឡាប់ខ្លួន

**១៦:១៤** ធ វវ ១:១១ ២:១៨,២៤ ន លក ២៤:៤៥
**១៦:១៥** ប កច ២:៣៨ ផ កច ១១:១៤
**១៦:១៦** ព ខ.១៣ ភ ចទ ១៨:១១ ១យស ២៨:៣,៧
**១៦:១៧** ម មក ៥:៧
**១៦:១៨** យ មក ១៦:១៧
**១៦:១៩** រ ខ.១៦ កច ១៩:២៥,២៦ ល កច ១៥:២២ វ កច ៨:៣ ១៧:៦ ២១:៣០ យក ២:៦
**១៦:២០** ស កច ១៧:៦
**១៦:២១** ហ ខ.១២ ឡ នអ ៣:៨
**១៦:២២** អ ២កថ ១១:២៥ ១ថន ២:២
**១៦:២៣** ក ខ.២៧,៣៦
**១៦:២៤** ខ យប ១៣:២៧ ៣៣:១១ យរ ២០:២,៣ ២៩:២៦
**១៦:២៥** គ ទដ ១១៩:៥៥,៦២ ឃ កច ១៥:២២ ង អភ ៥:១៩
**១៦:២៦** ច កច ៤:៣១ ឆ កច ៥:១៩ ១២:១០ ជ កច ១២:៧

ដែលរស់នៅទីនោះមកប្រជុំគ្នាតាមដងទន្លេកានស៊ីត (Gangites River) ដើម្បីអធិស្ឋាន ។ ពួកគេមានទម្លាប់សាងសង់កន្លែងសម្រាប់អធិស្ឋាន នៅតាមទីទួលក្បែរខ្សែទឹកហូរ ។

**១៦:១៤** *លីឌា* ជាស្ត្រីអ្នកជំនួញម្នាក់ ។ ឈ្មោះរបស់គាត់ប្រហែលមានជាប់ទាក់ទងទៅនឹងស្រុកលីឌា ដែលជាស្រុកកំណើតរបស់គាត់ ។ *ធាទេរ៉ា* គឺជាខេត្តមួយរបស់ចក្រភពរ៉ូម៉ាំង ស្ថិតនៅចម្ងាយ៣២,១៦គ.ម ពីភាគខាងជើងនៃទីក្រុងពើកាណុម (ឬហៅថា ពើកាម៉ុស) (Perganum or Pergamos) ។ ខេត្តនេះល្បីល្បាញខាងផ្នែកជ្រលក់ពណ៌ ជាពិសេសគឺពណ៌ស្វាយសម្រាប់ត្រកូលក្សត្រ (វវ ១:១១ មើលពន្យល់ វវ ២:១៨) ។ *ជាអ្នកដែលថ្វាយបង្គំព្រះ* នាងលីឌាក៏ដូចជាលោកកូនេលាសដែរ គាត់បានជឿដល់ព្រះដ៏ពិត និងប្រតិបត្តិតាមសេចក្តីបង្រៀនដ៏សុចរិតរបស់ទ្រង់ ។ *ព្រះអម្ចាស់ទ្រង់បើកចិត្តនាង* បន្ទាប់ពីការសុគតហើយរស់ឡើងវិញនៃព្រះយេស៊ូវ នោះពួកសិស្សរបស់ទ្រង់ក៏ចាប់ផ្តើមយល់យ៉ាងច្បាស់អំពីអត្ថន័យនៅក្នុងបទគម្ពីរ (លក ២៤:៤៥) ហើយដូចគ្នានោះដែរ ទ្រង់ក៏បើកចិត្តនាងលីឌាឱ្យបានយល់អំពីដំណឹងល្អ ដែលលោកប៉ុលប្រកាសប្រាប់នាងផងដែរ ។

**១៦:១៥** *អញ្ជើញទៅនៅឯផ្ទះខ្ញុំកុំខាន* "សូមប្រៀបធៀបនឹង លក ១៩:៥" ។

**១៦:១៦** *អារក្សភីថង់* គឺជាវិញ្ញាណអារក្ស ។ ភីថង់គឺជាឈ្មោះពស់មួយដែលគេប្រឌិតឡើងយ៉ាងសម្ងាត់ ដើម្បីឱ្យមនុស្សថ្វាយបង្គំនៅឯតំបន់មួយឈ្មោះថា "ភីថង់" ដោយជឿថាវិញ្ញាណរបស់វាអាចចូលទៅក្នុងរូបមនុស្ស ហើយអាចប្រាប់ឱ្យដឹងពីអនាគតបានទៀតផង ។ មនុស្សដែលមានវិញ្ញាណភីថង់នេះចូល ក៏ត្រូវបានហៅថាភីថង់ផងដែរ ។ ក្នុងករណីស្ត្រីបម្រើម្នាក់នោះពុំបានបញ្ជាក់ច្បាស់ថានាង បានទាយពីអ្វីនោះទេ ។

**១៦:១៧** *យើងខ្ញុំ* ចាប់ពី ខ.១៨ រហូតដល់ "២០:៤" មិនមានប្រើពាក្យនេះទេ (មើលការពន្យល់ ខ.១០) រហូតដល់ "២០:៥" ទើបមានប្រើបន្តទៀត ។ *ព្រះដ៏ខ្ពស់បំផុត* (មក ៥:៧ កច ៧:៤៨) នេះជាងាររមួយរបស់ព្រះអម្ចាស់ ដែលគេស្គាល់ច្រើន នៅក្នុងចំណោមពួកសាសន៍យូដា (ជន ២៤:១៦ អស ១៤:១៤ ដយ ៣:២៦) និងសាសន៍ក្រិក ។

**១៦:២០** *នាយកដំរួតនគរបាល* ពាក្យនេះច្រើនសំដៅលើមេបញ្ជាការកងទ័ព ឬចៅហ្វាយខេត្ត ឬក៏អ្នកត្រួតត្រានៅតំបន់អាណានិគមណាមួយ ។ រីឯនៅដែនដីអាណានិគមរបស់ចក្រភពរ៉ូម៉ាំងមួយចំនួន ដូចជានៅក្រុងភីលីពជាដើម គេប្រើពាក្យនេះគឺសំដៅលើចៅក្រម ឬតុលាការ ។

**១៦:២២** *វាយនឹងរំពាត់* គឺវាយនឹងរំពាត់ជាច្រើន ។

**១៦:២៣** *វាយមានស្នាមជាច្រើន* "មើលការពន្យល់ មក ១៥:១៥" ។

**១៦:២៤** *ដាក់ក្នុងគុកជ្រៅ ព្រមទាំងដាក់ខ្នោះ* ទង្វើដែលគេធ្វើនោះមិនគ្រាន់តែ ដើម្បីការពារអ្នកទោស មិនឱ្យរត់ចេញប៉ុណ្ណោះទេ គឺថែមទាំងធ្វើទារុណកម្មលើពួកគេមួយកម្រិតទៀត ។

**១៦:២៧** *បំរុងនឹងសំឡាប់ខ្លួនចោល* ប្រសិនបើអ្នកទោសរត់រួចនោះមេភូឃុំ (អ្នកយាមគុក) ត្រូវតែស្លាប់ជំនួសពួកគេ (១២:១៩) ។ ដូច្នោះ នៅពេលដែល

ចោល ដោយស្មានថា អ្នកទោសបានរត់រួចអស់ហើយ[ឈ]
២៨ ប៉ុន្តែ ប៉ុលស្រែកឡើងឃាត់ថា កុំធ្វើបាបខ្លួនឡើយ ដ្បិត
យើងនៅឯណេះទាំងអស់គ្នាទេ ២៩ មេភូឃុំក៏ឱ្យគេយកភ្លើង
មក រួចម្នីម្នាស្ទុះចូលទៅក្នុងគុក ផ្តួលខ្លួននៅទៀបជើងប៉ុល
នឹងស៊ីឡាស ទាំងញាប់ញ័រ[ញ] ៣០ គាត់នាំគេចេញទៅក្រៅ
សួរថា លោកម្ចាស់អើយ តើត្រូវឱ្យខ្ញុំធ្វើដូចម្តេចឱ្យបានសង្គ្រោះ
ផង[ដ] ៣១ គេក៏ប្រាប់គាត់ថា ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ
ទៅ[ឋ] នោះនឹងបានសង្គ្រោះហើយ[ឌ] ព្រមទាំងពួកគ្រួសារ
លោកផង[ឍ] ៣២ គេក៏ផ្សាយព្រះបន្ទូលនៃព្រះអម្ចាស់ដល់គាត់
នឹងពួកគ្រួគាត់ទាំងអស់ដែរ ៣៣ នៅវេលាយប់នោះឯង[ណ]
គាត់យកគេទៅលាងស្នាមរំពាត់ចេញ រួចខ្លួនគាត់ និងពួក
គាត់ទាំងអស់ក៏ទទួលបុណ្យជ្រមុជទឹកភ្លាម[ត] ៣៤ នោះគាត់[ថ]
នាំគេចូលទៅក្នុងផ្ទះ រៀបតុ ឱ្យបរិភោគដោយមានចិត្ត
រីករាយសាទរ ព្រមទាំងពួកគ្រួគាត់ផង ដោយព្រោះបាន
ជឿដល់ព្រះហើយ ។
៣៥ ដល់ភ្លឺឡើង នោះមេនគរបាលចាត់ពួកនាយ ឱ្យទៅ
ប្រាប់ថា ចូរលែងអ្នកទាំង២នោះទៅ ៣៦ មេភូឃុំ[ទ]ក៏ប្រាប់
ដល់ប៉ុល តាមពាក្យនោះថា លោក នគរបាលបានចាត់
គេមក ប្រាប់ឱ្យលែងលោកចេញទៅហើយ ដូច្នេះសូម
អញ្ជើញទៅដោយសុខសាន្តចុះ[ធ] ៣៧ តែប៉ុលឆ្លើយទៅគេថា
ពួកមេនគរបាលវាយយើងនឹងរំពាត់ នៅកណ្តាលជំនុំ ឥត
មានកាត់ទោស ហើយបានដាក់គុកយើងផង ដែលយើង
ជាជាតិរ៉ូមដូច្នេះ[ន] ឥឡូវនេះ លោកចង់គេចកែប្រែជាដេញ
យើងទៅដោយសំងាត់វិញឬ ធ្វើដូច្នេះពុំបានទេ ត្រូវឱ្យខ្លួន
លោកមកនាំយើងចេញទៅវិញ ៣៨ ពួកនាយក៏ទៅជំរាប
តាមពាក្យនោះ រួចពួកមេនគរបាលមានសេចក្តីភិតភ័យ
ដោយឮថាជាជាតិរ៉ូម[ប] ៣៩ ក៏មកសូមអង្វរដល់គាត់ទាំង២
នាក់ រួចនាំចេញពីក្នុងគុក ហើយសូមឱ្យចេញពីទីក្រុងគេ
ទៅ[ផ] ៤០ កាលចេញពីគុកហើយ ទើបនាំគ្នាទៅឯនាងលីឌា[ព]
លុះបានឃើញពួកជំនុំ[ភ] នោះក៏ទូន្មានដល់គេ រួចចេញដំ
ណើរទៅ។

## នៅឯទីក្រុងថែស្សាឡូនីច

**១៧** ១ រីឯកាលបានដើរកាត់ក្រុងអាំភីប៉ូលី និងក្រុង
អ័ប៉ុឡូនា នោះគេទៅដល់ក្រុងថែស្សាឡូនីច[ម] ជាកន្លែងដែល
មានសាលាប្រជុំរបស់សាសន៍យូដា ២ ប៉ុលក៏ចូលទៅឯគេ

**១៦:២៧** ឈ កច ១២:១៩
**១៦:២៩** ញ កច ១៥:២២
**១៦:៣០** ដ កច ២:៣៧
**១៦:៣១** ឋ យហ ៣:១៥ ឌ រម ១១:១៤ ឍ កច ១១:១៤
**១៦:៣៣** ណ ខ.២៥ ត កច ២:៣៨
**១៦:៣៤** ថ កច ១១:១៤
**១៦:៣៦** ទ ខ.២៣,២៧ ធ កច ១៥:៣៣
**១៦:៣៧** ន កច ២២:២៥–២៩
**១៦:៣៨** ប កច ២២:២៩
**១៦:៣៩** ផ មថ ៨:៣៤ លក ៨:៣៧
**១៦:៤០** ព ខ.១៤ ភ ខ.២ កច ១:១៦
**១៧:១** ម ខ.១១,១៣ ភល ៤:១៦ ១ថន ១:១ ២ថន ១:១ ២ធថ ៤:១០

មេភូឃុំគិតថាអ្នកទោសរត់អស់ហើយ នោះក៏គិតចង់សម្លាប់ខ្លួនឯងចោល ដោយយល់ថា អាចជួយកាត់បន្ថយការអាម៉ាស់ និងការឈឺចាប់ ដែលខ្លួនត្រូវទទួល ។

**១៦:៣០** *តើត្រូវឱ្យខ្ញុំធ្វើដូចម្តេច ឱ្យបានសង្គ្រោះផង?* មេភូឃុំបានឮថា ពួកអ្នកដែលគាត់យកមកដាក់គុកនោះ ជាអ្នកអធិប្បាយព្រះបន្ទូលព្រះដ៏ខ្ពស់បំផុត ដែលប្រាប់អំពីផ្លូវនៃសេចក្តីសង្គ្រោះ (ខ.១៧) ។ ដូច្នេះនៅពេលមានកក្រើកដី និងរញ្ជួយដល់ជើងជញ្ជាំងគុក រួមជាមួយនឹងសេចក្តីស្លាប់ដែលគាត់ត្រូវទទួល បានបណ្តាលឱ្យគាត់ចង់ដឹងពីផ្លូវ ដែលធ្វើឱ្យគាត់បានសង្គ្រោះពិតប្រាកដ ។

**១៦:៣១** *ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ* នេះគឺជាអត្ថន័យសង្ខេបអំពីរបៀបទទួលការសង្គ្រោះពីព្រះអម្ចាស់ (១០:៤៣) ។

**១៦:៣២** *ព្រះបន្ទូលនៃព្រះអម្ចាស់* លោកប៉ុល និងស៊ីឡាសបានធ្វើការពន្យល់យ៉ាងអស់ពីចិត្ត នូវព្រះបន្ទូលនៃដំណឹងល្អ ដល់មេភូឃុំ ព្រមទាំងក្រុមគ្រួសារ និងពួកអ្នកនៅក្រោមបង្គាប់គាត់ទាំងអស់ ។ ពួកគេក៏បានជឿដល់ព្រះយេស៊ូវគ្រីស្ទ និងបានសង្គ្រោះទាំងអស់គ្នា (ខ.៣៤) ។

**១៦:៣៣** *នៅវេលាយប់នោះឯង* គឺប្រហែលជាពេលកណ្តាលអធ្រាត្រ (ខ.២៥) ។

**១៦:៣៤** *នាំគេចូលទៅក្នុងផ្ទះ* "ប្រៀបធៀប ខ.១៥"។ *មានចិត្តរីករាយសាទរ* ត្រង់ចំណុចនេះបង្ហាញថា ការប្រែចិត្តពិតប្រាកដ ពុំអាស្រ័យលើកាលៈទេសៈណានោះទេ (មើលការពន្យល់ ៨:៣៩) ។

**១៦:៣៧** *ឥតមានកាត់ទោស* ការវាយមនុស្សណាម្នាក់ដែលមានសញ្ជាតិរ៉ូម (ខ.៣៨) គឺជាការរំលោភច្បាប់ ។ ដូច្នោះ ទើបមេនគរបាលចង់ដោះលែងលោកប៉ុល និងស៊ីឡាស ដោយពុំចាំបាច់មានការកាត់ទោសអ្វីនោះទេ (មើលការពន្យល់ ២២:២៥) ។ *ត្រូវឱ្យខ្លួនលោកមកនាំយើងចេញទៅវិញ* លោកប៉ុល និង ស៊ីឡាស ពុំចង់ឱ្យគេមកហែហម ដើម្បីជាថ្លៃសងនូវការឈឺចាប់នោះទេ ប៉ុន្តែ ពួកគាត់ចង់បង្ហាញអំពីសេចក្តីសុចរិត និងភាពស្មោះត្រង់របស់ខ្លួន សម្រាប់ជាប្រយោជន៍ដល់ពួកជំនុំនៅទីក្រុងភីលីពវិញ ។

**១៧:១** *ក្រុងអាំភីប៉ូលី... ក្រុងថែស្សាឡូនីច* គឺតាមផ្លូវមួយឈ្មោះ "អ៊ិចណេធាន" (Egnatian Way) មានទិសដៅពីលិចទៅកើត ស្ថិតនៅភាគខាងជើងនៃប្រទេសក្រេក កាត់តាមទីក្រុងភីលីព ក្រុងអាំភីប៉ូលី ក្រុងអ័ប៉ុឡូនា និងទីក្រុងថែស្សាឡូនីច ។ ផ្នែកខ្លះៗនៃផ្លូវនេះ ដូចជានៅកាវ៉ាឡា (Kavalla) ទីក្រុងភីលីព និងក្រុងអ័ប៉ុឡូនា អាចនៅមើលឃើញរហូតដល់សព្វថ្ងៃ ។ នៅសម័យនោះ ប្រសិនបើគេធ្វើដំណើរ ៤៨,២៤ គ.ម ក្នុងរយៈពេលមួយថ្ងៃ នោះពីទីក្រុង១ទៅទីក្រុង១ទៀតត្រូវប្រើរយៈពេល១ថ្ងៃ ។ *ថែស្សាឡូនីច* ជាទីក្រុងធំនៃខេត្តម៉ាសេដូន និងស្ថិតនៅចម្ងាយ ប្រហែល ១៦១ គ.ម ពីទីក្រុងភីលីព ។ ក្នុងពេលនោះទីក្រុងថែស្សាឡូនីចមានចំនួន ប្រជាជនជាង ២០០ ០០០ នាក់ ដែលរួមមានពួកសាសន៍យូដាផងដែរ ។ ទាំងនេះជាមូលហេតុ ដែលធ្វើឱ្យលោកប៉ុលសម្រេចចិត្ត ទៅប្រកាសដំណឹងល្អ នៅទីក្រុងថែស្សាឡូនីច (មើលសេចក្តីផ្តើម ១ថន) ។

**១៧:២** *ចូលទៅឯគេ* "មើលការពន្យល់ ១៣:១៤"។ *ក្នុង៣ថ្ងៃឈប់សំរាក* គឺស្មើនឹងរយៈពេល២សប្តាហ៍ ជាពេលដែលលោកប៉ុលចំណាយនៅក្នុងសាលាប្រជុំ ដើម្បីជជែក និងពន្យល់ដល់ពួកយូដា ប៉ុន្តែ ពុំមែនជារយៈពេល

តាមទំលាប់គាត់[យ] ហើយជជែកពន្យល់ដល់គេតាមគម្ពីរ[រ] ក្នុង
៣ថ្ងៃឈប់សំរាក[ល] ៣ក៏បើកសំដែងយ៉ាងច្បាស់ថា ព្រះគ្រីស្ទ
ត្រូវតែរងទុក្ខ[វ] រួចមានព្រះជន្មរស់ពីស្លាប់ឡើងវិញ[ស] គាត់ក៏
និយាយថា ព្រះយេស៊ូវនេះឯង ដែលខ្ញុំប្រកាសប្រាប់ដល់អ្នក
រាល់គ្នា ទ្រង់ជាព្រះគ្រីស្ទនោះហើយ[ហ] ៤ពួកអ្នកនោះ ខ្លះក៏
យល់ព្រម ហើយបានចូលខាងប៉ុល និងស៊ីឡាស[ឡ] ព្រមទាំង
ពួកសាសន៍ក្រេកសន្ធឹក ដែលតែងតែថ្វាយបង្គំព្រះ និងពួក
ស្រីអ្នកមុខជាក្រែលដែរ ៥តែពួកសាសន៍យូដាដែលមិន
ព្រមជឿ គេមានចិត្តឈ្នានីស ក៏នាំយកមនុស្សពាលអនាថា
ខ្លះមក រួចប្រមូលបានមនុស្សយ៉ាងសន្ធឹក ទៅបង្កើតវឹកវរ
ក្នុងទីក្រុង[អ] ហើយនាំគ្នាទៅ ចោមព័ទ្ធផ្ទះយ៉ាសុន[ក] រកចាប់
ប៉ុល នឹងស៊ីឡាស នាំចេញមកឯបណ្តាជន ៦លុះរកមិន
ឃើញ ក៏ចាប់យ៉ាសុន និងពួកជំនុំខ្លះ[ខ] កន្ត្រាក់[គ]ដឹកនាំទៅដាក់
នៅមុខចៅហ្វាយទីក្រុងដោយស្រែកថា ពួកដែលនាំឱ្យក្រ
ឡាប់ផែនដី[ឃ]នោះ បានមកទីនេះហើយ[ង] ៧ឯយ៉ាសុននេះ
ជាអ្នកបានទទួលគេ ពួកនោះ ប្រព្រឹត្តសុទ្ធតែខុសនឹងបញ្ញត្តិ
របស់សេសារ ដោយនិយាយថា មានស្តេច១ទៀតឈ្មោះ
យេស៊ូវ[ច] ៨មនុស្សទាំងនោះក៏នាំឱ្យអស់បណ្តាជន និង
ចៅហ្វាយនៃទីក្រុងកើតបារម្ភព្រួយ ដោយឮសេចក្តីនោះ
៩រួចកាលបានយកប្រាក់ធានាពីយ៉ាសុន[ឆ] និងអ្នកឯទៀត
ហើយ នោះក៏លែងគេចេញទៅ ។

## នៅឯទីក្រុងបេរា

១០ពួកជំនុំក៏ឱ្យប៉ុល និងស៊ីឡាស[ជ]ចេញទៅឯក្រុងបេរា[ឈ]
ទាំងយប់ភ្លាម កាលទៅដល់ នោះគេចូលទៅក្នុងសាលា
ប្រជុំរបស់ពួកសាសន៍យូដា[ញ] ១១រីឯពួកអ្នកស្រុកនោះមានចិត្ត
ល្អជាងពួកអ្នកនៅថែស្សាឡូនីច[ដ] គេប្រុងប្រៀបសព្វគ្រប់នឹង
ទទួលព្រះបន្ទូល ក៏ពិចារណាមើលគម្ពីរ[ឋ]រាល់តែថ្ងៃ ឱ្យ
បានដឹងជាសេចក្តីទាំងនោះត្រូវ ឬមិនត្រូវ[ឌ] ១២ដូច្នេះ មាន
ពួកគេ នឹងពួកស្រីសាសន៍ក្រេកជាអ្នកមុខអ្នកការជាច្រើន
បានជឿ ក៏មានប្រុសៗក្រែលដែរ[ឍ]។

**១៧:២** យ កច ៩:២០ រ កច ៨:៣៥ ១៨:២៨ ល កច ១៣:១៤ **១៧:៣** វ លក ២៤:២៦ កច ៣:១៨ ស លក ២៤:៤៦ កច ២:២៤ ហ កច ៩:២២ **១៧:៤** ឡ កច ១៥:២២ **១៧:៥** អ ខ.១៣ ១ថន ២:១៦ ក រម ១៦:២១ **១៧:៦** ខ កច ១:១៦ គ កច ១៦:១៩ ឃ មថ ២៤:១៤ ង កច ១៦:២០ **១៧:៧** ច លក ២៣:២ យហ ១៩:១២ **១៧:៩** ឆ ខ.៥

**១៧:១០** ជ កច ១៥:២២ ឈ ខ.១៣ កច ២០:៤ ញ កច ៩:២០ **១៧:១១** ដ ខ.១ ឋ លក ១៦:២៩ យហ ៥:៣៩ ឌ ចទ ២៩:២៩ **១៧:១២** ឍ កច ២:៤១

សរុបទាំងអស់ដែលគាត់ស្នាក់នៅទីក្រុងថែស្សាឡូនីចនោះទេ ។ តាមការវិភាគសំបុត្រ ដែលលោកប៉ុលផ្ញើទៅពួកអ្នកជឿនៅទីក្រុងថែស្សាឡូនីចបញ្ជាក់ថា គាត់បានបង្រៀនពួកគេអំពីសេចក្តីជាច្រើន ។ ដូច្នេះ រយៈពេលដែលគាត់ស្នាក់នៅក្នុងទីក្រុងនេះ គឺអាចលើសពី២ ឬ ៣សប្តាហ៍ ។

**១៧:៣** *បើកសំដែងយ៉ាងច្បាស់* នៅក្នុង "លក ២៤:៤៥" ជាភាសាក្រិកប្រើពាក្យថា "បើក"។ លោកលូកាប្រើពាក្យនេះ គឺដើម្បីពណ៌នាអំពីសេចក្តីដែលព្រះយេស៊ូវបង្រៀនដល់សាវ័ក ស្តីពីការសុគត និងរស់ឡើងវិញរបស់ទ្រង់ (លក ២៤:២៧) ។

**១៧:៤** *ពួកសាសន៍ក្រេកសន្ធឹក ដែលតែងតែថ្វាយបង្គំព្រះ* "មើលការពន្យល់ ១០:២ ១៦:១៤"។ *ពួកស្រីអ្នកមុខ* ប្រហែលជាប្រពន្ធរបស់ពួកអ្នកដឹកនាំនៅទីក្រុងនោះ ហើយជាអ្នកដែលមានសិទ្ធិ និងឋានៈគួរឱ្យគេគោរពនៅក្នុងចំណោមពួកបណ្តាជន (ខ.១២) ។

**១៧:៥** *គេមានចិត្តឈ្នានីស* ពេលនោះ ពួកសាសន៍យូដាដែលមិនព្រមជឿមានចិត្តក្តៅក្រហាយ ហើយបានប្រឆាំងនឹងព្រះបន្ទូលនៃដំណឹងល្អ ព្រោះឃើញមានមនុស្សជាច្រើន (រួមមានពួកយូដា និងពួកសាសន៍ដទៃដែលកោតខ្លាចដល់ព្រះ) បានជឿដល់ព្រះអម្ចាស់ តាមរយៈសេចក្តីបង្រៀនរបស់លោកប៉ុល (១៣:៤៥)។ *ផ្ទះយ៉ាសុន* លោកយ៉ាសុនប្រហែលជាញាតិសន្តានម្នាក់របស់លោកប៉ុល (រម ៩:៣ ១៦:១១,២១)។

**១៧:៦** *ចៅហ្វាយទីក្រុង* នៅឆ្នាំ១៨៣៥គ.ស គេបានរកឃើញផ្ទាំងសិលាចារឹកជាភាសាក្រិកដែលមានប្រើពាក្យថា "ចៅហ្វាយទីក្រុង" នៅតាមបណ្តោយផ្លូវអ៊ីចណោធាន (Egnatian) ភាគខាងលិចនៃទីក្រុងថែស្សាឡូនីច ។ ប៉ុន្តែផ្ទាំងសិលាចារឹកនេះបានបាក់បែកខូចខាតនៅឆ្នាំ១៨៦៧ ហើយបំណែកបាក់បែកទាំងអស់ ត្រូវបានគេយកទៅរក្សាទុក ក្នុងសារមន្ទីរ នៅឯទីក្រុងឡុងដ៏នៃប្រទេសអង់គ្លេស ។ ក្រោយមក គេបានរកឃើញផ្ទាំងសិលាចារឹកដែលមានប្រើពាក្យនេះចំនួន១៦ទៀតនៅតាមទីក្រុង ដែលស្ថិតនៅជុំវិញខេត្តម៉ាសេដូន និងកន្លែងផ្សេងៗទៀត ។

**១៧:៧** *ប្រព្រឹត្តសុទ្ធតែខុសនឹងបញ្ញត្តិរបស់សេសារ* ពួករ៉ូម៉ាំងបានចាត់ទុកអ្នកដែលគាំទ្រដល់ពួកប្រឆាំងនឹងស្តេចសេសារ ថាជាជនឧក្រិដ្ឋ និងត្រូវទទួលទោសយ៉ាងធ្ងន់ធ្ងរបំផុត (យហ ១៨:១២)។ ដូច្នោះហើយ ទើបពួកយូដានាំគ្នានិយាយមួលបង្កាច់លោកប៉ុល និងគូកនរបស់គាត់ថា បានប្រឆាំងនឹងសេសារ គឺក្នុងគោលបំណងចង់ឱ្យពួកគាត់ជាប់ទោសដ៏អយុត្តិធម៌ និងអាម៉ាស់បំផុត ។

**១៧:៩** *ធានា* ពួកគេបានបង្ខំឱ្យលោកយ៉ាសុនធានាចំពោះស្ថេរភាព និងភាពស្ងប់ស្ងាត់នៅក្នុងតំបន់ដែលគាត់រស់នៅនោះ បើពុំដូច្នោះទេ ពួកគេនឹងរឹបអូសយកទ្រព្យសម្បត្តិរបស់គាត់ ហើយអាចមានគ្រោះថ្នាក់រហូតដល់ជីវិត ។

**១៧:១០** *ក្រុងបេរា* (សព្វថ្ងៃហៅថា "វេរា Verria") ស្ថិតនៅចម្ងាយ៨០គ.ម ពីក្រុងថែស្សាឡូនីច ។ លោកធីម៉ូថេប្រហែលជាបានចាកចេញពីលោកប៉ុល និងស៊ីឡាសនៅក្រុងភីលីព ហើយបានមកជួបគ្នាវិញនៅក្រុងបេរានេះ (ខ.១០,១៤)។ *សាលាប្រជុំ* "មើលការពន្យល់ ១៣:១៤"។

**១៧:១១** *ពួកអ្នកស្រុកនោះ* គឺពួកអ្នកដែលរស់នៅក្នុងក្រុងបេរា ។ លោកលូកាបានបញ្ជាក់ថាអ្នកស្រុកនេះ មានម្នាក់ឈ្មោះលោកសូប៉ាត្រុស ជាកូនរបស់លោកពៀរូស បានធ្វើដំណើរទៅជាមួយលោកប៉ុល នាំយកអំណោយទៅឱ្យពួកបងប្អូន នៅឯទីក្រុងយេរូសាឡិម (មើលការពន្យល់ ២០:៤)។

**១៧:១២-១៣** ត្រង់ចំណុចនេះបញ្ជាក់ថា ពួកអ្នកក្រុងបេរាមានចិត្តចំហទទួលយកសេចក្តីបង្រៀនថ្មីរបស់លោកប៉ុល ដោយធ្វើការប្រៀបធៀបទៅនឹងបទគម្ពីរសញ្ញាចាស់ដែលពួកគេធ្លាប់ប្រតិបត្តិតាម ។ ដូច្នេះយើងជាអ្នកជឿដល់ព្រះអម្ចាស់ ត្រូវប្រៀបធៀបគ្រប់សេចក្តីបង្រៀនទាំងអស់ទៅនឹងព្រះបន្ទូលទ្រង់ ដែលបានចែងទុកក្នុងព្រះគម្ពីរបរិសុទ្ធ ។ បើសេចក្តីបង្រៀនណាស្របនឹងព្រះបន្ទូលនៃព្រះអម្ចាស់ នៅក្នុងព្រះគម្ពីរនោះសូមទទួលយកទៅតាមបំណងព្រះហឫទ័យទ្រង់ចុះ ។

១៣តែកាលពួកសាសន៍យូដានៅថែស្សាឡូនីច បានដឹងថា
ប៉ុលបានផ្សាយព្រះបន្ទូលក្នុងក្រុងបេរាដែរ[ណ] នោះគេក៏មក
ញុះញង់បណ្ដាជននៅទីនោះទៀត ១៤ដូច្នេះ ពួកជំនុំ[ត]ឱ្យ
ប៉ុលចេញទៅភ្លាម ធ្វើដូចជានឹងទៅឯសមុទ្រ តែស៊ីឡាស[ថ]
និងធីម៉ូថេ[ទ]នៅទីនោះតទៅ ១៥ឯពួកអ្នកដែលជូនប៉ុលទៅ
គេនាំទៅឯក្រុងអាថែន[ធ]វិញ រួចកាលគេទទួលពាក្យដែល
គាត់ផ្ដាំទៅស៊ីឡាស នឹងធីម៉ូថេ ឱ្យគេមកចួបនឹងគាត់ជា
ប្រញាប់ នោះគេនាំគ្នាត្រឡប់វិលទៅវិញ[ន]។

## នៅឯទីក្រុងអាថែន

១៦កំពុងដែលប៉ុលចាំគេ នៅក្រុងអាថែន នោះគាត់មាន
សេចក្ដីរំជួលក្នុងចិត្តជាខ្លាំង ដោយឃើញមានរូបព្រះ នៅ
ពេញក្នុងទីក្រុងនោះ ១៧ដូច្នេះ គាត់ក៏ជជែកពន្យល់ដល់
សាសន៍យូដា នឹងពួកអ្នកដែលថ្វាយបង្គំក្នុងសាលាប្រជុំ[ប]គេ
ហើយនៅទីផ្សារ ជាមួយនឹងអស់អ្នកដែលមកចួបនឹងគាត់
រាល់តែថ្ងៃដែរ ១៨តែមានពួកអេពីគួរ និងពួកស្ទអ៊ីកខ្លះ ជា
អ្នកប្រាជ្ញបរមត្ថ គេមកចួបនឹងគាត់ ខ្លះសួរថា តើអ្នកដែល
និយាយប៉ប៉ាច់នេះចង់ថាដូចម្ដេច ខ្លះទៀតថា មើលទៅ
ដូចជាគាត់សំដែងពីព្រះដទៃទេ ដ្បិតឮគាត់ប្រាប់គេពី
ព្រះយេស៊ូវ[ផ] ហើយពីសេចក្ដីរស់ពីស្លាប់ឡើងវិញ[ព] ១៩គេក៏
នាំយកគាត់ទៅឯភ្នំអើរីយ៉ូស[ភ]សួរថា តើយើងអាចនឹងដឹងជា
សេចក្ដីបង្រៀនថ្មី[ម] ដែលអ្នកអធិប្បាយនេះជាយ៉ាងណាបាន
ឬទេ ២០ដ្បិតយើងបានឮអ្នកអធិប្បាយយ៉ាងប្លែកណាស់
ដូច្នេះ យើងចង់ដឹងន័យសេចក្ដីទាំងនេះដែរ ២១[យ]រីឯពួកអ្នក
នៅក្រុងអាថែន[យ]នឹងពួកអ្នកប្រទេសក្រៅ ដែលមកស្នាក់នៅ
ទាំងប៉ុន្មាន គេមិនដែលបង់ពេលទំនេរនឹងធ្វើអ្វីទៀតទេ
គេគិតតែពីប្រាប់ ឬស្ដាប់សេចក្ដីថ្មីប៉ុណ្ណោះ ។
២២ឯប៉ុល គាត់ឈរនៅកណ្ដាលទីអើរីយ៉ូស[រ] សំដែងថា
ឱពួកអ្នកនៅក្រុងអាថែនអើយ ក្នុងការទាំងអស់ ខ្ញុំយល់
ឃើញថា អ្នករាល់គ្នាឧស្សាហ៍ខ្នះខ្នែងកាន់សាសនាណាស់[ល]
២៣ដ្បិតកំពុងដែលខ្ញុំដើរចុះឡើង មើលប្រដាប់ប្រដាដែល
អ្នករាល់គ្នាគោរពបូជា នោះខ្ញុំឃើញមានអាសនា១ ដែល
មានចារិកថា « ព្រះដ៏ពុំស្គាល់ » ដូច្នេះ ខ្ញុំនឹងប្រាប់ដល់អ្នក

**១៧:១៣** ណ ហព ៤:១២
**១៧:១៤** ត កច ៩:៣០ ថ កច ១៥:២២ ទ កច ១៦:១
**១៧:១៥** ធ ខ.១៦, ២១,២២ កច ១៨:១ ១ថន ៣:១ ន កច ១៨:៥
**១៧:១៧** ប កច ៩:២០
**១៧:១៨** ផ កច ១៣:៣២ ព ខ.៣១, ៣២ កច ៤:២
**១៧:១៩** ភ ខ.២២ ម មក ១:២៧
**១៧:២១** យ ខ.១៥
**១៧:២២** រ ខ.១៩ ល ខ.១៦

**១៧:១៤** *ឯសមុទ្រ* ពាក្យនេះចង់បញ្ជាក់ប្រាប់ថាពីទីក្រុងបេរាទៅឯក្រុងអាថែនគឺត្រូវធ្វើដំណើរតាមសមុទ្រ ។ ដូច្នេះហើយ បានជាពួកអ្នកជឿដល់ព្រះអម្ចាស់នៅទីក្រុងនោះនាំលោកប៉ុលទៅឯសមុទ្រ ។

**១៧:១៥–១៦** *ក្រុងអាថែន* ទីក្រុងអាថែនកាលពីប្រាំសតវត្សរ៍មុនសម័យកាលលោកប៉ុល មានភាពល្បីល្បាញខាងផ្នែកសិល្បៈ ទស្សនវិជ្ជា និងអក្សរសាស្ត្រ ។ រហូតមកដល់សម័យកាលលោកប៉ុល ទីក្រុងអាថែនក៏នៅតែមានសាកលវិទ្យាល័យឈានមុខគេ និងនៅតែបន្តភាពល្បីល្បាញរបស់ខ្លួនខាងផ្នែកទស្សនវិជ្ជាដដែល ។

**១៧:១៧** ក្នុងខណៈពេលស្នាក់នៅទីក្រុងអាថែន ដើម្បីរង់ចាំស៊ីឡាស និងធីម៉ូថេលោកប៉ុលបានបង្រៀនដល់បណ្ដាជន អំពីព្រះបន្ទូលនៃដំណឹងល្អមិនគ្រាន់តែនៅក្នុងសាលាប្រជុំរបស់សាសន៍យូដាប៉ុណ្ណោះទេ គឺនៅតាមទីផ្សារ និងទីសាធារណៈ ផ្សេងៗទៀតផងដែរ ។ *សាលាប្រជុំ* "មើលការពន្យល់ ១៣:១៤"។ *ពួកអ្នកដែល ថ្វាយបង្គំក្នុងសាលាប្រជុំ* "មើលពន្យល់ ១០:២"។

**១៧:១៨** *អេពីគួរ...ជាអ្នកប្រាជ្ញបរមត្ថ* ("អ្នកប្រាជ្ញបរមត្ថ"ភាសាអង់គ្លេសប្រើពាក្យថា "ទស្សនវិទូ") ក្រុមទស្សនវិទូនៅអេពីគួរគឺជាអ្នកបានប្រតិបត្តិតាមសេចក្ដីបង្រៀនរបស់ទស្សនវិទូឈ្មោះអេពីគួរូស (Epicurus) ដែលកើតនៅឆ្នាំទី៣៤១ មុន គ.ស ។ តាមរយៈទស្សនវិជ្ជារបស់លោកអេពីគួរូស "ជីវិតគឺគ្មានន័យអ្វីទាំងអស់ លើកលែងតែការសប្បាយ និងការសម្រាក ដោយសុខស្រួលរហូតប៉ុណ្ណោះ"។ រីឯពួកទស្សនវិទូនៅស្ទអ៊ីកវិញ មានទស្សនៈផ្សេងពីនេះដោយពួកគេជឿថា មនុស្សគ្រប់គ្នាគួរតែខ្លាំង និងពុះពាររាល់ឧបសគ្គព្រមទាំងការឈឺចាប់គ្រប់បែបយ៉ាង ហើយមិនគួរស្វែងរកការសប្បាយនោះទេ ប៉ុន្តែ ត្រូវខំប្រឹងគ្រប់គ្រងខ្លួនឯងវិញ ។ ក្រោយមកទៀត នៅក្នុងសម័យកាលលោកប៉ុល ទស្សនៈទាំងពីរនោះបានក្លាយទៅជាប្រព័ន្ធមួយ ដែលពេញទៅដោយសេចក្ដីអំនួត ។

ទស្សនវិទូទាំងពីរក្រុមនោះមិនបានយល់ពីព្រះបន្ទូលនៃសេចក្ដីពិតទេ ដូច្នោះ ហើយបានជានៅពេលឮការបង្រៀនរបស់លោកប៉ុល នោះក៏តាំងនាំគ្នាមកចំអកដាក់គាត់ ដោយពោលថា ជាមនុស្សនិយាយប៉ប៉ាច់ប៉ប៉ោច ។ *និយាយប៉ប៉ាច់* ពាក្យនេះនៅក្នុងភាសាក្រិកមានន័យថា "អ្នករើសគ្រាប់ធញ្ញជាតិ" (ប្រៀបប្រដូចទៅនឹងបក្សី) និងសំដៅលើមនុស្សដែលចំណាយពេលឥតប្រយោជន៍នៅតាមទីផ្សារ និងទីសាធារណៈ ។

**១៧:១៩–២០** *ភ្នំអើរីយ៉ូស* ពាក្យនេះក្លាយមកពីពាក្យថា"ខ្លង់រាបអើរ៉ាស" (អរ ២:៥) ដែលស្ថិតនៅកណ្ដាលទីក្រុងអាថែន (ពួកក្រិកមានរូបព្រះមួយឈ្មោះថា អើរ៉ាស ដែលជាព្រះផ្គរលាន់ និងសង្គ្រាម)។ ភ្នំអើរីយ៉ូស ឬទីអើរីយ៉ូស ធ្លាប់ជាទីកន្លែងសម្រាប់តុលាការជាន់ខ្ពស់ នៃទីក្រុងអាថែន មានសមាជិកដំបូង១២នាក់ ក្រោយមកមានចំនួនរហូតដល់៣០០នាក់ជាបុរសមកពីត្រកូលអ្នកមានកិត្តិយសនៅក្នុងទីក្រុងនេះ ។

**១៧:២១** ត្រង់ចំណុចនេះចង់បញ្ជាក់ប្រាប់ថា ពួកអ្នករស់នៅទីក្រុងអាថែនតែងតែចង់ដឹងចង់ឮនូវសេចក្ដីបង្រៀនដែលថ្មី ។ ដូច្នេះ មូលហេតុចំបងមួយដែលធ្វើឱ្យពួករ៉ូម៉ាំងយកជ័យជម្នះលើពួកក្រិកបាន គឺដោយសារពួកនេះចំណាយពេលក្នុងការនិយាយច្រើនជាងការប្រយុទ្ធ ។

**១៧:២២** *សាសនា* នៅក្នុងភាសាក្រិកគេប្រើពាក្យថា"សាសនា"នេះសម្រាប់ថ្លែងនូវការសរសើរ ឬរិះគន់ចំពោះអ្នកណាម្នាក់ ។ ដូច្នេះ នៅពេលដែលលោកប៉ុលនិយាយពាក្យនេះដំបូង ពួកអ្នកក្រុងអាថែនពុំបានយល់ពីអត្ថន័យដែលគាត់ចង់និយាយនោះទេ ។ ការដែលលោកប៉ុលធ្វើយ៉ាងដូច្នោះ ព្រោះចង់ឱ្យមានមនុស្សមកស្ដាប់សេចក្ដីដែលគាត់បង្រៀននោះកាន់តែច្រើន ។

**១៧:២៣** *ព្រះដ៏ពុំស្គាល់* ពួកសាសន៍ក្រិកនៅពេលនោះមានការភ័យខ្លាច និងពុំហ៊ានប្រមាថដល់ព្រះណាមួយឡើយ ដូច្នោះហើយ បានជាពួកគេនាំគ្នាធ្វើស្លាកដែលមានសរសេរពាក្យថា"ព្រះដ៏ពុំស្គាល់" ដោយគិតថា ប្រហែល

រាល់គ្នាពីព្រះ ដែលអ្នករាល់គ្នាគោរពបូជាដោយឥតស្គាល់នោះ
ឯង[រ] ២៤ដ្បិតព្រះដែលបង្កើតលោកិយ និងរបស់សព្វសារពើ
[ស] ព្រះអង្គនោះទ្រង់ជាព្រះអម្ចាស់ នៃស្ថានសួគ៌ និងផែនដី[ហ]
ទ្រង់មិនគង់ នៅក្នុងវិហារ ដែលដៃមនុស្សបានធ្វើទេ[ឡ] ២៥ក៏
មិនបាច់មានដៃមនុស្សបំរើទ្រង់ ដូចជាទ្រង់ត្រូវការអ្វីនោះ
ផងដែរ ដ្បិតគឺទ្រង់ដែលផ្ដត់ផ្គង់ដោយព្រះអង្គទ្រង់ ឱ្យគ្រប់
ទាំងអស់មានជីវិតមានដង្ហើមគ្រប់ជំពូក[អ] ២៦ទ្រង់បានបង្កើត
មនុស្សគ្រប់សាសន៍ពីឈាមតែ១ ឱ្យបាននៅពេញលើផែនដី
ព្រមទាំងសំរេចកំណត់ពេលវេលា ដែលបានតាំងជាមុន
នឹងព្រំទីលំនៅរបស់គេគ្រប់គ្នា[ក] ២៧ដើម្បីឱ្យគេស្វែងរក
ព្រះ ក្រែងគេនឹងរកទ្រង់ឃើញ ដោយខំរាវរកមែននោះ
ទេដឹង ទោះបើទ្រង់មិនគង់ឆ្ងាយពីយើងនិមួយៗក៏ដោយ[ខ]
២៨ដ្បិតគឺដោយសារទ្រង់ហើយ ដែលយើងរាល់គ្នាបាន
រស់កំរើក ហើយមាននៅផង[គ] ដូចជាពួកអ្នកលើកកំណាព្យ
ខ្លះរបស់អ្នករាល់គ្នា បាននិយាយដែរថា «មនុស្សយើងជា
ពូជព្រះដែរ»។

២៩ដូច្នេះ បើយើងរាល់គ្នាជាពូជព្រះហើយ នោះមិនត្រូវ
ឱ្យយើងស្មានថា ព្រះទ្រង់ដូចជាមាស ឬប្រាក់ ឬថ្ម ឬជា
របស់ឆ្លាក់ តាមការរចនា តាមគំនិតរបស់មនុស្សនោះទេ[ឃ]
៣០ពីដើមព្រះទ្រង់បានទតរំលង[ង]គ្រាខ្លៅល្ងង់[ច]មែន តែឥឡូវ
នេះ ទ្រង់ត្រាស់បង្គាប់ដល់មនុស្សទាំងអស់ នៅគ្រប់អន្លើ
ឱ្យប្រែចិត្តវិញ[ឆ] ៣១ពីព្រោះ ទ្រង់បានដាក់កំណត់ថ្ងៃដែល
ទ្រង់នឹងជំនុំជំរះ[ជ]លោកីយ ដោយយុត្តិធម៌[ឈ] ដោយសារ
មនុស្សម្នាក់ ដែលទ្រង់បានដំរូវរួចហើយ[ញ] ព្រមទាំងដាក់
ភស្តុតាងសំញែងយ៉ាងជាក់លាក់ ដល់មនុស្សទាំងឡាយ
ដោយទ្រង់ប្រោសមនុស្សនោះ ឱ្យរស់ពីស្លាប់ឡើងវិញ[ដ]។
៣២កាលគេបានឮនិយាយពីមនុស្សស្លាប់រស់ឡើងវិញ[ឋ]
នោះមានខ្លះចំអកឱ្យ ហើយខ្លះនិយាយថា យើងនឹងស្តាប់
អ្នកពីដំណើរនេះម្តងទៀត ៣៣ដូច្នេះប៉ុលក៏ចេញពីចំណោម

**១៧:២៣** វ យហ ៤:២២
**១៧:២៤** ស អស ៤២:៥ កច ១៤:១៥ ហ ចទ ១០:១៤ អស ៦៦:១,២ មថ ១១:២៥ ឡ ១ពវ ៨:២៧ កច ៧:៤៨
**១៧:២៥** អ ទដ ៥០:១០-១២ អស ៤២:៥
**១៧:២៦** ក ចទ ៣២:៨ យប ១២:២៣
**១៧:២៧** ខ ចទ ៤:៧ អស ៥៥:៦ យរ ២៣:២៣,២៤
**១៧:២៨** គ ចទ ៣០:២០ យប ១២:១០ ដយ ៥:២៣
**១៧:២៩** ឃ អស ៤០:១៨-២០ រម ១:២៣ **១៧:៣០** ង កច ១៤:១៦ រម ៣:២៥ ច ខ.២៣ ១ពត ១:១៤ ឆ លក ២៤:៤៧ ទត ២:១១,១២ **១៧:៣១** ជ មថ ១០:១៥ ឈ កច ១០:៤២ ញ ទដ ៩:៨ ៩៦:១៣ ៩៨:៩ ដ កច ២:២៤ **១៧:៣២** ឋ ខ.១៨,៣១

ជាមានព្រះដទៃទៀត ដែលធំជាងព្រះរបស់ពួកគេ ។

**១៧:២៤** *ព្រះដែលបង្កើតលោកីយ* គឺជាព្រះអាទិករដែលបានបង្កើតរបស់សព្វសារពើ ។ លោកប៉ុលប្រើពាក្យថា "ព្រះដែលបង្កើតលោកិយ" គឺចង់ប្រាប់ពួកគេថា ទ្រង់មិនត្រូវការយញ្ញបូជា ឬដង្វាយអ្វីពីមនុស្សនៅលើផែនដីនេះទេ ។ *ទ្រង់មិនគង់នៅក្នុងវិហារដែលដៃមនុស្សបានធ្វើទេ* ឃ្លានេះចង់បញ្ជាក់ប្រាប់ថា ព្រះអម្ចាស់ទ្រង់ជាវិញ្ញាណ ហើយមិនគង់នៅក្នុងវិហារដែលដៃមនុស្សធ្វើនោះទេ ដូច្នេះអស់អ្នកដែលចង់ថ្វាយបង្គំទ្រង់ នោះត្រូវថ្វាយបង្គំដោយវិញ្ញាណ និងសេចក្ដីពិតវិញ ។

**១៧:២៥** ខនេះបញ្ជាក់ថា គ្រប់ទាំងជីវិតនៅលើផែនដីនេះ គឺព្រះអម្ចាស់ទ្រង់ប្រទានឱ្យ ហើយមិនអាចរស់បានដោយគ្មានទ្រង់នោះទេ ។

**១៧:២៦** *ទ្រង់បានបង្កើតមនុស្សគ្រប់សាសន៍ពីឈាមតែ១* (ព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសខ្លះសរសេរថា "ទ្រង់បានបង្កើតមនុស្សគ្រប់សាសន៍ ពីមនុស្សតែមួយ") មានន័យថា មនុស្សគ្រប់ជាតិសាសន៍គឺជាបងប្អូននឹងគ្នា និងជាគ្រួសារតែមួយ ។ *ព្រមទាំងសំរេចកំណត់ពេលវេលា* ឃ្លានេះបញ្ជាក់ថា ព្រះអម្ចាស់មានគម្រោងការដ៏ជាក់លាក់ និងច្បាស់លាស់បំផុតសម្រាប់គ្រប់សារពើដែលទ្រង់បានបង្កើតមក ។ *ព្រំទីលំនៅរបស់គេគ្រប់គ្នា* ព្រះអម្ចាស់ជាអាទិករ និងជ្រាបគ្រប់ទាំងអស់ ហើយទ្រង់បានតាំងទីលំនៅសម្រាប់គ្រប់ជីវិតដែលទ្រង់បានបង្កើត ។

**១៧:២៧** លោកប៉ុលចង់ប្រាប់អស់អ្នករស់នៅទីក្រុងអាថែនថា ព្រះអម្ចាស់គង់នៅជិតបង្កើយ ហើយបានបើកផ្លូវសម្រាប់មនុស្សគ្រប់គ្នា ឱ្យចូលមកទទួលការសង្គ្រោះអំពីទ្រង់ ។

**១៧:២៨** *ពួកអ្នកលើកកំណាព្យខ្លះរបស់អ្នករាល់គ្នា* ពួកអ្នកលើកកំណាព្យទាំងនោះមាន (១).លោកអេពីមីណៃ ជាសាសន៍ក្រេក បានសរសេរឃ្លាថា "ដ្បិតគឺដោយសារទ្រង់ហើយ ដែលយើងរាល់គ្នាបានរស់ កម្រើក ហើយមាននៅផង (Epimenides ឆ្នាំ៦០០ មុនគ.ស) (២).លោកអារ៉ាទូស ជាអ្នកស្រុកគីលីគាបានសរសេរឃ្លាថា "មនុស្សយើងជាពូជព្រះដែរ" (Aratus ប្រហែលឆ្នាំ ៣១៥-២៤០ មុនគ.ស) (១កថ ១៥:៣៣ មើលការពន្យល់ ទត ១:២)។

**១៧:២៩** បទគម្ពីរនេះចង់ប្រាប់ថា រូបព្រះដែលពួកគេធ្វើពីមាស ប្រាក់ ថ្ម ឈើ ឬពីអ្វីផ្សេងពីនេះក៏ដោយ គឺសុទ្ធតែជារបស់ដែលកើតឡើងដោយសារដៃមនុស្ស និងមិនមែនជាព្រះដ៏ពិតនោះទេ ។ ព្រះអម្ចាស់ទ្រង់មានព្រះជន្មរស់អស់កល្បជានិច្ច ពុំមែនជាវត្ថុ ឬរបស់ដែលគ្មានវិញ្ញាណដូចដែលមនុស្សបានបង្កើតឡើងនោះទេ ។

**១៧:៣០** *ទតរំលងគ្រាខ្លៅល្ងង់* ឃ្លានេះចង់បញ្ជាក់ប្រាប់ថា ព្រះអម្ចាស់ទ្រង់ពុំបានដាក់ទោសចំពោះកំហុសឆ្គង ដែលពួកគេបានថ្វាយបង្គំរូបព្រះ ព្រោះតែសេចក្ដីល្ងង់ខ្លៅនោះទេ ។ ប៉ុន្ដែ នៅពេលពួកគេបានស្គាល់ព្រះដ៏ពិតហើយ នោះមិនត្រូវបន្តប្រព្រឹត្តទង្វើទាំងឡាយ ដែលទ្រង់មិនសព្វព្រះហឫទ័យទៀតទេ (ខ.៣១។

**១៧:៣១** *ដោយសារមនុស្សម្នាក់* ពាក្យថា "មនុស្សម្នាក់" គឺសំដៅលើព្រះយេស៊ូវហើយពេលខ្លះនៅក្នុងព្រះគម្ពីរបរិសុទ្ធប្រើពាក្យថា "កូនមនុស្ស" (ដយ ៧:១៣ មថ ២៥:៣១-៤៦ កច ១០:៤២)។

**១៧:៣២-៣៤** ត្រង់ចំណុចនេះ មានការឆ្លើយតបបីយ៉ាងទៅនឹងសេចក្ដីអធិប្បាយរបស់លោកប៉ុល (១). មនុស្សមួយចំនួនបដិសេធមិនព្រមទទួលតែម្ដង (២).អ្នកខ្លះចង់ស្ដាប់ម្ដងទៀត (៣).ខ្លះទៀតព្រមទទួលយក ហើយបានជឿ ។

**១៧:៣២** *មនុស្សស្លាប់រស់ឡើងវិញ* នៅពេលនោះ ពួកសាសន៍ក្រេកជឿថា ព្រលឹងរបស់មនុស្សមិនត្រូវស្លាប់ទេ ប៉ុន្តែពួកគេពុំជឿថា រូបកាយដែលស្លាប់ហើយអាចរស់ឡើងវិញបានទេ ។

**១៧:៣៣** ពាក្យថា "*ចំណោមគេ*" នៅក្នុងខនេះ គឺសំដៅទៅលើពួកក្រុមជំនុំ

គេទៅ ៣៤តែមានមនុស្សខ្លះ ត្រូវចិត្តជាប់នឹងគាត់ ព្រមទាំង
ជឿផង ក្នុងពួកនោះមានឈ្មោះឌេវនីស ជាចៅក្រមនៅភ្នំ
អើរីយ៉ូស[ឃ]នឹងស្ត្រីម្នាក់ឈ្មោះដាម៉ារីស ហើយនិងអ្នកខ្លះ
ទៀតដែរ ។

## នៅឯទីក្រុងកូរិនថូស

**១៨** ១ក្រោយនោះមក ប៉ុលចេញពីក្រុងអាថែន[ឈ] ទៅឯ
កូរិនថូស[ណ] ២នៅទីនោះ គាត់ជួបនឹងសាសន៍យូដាម្នាក់ឈ្មោះ
អ័គីឡា ដែលកើតនៅស្រុកប៉ុនតុស ជាអ្នកទើបនឹងមកពី
ស្រុកអ៊ីតាលី ព្រមទាំងព្រីស៊ីល[ត]ជាប្រពន្ធគាត់ផង ពីព្រោះ
មហារាជក្លូឌាស[ថ] ទ្រង់បានបង្គាប់ ឱ្យសាសន៍យូដាចេញ
ពីក្រុងរ៉ូមទាំងអស់ទៅ គាត់ក៏ទៅឯអ្នកទាំង២នោះ ៣រួច
គាត់ស្នាក់នៅ ហើយធ្វើការជាមួយនឹងគេ ពីព្រោះមានរបរ
រកស៊ីធ្វើជាងត្រសាលដូចគ្នា[ទ] ៤គាត់ក៏អធិប្បាយនៅក្នុង
សាលាប្រជុំ[ធ]រាល់តែថ្ងៃឈប់សំរាក[ន] ព្រមទាំងបញ្ចុះបញ្ចូល
ពួកសាសន៍យូដា នឹងសាសន៍ក្រេកឱ្យជឿផង ៥កាលស៊ីឡាស[ប]
និងធីម៉ូថេ[ផ] បានចុះពីស្រុកម៉ាសេដូន[ព]មកដល់ហើយ នោះ
ប៉ុលមានសេចក្តីបង្ខំក្នុងចិត្ត ឱ្យផ្សាយព្រះបន្ទូល ក៏ធ្វើបន្ទាល់
អស់ពីចិត្ត ដល់សាសន៍យូដាថា ព្រះយេស៊ូវ ជាព្រះគ្រីស្ទ
ពិត[ភ] ៦តែដោយព្រោះគេតាំងខ្លួន ទាស់ទទឹង ហើយក៏ជេរ
ប្រមាថផង[ម] បានជាប៉ុលរលាស់អាវខ្លួន[យ]និយាយថា ចូរ
ឱ្យឈាមអ្នករាល់គ្នា ធ្លាក់លើក្បាលអ្នករាល់គ្នាវិញចុះ[រ] ឯ
ខ្ញុំៗបរិសុទ្ធទេ[ល] អំណើះទៅមុខ ខ្ញុំនឹងទៅឯសាសន៍ដទៃ
ហើយ[វ] ។
៧គាត់ក៏ចេញពីទីនោះ ចូលទៅក្នុងផ្ទះម្នាក់ឈ្មោះយូស្ទុស
ជាអ្នកថ្វាយបង្គំព្រះ ដែលមានផ្ទះនៅជាប់នឹងសាលាប្រជុំ[ស]
៨ឯគ្រីសប៉ុស[ហ]ជាមេសាលាប្រជុំ[ឡ] គាត់ជឿដល់ព្រះអម្ចាស់
ព្រមទាំងពួកគ្រួ[អ]គាត់ទាំងអស់ដែរ ក៏មានពួកក្រុងកូរិនថូស
បានស្តាប់ ហើយជឿជាច្រើន ទាំងទទួលបុណ្យជ្រមុជទឹក ផង
៩វេលាយប់នោះ ព្រះអម្ចាស់ទ្រង់មានបន្ទូលទៅប៉ុល ក្នុង
ការជាក់ស្តែង[ក]ថា កុំខ្លាចអ្វី[ខ] ចូរសំដែងទៅ កុំនៅស្ងៀម

**១៧:៣៤** ឃ ខ.១៩,២២ **១៨:១** ឈ កច ១៧:១៥ ណ កច ១៩:១ ១កថ ១:២ ២កថ ១:១,២៣ ២ធថ ៤:២០ **១៨:២** ត ខ.១៩,២៦ រម ១៦:៣ ១កថ ១៦:១៩ ២ធថ ៤:១៩ ថ កច ១១:២៨ **១៨:៣** ទ កច ២០:៣៤ ១កថ ៤:១២ ១ថន ២:៩ ២ថន ៣:៨ **១៨:៤** ធ កច ៩:២០ ន កច ១៣:១៤ **១៨:៥** ប កច ១៥:២២ ផ កច ១៦:១ ព កច ១៦:៩ ១៧:១៤,១៥ ភ កច ៩:២២ **១៨:៦** ម កច ១៣:៤៥ យ មថ ១០:១៤ រ ២សយ ១:១៦ អគ ៣៣:៤ ល អគ ៣:១៧–១៩ កច ២០:២៦ វ កច ១៣:៤៦ **១៨:៧** ស កច ១៦:១៤ **១៨:៨** ហ ១កថ ១:១៤ ឡ មក ៥:២២ អ កច ១១:១៤ **១៨:៩** ក កច ៩:១០ ខ មថ ១៤:២៧

នៅឯអើរីយ៉ូសនៃទីក្រុងអាថែន ។
**១៧:៣៤** *ដាម៉ារីស* អ្នកខ្លះយល់ថាគាត់ជាស្ត្រីម្នាក់ដែលបានទទួលការអប់រំនៅប្រទេសក្រៅ ដូច្នេះ ទើបអាចចូលរួមប្រជុំជាមួយពួកក្រុមជំនុំនៅឯអើរីយ៉ូសនោះបាន ។ អ្នកខ្លះទៀតយល់ថា គាត់ជាសាសន៍ដទៃ ដែលបានទទួលជឿដល់ព្រះអម្ចាស់តាមរយៈការបង្រៀនរបស់លោកប៉ុលនៅឯសាលាប្រជុំណាមួយ (ខ.១៧) ។
**១៨:១** *ទៅឯកូរិនថូស* ទីក្រុងកូរិនថូសស្ថិតនៅភាគខាងកើតទីក្រុងអាថែន ចម្ងាយប្រហែល ៨០ គ.ម ។ ដំណើររបស់លោកប៉ុលពីទីក្រុងអាថែន ទៅឯទីក្រុងកូរិនថូសលើកនេះ ពុំបានបញ្ជាក់ច្បាស់ថាគាត់ទៅតាមផ្លូវគោក ឬតាមផ្លូវសមុទ្រនោះទេ ។
**១៨:២** *ស្រុកប៉ុនតុស* គឺជាខេត្តមួយនៅក្រោមការត្រួតត្រារបស់ចក្រភពរ៉ូម៉ាំង (ក្នុងសម័យកាលលោកប៉ុល) និងមានព្រំប្រទល់ជាប់ជាមួយនឹងខេត្តកាឡាទី ។ *អ័គីឡា...ព្រីស៊ីល* ត្រង់ចំណុចនេះមិនបានប្រាប់ថា អ្នកទាំងពីរគឺជាអ្នកជឿដល់ព្រះអម្ចាស់តាំងពីមុនពេលជួបនឹងលោកប៉ុលនោះទេ ។ ប៉ុន្តែដោយព្រោះពួកគាត់ទាំងពីរបានធ្វើការងាររួមគ្នា ជាមួយនឹងលោកប៉ុល (ខ.៣) នោះហាក់ដូចជាពួកគាត់ជាអ្នកជឿរួចទៅហើយ ។ អ្នកខ្លះយល់ថាពួកគាត់ប្រហែលជាបានប្រែចិត្តជឿនៅឯទីក្រុងរ៉ូម (ខ.១៨-១៩ ១កថ ១៦:៩ រម ១៦:៣,៤) ។ *មហារាជក្លូឌាស* ជាស្តេចអធិរាជទី៤របស់ចក្រភពរ៉ូម៉ាំងសោយរាជ្យចាប់ពីឆ្នាំ៤១គ.ស រហូតដល់ឆ្នាំ៥៤គ.ស ។ ដំបូងឡើយ ស្តេចអង្គនេះមិនបានប្រកាន់ទោសចំពោះពួកសាសន៍យូដាទេ ជាពិសេសពួកអ្នកដែលរស់នៅអាស៊ី និងអេស៊ីព្ទ ប៉ុន្តែ នៅឆ្នាំ៤៩គ.ស បែរជានិរទេសពួកគេទាំងអស់ឱ្យចេញពីទីក្រុងរ៉ូម (កច៨:២) ។ ក្រោយមក ពួកយូដាបានត្រឡប់ទៅរស់នៅឯទីក្រុងរ៉ូមវិញដដែល ។
**១៨:៣** *ជាងត្រសាល* (ភាសាអង់គ្លេសប្រើពាក្យថា អ្នកធ្វើតង់ ឬអ្នកធ្វើដំបូលតង់អំពីស្បែកសត្វ ឬក្រណាត់រោមពពែ) លោកប៉ុលប្រហែលជាចេះប្រកបមុខរបរនេះតាំងពីនៅវ័យក្មេងម្ល៉េះ ព្រោះថាពួកសាសន៍យូដា ទាំងអ្នកមាន និងអ្នកក្រ តែងតែមានទម្លាប់បន្តចំណេះដឹងទៅឱ្យកូនចៅរបស់ខ្លួនជានិច្ច ។
**១៨:៤** *សាលាប្រជុំ* "មើលការពន្យល់ ១៣:១៤"។
**១៨:៥** *ស៊ីឡាស និងធីម៉ូថេ បានចុះពីស្រុកម៉ាសេដូន* ដំណើររបស់លោកស៊ីឡាស និងធីម៉ូថេមកទីក្រុងអាថែន គឺធ្វើតាមសំណូមពររបស់លោកប៉ុល (១៧:១៥ ១ថន ៣:១-២) ។ បន្ទាប់ពីពួកគាត់បានជួបនឹងលោកប៉ុលរួចហើយនោះមិនយូរប៉ុន្មានក៏ត្រឡប់ទៅឯខេត្តម៉ាសេដូនវិញ ប្រហែលជាលោកស៊ីឡាសទៅឯទីក្រុងភីលីព ហើយលោកធីម៉ូថេទៅទីក្រុងថែស្សាឡូនីច ។
**១៨:៦** ពួកយូដានាំគ្នាប្រឆាំង និងជេរប្រមាថលោកប៉ុល ព្រោះតែគាត់ប្រកាសដំណឹងល្អអំពីការសង្គ្រោះដល់ពួកគេ ។ ទង្វើរបស់ពួកគេនោះពុំមានលទ្ធផលល្អសម្រាប់ខ្លួនទេ ព្រោះជាការប្រមាថដល់ព្រះអម្ចាស់ ដូចដែលទ្រង់មានបន្ទូលថា "អស់អ្នកណាដែលប្រមាថដល់អ្នកបម្រើស្មោះត្រង់របស់ទ្រង់ គឺមានន័យថា បានប្រមាថដល់ទ្រង់ហើយ"។
**១៨:៧** *យូស្ទុស* គាត់គឺជាសាសន៍ដទៃម្នាក់ រស់នៅក្បែរសាលាប្រជុំនៃទីក្រុងកូរិនថូស (២កថ ២:៣ ៧:១៣–១៤ ៨:១៦,២៣) ។ *ជាអ្នកថ្វាយបង្គំព្រះ* លោកយូស្ទុស (ក៏ដូចជាលោកទីតុសដែរ កទ ២:៣) គឺជាសាសន៍ដទៃដែលមិនកាត់ស្បែក និងធ្លាប់បានចូលរួមនៅក្នុងសាលាប្រជុំរបស់សាសន៍យូដា ហើយក្រោយមកបានទទួលជឿដល់ព្រះអម្ចាស់ ។
**១៨:៨** *គ្រីសប៉ុស* គាត់គឺជាមេសាលាប្រជុំនៅក្រុងកូរិនថូស ។ លោកគ្រីប៉ុស និងក្រុមគ្រួសារបានជឿដល់ព្រះយេស៊ូវគ្រីស្ទ ហើយលោកប៉ុលជាអ្នកធ្វើបុណ្យជ្រមុជទឹកឱ្យ (កច ១៣:១៥ ១កថ ១:១៤) ។
**១៨:៩** *ការជាក់ស្តែង* ត្រង់ចំណុចនេះប្រហែលជាលោកប៉ុលមានការចុះ

ឡើយ ១០ដ្បិតខ្ញុំនៅជាមួយនឹងអ្នកហើយ[គ] គ្មានអ្នកណានឹង
ប្រទូស្តដល់អ្នកបានទេ ខ្ញុំក៏មានមនុស្សជាច្រើន នៅក្នុង
ទីក្រុងនេះដែរ ១១គាត់ក៏នៅទីនោះអស់១ឆ្នាំ៦ខែ ព្រមទាំង
បង្រៀនព្រះបន្ទូលនៅក្នុងពួកគេ[ឃ]។
១២កាលលោកកាលីយ៉ូ ធ្វើជាអ្នកដំណាង[ង]សាសន៍រ៉ូម នៅ
ស្រុកអាខៃ[ច] នោះពួកសាសន៍យូដាលើកគ្នា ព្រួតទាស់
នឹងប៉ុល គេចាប់នាំគាត់ទៅឯទីជំនុំក្តី ចោទថា ១៣អ្នកនេះ
ជាអ្នក បញ្ចុះបញ្ចូលមនុស្ស ឱ្យថ្វាយបង្គំព្រះខុសច្បាប់
១៤តែកាលប៉ុលរៀបនឹងបើកមាត់ដោះសាខ្លួន នោះ លោក
កាលីយ៉ូនិយាយទៅពួកសាសន៍យូដាថា នែពួកសាសន៍
យូដាអើយ បើសិនណាជាមានការទុច្ចរិតណា ឬទោស
កំណាចអ្វីដទៃ នោះតាមទំនង ខ្ញុំត្រូវតែទទួលស្តាប់
អ្នករាល់គ្នា ១៥ប៉ុន្តែ បើសិនជាកើតក្តី ពីដំណើរពាក្យសំដី ឬ
ពីនាមឈ្មោះ ឬក្រិត្យវិន័យរបស់អ្នករាល់គ្នាវិញ[ឆ] នោះ
ស្រេចនឹងអ្នករាល់គ្នាចុះ ខ្ញុំមិនចូលចិត្តនឹងជំនុំជំរះចំពោះ
ការយ៉ាងនោះទេ ១៦លោកក៏បណ្តេញគេចេញពីសាលា
ជំនុំជំរះទៅ ១៧នោះគេក៏ចាប់សូស្ថេន[ជ] ជាមេសាលាប្រជុំ[ឈ]
មកវាយផ្ចាលនៅមុខសាលាជំនុំ តែលោកកាលីយ៉ូ មិនរវល់
សោះ ។

### លោកអ័ប៉ុឡូស លោកអ័គីឡា និងនាងព្រីស៊ីល

១៨ឯប៉ុល គាត់នៅទីនោះជាយូរថ្ងៃទៀត រួចក្រោយដែល
គាត់បានកោរសក់នៅក្រុងកេងក្រា[ញ]ហើយ គឺដោយព្រោះ
គាត់បានបន់បំណន់ នោះក៏លាពួកជំនុំ[ដ] ចុះសំពៅទៅឯស្រុក
ស៊ីរីវិញ[ឋ] មានទាំងព្រីស៊ីល នឹងអ័គីឡា[ឌ] ទៅជាមួយផង[ឍ]
១៩កាលទៅដល់ក្រុងអេភេសូរ[ណ]ហើយ នោះប៉ុលទុកគេ
នៅទីនោះ តែគាត់ចូលទៅក្នុងសាលាប្រជុំ របស់សាសន៍
យូដា ហើយក៏ជជែកពន្យល់ដល់គេ ២០រួចគេសូមឱ្យគាត់នៅ
ជាមួយនឹងគេជាយូរបន្តិចទៀត តែគាត់មិនព្រមទេ ២១គាត់
លាគេទៅដោយពាក្យថា ខ្ញុំត្រូវតែទៅធ្វើបុណ្យក្រោយ
នេះ នៅក្រុងយេរូសាឡិមជាមិនខាន តែបើព្រះទ្រង់សព្វ

**១៨:១០** គ មថ ២៨:២០
**១៨:១១** ឃ ហព ៤:១២
**១៨:១២** ង កច ១៣:៧,៨,១២ ១៩:៣៨ ច ខ.២៧ រម ១៥:២៦ ១កថ ១៦:១៥ ២កថ ៩:២ ១ថន ១:៧,៨
**១៨:១៥** ឆ កច ២៣:២៩ ៥:១១,១៩
**១៨:១៧** ជ ១កថ ១:១ ឈ ខ.៨
**១៨:១៨** ញ រម ១៦:១ ដ ខ.២៧ កច ១:១៦ ឋ លក ២:២ ឌ ខ.២ ឍ ជន ៦:២,៥,១៨ កច ២១:២៤
**១៨:១៩** ណ ខ.២១,២៤ កច ១៩:១,១៧, ២៦ ១កថ ១៥:៣២ ១៦:៨ អភ ១:១ ១ធថ ១:៣ វវ ១:១១ ២:១

ខ្សោយ បានជាព្រះអម្ចាស់បានលេចមកឱ្យគាត់ឃើញ នៅក្នុងការជាក់ស្តែង ដើម្បីជាកម្លាំងដល់គាត់ (៩:៤-៦ ២២:១៧-១៨ ២៣:១១ ១កថ ១៥:៨)។

**១៨:១០** *ខ្ញុំក៏មានមនុស្សជាច្រើននៅក្នុងទីក្រុងនេះដែរ* នេះមានន័យថាមានមនុស្សជាច្រើន ដែលមិនបានប្រឆាំងនឹងព្រះវិញ្ញាណរបស់ព្រះអម្ចាស់ ពួកគេកំពុងតែរង់ចាំទទួលដំណឹងល្អអំពីការសង្គ្រោះរបស់ទ្រង់ ។ ចំណុចដ៏សំខាន់មួយទៀតគឺ ទីក្រុងកូរិនថូសជាមជ្ឈមណ្ឌលសេដ្ឋកិច្ច នយោបាយ និងសាសនា ដូច្នេះពួកជំនុំដែលចាប់ផ្តើមនៅក្នុងទីក្រុងនេះត្រូវតែរឹងមាំ (មើលការពន្យល់ ខ.១)។

**១៨:១១** *១ឆ្នាំ៦ខែ* ក្នុងអំឡុងពេលនោះ ប្រហែលជាលោកប៉ុលបាននាំដំណឹងល្អ ទៅប្រកាសប្រាប់ ដល់អស់អ្នកដែលរស់នៅជុំវិញស្រុកអាខៃដែរ (២កថ ១:១)។

**១៨:១២** *លោកកាលីយ៉ូ* គឺជាអ្នកតំណាងរបស់ចក្រភពរ៉ូម៉ាំងនៅស្រុកអាខៃ ឆ្នាំ៥១-៥២គ.ស ។ បងប្រុសរបស់គាត់ឈ្មោះ សេនេកា (Seneca) ជាទស្សនវិទូម្នាក់ និងជាគ្រូរបស់ស្តេចអធិរាជចក្រភពរ៉ូម៉ាំងឈ្មោះ "នេរ៉ូ" (Nero កើតនៅថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ៣៧ គ.ស ឡើងសោយរាជ្យនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ៥៤គ.ស និងសុគត នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ៦៨គ.ស)។

នៅឆ្នាំ ៦២ គ.ស ស្តេចអធិរាជនេរ៉ូបានរៀបអភិសេកជាមួយស្ត្រីម្នាក់ជាអ្នកកាន់សាសនាយូដា ប៉ុន្តែពុំមានសញ្ជាតិយូដាពីកំណើតទេ ។ ពីពេលនោះមកស្តេចអង្គនេះក៏ចាប់ផ្តើមធ្វើការ បៀតបៀនដល់គ្រីស្ទបរិស័ទ ។ នៅឆ្នាំ៦៤ គ.ស មានភ្លើងឆេះដ៏ខ្លាំងនៅក្នុងទីក្រុងរ៉ូម ដែលធ្វើឱ្យមានការខូចខាតជាច្រើន ហើយស្តេចនេរ៉ូបានចោទថា អ្នកដែលធ្វើឱ្យមានភ្លើងឆេះនោះគឺជាគ្រីស្ទបរិស័ទ ដូច្នោះក៏បៀតបៀនពួកគេកាន់តែខ្លាំងឡើងៗ ។ លោកប៉ុល លោកពេត្រុស និងអ្នកដឹកនាំគ្រីស្ទបរិស័ទជាច្រើនទៀតត្រូវបានស្តេចនេរ៉ូនេះសម្លាប់ ។

**១៨:១៣** *ថ្វាយបង្គំព្រះខុសច្បាប់* ឃ្លានេះចង់បញ្ជាក់ថា នៅក្នុងសម័យនោះមានតែសាសនាយូដាទេ ដែលពួករ៉ូម៉ាំងចាត់ទុកថាស្របច្បាប់ និងអនុញ្ញាតឱ្យមាន សាលាប្រជុំសម្រាប់តែពួកអ្នកកាន់សាសនានេះប៉ុណ្ណោះ ។

**១៨:១៤-១៦** ខណៈពេលដែលលោកកាលីយ៉ូបានឮពួកសាសន៍យូដាចោទប្រឆាំងនឹងលោកប៉ុល នោះគាត់ក៏សន្និដ្ឋានបានភ្លាមថា ទាំងនោះគឺជាទំនាស់រវាងសាសនារបស់ពួកគេទេ ដូច្នោះហើយបានជាគាត់ពុំមានសួរនាំរកខុសត្រូវអ្វីទាំងអស់។ ម្យ៉ាងវិញទៀត លោកប៉ុលពុំបានប្រព្រឹត្តការអ្វីខុសនឹងច្បាប់របស់ពួករ៉ូម៉ាំងទេ ។

**១៨:១៧** *សូស្ថេន* គាត់ជាមេសាលាប្រជុំនៅទីក្រុងកូរិនថូស ក្នុងសម័យកាលដែលលោកកាលីយ៉ូធ្វើជាអ្នកតំណាងរ៉ូម៉ាំងនៅស្រុកអាខៃ ។ មានអ្នកខ្លះយល់ថា លោកសូស្ថេនគឺជាគូកនរបស់លោកប៉ុលម្នាក់ដែរ (១កថ ១:១)។

**១៨:១៨** *ព្រីស៊ីល និងអ័គីឡា* អ្នកទាំងពីរនេះគឺជាប្តីប្រពន្ធនឹងគ្នា ។ នៅក្នុងខនេះ លោកលូកាសរសេរឈ្មោះនាងព្រីស៊ីល ដាក់នៅមុខឈ្មោះរបស់ប្តីនាង នោះប្រហែលជានាងមានឋានៈខ្ពស់នៅក្នុងសង្គម (រម ១៦:៣ ២ធថ ៤:១៩)។ *ដោយព្រោះគាត់បានបន់បំណន់* លោកប៉ុលប្រហែលជាបានបន់បំណន់ ដើម្បីសូមសេចក្តីសុខសាន្តពីព្រះអម្ចាស់ ក្នុងពេលដែលគាត់ស្នាក់នៅទីក្រុងកូរិនថូសនោះ ។ បន្ទាប់ពីបានបន់បំណន់រួចហើយ នោះអ្នកដែលជាប់បំណន់ មិនត្រូវអនុញ្ញាតឱ្យកាត់សក់ ឬកោរសក់ទេ ដរាបណាដល់ផុតកំណត់នៃបំណន់នោះ ។ ហើយនៅថ្ងៃចុងក្រោយបង្អស់ នៃរយៈពេលដែលខ្លួនបានបន់បំណន់នោះត្រូវតែកោរសក់របស់ខ្លួនថ្វាយទៅព្រះ (ជន ៦:១-២១)។

**១៨:១៩** *ក្រុងអេភេសូរ* ជាទីក្រុងពាណិជ្ជកម្មដ៏សំខាន់មួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ចក្រភពរ៉ូម៉ាំង ។

**១៨:២០-២១** ក្នុងដំណើរបេសកកម្មលើកនេះ លោកប៉ុលមានពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ សម្រាប់បង្រៀនដល់ពួកអ្នកជឿ នៅក្នុងទីក្រុងកូរិនថូស ។ ប៉ុន្តែ លោកអ័គីឡា និងនាងព្រីស៊ីលបានបន្តរស់នៅក្នុងទីក្រុងនេះទៀត ដោយយកផ្ទះរបស់ពួកគាត់ធ្វើជាកន្លែងសម្រាប់ប្រកបគ្នានៃអ្នកជឿដល់ព្រះអម្ចាស់

ព្រះហឫទ័យ នោះខ្ញុំនឹងត្រឡប់មកឯអ្នករាល់គ្នាវិញ[ត] រួច
គាត់ចុះសំពៅ ចេញពីអេភេសូរទៅ ២២លុះចូលចតនៅ
ក្រុងសេសារា[ថ]ហើយ ក៏ឡើងទៅជិរាបសួរ ដល់ពួកជំនុំ
រួចចុះទៅឯអាន់ទីយ៉ូកវិញ[ទ] ។
២៣គាត់នៅទីនោះជាយូរក្រែល រួចចេញទៅ ដើរកាត់
ស្រុកកាឡាទី[ធ] និងស្រុកព្រីគា[ន]ដោយលំដាប់ ព្រមទាំងតាំង
ឱ្យពួកសិស្សទាំងអស់បានខ្ជាប់ខ្ជួនឡើង[ប] ២៤នៅក្នុងគ្រានោះ
មានសាសន៍យូដាម្នាក់ ឈ្មោះអ័ប៉ុឡូស[ផ] ដែលកើតនៅក្រុង
អ័លេក្សានទ្រា ជាអ្នកមានវោហារ ហើយក៏ចេះស្ទាត់ក្នុង
គម្ពីរដែរ គាត់មកដល់ក្រុងអេភេសូរ[ព] ២៥គាត់បានសិក្សា
ខាងឯផ្លូវព្រះអម្ចាស់ ហើយដោយព្រោះ គាត់មានចិត្ត
ឧស្សាហ៍ បានជាគាត់អធិប្បាយ[ភ] ហើយបង្រៀនយ៉ាងត្រឹម
ត្រូវពីអស់ទាំងសេចក្ដីខាងឯព្រះអម្ចាស់ ទោះបើស្គាល់តែ
បុណ្យជ្រមុជរបស់លោកយ៉ូហានក៏ដោយ[ម] ២៦ហើយគាត់
ចាប់តាំងអធិប្បាយ ក្នុងសាលាប្រជុំដោយក្លាហាន កាល
អ័គីឡា[យ] និងព្រីស៊ីលបានឮ នោះក៏នាំទៅពន្យល់ពីផ្លូវព្រះ
ឱ្យរឹតតែច្បាស់ទៅទៀត ។

២៧រួចគាត់គិតនឹងទៅឯស្រុកអាខៃ[រ] នោះពួកជំនុំ[ល]ក៏ធ្វើ
សំបុត្រផ្ញើទៅទូន្មានពួកសិស្ស ឱ្យទទួលគាត់ លុះដល់ហើយ
គាត់ក៏ជួយយ៉ាងសន្ធឹក ដល់ពួកអ្នកដែលជឿដោយព្រះគុណ
២៨ព្រោះ គាត់ជជែកផ្ចាញ់ពួកសាសន៍យូដា នៅកណ្ដាលជំនុំ
ដោយប៉ិនប្រសប់ ទាំងបង្ហាញតាមគម្ពីរថា ព្រះយេស៊ូវជា
ព្រះគ្រីស្ទមែន[ស] ។

## លោកប៉ុលនៅឯទីក្រុងអេភេសូរ

**១៩** ១កំពុងដែលអ័ប៉ុឡូស[ហ]នៅក្រុងកូរិនថូស[ឡ] នោះប៉ុល
បានដើរកាត់អស់ទាំងស្រុកខាងលើ រហូតដល់ក្រុងអេ
ភេសូរ[អ] កាលគាត់រកឃើញសិស្សខ្លះ នោះក៏សួរថា ២ចាប់
តាំងពីអ្នករាល់គ្នាជឿមក តើបានទទួលព្រះវិញ្ញាណបរិសុទ្ធ[ក]
ហើយឬនៅ គេឆ្លើយថា យើងខ្ញុំមិនបានទាំងឮនិយាយពី
ព្រះវិញ្ញាណបរិសុទ្ធផង ៣គាត់សួរគេទៀតថា ដូច្នេះ
តើអ្នករាល់គ្នាបានទទួល បុណ្យជ្រមុជទឹកដោយនូវអ្វី
គេឆ្លើយថា គឺដោយនូវបុណ្យ ជ្រមុជរបស់លោកយ៉ូហានទេ

**១៨:២១** ត រម ១:១០ ១៥:៣២ ១កថ ៤:១៩ យក ៤:១៥
**១៨:២២** ថ កច ៨:៤០ ទ កច ១១:១៩
**១៨:២៣** ធ កច ១៦:៦ ន កច ២:១០ ១៦:៦ ប កច ១៤:២២ ១៥:៣២,៤១
**១៨:២៤** ផ កច ១៩:១ ១កថ ១:១២ ៣:៥,៦,២២ ៤:៦ ១៦:១២ ទត ៣:១៣ ព ឧ.១៩
**១៨:២៥** ភ រម ១២:១១
**១៨:២៥** ម មក ១:៤
**១៨:២៦** យ ឧ.២
**១៨:២៧** រ ឧ.១២ ល ឧ.១៨ កថ ១:១៦
**១៨:២៨** វ កច ៨:៣៥ ១៧:២
ស ឧ.៥ កច ៩:២២ **១៩:១** ហ កច ១៨:២៤ ឡ កច ១៨:១ អ កច ១៨:១៩
**១៩:២** ក យហ ២០:២២

(១កថ ១៦:១៩) ។ ហើយនៅពេលដែលមហារាជក្លូឌាស បានសុគតនៅឆ្នាំ ៥៤គ.ស នោះលោកអ័គីឡា និងនាងព្រីស៊ីល ក៏ត្រឡប់ទៅរស់នៅឯទីក្រុងរ៉ូមវិញ (រម ១៦:៣) ។

**១៨:២២** *ក៏ឡើងទៅជិរាបសួរដល់ពួកជំនុំ* ត្រង់ចំណុចនេះអ្នកខ្លះគិតថា លោកប៉ុលបានឡើងទៅជិរាបសួរ ដល់ពួកជំនុំនៅឯទីក្រុងសេសារា ប៉ុន្តែខ្លះទៀតយល់ថា គាត់ទៅជិរាបសួរពួកជំនុំនៅឯទីក្រុងយេរូសាឡិមវិញ ។

**១៨:២៣** *រួចចេញទៅ ដើរកាត់ស្រុកកាឡាទី និងស្រុកព្រីគា* គឺដើរកាត់តាមតំបន់នៅភាគខាងត្បូងស្រុកកាឡាទី ដែលមានព្រំប្រទល់ជាប់ជាមួយស្រុកព្រីគា (មើលការពន្យល់ ១៦:៦) ។

**១៨:២៤** *ក្រុងអ័លេក្សានទ្រា* ជាទីក្រុងមួយស្ថិតនៅប្រទេសអេស៊ីព្ទ និងជាទីក្រុងលំដាប់ថ្នាក់លេខ២នៅក្រោមការត្រួតត្រារបស់ចក្រភពរ៉ូម៉ាំង ។ មានសាសន៍យូដាជាច្រើនរស់នៅក្នុងទីក្រុងនេះ ។

**១៨:២៥** *បុណ្យជ្រមុជរបស់លោកយ៉ូហាន* ពីធីបុណ្យជ្រមុជទឹករបស់លោកយ៉ូហាន គឺធ្វើឡើងសំដែងអំពីការប្រែចិត្ត និងពុំបានធ្វើនៅក្នុងព្រះនាមព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទទេ ។ បន្ទាប់ពីព្រះយេស៊ូវគ្រីស្ទបានសុគតហើយរស់ឡើងវិញ ទ្រង់បានបង្គាប់ឱ្យអស់អ្នកដែលបានជឿដល់ទ្រង់ធ្វើបុណ្យជ្រមុជទឹកដោយនូវព្រះនាមទ្រង់ (មថ ២៨:១៩) ។

**១៨:២៦** ពេលដែលលោកអ័គីឡា និងនាងព្រីស៊ីលបានឮថា លោកអ័ប៉ុឡូសបានបង្រៀន និងអធិប្បាយពីផ្លូវរបស់ព្រះអម្ចាស់ នោះក៏អញ្ជើញគាត់មកពន្យល់ណែនាំបន្ថែម ឱ្យបានដឹងកាន់តែច្បាស់អំពីជំនឿដ៏ពិតប្រាកដ ដែលនាំឱ្យបានការសង្គ្រោះ ។ ហើយទោះបីជាលោកអ័ប៉ុឡូសជាគ្រូអធិប្បាយដ៏ល្បីឈ្មោះក៏ដោយ ក៏លោកនៅតែបន្ទាបខ្លួន ទទួលយកការបង្រៀនដ៏ត្រឹមត្រូវរបស់លោកអ័គីឡា និងនាងព្រីស៊ីល ដែលជាអ្នកបម្រើស្មោះត្រង់របស់ព្រះអម្ចាស់ដដែល ។

**១៨:២៧–២៨** *ស្រុកអាខៃ* គឺជាខេត្តមួយនៅក្រោមការគ្រប់គ្រងរបស់ចក្រភពរ៉ូម៉ាំង និងមានទីក្រុងមួយឈ្មោះទីក្រុងកូរិនថូស ។ បន្ទាប់ពីលោកប៉ុលបានចាកចេញពីទីក្រុងកូរិនថូសគ្មានពួកសាវ័ក ឬអ្នកដឹកនាំណាមកជាជំនួយដល់ពួកជំនុំនៅទីនោះទេ ។ ដូច្នេះ ពួកជំនុំនៅទីក្រុងអេភេសូរក៏លើកទឹកចិត្តលោកអ័ប៉ុឡូសឱ្យធ្វើដំណើរទៅជួយពួកជំនុំនៅទីក្រុងកូរិនថូស ។

**១៩:១** *អ័ប៉ុឡូសនៅក្រុងកូរិនថូស* ពួកជំនុំបានស្គាល់លោកអ័ប៉ុឡូសនៅឯទីក្រុងអេភេសូរ (១៨:២៤) គឺក្នុងពេលពុំមានវត្តមានលោកប៉ុលនៅក្នុងទីក្រុងនោះ ។ លោកអ័ប៉ុឡូសបានត្រឡប់មកឯទីក្រុងកូរិនថូសវិញ មុនពេលដែលលោកប៉ុលធ្វើដំណើរទៅឯទីក្រុងអេភេសូរ ។ ប៉ុន្តែ ក្រោយមក លោកអ័ប៉ុឡូសក៏បានត្រឡប់ទៅឯទីក្រុងអេភេសូរវិញ ក្នុងខណៈពេលដែលលោកប៉ុលកំពុងបំពេញបេសកកម្មនៅទីនោះ (១កថ ១៦:១២) ។ *ដើរកាត់អស់ទាំងស្រុកខាងលើ* ពេលនោះលោកប៉ុលបានចេញដំណើរពីខេត្តកាឡាទីកាត់តាមស្រុកព្រីគារហូតទៅដល់ទីក្រុងអេភេសូរ (១៦:៦ មើលការពន្យល់ ១៨:២៤) ។ *ក្រុងអេភេសូរ* "មើលការពន្យល់ ១៨:១៩" ។ *សិស្សខ្លះ* ពួកសិស្សទាំងនោះធ្លាប់បានទទួលបុណ្យជ្រមុជទឹករបស់លោកយ៉ូហាន–បាទីស្ទ ប៉ុន្តែមិនបានដឹងថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះមែស៊ីដែល ត្រូវយាងមកនោះទេ ហើយក៏មិនបានឮអំពីព្រះវិញ្ញាណបរិសុទ្ធដែរ ។

**១៩:២** *តើបានទទួលព្រះវិញ្ញាណបរិសុទ្ធហើយឬនៅ?* មុនពេលលោកប៉ុលសួរសំណួរនេះទៅពួកសិស្សនៅទីក្រុងកូរិនថូស គាត់ដឹងហើយថាពួកគេមិនទាន់បានដឹងអំពីព្រះវិញ្ញាណបរិសុទ្ធនៅឡើយទេ បន្ទាប់មក គាត់ក៏បង្រៀន និងអធិស្ឋានឱ្យពួកគេ ។

**១៩:៣** លោកប៉ុលយល់ថា ពិធីបុណ្យជ្រមុជទឹក និងការទទួលព្រះវិញ្ញាណ

៤រួចប៉ុលនិយាយថា លោកយ៉ូហានបានធ្វើបុណ្យជ្រមុជ
ទឹក[ខ]ពីដំណើរការប្រែចិត្ត ទាំងប្រាប់ពួកជនឱ្យជឿដល់
ព្រះអង្គដែលយាងមកក្រោយលោកវិញ គឺដល់ព្រះយេស៊ូវ
គ្រីស្ទ[គ] ៥កាលបានឮដូច្នោះហើយ នោះគេក៏ទទួលបុណ្យ
ជ្រមុជទឹក ដោយនូវព្រះនាមព្រះអម្ចាស់យេស៊ូវវិញ[ឃ] ៦រួច
ប៉ុលដាក់ដៃលើគេ[ង] ហើយព្រះវិញ្ញាណបរិសុទ្ធបានមក
សណ្ឋិតលើគេ[ច] នោះគេចាប់តាំងនិយាយភាសាដទៃ[ឆ] ហើយ
អធិប្បាយផង ៧ពួកអ្នកទាំងនោះមានគ្នាប្រហែលជា១២
នាក់ ។

៨ប៉ុលក៏ចូលទៅអធិប្បាយក្នុងសាលាប្រជុំ[ជ]ដោយក្លាហាន
ហើយក្នុងរវាង៣ខែ គាត់ចេះតែជជែកពន្យល់ ព្រមទាំង
បញ្ចុះបញ្ចូលគេ ឱ្យជឿតាមអស់ទាំងសេចក្តីពីនគរព្រះ[ឈ]
៩លុះកាលអ្នកខ្លះ[ញ] កើតមានចិត្តរឹងទទឹង ហើយចចេស
ព្រមទាំងនិយាយអាក្រក់ពីផ្លូវនោះ[ដ] នៅមុខប្រជាជន នោះ

**១៩:៤** ខ មក ១:៤
គ យហ ១:៧
**១៩:៥** ឃ កច ២:៣៨
**១៩:៦** ង កច ៦:៦
ច កច ១០:៤៤
ឆ មក ១៦:១៧
**១៩:៨** ជ កច ៩:២០
ឈ មថ ៣:២ កច ២៨:២៣
**១៩:៩** ញ កច ១៤:៤
ដ ខ.២៣ កច ៩:២
ឋ ខ.៣០ កច១១:២៦
**១៩:១០** ឌ កច ២០:៣១
ឍ ខ.២២,២៦,២៧ កច ២:៩
ណ កច ១៣:៤៨
**១៩:១១** ត កច៨:១៣
**១៩:១២** ថ កច៥:១៥

គាត់ក៏ថយចេញពីគេទៅ ញែកយកទាំងពួកសិស្សទៅផង[ឋ]
រួចគាត់ជជែកពន្យល់ ក្នុងសាលាបង្រៀនរបស់ទីរ៉ានុស ជា
រាល់ថ្ងៃ ១០គាត់ធ្វើដូច្នោះអស់២ឆ្នាំ[ឌ] ដល់ម៉្លេះបានជា
អស់អ្នកដែលនៅស្រុកអាស៊ី[ឍ]បានឮព្រះបន្ទូលនៃព្រះអម្ចាស់
ទាំងសាសន៍យូដា និងសាសន៍ក្រេកផង[ណ] ។

១១ហើយ ព្រះទ្រង់ធ្វើការឫទ្ធិបារមីយ៉ាងប្លែកៗ[ត] ដោយ
សារដៃប៉ុល ១២ដល់ម៉្លេះបានជាគេគ្រាន់តែយកកន្សែង ឬ
ក្រមាពីខ្លួនគាត់ ទៅដាក់លើមនុស្សមានជំងឺ នោះគេក៏បាន
ជា[ថ] ហើយមានអារក្សអសោចិ៍ចេញពីមនុស្សដែរ ។

១៣រីឯមានមនុស្សសាសន៍យូដាខ្លះជាគ្រូមន្តអាគម ដែល
ដើរចុះឡើង គេក៏ចាប់តាំងអំពាវនាវ ដល់ព្រះនាម
ព្រះអម្ចាស់យេស៊ូវ ពីលើមនុស្សដែលមានអារក្សអសោចិ៍[ទ]
ចូលថា អញបង្គាប់ឯង ដោយនូវព្រះយេស៊ូវ[ធ] ដែលប៉ុល

**១៩:១៣** ទ មថ ១២:២៧ ធ មក ៩:៣៨

បរិសុទ្ធរបស់ព្រះអម្ចាស់ គឺជាការសំខាន់សម្រាប់អ្នកជឿដល់ទ្រង់ ។ ពេលខ្លះការទទួលពិធីបុណ្យជ្រមុជទឹក កើតឡើងមុនការទទួលព្រះវិញ្ញាណបរិសុទ្ធ (កច ២:៣៨ ៨:១៥–១៧) ។ ពេលខ្លះទៀត ការទទួលព្រះវិញ្ញាណបរិសុទ្ធកើតឡើងមុនការទទួលពិធីបុណ្យជ្រមុជទឹក (កច ១០:៤៤,៤៧,៤៨) ។ ទោះជាយ៉ាងណាក៏ដោយ គ្រីស្ទបរិស័ទពិតប្រាកដត្រូវមានការទាំងពីរយ៉ាងនេះ ។

**១៩:៤** *លោកយ៉ូហាន* (យ៉ូហាន–បាទីស្ទ) លោកយ៉ូហានម្នាក់នេះគឺជាកូនរបស់លោកសាការី (ជាសម្ដេចសង្ឃ) និងនាងអេលីសាបិត (ជាញាតិរបស់នាងម៉ារាជាមាតាព្រះយេស៊ូវគ្រីស្ទ) ។ *បានធ្វើបុណ្យជ្រមុជទឹកពីដំណើរការប្រែចិត្ត* ឃ្លានេះគឺជាសេចក្តីសង្ខេបអំពីសេចក្តីបង្រៀនរបស់លោកយ៉ូហាន–បាទីស្ទ។ សេចក្តីបង្រៀនសំខាន់របស់គាត់គឺ ឱ្យមនុស្សបានប្រែចិត្តចេញពីអំពើបាបរបស់ខ្លួន និងមកទទួលយកដំណឹងល្អរបស់ព្រះអម្ចាស់វិញ ប្រយោជន៍ឱ្យពួកគេបានសង្គ្រោះ ។

**១៩:៥** នៅក្នុងខនេះបញ្ជាក់ថា ពួកសិស្សទាំងនោះបានទទួលពិធីបុណ្យជ្រមុជទឹកពីរដង ប៉ុន្តែ ពិធីបុណ្យជ្រមុជទឹកទាំងពីរ នោះពុំមានអត្ថន័យដូចគ្នាទេ ។ ពិធីបុណ្យជ្រមុជទឹករបស់លោកយ៉ូហាន គឺគ្រាន់តែសំដែងអំពីការប្រែចិត្ត ប៉ុណ្ណោះ រីឯពិធីបុណ្យជ្រមុជទឹកដែលពួកគេទទួលនៅក្នុងព្រះនាមព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ គឺធ្វើតាមព្រះរាជបញ្ជារបស់ទ្រង់ សំដែងអំពីការស្លាប់បង្គាប់ ហើយជានិមិត្តរូបអំពីការបានស្លាប់ជាមួយទ្រង់ (ពេលជ្រមុជទៅក្នុងទឹក) និងរស់នៅជាមួយទ្រង់អស់កល្បជានិច្ច (ពេលងើបពីទឹកមកវិញ) ។

**១៩:៦-៧** *រួចប៉ុលដាក់ដៃលើគេ* "មើលការពន្យល់ ៦:៦" ។ *ព្រះវិញ្ញាណបរិសុទ្ធបានមកសណ្ឋិតលើគេ នោះគេចាប់តាំងនិយាយភាសាដទៃ ហើយអធិប្បាយផង* បន្ទាប់ពីពួកសិស្សទាំងនោះបានស្គាល់ព្រះវិញ្ញាណបរិសុទ្ធហើយ នោះលោកប៉ុលក៏អធិស្ឋានឱ្យ ។ ពួកគេក៏បានពេញជាព្រះវិញ្ញាណដូចជាពួកសាវ័ក (នៅថ្ងៃបុណ្យ ទី៥០ ២:៤,១១) និងពួកសាសន៍ដទៃនៅឯទីក្រុងសេសារាបានទទួលដូច្នោះដែរ (១០:៤៦) ។

**១៩:៨** *ក្នុងរវាង៣ខែ* ក្នុងរយៈពេលនោះលោកប៉ុលបានបង្រៀនពួកជំនុំជាច្រើន នៅទីក្រុងកូរិនថូស ឱ្យយល់ពីការសង្គ្រោះរបស់ព្រះអម្ចាស់តាមរយៈដំណឹងល្អរបស់ទ្រង់ ។ *នគរព្រះ* "មើលការពន្យល់ មថ ៣:២ លក ៤:៤៣" ។

**១៩:៩** ពាក្យថា "*ផ្លូវនោះ*" នៅក្នុងខនេះគឺមានទំនាក់ទំនងទៅនឹងព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ ដែលថាទ្រង់ជាផ្លូវ (មើលការពន្យល់ ៩:២) ។ *គាត់ជជែកពន្យល់ ក្នុងសាលាបង្រៀនរបស់ទីរ៉ានុសជារាល់ថ្ងៃ* តាមព្រះគម្ពីរជាភាសាក្រិកដំបូង បញ្ជាក់ថា លោកប៉ុលបានជជែកពន្យល់ និងបង្រៀនពួកបណ្ដាជននៅក្នុងសាលាប្រជុំរបស់លោកទីរ៉ានុស (ជាអ្នកទស្សនវិជ្ជា ឬអ្នកមានវោហារ) ចាប់ពីម៉ោង ១១:00ព្រឹក រហូតដល់ម៉ោង៤:00 រសៀល (ជាពេលក្តៅខ្លាំង ប៉ុន្តែ ពួកបណ្ដាជនទំនេរពីការងារ) ។

**១៩:១០** *គាត់ធ្វើដូច្នោះអស់២ឆ្នាំ* លោកប៉ុលបានបង្រៀនក្នុងសាលាប្រជុំរបស់សាសន៍យូដានៅឯទីក្រុងអេភេសូរាល់តែថ្ងៃសៅរ៍ អស់រយៈពេល ៣ខែ ។ ក្រោយពីនោះមក ពួកប្រឆាំងបានកើនឡើង ដូច្នោះ លោកប៉ុលក៏ប្តូរទៅបង្រៀននៅឯសាលាបង្រៀនរបស់លោកទីរ៉ានុស អស់រយៈពេល២ឆ្នាំទៀត ។ តាមទម្លាប់របស់ពួកយូដា រយៈពេល២ឆ្នាំ៣ខែពួកគេអាចនិយាយថា ៣ឆ្នាំតែម្ដង (២០:៣១) ។

**១៩:១១** នៅក្នុងខនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះអម្ចាស់បានប្រទានឱ្យលោកប៉ុល នូវអំណោយទានដ៏ពិសេស សម្រាប់បម្រើដំណឹងល្អរបស់ទ្រង់ ។

**១៩:១២** *កន្សែង ឬក្រមា* ជាទូទៅលោកប៉ុលបានយកកន្សែង ឬក្រមាតាមខ្លួនក្នុងពេលធ្វើដំណើរ ឬធ្វើការងារផ្សេងៗ (សម្រាប់ក្រវាត់ចង្កេះ ឬជូតក្បាល) ។ កន្សែង ឬក្រមា ដែលលោកប៉ុលប្រើនោះ ពុំមានអំណាចអ្វីអាចព្យាបាលពួកគេ ឱ្យបានជាពីជំងឺណាមួយនោះទេ ប៉ុន្តែ វាជានិមិត្តរូបសំដែងអំពីទំនាក់ទំនងផ្ទាល់រវាងគាត់ (លោកប៉ុល) និងពួកគេ ។ ការដែលពួកគេបានជា គឺដោយសារតែអំណាចព្រះចេស្តារបស់ព្រះយេស៊ូវគ្រីស្ទទ្រង់ធ្វើតាមរយៈលោកប៉ុល និងពួកសិស្សរបស់ទ្រង់ (មើលការពន្យល់ ៥:១៥) ។

**១៩:១៣** ពេលដែលបានឮថា លោកប៉ុលធ្វើការអស្ចារ្យជាច្រើន នៅក្នុងព្រះនាម ព្រះយេស៊ូវគ្រីស្ទ នោះមានពួកយូដាខ្លះបានយកព្រះនាមទ្រង់ទៅប្រើដើម្បីរកផលប្រយោជន៍សម្រាប់ខ្លួន ប៉ុន្តែ ពួកគេមិនអាចបានសម្រេចតាមបំណងរបស់ខ្លួនទេ ។

ប្រកាសប្រាប់នោះ [១៤]ក្នុងពួកមនុស្សដែលធ្វើដូច្នោះ មាន៧
នាក់ ជាកូននៃសាសន៍យូដាម្នាក់ ដែលធ្វើជាសង្គ្រាជ ឈ្មោះ
ស្កេវ៉ា [១៥]តែអារក្សអសោចិ៍ឆ្លើយទៅគេថា យើងស្គាល់
ព្រះយេស៊ូវ ហើយក៏ស្គាល់ប៉ុលបន្តិចបន្តួចដែរ តែឯងរាល់
គ្នា តើជាអ្នកណាវិញ [១៦]រួចមនុស្សដែលមានអារក្សអសោចិ៍
ចូល ក៏ស្ទុះទៅលើគេ ទាំងបង្ក្រប ហើយឈ្នះគេ ដល់ម្លេះបាន
ជាគេរត់ចេញពីផ្ទះនោះទាំងអាក្រាត ហើយ មានរបួសផង
[១៧]ឯអស់មនុស្សនៅក្រុងអេភេសូរ[ន]ទាំងសាសន៍យូដា នឹង
សាសន៍ក្រេកផង បានដឹងរឿងនោះ ក៏កើតមានចិត្តភ័យ
ខ្លាច[ប]ទាំងអស់គ្នា ហើយព្រះនាមព្រះអម្ចាស់យេស៊ូវក៏បាន
ថ្កើងឡើង [១៨]មានមនុស្សជាច្រើនដែលបានជឿ គេមកលន់
តួ ព្រមទាំងសំដែងប្រាប់ ពីការដែលខ្លួនបានប្រព្រឹត្តផង
[១៩]ឯមនុស្សដែលប្រព្រឹត្តវិជ្ជាប្លែកៗនោះ ក៏មានច្រើននាក់
បានយកក្បួនដំរារបស់ខ្លួន មកដុតចោល នៅចំពោះមុខ
មនុស្សទាំងអស់គ្នា គេបានគិតថ្លៃក្បួនទាំងនោះមើល ឃើញ
មានដំឡៃអស់៥ម៉ឺនរៀល [២០]គឺយ៉ាងដូច្នោះឯង ដែល
ព្រះបន្ទូលនៃព្រះអម្ចាស់[ផ] បានចំរើនកើនឡើង ហើយបាន
ឈ្នះដោយអំណាច[ព]។

[២១]ក្រោយការទាំងនោះមក ប៉ុលគិតសំរេចក្នុងចិត្តថា
កាលណាបានដើរកាត់ស្រុកម៉ាសេដូន[ភ] និងស្រុកអាខៃ[ម]
ហើយ នោះគាត់នឹងទៅឯក្រុងយេរូសាឡិម[យ] ក៏និយាយថា
ក្រោយដែលខ្ញុំបានទៅឯណោះហើយ នោះត្រូវឲ្យខ្ញុំទៅ
មើលក្រុងរ៉ូមដែរ[រ]។

## ភាពវឹកវរនៅទីក្រុងអេភេសូរ

[២២]គាត់ចាត់អ្នកជំនួយគាត់២នាក់[ល]គឺធីម៉ូថេ[វ]និងអេរ៉ាស្ទុស[ស]
ឲ្យទៅស្រុកម៉ាសេដូន តែខ្លួនគាត់ស្នាក់នៅក្នុងស្រុកអាស៊ី[ហ]
បន្តិចទៀត [២៣]នៅគ្រានោះ កើតមានវឹកវរជាធំពីដំណើរ
ផ្លូវនោះ[ឡ]។

[២៤]ដ្បិតមានមនុស្សម្នាក់ឈ្មោះដេមេទ្រាស ជាជាងប្រាក់
ដែលធ្វើអាស្រមព្រះឌីអានពីប្រាក់ គាត់ជួយដល់ពួកជាង
ទាំងប៉ុន្មានឲ្យបានកំរៃជាច្រើន [២៥]កាលគាត់បានប្រមូលគេ
ព្រមទាំងពួកអ្នក ដែលមានរបរដូចគ្នាទាំងប៉ុន្មានមក នោះ
គាត់និយាយថា អ្នករាល់គ្នាអើយ អ្នកដឹងថា យើងបានផល
ចំណេញពីរបរនេះមក[អ] [២៦]អ្នកក៏ឃើញ ហើយឮថា ឈ្មោះ
ប៉ុលនេះ បានបញ្ចុះបញ្ចូល ព្រមទាំងបង្វែរមនុស្សសន្ធឹក
ទៅហើយ មិនត្រឹមតែនៅអេភេសូរ[ក]ប៉ុណ្ណោះ គឺស្ទើរតែ
នឹងគ្រប់សព្វនៅស្រុកអាស៊ីផង[ខ] ដោយពាក្យថា អស់ទាំងព្រះ
ដែលដៃមនុស្សធ្វើ នោះមិនមែនជាព្រះទេ[គ] [២៧]ដូច្នេះ មាន
អន្តរាយកើតដល់យើង មិនត្រឹមតែសមាគមនេះ ដោយ
គេលែងរាប់អានប៉ុណ្ណោះ គឺក្រែងគេលែងទាំងគោរព

**១៩:១៧** ន កច ១៨:១៩
ប កច ៥:៥,១១
**១៩:២០** ផ កច ១៣:៤៨ ព កច ៦:៧ ១២:២៤
**១៩:២១** ភ កច ១៦:៩ ម កច ១៨:១២
យ កច ២០:១៦,២២ ២១:៤,១២,១៥
រ រម ១៥:២៥
រ រម ១៥:២៤,២៨
**១៩:២២** ល កច ១៣:៥ វ កច ១៦:១
ស រម ១៦:២៣ ២ធថ ៤:២០
ហ ខ.១០, ២៦,២៧ កច ២:៩
**១៩:២៣** ឡ កច ៩:២
**១៩:២៥** អ កច ១៦:១៦,១៩,២០
**១៩:២៦** ក កច ១៨:១៩ ខ កច ២:៩
គ ចទ ៤:២៨
ទដ ១១៥:៤
អស ៤៤:១០–២០
យរ ១០:៣–៥
កច ១៧:២៩ ១កថ ៨:៤ វវ ៩:២០

**១៩:១៤** *សាសន៍យូដាម្នាក់ដែលធ្វើជាសង្គ្រាជឈ្មោះស្កេវ៉ា* លោកស្កេវ៉ាម្នាក់នេះប្រហែលជាជាប់វង្សត្រកូលជាមួយពួកសង្គ្រាជនៅក្រុងយេរូសាឡិម ។

**១៩:១៥-១៦** ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា មានតែអស់អ្នកដែលជឿលើព្រះយេស៊ូវគ្រីស្ទទេ ទើបមានអំណាចព្រះចេស្ដាមកពីទ្រង់ ។

**១៩:១៧-១៨** នៅពេលបណ្ដាជនបានឃើញលោកប៉ុល ដេញអារក្សអសោចិ៍ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ នោះពួកគេក៏មានការអស្ចារ្យ និងភ័យខ្លាច ។ ដូច្នោះ បានជាមានពួកគេជាច្រើន ប្រែចិត្តជឿដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះសង្គ្រោះរបស់ ពួកគេរៀងៗខ្លួន ។

**១៩:១៩–២០** *ក្បួនដំរា* គឺសៀវភៅ ឬឯកសារដែលមានកត់ត្រាទុកនូវវិជ្ជាមន្តអាគម និងការសំងាត់ផ្សេងៗរបស់ពួកគេ ។ នៅសម័យនោះ ទីក្រុងអេភេសូរ គឺជាទីកន្លែងប្រមូលផ្តុំគ្រូមន្តអាគមជាច្រើន ។ *ឃើញមានដំឡៃអស់៥ម៉ឺនរៀល* តម្លៃក្បួនតម្រាដែលពួកគ្រូមន្តអាគមបានដុតចោល បន្ទាប់ពីបានទទួលជឿដល់ព្រះគ្រីស្ទហើយនោះ គិតជាតម្លៃប្រាក់សព្វថ្ងៃគឺប្រហែល ៣៧ ២០០ ០០០ រៀល ។

**១៩:២១** *ស្រុកម៉ាសេដូន និងស្រុកអាខៃ* "មើលពន្យល់ ១ថន ១:៧–៨"។

**១៩:២២** *អេរ៉ាស្ទុស* គាត់គឺជាមេត្រួតត្រា (ចៅហ្វាយក្រុង) នៅទីក្រុងកូរិនថូស(រម ១៦:២៣ ២ធថ ៤:២០)។

**១៩:២៣** *ពីដំណើរផ្លូវនោះ* អត្ថន័យនៃពាក្យនេះមានជាប់ទាក់ទងទៅនឹងព្រះបន្ទូលព្រះយេស៊ូវដែលថាទ្រង់ជាផ្លូវ (៩:២ និងការពន្យល់)។

**១៩:២៤** *ដេមេទ្រាស ជាជាងប្រាក់* ជាធម្មតានៅក្នុងរបរជំនួញតែងមានការរកស៊ីជាក្រុម ហើយដេមេទ្រាសម្នាក់នេះ ប្រហែលជាត្រូវបានគេចាត់ឲ្យធ្វើជាប្រធានក្រុមសម្រាប់ការសាងសង់អាស្រម និងរូបព្រះឌីអាននោះ ។ *ព្រះឌីអាន* ជារូបព្រះស្រីមួយដែលនៅលើរូបព្រះនេះចាប់ពីដើមទ្រូងរហូតដល់ចង្កេះមានសុដន់ (ដោះ) ជាច្រើន ។ ការដែលមានសុដន់ច្រើន ធ្វើឲ្យពួកគេយល់ថា រូបព្រះនេះជាមាតារបស់មនុស្សទាំងអស់ ។ តាមទំនៀមទម្លាប់ពួកអ្នកនៅក្នុងទីក្រុងអេភេសូរ ជឿថា រូបព្រះឌីអានកើតចេញមកពីឈើ (ធ្លាក់ពីលើមេឃ) នៅក្បែរទីក្រុងអេភេសូរ គឺក្បែរទីកន្លែងដែលគេសង់ព្រះវិហារសម្រាប់រូបព្រះនេះតែម្តង ។

**១៩:២៥–២៦** *បានផលចំណេញពីរបរនេះ* ពួកជាងប្រាក់ដែលរស់នៅទីនោះរកបានប្រាក់ចំណេញជាច្រើនអំពីការលក់រូបព្រះ ឬវត្ថុផ្សេងៗ ព្រោះថាមានទេសចរជាច្រើន ធ្វើដំណើរទៅទីនោះ ដើម្បីមកមើលព្រះវិហារនៃព្រះឌីអាន ដែលគេចាត់ទុកជាអច្ឆរិយវត្ថុមួយក្នុងចំណោមអច្ឆរិយវត្ថុបុរាណចំនួន៧នៅក្នុងលោក ។

**១៩:២៧** *ព្រះវិហាររបស់ព្រះឌីអានដ៏ធំ* ព្រះវិហារនៃព្រះឌីអានមានបណ្ដោយ ១២៩,៥៤ ម៉ែត្រ ទទឹង ៦៧,០៥ ម៉ែត្រ និងមានសសរចំនួន ១២៧ ដែលនីមួយៗមានកម្ពស់ ១៨,៩៩ ម៉ែត្រ ហើយចន្លោះពីសសរមួយទៅសសរមួយទៀតគឺ ១,២១ម៉ែត្រ ។ នៅក្នុងវិហារនោះមានរូបព្រះស្រី (ព្រះឌីអាន) មានដោះជាច្រើន ដែលពួកគេជឿថា រូបទាំងនោះធ្លាក់មកពីស្ថានសួគ៌ ។

ប្រតិបត្តិ ដល់ព្រះវិហាររបស់ព្រះឱអានដ៏ធំ ថែមទៀត
ផង រួចសិរីល្អនៃព្រះរបស់យើង ដែលគ្រប់ស្រុកអាស៊ី
នឹងលោកីយទាំងមូលក៏ថ្វាយបង្គំ នឹងត្រូវសាបសូន្យទៅ
២៨ កាលគេឮសេចក្ដីនោះហើយ គេក៏មានពេញដោយ
សេចក្ដីកំហឹង ហើយស្រែកប្រកាសថា ព្រះឱអាននៃពួក
ក្រុងអេភេសូរយើង ទ្រង់ធំវិសេស[ឃ] ២៩ នោះក៏កើតមាន
វឹកវរពេញក្នុងក្រុង គេស្រុះចិត្តគ្នាចាប់កន្ត្រាក់កៃយុស[ង] នឹង
អើរីស្តាក[ច] ជាអ្នកស្រុកម៉ាសេដូន[ឆ] ដែលដើរដំណើរជាមួយ
នឹងប៉ុល នាំម្នីម្នាចូលទៅក្នុងរោងជិនុំ ៣០ ឯប៉ុលគាត់គិត
ចូលទៅឯបណ្ដាជនដែរ តែពួកសិស្ស[ជ] មិនព្រមឱ្យទៅទេ
៣១ ហើយមានពួកចៅហ្វាយនៅស្រុកអាស៊ីខ្លះដែលស្រឡាញ់
គាត់ ក៏ចាត់គេមកអង្វរថាសូមកុំឱ្យចូលទៅក្នុងរោងជិនុំនោះ
ឡើយ ៣២ ឯបណ្ដាជន ខ្លះស្រែកយ៉ាងនេះ ខ្លះស្រែកយ៉ាង
នោះ[ឈ] ដ្បិតមនុស្សក្នុងចំណោមនោះ កំពុងជ្រួលជ្រើមជាខ្លាំង
ច្រើនមិនដឹងជាគេប្រជុំគ្នាដោយហេតុអ្វីផង ៣៣ ពួកសាសន៍
យូដា ក៏ច្រានអ័លេក្សានត្រុស ចេញពីហ្វូងមនុស្ស ទៅខាង
មុខ គាត់ក៏ធ្វើគ្រឿងសំគាល់នឹងដៃ[ញ] ចង់ដោះសានឹងបណ្ដា
មនុស្ស ៣៤ កាលគេបានដឹងថាគាត់ជាសាសន៍យូដា គេក៏
ស្រែកឡើងព្រមគ្នាចំនួនប្រហែលជា២ម៉ោងថា ព្រះឱ
អាននៃពួកក្រុងអេភេសូរយើង ទ្រង់ធំវិសេស[ដ] ៣៥ កាល
លោកភូឈួយបានធ្វើបង្អន់ដល់ហ្វូងមនុស្ស នោះក៏និ
យាយថា នៃពួកក្រុងអេភេសូរអើយ[ឋ] តើមានអ្នកឯណា
ដែលមិនដឹងថា ពួកអ្នកនៅក្រុងនេះ ជាអ្នកថែរក្សា
ព្រះវិហារនៃព្រះឱអានដ៏ធំ ដែលធ្លាក់មកពីព្រះសេយូស
នោះ ៣៦ ដូច្នេះ ដែលសេចក្ដីនោះជាពិតហើយ នោះគួរតែ
ឱ្យអ្នករាល់គ្នា បានធ្វើដោយស្រួលទៅចុះ មិនត្រូវឱ្យធ្វើ
ដោយរលះរលាំងដូច្នេះឡើយ ៣៧ អ្នករាល់គ្នាបាននាំ
មនុស្សទាំងនេះមក ដែលមិនមែនជាចោរលួចវិហារ[ឌ]
ឬប្រមាថដល់ព្រះនៃអ្នករាល់គ្នាទេ ៣៨ ដូច្នេះ បើសិនជា
ដេមេទ្រាស នឹងពួកជាង[ឍ] ដែលមកជាមួយគ្នានេះ មានរឿង
អ្វីនឹងអ្នកណា នោះមានទីសំរាប់ជំនុំជំរះក្ដីស្រាប់ ហើយមាន
ទាំងពួកចៅក្រមផង[ណ] ត្រូវឱ្យគេប្តឹងប្តល់គ្នាទៅចុះ ៣៩ តែ
បើអ្នករាល់គ្នា ចង់សួរពីដំណើរណាទៀត នោះត្រូវតែបាន
សំរេចក្នុងជំនុំ ដែលប្រជុំតាមច្បាប់វិញ ៤០ ដ្បិតខ្លាចក្រែង
យើងត្រូវទោសជាពួកបះបោរ ដោយព្រោះរឿងដែលកើត

**១៩:២៨** ឃ កច ១៨:១៩
**១៩:២៩** ង កច ២០:៤ រម ១៦:២៣ ១កថ ១:១៤ ច កច ២០:៤ ២៧:២ កល ៤:១០ ភម ២៤ ឆ កច ១៦:៩
**១៩:៣០** ជ កច ១១:២៦
**១៩:៣២** ឈ កច ២១:៣៤
**១៩:៣៣** ញ កច ១២:១៧
**១៩:៣៤** ដ ខ.២៨
**១៩:៣៥** ឋ កច ១៨:១៩
**១៩:៣៧** ឌ រម ២:២២
**១៩:៣៨** ឍ ខ.២៤ ណ កច ៣:៧,៨,១២ ១៨:១២

**១៩:២៨–២៩** នៅឯទីក្រុងអេភេសូរ ពេលនោះ មានរោងល្ខោនធំមួយដែលអាចទទួលមនុស្សបាន ២៥ ០០០ នាក់ ។ ពាក្យថា "រោងជិនុំ" ក្នុងខ២៩ ភាសាអង់គ្លេសប្រើពាក្យថា "រោងល្ខោន ឬរោងមហោស្រព"។ ការប្រជុំពិភាក្សាជាសាធារណៈ និងស្របច្បាប់ គឺធ្វើឡើងនៅក្នុងរោងមហោស្រព ។ *កៃយុស* "មើលការពន្យល់ ២០:៤"។ *អើរីស្តាក* គឺជាគូកនម្នាក់របស់លោកប៉ុលដែលបានធ្វើដំណើរជាមួយគាត់ទៅទីក្រុងយេរូសាឡិម (២០:៣–៤) និងពីទីក្រុងយេរូសាឡិមទៅឯទីក្រុងរ៉ូម (២៧:១–២ មើលពន្យល់ កល ៤:១០)។

**១៩:៣០–៣១** លោកប៉ុលចង់ចេញមុខចំពោះហ្វូងមនុស្សដែលកំពុងមានកំហឹង ព្រោះគាត់ពុំខ្លាចនឹងការពារ និងប្រកាសដំណឹងល្អរបស់ព្រះយេស៊ូវឡើយ ។ *ពួកចៅហ្វាយនៅស្រុកអាស៊ី* គឺជាសមាជិករបស់ពួកក្រុមជំនុំ (ក្រុមជំនុំជម្រះក្តី ឬ ពួកកាត់ក្តី) នៅទីនោះ ។ លោកប៉ុលក៏មានមិត្តភក្តិនៅក្នុងពួកក្រុមជំនុំនោះដែរ ។

**១៩:៣២** ពេលនោះពួកបណ្ដាជនបានមកផ្តុំគ្នា ដោយគ្មានមូលហេតុច្បាស់លាស់ ហើយក៏គ្មានច្បាប់ ឬអ្នកណាប្រកាសហៅឱ្យមកដែរ គឺពួកគេរកឱកាសដើម្បីធ្វើការអាក្រក់ (បំផ្លាញអ្នកដទៃ និងបញ្ចេញកំហឹងរបស់ខ្លួន) តែប៉ុណ្ណោះ ។

**១៩:៣៣–៣៤** ពួកសាសន៍យូដាបាននាំគ្នាច្រានលោកអ័លេក្សានត្រុសឱ្យទៅខាងមុខ ដើម្បីប្រកាសប្រាប់ពួកបណ្ដាជនថា ពួកខ្លួនគ្មានទំនាក់ទំនងជាមួយនឹងគ្រីស្ទបរិស័ទដែលនៅជាមួយលោកប៉ុលនោះទេ។ ប៉ុន្តែពួកបណ្ដាជនមិនព្រមស្តាប់ពាក្យសំដីរបស់លោកអ័លេក្សានត្រុសទេ ព្រោះថា គាត់ក៏ជាសាសន៍យូដាម្នាក់ដែរ ។

**១៩:៣៥** *លោកភូឈួយ* ពាក្យថា "ភូឈួយ" មានន័យថា មន្ត្រីដែលមានមុខងារជាអ្នកទទួលរងបន្ទុកធ្វើកិច្ចការរាជការ បន្ទាប់អំពីមន្ត្រីជាប្រធាន ។ នៅសម័យបុរាណគេប្រើពាក្យ "ជិទប់" លុះក្រោយមកប្រើពាក្យថា "ភូឈួយ" នេះ ប៉ុន្តែបច្ចុប្បន្នគេប្រើពាក្យ "រង" ជំនួសវិញ (ឧទាហរណ៍: អភិបាលខេត្តរង)។

**១៩:៣៦–៣៧** អ្នករស់នៅក្រុងអេភេសូរមានសេរីភាពជាងគេក្នុងចំណោមមនុស្សរស់នៅក្នុងតំបន់ ដែលស្ថិតនៅក្រោមការត្រួតត្រារបស់ចក្រភពរ៉ូម៉ាំង ។ ទោះជាយ៉ាងណាក៏ដោយ ក៏សេរីភាពទាំងនោះអាចបាត់បង់ទៅវិញបាន ប្រសិនបើពួកអភិបាលរ៉ូម៉ាំង ដែលមានទីបញ្ជាការធំនៅក្នុងទីក្រុងអេភេសូរឮថាមានការបះបោរ ឬការប្រឆាំងណាមួយកើតឡើងនៅទីនោះ ។ ដូច្នោះហើយបានជាលោកភូឈួយចង់ឱ្យពួកបណ្ដាជនទាំងអស់បានស្ងាត់ទៅវិញ ។ ពេលខ្លះពាក្យថា "ចៅហ្វាយទីក្រុង"នេះ ត្រូវបានហៅថា លោកភូឈួយ (ខ.៣៥)។

**១៩:៣៨** *មានទីសំរាប់ជំនុំជំរះក្ដីស្រាប់ ហើយមានទាំងពួកចៅក្រមផង* ដោយព្រោះទីក្រុងអេភេសូរជាទីបញ្ជាការធំរបស់ពួករ៉ូម៉ាំងនៅអាស៊ី ដូច្នោះហើយបានជាមានទីសម្រាប់ជំនុំជម្រះក្តី និងពួកចៅក្រមប្រចាំការនៅទីនោះតែម្តង ។

**១៩:៣៩** *ប្រជុំតាមច្បាប់* នៅពេលនោះជាធម្មតាពួកគេមានការប្រជុំជាផ្លូវការ៣ដងក្នុងមួយខែ ។

**១៩:៤០–៤១** លោកចៅហ្វាយទីក្រុងបានរំឭក ដល់ពួកបណ្ដាជនទាំងអស់ឱ្យដឹងថា ប្រសិនបើមានរឿងអ្វីត្រូវប្តឹងផ្តល់គ្នា នោះត្រូវទៅកាន់ទីជំនុំជម្រះក្តី និងមិនត្រូវធ្វើការបះបោរប្រឆាំង ដែលនាំឱ្យកើតចលាចលនៅក្នុងទីក្រុងឡើយ ។ ដូច្នេះ ទង្វើដែលពួកគេបានបង្កើតឡើងនោះ លោកបាន

មកនៅថ្ងៃនេះ ដ្បិតគ្មានហេតុណាមួយ ដែលយើងអាចនឹងដោះសាពីការប្រជុំនេះបានទេ ៤១កាលមានប្រសាសន៍សេចក្តីទាំងនេះរួចហើយ នោះលោកឱ្យគេទៅវិញទៅ ។

## ដំណើរឆ្លងកាត់ខេត្តម៉ាសេដូន និងស្រុកក្រេក

**២០** ១លុះក្រោយដែលការចលាចលនោះបានស្ងប់ស្ងាត់ហើយ នោះប៉ុលហៅពួកសិស្ស[ត]មក រួចលាគេចេញទៅឯស្រុកម៉ាសេដូនវិញ[ថ] ២កាលគាត់បានដើរកាត់ដែនស្រុកទាំងនោះ ហើយអធិប្បាយទូន្មានជាច្រើន ដល់ពួកសិស្សនោះគាត់បានដល់ទៅស្រុកក្រេក ៣ក៏នៅស្រុកនោះ អស់៣ខែ តែកាលគាត់រៀបនឹងចុះសំពៅទៅឯស្រុកស៊ីរី[ទ] នោះពួកសាសន៍យូដា គេគិតល្បិចទាស់នឹងគាត់[ធ] បានជាគាត់សំរេចនឹងទៅតាមស្រុកម៉ាសេដូនវិញ[ន] ៤មានសូប៉ាត្រុសដែលនៅក្រុងបេរា អើរីស្តាក[ប] នឹងសេគុនដុស ពីពួកថែស្សាឡូនីច[ផ] កៃយុស[ព] នឹងធីម៉ូថេ[ភ] ពីក្រុងឌើបេ ហើយទីឃីកុស[ម] នឹងទ្រភីម[យ] ពីស្រុកអាស៊ី[រ] គេជូនដំណើរទៅត្រឹមស្រុកអាស៊ី ៥អ្នកទាំងនោះចេញទៅមុន ក៏ចាំយើងរាល់គ្នា[ល] នៅត្រង់ក្រុងទ្រអាស[វ] ៦ក្រោយថ្ងៃបុណ្យនំបុ័ងឥតដំបែ នោះយើងក៏ចុះសំពៅ ចេញពីក្រុងភីលីព[ស] ទៅ៥ថ្ងៃទើបបានដល់ទៅគេនៅទ្រអាស[ហ] រួចយើងស្នាក់នៅទីនោះអស់៧ថ្ងៃ ។

## ក្មេងជំទង់ម្នាក់ឈ្មោះអើទីកុសបានរស់ឡើងវិញ

៧លុះថ្ងៃដំបូងក្នុងអាទិត្យនោះ[ឡ] កាលពួកសិស្សបានប្រជុំគ្នា ដើម្បីកាច់នំបុ័ង[អ] នោះប៉ុលក៏អធិប្បាយឱ្យគេស្តាប់ ដោយ

**២០:១** ត កច ១១:២៦ ថ កច ១៦:៩ **២០:៣** ទ លក ២:២ ធ ខ.១៩ កច ៩:២៣,២៤ ១៤:៥ ២៣:១២,១៥, ៣០ ២៥:៣ ២កថ ១១:២៦ ១ថន ២:១៦ ន កច ១៦:៩ **២០:៤** ប កច ១៩:២៩ ផ កច ១៧:១ ព កច ១៩:២៩ ភ កច ១៦:១ ម អភ ៦:២១ កល ៤:៧ តទ ៣:១២ យ កច ២១:២៩ ២ធថ ៤:២០ រ កច ២:៩ **២០:៥** ល កច ១៦:១០ វ កច ១៦:៨ **២០:៦** ស កច ១៦:១២ ហ កច ១៦:៨ **២០:៧** ឡ ១កថ ១៦:២ វវ ១:១០ អ មថ ១៤:១៩

បង្គាប់ឱ្យបញ្ឈប់ជាបន្ទាន់ ។

**២០:១** *នោះប៉ុលហៅពួកសិស្សមក រួចលាគេ* លោកប៉ុលហៅពួកសិស្សមកគឺចង់បញ្ជាក់ប្រាប់ឱ្យពួគេដឹងថា (១).គាត់ត្រូវចាកចេញពីទីក្រុងអេភេសូរ (២).គាត់នឹងប្រកាសព្រះបន្ទូល នៅទីក្រុងទ្រអាសតាមផ្លូវទៅកាន់ស្រុកម៉ាសេដូន (៣).គាត់នឹងទៅជួបលោកទីតុស នៅឯទីក្រុងទ្រអាស ដោយនាំមកជាមួយនូវរបាយការណ៍ស្តីអំពីទីក្រុងកូរិនថូស (២កថ ២:១២–១៣ និងការពន្យល់ ២កថ ២:១២) (៤).គាត់ចង់បន្តការប្រមូលដង្វាយទៅជួយពួកជំនុំនៅស្រុកយូដា (១កថ ១៦:១–៤ ២កថ ៨:១–៩:១៥ រម ១៥:២៥–២៨)។ *ស្រុកម៉ាសេដូន* គឺនៅស្រុកម៉ាសេដូននេះហើយ ដែលលោកប៉ុលបានសរសេរសំបុត្រទៅកាន់ពួកជំនុំ នៅឯទីក្រុងកូរិនថូសជាលើកទី២ (២កូរិនថូស) (២កថ ៧:៥ ៨:១ ៩:៤)។

**២០:២** *គាត់បានដើរកាត់ដែនស្រុកទាំងនោះ* លោកប៉ុលបានចំណាយពេលវេលាប្រហែល១ឆ្នាំ ធ្វើដំណើរកាត់តាមខេត្តម៉ាសេដូន រហូតដល់ស្រុកអ៊ីលីរីកុន (សព្វថ្ងៃហៅថាប្រទេស យូហ្គោស្លាវី Yugoslavia) (រម ១៥:១៩)។ បន្ទាប់ពីនោះមក លោកបានមកដល់ស្រុកក្រេក ហើយបានស្នាក់នៅទីនោះ៣ខែ ។

**២០:៣** *នៅស្រុកនោះអស់៣ខែ* ក្នុងអំឡុង៣ខែនោះ លោកប៉ុលចំណាយពេលច្រើន នៅក្នុងទីក្រុងកូរិនថូស ដែលជាទីក្រុងធំនៃស្រុកអាខៃ ។ ប្រហែលជាក្នុងរយៈពេលនោះហើយ ដែលគាត់បានសរសេរសំបុត្រទៅកាន់ពួកជំនុំនៅទីក្រុងរ៉ូម (មើលសេចក្តីផ្តើមព្រះគម្ពីររ៉ូម)។ *គេគិតល្បិចទាស់នឹងគាត់* ពួកយូដាបានប្តេជ្ញាប៉ងសម្លាប់លោកប៉ុល និងចង់ឆ្លៀតឱកាសប្លន់យកប្រាក់ដង្វាយ ដែលគាត់នាំយកទៅជួយពួកជំនុំនៅស្រុកយូដានោះផង ។ កំពង់ផែនៅទីក្រុងកេងគ្រា គឺជាកន្លែងដែលពួកអ្នកប្រឆាំងចាំស្នាក់សម្លាប់គាត់ ។

**២០:៤** អ្នកទាំងនោះប្រហែលត្រូវបានជ្រើសរើស ឱ្យទៅជាមួយលោកប៉ុលដើម្បីនាំយកដង្វាយទៅជួយពួកជំនុំនៅស្រុកយូដា (មើលការពន្យល់ ២កថ ៨:២៣)។ ហើយក្នុងចំណោមពួកគេមាន៣នាក់មកពីខេត្តម៉ាសេដូន ២នាក់មកពីខេត្តកាឡាទី និង២នាក់ទៀតមកពីស្រុកអាស៊ី ។ លោកលូកាប្រហែលជាបានមករួមដំណើរជាមួយនឹងពួកគេនៅឯទីក្រុងភីលីព (ខ.៦ មើលការពន្យល់ ១៦:១០)។ *សូប៉ាត្រុស* លោកសូប៉ាត្រុសម្នាក់នេះ និងសូសិប៉ាត្រុសប្រហែលជាមនុស្សតែមួយ (រម ១៦:២១)។ *អើរីស្តាក* "មើលការពន្យល់ ១៩:២៩"។ *សេគុនដុស* ឈ្មោះនេះពុំមានលើកមកនិយាយ នៅកន្លែងណាទៀតទេនៅក្នុងព្រះគម្ពីរ ។ ពាក្យថា "សេគុនដុស" មានន័យថា "ទី២"។ *កៃយុស . . . ពីក្រុងឌើបេ* លោកកៃយុសគឺជាគូកនម្នាក់របស់លោកប៉ុលដែលបានធ្វើដំណើរជាមួយគាត់ ក្នុងដំណើរបេសកកម្មចុងក្រោយបង្អស់ ពីទីក្រុងកូរិនថូស ទៅទីក្រុងយេរូសាឡិម ។ *ធីម៉ូថេ* លោកធីម៉ូថេមានដើមកំណើតនៅទីក្រុងលីស្ត្រា ប៉ុន្តែគាត់មានទំនួលខុសត្រូវលើការងារពួកជំនុំជាច្រើន (១កថ ១៦:១០–១១ ភល ២:១៩–២៣)។ គាត់ត្រូវបានបញ្ជូនឱ្យទៅខេត្តម៉ាសេដូន មុនពេលដែលលោកប៉ុលចាកចេញពីទីក្រុងអេភេសូរ (១៩:២២)។ *ទីឃីកុស* ជាអ្នកជំនួយដ៏ខ្ជាប់ខ្ជួនម្នាក់របស់លោកប៉ុលចំពោះកិច្ចការងារក្នុងពួកជំនុំនៅឯស្រុកអាស៊ី (អភ ៦:២១–២២ កល ៤:៧–៩ ២ធថ ៤:១២ ទត ៣:១២)។ *ទ្រភីម* គាត់គឺជាអ្នកក្រុងអេភេសូរ និងប្រហែលជាសាសន៍ដទៃផង (២១:២៩ ២ធថ ៤:២០)។

**២០:៥** *ក្រុងទ្រអាស* គឺជាកន្លែងជួបគ្នារវាងលោកប៉ុល និងអស់អ្នកដែលធ្វើដំណើរទៅមុនគាត់តាមផ្លូវសមុទ្រ ពីកំពង់ផែនាប៉ូលនៃទីក្រុងភីលីព (១៦:១១)។ លោកប៉ុល និងគូកនគាត់បានស្នាក់នៅក្នុងទីក្រុងភីលីពនោះអស់រយៈពេល១សប្តាហ៍ មុនពេលចេញដំណើរទៅឯក្រុងទ្រអាស ។

**២០:៦** *ចេញពីក្រុងភីលីព* គឺចេញពីកំពង់ផែនាប៉ូលដែលមានចម្ងាយប្រហែល១៦គ.មពីទីក្រុងនេះ ។ *ថ្ងៃបុណ្យនំបុ័ងឥតដំបែ* ក្នុងរយៈពេលនៃថ្ងៃបុណ្យនេះលោកប៉ុលបានស្នាក់នៅទីក្រុងភីលីព ។ ដំបូងឡើយ លោកប៉ុលចង់ឱ្យបានទៅដល់ទីក្រុងយេរូសាឡិមយ៉ាងឆាប់រហ័ស (១៩:២១)។ ប៉ុន្តែពេលនេះគាត់សង្ឃឹមថា នឹងបានទៅដល់ទីក្រុងយេរូសាឡិមនៅថ្ងៃបុណ្យទី៥០វិញ (២០:១៦)។ *៥ថ្ងៃ* ត្រង់ចំណុចនេះចង់បញ្ជាក់ថា ការធ្វើដំណើរពីកំពង់ផែនាប៉ូលទៅទីក្រុងទ្រអាស តាមផ្លូវសមុទ្រត្រូវប្រើរយៈពេល៥ថ្ងៃ ។ ប្រសិនបើធ្វើដំណើរតាមផ្លូវផ្សេងវិញប្រើរយៈពេលអស់២ថ្ងៃ (១៦:១១)។ *៧ថ្ងៃ* គឺជារយៈពេលដែលលោកប៉ុលស្នាក់នៅក្នុងទីក្រុងទ្រអាស ។ គាត់ស្នាក់នៅក្នុងទីក្រុងនេះ ប្រហែលព្រោះតែការពន្យាពេលចេញដំណើររបស់នាវា (ឬសំពៅ) ឬប្រហែលជាគាត់ចង់ជួបពួកសិស្សនៅក្នុងទីនោះ ។

ព្រោះគាត់រៀបនឹងចេញដំណើរទៅនៅថ្ងៃស្អែក ក៏សំដែង
ដរាបដល់ពេលកណ្ដាលអធ្រាត្រ ៨រីឯនៅបន្ទប់ខាងលើ[ក]ជា
កន្លែងដែលគេប្រជុំ នោះមានចង្កៀងជាច្រើន ៩គ្រានោះ
មានក្មេងជំទង់ម្នាក់ ឈ្មោះអើទីកុស វាអង្គុយនៅបង្អួច ក៏
យន់ជាខ្លាំងពេក ក្នុងពេលដែលប៉ុលអធិប្បាយជាយូរទៅទៀត
រួចងោកធ្លាក់ចុះពីជាន់ទី៣ ទៅខាងក្រោម នោះគេលើក
វាឡើងបានស្លាប់ហើយ ១០តែប៉ុលចុះទៅទ្រោបពីលើវា[ខ]
ឱបត្រកង រួចនិយាយថា កុំយំស្រែកអ្វីឡើយ ដ្បិតវាមាន
ជីវិតទេ[គ] ១១កាលបានឡើងទៅលើវិញ ហើយបានកាច់
នំបុ័ង[ឃ]បរិភោគទៅ នោះក៏និយាយគ្នា ជាយូរទៅទៀត
ដរាបដល់ភ្លឺ ទើបគាត់ចេញដំណើរទៅ ១២គេក៏នាំក្មេង
ជំទង់នោះមកវិញទាំងរស់ ហើយគេបានក្សាន្តចិត្តជាខ្លាំង ។

## បណ្ដាំលោកប៉ុលចំពោះពួកចាស់ទុំនៅទីក្រុងអេភេសូរ

១៣ឯយើងរាល់គ្នាក៏ចុះសំពៅជាមុន បើកទៅដល់អាសុស
ចាំទទួលប៉ុលនៅទីនោះ ដ្បិតគាត់បានផ្ដាំដូច្នោះ ព្រោះ
គាត់ចង់ដើរវិញ ១៤កាលគាត់មកដល់យើងនៅត្រង់អាសុស
នោះយើងទទួលគាត់ចុះសំពៅ ទៅឯមីទូលេន ១៥ក៏ចេញ
ពីទីនោះ រួចស្អែកឡើង បានទៅដល់ទន្ទឹមនឹងកោះឃីយ៉ូស
ហើយដល់ថ្ងៃក្រោយទៀត យើងបានដល់ទៅសាម៉ុស រួច
ចូលចតនៅក្រុងទ្រគីលាម លុះថ្ងៃក្រោយទៀតទើបបាន
ដល់ទៅក្រុងមីលេត[ង] ១៦ដ្បិតប៉ុលបានសំរេចនឹងទៅបង្ហួស
ក្រុងអេភេសូរ[ច] ដើម្បីមិនឱ្យខាតពេល នៅស្រុកអាស៊ី[ឆ]
ដោយគាត់ប្រញាប់នឹងទៅឯក្រុងយេរូសាឡិម[ជ] ឱ្យទាន់
ពេលបុណ្យថ្ងៃ៥០ បើសិនជាបាន[ឈ] ។
១៧ប៉ុលក៏ចាត់គេពីមីលេត[ញ] ទៅឯក្រុងអេភេសូរ ដើម្បី
នឹងហៅពួកចាស់ទុំ[ដ] ក្នុងពួកជំនុំនោះមក ១៨លុះមកដល់
ហើយ គាត់និយាយទៅគេថា ឯកិរិយារបស់ខ្ញុំ គ្រប់ពេល
គ្រប់វេលា ដែលនៅជាមួយនឹងអ្នករាល់គ្នា[ឋ] តាំងពីថ្ងៃ
ដែលខ្ញុំចូលទៅស្រុកអាស៊ីមុនដំបូង[ឌ] ១៩គឺដែលខ្ញុំបានបំរើ
ព្រះអម្ចាស់ ដោយចិត្តសុភាពគ្រប់ជំពូក ហើយស្រក់ទឹក
ភ្នែក[ឍ]ជាច្រើន ទាំងត្រូវសេចក្ដីល្បួង ដោយកិច្ចកលរបស់
ពួកសាសន៍យូដា បែបយ៉ាងណា នោះអ្នករាល់គ្នាដឹង
ស្រាប់ហើយ[ណ] ២០ក៏ដឹងថា ខ្ញុំមិនបានខាននឹងប្រាប់សេចក្ដី
អ្វី[ត] ដែលមានប្រយោជន៍ ដល់អ្នករាល់គ្នាដែរ គឺបាន
បង្រៀនដល់អ្នករាល់គ្នា នៅកណ្ដាលជំនុំវិញ ហើយពីផ្ទះ១
ទៅផ្ទះ១ផង ២១ក៏ធ្វើបន្ទាល់អស់ពីចិត្ត ដល់ទាំងពួកសាសន៍

**២០:៨** ក កច ១:១៣ ៩:៣៧
**២០:១០** ខ ១ពវ ១៧:២១ ២ពវ ៤:៣៤ គ មថ ៩:២៣,២៤
**២០:១១** ឃ ខ.៧ មថ ១៤:១៩
**២០:១៥** ង ខ.១៧ ២ធថ ៤:២០
**២០:១៦** ច កច ១៨:១៩ ឆ កច ២:៩ ជ កច ១៩:២១ ឈ កច ២:១
**២០:១៧** ញ ខ.១៥ ដ កច ១១:៣០
**២០:១៨** ឋ កច ១៨:១៩–២១ ១៩:១–៤១ ឌ កច ២:៩
**២០:១៩** ឍ ទដ ៦:៦ ណ ខ.៣
**២០:២០** ត ខ.២៧ ទដ ៤០:១០ យរ ២៦:២ ៤២:៤

**២០:៧** *ថ្ងៃដំបូងក្នុងអាទិត្យនោះ* ថ្ងៃដំបូងក្នុងអាទិត្យ គឺថ្ងៃអាទិត្យ ។ *កាច់នំបុ័ង* ត្រង់ចំណុចនេះគឺសំដៅលើពិធីលៀងព្រះអម្ចាស់ ព្រោះថាពិធីនេះក៏ជាបញ្ញត្តិមួយ (លក ២២:១៩) និងត្រូវបានប្រតិបត្តិជាទៀងទាត់ (មើលការពន្យល់ ២:៤២) ។ *ក៏សំដែងដរាបដល់ពេលកណ្ដាលអធ្រាត្រ* លោកប៉ុលបានអធិប្បាយ ក្នុងយប់នោះប្រហែលជា៦ម៉ោង ។ ធម្មតានៅក្នុងគម្ពីរកិច្ចការ ការអធិប្បាយរបស់លោកប៉ុលពុំប្រើរយៈពេលច្រើនប៉ុន្មានទេ ។

**២០:៩** *អើទីកុស វាអង្គុយនៅបង្អួច* (មើលការពន្យល់ ៦:៩) នៅយប់នោះ អើទីកុសអង្គុយនៅលើបង្អួច ដោយបែរខ្នងទៅខាងក្រៅផ្ទះ ។ កំពុងដែលស្ដាប់លោកប៉ុលអធិប្បាយនោះ ក៏ភ្លេចខ្លួនដេកលក់ ដូច្នោះហើយបានជាវាធ្លាក់ទៅខាងក្រៅផ្ទះទៅដល់ដីតែម្ដង រហូតដល់បាត់បង់ជីវិត ប៉ុន្តែ វាបានរស់វិញដោយអំណាចព្រះចេស្ដានៃព្រះយេស៊ូវគ្រីស្ទ ។

**២០:១០** *ដ្បិតវាមានជីវិតទេ* ការនេះកើតឡើងដូចក្នុងករណីដែលនាងតេប៊ីថា បានរស់ពីស្លាប់វិញដូច្នោះដែរ (៩:៤០) គឺដោយសារអំណាចព្រះចេស្ដារបស់ព្រះអម្ចាស់ ។

**២០:១៣** *អាសុស* ជាទីក្រុងមួយស្ថិតនៅក្នុងស្រុកមីស៊ានៃទ្វីបអាស៊ី ក្រោមការគ្រប់គ្រងរបស់ចក្រភពរ៉ូម៉ាំងនិងមានចម្ងាយ៣២គ.មពីទីក្រុងទ្រអាស ។

**២០:១៤** *មីទូលេន* ជាទីក្រុងសំខាន់មួយនៃកោះ លេបូស (Lesbos) មានកំពង់ផែ២ និងបន្ទាយដ៏រឹងមាំមួយ ។ នៅឆ្នាំ១៤៦២គ.ស ទីក្រុងនេះត្រូវបានគ្រប់គ្រង ដោយរដ្ឋាភិបាលប្រទេសទួរគី (Turkey) ។

**២០:១៥** *កោះឃីយ៉ូស* ជាកោះមួយរបស់ប្រទេសទួរគី ។ គូកនលោកប៉ុលបានស្នាក់នៅលើកោះនេះ ក្នុងយប់ទីពីរនៃដំណើរពួកគេ ទៅឯទីក្រុងយេរូសាឡិម ។ *សាម៉ូស* ជាកោះមួយស្ថិតនៅភាគខាងត្បូង ឆៀងខាងលិចនៃទីក្រុងអេភេសូរ មានឆកសមុទ្រលយទៅជិតទីក្រុងនេះ ។ គូកនរបស់លោកប៉ុលបានចូលចតលើកោះនេះ នៅយប់ទី៣ក្នុងដំណើររបស់ពួកគេ ទៅទីក្រុងយេរូសាឡិម ។ *ក្រុងមីលេត* ជាទីក្រុងមួយស្ថិតនៅចម្ងាយប្រហែល ៥៦គ.ម ភាគខាងត្បូងនៃទីក្រុងអេភេសូរ ។ លោកប៉ុលចង់ទៅសួរសុខទុក្ខពួកជំនុំនៅទីក្រុងអេភេសូរដែរ ព្រោះថា នាវាដែលគាត់ធ្វើដំណើរនោះត្រូវចូលចតនៅកំពង់ផែនៃក្រុងអេភេសូរ ប៉ុន្តែគាត់ពុំមានពេលគ្រប់គ្រាន់ ដូច្នោះក៏ទៅបង្ហួសទីក្រុងនេះតែម្ដង (១៩:២៣–៤១) ។

**២០:១៦** *ឱ្យទាន់ពេលបុណ្យថ្ងៃ៥០* រយៈពេលពីថ្ងៃបុណ្យរំលងរហូតដល់បុណ្យថ្ងៃទី៥០គឺមានចំនួន៥០ថ្ងៃ ។ ហើយក្នុង៥០ថ្ងៃនោះ លោកប៉ុលបានចំណាយពេលក្នុងការធ្វើដំណើររបស់គាត់អស់១៦ថ្ងៃហើយ គឺ ១២ថ្ងៃក្នុង "ខ៦" និង៤ថ្ងៃ ក្នុង "ខ១៣–១៥" ដូច្នេះ គាត់នៅមានពេល ៣៤ថ្ងៃទៀត ដែលត្រូវធ្វើដំណើរឱ្យដល់ ទីក្រុងយេរូសាឡិម ដើម្បីឱ្យបានទាន់ពេលបុណ្យថ្ងៃទី៥០ តាមគម្រោងដែលគាត់បានរៀបចំ ។ *បុណ្យថ្ងៃ៥០* "មើលការពន្យល់ ២:១" ។

**២០:១៧** *ពួកចាស់ទុំក្នុងពួកជំនុំ* ការងារដ៏សំខាន់របស់លោកប៉ុលគឺបណ្ដុះឱ្យមានអ្នកដឹកនាំ ឬពួកចាស់ទុំក្នុងពួកជំនុំ (១១:៣០ ១៤:២៣ ២០:២៨) ។ ប៉ុន្មានឆ្នាំក្រោយមកគាត់បានសរសេរអំពីគុណសម្បត្តិ ដែលអ្នកដឹកនាំត្រូវមាន (១ធថ ៣ ទត ១) ។

**២០:១៩** *ហើយស្រក់ទឹកភ្នែកជាច្រើន* ត្រង់ចំណុចនេះបង្ហាញថា លោកប៉ុលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដើម្បីបំពេញកិច្ចការថ្វាយព្រះអម្ចាស់នៅឯទីក្រុងអេភេសូរ ហើយមានពេលខ្លះគាត់ថែមទាំងស្រក់ទឹកភ្នែកផង ។ ទាំងនេះគឺជាគំរូសម្រាប់ពួកជំនុំសព្វថ្ងៃក្នុងការបម្រើព្រះ និងការ

យូដា[ថ] នឹងពួកសាសន៍ក្រេកផង គឺពីការប្រែចិត្ត[ទ]ទៅឯព្រះ
ហើយពីសេចក្តីជំនឿជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ នៃ
យើងរាល់គ្នា[ធ]។
២២ឥឡូវនេះ មើល ខ្ញុំមានសេចក្តីបណ្តាលក្នុងចិត្ត ចង់ទៅ
ឯក្រុងយេរូសាឡិម[ន] ឥតដឹងការអ្វីដែលនឹងកើតដល់ខ្ញុំនៅ
ទីនោះទេ ២៣ដឹងតែប៉ុណ្ណោះថា ព្រះវិញ្ញាណបរិសុទ្ធធ្វើ
បន្ទាល់ដល់ខ្ញុំ[ប]នៅគ្រប់ទីក្រុងថា មានចំណង នឹងសេចក្តី
វេទនានៅរង់ចាំខ្ញុំ[ផ] ២៤ប៉ុន្តែ នោះមិនអំពល់អ្វីដល់ខ្ញុំទេ[ព]
ខ្ញុំក៏មិនរាប់ជីវិតនេះ ទុកជារបស់វិសេសដល់ខ្ញុំដែរ ឱ្យ
តែខ្ញុំបានបង្ហើយ ការរត់ប្រណាំង[ភ]របស់ខ្ញុំ ដោយអំណរចុះ
ព្រមទាំងការងារ[ម]ដែលខ្ញុំបានទទួលអំពីព្រះអម្ចាស់យេស៊ូវ
គឺឱ្យខ្ញុំ បានធ្វើបន្ទាល់សព្វគ្រប់ ពីដំណឹងល្អនៃព្រះគុណ
វិញ[យ] ២៥ឥឡូវនេះ មើល ខ្ញុំដឹងហើយថា ក្នុងពួកអ្នករាល់គ្នា
ដែលខ្ញុំបានដើរទៅមកជាមួយ ដោយភប់ប្រសព្វគ្នា ទាំង
ប្រកាសប្រាប់ ពីនគរនៃព្រះ[ល] នោះគ្មានអ្នកណាមួយនឹង
ឃើញមុខខ្ញុំទៀតឡើយ[វ] ២៦ដូច្នេះ ខ្ញុំធ្វើបន្ទាល់ដល់អ្នក
រាល់គ្នានៅថ្ងៃនេះថា ខ្លួនខ្ញុំបរិសុទ្ធ ពីឈាមអ្នករាល់គ្នា
ទាំងអស់[ស] ២៧ព្រោះខ្ញុំមិនបានខាន នឹងប្រាប់អ្នករាល់គ្នា
ពីគ្រប់ទាំងគំនិតរបស់ព្រះទេ[ហ] ២៨ដូច្នេះ ចូរអ្នករាល់គ្នា
ប្រយ័ត្នខ្លួន ហើយខំថែរក្សាហ្វូងសិស្ស[ឡ] ដែលព្រះវិញ្ញាណ
បរិសុទ្ធ បានតាំងអ្នករាល់គ្នា ឱ្យធ្វើជាអ្នកគង្វាលដល់គេ[អ]
ដើម្បីឱ្យបានឃ្វាលពួកជំនុំរបស់ព្រះអម្ចាស់[ក] ដែលទ្រង់បាន
ទិញ[ខ] ដោយព្រះលោហិត[គ]ព្រះអង្គទ្រង់ចុះ ២៩ដ្បិតខ្ញុំដឹងថា
ក្រោយដែលខ្ញុំទៅបាត់ នោះនឹងមានឆ្កែព្រៃដ៏សាហាវ[ឃ]
ដែលមិនចេះប្រណីដល់ហ្វូង វានឹងចូលមកក្នុងពួកអ្នក
រាល់គ្នា[ង] ៣០ហើយក្នុងចំណោមអ្នករាល់គ្នា ក៏នឹងកើត
មានមនុស្ស ដែលនឹងអធិប្បាយសេចក្តីទំនាស់ខុសដែរ
ដើម្បីនឹងទាញនាំពួកសិស្ស[ច]ទៅតាមគេវិញ ៣១ដូច្នេះ
ឱ្យចាំយាមចុះ ចូរនឹកចាំថា ក្នុងរវាង៣ឆ្នាំ[ឆ] ខ្ញុំចេះ
តែប្រដៅទូន្មានដល់អ្នករាល់គ្នានិមួយៗ ដោយទឹកភ្នែក
ទាំងយប់ទាំងថ្ងៃ ឥតឈប់ឈរឡើយ[ជ] ៣២ឥឡូវនេះ
ខ្ញុំផ្ញើអ្នករាល់គ្នាទុកនឹងព្រះ[ឈ] ហើយនឹងព្រះបន្ទូលនៃព្រះ
គុណទ្រង់ ដែលអាចនឹងស្អាងចិត្ត ហើយនិងឱ្យអ្នករាល់គ្នា
មានកេរ្តិ៍អាករ[ញ]នៅក្នុងពួកនៃអស់អ្នកដែលបានញែក
ជាបរិសុទ្ធ[ដ] ៣៣ខ្ញុំមិនដែលលោភចង់បានប្រាក់ មាស
ឬសំលៀកបំពាក់របស់អ្នកណាឡើយ[ឋ] ៣៤អ្នករាល់គ្នា
ដឹងហើយថា ដៃខ្ញុំនេះបានផ្គត់ផ្គង់គ្រប់របស់ ដែលខ្ញុំត្រូវ
ការ ព្រមទាំងពួកអ្នកដែលនៅជាមួយផង[ឌ] ៣៥ខ្ញុំបាន
បង្ហាញអ្នករាល់គ្នាដោយគ្រប់ការទាំងអស់ថា គួរឱ្យខំធ្វើ

**២០:២១** ថ កច ១៨:៥ ទ កច ២:៣៨ ធ កច ២៤:២៤ ២៦:១៨ អភ ១:១៥ កល ២:៥ ភម ៥
**២០:២២** ន ខ.១៦
**២០:២៣** ប កច ៨:២៩ ២១:៤ ផ កច ៩:១៦
**២០:២៤** ព កច ២១:១៣ ភ ២ធថ ៤:៧ ម ២កថ ៤:១ យ កទ ១:១ ទត ១:៣ រ កច ១១:២៣
**២០:២៥** ល មថ ៤:២៣ វ ខ.៣៨
**២០:២៦** ស អគ ៣:១៧–១៩ កច ១៨:៦
**២០:២៧** ហ ខ.២០
**២០:២៨** ឡ ខ.២៩ យហ ២១:១៦ អ ១ធថ ៣:១ ក ១កថ ១០:៣២ ខ ១កថ ៦:២០ គ រម ៣:២៥
**២០:២៩** ឃ អគ ៣៤:៥ មថ ៧:១៥ ង ខ.២៨

**២០:៣០** ច កច ១១:២៦ **២០:៣១** ឆ កច ១៩:១០ ជ ខ.១៩ **២០:៣២** ឈ កច ១៤:២៣ ញ អភ ១:១៤ មថ ២៥:៣៤ កល ១:១២ ៣:២៤ ហព ៩:១៥ ១ពត ១:៤ ដ កច ២៦:១៨ **២០:៣៣** ឋ ១សយ ១២:៣ ១កថ ៩:១២ ២កថ ២:១៧ ៧:២ ១១:៩ ២:១៤–១៧ ១ថន ២:៥ **២០:៣៤** ឌ កច ១៨:៣

---

បម្រើគ្នាទៅវិញទៅមក ។

**២០:២២-២៣** *មានសេចក្តីបណ្តាលក្នុងចិត្ត* ការដែលលោកប៉ុលធ្វើដំណើរទៅទីក្រុងយេរូសាឡិម គឺពុំតាមបំណងចិត្តខ្លួនទេ ប៉ុន្តែ ធ្វើតាមព្រះហឫទ័យរបស់ព្រះវិញ្ញាណនៃព្រះអម្ចាស់វិញ (២១:៤,១១,១២)។

**២០:២៤** *បានបង្ហើយការរត់ប្រណាំង* "មើលការពន្យល់ ២ធថ ៤:៧"។

**២០:២៥** *នោះគ្មានអ្នកណាមួយនឹងឃើញមុខខ្ញុំទៀតឡើយ* នៅពេលដែលលោកប៉ុលនិយាយឃ្លានេះ គាត់ចង់បញ្ជាក់ប្រាប់ពួកគេថា ទោះបីជាគាត់បានរួចផុតពីទុក្ខវេទនាដែលនឹងត្រូវទទួលនៅឯទីក្រុងយេរូសាឡិមនោះក៏ដោយ ក៏គាត់មិនមានគម្រោងត្រឡប់មកទីក្រុងអេភេសូរវិញដែរគឺគាត់មានគម្រោងទៅឯទីក្រុងរ៉ូមវិញ (កច ១៩:២១ រម ១៥:២៣,២៤,២៨)។ *នគរនៃព្រះ* "មើលការពន្យល់ មថ ៣:២ លក ៤:៤៣"។

**២០:២៦–២៧** ត្រង់ចំណុចនេះ លោកប៉ុលប្រាប់យ៉ាងច្បាស់អំពីទំនួលខុសត្រូវរបស់ពួកគេបន្ទាប់ពីគាត់បានចាកចេញទៅ ។

**២០:២៨** *អ្នកគង្វាល* ពាក្យថា "អ្នកគង្វាល" ក្នុងព្រះគម្ពីរសញ្ញាថ្មី មានន័យដូចគ្នានឹងពាក្យថា "អ្នកដឹកនាំ" ឬ "ពួកចាស់ទុំ"។ មុននឹងអាចថែរក្សាហ្វូងសិស្សរបស់ខ្លួនបាន នោះពួកគេត្រូវតែបានរឹងមាំជាមុនសិន ព្រោះថាសាតាំងតែងមកចង់បំផ្លាញអ្នកដឹកនាំច្រើនជាងអ្នកដទៃទៀត ។ *ព្រះលោហិតព្រះអង្គទ្រង់* សំដៅលើព្រះលោហិតរបស់ព្រះយេស៊ូវ ដែលត្រូវបានបង្ហូរ ដើម្បីសង្គ្រោះមនុស្សនៅលើពិភពលោកនេះ ឱ្យបានរួចផុតពីអំណាចនៃសេចក្តីស្លាប់ ។

**២០:២៩** *ឆ្កែព្រៃដ៏សាហាវ* "មើលការពន្យល់ លក ១០:៣"។

**២០:៣០** លោកប៉ុលបានទូន្មានដល់ពួកជំនុំ ជាពិសេសអ្នកដឹកនាំ ឬពួកចាស់ទុំឱ្យប្រុងប្រយ័ត្នជានិច្ច ព្រោះថានឹងមានគ្រូក្លែងក្លាយ មកបង្រៀនសេចក្តីដែលនាំឱ្យវង្វេង (១ធថ ១:១៩–២០ ២ធថ ១៦–១៨ ៣យហ ៩–១០)។

**២០:៣១** *ក្នុងរវាង៣ឆ្នាំ* "មើលការពន្យល់ ១៩:១០"។

**២០:៣២** *កេរ្តិ៍អាករ* "មើលការពន្យល់ ១ពត ១:៤"។ *បានញែកជាបរិសុទ្ធ* "មើលការពន្យល់ ១កថ ១:២"។ *ខ្ញុំផ្ញើអ្នករាល់គ្នាទុកនឹងព្រះ ហើយនិងព្រះបន្ទូលនៃព្រះគុណទ្រង់* លោកប៉ុលគិតថាគាត់មិនបានមកជួបពួកគេទៀតទេ គឺមានតែព្រះបន្ទូលនៃព្រះអម្ចាស់ប៉ុណ្ណោះ ដែលនៅជាមួយនឹងពួកគេជារៀងរហូតបាន ។

**២០:៣៤** *ដៃខ្ញុំនេះបានផ្គត់ផ្គង់ គ្រប់របស់ដែលខ្ញុំត្រូវការ* នេះបញ្ជាក់ថាលោកប៉ុលបានធ្វើការយ៉ាងនឿយហត់ ដើម្បីផ្គត់ផ្គង់រាល់សេចក្តីត្រូវការរបស់គាត់ និង អ្នកដែលនៅមួយដូចជានៅទីក្រុងថែស្សាឡូនីច (១ថន ២:៩) និងទីក្រុងកូរិនថូស (កច ១៨:៣) ជាដើម ។

**២០:៣៥** *ហើយនិងនឹកចាំពីព្រះបន្ទូលនៃព្រះអម្ចាស់យេស៊ូវ* គឺចង់បញ្ជាក់ប្រាប់ពួកជំនុំទាំងអស់កុំឱ្យភ្លេចពីព្រះបន្ទូលរបស់ព្រះអម្ចាស់ និងប្រព្រឹត្តតាម

ការដូច្នោះ ដើម្បីឱ្យបានជួយ ដល់ពួកអ្នកខ្សោយ ហើយ
នឹងនឹកចាំពីព្រះបន្ទូលនៃព្រះអម្ចាស់យេស៊ូវ ដែលទ្រង់
មានបន្ទូលថា ដែលឱ្យ នោះបានពរជាជាងទទួល ៣៦លុះ
បាននិយាយសេចក្តីទាំងនោះរួចហើយ នោះប៉ុលក៏លុត
ជង្គង់អធិស្ឋានជាមួយនឹងគេទាំងអស់គ្នា[ឍ] ៣៧ហើយគ្រប់
គ្នាក៏យំជាច្រើន រួចគេឱបគាត់ថើបដោយថ្មិតថ្មម[ណ] ៣៨ទាំង
មានសេចក្តីព្រួយពីពាក្យនេះជាដើម គឺដែលគាត់ថា គេ
មិនឃើញមុខគាត់ទៀតឡើយ[ត] រួចក៏ជូនគាត់ទៅដល់
សំពៅ[ថ]។

## ដំណើរឆ្ពោះទៅកាន់ទីក្រុងយេរូសាឡិម

**២១** ១កាលយើង[ទ] បានឃ្លាតចេញផុតពីគេទៅហើយ
នោះក៏បើកក្តោង ដំរង់ទៅឯកោះកូស ហើយថ្ងៃក្រោយ
បានដល់កោះរ៉ូដូស រួចពីនោះទៅដល់ក្រុងប៉ាតារ៉ា ២កាល
ឃើញសំពៅ១មានដំណើរទៅឯស្រុកភេនីស[ធ] នោះយើង
ក៏ចុះតាមសំពៅនោះចេញទៅទៀត ៣ដល់បានឃើញកោះ
គីប្រុសហើយ នោះបានបើកបង្ហួសទៅខាងឆ្វេង រួចទៅ
ដល់ស្រុកស៊ីរី[ន] ចូលចតនៅត្រង់ក្រុងទីរ៉ុស ដ្បិតសំពៅត្រូវ
រើទំនិញនៅទីនោះ ៤លុះកាលរកឃើញពួកសិស្ស[ប]ហើយ
នោះ ក៏ស្នាក់នៅទីនោះ៧ថ្ងៃ ហើយគេឃាត់ប៉ុលដោយ
នូវព្រះវិញ្ញាណ[ផ] មិនឱ្យគាត់ឡើងទៅឯក្រុងយេរូសាឡិម
ឡើយ ៥ប៉ុន្តែ ដល់ផុតថ្ងៃទាំងនោះទៅ យើងក៏ចេញធ្វើ
ដំណើរដើរទៀត ឯពួកគេទាំងអស់ ព្រមទាំងប្រពន្ធកូន
បានជូនយើងខ្ញុំ ទៅខាងក្រៅទីក្រុង រួចយើងលុតជង្គង់
អធិស្ឋាននៅមាត់ច្រាំង[ព] ៦កាលបានលាគ្នារួចជាស្រេច
នោះយើងក៏ចុះសំពៅទៅ ហើយពួកគេត្រឡប់ទៅផ្ទះវិញ។
៧លុះសំរេចដំណើរពីក្រុងទីរ៉ុស[ភ]ទៅដល់ផ្តូលេមេហើយ
នោះក៏ទៅជំរាបសួរដល់ពួកជំនុំ[ម] ហើយបានសំចតនៅជា
មួយនឹងគេអស់១ថ្ងៃ ៨ដល់ស្អែកឡើង ប៉ុល និងពួកគាត់
បានចេញទៅឯសេសារា[យ] ក៏ចូលទៅក្នុងផ្ទះរបស់ភីលីព[រ]
ជាអ្នកផ្សាយដំណឹងល្អម្នាក់[ល]ក្នុងពួកទាំង៧នាក់នោះ ហើយ
ស្នាក់នៅនឹងគាត់ ៩អ្នកនោះមានកូនក្រមុំ៤នាក់ដែលចេះ
ទាយទំនាយ[វ] ១០លុះយើងបាននៅទីនោះជាយូរថ្ងៃ នោះ
មានហោរាម្នាក់ ឈ្មោះអ័ក្កាបុស[ស] គាត់ចុះពីស្រុកយូដា
មក ១១លុះមកដល់យើងហើយ គាត់ក៏យកខ្សែក្រវាត់របស់
ប៉ុលមក ចងជើងចងដៃខ្លួន ប្រាប់ថា ព្រះវិញ្ញាណបរិសុទ្ធ
មានបន្ទូល[ហ]ដូច្នេះថា ពួកសាសន៍យូដា នឹងចាប់ចង[ឡ]
ម្ចាស់ខ្សែក្រវាត់នេះបែបយ៉ាងនេះ នៅក្រុងយេរូសាឡិម
ហើយនិងបញ្ជូនទៅក្នុងកណ្តាប់ដៃនៃពួកសាសន៍ដទៃ[អ]

**២០:៣៦** ឍ លក ២២:៤១ កច ៩:៤០ ២១:៥
**២០:៣៧** ណ លក ១៥:២០
**២០:៣៨** ត ខ.២៥ ថ កច ២១:៥
**២១:១** ទ កច ១៦:១០
**២១:២** ធ កច ១១:១៩
**២១:៣** ន លក ២:២
**២១:៤** ប កច ១១:២៦ ផ ខ.១១ កច ២០:២៣
**២១:៥** ព លក ២២:៤១ កច ៩:៤០ ២០:៣៦
**២១:៧** ភ កច ១២:២០ ម កច ១:១៦
**២១:៨** យ កច ៨:៤០ រ កច ៦:៥ ៨:៥–៤០ ល អភ ៤:១១ ២ធថ ៤:៥
**២១:៩** វ នក ១៥:២០ ពច ៤:៤ នហ ៦:១៤ លក ២:៣៦ កច ២:១៧ ១កថ ១១:៥ **២១:១០** ស កច ១១:២៨
**២១:១១** ហ កច ៨:២៩ ឡ ខ.៣៣ អ ១ពវ ២២:១១ អស ២០:២–៤ យរ ១៣:១–១១ មថ ២០:១៩

ឱ្យបានខ្ជាប់ខ្លួន ។

**២០:៣៦–៣៨** បន្ទាប់ពីបានអធិស្ឋានរួចហើយ លោកប៉ុលក៏ចេញដំណើរទៅឯទីក្រុងយេរូសាឡិម ។ *គេមិនឃើញមុខគាត់ទៀតឡើយ* "មើលការពន្យល់ ខ.២៥"។

**២១:១** *កោះកូស* កោះនេះស្ថិតនៅក្នុងសមុទ្រអេជិន (Aegean Sea សមុទ្រនេះស្ថិតនៅភាគខាងត្បូងឆៀងខាងកើតនៃទ្វីបអឺរ៉ុប ចន្លោះប្រទេសក្រិក និងប្រទេសទួរគី)។ *កោះរ៉ូដូស* កោះនេះមានបណ្តោយប្រហែល៧៤គ.ម និងទទឹងប្រហែល ២៩គ.ម ស្ថិតនៅចន្លោះកោះកូស និងទីក្រុងប៉ាតារ៉ា ។ នៅលើកោះនេះមានរូប ចម្លាក់ធំល្បីល្បាញមួយ មានកម្ពស់ ៣២,៣ ម៉ែត្រ ត្រូវបានគេសង់ឡើងនៅឆ្នាំទី ២៩០ មុនគ.ស ហើយរលំទៅវិញនៅឆ្នាំទី ២២៤ មុនគ.សដោយសាររញ្ជួយដី ។ *ក្រុងប៉ាតារ៉ា* ជាទីក្រុងមួយស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រ ភាគខាងជើងនៃស្រុកលូគា ។

**២១:៣** *កោះគីប្រុស* "មើលការពន្យល់ ១៣:៤"។ *ក្រុងទីរ៉ុស* ជាទីក្រុងមួយនៃស្រុកភេនីស ។ លោកប៉ុលប្រហែលជាធ្លាប់បានធ្វើដំណើរមកកាន់តំបន់នេះម្តងរួចទៅហើយ (១៥:៣ មក ៧:២៤)។

**២១:៤** *៧ថ្ងៃ* ចាប់តាំងពីថ្ងៃដែលលោកប៉ុលចេញដំណើរពីទីក្រុងភីលីពមកដល់ពេលនេះគឺមានរយៈពេល៣៦ថ្ងៃហើយ ដូច្នេះនៅសល់ពេលតែ១៤ថ្ងៃទៀតទេ ដើម្បីឱ្យទាន់ថ្ងៃបុណ្យទី៥០ នៅឯទីក្រុងយេរូសាឡិមតាមគម្រោងដែលគាត់បានរៀបចំទុកមុនពេលចេញដំណើរ ។ *ហើយគេឃាត់ប៉ុល* ព្រះវិញ្ញាណបរិសុទ្ធបានបើកសំដែង ឱ្យលោកប៉ុលដឹងយ៉ាងច្បាស់ថា មានទុក្ខវេទនានៅរង់ចាំគាត់នៅឯទីក្រុងយេរូសាឡិម (២០:២៣)។ ដូច្នោះហើយបានជាពួកជំនុំនាំគ្នាឃាត់ គាត់មិនឱ្យទៅឯទីក្រុងយេរូសាឡិមនោះទេ ។ ប៉ុន្តែគាត់មិនអាចធ្វើតាមគំនិតរបស់ពួកគេបានឡើយ គឺធ្វើតាមព្រះហឫទ័យរបស់ព្រះវិញ្ញាណបរិសុទ្ធវិញ (មើលការពន្យល់ ២០:២២)។

**២១:៧** *ផ្តូលេមេ* ជាទីក្រុងមួយដែលស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រនៃស្រុកភេនីស ។ ចម្ងាយពីទីក្រុងនេះទៅទីក្រុងសេសារា គឺ៥៦គ.ម ។

**២១:៨** *សេសារា* ជាទីក្រុងរបស់សាសន៍ដទៃ និងជារដ្ឋធានីនៃចក្រភពរ៉ូម៉ាំងនៅស្រុកយូដា (មើលពន្យល់ ១០:១)។ *ភីលីពជាអ្នកផ្សាយដំណឹងល្អ* លោកភីលីពប្រហែលជាបានផ្សាយដំណឹងល្អ នៅក្នុងទីក្រុងសេសារាអស់រយៈពេលជិត២៥ឆ្នាំ (អភ ៤:១១ ២ធថ ៤:៥ មើលការពន្យល់ ៨:៤០)។

**២១:៩** *អ្នកនោះមានកូនក្រមុំ៤នាក់ ដែលចេះទាយទំនាយ* "១កថ ៧:៣៤ ១១:៥ ១២:៨–១០ លក ២:៣៦ នក ១៥:២០ ពច ៤:៤ ២ពវ ២២:១៤ នហ ៦:១៤"។

**២១:១០** *ហោរាម្នាក់ ឈ្មោះ អ័ក្កាបុស* គាត់គឺជាហោរាម្នាក់ដែលមានគេស្គាល់ច្រើនគឺដូចគ្នានឹងលោកភីលីពជាអ្នកផ្សាយដំណឹងល្អនោះដែរ (ខ.៨)។ ហើយគាត់ក៏ជាហោរាម្នាក់នៅទីក្រុងអាន់ទីយ៉ូក ដែលបានទាយទំនាយអំពីគ្រោះទុរ្ភិក្សដែលត្រូវកើតឡើង នៅឯទីក្រុងយេរូសាឡិម កាលពី១៥ឆ្នាំមុន (១១:២៧–២៩)។

[១២]កាលឮដូច្នោះ នោះយើង និងពួកអ្នកនៅទីនោះក៏
អង្វរប៉ុល មិនឱ្យឡើងទៅឯក្រុងយេរូសាឡិមឡើយ [១៣]តែ
គាត់ឆ្លើយថា ហេតុអ្វីបានជាយំ ហើយធ្វើឱ្យខ្ញុំពិបាកចិត្ត
យ៉ាងដូច្នេះ ពីព្រោះខ្ញុំព្រមស្រេចហើយ នឹងឱ្យគេចាប់
ចងខ្ញុំចុះ មិនតែប៉ុណ្ណោះសោត ថែមទាំងសុខចិត្តស្លាប់ផង[ក]
នៅក្នុងក្រុងយេរូសាឡិមទៀត គឺដោយយល់ដល់ព្រះនាម
ព្រះអម្ចាស់យេស៊ូវ[ខ] [១៤]នោះយើងក៏ឈប់និយាយ[គ] ដោយ
ថា សូមតាមព្រះហឫទ័យព្រះអម្ចាស់ចុះ[ឃ] ពីព្រោះគាត់
មិនយល់ព្រមតាមយើងទេ ។
[១៥]លុះផុតថ្ងៃទាំងនោះមក កាលយើងបានរៀបអីវ៉ាន់
ស្រេចហើយ នោះក៏ឡើងទៅឯក្រុងយេរូសាឡិម[ង] [១៦]ក៏
មានសិស្សខ្លះពីសេសារា[ច] ទៅជាមួយនឹងយើងដែរ បាន
នាំទាំងមនុស្សម្នាក់ ឈ្មោះ ម្ន៉ាសុន ជាសិស្សចាស់ពីកោះ
គីប្រុស[ឆ] ដែលយើងរាល់គ្នាត្រូវស្នាក់នៅក្នុងផ្ទះគាត់ទៅ
ផង ។

## ដំណើររបស់លោកប៉ុលមកដល់ទីក្រុងយេរូសាឡិម

[១៧]គ្រាដល់ក្រុងយេរូសាឡិមហើយ នោះពួកជំនុំ[ជ]ក៏ទទួល
យើងដោយអំណរ[ឈ] [១៨]ថ្ងៃស្អែកឡើង ប៉ុលក៏ចូលទៅសួរ
យ៉ាកុប[ញ] ជាមួយនឹងយើង ក្នុងកាលដែលពួកចាស់ទុំ[ដ]ទាំង
អស់ប្រជុំគ្នានៅទីនោះ [១៩]កាលគាត់បានជំរាបសួរដល់គេ
រួចហើយ នោះគាត់ថ្លែងប្រាប់ ពីអស់ទាំងការនិមួយៗ
ដែលព្រះទ្រង់បានធ្វើ ក្នុងពួកសាសន៍ដទៃ[ឋ] ដោយសារ
គាត់[ឌ] ។
[២០]គេឮដូច្នោះ ក៏សរសើរដំកើងដល់ព្រះ រួចនិយាយទៅ
ប៉ុលថា បងអើយ បងដឹងថា មានសាសន៍យូដាប៉ុន្មានម៉ឺន
បានជឿ ហើយគេសុទ្ធតែមានសេចក្តីឧស្សាហ៍ខ្មីឃ្មាត[ឍ]
កាន់តាមក្រិត្យវិន័យ[ណ]ទាំងអស់គ្នា [២១]ក៏បានឮនិយាយពីបង
ថា បងបង្រៀនដល់សាសន៍យូដាទាំងអស់ ដែលនៅជាមួយ
នឹងសាសន៍ដទៃ ឱ្យគេលះចោលលោកម៉ូសេ[ត] ចេញ ព្រម
ទាំងហាមប្រាមគេ កុំឱ្យកាត់ស្បែកកូន[ថ] ឬប្រតិបត្តិតាម
ទំលាប់ពីបុរាណផង[ទ] [២២]ដូច្នេះ តើដូចម្តេច មុខជានឹង
មានគេប្រជុំគ្នាទាំងហ្វូងជាមិនខាន ដ្បិតគេនឹងឮថា បង
មកដល់ហើយ [២៣]ដូច្នេះ ចូរបងធ្វើតាមពាក្យយើងវិញ
ដ្បិតមានមនុស្ស៤នាក់ក្នុងពួកយើង នៅជាប់ក្នុងបំណន់នៅ
ឡើយ[ធ] [២៤]ចូរបងនាំយកគេ ទៅលាបំណន់[ន] ជាមួយគ្នា
ហើយចេញសោហ៊ុយឱ្យគេផង ដើម្បីឱ្យគេបានកោរសក់[ប]
ចេញ នោះមនុស្សទាំងអស់នឹងដឹងថា សេចក្តីដែលគេ
ឮនិយាយពីបងនោះមិនពិតទេ គឺខ្លួនបងតែងប្រព្រឹត្ត
ទៀងត្រង់ ហើយកាន់តាមក្រិតវិន័យដែរ [២៥]ឯពួកសាសន៍
ដទៃដែលជឿ នោះយើងបានផ្ញើសំបុត្រទៅហើយ ដោយ
សំរេចថា មិនចាំបាច់ឱ្យគេកាន់តាមសេចក្តីទាំងនោះទេ

**២១:១៣** ក កច ២០:២៤ ខ យហ ១៥:២១ កច ៩:១៦ **២១:១៤** គ នរ ១:១៨ ឃ មថ ២៦:៣៩ **២១:១៥** ង កច ១៩:២១ **២១:១៦** ច កច ៨:៤០ ឆ ខ.៣,៤ **២១:១៧** ជ កច ៩:៣០ ឈ កច ១៥:៤ **២១:១៨** ញ កច ១៥:១៣ ដ កច ១១:៣០ **២១:១៩** ឋ កច ១៤:២៧ ១៥:៤,១២ ឌ កច ១:១៧ **២១:២០** ឍ កច ២២:៣ រម ១០:២ កទ ១:១៤ ភល ៣:៦ ណ កច ១៥:១,៥ **២១:២១** ត ខ.២៨ ថ កច ១៥:១៩–២១ ១កថ ៧:១៨,១៩ ទ កច ៦:១៤ **២១:២៣** ធ ជន ៦:២,៥,១៨ កច ១៨:១៨ **២១:២៤** ន ខ.២៦ កច ២៤:១៨ ប កច ១៨:១៨

**២១:១២** *យើង នឹងពួកអ្នកនៅទីនោះ* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា លោកលូកា ដែលជាអ្នកនិពន្ធកណ្ឌព្រះគម្ពីរកិច្ចការ គាត់មានវត្តមានជាមួយនឹងលោកប៉ុល ថែមទាំងចូលរួមជាមួយពួកជំនុំនៅទីក្រុងសេសារានោះ ក្នុងការឃាត់គាត់ (លោកប៉ុល) មិនឱ្យទៅឯទីក្រុងយេរូសាឡិមទៀតផង ។

**២១:១៣** *ថែមទាំងសុខចិត្តស្លាប់ផង* "មើលការពន្យល់ ភល ១:២១"។

**២១:១៤** *សូមតាមព្រះហឫទ័យព្រះអម្ចាស់ចុះ* ក្រោយដែលពួកគេបានយល់ច្បាស់ថា ការដែលលោកប៉ុលត្រូវតែទៅឯទីក្រុងយេរូសាឡិមនោះ គឺជាគម្រោងការ និងជាបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់នោះ ពួកគេក៏ឈប់ឃាត់ដំណើរគាត់ទៀតទៅ ។

**២១:១៦** *ម្ន៉ាសុន* ម្ន៉ាសុនម្នាក់នេះបានទទួលលោកប៉ុល និងគូកនដែលធ្វើដំណើរជាមួយដោយអំណរ ដូច្នេះអាចសន្និដ្ឋានថាគាត់ពិតជាអ្នកជឿដល់ព្រះអម្ចាស់និងជាសិស្សម្នាក់ដែរ ។

**២១:១៧** *ដល់ក្រុងយេរូសាឡិមហើយ* លោកប៉ុល និងគូកនបានមកដល់ទីក្រុងយេរូសាឡិមប្រហែលជា១ ឬ២ថ្ងៃ មុនថ្ងៃបុណ្យទី៥០ ។ *ពួកជំនុំក៏ទទួលយើងដោយអំណរ* ពួកជំនុំនៅឯទីក្រុងយេរូសាឡិមបានទទួលលោកប៉ុលនិងគូកនដោយអំណរ ហើយបានសរសើរដល់ព្រះអម្ចាស់ ចំពោះជង្វាយដែលពួកជំនុំសាសន៍ដទៃបានផ្ញើទៅជួយពួកគេ ។

**២១:១៨** *យ៉ាកុប* គាត់គឺជាប្អូនរបស់ព្រះអម្ចាស់យេស៊ូវ និងជាអ្នកនិពន្ធកណ្ឌគម្ពីរយ៉ាកុប ហើយជាអ្នកដឹកនាំពួកជំនុំនៅទីក្រុងយេរូសាឡិម (កទ ១:១៩ មើលការពន្យល់ កទ ២:៩)។ លោកយ៉ាកុបត្រូវបានគេហៅថាសាវកម្នាក់ដែរ ប៉ុន្តែគាត់មិនមែននៅក្នុងចំណោមពួកសាវកទាំង១២នាក់នោះទេ ។

**២១:២៣** *នៅជាប់ក្នុងបំណន់នៅឡើយ* ប្រហែលជាពួកគេនៅជាប់ក្នុងបំណន់ដូចដែលមានចែងនៅក្នុង "ជន ៦:២–១២"។

**២១:២៤** *លាបំណន់* ការនេះពេលខ្លះមានជាប់ទាក់ទងនឹងការថ្វាយយញ្ញបូជាទៀតផង ។ ទោះជាយ៉ាងណាក៏ដោយ ការលាបំណន់ដែលធ្វើឡើងដោយពួកជំនុំនៅទីក្រុងយេរូសាឡិមនោះ គ្មានអ្នកណាបង្គាប់ទេ ។ *ចេញសោហ៊ុយឱ្យគេផង* លោកប៉ុលមានទំនួលខុសត្រូវចំពោះអ្នកទាំងនោះរួមមាន (១).ចេញថ្លៃរាល់ការចំណាយទៅលើយញ្ញបូជាទាំងអស់ (មានសត្វព្រាប៨ ចៀម៤ ជន ៦:៩–១២) (២).ត្រូវទៅជួបពួកសង្ឃ ដើម្បីបញ្ជាក់ពីពេលវេលា ដែលត្រូវធ្វើការលាបំណន់នោះ (ខ.២៦)។ *តែងប្រព្រឹត្តទៀងត្រង់ហើយកាន់តាមក្រិត្យវិន័យដែរ* លោកប៉ុលទើបនឹងបានលាបំណន់ថ្មីៗ (មើលពន្យល់ ១៨:១៨) គឺព្រោះតែការងារក្នុងចំណោមពួកសាសន៍យូដា (១កថ ៩:២០–២១)។ រីឯលោកធីម៉ូថេវិញ ក៏ត្រូវបានកាត់ស្បែកផងដែរ (១៦:៣ និងពន្យល់)។ ប៉ុន្តែ លោកប៉ុលតែងមានការប្រុងប្រយ័ត្នជានិច្ចគ្រប់កិច្ចការទាំងអស់ គឺមិនឱ្យស្ថិតនៅក្រោមបង្គាប់នៃក្រឹត្យវិន័យទេ (កទ ២:៣)។

**២១:២៥** "មើលការពន្យល់ ១៥:២៣–២៩"។

ត្រូវប្រយ័ត្នតែនឹងរបស់អ្វី ដែលថ្វាយទៅរូបព្រះ ហើយ
ឈាម និងសត្វសំឡាប់ដោយច្របាច់ក ហើយនិងសេចក្ដី
កំផិតប៉ុណ្ណោះ[ផ] ២៦នោះប៉ុលក៏នាំយកអ្នកទាំងនោះទៅ
លុះស្អែកឡើង កាលបានញែកជាបរិសុទ្ធ ជាមួយនឹងគេ
ហើយ ក៏ចូលទៅក្នុងព្រះវិហារ ដើម្បីប្រាប់ពីកំណត់
ដែលត្រូវបានបរិសុទ្ធ ចាំទំរាំដល់បានថ្វាយដង្វាយសំរាប់
គេគ្រប់គ្នា[ព] ។

## ការចាប់ខ្លួនលោកប៉ុល

២៧កាលជិតគ្រប់៧ថ្ងៃនោះហើយ នោះពួកសាសន៍យូដា
ពីស្រុកអាស៊ី គេឃើញប៉ុលក្នុងព្រះវិហារ ក៏ញុះញង់ដល់
បណ្ដាមនុស្សទាំងប៉ុន្មាន រួចលូកដៃទៅចាប់យកគាត់[ភ]
ហើយស្រែកថា ២៨នែ អ្នករាល់គ្នាជាសាសន៍អ៊ីស្រាអែល
អើយ មករ៉ុយ ជួយគ្នា នេះហើយជាមនុស្សដែលបង្រៀន
ដល់មនុស្សទាំងអស់ នៅគ្រប់ទីដំបន់ ឲ្យទាស់នឹងសាសន៍
យើង និងក្រិត្យវិន័យ ហើយទីនេះដែរ ឥឡូវនេះបាននាំ
ទាំងសាសន៍ក្រេក ចូលមកក្នុងព្រះវិហារ ធ្វើបង្អាប់ទីបរិសុទ្ធ
នេះថែមទៀតផង[ម] ២៩ដំណើរនេះ គេស្មានថា គាត់នាំ
សាសន៍ក្រេកនោះ ទៅក្នុងព្រះវិហារ ដោយព្រោះពីថ្ងៃមុន
គេឃើញទ្រភីម[យ]ជាអ្នកស្រុកអេភេសូរ[រ] នៅជាមួយនឹងគាត់
ក្នុងទីក្រុង ៣០នោះក្រុងទាំងមូលក៏កើតជ្រួលជ្រើម បណ្ដា
ជនទាំងឡាយ គេរត់មកមូលគ្នា កាលចាប់ប៉ុលបានហើយ[ល]
នោះគេទាញកន្ត្រាក់គាត់ចេញ[វ] ទៅខាងក្រៅព្រះវិហារ
រួចបិទទ្វារភ្លាម ៣១តែកំពុងដែលគេរកចន្លោះសំឡាប់
គាត់ នោះដំណឹងក៏ឮផ្សាយទៅដល់មេទ័ពធំថា មានកើត
វឹកវរពេញក្នុងក្រុងយេរូសាឡិម ៣២លោកក៏យកទាហាន
នឹងមេទ័ពរង នាំរត់ចុះទៅឯគេភ្លាម កាលឃើញលោកនឹង
ទាហានមកដល់ គេក៏ឈប់លែងវាយប៉ុល[ស] ៣៣លោកចូល
ទៅចាប់គាត់[ហ] ហើយបង្គាប់ឲ្យដាក់ច្រវាក់[ឡ]២ខ្សែ[អ] រួចស៊ើប
សួរពីគាត់ជាអ្នកណា ហើយបានធ្វើអ្វីខ្លះ ៣៤តែក្នុងហ្វូង
មនុស្ស ខ្លះស្រែកយ៉ាងនេះ ខ្លះស្រែកយ៉ាងនោះ[ក] ដូច្នេះ
លោកពុំអាចនឹងដឹងអ្វីជាប្រាកដបាន ដោយព្រោះមានសូរ
ស៊ានអឺងកងជាខ្លាំង បានជាលោកបង្គាប់ ឲ្យនាំគាត់ចូល
ទៅក្នុងបន្ទាយ[ខ] ៣៥លុះបានដល់ទៅជណ្ដើរ[គ]បន្ទាយហើយ
នោះពួកទាហានត្រូវលើកសែងគាត់ឡើង ដោយព្រោះ
ហ្វូងមនុស្សច្រឡោតឡើងជា ខ្លាំង ៣៦ដ្បិតមានបណ្ដាជន
សន្ធឹកណាស់ដែលដើរតាមមក ទាំងស្រែកថា ឲ្យសំឡាប់
វាទៅ[ឃ] ។

## លោកប៉ុលថ្លែងទៅកាន់បណ្ដាជន

២២:៣–១៦ = កច ៩:១–២២ ២៦:៩–១៨

៣៧កាលគេរៀបនឹងនាំប៉ុល ចូលទៅក្នុងបន្ទាយ[ង] នោះ
គាត់និយាយទៅមេទ័ពធំថា តើលោកបើកឲ្យខ្ញុំជំរាប
បន្តិចបានឬទេ លោកសួរថា ឯងចេះនិយាយភាសា
ក្រេកដែរឬ ៣៨ដូច្នេះ តើឯងមិនមែនជាសាសន៍អេស៊ីព្ទ
នោះ ដែលនាំឲ្យបះបោរអំពីមុន ព្រមទាំងនាំពួកមនុស្ស

**២១:២៥** ផ កច ១៥:២០,២៩
**២១:២៦** ព ជន ៦:១៣–២០ កច ២៤:១៨
**២១:២៧** ភ យរ ២៦:៨ កច ២៤:១៨ ២៦:២១ ១ថន ២:១៦
**២១:២៨** ម មថ ២៤:១៥ កច ៦:១៣ ២៤:៥,៦
**២១:២៩** យ កច ២០:៤ ២ធថ ៤:២០ រ កច ១៨:១៩
**២១:៣០** ល កច ២៦:២១ វ កច ១៦:១៩
**២១:៣២** ស កច ២៣:២៧
**២១:៣៣** ហ ខ.១១ ឡ កច ១២:៦ អ ២០:២៣ ២២:២៩ អភ ៦:២០ ២ធថ ២:៩
**២១:៣៤** ក កច ១៩:៣២ ខ ខ.៣៧ កច ២២:២៤ ២៣:១០,១៦,៣២
**២១:៣៥** គ ខ.៤០
**២១:៣៦** ឃ លក ២៣:១៨ យហ ១៩:១៥ កច ២២:២២ **២១:៣៧** ង ខ.៣៤

**២១:២៧** *៧ថ្ងៃ* រយៈពេលនៃការលាបំណន់គឺត្រូវប្រព្រឹត្តទៅអស់ចំនួន៧ថ្ងៃ (ជន ៦:៩)។ *ពួកសាសន៍យូដាពីស្រុកអាស៊ី* លោកប៉ុលធ្លាប់បានទទួលការបៀតបៀនពីសំណាក់ពួកសាសន៍យូដានៅស្រុកអាស៊ីរួចទៅហើយ (២០:១៩) ហើយពួកនេះនៅតែតាមបៀតបៀនគាត់រហូតដល់ក្រុងយេរូសាឡិមទៀត ។

**២១:២៨** *បង្រៀន. . . ឲ្យទាស់នឹងសាសន៍យើង និងក្រិត្យវិន័យ ហើយនិងទីនេះ* សូមប្រៀបធៀបទៅនឹងការបៀតបៀនដែលកើតឡើងចំពោះលោកស្ទេផាន (៦:១៣)។ *បាននាំទាំងសាសន៍ក្រេកចូលមកក្នុងព្រះវិហារ* ពួកសាសន៍យូដាបាននាំគ្នាចោទប្រកាន់លោកប៉ុល ដោយនិយាយថាគាត់បាននាំសាសន៍ដទៃចូលទៅក្នុងព្រះវិហារ ប៉ុន្តែតាមពិតគាត់មិនបានធ្វើដូច្នោះទេ ។ តាមច្បាប់សម្រាប់ព្រះវិហារ ប្រសិនបើគេប្រទះឃើញសាសន៍ដទៃណាម្នាក់ចូលទៅក្នុងទីលានសម្រាប់ពួកអ៊ីស្រាអែល នោះគេត្រូវទទួលទោសដល់ស្លាប់ ។

**២១:២៩** *ទ្រភីម* "មើលការពន្យល់ ២០:៤"។ លោកប៉ុលពិតជាមិនបាននាំលោកទ្រភីមចូលទៅក្នុងទីហាមឃាត់នៅក្នុងព្រះវិហារទេ ។ ប្រសិនបើលោកទ្រភីមបានចូលទៅក្នុងទីហាមឃាត់នោះមែន ពួកគេពិតជាចាប់គាត់យកទៅកាត់ទោសជាមិនខាន គឺពុំមែនមកឡោមព័ទ្ធចង់ចាប់លោកប៉ុលទេ ។

**២១:៣០** *រួចបិទទ្វារភ្លាម* ពួកគេបិទទ្វារគឺខ្លាចមានហេតុការណ៍អាក្រក់កើតឡើងនៅក្នុងព្រះវិហារ ជាហេតុធ្វើឲ្យប៉ះពាល់ និងប្រមាថដល់ទីបរិសុទ្ធ ។

**២១:៣១** *មេទ័ពធំ* គឺលោកក្លូឌាស–លូស៊ា (២៣:២៦) ដែលត្រួតលើកងទ័ពចំនួន១ពាន់នាក់ និងមានបន្ទាយ (ស្ថិតនៅភាគខាងជើងឆៀងខាងលិចនៃព្រះវិហារ) នៅជិតព្រះវិហារនៅទីក្រុងយេរូសាឡិម (មើលការពន្យល់ ខ.៣៧)។

**២១:៣២** *មេទ័ពរង* ពាក្យថា "មេទ័ពរង" នៅក្នុងខនេះ ព្រះគម្ពីរជាភាសាអង់គ្លេសសរសេរជាពហុវចនៈ ។ ដូច្នេះមានមេទ័ពរងយ៉ាងតិចក៏២នាក់ដែរ ហើយមានទាហានចំនួន២០០នាក់មកជាមួយផង ។

**២១:៣៣** *ដាក់ច្រវាក់២ខ្សែ* ប្រហែលជាដៃលោកប៉ុលម្ខាងត្រូវចងភ្ជាប់នឹងដៃទាហានម្នាក់ ហើយដៃម្ខាងទៀតចងភ្ជាប់ទៅជាប់នឹងដៃទាហានម្នាក់ផ្សេងទៀត ។

**២១:៣៤,៣៧** *បន្ទាយ* "មើលការពន្យល់ ១២:៩"។ បន្ទាយនោះគឺស្ថិតនៅជាប់នឹងជ្រុងខាងជើងឆៀងខាងលិចព្រះវិហារប្រហែល២ជិហាន និងអាចមើលឃើញទីធ្លានៃព្រះវិហារនេះយ៉ាងច្បាស់ ។

**២១:៣៨** *សាសន៍អេស៊ីព្ទនោះ ដែលនាំឲ្យបះបោរអំពីមុន* លោកយ៉ូសែប–

កាប់ចាក់គ្នា៤ពាន់នាក់ ឱ្យទៅនៅទីរហោស្ថាន[ច]ទេឬអី[ឆ]
៣៩តែប៉ុលឆ្លើយតបថា ខ្ញុំជាសាសន៍យូដា មកពីក្រុង
តើសុស[ជ] ដែលនៅស្រុកគីលីគា[ឈ] ឯស្រុកកំណើតរបស់ខ្ញុំ
មិនមែនជាក្រុងឥតមានកេរ្តិ៍ឈ្មោះនោះទេ ដូច្នេះ សូម
លោកបើកឱ្យខ្ញុំនិយាយទៅជនទាំងឡាយបន្តិចសិន
៤០លោកក៏បើកឱកាសឱ្យ រួចប៉ុលឈរលើជណ្តើរ ធ្វើ
គ្រឿងសំគាល់[ញ]នឹងដៃដល់បណ្តាជន លុះបានស្ងប់ស្ងាត់
ហើយ នោះគាត់និយាយទៅគេជាភាសាហេព្រើរ[ដ]ថា
**២២** ១ឱអ្នករាល់គ្នាជាបងប្អូន ហើយជាឪពុកអើយ[ឋ]
សូមស្តាប់សេចក្តីដោះសារបស់ខ្ញុំសិន ២(កាលគេឮគាត់
និយាយជាភាសាហេព្រើរ[ឌ] នោះគេរឹតតែនៅស្ងៀមទៅ
ទៀត) រួចគាត់និយាយថា ៣"ខ្ញុំជាសាសន៍យូដា[ឍ] កើតនៅ
ក្រុងតើសុស[ណ] ក្នុងស្រុកគីលីគា[ត] តែបានរៀននៅទីក្រុង
នេះ ទៀបជើង[ថ]លោកកាម៉ាណល[ទ] ដែលលោកបង្រៀនខ្ញុំ
តាមន័យត្រឹមត្រូវ ក្នុងក្រិត្យវិន័យ របស់ពួកឰយុកោយើង[ធ]
ហើយខ្ញុំមានសេចក្តីឧស្សាហ៍[ន]ដល់ព្រះ ដូចជាអ្នករាល់គ្នា
សព្វថ្ងៃនេះដែរ ៤ពីដើមខ្ញុំជាអ្នកធ្វើទុក្ខបៀតបៀន[ប]ដល់
មនុស្សដែលកាន់តាមផ្លូវនេះ[ផ] ឱ្យដល់ស្លាប់ក៏មានព្រមទាំង
ចាប់ចងគេ ទាំងប្រុសទាំងស្រី បញ្ជូនទៅដាក់គុក[ព]ដែរ
៥ដូចជាសំដេចសង្ឃ និងពួកចាស់ទុំទាំងអស់[ភ] ជាទីបន្ទាល់
ពីខ្ញុំស្រាប់ហើយខ្ញុំបានទទួលយកសំបុត្រពីលោក ទៅឱ្យពួក
សាសន៍យើង[ម] នៅក្រុងដាម៉ាស[យ] រួចខ្ញុំក៏ចេញទៅ ដើម្បីនឹង
នាំយកអស់អ្នក ក្នុងពួកនេះទាំងប៉ុន្មាន ដែលនៅស្រុកនោះ
ទាំងជាប់ចំណង មកឯក្រុងយេរូសាឡិមវិញ ឱ្យគេជាប់
ទោស ៦លុះកាលខ្ញុំកំពុងតែដើរដំណើរទៅជិតដល់ក្រុង
ដាម៉ាស ក្នុងពេលប្រហែលជាថ្ងៃត្រង់ហើយ នោះស្រាប់តែ
មានពន្លឺយ៉ាងខ្លាំងពីលើមេឃបានភ្លឺមកនៅជុំវិញខ្ញុំ[រ] ៧ខ្ញុំក៏
ដួលដល់ដី ហើយឮសំឡេងមានបន្ទូលមកខ្ញុំថា សុល
នៃសុល ហេតុអ្វីបានជាធ្វើទុក្ខដល់ខ្ញុំ ៨ខ្ញុំបានឆ្លើយថា

**២១:៣៨** ច មថ ២៤:២៦ ឆ កច ៥:៣៦
**២១:៣៩** ជ កច ៩:១១ ឈ កច ៦:៩
**២១:៤០** ញ កច ១២:១៧ ដ យហ ៥:២
**២២:១** ឋ កច ៧:២
**២២:២** ឌ កច ១:៤០ យហ ៥:២
**២២:៣** ឍ កច ២១:៣៩ ណ កច ៩:១១ ត កច ៦:៩
**២២:៣** ថ លក ១០:៣៩ ទ កច ៥:៣៤ ធ កច ២៦:៥ ន ១ពវ ១៩:១០ កច ២១:២០
**២២:៤** ប កច ៨:៣ ផ កច ៩:២ ព ឧ.១៩,២០
**២២:៥** ភ លក ២២:៦៦ **២២:៥** ម កច ១:១៦ ២:២៩ ១៣:២៦ ២៣:១ ២៨:១៧,២១ រម ៧:១ ៩:៣ យ កច ៩:២ **២២:៦** រ កច ៩:៣

ហ្វីស (Josephus គឺជាទស្សនវិទូម្នាក់ កើតនៅឆ្នាំ៣៧ ឬ ៣៨គ.ស នៅក្រុងយេរូសាឡិម និងស្លាប់នៅដើមសតវត្សរ៍ទី២នៅទីក្រុងរ៉ូម) បានសរសេរទុកថាកាលពី២ឬ៣ឆ្នាំមុននោះ មានគ្រូអធិប្បាយជាតិអេស៊ីព្ទម្នាក់បាននាំមនុស្សប្រហែល៤ពាន់ នាក់ឱ្យដើរតាមផ្លូវរបស់ខ្លួន។ ពួកទាហានរ៉ូម៉ាំងបានសម្លាប់អ្នកទាំងនោះអស់រាប់រយនាក់ ប៉ុន្តែ មេដឹកនាំពួកគេបានគេចខ្លួនរួច ។ *ពួកមនុស្សកាប់ចាក់គ្នា* ឃ្លានេះភាសាឡាតាំងប្រើពាក្យថា "មនុស្សគ្រោះថ្នាក់" ឬ "ឃាតក"។

**២១:៣៩** *ក្រុងតើសុស* "មើលការពន្យល់ ២២:៣"។

**២១:៤០** *ភាសាហេព្រើរ* ភាសាហេព្រើរដែលលោកប៉ុលនិយាយទៅកាន់បណ្តាជននាពេលនោះ មានលក្ខណៈដូចជាភាសាអើរ៉ាម (២ពវ ១៨:២៦ អស ៣៦:១១) ដែលពួកយូដា–ភីលីស្ទីន និយមចូលចិត្តប្រើ ក្នុងការនិយាយទាក់ទងគ្នាទៅវិញទៅមក ។

**២២:១–២** *បងប្អូន* "មើលការពន្យល់ ១១:១"។ *ភាសាហេព្រើរ* "មើលការពន្យល់ ២១:៤០"។ ដំបូងឡើយ ពួកបណ្តាជនគិតថាលោកប៉ុលប្រាកដជានិយាយភាសាក្រិកទៅកាន់ពួកខ្លួន ព្រោះឃើញគាត់ដើរជាមួយមនុស្សដែលមកពីប្រទេសក្រិក ប៉ុន្តែ នៅពេលលោកប៉ុលនិយាយភាសាហេព្រើរ នោះក៏នាំគ្នានៅស្ងៀម ចាំស្តាប់គាត់ដោយយកចិត្តទុកដាក់វិញ ។

**២២:៣** *កើតនៅក្រុងតើសុស* ក្រុងតើសុស (ស្ថិតនៅប្រហែល១៩គ.ម ភាគខាងជើងនៃសមុទ្រមេឌីទែរ៉ាណេ) ជាទីក្រុងធំនៃស្រុកគីលីគា និងជាមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏សំខាន់ ហើយនិងមានបណ្តាញផ្លូវថ្នល់ជាច្រើន។ លោកប៉ុលបានកើតនៅក្នុងទីក្រុងនេះ (២១:៣៩) ហើយគាត់ក៏មានសញ្ជាតិរ៉ូមផងដែរ ។ *បានរៀននៅទីក្រុងនេះ* លោកប៉ុលត្រូវបានបញ្ជូនឱ្យមកសិក្សានៅទីក្រុងយេរូសាឡិម ក្រោមការបង្ហាត់បង្រៀនរបស់លោកកាម៉ាលាល តាំងពីគាត់ (លោកប៉ុល) នៅក្មេងម្ល៉េះ ។ *លោកកាម៉ាលាល* គឺជាគ្រូបង្រៀនសាសន៍យូដា ដែលមានគេគោរពច្រើន និងមានកេរ្តិ៍ឈ្មោះល្បីល្បាញនៅសតវត្សរ៍ទី១ ។ លោកកាម៉ាលាលម្នាក់នេះ ប្រហែលជាចៅរបស់លោកហ៊ីលេល (ពច ១២:១៣ កច ៥:៣៤–៤០)។

**២២:៤–៥** លោកប៉ុលបានថ្លែងទៅកាន់ពួកសាសន៍យូដា ដោយរំឭកប្រាប់អំពីទង្វើដែលគាត់បានប្រព្រឹត្តពីមុន ចំពោះអ្នកជឿព្រះយេស៊ូវគ្រីស្ទ (៨:៣ ៩:១,២) ហើយនៅពេលបានឮដូច្នោះ ពួកគេក៏នៅស្ងៀមស្តាប់គាត់ដោយយកចិត្តទុកដាក់ ។ *សំដេចសង្ឃ* ពាក្យថា "សំដេចសង្ឃ" នៅត្រង់ចំណុចនេះគឺសំដៅទៅលើលោកអាន្នានាស (២៣:២)។ គាត់ទទួលតំណែងជាសម្តេចសង្ឃនោះគឺបន្ទាប់ពីលោកកៃផាជាសម្តេចសង្ឃចាស់បានស្លាប់ទៅ ។ *ពួកចាស់ទុំ* ត្រង់ចំណុចនេះព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសប្រើពាក្យថា "ពួកក្រុមជំនុំ" មានន័យថា "ក្រុមជម្រះក្តី ក្រុមកាត់ក្តី ចៅក្រម តុលាការ ឬតុលាការជាន់ខ្ពស់(មថ ៥:២២ មក ១៤:៥៥)។

**២២:៦** *នោះស្រាប់តែមានពន្លឺយ៉ាងខ្លាំងពីលើមេឃ* ពួកសាសន៍យូដាបានដឹងថា ព្រះអម្ចាស់ទ្រង់ជាពន្លឺ ដូច្នេះលោកប៉ុលក៏លើកយកឃ្លានេះ ថ្លែងទៅកាន់ពួកគេ ព្រោះវាធ្វើឱ្យពួកគេងាយយល់ និងទទួលស្គាល់ថា ហេតុការណ៍ដែលគាត់បានជួបប្រទះនោះពិតជាមកអំពីទ្រង់ ។

**២២:៨** *ឱព្រះអម្ចាស់អើយ តើព្រះអង្គណានុ៎ះ ?* "មើលការពន្យល់ ៩:៥"។ *ដែលអ្នកបៀតបៀន* "មើលការពន្យល់ ៩:៤"។ នៅពេលដែលលោកប៉ុលបានឮព្រះអម្ចាស់យេស៊ូវមានព្រះបន្ទូលមកកាន់គាត់ នោះក៏មានការភ្ញាក់ផ្អើល និងចម្លែកក្នុងចិត្តជាខ្លាំង ព្រោះគាត់មិនបាននឹកស្មានថា ទ្រង់មានព្រះជន្មរស់ពីសុគតឡើងវិញទេ។ ប៉ុន្តែភ្លាមៗនោះគាត់ក៏បានដឹងច្បាស់ថាពិតជាព្រះយេស៊ូវគ្រីស្ទមានបន្ទូលមកកាន់គាត់ប្រាកដមែន ។

**២២:៩** *តែមិនឮសំឡេងព្រះអង្គដែលមានបន្ទូលមកខ្ញុំនោះទេ* ឃ្លានេះព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសខ្លះសរសេរថា "តែមិនយល់សំឡេង

ឱព្រះអម្ចាស់អើយ តើព្រះអង្គណានុ៎ះ រួចទ្រង់មានបន្ទូល
មកខ្ញុំថា ខ្ញុំជាព្រះយេស៊ូវ ពីភូមិណាសារ៉ែត[ល] ដែលអ្នក
បៀតបៀន ៩ឯពួកអ្នកដែលនៅជាមួយនឹងខ្ញុំ គេក៏ឃើញ
ពន្លឺ[វ] នោះដែរ ហើយមានសេចក្ដីភ័យខ្លាចតែមិនឮសំឡេង[ស]
ព្រះអង្គ ដែលមានបន្ទូលមកខ្ញុំនោះទេ ១០ខ្ញុំក៏ទូលសួរថា
ព្រះអម្ចាស់អើយ តើត្រូវឱ្យទូលបង្គំ ធ្វើដូចម្ដេច រួចព្រះ
អម្ចាស់ មានបន្ទូលមកខ្ញុំថា ចូរក្រោកឡើងចូលទៅក្នុង
ក្រុងដាម៉ាស នៅទីនោះនឹងមានគេប្រាប់អ្នក ពីអស់ទាំងការ
ដែលបានដំរូវឱ្យអ្នកត្រូវធ្វើ[ហ] ១១នោះពួកអ្នកដែលនៅជា
មួយនឹងខ្ញុំ បានដឹកដៃនាំខ្ញុំចូលទៅក្នុងក្រុងដាម៉ាស ពីព្រោះ
ខ្ញុំមើលអ្វីមិនឃើញសោះ ដោយព្រោះ រស្មីដ៏ឧត្ដមនៃពន្លឺ
នោះ[ឡ] ១២រួចមានមនុស្សម្នាក់ឈ្មោះ អាន៉្នានាស[អ] គឺជាអ្នក
កោតខ្លាចដល់ព្រះតាមក្រិត្យវិន័យ ដែលមានកេរ្ដិ៍ឈ្មោះល្អ
ក្នុងពួកសាសន៍យូដាទាំងអស់ដែលនៅទីនោះ[ក] ១៣អ្នកនោះក៏
មកឈរជិតខ្ញុំនិយាយថា អ្នកសុលអើយ សូមឱ្យភ្នែកអ្នកបាន
ភ្លឺឡើងនៅវេលានោះឯង ខ្ញុំក៏ងើបភ្នែកឡើង ឃើញគាត់
១៤រួចគាត់និយាយមកខ្ញុំថា ព្រះនៃពួកឰយុកោយើង[ខ] បាន
ដំរូវឱ្យអ្នកស្គាល់ចំណង់ នៃព្រះហឫទ័យទ្រង់[គ] ហើយឱ្យ
ឃើញ[ឃ] ព្រះដ៏សុចរិត ព្រមទាំងឮសំឡេងពីព្រះឱស្ឋទ្រង់
១៥ដ្បិតអ្នកត្រូវធ្វើជាស្មរបន្ទាល់ពីទ្រង់[ង] ដល់មនុស្សទាំងអស់
ពីគ្រប់ការដែលអ្នកបានឃើញបានឮ[ច] ១៦ឥឡូវនេះ តើអ្នក
បង្អង់ចាំអ្វីទៀត ចូរក្រោកឡើង ទទួលបុណ្យជ្រមុជទឹក[ឆ]
ហើយលាងបាបអ្នកចេញចុះ[ជ] ដោយការអំពាវនាវដល់
ព្រះនាមព្រះអម្ចាស់[ឈ] ១៧កាលខ្ញុំបានត្រឡប់ទៅឯក្រុង
យេរូសាឡិម[ញ]វិញ កំពុងដែលខ្ញុំអធិស្ឋាននៅក្នុងព្រះវិហារ
នោះខ្ញុំលង់ស្មារតីទៅ[ដ] ១៨ហើយក៏ឃើញទ្រង់មានបន្ទូលមក
ខ្ញុំថា ចូរប្រញាប់ចេញពីក្រុងយេរូសាឡិមទៅជាឆាប់
ពីព្រោះគេមិនទទួលពាក្យដែលអ្នកធ្វើបន្ទាល់ពីខ្ញុំទេ ១៩ខ្ញុំក៏
ទូលថាព្រះអម្ចាស់អើយ អ្នកទាំងនោះដឹងថា ទូលបង្គំបាន
ចាប់ពួកអ្នក ដែលជឿដល់ទ្រង់ដាក់គុក[ឋ] ហើយព្រមទាំង
វាយ[ឌ]គេនៅក្នុងគ្រប់ទាំងសាលាប្រជុំផង ២០កាលដែល
ឈាមស្ទេផាន ជាស្មរបន្ទាល់របស់ទ្រង់ បានត្រូវខ្ចាយ នោះ
ទូលបង្គំក៏ឈរនៅទីនោះដែរ បានទាំងយល់ព្រមឱ្យសំឡាប់
គាត់ ហើយនៅចាំអាវនៃពួកអ្នក ដែលសំឡាប់គាត់ផង[ឍ]
២១នោះទ្រង់មានបន្ទូលមកខ្ញុំថា ចូរទៅចុះដ្បិតខ្ញុំនឹងចាត់អ្នក
ឱ្យទៅឯសាសន៍ដទៃដែលនៅឆ្ងាយ[ណ]។

## លោកប៉ុលជាជាតិរ៉ូម

២២គេក៏ស្ដាប់គាត់ ដរាបដល់ពាក្យនោះ រួចគេស្រែក
កាត់ឡើងថា ចូរដកមនុស្សយ៉ាងនេះ ពីផែនដីចេញ[ត] ដ្បិត
មិនគួរឱ្យវានៅរស់ទៀតទេ[ថ] ២៣ហើយដោយព្រោះគេចេះ
តែស្រែកឡើង ទាំងកន្ត្រាក់ដោះអាវគេចេញ[ទ] ហើយបាចធូ
លីដីទៅលើ[ធ] ២៤នោះបានជាមេទ័ពធំបង្គាប់ឱ្យនាំគាត់
ចូលទៅក្នុងបន្ទាយ[ន] រួចប្រាប់[ប]ឱ្យវាយសួរចំឡើយ ដើម្បីឱ្យ

**២២:៨** ល មក ១:២៤
**២២:៩** វ កច ២៦:១៣ ស កច ៩:៧
**២២:១០** ហ កច ១៦:៣០
**២២:១១** ឡ កច ៩:៨
**២២:១២** អ កច ៩:១៧ ក កច ១០:២២
**២២:១៤** ខ កច ៣:១៣ គ កច ៧:៥២ ឃ ១កថ ១៥:៨
**២២:១៥** ង កច ២៣:១១ ២៦:១៦ ច ខ.១៤
**២២:១៦** ឆ កច ២:៣៨ ជ លវ ៨:៦ ទដ ៥១:២ អគ ៣៦:២៥ យហ ៣:៥ ១កថ ៦:១១ អភ ៥:២៦ ទត ៣:៥ ហព ១០:២២ ១ពត ៣:២១ ឈ រម ១០:១៣
**២២:១៧** ញ កច ៩:២៦ ដ កច ១០:១០
**២២:១៩** ឋ ខ.៤ កច ៨:៣ ឌ មថ ១០:១៧
**២២:២០** ឍ កច ៧:៥៧–៦០ ៨:១
**២២:២១** ណ កច ៩:១៥ ១៣:៤៦
**២២:២២** ត កច ២១:៣៦ ថ កច ២៥:២៤ **២២:២៣** ទ កច ៧:៥៨ ធ ២សយ ១៦:១៣ **២២:២៤** ន កច ២១:៣៤ ប ខ.២៩

ព្រះអង្គដែលមានបន្ទូលមកខ្ញុំនោះទេ” (៩:៧)។

**២២:១២** *អាន៉្នានាស គឺជាអ្នកកោតខ្លាចដល់ព្រះតាមក្រិត្យវិន័យ* អាន៉្នានាស គឺជាអ្នកកោតខ្លាច និងជឿដល់ព្រះអម្ចាស់ ហើយក៏ជាអ្នកកាន់តាមក្រិត្យវិន័យរបស់ទ្រង់យ៉ាងខ្ជាប់ខ្ជួនទៀតផង (មើលការពន្យល់ លក ១:៦)។

**២២:១៤** *ហើយឱ្យឃើញព្រះដ៏សុចរិត* “មើលការពន្យល់ កច ៣:១៤ លក ២៣:៤៧”។ *“ព្រះដ៏សុចរិត”* គឺព្រះយេស៊ូវគ្រីស្ទ។ ការដែលព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ពីសុគតឡើងវិញ និងការសំដែងអង្គទ្រង់ឱ្យលោកប៉ុលឃើញ គឺជាហេតុការណ៍ដ៏សំខាន់មួយ ដែលធ្វើឱ្យជីវិតគាត់បានផ្លាស់ប្រែ ហើយស្គាល់នូវសេចក្ដីពិតនៃដំណឹងល្អ (កច ២៦:១៦ ១កថ ៩:១ ១៥:៨)។

**២២:១៦** *ហើយលាងបាបអ្នកចេញចុះ* ពិធីបុណ្យជ្រមុជទឹកគ្រាន់តែជានិមិត្តរូបបញ្ជាក់ថា អំពើបាបត្រូវបានលាងជម្រះ ដោយសារព្រះលោហិត និងដោយព្រោះព្រះគុណនៃព្រះអម្ចាស់ប៉ុណ្ណោះ (២:៣៨ ទត ៣:៥ ១ពត ៣:២១ រម ២:២៨–២៩ ៦:៣–៤ អភ ២:៨–៩ ភល ៣:៤–៩)។

**២២:១៧** *កាលខ្ញុំបានត្រឡប់ទៅឯក្រុងយេរូសាឡិមវិញ* គឺសំដៅទៅលើដំណើរទៅកាន់ទីក្រុងយេរូសាឡិម ដូចដែលមានចែងនៅក្នុង “៩:២៦ កទ ១:១៧–១៨”។ *អធិស្ឋាននៅក្នុងព្រះវិហារ នោះខ្ញុំលង់ស្មារតីទៅ* “សូមមើលអំពីហេតុការណ៍ ដែលបានកើតឡើងចំពោះលោកពេត្រុស (១០:១០ ១១:៥ ២កថ ១២:៣)”។ ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា លោកប៉ុលពុំមែនជាអ្នកប្រមាថដល់ព្រះវិហារ ដូចពាក្យដែលពួកប្រឆាំងនិយាយនោះទេ ព្រោះថាគេបានឃើញគាត់នៅតែបន្តអធិស្ឋាននៅទី (ព្រះវិហារ) នោះដដែល ។

**២២:២០** *បានទាំងយល់ព្រមឱ្យសំឡាប់គាត់* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា លោកប៉ុលពិតជាបានយល់ព្រមក្នុងការសម្លាប់លោកស្ទេផាន ។

**២២:២៤** *មេទ័ពធំ* “មើលការពន្យល់ ២១:៣១”។ *បន្ទាយ* “មើលការពន្យល់ ២១:៣៧”។ *រួចប្រាប់ឱ្យវាយសួរចំឡើយ* រំពាត់ដែលគេយកមកវាយលោកប៉ុលនាពេលនោះមិនមែនជារំពាត់ធម្មតាទេ ប៉ុន្តែជារំពាត់ដែលមានភ្ជាប់ដោយឆ្អឹងសត្វ ឬលោហៈធាតុ គឺដើម្បីបង្កើនការឈឺចាប់ទៅលើអ្នកទោសនៅពេលធ្វើទារុណកម្មសួរចម្លើយ ។ តាមច្បាប់របស់ចក្រភពរ៉ូម៉ាំងទារុណកម្មបែបនោះ ពុំអាចធ្វើចំពោះពួកអ្នកដែលមានសញ្ជាតិរ៉ូមទេ

ដឹងពីហេតុអ្វី បានជាគេស្រែកទាស់នឹងគាត់ជាខ្លាំងម្ល៉េះ
[២៥]ប៉ុន្តែ កំពុងដែលគេយកខ្សែមកចងប៉ុលឱ្យចំកោង នោះ
គាត់និយាយទៅមេទ័ពរងដែលឈរនៅទីនោះថា តើមាន
ច្បាប់នឹងវាយសាសន៍រ៉ូមនឹងរំពាត់ មុនដែលកាត់ទោស
ដែរឬអី[ផ] [២៦]លុះមេទ័ពរងឮដូច្នោះ នោះក៏ទៅជិរាបដល់មេ
ទ័ពធំថា លោកគិតធ្វើអ្វីដូច្នេះ ដ្បិតមនុស្សនោះជាសាសន៍រ៉ូម
[២៧]នោះមេទ័ពធំចូលមកសួរប៉ុលថា ចូរប្រាប់អញ ឯងជា
សាសន៍រ៉ូមឬ គាត់ឆ្លើយថា បាទ [២៨]លោកក៏និយាយថា
អញបានបង់ប្រាក់ច្រើនណាស់ ដើម្បីឱ្យបានចូលជាតិរ៉ូម
នេះ តែប៉ុលនិយាយថា ខ្ញុំនេះកើតមកជាសាសន៍រ៉ូមតែម្តង
[២៩]ដូច្នេះ ពួកអ្នកដែលត្រូវសួរចំឡើយ[ព] ក៏ថយចេញជា
១រំពេច ហើយមេទ័ពធំមានសេចក្តីភិតភ័យ ដោយដឹងថា
គាត់ជាសាសន៍រ៉ូម[ភ] ពីព្រោះបានជ្រុលជាចង[ម]គាត់ហើយ ។

## លោកប៉ុលនៅមុខពួកក្រុមជំនុំ

[៣០]ដល់ថ្ងៃស្អែកឡើង លោកក៏ស្រាយចំណង[យ] ហើយ
ប្រាប់ដល់ពួកសង្គ្រាជ នឹងពួកក្រុមជំនុំ[រ]ទាំងអស់ ឱ្យប្រជុំគ្នា
រួចលោកនាំប៉ុលចុះមក ដាក់នៅកណ្តាលពួកគេ ដោយចង់
ដឹងច្បាស់ពីហេតុអ្វី បានជាពួកសាសន៍យូដា[ល] ចោទប្រកាន់
គាត់ដូច្នោះ ។

**២៣** [១]ប៉ុលក៏សំឡឹងមើលទៅពួកក្រុមជំនុំ[វ] និយាយថា
ឱអ្នករាល់គ្នា ជាបងប្អូនអើយ![ស] ខ្ញុំបានប្រព្រឹត្តដោយ
បញ្ញាចិត្តជ្រះស្អាត[ហ] នៅចំពោះព្រះ ដរាបមកដល់ថ្ងៃនេះ
[២]តែអាន្នាំនាស[ឡ] ជាសំដេចសង្ឃ លោកបានបង្គាប់
ដល់ពួកអ្នកដែលឈរជិត ឱ្យទះមាត់គាត់[អ] [៣]នោះប៉ុល
និយាយទៅលោកថា ឱកំផែងណបស[ក]អើយ ព្រះទ្រង់
នឹងវាយលោកវិញ លោកអង្គុយជំនុំជំរះខ្ញុំតាមក្រឹត្យវិ
ន័យ ចុះដូចម្តេចបានជាហ៊ានបង្គាប់ឱ្យគេវាយខ្ញុំ ខុស
នឹងក្រិត្យវិន័យដូច្នេះ[ខ] [៤]ឯពួកអ្នកដែលឈរជិតក៏ស្តីឱ្យ
គាត់ថា តើឯងហ៊ានជៀលដល់សំដេចសង្ឃនៃព្រះដែរឬ

**២២:២៥** ផ កច ១៦:៣៧
**២២:២៩** ព ខ.២៤ ភ ខ.២៤,២៥ កច ១៦:៣៨ ម កច ២១:៣៣
**២២:៣០** យ កច ២១:៣៣ រ មថ ៥:២២ ល កច ២៣:២៨
**២៣:១** វ កច ២២:៣០ ស កច ២២:៥ ហ កច ២៤:១៦ ១កថ ៤:៤ ២កថ ១:១២ ១ធថ ១:៥,១៩ ៣:៩ ២ធថ ១:៣ ហព ៩:១៤ ១០:២២ ១៣:១៨ ១ពត ៣:១៦,២១
**២៣:២** ឡ កច ២៤:១ អ យហ ១៨:២២ **២៣:៣** ក មថ ២៣:២៧ ខ លវ ១៩:១៥ ចទ ២៥:១,២ យហ ៧:៥១

(១៦:២២-២៤ មើលការពន្យល់ មក ១៥:១៥)។ ដូច្នេះ កាលបានឮថា លោកប៉ុលមានសញ្ជាតិរ៉ូម ពួកគេក៏មានការភ័យខ្លាច ព្រោះទង្វើដែលពួកគេធ្វើនោះគឺប្រឆាំងនឹងច្បាប់នៃចក្រភពរ៉ូម៉ាំង ។

**២២:២៥** *កំពុងដែលគេយកខ្សែមកចងប៉ុលឱ្យចំកោង* ឃ្លានេះជាភាសាក្រិកអាចមានន័យថា "ចាប់យកទៅប៉ុស្តិ៍ដើម្បីវាយសួរចម្លើយ"។ *តើមានច្បាប់នឹងវាយសាសន៍រ៉ូមនឹងរំពាត់ មុនដែលកាត់ទោសដែរឬទេ?* ត្រង់ចំណុចនេះបញ្ជាក់ថា តាមច្បាប់របស់ចក្រភពរ៉ូម៉ាំង គ្រប់អស់អ្នកដែលមានសញ្ជាតិរ៉ូម គឺត្រូវបានធានាមិនឱ្យទទួលរងនូវទារុណកម្មណាមួយឡើយ (ដូចជាវាយនឹងរំពាត់ ឬឆ្កាងជាដើម)។

**២២:២៨** *បានបង់ប្រាក់ច្រើនណាស់* មានរបៀប៣យ៉ាងដែលត្រូវធ្វើដើម្បីឱ្យបានសញ្ជាតិរ៉ូមគឺ (១).ជារង្វាន់ដោយព្រោះបានបម្រើការឱ្យចក្រភពរ៉ូម៉ាំង (២).ទិញនៅក្នុងតម្លៃណាមួយ (៣).ដោយសារកើតមកនៅក្នុងត្រកូលដែលមានសញ្ជាតិរ៉ូមតែម្តង ។ លោកប៉ុលមានសញ្ជាតិរ៉ូមតាំងពីកំណើត ព្រោះឪពុកម្តាយ ឬជីដូន ជីតារបស់គាត់មានសញ្ជាតិរ៉ូម ។ គ្មានអ្នកណាដឹងថាគ្រួសាររបស់លោកប៉ុលបាន ទទួលសញ្ជាតិរ៉ូមដោយរបៀបណានោះទេ ។

**២២:២៩** *មេទ័ពធំមានសេចក្តីភិតភ័យ* មេទ័ពធំមានសេចក្តីភិតភ័យពេលបានដឹងថា លោកប៉ុលមានសញ្ជាតិរ៉ូម ព្រោះថាត្រូវមានទោសរហូតដល់បាត់បង់ជីវិត ប្រសិនជាមានហេតុការណ៍អាក្រក់ណាមួយកើតឡើងចំពោះលោកប៉ុល (ដូចគ្នានឹងហេតុការណ៍ដែលបានកើតឡើងនៅឯទីក្រុងភីលីពដែរ ១៦:៣៨)។

**២២:៣០** *លោកក៏ស្រាយចំណង* ភ្លាមៗនោះលោកប៉ុលមានសេរីភាពអំពីច្បាប់នៃចក្រភពរ៉ូម៉ាំងទាំងស្រុង ប៉ុន្តែ ពួកសង្គ្រាជនិងពួកក្រុមជំនុំបាននាំគាត់ទៅសាកសួរបន្ថែមទៀត អំពីមូលហេតុដែលពួកសាសន៍យូដាបានចោទប្រកាន់គាត់នោះ។ *ពួកសង្គ្រាជ* សំដៅលើពួកអ្នកដែលជាវង្សត្រកូលនៃពួកសង្ឃ (ពិសេសគឺពួកសាឌូស៊ី មើលការពន្យល់ មថ ២:៤ ប៉ុន្តែ ក្រោយមក ពួកផារិស៊ីក៏ត្រូវបានរាប់បញ្ចូលជាសមាជិកនៃពួកនេះផងដែរ)។ ពួកសង្គ្រាជ និងពួកក្រុមជំនុំ គឺជាអ្នកបង្កើតច្បាប់សម្រាប់ដាក់ទោសដល់សាសន៍យូដាមុនពេលបញ្ជូនទៅឱ្យពួកអភិបាលរ៉ូម៉ាំងជំនុំជម្រះ ។

**២៣:១** *ពួកក្រុមជំនុំ* "មើលការពន្យល់ ៥:២១ ២២:៣០"។ *បងប្អូន* លោកប៉ុលនិយាយពាក្យនេះ គឺសំដៅទៅលើអស់អ្នកដែលជាសាសន៍យូដា ដូចជាគាត់ដែរ (មើលការពន្យល់ ១១:១)។ *បញ្ញាចិត្តជ្រះស្អាត* លោកប៉ុលតែងតែលើកយកឃ្លានេះមកប្រើ តាំងពីគាត់បានប្រែចិត្តទទួលព្រះយេស៊ូវជាព្រះសង្គ្រោះនៅក្នុងជីវិតគាត់មកម្ល៉េះ ដើម្បីបញ្ជាក់អំពីភាពច្បាស់លាស់និងត្រឹមត្រូវក្នុងគ្រប់កិច្ចការដែលគាត់ធ្វើ (២៤:១៦ រម ៩:១ ១កថ ៤:៤ ១កថ ១:១២ ២ធថ ១:៣)។

**២៣:២** *អាន្នាំនាស* គឺជាសម្តេចសង្ឃនៅឆ្នាំទី ៤៧-៤៩ គ.ស និងជាកូនប្រុសរបស់លោកនេបីដេស (Nebedaeus)។ អាន្នាំនាសជាមនុស្សម្នាក់ដែលគេស្គាល់ថាបានប្រព្រឹត្តអំពើឃោរឃៅជាច្រើន ហើយក្រោយមកត្រូវស្លាប់ដោយសារតែមនុស្សដែលនៅជាមួយគាត់ផ្ទាល់ ។ អាន្នាំនាសម្នាក់នេះ និងលោកអាណា (៤:៦) គឺជាមនុស្សពីរនាក់ផ្សេងគ្នា ។ លោកអាណាគឺជាសម្តេចសង្ឃនៅក្នុងអំឡុងឆ្នាំ៧-១៤គ.ស ។

**២៣:៣** *ឱកំផែងលាបសអើយ !* ឃ្លានេះមានន័យដូចគ្នាទៅនឹងឃ្លាថា "មនុស្សមានពុត"ដែរ (មថ ៦:២,៥,១៦)។ នៅពេលនោះពួកសង្ឃបានព្យាយាមធ្វើឱ្យអ្នកដទៃឃើញថាខ្លួនជាមនុស្សល្អប្រសើរខ្ពង់ខ្ពស់ តែខាងក្នុងចិត្តរបស់ពួកគេវិញ ពោរពេញទៅដោយសេចក្តីអាក្រក់ (មថ ២៣:២៧) គឺ

5 ប៉ុលឆ្លើយថា បងប្អូនអើយ ខ្ញុំមិនបានដឹងថា លោកជា
សំដេចសង្ឃទេ ដ្បិតមានសេចក្តីចែងទុកមកថា មិនត្រូវ
និយាយអាក្រក់ ពីចៅហ្វាយរបស់សាសន៍ឯងឡើយ[គ]
6 កាលប៉ុលបានដឹងថា ពួកគេ១ចំណែក ជាពួកសាឌូសី[ឃ]
ហើយ១ចំណែកទៀត ជាពួកផារិសី នោះគាត់បន្លឺសំឡេង
ឡើងក្នុងពួកក្រុមជំនុំថា បងប្អូនរាល់គ្នាអើយ[ង] ខ្ញុំជាពួក
ផារិសី[ច] ហើយជាកូននៃពួកផារិសី ខ្ញុំជាប់ជំនុំជំរះ គឺដោយ
ព្រោះតែសេចក្តីសង្ឃឹមនេះថា មនុស្សស្លាប់នឹងរស់ឡើង
វិញ[ឆ] 7 កាលគាត់និយាយដូច្នោះហើយ នោះពួកផារិសី
នឹងពួកសាឌូសី គេកើតទាស់ទែងគ្នា បណ្តាជំនុំក៏បែកខ្ញែក
ដែរ 8 ដ្បិតពួកសាឌូសីប្រកាន់ថា គ្មានសេចក្តីរស់ឡើងវិញ[ជ]
ក៏គ្មានទេវតា ឬវិញ្ញាណណាផង តែពួកផារិសីជឿថាមាន
វិញ 9 នោះកើតមានសូរទ្រហឹងអឹងអាប់ជាខ្លាំង ហើយពួក
អាចារ្យខ្លះ ខាងពួកផារិសី[ឈ] ក៏ឈរឡើងជជែកថា យើង
មិនឃើញជាមនុស្សនេះ មានទោសខុសអ្វីសោះ[ញ] តែបើ
មានវិញ្ញាណ ឬទេវតាបាននិយាយនឹងគាត់ នោះធ្វើ
ដូចម្តេចវិញ?[ដ] 10 លុះកើតទាស់គ្នាជាខ្លាំងដូច្នោះ នោះ
មេទ័ពធំក៏បង្គាប់ឱ្យពួកទាហាន ចុះទៅយកគាត់ពីកណ្តាល
គេមកដោយអំណាចហើយនាំចូលទៅក្នុងបន្ទាយវិញ ក្រោយ
លោកគេប្រញាយហែកគាត់ខ្ទេចខ្ទីទៅ[ឋ] 11 នៅវេលាយប់នោះ
ព្រះអម្ចាស់ទ្រង់ឈរជិតគាត់ មានបន្ទូលថាចូរសង្ឃឹមឡើង[ឌ]
ប៉ុលអើយ ដ្បិតអ្នកត្រូវធ្វើ បន្ទាល់នៅក្រុងរ៉ូម ដូចជាបាន
ធ្វើបន្ទាល់សព្វគ្រប់ពីខ្ញុំនៅ ក្រុងយេរូសាឡិមដែរ[ឍ]។

**ការរួមគំនិតគ្នាសម្លាប់លោកប៉ុល**

12 ដល់ភ្លឺឡើង មានពួកសាសន៍យូដាខ្លះ រួមគំនិតគ្នា[ណ]
ស្បថឡាក់ឡាំងថា មិនស៊ីមិនផឹក ទាល់តែបានសំឡាប់ប៉ុល
ហើយ[ត] 13 ឯមនុស្សដែលបង្កើតឧបាយយ៉ាងនេះ មានជាង
៤០នាក់ 14 គេក៏ទៅជិរាបពួកសង្គ្រាជ នឹងពួកចាស់ទុំថា
យើងខ្ញុំបានស្បថថា មិនភ្លក់អ្វីសោះ ទាល់តែបានសំឡាប់
ប៉ុលចេញ[ថ] 15 ដូច្នេះ សូមឱ្យលោកទាំងឡាយ នឹងពួកក្រុម
ជំនុំ[ទ] ចាត់ឱ្យទៅសូមវា ពីលោកមេទ័ពធំមកឥឡូវ ដើម្បីឱ្យ
លោកនាំវាចុះមក ធ្វើដូចជាលោកចង់ពិចារណាសួរពី
ដំណើរវាឱ្យច្បាស់លាស់ឡើង ឯពួកយើងខ្ញុំ ក៏ប្រុងប្រៀប
ជាស្រេចនឹងសំឡាប់វា មុនដែលវាចូលមកដល់ផង ។
16 ឯកូនរបស់ប្អូនស្រីប៉ុល កាលបានដឹងពីការដែលឈ្លប
លបនោះហើយ ក៏ចូលទៅក្នុងបន្ទាយ[ធ] ប្រាប់ដល់ប៉ុល ។
17 នោះប៉ុល គាត់ហៅមេទ័ពរងម្នាក់ មកជិរាបថា សូម

**២៣:៥** គ នក ២២:២៨
**២៣:៦** ឃ ខ.៧,៨ កច ៤:១ ង កច ២២:៥ ច ២៦:៥ ភល ៣:៥ ឆ កច ២៤:១៥,២១ ២៦:៨
**២៣:៨** ជ មថ ២២:២៣ ១កថ ១៥:១២
**២៣:៩** ឈ មក ២:១៦ ញ ខ.២៩ យរ ២៦:១៦ លក ២៣:៤ កច ២៥:២៥ ២៦:៣១ ២៨:១៨ ដ កច ២២:៧,១៧,១៨
**២៣:១០** ឋ កច ២១:៣៤
**២៣:១១** ឌ មថ ១៤:២៧ ឍ កច ១៩:២១ ២៨:២៣
**២៣:១២** ណ កច ២០:៣ ត ខ.១៤,២១,៣០ កច ២៥:៣
**២៣:១៤** ថ ខ.១២
**២៣:១៥** ទ ខ.១ កច ២២:៣០ **២៣:១៦** ធ ខ.១០ កច ២១:៣៤

ប្រៀបដូចជាផ្លែល្វាទុំ ដែលខាងក្រៅមានសោភ័ណភាពល្អ ប៉ុន្តែខាងក្នុងវិញពេញទៅដោយធាតុពុករលួយ ។

**២៣:៥** *សំដេចសង្ឃទេ* មានមតិផ្សេងៗគ្នាជាច្រើន បានលើកឡើងអំពីមូលហេតុ ដែលធ្វើឱ្យលោកប៉ុលនិយាយយ៉ាងដូច្នេះ (១).មកពីភ្នែកគាត់មើលមិនឃើញច្បាស់ (មើលពន្យល់ កទ ៤:១៥ ៦:១១) (២).ព្រោះមានអ្នកដទៃទៀតអង្គុយនៅកន្លែងសម្តេចសង្ឃ ដូច្នោះហើយបានជាលោកប៉ុលមិនដឹងថាអ្នកណាជាសម្តេចសង្ឃ (៣).គាត់មានចេតនាប្រើពាក្យសំដីប្រៀបធៀបថាសម្តេចសង្ឃពិតប្រាកដមិនបញ្ជាឱ្យគេធ្វើដូច្នោះទេ (៤).គាត់បដិសេធមិនទទួលស្គាល់សម្តេចសង្ឃឈ្មោះអាន្នានាសនោះតែម្តង ។

**២៣:៦-៨** សាសន៍យូដាត្រូវបានបែងចែកទៅជាពីរក្រុមធំៗគឺ (១).*ពួកសាឌូសី* ពួកនេះជឿថាគ្មានការរស់ឡើងវិញ គ្មានទេវតា និងគ្មានវិញ្ញាណទេ (ខ.៨ មើល ការពន្យល់ ៤:១) (២).*ពួកផារិសី* ពួកនេះជឿថាមានការរស់ឡើងវិញ មានទេវតា និងមានវិញ្ញាណ (មើលការពន្យល់ មថ ៣:៧ មក ២:១៦ លក ៥:១៧)។ ពួកសាឌូសីតែងព្យាយាមយកចិត្តពួកអភិបាលរ៉ូម៉ាំង ដូច្នោះហើយបានជាតំណែងជាសម្តេចសង្ឃត្រូវបានជ្រើសរើសចេញអំពីពួកនេះ ។

**២៣:៩** លោកប៉ុលបានថ្លែងទៅកាន់ពួកក្រុមជំនុំថា គាត់បានឃើញព្រះគ្រីស្ទដែលមានព្រះជន្មរស់ទ្រង់មានព្រះបន្ទូលមកកាន់គាត់ ។ កាលបានឮដូច្នោះ ពួកផារិស៊ីយល់ឃើញថា គាត់គ្មានកំហុសអ្វីគួរឱ្យទទួលទោសទេ ដោយពួកគេគិតថា ប្រហែលជាទេវតា ឬព្រះវិញ្ញាណនៃព្រះអម្ចាស់មានបន្ទូលមកគាត់ ព្រោះពួកគេក៏ជឿដូច្នោះដែរ ។

**២៣:១០** *មេទ័ពធំ* "មើលការពន្យល់ ២១:៣១"។ លោកមេទ័ពធំបានចូលរួមស្តាប់ពួកក្រុមជំនុំសួរចម្លើយ ព្រោះចង់ដឹងថាតើលោកប៉ុលបានប្រព្រឹត្តនូវទោសកំហុសអ្វីបានជាពួកគេចង់សម្លាប់គាត់ ប៉ុន្តែផ្ទុយទៅវិញគ្មានទទួលបានព័ត៌មានអ្វីទាំងអស់ ។

**២៣:១១** *ព្រះអម្ចាស់ទ្រង់ឈរជិតគាត់* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថាព្រះអម្ចាស់ទ្រង់គង់នៅជាមួយអ្នកជឿដល់ព្រះនាមទ្រង់គ្រប់ពេលវេលាទាំងអស់ (១៨:៩ ២២:១៨ ២៧:២៣ មើលការពន្យល់ ២កថ ១២:៧-១០)។

**២៣:១២-១៥** *ពួកសាសន៍យូដាខ្លះរួមគំនិតគ្នាស្បថ* ពួកនោះប្រហែលមកពីពួកឧស្សាហ៍ ឬហៅថា "ក្រុមភេរវជន" (មើលការពន្យល់ ២១:៣៨) ដែលតែងតែបះបោរប្រឆាំងនឹងរបបគ្រប់គ្រងនៃចក្រភពរ៉ូម៉ាំង ។ ពួកយូដាតែងមានទម្លាប់ ស្បថមិនបរិភោគ ឬមិនផឹកអ្វីទាំងអស់ រហូតដល់កិច្ចការដែលពួកគេចង់ធ្វើនោះទទួលបានជោគជ័យ ។ ប៉ុន្តែ បើកិច្ចការត្រូវទទួលបរាជ័យនោះពួកគេអាចបានរួចផុតពីពាក្យសម្បថរបស់ខ្លួន ។

**២៣:១៦** ត្រង់ចំណុចនេះមិនបានបញ្ជាក់ច្បាស់ថា ក្មួយរបស់លោកប៉ុលដឹងអំពីគម្រោងការដែលពួកគេចង់សម្លាប់គាត់ តាមរបៀបណានោះទេ ប៉ុន្តែយោងតាមបទគម្ពីរ "បស ១០:២០ កច ១៥:១៨ មថ ៦:៨,៣២ ហព ៤:១៣ ១យយ ១:៥" គ្មានអ្វីដែលអាចលាក់បំបាំងចំពោះព្រះអម្ចាស់បានឡើយ ។

**២៣:១៧** លោកប៉ុលតែងតែមានគំនិតវិជ្ជមានជានិច្ចចំពោះសុវត្ថិភាពរបស់

នាំអ្នកកំឡោះនេះ ទៅឯលោកមេទ័ពធំទៅ ដ្បិតវា
មានរឿងខ្លះចង់ជំរាបលោក ១៨អ្នកនោះ ក៏នាំវាទៅឯ
លោកមេទ័ពធំជំរាបថា ប៉ុល ជាអ្នកទោស[ន] បានហៅខ្ញុំ
ហើយសូមខ្ញុំ ឱ្យនាំអ្នកកំឡោះនេះមកឯលោក វាមានរឿង
ខ្លះចង់ជំរាបដល់លោក ១៩មេទ័ពធំក៏ចាប់ដៃវា នាំទៅ
ដោយឡែក សួរថា ឯង មានរឿងអ្វី នឹងប្រាប់ដល់អញខ្លះ
២០វាជំរាបថា ពួកសាសន៍យូដាបានស្រុះចិត្តគ្នានឹងសូម
លោក ឱ្យនាំប៉ុលចុះទៅឯពួកក្រុមជំនុំ[ប]នៅវេលាថ្ងៃស្អែក
ធ្វើដូចជាចង់ ពិចារណាសួរ ពីដំណើរគាត់ឱ្យច្បាស់ឡើង[ផ]
២១ដូច្នេះ សូមលោកកុំព្រមតាមគេឡើយ ដ្បិតមានពួកគេ
ចំនួនជាង៤០នាក់[ព] បានលបចាំគាត់តាមផ្លូវ គេបានស្បថ
ថា មិនស៊ីមិនផឹកអ្វីឡើយ ទាល់តែបានសំឡាប់គាត់ចេញ[ភ]
ឥឡូវនេះ គេប្រុងប្រៀបជាស្រេចហើយ ចាំតែលោក
អនុញ្ញាតិឱ្យប៉ុណ្ណោះទេ ២២នោះមេទ័ពធំឱ្យអ្នកកំឡោះនោះ
ទៅវិញ ទាំងហាមមិនឱ្យប្រាប់ដល់អ្នកណា ពីដំណើរ
ដែលវាជំរាបលោកនោះឡើយ ។

## ការបញ្ជូនលោកប៉ុលទៅឯទីក្រុងសេសារា

២៣លោកក៏ហៅមេទ័ពរង២នាក់មកប្រាប់ថា ចូររៀប
ទាហានថ្មើរជើង២០០នាក់ ពលសេះ៧០ នឹងពលកាន់
លំពែង២០០ ឱ្យទាន់ក្នុងវេលាម៉ោង៩យប់នេះ[ម] ដើម្បីនឹង
ទៅឯសេសារា[យ] ២៤ហើយឱ្យមានជំនិះសំរាប់ប៉ុលជិះដែរ
ដើម្បីនឹងនាំទៅឯលោកភេលីច ជាចៅហ្វាយខេត្ត ដោយ
សុខសាន្ត[រ] ២៥លោកក៏ធ្វើសំបុត្រ១ច្បាប់ មានសេចក្តីបែប
ដូច្នេះថា ២៦សំបុត្រក្លូឌាស-លូស៊ា សូមក្រាបប្រណិប័តន៍[ល]
ចូលមកដល់លោកចៅហ្វាយភេលីច ដ៏ជាធំសូមទានជ្រាប[វ]
២៧មនុស្សនេះ ពួកសាសន៍យូដាបានចាប់ ហើយគេ
រៀបនឹងសំឡាប់បង់[ស] ប៉ុន្តែ ខ្ញុំនាំទាហានទៅទាន់ ដោះ
រួចពីពួកគេចេញ[ហ]ដោយបានឮថាជាសាសន៍រ៉ូមដូច្នេះ[ឡ]
២៨ហើយដែលខ្ញុំចង់ដឹងពីហេតុអ្វី បានជាគេចោទប្រកាន់វា
នោះខ្ញុំបាននាំចុះ ទៅមុខពួកក្រុមជំនុំរបស់គេ[អ] ២៩ក៏ឃើញ
ថាគេចោទប្រកាន់ ពីរឿងជជែកគ្នាខាងឯក្រិត្យវិន័យរបស់
គេទេ[ក] តែគ្មានហេតុអ្វី ដែលគួរឱ្យស្លាប់ ឬជាប់ចំណង
សោះឡើយ[ខ] ៣០កាលមានគេមកប្រាប់ខ្ញុំ[គ] ពីឧបាយកល[ឃ]
ដែលពួកសាសន៍យូដា គិតធ្វើដល់វា នោះខ្ញុំក៏បញ្ជូនមកឯ
លោកភ្លាម ទាំងប្រាប់ពួកអ្នកដើមចោទ[ង] ឱ្យគេមកចោទ
ប្រកាន់នៅចំពោះលោកចុះ សូមឱ្យលោកបានប្រកបដោយ
សេចក្តីសុខសាន្ត សេចក្តីគួរពុំគួរ សូមទានអភ័យទោស ។
៣១ដូច្នេះ ពួកពលក៏នាំយកប៉ុលទាំងយប់ ទៅឯក្រុង
អាន់ទីប៉ាទ្រីសតាមបង្គាប់ ៣២ស្អែកឡើង គេទុកពលសេះ[ច]
ឱ្យទៅជាមួយនឹងគាត់ រួចគេត្រឡប់មកឯបន្ទាយវិញ[ឆ]

**២៣:១៨** ន អភ ៣:១
**២៣:២០** ប ខ.១
ផ ខ.១៤,១៥
**២៣:២១** ព ខ.១៣
ភ ខ.១២,១៤
**២៣:២៣** ម ខ.៣៣
យ កច ៨:៤០
**២៣:២៤** រ ខ.២៦,៣៣ កច ២៤:១-៣,១០ ២៥:១៤
**២៣:២៦** ល លក ១:៣ កច ២៤:៣ ២៦:២៥
វ កច ១៥:២៣
**២៣:២៧** ស កច ២១:៣២ ហ កច ២១:៣៣ ឡ កច ២២:២៥-២៩
**២៣:២៨** អ កច ២២:៣០
**២៣:២៩** ក កច ១៨:១៥ ២៥:១៩
ខ ខ.៩
**២៣:៣០** គ ខ.២០,២១
ឃ កច ២០:៣
ង ខ.៣៥ កច ២៤:១៩ ២៥:១៦
**២៣:៣២** ច ខ.២៣ ឆ កច ២១:៣៤

ខ្លួន ព្រោះគាត់បានយល់ ពីបំណងព្រះហឫទ័យនៃព្រះអម្ចាស់សម្រាប់ជីវិតគាត់ ។ ហើយនៅក្នុងខនេះបញ្ជាក់ថា លោកប៉ុលមិនបានអង្គុយរង់ចាំទទួលទោស ដោយគ្មានគិតពិចារណានោះទេ ផ្ទុយទៅវិញ គាត់ខំប្រឹងដោះស្រាយគ្រប់បញ្ហាដោយប្រាជ្ញាដ៏ឆ្លៀវឆ្លាត ដែលព្រះអម្ចាស់បានប្រទានមកគាត់ ។ *មេទ័ពរង* "មើលការពន្យល់ ១០:១"។

**២៣:១៨-២១** លោកមេទ័ពធំមានសេចក្តីព្រួយបារម្ភក្នុងចិត្តជាខ្លាំងនៅពេលបានឮថាមានពួកយូដាខ្លះបានរួមគំនិតគ្នាចង់សម្លាប់លោកប៉ុល ពីព្រោះថា បើមានហេតុការណ៍អាក្រក់ណាមួយ កើតឡើងចំពោះអ្នកទោសដែលមានសញ្ជាតិរ៉ូម នោះគាត់ពិតជាត្រូវមានទោសយ៉ាងធ្ងន់ធ្ងរជាមិនខាន ។

**២៣:២២** *ទាំងហាមមិនឱ្យប្រាប់ដល់អ្នកណា* លោកមេទ័ពធំមានប្រសាសន៍យ៉ាងដូច្នេះ ព្រោះចង់ការពារសេចក្តីសុខសាន្តរបស់ក្មេងកំលោះនោះ និងមិនចង់ឱ្យអ្នកណាផ្សេងទៀតដឹង អំពីគម្រោងការដែលគាត់ចង់នាំលោកប៉ុលចេញពីបន្ទាយ (ខ.២៣) ។

**២៣:២៣** លោកមេទ័ពធំបានបញ្ជាឱ្យនាំលោកប៉ុល ទៅឯលោកអភិបាលរ៉ូម៉ាំង ឈ្មោះភេលីចនៅឯសេសារា ដើម្បីធ្វើការជំនុំជម្រះតាមច្បាប់ ដោយមានទាហានចំនួន៤៧០នាក់ទៅតាមការពារផង ព្រោះខ្លាចមានគេលបសម្លាប់គាត់ ។

**២៣:២៤** *លោកភេលីច ជាចៅហ្វាយខេត្ត* ឈ្មោះពេញរបស់លោកភេលីចគឺអាន់តូនី-ភេលីច ។ ស្តេចអធិរាជ ក្លូឌាស បានតែងតាំងលោកភេលីចឱ្យធ្វើជាចៅហ្វាយខេត្តយូដា ប្រហែលនៅឆ្នាំទី៥២គ.ស ។

**២៣:២៧** *ដោយបានឮថាជាសាសន៍រ៉ូមដូច្នេះ* លោកមេទ័ពធំនិយាយយ៉ាងដូច្នោះ គឺព្រោះតែចង់បាននូវការកោតសរសើរ អំពីពួកអភិបាលរ៉ូម៉ាំងប៉ុណ្ណោះ ។ គាត់មិនបានដឹងថាលោកប៉ុលមានសញ្ជាតិរ៉ូមទេ (២២:២៤,២៥) មុនពេលដែលបញ្ជាឱ្យគេវាយសួរចម្លើយគាត់ (ប៉ុល) នោះ។

**២៣:២៩** *តែគ្មានហេតុអ្វីដែលគួរឱ្យស្លាប់ ឬជាប់ចំណងសោះឡើយ* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា តាមច្បាប់របស់រ៉ូម៉ាំង លោកប៉ុលគ្មានទោសកំហុសអ្វីទាំងអស់ (សូមប្រៀបធៀបនឹង ១៨:១៣-១៦) ។

**២៣:៣០** *ឱ្យគេមកចោទប្រកាន់នៅចំពោះលោកចុះ* លោកមេទ័ពធំនិយាយយ៉ាងដូច្នោះ ព្រោះគាត់គិតថា ពួកអ្នកដើមចោទពិតជាមកជួបនឹងលោកភេលីចជាមិនខាន ក្នុងពេលដែលសំបុត្រនោះបានទៅដល់គាត់ (ភេលីច) ។

**២៣:៣១** *ក្រុងអាន់ទីប៉ាទ្រីស* ស្ថិតនៅចម្ងាយប្រហែល៤៥គ.មភាគខាងត្បូងទីក្រុងសេសារា និងប្រហែល១៤គ.ម ភាគខាងកើតនៃឆ្នេរសមុទ្រមេឌីទែ-រ៉ាណេ (មើលការពន្យល់ ៨:៤០) ។ ស្តេចហេរ៉ូឌ-អធិរាជបានកសាងទីក្រុងនេះឡើងវិញ ដោយដាក់ឈ្មោះថា អាន់ទីប៉ាទ្រីស ដែលជាឈ្មោះរបស់បិតា

៣៣កាលចូលក្រុងសេសារា[ជ] ហើយជូនសំបុត្រដល់លោក
ចៅហ្វាយ[ឈ] នោះក៏ប្រគល់ប៉ុលទៅលោកដែរ ។
៣៤កាលលោកបានមើលសំបុត្ររួចជាស្រេចហើយ នោះ
លោកសួរពីគាត់នៅខេត្តណាលុះជ្រាបថា នៅស្រុកគីលីគា
៣៥ក៏មានប្រសាសន៍ថា ចាំកាលណាពួកដើមចោទ[ដ] បានចុះ
មកដល់ នោះអញនឹងស្តាប់រឿងឯងសព្វគ្រប់ រួចលោក
បង្គាប់ឱ្យឃុំគាត់[ឋ] ទុកក្នុងសាលាជំនុំរបស់ស្តេចហេរ៉ូឌ ។

## ការកាត់ទោសនៅមុខលោកភេលីច

**២៤** ១ក្រោយ៥ថ្ងៃមក អាន់ានាស[ឌ] ជាសំដេចសង្ឃក៏ចុះ
ទៅជាមួយនឹងពួកចាស់ទុំ នាំទាំងមនុស្សម្នាក់មានវោហារ
ឈ្មោះទើទូលុសទៅផង ដើម្បីឱ្យចូលទៅប្តឹង[ឍ]លោកចៅ
ហ្វាយ ពីរឿងប៉ុល[ណ] ២កាលលោកបានហៅប៉ុលមក នោះ
ទើទូលុសចាប់ចោទប្រកាន់គាត់ថា ៣ឱព្រះតេជព្រះគុណ[ត]
ភេលីចអើយ សាសន៍យើងខ្ញុំបានសេចក្តីសុខប្រពៃ ដោយ
សារលោកម្ចាស់ ក៏មានចំរើនការផ្លាស់ប្រែយ៉ាងប្រសើរ
ដែលមានប្រយោជន៍ ដល់សាសន៍យើងខ្ញុំនេះ ដោយសារ
គំនិតលោកម្ចាស់ ហើយទោះបើនៅវេលាណា ឬកន្លែង
ណាក៏ដោយ គង់តែយើងខ្ញុំទទួលការទាំងនោះ ដោយ
អំណរ ទាំងអរគុណដល់លោកម្ចាស់គ្រប់ជីពូកដែរ ៤តែ
ដើម្បីកុំឱ្យបង្ខាតពេលលោកម្ចាស់ទៀត នោះសូមមេត្តា
ស្តាប់យើងខ្ញុំបន្តិច ៥ដ្បិតយើងខ្ញុំបានឃើញថា អ្នកនេះជា
មនុស្សចង្រៃ ជាមេនៃពួកណាសារ៉ែត[ថ] ដែលញុះញង់[ទ]
ឱ្យពួកសាសន៍យូដា[ធ]ទាំងអស់ នៅលោកីយ[ន]នេះបះបោរ
ឡើង ៦ក៏ចង់ធ្វើបង្អាប់ដល់ព្រះវិហារផង[ប] នោះយើងខ្ញុំ
បានចាប់វាមក ប្រាថ្នាចង់ជំនុំជំរះតាមក្រឹត្យវិន័យរបស់
យើងខ្ញុំ ៧ប៉ុន្តែ លោកលូស៊ា ជាមេទ័ពធំ បានមកកន្ត្រាក់
យកវាពីដៃយើងខ្ញុំទៅ ដោយអំណាចយ៉ាងសំបើម ៨ទាំង
បង្គាប់ឱ្យពួកដើមចោទមកឯលោកម្ចាស់ បើកាលណា
លោកម្ចាស់បានពិចារណាវា នោះនឹងបានជ្រាបពីគ្រប់
ទាំងការ ដែលយើងខ្ញុំចោទប្រកាន់ដល់វាហើយ ៩ឯពួក
សាសន៍យូដា[ផ] ក៏យល់ព្រមដែរ ដោយបញ្ជាក់ថា រឿងទាំង
នោះប្រាកដមែន ។

**២៣:៣៣** ជ កច ៨:៤០ ឈ ខ.២៦
**២៣:៣៤** ញ កច ៦:៩ ២១:៣៩
**២៣:៣៥** ដ ខ.៣០ កច ២៤:១៩ ២៥:១៦ ឋ កច ២៤:២៧
**២៤:១** ឌ កច ២៣:២ ឍ កច ២៣:៣០,៣៥ ណ កច ២៣:២៤
**២៤:៣** ត លក ១:៣ កច ២៣:២៦ ២៦:២៥
**២៤:៥** ថ មក ១:១៤ ទ កច ១៦:២០ ១៧:៦ ធ កច ២១:២៨ ន ខ.១៤ កច ២៦:៥ ២៨:២២
**២៤:៦** ប កច ២១:២៨
**២៤:៩** ផ ១ថន ២:១៦

ទ្រង់តែម្តង (បិតាស្តេច ហេរ៉ូឌមាននាមថា អាន់ទីប៉ាត្រុស) ។

**២៣:៣៣** *ក្រុងសេសារា* ស្ថិតនៅចម្ងាយប្រហែល ៤៥គ.ម ភាគខាងជើងទីក្រុងយេរូសាឡិម ។ ទីបញ្ជាការធំរបស់ពួករ៉ូម៉ាំងប្រ ចាំនៅស្រុកសាម៉ារី និងយូដា គឺនៅក្នុងទីក្រុងនេះ ។

**២៣:៣៤–៣៥** បន្ទាប់ពីបានអានសំបុត្ររបស់មេទ័ពធំរួចហើយ នោះលោកភេលីចក៏សម្រេចចិត្តរង់ចាំរហូតពួកអ្នកដើមចោទមកដល់ ទើបធ្វើការជំនុំជម្រះតែម្តង ។ ហើយក្នុងពេលជាមួយគ្នានោះដែរ លោកបានបញ្ជាឱ្យគេនាំលោកប៉ុលទៅស្នាក់នៅក្នុងសាលាជំនុំរបស់ស្តេចហេរ៉ូឌជាបណ្តោះអាសន្នសិន ។ *សាលាជំនុំរបស់ស្តេចហេរ៉ូឌ* ឃ្លានេះព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសសរសេរថា "វាំងរបស់ស្តេចហេរ៉ូឌ"។ ទីនោះពីមុនគឺជាវាំងសម្រាប់ស្តេចហេរ៉ូឌ-អធិរាជ ប៉ុន្តែក្រោយមកត្រូវបានយកធ្វើជាទីបញ្ជាការរបស់ពួករ៉ូម៉ាំងវិញ ។ ទីបញ្ជាការពួករ៉ូម៉ាំងមាននៅទីក្រុងមួយចំនួនដូចជាទីក្រុងរ៉ូម (ភល ១:១៣) ទីក្រុងអេភេសូរ ទីក្រុងយេរូសាឡិម (មើលការពន្យល់ យហ ១៨:២៣) ទីក្រុងសេសារា និងនៅតំបន់ផ្សេងៗទៀត ដែលស្ថិតនៅក្រោមការត្រួតត្រារបស់ចក្រភពរ៉ូម៉ាំងនាសម័យនោះ ។

**២៤:១** *ក្រោយ៥ថ្ងៃមក* រយៈពេល៥ថ្ងៃនោះគឺចាប់ផ្តើមគិតពីពេលដែលលោកប៉ុលចេញដំណើរពីទីក្រុងយេរូសាឡិម ។ រយៈពេលនោះក៏ល្មមគ្រប់គ្រាន់សម្រាប់ការធ្វើដំណើរពីទីក្រុងយេរូសាឡិមទៅឯទីក្រុងសេសារា និងសម្រាប់ពួកក្រុមជំនុំចាត់ចែងអ្នកតំណាង ដើម្បីមកចោទប្តឹងលោកប៉ុលផងដែរ ។ *អាន់ានាស* "មើលការពន្យល់២៣:២"។ អាន់ានាសម្នាក់នេះបានធ្វើដំណើរ៩៨គ.ម ទៅឯទីក្រុងសេសារា ដើម្បីធ្វើជាប្រមុខក្រុមជំនុំ ក្នុងការចោទប្រកាន់លោកប៉ុល ។ *ពួកចាស់ទុំ* ពាក្យថា"ពួកចាស់ទុំ"នៅត្រង់ចំណុចនេះ គឺសំដៅលើសមាជិកពួកក្រុមជំនុំដែលមានចំនួនជាមធ្យម ៧១ នាក់ ។ ពួកនេះមានសិទ្ធិជំនុំជម្រះសាសន៍យូដា ទាំងផ្នែកសាសនានិងផ្នែកនយោបាយសង្គម (មើលការពន្យល់ នក ៣:១៦ ២សយ ៣:១៧ យអ ១:២ មថ ១៥:២) ។ *មនុស្សម្នាក់មានវោហារ* ឃ្លានេះព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសខ្លះប្រើពាក្យថា "អ្នកច្បាប់ម្នាក់"។ *ទើទូលុស* គាត់មានសញ្ជាតិរ៉ូម និងជាអ្នកមានវោហារ (ឬអ្នកច្បាប់) ដែលពួកក្រុមជំនុំជួលឱ្យទៅចោទប្រកាន់ លោកប៉ុលនៅចំពោះមុខលោកចៅហ្វាយភេលីច ។

**២៤:២–៣** *សាសន៍យើងខ្ញុំបានសេចក្តីសុខប្រពៃ. . . ទាំងអរគុណដល់លោកម្ចាស់គ្រប់ជីពូកដែរ* ឃ្លានេះជាការសរសើរ ហើយជាសេចក្តីផ្តើមក្នុងការនិយាយនៅមុខចៅក្រមជម្រះក្តី ។ ក្នុងរយៈពេល៥ឆ្នាំដែលលោកភេលីចបានធ្វើជាចៅហ្វាយនៅខេត្តយូដា អំពើចោរកម្ម និងចលនាបះបោរប្រឆាំងដែលបង្កឡើងដោយពួកអេសុីព្ទ ត្រូវបានកាត់បន្ថយជាច្រើន (មើលការពន្យល់ ២១:៣៨)។ ប៉ុន្តែជាទូទៅ លោកភេលីចម្នាក់នេះមិនមានកេរ្តិ៍ឈ្មោះល្អប៉ុន្មានទេ ។

**២៤:៥** *អ្នកនេះជាមនុស្សចង្រៃ ជាមេនៃពួកណាសារ៉ែត* ទើទូលុសនិយាយយ៉ាងដូច្នេះ គឺក្នុងគោលបំណងចង់ឱ្យលោកប៉ុលទទួលទោសដ៏ធ្ងន់ធ្ងរ ព្រោះថា ការបង្កើតឱ្យមានការទាស់ប្រឆាំងគ្នា នៅក្នុងដែនដីចំណុះនៃចក្រភពរ៉ូម៉ាំង ជាអំពើក្បត់ជាតិ ហើយប្រឆាំងនឹងស្តេចអធិរាជសេសារទៀតផង ។ ម្យ៉ាងទៀត អ្នកដឹកនាំសាសនាទាំងឡាយណា ដែលគ្មានការទទួលស្គាល់ពីចក្រភពរ៉ូម៉ាំង ក៏មានន័យថាប្រឆាំងនឹងច្បាប់ដែរ ។ *ពួកណាសារ៉ែត* ទើទូលុសប្រើពាក្យនេះ គឺសំដៅលើអស់អ្នកជឿព្រះយេស៊ូវគ្រីស្ទតែម្តង ។

**២៤:៦** *ក៏ចង់ធ្វើបង្អាប់ដល់ព្រះវិហារផង* នេះជាសំដីចោទប្រកាន់ចំពោះលោកប៉ុលទាំងស្រុងតែម្តង និងមិនមែនជាការជជែករកខុសត្រូវតាមផ្លូវច្បាប់នោះទេ (មើលការពន្យល់ ២១:២៨)។

**២៤:៧–៩** ត្រង់ចំណុចនេះបញ្ជាក់ច្បាស់ថា ទើទូលុសព្យាយាមទម្លាក់កំហុសលើលោកប៉ុលយ៉ាងពេញទំហឹង ព្រោះថាអ្វីដែលគាត់និយាយនៅមុខលោក

១០កាលលោកចៅហ្វាយ[ព]បានធ្វើគ្រឿងសំគាល់ ឱ្យប៉ុល
និយាយ នោះគាត់ឆ្លើយឡើងថា ខ្ញុំប្របាទនឹងដោះសារឿង
ខ្លួនដោយអំណរ ដោយដឹងថា ព្រះតេជព្រះគុណបានធ្វើជា
ចៅក្រមលើសាសន៍នេះជាយូរឆ្នាំហើយ ១១ក៏អាចនឹងជ្រាប
ថា តាំងពីខ្ញុំប្របាទឡើងទៅថ្វាយបង្គំ ឯក្រុងយេរូសាឡិម
នោះមិនលើសពី១២ថ្ងៃទេ[ភ] ១២គេក៏មិនបានឃើញខ្ញុំប្របាទ
កំពុងដែលជជែកនឹងអ្នកណា នៅក្នុងព្រះវិហារ[ម] ឬប្រ
មូលញុះញង់បណ្តាមនុស្សដែរ[យ] ទោះបើក្នុងសាលាប្រជុំគេ
ឬកន្លែងណានៅក្នុងទីក្រុងក្តី ១៣គេពុំអាចនឹងរកភស្តុតាង
ពីការដែលគេចោទខ្ញុំប្របាទឥឡូវនេះបានទេ[រ] ១៤ប៉ុន្តែ
សូមជំរាបលោកម្ចាស់តាមត្រង់ថា ខ្ញុំប្របាទគោរពប្រតិបត្តិ
ដល់ព្រះនៃពួកឰយុកោយើងខ្ញុំ[ល] តាមរបៀប[វ]ដែលគេហៅ
ថា ក្បត់សាសនា[ស] ដោយមានសេចក្តីជំនឿដល់អស់ទាំង
សេចក្តី ដែលចែងទុកមកក្នុងក្រិត្យវិន័យ និងក្នុងគម្ពីរពួក
ហោរា[ហ] ១៥ហើយខ្ញុំប្របាទមានសេចក្តីសង្ឃឹមដល់ព្រះ
ដែលគេក៏យល់ព្រមដែរ គឺថា ទាំងមនុស្សសុចរិត និង
មនុស្សទុច្ចរិត នឹងបានរស់ឡើងវិញ[ឡ]ទាំងអស់គ្នា[អ] ១៦ហេតុ
នោះបានជាខ្ញុំប្របាទខំប្រឹងឱ្យ មានបញ្ញាចិត្តឥតសៅហ្មង[ក]
នៅចំពោះព្រះ និងនៅចំពោះមនុស្សលោកជានិច្ចដែរ
១៧លុះក្រោយដែលខ្ញុំប្របាទបានចោលស្រុកទៅជាយូរ
ឆ្នាំ នោះក៏ត្រឡប់មកធ្វើទានវិញ ព្រមទាំងយកជំនូន
មកជូនដល់សាសន៍របស់ខ្ញុំប្របាទ[ខ] ១៨ហើយកំពុងដែលខ្ញុំ
ប្របាទរវល់នឹងការនោះ គេក៏ឃើញខ្ញុំប្របាទបានញែកជា
បរិសុទ្ធ[គ] នៅក្នុងព្រះវិហារ មិនមែនមានមនុស្សទាំងហ្វូង
ឬដោយវឹកវរទេ[ឃ] ប៉ុន្តែមានពួកសាសន៍យូដាខ្លះ ពីស្រុក
អាស៊ី[ង] បានឃើញខ្ញុំប្របាទ ១៩ដែលគួរ ឱ្យគេមកចោទ
ប្រកាន់ខ្ញុំប្របាទ នៅមុខលោកម្ចាស់វិញ បើសិនជាគេមាន
រឿងអ្វីទាស់នឹងខ្ញុំប្របាទ[ច] ២០ឬឱ្យអ្នកទាំងនេះធ្វើបន្ទាល់ចុះ
បើគេឃើញខ្ញុំប្របាទមានសេចក្តីទុច្ចរិតណា ក្នុងកាល
ដែលឈរនៅមុខក្រុមជំនុំនោះ ២១លើកតែពាក្យ១ម៉ាត់នេះ
ចេញ ដែលខ្ញុំប្របាទស្រែកឡើង នៅពេលកំពុងឈរជា
កណ្តាលពួកគេថា ថ្ងៃនេះខ្ញុំត្រូវអ្នករាល់គ្នាជំនុំជំរះ ពី
ដំណើររស់ពីស្លាប់ឡើងវិញប៉ុណ្ណោះ[ឆ]។

**២៤:១០** ព កច ២៣:២៤
**២៤:១១** ភ ខ.១ កច ២១:២៧
**២៤:១២** ម កច ២៥:៨ ២៨:១៧ យ ខ.១៨
**២៤:១៣** រ កច ២៥:៧
**២៤:១៤** ល កច ៣:១៣ វ កច ៩:២ ស ខ.៥ ហ កច ២៦:៦,២២ ២៨:២៣
**២៤:១៥** ឡ កច ២៣:៦ ២៨:២០ អ មថ ២៥:៤៦
**២៤:១៦** ក កច ២៣:១
**២៤:១៧** ខ កច ១១:២៩,៣០ រម ១៥:២៥–២៨,៣១ ១កថ ១៦:១–៤,១៥ ២កថ ៨:១–៤ កទ ២:១០
**២៤:១៨** គ កច ២១:២៦ ឃ ខ.១២ ង កច ២:៩
**២៤:១៩** ច កច ២៣:៣០ **២៤:២១** ឆ កច ២៣:៦

ចៅហ្វាយភេលីចនោះ សុទ្ធតែជាសេចក្តីមិនពិត ។

**២៤:១០** *បានធ្វើគ្រឿងសំគាល់* ឃ្លានេះអាចមានន័យថា ធ្វើសញ្ញាដោយដៃ ឬដោយពាក្យសំដី ដើម្បីឱ្យអ្នកដទៃចាប់អារម្មណ៍ ឬស្តាប់នូវអ្វីដែលខ្លួនចង់និយាយ ។ *ធ្វើជាចៅក្រមលើសាសន៍នេះជាយូរឆ្នាំហើយ* លោកប៉ុលផ្តើមនិយាយដោយត្រង់ៗតែម្តង និងពុំបានទម្លាក់កំហុសទៅលើអ្នកណាម្នាក់ ដូចដែលទើទូលុសបានធ្វើនោះទេ (ខ.២–៤) ព្រោះគាត់ដឹងថា លោកភេលីចមានបទពិសោធន៍ច្រើន ទាក់ទងទៅនឹងរឿងប្តឹងប្តល់ ហើយនិងហេតុការណ៍ដែលកើតឡើងនៅក្នុងចំណោមពួកសាសន៍យូដា ។

**២៤:១១** *មិនលើសពី១២ថ្ងៃទេ* គឺ៧ថ្ងៃនៅទីក្រុងយេរូសាឡិម និង៥ថ្ងៃនៅឯទីក្រុងសេសារា ។ ក្នុងរយៈពេល១២ថ្ងៃនោះ លោកប៉ុលបានប្រព្រឹត្តសុចរិតត្រឹមត្រូវ និងមិនបានបង្ករឿងហេតុជាមួយនឹងអ្នកណាម្នាក់ឡើយ ។ ដូច្នេះអ្វីដែលពួកដើមចោទបានលើកឡើង សុទ្ធតែជាពាក្យមួលបង្កាច់ទាំងស្រុង ។ ជាងនេះទៅទៀត មានមនុស្សជាច្រើន ដែលអាចធ្វើជាសាក្សីបញ្ជាក់ថា លោកប៉ុលពិតជាពុំបាន ធ្វើអ្វីឱ្យខុសនឹងច្បាប់ទម្លាប់ណាមួយរបស់ពួកគេនោះទេ ។

**២៤:១២–១៣** ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា លោកប៉ុលមិនបានបង្កហេតុនៅក្នុងព្រះវិហារ ឬញុះញង់បណ្តាជនទេ ហើយអ្វីដែលពួកដើមចោទបានលើកឡើងនោះក៏គ្មានភស្តុតាងដែរ ។

**២៤:១៤** *គោរពប្រតិបត្តិដល់ព្រះ. . . ដោយមានសេចក្តីជំនឿ* លោកប៉ុលពុំគ្រាន់តែបានទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះសង្គ្រោះប៉ុណ្ណោះទេ គឺគាត់ថែមទាំងប្រតិបត្តិគ្រប់ទាំងសេចក្តី ដែលបានចែងមកតាមរយៈពួកហោរារបស់ទ្រង់ផង ។

**២៤:១៥** ពួកយូដាភាគច្រើនមានសេចក្តីសង្ឃឹមថានឹងមានការរស់ឡើង និងការជំនុំជម្រះនៅថ្ងៃចុងបំផុតនោះ (យហ ១២:៤៨)។ មានតែពួកសាឌូស៊ីប៉ុណ្ណោះ ដែលមិនជឿថាមានការរស់ឡើងវិញ និងការជំនុំជម្រះ ។

**២៤:១៦** *បញ្ញាចិត្តឥតសៅហ្មង* "មើលការពន្យល់ ២៣:១"។

**២៤:១៧** *ជាយូរឆ្នាំ នោះក៏ត្រឡប់មកធ្វើទានវិញ* លោកប៉ុលនិយាយយ៉ាងដូច្នោះ ព្រោះចង់បង្ហាញពីគោលបំណង ដែលគាត់មកទីក្រុងយេរូសាឡិម គឺដើម្បីនាំយកជំនូនមកជូនដល់ពួកបងប្អូនដែលខ្វះខាតប៉ុណ្ណោះ (មើលការពន្យល់ ២០:៤)។ *សាសន៍របស់ខ្ញុំប្របាទ* គឺសំដៅទៅលើពួកអ្នកជឿដល់ព្រះយេស៊ូវនៅស្រុកយូដា ដែលកំពុងជួបការលំបាក និងការបៀតបៀន (មើលការពន្យល់ ២១:២៤)។

**២៤:១៨** *ពួកសាសន៍យូដាខ្លះពីស្រុកអាស៊ីបានឃើញខ្ញុំប្របាទ* (២១:២៧–២៩) ពួកដើមចោទគ្មានជំនឿចិត្ត ក្នុងការចោទប្រកាន់លោកប៉ុលទេ ព្រោះថាពួកយូដាដែលបានឃើញគាត់នៅក្នុងព្រះវិហារ មិនបានមកចូលរួមជជែកនៅក្នុងពេលជំនុំជម្រះក្តីនៅមុខលោកភេលីចនោះឡើយ ។

**២៤:១៩** *គួរឱ្យគេមកចោទប្រកាន់ខ្ញុំប្របាទនៅមុខលោកម្ចាស់វិញ* ពួកអ្នកដែលបានឃើញលោកប៉ុលនៅក្នុងព្រះវិហារ ពុំបានមកចូលរួមចោទប្រកាន់គាត់ដោយផ្ទាល់ទេ គឺមានតែពួកអ្នក ដែលមិនបានឃើញហេតុការណ៍ប៉ុណ្ណោះ ។ ដូច្នោះហើយ បានជាលោកប៉ុលសូមឱ្យលោកភេលីចនាំយកសាក្សីពិតប្រាកដ មកស្រាយបំភ្លឺឱ្យបានច្បាស់លាស់ ។

**២៤:២១** *ពីដំណើររស់ពីស្លាប់ឡើងវិញប៉ុណ្ណោះ* ពួកសាឌូស៊ី និងពួកផារិស៊ីតែងមានទំនាស់នឹងគ្នាដោយសារតែសេចក្តីនេះ (២៣:៦–៨)។ ពេលដែលលោកប៉ុលនិយាយអំពីដំណើររស់ពីស្លាប់ឡើងវិញ នោះធ្វើឱ្យពួកក្រុមជំនុំដែលមានសមាជិក ខ្លះជាពួកសាឌូស៊ី (ពួកសាឌូស៊ីជឿថា គ្មានការរស់ពីស្លាប់ឡើងវិញទេ) ហើយខ្លះទៀតជាពួកផារិស៊ី (ពួកផារិស៊ីជឿថា មានការរស់ពី

២២ឯលោកភេលីច ដែលដឹងជ្រៅជ្រះខាងសាសនាគេ
ដែរ[ង] កាលបានស្តាប់សេចក្តីចោទឆ្លើយរួចហើយ នោះ
លោកក៏ផ្អាករឿងនោះសិន ដោយថា កាលណា លោក
លូស៊ា ជាមេទ័ពធំបានចុះមក នោះចាំខ្ញុំនឹងពិចារណារឿង
អ្នករាល់គ្នាទៀត ២៣រួចលោកបង្គាប់មេទ័ពរង ឱ្យរក្សា[ឈ]
ប៉ុលដោយស្រួលបួល ឥតឃាត់ហាមពួកគាត់ណាមួយ[ញ]
មិន ឱ្យមកបំរើគាត់នោះឡើយ[ដ] ២៤លុះប្អូនដប់ថ្ងៃក្រោយ
មកលោកភេលីចមកដល់ ជាមួយនឹងទ្រូស៊ីលជាភរិយា
ដែលជាសាសន៍យូដា រួចលោកចាត់គេទៅនាំប៉ុលមក
ក៏ស្តាប់គាត់អធិប្បាយពីសេចក្តីជំនឿ ជឿដល់ព្រះគ្រីស្ទ[ឋ]
២៥កំពុងដែលគាត់សំដែង ពន្យល់ពីសេចក្តីសុចរិត
សេចក្តីដឹងខ្នាត[ឌ] និងសេចក្តីជំនុំជំរះ[ឍ] ដែលត្រូវមក
នោះលោកភេលីចកើតមានចិត្តភិតភ័យ[ណ] ក៏ឆ្លើយ ថា

**២៤:២២** ដ កច ៩:២
**២៤:២៣** ឈ កច ២៣:៣៥ ញ កច ២៨:១៦ ដ កច ២៣:១៦ ២៧:៣
**២៤:២៤** ឋ កច ២០:២១
**២៤:២៥** ឌ កទ ៥:២៣ ១ថន ៥:៦ ១ពត ៤:៧ ៥:៨ ២ពត ១:៦ ឍ កច ១០:៤២ ណ យរ ៣៦:១៦
**២៤:២៧** ត កច ២៥:១,៤,៩,១៤ ថ កច ១២:៣ ២៥:៩ ទ កច ២៣:៣៥ ២៥:១៤

ឥឡូវនេះ ឱ្យទៅសិនចុះ កាលណាមានឱកាសស្រួល
នោះអញនឹងហៅឯងមកទៀត ២៦លោកក៏សង្ឃឹមថា ប៉ុល
នឹងយកប្រាក់មកសូកលោក ឱ្យលែងចេញដែរ ហេតុនោះ
បានជាលោកឱ្យគេនាំគាត់ មកពិគ្រោះកាន់តែញឹកញយ
ឡើង ២៧ប៉ុន្តែ លុះបានកន្លងមកបាន២ឆ្នាំហើយ នោះមាន
លោក ព័រគាស-ភេស្ទុស[ត] មកឈរជំនួសលោកភេលីច
ហើយដោយព្រោះ លោកភេលីចចង់បានបំណាច់ ចំពោះ
សាសន៍យូដាផង[ថ] បានជាលោកទុកឱ្យប៉ុលជាប់គុកនៅ[ទ] ។

## ការកាត់ទោសនៅមុខលោកភេស្ទុស

**២៥** ១លុះកាលលោកភេស្ទុស[ធ] បានចូលមកក្នុងខេត្ត
នោះក្រោយ៣ថ្ងៃ លោកក៏ឡើងពីសេសារា[ន] ទៅឯក្រុង
យេរូសាឡិម ២ឯពួកសង្គ្រាជ នឹងពួកមេសាសន៍យូដា គេ

**២៥:១** ធ កច ២៤:២៧ ន កច ៨:៤០

ស្លាប់ឡើងវិញ) មានការខ្វែងគំនិតគ្នាជាខ្លាំង ។

**២៤:២២** *ដឹងជ្រៅជ្រះខាងសាសនាគេដែរ* លោកភេលីចបានធ្វើជាចៅហ្វាយនៅស្រុកយូដា និងស្រុកសាម៉ារី អស់រយៈពេល៦ឆ្នាំហើយ ដូច្នោះគាត់ពិតជាបានយល់ដឹងអំពីទីកន្លែង និងសកម្មភាពទាំងឡាយដែលកើតឡើងនៅក្នុងតំបន់ រួមទាំងបញ្ហាដែលទាក់ទងទៅនឹងពួកអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទផងដែរ ។

**២៤:២៣** *ឥតឃាត់ហាមពួកគាត់ណាមួយ មិនឱ្យមកបំរើគាត់នោះឡើយ* ការដែលលោកភេលីចឃុំលោកប៉ុលទុកនោះគឺព្រោះតែមិនចង់ឱ្យមានទំនាស់ជាមួយពួកសាសន៍យូដា ហើយម្យ៉ាងទៀតគាត់សង្ឃឹមថា នឹងទទួលបានសំណូកអំពីមិត្តភក្តិរបស់លោកប៉ុលផង ។ ការឃុំខ្លួនលោកប៉ុលនៅពេលនោះមានភាពស្រដៀងគ្នា ទៅនឹងការឃុំខ្លួនគាត់ នៅឯទីក្រុងរ៉ូមដែរ (២៨:៣០–៣១) ។ តាមច្បាប់រ៉ូម៉ាំង លោកប៉ុលគ្មានកំហុសអ្វីដែលត្រូវទទួលទោសទេ ។

**២៤:២៤** *ទ្រូស៊ីល* ទ្រូស៊ីលម្នាក់នេះជាសាសន៍យូដា និងជាបុត្រីរបស់ស្តេចហេរ៉ូឌ អ័គ្រីប៉ាទី១ ហើយជាភរិយាទី៣របស់លោកភេលីច ។ កាលមានព្រះជន្ម១៥វស្សា ព្រះនាងបានរៀបអភិសេកជាមួយនឹងស្តេចអាហ្ស៊ីហ្សូស (Azizus ) នៃអេមេសា (Emesa ) ប៉ុន្តែ មួយឆ្នាំក្រោយមក ព្រះនាងបានទៅរួមរស់ជាមួយនឹងលោកភេលីចវិញ ។ ព្រះនាងទ្រូស៊ីល និងបុត្រាត្រូវបានសុគតនៅឯទីក្រុងរ៉ូម ដោយសារឥទ្ធិពលបន្ទុះភ្នំភ្លើង នៅភាគខាងត្បូងឆៀងខាងកើតនៃប្រទេសអ៊ីតាលី នាឆ្នាំទី៧៩គ.ស ។

**២៤:២៥** *លោកភេលីចកើតមានចិត្តភ័យ* ដោយបានឮលោកប៉ុលពន្យល់អំពីសេចក្តីសុចរិត សេចក្តីដឹងខ្នាត និងសេចក្តីជំនុំជម្រះ នោះធ្វើឱ្យភេលីចសម្លឹងមើលទៅជីវិតអតីតកាលរបស់ខ្លួន ដែលធ្លាប់តែប្រព្រឹត្តផ្ទុយនឹងសេចក្តីទាំងនេះ ដូច្នោះគាត់ក៏មានចិត្តភ័យ ។ ហើយដោយព្រោះតែសេចក្តីវង្វេង អំនួត ការលោភលន់ ការគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន នោះធ្វើឱ្យគាត់ពិបាកនឹងប្រែចិត្តចេញអំពីផ្លូវនៃជីវិតចាស់ជាខ្លាំង ។

**២៤:២៦** *យកប្រាក់មកសូកលោក* លោកភេលីចបានដឹងថាលោកប៉ុលនាំយកប្រាក់ដង្វាយមួយចំនួន ទៅជួយពួកជំនុំនៅឯទីក្រុងយេរ៉ូសាឡិម (ខ.១៧) ។ ដូច្នោះ គាត់ក៏មានបំណងឱ្យលោកប៉ុលយកប្រាក់ទាំងនោះមកសូក ដើម្បីឱ្យបានរួចខ្លួន ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏លោកប៉ុលមិនព្រមធ្វើតាមបំណងចិត្តដ៏អាក្រក់របស់ភេលីចនោះដែរ ។

**២៤:២៧** *លោកព័រគាស–ភេស្ទុស មកឈរជំនួសលោកភេលីច* លោកភេលីចត្រូវបានហៅទៅទីក្រុងរ៉ូមនៅឆ្នាំទី ៥៩ ឬ ៦០ គ.ស ដើម្បីបកស្រាយ និងឆ្លើយបំភ្លឺអំពីភាពចលាចល និងភាពអយុត្តិធម៌ នៅក្នុងរយៈពេលនៃការកាន់អំណាចរបស់គាត់ ដូចជាទំនាស់រវាងពួកយូដា និងពួកស៊ីរីជាដើម ។ ចំណែកឯលោកភេស្ទុសវិញ គេមិនបានស្គាល់ច្បាស់អំពីការងារ និងតួនាទីរបស់គាត់នៅមុនពេលដែលគាត់មកធ្វើជាចៅហ្វាយនៅស្រុកយូដានោះទេ ។ ប៉ុន្តែ គាត់ជាមនុស្សមានប្រាជ្ញា និងស្មោះត្រង់ បើប្រៀបធៀបទៅនឹងលោកភេលីច ដែលកាន់តំណែងមុនគាត់ ហើយនិងលោកអាល់ប៊ីនូស (Albinus ) ដែលទទួលតំណែងបន្ទាប់ពីគាត់ ។ លោកភេស្ទុសបានស្លាប់ បន្ទាប់ពីទទួលតំណែងជាចៅហ្វាយនៅស្រុកយូដាបាន២ឆ្នាំ ។ *ដោយព្រោះលោកភេលីចចង់បានបំណាច់* លោកភេលីចខ្លាចពួកយូដាមានកំហឹង និងធ្វើការបះបោរបណ្តាលឱ្យមានភាពចលាចលកាន់តែខ្លាំង នៅក្នុងស្រុក ជាហេតុនាំឱ្យមានផលប៉ះពាល់ដល់យសស័ក្តិរបស់ខ្លួន បើហេតុការណ៍ទាំងនោះបានឮទៅដល់ពួកអភិបាលរ៉ូម៉ាំង ។ ម្យ៉ាងទៀត ការដែលដោះលែងលោកប៉ុល ក៏ជាមូលហេតុមួយ ធ្វើឱ្យពួកយូដាមានកំហឹងជាខ្លាំងដែរ ។ ដូច្នោះហើយ បានជាលោកភេលីចបង្ខំចិត្តឃុំខ្លួនលោកប៉ុល រហូតដល់គេបញ្ឈប់គាត់ពីតំណែង ។

**២៥:១** *លោកភេស្ទុស បានចូលមកក្នុងខេត្ត* មានន័យថាលោកភេស្ទុសចូលមកកាន់តំណែងជាចៅហ្វាយខេត្តយូដា ។ *សេសារាទៅឯក្រុងយេរូសាឡិម* ពីទីក្រុងសេសារាទៅទីក្រុងយេរូសាឡិមមានចម្ងាយប្រហែល ១១២ គ.ម ។ លោកភេស្ទុសចង់ធ្វើដំណើរទៅឯទីក្រុងយេរូសាឡិម ព្រោះទីនោះជាមជ្ឈ-មណ្ឌលដ៏សំខាន់សម្រាប់ពួកអ្នកដឹកនាំសាសន៍យូដា ហើយជាកន្លែងដែលពួកគេថ្វាយបង្គំផង ។ ម្យ៉ាងទៀត លោកភេស្ទុសក៏ចង់ឱ្យបណ្តាជនទាំងឡាយបានស្គាល់គាត់ដែរ ព្រោះគាត់ទើបតែទទួលតំណែងថ្មីៗ ។

**២៥:២** *ពួកសង្គ្រាជ និងពួកមេសាសន៍យូដា* គឺពួកក្រុមជំនុំ (មើលពន្យល់

ចូលទៅជិរាបលោក ពីដំណើរប៉ុល[ប] ៣ហើយសូមអង្វរឱ្យ
លោកអនុញ្ញាត ចាត់គេឱ្យទៅនាំគាត់ មកក្រុងយេរូសាឡិម
វិញ ពីព្រោះគេមត់គ្នានឹងសំឡាប់គាត់តាមផ្លូវ[ផ] ៤តែលោក
ភេស្ទុសឆ្លើយថា ត្រូវតែឃុំប៉ុលទុក[ព] នៅក្រុងសេសារា
នោះ[ភ] ចាំបន្តិចទៀត ខ្លួនខ្ញុំនឹងទៅឯណោះដែរ ៥ដូច្នេះ
លោកប្រាប់ថា ចូរអស់អ្នកដែលមានអំណាច ក្នុងពួកអ្នក
រាល់គ្នា ចុះទៅជាមួយគ្នា បើមនុស្សនោះមានទោសអ្វី
នោះត្រូវឱ្យចោទប្រកាន់វាចុះ ៦កាលបានស្នាក់នៅក្នុងទី
ក្រុងគេជាង១០ថ្ងៃ នោះក៏ចុះទៅឯសេសារាវិញ ដល់ថ្ងៃ
ស្អែកឡើង លោកអង្គុយនៅទីជំនុំជំរះក្តី[ម] ហើយបង្គាប់ឱ្យ
គេនាំប៉ុលមក[យ] ៧លុះគាត់ចូលមកដល់ នោះពួកសាសន៍
យូដា ដែលចុះពីក្រុងយេរូសាឡិមមក គេឈរនៅជុំវិញ
ក៏ចោទគាត់ពីរឿងធ្ងន់ៗជាច្រើន[រ] ដែលគេមិនអាចនឹងរក
ភស្តុតាងបាន[ល] ៨តែគាត់ដោះសាខ្លួនថា ខ្ញុំប្របាទមិនបាន
ធ្វើបាបអ្វីសោះ ទោះនឹងក្រឹត្យវិន័យរបស់សាសន៍យូដា ឬនឹង
ព្រះវិហារ[វ] ឬនឹងសេសារក្តី ៩តែលោកភេស្ទុសចង់បាន បំ
ណាច់ចំពោះពួកសាសន៍យូដា[ស] ក៏សួរទៅប៉ុលថាឯងសុខចិត្ត
ឡើងទៅឯក្រុងយេរូសាឡិម ឱ្យអញជំនុំជំរះឯងពីដំណើរ
នេះឬទេ[ហ] ១០នោះប៉ុលឆ្លើយថា ខ្ញុំប្របាទឈរនៅមុខទីជំ
នុំជំរះក្តី នៃសេសារ ជាកន្លែងដែលគួរជំនុំជំរះខ្ញុំប្របាទ ខ្ញុំ
ប្របាទគ្មានធ្វើខុសអ្វី នឹងពួកសាសន៍យូដាទេ[ឡ] ដូចជាព្រះ
តេជ ព្រះគុណក៏ជ្រាបច្បាស់ហើយ ១១បើសិនជាខ្ញុំប្របាទ
បានធ្វើអ្វីខុស ឬដែលគួរនឹងស្លាប់ នោះខ្ញុំប្របាទក៏យល់
ព្រមនឹងស្លាប់ឥតប្រកែក តែបើរឿងដែលគេចោទខ្ញុំប្រ
បាទមិនពិតវិញ នោះគ្មានអ្នកណាអាចនឹងបញ្ជូនទៅឱ្យ
គេបានឡើយ ខ្ញុំប្របាទសូមរើក្តីនេះដល់សេសារវិញ[អ]
១២ក្រោយដែលភេស្ទុសបានពិគ្រោះនឹងក្រុមជំនុំ នោះ

**២៥:២** ប ខ.១៥ កច ២៤:១
**២៥:៣** ផ កច ២០:៣
**២៥:៤** ព កច ២៤:២៣
ភ កច ៨:៤០
**២៥:៦** ម ខ.១៧
យ ខ.១០
**២៥:៧** រ មក ១៥:៣ លក ២៣:២,១០ កច ២៤:៥,៦
ល កច ២៤:១៣
**២៥:៨** វ កច ៦:១៣ ២៤:១២ ២៨:១៧
**២៥:៩** ស កច ២៤:២៧ ១២:៣
ហ ខ.២០
**២៥:១០** ឡ ខ.៨
**២៥:១១** អ ខ.២១,២៥ កច ២៦:៣២ ២៨:១៩

មក ១៤:៥៥)។ ពួកអ្នកដឹកនាំសាសន៍យូដាបានព្យាយាមរកឱកាសសម្លាប់លោកប៉ុលជានិច្ច។ ហេតុដូច្នោះហើយបានជានៅពេលដែលលោកភេស្ទុសមកដល់ទីក្រុងយេរូសាឡិមភ្លាម ពួកគេក៏ប្រញាប់ប្រញាល់ចូលទៅជួបដើម្បីសូមគាត់ឱ្យប្រគល់ប៉ុលមកពួកគេ ។

**២៥:៣** *ព្រោះគេមត់គ្នា* ពួកអ្នកដែលត្រៀមចាំសម្លាប់លោកប៉ុលគឺប្រហែលជាពួកសាសន៍យូដា ដែលរួមគំនិតគ្នាស្បថពីពេលមុននោះតែម្តង (មើលការពន្យល់ ២៣:១២)។

**២៥:៤-៥** ទោះជាលោកភេស្ទុសទើបទទួលតំណែងថ្មីៗក៏ដោយក៏លោកមិនបណ្តោយឱ្យលោកប៉ុលជាជាតិរ៉ូម ធ្លាក់ទៅក្នុងដៃរបស់ពួកសាសន៍យូដាដែលកំពុងតែពេញទៅដោយកំហឹងនោះដែរ ។ ផ្ទុយទៅវិញ លោកបានសម្រេចចិត្តស្តាប់ការបកស្រាយរបស់លោកប៉ុលនៅឯសេសារា ដោយផ្ទាល់វិញ ។

**២៥:៦** *លោកអង្គុយនៅទីជំនុំជំរះក្តី* ដើម្បីជំនុំជម្រះរឿងក្តីលោកប៉ុល ។ *ហើយបង្គាប់ឱ្យគេនាំប៉ុលមក* នៅពេលនោះលោកប៉ុលស្ថិតនៅក្រោមការការពាររបស់ពួកទាហាន ប៉ុន្តែមិនមានជាប់ចំណងទេ ។

**២៥:៧** *ដែលគេមិនអាចនឹងរកភស្តុតាងបាន* ជាថ្មីម្តងទៀត ពួកដើមចោទគ្មានសាក្សី និងភស្តុតាងអ្វីដែលបញ្ជាក់អំពីទោសកំហុសរបស់លោកប៉ុលនោះទេ (២៤:២-៤)។

**២៥:៨** *មិនបានធ្វើបាបអ្វីសោះ ទោះនឹងក្រិត្យវិន័យ* លោកប៉ុលមិនបានប្រឆាំងនឹងក្រឹត្យវិន័យ ដូចដែលពួកគេចោទប្រកាន់នោះទេ ព្រោះគាត់តែងប្រតិបត្តិតាមគ្រប់ទាំងសេចក្តី ដែលមានចែងទុកនៅក្នុងព្រះគម្ពីរបរិសុទ្ធរបស់ព្រះអម្ចាស់ជានិច្ច (រម ៧:១២ ៨:៣-៤ មើលពន្យល់ ១កថ ៩:២០)។ *ឬនឹងព្រះវិហារ* "មើលការពន្យល់ ២១:២៨-២៩"។ លោកប៉ុលពុំបាននាំយកលោកទ្រភីមចូលទៅទីកន្លែងហាមឃាត់នៅក្នុងព្រះវិហារ ដែលជាការមួយប្រឆាំងនឹងទំនៀមទម្លាប់របស់ពួកសាសន៍យូដានោះទេ (២១:២៩)។ *ឬនឹងសេសារក្តី* លោកប៉ុលប្រកាសតែអំពីនគរព្រះប៉ុណ្ណោះ ហើយថែមទាំងគោរពច្បាប់ (រម ១៣:១-៧) និងអធិស្ឋានឱ្យពួកអ្នកដឹកនាំរដ្ឋាភិបាលទៀតផង (១ធថ ២:១,២) ប៉ុន្តែ ពួកគេបែរជាចោទគាត់ថា បានប្រឆាំងនឹងស្តេចអធិរាជនៃចក្រភពរ៉ូម៉ាំងនោះទៅវិញ (១៧:៦-៧)។

**២៥:៩** *ឯងសុខចិត្តឡើងទៅឯក្រុងយេរូសាឡិម...?* លោកប៉ុលពិតជាមិនសុខចិត្តទៅឯទីក្រុងយេរូសាឡិម ដើម្បីឱ្យពួកសាសន៍យូដាជំនុំជម្រះអំពីទោសកំហុសរបស់គាត់ទេ ។ ប៉ុន្តែ គាត់ចង់ឱ្យគេដោះស្រាយរឿងក្តីរបស់គាត់នៅឯសាលាជំនុំជម្រះក្តីរបស់ពួករ៉ូម៉ាំង (ខ.១០) ជាជាងទទួលការកាត់ទោសនៅក្នុងដៃពួកអ្នកកាន់សាសនាយូដា ។ ម្យ៉ាងទៀត ដោយព្រោះគាត់មានសញ្ជាតិរ៉ូម ដូច្នោះ ការកាត់ទោសគួរតែធ្វើឡើងនៅតុលាការជាន់ខ្ពស់របស់រ៉ូម៉ាំងវិញ ។

**២៥:១០** លោកប៉ុលបដិសេធមិនព្រមទៅឯទីក្រុងយេរូសាឡិម ព្រោះគាត់ដឹងថា ពួកសាសន៍យូដាពិតជាមានបំណងអាក្រក់ចង់សម្លាប់គាត់ ។ មិនតែប៉ុណ្ណោះ គាត់ទទួលបានបទពិសោធន៍ជាច្រើន ដែលទាក់ទងទៅនឹងទង្វើដ៏អាក្រក់ និងអំពើអយុត្តិធម៌របស់ពួកសាសន៍យូដា ជាពិសេសមេដឹកនាំរបស់ពួកគេនាពេលនោះ ។

**២៥:១១** *ខ្ញុំប្របាទសូមរើក្តីនេះ ដល់សេសារវិញ* នៅពេលនោះអធិរាជនៃចក្រភពរ៉ូម៉ាំងគឺ នេរ៉ូ (Nero Claudius Caesar Germanicus) ឬហៅថាសេសារ ។ នេរ៉ូជាអធិរាជទី៥នៃចក្រភពរ៉ូម៉ាំង ប្រសូតនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ៣៧គ.ស ហើយបាន ឡើងគ្រងរាជ្យនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ៥៤គ.ស និងសុគតនៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ៦៨គ.ស ។ ក្នុងពេលនោះដែរ អ្នកណាដែលមានសញ្ជាតិរ៉ូមគឺមានសិទ្ធិស្នើសូមរើក្តីរបស់ខ្លួនទៅចំពោះសេសារ ឬអ្នកតំណាងរបស់ស្តេចនៅឯទីក្រុងរ៉ូមបាន ។ តុលាការកំពូលរបស់រដ្ឋាភិបាលរ៉ូម៉ាំងស្ថិតនៅទីក្រុងរ៉ូមនោះតែម្តង ។ ប្រសិនបើរឿងក្តីរបស់លោកប៉ុលត្រូវបានជំនុំជម្រះ នៅចំពោះអធិរាជសេសារ នោះពិតជាធ្វើឱ្យគេដឹងជាទូទៅថា ជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ និងសាសនាយូដា គឺផ្ទុយគ្នាទាំងស្រុង ។

ក៏ឆ្លើយថា ឯងបានសូមរើក្ដីនេះដល់សេសារវិញ បើដូច្នេះ
ឯងត្រូវទៅដល់សេសារចុះ ។

## លោកភេស្ទុសទូលពីរឿងប៉ុលថ្វាយស្ដេចអ័គ្រីប៉ា

១៣ក្រោយបួនដប់ថ្ងៃមកទៀត ព្រះរាជាអ័គ្រីប៉ា នឹង
ព្រះនាងបេរេនីស ស្ដេចយាងចុះមកឯសេសារា[ក] ក៏ចូល
ទៅសួរលោកភេស្ទុស ១៤កាលទ្រង់គង់នៅទីនោះ ជាយូរ
ថ្ងៃ នោះលោកភេស្ទុស ក៏ទូលពីរឿងប៉ុល ថ្វាយស្ដេចថា
លោកភេលីច បានទុកអ្នកទោសម្នាក់ ឱ្យជាប់គុកនៅទីនេះ[ខ]
១៥ហើយកាលដែលទូលបង្គំ នៅក្រុងយេរូសាឡិម នោះពួក
សង្គ្រាជ នឹងពួកចាស់ទុំនៃសាសន៍យូដា បានប្ដឹងទូលបង្គំ[គ]
ទាំងសូមឱ្យទូលបង្គំកាត់ទោសឱ្យ ១៦តែទូលបង្គំឆ្លើយ
ប្រាប់គេថា សាសន៍រ៉ូមមិនដែលបញ្ជូនមនុស្សណាឱ្យត្រូវ
ស្លាប់ មុនដែលចុងចំឡើយមានពួកដើមចោទនៅមុខខ្លួន
ហើយមានឱកាសនឹងដោះសាពីរឿងគេចោទនោះឡើយ[ឃ]
១៧ដូច្នេះ កាលគេបានមកទីនេះ នោះដល់ថ្ងៃស្អែកឡើង
ទូលបង្គំបានអង្គុយនៅទីជំនុំជំរះក្ដីដោយឥតបង្អង់ ហើយ
ក៏បង្គាប់ឱ្យនាំមនុស្សនោះមក[ង] ១៨តែកាលពួកដើម
ចោទបានឈរឡើង គេមិនបានចោទប្រកាន់វា អំពីរឿងអ្វី
ឱ្យដូចដែលទូលបង្គំបានស្មាននោះទេ ១៩គេគ្រាន់តែប្រ
កាន់[ច]ពីរបៀបសាសនា[ឆ]គេ ហើយពីដំណើរម្នាក់ឈ្មោះ
យេស៊ូវ ដែលស្លាប់ទៅហើយ តែប៉ុលប្រកាន់ ថានៅរស់
ទេប៉ុណ្ណោះ ២០ហើយដែលទូលបង្គំទ័លគំនិត នឹងពិចារ
ណាពីសេចក្ដីនោះ ក៏សួរវា បើវាសុខចិត្តនឹងទៅ ឯក្រុង
យេរូសាឡិម ឱ្យបានជំនុំជំរះ ពីរឿងនោះឬទេ[ជ] ២១តែវា
បានសូមរើក្ដីដល់មហារាជអូគូស្ទ ឱ្យបានជ្រាបវិញ បាន
ជាទូលបង្គំបង្គាប់ឱ្យឃុំទុកសិន ទំរាំតែទូលបង្គំមានឱកាស
នឹងបញ្ជូនទៅឯសេសារ[ឈ] ២២ព្រះរាជាអ័គ្រីប៉ា មានបន្ទូល
ទៅលោកភេស្ទុសថា ខ្ញុំក៏ចង់ស្ដាប់អ្នកនោះដែរ លោកទូល
ឆ្លើយថា ស្អែកនេះទ្រង់នឹងបានស្ដាប់វាហើយ[ញ] ។

## លោកប៉ុលនៅមុខស្ដេចអ័គ្រីប៉ា

*២៦:១២–១៨ = កច ៩:៣–៨ ២២:៦–១១*

២៣ដូច្នេះ លុះថ្ងៃស្អែកឡើង នោះព្រះរាជាអ័គ្រីប៉ា និង
ព្រះនាងបេរេនីស[ដ] ក៏យាងមក ដោយដំណើរដ៏រុងរឿង
ចូលទៅក្នុងសាលាក្ដី មានទាំងមេទ័ពធំ និងពួកអ្នកធំក្នុងទី
ក្រុងផង រួចកាលលោកភេស្ទុសបានបង្គាប់ហើយ នោះគេ
នាំប៉ុលចូលមក ២៤លោកភេស្ទុសក៏ទូលថា ឱព្រះករុណា
អ័គ្រីប៉ា និងអស់លោក ដែលនៅទីនេះជាមួយនឹងយើងខ្ញុំ
អើយ សូមទតមើលមនុស្សនេះ ដែលបណ្ដាជនសាសន៍
យូដាទាំងប៉ុន្មាន[ឋ] បានប្ដឹងដល់ទូលបង្គំ កាលនៅឯក្រុង
យេរូសាឡិម ហើយនិងនៅទីនេះដែរ ដោយសំរែកថា

**២៥:១៣** ក កច ៨:៤០
**២៥:១៤** ខ កច ២៤:២៧
**២៥:១៥** គ ខ.២ កច ២៤:១
**២៥:១៦** ឃ ខ.៤,៥ កច ២៣:៣០
**២៥:១៧** ង ខ.៦,១០
**២៥:១៩** ច កច ១៨:១៥ ២៣:២៩ ឆ កច ១៧:២២
**២៥:២០** ជ ខ.៩
**២៥:២១** ឈ ខ.១១,១២
**២៥:២២** ញ កច ៩:១៥
**២៥:២៣** ដ ខ.១៣ កច ២៦:៣០
**២៥:២៤** ឋ ខ.២,៣,៧

**២៥:១២** *ក្រុមជំនុំ* ពាក្យថា "ក្រុមជំនុំ" នៅត្រង់ចំណុចនេះ គឺសំដៅលើពួកមន្ត្រី និងពួកអ្នកជំនាញផ្នែកច្បាប់របស់រ៉ូម៉ាំង ដែលស្ថិតនៅក្រោមការដឹកនាំរបស់លោកភេស្ទុសនោះតែម្ដង ។

**២៥:១៣** *ព្រះរាជាអ័គ្រីប៉ា* គឺស្ដេចហេរ៉ូឌ អ័គ្រីប៉ាទី២ ។ ស្ដេចអង្គនេះមានព្រះជន្ម១៧វស្សា ក្នុងពេលដែលបិតារបស់ទ្រង់សុគត នៅឆ្នាំទី៤៤គ.ស (១២:២៣) ។ ដោយព្រោះនៅពេលនោះទ្រង់នៅមានព្រះជន្មក្មេងពេក ដូច្នោះហើយបានជារាជ្យសម្បត្តិរបស់បិតាទ្រង់ត្រូវផ្ទេរទៅឱ្យពួកអភិបាលរ៉ូម៉ាំងវិញ ។ ក្រោយមកទ្រង់បានគ្រប់គ្រងតំបន់ភាគខាងជើង និងភាគឦសាននៃសមុទ្រកាលីឡេ ហើយនិងទីក្រុងមួយចំនួននៅស្រុកកាលីឡេនិងស្រុកពេរេ (Perea) ។ ស្ដេចហេរ៉ូឌ អ័គ្រីប៉ាទី២ សុគតនៅឆ្នាំទី១០០គ.ស ។ *ព្រះនាងបេរេនីស* គឺជាបុត្រីរបស់ស្ដេចហេរ៉ូឌ អ័គ្រីប៉ាទី១ និងជាប្អូនស្រីរបស់ស្ដេចហេរ៉ូឌ អ័គ្រីប៉ាទី២ ។ *ក៏ចូលទៅសួរលោកភេស្ទុស* ត្រង់ចំណុចនេះបញ្ជាក់ថា ការចូលទៅសួរសុខទុក្ខអ្នកដឹកនាំដែលទើបចូលកាន់តំណែងថ្មីគឺជាទម្លាប់មួយរបស់ពួកគេ ។

**២៥:១៤** ពេលបានជួបព្រះរាជាអ័គ្រីប៉ា ដែលមានដើមកំណើតជាសាសន៍យូដា នោះប្រហែលជាអាចធ្វើឱ្យលោកភេស្ទុសយល់នូវរឿងទំនាស់រវាងលោកប៉ុល និងពួកសាសន៍យូដាកាន់តែច្រើន ។

**២៥:១៥–១៧** លោកភេស្ទុសចង់ដឹងឱ្យច្បាស់ថា តើពួកដើមចោទពិតប្រាកដជាអ្នកណា ដូច្នោះហើយបានជាលោកចង់ហៅពួកគេមក ដើម្បីឱ្យចុងចោទបានឮពាក្យចោទប្រកាន់ដោយផ្ទាល់ ហើយអាចមានឱកាសឆ្លើយបំភ្លឺផង ។

**២៥:១៨** ដំបូងឡើយ លោកភេស្ទុសគិតថា លោកប៉ុលប្រហែលជាបានប្រព្រឹត្តនូវទោសឧក្រិដ្ឋណាមួយមិនខាន ប៉ុន្តែ ក្រោយពីបានសាកសួរច្បាស់លាស់ហើយ នោះក៏ដឹងថាគាត់ (ប៉ុល) មិនបានធ្វើអ្វីគួរឱ្យទទួលទោសទេ ។

**២៥:១៩** *ពីរបៀបសាសនាគេ* លោកភេស្ទុសដឹងថាព្រះរាជាអ័គ្រីប៉ាជាសាសន៍យូដា ដូច្នេះនៅត្រង់ចំណុចនេះ គាត់និយាយដោយមានការប្រុងប្រយ័ត្ន និងដោយគោរពបំផុត (មើលការពន្យល់ ១៧:២២) ។

**២៥:២០** បទគម្ពីរនេះបញ្ជាក់ថា ការដែលលោកភេស្ទុស ចង់បញ្ជូនលោកប៉ុលទៅឯទីក្រុងយេរូសាឡិមវិញ ប្រហែលជាគាត់គិតថា នៅទីនោះអាចមានភស្តុតាងគ្រប់គ្រាន់ ដើម្បីងាយស្រួលក្នុងការវិនិច្ឆ័យទោសកំហុសរបស់គាត់ (ប៉ុល) ។

**២៥:២២** *ខ្ញុំក៏ចង់ស្ដាប់អ្នកនោះដែរ* ព្រះរាជាអ័គ្រីប៉ាពិតជាបានឮសេចក្ដីដែលលោកប៉ុលប្រកាសថា "ព្រះយេស៊ូវទ្រង់រស់ពីសុគតឡើងវិញ" ដូច្នោះហើយបាន ជាទ្រង់ចង់ជួបគាត់ផ្ទាល់តែម្ដង (សូមប្រៀបធៀបនឹង លក ៩:៩ ២៣:៨) ។

**២៥:២៣** *សាលាក្ដី* ពាក្យថា "សាលាក្ដី" នៅត្រង់ចំណុចនេះមិនមែនសំដៅលើទីកន្លែងជំនុំជម្រះក្ដីនោះទេ ប៉ុន្តែជាសាលប្រជុំក្នុងឱកាសមានកម្មវិធីធំៗ ដែលមានមហាក្សត្រជាអធិបតី និងមានអ្នកចូលរួមជាពួកអភិបាលរ៉ូម៉ាំង ហើយនិងមេដឹកនាំសំខាន់ៗនៃសាសន៍យូដា ។ *មានទាំងមេទ័ពធំ*

មិនគួរឱ្យវានៅរស់ទៀតទេ[ឌ] ២៥តែទូលបង្គំមិនឃើញថា
មានទោសអ្វី ដែលគួរឱ្យស្លាប់សោះ[ឍ] ហើយដែលខ្លួនវា
បានសូមរើក្ដី ដល់មហារាជអូគូស្ទុះវិញ[ណ] នោះបានជា
ទូលបង្គំសំរេចថា នឹងបញ្ជូនវាឱ្យទៅចុះ ២៦តែទូលបង្គំ
គ្មានរឿងអ្វីជាប្រាកដ នឹងសរសេរ ថ្វាយដល់ព្រះអម្ចាស់នៃ
ទូលបង្គំ ពីដំណើរវាទេ ហេតុនេះ បានជាទូលបង្គំនាំវាមក
នៅទីចំពោះមុខ នៃអស់លោកទាំងឡាយ មានព្រះរាជា
ជាដើម ឱព្រះរាជាអ័គ្រីប៉ាអើយ ដើម្បីកាលណាបាន
ពិចារណាសួរវារួចហើយ នោះទូលបង្គំនឹងបានរឿងអ្វីខ្លះ
ឱ្យដាក់ចុះក្នុងសំបុត្រ ២៧ដ្បិតបើតាមទូលបង្គំ មើលទៅ
ដូចជាគ្មានទំនង នឹងបញ្ជូនអ្នកទោសទៅ ឥតមានបង្ហាញ
ទោសទាំងប៉ុន្មាន ដែលគេចោទដល់វានោះទេ ។

**២៦** ១ព្រះរាជាអ័គ្រីប៉ាមានបន្ទូលទៅប៉ុលថា ឯងមាន
ច្បាប់និយាយដោយខ្លួនឯងបាន[ត] រួចប៉ុលក៏លើកដៃ[ថ]
ទៅមុខដោះសាខ្លួនថា ២បពិត្រព្រះករុណាអ័គ្រីប៉ា
អើយ នៅថ្ងៃនេះ ទូលបង្គំមានចិត្តអំណរណាស់ ដោយ
មានច្បាប់នឹងដោះសាខ្លួននៅចំពោះទ្រង់[ទ] ពីអស់ទាំង
សេចក្ដីដែលសាសន៍យូដាចោទប្រកាន់ទូលបង្គំ[ធ] ៣គឺ
ពីព្រោះទ្រង់ជ្រាប គ្រប់ទាំងទំលាប់[ន] នឹងសេចក្ដីជជែក[ប]
របស់ពួកសាសន៍យូដាជាដើម ដូច្នេះ ទូលបង្គំសូមអង្វរ
ឱ្យព្រះករុណាទ្រង់ព្រះសណ្ដាប់ទូលបង្គំ ដោយអំណត់សិន
៤ដ្បិតពួកសាសន៍យូដាទាំងអស់បានស្គាល់ចរិតដែល
ទូលបង្គំប្រព្រឹត្ត តាំងពីក្មេងមកហើយ[ផ] ថាពីដើមទូលបង្គំ
នៅកណ្ដាលសាសន៍ នៃទូលបង្គំនៅក្រុងយេរូសាឡិម
៥ហើយបើគេព្រមធ្វើបន្ទាល់ នោះមុខជាគេបានស្គាល់
ទូលបង្គំពីដើមមក[ព] ជាពិតថា ទូលបង្គំបានប្រព្រឹត្តតាមបក្ស
ពួកតឹងរ៉ឹង[ភ]ជាងគេ ក្នុងសាសន៍នៃទូលបង្គំ គឺជាពួកផារិស៊ី[ម]
៦ហើយឥឡូវ ទូលបង្គំជាប់ជំនុំជំរះនេះ នោះគឺដោយព្រោះ
តែមានចិត្តសង្ឃឹម[យ] ដល់សេចក្ដីសន្យា ដែលព្រះទ្រង់បាន
តាំងនឹងពួកឰយុកោ[រ]ទូលបង្គំ ៧ដែលពូជអំបូរទាំង១២[ល]
ខំប្រឹងប្រតិបត្តិតាមព្រះទាំងយប់ទាំងថ្ងៃ[វ] ដោយសង្ឃឹម
នឹង បានសេចក្ដីសន្យានោះដែរ បពិត្រព្រះរាជាអ័គ្រីប៉ា
អើយ គឺដោយព្រោះសេចក្ដីសង្ឃឹមនោះឯង បានជាពួក
សាសន៍យូដា គេចោទប្រកាន់ដល់ទូលបង្គំ[ស] ៨ហេតុអ្វីបានជា
អស់លោកទាំងឡាយ រាប់សេចក្ដី ដែលព្រះទ្រង់ប្រោស
មនុស្ស ស្លាប់ឱ្យរស់ឡើងវិញ ថាជាសេចក្ដីមិនគួរជឿ[ហ]
៩សូម្បីទូលបង្គំ ក៏បានគិតស្មាន[ឡ]ថា គួរឱ្យទូលបង្គំធ្វើ
ទាស់ទទឹង[អ]ជាច្រើន ដល់ព្រះនាមព្រះយេស៊ូវ ពីស្រុក

**២៥:២៤** ឌ កច ២២:២២
**២៥:២៥** ឍ កច ២៣:៩ ណ ខ.១១
**២៦:១** ត កច ៩:១៥ ២៥:២២ ថ កច ១២:១៧
**២៦:២** ទ ទដ ១១៩:៤៦ ធ កច ២៤:១,៥ ២៥:២,៧,១១
**២៦:៣** ន ខ.៧ កច ៦:១៤ ប កច ២៥:១៩
**២៦:៤** ផ កទ ១:១៣,១៤ ភល ៣:៥
**២៦:៥** ព កច ២២:៣ ភ កច ២៤:៥ ម កច ២៣:៦ ភល ៣:៥
**២៦:៦** យ កច ២៣:៦ ២៤:១៥ ២៨:២០ រ កច ១៣:៣២ រម ១៥:៨
**២៦:៧** ល យក ១:១ វ ១ថន ៣:១០ ១ធថ ៥:៥ ស ខ.២
**២៦:៨** ហ កច ២៣:៦ **២៦:៩** ឡ ១ធថ ១:១៣ អ យហ ១៦:២

នៅឯទីក្រុងសេសារាមាន កងទ័ពចំនួន៥កងវរសេនាធំ ដូច្នេះ មេទ័ពធំទាំង៥ក៏ប្រហែលជាមានវត្តមាន នៅក្នុងឱកាសនោះដែរ (មើលការពន្យល់ ២១:៣១) ។

**២៥:២៦,២៧** *ទូលបង្គំគ្មានរឿងអ្វីជាប្រាកដ* លោកភេស្ទុសមិនបានយល់ច្បាស់អំពីរឿងរ៉ាវ ដែលពួកសាសន៍យូដានាំគ្នាចោទប្រកាន់លោកប៉ុលនោះទេ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏គាត់ត្រូវតែធ្វើរបាយការណ៍ផ្ញើទៅថ្វាយអធិរាជសេសារ ស្ដីអំពីរឿងក្ដីនោះដែរ ។ ដូច្នេះ ការជួបជាមួយព្រះរាជាអ័គ្រីប៉ា ទោះមិនមែនជាផ្លូវការក៏ដោយ ក៏គាត់សង្ឃឹមថានឹងអាចទទួលបានព័ត៌មានខ្លះៗ ដើម្បីងាយស្រួលក្នុងការសរសេររបាយការណ៍របស់គាត់ដែរ ។

**២៦:១** *មានច្បាប់និយាយដោយខ្លួនឯងបាន* ព្រះរាជាអ័គ្រីប៉ាមានបន្ទូលយ៉ាងដូច្នោះ ព្រោះចង់ឮលោកប៉ុលនិយាយដោយផ្ទាល់ ម្យ៉ាងទៀតដើម្បីឱ្យលោកភេស្ទុសបានដឹងរឿងរ៉ាវកាន់តែច្បាស់ថែមទៀត ។

**២៦:២** *ទូលបង្គំមានចិត្តអំណរណាស់* លោកប៉ុលមានការសប្បាយចិត្ត ព្រោះមានឱកាសឆ្លើយបំភ្លឺគ្រប់សេចក្ដីទាំងអស់ នៅចំពោះព្រះរាជាអ័គ្រីប៉ា ដែលទ្រង់មានការយល់ដឹងអំពីសាសនា និងទំនៀមទម្លាប់ពួកយូដាយ៉ាងច្បាស់លាស់ ហើយអាចធ្វើការវិនិច្ឆ័យបានថា អ្វីដែលគាត់បានបង្រៀនដល់បណ្ដាជនពិតជាមិនប្រឆាំងនឹងក្រឹត្យវិន័យ ឬព្រះវិហារ ឬក៏សេសារទេ ។

**២៦:៣** *ព្រោះទ្រង់ជ្រាបគ្រប់ទាំងទំលាប់* ព្រះរាជាអ័គ្រីប៉ាជាអ្នកមើលការខុសត្រូវលើវត្ថុមានតម្លៃ និងការចំណាយរបស់ពួកសង្ឃនៅក្នុងព្រះវិហារ ហើយនិងជាអ្នកជ្រើសតាំងសម្ដេចសង្ឃទៀតផង ។ ពួករ៉ូម៉ាំងបានតែងតាំងទ្រង់ឱ្យធ្វើជាអ្នកប្រឹក្សាយោបល់ខាងផ្នែកសាសនា ។ ទាំងនោះជាមូលហេតុដែលលោកភេស្ទុសចង់ឱ្យទ្រង់សួរចម្លើយលោកប៉ុល (ពន្យល់ ២៥:២៦) ។

**២៦:៤-៥** ពួកសាសន៍យូដាបានដឹងយ៉ាងច្បាស់ថា លោកប៉ុលធ្លាប់ទទួលការអប់រំ និងប្រព្រឹត្តតាមពួកផារិស៊ីតាំងតែពីក្មេងមកម្ល៉េះ (កទ ១:១៤ ភល ៣:៤-៦) ។

**២៦:៦** *សង្ឃឹមដល់សេចក្ដីសន្យា* សេចក្ដីទាំងនោះរួមមាន (១).នគររបស់ព្រះ (២).ព្រះមែស៊ី (៣).ការរស់ពីស្លាប់ឡើងវិញ (ខ.៨) ។

**២៦:៧** *ពូជអំបូរទាំង១២* ពូជអំបូរទាំង១២នោះរួមមាន រូបេន ស៊ីម្មានយូដា អ៊ីសាខារ សាប់យូល៉ូន កាឌ់ អេស៊ើរ ម៉ាន៉ាសេ អេប្រាអិម បេនយ៉ាមីនដាន់ និង ណែបថាលី (លប ៤៦:៨-២៣) ។ លោកប៉ុលស្ថិតនៅក្នុងអំបូរបេនយ៉ាមីន (ភល ៣:៥) ។

**២៦:៨** ដំបូងឡើយ លោកប៉ុលនិយាយទៅកាន់តែព្រះរាជាអ័គ្រីប៉ាប៉ុណ្ណោះ ប៉ុន្តែនៅត្រង់ចំណុចនេះ គាត់ពិតជាចង់សំដៅលើលោកភេស្ទុស ពួកមេទ័ពធំ និងអ្នកផ្សេងៗទៀត ដែលមិនជឿលើសេចក្ដីរស់ពីស្លាប់ឡើងវិញផងដែរ (មើលការពន្យល់ ២១:៣១) ។ ព្រះរាជាអ័គ្រីប៉ាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងពួកសាឌូស៊ី ដែលទ្រង់បានតែងតាំងឱ្យធ្វើជាសម្ដេចសង្ឃ ដូច្នេះទ្រង់ប្រហែលជាបដិសេធ ចំពោះសេចក្ដីដែលថែងថា មនុស្សស្លាប់នឹងរស់ឡើងវិញនោះជាមិនខាន ។

ណាសារ៉ែតដែរ[ក] ១០គឺទូលបង្គំបានធ្វើការទាំងនោះនៅ
ក្រុងយេរូសាឡិម បានទាំងចាប់ពួកអ្នកបរិសុទ្ធ[ខ]ជាច្រើន
យកទៅដាក់គុក[គ] ដោយទទួលអំណាច ពីពួកសង្គ្រាជមក
ហើយកាលគេសំឡាប់អ្នកទាំងនោះ ទូលបង្គំក៏យល់ព្រម
ដែរ[ឃ] ១១ទូលបង្គំបានធ្វើទោស[ង]គេជាញឹកញយ នៅគ្រប់
ទាំងសាលាប្រជុំ ទាំងបង្ខំឱ្យគេពោលពាក្យប្រមាថដល់ព្រះ
ផង ហើយដោយព្រោះទូលបង្គំ មានចិត្តក្តៅក្រហាយជ្រុល
ពេក ទាស់នឹងគេដូច្នេះ បានជាទូលបង្គំធ្វើទុក្ខបៀតបៀន
ដល់គេ រហូតដល់ក្រុងនៃសាសន៍ដទៃផង ១២នៅគ្រានោះ
ទូលបង្គំបានទទួលអំណាច នឹងសេចក្តីបង្គាប់ មកពីពួក
សង្គ្រាជ ហើយកំពុងតែដើរដំណើរ ទៅឯក្រុងដាម៉ាស
១៣នោះបពិត្រព្រះករុណាអើយ នៅពេលថ្ងៃត្រង់ហើយ
ដែលទូលបង្គំកំពុងដើរ នោះស្រាប់តែមានពន្លឺ ពីលើមេឃ
ភ្លឺមកជុំវិញទូលបង្គំ នឹងពួកអ្នកដើរជាមួយ ជាពន្លឺភ្លឺជាងថ្ងៃ
១៤ទូលបង្គំទាំងអស់គ្នាក៏ដួលដល់ដី រួចទូលបង្គំឮសំឡេង[ច]
មានបន្ទូលមក ជាភាសាហេព្រើរថា[ឆ] សុល នែសុល
ហេតុអ្វីបានជាធ្វើទុក្ខដល់ខ្ញុំ ដែលធាក់ជល់នឹងជន្លួញដូច្នេះ
នោះពិបាកដល់អ្នកណាស់ ១៥ទូលបង្គំក៏ឆ្លើយថា ឱព្រះ
អម្ចាស់អើយ តើព្រះអង្គ ណានុ៎ះ រួចទ្រង់មានបន្ទូលថា ខ្ញុំ
នេះជាព្រះយេស៊ូវ ដែលអ្នកធ្វើទុក្ខ ១៦ចូរក្រោកឈរឡើង[ជ]
ដ្បិតខ្ញុំបានលេចមកឱ្យអ្នកឃើញ ដើម្បីនឹងតាំងអ្នក ឱ្យ
ធ្វើជាអ្នកបំរើ ហើយជាទីបន្ទាល់ ពីអស់ទាំងការដែល
អ្នកបានឃើញហើយព្រម ទាំងការ ដែលខ្ញុំនឹងលេចមក
ឱ្យអ្នកឃើញទៅមុខទៀត[ឈ] ១៧ខ្ញុំបានញែកអ្នក[ញ] ចេញពី
បណ្តាជន នឹងពីពួកសាសន៍ដទៃ[ដ] ដើម្បីនឹងចាត់អ្នកឱ្យទៅ
ឯគេវិញ ១៨ប្រយោជន៍នឹងបំភ្លឺភ្នែកគេ[ឋ] ឱ្យបានបែរចេញពី
សេចក្តីងងឹត មកឯពន្លឺ[ឌ] ហើយពីអំណាចអារក្សសាតាំង
មកឯព្រះវិញ ដើម្បីឱ្យគេបានរួចពីបាប[ឍ] ហើយបានទទួល
មរដក ជាមួយនឹងពួកអ្នកដែលបានញែកជាបរិសុទ្ធ ដោយ
សារសេចក្តីជំនឿជឿដល់ខ្ញុំ[ណ] ១៩ដូច្នេះ បពិត្រព្រះរាជា
អ័គ្រីប៉ាអើយ ទូលបង្គំមិនបានចចេស[ត]នឹងការជាក់ស្តែង
ពីស្ថានសួគ៌នោះទេ ២០គឺទូលបង្គំបានប្រាប់ឱ្យមនុស្ស
ទាំងអស់ប្រែចិត្ត[ថ] ហើយងាកបែរមកឯព្រះវិញ ទាំងប្រ
ព្រឹត្តបែបសំណុំនឹងការប្រែចិត្តផង គឺប្រាប់ដល់ពួកអ្នក
ដែលនៅក្រុងដាម៉ាសជាមុនដំបូង[ទ] រួចនៅក្រុងយេរូសា
ឡិម[ធ] នឹងគ្រប់ក្នុងខេត្តយូដា ហើយដល់អស់ទាំងសាសន៍
ដទៃ[ន]ផង[ប] ២១ដោយហេតុនោះបានជាពួកសាសន៍យូ
ដា ចាប់ទូលបង្គំ[ផ]នៅក្នុងព្រះវិហារ ហើយព្យាយាម
នឹងសំឡាប់ទូលបង្គំចោល[ព] ២២តែព្រះទ្រង់បានជួយ
ទូលបង្គំ ដរាបមកដល់ថ្ងៃនេះ បានជាទូលបង្គំឈរធ្វើ
បន្ទាល់ដល់អ្នកតូចធំ ដោយគ្មាននិយាយអ្វី ឱ្យលើសពី

**២៦:៩** ក យហ ១៥:២១
**២៦:១០** ខ កច ៩:១៣ គ កច ៨:៣ ៩:២,១៤,២១ ឃ កច ២២:២០
**២៦:១១** ង មថ ១០:១៧
**២៦:១៤** ច កច ៩:៧ ឆ យហ ៥:២
**២៦:១៦** ជ អគ ២:១ ដយ ១០:១១ ឈ កច ២:១៤,១៥
**២៦:១៧** ញ យរ ១:៨,១៩ ដ កច ៩:១៥ ១៣:៤៦
**២៦:១៨** ឋ អស ៣៥:៥ ឌ ទដ ១៨:២៨ អស ៤២:៧,១៦ អភ ៥:៨ កល ១:១៣ ១ពត ២:៩ ឍ លក ២៤:៤៧ កច ២:៣៨ ណ កច ២០:២១,៣២
**២៦:១៩** ត អស ៥០:៥
**២៦:២០** ថ កច ៣:១៩ ទ កច ៩:១៩–២៥ ធ កច ៩:២៦–២៩ ២២:១៧–២០ ន កច ៩:១៥ ១៣:៤៦ ប យរ ១៨:១១ ៣៥:១៥ មថ ៣:៨ លក ៣:៨
**២៦:២១** ផ កច ២១:២៧,៣០ ព កច ២១:៣១

**២៦:១០** ត្រង់ចំណុចនេះបញ្ជាក់ថា កាលពីមុនលោកប៉ុលបានធ្វើការបៀតបៀនដល់អ្នកជឿព្រះយេស៊ូវគ្រីស្ទ ដោយមានពួកក្រុមជំនុំ និងពួកសង្គ្រាជជាពួកសាឌូស៊ីជាអ្នកប្រគល់អំណាចឱ្យ ទោះបីខ្លួនគាត់ផ្ទាល់ជាពួកផារិស៊ីក៏ដោយ (ឧ.១២)។

**២៦:១១** *ទាំងបង្ខំឱ្យគេពោលពាក្យប្រមាថដល់ព្រះផង* មានន័យថាមុនពេលដែលលោកប៉ុលប្រែចិត្ត គាត់បានបង្ខំឱ្យពួកអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទពោលពាក្យប្រមាថដល់ទ្រង់ បើពុំដូច្នោះទេ ពួកគេត្រូវទទួលទោសអាចរហូតដល់ស្លាប់ (មថ ២៦:៦៣–៦៦)។

**២៦:១២** *ទូលបង្គំបានទទួលអំណាច...ទៅឯក្រុងដាម៉ាស* "៩:១–១៩ មើលការពន្យល់ ២២:៤–២២"។

**២៦:១៤** *ទូលបង្គំបានឮសំឡេង* "មើលការពន្យល់ ៩:៧ ២២:៩"។ *ដែលធាក់ជល់នឹងជន្លួញដូច្នេះ នោះពិបាកដល់អ្នកណាស់* ឃ្លានេះមានន័យថា "ខំប្រឹងដោយគ្មានប្រយោជន៍ ឬធ្វើឱ្យខ្លួនកាន់តែឈឺចាប់ប៉ុណ្ណោះ"។

**២៦:១៧** *ដើម្បីនឹងចាត់អ្នកឱ្យទៅឯគេវិញ* លោកប៉ុលបានទទួលការបើកសំដែងមកអំពីព្រះអម្ចាស់ឱ្យទៅឯពួកសាសន៍យូដា និងសាសន៍ដទៃ (២២:២១ កទ ១:១ ១:១៥–១៦)។

**២៦:១៨** *ឱ្យបានបែរចេញពីសេចក្តីងងឹត មកឯពន្លឺ* ព្រះអម្ចាស់ទ្រង់បានប្រើលោកប៉ុលឱ្យនាំព្រលឹងមនុស្ស ចេញអំពីសេចក្តីងងឹត ដែលគ្រប់គ្រងដោយសាតាំងឱ្យពួកគេមកឯពន្លឺរបស់ទ្រង់វិញ គឺដោយសារអំណាចព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ (រម ១៣:១២ ២កថ ៤:៦ អភ ៥:៨–១៤ កល ១:១៣ ១ថន ៥:៥)។ *សាតាំង* នៅក្នុងភាសាហេព្រើរប្រើពាក្យថា "សាតាំង" រីឯភាសាក្រិកវិញប្រើពាក្យថា "អារក្ស"។ "សាតាំង" មានន័យថា "អ្នកចោទប្រកាន់" ឬ "អ្នកនិយាយបង្ខូច" ឬក៏ "មារសត្រូវ" ហើយជាមេនៃសេចក្តីងងឹត (មថ ១៦:២៣ និងការពន្យល់ ១យហ ៣:៨)។ *បានញែកជាបរិសុទ្ធ* "មើលការពន្យល់ ១កថ ១:២"។

**២៦:២០** *ទូលបង្គំបានប្រាប់ឱ្យមនុស្សទាំងអស់ប្រែចិត្ត . . . ទាំងប្រព្រឹត្តបែបសំណុំនឹងការប្រែចិត្តផង* ត្រង់ចំណុចនេះលោកប៉ុលចង់បង្ហាញថា ការប្រព្រឹត្តិគ្រាន់តែជាភស្តុតាងបញ្ជាក់ ឱ្យឃើញអំពីការប្រែចិត្តប៉ុណ្ណោះ ពុំមែនមានន័យថា ការសង្គ្រោះបានមកដោយសារទង្វើរបស់មនុស្សនោះទេ ប៉ុន្តែគឺបានមកដោយសារអង្គព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ ៣:១៩)។

**២៦:២២** *ព្រះទ្រង់បានជួយទូលបង្គំ* មានមនុស្សជាច្រើនប៉ងសម្លាប់លោកប៉ុល ប៉ុន្តែគាត់អះអាងយ៉ាងច្បាស់ថា ព្រះអម្ចាស់ទ្រង់ការពារ និងសង្គ្រោះគាត់គ្រប់ពេលវេលាទាំងអស់ ។ *អ្នកតូច* គឺសំដៅលើអស់អ្នកដែលបន្ទាបខ្លួន អ្នកក្រីក្រ អ្នកល្ងង់ខ្លៅ និងអស់អ្នកដែលមិនបានយល់ច្បាស់ ។ *ធំ* គឺសំដៅ

សេចក្ដីដែលពួកហោរា នឹងលោកម៉ូសេ បានទាយថា ត្រូវ
មកនោះឡើយ[ភ] [២៣]គឺថា ព្រះគ្រីស្ទត្រូវរងទុក្ខ[ម] ហើយថា
ដោយសារទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ[យ]មុនគេ
ទាំងអស់ នោះទ្រង់បានប្រកាសប្រាប់ពីពន្លឺ ដល់សាសន៍នេះ
ហើយដល់សាសន៍ដទៃផង[រ] ។
[២៤]កំពុងដែលគាត់និយាយសេចក្ដីទាំងនោះ ដើម្បីដោះ
សាខ្លួន នោះលោកភេស្ទុសឡើងសំឡេងកាត់ថា ប៉ុលអើយ
ឯងឆ្កួតទេ[ល] ឯងរៀនសូត្រជាច្រើន[វ] ដល់ម្ល៉េះបានជាឆ្កួត
ហើយ [២៥]តែគាត់ប្រកែកថា ព្រះតេជព្រះគុណ[ស]ភេស្ទុស
អើយ ខ្ញុំប្របាទមិនមែនឆ្កួតទេ ខ្ញុំប្របាទនិយាយចំពោះ
ពាក្យពិត ហើយជានាទេតើ [២៦]ដ្បិតព្រះករុណាទ្រង់បាន
ជ្រាបការទាំងនេះហើយ[ហ] ខ្ញុំប្របាទក៏ទូលដល់ទ្រង់ដោយ
ក្លាហានដែរ ព្រោះខ្ញុំប្របាទជឿប្រាកដថា ក្នុងការទាំងនេះ
គ្មានអ្វីលាក់កំបាំងនឹងទ្រង់ទេ ដ្បិតមិនមែនធ្វើនៅទីកៀន
កោះឯណាឡើយ [២៧]បពិត្រព្រះរាជាអ័គ្រីប៉ាអើយ ! តើទ្រង់
ជឿសេចក្ដីទំនាយរបស់ពួកហោរា ឬទេ ? ទូលបង្គំដឹងថា
ទ្រង់ជឿហើយ [២៨]ស្ដេចអ័គ្រីប៉ា ក៏មានបន្ទូលទៅប៉ុលថា
បន្តិចទៀត ឯងនឹងនាំឱ្យយើងត្រឡប់ទៅជាអ្នកគ្រីស្ទាន
ដែរ[ឡ] [២៩]រួចប៉ុលទូលថា ទូលបង្គំសូមដល់ព្រះ មិនមែនឱ្យ
ត្រឹមតែព្រះករុណាប៉ុណ្ណោះ គឺឱ្យអស់អ្នកដែលស្ដាប់ទូលបង្គំ
នៅថ្ងៃនេះថែមទៀតផង ទោះបើនៅបន្តិចទៀត ឬយូរទៅ
ទៀតក្ដី ឱ្យតែគ្រប់គ្នាបានដូចទូលបង្គំ លើកតែចំណងនេះ
ចេញ[អ] ។
[៣០]នោះស្ដេច ព្រមទាំងចៅហ្វាយស្រុក នឹងព្រះនាង
បេរេនីស[ក] ហើយនឹងអស់អ្នកដែលអង្គុយជាមួយ ក៏ក្រោក
ឡើង [៣១]កាលបានថយចេញផុតហើយនោះ ក៏ពិភាក្សាគ្នា
ថា មនុស្សនេះមិនបានធ្វើអ្វីគួរនឹងស្លាប់ ឬនឹងជាប់ចំណង
សោះ[ខ] [៣២]ហើយស្ដេចអ័គ្រីប៉ាមានបន្ទូលទៅលោកភេស្ទុស
ថា មនុស្សនេះ បើមិនបានសូមរើក្ដីដល់សេសារទេ នោះ
នឹងលែងបាន[គឃ] ។

## ដំណើរទៅកាន់ទីក្រុងរ៉ូម

**២៧** [១]កាលបានសំរេច ឱ្យយើងខ្ញុំ[ង] ចុះសំពៅចេញទៅ
ឯស្រុកអ៊ីតាលី[ច] នោះគេក៏ប្រគល់ប៉ុល នឹងអ្នកទោសខ្លះ
ទៀតដល់មេទ័ពរងម្នាក់ឈ្មោះ យូលាស ក្នុងកងទ័ពអូគូស្ទ[ឆ]
[២]យើងចុះសំពៅ១ ពីស្រុកអាត្រាមីត ដែលរៀបនឹងបើក
ទៅតាមឆ្នេរសមុទ្រស្រុកអាស៊ី[ជ] ហើយក៏បើកទៅ មានទាំង
អើរីស្ដាក[ឈ] ជាសាសន៍ម៉ាសេដូន[ញ] ដែលនៅក្រុងថែស្សា

**២៦:២២** ភ លក ២៤:២៧,៤៤ កច ១០:៤៣ ២៤:១៤
**២៦:២៣** ម មថ ១៦:២១ យ ១កថ ១៥:២០,២៣ កល ១:១៨ វវ ១:៥ រ លក ២:៣២
**២៦:២៤** ល យហ ១០:២០ ១កថ ៤:១០ វ យហ ៧:១៥
**២៦:២៥** ស កច ២៣:២៦
**២៦:២៦** ហ ខ.៣
**២៦:២៨** ឡ កច ១១:២៦
**២៦:២៩** អ កច ២១:៣៣
**២៦:៣០** ក កច ២៥:២៣
**២៦:៣១** ខ កច ២៣:៩
**២៦:៣២** គ កច ២៨:១៨ ឃ កច ២៥:១១
**២៧:១** ង កច ១៦:១០ ច កច ១៨:២ ២៥:១២,២៥ ឆ កច ១០:១
**២៧:២** ជ កច ២:៩ ឈ កច ១៩:២៩ ញ កច ១៦:៩

លើស្ដេច មន្ត្រី ពួកអ្នកមាន ពួកអភិជន និងពួកអភិបាល ។

**២៦:២៣** *ទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ* មានន័យថា សេចក្ដីស្លាប់គ្មានអំណាចលើទ្រង់ឡើយ (១កថ ១៥:២០ កល ១:១៨)។ *សាសន៍ដទៃ* "អស ៤៩:៦"។

**២៦:២៤** *ឯងឆ្កួតទេ* ត្រង់ចំណុចនេះលោកភេស្ទុសមានអារម្មណ៍ថា ដោយព្រោះតែលោកប៉ុលអាន និងសិក្សាគម្ពីរដែលបង្រៀនអំពីសេចក្ដីអាថ៌កំបាំង ទើបធ្វើឱ្យគាត់ក្លាយទៅជាមនុស្សយល់ឆ្វេង ដែលនិយាយអំពីសេចក្ដីទំនាយ និងអំពីសេចក្ដីរស់ឡើងវិញនោះទៅវិញ ។ លោកភេស្ទុសនិយាយយ៉ាងដូច្នោះ ព្រោះគាត់ពុំបានយល់នូវសេចក្ដីពិតរបស់ព្រះអម្ចាស់ទេ ។

**២៦:២៦** *ការទាំងនេះគ្មានអ្វីលាក់កំបាំងនឹងទ្រង់ទេ* ហេតុការណ៍ ពេលវេលា និងទីកន្លែងទាំងអស់នៅក្នុងដំណឹងល្អរបស់ព្រះអម្ចាស់ សុទ្ធតែមានលក្ខណៈជាប្រវត្តិសាស្ត្រពិត ។ ដូច្នោះព្រះរាជាអ័គ្រីប៉ាពិតជាបានឮនូវសេចក្ដីទាំងនោះ ។

**២៦:២៧** *តើទ្រង់ជឿសេចក្ដីទំនាយរបស់ពួកហោរាឬទេ?* សំណួរនេះធ្វើឱ្យព្រះរាជាអ័គ្រីប៉ាពិបាកឆ្លើយជាខ្លាំង ។ បើទ្រង់ឆ្លើយថា "ជឿ" លោកប៉ុលពិតជាបន្តថា សេចក្ដីទំនាយនោះបានសម្រេចសព្វគ្រប់នៅក្នុងអង្គព្រះយេស៊ូវហើយ ។ បើឆ្លើយថា "មិនជឿ" នោះនឹងមានបញ្ហាជាមួយនឹងពួកសាសន៍យូដាជាមិនខាន ព្រោះពួកគេជឿថា គ្រប់ទាំងសេចក្ដីទំនាយរបស់ពួកហោរាគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ។

**២៦:២៨** *បន្តិចទៀតឯងនឹងនាំឱ្យយើងត្រឡប់ទៅជាអ្នកគ្រីស្ទានដែរ* ដោយព្រោះព្រះរាជាអ័គ្រីប៉ាមិនហ៊ានឆ្លើយតបទៅនឹងសំណួររបស់លោកប៉ុល ទើបមានបន្ទូលទៅកាន់គាត់នូវប្រយោគយ៉ាងដូច្នេះ ។

**២៦:២៩** *លើកតែចំណងនេះចេញ* ក្នុងខណៈនោះលោកប៉ុលនៅជាប់ចំណងនៅឡើយ ព្រោះថាគេចាត់ទុកគាត់ជាអ្នកទោស ។

**២៦:៣១** *មនុស្សនេះមិនបានធ្វើអ្វីគួរនឹងស្លាប់ឬនឹងជាប់ចំណងសោះ* ឃ្លានេះបញ្ជាក់យ៉ាងច្បាស់ថា លោកប៉ុលពិតជាមនុស្សសុចរិត និងគ្មានទោសកំហុសអ្វីទាំងអស់ (ប្រៀបធៀប លក ២៣:១៣–១៥)។

**២៧:១** *យើងខ្ញុំ* ត្រង់ចំណុចនេះលោកលូកាប្រើសព្វនាម "យើងខ្ញុំ" (២១:១៨ មើលការពន្យល់ ១៦:១០) ដូច្នោះ អំឡុងពេល២ឆ្នាំ ដែលលោកប៉ុលជាប់ឃុំនៅឯទីក្រុងសេសារា គាត់(លូកា)ប្រហែលជារស់នៅក្នុងតំបន់ក្បែរៗនោះដែរ ។ បន្ទាប់មក គាត់ក៏ធ្វើដំណើរទៅទីក្រុងរ៉ូមជាមួយនឹងលោកប៉ុលតែម្ដង ។ *កងទ័ពអូគូស្ទ* "មើលការពន្យល់ ១០:១"។

**២៧:២** *ស្រុកអាត្រាមីត* ស្រុកអាត្រាមីតនៅក្នុងខនេះគឺសំដៅលើកំពង់ផែសមុទ្រមួយនៅទីក្រុងអាត្រាមីត (ទីក្រុងអាត្រាមីតស្ថិតនៅភាគខាងកើតនៃទីក្រុងអាសុស ២០:១៣) នៃស្រុកមីស៊ា (១៦:៧)។ *អើរីស្ដាក* គាត់គឺជាគូកនស្មោះត្រង់ម្នាក់របស់លោកប៉ុល ដែលបានធ្វើការងារ និងទទួលការបៀតបៀនជាច្រើនជាមួយគ្នា (ភល ២៤ មើលការពន្យល់ ១៩:២៩)។ ម្យ៉ាងទៀតមានមតិមួយចំនួនយល់ថា ដោយព្រោះលោកអើរីស្ដាកមកពីស្រុកម៉ាសេដូន ដូច្នោះគាត់ប្រហែលជាបែកពី លោកប៉ុលនៅត្រង់កន្លែងប្ដូរសំពៅទី១ (នៅស្រុកម៉ាសេដូន) ក្រោយមក ទើបទៅជួបគ្នាជាថ្មីម្ដងទៀតនៅឯទីក្រុងរ៉ូម ។

ឡូនីច[ដ] ទៅជាមួយផង ៣ដល់ថ្ងៃស្អែក យើងបានចូលទៅចត
នៅក្រុងស៊ីដូន[ឋ] នោះយូលាសបានប្រព្រឹត្តនឹងប៉ុលដោយ
សប្បុរស[ឌ] បានបើកឱ្យគាត់ទៅសួរពួកសំឡាញ់ នឹងទទួល
របស់អ្វីដែលគេជូនដល់គាត់ដែរ[ឍ] ៤យើងបើកពីទីនោះ
សសៀរតាមកោះគីប្រុសទៅ ដោយព្រោះច្រាសខ្យល់[ណ]
៥ក្រោយដែលបានឆ្លងកាត់សមុទ្រក្បែរស្រុកគីលីគា[ត]
នឹងស្រុកប៉ាមភីលាផុតហើយ[ថ] ក៏មកដល់មីរ៉ា នៅស្រុក
លូគា ៦នៅទីនោះ មេទ័ពរកបានសំពៅ១ មកពីក្រុង
អ័លេក្សានទ្រា[ទ] ដែលទៅស្រុកអ៊ីតាលី[ធ] ក៏ឱ្យយើងជិះទៅ
៧កាលបើកបន្តិចៗទៅជាយូរថ្ងៃ ក៏មកទន្ទឹមនឹងគ្នីដុស
ដោយពិបាកណាស់ ពីព្រោះខ្យល់មិនស្រួលសោះ[ន] នោះ
យើងបើកសសៀរចូលទៅ តាមកោះក្រេត[ប] ទល់មុខ
នឹងជ្រោយសាលម៉ូន ៨បើកទៅតាមកោះនោះ ដោយពិ
បាកណាស់ ក៏ដល់កន្លែង១ហៅថា ទ្វារសមុទ្រលំអ ដែល
នៅជិតក្រុងឡាសេ ។

៩លុះបានកន្លងមកជាយូរថ្ងៃ កាលសំពៅណា បើកទៅ
នឹងមានអន្តរាយ ពីព្រោះបុណ្យតមបានកន្លងហើយ[ផ] នោះ
ប៉ុលទូន្មានគេថា ១០អ្នករាល់គ្នាអើយ បើបើកទៅឥឡូវ ខ្ញុំ
យល់ឃើញថា នឹងមានអន្តរាយ ហើយខូចខាតជាច្រើន
មិនត្រឹមតែទំនិញ និងសំពៅប៉ុណ្ណោះទេ គឺដល់ទាំងជីវិត
យើងរាល់គ្នាផង[ព] ១១ប៉ុន្តែ មេទ័ពបានទុកចិត្ត នឹងអ្នកកាន់
ចង្កូត ហើយនិងម្ចាស់សំពៅ ជាជាងពាក្យដែលប៉ុលថា
នោះវិញ ១២ហើយដោយព្រោះទ្វារសមុទ្រនោះមិនស្រួល
នឹងសំណាក់នៅក្នុងរដូវរងាផង បានជាច្រើនគ្នាគេទូន្មាន
ឱ្យបើកចេញពីទីនោះទៅ ដើម្បីនឹងស្រូត ទៅឯភេនីច
ហើយឱ្យស្នាក់នៅក្នុងរដូវរងាវិញ បើសិនជាបាន នោះជា
ទ្វារសមុទ្រនៅកោះក្រេត[ភ] ដែលបែរទៅទិសនិរតី និង
ទិសពាយ័ព្យ ។

## ព្យុះសង្ឃរា

១៣ដូច្នេះ កាលមានខ្យល់បក់រំភើយៗមកពីទិសខាងត្បូង

**២៧:២** កច ២:៩ កច ១៩:២៩ កច ១៦:៩ ដ កច ១៧:១
**២៧:៣** ឋ មថ ១១:២១ ឌ ខ.៤៣ ឍ កច ២៤:២៣ ២៨:១៦
**២៧:៤** ណ ខ.៧
**២៧:៥** ត កច ៦:៩
**២៧:៥** ថ កច ២:១០
**២៧:៦** ទ កច ២៨:១១ ធ ខ.១ កច ១៨:២ ២៥:១២,២៥
**២៧:៧** ន ខ.៤ ប ខ.១២,១៣,២១ ទត ១:៥
**២៧:៩** ផ លវ ១៦:២៩–៣១ ២៣:២៧–២៩ ជន ២៩:៧
**២៧:១០** ព ខ.២១
**២៧:១២** ភ ខ.៧

**២៧:៣** *ក្រុងស៊ីដូន* ទីក្រុងនេះស្ថិតនៅភាគខាងជើងទីក្រុងសេសារាចម្ងាយប្រហែល ១១២ គ.ម ។

**២៧:៤** *កោះគីប្រុស* ជាកោះធំមួយស្ថិតនៅក្នុងសមុទ្រមេឌីទែរ៉ាណេ មានបណ្ដោយប្រហែល ២៣៧គ.ម ទទឹងប្រហែល ៦៤គ.ម និងស្ថិតនៅចម្ងាយប្រហែល ៩៦គ.ម ភាគខាងលិចនៃឆ្នេរសមុទ្រស្រុកស៊ីរី ។

**២៧:៥** *ស្រុកគីលីគា* ចាប់ពីឆ្នាំទី៦៧មុនគ.ស ស្រុកនេះត្រូវបានដាក់ទៅជាខេត្តមួយរបស់ចក្រភពរ៉ូម៉ាំង ហើយមានព្រំប្រទល់ខាងជើងជាប់ជាមួយស្រុកលូកោនា និងស្រុកកាប៉ាដូគា ខាងកើតឆៀងខាងត្បូងជាប់ជាមួយស្រុកស៊ីរី ។ ទីក្រុងធំជាងគេនៅក្នុងស្រុកនេះគឺទីក្រុងតើសុស ត្រូវជាកន្លែងកំណើតរបស់លោកប៉ុល ។ សាសន៍យូដារស់នៅក្នុងស្រុកនេះ ត្រូវមកប្រជុំឯសាលាប្រជុំនៅក្រុងយេរូសាឡិម(៦:៩) ។ *ស្រុកប៉ាមភីលា* ស្ថិតនៅតាមបណ្ដោយឆ្នេរសមុទ្រមេឌីទែរ៉ាណេ មានព្រំប្រទល់ខាងជើងជាប់ជាមួយខេត្តកាឡាទី និងស្រុកកាប៉ាដូគា ខាងកើតជាប់ជាមួយខេត្តគីលីគា ខាងលិចជាប់ជាមួយខេត្តលូគា ។ លោកប៉ុល និងបាណាបាសគឺជាអ្នកនាំដំណឹងល្អមកកាន់ខេត្តនេះមុនគេបង្អស់ (១៣:១៣ ១៤:២៤) ។

**២៧:៦** *សំពៅ១ មកពីក្រុងអ័លេក្សានទ្រា* គឺជាសំពៅ (ដឹកទំនិញ) មកពីប្រទេសអេស៊ីព្ទ ដែលធ្វើដំណើរឆ្ពោះទៅកាន់ទីក្រុងរ៉ូមតែម្ដង ។ ប្រសិនបើលោកប៉ុល និងអ្នកផ្សេងៗទៀត នៅតែបន្តធ្វើដំណើរតាមសំពៅទី១ នោះត្រូវចូលចតនៅស្រុកម៉ាសេដូន បន្ទាប់មកនៅប្រទេសក្រេក ហើយឆ្ពោះទៅកាន់ទីក្រុងរ៉ូមតែម្ដង ។ ប៉ុន្តែលោកយូលាសជាមេទ័ពរងបានបញ្ជាឱ្យប្ដូរសំពៅទី១ ហើយឱ្យទៅធ្វើដំណើរតាមសំពៅ ដែលមកពីទីក្រុងអ័លេក្សានទ្រានោះវិញ ដោយគិតថានឹងបានទៅដល់ទីក្រុងរ៉ូមឆាប់ជាង ព្រោះពុំចាំបាច់ចូលចតនៅប្រទេសក្រិកនោះទេ ។ ជាលទ្ធផល ពួកគេទទួលនូវគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរ ព្រោះតែមិនព្រមស្ដាប់តាមដំបូន្មានរបស់លោកប៉ុល ។

**២៧:៧** *គ្នីដុស* ជាទីក្រុងមួយស្ថិតនៅតាមបណ្ដោយឆ្នេរសមុទ្រមេឌីទែ-រ៉ាណេ ចម្ងាយ២៧២គ.ម ពីទីក្រុងមីរ៉ា ។ ពួកសាសន៍យូដាបានមករស់នៅទីនោះប្រហែលជាសតវត្សរ៍ទី២មុនគ.ស ។ រយៈពេលធ្វើដំណើរពីទីក្រុងមីរ៉ាទៅឯទីក្រុងគ្នីដុស ប្រហែលជា១០ទៅ១៥ថ្ងៃ ។ *កោះក្រេត* ស្ថិតនៅក្នុងសមុទ្រមេឌីទែរ៉ាណេ ភាគខាងត្បូងឆៀងខាងកើតនៃប្រទេសក្រេក មានបណ្ដោយ ប្រហែល២២៤គ.ម និងទទឹងប្រហែល៥៦គ.ម ហើយសព្វថ្ងៃមានឈ្មោះថា "កោះឃែនឌា (Candia) "។ ពួកយូដាបានធ្វើដំណើរពីកោះនេះទៅឯទីក្រុងយេរូសាឡិមនៅថ្ងៃបុណ្យទី៥០ (កច ២:១១) ។ *ជ្រោយសាលម៉ូន* ជាតំបន់ (ជ្រោយ) មួយស្ថិតនៅភាគខាងកើតបំផុតនៃកោះក្រេត ។ ក្នុងដំណើរទៅកាន់ទីក្រុងរ៉ូម លោកប៉ុល និងគូកនបានឆ្លងកាត់តំបន់នោះ ដែលបច្ចុប្បន្នមានឈ្មោះថា "ឃែប ស៊ីដឺរ៉ូ (Cape Sidero) "។

**២៧:៨** *ទ្វារសមុទ្រលំអ ដែលនៅជិតក្រុងឡាសេ* គឺជាតំបន់មួយដែលស្ថិតនៅស្ទើរតែចំណុចកណ្ដាលនៃកោះក្រេត ភាគខាងត្បូងបំផុត ។ កាលពីមុនតំបន់នោះ គ្រាន់តែជាកំពង់ផែសមុទ្រមួយប៉ុណ្ណោះ ប៉ុន្តែក្រោយមកត្រូវបានគេអភិវឌ្ឍឱ្យទៅជាទីក្រុងវិញ ។

**២៧:៩** *បុណ្យតម* (ឬហៅថាថ្ងៃប្រោសលោះ) ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ។ នៅក្នុងរដូវកាលបុណ្យតមនោះ ការធ្វើដំណើរតាមសមុទ្រមានឧបសគ្គច្រើនណាស់ព្រោះខ្យល់ព្យុះ និងរលកធំៗ អាចកើតមានឡើងគ្រប់ពេលវេលា ។ តាមទម្លាប់ពួកយូដា ពេលវេលាដែលប្រសើរ សម្រាប់ការធ្វើដំណើរតាមសមុទ្រគឺចាប់ពីខែឧសភា រហូតដល់ខែមិថុនា ។ រីឯពួករ៉ូម៉ាំងវិញយល់ថា ឧបសគ្គទាំងនោះអាចកើតមានតែនៅខែកញ្ញា និងខែតុលាប៉ុណ្ណោះ ។ ដូច្នោះ បានជាមេទ័ពរងមិនព្រមស្ដាប់តាមការទូន្មានរបស់លោកប៉ុល និងបណ្ដាលឱ្យពួកគេជួបនូវគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរ ។

**២៧:១២** *ភេនីច* ជាកំពង់ផែមួយ ស្ថិតនៅភាគខាងលិចឆៀងខាងត្បូងនៃកោះក្រេត ហើយជាតំបន់ដែលជៀសផុតពីខ្យល់ព្យុះនៅរដូវរងាផងដែរ ។

**២៧:១៣-៤៤** ត្រង់ចំណុចនេះ មិនគ្រាន់តែជាហេតុការណ៍ដែលបានកើតឡើងពិតប៉ុណ្ណោះទេ គឺថែមទាំងជានិមិត្តរូបបង្ហាញអំពីការជំនុំជម្រះ ដែលនឹងត្រូវមកដល់ផងដែរ ។ អ្នកដំណើរនៅក្នុងសំពៅ តំណាងឱ្យមនុស្សនៅលើ

នោះគេស្មានថាបានដូចចិត្ត ហើយក៏ស្រាវយុថ្កាឡើង បើក
ទៅតាមក្បែរកោះក្រេត ១៤តែក្រោយមកបន្តិច នោះមាន
ធ្លាក់ខ្យល់ព្យុះកំណាច[ម] ដែលហៅថា ខ្យល់អើរ៉ាគ្លី
ដូន មកប៉ះនឹងសំពៅ ១៥ហើយយើងបំបែរក្បាលសំពៅ
ទៅចំខ្យល់ពុំបាន នោះក៏ទុកឱ្យបណ្ដោយតាមខ្យល់ទៅ
១៦បានសសៀរទៅតាមកោះ១តូច ឈ្មោះក្លូដេ ហើយ
លើកទូក[យ] ចងដោយពិបាកណាស់ ១៧កាលលើកចង
ស្រេចហើយ គេក៏យកខ្សែពួរចងព័ទ្ធសំពៅ រួចទំលាក់
ក្ដោងឱ្យរសាត់ទៅតាមខ្យល់ ខ្លាចក្រែងកឿង[រ]នឹងផ្ទុក
ខ្សាច់ ១៨ដល់ថ្ងៃស្អែកឡើង យើងទំលាក់ទំនិញចោល
ចេញ ព្រោះខ្យល់ព្យុះសង្ឃរាបោកប៉ះយើងជាខ្លាំង[ល]
១៩ហើយដល់ថ្ងៃទី៣ ក៏ចោលគ្រឿងប្រដាប់សំពៅដោយ
ដៃខ្លួនយើងទៀត ២០រួចដោយព្រោះមិនឃើញថ្ងៃ ឬផ្កាយ
ជាយូរថ្ងៃ ហើយព្យុះសង្ឃរាមិនចេះអន់ស្រាកសោះ បាន
ជាយើងលែងសង្ឃឹមនឹងរួចជីវិតបាន ។

២១កាលគេបានតមអាហារជាយូរថ្ងៃ នោះប៉ុលឈរ
ឡើងនៅកណ្ដាលគេ និយាយថា អ្នករាល់គ្នាអើយ គួរតែ
បានស្ដាប់តាមខ្ញុំ[វ] ហើយមិនចេញពីកោះក្រេត[ស]មក នោះ
យើងមិនត្រូវអន្តរាយ ហើយខូចខាតដូច្នេះទេ ២២តែឥឡូវ
នេះ ខ្ញុំទូន្មានអ្នករាល់គ្នា ឱ្យសង្ឃឹមឡើង[ហ] ដ្បិតគ្មានពួកអ្នក
រាល់គ្នាណា១ នឹងបាត់ជីវិតទេ ខូចខាតតែសំពៅប៉ុណ្ណោះ
២៣ព្រោះយប់មិញ មានទេវតានៃព្រះ[ឡ] ដែលខ្ញុំជាអ្នកបំរើ
របស់ទ្រង់[អ] បានមកឈរជិត[ក]ខ្ញុំ ប្រាប់ថា ២៤ប៉ុលអើយ
កុំខ្លាចអ្វីឡើយ ត្រូវឱ្យអ្នកឈរនៅមុខសេសារ[ខ] ហើយមើល
ព្រះទ្រង់បានអនុញ្ញាត ឱ្យអស់អ្នកដែលដើរដំណើរជាមួយ
នឹងអ្នកដែរ[គ] ២៥ដូច្នេះ អ្នករាល់គ្នាអើយ ចូរសង្ឃឹមឡើង[ឃ]
ព្រោះខ្ញុំជឿព្រះថា ការដែលទ្រង់មានបន្ទូលមកខ្ញុំ នឹងកើត
មកដូច្នោះមែន[ង] ២៦ប៉ុន្តែ យើងត្រូវធ្លាក់[ច]ទៅលើកោះណា
មួយ[ឆ] ។

## សំពៅត្រូវខូចខាត

២៧ដល់គំរប់១៤យប់ កំពុងដែលយើងរសាត់ទៅមក
ក្នុងសមុទ្រអាឌ្រា នោះប្រហែលជាកណ្ដាលអធ្រាត្រ ពួក
សំពៅស្មានថា យើងជិតដល់ទីគោកណាមួយហើយ ២៨លុះ
បានបោះសំណស្ទង់ទឹកចុះទៅ ក៏ឃើញមានជំរៅ២០ព្យាម
រួចទៅបន្តិចទៀត ក៏ស្ទង់មើល ឃើញមានតែ១៥ព្យាម
២៩នោះគេទំលាក់យុថ្កា៤ពីខាងកន្សៀ ក្រែងសំពៅទង្គិចប៉ះ
នឹងថ្ម រួចគេទន្ទឹងចាំភ្លឺឡើង ៣០ពួកសំពៅ ក៏សំរូតទូក[ជ]
ទំលាក់ទឹក ធ្វើដូចជាចង់ទំលាក់យុថ្កាពីខាងក្បាលដែរ តែ
គេចង់រត់ចោលសំពៅទេ ៣១នោះប៉ុល និយាយទៅមេទ័ព
នឹងពួកទាហានថា បើពួកនោះ មិននៅក្នុងសំពៅ នោះអ្នក
រាល់គ្នាមិនបានរួចទេ ៣២ពួកទាហានក៏កាត់ខ្សែឱ្យទូក
ធ្លាក់ទៅ[ឈ] ។

**២៧:១៤** ម មក ៤:៣៧
**២៧:១៦** យ ខ.៣០
**២៧:១៧** រ ខ.២៦,៣៩
**២៧:១៨** ល ខ.១៩, ៣៨ យណ ១:៥
**២៧:២១** វ ខ.១០ ស ខ.៧
**២៧:២២** ហ ខ.២៥,៣៦
**២៧:២៣** ឡ កច ៥:១៩ អ រម ១:៩ ក កច ១៨:៩ ២៣:១១ ២ធច ៤:១៧
**២៧:២៤** ខ កច ២៣:១១ គ ខ.៤៤
**២៧:២៥** ឃ ខ.២២,៣៦ ង រម ៤:២០,២១
**២៧:២៦** ច ខ.១៧,៣៩ ឆ កច ២៨:១
**២៧:៣០** ជ ខ.១៦
**២៧:៣២** ឈ ខ.២៤

ពិភពលោកនេះទាំងមូល ។ ខ្យល់ព្យុះតំណាងឱ្យការជំនុំជម្រះនៃព្រះអម្ចាស់ ។ រីឯការទូន្មានរបស់លោកប៉ុល គឺតំណាងឱ្យព្រះបន្ទូលនៃដំណឹងល្អ ដែលជាសេចក្ដីសង្ឃឹមតែមួយគត់របស់ពួកគេ (យហ ១:១៤–១៦) ។

**២៧:១៤** *ខ្យល់អើរ៉ាគ្លីដូន* គឺជាខ្យល់បក់មកពីឈូងសមុទ្រអាទ្រា នាំមកនូវរលកធំៗ ធ្វើឱ្យសំពៅដែលក្នុងនោះមានលោកប៉ុល និងគូកនរបស់គាត់ផងដែរ បានទៅប៉ះនឹងកោះមេលីត (Malta) បណ្ដាលឱ្យខូចខាតស្ទើរតែទាំងស្រុង ។

**២៧:១៦** *ក្លូដេ* ជាកោះមួយស្ថិតនៅភាគខាងត្បូងឆៀងខាងលិចនៃកោះក្រេត មានបណ្ដោយប្រហែល ១១,២គ.ម និងទទឹងប្រហែល ៤,៨គ.ម ។

**២៧:១៧** *ក៏យកខ្សែពួរចងព័ទ្ធសំពៅ* ការធ្វើយ៉ាងដូច្នោះ គឺមិនចង់ឱ្យបំណែកសំពៅត្រូវបាក់បែកចេញពីគ្នា ។ *ផ្ទុកខ្សាច់* សំដៅលើតំបន់ឆ្នេរសមុទ្រនៅភាគខាងជើងនៃទ្វីបអាហ្វ្រិក (Africa) ។

**២៧:១៨-១៩** *ទំលាក់ទំនិញចោលចេញ* ត្រង់ចំណុចនេះ ពុំមែនមានន័យថាពួកគេទម្លាក់ទំនិញ និងរបស់របរចោលទាំងអស់នោះទេ ប៉ុន្តែពួកគេបានរក្សាទុកនូវស្រូវអង្ករខ្លះដែរ (ខ.៣៨) ។

**២៧:២០** អ្នកធ្វើដំណើរតាមផ្លូវសមុទ្រនាសម័យនោះអាចដឹងទិសដៅរបស់ខ្លួនបានដោយសារមើលទៅលើទីតាំងរបស់ផ្កាយទាំងឡាយ ។ ដូច្នោះហើយបានជាពួកអ្នកនៅក្នុងសំពៅពុំដឹងថាខ្លួនកំពុងតែធ្វើដំណើរទៅណាទេ ព្រោះនៅពេល នោះមេឃងងឹតនិងមើលពុំឃើញផ្កាយទេ ។ សំពៅបានរសាត់ទៅតាមខ្យល់ ឆ្ពោះទៅទិសខាងលិចអស់រយៈពេល ១៤ថ្ងៃ ។

**២៧:២១-២២** អ្នកធ្វើដំណើរគ្រប់គ្នានៅក្នុងសំពៅចាប់ផ្ដើមអស់សង្ឃឹម ហើយម្នាក់ៗគិតថាខ្លួននឹងស្លាប់មិនខានឡើយ ។ ឃើញដូច្នោះ លោកប៉ុលក៏ក្រោកឈរឡើង លើកទឹកចិត្តពួកគេឱ្យមានសង្ឃឹមឡើងវិញ ។

**២៧:២៣–២៦** ត្រង់ចំណុចនេះបង្ហាញយ៉ាងច្បាស់ថា ព្រះអម្ចាស់ទ្រង់គង់នៅជាមួយនឹងលោកប៉ុល ហើយបំភ្លឺផ្លូវគាត់ជានិច្ច ។ ហើយសព្វថ្ងៃនេះទ្រង់ក៏គង់នៅជាមួយនឹងយើងគ្រប់គ្នាដែលជឿដល់ព្រះនាមទ្រង់ផងដែរ ។

**២៧:២៧** *១៤យប់* រយៈពេលនោះចាប់គិតពីពេលចេញដំណើរពីទ្វារសមុទ្រលំអ ។ *សមុទ្រអាទ្រា* ជាសមុទ្រមួយស្ថិតនៅចន្លោះប្រទេសអ៊ីតាលី និងប្រទេសក្រិក ។ នៅសម័យនោះ ផ្ទៃទឹកសមុទ្រអាទ្រាលាតសន្ធឹងរហូតដល់កោះក្រេត ប៉ុន្តែ បច្ចុប្បន្នទំហំរបស់វាត្រូវបានកាត់បន្ថយ ។

**២៧:២៨** *សំណស្ទង់ទឹក* គឺជាឧបករណ៍មួយបែបធ្វើអំពីខ្សែ (អាចជាអំបោះ) និងមានដុំសំណចងនៅខាងចុង ប្រើសម្រាប់វាស់ជម្រៅទឹកសមុទ្រ ។

**២៧:២៩** *នោះគេទំលាក់យុថ្កា* ខណៈនោះជាពេលយប់ងងឹតមើលអ្វីពុំឃើញទេ ដូច្នោះហើយទើបពួកគេទម្លាក់យុថ្កា ព្រោះថាបើធ្វើដំណើរទៅមុខទៀតខ្លាចក្រែងទៅប៉ះនឹងផ្ទាំងថ្ម ដែលជាហេតុបណ្ដាលឱ្យមានការខូចខាតដល់សំពៅកាន់តែធ្ងន់ធ្ងរថែមទៀត ។

**២៧:៣០–៣២** ពួកអ្នកដំណើរគិតថា គ្មានមធ្យោបាយណាមួយអាចជួយពួកគេឱ្យបានរួចជីវិតឡើយ ទើបសម្រេចចិត្តនាំគ្នាលួចរត់ ដោយប្រើទូកតូចៗ

៣៣លុះដល់ថ្ងៃជិតរះ ប៉ុលក៏ទូន្មាន ឱ្យគេបរិភោគទាំង
អស់គ្នាដោយពាក្យថា នេះគំរប់១៤ថ្ងៃហើយ ដែលអ្នក
រាល់គ្នានៅចាំយាម ទាំងតមអាហារ ៣៤ដូច្នេះ ខ្ញុំទូន្មានអ្នក
រាល់គ្នាឱ្យពិសាទៅ ដ្បិតនេះមានប្រយោជន៍ ឱ្យអ្នករាល់គ្នា
បានរួចជីវិត ព្រោះសក់១សរសៃ នៅក្បាលអ្នករាល់គ្នា ក៏
មិនត្រូវបាត់ផង[ញ] ៣៥កាលនិយាយដូច្នេះហើយ គាត់យក
នំបុ័ងមកអរព្រះគុណដល់ព្រះ នៅមុខគេទាំងអស់គ្នា រួច
កាច់[ដ]បរិភោគទៅ ៣៦គេមានសង្ឃឹមឡើង[ឋ] ហើយក៏
បរិភោគទាំងអស់គ្នាដែរ ៣៧រីឯយើងទាំងអស់ដែលនៅក្នុង
សំពៅនោះមាន២៧៦នាក់ ៣៨កាលបរិភោគឆ្អែតហើយ
ក៏សំរាលសំពៅចេញ ដោយទំលាក់ស្រូវចុះទៅក្នុងសមុទ្រ[ឌ]
៣៩លុះភ្លឺច្បាស់ហើយ នោះគេមិនបានស្គាល់ស្រុកនោះទេ
តែគេឃើញញោច១មានជំរាល[ឍ] រួចគេគិតជំរង់សំពៅ
ឱ្យទៅកឿងនៅទីនោះ បើសិនជាបាន ៤០គេក៏កាត់ពួរយុថ្កា
ចោល[ណ]នៅសមុទ្រ រួចស្រាយចង្កូត ហើយលើកក្តោងខាង
មុខឱ្យត្រូវខ្យល់ ជំរង់សំពៅទៅឯទីជំរាលនោះ ៤១សំពៅក៏
ចូលទៅកឿង នៅកន្លែងដែលទឹកហូរប្រសព្វគ្នា ហើយ
ក្បាលជ្រមុជជាប់នៅនឹងថ្កល់ តែកន្សៀត្រូវបាក់បែកទៅ
ដោយអំណាចរលក[ត] ។
៤២ឯពួកទាហាន គេចង់សំឡាប់អ្នកទោសទាំងប៉ុន្មាន
ចោលចេញ ដោយខ្លាចក្រែងហែលរត់រួចខ្លះ ៤៣តែមេទ័ព
ចង់ជួយប៉ុលឱ្យរួច[ថ] បានជាឃាត់គេ មិនឱ្យធ្វើតាមគំនិត
នោះឡើយ ក៏បង្គាប់អ្នកណាដែលចេះហែល ឱ្យលោត
ហែលទៅដល់គោកជាមុន ៤៤ហើយឱ្យអ្នកដែលនៅសល់
ទាំងប៉ុន្មាន តោងបន្ទះក្តារ ឬបំណែកសំពៅបណ្តែតទៅ
ដូច្នេះ អ្នកទាំងអស់គ្នា ក៏បានដល់គោក ដោយសុខសាន្ត
ត្រាណ[ទ] ។

**២៧:៣៤** ញ មថ ១០:៣០
**២៧:៣៥** ដ មថ ១៤:១៩
**២៧:៣៦** ឋ ខ.២២,២៥
**២៧:៣៨** ឌ ខ.១៨ យណ ១:៥
**២៧:៣៩** ឍ កច ២៨:១
**២៧:៤០** ណ ខ.២៩
**២៧:៤១** ត ២កថ ១១:២៥
**២៧:៤៣** ថ ខ.៣
**២៧:៤៤** ទ ខ.២២,៣១
**២៨:១** ធ កច ១៦:១០ ២៧:២៦,៣៩

## នៅលើកោះមេលីត

**២៨** ១កាលគេបានរួចជីវិតហើយ នោះទើបស្គាល់កោះ
នោះ[ធ] ថាជាកោះមេលីត ២មនុស្សស្រុកនោះ ក៏ប្រព្រឹត្តនឹង
យើង ដោយចិត្តសប្បុរស លើសជាងធម្មតា គេបង្កាត់ភ្លើង
ទទួលយើងទាំងអស់គ្នា ពីព្រោះធ្លាក់ភ្លៀង ហើយរងាផង
៣ឯប៉ុល ក៏ប្រមូលរំកាច់មែកឈើ១កង យកមកដាក់លើ
ភ្លើង នោះមានពស់វែក១ត្រូវកំដៅភ្លើង បានចេញមកចឹក
ជាប់នៅដៃគាត់ ៤លុះពួកអ្នកស្រុកនោះ ឃើញពស់សំយុង

(សំប៉ាន) នៅក្នុងសំពៅនោះតែម្តង ។ ភ្លាមៗនោះ លោកប៉ុលបានយល់អំពីគំនិតរបស់ពួកគេ រួចគាត់ក៏ប្រាប់លោកមេទ័ពរងឱ្យឃាត់ពួកគេជាបន្ទាន់ ដោយហេតុថា បើឱ្យពួកគេទៅយ៉ាងដូច្នោះ នោះនឹងមិនអាចទៅដល់ទីគោកបានទេ ហើយពួកគេនឹងត្រូវស្លាប់ទាំងអស់គ្នាមិនខាន ព្រោះចម្ងាយពីសំពៅទៅឆ្នេរនោះ នៅឆ្ងាយនៅឡើយ ម្យ៉ាងទៀតសមុទ្រក៏មានរលកធំៗផង ។

**២៧:៣៣** *ទាំងតមអាហារ* ត្រង់ចំណុចនេះពុំមានន័យថាពួកគេមិនបានបរិភោគអ្វីសោះនោះទេ គឺគ្រាន់តែមិនបានបរិភោគអាហារទៀងទាត់ប៉ុណ្ណោះ ។ ដូច្នេះ លោកប៉ុលក៏លើកទឹកចិត្តពួកគេឱ្យមានសង្ឃឹមនិងបរិភោគជាធម្មតាវិញ ។

**២៧:៣៥** *គាត់យកនំបុ័ងមកអរព្រះគុណដល់ព្រះ* នេះជាគំរូដ៏ល្អសម្រាប់គ្រប់អ្នកជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ គឺឱ្យពួកគេចេះពោលពាក្យអរព្រះគុណទ្រង់គ្រប់ទាំងព្រះពរដែលទ្រង់ប្រទាន និងគ្រប់កាលៈទេសៈទាំងអស់ (លក ៩:១៦ ២៤:៣០ ១ធថ ៤:៤–៥) ។

**២៧:៣៧** *នោះមាន២៧៦នាក់* ការដែលបញ្ជាក់អំពីចំនួនមនុស្សនៅក្នុងសំពៅ គឺដើម្បីងាយស្រួលក្នុងការបែងចែកអាហារដល់ពួកគេគ្រប់គ្នា ហើយប្រហែលជាចង់ដឹងចំនួនច្បាស់លាស់ មុនពេលពួកគេឡើងទៅទីគោក ។ ចំនួនមនុស្សនៅក្នុងសំពៅនោះមិនច្រើនទេ បើធៀបទៅនឹងសំពៅមួយ ដែលលោកយ៉ូសែបហ្វឺស (Josephus ជាអ្នកប្រវត្តិសាស្ត្រ កើតនៅឆ្នាំ៣៧ ឬ ៣៨ គ.ស) ជិះធ្វើដំណើរទៅប្រទេសអ៊ីតាលីនោះដែរ គឺមានចំនួនមនុស្សរហូតដល់៦០០នាក់ ។

**២៧:៣៨** *ក៏សំរាលសំពៅចេញ ដោយទំលាក់ស្រូវចុះទៅក្នុងសមុទ្រ* ពួកគេធ្វើដូច្នោះ ដើម្បីឱ្យសំពៅស្រាល និងអាចទៅក្បែរឆ្នេរគោកបាន ព្រោះគ្មានកំពង់ផែសម្រាប់ចូលចតទេ ។

**២៧:៣៩–៤១** ទីកន្លែងដែលសំពៅនោះកឿង គឺនៅត្រង់ឆកសមុទ្រមួយនៃកោះមេលីត (Malta) ហើយសព្វថ្ងៃឆកនោះមានឈ្មោះថា "ឆករបស់សាវកប៉ុល" ។

**២៧:៤២** *ឯពួកទាហាន គេចង់សំឡាប់អ្នកទោសទាំងប៉ុន្មានចោល* ពួកទាហានចង់សម្លាប់អ្នកទោសទាំងនោះចោល ព្រោះថាបើពួកគេរត់រួច ទោសកំហុសទាំងប៉ុន្មាននឹងត្រូវធ្លាក់មកលើពួកខ្លួន (១៦:២៧ និងពន្យល់) ។

**២៧:៤៣–៤៤** *មេទ័ព* គឺលោកមេទ័ពរងឈ្មោះយូលាស (ខ.៣ និងពន្យល់ ខ.១) ដែលតែងតែប្រព្រឹត្តដោយសប្បុរសចំពោះលោកប៉ុល ទោះបីគាត់ជាអ្នកទោសក៏ដោយ ។ ទង្វើរបស់លោកមេទ័ពរងនោះ បានបញ្ជាក់អំពីការចុះចូលមួយចំពោះព្រះអម្ចាស់ដូចដែលទ្រង់មានព្រះបន្ទូលថា អស់អ្នកណាទទួលអ្នកបម្រើស្មោះត្រង់របស់ទ្រង់ នោះក៏មានន័យថាទទួលទ្រង់ដែរ ។

**២៨:១** *កោះមេលីត* ជាកោះមួយមានបណ្តោយប្រហែល ២៧,២គ.ម និងទទឹងប្រហែល១៤,៤គ.ម ស្ថិតនៅខាងត្បូងប្រទេសអ៊ីតាលី ក្នុងសមុទ្រមេឌីទែរ៉ាណេ ។

**២៨:២** *មនុស្សស្រុកនោះ* សំដៅលើអស់អ្នកដែលរស់នៅលើកោះមេលីត ។ អ្នកទាំងនោះមានសញ្ជាតិរ៉ូម៉ាំង និយាយភាសា ផូនីស៊ាន (Phoenician dialect) ប៉ុន្តែមិនចេះនិយាយភាសាក្រិកទេ ។ *ព្រោះធ្លាក់ភ្លៀង ហើយរងាផង* ត្រង់ចំណុចនេះចង់បញ្ជាក់ថា លោកប៉ុលបានទៅដល់កោះមេលីតនោះនៅចុងខែតុលា និងដើមខែវិច្ឆិកា ។

**២៨:៣** *ពស់វែក* ប្រជាជនរស់នៅលើកោះនោះស្គាល់ច្បាស់ថា ពស់ដែលចឹកដៃរបស់លោកប៉ុលនោះ គឺជាពស់មានពិសសាហាវណាស់ ។

ចុះពីដៃគាត់មកដូច្នោះ[ន] នោះក៏និយាយគ្នាថា ប្រាកដជា
មនុស្សនេះ បានសំឡាប់គេហើយ បានជាទោះបើរួចពី
សមុទ្រក៏ដោយ គង់តែសេចក្ដីយុត្តិធម៌មិនព្រមឱ្យនៅរស់
ដែរ[ប] ៥តែគាត់រលាស់ពស់នោះ ទៅក្នុងភ្លើងវិញ ឥតមាន
ឈឺចាប់អ្វីឡើយ[ផ] ៦គេរង់ចាំមើលគាត់ជាហើម ឬដួលស្លាប់
ភ្លាមទៅ តែកាលគេបានចាំជាយូរ ហើយឥតឃើញមាន
ឈឺអ្វីសោះ នោះគេប្រែគំនិត ទៅជាថា គាត់ជាព្រះវិញ[ព]
៧នៅព័ទ្ធជុំវិញទីនោះមានដីរបស់អ្នកមេកោះឈ្មោះពូព្លាស
ដែលទទួលយើង ឱ្យស្នាក់នៅផ្ទះគាត់៣ថ្ងៃ ដោយសប្បុរស
៨គាប់ចួនជាឪពុកពូព្លាស ដេកគ្រុន ហើយមួលផង ប៉ុលក៏
ចូលទៅអធិស្ឋាន[ភ] ដាក់ដៃលើគាត់[ម] ឱ្យបានជា[យ] ៩ដូច្នេះ
អស់អ្នកឯទៀត ដែលឈឺនៅកោះនោះ ក៏មកហើយបានជា
ដែរ ១០គេក៏រាប់អាន[រ] យើងជាខ្លាំង ហើយដល់វេលា ដែល
យើងចេញទៅ នោះគេបានឱ្យគ្រប់ទាំងរបស់ដែលយើង
ត្រូវការដែរ ។

## នៅឯទីក្រុងរ៉ូម

១១លុះ៣ខែក្រោយមក យើងចុះសំពៅ១ទៅ ជាសំពៅ
ដែលមកពីក្រុងអ័លេក្សានទ្រា[ល] ឈ្មោះឌីអូស្គូរ ដែលនៅនឹង
កោះនោះក្នុងរដូវរងា ១២កាលបានចូលចតនៅស៊ីរ៉ាគូស
ក៏នៅក្រុងនោះ៣ថ្ងៃ ១៣ពីទីនោះ យើងបើកវាងទៅដល់
រេគាម ហើយ១ថ្ងៃក្រោយមក កើតមានខ្យល់ពីខាងត្បូង
ដល់ថ្ងៃទី២ យើងទៅដល់ពូទីយ៉ូលី ១៤នៅទីនោះ យើងរក
ឃើញពួកជំនុំខ្លះ[វ] គេក៏សូមឱ្យយើងនៅជាមួយអស់៧ថ្ងៃ
គឺដូច្នោះឯង ដែលយើងបានទៅឯក្រុងរ៉ូម ១៥រីឯពួកជំនុំ[ស]
នៅក្រុងរ៉ូម កាលបានឮនិយាយពីយើង នោះគេក៏ចេញមក
ចួបនឹងយើង ត្រឹមផ្សារអាប់ភាស នឹងផ្ទះសំណាក់បី លុះ
ប៉ុលឃើញគេ នោះក៏អរព្រះគុណដល់ព្រះ ហើយមានចិត្ត
សង្ឃឹមឡើង ១៦គ្រាដល់ក្រុងរ៉ូមហើយនោះ មេទ័ពក៏ប្រគល់
ពួកអ្នកទោសទៅលោកមេបន្ទាយ ប៉ុន្តែ គេបើកឱ្យប៉ុល
នៅដោយខ្លួន មានតែទាហាន១ ដែលរក្សាប៉ុណ្ណោះ[ហ] ។

## លោកប៉ុលប្រកាសព្រះបន្ទូលនៅទីក្រុងរ៉ូម

១៧ក្រោយ៣ថ្ងៃមក ប៉ុលអញ្ជើញ ពួកមេសាសន៍យូដា[ឡ]

**២៨:៤** ន មក ១៦:១៨
ប លក ១៣:២,៤
**២៨:៥** ផ លក ១០:១៩
**២៨:៦** ព កច ១៤:១១
**២៨:៨** ភ យក ៥:១៤,១៥
ម កច ៦:៦
យ កច ៩:៤០
**២៨:១០** រ ទដ ១៥:៤
**២៨:១១** ល កច ២៧:៦
**២៨:១៤** វ កច ១:១៦
**២៨:១៥** ស កច ១:១៦
**២៨:១៦** ហ កច ២៤:២៣ ២៧:៣
**២៨:១៧** ឡ កច ២៥:២

**២៨:៥** *ឥតមានឈឺចាប់អ្វីឡើយ* ឃ្លានេះជាព្រះបន្ទូលសន្យារបស់ព្រះយេស៊ូវ ដូចមានចែងនៅក្នុង "មក ១៦:១៨" ថា *"នឹងចាប់កាន់ពស់បាន ឬបើគេផឹកអ្វីពុលនោះមិនធ្វើឱ្យអន្តរាយទេ . . ."* ។

**២៨:៦** *គេរង់ចាំមើលគាត់ជាហើម* ពួកអ្នករស់នៅលើកោះមេលីតដឹងថា ពស់ដែលចឹកលោកប៉ុលមានពិសសាហាវណាស់ ដូច្នោះពួកគេគិតថាលោកប៉ុលពិតជាឈឺចាប់ ហើយខ្លួនរបស់គាត់នឹងត្រូវហើមជាមិនខាន ។ ប៉ុន្តែ ក្រោយដែលពួកគេរង់ចាំមើលជាយូរ និងគ្មានហេតុការណ៍អាក្រក់ណាកើតឡើងចំពោះលោកប៉ុល នោះក៏ចាប់ផ្ដើមមានការភាន់ច្រឡំ ដូចពួកអ្នកនៅឯទីក្រុងលីស្ត្រាដែរ ដោយគិតថា គាត់ជាព្រះ (១៤:១១–១៨) ។

**២៨:៧** *អ្នកមេកោះ ឈ្មោះពូព្លាស* ឃ្លានេះបញ្ជាក់ថាគាត់ជាមន្ត្រីធំរបស់ចក្រភពរ៉ូម៉ាំងនៅកោះមេលីតនោះ (មើល ខ.១១ ១៣:៧ ១៦:២០ ១៧:៦ ១៩:៣១) ។

**២៨:៨–១០** ត្រង់ចំណុចនេះមានន័យថា អស់អ្នកដែលមានជំងឺនៅលើកោះមេលីតនោះ បានជាដោយសារតែអំណាចព្រះចេស្ដានៃព្រះយេស៊ូវគ្រីស្ទ ។

**២៨:១១** *លុះ៣ខែក្រោយមក* លោកប៉ុល និងគូកន ហើយនិងអស់អ្នកដែលនៅក្រោមបង្គាប់របស់លោកមេទ័ពរងយូលាសទាំងអស់ បានស្នាក់នៅលើកោះមេលីតអស់រយៈពេល៣ខែ ព្រោះក្នុងអំឡុងពេលនោះការធ្វើដំណើរតាមសមុទ្រមានការលំបាកខ្លាំង ។ ពួកគេបានចេញដំណើរពីកោះនោះនៅចុងខែកុម្ភៈ ឬដើមខែមីនា ។

**២៨:១២** *ស៊ីរ៉ាគូស* ជាទីក្រុងមួយស្ថិតនៅឆ្នេរសមុទ្រភាគខាងត្បូងឆៀងខាងកើតនៃខេត្តស៊ីស៊ីលី (Sicily ជាខេត្តមួយនៃចក្រភពរ៉ូម៉ាំង ខាងត្បូងប្រទេសអ៊ីតាលី) ។

**២៨:១៣** *រេគាម* ជាទីក្រុងមួយ ស្ថិតនៅតាមឆ្នេរសមុទ្រភាគខាងត្បូងនៃប្រទេសអ៊ីតាលី និងចម្ងាយប្រហែល១១គ.ម ពីភាគខាងកើតនៃខេត្តស៊ីស៊ីលី (Sicily) ។ សព្វថ្ងៃទីក្រុងនេះមានឈ្មោះថា "រេកគីយ៉ូ (Rheggio)" ។ *ពូទីយ៉ូលី* ជាទីក្រុងមួយ ស្ថិតនៅតាមឆ្នេរសមុទ្រ ទៀររេីនាន (Tyrrhenian Sea) និងមានចម្ងាយប្រហែល ៣២០គ.ម ពីភាគខាងជើងនៃទីក្រុងរេគាម ។ ប្រជាជនរស់នៅទីនោះក៏មានពួកសាសន៍យូដា និងអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទផងដែរ ។

**២៨:១៥** *ផ្សារអាប់ភាស* គឺជាផ្សារមួយស្ថិតនៅភាគខាងត្បូងឆៀងខាងកើតទីក្រុងរ៉ូមចម្ងាយប្រហែល៦៩គ.ម ។ ពួកជំនុំខ្លះនៅទីក្រុងរ៉ូមបានមកជួបលោកប៉ុលនៅទីនោះ ។ *ផ្ទះសំណាក់បី* ជាឈ្មោះរបស់ទីប្រជុំជនមួយកន្លែងស្ថិតនៅភាគខាងត្បូងទីក្រុងរ៉ូម ប្រហែល ៥៣គ.ម ។ មានពួកជំនុំមួយចំនួនបានធ្វើដំណើរពីទីក្រុងរ៉ូម ដើម្បីមកជួបលោកប៉ុលនៅទីនោះ ។

**២៨:១៦** *ប៉ុលនៅដោយខ្លួន* មានន័យថាលោកប៉ុលមានសេរីភាពរស់នៅក្នុងផ្ទះដែលគាត់ជួលនៅទីក្រុងរ៉ូមនោះបាន (ខ.៣០) ព្រោះថាគាត់មិនបានប្រព្រឹត្តនូវបទឧក្រិដ្ឋ ឬបង្កឱ្យមានភាពចលាចលខាងផ្នែកនយោបាយណាមួយទេ ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏មានទាហាននៅចាំយាមគាត់ជានិច្ចដែរ ។ ម្យ៉ាងទៀតប្រហែលជាគេចងដៃរបស់គាត់ម្ខាងដោយច្រវាក់ភ្ជាប់ទៅនឹងដៃរបស់ទាហាន ដែលចាំយាមគាត់នោះតែម្ដង (អភ ៦:២០ ភល ១:១៣–១៤,១៧ លក ៤:៣,១៨ ភម ១០,១៣) ។

**២៨:១៧** *ពួកមេសាសន៍យូដា* សំដៅលើពួកអ្នកដឹកនាំរបស់សាសន៍យូដានៅក្នុងទីក្រុងរ៉ូម ។ ក្នុងរជ្ជកាលរបស់ស្ដេចអធិរាជក្លូឌាស (សោយរាជ្យពីឆ្នាំទី ៤១គ.ស រហូតដល់ឆ្នាំទី៥៤គ.ស) ពួកសាសន៍យូដាទាំងអស់ត្រូវបានបណ្ដេញចេញពីទីក្រុងរ៉ូម (មើលការពន្យល់ ១៨:២) ។ ប៉ុន្តែ ក្រោយមកពួកសាសន៍យូដាមួយចំនួនបាន ត្រឡប់ទៅរស់នៅឯទីក្រុងរ៉ូមវិញ ។ *ឱអ្នករាល់គ្នាជាបងប្អូនខ្ញុំអើយ* លោកប៉ុលនិយាយយ៉ាងដូច្នេះទៅកាន់ពួកសាសន៍យូដា ពីព្រោះគាត់ចង់បង្ហាញអំពីភាពស្និទ្ធស្នាល ក្នុងនាមគាត់ជាសាសន៍

ឱ្យមកប្រជុំគ្នា កាលគេមូលគ្នាហើយ នោះគាត់ពោលពាក្យ
ទៅគេថា ឱអ្នករាល់គ្នា ជាបងប្អូនខ្ញុំអើយ[អ] ខ្ញុំគ្មានធ្វើខុសអ្វី
នឹងសាសន៍យើង[ក] ឬនឹងទំលាប់ពួកឰយុកោ[ខ]ទេ តែគេចាប់
ខ្ញុំនៅក្រុងយេរូសាឡិម បញ្ជូនមកក្នុងកណ្តាប់ដៃនៃសាសន៍
រ៉ូម ១៨ដែលពិចារណាសួរខ្ញុំ[គ] រួចចង់លែងខ្ញុំ[ឃ] ពីព្រោះខ្ញុំ
គ្មានទោសអ្វីគួរនឹងស្លាប់ទេ[ង] ១៩ប៉ុន្តែ ពួកសាសន៍យូដា
ប្រកែកមិនព្រម បានជាបង្ខំឱ្យខ្ញុំសូមរើក្តី ដល់សេសារ[ច]វិញ
មិនមែនជាខ្ញុំមានការណ៍អ្វី នឹងចោទប្រកាន់ពីសាសន៍ខ្ញុំទេ
២០ហេតុនោះ បានជាខ្ញុំអញ្ជើញអ្នករាល់គ្នាមក ដើម្បីឱ្យ
បានឃើញមុខ ហើយនឹងពិគ្រោះគ្នា ដ្បិតគឺដោយព្រោះ
សេចក្តីសង្ឃឹមរបស់សាសន៍អ៊ីស្រាអែល[ឆ]ហើយ បានជាខ្ញុំ
ជាប់ច្រវាក់ដូច្នេះ[ជ] ២១គេឆ្លើយឡើងថា យើងមិនបាន
ទទួលសំបុត្រណា ពីស្រុកយូដា ពីរឿងអ្នកសោះ ក៏គ្មានបង
ប្អូន[ឈ]ណាមកប្រាប់ យើង ឬនិយាយសេចក្តីអ្វីអាក្រក់ពី
អ្នកដែរ ២២តែយើងចូលចិត្តចង់ដឹងគំនិតរបស់អ្នក ដែល
អ្នកគិតដូចម្តេច ព្រោះយើងដឹងថា នៅគ្រប់ទីកន្លែង គេតែង
តែនិយាយអាក្រក់ ពីពួកអ្នកកាន់សាសនានេះណាស់[ញ]។
២៣គេក៏ណាត់ថ្ងៃកំណត់ រួចមានគ្នាជាច្រើន មកឯគាត់
ក្នុងទីលំនៅរបស់គាត់ ហើយគាត់អធិប្បាយ ទាំងធ្វើបន្ទាល់
សព្វគ្រប់ តាំងពីព្រឹកដល់ល្ងាច ពីនគរព្រះ[ដ] ឱ្យគេស្តាប់
ក៏បញ្ចុះបញ្ចូល ឱ្យគេជឿអស់ទាំងសេចក្តី ដែលដំរូវពី
ព្រះយេស៊ូវ[ឋ] ក្នុងក្រិត្យវិន័យលោកម៉ូសេ ហើយក្នុងគម្ពីរពួក
ហោរា[ឌ] ២៤អ្នកខ្លះក៏ទទួលជឿសេចក្តី ដែលគាត់អធិប្បាយ
តែអ្នកខ្លះមិនព្រមជឿទេ[ឍ] ២៥នោះគេចេញទៅទាំងទាស់
ទែងគ្នា ក្រោយដែលប៉ុលបាននិយាយ១ម៉ាត់នេះ ទៅគេថា
ព្រះវិញ្ញាណបរិសុទ្ធ មានបន្ទូល[ណ] នឹងពួកឰយុកោយើង
ដោយសារហោរាអេសាយ ត្រូវណាស់ថា ២៦«ចូរទៅឯ
សាសន៍នេះប្រាប់គេថា ដែលឯងរាល់គ្នាឮ នោះនឹងឮមែន
តែស្តាប់មិនបាន ហើយដែលឯងរាល់គ្នាឃើញ នោះនឹង
ឃើញមែន តែមិនយល់សោះ ២៧ព្រោះចិត្តសាសន៍នេះ
បានត្រឡប់ជាស្ពឹក[ត] គេបានឮដោយត្រចៀកធ្ងន់ ហើយបាន
ធ្មេចភ្នែក ក្រែងមើលឃើញនឹងភ្នែក ស្តាប់ឮនឹងត្រចៀក
ហើយចិត្តបានយល់ រួចគេវិលមក ដើម្បីឱ្យអញបានប្រោស
ឱ្យគេជា»[ថ] ២៨ដូច្នេះ ចូរអ្នករាល់គ្នាដឹងថា ព្រះទ្រង់ផ្សាយ
សេចក្តីសង្គ្រោះ[ទ]នេះ ទៅដល់សាសន៍ដទៃវិញ[ធ] ហើយគេ
នឹងស្តាប់ជាពិត ២៩លុះកាលគាត់បាននិយាយសេចក្តីទាំង
នេះរួចហើយ នោះពួកសាសន៍យូដាក៏ចេញទៅទាំងជជែក
គ្នាជាខ្លាំង។
៣០រីឯប៉ុល គាត់នៅក្នុងផ្ទះដែលគាត់ជួលពេញ២ឆ្នាំ គាត់

**២៨:១៧** អ កច ២២:៥ ក កច ២៥:៨ ខ កច ៦:១៤
**២៨:១៨** គ កច ២២:២៤ ឃ កច ២៦:៣១,៣២ ង កច ២៣:៩
**២៨:១៩** ច កច ២៥:១១
**២៨:២០** ឆ កច ២៦:៦,៧
**២៨:១៩** ជ កច ២១:៣៣
**២៨:២១** ឈ កច ២២:៥
**២៨:២២** ញ កច ២៤:៥,១៤
**២៨:២៣** ដ មថ ៣:២ កច ១៩:៨
ឋ កច ១៧:៣
ឌ កច ៨:៣៥
**២៨:២៤** ឍ កច ១៤:៤ ១៧:៤,៥
**២៨:២៥** ណ ហេ ៣:៧
**២៨:២៧** ត ទដ ១១៩:៧០
ថ អស ៦:៩,១០ មថ ១៣:១៥ **២៨:២៨** ទ លក ២:៣០ ធ កច ១៣:៤៦

យូដាដូចពួកគេដែរ (ប្រៀបធៀប ខ.១៥ និងមើលការពន្យល់ ១១:១)។
**២៨:១៨** *ដែលពិចារណាសួរខ្ញុំ រួចចង់លែងខ្ញុំ* ត្រង់ចំណុចនេះលោកប៉ុលចង់បញ្ជាក់ប្រាប់ពួកអ្នកដឹកនាំសាសន៍យូដាថា គាត់ជាមនុស្សគ្មានកំហុសអ្វីដែលត្រូវទទួលទោសនោះទេ ។
**២៨:២០** *សេចក្តីសង្ឃឹមរបស់សាសន៍អ៊ីស្រាអែល* "មើលពន្យល់ ២៦:៦"។
**២៨:២១** ត្រង់ចំណុចនេះបង្ហាញថា ពួកសាសន៍យូដានៅទីក្រុងរ៉ូមពុំបានឮព័ត៌មានអ្វីដែលនិយាយអាក្រក់អំពីលោកប៉ុលទេ ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ពួកគេបានដឹងនូវរឿងរ៉ាវ ដែលទាក់ទងទៅនឹងពួកអ្នកជឿលើព្រះយេស៊ូវគ្រីស្ទ នៅឯទីក្រុងយេរូសាឡិមនោះដែរ (ខ.២២)។
**២៨:២២** *យើងចូលចិត្តចង់ដឹង គំនិតរបស់អ្នក* ពួកសាសន៍យូដានៅទីក្រុងរ៉ូមចង់ស្តាប់ការបកស្រាយរបស់លោកប៉ុលអំពីសេចក្តីដែលពួកគេបានឮនោះ។ លោកប៉ុលក៏អធិប្បាយពន្យល់ពួកគេ នូវគ្រប់សេចក្តីដែលថា ព្រះយេស៊ូវគ្រីស្ទពិតជាព្រះមែស៊ី ដែលត្រូវយាងមកសង្គ្រោះមនុស្សលោកនោះហើយ ។ ម្យ៉ាងទៀត ពេលនោះជាឱកាសល្អ សម្រាប់ធ្វើការពន្យល់ដល់ពួកសាសន៍យូដា ដែលរស់នៅទីក្រុងរ៉ូម ព្រោះពួកសាសន៍យូដាជាដើមចោទនៅឯទីក្រុងយេរូសាឡិមមិនទាន់បានមកដល់ទីនោះនៅឡើយ ។
**២៨:២៣-២៤** លោកប៉ុលបានលើកយកបទគម្ពីរនៅក្នុងសញ្ញាចាស់មកពន្យល់ពួកគេថា ព្រះយេស៊ូវ គឺជាព្រះសង្គ្រោះរាស្ត្រអ៊ីស្រាអែលពិតមែន ។ បន្ទាប់ពីបានស្តាប់លោកប៉ុលអធិប្បាយរួចហើយ នោះមានពួកសាសន៍យូដាខ្លះបានទទួលជឿ និងខ្លះទៀតមិនព្រមជឿទេ ។ *ក្រិត្យវិន័យលោកម៉ូសេ ហើយក្នុងគម្ពីរពួកហោរា* គឺព្រះគម្ពីរសញ្ញាចាស់ (លក ២៤:២៧,៤៤)។
**២៨:២៥-២៧** បន្ទាប់ពីថ្លែងព្រះបន្ទូលទៅកាន់ពួកសាសន៍យូដា នោះលោកប៉ុលសង្កេតឃើញថា មានពួកគេជាច្រើនមិនព្រមជឿ ។ ដូច្នោះគាត់ក៏លើកយកបទគម្ពីរ "អស ៦:៩–១០" មកព្រមានដល់ពួកគេ គឺដូចគ្នានឹងព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ ដែលព្រមានដល់ពួកបណ្តាជននៅក្នុងបទគម្ពីរ "មថ ១៣:១៣–១៧ មក ៤:១២ លក ៨:១០ យហ ១២:៣៩–៤០" នោះដែរ ។
**២៨:២៨** *ព្រះទ្រង់ផ្សាយសេចក្តីសង្គ្រោះនេះ ទៅដល់សាសន៍ដទៃវិញ* ឃ្លានេះ លោកប៉ុលចង់មានន័យថា ព្រះអម្ចាស់ទ្រង់ប្រទានសេចក្តីសង្គ្រោះដល់គ្រប់មនុស្សទាំងអស់ មិនចំពោះតែសាសន៍យូដាប៉ុណ្ណោះទេ ។ ម្យ៉ាងទៀតគាត់ចង់បញ្ជាក់ប្រាប់ពួកគេឱ្យដឹងច្បាស់ថា ព្រះអម្ចាស់ទ្រង់ជ្រើសរើសគាត់ ដើម្បីប្រកាសព្រះបន្ទូលនៃសេចក្តីសង្គ្រោះ ទៅគ្រប់មនុស្សទាំងអស់ទាំងសាសន៍យូដា និងសាសន៍ដទៃ (មើលការពន្យល់ ៩:១៥ រម ១:១៣ ១១:១៣)។
**២៨:២៩** *នោះពួកសាសន៍យូដាក៏ចេញទៅ ទាំងជជែកគ្នាជាខ្លាំង* ការជជែកគ្នានោះ បានកើតឡើងរវាងពួកអ្នកជឿ និងអស់អ្នកដែលមិនជឿ ហើយជាពិសេស គឺបានកើតឡើងនៅក្នុងចំណោមពួកអ្នកដែលមិនព្រមជឿនោះតែម្តង ។
**២៨:៣០** *គាត់នៅក្នុងផ្ទះដែលគាត់ជួលពេញ២ឆ្នាំ* រយៈពេល២ឆ្នាំនោះ

| | | |
|---|---|---|
| បានទទួលអស់អ្នកណា ដែលមកឯគាត់ ទាំងប្រកាសប្រាប់ពីនគរព្រះ[ន] ហើយបង្រៀនគ្រប់ទាំងសេចក្ដីពីព្រះអម្ចាស់ | **២៨:៣០** ន ខ.២៣ មថ ៤:២៣ ប កច ៤:២៩ | យេស៊ូវគ្រីស្ទ តាមចិត្ត[ប] ឥតមានអ្នកណាឃាត់ឃាំងឡើយ ។ |

ទោះបីលោកប៉ុលរស់នៅក្នុងផ្ទះជួល ក្នុងនាមជាអ្នកទោសក៏ដោយ ក៏គាត់នៅតែខិតខំ បម្រើព្រះអម្ចាស់យ៉ាងអស់ពីចិត្តរបស់គាត់ដដែល ។ បន្ទាប់ពីរយៈពេល២ឆ្នាំ នោះមកអ្នកខ្លះយល់ថា លោកប៉ុលត្រូវគេដោះលែងឱ្យមានសេរីភាពឡើងវិញ ដោយសំអាងលើពាក្យសំដីរបស់គាត់នៅក្នុង "ភល ២:២៤ និង ភម ២២"។

ទាំងអស់នេះគឺជាគំរូនៃជ័យជម្នះ និងព្រះគុណដែលព្រះអម្ចាស់ទ្រង់ប្រទានមកអ្នកបម្រើស្មោះត្រង់របស់ទ្រង់ ។

# សំបុត្ររបស់ប៉ុល

## ដល់ពួក

## រ៉ូម

សេចក្ដីផ្ដើម

**អ្នកនិពន្ធ**

អ្នកសរសេរកណ្ឌគម្ពីរនេះ គឺជាសាវ័កប៉ុល(១:១)។ នៅក្នុងសតវត្សរ៍ទីមួយ ពុំឃើញមានមតិជំទាស់ណាមួយសោះថា ប៉ុលពុំមែនជាអ្នកសរសេរនោះឡើយ ។ នៅក្នុងកណ្ឌនេះ មានរឿងប្រវត្តិសាស្ត្រមួយចំនួនដែលទាក់ទងទៅនឹងព្រឹត្តិការណ៍សំខាន់ៗនៃជីវិតរបស់លោកសាវ័កប៉ុល ហើយកណ្ឌនេះ ក៏ជាខ្នាតគំរូនៃគោលលទ្ធិរបស់សាវ័កប៉ុលផងដែរ បើប្រៀបធៀបទៅនឹងកណ្ឌគម្ពីរដទៃទៀតដែលគាត់បានសរសេរ ។

**កាលបរិច្ឆេទ និងទីកន្លែងសរសេរ**

កណ្ឌនេះប្រហែលត្រូវបានសរសេរនៅដើមនិទាឃរដូវនៃឆ្នាំ៥៧គ.ស ក្នុងដំណើរបេសកកម្មលើកទីបីរបស់លោកប៉ុល ពេលគាត់រៀបបម្រុងនឹងវិលត្រឡប់មកក្រុងយេរូសាឡិមវិញ ដោយមានទាំងប្រាក់ដង្វាយសម្រាប់ជួយគ្រីស្ទបរិស័ទក្រីក្រនៅក្រុងនោះផង(១៥:២៥–២៧ និងការពន្យល់)។ នៅត្រង់ ១៥:២៦ បានឱ្យដឹងថា លោកប៉ុលបានទទួលប្រាក់ដង្វាយរួចហើយ ពីពួកជំនុំនៅស្រុកម៉ាសេដូន និងស្រុកអាខៃ ដូច្នេះគាត់អាចនៅក្រុងកូរិនថូស ឬក៏នៅស្រុកម៉ាសេដូន និងស្រុកអាខៃ។ តែបើតាមផ្ទៃរឿងនៃសំបុត្រកូរិនថូសទី១បញ្ជាក់ថា គាត់មិនបានទៅក្រុងកូរិនថូសនៅឡើយទេ ក្នុងដំណើរបេសកកម្មលើកទីបីនោះ(១កថ ១៦:១–៤) ហើយសំបុត្រកូរិនថូសទី២បញ្ជាក់ថា ការរៃប្រាក់ដង្វាយក៏មិនទាន់គ្រប់នៅឡើយដែរ (២កថ ៨–៩) ដូច្នេះការសរសេរគម្ពីររ៉ូមនេះគឺបន្ទាប់ពីលោកប៉ុលបានសរសេរសំបុត្រកូរិនថូសទី១ និងកូរិនថូសទី២ចប់សព្វគ្រប់ក្នុងឆ្នាំទី៥៥គ.ស ។

ទីកន្លែងដែលគាត់បានសរសេរគឺនៅក្នុងក្រុងកូរិនថូស ឬក្រុងកេងក្រា(ទីក្រុងទាំងពីរនេះមានចម្ងាយពីគ្នាប្រហែល៩,៦គ.មតែប៉ុណ្ណោះ) ដោយព្រោះតែមានជាប់ទាក់ទងទៅនឹងនាងភីបេជាអ្នកក្រុងកេងក្រា(១៦:១ និងសេចក្ដីពន្យល់) និងលោកកៃយុសជាអ្នកទទួលឱ្យលោកប៉ុលស្នាក់នៅ (១៦:២៣ និងការពន្យល់) គាត់ម្នាក់នេះអាចជាអ្នកក្រុងកូរិនថូស(១កថ ១:១៤)។ លោកអេរ៉ាស្ទុស(១៦:២៣ និងការពន្យល់) ក៏អាចជាអ្នកក្រុងកូរិនថូសនោះដែរ (២ធថ ៤:២០)។

**អ្នកទទួល**

អ្នកទទួលសំបុត្រនេះដំបូងគេបំផុតនោះគឺជាពួកជំនុំនៅក្រុងរ៉ូមដែលភាគច្រើនជាសាសន៍ដទៃ(១:៧) ហើយនៅក្នុងនោះក៏មានសាសន៍យូដាខ្លះផងដែរ(៤:១ ជំពូក ៩–១១ និងមើលការពន្យល់ ១:១៣)។ ដូច្នេះ ដំបូងលោកប៉ុលបានផ្ញើសំបុត្រនេះទៅពួកជំនុំនៅក្រុងរ៉ូមទាំងមូលបន្ទាប់មកដល់អ្នកដទៃទៀត បានជាគាត់ប្រើជាទម្រង់ខ្លី(ជំពូក១–១៤ ឬ១–១៥) សម្រាប់ចែកចាយសំបុត្រនេះបន្តទៅទៀត(មើលការពន្យល់ ២ ពត ៣:១៥)។

**ផ្ទៃរឿងសំខាន់ៗ**

ផ្ទៃរឿងសំខាន់ៗនៃការសរសេររបស់សាវ័កប៉ុលនៅក្នុងគម្ពីររ៉ូមនេះគឺនិយាយអំពីមូលដ្ឋានគ្រឹះនៃដំណឹងល្អ ផែនការនៃសេចក្ដីសង្គ្រោះ និងសេចក្ដីសុចរិតរបស់ព្រះបានផ្ដល់មកដល់មនុស្សគ្រប់រូប ទាំងសាសន៍យូដា និងសាសន៍ដទៃ(មើលសេចក្ដីពន្យល់ ១:១៦–១៧)។ ការរាប់ជាសុចរិត ដោយសារសេចក្ដីជំនឿនេះត្រូវបានពន្យល់យ៉ាងច្រើនក្នុងផ្ទៃរឿងនីមួយៗ ក៏ដូចជានៅក្នុងបទគម្ពីរនេះទាំងមូល ។ "សេចក្ដីសុចរិតបានមកពីព្រះ" (១:១៧) បូករួមនឹងការរាប់ជាសុចរិតដោយសារជំនឿនេះ គឺមិនប្រកាន់ថាអ្នកនោះជាមនុស្សមានទោស និងមនុស្សបរិសុទ្ធនោះឡើយ ។

**គោលបំណង**

គោលបំណងរបស់លោកប៉ុលក្នុងការសរសេរសំបុត្រនេះមានបីយ៉ាងខុសៗគ្នា:

១. ដើម្បីប្រាប់ជាមុនពីដំណើររបស់គាត់មកសួរសុខទុក្ខពួកជំនុំនៅក្រុងរ៉ូម និងដំណើរបេសកកម្មរបស់គាត់ទៅប្រទេសអេស្ប៉ាញ (១:១០–១៥, ១៥:២២–២៩)។

២. ដើម្បីប្រាប់អំពីសេចក្ដីសង្គ្រោះដល់ពួកជំនុំដែលពុំធ្លាប់បានទទួលសេចក្ដីបង្រៀនពីពួកសាវ័កសោះកាលពីមុន ។

៣. ដើម្បីពន្យល់សាសន៍យូដា និងសាសន៍ដទៃនៅក្រុងរ៉ូមឱ្យមានទំនាក់ទំនងគ្នាល្អ ព្រោះព្រះមានផែនការសម្រាប់ប្រោសលោះពួកគេដូចៗគ្នា ។ នៅពេលនោះសាសន៍យូដាត្រូវបានសាសន៍ដទៃភាគច្រើនបដិសេធ ដោយព្រោះពួកអ្នកជឿសាសន៍យូដានេះនៅតែខំប្រព្រឹត្ត

គេដូចៗគ្នា ។ នៅពេលនោះសាសន៍យូដាត្រូវបានសាសន៍ដទៃភាគច្រើនបដិសេធ ដោយព្រោះពួកអ្នកជឿសាសន៍យូដានេះនៅតែខំប្រព្រឹត្តតាមក្រិត្យវិន័យនៃ ការតមអាហារ និងថ្ងៃបរិសុទ្ធ (១៤:២–៦) ។

**ព្រឹត្តិការណ៍សំខាន់**

នៅពេលដែលលោកប៉ុលសរសេរសំបុត្រនេះ ប្រហែលជាគាត់នៅឯក្រុងកូរិនថូស (កច ២០:២–៣ និងសេចក្ដីពន្យល់) ក្នុងដំណើរបេសកកម្មលើកទីបី ។ ការងាររបស់គាត់នៅត្រង់សមុទ្រមេឌីទែរ៉ាណេភាគខាងកើត គឺស្ទើរតែចប់សព្វគ្រប់អស់ហើយ (១៥:១៨–២៣) ហើយនៅពេលនេះគាត់ចង់ទៅសួរសុខទុកគ្រីស្ទបរិស័ទនៅក្រុងរ៉ូមខ្លាំងណាស់ (១:១១–១២ ១៥:២៣–២៤) ។ តែទោះជាយ៉ាងនេះក៏ដោយ គាត់មិនអាចទៅក្រុងរ៉ូមបានទេ ពីព្រោះគាត់ត្រូវយកប្រាក់ដែលប្រមូលបានពីសាសន៍ដទៃសម្រាប់ជួយដល់គ្រីស្ទបរិស័ទឈឺ និងក្រីក្រនោះទៅក្រុងយេរូសាឡិមដោយខ្លួនឯង (១៥:២៥–២៨ និងសេចក្ដីពន្យល់) ដូចច្នេះ បានជាគាត់សរសេរសំបុត្រនេះ ជំនួសការទៅដោយផ្ទាល់នោះវិញ ។ ហើយបានភ្ជាប់ពីបំណងដែល គាត់ចង់ទៅប្រទេសអេស្ប៉ាញ (១៥:២៣–២៤ និងសេចក្ដីពន្យល់ ខ.២៤) ទៀតផង ។ អស់រយៈកាលជាច្រើនឆ្នាំមកហើយ លោកប៉ុលបានចង់ទៅ សួរសុខទុក្ខ និងបម្រើការ នៅក្រុងរ៉ូម (១:១៣–១៥) ហើយសំបុត្រនេះបានលាតត្រដាងពីការយកចិត្តទុកដាក់ ហើយនិងផ្នែកដំបូងនៃទេវសាស្ត្រ ដែលស្ដីអំពីសេចក្ដីសង្ឃឹមថាខ្លួនគាត់ផ្ទាល់បានទៅបម្រើព្រះទៅទីនោះ ។ ដោយគាត់មិនបានស្គាល់ពួកជំនុំនៅក្រុងកូរិនថូសដោយផ្ទាល់នោះហើយ បានជាគាត់លើកយកបញ្ហាពួកជំនុំនៅទីនោះតិចតួចតែប៉ុណ្ណោះមកនិយាយ (១៤:១–១៥, ១៣:១–៧, ១៦:១៧–១៨) ។

**មាតិការឿង**

លោកប៉ុលបានចាប់ផ្ដើមស្ទង់មើលស្ថានភាពផ្នែកខាងព្រលឹងវិញ្ញាណដល់មនុស្សទាំងអស់ដែលរស់នៅក្រុងរ៉ូម នោះគាត់បានដឹងថាទាំង សាសន៍យូដា និងសាសន៍ដទៃ គឺត្រូវការសេចក្ដីសង្គ្រោះរបស់ព្រះដូចៗគ្នា ។ សេចក្ដីសង្គ្រោះរបស់ព្រះនោះ បានកំពុងផ្ដល់មកតាមរយៈព្រះយេស៊ូវគ្រីស្ទ ហើយនិងការដែលទ្រង់បានធ្វើនៅលើឈើឆ្កាង ។ តែទោះបីជាយ៉ាងនេះក៏ដោយ នេះគឺជាព្រះពរមួយសម្រាប់មនុស្ស ដែលត្រូវទទួលការនេះដោយសេចក្ដីជំនឿ ។ លោកប៉ុលបានលើកយករឿងលោកអ័ប្រាហាំមកធ្វើជាគំរូ ដែលស្ដីអំពីគោលការរបស់ព្រះអម្ចាស់ក្នុងការដោះស្រាយ រឿងរ៉ាវជាមួយនឹងមនុស្សលោក ។ លោកប៉ុលបានបង្ហាញថាសេចក្ដីសង្គ្រោះ គឺគ្រាន់តែជាការចាប់ផ្ដើមនៃបទពិសោធន៍ថ្មីមួយរបស់គ្រីស្ទបរិស័ទទេ ហើយអ្វីដែលមានបន្តទៅទៀតនោះគឺពួកគេបានរួចពីអំណាចនៃអំពើបាប ក្រិត្យវិន័យ ហើយនិងសេចក្ដីស្លាប់ ។ ព្រះពរនេះបានមកដោយសារការ រួមគ្នារបស់ពួកគេជាមួយនឹងព្រះយេស៊ូវគ្រីស្ទទាំងសុគត និងរស់ឡើងវិញ ហើយដោយសារអំណាចនៃព្រះវិញ្ញាណបរិសុទ្ធដែលកំពុងគង់នៅជាមួយនឹងពួកគេ ។ លោកប៉ុលបង្ហាញដល់ជនជាតិអ៊ីស្រាអែលផងដែរថា ទោះបីពួកគេមិនទាន់ជឿឥឡូវនេះក៏ដោយ ក៏ពួកគេស្ថិតនៅក្នុងផែនការសង្គ្រោះរបស់ព្រះដ៏មានគ្រប់ព្រះចេស្ដាដែរ ។ ឥឡូវនេះនៅសល់អ៊ីស្រាអែលខ្លះមិនទាន់ជឿនៅឡើយ ហើយពេលបន្តទៅទៀតនេះគឺជាការប្រែចិត្តរបស់សាសន៍ដទៃ តែមានពេលមួយមកដល់ នោះសាសន៍អ៊ីស្រាអែលទាំងអស់នឹងត្រូវបានសង្គ្រោះ (១១:២៦ និងមើលការពន្យល់) ។ នៅចុងបញ្ចប់នៃសំបុត្របានអំពាវនាវដល់អ្នកអានទាំងអស់ឱ្យពួកគេយកសេចក្ដីជំនឿដែលខ្លួនមានមកអនុវត្តទាំងនៅក្នុងពួកជំនុំ និងនៅក្នុងលោកីយ ។ គ្មានសំបុត្រផ្សេងណាទៀតដែលលោកប៉ុលបានបញ្ជាក់ច្បាស់ពីដំណឹងល្អជាងនេះឡើយ ដែលមានទាំងបច្ចុប្បន្ន និងអនាគត ។

**ចរិតលក្ខណៈពិសេស**

១. *ជាប្រភេទសំបុត្រដែលមានលក្ខណៈត្រឹមត្រូវតាមប្រព័ន្ធជាងគេបំផុតរបស់លោកប៉ុល* នៅពេលដែលយើងអានបានច្រើននោះធ្វើឱ្យយើងដឹងថា វាមិនត្រឹមតែជាសំបុត្រទេ តែហាក់បីដូចជាអត្ថបទទេវសាស្ត្រយ៉ាងល្អិតល្អន់ទៀតផង ។

២. *សង្កត់ធ្ងន់លើគោលលទ្ធិរបស់គ្រីស្ទបរិស័ទ* ផ្នែកទេវសាស្ត្រសំខាន់ៗមួយចំនួនបានលើកយកមកបង្ហាញយ៉ាងច្បាស់ៗដូចជា: អំពើបាបសេចក្ដីស្លាប់ សេចក្ដីសង្គ្រោះ ព្រះគុណ សេចក្ដីជំនឿ សេចក្ដីសុចរិត ការរាប់ជាសុចរិត ការរាប់ជាបរិសុទ្ធ ការប្រោសលោះ ការរស់ឡើងវិញ និងសិរីល្អរបស់ព្រះ ។

៣. *មានការដកស្រង់ពីគម្ពីរសញ្ញាចាស់ជាច្រើន* ក្នុងសំបុត្រមួយនេះ លោកប៉ុលបានដកស្រង់ចេញពីគម្ពីរសញ្ញាចាស់ដើម្បីជាជំនួយក្នុងការវែកញែកពន្យល់របស់គាត់ ជាពិសេសក្នុងជំពូក ៩–១១ ។

៤. *មានជាប់ទាក់ទងយ៉ាងខ្លាំងដល់សាសន៍អ៊ីស្រាអែល* លោកប៉ុលបានសរសេរអំពីស្ថានភាពរបស់អ៊ីស្រាអែលនាពេលបច្ចុប្បន្នរបៀបដែលពួក គេធ្វើការទំនាក់ទំនងជាមួយនឹងសាសន៍ដទៃ ហើយនិងសេចក្ដីសង្គ្រោះនៅថ្ងៃចុងក្រោយ ។

**គម្រោងសង្ខេប**

**I. សេចក្ដីផ្ដើម (១:១–១៥)**

**II. សាច់រឿង: សេចក្ដីសុចរិតបានមកពីព្រះ (១:១៦–១៧)**

**III. សេចក្ដីទុច្ចរិតរបស់មនុស្ស (១:១៨–៣:២០)**

ក. សាសន៍ដទៃ (១:១៨–៣២)

ខ. សាសន៍យូដា (២:១–៣:៨)

គ. សង្ខេបសេចក្ដីទុច្ចរិតរបស់មនុស្ស (៣:៩–២០)

**IV. ការរាប់ជាសុចរិត (៣:២១–៥:២១)**

ក. តាមរយៈព្រះយេស៊ូវគ្រីស្ទ (៣:២១–២៦)

ខ. ទទួលបានដោយសារជំនឿ (៣:២៧–៤:២៥)

១. ជំនឿ ហើយនិងក្រឹត្យវិន័យ (៣:២៧–៣១)

២. ជំនឿរបស់លោកអ័ប្រាហាំ (ជំពូក ៤)

គ. ផលផ្លែនៃសេចក្ដីសុចរិត (៥:១–១១)

ឃ. សេចក្ដីទុច្ចរិតរបស់មនុស្ស និងអំណោយទាននៃសេចក្ដីសុចរិតរបស់ព្រះ (៥:១២–២១)

**V. ការរាប់ជាបរិសុទ្ធ (ជំពូក ៦–៨)**

ក. ការរួចពីបាបរបស់ទីរ៉ានុស (ជំពូក ៦)

ខ. ការរួចពីបញ្ញត្តិរបស់ក្រឹត្យវិន័យ (ជំពូក ៧)

គ. ជីវិតនៅក្នុងអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ (ជំពូក ៨)

**VI. សេចក្ដីសុចរិតរបស់ព្រះបានដោះលែងអ៊ីស្រាអែល តាមផ្លូវដ៏យុត្តិធម៌របស់ទ្រង់ (ជំពូក ៩–១១)**

ក. ការបដិសេធន៍ដោយយុត្តិធម៌របស់ព្រះចំពោះអ៊ីស្រាអែល (៩:១–២៩)

ខ. មូលហេតុនៃការបដិសេធន៍ (៩:៣០–១០:២១)

គ. ការបដិសេធន៍ត្រូវបានលុបចោល (ជំពូក ១១)

១. ព្រះមិនបោះបង់រាស្ត្រទ្រង់ (១១:១–១០)

២. ការបោះបង់ គឺគ្រាន់តែជាការបណ្ដោះអាសន្នប៉ុណ្ណោះ (១១:១១–២៤)

៣. ព្រះហឫទ័យចុងក្រោយរបស់ព្រះអម្ចាស់ គឺសេចក្ដីមេត្តាករុណា (១១:២៥–៣៦)

**VII. ការប្រព្រឹត្តសេចក្ដីសុចរិត (១២:១–១៥:១៣)**

ក. ក្នុងរូបកាយ ក្នុងពួកជំនុំ (ជំពូក ១២)

ខ. ក្នុងលោកីយ (ជំពូក ១៣)

គ. ក្នុងចំណោមគ្រីស្ទបរិស័ទមានជំនឿខ្សោយ និងជំនឿមាំ (១៤:១–១៥:១៣)

**VIII. សរុបសេចក្ដី (១៥:១៤–៣៣)**

**IX. ពាក្យសរសើរ ពាក្យជម្រាបសួរ ហើយនិងបណ្ដាំចុងក្រោយ (ជំពូក ១៦)**

**១** ១សំបុត្រប៉ុលខ្ញុំ ជាបាវបំរើរបស់ព្រះយេស៊ូវគ្រីស្ទ
ដែលទ្រង់បានហៅមកធ្វើជាសាវក[ក] ទាំងញែកចេញទុក[ខ]
សំរាប់ដំណឹងល្អនៃព្រះ[គ] ២(ជាដំណឹងល្អដែលទ្រង់បាន
សន្យាពីដើម[ឃ] ដោយសារពួកហោរា[ង]ទ្រង់ ទុកក្នុងគម្ពីរ
បរិសុទ្ធ[ច] ៣គឺពីព្រះរាជបុត្រានៃព្រះដែលខាងឯសាច់
ឈាម[ឆ] ទ្រង់បានចាប់កំណើត ក្នុងព្រះវង្សាហ្លួងដាវីឌ[ជ] ៤តែ
ខាងឯព្រះវិញ្ញាណនៃសេចក្តីបរិសុទ្ធ នោះបានសំដែងមក
ច្បាស់ថា ទ្រង់ជាព្រះរាជបុត្រារបស់ព្រះពិត[ឈ]ទាំងមានព្រះ
ចេស្តាផង ដោយទ្រង់បានរស់ពីស្លាប់ឡើងវិញ[ញ] គឺជាព្រះ
យេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់[ដ]នៃយើងរាល់គ្នា ៥ដែលយើង
ខ្ញុំបានទទួលព្រះគុណ[ឋ] និងងារជាសាវកដោយសារទ្រង់
សំរាប់ឱ្យមានមនុស្សចុះចូល តាមសេចក្តីជំនឿ[ឌ] នៅ
កណ្តាលអស់ទាំងសាសន៍[ឍ] ទុកជាប្រយោជន៍ដល់ព្រះនាម
ទ្រង់ ៦ដែលអ្នករាល់គ្នាក៏នៅក្នុងពួកអ្នកទាំងនោះ ជាពួក
អ្នកដែលព្រះយេស៊ូវគ្រីស្ទ[ណ]ទ្រង់បានហៅដែរ)។
៧ខ្ញុំផ្ញើមកអស់អ្នកនៅក្រុងរ៉ូម ជាពួកស្ងួនភ្ងានៃព្រះ[ត]
ដែលទ្រង់បានហៅមកធ្វើជាពួកបរិសុទ្ធ[ថ] សូមឱ្យអ្នករាល់
គ្នាបានប្រកប ដោយនូវព្រះគុណ និងសេចក្តីសុខសាន្ត អំពី
ព្រះដ៏ជាព្រះវរបិតានៃយើងរាល់គ្នា ហើយអំពីព្រះអម្ចាស់
យេស៊ូវគ្រីស្ទ[ទ]។

## ការប៉ងទៅលេងក្រុងរ៉ូម

៨មុនដំបូងខ្ញុំសូមអរព្រះគុណដល់ព្រះនៃខ្ញុំ ដោយនូវព្រះ
យេស៊ូវគ្រីស្ទ ពីដំណើរអ្នករាល់គ្នា[ធ] ដោយឮគេថ្លែងប្រាប់
នៅគ្រប់ក្នុងលោកីយទាំងមូល[ន] ពីសេចក្តីជំនឿរបស់អ្នក
រាល់គ្នា ៩ដ្បិតព្រះដែលខ្ញុំបំរើដោយវិញ្ញាណខ្ញុំ[ប] ក្នុងដំណឹង
ល្អពីព្រះរាជបុត្រាទ្រង់ នោះជាស្មរបន្ទាល់[ផ]ពីខ្ញុំថា ខ្ញុំទូលដំ
ណាលពីអ្នករាល់គ្នា ក្នុងសេចក្តីអធិស្ឋានរបស់ខ្ញុំជានិច្ច
១០ព្រមទាំងសូមអង្វរជាដរាប[ព] ឱ្យខ្ញុំបានឱកាសស្រួលតាម

**១:១** ក ១កថ ១:១ ខ កថ ៩:១៥ គ រម ១៥:១៦ ២កថ ២:១២ ១១:៧ ១ថន ២:៨,៩ ១ពត ៤:១៧ **១:២** ឃ កថ ១៣:៣២ ទត ១:២ ង លក ១:៧០ រម ៣:២១ ច កទ ៣:៨ **១:៣** ឆ យហ ១:១៤ រម ៩:៥ ជ មថ ១:១ **១:៤** ឈ មថ ៤:៣ ញ កថ ២:២៤ ដ ១កថ ១:២ **១:៥** ឋ ១ធថ ១:១៤ ឌ កថ ៩:១៥ ឍ កថ ៦:៧ រម ១៦:២៦

**១:៦** ណ យដ ១ វវ ១៧:១៤ **១:៧** ត រម ៨:៣៩ ១ថន ១:៤ ថ កថ ៩:១៣ ទ ១កថ ១:៣ អភ ១:២ ១ថន ១:២ ទត ១:៤ ១ពត ១:២ **១:៨** ធ ១កថ ១:៤ អភ ១:១៦ ១ថន ២:១៣ ២ថន ១:៣ ២ធថ ១:៣ ន រម ១០:១៨ ១៦:១៩ **១:៩** ប ២ធថ ១:៣ ផ យប ១៦:១៩ យរ ៤២:៥ ២កថ ១:២៣ កទ ១:២០ ភល ១:៨ ១ថន ២:៥,១០ **១:១០** ព ១សយ ១២:២៣ លក ១៨:១ កថ ១:១៤ ភល ១:១៦ ភល ១:៤ កល ១:៩ ២ថន ១:១១ ២ធថ ១:៣ ភម ៤

**១:១** *ប៉ុល* កាលពីនៅសម័យបុរាណ អ្នកនិពន្ធតែងតែដាក់ឈ្មោះរបស់ខ្លួននៅដើមសំបុត្រ ។ ចំពោះរឿងរ៉ាវដែលលោកប៉ុលសរសេរពីកិច្ចការបម្រើព្រះរបស់គាត់ នោះ សូមមើល កថ ៩:១–៣០ ១៣:១–២៨:៣១ ។ ចំពោះជីវប្រវត្តិរបស់គាត់ សូម មើល ២កថ ៦:៣–១០ ១១:២១–១២:១០ កទ ១:១៣–២៤ ភល ៣:៤–១៤ ១ធថ ១:១២–១៦។ *បាវបំរើ* មានន័យពីរ (១)."ទាសករ" គឺខ្លួនមិនមែនជាម្ចាស់លើ ខ្លួនឯងទៀតទេ ឬគ្មានសេរីភាពធ្វើ និងសម្រេចចិត្តអ្វីឡើយ ។ (២)."អ្នកបម្រើ" អ្នកដែលមានឆន្ទះចាំតែបម្រើ ចៅហ្វាយខ្លួន(មើលការពន្យល់ នក ១៤:៣១ ទដ ១៨ អស ៤១:៨–៩ ៤២:១)។ *សាវក* គឺជាអ្នកដែលបានទទួលភារកិច្ចយ៉ាងពិសេសពីព្រះគ្រីស្ទ (មើលការពន្យល់ មក ៦:៣០ ១កថ ១:១ ហព ៣:១)។ *ញែកចេញ* មើលការពន្យល់ កទ ១:១៥ ។ *ដំណឹងល្អ* មើលការពន្យល់ មក ១:១ ។

**១:២** *ហោរា* ពាក្យនេះមិនមែនគ្រាន់តែនិយាយពីអ្នកសរសេរកណ្ឌគម្ពីរហោរា មួយចំនួននោះទេ គឺនិយាយសំដៅលើកណ្ឌគម្ពីរសញ្ញាចាស់ទាំងអស់ដែលបានថ្លែងអំពីទំនាយពីព្រះយេស៊ូវ(មើលការពន្យល់ លក ២៤:២៧, ៤៤–៤៧)។ *គម្ពីរបរិសុទ្ធ* គឺប៉ុលសំដៅលើតែបទគម្ពីរសញ្ញា ចាស់ទេ ប៉ុន្តែបច្ចុប្បន្ននេះគឺទាំងពីរសញ្ញា ។

**១:៣** *ព្រះរាជបុត្រានៃព្រះ* នេះគឺជាចំណុចកណ្តាលនៃដំណឹងល្អដែលសំដៅលើព្រះយេស៊ូវ ។ តួអង្គព្រះយេស៊ូវនេះហើយ ដែលធ្វើឱ្យទំនាយទាំងអស់នៅក្នុងគម្ពីរសញ្ញាចាស់បានសម្រេច(មើលការពន្យល់ លក ២៤:២៧,៤៤–៤៧ ២កថ ១:២០)។

**១:៤** *ព្រះរាជបុត្រារបស់ព្រះពិត* មើលពន្យល់ យហ ៣:១៦ ។ *ទ្រង់បានរស់ពីស្លាប់* នេះបញ្ជាក់ថាព្រះយេស៊ូវគឺជាព្រះពិតប្រាកដ ហើយក៏ជាកត្តាសំខាន់នៃការប្រកាសរបស់ពួកសាវក(មើលពន្យល់ កថ ២:១៤–៤០, ៤:៣៣)។

**១:៧** *ពួកបរិសុទ្ធ* ពាក្យនេះមកពីភាសាក្រិក មានន័យថា គ្រីស្ទបរិស័ទគ្រប់រូបគឺជាពួកបរិសុទ្ធ ។ ក្រោយពីបានទទួលជឿព្រះគ្រីស្ទរួចហើយ នោះទ្រង់ញែកពួកគេជាបរិសុទ្ធ ហើយបន្ទាប់មក ដំណើរបទពិសោធន៍នៃជីវិតរបស់ពួកគេនឹងឈានទៅរកភាពបរិសុទ្ធឡើងៗ ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ (មើលការពន្យល់ ១កថ ១:២)។ *ព្រះគុណ និងសេចក្តីសុខសាន្ត* លោកប៉ុល និងលោកពេត្រុសបានប្រើពាក្យជម្រាបសួរនៅដើមសំបុត្ររបស់ពួកគាត់ដូចៗគ្នា ។ ពាក្យទាំងពីរនេះមានប្រភពមកពីវប្បធម៌ក្រេក និងយូដាបូកបញ្ចូលគ្នា ។ សាសន៍ក្រេកច្រើនប្រើ ពាក្យ "ព្រះគុណ"នេះសម្រាប់ជូនពរដល់គ្នា ដ្បិតមនុស្សមានបាបមិនសមនឹងទទួលសេចក្តីសង្គ្រោះសោះ តែព្រះទ្រង់បានប្រទានដល់ពួកគេតាមរយៈ ព្រះយេស៊ូវគ្រីស្ទ ។ ចំពោះសាសន៍យូដាច្រើនប្រើពាក្យ "សេចក្តីសុខសាន្ត" ពីព្រោះមានតែព្រះទេដែលអាចឱ្យសេចក្តីសុខសាន្ត និងសន្តិភាពដ៏ពិតដល់ពួកគេបាន(៥:១ ភល ៤:៧ និងការពន្យល់ កទ ១:៣ អភ ១:២ យហ ១៤:២៧ ២០:១៩ និងការពន្យល់)។ ពាក្យជម្រាបសួរនេះបានបន្ទរម្តងទៀតក្នុងសេចក្តីបញ្ចប់នៃសំបុត្ររបស់លោកប៉ុល និងពេត្រុស ។ ដូច្នេះ ពាក្យទាំងនេះ គឺជាស៊ុមនៃពាក្យជម្រាបសួរ និងពាក្យជូនពរដល់អស់អ្នកណាដែលគាត់បានសរសេរទៅកាន់(នក ៣៤:៦–៧)។

**១:៨** *សូមអរព្រះគុណ* លោកប៉ុលតែងតែចាប់ផ្តើមដោយពាក្យ "អរព្រះគុណ" នៅក្នុងសំបុត្ររបស់គាត់(១កថ ១:៤ អភ ១:១៦ ភល ១:៣–៤ និងការពន្យល់ កល ១:៣ និងការពន្យល់ ១ធថ ១:២ ២ថន ១:៣ ២ធថ ១:៣ ភម ៤ និងការពន្យល់)។ *ដោយនូវព្រះយេស៊ូវគ្រីស្ទ* ក្នុងនាមយើងជាគ្រីស្ទបរិស័ទត្រូវចេះអរគុណដល់ព្រះយេស៊ូវគ្រីស្ទផង មិនមែនចេះតែសុំពីព្រះនោះទេ(យហ ១៥:១៦)។ *នៅគ្រប់ក្នុងលោកីយទាំងមូល* មានន័យថាគ្រប់កន្លែង ណាដែលដំណឹងល្អបានទៅដល់ ។

**១:៩** *ដំណឹងល្អពីព្រះរាជាបុត្រាទ្រង់* គឺមានន័យដូចគ្នានឹងពាក្យថា "ដំណឹងល្អនៃព្រះ" (ខ.១)។

**១:១០** *បានឱកាសស្រួល* មើល ១៥:២៣–២៩ ។

ព្រះហឫទ័យម្តងណោះ[ភ] ដើម្បីនឹងមកឯអ្នករាល់គ្នា បើសិនជា
បាន[ម] ១១ ដោយព្រោះខ្ញុំរឭកចង់ឃើញអ្នករាល់គ្នា[យ] ដើម្បីនឹង
ចែកអំណោយទានណាមួយខាងវិញ្ញាណ[រ] មកអ្នករាល់គ្នា
ប្រយោជន៍ឱ្យអ្នករាល់គ្នាបានតាំងនៅយ៉ាងខ្ជាប់ខ្ជួន ១២ គឺថា
ឱ្យយើងបានសេចក្តីកំសាន្តចិត្តគ្នាទៅវិញទៅមកក្នុងពួកអ្នក
រាល់គ្នា ដោយសារសេចក្តីជំនឿរបស់យើងនិមួយៗ គឺរបស់
អ្នករាល់គ្នា និងរបស់ខ្ញុំផង ១៣ តែបងប្អូនអើយ[ល] ខ្ញុំចង់ឱ្យអ្នក
រាល់គ្នាដឹងថា[វ] ខ្ញុំបានគិតមកឯអ្នករាល់គ្នាជារឿយៗ ដើម្បី
ឱ្យបានផលខ្លះក្នុងពួកអ្នករាល់គ្នា ដូចជាក្នុងពួកសាសន៍ឯ
ទៀតដែរ តែខ្ញុំមានសេចក្តីឃាត់ឃាំង ដរាបមកដល់ឥឡូវ
នេះ[ស] ១៤ ខ្ញុំមានសេចក្តីជំពាក់[ហ] ទាំងសាសន៍ក្រេក នឹងសាសន៍
ដទៃ ទាំងអ្នកប្រាជ្ញ និងអ្នកខ្លៅផង ១៥ ដូច្នេះ ឯខ្ញុំៗប្រុងប្រៀប
តែនឹងប្រាប់ដំណឹងល្អមកអ្នករាល់គ្នា ដែលនៅក្រុងរ៉ូមដែរ[ឡ]
១៦ ដ្បិតខ្ញុំគ្មានសេចក្តីខ្មាសចំពោះដំណឹងល្អ[អ] នៃព្រះគ្រីស្ទទេ
ពីព្រោះជាព្រះចេស្តានៃព្រះ[ក] សំរាប់នឹងជួយសង្គ្រោះដល់
អស់អ្នកណាដែលជឿ[ខ] គឺដល់ទាំងសាសន៍យូដាជាដើម[គ] និង
សាសន៍ក្រេកផង[ឃ] ១៧ ដ្បិតសេចក្តីសុចរិតនៃព្រះ បានសំដែង[ង]
មកក្នុងដំណឹងល្អនោះដោយសារសេចក្តីជំនឿ[ច] ហើយឱ្យ
បានសេចក្តីជំនឿចំរើនច្រើនឡើងផង ដូចមានសេចក្តីចែង
ទុកមកថា «មនុស្សសុចរិតនឹងរស់នៅដោយអាងសេចក្តី
ជំនឿ»[ឆ]។

## សេចក្តីក្រោធរបស់ព្រះ

១៨ ពីព្រោះសេចក្តីក្រោធរបស់ព្រះ[ជ] បានសំដែងមកពីស្ថាន
សួគ៌ទាស់នឹងគ្រប់ទាំងសេចក្តីទមិលល្មើស នឹងសេចក្តីទុច្ច
រិតរបស់មនុស្ស ដែលគេបង្ខាំងសេចក្តីពិតដោយសេចក្តីទុច្ច
រិត ១៩ ព្រោះការអ្វីដែលអាចនឹងស្គាល់ពីព្រះបាន នោះបាន
សំដែងមកក្នុងពួកគេហើយ ដោយព្រះទ្រង់សំដែងការនោះ
ឱ្យគេឃើញជាក់[ឈ] ២០ ដ្បិតអ្វីៗរបស់ទ្រង់ ដែលរកមើលមិន
ឃើញ តាំងពីកំណើតលោកីយមក ទោះទាំងព្រះចេស្តាដ៏

**១:១០** ភ កច ១៨:២១ ម ខ.១៣ រម ១៥:៣២ **១:១១** យ រម ១៥:២៣ រ ១កថ ១:៧ ១២:១–៣១ **១:១៣** ល រម ១១:២៥ វ រម ៧:១ ស រម ១៥:២២,២៣ **១:១៤** ហ ១កថ ៩:១៦ **១:១៥** ឡ រម ១៥:២០ **១:១៦** អ ២ធថ ១:៨ ក ១កថ ១:១៨ ខ យហ ៣:១៥ គ កច ៣:២៦ ១៣:៤៦ ឃ កច ១៣:៤៦ រម ២:៩,១០

**១:១៧** ង រម ៣:២១ ភល ៣:៩ ច រម ៩:៣០ ឆ ហប ២:៤ កទ ៣:១១ ហព ១០:៣៨ **១:១៨** ជ យហ ៣:៣៦ រម ៥:៩ អភ ៥:៦ កល ៣:៦ ១ថន ១:១០ វវ ១៩:១៥ **១:១៩** ឈ កច ១៤:១៧

**១:១២** *ទៅវិញទៅមក* ពាក្យនេះបានបង្ហាញឱ្យឃើញពីការបន្ទាបខ្លួនខ្លាំងរបស់លោកប៉ុល ដោយគាត់មានចិត្តចង់ទៅបម្រើគ្រីស្ទបរិស័ទនៅក្រុងរ៉ូម ។

**១:១៣** *បងប្អូនអើយ* លោកប៉ុលតែងតែប្រើពាក្យនេះគឺសំដៅទៅលើពួកហ្វូងបណ្តាជនដែលមានទាំងប្រុសទាំងស្រី(កច ១:១៤–១៦)។ *ឱ្យបានផល* ពាក្យនេះសំដៅលើអ្នកជឿថ្មី និងអ្នកជឿចាស់ឱ្យមានជំនឿរីកលូតលាស់បន្ថែមទៀត ។ *ពួកអ្នករាល់គ្នា . . . សាសន៍ឯទៀត* ចង់បញ្ជាក់ថានៅក្រុងរ៉ូមមានសាសន៍ដទៃច្រើន ។

**១:១៤** *សាសន៍ក្រេក* សំដៅលើសាសន៍ដទៃទាំងឡាយណាដែល និយាយភាសាក្រិក និងត្រាប់តាមជីវិតបែបជនជាតិក្រេក ទោះជាជនជាតិរ៉ូម៉ាំងនិយាយភាសាឡាតាំងនោះក៏ដោយ ។ *សាសន៍ដទៃ* មានន័យថា ក្រៅពីសាសន៍ក្រេក ឬអាចមានន័យថា ជាប្រភេទមនុស្សដែលមិនសូវមានប្រាជ្ញា (នៅសម័យនោះជនជាតិក្រេកមានប្រាជ្ញាណាស់ បានជាមនុស្សភាគច្រើនចង់ធ្វើជាជនជាតិក្រេក)។

**១:១៦–១៧** នេះគឺជាផ្ទៃរឿងសំខាន់នៅក្នុងគម្ពីររ៉ូមទាំងមូល ។

**១:១៦** *គ្មានសេចក្តីខ្មាស* នៅត្រង់នេះមានន័យថា ទោះបីជាលោកប៉ុលប្រកាសដំណឹងល្អនៅក្នុងរាជធានីរបស់ចក្រភពរ៉ូម៉ាំងក៏ដោយ ក៏លោកមិនខ្មាសដែរ (ខ.១៥)។ *ដំណឹងល្អ* មើលការពន្យល់ មក ១:១ ។ *ជាដើម* និយាយពីសេចក្តីសង្គ្រោះបានដល់សាសន៍យូដាមុនគេ "សេចក្តីសង្គ្រោះចេញពីសាសន៍យូដា (យហ ៤:២២) ព្រះមែស៊ីបានចេញពីជាតិសាសន៍យូដា"។ "ព្រះបានផ្ញើព្រះបន្ទូលទុកនឹងគេ" (៣:២) ការតាំងសញ្ញា ការប្រទានក្រឹត្យវិន័យរបៀបថ្វាយបង្គំការបើកសំដែងសិរីល្អរបស់ព្រះ ហើយនិងទំនាយពីព្រះមែស៊ី គឺចេញមកពីសាសន៍យូដានេះទាំងអស់ (៩:៣–៥ និងការពន្យល់)។ ទោះបីជាពួកគេមានឯកសិទ្ធិពិសេសជារាស្ត្រកេរ្តិ៍អាករ ឬព្រះរើសគេមុនក៏ដោយ ក៏ដំណឹងល្អមិនគ្រាន់តែពង្រីកនៅក្នុងចំណោមសាសន៍យូដានោះទេ គឺត្រូវបានពង្រីកពេញទាំងពិភពលោកដោយគ្រាន់ តែចាប់ផ្តើមពីសាសន៍យូដា ហើយបន្តទៅសាសន៍ផ្សេងៗទៀត ។

**១:១៧** *សេចក្តីសុចរិត* ការថ្លែងនេះ ចង់និយាយថាមនុស្សមានសិទ្ធិទំនាក់ទំនងជាមួយនឹងព្រះ (មើលការពន្យល់ ២:១៣ ៣:២១,២៤)។

**១:១៨–៣:២០** នេះគឺជាសេចក្តីពន្យល់បន្ថែមអំពីសេចក្តីសុចរិតរបស់ព្រះ (១:១៧ ៣:២១–៥:២១)។ លោកប៉ុលបានចាប់ផ្តើមដោយថ្លែងថាមនុស្សគ្រប់គ្នាសុទ្ធតែមានបាប ដូច្នេះពួកគេចាំបាច់ត្រូវទទួលសេចក្តីសុចរិត ហើយសេចក្តីសុចរិត នេះមានតែព្រះទេទើបប្រទានឱ្យបាន ។ គាត់ថែមទាំងបង្ហាញពីអំពើបាបរបស់សាសន៍ដទៃ (១:១៨–៣២) សាសន៍យូដា (២:១–៣:៨) បន្ទាប់មកគាត់បានសន្និដ្ឋានថា ទាំងសាសន៍ដទៃ និងសាសន៍យូដា គឺមានបាបដូចគ្នា (៣:៩–២០)។

**១:១៨–២០** គ្មាននរណាម្នាក់អាចប្រកែកថា មិនដែលបានឮពីព្រះបន្ទូល ឬពីព្រះគ្រីស្ទ ឬក៏ព្រះអម្ចាស់សោះនោះទេ ពីព្រោះតាំងពីកំណើតលោកិយមកព្រះបានបើក សំដែងតាមរយៈរបស់ដែលទ្រង់បានបង្កើត ។

**១:១៨** *សេចក្តីក្រោធរបស់ព្រះ* នេះពុំមែនជាសេចក្តីក្រោធឥតហេតុផល ហើយមិនអាចទប់បាននោះដែរ ពុំដូចជាកំហឹងរបស់មនុស្សដែលតែង តែបញ្ចេញនោះទេ ។ សេចក្តីក្រោធនេះ គឺទាស់គ្រប់ទាំងសេចក្តីទមិលល្មើស និងសេចក្តីទុច្ចរិតរបស់មនុស្ស ។ បាបទីមួយ ហើយធំជាងគេបំផុតនោះ គឺការបដិសេធន៍ពុំទទួលស្គាល់ព្រះដ៏ពិត ហើយបែរទៅជាទុកចិត្តលើមនុស្សដូចគ្នា ។ *បានសំដែងមក* សេចក្តីក្រោធរបស់ព្រះមិនមែនសំគាល់ថាជាការជំនុំជម្រះចុងក្រោយរបស់មនុស្សអាក្រក់នោះទេ (១ថន ១:១០ វវ ១៩:១៥ ២០:១១–១៥) សេចក្តីក្រោធរបស់ព្រះនៅទីនេះមានន័យថា ការបោះបង់មនុស្សអាក្រក់ ទុកក្នុងអំពើបាបរបស់ពួកគេ (ខ.២៤–៣២)។ *សេចក្តីពិត* គឺត្រូវបានបើកសំដែងតាមរយៈរបស់ដែលទ្រង់បានបង្កើត ។

នៅអស់កល្បជានិច្ច នឹងនិស្ស័យជាព្រះរបស់ទ្រង់ នោះ
ឃើញច្បាស់វិញ[ញ] ដោយពិចារណាយល់របស់ទាំងប៉ុន្មាន
ដែលទ្រង់បានបង្កើតមក[ដ] ២១ព្រោះកាលគេបានស្គាល់ព្រះ
នោះគេមិនបានដំកើងទ្រង់ ទុកជាព្រះទេ ក៏មិនដឹងគុណទ្រង់
ដែរ គេកើតមានគំនិតឥតប្រយោជន៍វិញ ហើយចិត្តគេ
ដែលឥតយោបល់ ក៏បានត្រឡប់ជាងងឹតទៅ[ឋ] ២២គេអួតខ្លួន
ថា មានប្រាជ្ញា បានជាគេត្រឡប់ទៅជាល្ងង់ល្ងើវិញ[ឌ] ២៣គឺ
គេបំផ្លាស់សិរីល្អនៃព្រះដែលមិនចេះខូច ឱ្យទៅជារូប[ឍ]
មើលទៅដូចជាមនុស្ស ដែលតែងតែខូចវិញ ហើយដូចជា
សត្វស្លាប សត្វជើង៤ នឹងសត្វលូនវារដែរ ២៤ហេតុនោះ
បានជាព្រះទ្រង់ប្រគល់គេ[ណ]ទៅឯសេចក្តីស្មោកគ្រោក តាម
ចិត្តគេប្រាថ្នាចង់បាន ឱ្យបានបង្អាប់ដល់រូបកាយគេទៅវិញ
ទៅមក[ត] ២៥គេបានផ្លាស់សេចក្តីពិតនៃព្រះ ឱ្យទៅជាសេចក្តី
ភូតភរវិញ[ថ] ក៏កោតខ្លាច ហើយគោរពបូជាដល់របស់ដែល
កើតមក[ទ] ជាជាងដល់ព្រះ ដែលបង្កើតរបស់ទាំងនោះ
មក ជាព្រះដែលមានព្រះពរអស់កល្បជានិច្ច[ធ] អាម៉ែន[ន]
២៦ហេតុនោះបានជាព្រះទ្រង់ប្រគល់គេ[ប] ទៅក្នុងសេចក្តី
រំជួលដ៏អាស្រូវបារាយ[ផ] ដ្បិតទាំងពួកស្រីៗរបស់គេក៏បាន
ផ្លាស់ប្រែទំនៀមទំលាប់ពីបវេណីចេញឱ្យខុសពីធម្មតា[ព]
២៧ហើយពួកប្រុសៗក៏បែបដូច្នោះដែរ គេបានលះចោលទំ
នៀមទំលាប់របស់ស្ត្រីពីបវេណីចេញ ហើយបង្កើតឱ្យមាន
សេចក្តីសំរើបរោលរាលដល់គ្នាទៅវិញទៅមកគឺប្រុសប្រ

**១:២០** ញ ទដ ១៩:១–៦ ដ រម ២:១
**១:២១** ឋ លប ៨:២១ យរ ២:៥ ១៧:៩ អភ ៤:១៧,១៨
**១:២២** ឌ ១កថ ១:២០,២៧ ៨:១៨,១៩
**១:២៣** ឍ ចទ ៤:១៦,១៧ ទដ ១០៦:២០ យរ ២:១១ កច ១៧:២៩
**១:២៤** ណ ខ.២៦,២៨ ទដ ៨១:១២ អភ ៤:១៩ ត ១ពត ៤:៣
**១:២៥** ថ អស ៤៤:២០ ទ យរ ១០:១៤ ១៣:២៥ ១៦:១៩,២០ ធ រម ៩:៥ ២កថ ១១:៣១ ន រម ១១:៣៦
**១:២៦** ប ខ.២៤,២៨ ផ អភ ៤:១៩ ១ថន ៤:៥ ព លវ ១៨:២២,២៣
**១:២៧** ភ លវ ១៨:២២ ២០:១៣ ១កថ ៦:១៨

ព្រឹត្តនឹងប្រុសៗ ជាការដ៏អាក្រក់ជួជាតិ នោះគេក៏ទទួល
រង្វាន់ចំពោះខ្លួនគេដែលសំណាំនឹងសេចក្តីកំហុសរបស់ខ្លួន[ភ]។
២៨ហើយដោយព្រោះគេមិនចូលចិត្តនឹងស្គាល់ដល់ព្រះ
សោះ បានជាទ្រង់ប្រគល់គេ[ម] ទៅតាមគំនិតចោលម្សៀត
វិញ ដើម្បីឱ្យបានសំរេចការដែលមិនគួរគប្បីធ្វើ ២៩ជា
មនុស្សមានពេញដោយសេចក្តីទុច្ចរិតគ្រប់យ៉ាង គឺសេចក្តី
កំផិត សេចក្តីកំណាច សេចក្តីលោភ និងសេចក្តីព្យាបាទ
ក៏មានសេចក្តីឈ្នានីស និងការកាប់សំឡាប់ ឈ្លោះប្រកែក
កិច្ចកល គំនិត ខិលខូចដ៏ពោរពេញផង[យ] ៣០ជាមនុស្សចែចូវ
បេះបួយ ស្អប់ព្រះ ព្រហើនឈ្លានពាន មានះ កាន់ខ្លួន
អួតអាង ជាមេបង្កើតការអាក្រក់ ហើយមិនស្តាប់បង្គាប់
តាមឪពុកម្តាយ[រ] ៣១ឥតយោបល់ មានចិត្តមិនទៀង មិនចេះ
ស្រឡាញ់តាមធម្មតា ក៏ឥតមានសេចក្តីមេត្តាករុណាសោះ[ល]
៣២គេក៏ស្គាល់សេចក្តីជំនុំជំរះដ៏សុចរិតរបស់ព្រះថា អស់អ្នក
ដែលប្រព្រឹត្តការយ៉ាងដូច្នោះ នោះគួរនឹងស្លាប់ហើយ[វ] ប៉ុន្តែ
គេមិនគ្រាន់តែប្រព្រឹត្តយ៉ាងនោះប៉ុណ្ណោះ គឺគេចូលចិត្ត
យល់ព្រម[ស] នឹងអស់អ្នកណាដែលប្រព្រឹត្តដូច្នោះផងដែរ ។

## ការជំនុំជម្រះដ៏សុចរិតរបស់ព្រះ

**២** ១ដូច្នេះ ឱមនុស្សអើយ! អស់អ្នកណាដែលថ្កោលទោស
គេ នោះគ្មានសេចក្តីដោះសាចំពោះខ្លួនឡើយ[ហ] ដ្បិតដែល

**១:២៨** ម ខ.២៤,២៦ **១:២៩** យ ២កថ ១២:២០ ១ធថ ៥:១៣ យក ៣:២ ៣យហ ១០ **១:៣០** រ ២ធថ ៣:២ **១:៣១** ល ២ធថ ៣:៣ **១:៣២** វ រម ៦:២៣ ស ទដ ៥០:១៨ លក ១១:៤៨ កច ៨:១ ២២:២០ **២:១** ហ រម ១:២០

**១:២១** *កាលណាគេបានស្គាល់ព្រះ* គឺព្រះបានបើកសំដែងអង្គទ្រង់ តាមរយៈរបស់ដែលទ្រង់បានបង្កើត(ខ.១៩–២០)។ ពួកគេបានបែរពីថ្វាយបង្គំព្រះដែលបង្កើតខ្លួនទៅថ្វាយបង្គំរូបព្រះដែលខ្លួនបង្កើតនោះទៅវិញ (ខ.២៣)។ *មិនដឹងគុណទ្រង់* និយាយពីព្រះពរដែលប្រទានមកកាលពីលើកដំបូងដូចជាពន្លឺព្រះអាទិត្យ ទឹកភ្លៀង គ្រាប់ពូជរុក្ខជាតិផ្សេងៗជាដើម(មើលការពន្យល់ មថ ៥:៤៥ កច ១៤:១៧)។

**១:២៣** *សិរីល្អ* សិរីល្អគឺជារបស់ព្រះតែមួយអង្គគត់(មើលការពន្យល់ អស ៤០:៥ ៤៨:១១)។ តែមនុស្សគេមើលមិនឃើញសោះ ហើយបែរទៅប្រឌិតរូបផ្សេង ដើម្បីគោរព និងថ្វាយសិរីល្អដល់រូបនោះទៅវិញ ។

**១:២៤,២៦,២៨** *បានជាព្រះទ្រង់ប្រគល់គេទៅ* មានន័យថាព្រះបានបណ្តោយអំពើបាបឱ្យចាត់ការតាមដំណើររឿង ដែលប្រៀបដូចជាការជំនុំជម្រះមួយនោះដែរ ។

**១:២៥** *អាម៉ែន* ស្មើរនឹងថា"បាទ ចាស ពិតមែនហើយ សូមឱ្យសម្រេចដូច្នេះចុះ!"(៩:៥ ១១:៣៦ ១៥:៣៣ ១៦:២៧ មើលសេចក្តីពន្យល់ ចទ ២៧:១៥ ១ពវ ១:៣៦)។

**១:២៦** *ទាំងពួកស្រីៗ* មិនសំដៅតែចំពោះប្រពន្ធរបស់ពួកគេនោះទេ ។

**១:២៧** ការរួមភេទដែលមានភេទដូចគ្នា គឺជាអំពើបាបចំពោះព្រះនេត្រព្រះក្នុងគម្ពីរសញ្ញាចាស់ ក៏មានដាក់ទោសដែរ(លវ ១៨:២២ ២២:១៣)។

**១:២៨** *ស្គាល់ដល់ព្រះ* មើល ខ.១៩,២១ ។ *គំនិតចោលម្សៀត* និយាយពីបំណងដែលពួកគេមានកាលពីមុន(ខ.២១ មក ៧:២០–២៣)។

**១:២៩–៣១** បញ្ជីនៃអំពើបាបទាំងនេះ ក៏ឃើញមាននៅក្នុង ១៣:១៣ ១កថ ៥:១០–១១ ៦:៩–១០ ២កថ ១២:២០–២១ កទ ៥:១៩–២១ អភ ៤:៣១ ៥:៣–៥ កល ៣:៥,៨ ១ធថ ៣:២–៥ វវ ២១:៨ ២២:១៥ ។

**១:៣២** *គេក៏ស្គាល់* នេះគឺជាគំនិតប្រមាថដ៏ធ្ងន់ធ្ងរបំផុត ដែលកើតឡើងពីការប៉ុនប៉ង និងគំនិតបះបោររបស់ពួកគេផ្ទាល់តែម្តង មិនមែនដោយសារតែភាពល្ងង់ខ្លៅរបស់ពួកគេនោះទេ ។ *យល់ព្រម* នេះជាភាពហួសប្រមាណនៃអំពើបាប ដោយការយល់ព្រមធ្វើបាបជាមួយនឹងអ្នកដទៃជាជាងការស្តាយក្រោយ ឬផ្លាស់ប្រែ ។

**២:១–១៦** នៅត្រង់វគ្គនេះ លោកប៉ុលបានបែងចែកការជំនុំជម្រះរបស់ព្រះជាគោលការធំៗដូចតទៅ: (១).ផ្អែកលើសេចក្តីពិត(ខ.២)។ (២).ផ្អែកលើការប្រព្រឹត្ត(ខ.៦–១១)។ (៣).ផ្អែកលើចំណេះ របស់មនុស្ស នោះ (ខ.១២–១៥)។ គោលការទាំងនេះនិយាយពីការវែកញែករបស់លោកប៉ុល ផ្អែកទៅលើមូលដ្ឋាននៃអំ ពើទុច្ចរិតរបស់សាសន៍យូដា(ខ.១៧–២៩)។

**២:១** *គ្មានសេចក្តីដោះសា* នេះជាសេចក្តីបង្រៀនរបស់លោកប៉ុលអំពីការ

អ្នកថ្កោលទោសគេ នោះឈ្មោះថាកាត់ទោសខ្លួនឯងហើយ
ពីព្រោះអ្នកឯងដែលថ្កោលទោសគេ ក៏ប្រព្រឹត្តដូចគ្នាដែរ[ឡ]
[២]តែយើងរាល់គ្នាដឹងថា ចំណែកសេចក្តីជំនុំជំរះរបស់
ព្រះវិញ នោះត្រូវនឹងសេចក្តីពិតទាស់នឹងពួកអ្នកដែល
ប្រព្រឹត្តយ៉ាងនោះ [៣]មួយទៀត ឱមនុស្សអើយ ដែលអ្នក
ថ្កោលទោសដល់អស់អ្នក ដែលប្រព្រឹត្តការយ៉ាងនោះ តែ
ខ្លួនអ្នកក៏ប្រព្រឹត្តដូច្នោះដែរ នោះតើអ្នកស្មានថា ខ្លួនអ្នក
នឹងរួចពីសេចក្តីជំនុំជំរះរបស់ព្រះឬអី? [៤]ឬអ្នកមើលងាយ[អ]
សេចក្តីសប្បុរស[ក]ដ៏ឥតគណនាព្រមទាំងសេចក្តីទ្រាំទ្រ[ខ] និង
សេចក្តីអត់ធន់[គ]របស់ទ្រង់ ដោយមិនដឹងថាសេចក្តីសប្បុរស
នៃព្រះទាញនាំឱ្យអ្នកបានប្រែចិត្តឬអី[ឃ]។
[៥]តែដោយអ្នករឹងរបឹង ហើយមិនព្រមប្រែចិត្តសោះ បាន
ជាអ្នកឈ្មោះថាកំពុងតែប្រមូលសេចក្តីក្រោធ ទុកសំរាប់
ខ្លួនដល់ថ្ងៃនៃសេចក្តីក្រោធវិញ[ង] ជាថ្ងៃដែលសេចក្តីជំនុំជំ
រះ[ច]ដ៏សុចរិតរបស់ព្រះនឹងសំដែងមក [៦]ដែលទ្រង់នឹងសង
ដល់គ្រប់គ្នា តាមអំពើដែលខ្លួនបានប្រព្រឹត្ត[ឆ] [៧]គឺជាជីវិត
អស់កល្បជានិច្ច[ជ] ដល់ពួកអ្នកដែលរកសិរីល្អ កេរ្តិ៍ឈ្មោះ[ជ]
និងសេចក្តីមិនពុករលួយ[ឈ] ដោយគេកាន់ខ្ជាប់ក្នុងការល្អ
[៨]តែពួកអ្នកដែលទាស់ទទឹង មិនព្រមស្តាប់តាមសេចក្តីពិត
គឺស្តាប់តាមតែសេចក្តីទុច្ចរិតវិញ[ញ] នោះនឹងបានសេចក្តី
ក្រោធ[ដ]និងសេចក្តីឃោរឃៅ [៩]ជាសេចក្តីវេទនា និងសេច
ក្តីលំបាកនៅលើគ្រប់ទាំងព្រលឹងមនុស្សណា ដែលប្រព្រឹត្ត
អាក្រក់[ឋ] មានសាសន៍យូដាជាដើម នឹងសាសន៍ក្រេកផង[ឌ]
[១០]តែអស់អ្នកដែលប្រព្រឹត្តល្អ នោះនឹងបានសិរីល្អ កេរ្តិ៍ ឈ្មោះ
នឹងសេចក្តីសុខវិញ គឺមានសាសន៍យូដាជាដើម នឹង សាសន៍
ក្រេកផង[ឍ] [១១]ដ្បិតព្រះទ្រង់មិនយោគយល់ខាងអ្នកណាសោះ[ណ]
[១២]ព្រោះអស់អ្នកណាដែលបានធ្វើបាបឥតស្គាល់ក្រិត្យ
វិន័យ[ត] នោះនឹងត្រូវវិនាសទៅឥតក្រិត្យវិន័យដែរ ហើយ
អស់អ្នកណាដែលបានធ្វើបាបក្នុងបន្ទុកក្រិត្យវិន័យ នោះនឹង
ត្រូវក្រិត្យវិន័យជំនុំជំរះវិញ [១៣](ដ្បិតពួកអ្នកដែលគ្រាន់តែ
ស្តាប់[ថ]ក្រិត្យវិន័យ នោះមិនមែនឈ្មោះថាសុចរិត នៅចំពោះ
ព្រះឡើយ គឺបានរាប់ជាសុចរិតតែពួកអ្នក ដែលប្រព្រឹត្ត
តាមក្រិត្យវិន័យប៉ុណ្ណោះទេ [១៤]ពីព្រោះកាលណាពួកសាសន៍
ដទៃ ដែលគ្មានក្រិត្យវិន័យ គេបានប្រព្រឹត្តតាមក្រិត្យវិន័យ[ទ]
ពីបវេណីនោះពួកដែលគ្មានក្រិត្យវិន័យនោះឯង គេជាក្រិត្យ

**២:១** ឡ ២សយ ១២:៥–៧ មថ ៧:១,២
**២:៤** អ រម ៩:២៣ ១១:៣៣ អភ ១:៧,១៨ ២:៧ ៣:៨,១៦ លក ២:២ ក រម ១១:២២ ខ រម ៣:២៥ គ នក ៣៤:៦ រម ៩:២២ ១ធថ ១:១៦ ១ពត ៣:២០ ២ពត ៣:១៥ ឃ ២ពត ៣:៩
**២:៥** ង ទដ ១១០:៥ វវ ៦:១៧ ច ពច ៦
**២:៦** ឆ ទដ ៦២ :១២ មថ ១៦:២៧ **២:៧** ជ មថ ២៥:៤៦ ឆ ខ.១០ ឈ ១កថ ១៥:៥៣,៥៤ ២ធថ ១:១០
**២:៨** ញ ២ ថន ២:១២ ដ អគ ២២:៣១
**២:៩** ឋ ទដ ៣២:១០ ឌ ខ.១០ រម ១:១៦ **២:១០** ឍ ខ.៩ រម ១:១៦ **២:១១** ណ កថ ១០:៣៤ **២:១២** ត រម ៣:១៩ ៦:១៤ ១កថ ៩:២០,២១ កទ ៤:២១ ៥:១៨ រម ៧:៤ **២:១៣** ថ យក ១:២២,២៣,២៥ **២:១៤** ទ កថ ១០:៣៥

ថ្កោលទោសស្របនឹងសេចក្តីបង្រៀនរបស់ព្រះយេស៊ូវដែរ (មើលការពន្យល់ មក ៧:១)។ *អ្នកថ្កោលទោសគេ* នេះជាសេចក្តីព្រមានមួយដល់ពួកយូដា ដែលតែងតែមើលងាយដល់សាសន៍ដទៃ ដោយព្រោះភាពល្ងង់ខ្លៅរបស់ពួកគេ ។ បានជានៅក្នុងគម្ពីរសញ្ញាចាស់ ព្រះបានបើកសំដែងអង្គទ្រង់ ដោយព្រោះជីវិតអសីលធម៌របស់ពួកគេ ។

**២:២** *យើងរាល់គ្នាដឹងថា* នេះគឺជាឃ្លាមួយដែលលោកប៉ុលតែងតែធ្លាប់ប្រើ ដើម្បីឱ្យមនុស្សដែលគាត់សរសេរទៅកាន់នោះ យល់ព្រមនូវសេចក្តីទាំងនេះ (៣:១៩ ៦:៦,៩ ៧:១៤ ៨:២២,២៨ ១កថ ៨:១,៤ ២កថ ៥:១ ១ធថ ១:៨)។

**២:៣** ព្រះយេស៊ូវបានដាក់ទោសដល់អស់អ្នកណាដែលថ្កោលទោសអ្នកដទៃ (មើល ការពន្យល់ មក ៧:៣ លក ១៨:៩)។

**២:៤** ព្រះហឫទ័យនៃសេចក្តីសប្បុរសរបស់ព្រះ គឺជាការទុកឱកាសឱ្យមនុស្សប្រែចិត្ត(មើលពន្យល់ ២ពត ៣:៩)។ តែពួកសាសន៍យូដាបែរជាយល់ខុសចំពោះសេចក្តីអត់ធ្មត់របស់ទ្រង់ថា ខ្វះការតាំងចិត្តជំនុំជម្រះនោះទៅវិញ ។

**២:៥** *ថ្ងៃនៃសេចក្តីក្រោធ* មើល ខ.៨ ។ សេចក្តីជំនុំជម្រះនឹងកើតមានឡើងនៅពេលចុងបញ្ចប់ តែផ្ទុយគ្នាទៅនឹងសេចក្តីបង្រៀននៅក្នុង ១:១៨–៣២ ។

**២:៦–៧** វគ្គនេះលោកប៉ុលបានបញ្ជាក់ពីគ្រប់ទាំងសេចក្តីបង្រៀនរបស់គាត់ទាំងនៅក្នុងគម្ពីររ៉ូមនេះដែរថា មនុស្សបានសង្គ្រោះមិនដោយសារការប្រព្រឹត្តនោះទេ គឺដោយសារការជឿលើទង្វើរបស់ព្រះគ្រីស្ទបានធ្វើវិញ ។ ការប្រកាន់ខ្ជាប់ក្នុងការល្អនោះបង្ហាញពីសេចក្តីជំនឿ (កទ ៥:៦ យក ២:១៤–២៦ និងការពន្យល់)។

**២:៨** *សេចក្តីក្រោធ និងសេចក្តីឃោរឃៅ* គឺនៅថ្ងៃជំនុំជម្រះចុងក្រោយ ។

**២:៩** *សាសន៍យូដាជាដើម* ឃ្លានេះចង់និយាយថា សាសន៍យូដាជាអ្នកទទួលឯកសិទ្ធិជារាស្ត្ររបស់ព្រះមុនដំបូងគេបង្អស់ ដូច្នេះការទទួលខុសត្រូវរបស់ពួកគេ ក៏ត្រូវតែមុនគេផងដែរ ។ (មើលការពន្យល់ អម ៣:២ លក ១២:៤៨)។

**២:១១** អត្ថន័យនៅក្នុងខនេះ គឺជាគ្រឹះដំបូងនៃសេចក្តីបង្រៀន ទាំងនៅក្នុងព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី ។

**២:១២** *ក្រិត្យវិន័យ* ពាក្យនេះគឺសំដៅលើក្បួនច្បាប់នានារបស់លោកម៉ូសេកាលនៅសម័យដើម "អស់អ្នកណាដែលធ្វើបាប ឥតស្គាល់ក្រឹត្យវិន័យ" ពាក្យនេះគឺសំដៅទៅលើសាសន៍ដទៃ ដែលមិនបានដឹងពីបញ្ញត្តិផ្សេងៗដែលបានចែងមក ។ ព្រះធ្វើការជំនុំជម្រះពួកបណ្តាជន អាស្រ័យទៅលើចំណេះដឹងរបស់ពួកគេ ។ ពួកសាសន៍ដទៃមិនត្រូវបានកាត់ទោសតាមក្រិត្យវិន័យទេ នៅពេលធ្វើខុសនោះ ព្រោះពួកគេពុំទាន់ស្គាល់ក្រិត្យវិន័យនៅឡើយ តែត្រូវជំនុំជម្រះតាមវិធីផ្សេងៗវិញ(មើល ខ.១៥ អម ១:៣–២:៣ និងការពន្យល់ ១:១៨–២០)។

**២:១៣** *បានរាប់ជាសុចរិត . . .* នេះគឺជាសេចក្តីប្រកាសរបស់ព្រះអម្ចាស់នៃការ រួចពីទោសនៅថ្ងៃជំនុំជម្រះ (មើលការពន្យល់ ៣:២៤)។

**២:១៤** *ពីបវេណី* មានន័យថាពួកសាសន៍ដទៃដែលគ្មានក្រិត្យវិន័យរបស់លោកម៉ូសេ នោះគេបានប្រព្រឹត្តតាមទម្លាប់ពីកំណើតខ្លួនជាហូរហែរតរៀងមក ដែលស្របគ្នានឹងក្រឹត្យវិន័យរបស់ម៉ូសេដែរ ដូចជាពួកគេចេះជួយយកអាសារដល់អ្នកជំងឺមនុស្សចាស់ ចេះគោរពឪពុកម្តាយ និងដាក់ទោសដល់មនុស្សកំផិតជាដើម ។ *ជាក្រិត្យវិន័យ ដល់ខ្លួនគេវិញ* គឺជាសីលធម៌ពីកំណើតរបស់សាសន៍ដទៃ ជាចំណេះដឹងផ្នែកបញ្ញាចិត្តដែលមាននៅក្នុងមនសិការរបស់ពួកគេ(ខ.១៥) ដូចគ្នានឹងក្រឹត្យវិន័យរបស់ម៉ូសេដែលបានចែងសម្រាប់ឱ្យសាសន៍យូដាធ្វើតាមនោះដែរ ។

វិន័យដល់ខ្លួនគេវិញ [១៥]ដោយសំដែងថា របៀបក្រិត្យវិន័យ
បានកត់ទុកក្នុងចិត្តគេ ហើយបញ្ញាចិត្តគេ ក៏ធ្វើបន្ទាល់ឱ្យ
ហើយគំនិតគេចួនកាលប្រកាន់ទោស ចួនកាលដោះសា
គ្នាទៅវិញទៅមក) [១៦]គឺក្នុងថ្ងៃដែលព្រះទ្រង់នឹងជំនុំជំរះ
អស់ទាំងការលាក់កំបាំងរបស់មនុស្ស[ធ] តាមដំណឹងល្អខ្ញុំ
ដោយសារព្រះយេស៊ូវគ្រីស្ទ[ន] ។

## ពួកសាសន៍យូដា និងក្រឹត្យវិន័យ

[១៧]បើអ្នកមានឈ្មោះជាសាសន៍យូដា ទាំងទុកចិត្តនឹងក្រិត្យ
វិន័យហើយអួតសរសើរពីព្រះ[ប] [១៨]ក៏ស្គាល់ព្រះហឫទ័យទ្រង់
ហើយចេះសំគាល់រើសសេចក្ដីល្អ ដោយបានរៀនតាម
ក្រឹត្យវិន័យ [១៩]ទាំងជឿប្រាកដថាខ្លួនជាអ្នកដឹកនាំមនុស្សខ្វាក់
ជាពន្លឺដល់ពួកអ្នកដែលងងឹត [២០]ជាអ្នកទូន្មានប្រដៅដល់ពួក
ខ្លៅល្ងង់ជាគ្រូបង្រៀនដល់កូនក្មេងក៏មានគំរូពីសេចក្ដីចេះ
ដឹងនឹងសេចក្ដីពិតនៅក្នុងក្រឹត្យវិន័យ [២១]ដូច្នេះអ្នកឯងដែល
បង្រៀនគេ តើមិនបង្រៀនដល់ខ្លួនឯងទេឬអី? អ្នកឯងដែល
ប្រដៅថាកុំឱ្យលួចគេ តើអ្នកលួចឬទេ?[ផ] [២២]អ្នកឯងដែលថា
កុំឱ្យផិតគ្នា តើអ្នកផិតឬទេ? អ្នកឯងដែលស្អប់ខ្ពើមរូបព្រះ
តើអ្នកប្លន់វិហារឬទេ?[ព] [២៣]អ្នកឯងដែលអួតពីក្រិត្យវិន័យ[ភ]
តើអ្នកបង្អាប់ព្រះដោយប្រព្រឹត្តរំលងនឹងក្រិត្យវិន័យឬទេ?
[២៤]ដ្បិតពួកសាសន៍ដទៃ គេប្រមាថដល់ព្រះនាមព្រះដោយ
ព្រោះតែអ្នករាល់គ្នា[ម] ដូចជាមានសេចក្ដីចែងទុកមកហើយ ។
[២៥]រីឯការកាត់ស្បែក នោះមានប្រយោជន៍មែន បើអ្នក
ប្រព្រឹត្តតាមក្រិត្យវិន័យ[យ] តែបើអ្នកប្រព្រឹត្តរំលងក្រិត្យវិន័យ

**២:១៦** ធ សស ១២:១៤ ១កថ ៤:៥ ន រម ១៦:២៥ ២ធថ ២:៨ កច ១០:៤២
**២:១៧** ប ខ.២៣ យរ ៨:៨ មីក ៣:១១ យហ ៥:៤៥ រម ៩:៤
**២:២១** ផ មថ ២៣:៣,៤
**២:២២** ព កច ១៩:៣៧
**២:២៣** ភ ខ.១៧
**២:២៤** ម អស ៥២:៥ អគ ៣៦:២២ ២ពត ២:២
**២:២៥** យ ខ.១៣,២៧ កទ ៥:៣ រ យរ ៤:៤ ៩:២៥,២៦
**២:២៦** ល រម ៨:៤ វ ១កថ ៧:១៩
**២:២៧** ស មថ ១២:៤១,៤២
**២:២៨** ហ មថ ៣:៩ យហ ៨:៣៩ រម ៩:៦,៧ ឡ កទ ៦:១៥

វិញ នោះការដែលទទួលកាត់ស្បែក បានត្រឡប់ដូចជាមិន
កាត់វិញ[រ] [២៦]ដូច្នេះ បើសិនជាពួកដែលមិនកាត់ស្បែក គេ
កាន់តាមបញ្ញត្តិក្រឹត្យវិន័យទៅ[ល] នោះការដែលមិនបានកាត់
ស្បែក តើមិនរាប់ដូចជាបានកាត់វិញទេឬអី?[វ] [២៧]ហើយពួក
ដែលមិនកាត់ស្បែកតាមបវេណី បើគេប្រព្រឹត្តតាមក្រិត្យ
វិន័យសព្វគ្រប់ តើគេមិនជំនុំជំរះអ្នកទេឬអី?[ស] ដែលអ្នកមាន
ទាំងគម្ពីរ នឹងការកាត់ស្បែកផង តែចេះតែប្រព្រឹត្តរំលង
ក្រឹត្យវិន័យវិញ ។
[២៨]ឯដំណើរដែលហៅថាសាសន៍យូដា នោះមិនចំពោះ
តែអ្នកណា ដែលមានទីសំគាល់ខាងក្រៅ[ហ]ប៉ុណ្ណោះទេ
ហើយការកាត់ស្បែកសោត ក៏មិនមែនចំពោះតែសាច់
ខាងក្រៅប៉ុណ្ណោះដែរ[ឡ] [២៩]រីឯសាសន៍យូដាដ៏ពិតប្រាកដ
នោះគឺខាងក្នុងវិញ ហើយការកាត់ស្បែកក៏នៅក្នុងចិត្ត[អ] ខាង
ព្រលឹងវិញ្ញាណដែរ[ក] មិនមែនតាមតែន័យពាក្យប៉ុណ្ណោះ
ទេ[ខ] មនុស្សយ៉ាងនោះតែងមានសេចក្ដីសរសើរ មិនមែន
មកពីមនុស្ស គឺពីព្រះវិញ[គ] ។

## សេចក្ដីស្មោះត្រង់របស់ព្រះ

**៣** [១]ដូច្នេះតើសាសន៍យូដាវិសេសជាងគេយ៉ាងណា ឬការ
កាត់ស្បែកមានប្រយោជន៍ដូចម្ដេចខ្លះ [២]មានគ្រប់ជំពូកជា
ច្រើនណាស់[ឃ] មុនដំបូងគឺពីព្រោះព្រះបានផ្ញើព្រះបន្ទូលទុក
នឹងគេ[ង] ។

**២:២៩** អ ចទ ៣០:៦ ក ភល ៣:៣ កល ២:១១ ខ រម ៧:៦ ២កថ ៣:៦ គ យហ ៥:៤៤ ១២:៤៣ ១កថ ៤:៥ ២កថ ១០:១៨ កទ ១:១០ ១ថន ២:៤ ១ពត ៣:៤ **៣:២** ឃ រម ៩:៤,៥ ង ចទ ៤:៨ ទដ ១៤៧:១៩ កច ៧:៣៨

**២:១៦** ខនេះត្រូវអានភ្ជាប់នឹងខ.១៣ ហើយបានបង្ហាញហេតុផលនៅក្នុងខ.១៤–១៥ ។ *តាមដំណឹងខ្ញុំ* មើលការពន្យល់ ១៦:២៥ ។

**២:១៧–២៤** នេះគឺជាសេចក្ដីណែនាំមួយដែលមានទម្រង់ជាការសន្ទនាគ្នា ។ លោកប៉ុលបានស្គាល់ពីគំនិត ដែលពួកយូដាបានចាត់ទុកខ្លួនគេថាជាមនុស្សសុចរិតពីព្រោះ លោកក៏ជាម្នាក់ដែលធ្លាប់គិតដូច្នេះដែរកាលពីមុន ។ គាត់បានលើកយកចំណុចមួយ ពីខទាំងនេះមកបញ្ជាក់ថាសាសន៍យូដា ក៏ពុំមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការ ធ្វើជាម្ចាស់លើក្រឹត្យវិន័យទេ ព្រោះពួកគេបានបង្ហាញពីភាពខុសគ្នារវាងការអះអាង ហើយនិងការប្រព្រឹត្តរបស់ពួកគេ ។ លោកប៉ុលបានបញ្ជាក់ថាគោលការនៃការជំនុំជម្រះលើសាសន៍យូដាគឺមានចែង ក្នុងខ.១–១៦ មើលការពន្យល់ខទាំងនេះ ។

**២:១៩–២០** *ដល់ពួកអ្នកដែលងងឹត . . . ដល់កូនក្មេង* ឃ្លានេះគឺនិយាយសំដៅលើសាសន៍ដទៃដែលប្រៀបទៅនឹងមនុស្សងងឹត ឬជាកូនក្មេងដោយពុំបានយល់ពីក្រិត្យវិន័យអ្វីឡើយ ។ តែចំពោះសាសន៍យូដាវិញ បានចាត់ទុកខ្លួនគេជាមនុស្សដ៏សំខាន់ បំផុតដោយព្រោះតែពួកគេ(សាសន៍យូដា) ជាម្ចាស់លើក្រិត្យវិន័យរបស់លោកម៉ូសេ ។

**២:២២** *តើអ្នកប្លន់វិហារឬទេ?* មើល កច ១៩:៣៧ ។ ពួកអ្នកមានមួយចំនួនធំបានយកទ្រព្យសម្បត្តិខ្លួន ទៅទុកនៅក្នុងព្រះវិហារពួកសាសន៍ដទៃដើម្បីសុវត្ថិភាព ។

**២:២៥** *ការកាត់ស្បែក* សកម្មភាពនេះគឺជាការតាំងសញ្ញាមួយរវាងព្រះហើយនិងអ៊ីស្រាអែល(មើល លវ ១២:៣) ហើយក៏ជាការសំគាល់នៃព្រះពរផងដែរ(៤:១១ និងការពន្យល់)។ ហេតុដូច្នេះហើយបានជាពួកយូដាបានកាត់ស្បែក ហើយចាត់ទុក ពិធីនេះជាការធានាអះអាងរបស់ព្រះអម្ចាស់ ។

**២:២៧** នៅក្នុងខនេះចង់បញ្ជាក់ថាសាសន៍ដទៃ គេមិនបានកាត់ស្បែកតាមប្រពៃណី ដូចដែលពួកយូដាបានធ្វើនោះទេ តែគេបានប្រព្រឹត្តតាមក្រិត្យវិន័យសព្វគ្រប់ ហើយលើសជាងពួកអ្នកដែលមានទាំងក្រិត្យវិន័យរបស់លោកម៉ូសេ ហើយកាត់ ស្បែកទៀតផង ដូច្នេះសាសន៍យូដាមិនត្រូវជំនុំជម្រះគេទេ ។

**២:២៩** *ខាងព្រលឹងវិញ្ញាណ* ការតាំងសញ្ញាដ៏ពិតប្រាកដរបស់ព្រះ គឺមិនមែនជាសញ្ញាលើរាងកាយខាងក្រៅនោះទេ តែជាអំណាចនៃព្រះវិញ្ញាណបរិសុទ្ធនៅខាងក្នុងចិត្តវិញ ។ ដូចលោកប៉ុលបញ្ជាក់ថា "កាត់ស្បែកនៅក្នុងចិត្ត" មើល ចទ ៣០:៦ និងការពន្យល់ លប ១៧:១០ យរ ៤:៤ ។ *សេចក្ដីសរសើរ មិនមែនមកពីមនុស្ស គឺពីព្រះវិញ* មើល យហ ៥:៤១,៤៤ ១២:៤៣ ១កថ ៤:៣–៥ និងការពន្យល់ ៤:៣,៥ ។

**៣:២** *មុនដំបូង* មានន័យថាចាប់ពីខនេះរហូតដល់ ៩:៤–៥ លោកប៉ុលឈប់រំលែកញែកពីអត្ថប្រយោជន៍របស់សាសន៍យូដាទៀតហើយ ព្រោះបាន

៣តែបើមានអ្នកខ្លះមិនជឿនោះ[ច]ដូចម្ដេចទៅសេចក្ដី
ដែលគេមិនជឿនោះ តើនឹងធ្វើឱ្យសេចក្ដីជំនឿជឿដល់ព្រះ
ទៅជាមិនកើតការវិញឬអី?[ឆ] ៤ទេមិនមែនឡើយ សូមឱ្យ
ព្រះបានរាប់ជាពិត[ជ] ហើយគ្រប់ទាំងមនុស្សជាភូតភរវិញ
ចុះ[ឈ]ដូចមានសេចក្ដីចែងទុកមកថា: «ឱ្យទ្រង់បានរាប់
ជាសុចរិត ក្នុងការដែលទ្រង់មានបន្ទូល ហើយឱ្យទ្រង់
បានឈ្នះ ក្នុងកាលដែលគេជំនុំជំរះទ្រង់»[ញ] ៥ប៉ុន្តែ
បើសិនជាសេចក្ដីទុច្ចរិតរបស់យើងរាល់គ្នាបាន នាំឱ្យ
គេឃើញសេចក្ដីសុចរិតរបស់ព្រះច្បាស់ជាង[ដ] នោះតើ
នឹងថាដូចម្ដេច តើព្រះទ្រង់ទុច្ចរិតឬអី ដែលទ្រង់ធ្វើ
ទោសនោះ (នេះខ្ញុំនិយាយតាមបែបមនុស្សលោក)[ឋ] ៦ទេ
មិនមែនឡើយ តែបើសិនជាទុច្ចរិតមែន នោះធ្វើដូចម្ដេច
ឱ្យព្រះជំនុំជំរះលោកកីយបាន?[ឌ] ៧ដ្បិតបើសិនជាសេចក្ដីពិត
របស់ព្រះបានចំរើនឡើងសំរាប់ជាសិរីល្អដល់ទ្រង់[ឍ] ដោយ
សារសេចក្ដីភូតភររបស់ខ្ញុំ នោះតើហេតុអ្វីបានជាខ្ញុំជាប់
សេចក្ដីជំនុំជំរះទុកដូចជាមនុស្សមានបាបទៀត?[ណ] ៨ហើយ
ហេតុអ្វីបានជាយើងខ្ញុំមិនថា ចូរប្រព្រឹត្តការអាក្រក់ដើម្បី
ឱ្យការល្អបានកើតឡើង[ត] ដូចជាគេនិយាយបង្កាច់យើងខ្ញុំ
ហើយខ្លះប្រកាន់ថា យើងខ្ញុំប្រដៅដូច្នោះមែន នោះឯ
ទោសនៃពួកអ្នកដែលប្រកាន់ដូច្នោះ នោះត្រឹមត្រូវហើយ ។

## គ្មានអ្នកណាម្នាក់សុចរិតឡើយ

៩ដូច្នេះ តើដូចម្ដេចយើងល្អជាងគេឬទេ?[ថ] មិនមែនទេ
ដ្បិតយើងខ្ញុំបានចោទប្រកាន់រួចហើយថា ទោះទាំងសាសន៍
យូដា នឹងសាសន៍ក្រេកផង សុទ្ធតែនៅក្រោមអំពើបាប[ទ]
១០ដូចមានសេចក្ដីចែកទុកមកថា គ្មានអ្នកណាសុចរិតសោះ
សូម្បីតែម្នាក់ក៏គ្មានផង ១១គ្មានអ្នកណាដែលយល់ គ្មានអ្នក
ណាដែលស្វែងរកព្រះ ១២គ្រប់គ្នាបានបែរចេញ ហើយ
ត្រឡប់ជាឥតប្រយោជន៍ទាំងអស់គ្នា «គ្មានអ្នកណាដែល
ប្រព្រឹត្តតាមសេចក្ដីសប្បុរសសោះ តែម្នាក់ក៏គ្មានផង[ធ]
១៣បំពង់កគេជាផ្នូរខ្មោចនៅចំហ គេប្រើអណ្ដាតគេសំរាប់
នឹងបញ្ឆោត[ន] ឯនៅបបូរមាត់គេ មានសុទ្ធតែពិសពស់ហនុ
មាន[ប] ១៤ហើយមាត់គេមានពេញដោយសេចក្ដីបណ្ដាសា
និងសេចក្ដីជូរចត់[ផ] ១៥ជើងគេរហ័សនឹងកំចាយឈាម ១៦នៅ
អស់ទាំងផ្លូវរបស់គេ មានសុទ្ធតែសេចក្ដីវិនាស និងសេចក្ដី
ទុក្ខលំបាក ១៧គេមិនបានស្គាល់ផ្លូវសុខសាន្តសោះ[ព] ១៨ក៏
គ្មានសេចក្ដីកោតខ្លាចចំពោះព្រះ នៅភ្នែកគេឡើយ»[ភ]

**៣:៣** ច រម ១០:១៦ ហាព ៤:២ ឆ ២ធថ ២:១៣
**៣:៤** ជ យហ ៣:៣៣ ឈ ទដ ១១៦:១១ ញ ទដ ៥១:៤
**៣:៥** ដ រម ៥:៨ ឋ រម ៦:១៩ កទ ៣:១៥
**៣:៦** ឌ លប ១៨:២៥ រម ២:១៦
**៣:៧** ឍ ខ.៤ ណ រម ៩:១៩
**៣:៨** ត រម ៦:១
**៣:៩** ថ ខ.១ ទ ខ.១៩,២៣ ១ពវ ៨:៤៦ ១រប ៦:៣៦ ទដ ១០៦:៦ រម ៥:១២ ១១:៣២ កទ ៣:២២
**៣:១២** ធ ទដ ១៤:១-៣ ៥៣:១-៣ សស ៧:២០
**៣:១៣** ន ទដ ៥:៩ ប ទដ ១៤០:៣ **៣:១៤** ផ ទដ ១០:៧ **៣:១៧** ព អស ៥៩:៧,៨ **៣:១៨** ភ ទដ ៣៦:១ **៣:១៩** ម យហ ១០:៣៤ យ រម ២:១២

និយាយរួចហើយ ។ *ផ្ញើព្រះបន្ទូលទុកនឹងគេ* គឺចង់និយាយសំដៅទៅលើព្រះបន្ទូលក្នុងគម្ពីរសញ្ញាចាស់ ។

**៣:៣** *សេចក្ដីជំនឿជឿដល់ព្រះ* ត្រង់ចំណុចនេះលោកប៉ុលចង់បញ្ជាក់ថា ព្រះអម្ចាស់ ទ្រង់ជាព្រះស្មោះត្រង់នឹងជាសេចក្ដីសន្យាជានិច្ច។ តែចំពោះពួកយូដាវិញ គេមិនជឿនឹងសេចក្ដីសន្យា ឬទំនាយដែលបានទាយនៅក្នុងគម្ពីរសញ្ញាចាស់ស្ដីអំពីការយាងមករបស់ព្រះយេស៊ូវគ្រីស្ទនោះទេ បានជាពួកគេត្រូវ ទទួលទោស (ខ.៥ ២ធថ ២:១៣) ។

**៣:៤** ក្នុងខនេះចង់ប្រាប់យើងថា នៅពេលអំពើបាបរបស់មនុស្សត្រូវបានបើកសំដែងចេញ នោះសេចក្ដីសុចរិតនៃព្រះក៏កាន់តែឃើញច្បាស់ឡើង ដូចជាភ្លើងឆេះនៅក្នុងទីងងឹត នោះវាភ្លឺជាងភ្លើងដែលឆេះនៅពេលថ្ងៃ ។ ដូច្នេះសេចក្ដីសុចរិតនៃព្រះក៏បានឃើញកាន់តែច្បាស់ឡើងនៅក្នុងសេចក្ដីទុច្ចរិតរបស់មនុស្សនោះដែរ ។

**៣:៥** បើសិនជាសេចក្ដីទុច្ចរិតរបស់យើងរាល់គ្នា "*បាននាំឱ្យគេឃើញសេចក្ដីសុចរិតរបស់ព្រះច្បាស់ជាង*" ម្ដេចក៏ព្រះមិនសព្វព្រះទ័យនឹងសេចក្ដីទុច្ចរិតរបស់មនុស្ស ពីព្រោះបើដូច្នេះ នោះមនុស្សនឹងបានលេសនិយាយថា ព្រះមួយអង្គនេះមិនយុត្តិធម៌ឡើយ ក្នុងការជំនុំជម្រះអ្នកដទៃនោះ ។ *និយាយតាមបែបលោកីយ* ឃ្លានេះសំដៅទៅលើភាពកម្សោយ និងភាពល្ងង់ខ្លៅរបស់មនុស្ស ។

**៣:៦** *ជំនុំជំរះ* សំដៅលើថ្ងៃជំនុំជម្រះចុងក្រោយ ។ *លោកីយ* សំដៅទៅលើអ្វីគ្រប់ យ៉ាងដែលព្រះបានបង្កើតមក (ខ.១៩ និង ១:២០) ។

**៣:៨** *ចូរប្រព្រឹត្តការអាក្រក់ ដើម្បីឱ្យការល្អបានកើតឡើង* នៅក្នុងឃ្លានេះលោកប៉ុលបានលើកឡើងច្រើននៅក្នុងជំពូក៦ ។

**៣:៩** *យើងល្អជាងគេឬទេ?* ត្រង់ចំណុចនេះលោកចង់សួរសំណួរថា ក្នុងព្រះនេត្រនៃព្រះអម្ចាស់ តើសាសន៍យូដាប្រសើរជាងសាសន៍ដទៃ (សាសន៍ក្រេក) ឬយ៉ាងណា? ចាប់ពីខ.៩-១២ យើងឃើញមានពាក្យ "*ទាំង . . .ផង គ្មានអ្នកណា សូម្បីតែម្នាក់ក៏គ្មានផង គ្រប់គ្នា ទាំងអស់គ្នា តែម្នាក់ក៏គ្មានផង*" ពាក្យទាំងនេះហើយដែលលោកប៉ុលចង់បញ្ជាក់ប្រាប់ឱ្យច្បាស់ថា មនុស្សទាំងអស់សុទ្ធតែមានបាប ។ *នៅក្រោមអំពើបាប* គឺចង់និយាយថានៅក្រោមអំណាច និងការដាក់ទោសនៃអំពើបាប ។

**៣:១០-១៨** នេះគឺជាវគ្គមួយដែលលោកប៉ុលបានដកស្រង់ចេញពីគម្ពីរសញ្ញាចាស់ ដោយសង្កត់ធ្ងន់ថា ទាំងសាសន៍យូដា និងសាសន៍ដទៃសុទ្ធតែនៅក្រោមអំណាចនៃអំពើបាប ។ មានកត្តាជាច្រើនបានពន្យល់ពីហេតុផលនៃការចម្លងមិនលំអៀងពីច្បាប់ដើម ។ (១). ការដកស្រង់ចេញពីគម្ពីរសញ្ញាថ្មីពេលខ្លះបានផ្ដល់គំនិតជាទូទៅមិន មែនម្ដង១ពាក្យៗ ។ (២). និមិត្តសញ្ញានៃការដកស្រង់ពុំមែនជាភាសាក្រិក ។ (៣). ការ ដកស្រង់ទាំងនេះជាញឹកញាប់ គឺយកមកពីគម្ពីរភាសាក្រិកបកប្រែចេញពីភាសាហេព្រើររបស់គ្រីស្ទបរិស័ទដំបូង (សម្រាប់អ្នកអានមិនសូវចេះភាសាហេព្រើរ)។ (៤). ដើម្បីឱ្យបានសម្រេចបំណងពេលខ្លះ អ្នកសរសេរគម្ពីរសញ្ញាថ្មី (ដោយព្រះវិញ្ញាណបើកសំដែង) បានពង្រីកបង្រួមបម្រែបម្រួល ឬបញ្ចូលអត្ថបទគម្ពីរសញ្ញាចាស់ផងដែរ ។

**៣:១១** *យល់* គឺយល់ពីព្រះ និងអ្វីដែលត្រឹមត្រូវ ។

**៣:១៣** *ផ្នូរខ្មោចនៅចំហ* ចង់និយាយពីអំពើពុករលួយដែលមាននៅក្នុងចិត្ត ។

**៣:១៨** *សេចក្ដីកោតខ្លាចចំពោះព្រះ* ខនេះបានដកស្រង់ចេញពី ទដ ៣៦:១ ដែលបាន ពិពណ៌នាអំពីមនុស្សដែលមិនកោតខ្លាចដល់ព្រះអម្ចាស់ ។ តែយើងសួរថា ហេតុអ្វីមនុស្សត្រូវកោតខ្លាចព្រះ? ពីព្រោះព្រះទ្រង់ស្អប់អំពើបាប ហើយទ្រង់នឹងជំនុំជម្រះមនុស្សដោយសារតែអំពើបាបនេះឯង (មើលការ

១៩ រីឯគ្រប់ទាំងសេចក្ដីដែលក្រិត្យវិន័យបង្គាប់[ម] នោះយើង
ដឹងថា បង្គាប់ដល់តែពួកអ្នកដែលនៅក្នុងបន្ទុកក្រិត្យវិន័យ
ទេ[យ] ដើម្បីឱ្យគ្រប់ទាំងមាត់ត្រូវបិទ[រ] ហើយឱ្យលោកិយទាំង
មូលជាប់មានទោសនៅចំពោះព្រះ[ល]
២០ ហេតុនោះបានជា
គ្មានមនុស្សណាបានរាប់ជាសុចរិតនៅចំពោះទ្រង់ ដោយ
អាងការប្រព្រឹត្តតាមក្រិត្យវិន័យនោះឡើយ[វ] ដ្បិតក្រិត្យវិន័យ
គ្រាន់តែសំដែងឱ្យស្គាល់អំពើបាបប៉ុណ្ណោះ[ស]។

## សេចក្ដីសុចរិតដោយសារជំនឿ

២១ ប៉ុន្តែឥឡូវនេះ ក្រៅពីក្រិត្យវិន័យ សេចក្ដីសុចរិតផង
ព្រះ[ហ] ដែលមានទាំងក្រិត្យវិន័យ និងពួកហោរាធ្វើបន្ទាល់
ឱ្យផង[ឡ] នោះបានលេចចេញមកហើយ
២២ គឺជាសេចក្ដី
សុចរិតរបស់ព្រះ[អ] ដែលបានដោយសារសេចក្ដីជំនឿជឿ[ក]
ដល់ព្រះយេស៊ូវគ្រីស្ទ[ខ] ក៏សំរាប់គ្រប់អស់អ្នកណា ដែលជឿ
ផង[គ] ដ្បិតគ្មានខុសអំពីគ្នាទេ[ឃ]
២៣ ពីព្រោះគ្រប់គ្នាបានធ្វើ
បាប[ង] ហើយខ្វះមិនដល់សិរីល្អនៃព្រះ
២៤ តែដោយពឹងដល់
ព្រះគុណទ្រង់[ច] នោះបានរាប់[ឆ]ជាសុចរិតទទេ ដោយសារ
សេចក្ដីប្រោសលោះ[ជ] ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ

**៣:១៩** ម យហ ១០:៣៤ យ រម ២:១២ រ ទដ ៦៣:១១ ១០៧:៤២ អគ ១៦:៦៣ ល ខ.៩ **៣:២០** វ កច ១៣:៣៩ កទ ២:១៦ ស រម ៤:១៥ **៣:២១** ហ អស ៤៦:១៣ យរ ២៣:៦ រម ១:១៧ ៩:៣០ ឡ កច ១០:៤៣ រម ១:២

**៣:២២** អ រម ១:១៧ ក រម ៩:៣០ ខ កទ ២:១៦ ៣:២២ គ យហ ៣:១៥ រម ៤:១១,១០:៤ ឃ រម ១០:១២ កទ ៣:២៨ កល ៣:១១
**៣:២៣** ង ខ.៩ រម ៤:១១ ១០:៤ ឃ រម ១០:១២ កទ ៣:២៨ កឡ ៣:១១
**៣:២៤** ច រម ៤:២៥ ឆ យហ ១:១៤,១៦,១៧ រម ៤:១៦ ៥:២១ ៦:១៤ ១១:៥ ២កថ ១២:៩ អភ ២:៨ ៤:៧ ទត ២:១១ ហព ៤:១៦ ជ ទដ ១៣០:៧ ១កថ ១:៣០ កទ ៤:៥ អភ ១:៧,១៤ កល ១:១៤ ហព ៩:១២

ពន្យល់ លប ២០:១១ សភ ១:៧ )។

**៣:១៩** *យើងដឹងថា* មើលការពន្យល់ រម ២:២ ។ *ក្រិត្យវិន័យ* គឺនិយាយពីព្រះគម្ពីរ សញ្ញាចាស់(ដូចគ្នានៅក្នុង យហ ១០:៣៤ ១៥:២៥ ១កថ ១៤:២១)។ *ពួកអ្នក... ក្នុងបន្ទុកក្រិត្យវិន័យ* គឺសំដៅលើសាសន៍យូដា។ *គ្រប់ទាំងមាត់ . . . លោកីយទាំងមូល* ឃ្លានេះមានន័យថា ទាំងសាសន៍យូដា និងសាសន៍ដទៃសុទ្ធតែមានបាបដូចគ្នា ។

**៣:២០** *រាប់ជាសុចរិត* មើលពន្យល់ ខ.២៤, ២:១៣ ។ *សំដែងឱ្យស្គាល់អំពើបាប* នេះគឺជាបំណងមួយយ៉ាងសំខាន់ក្នុងគោលបំណងទាំងឡាយនៃក្រិត្យវិន័យ បើផ្អែកលើសេចក្ដីបង្រៀនរបស់សាវ័កប៉ុល(មើលការពន្យល់ រម ៧:៧)។

**៣:២១–៥:២១** នៅត្រង់វគ្គនេះត្រូវបានគេបង្ហាញថា មនុស្សទាំងអស់ (សាសន៍យូដា និងសាសន៍ដទៃ) គ្មាននរណាម្នាក់សុចរិតនោះឡើយ (១:១៨–៣:២០) តែមកដល់ពេលនេះ លោកប៉ុលបង្ហាញថា មានតែព្រះអម្ចាស់ តែមួយអង្គគត់ដែលជាអ្នក ប្រទានសេចក្ដីសុចរិតដល់មនុស្សជាតិ ។

**៣:២១** *ប៉ុន្តែឥឡូវនេះ* ពាក្យនេះអាចមានន័យពីរយ៉ាងគឺ (១).ចង់សំដៅពីសេចក្ដីសុចរិតដែលព្រះបានកំពុងតែសំដែងមកដល់យើង ហើយនាពេលបច្ចុប្បន្ននេះ ។ (២).តាមពិតចង់និយាយអំពីភាពផ្ទុយគ្នារវាងសេចក្ដីសុចរិតដែលបានមកដោយសារការប្រព្រឹត្តតាមក្រិត្យវិន័យ (មិនអាច ទៅរួចឡើយ ខ.២០) ហើយនិងសេចក្ដីសុចរិតដែលបានមកដោយសារការប្រទានរបស់ព្រះ ។ *ក្រៅពីក្រិត្យវិន័យ* ចង់និយាយថា មិនបានប្រព្រឹត្តតាមក្រិត្យវិន័យ ។ *ក្រិត្យវិន័យ និងពួកហោរាធ្វើបន្ទាល់* មើល លប ១៥:៦ ទដ ៣២:១–២ ហព ២:៤ និងការពន្យល់ ។

**៣:២២–២៤** "ដ្បិតគ្មានខុសអំពីគ្នាទេ . . . សិរីល្អនៃព្រះ" នេះគឺជាការបញ្ចូលគំនិតគ្នារបស់លោកប៉ុល ដោយគាត់ចង់និយាយថា គ្រប់អស់ទាំងអ្នកជឿ (ខ.២២) គឺត្រូវបានរាប់ជាសុចរិត(ខ.២៤)។ មិនមែនមានន័យថា គ្រប់អស់ទាំងអ្នកធ្វើបាប (ខ.២៣)ត្រូវបានរាប់ជាសុចរិត(ខ២៤)នោះទេ ។

**៣:២២** *គ្មានខុសអំពីគ្នា* គឺចង់និយាយសំដៅលើសាសន៍យូដា និងសាសន៍ដទៃ (មើល ការពន្យល់ ១០:១២ )។

**៣:២៣** *សិរីល្អនៃព្រះ* គឺជាអ្វីដែលព្រះសព្វព្រះហឫទ័យឱ្យមនុស្សមាន ។ ដូចជាសិរីល្អដែលមានក្នុងសម័យអ័ដាមមុនធ្លាក់ក្នុងសេចក្ដីល្បួង (លប ១:២៦–២៨ ទដ ៨:៤–៨ អស ៤:២៤ កល ៣:១០) អ្នកជឿនឹងទទួលសិរីល្អម្ដងទៀត តាមរយៈព្រះ គ្រីស្ទ(មើលការពន្យល់ ហព ២:៥–៩)។

**៣:២៤** *រាប់ជាសុចរិត* លោកប៉ុលប្រើពាក្យនេះជាកិរិយាសព្ទនៃភាសាក្រិក មានចំនួន២៧ដង ភាគច្រើននៅក្នុងគម្ពីររ៉ូម និងកាឡាទី ។ វាជាពាក្យមួយសម្រាប់ពណ៌នាហេតុការណ៍ ក្រោយពីនរណាម្នាក់បានទទួលជឿព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះ នោះទ្រង់លុបកំហុសនៃអំពើបាបរបស់គេចោល ហើយប្រទានឱ្យសេចក្ដីសុចរិតដល់គេវិញ ។ ទាក់ទងនឹងចំណុចនេះលោកប៉ុលបានសង្កត់ធ្ងន់ទៅលើ២ចំណុច: (១).គ្មាននរណាមួយគ្រប់លក្ខណ៍ បរិសុទ្ធ សុចរិតនោះឡើយ ។ បើនិយាយឱ្យខ្លីទៅ គ្មាននរណាសុចរិតឡើយ(ខ.១០) គឺគ្រប់គ្នាមានបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ(ខ.២៣)។ ដូច្នេះហើយគ្មាននរណាម្នាក់ប្រកាសថាខ្លួនសុចរិតនៅចំពោះព្រះ ដោយប្រព្រឹត្តតាមក្រិត្យវិន័យនោះឡើយ(ខ.២០)។ (២).ប៉ុន្តែទោះបីជាមនុស្សទាំងអស់មានបាបក៏ដោយ ក៏ព្រះអម្ចាស់ប្រកាសថា អស់អ្នកណាដែលដាក់សេចក្ដីទុកចិត្តរបស់គេលើព្រះយេស៊ូវ នោះនឹងគ្មានទោសទៀតសោះឡើយ ហើយថែមទាំងបានរាប់ជាសុចរិតទៀតផង ។ នេះគឺជាសេចក្ដីប្រកាសស្របច្បាប់មួយ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការ ដោយព្រោះព្រះគ្រីស្ទបានសុគតសងថ្លៃបាបរបស់យើង ។ ជីវិតទ្រង់ គឺសុចរិត គ្រប់លក្ខណ៍ តែទ្រង់បែរជាមកទទួលទោសជំនួសយើងវិញ ។ នេះគឺជាផ្ទៃរឿងសំខាន់នៅក្នុងគម្ពីររ៉ូម ១:១៧(សេចក្ដីសុចរិតបានមកពីព្រះ)។ សេចក្ដីសុចរិតរបស់ព្រះគ្រីស្ទ(ការស្ដាប់បង្គាប់ដល់ក្រិត្យវិន័យរបស់ព្រះរហូតដល់សុគត) គឺជាទីសង្ឃឹមរបស់អ្នកជឿផ្ទាល់ខ្លួនគ្រប់ៗរូប ។ *ដោយពឹងដល់ព្រះគុណទ្រង់* នេះគឺជាចំណុចសំខាន់បំផុតដែលនាំឱ្យបានរាប់ជាសុចរិត ត្រង់ចំណុចនេះ ចង់និយាយថាមនុស្ស តែងតែមានកំហុសខុសឆ្គងដែលអាចមើលឃើញយ៉ាងច្បាស់ក្រឡែត(ខ.៩–១៩) តែព្រះអម្ចាស់បានប្រកាសថា ពួកគេត្រូវបានរាប់ជាសុចរិតដោយសារការជឿទុកចិត្តរបស់ពួកគេលើព្រះគ្រីស្ទ ។ ត្រង់ចំណុចនេះយើងក៏អាចនិយាយបានច្រើនបែបផងដែរ: (១).បានមកដោយទទេ (២).បានមកដោយព្រះគុណទ្រង់ (៣).បានមកដោយសេចក្ដីប្រោសលោះនៅក្នុងព្រះគ្រីស្ទយេស៊ូវ (៤).បានមកដោយសេចក្ដីជំនឿ(ខ.២៥)។ *សេចក្ដីប្រោសលោះ* ពាក្យនេះត្រូវបានគេប្រើសម្រាប់ពិពណ៌នាក្នុងកាល ដែលបានលោះទាសករចេញពីភាពជាខ្ញុំកញ្ជះដាច់ថ្លៃរបស់នរណាម្នាក់ ដោយមានការត្រូវរូវតម្លៃគ្នា ។ លោកប៉ុលប្រើពាក្យនេះចង់សំដៅថា មនុស្សមានសេរីភាពពីអំពើបាប រួចពីបំណុលបាប ពីការជំនុំជម្រះ ហើយពុំមែនជាទាសករនៃអំពើបាបទៀតទេ ពីព្រោះព្រះគ្រីស្ទបានសុគតដើម្បីលោះថ្លៃបាបរបស់យើងរួចហើយ ។

២៥ ដែលព្រះបានតាំងទ្រង់ទុក ជាទីសន្ដោសប្រោស[ឈ] ដោយ
សារសេចក្ដីជំនឿដល់ព្រះលោហិតទ្រង់[ញ] សំរាប់នឹងសំ
ដែងឱ្យឃើញសេចក្ដីសុចរិតរបស់ព្រះ ចំពោះការដែល
ទ្រង់មិនប្រកាន់អំពើបាប ដែលគេប្រព្រឹត្តពីដើម[ដ] ដោយ
ទ្រង់មានព្រះហឫទ័យអត់ធ្មត់ ២៦ ដើម្បីនឹងសំដែងឱ្យឃើញ
សេចក្ដីសុចរិតរបស់ព្រះ នៅជាន់ឥឡូវនេះ ប្រយោជន៍ឱ្យ
ទ្រង់បានសុចរិត ព្រមទាំងរាប់ពួកអ្នកដែលមានសេចក្ដី
ជំនឿជឿដល់ព្រះយេស៊ូវ ថាជាសុចរិតដែរ ។
២៧ ដូច្នេះ តើសេចក្ដីអួតអាងនៅឯណា[ឋ] គឺត្រូវលើក
ចោលហើយ តើច្បាប់ណាដែលលើកចោលនោះ តើជា
ច្បាប់ខាងឯការប្រព្រឹត្តឬ មិនមែនទេ គឺជាច្បាប់ខាងឯ
សេចក្ដីជំនឿវិញទេតើ ២៨ ដ្បិតយើងខ្ញុំអាងថា មនុស្សបាន
រាប់ជាសុចរិត ដោយសារសេចក្ដីជំនឿ គឺមិនមែនដោយ
ការប្រព្រឹត្តតាមក្រឹត្យវិន័យទេ[ឌ] ២៩ តើព្រះអង្គទ្រង់ជាព្រះ
នៃសាសន៍យូដាតែប៉ុណ្ណោះ តើទ្រង់មិនមែនជាព្រះនៃ
សាសន៍ដទៃដែរទេឬអី មែនហើយ ទ្រង់ជាព្រះនៃសាសន៍
ដទៃដែរ[ឍ] ៣០ ដ្បិតគឺជាព្រះតែ១ព្រះអង្គ ដែលនឹងរាប់ទាំង
ពួកកាត់ស្បែក ថាជាសុចរិត ដោយសារតែគេមានសេចក្ដី
ជំនឿ ព្រមទាំងពួកអ្នកដែលមិនកាត់ស្បែកផង ដោយគេ
មានសេចក្ដីជំនឿនោះដែរ[ណ] ៣១ ដូច្នេះ តើយើងឈ្មោះថាធ្វើ
ឱ្យក្រឹត្យវិន័យទៅជាឥតប្រយោជន៍ ដោយសេចក្ដីជំនឿឬអី
ទេ? មិនមែនឡើយ គឺឈ្មោះថា យើងតាំងក្រឹត្យវិន័យ ឱ្យ
កាន់តែមាំមួនឡើងវិញទេតើ ។

## លោកអ័ប្រាហាំត្រូវបានរាប់ជាសុចរិតដោយសារជំនឿ

**៤** ១ បើដូច្នេះ យើងនឹងថា[ត] លោកអ័ប្រាហាំ ជាឰយុកោ
យើង[ថ]បានអ្វីខ្លះ ខាងឯសាច់ឈាម ២ ដ្បិតបើសិនណាជា
លោកអ័ប្រាហាំបានរាប់ជាសុរិត ដោយការដែលលោក
ប្រព្រឹត្ត នោះលោកមានកន្លែងនឹងអួតខ្លួនហើយ តែមិន
មែនចំពោះព្រះទេ[ទ] ៣ តើគម្ពីរថាដូចម្ដេច គម្ពីរថា «អ័ប្រា
ហាំបានជឿដល់ព្រះ ហើយសេចក្ដីជំនឿនោះ បានរាប់ជា
សេចក្ដីសុចរិតដល់លោក»[ធ] ។
៤ រីឯអ្នកណាដែលធ្វើការនោះ រង្វាន់មិនរាប់ជាគុណ
របស់ចៅហ្វាយទេ[ន]គឺទុកជាថ្លៃឈ្នួលវិញទេតើ ៥ តែចំណែក
អ្នកដែលមិនធ្វើការសោះ គឺគ្រាន់តែជឿដល់ព្រះអង្គ ដែល
ទ្រង់ប្រោសឱ្យមនុស្សទមិលល្មើសបានសុចរិត នោះសេច
ក្ដី ជំនឿរបស់អ្នកនោះបានរាប់ទុកជាសេចក្ដីសុចរិតវិញ[ប]

**៣:២៥** ឈ នក ២៥:១៧ លវ ១៦:១០ ទដ ៦៥:៣ ហព ២:១៧ ៩:២៨ ១យហ ៤:១០ ញ កច ២០:២៨ រម ៥:៩ អភ ១:៧ ហព ៩:១២,១៤ ១៣:១២ ១ពត ១:១៩ វវ ១:៥ ដ កច ១៤:១៦ ១៧:៣០ **៣:២៧** ឋ រម ២:១៧,២៣ ៤:២ ១កថ ១:២៩–៣១ អភ ២:៩ **៣:២៨** ឌ ខ.២០,២១ កច ១៣:៣៩ កទ ២:១៦ ៣:១១ អភ ២:៩ យក ២:២០,២៤,២៦ **៣:២៩** ឍ កច ១០:៣៤,៣៥ រម ៩:២៤ ១០:១២ ១៥:៩ កទ ៣:២៨ **៣:៣០** ណ រម ៤:១១,១២ កទ ៣:៨

**៤:១** ត រម ៨:៣១ ថ លក ៣:៨ **៤:២** ទ ១កថ ១:៣១ **៤:៣** ធ ខ.៥,៩,២២ លប ១៥:៦ កទ ៣:៦ យក ២:២៣ **៤:៤** ន រម ១១:៦ **៤:៥** ប ខ.៣,៩,២២ រម ៩:៣០

**៣:២៥** *ដែលព្រះបានតាំង . . . ប្រោស* ឃ្លានេះនៅក្នុងភាសាក្រិក គឺសំដៅលើការបូជាជីវិត(ស្លាប់)ឱ្យសមនឹងសេចក្ដីក្រោធនៃព្រះដ៏សុចរិត ។ បើសិនជាព្រះយេស៊ូវមិនសុគតនោះទេ នោះមនុស្សទាំងអស់នឹងត្រូវជាប់ទោសរហូតដល់អស់កល្បបំផុត (ការពន្យល់ ១យហ ២:២)។ *ជំនឿដល់ព្រះលោហិតទ្រង់* គឺជាសេចក្ដីជំនឿ ដែលបាន ជឿថាព្រះគ្រីស្ទយេស៊ូវបានសុគត ដើម្បីលោះថ្លៃបាបរបស់ខ្លួន ។

**៣:២៥ខ–២៦** អំពើបាបនៃបណ្ដាជននិមិត្តសញ្ញានៃការសម្លាប់សត្វដើម្បីជំនួសការកាត់ទោសរបស់ព្រះអម្ចាស់នៅក្នុងអំឡុងពេលនៃគម្ពីរសញ្ញាចាស់ត្រូវបានយកមក សរុបតែម្ដងគត់លើតួអង្គព្រះយេស៊ូវនៅលើឈើឆ្កាង ។

**៣:២៨** *ដោយសារសេចក្ដីជំនឿ* នៅពេលលោកលូតធើរ (Luther) បកប្រែវគ្គនេះ គាត់បានបន្ថែមពាក្យមួយទៀតគឺ "ដោយសារសេចក្ដីជំនឿ តែមួយប៉ុណ្ណោះ" ដើម្បីបញ្ជាក់ន័យឱ្យកាន់តែច្បាស់ឡើង(មើលការពន្យល់ យក ២:១៤–២៦)។

**៣:៣០** *ព្រះតែ១ព្រះអង្គ* ដោយការតវ៉ានៅក្នុងអត្ថបទដំបូងនៃសេចក្ដីជំនឿរបស់សាសន៍យូដា("ព្រះតែ១ព្រះអង្គ"មើលការពន្យល់ ចទ៦:៤)។ លោកប៉ុលបានវែកញែកពន្យល់ថា មានសេចក្ដីសង្គ្រោះតែមួយគត់សម្រាប់ទាំងសាសន៍យូដា(អ្នកកាត់ស្បែក) និងសាសន៍ដទៃ(អ្នកមិនកាត់ស្បែក)គឺជឿលើព្រះនាមព្រះគ្រីស្ទយេស៊ូវ ។

**៣:៣១** លោកប៉ុលបានគិតពីចម្លើយ ទុកជា មុនពីការ ចោទ ប្រកាន់ លើគោលជំនឿ គ្រីស្ទបរិស័ទថា ជាអ្នកប្រឆាំងនឹងក្រិត្យវិន័យនោះរួចជាស្រេចហើយ ។ ដោយព្រោះថាការរាប់ជាសុចរិតគឺបានមកដោយសារសេចក្ដីជំនឿតែមួយគត់ បើដូច្នេះនោះមិនបដិសេធក្រិត្យវិន័យចោលបាត់ទៅ ហើយ? គាត់បានបំពេញចម្លើយបន្ថែមទៀតនៅក្នុងជំពូក ៦–៧ ព្រមទាំងបានអះអាងពីសុពលភាពនៃក្រិត្យវិន័យទៀតផង ក្នុង ១៣:៨–១០។

**៤:១** *អ័ប្រាហាំជាឰយុកោ* គាត់ជាព្រឹទ្ធាចារ្យដ៏អស្ចារ្យរបស់សាសន៍យូដា ហើយក៏ជាគំរូដ៏ជាក់ស្ដែងមួយនៃមនុស្សដែលបានរាប់ជាសុចរិតដោយសារជំនឿ (មើលការពន្យល់ យក ២:២១–២៣)។ ពួកសាសន៍យូដា នៅសម័យព្រះយេស៊ូវបានចាត់ទុកលោកអ័ប្រាហាំជាមនុស្សម្នាក់ដែលបានរាប់ជាសុចរិតដោយទង្វើនោះទៅវិញ ប៉ុន្តែលោកប៉ុលពន្យល់នៅក្នុងវគ្គនេះថាលោកអ័ប្រាហាំគឺជាគំរូដ៏ច្បាស់ក្រឡែតនៃការដែលរាប់ជាសុចរិត ដោយសារសេចក្ដីជំនឿ(លប ៣:៧–៩ និងការពន្យល់)។

**៤:២** *បើសិនណាជាលោកអ័ប្រាហាំ . . . ដោយការដែលលោកប្រព្រឹត្ត* មានពួកសាសន៍យូដាជាច្រើននៅសម័យលោកប៉ុលបានចាត់ទុកលោកអ័ប្រាហាំបានរាប់ជាសុចរិតដោយការប្រព្រឹត្ត ប៉ុន្តែតាមពិតមិនមែនដូច្នេះ នោះទេ (ខ.៣) យ៉ាងនេះ ហើយបានជាគាត់គ្មានអ្វីនឹងអួតខ្លួនបានឡើយ ។

**៤:៣** អត្ថន័យក្នុងខនេះគឺយោងតាម លប ១៥:៦ គ្មានកន្លែងណាផ្សេងទៀតនិយាយ អំពីការប្រព្រឹត្តនោះឡើយ(មើលការពន្យល់ ៣:២១)។ *រាប់ជា* មានន័យថាការសរសើរតម្កើង ការផ្ដល់កិត្តិយស ការផ្ដល់ងារជាទីគោរព ។ លោកអ័ប្រាហាំ មិនបានរក្សាក្រឹត្យវិន័យមិនបម្រើក្រិត្យវិន័យ ហើយក៏មិនប្រព្រឹត្តតាមទំនៀមទម្លាប់ពីបុរាណនោះដែរ នោះហើយដែលលោកទទួលបានការរាប់ជាសុចរិតនៅចំពោះព្រះ ។ សេចក្ដីជំនឿរបស់គាត់បានជឿទុកចិត្តនូវអ្វីដែលព្រះអម្ចាស់បានសន្យាចំពោះរូបគាត់នេះ ហើយដែលត្រូវបាន

៦ដូចជាហ្លួងដាវីឌបានសំដែងពីសណ្ឋានដ៏មានពរនៃ
មនុស្ស ដែលព្រះទ្រង់រាប់ជាសុចរិតក្រៅពីការប្រព្រឹត្តថា
៧«មានពរហើយ អ្នកណាដែលការទទឹងច្បាប់របស់ខ្លួនបាន
អត់ទោសឱ្យ នឹងបាបខ្លួនបានគ្របបាំង ៨មានពរហើយ
មនុស្សណាដែល ព្រះអម្ចាស់មិនរាប់ជាមានបាបឡើយ»[ផ]។
៩ដូច្នេះ តើបានពរនោះ ចំពោះតែពួកកាត់ស្បែកតែ
ប៉ុណ្ណោះ ឬពួកមិនកាត់ស្បែកក៏បានដែរ?[ព] ដ្បិតយើងថា
សេចក្តីជំនឿ បានរាប់ទុកជាសេចក្តីសុចរិត ដល់លោក
អ័ប្រាហាំ[ភ] ១០ចុះសេចក្តីនោះបានរាប់ដូចម្តេច តើពីកាល
លោកបានកាត់ស្បែករួចហើយ ឬនៅឡើយ? មិនមែនពី
កាលលោកបានកាត់ស្បែកហើយនោះទេ គឺក្នុងកាលដែល
មិនទាន់កាត់ស្បែកនៅឡើយវិញ ១១ហើយលោកបានទទួល
ពិធីកាត់ស្បែកនេះ ទុកជាទីសំគាល់ ជាត្រានៃសេចក្តីសុច-
រិត ដែលមកដោយសេចក្តីជំនឿនោះឯង គឺជាសេចក្តីជំនឿ
ដែលលោកមាន ពីកាលមិនទាន់កាត់ស្បែកនៅឡើយ[ម]
ដើម្បីឱ្យបានធ្វើជាឪពុក[យ] ដល់អស់អ្នកដែលជឿ[រ] ឥតកាត់
ស្បែកផង ប្រយោជន៍ឱ្យបានរាប់សេចក្តីសុចរិតនេះដល់
អ្នកទាំងនោះ ១២ហើយឱ្យបានធ្វើជាឪពុក ដល់ពួកដែលមិន
គ្រាន់តែកាត់ស្បែកប៉ុណ្ណោះ គឺដែលដើរតាមដាននៃសេចក្តី
ជំនឿរបស់លោកអ័ប្រាហាំ ជាឰយុកោយើងផង ជាសេចក្តី
ជំនឿដែលលោកមាន ពីកាលមិនទាន់កាត់ស្បែកនៅឡើយ។
១៣ដ្បិតសេចក្តីសន្យា[ល] ដល់លោកអ័ប្រាហាំ និងពូជ
លោក ឱ្យបានលោកីយជាមរដក[វ] នោះមិនមែនដោយសារ
ក្រិត្យវិន័យទេ គឺដោយសារសេចក្តីសុចរិតដែលមក ដោយ
សេចក្តីជំនឿវិញ[ស] ១៤ពីព្រោះបើសិនជាពួកអ្នកដែលអាង
ក្រិត្យវិន័យបានគ្រងមរដក នោះសេចក្តីជំនឿបានទៅជា
ឥតអំពើវិញ ហើយសេចក្តីសន្យាក៏ឥតប្រយោជន៍ដែរ[ហ]
១៥ឯក្រិត្យវិន័យ នោះបង្កើតសេចក្តីក្រោធ[ឡ] ដ្បិតកន្លែងណា
ដែលគ្មានក្រិត្យវិន័យ នោះក៏ឥតមានសេចក្តីរំលងដែរ[អ]។
១៦ដូច្នេះ សេចក្តីសន្យាបានមក ដោយសេចក្តីជំនឿ
ដើម្បីឱ្យបានត្រូវខាងព្រះគុណ[ក] ប្រយោជន៍ឱ្យសេចក្តីសន្យា
បានខ្ជាប់ខ្ជួន[ខ] ដល់ពូជលោកតទៅ មិនមែនត្រឹមតែពូជ
ដែលអាងក្រិត្យវិន័យប៉ុណ្ណោះ គឺដល់ទាំងពូជដែលអាង

**៤:៨** ផ ទដ ៣២:១,២ ១០៣:១២ ២កថ ៥:១៩
**៤:៩** ព រម ៣:៣០ ភ ខ.៣
**៤:១១** ម លប ១៧:១០,១១ យ ខ.១៦,១៧ លក ៣:៨ រ រម ៣:២២
**៤:១៣** ល កថ ១៣:៣២ កទ ៣:១៦,២៩ វ លប ១៧:៤-៦ ស រម ៩:៣០
**៤:១៤** ហ កទ ៣:១៨
**៤:១៥** ឡ រម ៧:៧-២៥ ១កថ ១៥:៥៦ ២កថ ៣:៧ កទ ៣:១០ រម ៧:១២ អ រម ៣:២០ ៥:១៣ ៧:៧
**៤:១៦** ក រម ៣:២៤ ខ រម ១៥:៨

រាប់គាត់ថាសុចរិតនោះមិនមែនដោយការប្រព្រឹត្តទេ ។

**៤:៦-៨** នៅត្រង់នេះបញ្ជាក់ថា ព្រះអម្ចាស់មិនរាប់មនុស្សមានបាប ដែលបានប្រែចិត្តនោះថាជាមនុស្សទុច្ចរិតតទៅទៀតទេ តែទ្រង់ថែមទាំងអត់ទោសឱ្យពួកគេទៀតផងនៅពេលដែលពួកគេលន់តួបាបនោះ(ទដ ៣២:៣-៥ និងការពន្យល់ អគ ១៨:២៣,២៧-២៨,៣២ ៣៣:១៤-១៦ និងការពន្យល់)។

**៤:៩** សេចក្តីពន្យល់នៅក្នុងខនេះ សូមមើលទៅ ៣:៣០ ។

**៤:១០** *មិនមែនពីការលោកបានកាត់រួច... គឺកាលដែលមិនទាន់កាត់* លោកអ័ប្រាហាំត្រូវបានគេប្រកាសរាប់ថាសុចរិត(លប ១៥:៦) ប្រហែលជា១៤ឆ្នាំមុននឹងគាត់បានទទួល ពិធីកាត់ស្បែក(លប ១៧:២៤,២៦)។ សូមមើលឧយោងនៅក្នុង លប ៣:១៧ ។

**៤:១១** *ទីសំគាល់* ការកាត់ស្បែកត្រូវបានចាត់ទុកជាទីសំគាល់មួយនៅក្នុងចំណោមទីសំគាល់ទាំងឡាយ ផ្នែករូបរាងខាងក្រៅនៃការសម្តែងពីសេចក្តីសុចរិត ដែលព្រះអម្ចាស់រាប់លោកអ័ប្រាហាំជាសុចរិតដោយសារសេចក្តីជំនឿនោះ(លប ១៧:១១ និងការពន្យល់)។ *ប្រយោជន៍ឱ្យ* លោកអ័ប្រាហាំគឺជាឪពុកខាងឯសេចក្តីជំនឿដល់សាសន៍ដទៃ (អ្នកមិនកាត់ស្បែក) ពីព្រោះគាត់បានជឿ ហើយត្រូវបានរាប់ជាសុចរិតមុននឹងពិធីបុណ្យកាត់ស្បែករបស់សាសន៍យូដានេះកើតទៅទៀត ។

**៤:១២** *ជាឪពុក* ពាក្យនេះមានន័យថាលោកអ័ប្រាហាំ គឺជាឰយុកោគំរូម្នាក់ផ្នែកសេចក្តីជំនឿសម្រាប់ទាំងសាសន៍យូដា(កាត់ស្បែក) និងសាសន៍ដទៃ (ឥតកាត់ស្បែក) ត្រង់នេះបញ្ជាក់ថាមានផ្លូវតែមួយទេ ដែលអាចរាប់ជាសុចរិតបានគឺសេចក្តីជំនឿ ។

**៤:១៣** *មិនមែនដោយសារក្រិត្យវិន័យទេ* ត្រង់ចំណុចនេះចង់និយាយថា មិនមែនជាលក្ខខ័ណ្ឌនៃកិច្ចសន្យាដែលសមនឹងបាន ពេលប្រព្រឹត្តតាមក្រិត្យវិន័យនោះទេ ។ *ពូជលោក* គឺសំដៅលើអស់អ្នកណាដែលហៅលោកអ័ប្រាហាំថាជាឪពុក (ខ.១១-១២)។ *ឱ្យបានលោកីយជាមរដក* "លោកីយ" គឺសំដៅលើការបង្កើតផ្ទៃមេឃផែនដី(១:២០)។ គ្មានការបញ្ជាក់អះអាងពីការទទួលលោកិយជាមរដកនេះនៅក្នុងជំនាន់លោកអ័ប្រាហាំនោះឡើយ ។ តែទ្រង់បានសន្យាថានឹងប្រទានឱ្យលោកមានកូនចៅច្រើនដូចជាគ្រាប់ខ្សាច់ (លប ១៣:១៦) ប្រទានទឹកដីកាណាន (លប ១២:៧ ១៣:១៤-១៥ ១៥:៧,១៨-២១ ១៧:៨) ហើយបណ្តាជនទាំងអស់នៅលើផែនដីនឹងបានទទួលព្រះពរតាមរយៈគាត់ (លប១២:២-៣ និងការពន្យល់ ១៨:១៨) ឬតាម រយៈកូនចៅគាត់ (លប ២២:១៨)។ ប៉ុន្តែរឿងនេះបាននិយាយយ៉ាងច្បាស់តាំងពីគម្ពីរលោកុប្បត្តិមកម្ល៉េះថា ព្រះអម្ចាស់មានបំណងព្រះហឫទ័យប្រកបជាមួយមនុស្សនៅក្នុងពិភពលោកនេះតាមរយៈលោកអ័ប្រាហាំ និងកូនចៅគាត់ ។ យើងឃើញនៅក្នុងការសន្យាជាមួយលោកអ័ប្រាហាំនេះថាគាត់ និងកូនចៅរបស់គាត់នឹងបានផែនដីជាមរដក(ទដ ៣៧:៩ និង ខពន្យល់ ខ.១១,២២,២៩,៣៤ មថ ៥:៥)។ ការនេះនឹងបានដឹងច្បាស់លាស់នោះ គឺនៅពេលព្រះគ្រីស្ទយាងមកម្តងទៀត ។

**៤:១៤** *ពួកអ្នកដែលអាងក្រិត្យវិន័យ* នៅសម័យនោះមានអ្នកខ្លះអះអាងថាគេនឹងទទួលមរដកនេះដោយការប្រព្រឹត្តតាមក្រិត្យវិន័យ ។ *សេចក្តីសន្យា* មើលការពន្យល់ ខ.១៣ ។

**៤:១៥** *ឯក្រិត្យវិន័យនោះ បង្កើតសេចក្តីក្រោធ* មានន័យថាក្រឹត្យវិន័យគ្រាន់តែបើកបង្ហាញ ហើយនិងដាស់តឿនអំពើបាបឱ្យមនុស្សដឹងតែប៉ុណ្ណោះ(៧:៧-១១)។ *សេចក្តីរំលង* មានន័យថាការធ្វើហួសពីគំនូសដែលបានកំណត់ទុក ។ ទីដែលគ្មានក្រឹត្យវិន័យ គឺទីនោះហើយដែលមានបាប តែពុំមានលក្ខណៈអ្វីថារំលងនោះទេ ។

**៤:១៦** ក្នុងខនេះបានសង្ខេបគំនិតនៅក្នុងខ.១១-១២ ។ នៅត្រង់នេះក៏ឃើញការជាប់ទាក់ទងគ្នាយ៉ាងជិតស្និទ្ធរវាងព្រះគុណ និងជំនឿ មើល ៣:២៤-២៥ អភ ២:៨-៩ និងការពន្យល់ ។ *ពូជដែលអាងក្រិត្យវិន័យ* សំដៅលើគ្រីស្ទ

សេចក្ដីជំនឿរបស់លោកអ័ប្រាហាំ ដែលជាឰយុកោនៃ
យើងទាំងអស់គ្នាថែមទៀតផង[គ] ១៧ដូចមានសេចក្ដីចែងទុក
មកថា «អញបានតាំងឯងឱ្យធ្វើជាឪពុក ដល់សាសន៍ជា
ច្រើន»[ឃ] រីឯនៅចំពោះព្រះ ជាទីជឿរបស់លោក ដែល
ទ្រង់ប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញ[ង] ទាំងមានបន្ទូល[ច]
ពីរបស់ដែលគ្មាន[ឆ]ទុកដូចជាមានហើយ នោះលោកជា
ឪពុករបស់យើងមែន ។
១៨ដ្បិតកាលលោកអស់ទីសង្ឃឹមហើយ នោះក៏ចេះតែជឿ
ដោយសង្ឃឹមវិញ ដើម្បីឱ្យបានត្រឡប់ជាឪពុកដល់សាសន៍
ជាច្រើន[ជ] ដូចសេចក្ដីដែលមានបន្ទូលទុកមកថា «ពូជឯង
នឹងបានដូច្នោះ»[ឈ] ១៩ហើយដោយព្រោះលោកមិនខ្សោយ
ខាងសេចក្ដីជំនឿបានជាលោកមិនគិតពីរូបកាយ លោក
ដែលរាប់ដូចជាស្លាប់[ញ] ដោយមានអាយុប្រហែលជា ១០០
ឆ្នាំហើយ[ដ] ឬពីផ្ទៃសារ៉ា ដែលរាប់ដូចជាស្លាប់ដែរនោះ
ទេ[ឋ] ២០លោកក៏មិនបានសង្ស័យ ចំពោះសេចក្ដីសន្យា
របស់ព្រះ ដោយចិត្តមិនជឿឡើយគឺរឹតតែមានសេចក្ដីជំនឿ
ខ្លាំងឡើង[ឌ] ទាំងសរសើរដំកើងដល់ព្រះវិញ[ឍ] ២១ហើយក៏
ជឿជាក់អស់ពីចិត្តថា សេចក្ដីអ្វីដែលទ្រង់សន្យា[ណ] នោះអាច
នឹងធ្វើឱ្យសំរេចបាន ២២ហេតុនោះបានជារាប់សេចក្ដី
ជំនឿរបស់លោក ទុកជាសេចក្ដីសុចរិតដល់លោក[ត] ២៣ប៉ុន្តែ
ដែលថា «បានរាប់ដល់លោក»ដូច្នេះ នោះមិនចែងទុកមក
សំរាប់លោកតែឯងទេ ២៤គឺសំរាប់យើងរាល់គ្នាដែរ[ថ]
សេចក្ដីសុចរិតនោះ នឹងបានរាប់ដល់យើងរាល់គ្នាជាពួក
អ្នកជឿដល់ព្រះអង្គ[ទ] ដែលទ្រង់ប្រោសព្រះយេស៊ូវជាព្រះ
អម្ចាស់នៃយើងរាល់គ្នា ឱ្យបានរស់ពីស្លាប់ឡើងវិញ[ធ]
២៥ដែលទ្រង់ត្រូវគេបញ្ជូនទៅឱ្យមានទោស ដោយព្រោះ
អំពើរំលងរបស់យើងរាល់គ្នា[ន] ហើយបានប្រោសឱ្យមាន
ព្រះជន្មរស់ឡើងវិញ ប្រយោជន៍ឱ្យយើងរាល់គ្នាបានរាប់
ជាសុចរិត[ប] ។

## សេចក្ដីសុខសាន្ត និងសេចក្ដីអំណរ

**៥** ១ដូច្នេះ ដែលយើងរាល់គ្នាបានរាប់ជាសុចរិត[ផ] ដោយ
ការជឿ[ព] នោះឈ្មោះថាយើងបានមេត្រី[ភ]នឹងព្រះ ដោយ

**៤:១៦** គ ខ.១១ លក ៣:៨ កទ ៣:១៦ **៤:១៧** ឃ លប ១៧:៥ ង យហ ៥:២១ ច អស ៤៨:១៣ ឆ ១កថ ១:២៨ **៤:១៨** ជ ខ.១៧ ឈ លប ១៥:៥ **៤:១៩** ញ ហព ១១:១១,១២ ដ លប ១៧:១៧ ឋ លប ១៨:១១ **៤:២០** ឌ ១សយ ៣០:៦ ឍ មថ ៩:៨ **៤:២១** ណ លប ១៨:១៤ មថ ១៩:២៦ **៤:២២** ត ខ.៣ **៤:២៤** ថ ទជ ១០២:១៨ ហព ២:២ រម ១៥:៤ ១កថ ៩:១០ ១០:១១ ២ធថ ៣:១៦,១៧ ទ រម ១០:៩ ១ពត ១:២១

ធ កថ ២:២៤ **៤:២៥** ន អស ៥៣:៥,៦ រម ៥:៦,៨ ៨:៣២ ២កថ ៥:២១ ប អស ៥៣:១១ រម ៣:២៤ ៥:១ ៩,១៦,១៨ ៨:៣០ ១កថ ៦:១១ ២កថ ៥:១៥ **៥:១** ផ រម ៤:២៥ ព រម ៣:២៨ ភ លក ២:១៤

បរិស័ទដែលជាសាសន៍យូដា ។ ពូជដែលអាងសេចក្ដីជំនឿរបស់លោកអ័ប្រាហាំ សំដៅលើគ្រីស្ទបរិស័ទ សាសន៍ដទៃដែលចូលចិត្តលោកអ័ប្រាហាំ តែមិនមែនជាអ្នកកាន់តាមក្រិត្យវិន័យ ។

**៤:១៧** *នៅចំពោះព្រះ* ពាក្យនេះមានន័យថាព្រះបានចាត់ទុកលោកអ័ប្រាហាំជាឪពុកលើសាសន៍យូដានិងសាសន៍ដទៃដូចគ្នា ដោយមិនប្រកាន់សាសន៍ណានោះឡើយ ។ *ទ្រង់ប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញ* ចំណុចនេះគឺទាក់ទងយ៉ាងខ្លាំងពីកំណើតអ៊ីសាក តាមរយៈលោកអ័ប្រាហាំ និងនាងសារ៉ាក្នុងកាលដែលអ្នកទាំងពីរនេះមានវ័យចំណាស់ពុំអាចមានកូននោះទៅហើយ (លប ១៨:១១)។ មួយទៀតគឺទាក់ទងនឹងការរស់ឡើងវិញរបស់ព្រះគ្រីស្ទនោះផងដែរ (ខ.២៤–២៥ និងការពន្យល់)។ *មានបន្ទូលពីរបស់ដែលគ្មាន ទុកដូចជាមានហើយ* ព្រះអម្ចាស់ទ្រង់មានសមត្ថភាពបង្កើតពីកន្លែងទទេ ឬគ្មានអ្វីសោះនោះបានដូចជាព្រះអម្ចាស់បង្កើតអ៊ីសាកនោះជាដើម ។

**៤:១៨** *អស់ទីសង្ឃឹម . . . តែជឿដោយសង្ឃឹមវិញ* វគ្គនេះចង់ប្រាប់ថា នៅពេលលោកអ័ប្រាហាំអស់សង្ឃឹមក្នុងឋានៈគាត់ជាមនុស្សលោកនោះគាត់នៅតែមានសេចក្ដី សង្ឃឹមលើព្រះអម្ចាស់ដោយជំនឿរបស់គាត់ ។

**៤:១៩** *មិនខ្សោយខាងសេចក្ដីជំនឿ* តាមបទគម្ពីរយើងឃើញថាលោកអ័ប្រាហាំក៏មានសេចក្ដីខ្វល់ខ្វាយមួយភ្លែតៗដែរ (លប ១៧:១៧–១៨) តែព្រះអម្ចាស់ទ្រង់មិនបានរាប់ការនេះជាការប្រឆាំងនឹងទ្រង់នោះទេ ។ *រាប់ដូចជា* មានន័យថាសេចក្ដីជំនឿមិនមែនរត់គេចពីការប្រឈរមុខនឹងសេចក្ដីពិតនោះទេ តែគឺជាការសម្លឹងមើលគ្រប់ការ លំបាកទាំងឡាយដោយតម្រង់ឆ្ពោះទៅរកព្រះ និងសេចក្ដីសន្យារបស់ទ្រង់វិញ ។ *ផ្ទៃ សារ៉ា ដែលរាប់ដូចជាស្លាប់* មានន័យថា នាងជាស្ត្រីអារ តាមធម្មតាពុំអាចមានកូនបានឡើយ ហើយវ័យក៏ចាស់ហួសក្នុងការដែលមានកូនទៅហើយដែរ (លប ១៧:១៧)។

**៤:២០** *សរសើរដំកើនដល់ព្រះ* ពាក្យនេះនៅក្នុងភាសាផ្សេងៗមួយចំនួនប្រើពាក្យថា "ថ្វាយសិរីល្អដល់ព្រះ" លោកអ័ប្រាហាំមានជំនឿជឿថា ព្រះអម្ចាស់នឹងធ្វើតាមការសន្យារបស់ទ្រង់ ។ ចំណុចនេះវាខុសគ្នាស្រឡះទៅនឹងការប្រព្រឹត្តរបស់មនុស្សដែលព្យាយាមធ្វើឱ្យសម្រេចនូវអ្វីដែលព្រះអម្ចាស់បានសន្យានោះ ។ ដូច្នេះការដែលមានជំនឿជឿទុកចិត្តលើទ្រង់ នោះហើយជាការថ្វាយសិរីល្អដល់ព្រះអម្ចាស់នៃយើង ។

**៤:២២** *ហេតុនោះបានជា* ត្រង់នេះបញ្ជាក់ថាសេចក្ដីជំនឿរបស់លោកអ័ប្រាហាំ គឺត្រូវបានគេរាប់គាត់ថាជាមនុស្សសុចរិតពីព្រោះគាត់មានសេចក្ដីជំនឿលើទ្រង់ពិតប្រាកដមួយរយភាគរយ (គាត់បានទុកចិត្តលើសេចក្ដីសន្យារបស់ព្រះអម្ចាស់ទាំងស្រុង)។

**៤:២៣** *មិនចែងទុកមកសំរាប់លោកតែឯងទេ* ឃ្លានេះចង់ប្រាប់យើងថាដោយយោងតាមបទពិសោធន៍របស់លោកអ័ប្រាហាំនោះគឺ គាត់ត្រូវបានរាប់ជាសុចរិត ដោយសារសេចក្ដីជំនឿដ៏ពិតលើព្រះអម្ចាស់ ។ បើដូច្នេះ នោះមនុស្សទាំងឡាយណាដែលមានសេចក្ដីជំនឿលើព្រះអម្ចាស់ដ៏ពិតដូចជាគាត់ នោះក៏ត្រូវបានរាប់ជាសុចរិតដែរ ។

**៤:២៤** *គឺសំរាប់យើងរាល់គ្នាដែរ* ខនេះប្រាប់យើងថា គ្រីស្ទបរិស័ទសព្វថ្ងៃក៏ដូចគ្នានឹងលោកអ័ប្រាហាំនៅសម័យមុនដែរ ។ លោកអ័ប្រាហាំត្រូវបានរាប់ជាសុចរិតដោយសារ គាត់ជឿលើព្រះមួយអង្គដែលបានលោះជីវិតគាត់ពីសេចក្ដីស្លាប់ ។ ដូច្នេះយើងក៏ត្រូវបានរាប់ជាសុចរិតដោយសារយើងជឿលើព្រះដែលបានប្រោសព្រះយេស៊ូវ ជាព្រះអម្ចាស់នៃយើងឱ្យរស់ពីសុគតឡើងវិញនោះផងដែរ (១០:៩ និងការពន្យល់)។

**៤:២៥** នៅក្នុងខនេះលោកប៉ុលបានដកស្រង់ចេញពី អស ៥៣:១២ ជាភាសាក្រិក។ *រាប់ជាសុចរិត* មើលការពន្យល់ ៣:២៤ ។

**៥:១** *មេត្រីនឹងព្រះ* មានន័យដូចគ្នានឹងពាក្យ"សន្តិភាពនឹងព្រះ"។ ចំណុចនេះពុំមែនជាគំនិត ឬអារម្មណ៍ផ្តាច់មុខរបស់បុគ្គលណាមួយនោះទេ តែវាជាទិសដៅ

សារព្រះយេស៊ូវគ្រីស្ទ[ម] ជាព្រះអម្ចាស់នៃយើងរាល់គ្នា
ហើយ ២ក៏ដោយសារទ្រង់ យើងមានផ្លូវ[យ]ចូលក្នុងព្រះគុណ
នេះ ជាទីដែលយើងកំពុងឈរ[រ] នៅដោយសេចក្ដីជំនឿ
ហើយយើងអួតពីសេចក្ដីសង្ឃឹម[ល]ដល់សិរីល្អនៃព្រះផង
៣មិនតែប៉ុណ្ណោះសោត យើងនៅតែអួតក្នុងកាលដែលមាន
ទុក្ខលំបាកដែរ[វ] ដោយដឹងថា សេចក្ដីទុក្ខលំបាកបង្កើតឱ្យ
មានសេចក្ដីទ្រាំទ្រ[ស] ៤សេចក្ដីទ្រាំទ្របង្កើតឱ្យមានសេចក្ដី
ស៊ាំថ្មីក សេចក្ដីស៊ាំថ្មីកបង្កើតឱ្យមានសេចក្ដីសង្ឃឹម ៥ឯ
សេចក្ដីសង្ឃឹម[ហ]ក៏មិនដែលនាំឱ្យមានសេចក្ដីខ្មាសឡើយ
ពីព្រោះសេចក្ដីស្រឡាញ់[ឡ]របស់ព្រះ បានផ្សាយមកសព្វក្នុង
ចិត្តយើងរាល់គ្នា ដោយសារព្រះវិញ្ញាណបរិសុទ្ធ[អ] ដែល
ព្រះបានប្រទានមកយើងហើយ ។
៦ដ្បិតកាលយើងនៅខ្សោយនៅឡើយ[ក] លុះដល់កំណត់
ហើយ[ខ] នោះព្រះគ្រីស្ទទ្រង់បានសុគតជំនួស មនុស្សទមិឡ
ល្មើស[គ] ៧កម្រនឹងមានអ្នកណាព្រមស្លាប់ជំនួសមនុស្ស
សុចរិតណាស់ ប៉ុន្តែប្រហែលជាមានអ្នកខ្លះហ៊ានស្លាប់
ជំនួសមនុស្សល្អដែរទេដឹង ៨តែឯព្រះ ទ្រង់សំដែងសេចក្ដី
ស្រឡាញ់របស់ទ្រង់ ដល់យើងរាល់គ្នាឱ្យឃើញច្បាស់
ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុង
កាលដែលយើងនៅមានបាបនៅឡើយផង[ឃ]។
៩ដូច្នេះ ដែលបានរាប់ជាសុចរិត[ង] ដោយសារព្រះ
លោហិត[ច]ទ្រង់ នោះប្រាកដជាយើងនឹងបានរួចចេញពី
សេចក្ដីក្រោធ[ឆ] ដោយសារទ្រង់ជាមិនខានលើសទៅទៀត
១០ដ្បិតកាលយើងជាខ្មាំងសត្រូវ[ជ] បើយើងបានជាមេត្រី[ឈ]នឹង
ព្រះវិញទៅហើយ ដោយព្រះរាជបុត្រាទ្រង់សុគត ដូច្នេះ

**៥:១** ម ខ.១០ **៥:២** យ អភ ២:១៨ ៣:១២ រ ១កថ ១៥:១ ល ហព ៣:៦ **៥:៣** វ មថ ៥:១២ ស ហព ១០:៣៦ **៥:៥** ហ ភល ១:២០ ហព ៣:៦ ១យហ ៣:២,៣ ឡ ខ.៨ យហ ៣:១៦ រម ៨:៣៩ អ កច ២:៣៣ ១០:៤៥ ទត ៣:៥,៦ **៥:៦** ក ខ.៨,១០ ខ មក ១:១៥ កទ ៤:៤ អភ ១:១០ គ រម ៤:២៥ **៥:៨** ឃ យហ ៣:១៦ ១៥:១៣ ១ពត ៣:១៨ ១យហ ៣:១៦ ៤:១០ **៥:៩** ង រម ៤:២៥ ច រម ៣:២៥ ឆ រម ១:១៨ **៥:១០** ជ រម ១១:២៨ កល ១:២១ ឈ ខ.១១ រម ១១:១៥ ២កថ ៥:១៨,១៩ កល ១:២០,២២

សំខាន់មួយដែលឆ្លោះតម្រង់ទៅរកភាពទំនាក់ទំនងជាមួយនឹងព្រះឡើងវិញ ។ កាលមុនយើងជាសត្រូវ តែឥឡូវនេះយើងជាមិត្តរបស់ទ្រង់(មើលខ.១០ អភ ២:១៦ កល ១:២១–២២)។

**៥:២** *ផ្លូវចូល* ព្រះយេស៊ូវជាផ្លូវនាំយើងចូលទៅឯព្រះវត្តមានព្រះ ។ វាំងននដ៏ក្រាស់របស់ព្រះវិហារដែលបានឃាំងយើងនឹងព្រះ និងឃាំងព្រះនឹងយើងនោះបានរហែកហើយ នៅពេលទ្រង់បានសុគតនោះ(មថ ២៧:៥១ ហព ១០:១៩–២២)។ *សេចក្ដីសង្ឃឹមដល់សិរីល្អនៃព្រះ* មានន័យថាយើងថ្វាយសេចក្ដីទុកចិត្តរបស់យើងទៅលើ ព្រះអម្ចាស់ដែលទ្រង់បានបង្កើតយើងរាល់គ្នាមក (មើលការពន្យល់ ៣:២៣)។

**៥:៣** *អួតក្នុងកាលដែលមានទុក្ខលំបាក* ត្រង់នេះលោកប៉ុលពុំមែនគាំទ្រនូវភាពឈឺចាប់លើរាងកាយនោះទេ តែមានអំណរនិងជ័យជម្នះ(យក ១:២ និងពន្យល់)។

**៥:៤** គ្រីស្ទបរិស័ទអាចមានអំណរនៅក្នុងសេចក្ដីទុក្ខលំបាក ពីព្រោះពួកគេបានដឹងយ៉ាងច្បាស់ថា ការរងទុក្ខនេះពុំមែនឥតប្រយោជន៍នោះទេ ។ មួយផ្នែកនៃបំណងព្រះហឫទ័យព្រះនោះគឺ បង្កើនការស៊ាំថ្មីកដល់រាស្ត្ររបស់ទ្រង់(យក ១:៣)។

**៥:៥** *សេចក្ដីសង្ឃឹមក៏មិនដែលនាំឱ្យមានសេចក្ដីខ្មាសឡើយ* ឬអាចថា សេចក្ដីសង្ឃឹមមិនដែលនាំឱ្យមានសេចក្ដីខកចិត្តឡើយ ។ សេចក្ដីសង្ឃឹមរបស់អ្នកជឿគឺមិនមែនជាសុទិដ្ឋិនិយមដែលគ្មានហេតុផលនោះទេ ។ តែផ្ទុយទៅវិញនេះគឺជាព្រះពរដែលមានការអះអាងនៃគោលដៅអនាគតរបស់យើង ដោយពឹងផ្អែកលើសេចក្ដីស្រឡាញ់របស់ព្រះ បានបើកសម្ដែងឱ្យយើងឃើញតាមរយៈព្រះវិញ្ញាណបរិសុទ្ធក្នុងកាលដែលព្រះអម្ចាស់បានប្រោសប្រទានឱ្យព្រះគ្រីស្ទរស់ឡើងវិញ ។ លោកប៉ុលបង្វែរពីសេចក្ដីជំនឿ(ខ.១) ទៅសេចក្ដីសង្ឃឹម(ខ.២,៤–៥)ទៅសេចក្ដីស្រឡាញ់ (១កថ ១៣:១៣ ១ថន ១:៣ និងការពន្យល់)។ *បានផ្សាយមក* ពាក្យនេះជាកិរិយាសព្ទបញ្ជាក់ពីស្ថានភាពនៃលទ្ធផលនាពេលបច្ចុប្បន្ន ដែលបានមកពីទង្វើក្នុងអតីតកាល ។ នៅពេលដែលយើងបានទទួលជឿព្រះគ្រីស្ទលើកដំបូង នោះព្រះវិញ្ញាណបរិសុទ្ធបានបង្ហូរសេចក្ដីស្រឡាញ់របស់ទ្រង់មកក្នុងដួងចិត្តរបស់យើងម្នាក់ៗ ហើយសេចក្ដីស្រឡាញ់នេះបានបន្តនៅក្នុងយើងជារហូតតទៅ ។ *ព្រះបានប្រទានមកយើងហើយ* មានន័យថាអ្នកដែលជឿលើព្រះយេស៊ូវពិតប្រាកដនោះនឹងមានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ(៨:៩ និងការពន្យល់)។

**៥:៦** *ដល់កំណត់* ចង់សំដៅពីខណៈពេលកំណត់មួយនៅក្នុងផែនការប្រោសលោះរបស់ព្រះអម្ចាស់(មក ១:១៥ និងការពន្យល់)។ *ព្រះគ្រីស្ទទ្រង់បានសុគតជំនួស មនុស្សទមិលល្មើស* មានន័យថាសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទគឺបាន ដាំជាប់នៅក្នុងព្រះគុណរបស់ព្រះជាម្ចាស់សម្រាប់ប្រទានដល់មនុស្សដោយទទេ ហើយពុំដែលឃើញបុគ្គលណាមួយមានសេចក្ដីស្រឡាញ់ ដូច្នេះឡើយនៅលើលោកនេះ ។

**៥:៧** *មនុស្សសុចរិត . . . មនុស្សល្អ* ត្រង់នេះចង់បញ្ជាក់ថា យើងទាំងអស់គ្នាមិនមែនជាមនុស្សសុរិត មនុស្សល្អ ប៉ុន្តែជាមនុស្សមានបាបវិញ បានជាព្រះគ្រីស្ទទ្រង់ សុគតជំនួសយើងរាល់គ្នា(ខ.៨, ៣:១០–១២)។

**៥:៩** *ដោយសារព្រះលោហិតទ្រង់* គឺចង់បញ្ជាក់ពីការដែលព្រះយេស៊ូវលះបង់ព្រះជន្មទ្រង់ធ្វើជាយញ្ញបូជាសម្រាប់លោះយើងទាំងអស់គ្នាឱ្យរួចពីអំពើបាប (មើលការពន្យល់ ៣:២៥)។ *សេចក្ដីក្រោធ* នេះគឺជាសេចក្ដីក្រោធរបស់ព្រះអម្ចាស់នៅថ្ងៃជំនុំជម្រះចុងក្រោយរបស់ទ្រង់(មើលការពន្យល់ ១:១៨ និង ១ថន ១:៩–១០) ប៉ុន្តែ អស់អ្នកដែលទទួលជឿព្រះយេស៊ូវ នោះប្រាកដជាបានរួចពីសេចក្ដីក្រោធ ។

**៥:១០** *កាលយើងជាខ្មាំងសត្រូវ* មនុស្សលោកគឺជាខ្មាំងសត្រូវនឹងព្រះ តែពុំមែនមិនអាចត្រូវគ្នាវិញបាននោះទេ ។ ដូច្នេះភាពប្រទូសរ៉ាយគ្នានេះនឹងរលាយបាត់ទៅនៅពេលការផ្សះផ្សាមួយបានចប់សព្វគ្រប់ ។ ព្រះអម្ចាស់ទ្រង់បានចាប់ផ្ដើមដំបូង តាមរយៈការសុគតនៃព្រះរាជបុត្រារបស់ទ្រង់(ខ.១១ កល ១:២១–២២ និងការ ពន្យល់ ១:២០)។ *បានជាមេត្រី* មានន័យថាបានផ្សះផ្សា បានសម្រុះសម្រួល ចង់បញ្ជាក់ថា ភាពប្រទូសរ៉ាយគ្នាបានចប់ហើយ ។ ពាក្យនេះក៏មានន័យទាក់ទងយ៉ាងខ្លាំងទៅនឹងពាក្យថា "រាប់ជាសុចរិត"ផងដែរ ដូចជាពាក្យស្រប នៅក្នុងខ.៩–១០ ។

| | |
|---|---|
| ខ.៩ | ខ.១០ |
| បានរាប់ជាសុរិត | បានជាមេត្រី |

ដែលយើងបានជាមេត្រីហើយ នោះប្រាកដជាយើងនឹង
បានសង្គ្រោះជាមិនខានលើសទៅទៀត ដោយទ្រង់មាន
ព្រះជន្មរស់ឡើងវិញ[ញ] ១១ហើយមិនតែប៉ុណ្ណោះសោត យើង
ក៏មានសេចក្ដីរីករាយចំពោះព្រះផង ដោយនូវព្រះយេស៊ូវ
គ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលឥឡូវនេះយើង
បានជាមេត្រីដោយសារទ្រង់ហើយ[ដ]។

## សេចក្ដីស្លាប់តាមរយៈអ័ដាម ឯជីវិតតាមរយៈព្រះគ្រីស្ទ

១២ដូច្នេះ ដែលបាបបានចូលមកក្នុងលោកីយ ដោយ
សារមនុស្សតែម្នាក់[ឋ] ហើយក៏មានសេចក្ដីស្លាប់ចូលមកដែរ
ដោយសារអំពើបាបនោះជាយ៉ាងណា[ឌ] នោះសេចក្ដីស្លាប់
បានឆ្លងរាលដាល ដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ ដ្បិត
គ្រប់គ្នាបានធ្វើបាបហើយ[ឍ] ១៣(ព្រោះរមែងមានបាបនៅ
ក្នុងលោកីយ ដរាបដល់ក្រឹត្យវិន័យ តែកាលមិនទាន់មាន
ក្រឹត្យវិន័យនៅឡើយ នោះមិនបានរាប់ជាទោសដល់គេ
ទេ[ណ] ១៤ប៉ុន្ដែចាប់តាំងពីលោកអ័ដាម ដរាបដល់លោក
ម៉ូសេ នោះសេចក្ដីស្លាប់បានសោយរាជ្យ លើទាំងពួកអ្នក
ដែលធ្វើបាប មិនមែនដូចជាអំពើរំលងរបស់លោកអ័ដាម
ផង[ត] ដែលលោកជាគំរូពីព្រះអង្គដែលត្រូវយាងមក[ថ]។

១៥ប៉ុន្ដែ ព្រះគុណមិនមែនដូចជាអំពើរំលងនោះទេ
ដ្បិតបើសិនជាមានមនុស្សជាច្រើនបានស្លាប់ ដោយព្រោះ
អំពើរំលងរបស់មនុស្សតែម្នាក់[ទ] នោះប្រាកដជាព្រះគុណ
នៃព្រះ ហើយនឹងអំណោយទាននៃព្រះគុណនោះ ដែលមក
ដោយសារមនុស្សតែម្នាក់ គឺព្រះយេស៊ូវគ្រីស្ទ[ធ] នឹងបាន
ចំរើនលើសទៅទៀត ដល់មនុស្សជាច្រើនដែរ ១៦ហើយ
អំណោយទាននោះ ក៏មិនមែនដូចជាអំពើបាប ដែលមនុស្ស
តែម្នាក់បានធ្វើនោះទៀត ដ្បិតសេចក្ដីជំនុំជំរះ ដែលកើត
មកដោយព្រោះម្នាក់នោះឯង នោះបានកាត់ទោសហើយតែ
ព្រះគុណ ដែលកើតមកដោយព្រោះការរំលងជាច្រើននោះ
បានរាប់យើងទុកជាសុចរិតវិញ ១៧ដ្បិត បើសិនជា សេចក្ដី
ស្លាប់[ន]បានសោយរាជ្យ ដោយសារមនុស្សតែម្នាក់ ដោយ
ព្រោះម្នាក់នោះឯងបានប្រព្រឹត្តសេចក្ដីរំលង ដូច្នេះ ប្រាកដ
ជាពួកអ្នកដែលទទួលព្រះគុណដ៏បរិបូរ នឹងអំណោយទានជា
សេចក្ដីសុចរិត នោះនឹងបានសោយរាជ្យក្នុងជីវិត[ប] លើស
ទៅទៀត ដោយសារតែម្នាក់ដែរ គឺជាព្រះយេស៊ូវគ្រីស្ទ)

**៥:១០** ញ រម ៨:៣៤ ហព ៧:២៥
**៥:១១** ដ ខ.១០
**៥:១២** ឋ ខ.១៥,១៦, ១៧ លប ៣:១–៧ ១កថ ១៥:២១,២២ ឌ ខ.១៤,១៨ លប ២:១៧ ៣:១៩ រម ៦:២៣ ឍ រម ៣:៩
**៥:១៣** ណ រម ៤:១៥
**៥:១៤** ត លប ៣:១១,១២ ថ ១កថ ១៥:២២,៤៥
**៥:១៥** ទ ខ.១២,១៨, ១៩ ធ កថ ១៥:១១
**៥:១៧** ន ខ.១២ ប យហ ១០:១០

| | |
|---|---|
| ដោយសារព្រះលោហិត | ដោយព្រះរាជបុត្រាទ្រង់សុគត |
| នោះប្រាកដជាយើង នឹងបាន | នោះប្រាកដជាយើងនឹងបានសង្គ្រោះ |
| រួចចេញពីសេចក្ដីក្រោធ | |

*បានសង្គ្រោះ . . . ដោយទ្រង់មានព្រះជន្មរស់ឡើងវិញ* ឃ្លានេះគឺទាក់ទងទៅនឹងគម្ពីរ ហព ៧:២៥។ ត្រង់នេះមានន័យថា ព្រះគ្រីស្ទយេស៊ូវទ្រង់នឹងអាចជួយសង្គ្រោះសព្វគ្រប់បានដល់មនុស្សទាំងអស់ ដែលចូលទៅឯព្រះវរបិតាដោយសារទ្រង់ ដ្បិតទ្រង់មានព្រះជន្មរស់នៅជានិច្ច ហើយព្រះរាជកិច្ចទ្រង់ក៏មានជានិច្ចផងដែរ ។

**៥:១១** *យើងបានជាមេត្រីដោយសារទ្រង់ហើយ* ពាក្យថាបានជាមេត្រីមានន័យដូច នឹងពាក្យ បានរាប់ជាសុចរិតនោះដែរ (ខ.១) ។ នេះគឺជាសេចក្ដីពិតហើយនិងសេចក្ដីអំណររបស់គ្រីស្ទបរិស័ទ (កល ១:២០) ។

**៥:១២–២១** នៅក្នុងវគ្គនេះជាផ្ទៃរឿងផ្ទុយគ្នាទាំងស្រុង រវាងលោកអ័ដាម និងព្រះយេស៊ូវគ្រីស្ទ ។ លោកអ័ដាមបាននាំមកនូវអំពើបាប ហើយនិងសេចក្ដីស្លាប់មកក្នុងលោកីយ តែព្រះយេស៊ូវគ្រីស្ទទ្រង់នាំមកនូវសេចក្ដីសុចរិត ហើយនិងជីវិត ។ ការប្រៀបធៀបតួអង្គនេះបានចាប់ផ្ដើមពី ខ.១២ ហើយបញ្ចប់ទៅវិញក្នុងខ.១៨ ហើយខទាំងពីរនេះ ក៏ជាខសង្ខេបនៅត្រង់វគ្គនេះផងដែរ ។ តួអង្គទាំងពីរនេះ ជាការបូកសរុបសេចក្ដីនៅក្នុងវគ្គដំបូងនៃគម្ពីររ៉ូម ដែលពណ៌នាអំពីលោកអ័ដាមជាតួអង្គតំណាងពីការផ្ដន្ទាទោស (១:១៨–៣:២០) រីឯព្រះគ្រីស្ទយេស៊ូវវិញ នោះជាតួអង្គតំណាងពីសេចក្ដីសុចរិតរបស់អ្នកជឿ (៣:២១–៥:១១) ។

**៥:១២** *សេចក្ដីស្លាប់* ពាក្យនេះសំដៅលើសេចក្ដីស្លាប់ខាងឯរូបកាយ ដែលជាលទ្ធផល (ទោស) នៃអំពើបាប ហើយនេះក៏បញ្ជាក់ពីការដាច់ចេញពីព្រះផងដែរ (វវ ២០:១៥, ២១:៨) ។ *ដ្បិតគ្រប់គ្នាបានធ្វើបាប* ពាក្យនេះមិនមែនជាការនិយាយស្ទួននឹងពាក្យនៅក្នុង ៣:២៣ នោះទេ ។ អត្ថន័យនៅក្នុងឃ្លានេះចង់ប្រាប់យើងថា អំពើបាបរបស់អ័ដាមតែម្នាក់ធ្វើឱ្យមនុស្សទាំងអស់ត្រូវទទួលទោសវិញ (ខ.១៨–១៩) ហើយនិងត្រូវស្លាប់ផង (ខ.១៥) ។ យើងទាំងអស់គ្នាពុំបានចាប់កំណើតមក ក្នុងជីវិតមួយដែលគ្មានបាបនោះឡើយ គឺយើងចាប់កំណើតមកជាមួយនឹងអំពើបាប តាំងពីដំបូងមកម្ល៉េះ (លប ៨:២១ ទដ ៥១:៥ ៥៨:៣ និងការពន្យល់ អភ ២:៣) ។

**៥:១៣** *មិនបានរាប់ជាទោសដល់គេទេ* ឃ្លានេះមានន័យថា ក្នុងពេលដែលគ្មានក្រិត្យវិន័យ (របស់លោកម៉ូសេ) ពួកបណ្ដាជនពុំបានរាប់ថាជាអ្នកមានទោស ដោយប្រព្រឹត្តរំលងក្រិត្យវិន័យនោះឡើយ (ខ.១៤) ។

**៥:១៤** *គំរូ* អំពើបាបរបស់លោកអ័ដាមបាននាំមកនូវសេចក្ដីហិនវិនាសដល់មនុស្សពេញទាំងពិភពលោក ។ នៅក្នុងទង្វើបែបនេះហើយបានជាគាត់ត្រឡប់ជាគំរូដើម ដែលតម្រូវឱ្យព្រះគ្រីស្ទជាព្រះដ៏សុចរិតមួយអង្គត្រូវយាងមក (ខ.១៨) ដើម្បីនាំ ព្រះពរមកដល់មនុស្សពេញទាំងពិភពលោក (មានសភាពដូចគ្នា តែន័យផ្ទុយគ្នា) ។

**៥:១៥** *មនុស្សជាច្រើន* គឺសំដៅលើមនុស្សទាំងអស់ (ខ.១២ ៥៣:១១ មក ១០:៤៥) *បានចំរើនលើសទៅទៀត* ពាក្យនេះបញ្ជាក់ពីអត្ថន័យក្នុងវគ្គនេះថា ព្រះគុណដ៏ធំមហិមាសម្រាប់ការល្អរបស់ព្រះ គឺធំលើសជាងអំពើបាបរបស់លោកអ័ដាម សម្រាប់ការអាក្រក់នោះទៅទៀត ។

**៥:១៦** *អំណោយទាន* នេះគឺជាអំណោយទាននៃសេចក្ដីសង្គ្រោះរបស់ព្រះអម្ចាស់ ។ *ការរំលងជាច្រើន* គឺជាអំពើបាបទាំងឡាយណាដែលចេះ តែបន្តដល់កូនចៅជំនាន់ក្រោយៗទៀត ។

**៥:១៧** *នឹង . . . សោយរាជ្យក្នុងជីវិតលើសទៅទៀត* នេះគឺនិយាយពីការសោយរាជ្យរបស់អ្នកជឿជាមួយនឹងព្រះយេស៊ូវគ្រីស្ទនាពេលអនាគតកាល

១៨ដូច្នេះ ដែលមនុស្សទាំងអស់ត្រូវទោស[ផ]ដោយព្រោះ
អំពើរំលងតែ១ នោះមនុស្សទាំងអស់ក៏បានរាប់ជាសុចរិត[ព]
ឱ្យបានជីវិតវិញ[ភ] ដោយសារអំពើសុចរិតតែ១ បែបដូច្នោះ
ដែរ ១៩ដ្បិតដូចជាមនុស្សជាច្រើន បានត្រឡប់ជាមាន
បាប[ម]ដោយសារមនុស្សតែម្នាក់[យ]មិនបានស្តាប់បង្គាប់ជា
យ៉ាងណា នោះមនុស្សជាច្រើន ក៏បានត្រឡប់ជាសុចរិត
ដោយសារ ម្នាក់បានស្តាប់បង្គាប់[រ]វិញយ៉ាងនោះដែរ
២០តែក្រឹត្យវិន័យបានចូលមកថែមទៀត ដើម្បីឱ្យសេចក្ដី
រំលងនោះបានរីតតែធ្ងន់ឡើង[ល] ប៉ុន្តែ កន្លែងណាដែល
មានបាប ចំរើនជាបរិបូរឡើង នោះព្រះគុណក៏ចំរើនជា
បរិបូរលើសទៅទៀត[វ] ២១ដើម្បីឱ្យព្រះគុណ[ស]បានសោយ
រាជ្យ ដោយសារសេចក្ដីសុចរិត សំរាប់ជាជីវិតអស់កល្បជា
និច្ច[ហ]ដោយនូវព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើងរាល់
គ្នា ដូចជាបាបបានសោយរាជ្យឱ្យត្រូវស្លាប់[ឡ]ពីដើមនោះ
ដែរ ។

**៥:១៨** ផ ខ.១២
ព រម ៤:២៥
ភ អស ៥៣:១១
**៥:១៩** ម រម ៣:៩
យ ខ.១២
រ ភល ២:៨
**៥:២០** ល រម ៣:២០
៧:៧,៨ កទ ៣:១៩
វ រម ៦:១
១ធថ ១:១៣,១៤
**៥:២១** ស រម ៣:២៤
ហ មថ ២៥:៤៦
ឡ ខ.១២,១៤
រម ៦:១៦

**៦:១** អ រម ៨:៣១
ក ខ.១៥ រម ៣:៥,៨
**៦:២** ខ ខ.៦ ខ.១០,១១
ខ.១៨ រម ៨:១៣
កល ៣:៣,៥
១ពត ២:២៤

## ស្លាប់ខាងឯអំពើបាប រស់ក្នុងព្រះគ្រីស្ទ

**៦** ១ដូច្នេះ យើងនឹងថាដូចម្តេច[អ] តើត្រូវឱ្យយើងចេះ
តែប្រព្រឹត្តអំពើបាបទៅទៀត ដើម្បីឱ្យព្រះគុណបានចំរើន
ឡើងឬអី[ក] ២ទេ មិនត្រូវឡើយ ធ្វើដូចម្តេចឱ្យយើងដែល
ស្លាប់ខាងឯអំពើបាបហើយ[ខ]បាននៅរស់ក្នុងអំពើបាបទៀត
បាន ៣តើអ្នករាល់គ្នាមិនដឹងទេឬអី ថា យើងទាំងប៉ុន្មាន
ដែលបានទទួលបុណ្យជ្រមុជ[គ] ក្នុងព្រះយេស៊ូវគ្រីស្ទ នោះគឺ
បានទទួលជ្រមុជ ក្នុងសេចក្ដីសុគតនៃទ្រង់ដែរ ៤ដូច្នេះ
យើងបានត្រូវកប់ជាមួយនឹងទ្រង់ហើយ ដោយទទួលជ្រមុជ
ក្នុងសេចក្ដីស្លាប់[ឃ] ដើម្បីឱ្យយើងបានដើរក្នុងជីវិតបែបថ្មី
ដូចជាព្រះគ្រីស្ទបានរស់ពីស្លាប់ឡើងវិញ[ង]ដោយសារសិរីល្អ
នៃព្រះវរបិតាដែរ[ច] ៥ដ្បិតបើយើងបានជាប់ជាមួយនឹង
ទ្រង់ ក្នុងការដែលជាគំរូពីសេចក្ដីសុគតរបស់ទ្រង់ នោះ
ក៏នឹងបានជាប់ក្នុងសេចក្ដីរស់ឡើងវិញរបស់ទ្រង់ដែរ[ឆ]

**៦:៣** គ មថ ២៨:១៩ **៦:៤** ឃ ខ.៦ ង កច ២:២៤ ច រម ៧:៦ ២កថ ៥:១៧ អភ ៤:២២–២៤ កល ៣:១០

(មើលការ ពន្យល់ ២ធថ ២:១២ វវ ២០:៤,៦ ២២:៥) ។

**៥:១៨** *មនុស្សទាំងអស់ . . . ឱ្យបានជីវិត* ឃ្លានេះបានបញ្ជាក់ថា សេចក្ដីសង្គ្រោះនៃព្រះអម្ចាស់បានប្រទានឱ្យមនុស្សគ្រប់គ្នាទាំងអស់(១យហ ២:២ និងការពន្យល់)តែអ្នកនោះត្រូវទទួលព្រះគុណនៃព្រះអម្ចាស់នេះជាអំណោយរៀងៗខ្លួន(ខ.១៧)។

**៥:១៩** *បានត្រឡប់ជាសុចរិត* នេះគឺជាការបញ្ជាក់ពីវត្តមានរបស់មនុស្សនៅចំពោះព្រះភក្ត្រទ្រង់(ខ.១៧, ២កថ ៥:២១ និងការពន្យល់) ពុំមែនជាការផ្លាស់ប្តូរបុគ្គលិកលក្ខណៈរបស់មនុស្សនោះទេ ។ តែទោះបីជាយ៉ាងណាមានពន្យល់បន្ថែមក្នុងជំពូក ៦–៨ ពីការរាប់ជាសុចរិតនេះ ។

**៥:២០** *ក្រិត្យវិន័យបានចូលមកថែមទៀត* ត្រង់នេះបញ្ជាក់ថាក្រិត្យវិន័យពុំបាននាំមកនូវសេចក្តីប្រោសលោះនោះទេ វាគ្រាន់តែបានបង្ហាញពីកំហុស តែប៉ុណ្ណោះ ។ ក្រឹត្យវិន័យ បានធ្វើឱ្យមានបាបកាន់តែធ្ងន់ឡើងថែមទៀត ដោយការបើកសំដែងពីការអាក្រក់របស់វាដែលផ្ទុយទៅនឹងភាពបរិសុទ្ធរបស់ព្រះ

**៦:១–៨:៣៩** នៅក្នុងជំពូក ៣:២១–៥:២១ លោកប៉ុលបានពន្យល់នូវរបៀបដែលព្រះអម្ចាស់ប្រទានសេចក្តីប្រោសលោះ និងសេចក្តីសុចរិតដល់យើង ។ បន្ទាប់មកគាត់បានពន្យល់ពីគោលលទ្ធិនៃការរាប់ជាសុចរិត និងដំណើររបស់វា ដែលអ្នកជឿទាំងអស់ត្រូវតែរីកចម្រើនពេញវ័យនៅក្នុងព្រះគ្រីស្ទជាអម្ចាស់ ។ លោកបានបែងចែកមេរៀននេះជាបីផ្នែកៈ (១).មានសេរីភាពពីអំណាចនៃអំពើបាប (ជំពូក ៦)។ (២).មានសិទ្ធិសេរីភាពពីការជំនុំជម្រះនៃក្រិត្យវិន័យ(ជំពូក ៧) និង(៣).ជីវិតនៅក្នុងអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ(ជំពូក ៨)។

**៦:១** *តើត្រូវឱ្យយើងចេះតែប្រព្រឹត្តអំពើបាបទៅទៀត ដើម្បីឱ្យព្រះគុណបានចំរើនឡើងឬអី?* សំណួរមួយនេះបានចោទសួរក្រោយពីលោកប៉ុលទើបបាននិយាយនៅក្នុង ៥:២០ "កន្លែងណាដែលមានបាបចម្រើនជាបរិបូរឡើង នោះព្រះគុណក៏ចម្រើន ជាបរិបូរលើសទៅទៀត"។

**៦:២** *ស្លាប់ខាងឯអំពើបាប* ការនិយាយឃ្លានេះគឺយោងតាមព្រឹត្តការណ៍ពីអតីត ហើយយកមកពន្យល់នៅក្នុង ខ.៣ ។

**៦:៣–៤** បទគម្ពីរនេះបានប្រាប់យើងពីពេលវេលា និងរបៀបនៃសេចក្តីស្លាប់ខាងឯអំពើបាបរបស់គ្រីស្ទបរិស័ទ ។ ពិធីបុណ្យជ្រមុជទឹកនៅក្នុងសម័យព្រះគម្ពីរសញ្ញាថ្មីគឺសំដែងពីការប្រែចិត្តផ្នែកខាងក្នុងគំនិត បន្ទាប់មកសំដែងចេញមកក្រៅជាពិធីបុណ្យជ្រមុជទឹកនេះឯង(កច ២:៣៨ និងការពន្យល់)។ ដូច្នេះមានន័យថា ពិធីបុណ្យជ្រមុជទឹកមិនមែនគ្រាន់តែបានឈានចូលទៅក្នុងទំនាក់ទំនងសេចក្តីជំនឿយ៉ាងរស់រវើកជាមួយព្រះយេស៊ូវប៉ុណ្ណោះទេ តែវាក៏ជាការបង្ហាញពីសេចក្តីជំនឿផងដែរ ។

ពិធីបុណ្យជ្រមុជទឹកបានពណ៌នាយ៉ាងច្បាស់នូវអ្វីដែលបានកើតឡើងជាលទ្ធផលនៃ ការរួបរួមរបស់គ្រីស្ទបរិស័ទជាមួយនឹងព្រះគ្រីស្ទដោយសេចក្តីជំនឿ ។ ហើយតាមរយៈសេចក្តីជំនឿនេះ យើងបានរួបរួមនឹងព្រះគ្រីស្ទ ដូចគ្នានឹងការដែលយើងបានទទួលអំពើបាបពីលោកអ័ដាមពីកំណើតនោះមកដែរ ។ កាលមុនយើងបានធ្លាក់ក្នុងអំពើបាប ហើយនាំទៅរកសេចក្តីស្លាប់ដោយព្ធយុកោរបស់យើង គឺលោកអ័ដាម ប៉ុន្តែ នៅពេលនេះយើងបានស្លាប់ ហើយរស់ឡើងវិញជាមួយនឹងព្រះគ្រីស្ទ ដូចដែលបានបង្ហាញជានិមិត្តរូបនៅក្នុងពិធីបុណ្យជ្រមុជទឹកនេះស្រាប់ ។

**៦:៣** *ដឹង* មានពាក្យគន្លឹះបីចេញពីក្នុងជំពូកទី៦នេះគឺ "ដឹង"(ខ.៣,៦,៩) "ប្រគល់" (១៣,១៦,១៩) ហើយនិង "ស្តាប់តាម"(ខ.១២,១៦–១៧)។

**៦:៤** *កប់ជាមួយនឹងទ្រង់ហើយ ដោយទទួលជ្រមុជក្នុងសេចក្តីស្លាប់* ឃ្លានេះបានយកមកពន្យល់បន្ថែមនៅក្នុង ខ.៥–៧ ។ *ដោយសារសិរីល្អនៃព្រះវរបិតា* ចង់បញ្ជាក់ពីអំណាចនៃព្រះអម្ចាស់ ។ សិរីល្អនៃព្រះអម្ចាស់ គឺជាភាពធំឧត្តុង្គឧត្តម និងភាពគ្រប់លក្ខណ៍របស់ទ្រង់ ។ គ្រប់ទាំងសណ្ឋានរបស់ទ្រង់ គឺជាការសំដែងនៃភាពធំឧត្តុង្គឧត្តមរបស់ទ្រង់ ។ អំណាចព្រះចេស្តារបស់ព្រះគឺជាការសំដែងនៃសិរីល្អទ្រង់ ដោយទ្រង់ជាព្រះដ៏សុចរិត (៣:២៣ និងការពន្យល់)។ សិរីល្អហើយនិងព្រះចេស្តា តែងតែមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធនៅក្នុងបទគម្ពីរ(ទដ ១៤៥:១១ កល ១:១១ ១ពត ៤:១១ វវ ១:៦ ៤:១១ ៥:១២–១៣ ៧:១២ ១៩:១)។ *ជីវិតបែបថ្មី* ពាក្យនេះយកមកពន្យល់យ៉ាងច្បាស់នៅក្នុងខ.៨–១០ ។

៦ ដោយដឹងសេចក្តីនេះថា មនុស្សចាស់របស់យើង[ជ] បាន
ត្រូវឆ្កាងជាមួយនឹងទ្រង់ហើយ[ឈ] ដើម្បីឱ្យតួអំពើបាប[ញ]
បានត្រូវសូន្យទៅ ប្រយោជន៍កុំឱ្យយើងនៅបំរើអំពើ
បាបទៀតឡើយ[ដ] ៧ ដ្បិតអ្នកណា ដែលស្លាប់ នោះក៏បាន
រាប់ជាសុចរិតរួចពីបាបហើយ[ឋ] ៨ បើសិនជាយើងស្លាប់ជា
មួយនឹងព្រះគ្រីស្ទ នោះយើងជឿថា យើងនឹងរស់ជាមួយ
នឹងទ្រង់ដែរ[ឌ] ៩ ដោយដឹងថា ដែលព្រះគ្រីស្ទមានព្រះជន្ម
រស់ពីស្លាប់ឡើងវិញ[ឍ] នោះទ្រង់មិនចេះសុគតទៀតឡើយ
ព្រោះសេចក្តីស្លាប់គ្មានអំណាចលើទ្រង់ទៀត[ណ] ១០ ដ្បិតដែល
ទ្រង់សុគត នោះគឺបានសុគត ខាងឯបាប[ត] ១ដងជាសំរេច[ថ]
ហើយដែលទ្រង់មានព្រះជន្មរស់ នោះទ្រង់រស់ខាងឯព្រះវិញ
១១ ដូច្នេះ ចូរអ្នករាល់គ្នារាប់ខ្លួនទុកជាស្លាប់ខាងឯបាប
ដែរ[ទ] តែរស់ខាងឯព្រះវិញចុះ ដោយនូវព្រះគ្រីស្ទយេស៊ូវ
ជាព្រះអម្ចាស់នៃយើងរាល់គ្នា ១២ ហេតុនេះ កុំឱ្យបាបសោយ
រាជ្យ[ធ] ក្នុងរូបកាយរបស់អ្នករាល់គ្នា ដែលតែងតែស្លាប់
ដើម្បីនឹងស្តាប់តាមសេចក្តីប៉ងប្រាថ្នារបស់បាបនោះឡើយ
១៣ ក៏កុំឱ្យប្រគល់អវយវៈ ទាំងប៉ុន្មាន របស់អ្នករាល់គ្នាទៅ
ក្នុងអំពើបាប ទុកដូចជាប្រដាប់ប្រដាទុច្ចរិតនោះឡើយ[ន] គឺ
ត្រូវប្រគល់ខ្លួនទៅព្រះ ដូចជាបានរស់ពីស្លាប់នោះឡើងវិញ
ហើយថ្វាយអវយវៈ របស់អ្នករាល់គ្នាទៅព្រះ ទុកដូចជា
ប្រដាប់ប្រដាសុចរិតផង[ប] ១៤ ដ្បិតបាបមិនត្រូវមានអំណាច
លើអ្នករាល់គ្នាទៀតឡើយ[ផ] ដោយព្រោះអ្នករាល់គ្នាមិន
នៅក្រោមក្រឹត្យវិន័យ[ព] គឺនៅក្រោមព្រះគុណវិញ[ភ]។

## បាវបម្រើនៃសេចក្តីសុចរិត

១៥ ដូច្នេះ ធ្វើដូចម្តេច តើគួរឱ្យយើងប្រព្រឹត្តអំពើបាប

**៦:៥** ឆ ខ.៤,៨ រម ៨:១១ ២កថ ៤:១០ អភ ២:៦ ភល ៣:១០,១១ កល ២:១២ ៣:១ ២ធថ ២:១១ **៦:៦** ជ កឡ ៥:២៤ អភ ៤:២២ កល ៣:៩ ឈ ខ.២ ខ.៣–៨ ២កថ ៤:១០ កទ ២:២០ ៥:២៤ ៦:១៤ ភល ៣:១០ កល ២:១២,២០ ៣:៣ ញ រម ៧:២៤ ដ ខ.១៦ **៦:៧** ឋ ខ.១៨ **៦:៨** ឌ ខ.៥ **៦:៩** ឍ ខ.៤ កច ២:២៤ ណ វវ ១:១៨

**៦:១០** ត ខ.២ ថ ហព ៧:២៧ **៦:១១** ទ ខ.២ **៦:១២** ធ ខ.១៦ **៦:១៣** ន ខ.១៦,១៩ រម ៧:៥ ប រម ១២:១ ២កថ ៥:១៤,១៥ ១ពត ២:២៤ **៦:១៤** ផ ខ.១៦ ព រម ២:១២ ភ រម ៣:២៤

**៦:៦** *មនុស្សចាស់របស់យើង* គឺចង់បញ្ជាក់ពីខ្លួនយើងកាលមិនទាន់ប្រែចិត្ត ។ *តួអំពើបាប* ពាក្យនេះបានថ្លែងពីបុគ្គលដែលជាគ្រីស្ទបរិស័ទដំបូងដែលបានគ្រប់គ្រងដោយអំពើបាប ។ នេះគឺជាការបញ្ជាក់ពីនិមិត្តរូបនៅក្នុងតួអង្គមនុស្សចាស់ ។ វាជារូបកាយដែលអាចនឹងសម្លាប់បាន។ ចំពោះអ្នកដែលជឿលើព្រះរូបកាយចាស់នេះ គ្មានអំណាចត្រឡប់មកវិញនោះឡើយ ។ ដូច្នេះរូបកាយនេះពុំអាចធ្វើឱ្យយើងក្លាយ ជាទាសករនៃអំពើបាបបានទៀតឡើយ តែអ្វីៗដែលកំពុងមានអំណាចលើយើងនាពេលសព្វថ្ងៃនេះ នោះអាចមកពីឥទ្ធិពលរូបកាយមុននឹងដាច់ខ្យល់ស្លាប់ ។

**៦:៧** *ដែលស្លាប់* គឺនិយាយពីសេចក្តីស្លាប់របស់អ្នកជឿជាមួយនឹងព្រះគ្រីស្ទទៅក្នុងអំណាចត្រួតត្រានៃអំពើបាប(ខ.៣)។ *រួចពីបាប* ត្រង់នេះពុំមែន មានន័យថា គ្មានបាបនោះទេ តែបានរួចផុតពីច្រវ៉ាក់ និងអំណាចនៃអំពើបាប ។

**៦:៨** តាមបទពិសោធន៍ ដែលព្រះគ្រីស្ទបានរស់ពីស្លាប់ឡើងវិញ នោះអ្នកជឿដែលស្លាប់ក្នុងព្រះគ្រីស្ទ នេះនឹងរស់ឡើងវិញដូចជាទ្រង់ដែរ ។ តាមពិតគំនិតនៃការរស់ឡើងវិញក្នុងកំណើតថ្មីនេះ បានមានជាស្រេចរួចទៅហើយ ហើយវាធំលូតលាស់ទៅតាមដំណើរក្នុងជីវិតរបស់អ្នកជឿនោះទៀតផង ។

**៦:១០** *សុគតខាងឯបាប ១ដងជាសំរេច* ត្រង់នេះបញ្ជាក់ថា ការសុគតរបស់ព្រះគ្រីស្ទតែមួយអង្គគឺសម្រាប់មនុស្ស(មានបាប)ទាំងអស់បានដែលហាក់បីដូចជាទ្រង់បានចុះចូលនឹងបាបដែលបានសោយរាជ្យកាលពីដើមនោះមក(៥:២១) ប៉ុន្តែ ការសុគតរបស់ទ្រង់នេះបានផ្តាច់អស់នូវចំណងនៃសេចក្តីជិនុំជម្រះរវាងអំពើបាប និងសេចក្តីស្លាប់ទាំងនោះរួចរាល់អស់ហើយ រួចទ្រង់ក៏បានឆ្លងផុតពីឥទ្ធិពលនៃអំពើបាបទាំងនោះផងដែរ ។ ក្រោយពីការដែលទ្រង់បានរស់ឡើងវិញហើយ នោះក៏មានព្រះជន្មរស់មកដល់សព្វថ្ងៃ ហើយនិងរហូតដល់អស់កល្បជានិច្ចតរៀងទៅ ។

**៦:១១** *រាប់ខ្លួនទុកជា* នេះគឺជាជំហានទីមួយនៃជ័យជម្នះរបស់គ្រីស្ទបរិស័ទក្នុងកាលដែលបានរាប់ខ្លួនទុកជាស្លាប់នៅក្នុងអំពើបាប រួចរស់នៅក្នុងព្រះអម្ចាស់ ហើយដោយសេចក្តីជំនឿនោះពួកគេគឺជាពន្លឺនៅក្នុងសេចក្តីពិតនេះ (ជំហាននៃជ័យជម្នះ មើលការពន្យល់ខ.១២–១៣)។ *ដោយនូវព្រះគ្រីស្ទយេស៊ូវ* នេះគឺជាឃ្លាដំបូង ដែលបានឃើញនៅក្នុងគម្ពីររ៉ូម ដែលលោកប៉ុលតែងតែសរសេរ ។ ចំពោះអ្នកជឿលើព្រះពិតប្រាកដ គឺជឿលើ "ព្រះគ្រីស្ទ" ដែលហៅថា គ្រីស្ទបរិស័ទ ពីព្រោះពួក គេបានស្លាប់ជាមួយនឹងព្រះគ្រីស្ទ និងបានរស់ឡើងវិញបែបជាជីវិតថ្មីក៏នៅជាមួយព្រះគ្រីស្ទដែរ (មើលការពន្យល់ អភ ១:១)។

**៦:១២–១៣** ការត្រាស់ហៅគ្រីស្ទបរិស័ទទាំងអស់ ឱ្យចូលមកអនុវត្តនូវអ្វីដែលពួកគេបានកំពុងមានស្ថានភាពនៅក្នុងព្រះអម្ចាស់ជាស្រេច ហើយនោះគឺស្លាប់ក្នុងអំពើបាប(ខ.៥–៧) ហើយមករស់ខាងឯព្រះវិញ(ខ.៨–១០)។ ជំហានទី២ដែលឈានទៅរកជ័យជម្នះលើអំពើបាបនោះ គឺមិនអនុញ្ញាតឱ្យបាបបន្តសោយរាជ្យក្នុងរូបកាយយើងទៀត(ខ.១២) និងជំហានទី៣គឺត្រូវប្រគល់ខ្លួនទៅព្រះ(ខ.១៣)។

**៦:១៣** *ប្រគល់* ពាក្យនេះមានន័យថា យកខ្លួនទៅបម្រើដល់អ្វីមួយ ឬអាចមានន័យថា ពលិកម្មនោះដែរ ។ *អវយវៈទាំងប៉ុន្មានរបស់អ្នករាល់គ្នា* អត្ថន័យត្រង់នេះ គឺសំដៅលើគ្រប់ផ្នែកទាំងអស់នៃសារពាង្គកាយរបស់មនុស្សយើង(ខ.១៩)។

**៦:១៤** *ដ្បិតបាបមិនត្រូវមានអំណាចលើអ្នករាល់គ្នាទៀតឡើយ* ឃ្លានេះ អាចនិយាយម្យ៉ាងទៀតថា ដ្បិតបាបពុំមែនជាចៅហ្វាយលើអ្នករាល់គ្នាទៀតឡើយ ។ លោកប៉ុលបានគិតដល់អំពើបាបថា វាជាអំណាចមួយដែលអាចចាប់យើងធ្វើជាទាសករបាន ដូច្នេះយើងចាំបាច់ត្រូវកំណត់ចំណាំវាឱ្យបានច្បាស់(ទដ ១៩:១៣)។ *មិននៅក្រោមក្រិក្យវិន័យ* ឃ្លានេះមិនមែនចង់និយាយថា គ្រីស្ទបរិស័ទពុំគោរពសីលធម៌របស់ខ្លួននោះទេ ។ ទោះជាយ៉ាងណាក៏ដោយគ្រីស្ទបរិស័ទមិននៅក្រោមក្រឹត្យវិន័យដូចក្នុង សម័យគម្ពីរសញ្ញាចាស់នោះទេ ។ ក្រឹត្យវិន័យមិនបានផ្តល់នូវអ្វីដែលអាចទប់ទល់នឹងអំណាចនៃអំពើបាបបានឡើយ គឺគ្រាន់តែដាក់ទោសអ្នកដែល ធ្វើបាបប៉ុណ្ណោះ ប៉ុន្តែព្រះគុណនៃព្រះអាចជួយបានវិញ ។ *នៅក្រោមព្រះគុណ* គឺបញ្ជាក់ពីទិដ្ឋភាពដែលហ៊ឹកហ៊ឺននៃព្រះគុណ(មើលការពន្យល់ ទត ២:១១–១២)។

**៦:១៥–២៣** សំណួរដែលបានលើកឡើងនៅក្នុងខនេះ ហាក់បីដូចជាមកពីពួកដែលភ័យខ្លាចពីគោលលទ្ធិនៃការរាប់ជាសុចរិតដោយសារជំនឿ តែ

ដោយព្រោះនៅក្រោមព្រះគុណ មិននៅក្រោមក្រឹត្យវិន័យ
ឬអី[ភ] ទេ មិនគួរឡើយ ១៦តើអ្នករាល់គ្នាមិនដឹងទេឬអី ថា
អ្នករាល់គ្នាប្រគល់ខ្លួនទៅធ្វើជាបាវបំរើ និងស្ដាប់តាម[ម]
ចៅហ្វាយណា នោះអ្នកជាបាវបំរើរបស់ចៅហ្វាយនោះ
ឯង ដែលអ្នកស្ដាប់តាម ទោះជារបស់ផងអំពើបាប[យ] ឱ្យ
បានសេចក្ដីស្លាប់[រ] ឬជារបស់ផងសេចក្ដីស្ដាប់បង្គាប់ ឱ្យ
បានសុចរិតក្ដី ១៧ឯអ្នករាល់គ្នា ពីដើមជាបាវបំរើរបស់
អំពើបាបមែន[ល] ប៉ុន្តែអរព្រះគុណដល់ព្រះអង្គ[វ] ឥឡូវនេះ
បានស្ដាប់ដោយស្ម័គ្រពីចិត្ត តាមក្បួននៃលទ្ធិ[ស] ដែលគេបាន
ប្រគល់មកអ្នករាល់គ្នា ១៨ហើយអ្នករាល់គ្នាបានត្រឡប់ជា
បាវបំរើនៃសេចក្ដីសុចរិតវិញ[ហ] ដោយទ្រង់បានប្រោសឱ្យ
រួចពីអំពើបាបហើយ[ឡ]។

១៩ខ្ញុំនិយាយតាមបែបមនុស្សលោក[អ] ដោយព្រោះសេច
ក្ដីកំសោយរបស់សាច់ឈាមនៃអ្នករាល់គ្នា ដ្បិតដូចជាកាល
ពីដើម អ្នករាល់គ្នាបានប្រគល់អវយវៈទាំងប៉ុន្មាន ទៅបំរើ
សេចក្ដីស្មោកគ្រោក នឹងសេចក្ដីទទឹងច្បាប់ កាន់តែច្រើន
ឡើងយ៉ាងណា ឥឡូវនេះ ចូរអ្នករាល់គ្នាប្រគល់អវយវៈ
ទាំងអស់នោះ ទៅបំរើសេចក្ដីសុចរិតវិញ[ក] ប្រយោជន៍ឱ្យ
បានបរិសុទ្ធយ៉ាងនោះដែរ ២០ពីព្រោះកាលពីដើម ដែល
នៅជាបាវបំរើរបស់អំពើបាប[ខ] នោះអ្នករាល់គ្នាមិននៅក្នុង
អំណាចនៃសេចក្ដីសុចរិតទេ[គ] ២១កាលណោះ តើអ្នករាល់
គ្នាបានផលអ្វីខ្លះ ក្នុងអំពើដែលឥឡូវនេះអ្នករាល់គ្នាអៀន
ខ្មាសវិញ ដ្បិតទីបំផុតនៃអំពើទាំងនោះជាសេចក្ដីស្លាប់[ឃ]
២២តែឥឡូវនេះ ដែលព្រះបានប្រោសឱ្យរួចពីបាប[ង] ហើយ
អ្នករាល់គ្នាបានត្រឡប់ជាបាវបំរើដល់ទ្រង់[ច] នោះអ្នករាល់
គ្នាបានផលខាងឯសេចក្ដីបរិសុទ្ធវិញ ហើយទីបំផុតនៃអំពើ
ទាំងនោះ គឺជាជីវិតអស់កល្បជានិច្ចផង[ឆ] ២៣ដ្បិតឈ្នួលរបស់
អំពើបាប នោះជាសេចក្ដីស្លាប់[ជ] តែអំណោយទាននៃព្រះ
វិញ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច[ឈ] ដោយព្រះគ្រីស្ទ
យេស៊ូវជាព្រះអម្ចាស់នៃយើងរាល់គ្នា ។

## ការបកស្រាយពីអាពាហ៍ពិពាហ៍

៧ ១ឱបងប្អូនអើយ[ញ] តើអ្នករាល់គ្នាមិនដឹងទេឬអី ដ្បិតខ្ញុំ
និយាយនឹងអ្នករាល់គ្នា ដែលស្គាល់ក្រឹត្យវិន័យហើយ ថា
ក្រឹត្យវិន័យមានអំណាចលើមនុស្ស ដរាបដល់អស់មួយជីវិត
២ពីព្រោះស្ត្រីណាដែលមានប្ដីនៅរស់ នោះជាប់នឹងប្ដីដោយ
សារក្រឹត្យវិន័យ ប៉ុន្តែ បើកាលណាប្ដីស្លាប់ទៅ នោះបានរួច
ពីច្បាប់របស់ប្ដីហើយ[ដ] ៣ដូច្នេះ កាលប្ដីកំពុងរស់នៅឡើយ
បើស្ត្រីនោះទៅយកប្ដី១ទៀត នោះគេសន្មតិហៅថាជាស្រី
កំផិត[ឋ] តែបើប្ដីស្លាប់ទៅ នោះនាងបានរួចពីច្បាប់នោះ
ហើយ បានជាទោះបើនាងយកប្ដី១ទៀត ក៏មិនបានហៅថា

**៦:១៥** ភ ខ.១,១៤
**៦:១៦** ម ២ពត ២:១៩ យ ខ.៦,១២,១៤,១៧,២០ លប ៤:៧ ទដ ៥១:៥ ១១៩:១៣៣ យហ ៨:៣៤ រម ៥:២១ ៧:១៤,២៣,២៥ ៨:២ ២ពត ២:១៩ រ ខ.២៣
**៦:១៧** ល ខ.១៦ វ រម ១:៨ ២កថ ២:១៤ ស ១ធថ ១:១៣
**៦:១៨** ហ ខ.២២ ឡ ខ.២,៧,២២ រម ៨:២ ១ពត ៤:១ ខ.១៦
**៦:១៩** អ រម ៣:៥ កទ ៣:១៥ ក ខ.១៣,២២
**៦:២០** ខ ខ.១៦ គ ខ.១៦
**៦:២១** ឃ ខ.២៣
**៦:២២** ង ខ.១៨ ច ខ.១៨,១៩ រម ៧:២៥ ១កថ ៧:២២
អភ ៦:៦ ១ពត ២:១៦ ឆ មថ ២៥:៤៦ **៦:២៣** ជ ខ.១៦,២១ លប ២:១៧ សភ ១០:១៦ អគ ១៨:៤ រម ១:៣២ ៥:១២ ៧:៥,១៣ ៨:៦,១៣ កឡ ៦:៧,៨ យក ១:១៥ ឈ មថ ២៥:៤៦ **៧:១** ញ កថ ១:១៦ ២២:៥ រម ១:១៣ ១កថ ១:១០ ៥:១១ ៦:៦ ១៤:២០,២៦ កទ ៣:១៥ ៦:១៨ **៧:២** ដ ១កថ ៧:៣៩ **៧:៣** ឋ លក ១៦:១៨

មួយប៉ុណ្ណោះ ថានឹងនាំឱ្យរលុបរនាំងសីលធម៌បាត់អស់។ ប៉ុន្តែលោកប៉ុលបដិសេធគំនិតនេះ ហើយបានពន្យល់ថា គ្រីស្ទបរិស័ទមិនត្រូវបោះបង់សីលធម៌ល្អៗចោលនោះទេ តែផ្ទុយទៅវិញ ពួកគេត្រូវប្ដូរចៅហ្វាយនៃ អំពើបាបចេញ ហើយមកទទួលចៅហ្វាយនៃសេចក្ដីសុចរិតវិញ ។

**៦:១៦** នៅក្នុងខនេះបាននិយាយអំពីភាពផ្ទុយគ្នារវាងអំពើបាប និងការស្ដាប់បង្គាប់ ថា អំពើបាបកើតឡើងដោយសារការមិនស្ដាប់បង្គាប់ដល់ព្រះ ។

**៦:១៧** *បានស្ដាប់ដោយស្ម័គ្រពីចិត្ត* ការស្ដាប់បង្គាប់របស់គ្រីស្ទបរិស័ទពុំមែនជាការបង្ខំ ឬជាក្បួនច្បាប់អ្វីនោះទេ តែវាជាឆន្ទៈវិញ ។ *តាមក្បួននៃលទ្ធិ* ពាក្យនេះប្រហែលជាសំដៅលើសេចក្ដីសង្ខេបនៃសេចក្ដីបង្រៀនរបស់ព្រះគ្រីស្ទអំពីសីលធម៌ និងសុជីវធម៌ដែលត្រូវបានគេលើកមកបង្រៀនដល់អ្នកជឿថ្មីនៅក្នុងពួកជំនុំដំបូង ។

**៦:១៨** *បាវបំរើនៃសេចក្ដីសុចរិត* ចង់ញ្ជាក់ថា គ្រីស្ទបរិស័ទបានផ្លាស់ប្ដូរស្ថានភាពពីបាវបម្រើនៃអំពើបាប(ខ.១៦–១៧) មកជាបាវបម្រើនៃសេចក្ដីសុចរិតវិញ ។

**៦:១៩** *ខ្ញុំនិយាយតាមបែបមនុស្សលោក* ឃ្លានេះលោកប៉ុលចង់និយាយសូមទោសចំពោះការប្រើពាក្យមិនសមរម្យរបស់គាត់ក្នុងវគ្គនេះ ។ កាលណាប្រើពាក្យថា"បាវបម្រើ" គឺប្រើទៅលើគ្រីស្ទបរិស័ទដែលមានសេរីភាពនៅក្នុងព្រះគ្រីស្ទ ហើយជាធម្មតាបង្ហាញពីការតស៊ូនឹងសេចក្ដីទុក្ខលំបាកផងដែរ ។

**៦:២២** *ប្រោសឱ្យរួចពីបាប* សូមមើលការពន្យល់ ខ.៦ ។ *សេចក្ដីបរិសុទ្ធ* មានន័យថា ក្នុងនាមជាបាវបម្រើព្រះ នោះត្រូវតែមានជីវិតបរិសុទ្ធរហូតដល់ទីបញ្ចប់នៃដំណើរនៅលើផែនដីនេះ គឺជាជីវិតអស់កល្ប(គំនិតនេះចង់បញ្ជាក់ពីទីបញ្ចប់នាពេលអនាគត ពុំមែនសំដៅលើបច្ចុប្បន្ននេះទេ)។ ពុំមានជីវិតអស់កល្បណាមួយគ្មានភាពបរិសុទ្ធនោះឡើយ(ហព ១២:១៤)។ អស់អ្នកដែលបានរាប់ជាសុចរិត គឺជាអ្នកដែលបានបង្ហាញភស្ដុតាងនៃសេចក្ដីពិតយ៉ាងច្បាស់ ដោយមានវត្តមាននៃភាពបរិសុទ្ធនៅក្នុងជីវិតរបស់ពួកគេនេះឯង ។ ចំពោះហេតុការណ៍ផ្សេងៗទៀតនៃ "បរិសុទ្ធ"គឺមើល ខ.១៩ លវ ១១:៤៤ និងការពន្យល់ ១កថ ១:៣០ និងមើល ការពន្យល់ ១:២ ១ថន ៤:៣–៤,៧ ២ថន ២:១៣ ១ធថ ២:១៥ ហព ១២:១៤ ១ពត ១:២ និងការពន្យល់ ។

**៦:២៣** នៅក្នុងខនេះមានសភាវគតិពីរដែលផ្ទុយគ្នា ។ ទីមួយនាំទៅរកសេចក្ដីស្លាប់ដែលជាឈ្នួលរបស់វា ។ ទីពីរគឺទទួលបានជីវិតអស់កល្បជានិច្ច តែនេះពុំមែនជាឈ្នួល ឬជាមរដកទេ តែជាអំណោយរបស់ព្រះអម្ចាស់វិញ(អស ២:៨–៩ និងការពន្យល់ ។ ចំពោះអត្ថន័យនៃភាពផ្ទុយគ្នារវាងពាក្យឈ្នួល ហើយនិងអំណោយនោះ(សូមមើល ៤:៤)។

**៧:១** *ក្រិត្យវិន័យ* ត្រង់នេះប្រហែលជាលោកប៉ុលចង់និយាយពីក្រិត្យវិន័យរបស់លោកម៉ូសេ ប៉ុន្តែអ្វីដែលលោកចង់លើកយកមកនិយាយពេលនេះ គឺគោលសំខាន់នៃក្រិត្យវិន័យនេះតែម្ដង ។

**៧:២–៣** នៅក្នុងខទាំងនេះ គឺជាការពន្យល់ពីគោលការដែលបានលើកឡើងនៅក្នុងខ.១ ដើម្បីញ្ជាក់ថា មានតែសេចក្ដីស្លាប់ទេ ដែលអាចផ្ដាច់ទំនាក់ទំនង

ជាស្រីកំផិតឡើយ ។
៤ យ៉ាងដូច្នោះ បងប្អូនអើយ អ្នករាល់គ្នាក៏បានស្លាប់ពី
ខាងឯក្រិត្យវិន័យដែរ[ឌ] ដោយសាររូបអង្គនៃព្រះគ្រីស្ទ[ឍ] ដើម្បី
ឱ្យអ្នករាល់គ្នាបានទៅជារបស់ផងអ្នកម្នាក់ទៀត[ណ] ដែលបាន
រស់ពីស្លាប់ឡើងវិញ ប្រយោជន៍ឱ្យយើងបានបង្កើតផល
ថ្វាយព្រះ ៥ ដ្បិតកាលយើងនៅខាងសាច់ឈាមនៅឡើយ[ត]
នោះសេចក្ដីរំជួលរបស់អំពើបាប ដែលកើតដោយនូវក្រិត្យ
វិន័យ[ថ] បានបណ្ដាលឱ្យអស់ទាំងអវយវៈ ក្នុងរូបកាយរបស់
យើងរាល់គ្នា[ទ] បង្កើតផលដល់សេចក្ដីស្លាប់[ធ] ៦ តែឥឡូវនេះ
យើងបានរួចពីក្រិត្យវិន័យហើយ[ន] ដោយបានស្លាប់ក្នុងសេចក្ដី
ដែលឃុំឃាំងយើងទុក ប្រយោជន៍ឱ្យយើងបានគោរព
ប្រតិបត្តិដោយវិញ្ញាណដែលបានកែជាថ្មីវិញ មិនមែនតាម
តែន័យពាក្យពីបុរាណនោះទៀតឡើយ[ប] ។

**៧:៤** ឌ ខ.៦ រម ៦:៦ ៨:២ កទ ២:១៩ ៣:២៣–២៥ ៤:៣១ ៥:១ ឍ កល ១:២២ ណ កទ ២:១៩,២០
**៧:៥** ត កទ ៥:២៤ ថ រម ៧:៧–១១ ទ រម ៦:១៣ ធ រម ៦:២៣
**៧:៦** ន ខ.៤ ប រម ២:២៩ ២កច ៣:៦
**៧:៧** ផ រម ៨:៣១ ព ខ.១២ ភ រម ៤:១៥ ម នក ២០:១៧ ចទ ៥:២១

## ការតតាំងនឹងអំពើបាប

៧ ដូច្នេះ យើងនឹងថាដូចម្ដេច[ផ] តើក្រិត្យវិន័យជាតួបាបឬ
អី ទេ មិនមែនឡើយ[ព] ខ្ញុំមិនបានទាំងស្គាល់បាបផង លើក
តែដោយសារក្រឹត្យវិន័យចេញ[ភ] ដ្បិតបើសិនជាក្រិត្យវិន័យ
មិនបានថា«កុំឱ្យលោភ»[ម] នោះខ្ញុំឥតបានដឹងថាមានសេចក្ដី
លោភផងឡើយ ៨ តែកាលអំពើបាបបានឱកាស ដោយសារ
បញ្ញត្តិ[យ] នោះក៏បង្កើតគ្រប់ទាំងសេចក្ដីលោភ នៅក្នុងខ្លួនខ្ញុំ
វិញ ដ្បិតក្រៅពីក្រឹត្យវិន័យ អំពើបាបបានស្លាប់សូន្យ[រ] ៩ តែពី
ដើម ក្រៅពីក្រឹត្យវិន័យ នោះខ្ញុំបានរស់នៅ លុះសេចក្ដីបញ្ញត្តិ
បានកើតមក នោះបាបក៏រស់ឡើង ឯខ្ញុំក៏ត្រូវស្លាប់វិញ
១០ ហើយខ្ញុំឃើញថា បញ្ញត្តិនោះ ដែលសំរាប់ឱ្យមានជីវិត[ល]

**៧:៨** យ ខ.១១ រ រម ៤:១៥
**៧:១០** ល លវ ១៨:៥ លក ១០:២៦–២៨ រម ១០:៥ កទ ៣:១២

របស់មនុស្សនឹងក្រឹត្យវិន័យបាននោះ ។

**៧:៤** *យ៉ាងដូច្នោះ* នៅពេលនេះលោកប៉ុលបានធ្វើការសន្និដ្ឋានមួយចេញពីគោលការដែលបានថ្លែងនៅក្នុងខ.១ ហើយពន្យល់ជារូបភាពនៅក្នុងខ.២–៣ ។ បាន *ស្លាប់ពីខាងឯក្រិត្យវិន័យ* អំណាចនៃក្រឹត្យវិន័យ ដើម្បីកាត់ទោសនោះ ពុំអាចគំរាមដល់អ្នកជឿតទៅទៀតបានទេ ។ ការលើកយកមនុស្សស្លាប់មកនិយាយនៅក្នុងខនេះ គឺដើម្បីធ្វើឱ្យយល់នៅក្នុងវគ្គ ៦:២–៧ ដែលបញ្ជាក់ថា អស់អ្នកដែលបានស្លាប់ខាងឯអំពើបាប គឺដូចគ្នានឹងស្លាប់ខាងឯក្រឹត្យវិន័យដែរ នោះនាំឱ្យគេមិននៅក្រោមក្រឹត្យវិន័យទៀតឡើយ ។ *ដោយសាររូបអង្គនៃព្រះគ្រីស្ទ* ពាក្យនេះសំដៅលើសាច់ឈាម(រូបកាយ) របស់ទ្រង់ ដែលបានសុគតលើឈើឆ្កាង ។ *ជារបស់ផងអ្នកម្នាក់ទៀត* គឺសំដៅលើការរស់ឡើងវិញរបស់ព្រះគ្រីស្ទ(៦:៥ ទត ២:១៤ ១ពត ២:១៤ និងការពន្យល់)។ គោលបំណងនៃការរួបរួមជាមួយព្រះគ្រីស្ទ ឬជារបស់ផងព្រះគ្រីស្ទនេះ គឺដើម្បីបង្កើតផលផ្លែនៃភាពបរិសុទ្ធ ។

**៧:៥** *កាលយើងនៅខាងសាច់ឈាម* នេះជាស្ថានភាពមួយដែលគ្រីស្ទបរិស័ទយើងសព្វថ្ងៃបានព្រួយបារម្ភដោយពួកគេមិនកែគំនិតជាថ្មី(១កថ ៦:១១ កទ ៥:១៩–២៣ និងការពន្យល់)។ *កើតដោយនូវក្រិត្យវិន័យ* ក្រឹត្យវិន័យពុំមែនគ្រាន់តែបើកសំដែងឱ្យដឹងតែអំពើបាបប៉ុណ្ណោះទេ វាថែមទាំងលើកទឹកចិត្តឱ្យធ្វើទៀតផងដែរ។ ចំណង់និស្ស័យរបស់មនុស្ស គឺប៉ងទៅរកនូវអ្វីដែលគេបានហាមឃាត់ ។ *សេចក្ដីស្លាប់* គឺសំដៅលើសេចក្ដីស្លាប់ខាងរូបកាយ ហើយលើសពីនេះទៅទៀតនោះគឺសេចក្ដីខាងឯព្រលឹងវិញ្ញាណ ហើយទីបញ្ចប់ក៏ដាច់ចេញពីព្រះ(មើលការពន្យល់ ៥:១២)។ ទាំងនេះហើយជាផលផ្លែនៃការរួបរួមជាមួយនឹងក្រឹត្យវិន័យ(មើលការពន្យល់ ខ.៤)។

**៧:៦** *សេចក្ដីដែលឃុំឃាំងយើងទុក* ឃ្លានេះគឺសំដៅលើក្រឹត្យវិន័យដែលបានឃុំឃាំងយើង តែពេលនេះយើងបានរួចខ្លួនវិញ ដូច្នេះយើងអាចគោរពប្រតិបត្តិដោយ វិញ្ញាណដែលបានកែជាថ្មីវិញ(ខ.៤)។ *បានរួចពីក្រិត្យវិន័យហើយ* ឃ្លានេះចង់បញ្ជាក់ថាបានរួចពីគំនិតនៃការចោទប្រកាន់ ឬគំនិតនៃការកាត់ទោស(មើលការពន្យល់ខ.៤)។ *ដោយវិញ្ញាណដែលបានកែជាថ្មី* មើលការពន្យល់ ៨:៤ ។ *ន័យពាក្យពីបុរាណ* ពាក្យនេះសំដៅទៅលើជីវិតនៅក្រោមក្រិត្យវិន័យក្នុងគម្ពីរសញ្ញាចាស់ ។

**៧:៧** *តើក្រិត្យវិន័យជាតួបាបឬអី?* នេះគឺជាសំណួរដែលបានលើកឡើងដើម្បីបញ្ជាក់ពីក្រឹត្យវិន័យនៅក្នុងខ.៤–៦។ *ខ្ញុំ* នេះគឺជាសព្វនាមដែលបញ្ជាក់អំពីលោកប៉ុលខ្លួនឯងផ្ទាល់ ប៉ុន្តែវាក៏តំណាងដល់មនុស្សទូទៅ(ខ.៧–១២) ហើយជាពិសេស ទៅទៀតនោះ គឺសំដៅលើគ្រីស្ទបរិស័ទផងដែរ(ខ.១៣–២៥)។ *ខ្ញុំមិនបានទាំងស្គាល់បាបផង* ចង់បញ្ជាក់ប្រាប់ថា ក្រឹត្យវិន័យបានសម្រេចការមួយយ៉ាងសំខាន់នៃការបើកសំដែងពីពេលបច្ចុប្បន្ន និងសេចក្ដីពិតនៃអំពើបាប ។

**៧:៨** *តែកាលអំពើបាបបានឱកាស ដោយសារបញ្ញត្តិ* មើលការពន្យល់ ខ.៥។ *អំពើបាបបានស្លាប់សូន្យ* ពាក្យនេះពុំមែនមានន័យថា គ្មានអ្វីសោះនោះទេ គ្រាន់តែពុំបាន ដឹងសព្វគ្រប់នោះឡើយ(មើលការពន្យល់ ៥:១៣)។

**៧:៩** *នោះខ្ញុំបានរស់នៅ* ចង់និយាយពីអ្វីដែលលោកប៉ុលយល់ឃើញតាមបទពិសោធន៍ជីវិតនាសម័យកាលរបស់គាត់រស់នៅ។ កាលមុនគាត់យល់ថាក្រឹត្យវិន័យ នឹងនាំគាត់ទៅរកសេចក្ដីស្លាប់ ។ នេះអាចទាក់ទងនឹងលោកប៉ុលក្នុងវ័យអាយុមុន ១៣ឆ្នាំ(ដែលសាសន៍យូដាចាត់ទុកថាជាមនុស្សពេញវ័យខាងឯជំនឿសាសនា) ឬមុនពេលដែលលោកប្រែចិត្តក្នុងកាលដែលភាពហ្មត់ចត់ ពិតប្រាកដនៃក្រឹត្យវិន័យបានបង្ហាញគាត់ច្បាស់លាស់នោះ(លក ១៨:២០–២១ និងការពន្យល់ ភល ៣:៦)។ *លុះសេចក្ដីបញ្ញត្តិបានកើតមក* ចង់បញ្ជាក់ថា នៅពេលដែលលោកប៉ុលបានដឹងនូវអ្វីដែលបានធ្វើខុសចំពោះក្រឹត្យវិន័យ ។ ចំណុចនេះគឺសំដៅទៅលើកាលដែលគាត់ទទួលពិធីពេញវ័យខាងឯសាសនាក្រោយពីបានអាយុ១៣ឆ្នាំ ឬក្រោយពីបានដឹងពីអំណាច ពេញលេញនៃក្រឹត្យវិន័យក្នុងកាលបានប្រែចិត្តនោះ ។ *ខ្ញុំក៏ត្រូវស្លាប់វិញ* មកដល់ពេលនេះលោកប៉ុលដឹងថា គាត់ត្រូវតែស្លាប់ពីព្រោះក្រឹត្យវិន័យបានបើកសំដែងថាគាត់មានបាប ហើយឈ្នួលនៃអំពើបាបនោះគឺជាសេចក្ដីស្លាប់ (មើលការពន្យល់ ៦:២៣)។

**៧:១០** *ដែលសំរាប់ឱ្យមានជីវិត* មើលពន្យល់ លវ ១៨:៥ ។ នៅត្រង់នេះបានសំដែងមកដូចនូវអ្វីដែលលោកប៉ុលបានជួបប្រទះដែរ នោះគឺថា ក្រិត្យវិន័យគឺជាផ្លូវមួយដែលនាំបាបចូលមកក្នុងជីវិត ហើយមិនគ្រាន់តែផ្ដល់ជីវិតនោះទេ តែថែមទាំងនាំមកនូវការកាត់ទោសទៀតផង ។ ទាំងនេះមិនគ្រាន់ តែពុំបានផ្ដល់សេចក្ដីបរិសុទ្ធនោះទេ វាថែមទាំងបើកឱកាសឱ្យធ្វើបាបទៀតផង ។

នោះបានឱ្យខ្ញុំត្រូវស្លាប់វិញ ១១ដ្បិតដែលបាបបានឱកាស
ដោយសារសេចក្ដីបញ្ញត្តិ[វ] នោះក៏មកបញ្ឆោតខ្ញុំ[ស] ព្រមទាំង
សំឡាប់ខ្ញុំផងដោយសារបញ្ញត្តិនោះឯង ១២ដូច្នេះក្រឹត្យ
វិន័យជាបរិសុទ្ធទេ ហើយសេចក្ដីបញ្ញត្តិក៏បរិសុទ្ធ សុចរិត
ល្អដែរ[ហ]។

១៣ចុះសេចក្ដីល្អនេះ បានប្រែទៅជាឱ្យខ្ញុំស្លាប់ឬអី ទេ
មិនមែនឡើយ គឺជាបាបវិញទេតើ ដែលនាំឱ្យខ្ញុំស្លាប់[ឡ]
ដោយសារសេចក្ដីល្អនោះ[អ] ដើម្បីឱ្យបាបបានសំដែងចេញ
មកថាជាបាបមែន ហើយឱ្យបាបបានត្រឡប់ទៅជាធ្ងន់ក្រៃ
លែង ដោយសារសេចក្ដីបញ្ញត្តនោះផង ។

១៤ដ្បិតយើងដឹងថា ក្រឹត្យវិន័យត្រូវខាងវិញ្ញាណ តែខ្ញុំ
នៅខាងសាច់ឈាមវិញ[ក] ដោយបានត្រូវលក់[ខ] ទៅក្នុង
អំណាចរបស់បាប[គ] ១៥ពីព្រោះខ្ញុំមិនដឹងការដែលខ្ញុំប្រព្រឹត្ត
ទេ ដ្បិតខ្ញុំមិនធ្វើការដែលខ្ញុំចង់ធ្វើសោះ គឺតែងតែប្រព្រឹត្ត
ការដែលខ្ញុំស្អប់វិញ[ឃ] ១៦បើសិនជាខ្ញុំតែងតែប្រព្រឹត្តការ
ដែលខ្ញុំមិនចង់ធ្វើ នោះខ្ញុំយល់ព្រមថា ក្រឹត្យវិន័យល្អមែន[ង]
១៧ដូច្នេះ មិនមែនខ្ញុំដែលធ្វើការនោះទៀតទេ គឺជាបាបទេ
តើដែលនៅក្នុងខ្លួនខ្ញុំវិញ[ច] ១៨ដ្បិតខ្ញុំដឹងថា នៅក្នុងខ្លួនខ្ញុំគឺ
ក្នុងសាច់ឈាមខ្ញុំ[ឆ]គ្មានអ្វីល្អទេ ព្រោះខ្ញុំមានចិត្តចង់ធ្វើល្អ
ជានិច្ច ប៉ុន្តែ រកធ្វើមិនកើតសោះ ១៩ខ្ញុំមិនប្រព្រឹត្តការល្អ
ដែលខ្ញុំចង់ធ្វើនោះទេ តែការអាក្រក់ដែលខ្ញុំមិនចង់ធ្វើ
នោះបែរជាខ្ញុំធ្វើវិញ[ជ] ២០ដូច្នេះ បើខ្ញុំប្រព្រឹត្តការដែលខ្ញុំមិន
ចង់ធ្វើ នោះមិនមែនខ្ញុំដែលធ្វើការនោះទៀតទេ គឺជាបាប
ទេតើ ដែលនៅក្នុងខ្លួនខ្ញុំវិញ[ឈ]។

២១យ៉ាងនោះខ្ញុំឃើញច្បាប់១នេះ[ញ]ថា ឯខ្ញុំដែលចង់
ប្រព្រឹត្តតែសេចក្ដីល្អ នោះចេះតែមានសេចក្ដីអាក្រក់ជាប់
នៅនឹងខ្ញុំជានិច្ច ២២ដ្បិតតាមប៉ែកខាងក្នុង[ដ] ខ្ញុំត្រេកអរ
ចំពោះក្រឹត្យវិន័យរបស់ព្រះ[ឋ] ២៣តែខ្ញុំឃើញមានអំណាច១
ទៀត ក្នុងអស់ទាំងអវយវៈរបស់រូបកាយខ្ញុំ ដែលច្បាំង[ឌ]

**៧:១១** វ ខ.៨ ស លប ៣:១៣
**៧:១២** ហ ខ.៧,១៣, ១៤,១៦ រម ៨:៤ កទ ៣:២១ ១ធថ ១:៨ រម ៤:១៥
**៧:១៣** ឡ រម ៦:២៣ អ ខ.១២
**៧:១៤** ក ១កថ ៣:១ ខ ១ពវ ២១:២០,២៥ ២ពវ ១៧:១៧ គ រម ៦:១៦
**៧:១៥** ឃ ខ.១៩ កទ ៥:១៧
**៧:១៦** ង ខ.១២
**៧:១៧** ច ខ.២០
**៧:១៨** ឆ ខ.២៥ កទ ៥:២៤
**៧:១៩** ជ ខ.១៥
**៧:២០** ឈ ខ.១៧ **៧:២១** ញ ខ.២៣,២៥ **៧:២២** ដ អភ ៣:១៦ ឋ ទដ ១:២ ៤០:៨ **៧:២៣** ឌ កទ ៥:១៧ យក ៤:១ ១ពត ២:១១

**៧:១២** *ក្រិត្យវិន័យជាបរិសុទ្ធទេ* ចង់បញ្ជាក់ថា ទោះបើបាបបង្ខូចប្រយោជន៍ក្រឹត្យវិន័យយ៉ាងណាក៏ដោយ ក៏យើងពុំអាចបន្ទោសដល់ក្រឹត្យវិន័យបានដែរ ពីព្រោះបាបទេដែលអាក្រក់នោះ ។ ចំណែកឯក្រិត្យវិន័យ គឺជារបស់ព្រះអម្ចាស់ ដែលបរិសុទ្ធ សុចរិត និងល្អប្រសើរបំផុត ។

**៧:១៣–២៥** នៅក្នុងវគ្គនេះមិនថាលោកប៉ុលកំពុងបកស្រាយនៃបទពិសោធន៍គ្រីស្ទបរិស័ទ ឬមិនមែនជាគ្រីស្ទបរិស័ទនោះទេ ដែលបានជជែកវែកញែកអស់ជាច្រើនសតវត្សរ៍នោះមកហើយ ។ តែបើនិយាយពីជីវិតមិនមែនជាគ្រីស្ទបរិស័ទវិញគឺសំអាងលើ : (១).ការប្រើឃ្លាដូចជា "ដោយបានត្រូវលក់ទៅក្នុងអំណាចរបស់ បាប"(ខ.១៤) "ដ្បិតខ្ញុំដឹងថានៅក្នុងខ្លួនខ្ញុំ គឺក្នុងសាច់ឈាមខ្ញុំ គ្មានអ្វីល្អទេ"(ខ.១៨) ហើយនិង"វេទនាណាស់ខ្ញុំ"(ខ.២៤) ទាំងនេះហើយដែលបញ្ជាក់ថាមិនមែននិយាយពីជីវិតគ្រីស្ទបរិស័ទនោះ ។ (២).គឺមានភាពផ្ទុយគ្នារវាងជំពូក៧ និងជំពូក៨ ដែលធ្វើឱ្យវាពិបាកសម្រាប់ទស្សនៈផ្សេងៗទៀតចំពោះការជឿទុកចិត្តនោះ។ (៣).អំពីតម្លៃនៃការប្រែចិត្តនៅតែមាន វិញ្ញាណធ្លាក់ទៅក្នុងទុក្ខវេទនា ដដែលក្រោយពីការប្រែចិត្ត។ តែបើនិយាយពីជីវិតជាគ្រីស្ទបរិស័ទវិញគឺសំអាងលើ :
(១).ការប្រើប្រយោគជាបច្ចុប្បន្នកាលនៅក្នុងអត្ថបទនេះ។ (២)គំនិតនៃការបន្ទាបខ្លួនរបស់លោកប៉ុលផ្ទាល់។ (៣).ការគោរពដ៏ខ្ពង់ខ្ពស់របស់គាត់ចំពោះក្រឹត្យវិន័យរបស់ព្រះ(ខ.១៤,១៦)។ (៤).អត្ថបទគម្ពីររ៉ូមត្រង់វគ្គនេះលោកប៉ុលកំពុងពន្យល់ពីការរាប់ជាសុចរិត ការរីកចម្រើននៃភាពបរិសុទ្ធរបស់គ្រីស្ទបរិស័ទ ។

**៧:១៣** បាបបានធ្វើឱ្យរបស់បរិសុទ្ធមួយ(ក្រឹត្យវិន័យ)ក្លាយទៅជារបស់មិនបរិសុទ្ធវិញនៅទីបញ្ចប់(ស្លាប់)។ និស្ស័យគួរឱ្យស្អប់ខ្ពើមនៃអំពើនេះត្រូវបានបើកសំដែង ឱ្យដឹងដោយសេចក្ដីពិតនៅត្រង់ចំណុចនេះ ។

**៧:១៤** *ខាងវិញ្ញាណ* ក្រឹត្យវិន័យមានដើមកំណើតមកពីព្រះ ។ *ខ្ញុំនៅ* ពាក្យនេះជាសព្វនាមជំនួសឱ្យមនុស្សបូកនឹងកិរិយាសព្ទ ដែលបញ្ជាក់ពីពេលវេលាបច្ចុប្បន្នក្នុងកាល ដែលលោកប៉ុលកំពុងតែនិយាយដំណើររឿង(របស់គ្រីស្ទបរិស័ទនោះ)។ *ខាងសាច់ឈាមវិញ* ពាក្យនេះផ្ទុយនឹងពាក្យថា ខាងវិញ្ញាណ ចង់ប្រាប់ថា សូម្បីតែអ្នកជឿមួយចំនួនក៏នៅតែមានកូនចិត្តនៃការបះបោរនោះដែរ ។ *ដោយបានត្រូវលក់ទៅក្នុងអំណាចរបស់បាប* ឃ្លាមួយនេះមានការបដិសេធន៍ជាច្រើនដើម្បីទទួលថា នេះជាការពិពណ៌នាពីគ្រីស្ទបរិស័ទនោះ ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏វាជាចំណុចចាប់ផ្ដើមដំបូងនៃការយល់ខុសរបស់គ្រីស្ទបរិស័ទខាងផ្នែកសីលធម៌ និងសុជីវធម៌ទៅចំពោះដំណឹងល្អនោះដែរ ហើយវាក៏ជាការបង្ហាញពីនិស្ស័យមានះនៃអំពើបាបនោះដែរ ។

**៧:១៥** *ខ្ញុំមិនដឹងការដែលខ្ញុំប្រព្រឹត្តទេ* នេះចង់និយាយពីការតទល់គ្នានៃគំនិតដែលស្ដែងចេញមកមានភាពផ្ទុយគ្នា និងភាពច្របូកច្របល់នៅក្នុងអារម្មណ៍ (កទ ៥:១៦–១៧ និងការពន្យល់)។

**៧:១៦** *ខ្ញុំយល់ព្រមថា ក្រិត្យវិន័យល្អមែន* ឃ្លានេះបញ្ជាក់ថា សូម្បីតែនៅពេលដែលលោកប៉ុលបះបោរមិនស្ដាប់បង្គាប់ព្រះ នោះព្រះវិញ្ញាណបរិសុទ្ធបើកសំដែងដល់លោកពីសារសំខាន់នៃក្រឹត្យវិន័យ ។

**៧:១៧** *មិនមែនខ្ញុំដែលធ្វើការនោះទៀតទេ* ឃ្លានេះពុំមែនជាការប៉ុនប៉ងគេចចេញពីការទទួលខុសត្រូវលើផ្នែកសីលធម៌នោះទេ ប៉ុន្តែ វាជាសេចក្ដីថ្លែងនៃការគ្រប់គ្រងរបស់អំពើបាបដែលអាចមានលើជីវិតគ្រីស្ទបរិស័ទ ។

**៧:១៨** *នៅក្នុងខ្លួនខ្ញុំ គឺនៅក្នុងសាច់ឈាមខ្ញុំគ្មានអ្វីល្អទេ* ចង់សំដៅទៅលើនិស្ស័យធ្លាក់ចុះរបស់លោកប៉ុល ដូចដែលបានបញ្ជាក់នៅក្នុងខ.១៨នេះស្រាប់ ។

**៧:២០** *មិនមែនខ្ញុំដែលធ្វើការនោះ. . .បាបទេតើ* មើលការពន្យល់ខ.១៧ ។

**៧:២១** *ច្បាប់* នៅត្រង់នេះអាចមានន័យដូចជាពាក្យគោលកាដែរ ។

**៧:២២** *ខ្ញុំត្រេកអរចំពោះក្រិត្យវិន័យរបស់ព្រះ* ជាទូទៅសំដៅទៅលើក្រឹត្យវិន័យរបស់ព្រះដែលបានប្រទានមកតាមរយៈលោកម៉ូសេ ។ នេះជាបំណែកមួយក្នុងការ លើកទឹកចិត្តដល់អ្នកជឿអំពីក្រឹត្យវិន័យផងដែរ ។

**៧:២៣** *អំណាច១ទៀត* ពាក្យនេះសំដៅទៅលើគោលការ ឬកម្លាំងម្យ៉ាងដែល ធ្វើការនៅក្នុងរូបកាយរបស់លោកប៉ុល ដើម្បីកុំឱ្យលោកស្ដាប់បង្គាប់ក្រឹត្យវិន័យរបស់ព្រះ ។ *អំណាចនៃគំនិតខ្ញុំ* មានន័យថាបំណងចិត្តរបស់លោក

នឹងអំណាចនៃគំនិតខ្ញុំ ទាំងចាប់នាំខ្ញុំទៅជាប់ក្រោមអំណាច
អំពើបាប[ឈ] ដែលនៅក្នុងអវយវៈនៃខ្លួនខ្ញុំទាំងប៉ុន្មានផង
២៤វេទនាណាស់ខ្ញុំ តើអ្នកណានឹងជួយឱ្យខ្ញុំរួចពីតួសេចក្ដី
ស្លាប់នេះទៅបាន[ណ] ២៥អរព្រះគុណដល់ព្រះអង្គ គឺដោយ
សារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា[ត]
ដូច្នេះ ខ្លួនខ្ញុំគោរពប្រតិបត្តិតាមក្រិត្យវិន័យរបស់ព្រះ[ថ]
ដោយគំនិតខ្ញុំ តែខាងសាច់ឈាមខ្ញុំ នោះតាមច្បាប់របស់
អំពើបាបវិញ[ទ]។

## ជីវិតបានតាមរយៈព្រះវិញ្ញាណ

**៨** ១ហេតុនោះ នៅជាន់នេះ អ្នកណាដែលនៅក្នុងព្រះគ្រីស្ទ
យេស៊ូវ[ធ] នោះគ្មានទោសសោះ[ន] ២ដ្បិតអំណាចរបស់
ព្រះវិញ្ញាណនៃជីវិត[ប] ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ[ផ] នោះ
បានប្រោសឱ្យខ្ញុំរួច[ព]ពីអំណាចរបស់អំពើបាប[ភ] និងសេចក្ដី
ស្លាប់ហើយ ៣ពីព្រោះ ឯការដែលក្រិត្យវិន័យធ្វើមិនកើត[ម]
ដោយមានសេចក្ដីកំសោយព្រោះសាច់ឈាម[យ] នោះព្រះ
ទ្រង់បានធ្វើវិញ ដោយចាត់ព្រះរាជបុត្រាទ្រង់ឱ្យមកមាន
រូបអង្គបែបដូចជាសាច់ឈាម[រ]ដែលតែងតែមានបាប[ល]
ហើយដោយព្រោះអំពើបាប ក៏កាត់ទោសអំពើបាបនៅ
ក្នុងសាច់ឈាម ៤ដើម្បីឱ្យសេចក្ដីដែលក្រឹត្យវិន័យបង្គាប់មក[វ]
បានសំរេចក្នុងខ្លួនយើងរាល់គ្នា ដែលមិនដើរតាមសាច់
ឈាម គឺដើរតាមព្រះវិញ្ញាណវិញ[ស]។
៥ពីព្រោះអស់អ្នកណាដែលតាមសាច់ឈាម នោះគិតតែ
ខាងសាច់ឈាម[ហ] តែអស់អ្នកណាដែលតាមព្រះវិញ្ញាណ
នោះគិតតែខាងវិញ្ញាណវិញ[ឡ] ៦ដ្បិតគំនិតខាងសាច់ឈាម
នោះជាសេចក្ដីស្លាប់ទទេ[អ] ឯគំនិតនៃព្រះវិញ្ញាណ នោះ
ទើបជាជីវិត[ក] និងសេចក្ដីសុខសាន្តវិញ ៧ព្រោះគំនិតខាង

**៧:២៣** ឈ រម ៦:១៦ **៧:២៤** ណ រម ៦:៦ ៨:២ **៧:២៥** ត ២កថ ២:១៤ ថ រម ៦:២២ ទ រម ៦:១៦ **៨:១** ធ ខ.៣៩ រម ១៦:៣ ន ខ.៣៤ **៨:២** ប ១កថ ១៥:៤៥ ផ រម ៧:២៥ រម ៦:១៨ ព រម ៦:១៦ ៧:៤ ភ យហ ៨:៣២,៣៦ **៨:៣** ម ហព ៧:១៨ ១០:១-៤ យ រម ៧:១៨,១៩ កទ ៥:២៤ រ ភល ២:៧ ល ហព ២:១៤,១៧ **៨:៤** វ រម ២:២៦ ស កទ ៥:១៦ **៨:៥** ហ កទ ៥:១៩–២១ ឡ កទ ៥:២២–២៥ **៨:៦** អ រម ៦:២៣ ក ខ.១៣ កទ ៦:៨

ប៉ុល គឺចង់ស្ដាប់បង្គាប់ដល់ក្រឹត្យវិន័យរបស់ព្រះ ។

**៧:២៤** *តួសេចក្ដីស្លាប់* វាជានិមិត្តរូបនៃតួអំពើបាប(៦:៦ ៨:១០ និងការពន្យល់) ដែលចងព្យួរលើរូបគាត់ដូចជាសាកសពមួយ ដែលធ្វើឱ្យគាត់គ្មានសិទ្ធិសេរីភាព ។

**៧:២៥** ពាក់កណ្ដាលវគ្គដំបូងនៃខនេះ គឺជាការឆ្លើយទៅនឹងសំណួរនៅក្នុង ខ.២៤ថា គាត់បានរួចពីអំណាចនៃសេចក្ដីស្លាប់នេះ មិនមែនដោយសារក្រឹត្យវិន័យ(ច្បាប់)នោះទេ គឺដោយសារព្រះយេស៊ូវគ្រីស្ទវិញ(៨:២ និងការពន្យល់)។ ចំណែកឯពាក់កណ្ដាលវគ្គចុងក្រោយគឺជាសេចក្ដីសង្ខេបរបស់ ខ.១៣–២៤ ។ *ខ្លួនខ្ញុំ* ពាក្យនេះ បញ្ជាក់ពីសេចក្ដីខាងក្នុងរបស់ដែលថា ត្រេកអរចំពោះក្រឹត្យវិន័យរបស់ព្រះ(ខ.២២ និងការពន្យល់)។ *ច្បាប់របស់អំពើបាប* ចង់ប្រាប់ថា គ្រីស្ទបរិស័ទត្រូវតែ គិតអំពីអំណាចដែលធ្វើឱ្យយើងក្លាយជាទាសករនៃសាច់ឈាម(មើលការពន្យល់ ខ.២៣)ក្នុងខណៈពេលដែលយើងកំពុងរស់នៅលើផែនដីនេះ ទំរាំទទួលបានសេចក្ដីប្រោសលោះដល់រូបកាយយើង(៨:២៣)។

**៨:១** *ទោស* ក្រឹត្យវិន័យនាំមកនូវការដាក់ទោស ពីព្រោះវាបង្ហាញពីកំហុសហើយនិងកម្រិតរបស់ទោស ប៉ុន្តែចំពោះគ្រីស្ទបរិស័ទវិញ យើងមិននៅក្រោមក្រឹត្យវិន័យនោះទៀតទេ(៦:១៤)។ *នៅក្នុងព្រះគ្រីស្ទយេស៊ូវ* មានន័យថា យើងរួមគ្នាជាមួយនឹងទ្រង់ដូចដែលបានពន្យល់នៅក្នុង ៦:១–១០ (មើលការពន្យល់ ៦:១១ ភល ២:១)។

**៨:២** *អំណាចរបស់ព្រះវិញ្ញាណនៃជីវិត* មានន័យថាថាព្រះវិញ្ញាណបរិសុទ្ធជាអ្នកគ្រប់គ្រងមកលើជីវិតអ្នកជឿព្រះយេស៊ូវគ្រីស្ទ ។ លោកប៉ុលបានប្រើពាក្យ "អំណាច ឬក្រឹត្យវិន័យ"ជាភាសារ៉ូម៉ាំង តាមបែបខុសៗគ្នាច្រើនយ៉ាងដែលមានន័យថា "អំណាចគ្រប់គ្រង" (នៅទីនេះ) "ក្រឹត្យវិន័យរបស់ព្រះ" (២:១៧–២០ ៩:៣១ ១០:៣–៥) "គម្ពីរប្រាំកណ្ឌដំបូង"(៣:២១ខ) "គម្ពីរសញ្ញាចាស់ទាំងមូល"(៣:១៩ និងការពន្យល់)"ច្បាប់ ឬគោលការណ៍" (៣:២៧) *អំណាចរបស់អំពើបាប និងសេចក្ដីស្លាប់* គឺជាអំណាចគ្រប់គ្រងនៃអំពើបាបដែល ជាប្រភពនាំឱ្យទទួលបានសេចក្ដីស្លាប់(៧:២៤ និងពន្យល់)។

**៨:៣** *ធ្វើមិនកើត* ក្រឹត្យវិន័យមិនអាចយកជ័យជម្នះលើអំពើបាបបានឡើយ (ហព ៧:១៨ និងការពន្យល់) ថែមទាំងបង្ហាញពីការមានទោស និងធ្វើឱ្យនឹកឃើញបាប ដែលពុំអាចជៀសរួចនោះបានឡើយ ។ *មានរូបអង្គបែបដូចជាសាច់ឈាម* ចង់បញ្ជាក់ថា នៅពេលព្រះយេស៊ូវយាងមកផែនដីនេះ គឺទ្រង់ជាមនុស្សមួយរយភាគរយ ប៉ុន្តែ ទ្រង់គ្មានបាបសោះមិនដូចគ្នានឹងមនុស្សផ្សេងៗដទៃនោះទេ(មើលការ ពន្យល់ មថ ៤:១–១១) *នៅក្នុងសាច់ឈាម* ពាក្យនេះបញ្ជាក់ពី"រូបកាយខាងក្នុង" ប្រហែលជាលោកប៉ុលនិយាយទៅដល់រូបកាយព្រះគ្រីស្ទ(នៅលើឈើឆ្កាង)។

**៨:៤** *ដើម្បីឱ្យសេចក្ដីដែលក្រិត្យវិន័យបង្គាប់មក បានសំរេចក្នុងខ្លួន* ត្រង់នេះបញ្ជាក់ថា ក្រឹត្យវិន័យនៅតែមានតួនាទីយ៉ាងសំខាន់ដដែលនៅក្នុងជីវិតគ្រីស្ទបរិស័ទ ។ ម្យ៉ាងទៀតក៏សំដៅទៅលើសេចក្ដីសង្គ្រោះដែរ តែផ្ដោតលើផ្នែកសីលធម៌ ហើយនិងអាកប្បកិរិយាក្នុងការស្ដាប់បង្គាប់ដោយក្ដីស្រឡាញ់ចំពោះទ្រង់ ហើយដោយមានជំនួយពីព្រះវិញ្ញាណបរិសុទ្ធផងដែរ ។ ឃ្លាខាងលើនេះគឺជាការសម្រេចទំនាយនៃការតាំងសញ្ញាថ្មី ដែលបានទាយទុកតាំងពីនៅក្នុង យរ ៣១:៣១–៣៤ ។ *បានសំរេច* ចង់សំដៅពីបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ ក្នុងការបញ្ជូនព្រះរាជបុត្រាទ្រង់តែមួយគត់មកលើផែនដីនេះ ដើម្បីឱ្យអស់អ្នកណាដែលជឿលើទ្រង់ នោះមានសមត្ថភាពធ្វើជាអ្នកតំណាងការពិត និងមានឆន្ទៈគ្រប់គ្រាន់ដើម្បីកាន់តាមក្រឹត្យវិន័យ ។ *គឺដើរតាមព្រះវិញ្ញាណវិញ* នេះគឺជារបៀបដែលបានតម្រូវដើម្បីឱ្យ ការ–បង្គាប់របស់ក្រឹត្យវិន័យអាចសម្រេចទៅបាន ដោយពុំអនុញ្ញាតឱ្យនិស្ស័យសាច់ឈាម(និស្ស័យបាប)ដឹកនាំតទៅទៀត ហើយបែរមកបម្រើតាមការដឹកនាំដោយ នៅក្រោមអំណាចព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធវិញ ។

**៨:៥–៨** នៅត្រង់នេះបានលើកយកគំនិតពីរមកពិពណ៌នាប្រាប់: ទី១ របៀបដើរតាមសាច់ឈាមដែលនាំទៅរកសេចក្ដីស្លាប់ ។ ទី២ របៀបដើរតាមព្រះវិញ្ញាណដែលនាំទៅឯជីវិត និងសេចក្ដីសុខសាន្ត។ គំនិតខាងសាច់ឈាមនោះជាសេចក្ដីស្លាប់ទទេ(ខ.៦) ពីព្រោះគំនិតនោះរមែងទាស់ទទឹងនឹងព្រះមិនចុះចូលនឹងក្រឹត្យវិន័យរបស់ព្រះ(ខ.៧) និងពុំមែនជារបស់ផងព្រះ(ខ.៨)។

សាច់ឈាម នោះរមែងទាស់ទទឹងនឹងព្រះ[ខ] ដ្បិតមិនចុះចូល
នឹងក្រឹត្យវិន័យរបស់ព្រះទេ ក៏ពុំអាចនឹងចុះចូលបានផង
៨ ពួកអ្នកដែលនៅខាងសាច់ឈាម[គ] នោះពុំអាចនឹងគាប់
ព្រះហឫទ័យដល់ព្រះបានឡើយ ។
៩ តែបើសិនជាព្រះវិញ្ញាណនៃព្រះសណ្ឋិតក្នុងខ្លួនអ្នក
រាល់គ្នា[ឃ] នោះអ្នករាល់គ្នាមិននៅខាងសាច់ឈាមទៀតទេ[ង]
គឺនៅខាងវិញ្ញាណវិញ ប៉ុន្តែ បើអ្នកណាគ្មានព្រះវិញ្ញាណ
របស់ព្រះគ្រីស្ទ[ច] អ្នកនោះមិនមែនជារបស់ផងទ្រង់ទេ
១០ ហើយបើសិនជាព្រះគ្រីស្ទសណ្ឋិតក្នុងអ្នករាល់គ្នា[ឆ] នោះ
រូបសាច់បានស្លាប់ ដោយព្រោះអំពើបាបមែន តែវិញ្ញាណ
មានជីវិតវិញ ដោយព្រោះសេចក្តីសុចរិត ១១ មួយទៀត
បើព្រះវិញ្ញាណនៃព្រះអង្គ ដែលបានប្រោសឱ្យព្រះយេស៊ូវ
រស់ពីស្លាប់ឡើងវិញ[ជ] ទ្រង់សណ្ឋិតក្នុងខ្លួនអ្នករាល់គ្នា នោះ
ព្រះអង្គនោះឯង ដែលបានប្រោសឱ្យព្រះគ្រីស្ទរស់ពីស្លាប់
ឡើង ទ្រង់នឹងប្រោសរូបកាយនៃអ្នករាល់គ្នា ដែលទៀងតែ
ស្លាប់[ឈ] ឱ្យមានជីវិតឡើងដែរ ដោយសារព្រះវិញ្ញាណទ្រង់
ដែលសណ្ឋិតនៅក្នុងខ្លួនអ្នករាល់គ្នា ។
១២ ដូច្នេះបងប្អូនអើយ យើងមានសេចក្តីជាប់ជំពាក់មិនមែន
ជំពាក់ចំពោះសាច់ឈាម ឱ្យបានរស់តាមសាច់ឈាមនោះ
ទេ[ញ] ១៣ ដ្បិតបើសិនជាអ្នករាល់គ្នារស់តាមសាច់ឈាម នោះ
នឹងត្រូវស្លាប់ទៅ[ដ] តែបើសំឡាប់អំពើរបស់រូបសាច់[ឋ] ចេញ
ដោយសារព្រះវិញ្ញាណ នោះអ្នករាល់គ្នានឹងបានរស់វិញ[ឍ]
១៤ ហើយអស់អ្នកណាដែលព្រះវិញ្ញាណនៃព្រះ[ឍ] ទ្រង់នាំអ្នក
ទាំងនោះហើយជាពួកកូនរបស់ព្រះ[ណ] ១៥ អ្នករាល់គ្នាមិន
បានទទួលនិស្ស័យ[ត] ជាបាវបំរើ ឱ្យត្រូវភ័យខ្លាចទៀតឡើយ[ថ]
គឺបានទទួលនិស្ស័យជាកូនចិញ្ចឹមវិញ ដោយហេតុនោះបាន
ជាយើងស្រែកឡើងថា ឱអ័ប្បា ព្រះវរបិតាអើយ[ទ] ១៦ ហើយ
ព្រះវិញ្ញាណទ្រង់ក៏ធ្វើបន្ទាល់នឹងវិញ្ញាណយើង[ធ] ថា យើងជា
កូនរបស់ព្រះ[ន] ១៧ បើសិនណាជាកូនព្រះ ហើយនោះយើង
ក៏បានគ្រងមរដកដែរ[ប] គឺជាអ្នកគ្រងមរដកនៃព្រះជាមួយ
នឹងព្រះគ្រីស្ទផង ឱ្យតែយើងទទួលរងទុក្ខជាមួយនឹងទ្រង់ចុះ[ផ]
ដើម្បីឱ្យបានដំកើងឡើងជាមួយនឹងទ្រង់ ដែរ[ព] ។

**៨:៧** ខ យក ៤:៤
**៨:៨** គ កទ ៥:២៤
**៨:៩** ឃ ខ.១១ ១កថ ៦:១៩ ២ធថ ១:១៤ ង កទ ៥:២៤ ច យហ ១៤:១៧ កច ១៦:៧ ១យហ ៤:១៣
**៨:១០** ឆ ខ.៩ នក ២៩:៤៥ យហ ១៤:២០,២៣ ២កថ ១៣:៥ កទ ២:២០ អភ ៣:១៧ កល ១:២៧ វវ ៣:២០
**៨:១១** ជ កច ២:២៤ ឈ យហ ៥:២១ រម ៦:៥
**៨:១២** ញ ខ.៤ កទ ៥:២៤
**៨:១៣** ដ រម ៦:២៣ ឋ រម ៦:២ ឌ ខ.៦ កទ ៦:៨ **៨:១៤** ឍ កទ ៥:១៨ ណ ខ.១៩ ហស ១:១០ មទ្ឋ ៣:១៧ មថ ៥:៩ យហ ១:១២ កទ ៣:២៦ ៤:៥ អភ ១:៥ វវ ២១:៧ **៨:១៥** ត យហ ២០:២២ ថ ២ធថ ១:៧ ទ មក ១៤:៣៦ កទ ៤:៥,៦ **៨:១៦** ធ ២កថ ១:២២ អភ ១:១៣ ន ខ.១៤ យហ ១:១២ **៨:១៧** ប កច ២០:៣២ កទ ៣:២៩ ៤:៧ អភ ៣:៦ ទត ៣:៧ ផ ២កថ ១:៥ ព ២ធថ ២:១២ ១ពត ៤:១៣

**៨:៩** នៅក្នុងខនេះលោកប៉ុលបញ្ជាក់យ៉ាងច្បាស់ក្រឡែតថា "ព្រះវិញ្ញាណនៃព្រះសណ្ឋិតក្នុងខ្លួន"អ្នកជឿគ្រប់ៗរូបទាំងអស់ ។

**៨:១០** *រូបសាច់បានស្លាប់ ដោយព្រោះអំពើបាប* មានន័យថាសូម្បី តែរូបកាយផ្នែកសាច់ឈាមរបស់គ្រីស្ទបរិស័ទនោះក៏ត្រូវចាត់ទុកថា បានស្លាប់ទៅហើយដែរ ដោយព្រោះតែអំពើបាប ។ *វិញ្ញាណមានជីវិត* មានន័យថាវិញ្ញាណរបស់គ្រីស្ទបរិស័ទនៅរស់(ខ.២ និងការពន្យល់)។ ពាក្យថា "រូបសាច់"នៅទីនេះគឺចង់មានន័យដូចគ្នានៅ ៧:២៤ ។ *ដោយព្រោះសេចក្តីសុចរិត* មានន័យថាគ្រីស្ទបរិស័ទគ្រប់រូបត្រូវបានវិញ្ញាណនៃជីវិតសណ្ឋិតនៅក្នុងខ្លួនគ្រប់ៗគ្នា ទុកជាលទ្ធផលនៃការរាប់ជាសុចរិត ។

**៨:១១** នេះជាខតភ្ជាប់គ្នារវាងសេចក្តីរស់ឡើងវិញរបស់ព្រះគ្រីស្ទ ហើយនិងគ្រីស្ទបរិស័ទ(១កថ ៦:១៤ ១៥:២០,២៣ ២កថ ៤:១៤ ភល ៣:២១ ១ថន ៤:១៤ និងការពន្យល់)។ *ប្រោសរូបកាយនៃអ្នករាល់គ្នា ដែលទៀងតែស្លាប់* មានន័យថាការរស់ ឡើងវិញនៃរូបកាយរបស់យើងនេះត្រូវបានធានាអះអាងដោយព្រះវត្តមាននៃព្រះវិញ្ញាណបរិសុទ្ធបានសណ្ឋិតនៅក្នុងយើង ។ វត្តមាននៃព្រះវិញ្ញាណនោះហើយដែលជាភស្តុតាងបញ្ជាក់ថា ជីវិតមានព្រះវិញ្ញាណគ្រប់គ្រង(ខ.៤–៩) នេះហើយដែលធ្វើឱ្យយើងដឹងច្បាស់ពីការរស់ឡើងវិញរបស់យើងពីឥឡូវនេះរហូតតទៅ ។

**៨:១៤** *ពួកកូនរបស់ព្រះ* ព្រះអម្ចាស់គឺជាព្រះវរបិតានៃយើងទាំងអស់គ្នានៅក្នុងគំនិតនេះបញ្ជាក់ថា ទ្រង់ជាព្រះបានបង្កើតពួកយើងព្រមទាំងផ្តល់សេចក្តីស្រឡាញ់ និងការថែរក្សាដល់យើងរាល់គ្នាទៀតផង(មថ ៥:៤៥ និងការពន្យល់)។ ប៉ុន្តែ មិនមែនគ្រប់គ្នាសុទ្ធតែជាកូនរបស់ព្រះនោះទេ ។ ព្រះយេស៊ូវទ្រង់មានបន្ទូលទៅពួកសាសន៍ដែលមិនជឿនៅក្នុងសម័យទ្រង់ថា "អ្នករាល់គ្នាមានអារក្សសាតាំងជាឪពុក"(យហ ៨:៤៤ និងការពន្យល់)។ មនុស្សអាចក្លាយជាកូនព្រះបាន មានតែផ្លូវមួយប៉ុណ្ណោះ គឺទទួលជឿព្រះរាជបុត្រារបស់ព្រះ(យហ ១:១២ និងការពន្យល់) ហើយនេះក៏ជាទីសំគាល់ពីភាពទំនាក់ទំនងដែលត្រូវបានដឹកនាំដោយព្រះវិញ្ញាណនៃព្រះនោះផងដែរ ។

**៨:១៥** *និស្ស័យជាកូនចិញ្ចឹម* ពាក្យសំខាន់នៅក្នុងឃ្លានេះ"ចិញ្ចឹម" មានឃើញ៤កន្លែង ផ្សេងទៀតនៅក្នុងគម្ពីរសញ្ញាថ្មី(ខ.២៣ ៩:៤ អភ ១:៥)។ ពាក្យចិញ្ចឹមនេះ ត្រូវបានគេនិយមប្រើជាទូទៅនៅក្នុងចំណោមសាសន៍ក្រេក និងសាសន៍រ៉ូម៉ាំង ដែលកូនចិញ្ចឹមប្រុសនេះមានឯកសិទ្ធិដូចគ្នានឹងកូនប្រុសពីកំណើតដែរ រួមទាំងសិទ្ធិទទួលមរដកនោះផង ។ គ្រីស្ទបរិស័ទគឺជាកូនចិញ្ចឹមដោយព្រះគុណរបស់ព្រះចំណែកឯព្រះគ្រីស្ទវិញទ្រង់គឺជាព្រះរាជបុត្រារបស់ព្រះពិតៗតែម្តង ។ *ឱអ័ប្បា ព្រះវរបិតាអើយ* ពាក្យនេះគឺជាឧទានសព្ទ១ ដែលបញ្ជាក់ពីភាពជិតស្និទ្ធទៅនឹងព្រះអម្ចាស់ ។

**៨:១៦** *ធ្វើបន្ទាល់នឹងវិញ្ញាណ* នេះគឺជាទីបន្ទាល់ផ្នែកខាងក្នុងនៃព្រះវិញ្ញាណបរិសុទ្ធសម្រាប់ទំនាក់ទំនងរបស់យើងជាមួយនឹងព្រះគ្រីស្ទ ។ *កូនរបស់ព្រះ* ពាក្យនេះមានន័យដូចគ្នានឹងពាក្យ "កូនប្រុសរបស់ព្រះ"។

**៨:១៧** *គ្រងមរដក* ពាក្យនេះសំដៅលើអស់អ្នកដែលបានចូលនគរស្ថានសួគ៌ប្ញយ៉ាង ហោចណាស់ក៏បង្ហាញពីផ្នែកខ្លះនៃកម្មសិទ្ធិមរដកស្ថានសួគ៌ដែរ ។ *អ្នកគ្រងមរដកនៃព្រះជាមួយនឹងព្រះគ្រីស្ទ* មានន័យថាអ្វីៗគ្រប់យ៉ាងជារបស់ផងព្រះគ្រីស្ទ ប៉ុន្តែ ដោយព្រះគុណយើងមានបំណែកនូវអ្វីដែលជារបស់ផងទ្រង់ ។ *ឱ្យតែយើងទទួលរងទុក្ខជាមួយនឹងទ្រង់ចុះ* ត្រង់ចំណុចនេះពុំមែនមានន័យថា យើងសង្ស័យលើការចែករំលែកសិរីល្អរបស់ព្រះគ្រីស្ទនោះឡើយ ។ ថ្វីបើសេចក្តីពិតបានចែងថា គ្រីស្ទបរិស័ទត្រូវតែរងទុក្ខនាពេលបច្ចុប្បន្ននេះក៏ដោយ ក៏ពួកគេនៅមានតែភាពជឿជាក់ថា ពួកគេនឹងទទួលមរដកនាពេលអនាគតជាមិនខាន ។

## សិរីល្អនាពេលខាងមុខ

១៨ខ្ញុំរាប់អស់ទាំងសេចក្ដីទុក្ខលំបាកនៅជាន់នេះ ថាជា
សេចក្ដីមិនគួរប្រៀបផ្ទឹមនឹងសិរីល្អ ដែលនឹងបើកសំដែង
មកឱ្យយើងរាល់គ្នាឃើញនោះទេ[ភ] ១៩ដ្បិតសេចក្ដីទន្ទឹង
របស់ជីវិតទាំងឡាយ នោះរង់ចាំតែពួកកូនរបស់ព្រះ[ម]
លេចមកឱ្យឃើញប៉ុណ្ណោះទេ ២០ពីព្រោះជីវិតទាំងឡាយ
បានត្រូវចុះចូលនឹងសេចក្ដីឥតប្រយោជន៍ តែមិនមែនដោយ
ស្ម័គ្រពីចិត្ត គឺដោយព្រោះព្រះអង្គ ដែលទ្រង់បញ្ចុះបញ្ចូល
វិញ[យ] ដោយសង្ឃឹមថា ២១ជីវិតទាំងនោះឯង នឹងបានរួចពី
ចំណងនៃសេចក្ដីពុករលួយ[រ] ឱ្យបានសេរីភាពនៃសិរីល្អ
របស់ពួកកូនព្រះវិញ[ល] ២២ដ្បិតយើងដឹងថា ជីវិតទាំងឡាយ
ក៏ថ្ងូរ ហើយឈឺចាប់ជាមួយគ្នា[វ] ដរាបដល់គ្រាឥឡូវនេះ
២៣មិនតែប៉ុណ្ណោះសោត ខ្លួនយើងរាល់គ្នាដែលមានផល
ជាដំបូងរបស់ព្រះវិញ្ញាណ[ស] ក៏ថ្ងូរក្នុងខ្លួនដែរ[ហ] ទាំងរង់ចាំ[ឡ]
ទំរាំការទទួលជាកូនចិញ្ចឹម គឺជាសេចក្ដីប្រោសលោះដល់
រូបកាយយើងផង[អ] ២៤ដ្បិតយើងបានសង្គ្រោះរួច[ក] ដោយ
សេចក្ដីសង្ឃឹម តែសេចក្ដីសង្ឃឹមដែលមើលឃើញ នោះមិន
ឈ្មោះថាជាសេចក្ដីសង្ឃឹមទេ[ខ] ដ្បិតរបស់អ្វីដែលអ្នកណា
មើលឃើញហើយ នោះនឹងសង្ឃឹមចង់បានធ្វើអ្វីទៀត ២៥តែ
បើយើងសង្ឃឹមនឹងបានអ្វីដែលមើលមិនឃើញវិញ នោះ
យើងនឹងរង់ចាំនៅដោយអំណត់[គ] ។
២៦ព្រះវិញ្ញាណទ្រង់ក៏ជួយសេចក្ដីកំសោយរបស់យើង
បែបដូច្នោះដែរ ដ្បិតយើងមិនដឹងជាគួរអធិស្ឋានសូមអ្វីទេ
តែព្រះវិញ្ញាណ[ឃ] ទ្រង់ ជួយអង្វរជំនួសយើង[ង] ដោយដំងូរ
ដែលរកថ្លែងពុំបានវិញ ២៧ប៉ុន្តែ ព្រះអង្គដែលស្ទង់ចិត្ត[ច]
ទ្រង់ជ្រាបនូវគំនិតនៃព្រះវិញ្ញាណ ដ្បិតព្រះវិញ្ញាណជួយ
អង្វរ[ឆ] ជួសពួកបរិសុទ្ធ ឱ្យត្រូវនឹងព្រះហឫទ័យព្រះ ។

## វិសេសជាងអ្នកដែលមានជ័យជម្នះ

២៨តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នាសំរាប់សេចក្ដី
ល្អ[ជ] ដល់ពួកអ្នកដែលស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់
ហៅមក[ឈ] តាមព្រះដំរិះទ្រង់[ញ] ២៩ដ្បិតអ្នកណាដែលទ្រង់បាន
ស្គាល់ជាមុន[ដ] នោះទ្រង់ក៏ដំរូវទុកជាមុន[ឋ] ឱ្យបានត្រឡប់ដូច

**៨:១៨** ភ ២កថ ៤:១៧ ១ពត ៤:១៣ ៥:១
**៨:១៩** ម ខ.១៤
**៨:២០** យ លប ៣:១៧–១៩ ៥:២៩
**៨:២១** រ កច ៣:២១ ២ពត ៣:១៣ វវ ២១:១ ល យហ ១:១២
**៨:២២** វ យរ ១២:៤
**៨:២៣** ស ២កថ ៥:៥ ហ ២កថ ៥:២,៤ ឡ ខ.១៩ កទ ៥:៥ អ ខ.១១ ភល ៣:២១
**៨:២៤** ក ១ថន ៥:៨ ទត ៣:៧ ខ ២កថ ៤:១៨
**៨:២៥** គ ទដ ៣៧:៧
**៨:២៦** ឃ ខ.១៥,១៦ ង អភ ៦:១៨
**៨:២៧** ច វវ ២:២៣ ឆ ខ.៣៤
**៨:២៨** ជ លប ៥០:២០ អស ៣៨:១៧ យរ ២៩:១១ ឈ ខ.៣០ រម ១១:២៩ ១កថ ១:៩ កទ ១:៦,១៥ អភ ៤:១,៤ ១ថន ២:១២ ២ថន ១:៩ ហព ៩:១៥ ១ពត ២:៩ ២ពត ១:១០ ញ អភ ១:១១ ៣:១១ ហព ៦:១៧
**៨:២៩** ដ រម ១១:២ ១ពត ១:២ ឋ អភ ១:៥,១១ ឌ ១កថ ១៥:៤៩ ២កថ ៣:១៨ ភល ៣:២១ ១យហ ៣:២

**៨:១៩** *ជីវិតទាំងឡាយ* គឺចង់និយាយពីរបស់សព្វសារពើដែលព្រះបានបង្កើតមករួមទាំងមនុស្សលោកយើងនេះផងដែរ (ខ.២២–២៣) ។ *កូនរបស់ព្រះលេចមកឱ្យឃើញ* មានន័យថា គ្រីស្ទបរិស័ទត្រូវបានចាត់ទុកជាកូនរបស់ព្រះ ប៉ុន្តែ ការសំដែងពេញលេញនោះមិនទាន់មកដល់ទេ រហូតដល់ចុងបញ្ចប់សិន (១យហ ៣:១–២) ។

**៨:២០** *ចុះចូលនឹងសេចក្ដីឥតប្រយោជន៍* ពាក្យនេះភ្ជាប់ទាក់ទងនឹងបទគម្ពីរ លប ៣:១៧–១៩ ។ *ដោយសង្ឃឹម* ប្រហែលនិយាយទៅដល់ការសន្យានៅក្នុង លប ៣:១៥ (មើលពន្យល់ក្នុងខនោះ) ។

**៨:២១** *នឹងបានរួចពីចំណងនៃសេចក្ដីពុករលួយ* រូបកាយរបស់មនុស្សលោកយើងនេះមិនមែនទុកសម្រាប់បំផ្លាញ (ឬរំលាយសូន្យ) នោះទេ ប៉ុន្តែសម្រាប់ផ្លាស់ប្រែជាថ្មីវិញ (២ពត ៣:១៣ វវ ២១:១) ។ ជីវិតទាំងឡាយនឹងមិននៅជាប់ចំណងនៃសេចក្ដីស្លាប់ ហើយនិងសេចក្ដីពុករលួយដូច នៅសព្វថ្ងៃនេះទៀតឡើយ ។

**៨:២២** *ថ្ងូរ* និយាយពីជីវិតទាំងឡាយដែលព្រះបង្កើតមក ដូចជាសម្លេងស្ត្រីដែល មានផ្ទៃពោះម្នាក់នៅក្នុងបន្ទប់សម្រាលកូនដូច្នេះដែរ ។

**៨:២៣** *ផលដំបូងរបស់ព្រះវិញ្ញាណ* មានន័យថាអ្នកជឿទាំងអស់គឺជាកម្មសិទ្ធិរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលមិនត្រឹមតែជាភស្តុតាងបង្ហាញពីសេចក្ដីសង្គ្រោះ (ខ.១៤,១៦) នាពេលបច្ចុប្បន្នប៉ុណ្ណោះទេ តែថែមទាំងជាការសន្យាពីដំណើរកេរ្ដិ៍អាកររបស់យើងរាល់គ្នា ទាល់តែបានលោះរបស់កំណាន់ដែលទ្រង់បានទិញទុកឱ្យនោះទៀតផង (២កថ ១:២២ ៥:៥ និងការពន្យល់ អភ ១:១៤) ។ *ផលដំបូង* មើលការពន្យល់ នក ២៣:១៩ ១កថ ១៥:២០ ។ *ជាកូនចិញ្ចឹម* មើលការពន្យល់ ខ.១៥ ។ គ្រីស្ទបរិស័ទគឺជាកូនរបស់ព្រះដែលមានកេរ្ដិ៍អាករនៅក្នុងព្រះគ្រីស្ទ ។ *សេចក្ដីប្រោសលោះ ដល់រូបកាយយើង* មានន័យថាការរស់ឡើងវិញគឺជាដំណាក់កាលចុងក្រោយនៃកូនចិញ្ចឹម ។ ដំបូងទ្រង់បានយើងជាកូនចិញ្ចឹម (អភ ១:៥) បន្ទាប់មកទ្រង់បានរាប់យើងជាកូនរបស់ព្រះ (ខ.១៤ កទ ៣:២៥–២៦ និងការពន្យល់) ។

**៨:២៤** *ដោយសេចក្ដីសង្ឃឹម* ពាក្យនេះបញ្ជាក់ពីសេចក្ដីសង្ឃឹម ដែលយើងរាល់គ្នាមានក្នុងការដែលបានទទួលសង្គ្រោះដោយសារជំនឿ (មើលការពន្យល់ ២:៨) ។

**៨:២៦** *បែបដូច្នេះដែរ* មានន័យថា គ្រីស្ទបរិស័ទមានសង្ឃឹមជានិច្ចទោះជារងទុក្ខក៏ដោយ ពីព្រោះមានព្រះវិញ្ញាណបរិសុទ្ធចាំជួយ នៅពេលពួកគេអធិស្ឋាន ។ *ជួយអង្វរជំនួសយើង ដោយដំងូរដែលរកថ្លែងពុំបាន* ឃ្លានេះបើយើងប្រៀបធៀបនឹង ខ.២៣ អ្នកជឿជាអ្នកថ្ងូរ តែនៅទីនេះគឺព្រះវិញ្ញាណបរិសុទ្ធជាអ្នកថ្ងូរវិញ យើងមិនដឹងថា តើលោកប៉ុលចង់មានន័យថា ជាពាក្យដែលពុំអាចនិយាយចេញបាន ឬក៏ជាពាក្យដែលពុំមែនជាភាសារបស់មនុស្ស? ពោលគឺមិនប្រាកដណាមួយនោះទេ ប៉ុន្តែ មានសេចក្ដីបញ្ជាក់បន្ថែមទៀតនៅក្នុង ខ.២៧ ។

**៨:២៧** នៅក្នុងខនេះយើងឃើញពីភាពទំនាក់ទំនងគ្នាយ៉ាងស្និទ្ធស្នាលបំផុតរវាងព្រះវិញ្ញាណបរិសុទ្ធ និងព្រះវរបិតា ព្រោះថាសេចក្ដីអធិស្ឋានរបស់ព្រះវិញ្ញាណបរិសុទ្ធ នោះព្រះវរបិតាមិនចាំបាច់ស្ដាប់ទេគឺទ្រង់បានជ្រាបគ្រប់ទាំងគំនិតនោះ រួចបាត់ទៅហើយ ។

**៨:២៨** *សំរាប់សេចក្ដីល្អ* នេះគឺជាការអះអាងបញ្ជាក់ដល់យើងរាល់គ្នា "ឱ្យបានត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រា" (ខ.២៩) ។ *ទ្រង់ហៅមក* នេះគឺជាការត្រាស់ហៅដ៏មានប្រសិទ្ធភាពមួយរបស់ព្រះអម្ចាស់ដែលមានចម្លើយវិជ្ជមានជានិច្ច ។

**៨:២៩** *បានស្គាល់ជាមុន* ត្រង់ចំណុចនេះមានអ្នកខ្លះយល់ថាវាជាចំណេះដឹងអរូបី ប៉ុន្តែ ដោយផ្អែកលើសេចក្ដីស្រឡាញ់ បូករួមនឹងគោលបំណងផង ។ ពួកគេប្រកាន់ចំណុចមួយថា ព្រះអម្ចាស់មិនគ្រាន់តែស្គាល់យើងរាល់គ្នាមុន

ជារូបអង្គនៃព្រះរាជបុត្រាទ្រង់[ឲ] ដើម្បីឱ្យព្រះរាជបុត្រា បាន
ធ្វើជាបងច្បងគេ[ឍ] ក្នុងពួកបងប្អូនជាច្រើន ៣០ឯពួកអ្នកដែល
ទ្រង់បានដំរូវទុកជាមុន[ណ] នោះទ្រង់ក៏ហៅ ហើយពួកអ្នក
ដែលទ្រង់បានហៅ[ត] នោះទ្រង់ក៏រាប់ទុកជាសុចរិត ហើយ
ពួកអ្នកដែលទ្រង់បានរាប់ជាសុចរិត[ថ] នោះទ្រង់ក៏បាន
ដំកើងឡើងដែរ[ទ]។
៣១ដូច្នេះ យើងនឹងថ្លែងប្រាប់ពីសេចក្ដីទាំងនេះថាដូច
ម្ដេច[ធ] បើសិនជាព្រះកាន់ខាងយើង[ន] តើអ្នកណាអាចទាស់
នឹងយើងបាន[ប] ៣២ឯព្រះអង្គ ដែលមិនបានសំចៃទុកនូវ
ព្រះរាជបុត្រាទ្រង់បង្កើត[ផ] គឺបានបញ្ជូនទ្រង់ទៅជំនួស
យើងរាល់គ្នា នោះតើមានទំនងអ្វី ឱ្យទ្រង់មិនប្រទានគ្រប់
ទាំងអស់មកយើង ជាមួយនឹងព្រះរាជបុត្រាទ្រង់នោះផង
៣៣តើអ្នកណានឹងចោទប្ដឹង[ព]ពីពួករើសតាំងរបស់ព្រះបាន
ដ្បិតគឺជាព្រះហើយ ដែលទ្រង់រាប់គេជាសុចរិត ៣៤តើអ្នក
ណានឹងកាត់ទោសគេបាន[ភ] ដ្បិតព្រះគ្រីស្ទទ្រង់បានសុគត[ម]
ជំនួសគេហើយ តែដែលថា ទ្រង់រស់ឡើងវិញ[យ] នោះមាន
ទំនងជាង ទ្រង់ក៏គង់នៅខាងស្ដាំនៃព្រះ[រ] ហើយជាអ្នកអង្វរ
ជំនួសយើងរាល់គ្នាដែរ[ល] ៣៥តើអ្នកណានឹងពង្រាត់យើង
ចេញពីសេចក្ដីស្រឡាញ់របស់ផងព្រះគ្រីស្ទបាន[វ] តើសេច
ក្ដីទុក្ខលំបាក ឬសេចក្ដីវេទនា សេចក្ដីបៀតបៀន សេចក្ដី
អត់ឃ្លាន សេចក្ដីអាក្រាត សេចក្ដីអន្តរាយ ឬដាវ ឬអ្វី[ស]
៣៦ដូចមានសេចក្ដីចែងទុកមកថា «យើងខ្ញុំត្រូវគេសំឡាប់
វាល់ព្រឹកវាល់ល្ងាច ដោយយល់ដល់ទ្រង់ គេរាប់យើងទុក
ដូចជាចៀមដែលសំរាប់សំឡាប់»[ហ] ៣៧ទេគឺក្នុងសេចក្ដីទាំង
នោះ យើងខ្ញុំវិសេសលើសជាងអ្នកដែលមានជ័យជំនះទៅ
ទៀត[ឡ] ដោយសារព្រះអង្គដែលទ្រង់ស្រឡាញ់យើង[អ] ៣៨ដ្បិត
ខ្ញុំជឿជាក់ថា ទោះស្លាប់ ឬរស់ ពួកទេវតា ឬអំណាចអ្វី ការ
អ្វីនៅជាន់នេះ ឬទៅមុខ ឬឥទ្ធិឫទ្ធិអ្វី ៣៩ទីមានកំពស់ ទីជំរៅ
ឬរបស់អ្វីដែលកើតមកឯទៀតក្ដី នោះពុំអាចនឹងពង្រាត់
យើងចេញពីសេចក្ដីស្រឡាញ់របស់ព្រះ[ក] ដែលនៅក្នុងព្រះ
គ្រីស្ទយេស៊ូវជាព្រះអម្ចាស់នៃយើងរាល់គ្នាទៅបានឡើយ[ខ]។

## ការជ្រើសតាំងរបស់ព្រះអម្ចាស់

៩ ១ខ្ញុំនិយាយសេចក្ដីពិត ដោយនូវព្រះគ្រីស្ទ ខ្ញុំមិនភូត
កុហកទេ[គ] បញ្ញាចិត្តខ្ញុំក៏ធ្វើបន្ទាល់ជាមួយនឹងខ្ញុំ[ឃ] ដោយនូវ
ព្រះវិញ្ញាណបរិសុទ្ធផងថា ២ខ្ញុំមានសេចក្ដីទុក្ខសោកជាខ្លាំង

**៨:២៩** ឍ កល ១:១៨ **៨:៣០** ណ អភ ១:៥, ១១ ត ខ.២៨ ថ រម ៤:២៥ ទ រម ៩:២៣ **៨:៣១** ធ រម ៤:១ ៦:១ ៧:៧ ៩:១៤,៣០ ន នក ៣:១២ អស ៤១:១០ ហក ១:១៣ ប ទដ ៥៦:៩ ១១៨:៦ អស ៨:១០ យរ ២០:១១ ហព ១៣:៦ **៨:៣២** ផ លប ២២:១៣ មឡ ៣:១៧ យហ ៣:១៦ រម ៥:៨ **៨:៣៣** ព អស ៥០:៨,៩ **៨:៣៤** ភ ខ.១ ម រម ៥:៦–៨ យ កច ២:២៤ រ មក ១៦:១៩ ល ខ.២៧ យប ១៦:២០ អស ៥៣:១២ ហព ៧:២៥ ៩:២៤ ១យហ ២:១

**៨:៣៥** វ ខ.៣៧–៣៩ ស ១កថ ៤:១១ ១កថ ១១:២៦,២៧ **៨:៣៦** ហ ទដ ៤៤:២២ ១កថ ៤:៩ ១៥:៣០,៣១ ២កថ ៤:១១ ៦:៩ ១១:២៣ **៨:៣៧** ឡ ១កថ ៣:២២ អ អភ ១:២១ កឡ ១:១៦ ១ពត ៣:២២ **៨:៣៩** ក រម ៥:៨ ខ ខ.១ រម ១៦:៣ **៩:១** គ ទដ ១៥:២ ២កថ ១១:១០ កទ ១:២០ ១ធថ ២:៧ ឃ រម ១:៩

នឹងយើងស្គាល់ទ្រង់ ប៉ុណ្ណោះនោះទេ តែទ្រង់ថែមទាំងដឹងពីរបៀបនៃការជ្រើសរើសយើងដោយព្រះគុណរបស់ទ្រង់ មុនកំណើតលោកីយនោះទៀតផង (អភ ១:៤ ២ធថ ១:៩ និងការ ពន្យល់)។ អ្នកខ្លះទៀតជឿថា ត្រង់ចំណុចនេះ លោកប៉ុលបញ្ជាក់ពីសេចក្ដីពិតថា អ្នកដែលមានជំនឿនោះបានក្លាយទៅជារាស្ត្ររបស់ទ្រង់ ។ *ដំរូវទុកជាមុន* ការតម្រូវទុកជាមុននៅត្រង់នេះគឺជាការអនុលោមទៅនឹងភាពស្រដៀងគ្នានៃព្រះ រាជបុត្រារបស់ព្រះ ។ *បានធ្វើជាបងច្បងគេ ក្នុងពួកបងប្អូនជាច្រើន* នេះហើយជាហេតុផលដែលព្រះអម្ចាស់បានស្គាល់មុនតម្រូវទុកជាមុន ហើយនិងជាគំរូដល់អ្នកជឿជាច្រើន ដើម្បីឱ្យពួកគេបានត្រឡប់ដូចជារូបអង្គព្រះគ្រីស្ទគឺជាព្រះរាជបុត្រាដែលទ្រង់គង់នៅកន្លែងដ៏ខ្ពស់បំផុតក្នុងដំណាក់គ្រួសារនៃព្រះ ។

**៨:៣០** *ដំរូវវទុកជាមុន . . . បានដំកើងឡើង* នេះជាលទ្ធផលដែលព្រះអម្ចាស់បានបន្តការតម្រូវទុកជាមុននោះ ។ *ដំកើងឡើង* ដោយសារការតម្កើងឡើងនេះជាចំណុចចុងក្រោយ នោះព្រះអម្ចាស់ត្រូវកំណត់ទិសដៅយ៉ាងរឹងមាំនៅក្នុងការតម្រូវទុកជាមុន ដូចដែលបានឃើញក្នុងបទគម្ពីរ ។

**៨:៣២** នៅក្នុងខនេះគឺជាការវែកញែកពីការដែលធំបំផុតមកតូចបំផុតវិញគឺមានភាពស្រដៀងគ្នានៅក្នុង ៥:៩–១០ ។ បើព្រះអម្ចាស់បានប្រទានអំណោយដ៏សំខាន់ បំផុតគឺព្រះរាជបុត្រារបស់ទ្រង់ដើម្បីឱ្យយើងបានសង្គ្រោះនោះប្រាកដជាទ្រង់នឹង ប្រទានអ្វីៗគ្រប់យ៉ាងដើម្បីនាំមកនូវជ័យជម្នះ ដោយ–ចាប់ផ្ដើមពីលើឈើឆ្កាង (មើលការពន្យល់ លប ២២:១៦)។

**៨:៣៣–៣៤** នៅក្នុងខនេះបាននិយាយពីច្បាប់តុលាការនៅក្នុងគំនិតថា គ្មានការចោទប្ដឹងណាមួយអាចទាស់នឹងគ្រីស្ទបរិស័ទបាននោះឡើយ ពីព្រោះព្រះអម្ចាស់បានប្រកាសសាលក្រមនៃការគ្មានទោសនោះ រួចបាត់ទៅហើយ

**៨:៣៤** *តើអ្នកណានឹងកាត់ទោសគេបាន?* នេះជាភាសាបន្ទរមួយចេញពី អស ៥០:៩ លោកសាវ័កប៉ុលបានផ្ដល់ហេតុផល៣យ៉ាងដែលថា គ្មាននរណាម្នាក់អាចកាត់ទោសពួករើសតាំងរបស់ព្រះបានៈ (១).ព្រះគ្រីស្ទបានសុគតជំនួសយើង (២).ព្រះគ្រីស្ទទ្រង់កំពុងមានព្រះជន្មរស់ ហើយគង់នៅខាងស្ដាំព្រះហស្តនៃព្រះអម្ចាស់ជា កន្លែងមានអំណាចព្រះចេស្ដា (៣).ព្រះគ្រីស្ទទ្រង់កំពុងទូលអង្វរជំនួសយើង ។

**៨:៣៥–៣៩** ត្រង់នេះ លោកប៉ុលចង់បង្ហាញដល់អ្នកអានរបស់លោកថាការរងទុក្ខលំបាក មិនមែនញែកអ្នកជឿចេញពីព្រះគ្រីស្ទនោះទេ តែតាមពិតគឺជាដំណើរដែលនាំឆ្ពោះទៅរកគោលដៅចុងបំផុតវិញ ។

**៨:៣៦** ខនេះដកស្រង់ពី ទដ ៤៤:២២ ដែលបញ្ជាក់ថាការរងទុក្ខលំបាកគឺជាផ្នែកមួយនៃបទពិសោធន៍នៃរាស្ត្ររបស់ព្រះ (មើលការពន្យល់ ភល ១:២៩)

**៨:៣៧** *ដែលទ្រង់ស្រលាញ់យើង* នេះគឺជាសេចក្ដីស្រលាញ់របស់ព្រះគ្រីស្ទយេស៊ូវ ដែលបានបង្ហាញដល់យើងរាល់គ្នាដោយការសុគតនៅលើឈើឆ្កាង (លប ២២:១៦ កទ ២:២០ អភ ៥:២៥)។

**៨:៣៩** *ទីមានកំពស់ ទីជំរៅ* គ្មានអ្វីជ្រាលជ្រៅ ឬពិសេសជាងសេចក្ដីស្រលាញ់របស់ព្រះយេស៊ូវនោះឡើយ(អភ ៣:១៧–១៩)។ *របស់អ្វីដែលកើតមក* មានន័យថា របស់ទាំងអស់ដែលព្រះអម្ចាស់បានបង្កើតមក នោះពុំអាចនឹងពង្រាត់យើងចេញពីសេចក្ដីស្រលាញ់របស់ព្រះបានឡើយ (ដោយមិនរាប់ពីព្រះអម្ចាស់) ទ្រង់តែ១អង្គគត់ដែលបានរាប់យើងជាសុចរិត (មើលការពន្យល់ ខ.៣៣–៣៤)។

**៩:១** *ដោយនូវព្រះវិញ្ញាណបរិសុទ្ធ* បញ្ញាចិត្តដែលធ្វើឱ្យយើងដឹងខុសត្រូវបានមានតែព្រះវិញ្ញាណបរិសុទ្ធនេះទេ ។

នឹងសេចក្ដីព្រួយលំបាកក្នុងចិត្តជានិច្ច ៣ដ្បិតខ្ញុំស្ទើរតែនឹង
សូមឱ្យព្រះគ្រីស្ទដាក់បណ្ដាសា[ង]ខ្ញុំវិញ[ច] ជំនួសបងប្អូនជាញាតិ
សន្តានរបស់ខ្ញុំ[ឆ] ខាងឯសាច់ឈាម[ជ] ៤គឺជាសាសន៍អ៊ីស្រា-
អែល[ឈ] ដែលគេមានការចិញ្ចឹមជាកូនព្រះ[ញ] នឹងសិរីល្អ[ដ]
សេចក្ដីសញ្ញា[ឋ] ការប្រទានក្រឹត្យវិន័យ[ឌ] របៀបថ្វាយបង្គំ[ឍ]
នឹងសេចក្ដីសន្យាជារបស់ផងខ្លួន[ណ] ព្រមទាំងពួកឰយុកោ
ផង ៥ហើយព្រះគ្រីស្ទក៏បានកើតពីពួកគេ[ត]ខាងឯសាច់ឈាម
ដែរ[ថ] ដែលទ្រង់ខ្ពស់លើសទាំងអស់[ទ] ជាព្រះដ៏មានពរអស់
កល្បជានិច្ច[ធ] អាម៉ែន ។
៦ប៉ុន្តែ មិនមែនថាព្រះបន្ទូលទចអាក់នោះទេ[ន] ដ្បិតមិន
មែនអស់អ្នកដែលកើតក្នុងសាសន៍អ៊ីស្រាអែល ជាសាសន៍
អ៊ីស្រាអែលពិតនោះឡើយ[ប] ៧ក៏មិនមែនជាកូនលោក
អ័ប្រាហាំទាំងអស់គ្នា ដោយព្រោះតែជាពូជលោកនោះ
ដែរ តែមានសេចក្ដីចែងទុកមកថា «ពូជឯងនឹងបានរាប់ពី
អ៊ីសាកមក»[ផ] ៨គឺថា មិនមែនកូនខាងសាច់ឈាម ដែលជា
កូនរបស់ព្រះនោះទេ[ព] ឯកូនខាងឯសេចក្ដីសន្យា នោះទើប
បានរាប់ជាពូជវិញ[ភ] ៩ដ្បិតសេចក្ដីសន្យានោះ គឺជាព្រះ
បន្ទូលនេះដែលថា «អញនឹងមកវិញតាមកំណត់នេះ នោះ
សារ៉ានឹងមានកូន»[ម] ១០មិនតែប៉ុណ្ណោះសោត រេបិកាក៏មាន
ផ្ទៃពោះនឹងមនុស្សម្នាក់ដែរ គឺអ៊ីសាក ជាឰយុកោនៃយើងរាល់
គ្នា[យ] ១១គ្រាដែលកូនមិនទាន់កើតមកនៅឡើយហើយមិនទាន់
ធ្វើការល្អឬអាក្រក់អ្វី[រ] ១២នោះព្រះទ្រង់មានបន្ទូលប្រាប់នាង

**៩:៣** ង ១កថ ១២:៣ ១៦:២២ ច នក ៣២:៣២ ឆ កច ២២:៥ ជ រម ១១:១៤ **៩:៤** ឈ ខ.៦ ញ នក ៤:២២ ៦:៧ ចទ ៧:៦ ដ ហព ៩:៥ ឋ លប ១៧:២ ចទ ៤:១៣ កច ៣:២៥ អភ ២:១២ ឌ ទដ ១៤៧:១៩ ឍ ហព ៩:១ ណ កច ១៣:៣២ កទ ៣:១៦ **៩:៥** ត រម ១១:២៨ ថ មថ ១:១-១៦ រម ១:៣ ទ យហ ១:១ កល ២:៩ ធ រម ១:២៥ ២កថ ១១:៣១ **៩:៦** ន ហព ៤:១២ ប រម ២:២៨,២៩ កទ ៦:១៦ **៩:៧** ផ លប ២១:១២ ហព ១១:១៨ **៩:៨** ព រម ៨:១៤ ភ កទ ៣:១៦ **៩:៩** ម លប ១៨:១០,១៤ **៩:១០** យ លប ២៥:២១ **៩:១១** រ ខ.១៦

**៩:៣** *ដាក់បណ្ដាសា* ពាក្យនេះជាសាភាក្រិកមានន័យថា សេចក្ដីក្រោធរបស់ព្រះអម្ចាស់ឱ្យមកបំផ្លាញអស់កល្បជានិច្ច(១កថ ១២:២២ កទ ១:៨ និងការពន្យល់)។ នេះជាការថ្លែងបញ្ជាក់ពីក្ដីស្រលាញ់យ៉ាងខ្លាំងរបស់លោកប៉ុលចំពោះញាតិសន្តានរបស់ខ្លួនជាសាសន៍យូដា(នក ៣២:៣២ ជាឧយោងពីក្ដីស្រលាញ់)។

**៩:៤** *សាសន៍អ៊ីស្រាអែល* ចង់សំដៅលើដំណរកូនចៅរបស់លោកយ៉ាកុប (ដែលបន្សល់ពីអ៊ីស្រាអែលដោយព្រះគុណរបស់ព្រះអម្ចាស់ លប ៣២:២៨ និងការពន្យល់)។ ឈ្មោះអ៊ីស្រាអែលត្រូវបានប្រើពេញទាំងជាតិសាសន៍ (ពច ៥:៧) រហូតដល់នគរភាគខាងជើង ក្រោយមកនគរក៏ត្រូវបំបែកជាពីរ (១ពវ ១២) ភាគខាងត្បូងត្រូវបានហៅថាយូដា ។ នៅក្នុងចន្លោះគម្ពីរសញ្ញាចាស់ និងគម្ពីរសញ្ញាថ្មី ហើយនិងនៅសម័យដើមគម្ពីរសញ្ញាថ្មី ពួកសាសន៍ប៉ាឡេស្ទីន សាសន៍យូដាបានប្រកាន់ខ្ជាប់ថា ខ្លួនគេត្រូវបានជ្រើសរើសធ្វើជារាស្ត្ររបស់ព្រះ ។ ការប្រើនៅត្រង់នេះ ក៏មានការទាក់ទងជាពិសេសផងដែរ ពីព្រោះប្រហែលជាលោក ប៉ុលចង់បង្ហាញថា ទោះបីពួកអ៊ីស្រាអែលមិនជឿ និងមិនស្ដាប់បង្គាប់យ៉ាងណាក៏ដោយ ក៏សេចក្ដីសន្យារបស់ព្រះជាមួយនឹងពួកអ៊ីស្រាអែលនៅតែមានប្រសិទ្ធភាព ។ *ការចិញ្ចឹម* មានន័យថាពួកអ៊ីស្រាអែលបានទទួលធ្វើជាកូនរបស់ព្រះអម្ចាស់ (នក ៤:២២ យរ ៣១:៩ ហស ១១:១ និងការពន្យល់)។ *សិរីល្អ* គឺជាភស្ដុតាងនៃព្រះវត្តមានរបស់ព្រះនៅក្នុងចំណោមរាស្ត្ររបស់ទ្រង់(នក ១៦:៧,១០ លវ ៩:៦, ២៣ ជន ១៦:១៩)។ *សេចក្ដីសញ្ញា* នេះគឺជាការតាំងសញ្ញារវាងព្រះអម្ចាស់ និងមនុស្ស ឧទាហរណ៍ លោកអាប់រ៉ាម(លប ១៥:១៧-២១ ១៧:១-៨), លោកម៉ូសេ(នក ១៩:៥ ២៤:១-៤) ការកែប្រែថ្មីលើទឹកដីស្រុកម៉ូអាប់(ចទ ២៩:១-១៥) ត្រង់ភ្នំអេបាល និងភ្នំកេរិស៊ីម(យស ៨:៣០-៣៥) និងនៅត្រង់ស្រុកស៊ីគែម(យស ២៤) ពូជលេវី(ជន ២៥:១២-១៣ យរ ៣៣:២១ មឡ ២:៤-៥) ពូជដាវីឌ(២សយ ៧ ២៣:៥ ទដ ៨៩:៣-៤,២៨-២៩ ១៣២:១១-១២) ហើយចុងក្រោយនេះគឺជាបទទំនាយមាននៅក្នុង យរ ៣១:៣១-៣៤ ។ *សេចក្ដីសន្យា* នេះគឺនិយាយពីការសន្យារបស់ព្រះអម្ចាស់ជាពិសេសការសន្យាជាមួយនឹងលោកអ័ប្រាហាំ(លប ១២:៧ ១៣:១៤-១៧ ១៧:៥-៨ ២២:១៦-១៨ និងការពន្យល់)។ ប៉ុន្តែក៏រួមមានទាំងការសន្យាជាច្រើនទៀតអំពីព្រះមែស៊ីនៅក្នុងគម្ពីរសញ្ញាចាស់ផងដែរ(២សយ ៧:១២,១៦ អស ៩:៦-៧ យរ ២៣:៥ ៣១:៣១-៣៤ អគ ៣៤:២៣-២៤ ៣៧:២៤)។

**៩:៥** *ពួកគេ* គឺនិយាយពីដំណរពូជរបស់លោកអ័ប្រាហាំអ៊ីសាក យ៉ាកុប និងកូនចៅរបស់គាត់ ។ *ព្រះគ្រីស្ទ . . . ជាព្រះ* នេះជាសេចក្ដីថ្លែងដែលច្បាស់ជាងគេបំផុតនៃភាពជាព្រះរបស់ព្រះគ្រីស្ទយេស៊ូវដែលមានពេញគម្ពីរសញ្ញា ថ្មី ដូចជា ១:៤ ១០:៩ មថ ១:២៣ ២៨:១៩ លក ១:៣៥ ៥:២០-២១ យហ ១:១,៣,១០,១៤,១៨ ៥:១៨ ២០:២៨ ២កថ ១៣:១៤ ភល ២:៦ កល ១:១៥-២០ ២:៩ ទត ២:១៣ ហព ១:២-៣,៦,៨ ២ពត ១:១ វវ ១:១៣-១៨ ២២:១៣ ព្រមទាំងការពន្យល់ផងដែរ ។

**៩:៦** *ព្រះបន្ទូល* ព្រះបន្ទូលត្រង់នេះមានគោលបំណងយ៉ាងច្បាស់លាស់ មិនមែនធ្វើឱ្យនរណាម្នាក់ទចអាក់នោះទេ ពីព្រោះសាសន៍ អ៊ីស្រាអែលទាំងអស់ពុំមែនជា អ៊ីស្រាអែលពិតគ្រប់គ្នានោះទេ ។ ទាំងនេះពុំមានន័យថាអ៊ីស្រាអែលជាសាសន៍មិនបានជ្រើសរើសនោះទេ តែមានន័យថា នៅក្នុងចំណោមសាសន៍អ៊ីស្រាអែលទាំងមូលត្រូវបានចែកជាពីរ គឺអ៊ីស្រាអែលជាអ្នកជឿ និងអ៊ីស្រាអែលជាអ្នកមិនជឿ ។ ការតាំងខ្លួនជាអ៊ីស្រាអែលខាងសាច់ឈាម នោះពុំមានកន្លែងណាដែលធានាថា ជាក្រុមគ្រួសារនៃព្រះខាងឯវិញ្ញាណនោះឡើយ ។

**៩:៧** *កូន* សំដៅលើកូនខាងឯសាច់ឈាម ដែលមិនមែនជាសេចក្ដីសន្យារបស់ទ្រង់ ទេ(ឧទាហរណ៍ អ៊ីសម៉ាអែល និងកូនចៅរបស់គាត់)។

**៩:៨** *កូនខាងឯសេចក្ដីសន្យា* មិនផ្ដោតលើកូនខាងសាច់ឈាមដែលចេញពីលោកអ័ប្រាហាំនោះទេ តែផ្ដោតលើកូនដែលព្រះបានសន្យាឱ្យនោះវិញ ។ *កូនរបស់ព្រះ* មើលខ.៤ ។ ត្រង់នេះពុំមែនមានន័យថាអ៊ីស្រាអែលទាំងអស់គឺជាកូនរបស់ព្រះទេ (យហ ៨:៤៤ និងការពន្យល់) ប៉ុន្តែសំដៅលើអ៊ីស្រាអែលណាដែលជឿព្រះ ។

**៩:១១-១២** ខនេះចង់ប្រាប់ថា ព្រះអម្ចាស់មានគម្រោងជ្រើសរើសមនុស្សដោយមិនគិតពីអំពើដែលគេប្រព្រឹត្តនោះទេ ។ ការជ្រើសរើសតាមព្រះហឫទ័យរបស់ទ្រង់ ដែលត្រាស់ហៅ ដើម្បីឱ្យបានស្របតាមគម្រោងការនេះ ពេលកូនភ្លោះនៅក្នុងផ្ទៃ ពុំទាន់បានប្រព្រឹត្តការល្អ ឬអាក្រក់នៅឡើយផង (អភ ១:៤)។ នេះជាសាច់រឿងរបស់លោកអ៊ីសាកដែលមានប្រពន្ធឈ្មោះ

ថា «កូនច្បងនឹងត្រូវបំរើប្អូន»[ល] ១៣ដូចមានសេចក្ដីចែងទុក
មកថា «អញបានស្រឡាញ់យ៉ាកុប តែស្អប់អេសាវវិញ»[វ] គឺ
ដើម្បីឱ្យព្រះដំរិះរបស់ព្រះ[ស] ខាងឯសេចក្ដីរើសតាំងបាន
ជាប់នៅ មិនមែនដោយអាងការប្រព្រឹត្តទេ គឺដោយអាង
ព្រះដែលទ្រង់ហៅវិញ ។
១៤ដូច្នេះ យើងនឹងថាដូចម្ដេច[ហ] តើព្រះមានសេចក្ដីទុច្ចរិត
ឬអី ទេ គ្មានសោះ[ឡ] ១៥ដ្បិតទ្រង់មានបន្ទូលទៅលោកម៉ូសេ
ថា «អញនឹងផ្សាយសេចក្ដីមេត្តាករុណា ដល់អ្នកណាដែល
អញមេត្តាករុណា ក៏នឹងមានសេចក្ដីក្ដួលអាណិតដល់អ្នក
ណាដែលអញក្ដួលអាណិត»[អ] ១៦ដូច្នេះមិនសំរេចនឹងអ្នកណា
ដែលចង់បាន ឬនឹងអ្នកណាដែលខំរត់តាមនោះទេ គឺស្រេច
នឹងព្រះ ដែលមានសេចក្ដីមេត្តាករុណាវិញ[ក] ១៧ដ្បិតមាន
បទគម្ពីរសំដែងដល់ផារ៉ោនថា «អញបានតាំងឯងឡើង
សំរាប់ការនេះឯង គឺដើម្បីសំដែងឫទ្ធិបារមីអញក្នុងខ្លួនឯង
ប្រយោជន៍ឱ្យគេប្រកាសប្រាប់ពីឈ្មោះអញ ទូទៅពេញលើ
ផែនដី»[ខ] ១៨ដូច្នេះ ទ្រង់តែងផ្សាយមេត្តាករុណាដល់អ្នក
ណាតាមព្រះហឫទ័យ ហើយទ្រង់ធ្វើឱ្យអ្នកណារឹងទទឹង ក៏
តាម តែព្រះហឫទ័យដែរ[គ] ។
១៩ដូច្នេះ អ្នកនឹងសួរខ្ញុំថា[ឃ] ហេតុអ្វីបានជាទ្រង់នៅ
តែបន្ទោសទៀត[ង] ដ្បិតតើអ្នកណាបានទទឹងនឹងព្រះហឫ
ទ័យទ្រង់[ច] ២០ប៉ុន្តែ ឱមនុស្សអើយ តើអ្នកជាអ្វី ដែល
ហ៊ានឆ្លើយទាស់នឹងព្រះដូច្នេះ[ឆ] តើរបស់ដែលជាងស្មូន
បានសូនធ្វើហើយ នឹងនិយាយ[ជ]ទៅជាងនោះថា ហេតុអ្វី
បានជាសូនធ្វើអញដូច្នេះឬអី[ឈ] ២១តើជាងស្មូនគ្មានអំ
ណាច លើដីឥដ្ឋ និងយកដុំដីដដែលធ្វើជាវត្ថុ១ សំរាប់ការ
ដ៏ប្រសើរ ហើយ១ទៀតសំរាប់ការមិនប្រសើរទេឬអី[ញ]

**៩:១២** ល លប ២៥:២៣ **៩:១៣** វ មឡ ១:២,៣ ស រម ៨:២៨ **៩:១៤** ហ រម ៨:៣១ ឡ ២កថ ១៩:៧ **៩:១៥** អ នក ៣៣:១៩ **៩:១៦** ក អភ ២:៨ ទត ៣:៥ **៩:១៧** ខ នក ៩:១៦ ១៤:៤ ទដ ៧៦:១០ **៩:១៨** គ នក ៤:២១ ៧:៣ ១៤:៤,១៧ ចទ ២:៣០ យក ១១:២០ រម ១១:២៥

**៩:១៩** ឃ រម ១១:១៩ ១កថ ១៥:៣៥ យក ២:១៨ ង រម ៣:៧ ច ២សយ ១៦:១០ ២រប ២០:៦ ដយ ៤:៣៥ **៩:២០** ឆ យប ១:២២ ៩:១២ ៤០:២ ជ សយ ៦៤:៨ យរ ១៨:៦ ឈ អស ២៩:១៦ ៤៥:៩ ១០:១៥ **៩:២១** ញ ២ធថ ២:២០

---

របិកាបានបង្កើតកូនភ្លោះ បើតាមប្រពៃណីរបស់សាសន៍យូដា កូនច្បងអេសាវត្រូវទទួលមរដក តែនៅត្រង់នេះយ៉ាកុបជាប្អូនបានទទួលវិញ(លប ២៥:២០–២៦ ២៧:១–៣៥)។

**៩:១៣** *អញបានស្រឡាញ់យ៉ាកុប តែស្អប់អេសាវវិញ* ឃ្លានេះមានន័យថា "អញបានជ្រើសរើសយ៉ាកុប តែបដិសេធអេសាវវិញ"(លក ១៤:២៦ និងការពន្យល់)។ នៅក្នុងខ.៦–១៣ លោកប៉ុលបានបកស្រាយពីការជ្រើសរើសជាបុគ្គលមិនមែនជាជាតិសាសន៍នោះទេ ។ គាត់មិនមែនកំពុងនិយាយពីជាតិសាសន៍អ៊ីស្រាអែល(មកពីយ៉ាកុប) ដែលប្រសើរជាងជាតិសាសន៍អេដុំម (មកពីអេសាវ)នោះដែរ។ តែទោះបីយ៉ាងនេះក៏ដោយនៅក្នុង មឡ ១:២–៣ ក៏បាននិយាយពីជាតិសាសន៍ទាំងពីរនេះដែរ ។ លោកប៉ុលបានផ្ដោតទៅលើរបៀបដោះស្រាយបញ្ហាថា តើសេចក្ដីសន្យារបស់ព្រះអម្ចាស់បានសម្រេចលើសាសន៍អ៊ីស្រាអែលមានគ្នាច្រើន (ការប្រមូលគំនិតនៅក្នុងអត្ថបទគម្ពីរសញ្ញាចាស់)មិនជឿនិងកាត់ចេញយ៉ាងណា? មើលក្នុងជំពូក១១ និងការពន្យល់ ។

**៩:១៤** *តើព្រះមានសេចក្ដីទុច្ចរិតឬអី?* សំណួរចង់សួរថា តើព្រះមានសេចក្ដីទុច្ចរិតឬអី ក្នុងការជ្រើសរើសយ៉ាកុបនោះ? នេះជាសំណួរដែលវែកញែកពីព្រះហឫទ័យរបស់ព្រះក្នុងការជ្រើសរើសលោកយ៉ាកុប ។

**៩:១៥** ត្រង់នេះលោកប៉ុលប្រាប់ថា ពុំមែនជារឿងអយុត្តិធម៌នោះទេ ក្នុងដំណើរដែលព្រះអម្ចាស់បានដោះស្រាយជាមួយអ៊ីសាក និងអ៊ីសម៉ាអែល ហើយយ៉ាកុប និងអេសាវគឺអាស្រ័យលើព្រះទ័យមេត្តាករុណារបស់ទ្រង់ទេ ។

**៩:១៦** ក្នុងខនេះបានពន្យល់យ៉ាងច្បាស់ថា ការសម្រេចរបស់ព្រះអម្ចាស់មនុស្សពុំអាចគ្រប់គ្រង ឬដឹងបានទេ ។ លោកប៉ុលបានប្រាប់ផងដែរថា ការបដិសេធរបស់សាសន៍អ៊ីស្រាអែល គឺដោយសារតែគេមិនជឿ(ខ.៣០–៣២ និងការពន្យល់)។

**៩:១៧** *ផារ៉ោន* នេះគឺជាឈ្មោះនៃវង្សត្រកូលស្ដេចនៅប្រទេសអេស៊ីព្ទដែលបានអនុញ្ញាតឱ្យអ៊ីស្រាអែលចេញមកដោយសារការអស្ចារ្យរបស់ព្រះ ។ *អញបានតាំងឯងឡើង* មានន័យថាឱ្យធ្វើជាអ្នកគ្រប់គ្រងនៅប្រទេសអេស៊ីព្ទ *ឈ្មោះអញ* ពាក្យនេះសំដែងពីបុគ្គលិកលក្ខណៈនៃព្រះអម្ចាស់ជាពិសេសក្នុងការបើកសំដែងឱ្យពួកអ៊ីស្រាអែលចេញពីអេស៊ីព្ទ(នក ១៥:១៣–១៨ យស ២:១០–១១ ៩:៩ ១យស ៤:៨)។

**៩:១៨** នៅត្រង់ផ្នែកដំបូងនៃខនេះបន្ទរពី នក ៣៣:១៩(មើល ខ.១៥) ហើយផ្នែកចុងក្រោយនៃខនេះមានអត្ថបទដូចគ្នានឹង នក ៧:៣ ៩:១២ ១៤:៤,១៧ ដែលប្រាប់ពីចិត្តរឹងរបស់ស្ដេចផារ៉ោន និងពួកអេស៊ីព្ទ ។ *ផ្សាយមេត្តាករុណាដល់អ្នកណាតាមព្រះហឫទ័យ* ត្រង់ចំណុចនេះពុំមែនមានន័យថា ព្រះអម្ចាស់រំលោភបំពានលើសេចក្ដីមេត្តាករុណារបស់ទ្រង់នោះទេ ពីព្រោះលោកប៉ុលសំអាងលើការបដិសេធរបស់ព្រះចំពោះអ៊ីស្រាអែល ដោយផ្អែកលើការមិនជឿរបស់ពួកគេ (ខ.៣០–៣២)។

**៩:១៩** មានមនុស្សខ្លះអាចជំទាស់ថា បើព្រះទ្រង់ជាអ្នកធ្វើឱ្យមនុស្សខ្លះមានចិត្តរឹងហើយខ្លះទៀតគ្មាន នោះតើទ្រង់អាចបន្ទោសអ្នកដែលមានចិត្តរឹងនោះយ៉ាងម៉េច?

**៩:២០** *ឱមនុស្សអើយ តើអ្នកជាអ្វី ដែលហ៊ានឆ្លើយទាស់នឹងព្រះដូច្នេះ?* ត្រង់នេះមិនមែនលោកប៉ុលមិនឆ្លើយសំណួររបស់អ្នកដទៃអំពីព្រះនោះទេ ប៉ុន្តែពេលនេះ គាត់កំពុងតែនិយាយទៅកាន់អ្នកដែលមិនចេះអត់ធ្មត់អ្នកដែលបំពានលើឥរិយាបថរបស់ព្រះ អ្នកដែលចង់ដឹងពីសកម្មភាពរបស់ព្រះ ហើយនិងអ្នកដែលសួរសំណួរដើម្បីប្រមាថដល់អង្គទ្រង់ ។

**៩:២១** នៅក្នុងខនេះគឺជាការពន្យល់ប្រៀបធៀបរវាងព្រះ និងជាងស្មូនហើយចំណែកឯមនុស្សធៀបទៅនឹងដីឥដ្ឋ ដូច្នេះឃើញខុសគ្នាឆ្ងាយណាស់ ។ ចំណុចសំខាន់ គឺថានេះជាសិទ្ធិសេរីភាពរបស់ព្រះក្នុងការដោះស្រាយជាមួយនឹងមនុស្ស (យរ ១៨:១–១០ និងការពន្យល់)។

**៩:២២–២៣** នៅក្នុងខនេះគឺជាសេចក្ដីពន្យល់ជាឧទាហរណ៍បញ្ជាក់បន្ថែមទៅលើ ខ.២១ ដោយផ្ដោតលើសេចក្ដីមេត្តាករុណា និងសេចក្ដីក្រោធរបស់ព្រះអម្ចាស់ ។

២២ចុះបើសិនជាព្រះទ្រង់ចង់សំដែងសេចក្ដីក្រោធ ព្រម
ទាំងបើកឱ្យស្គាល់ព្រះចេស្ដា ដល់គ្រឿងប្រដាប់គួរនឹង
ក្រោធ ដែលរៀបចំឡើងសំរាប់តែត្រូវបំផ្លាញដូច្នេះ[ដ]
ដែលទ្រង់ទ្រាំទ្រដោយអំណត់[ឋ]ជាយូរមកហើយ ២៣ហើយ
បើទ្រង់ចង់បើកឱ្យពួកគ្រឿងប្រដាប់[ឌ] ដែលគួរនឹងសេចក្ដី
មេត្តាករុណា ដែលទ្រង់បានរៀបចំជាមុន បានស្គាល់
សេចក្ដីវិសេសនៃសិរីល្អដ៏បរិបូររបស់ទ្រង់វិញ[ឍ] ២៤គឺយើង
រាល់គ្នាដែលទ្រង់បានហៅមក[ណ] មិនមែនពីសាសន៍យូដាតែ
ប៉ុណ្ណោះ គឺពីសាសន៍ដទៃផង[ត] នោះធ្វើដូម្ដេចទៅ ២៥ដូច
មានសេចក្ដីចែងទុកក្នុងគម្ពីរហូសេ សំដែងមកថា «អញនឹង
ហៅសាសន៍នោះ ដែលមិនមែនជារាស្ត្រអញ ថាជារាស្ត្រ
អញវិញ ហើយអ្នកនោះដែលមិនមែនជាស្ងួនភ្ញា ថាជា
ស្ងួនភ្ញាដែរ»[ថ] ២៦ដូច្នេះ នៅកន្លែងដែលបានសំដែងថា
«ឯងរាល់គ្នាមិនមែនជារាស្ត្រអញទេ» ត្រង់កន្លែងនោះឯង
នឹងហៅគេថា ជាកូនរបស់ព្រះដ៏មានព្រះជន្មរស់នៅវិញ[ទ]
២៧ឯហោរាអេសាយលោកក៏បន្លឺឡើង ពីដំណើរសាសន៍
អ៊ីស្រាអែលថា «ទោះបើជនជាតិអ៊ីស្រាអែលមានចំនួន
ច្រើនដូចខ្សាច់នៅមាត់សមុទ្រក៏ដោយ[ធ] គង់តែនឹងបាន
សង្គ្រោះតែសំណល់ដែលសល់ទេ[ន] ២៨ដ្បិតការនោះកំពុង
តែបង្ហើយ ហើយបង្រួមជាខ្លី ដោយសេចក្ដីសុចរិត ពីព្រោះ
ព្រះអម្ចាស់ទ្រង់នឹងកាត់ការនោះយ៉ាងខ្លីនៅលើផែនដី»[ប]
២៩ដូចជាលោកអេសាយបានទាយទុកមកអំពីមុនថា «បើ
សិនណាជាព្រះអម្ចាស់នៃពួកពលបរិវារ[ផ] ទ្រង់មិនបានទុក
ពូជឱ្យយើង នោះយើងនឹងបានត្រឡប់ដូចជាក្រុងសូដុំម
ហើយដូចជាក្រុងកូម៉ូរ៉ាដែរ»[ព]។

## ការមិនព្រមប្រែចិត្តរបស់សាសន៍អ៊ីស្រាអែល

៣០ដូច្នេះ តើយើងនឹងថាដូចម្ដេច[ភ] គឺត្រូវថាសាសន៍ដទៃ
ដែលមិនដេញតាមសេចក្ដីសុចរិត នោះបានទាន់សេចក្ដី
សុចរិតនោះហើយ គឺជាសេចក្ដីសុចរិត ដែលមកដោយ
សារសេចក្ដីជំនឿ[ម] ៣១តែឯសាសន៍អ៊ីស្រាអែលវិញ ដែល
គេដេញតាមក្រឹត្យវិន័យដ៏សុចរិត[យ] នោះគេមិនបានទាន់
ក្រិត្យវិន័យដ៏សុចរិតទេ[រ] ៣២តើដោយហេតុអ្វី គឺដោយព្រោះ
តែគេរក ដោយអាងការគេប្រព្រឹត្ត មិនមែនដោយសេចក្ដី
ជំនឿទេ ដ្បិតគេបានជំពប់នឹងថ្មជំពប់នោះ[ល] ៣៣ដូចមាន
សេចក្ដីចែងទុកមកថា «មើល អញដាក់ថ្មជំពប់១ គឺជាថ្មដា
បង្អាក់បង្អន់ចិត្ត នៅក្រុងស៊ីយ៉ូន អស់អ្នកណាដែលជឿដល់
ថ្មនោះ នឹងគ្មានហេតុនាំឱ្យខ្មាសឡើយ»[វ]។

**៩:២២** ដ រម ២:៤
ឋ សភ ១៦:៤
**៩:២៣** ឌ រម ២:៤
ឍ រម ៨:៣០
**៩:២៤** ណ រម
៨:២៨ ត រម ៣:២៩
**៩:២៥** ថ ហស
២:២៣ ១ពត ២:១០
**៩:២៦** ទ ហស ១:១០
មថ ១៦:១៦
រម ៨:១៤
**៩:២៧** ធ លប
២២:១៧
ហស ១:១០
ន ២ពវ ១៩:៤
យរ ៤៤:១៤ ៥០:២០
យអ ២:៣២
រម ១១:៥
**៩:២៨** ប អស
១០:២២,២៣
**៩:២៩** ផ យក ៥:៤
ព អស ១:៩
លប ១៩:២៤–២៩
ចទ ២៩:២៣
អស ១៣:១៩
យរ ៥០:៤០

**៩:៣០** ភ រម ៨:៣១ ម រម ១:១៧ ៣:២២ ៤:៥,១៣ ១០:៦ កទ ២:១៦ ភល ៣:៩ ហព ១១:៧ **៩:៣១** យ ចទ ៦:២៥ អស ៥១:១ រម ១០:២,៣ ១១:៧ រ កទ ៥:៤ **៩:៣២** ល ១ពត ២:៨ **៩:៣៣** វ អស ៨:១៤ ២៨:១៦ រម ១០:១១ ១ពត ២:៦,៨

**៩:២២** ត្រង់នេះចង់បញ្ជាក់ថា គ្មាននរណាម្នាក់អាចទូលទៅព្រះអម្ចាស់ឱ្យរាប់នូវអ្វីដែលទ្រង់បានធ្វើនោះឡើយ ។ ប៉ុន្តែទ្រង់មិនប្រើសិទ្ធិអំណាចក្នុងការសម្រេចព្រះទ័យដោយបំពាននោះឡើយ ហើយព្រមទាំងបង្ហាញពីសេចក្ដីអត់ធ្មត់ចំពោះសេចក្ដីក្រោធរបស់ទ្រង់ដល់អ្នក ដែលរឹងទទឹងផងដែរ ។ ការអត់ធ្មត់នេះ នាំមកនូវ ការប្រែចិត្តដល់មនុស្សលោក(២:៤ និងការពន្យល់)។

**៩:២៣** *សិរីល្អ* មើលការពន្យល់ ៣:២៣ ។

**៩:២៥–២៦** នៅក្នុងអត្ថបទដើមដែលចេញមកពីគម្ពីរហូសេ ដែលនិយាយទាក់ទងនឹងការស្អាងវិញ្ញាណឡើងវិញនៃសាសន៍អ៊ីស្រាអែល ។ ប៉ុន្តែ លោកប៉ុលបានឃើញគោលការសំខាន់ៗថាទ្រង់គឺជាព្រះសង្គ្រោះ ។ ព្រះនៃការអត់ទោសព្រះ និងការស្ដាបនា ហើយបានសំដែងដល់បណ្ដាជនដែល "មិនមែនជារាស្ត្រទ្រង់"ថា"ជារាស្ត្ររបស់ទ្រង់"វិញ ។ បន្ទាប់មកលោកប៉ុលក៏អនុវត្តគោលការនេះទៅចំពោះសាសន៍ដទៃដែលទ្រង់បានហៅពួកគេថា ជារាស្ត្ររបស់ព្រះអង្គ ដោយនាំពួកគេឱ្យមានទំនាក់ទំនងនឹងទ្រង់(ជំពូក ១១)។

**៩:២៧–២៩** ខនេះបានដកស្រង់ពី អស ១០:២២–២៣ និង ១:៩ បានបង្ហាញថា ជនជាតិអ៊ីស្រាអែលមានចំនួនច្រើន ប៉ុន្តែបានសង្គ្រោះ តែសំណល់បន្តិចបន្តួចទេ។ ការត្រាស់ហៅរបស់ព្រះអម្ចាស់មាន ទាំងសាសន៍យូដា ហើយនិងសាសន៍ដទៃ(ខ.២៤)ប៉ុន្តែ ចំពោះសាសន៍ដទៃមានទំហំធំធេងជាង(ខ.៣០)។

**៩:៣០–១០:២១** ខទាំងនេះប្រាប់ពីមូលហេតុនៃការបដិសេធរបស់ពួកអ៊ីស្រាអែល ។

**៩:៣០–៣២** នេះជាជំហានថ្មីមួយទៀតក្នុងការវែកញែករបស់លោកប៉ុលអំពីហេតុផលក្នុងការបដិសេធដល់ជនជាតិអ៊ីស្រាអែល ។ ការមិនស្ដាប់បង្គាប់បានធ្វើឱ្យពួក គេបរាជ័យក្នុងការកាន់តាមក្រឹត្យវិន័យរបស់ព្រះ ដែលបានប្រទានមកឱ្យពួកគេ ដោយបែរទៅទុកចិត្តលើការប្រព្រឹត្តផ្ទាល់ខ្លួន–របស់ពួកនោះវិញ។ ដូច្នេះ មូលហេតុដ៏ពិតប្រាកដនៃការបដិសេធរបស់ពួកគេ នេះ គឺដោយសារតែខ្វះជំនឿនេះឯង ។

**៩:៣១** *ក្រិត្យវិន័យដ៏សុចរិត* មានន័យថា ជាក្រឹត្យវិន័យដែលតម្រង់ផ្លូវទៅរកសេចក្ដីសុចរិត ។ លោកប៉ុលមិនបដិសេធក្នុងការស្ដាប់តាមក្រឹត្យវិន័យដ៏សុចរិតរបស់ព្រះអម្ចាស់តាមជំនឿដែលមានក្នុងព្រះគ្រីស្ទយេស៊ូវនោះទេ ។

**៩:៣២** *មិនមែនដោយសេចក្ដីជំនឿទេ* នេះគឺជាភាពបរាជ័យរបស់ជនជាតិអ៊ីស្រាអែលដែលបន្តនូវអ្វីដែលជាការខុសឆ្គង(ឧ: សេចក្ដីសុចរិតមាននៅតែក្នុងព្រះអម្ចាស់ទេ) ប៉ុន្តែ ពួកគេបែរជាខំប្រឹងឱ្យបានសេចក្ដីសុចរិតដោយខំប្រព្រឹត្តការឥតប្រយោជន៍ ដើម្បីឱ្យព្រះអម្ចាស់សព្វព្រះទ័យ ជាជាងឱ្យបានសេចក្ដីសុចរិតដោយសារជំនឿនោះវិញ ។ *ថ្មជំពប់* ពាក្យនេះសំដៅទៅលើព្រះយេស៊ូវដែលជាព្រះមែស៊ីថា ការបដិសេធរបស់ព្រះអម្ចាស់ចំពោះជនជាតិអ៊ីស្រាអែលមិនមែនដោយសារទ្រង់អយុត្តិធម៌នោះទេ តែដោយសារពួកអ៊ីស្រាអែលខ្លួនឯងទេ ដែលបានបដិសេធផ្លូវរបស់ព្រះដែលនាំទៅរកសេចក្ដីសុចរិតដោយសារសេចក្ដីជំនឿនោះ ។

**៩:៣៣** ខនេះបានដកស្រង់ពី អស ៨:១៤ និង ២៨:១៦ ជាបទគម្ពីរដែលត្រូវបានគ្រីស្ទបរិស័ទដំបូងយកមកប្រើសម្រាប់ពិពណ៌នាអំពីព្រះយេស៊ូវថា ជាព្រះមែស៊ី(១ពត ២:៤,៦–៨ ទដ ១១៨:២២ និងការពន្យល់ លក ២០:១៧–១៨)។

**១០** ១ បងប្អូនអើយ បំណងចិត្តខ្ញុំ[ស] និងសេចក្តីដែលខ្ញុំអង្វរ
ដល់ព្រះឱ្យសាសន៍អ៊ីស្រាអែល នោះគឺឱ្យគេបានសង្គ្រោះ
២ ដ្បិតខ្ញុំធ្វើបន្ទាល់ពីគេថា គេមានសេចក្តីឧស្សាហ៍[ហ]ដល់ព្រះ
ប៉ុន្តែ មិនមែនដោយប្រាជ្ញាទេ ៣ ពីព្រោះគេមិនបានចុះចូល
តាមសេចក្តីសុចរិតនៃព្រះ ដោយគេរកតាំងសេចក្តីសុចរិត
របស់ខ្លួនគេ ឥតស្គាល់សេចក្តីសុចរិតរបស់ទ្រង់ឡើយ[ឡ]
៤ ដ្បិតព្រះគ្រីស្ទជាចុងបំផុតនៃក្រឹត្យវិន័យ[អ] សំរាប់ជាសេចក្តី
សុចរិតដល់អស់អ្នកណាដែលជឿ[ក]។
៥ លោកម៉ូសេបានថែងពីសេចក្តីសុចរិត ដែលមកដោយ
សារក្រឹត្យវិន័យថា «មនុស្សណាដែលបានប្រព្រឹត្តតាម
សេចក្តីទាំងនោះ នឹងរស់នៅដោយសារការខ្លួនប្រព្រឹត្ត
នោះឯង»[ខ] ៦ តែសេចក្តីសុចរិតដែលមកដោយសេចក្តីជំនឿ[គ]
នោះថាដូច្នេះវិញ គឺកុំឱ្យគិតក្នុងចិត្តថា «តើអ្នកណានឹងឡើង
ទៅឯស្ថានសួគ៌»[ឃ] គឺដើម្បីនឹងនាំព្រះគ្រីស្ទចុះមក ៧ ឬ «តើ
អ្នកណានឹងចុះទៅក្នុងជង្ហុកធំ»[ង] គឺដើម្បីនឹងនាំព្រះគ្រីស្ទពី
ពួកស្លាប់ឡើងមកនោះឡើយ[ច] ៨ តែសេចក្តីសុចរិតនោះ តើ
ថាដូចម្តេច នោះថា «ព្រះបន្ទូលនៅជិតឯង ក៏នៅក្នុងមាត់
ហើយក្នុងចិត្តឯងផង»[ឆ] នោះគឺជាព្រះបន្ទូលនៃសេចក្តីជំនឿ
ដែលយើងខ្ញុំកំពុងតែប្រកាសប្រាប់ថា ៩ បើមាត់អ្នកនឹង
ទទួលថ្លែងប្រាប់[ជ] ពីព្រះអម្ចាស់យេស៊ូវ[ឈ] ហើយអ្នកជឿ[ញ]ក្នុង
ចិត្តថា ព្រះបានប្រោសឱ្យទ្រង់រស់ពីស្លាប់ឡើងវិញ[ដ] នោះ

**១០:១** ស ទដ ២០:៤ **១០:២** ហ កច ២១:២០ **១០:៣** ឡ រម ១:១៧ ៩:៣១ **១០:៤** អ កទ ៣:២៤ រម ៧:១–៤ ក រម ៣:២២ **១០:៥** ខ លវ ១៨:៥ ចទ ៤:១ ៦:២៤ នហ ៩:២៩ សក ១៩:១៦ អស ៥៥:៣ អក ២០:១១,១៣, ២១ រម ៧:១០ **១០:៦** គ រម ៩:៣០ ឃ ចទ ៣០:១២ **១០:៧** ង ចទ ៣០:១៣ ច កច ២:២៤ **១០:៨** ឆ ចទ ៣០:១៤ **១០:៩** ជ មថ ១០:៣២ ឈ យហ ១៣:១៣ ញ យហ ៣:១៥ ដ កច ២:២៤ ឋ រម ១១:១៤

**១០:១** *អង្វរដល់ព្រះឱ្យសាសន៍អ៊ីស្រាអែល* មានន័យថា លោកប៉ុលតែងតែអធិស្ឋានជូនដល់ពួកជំនុំនៅទីនោះជាច្រើន (អភ ១:១៥–២៣ ៣:១៤–២១ ភល ១:៩–១១ កល ១:៣–១៤ ១ថន ១:២–៣ ២ថន ១:៣,១១–១២)។ នៅក្នុងខនេះគាត់បានសូមសេចក្តីសង្គ្រោះដល់ជនជាតិអ៊ីស្រាអែល ។

**១០:២** *សេចក្តីឧស្សាហ៍ដល់ព្រះ* និយាយពីសេចក្តីឧស្សាហ៍របស់ពួកយូដាចំពោះព្រះ (កច ២១:២០ ២២:៣ កទ ១:១៤) ដែលគួរឱ្យកោតសរសើរពីបំណងរបស់គេចំពោះព្រះអម្ចាស់ ប៉ុន្តែ នោះជាគុណវិបត្តិទៅវិញ ពីព្រោះវាមិនបានឈរលើចំណេះ ដឹងត្រឹមត្រូវអំពីផ្លូវនៃសេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់ ។ លោកប៉ុលគាត់ក៏ជាមនុស្សម្នាក់ដែលជាគំរូខាងឯសេចក្តីឧស្សាហ៍នេះដែរ (កទ ១:១៤ និងការពន្យល់)។

**១០:៣** *សេចក្តីសុចរិតនៃព្រះ* នេះគឺជាសេចក្តីសុចរិតដែលឈរលើសេចក្តីជំនឿ (១:១៧ និងការពន្យល់) ដែលមកពីព្រះអម្ចាស់ជាអំណោយទាន ហើយមនុស្សមិនអាចទទួលបានដោយការប្រព្រឹត្តនោះឡើយ ។ *របស់ខ្លួនគេ* ជាសេចក្តីសុចរិតដែល ឈរលើការខំប្រព្រឹត្តរបស់មនុស្ស ។

**១០:៤** *ព្រះគ្រីស្ទជាចុងបំផុតនៃក្រិត្យវិន័យ* ពាក្យថាចុងបំផុតជាភាសាក្រិកអាចមានន័យថា (១)ការបញ្ចប់ ការបញ្ឈប់ ឬ(២)ការសំរេចគោលដៅ ។ និយាយឱ្យងាយយល់ទៅគឺពាក្យនេះសំដៅលើអ្វីដែលកើតឡើងតាមក្រោយ ។ ព្រះគ្រីស្ទបានយាងមកដើម្បីឱ្យក្រិត្យវិន័យបានសម្រេច (មថ ៥:១៧ និងការពន្យល់) នៅត្រង់នេះមានន័យថាទ្រង់បានចាក់បំពេញដោយការស្តាប់បង្គាប់យ៉ាងឥតខ្ចោះ ហើយបានសម្រេចគ្រប់ទាំងបទទំនាយ ។ គ្រីស្ទបរិស័ទមិននៅក្រោមក្រិត្យវិន័យទៀតទេ (៦:១៤ និងការពន្យល់) ពីព្រោះព្រះគ្រីស្ទបានរំដោះយើងរាល់គ្នាឱ្យរួចផុតពីការជាប់ទោសរបស់ក្រិត្យវិន័យ នោះហើយប៉ុន្តែក្រិត្យវិន័យនៅ តែមានតួនាទីសំខាន់ដដែលនៅក្នុងជីវិតរបស់ពួកគេ ។ ពួកគេត្រូវបានព្រះវិញ្ញាណបរិសុទ្ធរំដោះឱ្យមានសិទ្ធិសេរីភាពបានរួចផុតពីការគម្រាមខាងឯផ្លូវចិត្តនោះផងដែរ (៨:៤ និងការ ពន្យល់)។ *សុចរិត* មានន័យថា សេចក្តីសុចរិតរបស់ផងព្រះអម្ចាស់ព្រះយេស៊ូវបានប្រទានដល់អ្នកជឿគ្រប់ៗគ្នា (មើលការពន្យល់ ១:១៧ ៣:២៤)។

**១០:៥** *មនុស្សណាដែលបានប្រព្រឹត្តតាមសេចក្តីទាំងនោះ នឹងរស់នៅដោយសារការខ្លួនប្រព្រឹត្តនោះឯង* ខនេះបានដកស្រង់ចេញពី លវ ១៨:៥ (មើលការពន្យល់ ខនោះ ចទ ៦:២៥ និងការពន្យល់) និយាយពីសេចក្តីសុចរិតដែលព្រះបានត្រាស់ហៅពួកអ៊ីស្រាអែល ដោយមានទាំងការតាំងសញ្ញាផងនៅត្រង់ភ្នំស៊ីណាយ ។ មានអ្នកខ្លះយល់ ថាការដកស្រង់របស់សាវកប៉ុលនៅត្រង់នេះគឺដើម្បីពណ៌នាអំពីផ្លូវដែលនាំទៅរកសេចក្តីសុចរិត (ជីវិតបែបសុចរិត) ដោយប្រកាន់ខ្ជាប់នូវក្រិត្យវិន័យ (២:៦–១០)។ អ្នកផ្សេងទៀតគិតថាការដកស្រង់នេះមានជាប់ទាក់ទងទៅនឹងអត្ថន័យថាមានតែ ព្រះគ្រីស្ទមួយអង្គគត់ ដែលអាចបំពេញតម្រូវការបានល្អឥតខ្ចោះ តាមការទាមទាររបស់ក្រិត្យវិន័យ និងព្រមទាំងបានផ្តល់សេចក្តីសង្គ្រោះដល់អស់អ្នកណាដែលជឿដល់ទ្រង់ទៀតផង (ហព ៥:៩)។

**១០:៦–៧** ខទាំងនេះត្រូវបានលោកប៉ុលដកស្រង់ចេញពីគម្ពីរសញ្ញាចាស់ដើម្បីយកមកពន្យល់ពីលក្ខណៈដើមនៃសេចក្តីសុចរិតថា គឺបានមកដោយសារសេចក្តីជំនឿ ។ វាមិនចាំបាច់ត្រូវការវីរជនក្លាហានណាមួយមកនាំព្រះគ្រីស្ទចុះពីស្ថានសួគ៌ ឬលើកទ្រង់ចេញពីជង្ហុកធំនោះឡើយ ។ តាមបទគម្ពីរ ចទ ៣០:១២–១៣ ន័យដើមគឺសំដៅទៅលើក្រិត្យវិន័យ ហើយនៅត្រង់នេះលោកប៉ុលយកមកអនុវត្តដោយឈរលើគោលការរបស់ព្រះយេស៊ូវគ្រីស្ទ ។

**១០:៨** *ព្រះបន្ទូលនៅជិតឯង* គឺដកស្រង់ចេញពីបទគម្ពីរ ចទ ៣០:១៤ និងមើលការពន្យល់ ៣០:១២,១៤ ។ ពាក្យថា ព្រះបន្ទូលកាលនោះ គឺមាននៅក្នុងក្រិត្យវិន័យ តែពេលនេះលោកប៉ុលបានយកមកអនុវត្តនៅក្នុងដំណឹងល្អ ។ ចំណែកពាក្យថា ព្រះបន្ទូលនៃសេចក្តីជំនឿ គឺជាចំណុចសំខាន់ដែលសំដៅទៅឯដំណឹងល្អ ។ សេចក្តីសុចរិតគឺបានមកដោយសារសេចក្តីជំនឿមិនមែនដោយទង្វើទេ ហើយគ្រប់គ្នាអាចទទួលបានដោយសេរីមកពីព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។

**១០:៩** *ព្រះអម្ចាស់យេស៊ូវ* មានន័យថាព្រះយេស៊ូវគឺជាព្រះអម្ចាស់ ។ នេះគឺជាប្រយោគ ដែលគ្រីស្ទបរិស័ទសម័យដំបូងប្រើនៅពេលខ្លួនបានប្រែចិត្ត (១កថ ១២:៣ និងការពន្យល់) ដូចជានៅក្នុងពិធីបុណ្យជ្រមុជទឹកជាដើម ។ ដោយឃើញថាពាក្យ "ព្រះអម្ចាស់" នេះត្រូវបានប្រើច្រើនជាង៦ពាន់ដងនៅក្នុងគម្ពីរសញ្ញាចាស់ជាភាសាក្រិក ក្នុងការបកប្រែព្រះនាមព្រះរបស់អ៊ីស្រាអែលថា "ព្រះយេហូវ៉ា" ដូច្នេះនៅពេលលោកប៉ុលប្រើពាក្យព្រះអម្ចាស់នោះសំដែងពីភាពជាព្រះរបស់ទ្រង់ ។ *ក្នុងចិត្ត* ពាក្យថា «ចិត្ត» នៅក្នុងព្រះគម្ពីរមិនមែនគ្រាន់តែអារម្មណ៍ និងមនោសញ្ចេតនាប៉ុណ្ណោះទេ តែជា «បញ្ញា និងឆន្ទៈ» ផងដែរ (ទដ ៤:៧ និងការពន្យល់)។ *ព្រះបានប្រោសឱ្យទ្រង់*

អ្នកនឹងបានសង្គ្រោះពិត[ឋ] ១០ដ្បិតយើងបានសុចរិត ដោយមាន
ចិត្តជឿ ហើយក៏បានសង្គ្រោះ ដោយមាត់ទទួលថ្លែងប្រាប់
១១ពីព្រោះគម្ពីរថា «អស់អ្នកណាដែលជឿដល់ទ្រង់ នោះនឹង
គ្មានហេតុនាំឱ្យខ្មាសឡើយ» [ឌ] ១២ហើយសាសន៍យូដា នឹង
សាសន៍ក្រេក[ឍ] មិនខុសអំពីគ្នាឡើយ ដ្បិតព្រះអម្ចាស់ដដែល
នៃគ្រប់គ្នា[ណ] ទ្រង់មានជាបរិបូរ សំរាប់អស់អ្នកណាដែល
អំពាវនាវរកទ្រង់ ១៣ហើយគ្រប់គ្នា គឺអស់អ្នកណាដែល
អំពាវនាវដល់ព្រះនាមព្រះអម្ចាស់[ត] នោះនឹងបានសង្គ្រោះ[ថ]
១៤ដូច្នេះ បើគេមិនជឿ ធ្វើដូចម្តេចឱ្យគេអំពាវនាវដល់
ព្រះបាន ហើយបើគេមិនបានឮនិយាយ នោះធ្វើដូចម្តេចឱ្យ
គេជឿដល់ព្រះបាន ហើយធ្វើដូចម្តេចឱ្យគេឮនិយាយបាន
បើគ្មានអ្នកណាប្រាប់សោះ ១៥មួយទៀត ធ្វើដូចម្តេចឱ្យមាន
អ្នកណាប្រាប់បាន លើកតែមានអ្នកណាចាត់ឱ្យគេទៅដូច
ជាមានសេចក្តីចែងទុកមកថា «ជើងនៃពួកអ្នកដែល
ប្រកាសប្រាប់ដំណឹងល្អពីសេចក្តីសុខសាន្ត ហើយថ្លែង
ប្រាប់ពីសេចក្តីដែលបណ្តាលឱ្យរីករាយចិត្ត នោះល្អប្រពៃ
យ៉ាងណាហ្ន៎» [ទ] ។
១៦ប៉ុន្តែ គេមិនបានស្តាប់តាមដំណឹងល្អទាំងអស់គ្នាទេ[ធ]
ដ្បិតលោកអេសាយមានប្រសាសន៍ថា «ឱព្រះអម្ចាស់អើយ
តើមានអ្នកណាខ្លះ បានជឿសេចក្តី ដែលយើងខ្ញុំប្រាប់» [ន]
១៧ដូច្នេះ សេចក្តីជំនឿកើតឡើងដោយឮ[ប] ហើយដែលឮ
នោះ គឺដោយសារព្រះបន្ទូលនៃព្រះ[ផ] ១៨តែខ្ញុំសួរថាតើគេ
មិនបានឮទេឬអី បានឮមែន «សំឡេងនោះបានចេញទៅ
ដល់គ្រប់លើផែនដី ហើយពាក្យនោះបានឮទៅដល់ចុង
លោកីយបំផុត» [ព] ១៩ប៉ុន្តែ ខ្ញុំសួរទៀតថា តើសាសន៍អ៊ីស្រា-
អែលមិនបានដឹងទេឬអី លោកម៉ូសេមានប្រសាសន៍ជាមុន
ថា «អញនឹងបណ្តាលឱ្យឯងរាល់គ្នាមានចិត្តច្រណែន[ភ]
ដោយសារពួកមនុស្សដែលមិនមែនជាសាសន៍ណាទេ
ហើយនាំឱ្យឯងខឹង ដោយសារសាសន៍១ ដែលឥតប្រាជ្ញា» [ម]
២០លោកអេសាយក៏មានចិត្តក្លាហានណាស់ និងមានប្រ-
សាសន៍ថា «ពួកអ្នកដែលមិនស្វែងរកអញ នោះបានឃើញ
អញហើយ អញបានសំដែងមកច្បាស់ឱ្យពួកអ្នក ដែលមិន
សួររកអញបានឃើញ» [យ] ២១ក៏មានប្រសាសន៍ពីដំណើរ
សាសន៍អ៊ីស្រាអែលថា «អញបានលូកដៃអញវាល់ព្រឹកវាល់
ល្ងាច ទៅឯសាសន៍១ ដែលមិនស្តាប់បង្គាប់ ហើយចេះតែ
និយាយទាស់ទទឹង» [រ] ។

**១០:១១** ឌ អស ២៨:១៦ រម ៩:៣៣
**១០:១២** ឍ រម ៣:២២,២៩ ណ មថ ២៨:១៨
**១០:១៣** ត កច ២:២១ ថ យអ ២:៣២
**១០:១៥** ទ អស ៥២:៧ ណាហ ១:១៥
**១០:១៦** ធ ហព ៤:២ ន អស ៥៣:១ យហ ១២:៣៨
**១០:១៧** ប កទ ៣:២,៥ ផ កល ៣:១៦
**១០:១៨** ព ទដ ១៩:៤ មថ ២៤:១៤ រម ១:៨ កល ១:៦,២៣ ១ថន ១:៨
**១០:១៩** ភ រម ១១:១១,១៤ ម ចទ ៣២:២១
**១០:២០** យ អស ៦៥:១ រម ៩:៣០
**១០:២១** រ អស ៦៥:២ យរ ៣៥:១៧

*រស់ពីស្លាប់ឡើងវិញ* នេះគឺជាសេចក្តីពិតដ៏សំខាន់នៃគោលលិទ្ធិរបស់គ្រីស្ទបរិស័ទ (១កថ ១៥:៤,១៤,១៧) ហើយជាគំនិតស្នូលនៃសេចក្តីបង្រៀនរបស់ពួកសាវក (មើលការពន្យល់ កច ២:១៤–៤០ កច ៣:១៥ ៤:១០ ១០:៤០) ។ គ្រីស្ទបរិស័ទមិនគ្រាន់តែជឿថា ព្រះយេស៊ូវបានរស់នៅប៉ុណ្ណោះទេ តែក៏ជឿផងដែរថាទ្រង់កំពុង តែរស់នៅសព្វថ្ងៃនេះផងដែរ ។ *បានសង្គ្រោះពិត* ត្រង់នេះបូករួមទាំងសេចក្តីសង្គ្រោះនៅទីបំផុតនោះដែរ (សង្គ្រោះចុងក្រោយ ហព ៩:២៨ និងការពន្យល់) ។

**១០:១០** សេចក្តីសង្គ្រោះគឺជាប់ទាក់ទងទៅនឹងជំនឿខាងក្នុង (ដោយនៅក្នុងចិត្ត) ព្រមទាំងលន់តួនៅផ្នែកខាងក្រៅផងដែរ (ដោយមាត់ថ្លែងប្រាប់) ។

**១០:១២** *សាសន៍យូដា និងសាសន៍ក្រេកមិនខុសអំពីគ្នាឡើយ* មានន័យថាក្រុមទាំងពីរដើរទៅដល់ទីណា នោះសេចក្តីសង្គ្រោះក៏ទៅដល់ទីនោះដែរ (ខ.១៣ ៣:២២) ។

**១០:១៣** លោកពេត្រុសក៏សំអាងលើហេតុផលនៅក្នុងវគ្គនេះដែរ (យអ ២:៣២) គឺ នៅថ្ងៃទី៥០ (កច ២:២១ និងការពន្យល់) ។

**១០:១៤–១៥** ប្រហែលដោយសារតែមាន ការវែកញែកថា ពួកសាសន៍យូដាពុំដែលមានឱកាសឮ និងទទួលដំណឹងល្អឱ្យបានសមរម្យនឹងគេសោះ បានជាលោកប៉ុល ថ្លែងជាសំណួរវោហាស័ព្ទតាមលំដាប់ ដែលជាល័ក្ខខ័ណ្ឌចាំបាច់ដើម្បីអំពាវនាវដល់ព្រះគ្រីស្ទ និងដើម្បីឱ្យបានសង្គ្រោះនោះថា: (១).អ្នកអធិប្បាយមកពីព្រះ (២).ការប្រកាសនៃព្រះបន្ទូល (៣).ការឮព្រះបន្ទូល (៤).ការជឿព្រះបន្ទូល ។

**១០:១៥** *ជើងនៃពួកអ្នកដែលប្រកាសប្រាប់ដំណឹងល្អពីសេចក្តីសុខសាន្ត ហើយថ្លែងប្រាប់ពីសេចក្តីដែលបណ្តាលឱ្យរីករាយចិត្ត នោះល្អប្រពៃយ៉ាងណាហ្ន៎!* ខនេះបានដកស្រង់ចេញពី អស ៥២:៧ (និងមើលការពន្យល់) ដែលនិយាយពីអស់អ្នកដែលនាំដំណឹងល្អទៅប្រាប់ពួកនិរទេសមកពីស្រុកបាប៊ីឡូន ។ ឃ្លានោះក៏និយាយអំពីអ្នកប្រកាសដំណឹងល្អ ដើម្បីរំដោះមនុស្សចេញពីនឹមនៃអំពើបាបផងដែរ ។

**១០:១៧** *ព្រះបន្ទូលនៃព្រះ* ពាក្យនេះសំដៅទៅលើ: (១).ដំណឹងល្អដែលនិយាយពីព្រះគ្រីស្ទ ឬ (២).ព្រះគ្រីស្ទកំពុងមានបន្ទូលតាមរយៈអ្នកប្រកាសដំណឹងល្អដូចកាលពីមុនដែរ ។

**១០:១៨** *សំឡេងនោះបានចេញទៅដល់ . . . លោកីយបំផុត* ខនេះបានដកស្រង់ចេញពី ទដ ១៩:៤ (មើលការពន្យល់នៅទីនោះ) ដែលជាប់ទាក់ទងទៅនឹងទីបន្ទាល់នៃស្ថានសួគ៌ សិរីល្អនៃព្រះ ។ ពាក្យថាសំឡេង គឺសំដៅលើអ្នកប្រកាសដំណឹងល្អ ហើយពាក្យនេះត្រូវបានប្រើសម្រាប់ពួកអ៊ីស្រា-អែល ដែលមិនអាចប្រកែកថា ខ្លួនពុំដែលឮដំណឹងល្អសោះនោះឡើយ ពីព្រោះអ្នកប្រកាសដំណឹងល្អបានទៅដល់គ្រប់ទីកន្លែងដែលពួកគេបានរស់នៅរួចហើយ ។ នៅក្នុងអត្ថន័យដើមនៃពាក្យនេះត្រូវបានប្រើសម្រាប់ពិពណ៌នាអំពីការបើកសំដែងរបស់ព្រះអម្ចាស់តាមរយៈធម្មជាតិ ដែលព្រះបានបង្កើតមកនោះថា ជាការរីករាលដាលនៃដំណឹងល្អដល់គ្រប់ទីកន្លែង ។

**១០:១៩** *តើសាសន៍អ៊ីស្រាអែលមិនបានដឹងទេឬអី?* នេះគឺជាការដកស្រង់ចេញពី ចទ ៣២:២១ (និងមើលការពន្យល់នៅទីនោះ) ដើម្បីឆ្លើយនឹងសំណួរ ដែលបានចោទសួរដល់សាសន៍ដទៃថាសាសន៍យូដាជាពួកដែលឥតប្រាជ្ញាខាងឯវិញ្ញាណ ។ បើពួកគេមានប្រាជ្ញា នោះពួកគេនឹងបានយល់ពីដំណឹងល្អជាមិនខាន ។ *មិនមែនជាសាសន៍ណាទេ* ពាក្យនេះសំដៅលើសាសន៍ដទៃ ក្រៅអំពីសាសន៍អ៊ីស្រាអែល ។

**១០:២១** នេះគឺជាការទទួលខុសត្រូវសម្រាប់ការបដិសេធរបស់ពួកអ៊ីស្រា-អែលក្នុងឋានៈជាជាតិសាសន៍មួយ ដែលជួបការបរាជ័យនឹងសេចក្តីតម្រូវ

## សំណល់នៃសាសន៍អ៊ីស្រាអែល

**១១** ១ដូច្នេះខ្ញុំសួរថា តើព្រះបានបោះបង់ចោលរាស្ត្រទ្រង់
ឬអី[ល] ទេ មិនមែនទេ ដ្បិតខ្លួនខ្ញុំជាសាសន៍អ៊ីស្រាអែលដែរ
គឺជាពូជលោកអ័ប្រាហាំ[វ] កើតក្នុងពូជអំបូរបេនយ៉ាមីន[ស]
២ព្រះទ្រង់មិនបានបោះបង់ចោលរាស្ត្រទ្រង់[ហ] ដែលទ្រង់
ស្គាល់ជាមុននោះទេ[ឡ] តើអ្នករាល់គ្នាមិនដឹងរឿងពីលោក
អេលីយ៉ា ដែលគម្ពីរថា ដូចម្ដេចទេឬអី គឺដែលលោក
អង្វរដល់ព្រះ ទាស់នឹងសាសន៍អ៊ីស្រាអែលថា ៣«ឱព្រះ
អម្ចាស់អើយ គេបានសំឡាប់ពួកហោរាទ្រង់ ហើយរំលំ
អាសនាទាំងប៉ុន្មានរបស់ទ្រង់ មានសល់តែទូលបង្គំ១ហើយ
គេរកសំឡាប់ទូលបង្គំទៀត»[អ] ៤ប៉ុន្តែ ព្រះទ្រង់ ឆ្លើយនឹង
លោកយ៉ាងដូចម្ដេច គឺឆ្លើយថា«អញបានទុកមនុស្ស៧ពាន់
នាក់សំរាប់អញ ដែលមិនបានលុតជង្គង់នៅមុខព្រះបាល
សោះ»[ក] ៥ដូច្នេះ សព្វថ្ងៃនេះ ក៏មានសំណល់សល់[ខ] ដែល
ទ្រង់បានរើសតាំង ដោយព្រះគុណដែរ[គ] ៦ហើយបើសិន
ជាដោយសារព្រះគុណពិត នោះមិនមែនដោយអាងការ
ប្រព្រឹត្តទៀតទេ ពុំនោះ ព្រះគុណមិនមែនជាព្រះគុណទៀត
តែបើដោយអាងការប្រព្រឹត្តមែន[ឃ] នោះមិនមែនដោយព្រះ
គុណទៀត ពុំនោះការប្រព្រឹត្តមិនមែនជាការប្រព្រឹត្ត ទៀត
ទេ ៧ដូច្នេះ តើដូចម្ដេច គឺថា សេចក្ដីដែលសាសន៍អ៊ីស្រា
អែលស្វែងរក នោះគេរកមិនបានទេ[ង] តែពួករើសតាំងរក
បានសេចក្ដីនោះវិញ ហើយពួកអ្នកឯទៀតត្រូវមានចិត្តរឹង
រូស[ច] ៨ដូចមានសេចក្ដីចែងទុកមកថា «ព្រះទ្រង់បានប្រទាន
ឱ្យគេមានវិញ្ញាណរលីវ ភ្នែកដែលមើលមិនឃើញ នឹង
ត្រចៀកដែលស្ដាប់មិនឮ[ឆ] ដរាបមកដល់សព្វថ្ងៃនេះ»[ជ]
៩ហ្លួងដាវីឌក៏មានបន្ទូលថា «ឱ្យតុគេត្រឡប់ទៅជាអង្គប់
ហើយជាអន្ទាក់ដល់គេចុះ គឺជាហេតុឱ្យវិនាស រវាតចិត្ត
ហើយជាសំណាងដល់គេដែរ ១០ឱ្យភ្នែកគេត្រូវងងឹត មិនឱ្យ
ឃើញឡើយ[ឈ] ហើយឱ្យខ្នងគេត្រូវបង្អោនជានិច្ចផង»[ញ]។

## មែកបំបៅ

១១ដូច្នេះ ខ្ញុំសួរថា តើគេបានជំពប់ ឱ្យគ្រាន់តែដួលប៉ុណ្ណោះ
ឬអី ទេ មិនមែនឡើយ[ដ] គឺដោយសារការដួលរបស់គេ បាន
ជាមានសេចក្ដីសង្គ្រោះ ផ្សាយទៅដល់ពួកសាសន៍ដទៃវិញ[ឋ]
ដើម្បីបណ្ដាលឱ្យគេច្រណែន[ឌ] ១២ដូច្នេះបើការដួលរបស់គេ
ជាសេចក្ដីចំរើនដល់លោកីយ ហើយសេចក្ដីខ្វះមិនពេញខ្នាត
របស់គេ ជាសេចក្ដីចំរើនដល់ពួកសាសន៍ដទៃវិញ[ឍ] នោះតេ
សេចក្ដីពេញខ្នាតរបស់គេនឹងបានលើសជាងយ៉ាងណាទៅ

**១១:១** ល លវ ២៦:៤៤ ១សយ ១២:២២ ទដ ៩៤:១៤ យរ ៣១:៣៧ ៣៣:២៤–២៦
វ ២កថ ១១:២២ ស ភល ៣:៥
**១១:២** ហ ខ.១ ឡ រម ៨:២៩
**១១:៣** អ ១ពវ ១៩:១០,១៤
**១១:៤** ក ១ពវ ១៩:១៨
**១១:៥** ខ រម ៩:២៧ គ រម ៣:២៤
**១១:៦** ឃ រម ៤:៤
**១១:៧** ង រម ៩:៣១ ច ខ.២៥ រម ៩:១៨
**១១:៨** ឆ មថ ១៣:១៣–១៥ ជ ចទ ២៩:៤ អស ២៩:១០
**១១:១០** ឈ ខ.៨ ញ ទដ ៦៩:២២,២៣
**១១:១១** ដ ខ.១ ឋ កច ១៣:៤៦ ឌ ខ.១៤ រម ១០:១៩
**១១:១២** ឍ ខ.២៥

ការរបស់ព្រះអម្ចាស់ ដោយឈ្មោះថាខ្វះជំនឿ ។ ប៉ុន្តែ សូម្បីតែយ៉ាងនេះក៏ដោយ ក៏នៅក្នុង អស ៦៥:២ បានចែងថា ព្រះអម្ចាស់នៅតែបន្តឈោងចាប់ជនជាតិអ៊ីស្រាអែលដោយក្ដីស្រលាញ់ដដែល ទោះបីជាពួកគេខ្វះការស្ដាប់បង្គាប់ក៏ដោយ ។

**១១:១** *បោះបង់* ពាក្យនេះសំដៅលើការបោះបង់ចោលទាំងស្រុង ។ ជានិច្ចជាកាលនៅតែមានអ្នកស្មោះត្រង់នៅក្នុងចំណោមជន ជាតិសាសន៍យូដា ។

**១១:២** *ស្គាល់ជាមុននោះ* មើលការពន្យល់ ៨:២៩ ។

**១១:៥** *សំណល់សល់* គឺនៅក្នុងសម័យលោកអេលីយ៉ា ដូចគ្នានឹងសម័យលោកប៉ុលដែរ ។ ថ្វីបើការបោះបង់សាសនាបានរីកធំឡើងៗយ៉ាងណាក៏ដោយ ក៏នៅតែមាន សាសន៍យូដាដែលស្មោះត្រង់នឹងសេចក្ដីជំនឿនោះដែរ ។ *រើសតាំង ដោយព្រះគុណ* នេះជាប្រភពសំណល់នៃអ្នកស្មោះត្រង់នឹងសេចក្ដីជំនឿ ដែលមិនមែនដោយ សារទង្វើល្អរបស់ពួកគេទេ តែត្រូវបានរើសតាំងដោយព្រះគុណនៃព្រះវិញ ។

**១១:៧** *សេចក្ដីដែលសាសន៍អ៊ីស្រាអែលស្វែងរក* សំដៅពីសេចក្ដីសុចរិតនៅចំពោះព្រះភក្ត្រព្រះដែលជាផ្នែកធំជាងគេនៃពួកអ៊ីស្រាអែលបានបរាជ័យ ។ *ពួករើសតាំង* គឺជាពួកដែលមានជំនឿស្មោះត្រង់នៅសល់ក្នុងចំណោមសាសន៍យូដា ។ *ហើយពួកអ្នកឯទៀតត្រូវមានចិត្តរឹងរូស* គឺសំដៅលើពួកដែលបដិសេធផ្លូវនៃសេចក្ដីជំនឿ (៩:៣០–៣២ និងការពន្យល់) ។ ព្រះអម្ចាស់បានធ្វើឱ្យពួកគេមិនអាចយល់ សេចក្ដីពិតខាងឯងវិញ្ញាណបាន (មើលការពន្យល់ ខ.២៥ អស ៦:៨–១០ មក ៤:១២ លក ៨:១០) នេះគឺជាការប្រិតប្រៀបមួយដ៏តឹងរឹងចំពោះពួកអ៊ីស្រាអែល ។

**១១:៨** *ដរាបមកដល់សព្វថ្ងៃនេះ* សំដៅលើវិញ្ញាណរលីវនៃពួកយូដាបានបន្តតាំងពីសម័យហោរាអេសាយរហូតដល់សម័យលោកប៉ុល ។

**១១:៩–១០** ត្រង់នេះដកស្រង់ពី ទដ ៦៩:២២–២៣ (មើលការពន្យល់) នេះប្រហែលជាសំដីផ្ទាល់របស់ស្ដេចដាវីឌដែលសំដៅទៅសត្រូវរបស់ទ្រង់ ។ លោកប៉ុលលើកខនេះមកដើម្បីពិពណ៌នាពីហេតុផលដ៏តឹងរឹងនៃព្រះអម្ចាស់

**១១:១១** *ដោយសារការដួលរបស់គេ* ឃ្លានេះសំដៅទៅលើការបដិសេធដំណឹងល្អរបស់សាសន៍អ៊ីស្រាអែលមួយចំនួន ។ *បណ្ដាលឱ្យគេច្រណែន* មើលនៅក្នុង ខ.១៤ ១០:១៩ ។

**១១:១២** *ជាសេចក្ដីចរើនដល់លោកីយ* មានន័យដូចគ្នានឹងពាក្យថា សេចក្ដីចម្រើនដល់សាសន៍ដទៃ ។ ត្រង់ចំណុចនេះសំដៅទៅលើប្រយោជន៍ដ៏បរិបូរណ៍នៃសេចក្ដីសង្គ្រោះនោះរួចបាត់ទៅហើយ ហើយនេះក៏ជាអំណរដ៏ពិតនៃជំនឿរបស់សាសន៍ដទៃដែលបានមកដោយសារការបដិសេធន៍ដំណឹងល្អរបស់សាសន៍យូដា ។ ការបដិសេធន៍នេះហើយដែលបណ្ដាលឱ្យពួកសាវ័កបែរទៅរកសាសន៍ដទៃវិញ (កច ១៣:៤៦–៤៨ ១៨:៦) ។ *សេចក្ដីខ្វះមិនពេញខ្នាតរបស់គេ* មានន័យដូចគ្នានឹងពាក្យ *ការដួលរបស់ពួកគេ* នោះដែរ (មើលការពន្យល់ ខ.១១) ។ ប៉ុន្តែសេចក្ដីខ្វះមិនពេញខ្នាតនេះចេញមកពីការដួលនេះឯង ។ *លើសជាងយ៉ាងណាទៅ* មើលការពន្យល់នៅក្នុង ខ.១៥ ។ *សេចក្ដីពេញខ្នាតរបស់គេ* មានន័យថា ជាសេចក្ដីសង្គ្រោះនៃពួកអ៊ីស្រាអែល (ខ.២៦–២៧ និងការពន្យល់) ។

១៣ ខ្ញុំនិយាយនឹងអ្នករាល់គ្នាដែលជាសាសន៍ដទៃ ហើយ
ពីព្រោះខ្ញុំជាសាវកដល់សាសន៍ដទៃ[ណ] បានជាខ្ញុំដំកើងដល់
ការងារខ្ញុំ ១៤ ដើម្បីនឹងបណ្ដាលសាច់ញាតិខ្ញុំ ឱ្យមានសេចក្ដី
ច្រណែន[ត] ហើយនឹងជួយសង្គ្រោះ[ថ]អ្នកខ្លះក្នុងពួកគេ បើសិន
ជាបាន ១៥ ដ្បិតបើសិនជាការបោះបង់ចោលគេនោះ ជា
សេចក្ដីមេត្រី[ទ]ដល់លោកីយដូច្នេះ នោះតើការទទួលគេនឹង
បានជាអ្វី បើមិនមែនជាជីវិតរស់ពីស្លាប់ឡើងវិញ[ធ] ១៦ បើ
ម្សៅ១ក្ដាប់មុនដំបូង[ន]ជាបរិសុទ្ធ នោះដុំទាំងមូល ក៏បរិសុទ្ធ
ហើយបើឫសបរិសុទ្ធ នោះមែកក៏បរិសុទ្ធដែរ ។
១៧ ប៉ុន្តែ បើមែកខ្លះត្រូវកាច់ចេញ[ប] ហើយអ្នកឯងដែល
ជាដើមអូលីវព្រៃ បានត្រូវបំបៅកណ្ដាលមែកទាំងនោះ[ផ]
ទាំងត្រឡប់ទៅជាស្រូបជាតិឫសនៃដើមអូលីវស្រុក ជាមួយ
នឹងមែកឯទៀត ១៨ នោះកុំឱ្យអួតនឹងមែកទាំងនោះឡើយ តែ
បើអ្នកអួតនឹងគេ នោះត្រូវដឹងថា មិនមែនអ្នកដែលចិញ្ចឹម
ឫសទេ គឺឫសទេតើ ដែលចិញ្ចឹមអ្នកវិញ[ព] ១៩ ដូច្នេះ អ្នកនឹង
ប្រកែកថា «មែកទាំងនោះត្រូវកាច់ចេញ ដើម្បីនឹងបំបៅខ្ញុំ
វិញ» ២០ ត្រូវហើយ គេត្រូវកាច់ចេញ ដោយព្រោះមិន
ជឿ ហើយដែលអ្នកជាប់នៅ គឺដោយសារសេចក្ដីជំនឿ[ភ]
ដូច្នេះ កុំឱ្យឆ្មើងឆ្មៃឡើយ[ម] ចូរភ័យខ្លាចវិញ[យ] ២១ ពីព្រោះ
បើព្រះទ្រង់មិនបានសំចៃទុកនូវមែកកំណើត នោះក្រែង
មិនសំចៃទុកអ្នកដែរ ២២ ដូច្នេះ ចូរមើលសេចក្ដីសប្បុរស[រ]
នឹង សេចក្ដីប្រិតប្រៀបនៃព្រះ គឺទ្រង់ប្រិតនឹងពួកអ្នក
ដែលដួលតែសប្បុរសនឹងអ្នកវិញ បើអ្នកនៅជាប់[ល]នឹង
សេចក្ដីសប្បុរសនោះ ពុំនោះ អ្នកនឹងត្រូវកាត់ចេញដែរ[វ]

**១១:១៣** ណ កច ៩:១៥
**១១:១៤** ត ខ.១១ រម ១០:១៩ ១កថ ១០:៣៣ ១ថន ២:១៦ ថ មថ ១:២១ លក ២:១១ យហ ៣:១៧ កច ៤:១២ ១៦:៣១ ១កថ ១:២១ ១ធថ ២:៤ ទត ៣:៥
**១១:១៥** ទ រម ៥:១០ ធ លក ១៥:២៤,៣២
**១១:១៦** ន លវ ២៣:១០,១៧ ជន ១៥:១៨–២១
**១១:១៧** ប យរ១១:១៦ យហ ១៥:២ ផ កច ២:៣៩ អភ ២:១១–១៣
**១១:១៨** ព យហ ៤:២២ **១១:២០** ភ ១កថ ១០:១២ ២កថ ១:២៤ ម ១ធថ ៦:១៧ យ ១ពត ១:១៧ **១១:២២** រ រម ២:៤ ល ២កថ ១៥:២ កឡ ១:២៣ ហព ៣:៦ វ យហ ១៥:២ **១១:២៣** ស ២កថ ៣:១៦

**១១:១៣** *សាវកដល់សាសន៍ដទៃ* មើល ១:៥ ១៥:៩,១២,១៦ និងការពន្យល់ កច ៩:១៥ កទ ១:១៦ ២:៧ និងការពន្យល់, ខ.៩ អភ ២:១១–២២ ៣:៣,៦,១០ ។

**១១:១៥** *ការបោះបង់ចោល* នេះគឺជាការបោះបង់ចោលបណ្ដោះអាសន្នរបស់ព្រះអម្ចាស់ និងការបដិសេធន៍ដ៏មិនសមរម្យរបស់សាសន៍យូដា (ខ.២៥ និងការពន្យល់)។ *ជាសេចក្ដីមេត្រីដល់លោកីយ* ពាក្យនេះមានន័យដូចគ្នានឹងពាក្យ "សេច ក្ដីចម្រើនដល់លោកិយ" (មើលការពន្យល់ ខ.១២)។ *ជីវិតរស់ពីស្លាប់* អត្ថន័យនេះ បញ្ជាក់លើពាក្យថា "លើសជាងយ៉ាងណាទៅ" (ខ.១២) ដែលបង្ហាញពីដំណើរនៃសេចក្ដីប្រោសលោះដល់សាសន៍ដទៃ "ការដួល"និង"សេចក្ដីខ្វះមិនពេញខ្នាត" (ខ.១២) របស់សាសន៍អ៊ីស្រាអែល នាំទៅរកសេចក្ដីសង្គ្រោះដល់សាសន៍ដទៃ ដែលបណ្ដាលឱ្យពួកអ៊ីស្រាអែលមានសេចក្ដីច្រណែន តែបើសាសន៍អ៊ីស្រាអែលពោរពេញទៅដោយ "សេចក្ដីពេញខ្នាត" (ខ.១២) នោះរឹតតែធ្វើឱ្យសាសន៍ដទៃបានលើសជាងយ៉ាងនោះទៀត ។ ប៉ុន្តែ តើអ្វីទៅដែលថា "នឹងបានលើសជាងនេះទៅទៀត" តើនោះគឺជាការរស់ពីស្លាប់ឡើងវិញឬយ៉ាងណា? មានគំនិត៣ដែលជាចម្លើយនឹងសំណួរនេះ (១).គឺជាការដាស់ឱ្យភ្ញាក់ឡើងខាង ឯងវិញ្ញាណដែលពុំ ធ្លាប់មានកាលពីមុនមកនៅក្នុងពិភពលោកនេះ (២).គឺជាការធ្វើឱ្យពេញបរិបូរណ៏នៃការប្រោសលោះ នៅថ្ងៃរស់ពីស្លាប់ឡើងវិញ (៣).គឺជាទិដ្ឋភាពការពណ៌នា បញ្ជាក់ពីការប្រែចិត្តនៃជនជាតិយូដា ដែលជាព្រឹត្តិការណ៍នៃក្ដីអំណរ និងកិត្តិយស(ដូចជាការរស់ឡើងវិញ) ជាលទ្ធផលនៃព្រះពរដ៏ធំឧត្តមនៅលើលោកនេះ ។ គំនិតមួយក្នុងចំណោមគំនិតទាំងបីហាក់បីដូចជាបាននិយាយមុនដែលពួកអ៊ីស្រាអែលកើតម្ដងទៀតខាងឯវិញ្ញាណ ។ សេចក្ដីពេញខ្នាតរបស់សាសន៍ដទៃនឹងបានមកដល់ (ខ.២៥)។ ដោយព្រោះតែបេសកកម្មរបស់សាសន៍ដទៃនឹងត្រូវបានពេញលេញ នោះនឹងគ្មានកន្លែងណាត្រូវដាស់ឱ្យភ្ញាក់ឡើងវិញខាងឯវិញ្ញាណទៀតទេ ។ ចំណែកគំនិតទីពីរហាក់បីមិនដូចជាការលើកឡើងរបស់បរិបទនោះទេ ពុំមានអ្វី តំណាងនៃការរស់ឡើងវិញសោះ ។

**១១:១៦** វគ្គទីមួយនៃពាក់កណ្ដាលខនេះគឺជាខយោងក្នុង ជន ១៥:១៧–២១ ។ នេះជាផ្នែកមួយនៃម្សៅដែលបានធ្វើឡើងពីការប្រមូលផលលើកដំបូងដែលត្រូវថ្វាយជាដង្វាយដល់ព្រះអម្ចាស់ ។ ត្រង់នេះមានន័យដូចគ្នាថា បើឫសបរិសុទ្ធ នោះ មែកក៏បរិសុទ្ធដែរ ។ *ម្សៅ១ក្ដាប់មុនដំបូង* អត្ថន័យត្រង់នេះគឺសំដៅទៅលើពួកសម្ដេចសង្ឃ(នក ២៣:១៩ និងការពន្យល់)។ *មែក* អត្ថន័យត្រង់នេះគឺសំដៅទៅ លើពួកសាសន៍យូដា ។ *បរិសុទ្ធ* ពាក្យនេះពុំមានន័យថាសាសន៍យូដាទាំងអស់ សុចរិតនោះឡើយ(ឧ: ការដែលបានសង្គ្រោះ) ប៉ុន្តែ ព្រះអម្ចាស់នឹងប្រទានសេចក្ដីពិតចំពោះការសន្យារបស់ទ្រង់ដល់ពួកគេ(៣:៣–៤ និងការពន្យល់)។ ត្រង់នេះបញ្ជាក់ថាលោកប៉ុលបានមើលឃើញពីអនាគតនៃជនជាតិអ៊ីស្រាអែល ទោះជាពេលនេះពួកគេត្រូវបានញែកទុកមួយឡែកនោះក៏ដោយ ។ *ឫស* គឺជាសម្ដេចសង្ឃ *មែក* គឺជាជនជាតិយូដា ។

**១១:១៧** *មែក* ពាក្យនេះចង់និយាយពីសាសន៍យូដាម្នាក់ៗ ។ *ដើមអូលីវ* ពាក្យនេះ គឺសំដៅលើគ្រីស្ទបរិស័ទសាសន៍ដទៃ ។ *បានត្រូវបំបៅកណ្ដាល* នេះបង្ហាញពីដំណើរ ជាធម្មតាក្នុងការបណ្ដុះពន្លកដើមឈើថ្មី ចេញពីដើមកំណើតមួយទៀតនោះ ។ តែទោះជាយ៉ាងនេះក៏ដោយ នៅក្នុង ខ.១៧–២៤ នេះត្រូវបានគេលើកយកមកធ្វើជាការប្រៀបធៀបនៃការបំបៅមែកអូលីវព្រៃ(សាសន៍ដទៃ) ទៅដាំនៅលើដើមអូលីវស្រុក តែប៉ុណ្ណោះ (ពុំមែនជារឿងពិតនោះទេ វាផ្ទុយនឹងធម្មជាតិ ខ.២៤)។ ដោយសារដំណើរការបំបៅនេះ មិនតាមលក្ខណៈធម្មជាតិជាក់លាក់នោះ ក៏ធ្វើឱ្យគ្មានផលផ្លែដែរ ។ *ឫសនៃដើមអូលីវ* គឺតំណាងឱ្យសម្ដេចសង្ឃ ចំណែកឯដើមអូលីវទាំងមូល គឺតំណាងឱ្យរាស្ត្ររបស់ព្រះអម្ចាស់ ។

**១១:១៨** *គឺឫសទេតើដែលចិញ្ចឹមអ្នក* មានន័យថា សេចក្ដីសង្គ្រោះរបស់គ្រីស្ទបរិស័ទសាសន៍ដទៃ គឺបានមកពីសាសន៍យូដា ជាពិសេសគឺពួកព្វយុកោ (ឧ: ការតាំង សញ្ញារបស់លោកអ័ប្រាហាំ យហ ៤:២២ និងការពន្យល់)។

**១១:១៩** *មែក* គឺសំដៅលើពួកសាសន៍យូដាដែលមិនជឿព្រះ ។

**១១:២០** *ចូរភ័យខ្លាច* គឺការកោតខ្លាចដល់ព្រះ មើលការពន្យល់ លប ២០:១១ សភ ១:៧ និងការពន្យល់ ភល ២:១២–១៣ ហព ៤:១ "ចូរប្រយ័ត្ន" ១ពត ១:១៧ ។

២៣ហើយមែកកំណើតទាំងនោះដែរ បើគេលះសេច
ក្ដីមិនជឿចោលចេញ នោះនឹងបំបៅគេវិញ ដ្បិតព្រះទ្រង់
អាចនឹងភ្ជាប់ជាតិវិញបាន[ស] ២៤ពីព្រោះ បើសិនជាអ្នកត្រូវ
កាត់ចេញពីដើមអូលីវព្រៃពីកំណើត ហើយបានបំបៅជាប់
នឹងដើមអូលីវស្រុក[ហ] ខុសពីធម្មតា នោះតើមែកកំណើត
ទាំងនោះ នឹងបានបំបៅជាប់ នឹងគល់កំណើតរបស់វា
លើសជាងអម្បាលម៉ានទៅទៀត ។

### សាសន៍អ៊ីស្រាអែលទាំងអស់នឹងបានសង្គ្រោះ

២៥បងប្អូនអើយ ខ្ញុំមិនចង់ឱ្យអ្នករាល់គ្នានៅល្ងង់[ឡ] ខាង
ឯសេចក្ដីអាថ៌កំបាំងនេះទេ[អ] ក្រែងអ្នករាល់គ្នាទុកចិត្តថាខ្លួន
មានប្រាជ្ញា[ក] គឺចង់ឱ្យដឹងថា សាសន៍អ៊ីស្រាអែលកើតមាន
សេចក្ដីរឹងរូបឹង[ខ]ប៉ុន្មានភាគនេះទៅហើយ ទាល់តែសាសន៍
ដទៃទាំងប៉ុន្មានបានចូលជឿគ្រប់ចំនួន[គ] ២៦នោះសាសន៍
អ៊ីស្រាអែលទាំងអស់គ្នា នឹងបានសង្គ្រោះជាក្រោយ[ឃ] ដូចជា
មានសេចក្ដីចែងទុកមកថា «មានព្រះដ៏ប្រោសឱ្យរួច ទ្រង់
នឹងចេញពីស៊ីយ៉ូនមក ទ្រង់នឹងបង្វែរសេចក្ដីទមិលល្មើស
ពីយ៉ាកុបទៅ ២៧នោះហើយជាសេចក្ដីសញ្ញាដែលអញតាំង
នឹងគេ ក្នុងកាលដែលអញបានដោះបាបគេចេញហើយ»[ង]
២៨ខាងឯដំណឹងល្អ គេជាខ្មាំងសត្រូវ[ច] ដើម្បីប្រយោជន៍ដល់

**១១:២៤** ហ យរ ១១:១៦ **១១:២៥** ឡ រម ១:១៣ ១កថ ១០:១ ១២:១ ២កថ ១:៨ ១ថន ៤:១៣ អ រម ១៦:២៥ ក រម ១២:១៦ ខ ខ.៧ រម ៩:១៨ គ លក ២១:២៤ **១១:២៦** ឃ អស ៤៥:១៧ យរ ៣១:៣៤ **១១:២៧** ង អស ៥៩:២០,២១ ២៧:៩ ហព ៨:១០,១២ **១១:២៨** ច រម ៥:១០

**១១:២៣** *ព្រះទ្រង់អាចនឹងភ្ជាប់ជាតិវិញបាន* មានន័យថា លោកប៉ុលនៅ តែមានសង្ឃឹមជានិច្ចសម្រាប់សាសន៍យូដា ពីព្រោះព្រះទ្រង់អាចធ្វើការគ្រប់យ៉ាងបាន(មក ១០:២៧ និងការពន្យល់) ។

**១១:២៤** *ខុសពីធម្មតា* មានន័យថា លោកប៉ុលបានដឹងថាការបំបៅនេះមិនត្រូវបានគេយកមកអនុវត្តនោះទេ(ខ.១៧) ។ រឿងនេះរួមទាំងសាសន៍ដទៃនៅក្នុងគ្រួសារនៃព្រះផងដែរថា "ខុសពីធម្មតា"(អភ ២:១២ និងការពន្យល់) ។ ជាការជាក់ស្ដែង ហេតុផលនៅក្នុងខនេះគឺជារឿងរ៉ាវផ្នែកទេវសាស្ត្រច្រើនជាងផ្នែកសាកវប្បកម្ម (ផ្នែកសិល្បៈដាំដំណាំ) ។ វាជាការពិបាកសម្រាប់ផ្នែកសាកវប្បកម្មដែលយកមែកខ្លួនបានបំបៅរួច ហើយកាត់យកទៅដាំលើដើមឈើកំណើតនោះវិញ ប៉ុន្តែសាសន៍យូដាគឺពិតជាដើមឈើពីកំណើតមែន (តាមប្រវត្តិសាស្ត្រ និងទេវសាស្ត្រ) ។ បើដូច្នេះតើមែកកំណើតទាំងនោះនឹងបានបំបៅជាប់នឹងគល់កំណើតរបស់វា លើសជាងអម្បាលម៉ានទៅទៀត ។

**១១:២៥** *សេចក្ដីអាថ៌កំបាំង* បញ្ជាក់ពីសាសនាអាថ៌កំបាំងដូចដែលធ្លាប់ប្រើនៅសម័យរបស់លោកប៉ុលជាភាសាក្រិកមានន័យថា កិច្ចការមួយចំនួនដែលត្រូវបើកសំដែងឱ្យដឹងតែមនុស្សនៅក្នុងក្រុមខ្លួនតែប៉ុណ្ណោះ ។ តែទោះជាយ៉ាងណា ក៏ដោយខ្លួនរបស់លោកប៉ុលផ្ទាល់បានជាប់ទាក់ទងនឹងសេចក្ដីអាថ៌កំបាំង ឬភាពងងឹតនេះខ្លះ ដែរកាលពីអតីតកាលនោះ ប៉ុន្តែ ក្រោយមកត្រូវព្រះអម្ចាស់បើកសំដែងឱ្យគាត់ដឹង និងយល់គ្រប់ការទាំងអស់វិញ (១៦:២៥ ១កថ ២:៧ និងការពន្យល់ ៤:១ ១៣:២ ១៤:២ ១៥:៥១ និងការពន្យល់ អភ ១:៩ ៣:៣ និងការពន្យល់, ខ.៩ ៥:៣២ និងការពន្យល់ ៦:១៩ កល ១:២៦–២៧ និងការពន្យល់ ២:២ ៤:៣ ២ថន ២:៧ និង ការពន្យល់ ១ធថ ៣:៩,១៦) ។ ពាក្យនេះត្រូវបានយកមកប្រើចំពោះ (១).ការចាប់កំណើតរបស់ព្រះយេស៊ូវគ្រីស្ទនៅលើផែនដី(១ធថ ៣:១៦ និងការពន្យល់) ។ (២).ការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ(១កថ ២:១ និងការពន្យល់ ២:៧ "ប្រាជ្ញាដ៏អាថ៌កំបាំង" ។ (៣).គ្រប់ទាំងបំណងព្រះហឫទ័យត្រូវសរុបមកលើព្រះគ្រីស្ទ(អភ ១:៩–១០) ហើយជាពិសេសគឺបូករួមទាំងសាសន៍យូដា និងសាសន៍ដទៃនៅក្នុងពួកជំនុំសញ្ញាថ្មី(អភ ៣:៣–៦) ។ (៤).ការផ្លាស់ប្រែនឹងចូលមកដល់នៅថ្ងៃរស់ឡើងវិញ (១កថ ១៥:៥១–៥២) ។ (៥).ផែនការរបស់ព្រះអម្ចាស់មានសម្រាប់ទាំងសាសន៍យូដា និងសាសន៍ដទៃ ក្រោយពីការមិនស្ដាប់បង្គាប់កន្លងបាត់ទៅ នោះព្រះហឫទ័យ និងសេចក្ដីមេត្តារបស់ទ្រង់នឹងនាំសាសន៍ទាំងពីរនេះចូលនគរព្រះ ។ *ក្រែងអ្នករាល់គ្នាទុកចិត្តថាខ្លួនមានប្រាជ្ញា* ចង់បញ្ជាក់ថា នៅពេលដែលពួកគេទទួលបានសេចក្ដីសង្គ្រោះ នោះគឺជាគម្រោងផែនការនៃសេចក្ដីមេត្តាករុណារបស់ព្រះអម្ចាស់ រួមមានទាំងសាសន៍ដទៃផងដែរ ដែលជាផែនការសង្គ្រោះដ៏ធំអស្ចារ្យរបស់ទ្រង់ទេ ដូច្នេះ ត្រូវតែចេះបន្ទាបខ្លួនផង កុំវាយឫកឱ្យសោះ ។ *ប៉ុន្មានភាគនេះ* បញ្ជាក់ពីចិត្តរឹងរូសរបស់សាសន៍អ៊ីស្រាអែលមួយចំនួនមិនមែនទាំងអស់នោះទេ ។ *ទាល់តែ* មានន័យថា ចិត្តរឹងរូសរបស់ជនជាតិអ៊ីស្រាអែលមួយចំនួននោះ ពុំមែនរឹងរូសជាអចិន្ត្រៃយ៍(រហូត)នោះទេ គឺមានចិត្តរឹងរូសបណ្ដោះអាសន្នតែប៉ុណ្ណោះ។ *គ្រប់ចំនួន* នេះគឺជាចំនួននៃការជ្រើសរើសរបស់ព្រះអម្ចាស់ចំពោះសាសន៍ដទៃ ។

**១១:២៦** *នោះ* ពាក្យនេះមានន័យថា ដូច្នេះហើយបានជា ។ ត្រង់នេះជាសេចក្ដីថ្លែងបញ្ជាក់ពីវិធីដែលសាសន៍អ៊ីស្រាអែលទាំងអស់បានទទួលសេចក្ដីសង្គ្រោះ ។ *សាសន៍អ៊ីស្រាអែលទាំងអស់* ពាក្យនេះបានបកស្រាយ៣យ៉ាងគឺ (១).ជាចំនួនសរុបនៃការជ្រើសរើសសាសន៍យូដាគ្រប់ជំនាន់ (មានន័យដូចគ្នានឹងពាក្យថា"ពេញខ្នាត"នៃសាសន៍អ៊ីស្រាអែល ខ.១២ និងការពន្យល់ ហើយក៏មានន័យស្រដៀងនឹងពាក្យថា"គ្រប់ចំនួន" នៃសាសន៍ដទៃ ខ.២៥ និងការពន្យល់) ។ (២).ជាចំនួនសរុបនៃការជ្រើសរើសទាំង សាសន៍យូដា និងសាសន៍ដទៃនៅគ្រប់ៗជំនាន់ ។ (៣).ជាចំនួនច្រើនដ៏មហិមា នៃសាសន៍យូដានៅជំនាន់ចុងក្រោយ ។ *នឹងបានសង្គ្រោះ* ត្រង់នេះមានន័យថាសេចក្ដីសង្គ្រោះនៃសាសន៍យូដាជាបុគ្គលដែលបានជឿលើការសុគត និងរស់ពីស្លាប់ឡើងវិញរបស់ព្រះគ្រីស្ទយេស៊ូវ ។ *មានព្រះដ៏ប្រោសឱ្យរួច ទ្រង់នឹងចេញពីស៊ីយ៉ូនមក* ពាក្យនេះបានដកស្រង់ចេញពី អស ៥៩:២០ ។ លោកប៉ុលលើកយកមកនិយាយត្រង់នេះគឺសំដៅលើព្រះមែស៊ី ។ *ស៊ីយ៉ូន* មើល កទ ៤:២៦ ហព ១២:២២ ។

**១១:២៧** *សញ្ញា* ពាក្យនេះក្នុងគម្ពីរខ្មែរយើងពេលខ្លះឃើញពាក្យ "ការតាំងសញ្ញា" នេះគឺជាការតាំងសញ្ញាថ្មីមួយដែលកត់ចុះនៅក្នុង យរ ៣១:៣១–៣៤ (មើលការពន្យល់ក្នុងខនោះ) ។ *កាលដែលអញបានដោះបាបគេចេញហើយ* មើល យរ ៣១:៣៤ សក ១៣:១ និងការពន្យល់ ។ ត្រង់នេះបញ្ជាក់ថាសេចក្ដីសង្គ្រោះរបស់សាសន៍ដទៃបានមកដោសារ ការអត់ទោសបាបមកពីព្រះអម្ចាស់ ហើយដូចគ្នានឹងសាសន៍យូដាផងដែរ ។ ពួកគេបានសង្គ្រោះដោយសារ តែព្រះបានអត់ទោសអំពើបាបឱ្យគេ ដោយសេចក្ដីមេត្តាករុណានៃព្រះអម្ចាស់ ។ តែការអត់ទោសនេះបានឈរលើមូលដ្ឋាននៃការប្រែចិត្ត និងសេចក្ដីជំនឿរបស់ពួកគេដែរ(ខ.២៣ សក ១២:១០–១៣:១ និងពន្យល់) ។

**១១:២៨** *គេជាខ្មាំងសត្រូវ* ភាពជាសត្រូវនេះ គឺជាការបណ្ដោះអាសន្ន តែ

អ្នករាល់គ្នា តែត្រង់សេចក្ដីរើសតាំង នោះគេជាស្ងួនភ្ងាវិញ
ដោយព្រោះពួកព្ធយុកោ[ឆ] ២៩ដ្បិតព្រះទ្រង់មិនដែលស្ដាយ
អំណោយទានទ្រង់ ឬការដែលទ្រង់ហៅ[ជ]មនុស្សណានោះ
ឡើយ[ឈ] ៣០ពីព្រោះ ដូចជាកាលពីដើម អ្នករាល់គ្នាមិនបាន
ស្ដាប់បង្គាប់[ញ]ព្រះ តែឥឡូវនេះ ទ្រង់បានផ្ដល់សេចក្ដីមេត្ដា
ករុណាដល់អ្នករាល់គ្នា ដោយព្រោះពួកនោះមិនស្ដាប់
បង្គាប់វិញ ៣១ដូច្នេះ ដែលគេមិនស្ដាប់បង្គាប់នៅជាន់នេះ
នោះគឺដើម្បីឱ្យគេបានទទួលសេចក្ដីមេត្ដាករុណា ដោយ
សារសេចក្ដីមេត្ដាករុណាដែលទ្រង់បានផ្ដល់មកអ្នករាល់
គ្នាដូច្នោះដែរ ៣២ដ្បិតព្រះទ្រង់បានបង្ខាំងទាំងអស់គ្នាទុក
ក្នុងសេចក្ដីមិនស្ដាប់បង្គាប់[ដ] ដើម្បីឱ្យបានសំដែងនូវសេចក្ដី
មេត្ដាករុណា ដល់គ្រប់គ្នា ។

## ទំនុកតម្កើង

៣៣អើហ្ន៎ ប្រាជ្ញា នឹងចំណេះដ៏បរិបូររបស់ព្រះជ្រៅ
ណាស់[ឋ] តើ[ឌ] ឯព្រះដំរិះរបស់ទ្រង់ តើមានអ្នកណានឹងស្ទង់
បាន ហើយផ្លូវទ្រង់ តើមានអ្នកណានឹងរកតាមបាន[ឍ]
៣៤តើអ្នកណាបានស្គាល់គំនិតនៃព្រះអម្ចាស់ ឬធ្វើជាអ្នក
ជួយគំនិតទ្រង់បាន[ណ] ៣៥តើអ្នកណាបានថ្វាយដល់ទ្រង់ជា
មុន នោះនឹងបានប្រគល់ មកអ្នកនោះវិញ[ត] ៣៦ដ្បិតរបស់
សព្វសារពើ[ថ] បានកើតមកពីទ្រង់ ដោយសារទ្រង់ ហើយ
សំរាប់ទ្រង់ សូមឱ្យទ្រង់បានសិរីល្អនៅ អស់កល្បជានិច្ច
អាម៉ែន[ទ] ។

## យញ្ញបូជារស់

**១២** ១ដូច្នេះ បងប្អូនអើយ ខ្ញុំទូន្មានអ្នករាល់គ្នា[ធ] ដោយ
សេចក្ដីមេត្ដាករុណានៃព្រះ ឱ្យបានថ្វាយរូបកាយទុកជា
យញ្ញបូជារស់[ន] ហើយបរិសុទ្ធ ដែលគាប់ព្រះហឫទ័យដល់
ព្រះ ជាការគោរពនៃអ្នករាល់គ្នាដែលមានទំនង ២កុំឱ្យ
ត្រាប់តាម[ប]សម័យនេះឡើយ[ផ] ចូរឱ្យអ្នករាល់គ្នាបានផ្លាស់
ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង[ព] ដើម្បីនឹងអាចមើល

**១១:២៨** ឆ ចទ ៧:៨ ១០:១៥ រម ៩:៥
**១១:២៩** ជ រម ៨:២៨
ឈ ហព ៧:២១
**១១:៣០** ញ អភ ២:២
**១១:៣២** ដ រម ៣:៩
**១១:៣៣** ឋ រម ២:៤
ឌ ទដ ៩២:៥
អភ ៣:១០ កល ២:៣
ឍ យប ៥:៩ ១១:៧
ទដ ១៣៩:៦
សស ៨:១៧
អស ៤០:២៨
**១១:៣៤** ណ អស ៤០:១៣,១៤
យប ១៥:៨ ៣៦:២២
យរ ២៣:១៨
១កថ ២:១៦
**១១:៣៥** ត យប ៤១:១១ ៣៥:៧
**១១:៣៦** ថ ១កថ ៨:៦

១១:១២ កល ១:១៦ ហព ២:១០ ទ រម ១៦:២៧ អភ ៣:២១ ១ធថ ១:១៧ ១ពត ៥:១១ យដ ២៥ វវ ៥:១៣ ៧:១២ **១២:១** ធ អភ ៤:១ ១ពត ២:១១ ន រម ៦:១៣,១៦,១៩ ១កថ ៦:២០ ១ពត ២:៥ **១២:២** ប ១ពត ១:១៤ ផ ១កថ ១:២០ ២កថ ១០:២ ១យហ ២:១៥

ប៉ុណ្ណោះ។ *ដើម្បីប្រយោជន៍ដល់អ្នករាល់គ្នា* ឃ្លានេះមានពន្យល់ក្នុង ខ.១១ ។ *សេចក្ដីរើសតាំង នោះគេជាស្ងួនភ្ងាវិញ ដោយព្រោះពួកព្ធយុកោ* ចំណុចនេះមានន័យថាការជ្រើសរើសរបស់ព្រះ ពុំមែនដោយសារតែសាសន៍យូដាមានសគុណតាំងពីពួកព្ធយុកោ គេនោះទេ ប៉ុន្តែ ដោយសារសេចក្ដីស្រឡាញ់ព្រះបានជ្រើសរើសពួកអ៊ីស្រាអែល ហើយនេះជាការពិតដែលពុំអាចបដិសេធបាន ។

**១១:២៩** *ដ្បិតព្រះមិនដែលស្ដាយអំណោយទានទ្រង់ ឬការដែលទ្រង់ហៅមនុស្សណានោះឡើយ* មានន័យថា ព្រះអម្ចាស់មិនដែលផ្លាស់ប្ដូរព្រះទ័យឡើយចំពោះការត្រាស់ហៅរបស់ទ្រង់នោះ ។ ទោះបីនៅសព្វថ្ងៃនេះប្រជា–ជននៅប្រទេសអ៊ីស្រាអែល ដែលជាអ្នកមិនជឿលើព្រះគ្រីស្ទនោះ ក៏បំណងព្រះហឫទ័យទ្រង់នឹងត្រូវតែបានសម្រេចដែរ ។

**១១:៣២** *ទាំងអស់គ្នា* ពាក្យនេះសំដៅទៅលើទាំងពីរក្រុម(សាសន៍យូដា និងសាសន៍ដទៃ)។ រយៈពេលនៃការមិនស្ដាប់បង្គាប់ចំពោះក្រុមណាមួយ ដើម្បីឱ្យព្រះអម្ចាស់មានសេចក្ដីមេត្ដាដល់ពួកគេទាំងអស់គ្នា ។ លោកប៉ុលគ្មានមធ្យោបាយ ដើម្បីបង្រៀនពីសេចក្ដីសង្គ្រោះដល់មនុស្សទាំងអស់គ្នាពេញសកលលោកនេះបានទេ ។

**១១:៣៣–៣៦** នេះគឺជាបទចម្រៀងនៃវគ្គបញ្ចប់នៅក្នុងគម្ពីររ៉ូម ដែលលោកប៉ុលលើកយកមកសរសើរតម្កើងពីប្រាជ្ញា និងចំណេះដ៏ជ្រៅនៃព្រះអម្ចាស់របស់យើង ក្នុងការរៀបចំផែនការសម្រាប់សង្គ្រោះទាំងសាសន៍យូដា និងសាសន៍ដទៃ ។

**១២:១–១៦:២៧** នៅក្នុងជំពូកទាំងនេះ លោកប៉ុលបែរមករំលឹកឱ្យប្រតិបត្តិនូវអ្វីដែលលោកបានប្រាប់កាលពីមុននៅក្នុងសំបុត្រនេះ ។ ត្រង់នេះពុំមែនមានន័យថា ពីមុនគាត់ហាមគ្រីស្ទបរិស័ទមិនឱ្យធ្វើតាមនូវអ្វីដែលគាត់បាននិយាយនោះទេ ។ ក្នុងជំពូក ៦–៨ បានបង្រៀនខ្លះរួចមកហើយ ប៉ុន្តែ ពេលនេះគាត់បង្រៀនលំអិត ដើម្បីប្រាប់ថាព្រះយេស៊ូវគ្រីស្ទគឺជាព្រះអម្ចាស់នៃមនុស្សនៅគ្រប់ទីកន្លែងទាំងអស់ ។ ក្នុងជំពូកទាំងនេះក៏មិនមែនជាសេចក្ដីបន្ថែមលើការវែកញែកផ្នែកទេវសាស្ត្រដ៏ជ្រៅ ដូចនៅក្នុងជំពូក ១–១១នោះដែរ ។ និយាយឱ្យចំទៅ នៅក្នុងសំបុត្រទាំងមូលបាននាំយើងឆ្ពោះទៅរកទិសដៅនៃការបង្ហាញនូវអ្វីដែលព្រះអម្ចាស់ ទ្រង់ចង់បានពីយើងរាល់គ្នា នោះគឺភាពស្មោះត្រង់របស់យើង ទាំងទង្វើ ជំនឿ និងគំនិត ។ ជំនឿបង្ហាញចេញមកនូវការស្ដាប់បង្គាប់(មើលការពន្យល់ យក ២:១៤–២៦)។

**១២:១** *ដូច្នេះ បងប្អូនអើយ ខ្ញុំទូន្មានអ្នករាល់គ្នា* នេះគឺជាឃ្លាមួយ ដែលលោកប៉ុលបានទាញការពិចារណាដ៏សំខាន់មួយចេញពីជំពូក ១–១១។ *សេចក្ដីមេត្ដាករុណានៃព្រះ* ភាគច្រើននៃសំបុត្រនៅក្នុងព្រះគម្ពីរត្រូវបានជាប់ទាក់ ទងពីការបង្ហាញនូវសេចក្ដីមេត្ដាករុណានៃព្រះ ដែលមានចំពោះមនុស្សនាពេលបច្ចុប្បន្ននេះ ។ *រូបកាយ* មើល ៦:១៣ និងការពន្យល់ ។ *យញ្ញបូជារស់* ពាក្យនេះ មានជាប់ទាក់ទងទៅនឹងរបៀបដែលបណ្ដាជនយកសត្វមកសម្លាប់ ដើម្បីធ្វើយញ្ញបូជាដល់ព្រះនៅក្នុងសម័យដើម ប៉ុន្តែឥឡូវនេះ គឺយករូបកាយដ៏រស់ទុកជាយញ្ញបូជាដល់ព្រះវិញដោយរស់របៀបជាជីវិតថ្មី ក្រោមការដឹកនាំនៃព្រះវិញ្ញាណបរិសុទ្ធ ដែលសណ្ឋិតក្នុងយើងរាល់គ្នា (៦:៤ ៨:២ និងការពន្យល់)។ *ជាការគោរពនៃអ្នករាល់គ្នា* ត្រង់ចំណុចនេះមិនគ្រាន់តែជាសកម្មភាពខាងឯប្រពៃណីនោះទេ ប៉ុន្តែ ន័យក្នុងឃ្លានេះគឺសំដៅទៅលើចិត្តគំនិត និងឆន្ទៈរបស់យើងទៀតផង ។ *ដែលមានទំនង* ពាក្យនេះសំដៅលើការបម្រើដោយស្ដាប់បង្គាប់ដល់ព្រះអម្ចាស់យេស៊ូវនៃយើង ។

**១២:២** *សម័យនេះ* គឺសំដៅទៅលើរឿងរ៉ាវក្នុងលោកីយដែលសម្បូរដោយអំពើ អាក្រក់ និងអំពើពុយរលួយ(កទ ១:៤ ១យហ ២:១៥ និងការពន្យល់)។ *ចូរឱ្យអ្នក រាល់គ្នាផ្លាស់ប្រែវិញ* នៅក្នុងន័យនេះ គឺបញ្ជាក់ពីដំណើរបន្តិចម្ដងៗ ពុំមែនជាព្រឹត្តការណ៍តែមួយភ្លែតនោះទេ ។ ពាក្យនេះជាភាសាក្រិកត្រូវបាន

ឱ្យបានស្គាល់បំណងព្រះហឫទ័យនៃព្រះ[ព] ដែលល្អ ស្រួល
ទទួល[ភ] ហើយគ្រប់លក្ខណ៍ផង ៣ដ្បិត ខ្ញុំនិយាយនឹងមនុស្ស
ទាំងអស់ក្នុងពួកអ្នករាល់គ្នា ដោយព្រះគុណដែលទ្រង់បាន
ផ្តល់មកខ្ញុំ[យ]ថា ចូរគិតបែបឱ្យមានគំនិតនឹងធឹង តាមខ្នាត
នៃសេចក្តីជំនឿ ដែលព្រះបានចែកមកអ្នករាល់គ្នានិមួយៗ
កុំឱ្យមានគំនិតខ្ពស់ លើសជាងគំនិត ដែលគួរគប្បីឱ្យ
គិតនោះឡើយ ៤ដ្បិត ដែលយើងរាល់គ្នាមានអវយវៈជា
ច្រើនរួមគ្នាជារូបកាយតែមួយ តែអវយវៈ ទាំងនោះមាន
ការងារផ្សេងៗពីគ្នាជាយ៉ាងណា[រ] ៥នោះយើងដែលមានគ្នា
ច្រើនក៏ជារូបកាយតែមួយ[ល]ក្នុងព្រះគ្រីស្ទ ហើយជាអវយវៈ
ដល់គ្នានឹងគ្នាបែបយ៉ាងនោះដែរ ៦ដូច្នេះដែលមានអំណោយ
ទានផ្សេងពីគ្នា[វ] តាមព្រះគុណ ដែលផ្តល់មកយើង ទោះបើ
ជាសេចក្តីទំនាយ[ស] នោះក៏ត្រូវទាយតាមខ្នាតនៃសេចក្តីជំ
នឿ[ហ] ៧ឬបើជាការបំរើ នោះចូរបំរើចុះ ឬជាការបង្រៀន
ចូរបង្រៀនទៅ[ឡ] ៨ឬជាការទូន្មាន ចូរទូន្មានទៅ[អ] ឬជាការ
ចែកទាន ចូរចែកដោយចិត្តស្មោះ[ក] ឬជាការនាំមុខ ចូរធ្វើ
ដោយឧស្សាហ៍ ឬតាមមេត្តាករុណា ក៏ចូរធ្វើដោយរីក
រាយចុះ ។

## សេចក្តីស្រឡាញ់

៩ចូរឱ្យមានសេចក្តីស្រឡាញ់ឥតពុតមាយា[ខ] ទាំងខ្ពើម
សេចក្តីអាក្រក់ ហើយកាន់ខ្ជាប់ខាងសេចក្តីល្អវិញ[គ] ១០ខាង
ឯសេចក្តីស្រឡាញ់ជាបងប្អូន[ឃ] នោះចូរមានចិត្តថ្នមគ្នាទៅ
វិញទៅមកចុះ ខាងឯសេចក្តីរាប់អាន នោះឱ្យខំរាប់អាន
គេជាមុន[ង] ១១ខាងឯសេចក្តីឧស្សាហ៍ នោះកុំឱ្យខ្ជិលឡើយ

**១២:២** ព អភ ៤:២៣ ភ អភ ៥:១៧ ម ១ធថ ៥:៤ **១២:៣** យ រម ១៥:១៥ ១កថ ១៥:១០ កទ ២:៩ អភ ៣:៧ ៤:៧ ១ពត ៤:១០,១១ **១២:៤** រ ១កថ ១២:១២-១៤ អភ ៤:១៦ **១២:៥** ល ១កថ ៦:១៥ ១០:១៧ ១២:១២,២០,២៧ អភ ២:១៦ ៤:៤,២៥ ៥:៣០ កល ៣:១៥ **១២:៦** វ ១កថ ៧:៧ ១២:៤,៨-១០ ស អភ ៤:១១ ហ ១ពត ៤:១០,១១

**១២:៧** ឡ អភ ៤:១១ **១២:៨** អ កច ១១:២៣ ១៣:១៥ ១៥:៣២ ក ២កថ ៨:២ ៩:៥-១៣ **១២:៩** ខ ២កថ ៦:៦ ១ធថ ១:៥ គ ទដ ៩៧:១០ អម ៥:១៥ ១ថន ៥:២១,២២ **១២:១០** ឃ ទដ ១៣៣:១ ១ថន ៤:៩ ហព ១៣:១ ១ពត ១:២២ ង ភល ២:៣

ប្រើសម្រាប់ការផ្លាស់ប្តូរដូចគ្នានេះដែរ (មថ ១៧:២-៨ មក ៩:២-៨) និង មាននៅក្នុង ២កថ ៣:១៨ (មើលការពន្យល់ទីនោះ) ។ *គំនិត* គឺបានមកពីការ គិត និងឆន្ទៈដែលមានទាក់ទងទៅនឹងការដែលគួរគប្បីធ្វើឱ្យសំណាំនឹងបានកែ ជាថ្មី (១:២៨) ។ *បំណងព្រះហឫទ័យនៃព្រះ* នេះចង់បញ្ជាក់ពីអ្វីដែលព្រះ អម្ចាស់យេស៊ូវចង់បានពីអ្នកជឿ ។ *ដែលល្អ* គឺអ្វីដែលនាំទៅរកខាងឯវិញ្ញាណ និងការរីកលូតលាស់ផ្នែកសីលធម៌របស់គ្រីស្ទបរិស័ទ ។ *ស្រួលទទួល* មានន័យ ថាព្រះអម្ចាស់ទ្រង់ជាអ្នកទទួល ពុំមែនមនុស្សទេ ។ *គ្រប់លក្ខណ៍* មានន័យថា ការធ្វើតាមបំណងព្រះហឫទ័យព្រះ ។ គ្មានអ្វីដែលអាចធ្វើ ឱ្យប្រសើរជាងការ ដែលធ្វើតាមបំណងព្រះហឫទ័យនៃព្រះអម្ចាស់នោះឡើយ ។

**១២:៣** *តាមខ្នាតនៃសេចក្តីជំនឿ* នេះគឺនិយាយពីអំណាចដែលព្រះអម្ចាស់បាន ប្រទានឱ្យអ្នកជឿនិមួយៗ ដើម្បីសម្រេចការកិច្ចផ្សេងៗនៅក្នុងព្រះវិហារ (ខ.៤-៨ និងការពន្យល់) ។ *ទ្រង់បានប្រទានមក* មានន័យថាគ្រប់ទាំងអំណាច សុទ្ធតែមកពីព្រះ ដូច្នេះ គ្មានអ្វីដែលមនុស្សត្រូវអួតអំពីខ្លួនឯងនោះទេ ។

**១២:៤-៨** នៅក្នុងខនេះលោកប៉ុលបានប្រដូចគ្រីស្ទបរិស័ទទៅនឹងអវយវៈ របស់មនុស្សម្នាក់ ។ មានអវយវៈជាច្រើនដែលមានតួនាទីផ្សេងៗគ្នា ប៉ុន្តែ អវយវៈទាំងអស់នោះត្រូវការដងខ្លួនមួយដែលមានសុខភាពល្អ ។ ចំណុចនេះ បង្ហាញពីការរួបរួមគ្នារបស់គ្រីស្ទស័ទ (១កថ ១២:១២-៣១ និងការពន្យល់) ។

**១២:៥** *ក្នុងព្រះគ្រីស្ទ* នេះគឺជាពាក្យនៃគំនិតរបស់លោកប៉ុលអំពីការរួបរួម របស់គ្រីស្ទបរិស័ទ ។ មានតែតាមរយៈព្រះយេស៊ូវគ្រីស្ទតែមួយអង្គគត់ ដែល អាចធ្វើឱ្យពួកឱ្យពួកជំនុំរួបរួមគ្នាបាន ។ សេចក្តីរួបរួមដ៏ពិតនោះគឺផ្តោត លើព្រលឹងវិញ្ញាណ (មើលការពន្យល់ ៦:១១) ។

**១២:៦** *អំណោយទាន* ពាក្យនេះជាភាសាក្រិកសំដៅលើអំណោយពិសេស នៃព្រះគុណរបស់ព្រះដែលបានប្រទានដល់រាស្ត្រទ្រង់ ដោយឥតគិតកម្រៃ ដើម្បីឆ្លើយតបនឹងតម្រូវការរូបកាយ (មើលការពន្យល់ ១កថ ១:៧ ១២:៤) ។ *សេចក្តីទំនាយ* មើល ការពន្យល់ ១កថ ១២:១០ ១៤:១-៥ ។ *នោះក៏ត្រូវទាយ* គឺចង់និយាយអំពីការប្រើអំណោយទាន ហើយការទាយនេះជាឧទាហរណ៍ នៃអំណោយទានជាច្រើនដែលព្រះបានប្រទានឱ្យ ។

**១២:៧** *ការបំរើ* គឺជាកិច្ចការគ្រប់បែបយ៉ាងដែលរូបកាយព្រះគ្រីស្ទ ឬសមាជិកពួកជំនុំត្រូវការឱ្យជួយ ។ *ការបង្រៀន* មើលកាពន្យល់ ១កថ ១២:២៨ អភ ៤:១១ ។

**១២:៨** *ការទូន្មាន* ត្រង់នេះមានន័យថា ការជួយជំរុញ និងលើកតម្កើង អ្នកដទៃដោយអំណរ ដើម្បីឱ្យបានសម្រេចកិច្ចការល្អណាមួយ ។ គ្រូបង្រៀន ល្អតែងតែប្រតិបត្តិតួនាទីនេះ ។ ក្នុងការបង្រៀនដល់អ្នកជឿគឺត្រូវបានបង្ហាញ នូវអ្វីដែលពួកគេត្រូវធ្វើចំណែកឯការទូន្មាន គឺជាជំនួយជួយពួកគេនៅក្នុង ការអនុវត្តន៍ ។ *ការចែកទាន* មានន័យថា ឱ្យនូវអ្វីដែលជារបស់ខ្លួនទៅអ្នក ដទៃ ឬក៏ជារបស់ដែលយើងបានទទួលពីអ្នកដទៃ ។ *ការនាំមុខ* ពាក្យនេះ ប្រហែល សំដៅទៅលើពួកចាស់ទុំនៅក្នុងព្រះវិហារ ដោយសារតែនៅ សម័យនោះ ពួកជំនុំនៅក្រុងអេភេសូរចាប់ផ្តើមមានចាស់ទុំហើយ (កច ២០:១៧ ១ធថ ៥:១៧ និងការពន្យល់) ។ *ចូរធ្វើ... តាមមេត្តាករុណា* មាន ន័យថា ការយកចិត្តទុកដាក់មើលថែអ្នកជម្ងឺ មនុស្សចាស់ជរា ជនពិការ និងអ្នកក្រីក្រ ។ *ចូរធ្វើដោយរីករាយចុះ* មានន័យថា ផ្តល់សេចក្តីតម្រូវការ ដល់អ្នកដទៃដោយ រីករាយមិនមែនចាំបាច់តែមុខងារនោះទេ ។

**១២:៩** *សេចក្តីស្រឡាញ់* នេះគឺជាសេចក្តីស្រឡាញ់របស់អ្នកជឿព្រះដែលមាន ចំពោះគ្រីស្ទបរិស័ទដូចគ្នា ហើយក៏សម្រាប់មនុស្សដទៃទៀតដែរ ។ *ឥតពុតមាយា* ត្រង់នេះបញ្ជាក់ពីសេចក្តីស្រឡាញ់ ស្មោះត្រង់ដ៏ពិតប្រាកដ ។ ដោយ យោងតាមការបកស្រាយខាងលើ សេចក្តីនេះមានជាប់ទាក់ទងទៅនឹងសង្គម មនុស្ស ដូច្នេះសេចក្តីស្រឡាញ់ដែលលោកប៉ុល លើកមកនិយាយត្រង់ចំណុច នេះមិនមែនគ្រាន់តែ ជាសេចក្តីស្រឡាញ់ដែលមានតែក្នុងចិត្តនោះទេ តែជា សេចក្តីស្រឡាញ់មានទាំងសកម្មភាពផងដែរ ដូចដែលបានពណ៌នានៅក្នុង ជំពូកនេះស្រាប់ ។ *សេចក្តីអាក្រក់... និងសេចក្តីល្អវិញ* មើល អម ៥:១៥ ។ "អាក្រក់" និង "ល្អ" គឺជាពាក្យចាប់ផ្តើម និងបញ្ចប់នៃវគ្គ ខ.៩-២១ ។

**១២:១០** *សេចក្តីស្រឡាញ់ជាបងប្អូន* នេះគឺជាសេចក្តីស្រឡាញ់នៅក្នុងក្រុម គ្រួសារនៃព្រះ ។ *ឱ្យខំរាប់អានគេជាមុន* អាចមានន័យថាផ្តល់កិត្តិយសដល់អ្នក ដទៃជាមុន ។ អ្នកដែលមានចិត្តដូច្នេះទាល់តែមានការបើកសំដែងពីព្រះ វិញ្ញាណ (ខ.២) ទើបអាចធ្វើការទាំងនេះបាន (ភល ២:៣ និងការពន្យល់) ។

**១២:១១** *កុំឱ្យខ្ជិលឡើយខាងឯវិញ្ញាណ* បើពាក្យថា "វិញ្ញាណ" នៅត្រង់នេះ

ខាងឯវិញ្ញាណ នោះក៏ចូរព្យាយាមចុះ ដោយខំប្រឹង[ច]បំរើ
ព្រះអម្ចាស់ ១២ចូរអរសប្បាយ ដោយមានសង្ឃឹម[ឆ]ចូរអត់
ធន់ ក្នុងសេចក្ដីទុក្ខលំបាក[ជ]ចូរឱ្យខ្ជាប់ខ្ជួនក្នុងសេចក្ដីអធិ
ស្ឋាន[ឈ] ១៣ខាងសេចក្ដីខ្វះខាតរបស់ពួកបរិសុទ្ធ[ញ] នោះក៏
ចូរផ្គត់ផ្គង់ឱ្យ ទាំងខំប្រឹងឱ្យមានសេចក្ដីចៅរ៉ៅផងចុះ[ដ]
១៤ចូរសូមពរឱ្យដល់អ្នកណាដែលបៀតបៀនអ្នក[ឋ] ចូរសូម
ពរចុះ កុំឱ្យប្រទេចផ្ដាសាឡើយ ១៥ចូរអរសប្បាយជា
មួយនឹងអ្នកណាដែលអរសប្បាយ ហើយយំជាមួយនឹង
អ្នកណាដែលយំផង[ឌ] ១៦ចូរឱ្យមានគំនិតព្រមព្រៀងគ្នាទៅ
វិញទៅមក[ឍ] កុំឱ្យមានគំនិតឆ្មើងឆ្មៃសោះឡើយ គឺត្រូវភប់
ប្រសព្វនឹងមនុស្សរាបសាវិញ កុំឱ្យទុកចិត្តនឹងខ្លួនថាមាន
ប្រាជ្ញាឱ្យសោះ[ណ]។
១៧កុំឱ្យធ្វើការអាក្រក់ស្នងនឹងការក្រក់ឡើយ[ត] ត្រូវខំសំ
ដែងកិរិយាល្អ នៅចំពោះមុខមនុស្សទាំងអស់វិញ[ថ] ១៨ខាង
ឯពួកអ្នករាល់គ្នា នោះឱ្យខំនៅជាមេត្រីនឹងមនុស្សទាំងអស់
ចុះ បើសិនជាបាន[ទ] ១៩ឱពួកស្ងួនភ្ងាអើយ កុំឱ្យសងសឹក
ឡើយ[ធ] ចូរថយចេញពីសេចក្ដីកំហឹងទៅ ដ្បិតមានសេចក្ដី
ចែងទុកមកថា ព្រះអម្ចាស់ ទ្រង់មានបន្ទូលថា ការសង
សឹកនោះស្រេចនឹងអញ អញនឹងសងដល់គេ[ន] ២០ដូច្នេះ
បើសិនណាជាខ្មាំងសត្រូវអ្នកឃ្លាន នោះចូរឱ្យគេបរិភោគ
ចុះ បើគេស្រេក ចូរឱ្យផឹកទៅ បើប្រព្រឹត្តដូច្នោះ នោះដូច
ជាអ្នកបានប្រមូលរងើកភ្លើងដាក់លើក្បាលគេវិញ[ប] ២១កុំ
ឱ្យសេចក្ដីអាក្រក់ឈ្នះអ្នកឡើយ ត្រូវឱ្យអ្នកឈ្នះសេចក្ដី
អាក្រក់ ដោយសារសេចក្ដីល្អវិញ ។

## ការចុះចូលនឹងរដ្ឋអំណាច

១៣ ១ចូរឱ្យគ្រប់ទាំងមនុស្សចុះចូលនឹងរាជការ[ផ]ដ្បិត
គ្មានអំណាចណាទេ លើកតែមកពីព្រះ[ព] គឺព្រះទ្រង់បាន
តាំងពួកលោកទាំងនោះឱ្យមានអំណាច ២បានជាអ្នកណា
ដែលតាំងខ្លួនទាស់នឹងអំណាចនោះ ក៏ទាស់ទទឹងនឹងបញ្ញត្តិ

**១២:១១** ច កច ១៸:២៥
**១២:១២** ឆ រម ៥:២ ជ ហព ១០:៣២,៣៦ ឈ លក ១៨:១
**១២:១៣** ញ កច ២៤:១៧ ដ ១ពរ ៤:១០ យប ៣១:៣២ ១ធថ ៣:២ ៥:១០ ហព ១៣:២ ១ពត ៤:៩
**១២:១៤** ឋ មថ ៥:៤៤
**១២:១៥** ឌ យប ៣០:២៥
**១២:១៦** ឍ រម ១៥:៥ ណ ខ.៣ ទដ ១៣១:១ អស ៥:២១ យរ ៤៥:៥ រម ១១:២៥
**១២:១៧** ត ខ.១៩ សក ២០:២២ ២៤:២៩

ថ ២កថ ៨:២១ **១២:១៨** ទ មក ៩:៥០ រម ១៤:១៩ **១២:១៩** ធ ខ.១៧ លវ ១៩:១៨ សក ២០:២២ ២៤:២៩ ន ចទ ៣២:៣៥ លប ៥០:១៩ ១សយ ២៦:១០ ទដ ៩៤:១ យរ ៥១:៣៦ **១២:២០** ប សក ២៥:២១,២២ នក ២៣:៤ មថ ៥:៤៤ លក ៦:២៧ **១៣:១** ផ ទត ៣:១ ១ពត ២:១៣,១៤ ព ដយ ២:២១ ៤:១៧ យហ ១៩:១១

មានន័យថា ជាព្រះវិញ្ញាណបរិសុទ្ធនោះក៏បញ្ជាក់ឱ្យយើងពេញចិត្តនៅពេលព្រះវិញ្ញាណបរិសុទ្ធផ្គត់ផ្គង់ ។

**១២:១២** *ចូរអរសប្បាយ ដោយមានសង្ឃឹម* មានន័យថា សេចក្ដីសង្ឃឹមដ៏ពិតប្រាកដរបស់គ្រីស្ទបរិស័ទនោះគឺបុព្វហេតុនៃអំណរ (៥:៥ និងការពន្យល់ ៨:១៦–២៥ ១ពត ១:៣–៩)។ *អត់ធន់* មានន័យថា ភាពស្ថិតស្ថេរ ភាពជោគជ័យ ជាពិសេសចំពោះគ្រីស្ទបរិស័ទ ពីព្រោះពួកគេពុំអាចចៀសពីសេចក្ដីទុក្ខព្រួយផុតឡើយ(យហ ១៦:៣៣ ២ធថ ៣:១២ និងការពន្យល់)។ *ចូរឱ្យខ្ជាប់ខ្ជួនក្នុងសេចក្ដីអធិស្ឋាន* ត្រង់នេះចង់បញ្ជាក់ថា ពុំមែនត្រូវតែអធិស្ឋាននៅក្នុងគ្រាលំបាកនោះទេ តែត្រូវអធិស្ឋានគ្រប់ពេលវេលាផងដែរ (លក ១៨:១ ១ថេ ៥:១៧ និងការពន្យល់)។

**១២:១៣** *ខាងសេចក្ដីខ្វះខាតរបស់ពួកបរិសុទ្ធ* មានន័យថា គ្រីស្ទបរិស័ទមានការទទួលខុសត្រូវនៅក្នុងសង្គមចំពោះមនុស្សទាំងអស់គ្នា ប៉ុន្តែជាពិសេសទៅលើអ្នកជឿព្រះគ្រីស្ទដូចគ្នាជាមុនសិន(កទ ៦:១០ ១ធថ ៥:៨)។

**១២:១៤** *ចូរសូមពរឱ្យដល់អ្នកណាដែលបៀតបៀនអ្នក* ត្រង់នេះលោកប៉ុលបានដកស្រង់ចេញពីសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវ (មថ ៥:៤៤ និងការពន្យល់ លក ៦:២៨ និងមើលការពន្យល់ ៦:២៧)។

**១២:១៥** ការបង្ហាញភាពអរសប្បាយជាមួយនឹងអ្នកណាដែលអរសប្បាយ ហើយយំជាមួយនឹងអ្នកណាដែលយំ នោះហើយជាការទទួលខុសត្រូវ និងជាឯកសិទ្ធិមួយរបស់គ្រីស្ទបរិស័ទ ។

**១២:១៧** *កុំឱ្យធ្វើការអាក្រក់ស្នងនឹងការអាក្រក់* មើល មថ ៥:៣៩–៤២,៤៤–៤៥ ១ថេ ៥:១៥ ១ពត ៣:៩ និងការពន្យល់ ។ *ត្រូវខំសំដែងកិរិយាល្អនៅចំពោះមុខ មនុស្សទាំងអស់* នៅចំណុចនេះប្រហែលជាដកស្រង់ចេញពី សភ ៣:៤ ។ អត្តចរិតរបស់គ្រីស្ទបរិស័ទមិនត្រូវរក្សាត់នឹងបទដ្ឋានសីលធម៌ដ៏ថ្លៃថ្នូរនៃដំណឹងល្អនោះឡើយ បើមិនដូច្នេះទេ នោះនឹងបង្កឱ្យមានការមាក់ងាយពីសំណាក់អ្នកមិនជឿ ហើយនិងនាំឱ្យដំណឹងល្អខូចទទេ (២កថ ៨:២១ និងការពន្យល់ ១ធថ ៣:៧)។

**១២:១៨** *នោះឱ្យខំនៅជាមេត្រីនឹង . . . បើសិនជាបាន* ចំណុចនេះបានបញ្ជាក់ម្ដងទៀតទៅលើសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវថា មានពរហើយអ្នកដែលផ្សះផ្សាគេ (មថ ៥:៩ និងការពន្យល់)និងអ្នកជឿលើព្រះយេស៊ូវត្រូវតែបណ្ដុះសន្តិភាពជាមួយនឹងមនុស្សគ្រប់គ្នាតាមដែលខ្លួនអាចធ្វើទៅបាន (យក ៣:១៨ និងការពន្យល់)។

**១២:២០** *ប្រមូលរងើកភ្លើងដាក់លើក្បាលគេ* នេះគឺជាការឆ្លើយតបដោយទង្វើល្អរបស់អ្នកជឿព្រះទៅនឹងសត្រូវរបស់ខ្លួន(ខ.២១)។ បើធ្វើយ៉ាងដូច្នេះនោះយើងអាចចៀសចេញពីការសងសឹក ហើយអាចនាំគេប្រែចិត្តជឿលើព្រះគ្រីស្ទបានទៀតផង(មើលការពន្យល់ សភ ២៥:២២)។

**១២:២១** *សេចក្ដីអាក្រក់ . . . សេចក្ដីល្អ* មើលការពន្យល់នៅក្នុង ខ.៩ ។

**១៣:១** *ចុះចូល* នេះគឺជាពាក្យសំខាន់មួយនៅក្នុង ខ.១–៧ ។ *អំណាច* នេះគឺជាអំណាចគ្រប់គ្រងលើពលរដ្ឋនៅតាមស្រុកនីមួយៗ ។ ត្រង់ចំណុចនេះប្រហែលជាលោកប៉ុលនិយាយអំពីសាសន៍ដទៃនៅក្រុងរ៉ូម នាសម័យកាលរបស់លោក ។ ចំពោះជីវិតសព្វថ្ងៃនេះយើងសួរថា តើចំណុចណាដែលយើងចុះចូល? ហើយចំណុចណាដែល យើងមិនចុះចូលនឹងរាជការនោះ? លោកប៉ុលបានប្រាប់ថា ចូរឱ្យគ្រប់ទាំងមនុស្សចុះចូលនឹងរាជការ ។ តែយើងមិនត្រូវព្រមតាមរាជការណាដែលបង្ខំយើងមិនឱ្យស្ដាប់បង្គាប់ព្រះនោះឡើយ ។ ព្រះយេស៊ូវ និងសិស្សរបស់ទ្រង់មិនដែលបដិសេធនឹងរាជការ ចំពោះរឿងផ្ទាល់ខ្លួនឡើយ តែនៅពេលពួកគេបដិសេធ នោះគឺដើម្បីចុះចូលនឹងព្រះដ៏ខ្ពស់បំផុតវិញ ទោះជាត្រូវទទួលទោសក៏ដោយ ។ គ្រីស្ទបរិស័ទគួរ តែចុះចូលនឹងព្រះគ្រីស្ទតែមួយអង្គគត់ បើក្នុងករណីមានរាជការប្រើអំណាចខុសទំនងនោះ ។ *ព្រះទ្រង់បានតាំង* ត្រង់ចំណុចនេះបញ្ជាក់ពីព្រឹត្តិការណ៍នៅសម័យរបស់លោកប៉ុលថា ទោះជារដ្ឋាភិបាលបានបៀតបៀនដល់គាត់យ៉ាងណាក៏ដោយក៏ពុំអាចធ្វើឱ្យសេចក្ដីជំនឿរបស់គាត់រង្គើបានដែរ ហើយគាត់ក៏នៅតែជឿថាព្រះជាអ្នកតាំងពួកគេឡើង(១ពត ២:១៣–១៧ និងការពន្យល់)។

**១៣:២** *ត្រូវទោស* ការដែលត្រូវមានទោសនេះអាចមកពីព្រះផង និងមក

នៃព្រះដែរ[ក] ហើយអស់អ្នកដែលទាស់ទទឹង នោះនឹងត្រូវ
ទោសជាមិនខាន ៣ដ្បិតពួកនាម៉ឺនមិនមែនជាសេចក្ដីស្ញែង
ខ្លាចដល់ការល្អទេ គឺដល់ការអាក្រក់វិញ តើអ្នកចង់រួច
ពីសេចក្ដីស្ញែងខ្លាចចំពោះអំណាចនោះឬទេ បើដូច្នេះ
ចូរប្រព្រឹត្តល្អចុះ នោះលោកនឹងពោលសរសើរដល់អ្នក
ហើយ[ម] ៤ដ្បិតលោកជាអ្នកបំរើរបស់ព្រះ សំរាប់សេចក្ដីល្អ
ដល់អ្នក ប៉ុន្តែ បើអ្នកប្រព្រឹត្តអាក្រក់ នោះត្រូវខ្លាចវិញ
ដ្បិតលោកមិនមែនស្ពាយដាវជាឥតអំពើទេ ពីព្រោះជា
អ្នកបំរើរបស់ព្រះ គឺជាអ្នកសំរាប់សងសឹក ដើម្បីនឹងនាំ
សេចក្ដីក្រោធរបស់ព្រះមកលើអ្នកណាដែលប្រព្រឹត្តអា
ក្រក់[យ] ៥ដូច្នេះត្រូវឱ្យចុះចូល មិនមែនដោយព្រោះតែ
សេចក្ដី ក្រោធប៉ុណ្ណោះ គឺដោយព្រោះបញ្ញាចិត្តផង[រ]
៦ដោយហេតុនោះបានជាអ្នករាល់គ្នាត្រូវបង់ពន្ធដែរ[ល]
ពីព្រោះលោកទាំងនោះជាភ្នាក់ងាររបស់ព្រះ សំរាប់នឹង
ត្រួតត្រាការនោះឯងជានិច្ច ៧ដូច្នេះ ចូរសងដល់លោក
ទាំងនោះ តាមដែលអ្នកជំពាក់ចុះ[វ] គឺឱ្យបង់ពន្ធខ្លួនដល់
លោកណាដែលត្រូវទទួល បង់ពន្ធគយដល់លោកណា
ដែលទទួលខាងពន្ធគយ ត្រូវមានសេចក្ដីកោតខ្លាច ចំពោះ

**១៣:២** ភ នក ១៦:៨
**១៣:៣** ម ១ពត ២:១៤
**១៣:៤** យ ១ថន ៤:៦
**១៣:៥** រ សក ២៤:២១,២២
**១៣:៦** ល មថ ២២:១៧
**១៣:៧** វ មថ ១៧:២៥ ២២:១៧,២១ លក ២៣:២
**១៣:៨** ស ខ.១០ មថ ៥:៤៣ យហ ១៣:៣៤ កល ៣:១៤
**១៣:៩** ហ នក ២០:១៣–១៥,១៧ ចទ ៥:១៧–១៩,២១ ឡ មថ ៧:១២ អ លវ ១៩:១៨ មថ ៥:៤៣
**១៣:១០** ក ខ.៨,៩

លោកណាដែលគួរកោតខ្លាច ហើយត្រូវគោរពប្រតិបត្តិ
ដល់លោកណាដែលគួរគោរពដែរ ។

## ចូរមានសេចក្ដីស្រឡាញ់ ព្រោះថ្ងៃជិតមកដល់ហើយ

៨កុំឱ្យជំពាក់អ្វីដល់អ្នកណាឡើយ ជំពាក់បានតែសេចក្ដី
ស្រឡាញ់ដល់គ្នាទៅវិញទៅមកប៉ុណ្ណោះ ដ្បិតអ្នកដែល
ស្រឡាញ់ដល់គេ នោះបានធ្វើសំរេចតាមក្រិត្យវិន័យ
ហើយ[ស] ៩ពីព្រោះបទដែលថា «កុំឱ្យផិតឱ្យសោះ កុំឱ្យ
សំឡាប់មនុស្សឱ្យសោះ កុំឱ្យលួចឱ្យសោះ កុំឱ្យលោភឱ្យ
សោះ»[ហ] ហើយបើមានបញ្ញត្តិណាទៀត នោះក៏រួមគ្នា[ឡ]មក
ក្នុងពាក្យ១ម៉ាត់នេះឯង ដែលថា «ចូរស្រឡាញ់អ្នកជិតខាង
ដូចខ្លួនឯង»[អ] ១០សេចក្ដីស្រឡាញ់មិនដែលធ្វើអាក្រក់ដល់
អ្នកជិតខាងឡើយ ដូច្នេះសេចក្ដីស្រឡាញ់ជាកិច្ចសំរេច
តាមក្រិត្យវិន័យហើយ[ក]។
១១ត្រូវប្រព្រឹត្តដូច្នោះ ដោយដឹងពេលវេលា[ខ]ថា ដល់
ម៉ោងនឹងភ្ញាក់ពីដេកហើយ[គ] ដ្បិតឥឡូវនេះ សេចក្ដីសង្គ្រោះ
បានមកជិតបង្កើយ ជាជាងកាលយើងទើបនឹងជឿនោះ

**១៣:១១** ខ ១កថ ៧:២៩–៣១ ១០:១១ យក ៥:៨ ១ពត ៤:៧ ១យហ ២:១៨ វវ ២២:១០ គ អភ ៥:១៤ ១ថន ៥:៥,៦

ពីរដ្ឋអំណាចផង (ខ.៣–៤) ។

**១៣:៣** *ចូរប្រព្រឹត្តល្អចុះ នោះលោកនឹងពោលសរសើរដល់អ្នក* អត្ថន័យនេះវាពុំមែនជាការពិតជានិច្ចនោះទេ គឺលោកប៉ុលចង់សំដៅទៅលើ តែមន្ត្រី ឬនាម៉ឺនទាំងឡាយណាដែលបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះ ។ តែបើមន្ត្រីណាប្រើតួនាទីរបស់ខ្លួនមកបំពាន នោះគ្រីស្ទបរិស័ទយើងត្រូវតែស្ដាប់បង្គាប់ព្រះជាជាងអំណាចរបស់មនុស្ស (កច ៤:១៩ ៥:២៩) ។

**១៣:៤** *លោកជាអ្នកបំរើរបស់ព្រះ* នៅក្នុងន័យនេះ ចង់បញ្ជាក់ពីលំដាប់លំដោយនៃការប្រទានអំណាចគ្រប់គ្រងរបស់ព្រះ ដែលធ្វើឡើងតាមរយៈអ្នកបម្រើរបស់ទ្រង់ (អស ៤៥:១ និងការពន្យល់) ។ *សេចក្ដីល្អ* មានន័យថា អ្នកត្រួតត្រាដែលមានប្រយោជន៍ ដល់សង្គម អ្នកការពារផលប្រយោជន៍សាធារណៈ និងអ្នកថែរក្សាឱ្យមានសណ្ដាប់ធ្នាប់ល្អ ។ *ដាវ* គឺជានិមិត្តរូបនៃរដ្ឋអំណាចរបស់ពួករ៉ូម៉ាំងសម្រាប់ទាំងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ។ ត្រង់នេះហើយដែលយើងឃើញពីគោលការនៅក្នុងព្រះគម្ពីរនៃការប្រើកម្លាំងសម្រាប់រក្សាឱ្យមានសណ្ដាប់ធ្នាប់ល្អ ។

**១៣:៥** *ដោយព្រោះបញ្ញាចិត្ត* ចង់បញ្ជាក់ថាអំណាចគ្រប់គ្រងលើពលរដ្ឋ គឺព្រះអម្ចាស់ជាអ្នករើសតាំង ដើម្បីរក្សាបញ្ញាចិត្តរបស់គ្រីស្ទបរិស័ទឱ្យបានល្អ នោះយើងគ្រប់គ្នាត្រូវតែគោរពដល់ពួកគេ ។

**១៣:៦** *អ្នករាល់គ្នាត្រូវបង់ពន្ធ* ឃ្លានេះតមកពីខខាងលើ ដែលថាអ្នកត្រួតត្រាគឺជាភ្នាក់ងាររបស់ព្រះ ដែលមានតួនាទីធ្វើយ៉ាងណាឱ្យមានផលប្រយោជន៍ដល់សង្គមជាតិទូទៅ ។

**១៣:៨** *ជំពាក់បានតែសេចក្ដីស្រឡាញ់* មានន័យថា កាលណាមនុស្សម្នាក់បានជំពាក់សេចក្ដីស្រឡាញ់ដល់ម្នាក់ផ្សេងទៀតហើយ នោះពុំមានថ្ងៃនឹងសងអស់ឡើយ ។ គ្មានបញ្ហាអ្វីទេចំពោះការដែលមានសេចក្ដីស្រឡាញ់ច្រើននោះ គឺយើងរាល់គ្នាមានកាតព្វកិច្ចមួយគឺបន្តសេចក្ដីស្រឡាញ់នោះជារៀងរហូតតទៅ។ *ដល់គ្នាទៅវិញទៅមក* ត្រង់នេះមានន័យថា សេចក្ដីស្រឡាញ់មិនមែនមានតែនៅក្នុងចំណោម គ្រីស្ទបរិស័ទប៉ុណ្ណោះទេ តែត្រូវមានសេចក្ដីស្រឡាញ់ដល់គ្នាទៅវិញទៅមកដល់គ្រប់មនុស្សទាំងអស់ ។ *ក្រិត្យវិន័យ* នេះគឺជាក្រឹត្យវិន័យ (ច្បាប់) របស់លោកម៉ូសេ ដែលមានចែងសម្រាប់អនុវត្តទាំងផ្នែកជំនឿ និងផ្នែកសង្គម ។

**១៣:៩** ខនេះគឺជាការពន្យល់បន្ថែមទៅលើខ.៨ ហើយថែមទាំងបានរៀបរាប់ពីបទបញ្ញត្តិជាច្រើនដែលត្រូវបានហាម ដោយបង្រួមមកតែមួយឃ្លា ថា "ចូរស្រលាញ់អ្នកជិតខាងដូចខ្លួនឯង" ដែលជាការទទួលខុសត្រូវរបស់សង្គមជាតិយើងទាំងមូល ។ *អ្នកជិតខាង* បើតាមសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទថា អ្នកជិតខាងរបស់យើងនោះ គឺអស់អ្នកដែលមានសេចក្ដីខ្វះខាតនេះឯង (លក ១០:២៥–៣៦ និងការពន្យល់) ហើយដូចគ្នានឹងគំនិតរបស់លោកប៉ុលនៅត្រង់នេះដែរ ។ *ដូចខ្លួនឯង* ពាក្យនេះពុំមែនជាការបង្គាប់ឱ្យមនុស្សស្រលាញ់ខ្លួនឯងនោះទេ ប៉ុន្តែ ការពិតពេលមនុស្សកើតមកនោះចេះស្រលាញ់ខ្លួនឯងរួចបាត់ទៅហើយ (អភ ៥:៣៣) ។

**១៣:១១–១៤** នៅក្នុងអត្ថន័យនៃវគ្គនេះ បើចែងនៅក្នុងបទគម្ពីរសញ្ញាថ្មីត្រង់កន្លែងផ្សេងវិញនោះ គឺពិតជាសេចក្ដីដែលបានថ្លែងពីការមកដល់នៃទីអវសាននាពេលបច្ចុប្បន្ន ហើយអត្ថន័យនេះត្រូវបានគេធ្លាប់យកមកប្រើដើម្បីនឹងលើកទឹកចិត្ត ដល់មនុស្សជំនាន់នេះ ឱ្យចេះកោតខ្លាចព្រះ (មថ ២៥:៣១–៤៦ មក ១៣:៣៣–៣៧ លក ២១:៣៦ ភល ៤:៥ ១ថន ៥:៦,៨ ទត ២:១១–១៤ យក ៥:៧–១១ ២ពត ៣:១១–១៤ ១យហ ២:២៨ ៣:២–៣) ។

**១៣:១១** *ពេលវេលា* នេះគឺជាពេលវេលានៃសេចក្ដីសង្គ្រោះបានមកដល់នាសម័យនោះ មុននឹងនគរព្រះបានសម្រេចពេញលេញ ។ *ដល់ម៉ោង* គឺជា

[១២]យប់យូរណាស់ហើយ ថ្ងៃក៏ជិតរះ[ឃ]ដូច្នេះ យើងត្រូវដោះ
ចោលអស់ទាំងការរបស់សេចក្ដីងងឹតចេញ[ង] ហើយពាក់
គ្រឿងសឹក[ច]របស់ពន្លឺវិញ [១៣]ត្រូវឱ្យយើងដើរតាមដែល
គួរគប្បី ដូចជាដើរនៅពេលថ្ងៃ មិនមែនដោយស៊ីផឹក
លេងល្បែង[ឆ] ឬមានស្រីញី ឬដោយឈ្លោះប្រកែក និង
ឈ្នានីស[ជ]នោះឡើយ [១៤]គឺត្រូវប្រដាប់ខ្លួន ដោយព្រះអម្ចាស់
យេស៊ូវគ្រីស្ទវិញ[ឈ] ហើយកុំឱ្យផ្គត់ផ្គង់ ដើម្បីនឹងបំពេញ
សេចក្ដីប៉ងប្រាថ្នា ខាងឯសាច់ឈាមឡើយ[ញ] ។

## **ភាពខ្សោយ និងភាពខ្លាំង**

**១៤** [១]ចូរទទួលអ្នកណា ដែលខ្សោយខាងឯសេចក្ដីជំនឿ
ដែរ[ដ] មិនមែនឱ្យបានជជែកគ្នាពីសេចក្ដីប្រកាន់ផ្សេងៗ
ឡើយ [២]ដ្បិតម្នាក់ជឿថា បរិភោគបានគ្រប់មុខទាំងអស់
ម្នាក់ទៀតដែលខ្សោយ បរិភោគតែបន្លែទេ[ឋ] [៣]កុំឱ្យអ្នក
ដែលបរិភោគ មើលងាយ[ឌ]ដល់អ្នកដែលមិនបរិភោគ
ឡើយ ក៏កុំឱ្យអ្នកដែលមិនបរិភោគនិន្ទា[ឍ] ចំពោះអ្នកដែល
បរិភោគដែរ ដ្បិតព្រះទ្រង់ទទួលអ្នកនោះដូចគ្នា [៤]តើអ្នកជា
អ្វីដែលនិន្ទាបាវបំរើរបស់គេ[ណ] អ្នកនោះឈរ ឬដួលក្ដី
នោះស្រេចនឹងចៅហ្វាយទេតើ ហើយគេនឹងបានឈរមែន
[៥]ម្នាក់រាប់ថា ថ្ងៃ១ល្អជាងថ្ងៃ១[ត] ម្នាក់ទៀតរាប់ថា ថ្ងៃ
ណាក៏ដូចជាថ្ងៃណា ត្រូវឱ្យគ្រប់គ្នាជឿពិតប្រាកដក្នុងចិត្ត

**១៣:១២** ឃ ហព ១០:២៥ ១យហ ២:៨ ង អភ ៥:១១ ច អភ ៦:១១,១៣ ១ថន ៥:៨ **១៣:១៣** ឆ អភ ៥:១៨ ជ លក ២១:៣៤ កទ ៥:២០,២១ អភ ៥:១៨ ១ពត ៤:៣ **១៣:១៤** ឈ កទ ៣:២៧ អភ ៤:២៤ កល ៣:១០,១២ ញ កទ ៥:២៤ **១៤:១** ដ រម ១៥:១ ១កថ ៨:៩–១២ ៩:២២ **១៤:២** ឋ ខ.១៤ **១៤:៣** ឌ ខ.១០ លក ១៨:៩ ឍ ខ.១០,១៣ កល ២:១៦ **១៤:៤** ណ មថ ៧:១ **១៤:៥** ត កទ ៤:១០ កល ២:១៦

ពេលវេលាសម្រាប់អនុវត្ត ។ *សេចក្ដីសង្គ្រោះ* គឺសំដៅពីសេចក្ដីសង្គ្រោះដ៏ពេញលេញពិត ប្រាកដនៅពេលព្រះយេស៊ូវគ្រីស្ទយាងមកលើកទី២ (៨:២៣ ហព ៩:២៨ ១ពត ១:៥ និងការពន្យល់) ។ *បានមកជិតបង្កើយ* ពាក្យនេះប្រាប់យើងថាជារៀងរាល់ថ្ងៃនាំ យើងទៅរកថ្ងៃនៃការយាងមកជាលើកទី២ របស់ព្រះគ្រីស្ទកាន់តែឆាប់ឡើងៗ ។

**១៣:១២** *យប់* គឺជាសម័យកាលដ៏អាក្រក់នាពេលបច្ចុប្បន្ន ។ *ថ្ងៃក៏ជិតរះ* នេះគឺជា ការឧទាហរណ៍មួយយ៉ាងច្បាស់នៃសេចក្ដីបង្រៀននៅក្នុងគម្ពីរសញ្ញាថ្មីថា "ពេលនៃចុងបញ្ចប់ បានជិតមកដល់ហើយ" (១កថ ៧:២៩ ភល ៤:៥ យក ៥:៩ ១ពត ៤:៧ ១យហ ២:១៨ និងការពន្យល់) ។ អត្ថបទទាំងនេះពុំមែនមានន័យថា គ្រីស្ទបរិស័ទ សម័យដំបូងបានជឿថា ព្រះយេស៊ូវនឹងយាងមកក្នុងអំឡុងពេល២ឬ៣ឆ្នាំ (ការនេះត្រូវបានគេយល់ច្រឡំ) ដូច្នេះហើយបានជាពួកគេចាត់ទុកការសុគត និងការរស់ឡើងវិញនៃព្រះគ្រីស្ទជាព្រឹត្តិការណ៍សំខាន់នៃប្រវត្តិសាស្ត្រចាប់តាំងពីពេលនោះមក (ហព ១:១-២ និងការពន្យល់) ។ ព្រឹត្តិការណ៍បន្ទាប់នៅក្នុងផែនការប្រោសលោះដ៏អស្ចារ្យរបស់ព្រះនោះគឺ ការយាងត្រឡប់មកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ "យប់ងងឹត"មិនសំខាន់ថាវាយូរប៉ុណ្ណាក្នុងពេលកន្លងមកនោះទេ តែពេលនេះវាជិតដល់ទីបញ្ចប់របស់វាហើយ ។ *ថ្ងៃ* ពាក្យនេះសំដៅលើការយាងមកនៃអង្គព្រះគ្រីស្ទជាលើកទីពីរ ដើម្បីនាំយើងជាគ្រីស្ទបរិស័ទចូលទៅក្នុងនគរព្រះ ។

**១៣:១៣** សេចក្ដីពន្យល់នៅក្នុងខនេះ មើល១:២៨-៣១ និងការពន្យល់ ។

**១៣:១៤** *ត្រូវប្រដាប់ខ្លួនដោយព្រះអម្ចាស់យេស៊ូវគ្រីស្ទ* មើល កទ ៣:២៧ ។ លោកប៉ុលបានដាស់តឿនដល់អ្នកជឿឱ្យសំដែងអាកប្បកិរិយានៅខាងក្រៅឱ្យដូច នូវអ្វីដែលយើងមាននៅខាងក្នុង (កល ៣:១-១០ និងការពន្យល់) ដែលជាតម្លៃនៃការប្រកបទាក់ទងនឹងព្រះគ្រីស្ទ ។ *ត្រូវប្រដាប់* មើលការពន្យល់ ទដ ១០៩:២៩ ។

**១៤:១** *ខ្សោយខាងឯសេចក្ដីជំនឿ* ចំណុចនេះប្រហែលជាលោកប៉ុលសំដៅលើគ្រីស្ទបរិស័ទសាសន៍យូដានៅក្នុងក្រុងរ៉ូម ដែលគ្មានឆន្ទះនឹងបោះបង់តម្រូវការហាមប្រាមផ្សេងៗនៃក្រឹត្យវិន័យមានដូចជាការតម្រូវឱ្យតមអាហាររក្សានៅថ្ងៃឈប់សម្រាក ហើយនិងថ្ងៃពិសេសផ្សេងៗទៀត ។ ការកង្វល់របស់ពួកគេនៅត្រង់ នេះមិនទាន់ខ្លាំងដូចពួកសាសន៍យូដានៅក្រុងកាឡាទីនោះទេ ។ សាសន៍យូដានៅទីនោះបានគិតថា ពួកគេអាចទទួលសេចក្ដីសុចរិតបានដោយសារការប្រព្រឹត្ត ហើយព្យាយាមបង្ខំឱ្យមានសេចក្ដីបង្រៀនបែបនេះ បន្តទៅដល់ពួកជំនុំនៅស្រុក កាឡាទីជាច្រើនទៀតផង ប៉ុន្តែគ្រីស្ទបរិស័ទដែលខ្សោយខាងឯសេចក្ដីជំនឿនៅក្រុងរ៉ូមនេះ ពុំមែនមានបញ្ហាដូចទាំងពីរយ៉ាងខាងលើនេះទេ ។ ពួកគេមិនទាន់ដឹងច្បាស់នៅក្នុងខ្លួននៅឡើយទេថា ពួកគេស្ថិតនៅក្នុងស្ថានភាពនៃបទបញ្ញត្តិគម្ពីរសញ្ញាចាស់ និងក្រោមការចាប់ផ្ដើមនៃការតាំងសញ្ញាថ្មី ដោយការយាងមកនៃព្រះគ្រីស្ទ ។ *មិនមែនឱ្យបានជជែកគ្នាពីសេចក្ដីប្រកាន់ផ្សេងៗឡើយ* មានន័យថា ការចូលរួមប្រកបគ្នានៅក្នុងចំណោមបងប្អូនគ្រីស្ទបរិស័ទ មិនអាស្រ័យលើការយល់ស្របគំនិតគ្រប់គ្នា ស្ដីអំពីបញ្ហាដែលមានជម្លោះនោះទេ ។ គ្រីស្ទបរិស័ទទាំងមូលពុំចាំបាច់យល់ស្របគ្នាគ្រប់ទាំងបញ្ហានៃជីវិតខ្លួនទេ ហើយពួកគេក៏មិនចាំបាច់ត្រូវការយល់ស្របគ្នាគ្រប់យ៉ាងនោះដែរ ។

**១៤:២** *ម្នាក់ជឿថា* ឃ្លានេះលោកប៉ុលបានពិពណ៌នាអំពីគ្រីស្ទបរិស័ទ ដែលមានជំនឿរឹងមាំវិញម្ដងថា គាត់បានប្រើសេចក្ដីជំនឿនោះនៅក្នុងន័យនៃការធានាអះអាង ឬជាទំនុកទុកចិត្តដែលខ្លួនមាន ។ ការយល់ដឹងនៃដំណឹងល្អរបស់គ្រីស្ទបរិស័ទ ដែលមានជំនឿរឹងមាំនោះបានអនុញ្ញាតឱ្យគាត់ស្គាល់អំពីការតមអាហារថា គ្រាន់តែជាជម្រើសមួយរបស់មនុស្សខ្លះប៉ុណ្ណោះ មិនសំខាន់ដល់ខាងឯវិញ្ញាណនោះទេ ។

**១៤:៤** *បាវបំរើរបស់គេ* មានន័យថា បាវបម្រើរបស់ព្រះ ។ ក្នុងនាមយើងជាគ្រីស្ទបរិស័ទមិនត្រូវបដិសេធនឹងគ្រីស្ទបរិស័ទផ្សេងទៀត ដែលជាបាវបម្រើព្រះដូចគ្នានោះទេ ។ *ឈរ ឬដួលក្ដី នោះស្រេចនឹងចៅហ្វាយទេតើ* ឃ្លានេះមានន័យថា គ្រីស្ទបរិស័ទដែលមានជំនឿរឹងមាំមិនមែនជាចៅហ្វាយលើគ្រីស្ទបរិស័ទដែលមានជំនឿខ្សោយនោះទេ ហើយគ្រីស្ទបរិស័ទដែលមានជំនឿខ្សោយក៏មិនមែនជាចៅ ហ្វាយលើគ្រីស្ទបរិស័ទមានជំនឿរឹងមាំនោះដែរ គឺព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ តែមួយអង្គគត់ដែលជាចៅហ្វាយ និងជាអ្នកទទួលខុសត្រូវលើយើងគ្រប់គ្នា ។

**១៤:៥** *ថ្ងៃ១ល្អជាងថ្ងៃ១* ពាក្យនេះហាក់បីដូចជាសំដៅទៅលើថ្ងៃឈប់សម្រាកដែលត្រូវបានគេចាត់ទុកថាជាថ្ងៃបរិសុទ្ធនោះ ប៉ុន្តែវាក៏អាចសំដៅទៅលើគ្រប់ទាំងថ្ងៃពិសេស ឬថ្ងៃបរិសុទ្ធនៃពិធីបុណ្យនានានៅក្នុងគម្ពីរក្រឹត្យវិន័យសញ្ញាចាស់ដែរ ។ *ថ្ងៃណាក៏ដូចជាថ្ងៃណា* មានន័យថាគ្រប់ថ្ងៃទាំងអស់ត្រូវបានថ្វាយដល់ព្រះអម្ចាស់ តាមរយៈជាជីវិតរស់នៅដ៏បរិសុទ្ធ និងការប្រតិបត្តិដល់ព្រះដោយកោតខ្លាច ។ *ត្រូវឱ្យគ្រប់គ្នាជឿពិតប្រាកដក្នុងចិត្តខ្លួន* ឃ្លានេះបង្ហាញពីភាពសំខាន់នៃជំនឿផ្ទាល់ខ្លួនក្នុងពេលជួបរឿងរ៉ាវដែលអាចមាន

ខ្លួន ៦ អ្នកណាដែលប្រកាន់ថ្ងៃណា នោះក៏ប្រកាន់ដោយ
គោរពដល់ព្រះអម្ចាស់ ហើយអ្នកណាដែលមិនប្រកាន់ថ្ងៃ
ណា នោះក៏មិនប្រកាន់ ដោយគោរពដល់ព្រះអម្ចាស់ដែរ
អ្នកណាដែលបរិភោគ នោះបរិភោគដោយគោរពដល់
ព្រះអម្ចាស់ ដ្បិតគេអរព្រះគុណដល់ព្រះ[ថ] ហើយអ្នកណា
ដែលមិនបរិភោគ នោះគឺមិនបរិភោគដោយគោរពដល់
ព្រះអម្ចាស់ដែរ ក៏អរព្រះគុណដល់ព្រះដូចគ្នា ។
៧ ដ្បិតគ្មានអ្នកណាក្នុងពួកមនុស្សយើង ដែលរស់
សំរាប់ខ្លួនឯងទេ[ទ] ក៏គ្មានអ្នកណាស្លាប់សំរាប់ខ្លួនឯង
ដែរ ៨ ទោះបើយើងរស់ឬស្លាប់ក្តី គង់តែយើងត្រូវ
រស់ឬស្លាប់ថ្វាយព្រះអម្ចាស់វិញ ដូច្នេះ បើរស់ឬស្លាប់
ក្តី នោះយើងក៏ជារបស់ផងព្រះអម្ចាស់ដែរ[ធ] ៩ ដ្បិតដោយ
ហេតុនោះឯង បានជាព្រះគ្រីស្ទទ្រង់សុគត ហើយមានព្រះ
ជន្មរស់ឡើងវិញ[ន] គឺដើម្បីនឹងធ្វើជាម្ចាស់ លើទាំងមនុស្ស
ស្លាប់ នឹងមនុស្សរស់ផង[ប] ១០ ដូច្នេះ ហេតុអ្វីបានជាអ្នក
និន្ទាចំពោះបងប្អូនខ្លួន ឬមើលងាយ[ផ]ដល់បងប្អូនខ្លួន ពី
ព្រោះយើងទាំងអស់គ្នា នឹងត្រូវឈរនៅមុខទីជំនុំជំរះ
របស់ផងព្រះគ្រីស្ទ[ព] ១១ ដ្បិតមានសេចក្តីចែងទុកមកថា «ព្រះ
អម្ចាស់ទ្រង់ស្បថដោយព្រះជន្មទ្រង់[ភ]ថា ត្រូវឱ្យគ្រប់ទាំង
ជង្គង់លុតចុះនៅមុខអញ ហើយគ្រប់ទាំងអណ្តាតត្រូវសរ
សើរដល់ព្រះផង»[ម] ១២ ដូច្នេះយើងទាំងអស់គ្នានឹងត្រូវរាប់
រៀបទូលថ្វាយព្រះ ពីដំណើររបស់ខ្លួនយើងជាមិនខាន[យ]។
១៣ ហេតុនោះ កុំបីឱ្យយើងរាល់គ្នានិន្ទាគ្នា[រ]ទៅវិញទៅ
មកទៀតឡើយ ស៊ូឱ្យយើងគិតសំរេចក្នុងចិត្តដូច្នេះវិញថា
យើងមិនធ្វើក្បួនឱ្យបងប្អូនជំពប់ដួល ឬរវាតចិត្តចេញ
ឡើយ[ល] ១៤ ខ្ញុំដឹង ហើយក៏ជឿពិត ដោយនូវព្រះអម្ចាស់
យេស៊ូវថា គ្មានអ្វីស្មោកគ្រោក[វ]ដោយខ្លួនឯងទេ គឺស្មោក
គ្រោកដល់តែអ្នកណាដែលជឿថារបស់នោះស្មោកគ្រោក
ប៉ុណ្ណោះ[ស] ១៥ ប៉ុន្តែបើអ្នកធ្វើឱ្យបងប្អូនអ្នកព្រួយចិត្តដោយ
ព្រោះម្ហូបចំណីអ្វី នោះអ្នកប្រព្រឹត្ត មិនមែនដោយស្រឡាញ់
ទៀតទេ[ហ] កុំធ្វើឱ្យអ្នកណាដែលព្រះគ្រីស្ទបានសុគតជំនួស
ត្រូវវិនាសដោយសារម្ហូបរបស់អ្នកឡើយ[ឡ] ១៦ ក៏កុំឱ្យគេ
មានឱកាសនឹងនិយាយអាក្រក់ ពីការល្អរបស់អ្នកដែរ[អ]
១៧ ដ្បិតនគរព្រះមិនសំរេចនឹងការស៊ី ឬផឹកនោះទេ[ក] គឺ

**១៤:៦** ថ មថ ១៤:១៩ ១កថ ១០:៣០,៣១ ១ធថ ៤:៣,៤ **១៤:៧** ទ ២កថ ៥:១៥ កទ ២:២០ **១៤:៨** ធ ភល ១:២០ **១៤:៩** ន វវ ១:១៨ ២:៨ ប កថ ១០:៤២ ២កថ ៥:១៥ **១៤:១០** ផ ខ.៣ មថ ៧:១ ព ២កថ ៥:១០ **១៤:១១** ភ អស ៤៩:១៨ ម អស ៤៥:២៣ ភល ២:១០,១១ **១៤:១២** យ មថ ១២:៣៦ ១ពត ៤:៥ **១៤:១៣** រ ខ.១ មថ ៧:១ ល ២កថ ៦:៣ **១៤:១៤** វ ខ.២០ កថ ១០:១៥ ស ១កថ ៨:៧ **១៤:១៥** ហ អភ ៥:២ ឡ ខ.២០ ១កថ ៨:១១ **១៤:១៦** អ ១កថ ១០:៣០ **១៤:១៧** ក ១កថ ៨:៨

ទំនាស់ នោះត្រូវធ្វើតាមគោលការក្នុងបទគម្ពីរនេះ (ខ.១៤,១៦,២២–២៣) ។

**១៤:៦** នៅក្នុងខនេះបានប្រាប់ពីហេតុផលដែលនៅខាងក្រោយសកម្មភាពរបស់គ្រីស្ទបរិស័ទទាំងមានជំនឿរឹងមាំ និងជំនឿខ្សោយ ពួកគេត្រូវប្រព្រឹត្តដូចគ្នា ។ ទាំងពីរក្រុមត្រូវតែបម្រើព្រះអម្ចាស់ ហើយត្រូវអរគុណដល់ព្រះចំពោះការផ្គត់ផ្គង់ ។

**១៤:៧** *គ្មានអ្នកណាក្នុងពួកមនុស្សយើង ដែលរស់សំរាប់ខ្លួនឯងទេ* ឃ្លានេះគឺសំដៅលើយើងទាំងអស់គ្នាជាគ្រីស្ទបរិស័ទ ។ យើងរស់នៅមិនមែនសម្រាប់ផ្គាប់ចិត្តខ្លួនយើងនោះទេ ប៉ុន្តែ គឺសម្រាប់ព្រះអម្ចាស់ ។ *គ្មានអ្នកណាស្លាប់សំរាប់ខ្លួនឯងដែរ* មានន័យថាសូម្បីតែសេចក្តីស្លាប់ ការទំនាក់ទំនងរបស់យើងជាមួយនឹង ព្រះអម្ចាស់នោះសំខាន់ណាស់។ ត្រង់នេះលោកប៉ុលនិយាយសារឡើងវិញពីសេចក្តី ពិតក្នុងខ.៨ ។

**១៤:៩** *ជាម្ចាស់* មើលពន្យល់ ១០:៩ ។ ព្រះគ្រីស្ទគឺជាអម្ចាស់លើទាំងពួកស្លាប់ និងពួកមានជីវិតតាមរយៈការសុគត និងការរស់ឡើងវិញរបស់ ព្រះគ្រីស្ទ ។

**១៤:១០** *ហេតុអ្វីបានជាអ្នកនិន្ទាចំពោះបងប្អូនខ្លួន?* ត្រង់នេះបញ្ជាក់ពីបុគ្គលិកលក្ខណៈរបស់គ្រីស្ទបរិស័ទដែលមានជំនឿទន់ខ្សោយ ។ *ឬមើលងាយដល់បងប្អូនខ្លួន?* ត្រង់នេះបញ្ជាក់ពីបុគ្គលិកលក្ខណៈ របស់គ្រីស្ទបរិស័ទដែលមានជំនឿរឹងមាំ ។ *យើងទាំងអស់គ្នា* ពាក្យនេះបញ្ជាក់ពីបុគ្គលិកលក្ខណៈរបស់គ្រីស្ទបរិស័ទទាំងអស់ ។ *ឈរនៅមានទីជំនុំជំរះរបស់ផងព្រះគ្រីស្ទ* គ្រីស្ទបរិស័ទទាំងអស់នឹងត្រូវជំនុំជម្រះ ហើយការជំនុំជម្រះនេះត្រូវផ្អែកលើការងាររបស់ខ្លួន (មើលការពន្យល់ ២កថ ៥:១០ និង ១កថ ៣:១០–១៥) ។

**១៤:១៣** *ស៊ូ* ពាក្យនេះមានន័យថា "ផ្ទុយទៅវិញ" ចង់ប្រាប់ថា ឃ្លាខាងដើម និងឃ្លា ខាងចុងនៃខនេះគឺមានន័យផ្ទុយគ្នា ។ ន័យបន្ទាប់ពីពាក្យនេះគឺបញ្ជាក់ពីគ្រីស្ទបរិស័ទដែលមានជំនឿរឹងមាំ ។ *រវាតចិត្តចេញ* គឺជាទង្វើទាំងឡាយណាដែលបណ្តាលឱ្យអ្នកដទៃធ្លាក់ទៅក្នុងអំពើបាប ។

**១៤:១៤** *ខ្ញុំដឹង ហើយក៏ជឿពិត ដោយនូវព្រះអម្ចាស់យេស៊ូវ* ត្រង់នេះបញ្ជាក់ថាឥឡូវនេះលោកប៉ុលបានដឹងថាគាត់គឺជាគ្រីស្ទបរិស័ទម្នាក់ ដូច្នេះគ្មានអ្វីដែលត្រូវហាមទៀតឡើយ (មក ៧:១៩–២០ កច ១០:១៥,២៨ និងការពន្យល់) ។ *គ្មានអ្វីស្មោកគ្រោកដោយខ្លួនឯងទេ* សូមមើលសេចក្តីបង្រៀនរបស់លោកប៉ុលនៅ ក្នុង ១ធថ ៤:៤ ទត ១:១៥ និងការពន្យល់ ។ *ស្មោកគ្រោកដល់តែអ្នកណាដែលជឿថា របស់នោះស្មោកគ្រោកប៉ុណ្ណោះ* ត្រង់នេះពុំមែនមានន័យជាទូទៅទេថា មានតែអំពើបាបមួយប៉ុណ្ណោះដែលជាបញ្ហានៃគំនិតឬមនសិការនោះ ។ លោកប៉ុលពុំបានវែកញែកពីចរិតមាយាទនៃអំពើបាបដែលចែងច្បាស់នៅក្នុងបទគម្ពីរនោះទេ ប៉ុន្តែលោកនិយាយពីចរិតមាយាទដែលទាក់ទងទៅនឹងគ្រីស្ទបរិស័ទដែលធ្វើខុសពីច្បាប់ (ក្នុងករណីពីបទបញ្ញត្តិនៃម្ហូបអាហារ) ។ រឿងរ៉ាវជាច្រើនដែលទាក់ទងនឹង បញ្ហានេះត្រូវតែដោះស្រាយដោយផ្អែកលើមនសិការនៃជំនឿរបស់ខ្លួន ។

**១៤:១៥** *ស្រឡាញ់* នេះគឺជាចំណុចគន្លឹះដើម្បីដោះស្រាយឱ្យបានត្រឹមត្រូវនៃជម្លោះ។ *កុំធ្វើឱ្យអ្នកណាដែលព្រះគ្រីស្ទបានសុគតជំនួស* ឃ្លានេះបញ្ជាក់ថាព្រះគ្រីស្ទឱ្យតម្លៃយ៉ាងខ្លាំងដល់គ្រីស្ទបរិស័ទដែលមានជំនឿខ្សោយ ដោយការសុគតជំនួសពួកគេ ។ ដូច្នេះគ្រីស្ទបរិស័ទ ដែលមានជំនឿរឹងមាំត្រូវមានតែឆន្ទៈមួយធ្វើយ៉ាងណាឱ្យចរិតមាយាទរបស់ខ្លួនបានសមរម្យសម្រាប់ជាប្រយោជន៍ដល់អ្នកជឿផ្សេងៗទៀតផងដែរ (១កថ ៨:១១–១៣ ១០:២៣ ២៨–២៩,៣២–៣៣ និងការពន្យល់) ។

**១៤:១៦** *កុំឱ្យគេមានឱកាស* ចង់បញ្ជាក់ពីការយល់ដឹងផ្ទាល់ខ្លួននៃសិទ្ធិសេរីភាពរបស់គ្រីស្ទបរិស័ទ ។ *និយាយអាក្រក់* នេះគឺជាវិធីដែលហ៊ឹកហ៊ើនសិទ្ធិសេរីភាពផ្អែកចិត្តគំនិតដែលគេចចេញពីការអាក្រក់បាន ។

**១៤:១៧** *នគរព្រះ* មើលការពន្យល់ មថ ៣:២ លក ៤:៤៣ ។ *មិនសំរេចនឹងការស៊ី ឬផឹកនោះទេ* មានន័យថា គ្រីស្ទបរិស័ទមិនត្រូវខ្វាយខ្វល់នឹងរឿងរ៉ាវ

ស្រេចនឹងសេចក្ដីសុចរិត សេចក្ដីមេត្រី[ខ] និងសេចក្ដីអំណរ
ដោយនូវព្រះវិញ្ញាណបរិសុទ្ធវិញទេតើ[គ] [១៨]ពីព្រោះអ្នក
ណាដែលបំរើព្រះគ្រីស្ទ ដោយសារសេចក្ដីទាំងនោះអ្នក
នោះជាទីគាប់ព្រះហឫទ័យដល់ព្រះហើយ ព្រមទាំងមាន
មនុស្សរាប់អានដល់ខ្លួនដែរ[ឃ]។
[១៩]ហេតុដូច្នេះ ត្រូវឱ្យយើងដេញតាមអស់ទាំងសេចក្ដី
ដែលនាំឱ្យមេត្រីគ្នា[ង] និងសេចក្ដីទាំងប៉ុន្មានដែលជួយ
ស្អាងចិត្តគ្នាទៅវិញទៅមកវិញ[ច] [២០]កុំឱ្យបំផ្លាញការ
ព្រះ ដោយព្រោះតែម្ហូបណានោះឡើយ[ឆ] គ្រប់របស់ទាំង
អស់ ឈ្មោះថាស្អាតមែន[ជ] តែរមែងជាអាក្រក់ដល់អ្នក
ណា ដែលបរិភោគដោយប្រទាំងវិញ[ឈ] [២១]គួរតែកុំឱ្យបរិ
ភោគ សាច់ ឬស្រាទំពាំងបាយជូរ ឬអ្វីដែលនាំឱ្យបង
ប្អូនអ្នក ជំពប់ ឬរវាតចិត្ត ឬធ្វើឱ្យខ្សោយនោះឡើយ[ញ]
[២២]អ្នកឯងមានសេចក្ដីជំនឿយ៉ាងណា ចូរជឿយ៉ាងនោះ
តែម្នាក់ឯងនៅចំពោះព្រះចុះ មានពរហើយ អ្នកណា
ដែលមិនកាត់ទោសខ្លួនឯង[ដ] ក្នុងការដែលខ្លួនរាប់ថាធ្វើ

**១៤:១៧** ខ អស ៣២:១៧
គ រម ១៥:១៣ កទ ៥:២២
**១៤:១៨** ឃ លក ២:៥២ កថ ២៤:១៦ ២កថ ៨:២១
**១៤:១៩** ង ទដ ៣៤:១៤ រម ១២:១៨ ១កថ ៧:១៥ ២ធថ ២:២២ ហព ១២:១៤ ច រម ១៥:២ ១កថ ១៤:៣–៥,១២,១៧,២៦ ២កថ ១២:១៩ អភ ៤:១២,២៩
**១៤:២០** ឆ ខ.១៥ ជ ខ.១៤ កថ ១០:១៥ ឈ ខ.១៣ ១កថ ៨:៩–១២
**១៤:២១** ញ មថ ៥:២៩
**១៤:២២** ដ ១យហ ៣:២១

បាន [២៣]តែបើអ្នកណាបរិភោគទាំងសង្ស័យ[ឋ] នោះមាន
ទោសហើយ ពីព្រោះមិនបានបរិភោគដោយសេចក្ដីជំនឿ
ដ្បិតការទាំងប៉ុន្មានដែលធ្វើដោយឥតមានសេចក្ដីជំនឿ
នោះសុទ្ធតែជាបាបទាំងអស់ហើយ ។
**១៥** [១]គួរតែឱ្យយើងរាល់គ្នាដែលមានកំឡាំង បានទ្រាំ
ទ្រនឹងសេចក្ដីកំសោយ[ឌ] របស់ពួកអ្នកដែលគ្មានកំឡាំងវិញ
ឥតបំពេញចិត្តខ្លួនយើងឡើយ [២]ត្រូវឱ្យយើងទាំងអស់គ្នា
បំពេញចិត្តអ្នកជិតខាងខ្លួន សំរាប់ជាសេចក្ដីល្អ[ឍ] ឱ្យបាន
ស្អាងចិត្តឡើង[ណ] [៣]ដ្បិតព្រះគ្រីស្ទ ទ្រង់មិនបានបំពេញ
ព្រះហឫទ័យទ្រង់ដែរ[ត] ដូចជាមានសេចក្ដីចែងទុកមកថា
«សេចក្ដីដំនៀលដែលគេត្មះតិះដៀលទ្រង់ នោះបានធ្លាក់
មកលើទូលបង្គំវិញ»[ថ] [៤]ដ្បិតអស់ទាំងសេចក្ដីដែលបាន
ចែងទុកមកជាមុន នោះបានចែងសំរាប់នឹងបង្រៀនដល់
យើងរាល់គ្នា[ទ] ដើម្បីឱ្យយើងបានសេចក្ដីសង្ឃឹម ដោយ
សេចក្ដីអត់ធន់ និងសេចក្ដីកំសាន្តចិត្ត ដោយសារគម្ពីរ

**១៤:២៣** ឋ ខ.៥ **១៥:១** ឌ រម ១៤:១ ១ថន ៥:១៤ **១៥:២** ឍ ១កថ ១០:២៤ ណ រម ១៤:១៩ **១៥:៣** ត ២កថ ៨:៩ ថ ទដ ៦៩:៩ **១៥:៤** ទ រម ៤:២៣,២៤

ទាំងឡាយណាដែលមិនសំខាន់ច្រើនពេកនោះទេ ព្រោះវាបណ្ដាលឱ្យខកខានបំពេញកិច្ចការសំខាន់ៗ ។ *ស្រេចនឹងសេចក្ដីសុចរិត* គឺសំដៅលើជីវិតរស់នៅដ៏សុចរិត ។ សេចក្ដីកង្វល់របស់លោកប៉ុលនៅត្រង់នេះ គឺសំខាន់ផ្ដោតទៅលើក្រមសីលធម៌ និងចរិតមាយាទខាងក្រៅនៃជីវិតគ្រីស្ទបរិស័ទ ។ *សេចក្ដីមេត្រី* មើល ៥:១ និងការពន្យល់ ។ *សេចក្ដីអំណរដោយនូវព្រះវិញ្ញាណបរិសុទ្ធ* មានន័យថា សេចក្ដីអំណរ គឺព្រះវិញ្ញាណជាអ្នកប្រទានមកឱ្យ ។

**១៤:១៩** *ស្អាងចិត្តគ្នាទៅវិញទៅមក* ឃ្លានេះមានន័យថា ការស្អាងឡើងខាងឯវិញ្ញាណនៃគ្រីស្ទបរិស័ទម្នាក់ៗ និងពួកជំនុំ (១:១១–១២ និងពន្យល់ ១:១២) ។

**១៤:២០** *ការព្រះ* មានន័យថា"ការងាររបស់ព្រះ" គឺសំដៅទៅលើគ្រីស្ទបរិស័ទដែលទទួលបានការប្រោសលោះ តែនៅមានជំនឿខ្សោយ ។ ករណីនេះហើយដែលហៅថាការងាររបស់ព្រះ ហើយទ្រង់នៅតែបន្តការងារនេះរហូត (អភ ២:១០) ។ *បរិភោគដោយប្រទាំង* ឃ្លានេះមានន័យថា លោកប៉ុលបានទទួលស្គាល់សិទ្ធិរបស់គ្រីស្ទបរិស័ទ ដែលមានជំនឿរឹងមាំថាពិតជាមានសេរីភាពពិតប្រាកដមែនក្នុងការបរិភោគនោះ ប៉ុន្តែត្រូវតែគិតដល់ពីគោលការនៃសិទ្ធិរបស់គ្រីស្ទបរិស័ទ ដែលមានជំនឿខ្សោយផងដែរ ដូច្នេះសរុបមកត្រូវដឹងថា ធ្វើអ្វីខុស និងធ្វើអ្វីត្រូវ ។

**១៤:២២** *ចូរជឿយ៉ាងនោះតែម្នាក់ឯងនៅចំពោះព្រះចុះ* ឃ្លានេះមានន័យថា គ្រីស្ទបរិស័ទដែលមានជំនឿរឹងមាំ មិនតម្រូវឱ្យទំនាស់នឹងសេចក្ដីជំនឿរបស់ខ្លួនដែលកំពុងមាននោះទេ ឬក៏ទៅផ្លាស់ប្ដូរបទដ្ឋាននៃសេចក្ដីជំនឿរបស់អ្នកដទៃនោះដែរ ។ ពោលគឺពួកគេមិនត្រូវសម្ញែងពីសេរីភាពរបស់ខ្លួន (អ្នកមានជំនឿរឹងមាំ) នោះឡើយ គឺត្រូវរក្សាការនោះជារឿងផ្ទាល់ខ្លួនវិញ ។ *ខ្លួនរាប់ថាធ្វើបាន* ឃ្លានេះសំដៅទៅលើការបរិភោគអាហារ ដែលខ្លួនគិតថាឥតសៅហ្មងដល់ខ្លួននិងអ្នកដទៃ។

**១៤:២៣** *ការទាំងប៉ុន្មាន* ពាក្យនេះសំដៅទៅលើរឿងរ៉ាវទាំងឡាយ ដែលបានពិភាក្សាគ្នានៅខាងដើមអំពីចរិតមាយាទ ដែលត្រូវនឹងបញ្ញត្តិផ្សេងៗនៃគំនិតនៅក្នុងចំណោមគ្រីស្ទបរិស័ទយើង ។ *សេចក្ដីជំនឿ* នៅត្រង់នេះមានន័យថា គឺជាសកម្មភាពផ្សេងៗរបស់គ្រីស្ទបរិស័ទដែលកំពុងតែធ្វើតាមបំណងព្រះហឫទ័យនៃព្រះ ។

**១៥:១** *គួរតែឱ្យយើងរាល់គ្នាដែលមានកំឡាំង* ត្រង់នេះលោកប៉ុលបានកំណត់ខ្លួនលោកថាជាគ្រីស្ទបរិស័ទមានជំនឿរឹងមាំ គឺជាជំនឿផ្ទាល់ខ្លួន ដែលអនុញ្ញាតឱ្យពួកគាត់មានសេរីភាពខ្លាំងជាងអ្នកដែលមានជំនឿខ្សោយ ។ *បានទ្រាំទ្រ* ពាក្យនេះមានន័យថា ពុំមែនគ្រាន់តែប្រណីសណ្ដោសដល់គ្នា ឬជួយគ្នានោះទេ តែថែមទាំងលើកតម្កើងគ្នាដោយសេចក្ដីស្រលាញ់ទៀតផង ។ *ពួកអ្នកដែលគ្មានកំឡាំង* ឃ្លានេះពុំមានន័យថា ពួកអ្នកដែលបានធ្វើបាបនោះ គឺជាពួកអ្នកដែលមានជំនឿនៅខ្សោយដូចបាននិយាយគ្នាពីខាងដើម ។ *ឥតបំពេញចិត្តខ្លួនយើងឡើយ* ត្រង់នេះមាន ន័យថា ពួកអ្នកដែលមានជំនឿរឹងមាំមិនត្រូវទទូចធ្វើអ្វីៗដែលពួកគេចង់ធ្វើដោយ ពុំបានគិតពីការរវាតចិត្តដល់គ្រីស្ទបរិស័ទដទៃទៀតនោះឡើយ ។

**១៥:៣** *ព្រះគ្រីស្ទ ទ្រង់មិនបានបំពេញព្រះហឫទ័យទ្រង់* ឃ្លានេះមានន័យថា ព្រះគ្រីស្ទបានយាងមកដើម្បីនឹងធ្វើតាមព្រះហឫទ័យព្រះវរបិតា មិនមែនតាមចិត្តទ្រង់ឡើយ (យហ ៤:៣៤ និងពន្យល់) ។ ចំណុចនេះបូករួមទាំងការរងទុក្ខរហូតសុគតដល់ ផង (មថ ២០:២៨ មក ១០:៤៥ ២កថ ៨:៩ ភល ២:៥–៨ និងការពន្យល់) ។ *សេចក្ដីដំនៀលដែលគេត្មះតិះដៀលទ្រង់ នោះបានធ្លាក់មកលើទូលបង្គំវិញ* ឃ្លានេះបានដកស្រង់ចេញពី ទដ ៦៩:៩ (មើលការពន្យល់នៅទីនោះ) ដែលសំដៅលើព្រះគ្រីស្ទ ។ លោកប៉ុលបានដកស្រង់ពីការបម្រើដើម្បីបង្ហាញថា ការដែលព្រះគ្រីស្ទបានសព្វព្រះទ័យមកយកនិស្ស័យជាមនុស្សដើម្បីនាំមនុស្សទៅឯព្រះ នេះទ្រង់មិនបានធ្វើតាមព្រះទ័យទ្រង់ផ្ទាល់នោះឡើយ ។

**១៥:៤** នៅក្នុងខនេះលោកប៉ុលបានពន្យល់បន្ថែមពីមូលហេតុដែលគាត់បានដកស្រង់ពី ទដ ៦៩:៩ បញ្ជាក់ពីព្រះយេស៊ូវគ្រីស្ទ ដោយលោកបានថ្លែងពី

៥ឥឡូវនេះ សូមព្រះនៃសេចក្ដីអត់ធ្មត់ នឹងសេចក្ដី
កំសាន្តចិត្ត ទ្រង់ប្រទានឱ្យអ្នករាល់គ្នាមានគំនិតតែ១[ធ] តាម
ព្រះគ្រីស្ទយេស៊ូវ ៦ដើម្បីឱ្យអ្នករាល់គ្នាព្រមព្រៀងមូលមាត់
តែមួយនឹងសរសើរដំកើង[ន] ដល់ព្រះដ៏ជាព្រះវរបិតា[ប]នៃ
ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ។
៧ដូច្នេះ ចូរទទួលគ្នាទៅវិញទៅមក[ផ] ដូចជាព្រះគ្រីស្ទបាន
ទទួលយើងដែរ សំរាប់នឹងសរសើរដល់ព្រះចុះ ៨ឥឡូវ
ខ្ញុំថា ព្រះយេស៊ូវគ្រីស្ទទ្រង់បានត្រឡប់ជាអ្នកបំរើដល់ពួក
កាត់ស្បែក[ព] ដើម្បីនឹងសំដែងសេចក្ដីស្មោះត្រង់នៃព្រះ
ប្រយោជន៍នឹងបញ្ជាក់សេចក្ដីសន្យា[ភ] ដែលបានតាំងនឹង
ពួកព្ធយុកោ ៩ហើយឱ្យពួកសាសន៍ដទៃ[ម]បានសរសើរ
ដំកើងព្រះ[យ]ដែរ ដោយព្រោះសេចក្ដីមេត្តាករុណារបស់
ទ្រង់តាមសេចក្ដីដែលចែងទុកមកថា «ហេតុនោះបានជា
ទូលបង្គំនឹងសរសើរដំកើងទ្រង់ក្នុងពួកសាសន៍ដទៃ ហើយ
ទូលបង្គំនឹងច្រៀងទំនុកបរិសុទ្ធ[រ]ថ្វាយព្រះនាមទ្រង់»
១០ហើយមានសេចក្ដី១ទៀតថា «ឱសាសន៍ ដទៃទាំងប៉ុន្មាន
អើយ ចូរអរសប្បាយជាមួយនឹងរាស្ត្រទ្រង់»[ល] ១១ក៏មាន
១ទៀតថា «ឱសាសន៍ទាំងឡាយអើយ ចូរសរសើរដល់
ព្រះអម្ចាស់ ឱជនរាល់គ្នាអើយ ចូរដំកើងទ្រង់ចុះ»[វ] ១២ក្នុង
បទ១ទៀត លោកអេសាយក៏មានប្រសាសន៍ថា «នឹងមាន
ឫសរបស់អ៊ីសាយ[ស]១ កើតឡើងសំរាប់នឹងកាន់កាប់លើ
អស់ទាំងសាសន៍ដទៃ សាសន៍ទាំងនោះនឹងយកទ្រង់ជាទី
សង្ឃឹម»[ហ] ១៣ឥឡូវនេះ សូមព្រះនៃសេចក្ដីសង្ឃឹម ប្រទាន
ឱ្យអ្នករាល់គ្នាបានគ្រប់អស់ទាំងសេចក្ដីអំណរ នឹងសេចក្ដី
សុខសាន្តដ៏ពោរពេញ[ឡ] ដោយសារសេចក្ដីជំនឿប្រយោជន៍
ឱ្យបានសេចក្ដីសង្ឃឹមជាបរិបូរ ដោយព្រះចេស្ដានៃព្រះ
វិញ្ញាណបរិសុទ្ធ[អ] ។

## សាវ័កប៉ុលជាអ្នកទំនុកបម្រុងដល់ពួកសាសន៍ដទៃ

១៤ឱបងប្អូនអើយ ខ្ញុំជឿជាក់ខាងឯអ្នករាល់គ្នាថា អ្នក
រាល់គ្នាមានសេចក្ដីល្អពេញលេញហើយ[ក] ក៏បានពេញជា
ចំណេះគ្រប់មុខផង[ខ] អាចនឹងទូន្មានគ្នាទៅវិញទៅមកបាន

**១៥:៥** ធ រម ១២:១៦ ១កថ ១:១០ ២កថ ១៣:១១ អភ ៤:៣ ភល ២:២ កល ៣:១៤ ១ពត ៣:៨ **១៥:៦** ន ទដ ៣៤:៣ ប វវ ១:៦ **១៥:៧** ផ រម ១៤:១ **១៥:៨** ព មថ ១៥:២៤ កថ ៣:២៥,២៦ ភ ២កថ ១:២០ **១៥:៩** ម រម ៣:២៩ យ មថ ៩:៨ រ ២សយ ២២:៥០ ទដ ១៨:៤៩ **១៥:១០** ល ចទ ៣២:៤៣ អស ៦៦:១០ **១៥:១១** វ ទដ ១១៧:១

**១៥:១២** ស វវ ៥:៥ ហ អស ១១:១០ មថ ១២:២១ **១៥:១៣** ឡ រម ១៤:១៧ អ ឧ.១៩ ១កថ ២:៤ ៤:២០ ១ថន ១:៥ **១៥:១៤** ក អភ ៥:៩ ខ ២កថ ៨:៧ ២ពត ១:១២ **១៥:១៥** គ រម ១២:៣ **១៥:១៦** ឃ កថ ៩:១៥ ង ឧ.១៩ រម ១:១ ច អស ៦៦:២០

សេចក្ដីពិត បំផុតមួយដែលទាក់ទងទៅនឹងគោលបំណងនៃបទគម្ពីរនេះថា សេចក្ដីដែលបាន ចែងទុកមកជាមុននោះ សម្រាប់នឹងបង្រៀនដល់យើងរាល់គ្នា ដើម្បីឱ្យយើងមានសេចក្ដីសង្ឃឹមដោយសេចក្ដីអត់ធន់ និងសេចក្ដីកម្សាន្តចិត្តដែលមាននៅក្នុងព្រះគ្រីស្ទ (១កថ ១០:៦,១១) ។

**១៥:៥** *ទ្រង់ប្រទានឱ្យអ្នករាល់គ្នាមានគំនិតតែ១* ត្រង់ចំណុចនេះពុំមែនមានន័យថា គ្រីស្ទបរិស័ទទាំងអស់ត្រូវតែមានគំនិតជាធ្លុងមួយចំពោះមនសិការដែលបានវែកញែកពីខាងលើនោះទេ ប៉ុន្តែ បើពួកគេមិនយល់ព្រម ឬយល់ព្រមត្រូវតែធ្វើឡើងដោយសេចក្ដីស្រឡាញ់ ។

**១៥:៧** *ដូចជាព្រះគ្រីស្ទទទួលយើងដែរ* មើល ១៤:៣ ១៤:៤,១៥ និងការពន្យល់ ។

**១៥:៨** *ព្រះយេស៊ូវគ្រីស្ទទ្រង់បានត្រឡប់ជាអ្នកបំរើ* ត្រង់នេះបញ្ជាក់ថា ព្រះយេស៊ូវគ្រីស្ទយាងមកដើម្បីបម្រើដល់មនុស្សលោក តាំងពីទ្រង់បំពេញភារកិច្ចដំបូងមកម្ល៉េះ ។ *ពួកកាត់ស្បែក* ពួកនេះគឺសំដៅលើសាសន៍យូដា ដែលព្រះយេស៊ូវត្រូវបានបញ្ជូនទៅបម្រើដល់សាសន៍នេះ ដើម្បីបន្តពង្រីកព្រះរាជកិច្ចជាមួយនឹងពួកគេ (មថ ១៥:២៤) ។ ព្រះអម្ចាស់ទ្រង់បានប្រទានឯកសិទ្ធិយ៉ាងពិសេសផ្នែកឯដំណឹងល្អដល់សាសន៍យូដា (១:១៦ និងការពន្យល់ ៣:១–៨ ៩:៤–៥ និងការពន្យល់) ។ *ប្រយោជន៍នឹងបញ្ជាក់សេចក្ដីសន្យាដែលបានតាំងនឹងពួកព្ធយុកោ* ត្រង់នេះគឺនិយាយពីការតាំងសញ្ញារបស់ព្រះជាមួយនឹងលោកអ័ប្រាហាំ (លប ១២:១–៣ ១៧:៧ ១៨:១៩ ២២:១៨) លោកអ៊ីសាក (លប ២៦:៣–៤) ហើយនិងលោកយ៉ាកុប (លប ២៨:១៣–១៥ ៤៦:២–៤) ។

**១៥:៩** *ឱ្យពួកសាសន៍ដទៃ បានសរសើរដំកើងព្រះ* មានន័យថាចាប់តាំងពីដើមមក កិច្ចការប្រោសលោះរបស់ព្រះនៅផ្នែកខាងក្នុង និងសម្រាប់អ៊ីស្រា–អែល ដើម្បីឈានទៅរកការប្រោសលោះដល់សាសន៍ដទៃ (លប ១២:២–៣ និងការពន្យល់) ។ ទាំងសាសន៍យូដា និងសាសន៍ដទៃនឹងបានឃើញពីអំណាចព្រះចេស្ដា និងព្រះគុណរបស់ព្រះដែលមានចំពោះរាស្ត្រទ្រង់ ហើយទ្រង់បានទទួលការសរសើរពីពួកបណ្ដាជនទាំងនោះវិញ នូវអ្វីដែលព្រះអម្ចាស់បានធ្វើសម្រាប់ពួកគេ (គោលរឿងរួមគ្នាមួយនៅក្នុងទំនុកបទសរសើរតម្កើងដែលលោកប៉ុលបានដកស្រង់នេះគឺនៅក្នុង ៩ខ–១២ និងការពន្យល់ចេញពីបទគម្ពីរ ទដ ៩:១) ។ ដូច្នេះ ពួកគេគួរតែដឹងពីព្រះដ៏ពិត ហើយត្រូវតែថ្វាយសិរីរុងរឿងដល់ទ្រង់ចំពោះសេចក្ដីមេត្តារបស់ទ្រង់ (មើលការពន្យល់ ទដ ៤៦:១០ ៤៧:៩) ។ សកម្មភាព និងពេលវេលាដ៏អស្ចារ្យសម្រាប់សង្គ្រោះនៃសាសន៍អ៊ីស្រាអែល គឺជាការបញ្ជូនព្រះមែស៊ីឱ្យមកដើម្បីសម្រេចតាមសេចក្ដីសន្យា ដែលធ្វើឡើងជាមួយនឹងពួកព្ធយុកោ ហើយក៏ដូចគ្នានឹងសម្រាប់ចម្រូតដ៏ធំអស្ចារ្យនៃសាសន៍ដទៃនោះដែរ ។

**១៥:១២** *នឹងមានឫសរបស់អ៊ីសាយ១កើតឡើង* លោកអ៊ីសាយគឺជាឪពុករបស់ដាវីឌ (១សយ ១៦:៥–១៣ មថ ១:៦) ហើយព្រះមែស៊ីគឺជា "ព្រះរាជបុត្រានៃស្ដេច ដាវីឌ" (មថ ១:១ និងការពន្យល់ ២១:៩ និង អស ១១:១ វវ ៥:៥ និងការពន្យល់) *សាសន៍ទាំងនោះនឹងយកទ្រង់ជាទីសង្ឃឹម* នេះគឺជាបេសកម្មដល់សាសន៍ដទៃនៃពួកជំនុំដំបូងដែលត្រូវបានសម្រេចនៃបទទំនាយនេះ (អស ១១:១០ និងការពន្យល់) ហើយក៏កំពុងបន្តការផ្សាយដំណឹងល្អនេះទៅដល់ជាតិសាសន៍ផ្សេងៗទៀតផងដែរ (អស ៤២:៤ និងការពន្យល់) ។

**១៥:១៣** *ព្រះនៃសេចក្ដីសង្ឃឹម* គ្រប់ទាំងសេចក្ដីសង្ឃឹមរបស់គ្រីស្ទបរិស័ទយើងគឺបានមកពីព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ តែមួយអង្គគត់ (មើលការពន្យល់ ៥:៥) ។ *ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ* មានន័យថាសេចក្ដីសង្ឃឹមដែលបាននិយាយខាងលើនេះ គឺមិនអាចកើតឡើងបានដោយសារការខំប្រឹងប្រែងរបស់មនុស្សនោះទេ តែនេះគឺជាអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដែលត្រូវបាន ប្រទានឱ្យមនុស្សលោកយើងនេះវិញ (៨:២៤–២៥) ។

ហើយ ១៥ហេតុដូច្នេះ បងប្អូនអើយ ខ្ញុំធ្វើសំបុត្រនេះផ្ញើមក
អ្នករាល់គ្នា ដោយមានចិត្តក្លៀវក្លាលើសទៅទៀត ដែល
មាន១ ផ្នែក សំរាប់នឹងរំឭកដល់អ្នករាល់គ្នា ដោយសារ
ព្រះគុណដែលព្រះទ្រង់បានផ្តល់មកខ្ញុំ[គ] ១៦ឱ្យខ្ញុំបានធ្វើជា
ភ្នាក់ងារនៃព្រះយេស៊ូវគ្រីស្ទ ដល់ពួកសាសន៍ដទៃ[ឃ] ព្រម
ទាំងធ្វើការងារបរិសុទ្ធ គឺជាការផ្សាយដំណឹងល្អរបស់
ព្រះ[ង] ដើម្បីឱ្យការប្រមូលពួកសាសន៍ដទៃបានទុកជា
ដង្វាយ[ច]ថ្វាយព្រះ ដែលទ្រង់សព្វព្រះហឫទ័យទទួលបាន
ទាំងញែកចេញជាបរិសុទ្ធដោយព្រះវិញ្ញាណបរិសុទ្ធផង
១៧ដូច្នេះ ខ្ញុំមានហេតុនឹងអួតក្នុងព្រះគ្រីស្ទយេស៊ូវ[ឆ] ពី
សេចក្តីទាំងប៉ុន្មានខាងឯព្រះ[ជ] ១៨ព្រោះខ្ញុំមិនហ៊ាននិយាយ
ពីការអ្វី លើកតែពីការដែលព្រះគ្រីស្ទបានធ្វើដោយសារ
ខ្ញុំប៉ុណ្ណោះទេ គឺជាការនាំសាសន៍ដទៃ[ឈ] ឱ្យស្តាប់បង្គាប់[ញ]
ទោះដោយពាក្យសំដី ឬការធ្វើក្តី ១៩ទោះដោយអំណាចនៃ
ទីសំគាល់ ឬការអស្ចារ្យ[ដ] ឬដោយព្រះចេស្តាព្រះវិញ្ញាណ
នៃព្រះក្តី[ឋ]ដល់ម្ល៉េះបានជាខ្ញុំបានផ្សាយដំណឹងល្អពីព្រះគ្រីស្ទ
ពេញពាសទូទៅ តាំងពីក្រុងយេរូសាឡិម[ឌ] ដើរវាងរហូត
ទៅដល់ស្រុកអ៊ីលីរីកុន[ឍ] ២០គឺយ៉ាងដូច្នោះឯងដែលខ្ញុំខំ
សង្វាតនឹងផ្សាយដំណឹងល្អ[ណ] មិនមែននៅកន្លែងដែលគេ
បានឮពីព្រះនាមព្រះគ្រីស្ទរួចហើយនោះទេ ដើម្បីកុំឱ្យខ្ញុំ
សង់លើជើងជញ្ជាំងរបស់គេ[ត] ២១ដូចជា មានសេចក្តីចែង
ទុកមកថា «ពួកអ្នកដែលគ្មានអ្នកណាទៅផ្សាយដំណឹងពី
ទ្រង់ឱ្យគេស្តាប់ នោះនឹងឃើញ ហើយពួកដែលមិនបាន
ឮសោះ នោះនឹងបានយល់វិញ»[ថ] ២២គឺដោយហេតុនោះ
បានជាខ្ញុំមានសេចក្តីឃាត់ឃាំងជាច្រើនដង មិនឱ្យខ្ញុំមកឯ
អ្នករាល់គ្នា[ទ] ។

## ប៉ុលមានគម្រោងទៅសួរសុខទុក្ខនៅក្រុងរ៉ូម

២៣ប៉ុន្តែឥឡូវនេះ ដោយគ្មានកន្លែងណាសល់ នៅ
ស្រុកទាំងនេះទៀត ហើយដោយខ្ញុំមានចិត្តរឭកចង់មក
ឯអ្នករាល់គ្នាជាយូរឆ្នាំមកហើយផង[ធ] ២៤បានជាកាល
ណាខ្ញុំទៅឯស្រុកអេស្ប៉ាញ[ន] នោះខ្ញុំនឹងចូលមកសួរអ្នក
រាល់គ្នា ដ្បិតខ្ញុំសង្ឃឹមថា នឹងឃើញអ្នករាល់គ្នាតាមផ្លូវ
ហើយឱ្យអ្នករាល់គ្នាបានជួយ[ប]ដំណើរខ្ញុំទៅមុខទៀត គឺ
ក្នុងគ្រាក្រោយដែលបានពេញចិត្តនឹងអ្នករាល់គ្នាបន្តិច
២៥តែឥឡូវនេះ ខ្ញុំឡើងទៅឯក្រុងយេរូសាឡិម[ផ] ដើម្បីនឹង

**១៥:១៧** ឆ ភល ៣:៣ ជ ហាព ២:១៧
**១៥:១៨** ឈ កច ១៥:១២ ២១:១៩ រម ១:៥ ញ រម ១៦:២៦
**១៥:១៩** ដ យហ ៤:៤៨ កច ១៩:១១ ឋ ខ.១៣ ឌ កច ២២:១៧–២១ ឍ ២កថ ២:១២
**១៥:២០** ណ រម ១:១៥ ត ២កថ ១០:១៥,១៦
**១៥:២១** ថ អស ៥២:១៥
**១៥:២២** ទ រម ១:១៣
**១៥:២៣** ធ កច ១៩:២១ រម ១:១០,១១
**១៥:២៤** ន ខ.២៨ ប ១កថ ១៦:៦ ទត ៣:១៣
**១៥:២៥** ផ កច ១៩:២១

**១៥:១៥** *សំរាប់នឹងរំឭកដល់អ្នករាល់គ្នា* ត្រង់ចំណុចនេះប្រហែលជាលោកប៉ុលចង់និយាយពីគោលលទ្ធិរបស់គ្រីស្ទបរិស័ទនៅក្រុងរ៉ូម ពីព្រោះលោកមិនមែនជាអ្នកដែលបានផ្សាយដំណឹងល្អ ឬក៏បង្រៀនផ្ទាល់នៅក្រុងរ៉ូមនោះទេ ។
**១៥:១៦** *ភ្នាក់ងារនៃព្រះយេស៊ូវគ្រីសដល់ពួកសាន៍ដទៃ* មើលការពន្យល់ ១១:១៣ *ធ្វើការងារបរិសុទ្ធ* ការងារនេះពុំដូចនឹងពួកសង្ឃលេវីក្នុងសម័យសញ្ញាចាស់នោះទេ ដែលរវល់តែនឹងពិធីបុណ្យផ្សេងៗនៃព្រះវិហារ ប៉ុន្តែចំពោះការងារបរិសុទ្ធនៅត្រង់នេះគឺជាការផ្សាយដំណឹងល្អវិញ ។ *ទុកជាដង្វាយថ្វាយព្រះ . . . ញែកចេញជាបរិសុទ្ធ ដោយព្រះវិញ្ញាណបរិសុទ្ធ* មានន័យថា ដង្វាយដែលលោកប៉ុលបានថ្វាយ ព្រះនោះគឺជាពួកជំនុំសាសន៍ដទៃ ។ *ញែកជាបិរសុទ្ធ* មើលការពន្យល់ ១កថ ១:២ ។
**១៥:១៧** *ខ្ញុំមានហេតុនឹងអួត* ត្រង់នេះបញ្ជាក់ថា លោកប៉ុលមិនបានអួតពីខ្លួនរបស់គាត់ផ្ទាល់នោះទេ ប៉ុន្តែ គាត់បានអួតពីអ្វីដែលព្រះគ្រីស្ទបានសម្រេចព្រះរាជកិច្ចរបស់ទ្រង់តាមរយៈជីវិតរបស់គាត់(ខ.១៨)។
**១៥:១៩** *ដោយអំណាចនៃទីសំគាល់* មើល កច ១៤:៨–១០ ១៦:១៦–១៨,២៥–២៦ ២០:៩–១២ ២៨:៨–៩ ២កថ ១២:១២ និងការពន្យល់ ហព ២:៤ និងការពន្យល់ ។ *តាំងពីក្រុងយេរូសាឡិម* ទីក្រុងយេរូសាឡិម គឺជាទីកន្លែងដើមដំបូងនៃពួកជំនុំ ហើយក៏ជាកន្លែងដំណឹងល្អបានចាប់កំណើត និងការរីកសាយភាយក៏ចេញពីនេះដែរ (កច ១:៨ និងការពន្យល់ និងមើលសេចក្តីផ្តើមគម្ពីរកិច្ចការ ត្រង់គម្រោង)។ *ស្រុកអ៊ីលីរីកុន* ស្រុកនេះគឺជាខេត្តមួយរបស់ចក្រភពរ៉ូមនៅភាគខាងជើងនៃស្រុកម៉ាសេដូន (បច្ចុប្បន្ននេះគឺជាប្រទេសអាល់បានី និងប្រទេសយូហ្គោស្លាវី)។ គម្ពីរកិច្ចការពុំបាននិយាយអ្វីដែលទាក់ទងនឹងដំណឹងល្អនៅស្រុកនេះទេ ត្រង់នេះប្រហែលជាមានន័យថា គាត់គ្រាន់តែបានមកដល់ព្រំដែនប៉ុណ្ណោះ ។ *ខ្ញុំបានផ្សាយដំណឹងល្អពីព្រះគ្រីស្ទពេញពាសទូទៅ* ចំណុចនេះពុំមានន័យថា អ្នកស្រុកនៅតំបន់សមុទ្រមេឌីទែ–រ៉ាណេភាគខាងកើតបានឮដំណឹងល្អគ្រប់គ្នានោះទេ ប៉ុន្តែលោកប៉ុលបានជឿថា ការងាររបស់គាត់នៅទីនោះត្រូវបានបញ្ចប់សព្វគ្រប់ ហើយដល់ពេលដែលគាត់ត្រូវបន្តទៅកន្លែងផ្សេងៗទៀត ។
**១៥:២២** *មានសេចក្តីឃាត់ឃាំងជាច្រើនដង មិនឱ្យខ្ញុំមកឯអ្នករាល់គ្នា* ត្រង់នេះគឺបញ្ជាក់ពីបំណងដ៏ធំរបស់លោកប៉ុល ដែលចង់បញ្ចប់បេសកកម្មនៅតំបន់សមុទ្រមេឌីទែរ៉ាណេភាគខាងកើត បានជាលោកពុំអាចនឹងធ្វើដំណើរមកក្រុងរ៉ូមបាន ។
**១៥:២៣** *គ្មានកន្លែងណាសល់* ឃ្លានេះគឺយោងតាមគោលការដែលបានពោលនៅក្នុងខ.២០ ។ *ចិត្តរឭកចង់មកឯអ្នករាល់គ្នាជាយូរមកហើយ* មើល ១:១១–១៥ ។
**១៥:២៤** *ឱ្យអ្នករាល់គ្នាបានជួយដំណើរខ្ញុំទៅមុខទៀត* ត្រង់នេះមានន័យថា លោក ប៉ុលចង់ប្រើពួកជំនុំនៅក្រុងរ៉ូមធ្វើជាមូលដ្ឋាននៃប្រតិបត្តិការណ៍សម្រាប់បេសកកម្មរបស់គាត់ទៅប្រទេសអេស្ប៉ាញ(ខ.២៨)។ *ពេញចិត្តនឹងអ្នករាល់គ្នាបន្តិច* ត្រង់នេះមានន័យថា លោកប៉ុលមានការងារត្រូវធ្វើក្នុងខណៈពេលដែលគាត់ស្នាក់នៅក្រុងរ៉ូមមួយរយៈនោះ គឺសញ្ជឹងគិតពីពួកជំនុំនៅទីនោះ(១:១១–១២)។
**១៥:២៥** *ជួយដល់ពួកបរិសុទ្ធ* ត្រង់នេះលោកប៉ុលចង់ជូនអំណោយដល់ពួកជំនុំនៅក្រុងយេរូសាឡិម(ខ.២៦)។ អំណោយដែលលោកប៉ុលចង់ជួយនោះមិនត្រឹមតែប្រាក់នោះទេ តែវាតំណាងឱ្យសេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់ដល់ពួកជំនុំសាសន៍ដទៃ ដែលមកពីបងប្អូនប្រុសស្រីក្នុងព្រះគ្រីស្ទជាសាសន៍យូដា ។ *ពួកបរិសុទ្ធ* ពាក្យនេះសំដៅលើអស់អ្នកដែលជឿលើព្រះគ្រីស្ទយេស៊ូវ (មើលការពន្យល់ ១:៧)។

ជួយ[ព]ដល់ពួកបរិសុទ្ធសិន[ភ] ២៦ដ្បិតពួកស្រុកម៉ាសេដូន[ម]
និងស្រុកអាខៃ[យ] គេសុខចិត្តរៃគ្នាផ្ញើទៅជួយដល់ពួកអ្នក
ក្រីក្រ ក្នុងពួកបរិសុទ្ធនៅក្រុងយេរូសាឡិម[រ] ២៧គេសុខចិត្ត
ចង់ធ្វើការនោះ ហើយគេក៏ជំពាក់ពួកនោះដែរ ដ្បិតបើ
សិនជាពួកសាសន៍ដទៃ បានទទួលចំណែកនៃអស់ទាំង
សេចក្ដីខាងព្រលឹងវិញ្ញាណពីគេ នោះគួរតែជួយគេក្នុង
របស់ទាំងប៉ុន្មាន ខាងសាច់ឈាមវិញ[ល] ២៨ដូច្នេះ កាល
ណាខ្ញុំបានសំរេចការនេះ គឺប្រគល់ផលនៃការជំនួយនេះ
ដល់គេរួចហើយ នោះខ្ញុំនឹងចេញដំណើរទៅឯស្រុក
អេស្ប៉ាញ[វ] ដោយសារអ្នករាល់គ្នា ២៩ហើយខ្ញុំដឹងថា ដែល
ខ្ញុំមកឯអ្នករាល់គ្នា[ស] នោះខ្ញុំនឹងនាំទាំងព្រះពរនៃដំណឹង
ល្អផងព្រះគ្រីស្ទដ៏ពោរពេញមកដែរ ។
៣០តែបងប្អូនអើយ ខ្ញុំទូន្មានអ្នករាល់គ្នា ដោយនូវ
ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ហើយ
ដោយនូវសេចក្ដីស្រឡាញ់នៃព្រះវិញ្ញាណ[ហ]ថា ចូរអ្នក
រាល់គ្នាខំប្រឹងអធិស្ឋានដល់ព្រះជាមួយនឹងខ្ញុំ[ឡ] ៣១ដើម្បី
ឱ្យខ្ញុំបានរួច[អ]ពីពួកមនុស្សមិនជឿនៅស្រុកយូដា ហើយឱ្យ
ការ[ក]ដែលខ្ញុំទៅធ្វើនៅក្រុងយេរូសាឡិម បានគាប់ចិត្ត
ដល់ពួកបរិសុទ្ធ[ខ]ផង ៣២ប្រយោជន៍ឱ្យខ្ញុំមកឯអ្នករាល់គ្នា[គ]
ដោយអំណរតាមព្រះហឫទ័យព្រះ[ឃ] ហើយឱ្យខ្ញុំបានលំ
ហើយចិត្តជាមួយនឹងអ្នករាល់គ្នា[ង] ៣៣សូមឱ្យព្រះនៃសេចក្ដី
សុខសាន្ត[ច]គង់ជាមួយនឹងអ្នករាល់គ្នា អាម៉ែន ។

## ការជម្រាបសួរជាបុគ្គលផ្ទាល់ៗខ្លួន

**១៦** ១ខ្ញុំទុកដាក់[ឆ]នាងភីបេ ជាបងប្អូនយើង នឹងអ្នករាល់
គ្នា នាងជាអ្នកជំនួយដល់ពួកជំនុំ នៅក្រុងកេងគ្រា[ជ] ២ដើម្បី
ឱ្យអ្នករាល់គ្នាបានទទួលនាងក្នុងព្រះអម្ចាស់[ឈ] តាមបែប
ដែលគួរឱ្យពួកបរិសុទ្ធ[ញ]ធ្វើ ហើយឱ្យអ្នករាល់គ្នាបានជួយ
នាង ក្នុងការអ្វីដែលនាងត្រូវការនឹងអ្នករាល់គ្នាដែរ ដ្បិត
នាងបានជួយគេជាច្រើន ព្រមទាំងខ្ញុំផង ។
៣សូមជំរាបសួរដល់នាងព្រីស៊ីល និងអ្នកអ័គីឡា[ដ] ជាអ្នក
ដែលធ្វើការជាមួយនឹងខ្ញុំ[ឋ] ក្នុងព្រះគ្រីស្ទយេស៊ូវ[ឌ] ៤គេបាន
ប្រថុយជីវិតដោយព្រោះខ្ញុំ មិនមែនតែខ្ញុំដែលអរគុណដល់
គេប៉ុណ្ណោះ គឺទាំងពួកជំនុំសាសន៍ដទៃទាំងប៉ុន្មានថែមទៀត
៥សូមជំរាបសួរពួកជំនុំ ដែលប្រជុំនៅផ្ទះគេដែរ[ឍ] សូម
ជំរាបសួរអ្នកអេប៉ាយនេត ជាស្ងួនភ្ងាខ្ញុំ ដែលជាផលដំបូង[ណ]
ថ្វាយព្រះគ្រីស្ទពីស្រុកអាស៊ី[ត] ៦សូមជំរាបសួរនាងម៉ារា
ដែលបាននឿយហត់ជាច្រើន ប្រយោជន៍នឹងជួយយើង
៧សូមជំរាបសួរអ្នកអាន់ត្រូនីក នឹងអ្នកយូនាសជាញាតិខ្ញុំ[ថ] គឺ
ជាអ្នកជាប់គុកជាមួយនឹងខ្ញុំ[ទ] ដែលមានកេរ្តិ៍ឈ្មោះក្នុងពួក

**១៥:២៥** ព កថ ២៤:១៧ ភ កថ ៩:១៣ **១៥:២៦** ម កថ ១៦:៩ យ កថ ១៨:១២ រ កថ ២៤:១៧ **១៥:២៧** ល ១កថ ៩:១១ **១៥:២៨** វ ខ.២៤ **១៥:២៩** ស រម ១:១០,១១ **១៥:៣០** ហ កទ ៥:២២ កល ១:៨ ឡ ២កថ ១:១១ កល ៤:១២ **១៥:៣១** អ ២កថ ១:១០ ២ថន ៣:២ ២ធថ ៣:១១ ២ពត ២:៩ ក ខ.២៥ កថ ២៤:១៧ ខ កថ ៩:១៣ **១៥:៣២** គ រម ១:១០,១៣ ឃ កថ ១៨:២១ ង ១កថ ១៦:១៨ ភម ៧ **១៥:៣៣** ច រម ១៦:២០ ២កថ ១៣:១១ ភល ៤:៩ ១ថន ៥:២៣

២ថន ៣:១៦ ហព ១៣:២០ **១៦:១** ឆ ២កថ ៣:១ ជ កថ ១៨:១៨ **១៦:២** ឈ ភល ២:២៩ ញ កថ ៩:១៣ **១៦:៣** ដ កថ ១៨:២ ឋ ភល ២:២៥ ឌ ខ.៧,៩,១០ រម ៨:១,៣៩ ១កថ ១:៣០ ២កថ ៥:១៧ កទ ១:២២ ៥:៦ អភ ១:១៣ **១៦:៥** ឍ ១កថ ១៦:១៩ កល ៤:១៥ ភម ២ ណ ១កថ ១៦:១៥ ត កថ ២:៩ **១៦:៧** ថ ខ.១១,២១ ទ កល ៤:១០ ភម ២៣

**១៥:២៦** *ស្រុកម៉ាសេដូន និងស្រុកអាខៃ* មើលការពន្យល់ ១ថន ១:៧ ។ *ទៅជួយ* សូមមើល ១កថ ១៦:១–៤ ២កថ ៨:១–៩:១៥ និងការពន្យល់ ។

**១៥:២៧** *បានទទួលចំណែកនៃអស់ទាំងសេចក្ដីខាងព្រលឹងវិញ្ញាណពីគេ* ពាក្យថា គេ គឺតំណាងឱ្យពួកសាសន៍យូដា ដូច្នេះឃ្លានេះមានន័យថាបានទទួលចំណែកនៃអស់ទាំងសេចក្ដីខាងព្រលឹងវិញ្ញាណពីសាសន៍យូដា ជាពិសេសគឺព្រះយេស៊ូវគ្រីស្ទ ហើយនិងដំណឹងល្អ ។

**១៥:២៨** *ផលនៃការជំនួយ* គឺជាការប្រមូលអំណោយពីពួកជំនុំសាសន៍ដទៃ ។

**១៥:៣១** *ឱ្យខ្ញុំរួចពីពួកមនុស្សមិនជឿនៅស្រុកយូដា* មានន័យថា លោកប៉ុលមានចិត្តចង់ទៅក្រុងយេរូសាឡិម ហើយប្រគល់ប្រាក់ដែលប្រមូលបាននោះទៅពួកគេ ដូច្នេះការធ្វើដំណើរនេះសំខាន់ណាស់សម្រាប់រូបគាត់ ប៉ុន្តែគាត់ក៏បានទទួលការព្រមានអំពីហេតុការណ៍មិនល្អ ដោយសារពួកមនុស្សមិនជឿនៅទីនោះ ដូច្នេះហើយបានជាគាត់សូមឱ្យជួយអធិស្ឋាន(កថ ២០:២២–២៣ និងការពន្យល់ ២០:២២)។ *ឱ្យការដែលខ្ញុំធ្វើ... បានគាប់ចិត្ត* ត្រង់នេះប្រហែលសំដៅទៅលើមធ្យោបាយបញ្ជូនប្រាក់ ពីព្រោះជាញឹកញាប់ត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្ន និងលំបាកទៀតផង ។

**១៥:៣២** *បានលំហើយចិត្តជាមួយនឹងអ្នករាល់គ្នា* មើល ១:១១–១២ ។

**១៥:៣៣** *ព្រះនៃសេចក្ដីសុខសាន្ត* មើលការពន្យល់ ៥:១ ១ថន ៥:២៣ ។

**១៦:១** *បងប្អូនយើង* សំដៅលើអ្នកដែលមានជំនឿលើព្រះគ្រីស្ទដូចគ្នា ។ *នាងភីបេ* ម្នាក់នេះប្រហែលជាអ្នកយកសំបុត្រទៅក្រុងរ៉ូម(ខ.២)។ *អ្នកជំនួយ* គឺជាអ្នកបម្រើ ឬជាអ្នកទទួលបន្ទុកទូទៅណាមួយ ។ គេប្រើពាក្យនេះសម្រាប់ពួកជំនុំក្នុងសម័យ នោះគឺសំដៅលើអ្នកធ្វើការនៅការិយាល័យ ឬជាចាស់ទុំផ្នែកស្រ្តីដែរ ។ *ក្រុងកេងគ្រា* គឺជាទីក្រុងកំពុងផែមួយដែលមានចម្ងាយប្រហែល ៩,៧គ.ម ភាគខាងកើតនៃក្រុងកូរិនថូសនៅឈូងសមុទ្រសារ៉ូន ។

**១៦:៣** *នាងព្រីស៊ីល និងអ្នកអ័គីឡា* ទាំងពីរនេះគឺជាមិត្តជិតស្និទ្ធនឹងលោកប៉ុលដែលបានជួញដូរត្រសាល(តង់)ជាមួយនឹងគ្នា(កថ ១៨:២–៣ និងពន្យល់)។

**១៦:៤** *បានប្រថុយជីវិតដោយព្រោះខ្ញុំ* ឃ្លានេះពុំឃើញមានកត់ចុះនៅកន្លែងណាទៀត ឬក្នុងគម្ពីរសញ្ញាថ្មីនោះឡើយ ប៉ុន្តែត្រូវបានគេដឹងជាទូទៅថាមានផ្នែកខ្លះនៃខចុងក្រោយមានខ្លះៗដែរ (ភល ២:២៥–៣០ និងការពន្យល់)។

**១៦:៦** *នាងម៉ារា* មានមនុស្ស៦នាក់ដែលមានឈ្មោះដូចនេះនៅក្នុងគម្ពីរសញ្ញាថ្មី ប៉ុន្តែ នាងម្នាក់នេះ គ្មាននរណាស្គាល់ប្រវត្តិនាងនោះឡើយ ។

**១៦:៧** *អ្នកយូនាស* នេះគឺជាឈ្មោះស្ត្រីម្នាក់ ។ អ្នកអាន់ត្រូនីក និងអ្នកយូនាសអាចជាប្ដីប្រពន្ធនឹងគ្នា "នាងព្រីស៊ីល និងអ្នកអ័គីឡា(ខ.៣) អ្នកភីឡូឡូក និងនាងយូលាស (ខ.១៥)"។ *មានកេរ្តិ៍ឈ្មោះនៅក្នុងពួកសាវក* ត្រង់ចំណុចនេះមានការបកស្រាយពីរបែបគឺ ១."ពួកសាវក" ត្រូវបានប្រើនៅក្នុងន័យទូលំទូលាយជាងពួកសាវ័កទាំង១២នាក់ ដែលមានដូចជាអ្នកផ្សាយដំណឹងល្អដែលមានពួកជំនុំជាច្រើនទទួលស្គាល់ (កថ ១៤:៤ និងការពន្យល់ខ.១៤ ១ថន ២:៦)។ ២."ពួកសាវ័ក" គឺជាពួកសាវ័ក ដែលបានទទួលងារពីមុនមកនោះគឺជាសាវ័កទាំង១២នាក់ ។ បើសំដៅលើសាវ័ក ទាំងនេះមែន នោះមានន័យថា

សាវក ក៏ជឿដល់ព្រះគ្រីស្ទ[ធ]មុនខ្ញុំដែរ ៨សូមជំរាបសួរ
អ្នកអាំភ្លាស ជាស្ងួនភ្ងាខ្ញុំក្នុងព្រះអម្ចាស់ ៩សូមជំរាបសួរអ្នក
អើបាន់ ដែលធ្វើការជាមួយនឹងយើង ក្នុងព្រះគ្រីស្ទ[ន]នឹងអ្នក
ស្តាឃីស ជាស្ងួនភ្ងាខ្ញុំដែរ ១០សូមជំរាបសួរអ្នកអ័ពេលេស
ដែលជាអ្នកខ្ជាប់ខ្ជួនក្នុងព្រះគ្រីស្ទ[ប] ហើយសូមជំរាបសួរពួក
ផ្ទះ[ផ]អើរិស្តូប៊ូល ១១សូមជំរាបសួរអ្នកហេរ៉ូឌាន ជាញាតិខ្ញុំ[ព]
សូមជំរាបសួរពួកផ្ទះ[ភ]ណើគីស ដែលនៅក្នុងព្រះអម្ចាស់
១២សូមជំរាបសួរនាងទ្រីភេន នឹងនាងទ្រីផូស ដែលធ្វើការ
ក្នុងព្រះអម្ចាស់ សូមជំរាបសួរនាងពើស៊ីស ជាអ្នកស្ងួនភ្ងា
ដែលធ្វើការនឿយហត់ជាច្រើនក្នុងព្រះអម្ចាស់ ១៣សូម
ជំរាបសួរអ្នករូភូស[ម] ដែលព្រះអម្ចាស់បានរើសតាំង[យ] និង
ម្តាយគាត់ដែលរាប់ជាម្តាយខ្ញុំដែរ ១៤សូមជំរាបសួរអ្នក
អ័ស៊ីងគ្រីត អ្នកភ្លេកូន អ្នកហើម៉ាស អ្នកប៉ាត្រូបាស អ្នក
ហើមេស និងពួកបងប្អូនដែលនៅជាមួយនឹងអ្នកទាំងនោះ
១៥សូមជំរាបសួរអ្នកភីឡូឡូក នឹងនាងយូលាស អ្នកនេរើស
និងប្អូនស្រីគាត់ ហើយអ្នកអូលីមប៉ាស នឹងពួកបរិសុទ្ធ[រ] ដែល
នៅជាមួយនឹងអ្នកទាំងនោះ[ល] ១៦សូមអ្នករាល់គ្នាជំរាបសួរ
គ្នាទៅវិញទៅមក ដោយការថើបយ៉ាងបរិសុទ្ធ[វ] ពួកជំនុំនៃ
ព្រះគ្រីស្ទទាំងអស់ សូមជំរាបសួរមកអ្នករាល់គ្នា ។
១៧ឱបងប្អូនអើយ ខ្ញុំទូន្មានអ្នករាល់គ្នា ឱ្យចំណាំមើល
អស់អ្នកដែលបណ្តាលឱ្យបាក់បែកគ្នា ហើយនាំឱ្យមាន
សេចក្តីរវាតចិត្ត ខុសនឹងសេចក្តីដែលអ្នករាល់គ្នាបានរៀន
មក[ស] ត្រូវឱ្យបែរចេញពីអ្នកទាំងនោះ[ហ] ១៨ដ្បិតមនុស្សបែប
យ៉ាងនោះ មិនមែនគោរពប្រតិបត្តិដល់ព្រះគ្រីស្ទ ជាព្រះ
អម្ចាស់នៃយើងរាល់គ្នាទេ[ឡ] គេបំរើតែពោះខ្លួនគេវិញ[អ]
ទាំងបញ្ឆោត[ក]ចិត្តមនុស្សស្លូតត្រង់ ដោយពាក្យផ្អែមពីរោះ
នឹងពាក្យបញ្ចើចផង ១៩ដ្បិតមនុស្សទាំងអស់បានដឹង[ខ] ពី
បែប ដែលអ្នករាល់គ្នាស្តាប់បង្គាប់ហើយ ដូច្នេះ ខ្ញុំត្រេកអរ
ពីដំណើរអ្នករាល់គ្នាណាស់ ប៉ុន្តែខ្ញុំចង់ឱ្យអ្នករាល់គ្នាមាន
ប្រាជ្ញាខាងឯសេចក្តីល្អ ហើយល្ងង់ខាងឯសេចក្តីអាក្រក់
វិញ[គ] ២០ឯព្រះនៃសេចក្តីសុខសាន្ត[ឃ] នៅបន្តិចទៀតទ្រង់
នឹងកិន[ង]អារក្សសាតាំង[ច] នៅក្រោមជើងអ្នករាល់គ្នាហើយ
សូមឱ្យអ្នករាល់គ្នាបានប្រកបដោយនូវព្រះគុណនៃព្រះ
យេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងចុះ[ឆ]។
២១អ្នកធីម៉ូថេ[ជ] ជាអ្នកធ្វើការជាមួយនឹងខ្ញុំ ហើយអ្នក
លូគាស[ឈ] អ្នកយ៉ាសុន[ញ] និងអ្នកសូសិប៉ាត្រុស ជាញាតិខ្ញុំគេ
សូមជំរាបសួរមកអ្នករាល់គ្នាដែរ[ដ] ២២ឯខ្ញុំឈ្មោះទើទាស
ដែលសរសេរសំបុត្រនេះ ក៏សូមជំរាបសួរមកអ្នករាល់គ្នា
ក្នុងព្រះអម្ចាស់ដែរ ២៣អ្នកកៃយុស[ឋ]ជាអ្នកដែលទទួលខ្ញុំ និង

**១៦:៧** ធ ខ.៣
**១៦:៩** ន ខ.៣
**១៦:១០** ប ខ.៣ ផ កច ១១:១៤
**១៦:១១** ព ខ.៧,២១ ភ កច ១១:១៤
**១៦:១៣** ម មក ១៥:២១ យ ២យហ ១
**១៦:១៥** រ ខ.២ កច ៩:១៣ ល ខ.១៤
**១៦:១៦** វ ១កថ ១៦:២០ ២កថ ១៣:១២ ១ថន ៥:២៦ ១ពត ៥:១៤
**១៦:១៧** ស កទ ១:៨,៩ ១ធថ ១:៣ ៦:៣ ហ មថ ១៨:១៥–១៧ ១កថ ៥:១១ ២ថន ៣:៦,១៤ ២ថន ៣:៥ ទត ៣:១០ ២យហ ១០
**១៦:១៨** ឡ រម ១៤:១៨ អ ភល ៣:១៩ ក ២សយ ១៥:៦ ទដ ១២:២ អស ៣០:១០ កល ២:៤ **១៦:១៩** ខ រម ១:៨ គ ១កថ ១៤:២០ **១៦:២០** ឃ រម ១៥:៣៣ ង លប ៣:១៥ ច មថ ៤:១០ ឆ ២កថ ១៣:១៤ កទ ៦:១៨ ១ថន ៥:២៨ វវ ២២:២១**១៦:២១** ជ កច ១៦:១ ឈ កច ១៣:១ ញ កច ១៧:៥ ដ ខ.៧,១១

មនុស្សទាំងពីរខាងលើនេះ គឺជាអ្នកដែលលេចធ្លោរ "នៅក្នុងគំនិត" នៃពួកសាវក ទាំង១២តែប៉ុណ្ណោះ ។

**១៦:៨–១០** *អ្នកអាំភ្លាស . . . អើបាន់ . . . ស្តាឃីស . . . អ័ពេលេស* មនុស្សទាំងនេះគឺជា ទាសករដ៏សាមញ្ញ ដែលបម្រើនៅក្នុងផ្ទះរបស់រាជាធិរាជ ។

**១៦:១០** *អើរិស្តូប៊ូល* ម្នាក់នេះប្រហែលជាប់ទាក់ទងនឹងចៅប្រុសរបស់ស្តេចហេរ៉ូឌ អធិរាជ ហើយជាបងប្អូនប្រុសរបស់ស្តេចហេរ៉ូឌ អ័គ្រីប៉ា I ។

**១៦:១១** *ជាញាតិខ្ញុំ* ត្រង់នេះប្រហែលជាបញ្ជាក់ពីភាពជាសាសន៍យូដារបស់គាត់ ។ *ណើគីស* ឈ្មោះនេះពេលខ្លះប្រើជាឈ្មោះពេញគឺមហារាជទីបេរី–ក្លូឌាសណើគីស គឺជាអ្នកដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភម្នាក់នៃរាជាធិរាជទីបេរីរ៉ូម៉ាំង ។

**១៦:១២** *នាងទ្រីភេន និងនាងទ្រីផូស* ស្ត្រីទាំងពីរនេះប្រហែលជាបងប្អូននឹងគ្នាឬក៏ ជាកូនភ្លោះផង ពីព្រោះឈ្មោះនេះមានប្រភពតែមួយ ប៉ុន្តែសម្រាប់មនុស្សពីរនាក់ ។ *នាងពើស៊ីស* ឈ្មោះនេះមានន័យថា "ស្ត្រីសាសន៍ពើស៊ី"។

**១៦:១៤–១៥** គ្មាននរណាបានស្គាល់មនុស្សក្នុងខទាំងពីរនេះឱ្យលើសពីនេះឡើយ លើកលែងតែពួកគេជាទាសករ ឬជាអ្នកដែលមានសេរីភាពនៅក្នុងពួកជំនុំរ៉ូម៉ាំង ។

**១៦:១៦** *ថើបយ៉ាងបរិសុទ្ធ* មើល ១កថ ១៦:២០ ២កថ ១៣:១២ ១ថន ៥:២៦ និងការពន្យល់ ១ពត ៥:១៤ ។ តាមឯកសារលោកយ៉ាក់ស្ទីន ម៉ាត់ធើ (Justin Martyr) នៅឆ្នាំ១៥០គ.សបានឱ្យដឹងថា ការថើបនេះគឺជាផ្នែកមួយត្រឹមត្រូវនៃកម្មវិធីថ្វាយបង្គំព្រះនៅសម័យនោះ ហើយក៏នៅតែអនុវត្តផងដែរក្នុងពួកជំនុំខ្លះនាសព្វថ្ងៃនេះ ។

**១៦:១៧** *អស់អ្នកដែលបណ្តាលឱ្យបាក់បែកគ្នា ហើយនាំឱ្យមានសេចក្តីរវាតចិត្ត* មានន័យថា មនុស្សទាំងឡាយណាដែលយើងមិនអាចស្គាល់បាន ប៉ុន្តែយើងអាចស្គាល់ពីកិរិយាមាយាទរបស់ពួកគេបាន ដូចដែលបានពោលនៅក្នុង ខ.១៨ ។

**១៦:១៩** *មានប្រាជ្ញាខាងឯសេចក្តីល្អ* មានន័យថា គ្រីស្ទបរិស័ទត្រូវតែជាអ្នកដែលមានឯកទេសខាងឯការធ្វើល្អ ។

**១៦:២០** *ព្រះនៃសេចក្តីសុខសាន្ត* មើលការពន្យល់ ១៥:៣៣ ១:៧ ។ *នៅតែបន្តិចទៀតទ្រង់នឹងកិនអារក្សសាតាំង* នេះគឺជាសេចក្តីបញ្ជាក់ពីភាពវិនាសចុងក្រោយរបស់អារក្សសាតាំង(មើល លប ៣:១៥ និងការពន្យល់)។ ចំពោះពាក្យ "បន្តិចទៀត" មើលការពន្យល់ ១៣:១២ ។ *ព្រះគុណ* មើលការពន្យល់ ១:៧ ។ *ប្រកបដោយនូវ* មើលការពន្យល់ ២កថ ១៣:១៤ ។

**១៦:២១** *យ៉ាសុន* ឈ្មោះនេះប្រហែលជាមនុស្សតែម្នាក់ដែលនិយាយនៅក្នុងគម្ពីរ កច ១៧:៥–៩ ។ *សូសិប៉ាត្រុស* ឈ្មោះនេះ និងឈ្មោះសូប៉ាត្រុស ជាកូនប្រុសរបស់លោកភីរ៉ូសមកពីក្រុងបេរា អាចជាមនុស្សតែម្នាក់(កច ២០:៤ និងការពន្យល់)។

**១៦:២២** *ឯខ្ញុំឈ្មោះទើទាស ដែលសរសេរសំបុត្រនេះ* លោកម្នាក់នេះ គឺមានតួនាទីជាលេខាធិការរបស់លោកប៉ុល ។

**១៦:២៣** *កៃយុស* ជាធម្មតាឈ្មោះនេះបានបញ្ជាក់ពីលោកទីតុស–យូស្ទុស (គម្ពីរ ភាសាខ្មែរ ប្រើតែឈ្មោះយូស្ទុសទេ) ជាអ្នកដែលកោតខ្លាចដល់ព្រះ

ពួកជំនុំទាំងអស់គ្នាផង គាត់សូមជំរាបសួរមកអ្នករាល់គ្នា
អ្នកអេរ៉ាស្ទុស[ឱ] ជាមេត្រួតត្រាក្នុងទីក្រុង និងអ្នកក្វើតុស ជា
ពួកបងប្អូនគេក៏សូមជំរាបសួរមកអ្នករាល់គ្នាដែរ ២៤សូមឱ្យ
អ្នករាល់គ្នាបានប្រកប ដោយនូវព្រះគុណនៃព្រះយេស៊ូវ
គ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាទាំងអស់ អាម៉ែន ។
២៥[ជ]រីឯព្រះ ដែលអាច[ឈ]នឹងតាំងអ្នករាល់គ្នា ឱ្យខ្ជាប់ខ្ជួន
តាមដំណឹងល្អខ្ញុំ[ណ] និងតាមខ្លឹមនៃលទ្ធិរបស់ព្រះយេស៊ូវគ្រីស្ទ
ដែលត្រូវនឹងសេចក្តីបើកសំដែង អំពីការអាថ៌កំបាំង ដែល
បានលាក់ទុក[ត]នៅអស់ទាំងកល្បរៀងមក ២៦តែឥឡូវនេះ
បានបើកសំដែងមក ឱ្យគ្រប់ទាំងសាសន៍ដឹង ដោយសារ
គម្ពីរហោរា[ថ] តាមបង្គាប់នៃព្រះដ៏មានព្រះជន្មរស់អស់កល្ប
ជានិច្ច ដើម្បីឱ្យគេបានចុះចូលជឿ[ទ] ដោយសារព្រះយេស៊ូវ
គ្រីស្ទ ២៧ជាព្រះដ៏មានប្រាជ្ញាតែ១ព្រះអង្គ សូមឱ្យទ្រង់បាន
សិរីល្អ នៅអស់កល្បរៀងទៅ[ធ]។ អាម៉ែន ។

**១៦:២៣** ឫ កច ១៩:២៩ ឱ កច ១៩:២២ ២ធថ ៤:២០ **១៦:២៥** ឈ ២កថ ៩:៨ អភ ៣:២០ យដ ២៤ ណ រម ២:១៦ ២ធថ ២:៨ ត អស ៤៨:៦ អភ ១:៩ ៣:៣–៦,៩ កល ១:២៦,២៧ ២:២ ១ធថ ៣:១៦ **១៦:២៦** ថ រម ១:២ ទ រម ១:៥ **១៦:២៧** ធ រម ១១:៣៦

ជាម្នាក់ដែលលោកប៉ុលបានស្នាក់នៅផ្ទះគាត់នៅក្រុងកូរិនថូស (មើលការពន្យល់ កច ១៨:៧ និង១កថ ១:១៤)។ ឈ្មោះពេញរបស់គាត់គឺកៃយុស–ទីតុស–យូស្ទុស ។ *អេរ៉ាស្ទុស* អ្នកបុរាណវិទ្យាបានរកឃើញថ្មមួយដុំដែលបានយកមកតម្រៀបជាអក្សឡាតាំង រាងបួនជ្រុងឡើងវិញ នោះបានឃើញឈ្មោះ"អេរ៉ាស្ទុស"នេះ នៅក្រុងកូរិនថូស ។ តាមការស្រាវជ្រាវបានឱ្យដឹងថា គាត់គឺជាអ្នកត្រួតត្រាលើការចំណាយទូទៅផ្នែកកម្រាលថ្មនេះ ។ ដូច្នេះបើឈ្មោះអេរ៉ាស្ទុសដែលបានរកឃើញនៅលើកម្រាលថ្មនេះ និងឈ្មោះអេរ៉ាស្ទុសនៅក្នុងខនេះជាមនុស្សតែម្នាក់ពិតមែននោះ នេះហើយជាលើកដំបូងគេបំផុតដែលរកឃើញឈ្មោះគ្រីស្ទបរិស័ទនៅខាងក្រៅបទគម្ពីរ ។ ឈ្មោះនេះក៏អាចជាមនុស្សតែម្នាក់នៅក្នុង កច ១៩:២២ ២ធថ ៤:២០(មើលការពន្យល់)ទោះបើវាពិបាកក្នុងការកំណត់ថាពិតប្រាកដ ដោយព្រោះតែមនុស្សមានឈ្មោះដូចនេះច្រើនគ្នាក៏ដោយ ។ *ក្វើតុស* ឈ្មោះនេះមានន័យថា "៤នាក់(កូន៤)"។

**១៦:២៤** មើលការពន្យល់ នៅខ.២៣ ។

**១៦:២៥** *ដំណឹងល្អខ្ញុំ* ដំណឹងល្អនេះមិនខុសគ្នានឹងដំណឹងដែលពួកបងប្អូនគ្រីស្ទបរិស័ទដទៃបានប្រកាសនោះទេ ប៉ុន្តែដំណឹងល្អរបស់ប៉ុលគ្រាន់តែគាត់បានទទួលការបើកសំដែងដោយផ្ទាល់(កទ ១:១២ និងមើលការពន្យល់ ១:១១)។ *លទ្ធិរបស់ព្រះយេស៊ូវគ្រីស្ទ* គឺសំដៅលើដំណឹងល្អដែលពិពណ៌នាអំពីព្រះយេស៊ូវដែលមាន នៅក្នុង (១:៣ ១កថ ១៥:៣–៤ និងការពន្យល់)។ *ការអាថ៌កំបាំង* មើលការពន្យល់ ១១:២៥ ។ *អស់ទាំងកល្បរៀងមក* មានន័យថា តាំងពីដើមដំបូងរៀងមក (១កថ ២:៧ និងការពន្យល់)។

**១៦:២៦** *បានបើកសំដែងមក . . . ដោយសារគម្ពីរហោរា* មើលការពន្យល់ ១:២ ។ *គ្រប់ទាំងសាសន៍* មានន័យថា ដំណឹងល្អបានពូពេញទាំងសកលលោក(មថ ២៨:១៩ និងការពន្យល់)។

**១៦:២៧** *សូមឱ្យទ្រង់បានសិរីល្អ* ការថ្វាយសិរីល្អដល់ព្រះអម្ចាស់នេះហើយគឺជា បំណងដ៏សំខាន់ជាងគេបំផុតរបស់គ្រីស្ទបរិស័ទ(១១:៣៦ ទដ២៩:១–២ ៨៦:៩,១២ ៩៦:៧–៨ ១១៥:១ លក ២:១៤ និងការពន្យល់ ១កថ ១០:៣១ និងការពន្យល់ អភ ១:១២,១៤ វវ ៥:១៣ ៧:១២ ១៥:៤ ១៩:១,៧)។

សំបុត្រទី១របស់លោកប៉ុល

ដល់ពួកជំនុំ

# កូរិនថូស

សេចក្តីផ្តើម

**អ្នកនិពន្ធ និងកាលបរិច្ឆេទ**

តាមរយៈសំបុត្រកូរិនថូសនេះផ្ទាល់ និងពួកអ្នកប្រាជ្ញព្រះគម្ពីរជំនាន់ដើមបានបញ្ជាក់យ៉ាងច្បាស់ថា លោកប៉ុលគឺជាអ្នកសរសេរកណ្ឌគម្ពីរនេះឡើង(១:១-២ ១៦:២១)។ នៅឆ្នាំទី៩៦គ.ស លោកក្លេមេនបានអះអាងថា លោកប៉ុលគឺជាអ្នកនិពន្ធកណ្ឌគម្ពីរកូរិនថូស ហើយពួកអ្នកបកស្រាយព្រះគម្ពីរនាពេលបច្ចុប្បន្នក៏យល់ស្របដូច្នេះដែរ ។ សំបុត្រនេះត្រូវបានសរសេរឡើងនៅឆ្នាំទី៥៥គ.ស គឺនៅចុងឆ្នាំទីបីនៃរយៈពេលបីឆ្នាំដែលគាត់បានស្នាក់នៅក្នុងទីក្រុងអេភេសូរ (១៦:៥-៩ កច ២០:៣១)។

**ទីក្រុងកូរិនថូស**

ទីក្រុងកូរិនថូសគឺជាទីក្រុងមួយដែលមានលក្ខណៈជឿនលឿន និងជាទីក្រុងសំខាន់របស់ប្រទេសក្រិកខាងផ្នែកពាណិជ្ជកម្ម និងនយោបាយ ។

១. ពាណិជ្ជកម្ម

ទីក្រុងកូរិនថូសមានបណ្តាញផ្លូវច្រើនសម្រាប់ការធ្វើដំណើរ និងការប្រកបរបរជំនួញ ។ ទីក្រុងនេះមានកំពង់ផែសំខាន់ពីរ (១). កំពង់ផែកេងគ្រា (កច ១៨:១៨) ស្ថិតនៅចម្ងាយ៩,៦៥គ.ម ភាគខាងកើតឈូងសមុទ្រសារ៉ូនីក (Saronic Gulf) (២). កំពង់ផែលីកែយ៉ូន (Lechaion) ស្ថិតនៅចម្ងាយ ២,៤១ គ.ម ភាគខាងជើងឈូងសមុទ្រទីក្រុងកូរិនថូស ។ ទំនិញត្រូវបានដឹកជញ្ជូនតាមច្រកផ្លូវឌីយ៉ូលកូស (Diolkos ជាច្រកផ្លូវថ្មតូចមួយដែលទូកតូចៗអាចឆ្លងកាត់បាន រីឯទំនិញរបស់កប៉ាល់ធំៗវិញត្រូវបានដឹកជញ្ជូនតាមរទេះ)។ ផ្នែកពាណិជ្ជកម្មមានការរីកចម្រើនឆ្ពោះទៅទិសខាងលិចមានប្រទេសអ៊ីតាលី ប្រទេសអេស្ប៉ាញ និងឆ្ពោះទៅទិសខាងកើតមានដូចជាតំបន់អាស៊ីមីន័រ (Asia Minor) ស្រុកភេនីស និងប្រទេសអេស៊ីព្ទ ។

២. វប្បធម៌

ប្រជាជនរស់នៅក្នុងទីក្រុងកូរិនថូសបានទទួលនូវវប្បធម៌ក្រិក ទោះបីនៅក្នុងទីក្រុងនេះមិនមានសាកលវិទ្យាល័យ ដូចនៅឯទីក្រុងអាថែនក៏ដោយ ។ ពួកអ្នករស់នៅក្នុងទីក្រុងនេះ មានការពេញចិត្តចំពោះទស្សនវិជ្ជារបស់ក្រិក និងមានការឱ្យតម្លៃខ្ពស់ទៅលើប្រាជ្ញា ។

៣. សាសនា

នៅក្នុងទីក្រុងកូរិនថូសមានវិហារសាសនាយ៉ាងតិចចំនួន១២ ។ នៅសម័យកាលលោកប៉ុល គេពុំបានដឹងច្បាស់ថាវិហារទាំង១២ នោះនៅតែដំណើរការជាធម្មតាទាំងអស់ ឬយ៉ាងណានោះទេ ។ មានវិហារដ៏ល្បីមួយក្នុងចំណោមវិហារទាំងនោះគឺ វិហាររបស់រូបព្រះអាប្រូឌីត ដែលជារូបព្រះតំណាងឱ្យសេចក្តីស្រឡាញ់ ហើយរបៀបដែលគោរពប្រតិបត្តិរូបព្រះនេះ គឺត្រូវប្រព្រឹត្តអំពើពេស្យាចារ្យ ។ វិហាររបស់រូបព្រះអាក្លេពៀស (Asclepius ជារូបព្រះតំណាងឱ្យការព្យាបាល) ស្ថិតនៅភាគខាងជើងរោងល្ខោនប្រហែល ០,៤ គ.ម ។ នាសតវត្សរ៍ទី៦មុនគ.ស នៅចំកណ្តាលទីក្រុងកូរិនថូសមានវិហាររបស់រូបព្រះមួយឈ្មោះថា វិហារអាប៉ុឡូស (Temple of Apollos)។ ពួកយូដាដែលរស់នៅក្នុងទីក្រុងនេះ បានសាងសង់សាលាប្រជុំមួយសម្រាប់ប្រជុំគ្នា ដែលក្រោយមកគេបានរកឃើញសំណល់ធ្នឹមនៃសាលាប្រជុំនោះ ហើយបានយកទៅតម្កល់ទុកនៅឯ សារមន្ទីរ នៅទីក្រុងកូរិនថូសចាស់ ។

៤. អំពើអសីលធម៌

ទីក្រុងកូរិថូសជាមជ្ឈមណ្ឌលដ៏ធំ ដែលបើកចំហចំពោះអំពើអសីលធម៌ផ្សេងៗ គឺដូចជាទីក្រុងពាណិជ្ជកម្មធំៗដទៃទៀតដែរ ។ ការគោរពប្រតិបត្តិដល់រូបព្រះអាប្រូឌីត បានបណ្តាលឱ្យអំពើពេស្យាចារ្យកើតមានឡើងជាច្រើននៅក្នុងទីក្រុងនេះ ដែលពេលមួយមានស្ត្រីពេស្យាចារ្យជាសង្ឃចំនួន១០០០នាក់បម្រើការនៅក្នុងវិហារនោះ ។ ដូច្នេះហើយ ទើបក្រោយមកទៀត គេបានដាក់ឈ្មោះទីក្រុងនេះថា "ទីក្រុងដែលប្រតិបត្តិអំពើពេស្យាចារ្យ"។ ដោយព្រោះតែមូលហេតុទាំងនេះហើយ ទើបធ្វើឱ្យពួកជំនុំនៅទីក្រុងកូរិនថូសជួបប្រទះនូវបញ្ហាជាច្រើន ។

**គោលបំណង**

លោកប៉ុលបានទទួលព័ត៌មានពីប្រភពផ្សេងៗ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ពួកជំនុំនៅឯទីក្រុងកូរិថូស ។ សមាជិកខ្លះនៅ

ក្នុងផ្ទះរបស់នាងខ្លូអេ បានផ្តល់ដំណឹងទៅលោកប៉ុល ស្តីពីទង្វើទាំងឡាយដែលបានកើតឡើងនៅក្នុងពួកជំនុំនៅទីក្រុងនេះ (១:១១)។ មានមនុស្សបីនាក់ ដែលបានមកជួបលោកប៉ុល និងបានយកប្រាក់ដង្វាយមកប្រគល់ឱ្យគាត់ ដើម្បីចាត់ចែងនៅក្នុងដំណើរបេសកកម្មបម្រើព្រះអម្ចាស់ (១៦:១៧) ប៉ុន្តែ មិនបានបញ្ជាក់ថា អ្នកទាំងបីនោះមកពីផ្ទះរបស់នាងខ្លូអេ ឬយ៉ាងណានោះទេ ។

ពួកអ្នកដែលបានមកឯលោកប៉ុល បាននាំមកនូវព័ត៌មានមួយចំនួន ដែលទាក់ទងទៅនឹងភាពមិនប្រក្រតីនៃសីលធម៌ នៅក្នុងពួកជំនុំនៅឯទីក្រុងកូរិនថូស (ជំពូក ៥-៦)។ ហើយអំពើអសីលធម៌បានបៀតបៀនពួកជំនុំនៅក្នុងទីក្រុងនេះតាំងពីពេលចាប់ផ្តើមដំបូងម្ល៉េះ ។ តាមរយៈសេចក្តីដែលលោកប៉ុលបានសរសេរនៅក្នុង "៥:៩-១០" បញ្ជាក់ថា គាត់ធ្លាប់បានសរសេរសំបុត្រផ្ញើទៅពួកគេម្តងរួចហើយ ទាក់ទងទៅនឹងការធ្វេសប្រហែសផ្នែកសីលធម៌នៅក្នុងពួកជំនុំ ។ គាត់បានព្រមានដល់ពួកគេថា មិនត្រូវមានការទាក់ទងនឹងពួកអ្នកដែលប្រព្រឹត្តអំពើផិតក្បត់ទេ (៥:៩)។ ម្យ៉ាងទៀត ដោយព្រោះតែមានការយល់ច្រឡំចំពោះសេចក្តីដែលគាត់បានសរសេរទៅកាន់ពួកគេទើបធ្វើឱ្យគាត់ធ្វើការបញ្ជាក់ជាថ្មីម្តងទៀត (៥:១០-១១) និងធ្វើការព្រមានយ៉ាងធ្ងន់ៗ និងជាបន្ទាន់ ចំពោះសកម្មភាពខុសឆ្គងរបស់ពួកគេ (៥:៣-៥,១៣)។

មានពួកអ្នកដំណើរមកឯទីក្រុងកូរិនថូស បាននាំយកសំបុត្រដែលមានកត់ត្រានូវសំណួរផ្សេងៗពីពួកជំនុំនៅទីក្រុងកូរិនថូសមកឯលោកប៉ុលដើម្បីសូមនូវការប្រឹក្សាយោបល់ផ្សេងៗអំពីគាត់ (៨:១ ១២:១ ១៦:១ មើលការពន្យល់ ៧:១)។

ទោះជាក្នុងបទគម្ពីរបានបញ្ជាក់ថា ពួកជំនុំនៅទីក្រុងកូរិនថូសបានទទួលនូវអំណោយទានជាច្រើនយ៉ាងណាក៏ដោយ (១:៤-៧) ក៏ពួកគេនៅតែមិនទាន់បានពេញវ័យខាងឯវិញ្ញាណនៅឡើយទេ (៣:១-៤)។ គោលបំណងនៃការសរសេររបស់លោកប៉ុលគឺ (១).ដើម្បីបង្រៀន និង កែតម្រង់ពួកជំនុំត្រង់ចំណុចខ្សោយរបស់ពួកគេ ហើយនិងកែតម្រូវកំហុសទាំងឡាយដែលមានដូចជាការបាក់បែក (១:១០-៤:២១) អំពើផិតក្បត់ (ជំពូក ៥,៦:១២-២០) ការប្តឹងប្តល់នៅក្នុងទីជម្រះក្តីរបស់សាសន៍ដទៃ (៦:១-៨) និងការភាន់ច្រឡំចំពោះពិធីលៀងព្រះអម្ចាស់ (១១:១៧-៣៤)។ (២).ដើម្បីកែតម្រង់នូវសេចក្តីបង្រៀនខុសឆ្គងស្តីអំពីការរស់ឡើងវិញ (ជំពូក ១៥)។ (៣).ដើម្បីឆ្លើយតបទៅនឹងសំណួរផ្សេងៗរបស់ពួកជំនុំ ដែលបានសួរដល់គាត់ ។

**គោលរឿង**

គោលរឿងសំខាន់នៅក្នុងសំបុត្រនេះ គឺនិយាយផ្តោតទៅលើការប្រព្រឹត្តិ និងបញ្ហាដែលកើតមានឡើងនៅក្នុងពួកជំនុំនៅទីក្រុងកូរិនថូស ។ ការចម្រើនឡើងនៃការញែកជាបរិសុទ្ធ និងការលូតលាស់នូវចរិតលក្ខណៈបរិសុទ្ធរបស់ពួកគេក៏ត្រូវបានលើកឡើងគួរឱ្យកត់សម្គាល់ ។ ម្យ៉ាងទៀត តាមស្ថានភាពជាក់ស្តែង លោកប៉ុលមានការបារម្ភអំពីបញ្ហារបស់ពួកជំនុំនៅទីក្រុងកូរិនថូសតែម្តងដូច្នេះបញ្ជាក់ថាគាត់ក៏មាននាទីជាអ្នកគង្វាលដល់ពួកគេផងដែរ ។

**ទំនាក់ទំនង**

សំបុត្រនេះនៅតែមានសារៈសំខាន់ចំពោះពួកជំនុំនាពេលបច្ចុប្បន្នសម្រាប់ការបង្រៀននិងការទូន្មាន។ គ្រីស្ទបរិស័ទនៅតែទទួលឥទ្ធិពលពីបរិស្ថានវប្បធម៌ ក្នុងតំបន់ដែលខ្លួនកំពុងរស់នៅ ។ សំណួរ និងបញ្ហាទាំងឡាយ ដែលពួកជំនុំនៅទីក្រុងកូរិនថូសបានសួរទៅលោកប៉ុលនៅតែបន្តកើតឡើងចំពោះពួកជំនុំនាពេលបច្ចុប្បន្ន រួមមានបញ្ហាដែលទាក់ទងទៅនឹងការមិនពេញវ័យខាងឯវិញ្ញាណ ការគ្មានស្នេហភាព ការបែកបាក់ ការច្រណែន កំហឹង ការប្តឹងប្តល់ ការរៀបការ អំពើផិតក្បត់ និងការប្រើប្រាស់មិនបានត្រឹមត្រូវនូវអំណោយទានខាងឯវិញ្ញាណ ។

**គម្រោងសង្ខេប**

**I. សេចក្តីផ្តើម (១:១-៩)**

**II. ការបែកបាក់នៅក្នុងពួកជំនុំ (១:១០-៤:២១)**

ក. កត្តានៃការបែកបាក់ (១:១០-១៧)

ខ. មូលហេតុដែលនាំឱ្យមានការបែកបាក់ (១:១៨-៤:១៣)

១. ការយល់ខុសអំពីសេចក្តីបង្រៀនរបស់គ្រីស្ទបរិស័ទ (១:១៨-៣:៤)

២. ការយល់ខុសអំពីបេសកកម្ម និងបេសកជនរបស់គ្រីស្ទបរិស័ទ (៣:៥-៤:៥)

៣. ការយល់ខុសរបស់គ្រីស្ទបរិស័ទ (៤:៦-១៣)

គ. សេចក្តីដាស់តឿនចំពោះការបែកបាក់ (៤:១៤-២១)

**III. ភាពគ្មានសណ្តាប់ធ្នាប់នៃសីលធម៌ និងសុជីវធម៌នៅក្នុងជីវិតរបស់ពួកជំនុំ (ជំពូក ៥–៦)**

ក. ភាពធូររលុងខាងវិន័យក្នុងពួកជំនុំ (ជំពូក ៥)

ខ. ការប្តឹងប្តល់នៅមុខពួកអ្នកមិនជឿ (៦:១–១១)

គ. អំពើផិតក្បត់ (៦:១២–២០)

**IV. សេចក្តីបង្រៀនអំពីការរៀបការ (ជំពូក ៧)**

ក. គោលការទូទៅ (៧:១–៧)

ខ. បញ្ហារវាងប្តី និងប្រពន្ធ (៧:៨–២៤)

គ. បញ្ហាទាក់ទងនឹងអ្នកដែលមិនរៀបការ (៧:២៥–៤០)

**V. សេចក្តីបង្រៀនចំពោះការអនុវត្តន៍ផ្សេងៗ (៨:១–១១:១)**

ក. គោលការសំខាន់ៗដែលទាក់ទង (ជំពូក ៨)

ខ. គោលការសំខាន់ៗដែលត្រូវបង្ហាញ (ជំពូក ៩)

គ. ការព្រមានអំពីប្រវត្តិសាស្ត្រអ៊ីស្រាអែល (១០:១–២២)

ឃ. គោលការអនុវត្តន៍ (១០:២៣–១១:១)

**VI. សេចក្តីបង្រៀនអំពីការថ្វាយបង្គំនៅទីសាធារណៈ (១១:២–១៤:៤០)**

ក. ភាពសមរម្យនៃការថ្វាយបង្គំ (១១:២–១៦)

ខ. ពិធីលៀងព្រះអម្ចាស់ (១១:១៧–៣៤)

គ. អំណោយទានខាងឯវិញ្ញាណ (១២–១៤)

១. ការពិសោធន៍នៃអំណោយទាន (១២:១–៣)

២. ការរួបរួមនៃអំណោយទាន (១២:៤–១១)

៣. ភាពផ្សេងៗនៃអំណោយទាន (១២:១២–៣១ក)

៤. សារៈសំខាន់នៃការហ្វឹកហាត់អំណោយទានដោយសេចក្តីស្រឡាញ់ (១២:៣១ខ–១៣:១៣)

៥. ការថ្លែងទំនាយ ការអធិប្បាយ និងការនិយាយភាសាដទៃ (១៤:១–២៥)

៦. ការគ្រប់គ្រងការថ្វាយបង្គំនៅទីសាធារណៈ (១៤:២៦–៤០)

**VII. សេចក្តីបង្រៀនអំពីការរស់ឡើងវិញ (ជំពូក ១៥)**

ក. សេចក្តីពិតអំពីការរស់ឡើងវិញ (១៥:១–៣៤)

ខ. ការពិចារណារលើការប្រឆាំងផ្សេងៗ (១៥:៣៥–៥៧)

គ. ការសរុបសេចក្តី (១៥:៥៨)

**VIII. សេចក្តីសន្និដ្ឋានៈ រឿងរ៉ាវផ្ទាល់ខ្លួន និងការអនុវត្តន៍ (ជំពូក ១៦)**

**១** ១សំបុត្រប៉ុលខ្ញុំ ជាអ្នកដែលព្រះយេស៊ូវគ្រីស្ទ បានហៅ
មកធ្វើជាសាវក[ក] របស់ទ្រង់ តាមបំណងព្រះហឫទ័យព្រះ[ខ]
ព្រមទាំងសូស្ថេន[គ] ជាពួកបងប្អូន ២ផ្ញើមកពួកជំនុំនៃព្រះ[ឃ]
នៅក្រុងកូរិនថូស[ង] ជាពួកអ្នកដែលបានញែកចេញជា
បរិសុទ្ធ ក្នុងព្រះគ្រីស្ទយេស៊ូវ បានទាំងហៅ[ច]មកធ្វើជាពួក
បរិសុទ្ធ ជាមួយនឹងអស់អ្នកនៅគ្រប់ទីកន្លែង ដែលអំពាវនាវ
ដល់ព្រះនាម[ឆ] នៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង
រាល់គ្នា គឺនៃគេ និងយើងផង ៣សូមឱ្យអ្នករាល់គ្នាបាន
ប្រកបដោយនូវព្រះគុណ និងសេចក្ដីសុខសាន្ត អំពីព្រះដ៏ជា
ព្រះវរបិតានៃយើងរាល់គ្នា និងពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ
ផង[ជ]។

## ការអរព្រះគុណ

៤ខ្ញុំអរព្រះគុណដល់ព្រះនៃខ្ញុំ អំពីដំណើរអ្នករាល់គ្នា[ឈ]
ជាដរាប ដោយព្រោះព្រះគុណនៃព្រះ ដែលបានផ្ដល់មក
អ្នករាល់គ្នា ក្នុងព្រះគ្រីស្ទយេស៊ូវ ៥ព្រោះអ្នករាល់គ្នាបាន
ចំរើនឡើងគ្រប់ចំពូក[ញ] ដោយសារទ្រង់ គឺក្នុងគ្រប់ទាំង
ពាក្យសំដី និងចំណេះទាំងអស់ដែរ[ដ] ៦តាមដែលសេចក្ដី
បន្ទាល់[ឋ] ពីព្រះគ្រីស្ទបានបញ្ជាក់ក្នុងពួកអ្នករាល់គ្នា ៧ដល់
ម្ល៉េះ បានជាអ្នករាល់គ្នាមិនចាញ់គេ ខាងឯអំណោយទាន
ណាមួយឡើយ[ឌ] ទាំងចាំទំរាំព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់
នៃយើងរាល់គ្នា លេចមកផង[ឍ] ៨ដែលទ្រង់នឹងតាំងអ្នក
រាល់គ្នាឱ្យខ្ជាប់ខ្ជួន ដរាបដល់ចុងបំផុត ឱ្យបានឥតកន្លែង
បន្ទោសបាន[ណ] ក្នុងថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ[ត] ជាព្រះអម្ចាស់
នៃយើង ៩ឯព្រះដែលបានហៅអ្នករាល់គ្នា[ថ]មក ឱ្យមាន
សេចក្ដីប្រកប នឹងព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ
ជាព្រះអម្ចាស់[ទ]នៃយើង នោះទ្រង់ស្មោះត្រង់[ធ]។

## ការបែកបាក់ក្នុងពួកជំនុំ

១០ឥឡូវនេះ បងប្អូនអើយ[ន] ខ្ញុំទូន្មានដល់អ្នករាល់គ្នា
ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង
ថា ចូរនិយាយសេចក្ដីដដែលទាំងអស់គ្នា កុំឱ្យមានសេចក្ដី
បាក់បែកក្នុងពួកអ្នករាល់គ្នាឡើយ[ប] ត្រូវឱ្យបានរួបរួមគ្នា[ផ]
ដោយមានចិត្តមានគំនិតតែ១វិញ ១១ឱបងប្អូនអើយ ពីព្រោះ
មានពួកអ្នកផ្ទះ[ព]នាងខ្លូអេបានប្រាប់ខ្ញុំ ពីដំណើរអ្នករាល់គ្នា
ថា តែងតែមានសេចក្ដីឈ្លោះប្រកែក ក្នុងពួកអ្នករាល់គ្នា
១២គឺថា អ្នករាល់គ្នានិមួយៗប្រកាន់ថា ខ្លួនជាសិស្សរបស់

**១:១** ក រម ១:១ អភ ១:១ ២ធថ ១:១ ខ ២កថ ១:១ គ កច ១៨:១៧ **១:២** ឃ ១កថ ១០:៣២ ង កច ១៨:១ ច រម ១:៧ ឆ កច ២:២១ **១:៣** ជ រម ១:៧ **១:៤** ឈ រម ១:៨ **១:៥** ញ ២កថ ៩:១១ ដ ២កថ ៨:៧ **១:៦** ឋ ២ថន ១:១០ ១ធថ ២:៦ វវ ១:២ **១:៧** ឌ រម ១:១១ ១កថ ១២:១–៣១ ឍ មថ ១៦:២៧ លក ១៧:៣០ ១ថន ១:១០ ២:១៩ ទត ២:១៣ យក ៥:៧,៨ ១ពត ១:១៣ ២ពត ៣:១២ វវ ១:៧ **១:៨** ណ ១ថន ៣:១៣ ត អម ៥:១៨ ១កថ ៥:៥

ភល ១:៦,១០ ២:១៦ ១ថន ៥:២ **១:៩** ថ រម ៨:២៨ ទ ១យហ ១:៣ ធ ចទ ៧:៩ អស ៤៩:៧ ១កថ ១០:១៣ ១ថន ៥:២៤ ២ថន ៣:៣ ២ធថ ២:១៣ ហព ១០:២៣ ១១:១១ **១:១០** ន រម ៧:១ ប ១កថ ១១:១៨ ផ រម ១៥:៥ **១:១១** ព កថ ១១:១៤

**១:១** *ប៉ុល* (មើលការពន្យល់ រម ១:១)។ *ជាសាវករបស់ទ្រង់* (មើលការពន្យល់ មក ៦:៣០ ហព ៣:១)។ នៅក្នុងសំបុត្រទាំងអស់របស់សាវកប៉ុល គឺសុទ្ធ តែមានប្រើងារថា "សាវក ឬសិស្សរបស់ព្រះគ្រីស្ទ" ឬក៏ "ទូតរបស់ព្រះគ្រីស្ទ" (ខ.៩ ២កថ ១១)។ លោកប៉ុលបានបញ្ជាក់យ៉ាងច្បាស់ថា អំណាច ដែលព្រះអម្ចាស់បានប្រទានមកគាត់គឺជា "បំណងព្រះហឫទ័យទ្រង់" (១៥:៩–១១ កច ៩:១–១៦ ១៣:២ ១៨:៩–១០ ២២:៦–២១ ២៦:១២–១៨)។ *សូស្ថេន* គាត់ប្រហែលជាអ្នកដឹកនាំសាលាប្រជុំនៅទីក្រុងកូរិនថូស ដែលទទួលការបៀតបៀនពីសំណាក់ពួកសាសន៍ក្រេក (កច ១៨:១៧)។ ប្រសិនបើគាត់ជាអ្នកដឹកនាំនោះមែន ដូច្នេះអាចសន្និដ្ឋានបានថា គាត់ប្រហែលជាបានទទួលជឿដល់ព្រះអម្ចាស់ក្នុងពេលដែល លោកប៉ុលបានផ្សាយព្រះបន្ទូលនៅឯទីក្រុងកូរិនថូស (កច ១៨:១៨) និងជាពេល ដែលលោកអ័ប៉ុឡូស កំពុងបម្រើការងារនៅក្នុងទីក្រុងនោះតែម្ដង (កច ១៩:១)។

**១:២** *ពួកជំនុំនៃព្រះ* មានតែលោកប៉ុលម្នាក់ប៉ុណ្ណោះដែលប្រើពាក្យនេះ (កច ២០:២៨ ២កថ ១:១)។ នៅក្នុងសញ្ញាចាស់ប្រើពាក្យថា "ពួកជំនុំនៃព្រះយេហូវ៉ា" (ចទ ២៣:១)។ *ដែលបានញែកចេញជាបរិសុទ្ធ ក្នុងព្រះគ្រីស្ទយេស៊ូវ* ត្រង់ចំណុចនេះបញ្ជាក់ថា អស់អ្នកដែលទទួលជឿដល់ព្រះនាមព្រះអម្ចាស់ នោះត្រូវបានញែកជាបរិសុទ្ធ (មើលការពន្យល់ យហ ១៧:១៧,១៩) សម្រាប់ព្រះរាជកិច្ចរបស់ទ្រង់ ។ ម្យ៉ាងទៀត គឺឱ្យពួកគេប្រកាន់ខ្ជាប់នូវភាពបរិសុទ្ធនេះនៅក្នុងជីវិតរបស់ពួកគេ (នក ៣:៥ ១៩:៦ លវ ១១:៤៤ រម ៦:២២ និងការពន្យល់)។ *នៅគ្រប់ទីកន្លែង* មើលការពន្យល់ ១ធថ ១:៨ ។

**១:៣** *ព្រះគុណ និងសេចក្ដីសុខសាន្ត* (មើលការពន្យល់ រម ១:៧)។

**១:៤** *អរព្រះគុណ* (មើលការពន្យល់ រម ១:៨)។

**១:៥** *ពាក្យសំដី និងចំណេះ* គឺសំដៅលើអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ (១២:៨–១០ និងការពន្យល់ ២កថ ៨:៧)។

**១:៦** ពួកជំនុំនៅឯទីក្រុងកូរិនថូស បានទទួលជឿព្រះបន្ទូលនៃដំណឹងល្អតាមរយៈលោកប៉ុល ហើយសេចក្ដីជំនឿរបស់ពួកគេបានបង្ហាញយ៉ាងច្បាស់ដោយជីវិត របស់ពួកគេបានផ្លាស់ប្រែ ។

**១:៧** *អំណោយទានណាមួយ* ពាក្យថា "អំណោយទាន" ត្រង់ចំណុចនេះ សំដៅលើអំណោយទានខាងឯវិញ្ញាណ (ជំពូក ១២–១៤)។ ព្រះវិញ្ញាណបរិសុទ្ធប្រទានឱ្យអ្នកជឿដល់ព្រះនាមព្រះអម្ចាស់ នូវអំណោយទានខាងឯវិញ្ញាណ (១២:៧–១១ ១៤:៣,១២,១៧)។ ម្យ៉ាងទៀតពាក្យថា "អំណោយទាន" នៅត្រង់ចំណុចនេះ ព្រះគម្ពីរបរិសុទ្ធជាភាសាក្រិកសង្កត់ធ្ងន់លើ "អំណោយទាននៃព្រះគុណ"។

**១:៨** *ទ្រង់* ពាក្យនេះគឺជាសព្វនាមដែលសំដៅលើព្រះវរបិតា (ខ.៩)។ *ចុងបំផុត* សំដៅលើពេលវេលាដែលព្រះយេស៊ូវគ្រីស្ទយាងមកជាលើកទីពីរ ។ *ក្នុងថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ* គឺថ្ងៃដែលទ្រង់យាងមកជាលើកទីពីរ (ខ.៧ ភល ១:៦ និងការពន្យល់)។

**១:៩** *ព្រះ... ទ្រង់ស្មោះត្រង់* មានន័យថា ព្រះអម្ចាស់ស្មោះត្រង់ចំពោះព្រះបន្ទូលសន្យារបស់ទ្រង់ជានិច្ច (ខ.៨ ១ថន ៥:២៤ និងការពន្យល់)។

**១:១០** *បងប្អូន* (មើលការពន្យល់ រម ១:១៣)។

**១:១១** *សេចក្ដីឈ្លោះប្រកែក* (កទ ៥:២០ យក ៤:១–២)។

**១:១២** *អ័ប៉ុឡូស* គាត់បានបន្តការងារបម្រើព្រះអម្ចាស់ នៅឯទីក្រុងកូរិនថូស

ប៉ុល[ភ] ជារបស់អ័ប៉ូឡូស[ម] ជារបស់កេផាស[យ] ឬជារបស់
ព្រះគ្រីស្ទ ។ ១៣ដូច្នេះ តើព្រះគ្រីស្ទបានបាក់បែកឬអី តើប៉ុល
ត្រូវឆ្កាងជំនួសអ្នករាល់គ្នាឬអី តើអ្នករាល់គ្នាបានទទួល
បុណ្យជ្រមុជដោយនូវឈ្មោះប៉ុលឬអី[រ] ១៤ខ្ញុំអរព្រះគុណដល់
ព្រះថា ខ្ញុំមិនបានធ្វើបុណ្យជ្រមុជឱ្យអ្នកណាមួយក្នុងពួកអ្នក
រាល់គ្នាទេ បានធ្វើឱ្យតែគ្រីសប៉ុស[ល] និងកៃយុស[វ] ប៉ុណ្ណោះ
១៥ដើម្បីកុំឱ្យមានអ្នកណាប្រកាន់ថា ខ្ញុំបានធ្វើបុណ្យជ្រមុជ
ដោយនូវឈ្មោះខ្ញុំនោះឡើយ ១៦ខ្ញុំក៏បានធ្វើបុណ្យជ្រមុជ
ឱ្យពួកផ្ទះ[ស] ស្ទេផានាស[ហ]ដែរ តែឯមនុស្សឯទៀត ខ្ញុំមិនដឹង
ជាបានធ្វើបុណ្យជ្រមុជឱ្យអ្នកណាទេ ១៧ដ្បិតព្រះគ្រីស្ទមិន
បានចាត់ខ្ញុំឱ្យមកធ្វើបុណ្យជ្រមុជទឹកទេ[ឡ] គឺឱ្យមកផ្សាយ
ដំណឹងល្អប៉ុណ្ណោះ តែមិនមែនដោយពាក្យឧត្តុង្គឧត្តមឡើយ[អ]
ក្រែងឈើឆ្កាង នៃព្រះគ្រីស្ទទៅជាអសារឥតការវិញ ។

## ប្រាជ្ញា និងព្រះចេស្ដានៃព្រះអម្ចាស់

១៨ដ្បិតដំណឹងពីឈើឆ្កាង នោះជាសេចក្ដីចំកួត[ក]ដល់អស់
អ្នកដែលកំពុងតែវិនាស[ខ] តែជាព្រះចេស្ដា[គ]នៃព្រះដល់យើង
រាល់គ្នា ដែលកំពុងតែបានសង្គ្រោះ[ឃ]វិញ ១៩ព្រោះមាន
សេចក្ដីចែងទុកមកថា «អញនឹងបំផ្លាញប្រាជ្ញារបស់ពួកអ្នក
ប្រាជ្ញ ហើយនិងលើកចំណេះ របស់ពួកអ្នកដែលចេះចោល
ចេញ»[ង] ២០តើអ្នកប្រាជ្ញនៅឯណា[ច] តើអាចារ្យនៅឯ
ណា តើអ្នកដេញដោលនៃសម័យនេះនៅឯណា[ឆ] ព្រះទ្រង់
បានធ្វើឱ្យប្រាជ្ញារបស់លោកីយនេះ ទៅជាសេចក្ដីល្ងង់ល្ងើ
វិញទេតើ[ជ] ២១ដ្បិតដោយព្រោះព្រះទ្រង់បានសំរេចតាម
ប្រាជ្ញានៃទ្រង់ថា មនុស្សលោក[ឈ] នឹងរកស្គាល់ព្រះដោយ
អាងប្រាជ្ញាខ្លួនមិនបានទេ បានជាទ្រង់សព្វព្រះហឫទ័យ

**១:១២** ភ ១កថ ៣:៤,២២ ម កច ១៨:២៤ យ យហ ១:៤២ ១កថ ៣:២២ ៩:៥ **១:១៣** រ មថ ២៨:១៩ **១:១៤** ល កច ១៨:៨ វ កច ១៩:២៩ **១:១៦** ស កច ១១:១៤ ហ ១កថ ១៦:១៥ **១:១៧** ឡ យហ ៤:២ កច ២:៣៨ អ ១កថ ២:១,៤,១៣ **១:១៨** ក ខ.២១,២៣,២៥ ១កថ ២:១៤ ខ ២កថ ២:១៥ ៤:៣ ២ថន ២:១០ គ កច ២:៤៧ ឃ ខ.២៤ រម ១:១៦

**១:១៩** ង អស ១៩:១១ **១:២០** ច អស ១៩:១១,១២ ឆ ១កថ ២:៦,៨ ៣:១៨ ២កថ ៤:៤ កទ ១:៤ ជ ខ.២៧ យប ១២:១៧ អស ៤៤:២៥ យរ ៨:៩ រម ១:២២ ១កថ ៣:១៨,១៩ **១:២១** ឈ ខ.២៧:២៨ ១កថ ៦:២ ១១:៣២ ញ រម ១១:១៤

ប្រកបដោយផលផ្លែ (កច ១៨:២៤–២៨ ១៩:១) ។ *កេផាស* គឺជាឈ្មោះដែលព្រះយេស៊ូវបានប្រទានដល់លោកស៊ីម៉ូន (យហ ១:៤២ និងការពន្យល់) ។ ពាក្យថា "កេផាស" ជាភាសាអារ៉ាម (១ពវ ១៨:២៦) មានន័យថា "ថ្ម" រីឯនៅក្នុងភាសាក្រិកវិញសរសេរថា "ពេត្រុស" ។ ពួកអ្នកដើរតាមលោកកេផាសនៅក្រុងកូរិនថូស ប្រហែលជាមានដើមកំណើតជាសាសន៍យូដា និងបានទទួលជឿដល់ព្រះអម្ចាស់ ។

**១:១៣** *តើព្រះគ្រីស្ទបានបាក់បែកឬអី?* (មើលការពន្យល់ ១២:១២–១៣) ។ *ទទួលបុណ្យជ្រមុជ* (សូមប្រៀបធៀបនឹង រម ៦:៣–៤ និងការពន្យល់) ។

**១:១៤** *គ្រីសប៉ុស* ប្រហែលជាអ្នកដឹកនាំសាលាប្រជុំម្នាក់ ដែលបានលើកឡើងនៅក្នុងព្រះគម្ពីរ "កច ១៨:៨" ។ *កៃយុស* គាត់ប្រហែលជាលោកកៃយ៉ុសដែល បានលើកឡើងនៅក្នុងព្រះគម្ពីរ "រម ១៦:២៣" នោះតែម្ដង ។

**១:១៦** *ពួកផ្ទះ* ពាក្យថា "ពួកផ្ទះ" ត្រង់ចំណុចនេះ សំដៅលើពួកអ្នកដែលរស់នៅក្នុងគ្រួសារលោកកូនេលាស (កច ១០:២៤,៤៨) គ្រួសារនាងលីឌា (កច ១៦:១៥) និងគ្រួសារលោកមេភូឃុំនៅឯទីក្រុងភីលីព (កច ១៦:៣៣–៣៤) ។ ម្យ៉ាងទៀត ពាក្យនេះប្រហែលជារាប់បញ្ចូលទាំង សមាជិកគ្រួសារអ្នកបម្រើ និងពួកអ្នករស់នៅក្នុងផ្ទះទាំងនោះតែម្ដង (លប ១៧:១២,១៣,២៣) ។ *ពួកផ្ទះស្ទេផានាស* (មើលការពន្យល់ ១៦:១៥) ។

**១:១៧** *មិន . . . ធ្វើបុណ្យជ្រមុជទឹកទេ* ត្រង់ចំណុចនេះលោកប៉ុលបញ្ជាក់យ៉ាងច្បាស់ថា ការងារដ៏សំខាន់បំផុតដែលព្រះអម្ចាស់បានត្រាស់ហៅឱ្យគាត់ធ្វើគឺការផ្សាយដំណឹងល្អ ប៉ុន្តែ ពុំមានន័យថា ការធ្វើពិធីបុណ្យជ្រមុជទឹកមិនសំខាន់នោះទេ ។ ព្រះយេស៊ូវពុំបានធ្វើបុណ្យជ្រមុជទឹកឱ្យអ្នកណាម្នាក់ទេ ប៉ុន្តែ ទ្រង់បង្គាប់ឱ្យពួកសិស្សរបស់ទ្រង់ជាអ្នកធ្វើវិញ (យហ ៤:២) ។ រីឯលោកពេត្រុសវិញ ពេលខ្លះគាត់បង្គាប់ឱ្យអ្នកដទៃធ្វើបុណ្យជ្រមុជទឹកដល់អ្នកជឿមួយចំនួនផងដែរ (កច ១០:៤៨) ។ *មិនមែនដោយពាក្យឧត្តុង្គឧត្តមឡើយ* មានន័យថា លោកប៉ុលពុំបានប្រើវោហារ ក្នុងគោលបំណងចង់ឱ្យគេសរសើរថា គាត់ជាមនុស្សមានប្រាជ្ញានោះឡើយ ។ ពួកគ្រូក្រិត្យវិន័យសាសន៍យូដា និងពួកទស្សនវិទូក្រិកបានបង្កើតឡើងនូវវិធីសាស្ត្រពិសេសៗ ដើម្បីបញ្ចុះបញ្ចូលពួកបណ្ដាជន ។ ផ្ទុយទៅវិញ លោកប៉ុលមិនបានប្រើប្រាស់ពាក្យពេចន៍តាមវិធីសាស្ត្រទាំងនោះ នៅក្នុងការផ្សាយដំណឹងល្អទេ ។ ការដែលគាត់ធ្វើយ៉ាងដូច្នោះ គឺគាត់ចង់ឱ្យពួកអ្នកដែលស្ដាប់គាត់មានការប៉ះពាល់ចិត្ត ដោយព្រះបន្ទូលមិនមែនដោយសារបែបបទនៃការប្រើប្រាស់ពាក្យពេចន៍នោះឡើយ (១កថ ២:១–៥) ។ ម្យ៉ាងទៀតលោកប៉ុលមិនបាននិយាយប្រឆាំងនឹងពួកអ្នក ដែលចេះរៀបចំដោយប្រុងប្រយ័ត្ននូវសេចក្ដីដែលពួកគេត្រូវនិយាយនោះឡើយ (១កថ ២:៦) ប៉ុន្តែ គាត់ប្រឆាំងនឹងពួកអ្នកដែលព្យាយាមធ្វើឱ្យអ្នកដទៃមានការប៉ះពាល់ចិត្ត ដោយសារចំណេះដឹង និងសមត្ថភាពរបស់ខ្លួនប៉ុណ្ណោះ ។ *ក្រែងឈើឆ្កាងនៃព្រះគ្រីស្ទទៅជាអសារឥតការ* មានន័យថា លោកប៉ុលមិនបានពឹង អាងលើសមត្ថភាពរបស់ខ្លួននៅក្នុងការផ្សាយដំណឹងល្អទេ គឺគាត់ពឹងអាងដល់ព្រះអម្ចាស់វិញ ។

**១:១៩** លោកប៉ុលបានប្រើបទគម្ពីរ "អស ២៩:១៤" ដើម្បីបញ្ជាក់ថា ផ្លូវរបស់ព្រះគឺខុសពីផ្លូវរបស់លោកីយ ។ *ពួកអ្នកប្រាជ្ញ* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកអ្នកដែលរស់នៅក្នុងទីក្រុងកូរិនថូសយល់ឃើញថា មានពួកអ្នកប្រាជ្ញដែលអាចដោះស្រាយ នូវបញ្ហាផ្សេងៗរបស់ពួកគេ ។

**១:២០** *អ្នកប្រាជ្ញ* ពាក្យនេះជាទូទៅសំដៅលើពួកទស្សនវិទូដែលជាសាសន៍ដទៃ ។ *អាចារ្យ* ប្រហែលជាសំដៅលើពួកគ្រូក្រឹត្យវិន័យសាសន៍យូដា (មើលការពន្យល់ មថ ២:៤) ។ *អ្នកដេញដោល* ត្រង់ចំណុចនេះអាចសំដៅលើពួកទស្សនវិទូក្រិក ។ *ព្រះទ្រង់បានធ្វើឱ្យប្រាជ្ញារបស់លោកីយនេះ ទៅជាសេចក្ដីល្ងង់ល្ងើ* ឃ្លានេះបញ្ជាក់ថា គ្រប់ប្រព័ន្ធទស្សនវិជ្ជា និងមនោគមវិជ្ជាដែលមនុស្សបង្កើតឡើងត្រូវបញ្ចប់ដោយគ្មានន័យ ព្រោះថាប្រព័ន្ធទាំងអស់នេះបាននាំឱ្យមនុស្សទាស់ប្រឆាំង នឹងព្រះអម្ចាស់ និងគិតខុសចំពោះទ្រង់ ។

**១:២១** *ប្រាជ្ញា . . . សេចក្ដីល្ងង់ល្ងើ* ព្រះបន្ទូលនៅត្រង់ចំណុចនេះ មានលក្ខណៈ ដូចគ្នាទៅនឹងព្រះបន្ទូលនៅក្នុងបទគម្ពីរ "លក ១០:២១" ដែរ ។ មនុស្សមិនអាចស្គាល់ព្រះអម្ចាស់ដោយពឹងអាង ឬដោយប្រើប្រាជ្ញារបស់ខ្លួនឡើយ ។ *សេចក្ដីល្ងង់ល្ងើវិញ គឺជាការប្រកាសដំណឹងល្អ* ត្រង់ចំណុចនេះពុំមានន័យថា ការប្រកាសដំណឹងល្អជាការល្ងង់ល្ងើនោះទេ ប៉ុន្តែ គឺលោកីយ

នឹងជួយសង្គ្រោះ[ញ] អស់អ្នកដែលជឿ[ដ] ដោយសារសេចក្តី
ល្ងង់ល្ងើវិញ គឺជាការប្រកាសដំណឹងល្អ ២២ពីព្រោះសាសន៍
យូដា គេចង់ឃើញភស្តុតាង[ឋ] ហើយសាសន៍ក្រេក គេស្វែង
រកប្រាជ្ញា ២៣តែយើងខ្ញុំប្រកាសប្រាប់ពីព្រះគ្រីស្ទដែល
ទ្រង់ត្រូវឆ្កាងវិញ[ឌ] ជាហេតុនាំឱ្យរវាតចិត្ត[ឍ] ដល់សាសន៍
យូដា នឹងជាសេចក្តី ល្ងង់ល្ងើ[ណ]ដល់សាសន៍ក្រេក ២៤តែ
ព្រះគ្រីស្ទ ទ្រង់ជាព្រះចេស្តា[ត] ហើយជាប្រាជ្ញា[ថ]របស់ព្រះវិញ
ដល់អស់អ្នកដែលទ្រង់ហៅ[ទ] ទាំងសាសន៍យូដា ហើយនឹង
សាសន៍ក្រេកផង ២៥ដ្បិតសេចក្តីល្ងង់ល្ងើ[ធ]របស់ព្រះ
នោះមានប្រាជ្ញា លើសជាងមនុស្ស ហើយសេចក្តីកំសោយ[ន]
របស់ព្រះ ក៏មានកំឡាំងលើសជាង មនុស្សដែរ ។
២៦ឱបងប្អូនអើយ អ្នករាល់គ្នាឃើញថា ក្នុងពួកអ្នក
ដែលទ្រង់បានហៅ[ប] មិនសូវមានអ្នកប្រាជ្ញ[ផ]ច្រើន ខាងឯ
សាច់ឈាម ឬច្រើននាក់មានអំណាច និងច្រើននាក់ដែល
មានត្រកូលខ្ពស់នោះទេ ២៧ព្រះទ្រង់បានរើស[ព]ពួកល្ងង់ល្ងើ[ភ]
នៅលោកិយនេះ ដើម្បីនឹងធ្វើឱ្យអ្នកប្រាជ្ញ មានសេចក្តីខ្មាស
វិញ ទ្រង់បានរើសពួកកំសោយនៅលោកីយនេះ ដើម្បីនឹង
ធ្វើឱ្យពួកខ្លាំងពូកែមានសេចក្តីខ្មាស ២៨ហើយទ្រង់បាន
រើសអ្នកទាបថោក នៅលោកិយនេះ និងពួកអ្នកដែល
គេមើលងាយ ព្រមទាំងរបស់ដែលគ្មានផង[ម] ដើម្បីនឹង
លើកចោលរបស់ដែលមានចេញ ២៩ប្រយោជន៍កុំឱ្យមនុស្ស
ណាបានអួតខ្លួន នៅចំពោះព្រះឡើយ ៣០តែដោយសារ
ព្រះ នោះអ្នករាល់គ្នានៅក្នុងព្រះគ្រីស្ទយេស៊ូវ[យ] ដែលទ្រង់
បានតាំងឡើង ទុកជាប្រាជ្ញា ដែលមកពីព្រះ ហើយជា
សេចក្តីសុចរិត[រ] សេចក្តីបរិសុទ្ធ[ល] និងសេចក្តីប្រោសលោះ[វ]
ដល់យើងផង ៣១ដើម្បីឱ្យបានត្រូវនឹងសេចក្តីដែលចែង
ទុកមកថា «អ្នកណាដែលអួត ត្រូវអួតតែពីព្រះអម្ចាស់
ប៉ុណ្ណោះ»[ស] ។

**២** ១រីឯខ្ញុំ បងប្អូនអើយ កាលខ្ញុំបានមកឯអ្នករាល់គ្នា នោះ
មិនបានមកដោយប្រើវោហារ ឬប្រាជ្ញាដ៏ឧត្តម[ហ] ដើម្បីនឹង
ប្រាប់សេចក្តីបន្ទាល់ពីព្រះដល់អ្នករាល់គ្នាទេ ២ដ្បិតខ្ញុំបាន
ផ្តាច់ចិត្តថា នៅក្នុងពួកអ្នករាល់គ្នា នោះខ្ញុំមិនព្រមស្គាល់
រឿងអ្វីទៀត ក្រៅពីព្រះយេស៊ូវគ្រីស្ទទេ ហើយគឺដែលទ្រង់
ត្រូវឆ្កាងផង[ឡ] ៣ខ្ញុំក៏បាននៅជាមួយនឹងអ្នករាល់គ្នា[អ] ទាំង

**១:២១** ដ រម ៣:២២ **១:២២** ឋ មថ ១២:៣៨ យហ ២:១១ ៤:៤៨ **១:២៣** ឌ ១កថ ២:២ កទ ៣:១ ឍ លក ២:៣៤ ណ ខ.១៨ **១:២៤** ត ខ.១៨ រម ១:១៦ ថ ខ.៣០ កល ២:៣ ទ រម ៨:២៨ **១:២៥** ធ ខ.១៨ ន ២កថ ១៣:៤ **១:២៦** ប រម ៨:២៨ ផ ខ.២០ **១:២៧** ព យក ២:៥ ភ ខ.២០ រម ១:២២ ១កថ ៣:១៨,១៩ **១:២៨** ម រម ៤:១៧ **១:២៩** អភ ២:៩ **១:៣០** យ រម ១៦:៣ រ យរ ២៣:៥,៦ ៣៣:១៦ ២កថ ៥:២១ ភល ៣:៩ ល ១កថ ១:២ វ រម ៣:២៤ **១:៣១** ស យរ ៩:២៣,២៤ ទដ ៣៤:២,៤៤:៨ ២កថ ១០:១៧ **២:១** ហ ខ.៤,១៣ ១កថ ១:១៧ **២:២** ឡ កទ ៦:១៤ ១កថ ១:២៣ **២:៣** អ កច ១៨:១–១៨

វិញដែលយល់ថាការនេះជា ការល្ងង់ល្ងើ ។

**១:២២** *សាសន៍យូដា គេចង់ឃើញភស្តុតាង* មានន័យថា ពួកសាសន៍យូដាតែងតែចង់ឃើញការបើកសំដែងមកអំពីព្រះអម្ចាស់ (មថ ១២:៣៨ ១៦:១,៤ មក ៨:១១–១២ យហ ២:១៨ ៦:៣០)។ *សាសន៍ក្រេក គេស្វែងរកប្រាជ្ញា* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកសាសន៍ក្រេកបានស្វែងរកប្រភេទប្រាជ្ញារបស់លោកីយ ដែលអាចរំដោះពួកគេ និងមនុស្សជាតិឱ្យរួចផុតពីសេចក្តីវេទនា ។ ប៉ុន្តែ អ្វីដែលពួកគេ ខំប្រឹងនោះមិនបានសម្រេចដូចបំណងរបស់ខ្លួនឡើយ ។

**១:២៣** *ជាហេតុនាំឱ្យរវាតចិត្តដល់សាសន៍យូដា* ឃ្លានេះបញ្ជាក់ថា ពួកសាសន៍យូដាបានរង់ចាំព្រះមែស៊ី ដោយគិតថា ទ្រង់យាងមកក្នុងនាមជាអ្នកមានជ័យជម្នះ ខាងសឹកសង្គ្រាម និងនយោបាយប៉ុណ្ណោះ ។ ពួកគេមិនបានគិតថា ទ្រង់ត្រូវគេឆ្កាង នោះទេ (រម ១១:៩ រម ៩:៣២–៣៣ ១ពត ២:៨)។ *ជាសេចក្តីល្ងង់ល្ងើដល់សាសន៍ក្រេក* ឃ្លានេះនៅក្នុងព្រះគម្ពីរបរិសុទ្ធមួយចំនួនសរសេរថា *"ជាសេចក្តីល្ងង់ល្ងើដល់សាសន៍ដទៃ"*។ ពួករ៉ូម៉ាំង និងសាសន៍ក្រេកយល់ថា គេពុំដែលឆ្កាង មនុស្សដែលមានកេរ្តិ៍ឈ្មោះល្អទេ ។ ពួកគេគិតថា ឧក្រិដ្ឋជនដែលត្រូវគេឆ្កាង មិនអាចធ្វើជាអ្នកសង្គ្រោះមនុស្សលោកបានទេ ។ ដូច្នេះហើយ ទើបបទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាសេចក្តីល្ងង់ល្ងើដល់សាសន៍ក្រេក (ឬសាសន៍ដទៃ) ដែលមិនព្រមទទួលជឿដល់ព្រះនាមទ្រង់វិញ ។

**១:២៤** *ព្រះចេស្តា* (រម ១:៤,១៦)។ *ប្រាជ្ញារបស់ព្រះ* (ខ.៣០)។

**១:២៦-៣១** គ្រីស្ទបរិស័ទនៅទីក្រុងកូរិនថូសជាស្មរបន្ទាល់ដ៏រស់ ដែលបានបញ្ជាក់ថាសេចក្តីសង្គ្រោះមិនអាស្រ័យលើអ្វីដែលពួកគេមានខាងឯលោកីយនេះទេ ។ ដូច្នេះ អស់អ្នកដែលបានទទួលសេចក្តីសង្គ្រោះពីព្រះអម្ចាស់ ពួកគេអាចអួតតែអំពីទ្រង់ប៉ុណ្ណោះ (ខ.៣១)។ សេចក្តីសង្គ្រោះដែលពួកគេទទួលបានមិនមែនកើតឡើងពីប្រាជ្ញា ឬកម្លាំងមនុស្សឡើយ គឺកើតឡើងដោយសារតែព្រះគុណនៃព្រះអម្ចាស់ប៉ុណ្ណោះ ។ សូមប្រៀបធៀបបទគម្ពីរនៅក្នុងវគ្គនេះ ជាមួយនឹងបទចម្រៀងរបស់នាងហាណា (១សយ ២:១–១០) និងបទចម្រៀងនាងម៉ារា (លក ១:៤៦-៥៥)។

**១:៣០** *ដោយសារព្រះ នោះអ្នករាល់គ្នានៅក្នុងព្រះគ្រីស្ទយេស៊ូវ* ឃ្លានេះអាចមានន័យថា "គឺជាព្រះដែលទ្រង់បានត្រាស់ហៅអ្នករាល់គ្នា ឱ្យមានការប្រកបស្និទ្ធស្នាលជាមួយនឹងព្រះគ្រីស្ទ"។ *សេចក្តីសុចរិត* គ្រីស្ទបរិស័ទបានរាប់ជាសុចរិតដោយសារសេចក្តីជំនឿ ដែលពួកគេមានក្នុងព្រះយេស៊ូវគ្រីស្ទ (រម ៥:១៩)។ *សេចក្តីបរិសុទ្ធ* (មើលការពន្យល់ ខ.២)។ *សេចក្តីប្រោសលោះ* (មើលការពន្យល់ រម ៣:២៤)។

**១:៣១** "មើលការពន្យល់ យរ ៩:២៤"។

**២:១** *កាលខ្ញុំបានមកឯអ្នករាល់គ្នា* ត្រង់ចំណុចនេះបញ្ជាក់ថា លោកប៉ុលបានធ្វើ ដំណើរមកដល់ទីក្រុងកូរិនថូសលើកដំបូង ប្រហែលនៅឆ្នាំទី៥១គ.ស (កច ១៨)។ *បងប្អូន* (មើលការពន្យល់ ១:១០)។ *ប្រើវោហារ ឬប្រាជ្ញាដ៏ឧត្តម* (មើលការ ពន្យល់ ១:១៧)។

**២:២** *មិនព្រមស្គាល់រឿងអ្វីទៀត ក្រៅពីព្រះយេស៊ូវគ្រីស្ទ* ចំណុចនេះលោកប៉ុលបញ្ជាក់យ៉ាងច្បាស់ថា ក្នុងអំឡុងពេលដែលគាត់បានស្នាក់នៅជាមួយនឹងពួកជំនុំនៅឯទីក្រុងកូរិនថូស គាត់ពុំដែលនិយាយ និងបង្រៀនអ្វីក្រៅអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់ទេ ។ *ព្រះយេស៊ូវគ្រីស្ទ . . . ទ្រង់ត្រូវឆ្កាង* (មើលការពន្យល់ ១:១៧, ១៨,២៣,៣០)។

មានសេចក្ដីកំសោយ[ក] ភិតភ័យ ហើយញាប់ញ័រជាច្រើន
ដែរ[ខ] ៤ឯពាក្យសំដី និងវោហារអធិប្បាយរបស់ខ្ញុំ ក៏មិន
មែនដោយពាក្យឧត្តុង្គឧត្តម ដែលពូកែបញ្ចុះបញ្ចូលនោះ
ដែរ[គ] គឺដោយការសំដែងចេញជាព្រះវិញ្ញាណ និងព្រះ
ចេស្ដាវិញទេតើ[ឃ] ៥ដើម្បីកុំឱ្យសេចក្ដីជំនឿរបស់អ្នករាល់
គ្នាបានតាំងនៅ ដោយប្រាជ្ញារបស់មនុស្សឡើយ គឺដោយ
ព្រះចេស្ដានៃព្រះវិញ[ង]។

## ប្រាជ្ញាដែលមកពីព្រះវិញ្ញាណបរិសុទ្ធ

៦ប៉ុន្ដែ នៅក្នុងចំណោមមនុស្សគ្រប់លក្ខណ៍[ច] នោះ
យើងខ្ញុំក៏និយាយតាមប្រាជ្ញាដែរ តែមិនមែនតាមប្រាជ្ញា
របស់លោកីយនេះ[ឆ] ឬរបស់ពួកចៅហ្វាយនៅលោកីយនេះ
ដែលត្រូវសាបសូន្យនោះទេ[ជ] ៧គឺនិយាយតាមតែប្រាជ្ញានៃ
ព្រះវិញ ជាសេចក្ដីអាថ៌កំបាំង[ឈ]ដ៏លាក់ទុក[ញ] ដែលព្រះបាន
គិតគូ តាំងពីមុនអស់ទាំងកល្ប សំរាប់ជាសិរីល្អដល់យើង
រាល់គ្នា ៨គ្មានចៅហ្វាយណាក្នុងលោកីយនេះ[ដ] បានស្គាល់
សេចក្ដីអាថ៌កំបាំងនោះឡើយ បើបានស្គាល់ នោះគេមិន
បានឆ្កាងព្រះអម្ចាស់ដ៏មានសិរីទេ[ឋ] ៩ដូចមានសេចក្ដីចែង
ទុកមកថា «សេចក្ដីដែលភ្នែកមិនដែលឃើញ ត្រចៀកមិន
ដែលឮ ហើយចិត្តនឹកមិនដែលដល់ គឺសេចក្ដីនោះឯង
ដែលព្រះបានរៀបចំទុក សំរាប់ពួកអ្នកដែលស្រឡាញ់
ទ្រង់[ឌ]» ១០ព្រះទ្រង់បានសំដែង[ឍ] ឱ្យយើងរាល់គ្នាឃើញ
សេចក្ដីទាំងនោះ ដោយសារព្រះវិញ្ញាណទ្រង់[ណ] ដ្បិតព្រះ
វិញ្ញាណនៃទ្រង់ស្ទង់មើលគ្រប់ទាំងអស់ ព្រមទាំងសេចក្ដី
ជ្រាលជ្រៅនៃព្រះដែរ ១១ដ្បិតបើមិនមែនជាវិញ្ញាណ ដែល
នៅក្នុងខ្លួនមនុស្សទេ នោះ[ត]តើមានអ្វីនឹងស្គាល់សណ្ឋាន
មនុស្សនោះបាន[ថ] ហើយបើមិនមែនជាព្រះវិញ្ញាណនៃព្រះ
នោះក៏គ្មានអ្នកណាស្គាល់សណ្ឋានព្រះបានដែរ។
១២ឯយើងរាល់គ្នា យើងមិនបានទទួលវិញ្ញាណ[ទ]របស់
លោកីយទេ[ធ] គឺទទួលព្រះវិញ្ញាណដែលមកពីព្រះវិញ ដើម្បី
ឱ្យបានស្គាល់អស់ទាំងព្រះគុណ ដែលព្រះបានផ្ដល់មកយើង
១៣ហើយយើងក៏និយាយពីសេចក្ដីទាំងនោះឯង មិនមែនដោយ
ពាក្យសំដី ដែលប្រាជ្ញាមនុស្សបានបង្រៀនទេ[ន]គឺដោយពាក្យ
សំដី ដែលព្រះវិញ្ញាណបង្រៀនវិញ ព្រមទាំងផ្ទឹមពន្យល់
សេចក្ដីខាងឯវិញ្ញាណ ដោយសារសេចក្ដីខាងឯវិញ្ញាណផង

ក ១កថ ៤:១០ ៩:២២ ២កថ ១១:២៩,៣០ ១២:៥,៩,១០ ១៣:៩
ខ ២កថ ៧:១៥
**២:៤** គ ខ.១
ឃ រម ១៥:១៣
**២:៥** ង ២កថ ៤:៧ ៦:៧
**២:៦** ច អភ ៤:១៣ ភល ៣:១៥ កល ៤:១២ ហព ៥:១៤ ៦:១ យក ១:៤ ឆ ខ.៨ ១កថ ១:២០
ជ ទដ ១៤៦:៤
**២:៧** ឈ ខ.១
ញ រម ១៦:២៥
**២:៨** ដ ខ.៦ ១កថ ១:២០ ឋ ទដ ២៤:៧ កថ ៧:២ យក ២:១
**២:៩** ឌ អស ៦៤:៤ ៦៥:១៧
**២:១០** ឍ មថ ១៣:១១ ២កថ ១២:១,៧ កទ ១:១២
២:២ អភ ៣:៣,៥ ណ យហ ១៤:២៦ **២:១១** ត យរ ១៧:៩ ថ សភ ២០:២៧
**២:១២** ទ យម ៨:១៥ ធ ១កថ ១:២០,២៧ យក ២:៥ **២:១៣** ន ខ.១,៤ ១កថ ១:១៧

**២:៤** *មិនមែនដោយពាក្យឧត្តុង្គឧត្តម ដែលពូកែបញ្ចុះបញ្ចូល* បទគម្ពីរនេះមិនមែនមានន័យថា ឱ្យពួកអ្នកជឿដល់ព្រះអម្ចាស់ ឈប់យកចិត្តទុកដាក់ក្នុងការសិក្សា និងក្នុងការរៀបចំមេរៀន ដែលត្រូវបង្រៀននោះឡើយ ។ សំបុត្ររបស់សាវ័កប៉ុលបានផ្ដល់នូវចំណេះដឹងជាច្រើនដល់យើងជាអ្នកជឿដល់ព្រះនាមព្រះអម្ចាស់ ដូចជាការដែលលោកថ្លែងទៅកាន់ពួកបណ្ឌាជននៅកណ្ដាលទីអើរីយ៉ូសជាដើម (កច ១៧:២២–៣១ និងការពន្យល់)។ ម្យ៉ាងទៀត លោកចង់បញ្ជាក់ថា ការថ្លែងព្រះបន្ទូលមានប្រសិទ្ធភាពលុះណាតែព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុងចិត្តអ្នកស្ដាប់ ។ ក្នុងពេលផ្សាយដំណឹងល្អ លោកប៉ុលមិនបានពឹងអាងលើប្រាជ្ញា និងសមត្ថភាពរបស់គាត់ ដូចជាពួកគ្រូក្រឹត្យវិន័យសាសន៍យូដា និងសាសន៍ក្រេកដែលជាអ្នកពូកែខាងវោហារនោះឡើយ (មើលការពន្យល់ ១:១៧)។ *ការសំដែង* ពាក្យនេះ នៅក្នុងភាសាក្រិកសំដៅលើ "ទីបន្ទាល់ ឬភស្តុតាង" ដែលគេប្រើក្នុងទីកាត់ក្ដី ។ ម្យ៉ាងទៀត បញ្ជាក់ថា លោកប៉ុលបានថ្លែងព្រះបន្ទូលដោយមានការបើកសំដែងមកពីព្រះវិញ្ញាណបរិសុទ្ធ ។

**២:៦** *មនុស្សគ្រប់លក្ខណ៍* សំដៅលើពួកអ្នកជឿដល់ព្រះអម្ចាស់ ហើយដែលបានពេញវ័យខាងឯជំនឿ (៣:១ ហព ៥:១៣–៦:៣)។

**២:៧** *សេចក្ដីអាថ៌កំបាំង* ពាក្យថា "សេចក្ដីអាថ៌កំបាំង" នេះ ព្រះអម្ចាស់ទ្រង់បានបើកសំដែងដល់រាស្ដ្ររបស់ទ្រង់ ដើម្បីឱ្យពួកគេបានដឹង (ខ.១០ សូមប្រៀបធៀបនឹង រម ១១:២៥ អភ ៣:៣ ១ធថ ៣:១៦ និងការពន្យល់) ប៉ុន្ដែចំពោះពួកអ្នកដែលមិនព្រមជឿដល់ព្រះនាមទ្រង់ សេចក្ដីនេះនៅតែជាសេចក្ដីលាក់កំបាំងដដែល ។ *សិរីល្អដល់យើង* មានន័យថា នៅថ្ងៃចុងបំផុត ព្រះអម្ចាស់នឹងប្រទានឱ្យអ្នកជឿដល់ព្រះនាមទ្រង់ទាំងអស់ មានចំណែកនៅក្នុងសិរីល្អរបស់ទ្រង់ (មើលការពន្យល់ រម ៨:១៧)។ *តាំងពីមុនអស់ទាំងកល្ប* (យហ ១៧:២៤ រម ៨:២៩–៣០ អភ ១:៤ ១ធថ ១:៩ និងការពន្យល់)។

**២:៨** *ចៅហ្វាយណាក្នុងលោកីយ* ឃ្លានេះសំដៅលើពួកអ្នកដឹកនាំទាំងឡាយដែលមានដូចជាពួកសង្គ្រាជ (លក ២៤:២០) លោកប៉ុនទាសពីឡាត់ និងស្ដេចហេរ៉ូឌ–អាន់ទីប៉ាសជាដើម (កច ៤:២៧)។

**២:៩** *ព្រះបានរៀបចំទុក* ត្រង់ចំណុចនេះបញ្ជាក់ថា ព្រះអម្ចាស់ទ្រង់បានរៀបចំនូវព្រះពរសម្រាប់អស់អ្នកជឿដល់ព្រះនាមទ្រង់ ទាំងនៅពេលបច្ចុប្បន្ន និងនៅពេលអនាគត (ខ.៧,១២)។

**២:១០** *ព្រះវិញ្ញាណនៃទ្រង់ស្ទង់មើលគ្រប់ទាំងអស់* បញ្ជាក់ថា ព្រះវិញ្ញាណជ្រាបគ្រប់ទាំងអស់ដែលរួមមានសេចក្ដីអាថ៌កំបាំង និងផែនការនៃព្រះអម្ចាស់ផង ។ គ្មានអ្វីដែលអាចលាក់កំបាំងពីព្រះវិញ្ញាណបានឡើយ ។ *សេចក្ដីជ្រាលជ្រៅនៃព្រះ* (មើលការពន្យល់ រម ១១:៣៣–៣៦ ប្រៀបធៀបនឹង *វវ* ២:២៤)។

**២:១២** *វិញ្ញាណរបស់លោកីយ* (ឬហៅថា "ប្រាជ្ញារបស់លោកិយ") ជាវិញ្ញាណ ឬប្រាជ្ញារបស់មនុស្ស ដែលពេញទៅដោយបំណងចិត្តអាត្មានិយម ហើយត្រូវ ផាច់ចេញពីព្រះអម្ចាស់ (មើលការពន្យល់ រម ៨:៥–៨)។

**២:១៣** *ពាក្យសំដី ដែលព្រះវិញ្ញាណបង្រៀន* មានន័យថា ពាក្យសំដីដែលលោកប៉ុលនិយាយក្នុងការប្រកាសព្រះបន្ទូល គឺមានការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ។

**២:១៤–៣:៤** នៅក្នុងវគ្គនេះ មានបញ្ជាក់អំពីហេតុផល ដែលមនុស្សជាច្រើនមិនបានស្គាល់ប្រាជ្ញាខាងឯសេចក្ដីពិត (២:៩)។ អ្នកដែលអាចស្គាល់ប្រាជ្ញាប្រភេទនេះ មានតែអ្នកដែលទទួលជឿដល់ព្រះអម្ចាស់ និងមានការបំភ្លឺអំពីព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ (២:១៤–១៦ ប្រៀបធៀបនឹង ខ.៦)។ ម្យ៉ាងទៀត នៅក្នុងវគ្គនេះមានបញ្ជាក់អំពីសេចក្ដីពិត នៅក្នុងពួកជំនុំនៅ

១៤ប៉ុន្តែ មនុស្សខាងសាច់ឈាម គេមិនទទួលសេចក្ដីខាងឯ
ព្រះវិញ្ញាណនៃព្រះទេ[ប] ពីព្រោះជាសេចក្ដីល្ងង់ល្ងើដល់គេ[ផ]
ក៏រកស្គាល់មិនបានដែរ ដ្បិតត្រង់ឯសេចក្ដីទាំងនោះ ត្រូវ
ពិចារណាយល់ខាងវិញ្ញាណវិញ ១៥ឯមនុស្សខាងវិញ្ញាណ
វិញ[ព] គេពិចារណាយល់គ្រប់ទាំងអស់បាន តែមិនត្រូវអ្នក
ណាពិចារណាខ្លួនឡើង ១៦ដ្បិតតើអ្នកណាបានស្គាល់គំនិត
នៃព្រះអម្ចាស់ តើអ្នកណានឹងបង្រៀនទ្រង់បាន[ភ] តែយើង
រាល់គ្នាមានគំនិតជារបស់ផងព្រះគ្រីស្ទវិញ[ម]។

## ការបែកបាក់ក្នុងពួកជំនុំ

**៣** ១ឯខ្ញុំ បងប្អូនអើយ ខ្ញុំពុំអាចនិយាយនឹងអ្នករាល់គ្នា ដូច
នឹងមនុស្សខាងឯវិញ្ញាណបានទេ[យ] ត្រូវតែនិយាយដូចនឹង
មនុស្សខាងឯសាច់ឈាមវិញ[រ] គឺដូចជានិយាយនឹងកូនខ្ចី[ល]
ក្នុងព្រះគ្រីស្ទ ២ខ្ញុំបានឱ្យទឹកដោះមកអ្នករាល់គ្នាផឹក[វ] មិន
បានឱ្យសាច់បរិភោគទេ[ស] ដ្បិតកាលណោះអ្នករាល់គ្នាពុំ
អាចនឹងបរិភោគបាន ហើយឥឡូវនេះ ក៏មិនទាន់បានដែរ
៣ដោយព្រោះអ្នករាល់គ្នា នៅតែខាងសាច់ឈាមនៅឡើយ
ដ្បិតដែលមានសេចក្ដីឈ្នានីសឈ្លោះប្រកែក[ហ]និងបាក់បែក
គ្នា ក្នុងពួកអ្នករាល់គ្នា នោះតើមិននៅខាងសាច់ឈាម
ហើយដើរតាមបែបមនុស្សលោកទេឬអី ៤គឺកាលដែល
ម្នាក់ប្រកាន់ថា ខ្លួនជាសិស្សរបស់ប៉ុល ហើយម្នាក់ទៀតថា
ខ្លួនជារបស់អ័ប៉ុឡូស[ឡ] នោះតើមិនមែននៅខាងសាច់ឈាម
ទេឬអី ៥ដូច្នេះ តើប៉ុលជាអ្វី ឬ អ័ប៉ុឡូសជាអ្វី[អ] គឺគ្រាន់តែ
ជាអ្នកបំរើ[ក] ដែលនាំឱ្យអ្នករាល់គ្នាជឿ តាមដែលព្រះ
អម្ចាស់បានប្រទានមកគ្រប់គ្នាតែប៉ុណ្ណោះទេតើ ៦ខ្ញុំបាន
សាបព្រោះ[ខ] អ័ប៉ុឡូសជាអ្នកស្រោច តែដែលបានដុះឡើង
នោះ គឺព្រះបានធ្វើវិញ ៧ហេតុនោះបានជាអ្នកដែលសាប
ព្រោះ នឹងអ្នកដែលស្រោច នោះមិនមែនជាអ្វីទេ ស្រេច
ហើយនឹងព្រះដែលធ្វើឱ្យដុះវិញទេតើ ៨ឯអ្នកដែលសាប
ព្រោះ នឹងអ្នកដែលស្រោច នោះដូចគ្នាទេ ហើយក្នុងអ្នក
និមួយៗ នោះនឹងបានរង្វាន់តាមការដែលខ្លួនធ្វើ[គ] ៩ដ្បិត
យើងរាល់ គ្នាជាអ្នកធ្វើការជាមួយនឹងព្រះ[ឃ] ឯអ្នករាល់គ្នា
ជាស្រែដែលព្រះទ្រង់ភ្ជួរ[ង] ហើយជាផ្ទះដែលព្រះទ្រង់ធ្វើ[ច]។
១០ខ្ញុំបានដាំជើងជញ្ជាំង ដូចជាមេជាងផ្ទះដ៏ចំណាន[ឆ]
តាមព្រះគុណដែលព្រះបានប្រទានមកខ្ញុំ[ជ] មានម្នាក់ទៀតជា
អ្នកសង់ពីលើ ប៉ុន្តែ ត្រូវឱ្យមនុស្សប្រយ័ត្នរៀងខ្លួន អំពីបែប
ណាដែលសង់ពីលើជើងនោះ ១១ដ្បិតគ្មានអ្នកណាអាចនឹង
ដាំជើងជញ្ជាំងណាផ្សេងទៀត ក្រៅពីជើងដែលបានដាំរួច
ហើយនោះបានទេ គឺជាព្រះយេស៊ូវគ្រីស្ទ[ឈ] ១២បើអ្នកណា
យកមាស ប្រាក់ ត្បូង ឈើ ស្បូវ ឬស្លឹក ដើម្បីនឹងធ្វើពីលើ
ជើងជញ្ជាំងនេះ ១៣នោះការដែលអ្នករាល់គ្នាធ្វើ នឹងលេច
មកឱ្យឃើញ[ញ] ដ្បិតថ្ងៃនោះ[ដ]នឹងបង្ហាញពីការនោះយ៉ាង
ច្បាស់លាស់ ព្រោះការនោះនឹងសំដែងចេញមក ដោយ
សារភ្លើង ហើយភ្លើងនឹងសាកមើលការដែលនិមួយៗធ្វើ

**២:១៤** ប យហ ១៤:១៧ ផ ១កថ ១:១៨ **២:១៥** ព ១កថ ៣:១ កទ ៦:១ **២:១៦** ភ អស ៤០:១៣ រម ១១:៣៤ ម យហ ១៥:១៥ **៣:១** យ ១កថ ២:១៥ រ រម ៧:១៤ ១កថ ២:១៤ ល ១កថ ១៤:២០ **៣:២** វ ហព ៥:១២–១៤ ១ពត ២:២ ស យហ ១៦:១២ **៣:៣** ហ រម ១៣:១៣ ១កថ ១:១១ កទ ៥:២០ **៣:៤** ឡ ១កថ ១:១២ **៣:៥** អ កច ១៨:២៤ ក ១កថ ៤:១ ២កថ ៦:៤ អភ ១:២៣,២៥ **៣:៦** ខ កច ១៨:៤–១១ ១កថ ៤:១៥ ៩:១ ១៥:១ **៣:៨** គ ឧ.១៤ ទដ ១៨:២០
៦២:១២ មថ ២៥:២១ ១កថ ៩:១៧ **៣:៩** ឃ មក ១៦:២០ ២កថ ៦:១ ១ថន ៣:២ ង អស ៦១:៣ ច អភ ២:២០–២២ ១ពត ២:៥ **៣:១០** ឆ រម ១៥:២០ អភ ២:២០ ជ រម ១២:៣ **៣:១១** ឈ អស ២៨:១៦ អភ ២:២០

ឯទីក្រុងកូរិនថូស ដែលបង្ហាញនូវភាពមិនទាន់ពេញវ័យខាងឯជំនឿរបស់ពួកគេ (៣:៣–៤)។

**២:១៤** *មនុស្សខាងសាច់ឈាម* សំដៅលើពួកអ្នកដើរតាមនិស្ស័យសាច់ឈាម (ប្រៀបធៀបនឹង រម ៨:៩ យដ ១៩)។ ពួកអ្នកដែលមិនទទួលជឿព្រះយេស៊ូវគ្រីស្ទ ពួកគេត្រូវបានគ្រប់គ្រងដោយបំណងចិត្តលោកីយ ។ ពួកគេជាមនុស្សដែលមិនទាន់បើកចំហចំពោះសេចក្ដីពិតនៃព្រះអម្ចាស់នៅឡើយ (យហ ៣:៨ ទត ៣:៥ និងការពន្យល់)។ *សេចក្ដីល្ងង់ល្ងើ* មើល ១:១៨ ។

**២:១៥** *មនុស្សខាងវិញ្ញាណ* គឺពួកអ្នកបានកើតជាថ្មីខាងឯវិញ្ញាណ (ឧ.៦)។

**៣:១** *បងប្អូន* (មើលការពន្យល់ ១:១០)។ *ខាងឯវិញ្ញាណ* (មើលការពន្យល់ ២:១៥)។ *ខាងឯសាច់ឈាម* (មើលការពន្យល់ ២:១៤–៣:៤)។

**៣:២** *ទឹកដោះ . . . សាច់* (មើលការពន្យល់ ហព ៥:១២–១៤)។

**៣:៣** *តាមបែបមនុស្សលោក* សំដៅលើពួកអ្នករស់នៅតាមរបៀបលោកីយ។

**៣:៤** *ខ្លួនជាសិស្សរបស់ប៉ុល . . . អ័ប៉ុឡូស* (មើល ១:១២)។

**៣:៦** *ខ្ញុំបានសាបព្រោះ* ត្រង់ចំណុចនេះបញ្ជាក់ថា កិច្ចការរបស់លោកប៉ុលតែងតែចាប់ផ្ដើមនៅទីកន្លែង ដែលមិនទាន់មានអ្នកណាម្នាក់ចាប់ផ្ដើមនៅឡើយ (កច ១៨:៤-១១ ២កថ ១០:១៣–១៦ រម ១៥:២០-២១)។ *អ័ប៉ុឡូសជាអ្នកស្រោច* ការងាររបស់លោកអ័ប៉ុឡូស នៅក្នុងពួកជំនុំមានដូចជាការបង្រៀន និងការលើកទឹកចិត្តដល់អស់អ្នកដែលទទួលជឿព្រះយេស៊ូវគ្រីស្ទ ។

**៣:៩** *ស្រែដែលព្រះទ្រង់ភ្ជួរ* ឃ្លានេះមានន័យថា មនុស្សនៅលើផែនដីនេះគឺជាទីចម្រូតរបស់ព្រះអម្ចាស់ ។ *ផ្ទះដែលព្រះទ្រង់ធ្វើ* ពាក្យថា "ផ្ទះ" ត្រង់ចំណុចនេះ សំដៅលើព្រះវិហារនៃព្រះអម្ចាស់ ។ លោកប៉ុលបានបញ្ជាក់ថា ពួកជំនុំគឺជា ព្រះវិហារនៃព្រះអម្ចាស់ (ឧ.១៦–១៧)។

**៣:១០** *ខ្ញុំបានដាំជើងជញ្ជាំង* មានន័យថា ព្រះអម្ចាស់បានត្រាស់ហៅលោកប៉ុលឱ្យចាប់ផ្ដើមបង្កើតពួកជំនុំនៅឯទីក្រុងកូរិនថូស ដោយការផ្សាយដំណឹងល្អដល់ ពួកគេ (២:២)។ *ម្នាក់ទៀត* ប្រហែលជាសំដៅលើលោកអ័ប៉ុឡូស ឬអាចសំដៅ លើអ្នកផ្សេងៗទៀត ។

**៣:១២** *មាស ប្រាក់ ត្បូង* តំណាងឱ្យការដែលស្ថិតស្ថេរ និងឈរមាំនៅចំពោះ សេចក្ដីជំនុំជម្រះនៃព្រះអម្ចាស់ ហើយជានិមិត្តរូបតំណាងឱ្យគោលទ្ធិដ៏ត្រឹមត្រូវ និងការរស់នៅដ៏បរិសុទ្ធរបស់គ្រីស្ទបរិស័ទ ។ *ឈើ ស្បូវ ឬស្លឹក* ជានិមិត្តរូបនៃគ្រប់ការដែលមិនអាចឈរមាំនៅក្នុងសេចក្ដីជំនុំជម្រះនៃព្រះអម្ចាស់ ។

**៣:១៣** "មើលការពន្យល់ ៤:៥ ២កថ ៥:១០"។ *ថ្ងៃនោះ* សំដៅលើថ្ងៃជំនុំជម្រះ ដែលនឹងត្រូវមកដល់នៅថ្ងៃចុងបំផុត (មើលការពន្យល់ ១:៨)។ *ភ្លើង* សំដៅលើសេចក្ដីជំនុំជម្រះ។ គ្រប់ការទាំងអស់ដែលមនុស្សលោកធ្វើ

ឱ្យដឹងជាយ៉ាងណា[ឋ] ១៤បើការដែលអ្នកណាសង់ឡើងបាន
ជាប់នៅ អ្នកនោះនឹងបានរង្វាន់[ឌ] ១៥បើការដែលអ្នកណា
ធ្វើត្រូវឆេះ អ្នកនោះនឹងត្រូវខាតវិញ តែខ្លួនអ្នកនោះនឹង
បានរួច បែបដូចជាដើរកាត់ភ្លើង[ឍ] ។
១៦តើអ្នករាល់គ្នាមិនដឹងទេឬអី ថាខ្លួនអ្នករាល់គ្នាជា
ព្រះវិហារនៃព្រះ[ណ] ហើយថា ព្រះវិញ្ញាណនៃព្រះទ្រង់
សណ្ឋិតក្នុងអ្នករាល់គ្នា[ត] ១៧បើអ្នកណាបង្ខូចព្រះវិហារនៃ
ព្រះ នោះព្រះនឹងធ្វើឱ្យអ្នកនោះត្រូវខូចដែរ ដ្បិតព្រះវិហារ
នៃព្រះជាវត្ថុដ៏បរិសុទ្ធ គឺជាខ្លួនអ្នករាល់គ្នានេះឯង ។
១៨កុំឱ្យអ្នកណាបញ្ឆោតខ្លួនឡើយ បើអ្នកណាក្នុងពួកអ្នក
រាល់គ្នាស្មានថា ខ្លួនមានប្រាជ្ញា[ថ]ក្នុងលោកីយនេះ[ទ] ត្រូវឱ្យ
អ្នកនោះត្រឡប់ជាល្ងង់ល្ងើវិញ ដើម្បីឱ្យមានប្រាជ្ញាឡើង
១៩ពីព្រោះប្រាជ្ញារបស់លោកីយនេះ ជាសេចក្ដីល្ងង់ល្ងើ[ធ]
នៅចំពោះព្រះ ដ្បិតមានសេចក្ដីចែងទុកមកថា «ព្រះទ្រង់
ចាប់ពួកអ្នកប្រាជ្ញ ដោយសារកិច្ចកលរបស់ខ្លួនគេ »[ន]
២០ហើយមានបទ១ទៀតថា «ព្រះអម្ចាស់ទ្រង់ជ្រាប គំនិតនៃ
ពួកអ្នកប្រាជ្ញ ថាជាឥតប្រយោជន៍ទាំងអស់»[ប] ២១ដូច្នេះ កុំឱ្យ
អ្នកណាអួតពីមនុស្សឡើយ[ផ] ដ្បិតគ្រប់ទាំងអស់ជារបស់ផង
អ្នករាល់គ្នា[ព] ២២ទោះទាំងប៉ុល ឬអ័ប៉ុឡូស[ភ] កេផាស[ម]
លោកីយ ជីវិត សេចក្ដីស្លាប់ របស់នៅជំនាន់សព្វថ្ងៃ ឬទៅ
មុខក្ដី[យ] នោះសុទ្ធតែជារបស់ផងអ្នករាល់គ្នាទាំងអស់ ២៣តែ
ឯអ្នករាល់គ្នា ជារបស់ផងព្រះគ្រីស្ទវិញ ហើយព្រះគ្រីស្ទ[រ]
ទ្រង់ជារបស់ព្រះ ។

## ទូតរបស់ព្រះគ្រីស្ទ

**៤** ១ដូច្នេះ មនុស្សត្រូវរាប់យើងខ្ញុំ ទុកដូចជាអ្នកជំនួយ[ល]នៃ
ព្រះគ្រីស្ទ ហើយជាអ្នករ៉ាប់រង[វ]ចំពោះសេចក្ដីអាថ៌កំបាំង[ស]
នៃព្រះវិញ ២រីឯអ្នករ៉ាប់រង ត្រូវឱ្យគេបានស្មោះត្រង់ ៣តែ
ខាងឯដំណើររបស់ខ្ញុំ ដែលអ្នករាល់គ្នា ឬមនុស្សណាក៏
ដោយ ចោទប្រកាន់ទោសខ្ញុំ នោះមិនជាការអំពល់អ្វីដល់ខ្ញុំ
ឡើយ ខ្ញុំក៏មិនចោទប្រកាន់ទោសខ្លួនខ្ញុំផង ៤ពីព្រោះខ្ញុំមិន
ឃើញ[ហ]មានអ្វីនៅក្នុងខ្លួនខ្ញុំសោះ ប៉ុន្តែ ខ្ញុំមិនបានរាប់ជា
សុចរិត[ឡ] ដោយសារហេតុនោះទេ អ្នកដែលចោទប្រកាន់
ទោស នោះគឺជាព្រះអម្ចាស់វិញទេតើ[អ] ៥ដូច្នេះ កុំឱ្យចោទ
ប្រកាន់ទោសគ្នា[ក]មុនកំណត់ឡើយ លុះត្រាតែព្រះអម្ចាស់
ទ្រង់យាងមក[ខ] ដែលទ្រង់នឹងយកអស់ទាំងអំពើលាក់កំបាំង

**៣:១៣** ញ ១កថ ៤:៥ ដ ១កថ ១:៨ ២ថន ១:៧-១០ ២ធថ ១:១២,១៨ ៤:៨ ឋ ជន ៣១:២២,២៣ យរ ២៣:២៨,២៩ មឡ ៣:៣ ២ថន ១:៧
**៣:១៤** ឌ ខ.៨
**៣:១៥** ឍ យដ ២៣
**៣:១៦** ណ ១កថ ៦:១៩ ២កថ ៦:១៦ អភ ២:២១,២២ ហព ៣:៦ ត រម ៨:៩
**៣:១៨** ថ អស ៥:២១ ១កថ ៨:២ កទ ៦:៣ ទ ១កថ ១:២០
**៣:១៩** ធ ខ.១៨ រម ១:២២ ១កថ ១:២០,២៧ ន យប ៥:១៣
**៣:២០** ប ទដ ៩៤:១១
**៣:២១** ផ ១កថ ៤:៦ ព រម ៨:៣២
**៣:២២** ភ ខ.៥,៦ ម ១កថ ១:១២ យ រម ៨:៣៨ **៣:២៣** រ ១កថ ១៥:២៣ ២កថ ១០:៧ កទ ៣:២៩ **៤:១** ល ១កថ ៣:៥ វ ១កថ ៩:១៧ ទត ១:៧ ស រម ១៦:២៥ **៤:៤** ហ កច ២៣:១ ឡ រម ២:១៣ អ ២កថ ១០:១៨ **៤:៥** ក មថ ៧:១,២ ខ ១ថន ២:១៩

នឹងត្រូវឆ្លងកាត់ការ ជំនុំជម្រះរបស់ព្រះអម្ចាស់ នៅថ្ងៃចុងបំផុត ។

**៣:១៥** *ត្រូវឆេះ* បញ្ជាក់ថា បើការរបស់អ្នកណាម្នាក់មិនអាចឈរមាំនៅក្នុងសេចក្ដីជំនុំជម្រះនៃព្រះអម្ចាស់ទេ អ្នកនោះនឹងបាត់រង្វាន់ ។ *តែខ្លួនអ្នកនោះនឹងបានរួច បែបដូចជាដើរកាត់ភ្លើង* ត្រង់ចំណុចនេះបញ្ជាក់ថាប្រហែលមានពេលខ្លះកិច្ចការដែលយើងធ្វើមិនបានគាប់ព្រះហឫទ័យដល់ព្រះអម្ចាស់ ប៉ុន្តែសេចក្ដីសង្គ្រោះរបស់យើងមិនត្រូវបាត់បង់ទេ (មើលពន្យល់ សក ៣:២) ។

**៣:១៦** *ព្រះវិហារនៃព្រះ* លោកប៉ុលប្រើពាក្យនេះគឺសំដៅលើពួកជំនុំរបស់ទ្រង់តែម្ដង (ខ.១៧ និងមើលការពន្យល់ អភ ២:២១-២២) ។ នៅក្នុងបទគម្ពីរ "១កថ ៦:១៩" លោកប៉ុលបានបញ្ជាក់ថា គ្រប់អ្នកជឿដល់ព្រះនាមព្រះយេស៊ូវទាំងអស់ គឺជាព្រះវិហារនៃព្រះ វិញ្ញាណបរិសុទ្ធ ។

**៣:១៧** នៅក្នុងជំពូក ១-៤ លោកប៉ុលនិយាយសង្កត់ធ្ងន់ទៅលើបញ្ហាកើតឡើងនៅក្នុងពួកជំនុំ ជាពិសេសគឺការបែកបាក់គ្នា ដែលបង្ករឡើងដោយសារតែការប្រកាន់បក្សពួក និងការយល់ឃើញផ្សេងៗពីគ្នា (១:១១-១២) ។ ម្យ៉ាងទៀតក្នុងបទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា មិនត្រូវឱ្យពួកអ្នកជឿដល់ព្រះអម្ចាស់បង្ករឱ្យមានការបាក់បែកនៅ ក្នុងពួកជំនុំរបស់ទ្រង់ឡើយ គឺត្រូវរួបរួមគ្នានៅក្នុងព្រះគុណ របស់ទ្រង់វិញ (១:២) ។

**៣:១៨** *ត្រូវឱ្យអ្នកនោះត្រឡប់ជាល្ងង់ល្ងើវិញ* មានន័យថា ត្រូវឱ្យងាកចេញពីប្រាជ្ញារបស់លោកីយ ហើយទូលសូមដល់ព្រះអម្ចាស់ នូវប្រាជ្ញាដែលមកពីទ្រង់វិញ (មើលការពន្យល់ ១:១៨,២១,២៤) ។

**៣:២១** ក្នុងបទគម្ពីរនេះ បញ្ជាក់យ៉ាងច្បាស់ថា មិនត្រូវឱ្យអ្នកជឿដល់ព្រះយេស៊ូវ អួតអំពីមនុស្សឡើយ (៤:៦) ។ ប្រសិនបើអ្នកណាដែលអួត ត្រូវអួតតែពីព្រះយេស៊ូវ ប៉ុណ្ណោះ (ខ.២៣ ១:២៩,៣១ មើលការពន្យល់ រម ៨:១៧) ។

**៣:២៣** *អ្នករាល់គ្នាជារបស់ផងព្រះគ្រីស្ទ* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា អស់អ្នកណាជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ នោះគេគឺជារបស់ផងទ្រង់យ៉ាងពិតប្រាកដ (៦:១៩-២០ មើលការពន្យល់ ១:៣០) ។ *ព្រះគ្រីស្ទទ្រង់ជារបស់ព្រះ* (យហ ១០:៣០ និងការពន្យល់) ។

**៤:១** *អ្នករ៉ាប់រង* គឺអ្នកគ្រប់គ្រង ឬអ្នកមើលការខុសត្រូវ ។ *សេចក្ដីអាថ៌កំបាំង* សំដៅលើគ្រប់សេចក្ដីដែលប្រាជ្ញារបស់មនុស្សពុំអាចយល់បាន ប៉ុន្តែព្រះបើកសំដែងឱ្យរាស្ត្ររបស់ទ្រង់បានយល់វិញ (មើលការពន្យល់ ២:៧) ។

**៤:២** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា អស់អ្នកដែលព្រះអម្ចាស់បានត្រាស់ហៅឱ្យបំពេញកិច្ចការអ្វីមួយត្រូវមានភាពស្មោះត្រង់ និងការទទួលខុសត្រូវចំពោះ កិច្ចការ នោះ ។

**៤:៤** លោកប៉ុលមិនមានការភ័យខ្លាច ចំពោះពាក្យចោទប្រកាន់របស់អ្នកណា ម្នាក់ទេ ពីព្រោះគាត់បានបម្រើព្រះអម្ចាស់ដោយស្មោះពីចិត្ត (២កថ ១:១២) ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏គាត់មិនបានរាប់ជាសុចរិតដោយសារការងារ ដែលគាត់ធ្វើថ្វាយព្រះអម្ចាស់នោះទេ គឺបានរាប់ជាសុចរិត ដោយសារតែសេចក្ដី ជំនឿលើទ្រង់ប៉ុណ្ណោះ ។

**៤:៥** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់សុចរិត និងមានគ្រប់អំណាចព្រះចេស្ដាទាំងអស់ ក្នុងការជំនុំជម្រះមនុស្សលោក (មថ ១៣:២៤-៣០,៣៧-៤៣ រម ២:១៦) ។ *កំណត់* ពាក្យថា "កំណត់" ក្នុងបទគម្ពីរនេះ គឺសំដៅលើថ្ងៃជំនុំជម្រះដែលនឹងត្រូវមកដល់ (មើលការពន្យល់ ៣:១៣) ។

ដែលធ្វើនៅទីងងឹត មកដាក់នៅទីភ្លឺវិញ[គ] ហើយនឹងបើក
សំដែងឱ្យឃើញអស់ទាំងគំនិតក្នុងចិត្តរបស់មនុស្សផង នោះ
គ្រប់គ្នានឹងបានសេចក្តីសរសើរពីព្រះរៀងខ្លួន[ឃ] ។
៦បងប្អូនអើយ ខ្ញុំបានបង្វែរសេចក្តីទាំងនេះមកលើខ្លួនខ្ញុំ
និងអ័ប៉ុឡូស ដោយព្រោះតែអ្នករាល់គ្នា ដើម្បីឱ្យអ្នករាល់
គ្នាហាត់រៀនតាមយើង មិនឱ្យគិតខ្ពស់លើសជាងសេចក្តី
ដែលបានចែងទុកមក[ង] ប្រយោជន៍កុំឱ្យអ្នកណា មានសេចក្តី
អំនួត អួតពីអ្នក ១ ទាស់នឹងអ្នក ១ ឡើយ[ច] ៧ដ្បិតតើអ្នកណា
បានធ្វើឱ្យអ្នកផ្សេងពីគេ តើអ្នកមានអ្វីខ្លះ ដែលអ្នកមិនបាន
ទទួល ចុះបើបានទទួលមែន ហេតុអ្វីបានជាអួតខ្លួនដូចជា
មិនបានទទួលវិញ[ឆ] ៨អ្នករាល់គ្នាឆ្អែតហើយក៏ជាអ្នកមាន
ផង[ជ] កាលឥតពីយើងខ្ញុំ នោះអ្នករាល់គ្នាបានសោយរាជ្យ
ឡើង ហើយខ្ញុំក៏ សុខចិត្តឱ្យអ្នករាល់គ្នាបានសោយរាជ្យដែរ
ដើម្បីឱ្យយើងខ្ញុំ បានសោយរាជ្យជាមួយគ្នា ៩ខ្ញុំស្មានថា
ព្រះទ្រង់បានដាក់យើងខ្ញុំ ដែលជាពួកសាវក ឱ្យនៅក្រោយ
បង្អស់ ហាក់ដូចជាបានដំរូវឱ្យត្រូវស្លាប់ដែរ[ឈ] ពីព្រោះយើង
ខ្ញុំបានត្រឡប់ជាទី ដែលសំរាប់ឱ្យលោកីយបានមើលលេង[ញ]
គឺដល់ទាំងពួកទេវតា នឹងពួកមនុស្សផង ១០យើងខ្ញុំជា
មនុស្សល្ងង់ល្ងើដោយយល់ដល់ព្រះគ្រីស្ទ[ដ] តែអ្នករាល់
គ្នាជាអ្នកប្រាជ្ញក្នុងព្រះគ្រីស្ទវិញ[ឋ] យើងខ្ញុំខ្សោយ តែអ្នក
រាល់គ្នាមានកំឡាំង[ឌ] អ្នករាល់គ្នាមានសេចក្តីរុងរឿង
តែយើងខ្ញុំអាប់ឱនកេរ្តិ៍ឈ្មោះវិញ ១១លុះមកដល់ឥឡូវនេះ
យើងខ្ញុំត្រូវទាំងឃ្លាន ទាំងស្រេក ហើយនៅអាក្រាត ទាំង
ត្រូវគេវាយ ហើយក៏ដើរសាត់អណ្តែត[ឍ] ១២យើងខ្ញុំធ្វើការ
នឿយហត់នឹងដៃយើង[ណ] កាលណាគេជេរនោះយើងខ្ញុំឱ្យ
ពរវិញ[ត] កាលណាគេបៀតបៀន[ថ] នោះយើងខ្ញុំទ្រាំទ្រ ១៣កាល
ណាគេប្រមាថ នោះយើងខ្ញុំអង្វរដល់គេ យើងខ្ញុំបានត្រ
ឡប់ដូចជាសំរាមរបស់លោកីយ ហើយដូចជាកំអែលនៃ
មនុស្សទាំងអស់[ទ] ដរាបដល់ឥឡូវនេះ ១៤ខ្ញុំសរសេរសេចក្តី
ទាំងនេះ មិនមែនចង់ឱ្យអ្នករាល់គ្នាមានសេចក្តីខ្មាសទេ[ធ]
ខ្ញុំគ្រាន់តែទូន្មានដល់អ្នករាល់គ្នា ទុកដូចជាកូនស្ងួនភ្ងាវិញ
ប៉ុណ្ណោះ[ន] ១៥ដ្បិតថ្វីបើអ្នករាល់គ្នាមានគ្រូទាំងម៉ឺនក្នុង
ព្រះគ្រីស្ទ តែគ្មានឪពុកជាច្រើនទេ មានតែខ្ញុំ ១ ប៉ុណ្ណោះ[ប]
ដែលបានបង្កើតអ្នករាល់គ្នាក្នុងព្រះគ្រីស្ទ ដោយសារដំណឹង
ល្អ[ផ] ១៦ដូច្នេះ ខ្ញុំទូន្មានដល់អ្នករាល់គ្នា ឱ្យយកដំរាប់តាមខ្ញុំ
ចុះ[ព] ។
១៧ដោយហេតុនោះបានជាខ្ញុំចាត់[ភ]ធីម៉ូថេ[ម] ឱ្យមកឯអ្នករាល់
គ្នា គាត់ជាកូនស្ងួនភ្ងា[យ]ហើយស្មោះត្រង់របស់ខ្ញុំ ក្នុងព្រះអម្ចាស់
គាត់នឹងរំឭកអ្នករាល់គ្នា ពីគ្រប់ទាំងកិរិយារបស់ខ្ញុំក្នុងព្រះគ្រីស្ទ
តាមសេចក្តីដែលខ្ញុំបង្រៀន ក្នុងគ្រប់ទាំងពួកជំនុំនៅសព្វអន្លើ[រ]
១៨មានអ្នកខ្លះកើតមានចិត្តធំ[ល]ដោយគិតស្មានថា ខ្ញុំមិន

**៤:៥** គ យប ១២:២២ ទដ ៩០:៨ ១កថ ៣:១៣ ឃ រម ២:២៩ **៤:៦** ង ១កថ ១:១៩,៣១ ៣:១៩,២០ ច ១កថ ១:១២ ៣:៤ **៤:៧** ឆ យហ ៣:២៧ រម ១២:៣,៦ **៤:៨** ជ វវ ៣:១៧,១៨ **៤:៩** ឈ រម ៨:៣៦ ញ ទដ ៧១:៧ ហព ១០:៣៣ **៤:១០** ដ ១កថ ១:១៨ កច ១៧:១៨ ២៦:២៤ ឋ ១កថ ៣:១៨ ២កថ ១១:១៩ ឌ ១កថ ២:៣ **៤:១១** ឍ រម ៨:៣៥ ២កថ ១១:២៣–២៧ **៤:១២** ណ កច ១៨:៣ ត រម ១២:១៤ ១ពត ៣:៩ ថ មថ ៥:៤៤ **៤:១៣** ទ យរ ២០:១៨ បទ ៣:៤៥ **៤:១៤** ធ ១កថ ៦:៥ ១៥:៣៤ ២ថន ៣:១៤ ន ១ថន ២:១១ **៤:១៥** ប ខ.១៤ ផ ១កថ ៩:១២,១៤, ១៨,២៣ ១៥:១ **៤:១៦** ព ១កថ ១១:១ ភល ៣:១៧ ៤:៩ ១ថន ១:៦ ២ថន ៣:៧,៩ **៤:១៧** ភ ១កថ ១៦:១០ ម កច ១៦:១ យ ១ធថ ១:២ រ ១កថ ៧:១៧

**៤:៦** *សេចក្តីអំនួត* ត្រង់ចំណុចនេះបញ្ជាក់ថា សេចក្តីអំនួតគឺជាមូលហេតុ និងជា ឫសគល់ ដែលបណ្តាលឱ្យមានការបាក់បែកគ្នា នៅក្នុងពួកជំនុំ ។
**៤:៨** ក្នុងបទគម្ពីរនេះ លោកប៉ុលនិយាយជាលក្ខណៈប្រៀបធៀប ដើម្បីបង្ហាញពីភាពកម្សោយខាងឯវិញ្ញាណនៃពួកជំនុំនៅឯទីក្រុងកូរិនថូស ។ *អ្នករាល់គ្នាឆ្អែត ហើយ ក៏ជាអ្នកមានផង* "សូមប្រៀបធៀបនឹង ១:៥ ២កថ ៩:១១"។ *អ្នករាល់គ្នា បានសោយរាជ្យដែរ* ឃ្លានេះបញ្ជាក់ថា នៅពេលនោះ ពួកជំនុំនៅទីក្រុងកូរិនថូសយល់ច្រឡំថា ពួកគេកំពុងតែអង្គុយសោយរាជ្យជាមួយព្រះគ្រីស្ទតែម្តង (២ធថ ២:១២ មើលពន្យល់ រម ៥:១៧) និងមិនត្រូវការពួកសាវកទៀតទេ ។
**៤:៩–១១** ត្រង់ចំណុចនេះបានបញ្ជាក់អំពីបទពិសោធន៍ដែលលោកប៉ុល និងពួកសាវកដទៃទៀត តែងតែជួបប្រទះនៅក្នុងជីវិតជាអ្នកបម្រើព្រះអម្ចាស់ ។ ក្នុងសម័យចក្រភពរ៉ូម៉ាំង អ្នកទោសឧក្រិដ្ឋ ត្រូវបានគេបណ្តើរឱ្យដើរតាមផ្លូវនៅទីសាធារណៈ ដោយបង្ខំឱ្យលីឈើឆ្កាងរបស់ខ្លួន ដើម្បីឱ្យពួកបណ្តាជនបានឃើញ និងពោលពាក្យចំអកដាក់ទៀតផង ។ លោកប៉ុលមានប្រសាសន៍ថា ខ្លួនគាត់ និងពួកសាវកដទៃទៀត ក៏មានលក្ខណៈដូចជាអ្នកទោសឧក្រិដ្ឋដែរ ព្រោះថាពួកគាត់តែងតែត្រូវគេប្រមាថមើលងាយជានិច្ច ទោះបីពួកគាត់មិនបានប្រព្រឹត្តការអាក្រក់ ណាមួយក៏ដោយ ។
**៤:១២** *យើងខ្ញុំធ្វើការនឿយហត់* ឃ្លានេះបញ្ជាក់ថា លោកប៉ុល តែងតែធ្វើការ ដោយខំប្រឹងជានិច្ចនៅក្នុងការបម្រើព្រះអម្ចាស់ ។ ក្រៅពីការបង្រៀនព្រះបន្ទូល លោកប៉ុលបានធ្វើជាជាងត្រសាល (ភាសាអង់គ្លេសសរសេរថា អ្នកធ្វើតង់ ឬអ្នកធ្វើដំបូលតង់អំពីស្បែកសត្វ ឬក្រណាត់រោមពពែ) ដើម្បីជីវភាពរស់នៅប្រចាំថ្ងៃ ទៀតផង (១កថ ៩:៦,១៨ កច ២០:៣៤–៣៥ មើលការពន្យល់ កច ១៨:៣)។ *កាលណាគេជេរនោះយើងឱ្យពរវិញ* (មថ ៥:៤៤ លក ៦:២៨ មើលការពន្យល់ រម ១២:១៤)។ *កាលណាគេបៀតបៀន នោះយើងខ្ញុំទ្រាំទ្រ* មានន័យថា នៅពេលមានការបៀតបៀនត្រូវឱ្យគ្រីស្ទបរិស័ទគ្រប់ៗ រូបចេះទ្រាំទ្រ ហើយមិនត្រូវធ្វើការសងសឹក ឬធ្វើការអាក្រក់ណាមួយឡើយ ។
**៤:១៤** *កូនស្ងួនភ្ងា* (ខ.១៥)។
**៤:១៥** បទគម្ពីរនេះបញ្ជាក់ថា ពួកជំនុំនៅទីក្រុងកូរិនថូស បានទទួលជឿដល់ព្រះអម្ចាស់ តាមរយៈលោកប៉ុល ។
**៤:១៦** *ឱ្យយកដំរាប់តាមខ្ញុំចុះ* "មើលការពន្យល់ ១១:១"។
**៤:១៧** *ខ្ញុំចាត់ធីម៉ូថេ ឱ្យមកឯអ្នករាល់គ្នា* ត្រង់ចំណុចនេះបញ្ជាក់អំពីការចាប់ផ្តើមការងាររបស់លោកធីម៉ូថេ ដោយគាត់បានធ្វើដំណើរឆ្លងកាត់ស្រុកម៉ាសេដូន ទៅឯទីក្រុងកូរិនថូស (មើលការពន្យល់ ១៦:១០)។
**៤:១៨** *អ្នកខ្លះកើតមានចិត្តធំ* ពាក្យថា "អ្នកខ្លះ" ក្នុងបទគម្ពីរនេះ សំដៅលើពួកអ្នកដែលព្យាយាមបន្ទាបបន្ថោកតម្លៃការងាររបស់លោកប៉ុល (មើល

មកឯអ្នករាល់គ្នាទេ[វ] ១៩ប៉ុន្តែ បន្តិចទៀត[ស] បើព្រះអម្ចាស់
ទ្រង់សព្វព្រះហឫទ័យ[ហ] នោះខ្ញុំនឹងមកជាមិនខាន ហើយខ្ញុំ
នឹងស្គាល់ មិនត្រឹមតែពាក្យសំដីរបស់ពួកអ្នកដែលមានចិត្ត
ធំប៉ុណ្ណោះ គឺនឹងស្គាល់ដល់ទាំងអំណាចគេថែមទៀតផង
២០ដ្បិតនគរព្រះមិនសំរេចនឹង[ឡ]ពាក្យសំដីប៉ុណ្ណោះទេ គឺ
ស្រេចនឹងឥទ្ធិឫទ្ធិវិញ[អ] ២១តើអ្នករាល់គ្នាចូលចិត្តយ៉ាងណា
ចង់ឱ្យខ្ញុំមកទាំងកាន់ដំបង[ក] ឬដោយសេចក្តីស្រឡាញ់ នឹង
ចិត្តសុភាពរាបសាវិញ ។

## ការបណ្តេញមនុស្សកំផិត

**៥** ១មានពួរន្ទីសុសសាយជានិច្ចថា មានការកំផិតកើតឡើង
ក្នុងពួកអ្នករាល់គ្នាពិត ជាការកំផិតម្យ៉ាង ដែលមិនដែល
ទាំងមានឮនិយាយក្នុងសាសន៍ដទៃផង គឺថា មានមនុស្ស
ម្នាក់បានយកប្រពន្ធរបស់ឪពុកខ្លួន[ខ] ២តែអ្នករាល់គ្នានៅ
តែមានចិត្តធំ ឥតកើតទុក្ខព្រួយ[គ] ដើម្បីនឹងដកអ្នកដែល
ប្រព្រឹត្តការនោះ ឱ្យថយចេញពីចំណោមអ្នករាល់គ្នាឡើយ[ឃ]
៣ឯខ្ញុំ ទោះបើមិននៅជាមួយខាងសាច់ឈាមក៏មែន គង់តែ
នៅជាមួយខាងឯវិញ្ញាណ[ឃ] ខ្ញុំក៏បានកាត់ទោសដល់អ្នក
ដែលប្រព្រឹត្តដូច្នោះហើយ ហាក់ដូចជាបាននៅជាមួយគ្នា
ដែរ ៤គឺក្នុងកាលដែលអ្នករាល់គ្នា និងវិញ្ញាណខ្ញុំបាន
ប្រជុំគ្នា ព្រមទាំងមានព្រះចេស្តា នៃព្រះអម្ចាស់យេស៊ូវនៃ
យើងផង[ង] នោះខ្ញុំបានកាត់ទោសអ្នកនោះ ដោយនូវព្រះនាម
ព្រះយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ៥ដើម្បីនឹង
បញ្ជូន[ឆ]មនុស្សយ៉ាងនោះ ទៅអារក្សសាតាំង[ជ] ឱ្យបំផ្លាញ
និស្ស័យសាច់ឈាមគេ ប្រយោជន៍ឱ្យព្រលឹងវិញ្ញាណបាន
សង្គ្រោះ ក្នុងថ្ងៃនៃព្រះអម្ចាស់យេស៊ូវវិញ[ឈ] ៦សេចក្តីអំនួត
របស់អ្នករាល់គ្នាមិនល្អទេ[ញ] តើមិនដឹងថា ដំបែតែបន្តិច[ដ]
អាចនឹងធ្វើឱ្យម្សៅទាំងអស់ដោរឡើងបាន ទេឬអី[ឋ] ៧ចូរ
សំអាតដំបែចាស់ចេញ ដើម្បីឱ្យអ្នករាល់គ្នាបានត្រឡប់
ជាដុំម្សៅថ្មីវិញ ដ្បិតអ្នករាល់គ្នាបានឥតដំបែហើយ ព្រោះ
ព្រះគ្រីស្ទ ដ៏ជាយញ្ញបូជានៃបុណ្យរំលង នោះបានត្រូវ

**៤:១៨** ល យរ ៤៣:២ វ ខ.២១
**៤:១៩** ស ១កថ ១៦:៥,៦ ២កថ ១:១៥,១៦ ហ កថ ១៨:២១
**៤:២០** ឡ រម ១៤:១៧ អ រម ១៥:១៣
**៤:២១** ក ២កថ ១:២៣ ២:១ ១៣:២,១០
**៥:១** ខ លវ ១៨:៨ ចទ ២២:៣០ ២៧:២០
**៥:២** គ ២កថ ៧:៧–១១ ឃ ខ.១៣
**៥:៣** ង កល ២:៥ ១ថន ២:១៧
**៥:៤** ច ២ថន ៣:៦
**៥:៥** ឆ ១ធថ ១:២០ ជ មថ ៤:១០ ឈ ១កថ ១:៨
**៥:៦** ញ យក ៤:១៦ ដ មថ ១៦:៦,១២ ឋ កទ ៥:៩ **៥:៧** ឌ នក ១២:៣–៦, ២១ មក ១៤:១២ ១ពត ១:១៩ **៥:៨** ឍ នក ១២:១៤,១៥ ចទ ១៦:៣

ការពន្យល់ ២កថ ១:១៧)។ ពួកគេបានប្រកាសថា ការងារដែលលោកប៉ុលធ្វើនោះគ្មានប្រយោជន៍អ្វីទាំងអស់ (មើលការពន្យល់ ២កថ ១០:១០ ១២:១១–១២)។

**៤:១៩** *ពួកអ្នកដែលមានចិត្តធំ* ឃ្លានេះក្នុងព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសសរសេរថា "ពួកអ្នកដែលមានពុត ឬពួកអ្នកអួតអាង" (មើលការពន្យល់ ៥:២)។

**៤:២០** បទគម្ពីរនេះបញ្ជាក់ថា ព្រះវត្តមានរបស់ព្រះអម្ចាស់គឺនៅជាមួយនឹងរាស្ត្ររបស់ទ្រង់ជានិច្ច (មើលការពន្យល់ មថ ៣:២) និងសំដែងឱ្យឃើញតាមរយៈជីវិតរបស់ពួកគេម្នាក់ៗ និងការលះបង់របស់ពួកគេ ដើម្បីទ្រង់ និងមហាបេសកកម្មរបស់ទ្រង់ ។ ម្យ៉ាងទៀត ព្រះវត្តមានរបស់ព្រះអម្ចាស់មិនអាស្រ័យលើពាក្យសម្តីរបស់មនុស្សណាម្នាក់ទេ (១:២៤)។

**៤:២១** ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ អំពីបែបបទនៃការបម្រើរបស់លោកប៉ុល ។ គាត់តែងតែស្គាល់នូវតម្រូវការរបស់ពួកជំនុំ និងរបៀបផ្ទេរចំណេះដឹងដល់ពួកគេថែមទៀតផង (មើលការពន្យល់ ២កថ ១:២៨ ២:១ ១៣:២,១០)។ ម្យ៉ាងទៀត ការងារដែលគាត់ធ្វើ គឺមានការដឹកនាំពីព្រះអម្ចាស់ ។

**៥:១** *ជាការកំផិតម្យ៉ាង ដែលមិនដែលទាំងមានឮនិយាយក្នុងសាសន៍ដទៃផង* ត្រង់ចំណុចនេះ លោកស៊ីសេរ៉ូ (Cicero ជាអ្នកនយោបាយជាតិរ៉ូម៉ាំងនៅឆ្នាំទី១០៦-៤៣ មុនគ.ស) បានសរសេរថា នៅពេលនោះមិនមានគេនិយាយអំពីសេចក្តីកំផិតក្នុងសង្គមរ៉ូម៉ាំងទេ ។ *ប្រពន្ធរបស់ឪពុកខ្លួន* ឃ្លានេះ អាចសរសេរថា "ប្រពន្ធចុងរបស់ឪពុកខ្លួន"។ ដូច្នេះ ពាក្យសម្តីរបស់លោកប៉ុលនៅត្រង់ចំណុចនេះ មិនមែនមានន័យថា មនុស្សម្នាក់នោះបានប្រព្រឹត្តអំពើផិតក្បត់ជាមួយម្តាយបង្កើតរបស់ខ្លួនទេ ប៉ុន្តែ គឺបានប្រព្រឹត្តអំពើនេះ ជាមួយម្តាយចុងរបស់ខ្លួនវិញ (លវ ១៨:៨ ចទ ២២:៣០ និងការពន្យល់)។

**៥:២** *មានចិត្តធំ* ឃ្លានេះនៅក្នុងព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសសរសេរថា "មានចិត្តអំនួត" (មើលការពន្យល់ រម ៦:១–២)។ ម្យ៉ាងទៀត ក្នុងបទគម្ពីរនេះបញ្ជាក់ថា អស់អ្នកណាដែលនៅតែបន្តអំពើផិតក្បត់ ដូចដែលមានចែងនៅក្នុងខ១ គឺត្រូវតែកាត់ចេញពីពួកជំនុំ (យហ ៩:២២)។

**៥:៤** *កាត់ទោស* ពាក្យថា "កាត់ទោស" នៅត្រង់ចំណុចនេះ មានន័យថា ឈប់ទទួលស្គាល់អ្នក ដែលនៅតែបន្តប្រព្រឹត្តអំពើផិតក្បត់ជាមួយម្តាយចុងរបស់ខ្លួននោះ ប៉ុណ្ណោះ មិនមែនជាការកាត់ទោសព្រលឹងវិញ្ញាណរបស់អ្នកនោះទេ ។ នៅក្នុងព្រះគម្ពីរបរិសុទ្ធបានបញ្ជាក់យ៉ាងច្បាស់ថា ការជំនុំជម្រះរបស់ព្រះអម្ចាស់នឹងត្រូវមកដល់នៅថ្ងៃចុងបំផុត គឺនៅពេលដែលទ្រង់យាងមកជាលើកទីពីរ (យហ ៦:៣៩ ,៤០,៤៤ ១១:២៤ ២ធថ ៣:១ ២ពត ៣:៣)។

**៥:៥** បទគម្ពីរនេះបញ្ជាក់ថា ការដែលពួកជំនុំនៅទីក្រុងកូរិនថូសឈប់ទទួលស្គាល់អ្នកដែលបានបន្តប្រព្រឹត្តអំពើកំផិតនោះ គឺមានន័យថា ពួកគេគ្មានទំនាក់ទំនងអ្វីជាមួយអ្នកនោះទៀតទេ ។ ដូច្នេះ អ្នកនោះមិនមែនជាផ្នែកមួយនៃពួកជំនុំទៀតទេ (ខ.២,៧,១១,១៣)។ ម្យ៉ាងទៀតការដែលពួកគេធ្វើដូច្នោះចំពោះអ្នកនោះ ប្រហែលមកពីពួកគេចង់ឱ្យអ្នកដែលបន្តប្រព្រឹត្តអំពើនោះបានភ្ញាក់ខ្លួន និងប្រែចិត្តបន្ទាប់ពីបានទទួលនូវបទពិសោធន៍នៃការឈឺចាប់ដោយសារអំណាចនៃសេចក្តីងងឹតរួចហើយ (១:៧)។

**៥:៦** *ដំបែ* ពាក្យថា "ដំបែ" ក្នុងបទគម្ពីរនេះ គឺជានិមិត្តរូបតំណាងឱ្យការអាក្រក់ ឬអំពើបាប ។ លោកប៉ុលបានប្រើពាក្យនេះ ដើម្បីពន្យល់ប្រាប់ពួកជំនុំនៅឯទីក្រុងកូរិនថូសថា ចំពោះការអាក្រក់ខ្លះ មើលទៅហាក់ដូចជាតូច ប៉ុន្តែ វានឹងរីកធំឡើងប្រសិនជាមិនបានកម្ចាត់វាចេញពីពួកជំនុំនោះទេ (ខ.៨ មើលការពន្យល់ មក ៨:១៥ ២កថ ៥:១៧)។

**៥:៧** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា អ្នកជឿដល់ព្រះនាមព្រះយេស៊ូវទាំងអស់ គឺបានទទួលជីវិតថ្មីមកពីទ្រង់ ដូច្នេះត្រូវលះបង់ចោលនូវអំពើបាបទាំងឡាយដែលខ្លួនធ្លាប់តែប្រព្រឹត្តនៅក្នុងជីវិតចាស់ (មើលការពន្យល់ ១:២ ៦:១១)។ ម្យ៉ាងទៀត ព្រះយេស៊ូវគឺជាកូនចៀមនៃព្រះ និងជាយញ្ញបូជាដ៏ពិត

ថ្វាយជំនួសយើងរាល់គ្នាហើយ[ឌ] ៨បានជាត្រូវឱ្យយើងធ្វើ
បុណ្យនេះដោយឥតមានដំបែ[ឍ] គឺដោយសេចក្ដីស្មោះត្រង់
និងសេចក្ដីពិតវិញ មិនមែនដោយដំបែចាស់ ឬនឹងដំបែជា
សេចក្ដីអាក្រក់ និងសេចក្ដីកំណាចនោះទៀតឡើយ ។
៩ខ្ញុំបានផ្ញើសំបុត្រផ្ញើមកប្រាប់អ្នករាល់គ្នាថា កុំឱ្យភប់
ប្រសព្វ[ណ]នឹងមនុស្សកំផិតឡើយ ១០តែពាក្យនោះមិនសំដៅ
ចំពោះមនុស្សកំផិតរបស់ផងលោកីយនេះ[ត] ឬមនុស្សលោភ
មនុស្សប្លន់កំហែង ឬមនុស្សថ្វាយបង្គំរូបព្រះនោះទេ ដ្បិត
បើដូច្នោះ នោះត្រូវតែចេញ ឱ្យផុតពីលោកីយនេះទៅ
១១គឺខ្ញុំបានសរសេរមកអ្នករាល់គ្នា ដោយន័យយ៉ាងនេះថា
បើមានអ្នកណានៅក្នុងពួកជំនុំ[ថ] ជាមនុស្សកំផិត ឬលោភ ឬ
ថ្វាយបង្គំរូបព្រះ[ទ] ឬជេរប្រមាថ ជាអ្នកប្រមឹក ឬប្លន់កំហែង
នោះមិនត្រូវឱ្យភប់ប្រសព្វនឹងគេឡើយ ក៏មិនត្រូវទាំង
បរិភោគជាមួយនឹងគេផង[ធ] ១២ដ្បិតតើត្រូវការអ្វីឱ្យខ្ញុំជំនុំ
ជំរះដល់មនុស្សខាងក្រៅ[ន] តើអ្នករាល់គ្នាមិនជំនុំជំរះមនុស្ស
ក្នុងពួកជំនុំទេឬអី[ប] ១៣ឯចំណែកពួកអ្នកខាងក្រៅ នោះ
ព្រះនឹងជំនុំជំរះគេ ហើយត្រូវឱ្យអ្នករាល់គ្នាបណ្ដេញមនុស្ស
អាក្រក់នោះ ពីពួកអ្នករាល់គ្នាចេញ[ផ]។

**៥:៩** ណ អភ ៥:១១ ២ថន ៣:៦,១៤
**៥:១០** ត ១កថ ១០:២៧
**៥:១១** ថ រម ៧:១ ទ ១កថ ១០:៧,១៤ ធ រម ១៦:១៧
**៥:១២** ន មក ៤:១១ ប ខ.៣–៥ ១កថ ៦:១–៤
**៥:១៣** ផ ចទ ១៣:៥ ១៧:៧ ១៩:១៩ ២២:២១,២៤ ២៤:៧ ចទ ២០:១៣
**៦:១** ព មថ ១៨:១៧
**៦:២** ភ មថ ១៩:២៨ លក ២២:៣០ ១កថ ៥:១២

## ការប្ដឹងប្ដល់ក្នុងចំណោមអ្នកជឿ

**៦** ១ក្នុងពួកអ្នករាល់គ្នា បើអ្នកណាមានរឿងទាស់នឹងអ្នកឯ
ទៀត តើហ៊ានប្ដឹងដល់ពួកមនុស្សទុច្ចរិត មិនប្ដឹងដល់ពួក
បរិសុទ្ធវិញទេឬអី[ព] ២តើមិនដឹងថា ពួកបរិសុទ្ធនឹងជំនុំជំរះ
លោកីយដែរទេឬ[ភ] ដូច្នេះ បើអ្នករាល់គ្នានឹងជំនុំជំរះ
លោកីយបាន នោះតើមិនគួរនឹងជំនុំជំរះការណ៍តូចបំផុត
នេះបានដែរទេឬអី ៣តើមិនដឹងថា យើងរាល់គ្នានឹងជំនុំ
ជំរះ ដល់ទាំងពួកទេវតាផងទេឬអី ដូច្នេះចំណង់បើការណ៍
នៅជីវិតនេះ តើលើសជាងអម្បាលម៉ានទៅទៀត ៤ចុះបើ
អ្នករាល់គ្នាមានរឿងអ្វីពីជីវិតនេះ នោះតើនឹងយកមនុស្ស
ដែលពួកជំនុំរាប់អានតិចជាងគេ ឱ្យបានជំនុំជំរះរឿងនោះ
ឬអី ៥ដែលខ្ញុំនិយាយដូច្នេះនេះ គឺដើម្បីឱ្យអ្នករាល់គ្នាមាន

---

ប្រាកដដែលត្រូវបានឆ្កាង និងសុគតលោះបាបមនុស្សលោកគ្រប់គ្នាដើម្បីឱ្យអស់អ្នកណាដែលទទួលជឿដល់ព្រះនាមទ្រង់ បានជីវិតរស់អស់កល្បជានិច្ច និងមិនត្រូវវិនាសឡើយ (នក១២:៨ មើលការពន្យល់ យហ ១:២៩)។

**៥:៨** *ត្រូវឱ្យយើងធ្វើបុណ្យនេះដោយឥតមានដំបែ* លោកប៉ុលនិយាយយ៉ាងដូច្នេះ មានន័យថា ឱ្យអ្នកជឿដល់ព្រះអម្ចាស់ទាំងអស់ រស់នៅក្នុងជីវិតមួយបែបថ្មី ដោយប្រកាន់ខ្ជាប់នូវភាពបរិសុទ្ធ និងមិនជាប់ទាក់ទងនឹងអំពើអាក្រក់ណាមួយឡើយ ។

**៥:៩** នៅពេលដែលពួកជំនុំនៅទីក្រុងកូរិនថូស បានទទួលសំបុត្ររបស់លោកប៉ុលដែលសរសេរថា កុំឱ្យភប់ប្រសព្វជាមួយមនុស្សកំផិត នោះពួកគេបែរជាយល់ច្រឡំថា មិនត្រូវមានទំនាក់ទំនងជាមួយនឹងពួកអ្នកមិនជឿឡើយ ។ នៅក្នុងសំបុត្ររបស់លោកប៉ុលមិនមែនមានន័យដូច្នេះទេ គឺគ្រាន់តែឱ្យពួកគេរស់នៅដោយញែកខ្លួនឱ្យបានបរិសុទ្ធនៅចំពោះព្រះអម្ចាស់ និងកុំឱ្យជីវិតរបស់ពួកគេ ជាប់ទាក់ទងនឹងមនុស្សដែលប្រព្រឹត្តការអាក្រក់ឡើយ ប៉ុន្តែត្រូវឱ្យជីវិតរបស់ពួកជំនុំទាំងអស់ជាពន្លឺដល់ពួកគេវិញ (ខ.១០–១១)។

**៥:១០–១១** "មើលការពន្យល់ រម ១:២៩–៣១"។

**៥:១១** *ក៏មិនត្រូវទាំងបរិភោគជាមួយនឹងគេផង* ការដែលលោកប៉ុលនិយាយយ៉ាងដូច្នេះ ព្រោះថា ប្រសិនបើមានពួកអ្នកដែលបន្តប្រព្រឹត្តអំពើផិតក្បត់នៅក្នុងពួកជំនុំ នោះជាទីបន្ទាល់ដ៏អាក្រក់សម្រាប់ពួកអ្នកដែលមិនជឿ ។ម្យ៉ាងទៀត ធ្វើឱ្យពួកអ្នកមិនជឿដល់ព្រះអម្ចាស់យល់ថា ពួកជំនុំទាំងអស់សុទ្ធតែប្រព្រឹត្តអំពើអាក្រក់ទៀតផង ។ ដូច្នេះ អ្នកដឹកនាំពួកជំនុំត្រូវលើកទឹកចិត្ត និងយកចិត្តទុកដាក់ណែនាំ និងបង្រៀនសមាជិករបស់ខ្លួនឱ្យធ្វើជាទីបន្ទាល់ដ៏ល្អសម្រាប់អ្នកជិតខាង ពិសេសពួកអ្នកដែលមិនទាន់ជឿលើព្រះអម្ចាស់នៅឡើយ(រម ១៦:១៧–១៨ ២ថន ៣:៦,១៤–១៥ និងការពន្យល់)។

**៥:១២–១៣** ត្រង់ចំណុចនេះបញ្ជាក់ថា ពួកជំនុំត្រូវយកចិត្តទុកដាក់លើការពង្រឹង និងថែបំប៉ន ចំណេះដឹងខាងឯព្រលឹងវិញ្ញាណ ដល់សមាជិករបស់ខ្លួន (មថ ១៨:១៥–១៨) និងមិនត្រូវជំនុំជម្រះពួកអ្នកដែលនៅខាងក្រៅពួកជំនុំទេ ។ ការជំនុំជម្រះមនុស្សទូទៅដែលមិនមែនជាសមាជិកពួកជំនុំគឺជាតួនាទីរបស់រដ្ឋាភិបាល ។ នៅថ្ងៃចុងបំផុតព្រះអម្ចាស់ទ្រង់នឹងជំនុំជម្រះមនុស្សទាំងអស់នៅលើពិភពលោក នេះ (វវ ២០:១១–១៥)។

**៦:១** *បើអ្នកណាមានរឿងទាស់នឹងអ្នកឯទៀត* ពាក្យថា "រឿង" ត្រង់ចំណុចនេះ គឺសំដៅលើទំនាស់ផ្នែករដ្ឋប្បវេណីប៉ុណ្ណោះ (ខ.៧)។ ក្នុងករណីទោសឧក្រិដ្ឋ គឺជាភារកិច្ចរបស់តុលាការនៃប្រទេសនីមួយៗវិញ (រម ១៣:៣–៤)។ម្យ៉ាងទៀតពួកជំនុំនៅទីក្រុងកូរិនថូស គឺជាបងប្អូននឹងគ្នា ដូច្នេះនៅពេលមានទំនាស់ផ្នែករដ្ឋប្បវេណីក្នុងចំណោមពួកគេ គួរតែដោះស្រាយនៅចំពោះពួកអ្នកដឹកនាំរបស់ខ្លួន ហើយមិនគួរធ្វើការប្ដឹងប្ដល់គ្នារហូតដល់តុលាការនៃរដ្ឋាភិបាលទេ ។

**៦:២** *ពួកបរិសុទ្ធនឹងជំនុំជំរះលោកីយ* ឃ្លានេះបញ្ជាក់យ៉ាងច្បាស់ថា ពួកអ្នកដែលជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ នឹងជំនុំជម្រះលោកិយជាមួយនឹងទ្រង់ នៅថ្ងៃដែលទ្រង់យាងមកជាលើកទីពីរ (មថ ១៩:២៨ ២ធថ ២:១២ វវ ២០:៤)។ *ជំនុំជំរះការណ៍តូចបំផុត* ពាក្យថា "ការណ៍តូចបំផុត" ក្នុងបទគម្ពីរនេះ សំដៅលើបញ្ហាទាំងឡាយ ដែលកើតឡើងនៅក្នុងពួកជំនុំ ។ ដូច្នេះ ពួកបរិសុទ្ធមានសិទ្ធិសម្រេចសេចក្ដីចំពោះបញ្ហា ដែលកើតមានឡើងរវាងពួកបងប្អូនរបស់ខ្លួន ដោយមានការដឹកនាំមកពីព្រះអម្ចាស់ ។

**៦:៣** *យើងរាល់គ្នានឹងជំនុំជំរះ ដល់ទាំងពួកទេវតា* "សូមប្រៀបធៀបនឹង ២ពត ២:៤,៩ យដ ៦"។

**៦:៤–៧** ត្រង់ចំណុចនេះបញ្ជាក់ថា ការដែលយករឿងប្ដឹងប្ដល់រវាងពួកបងប្អូនជាអ្នកជឿដល់ព្រះអម្ចាស់ទៅឱ្យតុលាការរបស់លោកីយ ជាអ្នកជំនុំជម្រះ គឺជាការមិនត្រឹមត្រូវទេ ។ ប្រសិនបើមានបញ្ហាទំនាស់កើតឡើងនៅក្នុងពួកជំនុំ ត្រូវចេះអត់ទោសឱ្យគ្នា និងត្រូវរកដំណោះស្រាយ ដែលប្រកបដោយសេចក្ដី ស្រលាញ់មក អំពីព្រះអម្ចាស់ (មថ ៥:២៥,៣៩–៤១)។

សេចក្ដីខ្មាសវិញ[ម] តើគ្មានអ្នកមានប្រាជ្ញាណា ក្នុងពួកអ្នក
រាល់គ្នា សូម្បីតែមួយ ដែលអាចនឹងជំនុំជំរះរឿង ដែលពួក
បងប្អូនប្ដឹងប្ដល់គ្នាទេឬអី[យ] ៦បានជាពួកបងប្អូន[រ] កើត
ក្ដីនឹងគ្នា ហើយនៅមុខពួកអ្នកដែលមិនជឿផងដូច្នេះ[ល]
៧យ៉ាងនោះ មានពេញជាការកំហុស ក្នុងពួកអ្នករាល់
គ្នាហើយគឺដែលគ្រាន់តែកើតក្ដីនឹងគ្នាទៅវិញទៅមកនោះ
ឯង ហេតុអ្វីបានជាមិនស៊ូទ្រាំក្នុងការអាក្រក់នោះ ហើយ
មិនស៊ូទ្រាំឱ្យគេបំបាត់អ្នកវិញ[វ] ៨តែអ្នករាល់គ្នាធ្វើបាប
ហើយបំបាត់គេ ទាំងប្រព្រឹត្តដូច្នោះនឹងពួកបងប្អូនផង[ស]
៩តើមិនដឹងថា ពួកមនុស្សទុច្ចរិតមិនដែលបានគ្រងនគរ
ព្រះទុកជាមរដកទេឬអី[ហ] កុំឱ្យច្រឡំឡើយ[ឡ] ដ្បិតពួកមនុស្ស
កំផិត ពួកថ្វាយបង្គំរូបព្រះ ពួកសាហាយស្មន់[អ] ពួកអ្នក
សំរេចកិច្ចដោយខ្លួនឯង ពួកលេងកូនដឹង[ក] ១០ពួកចោរ ពួក
មនុស្សលោភ ពួកប្រមឹក ពួកត្មះតិះដៀល និងពួកប្លន់
កំហែង[ខ] នោះមិនដែលបានគ្រងនគរព្រះទុកជាមរដក
ឡើយ ១១ឯពួកអ្នករាល់គ្នាខ្លះ ពីដើមក៏ជាមនុស្សយ៉ាង
ដូច្នោះដែរ[គ] តែបានលាងស្អាតហើយ[ឃ] ក៏បានញែកជា
បរិសុទ្ធ[ង] ហើយរាប់ជាសុចរិតផង[ច] ដោយនូវព្រះនាមព្រះ
អម្ចាស់យេស៊ូវ និងព្រះវិញ្ញាណរបស់ព្រះនៃយើងរាល់គ្នា។

## ការផិតក្បត់

១២ខ្ញុំមានច្បាប់នឹងធ្វើគ្រប់ការទាំងអស់បាន ប៉ុន្តែមិន
មែនការទាំងនោះមានប្រយោជន៍ទាំងអស់ទេ[ឆ] ខ្ញុំមានច្បាប់
នឹងធ្វើគ្រប់ទាំងអស់បានមែន ប៉ុន្តែខ្ញុំមិនព្រមចុះចូលក្នុង
អំណាចនៃការណាមួយនោះសោះ ១៣ឯចំណីអាហារនោះ
សំរាប់ក្រពះ ហើយក្រពះក៏សំរាប់ចំណីអាហារដែរ តែព្រះ
ទ្រង់នឹងឱ្យទាំង ២ យ៉ាងសាបសូន្យទៅ[ជ] ឯរូបកាយមិនមែន
សំរាប់ការកំផិតទេ គឺសំរាប់តែព្រះអម្ចាស់វិញ[ឈ] ហើយ
ព្រះអម្ចាស់ក៏សំរាប់រូបកាយដែរ ១៤ព្រះទ្រង់បានទាំង
ប្រោសឱ្យព្រះអម្ចាស់រស់ឡើងវិញ[ញ] ហើយនឹងប្រោសឱ្យ
យើងរាល់គ្នារស់ឡើងដែរ ដោយសារព្រះចេស្ដានៃទ្រង់[ដ]
១៥តើមិនដឹងថា រូបកាយអ្នករាល់គ្នា ជាអវយវៈរបស់ព្រះ
គ្រីស្ទទេឬអី[ឋ] ដូច្នេះ តើខ្ញុំនឹងយកអវយវៈរបស់ព្រះគ្រីស្ទ
ឱ្យទៅធ្វើជាអវយវៈរបស់ស្រីសំផឹងវិញឬ ទេ មិនត្រូវ
ឡើយ ១៦ចុះតើអ្នករាល់គ្នាមិនដឹងទេឬអីថា អ្នកណាដែល
ទៅសេពសម្ពពនឹងស្រីសំផឹង នោះជារូបសាច់តែ ១ ផងគ្នា
ដ្បិតព្រះទ្រង់មានបន្ទូលថា «អ្នកទាំង ២ នឹងទៅជាសាច់
តែ ១»[ឌ] ១៧ឯអ្នកដែលនៅជាប់នឹងព្រះអម្ចាស់ នោះក៏ជា
វិញ្ញាណតែ ១ នឹងទ្រង់ដែរ[ឍ] ១៨ចូររត់ពីការសហាយស្មន់
ចេញ[ណ] គ្រប់ទាំងអំពើបាបណាដែលមនុស្សប្រព្រឹត្តនោះនៅ

**៦:៥** ម ១កថ ៤:១៤
យ កថ ១:១៥
**៦:៦** រ រម ៧:១
ល ២កថ ៦:១៤,១៥
១ធថ ៥:៨
**៦:៧** វ មថ
៥:៣៩,៤០
**៦:៨** ស ១ថន ៤:៦
**៦:៩** ហ មថ ២៥:៣៤
ឡ យប ១៣:៩
១កថ ១៥:៣៣
កទ ៦:៧ យក ១:១៦
អ លវ ១៨:២០
ចទ ២២:២២
ក លវ ១៨:២២
**៦:១០** ខ ១ធថ ១:១០
វវ ២១:៨ ២២:១៥
**៦:១១** គ អភ ២:២
ឃ កថ ២២:១៦
ង ១កថ ១:២
ច រម ៤:២៥
**៦:១២** ឆ ១កថ
១០:២៣
**៦:១៣** ជ កល ២:២២
ឈ ខ.១៥,១៩
រម ១២:១
**៦:១៤** ញ កថ
២:២៤
ដ រម ៦:៥ អភ ១:១៩,២០ ១ថន ៤:១៦
**៦:១៥** ឋ រម ១២:៥ **៦:១៦** ឌ លប ២:២៤ មថ ១៩:៥ អភ ៥:៣១

---

**៦:៩–១០** "មើលការពន្យល់ រម ១:២៩–៣១"។

**៦:៩** *ពួកមនុស្សទុច្ចរិតមិនដែលបានគ្រងនគរព្រះទុកជាមរដកទេ* (អភ ៥:៥)។ *ពួកអ្នកសំរេចកិច្ចដោយខ្លួនឯង* ឃ្លានេះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសសរសេរថា"បុរសពេស្យាចារ"។ *ពួកលេងកូនដឹង* ឃ្លានេះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសសរសេរថា"ពួករួមភេទដូចគ្នា"(រម ១:២៦)។

**៦:១១** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា អស់អ្នកណាដែលប្រែចិត្តទទួលជឿដល់ ព្រះយេស៊ូវគ្រីស្ទ នោះគេបានទទួលនូវការសង្គ្រោះមកអំពីទ្រង់ ហើយអំពើបាប ដែលគេបានប្រព្រឹត្តនៅអតីតកាល ក៏ត្រូវបានលាងជម្រះ និងអត់ទោសឱ្យដែរ ។ *បានញែកជាបរិសុទ្ធ* "មើលការពន្យល់ ១:២"។ *សុចរិត* "មើលការពន្យល់ រម ៣:២៤"។

**៦:១២** ពួកជំនុំនៅឯទីក្រុងកូរិនថូសតែងតែនិយាយថា ខ្លួនមានច្បាប់នឹងធ្វើគ្រប់ការទាំងអស់បាន ហើយសកម្មភាពមួយចំនួនរបស់ពួកគេធ្វើឱ្យបងប្អូនរួមជំនឿមានការឈឺចាប់ និងបាក់ទឹកចិត្ត ។ ដូច្នេះ ទើបលោកប៉ុលសរសេរសំបុត្រផ្ញើទៅពួកគេ ដោយបានបញ្ជាក់យ៉ាងច្បាស់ថា ការដែលព្រះអម្ចាស់បានសុគតលោះបាបពួកគេ គឺមិនមែនឱ្យពួកគេប្រើសេរីភាពរបស់ខ្លួន ដើម្បីធ្វើការអាក្រក់នោះទេ (ខ.១៣ ៧:១ រម ១៤:២១ ១ពត ២:១៦ មើលការពន្យល់ ១០:២៣)។

**៦:១៣** *ចំណីអាហារ នោះសំរាប់ក្រពះ ហើយក្រពះក៏សំរាប់ចំណីអាហារដែរ* ពួកជំនុំនៅទីក្រុងកូរិនថូសតែងតែលើកយកឃ្លានេះមកនិយាយដោយពួកគេយល់ថា សកម្មភាពខាងក្រៅ (សកម្មភាពដែលផ្ទុយនឹងព្រះបន្ទូល) របស់មនុស្សពុំមានអ្វីប៉ះពាល់ដល់ព្រលឹងវិញ្ញាណដែលនៅខាងក្នុងនោះទេ ដូចជាការហូបអាហារដូច្នោះដែរ ប៉ុន្តែលោកប៉ុលបានពន្យល់ពួកគេយ៉ាងច្បាស់ថាការដែលពួកគេយល់ដូច្នោះ គឺមិនត្រឹមត្រូវទេ ។ ម្យ៉ាងទៀតពួកគេយល់ច្រឡំថា អំពើផិតក្បត់គឺជាសកម្មភាពខាងក្រៅ ហើយគ្មានអ្វីប៉ះពាល់ដល់ព្រលឹងវិញ្ញាណរបស់ពួកគេទេ ដូច្នោះហើយ បានជាលោកប៉ុលពន្យល់ពួកគេឱ្យបានយល់យ៉ាងច្បាស់ថា ការដែលពួកគេគិតនោះគឺខុសទាំងស្រុង ។

**៦:១៤** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ដោយព្រោះព្រះយេស៊ូវគ្រីស្ទបានរស់ពីសុគតឡើងវិញ នោះពួកអ្នកដែលទទួលជឿដល់ព្រះនាមទ្រង់ក៏បានរស់ឡើងវិញដែរ (១៥:៥១–៥៣ ១ថន ៤:១៦–១៧ រម ៦:៥,៨ ៨:១១ អភ ២:៦ ភល ៣:២០–២១)។

**៦:១៥** *អវយវៈរបស់ព្រះគ្រីស្ទ* ឃ្លានេះសំដៅលើរូបកាយ និងព្រលឹងវិញ្ញាណរបស់ពួកអ្នកដែលទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ (១២:២៧)។

**៦:១៦** *ជារូបសាច់តែ១* មានន័យថា នៅពេលមានការរួមភេទ មនុស្សពីរនាក់គឺក្លាយជាសាច់តែមួយ (លប ២:២៤ មថ ១៩:៤–៥) ហើយជាទូទៅនឹងបង្កើតឱ្យមានមនុស្សថ្មីម្នាក់ទៀត ។ ដូច្នេះការរួមភេទជាមួយអ្នកដទៃក្រៅពីប្ដី ឬប្រពន្ធរបស់ខ្លួន គឺជាទង្វើមួយប្រឆាំងនឹងព្រះបន្ទូលនៃព្រះអម្ចាស់ទាំងស្រុង ។

**៦:១៧** *ជាវិញ្ញាណតែ១* មានន័យថា ពួកអ្នកដែលទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ នោះបានរួមមកឯទ្រង់តែមួយខាងឯវិញ្ញាណ ។

**៦:១៨** *អ្នកណាដែលសហាយស្មន់គ្នា នោះឈ្មោះថាធ្វើបាបដល់រូបកាយខ្លួន*

ខាងក្រៅរូបកាយទេ តែអ្នកណាដែលសហាយស្មន់គ្នា នោះ
ឈ្មោះថាធ្វើបាបដល់រូបកាយខ្លួនឯងផង[ត] ១៩ តើមិនដឹងទេ
ឬអីថា រូបកាយអ្នករាល់គ្នាជាវិហារ[ថ] នៃព្រះវិញ្ញាណ
បរិសុទ្ធ ដែលអ្នករាល់គ្នាបានទទួលមកពីព្រះ ហើយអ្នក
រាល់គ្នាមិនមែនជារបស់ផងខ្លួនទេ[ទ] ២០ ដ្បិតព្រះទ្រង់បាន
ចេញថ្លៃលោះអ្នករាល់គ្នាហើយ[ធ] ដូច្នេះ ចូរដំកើងព្រះនៅ
ក្នុងរូបកាយ ហើយក្នុង វិញ្ញាណនៃអ្នករាល់គ្នា ដែលជា
របស់ផងទ្រង់ចុះ[ន]។

## អាពាហ៍ពិពាហ៍

**៧** ១ ឯសេចក្ដីដែលអ្នករាល់គ្នាបានផ្ញើទៅសួរខ្ញុំ នោះខ្ញុំ
យល់ឃើញថា បើមនុស្សប្រុសមិនដែលប៉ះពាល់នឹងស្រី
សោះ នោះល្អជាជាង[ប] ២ តែដោយព្រោះមានការសហាយ
ស្មន់កើតឡើង បានជាគួរឱ្យគ្រប់គ្នាមានប្រពន្ធជារបស់ផង
ខ្លួនវិញ ហើយគ្រប់ទាំងស្រីក៏ត្រូវមានប្ដីជារបស់ផងខ្លួនដែរ
៣ ត្រូវឱ្យប្ដីប្រព្រឹត្តនឹងប្រពន្ធដោយចិត្តសប្បុរស[ផ] ហើយត្រូវ
ឱ្យប្រពន្ធប្រព្រឹត្តនឹងប្ដីក៏ដូច្នោះដែរ ៤ ប្រពន្ធមិនមែនជា
ម្ចាស់លើរូបកាយខ្លួនឯងទេ គឺជាប្ដីវិញ ហើយប្ដីក៏មិនមែន
ជាម្ចាស់លើរូបកាយខ្លួនឯងដែរ គឺជាប្រពន្ធវិញ ៥ ដូច្នេះ កុំ
ឱ្យបង្អត់គ្នាឡើយ លើកតែស្រុះចិត្តគ្នាក្នុង១ពេល[ព] ដើម្បីឱ្យ
បានទំនេរនឹងអធិស្ឋាន រួចត្រូវវិលមកនៅជាមួយគ្នាវិញ
ក្រែងអារក្សសាតាំង[ភ] ល្បួងលួងអ្នករាល់គ្នា[ម] ដោយមិនចេះ
អត់ទ្រាំ ៦ ប៉ុន្តែ ខ្ញុំនិយាយសេចក្ដីនេះ ដោយអាធ្យាស្រ័យ
ទេ មិនមែនដោយបង្គាប់ឡើយ[យ] ៧ ខ្ញុំចូលចិត្តឱ្យគ្រប់មនុស្ស
ទាំងអស់បានដូចជាខ្ញុំ[រ] តែគ្រប់គ្នាមានអំណោយទានមកពី
ព្រះផ្សេងគ្នារៀងខ្លួន គឺម្នាក់យ៉ាងនេះ ម្នាក់យ៉ាងនោះ[ល]
៨ ខ្ញុំក៏និយាយចំពោះនឹងពួកក្រមុំ កំឡោះ ហើយនិងពួក
មេម៉ាយថា បើគេនៅដូចជាខ្ញុំ នោះល្អហើយ[វ] ៩ ប៉ុន្តែ បើអ្នក
ទាំងនោះអត់ទ្រាំមិនបាន នោះចូរយកប្ដីប្រពន្ធចុះ[ស] ដ្បិត
ដែលយកប្ដីប្រពន្ធ នោះជាជាងទ្រាំឱ្យមានសេចក្ដីរោល
រាលវិញ ១០ ឯខាងអ្នកដែលមានប្ដីប្រពន្ធហើយ នោះខ្ញុំនឹង
បង្គាប់ដែរ តែមិនគឺខ្ញុំ គឺជាព្រះអម្ចាស់វិញ ទ្រង់បង្គាប់ថា
កុំឱ្យប្រពន្ធលែងប្ដីឡើយ[ហ] ១១ ឬបើបានលែងប្ដីហើយនោះ

**៦:១៧** ឈ យហ ១៧:២១–២៣ រម ៨:៩–១១ កទ ២:២០
**៦:១៨** ណ ខ.៩ ១កថ ៥:១ ២កថ ១២:២១ កទ ៥:១៩ អភ ៥:៣ ១ថន ៤:៣,៤ ហព ១៣:៤ ត រម ៦:១២ ថ យហ ២:២១
**៦:១៩** ទ រម ១៤:៧,៨
**៦:២០** ធ ទដ ៣៤:២ មថ ២០:២៨ កថ ២០:២៨ ១កថ ៧:២៣ វវ ៥:៩ ១៤:៤ ន ភល ១:២០
**៧:១** ប ខ. ៨,២៦
**៧:៣** ផ នក ២១:១០ ១ពត ៣:៧
**៧:៥** ព នក ១៩:១៥ ១សយ ២១:៤,៥

ភ មថ ៤:១០ម ១ថន ៣:៥ **៧:៦** យ ២កថ ៨:៨ **៧:៧** រ ខ.៨ ១កថ ៩:៥ ល មថ ១៩:១១,១២ រម ១២:៦ ១កថ ១២:៤,១១ **៧:៨** វ ខ.១,២៦ **៧:៩** ស ១ធថ ៥:១៤

*ឯង* មានន័យថា រូបកាយគឺជាព្រះវិហារនៃព្រះវិញ្ញាណបរិសុទ្ធ (ខ.១៩) ដូច្នេះ ការប្រើប្រាស់រូបកាយទៅក្នុងអំពើពេស្យាចារ (មើលការពន្យល់ លប ២០:៩ នក ៣៤:១៥) គឺមានឈ្មោះថា បានធ្វើឱ្យខូចដល់ព្រះវិហារនៃព្រះអម្ចាស់ហើយ ។ ម្យ៉ាងទៀតនៅសម័យកាលលោកប៉ុល ការប្រព្រឹត្តិអំពើពេស្យាចារនៅក្នុងទីក្រុង កូរិនថូស គឺដើម្បីឧទ្ទិសដល់រូបព្រះអាប្រូឌីត (Aphrodite) ដែលពួកគេជឿថា ជាព្រះនៃក្ដីស្រឡាញ់ និងការរួមភេទ (មើលការពន្យល់ ៧:២)។

**៦:១៩** *អ្នករាល់គ្នាមិនមែនជារបស់ផងខ្លួនទេ* គឺជារបស់ផងព្រះអម្ចាស់វិញ (មើលការពន្យល់ ១ពត ២:៩)។

**៦:២០** *ព្រះទ្រង់បានចេញថ្លៃលោះអ្នករាល់គ្នា*" មើលពន្យល់ ៧:២៣"។ *ចូរដំកើងព្រះនៅក្នុងរូបកាយ* "មើលការពន្យល់ រម ៦:១២–១៣ ប្រៀបធៀបជាមួយ ១កថ ១០:៣១"។

**៧:១** *សេចក្ដីដែលអ្នករាល់គ្នាបានផ្ញើទៅសួរខ្ញុំ* ឃ្លានេះបញ្ជាក់ថា ពួកជំនុំនៅទីក្រុងកូរិនថូសបានសរសេរសំបុត្រទៅសួរលោកប៉ុលនូវសំណួរ ជាច្រើន ដែលទាក់ទងទៅនឹងបញ្ហាជីវិតរបស់គ្រីស្ទបរិស័ទ និងបញ្ហានៅក្នុងពួកជំនុំរបស់ខ្លួន ។ សំណួរទីមួយដែលពួកគេសួរទៅលោកប៉ុលគឺ "តើ ការរៀបការជាការល្អដែរឬទេ?" ចម្លើយរបស់លោកប៉ុលគឺមាននៅក្នុងជំពូក៧នេះ (៨:១ ១២:១ ១៦:១ អភ ៥:២២–២៣ កល ៣:១៨–១៩ ១ធថ ៣:២,១២ ៥:១៤ មើលការពន្យល់ ខ.២៦,២៨ ៦:១២–១៣,១៨)។

**៧:២** *ដោយព្រោះមានការសហាយស្មន់កើតឡើង* លោកប៉ុលនិយាយយ៉ាងដូច្នេះ ព្រោះថាពេលនោះមានការគោរពដល់រូបព្រះអាប្រូឌីតនៅក្នុងទីក្រុងកូរិនថូសត្រង់ទីទួលខ្ពស់មួយ ក្បែរទីក្រុងនេះតែម្ដង ដែលពេលខ្លះមានពួកសង្ឃជាស្ត្រីពេស្យាចារបានមកចូលរួមរហូតដល់១000នាក់ (មើលការពន្យល់ ៦:១៨)។

**៧:៣–៤** ត្រង់ចំណុចនេះបញ្ជាក់ថា ប្ដី និងប្រពន្ធត្រូវចេះបំពេញគ្នាទៅវិញទៅមកជាពិសេសគឺសំដៅលើទំនាក់ទំនងផ្លូវភេទ ដើម្បីជៀសវាងអំពើផិតក្បត់កើតឡើង (ខ.៥)។

**៧:៥** *កុំឱ្យបង្អត់គ្នាឡើយ* ឃ្លានេះសំដៅលើទំនាក់ទំនងផ្លូវភេទរវាងប្ដី និងប្រពន្ធរបស់ខ្លួន គឺត្រូវចេះបំពេញគ្នាទៅវិញទៅមក ។ *ក្រែងអារក្សសាតាំងល្បួងលួងអ្នករាល់គ្នា ដោយមិនចេះអត់ទ្រាំ* ត្រង់ចំណុចនេះបញ្ជាក់ ថាប្ដី និងប្រពន្ធ ត្រូវ តែប្រុងប្រយ័ត្នចំពោះបញ្ហាទំនាក់ទំនងផ្លូវភេទ ព្រោះថា ប្រសិនបើមិនបានបំពេញគ្នាឱ្យបានគ្រប់គ្រាន់ទេ នោះវានឹងអាចបណ្ដាលឱ្យកើតមានអំពើផិតក្បត់ជាមិនខាន ។

**៧:៦** *សេចក្ដីនេះ* គឺសំដៅលើសេចក្ដីដែលលោកប៉ុលនិយាយនៅក្នុង "ខ.២"។ លោកប៉ុលមិនបានបង្គាប់បញ្ជាពួកជំនុំ នៅទីក្រុងកូរិនថូសទាំងអស់ថាត្រូវតែមានប្ដី ឬប្រពន្ធនោះទេ ។ គាត់យល់ថាមនុស្សភាគច្រើនត្រូវការមានប្ដី ឬប្រពន្ធ ដើម្បីជៀសវាងកុំឱ្យមានអំពើសហាយស្មន់កើតឡើងនៅក្នុងជីវិតរបស់ខ្លួន ។

**៧:៧** *ខ្ញុំចូលចិត្តឱ្យគ្រប់មនុស្សទាំងអស់បានដូចជាខ្ញុំ* មានន័យថា លោកប៉ុលចង់ឱ្យមនុស្សទាំងអស់នៅលីវដូចគាត់ដែរ ប្រសិនបើអាចធ្វើបាន ។ ទោះជាយ៉ាងណាក៏ដោយ ក៏គាត់បានបញ្ជាក់បន្ថែមទៀតថា ការដែលមនុស្សម្នាក់អាចរស់នៅដោយមិនយកប្ដី ឬប្រពន្ធគឺជាអំណោយទានមកពីព្រះអម្ចាស់ ។

**៧:១០** សេចក្ដីនៅក្នុងបទគម្ពីរនេះ គឺជាបញ្ញត្តិដែលព្រះយេស៊ូវគ្រីស្ទប្រទានមកពួកអ្នកដែលដើរតាមទ្រង់ កាលពីទ្រង់គង់នៅជាមួយពួកសិស្សរបស់ទ្រង់នៅលើ ផែនដីនៅឡើយ (មថ ៥:៣២ ១៩:៣–៩ មក ១០:២–១២ លក ១៦:១៨)។ លោកប៉ុលប្រហែលជាបានទទួលបញ្ញត្តិនៅក្នុងបទគម្ពីរ

ចូរនៅជាឥតប្ដីទៅចុះ ឬឱ្យជានឹងប្ដីខ្លួនវិញទៅ[ឃ] ហើយឯប្ដី
ក៏កុំ ឱ្យលែងប្រពន្ធខ្លួនដែរ ។
១២ឯមនុស្សឯទៀត មិនមែនព្រះអម្ចាស់មានបន្ទូលទេ[អ]
គឺខ្លួនខ្ញុំនិយាយថា បើបងប្អូនណាមានប្រពន្ធដែលមិនជឿ
តែព្រមនៅជាមួយនឹងខ្លួន នោះមិនត្រូវលះចោលនាង
ឡើយ ១៣ហើយស្ត្រីណាមានប្ដីដែលមិនជឿ តែព្រមនៅ
ជាមួយនឹងនាង នោះក៏មិនត្រូវឱ្យនាងលះចោលគេដែរ
១៤ដ្បិតប្ដីដែលមិនជឿ នោះបានរាប់ជាស្អាតដោយសារ
ប្រពន្ធ ហើយប្រពន្ធដែលមិនជឿក៏ដោយសារប្ដីដែរ ពុំ
នោះ កូនចៅគេមិនស្អាតទេ តែឥឡូវនេះ វាស្អាតហើយ[ក]
១៥តែបើអ្នកដែលមិនជឿគេដកខ្លួនចេញ នោះឱ្យគេចេញ
ចុះ យ៉ាងនោះ បងប្អូនប្រុសឬស្រី នឹងមិននៅជាប់ចំណង
ទៀតទេ ប៉ុន្តែ ព្រះទ្រង់បានហៅយើងរាល់គ្នា ឱ្យមាន
សេចក្ដីមេត្រីនឹងគ្នាវិញ[ខ] ១៦ដ្បិតឱស្ត្រីអើយ ប្រហែល
ជានាងនឹងសង្គ្រោះ[គ]ប្ដីបានទេដឹង[ឃ] ឬបុរសអើយ ប្រហែល
ជា អ្នកនឹងសង្គ្រោះប្រពន្ធបានដែរទេដឹង ១៧តែត្រូវឱ្យ
គ្រប់គ្នាដើរតាមដែលព្រះអម្ចាស់បានចែកឱ្យ ហើយតាម
ដែលព្រះបានហៅមករៀងខ្លួន[ង] ខ្ញុំក៏តាំងរបៀបយ៉ាង

**៧:១០** ហ មឡ ២:១៤–១៦ លក ១៦:១៨
**៧:១១** ឡ ខ.៣៩ រម ៧:២,៣
**៧:១២** អ ខ.៦,១០ ២កថ ១១:១៧
**៧:១៤** ក មឡ ២:១៥
**៧:១៥** ខ រម ១៤:១៩ ១កថ ១៤:៣៣
**៧:១៦** គ រម ១១:១៤ ឃ ១ពត ៣:១
**៧:១៧** ង រម ១២:៣ ច ស ១កថ ៤:១៧ ១៤:៣៣ ២កថ ៨:១៨ ១១:២៨
**៧:១៨** ឆ កច ១៥:១,២
**៧:១៩** ជ រម ២:២៥–២៧ កទ ៥:៦ ៦:១៥ កល ៣:១១
**៧:២០** ឈ ខ.២៤

ដូច្នេះ ក្នុងគ្រប់ទាំងពួកជំនុំដែរ[ច] ១៨បើទ្រង់បានហៅអ្នក
ណាដែលកាត់ស្បែកហើយ កុំឱ្យអ្នកនោះត្រឡប់ដូចជាមិន
កាត់ស្បែកវិញឡើយ បើទ្រង់ហៅអ្នកណាដែលមិនបាន
កាត់ស្បែក កុំឱ្យអ្នកនោះកាត់ស្បែកឱ្យសោះ[ឆ] ១៩ព្រោះ
ការកាត់ស្បែកមិនជាអ្វីទេ ឬដែលមិនកាត់ស្បែក នោះក៏
មិនជាអ្វីដែរ[ជ] តែដែលមានប្រយោជន៍ នោះគឺស្រេចនឹង
កាន់តាមបញ្ញត្តិរបស់ព្រះវិញ ២០បើមនុស្សមានសណ្ឋាន
ជាយ៉ាងណា ក្នុងកាលដែលព្រះទ្រង់ហៅ នោះឱ្យប្រព្រឹត្ត
តាមសណ្ឋាននោះចុះ[ឈ] ២១កាលទ្រង់ហៅអ្នកមក តើអ្នកជា
បាវបំរើគេឬអី កុំឱ្យព្រួយពីសេចក្ដីនោះឡើយ តែបើអាច
នឹងដោះខ្លួនរួច នោះស៊ូដោះខ្លួនចេញទៅ ២២ដ្បិតអ្នកណា
ដែលធ្វើជាបាវបំរើគេ ក្នុងកាលដែលព្រះអម្ចាស់ហៅមក
នោះជាអ្នកជារបស់ព្រះអម្ចាស់[ញ] ហើយអ្នកជាណាដែល
ទ្រង់ហៅមក នោះជាបាវបំរើនៃព្រះគ្រីស្ទវិញ[ដ] ២៣ទ្រង់បាន
ចេញថ្លៃលោះអ្នករាល់គ្នាហើយ[ឋ] ដូច្នេះ កុំឱ្យត្រឡប់ជាបាវ
បំរើរបស់មនុស្សទៀតឡើយ ២៤បងប្អូនអើយ អ្នករាល់គ្នា

**៧:២២** ញ យហ ៨:៣២,៣៦ ដ រម ៦:២២ **៧:២៣** ឋ ១កថ ៦:២០

នេះ តាមរយៈពួកសាវ័កដទៃទៀតរបស់ព្រះអម្ចាស់ (កទ ១:១៨–១៩) ។

**៧:១១** ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ចំពោះបុរស ឬស្ត្រីដែលរៀបការហើយ នោះមិនត្រូវលែងលះគ្នាឡើយ ។ ប្រសិនបើមានករណីលែងលះគ្នាកើតឡើងត្រូវឱ្យផ្សះផ្សាគ្នាវិញ ។

**៧:១២–១៣** សេចក្ដីនៅក្នុងបទគម្ពីរទាំងនេះ គឺនិយាយសំដៅលើប្ដីប្រពន្ធដែលបានរៀបការរួចហើយ ។ បន្ទាប់មកម្នាក់ក្នុងចំណោមទាំងពីរបានទទួលជឿដល់ព្រះអម្ចាស់ ។ ដូច្នេះត្រូវរស់នៅជាមួយគ្នាមិនឱ្យលែងលះគ្នាឡើយប៉ុន្តែបើអ្នកដែលមិនជឿគេដកខ្លួនចេញនោះឱ្យគេចេញចុះ (ខ.១៥) ។

**៧:១៤** *ដ្បិតប្ដីដែលមិនជឿ នោះបានរាប់ជាស្អាតដោយសារប្រពន្ធ* ឃ្លានេះមិនមែនមានន័យថា ប្ដីដែលមិនជឿដល់ព្រះអម្ចាស់បានទទួលការសង្គ្រោះដោយសារមានប្រពន្ធជាអ្នកជឿនោះទេ ។ ព្រះអម្ចាស់មានព្រះបន្ទូលយ៉ាងប្រាកដច្បាស់ថា សេចក្ដីសង្គ្រោះ គឺបានដល់អស់អ្នកដែលទទួលជឿដល់ព្រះនាមទ្រង់ប៉ុណ្ណោះ មិនមែនតាមរយៈមនុស្សណាម្នាក់ទេ ។ ការដែលលោកប៉ុលនិយាយយ៉ាងដូច្នេះ គឺបញ្ជាក់ថា ភាពបរិសុទ្ធ និងព្រះពរដែលព្រះអម្ចាស់បានប្រទានឱ្យដល់ប្រពន្ធ ដែលបានទទួលជឿដល់ព្រះនាមទ្រង់ក៏មានឥទ្ធិពលទៅលើប្ដីដែលមិនជឿផងដែរ (១:២ លប ៧:៧ ៣៩:៤–៥) ។

**៧:១៥** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា បើប្ដី ឬប្រពន្ធដែលមិនជឿគេដកខ្លួនចេញ នោះឱ្យគេចេញចុះ (មើលការពន្យល់ ខ.១២–១៣) ។

**៧:១៦** បទគម្ពីរនេះបញ្ជាក់ថា ប្ដី ឬប្រពន្ធដែលជឿដល់ព្រះអម្ចាស់រួចហើយត្រូវព្យាយាមអធិស្ឋានយ៉ាងអស់ពីចិត្តឱ្យប្រពន្ធ ឬប្ដីរបស់ខ្លួនដែលមិនជឿដើម្បីឱ្យបានទទួលការសង្គ្រោះពីទ្រង់ដូចជាខ្លួនផងដែរ (១ពត ៣:១–២) ។

**៧:១៧** ការដែលមនុស្សម្នាក់ទទួលជឿដល់ព្រះអម្ចាស់ នោះគេទទួលបានជីវិត ថ្មីខាងឯវិញ្ញាណ ប៉ុន្តែ ពុំមែនមានន័យថា ធ្វើឱ្យផ្លាស់ប្ដូរឋានៈសង្គម–របស់គេទេ ។ ម្យ៉ាងទៀតអ្នកណាដែលមានប្ដី ឬប្រពន្ធជាអ្នកមិនជឿដល់ព្រះអម្ចាស់ត្រូវឱ្យបន្តរស់នៅជាមួយគ្នា និងមិនត្រូវលែងលះគ្នាឡើយ (មើលការពន្យល់ ខ.១១,១២,១៣) ។

**៧:១៨–១៩** ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ការកាត់ស្បែក ឬមិនកាត់ស្បែកពុំមែនជាការសំខាន់ទេ ។ រីឯការដែលសំខាន់បំផុតនោះគឺការប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ និងការធ្វើតាមព្រះហឫទ័យទ្រង់ (យហ ១៤:២១ កច ១៥:១–៥ កទ ៣:២៨ ៥:១–៣ មើលការពន្យល់ កទ ៥:៦) ។

**៧:២០–២១** ព្រះអម្ចាស់ទ្រង់ជ្រាប និងអាចបំផ្លាស់បំប្រែហេតុការណ៍ទាំងឡាយដែលយើងជួបប្រទះក្នុងការរស់នៅប្រចាំថ្ងៃ ។ ប្រសិនបើអ្នកណាម្នាក់ជាអ្នកបម្រើគេ នោះព្រះអម្ចាស់អាចរំដោះគេឱ្យមានសេរីភាពវិញបាន ។ ម្យ៉ាងទៀត ការដែលចង់រួចផុតពីភាពជាបាវបម្រើគេ មិនមែនជាការខុសឆ្គងអ្វីទេ ប៉ុន្តែ ត្រូវដឹងថាមិនត្រូវធ្វើអ្វីដោយបង្ខំតាមបំណងចិត្តរបស់ខ្លួនឡើយ គឺត្រូវធ្វើតាមព្រះហឫទ័យនៃព្រះអម្ចាស់វិញ (យហ ៨:៣២,៣៦) ។

**៧:២២** *ជាអ្នកជារបស់ព្រះអម្ចាស់* មានន័យថា អស់អ្នកណាដែលទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ នោះគេបានរួចផុតពីអំណាចនៃសេចក្ដីស្លាប់ (យហ ៨:៣៤,៣៦ រម ៦:១៨,២២ ពត ២:១៦ មើលការពន្យល់ ហព ៩:១៥) ហើយទ្រង់ប្រទានឱ្យ គេនូវសេរីភាពគ្រប់គ្រាន់ នៅក្នុងការសរសើរតម្កើងទ្រង់ និងការបម្រើទ្រង់ (នក ៦:៦–៧ ១៩:៤–៦) ។

**៧:២៣** *ទ្រង់បានចេញថ្លៃលោះអ្នករាល់គ្នា* បញ្ជាក់ថា គ្រីស្ទបរិស័ទគ្រប់ៗរូប គឺព្រះអម្ចាស់បានចេញថ្លៃលោះ ឱ្យបានរួចផុតពីអំណាចនៃសេចក្ដីងងឹតមកវិញ ដោយសារការបង្ហូរព្រះលោហិតទ្រង់នៅលើឈើឆ្កាង (៦:២០ ១ពត ១:១៨,១៩ មើលការពន្យល់ ១:១៨) ។

មានសណ្ឋានយ៉ាងណា ក្នុងកាលដែលព្រះទ្រង់ហៅមក
នោះឱ្យប្រព្រឹត្តតាមសណ្ឋាននោះ នៅចំពោះទ្រង់ចុះ[ឌ]។
២៥ឯត្រង់ពួកស្រីក្រមុំៗ ខ្ញុំគ្មានទទួលសេចក្ដីបង្គាប់ ពី
ព្រះអម្ចាស់មកទេ[ឍ] តែខ្ញុំសំដែងដោយគំនិតខ្ញុំ ទុកដូចជាបាន
ទទួលសេចក្ដីមេត្តាករុណាមកពីព្រះអម្ចាស់[ណ] ឱ្យបានគួរជឿ
ដែរ ២៦ដូច្នេះ ដោយព្រោះគ្រាលំបាកនេះ ខ្ញុំស្មានជាយ៉ាង
នេះបានស្រួល គឺថាគួរឱ្យមនុស្សនៅតែដដែលវិញ[ត] ២៧តើ
ជាប់មានប្រពន្ធឬអី កុំឱ្យរកផ្លូវនឹងលែងគ្នាឡើយ បើមិន
ទាន់ជាប់មានប្រពន្ធនៅឡើយ នោះក៏កុំឱ្យរកប្រពន្ធដែរ[ថ]
២៨ប៉ុន្តែ បើអ្នកបានយកប្រពន្ធហើយ នោះមិនមែនហៅថា
មានបាបទេ[ទ] ហើយបើស្ត្រីក្រមុំណាយកប្ដីហើយ នាងនោះ
ក៏មិនមែនហៅថាមានបាបដែរ តែពួកអ្នកយ៉ាងនោះនឹង
មានសេចក្ដីទុក្ខព្រួយខាងសាច់ឈាម ណ្ហើយ ខ្ញុំឈប់ស្ដែះ
ប៉ុណ្ណោះចុះ ដោយព្រោះអាណិតដល់អ្នករាល់គ្នា ។
២៩បងប្អូនអើយ ខ្ញុំប្រាប់សេចក្ដីនេះថា ពេលវេលា
ចង្អៀតណាស់ហើយ[ធ] ពីនេះទៅមុខ គួរតែឱ្យពួកអ្នកដែល
មានប្រពន្ធ បាននៅដូចជាគ្មានវិញ ៣០ពួកដែលយំ
ដូចជាមិនយំ ពួកដែលអរសប្បាយ ដូចជាមិនអរសប្បាយ
ពួកដែលទិញ ដូចជាគ្មានអ្វីសោះ ៣១ហើយពួកអ្នកដែល
ប្រើប្រាស់លោកីយនេះ ដូចជាមិនប្រើហួសខ្នាតទេ ដ្បិត
គំរូនៃលោកីយនេះតែងតែផ្លាស់ទៅ[ន] ៣២ខ្ញុំចង់ឱ្យអ្នក
រាល់គ្នាបានរួចពីសេចក្ដីកង្វល់ ឯអ្នកដែលគ្មានប្រពន្ធ
នោះតែងរវល់តែនឹងការរបស់ព្រះអម្ចាស់[ប] ដែលនឹងធ្វើ
ដូចម្ដេចឱ្យទ្រង់សព្វព្រះហឫទ័យប៉ុណ្ណោះ ៣៣តែអ្នកណា
ដែលមានប្រពន្ធ នោះតែងរវល់នឹងការនៅ លោកីយ
នេះវិញ ដែលនឹងធ្វើដូចម្ដេច ឱ្យប្រពន្ធបានពេញចិត្ត
៣៤ស្ត្រីមានប្ដី នឹងស្ត្រីក្រមុំក៏ខុសពីគ្នាយ៉ាងនោះដែរ គឺ
ស្ត្រីដែលគ្មានប្ដី នោះតែងរវល់នឹងការរបស់ព្រះអម្ចាស់ ឱ្យ
បានបរិសុទ្ធទាំងខ្លួនប្រាណ នឹងព្រលឹងវិញ្ញាណផង[ផ] តែស្ត្រី
ណាដែលមានប្ដី នោះតែងរវល់នឹងការនៅលោកីយនេះ
វិញ ដែលនឹងធ្វើដូចម្ដេចឱ្យប្ដីបានពេញចិត្ត ៣៥ដែលខ្ញុំ
និយាយសេចក្ដីនេះ នោះសំរាប់ជាប្រយោជន៍ដល់អ្នករាល់
គ្នា មិនមែនជាការដាក់អន្ទាក់រូតនៅមុខអ្នករាល់គ្នាទេ គឺ
សំរាប់ការដែលគួរគប្បី ហើយឱ្យអ្នករាល់គ្នាបានឧស្សាហ៍
បំរើព្រះអម្ចាស់ ឥតមានសេចក្ដីណានាំឱ្យទាស់ចិត្តឡើយ[ព]
៣៦បើមានអ្នកណាស្មានថា មិនគួរគប្បីចំពោះកូនក្រមុំ
ដែលហួសអាយុគ្រប់ការហើយ ក៏មានសេចក្ដីបង្ខំក្នុងការ
នោះដែរ នោះឱ្យឪពុកធ្វើតាមចិត្តទៅ គឺឱ្យកូនយកប្ដីចុះ
គ្មានបាបទេ[ភ] ៣៧តែឪពុកអ្នកណាដែលមានចិត្តដាច់ ឥតមាន
សេចក្ដីបង្ខំទេ គឺមានអំណាចនឹងសំរេចដោយខ្លួនឯងបាន
ហើយបានតាំងចិត្តថា នឹងទុកកូនឱ្យនៅជាក្រមុំដរាបទៅ
នោះក៏ស្រួលហើយ ៣៨បានជាអ្នកដែលឱ្យកូនទៅគេ ក៏បាន
ប្រព្រឹត្តល្អ[ម] ហើយអ្នកដែលមិនឱ្យកូនទៅគេ នោះក៏ប្រព្រឹត្ត
ល្អជាងទៅទៀត ៣៩កាលប្ដីនៅរស់នៅឡើយ[យ] នោះប្រពន្ធ
ត្រូវតែជាប់នៅក្នុងចំណងរបស់ប្ដីជាដរាប តែបើកាល
ណាប្ដីស្លាប់ទៅ នោះនាងមានច្បាប់នឹងយកប្ដីបានតាមចិត្ត
ឱ្យតែយកក្នុងព្រះអម្ចាស់[រ] ៤០ប៉ុន្តែ តាមគំនិតខ្ញុំយល់ថា[ល]
បើនាងនោះនៅតែមេម៉ាយតទៅ នោះនាងបានសប្បាយ
ជាង ហើយខ្ញុំស្មានថា ខ្ញុំមានវិញ្ញាណនៃព្រះដែរ ។

**៧:២៤** ឌ ខ.២០
**៧:២៥** ឍ ខ.៦
២កថ ៨:៨
ណ ២កថ ៤:១
១ធថ ១:១៣,១៦
**៧:២៦** ត ខ.១,៨
**៧:២៧** ថ ខ.២០,២១
**៧:២៨** ទ ខ.៣៦
**៧:២៩** ធ ខ.៣១ រម
១៣:១១,១២
**៧:៣១** ន ខ.២៩
ហេព ១២:២៧
**៧:៣២** ប ២ធថ ៥:៥
**៧:៣៤** ផ លក ២:៣៧
**៧:៣៥** ព ទដ ៨៦:១១
**៧:៣៦** ភ ខ.២៨
**៧:៣៨** ម ហេព ១៣:៤
**៧:៣៩** យ រម
៧:២,៣
រ ២កថ ៦:១៤
**៧:៤០** ល ខ.២៥

**៧:២៥** *ពួកស្រីក្រមុំៗ* ត្រង់ចំណុចនេះ នៅក្នុងព្រះគម្ពីរបរិសុទ្ធជាភាសាក្រិក មិនមែននិយាយសំដៅចំពោះតែស្រីក្រមុំប៉ុណ្ណោះទេ គឺនិយាយចំពោះទាំងបុរស និងស្ត្រីដែលមិនទាន់រៀបការនៅឡើយ ។

**៧:២៦** *គ្រាលំបាកនេះ* លោកប៉ុលនិយាយដូច្នេះ ប្រហែលសំដៅលើស្ថានភាព ដ៏លំបាកដែលកើតឡើងចំពោះជីវិតគ្រីស្ទបរិស័ទជាពិសេសនៅតំបន់ណាដែល មានការបៀតបៀនច្រើនពីសំណាក់អ្នកប្រឆាំង (ខ.២,២៨ ៥:១ ២ធថ ៣:១២)។

**៧:២៨** *មានសេចក្ដីទុក្ខព្រួយខាងសាច់ឈាម* ឃ្លានេះបញ្ជាក់ថា ក្នុងគ្រាមានទុក្ខលំបាកនោះអស់អ្នកដែលរៀបការ និងមានកូនចៅ គឺមានទំនួលខុសត្រូវច្រើន ជាងពួកអ្នកដែលនៅលីវ ។

**៧:២៩** *បងប្អូនអើយ* (មើលការពន្យល់ រម ១:១៣)។

**៧:៣១** *ដ្បិតគំរូនៃលោកីយនេះតែងតែផ្លាស់ទៅ* (សូមប្រៀបធៀបជាមួយនឹង ១យហ ២:១៧)។

**៧:៣២-៣៤** លោកប៉ុលយល់ថា ការរស់នៅលីវគឺជាការប្រសើរ ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅក្នុងបទគម្ពីរខាងលើបានបញ្ជាក់យ៉ាងច្បាស់ថា ការមានប្ដី ឬប្រពន្ធមិនមែនជាបាបទេ ។

**៧:៣៩** *កាលប្ដីនៅរស់នៅឡើយ នោះប្រពន្ធត្រូវតែជាប់នៅក្នុងចំណងរបស់ប្ដីជាដរាប* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ប្ដី និងប្រពន្ធដែលបានរៀបការ រួចហើយ គឺត្រូវរស់នៅជាមួយគ្នារហូត ។ *តែបើកាលណាប្ដីស្លាប់ . . . ព្រះអម្ចាស់* មានន័យថា នៅពេលប្ដី ឬប្រពន្ធស្លាប់ នោះអ្នកដែលនៅមានជីវិតរស់ត្រូវ បានរួចផុតពីចំណងអាពាហ៍ពិពាហ៍ ហើយមានសិទ្ធិរៀបការជាមួយម្នាក់ ទៀតដែលជឿ ដល់ព្រះអម្ចាស់ ។

**៧:៤០** ក្នុងបទគម្ពីរនេះ លោកប៉ុលយល់ថា ការដែលស្ត្រីមេម៉ាយបន្តរស់នៅក្នុងភាពជាស្ត្រីមេម៉ាយ នោះជាការប្រសើរ ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅក្នុងបទគម្ពីរ "១ធថ ៥:១៤" លោកប៉ុលបានបញ្ជាក់ថា ចំពោះស្រីមេម៉ាយប្ដីស្លាប់ដែលនៅក្មេងគួរ តែរៀបការជាមួយនឹងម្នាក់ទៀតដែលជឿដល់ព្រះអម្ចាស់ ។

## អំពីអាហារដែលថ្វាយទៅរូបព្រះ

**៨** ១ឯត្រង់ភោជនាហារ ដែលបានថ្វាយទៅរូបព្រះ[រ] នោះ
យើងរាល់គ្នាដឹងថា (ដ្បិតយើងទាំងអស់គ្នាមានចំណេះ[ស]
រីឯចំណេះ នោះនាំឱ្យចិត្តប៉ោងឡើង តែសេចក្តីស្រឡាញ់
ស្អាងចិត្តឡើងវិញ ២បើអ្នកណាស្មានថាខ្លួនចេះអ្វី[ហ] នោះមិន
ទាន់បានចេះតាមដែលគួរចេះនៅឡើយទេ[ឡ] ៣តែបើអ្នក
ណាស្រឡាញ់ព្រះ ទ្រង់ក៏ស្គាល់អ្នកនោះ[អ]) ៤ឯដំណើរបរិ
ភោគភោជនាហារ ដែលបានថ្វាយទៅរូបព្រះ[ក] នោះយើង
ដឹងថា ក្នុងលោកីយនេះ រូបព្រះមិនជាអ្វី ទេ[ខ] ហើយថាគ្មាន
ព្រះណាទៀត ក្រៅពីព្រះតែ១ឡើយ[គ] ៥ដ្បិត ថ្វីបើមានអ្វី
ដែលហៅថាព្រះ[ឃ] ទោះនៅលើមេឃ ឬនៅផែនដីក្តី ដូច
ជាមានព្រះជាច្រើន នឹងម្ចាស់ជាច្រើនមែន ៦គង់តែខាង
យើង មានព្រះតែ១ប៉ុណ្ណោះ[ង] គឺជាព្រះវរបិតា[ច] ដែលរបស់
សព្វសារពើកើតមកពីទ្រង់[ឆ] ហើយយើងរាល់គ្នាក៏សំរាប់
ទ្រង់ ក៏មានព្រះអម្ចាស់តែ១[ជ] គឺជាព្រះយេស៊ូវគ្រីស្ទ
ដែលរបស់សព្វសារពើកើតមក[ឈ]ដោយសារទ្រង់ ហើយ
យើងក៏ដោយសារទ្រង់ដែរ ៧តែមនុស្សទាំងអស់គ្មានចំ
ណេះនេះទេ[ញ] មានអ្នកខ្លះ នៅតែកោតខ្លាចចំពោះរូបព្រះ
ហើយគេបរិភោគភោជនាហារទាំងនោះ ទុកដូចជាដង្វាយ
ថ្វាយទៅរូបព្រះលុះមកដល់សព្វថ្ងៃនេះ ម្ល៉ោះហើយបញ្ញា
ចិត្តគេដែលខ្សោយ[ដ] នោះត្រូវស្មោកគ្រោកទៅវិញ ៨ប៉ុន្តែ
ចំណីអាហារ មិនមែនជាគ្រឿង ដែលនាំឱ្យព្រះរាប់អាន
យើងទេ[ឋ] ដ្បិតបើយើងបរិភោគ នោះមិនមែនមានបំណាច់
អ្វី ហើយបើមិនបរិភោគទេ នោះយើងក៏មិនខ្វះអ្វីដែរ ៩តែ
ត្រូវប្រយ័ត ក្រែងអំណាចយើងនេះ បានបង្កើតជាហេតុ[ឌ]នាំ
ឱ្យ ពួកកំសោយជំពប់ដួល[ឍ] ១០ដ្បិត បើអ្នកណាឃើញអ្នក
ឯងដែលមានចំណេះ កំពុងតែអង្គុយបរិភោគ ក្នុងវិហារ
មានរូបព្រះ នោះតើមិនបានកំឡាចិត្តអ្នកកំសោយ ឱ្យបរិភោគ
ដង្វាយដែលបានថ្វាយដល់រូបព្រះដែរទេឬអី ១១ដូច្នេះ
បងប្អូនកំសោយ ដែលព្រះគ្រីស្ទបានសុគតជំនួស គេនឹង
ត្រូវវិនាស[ណ]ដោយសារចំណេះរបស់អ្នកវិញ ១២យ៉ាង
នោះដែលធ្វើបាបនឹងពួកបងប្អូន[ត] ហើយធ្វើឱ្យបញ្ញាចិត្ត
កំសោយរបស់គេត្រូវរបួស នោះឈ្មោះថាធ្វើបាបនឹងព្រះ
គ្រីស្ទដែរ[ទ] ១៣ហេតុដូច្នេះ បើសិនជាចំណីអាហារអ្វី នាំ
ឱ្យបងប្អូនខ្ញុំជំពប់ដួល នោះខ្ញុំមិនព្រមទទួលទានចំណីអា
ហារនោះជាដរាបតទៅ ក្រែងបងប្អូនខ្ញុំជំពប់ដួល[ធ]។

**៨:១** រ ខ.៤,៧,១០ កច ១៥:២០ ស រម ១៥:១៤ **៨:២** ហ ១កថ ៣:១៨ ឡ ១កថ ១៣:៨,៩,១២ ១ធថ ៦:៤ **៨:៣** អ យរ ១:៥ រម ៨:២៩ កទ ៤:៩ **៨:៤** ក ខ.១,៧,១០ នក ៣៤:១៥ ខ កច ១៤:១៥ ១កថ ១០:១៩ កទ ៤:៨ គ ខ.៦ ចទ ៦:៤ ទដ ៨៦:១០ អភ ៤:៦ ១ធថ ២:៥ **៨:៥** ឃ ២ថន ២:៤ **៨:៦** ង ខ.៤ ច មឡ ២:១០ ឆ រម១១:៣៦ ជ អភ ៤:៥ ឈ យហ ១:៣ **៨:៧** ញ ខ.១ ដ រម ១៤:១៤ ១កថ ១០:២៨ **៨:៨** ឋ រម ១៤:១៧ **៨:៩** ឌ ២កថ ៦:៣ កទ ៥:១៣ ឍ រម ១៤:១ **៨:១០** ណ ខ.១,៤,៧ **៨:១១** ត រម ១៤:១៥,២០ **៨:១២** ថ មថ ១៨:៦ ទ មថ ២៥:៤០,៤៥ **៨:១៣** ធ មថ ៥:២៩

**៨:១** *ឯត្រង់ភោជនាហារ* ឃ្លានេះបញ្ជាក់ថា ពួកជំនុំនៅឯទីក្រុងកូរិនថូសបានសរសេរសំបុត្រទៅសួរលោកប៉ុលអំពីបញ្ហាផ្សេងៗ ទាក់ទងនឹងការបរិភោគអាហារ (មើលការពន្យល់ ៧:១)។ *ថ្វាយទៅរូបព្រះ* ត្រង់ ចំណុចនេះបញ្ជាក់ថា នៅពេលនោះមានពួកអ្នកដែលគោរពប្រតិបត្តិដល់រូបព្រះ និងតែងតែយកសាច់សត្វទៅធ្វើជាយញ្ញបូជា ។ ពួកសង្ឃ ឬអ្នកថ្វាយយញ្ញបូជា និងមិត្តភក្តិរបស់ពួកគេ អាចបរិភោគសាច់សត្វដែលនៅសល់បាន (ខ.១០)។ ម្យ៉ាងទៀត សាច់សត្វដែលនៅសល់អាចត្រូវបានពួកគេយកទៅលក់នៅតាមផ្សារទៀតផង ។ ដូច្នេះហើយបានជាពួកជំនុំ នៅទីក្រុងកូរិនថូសមួយចំនួនគិតថា ការដែលបរិភោគសាច់សត្វទាំងនោះ គឺមានន័យថាបានរួមចំណែកនៅក្នុងការថ្វាយបង្គំដល់រូបព្រះដែរ ។ រីឯអ្នកជឿដល់ព្រះអម្ចាស់មួយចំនួនទៀតយល់ថា ការបរិភោគសាច់សត្វទាំងនោះមិនមែនជាបញ្ហាអ្វីទេ ។ *ចំណេះ* "មើលការពន្យល់ ខ.២–៦"។ *ចិត្តប៉ោងឡើង* មានន័យថា ចិត្តពេញទៅដោយសេចក្តីអំនួត ។ *សេចក្តីស្រឡាញ់ស្អាងចិត្តឡើង* (មើលការពន្យល់ ខ.៧–១៣)។

**៨:២** *មិនទាន់បានចេះតាមដែលគួរចេះនៅឡើយ* លោកប៉ុលនិយាយយ៉ាងដូច្នេះបញ្ជាក់ថា ទោះបីអ្នកណាម្នាក់ជឿដល់ព្រះអម្ចាស់យូរឆ្នាំ និងមានចំណេះច្រើនយ៉ាងណាក៏ដោយ ក៏ចំណេះរបស់គេនៅតែមានកម្រិតដែរគឺមានតែព្រះអម្ចាស់ប៉ុណ្ណោះដែលជ្រាបគ្រប់ទាំងអស់ (រម ១១:៣៣–៣៦)។

**៨:៣** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា សេចក្តីស្រលាញ់សំខាន់ណាស់សម្រាប់អស់អ្នកដែលទទួលជឿដល់ព្រះអម្ចាស់ ។ ម្យ៉ាងទៀតយើងអាចទទួលចំណេះមក អំពីព្រះអម្ចាស់ក៏ដោយសារ យើងស្រលាញ់ទ្រង់ដែរ (យក ៣:១៧,១៨ ១យហ ៤:៧,៨)។ ផ្ទុយទៅវិញការដែលមានចំណេះ ប៉ុន្តែគ្មានសេចក្តីស្រលាញ់របស់ព្រះអម្ចាស់ នោះគ្មានន័យអ្វីទេ ។

**៨:៤** *រូបព្រះមិនជាអ្វីទេ* មានន័យថា រូបព្រះមិនមែនជាព្រះដ៏ពិតទេ និងគ្មានអំណាចអ្វីទាំងអស់ (ទដ ១១៥:៤–៧ ១៣៥:១៥–១៧ អស ៤៤:១២–២០)។ ប៉ុន្តែ ការមួយដែលយើងត្រូវយល់ដឹងនោះគឺ ការថ្វាយបង្គំរូបព្រះ មានន័យថាថ្វាយបង្គំដល់អារក្ស (១០:២០)។

**៨:៥** *ដ្បិត ថ្វីបើមានអ្វីដែលហៅថាព្រះ* ឃ្លានេះនិយាយសំដៅលើរូបព្រះរបស់ពួកក្រេក និងរូបព្រះរបស់ពួករ៉ូម៉ាំង ។

**៨:៦** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះអម្ចាស់គឺជាព្រះដ៏ពិត ដែលបង្កើតរបស់សព្វសារពើទាំងអស់ (យហ ១:៣ រម ១១:៣៦ កល ១:១៦ ហព ២:១០ មើលការពន្យល់ ចទ ៦:៤ ហព ១:២)។

**៨:៧** បទគម្ពីរនេះបញ្ជាក់ថា អាហារទាំងអស់សុទ្ធតែស្អាត ប៉ុន្តែ បើអ្នកណាម្នាក់គិតថា អាហារដែលថ្វាយទៅដល់រូបព្រះ គឺជាអាហារមិនស្អាត នោះចូរ កុំឱ្យបរិភោគឡើយ (មក ៧:១៨–១៩ រម ១៤:១៤,២៣)។

**៨:៩–១០** ត្រង់ចំណុចនេះបញ្ជាក់ថា ចំពោះអស់អ្នកដែលយល់ច្បាស់ថា អាហារ ដែលថ្វាយដល់រូបព្រះ គឺជាអាហារស្អាតបរិសុទ្ធ និងអាចបរិភោគបាន នោះចូរបរិភោគចុះ ប៉ុន្តែ ត្រូវប្រយ័ត្ន បើការដែលខ្លួនបរិភោគអាហារនោះ ធ្វើឱ្យបងប្អូន ដទៃបាក់ទឹកចិត្ត នោះចូរកុំបរិភោគឡើយ (ខ.៤ រម ១៤:១៣,១៥,២០–២១)។

**៨:១១–១៣** ការដែលយើងបានយល់ដឹងច្បាស់ថា អាហារទាំងអស់សុទ្ធតែស្អាតបរិសុទ្ធ នោះគឺជាការត្រឹមត្រូវ ។ ប៉ុន្តែ ត្រូវចងចាំថា ប្រសិនបើការ

## សិទ្ធិរបស់សាវ័ក

**៩** ១តើខ្ញុំមិនមែនជាសាវកទេឬអី[ន] តើខ្ញុំមិនមែនជា
អ្នកមានសេរីភាពទេឬអី[ប] តើខ្ញុំមិនបានឃើញព្រះយេស៊ូវ
គ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាទេឬអី[ផ] តើអ្នក
រាល់គ្នាមិនមែនជាស្នាដៃ ដែលខ្ញុំធ្វើក្នុងព្រះអម្ចាស់ទេឬ
អី[ព] ២បើខ្ញុំមិនមែនជាសាវកដល់មនុស្សឯទៀត ក៏គង់តែ
ជាសាវកដល់អ្នករាល់គ្នាដែរ ដ្បិតអ្នករាល់គ្នាជាភស្តុ
តាង[ភ] ពីការងារជាសាវករបស់ខ្ញុំក្នុងព្រះអម្ចាស់ ៣ឯ
សេចក្ដីដោះសាររបស់ខ្ញុំ នៅមុខពួកអ្នកដែលចោទ ប្រកាន់ខ្ញុំ
៤នោះគឺថា តើយើងខ្ញុំគ្មានច្បាប់នឹងទទួលទាន ទេឬអី[ម]
៥តើគ្មានច្បាប់នឹងនាំសិស្សស្រីម្នាក់ ជាប្រពន្ធយើង ខ្ញុំ[យ]
ទៅជាមួយ ដូចជាសាវកឯទៀត និងបងប្អូន[រ]ព្រះអម្ចាស់
ហើយកេផាសដែរទេឬអី[ល] ៦ឬមួយ តើមានតែខ្ញុំ នឹង
បាណាបាស[វ] ដែលគ្មានច្បាប់នឹងលែងធ្វើការរកស៊ីឬអី
៧ចុះតើដែលមានអ្នកណាធ្វើជាទាហាន[ស] ហើយចាយ
តែប្រាក់ខ្លួនឯងឬទេ តើដែលមានអ្នកណាដាំចំការទំពាំង
បាយជូរ[ហ] រួចមិនបរិភោគផលពីចំការនោះ ឬដែលមាន
អ្នកណាឃ្វាលហ្វូងសត្វ ឥតផឹកទឹកដោះវាឬទេ ៨ដែលខ្ញុំ
និយាយសេចក្ដីទាំងនេះ នោះតើតាមតែរបៀបមនុស្ស
ប៉ុណ្ណោះ ឯក្រិត្យវិន័យ តើមិនថាដូច្នេះដែរទេឬ ៩ដ្បិតមាន
សេចក្ដីចែងទុកមក ក្នុងក្រិត្យវិន័យលោកម៉ូសេថា «កុំឲ្យឃ្លុំ
មាត់របស់គោ ដែលបញ្ជាន់ស្រូវឡើយ»[ឡ] នោះតើព្រះទ្រង់
គិតដល់គោតែប៉ុណ្ណោះ[អ] ១០ឬទ្រង់មានបន្ទូលដូច្នោះចំពោះ
ដល់យើងរាល់គ្នាដែរ គឺដោយព្រោះតែយើងរាល់គ្នា
ហើយ បានជាសេចក្ដីនោះបានចែងទុកមក[ក] ដើម្បីឲ្យអ្នក
ណាដែលភ្ជួររាស់ បានភ្ជួររាស់ដោយសង្ឃឹម ហើយអ្នក
ណា ដែលបញ្ជាន់ដោយសង្ឃឹម នោះនឹងបានតាមសេចក្ដី
សង្ឃឹមនោះឯង[ខ] ១១បើសិនជាយើងខ្ញុំបានសាបព្រោះរបស់
ខាងព្រលឹងវិញ្ញាណ នៅក្នុងពួកអ្នករាល់គ្នា ហើយច្រូត
បានរបស់អ្នករាល់គ្នាខាងសាច់ឈាមវិញ នោះតើច្រើន
ហួសពេកឬអី[គ] ១២បើអ្នកឯទៀតមានអំណាចនោះលើអ្នក
រាល់គ្នា នោះតើយើងខ្ញុំមិនត្រូវមានលើសជាងគេទៅទៀត
ទេឬអី ប៉ុន្តែ យើងខ្ញុំមិនបានប្រើអំណាចនោះទេ យើងខ្ញុំ
បានទ្រទ្រង់ទាំងអស់វិញ[ឃ] ដើម្បីមិនឲ្យដំណឹងល្អនៃព្រះ
គ្រីស្ទត្រូវបង្អាក់ឡើយ[ង] ១៣តើមិនដឹងទេឬអី ថាពួកអ្នក
ដែលធ្វើការព្រះ គេបរិភោគដោយសារព្រះវិហារ ហើយ
ពួកអ្នកដែលបំរើអាសនា ក៏បានចំណែកពីអាសនាដែរ[ច]។
១៤ព្រះអម្ចាស់ទ្រង់ក៏បង្គាប់ ឲ្យពួកអ្នកដែលផ្សាយដំ
ណឹងល្អ បានរស់ដោយសារដំណឹងល្អដូច្នោះដែរ[ឆ] ១៥តែ
ខ្ញុំមិនបានប្រើអំណាចណា១នេះទេ[ជ] ខ្ញុំក៏មិនបានសរសេរ
សេចក្ដីទាំងនេះ ដោយប្រាថ្នាចង់ឲ្យគេប្រព្រឹត្តយ៉ាងនោះ
ដល់ខ្លួនខ្ញុំដែរ ខ្ញុំស៊ូតែស្លាប់វិញ ជាជាងឲ្យសេចក្ដីអំនួត
របស់ខ្ញុំនេះត្រូវវិនាស[ឈ] ១៦ពីព្រោះបើខ្ញុំផ្សាយដំណឹង

**៩:១** ន ខ.១៩ ប ១កថ ១:១ ២កថ ១២:១២ ផ ១កថ ១៥:៨ ព ១កថ ៣:៦ ៤:១៥ **៩:២** ភ ២កថ ៣:២,៣ **៩:៤** ម ខ.១៤ កច ១៨:៣ **៩:៥** យ ១កថ ៧:៧,៨ រ មថ ១២:៤៦ ល ១កថ ១:១២ **៩:៦** វ កច ៤:៣៦ **៩:៧** ស ២ធថ ២:៣,៤ ហ ចទ ២០:៦ សភ ២៧:១៨ ១កថ ៣:៦,៨ **៩:៩** ឡ ចទ ២៥:៤ ១ធថ ៥:១៨ អ ចទ ២២:១-៤ សភ ១២:១០ **៩:១០** ក រម ៤:២៣,២៤ ខ សក ១១:២៥ ២ធថ ២:៦ **៩:១១** គ ខ.១៤ រម ១៥:២៧ កទ ៦:៦ **៩:១២** ឃ ខ.១៥,១៨ កច ១៨:៣ ង ២កថ ៦:៣ ១១:៧-១២ **៩:១៣** ច លវ ៦:១៦,២៦ ចទ ១៨:១ **៩:១៤** ឆ ១ធថ ៥:១៨ **៩:១៥** ជ ខ.១២,១៨ កច ១៨:៣ ឈ ២កថ ១១:៩,១០ **៩:១៦** ញ រម ១:១៤ កច ៩:១៥ ២៦:១៦-១៨

ដែលយើងបរិភោគអាហារ ដែលថ្វាយដល់រូបព្រះធ្វើឲ្យបងប្អូនដទៃទៀត ធ្លាក់ទឹកចិត្ត ហើយអាចធ្វើឲ្យបាត់បង់ជំនឿ នោះចូរកុំបរិភោគឲ្យសោះ (មក ៩:៤២ រម ១៤:១៥)។ *នោះឈ្មោះថាធ្វើបាបនឹងព្រះគ្រីស្ទដែរ* (ប្រៀបធៀបនឹង មថ ១០:៤០ ១៨:៥ មក ៩:៣៧ លក ៩:៤៨ រម ១៤:១៩-២១ មើលការពន្យល់ រម ១៤:១៥)។

**៩:១** គ្រីស្ទបរិស័ទមួយចំនួន នៅឯទីក្រុងកូរិនថូស បានចាប់ផ្ដើមប្រឆាំងនឹងលោកប៉ុលដោយចោទថា គាត់មិនមែនជាសាវកពិតប្រាកដទេ ។ លោកប៉ុលបានឆ្លើយតបទៅនឹងការចោទប្រកាន់របស់ពួកគេ ដោយគាត់បានបញ្ជាក់យ៉ាងច្បាស់ថា ព្រះអម្ចាស់បានលេចមកឲ្យគាត់ឃើញ ដោយផ្ទាល់ (កច ១:២១-២២ ៩:១-៩ ២២:៦-១៦ ២៦:១២-១៨)។ ម្យ៉ាងទៀតគាត់បានបង្កើតផលផ្លែខាងវិញ្ញាណ ជាច្រើនថ្វាយដល់ព្រះអម្ចាស់នៅក្នុងដំណើរជីវិតរបស់គាត់។ការទាំងអស់នេះហើយ ដែលធ្វើឲ្យគាត់ពិតជាស័ក្តិសមទទួលងារជាសាវកប្រាកដមែន ។

**៩:៤** *តើយើងខ្ញុំគ្មានច្បាប់នឹងទទួលទានទេឬអី* មានន័យថា ក្នុងនាមជាអ្នកបម្រើរបស់ព្រះអម្ចាស់លោកប៉ុល និងបាណាបាសមានសិទ្ធិគ្រប់គ្រាន់ក្នុងការបរិភោគអាហារដែលពួកជំនុំបានរៀបចំឲ្យពួកគាត់(ខ.១៣-១៤)។

**៩:៥** ក្នុងបទគម្ពីរនេះ មិនមែនមានន័យថា លោកប៉ុលមានប្រពន្ធនោះទេ (មក ១:៣០ មើលការពន្យល់ ៧:៧)។

**៩:៨-៩** លោកប៉ុលមានប្រសាសន៍ថា អ្នកធ្វើការគ្រប់ៗរូបត្រូវតែទទួលបានរង្វាន់ ដូចមានចែងទុកនៅក្នុងគម្ពីរបរិសុទ្ធសញ្ញាចាស់ រួចជាស្រេច (ខ.១០ ចទ ២៥:៤ ១ធថ ៥:១៨ មើលការពន្យល់ យណ ៤:១១)។ ព្រះអម្ចាស់នឹងប្រទានរង្វាន់ដល់អ្នកបម្រើទ្រង់គ្រប់ៗគ្នាទៅតាមការដែលគេធ្វើ

**៩:១០-១១** ត្រង់ចំណុចនេះ លោកប៉ុលបញ្ជាក់ថា អស់អ្នកណាដែលបម្រើការងារថ្វាយព្រះអម្ចាស់នៅក្នុងពួកជំនុំ គឺត្រូវឲ្យពួកជំនុំជួយផ្គត់ផ្គង់អ្នកនោះឲ្យបានសមរម្យ (កទ ៦:៦ ភល ៤:១៤-១៩)។

**៩:១២** សេចក្ដីនៅក្នុងបទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា លោកប៉ុលមានសិទ្ធិបង្គាប់បញ្ជាដល់ពួកជំនុំនៅទីក្រុងកូរិនថូស ប៉ុន្តែ គាត់មិនបានប្រើសិទ្ធិរបស់ខ្លួនទេ ព្រោះគាត់ចង់បង្ហាញពួកគេ ឲ្យដើរតាមផ្លូវរបស់ព្រះអម្ចាស់ដោយសារសេចក្ដីស្រលាញ់វិញ (មើលការពន្យល់ រម ១៤:១៥)។

**៩:១៣** *ពួកអ្នកដែលបំរើអាសនា ក៏បានចំណែកពីអាសនាដែរ* ឃ្លានេះបញ្ជាក់ថា នៅក្នុងក្រិត្យវិន័យរបស់ពួកសាសន៍យូដា អស់អ្នកដែលបម្រើការងារនៅក្នុងវិហារ គឺបានទទួលនូវកម្រៃសម្រាប់ផ្គត់ផ្គង់ការរស់នៅរបស់ខ្លួន (លវ ៧:២៨-៣៦ នក ១៨:៨-៩,១២-១៤)។

**៩:១៦** *ដ្បិតខ្ញុំជាប់ក្នុងសេចក្ដីបង្ខំ* ឃ្លានេះបញ្ជាក់ថា ព្រះអម្ចាស់បានត្រាស់

ល្អទៅ នោះមិនមែនជាហេតុឱ្យខ្ញុំអួតខ្លួនទេ ដ្បិតខ្ញុំជាប់ក្នុង
សេចក្ដីបង្ខំ[ញ] បើខ្ញុំមិនផ្សាយដំណឹងល្អវិញ នោះវរដល់ខ្ញុំ
ហើយ ១៧ បើខ្ញុំធ្វើដោយស្ម័គ្រពីចិត្ត នោះខ្ញុំបានរង្វាន់[ដ] តែ
បើធ្វើទាំងទើសទ័ល នោះគង់តែមានការងារចែកចាយ
ផ្ញើទុកនឹងខ្ញុំដែរ[ឋ] ១៨ ដូច្នេះ តើរង្វាន់ខ្ញុំជាយ៉ាងណា គឺឱ្យ
តែខ្ញុំបានផ្សាយដំណឹងល្អពីព្រះគ្រីស្ទ ដោយឥតយកថ្លៃ
ប៉ុណ្ណោះ[ឌ] ដើម្បីកុំឱ្យខ្ញុំបានប្រើអំណាចខ្លួន[ឍ] ក្នុងដំណឹងល្អ
ហួសល្បត់ឡើយ ១៩ ដ្បិតទោះបើខ្ញុំមិនជាប់បំរើអ្នកណា
សោះក៏ដោយ[ណ] គង់តែខ្ញុំបានត្រឡប់ទៅជាអ្នកបំរើដល់
មនុស្សទាំងអស់វិញ[ត] ដើម្បីឱ្យបានមនុស្សជាច្រើនទៅទៀត[ថ]
២០ ខ្ញុំបានត្រឡប់ ដូចជាសាសន៍យូដា ដល់ពួកសាសន៍យូដា
ដើម្បីឱ្យបានពួកយូដា[ទ] ហើយដូចជានៅក្រោមបន្ទុកក្រិត្យ
វិន័យ ដល់ពួកអ្នកដែលនៅក្រោមបន្ទុកក្រិត្យវិន័យ (តែខ្ញុំ
មិនមែននៅក្រោម បន្ទុកក្រិត្យវិន័យទេ)[ធ] ដើម្បីឱ្យបានពួក
អ្នក ដែលនៅក្នុង បន្ទុកក្រិត្យវិន័យ ២១ ហើយដូចជាឥតក្រិត្យ
វិន័យដល់ពួកអ្នកដែលគ្មានក្រិត្យវិន័យ[ន] (មិនមែនថាខ្ញុំឥត
ក្រិត្យវិន័យរបស់ព្រះទេ គឺខ្ញុំនៅក្នុងក្រិត្យវិន័យព្រះគ្រីស្ទ
វិញ)[ប] ដើម្បីឱ្យបានពួកអ្នកដែលគ្មានក្រិត្យវិន័យដែរ ២២ ខ្ញុំ
បានត្រឡប់ដូចជាខ្សោយដល់ពួកអ្នកកំសោយ ដើម្បីឱ្យបាន
ពួកកំសោយ[ផ] គឺបានត្រឡប់ជាគ្រប់សណ្ឋានទាំងអស់

**៩:១៧** ដ ១កថ ៣:៨,១៤
ឋ ១កថ ៤:១
កទ ២:៧ កល ១:២៥
**៩:១៨** ឌ ២កថ ១១:៧ ១២:១៣
ឍ ខ.១២,១៥
**៩:១៩** ណ ខ.១
ត ២កថ ៤:៥
កទ ៥:១៣
ថ មថ ១៨:១៥
១ពត ៣:១
**៩:២០** ទ កថ ១៦:៣ ២១:២០–២៦ រម ១១:១៤ ធ រម ២:១២
**៩:២១** ន រម ២:១២ ,១៤ ប កទ ៦:២
**៩:២២** ផ រម ១៤:១ ១កថ ២:៣

ព ១កថ ១០:៣៣ ភ រម ១១:១៤
**៩:២៤** ម ភល ៣:១៤ កល ២:១៨ យ ខ.២៥,២៦ កទ ២:២ ៥:៧ ភល ២:១៦ ២ធថ ៤:៧ ហព ១២:១

ដល់មនុស្សទាំងអស់[ព] ប្រយោជន៍ឱ្យបានសង្គ្រោះដល់អ្នកខ្លះ
ដោយសារសណ្ឋាន ទាំងនោះឯង[ភ] ២៣ ខ្ញុំធ្វើការទាំងនោះ
ដោយយល់ដល់តែដំណឹងល្អ ដើម្បីឱ្យខ្ញុំបានចំណែកជាមួយ
គ្នាក្នុងដំណឹងល្អ ។
២៤ តើអ្នករាល់គ្នាមិនដឹងទេឬអី ថាពួកអ្នកដែលរត់នៅទី
ប្រណាំង គេរត់ទាំងអស់គ្នា ប៉ុន្តែ មានតែ១ទេដែលបាន
រង្វាន់[ម] ដូច្នេះ ចូររត់[យ] បែបឱ្យបានរង្វាន់ចុះ ២៥ ហើយអស់
អ្នកដែលតយុទ្ធគ្នា គេខំអត់សង្កត់ចិត្តគ្រប់ជំពូក គឺធ្វើដូច្នោះ
ដើម្បីឱ្យបានតែភួងជ័យ[រ] ដែលត្រូវពុករលួយ តែយើងរាល់
គ្នាវិញ គឺឱ្យបានមកុដ១ ដែលមិនចេះពុករលួយឡើយ[ល]
២៦ បានជាខ្ញុំខំរត់យ៉ាងដូច្នោះ មិនមែនបែបដូចជាមិនស្គាល់
ផ្លូវទេ[វ] ខ្ញុំក៏ខំប្រដាល់យ៉ាងដូច្នោះដែរ មិនមែនដូចជាដាល់
ខ្យល់ទេ[ស] ២៧ គឺខ្ញុំវាយដំរូបកាយខ្ញុំ[ហ] ទាំងបង្ខំឱ្យចុះចូល ក្រែង
ក្រោយដែលខ្ញុំបានប្រដៅមនុស្សឯទៀតហើយ នោះខ្លួនខ្ញុំ
ត្រូវចោលចេញវិញ[ឡ]។

## ការព្រមានតាមរយៈប្រវត្តិសាស្ត្រអ៊ីស្រាអែល

**១០** ១ បងប្អូនអើយ ខ្ញុំមិនចង់ឱ្យអ្នករាល់គ្នានៅល្ងង់[អ] ពី
ដំណើរពួកព្ឋយុកោយើងទេ ថាគេបាននៅក្រោមពពក

**៩:២៥** រ ២ធថ ២:៥ ល ២ធថ ៤:៨ យក ១:១២ ១ពត ៥:៤ វវ ២:១០ ៣:១១ **៩:២៦** វ ខ.២៤ ស ១ធថ ៦:១២ **៩:២៧** ហ រម ៨:១៣ ឡ ខ.២៤

ហៅលោកប៉ុលឱ្យប្រកាសដំណឹងល្អដល់ពួកអ្នកដែលបាត់បង់ប្រយោជន៍ឱ្យពួកគេបានសេចក្ដីសង្គ្រោះមកអំពីទ្រង់ (ខ.២៧ យរ ២០:៩ កថ ៩:១–១៦ ២៦:១៦–១៨)។

**៩:១៨** *រង្វាន់ខ្ញុំ . . . គឺឱ្យតែខ្ញុំបានផ្សាយដំណឹងល្អ* មានន័យថា លោកប៉ុលមិនចង់បានអ្វីពីពួកជំនុំនៅទីក្រុងកូរិនថូសទេ គឺគាត់ចង់ឱ្យដំណឹងល្អរបស់ព្រះអម្ចាស់បានចម្រើនឡើងវិញ (ខ.៣–១២)។

**៩:១៩** *ខ្ញុំបានត្រឡប់ទៅជាអ្នកបំរើដល់មនុស្សទាំងអស់វិញ* ឃ្លានេះបញ្ជាក់ថា លោកប៉ុលមិនគ្រាន់តែមិនប្រើសិទ្ធិបង្គាប់បញ្ជាដល់ពួក ជំនុំប៉ុណ្ណោះទេ គឺគាត់ថែមទាំងបន្ទាបខ្លួនធ្វើជាអ្នកបម្រើដល់ពួកគេវិញ ។

**៩:២០** *ពួកអ្នកដែលនៅក្រោមបន្ទុកក្រិត្យវិន័យ* សំដៅលើពួកអ្នកដែលស្ថិតនៅក្រោមក្រិត្យវិន័យនៃសញ្ញាចាស់ និងពួកអ្នកដែលគោរពប្រតិបត្តិតាមគោលលទ្ធិរបស់សាសនាផ្សេងៗ (ពួកយូដា)។ម្យ៉ាងទៀត បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា លោកប៉ុលបានប្រឹងប្រែងយ៉ាងអស់ពីចិត្ត ដើម្បីជួយពួកអ្នកទាំងនោះ ឱ្យបានស្គាល់សេចក្ដីពិតនៃព្រះអម្ចាស់ (កថ ១៦:៣ ២១:២០–២៦ មើលពន្យល់ កថ ១៨:១៨ ២១:២៣–២៤)។

**៩:២១** *ពួកអ្នកដែលគ្មានក្រិត្យវិន័យ* សំដៅលើពួកសាសន៍ដទៃដែលមិនបានស្គាល់ក្រិត្យវិន័យនៃសញ្ញាចាស់ ។

**៩:២២** *ខ្ញុំបានត្រឡប់ដូចជាខ្សោយ* ឃ្លានេះបញ្ជាក់ថា លោកប៉ុលមិនបានប្រើនូវសេរីភាពរបស់ខ្លួន ធ្វើឱ្យអ្នកណាម្នាក់បាក់ទឹកចិត្តទេ ។ ផ្ទុយទៅវិញ គឺគាត់ព្យាយាមធ្វើយ៉ាងណា ឱ្យអ្នកជឿដល់ព្រះអម្ចាស់គ្រប់រូបបានរឹងមាំនៅក្នុងសេចក្ដីជំនឿ ។ *ពួកអ្នកកំសោយ* គឺពួកអ្នកដែលមានបញ្ញាចិត្តនៅខ្សោយ (៨:៩–១២)។

**៩:២៣** ក្នុងបទគម្ពីរនេះ លោកប៉ុលមានសេចក្ដីសង្ឃឹមនៅក្នុងចិត្តថា គាត់នឹងបានរួមចំណែកនៅក្នុងសិរីល្អនៃព្រះអម្ចាស់ ជាមួយនឹងបងប្អូនដទៃៗទៀតដែលជឿដល់ទ្រង់ (២កថ ៣:១–៣ ៥:១០ ភល ២:១៦ មើលការពន្យល់ ខ.២៧ ១ថន ២:១៩–២០)។

**៩:២៤** *ពួកអ្នកដែលរត់នៅទីប្រណាំង* អ្នកឈ្នះនៅក្នុងទីរត់ប្រណាំងនាសម័យនោះ គឺទទួលបាននូវកម្រងផ្កាមួយ ដែលជានិមិត្តរូបនៃជ័យជម្នះ (ខ.២៥)។ លោកប៉ុលមានប្រសាសន៍ជាពាក្យប្រៀបប្រដូចនេះ គឺដើម្បីធ្វើឱ្យពួកជំនុំនៅក្រុងកូរិនថូសងាយយល់នូវសេចក្ដីបង្រៀនរបស់គាត់ ។

**៩:២៥** *មកុដ១ . . . ពុករលួយ* (មើលពន្យល់ ១ពត ៥:៤ ១ថន ២:១៩)។

**៩:២៦** *មិនមែន . . . មិនស្គាល់ផ្លូវទេ* (មើលការពន្យល់ ភល ៣:១៤)។

**៩:២៧** *ខ្ញុំវាយដំរូបកាយខ្ញុំ ទាំងបង្ខំឱ្យចុះចូល* ត្រង់ចំណុចនេះ លោកប៉ុលប្រៀបធៀបជីវិតរបស់គ្រីស្ទបរិស័ទ ដូចជាកីឡាករម្នាក់ដែរ ។ មានន័យថា គាត់ត្រូវ ហ្វឹកហ្វឺនខ្លួនគាត់យ៉ាងតឹងរ៉ឹងបំផុត នៅក្នុងការបម្រើព្រះអម្ចាស់ (៣:១០–១៥)។

**១០:១** *ពពក . . . សមុទ្រ* ពពក និងសមុទ្រគឺជានិមិត្តរូបដែលរំឭកឱ្យដឹងអំពីព្រះរាជកិច្ចរបស់ព្រះអម្ចាស់ ក្នុងការរំដោះពួកអ៊ីស្រាអែលឱ្យរួចផុតពីភាពជាទាសកររបស់ពួកអេស៊ីព្ទ តាមរយៈលោកម៉ូសេជាអ្នកបម្រើរបស់ទ្រង់ ។ *ពពក* ជានិមិត្តរូបតំណាងឱ្យការដឹកនាំមកពីព្រះអម្ចាស់ (នក ១៣:២១ ៤០:៣៦–៣៧ ជន ៩:១៧,២១ ១០:១១–១២ ១៤:១៤ នហ ៩:១២,១៩ ទដ ៧៨:១៤)។ *សមុទ្រ* ជានិមិត្តរូបតំណាងឱ្យព្រះរាជកិច្ចដ៏

ទាំងអស់គ្នា[ក] ហើយគ្រប់គ្នាបានដើរកាត់សមុទ្រ[ខ] ២ គ្រប់គ្នា
បានទទួលបុណ្យជ្រមុជក្នុង[គ]ពពក ហើយក្នុងសមុទ្រនោះ ឱ្យ
បានតាមលោកម៉ូសេ ៣ គ្រប់គ្នាបានបរិភោគចំណីអាហារ
ដដែលខាងព្រលឹងវិញ្ញាណ[ឃ] ៤ ហើយគ្រប់គ្នាបានផឹកទឹក
ដដែលខាងព្រលឹងវិញ្ញាណដែរ ដ្បិតបានផឹកពីថ្មដា[ង]ខាង
ព្រលឹងវិញ្ញាណដែលតាមគេ ឯថ្មដានោះ គឺជាព្រះគ្រីស្ទ
៥ ប៉ុន្តែ ព្រះទ្រង់មិនពេញព្រះហឫទ័យនឹងគេជាច្រើនគ្នាទេ
ដ្បិតគេត្រូវដួលស្លាប់រាត់រាយ នៅក្នុងទីរហោស្ថាន[ច] ៦ ការ
ទាំងនោះបានត្រឡប់ជាគំរូ[ឆ]ដល់យើង ប្រយោជន៍កុំឱ្យ
យើងប្រាថ្នាចង់បានសេចក្តីអាក្រក់ ដូចជាគេឡើយ ៧ ឬ
ថ្វាយបង្គំរូបព្រះ[ជ] ដូចជាពួកគេខ្លះបានថ្វាយដែរ ដូចមាន
សេចក្តីចែងទុកមកថា «បណ្តាជនបានអង្គុយស៊ីផឹក រួច
ក្រោកឡើងលេងសប្បាយ»[ឈ] ៨ ឬប្រព្រឹត្តសេចក្តីកំផិត ដូច
ជាពួកគេខ្លះបានប្រព្រឹត្ត ហើយមាន២ម៉ឺន៣ពាន់នាក់ បាន
ត្រូវវិនាសក្នុង១ថ្ងៃនោះឯង[ញ] ៩ ឬល្បងព្រះគ្រីស្ទ[ដ] ដូចជាពួក
គេខ្លះបានល្បងទ្រង់ ហើយត្រូវវិនាសទៅ ដោយពស់ចឹក[ឋ]
១០ ក៏កុំឱ្យត្អូញត្អែរ ដូចជាពួកគេខ្លះបានត្អូញត្អែរ[ឌ] ហើយត្រូវ
វិនាស[ឍ]ដោយមេបំផ្លាញនោះឡើយ[ណ] ១១ រីឯការទាំងនោះ
បានកើតមកដល់គេ ទុកជាគំរូ[ត] ហើយបានកត់ទុក សំរាប់ជា
សេចក្តីទូន្មានប្រដៅ ដល់យើងរាល់គ្នា[ថ] ដែលយើងនៅគ្រា
ចុងបំផុតនៃអស់ទាំងកល្ប[ទ] ១២ បានជាអ្នកណាដែលស្មាន
ថាខ្លួនឈរ[ធ] នោះត្រូវប្រយ័ត ក្រែងលោដួល ១៣ ដ្បិតគ្មាន
សេចក្តីល្បួងណាកើតដល់អ្នករាល់គ្នា ក្រៅពីសេចក្តីល្បួង
ដែលត្រូវខាងមនុស្សលោកទេ រីឯព្រះទ្រង់ក៏ស្មោះត្រង់
ដែរ[ន]ទ្រង់មិនឱ្យកើតមានសេចក្តីល្បួងហួសកំឡាំងអ្នករាល់
គ្នាឡើយ[ប] គឺនៅវេលាណាដែលត្រូវល្បួង នោះទ្រង់ក៏រៀប
ផ្លូវឱ្យចៀសរួច ដើម្បីឱ្យអ្នករាល់គ្នាអាចនឹងទ្រាំបាន ។

**១០:១** អ រម ១១:២៥ ក នក ១៣:២១ ទដ ១០៥:៣៩ ខ នក ១៤:២២,២៩ ទដ ៦៦:៦ **១០:២** គ រម ៦:៣ **១០:៣** ឃ យហ ៦:៣១ **១០:៤** ង នក ១៧:៦ ជន ២០:១១ ទដ ៧៨:១៥ ១០៥:៤១ **១០:៥** ច ជន ១៤:២៩ ហព ៣:១៧ យដ ៥ **១០:៦** ឆ ខ.១១ **១០:៧** ជ ខ.១៤ ឈ នក ៣២:៤,៦,១៩ **១០:៨** ញ ជន ២៥:១-៩ **១០:៩** ដ នក ១៧:២ ទដ ៧៨:១៨ ៩៥:៩ ១០៦:១៤ ឋ ជន ២១:៥,៦

**១០:១០** ឌ ជន ១៦:៤១ ១៧:៥,១០ ឍ ជន ១៦:៤៩ ណ នក ១២:២៣ ១របា ២១:១៥ ហព ១១:២៨ **១០:១១** ត ខ.៦ ថ រម ៤:២៤ ទ រម ១៣:១១ **១០:១២** ធ រម ១១:២០ ២កថ ១:២៤ **១០:១៣** ន ១កថ ១:៩ ប ២ពត ២:៩

អស្ចារ្យរបស់ព្រះអម្ចាស់ក្នុងការរំដោះពួកអ៊ីស្រាអែលដោយសុវត្ថិភាព (នក ១៤:១-១៥:២០ ចទ ១១:៤ យស ២:១០ នហ ៩:៩,១១ ទដ ៦៦:៦ ៧៧:១៦,១៩ ៧៨:១៣,៥៣ ១០៦:៩-១១ ១៣៦:១៣-១៥ អស ៤៣:១៦-១៧ ៥១:១០ ៦៣:១១-១៣ មើលការពន្យល់ ខ.២)។

**១០:២** *បុណ្យជ្រមុជក្នុងពពក ហើយក្នុងសមុទ្រ* ឃ្លានេះជាភាសាប្រៀបធៀប ដែលលោកប៉ុលប្រើ ដើម្បីបង្ហាញអំពីទំនាក់ទំនងរវាងពួកអ៊ីស្រា-អែល និងលោកម៉ូសេ ក្នុងពេលដែលព្រះអម្ចាស់រំដោះពួកគេ ឱ្យចេញពីប្រទេសអេស៊ីព្ទ ។ លោកប៉ុលមានប្រសាសន៍យ៉ាងដូច្នេះ គឺគាត់ចង់ឱ្យពួកជំនុំនៅទីក្រុងកូរិនថូសដឹងថា ពិធីបុណ្យជ្រមុជទឹក គឺជានិមិត្តរូបបញ្ជាក់អំពីការដែលពួកគេចូលមកប្រកប ជាមួយនឹងព្រះយេស៊ូវគ្រីស្ទនៅក្នុងសេចក្តីស្លាប់និងរស់ឡើងវិញរបស់ទ្រង់ (មើលការពន្យល់ រម ៦:៣-៤)។

**១០:៣-៤** *បរិភោគចំណីអាហារ . . . ផឹកទឹកដដែលខាងព្រលឹងវិញ្ញាណ* ពាក្យថា "ចំណីអាហារ" ត្រង់ចំណុចនេះគឺសំដៅលើនំម៉ាន៉ា ហើយពាក្យថា "ទឹក" គឺសំដៅលើទឹកដែលហូរចេញពីថ្មដាមក (នក ១៦:២-៣៦ ១៧:១-៧ ជន ២០:២-១១ ២១:១៦)។ លោកប៉ុលលើកយកសេចក្តីទាំងនេះមកនិយាយ គឺដើម្បីឱ្យពួកអ្នកជឿដល់ព្រះអម្ចាស់ទាំងអស់ដឹងច្បាស់ថា ទ្រង់តែងតែផ្គត់ផ្គង់ដល់ពួកគេជានិច្ច ។

**១០:៤** *ថ្មដានោះ គឺជាព្រះគ្រីស្ទ* មានន័យថា ព្រះយេស៊ូវគ្រីស្ទគឺជាថ្មដាដែលបង្ហូរទឹករស់ និងជានំបុ័ងដែលផ្តល់ជីវិតយ៉ាងពិតប្រាកដ (៨:៦ យហ ៤:១៤ មើលការពន្យល់ យហ ៦:៣០-៣៥)។

**១០:៥** *ព្រះទ្រង់មិនពេញព្រះហឫទ័យនឹងគេជាច្រើនគ្នាទេ* លោកប៉ុលនិយាយយ៉ាងដូច្នេះ ពីព្រោះក្នុងចំណោមពួកអ៊ីស្រាអែលដែលបានចាកចេញពីប្រទេសអេស៊ីព្ទ រាប់ចាប់ពីមនុស្សពេញវ័យរហូតដល់មនុស្សចាស់ គ្មានអ្នកណាបានចូលទៅក្នុងទឹកដីសន្យាទេ មានតែលោកយ៉ូស្វេ និងលោកកាលែបប៉ុណ្ណោះ (ជន ១៤:២២-២៤,២៨-៣៥ ចទ ១:៣៤-៣៦ យស ១:១-២ ១៤:៦-១៤)។

**១០:៧** *រូបព្រះ* ពាក្យថា "រូបព្រះ" ត្រង់ចំណុចនេះ គឺសំដៅលើ "រូបកូនគោ" ដែលពួកអ៊ីស្រាអែលបានសូមឱ្យលោកអើរ៉ុនធ្វើសម្រាប់ពួកគេថ្វាយបង្គំ (នក ៣២:១-៦)។ ម្យ៉ាងទៀតក្នុងសម័យកាលសញ្ញាចាស់មានរូបព្រះជាច្រើនដែលគេបង្កើតឡើងសម្រាប់ថ្វាយបង្គំ (ប្រៀបធៀបនឹងជំពូក ៨)។

**១០:៨** សេចក្តីនៅក្នុងបទគម្ពីរនេះ សំដៅលើហេតុការណ៍ ដែលបានកើតឡើងចំពោះពួកអ៊ីស្រាអែលមួយចំនួន ដែលបានចូលខ្លួនទៅថ្វាយបង្គំព្រះបាល-ពេអរ និងបានប្រព្រឹត្តអំពើកំផិតផ្សេងៗ ក្នុងការថ្វាយបង្គំរូបព្រះនោះ (នក ២៥:១-៩)។

**១០:១០** ព្រះអម្ចាស់បានរំដោះពួកអ៊ីស្រាអែលចេញពីប្រទេសអេស៊ីព្ទ ដោយការពារ និងបង្ហាញនូវសេចក្តីស្រលាញ់របស់ទ្រង់ដល់ពួកគេ ព្រមទាំងបានធ្វើការ អស្ចារ្យជាច្រើនឱ្យពួកគេបានឃើញដោយផ្ទាល់ទៀតផង ។ ទោះជាយ៉ាងនេះក្តី ក៏ពួកគេនៅតែមិនព្រមដាក់សេចក្តីជំនឿទៅលើទ្រង់ដដែល ។ ផ្ទុយទៅវិញ ពួកគេបែរជាត្អូញត្អែរប្រឆាំងនឹងទ្រង់ដូច្នោះហើយបានជាពួកគេស្ទើរតែ ទាំងអស់ត្រូវវិនាស និងមិនបានចូលទៅក្នុងទឹកដីសន្យាឡើយ (នក១២:២៣ ជន ១៦:៤១-៥០)។

**១០:១១** *សំរាប់ជាសេចក្តីទូន្មានប្រដៅ* "មើលការពន្យល់ រម ១៥:៤"។ ម្យ៉ាងទៀតបទគម្ពីរនេះបញ្ជាក់ថា គ្រប់ទាំងសេចក្តីពិតដែលព្រះយេស៊ូវគ្រីស្ទបានប្រទានមកយើងរាល់គ្នា គឺស្ថិតនៅរហូតដល់ទ្រង់យាងមកជាលើកទីពីរ និង រហូតដល់អស់កល្បជានិច្ច ។

**១០:១៣** *សេចក្តីល្បួង* ពាក្យនេះនៅក្នុងភាសាក្រិកអាចមានន័យថា "ល្បងល" ឬ "ធ្វើពិសោធន៍"។ *ដើម្បីឱ្យអ្នករាល់គ្នាអាចនឹងទ្រាំបាន* ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះអម្ចាស់ទ្រង់ស្មោះត្រង់ ហើយសេចក្តីល្បួងដែលកើតមានឡើងចំពោះយើងម្នាក់ៗ គឺមិនលើសពីកម្លាំងយើងទេ ។ ដូច្នេះ គ្រប់ពេលមានសេចក្តីល្បួងកើតឡើងនៅក្នុងជីវិតយើងត្រូវឱ្យយើងអធិស្ឋានទូលសូមជំនួយមកអំពីព្រះអម្ចាស់នៃយើង ព្រោះទ្រង់គង់ចាំជួយយើងគ្រប់ពេលវេលាទាំងអស់ ។

១៤ហេតុនោះ ឱពួកស្ងួនភ្ងាខ្ញុំអើយ[ផ] ចូររត់ពីការថ្វាយ
បង្គំរូបព្រះចេញ[ព] ១៥ខ្ញុំនិយាយនេះ ដូចជានិយាយនឹងមនុស្ស
មានប្រាជ្ញា ចូរពិចារណាពីសេចក្ដីដែលខ្ញុំថានេះចុះ ១៦ឯ
ពែងដ៏មានពរ ដែលយើងសូមពរឱ្យ តើមិនមែនជាសេចក្ដី
ប្រកបនឹងលោហិតរបស់ព្រះគ្រីស្ទទេឬអី ហើយនំបុ័ង
ដែលយើងកាច់[ភ] នោះតើមិនមែនជាសេចក្ដីប្រកបនឹងរូប
អង្គនៃព្រះគ្រីស្ទទេឬអី[ម] ១៧ដ្បិតដែលមាននំបុ័ងតែ ១ ដុំ
នោះយ៉ាងណា ចំណែកពួកយើងដែលមានគ្នាច្រើន ក៏ជា
រូបកាយតែ ១ យ៉ាងនោះដែរ[យ] ពីព្រោះយើងទាំងអស់គ្នា
ទទួលទានពីដុំនំបុ័ងតែមួយនោះឯង ។

## ដង្វាយដល់រូបព្រះ និងពិធីលៀងព្រះអម្ចាស់

១៨ចូរពិចារណាពីសាសន៍អ៊ីស្រាអែលខាងសាច់ឈាម
ចុះ ឯពួកអ្នកដែលបរិភោគយញ្ញបូជាទាំងនោះ[រ] តើមិនមាន
សេចក្ដីប្រកបនឹងអាសនាទេឬអី ១៩ដែលខ្ញុំនិយាយដូច្នេះ
តើមានន័យថា រូបព្រះជាអ្វីឬទេ ឬដង្វាយថ្វាយដល់រូប
ព្រះជាអ្វីឬទេ[ល] ២០មិនមែនជាអ្វីទេ ឯរបស់ដែលសាសន៍
ដទៃបូជាថ្វាយនោះមិនមែនថ្វាយដល់ព្រះទេ គឺថ្វាយដល់
អារក្សវិញទេតើ[វ] ហើយខ្ញុំមិនចង់ឱ្យអ្នករាល់គ្នា មានសេចក្ដី
ប្រកបនឹងអារក្សឡើយ ២១អ្នករាល់គ្នាពុំអាចនឹងផឹកពីពែង
នៃព្រះអម្ចាស់ និងពីពែងរបស់អារក្សផងបានទេ ក៏ពុំអាច
នឹងបរិភោគនៅតុព្រះអម្ចាស់ នឹងតុរបស់អារក្សផងបាន
ដែរ[ស] ២២ឬតើយើងចង់បណ្ដាលឱ្យព្រះអម្ចាស់ទ្រង់ប្រចណ្ឌ
ឬអី[ហ] តើយើងខ្លាំងពូកែជាងទ្រង់ឬ[ឡ] ។

## សេរីភាពរបស់អ្នកជឿ

២៣មានច្បាប់ធ្វើគ្រប់ការទាំងអស់ តែគ្រប់ទាំងការគ្មាន
ប្រយោជន៍ទេ[អ] មានច្បាប់ធ្វើគ្រប់ការទាំងអស់ តែគ្រប់
ទាំងការមិនស្អាងចិត្តឡើងទេ ២៤កុំឱ្យអ្នកណាស្វែងរកតែ
ប្រយោជន៍ផ្ទាល់ខ្លួនឡើយ ត្រូវរកដល់អ្នកដទៃវិញ[ក] ២៥ចូរ
បរិភោគគ្រប់របស់ទាំងអស់ ដែលគេលក់នៅទីផ្សារ
ឥតចាំបាច់ស៊ើបសួរអ្វីឡើយ ដោយយល់ដល់បញ្ញាចិត្ត[ខ]
២៦ដ្បិតផែនដី និងរបស់ទាំងអស់នៅផែនដី សុទ្ធតែជា
របស់ផងព្រះអម្ចាស់[គ] ២៧តែបើអ្នកណាដែលមិនជឿ
គេអញ្ជើញអ្នកទៅពិសា ហើយអ្នកចង់ទៅដែរ នោះត្រូវ
បរិភោគគ្រប់មុខ ដែលគេដាក់នៅមុខអ្នកចុះ[ឃ] ឥតចាំ
សួរអ្វីឡើយ ដោយយល់ដល់បញ្ញាចិត្ត ២៨ប៉ុន្តែ បើអ្នក
ណាប្រាប់អ្នកថា មុខនេះជាដង្វាយថ្វាយដល់រូបព្រះហើយ
នោះកុំឱ្យបរិភោគឡើយ ដោយយល់ដល់អ្នកដែលប្រាប់
នោះនឹងបញ្ញាចិត្តផង[ង] ២៩ដែលខ្ញុំថា បញ្ញាចិត្តនេះនោះ

**១០:១៤** ផ ហាព ៦:៩ ១ពត ២:១១ ១យហ ២:៧ យដ ៣ ព ខ.៧ ១យហ ៥:២១
**១០:១៦** ភ មថ ១៤:១៩ ម មថ ២៦:២៦-២៨ ១កថ ១១:២៣-២៥
**១០:១៧** យ រម ១២:៥
**១០:១៨** រ លវ ៧:៦,១៤,១៥
**១០:១៩** ល ១កថ ៨:៤
**១០:២០** វ លវ ១៧:៧ ចទ ៣២:១៧ ទដ ១០៦:៣៧ វវ ៩:២០
**១០:២១** ស ២កថ ៦:១៥,១៦
**១០:២២** ហ ចទ ៣២:១៦,២១ ១ពវ ១៤:២២ ទដ ៧៨:៥៨ យរ ៤៤:៨ ឡ សស ៦:១០ អស ៤៥:៩
**១០:២៣** អ ១កថ ៦:១២
**១០:២៤** ក ខ.៣៣ រម ១៥:១,២ ១កថ ១៣:៥ ភល ២:៤,២១
**១០:២៥** ខ កថ ១០:១៥ ១កថ ៨:៧ **១០:២៦** គ ទដ ២៤:១ នក ៩:២៩ ១៩:៥ យប ៤១:១១ ទដ ៥០:១២ ១ធថ ៤:៤ **១០:២៧** ឃ លក ១០:៧

**១០:១៤** *ចូររត់ពីការថ្វាយបង្គំរូបព្រះចេញ* លោកប៉ុលមានប្រសាសន៍យ៉ាង ដូច្នេះទៅកាន់ពួកជំនុំនៅទីក្រុងកូរិនថូស ពីព្រោះថាពួកគេធ្លាប់ថ្វាយបង្គំរូបព្រះជាច្រើន កាលពីមុនទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ ។ ម្យ៉ាងទៀតនៅក្នុងទីក្រុង នោះមានវិហារថ្វាយបង្គំរូបព្រះជាច្រើនមានដូចជារូបព្រះអាប៉ូឡូ (Apollo) រូបព្រះអាសក្លីពៀស (Asclepius) រូបព្រះអាប្រូឌីត (Aphrodite) និងរូបព្រះផ្សេងៗជាច្រើនទៀត (មើលការពន្យល់ ៦:១៨) ។

**១០:១៦** *ពែងដ៏មានពរ* សំដៅលើពែងទឹកទំពាំងបាយជូរដែលគ្រីស្ទបរិស័ទផឹកនៅពេលធ្វើពិធីលៀងព្រះអម្ចាស់ (មថ ២៦:២៧-២៨ លក ២២:២០ មើលការពន្យល់ មក ១៤:២៣-២៤) ។ ការផឹកទឹកទំពាំងបាយជូរនៅក្នុងពិធីលៀងព្រះអម្ចាស់ គឺរំឭកយើងឱ្យចងចាំ នូវការបង្ហូរព្រះលោហិតរបស់ទ្រង់សម្រាប់យើងគ្រប់គ្នា ។ *នំបុ័ងដែលយើងកាច់នោះ* សំដៅលើចំណិតនំបុ័ងដែលកាច់ ពិសានៅក្នុងពិធីលៀងព្រះអម្ចាស់ (មថ ២៦:២៦ មើលការពន្យល់ មក ១៤:២២ លក ២២:១៩) ។

**១០:១៧** *នំបុ័ងតែ១ដុំនោះ* ពាក្យថា "នំបុ័ង១ដុំ" ជានិមិត្តរូបនៃការរួបរួមគ្នាតែមួយនៅក្នុងព្រះកាយរបស់ព្រះយេស៊ូវគ្រីស្ទ (យហ ៦:៣៣-៥៨) ។

**១០:១៨** *ពួកអ្នកដែលបរិភោគយញ្ញបូជាទាំងនោះ* សំដៅលើពួកអ៊ីស្រាអែល ដែលបានចូលរួមក្នុងការថ្វាយយញ្ញបូជានៅលើអាសនា និងបានពិសាចំណែក ដែលសល់ (លវ ៧:១៥ ៨:៣១ ចទ ១២:១៧-១៨ មើលការពន្យល់ ៨:៤-៦) ។

**១០:២០** ក្នុងបទគម្ពីរនេះ លោកប៉ុលបញ្ជាក់ថា ប្រសិនបើអ្នកណាម្នាក់បរិភោគអាហារដែលថ្វាយដល់រូបព្រះ គឺមិនត្រូវបរិភោគនៅក្នុងវិហាររបស់រូបព្រះនោះទេ ។ ម្យ៉ាងទៀត មិនត្រូវធ្វើឱ្យបងប្អូនណាម្នាក់បាក់ទឹកចិត្តឡើយ ។ ដូច្នេះ បើការដែលអ្នកណាម្នាក់បរិភោគអាហារនោះធ្វើឱ្យបងប្អូនដទៃធ្លាក់ទឹកចិត្ត ចូរកុំបរិភោគឡើយ ។

**១០:២២-២៣** ត្រង់ចំណុចនេះ លោកប៉ុលបានបង្ហាញនូវគោលការសំខាន់ៗ ដែលទាក់ទងនឹងការងារបម្រើព្រះអម្ចាស់ (១).ស្វែងយល់អំពីជំនឿរបស់អ្នក ដែលយើងមានទំនាក់ទំនងជាមួយ (២).ធ្វើយ៉ាងណាឱ្យអ្នកនោះមានអារម្មណ៍ថា យើងឱ្យតម្លៃគេ (៣).ស្វែងយល់អំពីតម្រូវការរបស់គេ (៤).ព្យាយាមរកឱកាស ប្រាប់គេអំពីព្រះយេស៊ូវគ្រីស្ទ (ខ. ២៤ ៨:១ នក ២០:៥ កទ ៦:២) ។

**១០:២៥** បទគម្ពីរនេះលោកប៉ុលបញ្ជាក់យ៉ាងច្បាស់ថា គ្រប់អាហារដែលគេលក់នៅតាមទីផ្សារ គឺអាចបរិភោគបានប្រសិនបើអ្នកណាម្នាក់ចង់បរិភោគ ។

**១០:២៦** បទគម្ពីរនេះ លោកប៉ុលបានដកស្រង់ចេញពី "ទដ ២៤:១" ដែលពួកយូដាតែងតែប្រើក្នុងសេចក្ដីអធិស្ឋានរបស់ពួកគេ នៅពេលបរិភោគអាហារ ដើម្បីអរព្រះគុណដល់ព្រះ (ទដ ៥០:១២ ៨៩:១១) ។

**១០:២៧-២៨** ត្រង់ចំណុចនេះ លោកប៉ុលបញ្ជាក់សារជាថ្មីថា គ្រប់អាហារទាំងអស់អាចបរិភោគបាន ប៉ុន្តែ ត្រូវចាំថាមិនត្រូវធ្វើឱ្យបងប្អូនដទៃទៀតបាក់ទឹកចិត្តឡើយ (ខ.២៩) ។

**១០:២៩** បទគម្ពីរនេះបញ្ជាក់ថា អស់អ្នកដែលបានទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទហើយ គឺត្រូវចេះប្រើសេរីភាពដែលទ្រង់ប្រទានឱ្យសម្រាប់សរសើរ

មិនមែនបញ្ញាចិត្តរបស់អ្នកទេ គឺរបស់គេវិញ ដ្បិតហេតុអ្វី
បានជាសេរីភាព[ច] របស់ខ្ញុំត្រូវបញ្ញាចិត្តរបស់គេជំនុំជំរះ
៣០បើខ្ញុំទទួលទានដោយអរព្រះគុណ នោះតើហេតុអ្វី
បានជាគេប្រកាន់ទោសខ្ញុំ ដោយព្រោះរបស់ដែលខ្ញុំបាន
អរព្រះគុណរួចហើយនោះ[ឆ] ៣១ដូច្នេះ ទោះបើស៊ី ឬផឹក
ឬធ្វើការអ្វីក៏ដោយ នោះចូរធ្វើទាំងអស់សំរាប់ចំរើនសិរី
ល្អដល់ព្រះចុះ[ជ] ៣២កុំឱ្យធ្វើជាទីបង្អាក់ចិត្ត[ឈ] ដល់ពួក
សាសន៍យូដា ឬសាសន៍ក្រេក ឬពួកជំនុំនៃព្រះឡើយ[ញ]
៣៣ដូចជាខ្លួនខ្ញុំក៏ផ្គាប់ដល់ចិត្តមនុស្សគ្រប់គ្នា ក្នុងការទាំង
អស់ដែរ[ដ] ដោយឥតរកផល ប្រយោជន៍ដល់ខ្លួនឡើយ
គឺជាប្រយោជន៍ ដល់មនុស្សជាច្រើនវិញ[ឋ] ដើម្បីឱ្យគេបាន
សង្គ្រោះរួច[ឌ] ១ចូរត្រាប់តាមខ្ញុំ[ឍ] ដូចជាខ្ញុំបានត្រាប់តាម
ព្រះគ្រីស្ទដែរ[ណ]។

## បែបបទនៃការថ្វាយបង្គំ

**១១** ២បងប្អូនអើយ ខ្ញុំសរសើរដល់អ្នករាល់គ្នា[ត] ពីព្រោះអ្នក
រាល់គ្នានឹកចាំពីខ្ញុំ ក្នុងគ្រប់ការទាំងអស់[ថ] ហើយដោយព្រោះ
អ្នករាល់គ្នាកាន់តាមសេចក្តី ដែលខ្ញុំបានបង្ហាត់បង្រៀន ផង[ទ]
៣តែខ្ញុំចង់ឱ្យអ្នករាល់គ្នាដឹងថា ព្រះគ្រីស្ទជាសិរសានៃ
បុរសទាំងអស់[ធ] ឯបុរសវិញ នោះជាក្បាលនៃស្ត្រី[ន] ហើយ
សិរសានៃព្រះគ្រីស្ទ គឺជាព្រះ[ប] ៤បុរសណាដែលអធិស្ឋាន
ឬអធិប្បាយ[ផ]ទាំងមានពាក់អ្វីនៅលើក្បាល នោះឈ្មោះថា
ធ្វើបង្អាប់ដល់សិរសាខ្លួន ៥ឯស្ត្រីណាដែលអធិស្ឋាន ឬ
អធិប្បាយ[ព] ដោយមានក្បាលទទេ នោះឈ្មោះថា ធ្វើបង្អាប់
ដល់ក្បាលខ្លួនវិញ ដ្បិតដែលធ្វើដូច្នោះ នោះដូចជាបាន
កោរសក់ចេញដែរ[ភ] ៦បើស្ត្រីណាមិនពាក់អ្វីនៅលើក្បាល
នោះត្រូវកាត់សក់ចេញ តែបើពួកស្រីៗ អៀនខ្មាសចំពោះ
ការកាត់ ឬកោរសក់ នោះត្រូវតែមានអ្វីពាក់វិញ ៧ផ្នែក
ខាងពួកបុរសវិញ នោះមិនត្រូវពាក់អ្វីលើក្បាលទេ ពីព្រោះ

**១០:២៨** ង ១កថ ៨:៧,១០–១២
**១០:២៩** ច ១កថ ៩:១,១៩
**១០:៣០** ឆ រម ១៤:៦
**១០:៣១** ជ សក ១៤:២១ កល ៣:១៧ ១ពត ៤:១១
**១០:៣២** ឈ មថ ៥:២៩ កច ២៤:១៦ ២កថ ៦:៣ ញ កច ២០:២៨ ១កថ ១:២ ១១:១៦,២២ ១៥:៩ ១ធថ ៣:៥,១៥
**១០:៣៣** ដ រម ១៥:២ ១កថ ៩:២២ ឋ ខ.២៤ ឌ រម ១១:១៤
**១១:១** ឍ ១កថ ៤:១៦ ណ រម ១៥:៣ ១ពត ២:២១

**១១:២** ត ខ.១៧,២២ ថ ១កថ ៤:១៧ ទ ខ.២៣ ១កថ ១៥:២,៣ ២ថន ២:១៥ ៣:៦ **១១:៣** ធ អភ ១:២២ ន លប ៣:១៦ អភ ៥:២៣ ប ១កថ ៣:២៣ **១១:៤** ផ កថ ១១:២៧ **១១:៥** ព កថ ២១:៩ ភ ចទ ២១:១២

តម្កើងដល់ទ្រង់ និងស្អាងពួកជំនុំរបស់ទ្រង់ឱ្យចម្រើនឡើង ។ ម្យ៉ាងទៀត ត្រូវលើកទឹកចិត្តដល់ពួកអ្នក ដែលមិនទាន់បានទទួលការសង្គ្រោះមកអំពីទ្រង់នៅឡើយឱ្យពួកគេ បានទទួលទ្រង់ជាព្រះសង្គ្រោះរបស់ខ្លួនផងដែរ (ខ. ៣១–៣២) ។

**១០:៣០** បទគម្ពីរនេះបញ្ជាក់ថា គ្រប់របស់ទាំងអស់ដែលព្រះប្រទាន ចូរឱ្យយើងពោលពាក្យអរព្រះគុណដល់ទ្រង់គ្រប់ពេលវេលា (១ធថ ៤:៤) ។

**១០:៣១** បទគម្ពីរនេះបញ្ជាក់ថា មុនពេលដែលយើងធ្វើការអ្វីមួយ នោះចូរយើងសួរខ្លួនឯងថា "តើហេតុអ្វីបានជាយើងធ្វើការនោះ? តើយើងធ្វើសម្រាប់អ្នកណា?" រីឯចម្លើយសម្រាប់សំណួរនេះគឺ "ធ្វើសម្រាប់ព្រះអម្ចាស់ និងដើម្បី សរសើរតម្កើងដល់ទ្រង់" (មថ ៥:១៦ រម ១៤:៧–៨) ។

**១០:៣២** *កុំឱ្យធ្វើជាទីបង្អាក់ចិត្ត . . . ឬពួកជំនុំនៃព្រះឡើយ* មានន័យថា ជីវិត ជាគ្រីស្ទបរិស័ទ គឺត្រូវរស់នៅដើម្បីសរសើរតម្កើងដល់ព្រះអម្ចាស់ និងជា ប្រយោជន៍ដល់មនុស្សគ្រប់គ្នា ។

**១០:៣៣** *ដូចជាខ្លួនខ្ញុំក៏ផ្គាប់ដល់ចិត្តមនុស្សគ្រប់គ្នា* ឃ្លានេះមិនមែនមានន័យថា លោកប៉ុលធ្វើអ្វីៗ ដើម្បីផ្គាប់ចិត្តមនុស្សលោក ឬដើម្បីឱ្យគេយល់ថា គាត់ជាមនុស្សអស្ចារ្យនោះទេ ប៉ុន្តែ ផ្ទុយទៅវិញ គ្រប់ការទាំងអស់ដែលគាត់ធ្វើ គឺគាត់ចង់តម្កើងដល់ព្រះនាមព្រះយេស៊ូវ និងឱ្យមនុស្សទាំងអស់បានទទួលព្រះបន្ទូលនៃដំណឹងល្អ ប្រយោជន៍ឱ្យពួកគេបានទទួលការសង្គ្រោះគ្រប់ៗគ្នា (៩:២២) ។

**១១:១** ក្នុងបទគម្ពីរនេះមានលក្ខណៈគួរឱ្យកត់សម្គាល់ (១). ព្រះគ្រីស្ទគឺជាគំរូដ៏ពិត និងគ្រប់លក្ខណ៍ (២).ពួកសាវ័កយកគំរូតាមព្រះគ្រីស្ទ (៣).ពួកសាវ័កធ្វើជាគំរូដល់អ្នកជឿដទៃ ។

**១១:៣–១៦** ក្នុងវគ្គនេះបង្ហាញអំពីរបៀប និងបែបបទនៃការថ្វាយបង្គំ ។ លោកប៉ុលបញ្ជាក់យ៉ាងច្បាស់អំពីទំនាក់ទំនងត្រឹមត្រូវរវាងប្តី និងប្រពន្ធ ដែលជះឥទ្ធិពលទៅលើការថ្វាយបង្គំ ។ នៅក្នុងវគ្គមុនលោកប៉ុលបានបញ្ជាក់ថា គ្រប់ការទាំងអស់ គឺដើម្បីសិរីល្អនៃព្រះអម្ចាស់ (១០:៣១) ។

**១១:៣** *សិរសា* មានមតិយល់ឃើញផ្សេងៗពីគ្នាអំពីពាក្យនេះ ។ អ្នកខ្លះយល់ថា ពាក្យនេះសំដៅលើកិត្តិយសជាសំខាន់ (ខ.៤–៥) ។ មានន័យថា ព្រះគ្រីស្ទទ្រង់ថ្វាយព្រះកិត្តិយសដល់ព្រះវរបិតា ហើយមនុស្សទាំងអស់ត្រូវថ្វាយព្រះកិត្តិយសដល់ព្រះគ្រីស្ទ ។ ម្យ៉ាងទៀតប្រពន្ធទាំងឡាយត្រូវផ្តល់កិត្តយសដល់ប្តីរបស់ខ្លួន ។ អ្នកផ្សេងទៀតយល់ថា ពាក្យនេះច្រើនសំដៅលើអំណាច ដូចជាលោកប៉ុលបានលើកឡើងនៅក្នុង "អភ ១:២១–២២ ៥:២២–២៣ កល ១:១៨ ២:១០" ។ មានន័យថា ព្រះគ្រីស្ទទ្រង់មានអំណាចលើគ្រប់ទាំងអស់ រួមមានទាំងមនុស្សលោក ទាំងអស់ផងដែរ ដូច្នេះពួកគេត្រូវតែផ្តល់ព្រះកិត្តិយសដល់ទ្រង់ ។ រីឯប្រពន្ធក៏ត្រូវគោរពចុះចូលនឹងប្តីរបស់ខ្លួនដែរ (មើលការពន្យល់ ១៥:២៨) ។

**១១:៤** ពាក្យថា "ក្បាល" ក្នុងបទគម្ពីរនេះជាអត្ថន័យត្រង់ គឺសំដៅលើសរីរាង្គក្បាលតែម្តង ។ រីឯពាក្យថា "សិរសា" នៅក្នុងបទគម្ពីរនេះវិញ គឺអាចសំដៅលើក្បាលខាងឯវិញ្ញាណ (ប្រហែលសំដៅលើព្រះគ្រីស្ទ) ។ នៅសម័យកាលលោកប៉ុល បុរសមិនពាក់អ្វីលើក្បាលរបស់ខ្លួនទេ នៅពេលថ្វាយបង្គំ ដើម្បីបញ្ជាក់អំពី ការគោរពដល់ព្រះ ។

**១១:៥-៦** សំបុត្ររបស់លោកប៉ុលទៅពួកស្រីៗនៅទីក្រុងកូរិនថូសគឺ ឱ្យពួកគេចេះគោរពចុះចូលនឹងប្តីរបស់ខ្លួន ។ ម្យ៉ាងទៀតនៅក្នុងវគ្គនេះមានមតិយល់ឃើញផ្សេងៗពីគ្នាស្តីអំពីការដែលស្ត្រីត្រូវពាក់អ្វីលើក្បាលរបស់ខ្លួន ។ មតិខ្លះយល់ថា ការដែលលោកប៉ុលមានប្រសាសន៍មិនឱ្យស្រីៗនៅក្បាលទទេ គឺត្រូវអនុវត្តរហូតដល់សព្វថ្ងៃ (ខ.៧–៩) ។ មានមតិផ្សេងទៀតយល់ថា ការដែលលោកប៉ុលមានប្រសាសន៍យ៉ាងដូច្នេះ គឺសំដៅលើការដែលប្រពន្ធត្រូវគោរពចុះចូលចំពោះប្តីរបស់ខ្លួនប៉ុណ្ណោះ (ខ. ៣ លប ២:២០ ១ធថ ២:១១–១៤) ។ ការមួយដែលគួរចងចាំគឺ នាសម័យកាល នោះនៅទីក្រុងកូរិនថូស ស្រីៗត្រូវពាក់អ្វីលើក្បាលរបស់ខ្លួនធ្វើដំណើរចេញពីផ្ទះ ។

ខ្លួនជាគំរូ[ម] ហើយជាសិរីល្អនៃព្រះ តែស្ត្រីជាសិរីល្អដល់
បុរសវិញ ៨ដ្បិតបុរសដើមមិនបានកើតចេញពីស្ត្រីមកទេ
គឺស្ត្រីបានចេញមកពីបុរសនោះវិញ[យ] ៩ព្រះក៏មិនបានបង្កើត
បុរសមកសំរាប់ស្ត្រីដែរ គឺស្ត្រីសំរាប់បុរសវិញ[រ] ១០ហេតុ
នោះត្រូវឱ្យពួកស្ត្រីមានទីសំគាល់ ពីអំណាចរបស់ប្តី នៅ
លើក្បាលខ្លួន ដោយព្រោះពួកទេវតា ១១ប៉ុន្តែ ក្នុងព្រះ
អម្ចាស់ នោះបុរសមិនមែនជាឥត ពឹងអាស្រ័យដល់ស្ត្រី
ឡើយ ហើយស្ត្រីក៏មិនមែនជាឥតពឹង អាស្រ័យដល់បុរស
ដែរ ១២ដ្បិតបុរសកើតមកដោយសារស្ត្រី ដូចជាស្ត្រីដើម
បានកើតមកពីបុរសនោះដែរ តែគ្រប់របស់ទាំងអស់
សំរេចកើតមកអំពីព្រះវិញ[ល] ១៣ចូរពិចារណាក្នុងខ្លួន
អ្នករាល់គ្នាមើល តើគួរគប្បីឱ្យស្ត្រីអធិស្ឋានដល់ព្រះ ដោយ
ឥតមានពាក់អីលើក្បាលឬទេ ១៤តើធម្មតាលោកមិន
បង្រៀនអ្នករាល់គ្នាទេឬអីថា បើបុរសទុកសក់វែង នោះជា
ការបង្អាប់ដល់ខ្លួន ១៥តែបើស្ត្រីទុកសក់វែង នោះឯងជា
សេចក្តីលំអដល់នាងវិញ ដ្បិតសក់វែងនោះ ទ្រង់បាន
ប្រទានមកនាង ទុកជាប្រដាប់សំរាប់ទទូរ ១៦ប៉ុន្តែ បើមាន
អ្នកណាចង់ជជែកពីសេចក្តីនេះ នោះយើងរាល់គ្នាគ្មាន
ទំលាប់យ៉ាងនោះទេ ហើយពួកជំនុំនៃព្រះក៏គ្មានដែរ[វ]។

**ពិធីលៀងព្រះអម្ចាស់**

*១១:២៣–២៥ = មថ ២៦:២៦–២៨ មក ១៤:២២–២៤*
*លក ២២:១៧–២០*

១៧ខាងឯសេចក្តីដែលខ្ញុំប្រាប់មកក្រោយនេះ ខ្ញុំមិន
សរសើរដល់អ្នករាល់គ្នាទេ[ស] ដ្បិតដែលអ្នករាល់គ្នាប្រជុំគ្នា
នោះមិនមែនឱ្យបានល្អឡើងទេ គឺឱ្យបានអាក្រក់ជាងទៅ
វិញ ១៨ព្រោះមុនដំបូងខ្ញុំឮថា កាលណាអ្នករាល់គ្នាមូលមក
ក្នុងពួកជំនុំ នោះតែងមានការបែកខ្ញែកគ្នាទៅ[ហ] ហើយខ្ញុំ
ក៏បានជឿខ្លះដែរ ១៩ពីព្រោះត្រូវតែមានបក្សពួកក្នុងពួក
អ្នករាល់គ្នា ដើម្បីឱ្យពួកខ្ជាប់ខ្ជួនបានសំដែងមកឱ្យស្គាល់
ច្បាស់[ឡ] ២០ដូច្នេះ ដែលប្រជុំគ្នានៅទីណាមួយ នោះមិន
មែនប្រជុំ ដើម្បីនឹងបរិភោគលៀងបរិសុទ្ធនៃព្រះអម្ចាស់ទេ
២១ដ្បិតកាលបរិភោគ នោះគ្រប់គ្នាខំបរិភោគម្ហូបរបស់ខ្លួន
ឱ្យតែឆ្អែតមុនគេទៅ[អ] បានជាមានមួយនៅឃ្លាន ហើយមួយ
ទៀតស្រវឹង ២២ចុះតើអ្នករាល់គ្នាគ្មានផ្ទះ សំរាប់ជាទីឱ្យបាន
បរិភោគអាហារទេឬអី ឬតើអ្នកមើលងាយដល់ពួកជំនុំ
នៃព្រះ[ក] ហើយចង់ធ្វើឱ្យពួកអ្នកដែលគ្មានអ្វីសោះ[ខ] មាន

**១១:៧** ម លប ១:២៦ ៥:១ ៩:៦ យក ៣:៩
**១១:៨** យ លប ២:២១–២៣ ១ធថ ២:១៣
**១១:៩** រ លប ២:១៨
**១១:១២** ល រម ១១:៣៦
**១១:១៦** វ ១កថ ៧:១៧ ១០:៣២
**១១:១៧** ស ខ.២,២២
**១១:១៨** ហ ១កថ ១:១០–១២ ៣:៣៣
**១១:១៩** ឡ ១យហ ២:១៩
**១១:២១** អ ២ពត ២:១៣ យដ ១២
**១១:២២** ក ១កថ ១០:៣២ ខ យក ២:៦

ប្រសិនបើស្ត្រីណាម្នាក់ដើរចេញពីផ្ទះ ដោយមិនពាក់អ្វីលើក្បាល នោះនឹងធ្វើឱ្យគេយល់ច្រឡំថា នាងជាស្រីពេស្យាចារជាមិនខាន (ព្រោះស្រីពេស្យាចារមិនពាក់អ្វីលើក្បាលទេ)។

**១១:១០** *ពួកទេវតា* នៅសម័យកាលលោកប៉ុល មានមនុស្សមួយចំនួនយល់ថា មានទេវតានៅក្នុងព្រះវិហារ ពេលមានកម្មវិធីផ្សេងៗ ។ ដូច្នោះ ហើយបានជាស្រីៗនាពេលនោះពាក់ស្បៃ នៅលើក្បាលពេលមានកម្មវិធីថ្វាយបង្គំ ដើម្បីបញ្ជាក់ ថាខ្លួនមិនបានប្រមាថដល់ទេវតាទេ ។

**១១:១១** បទគម្ពីរនេះបញ្ជាក់ច្បាស់ថា ប្តីនិងប្រពន្ធត្រូវចេះជួយគ្នា ។

**១១:១៣–១៤** ត្រង់ចំណុចនេះ បញ្ជាក់ថា អស់អ្នកដែលទទួលជឿដល់ព្រះអម្ចាស់ត្រូវយល់ដឹងឱ្យបានច្បាស់លាស់នូវរបៀបរបបរស់នៅ និងអាកប្បកិរិយាប្រព្រឹត្តនៅក្នុងសង្គម និងវប្បធម៌ផ្សេងៗ ។

**១១:១៦** បទគម្ពីរនេះបញ្ជាក់ថា ជាទូទៅ ទម្លាប់សម្រាប់ពួកជំនុំ គឺបុរសត្រូវកាត់សក់ខ្លី ហើយស្ត្រីត្រូវទុកសក់វែង (១៣–១៦)។

**១១:១៧,១៨** នៅក្នុង"ខ.២"លោកប៉ុលបានពោលពាក្យសរសើរ ដល់ពួកជំនុំនៅទីក្រុងកូរិនថូស ប៉ុន្តែ នៅត្រង់ចំណុចនេះ គាត់បែរជាមានប្រសាសន៍ថា គាត់មិនសរសើរដល់ពួកគេរាល់គ្នាទៅវិញ ។ ការដែលគាត់មានប្រសាសន៍យ៉ាងដូច្នេះ ពីព្រោះនៅក្នុងចំណោមពួកគេ មានការបែកបាក់គ្នាជាច្រើនបានកើតឡើង ដោយព្រោះអ្នកខ្លះនិយាយថា ខ្លួនដើរតាមសាវករូបនេះ ហើយអ្នកខ្លះទៀតថាខ្លួនដើរតាមសាវករូប នោះ (១:១១–១២) និងមានទំនាស់ជាច្រើនទៀត ដូចជាទំនាស់រវាងអ្នកមាន និងអ្នកក្រទំនាស់រវាងអ្នកមានកិត្តិយសនៅក្នុងសង្គម និងអ្នកដែលគ្មានកិត្តយសនៅក្នុងសង្គម ។ ដោយព្រោះតែការទាំងនេះហើយ បានជាលោកប៉ុលនិយាយថា ប្រសិនបើពួកគេមិនបានប្រជុំគ្នា នោះជាការប្រសើរជាង (១:១០–១៧)។

**១១:១៩** បទគម្ពីរនេះ បញ្ជាក់យ៉ាងច្បាស់ថា គ្រីស្ទបរិស័ទតែងតែមានយោបល់ និងការយល់ឃើញផ្សេងៗពីគ្នា ។ ការដែលមានមតិយោបល់ និងការយល់ឃើញផ្សេងគ្នាមិនជាការខុសឆ្គងទេ ប៉ុន្តែ ការមួយដែលត្រូវចងចាំគឺគ្រប់ក្រុមនីមួយៗ ត្រូវបញ្ចេញនូវទស្សនៈរបស់ខ្លួន ដោយសេចក្តីស្រឡាញ់ និងដោយការបន្ទាបខ្លួនចំពោះគ្នាទៅវិញទៅមក ។ អ្នកដែលបញ្ចេញយោបល់ដោយសេចក្តីស្រឡាញ់ និងការបន្ទាបខ្លួនត្រូវបានហៅថា ពួកខ្ជាប់ខ្ជួន (នឹងព្រះអម្ចាស់)។ រីឯអ្នកណាដែលពោលពាក្យ ដែលនាំឱ្យមានការបែកបាក់ និងទំនាស់ក្នុងចំណោមពួកអ្នកជឿដល់ព្រះអម្ចាស់ នោះមិនត្រូវបានហៅថា ពួកខ្ជាប់ខ្ជួនទេ ។

**១១:២០** ពួកជំនុំនៅទីក្រុងកូរិនថូស ធ្វើពិធីលៀងព្រះអម្ចាស់ រួមជាមួយការបរិភោគអាហារធម្មតាដែរ ។ ដូច្នេះ នៅពេលដែលមានការជួបជុំគ្នាដើម្បីធ្វើពិធីនេះ ពួកគេនាំគ្នាបរិភោគទាល់តែឆ្អែតស្កប់ស្កល់ ហើយពេលខ្លះអាចរហូតដល់ស្រវឹងទៀតផង ។

**១១:២១** នៅសម័យកាលលោកប៉ុល អស់អ្នកដែលមកចូលរួមនៅក្នុងពិធីលៀងព្រះអម្ចាស់ ម្នាក់ៗត្រូវនាំយកអាហារពីផ្ទះ សម្រាប់បរិភោគផ្ទាល់ខ្លួន ។ ពួកអ្នកមានតែងតែនាំយកមកនូវអាហារជាច្រើន ប៉ុន្តែពុំបានចែករំលែកដល់អ្នកក្រទេ។ ម្យ៉ាងទៀត ពួកអ្នកដឹកនាំព្រះវិហារអាចបរិភោគអាហារ ដោយមិនរង់ចាំអ្នកដទៃទៀតទេ ដូច្នោះហើយទើបជាញឹកញាប់ធ្វើឱ្យពួកអ្នកដែលខ្វះខាតតែងតែ ឃ្លាននៅពេលធ្វើពិធីនេះ ពីព្រោះពួកគេមិនសូវមានអាហារច្រើនសម្រាប់បរិភោគទេ (២ពត ២:១៣ យដ ១២)។

**១១:២២** បទគម្ពីរនេះ លោកប៉ុលបញ្ជាក់ថា ប្រសិនបើពួកអ្នកមាន

សេចក្ដីខ្មាសឬអី តើគួរឱ្យខ្ញុំនិយាយនឹងអ្នករាល់គ្នាថាដូច
ម្ដេច គួរឱ្យសរសើរឬ[គ] ខ្ញុំមិនសរសើរទេ ។
២៣ ដ្បិតឯសេចក្ដីដែលខ្ញុំបានបង្រៀនដល់អ្នករាល់គ្នា[ឃ]
នោះខ្ញុំបានទទួលពីព្រះអម្ចាស់មក[ង] គឺថានៅពេលយប់ដែល
ព្រះអម្ចាស់យេស៊ូវត្រូវគេបញ្ជូន នោះទ្រង់បានយកនំបុ័ង
២៤ លុះទ្រង់បានអរព្រះគុណរួចហើយ ក៏កាច់នំបុ័ង ដោយ
បន្ទូលថា «ចូរយកពិសាចុះ នេះជារូបកាយខ្ញុំ[ច] ដែលត្រូវ
កាច់សំរាប់អ្នករាល់គ្នា ចូរធ្វើកិច្ចនេះ ទុកជាសេចក្ដីរំឭក
ពីខ្ញុំចុះ» ២៥ លុះក្រោយដែលបានបរិភោគរួចហើយ នោះ
ទ្រង់ក៏យកពែងបែបដូច្នោះដែរ ដោយបន្ទូលថា «ពែងនេះ
ជាសញ្ញាថ្មី[ឆ] ដោយនូវឈាមខ្ញុំ[ជ] ចូរធ្វើដូច្នេះរាល់វេលា
ណាដែលផឹក ទុកជាសេចក្ដីរំឭកដល់ខ្ញុំ» ២៦ ដ្បិតរាល់វេលា
ណា ដែលអ្នករាល់គ្នាបរិភោគនំបុ័ងនេះ ហើយផឹកពី
ពែងនេះ នោះឈ្មោះថាសំដែងពីសេចក្ដីសុគតរបស់ផង
ព្រះអម្ចាស់ ដរាបដល់ទ្រង់យាងមក[ឈ] ២៧ បានជាអ្នកណា
ដែលបរិភោគនំបុ័ងនេះ ឬផឹងពីពែងនៃព្រះអម្ចាស់បែប
មិនគួរសម នោះនឹងមានទោសចំពោះរូបអង្គ ហើយនឹង
ព្រះលោហិតនៃព្រះអម្ចាស់[ញ] ២៨ ត្រូវឱ្យមនុស្សល្បងខ្លួន
ឯងមើល[ដ] រួចសឹមបរិភោគនំបុ័ង ហើយផឹក ពីពែងនេះចុះ
២៩ ដ្បិតអ្នកណាដែលបរិភោគបែបមិនគួរ សមអ្នកនោះ
ឈ្មោះថាបរិភោគជាសេចក្ដីជំនុំជំរះដល់ខ្លួនវិញ ដោយ
ព្រោះមិនពិចារណាឃើញរូបអង្គនៃព្រះអម្ចាស់ទេ ៣០ គឺ
ដោយហេតុនោះបានជាមានអ្នករាល់គ្នាជាច្រើន ទៅជា
ខ្សោយ ហើយឈឺ ក៏មានគ្នាជាច្រើនដេកលក់ទៅហើយ
ដែរ[ឋ] ៣១ បើសិនជាយើងរាល់គ្នាពិចារណាមើលក្នុងខ្លួន
យើង នោះយើងមិនត្រូវជាប់ជំនុំជំរះទេ[ឌ] ៣២ តែកាលណា
យើងរាល់គ្នាត្រូវជាប់ជំនុំជំរះ នោះព្រះអម្ចាស់ទ្រង់វាយ
ផ្ចាលយើងវិញ[ឍ] ដើម្បីកុំឱ្យយើងជាប់ទោសជាមួយនឹងលោ
កីយឡើយ[ណ] ៣៣ ដូច្នេះបងប្អូនអើយ កាលណាប្រជុំគ្នា
ដើម្បីនឹងបរិភោគ នោះត្រូវបង្អង់ចាំគ្នាផង។

**១១:២២** គ ខ.២,១៧
**១១:២៣** ឃ ខ.២ ង កទ ១:១២
**១១:២៤** ច ១កថ ១០:១៦
**១១:២៥** ឆ លក ២២:២០ ជ ១កថ ១០:១៦
**១១:២៦** ឈ ១កថ ១:៧
**១១:២៧** ញ ហព ១០:២៩
**១១:២៨** ដ ២កថ ១៣:៥
**១១:៣០** ឋ មថ ៩:២៤
**១១:៣១** ឌ ទដ ៣២:៥ ១យហ ១:៩
**១១:៣២** ឍ ទដ ៩៤:១២ ១១៨:១៨ សភ ៣:១១,១២ ហព ១២:៧-១០ វវ ៣:១៩ ណ យហ ១៥:១៨,១៩

និងពួកអ្នក ដែលមានកិត្តិយសនៅក្នុងសង្គម នៅតែបន្តប្រព្រឹត្ត តាមរបៀបដែលពួកគេធ្លាប់ធ្វើពីមុន (ពួកគេនាំយកអាហារមកយ៉ាងច្រើន ប៉ុន្តែ មិនបានចែកដល់ពួកបងប្អូនដែលខ្វះខាតទេ) នោះចូរឱ្យពួកគេបរិភោគអាហារនៅឯផ្ទះរបស់ខ្លួនរួច ជាស្រេចទើបមកចូលរួមជាមួយពួកបងប្អូនដទៃទៀតនៅក្នុងពួកជំនុំ ដើម្បីធ្វើពិធី លៀងព្រះអម្ចាស់ (ខ.១៧)។

**១១:២៣-២៦** សេចក្ដីដែលលោកប៉ុលមានប្រសាសន៍ត្រង់ចំណុចនេះ គឺមានលក្ខណៈដូចគ្នានឹងព្រះបន្ទូលនៅក្នុង "មថ ២៦:២៦-២៩ មក ១៤:២២-២៥ លក ២២:១៧-២០" ដែរ ។

**១១:២៣** *សេចក្ដីដែលខ្ញុំបានបង្រៀន . . . នោះខ្ញុំបានទទួល ពីព្រះអម្ចាស់មក* ឃ្លានេះមិនមែនមានន័យថា លោកប៉ុលបានទទួលសេចក្ដីដែលនិយាយអំពីពិធីលៀងព្រះអម្ចាស់ដោយផ្ទាល់មកអំពីទ្រង់ទេ ។ គាត់អាចទទួលសេចក្ដីបង្រៀននេះ តាមរយៈសិស្សដទៃទៀតរបស់ព្រះអម្ចាស់ (មើលការពន្យល់ ១៥:៣ ៧:១០)។

**១១:២៤** *អរព្រះគុណ* ពួកយូដាតែងតែពោលពាក្យអរព្រះគុណព្រះនៅពេលបរិភោគអាហារ ។ *រូបកាយខ្ញុំ* ត្រង់ចំណុចនេះបញ្ជាក់ថានំបុ័ង គឺជានិមិត្តរូបតំណាងឱ្យព្រះកាយរបស់ព្រះយេស៊ូវគ្រីស្ទ ដែលត្រូវប្រទានឱ្យដល់គ្រប់មនុស្សមានបាបទាំងអស់ (មើលការពន្យល់ លក ២២:១៩)។ *ទុកជាសេចក្ដីរំឭកពីខ្ញុំចុះ* មានន័យថា ពិធីលៀងព្រះអម្ចាស់ធ្វើឡើង គឺដើម្បីរំឭកអំពីការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ សម្រាប់មនុស្សមានបាបទាំងអស់គ្នា (នក ១២:១៤)។

**១១:២៥** *ពែង* ជានិមិត្តរូបនៃសេចក្ដីសញ្ញាថ្មីដោយសារព្រះលោហិតរបស់ព្រះយេស៊ូវគ្រីស្ទ (យរ ៣១:៣១-៣៤ មក ១៤:២៤ លក ២២:២០)។ សេចក្ដីសញ្ញាចាស់ត្រូវបានប្រទានមកតាមរយៈលោកម៉ូសេ និងពួកហោរាបរិសុទ្ធដទៃទៀតរបស់ព្រះអម្ចាស់ (នក ២៤:៣-៨)។ សេចក្ដីសញ្ញាថ្មីគឺជាសេចក្ដីសង្គ្រោះ ដែលត្រូវបានប្រទានមកមនុស្សលោក តាមរយៈការបង្ហូរព្រះលោហិតរបស់ ព្រះយេស៊ូវគ្រីស្ទ ។

**១១:២៦** បទគម្ពីរនេះបញ្ជាក់ថា ត្រូវធ្វើពិធីលៀងព្រះអម្ចាស់ ប៉ុន្តែ មិនបានបញ្ជាក់អំពីរយៈពេលដែលត្រូវធ្វើពិធីនេះ ពីមួយទៅមួយទៀតទេ ។ *សំដែងពីសេចក្ដីសុគតរបស់ផងព្រះអម្ចាស់* មានន័យថាពិធីលៀងព្រះអម្ចាស់ប្រារព្ធធ្វើឡើង គឺដើម្បីរំឭកអំពីការសុគតរបស់ព្រះយេស៊ូវគ្រីស្ទនៅលើឈើឆ្កាង (១:២៣ ២:២)។ *ដរាបដល់ទ្រង់យាងមក* គឺរហូតដល់ព្រះយេស៊ូវគ្រីស្ទយាងមកជាលើកទីពីរ (មើលការពន្យល់ មថ ២៦:២៩)។

**១១:២៧** *បរិភោគ...បែបមិនគួរសម* មានន័យថា បរិភោគដោយមិនបានលន់តួអំពើបាបរបស់ខ្លួន ហើយដោយគ្មានសេចក្ដីស្រលាញ់ចំពោះអ្នកដទៃ និងមិនបន្ទាបខ្លួន ។ ប្រសិនបើអ្នកណាម្នាក់បរិភោគអាហារនៃពិធីលៀងព្រះអម្ចាស់បែបយ៉ាងដូច្នេះ នោះមានឈ្មោះថា ធ្វើបាបទាស់ប្រឆាំងនឹងទ្រង់ហើយ (ខ. ២០-២៦)។

**១១:២៨** *ត្រូវឱ្យមនុស្សល្បងខ្លួនឯងមើល* ឃ្លានេះបញ្ជាក់ថា នៅពេលធ្វើពិធីលៀងព្រះអម្ចាស់ ត្រូវឱ្យអ្នកដែលចូលរួមពិនិត្យមើលចិត្តគំនិត និងការប្រព្រឹត្តរបស់ខ្លួន និងត្រូវលន់តួនូវអំពើបាបរបស់ខ្លួនមុននឹងទទួលទានចំណិតនំបុ័ង និងទឹកទំពាំងបាយជូរ ដែលតំណាងឱ្យព្រះកាយ និងព្រះលោហិតរបស់ព្រះយេស៊ូវ ។

**១១:២៩** *សេចក្ដីជំនុំជំរះ* មិនមែនសំដៅលើសេចក្ដីជំនុំជម្រះរបស់ព្រះអម្ចាស់នៅថ្ងៃចុងបំផុតនោះទេ ប៉ុន្តែ សំដៅលើការព្រមានរបស់ទ្រង់ចំពោះរាស្ត្រទ្រង់នាពេលបច្ចុប្បន្នវិញ (ខ.៣០)។ *រូបអង្គនៃព្រះអម្ចាស់* ឃ្លានេះអាចសំដៅលើព្រះកាយរបស់ព្រះគ្រីស្ទផ្ទាល់តែម្ដង ឬអាចសំដៅលើពួកជំនុំរបស់ទ្រង់ (ខ.២០-២១ មើលការពន្យល់ ១២:១៣,២៧)។

**១១:៣០** *មានគ្នាជាច្រើនដេកលក់* "មើលការពន្យល់ យហ ១១:១១"។

**១១:៣២** *ព្រះអម្ចាស់ទ្រង់វាយផ្ចាល* មានន័យថាព្រះអម្ចាស់តែង តែប្រដៅតម្រង់រាស្ត្ររបស់ទ្រង់ ដើម្បីឱ្យពួកគេដើរនៅក្នុងផ្លូវដ៏ត្រឹមត្រូវ និងសុចរិតរបស់ទ្រង់ (មើលការពន្យល់ ហព ១២:៥-១១)។

**១១:៣៣** បទគម្ពីរនេះបញ្ជាក់ថា នៅពេលធ្វើពិធីលៀងព្រះអម្ចាស់ ត្រូវឱ្យ

៣៤ បើសិនជាអ្នកណាឃ្លាន[ត] ឱ្យអ្នកនោះបរិភោគនៅឯផ្ទះ
ចុះ[ថ] ដើម្បីកុំឱ្យអ្នករាល់គ្នាប្រជុំទៅ នាំឱ្យជាប់មានទោស
ឡើយ ឯការឯទៀត ដល់កាលណាខ្ញុំមក[ទ] នោះខ្ញុំនឹងសំ
រេចគ្រប់ទាំងអស់ ។

## អំណោយទានខាងឯវិញ្ញាណ

**១២** ១ ចំណែកឯអំណោយទានខាងវិញ្ញាណ[ធ] បងប្អូន
អើយ ខ្ញុំមិនចង់ឱ្យអ្នករាល់គ្នានៅល្ងង់ទេ[ន] ២ អ្នករាល់គ្នាដឹង
ហើយថា ពីដើមអ្នករាល់គ្នាជាសាសន៍ដទៃ[ប] ដែលត្រូវ
បង្វែរទៅឯរូបព្រះគ តាមតែមានសេចក្តីដឹកនាំទៅនោះ[ផ]
៣ ហេតុនោះ បានជាខ្ញុំប្រាប់ឱ្យអ្នករាល់គ្នាដឹងថា មិនដែល
មានអ្នកណានិយាយ ដោយនូវព្រះវិញ្ញាណនៃព្រះថា
ព្រះយេស៊ូវត្រូវបណ្តាសានោះឡើយ[ព] ក៏គ្មានអ្នកណាអាច
នឹងថា ព្រះយេស៊ូវទ្រង់ជាព្រះអម្ចាស់ដែរ[ភ] លើកតែដោយ
នូវព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ[ម]។
៤ រីឯអំណោយទាន នោះមានផ្សេងៗពីគ្នា តែគឺជាព្រះ
វិញ្ញាណដដែលទេ[យ] ៥ ហើយក៏មានមុខងារផ្សេងៗពីគ្នា តែ
គឺជាព្រះអម្ចាស់ដដែលដែរ ៦ ព្រមទាំង មានរបៀបធ្វើ
ផ្សេងៗពីគ្នាទៀត តែគឺជាព្រះដដែលនោះឯង[រ] ដែលទ្រង់
ធ្វើគ្រប់ទាំងអស់ ក្នុងមនុស្សទាំងអស់[ល] ៧ ហើយទ្រង់ប្រទាន
ឱ្យព្រះវិញ្ញាណសំដែងមកក្នុងគ្រប់គ្នា ដើម្បីឱ្យបានកើតផល[វ]
៨ ដ្បិតទ្រង់ប្រទានឱ្យម្នាក់មានពាក្យសំដីនៃប្រាជ្ញាវាងវៃ[ស]
ដោយសារព្រះវិញ្ញាណ ឱ្យម្នាក់ទៀតមានពាក្យសំដីនៃ
ចំណេះចេះស្ទាត់[ហ] តាមព្រះវិញ្ញាណដដែល ៩ ហើយឱ្យម្នាក់
ផ្សេងទៀតមានសេចក្តីជំនឿ[ឡ] ដោយនូវព្រះវិញ្ញាណ
ដដែល ឱ្យមួយទៀតបានអស់ទាំងអំណោយទាន នឹងអាច
ប្រោសឱ្យជា[អ] ដោយនូវព្រះវិញ្ញាណដដែល ១០ ឱ្យមួយ
ទៀតបានសំដែងការឫទ្ធិបារមី[ក] នឹងឱ្យមួយទៀតចេះ
អធិប្បាយ[ខ] ឱ្យមួយទៀតសង្កេតស្គាល់អស់ទាំងវិញ្ញាណ[គ]
ឱ្យមួយទៀតចេះនិយាយភាសាដទៃផ្សេងៗ[ឃ] ហើយឱ្យមួយ

**១១:៣៤** ត ខ.២១
ថ ខ.២២
ទ ១កថ ៤:១៩
**១២:១** ធ រម ១:១១
១កថ ១:៧ ១៤:១,៣៧
ន រម ១១:២៥
**១២:២** ប អភ ២:២
ផ ទដ ១១៥:៥
យរ ១០:៥
ហាព ២:១៨,១៩
**១២:៣** ព រម ៩:៣
១កថ ១៦:២២
ភ យហ ១៣:១៣
ម ១យហ ៤:២,៣
**១២:៤** យ ខ.៨-១១
រម ១២:៤-៨
អភ ៤:១១ ហាព ២:៤
**១២:៦** រ អភ ៤:៦
ល ភល ២:១៣
**១២:៧** វ ១កថ
១៤:១២ អភ ៤:១២
**១២:៨** ស ១កថ ២:៦ ហ ២កថ ៨:៧ **១២:៩** ឡ មថ ១៧:១៩,២០ ១កថ
១៣:២ អ ខ.២៨,៣០ មថ ១០:១ **១២:១០** ក ខ.២៨-៣០ កទ ៣:៥ ខ អភ
៤:១១ គ យហ ៤:៤ យហ ៤:១ ឃ មក ១៦:១៧

រង់ចាំបរិភោគជាមួយគ្នា ។ ប្រសិនបើអ្នកណាឃ្លាន នោះត្រូវបរិភោគពីផ្ទះរបស់ខ្លួន ។ ម្យ៉ាងទៀតមិនត្រូវឱ្យមានការរិះគន់គ្នា ដោយសាររឿងបរិភោគទេ (ខ.៣៤)។

**១២:១** ព្រះវិញ្ញាណបរិសុទ្ធប្រទានឱ្យគ្រីស្ទបរិស័ទ នូវអំណោយទានពីរយ៉ាងគឺ (១) អំណោយទានដែលជាផលផ្លែខាងឯវិញ្ញាណ រួមមានសេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត ហើយដឹងខ្នាត (កទ ៥:២២-២៣)។ (២) អំណោយទានពិសេសសម្រាប់អស់អ្នក ដែលព្រះអម្ចាស់ត្រាស់ហៅឱ្យបំពេញព្រះរាជកិច្ចពិសេសណាមួយថ្វាយទ្រង់ ។

**១២:២** *ត្រូវបង្វែរទៅនឹងរូបព្រះគ* មានពេលមួយពួកអ្នករស់នៅទីក្រុងកូរិនថូសបានទទួលឥទ្ធិពលពីមជ្ឈដ្ឋានខាងក្រៅ ដោយនាំគ្នាថ្វាយបង្គំរូបព្រះគ (មើលការពន្យល់ ៨:៤-៦)។ បន្ទាប់ពីពួកគេបានទទួលដំណឹងល្អរបស់ព្រះអម្ចាស់ តាមរយៈអ្នកបម្រើរបស់ទ្រង់ធ្វើឱ្យពួកគេបែរមកទទួលការដឹកនាំពីព្រះវិញ្ញាណវិញ ។

**១២:៣** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា អស់អ្នកដែលបានកើតជាថ្មីដោយសារព្រះវិញ្ញាណ នោះមិនដែលពោលពាក្យដាក់បណ្តាសាដល់ព្រះយេស៊ូវទេ គឺគេតែងតែប្រកាសយ៉ាងអស់ពីចិត្តថា ទ្រង់ជាព្រះអម្ចាស់វិញ (យហ ២០:២៨ ១យហ ៤:២-៣ មើលការពន្យល់ រម ១០:៩)។

**១២:៤-៦** *ព្រះវិញ្ញាណ. . . ព្រះអម្ចាស់. . . ព្រះ* ត្រង់ចំណុចនេះបញ្ជាក់អំពីលក្ខណៈព្រះត្រៃឯក និងភាពផ្សេងៗគ្នានៃអំណោយទានខាងឯវិញ្ញាណ។

**១២:៤** *អំណោយទាន* សំដៅលើអំណោយទានខាងឯវិញ្ញាណ ដែលប្រទានមកពួកអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទតាមរយៈព្រះវិញ្ញាណបរិសុទ្ធ (ខ.១)។

**១២:៥** *មុខងារ* អត្ថន័យដើមរបស់ពាក្យនេះជាភាសាក្រិក គឺសំដៅលើមុខងារ នៅក្នុងសហគមន៍គ្រីស្ទបរិស័ទ (កច ៦:២-៣ ភល ១:១)។

**១២:៦** ព្រះអម្ចាស់ប្រទានឱ្យអ្នកបម្រើទ្រង់នូវមុខងារផ្សេងៗ នៅក្នុងព្រះរាជកិច្ចរបស់ទ្រង់ ប៉ុន្តែគ្រប់ទាំងអស់គឺស្ថិតនៅក្រោមការដឹកនាំរបស់ទ្រង់។

**១២:៧** *ដើម្បីឱ្យបានកើតផល* មានន័យថា ព្រះអម្ចាស់ប្រទានឱ្យអស់អ្នកដែលជឿដល់ព្រះនាមទ្រង់នូវអំណោយទានខាងឯវិញ្ញាណ ដើម្បីបង្ហាញឱ្យឃើញថា ព្រះវិញ្ញាណបរិសុទ្ធពិតជាកំពុងធ្វើការ នៅក្នុងជីវិតគេមែន ។ ម្យ៉ាងទៀតរាល់អំណោយទានទាំងអស់ ត្រូវបានប្រទានមកសម្រាប់ស្អាងពួកជំនុំ និងសមាជិកនៃសហគមន៍របស់ខ្លួន (១ពត ៤:១០-១១) គឺមិនមែនសម្រាប់បម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ឬដើម្បីប្រកួតប្រជែង យកឈ្នះលើអ្នកដទៃ ដូចដែលពួកជំនុំនៅទីក្រុងកូរិនថូសធ្លាប់ធ្វើនោះឡើយ ។

**១២:៨** *ប្រាជ្ញាវាងវៃ* សំដៅលើប្រាជ្ញាដែលមកពីព្រះអម្ចាស់មិនមែនជាប្រាជ្ញាមកពីមនុស្ស និងលោកីយទេ (យក ១:៥)។ អំណោយទាននេះត្រូវបានប្រទានមក ដើម្បីដោះស្រាយនូវបញ្ហា ដែលកើតឡើងនៅក្នុងពួកជំនុំរបស់ព្រះអម្ចាស់ ។ ពាក្យនេះនៅក្នុងវចនានុក្រម មានន័យថា ជាសមត្ថភាពក្នុងការប្រើប្រាស់នូវបទពិសោធន៍ និងចំណេះដឹង ដើម្បីធ្វើការសម្រេចដ៏ជាក់លាក់ និងត្រឹមត្រូវ ។ *ពាក្យសំដី នៃចំណេះចេះស្ទាត់* ព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសប្រើពាក្យថា "ចំណេះ"។ ពាក្យថា "ចំណេះ" មានន័យថាជាព័ត៌មានជំនាញ និងសេចក្តីយល់ដឹងទាំងឡាយ ដែលមនុស្សម្នាក់ៗទទួលបាន តាមរយៈការរៀនសូត្រ ឬតាមរយៈបទពិសោធន៍ផ្សេងៗ ។

**១២:៩** *ប្រោសឱ្យជា* ព្រះអម្ចាស់ប្រទានឱ្យអ្នកបម្រើទ្រង់មួយចំនួនមានអំណោយទាននេះ ដើម្បីព្យាបាលអ្នកជំងឺឱ្យបានជាមិនមែនដោយសារថ្នាំពេទ្យទេ គឺដោយសារអំណាចព្រះចេស្តាទ្រង់វិញ ។

**១២:១០** *សំដែងការឫទ្ធិបារមី* មានលក្ខណៈខុសពីអំណោយទាននៃការប្រោសឱ្យជា ។ អំណោយទាននេះត្រូវបានប្រទានមក ដើម្បីសំដែងឱ្យឃើញនូវអំណាចព្រះចេស្តា និងព្រះវត្តមានរបស់ព្រះអម្ចាស់ (មក ៦:៣០-៤៤ យហ ២:១-១១ កច ៥:៥ ១៣:៦-១២)។ *អធិប្បាយ* នៅក្នុងព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសប្រើពាក្យថា "ថ្លែងទំនាយ"។ មានន័យថា អស់អ្នក

ទៀតចេះបកប្រែភាសាដទៃ ១១ តែគឺជាព្រះវិញ្ញាណតែមួយ
ដដែលនោះឯង[ង] ដែលធ្វើគ្រប់ការទាំងនោះ ទាំងចែកដល់
គ្រប់គ្នាដោយមុខៗផង តាមដែលទ្រង់សព្វព្រះហឫទ័យ ។

**រូបកាយ១ អវយវៈច្រើន**

១២ ដ្បិតដូចជារូបកាយ១ មានអវយវៈជាច្រើន តែ
អវយវៈទាំងនោះ ទោះមានច្រើនក៏ពិត គង់តែរួមគ្នាមក
ជារូបតែ១ទេ[ច] នោះព្រះគ្រីស្ទក៏ដូច្នោះដែរ[ឆ] ១៣ ដ្បិតយើង
ទាំងអស់គ្នាទោះបើជាសាសន៍យូដា ឬសាសន៍ក្រេក បាវ
បំរើ ឬអ្នកជាក្តី[ជ] យើងបានទទួលបុណ្យជ្រមុជ[ឈ] ចូលក្នុង
រូបកាយតែ១ ដោយសារព្រះវិញ្ញាណតែ១[ញ] ហើយគ្រប់គ្នា
ក៏បានត្រូវផឹកពីព្រះវិញ្ញាណតែ១ដែរ[ដ] ១៤ រូបកាយមិន
មែនសុទ្ធតែមានអវយវៈតែ១ទេ គឺមាន ច្រើនវិញ[ឋ] ១៥ បើ
សិនជាជើងនឹងនិយាយថា អញមិនមែនជារបស់ផងរូប
កាយទេ ពីព្រោះអញមិនមែនជាដៃ នោះតើមិនមែន
ជារបស់ផងរូបកាយ ដោយហេតុតែប៉ុណ្ណោះឬអី ១៦ ហើយ
បើសិនជាត្រចៀកនឹងនិយាយថា អញមិនមែនជារបស់
ផងរូបកាយទេ ពីព្រោះអញមិនមែនជាភ្នែក នោះតើ
មិនមែនជារបស់ផងរូបកាយ ដោយហេតុតែប៉ុណ្ណោះឬអី
១៧ បើរូបកាយទាំងស្រុងសុទ្ធតែជាភ្នែក នោះតើនឹងស្តាប់
នៅត្រង់ណា បើរូបកាយទាំងស្រុង សុទ្ធតែជាត្រចៀក
នោះតើនឹងដឹងក្លិននៅត្រង់ណា ១៨ តែព្រះទ្រង់បានដាក់ចុះ[ឌ]
នូវអវយវៈនិមួយៗ ក្នុងរូបកាយតាមព្រះហឫទ័យទ្រង់[ឍ]
១៩ បើគ្រប់ទាំងអស់សុទ្ធតែជាអវយវៈតែ១ នោះតើរូប
កាយនឹងនៅឯណា ២០ តែមានអវយវៈជាច្រើនវិញ ប៉ុន្តែ
រូបកាយតែ១ទេ[ណ] ២១ ហើយភ្នែកពុំអាចនិយាយទៅដៃថា
អញមិនត្រូវការនឹងឯងទេ ឬក្បាលនិយាយទៅជើងថា
អញមិនត្រូវការនឹងឯងដែរនោះឡើយ ២២ ប៉ុន្តែ អស់ទាំង
អវយវៈក្នុងរូបកាយដែលមើលទៅដូចជាខ្សោយជាងគេ
នោះមានប្រយោជន៍ជាជាងវិញ ២៣ ហើយអវយវៈណា
ក្នុងរូបកាយ ដែលយើងស្មានថា មិនគួររាប់អានប៉ុន្មាន
នោះយើងបានរាប់អានលើសទៅទៀត ឯអវយវៈណា
របស់យើង ដែលមិនល្អ មើលនោះបានល្អមើលកាន់តែ

**១២:១១** ង ខ.៤
**១២:១២** ច រម ១២:៥ ឆ ខ.២៧
**១២:១៣** ជ កទ ៣:២៨ កល ៣:១១ ឈ មក ១:៨ ញ អភ ២:១៨ ដ យហ ៧:៣៧–៣៩
**១២:១៤** ឋ ខ.១២,២០
**១២:១៨** ឌ ខ.២៨ ឍ ខ.១១
**១២:២០** ណ ខ.១២,១៤ រម ១២:៥

ដែលមានអំណោយទាននេះ គឺថ្លែងចេញនូវព្រះបន្ទូល ដែលខ្លួនទទួលពីព្រះអម្ចាស់ដោយផ្ទាល់តែម្តង ដើម្បីឱ្យដឹងនូវព្រះហឫទ័យទ្រង់ និងហេតុការណ៍ដែលនឹងកើតមានឡើងនៅពេលអនាគត ។ *សង្កេតស្គាល់អស់ទាំងវិញ្ញាណ* (មថ ២៤:២៤ ២កថ ១១:១៣–១៥)។ *និយាយភាសាដទៃផ្សេងៗ* ពាក្យថា "ភាសាដទៃ" ត្រង់ចំណុចនេះ មានន័យពីរយ៉ាងគឺ (១) សំដៅលើភាសារបស់ប្រទេសដទៃនៅលើផែនដីនេះ ដែលខ្លួនមិនដែលធ្លាប់រៀនសូត្រទាល់តែសោះ (២) សំដៅលើភាសាដែលមនុស្ស ជាតិនៅផែនដីនេះមិនអាចយល់បាន (១៤:២,៩,១៩ កច ១៩:៦)។ *បកប្រែភាសាដទៃ* អ្នកដែលមានអំណោយទាននេះ មានសមត្ថភាពបកប្រែភាសា ដទៃផ្សេងៗឱ្យទៅ ជាភាសាដែលអ្នកផ្សេងៗទៀតអាចយល់បាន ។

**១២:១១** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះវិញ្ញាណបរិសុទ្ធជ្រាបគ្រប់ទាំងអស់ថា តើអំណោយទានណាមួយដែលគ្រីស្ទបរិស័ទម្នាក់ៗត្រូវទទួល ។

**១២:១២** *រូបកាយ១ មានអវយវៈជាច្រើន* បញ្ជាក់អំពីការរួបរួម និងភាពខុសគ្នានៃអំណោយទាន ដែលព្រះអម្ចាស់ប្រទានមកអស់អ្នកជឿដល់ព្រះនាមទ្រង់គ្រប់ៗគ្នា ។ ម្យ៉ាងទៀត ទោះបីម្នាក់ៗមានអំណោយទានផ្សេងៗពីគ្នាក៏ដោយ ក៏ត្រូវតែផ្តុំគ្នាជារូបកាយតែមួយរបស់ព្រះគ្រីស្ទដែរ (អភ ១:២២-២៣ មើលការ ពន្យល់ រម ៦:៣–៤)។

**១២:១៣** "មើលការពន្យល់ រម ៦:៣,៤"។ *សាសន៍យូដា ឬសាសន៍ក្រេក* បញ្ជាក់ថា នៅក្នុងព្រះយេស៊ូវគ្រីស្ទ ពុំត្រូវឱ្យមានការប្រកាន់ពូជសាសន៍ និងវប្បធម៌ទេ ។ *បាវបំរើ ឬអ្នកជាក្តី* មានន័យថាក្នុងព្រះគ្រីស្ទមិនត្រូវឱ្យមានការប្រកាន់ឋានៈ ឬមុខងារអ្វីនោះទេ ។ *បានទទួលបុណ្យជ្រមុជចូលក្នុងរូបកាយតែ១ ដោយសារព្រះវិញ្ញាណតែ១* មានន័យថាទោះបីម្នាក់ៗទទួលបានអំណោយទានខុសគ្នាក៏ដោយក៏ទាំងអស់គ្នាសុទ្ធតែកើតពីព្រះវិញ្ញាណតែមួយ និងផ្តុំជារូបកាយតែមួយដែរ ។ *គ្រប់គ្នាក៏បានត្រូវផឹកពីព្រះវិញ្ញាណតែ១ដែរ* មានន័យថា ព្រះអម្ចាស់បានប្រទានព្រះវិញ្ញាណទ្រង់ឱ្យគង់នៅក្នុងជីវិតយើងម្នាក់ៗ ដែលទទួលជឿដល់ព្រះនាមទ្រង់ (៦:១៩) ដើម្បីឱ្យជីវិត យើង បានពេញទៅដោយផលផ្លែខាងឯវិញ្ញាណ (កទ ៥:២២–២៣ យហ ៧:៣៧–៣៩)។

**១២:១៤-២០** ក្នុងវគ្គនេះ ច្រើននិយាយសំដៅលើការលើកទឹកចិត្ត ដល់ពួកអ្នក ដែលគិតថាខ្លួនមិនសូវសំខាន់នៅក្នុងពួកជំនុំ ។

**១២:១៤** ពួកជំនុំជារូបកាយរបស់ព្រះគ្រីស្ទត្រូវរួបរួមគ្នាតែមួយ គឺដូចជារូបកាយរបស់មនុស្ស ត្រូវការអវយវៈទាំងអស់ ឱ្យធ្វើការព្រមគ្នាដូច្នោះដែរ (រម ១២:៤–៨)។

**១២:១៨** លោកប៉ុលបានបញ្ជាក់ថា ការដែលពួកជំនុំដែលជាព្រះកាយរបស់ព្រះអម្ចាស់ បានរួមគ្នាតែមួយ នោះគឺជាបំណងព្រះហឫទ័យទ្រង់ ។

**១២:២១-២៦** បទគម្ពីរទាំងនេះ និយាយផ្តោតទៅលើពួកអ្នកដែលបានទទួលនូវអំណោយទានពិសេសៗ ហើយគិតថាខ្លួនសំខាន់ជាងអ្នកដទៃ (ខ.១៤–២០)។ ម្យ៉ាងទៀត ត្រង់ចំណុចនេះបញ្ជាក់ថា ការដែលអ្នកណាម្នាក់គិតថាខ្លួនសំខាន់ជាងអ្នកដទៃ គឺមិនត្រឹមត្រូវទេ ។

**១២:២១** គ្រប់ផ្នែកទាំងអស់នៃរូបកាយត្រូវពឹងអាស្រ័យគ្នាទៅវិញទៅមក ។ ដូច្នេះ ប្រសិនបើអ្នកណាម្នាក់ដែលជឿដល់ព្រះអម្ចាស់គិតថាខ្លួនអាចធ្វើគ្រប់អ្វីៗទាំងអស់ដោយមិនត្រូវការបងប្អូនដទៃទៀត គឺជាកំហុសឆ្គងដ៏ធ្ងន់ធ្ងរបំផុត ។

**១២:២២** *ខ្សោយជាងគេ នោះមានប្រយោជន៍ជាជាងគេ* មានគ្រីស្ទបរិស័ទមួយចំនួនគិតថាខ្លួនមិនសូវសំខាន់ទេនៅក្នុងពួកជំនុំ ។ ប៉ុន្តែ ត្រង់ចំណុចនេះបញ្ជាក់ថា ពួកអ្នកដែលគិតថាខ្លួនខ្សោយ និងមិនសូវមានប្រយោជន៍នោះពួកគេជាអ្នកខ្លាំង និងមានប្រយោជន៍វិញ ។

**១២:២៣-២៤** បទគម្ពីរទាំងនេះរំលឹកយើងឱ្យចេះគោរព និងលើកទឹកចិត្ត

ខ្លាំងឡើងទៅទៀត ២៤ តែអវយវៈណារបស់យើងដែល
ល្អមើល នោះមិនត្រូវការអ្វីទេ ដូច្នេះ ព្រះទ្រង់បានផ្សំ
រូបកាយ ព្រមទាំងប្រទានឱ្យអវយវៈណាដែលខ្វះ បានប្រ
សើរលើសជាងទៅទៀត ២៥ ដើម្បីមិនឱ្យមានសេចក្ដី
បែកខ្ញែកគ្នាក្នុងរូបកាយឡើយតែឱ្យអវយវៈទាំងប៉ុន្មាន
បានជួយគាំពារគ្នាទៅវិញទៅមក ២៦ ដូច្នេះ បើអវយវៈ១
ឈឺ នោះទាំងអស់នឹងឈឺជាមួយគ្នា បើ១បានដំកើងឡើង
នោះទាំងអស់នឹងបានរីករាយជាមួយដែរ ២៧ អ្នករាល់គ្នា
ជារូបកាយនៃព្រះគ្រីស្ទ[ត] ហើយជាអវយវៈរបស់រូបកាយ
រៀងខ្លួន[ថ] ២៨ ព្រះទ្រង់បានតាំងអ្នកខ្លះក្នុង ពួកជំនុំឡើង[ទ]
មុនដំបូង គឺពួកសាវក[ធ] ទី២ ពួកគ្រូអធិប្បាយ[ន] ទី៣
ពួកគ្រូបង្រៀន រួចមកមានការឫទ្ធិបារមីមានអំណោយ
ទានជាការប្រោសឱ្យជា[ប] ជាការជំនួយ ជាការគ្រប់គ្រង[ផ]
ហើយជាភាសាដទៃផង[ព] ២៩ តើគ្រប់គ្នាជាសាវក ឬអី គ្រប់
គ្នាជាគ្រូអធិប្បាយឬអី គ្រប់គ្នាជាគ្រូបង្រៀន ឬអី គ្រប់
គ្នាធ្វើការឫទ្ធិបារមីបានឬអី ៣០ គ្រប់គ្នាមានអស់ទាំងអំ
ណោយទាននឹងប្រោសឱ្យជាបានឬអី គ្រប់គ្នាអាចនិយាយ
ភាសាដទៃបានឬអី[ភ] គ្រប់គ្នាចេះបកប្រែភាសាបាន ឬអី
៣១ ចូរសង្វាតឱ្យបាន[ម]អំណោយទានយ៉ាងវិសេសទៅចុះ
ប៉ុន្តែ ខ្ញុំនឹងបង្ហាញផ្លូវ១ ដ៏ប្រសើរលើសលែងទៅទៀត ។

## សេចក្ដីស្រឡាញ់

**១៣** ១ ទោះបើខ្ញុំចេះនិយាយ ជាភាសា[យ]របស់មនុស្សជាតិ
ទាំងប៉ុន្មាន និងភាសារបស់ពួកទេវតាផង តែគ្មានសេចក្ដី
ស្រឡាញ់ នោះខ្ញុំបានត្រឡប់ដូចជាលង្ហិនដែលឮខ្ទរ ឬដូច
ជាឈឹង ដែលឮទ្រហឹងប៉ុណ្ណោះ ២ បើខ្ញុំចេះអធិប្បាយ[រ]
ហើយស្គាល់អស់ទាំងសេចក្ដីអាថ៌កំបាំង[ល] និងគ្រប់ទាំង
ចំណេះវិជ្ជា[វ] ហើយបើខ្ញុំមានគ្រប់ទាំងសេចក្ដីជំនឿ[ស] ល្មម
នឹងឱ្យភ្នំរើចេញបាន[ហ] តែគ្មានសេចក្ដីស្រឡាញ់ នោះខ្ញុំមិន
ជាអ្វីទេ ៣ បើខ្ញុំចែកអស់ទាំងទ្រព្យសម្បត្តិខ្ញុំជាអាហារដល់
គេ[ឡ] ហើយបើខ្ញុំប្រគល់រូបកាយខ្ញុំទៅឱ្យគេដុត[អ] តែគ្មាន
សេចក្ដីស្រឡាញ់ នោះគ្មានប្រយោជន៍ដល់ខ្ញុំសោះ ៤ ឯសេច
ក្ដីស្រឡាញ់តែងតែអត់ធ្មត់[ក] ហើយក៏សប្បុរសសេចក្ដីស្រ
ឡាញ់មិនចេះឈ្នានីសមិនចេះអួតខ្លួន[ខ] ក៏មិនដែលមានចិត្តធំផង

**១២:២៧** ត អភ ១:២៣ ៤:១២ កល ១:១៨,២៤ ថ រម ១២:៥
**១២:២៨** ទ ១កថ ១០:៣២ ធ អភ ៤:១១ ន អភ ៤:១១ ប ខ.៩ ផ រម ១២:៦–៨ ព ខ.១០ មក ៦:១៧
**១២:១៣** ភ ខ.១០
**១២:៣១** ម ១កថ ១៤:១,៣៩
**១៣:១** យ ខ.៨ មក ១៦:១៧
**១៣:២** រ ខ.៨ អភ ៤:១១ កច ១១:២៧ ល ១កថ ១៤:២ វ ២កថ ៨:៧ ស ១កថ ១២:៩ ហ មថ ១៧:២០ ២១:២១
**១៣:៣** ឡ លក ១៩:៨ កច ២:៤៥ អ ដយ ៣:២៨
**១៣:៤** ក ១ថន ៥:១៤ ខ ១កថ ៥:២

ដល់គ្រប់គ្នានៅក្នុងពួកជំនុំ ជាពិសេសចំពោះពួកអ្នក ដែលនៅខ្សោយនៅឡើយ ។

**១២:២៥** *សេចក្ដីបែកខ្ញែកគ្នា* "មើលការពន្យល់ ១:១០–១២"។

**១២:២៦** *បើអវយវៈ១ឈឺ* ឃ្លានេះបញ្ជាក់ថា នៅក្នុងរូបកាយព្រះគ្រីស្ទប្រសិនបើមានបងប្អូនណាម្នាក់ជួបប្រទះនឹងការឈឺចាប់ នោះវាក៏ជះឥទ្ធិពលដល់បងប្អូនដទៃទៀតដែរ (កច ១២:១–៥)។ ដូច្នេះ ត្រូវតែចេះជួយគ្នា និងលើកទឹកចិត្តគ្នា ដើម្បីឱ្យព្រះកាយរបស់ព្រះគ្រីស្ទបានតម្កើងឡើង ។

**១២:២៧** *អ្នករាល់គ្នាជារូបកាយនៃព្រះគ្រីស្ទ* មានន័យថា ពួកជំនុំទាំងអស់គឺជារូបកាយរបស់ព្រះគ្រីស្ទ ។

**១២:២៨** បទគម្ពីរនេះ លោកប៉ុលផ្ដល់ជាឧទាហរណ៍ នៃផ្នែកផ្សេងៗរបស់រូបកាយព្រះគ្រីស្ទ ។ *ពួកសាវក . . . ពួកគ្រូអធិប្បាយ . . . ពួកគ្រូបង្រៀន* អំណោយ ទានទាំងបីនេះមានសារសំខាន់ណាស់នៅក្នុងការចាប់ផ្ដើមបង្កើតពួកជំនុំដំបូង (មថ ១៦:១៨ អភ ២:២០ និងការពន្យល់)។ អំណោយទានជាគ្រូបង្រៀន មានទំនាក់ទំនងជិតស្និទ្ធទៅនឹងភាពជាគ្រូគង្វាល (អភ ៤:១១ ១ធថ ៣:២)។ ទោះជាយ៉ាងណាក៏ដោយគ្រប់ទាំងអំណោយទានទាំងអស់សុទ្ធតែសំខាន់ (ខ.២១-២៦)។ *ការឫទ្ធិបារមី . . . ប្រោសឱ្យជា . . . ភាសាដទៃ* "មើលពន្យល់ ខ.៩–១០"។ *ជាការជំនួយ* សំដៅលើការជួយដល់អ្នកដទៃអាចទាំងផ្នែកព្រលឹងវិញ្ញាណ និងតម្រូវការខាងឯរូបកាយជាពិសេសគឺដល់អស់អ្នកក្រីក្រ ខ្វះខាតអ្នកមានជំងឺ និងពួកអ្នកកំពុងជួបប្រទះនឹងបញ្ហាលំបាកផ្សេងៗ (កច ៦:១–៦)។ *ការគ្រប់គ្រង* សំដៅលើអំណោយទានផ្នែករដ្ឋបាល ដែលមានការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីចាប់ផ្ដើម និងរៀបចំកម្មវិធីផ្សេងៗនៅក្នុងពួកជំនុំ ។

**១២:២៩–៣០** លោកប៉ុលបញ្ជាក់យ៉ាងច្បាស់ថា ពុំមែនគ្រប់គ្នាមានអំណោយទានដូចគ្នាទាំងអស់នោះទេ ។

**១២:៣១** ពួកជំនុំនៅទីក្រុងកូរិនថូស តែងតែប្រាថ្នាចង់បាននូវអំណោយទានដ៏ពិសេសៗ ដើម្បីឱ្យអ្នកដទៃទៀតឃើញថាខ្លួនសំខាន់ជាងគេ ។ លោកប៉ុលបានបញ្ជាក់ប្រាប់ពួកគេ អំពីរបៀបហ្វឹកហ្វាត់ឱ្យលូតលាស់នូវអំណោយទានដែលព្រះអម្ចាស់បានប្រទានមក គឺត្រូវឱ្យគ្រប់គ្នាធ្វើគ្រប់កិច្ចការទាំងអស់ដោយមានសេចក្ដីស្រឡាញ់ ។ លោកប៉ុលបានបញ្ជាក់យ៉ាងច្បាស់ថា សេចក្ដីស្រលាញ់គឺជាផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធ (កទ ៥:២២)។

**១៣:១** លោកប៉ុលមានប្រសាសន៍យ៉ាងច្បាស់ថា ទោះបីគាត់ចេះនិយាយទាំងភាសាមនុស្ស និងភាសាទេវតាក្ដីក៏វាគ្មានប្រយោជន៍អ្វីទាំងអស់ ប្រសិនបើគាត់ និយាយដោយគ្មានសេចក្ដីស្រឡាញ់ ។ *សេចក្ដីស្រឡាញ់* ពាក្យនេះក្នុងភាសាក្រិក គឺបញ្ជាក់អំពីការគិតផលប្រយោជន៍អ្នកដទៃជាជាងខ្លួនឯង ។ ព្រះយេស៊ូវបានបង្ហាញនូវសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះមនុស្សលោកដោយការសុគតនៅលើឈើឆ្កាង (យហ ៣:១៦ ១៣:៣៤–៣៥ អភ ៥:២៥ ១យហ ៣:១៦)។

**១៣:២** *សេចក្ដីអាថ៌កំបាំង និងគ្រប់ទាំងចំណេះវិជ្ជា* ឃ្លានេះលោកប៉ុលចង់មានន័យថា ទោះបីគាត់ស្គាល់នូវសេចក្ដីអាថ៌កំបាំង និងគ្រប់ទាំងចំណេះក៏ដោយ ក៏គ្មានប្រយោជន៍អ្វីដែរ បើសិនគ្មានសេចក្ដីស្រឡាញ់ (សក ៤:៧ មថ ១៧:២០)។

**១៣:៣** *បើខ្ញុំប្រគល់រូបកាយខ្ញុំទៅឱ្យគេដុត* លោកប៉ុលមានប្រសាសន៍ដូច្នេះ ពីព្រោះនៅសម័យគាត់មានអ្នកបម្រើព្រះអម្ចាស់មួយចំនួនត្រូវបានគេយកទៅដុតទាំងរស់ ។ ទោះជាយ៉ាងនេះក្ដីលោកប៉ុលបញ្ជាក់បន្ថែមទៀតថា បើអ្នកដែលត្រូវគេដុតគ្មានសេចក្ដីស្រឡាញ់នៅក្នុងខ្លួន នោះក៏គ្មានន័យដែរ ។

**១៣:៤** *មិនចេះអួតខ្លួន* (មើលការពន្យល់ ៨:១)។

៥មិនដែលប្រព្រឹត្តបែបមិនគួរសមមិន ដែលរកប្រយោជន៍
ផ្ទាល់ខ្លួន[គ] មិនរហ័សខឹង[ឃ] មិនប្រកាន់ទោស[ង] ៦មិនដែល
អរសប្បាយចំពោះសេចក្ដីទុច្ចរិតឡើយ[ច] គឺអរសប្បាយតែ
នឹងសេចក្ដីស្មោះត្រង់វិញ[ឆ] ៧ក៏គ្របបាំងទាំងអស់ ជឿទាំង
អស់ សង្ឃឹមទាំងអស់ ហើយទ្រាំទ្រទាំងអស់[ជ] ៨រីឯការ
អធិប្បាយ[ឈ] នោះនឹងត្រូវបាត់ទៅ ការនិយាយភាសាដទៃ[ញ]
នឹងត្រូវឈប់ ហើយចំណេះក៏ត្រូវសាបសូន្យទៅដែរ តែ
ឯសេចក្ដីស្រឡាញ់មិនដែលផុតឡើយ ៩ដ្បិតយើងចេះ
មិនទាន់សព្វគ្រប់[ដ] ហើយយើងអធិប្បាយក៏មិន ទាន់បាន
ពេញខ្នាតផង ១០តែកាលណាសេចក្ដីគ្រប់លក្ខណ៍បាន
ចូលមក[ឋ] នោះសេចក្ដីដែលមិនពេញខ្នាតនឹងបាត់ទៅ
១១កាលដែលខ្ញុំនៅក្មេងនៅឡើយ នោះខ្ញុំបាននិយាយដូចជា
កូនក្មេងក៏មានគំនិតដូចជាកូនក្មេង ហើយបានពិចារណាដូច
ជាកូនក្មេងដែរ លុះកាលខ្ញុំធំ ហើយនោះខ្ញុំបានលះចោល
ការរបស់កូនក្មេងចេញទៅ[ឌ] ១២ដ្បិតឥឡូវនេះ យើងមើល
ឃើញបែបស្រអាប់ ដូចជាដោយសារកញ្ចក់[ឍ] តែនៅវេលា
នោះ នឹងឃើញមុខទល់នឹងមុខ[ណ] ឥឡូវនេះ ខ្ញុំស្គាល់មិនទាន់
អស់ តែនៅវេលានោះ ខ្ញុំនឹងស្គាល់វិញ ដូចជាព្រះទ្រង់
ស្គាល់ខ្ញុំដែរ[ត] ១៣ឥឡូវនេះ នៅមានសេចក្ដីជំនឿ សេចក្ដី
សង្ឃឹម និងសេចក្ដីស្រឡាញ់[ថ] ទាំង៣មុខនេះ តែសេចក្ដី
ដែលវិសេសជាងគេ គឺជាសេចក្ដីស្រឡាញ់[ទ]។

**អំណោយទានអធិប្បាយ និងការនិយាយភាសាដទៃ**

**១៤** ១ចូរដេញតាមសេចក្ដីស្រឡាញ់ចុះ[ធ] ហើយសង្វាត
ចង់បាន[ន]អស់ទាំងអំណោយទាន ខាងឯវិញ្ញាណដែរ[ប] តែ
ស៊ូឱ្យចេះអធិប្បាយជាដើម[ផ] ២ដ្បិតអ្នកណាដែលនិយាយ
ភាសាដទៃ[ព] នោះមិនមែននិយាយនឹងមនុស្ស គឺទូលនឹងព្រះ
វិញ ពីព្រោះគ្មានអ្នកណាស្ដាប់បានទេ[ភ] ប៉ុន្តែ អ្នកនោះ
និយាយជាសេចក្ដីអាថ៌កំបាំង ដោយនូវវិញ្ញាណ ៣ឯអ្នក
ដែលអធិប្បាយវិញ អ្នកនោះនិយាយនឹងមនុស្ស សំរាប់នឹង
ស្អាងចិត្ត កំឡាចិត្ត[ម] ហើយកំសាន្តចិត្ត[យ] ៤អ្នកណាដែល
និយាយភាសាដទៃ[រ] នោះស្អាងតែចិត្តខ្លួនឯងទេ[ល] តែអ្នក
ណាដែលអធិប្បាយ[វ] នោះទើបស្អាងចិត្តចំពោះពួកជំនុំ
ទាំងអស់គ្នាវិញ ៥ខ្ញុំចង់ឱ្យអ្នករាល់គ្នានិយាយភាសាដទៃ

**១៣:៥** គ ១កថ ១០:២៤ ឃ មថ ៥:២២ ង យប ១៤:១៦,១៧ សភ ១០:១២ ១៧:៩ ១ពត ៤:៨ **១៣:៦** ច ២ថន ២:១២ ឆ ២យហ ៤ ៣យហ ៣,៤ **១៣:៧** ជ ខ.៨,១៣ **១៣:៨** ឈ ខ.២ ញ ខ.១ **១៣:៩** ដ ខ.១២ ១កថ ៨:២ **១៣:១០** ឋ ភល ៣:១២ **១៣:១១** ឌ ទជ ១៣១:២ **១៣:១២** ឍ យប ២៦:១៤ ៣៦:២៦ ណ លប ៣២:៣០ យប ១៩:២៦ ១យហ ៣:២ ត ១កថ ៨:៣ កទ ៤:៩ **១៣:១៣** ថ រម ៥:២-៥

កទ ៥:៥,៦ អភ ៤:២-៥ កល ១:៤,៥ ១ថន ១:៣ ៥:៨ ហព ៦:១០-១២ ទ មថ ២២:៣៧-៤០ ១កថ ១៦:១៤ កទ ៥:៦ ១យហ ៤:៧-១២,១៦ **១៤:១** ធ ១កថ ១៦:១៤ ន ខ.៣៩ ១កថ ១២:៣១ ប ១កថ ១២:១ ផ ខ.៣៩ អភ ៤:១១ **១៤:២** ព មក ១៦:១៧ ភ ខ.៦-១១,១៦ ១កថ ១៣:២ **១៤:៣** ម ខ.៤,៥, ១២,១៧,២៦ រម ១៤:១៩ យ ខ.៣១ **១៤:៤** រ មក១៦:១៧ ល ខ.៣ វ ១កថ ១៣:២

**១៣:៥** *មិនដែលប្រព្រឹត្តបែបមិនគួរសម* មានន័យថា ត្រូវប្រព្រឹត្តនឹង គ្នាទៅវិញ ទៅមកដោយសេចក្ដីមេត្តាករុណា និងសេចក្ដីស្រឡាញ់គ្រប់វេលាទាំងអស់ ។

**១៣:៦** *មិនដែលអរសប្បាយចំពោះសេចក្ដីទុច្ចរិតឡើយ* ឃ្លានេះបញ្ជាក់ថា មនុស្សភាគច្រើនតែងតែចង់ស្ដាប់រឿងអាក្រក់របស់អ្នកដទៃ ព្រោះថា នៅពេលដែលបានឮរឿងទាំង នោះធ្វើឱ្យពួកគេមានអារម្មណ៍ថា ខ្លួនប្រសើរជាងគេ ។ ប៉ុន្តែ អស់អ្នកដែលមានសេចក្ដីស្រឡាញ់ ពុំដែលអរសប្បាយចំពោះការទាំងនេះទេ ។

**១៣:៨** *សេចក្ដីស្រឡាញ់មិនដែលផុតឡើយ* មានន័យថា សេចក្ដីស្រឡាញ់ពិតមិន ដែលមានថ្ងៃបញ្ចប់ទេ (ខ.៩-១០ មើលការពន្យល់ ខ.១៣)។

**១៣:១០** *សេចក្ដីគ្រប់លក្ខណ៍បានចូលមក* ពាក្យថា "សេចក្ដីគ្រប់លក្ខណ៍" នៅក្នុងភាសាក្រិកអាចមានន័យថា "ចុងបញ្ចប់" ឬ "ពេញលេញ"។ ម៉្យាងទៀតឃ្លានេះ អាចសំដៅលើថ្ងៃដែលព្រះអម្ចាស់យាងមកជាលើកទីពីរ ។

**១៣:១២** នៅពេលយើងមើលទៅក្នុងកញ្ចក់ចាស់ ដែលពេញដោយធូលីនោះ យើងមិនអាចមើលឃើញរូបយើងច្បាស់ទេ ។ មានន័យថា ជីវិតចាស់របស់យើងមិនអាចមើលឃើញព្រះអម្ចាស់បានទេ គឺត្រូវប្រើជីវិតថ្មីដែលទ្រង់ប្រទានឱ្យវិញ ។

**១៣:១៣** *សេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់* "មើលការពន្យល់ ១ថន ១:៣"។ *សេចក្ដីដែលវិសេសជាងគេ គឺជាសេចក្ដីស្រឡាញ់* ព្រោះថា ព្រះអម្ចាស់ទ្រង់ជាសេចក្ដីស្រឡាញ់ (១យហ ៤:៨) និងប្រទានសេចក្ដីស្រឡាញ់ មកយើងរាល់គ្នា (១យហ ៤:១០) ហើយទ្រង់បានបង្គាប់ឱ្យយើងចេះស្រឡាញ់ គ្នាទៅវិញទៅមក (យហ ១៣:៣៤-៣៥ រម ១៣:១០ ១កថ ៨:១ កទ ៥:៦ អភ ៤:១៦ ៥:២០ ភល ១:៩ កល ៣:១៤ ១ពត ៤:៨)។

**១៤:១** *សេចក្ដីស្រឡាញ់* ចំណុចនេះបញ្ជាក់ថា ការប្រើប្រាស់អំណោយទានអាចមានប្រសិទ្ធភាពទៅបាន គឺអាស្រ័យលើសេចក្ដីស្រឡាញ់ ។ *អធិប្បាយ* ពាក្យថា "អធិប្បាយ" ត្រង់ចំណុចនេះព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសប្រើពាក្យថា "ថ្លែងទំនាយ" (មើលការពន្យល់ ១២:១០)។

**១៤:២** *ភាសាដទៃ* សំដៅលើភាសាដែលគ្មានអ្នកណាអាចយល់បានក្រៅអំពីព្រះ ។ អ្នកដទៃទៀតអាចយល់បាន លុះណាតែមានអ្នកណាម្នាក់ ដែលមានអំណោយទានចេះបកប្រែភាសាដទៃនោះ (ខ.១៤-១៧)។

**១៤:៣** បទគម្ពីរនេះបញ្ជាក់ថា អ្នកអធិប្បាយ (ព្រះគម្ពីរភាសាអង់គ្លេសប្រើពាក្យថា អ្នកថ្លែងទំនាយ) គឺមានតួនាទីលើកទឹកចិត្ត និងស្អាងពួកជំនុំឡើង (មើលការ ពន្យល់ ១២:៧)។

**១៤:៤** *ស្អាងតែចិត្តខ្លួនឯងទេ* មានន័យថា នៅពេលអ្នកណាម្នាក់និយាយភាសាដទៃ នោះគេនឹងបានស្អាងខ្លួនឡើង ដោយទទួលបាននូវព្រះពរខាងឯវិញ្ញាណនិងបទពិសោធន៍នៃសេចក្ដីអំណរ ហើយនិងព្រះវត្តមាននៃព្រះ។ សម្រាប់អ្នកដែលស្ដាប់គេនិយាយភាសាដទៃ ដោយពុំបានយល់នូវសេចក្ដីដែលគេនិយាយ នោះមិនបានទទួលអ្វីទេ ។ ប៉ុន្តែ ប្រសិនបើភាសាដទៃនោះត្រូវបានបកប្រែ នោះអ្នកដែលស្ដាប់ក៏ទទួលបាននូវព្រះពរដែរ ។

**១៤:៥-៦** ត្រង់ចំណុចនេះ លោកប៉ុលមិនបានជំទាស់មិនឱ្យនិយាយភាសាដទៃទេ ប៉ុន្តែ គាត់ចង់ឱ្យពួកគេនិយាយដោយមានរបៀបត្រឹមត្រូវតាមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ ។ ម៉្យាងទៀត ប្រសិនបើអ្នកណាម្នាក់និយាយភាសាដទៃទៅ កាន់ពួកជំនុំ នោះត្រូវឱ្យមានអ្នកបកប្រែផង ទើបជាការត្រឹមត្រូវ (ខ.១៣)។ *អ្នកដែលអធិប្បាយ នោះប្រសើរជាង* លោកប៉ុលមាន

ទាំងអស់ដែរ តែស៊ូឱ្យអ្នករាល់គ្នាចេះអធិប្បាយជាជាង[ស]
ដ្បិតអ្នកដែលអធិប្បាយ នោះប្រសើរជាងអ្នកដែលនិយាយ
ភាសាដទៃទៅទៀត លើកតែអ្នកនោះចេះបកប្រែផង
ដើម្បី ឱ្យពួកជំនុំបានស្អាងចិត្តឡើង[ហ] ៦ដូច្នេះ បងប្អូន
អើយ បើខ្ញុំមកឯអ្នករាល់គ្នា ដោយនិយាយភាសាដទៃ
នោះតើខ្ញុំនឹងមានប្រយោជន៍អ្វីដល់អ្នករាល់គ្នា លើកតែ
ខ្ញុំនិយាយនឹងអ្នករាល់គ្នាជាការបើកសំដែង[ឡ] ឬតាមចំ
ណេះ[អ] ឬជាសេចក្តីអធិប្បាយ ឬសេចក្តីបង្រៀនណាមួយ
វិញ[ក] ៧ឯរបស់ឥតជីវិតទាំងប៉ុន្មានដែលមានចេញសូរ
ទោះបើជាខ្លុយឬស៊ុងក្តី បើមិនមានឮសូរខ្ពស់ទាប នោះ
ធ្វើដូចម្តេចឱ្យដឹងថា ផ្លុំឬចាប់លេងបទណាទៅបាន ៨ឯ
ត្រែ ក៏ដូចគ្នា បើឮសូរមិនច្បាស់ នោះតើនឹង មានអ្នក
ណាប្រុងប្រៀបខ្លួនទៅច្បាំងបាន[ខ] ៩អ្នករាល់គ្នាក៏យ៉ាង
ដូច្នោះដែរ បើសិនជាអណ្តាតមិនបញ្ចេញចំពោះពាក្យ
ដែលស្តាប់បាន នោះធ្វើដូចម្តេចឱ្យគេដឹងជាថាអ្វីៗបាន គឺ
ដូចជានិយាយទៅតាមខ្យល់ទេ ១០នៅក្នុងលោកីយ នេះ
មានសូរសំឡេងជាច្រើនយ៉ាងណាស់ តែគ្មានណាមួយ
ដែលមិនច្បាស់ឡើយ ១១ដូច្នេះ បើខ្ញុំមិនយល់ន័យសំឡេង
នោះ នោះអ្នកដែលនិយាយនឹងទុកខ្ញុំដូចជាអ្នកប្រទេសដទៃ
ហើយអ្នកដែលនិយាយ នឹងបានដូចជាអ្នកប្រទេសដទៃដល់
ខ្ញុំដែរ[គ] ១២ដូច្នេះ ដែលអ្នករាល់គ្នាសង្វាតចង់បានអំណោយ
ទានខាងឯវិញ្ញាណ[ឃ] នោះត្រូវស្វែងរក ឱ្យបានកាន់តែច្រើន
ចុះ ដើម្បីនឹងស្អាងចិត្ត[ង]នៃពួកជំនុំឡើង ១៣ហេតុនោះបាន
ជាអ្នកណាដែលនិយាយភាសាដទៃ នោះត្រូវអធិស្ឋានសូម
ឱ្យចេះបកប្រែដែរ[ច] ១៤បើខ្ញុំអធិស្ឋានជាភាសាដទៃ នោះ
គឺជាវិញ្ញាណខ្ញុំ ដែលអធិស្ឋាន[ឆ] តែឥតមានប្រយោជន៍ដល់
ប្រាជ្ញាខ្ញុំសោះ ១៥ដូច្នេះត្រូវធ្វើដូចម្តេច ខ្ញុំត្រូវអធិស្ឋាន
ដោយនូវវិញ្ញាណ[ជ] ហើយត្រូវ អធិស្ឋានដោយនូវប្រាជ្ញាផង
ខ្ញុំនឹងច្រៀង[ឈ]ដោយវិញ្ញាណ ហើយនឹងច្រៀងដោយប្រាជ្ញា
ដែរ ១៦ពុំនោះបើសូមពរដោយនូវវិញ្ញាណទទេ នោះធ្វើ
ដូចម្តេចឱ្យអ្នកដែលមិនចេះ បានថា «អាម៉ែន»[ញ]បាន ក្នុង
កាលដែលអ្នកអរព្រះគុណនោះ[ដ] ដ្បិតអ្នកនោះមិនដឹងជា
អ្នកថាដូម្តេចទេ ១៧ឯអ្នកៗ អរព្រះគុណយ៉ាងល្អមែន តែ
អ្នកនោះមិនបានស្អាងចិត្តឡើងសោះ[ឋ] ១៨ខ្ញុំអរព្រះគុណដល់
ព្រះនៃខ្ញុំដ្បិតខ្ញុំនិយាយភាសាដទៃជាច្រើន លើសជាងអ្នក
រាល់គ្នាទាំងអស់ ១៩ប៉ុន្តែ ក្នុងពួកជំនុំ ខ្ញុំចូលចិត្តនិយាយ
តែពាក្យ ៥ម៉ាត់ដោយនូវប្រាជ្ញាខ្ញុំ ដើម្បីនឹងបង្រៀនដល់
មនុស្សឯទៀត ជាជាងនិយាយភាសាដទៃ១ម៉ឺនម៉ាត់វិញ[ឍ]។
២០បងប្អូនអើយ កុំឱ្យអ្នករាល់គ្នានៅខ្ចីខាងឯគំនិត
ឡើយ[ណ] បើខាងឯបំណងអាក្រក់ នោះចូរនៅជាកូនង៉ែត

**១៤:៥** ស ជន ១១:២៩ ហ ខ.៣
**១៤:៦** ឡ ខ.២៦ អភ ១:១៧ អ ២កថ ៨:៧ ក រម ៦:១៧
**១៤:៨** ខ ជន ១០:៩ យរ ៤:១៩
**១៤:១១** គ លប ១១:៧
**១៤:១២** ឃ ១កថ ១២:១ ង ខ.៣
**១៤:១៣** ច ខ.៥
**១៤:១៤** ឆ ខ.២
**១៤:១៥** ជ ខ.២,១៤ ឈ អភ ៥:១៩
**១៤:១៦** ញ ចទ ២៧:១៥-២៦ ១រប ១៦:៣៦ នហ ៨:៦ ទដ ១០៦:៤៨ វវ ៥:១៤ ៧:១២ ដ មថ ១៤:១៩ ១កថ ១១:២៤
**១៤:១៧** ឋ ខ.៣
**១៤:១៩** ឍ ខ.៦
**១៤:២០** ណ ១កថ ៣:១១ អភ ៤:១៤ ហាប ៥:១២,១៣ ១ពត ២:២

ប្រសាសន៍យ៉ាងដូច្នេះ ពីព្រោះអ្នកអធិប្បាយ គឺជាអ្នកដែលស្អាងអ្នកដទៃ និងពួកជំនុំឡើង ។

**១៤:៧** *ខ្លុយ ឬស៊ុង* នៅប្រទេសក្រិកមនុស្សភាគច្រើនស្គាល់ឧបករណ៍ភ្លេងទាំងពីរនេះ ។ ម្យ៉ាងទៀត ក្នុងបទគម្ពីរនេះ លោកប៉ុលចង់បញ្ជាក់ថា អស់អ្នកដែលនិយាយភាសាដទៃ បើគ្មានអ្នកណាអាចយល់បាននោះប្រៀបបាននឹងទំនុកភ្លេង ដែលគ្មានសូរទាបខ្ពស់យ៉ាងដូច្នោះដែរ ។

**១៤:៨-៩** ក្នុងជួរទាហាន គេផ្លុំត្រែដែលមានសូរផ្សេងៗពីគ្នា ដើម្បីបញ្ជាក់ថា សំឡេងណាសម្រាប់ដាស់ឱ្យក្រោកពីដំណេក សំឡេងណាសម្រាប់ពេលបរិភោគអាហារ និងសំឡេងណាសម្រាប់ចេញទៅច្បាំង ។ អ្នកផ្លុំត្រែត្រូវតែផ្លុំឱ្យចេញសំឡេងច្បាស់លាស់ ទៅតាមស្ថានភាពនីមួយៗ បើពុំដូច្នោះទេ ពួកទាហាននឹងពុំដឹងថាត្រូវធ្វើអ្វីនោះទេ ។ លោកប៉ុលមានប្រសាសន៍ជាពាក្យប្រៀបធៀបដូច្នេះ គឺចង់ឱ្យពួកអ្នកដែលនិយាយទៅកាន់ពួកជំនុំនិយាយអ្វីដែលពួកគេអាចស្តាប់បាន (ជន ១០:៩ យស ៦:៤,៩) ។

**១៤:១០-១២** ប្រសិនបើអ្នកណាម្នាក់និយាយមកកាន់យើងជាភាសាបរទេសដែលយើងមិនអាចយល់បាន នោះអ្វីដែលគេនិយាយគឺគ្មានប្រយោជន៍សម្រាប់យើងទេ ។ ដូចគ្នាដែរ ចំពោះពួកអ្នកនិយាយភាសាដទៃ ដែលគ្មានអ្នកបកប្រែក៏គ្មានប្រយោជន៍អ្វីដល់អ្នកដែលស្តាប់ដែរ ។ ម្យ៉ាងទៀតគ្រប់ទាំងអំណោយទានត្រូវបានប្រទានមកសម្រាប់ស្អាងដល់អ្នកដទៃទៀត ឱ្យបានចម្រើនឡើង (ខ.១៤) ។

**១៤:១៥-១៧** ចំណុចនេះបញ្ជាក់ថា នៅពេលដែលយើងអធិប្បាយ និងអធិស្ឋាន គឺត្រូវឱ្យនិយាយជាភាសា ដែលពួកអ្នកស្តាប់អាចយល់បានទើបជាការប្រសើរ ។ បើពុំដូច្នោះទេ តើធ្វើដូចម្តេចឱ្យពួកគេនិយាយថា "អាម៉ែន" បាន (១រប ១៦:៣៦ នហ ៥:១៣ ៨:៦ ទដ ១០៤:៣៣ ១៣៦:១ រម ១:២៥ ១១:៣៦ អភ ៥:១៨-២០) ។ ម្យ៉ាងទៀត ប្រសិនបើអ្នកណាម្នាក់អធិប្បាយជាភាសាបរទេសនោះចូរឱ្យមានអ្នកបកប្រែ ដើម្បីឱ្យអ្នកដែលស្តាប់អាចយល់នូវសេចក្តីដែលអធិប្បាយនោះផង ។

**១៤:១៨-១៩** ពួកជំនុំនៅទីក្រុងកូរិនថូសតែងតែមានអំនួត ដោយព្រោះតែបានទទួលនូវអំណោយទាននិយាយភាសាដទៃ ។ លោកប៉ុលមានប្រសាសន៍ទៅកាន់ពួកគេទាំងនោះថា គាត់អាចនិយាយភាសាដទៃច្រើនជាងពួកគេទៅទៀត ប៉ុន្តែ គាត់មិននិយាយ នៅក្នុងពេលអធិប្បាយព្រះបន្ទូលទេ ។ ប្រសិនបើគាត់និយាយភាសាដទៃទៅកាន់ពួកជំនុំ គឺត្រូវតែឱ្យមានអ្នកណាម្នាក់ ដែលមានអំណោយទានបកប្រែភាសាដទៃបកប្រែនូវសេចក្តីដែលគាត់និយាយ ដើម្បីឱ្យពួកគេអាចយល់ និងបានស្អាងឡើងនៅក្នុងព្រះគុណនៃព្រះអម្ចាស់ផងដែរ ។

**១៤:២០** *បើខាងឯបំណងអាក្រក់ នោះចូរនៅជាកូនង៉ែតចុះ* ឃ្លានេះបញ្ជាក់ថា កូនង៉ែតគ្មានបំណង ឬគំនិតអាក្រក់ណាមួយទេ ។ មានន័យថា លោកប៉ុលមិនចង់ឱ្យពួកជំនុំ នៅឯទីក្រុងកូរិនថូសសង្វាតចង់បានអំណោយទានរបស់ព្រះអម្ចាស់ ដើម្បីយកទៅប្រើនៅក្នុងផ្លូវអាក្រក់ណាមួយទេ ។

ចុះ[ណ] តែចំណែកខាងឯគំនិត នោះចូរធ្វើជាមនុស្សពេញ
អាយុវិញ 21 មានសេចក្ដីចែងទុកមកក្នុងក្រិត្យវិន័យ[ត]ថា
«អញនឹងនិយាយនឹងសាសន៍នេះដោយភាសាផ្សេងៗ ហើយ
ដោយបបូរមាត់មនុស្សដទៃ តែយ៉ាងនោះ គេក៏មិនស្ដាប់
អញដែរ[ថ] នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ » 22 បានជាភា
សាដទៃ នោះសំរាប់ជាទីសំគាល់ មិនមែនដល់ពួកអ្នក
ដែលជឿទេ គឺដល់អស់ពួកអ្នកដែលមិនជឿវិញ តែការ
អធិប្បាយ[ទ] នោះមិនមែនសំរាប់ពួកអ្នកដែលមិនជឿ គឺសំ
រាប់ពួកអ្នកដែលជឿវិញ 23 ដូច្នេះ បើកាលណាពួកជំនុំ
ទាំងមូលប្រជុំគ្នានៅកន្លែងណាមួយ ហើយគ្រប់គ្នានិយាយ
ភាសាដទៃ រួចមានមនុស្សដែលមិនចេះ ឬមនុស្សមិនជឿ
គេចូលមក នោះតើគេមិនថា អ្នករាល់គ្នាឆ្កួតទេឬអី[ធ]
24 តែបើគ្រប់គ្នាអធិប្បាយវិញ ហើយមានមនុស្សដែលមិន
ជឿ ឬមនុស្សខ្លះដែលមិនចេះ គេចូលមក នោះគេត្រូវភ្ញាក់
ដឹងខ្លួនឡើង ដោយសារអ្នករាល់គ្នា ហើយត្រូវអ្នករាល់គ្នា
ពិចារណាខ្លួនដែរ 25 យ៉ាងនោះ អស់ទាំងសេចក្ដីលាក់
កំបាំង[ន]ក្នុងចិត្តគេ នឹងបានសំដែងមក ហើយយ៉ាងនោះ គេ
នឹងក្រាបផ្កាប់មុខថ្វាយបង្គំដល់ព្រះវិញ ព្រមទាំងធ្វើបន្ទាល់
ថា ព្រះទ្រង់គង់នៅក្នុងចំណោមអ្នករាល់គ្នាមែន[ប]។

## លំដាប់លំដោយនៃការថ្វាយបង្គំ

26 ដូច្នេះ ធ្វើដូចម្ដេច បងប្អូនអើយ[ផ] កាលណាអ្នករាល់
គ្នា[ព]ប្រជុំ នោះគ្រប់គ្នា[ភ]មានទំនុកដំកើង[ម] មានសេចក្ដី
បង្រៀន[យ] មានសេចក្ដីបើកសំដែង មាននិយាយភាសា
ដទៃ[រ]មានសេចក្ដីបកប្រែដែរ[ល] ត្រូវឱ្យធ្វើការទាំងអស់ សំ
រាប់នឹងស្អាងចិត្តឡើង 27 បើមានអ្នកណានិយាយជា
ភាសាដទៃ នោះនិយាយបានតែ ២ឬ ៣នាក់យ៉ាងច្រើន
ហើយម្នាក់ម្ដងៗ ផងរួចត្រូវមានអ្នក ១ ជាអ្នកបកប្រែ
28 បើគ្មានអ្នកណាសំរាប់បកប្រែទេ នោះត្រូវឱ្យគេនៅ
ស្ងៀមក្នុងពួកជំនុំចុះ ហើយទូលដល់ព្រះដោយខ្លួនឯងវិញ
29 ឯអ្នកដែលអធិប្បាយ[វ] នោះទុកឱ្យ២ ឬ៣ នាក់សំដែង
ទៅហើយឱ្យអ្នកឯទៀតគិតពិចារណាចុះ[ស] 30 បើមានអ្នក
ណាទៀតអង្គុយនៅទីនោះ ដែលក៏មានសេចក្ដីសំរាប់នឹង
បើកសំដែងដែរ នោះត្រូវឱ្យអ្នកមុនផ្អាកនៅស្ងៀមសិន
31 ដ្បិតអ្នករាល់គ្នាមានច្បាប់នឹងអធិប្បាយបានទាំងអស់គ្នា

**១៤:២០** ណ យរ ៤:២២ មថ ១០:១៦ រម ១៦:១៩
**១៤:២១** ត ខ.៣៤ យហ ១០:៣៤ ថ ចទ ២៨:៤៩ អស ២៨:១១-១២
**១៤:២២** ទ ខ.១
**១៤:២៣** ធ កច ២:១៣
**១៤:២៥** ន រម ២:១៦
ប អស ៤៥:១៤ សក ៨:២៣
**១៤:២៦** ផ រម ៧:១ ព ១កថ ១២:៧-១០ ភ អភ ៥:១៩ ម ខ.៦ យ ខ.២ រ ១កថ ១២:១០ ល រម ១៤:១៩
**១៤:២៩** វ ខ.៣២, ៣៧ ១កថ ១៣:២ ស ១កថ ១២:១០

---

**១៤:២១-២២** បទគម្ពីរត្រង់ចំណុចនេះ បានដកស្រង់ចេញពីព្រះបន្ទូលនៅក្នុងកណ្ឌគម្ពីរអេសាយជំពូក២៨ ដែលបញ្ជាក់ថា ភាសាដទៃគឺជាទីសំគាល់បង្ហាញអំពីការជំនុំជម្រះ ដែលត្រូវធ្លាក់មកលើពួកអ៊ីស្រាអែលដែលមិនព្រមជឿដល់ព្រះអម្ចាស់ ។ លោកប៉ុលបញ្ជាក់ថាភាសាដទៃគឺសម្រាប់ជាទីសំគាល់ដល់ពួក អ្នកដែលមិនជឿដល់ព្រះអម្ចាស់វិញ (ខ.២២) ដូចមានឧទាហរណ៍នៅក្នុង "កច ២:៤-១២" ជាដើម ។ រីឯការអធិប្បាយវិញ គឺមានប្រយោជន៍ដល់ពួកអ្នកដែលជឿដល់ទ្រង់ ព្រោះវាបានសំដែងនូវសេចក្ដីពិតដល់ពួកអ្នកដែលបើកចិត្តចំហទទួល (មថ ១៣:១១-១៦)។

**១៤:២១** *ក្រិត្យវិន័យ* (យហ ១០:៣៤ ១៥:២៥ មើលការពន្យល់ យហ ១២:៣៤ រម ៣:១៩)។

**១៤:២២** *ភាសាដទៃ នោះសំរាប់ជាទីសំគាល់ មិនមែនដល់ពួកអ្នកដែលជឿទេ* មានន័យថាទីសំគាល់ពីការជំនុំជម្រះ ពុំមែនសម្រាប់ពួកអ្នកដែលទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទទេ គឺសម្រាប់ពួកអ្នកដែលមិនជឿដល់ទ្រង់វិញ ។

**១៤:២៣** *មនុស្សដែលមិនចេះ* អាចសំដៅលើពួកអ្នកដែលបើកចិត្តចំហចំពោះដំណឹងល្អ ប៉ុន្តែ មិនបានយល់ច្បាស់នូវព្រះបន្ទូលនៃព្រះអម្ចាស់នៅឡើយ ។ *មនុស្សមិនជឿ* សំដៅលើពួកអ្នកដែលមិនបានទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ ។

**១៤:២៤** *បើគ្រប់គ្នាអធិប្បាយ* គឺសំដៅលើការអធិប្បាយជាភាសាដែលមនុស្សទូទៅស្ដាប់បាន និងមានឥទ្ធិពលវិជ្ជមានចំពោះពួកអ្នកមិនជឿផងដែរ ពីព្រោះនៅពេលដែលគេស្ដាប់ឮព្រះបន្ទូល នោះគេអាចមានការប៉ះពាល់ចិត្ត ហើយអាចប្រែចិត្តទទួលជឿដល់ព្រះអម្ចាស់ផង (មើលការពន្យល់ ខ.២៩-៣២)។

**១៤:២៦** *ទំនុកដំកើង មានសេចក្ដីបង្រៀន មានសេចក្ដីបើកសំដែង មាននិយាយភាសាដទៃ មានសេចក្ដីបកប្រែដែរ* ទាំងអស់នេះគឺជាកត្តាសំខាន់នៅក្នុងការថ្វាយបង្គំព្រះអម្ចាស់ របស់ពួកជំនុំនៅឯទីក្រុងកូរិនថូស (មើលការពន្យល់ ខ.១៥-១៧)។ កត្តាទាំងនេះ មានខ្លះ (ទំនុកតម្កើង សេចក្ដីបង្រៀន) ត្រូវបានដកស្រង់ចេញពីព្រះគម្ពីរសញ្ញាចាស់ (លក ៤:១៦-២២)។ ម្យ៉ាងទៀតគ្រប់ផ្នែកទាំងអស់ត្រូវធ្វើយ៉ាងណាឱ្យពួកជំនុំមានការចម្រើនឡើង ។

**១៤:២៧-២៨** ត្រង់ចំណុចនេះ បង្ហាញអំពីបែបបទនៃការនិយាយភាសាដទៃនៅក្នុងពួកជំនុំ (១) នៅពេលមានការជួបប្រជុំត្រូវឱ្យមានតែ២ ឬ ៣នាក់និយាយ (២) និយាយម្នាក់ម្ដងៗ (៣) ត្រូវឱ្យមានអ្នកបកប្រែ ។

**១៤:២៨** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ប្រសិនបើអ្នកណាម្នាក់អធិប្បាយជាភាសាដទៃ ប៉ុន្តែគ្មានអ្នកបកប្រែនោះត្រូវឱ្យនៅស្ងៀមវិញ ។ ម្យ៉ាងទៀត បើអ្នកណាម្នាក់និយាយភាសាដទៃ ដោយគ្មានអ្នកបកប្រែនោះ អាចនិយាយទៅកាន់ព្រះអម្ចាស់ដោយផ្ទាល់ខ្លួន មិនត្រូវនិយាយទៅកាន់មនុស្សដទៃទៀតទេ ។

**១៤:២៩** *ទុកឱ្យ ២ឬ ៣នាក់សំដែងទៅ* គឺឱ្យសំដែងម្នាក់ម្ដងៗ មិនមែនសំដែងដំណាលគ្នានោះទេ (ខ.២៧,៣១)។ *ហើយឱ្យអ្នកឯទៀតគិតពិចារណាចុះ* មានន័យថា នៅពេលអធិប្បាយព្រះបន្ទូលត្រូវឱ្យអ្នកស្ដាប់ទាំងអស់ពិចារណាគ្រប់សេចក្ដីដែលគ្រូអធិប្បាយថ្លែងចេញមក ដើម្បីឱ្យដឹងថា សេចក្ដីទាំងនោះត្រឹមត្រូវដែរឬទេ (មើលការពន្យល់ ខ.៣២)។

**១៤:៣០** បទគម្ពីរនេះបញ្ជាក់ថា សមាជិកទាំងអស់នៅក្នុងពួកជំនុំអាចទទួលបានការបើកសំដែងមកពីព្រះអម្ចាស់ (ខ.២៦,២៩-៣១ ជំពូក ១២-១៤)។ ការបើកសំដែងអាចមានដូចជាការប្រាប់ឱ្យដឹងជាមុននូវហេតុការណ៍ដែលនឹងកើតឡើងនៅពេលអនាគត (កច ១១:២៨ ២១:១០-១១) ការបង្ហាញផ្លូវមកពីព្រះអម្ចាស់ (កច ១៣:១-២) ឬព្រះបន្ទូលដើម្បីពង្រឹង និងលើកទឹកចិត្តពួកជំនុំ (ខ.៣)។

តែត្រូវសំដែងម្នាក់ម្ដងៗ ដើម្បីឱ្យគ្រប់គ្នាបានរៀនតាម
ហើយឱ្យគ្រប់គ្នាបានសេចក្ដីទូន្មានដែរ
៣២ ឯវិញ្ញាណនៃពួក
អ្នកដែលអធិប្បាយ នោះនៅក្រោមអំណាចអ្នកនោះឯង[ហ]
៣៣ ដ្បិតព្រះទ្រង់មិនមែនជាព្រះនៃសេចក្ដីវឹកវរទេ[ឡ] គឺទ្រង់
ជាព្រះនៃសេចក្ដីសុខសាន្តវិញ[អ] ដូចក្នុងអស់ទាំងពួកជំនុំ[ក]
របស់ពួកបរិសុទ្ធដែរ[ខ] ។

៣៤ នៅក្នុងពួកជំនុំ ត្រូវឱ្យពួកស្រីៗនៅស្ងៀម ដ្បិតគ្មាន
ច្បាប់ឱ្យនិយាយឡើយ[គ] ត្រូវឱ្យគេប្រតិបត្តិតាមវិញ[ឃ] ដូចជា
ក្រិត្យវិន័យក៏សំដែងដែរ[ង]
៣៥ បើគេចង់រៀនអ្វី នោះត្រូវតែ
សួរប្ដីនៅឯផ្ទះចុះ ដ្បិតដែលពួកស្រីៗ និយាយនៅក្នុងពួក
ជំនុំ នោះគួរខ្មាសហើយ ។

៣៦ ចុះដូចម្ដេច តើព្រះបន្ទូល[ច]បានចេញពីពួកអ្នករាល់
គ្នាមក ឬបានមកត្រឹមតែអ្នករាល់គ្នាតែប៉ុណ្ណោះ
៣៧ បើអ្នក
ណាស្មានថា ខ្លួនចេះអធិប្បាយ[ឆ] ឬថា ខ្លួនជាមនុស្សប្រកប
ដោយព្រះវិញ្ញាណ[ជ] នោះត្រូវតែយល់ព្រមថា សេចក្ដីទាំង
ប៉ុន្មានដែលខ្ញុំសរសេរផ្ញើមកអ្នករាល់គ្នានេះ សុទ្ធតែជា
បញ្ញត្តផងព្រះអម្ចាស់ទាំងអស់[ឈ]
៣៨ បើអ្នកណាមិនយល់ទេ
នោះឱ្យគេនៅតែមិនយល់ទៅចុះ
៣៩ ដូច្នេះ បងប្អូនអើយ
ចូរសង្វាត[ញ]ឱ្យបានចេះអធិប្បាយ[ដ] ហើយកុំឱ្យឃាត់មិនឱ្យ
និយាយភាសាដទៃនោះឡើយ
៤០ ត្រូវតែធ្វើការទាំងអស់
តាមបែបគួរសម ហើយដោយ លំដាប់លំដោយ[ឋ]ផង ។

## ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទ

**១៥** ១ បងប្អូនអើយ ខ្ញុំចង់ប្រាប់ឱ្យអ្នករាល់គ្នាដឹងពីដំ
ណឹងល្អ[ឌ] ដែលខ្ញុំបានផ្សាយរួចមកហើយ[ឍ] ជាដំណឹងដែល
អ្នករាល់គ្នាបានទទួល ក៏ឈរជាប់ក្នុងនោះផង
២ អ្នករាល់
គ្នាកំពុងតែបានសង្គ្រោះ[ណ] ដោយសារដំណឹងល្អនោះផង
គឺបើសិនជាកាន់ខ្ជាប់[ត]តាមព្រះបន្ទូល ដែលខ្ញុំបានថ្លែង
ប្រាប់មក លើកតែអ្នករាល់គ្នាបានជឿ ដោយឥតបើគិត
៣ ដ្បិតមុនដំបូង ខ្ញុំបានប្រាប់មកអ្នករាល់គ្នា[ថ] តាមសេចក្ដី
ដែលខ្ញុំបានទទួលដែរ[ទ] គឺថាព្រះគ្រីស្ទបានសុគត ដោយ
ព្រោះបាប[ធ]របស់យើងរាល់គ្នា តាមបទគម្ពីរ[ន]
៤ ហើយថា

**១៤:៣២** ហ ១យហ ៤:១
**១៤:៣៣** ឡ ឧ.៤០
អ រម ១៥:៣៣
ក ១កថ ៧:១៧ ១០:៣២ ខ កថ ៩:១៣
**១៤:៣៤** គ ១កថ ១១:៥,១៣
ឃ អភ ៥:២២ ១ធថ ២:១១,១២
ង ឧ.២១ លប ៣:១៦
**១៤:៣៦** ច ហព ៤:១២
**១៤:៣៧** ឆ កថ ១១:២៧ ១កថ ១៣:២ ២កថ ១០:៧
ជ ១កថ ២:១៥ ១២:១
ឈ ១យហ ៤:៦
**១៤:៣៩** ញ ឧ.១ ១កថ ១២:៣១
ដ ឧ.១ អភ ៤:១១
**១៤:៤០** ឋ ឧ.៣៣ កល ២:៥

**១៥:១** ឌ អស ៤០:៩ រម ២:១៦ ឍ ១កថ ៣:៦ កទ ១:៨ **១៥:២** ណ រម ១:១៦ ត រម ១១:២២ **១៥:៣** ថ ១កថ ១១:២ ទ កទ ១:១២ ធ អស ៥៣:៥ យហ ១:២៩ កទ ១:៤ ១ពត ២:២៤ ន មថ ២៦:២៤ លក ២៤:២៧ ២៤:៤៤ កថ ១៧:២ ២៦:២២,២៣

**១៤:៣២** បទគម្ពីរនេះបញ្ជាក់ថា អ្នកថ្លែងទំនាយ និងអ្នកអធិប្បាយព្រះបន្ទូល មិនត្រូវនិយាយតាមអារម្មណ៍រវើរវាយនោះទេ គឺត្រូវធ្វើដោយមានការគិតពិចារណាច្បាស់លាស់ និងត្រូវមានការដឹកនាំមកពីព្រះវិញ្ញាណបរិសុទ្ធ (ឧ.១៥ ២៦–៣២ មើលការពន្យល់ ឧ.២៧–២៩) ។

**១៤:៣៣** *ព្រះទ្រង់មិនមែនជាព្រះនៃសេចក្ដីវឹកវរទេ* ត្រង់ចំណុចនេះបញ្ជាក់អំពីការបារម្ភរបស់លោកប៉ុល ចំពោះពួកជំនុំនៅទីក្រុងកូរិនថូស ព្រោះថាប្រសិន បើពួកជំនុំគ្មានសណ្ដាប់ធ្នាប់ និងគ្មានរបៀបរៀបរយនោះអាចធ្វើឱ្យពួកគេ បាត់បង់សេចក្ដីជំនឿលើព្រះអម្ចាស់ ដែលបានត្រាស់ហៅពួកគេឱ្យមានសេចក្ដីសុខសាន្ត និងរួមគ្នាតែមួយក្នុងទ្រង់ ។ *ទ្រង់ជាព្រះនៃសេចក្ដីសុខសាន្ត* (មើលការពន្យល់ ១ថន ៥:២៣) ។ *ពួកជំនុំរបស់ពួកបរិសុទ្ធ* សំដៅលើពួកជំនុំជាសាកលរបស់ព្រះអម្ចាស់នៅលើផែនដីនេះតែម្ដង ។

**១៤:៣៤–៣៥** ស្ត្រីត្រូវគោរពចុះចូលនឹងប្ដីរបស់ខ្លួន ទោះជានៅឯផ្ទះ ឬនៅព្រះវិហារ ឬក៏នៅទីកន្លែងផ្សេងៗទៀតក្ដី (១ធថ ២:១១–១២) ។

**១៤:៣៤** *ដូចជាក្រិត្យវិន័យក៏សំដែង* (លប ៣:១៦ មើលពន្យល់ ១ពត ៣:៦)

**១៤:៣៥** នៅសម័យកាលលោកប៉ុល ស្រីៗមិនសូវមានការយល់ដឹងជ្រៅជ្រះទេ ដូច្នេះហើយបានជាគាត់មានប្រសាសន៍ថា ចូរឱ្យពួកគេរៀនសូត្រពីប្ដីរបស់ខ្លួន ដើម្បីឱ្យបានរីកចម្រើនឡើងខាងឯវិញ្ញាណ ។

**១៤:៣៧** លោកប៉ុលបញ្ជាក់យ៉ាងច្បាស់ដល់ពួកជំនុំនៅទីក្រុងកូរិនថូសថា ប្រសិនបើអ្នកណាគិតថាខ្លួនជាហោរា ឬជាអ្នកអធិប្បាយព្រះបន្ទូលដោយព្រះវិញ្ញាណប្រាកដជាដឹងថាសេចក្ដីដែលគាត់បង្រៀនគឺមកពីព្រះអម្ចាស់ ។

**១៤:៣៩–៤០** ត្រង់ចំណុចនេះ លោកប៉ុលបញ្ជាក់យ៉ាងច្បាស់ថា ការនិយាយភាសាដទៃ និងអំណោយទានផ្សេងៗទៀត គឺត្រូវប្រើប្រាស់សម្រាប់សរសើរតម្កើងព្រះយេស៊ូវគ្រីស្ទ និងត្រូវឱ្យមានរបៀបរបបត្រឹមត្រូវ ។

**១៥:១–៥៨** លោកប៉ុលចាប់ផ្ដើមសរសេរសំបុត្រផ្ញើទៅពួកជំនុំនៅក្រុងកូរិនថូសអំពីដំណឹងល្អនៃការសុគតរបស់ព្រះគ្រីស្ទ (១:១៧–១៨) ដោយគាត់និយាយថា "យើងខ្ញុំប្រកាសប្រាប់ពីព្រះគ្រីស្ទដែលទ្រង់ត្រូវឆ្កាង" (១:២៣) "ខ្ញុំមិនព្រមស្គាល់រឿងអ្វីទៀត ក្រៅពីព្រះយេស៊ូវគ្រីស្ទទេ ហើយគឺដែលទ្រង់ត្រូវឆ្កាងផង" (២:២ ១៥:៣–៤) ។ នៅចុងបញ្ចប់នៃសំបុត្រនេះ លោកប៉ុលបានបញ្ជាក់នូវសារសំខាន់នៃសេចក្ដីពិតអំពីការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។

**១៥:១** *ដំណឹងល្អ* (មើលការពន្យល់ មក ១:១) ។

**១៥:២** *បើសិនជាកាន់ខ្ជាប់តាមព្រះបន្ទូល* (មើលពន្យល់ ហព ៣:១៤) ។ ដំណឹងល្អដែលលោកប៉ុលបានប្រកាស គឺជាដំណឹងល្អ ដែលនាំឱ្យមានជ័យជម្នះលើអំពើបាបតាមរយៈការសុគត និងរស់ឡើងវិញរបស់ព្រះយេស៊ូវ ព្រោះទ្រង់បានឈ្នះលើសេចក្ដីស្លាប់រួចជាស្រេចហើយ (១:២៣ ១៥:២០) ។ ដូច្នេះ មានតែព្រះបន្ទូលនៃដំណឹងល្អនេះទេ ដែលជាទីសង្ឃឹមដល់មនុស្សទាំងអស់ ដើម្បីឱ្យបានចូលទៅឯនគរព្រះ (ឧ.៥០ ៥៣–៥៧) ។

**១៥:៣** *ខ្ញុំបានប្រាប់មកអ្នករាល់គ្នា តាមសេចក្ដីដែលខ្ញុំបានទទួលដែរ* ឃ្លានេះលោកប៉ុលបញ្ជាក់ថា គាត់ក៏បានទទួលសេចក្ដីបង្រៀនផ្សេងៗ ពីពួកអ្នកជឿដល់ព្រះអម្ចាស់ដែរ (១១:២៣) ។ ម្យ៉ាងទៀតអ្វីដែលសំខាន់បំផុតនៅក្នុងជីវិតរបស់គាត់គឺ ព្រះបន្ទូលនៃដំណឹងល្អអំពីការសុគត និងរស់ឡើងវិញរបស់ព្រះយេស៊ូវ ដើម្បីលោះបាបមនុស្សលោក (ហព ៧:២៧) ។ *តាមបទគម្ពីរ* លោកប៉ុលប្រហែលជាសំដៅលើគម្ពីរ "អស ៥៣:៥–៦ ១១–១២" ។

**១៥:៤** *រួចដល់ថ្ងៃទី៣* (សូមប្រៀបធៀបទៅនឹង មថ ១២:៤០ យហ ២០:៦) ។ *តាមបទគម្ពីរ* នៅក្នុងគំនិតរបស់លោកប៉ុលប្រហែលជាសំដៅ

ទ្រង់ត្រូវគេបញ្ចុះក្នុងផ្នូរ[ប] រួចដល់ថ្ងៃទី ៣[ផ] នោះទ្រង់មាន
ព្រះជន្មរស់ឡើងវិញ[ព] ក៏តាមបទគម្ពីរ[ភ] ៥ហើយថា ទ្រង់បាន
លេចមកឱ្យកេផាសឃើញ[ម] រួចដល់ពួក ១២ នាក់ដែរ[យ]
៦ក្រោយទៀត ទ្រង់លេចមកឱ្យពួកបងប្អូនជាង ៥០០ នាក់
ឃើញតែម្តង ជាពួកដែលមានគ្នាច្រើនរស់នៅ ដរាបដល់
សព្វថ្ងៃនេះ តែមានខ្លះបានដេកលក់ទៅហើយ[រ] ៧ក្រោយ
ទៀត ទ្រង់លេចមកឱ្យយ៉ាកុបឃើញ[ល] ក៏ឱ្យពួកសាវកទាំង
អស់គ្នាឃើញដែរ[វ] ៨រួចទ្រង់បានលេចមកឱ្យខ្ញុំឃើញ[ស] ជា
ខាងក្រោយគេបង្អស់ ដូចជាលេចមកដល់កូនកើតមុនកំណត់
ដែរ ៩ដ្បិតក្នុងបណ្តាពួកសាវក នោះខ្ញុំជាអ្នកតូចជាងគេ[ហ]
មិនគួរនឹងហៅខ្ញុំជាសាវកផងទេ ពីព្រោះខ្ញុំបានបៀត
បៀន[ឡ]ដល់ពួកជំនុំនៃព្រះ[អ] ១០ប៉ុន្តែ ដែលខ្ញុំបានជាយ៉ាងណា
នោះគឺបានដោយព្រះគុណ[ក]នៃព្រះទេ ហើយព្រះគុណដែល
ទ្រង់បានផ្តល់មកខ្ញុំ[ខ] នោះមិនមែនជាអសារឥតការឡើយ
ដ្បិតខ្ញុំបានខំធ្វើការលើសជាងអ្នកទាំងនោះសន្ធឹកណាស់[គ]
ប៉ុន្តែ មិនមែនជាខ្ញុំ គឺជាព្រះគុណនៃព្រះដែលសណ្ឋិតនៅ
នឹងខ្ញុំវិញ[ឃ] ១១ដូច្នេះ ទោះបើជាខ្ញុំ ឬអ្នកទាំងនោះក្តី[ង] គង់
តែយើងផ្សាយដំណឹងបែបយ៉ាងនោះ ក៏យ៉ាងនោះឯងដែល
អ្នករាល់គ្នាបានជឿដែរ ។

## ការរស់ឡើងវិញនៃពួកអ្នកស្លាប់

**១៥:៤** ប មថ ២៧:៥៩,៦០ ផ មថ ១៦:២១ ព កច ២:២៤ ភ យហ ២:២១,២២ កច ២:២៥,៣០,៣១ **១៥:៥** ម លក ២៤:៣៤ យ មក ១៦:១៤ លក ២៤:៣៦–៤៣ **១៥:៦** រ ខ.១៨,២០ មថ ៩:២៤ **១៥:៧** ល កច ១៥:១៣ វ លក ២៤:៣៣, ៣៦,៣៧ កច ១:៣,៤ **១៥:៨** ស កច ៩:៣–៦,១៧ ១កថ ៩:១ កទ ១:១៦ **១៥:៩** ហ ២កថ ១២:១១ អភ ៣:៨ ១ធថ ១:១៥ ឡ កច ៨:៣ អ ១កថ ១០:៣២ **១៥:១០** ក រម ៣:២៤ ខ រម ១២:៣ គ ២កថ ១១:២៣ កល ១:២៩ ឃ ភល ២:១៣

១២បើសិនជាបានផ្សាយដំណឹងល្អពីព្រះគ្រីស្ទថា ទ្រង់
មានព្រះជន្មរស់ពីស្លាប់ឡើងវិញហើយ[ច] នោះធ្វើដូចម្តេចឱ្យ
ពួកអ្នករាល់គ្នាខ្លះ និយាយបាន ថាពួកស្លាប់[ឆ]មិនរស់ឡើង
វិញ[ជ]ទេ ១៣បើសិនជាពួកស្លាប់មិនរស់ឡើងវិញមែន នោះ
ព្រះគ្រីស្ទក៏មិនបានរស់ឡើងវិញដែរ ១៤ហើយបើព្រះគ្រីស្ទ
មិនបានរស់ឡើងវិញ[ឈ] នោះដំណឹងដែលយើងខ្ញុំផ្សាយនេះ
ជាការឥតប្រយោជន៍ទទេ ហើយសេចក្តីជំនឿរបស់អ្នក
រាល់គ្នា ក៏ឥតអំពើដែរ ១៥ឈ្មោះថាយើងខ្ញុំជាស្មរបន្ទាល់
ក្លែងក្លាយពីព្រះវិញ ដ្បិតយើងខ្ញុំបានធ្វើបន្ទាល់ពីព្រះថា
ទ្រង់បានប្រោសឱ្យព្រះគ្រីស្ទរស់ឡើងវិញហើយ[ញ] តែបើពួក
ស្លាប់មិនរស់ឡើងវិញមែន នោះប្រាកដជាទ្រង់មិនបាន
ប្រោសឱ្យព្រះគ្រីស្ទរស់ឡើងវិញពិត ១៦ដ្បិតបើសិនជាពួក
ស្លាប់មិនរស់ឡើងទេ នោះព្រះគ្រីស្ទក៏មិនបានរស់ឡើងដែរ
១៧ហើយបើព្រះគ្រីស្ទមិនបានរស់ឡើងវិញមែននោះសេចក្តី
ជំនឿរបស់អ្នករាល់គ្នាក៏ជាការឥតអំពើ អ្នករាល់គ្នានៅ
ក្នុងអំពើបាបនៅឡើយ[ដ] ១៨ហើយអស់អ្នកដែលបានដេក
លក់[ឋ]ទៅក្នុងព្រះគ្រីស្ទ គេបានត្រូវវិនាសហើយ ១៩បើសិន
ជាយើងមានទីសង្ឃឹមក្នុងព្រះគ្រីស្ទ នៅតែក្នុងជីវិតនេះ

**១៥:១១** ង កទ ២:៦ **១៥:១២** ច ខ.៤ ឆ យហ ១១:២៤ ជ កច ១៧:៣២ ២៣:៨ ២ធថ ២:១៨ **១៥:១៤** ឈ ១ថន ៤:១៤ **១៥:១៥** ញ កច ២:២៤ **១៥:១៧** ដ រម ៤:២៥ **១៥:១៨** ឋ ខ.៦,២០ មថ ៩:២៤

លើគម្ពីរ "ទដ ១៦:៨–១១ អស ៥៣:១០–១២ ហស ៦:២ យណ ១:១៧"។
**១៥:៥–៨** ត្រង់ចំណុចនេះបញ្ជាក់អំពីការដែលព្រះយេស៊ូវគ្រីស្ទបានសំដែងព្រះអង្គទ្រង់ឱ្យមនុស្សលោកឃើញបន្ទាប់ពីទ្រង់បានរស់ពីសុគតឡើងវិញ ។
**១៥:៥** *កេផាស* ជាឈ្មោះដែលព្រះយេស៊ូវបានដាក់ឱ្យលោកពេត្រុស ។ ទ្រង់សំដែងអង្គទ្រង់ឱ្យលោកពេត្រុសឃើញ បន្ទាប់ពីទ្រង់រស់ពីសុគតឡើងវិញនៅថ្ងៃអាទិត្យ ។ ការសំដែងព្រះអង្គទ្រង់ដល់ពួកសិស្សរបស់ទ្រង់ទាំងអស់បានឃើញប្រហែលជានៅល្ងាចថ្ងៃអាទិត្យ (លក ២៤:៣៦–៤៣ យហ ២០:១៩–២៣)។
**១៥:៦** *ទ្រង់លេចមកឱ្យពួកបងប្អូនជាង៥០០នាក់ឃើញ* ព្រះយេស៊ូវបានសំដែងព្រះអង្គទ្រង់ឱ្យមនុស្សជាង៥០០នាក់បានឃើញ ប្រហែលជានៅស្រុកកាលីឡេដូចមានចែងនៅក្នុង "មថ ២៨:១០ ១៦–២០"។ *មានខ្លះបានដេកលក់ទៅហើយ* (មើលការពន្យល់ យហ ១១:១១)។
**១៥:៧** *យ៉ាកុប* យ៉ាកុបម្នាក់នេះមិនមែនជាយ៉ាកុបកូនរបស់លោកសេបេដេទេ ហើយក៏មិនមែនជាយ៉ាកុបកូនរបស់ លោកអាលផាយដែរ (មថ ១០:២–៣)។ លោកយ៉ាកុបដែលលោកប៉ុលលើកឡើងនៅត្រង់ចំណុចនេះ គឺជាយ៉ាកុបប្អូនរបស់ព្រះយេស៊ូវតែម្តង (មថ ១៣:៥៥ យហ ៧:៥)។ ក្រោយមកគាត់គឺជាអ្នកដឹកនាំដ៏សំខាន់ម្នាក់នៅក្នុងពួកជំនុំក្រុងយេរូសាឡិម (កច ១:១៤ ១៥:១៣)។
**១៥:៨** លោកប៉ុលមិនបានរស់នៅ និងដើរតាមព្រះយេស៊ូវដោយផ្ទាល់ដូចពួកសាវកដទៃទៀតទេ ។ គាត់ស័ក្តិសមទទួលងារជាសាវករបស់ព្រះយេស៊ូវ ព្រោះទ្រង់បានសំដែងព្រះអង្គទ្រង់ឱ្យគាត់ឃើញដោយផ្ទាល់ និងដោយសារផលផ្លែ ដែលគាត់បានបង្កើតថ្វាយទ្រង់តែម្តង (កច ៩:៣–៦)។
**១៥:៩** *ខ្ញុំបានបៀតបៀនដល់ពួកជំនុំនៃព្រះ* លោកប៉ុលកាលពីមិនទាន់បានទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទនៅឡើយ គាត់បានធ្វើការបៀតបៀនដល់ពួកអ្នកជឿដល់ព្រះនាមទ្រង់ជាច្រើន ។ ការដែលបៀតបៀនដល់ពួកជំនុំទ្រង់មានន័យថា ធ្វើការបៀតបៀនដល់ទ្រង់តែម្តង (មើលការពន្យល់ កច ៩:៤ ១ធថ ១:១៣)។
**១៥:១២–១៩** ពួកអ្នកនៅទីក្រុងកូរិនថូសមួយចំនួនគិតថា គ្មានការរស់ឡើងវិញនោះទេ ។ ដូច្នេះហើយបានជាលោកប៉ុលបញ្ជាក់ប្រាប់ពួកជំនុំនៅក្នុងទីក្រុងនេះយ៉ាងច្បាស់ថា ពិតជាមានការរស់ឡើងវិញនៅថ្ងៃចុងបំផុត ។
**១៥:១២** *ទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ* លោកប៉ុលបានលើកយកសេចក្តីដែលព្រះយេស៊ូវមានព្រះជន្មរស់ពីសុគតឡើងវិញ មកធ្វើការពន្យល់បំភ្លឺដល់ពួកជំនុំនៅទីក្រុងកូរិនថូសថា នៅថ្ងៃចុងបំផុតមនុស្សនឹងរស់ឡើងវិញ (ខ.៤,១២-១៤ ១៦–១៧,២០)។
**១៥:១៩** ប្រសិនបើសេចក្តីជំនឿនៅក្នុងព្រះគ្រីស្ទមានប្រយោជន៍សម្រាប់តែក្នុងជីវិតនេះនិងមិនបានជួយឱ្យរួចផុតពីអំណាចនៃអំពើបាបទេ នោះអ្នកជឿដល់ទ្រង់ គឺអន់ជាងអ្នកដែលមិនជឿទៅទៀត (រម ៦:២៣ អភ ២:១២)។ ព្រះយេស៊ូវមានបន្ទូលយ៉ាងប្រាកដច្បាស់ថា អស់អ្នកណាដែល

ប៉ុណ្ណោះ នោះយើងវេទនា លើសជាងមនុស្សទាំងអស់
ទៅទៀត[ឱ]។
[២០]តែឥឡូវនេះ ព្រះគ្រីស្ទទ្រង់មានព្រះជន្មរស់ពីស្លាប់
ឡើងវិញជាពិត[ឍ] ជាផលដំបូង[ណ]ពីពួកអ្នកដែលបានដេក
លក់ទៅហើយ[ត] [២១]ដ្បិតដែលសេចក្ដីស្លាប់បានមកដោយ
សារមនុស្ស[ថ] នោះសេចក្ដីដែលមនុស្សស្លាប់បានរស់ឡើង
វិញ[ទ] ក៏មកដោយសារមនុស្សដែរ [២២]ព្រោះ ដូចជាគ្រប់
មនុស្សទាំងអស់បានត្រូវស្លាប់ ក្នុងលោកអ័ដាមជាយ៉ាងណា
នោះគ្រប់គ្នាក៏នឹងបានប្រោសឱ្យរស់ ក្នុងព្រះគ្រីស្ទយ៉ាង
នោះដែរ[ធ] [២៣]តែគ្រប់គ្នាតាមលំដាប់រៀងខ្លួន គឺព្រះគ្រីស្ទ
ជាផលដំបូង[ន]រួចពួកអ្នកដែលជារបស់ផងព្រះគ្រីស្ទ[ប] ក្នុង
កាលដែលទ្រង់យាងមក[ផ] [២៤]គ្រានោះបានដល់ចុងបំផុត
ហើយ ជាវេលាដែលទ្រង់នឹងប្រគល់នគរ[ព] ដល់ព្រះដ៏ជា
ព្រះវរបិតាទៅវិញ ក្រោយដែលទ្រង់បានទំលាក់អស់ទាំង
រាជ្យ និងអំណាច ហើយនិងឥទ្ធិឫទ្ធិទាំងប៉ុន្មានចេញ[ភ]
[២៥]ដ្បិតគួរឱ្យទ្រង់បានសោយរាជ្យ[ម] ទាល់តែដាក់អស់ទាំង
ខ្មាំងសត្រូវនៅក្រោមព្រះបាទទ្រង់[យ] [២៦]ឯខ្មាំងសត្រូវក្រោយ
បង្អស់ ដែលត្រូវបំផ្លាញ គឺជាសេចក្ដីស្លាប់[រ] [២៧]ពីព្រោះ
ទ្រង់បានបង្ក្រាបគ្រប់ទាំងអស់ នៅក្រោមព្រះបាទទ្រង់[ល]
ហើយ តែដែលថាបានបង្ក្រាបគ្រប់ទាំងអស់ នោះច្បាស់ជា
មិននិយាយពីព្រះ ដែលបង្ក្រាបគ្រប់របស់ទាំងអស់នៅ
ក្រោមទ្រង់នោះទេ[វ] [២៨]ហើយកាលណាទ្រង់បានបង្ក្រាប
គ្រប់របស់ទាំងអស់នៅក្រោមទ្រង់ នោះព្រះរាជបុត្រានោះ
ឯង ក៏នឹងត្រូវក្រាបក្រោមព្រះ ដែលបានបង្ក្រាបគ្រប់ទាំង
អស់ នៅក្រោមទ្រង់ដែរ[ស]ដើម្បីឱ្យព្រះបានធ្វើជាគ្រប់ទាំង
អស់ក្នុងគ្រប់ទាំងអស់[ហ]។
[២៩]ពុំនោះ ពួកអ្នកដែលទទួលបុណ្យជ្រមុជ ទុកជាគំរូពី
សេចក្ដីស្លាប់ នឹងធ្វើដូចម្ដេច បើសិនជាពួកស្លាប់មិនរស់
ឡើងវិញទេ នោះតើហេតុអ្វីបានជាគេទទួលបុណ្យជ្រមុជ
ទុកជាគំរូពីសេចក្ដីស្លាប់ធ្វើអ្វី [៣០]ហេតុអ្វីបានជាយើងមាន
សេចក្ដីអន្តរាយ រាល់ពេលរាល់វេលាដែរ[ឡ] [៣១]ខ្ញុំស្បថ
ដោយនូវសេចក្ដីអំនួត ដែលខ្ញុំអួតពីអ្នករាល់គ្នា ក្នុងព្រះ
គ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នាថា ខ្ញុំស្លាប់រាល់

**១៥:១៩** ឱ ១កថ ៤:៩
**១៥:២០** ឍ ១ពត ១:៣ ណ ខ.២៣ កច ២៦:២៣ ត ខ.៦,១៨ មថ ៩:២៤
**១៥:២១** ថ រម ៥:១២ ទ ខ.១២
**១៥:២២** ធ រម ៥:១៤–១៨ ១កថ ៦:១៤
**១៥:២៣** ន ខ.២០ ប ខ.៥២ ១ថន ២:១៩ ផ ១កថ ៣:២៣
**១៥:២៤** ព ដយ ២:៤៤ ៧:១៤,២៧ ២ពត ១:១១ ភ រម ៨:៣៨
**១៥:២៥** ម អស ៩:៧ ៥២:៧ យ ខ.២៧ មថ ២២:៤៤
**១៥:២៦** រ ២ធថ ១:១០ វវ ២០:១៤ ២១:៤
**១៥:២៧** ល ខ.២៥ ទដ ៨:៦ មថ២២:៤៤ វ មថ ២៨:១៨ **១៥:២៨** ស ភល ៣:២១ ហ ១កថ ៣:២៣ **១៥:៣០** ឡ ២កថ ១១:២៦

ទទួលជឿដល់ព្រះនាមទ្រង់នោះគេបានរួចពីបាប និងបានត្រឡប់ជាកូនព្រះដ៏ពិត (យហ ៣:១៦)។

**១៥:២០** *ព្រះគ្រីស្ទទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញជាពិត* លោកប៉ុលមានប្រសាសន៍យ៉ាងដូច្នេះ ព្រោះសំអាងលើការដែលព្រះគ្រីស្ទបានសំដែងអង្គទ្រង់ឱ្យ គាត់ឃើញដោយផ្ទាល់ និងសំអាងលើភស្តុតាងដែលគាត់បានបញ្ជាក់នៅក្នុង "ខ. ៣–៨"។ *ជាផលដំបូង* មានន័យថា ព្រះយេស៊ូវគឺជាផលដំបូងដែលបានរស់ពីសុគតឡើងវិញ (នក ២៣:១៩ លវ ២:១២)។ ដោយព្រោះព្រះគ្រីស្ទបានរស់ពីសុគតឡើងវិញ នោះអស់អ្នកដែលជឿដល់ទ្រង់ក៏បានរស់ឡើងជាមួយទ្រង់ដែរ (មើលការពន្យល់ ១ថន ៤:១៣–១៨)។

**១៥:២១** *សេចក្ដីស្លាប់បានមកដោយសារមនុស្ស* ពាក្យថា "មនុស្ស" ក្នុងឃ្លានេះគឺសំដៅលើអ័ដាម (លប ៣:១៧–១៩ រម ៥:១២)។ *បានរស់ឡើងវិញ ក៏មកដោយសារមនុស្សដែរ* ពាក្យថា "មនុស្ស" នៅក្នុងឃ្លានេះសំដៅលើព្រះគ្រីស្ទ (មើលការពន្យល់ ខ.៤៥ រម ៥:១២–២១)។

**១៥:២២** *មនុស្សទាំងអស់បានត្រូវស្លាប់ ក្នុងលោកអ័ដាម* មានន័យថា គ្រប់មនុស្សទាំងអស់ដែលកើតពីអ័ដាមសុទ្ធតែត្រូវស្លាប់នៅក្នុងអំពើបាប ។ *គ្រប់គ្នាក៏នឹងបានប្រោសឱ្យរស់ ក្នុងព្រះគ្រីស្ទ* អស់អ្នកដែលជឿដល់ព្រះនាមព្រះយេស៊ូវ នោះបានទទួលនូវជីវិតរស់យ៉ាងពិតប្រាកដដែលទ្រង់បានប្រទានឱ្យ (យហ ៥:២៥ រម ៥:១៧–១៨ វវ ២០:៦ មើលការពន្យល់ ១ថន ៤:១៦–១៧)។

**១៥:២៣** បទគម្ពីរនេះបញ្ជាក់ថា ព្រះយេស៊ូវជាផលដំបូង ដែលបានរស់ពីសុគតឡើងវិញ ហើយអស់អ្នកដែលទទួលជឿដល់ព្រះនាមទ្រង់នឹងបានរស់ឡើងវិញ នៅពេលដែលទ្រង់យាងមកជាលើកទីពីរ ។

**១៥:២៤** *គ្រានោះបានដល់ចុងបំផុតហើយ* ពាក្យថា "ចុងបំផុត" ត្រង់ចំណុចនេះ សំដៅលើពេលដែលព្រះគ្រីស្ទយាងមកជាលើកទីពីរ ។

**១៥:២៥** *ដ្បិតគួរឱ្យទ្រង់បានសោយរាជ្យ* ព្រះបន្ទូលត្រង់ចំណុចនេះគឺជាសេចក្ដីសន្យាដែលមានចែងនៅក្នុង "ទដ ១១០:១"(មថ ២២:៤៤ កច ២:៣៤ មើលការពន្យល់ ហព ១:១៣)។

**១៥:២៦** *ខ្មាំងសត្រូវក្រោយបង្អស់* សេចក្ដីស្លាប់ជាខ្មាំងសត្រូវចុងក្រោយបង្អស់ដែលត្រូវបំផ្លាញ នៅពេលដែលព្រះគ្រីស្ទយាងមកជាលើកទីពីរ (ទដ ៤៩:១៤ យរ ៩:២១ ២ធថ ១:១០ វវ ២០:១៤ ២១:៤)។

**១៥:២៧** លោកប៉ុលលើកយកព្រះបន្ទូលនៅក្នុង "ទដ ៨:៦" ដែលចែងថា "ទ្រង់បានតាំងគេឱ្យត្រួតលើអស់ទាំងការនៃព្រះហស្តទ្រង់ ក៏បានបញ្ចុះបញ្ចូលគ្រប់ទាំងអស់ឱ្យនៅក្រោមជើងគេ" (មើលពន្យល់ ហព ២:៥–៩)។

**១៥:២៨** សេចក្ដីនៅក្នុងបទគម្ពីរនេះពុំមែនមានន័យថា ព្រះយេស៊ូវមានអំណាចទាបជាងព្រះវរបិតានោះទេ ។ ព្រះគម្ពីរបានបញ្ជាក់យ៉ាងច្បាស់ថា ព្រះវរបិតាព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះត្រៃឯកដែលរួមតែមួយតាំងពីអស់កល្បជានិច្ចមក (យហ ១០:៣០ មើលការពន្យល់ ១កថ ៣:៧ យហ ៤:៣៤ ៥:១៩ ៧:១៦)។

**១៥:៣០** "ប្រៀបធៀបនឹង ២កថ ១១:២៣–២៩"។

**១៥:៣១** *ខ្ញុំអួតពីអ្នករាល់គ្នា* មានន័យថា លោកប៉ុលតែងតែពោល សរសើរពួកជំនុំនៅទីក្រុងកូរិនថូសអំពីការផ្លាស់ប្រែ និងការរីកចម្រើនខាងឯសេចក្ដីជំនឿរបស់ពួកគេ ដោយព្រះគុណ នៅក្នុងព្រះយេស៊ូវគ្រីស្ទ (១ថន ២:២០)។ *ខ្ញុំស្លាប់រាល់តែថ្ងៃ* ត្រង់ចំណុចនេះ លោកប៉ុលបញ្ជាក់ថា គាត់ប្រឈមមុខនឹងសេចក្ដីស្លាប់ជារៀងរាល់ថ្ងៃ ហើយគាត់ចង់ឱ្យពួកជំនុំនៅទីក្រុងកូរិនថូសដឹងនូវសេចក្ដីពិតនេះដែរ (២កថ ៤:៨–១២ ១១:២៣–២៦)

តែថ្ងៃ[អ] ៣២បើសិនជាខ្ញុំបានតយុទ្ធនឹងសត្វព្រៃ[ក] នៅក្រុង
អេភេសូរ[ខ] តាមរបៀបជាមនុស្ស នោះតើមានប្រយោជន៍
អ្វីដល់ខ្ញុំ បើសិនណាជាមនុស្សស្លាប់មិនរស់ឡើងវិញមែន
នោះចូរយើងស៊ីផឹកទៅចុះ ដ្បិតស្អែកយើងត្រូវស្លាប់
ហើយ[គ] ៣៣កុំឱ្យច្រឡំឡើយ[ឃ] ពីព្រោះពួកម៉ាកអាក្រក់តែង
នឹងបង្ខូចកិរិយាល្អ[ង] ៣៤ចូរភ្ញាក់ដឹងខ្លួនឡើងខាងឯសេចក្ដី
សុចរិតចុះ កុំឱ្យធ្វើបាបឡើយ ដ្បិតអ្នករាល់គ្នាខ្លះមិនស្គាល់
ព្រះទេ[ច] ខ្ញុំថាដូច្នេះ ដើម្បីឱ្យអ្នករាល់គ្នាមានសេចក្ដីខ្មាស[ឆ]។
៣៥មុខជានឹងមានអ្នកណាមួយសួរថា[ជ] ឯពួកមនុស្សស្លាប់
នឹងរស់ឡើងវិញយ៉ាងណា តើមកវិញមានរូបកាយដូច
ម្ដេច[ឈ] ៣៦ឱមនុស្សកំឡៅអើយ[ញ] គ្រាប់ពូជដែលអ្នក
ព្រោះទៅ បើមិនងាប់ នោះមិនពន្លកដុះឡើងទេ[ដ] ៣៧ហើយ
គ្រាប់ដែលអ្នកព្រោះនោះ មិនមែនដូចជាដើមដែលពន្លក
ឡើងនោះដែរ គឺជាគ្រាប់សុទ្ធ ដូចជាគ្រាប់ស្រូវ ឬពូជណា
ទៀតក្ដី ៣៨តែព្រះទ្រង់ប្រទានឱ្យមានដើមទីទៃពីគ្នារៀង
រាល់ពូជតាមព្រះហឫទ័យទ្រង់[ឋ] ៣៩គ្រប់ទាំងសាច់ក៏មិន
ដូចគ្នាដែរ គឺមាន១របស់មនុស្ស ១របស់សត្វ ១របស់ត្រី
ហើយ១របស់សត្វហើរ ៤០ក៏មានរូបកាយសំរាប់ស្ថានសួគ៌
ហើយមានរូបកាយសំរាប់ផែនដីដែរ តែសិរីរបស់រូបកាយ
នៅស្ថានសួគ៌ នឹងរបស់រូបកាយនៅផែនដីនោះទីទៃពី
គ្នា ៤១ឯព្រះអាទិត្យ នោះមានរស្មីម្យ៉ាងទៅ[ឌ] ព្រះចន្ទក៏
មានរស្មីម្យ៉ាងទៅ ហើយផ្កាយក៏មានរស្មីម្យ៉ាងទៅ[ឍ] សូម្បី
តែផ្កាយទាំង ប៉ុន្មានសោតក៏មានរស្មីខុសពីគ្នាដែរ ៤២សេច
ក្ដីដែលមនុស្សស្លាប់[ណ]បានរស់ឡើងវិញ នោះក៏បែបដូច្នោះ
ដែរ[ត] គេបានកប់ទៅ ជារូបកាយ ដែលពុករលួយ
តែរស់ឡើងវិញ ជារូបកាយ មិនចេះពុករលួយឡើយ[ថ]
៤៣បានកប់ទៅ ទាំងមានសេចក្ដីអាប់ឱន តែរស់ ឡើងវិញ
ទាំងមានសិរីល្អ[ទ] បានកប់ទៅទាំងមានសេចក្ដី កំសោយ
តែរស់ឡើងវិញ ទាំងមានព្រះចេស្ដា ៤៤បានកប់ ទៅ
ជារូបកាយ ខាងសាច់ឈាម តែរស់ឡើង ជារូបកាយ
ខាងវិញ្ញាណវិញ បើមានរូបកាយ ខាងសាច់ឈាមនោះ
ក៏មានរូបកាយ ខាងវិញ្ញាណដែរ[ធ] ៤៥ដូចជាសេចក្ដីដែល
ចែងទុក ពីលោកអ័ដាម ដែលជាមនុស្សមុនដំបូងថា «បាន
ត្រឡប់ជាមានព្រលឹងរស់»[ន] តែលោកអ័ដាមក្រោយអង្គស់[ប]
ជាវិញ្ញាណដ៏ប្រោសឱ្យរស់វិញ[ផ] ៤៦ឯវិញ្ញាណ មិនមែនកើត
មុនទេ គឺជារូបសាច់ទេតើ រួចទើបមានវិញ្ញាណជាខាង
ក្រោយ[ព] ៤៧មនុស្សមុនដំបូងកើតមកពីដី គឺធ្វើមកពីធូលីដី[ភ]
តែមនុស្សទី២ ជាព្រះអម្ចាស់ដែលចេញមកពីស្ថានសួគ៌វិញ[ម]
៤៨ឯមនុស្សដែលកើតពីធូលីដីមកជាយ៉ាងណា នោះអស់អ្នក
ដែលកើតពីធូលីដី ក៏យ៉ាងនោះដែរ ហើយព្រះអម្ចាស់
ដែលយាងមកពីស្ថានសួគ៌ ជាយ៉ាងណា ពួកស្ថានសួគ៌ក៏
យ៉ាងនោះដែរ[យ] ៤៩យើងក៏នឹងមានរូបរាងរបស់ព្រះអម្ចាស់
ពីស្ថានសួគ៌[រ] ដូចជាយើងមានរូបរាងរបស់មនុស្ស ដែលធ្វើ
ពីធូលីដី[ល]មកដែរ ។
៥០បងប្អូនអើយ សេចក្ដីដែលខ្ញុំចង់និយាយនេះ គឺថា
សាច់ឈាម[វ]ពុំអាចនឹងគ្រងនគរព្រះ ជាមរដកបានឡើយ[ស]

**១៥:៣១** អ រម ៨:៣៦
**១៥:៣២** ក ២កថ ១:៨ ខ កថ ១៨:១៩ គ អស ២២:១៣ លក ១២:១៩
**១៥:៣៣** ឃ ១កថ ៦:៩ ង ទដ ២២:២៤,២៥
**១៥:៣៤** ច កទ ៤:៨ ឆ ១កថ ៤:១៤
**១៥:៣៥** ជ រម ៩:១៩ ឈ អគ ៣៧:៣
**១៥:៣៦** ញ លក ១១:៤០ ១២:២០ ដ យហ ១២:២៤
**១៥:៣៨** ឋ លប ១:១១
**១៥:៤១** ឌ ទដ ១៩:៤–៦ ឍ ទដ ៨:១,៣
**១៥:៤២** ណ ខ.១២ ត ដយ ១២:៣ មថ ១៣:៤៣ ថ ខ.៥០,៥៣,៥៤
**១៥:៤៣** ទ ភល ៣:២១ កល ៣:៤
**១៥:៤៤** ធ ខ.៥០
**១៥:៤៥** ន លប ២:៧ ប រម ៥:១៤ ផ យហ ៥:២១ ៦:៥៧,៥៨ រម ៨:២
**១៥:៤៦** ព ខ.៤៤
**១៥:៤៧** ភ លប ២:៧ ៣:១៩ ទដ ៩០:៣ ម យហ ៣:១៣,៣១
**១៥:៤៨** យ ភល ៣:២០,២១ **១៥:៤៩** រ រម ៨:២៩ ល លប ៥:៣
**១៥:៥០** វ អភ ៦:១២ ហព ២:១៤ ស មថ ២៥:៣៤ ហ ខ.៤២,៥៣,៥៤

**១៥:៣២** *ខ្ញុំបានតយុទ្ធនឹងសត្វព្រៃ នៅក្រុងអេភេសូរ* ឃ្លានេះបញ្ជាក់ថា ក្នុងខណៈពេល ដែលលោកប៉ុលស្នាក់នៅឯទីក្រុងអេភេសូរ គាត់បានជួបប្រទះនូវការបៀតបៀនដ៏ធ្ងន់ធ្ងរជាច្រើន ពីសំណាក់ពួកប្រឆាំង ដែលមានលក្ខណៈដូចជាសត្វសាហាវ ។ *នោះចូរយើងស៊ីផឹកទៅចុះ ដ្បិតថ្ងៃស្អែកយើងត្រូវស្លាប់ហើយ* លោកប៉ុលមានប្រសាសន៍យ៉ាង ដូច្នេះទៅកាន់ពួកអ្នកនៅទីក្រុងកូរិនថូស ពីព្រោះមានពួកគេមួយចំនួនមិនជឿលើសេចក្ដីរស់ឡើងវិញទេ (អស ២២:១៣)។

**១៥:៣៣** បទគម្ពីរនេះបញ្ជាក់ថា នៅក្នុងទីក្រុងកូរិនថូសនាសម័យកាលលោកប៉ុលមានពួកគ្រូមួយចំនួនបានដើរបង្រៀននូវសេចក្ដីខុសឆ្គង ដោយនិយាយថាគ្មានការរស់ឡើងវិញទេ (ខ.១២ ទដ ១:១ មើលការពន្យល់ សភ ២២:២៤–២៥)។

**១៥:៣៤** *កុំឱ្យធ្វើបាបឡើយ* សំដៅលើអំពើបាបដែលកើតឡើង ដោយសារការបដិសេធន៍នូវសេចក្ដីរស់ឡើងវិញ និងការសង្ស័យថា ប្រហែលជាព្រះយេស៊ូវ មិនបានរស់ពីសុគតឡើងវិញទេ ។

**១៥:៣៥–៤៩** លោកប៉ុលប្រៀបធៀបលក្ខណៈនៃការរស់ឡើងវិញ ទៅនឹងគ្រាប់ពូជដែលព្រោះទៅដូច្នោះដែរ (ខ.៣៦–៤១)។ ព្រះអម្ចាស់ជាអាទិករ និងជាប្រភពនៃជីវិតទាំងអស់ ។

**១៥:៣៩** *គ្រប់ទាំងសាច់ក៏មិនដូចគ្នាដែរ* ត្រង់ចំណុចនេះបញ្ជាក់ថា ទោះបីជាសាច់របស់មនុស្ស និងសាច់របស់សត្វមានលក្ខណៈ ស្រដៀងគ្នាក៏ដោយ ក៏មានលក្ខណៈពិសេសផ្សេងពីគ្នាដែរ ។

**១៥:៤២–៤៤** លោកប៉ុលបានពន្យល់អំពីរបៀប ដែលមនុស្សស្លាប់នឹងរស់ឡើងវិញថា ព្រះអម្ចាស់នឹងប្រទានឱ្យអ្នកជឿដល់ព្រះនាមទ្រង់នូវរូបកាយ ដែលមិនចេះពុករលួយ និងពេញដោយសិរីល្អ ជំនួសឱ្យរូបកាយដែលពុករលួយ ហើយពេញដោយភាពកម្សោយវិញ ។

**១៥:៤៤–៤៩** ត្រង់ចំណុចនេះ លោកប៉ុលបានលើកឡើងនូវភាពខុសគ្នារវាងរូបកាយពីរប្រភេទ (មើលការពន្យល់ ខ.២១–២២) (១) រូបកាយតែងតែពុករលួយដែលទទួលបានតាមរយៈលោកអ័ដាម (២) រូបកាយខាងឯវិញ្ញាណ ដែលព្រះគ្រីស្ទទ្រង់ប្រទានឱ្យដល់អស់អ្នកណាដែលទទួលជឿដល់ព្រះនាមទ្រង់ (លក ២៤:៣៦–៤៣ យហ ៥:២៦ ១យហ ៣:២ មើលការពន្យល់ ភល ៣:២១)។

**១៥:៥០** លោកប៉ុលបញ្ជាក់ថា សាច់ឈាមពុំអាចនឹងទទួលបាននគរព្រះជាមរតកឡើយ ។ ដូច្នេះមានន័យថា អស់អ្នកដែលចូលទៅនគរព្រះបានគឺត្រូវ

ហើយសេចក្ដីពុករលួយ ក៏ពុំអាចនឹងគ្រងសេចក្ដី ដែលមិន
ចេះពុករលួយបានដែរ[ហ] ៥១នែ ខ្ញុំប្រាប់អ្នករាល់គ្នាពីសេចក្ដី
អាថ៌កំបាំង[ឡ] គឺថា យើងទាំងអស់គ្នានឹងមិនដេកលក់ទៅទេ[អ]
៥២តែទាំងអស់គ្នា នឹងបានផ្លាស់ប្រែ[ក]ទៅក្នុង១រំពេចវិញ
គឺក្នុង ១ ប៉ប្រិចភ្នែកប៉ុណ្ណោះ ក្នុងកាលដែលឮសូរត្រែ
ក្រោយបង្អស់ ដ្បិតត្រែនឹងឮឡើងមែន[ខ] នោះពួកស្លាប់[គ]នឹង
រស់ឡើងវិញ មិនពុករលួយទៀតឡើយ រួចយើងរាល់គ្នា
នឹងបានផ្លាស់ប្រែទៅ ៥៣ដ្បិតត្រូវតែរូបកាយដ៏ពុករលួយ
នេះ[ឃ] បានប្រដាប់ដោយសេចក្ដីមិនពុករលួយវិញ[ង] ហើយ
រូបកាយដែលរមែងស្លាប់នេះ ត្រូវតែបានប្រដាប់ដោយ
សេចក្ដីមិនចេះស្លាប់វិញដែរ ៥៤កាលណារូបកាយពុក
រលួយនេះបានប្រដាប់ដោយសេចក្ដីមិនពុករលួយ ហើយ
រូបកាយដែលតែងតែស្លាប់នេះ បានប្រដាប់ដោយសេចក្ដី
មិនចេះស្លាប់វិញ នោះទើបនឹងបានសំរេចតាមពាក្យ ដែល
ចែងទុកមកថា «សេចក្ដីជ័យជំនះបានលេបសេចក្ដីស្លាប់
បាត់ហើយ»[ច] ៥៥«ឱសេចក្ដីស្លាប់អើយ ទ្រនិចឯងនៅឯ
ណា[ឆ] សេចក្ដីស្លាប់អើយ ជ័យជំនះរបស់ឯងនៅឯណា»
៥៦រីឯទ្រនិចនៃសេចក្ដីស្លាប់ គឺជាអំពើបាប[ជ] ហើយអំណាច
របស់បាប គឺជាក្រិត្យវិន័យ[ឈ] ៥៧តែអរព្រះគុណដល់ព្រះ

**១៥:៥១** ឡ ១កថ ១៣:២ ១៤:២
អ មថ ៩:២៤
**១៥:៥២** ក ២កថ ៥:៤ ភល ៣:២១
ខ មថ ២៤:៣១
គ យហ ៥:២៥
**១៥:៥៣** ឃ ខ.៤២,៥០,៥៤
ង ២កថ ៥:២,៤
**១៥:៥៤** ច អស ២៥:៨ ហព ២:១៤ វវ ២០:១៤
**១៥:៥៥** ឆ ហស ១៣:១៤
**១៥:៥៦** ជ រម ៥:១២
ឈ រម ៤:១៥
**១៥:៥៧** ញ ២កថ ២:១៤ ដ រម ៨:៣៧ ហព ២:១៤,១៥
**១៥:៥៨** ឋ ១កថ ១៦:១០
ឌ អស ៦៥:២៣
**១៦:១** ឍ កថ ២៤:១៧

អង្គ[ញ] ពីព្រោះទ្រង់ប្រទានឱ្យយើងរាល់គ្នាមានជ័យជំនះ
ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង[ដ] ៥៨បាន
ជាបងប្អូនស្ងួនភ្ងាអើយ ចូរកាន់យ៉ាងខ្ជាប់ខ្ជួន ដោយឥតរង្គើ
ទាំងធ្វើការព្រះអម្ចាស់ ឱ្យបរិបូរជាដរាបចុះ ដោយដឹងថា
ការដែលអ្នករាល់គ្នាខំប្រឹងធ្វើក្នុងព្រះអម្ចាស់[ឋ] នោះមិន
មែនឥតប្រយោជន៍ទេ[ឌ]។

## ការរៃប្រាក់សម្រាប់ពួកបរិសុទ្ធ

**១៦** ១ឥឡូវនេះ ខាងឯការរៃប្រាក់[ឍ]សំរាប់ពួកបរិសុទ្ធ[ណ]
នោះចូរឱ្យអ្នករាល់គ្នាធ្វើ ដូចជាខ្ញុំបានផ្ដាំទុកក្នុងពួកជំនុំ
នៅស្រុកកាឡាទី[ត]ទាំងប៉ុន្មានដែរ ២គឺរាល់តែអាទិត្យ ក្នុងថ្ងៃ
ដំបូង[ថ] នោះត្រូវឱ្យអ្នករាល់គ្នាប្រមូលដាក់ទុកនូវអ្វីៗ ដោយ
ឡែក តាមដែលព្រះបានចំរើនឱ្យ ដើម្បីកាលណាខ្ញុំមកដល់
នោះមិនបាច់នឹងរៃទៀត[ទ] ៣កាលណាខ្ញុំមកដល់ នោះខ្ញុំនឹង
ចាត់អ្នកណាដែលពេញចិត្តអ្នករាល់គ្នា[ធ] ឱ្យកាន់សំបុត្រ និង
យកទេយ្យទានរបស់អ្នករាល់គ្នា ទៅដល់ក្រុងយេរូសាឡិម
៤ហើយបើសិនជាគួរឱ្យខ្ញុំទៅដែរ នោះគេនឹងទៅជាមួយ
នឹងខ្ញុំផង ។

ណ កថ ៩:១៣ ត កថ ១៦:៦ **១៦:២** ថ កថ ២០:៧ ទ ២កថ ៩:៤,៥ **១៦:៣** ធ ២កថ ៣:១ ៨:១៨,១៩

ទទួលការបំផ្លាស់បំប្រែមកពីព្រះយេស៊ូវគ្រីស្ទជាមុនសិន (ខ.៥៣)។ ម្យ៉ាងទៀត អស់អ្នកដែលទទួលជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ គឺទទួលបានជីវិតថ្មីខាងឯវិញ្ញាណយ៉ាងពិតប្រាកដ (មើលការពន្យល់ កទ ១:១៦)។

**១៥:៥១** *សេចក្ដីអាថ៌កំបាំង* សំដៅលើសេចក្ដីរស់ឡើងវិញនៃរូបកាយ ដែលពីមុនមកគ្មានអ្នកណាអាចយល់បានទេ ប៉ុន្តែ ព្រះអម្ចាស់បានបើកសំដែងឱ្យពួកអ្នក ជឿដល់ព្រះនាមទ្រង់បានយល់វិញ (មើលការពន្យល់ រម ១១:២៥)។ *យើងទាំងអស់គ្នានឹងមិនដេកលក់ទៅទេ* ឃ្លានេះបញ្ជាក់ថា មានអ្នកជឿដល់ព្រះនាមព្រះយេស៊ូវខ្លះនឹងមិនស្គាល់សេចក្ដីស្លាប់ និងសេចក្ដីពុករលួយទេ (មើលការពន្យល់ ១ថន ៤:១៥)។

**១៥:៥២** ពេលដែលព្រះយេស៊ូវយាងមកជាលើកទីពីរ មនុស្សស្លាប់ទាំងអស់នឹងរស់ឡើងវិញ ។ នៅពេលនោះពួកអ្នកជឿដល់ព្រះនាមទ្រង់នឹងទទួលបានរូបកាយដែលមិនចេះពុករលួយទៀតឡើយ (មថ ២៤:៣១ មក ១៣:២៦–២៧ ១ថន ៤:១៦–១៧ វវ ១១:១៥)។

**១៥:៥៣–៥៤** "មើលការពន្យល់ ទដ ១០៩:២៩"។

**១៥:៥៦** *ទ្រនិចនៃសេចក្ដីស្លាប់ គឺជាអំពើបាប* បញ្ជាក់ថា ដោយសារតែអំពើបាបធ្វើឱ្យមនុស្សស្ថិតនៅក្រោមអំណាចនៃសេចក្ដីស្លាប់ (មើលការពន្យល់ រម ៥:១២–២១)។ *អំណាចរបស់បាប គឺជាក្រិត្យវិន័យ* "មើលការពន្យល់ រម ៧:៧–១២"។

**១៥:៥៧** *មានជ័យជំនះ ដោយសារព្រះយេស៊ូវគ្រីស្ទ* មានន័យថាយើងបានឈ្នះសេចក្ដីស្លាប់អំពើបាប និងសេចក្ដីពុករលួយ ដោយសារតែព្រះយេស៊ូវគ្រីស្ទតាមរយៈការសុគត និងរស់ឡើងវិញរបស់ទ្រង់ (ខ.៥៤–៥៥ រម ៤:២៥)។

**១៥:៥៨** ដោយព្រោះតែព្រះយេស៊ូវមានព្រះជន្មរស់ពីសុគតឡើងវិញ នោះយើងដឹងច្បាស់ថា ការដែលយើងបានបម្រើទ្រង់ គឺជាព្រះគុណ និងព្រះពរដ៏លើសលប់សម្រាប់យើង (មថ ២៥:២១ លក ១៩:១៧ ១កថ ២:៧ ១កថ ៤:១៧)។

**១៦:១** បទគម្ពីរនេះបញ្ជាក់អំពីចម្លើយ ដែលលោកប៉ុលបានឆ្លើយតបទៅនឹងសំណួរផ្សេងទៀត ដែលពួកជំនុំនៅទីក្រុងកូរិនថូសបានសួរដល់គាត់ (៧:១ ៨:១ ១២:១)។ *ប្រាក់* (ប្រៀបធៀប ២កថ ៨–៩ រម ១៥:២៥–២៨)។ *ពួកបរិសុទ្ធ* សំដៅលើពួកជំនុំនៅទីក្រុងយេរូសាឡិម (ខ.៣ រម ១៥:២៦)។ *ពួកជំនុំនៅស្រុកកាឡាទី* ដោយព្រោះមានការចូលរួមពីសំណាក់ពួកជំនុំនៅទីក្រុងកាឡាទី ពួកជំនុំនៅស្រុកម៉ាសេដូន និងពួកជំនុំនៅទីក្រុងកូរិនថូស ក្នុងការរៃប្រាក់យកទៅជួយដល់ពួកជំនុំនៅទីក្រុងយេរូសាឡិម ដូច្នេះបញ្ជាក់ថា ពួកជំនុំនៅទីក្រុងនេះ (ក្រុងយេរូសាឡិម) មានការខ្វះខាតយ៉ាងខ្លាំង ព្រោះពួកគេជួបប្រទះនូវគ្រោះទុរភិក្ស និងការបៀតបៀនជាច្រើន ដូចមានចែងនៅក្នុង"កថ ១១:២៨" (ប្រហែលឆ្នាំទី៤៤ ឬ៤៦ គ.ស) (កថ ៨:១)។

**១៦:២** *ថ្ងៃដំបូង* គឺថ្ងៃអាទិត្យ ។ ពួកជំនុំនៅពេលនោះបាននាំគ្នាយកដង្វាយមកថ្វាយព្រះអម្ចាស់ជាដង្វាយមួយភាគក្នុងដប់ ឬដង្វាយស្ម័គ្រពីចិត្ត (កថ ២០:៧ វវ ១:១០ និងការពន្យល់)។

**១៦:៣–៤** *អ្នកណាដែលពេញចិត្តអ្នករាល់គ្នា* សំដៅលើអ្នកមើលការខុសត្រូវលើដង្វាយ ដែលពួកជំនុំនៅទីក្រុងកូរិនថូស បានប្រមូលមកទុកសម្រាប់យកទៅជួយពួកអ្នកខ្វះខាតនៅកន្លែងផ្សេងៗទៀត (២កថ ៨:១៦–២១ និងការពន្យល់)។ លោកប៉ុលមិនបានបង្គាប់ពួកគេឱ្យរៀបចំប្រាក់

## សេចក្តីស្នើសូមរបស់លោកប៉ុល

៥កាលណាខ្ញុំបានដើរកាត់ស្រុកម៉ាសេដូនហើយ នោះខ្ញុំ
នឹងមកឯអ្នករាល់គ្នា[ន] ដ្បិតខ្ញុំត្រូវដើរកាត់ស្រុកម៉ាសេដូន
សិន[ប] ៦ប្រហែលជាខ្ញុំនឹងស្នាក់នៅជា១ នឹងអ្នករាល់គ្នាបន្តិច
ឬអស់១ រដូវរងារផងទេដឹង ដើម្បីឱ្យអ្នករាល់គ្នាបានជូន
ដំណើរខ្ញុំ[ផ] ទៅឯទីកន្លែងណា ដែលខ្ញុំនឹងទៅតទៅមុខទៀត
៧ដ្បិតខ្ញុំមិនចូលចិត្តមកសួរអ្នករាល់គ្នាតាមផ្លូវឥឡូវនេះទេ
តែខ្ញុំសង្ឃឹមថា នឹងមកនៅជាមួយនឹងអ្នករាល់គ្នាជាយូរ
បន្តិច បើសិនជាព្រះអម្ចាស់ទ្រង់អនុញ្ញាតឱ្យ[ព] ៨ប៉ុន្តែ ខ្ញុំនឹង
នៅក្រុងអេភេសូរ[ភ] ទាល់តែដល់បុណ្យថ្ងៃទី៥០[ម] ៩ដ្បិតមាន
ទ្វារយ៉ាងធំ ហើយស្រួលបានបើកចំហឱ្យខ្ញុំ[យ] ហើយក៏មាន
ពួកឃាត់ឃាំងជាច្រើនដែរ ។

១០បើធីម៉ូថេ[រ]មកឯអ្នករាល់គ្នា នោះចូរខំទំនុកបំរុងឱ្យ
គាត់នៅជាមួយផង កុំឱ្យគាត់ភ័យខ្លាចអ្វីឡើយ ដ្បិតគាត់ក៏
ធ្វើការរបស់ព្រះអម្ចាស់[ល] ដូចជាខ្ញុំដែរ ១១កុំឱ្យអ្នកណា
មើលងាយគាត់[វ] ត្រូវជូនដំណើរគាត់ទៅមុខ[ស] ដោយសុខ
សាន្ត[ហ] ឱ្យគាត់បានទៅដល់ខ្ញុំផង ដ្បិតខ្ញុំនឹងចាំគាត់ ជាមួយ
នឹងបងប្អូនឯទៀត ១២ឯអ័ប៉ុឡូស[ឡ] ជាបងប្អូន ខ្ញុំបានទូន្មាន
គាត់ជាច្រើន ឱ្យបានមកឯអ្នករាល់គ្នា ជាមួយនឹងពួកបង
ប្អូននោះដែរ តែគាត់មិនសុខចិត្តនឹងមកឥឡូវនេះទេ គឺ
នឹងមកក្នុងកាល ដែលមានឱកាសស្រួល ១៣ចូរចាំយាម
ចូរឈរឱ្យមាំមួន[អ]ក្នុងសេចក្តីជំនឿ ចូរប្រព្រឹត្តឱ្យពេញជា
ភាពបុរស ចូរឱ្យមានកំឡាំងចុះ[ក] ១៤ត្រូវ ឱ្យអ្នករាល់គ្នាធ្វើ
ការទាំងអស់ ដោយសេចក្តីស្រឡាញ់[ខ]។

១៥បងប្អូនអើយ អ្នករាល់គ្នាស្គាល់ពួកផ្ទះស្ទេផាន៉ាស[គ] ថា
គេជាផលដំបូង[ឃ]ពីស្រុកអាខៃ[ង] ហើយថា គេបានតាំង
ខ្លួនគេ សំរាប់នឹងបំរើ[ច]ពួកបរិសុទ្ធ[ឆ] ១៦ដូច្នេះខ្ញុំទូន្មានអ្នក
រាល់គ្នាឱ្យចុះចូល[ជ] នឹងមនុស្សយ៉ាងនោះ ហើយនិងអស់
អ្នកដែលធ្វើការនឿយហត់ជាមួយនឹងយើងខ្ញុំផង ១៧ខ្ញុំអរ
ណាស់ ដែលស្ទេផាន៉ាស ភ័រទូន៉ាតុស និងអ័ខៃកុសបានទៅ
ដល់ខ្ញុំហើយ ដ្បិតសេចក្តីណាដែលអ្នករាល់គ្នាខានធ្វើ នោះ
គេបានធ្វើបំពេញឡើង[ឈ] ១៨គេបានលំហើយ[ញ]ចិត្តខ្ញុំ នឹងចិត្ត
អ្នករាល់គ្នាផង ដូច្នេះ ចូររាប់អានមនុស្សយ៉ាងនោះចុះ[ដ] ។

## ពាក្យជម្រាបសួរជាលើកចុងក្រោយ

១៩អស់ទាំងពួកជំនុំនៅស្រុកអាស៊ី[ឋ] គេសូមជំរាបសួរ

**១៦:៥** ន ១កថ ៤:១៩ ប កច ១៦:៩ **១៦:៦** ផ រម ១៥:២៤ ទត ៣:១៣ **១៦:៧** ព កច ១៨:២១ **១៦:៨** ភ កច ១៨:១៩ ម កច ២:១ **១៦:៩** យ កច ១៤:២៧ **១៦:១០** រ កច ១៦:១ ល ១កថ ១៥:៥៨ **១៦:១១** វ ១ធថ ៤:១២ ស ២កថ ១:១៦ ៣យហ ៦ ហ កច ១៥:៣៣ **១៦:១២** ឡ កច ១៨:២៤ **១៦:១៣** អ ១កថ ១:៨ ២កថ ១:២១ កទ ៥:១ ភល ១:២៧ ១ថន ៣:៨ ទត ១:៩ ក អភ ៦:១០ **១៦:១៤** ខ ១កថ ១៤:១

**១៦:១៥** គ ១កថ ១:១៦ ឃ រម ១៦:៥ ង កច ១៨:១២ ច កច ២៤:១៧ ឆ កច ៩:១៣ **១៦:១៦** ជ ១ថន ៥:១២ ហព ១៣:១៧

ដង្វាយទុកឱ្យគាត់ជាអ្នកនាំយកទៅជួយពួកបងប្អូនដែលខ្វះខាតទេផ្ទុយទៅវិញ គាត់បង្គាប់ឱ្យរើសយកអ្នកណាម្នាក់ក្នុងចំណោមពួកគេ ឱ្យនាំយកប្រាក់កម្រៃទាំងនោះវិញ (២កថ ៨:១៩–២១)។

**១៦:៥** *ស្រុកម៉ាសេដូន* គឺជាខេត្តសំខាន់មួយរបស់ចក្រភពរ៉ូម៉ាំងស្ថិតនៅភាគខាងជើងនៃប្រទេសក្រិក ។ ការធ្វើដំណើរតាមផ្លូវគោកពីទីក្រុងអេភេសូរ ទៅ កាន់ទីក្រុងកូរិនថូស គឺត្រូវឆ្លងកាត់ខេត្តម៉ាសេដូន (២កថ ១:១២–២៤)។ ការដែលលោកប៉ុលចង់ធ្វើដំណើរឆ្លងកាត់ស្រុកម៉ាសេ–ដូនអាចមកពីគាត់ចង់ទៅសួរសុខទុក្ខពួកជំនុំនៅទីក្រុងភីលីព និងទីក្រុងថែស្សាឡូនីចដែលស្ថិតនៅក្នុង ស្រុកនេះ ។

**១៦:៦** *ខ្ញុំនឹងស្នាក់នៅជា១នឹងអ្នករាល់គ្នាបន្តិច ឬអស់១រដូវរងារ* ឃ្លានេះបញ្ជាក់ថា លោកប៉ុលបានស្នាក់នៅប្រទេសក្រិកប្រហែល៣ខែ ដូចមានចែងនៅក្នុង "កច ២០:៣" (មើលការពន្យល់)។ នៅទីនោះពួកជំនុំបានជួយទំនុកបម្រុងលោកប៉ុលអាចទាំងផ្នែកសម្ភារៈ សេចក្តីអធិស្ឋាន និងការលើកទឹកចិត្ត ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅក្នុងសំបុត្ររបស់លោកប៉ុលបានបញ្ជាក់យ៉ាងច្បាស់ថា គាត់មិនដែលធ្វើជាបន្ទុកដល់ពួកជំនុំ ផ្នែកសម្ភារៈ និងថវិកាទេ (៩:៧–១២)។

**១៦:៨** *បុណ្យថ្ងៃទី៥០* គឺជាពិធីបុណ្យមួយរបស់ពួកយូដាដែលប្រារព្ធធ្វើនៅថ្ងៃទី៥០បន្ទាប់ពីពិធីបុណ្យរំលង ។ បុណ្យនេះត្រូវបានហៅថា "បុណ្យចម្រូត"ឬ"បុណ្យផលដំបូង" (នក ២៣:១៦ លវ ២៣:១០–១៦ ជន ២៨:២៦)

**១៦:៩** *ពួកឃាត់ឃាំង* សំដៅលើពួកសាសន៍ដទៃ ដែលជាជាងប្រាក់ធ្វើអាស្រមព្រះឌីអាន និងពួកអ្នកប្រឆាំងដទៃទៀត (កច ១៩:២៣–៣៤)។

**១៦:១០** *បើធីម៉ូថេមកឯអ្នករាល់គ្នា* នៅក្នុង "កច ១៩:២២" លោកប៉ុលបានបញ្ជូនលោកធីម៉ូថេ (និងអេរ៉ាស្ទុស) ឱ្យទៅឯស្រុកម៉ាសេដូន ហើយបន្ទាប់មកឱ្យ ទៅឯទីក្រុងកូរិនថូស (១កថ ៤:១៧)។ *កុំឱ្យគាត់ភ័យខ្លាចអ្វីឡើយ* តាមរយៈពាក្យសំដីរបស់លោកប៉ុលត្រង់ចំណុចនេះបញ្ជាក់ថាលោកធីម៉ូថេប្រហែលជាមានការខ្មាសអៀនខ្លះដែរ នៅពេលចាប់ផ្តើមបេសកកម្មដំបូង (១ធថ ៤:១២ ២ធថ ១:៧ និងការពន្យល់)។

**១៦:១១** *បងប្អូនឯទៀត* អាចសំដៅលើលោកអេរ៉ាស្ទុស ។ លោកអេរ៉ា–ស្ទុស គឺជាអ្នកជឿដល់ព្រះអម្ចាស់ និងជានាយកទទួលបន្ទុកកិច្ចការងារសាធារណៈនៅទីក្រុងកូរិនថូស (កច ១៩:២២ រម ១៦:២៣ និងពន្យល់)។

**១៦:១២** បទគម្ពីរនេះ លោកប៉ុលបានឆ្លើយតប ទៅនឹងសំណួររបស់ពួកជំនុំនៅទីក្រុងកូរិនថូស ទាក់ទងទៅនឹងបញ្ហាស្តីអំពីលោកអ័ប៉ុឡូស (១:១២ ៣:៤-៦ ៧:១ ៨:១ ១២:១ ១៦:១ កច ១៨:២៤,២៧ ១៩:១ ទត ៣:១៣)។

**១៦:១៥** *ពួកផ្ទះស្ទេផាន៉ាស* ជាពួកអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទនៅស្រុកអាខៃ (ប្រទេសក្រេក) និងបានទទួលពិធីបុណ្យជ្រមុជទឹកដោយលោកប៉ុល (១:១៦ កច ១៧:៣៤)។

**១៦:១៧** ឈ្មោះពួកអ្នកនៅក្នុងបទគម្ពីរនេះ អាចជាពួកអ្នកដែលបាននាំសំបុត្រពីទីក្រុងកូរិនថូស ទៅឱ្យលោកប៉ុលនៅក្នុង "៧:១"។

**១៦:១៨** *គេបានលំហើយចិត្តខ្ញុំ និងចិត្តអ្នករាល់គ្នាផង* ការដែលលោកប៉ុលមានប្រសាសន៍យ៉ាងដូច្នេះ អាចមកពីពួកគេ (១៦:១៧) សុខចិត្តទៅទទួលដំបូន្មានពីគាត់ ដើម្បីយកទៅកាន់ពួកជំនុំនៅឯទីក្រុងកូរិនថូសវិញ ។

**១៦:១៩** *ស្រុកអាស៊ី* ជាខេត្តមួយរបស់ចក្រភពរ៉ូម៉ាំង (សព្វថ្ងៃខេត្តនេះស្ថិតនៅភាគខាងលិចនៃប្រទេសទួរគី)។ ក្រុងអេភេសូរស្ថិតនៅក្នុងខេត្តនេះ (កច ១៩:១០ និងការពន្យល់)។ ម្យ៉ាងទៀត ពួកជំនុំនៅទីក្រុង

មកអ្នករាល់គ្នា អ្នកអ័គីឡា និងនាងព្រីស៊ីល[ឌ] ព្រមទាំងពួក
ជំនុំដែលប្រជុំនៅផ្ទះគេ[ឍ] សូមជំរាបសួរមកអ្នករាល់គ្នា
យ៉ាងថ្លុម ក្នុងព្រះអម្ចាស់ ២០ ពួកបងប្អូនទាំងអស់គ្នា ក៏សូម
ជំរាបសួរមកអ្នករាល់គ្នាដែរ សូមឱ្យអ្នករាល់គ្នាជំរាបសួរ
គ្នាទៅវិញទៅមក ដោយថើបយ៉ាងបរិសុទ្ធផង[ណ]។
២១ នេះជាពាក្យដែលប៉ុលខ្ញុំ សរសេរដោយដៃខ្លួនខ្ញុំផ្ញើ
មកជំរាបសួរអ្នករាល់គ្នា[ត] ២២ បើអ្នកណាមិនស្រឡាញ់
ព្រះអម្ចាស់យេស៊ូវគ្រីស្ទ[ថ] ឱ្យអ្នកនោះត្រូវបណ្ដាសាចុះ[ទ]
ដ្បិតព្រះអម្ចាស់ទ្រង់យាងមក[ធ] ២៣ សូមឱ្យអ្នករាល់គ្នាបានប្រ
កបដោយព្រះគុណនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ[ន] ២៤ សូមឱ្យ
សេចក្ដីស្រឡាញ់របស់ខ្ញុំ នៅជាមួយនឹងអ្នករាល់គ្នាទាំង
អស់ ក្នុងព្រះគ្រីស្ទយេស៊ូវ ។ អាម៉ែន ។

**១៦:១៧** ឈ ២កថ ១១:៩ ភល ២:៣០ **១៦:១៨** ញ រម ១៥:៣២ ភម ៧ ដ ភល ២:២៩ **១៦:១៩** ឋ កច ២:៩ ឌ កច ១៨:២ ឍ រម ១៦:៥ **១៦:២០** ណ រម ១៦:១៦

**១៦:២១** ត កទ ៦:១១ កល ៤:១៨ ២ថន ៣:១៧ ភម ១៩ **១៦:២២** ថ អភ ៦:២៤ ទ រម ៩:៣ ធ វវ ២២:២០ **១៦:២៣** ន រម ១៦:២០

កូល៉ុស ទីក្រុងឡៅឌីសេ ទីក្រុងហេរ៉ាប៉ូល និងពួកជំនុំដែលបានរៀបរាប់នៅក្នុង "វវ ២–៣" ក៏បានផ្ញើនូវ សេចក្ដីនឹករឭកតាមរយៈលោកប៉ុលទៅពួកជំនុំនៅឯទីក្រុងកូរិនថូសដែរ (កល ៤:១២–១៣ វវ ១:១១)។ *អ័គីឡា និងនាងព្រីស៊ីល* អ្នកទាំងពីរនេះបានជួយលោកប៉ុលក្នុងការស្វែងរកពួកជំនុំនៅទីក្រុងកូរិនថូស (កច ១៨:១–៤)។ ពួកគាត់បានចាកចេញពីទីក្រុងកូរិនថូស ជាមួយលោកប៉ុលទៅឯទីក្រុងអេភេសូរ (កច ១៨:១៨–១៩)។ អ្នកទាំងនេះក៏នៅជាមួយលោកប៉ុលផងដែរ ក្នុងពេលដែលគាត់សរសេរសំបុត្រផ្ញើទៅពួកជំនុំនៅក្រុងកូរិនថូស ។ ជាទូទៅពួកជំនុំនាពេលនោះ ច្រើនជួបប្រជុំគ្នានៅតាមផ្ទះ (រម ១៦:៣–៥ ភម ២)។

**១៦:២០** *ថើបយ៉ាងបរិសុទ្ធ* គឺបុរសថើបបុរស ហើយស្ត្រីថើបស្ត្រីដោយសេចក្ដីគោរព និងដោយសេចក្ដីស្រឡាញ់ក្នុងព្រះអម្ចាស់ (២កថ ១៣:១២ រម១៦:១៦ និងការពន្យល់)។

**១៦:២១** *នេះជាពាក្យដែលប៉ុលខ្ញុំ សរសេរដោយដៃខ្លួនខ្ញុំ* ឃ្លានេះបញ្ជាក់ថាមានអ្នកសរសេរសំបុត្រឱ្យលោកប៉ុល ហើយមកដល់ត្រង់ចំណុចនេះ គាត់ចាប់ផ្ដើមសរសេរដោយផ្ទាល់ខ្លួនគាត់តែម្ដង (រម ១៦:២២ កទ ៦:១១ កល ៤:១៨ ២ថន ៣:១៧ ភម ១៩)។

**១៦:២៣** *ព្រះគុណ* ពាក្យថា "ព្រះគុណ" គឺរួមបញ្ចូលទាំងសេចក្ដីមេត្តាករុណាសេចក្ដីស្រឡាញ់ផលផ្លែខាងឯវិញ្ញាណ និងព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ (២កថ ១៣:១៤ កទ ៦:១៨ អភ ៦:២៤ ភល ៤:២៣)។

**១៦:២៤** បទគម្ពីរនេះបញ្ជាក់ថា ទោះបីសេចក្ដីដែលលោកប៉ុលសរសេរផ្ញើទៅពួកជំនុំនៅទីក្រុងកូរិនថូសមានលក្ខណៈតឹងរ៉ឹងយ៉ាងណាក៏ដោយ ក៏គាត់ចង់បង្ហាញប្រាប់ពួកគេថា គាត់ស្រឡាញ់ពួកគេដោយស្មោះនៅក្នុងព្រះអម្ចាស់ ។

សំបុត្រទី ២ របស់ប៉ុល

ដល់ពួក

# កូរិនថូស

សេចក្ដីផ្ដើម

**អ្នកនិពន្ធ**

លោកសាវ័កប៉ុលគឺជាអ្នកនិពន្ធសំបុត្រនេះ (១:១ ១០:១) ។ សំបុត្រនេះមានរចនាបថនៃការតែងនិពន្ធ និងនិយាយពីជីវប្រវត្តិរបស់គាត់ផ្ទាល់ច្រើនជាងសំបុត្រដែលគាត់បានសរសេរដទៃៗទៀត ។

**កាលបរិច្ឆេទ**

ភស្តុតាងដែលអាចទទួលយកបានមួយ បានកំណត់យកឆ្នាំ ៥៥ គ.ស. ធ្វើជាកាលបរិច្ឆេទនៃការតែងនិពន្ធនៃសំបុត្រនេះ ក៏ជាការសមហេតុផលមួយដែរ ។ តាម ១កថ ១៦:៥-៨ គេអាចសន្និដ្ឋានបានថា សំបុត្រកូរិនថូសខ្សែទី១ត្រូវបានសរសេរឡើងនៅក្រុងអេភេសូរគឺនៅមុនថ្ងៃបុណ្យទី៥០ (នៅចុងរដូវផ្ការីក) ហើយសំបុត្រកូរិនថូសខ្សែទី២ត្រូវបានសរសេរឡើង នៅឆ្នាំបន្ទាប់ គឺមុនពេលរដូវរងារមកដល់។ តាមការបង្ហាញនៅក្នុង ២កថ ២:១៣ ៧:៥ គេជឿថាសំបុត្រនេះត្រូវបាននិពន្ធនៅស្រុកម៉ាសេដូន ។

**អ្នកទទួល**

តាមរយការវកថានៃសំបុត្រនេះ គេអាចដឹងថាអ្នកទទួលសំបុត្រនេះ គឺពួកជំនុំនៅក្រុងកូរិនថូស និងគ្រីស្ទបរិស័ទនៅទូទាំងស្រុកអាខៃ (ខេត្តចំណុះរបស់ចក្រភពរ៉ូម៉ាំង ដែលរួមមានដែនដីក្រិកទាំងមូល ស្ថិតនៅភាគខាងត្បូងស្រុកម៉ាសេដូន) ។

**ឱកាស**

លោកប៉ុលហាក់ដូចជាបានសរសេរសំបុត្រទាំងពីរចែកជាបួនសំបុត្រ ផ្ញើទៅពួកជំនុំក្រុងកូរិនថូសដែលមានដូចជា (១) គឺសំបុត្រដែលគាត់និយាយនៅក្នុង ១កថ ៥:៩ (សូមមើលការពន្យល់) ។ (២) សំបុត្រកូរិនថូសខ្សែទី១ ។ (៣) សំបុត្រដែលនិយាយពីសេចក្ដីធ្ងន់ធ្ងរ (មើល ២កថ ២:៣-៤ និងសេចក្ដីរៀបរាប់ខាងក្រោម) ។ (៤) សំបុត្រកូរិនថូសខ្សែទី២ ។ បន្ទាប់ពីគាត់បានសរសេរសំបុត្រកូរិនថូសខ្សែទី១ លោកប៉ុលបានបន្តការងារបម្រើព្រះរបស់គាត់នៅក្រុងអេភេសូរទៀត រហូតដល់ពេលដែលគាត់បានទទួលដំណឹងថា សំបុត្រដែលគាត់បានផ្ញើទៅនោះមិនទាន់បានសម្រេចគោលដៅនៅឡើយទេ ។ មានមនុស្សប្រុសមួយក្រុមបានទៅដល់ក្រុងកូរិនថូស ហើយបានតាំងខ្លួនជាពួកសាវ័ក ។ ពួកគេជាគ្រូបង្រៀនខុសឆ្គងដែលរករឿង បង្ខូចភាពសុចរិត និងសិទ្ធិអំណាចជាសាវ័ករបស់សាវ័កប៉ុល (១១:៤ ១២:១១) ។

ដោយត្រូវប្រឈមមុខនឹងស្ថានភាពដ៏ធ្ងន់ធ្ងរនេះ លោកសាវ័កប៉ុលបានសម្រេចចិត្តធ្វើដំណើរទៅកាន់ក្រុងកូរិនថូសជាបន្ទាន់ (១២:៤ ១៣:១-២) ដើម្បីឱ្យដឹងថាតើគាត់អាចធ្វើឱ្យមានស្ថានភាពល្អឡើងវិញដោយរបៀបណា ។ ការធ្វើដំណើរសួរសុខទុក្ខនេះបាននាំឱ្យគាត់មានការលំបាកចិត្ត ហើយមិនបានសម្រេចដូចចិត្តដែលបានប៉ងនោះឡើយ ។ ដូចនេះនៅពេលដែលសាវ័កប៉ុលបានត្រឡប់ទៅដល់ក្រុងអេភេសូរវិញ គាត់បានសរសេរសំបុត្រដែលនិយាយពីសេចក្ដីធ្ងន់ធ្ងរផ្ញើទៅកាន់ក្រុងកូរិនថូស "ដោយចិត្តលំបាក ហើយថប់ព្រួយ ព្រមទាំងស្រក់ទឹកភ្នែកជាច្រើន" (២:៤) ដែលគេជឿថាជាសំបុត្រដែលត្រូវបានផ្ញើតាមរយៈលោកទីតុស (១២:៨) ។

បន្ទាប់ពីលោកប៉ុលបានសរសេរសំបុត្រដែលនិយាយពីសេចក្ដីធ្ងន់ធ្ងរ គាត់ក៏មានការខ្វល់ខ្វាយយ៉ាងខ្លាំងអំពីការឆ្លើយតបរបស់ពួកក្រុងកូរិនថូសដែលនឹងអាចកើតមាន ។ ដូចនេះហើយ បន្ទាប់ពីមានភាពវឹកវរដែលបង្ករដោយជាងប្រាក់ឈ្មោះដេមេទ្រាស និងពួកជាងប្រាក់ដទៃទៀត (កថ ១៩:២៣-៤១) គាត់ក៏បានធ្វើដំណើរចេញពីក្រុងអេភេសូរទៅកាន់ស្រុកម៉ាសេដូន ដោយកាត់តាមក្រុងទ្រអាស ។ ដោយរំពឹងថានឹងបានជួបលោកទីតុសនៅក្រុងទ្រអាស ហើយបានសាកសួរដំណឹងអំពីផលនៃសំបុត្រដែលនិយាយពីសេចក្ដីធ្ងន់ធ្ងរ ដែលបានផ្ញើទៅពួកជំនុំក្រុងកូរិនថូសនេះផង ប៉ុន្តែលោកទីតុសមិននៅទីនោះទេ (មើល ២កថ ២:១២-១៣) ។ លោកប៉ុលនៅតែខ្វល់ខ្វាយ ហើយទោះជាគាត់ដឹងប្រាកដថាមានឱកាសផ្សាយដំណឹងល្អនៅក្រុងទ្រអាសក៏ដោយ ក៏លោកប៉ុលបានជម្រាបលា គ្រីស្ទបរិស័ទនៅទីនោះ ហើយបន្តដំណើរទៅស្រុកម៉ាសេដូនទៀត ដែលនៅទីនោះគាត់ក៏បានជួបលោកទីតុស ។ គាត់មានជំនឿថា ដំណឹងពីពួកជំនុំក្រុងកូរិនថូសគឺជាដំណឹងល្អ ។ សំបុត្រដែលនិយាយពីសេចក្ដីធ្ងន់ធ្ងរបានផ្ដល់ឱ្យនូវផលដែលលោកប៉ុលចង់បាន (៧:៥-១៦) ។ ដំណឹងដែលលោកទីតុសជម្រាបសាវ័កប៉ុលអំពីការរីកចម្រើនរបស់ពួកជំនុំក្រុងកូរិនថូសបានលើកទឹកចិត្តលោកប៉ុល ហើយបានផ្ដល់ឱកាសឱ្យគាត់បានសរសេរសំបុត្រកូរិនថូសខ្សែទី២នេះទៀត ។

សរុបមក តើគេពន្យល់សេចក្ដីធ្ងន់ធ្ងរនៃជំពូក១០-១៣ ដែលមានលក្ខណៈខុសប្លែកពីផ្នែកដទៃទៀតនៃសំបុត្រនេះដោយរបៀបណា?

អ្នកខ្លះយល់ថា នៅពេលដែលលោកប៉ុលទើបតែនិពន្ធបានប្រាំបួនជំពូកដំបូង គាត់បានទទួលដំណឹងថា ពួកមនុស្សខុសឆ្គងមួយក្រុមតូច នោះមិនទាន់ឈប់បង្កបញ្ហានៅក្រុងកូរិនថូសទេ ។ ដូចនេះមុននឹងផ្ញើសំបុត្រនេះទៅ គាត់បានសរសេរបន្ថែមបួនជំពូកចុងក្រោយទៀត ដើម្បីនឹងនិយាយអំពីក្រុមមនុស្សដែលបង្កបញ្ហានោះ ។ អ្នកខ្លះទៀតជឿថា ជំពូក ១០–១៣ ត្រូវបានសរសេរឡើងនៅក្នុងពេលណាមួយ បន្ទាប់ពីលោកប៉ុលបានផ្ញើសំបុត្រដែលមានប្រាំបួនជំពូកនោះ ហើយពួកគេបានចែកសំបុត្រកូរិនថូសខ្សែទីពីរនេះជាពីរសំបុត្រផ្សេងគ្នាទៀតផង ។ ទោះជាយ៉ាងណាក៏ដោយ មិនមានភស្តុតាងជាលាយលក្ខអក្សរ ដែលបានធានាពីការបែងចែកសំបុត្រកូរិនថូសខ្សែទី២ នេះឡើយ ។

**គោលបំណង**

គោលបំណងនៃការសរសេររបស់លោកសាវ័កប៉ុលគឺដើម្បី :

១. បង្ហាញពីសេចក្តីកម្សាន្តចិត្ត និងអំណរដែលគាត់មាន ដោយសារការឆ្លើយតបរបស់ពួកជំនុំកូរិនថូស ចំពោះសំបុត្រដែលគាត់សរសេរដោយចិត្តព្រួយ (១:៣–៤ ៧:៨–៩ ១២–១៣) ។

២. ឱ្យពួកគេបានដឹងអំពីសេចក្តីទុក្ខវេទនាដែលគាត់បានទទួលនៅក្នុងស្រុកអាស៊ី (១:៨–១១) ។

៣. ពន្យល់ពីមូលហេតុដែលគាត់ផ្លាស់ប្តូរគម្រោងធ្វើដំណើររបស់គាត់ (១:១២–២:៤) ។

៤. ឱ្យពួកគេអត់ទោសឱ្យក្រុមអ្នកធ្វើឱ្យរវាតចិត្តទាំងនោះ (២:៥–១១) ។

៥. ព្រមានពួកគេកុំឱ្យ "ទឹមនឹមស្រៀកជាមួយនឹងអ្នកមិនជឿ" (៦:១៤–៧:១) ។

៦. ពន្យល់ពួកគេអំពីលក្ខណៈពិតរបស់គ្រីស្ទបរិស័ទ (សេចក្តីអំណរ សេចក្តីទុក្ខវេទនា និងរង្វាន់) និងការត្រាស់ហៅដ៏ឧត្តមដល់គ្រីស្ទបរិស័ទសម្រាប់ការងារបម្រើព្រះ ។ លោកប៉ុលស្លេះការនិយាយអំពីការធ្វើដំណើរ ហើយនិយាយអំពីសេចក្តីមួយទៀតដ៏សំខាន់ (២:១៤–៧:៤ មើលការពន្យល់ ២:១៤) ។

៧. បង្រៀនពួកជំនុំកូរិនថូសអំពីព្រះគុណដែលប្រទាន និងដើម្បីឱ្យបានដឹងច្បាស់ថា ពួកគេបានសម្រេចការងារប្រមូលប្រាក់ដង្វាយសម្រាប់គ្រីស្ទ បរិស័ទជាអ្នកក្រីក្រនៅក្រុងយេរូសាឡិម (ជំពូក ៨–៩) ។

៨. ដោះស្រាយជាមួយនឹងពួកអ្នកប្រឆាំងមួយក្រុមតូចនៅក្នុងពួកជំនុំ (ជំពូក ១០–១៣) ។

៩. ឱ្យពួកជំនុំក្រុងកូរិនថូសត្រៀមខ្លួនសម្រាប់ការមកសួរសុខទុក្ខរបស់លោកសាវ័កប៉ុលនៅពេលខាងមុខ (១២:១៤ ១៣:១–៣,១០) ។

**រចនាសម្ព័ន្ធ**

រចនាសម្ព័ន្ធរបស់សំបុត្រនេះមានការទាក់ទងជាបឋមនឹងការមកសួរសុខទុក្ខជាលើកទីបីរបស់លោកប៉ុល នៅក្រុងកូរិនថូសដែលនឹងធ្វើឡើងក្នុងពេលដ៏ខ្លីខាងមុខ ។ សំបុត្រនេះមានជាបីផ្នែកសំខាន់ៗ:

១. លោកប៉ុលពន្យល់ពីមូលហេតុនៃការកែប្រែគម្រោងធ្វើដំណើររបស់គាត់ (ជំពូក ១–៧) ។

២. លោកប៉ុលលើកទឹកចិត្តពួកជំនុំកូរិនថូសឱ្យសម្រេចការងារប្រមូលប្រាក់ដង្វាយមុននឹងគាត់មកដល់ (ជំពូក ៨–៩) ។

៣. លោកប៉ុលសង្កត់ធ្ងន់ពីភាពប្រកដប្រជានៃការធ្វើដំណើរមកក្រុងកូរិនថូស ពីសិទ្ធិអំណាចរបស់គាត់ជាគ្រីស្ទទូត និងពីការត្រៀមខ្លួនជាស្រេច សម្រាប់ការធ្វើទោសដល់គ្រប់ទាំងសេចក្តីវិងចចេស បើសិនជាមានការចាំបាច់ (ជំពូក ១០–១៣) ។

**បញ្ហាបង្រួមសំបុត្រពីរចូលគ្នា**

មានអ្នកខ្លះបានចោទសួរពីបញ្ហាដែលសំបុត្រកូរិនថូសខ្សែទី២កើតពីសំបុត្រពីរបង្រួមចូលគ្នា (សូមមើលសេចក្តីខាងលើ) ប៉ុន្តែផ្នែកនីមួយៗនៃសំបុត្រនេះមានការស៊ីសង្វាក់គ្នាយ៉ាងល្អ ដូចដែលអាចឃើញនៅក្នុងរចនាសម្ព័ន្ធខាងលើ ។ មិនមានការបញ្ជាក់អំពីការបង្រួមសំបុត្រនេះទេ ។ ជាងនេះទៅទៀត ក៏គ្មានឯកសារបុរាណជាភាសាក្រេកណាមួយបានបែងចែកសំបុត្រនេះជាពីរដែរ ។

**គម្រោងសង្ខេប**

**I. ការបង្រៀនៈ សេចក្តីពន្យល់របស់លោកប៉ុលអំពីការប្រព្រឹត្ត និងការការពាររបស់គាត់ (ជំពូក ១–៧)**

ក. ពាក្យជម្រាបសួរ (១:១–២)

ខ. ការអរព្រះគុណសម្រាប់ការកម្សាន្តចិត្តដែលព្រះទ្រង់បានប្រទានដល់លោកសាវ័កប៉ុលនៅពេលរងទុក្ខ (១:៣–១១)

គ. ភាពសុចរិតនៃចិត្ត និងការប្រព្រឹត្តរបស់សាវ័កប៉ុល (១:១២–២:៤)

ឃ. ការអត់ទោសឱ្យចំពោះពួកអ្នកធ្វើឱ្យមានការរវាតចិត្តនៅក្រុងកូរិនថូស (២:៥–១១)

ង. ការដឹកនាំរបស់ព្រះនៅក្នុងការបម្រើទ្រង់ (២:១២–១៧)

ច. ពួកជំនុំកូរិនថូស ជាសំបុត្រមកពីព្រះគ្រីស្ទ (៣:១–១១)

ឆ. ការមើលឃើញសិរីល្អរបស់ព្រះ ដែលទ្រង់មិនមានស្បៃគ្របបាំងព្រះភក្ត្រ (៣:១២–៤:៦)

ជ. ទ្រព្យសម្បត្តិនៅក្នុងភាជនៈដី (៤:៧–១៦ក)

ឈ. ការប្រមើលមើលពីសេចក្តីស្លាប់ និងអត្ថន័យនៃសេចក្តីនេះដែលមានសម្រាប់គ្រីស្ទបរិស័ទ (៤:១៦ខ–៥:១០)

ញ. ការងារបង្រួបបង្រួម (៥:១១–៦:១០)

ដ. បង្គាប់ដែលឪពុកខាងវិញ្ញាណមានដល់កូន (៦:១១–៧:៤)

ឋ. ការជួបគ្នាជាមួយនឹងលោកទីតុស (៧:៥–១៦)

**II. ការលើកទឹកចិត្ត: ការប្រមូលប្រាក់ដង្វាយសម្រាប់គ្រីស្ទបរិស័ទនៅក្រុងយេរូសាឡិម (ជំពូក ៨–៩)**

ក. ការលើកទឹកចិត្តអំពីសេចក្តីសប្បុរស (៨:១–១៥)

ខ. លោកទីតុស និងអ្នករួមដំណើរជាមួយគាត់ទៅក្រុងកូរិនថូស (៨:១៦–៩:៥)

គ. លទ្ធផលនៃការឱ្យដោយសប្បុរស (៩:៦–១៥)

**III. ការការពារ: ការការពារសិទ្ធិអំណាចជាទូតព្រះគ្រីស្ទរបស់លោកប៉ុល (ជំពូក ១០–១៣)**

ក. ការការពារសិទ្ធិអំណាចជាទូតព្រះគ្រីស្ទ និងបេសកកម្មរបស់លោកប៉ុល (ជំពូក ១០)

ខ. លោកប៉ុល និងការជំរុញឱ្យមានអំនួតយ៉ាងល្ងីល្ងើ (ជំពូក ១១–១២)

គ. ការព្រមានជាលើកចុងក្រោយ (១៣:១–១០)

ឃ. សេចក្តីសន្និដ្ឋាន ការគួរសម និងការជូនពរជាបញ្ចប់ (១៣:១១–១៤)

**១** ១ សំបុត្រប៉ុលខ្ញុំ ជាសាវក[ក]នៃព្រះយេស៊ូវគ្រីស្ទ តាម
បំណងព្រះហឫទ័យព្រះ[ខ] និងធីម៉ូថេ[គ] ជាពួកបងប្អូន ផ្ញើមក
ពួកជំនុំនៃព្រះ[ឃ] ដែលនៅក្រុងកូរិនថូស[ង] ព្រមទាំងពួក
បរិសុទ្ធទាំងអស់គ្នា ដែលនៅគ្រប់ក្នុងស្រុកអាខៃ[ច] ២ សូមឱ្យ
អ្នករាល់គ្នាបានប្រកបដោយព្រះគុណ និងសេចក្ដីសុខសាន្ត
មកអំពីព្រះដ៏ជាព្រះវរបិតានៃយើង ហើយអំពីព្រះអម្ចាស់
យេស៊ូវគ្រីស្ទ[ឆ] ។

## ព្រះដ៏កម្សាន្តចិត្តគ្រប់ជំពូក

៣ សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវ
គ្រីស្ទ[ជ] ជាអម្ចាស់នៃយើងរាល់គ្នា គឺជាព្រះវរបិតាដ៏មាន
សេចក្ដីមេត្តាករុណា ជាព្រះដ៏កំសាន្តចិត្តគ្រប់ជំពូក ៤ ដែល
ទ្រង់កំសាន្តចិត្តយើងរាល់គ្នា[ឈ] ក្នុងគ្រប់ទាំងសេចក្ដីវេទនា
ប្រយោជន៍ឱ្យយើងអាចនឹងកំសាន្តចិត្តអ្នកឯទៀត ក្នុងអស់
ទាំងសេចក្ដីវេទនារបស់គេបានដែរ គឺដោយសារសេចក្ដី
ក្សាន្តនោះឯង ដែលព្រះបានកំសាន្តចិត្តយើងស្រេចហើយ
៥ ដ្បិតដូចជាសេចក្ដីទុក្ខលំបាករបស់ព្រះគ្រីស្ទ បានចំរើន
ឡើងដល់យើងរាល់គ្នាយ៉ាងណា[ញ] នោះសេចក្ដីក្សាន្តចិត្ត
នៃយើងរាល់គ្នា ក៏ចំរើនដោយសារព្រះគ្រីស្ទបែបដូច្នោះ
ដែរ ៦ ដូច្នេះ បើសិនជាយើងខ្ញុំកើតមានសេចក្ដីវេទនា
នោះគឺសំរាប់ជាសេចក្ដីកំសាន្តចិត្ត នឹងសេចក្ដីសង្គ្រោះ
ដល់អ្នករាល់គ្នា[ដ] ជាសេចក្ដីដែលបានកើតមក ដោយការ
ទ្រាំទ្រនឹងសេចក្ដីទុក្ខលំបាកដដែល ដែលយើងខ្ញុំក៏រងទុក្ខ
ដែរ ឬបើយើងមានសេចក្ដីក្សាន្ត នោះក៏សំរាប់ជាសេច
ក្ដីកំសាន្តចិត្ត នឹងសេចក្ដីសង្គ្រោះដល់អ្នករាល់គ្នាដែរ
ហើយយើងខ្ញុំមានសង្ឃឹមដល់អ្នករាល់គ្នាជាមាំមួនផង
៧ ដោយដឹងថាអ្នករាល់គ្នានឹងបានចំណែកក្នុងសេចក្ដីកំ
សាន្តចិត្ត ដូចជាបានចំណែកក្នុងការទុក្ខលំបាកនោះដែរ[ឋ]
៨ ដ្បិតបងប្អូនអើយ យើងខ្ញុំចង់ឱ្យអ្នករាល់គ្នាដឹង[ឌ] ពីសេចក្ដី
វេទនាដែលកើតឡើង[ឍ] ដល់យើងខ្ញុំនៅស្រុកអាស៊ី[ណ]ថា
យើងខ្ញុំមានបន្ទុកយ៉ាងធ្ងន់ក្រៃលែង ហួសពីកំឡាំងនៃ
យើងខ្ញុំទៅទៀត ដល់ម្ល៉េះបានជាយើងខ្ញុំអស់សង្ឃឹមនឹងនៅ
រស់ផង ៩ យើងខ្ញុំក៏មានសាន្តក្រមនៃសេចក្ដីស្លាប់ នៅក្នុងខ្លួន
យើងខ្ញុំដែរ ដើម្បីមិនឱ្យយើងខ្ញុំទុកចិត្តដល់ខ្លួនឡើយ គឺឱ្យ
ទុកចិត្តដល់ព្រះ[ត] ដែលទ្រង់ប្រោសឱ្យមនុស្សស្លាប់បានរស់
ឡើងនោះវិញ[ថ] ១០ ទ្រង់បានប្រោសយើងខ្ញុំ ឱ្យរួចពីសេចក្ដី
ស្លាប់ យ៉ាងសំបើមនោះហើយ[ទ] ក៏ចេះតែប្រោសឱ្យរួចតទៅ
ហើយយើងខ្ញុំសង្ឃឹមថា[ធ] ទ្រង់នឹងប្រោសឱ្យរួចទៅមុខទៀត
ដែរ ១១ ដោយអ្នករាល់គ្នាខំប្រឹងជួយអង្វរជួសយើងខ្ញុំផង[ន]
ដើម្បីឱ្យអំណោយទាននោះ ដែលបានប្រទានមកយើងខ្ញុំ
ដោយសារមនុស្សជាច្រើនបានត្រឡប់ជាហេតុ ឱ្យមនុស្ស
ជាច្រើនបានអរព្រះគុណ[ប] ដោយព្រោះយើងខ្ញុំ ។

## ការកែប្រែគម្រោងរបស់សាវ័កប៉ុល

១២ ដ្បិតសេចក្ដីអំនួតរបស់យើងខ្ញុំ នោះគឺជាសេចក្ដី

**១:១** ក ១កថ ១:១ ខ ១កថ ១:១ អភ ១:១ កល ១:១ ២ធថ ១:១ គ កច ១៦:១ ឃ ១កថ ១០:៣២ ង កច ១៨:១ ច កច ១៨:១២
**១:២** ឆ រម ១:៧
**១:៣** ជ អភ ១:៣ ១ពត ១:៣
**១:៤** ឈ អស ៤៩:១៣ ៥១:១២ ៦៦:១៣ ២កថ ៧:៦,៧,១៣
**១:៥** ញ រម ៨:១៧ ២កថ ៤:១០ កទ ៦:១៧ ភល ៣:១០ កល ១:២៤ ១ពត ៤:១៣
**១:៦** ដ ២កថ ៤:១៥
**១:៧** ឋ ខ.៥
**១:៨** ឌ រម ១១:២៥ ឍ ១កថ ១៥:៣២ ណ កច ២:៩
**១:៩** ត យរ ១៧:៥,៧ ថ យហ ៥:២១
**១:១០** ទ រម ១៥:៣០ ធ ២ធថ ៤:១០
**១:១១** ន រម ១៥:៣១ ភម ១:១៩ ប ២កថ ៤:១៥,៩:១១

**១:១** *ប៉ុលខ្ញុំ* មើលការពន្យល់ រម ១:១ ។ *សាវក . . . តាមបំណងព្រះហឫទ័យព្រះ* មើល ១កថ ១:១ និងការពន្យល់ ។ *ធីម៉ូថេ* លោកធីម៉ូថេច្បាស់ជានៅជាមួយនឹងលោកប៉ុល ក្នុងពេលដែលសំបុត្រនេះត្រូវបានសរសេរឡើង ប៉ុន្តែក៏មិនប្រាកដថា គាត់បានសរសេរសំបុត្រនេះជាមួយនឹងលោកប៉ុលឡើយ ។ *ពួកបងប្អូន* គឺបងប្អូនរួមជំនឿ ឬបងប្អូនក្នុងព្រះគ្រីស្ទ (កច ៩:១៧ ហព ២:១១ និងការពន្យល់) ។ *ពួកជំនុំនៃព្រះ* គឺសហគមន៍អ្នកជឿព្រះ ដែលជាតំណាង (ក្នុងតំបន់) ឱ្យពួកជំនុំជាទូទៅ (ការពន្យល់ ១កថ ១:២) ។ *ក្រុងកូរិនថូស* សូមមើលសេចក្ដីផ្ដើម ១កូរិនថូស ។ *ពួកបរិសុទ្ធទាំងអស់គ្នា* ពាក្យនេះប្រើសម្រាប់ហៅរាស្ត្ររបស់ព្រះ (ការពន្យល់ រម ១:៧) ។ *ស្រុកអាខៃ* នៅសម័យកាន់កាប់ដោយចក្រភពរ៉ូម៉ាំង ពាក្យនេះត្រូវបានគេប្រើសំដៅទៅលើទឹកដីរបស់ប្រទេសក្រេកទាំងមូល គឺមិនមែនជាស្រុកម៉ាសេដូន ដែលនៅភាគខាងជើងនោះឡើយ ។ ទោះជាសំបុត្រនេះត្រូវបានសរសេរតម្រូវ នឹងស្ថានភាពរបស់ក្រុងកូរិនថូសក៏ដោយ ក៏វាត្រូវបានសរសេរសម្រាប់ពួកជំនុំដទៃទៀតនៅក្នុងប្រទេសក្រេកផងដែរ ។ សំបុត្រនេះប្រហែលជាត្រូវបានចម្លងនៅក្នុងក្រុងកូរិនថូស ហើយផ្ញើពីកន្លែងមួយទៅកន្លែងមួយទៀត ។

**១:២** *ព្រះគុណ និងសេចក្ដីសុខសាន្ត* មើលការពន្យល់ រម ១:៧ ។

**១:៣** *ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាអម្ចាស់នៃយើងរាល់គ្នា* មើលការពន្យល់ អភ ១:៣ ។ *កំសាន្តចិត្តគ្រប់ជំពូក* គឺធ្វើឱ្យស្រាលទុក្ខ ឬលើកទឹកចិត្ត ។ ការកម្សាន្តចិត្តនេះកើតមានដល់អ្នកជឿ ក្នុងពេលរងទុក្ខថ្វាយព្រះគ្រីស្ទ ហើយផ្ដល់លទ្ធភាពដល់ពួកគេ ឱ្យអាចកម្សាន្តចិត្តអ្នកឯទៀតដែលមានទុក្ខព្រួយផងដែរ (ខ.៤–៧) ។

**១:៨** *យើងខ្ញុំ* ចាប់ពីដើមរហូតដល់ចប់សំបុត្រនេះ លោកប៉ុលបានប្រើសព្វនាមជាពហុវចនៈដូចជា យើងខ្ញុំ នៃយើង ខ្លួនយើង ។ *បងប្អូន* មើលការពន្យល់ រម ១:១៣ ។ *ស្រុកអាស៊ី* គឺជាខេត្តរបស់ចក្រភពរ៉ូម៉ាំង ដែលស្ថិតនៅភូមិភាគខាងលិចនៃប្រទេសអាស៊ីមីន័រ (ទឹកដីប្រទេសទួរគីសព្វថ្ងៃ) ។

**១:៩** លោកប៉ុលជួបការរងទុក្ខវេទនាស្ទើរបាត់បង់ជីវិតទៅហើយ ជាហេតុនាំឱ្យ គាត់ចាត់ទុកការដែលគាត់មិនបានស្លាប់ក្នុងពេលនោះ និងការជាសះស្បើយឡើងវិញ ថាដូចបានប្រោសឱ្យរស់ពីស្លាប់ឡើងវិញអញ្ចឹងដែរ ។ *ទុកចិត្ត . . . ដល់ព្រះ* គឺជាគោលលទ្ធិនៅក្នុងសំបុត្រនេះ ។ ព្រះគុណនៃព្រះគឺមានគ្រប់គ្រាន់ មានន័យថា ព្រះគ្រីស្ទទ្រង់ចម្រើនកម្លាំងដល់យើងនៅពេលដែលយើងខ្សោយ (១២:៩–១០ ភល ៤:១៣ និងការពន្យល់) ។

**១:១០** *សង្ឃឹម* មើលការពន្យល់ អភ ១:១៨ ។

**១:១១** *អ្នករាល់គ្នាខំប្រឹងជួយអង្វរជួសយើងខ្ញុំ* សូមផ្ទៀបជាមួយនឹង រម ១៥:១៣ អភ ៦:១៩–២០ ។

**១:១២** លោកប៉ុលបានប្រើសេចក្ដីបន្ទាល់នៃបញ្ញាចិត្តរបស់ខ្លួនគាត់ និងការដែលពួកក្រុងកូរិនថូសបានស្គាល់ដោយផ្ទាល់ពីចរិតលក្ខណៈរបស់គាត់ –

បន្ទាល់របស់បញ្ញាចិត្ត[ផ] យើងខ្ញុំ ដែលសំដែងថា យើងខ្ញុំបាន
ប្រព្រឹត្តក្នុងលោកីយនេះ ហើយដល់អ្នករាល់គ្នាលើសទៅ
ទៀត ដោយសេចក្តីបរិសុទ្ធ[ព] និងសេចក្តីស្មោះត្រង់[ភ]របស់
ព្រះ មិនមែនដោយប្រាជ្ញាខាងសាច់ឈាមឡើយ [ម]គឺដោយ
ព្រះគុណនៃព្រះវិញ ១៣ យើងខ្ញុំមិនសរសេរសេចក្តីណា
ផ្សេងទៀត ផ្ញើមកអ្នករាល់គ្នា ក្រៅពីសេចក្តីដែលបាន
អានមើល និងយល់ព្រមហើយនោះទេ ហើយខ្ញុំសង្ឃឹមថា
អ្នករាល់គ្នានឹកយល់ព្រមតាមសេចក្តីនោះឯង ដរាបដល់
ចុងបំផុតដែរ ១៤ ដូចជាអ្នករាល់គ្នាខ្លះបានយល់ព្រមហើយ
ថា យើងខ្ញុំជាទីអំនួតរបស់អ្នករាល់គ្នា ដូចជាអ្នករាល់
គ្នាក៏ជាទីអំនួតរបស់យើងខ្ញុំដែរ នៅថ្ងៃនៃព្រះអម្ចាស់
យេស៊ូវ[យ]។

១៥ ដោយព្រោះខ្ញុំមានសេចក្តីសង្ឃឹមនោះ បានជាខ្ញុំគិត
នឹងមកឯអ្នករាល់គ្នាពីកាលមុន[រ] ដើម្បីឱ្យអ្នករាល់គ្នាបាន
ទទួលព្រះគុណមួយលើកទៀត[ល] ១៦ ហើយឱ្យខ្ញុំបានហួសទៅ
ឯស្រុកម៉ាសេដូន[វ] ដោយសារអ្នករាល់គ្នា រួចសឹមត្រឡប់មក
ឯអ្នករាល់គ្នាវិញ[ស] ដើម្បីឱ្យអ្នករាល់គ្នាបានជួយដំណើរខ្ញុំ[ហ]
ទៅឯស្រុកយូដាផង[ឡ] ១៧ ដូច្នេះ ដែលខ្ញុំសំរេចធ្វើយ៉ាងនោះ
តើខ្ញុំបានប្រព្រឹត្តដោយចិត្តសាវ៉ាឬអី ឬការដែលខ្ញុំសំរេច
នឹងធ្វើ តើបានសំរេចតាមសាច់ឈាម[អ] បានជាជួនកាល
ខ្ញុំថា «បាទ» ជួនកាលថា«ទេ» វិញឬអី ១៨ រីឯព្រះទ្រង់
ស្មោះត្រង់[ក] បានជាពាក្យសំដីដែលយើងខ្ញុំនិយាយនឹងអ្នក
រាល់គ្នា នោះមិនមែនថា «បាទ»ផង «ទេ» ផងឡើយ
១៩ ដ្បិតព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ[ខ] ដែល
យើងខ្ញុំ គឺខ្លួនខ្ញុំ ស៊ីលវ៉ាន[គ] នឹងធីម៉ូថេ[ឃ] បានប្រកាស
ប្រាប់ក្នុងពួកអ្នករាល់គ្នា ទ្រង់មិនមែនជា «បាទ»ផង «ទេ»
ផងនោះទេ គឺមានតែ[ង] «បាទ» សុទ្ធនៅក្នុងទ្រង់ប៉ុណ្ណោះ
២០ ដ្បិតទោះបើមានសេចក្តីសន្យារបស់ព្រះយ៉ាងណាក៏
ដោយ[ច] ក៏នៅសុទ្ធតែជា «បាទ»ក្នុងទ្រង់ហើយ «អាម៉ែន»[ឆ]
ក្នុងទ្រង់ដែរ សំរាប់នឹងចំរើនសិរីល្អដល់ព្រះ[ជ] ដោយសារ
យើងរាល់គ្នា ២១ រីឯអ្នកដែលតាំងយើងខ្ញុំ ឱ្យខ្ជាប់ខ្ជួនក្នុង
ព្រះគ្រីស្ទ[ឈ] ជាមួយនឹងអ្នករាល់គ្នា ហើយដែលចាក់ប្រេង[ញ]
ឱ្យយើង នោះគឺជាព្រះ ២២ ទ្រង់ក៏បានដៅចំណាំយើងរាល់
គ្នា[ដ] ហើយបានប្រទានព្រះវិញ្ញាណ មកបញ្ចាំចិត្តយើងរាល់
គ្នាផង[ឋ]។

**១:១២** ផ កច ២៣:១ ព ១ថន ២:១០ ភ ២កថ ២:១៧ ម ១កថ ១:១៧ ២:១,៤,១៣
**១:១៤** យ ១កថ ១:៨
**១:១៥** រ ១កថ ៤:១៩ ល រម ១:១១,១៣ ១៥:២៩
**១:១៦** វ ១កថ ១៦:៥-៧ ស កច ១៦:៩ ហ ១កថ ១៦:១១ ៣យហ ៦ ឡ កច ១៩:២១
**១:១៧** អ ២កថ ១០:២,៣ ១១:១៨
**១:១៨** ក ១កថ ១:៩
**១:១៩** ខ មថ ៤:៣ គ កច ១៥:២២ ឃ កច ១៦:១ ង ហព ១៣:៨
**១:២០** ច រម ១៥:៨ ឆ ១កថ ១៤:១៦ ជ រម ១៥:៩
**១:២១** ឈ ១កថ ១៦:១៣ ញ ១យហ ២:២០,២៧
**១:២២** ដ លប ៣៨:១៨ អគ ៩:៤ ហក ២:២៣ ឋ ២កថ ៥:៥

ដើម្បីទប់ទល់នឹងការនិយាយបង្ខូចភាពស្មោះត្រង់របស់គាត់ ។ គាត់បានចំណាយពេលនៅជាមួយនឹងពួកគេអស់រយៈ១៨ខែ នៅពេលដែលគាត់មកឯក្រុងកូរិនថូសជាលើកទីមួយ (កច ១៨:១១) ដូចនេះពួកគេប្រាកដជាដឹងថាគាត់ជាមនុស្សស្មោះត្រង់យ៉ាងណាហើយ ។

**១:១៤** *ថ្ងៃនៃព្រះអម្ចាស់យេស៊ូវ* គឺជាពេលដែលទ្រង់យាងត្រឡប់មកវិញ (សូមធៀបនឹង ១ថន ២:១៩-២០) ។

**១:១៥** *ដើម្បីឱ្យអ្នករាល់គ្នាបានទទួលព្រះគុណមួយលើកទៀត* ក្នុងខ.១៥ និង ខ.១៦ លោកប៉ុលនិយាយសំដៅទៅលើការកែប្រែគម្រោងធ្វើដំណើររបស់គាត់ ។ ដំបូង គាត់មានគម្រោងធ្វើដំណើតាមសមុទ្រពីក្រុងអេភេសូរទៅក្រុងកូរិនថូស ដោយសួរសុខទុក្ខពួកក្រុងកូរិនថូស មុននឹងបន្តដំណើរទៅស្រុកម៉ាសេដូនដែលនៅទិសខាងជើង ហើយត្រឡប់ពីស្រុកម៉ាសេដូន មកសួរសុខទុក្ខពួកក្រុងកូរិនថូសម្តងទៀត ដូចនេះគាត់ផ្តល់ឱ្យពួកគេនូវផលចំណេញពីការមកសួរសុខទុក្ខរយៈពេលខ្លីចំនួនពីរលើក ។ ផលចំណេញនោះកើតមាន នៅពេលដែលគាត់មានការប្រកបស្និទ្ធស្នាលជាមួយនឹងពួកគេ ។ គាត់ធ្វើដំណើរមកសួរសុខទុក្ខរយៈពេលខ្លី ពីក្រុងអេភេសូរតែម្តង ជាដំណើរដែលគ្មានការគិតទុកមុនឱ្យបានហ្មត់ចត់ ហើយបណ្តាលឱ្យមាន "ចិត្តព្រួយ" (២:១ និងការពន្យល់) ។ ការធ្វើដំណើរមកសួរសុខ ទុក្ខនេះគឺជាមូលហេតុនៃការសរសេរសំបុត្រ ដែលនាំឱ្យពួកគេកើតទុក្ខព្រួយ (៧:៨-៩ និងការពន្យល់) ។

**១:១៦** *ស្រុកម៉ាសេដូន* មើលការពន្យល់ ខ.១ ភល ៤:១៥ ។

**១:១៧** ពួកអ្នកដែលប្រឆាំងនឹងលោកប៉ុលនៅក្រុងកូរិនថូស បានប៉ុនប៉ងបញ្ចុះបញ្ចូលគ្រីស្ទបរិស័ទនៅក្រុងនោះថា ការដែលលោកប៉ុលកែប្រែគម្រោងនោះគឺជាភស្តុតាងបញ្ជាក់ថា ពាក្យសំដីរបស់លោកប៉ុលមិនត្រូវជឿឡើយ ហើយគាត់ជាមនុស្សដែលសាវ៉ា និងទុកចិត្តមិនបានទេ ។ ក្នុងខនេះ លោកប៉ុលសួរសំណួរទាំងពីរក្នុងន័យបដិសេធន៍ថា គាត់មិនមែនធ្វើដោយគ្មានការពិចារណាឡើយ ហើយក៏មិនមែននិយាយជួនកាលថា "បាទ" ជួនកាលថា "ទេ" ដែលធ្វើឱ្យគេមិនអាចយល់ពីគាត់បាននោះដែរ ។ ជាងនេះទៅទៀត គាត់មិនបានលុបចោលគម្រោងទៅសួរ សុខទុក្ខអ្នកក្រុងកូរិនថូសទេ គឺគ្រាន់តែមានការកែប្រែបន្តិចបន្តួចប៉ុណ្ណោះ ។

**១:១៨-១៩** *មិនមែនជា «បាទ» ផង «ទេ» ផង* ក្នុងខនេះសាវកប៉ុលបានលើកឡើងពីសេចក្តីពិតនៃដំណឹងល្អដែលគាត់បានផ្សាយទៅពួកគេ ។ បើពួកគេជឿលើដំណឹងល្អ ពួកគេនឹងឃើញថាដំណឹងល្អគឺជាដំណឹងពីសេចក្តីពិតហើយគ្មានភាពច្របូកច្របល់ឡើយ ហើយការពិសោធន៍របស់ពួកគេជាមួយនឹងអំណាចនៃដំណឹងល្អនាំ ឱ្យពួកគេដឹងច្បាស់ថាទ្រង់គឺជា "បាទ" សុទ្ធនៅក្នុងទ្រង់ ។

**១:១៩** *ប្រកាសប្រាប់ក្នុងពួកអ្នករាល់គ្នា* គឺក្នុងរយៈពេលដែលលោកប៉ុលមកសួរសុខទុក្ខពួកក្រុងកូរិនថូសលើកទីមួយ (កច ១៨:៥) ។ *ស៊ីលវ៉ាន* មើល កច ១៥:២២ និងការពន្យល់ ។

**១:២០** *អាម៉ែន* ពួកជំនុំប្រើពាក្យនេះនៅពេលបញ្ចប់ការអធិស្ឋាន ឬការសរសើរតម្កើង (សូមធៀបនឹង ១កថ ១៤:១៦ និងពន្យល់ ១៤:១៥-១៧) ។

**១:២១** *ចាក់ប្រេងឱ្យយើង* មើល នក ២៩:៧ និងការពន្យល់ ១សយ ១៦:១៣ អស ៦១:១ ។

**១:២២** *ដៅចំណាំ* មើលការពន្យល់ ហក ២:២៣ អភ ១:១៣ សូមធៀបនឹង អភ ៤:៣០ ។ *បញ្ចាំចិត្ត* ការដែលឱ្យតែមួយភាគសិន គឺដូចជាការធានាថា

២៣ ខ្ញុំសូមយកព្រះធ្វើជាសាក្សី[ឌ] ពីចិត្តខ្ញុំថា ដែលខ្ញុំមិន
ទាន់មកឯក្រុងកូរិនថូស នោះគឺដោយប្រណីដល់អ្នករាល់
គ្នា[ឍ]ទេ ២៤ មិនមែនថា យើងខ្ញុំធ្វើជាម្ចាស់លើ[ណ]សេចក្ដីជំនឿ
របស់អ្នករាល់គ្នាទេ គឺធ្វើជាគូកន ជួយឱ្យអ្នករាល់គ្នាបាន
សេចក្ដីអំណរវិញ ដ្បិតអ្នករាល់គ្នាកំពុងឈរហើយ[ត] ដោយ
សារសេចក្ដីជំនឿ ។

**២** ១ តែខ្ញុំបានគិតសំរេចសេចក្ដីនេះក្នុងខ្លួនខ្ញុំ គឺថា ខ្ញុំមិន
មកឯអ្នករាល់គ្នា ដោយចិត្តព្រួយទៀតទេ[ថ] ២ ដ្បិតបើសិនជា
ខ្ញុំធ្វើ ឱ្យអ្នករាល់គ្នាព្រួយទៅហើយ[ទ] នោះតើមានអ្នកណា
នឹង ធ្វើឱ្យខ្ញុំសប្បាយបាន លើកតែអ្នកនោះឯងដែលព្រួយ
ដោយសារខ្ញុំប៉ុណ្ណោះ ៣ ហើយខ្ញុំបានសរសេរសេចក្ដីនោះ
ផ្ញើមកអ្នករាល់គ្នា[ធ] ក្រែងកាលណាខ្ញុំមកដល់ នោះខ្ញុំនឹង
កើតព្រួយចិត្ត[ន]ពីដំណើរអ្នកខ្លះ ដែលមុខគួរឱ្យខ្ញុំបានអរ
សប្បាយដោយសារគេវិញ ដោយទុកចិត្ត[ប]នឹងអ្នករាល់គ្នា
ទាំងអស់ថា ការអ្វីដែលនាំឱ្យខ្ញុំរីករាយ នោះក៏នាំឱ្យអ្នក
រាល់គ្នារីករាយដែរ ៤ ដ្បិតខ្ញុំបានសរសេរផ្ញើមកអ្នករាល់
គ្នា[ផ] ដោយខ្ញុំមានចិត្តលំបាក ហើយថប់ព្រួយ ព្រមទាំងស្រក់
ទឹកភ្នែកជាច្រើន មិនមែនចង់ឱ្យអ្នករាល់គ្នាព្រួយដែរនោះ
ទេ គឺចង់ឱ្យអ្នករាល់គ្នាស្គាល់សេចក្ដីស្រឡាញ់ ដែលខ្ញុំមាន
ជាបរិបូរដល់អ្នករាល់គ្នាប៉ុណ្ណោះឯង ។

## ការអត់ទោសបាប

៥ ប៉ុន្តែ បើមានអ្នកណាបានបណ្ដាលឱ្យកើតមានសេចក្ដី
ព្រួយ[ព] នោះមិនមែនធ្វើឱ្យខ្ញុំព្រួយទេ គឺឱ្យអ្នករាល់គ្នាទាំង
អស់មានទុក្ខខ្លះវិញ ដ្បិតខ្ញុំមិនចង់និយាយពន្លើសឡើយ ៦ ឯ
ទោស[ភ]ដែលច្រើនគ្នាបានធ្វើដល់មនុស្សយ៉ាងនោះ នោះ
ល្មមប៉ុណ្ណឹងហើយ ៧ បានជាស៊ូឱ្យអត់ទោស ហើយកំសាន្ត
ចិត្តមនុស្សនោះវិញ[ម] ក្រែងមនុស្សនោះត្រូវស្រូបបាត់ ដោយ
កើតទុក្ខព្រួយកាន់តែខ្លាំងឡើង ៨ ហេតុនោះបានជាខ្ញុំទូន្មាន
ឱ្យអ្នករាល់គ្នាសំដែងសេចក្ដីស្រឡាញ់ ដល់អ្នកនោះឱ្យជាក់
លាក់ ៩ ដ្បិតដោយហេតុនោះបានជាខ្ញុំធ្វើសំបុត្រនេះដែរ[យ]
គឺដើម្បីនឹងលមើលអ្នករាល់គ្នាឱ្យដឹង តើនឹងស្ដាប់បង្គាប់
ក្នុងគ្រប់ការទាំងអស់ឬទេ[រ] ១០ បើអ្នករាល់គ្នាអត់ទោសដល់
អ្នកណាពីរឿងអ្វី នោះខ្ញុំក៏អត់ទោសដែរ ហើយរឿងអ្វី
ដែលខ្ញុំបានអត់ទោសឱ្យគេ បើសិនជាបានអត់ទោសអ្វីមែន
នោះគឺដោយព្រោះអ្នករាល់គ្នា នៅចំពោះព្រះគ្រីស្ទហើយ
១១ ដើម្បីមិនឱ្យអារក្សសាតាំង[ល]មានឱកាសនឹងឈ្នះយើងបាន
ឡើយ ដ្បិតយើងស្គាល់អស់ទាំងកិច្ចកលរបស់វាហើយ[វ] ។

## អ្នកបម្រើនៃសញ្ញាថ្មី

១២ កាលខ្ញុំបានទៅដល់ក្រុងទ្រអាស[ស] ដើម្បីនឹងផ្សាយ

**១:២៣** ឌ រម ១:៩ ឍ ១កថ ៤:២១ ២កថ ២:១,៣ ១៣:២,១០
**១:២៤** ណ ១ពត ៥:៣ ត រម ១១:២០ ១កថ ១៥:១
**២:១** ថ ២កថ ១:២៣
**២:២** ទ ២កថ ៧:៨
**២:៣** ធ ខ.៤,៩ ២កថ ៧:៨,១២ ន ២កថ ១២:២១ ប ២កថ ៧:១៦ ៨:២២ កទ ៥:១០ ២ថន ៣:៤ ភម ២១
**២:៤** ផ ខ.៣,៩ ២កថ ៧:៨,១២
**២:៥** ព ១កថ ៥:១,២
**២:៦** ភ ១កថ ៥:៤,៥ ២កថ ៧:១១
**២:៧** ម កទ ៦:១ អភ ៤:៣២ កល ៣:១៣
**២:៩** យ ខ.៣,៤ ២កថ ៧:៨,១២ រ ២កថ ៧:១៥ ១០:៦
**២:១១** ល មថ ៤:១០ វ លក ២២:៣១ ២កថ ៤:៤ ១ពត ៥:៨,៩
**២:១២** ស កច ១៦:៨

---

នឹងបានទទួលទាំងស្រុង(រម ៨:២៣ និងការពន្យល់)។

**១:២៣** *ប្រណីដល់អ្នករាល់គ្នា* ការដែលលោកប៉ុលផ្លាស់ប្ដូរគម្រោងមកសួរសុខទុក្ខគ្រីស្ទបរិស័ទនៅក្រុងកូរិនថូស គឺមិនមែនបណ្ដាលមកពីគាត់មានចិត្តសាវ៉ា និងមិនខ្វល់ពីអារម្មណ៍របស់ពួកគេឡើយ ប៉ុន្តែមកពីគាត់មានសេចក្ដីស្រលាញ់ និងការខ្វល់ខ្វាយពីពួកគេ ។

**២:១** *មកឯអ្នករាល់គ្នា ដោយចិត្តព្រួយ* លោកប៉ុលធ្លាប់បានមកសួរសុខទុក្ខពួកក្រុងកូរិនថូស ដោយចិត្តព្រួយម្ដងរួចទៅហើយ ដូចនេះគាត់ចង់ជៀសវាងការធ្វើដូចនោះទៀត ទោះបីជាគាត់មានសិទ្ធិអំណាចជាទូតព្រះគ្រីស្ទក៏ដោយ(សូមផ្ទៀបនឹង ១៣:២)។ ការមកសួរសុខទុក្ខលើកមុននោះ មិនអាចនៅពេលដែលពួកជំនុំនៅទីនោះត្រូវបានបង្កើតឡើង បន្ទាប់ពីមានការផ្សាយដំណឹងល្អនោះឡើយ (កច ១៨)។ តាម ១២:១៤ និង ១៣:១ គាត់ប្រាកដជាបានមកសួរសុខទុក្ខជាលើក ទីពីរ ហើយពីព្រោះគាត់បាននិយាថាគាត់រៀបនឹងមកឯពួកគេរាល់គ្នាជាគម្រប់ ៣ លើក ។ គេជឿថាការមកសួរសុខទុក្ខលើកទីពីរគឺបានធ្វើនៅចន្លោះពេលនៃការសរសេរសំបុត្រ ១កូរិនថូស និង២កូរិនថូស ដែលទោះបីជាអ្នកខ្លះជឿថា បានធ្វើនៅមុនការសរសេរសំបុត្រ ១កូរិនថូសក៏ដោយ ។

**២:៣–៤** មើលសេចក្ដីផ្ដើមត្រង់ឱកាស ។

**២:៥–១១** វគ្គនេះនិយាយចំពោះអ្នកដែលបានបង្ករឱ្យមានសេចក្ដីទុក្ខព្រួយនៅក្នុងពួកជំនុំកូរិនថូស និងចំពោះអ្នកដែលពួកជំនុំកូរិនថូសធ្វើទោស ។ លោកប៉ុលបានទូន្មានដល់ពួកជំនុំកូរិនថូសថា អ្នកប្រព្រឹត្តនោះពិតជាបានបង្ហាញពីការសោកស្ដាយ និងបានលន់តួបាបហើយ ដូចនេះត្រូវឈប់ធ្វើទោសគាត់ ហើយគួរតែឱ្យគាត់មានការប្រកបជាមួយពួកគេឡើងវិញ ។ គេជឿថា អ្នកនោះបានប្រព្រឹត្តខុស ក្នុងអំឡុងពេលដែលលោកប៉ុលមកសួរសុខទុក្ខពួកជំនុំក្រុងកូរិនថូស នៅលើកទីពីរ (មើលការពន្យល់ ខ.១) ហើយការនេះប្រហែលជាបាននាំឱ្យគាត់សរសេរ សំបុត្រឱ្យធ្វើទោសដល់អ្នកដែលប្រព្រឹត្តខុសនោះ(មើលការពន្យល់ ខ.៣–៤)។ មានការកាត់ស្រាយមួយទៀតថា លោកប៉ុលនិយាយសំដៅទៅលើរឿងរ៉ាវ ដែលមាននៅក្នុង ១កថ ៥ ។

**២:៧** *កំសាន្តចិត្ត* មើល ១:៣–៧ និងការពន្យល់ ១:៣ ។

**២:១១** *អារក្សសាតាំង* មើល មថ ១៦:២៣ និង ១យហ ៣:៨ និងការពន្យល់ *កិច្ចកល* លប ៣:១ លក ២២:៣១ យហ ៨:៤៤ និងការពន្យល់ ១ពត ៥:៨

**២:១២** *ក្រុងទ្រអាស* សាវ័កប៉ុលបានធ្វើដំណើរពីអេភេសូរទៅក្រុងទ្រអាសជាក្រុងដែលស្ថិតនៅលើឆ្នេរអ៊ីជៀន(Aegean) (កច ១៦:៨ និងការពន្យល់) ដោយសង្ឃឹមថានឹងបានជួបលោកទីតុសនៅទីនោះ ហើយទទួលដំណឹងរបស់ពួកជំនុំកូរិនថូសពីគាត់ផង ។ គេសន្និដ្ឋានថា លោកប៉ុលបានដឹងថា លោកទីតុសនឹងធ្វើដំណើរត្រឡប់មកវិញតាមផ្លូវដូចគ្នា ហើយលោកទីតុសមិនបញ្ចប់ដំណើររបស់គាត់នៅក្រុងត្រូអាសទេ ដូចនេះ ដោយសារលោកប៉ុលចង់ដឹងពីដំណឹងរបស់ពួកជំនុំកូរិនថូសខ្លាំងណាស់ គាត់ក៏បានបន្តដំណើរទៅប្រទេសម៉ាសេដូន(ខ.១៣) គឺប្រហែលទៅក្រុងភីលីពតែម្ដង ។ *ទ្វារបើក* មើល កច ១៤:២៧ វវ ៣:៨ និង ការពន្យល់ និងមើល

ដំណឹងល្អពីព្រះគ្រីស្ទ[ហ] ហើយមានទ្វារ[ឡ]បើកឱ្យខ្ញុំ ដោយនូវ
ព្រះអម្ចាស់ ១៣ នោះខ្ញុំឥតមានធូរក្នុងចិត្តសោះ[អ] ដោយហេតុ
រកទីតុស[ក]ជាបងប្អូនខ្ញុំមិនឃើញ បានជាខ្ញុំលាគេទៅឯ
ស្រុកម៉ាសេដូនវិញ[ខ] ១៤ តែអរព្រះគុណដល់ព្រះអង្គ[គ]
ដែលទ្រង់ចេះតែនាំយើងខ្ញុំ ឱ្យមានជ័យជំនះក្នុងព្រះគ្រីស្ទ
ហើយក៏ផ្សាយក្លិន[ឃ] ពី ដំណើរដែលយើងខ្ញុំស្គាល់[ង]ព្រះ
ឱ្យបានសុសសាយទូទៅគ្រប់កន្លែងផង ១៥ ដ្បិតយើងខ្ញុំជា
ក្លិនក្រអូប[ច]នៃព្រះគ្រីស្ទដល់ព្រះ នៅក្នុងពួកមនុស្សដែល
កំពុងតែបានសង្គ្រោះ ហើយក្នុងពួកអ្នកដែលកំពុងតែវិ
នាសទៅដែរ[ឆ] ១៦ ដល់ពួក១ជាក្លិននៃសេចក្ដីស្លាប់[ជ] ឱ្យ
ត្រូវស្លាប់ដល់ពួក១ទៀត ជាក្លិននៃជីវិត ឱ្យបានរស់នៅ
តើអ្នកណាគួរនឹងសេចក្ដីទាំងនេះ[ឈ] ១៧ ដ្បិតយើងខ្ញុំមិនមែន
ដូចជាមនុស្សច្រើនគ្នា ដែលបំប្លែងព្រះបន្ទូលនោះទេ[ញ] គឺ
ដូចជាអ្នកស្មោះត្រង់[ដ] ដែលមកពីព្រះវិញ[ឋ] ហើយយើង
និយាយចំពោះព្រះដោយនូវ ព្រះគ្រីស្ទ ។

**៣** ១ ដូច្នេះ តើយើងចាប់តាំងផ្ទុកផ្ដាក់ខ្លួនយើងខ្ញុំម្ដងទៀត
ឬអី[ឌ] តើយើងខ្ញុំត្រូវការនឹងសំបុត្រផ្ទុកផ្ដាក់ខ្លួនយើងនឹងអ្នក
រាល់គ្នា ឬត្រូវការនឹងអ្នករាល់គ្នាឱ្យសំបុត្រផ្ទុកផ្ដាក់[ឍ]យើង
នឹងគេ ដូចជាអ្នកខ្លះត្រូវការឬអី ២ គឺអ្នករាល់គ្នាជាសំបុត្រ
របស់យើងខ្ញុំហើយ ទាំងកត់ទុកក្នុងចិត្តយើងខ្ញុំផងដែល
មនុស្សទាំងអស់ក៏ដឹង ហើយអានមើលដែរ[ណ] ៣ ដោយបាន
សំដែងមកច្បាស់ថា អ្នករាល់គ្នាជាសំបុត្ររបស់ព្រះគ្រីស្ទ
ដែលយើងខ្ញុំបានតែងទុក ដោយការងារយើងខ្ញុំ មិនមែន
សរសេរនឹងទឹកខ្មៅទេ គឺនឹងព្រះវិញ្ញាណនៃព្រះដ៏មាន
ព្រះជន្មរស់[ត] ក៏មិនមែនលើបន្ទះថ្មដែរ[ថ] គឺក្នុងចិត្តខាងសាច់

**២:១២** ហ រម ១:១ ២កថ ៤:៣,៤ ៨:១៨ ៩:១៣ ១ថន ៣:២ ឡ កច ១៤:២៧
**២:១៣** អ ២កថ ៧:៥ ក ២កថ ៧:៦,១៣ ៨:៦,១៦,២៣ ១២:១៨ កទ ២:១,៣ ទត ១:៤ ខ កច ១៦:៩
**២:១៤** គ រម ៦:១៧ ៧:២៥ ១កថ ១៥:៥៧ ២កថ ៩:១៥ ឃ អគ ២០:៤១ អភ ៥:២ ភល ៤:១៨ ង ២កថ ៨:៧
**២:១៥** ច ខ.១៤ លប ៨:២១ នក ២៩:១៨ ជន ១៥:៣ ឆ ១កថ ១:១៨
**២:១៦** ជ លក ២:៣៤ យហ ៣:៣៦ ឈ ២កថ ៣:៥,៦
**២:១៧** ញ កច ២០:៣៣ ២កថ ៤:២ ១ថន ២:៥ ដ ១កថ ៥:៨ ឋ ២កថ ១:១២ ១២:១៩ **៣:១** ឌ រម ១៦:១ ២កថ ៥:១២ ១០:១២,១៨ ១២:១១ ឍ កច ១៨:២៧ រម ១៦:១ ១កថ ១៦:៣ **៣:២** ណ ១កថ ៩:២
**៣:៣** ត មថ ១៦:១៦ ថ ខ.៧ នក ២៤:១២ ៣១:១៨ ៣២:១៥,១៦

១កថ ១៦:៩ កល ៤:៣ ។

**២:១៣** *បងប្អូនខ្ញុំ* សូមផ្ទៀបនឹង ៨:២៣ ។ *ទីតុស* សូមមើលសេចក្ដីផ្ដើមព្រះគម្ពីរទីតុសត្រង់អ្នកទទួល ។ លោកប៉ុលមានការជឿជាក់លើលោកទីតុសយ៉ាងខ្លាំង ហើយបានផ្ទុកផ្ដាក់ឱ្យគាត់ចាត់ចែងការប្រមូលប្រាក់ជំនួយនៅក្រុងកូរិនថូស ដើម្បីជួយដល់គ្រីស្ទបរិស័ទក្រីក្រនៅទីក្រុងយេរូសាឡិម (៨:៦ និងការពន្យល់) ហើយបានជ្រើសរើសគាត់ឱ្យយកសំបុត្រនេះទៅទីក្រុងកូរិនថូស(៨:១៦–១៧ និង ការពន្យល់ ៨:១៦)។

**២:១៤** មកដល់ខនេះ លោកប៉ុលបានស្លេះការនិយាយអំពីការធ្វើដំណើររបស់គាត់(គាត់និយាយបន្តអំពីការធ្វើដំណើរនៅ ៧:៥ សូមមើលការពន្យល់ខនេះ) ការស្លេះ ហើយនិយាយពីសេចក្ដីមួយទៀតយ៉ាងដូចនេះគឺមានសារសំខាន់ចំពោះខ្លឹមសារទូទៅរបស់សំបុត្រ ព្រោះជាការបង្ហាញពីសេចក្ដីជំនឿដែលប្រកបដោយជ័យជម្នះ និងអំណរជាសេចក្ដីជំនឿដោយសរសើរដល់ព្រះ ដែលទ្រង់មានព្រះគុណដែលល្មមសម្រាប់គ្រប់ស្ថានភាពទាំងអស់ ។ *ចេះតែនាំយើងខ្ញុំ ឱ្យមាន ជ័យជំនះក្នុងព្រះគ្រីស្ទ* មេទ័ពរូម៉ាំងដែលបានទទួលជ័យជម្នះក្នុងសឹកសង្គ្រាម គាត់ដឹកនាំទ័ព និងដឹកឈ្លើយសឹកទីសមរភូមិមកយ៉ាងសប្បាយអឺកធឹក ចំណែកឯប្រជាជនវិញ ពួកគេនាំគ្នាមើលហើយអបអរសាទរ ហើយខ្យល់នៅពេលនោះក៏ ត្រូវពោរពេញទៅដោយក្លិនក្រអូបឈ្ងុយឈ្ងប់ ជាក្លិនភាយចេញពីការដុតគ្រឿង ក្រអូបនៅតាមដងផ្លូវ(សូមផ្ទៀបនឹងការពន្យល់ ១កថ ៤:៩)។ *គ្រប់កន្លែងផង* សូមផ្ទៀបនឹងការពន្យល់ ១ថន ១:៨ ។

**២:១៦** *ក្លិននៃសេចក្ដីស្លាប់...ក្លិននៃជីវិត* ក្លិននៃដំណឹងល្អដែលបានសាយភាយក្នុងលោកីយតាមរយៈការធ្វើបន្ទាល់របស់គ្រីស្ទបរិស័ទ គឺក្លិនក្រអូបដែលធ្វើឱ្យស្អប់ដល់ចិត្ត ទោះបីជាក្លិននេះប្រហែលជាត្រូវបានទទួលតាមរបៀបផ្សេងៗពីគ្នាក៏ដោយ ។ មានពួកមនុស្សពីរប្រភេទគឺ "ពួកអ្នកដែលកំពុងតែបានសង្គ្រោះ និងពួកអ្នកដែលកំពុងវិនាស"(ខ.១៥)។ គ្រីស្ទបរិស័ទដែលធ្វើបន្ទាល់គឺជាក្លិននៃសេចក្ដីស្លាប់ មិនមែនដោយសារដំណឹងល្អត្រឡប់ជាមានក្លិនអាក្រក់ ឬជាជំនួញនៃសេចក្ដីស្លាប់នោះឡើយ ពីព្រោះតែអ្នកមិនជឿព្រះជ្រើសរើសយកសេចក្ដីស្លាប់ដោយខ្លួនឯង ដោយបដិសេធព្រះគុណដែលផ្ដល់ជីវិត ។ តែគ្រីស្ទបរិស័ទគឺជាក្លិននៃជីវិតដល់អ្នកដែលទទួលដំណឹងល្អនៃព្រះគុណរបស់ព្រះ ។ *តើអ្នកណាគួរនឹងសេចក្ដីទាំងនេះ?* សូមមើលក្នុង ៣:៤–៥ ។

**២:១៧** *បំប្លែងព្រះបន្ទូល* សាវ័កប៉ុលកំពុងនិយាយសំដៅទៅលើពួកគ្រូខុសឆ្គង ដែលជ្រាបចូលទៅក្នុងពួកជំនុំកូរិនថូស ។ ពួកនោះជាប្រភេទមនុស្សដែលមិនស្មោះត្រង់ អាត្មានិយម ហើយមានអំនួត ។ ពួកគេពូកែបញ្ចុះបញ្ចូល ហើយគោលបំណងសំខាន់បំផុតរបស់ពួកគេគឺបោកប្រាស់សមាជិកពួកជំនុំយកប្រាក់ (សូមផ្ទៀប មីក ៣:៥,១១)គឺផ្ទុយពីសាវ័កប៉ុល ដែលផ្សាយដំណឹងល្អយ៉ាងស្មោះត្រង់ ហើយរកចាប់កំហុសគាត់ពុំបានឡើយ ម្យ៉ាងទៀតគាត់មិនធ្វើជាបន្ទុកខាង ហិរញ្ញវត្ថុដល់អ្នកជឿនៅក្រុងកូរិនថូសឡើយ(១១:៧–៩ ១កថ ៩:១១–១៥ និងការពន្យល់)។

**៣:១** *តើយើងចាប់តាំងផ្ទុកផ្ដាក់ខ្លួនយើងខ្ញុំម្ដងទៀតឬអី?* សាវ័កប៉ុលដឹងថាអ្វីៗ ដែលគាត់សរសេរឬនិយាយស្ទើរតែទាំងអស់ ទំនងជាត្រូវបានបង្ខូចដោយពួកគ្រូបង្រៀនខុសឆ្គងនៅក្រុងកូរិនថូស ។ *សំបុត្រផ្ទុកផ្ដាក់* គឺជាសំបុត្របញ្ជាក់ដែល ចាំបាច់ត្រូវមានដើម្បីឆ្លើយតបចំពោះបញ្ហាពួកខុសឆ្គងទាំងនោះ ។ សាវ័កប៉ុលមិនត្រូវការនឹងសំបុត្របញ្ជាក់ទេ ប៉ុន្តែពួកខុសឆ្គងទាំងនោះពិតជាត្រូវការការបញ្ជាក់ខ្លាំងណាស់ ហើយច្រើនតែប្រើល្បិចដើម្បីឱ្យបានការបញ្ជាក់នោះ ឬក្លែងបន្លំការបញ្ជាក់តែម្ដង ។

**៣:២** *ដឹងហើយអានមើលដែរ* គឺដោយសារអំណាចនៃដំណឹងល្អដែលបង្ហាញចេញមកតាមរយៈជីវិតផ្លាស់ប្រែរបស់ពួកគេ ។

**៣:៣** *សំបុត្ររបស់ព្រះគ្រីស្ទ* សាវ័កប៉ុលគឺដូចជាឧបករណ៍ ដែលនៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ។ *មិនមែនសរសេរនឹងទឹកខ្មៅ* នៅក្នុងសម័យនោះការសរសេរនឹងទឹកខ្មៅនៅលើសន្លឹកស្បែក(ចៀម ឬពពែ) ឬក្រដាសដែលធ្វើពីដើមប៉ាពីរីស (Papyrus)គឺងាយនឹងហើរពណ៌រលប់ និងខូចទ្រង់ទ្រាយតួអក្សរណាស់ ។ *នឹងព្រះវិញ្ញាណនៃព្រះដ៏មានព្រះជន្មរស់* ព្រះវិញ្ញាណទ្រង់ជាជីវិត ហើយដោយយ៉ាងនោះទ្រង់ប្រទានឱ្យមានជីវិត(ខ.៦)

ឈាមវិញ[ទ] ៤ហើយយើងមានសេចក្តីសង្ឃឹមយ៉ាងនោះ[ធ]
ដល់ព្រះ ដោយសារព្រះគ្រីស្ទ ៥មិនមែនថា យើងខ្ញុំពូកែ
ល្មមដោយខ្លួនឯង[ន] នឹងគិតស្មានថា មានអ្វីកើតពីខ្លួន
យើងខ្ញុំនោះឡើយ តែដែលយើងខ្ញុំពូកែ នោះមកតែពី
ព្រះទេ[ប] ៦ដែលទ្រង់បានប្រោស ឱ្យយើងខ្ញុំអាចនឹងធ្វើ
ជាអ្នកបំរើនៃសញ្ញាថ្មី[ផ]បាន មិនមែនតាមតែន័យពាក្យ
ប៉ុណ្ណោះទេ[ព] គឺតាមព្រះវិញ្ញាណវិញ ដ្បិតន័យពាក្យ នោះ
ធ្វើឱ្យស្លាប់ តែព្រះវិញ្ញាណ ទ្រង់ប្រទានឱ្យមានជីវិតវិញ[ភ]។

## សិរីល្អនៃសញ្ញាថ្មី

៧ហើយបើការងារខាងឯសេចក្តីស្លាប់[ម] ដែលបានឆ្លាក់
ជាអក្សរលើថ្ម បានកើតមកក្នុងសិរីល្អ ដល់ម្ល៉េះបានជាជន
ជាតិអ៊ីស្រាអែល មិនអាចនឹងសំឡឹងមើលមុខលោកម៉ូសេ
បានទេ ដោយព្រោះសិរីល្អ[យ]នៃមុខលោក គឺជាសេចក្តី
ដែលកំពុងតែសូន្យបាត់ទៅ ៨នោះចំណង់បើការងារខាង
ឯព្រះវិញ្ញាណ តើនឹងមានសិរីល្អលើសជាងអម្បាលម៉ាន
ទៅ ៩ដ្បិតបើសិនជាការងារខាងឯសេចក្តីកាត់ទោស[រ]មានសិ
រីល្អទៅហើយ នោះការងារខាងឯសេចក្តីសុចរិត[ល]ប្រាកដ
ជានឹងមានសិរីល្អជាបរិបូរលើសទៅទៀត ១០ពីព្រោះឯ
សេចក្តីដែលមានសិរីល្អពីដើមនោះ បានដូចជាគ្មានសិរីល្អវិញ
ដោយព្រោះសិរីល្អនេះដែលលើសទៅទៀត ១១ដ្បិតបើសិន
ជាសេចក្តីនោះ ដែលកំពុងតែសូន្យបាត់ទៅ បានមកដោយសា
រសិរីល្អ នោះសេចក្តីដែលជាប់នៅ ប្រាកដជាមានសិរីល្អលើស
ទៅទៀត ១២ដូច្នេះដែលមានសេចក្តីសង្ឃឹមជាខ្លាំងក្រៃដល់ម្ល៉េះ[វ]
នោះយើងខ្ញុំកើតមានសេចក្តីក្លាហានណាស់[ស] ១៣មិនមែន
ដូចលោកម៉ូសេ ដែលយកស្បៃបាំងមុខ[ហ] ដើម្បីមិនឱ្យជន

**៣:៣** ទ សភ ៣:៣ ៧:៣ យរ ៣១:៣៣ អគ ៣៦:២៦ **៣:៤** ធ អភ ៣:១២ **៣:៥** ន ២កថ ២:១៦ ប ១កថ ១៥:១០ **៣:៦** ផ លក ២២:២០ ព រម ២:២៩ ៧:៦ ភ យហ ៦:៦៣ **៣:៧** ម ខ.៩ រម ៤:១៥ យ ខ.១៣ នក ៣៤:២៩–៣៥ អស ៤២:២១ **៣:៩** រ ខ.៧ ចទ ២៧:២៦ ល រម ១:១៧ ៣:២១,២២ **៣:១២** វ រម ៥:៤,៥ ៨:២៤,២៥ ស កច ៤:២៩ **៣:១៣** ហ ខ.៧ នក ៣៤:៣៣

ដែលរស់នៅអស់កល្បជានិច្ច ហើយឥតខ្ចោះ ។ *មិនមែនលើបន្ទះថ្ម* ដូចដែលលោកម៉ូសេបានទទួលនៅភ្នំស៊ីណៃឡើយ (មើលការពន្យល់ ខ.៦)។ *ក្នុងចិត្តខាងសាច់ឈាម* មើល យរ ៣១:៣៣ អគ ១១:១៩ ៣៦:២៦ និងការពន្យល់ ។ លោកប៉ុលពន្យល់អំពីសារសំខាន់នៃភាពផ្ទុយគ្នារវាងសញ្ញាចាស់ និងសញ្ញាថ្មីនៅក្នុង ខ.៧–១៨ ។

**៣:៤–៥** វគ្គនេះឆ្លើយសំនួរដែលលើកឡើងក្នុង ២:១៦ ។

**៣:៦** *អ្នកបំរើនៃ* សូមមើល រម ១៥:១៦ កល ១:៧ ៤:៧ ១ធថ ៤:៦ ។ *សញ្ញាថ្មី* ត្រង់ចំណុចនេះសាវកប៉ុលនិយាយពីខ្លឹមសារនៃឃ្លា "ក្នុងចិត្តខាងសាច់ឈាម" (ខ.៣ សូមមើលការពន្យល់ខនេះ)។ សូមមើល ហព ៨–១០។ ការដែលសាវកប៉ុលនិយាយសំដៅទៅលើ "អ្នកបម្រើនៃសញ្ញាថ្មី" ផ្ទុយនឹង "ការងារខាងឯសេចក្តីស្លាប់" (ខ.៧) ប្រហែលជាបណ្តាលមកពីពួកគ្រីស្ទបរិស័ទដែលកាន់ប្រពៃណីសាសនាយូដា ដែលប្រហែលជាពួកអ្នកដែលអះអាងថាជាសិស្សរបស់លោកពេត្រុស (១កថ ១:១២ និងការពន្យល់) និងពួកដែលហៅថាពួកសាសន៍យូដានៅក្នុង ១១:២២ (សូមមើលការពន្យល់) *ន័យពាក្យនោះធ្វើឱ្យស្លាប់ តែព្រះវិញ្ញាណទ្រង់ប្រទានឱ្យមានជីវិត* មានន័យថា ទីបញ្ចប់នៃការព្យាយាមឱ្យបានសេចក្តីសង្គ្រោះ ដោយខំកាន់តាមក្រិត្យវិន័យសញ្ញាចាស់គឺជាសេចក្តីស្លាប់ ។ មានតែការជឿលើព្រះយេស៊ូវទេ ដែលអាចនាំឱ្យមានជីវិតអស់កល្បជានិច្ចតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ ក្រិត្យវិន័យប្រាប់មនុស្សឱ្យស្គាល់អ្វីជាអំពើបាប ប៉ុន្តែមិនអាចផ្តល់ឱ្យនូវជីវិតបានឡើយ ។ តាមសេចក្តីសញ្ញាថ្មី ដែលមានន័យថាសេចក្តីសន្យា ឬកិច្ចព្រមព្រៀង ជីវិតអស់កល្បជានិច្ចបានមកពីព្រះវិញ្ញាណបរិសុទ្ធ (រម ៧:១០ រម ៨:២) ។

**៣:៧–១៨** ក្នុងវគ្គនេះលោកប៉ុលកំពុងតែនិយាយការពារការដែលគាត់បម្រើសញ្ញាថ្មី នៅក្នុងព្រះគ្រីស្ទ (សូមផ្ទៀបនឹង ខ.៦ និងការពន្យល់) ហើយគាត់បានធ្វើការប្រៀបធៀបបទពិសោធន៍របស់លោកម៉ូសេ ជាអ្នកនាំសេចក្តីសញ្ញាចាស់នៃភ្នំស៊ីណាយ ជាមួយនឹងបទពិសោធន៍របស់គាត់ ដែលជាអ្នកបម្រើនៃសេចក្តីសញ្ញាថ្មី ។ ប៉ុន្តែនៅពេលនេះគាត់ប្រើពាក្យ "ការងារ" (ខ.៧) បម្រើក្រិត្យវិន័យ ដែលត្រូវបានចារជាអក្សរនៅលើបន្ទះថ្ម និងការងាររបស់ព្រះវិញ្ញាណដែល បានចារនៅក្នុងចិត្តខាងសាច់ឈាមរបស់មនុស្ស (ខ.៣ សូមមើលការពន្យល់ខនេះ)។ ចំណុចសំខាន់នៃការប្រៀបធៀបនេះ គឺនិយាយអំពីពន្លឺដែលខ្សោយទៅៗ នៃសិរីល្អដែលចែងចាំងលើមុខលោកម៉ូសេ និងពី "សិរីល្អដែលចេះតែកើនឡើងជានិច្ច" (ខ.១៨ សូមមើលការពន្យល់) ដែលនាំឱ្យមានការឆ្លុះមើលព្រះក្នុងកញ្ចក់ដល់ពួកអ្នកដែលបម្រើសេចក្តីសញ្ញាថ្មី ។

**៣:៧** *កើតមកក្នុងសិរីល្អ* មតិដែលយល់ថាក្រិត្យវិន័យសញ្ញាចាស់ដែលព្រះប្រទាននៅភ្នំស៊ីណៃមិនល្អឬអាក្រក់ គឺជាមតិមិនត្រឹមត្រូវឡើយ ពីព្រោះលោកសាវកប៉ុល បានបកស្រាយផ្ទុយពីនេះនៅកន្លែងផ្សេងទៀតក្នុងព្រះគម្ពីរថា ជាក្រឹត្យវិន័យបរិសុទ្ធ សុចរិតល្អ ហើយជាក្រិត្យវិន័យខាងវិញ្ញាណ (រម ៧:១២,១៤)។ សេចក្តីអាក្រក់គឺមាននៅក្នុងចិត្តនិងការប្រព្រឹត្តរបស់មនុស្ស ដែលត្រូវទទួលនូវការថ្កោលទោសនិងការជំនុំជម្រះ របស់សេចក្តីស្លាប់តាមក្រិត្យវិន័យ។ ក្រិត្យវិន័យដែលចារលើបន្ទះថ្មនោះ មិនអាចដកយកចេញនូវសេចក្តីអាក្រក់ទាំងនោះបានឡើយ ។ សិរីល្អរបស់ព្រះហ៊ុមព័ទ្ធការដាក់ឱ្យមានក្រិត្យវិន័យនោះ ហើយបានបង្ហាញឱ្យឃើញនៅលើស្បែកមុខលោកម៉ូសេនៅពេលដែលលោកចុះពីលើភ្នំ (នក ៣៤:២៩–៣០)។

**៣:៨–៩** *ការងារខាងឯព្រះវិញ្ញាណ . . . សិរីល្អជាបរិបូរលើសទៅទៀត* ការងារខាងឯព្រះវិញ្ញាណគឺប្រទានឱ្យនូវជីវិត ជាជំនួសសេចក្តីស្លាប់ (សូមផ្ទៀបនឹង អស ៤៦:១៣ និងការពន្យល់)។

**៣:១១** *សេចក្តីនោះ ដែលកំពុងតែសូន្យបាត់ទៅ* គឺជាសេចក្តីសញ្ញាចាស់នៃភ្នំស៊ីណាយ ដែលមិនស្ថិតស្ថេរនៅជារហូតឡើយ ។ តាមការពិតសញ្ញាចាស់ត្រូវបានជំនួសដោយសញ្ញាថ្មី ដែលពន្លឺរបស់សេចក្តីថ្មីនេះមិនចេះស្រអាប់ ហើយមានពេញទៅដោយសិរីល្អជានិច្ច (ហព ៨ និងការពន្យល់ ៨:៧–១៣)។

**៣:១៣** *លោកម៉ូសេ ដែលយកស្បៃបាំងមុខ* មើល នក ៣៤:៣៣–៣៥ និងការពន្យល់ ៣៤:៣៣។ ការយកស្បៃបាំងមុខនេះគឺដើម្បីធ្វើឱ្យពួកសាសន៍

ជាតិអ៊ីស្រាអែល បានសំឡឹងមើលទៅដល់ចុងនៃសេចក្ដី
ដែលកំពុងតែសូន្យបាត់ទៅនោះឡើយ ១៤ តែចិត្តគេបានរឹង
ទទឹងវិញ[ឡ] ដ្បិតដរាបដល់ឥឡូវនេះ កាលបើគេមើល[អ]
ក្នុងសញ្ញាចាស់[ក] នោះនៅតែមានស្បៃដដែល ឥតបកចេញ
ឡើយ ដែលស្បៃនោះត្រូវតែសូន្យបាត់ទៅក្នុងព្រះគ្រីស្ទ
១៥ ដរាបដល់ថ្ងៃនេះ កាលណាគេមើលគម្ពីរលោកម៉ូសេ
នោះក៏គង់តែនៅមានស្បៃបាំងចិត្តគេនៅឡើយ ១៦ តែកាល
គេបានងាកបែរមកឯព្រះអម្ចាស់វិញ[ខ] នោះទើបស្បៃនឹង
បានដោះចោលចេញ[គ] ១៧ រីឯព្រះអម្ចាស់ ទ្រង់ជាព្រះ
វិញ្ញាណ[ឃ] ហើយកន្លែងណាដែលមានព្រះវិញ្ញាណនៃ
ព្រះអម្ចាស់ នោះក៏មានសេរីភាពដែរ[ង] ១៨ ហើយយើងរាល់
គ្នាទាំងអស់ ដែលកំពុងតែរំពឹងមើលសិរីល្អព្រះអម្ចាស់
ទាំងមុខទទេ ដូចជាឆ្លុះមើលទ្រង់ក្នុងកញ្ចក់[ច] យើងកំពុងតែ
ផ្លាស់ប្រែទៅ ឱ្យដូចជារូបឆ្លុះនោះឯង[ឆ] ពីសិរីល្អទៅដល់
សិរីល្អ[ជ] គឺដោយសារព្រះអម្ចាស់ដ៏ជាព្រះវិញ្ញាណ ។

## ទ្រព្យសម្បត្តិនៅក្នុងភាជនៈដី

**៤** ១ ដូច្នេះ ដែលមានការងារនេះនោះយើងខ្ញុំមិនណាយ
ចិត្តឡើយ[ឈ] តាមខ្នាតនៃសេចក្ដីមេត្តាករុណា[ញ] ដែលយើង
ខ្ញុំទទួលមក ២ យើងខ្ញុំលះចោលអស់ទាំងការលាក់កំបាំង
ដែលគួរខ្មាស[ដ] ឥតប្រព្រឹត្តដោយឧបាយកល ឬបំប្លែងព្រះ
បន្ទូលឡើយ[ឋ] គឺយើងខ្ញុំផ្ទុកផ្ដាក់ខ្លួន និងបញ្ញាចិត្តរបស់
មនុស្សទាំងអស់[ឌ] នៅចំពោះព្រះ ដោយសំដែងសេចក្ដីពិត
វិញ ៣ បើសិនណាជាដំណឹងល្អរបស់យើងខ្ញុំ[ឍ] ត្រូវគ្របបាំង[ណ]
នោះគឺត្រូវគ្របបាំងចំពោះតែពួកអ្នក ដែលកំពុងវិនាស
ទេ[ត] ៤ ជាពួកអ្នក ដែលព្រះ[ថ] របស់លោកិយនេះ[ទ] បានបង្អាប់[ធ]
ដល់គំនិតពួកគេដែលមិនជឿ ក្រែងរស្មីពន្លឺនៃដំណឹងល្អ
ដែលសំដែងពីសិរីល្អនៃព្រះគ្រីស្ទ[ន] ដ៏ជារូបអង្គព្រះ[ប] បាន
ភ្លឺមកដល់គេ ៥ យើងខ្ញុំមិនប្រកាសប្រាប់ពីខ្លួនយើងខ្ញុំទេ[ផ] គឺ
ពីព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់វិញ[ព] ហើយក៏រាប់ខ្លួន
យើងខ្ញុំ ថាជាបាវបំរើ[ភ] របស់អ្នករាល់គ្នា ដោយព្រោះ
ព្រះយេស៊ូវដែរ ៦ ដ្បិតគឺជាព្រះដែលមានបន្ទូលបង្គាប់ឱ្យ

**៣:១៤** ឡ រម ១១:៧,៨ ២កថ ៤:៤ អ កថ ១៣:១៥ ១៥:២១ ក ខ.៦ **៣:១៦** ខ រម ១១:២៣ គ នក ៣៤:៣៤ អស ២៥:៧ **៣:១៧** ឃ អស ៦១:១,២ កទ ៤:៦,៧ ង យហ ៨:៣២ **៣:១៨** ច ១កថ ១៣:១២ ឆ រម ៨:២៩ ជ យហ ១៧:២២, ២៤ ២កថ ៤:៤,៦ **៤:១** ឈ ១កថ ៧:២៥ ១ធថ ១:១៣,១៦ ញ ខ.១៦ ទដ ១៨:៤៥ អស ៤០:៣១ **៤:២** ដ រម ៦:២១ ១កថ ៤:៥ ឋ ២កថ ២:១៧ ហព ៤:១២ ឌ ២កថ ៥:១១ **៤:៣** ឍ ២កថ ២:១២ ណ ២កថ ៣:១៤ ត ១កថ ១:១៨ **៤:៤** ថ យហ ១២:៣១ ទ ១កថ ១:២០ ធ ២កថ ៣:១៤ ន ខ.៦ ប យហ ១៤:៩ **៤:៥** ផ ១កថ ១:១៣ ព ១កថ ១:២៣ ភ ១កថ ៩:១៩

អ៊ីស្រាអែល មិនអាចមើលឃើញពន្លឺនៃសិរីល្អនៅលើមុខលោកដែលចេះតែខ្សោយទៅៗ ។

**៣:១៤** *ដរាបដល់នេះ . . . នៅតែមានស្បៃដដែល* ស្បៃដែលបាំងមុខលោកម៉ូសេ ដើម្បីកុំឱ្យពួកអ៊ីស្រាអែលមើលឃើញពន្លឺនៃសិរីល្អនៅលើមុខលោកម៉ូសេដែលចេះតែខ្សោយទៅៗ គឺជាស្បៃដែលធ្វើឱ្យពួកគេមើលមិនស្គាល់លក្ខណៈមិនស្ថិតស្ថេរ និងមិនគ្រប់គ្រាន់របស់សេចក្ដីសញ្ញាចាស់ ហើយ"ស្បៃ"ដែលបានដក ចេញ គឺមានតែនៅក្នុងព្រះគ្រីស្ទប៉ុណ្ណោះ ។

**៣:១៧** *ព្រះអម្ចាស់ ទ្រង់ជាព្រះវិញ្ញាណ* អ្នកសិក្សាព្រះគម្ពីរគួរតែតភ្ជាប់ឃ្លានេះនឹងសេចក្ដីដែលមាននិយាយនៅខាងចុងខ.៦ ("ព្រះវិញ្ញាណទ្រង់ប្រទានឱ្យមានជីវិតវិញ") ។ ចំពោះអ្នកដែលប្រព្រឹត្តរំលងក្រិត្យវិន័យនោះ មានតែការងាកបែរមករកព្រះអម្ចាស់យេស៊ូវគ្រីស្ទវិញប៉ុណ្ណោះ (ខ.១៦) ដែលអាចលប់បំបាប់ការថ្កោលទោស និងការជំនុំជម្រះរបស់សេចក្ដីស្លាប់ ហើយអាចជំនួសការទាំងនេះ ដោយព្រះគុណរបស់សេចក្ដីសញ្ញាថ្មី ជាព្រះគុណដែលប្រទានជីវិត ។ *កន្លែងណាដែលមានព្រះវិញ្ញាណនៃព្រះអម្ចាស់ នោះក៏មានសេរីភាពដែរ* មើល យហ ៨:៣៣,៣៦ និងការពន្យល់ ៨:៣២ ។

**៣:១៨** *ទាំងមុខទទេ* គឺផ្ទុយពីលោកម៉ូសេ ។ *យើងកំពុងតែផ្លាស់ប្រែទៅ ឱ្យដូចជារូបឆ្លុះនោះឯង ពីសិរីល្អទៅដល់សិរីល្អ* ព្រះគ្រីស្ទទ្រង់គឺជាសិរីល្អដ៏ពោពេញរបស់ព្រះ (សូមមើល ហព ១:២–៣ និងការពន្យល់) ទ្រង់គឺជាសិរីល្អដ៏អស់កល្បជានិច្ច ហើយមិនចេះខ្សោយពន្លឺ ជាសិរីល្អដែលទ្រង់មានជាមួយនឹងព្រះវរបិតាទ្រង់ "តាំងពីមុនកំណើតលោកីយ" (យហ ១៧:៥) ។

**៤:១** *ការងារនេះ* មើល ៣:៦ និងការពន្យល់ ។ *មិនណាយចិត្ត* នៅពេលដែលព្រះអម្ចាស់ទ្រង់ត្រាស់ហៅ និងប្រគល់អំណាចឱ្យអ្នកបម្រើរបស់ទ្រង់ ទ្រង់ក៏ប្រទាននូវកម្លាំងដែលពួកគេត្រូវមានក្នុងពេលតស៊ូនឹងទុក្ខលំបាក និងការបៀតបៀនផងដែរ ។

**៤:២** *លះចោលអស់ទាំងការលាក់កំបាំង ដែលគួរខ្មាស* ចំពោះឃ្លានេះ សាវ័កប៉ុលកំពុងនិយាយសំដៅទៅលើពួកគ្រូបង្រៀនខុសឆ្គងនៅក្រុងកូរិនថូស ។ ចំពោះការនេះពួកជំនុំម្នាក់ៗ និងសេចក្ដីសុចរិតដែលគាត់មាន "នៅចំពោះព្រះ" អាចបញ្ជាក់អំពីគាត់បាន ថាការដែលគាត់ប្រព្រឹត្តតែងតែបានបើកសំដែងពីសេចក្ដីពិត ដោយមិនលាក់បាំង ឬប្រើឧបាយកលអ្វីឡើយ (សូមធៀបនឹង ១:១២,១៨–២៤ និងការពន្យល់ ១:១២) ។

**៤:៣** *ដំណឹងល្អរបស់យើងខ្ញុំត្រូវគ្របបាំង* មើល ៣:១៣–១៨ និងពន្យល់ ។

**៤:៤** *ព្រះរបស់លោកិយនេះ* គឺអារក្ស ដែលជាសត្រូវទីមួយរបស់ព្រះ និងជាអំណាចងងឹតដែលជាប្រភពដែលនាំឱ្យមានការមិនជឿ និងការទាស់ប្រឆាំងនឹងព្រះ ។ អ្នកដែលដើរតាមអារក្ស គឺមិនខុសពីយកអារក្សធ្វើជាព្រះឡើយ ។ *លោកិយនេះ* គឺលោកិយដែលមិនស្ថិតស្ថេរ ហើយមានពេញទៅដោយសេចក្ដីអាក្រក់ គឺដូចជាអ្វីដែលលោកប៉ុលហៅនៅក្នុង កទ ១:៤ ថា "លោកិយដ៏អាក្រក់ សព្វថ្ងៃនេះ" (មើលការពន្យល់ខនេះ) ។ *បង្អាប់ដល់គំនិតពួកគេដែលមិនជឿ* តាមឃ្លានេះ សាវកប៉ុលបានបន្តនិយាយអំពីស្បៃដែលគ្របសិរីល្អមិនឱ្យឃើញ ដល់អស់អ្នកណាដែលបដិសេធដំណឹងល្អ (៣:១៣–១៨) ។ *រូបអង្គព្រះ* គឺព្រះគ្រីស្ទ ដែលជាព្រះរាជបុត្រានៃព្រះ ដែលបានយាងមកយកកំណើតជាមនុស្ស ដោយសារទ្រង់ យើងបានជានឹងព្រះ ដ្បិតព្រះគ្រីស្ទទ្រង់ជារស្មីភ្លឺមកពីសិរីល្អនៃព្រះ (ហព ១:៣) ។

**៤:៥** *យើងខ្ញុំមិនប្រកាសប្រាប់ពីខ្លួនយើងខ្ញុំទេ* គឺមិនធ្វើដូចជាពួកគ្រូខុសឆ្គងដែលអួតតែអំពីខ្លួនឯងនោះទេ (សូមធៀបនឹង ១កថ ២:២ និងពន្យល់) ។

**៤:៦** *ឱ្យមានពន្លឺភ្លឺចេញពីសេចក្ដីងងឹត* ព្រះទ្រង់មានព្រះបន្ទូលដូចនេះ នៅពេលដែលទ្រង់បង្កើតផ្ទៃមេឃនិងផែនដី (លប ១:២–៤ និងការពន្យល់) ហើយទ្រង់បានមានបន្ទូលជាសេចក្ដីនេះម្ដងទៀត ក្នុងការបង្កើតជាថ្មី ឬកំណើតថ្មី (មើល ៥:១៧ យហ ៣:៣ និងការពន្យល់ ១ពត ១:៣) ។

មានពន្លឺភ្លឺចេញពីសេចក្តីងងឹត[ម] ទ្រង់បានបំភ្លឺមកក្នុងចិត្ត
យើងខ្ញុំ[យ] ឱ្យយើងខ្ញុំ មានរស្មីពន្លឺនៃដំណើរស្គាល់សិរីល្អ
របស់ព្រះ ដែលនៅព្រះភក្ត្រនៃព្រះយេស៊ូវគ្រីស្ទ[រ] ។
៧ យើងមានទ្រព្យសម្បត្តិនេះនៅក្នុងភាជនៈដី[ល] ដើម្បីឱ្យ
ឥទ្ធឫទ្ធិដ៏លើសលប់បានមកពីព្រះ[វ] មិនមែនពីយើងខ្ញុំទេ
៨ ដែលយើងខ្ញុំត្រូវគេសង្កត់សង្កិនគ្រប់ជំពូក[ស] តែមិនទ័លផ្លូវ
ឡើយ មានសេចក្តីវិលវល់[ហ] តែមិនទ័លគំនិតទេ ៩ មានគេ
ធ្វើទុក្ខ[ឡ] តែមិនមែនត្រូវចោលនៅម្នាក់ឯងទេ[អ] ត្រូវគេវាយ
ដួលស្តូក តែមិនស្លាប់ទេ[ក] ១០ យើងខ្ញុំផ្ទុកសេចក្តីសុគតនៃ
ព្រះអម្ចាស់យេស៊ូវ[ខ] នៅក្នុងរូបកាយយើងខ្ញុំជានិច្ច ដើម្បីឱ្យ
ព្រះជន្មនៃទ្រង់បានសំដែងមក ក្នុងរូបកាយយើងខ្ញុំដែរ[គ]
១១ ដ្បិតយើងរាល់គ្នាដែលរស់នៅ នោះយើងត្រូវប្រគល់
ដល់សេចក្តីស្លាប់ជាដរាប ដោយព្រោះព្រះយេស៊ូវ[ឃ] ដើម្បី
ឱ្យព្រះជន្មនៃទ្រង់បានសំដែងមកក្នុងរូបសាច់យើងដែលតែង
តែស្លាប់នេះ ១២ ហេតុនោះបានជា សេចក្តីស្លាប់កំពុងតែ
ចំរើនឡើងក្នុងយើងខ្ញុំ តែជីវិតចំរើនក្នុងអ្នករាល់គ្នាវិញ[ង]
១៣ ហើយដែលមានចិត្តជឿដូចគ្នា ត្រូវនឹងសេចក្តីដែល
ចែងទុកមកថា «ខ្ញុំបានជឿ បានជាខ្ញុំនិយាយ»[ច] នោះយើងខ្ញុំ

**៤:៦** ម លប ១:៣
ទដ ១៨:២៨
យ ២ពត ១:១៩
រ ខ.៤
**៤:៧** ល យប ៤:១៩
អស ៦៤:៨
២ធថ ២:២០
វ ពច ៧:២
១កថ ២:៥
២កថ ៦:៧
**៤:៨** ស ២កថ ៧:៥
ហ កទ ៤:២០
**៤:៩** ឡ យហ ១៥:២០
រម ៨:៣៥
អ ហព ១៣:៥
ក ទដ ៣៧:២៤
សភ ២៤:១៦
**៤:១០** ខ រម ៦:៦
២កថ ១:៥
គ រម ៦:៥
**៤:១១** ឃ រម ៨:៣៦
**៤:១២** ង ២កថ
១៣:៩
**៤:១៣** ច ទដ
១១៦:១០

ក៏ជឿដែរ[ឆ] បានជាយើងខ្ញុំនិយាយ ១៤ ដោយដឹងថាព្រះអង្គ
ដែលប្រោសព្រះអម្ចាស់យេស៊ូវ ឱ្យមានព្រះជន្មរស់ឡើង
វិញ[ជ] ទ្រង់នឹងប្រោសឱ្យយើងខ្ញុំរស់ឡើងដែរ[ឈ] ដោយសារ
ព្រះយេស៊ូវ ហើយនឹងនាំយើងខ្ញុំទៅនៅចំពោះទ្រង់ជាមួយ
នឹងអ្នករាល់គ្នាដែរ[ញ] ១៥ ពីព្រោះគ្រប់ទាំងអស់សំរាប់អ្នក
រាល់គ្នា ដើម្បីឱ្យព្រះគុណ ដែលចំរើនឡើង ដោយសារ
មនុស្សជាច្រើន បានបណ្តាលឱ្យមានសេចក្តីអរព្រះគុណ[ដ]
ចំរើនជាបរិបូរឡើង ដល់សិរីល្អនៃព្រះលើសទៅទៀត ។
១៦ ហេតុនោះយើងខ្ញុំមិនណាយចិត្តឡើយ[ឋ] ប៉ុន្តែទោះបើ
មនុស្សខាងក្រៅរបស់យើងខ្ញុំ កំពុងតែពុករលួយទៅក៏ពិត
មែន តែនៅខាងក្នុង[ឌ] កំពុងតែកែប្រែជាថ្មីឡើង[ឍ] រាល់ថ្ងៃ
ជានិច្ចវិញ ១៧ ដ្បិតសេចក្តីទុក្ខលំបាកយ៉ាងស្រាលរបស់យើង
ខ្ញុំ ដែលនៅតែមួយភ្លែតនេះ នោះបង្កើតឱ្យយើងខ្ញុំមាន
សិរីល្អយ៉ាងធ្ងន់លើសលប់ ដ៏នៅអស់កល្បជានិច្ចវិញ[ណ]
១៨ ដោយយើងខ្ញុំមិនរាប់អានរបស់ដែលមើលឃើញឡើយ[ត]

ឆ ១កថ ១២:៩ **៤:១៤** ជ កច ២:២៤ ឈ ១ថន ៤:១៤ ញ អភ ៥:២៧ កល ១:២២ យដ ២៤ **៤:១៥** ដ ២កថ ១:១១ ៩:១១ **៤:១៦** ឋ ខ.១ ទដ ១៨:៤៥ ឌ រម ៧:២២ ឍ ទដ ១០៣:៥ អស ៤០:៣១ កល ៣:១០ **៤:១៧** ណ ទដ ៣០:៥ រម ៨:១៨ ១ពត ១:៦,៧ **៤:១៨** ត ២កថ ៥:៧ រម ៨:២៤ ហព ១១:១

គឺនៅពេលដែលភាពងងឹតនៃអំពើបាបត្រូវបានលុបបំបាត់ដោយពន្លឺ នៃដំណឹងល្អ ។

**៤:៧** *ទ្រព្យសម្បត្តិនេះ* គឺដំណឹងល្អ ។ *ភាជនៈដី* ដំណឹងល្អមានតម្លៃបំផុតពីព្រោះសេចក្តីសង្គ្រោះនៃព្រះយេស៊ូវគ្រីស្ទ ដែលព្រះទ្រង់ផ្ទុកផ្តាក់នឹងមនុស្ស ដែលពួកគេមានទៅដោយភាពកម្សោយ និងមិនមានភាពគ្រប់លក្ខណ៍ ។

**៤:៨–១២** មើល ១១:២៣–២៦ និងការពន្យល់ ។

**៤:១០** *យើងខ្ញុំផ្ទុកសេចក្តីសុគតនៃព្រះអម្ចាស់យេស៊ូវ នៅក្នុងរូបកាយយើងជានិច្ច* ភាពកម្សោយនៃភាជនៈដី ដែលតំណាងឱ្យភាពកម្សោយនៃភាពមនុស្សរបស់សាវកប៉ុល (ខ.៧) ត្រូវបានឃើញយ៉ាងច្បាស់ នៅក្នុងការរងទុក្ខលំបាក និងការបៀតបៀន ដែលគាត់ទទួលរងព្រោះដំណឹងល្អ ជាការរួមចំណែកក្នុងការរង ទុក្ខរបស់ព្រះគ្រីស្ទ (១:៥ រម ៨:១៧ ភល ៣:១០ កល ១:២៤ និងការពន្យល់) ។ *ដើម្បីឱ្យព្រះជន្មនៃទ្រង់បានសំដែងមក ក្នុងរូបកាយយើងខ្ញុំដែរ* គឺសំដៅទៅលើព្រះជន្មដែលមានឡើងវិញ និងអំណាចរបស់ព្រះគ្រីស្ទ (ភល ៣:១០ និងការពន្យល់) ។ ខនេះបាននិយាយម្តងទៀតពីភាពកម្សោយរបស់មនុស្សដែលជា ឱកាសសម្រាប់បង្ហាញពីអំណាចព្រះចេស្តារបស់ព្រះ ។

**៤:១២** *សេចក្តីស្លាប់* មើល ១កថ ១៥:៣១ និងការពន្យល់ ។ *ជីវិត* មើល ខ.១០ និងការពន្យល់ ។

**៤:១៣** *ខ្ញុំបានជឿ បានជាខ្ញុំនិយាយ* សេចក្តីជំនឿនាំឱ្យមានការធ្វើបន្ទាល់ ។ ដូចនេះហើយបានជាសាវកប៉ុលបានធ្វើការ និងធ្វើដំណើរទៅប្រាប់អ្នកឯទៀតអំពីដំណឹងល្អ ដោយគ្មានគិតពីការនឿយហត់អ្វីឡើយ ។

**៤:១៤** *ព្រះអង្គ ដែលប្រោសព្រះអម្ចាស់យេស៊ូវ* គឺជាព្រះ (កច ២:២៤) ។ *នឹងប្រោសឱ្យយើងខ្ញុំរស់ឡើងដែរ* មើល រម ៨:១១ ១កថ ១៥:២០ និងការពន្យល់ ។

**៤:១៦** *មិនណាយចិត្តឡើយ* គឺជាការនិយាយសំដីក្នុងខ.១ម្តងទៀត ។ វគ្គដែលនៅចន្លោះខ.១ និង ខ.១៦នេះ ពន្យល់ពីមូលហេតុដែលសាវកប៉ុលនៅតែបន្តមានអំណរ ហើយវគ្គដទៃទៀតនៅក្នុងជំពូកនេះនិយាយសង្ខេបសេចក្តីសំអាងដែលសាវកប៉ុលបានបកស្រាយក្នុងខនេះរហូតមក ។ *កំពុងតែពុករលួយទៅ* គឺដោយសារសេចក្តីទុក្ខលំបាកដែលគាត់បានទទួលរង ។ *កំពុងតែកែប្រែជាថ្មីឡើង* គឺដោយសារតែអណ្តាតភ្លើងនៃព្រះជន្មរស់ឡើងវិញកំពុងតែឆេះនៅខាងក្នុង ។

**៤:១៧** *សេចក្តីទុក្ខលំបាកយ៉ាងស្រាលរបស់យើងខ្ញុំ ដែលនៅតែមួយភ្លែតនេះ* ដោយឃើញតាមការប្រមើលមើលពីភាពអស់កល្ប សេចក្តីទុក្ខលំបាករបស់គ្រីស្ទបរិស័ទត្រូវអន់ថយកម្លាំងទៅ ។ *សិរីល្អយ៉ាងធ្ងន់លើសលប់ ដ៏នៅអស់កល្បជានិច្ចវិញ* តាមការប្រៀបធៀប សិរីល្អដែលអស់កល្បជានិច្ច ធំជាងសេចក្តីទុក្ខលំបាកទាំងអស់ ដែលមនុស្សម្នាក់ៗអាចជួបប្រទះក្នុងជីវិត (រម ៨:១៧–១៨ និងការ ពន្យល់ ៨:១៧) ។

**៤:១៨** *របស់ដែលមើលឃើញ . . . របស់ដែលមើលមិនឃើញ* បទពិសោធន៍ និងកាលៈទេសៈនៃជីវិតបច្ចុប្បន្ននេះ គឺអាចមើលឃើញដោយគ្រីស្ទបរិស័ទ ប៉ុន្តែ ទាំងនោះគ្រាន់តែជាការបណ្តោះអាសន្ន ហើយមិនស្ថិតស្ថេរទេ ។ ការសម្លឹងមើលទៅការទាំងនោះ នឹងនាំឱ្យយើងមាន "ការណាយចិត្ត" ជាមិនខានទេ (ខ.១,១៧) ។ ផ្ទុយទៅវិញការពិតដែលមើលមិនឃើញ (ប្រៀបធៀប ហព ១១:១,៧, ២៦–២៧) គឺស្ថិតស្ថេរនៅអស់កល្បជានិច្ច ។

គឺរាប់អានតែរបស់ដែលមើលមិនឃើញវិញ ដ្បិតរបស់
ដែលមើលឃើញ នោះស្ថិតស្ថេរមិនយូរប៉ុន្មានទេ តែឯ
របស់ដែលមើលមិនឃើញ នោះនៅស្ថិតស្ថេរអស់កល្ប
ជានិច្ចវិញ ។

## ទីលំនៅដែលមកពីស្ថានសួគ៌

**៥** ១ពីព្រោះយើងខ្ញុំដឹងថា បើត្រសាលដែលជាទីលំនៅ[ឋ]
របស់យើងខ្ញុំ នៅផែនដីនេះ[ទ] ត្រូវបំផ្លាញវេលាណា នោះ
យើងខ្ញុំមានវិមាន១ ដែលមកពីព្រះ មិនមែនធ្វើនឹងដៃទេគឺ
នៅលើស្ថានសួគ៌វិញ ជាវិមានដ៏នៅជាប់អស់កល្បជានិច្ច
២ដ្បិតនៅក្នុងត្រសាលនេះ យើងខ្ញុំតែងតែថ្ងូរ[ធ]ដោយសង្វាត
នឹងចង់ប្រដាប់ខ្លួន ដោយទីលំនៅរបស់យើងខ្ញុំ ជាទីលំនៅ
ដែលមកពីស្ថានសួគ៌ណាស់[ន] ៣ឱ្យតែយើងខ្ញុំបានប្រដាប់ខ្លួន
ចុះ ដើម្បីកុំឱ្យមានឃើញយើងខ្ញុំនៅអាក្រាតឡើយ ៤ដ្បិត
យើងខ្ញុំ ដែលនៅក្នុងត្រសាលនេះ យើងថ្ងូរមែន[ប] ដោយ
មានបន្ទុកយ៉ាងធ្ងន់ ពីព្រោះយើងមិនចង់ដោះសំលៀក
បំពាក់នេះចេញទេ គឺចង់តែស្លៀកពាក់វិញ[ផ] ដើម្បីឱ្យជីវិត
បានលេបរបស់ដែលតែងតែស្លាប់ ឱ្យបាត់ទៅនោះ ៥រីឯ
អ្នកដែលបានបង្កើតយើងខ្ញុំសំរាប់ការនោះឯង ជាព្រះ
ដែលទ្រង់ក៏ប្រទានព្រះវិញ្ញាណ មកបញ្ចាំចិត្តយើងខ្ញុំដែរ[ព]។
៦ដូច្នេះ យើងខ្ញុំមានចិត្តជឿជាក់ជាដរាប ហើយដឹងថា
ដែលយើងខ្ញុំនៅក្នុងរូបកាយនេះ នោះយើងខ្ញុំនៅឃ្លាត
ពីព្រះអម្ចាស់ ៧ដ្បិតយើងខ្ញុំដើរដោយជំនឿ មិនមែនដោយ
មើលឃើញទេ[ភ] ៨ដូច្នេះ យើងខ្ញុំមានចិត្តជឿជាក់ ហើយ
ក៏សុខចិត្តស៊ូចេញពីរូបកាយនេះ ទៅនៅជាមួយនឹងព្រះ
អម្ចាស់ជាជាង[ម] ៩ហេតុនោះបានជាយើងខ្ញុំសង្វាត ឱ្យបាន
គាប់ដល់ព្រះហឫទ័យទ្រង់[យ] ទោះនៅក្នុងរូបកាយ ឬឃ្លាតពី
រូបកាយក្តី ១០ដ្បិតយើងទាំងអស់គ្នាត្រូវទៅនៅមុខទីជំនុំ
ជំរះរបស់ព្រះគ្រីស្ទ ដើម្បីឱ្យគ្រប់គ្នាបានទទួលតាមការ

**៥:១** ឋ អស ៣៨:១២
២ពត ១:១៣,១៤
ទ ១កថ ១៥:៤៧
**៥:២** ធ ខ.៤
រម ៨:២៣ ន ខ.៤
១កថ ១៥:៥៣,៥៤
**៥:៤** ប ខ.២
រម ៨:២៣ ផ ខ.២
១កថ ១៥:៥៣,៥៤
**៥:៥** ព រម ៨:២៣
២កថ ១:២២
អភ ១:១៣,១៤
**៥:៧** ភ ១កថ
១៣:១២ ២កថ ៤:១៨
**៥:៨** ម យហ ១២:២៦
**៥:៩** យ រម ១៤:១៨
អភ ៥:១០
កល ១:១០
១ថន ៤:១
**៥:១០** រ មថ ១៦:២៧ កថ ១០:៤២ រម ២:១៦ ១៤:១០ អភ ៦:៨

តាមរយៈនេះ យើងងាកចេញពីរូប ភាពដែលមិនស្ថិតស្ថេររបស់លោកីយនេះ(ភល ៣:២០ ហព ១២:២ និងការពន្យល់)។

**៥:១** *ទីលំនៅរបស់យើងខ្ញុំ នៅផែនដីនេះ* គឺរូបកាយបច្ចុប្បន្នរបស់យើង (យហ ១:១៤ និងការពន្យល់ ២ពត ១:១៣)។ រូបកាយរបស់យើងមានភាពទន់ខ្សោយទៅៗ ហើយងាយរងគ្រោះ ដូចជាទីលំនៅដែលបណ្តោះអាសន្ន ហើយមិនមាំមួន (៤:១០–១២,១៦ និងការពន្យល់)។ *វិមាន១ ដែលមកពីព្រះ មិនមែនធ្វើនឹងដៃទេ គឺនៅលើស្ថានសួគ៌វិញ* គឺជាសំណង់ដែលស្ថិតស្ថេរមិនមែនបណ្តោះអាសន្ន ។ ការនេះជាសេចក្តីពិតមួយក្នុងចំណោមសេចក្តីពិតអស់កល្បទាំងឡាយ ដែលមកដល់ពេលនេះ មិនទាន់មើលឃើញ (៤:១៨)។ *មិនមែនធ្វើដោយដៃ* គឺជាស្នាព្រះ ហស្តរបស់ព្រះដែលឥតខ្ចោះ ហើយស្ថិតស្ថេរ (ហព ៩:១១ និងការពន្យល់)។

**៥:២** *ដ្បិតនៅក្នុងត្រសាលនេះ* គឺក្នុងត្រសាលដែលយើងកំពុងរង់ចាំការយាងត្រឡប់មកវិញរបស់ព្រះអម្ចាស់ ។ *យើងខ្ញុំតែងតែថ្ងូរ* ពីព្រោះយើងចង់បានយ៉ាងខ្លាំង នូវភាពគ្រប់លក្ខណ៍ដែលនឹងក្លាយជារបស់យើង នៅពេលដែលយើងបានរូបកាយខាងឯវិញ្ញាណមានសិរីល្អ(សូមធៀបនឹង ១កថ ១៥:៤១–៤៩ និងការពន្យល់)។ *ដោយសង្វាតនឹងចង់ប្រដាប់ខ្លួន ដោយទីលំនៅរបស់យើងខ្ញុំ ជាទីលំនៅដែលមកពីស្ថានសួគ៌* ទីលំនៅដែលអស់កល្បជានិច្ចដែលជាការប្រទានរបស់ព្រះ គឺត្រូវបានរៀបរាប់ដូចជាការប្រដាប់កាយ ។

**៥:៣** *នៅអាក្រាត* គឺគ្មានការប្រដាប់ខ្លួន ដែលជាសភាពរបស់ពួកអ្នកដែលលំនៅ ខាងលោកីយរបស់ពួកគេត្រូវរុះរើដោយសេចក្តីស្លាប់(មើលខ.៨ និងការពន្យល់)

**៥:៤** *របស់ដែលតែងតែស្លាប់* គឺរូបកាយបច្ចុប្បន្នរបស់យើង ។ *ឱ្យជីវិតបានលេប* ដោយការចូលរួមរបស់យើងនៅក្នុងព្រះជន្មដែលរស់ពីការសុគតនៃព្រះគ្រីស្ទ (៤:១០ និងការពន្យល់) រូបកាយដែលតែងតែស្លាប់របស់យើងត្រូវបាន "លេបដោយជីវិត" មិនមែនដោយសេចក្តីស្លាប់ទេ ។ លោកប៉ុលបាននិយាយត្រឡប់ទៅរករូបភាពពីសម័យមុន និងផ្លូវដែលជាអ្នកលេបដ៏ធំ (ទដ ៤៩:១៤ និងការពន្យល់) ដូចដែលលោកអេសាយបាននិយាយ(អស ២៥:៨ និង ១កថ ១៥:៥៤)។

**៥:៥** *ព្រះ. . . ប្រទានព្រះវិញ្ញាណ* ព្រះវិញ្ញាណបរិសុទ្ធទ្រង់ធ្វើឱ្យផលនៃព្រះរាជកិច្ចសង្គ្រោះរបស់ព្រះគ្រីស្ទ មានឥទ្ធិពលលើចិត្តរបស់អ្នកជឿ ហើយធ្វើឱ្យអំណាច នៃការរស់ឡើងវិញរបស់ទ្រង់ក្លាយទៅជាការពិតនៃការពិសោធន៍ ដែលពួកគេមានជារៀងរាល់ថ្ងៃ(សូមធៀបនឹង ៤:១០–១៦ និងការពន្យល់)។ ការនេះធានាការ ដែលពួកគេផ្លាស់ប្រែទៅជាដូចព្រះអង្គប្រកបដោយសិរីល្អរបស់ព្រះគ្រីស្ទ (ភល ៣:២១ និងការពន្យល់)។

**៥:៦** *នៅក្នុងរូបកាយនេះ... ឃ្លាតពីព្រះអម្ចាស់* ការដែលយើងនៅរស់នៅលើផែនដីនេះនៅក្នុងរូបកាយរបស់យើងនៅឡើយ(ខ.១ និងការពន្យល់) ពុំមានន័យថាយើងត្រូវបានបង្អត់ មិនឱ្យមានព្រះវត្តមានខាងឯវិញ្ញាណរបស់ព្រះអម្ចាស់ជាមួយនឹងយើងនៅក្នុងការរស់នៅរាល់ថ្ងៃឡើយ ។

**៥:៧** *ដោយជំនឿ មិនមែនដោយមើលឃើញ* មើល ៤:១៨ និងការពន្យល់ សូមធៀបនឹង ១កថ ១៣:១២ និងការពន្យល់ ។

**៥:៨** *ចេញពីរូបកាយនេះ ទៅនៅជាមួយនឹងព្រះអម្ចាស់* នេះជាស្ថានភាពរបស់អ្នកជឿព្រះបន្ទាប់ពីពួកគេស្លាប់ទៅ ហើយឈប់រស់នៅក្នុងរូបកាយដែលតែងតែស្លាប់ទៀត(ភល ១:២៣ និងការពន្យល់)។

**៥:៩** *ទោះនៅក្នុងរូបកាយ ឬឃ្លាតពីរូបកាយក្តី* មានន័យថា ទោះជានៅរស់ឬទៅ នៅជាមួយនឹងព្រះអម្ចាស់ហើយក្តី ។

**៥:១០** *ត្រូវទៅនៅមុខទីជំនុំជំរះរបស់ព្រះគ្រីស្ទ* គឺដើម្បីទទួលខុសត្រូវចំពោះអ្វីដែលយើងបានធ្វើកាលនៅរស់ជាគ្រីស្ទបរិស័ទ(សូមធៀបនឹង ១កថ ៣:១១–១៥ និងការពន្យល់ ៣:១៣)។ *ការដែលបានធ្វើ ពីកាលនៅក្នុងរូបកាយរៀងខ្លួន* ទោះបីជារូបកាយត្រូវសូន្យទៅក៏ដោយ ក៏យើងត្រូវមានការទទួលខុសត្រូវចំពោះ ការដែលយើងបានប្រព្រឹត្ត កាលនៅរស់ក្នុងរូបកាយនោះឡើយ ។

## ការងារបង្រួបបង្រួម

១១ដូច្នេះ ដែលស្គាល់សេចក្ដីស្ញែងខ្លាចរបស់ព្រះអម្ចាស់[ល]
នោះយើងខ្ញុំក៏ខំបញ្ចុះបញ្ចូលមនុស្សឱ្យជឿ តែយើងខ្ញុំជាអ្នក
ប្រាកដច្បាស់ដល់ព្រះហើយ ខ្ញុំក៏សង្ឃឹមថា ដល់បញ្ញាចិត្ត
របស់អ្នករាល់គ្នាដែរ[វ] ១២ដ្បិតយើងខ្ញុំមិនមែនផ្ទុកផ្ដាក់ខ្លួន
នឹងអ្នករាល់គ្នាម្ដងទៀតទេ[ស] គឺយើងខ្ញុំឱ្យអ្នករាល់គ្នាមាន
ឱកាសនឹងអួតពីយើងខ្ញុំវិញ[ហ] ដើម្បីឱ្យអ្នករាល់គ្នាមានពាក្យ
តបឆ្លើយ ដល់អស់អ្នកដែលអួតតែពីចរិតខាងក្រៅ មិន
មែនពីសណ្ដានក្នុងចិត្តនោះទេ ១៣ដ្បិតទោះបើយើងខ្ញុំវង្វេង
ស្មារតី[ឡ]ក្ដី នោះគឺវង្វេងសំរាប់ព្រះអង្គ ឬបើមានគំនិតនឹង
ធឹងក្ដី ក៏សំរាប់អ្នករាល់គ្នាវិញ ១៤ដ្បិតសេចក្ដីស្រឡាញ់
របស់ព្រះគ្រីស្ទបង្ខំយើងខ្ញុំ ដោយយើងខ្ញុំពិចារណាឃើញ
ថា បើម្នាក់បានស្លាប់ជំនួសអ្នកទាំងអស់ នោះទាំងអស់
ឈ្មោះថា បានស្លាប់ហើយ[អ] ១៥ទ្រង់ក៏បានសុគតជំនួសមនុស្ស
ទាំងអស់យ៉ាងនោះ គឺដើម្បីឱ្យពួកអ្នកដែលរស់នៅ មិនរស់
សំរាប់តែខ្លួនឯងទៀត[ក] គឺរស់សំរាប់ព្រះអង្គ ដែលសុគត
ជំនួសគេ[ខ] ហើយបានរស់ឡើងនោះវិញ ១៦បានជាពីនេះ
ទៅមុខ យើងខ្ញុំមិនស្គាល់អ្នកណាខាងឯសាច់ឈាមទៀត
ទេ[គ] តែបើយើងខ្ញុំបានស្គាល់ព្រះគ្រីស្ទខាងសាច់ឈាម
ហើយ គង់តែឥឡូវនេះមិនស្គាល់ទ្រង់យ៉ាងនោះទៀតឡើយ
១៧បានជាបើអ្នកណានៅក្នុងព្រះគ្រីស្ទ[ឃ] នោះឈ្មោះថាបាន
កើតជាថ្មីហើយ[ង] អស់ទាំងសេចក្ដីចាស់បានកន្លងបាត់ទៅ
មើល គ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ[ច] ១៨គ្រប់ទាំង
អស់ក៏មកពីព្រះ[ឆ] ដែលទ្រង់បានផ្សះផ្សាយើងនឹងព្រះអង្គ
ទ្រង់ ដោយសារព្រះយេស៊ូវគ្រីស្ទ[ជ] ហើយបានប្រទានការ
ងារផ្សះផ្សានោះ មកយើងខ្ញុំដែរ ១៩គឺពីដំណើរដែល
ព្រះទ្រង់គង់ក្នុងព្រះគ្រីស្ទ កំពុងផ្សះផ្សាលោកីយនឹងព្រះអង្គ
ទ្រង់ ឥតប្រកាន់ទោសគេទៀត[ឈ] ហើយទ្រង់បានប្រគល់
ព្រះបន្ទូលពីការផ្សះផ្សានោះមកយើងខ្ញុំ ២០ដូច្នេះយើងខ្ញុំជា
ទូតដំណាងព្រះគ្រីស្ទ[ញ] ហាក់ដូចជាព្រះទ្រង់អង្វរដោយសារ

**៥:១១** ល យប ២៣:១៥ ហព ១០:៣១ ១២:២៩ យដ ២៣ វ ២កថ ៤:២
**៥:១២** ស ២កថ ៣:១ ហ ២កថ ១:១៤
**៥:១៣** ឡ ២កថ ១១:១,១៦,១៧ ១២:១១
**៥:១៤** អ រម ៦:៦,៧ កទ ២:២០ កល ៣:៣
**៥:១៥** ក រម ១៤:៧-៩ ខ រម ៤:២៥
**៥:១៦** គ ២កថ ១០:៤ ១១:១៨
**៥:១៧** ឃ រម ១៦:៣ ង យហ ១:១៣ រម ៦:៤ កទ ៦:១៥ ច អស ៦៥:១៧ វវ ២១:៤,៥
**៥:១៨** ឆ រម ១១:៣៦ ជ រម ៥:១០ **៥:១៩** ឈ រម ៤:៨
**៥:២០** ញ ២កថ ៦:១ អភ ៦:២០

**៥:១១** *សេចក្ដីស្ញែងខ្លាចរបស់ព្រះអម្ចាស់* គឺព្រះអង្គដែលយើងត្រូវទទួលខុសត្រូវនៅចំពោះទ្រង់(ខ.១០ មើល លប ២០:១១ ទដ ១:៧ និងការពន្យល់)។ *យើងខ្ញុំក៏ខំបញ្ចុះបញ្ចូលមនុស្ស* លោកប៉ុលត្រូវការបញ្ចុះបញ្ចូលសមាជិកមួយចំនួនរបស់ពួកជំនុំកូរិនថូសថា គាត់(មិនមែនជាពួកគ្រូបង្រៀនខុសឆ្គងណាមួយដែលបានជ្រៀតចូលក្នុងពួកជំនុំកូរិនថូសទេ) គឺជាគ្រីស្ទទូតម្នាក់ដ៏ស្របច្បាប់នៃពួកគេ ។

**៥:១២** *អួតតែពីចរិតខាងក្រៅ* ពុតត្បុតរបស់ពួកសាវកក្លែងក្លាយ គឺជាបញ្ហាចំពោះមុខ ពីព្រោះពួកគេមិនមានការខ្វល់ខ្វាយពីបញ្ហាព្រលឹងវិញ្ញាណដែលពិត ហើយស៊ីជម្រៅទេ ប៉ុន្តែពួកគេខ្វល់ខ្វាយពីទ្រព្យសម្បត្តិកេរ្តិ៍ឈ្មោះ និងអំណួត ។

**៥:១៣** *យើងខ្ញុំវង្វេងស្មារតី . . . គំនិតនឹងធឹង* សត្រូវរបស់សាវកប៉ុលប្រហែលជាកំពុងតែចោទថា លោកប៉ុលមានជំងឺសាសនា ដែលពួកគេចាត់ទុកថាជាភាពវិកលចរិត ។ ប្រសិនបើលោកសាវកប៉ុលពិតជាវង្វេងស្មារតីមែននោះ គាត់មិនបដិសេធទេ ពីព្រោះសំបុត្រនេះទាំងមូលបង្ហាញថាតើលោកសាវកប៉ុលបានរងទុក្ខដោយសារដំណឹងល្អ ដោយស្ម័គ្រចិត្ត និងអំណរប៉ុណ្ណា(១២:១០)។ ម្យ៉ាងវិញទៀត លក្ខណៈនៃការផ្សាយដំណឹងល្អរបស់គាត់ទៅកាន់ពួកកូរិនថូស គ្មានអ្វីដែលចម្លែកឡើយ ពីព្រោះ គាត់មានហេតុផល និងប្រាជ្ញានឹងធឹង ដោយជៀសវាងការនិយាយប្រើពាក្យលំអច្រើន និងការនិយាយបំផ្លើសដើម្បីធ្វើឱ្យមានការចាប់អារម្មណ៍ខ្លាំងជាដើម (១កថ ២:១-៥ និងការពន្យល់)។

**៥:១៤** *សេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទ* គឺបានបង្ហាញឱ្យយើងឃើញនៅក្នុងការសុគតរបស់ទ្រង់ដើម្បីយើងរាល់គ្នា ទោះជាមានអ្នកខ្លះជឿថា ន័យរបស់ឃ្លានេះគឺ "សេចក្ដីស្រឡាញ់របស់យើងចំពោះព្រះគ្រីស្ទ"ក៏ដោយ ។ *ម្នាក់* គឺព្រះរាជបុត្រាតែមួយរបស់ព្រះដែលបានយាងមកយកកំណើតជាមនុស្ស ។ *ទាំងអស់ឈ្មោះថា បានស្លាប់ហើយ* ពីព្រោះព្រះគ្រីស្ទទ្រង់បានសុគតសម្រាប់មនុស្សទាំងអស់ ទ្រង់បានឱ្យមនុស្សគ្រប់គ្នាមានចំណែកក្នុងការសុគតរបស់ទ្រង់ ។ ចំពោះអ្នកខ្លះការសុគតរបស់ទ្រង់នឹងបញ្ជាក់ការស្លាប់របស់ពួកគេ ប៉ុន្តែ ចំពោះអ្នកខ្លះទៀត(អ្នកដែលនឹងបានរួបរួមជាមួយនឹងទ្រង់ដោយសេចក្ដីជំនឿ) ការសុគតរបស់ទ្រង់គឺជា ការស្លាប់របស់ពួកគេខាងឯអំពើបាប និងរូបកាយ ដើម្បីឱ្យពួកគេបានរស់នៅក្នុង ព្រមទាំងជាមួយព្រះគ្រីស្ទដែលទ្រង់មានព្រះជន្មឡើងវិញ(ខ.១៥ មើល រម ៦:១-១១) ទោះជាយ៉ាងណាក៏ដោយ អ្នកខ្លះជឿថា ក្នុងខនេះសាវកប៉ុលកំពុងនិយាយ អំពីឥទ្ធិពលនៃការសុគតរបស់ព្រះគ្រីស្ទលើជីវិតគ្រីស្ទបរិស័ទ ប៉ុន្តែមិនមែនកំពុង និយាយជាក់លាក់លើប្រធានបទការប្រោសលោះរបស់ព្រះគ្រីស្ទទេ ដូចនេះ ពាក្យ "ទាំងអស់" ក្នុងខនេះ គឺសំដៅទៅលើអ្នកជឿតែប៉ុណ្ណោះ គឺមិនមែនមនុស្សលោកទាំងអស់ឡើយ ។

**៥:១៦** *យើងខ្ញុំបានស្គាល់ព្រះគ្រីស្ទខាងសាច់ឈាម* សាវកប៉ុលបានទទួលស្គាល់ថា មុនពេលគាត់ផ្លាស់ប្រែចិត្ត គាត់ជឿថាព្រះយេស៊ូវមិនមែនជាព្រះ ដោយសំអាងទៅលើការយល់ដឹងដែលមិនបរិសុទ្ធរបស់មនុស្សលោក ។

**៥:១៧** *នៅក្នុងព្រះគ្រីស្ទ* គឺបានរួបរួមជាមួយព្រះគ្រីស្ទ ដោយសេចក្ដីជំនឿ និងការប្ដេជ្ញាចំពោះទ្រង់(រម ៦:១១ អភ ១:១ ភល ២:១ និងការពន្យល់)។ *បានកើតជាថ្មី* ការប្រោសលោះគឺជាការបំបែរមនុស្សលោកឱ្យវិលមកឯព្រះវិញ និងការសម្រេចបំណងព្រះហឫទ័យព្រះនៅក្នុងការបង្កើត(មើល ៤:៦ និងការពន្យល់) ហើយការនេះបានកើតឡើងនៅក្នុងព្រះគ្រីស្ទ ដែលតាមរយៈទ្រង់គ្រប់ទាំងអស់ ត្រូវបានបំបែរឱ្យមករកព្រះវិញ ឬបានកើតជាថ្មី(សូមធៀបនឹង រម ៨:១៩-២៣ អភ ២:១០)។

**៥:១៨** *គ្រប់ទាំងអស់ក៏មកពីព្រះ* ព្រះអម្ចាស់ទ្រង់បានចាប់ផ្ដើមឱ្យមានការប្រោសលោះ(យហ ៣:១៦ និងការពន្យល់ រម ៥:៨) ហើយទ្រង់បានបន្តនិងធ្វើឱ្យការប្រោសលោះបានសម្រេច(ភល ១:៦ និងការពន្យល់)។ *ការងារផ្សះផ្សា* យើងជាអ្នកទទួលការផ្សះផ្សារបស់ព្រះ យើងមានអភ័យឯកសិទ្ធិ និងកាតព្វកិច្ចធ្វើជាឧបករណ៍របស់ព្រះក្នុងពេលបច្ចុប្បន្ន ដើម្បីប្រកាសពី "ដំណឹងនៃការរួបរួម"(ខ.១៩)នៅទូទាំងពិភពលោក ។ *ផ្សះផ្សា*

យើងខ្ញុំ គឺយើងខ្ញុំអង្វរ[ដ]គេជំនួសព្រះគ្រីស្ទថា ចូរឱ្យបាន
ជាមេត្រីនឹងព្រះចុះ[ឋ] ២១ដ្បិតឯព្រះអង្គដែលមិនបានស្គាល់
បាបសោះ[ឌ] នោះព្រះទ្រង់បានធ្វើឱ្យត្រឡប់ជាតួបាបជំនួស
យើងរាល់គ្នាវិញ ដើម្បីឱ្យយើងរាល់គ្នាបានត្រឡប់ទៅជា
សេចក្ដីសុចរិតរបស់ព្រះ ដោយនូវព្រះអង្គនោះឯង[ឍ]។
**៦** ១ហើយដែលយើងខ្ញុំធ្វើការជាមួយ[ណ]នឹងព្រះ បានជា
យើងខ្ញុំទូន្មានអ្នករាល់គ្នាថា កុំឱ្យទទួលព្រះគុណរបស់ព្រះ
ដោយបែបឥតប្រយោជន៍ឡើយ[ត] ២ដ្បិតទ្រង់មានបន្ទូលថា
នៅវេលាដែលគាប់ចិត្តដល់អញ នោះអញបានស្ដាប់ឯង
ហើយក្នុងថ្ងៃសង្គ្រោះ នោះអញបានជួយឯង[ថ] មើលឥឡូវ
នេះជាវេលាដែលគាប់ព្រះហឫទ័យទ្រង់ មើល ថ្ងៃនេះជា
ថ្ងៃសង្គ្រោះហើយ ។

## សេចក្ដីទុក្ខលំបាករបស់លោកប៉ុល

៣យើងខ្ញុំក៏មិនបង្អាក់បង្អន់ចិត្តដល់អ្នកណា ក្នុងកិច្ចការ
អ្វីឡើយ[ទ] ក្រែងមានអ្នកណាថ្កោលទោសចំពោះការងារ
នេះ ៤ក្នុងគ្រប់ការទាំងអស់ នោះយើងខ្ញុំខំផ្ទុកផ្ដាក់ខ្លួន ទុក
ដូចជាអ្នកបំរើព្រះ គឺក្នុងការទ្រាំទ្រជាច្រើន ក្នុងការទុក្ខ
លំបាក ការខ្វះខាត ការចង្អៀតចង្អល់ ៥កាលគេវាយ ដាក់
គុក[ធ] កើតវឹកវរ ក្នុងការនឿយហត់ ចាំយាម តមអត់[ន]
៦ដោយចិត្តស្អាត ដោយចេះដឹងដោយអត់ធ្មត់ ដោយ
សប្បុរស ដោយព្រះវិញ្ញាណបរិសុទ្ធ[ប] ដោយសេចក្ដី
ស្រឡាញ់ស្មោះត្រង់[ផ] ៧ដោយសារព្រះបន្ទូលដ៏ពិត[ព] ដោយ
ព្រះចេស្ដានៃព្រះ[ភ] ដោយកាន់គ្រឿងសាស្ត្រាវុធសុចរិត[ម]
ទាំងស្ដាំទាំងឆ្វេង ៨ដោយមានកេរ្តិ៍ឈ្មោះ ហើយត្រូវអាប់
ឱន[យ] ដោយគេនិយាយអាក្រក់[រ] ឬល្អក្តី ទុកដូចជាមនុស្ស
កំភូត តែពិតត្រង់ទេ[ល] ៩ដូចជាគ្មានអ្នកណាស្គាល់យើងខ្ញុំ តែ
មនុស្សទាំងអស់បានស្គាល់វិញ ដូចជាហៀបនឹងស្លាប់[វ] តែ
មើលយើងខ្ញុំរស់ទេ[ស] ដូចជាត្រូវវាយផ្ចាល់ តែមិនបានដល់
ស្លាប់ទេ ១០ដូចជាមានសេចក្ដីព្រួយ តែចេះតែបានសប្បាយ
វិញ[ហ] ដូចជាទ័លក្រ តែកំពុងតែចំរើនដល់មនុស្សជាច្រើន[ឡ]
ដូចជាគ្មានអ្វីសោះ[អ] តែមានគ្រប់ទាំងអស់វិញ[ក]។
១១ឱពួកកូរិនថូសអើយ មាត់យើងខ្ញុំបើកចំពោះអ្នក
រាល់គ្នាហើយ ចិត្តយើងខ្ញុំបានទូលាយឡើង[ខ] ១២អ្នករាល់គ្នា
មិនចង្អៀតក្នុងយើងខ្ញុំទេ គឺចង្អៀតតែក្នុងចិត្តរបស់អ្នក
រាល់គ្នាវិញ ១៣ខ្ញុំនិយាយនឹងអ្នករាល់គ្នា ទុកដូចជាដល់កូន
ថា[គ] ចូរសងដូចគ្នាវិញ ដោយបើកចិត្ត[ឃ]ឱ្យទូលាយឡើង
ដូច្នោះដែរ ។

## កុំឱ្យទឹមនឹមស្រៀកជា១នឹងអ្នកមិនជឿ

១៤កុំឱ្យទឹមនឹមស្រៀក[ង] ជា ១ នឹងមនុស្សមិនជឿឡើយ[ច]
ដ្បិតឯសេចក្ដីសុចរិត និងសេចក្ដីទទឹងច្បាប់ តើមានការ

**៥:២០** ដ ឧ.១៨
ឋ អស ២៧:៥
**៥:២១** ឌ ហព ៤:១៥
៧:២៦
១ពត ២:២២,២៤
១យហ ៣:៥
ឍ រម ១:១៧
១កថ ១:៣០
**៦:១** ណ ១កថ ៣:៩
២កថ ៥:២០
ត ១កថ ១៥:២
**៦:២** ថ អស ៤៩:៨
ទដ ៦៩:១៣
អស ៥៥:៦
**៦:៣** ទ មថ ៥:២៩
រម ១៤:១៣,២០
១កថ ៨:៩,១៣ ៩:១២
១០:៣២
**៦:៤** ធ កច ១៦:២៣
២កថ ១១:២៣–២៥
ន ១កថ ៤:១១
**៦:៦** ប ១កថ ២:៤
១ថន ១:៥
ផ រម ១២:៩
១ធថ ១:៥
**៦:៧** ព ២កថ ៤:២
ភ ២កថ ៤:៧
ម រម ១៣:១២
២កថ ១០:៤
អភ ៦:១០–១៨

**៦:៨** យ ១កថ ៤:១០ រ ១កថ ៤:១៣ ល មថ ២៧:៦៣ **៦:៩** វ រម ៨:៣៦ ស ២កថ ១:៨–១០ ៤:១០,១១ **៦:១០** ហ មថ ៥:១២ ២កថ ៧:៤ ភល ២:១៧ ៤:៤ កល ១:២៤ ១ថន ១:៦ ឡ ២កថ ៨:៩ អ កច ៣:៦ ក រម ៨:៣២ ១កថ ៣:២១ **៦:១១** ខ ២កថ ៧:៣ **៦:១៣** គ ១ថន ២:១១ ឃ ២កថ ៧:២ **៦:១៤** ង លប ២៤:៣ ចទ ២២:១០ ១កថ ៥:៩,១០ ច ១កថ ៦:៦

រម ៥:១០ និងការពន្យល់ ។

**៥:២១** គឺជាសេចក្ដីសង្ខេបនៃដំណឹងល្អ ។ នៅកាលវ៉ារី ព្រះគ្រីស្ទដែលជាអង្គសុចរិត បានផ្ទុកអំពើបាបរបស់យើងលើអង្គទ្រង់ ហើយបានទទួលទោសដែលយើងគួរតែទទួល (ធ្វើជាដង្វាយលោះបាប) គឺការសុគត និងការបែកចេញពីព្រះ ដូចនេះ ទ្រង់បានផ្ដល់ឱកាសឱ្យយើងទទួលសេចក្ដីសុចរិតពីទ្រង់ ដោយការប្ដូរដ៏អស្ចារ្យនេះ ហើយយើងបានផ្សះផ្សាជាមួយនឹងទ្រង់វិញ (សូមផ្ទៀប ១កថ ១:៣០ និងការពន្យល់) ។

**៦:១** *ទទួលព្រះគុណរបស់ព្រះ ដោយបែបឥតប្រយោជន៍* ការនេះកើតឡើងតាមរយៈការរស់នៅសម្រាប់តែខ្លួនឯង (៥:១៥) ។

**៦:២** *វេលាដែលគាប់ចិត្តដល់អញ . . . ថ្ងៃសង្គ្រោះ* ជាការបញ្ជាក់ដ៏ពិតមួយអំពីគ្រប់ទាំងព្រះរាជកិច្ចសង្គ្រោះដែលព្រះបានធ្វើ នៅក្នុងប្រវត្តិសាស្ត្រនៃរាស្ត្ររបស់ទ្រង់ ប៉ុន្តែបានរកឃើញនូវការសម្រេចដ៏ពិសេសក្នុងគ្រាព្រះគុណនេះ ដែលស្ថិតនៅចន្លោះការយាងមកទាំងពីរលើករបស់ព្រះគ្រីស្ទ ។ *ឥឡូវនេះ* គឺសង្កត់ធ្ងន់ទៅលើភាពបន្ទាន់នៃការអញ្ជើញរបស់ព្រះ (ទដ ៣២:៦ និងការពន្យល់) ។

**៦:៤–១០** សូមផ្ទៀបនឹង ៤:៨–១២ ។

**៦:៤** *យើងខ្ញុំខំផ្ទុកផ្ដាក់ខ្លួន ទុកដូចជាអ្នកបំរើព្រះ* ដោយហេតុថាដំណឹងល្អដែលលោកប៉ុលផ្សាយនៅក្រុងកូរិនថូសកំពុងជួបបញ្ហា គាត់បានធ្វើការផ្ទុកផ្ដាក់ខ្លួនគាត់ម្ដងទៀត ទុកដូចជាអ្នកបម្រើព្រះ ដែលផ្ទុយពីពួកសាវកខុសឆ្គង ដែលបម្រើតែប្រយោជន៍ផ្ទាល់ខ្លួន ។

**៦:៥** *ដាក់គុក* មើលឧទាហរណ៍ កច ១៦:២៣ អភ ៣:១ ភល ១:១៣–១៤ កល ៤:១៨ ២ធថ ១:១៦ ភល ១ ។

**៦:៧** *គ្រឿងសាស្ត្រាវុធសុចរិត* សូមផ្ទៀប អភ ៦:១៤–១៧ និងការពន្យល់ ។

**៦:១០** *កំពុងតែចំរើនដល់មនុស្សជាច្រើន* ទ្រព្យសម្បត្តិដ៏ពិត គឺមិនមាននៅក្នុងលោកីយនេះទេ ប៉ុន្តែ ទ្រព្យសម្បត្តិដ៏ពិតមាននៅក្នុងការ "មានខាងឯព្រះ" (លក ១២:២១) ។ ទោះបីជាគ្រីស្ទបរិស័ទគ្មានអ្វីដែលជារបស់ល្អរបស់លោកីយនេះក៏ដោយ ក៏ពួកគេមានអ្វីៗគ្រប់យ៉ាងនៅក្នុងព្រះដ៏ជាព្រះអម្ចាស់នៃគ្រប់ទាំងអស់ (សូមផ្ទៀប ១កថ ១:៤–៥ ៣:២១–២៣ អភ ២:៧ ៣:៨ ភល ៤:១៩ និងការពន្យល់, កល ២:៣) ។

**៦:១១–១៣** ជានិច្ចជាកាលនៅក្នុងទំនាក់ទំនង សាវកប៉ុលតែងតែស្មោះត្រង់ ហើយគ្មានអ្វីបិទបាំងនឹងពួកជំនុំកូរិនថូសឡើយ (សូមផ្ទៀប ១:១២–១៤ ៤:២ និងការពន្យល់) ប៉ុន្តែពួកសាវកខុសឆ្គងដែលនៅក្នុងចំណោមពួកគេ បានព្យាយាមបញ្ចុះបញ្ចូលថា លោកប៉ុលមិនពិតជាស្រឡាញ់ពួកគេឡើយ ។ ពេលនេះពួកលោកទាំងនោះបានប្រើល្បិចអូសទាញអ្នកដែលបានទទួលសេចក្ដីស្រឡាញ់ពីលោកប៉ុល (សូមផ្ទៀប ១១:១១) ។

**៦:១៤** *កុំឱ្យទឹមនឹមស្រៀក ជា១នឹងមនុស្សមិនជឿ* សូមផ្ទៀប ចទ ២២:១០ ។

ប្រកបអ្វីនឹងគ្នា ឬពន្លឺ និងងងឹតលាយឡំគ្នាដូចម្ដេចបាន[ឆ]
15 តើព្រះគ្រីស្ទ និងអារក្សបេលាលត្រូវអ្វីនឹងគ្នា[ជ] ឬអ្នកជឿ[ឈ]
មានចំណែកអ្វីនឹងអ្នកដែលមិនជឿ[ញ] 16 តើវិហារនៃព្រះ
សំណាំអ្វីនឹងរូបព្រះ[ដ] ដ្បិតអ្នករាល់គ្នាជាវិហារ[ឋ]នៃព្រះដ៏
មានព្រះជន្មរស់[ឌ]ដូចជាព្រះទ្រង់មានបន្ទូលថា «អញនឹងនៅ
ក្នុងគេ ហើយនិងដើរជាមួយផង អញនឹងធ្វើជាព្រះដល់គេ
ហើយគេនឹងធ្វើជារាស្ត្រដល់អញ»[ឍ] 17 ហេតុនោះបានជា
ព្រះអម្ចាស់ទ្រង់មានបន្ទូលថា «ចូរចេញពីកណ្ដាលពួកគេ
ទៅ[ណ] ហើយញែកខ្លួនទៅដោយឡែក កុំឱ្យពាល់របស់ស្មោក
គ្រោកឡើយ នោះអញនឹងទទួលឯងរាល់គ្នា[ត] 18 អញនឹង
ធ្វើជាឪពុកដល់ឯងរាល់គ្នា ហើយឯងរាល់គ្នានឹងធ្វើជា
កូនប្រុសកូនស្រីដល់អញ[ថ] នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
ដ៏មានព្រះចេស្តាបំផុត»[ទ] ។
**៧** 1 ដូច្នេះ ពួកស្ងួនភ្ងាអើយ[ធ] ដែលមានសេចក្ដីសន្យាទាំង
នេះ[ន] នោះត្រូវឱ្យយើងរាល់គ្នាសំអាតខ្លួនយើង ពីគ្រប់ទាំង
សេចក្ដីដែលប្រឡាក់ខាងសាច់ឈាមចេញ ហើយខាង
ព្រលឹងវិញ្ញាណផង ព្រមទាំងបង្ហើយសេចក្ដីបរិសុទ្ធ[ប] ដោយ
នូវសេចក្ដីកោតខ្លាចដល់ព្រះ ។

## សេចក្ដីអំណររបស់លោកប៉ុល

2 ចូរទទួលយើងខ្ញុំ[ផ] យើងខ្ញុំមិនបានធ្វើខុសនឹងអ្នកណា
ក៏មិនបានបង្ខូចអ្នកណា ឬបំបាត់អ្នកណាសោះឡើយ 3 ខ្ញុំ
និយាយដូច្នេះ មិនមែនចង់ប្រកាន់ទោសដល់អ្នកណាទេ
ដ្បិតខ្ញុំបាននិយាយអំពីមុនរួចហើយថា អ្នករាល់គ្នានៅក្នុង
ចិត្តយើងខ្ញុំ[ព] ឱ្យបានស្លាប់ឬរស់ជាមួយគ្នា 4 ខ្ញុំទុកចិត្ត
នឹងអ្នករាល់គ្នាជាខ្លាំង ខ្ញុំអួតពីអ្នករាល់គ្នាជាខ្លាំងដែរ[ភ]
ខ្ញុំមានចិត្តពេញដោយសេចក្ដីក្សេមក្សាន្ត ខ្ញុំមានសេចក្ដី
អំណរលើសលប់[ម] ពីគ្រប់ទាំងសេចក្ដីវេទនារបស់យើងខ្ញុំ[យ]
5 ដ្បិតកាលយើងខ្ញុំបានចូលទៅក្នុងស្រុកម៉ាសេដូន[រ] នោះ
យើងខ្ញុំឥតមានសេចក្ដីស្រាកស្រាន្ត ខាងសាច់ឈាមសោះ
មានសុទ្ធតែសេចក្ដីលំបាកវិញ[ល] គឺនៅខាងក្រៅមានសេច
ក្ដីតតាំង ហើយខាងក្នុងមានសេចក្ដីភ័យខ្លាច[វ] 6 តែព្រះ
អង្គដែលកំសាន្តចិត្តពួកអ្នកដែលត្រូវបន្ទាប[ស] ទ្រង់ក៏បាន

**៦:១៤** ឆ អភ ៥:៧,១១ ១យហ ១:៦
**៦:១៥** ជ ១កថ ១០:២១
ឈ កច ៥:១៤
ញ ១កថ ៦:៦
**៦:១៦** ដ ១កថ ១០:២១ ឋ ១កថ ៣:១៦ ឌ មថ ១៦:១៦
ឍ លវ ២៦:១២ យរ ៣២:៣៨ អក ៣៧:២៧ វវ ២១:៣
**៦:១៧** ណ វវ ១៨:៤
ត អស ៥២:១១ អក ២០:៣៤,៤១
**៦:១៨** ថ នក ៤:២២ ២សយ ៧:១៤ ១របា ១៧:១៣ អស ៤៣:៦ រម ៨:១៤
ទ ២សយ ៧:៨
**៧:១** ធ ១កថ ១០:១៤
ន ២កថ ៦:១៧,១៨
ប ១ថន ៤:៧ ១ពត ១:១៥,១៦ **៧:២** ផ ២កថ ៦:១២,១៣
**៧:៣** ព ២កថ ៦:១១,១២ ភល ១:៧ **៧:៤** ភ ខ.១៤ ២កថ ៨:២៤ ម ខ.១៣
យ ២កថ ៦:១០ **៧:៥** រ ២កថ ២:១៣ កច ១៦:៩ **៧:៥** ល ២កថ ៤:៨
វ ចទ ៣២:២៥ **៧:៦** ស ២កថ ១:៣,៤

បានជាលោកប៉ុលហាមដូចនេះពីព្រោះ វាអាចធ្វើឱ្យចុះខ្សោយដល់ ការប្ដេជ្ញាចិត្ត សេចក្ដីសុចរិត ឬភាពជាគំរូរបស់គ្រីស្ទបរិស័ទ ហើយទំនាក់ទំនងនេះអាចនឹងជួបបរាជ័យ ។ កាលលើកមុន លោកប៉ុលបានពន្យល់ថា ការនេះមិនមែនមានន័យថា ជាការផ្ដាច់ខ្លួនចេញពីអ្នកមិនជឿនោះឡើយ(១កថ ៥:៩,១០)។ លោកប៉ុលក៏បានប្រាប់គ្រីស្ទបរិស័ទឱ្យបន្តរួមរស់ជាមួយប្ដីប្រពន្ធដែលមិនជឿព្រះផងដែរ (១កថ ៧:១២,១៣)។

**៦:១៥** *អារក្សបេលាស* គឺអារក្សសាតាំង(ចទ ១៣:១៣ និងការពន្យល់)។

**៦:១៦** *វិហារនៃព្រះសំណាំអ្វីនឹងរូបព្រះ* មិនអាចឱ្យមានការវិលត្រឡប់ទៅរក ឬការត្រូវរូវគ្នាជាមួយនឹងការថ្វាយបង្គំរូបព្រះបានឡើយ ពីព្រោះជាការលះបង់ចោលដំណឹងល្អ(សូមផ្ទៀប ១ថន ១:៩)។ *វិហារនៃព្រះដ៏មានព្រះជន្មរស់* ដែលត្រូវបានសាងសង់ឡើងពី"ថ្មដ៏រស់" គឺគ្រីស្ទបរិស័ទដែលជាអ្នកជឿ(១ពត ២:៥ និងការពន្យល់) ដូចនេះវិហារនេះមិនបង្កើតឱ្យមានទំនាក់ទំនងដែលស្មោកគ្រោក និងមិនបរិសុទ្ធឡើយ(សូមផ្ទៀបនឹង ១កថ ៦:១៩–២០)។ *ជាព្រះដល់គេ . . . ជា រាស្ត្រដល់អញ* ឃ្លានេះជាសេចក្ដីបញ្ជាក់ដ៏ខ្ពស់បំផុតក្នុងសេចក្ដីសញ្ញាចាស់ អំពីកិច្ចសន្យាទំនាក់ទំនងរវាងព្រះអម្ចាស់ និងរាស្ត្ររបស់ទ្រង់(យរ ៧:២៣ ហស ១:៩ សក ៨:៨ និងការពន្យល់)។

**៦:១៧** *ចេញពីកណ្ដាលពួកគេ* មើល វវ ១៨:៤ និងការពន្យល់ ។

**៧:១** *សេចក្ដីបរិសុទ្ធ* (១កថ ១:២ នក ៣:៥ លវ ១១:៤៤ រម ៦:២២ ១ថន ៤:៧ និងការពន្យល់)។

**៧:២** *យើងខ្ញុំមិនបានធ្វើខុសនឹងអ្នកណា* ឃ្លានេះបញ្ជាក់ថា លោកប៉ុល និងគូកនរបស់គាត់ មិនប្រព្រឹត្តអំពើអយុត្តិធម៌ចំពោះមនុស្សណាម្នាក់ទេ ។ ម្យ៉ាងទៀត នៅពេលនោះមានពួកគ្រូខុសឆ្គងជាច្រើនបានទាស់ប្រឆាំងនឹងលោកប៉ុល និងគូកនរបស់គាត់ (ប្រៀបធៀប ១សយ ១២:៣)។

**៧:៣** បទគម្ពីរនេះលោកប៉ុលបញ្ជាក់យ៉ាងច្បាស់ អំពីសេចក្ដីស្រលាញ់របស់គាត់ ចំពោះពួកជំនុំនៅទីក្រុងកូរិនថូស ហើយគាត់ចង់ឱ្យពួកគេមានការឆ្លើយតបវិញ ដោយបង្ហាញនូវសេចក្ដីស្រលាញ់របស់ពួកគេ (ប្រៀបធៀប ៦:១១–១៣ និងការពន្យល់)។

**៧:៤** *ខ្ញុំទុកចិត្តនឹងអ្នករាល់គ្នាជាខ្លាំង . . . ខ្ញុំមានសេចក្ដីអំណរលើសលប់* សេចក្ដីដែលបានរៀបរាប់ចាប់ពី "២:១៤" មកដល់ចំណុចនេះ បញ្ជាក់នូវសេចក្ដីអំណររបស់លោកប៉ុល ។ គាត់បានរង់ចាំទទួលព័ត៌មាន មកពីពួកជំនុំនៅទីក្រុងកូរិនថូស ដោយមានចិត្តអន្ទះសាយ៉ាងខ្លាំង ហើយទីបំផុតគាត់បានពេញជាសេចក្ដីអំណរឡើងវិញ ក្នុងពេលដែលគាត់បានទទួលព័ត៌មានអំពីពួកគេតាមរយៈលោកទីតុស ។

**៧:៥** *យើងខ្ញុំ* សំដៅលើលោកប៉ុល និងលោកទីតុស ។ លោកប៉ុលបានបង្ហាញនូវទឹកចិត្តរបស់គាត់ ក្នុងខណៈពេលដែលគាត់បានស្នាក់នៅឯទីក្រុងទ្រអាស ។ នៅពេលដែលលោកប៉ុលមកដល់ស្រុកម៉ាសេដូន គាត់បានកម្សាន្តចិត្ត ព្រោះបានជួបនឹងលោកទីតុស ដែលត្រឡប់មកពីទីក្រុងកូរិន–ថូស(ខ.៧) និងទទួលបានការរាក់ទាក់ពីពួកជំនុំនៅទីនោះយ៉ាងកក់ក្ដៅបំផុត ។ ពួកជំនុំនៅទីក្រុងកូរិនថូសបានសម្ដែងនូវការសោកស្ដាយ ចំពោះទង្វើដែលពួកគេធ្លាប់ប្រឆាំងនឹងលោកប៉ុល ដូច្នេះហើយបានជាធ្វើឱ្យគាត់(ប៉ុល)មានសេចក្ដីអំណរជាខ្លាំង ។ *ស្រុកម៉ាសេដូន* (មើលការពន្យល់ ១:១ ភល ៤:១៥)។

**៧:៦** *ព្រះអង្គដែលកំសាន្តចិត្តពួកអ្នកដែលត្រូវបន្ទាប* (មើលការពន្យល់ ១:៣ ប្រៀបធៀបនឹង ទដ ៤២:៥,១១ ៤៣:៥)។ *ទីតុស* (សូមមើលសេចក្ដីផ្ដើមកណ្ឌគម្ពីរទីតុសត្រង់ចំណុចអ្នកទទួល)។

កំសាន្តចិត្តយើងខ្ញុំ ដោយអ្នកទីតុសមកដល់[ហ] ៧ មិនមែនដោយ
គាត់មកដល់តែប៉ុណ្ណោះ គឺដោយព្រោះសេចក្ដីក្សេម ក្សាន្ត
ដែលបានកំសាន្តចិត្តគាត់ ពីដំណើរអ្នករាល់គ្នាដែរគាត់បាន
ប្រាប់ពីសេចក្ដីសង្វាត សេចក្ដីទុក្ខព្រួយ នឹងសេចក្ដី ឧស្សាហ៍
របស់អ្នករាល់គ្នាដល់ខ្ញុំ បានជាខ្ញុំមានចិត្តអររីត តែខ្លាំងឡើង
៨ ដ្បិតបើសិនជាខ្ញុំបានធ្វើឱ្យអ្នករាល់គ្នាព្រួយចិត្ត ដោយ
សំបុត្រនោះ[ឡ] ខ្ញុំក៏មិនស្ដាយដែរ ទោះបើបានស្ដាយពីមុនក៏
មែន ព្រោះខ្ញុំឃើញថា សំបុត្រនោះបានធ្វើឱ្យអ្នករាល់គ្នា
ព្រួយ សូម្បីតែ១ភ្លែតក៏មែន ៩ គង់តែខ្ញុំអរក្នុងពេលឥឡូវ
នេះវិញ មិនមែនដោយព្រោះអ្នករាល់គ្នាកើតទុក្ខព្រួយទេ
គឺដោយព្រោះអ្នករាល់គ្នាព្រួយ រហូតដល់បានប្រែចិត្តវិញ
ទេតើ ដ្បិតអ្នករាល់គ្នាបានកើតទុក្ខព្រួយបែបដែលគាប់
ព្រះហឫទ័យដល់ព្រះ ដើម្បីកុំឱ្យអ្នករាល់គ្នាខូចខាតអ្វី
ដោយព្រោះយើងខ្ញុំឡើយ ១០ ព្រោះសេចក្ដីព្រួយដែលគាប់
ព្រះហឫទ័យដល់ព្រះ នោះរមែងនាំឱ្យប្រែចិត្តឡើង ប្រ
យោជន៍ឱ្យបានសង្គ្រោះ[អ] ជាសេចក្ដីដែលមិនត្រូវស្ដាយ
ឡើយ តែសេចក្ដីព្រួយរបស់លោកីយ នោះបង្កើតសេចក្ដី
ស្លាប់វិញ ១១ ដ្បិតមើល សេចក្ដីនេះឯង គឺដែលអ្នករាល់គ្នា
មានសេចក្ដីព្រួយដ៏គាប់ដល់ព្រះហឫទ័យនៃព្រះ នោះបាន
បង្កើតឱ្យអ្នករាល់គ្នាមានសេចក្ដីសង្វាត សេចក្ដីដោះសា
សេចក្ដីគ្នាន់ក្នាញ់ សេចក្ដីភ័យខ្លាច[ក] សេចក្ដីនឹករឮក សេចក្ដី
ឧស្សាហ៍ និងសេចក្ដីសងសឹកជាខ្លាំងទាំងម្ល៉េះ អ្នករាល់គ្នា
បានសំដែងយ៉ាងច្បាស់ថា ខ្លួនបរិសុទ្ធក្នុងដំណើរនេះគ្រប់
ជំពូក ។
១២ ដូច្នេះ ដែលខ្ញុំបានធ្វើសំបុត្រនេះ ផ្ញើមកអ្នករាល់គ្នា[ខ]
នោះមិនមែនដោយព្រោះតែអ្នកដែលធ្វើខុស ឬដោយ
ព្រោះអ្នកដែលត្រូវគេធ្វើខុសនោះទេ[គ] គឺដើម្បីនឹងសំដែង
ឱ្យឃើញសេចក្ដីសង្វាតរបស់អ្នករាល់គ្នា ដល់យើងខ្ញុំ នៅ
ចំពោះព្រះទេតើ ១៣ ហេតុនោះបានជាយើងខ្ញុំបានសេចក្ដី
ក្សាន្តចិត្ត ដោយសារសេចក្ដីកំសាន្តរបស់អ្នករាល់គ្នា ក៏មាន
សេចក្ដីអំណរលើសទៅទៀត ដោយឃើញសេចក្ដីអំណរ
របស់ទីតុស[ឃ] ដ្បិតអ្នករាល់គ្នាបានលំហើយចិត្តគាត់ ១៤ ពី
ព្រោះបើសិនជាខ្ញុំបានអួតនឹងគាត់ ពីដំណើរអ្នករាល់គ្នា
យ៉ាងណាខ្លះ[ង] នោះខ្ញុំមិនខ្មាសទេ ព្រោះសេចក្ដីដែលយើង
ខ្ញុំបានអួតនឹងទីតុស[ច] ពីអ្នករាល់គ្នា នោះឃើញថាពិតមែន
ដូចជាសេចក្ដីទាំងប៉ុន្មាន ដែលយើងខ្ញុំបានប្រាប់ដល់អ្នក
រាល់គ្នាក៏ពិតដែរ ១៥ ហើយគាត់មានចិត្តស្រឡាញ់ដល់អ្នក
រាល់គ្នាលើសទៅទៀត ដោយនឹកឃើញពីអ្នករាល់គ្នាចុះ
ចូលតាម[ឆ] ហើយដែលទទួលគាត់ដោយភ័យខ្លាច ហើយ
ញាប់ញ័រ[ជ] ១៦ ខ្ញុំត្រេកអរណាស់ ពីព្រោះខ្ញុំទុកចិត្តនឹងអ្នក
រាល់គ្នា ក្នុងគ្រប់ការទាំងអស់[ឈ] ។

## ការលើកទឹកចិត្តពីភាពសប្បុរស

**៨** ១ បងប្អូនអើយ យើងខ្ញុំប្រាប់ឱ្យអ្នករាល់គ្នាដឹង ពីព្រះគុណ
នៃព្រះ ដែលបានផ្ដល់មកពួកជំនុំទាំងប៉ុន្មាន នៅស្រុក
ម៉ាសេដូន[ញ] ថា ២ កាលមានសេចក្ដីទុក្ខលំបាកកំពុងតែល្បង
គេជាខ្លាំង នោះសេចក្ដីអំណរជាបរិបូរ និងសេចក្ដីកំសត់
ទុគ៌តរបស់គេ បានបណ្ដាលឱ្យគេមានចិត្តសទ្ធាដ៏លើស
លប់វិញ[ដ] ៣ ដ្បិតខ្ញុំធ្វើបន្ទាល់ថា គេស្ម័គ្រចិត្តតាមកំឡាំងគេ
ហើយហួសកំឡាំងគេផង[ឋ] ៤ ក៏សូមយើងខ្ញុំដោយពាក្យទទូច
អង្វរ ឱ្យយើងខ្ញុំទទួលយកទានរបស់គេនេះ ដែលជាសេចក្ដី

**៧:៦** ហ ៦.១៣ ២កថ ២:១៣
**៧:៨** ឡ ២កថ ២:២,៤
**៧:១០** អ កថ ១១:១៨
**៧:១១** ក ៦.៧
**៧:១២** ខ ៦.៨ ២កថ ២:៣,៩
គ ១កថ ៥:១,២
**៧:១៣** ឃ ៦.៦ ២កថ ២:១៣
**៧:១៤** ង ៦.៤ ច ៦.៦
**៧:១៥** ឆ ២កថ ២:៩ ១០:៦ ជ ទដ ៥៥:៥ ១កថ ២:៣ ភល ២:១២
**៧:១៦** ឈ ២កថ ២:៣
**៨:១** ញ កច ១៦:៩
**៨:២** ដ នក ៣៦:៥ ២កថ ៩:១១
**៨:៣** ឋ ១កថ ១៦:២

**៧:៨** លោកប៉ុលមានការសោកស្ដាយ ចំពោះសេចក្ដីដែលគាត់បានសរសេរផ្ញើទៅពួកជំនុំនៅទីក្រុងកូរិនថូស ដែលធ្វើឱ្យពួកគេមានចិត្តព្រួយ *សំបុត្រនោះ* មានមតិខ្លះយល់ថា សំបុត្រដែលលោកប៉ុលសរសេរផ្ញើទៅពួកជំនុំនៅទីក្រុងកូរិនថូស គឺអាចជាកណ្ឌគម្ពីរ "១កូរិនថូស" ឬ "២កូរិនថូស ១០–១៣" ប៉ុន្តែ មានមតិខ្លះទៀតយល់ថា វាអាចជាសំបុត្រផ្សេងទៀត (២:១ និងការពន្យល់) ។

**៧:១០** *សេចក្ដីព្រួយដែលគាប់ព្រះហឫទ័យដល់ព្រះ* សំដៅលើសេចក្ដីដែលនាំទៅដល់ការប្រែចិត្ត ។ ការប្រែចិត្តនឹងនាំទៅដល់ការអត់ទោស ហើយការអត់ទោសនាំទៅដល់សេចក្ដីសង្គ្រោះ ។ *សេចក្ដីព្រួយរបស់លោកីយ* កើតឡើង ដោយសារបញ្ហារបស់លោកីយ ។ ប្រសិនបើយើងមានចិត្តរឹងមានះ និងបដិសេធការកែតម្រង់ពីព្រះអម្ចាស់ នោះយើងនឹងទទួលនូវសេចក្ដីព្រួយរបស់លោកីយជាមិនខាន ។ សេចក្ដីព្រួយរបស់លោកីយនាំមកនូវសេចក្ដីអស់សង្ឃឹម និងនាំទៅដល់សេចក្ដីស្លាប់ ។

**៧:១៥** *អ្នករាល់គ្នាចុះចូលតាម* ត្រង់ចំណុចនេះបញ្ជាក់ថា នៅពេលដែលលោកទីតុសបានចាកចេញពីទីក្រុងកូរិនថូស ដើម្បីនាំយកនូវព័ត៌មានទាំងឡាយមកឯលោកប៉ុលនោះ ពុំសូវមានពួកអ្នកប្រឆាំងខ្លាំងក្លាប៉ុន្មានទេ (មើលការពន្យល់ ១០:១) ។

**៨:១–៩:១៥** ក្នុងវគ្គនេះ លោកប៉ុលបញ្ជាក់អំពីបញ្ហា ទាក់ទងទៅនឹងប្រាក់ដង្វាយដែលប្រមូលបាន សម្រាប់យកទៅជួយពួកជំនុំ ដែលកំពុងជួបប្រទះនូវការខ្វះខាតនៅឯទីក្រុងយេរូសាឡិម ។ គាត់បញ្ជាក់ថា ពួកជំនុំនៅទីក្រុងកូរិនថូសបានចាប់ផ្ដើមធ្វើធ្វើការប្រមូលហើយ ប៉ុន្តែ មិនទាន់បានចប់សព្វគ្រប់នៅឡើយទេ ។

**៨:១-២** ពួកជំនុំនៅទីក្រុងភីលីព និងក្រុងថែស្សាឡូនីច ត្រូវបានគេស្គាល់ជាទូទៅនៅស្រុកម៉ាសេដូន ។ ទោះបីពួកជំនុំទាំងពីរនេះជួបប្រទះនឹងការលំបាក និងការខ្វះខាតយ៉ាងណាក៏ដោយ ក៏ពួកគេបានធ្វើជាគំរូដ៏ល្អដល់ពួកជំនុំនៅក្នុងតំបន់នោះដែរ ។ ដូច្នេះហើយ បានជាលោកប៉ុលសង្ឃឹមថា ពួកជំនុំនៅទីក្រុងកូរិនថូសនឹងយកគំរូតាមពួកជំនុំនៅស្រុកម៉ាសេដូន ក្នុងការថ្វាយដង្វាយទៅជួយដល់ពួកជំនុំ នៅឯទីក្រុងយេរូសាឡិមដែរ ។

ប្រកប[ឌ]ក្នុងការងារ[ឍ]សំរាប់ពួកបរិសុទ្ធ[ណ] ៥មិនមែនដូចជា
យើងខ្ញុំបានសង្ឃឹមតែប៉ុណ្ណោះទេ គឺគេបានប្រគល់ខ្លួនគេ
ទៅព្រះអម្ចាស់ជាមុនដំបូង ហើយដល់យើងខ្ញុំថែមទៀត
តាមបំណងព្រះហឫទ័យព្រះ ៦បានជាយើងខ្ញុំទូន្មាន[ត]ទីតុស[ថ]
តាមការដែលគាត់បានចាប់ផ្ដើមធ្វើហើយ ឱ្យគុណនេះបាន
ពេញខ្នាត[ទ] នៅក្នុងពួកអ្នករាល់គ្នាដែរ ៧ដើម្បីឱ្យអ្នករាល់
គ្នាបានធ្វើគុណនេះរឹតតែច្រើនឡើង[ធ] ដូចជាបានចំរើនក្នុង
គ្រប់សេចក្ដីឯទៀត គឺក្នុងសេចក្ដីជំនឿពាក្យសំដី ចំណេះ[ន]
សេចក្ដីឧស្សាហ៍គ្រប់ជំពូក ហើយក្នុងសេចក្ដីស្រឡាញ់របស់
អ្នករាល់គ្នា ដល់យើងខ្ញុំដែរ ៨ខ្ញុំនិយាយដូច្នេះ មិនមែន
ជាពាក្យបង្គាប់ទេ[ប] គឺចង់តែយកសេចក្ដីឧស្សាហ៍របស់គេ
មកល្បងលមើលចំពោះសេចក្ដីស្រឡាញ់របស់អ្នករាល់គ្នា
តើពិតត្រង់ឬទេប៉ុណ្ណោះ ៩ដ្បិតអ្នករាល់គ្នាបានស្គាល់ព្រះ
គុណ[ផ]នៃព្រះយេស៊ូវគ្រីស្ទ[ព] ជាព្រះអម្ចាស់នៃយើងរាល់គ្នា
ហើយ ថាទោះបើទ្រង់ជាសេដ្ឋីក៏ដោយ គង់តែទ្រង់បាន
ត្រឡប់ជាក្រ[ភ] ដោយព្រោះអ្នករាល់គ្នា ដើម្បីឱ្យអ្នករាល់
គ្នាបានមានឡើង ដោយសារសេចក្ដីកម្ររបស់ទ្រង់[ម] ១០ខ្ញុំ
សំដែងគំនិតខ្ញុំ[យ]ក្នុងការនេះដែរ ដ្បិតនោះមានប្រយោជន៍
ដល់អ្នករាល់គ្នា ដែលអ្នករាល់គ្នាមិនគ្រាន់តែចាប់ផ្ដើម
ធ្វើតែប៉ុណ្ណោះ គឺមានទាំងចិត្តប្រាថ្នាចង់ធ្វើ តាំងតែពីឆ្នាំ
មុនមកហើយផង[រ] ១១ឥឡូវនេះ ចូរបំពេញការនោះចុះ
ដើម្បីឱ្យអ្នករាល់គ្នាបានបំពេញតាមដែលមាន[ល] ដូចជា
បំណង ដែលអ្នករាល់គ្នាប្រុងប្រៀបនឹងធ្វើមកហើយនោះ
ដែរ ១២ដ្បិតបើសិនជាប្រុងប្រៀបនឹងធ្វើហើយ នោះ
ព្រះទ្រង់ទទួលអ្នកតាមដែលមាន[វ] មិនមែនតាមដែលគ្មាន
នោះទេ ១៣ការនោះមិនមែនដើម្បីឱ្យអ្នកឯទៀតបានទំនេរ
ហើយឱ្យអ្នករាល់គ្នាមានសេចក្ដីលំបាកនោះទេ គឺឱ្យបាន
ស្មើគ្នាវិញ ឱ្យសេចក្ដីបរិបូររបស់អ្នករាល់គ្នាក្នុងជាន់នេះ
បានបំពេញការដែលគេខ្វះខាត ១៤ដើម្បីកាលណាគេមាន
បរិបូរ នោះនឹងបានបំពេញការ ដែលអ្នករាល់គ្នាខ្វះខាត
វិញ[ស] ប្រយោជន៍ឱ្យបានស្មើគ្នាឡើង ១៥ដូចជាសេចក្ដីដែល
ចែងទុកមកថា «អ្នកណាដែលរើសបានច្រើន នោះគ្មាន
សល់ឡើយ ឯអ្នកដែលរើសបានតិច នោះមិនបានខ្វះទេ»[ហ]។

## លោកទីតុសត្រូវបានបញ្ជូនទៅទីក្រុងកូរិនថូស

១៦អរព្រះគុណដល់ព្រះ[ឡ] ដែលទ្រង់បានបណ្ដាលចិត្ត[អ]
ទីតុស[ក] ឱ្យមានសេចក្ដីឧស្សាហ៍នោះ ដល់អ្នករាល់គ្នាដែរ
១៧គាត់បានទទួលសេចក្ដីទូន្មាននោះ តែដោយព្រោះគាត់
មានសេចក្ដីឧស្សាហ៍លើសទៅទៀត បានជាគាត់មកឯអ្នក

**៨:៤** ឌ ឧ.១ ឍ កច ២៤:១៧ ណ កច ៩:១៣ **៨:៦** ត ឧ.១៧ ២កថ ១២:១៨ ថ ឧ.១៦,២៣ ២កថ ២:១៣ ទ ឧ.១០,១១ **៨:៧** ធ ២កថ ៩:៨ ន រម ១៥:១៤ ១កថ ១:៥ ១២:៨ ១៣:១,២ ១៤:៦ **៨:៨** ប ១កថ ៧:៦ **៨:៩** ផ រម ៣:២៤ ព ២កថ ១៣:១៤ ភ មថ ២០:២៨ ភល ២:៦-៨ ម ២កថ ៦:១០ **៨:១០** យ ១កថ ៧:២៥,៤០ រ ១កថ ១៦:២,៣ ២កថ ៩:២ **៨:១១** ល ឧ.១២,១៩ នក ២៥:២ ២កថ ៩:២ **៨:១២** វ មក ១២:៤៣,៤៤ ២កថ ៩:៧

**៨:១៤** ស កច ៤:៣៤ ២កថ ៩:១២ **៨:១៥** ហ នក ១៦:១៨
**៨:១៦** ឡ ២កថ ២:១៤ អ វវ ១៧:១៧ ក ២កថ ២:១៣

**៨:៥** *គេបានប្រគល់ខ្លួនគេទៅព្រះអម្ចាស់ជាមុនដំបូង* ឃ្លានេះបញ្ជាក់អំពីការថ្វាយដ៏ពិតប្រាកដរបស់គ្រីស្ទបរិស័ទទៅព្រះអម្ចាស់ ។ ព្រះគុណរបស់ព្រះអម្ចាស់បានធ្វើឱ្យជីវិត និងចរិតលក្ខណៈនៃអ្នកជឿដល់ទ្រង់ បានទទួលនូវការផ្លាស់ប្រែ (១២:៩-១០)។

**៨:៦** *យើងខ្ញុំទូន្មានទីតុស* ការរៃប្រាក់ដង្វាយបានចាប់ផ្ដើមនៅក្នុងពួកជំនុំនៅទីក្រុងកូរិនថូស ក្រោមការដឹកនាំរបស់លោកទីតុស (ខ.១០ ៩:២) ប៉ុន្តែ ក្រោយមកមានការថយចុះយ៉ាងខ្លាំង ។ លោកប៉ុលបានបញ្ជូនលោកទីតុសឱ្យទៅឯពួកគេវិញ ដោយនាំយកសំបុត្ររបស់គាត់ទៅជាមួយផង ដើម្បីឱ្យពួកគេបំពេញនូវគោលបំណងនៃទង្វើដែលប្រកបដោយព្រះគុណ។

**៨:៧** *ដើម្បីឱ្យអ្នករាល់គ្នាបានធ្វើគុណនេះរឹតតែច្រើនឡើង ដូចជាបានចំរើនក្នុងគ្រប់សេចក្ដីឯទៀត* (សូមប្រៀបធៀបនឹង ១កថ ១:៤-៧)។

**៨:៨** *ខ្ញុំនិយាយដូច្នេះ មិនមែនជាពាក្យបង្គាប់ទេ* មានន័យថា ការថ្វាយ និងភាពសប្បុរសដ៏ពិតប្រាកដមិនត្រូវបានបង្ខំទេ ។ *សេចក្ដីឧស្សាហ៍របស់គេ* សំដៅលើសេចក្ដីឧស្សាហ៍នៃពួកជំនុំនៅស្រុកម៉ាសេដូន (ខ.១-៥)។ *សេចក្ដីស្រលាញ់របស់អ្នករាល់គ្នា* បញ្ជាក់ថា ពួកគេអាចបង្ហាញនូវសេចក្ដីស្រលាញ់របស់ខ្លួន តាមរយៈការថ្វាយដោយគ្មានការបង្ខិតបង្ខំ និងដោយស្មោះពីចិត្តតែម្ដង ។

**៨:៩** *ទ្រង់ជាសេដ្ឋីក៏ដោយ គង់តែទ្រង់បានត្រឡប់ជាក្រ* មានន័យថា ព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត បានមកយកកំណើតជាមនុស្ស និងបានសុគតដើម្បីលោះបាបមនុស្សលោក ដូច្នេះបញ្ជាក់ថា ទ្រង់បានធ្វើឱ្យព្រះអង្គទ្រង់ក្លាយជាទទេ (ភល ២:៧ និងការពន្យល់)។ *ដើម្បីឱ្យអ្នករាល់គ្នាបានមានឡើង ដោយសារសេចក្ដីកម្ររបស់ទ្រង់* មានន័យថា ការសុគតរបស់ព្រះយេស៊ូវគ្រីស្ទនៅលើឈើឆ្កាង គឺដើម្បីឱ្យយើងបានចម្រើនឡើងខាងឯវិញ្ញាណ (២:៦-៧)។

**៨:១១** កិច្ចការដែលពួកជំនុំនៅទីក្រុងកូរិនថូស បានចាប់ផ្ដើមមួយឆ្នាំកន្លងទៅហើយ (ខ.១០) ពួកគេត្រូវតែបញ្ចប់ឱ្យបានសព្វគ្រប់ (មើលការពន្យល់ ខ.៦)។

**៨:១២** *ទ្រង់ទទួលអ្នកតាមដែលមាន* មានន័យថា ម្នាក់ៗត្រូវថ្វាយដល់ព្រះអម្ចាស់ដោយចិត្តសប្បុរស ទោះជាមានចំនួនតិចតួចយ៉ាងណាក៏ដោយ ក៏មិនត្រូវធ្វើដោយមានការបង្ខិតបង្ខំដែរ (មក ១២:៤១-៤៤ មើលការពន្យល់ មក ១២:៤២)។ លោកប៉ុលជាអ្នកសរសេរសំបុត្រទៅពួកជំនុំនៅទីក្រុងកូរិនថូស ឱ្យប្រមូលនូវដង្វាយដើម្បីយកទៅជួយពួកជំនុំនៅឯទីក្រុងយេរូសាឡិម (១កថ ១៦:១-២)។

**៨:១៣-១៥** គោលបំណងរបស់លោកប៉ុលគឺ ចង់ឱ្យពួកជំនុំទាំងអស់ចែកចាយនូវអ្វីដែលខ្លួនមាន ដល់ពួកបងប្អូនដែលខ្វះខាត ដើម្បីឱ្យពួកជំនុំមានលំនឹង និងតុល្យភាព គឺឱ្យដូចជាពួកអ៊ីស្រាអែលកាលនៅឯទីរហោស្ថានដូច្នោះដែរ (ខ.១៥ នក ១៦:១៨)។

**៨:១៦-១៧** លោកទីតុសបានបង្កើតនូវទំនាក់ទំនង ប្រកបដោយការទុកចិត្ត និងសេចក្ដីស្រលាញ់ ជាមួយពួកជំនុំនៅទីក្រុងកូរិនថូស (៧:៦-៧, ១៣-១៥)។ គាត់ជាអ្នកដែលបានចាប់ផ្ដើមរៃប្រាក់ដង្វាយ កាលពីមួយឆ្នាំកន្លង

រាល់គ្នា តាមបំណងចិត្តគាត់វិញ[ខ] ១៨ហើយយើងខ្ញុំបានចាត់
បងប្អូនម្នាក់[គ] ឱ្យមកជាមួយដែរ អ្នកនោះក៏មានល្បីឈ្មោះ
ក្នុងដំណឹងល្អ[ឃ] នៅគ្រប់ទាំងពួកជំនុំ[ង] ១៩មិនតែប៉ុណ្ណោះ ពួក
ជំនុំទាំងប៉ុន្មានក៏រើសអ្នកនោះ ឱ្យបានដើរដំណើរជាមួយ
នឹងយើងខ្ញុំ[ច] ក្នុងការធ្វើទាននេះដែរ ជាការដែលយើង
ខ្ញុំទទួលរ៉ាប់រង សំរាប់ជាសិរីល្អដល់ព្រះអម្ចាស់ ហើយ
ដើម្បីនឹងសំដែងសេចក្តីប្រុងប្រៀបរបស់អ្នករាល់គ្នា[ឆ]
២០ព្រមទាំងខំចៀសវាង មិនឱ្យគេបន្ទោសយើងខ្ញុំ ពីដំណើរ
ទានដ៏បរិបូរនេះ ដែលយើងខ្ញុំទទួលរ៉ាប់រងឡើយ ២១ដ្បិត
យើងខ្ញុំខំធ្វើការល្អ មិនមែននៅចំពោះព្រះអម្ចាស់តែ
ប៉ុណ្ណោះ គឺនៅចំពោះមនុស្សលោកដែរ[ជ] ២២យើងខ្ញុំក៏ចាត់
បងប្អូនម្នាក់ ឱ្យទៅជាមួយនឹងគេ ជាអ្នកដែលយើងខ្ញុំ
បានលមើលជាញឹកញយ ហើយក៏ឃើញថា មានសេចក្តី
ឧស្សាហ៍ក្នុងការជាច្រើន ហើយឥឡូវនេះ គាត់មានចិត្ត
ឧស្សាហ៍លើសទៅទៀត ដោយទុកចិត្តនឹងអ្នករាល់គ្នាជា
ខ្លាំង ២៣រីឯទីតុស[ឈ] គាត់ជាគូកន[ញ]ធ្វើការជាមួយនឹង ខ្ញុំ[ដ]
នៅចំពោះអ្នករាល់គ្នា ឯពួកបងប្អូនយើងខ្ញុំឯទៀតនោះ[ឋ]
គេជាពួកអ្នកដែលពួកជំនុំទាំងប៉ុន្មានចាត់ឱ្យធ្វើការ ហើយ
ជាសិរីល្អនៃព្រះគ្រីស្ទ ២៤ដូច្នេះ ចូរសំដែងភស្តុតាងពី
សេចក្តីស្រឡាញ់របស់អ្នករាល់គ្នា ហើយពីសេចក្តីដែល
យើងខ្ញុំបានអួតពីអ្នករាល់គ្នាចុះ[ឌ] ឱ្យអ្នកទាំងនោះបានឃើញ
ព្រមទាំងនៅមុខពួកជំនុំទាំងអស់ផង ។
**៩** ១ឯត្រង់ការជំនួយ[ឍ]ជួយដល់ពួកបរិសុទ្ធ[ណ] នោះមិនចាំ[ត]
បាច់ឱ្យខ្ញុំសរសេរ ផ្ញើមកអ្នករាល់គ្នាទេ ២ដ្បិតខ្ញុំស្គាល់
សេចក្តីប្រុងប្រៀបរបស់អ្នករាល់គ្នាហើយ[ថ] ក៏បានអួត[ទ]ដល់
ពួកម៉ាសេដូន ពីអ្នករាល់គ្នាខាងឯដំណើរនោះដែរថា ពួក
ស្រុកអាខៃ[ធ]បានប្រុងប្រៀបជាស្រេច តាំងតែពីឆ្នាំមុន[ន]មក
ហើយសេចក្តីឧស្សាហ៍របស់អ្នករាល់គ្នាបានបណ្តាលចិត្ត
មនុស្សជាច្រើន ៣ខ្ញុំក៏បានចាត់ពួកបងប្អូននោះ[ប]មកក្រែង
សេចក្តីអំនួតដែលយើងខ្ញុំអួតពីអ្នករាល់គ្នា ក្នុងដំណើរនោះ
បានទៅជាឥតប្រយោជន៍វិញ ដើម្បីឱ្យអ្នករាល់គ្នាបានរៀប
ចំជាស្រេច ដូចជាខ្ញុំបាននិយាយមកហើយ[ផ] ៤ក្រែងមានពួក
ស្រុកម៉ាសេដូន[ព]មកជាមួយនឹងខ្ញុំ វេលាណាមិនឃើញអ្នក
រាល់គ្នាបានរៀបចំទេ នោះមិនចាំថាតែអ្នករាល់គ្នានឹង
ខ្មាសប៉ុណ្ណោះ គឺយើងខ្ញុំក៏នឹងខ្មាសពីសេចក្តីអំនួត ដែល
យើងខ្ញុំអួត ដោយទុកចិត្តនឹងអ្នករាល់គ្នាថែមទៀតផង
៥ដូច្នេះ ខ្ញុំបានរាប់ថា គួរនឹងទូន្មានពួកបងប្អូននោះ[ភ] ឱ្យមក
ឯអ្នករាល់គ្នាជាមុន ដើម្បីនឹងបំពេញគុណអ្នករាល់គ្នានោះ
ឱ្យបានហើយជាមុន ដូចជាបានប្រាប់តាំងពីមុនមកដែរ
ប្រយោជន៍ឱ្យបានរាប់ជាគុណនៃអ្នករាល់គ្នាពិត[ម] មិនមែន
ដូចជាយើងខ្ញុំបោកយកទេ[យ] ។

## ការព្រោះដោយចិត្តសប្បុរស

៦ខ្ញុំចង់និយាយដូច្នេះ គឺថា អ្នកណាដែលព្រោះដោយ
កំណាញ់ នោះនឹងច្រូតបានតិច ហើយអ្នកណាដែលព្រោះ
ដោយសទ្ធា នោះនឹងច្រូតបានច្រើនវិញ[រ] ៧ចូរឱ្យគ្រប់គ្នាធ្វើ
តាមដែលសំរេចក្នុងចិត្តចុះ[ល]មិនមែនដោយស្តាយ[វ]ឬដោយ
បង្ខំឡើយ ដ្បិតព្រះទ្រង់ស្រឡាញ់ដល់អ្នកណាដែលថ្វាយ
ដោយអំណរ[ស] ៨ហើយព្រះទ្រង់អាច[ហ]នឹងធ្វើឱ្យគ្រប់ទាំង

**៨:១៧** ខ ឌ.៦
**៨:១៨** គ ២កថ ១២:១៨
ឃ ២កថ ២:១២
ង ១កថ ៧:១៧
**៨:១៩** ច កថ ១៤:២៣ ១កថ ១៦:៣,៤
ឆ ឌ.១១,១២
**៨:២១** ជ រម ១២:១៧ ១៤:១៨ ទត ២:១៤
**៨:២៣** ឈ ២កថ ២:១៣ ញ ភម ១៧
ដ ភល ២:២៥
ឋ ឌ.១៨,២២
**៨:២៤** ឌ ២កថ ៧:៤,១៤ ៩:២
**៩:១** ឍ កថ ៩:១៣
ណ ១ថន ៤:៩
ត កថ ២៤:១៧
**៩:២** ថ ២កថ ៨:១១,១២,១៩
ទ ២កថ ៧:៤,១៤ ៨:២៤
ធ ២កថ ៨:១០
ន កថ ១៨:១២
**៩:៣** ប ២កថ ៨:២៣
ផ ១កថ ១៦:២
**៩:៤** ព រម ១៥:២៦
**៩:៥** ភ ឌ.៣
ម ភល ៤:១៧
យ ២កថ ១២:១៧,១៨
**៩:៦** រ សភ ១១:២៤,២៥ ២២:៩ កទ ៦:៧,៩ **៩:៧** ល នក ២៥:២ ២កថ ៨:១២
វ ចទ ១៥:១០ ស រម ១២:៨ **៩:៨** ហ អភ ៣:២០

ទៅនោះ (មើលការពន្យល់ ឌ.៦)។
**៨:១៨** *បងប្អូនម្នាក់* ប្រហែលជាសំដៅលោកលូកា ឬលោកបាណាបាស។
**៨:១៩** លោកប៉ុលបានផ្តល់នូវគំរូដ៏ល្អដល់ពួកអ្នកដឹកនាំពួកជំនុំ ក្នុងការចាត់ចែងប្រាក់ដង្វាយ (១កថ ១៦:៣-៤ មើលការពន្យល់ ១៦:៣)។
**៨:២០-២១** ត្រង់ចំណុចនេះបញ្ជាក់ថា គ្រប់ការទាំងអស់ដែលពួកជំនុំធ្វើ គឺមានសារសំខាន់ណាស់ចំពោះព្រះអម្ចាស់ ហើយធ្វើឱ្យមនុស្សទូទៅមើលឃើញថា ពួកគេបានបម្រើការថ្វាយទ្រង់ ដោយមានភាពស្មោះត្រង់ និងប្រកបដោយសីលធម៌ខ្ពស់(ប្រៀបធៀប ឌ.១៩,២១ ១២:១៧-១៨)។
**៨:២២** *បងប្អូន* (ប្រៀបធៀបនឹង ឌ.១៨)។
**៨:២៣-២៤** លោកប៉ុលបានប្រាប់ទៅពួកជំនុំនៅទីក្រុងកូរិនថូសថា លោកទីតុស និងបងប្អូនពីរនាក់ទៀត គឺជាមនុស្សស្មោះត្រង់ ហើយទទួលបានការស្រលាញ់ និងការគោរពពីពួកជំនុំ។ លោកទីតុសជាគូកនផ្ទាល់របស់លោកប៉ុល(ឌ.២៣)។ បងប្អូនពីរនាក់ទៀត ដែលបានធ្វើដំណើរទៅជាមួយនឹងលោកទីតុស ទៅឯទីក្រុងកូរិនថូស ពួកគេគឺជាតំណាងរបស់ពួកជំនុំ ។ ម្យ៉ាងទៀត ពួកគេជាមនុស្សស្មោះត្រង់ចំពោះព្រះអម្ចាស់ ។
**៨:២៣** *ជាគូកនធ្វើការជាមួយនឹងខ្ញុំ* (មើលការពន្យល់ ២:១៣)។ *ជាពួកអ្នកដែលពួកជំនុំទាំងប៉ុន្មានចាត់ឱ្យធ្វើការ* មានន័យថា ពួកអ្នកដែលត្រូវបានពួកជំនុំចាត់ឱ្យទៅឯទីក្រុងកូរិនថូស ជាមួយនឹងលោកទីតុស សុទ្ធតែត្រូវបានពួកគេជ្រើសរើសដោយយកចិត្តទុកដាក់បំផុត (មើលការពន្យល់ កថ ២០:៤)។ *ជាសិរីល្អនៃព្រះគ្រីស្ទ* បញ្ជាក់ថា ពួកអ្នកដែលត្រូវបានបញ្ជូនឱ្យទៅជាមួយនឹងលោកទីតុស គឺសុទ្ធតែជាមនុស្សស្មោះត្រង់ចំពោះព្រះយេស៊ូវគ្រីស្ទ ។
**៩:២** *ស្រុកម៉ាសេដូន* (មើលការពន្យល់ ១:១)។
**៩:៥** *ឱ្យបានរាប់ជាគុណនៃអ្នករាល់គ្នាពិត មិនមែនដូចជាយើងខ្ញុំបោកយកទេ* (ប្រៀបធៀបនឹង ឌ.៦-៧,១១)។
**៩:៦** បទគម្ពីរនេះគឺជាសុភាសិតដែលពួកគេធ្លាប់ដឹងឮ (សូមប្រៀបធៀបនឹង សភ ១១:២៤-២៥ ២២:៨-៩ លក ៦:៣៨ កទ ៦:៧)។
**៩:៨** *គ្រប់ទាំងព្រះគុណ . . . គ្រប់គ្រាន់ជានិច្ច . . . គ្រប់ជំពូក* ត្រង់ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ដោយព្រោះព្រះអម្ចាស់ជាព្រះមានគ្រប់ទាំងអស់នោះ ទ្រង់ក៏ប្រទានព្រះពរដល់ពួកអ្នកជឿដល់ព្រះនាមទ្រង់យ៉ាងគ្រប់គ្រាន់

ព្រះគុណបានចំរើនដល់អ្នករាល់គ្នា ប្រយោជន៍ឱ្យមានទាំង
អស់គ្រប់គ្រាន់ជានិច្ច[ឡ] ដើម្បីឱ្យបានចំរើនឡើងខាងឯការ
ល្អគ្រប់ជំពូក ៩ ដូចសេចក្ដីដែលចែងទុកមកថា «ទ្រង់បាន
ចែកសុសសាយ ទ្រង់បានប្រទាន[អ]ទៅពួកទ័លក្រ សេចក្ដី
សុចរិតទ្រង់នៅជាប់អស់កល្បជានិច្ច»[ក] ១០ រីឯព្រះដែលទ្រង់
ផ្គត់ផ្គង់ពូជ សំរាប់អ្នកដែលព្រោះ និងអាហារសំរាប់
បរិភោគផង[ខ] នោះទ្រង់នឹងផ្គត់ផ្គង់ ហើយចំរើនពូជដែល
អ្នករាល់គ្នាព្រោះនោះដែរ ព្រមទាំងចំរើនផលពីការ
សុចរិតរបស់អ្នករាល់គ្នាផង[គ] ១១ ដូច្នេះ អ្នករាល់គ្នានឹងបាន
ចំរើនកាន់តែច្រើនឡើង[ឃ]គ្រប់ជំពូក សំរាប់ជាការសទ្ធា[ង]
គ្រប់យ៉ាង ដែលនឹងបង្កើតសេចក្ដីអរព្រះគុណដល់ព្រះ
ដោយសារយើងរាល់គ្នា[ច] ១២ ពីព្រោះការជំនួយជួយពួក
បរិសុទ្ធនេះ មិនមែនគ្រាន់តែបំពេញសេចក្ដីដែលគេត្រូវ
ការប៉ុណ្ណោះ[ឆ] គឺបានចំរើនឡើងជាហូរហៀរដល់ព្រះដែរ
ដោយសារពាក្យគេអរ ព្រះគុណជាច្រើន[ជ] ១៣ ហើយ
ដោយគេឃើញភស្តុតាងពីការជំនួយនេះ[ឈ] នោះគេសរ
សើរដំកើងដល់ព្រះ[ញ] ដោយព្រោះអ្នករាល់គ្នាសំដែង
ច្បាស់ថា ខ្លួនជាអ្នកចុះចូល[ដ]តាមដំណឹងល្អនៃព្រះគ្រីស្ទពិត[ឋ]
ហើយដោយព្រោះការសទ្ធា[ឌ]ដែលអ្នករាល់គ្នាផ្ញើទៅគេ
នឹងមនុស្សទាំងអស់ផង ១៤ គេក៏អធិស្ឋាន ឱ្យអ្នករាល់គ្នា
ដោយស្រឡាញ់ជាខ្លាំង ដោយព្រោះព្រះគុណនៃព្រះដ៏
លើសលប់ ដែលសណ្ឋិតលើអ្នករាល់គ្នា ១៥ អរព្រះគុណ
ដល់ព្រះអង្គ[ឍ]ដោយព្រោះអំណោយទានទ្រង់ ដ៏រកថ្លៃងពុំ
បាន[ណ] ។

## ការការពារការងាររបស់លោកសាវ័កប៉ុល

**១០** ១ ឯប៉ុលខ្ញុំ[ណ] ដែលកាលណានៅជាមួយនឹងអ្នករាល់គ្នា
នោះមានឫកពាជាថោកទាប តែកាលណាឃ្លាតចេញពី
អ្នករាល់គ្នាទៅ នោះមានសេចក្ដីក្លាហានចំពោះអ្នករាល់
គ្នាវិញ ខ្ញុំទូន្មានអ្នករាល់គ្នា ដោយសេចក្ដីសុភាពនឹងសេចក្ដី
សំឡូត[ត]របស់ព្រះគ្រីស្ទ ២ ក៏អង្វរអ្នករាល់គ្នាថា កាលណាខ្ញុំ
មកឯអ្នករាល់គ្នា នោះកុំឱ្យខ្ញុំត្រូវមានសេចក្ដីក្លាហាន[ថ]តាម
ដែលខ្ញុំសំរេចថា នឹងមានចំពោះអ្នកខ្លះ ដែលស្មានថាយើង
ខ្ញុំដើរតាមសាច់ឈាមនោះឡើយ[ទ] ៣ ដ្បិតទោះបើយើងខ្ញុំ
ដើរក្នុងសាច់ឈាមមែន គង់តែមិនតយុទ្ធតាមសាច់ឈាម
ទេ[ធ] ៤ ព្រោះគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់យើងខ្ញុំ[ន]
មិនមែនជារបស់ខាងសាច់ឈាមទេ គឺជាឥទ្ធិឫទ្ធិដែលមក
ពីព្រះ[ប] សំរាប់នឹងរំលំទីមាំមួនវិញ[ផ] ៥ ដែលអាចនឹងរំលាយ

**៩:៨** ឡ ភល ៤:១៩
**៩:៩** អ មឡ ៣:១០
ក ទដ ១១២:៩
**៩:១០** ខ អស ៥៥:១០
គ ហស ១០:១២
**៩:១១** ឃ ១កថ ១:៥
ង ខ.៥ ច ២កថ ១:១១
៤:១៥
**៩:១២** ឆ ២កថ ៨:១៤
ជ ២កថ ១:១១
**៩:១៣** ឈ ២កថ ៨:៤
ញ មថ ៩:៨
ដ ហព ៣:១
ឋ ២កថ ២:១២
ឌ ខ.៥
**៩:១៥** ឍ ២កថ ២:១៤
ណ រម ៥:១៥,១៦
**១០:១** ណ មថ
១១:២៩ ត កទ ៥:២
អភ ៣:១
**១០:២** ថ ១កថ ៤:២១
ទ រម ១២:២
**១០:៣** ធ ខ.២
**១០:៤** ន ២កថ ៦:៧
ប ១កថ ២:៥
ផ ខ.៨ យរ ១:១០ ២៣:២៩ ២កថ ១៣:១០

ទៅតាមបំណងព្រះហឫទ័យទ្រង់ផងដែរ (ខ.១១) ។

**៩:៩–១០** *សេចក្ដីសុចរិត* (ទដ ១:៥ និងការពន្យល់) ។

**៩:១០** ព្រះអម្ចាស់ជាប្រភពនៃការផ្គត់ផ្គង់ ដល់គ្រប់ជីវិតមនុស្សទាំងអស់ ទ្រង់ក៏ប្រទាននូវអាហារខាងឯវិញ្ញាណ ដែលធ្វើឱ្យពួកអ្នកជឿដល់ព្រះនាមទ្រង់ បានចម្រើនឡើងផងដែរ ។

**៩:១២** បទគម្ពីរនេះបញ្ជាក់ថា ដោយសារតែសេចក្ដីសប្បុរសរបស់ពួកជំនុំនៅទីក្រុងកូរិនថូស ក្នុងការថ្វាយដង្វាយទៅព្រះអម្ចាស់ និងដើម្បីយកទៅជួយដល់ពួកជំនុំនៅទីក្រុងយេរូសាឡិម បានធ្វើឱ្យពួកអ្នកជឿទាំងអស់ដែលបានទទួលនូវដំណឹងនេះក៏នាំគ្នាប្រជុំអធិស្ឋាន និងសរសើរតម្កើងដល់ទ្រង់ដោយអំណរ (ខ.១១,១៣–១៤) ។

**៩:១៤** *ព្រះគុណនៃព្រះដ៏លើសលប់ ដែលសណ្ឋិតលើអ្នករាល់គ្នា* មានន័យថា គំរូនៃការលះបង់របស់ព្រះយេស៊ូវគ្រីស្ទ បានធ្វើឱ្យពួកជំនុំមានសេចក្ដីស្រលាញ់ និងការបារម្ភ ចំពោះពួកបងប្អូនរួមជំនឿដទៃៗទៀតដែលកំពុងតែជួបប្រទះនូវការខ្វះខាត ។

**៩:១៥** *អំណោយទានទ្រង់ដ៏រកថ្លៃងពុំបាន* សំដៅលើការដែលព្រះទ្រង់ប្រទានព្រះរាជបុត្រាតែមួយរបស់ទ្រង់ មកសុគតដើម្បីលោះបាបមនុស្សលោក (យហ ៣:១៦ និងការពន្យល់) ។ ព្រះអម្ចាស់បានប្រទានមកយើងជាមុន នូវរូបអង្គទ្រង់ ដែលបង្ហាញអំពីសេចក្ដីស្រលាញ់ដ៏លើសលប់សម្រាប់យើងរាល់គ្នា ដូច្នេះយើងត្រូវមានការឆ្លើយតប ដោយអរព្រះគុណទ្រង់ជានិច្ច (១យហ ៤:៩–១១ មើលការពន្យល់ ២កថ ៨:៩) ។

**១០:១–១៣:១៤** តាមរយៈការរៀបរាប់ នៅក្នុង៩ជំពូកដំបូង នៃសំបុត្រនេះបង្ហាញថា ពួកអ្នកជឿដល់ព្រះអម្ចាស់ នៅទីក្រុងកូរិនថូស ភាគច្រើនបានស្តាប់តាមលោកប៉ុល (៧:៦–១៦) ដោយសារការអះអាងរបស់គាត់ ។ នៅក្នុងវគ្គចុងក្រោយនៃសំបុត្រនេះ លោកប៉ុលធ្វើការវែកញែកយ៉ាងច្បាស់លាស់លើបញ្ហា ដែលទាក់ទងនឹងពួកអ្នកដែលនៅតែបន្តប្រឆាំងនឹងគាត់នៅក្នុងទីក្រុងនេះ ។ ពួកអ្នកប្រឆាំងនឹងលោកប៉ុលបានពោលថា គាត់ជាមនុស្សក្លាហានតែពីចម្ងាយ គឺបានតែនិយាយគំរាមកំហែងនៅក្នុងសំបុត្រប៉ុណ្ណោះ (១កថ ៤:២១) ។ ពួកគេនិយាយថា គាត់ជាមនុស្សខ្សោយ និងមិនប្រាកដប្រជា ហើយគ្មានហ៊ានធ្វើអ្វីទាំងអស់ ប្រសិនបើគាត់បានជួបផ្ទាល់នឹងពួកគេនោះ ។ ម្យ៉ាងទៀត ពួកគេចោទថា គាត់គ្មានអំណាចជាសាវ័ក ដូចដែលគាត់មានប្រសាសន៍ទេ ។ ទោះជាយ៉ាងណា ក៏ត្រៀមខ្លួនជាស្រេច និងរង់ចាំតែពេលវេលាមកដល់ គាត់នឹងធ្វើដំណើរជាលើកទីបីទៅឯទីក្រុងកូរិនថូសជាថ្មីទៀត (១០:៦,១០–១១ និងការពន្យល់) ។

**១០:១** *សេចក្ដីសុភាព និងសេចក្ដីសំឡូតរបស់ព្រះគ្រីស្ទ* គ្រីស្ទបរិស័ទដែលពេញវ័យខាងឯសេចក្ដីជំនឿ គឺមានសេចក្ដីទាំងពីរនេះ ។ សេចក្ដីទាំងពីរនេះបង្ហាញនូវភាពខ្លាំងរបស់គ្រីស្ទបរិស័ទ ។

**១០:៤** *គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់យើងខ្ញុំ* ត្រង់ចំណុចនេះបញ្ជាក់ថា លោកប៉ុលតែងតែត្រៀមខ្លួនជានិច្ច ក្នុងការតយុទ្ធដើម្បីដំណឹងល្អនៃព្រះអម្ចាស់ ។ លោកិយមិនចូលចិត្ត និងមិនឱ្យតម្លៃ ចំពោះគ្រឿងសស្ត្រាវុធដែលលោកប៉ុលប្រើទេ (១:១៧ ៤:២) ។ *ទីមាំមួន* សំដៅលើគ្រប់គម្រោងការណ៍របស់សាតាំង និងគ្រប់ការទាំងឡាយណា ដែលប្រឆាំងនឹងព្រះហឫទ័យព្រះអម្ចាស់ (ខ.៥ រម ១:១៨–២៣) ។ ម្យ៉ាងទៀត នៅក្នុងនៅទីក្រុងកូរិនថូសមានពួកគ្រូខុសឆ្គងបានព្យាយាមធ្វើឱ្យពួកជំនុំ បាត់បង់នូវសេចក្ដីជំនឿរបស់ខ្លួនលើព្រះយេស៊ូវគ្រីស្ទ (១កថ ២:១៣–១៤) ។

អស់ទាំងគំនិតដែលគេរិះគិត នឹងគ្រប់ទាំងសេចក្ដីយ៉ាង
ខ្ពង់ខ្ពស់ ដែលលើកខ្លួនឡើងទាស់នឹងចំណេះនៃព្រះ[ព] ព្រម
ទាំងនាំអស់ទាំងគំនិត ឱ្យចុះចូលស្ដាប់បង្គាប់[ភ]ព្រះគ្រីស្ទវិញ
៦ក៏ប្រុងប្រៀបទុកជាស្រេច និងធ្វើទោសដល់គ្រប់ទាំង
សេចក្ដីរឹងចចេស ក្នុងកាលដែលអ្នករាល់គ្នាបានស្ដាប់
បង្គាប់គ្រប់ជំពូកហើយ[ម]។
៧អ្នករាល់គ្នាមើលតែឫកពាខាងក្រៅឬអី[យ] បើអ្នកណា
ជឿប្រាកដថា ខ្លួនជារបស់ផងព្រះគ្រីស្ទ[រ] នោះត្រូវពិចារ
ណាសេចក្ដីនេះ ដោយខ្លួនឯងទៀត គឺថា យើងខ្ញុំជារបស់
ព្រះគ្រីស្ទដូចជាអ្នកនោះដែរ[ល] ៨ដ្បិតទោះបើខ្ញុំអួតខ្លួនហួស
បន្តិច ពីអំណាចដែលព្រះអម្ចាស់បានប្រទានមកយើងខ្ញុំ[វ]
សំរាប់នឹងស្អាងចិត្តឡើង មិនមែនសំរាប់នឹងផ្ដួលអ្នករាល់
គ្នាទេ[ស] នោះគង់តែខ្ញុំមិនមានសេចក្ដីខ្មាសដែរ ៩ក្រែងមើល
ទៅដូចជាខ្ញុំចង់បំភ័យអ្នករាល់គ្នា ដោយសារសំបុត្រ ១០ដ្បិត
គេថា«សំបុត្រលោកមានពាក្យធ្ងន់ ហើយមានអំណាច
តែកាលណាលោកនៅជាមួយ នោះលោកខ្សោយខាង
រូបសាច់វិញ[ហ] ហើយពាក្យសំដីលោកក៏គួរឱ្យមើលងាយ
ដែរ»[ឡ] ១១ត្រូវឱ្យមនុស្សយ៉ាងនោះបានយល់ថា កាលណា
យើងខ្ញុំនៅជាមួយ នោះយើងខ្ញុំនឹងប្រព្រឹត្ត ដូចជាយើងខ្ញុំ

**១០:៥** ព អស ២:១១, ១២ ១កថ ១:១៩ ភ ២កថ ៩:១៣ **១០:៦** ម ២កថ ២:៩ ៧:១៥ **១០:៧** យ យហ ៧:២៤ ២កថ ៥:១២ រ ១កថ ១:១២ ៣:២៣ ១៤:៣៧ ល ២កថ ១១:២៣ **១០:៨** វ ខ.១៣,១៥ ស ខ.៤ យរ ១:១០ ២កថ ១៣:១០ **១០:១០** ហ ខ.១ ១កថ ២:៣ កទ ៤:១៣,១៤ ឡ ១កថ ១:១៧ ២កថ ១១:៦ **១០:១២** អ ខ.១៨ ២កថ ៣:១ **១០:១៣** ក ខ.១៥,១៦ រម ១២:៣ **១០:១៤** ខ ១កថ ៣:៦ គ ២កថ ២:១២ **១០:១៥** ឃ ខ.១៣ ង រម ១៥:២០

បានសរសេរចុះក្នុងសំបុត្រ ពីកាលដែលមិនបាននៅជាមួយ
ដែរ ១២ដ្បិតយើងខ្ញុំមិនហ៊ានរាប់ខ្លួន ជាមួយនឹងពួកអ្នកនោះ
ខ្លះ ឬផ្ទឹមខ្លួននឹងគេ ដែលផ្ទុកផ្ដាក់ខ្លួនគេនោះឡើយ[អ] ពួកអ្នក
នោះដែលគេវាស់ ហើយផ្ទឹមខ្លួននឹងខ្លួនគេ នោះគ្មានប្រាជ្ញា
ទេ ១៣រីឯយើងខ្ញុំៗ មិនព្រមអួតពីការក្រៅខ្នាតរបស់យើងខ្ញុំ
ឡើយ គឺអួតតាមតែមាត្រាខ្នាត ដែលព្រះដ៏ជាម្ចាស់នៃខ្នាត
ទ្រង់បានចែកមកយើងខ្ញុំ[ក] ជាខ្នាតដែលបានលូកមករហូត
ដល់អ្នករាល់គ្នាផង ១៤ដ្បិតយើងខ្ញុំមិនមែនលូករំលងហួស
ខ្នាតយើងខ្ញុំ ទុកដូចជាខ្នាតនោះមិនដល់អ្នករាល់គ្នានោះទេ[ខ]
ពីព្រោះយើងខ្ញុំបានមកដល់អ្នករាល់គ្នា ក្នុងដំណឹងល្អនៃ
ព្រះគ្រីស្ទដែរ[គ] ១៥ហើយយើងខ្ញុំមិនអួតពីការអ្វីក្រៅខ្នាត[ឃ]
ដែលមនុស្សឯទៀតបានធ្វើនោះឡើយ[ង] ដ្បិតយើងខ្ញុំមាន
សេចក្ដីសង្ឃឹមថា កាលណាសេចក្ដីជំនឿរបស់អ្នករាល់គ្នា
បានចំរើនឡើង[ច] នោះយើងខ្ញុំនឹងបានដំកើងធំឡើងជា
បរិបូរ ក្នុងពួកអ្នករាល់គ្នា តាមមាត្រារបស់យើងខ្ញុំដែរ
១៦ប្រយោជន៍ឱ្យបានផ្សាយដំណឹងល្អ[ឆ] ទៅខាងនាយអ្នករាល់
គ្នាទៅទៀត[ជ] ឥតអួតពីការអ្វីដែលរៀបចំជាស្រេច ក្នុង
មាត្រានៃមនុស្សឯទៀតឡើយ ១៧ឯអ្នកណាដែលអួត នោះ

ច ២ថន ១:៣ **១០:១៦** ឆ រម ១:១ ២កថ ២:១២ ជ កច ១៩:២១

**១០:៦** លោកប៉ុលសង្ឃឹម និងជឿជាក់ថា ពួកជំនុំនៅទីក្រុងកូរិនថូសនឹងបដិសេធ ចំពោះសេចក្ដីបង្រៀនខុសឆ្គង ។ ម្យ៉ាងទៀត គាត់ចង់ឱ្យពួកអ្នកដែលគាប់ចិត្តនឹងសេចក្ដីបង្រៀនខុសឆ្គង បានវិលមកឯសេចក្ដីពិតវិញ ហើយនៅពេលដែលគាត់បានទៅឯទីក្រុងកូរិនថូស គាត់នឹងព្រមានដល់ពួកគ្រូខុសឆ្គងទាំងនោះ និងបណ្ដេញពួកគេឱ្យចេញពីពួកជំនុំទៀតផង ។

**១០:៧** *ខ្លួនជារបស់ផងព្រះគ្រីស្ទ* ត្រង់ចំណុចនេះបញ្ជាក់ថា គ្រីស្ទបរិស័ទទីក្រុងកូរិនថូសមួយចំនួនបានប្រកាសថា ពួកគេនៅខាងព្រះគ្រីស្ទ ។ ការដែលពួកគេនិយាយយ៉ាងដូច្នេះ បានបង្ហាញនូវភាពមិនឱ្យតម្លៃចំពោះពួកអ្នកជឿដទៃទៀតទេ ព្រោះពួកគេគិតថាមានតែពួកខ្លួនទេ ដែលជាគ្រីស្ទបរិស័ទពិតប្រាកដ (១កថ ១:១២)។ ពួកអ្នកដែលនិយាយយ៉ាងដូច្នេះ នាំគ្នាវាយតម្លៃមនុស្សដោយសម្លឹងមើលតែសំបកក្រៅប៉ុណ្ណោះ ។ លោកប៉ុលបញ្ជាក់ថា គាត់ក៏ជារបស់ផងព្រះគ្រីស្ទដែរ ថែមទាំងបានទទួលការត្រាស់ហៅជាពិសេសផង (កច ៩:៣–៩ ២២:៦–១១ ២៦:១២–១៨) និងបានទទួលព្រះបន្ទូល ដោយបានផ្សាយតាមរយៈការបើកសំដែង ពីព្រះយេស៊ូវគ្រីស្ទដោយផ្ទាល់ (កទ ១:១២ ២កថ ១២:២–៧)។ ហេតុការណ៍ដូចគ្នានេះបានកើតឡើងចំពោះគ្រីស្ទបរិស័ទពេលបច្ចុប្បន្នផងដែរ។

**១០:៨** *អំណាច...សំរាប់នឹងស្អាង* ត្រង់ចំណុចនេះបញ្ជាក់ថា អំណាចក្នុងភាពជាសាវ័កដែលព្រះអម្ចាស់បានប្រទានមកលោកប៉ុល គឺសម្រាប់ស្អាងពួកជំនុំរបស់ទ្រង់ ពុំមែនសម្រាប់ធ្វើឱ្យពួកគេធ្លាក់ចុះនោះទេ (១៣:១០)។

**១០:៩** *មើលទៅដូចជាខ្ញុំចង់បំភ័យអ្នករាល់គ្នា* (៧:៨–៩ ជំពូក ១០–១៣ ១កថ ៤:១៤–២១ មើលការពន្យល់ ២:៣–៤)។

**១០:១០** *សំបុត្រលោកមានពាក្យធ្ងន់ ហើយមានអំណាច* ត្រង់ចំណុចនេះបញ្ជាក់ថា លោកប៉ុលធ្លាប់បានសរសេរសំបុត្រ ទៅពួកជំនុំនៅទីក្រុងរួចហើយ(មើលសេចក្ដីផ្ដើម)។ *ពាក្យសំដីលោកក៏គួរឱ្យមើលងាយដែរ* ពួកអ្នកប្រឆាំងនឹងលោកប៉ុលនិយាយយ៉ាងដូច្នេះ គឺក្នុងគោលបំណងធ្វើឱ្យអ្នកស្ដាប់ធ្វើតាមខ្លួន និងប្រមូលប្រាក់យកមកប្រគល់ឱ្យពួកគេ ។ ទោះជាយ៉ាងណាក៏ដោយក៏អ្វីដែលលោកប៉ុល បានលើកឡើងគឺត្រឹមត្រូវ និងនិយាយចំពោះពួកជំនុំផ្ទាល់ ហើយផ្ដល់នូវសេរីភាព គ្រប់គ្រាន់ដល់ពួកគេ(១១:៧ និងការពន្យល់)។ គាត់បានប្រកាស ជាចំហនូវព្រះបន្ទូលអំពីការដែលព្រះគ្រីស្ទជាប់ឆ្កាង និងការដែលពួកជំនុំនៅទីក្រុងកូរិនថូស ផ្ទាល់បានផ្លាស់ប្រែដែលបញ្ជាក់នូវអំណាចព្រះចេស្ដា របស់ទ្រង់ផ្ទាល់នៅជាមួយនឹងគាត់ (១០:១–១៣:១៤ ១កថ ២:១–៥ និងការពន្យល់)។

**១០:១២** *ពួកអ្នកនោះដែលគេវាស់ ហើយផ្ទឹមខ្លួននឹងខ្លួនគេ* ពួកគ្រូខុសឆ្គងនៅទីក្រុងកូរិនថូសយល់ថា គ្មានគំរូណាដែលអាចប្រៀបផ្ទឹមនឹងពួកគេបានទេ ប៉ុន្តែ លោកប៉ុលប្រកាសថា មានតែព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ ដែលជាគំរូដ៏គ្រប់លក្ខណ៍ (ខ.១៧ ប្រៀបធៀបនឹង ១កថ ១:៣១ និងការពន្យល់)។

**១០:១៣–១៤** ត្រង់ចំណុចនេះបញ្ជាក់ថា លោកប៉ុលមិនបានអួតអំពីខ្លួនគាត់ទេ ។ គាត់អួតតែអំពីព្រះបន្ទូលនៃដំណឹងល្អដែលគាត់ទទួលពីព្រះអម្ចាស់ និងត្រូវប្រកាសដល់ពួកអ្នកបាត់បង់ប៉ុណ្ណោះ(ខ.១៥–១៦ កច ៩:១៥ រម ១:៥)។

**១០:១៦** *ទៅខាងនាយអ្នករាល់គ្នាទៅទៀត* លោកប៉ុលនិយាយឃ្លានេះគឺអាចសំដៅលើពួកអ្នកដែលរស់នៅប្រទេសអេស្ប៉ាញ(រម ១៥:២៤,២៨)។

**១០:១៧** *ត្រូវអួតតែក្នុងព្រះអម្ចាស់ប៉ុណ្ណោះ* មានន័យថា ត្រូវអួតតែអំពីអ្វី

ត្រូវអួតតែក្នុងព្រះអម្ចាស់ប៉ុណ្ណោះ[ឈ] [18]ដ្បិតមិនមែនជាអ្នក
ដែលផ្ទុកផ្ដាក់ខ្លួនឯង[ញ] ដែលបានលើកតាំងនោះទេ គឺជា
អ្នកណាដែលព្រះអម្ចាស់ទ្រង់ផ្ទុកផ្ដាក់វិញទេតើ[ដ] ។

## លោកសាវកប៉ុល និងពួកសាវកក្លែងក្លាយ

**១១** [1]ឱបើសិនណាជាអ្នករាល់គ្នានឹង[ឋ]ទ្រាំទ្រ ចំពោះ
សេចក្ដីចំកួត[ឌ]របស់ខ្ញុំបន្តិចទៅអេះ សូមអ្នករាល់គ្នាទ្រាំទ្រ
នឹងខ្ញុំចុះ [2]ពីព្រោះខ្ញុំប្រចណ្ឌចំពោះអ្នករាល់គ្នា ដោយសេច
ក្ដីប្រចណ្ឌនៃព្រះ ដ្បិតខ្ញុំបានបំរុងអ្នករាល់គ្នាទុក ឱ្យមានប្ដី
តែ១[ឍ] ទុកដូចជាក្រមុំបរិសុទ្ធ គឺដើម្បីនឹងថ្វាយទៅ[ណ] ព្រះ
គ្រីស្ទតែមួយប៉ុណ្ណោះ [3]តែខ្ញុំខ្លាចក្រែងគំនិតអ្នករាល់គ្នាត្រូវ
បង្ខូច[ត]ចេញពីសេចក្ដីទៀងត្រង់ខាងឯព្រះគ្រីស្ទ ដូចជាសត្វ
ពស់បានបញ្ឆោតនាងអេវ៉ា ដោយឧបាយកលយ៉ាងនោះ
ដែរ [4]ពីព្រោះបើសិនជាមានអ្នកណាមក ប្រកាសប្រាប់ពី
ព្រះយេស៊ូវ ១ ទៀត ដែលយើងខ្ញុំមិនបានប្រកាសប្រាប់[ថ] ឬ
បើអ្នករាល់គ្នាទទួលវិញ្ញាណណាផ្សេងទៀត[ទ] ដែលមិនបាន
ទទួលពីដើម ឬដំណឹងណាផ្សេងទៀត[ធ] ដែលមិនទទួលកាល
ពីមុន[ន] នោះអ្នករាល់គ្នានឹងទ្រាំទ្រវិញជាមិនខាន [5]ខ្ញុំស្មានថា
ខ្លួនខ្ញុំមិនចាញ់ពួកសាវកយ៉ាងធំនេះ ក្នុងការអ្វីសោះឡើយ[ប]
[6]ដ្បិតទោះបើខ្ញុំមិនប៉ិនប៉ាវខាងឯពាក្យសំដីក៏មែន[ផ] ប៉ុន្តែខ្ញុំ
មិនមែនខ្សត់ខ្សោយខាងឯចំណេះទេ[ព] ហើយក្នុងគ្រប់ការ
ទាំងអស់ យើងខ្ញុំបានសំដែង ឱ្យអ្នករាល់គ្នាស្គាល់ច្បាស់
គ្រប់ជំពូកដែរ [7]កាលខ្ញុំបានផ្សាយដំណឹងល្អ[ភ]នៃព្រះមក
អ្នករាល់គ្នាទទេ[ម] ទាំងបន្ទាបខ្លួនខ្ញុំឱ្យអ្នករាល់គ្នាបានថ្កើង
ឡើង នោះតើឈ្មោះថាខ្ញុំបានធ្វើបាបឬអី[យ] [8]ខ្ញុំបានបង្អត់
ពួកជំនុំឯទៀត ដោយទទួលឈ្នួលពីគេ[រ] ដើម្បីនឹងយកមក
បំរើអ្នករាល់គ្នាវិញ [9]ហើយកាលខ្ញុំនៅជាមួយនឹងអ្នករាល់
គ្នា បើកាលណាខ្វះខាត នោះខ្ញុំមិនបានឱ្យអ្នកណាកើត
ទុក្ខទេ ដ្បិតពួកបងប្អូន ដែលមកពីស្រុកម៉ាសេដូន បាន
ជួយបំពេញសេចក្ដីដែល ខ្ញុំខ្វះនោះហើយ[ល] ខ្ញុំមិនដែលឱ្យ
អ្នករាល់គ្នាកើតទុក្ខពីព្រោះខ្ញុំ[វ] ក្នុងការអ្វីសោះ ហើយទៅ

**១០:១៧** ឈ យរ ៩:២៤ ទដ ៣៤:២ ៤៤:៨ ១កថ ១:៣១ **១០:១៨** ញ ឱ.១២ ដ រម ២:២៩ **១១:១** ឋ ឱ.៤,១៩,២០ មថ ១៧:១៧ ឌ ឱ.១៦,១៧,២១ ២កថ ៥:១៣ **១១:២** ឍ ហស ២:១៩ អភ ៥:២៦,២៧ ណ ២កថ ៤:១៤ **១១:៣** ត លប ៣:១–៦,១៣ ១ធថ ២:១៤ វវ ១២:៩ **១១:៤** ថ ១កថ ៣:១១ ទ រម ៨:១៥ ធ កទ ១:៦–៩ ន ឱ.១ **១១:៥** ប ២កថ ១២:១១ កទ ២:៦ **១១:៦** ផ ១កថ ១:១៧ ព ២កថ ៨:៧ អភ ៣:៤ **១១:៧** ភ ២កថ ១២:១៣ ម ១កថ ៩:១៨ យ រម ១:១ **១១:៨** រ ភល ៤:១៥,១៨ **១១:៩** ល ភល ៤:១៥,១៨

ដែលព្រះយេស៊ូវគ្រីស្ទទ្រង់ធ្វើនៅក្នុងយើង និងតាមរយៈយើងប៉ុណ្ណោះ (រម ១៥:១៨ ប្រៀបធៀបនឹង កថ ១៤:២៧) ។

**១១:១** *សេចក្ដីចំកួតរបស់ខ្ញុំ* លោកប៉ុលនិយាយយ៉ាងដូច្នេះ គឺដើម្បីប្រៀបធៀបការងាររបស់គាត់ ជាមួយនឹងការងាររបស់ពួកគ្រូខុសឆ្គងនៅឯទីក្រុងកូរិនថូស ។

**១១:២** *សេចក្ដីប្រចណ្ឌនៃព្រះ* លោកប៉ុលមានប្រសាសន៍យ៉ាងដូច្នេះ បញ្ជាក់ថា គាត់មិនអាចទ្រាំទ្រនឹងសេចក្ដីដែលប្រជែងនឹងព្រះគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់ទេ ។ *ខ្ញុំបានបំរុងអ្នករាល់គ្នាទុកឱ្យមានប្ដីតែ១* ក្នុងនាមជាឪពុកខាងឯវិញ្ញាណ លោកប៉ុលបានសន្យាថ្វាយពួកជំនុំ នៅទីក្រុងកូរិនថូសដល់ព្រះគ្រីស្ទ ដែលនៅក្នុងព្រះគម្ពីរសញ្ញាថ្មីរាប់ថាជាប្ដី ហើយពួកជំនុំគឺទុកដូចជាប្រពន្ធ (មថ ៩:១៥ វវ ១៩:៧–៩ ២១:២ មើលការពន្យល់ យហ ៣:២៩ អភ ៥:២៣–៣២) ។ *ទុកដូចជាក្រមុំបរិសុទ្ធ* សំដៅលើពួកជំនុំ ដែលមិនបានធ្វើឱ្យកខ្វក់ដោយគោលលទ្ធិខុសឆ្គងណាមួយឡើយ (ឱ.៣–៤) ។

**១១:៣** *ដូចជាសត្វពស់បានបញ្ឆោត* (លប ៣:១–៧ និងការពន្យល់) ។

**១១:៤** ពួកអ្នករស់នៅក្នុងទីក្រុងកូរិនថូស ក៏ដូចជាពួកក្រេកដែរ តែងតែចង់ដឹង និងចង់ស្ដាប់នូវសេចក្ដីបង្រៀនថ្មីៗជានិច្ច (កថ ១៧:១៨–២១) ។ ដោយព្រោះតែហេតុដូច្នេះហើយ ទើបបានជាធ្វើឱ្យពួកជំនុំនៅទីក្រុងកូរិនថូសងាយនឹងទទួលយកនូវសេចក្ដីបង្រៀនខុសឆ្គងផ្សេងៗ ដែលផ្ទុយនឹងសេចក្ដីពិត (២ធថ ៤:៣–៤) ។ លោកប៉ុលបានបញ្ជាក់ប្រាប់ពួកគេយ៉ាងច្បាស់ថា មានព្រះគ្រីស្ទតែមួយ មានព្រះវិញ្ញាណតែមួយ និងមានដំណឹងល្អតែមួយប៉ុណ្ណោះ ។ *វិញ្ញាណណាផ្សេងទៀត* សំដៅលើវិញ្ញាណដែលជាប់ចំណងវិញ្ញាណនៃសេចក្ដីភ័យខ្លាច និងវិញ្ញាណនៃលោកីយ (រម ៨:១៥ កទ ២:៤ កល ២:២០–២៣ មើលការពន្យល់ ១កថ ២:១២) ។ *ដំណឹងល្អណាផ្សេងទៀត* (កទ ១:៦–៩) ។ *នោះអ្នករាល់គ្នានឹងទ្រាំទ្រវិញជាមិនខាន* មានន័យថា ពួកគេតែងតែទ្រាំទ្រនឹងពួកគ្រូខុសឆ្គងដែលនៅក្នុង ចំណោមពួកគេដោយមិនដឹងខ្លួន ។

**១១:៥** *ពួកសាវកយ៉ាងធំនោះ* លោកប៉ុលនិយាយយ៉ាងដូច្នេះ គឺសំដៅលើពួកគ្រូខុសឆ្គងតែម្ដង ។ ពួកគ្រូទាំងនោះពុំមែនជាពួកសាវកទេ ប៉ុន្តែពួកគេបានព្យាយាមបំផ្លាញពួកជំនុំនៅទីក្រុងកូរិនថូស ដោយសារគំនិតដ៏អាក្រក់របស់ខ្លួន (១០:១២ និងការពន្យល់) ។

**១១:៦** *ខ្ញុំមិនប៉ិនប៉ាវខាងឯពាក្យសំដី* បញ្ជាក់ថា លោកប៉ុលពុំបានប្រើពាក្យសំដី ឬវោហារសាស្ត្ររបស់ខ្លួន ដើម្បីទាក់ទាញពួកជំនុំឱ្យស្ដាប់តាមខ្លួនទេ គឺគាត់ប្រើព្រះបន្ទូលនៃព្រះអម្ចាស់វិញ (១០:១០ និងការពន្យល់) ។ *ខ្ញុំមិនមែនខ្សោយខាងឯចំណេះទេ* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកជំនុំនៅទីក្រុងកូរិនថូសបានដឹងយ៉ាងច្បាស់ថា លោកប៉ុលមានគ្រប់ទាំងចំណេះដ៏ពិតប្រាកដដែលព្រះអម្ចាស់ប្រទានឱ្យ ។

**១១:៧** *ខ្ញុំបានផ្សាយដំណឹងល្អ នៃព្រះមកអ្នករាល់គ្នាទទេ* ពួកអ្នកប្រឆាំងនឹងលោកប៉ុលតែងតែនិយាយថា ដំណឹងល្អដែលគាត់បានផ្សាយនោះមិនមានតម្លៃអ្វីទេ ពីព្រោះពួកគេទទួលបានដោយគ្មានចំណាយអ្វីបន្តិចសោះ ។ ម្យ៉ាងទៀតបញ្ជាក់ថា ពួកគ្រូខុសឆ្គងទាំងនោះ បានរិះរកគ្រប់មធ្យោបាយទាំងអស់ដើម្បីធ្វើយ៉ាងណាឱ្យពួកជំនុំបង់ប្រាក់ឱ្យខ្លួន ។ ដូច្នេះហើយ បានជាលោកប៉ុលបញ្ជាក់ប្រាប់ពួកជំនុំឱ្យដឹងច្បាស់ថា ដំណឹងល្អនៃព្រះអម្ចាស់ត្រូវបានផ្សាយមកពួកគេដោយទទេ ហើយមិនត្រូវឱ្យអ្នកណា ឆ្លៀតឱកាសកេងចំណេញ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ (១កថ ៩:៣–១៤) ។

**១១:៨** លោកប៉ុលបានទទួលជំនួយពីពួកជំនុំផ្សេងៗ ហើយគាត់មានប្រសាសន៍ថា ការដែលគាត់ទទួលជំនួយទាំងនោះ គឺហាក់ដូចជាគាត់បង្អត់ពួកគេដូច្នោះដែរ ។ នៅក្នុងគំនិតគាត់គឺគាត់មិនចង់ទទួលជំនួយពីពួកជំនុំ ដែលគាត់បានបង្កើតទេ ។

**១១:៩** *ខ្ញុំមិនបានធ្វើឱ្យអ្នកណាកើតទុក្ខទេ* មានន័យថា លោកប៉ុលមិនបានធ្វើឱ្យអ្នកណាម្នាក់បារម្ភពីគាត់ ខាងឯតម្រូវការផ្សេងៗទេ (២:១៧ និងការ

មុខក៏មិនដែលដែរ ១០ខ្ញុំប្រាប់ដោយនូវសេចក្ដីពិតរបស់
ព្រះគ្រីស្ទ ដែលនៅក្នុងខ្លួនខ្ញុំ[ស]ថា គ្មានអ្នកណាអាចនឹងបំ
បាត់សេចក្ដីអំនួតនេះ[ហ]ពីខ្ញុំ នៅក្នុងស្រុកអាខៃ[ឡ]បានឡើយ
១១ចុះតើដោយហេតុអ្វី ដោយព្រោះខ្ញុំមិនស្រឡាញ់អ្នករាល់
គ្នាឬអី នោះព្រះអង្គទ្រង់ជ្រាប[អ] ហើយ[ក] ១២តែការដែលខ្ញុំ
ធ្វើ ខ្ញុំនឹងចេះតែធ្វើទៅ ដើម្បីនឹងដកឱកាសចេញពីពួកអ្នក
ដែលរករឿង ប្រយោជន៍ឱ្យគេបានដូចជាយើងខ្ញុំ ក្នុងការ
អ្វីដែលគេអួតខ្លួននោះដែរ ១៣ដ្បិតមនុស្សយ៉ាងនោះជា
សាវកក្លែងក្លាយ[ខ] ជាអ្នកឆបោក[គ]ដែលក្លែងខ្លួនធ្វើជាសា
វកនៃព្រះគ្រីស្ទទេ[ឃ] ១៤ហើយសេចក្ដីនោះមិនជាអស្ចារ្យ
ឡើយ ព្រោះអារក្សសាតាំង[ង]ក៏ក្លែងខ្លួនធ្វើជាទេវតានៃពន្លឺ
ដែរ ១៥ដូច្នេះ បើអ្នក បំរើរបស់វាក្លែងខ្លួន ធ្វើជាអ្នកបំរើ
សេចក្ដីសុចរិតវិញ នោះមិនមែនជាការធំអ្វីទេឯចុងបំផុត
របស់គេនឹងបានត្រូវតាម អំពើដែលគេធ្វើដែរ[ច]។

## លោកសាវកប៉ុលអួតពីការរងទុក្ខរបស់គាត់

១៦ខ្ញុំប្រាប់ម្ដងទៀតថា កុំឱ្យអ្នកណារាប់ខ្ញុំទុកដូចជាល្ងង់
ខ្លៅឡើយ[ឆ] តែបើរាប់ទុកជាល្ងង់ខ្លៅមែន នោះត្រូវទទួលខ្ញុំ
ទុកដូចជាមនុស្សល្ងង់ខ្លៅដែរ ដើម្បីឱ្យខ្ញុំបានអួតខ្លួនបន្តិច
១៧សេចក្ដីដែលខ្ញុំប្រាប់នេះ មិនមែនប្រាប់តាមព្រះអម្ចាស់
ទេ[ជ] គឺប្រាប់បែបដូចជាល្ងង់ខ្លៅវិញ[ឈ] ដោយស្មានថា ខ្ញុំមាន
កន្លែងអួតខ្លួនបានខ្លះ ១៨ដ្បិតដែលមានមនុស្សជាច្រើនអួត
ខ្លួនខាងសាច់ឈាម[ញ] នោះខ្ញុំនឹងអួតដែរ[ដ] ១៩ព្រោះអ្នករាល់
គ្នាដែលមានប្រាជ្ញា នោះចេះតែទ្រាំទ្រនឹងមនុស្សល្ងង់ខ្លៅ[ឋ]
ដោយស្ម័គ្រពីចិត្តវិញ[ឌ] ២០ពីព្រោះអ្នករាល់គ្នាទ្រាំទ្រនឹង[ឍ]
ការដែលគេចាប់អ្នកប្រើ[ណ] ឬស៊ីសាច់អ្នក ឬដណ្ដើមយកអ្វីពី
អ្នក ឬបើអ្នកណាដំកើងខ្លួនលើអ្នក ឬបើអ្នកណាទះកំផ្លៀង
អ្នកនោះផង ២១ខ្ញុំនិយាយបែបជាបន្ទាបខ្លួន ទុកដូចជាយើង
ខ្ញុំខ្សោយមែន[ត] ប៉ុន្តែ ក្នុងការអ្វីដែលអ្នកណាហ៊ាន នោះខ្ញុំ
ក៏ហ៊ានដែរ ខ្ញុំនិយាយនេះដោយសេចក្ដីល្ងង់ខ្លៅ[ថ] ២២តើគេ
ជាពួកហេព្រើរឬអី ខ្ញុំក៏ដែរ[ទ] គេជាសាសន៍អ៊ីស្រាអែលឬអី
ខ្ញុំក៏ដែរ[ធ] គេជាពូជលោកអ័ប្រាហាំឬអី ខ្ញុំក៏ដែរ[ន] ២៣គេជា
អ្នកបំរើព្រះគ្រីស្ទឬអី[ប] (ខ្ញុំនិយាយបែបដូចជាវង្វេងស្មារតី

**១១:៩** វ ២កថ ១២:១៣,១៤,១៦ **១១:១០** ស រម ៩:១ ហ កថ ១៨:១២ ឡ ១កថ ៩:១៥ **១១:១១** អ ខ.៣១ រម ១:៩ ក ២កថ ១២:១៥ **១១:១៣** ខ មថ ៧:១៥ គ ទត ១:១០ ឃ វវ ២:២ **១១:១៤** ង មថ ៤:១០ **១១:១៥** ច មថ ១៦:២៧ ភល ៣:១៩ **១១:១៦** ឆ ខ.១ **១១:១៧** ជ ១កថ ៧:១២,២៥ ឈ ខ.២១ **១១:១៨** ញ ២កថ ៥:១៦ ១០:៤ ដ ខ.២១ ភល ៣:៣,៤ **១១:១៩** ឋ ខ.១ ឌ ១កថ ៤:១០

**១១:២០** ឍ ខ.១ ណ កទ ២:៤ ៤:៩ ៥:១ **១១:២១** ត ២កថ ១០:១,១០ ថ ខ.១៧,១៨ ភល ៣:៤ **១១:២២** ទ ភល ៣:៥ ធ រម ៩:៤ ១១:១ ន លក ៣:៨ រម ១១:១ **១១:២៣** ប ១កថ ៣:៥

ពន្យល់)។ ការនេះគាត់ចង់បញ្ជាក់ថា ដំណឹងល្អរបស់ព្រះអម្ចាស់ គឺជាអំណោយ ដែលត្រូវប្រទានមកដោយឥតគិតថ្លៃអ្វីទាំងអស់ (រម ៦:២៣ និងការពន្យល់)។ *ពួកបងប្អូន ដែលមកពីស្រុកម៉ាសេដូន* (មើលការពន្យល់ ១:១)។ ពួកអ្នកទាំងនោះបាននាំយកអំណោយពីពួកជំនុំ (កថ ១៨:៥) ដែលមានដូចជាពួកជំនុំនៅទីក្រុងភីលីព ជាដើម (ភល ៤:១៥)។

**១១:១០** *ស្រុកអាខៃ* (មើលការពន្យល់ ១:១)។

**១១:១២** *ខ្ញុំនឹងចេះតែធ្វើទៅ* មានន័យថា លោកប៉ុលមិនញញើតនឹងប្រកាសដំណឹងល្អដោយឥតគិតថ្លៃនោះទេ ។

**១១:១៣** *សាវកក្លែងក្លាយជាអ្នកឆបោក* ត្រង់ចំណុចនេះ លោកប៉ុលបង្ហាញនូវអត្តសញ្ញាណរបស់ពួកសាវកធំៗទាំងនោះ ថាពួកគេគឺជាសាវកក្លែងក្លាយ (ខ.៥ និងការពន្យល់) ជាអ្នកបម្រើរបស់សាតាំង (ខ.១៤) ដែលតែងតែគ្របបាំងសេចក្ដីពិតរបស់ព្រះអម្ចាស់ ។

**១១:១៤** *ក្លែងខ្លួនធ្វើជាទេវតានៃពន្លឺ* មានន័យថា សាតាំងតែងតែក្លែងខ្លួនធ្វើជាទេវតានៃពន្លឺ ប៉ុន្តែ តាមការពិត វាគឺជាមេនៃសេចក្ដីងងឹតវិញ ។

**១១:១៦** *កុំឱ្យអ្នកណារាប់ខ្ញុំទុកដូចជាល្ងង់ខ្លៅឡើយ* (មើលពន្យល់ ខ.១)។

**១១:១៨** *ខ្ញុំនឹងអួតដែរ* លោកប៉ុលមានប្រសាសន៍យ៉ាងដូច្នេះ គឺចង់បង្ហាញនូវភាពពិតនៃការងាររបស់គាត់ ក្នុងនាមជាសាវករបស់ព្រះអម្ចាស់ ។

**១១:១៩** ត្រង់ចំណុចនេះ ជាសេចក្ដីប្រៀបធៀបរបស់លោកប៉ុល ទៅកាន់ពួកជំនុំនៅទីក្រុងកូរិនថូស ព្រោះពួកគេចូលចិត្តស្ដាប់នូវសេចក្ដីបង្រៀនរបស់គ្រូខុសឆ្គង ហើយម្យ៉ាងទៀតគឺដោយព្រោះតែពួកគេគិតថា ខ្លួនជាមនុស្សមានប្រាជ្ញា ។ ទោះបីជាពួកគេគិតថា ខ្លួនជាមនុស្សមានប្រាជ្ញាក៏ដោយ ក៏ពួកគេទទួលនូវការគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរខាងឯវិញ្ញាណដែរ ព្រោះតែពួកគេចូលចិត្តស្ដាប់សេចក្ដីបង្រៀនរបស់ពួកគ្រូខុសឆ្គង (ខ.៤)។

**១១:២០** *គេចាប់អ្នកប្រើ* គឺដោយប្រើនូវប្រព័ន្ធគ្រប់គ្រងរបស់មនុស្ស (កទ ៥:១ និងការពន្យល់)។ *ស៊ីសាច់អ្នក* (មើលការពន្យល់ មក ១២:៤០)។ *ដណ្ដើមយកអ្វីពីអ្នក* បញ្ជាក់ថា ការដែលពួកគ្រូខុសឆ្គងមកបង្រៀនដល់ពួកជំនុំ នៅទីក្រុងកូរិនថូស គឺដើម្បីស្វែងរកប្រាក់កម្រៃប៉ុណ្ណោះ ។ *បើអ្នកណាដំកើងខ្លួនលើអ្នក* មានន័យថា ពួកគ្រូខុសឆ្គងទាំងនោះ តែងតែមានបំណងធ្វើជាម្ចាស់លើពួកជំនុំ (១:២៤)។ *ទះកំផ្លៀងអ្នកនោះផង* តាមរយៈសេចក្ដីបង្រៀនខុសឆ្គងផ្សេងៗ ពួកគ្រូខុសឆ្គងទាំងនោះ ហាក់ដូចជាបានទះកំផ្លៀងពួកជំនុំតែម្ដង ។

**១១:២១** បទគម្ពីរនេះ លោកប៉ុលមានប្រសាសន៍ជាសេចក្ដីប្រៀបធៀប ដោយគាត់ចង់បញ្ជាក់ប្រាប់ពួកជំនុំនៅទីក្រុងកូរិនថូសថា គាត់មិនអាចធ្វើអ្វីដែលពួកគ្រូខុសឆ្គងធ្វើនោះឡើយ ។ ដូច្នោះហើយ បានជាគាត់ប្រើនូវពាក្យប្រៀបធៀបដោយថា គាត់ជាមនុស្សខ្សោយ ព្រោះគាត់មិនបានតម្កើងខ្លួនគាត់ឱ្យលើពួកជំនុំទេ ហើយក៏មិនចាប់ពួកគេប្រើ ដូចពួកគ្រូខុសឆ្គងទាំងនោះដែរ (ខ.២០)។

**១១:២២** ពួកគ្រូខុសឆ្គងតែងតែនិយាយថា ខ្លួនជាសាសន៍យូដា និងគិតថាខ្លួនវិសេសជាងពួកអ្នកជឿជាសាសន៍ដទៃ ។ ត្រង់ចំណុចនេះបញ្ជាក់ថា ពួកគេគឺជាអ្នកតាមគោលលទ្ធិសាសនាយូដាតែម្ដង ហើយរបៀបនៃការថ្វាយបង្គំរបស់ពួកគេក៏ធ្វើតាមគោលលទ្ធិនេះដែរ ។ ម្យ៉ាងទៀត ពួកគ្រូខុសឆ្គងទាំងនោះ តែងតែបង្ខិតបង្ខំឱ្យពួកអ្នកជឿជាសាសន៍ដទៃធ្វើតាមរបៀបរបស់ខ្លួន។ ទោះជាយ៉ាង ក៏លោកប៉ុលមិនបានប្រកាន់នូវគោលជំហរយ៉ាងដូច្នេះឡើយ (កថ ២២:៣-៥ ២៦:៤-៥ រម ២:២៨-២៩ ១កថ ១២:១៣ កទ ៣:២៨-២៩ អភ ២:១១-១៨ កល ៣:១១ ភល ៣:៥-៦)។

**១១:២៣** *គេជាអ្នកបំរើព្រះគ្រីស្ទឬអី* ត្រង់ចំណុចនេះលោកប៉ុលមិនបាន

ហើយ) ខ្ញុំក៏លើសជាងគេទៅទៀត ក្នុងការនឿយហត់
លើសជាងគេ[ផ] ដោយត្រូវរំពាត់ហួសល្បត់[ព] ទាំងត្រូវជាប់
គុកច្រើនជាងគេ[ភ] ក៏ដល់នូវភាពជិតស្លាប់ជាញឹកញយ[ម]
២៤ ប្រាំដងហើយ សាសន៍យូដាវាយខ្ញុំ៤០រំពាត់[យ]ខ្វះ១ ២៥ គេ
វាយខ្ញុំនឹងដំបង ៣ ដង[រ] គេចោលខ្ញុំនឹងថ្ម ១ ដង[ល] ខ្ញុំត្រូវ
សំពៅលិច ៣ ដង[វ] ខ្ញុំនៅនាសមុទ្រជ្រៅអស់ ១ ថ្ងៃ ១ យប់
២៦ ខ្ញុំដើរដំណើរជាច្រើន ក៏មានសេចក្តីអន្តរាយនៅទន្លេ
អន្តរាយដោយពួកចោរប្លន់ អន្តរាយដោយសាសន៍របស់ខ្ញុំ[ស]
អន្តរាយដោយសាសន៍ដទៃ ក៏អន្តរាយក្នុងទីក្រុង[ហ] ក្នុង
ទីរហោស្ថាន ក្នុងសមុទ្រក្នុងពួកបងប្អូនក្លែងក្លាយដែរ[ឡ]
២៧ ត្រូវនឿយហត់ ហើយលំបាក[អ] ត្រូវចាំយាមជាញយ ត្រូវ
ស្រេកឃ្លាន[ក] ត្រូវអត់ជាញឹកញយ ត្រូវរងា ហើយត្រូវ
អាក្រាតផង ២៨ ក្រៅពីការខាងសាច់ឈាមទាំងនោះ ក៏មាន
សេចក្តីកង្វល់ខាងឯពួកជំនុំទាំងប៉ុន្មាន ដែលប្រជ្រៀតមក
លើខ្ញុំ រាល់តែថ្ងៃជានិច្ចថែមទៀត[ខ] ២៩ តើអ្នកឯណាខ្សោយ
ហើយខ្ញុំមិនបានខ្សោយផង [គ] តើអ្នកឯណាអាក់អន់ចិត្ត[ឃ]
ហើយខ្ញុំមិនឈឺឆ្អាលផង ៣០ បើសិនជាគួរនឹងអួតខ្លួន[ង]
នោះខ្ញុំនឹងអួតពីសេចក្តីកំសោយរបស់ខ្ញុំវិញ[ច] ៣១ ព្រះដ៏ជា
ព្រះវរបិតានៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលមានព្រះពរ
អស់កល្បជានិច្ច[ឆ]ទ្រង់ជ្រាប[ជ]ថា ខ្ញុំមិនកុហកទេ ៣២ នៅក្រុង
ដាម៉ាស ចៅហ្វាយស្រុកនៃស្តេចអើរេតាសបានឱ្យគេចាំ

**១១:២៣** ផ ១កថ ១៥:១០
ព កថ ១៦:២៣
២កថ ៦:៤,៥
ភ កថ ១៦:២៣
២កថ ៦:៤,៥
ម រម ៨:៣៦
**១១:២៤** យ ចទ ២៥:៣
**១១:២៥** រ កថ ១៦:២២
ល កថ ១៤:១៩
វ កថ ២៧:១-៤៤
**១១:២៦** ស កថ ២០:៣ ហ កថ ២១:៣១ ឡ កទ ២:៤
**១១:២៧** អ កថ ១៨:៣ កល ១:២៩
ក ១កថ ៤:១១,១២
២កថ ៦:៥
**១១:២៨** ខ ១កថ ៧:១៧
**១១:២៩** គ រម ១៤:១
១កថ ២:៣
ឃ មថ ៥:២៩
**១១:៣០** ង ខ.១៦
កទ ៦:១៤
២កថ ១២:៥,៩

យាមទីក្រុងដោយចង់ចាប់ខ្ញុំ[ឈ] ៣៣ ប៉ុន្តែ មានគេដាក់ខ្ញុំក្នុង
កញ្ជើ សំរូតចុះ តាមបង្អួចកំផែង ឱ្យខ្ញុំរួចពីកណ្តាប់ដៃ
លោកចេញ[ញ]។

**១២** ១ ប្រាកដជាគ្មានប្រយោជន៍ឱ្យខ្ញុំអួតខ្លួនទេ[ដ] ប៉ុន្តែខ្ញុំនឹង
និយាយពីការជាក់ស្តែង និងការបើកសំដែង[ឋ]មកពី ព្រះ
អម្ចាស់ទៀត ២ ខ្ញុំស្គាល់មនុស្សម្នាក់នៅក្នុងព្រះគ្រីស្ទ[ឌ] ដែល
បានលើកឡើង[ឍ]ទៅស្ថានសួគ៌នៅជាន់ទី៣[ណ]នោះ ប្រហែល
១៤ ឆ្នាំមកហើយ ទោះបើក្នុងរូបកាយ ឬក្រៅពីរូបកាយ
នោះខ្ញុំមិនដឹងទេ មានតែព្រះដែលទ្រង់ជ្រាប[ត] ៣ ខ្ញុំស្គាល់
មនុស្សនោះ (ទោះបើក្នុងរូបកាយ ឬក្រៅពីរូបកាយក្តី ខ្ញុំមិន
ដឹងទេ មានតែព្រះដែលទ្រង់ជ្រាប) ថា ៤ អ្នកនោះបាន
លើកឡើង[ថ]ដល់ស្ថានបរមសុខ[ទ] ហើយបាន ឮពាក្យដែល
ថ្លែងប្រាប់មិនបាន ក៏គ្មានច្បាប់ឱ្យមនុស្សណានិយាយឡើយ
៥ ខ្ញុំនឹងមានសេចក្តីអំនួតពីមនុស្សនោះ ខ្ញុំមិនអួតពីខ្លួនខ្ញុំទេ
លើកតែពីសេចក្តី កំសោយរបស់ខ្ញុំចេញ[ធ] ៦ ទោះបើខ្ញុំចង់
អួតខ្លួន[ន] នោះគង់តែខ្ញុំមិនមែនខ្លៅល្ងង់ទេ[ប] ដ្បិតខ្ញុំនិយាយ

ច ១កថ ២:៣ **១១:៣១** ឆ រម ១:២៥ ៩:៥ ជ ខ.១១ រម ១:៩ **១១:៣២** ឈ កថ ៩:២៤ **១១:៣៣** ញ កថ ៩:២៥ **១២:១** ដ ខ.៥,៩ ២កថ ១១:១៦,៣០ ឋ ខ.៧ ១កថ ២:១០ **១២:២** ឌ រម ១៦:៣ ឍ ខ.៤ កថ ៨:៣៩ ណ អភ ៤:១០ ត ២កថ ១១:១១ **១២:៤** ថ ខ.២ ទ លក ២៣:៤៣ វវ ២:៧ **១២:៥** ធ ខ.៩,១០ ១កថ ២:៣ **១២:៦** ន ២កថ ១០:៨ ប ខ.១១ ២កថ ១១:១៦

ប្រកាសថា ពួកគ្រូខុសឆ្គងទាំងនោះជាអ្នកបម្រើព្រះគ្រីស្ទទេ ប៉ុន្តែគាត់ចង់បង្ហាញដល់ពួកជំនុំនៅទីក្រុងកូរិនថូសឱ្យឃើញច្បាស់នូវភាពជាអ្នកបម្រើព្រះគ្រីស្ទដ៏ពិតប្រាកដ ។ *ក៏ដល់នូវភាពជិតស្លាប់ជាញឹកញយ* (៤:៨-១១)។

**១១:២៤-២៥** ក្នុងបទគម្ពីរទាំងពីរនេះ លោកប៉ុលត្រូវបានគេវាយចំនួន ៨ដង ។ ពួកយូដាបានវាយគាត់នឹងរំពាត់ចំនួនប្រាំដង (ចទ ២៥:៣ មក ១៥:១៥ និងការពន្យល់) ហើយពួករ៉ូម៉ាំងបានវាយគាត់នឹងដំបងចំនួន៣ដង (កថ ១៦:២២,៣៧ ២២:២៥ និងការពន្យល់)។

**១១:២៥** *ចោលខ្ញុំនឹងថ្ម* ការចោលនឹងថ្មដើម្បីសម្លាប់មនុស្ស គឺជាទំនៀមទម្លាប់របស់សាសន៍យូដា ក្នុងការដាក់ទោសមនុស្ស (យហ ៨:៥៩ កថ ៧:៥៧-៥៩)។ *សំពៅលិច* នៅក្នុងព្រះគម្ពីរកិច្ចការបានកត់ត្រានូវហេតុការណ៍លិចសំពៅតែម្តងប៉ុណ្ណោះ ។ ក្នុងសំបុត្ររបស់លោកប៉ុលទៅពួកជំនុំនៅក្រុងកូរិនថូសលើកទីពីរនេះបញ្ជាក់ថា គាត់ត្រូវលិចសំពៅបីដង (កថ ២៧:៣៩-៤៤)។ ការលិចសំពៅបីដងដែលលោកប៉ុលបានលើកឡើង អាចសំដៅលើហេតុការណ៍នៅក្នុង "កថ ៩:៣០ ១១:២៥-២៦ ១៣:៤,១៣ ១៤:២៦ ១៦:១១ ១៨:១៨-១៩,២១-២២"។

**១១:២៦** *អន្តរាយដោយពួកចោរប្លន់* (មើលការពន្យល់ កថ ១៤:២៤)។

**១១:២៨-២៩** ត្រង់ចំណុចនេះបង្ហាញឱ្យឃើញនូវទឹកចិត្តរបស់លោកប៉ុលចំពោះពួកជំនុំនៅទីក្រុងកូរិនថូស ។ ប្រសិនបើពួកជំនុំខ្សោយ នោះលោកប៉ុលក៏មានអារម្មណ៍ថា ខ្លួនគាត់ខ្សោយដែរ ។

**១១:៣០** *នោះខ្ញុំនឹងអួតពីសេចក្តីកំសោយរបស់ខ្ញុំវិញ* លោកប៉ុលបានបង្ហាញនូវសេចក្តីកម្សោយរបស់គាត់ ដើម្បីឱ្យភាពខ្លាំងនៃព្រះគុណរបស់ព្រះគ្រីស្ទសំដែងឡើងនៅក្នុងគាត់វិញ ។

**១១:៣២-៣៣** លោកប៉ុលលើកយកហេតុការណ៍ទាំងនេះមកនិយាយ ដើម្បីបង្ហាញនូវការបន្ទាបខ្លួន និងការដែលគេប្រមាថដល់គាត់ (ខ.៣០)។

**១១:៣២** *ក្រុងដាម៉ាស* (មើលការពន្យល់ កថ ៩:២)។ *ស្តេចអើរេតាស* គឺស្តេចអើរេតាសទី៤ ជាបិតាក្មេករបស់ស្តេចហេរ៉ូឌអាន់ទីប៉ាស ។ ស្តេចអើរេតាសអង្គនេះ បានគ្រប់គ្រងនៅឯណាបាធៀន-អារ៉ាប់ (Nabatean Arabs) ចាប់ពីឆ្នាំទី៩ មុនគ.សដល់ឆ្នាំ៤០គ.ស ។ អធិរាជរ៉ូម៉ាំងឈ្មោះកាលីហ្គូឡា (Caligula) បានប្រគល់ក្រុងដាម៉ាសនេះទៅស្តេចអើរេតាស ។

**១១:៣៣** *តាមបង្អួច* (យស ២:១៥ ១សយ ១៩:១២ កថ ៩:២៥)។

**១២:២,៤** *ស្ថានសួគ៌នៅជាន់ទី៣* តាមរយៈសេចក្តីបង្រៀនរបស់ពួកយូដា ពាក្យថា "ស្ថានសួគ៌" ត្រូវចែកជា៣ផ្នែកគឺ (១).ស្ថានសួគ៌ជាន់ទី១ សំដៅលើផ្ទៃមេឃ (២).ស្ថានសួគ៌ជាន់ទី២ សំដៅលើពិភពលោក (៣).ស្ថានសួគ៌ជាន់ទី៣ សំដៅលើទីកន្លែងដែលព្រះគង់នៅ (នហ ២:៨ លក ២៣:៤៣ ហព ៤:១៤ ៧:២៦ អភ ៤:១០ ភល ១:២៣ វវ ២:៧)។

**១២:២** *មនុស្សម្នាក់នៅក្នុងព្រះគ្រីស្ទ* លោកប៉ុលមានប្រសាសន៍យ៉ាងដូច្នេះគឺសំដៅលើរូបគាត់ផ្ទាល់ ។ *ប្រហែល១៤ឆ្នាំមកហើយ* ត្រង់ចំណុចនេះបញ្ជាក់ថា លោកប៉ុលបានទទួលការបើកសំដែងឱ្យឃើញពីទិដ្ឋភាពនៃស្ថានសួគ៌ ក្នុងពេលដែលគាត់ចាប់ផ្តើមបម្រើការងាររបស់ព្រះអម្ចាស់ មុនពេលដំណើរបេសកកម្មលើកទីមួយរបស់គាត់ (កថ ១៣:៤-១៤:២៨)។

តាម តែសេចក្ដីពិត ប៉ុន្ដែ ខ្ញុំឈប់ស្លេះចុះ ក្រែងអ្នកណារាប់
ខ្ញុំ ទុកជាលើសជាង ភាពដែលឃើញ ឬឮនិយាយពីខ្ញុំ ។
៧ហើយក្រែងខ្ញុំកើតមានចិត្ដធំ ដោយព្រោះការបើក
សំដែងដ៏ហួសល្បត់នោះ[ផ] បានជាមានបន្លា ១ ចាក់មកក្នុង
សាច់ឈាមខ្ញុំ[ព] គឺជាទេវតារបស់អារក្សសាតាំង[ភ] ដែលមក
ធ្វើទុក្ខខ្ញុំ ដើម្បីកុំឲ្យខ្ញុំមានចិត្ដធំឡើយ ៨ខ្ញុំបានសូមអង្វរដល់
ព្រះអម្ចាស់ ៣ ដង ឲ្យសេចក្ដីនោះថយចេញពីខ្ញុំទៅ[ម] ៩តែ
ទ្រង់មានបន្ទូលមកខ្ញុំថា គុណរបស់អញ[យ]ល្មមដល់ឯង
ហើយ ដ្បិតកំឡាំង[រ]អញបានពេញខ្នាត ដោយសេចក្ដី
កំសោយ[លវ] ដូច្នេះ ខ្ញុំនឹងស៊ូអួតពីសេចក្ដីកំសោយរបស់ខ្ញុំ
ដោយអំណរជាខ្លាំង ដើម្បីឲ្យព្រះចេស្ដានៃព្រះគ្រីស្ទបាន
សណ្ឋិតនៅនឹងខ្ញុំ ១០ហេតុនោះបានជាខ្ញុំអរសប្បាយ[ស]ក្នុង
កាលដែលមានសេចក្ដីកំសោយ ក្នុងកាលដែលគេត្មះតិះ
ដៀលក្នុងសេចក្ដីលំបាក[ហ] កាលគេធ្វើទុក្ខបៀតបៀន[ឡ]
ហើយក្នុងសេចក្ដីដែលខ្ញុំត្រូវចង្អៀតចង្អល់ ដោយយល់ដល់
ព្រះគ្រីស្ទ ដ្បិតកាលណាខ្ញុំខ្សោយ នោះខ្ញុំមានកំឡាំងយ៉ាង
ចំណានវិញ[អ]។

## ការព្រួយបារម្ភរបស់លោកសាវ័កប៉ុលដល់ពួកកូរិនថូស

១១ខ្ញុំបានត្រឡប់ជាល្ងង់ខ្លៅ[ក] ដោយសេចក្ដីអំនួត គឺអ្នក
រាល់គ្នាបានបង្ខំខ្ញុំ ដ្បិតគួរឲ្យអ្នករាល់គ្នាបានផ្ទុកផ្ដាក់ខ្ញុំវិញ
ទោះបើខ្ញុំមិនមែនជាអ្វីក៏ដោយ[ខ] គង់តែខ្ញុំមិនចាញ់ពួកសាវក
ធំ[គ]ណាមួយនោះទេ ១២ពិតមែន មានភស្ដុតាងបានកើត
ឡើងក្នុងពួកអ្នករាល់គ្នា ដើម្បីនឹងបញ្ជាក់ការងារជាសាវក
របស់ខ្ញុំ ដោយការអត់ធន់ ដោយទីសំគាល់ ការអស្ចារ្យ[ឃ]
និងការឫទ្ធិបារមីគ្រប់យ៉ាង ១៣តើអ្នករាល់គ្នាបានចាញ់
ពួកជំនុំឯទៀតទាំងប៉ុន្មានយ៉ាងណាខ្លះ លើកចេញតែការ
ដែលខ្ញុំមិនឲ្យអ្នកណាព្រួយនឹងខ្ញុំ[ង] សូមអត់ទោសសេចក្ដី
កំហុសនេះឲ្យខ្ញុំផង[ច]។
១៤មើល ខ្ញុំរៀបនឹងមកឯអ្នករាល់គ្នា ជាគំរប់ ៣ លើក
នេះហើយ[ឆ] ខ្ញុំក៏មិនឲ្យអ្នកណាព្រួយនឹងខ្ញុំទៀត ដ្បិតខ្ញុំមិនរក
ចង់បានរបស់ទ្រព្យអ្នករាល់គ្នាទេ គឺរកតែខ្លួនអ្នករាល់គ្នា
ប៉ុណ្ណោះ ដ្បិតមិនគួរឲ្យកូនចៅត្រូវប្រមូលទុកឲ្យឪពុកម្ដាយ
ទេ[ជ] គឺឪពុកម្ដាយទេតើ ដែលត្រូវប្រមូលទុកឲ្យកូនវិញ[ឈ]
១៥ឯខ្ញុំៗសុខចិត្ដនឹងចែកចាយ ហើយនិងត្រូវហិនអស់រលីង
ទៅចុះ ដោយព្រោះព្រលឹងរបស់អ្នករាល់គ្នា[ញ] ថ្វីបើខ្ញុំ
ស្រឡាញ់អ្នករាល់គ្នាកាន់តែខ្លាំងឡើងប៉ុណ្ណា[ដ]នោះអ្នករាល់
គ្នាស្រឡាញ់ខ្ញុំ ក៏កាន់តែថយចុះប៉ុណ្ណោះដែរ ១៦ទោះបើ
ដូច្នោះក៏ដោយ គង់តែខ្ញុំមិនបានឲ្យអ្នកណាមួយព្រួយនឹងខ្ញុំ
ឡើយ[ឋ] តែដោយខ្ញុំឆ្លាត បានជាខ្ញុំចាប់អ្នករាល់គ្នា ដោយ
ឧបាយកល ១៧តើខ្ញុំបានចំណេញពីអ្នករាល់គ្នា ដោយសារ
អ្នកណាដែលខ្ញុំចាត់មកឬអី ១៨ខ្ញុំបានអង្វរ[ឌ]អ្នកទីតុស[ឍ]ឲ្យមក
ហើយបានចាត់បងប្អូនម្នាក់[ណ]ឲ្យមកជាមួយដែរ តើទីតុស
បានចំណេញពីអ្នករាល់គ្នាឬអី តើយើងទាំង ២ នាក់មិនបាន
ដើរដោយគំនិតតែ ១ ហើយតាមដានជើងដដែលទេឬអី ។
១៩មួយទៀត តើអ្នករាល់គ្នាគិតស្មានថា យើងខ្ញុំកំពុងតែ

**១២:៧** ផ ខ.១ ១កថ ២:១០ ព ជន ៣៣:៥៥ ភ មថ ៤:១០ **១២:៨** ម មថ ២៦:៣៩,៤៤ **១២:៩** យ រម ៣:២៤ រ ភល ៤:១៣ ល ១កថ ២:៣ វ ១ពវ ២:៣ **១២:១០** ស មថ ៥:១២ ហ ២កថ ៦:៤ អ ២ថន ១:៤ ឡ ២កថ ១៣:៤ **១២:១១** ក ២កថ ១១:១ ខ ១កថ ១៥:៩,១០ គ ២កថ ១១:៥ **១២:១២** ឃ យហ ៤:៤៨ **១២:១៣** ង ខ.១៤ ១កថ ៩:១២,១៨ ច ២កថ ១១:៧ **១២:១៤** ឆ ២កថ ១៣:១ ជ ១កថ ៤:១៤,១៥ ឈ សភ ១៩:១៤ **១២:១៥** ញ ភល ២:១៧ ១ថន ២:៨ ដ ២កថ ១១:១១ **១២:១៦** ឋ ២កថ ១១:៩ **១២:១៨** ឌ ២កថ ៨:៦,១៦ ឍ ២កថ ២:១៣ ណ ២កថ ៨:១៨

**១២:៧** *ការបើកសំដែង* (សូមមើលខ.១)។ *មានបន្លា១ចាក់មកក្នុងសាច់ឈាមខ្ញុំ* ត្រង់ចំណុចនេះមិនបានបញ្ជាក់ថា គាត់ទទួលការឈឺចាប់យ៉ាងដូច្នេះ នៅឯកន្លែងណា និងក្នុងពេលណានោះទេ ។ *ទេវតារបស់អារក្សសាតាំង* ឃ្លានេះអាចសំដៅលើបន្លាដែលចាក់នៅក្នុងសាច់ឈាមរបស់លោកប៉ុលតែម្ដង (យហ ២:៧ និង ការពន្យល់)។

**១២:៩** *គុណរបស់អញល្មមដល់ឯងហើយ* មានន័យថា ព្រះគុណនៃព្រះអម្ចាស់ គឺខ្លាំងក្លាជាងបន្លានៅក្នុងសាច់ឈាមរបស់លោកប៉ុលទៅទៀត ។ ការដែលលោកប៉ុលទទួលស្គាល់ថាខ្លួនខ្សោយ គឺសំដែងឲ្យឃើញនូវព្រះចេស្ដារបស់ព្រះអម្ចាស់នៅក្នុងគាត់វិញ ។

**១២:១០** គំរូនៃអំណាចព្រះចេស្ដា ដែលស្ដែងចេញពីភាពកម្សោយគឺបង្ហាញឲ្យឃើញយ៉ាងច្បាស់ នៅពេលដែលព្រះយេស៊ូវគ្រីស្ទត្រូវគេឆ្កាង នៅលើឈើឆ្កាង (១៣:៤ មើលការពន្យល់ ភល ៤:១៣)។

**១២:១១** *ខ្ញុំបានត្រឡប់ជាល្ងង់ខ្លៅ* (មើលការពន្យល់ ១១:១)។ *គឺអ្នករាល់គ្នាបានបង្ខំខ្ញុំ* មានន័យថា ពួកជំនុំនៅទីក្រុងកូរិនថូសបានបង្ខំឲ្យលោកប៉ុលសរសេរនូវសេចក្ដីទាំងឡាយអំពីខ្លួនគាត់ផ្ទាល់ ព្រោះពួកគេបានទទួលនូវសេចក្ដីបង្រៀនរបស់ពួកគ្រូខុសឆ្គង(ពួកសាវកធំ) ជាច្រើន ដែលជាពួកអ្នកប្រឆាំងនឹងគាត់ និងអំណាចដែលគាត់បានទទួលមកអំពីព្រះអម្ចាស់ ។

**១២:១២** *ទីសំគាល់ ការអស្ចារ្យ និងការឫទ្ធិបារមី* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកគ្រូខុសឆ្គងបានមកឯពួកជំនុំនៅឯទីក្រុងកូរិនថូសដោយពុំមានការទាំងបីនេះទេ គឺផ្ទុយពីពួកសាវ័កពិតប្រាកដរបស់ព្រះអម្ចាស់ ដូចជាលោកប៉ុលជាដើម (មើលការពន្យល់ ហព ២:៤)។

**១២:១៣** *ខ្ញុំមិនឲ្យអ្នកណាព្រួយនឹងខ្ញុំ* (១១:៧,៩,១២ និងការពន្យល់)។ *សូមអត់ទោសសេចក្ដីកំហុសនេះឲ្យខ្ញុំផង* គឺសំដៅលើសេចក្ដីដែលបានសង្ខេបនៅក្នុង "២កថ ១១:៧–១២"។

**១២:១៤** *គំរប់៣លើក* (១៣:១ និងការពន្យល់)។ *កូនចៅ* ត្រង់ចំណុចនេះបញ្ជាក់ថា លោកប៉ុលជាឪពុកខាងឯវិញ្ញាណនៃពួកជំនុំនៅទីក្រុងកូរិនថូស។

**១២:១៦** *ខ្ញុំចាប់អ្នករាល់គ្នា ដោយឧបាយកល* នេះជាសេចក្ដីប្រៀបធៀបដែលលោកប៉ុលមានប្រសាសន៍ទៅកាន់ពួកជំនុំនៅទីក្រុងកូរិនថូស ដើម្បីបញ្ជាក់ប្រាប់ពួកគេឲ្យដឹងនូវការទាំងឡាយ ដែលពួកគ្រូខុសឆ្គង តែងតែរកឧបាយកលដ៏អាក្រក់ក្នុងការប្រឆាំងនឹងគាត់ ដោយពួកគ្រូទាំងនោះនិយាយថា គាត់បានឆ្លៀតឱកាសរកផលប្រយោជន៍ពីពួកជំនុំ និងមិនបានយកប្រាក់ដង្វាយទៅដល់ពួកជំនុំនៅទីក្រុងយេរូសាឡិមទេ (ខ.១៧)។

**១២:១៨** *អ្នកទីតុស . . . បងប្អូន* មើល ៨:៦,១៦–១៧,១៨,២៣ និងពន្យល់។

**១២:១៩** *យើងខ្ញុំនិយាយក្នុងព្រះគ្រីស្ទនៅចំពោះព្រះ* (១កថ ៤:៣–៤ មើល

ដោះសានឹងអ្នករាល់គ្នាឬអី ឱពួកស្ងួនភ្ងាអើយ[ត] យើងខ្ញុំ
និយាយក្នុងព្រះគ្រីស្ទនៅចំពោះព្រះ[ថ] ហើយយើងខ្ញុំនិយាយ
គ្រប់ទាំងអស់នេះ សំរាប់នឹងស្អាងចិត្តអ្នករាល់គ្នាឡើងទេ[ទ]
២០ ដ្បិតខ្ញុំខ្លាចក្រែងកាលណាខ្ញុំមកដល់ [ធ]នោះមិនឃើញអ្នក
រាល់គ្នា ដូចជាខ្ញុំចូលចិត្តនោះទេ ហើយអ្នករាល់គ្នាក៏មិន
ឃើញខ្ញុំ ដូចជាអ្នករាល់គ្នាចូលចិត្តដែរ[ន] ក្រែងកើតមាន
សេចក្តីឈ្លោះប្រកែក[ប] ឈ្នានីស គ្នាន់ក្នាញ់ បាក់បែក
បិរហារ[ផ] បង្កាច់[ព,ភ] ឆ្មើងឆ្មៃ[ម] ហើយវឹកវរឡើង[យ] ២១ ក្រែង
កាលណាខ្ញុំមកម្តងទៀត នោះព្រះនៃខ្ញុំនឹងបន្ទាបខ្ញុំ នៅ
ចំពោះអ្នករាល់គ្នា ហើយខ្ញុំនឹងត្រូវយំ[រ]នឹងមនុស្សជាច្រើន
ដែលធ្វើបាបពីមុន[ល] តែមិនបានប្រែចិត្តចេញ ពីសេចក្តី
ស្មោកគ្រោក សេចក្តីកំផិត និងសេចក្តីអាសអាភាស[វ] ដែល
គេបានប្រព្រឹត្តនោះឡើយ ។

## ការព្រមានជាលើកចុងក្រោយ

**១៣** ១ នេះជាគំរប់៣ដងហើយ[ស] ដែលខ្ញុំមកឯអ្នករាល់គ្នា
គ្រប់ការទាំងអស់នឹងបានសំរេច ដោយនូវមាត់ស្មរបន្ទាល់
២ ឬ៣នាក់[ហ] ២ ខ្ញុំបានប្រាប់កាលពីដើម ហើយឥឡូវនេះក៏
និយាយទុកជាមុន ទុកដូចជាកាលបាននៅជាមួយនឹងអ្នក
រាល់គ្នាក្នុងលើកទី២ នោះនៅឡើយ ហើយសព្វថ្ងៃនេះ
ដែលនៅឃ្លាតគ្នា[ឡ] ខ្ញុំសរសេរ[អ]មកពួកអ្នកនោះដែលធ្វើ
បាបពីមុន[ក] ហើយទៅអ្នកឯទៀតទាំងអស់ដែរថា បើខ្ញុំមក
ម្តងទៀត នោះខ្ញុំមិនត្រាប្រណីទេ ៣ ដ្បិតអ្នករាល់គ្នារក
ភស្តុតាងពីព្រះគ្រីស្ទ ដែលទ្រង់មានបន្ទូលដោយសារខ្ញុំ[ខ]
(ដែលទ្រង់មិនខ្សោយចំពោះអ្នករាល់គ្នា គឺមានព្រះចេស្តា
ក្នុងអ្នករាល់គ្នាវិញ ៤ ទោះបើទ្រង់ត្រូវគេឆ្កាង ដោយ
សេចក្តីកំសោយក៏ដោយ[គ] គង់តែទ្រង់មានព្រះជន្មរស់នៅ
ដោយព្រះចេស្តានៃព្រះដែរ[ឃ] ព្រោះយើងខ្ញុំខ្សោយ[ង]ក្នុង
ទ្រង់មែន តែយើងខ្ញុំនឹងរស់នៅជាមួយនឹងទ្រង់[ច] ដោយ
សារព្រះចេស្តានៃព្រះ ដែលផ្តល់មកអ្នករាល់គ្នាវិញ) ។
៥ ចូរអ្នករាល់គ្នាពិចារណាខ្លួនឯងមើល[ឆ] តើស្ថិតនៅ
ក្នុងសេចក្តីជំនឿឬទេ ចូរល្បងខ្លួនមើលចុះ[ជ] តើអ្នករាល់គ្នា
មិនយល់ឃើញថា ព្រះយេស៊ូវគ្រីស្ទគង់ក្នុងអ្នករាល់គ្នា[ឈ]
ទេឬអី លើកតែអ្នករាល់គ្នាត្រូវកាត់ចោលចេញប៉ុណ្ណោះ
៦ តែខ្ញុំសង្ឃឹមថា អ្នករាល់គ្នានឹងដឹងថា យើងខ្ញុំមិនត្រូវកាត់
ចោលចេញទេ ៧ ហើយខ្ញុំអធិស្ឋានដល់ព្រះ សូមកុំឱ្យអ្នក
រាល់គ្នាធ្វើការអាក្រក់អ្វីឡើយ មិនមែនដើម្បីឱ្យយើងខ្ញុំបាន
រាប់ជាគួរទេ គឺប្រយោជន៍ឱ្យអ្នករាល់គ្នាបានប្រព្រឹត្តសេច
ក្តីល្អតែប៉ុណ្ណោះ ហើយឱ្យយើងខ្ញុំទុកដូចជាត្រូវកាត់ចេញ
វិញចុះ ៨ ដ្បិតយើងខ្ញុំពុំអាចនឹងធ្វើអ្វី ទាស់នឹងសេចក្តីពិត
បានទេ ធ្វើបានតែអ្វីដែលសំរាប់សេចក្តីពិតវិញ ៩ ពីព្រោះ
យើងខ្ញុំមានសេចក្តីអំណរ ក្នុងកាលដែលយើងខ្ញុំខ្សោយ[ញ]
ហើយអ្នករាល់គ្នាមានកំឡាំងឡើង[ដ] តែយើងខ្ញុំអធិស្ឋាន
សូមសេចក្តីនេះទៀត គឺឱ្យពួកអ្នករាល់គ្នាបានគ្រប់លក្ខណ៍
ទាំងអស់គ្នា[ឋ] ១០ ហេតុនោះបានជាកាលខ្ញុំនៅឃ្លាតពីអ្នក
រាល់គ្នា នោះខ្ញុំធ្វើសំបុត្រនេះ ក្រែងកាលណាខ្ញុំមកនៅ ជា

**១២:១៩** ត រម ៩:១ ថ ១កថ ១០:១៤ ទ រម ១៤:១៩ ២កថ ១០:៨ **១២:២០** ធ ១កថ ២:១–៤ ន ១កថ ៤:២១ ប ២កថ ១:១១ ៣:៣ ផ កទ ៥:២០ ភ រម ១:៣០ ព រម ១:២៩ ម ១កថ ៤:១៨ យ ១កថ ១៤:៣៣ **១២:២១** រ ២កថ ២:១,៤ ល ២កថ ១៣:២ វ ១កថ ៦:១៨ **១៣:១** ស ២កថ ១២:១៤ ហ ចទ ១៩:១៥ មថ ១៨:១៦ **១៣:២** ឡ ខ.១០ អ ២កថ ១:២៣ ក ២កថ ១២:២១ **១៣:៣** ខ មថ ១០:២០ ១កថ ៥:៤ **១៣:៤** គ ១កថ ១:២៥ ភល ២:៧,៨ ១ពត ៣:១៨ ឃ រម ១:៤ ៦:៤ ១កថ ៦:១៤ ង ខ.៩ ១កថ ២:៣ ច រម ៦:៥ **១៣:៥** ឆ ១កថ ១១:២៨ ជ បទ ៣:៤០ យហ ៦:៦ ឈ រម ៨:១០ **១៣:៩** ញ ១កថ ២:៣ ដ ២កថ ៤:១២ ឋ ខ.១១ អភ ៤:១៣

ការពន្យល់ ៤:៣)។ *គ្រប់ការទាំងអស់ . . . សំរាប់នឹងស្អាងចិត្តអ្នករាល់គ្នា* (១០:៨ និងការពន្យល់)។

**១២:២០–២១** "មើលការពន្យល់ រម ១:២៩–៣១"។

**១២:២០** បទគម្ពីរនេះបញ្ជាក់ថា ពួកជំនុំនៅទីក្រុងកូរិនថូសមិនទាន់បានពេញវ័យខាងឯជំនឿ មិនសូវរឹងមាំ ពុំមានការរៀបចំត្រឹមត្រូវ និងមិនសូវមានភាពចុះសម្រុងគ្នាទេ (មើលការពន្យល់ ១កថ ៣:១–៤)។

**១២:២១** *ធ្វើបាបពីមុន . . . សេចក្តីស្មោកគ្រោក សេចក្តីកំផិត និងសេចក្តីអាសអាភាស* (មើលការពន្យល់ ១កថ ៥:១,១១ ៦:១៣,១៦,១៨–១៩)។

**១៣:១** *ជាគំរប់៣ដង* (១២:១៤ មើលការពន្យល់ ២:១)។ *ដោយនូវមាត់ស្មរបន្ទាល់ ២ឬ៣នាក់* (ចទ ១៧:៦ និងការពន្យល់)។

**១៣:២** *ពួកអ្នកនោះដែលធ្វើបាបពីមុន* (១២:២១ និងការពន្យល់)។ *អ្នកឯទៀត* សំដៅលើពួកអ្នកដែលចុះចូលទៅខាងពួកគ្រូខុសឆ្គង ។

**១៣:៣** *ដ្បិតអ្នករាល់គ្នារកភស្តុតាងពីព្រះគ្រីស្ទ ដែលទ្រង់មានបន្ទូលដោយសារខ្ញុំ* (មើលការពន្យល់ ១០:១០)។

**១៣:៤** *ទ្រង់ត្រូវគេឆ្កាង ដោយសេចក្តីកំសោយ* (៨:៩ ភល ២:៦–៨ មើលការពន្យល់ ២កថ ១២:១០)។

**១៣:៥** *ចូរអ្នករាល់គ្នាពិចារណាខ្លួនឯង . . . ចូរល្បងខ្លួនមើល* (មើលការពន្យល់ ២ពត ១:១០–១១)។

**១៣:៦៧** *ឱ្យអ្នករាល់គ្នាបានប្រព្រឹត្តសេចក្តីល្អតែប៉ុណ្ណោះ* លោកប៉ុលមានប្រសាសន៍យ៉ាងដូច្នេះ ព្រោះគាត់មិនចង់ប្រើអំណាចជាសាវ័ក ដើម្បីបង្ខំពួកជំនុំឱ្យប្រតិបត្តិតាមគាត់ នៅពេលដែលគាត់បានជួបពួកគេនោះទេ។ *ប្រព្រឹត្តសេចក្តីល្អ* គឺដើម្បីឱ្យសាវ័កប៉ុលមិនចាំបាច់បង្ហាញភស្តុតាងនៃសិទ្ធិអំណាចរបស់គាត់ ដោយប្រៀនប្រដៅពួកគេ នៅពេលដែលគាត់ទៅដល់ពួកគេនោះឡើយ ។

**១៣:៨** *យើងខ្ញុំពុំអាចនឹងធ្វើអ្វី ទាស់នឹងសេចក្តីពិតបានទេ* បញ្ជាក់ថា លោកប៉ុលអាចសំដែងអំណាចជាសាវ័កដើម្បីគាំទ្រ និងការពារសេចក្តីពិតប៉ុណ្ណោះ

**១៣:៩** *ក្នុងកាលដែលយើងខ្ញុំខ្សោយ* (១២:៩–១០ និងការពន្យល់)។ *អ្នករាល់គ្នាមានកំឡាំងឡើង* គឺឱ្យមានកម្លាំងឡើងនៅក្នុងសេចក្តីពិត ។ *ឱ្យពួកអ្នករាល់គ្នាបានគ្រប់លក្ខណ៍* គឺឱ្យពួកគេបានគ្រប់លក្ខណ៍ក្នុងសេចក្តីជំនឿ និងដោយសេចក្តីស្រឡាញ់ក្នុងព្រះអម្ចាស់ (កទ ៦:១ និងការពន្យល់)។

**១៣:១០** *សំរាប់នឹងស្អាងចិត្តឡើង មិនមែននឹងផ្តួលទេ* សូមមើល ១០:៨ និងការពន្យល់) ។

មួយ នោះខ្ញុំនឹងប្រព្រឹត្តនឹងអ្នករាល់គ្នាដោយតឹងរ៉ឹង[ឌ] តាម
អំណាចដែលព្រះអម្ចាស់បានប្រទានមកខ្ញុំ គឺសំរាប់នឹង
ស្អាងចិត្តឡើង មិនមែននឹងផ្តួលទេ[ឍ]។

## ការគួរសមជាលើកចុងក្រោយ

១១ឯសេចក្តីឯទៀត បងប្អូនអើយ[ណ] ចូរមានសេចក្តី
អំណរ ចូរឱ្យបានគ្រប់លក្ខណ៍ ចូរឱ្យមានចិត្តក្សេមក្សាន្ត
ចូរមានគំនិតដូចគ្នា ចូរនៅដោយមេត្រីនឹងគ្នាចុះ[ត] នោះ
ព្រះនៃសេចក្តីស្រឡាញ់[ថ] នឹងសេចក្តីសុខសាន្ត[ទ] ទ្រង់នឹងគង់
នៅជាមួយនឹងអ្នករាល់គ្នា ១២សូមជំរាបសួរគ្នាទៅវិញ
ទៅមក ដោយថើបយ៉ាងបរិសុទ្ធ[ធ] ១៣ពួកបរិសុទ្ធគ្រប់គ្នា
សូមជំរាបសួរមកអ្នករាល់គ្នា[ន]។
១៤សូមឱ្យអ្នករាល់គ្នា បានប្រកបដោយព្រះគុណនៃ
ព្រះអម្ចាស់យេស៊ូវគ្រីស្ទ[ប] និងសេចក្តីស្រឡាញ់របស់ព្រះ[ផ]
ហើយនិងសេចក្តីរួបរួមគ្នានឹងព្រះវិញ្ញាណបរិសុទ្ធ[ព]។
អាម៉ែន ។

**១៣:១០** ឌ ២កថ ១:២៣ ឍ ២កថ ១០:៨
**១៣:១១** ណ ១ថន ៤:១ ២ថន ៣:១ ត មក ៩:៥០ ថ ១យហ ៤:១៦ ទ រម ១៥:៣៣ អភ ៦:២៣
**១៣:១២** ធ រម ១៦:១៦
**១៣:១៣** ន ភល ៤:២២
**១៣:១៤** ប រម ១៦:២០ ២កថ ៨:៩ ផ រម ៥:៥ យដ ២១ ព ភល ២:១

**១៣:១១–១៣** ត្រង់ចំណុចនេះ គឺជាការសរុបសេចក្តីរបស់លោកប៉ុល ក្នុងការដាស់តឿន និងសួរសុខទុក្ខ ដោយបង្ហាញនូវការទុកចិត្តបំផុត ។
**១៣:១១,១៤** *សេចក្តីសុខសាន្ត . . . ព្រះគុណ* (មើលពន្យល់ រម ១:៧)។
**១៣:១១** *បងប្អូន* (មើលការពន្យល់ រម ១:១៣)។ *សេចក្តីស្រឡាញ់របស់ព្រះ* (១យហ ៤:៨ និងការពន្យល់) ។ *ព្រះនៃសេចក្តីស្រឡាញ់ និងសេចក្តីសុខសាន្ត* (ហព ១៣:២០ មើលការពន្យល់ ១ថន ៥:២៣) ។
**១៣:១២** *ថើបយ៉ាងបរិសុទ្ធ* មើល ១កថ ១៦:២០ និងពន្យល់ រម ១៦:១៦។
**១៣:១៣** *ពួកបរិសុទ្ធ* មើលការពន្យល់ រម ១:៧ ។
**១៣:១៤** បទគម្ពីរនេះបញ្ជាក់អំពីទំនាក់ទំនងយ៉ាងជិតស្និទ្ធនៃព្រះត្រៃឯក (មថ ២៨:១៩ និងការពន្យល់) និងព្រះនាម "អេម៉ាញូអែល" ដែលមានន័យថា "ព្រះអង្គទ្រង់គង់ជាមួយនឹងយើងខ្ញុំ" (លប ២៦:៣ អស ៧:១៤ មថ ១:២៣ វវ ២១:៣ និងការពន្យល់)។ *សេចក្តីរួបរួមគ្នានឹងព្រះវិញ្ញាណបរិសុទ្ធ* (ភល ២:១ និងការពន្យល់)។ ម្យ៉ាងទៀត សេចក្តីនៅក្នុងបទគម្ពីរនេះ គឺជាសេចក្តីបញ្ចប់នៅក្នុងសំបុត្រទាំងអស់របស់លោកប៉ុល លើកលែងតែសំបុត្រទៅទីក្រុងអេភេសូរមួយប៉ុណ្ណោះ (លទ ៦:១៨ ២ធថ ៤:២២ ភម ២៥ មើលការពន្យល់ ភល ៤:២៣)។

សំបុត្ររបស់សាវ័កប៉ុល
ដល់ពួកជំនុំ

# កាឡាទី

## សេចក្ដីផ្ដើម

### អ្នកនិពន្ធ

នៅក្នុងបទគម្ពីរដំបូងនៃកណ្ឌគម្ពីរកាឡាទីបានបញ្ជាក់យ៉ាងច្បាស់ថា លោកសាវ័កប៉ុលគឺជាអ្នកនិពន្ធនៃកណ្ឌគម្ពីរនេះ ។ ពុំមានអ្នកណាម្នាក់ជជីកសួរអំពីភាពជាអ្នកនិពន្ធរបស់ព្រះម្ពីរកាឡាទីនេះនៅឡើយទេ លើកលែងតែអ្នកកាត់ស្រាយប៉ុន្មាននាក់នៅសតវត្សទី១៩ ប៉ុណ្ណោះ ។

### កាលបរិច្ឆេទ និងអ្នកទទួល

កាលបរិច្ឆេទនៃការសរសេរកណ្ឌគម្ពីរកាឡាទី គឺអាស្រ័យមួយផ្នែកធំទៅលើទីកន្លែងដែលទទួលសំបុត្រនេះ ។ រីឯទីកន្លែងទទួលសំបុត្រនេះគឺមានទស្សនៈសំខាន់ៗពីរ:

១. *ទស្សនៈកាឡាទីខាងជើង:* ទស្សនៈបុរាណមួយនេះយល់ឃើញថា សំបុត្រកាឡាទីនេះត្រូវបានសរសេរទៅកាន់ គឺពួកជំនុំនៅតាមភូមិភាគកណ្ដាលនៃតំបន់អាស៊ីមីន័រ (Asia Minor) ភាគខាងជើង ដែលជាតំបន់មានជនជាតិហ្គោល (Gauls) បានឈ្លានពានចូល និងបានតាំងទីលំនៅទីនោះ នាសតវត្សទី៣មុនគ.ស ។ តាមទស្សនៈនេះយល់ឃើញថា លោកសាវ័កប៉ុលបានទៅសួរសុខទុក្ខពួកជំនុំនៅតំបន់នេះនៅក្នុងដំណើរបេសកកម្មលើកទីពីររបស់គាត់ ទោះជាព្រះគម្ពីរកិច្ចការមិនបានបញ្ជាក់ពីការដែលគាត់ទៅនោះក៏ដោយ ។ មានការអះអាងថា កាលបរិច្ឆេទនៃការនិពន្ធកណ្ឌគម្ពីរកាឡាទី គឺនៅចន្លោះឆ្នាំទី៥៣គ.ស និងឆ្នាំទី៥៧គ.ស ពីទីក្រុងអេភេសូរ ឬ ខេត្តម៉ាសេដូន ។

២. *ទស្សនៈកាឡាទីខាងត្បូង:* តាមទស្សនៈនេះ សំបុត្រកាឡាទីត្រូវបានសរសេរទៅកាន់ពួកជំនុំទាំងឡាយ នៅតំបន់ភាគខាងត្បូងនៃខេត្តកាឡាទីនៃចក្រភពរ៉ូម៉ាំង (ទីក្រុងអាន់ទីយ៉ូក អ៊ីកូនាម លីស្ត្រា ឌើបេ) ដែលសាវ័កប៉ុលលោកបានបង្កើតឡើងនៅក្នុងដំណើរបេសកកម្មលើកទីមួយរបស់គាត់ ។ មានអ្នកខ្លះជឿថា ការសរសេរសំបុត្រកាឡាទីគឺធ្វើឡើង នៅទីក្រុងអាន់ទីយ៉ូកនៃប្រទេសស៊ីរី ក្នុងអំឡុងឆ្នាំទី៤៨គ.សដល់ឆ្នាំទី៤៩គ.ស បន្ទាប់ពីដំណើរបេសកកម្មលើកទីមួយរបស់សាវ័កប៉ុល និងនៅមុនការប្រជុំប្រឹក្សានៅក្រុងយេរូសាឡិម (កច ១៥)។ រីឯអ្នកខ្លះទៀតយល់ថា សំបុត្រកាឡាទីត្រូវបានសរសេរឡើងនៅទីក្រុងអាន់ទីយ៉ូកនៃប្រទេសស៊ីរី ឬ ទីក្រុងកូរិនថូស នៅចន្លោះឆ្នាំទី៥១គ.ស ដល់ឆ្នាំទី៥៣គ.ស ។

### គោលបំណង

ពួកអ្នកកាន់សាសនាយូដា គឺជាពួកអ្នកដែលមានជំនឿថា ការអនុវត្តន៍ពិធីបុណ្យផ្សេងៗនៅក្នុងសញ្ញាចាស់ នៅតែជាកាតព្វកិច្ចដែលពួកជំនុំសញ្ញាថ្មីត្រូវប្រកាន់យក ។ បន្ទាប់ពីលោកប៉ុលបានទទួលជោគជ័យ នៅក្នុងការផ្សាយដំណឹងល្អនៅឯទីក្រុងកាឡាទី ពួកអ្នកកាន់សាសនាយូដាបានទទូចសុំឱ្យពួកសាសន៍ដទៃ ដែលបានប្រែចិត្តជឿដល់ព្រះយេស៊ូវ គោរពតាមពិធីផ្សេងៗក្នុងសញ្ញាចាស់ ជាពិសេសគឺការកាត់ស្បែក ។ ការដែលពួកគេធ្វើយ៉ាងដូច្នេះ គឺប្រហែលជាពួកគេចង់ជៀសវាងការធ្វើទុក្ខបៀតបៀន ពីសំណាក់ពួកឧស្សាហ៍ ដែលបានបដិសេធចំពោះការមានទំនាក់ទំនងជិតស្និទ្ធរវាងពួកគេ និងពួកសាសន៍ដទៃ (៦:១២)។ ពួកគេទាំងនោះបានជំទាស់ថា លោកប៉ុលមិនមែនជាសាវ័កស្របច្បាប់ទេ ហើយថា អ្វីដែលគាត់ធ្វើ គឺដើម្បីទាក់ទាញពួកសាសន៍ដទៃប៉ុណ្ណោះ និងបានលុបចោលនូវការសំខាន់ៗដែលបានតម្រូវឱ្យមាននៅក្នុងក្រឹត្យវិន័យ ។

ដើម្បីឆ្លើយតបចំពោះបញ្ហាចោទប្រកាន់នេះ លោកប៉ុលបង្កើតឱ្យមានយ៉ាងច្បាស់លាស់ នូវសិទ្ធិអំណាចជាសាវ័ករបស់គាត់ និងបានធ្វើការចង្អុលបង្ហាញយ៉ាងច្បាស់ អំពីភស្តុតាងនៃដំណឹងល្អដែលគាត់បានផ្សាយ ។ ពួកអ្នកប្រឆាំងរបស់លោកប៉ុល បានធ្វើឱ្យខូចដល់ដំណឹងល្អនៃព្រះគុណ ដោយនិយាយថា ដើម្បីឱ្យបានសុចរិត គឺត្រូវតែបន្ថែមនូវការខ្លះៗទៀត ដូចជា ការធ្វើល្អ និងការប្រតិបត្តិតាមក្រឹត្យវិន័យជាដើម ។ បើសិនជាលោកប៉ុល ពុំបានការពារដំណឹងល្អនៃព្រះគុណនេះទេ ពួកអ្នកប្រឆាំងទាំងនោះនឹងធ្វើឱ្យអ្នកជឿទាំងឡាយធ្លាក់ចូលទៅក្នុងទាសភាពនៃការ និយមក្រឹត្យវិន័យមិនខាន ។ មនុស្សលោកបានរាប់ជាសុចរិត គឺដោយសារតែព្រះគុណ តាមរយៈសេចក្ដីជំនឿប៉ុណ្ណោះ ។ ជីវិតថ្មីរបស់យើងត្រូវរស់ នៅក្នុងសេរីភាពនៃព្រះវិញ្ញាណបរិសុទ្ធ ។

### សេចក្ដីបង្រៀននូវវិជ្ជាសិក្សាអំពីព្រះ

កណ្ឌគម្ពីរកាឡាទីគឺជាជំហរដ៏រឹងមាំសម្រាប់ការថ្លែង និងអះអាងនូវសារៈសំខាន់នៃសេចក្ដីពិតនៅក្នុងសញ្ញាថ្មីដែលថា មនុស្សគ្រប់រូបបានញែកជាបរិសុទ្ធ គឺដោយសារតែសេចក្ដីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ គឺគ្មានអ្វីខ្វះ ហើយក៏គ្មានអ្វីបន្ថែមទេ និងមិនមែន

បានញែកជាបរិសុទ្ធដោយសារការធ្វើតាមច្បាប់ទម្លាប់ ឬក្រិត្យវិន័យ ប៉ុន្តែគឺបានមកដោយការស្តាប់បង្គាប់ ដោយទទួលស្គាល់ថា ការនេះកើតឡើងដោយសារ ព្រះរាជកិច្ចដ៏អស្ចារ្យនៃព្រះអម្ចាស់ ដោយព្រះគុណ និងអំណាចព្រះចេស្តារបស់ព្រះគ្រីស្ទ និងព្រះវិញ្ញាណបរិសុទ្ធ ។ ម្យ៉ាងទៀត កណ្ឌគម្ពីរកាឡាទី (និងកណ្ឌគម្ពីររ៉ូម) ត្រូវបានគេទទួលស្គាល់ថា វាជាមូលដ្ឋានគ្រឹះ ដែលនាំឱ្យមានការកែទម្រង់របស់គ្រីស្ទបរិស័ទដំណឹងល្អ ។ លោកម៉ាទីន លូធ័រ (Martin Luther) បានប្រើកណ្ឌគម្ពីរនេះ នៅក្នុងសេចក្តីអធិប្បាយ សេចក្តីបង្រៀន និងនៅក្នុងការសរសេររបស់គាត់ដើម្បីប្រឆាំងនឹងការបង្រៀនខុសឆ្គងនៅក្នុងសម័យគាត់ ។ ខគន្លឹះនៃកណ្ឌគម្ពីរនេះគឺ បទគម្ពីរ "២:១៦" (មើលពន្យល់) ។

**គម្រោងសង្ខេប**

I. **សេចក្តីផ្តើម (១:១–១០)**

ក. ពាក្យជម្រាបសួរ (១:១–៥)

ខ. ការព្រមាន (១:៦–១០)

II. **រឿងផ្ទាល់ខ្លួន: ភាពពិតរបស់សារកនៃសេរីភាព និងជំនឿ (១:១១–២:២១)**

ក. ដំណឹងល្អដែលលោកប៉ុលបានទទួលគឺតាមរយៈការបើកសំដែងជាពិសេសពីព្រះអម្ចាស់ (១:១១–១២)

ខ. ដំណឹងល្អដែលលោកប៉ុលបានទទួល មានលក្ខណៈឯករាជ្យ (១:១៣–២:២១)

១. ភស្តុតាងពីសកម្មភាពរបស់គាត់ជាគ្រីស្ទបរិស័ទ (១:១៣–១៧)

២. ភស្តុតាងពីការធ្វើដំណើរលើកទីមួយទៅក្រុងយេរូសាឡិម (១:១៨–២៤)

៣. ភស្តុតាងពីការធ្វើដំណើរលើកទីពីរទៅក្រុងយេរូសាឡិម (២:១–១០)

៤. ភស្តុតាងពីការស្តីបន្ទោសលោកពេត្រុសនៅក្រុងអាន់ទីយ៉ូក (២:១១–២១)

III. **គោលលទ្ធិ: ការបង្ហាញអំពីគោលលទ្ធិនៃសេរីភាព និងសេចក្តីជំនឿ (ជំពូក ៣–៤)**

ក. បទពិសោធន៍របស់ពួកជំនុំក្រុងកាឡាទីស្តីពីដំណឹងល្អ (៣:១–៥)

ខ. បទពិសោធន៍របស់លោកអ័ប្រាហាំ (៣:៦–៩)

គ. បណ្តាសានៃក្រឹត្យវិន័យ (៣:១០–១៤)

ឃ. អាទិភាពនៃសេចក្តីសន្យា (៣:១៥–១៨)

ង. គោលបំណងនៃក្រឹត្យវិន័យ (៣:១៩–២៥)

ច. ជាកូន មិនមែនជាបាវបម្រើ (៣:២៦–៤:៧)

ឆ. គ្រោះថ្នាក់នៃការបែកចេញពីព្រះអម្ចាស់ (៤:៨–១១)

ជ. ការប្រើប្រាស់នូវសេរីភាពរបស់ពួកអ្នកជឿដល់ព្រះអម្ចាស់ (៤:១២–២០)

ឈ. កូននៃព្រះ គឺជាកូននៃស្ត្រីអ្នកជា (៤:២១–៣១)

IV. **ការអនុវត្តន៍: ការអនុវត្តន៍នូវជីវិតដែលមានសេរីភាព និងសេចក្តីជំនឿ (៥:១–៦:១០)**

ក. ការណែនាំអំពីសេរីភាព (៥:១–១២)

ខ. ជីវិតដើរដោយព្រះវិញ្ញាណ មិនមែនដើរដោយសាច់ឈាម (៥:១៣–២៦)

គ. ការត្រាស់ហៅឱ្យជួយគ្នាទៅវិញទៅមក (៦:១–១០)

V. **សេចក្តីសន្និដ្ឋាន និង ការទូលសូមឱ្យព្រះអម្ចាស់ប្រទានពរ (៦:១១–១៨)**

**១** ១សំបុត្រប៉ុលខ្ញុំ ដែលជាសាវក[ក] មិនមែនអំពីមនុស្ស ឬ
ដោយសារមនុស្សទេ[ខ] គឺដោយសារព្រះយេស៊ូវគ្រីស្ទ[គ] និង
ព្រះដ៏ជាព្រះវរបិតា[ឃ] ដែលបានប្រោសឱ្យទ្រង់រស់ពីស្លាប់
ឡើងនោះវិញ[ង] ២ខ្ញុំ និងពួកបងប្អូនទាំងអស់គ្នា ដែលនៅជា
មួយនឹងខ្ញុំ[ច]យើងផ្ញើមកពួកជំនុំទាំងប៉ុន្មាន នៅស្រុកកាឡាទី[ឆ]
៣សូមឱ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ និងសេចក្តី
សុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតា និងពីព្រះយេស៊ូវគ្រីស្ទជា
ព្រះអម្ចាស់នៃយើងរាល់គ្នា[ជ] ៤ដែលទ្រង់បានប្រគល់ព្រះអង្គ
ទ្រង់ទៅ ដោយព្រោះបាបយើងរាល់គ្នា[ឈ]ដើម្បីនឹងប្រោស
ឱ្យយើងបានរួចពីលោកិយ ដ៏អាក្រក់សព្វថ្ងៃនេះ[ញ] តាម
បំណងព្រះហឫទ័យរបស់ព្រះដ៏ជាព្រះវរបិតានៃយើង[ដ]
៥សូមឱ្យទ្រង់បានសិរីល្អ ដល់អស់កល្បជានិច្ចរៀងតទៅ
អាម៉ែន[ឋ]។

**១:១** ក ១កថ ១:១ ខ ខ.១១,១២ គ ខ.១៥,១៦ កថ ៩:១៥ ២០:២៤ ឃ ខ.១៥,១៦ កថ ៩:១៥ ២០:២៤ ង កថ ២:២៤
**១:២** ច ភល ៤:២១ ឆ កថ ១៦:៦
**១:៣** ជ រម ១:៧
**១:៤** ឈ មថ ២០:២៨ រម ៤:២៥ ១កថ ១៥:៣ កទ ២:២០ ញ ១កថ ១:២០ ដ ភល ៤:២០
**១:៥** ឋ រម ១១:៣៦
**១:៦** ឌ ខ.១៥ រម ៨:២៨

## មានដំណឹងល្អតែមួយ

៦ខ្ញុំឆ្ងល់ណាស់ ពីដំណើរដែលអ្នករាល់គ្នាបានផ្លាស់
ប្រែចេញពីព្រះ ដែលទ្រង់ហៅអ្នករាល់គ្នាមក[ឌ] ក្នុងព្រះ
គុណនៃព្រះគ្រីស្ទ ជាឆាប់ម្ល៉េះ នឹងទៅតាមដំណឹងល្អផ្សេង
ទៀតនេះ[ឍ] ៧ដែលមិនមែនជាដំណឹងល្អ១ទៀតទេ គឺមាន
មនុស្សខ្លះបំភាន់អ្នករាល់គ្នាវិញ[ណ] ហើយចង់បង្ខូច[ត]ដំណឹង
ល្អព្រះគ្រីស្ទផង ៨ប៉ុន្តែ បើយើងខ្ញុំ ឬទេវតាពីស្ថានសួគ៌ នឹង
ប្រាប់ដំណឹងណាមកអ្នករាល់គ្នា[ថ]ខុសពីដំណឹងល្អដែលយើង
ខ្ញុំបានប្រាប់ហើយ នោះឱ្យគេត្រូវបណ្តាសាចុះ[ទ] ៩ឯសេចក្តី
ដែលខ្ញុំទើបនឹងនិយាយអម្បាញ់មិញនេះ នោះខ្ញុំនិយាយម្តង
ទៀតថា បើអ្នកណាប្រាប់ដំណឹងណា ខុសអំពីដំណឹងល្អ ដែល

ឍ ២កថ ១១:៤ **១:៧** ណ កថ ១៥:២៤ កទ ៥:១០ ត យរ ២៣:១៦,៣៦
**១:៨** ថ ខ.១១,១៦ ១កថ ១៥:១ ២កថ ១១:៤ កទ ២:២ ទ រម ៩:៣

**១:១** *ប៉ុល* (មើលពន្យល់ រម ១:១)។ *សាវក* ជាមនុស្សរបស់ព្រះអម្ចាស់ដែលទ្រង់បញ្ជូន ឱ្យទៅបំពេញព្រះរាជកិច្ចរបស់ទ្រង់ និងបានពេញដោយអំណាចព្រះចេស្តាមកអំពីទ្រង់ (១កថ ១:១ និងការពន្យល់)។ *បានប្រោសឱ្យទ្រង់រស់ពីស្លាប់ឡើងនោះវិញ* ត្រង់ចំណុចនេះបញ្ជាក់ថា ការរស់ឡើងវិញគឺជាគោលជំនឿរបស់គ្រីស្ទបរិស័ទ (កថ ១៧:១៨ រម ១:៤ ១កថ ១៥:២០ ១ពត ១:៣)។ លោកប៉ុលបានឃើញព្រះយេស៊ូវគ្រីស្ទ ដែលមានព្រះជន្មរស់ពីសុគតឡើងវិញ ដូច្នេះបញ្ជាក់ថា គាត់ពិតជាស័ក្តិសមទទួលងារជាសាវករបស់ទ្រង់ប្រាកដមែន (កថ ២:៣២ ១កថ ១៥:៨ កថ ១:២២ និងពន្យល់)។

**១:២** *ពួកបងប្អូន* លោកប៉ុលតែងតែប្រើពាក្យនេះ សំដៅលើពួកបណ្តាជនទាំងប្រុសទាំងស្រី (កថ ១:១៤-១៦ រម ១:១៣ និងការពន្យល់)។ *យើងផ្ញើមកពួកជំនុំទាំងប៉ុន្មាន នៅស្រុកកាឡាទី* មានន័យថា សំបុត្រកាឡាទីនេះលោកប៉ុលសរសេរទៅកាន់ពួកជំនុំទាំងអស់ ដែលនៅក្នុងស្រុកកាឡាទីតែម្តង។ *ស្រុកកាឡាទី* ពាក្យនេះត្រូវបានលើកឡើងចំនួនបីដងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី (១កថ ១៦:១)។ នៅក្នុង "២ធថ ៤:១០" ពុំបានបញ្ជាក់ច្បាស់ពីតំបន់ណាមួយនៅស្រុកកាឡាទីទេ។ រីឯនៅក្នុង "១ពត ១:១" វិញ គឺនិយាយសំដៅលើតំបន់មួយស្ថិតនៅភាគខាងជើងនៃអាស៊ីមីន័រ (Asia Minor)។ ចំពោះសេចក្តីនៅក្នុងបទគម្ពីរនេះ លោកប៉ុលនិយាយសំដៅលើស្រុកកាឡាទីភាគខាងត្បូង ដែលពេលនោះកំពុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ចក្រភពរ៉ូម៉ាំង និងជាតំបន់ដែលគាត់បានឆ្លងកាត់ក្នុងដំណើរបេសកកម្មលើកទីមួយរបស់គាត់ (កថ ១៣:១៤-១៤:២៣ និងមើលសេចក្តីផ្តើម)។

**១:៣** *ព្រះគុណ និងសេចក្តីសុខសាន្ត* លោកប៉ុលនិងលោកពេត្រុសបានប្រើពាក្យជម្រាបសួរនៅដើមសំបុត្ររបស់ពួកគាត់ដូចគ្នា។ ពាក្យទាំងពីរនេះកើតឡើងពីពាក្យជម្រាបសួរជាទំនៀមទម្លាប់របស់ពួកសាសន៍ក្រេក (ព្រះគុណ) និងទំនៀមទម្លាប់របស់ពួកយូដា (សេចក្តីសុខសាន្ត) ដាក់បញ្ចូលគ្នា។ សាសន៍ក្រេកច្រើនប្រើពាក្យ "ព្រះគុណ"នេះ សម្រាប់ជូនពរគ្នា ដ្បិតមនុស្សមានបាបមិនសមនឹងទទួលសេចក្តីសង្គ្រោះសោះ តែព្រះទ្រង់បានប្រទានដល់ពួកគេតាមរយៈព្រះយេស៊ូវ។ ចំពោះសាសន៍យូដាច្រើនប្រើពាក្យ "សេចក្តីសុខសាន្ត"ពីព្រោះមានតែព្រះទេដែលអាចប្រទានសេចក្តីសុខសាន្ត និងសន្តិភាពដ៏ពិតដល់ពួកគេបាន (៥:១ ភល ៤:៧ និងការពន្យល់ កទ ១:៣ អភ ១:២ យហ ១៤:២៧ ២០:១៩ និងការពន្យល់)។ ពាក្យជម្រាបសួរនេះ ត្រូវបានប្រើនៅក្នុងសេចក្តីបញ្ចប់នៃសំបុត្ររបស់លោកប៉ុល និងលោកពេត្រុស (នក ៣៤:៦-៧)។

**១:៤** *ដោយព្រោះបាបយើងរាល់គ្នា* (មថ ១:២១ យហ ១:២៩ ១កថ ១៥:៣ ១ពត ២:២៤ និងការពន្យល់)។ *លោកិយដ៏អាក្រក់សព្វថ្ងៃនេះ* សំដៅលើអំឡុងពេលនៃប្រវត្តិសាស្ត្ររបស់មនុស្សជាតិ នាពេលបច្ចុប្បន្ននេះតែម្តង (២កថ ៤:៤ និងពន្យល់)។ លោកិយនាពេលបច្ចុប្បន្ននេះត្រូវបានកត់សម្គាល់ដោយមានការអាក្រក់ជាច្រើនបានកើតឡើង (អភ ២:១-២ ៦:១២)។

**១:៥** សេចក្តីនៅក្នុងបទគម្ពីរនេះ គឺជាលំនាំនៃការសរសើរតម្កើងដល់ព្រះអម្ចាស់ (រម ៩:៥ ១១:៣៦ ១៦:២៧ អភ ៣:២១ ១ធថ ១:១៧)។

**១:៦** *ព្រះ ដែលទ្រង់ហៅអ្នករាល់គ្នា* គឺព្រះយេស៊ូវគ្រីស្ទដែលបានហៅពួកគេឱ្យមកទទួលសេចក្តីសង្គ្រោះនៅក្នុងទ្រង់។ ក្នុងបទគម្ពីរនេះបញ្ជាក់ថា នៅក្នុងស្រុកកាឡាទីនាពេលនោះ មានពួកគ្រូខុសឆ្គង បានដើរបង្រៀននូវដំណឹងល្អផ្សេងទៀត ដោយប្រកាសថា ចំពោះពួកសាសន៍ដទៃ ដើម្បីឱ្យបានសង្គ្រោះ គឺត្រូវតែប្រតិបត្តិតាមក្រិត្យវិន័យ និងទំនៀមទម្លាប់របស់សាសន៍យូដា ជាពិសេសគឺត្រូវតែទទួលការកាត់ស្បែក។

**១:៧** *មិនមែនជាដំណឹងល្អ១ទៀតទេ* ត្រង់ចំណុចនេះ លោកប៉ុលបញ្ជាក់ថាគ្មានដំណឹងល្អណាទៀតទេ គឺមានតែដំណឹងរបស់ព្រះយេស៊ូវមួយប៉ុណ្ណោះ (១កថ ១៥:៣ មើលការពន្យល់ មក ១:១)។ *មានមនុស្សខ្លះ* សំដៅលើពួកអ្នកដែលកាន់តាមគោលលទ្ធិសាសនាយូដា (សូមមើលសេចក្តីផ្តើម)។

**១:៨-៩** នៅក្នុងបទគម្ពីរទាំងពីរនេះ យើងឃើញនូវសារសំខាន់នៃព្រះរាជកិច្ចនៃព្រះអម្ចាស់ និងដំណឹងល្អរបស់ទ្រង់។ ម្យ៉ាងទៀត គ្មានអ្នកណាម្នាក់មានអំណាចក្នុងការផ្លាស់ប្តូរដំណឹងល្អរបស់ព្រះអម្ចាស់បានទេ។ បើអ្នកណាផ្សាយនូវដំណឹងល្អណាផ្សេងទៀត នោះនឹងត្រូវទទួលនូវការជំនុំជម្រះមិនខាន (១កថ ១២:៣ ១៦:២២ មើលការពន្យល់ រម ៩:៣)។

អ្នករាល់គ្នាបានទទួលហើយ[ធ] នោះឱ្យគេត្រូវបណ្ដាសាចុះ
១០ដ្បិតតើខ្ញុំរកបញ្ចុះបញ្ចូលអ្នកណា តើជាមនុស្ស ឬព្រះ
ឬចង់បំពេញចិត្តមនុស្សឬអី[ន] បើសិនជាខ្ញុំចង់បំពេញចិត្ត
មនុស្ស នោះខ្ញុំមិនមែនជាបាវបំរើរបស់ព្រះគ្រីស្ទទេ ។

## សាវ័កប៉ុលជាមនុស្សដែលព្រះត្រាស់ហៅ

១១បងប្អូនអើយ[ប] ខ្ញុំចង់ប្រាប់ឱ្យអ្នករាល់គ្នាដឹងច្បាស់ថា
ដំណឹងល្អដែលខ្ញុំបានថ្លែងប្រាប់[ផ] នោះមិនមែនតាមមនុស្ស
ទេ ១២ដ្បិតខ្ញុំមិនបានទទួលមកពីមនុស្ស[ព] ក៏គ្មានអ្នកណា
បង្រៀនខ្ញុំផង គឺដោយព្រះយេស៊ូវគ្រីស្ទ[ភ]បានបើកសំដែង
វិញ[ម] ១៣អ្នករាល់គ្នាបានឮនិយាយពីកិរិយារបស់ខ្ញុំ នៅក្នុង
សាសនាពួកយូដា[យ]កាលពីដើមថា ខ្ញុំបានធ្វើទុក្ខបៀតបៀន
ហើយបំផ្លាញ[រ]ដល់ពួកជំនុំនៃព្រះ[ល]ជាខ្លាំងណាស់ ១៤ហើយ
ថា ខ្ញុំកំពុងតែជឿនឡើងក្នុងសាសនារបស់ពួកយូដា លើស
ជាងពួកសាសន៍ខ្ញុំ ដែលស្រករនឹងខ្ញុំជាច្រើនដែរ ពីព្រោះខ្ញុំ
មានចិត្តឧស្សាហ៍[វ]តាមសណ្ដាប់បុរាណរបស់ពួកឰយុកោខ្ញុំ[ស]
លើសជាងគេសន្ធឹក ១៥ប៉ុន្តែ កាលព្រះដែលរើសខ្ញុំតាំង
ពីផ្ទៃម្ដាយមក[ហ] ហើយបានហៅខ្ញុំ[ឡ] ដោយព្រះគុណទ្រង់
១៦បានសព្វព្រះហឫទ័យ នឹងបើកសំដែងព្រះរាជបុត្រាទ្រង់
មកក្នុងខ្ញុំ ដើម្បីឱ្យខ្ញុំបានផ្សាយដំណឹងល្អពីទ្រង់ ដល់ពួក
សាសន៍ដទៃ[អ] នោះខ្ញុំមិនបានទៅប្រឹក្សានឹងសាច់ឈាមទេ[ក]
១៧ក៏មិនបានឡើងទៅឯពួកអ្នកដែលជាសាវកមុនខ្ញុំ នៅក្រុង
យេរូសាឡិមដែរ គឺបានទៅឯស្រុកអារ៉ាប់ភ្លាម រួចត្រឡប់
ទៅឯក្រុងដាម៉ាសវិញ[ខ] ១៨លុះក្រោយ៣ឆ្នាំមក[គ] ខ្ញុំបានឡើង
ទៅឯក្រុងយេរូសាឡិម[ឃ] ដើម្បីឱ្យបានស្គាល់លោកពេត្រុស
ក៏នៅជាមួយ នឹងលោកអស់១៥ថ្ងៃ ១៩តែមិនបានឃើញ
ពួកសាវកឯទៀតទេ ឃើញតែយ៉ាកុប[ង] ជាប្អូននៃព្រះអម្ចាស់
ប៉ុណ្ណោះ ២០រីឯសេចក្ដីដែលខ្ញុំសរសេរមកអ្នករាល់គ្នានេះ
មើល ខ្ញុំនៅចំពោះព្រះហើយ[ច] ខ្ញុំមិនកុហកទេ[ឆ] ២១ក្រោយ
នោះ ខ្ញុំបានមកក្នុងស្រុកស៊ីរី[ជ] នឹងស្រុកគីលីគា[ឈ] ២២តែ
ពួកជំនុំក្នុងព្រះគ្រីស្ទ[ញ]ដែលនៅស្រុកយូដា[ដ] មិនបានស្គាល់
មុខខ្ញុំទេ ២៣គេគ្រាន់តែឮថា អ្នកដែលធ្វើទុក្ខគេកាលពីដើម

**១:៩** ធ រម ១៦:១៧
**១:១០** ន រម ២:២៩
**១:១១** ប ១កថ ១៥:១ ផ ឧ.៨
**១:១២** ព ឧ.១ ភ ១កថ ១១:២៣ ១៥:៣ ម ឧ.១៦ ១កថ ២:១០
**១:១៣** យ កថ ២៦:៤,៥ រ ១កថ ១០:៣២ ល កច ៨:៣
**១:១៤** វ កច ២១:២០ ស មថ ១៥:២
**១:១៥** ហ អស ៤៩:១,៥ យរ ១:៥ ឡ កច ៩:១៥ រម ៨:២៨
**១:១៦** អ កច ៩:១៥ កទ ២:៩ ក មថ ១៦:១៧
**១:១៧** ខ កច ៩:២,១៩–២២
**១:១៨** គ កច ៩:២២,២៣ ឃ កច ៩:២៦,២៧ **១:១៩** ង មថ ១៣:៥៥ កថ ១៥:១៣ **១:២០** ច រម ១:៩ ឆ រម ៩:១ **១:២១** ជ លក ២:២ ឈ កច ៦:៩ **១:២២** ញ រម ១៦:៣ ដ ១ថន ២:១៤

**១:១០** *បាវបំរើរបស់ព្រះគ្រីស្ទ* លោកប៉ុលមានប្រសាសន៍ថា គាត់មានឋានៈជាបាវបម្រើក៏ពិតមែន ប៉ុន្តែគាត់មានសេរីភាពពីអំពើបាប ដោយសារតែការប្រោសលោះរបស់ព្រះយេស៊ូវគ្រីស្ទ (៥:១)។ ម្យ៉ាងទៀត គាត់គឺជាបាវបម្រើនៃសេចក្ដីសុចរិត និងព្រះដ៏ខ្ពស់បំផុតវិញ (រម ៦:១៨,២២ និងការពន្យល់)។

**១:១១** *បងប្អូនអើយ ខ្ញុំចង់ប្រាប់ឱ្យអ្នករាល់គ្នាដឹងច្បាស់* ឃ្លានេះមានលក្ខណៈស្រដៀងគ្នានឹងសេចក្ដី ដែលលោកប៉ុលលើកឡើងនៅក្នុង "១កថ ១៥:១" ដែរ។ *ដំណឹងល្អដែលខ្ញុំបានថ្លែងប្រាប់* (រម ២:១៦ ១៦:២៥ និងពន្យល់)។

**១:១២** *ដោយព្រះយេស៊ូវគ្រីស្ទ បានបើកសំដែង* (អភ ៣:២–៦)។

**១:១៣** *សាសនាពួកយូដា* គឺសំដៅលើជំនឿ និងរបៀបរស់នៅរបស់ពួកសាសន៍យូដាដែលបានចាប់ផ្ដើមឡើង នៅក្នុងអំឡុងពេលរវាងសម័យកាលសញ្ញាចាស់ និងសម័យកាលសញ្ញាថ្មី ។ ពាក្យថា "យូដា" គឺសំដៅលើអាណាចក្រខាងត្បូង ដែលត្រូវបានឈានដល់ទីបញ្ចប់របស់ខ្លួន នៅសតវត្សរ៍ទី៦មុនគ.ស ព្រមគ្នាជាមួយនឹងការដាក់បញ្ចូល ឱ្យទៅជាដែនដីចំណុះរបស់ប្រទេសបាប៊ីឡូន។ *ពួកជំនុំនៃព្រះ* សំដៅលើពួកអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទ (ជន ១៦:២១ ២០:៤)។

**១:១៤** *ខ្ញុំមានចិត្តឧស្សាហ៍* (ភល ៣:៦)។ *តាមសណ្ដាប់បុរាណរបស់ពួកឰយុកោខ្ញុំ* សំដៅលើទំនៀមទម្លាប់ ដែលបានបន្តពីបុរាណ មកដល់ជំនាន់លោកប៉ុល ហើយដែលទំនៀមទម្លាប់ទាំងនោះ គឺប្រឆាំងនឹងក្រិត្យវិន័យរបស់លោកម៉ូសេផង (មថ ១៥:២)។

**១:១៥** *ព្រះដែលរើសខ្ញុំតាំងពីផ្ទៃម្ដាយ* (អស ៤៩:១ យរ ១:៥ រម ១:១)។

**១:១៦** *ពួកសាសន៍ដទៃ* សំដៅលើគ្រប់ជាតិសាសន៍ដែលពុំមែនជាសាសន៍យូដា ។ *ខ្ញុំមិនបានទៅប្រឹក្សានឹងសាច់ឈាមទេ* បញ្ជាក់ថា លោកប៉ុលបានទទួលដំណឹងល្អនៃការសង្គ្រោះនេះមកអំពីព្រះយេស៊ូវគ្រីស្ទ ។ ម្យ៉ាងទៀត គាត់ចង់បញ្ជាក់ថា ដំណឹងល្អដែលគាត់បានទទួល មិនជាប់ទាក់ទងទៅនឹងលោកិយទេ (មថ ១៦:១៧ ១កថ ១៥:៥០ និងការពន្យល់)។

**១:១៧** *ក្រុងយេរូសាឡិម* ទីក្រុងនេះជាមជ្ឈមណ្ឌលប្រមូលផ្ដុំនូវសាសនាយូដា ហើយក៏ជាទីកន្លែងចាប់ផ្ដើមនៃគ្រីស្ទបរិស័ទដែរ ។ *ស្រុកអារ៉ាប់* ជាប្រទេសមួយដែលមានព្រំប្រទល់ខាងជើងជាប់ជាមួយប្រទេសអ៊ីរ៉ាក់ (Iraq) ខាងត្បូងជាប់ជាមួយប្រទេសយេមែន (Yemen) ហើយភាគនិរតីជាប់ជាមួយនឹងសមុទ្រក្រហម (Red Sea)។ *ក្រុងដាម៉ាស* នៅពេលនោះ ទីក្រុងនេះគឺជារាជធានីនៃប្រទេសស៊ីរី ។ លោកប៉ុលបានទទួលការផ្លាស់ប្រែនៅតាមផ្លូវពីក្រុងយេរូសាឡិមទៅកាន់ ទីក្រុងដាម៉ាស (កច ៩:១–៩ និងការពន្យល់)។

**១:១៨** *លុះក្រោយ៣ឆ្នាំមក* គឺចាប់ពីពេលដែលលោកប៉ុលបានចេញដំណើរទៅឯស្រុកអារ៉ាប់ ។ ក្នុងបទគម្ពីរនេះមិនបានបញ្ជាក់ថា គាត់បានស្នាក់នៅឯស្រុកអារ៉ាប់នោះអស់រយៈពេលប៉ុន្មានឆ្នាំទេ ។ *ខ្ញុំបានឡើងទៅឯក្រុងយេរូសាឡិម* អាចសំដៅលើការដែលលោកប៉ុលមកសួរសុខទុក្ខពួកបងប្អូនដែលមានចែងនៅក្នុង "កច ៩:២៦–៣០ ១១:៣០"។ *លោកពេត្រុស* (មើលការពន្យល់ មថ ១៦:១៨ យហ ១:៤២)។

**១:១៩** *យ៉ាកុប* គឺសំដៅលើលោកយ៉ាកុប ដែលជាអ្នកដឹកនាំពួកជំនុំនៅទីក្រុងយេរូសាឡិម (កច ២១:១៨)។ *ជាប្អូននៃព្រះអម្ចាស់* មានន័យថា លោកយ៉ាកុប នៅក្នុងបទគម្ពីរនេះគឺជាប្អូនរបស់ព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ លក ៨:១៩)។

**១:២១** *ស្រុកស៊ីរី និងស្រុកគីលីគា* ស្រុកទាំងពីរនេះស្ថិតនៅក្នុងតំបន់នៃអាស៊ីមីន័រ (Asia Minor)។ ម្យ៉ាងទៀត ត្រង់ចំណុចនេះបញ្ជាក់ថាលោកប៉ុលបានធ្វើដំណើរទៅឯស្រុកតើសុស ជាទីកន្លែងកំណើតរបស់គាត់តែម្ដង (កច

ឥឡូវនេះ កំពុងផ្សាយដំណឹងពីសេចក្ដីជំនឿ[ឋ] ដែលខ្លួនបាន
បំផ្លាញពីដើមនោះវិញ[ឌ] ២៤ហើយគេក៏សរសើរដំកើងដល់
ព្រះ[ឍ]ដោយព្រោះខ្ញុំ ។

## ការទទួលស្គាល់លោកប៉ុលជាសាវ័ក

**២** ១លុះកន្លងក្រោយមក ១៤ ឆ្នាំ នោះខ្ញុំបានឡើងទៅឯ
ក្រុងយេរូសាឡិមម្ដងទៀត[ណ] ជាមួយនឹងបាណាបាស[ត] ក៏យក
ទីតុស[ថ]ទៅជាមួយដែរ ២ខ្ញុំបានឡើងទៅ តាមសេចក្ដីដែល
បើកសំដែងមក[ទ] ហើយបានបង្ហាញដំណឹងល្អ ដែលខ្ញុំថ្លែង
ប្រាប់នៅក្នុងពួកសាសន៍ដទៃ[ធ] ឱ្យពួកអ្នកមុខបានស្គាល់
ដោយឡែក ក្រែងខ្ញុំកំពុងតែរត់ ឬបានរត់ពីដើមនោះ[ន] ជា
បែបឥតប្រយោជន៍យ៉ាងណា ៣(តែគេមិនបង្ខំឱ្យទីតុស[ប] ជា
សាសន៍ក្រេក[ផ] ដែលនៅជាមួយនឹងខ្ញុំ បានកាត់ស្បែកទេ)
៤ដែលបង្ហាញគេដូច្នេះ គឺដោយព្រោះពួកបងប្អូនក្លែង
ក្លាយ[ព] ដែលបានសិកសៀតចូលមកដោយលួចលាក់ គេ
បានលួចចូល ដើម្បីនឹងលបមើល[ភ]សេរីភាពនៃយើងខ្ញុំ[ម]
ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ ដោយចង់នាំឱ្យយើងខ្ញុំជាប់
ចំណងវិញ ៥តែយើងខ្ញុំមិនព្រមចុះចូលនឹងពួកនោះ សូម្បី
តែ១ភ្លែតផង ដើម្បីឱ្យសេចក្ដីពិតរបស់ដំណឹងល្អ[យ] បាននៅ
ស្ថិតស្ថេរជាប់នឹងអ្នករាល់គ្នា ៦តែពួកអ្នក ដែលគេរាប់
ទុកជាប្រសើរ[រ] ទោះបើគេជាអ្វីក៏ដោយ នោះឥតមានអំ
ពល់អ្វីដល់ខ្ញុំទេ[ល] ព្រោះព្រះទ្រង់មិនរើសមុខអ្នកណាឡើយ[វ]
៧តែកាលគេបានឃើញថា ដំណឹងល្អសំរាប់ពួកមិនកាត់
ស្បែក បានផ្ញើទុកនឹងខ្ញុំ[ស] ដូចជាដំណឹងល្អ សំរាប់ពួក
កាត់ស្បែក[ហ] បានផ្ញើទុកនឹងលោកពេត្រុសដែរ[ឡ] ៨(ដ្បិត
ព្រះ ដែលបណ្ដាលឱ្យលោកពេត្រុស ធ្វើជាសាវក[អ]ដល់
ពួកកាត់ស្បែក នោះបានបណ្ដាលឱ្យខ្ញុំ ធ្វើជាសាវក[ក]ដល់
ពួកសាសន៍ដទៃដែរ) ៩ហើយកាលបានឃើញព្រះគុណ
ដែលទ្រង់ប្រទានមកខ្ញុំ[ខ]នោះលោកយ៉ាកុប[គ]លោកកេផាស[ឃ]
និងលោកយ៉ូហាន ដែលគេរាប់ទុកជាសសរទ្រូង[ង] លោក
បានលូកដៃស្តាំមកទទួលខ្ញុំនិងបាណាបាស[ច] ក្នុងសេចក្ដី
ប្រកបគ្នា ដើម្បីឱ្យយើងខ្ញុំទៅឯសាសន៍ដទៃ[ឆ] ហើយលោក
ទៅឯពួកកាត់ស្បែកវិញ ១០លោកផ្ដាំឱ្យតែយើងខ្ញុំនឹកចាំពី
ពួកអ្នកក្រ[ជ] ជាការដែលខ្ញុំឧស្សាហ៍ខំធ្វើដែរ ។

**១:២៣** ឋ កច ៦:៧ ឌ កច ៨:៣
**១:២៤** ឍ មថ ៩:៨
**២:១** ណ កច ១៥:២ ត កច ៤:៣៦ ថ ១កថ ៩:២៤
**២:២** ទ ១កថ ២:១០ ធ កច ១៥:៤,១២ ន ២កថ ២:១៣
**២:៣** ប ខ.១ ២កថ ២:១៣ ផ កច ១៦:៣ ១កថ ៩:២១
**២:៤** ព កច ១:១៦ ២កថ ១១:២៦ ភ យដ ៤ ម កទ ៥:១,១៣
**២:៥** យ ខ.១៤
**២:៦** រ ខ.២ ល កច ១០:៣៤ វវ ២:២៣ វ ២កថ ១៥:១១
**២:៧** ស ១ថន ២:៤ ១ធថ ១:១១ ហ កច ៩:១៥ ឡ ខ.៩,១១,១៤
**២:៨** អ កច ១:២៥

ក ១កថ ១:១ **២:៩** ខ កច ៩:១៥ គ កច ១៥:១៣ ឃ ខ.៧,១១,១៤ ង ១ធថ ៣:១៥ វវ ៣:១២ ច ខ.១ កច ៤:៣៦ ឆ រម ១២:៣ **២:១០** ជ កច ២៤:១៧

៩:៣០ និងការពន្យល់)។

**២:១** *លុះកន្លងក្រោយមក១៤ឆ្នាំ* រយៈពេលនេះគឺអាចចាប់ផ្ដើមរាប់ពីថ្ងៃដែលលោកប៉ុលបានប្រែចិត្ត ។ *ខ្ញុំបានឡើងទៅឯក្រុងយេរូសាឡិមម្ដងទៀត* ឃ្លានេះមានមតិខ្លះយល់ថា សំដៅលើហេតុការណ៍នៅក្នុង "កច ១១:៣០"។ មតិខ្លះទៀតយល់ថា ហេតុនេះគឺបានកើតឡើងនៅក្នុង "កច ១៥:១–៤" (មើលការពន្យល់ កច ១២:១ ១៥:២)។ *បាណាបាស* មានន័យថា "អ្នកលើកទឹកចិត្ត ឬអ្នកជំនួយ"។ ឈ្មោះពីកំណើតរបស់គាត់គឺ "យ៉ូសែប"។ លោកបាណាបាសគឺជាពួកលេវីម្នាក់ ដែលមកពីកោះគីប្រុស (កច ៤:៣៦)។ គាត់គឺជាគូកនម្នាក់របស់លោកប៉ុល ក្នុងដំណើរបេសកកម្មរបស់គាត់ (កច ១៣:១–១៤:២៨)។ *ទីតុស* គឺជាសាសន៍ដទៃម្នាក់ដែលបានទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ ហើយត្រូវបានលោកប៉ុលបញ្ជូនទៅឯទីក្រុងកូរិនថូស (២កថ ២:១៣ ៧:៦–៧ ៨:៦,១៦ ១២:១៨)។ ក្រោយមក គាត់បានទៅឯកោះក្រេត ដើម្បីមើលការខុសត្រូវពួកជំនុំនៅទីនោះ (ទត ១:៥ មើលសេចក្ដីផ្ដើមកណ្ឌគម្ពីរទីតុស)។

**២:២** *ពួកអ្នកមុខ* លោកប៉ុលនិយាយយ៉ាងដូច្នេះ អាចសំដៅលើលោកយ៉ាកុប លោកពេត្រុស និងលោកយ៉ូហាន (ខ.៦,៩)។ *ខ្ញុំកំពុងតែរត់ ឬបានរត់ពីដើមនោះ* (ប្រៀបធៀបនឹង ១កថ ១៥:៥៨ ភល ២:១៦)។

**២:៤** *ពួកបងប្អូនក្លែងក្លាយ* សំដៅលើពួកអ្នកដែលកាន់តាមគោលលទ្ធិសាសនាយូដាដែលប្រកាសថាពួកសាសន៍ដទៃដែលទទួលជឿដល់ព្រះយេស៊ូវគឺត្រូវតែកាន់តាមក្រិត្យវិន័យទាំងឡាយ ដូចជាការកាត់ស្បែកជាដើម (កច ១៥:៥ ២កថ ១១:២៦)។ *គេបានលួចចូល* សំដៅលើការលួចចូលដែលមានលក្ខណៈដូចជា ការលួចចូលទៅដែនដីរបស់ប្រទេសណាមួយ ដើម្បីស៊ើបការណ៍ (២សយ ១០:៣ ១រប ១៩:៣)។ *សេរីភាព* ពាក្យថា "សេរី ឬសេរីភាព" គឺជាពាក្យគន្លឹះដែលបានលើកឡើងចំនួន១១ដងនៅក្នុងកណ្ឌគម្ពីរកាឡាទី (៣:២៨ ៤:២២–២៣,២៦, ៣០–៣១ ៥:១,១៣)។

**២:៦** *ពួកអ្នកដែលគេរាប់ទុកជាប្រសើរ* (មើលការពន្យល់ ខ.២)។ *ព្រះទ្រង់មិនរើស មុខអ្នកណាឡើយ* (ចទ ១០:១៧ ១សយ ១៦:៧ លក ២០:២១ យក ២:១)។

**២:៧** *ពួកមិនកាត់ស្បែក* ត្រង់ចំណុចនេះមិនមែនមានន័យថា លោកប៉ុលប្រកាសដំណឹងល្អតែក្នុងចំណោមពួកសាសន៍ដទៃនោះទេ ។ គាត់តែងតែទៅឯសាលាប្រជុំរបស់សាសន៍យូដាជាមុន នៅទីកន្លែងដែលគាត់បានទៅដល់ (កច ១៣:១៤ និងការពន្យល់)។ ទោះជាយ៉ាងណាក៏ដោយ ក៏លោកប៉ុលគឺជាសាវ័កម្នាក់ ដែលបានទៅប្រកាសដំណឹងល្អដល់សាសន៍ដទៃដែរ (រម ១១:១៣ និងការពន្យល់)។

**២:៩** *យ៉ាកុប* ឈ្មោះគាត់ត្រូវបានសរសេរនៅមុខឈ្មោះរបស់អ្នកដទៃទៀត ដូច្នេះអាចបញ្ជាក់ថា គាត់មាននាទីសំខាន់ជាងគេ នៅក្នុងពួកជំនុំនៅទីក្រុងយេរូសាឡិម (កច ១៥:១២–២១)។ *ព្រះគុណ* ពាក្យថា "ព្រះគុណ" ក្នុងបទគម្ពីរនេះ សំដៅលើដំណឹងល្អ ដែលព្រះអម្ចាស់បានប្រទានឱ្យលោកប៉ុលទៅប្រកាសប្រាប់ពួកសាសន៍ដទៃ (ខ.៧)។ *សសរទ្រូង* នេះជាពាក្យប្រៀបធៀប សំដៅលើពួកអ្នកដែលមានវត្តមាន និងជួយជ្រោមជ្រែងពួកជំនុំ ។ *លូកដៃស្តាំ... ក្នុងសេចក្ដីប្រកប* នេះជារបៀបដែលពួកក្រេក និងពួកយូដាស្វាគមន៍គ្នា ដែលប្រកបដោយមេត្រីភាព ។

**២:១០** បទគម្ពីរត្រង់ចំណុចនេះបញ្ជាក់ថា លោកប៉ុលធ្លាប់ធ្វើដំណើរទៅទីក្រុងយេរូសាឡិមរួចហើយ ដើម្បីចូលរួម និងជួយពួកជំនុំនៅទីនោះ (កច

## លោកប៉ុល និងលោកពេត្រុស

១១ប៉ុន្តែកាលណាលោកពេត្រុស[ឈ]បានមកដល់អាន់ទីយ៉ូក[ញ]
នោះខ្ញុំបានទាស់ទទឹងនឹងលោកនៅប្រទល់មុខ ពីព្រោះ
លោកគួរឱ្យបន្ទោសបាន ១២ដ្បិតមុនដែលមានអ្នកខ្លះមក
ពីលោកយ៉ាកុប[ដ] នោះលោកបានបរិភោគជាមួយនឹងពួក
សាសន៍ដទៃ[ឋ] តែលុះគេមកដល់ហើយ នោះលោកដកខ្លួន
ថយចេញ ដោយកោតខ្លាចដល់ពួកកាត់ស្បែក[ឌ] ១៣ឯពួក
សាសន៍យូដាឯទៀត ក៏ធ្វើជាពើជាមួយនឹងលោកដែរ ដល់
ម្ល៉េះបានជាបាណាបាស[ឍ] ត្រូវបណ្ដោយតាមអំពើកំពុត
របស់គេទៀត ១៤កាលខ្ញុំឃើញថា គេមិនដើរត្រង់តាម
សេចក្ដីពិតនៃដំណឹងល្អទេ[ណ] នោះខ្ញុំក៏សួរលោកពេត្រុស[ត]
នៅមុខមនុស្សទាំងអស់ថា បើលោក ដែលជាសាសន៍យូដា[ថ]
មិនប្រព្រឹត្ត តាមទំនៀមទំលាប់របស់សាសន៍យូដាទេ គឺប្រ
ព្រឹត្តតាមទំនៀមទំលាប់សាសន៍ដទៃវិញ នោះហេតុអ្វីបាន
ជាបង្ខំឱ្យសាសន៍ដទៃ ប្រព្រឹត្តដូចជាសាសន៍យូដាដូច្នេះ[ទ]
១៥ឯយើងដែលជាសាសន៍យូដាពីកំណើត[ធ] ហើយមិនមែន
ជាអ្នកដែលមានបាបក្នុងសាសន៍ដទៃ[ន] ១៦យើងដឹងថាមនុស្ស
មិនបានរាប់ជាសុចរិត ដោយប្រព្រឹត្តតាមក្រិត្យវិន័យ នោះ
ឡើយ[ប] គឺដោយសេចក្ដីជំនឿ ជឿដល់ព្រះយេស៊ូវគ្រីស្ទ វិញ[ផ]
ហេតុនោះបានជាយើងជឿដល់ព្រះគ្រីស្ទយេស៊ូវ ដើម្បីឱ្យបាន
រាប់ជាសុចរិត ដោយសារសេចក្ដីជំនឿ ជឿដល់ព្រះគ្រីស្ទនោះ
មិនមែនដោយប្រព្រឹត្តតាមក្រិត្យវិន័យទេពីព្រោះគ្មានមនុស្ស
ណាបានរាប់ជាសុចរិត ដោយប្រព្រឹត្ត តាមក្រិត្យវិន័យឡើយ[ព]
១៧រីឯ កាលយើងខ្ញុំកំពុងតែស្វែងរក ឱ្យបានរាប់ជា
សុចរិតក្នុងព្រះគ្រីស្ទ នោះបើសិនជាគេឃើញយើងមាន
បាបវិញ[ភ] ដូច្នេះ តើព្រះគ្រីស្ទជាអ្នកចែកចាយអំពើបាបឬ
អី ទេ មិនមែនឡើយ[ម] ១៨ដ្បិតបើសិនជាខ្ញុំតាំងការទាំងនោះ
ឡើងវិញ ដែលខ្ញុំបានរំលំពីដើម នោះឈ្មោះថា ខ្ញុំតាំងខ្លួន
ខ្ញុំជាអ្នករំលងច្បាប់ហើយ ១៩ពីព្រោះខ្ញុំបានស្លាប់ខាងឯ
ក្រិត្យវិន័យ ដោយសារក្រិត្យវិន័យនោះឯង[យ] ដើម្បីឱ្យខ្ញុំបាន
រស់ខាងឯព្រះវិញ[រ] ២០ខ្ញុំបានជាប់ឆ្កាងជាមួយនឹងព្រះគ្រីស្ទ[ល]
ប៉ុន្តែខ្ញុំរស់នៅ មិនមែនជាខ្ញុំទៀត គឺជាព្រះគ្រីស្ទទ្រង់រស់
ក្នុងខ្ញុំវិញ[វ] ហើយដែលខ្ញុំរស់ក្នុងសាច់ឈាមឥឡូវនេះ នោះ
គឺរស់ដោយសេចក្ដីជំនឿ ជឿដល់ព្រះរាជបុត្រានៃព្រះ[ស]
ដែលទ្រង់ស្រឡាញ់ខ្ញុំ[ហ] ក៏បានប្រគល់ព្រះអង្គទ្រង់ជំនួសខ្ញុំ

**២:១១** ឈ ខ.៧,៩, ១៤ ញ កច ១១:១៩
**២:១២** ដ កច ១៥:១៣ ឋ កច ១១:៣ ឌ កច ១០:៤៥ ១១:២
**២:១៣** ឍ ខ.១ កច ៤:៣៦
**២:១៤** ណ ខ.៥ ត ខ.៧,៩,១១ ថ កច ១០:២៨ ទ ខ.១២
**២:១៥** ធ ភល ៣:៤,៥ ន ១សយ ១៥:១៨ លក ២៤:៧
**២:១៦** ប រម ៣:២៨ ផ រម ៩:៣០ ព រម ៣:២៨ ៤:២៥
**២:១៧** ភ ខ.១៥ ម កទ ៣:២១
**២:១៩** យ រម ៧:៤ រ រម ៦:១០,១១,១៤ ២កថ ៥:១៥
**២:២០** ល រម ៦:៦ វ រម ៨:១០ ១ពត ៤:២ ស មថ ៤:៣ ហ រម ៨:៣៧

១១:២៩–៣០)។ គាត់ធ្វើដំណើរទៅទីក្រុងយេរូសាឡិមជាថ្មីទៀត នៅក្នុងដំណើរបេសកកម្មលើកទីបីរបស់គាត់ (រម ១៥:២៥–២៧ ១កថ ១៦:៣–៤ ២កថ ៩ កច ២៤:១៧)។

**២:១១** *អាន់ទីយ៉ូក* គឺជាទីក្រុងសំខាន់របស់ប្រទេសស៊ីរី ដែលជាដែនដីស្ថិតនៅក្រោមការត្រួតត្រារបស់ចក្រភពរ៉ូម៉ាំង ។ ទីក្រុងនេះគឺជាទីក្រុងលំដាប់ទីបី (បន្ទាប់ពីទីក្រុងរ៉ូម និងទីក្រុងអ័លេក្សានទ្រា) ក្នុងចំណោមទីក្រុងសំខាន់ៗរបស់ចក្រភពរ៉ូម៉ាំង ។ លោកប៉ុលត្រូវបានបញ្ជូនឱ្យទៅធ្វើបេសកកម្មដោយចេញពីទីក្រុងនេះ (កច ១៣:១–៣ ១៤:២៦)។ *ពីព្រោះលោកគួរឱ្យបន្ទោសបាន* ត្រង់ចំណុចនេះបញ្ជាក់ថា លោកប៉ុលធ្លាប់បានជួបជាមួយលោកពេត្រុស និងបានពិភាក្សាគ្នាលើបញ្ហាដែលទាក់ទងនឹងក្រុមអ្នកដែលប្រកាន់យកការកាត់ស្បែក ។

**២:១២** *ពួកកាត់ស្បែក* សំដៅលើពួកអ្នកដែលយល់ថា ការកាត់ស្បែកគឺសំខាន់សម្រាប់ទទួលនូវសេចក្ដីសង្គ្រោះ (កច ១០:៤៥ ១១:២ រម ៤:១២)។

**២:១៣** *ពួកសាសន៍យូដាឯទៀត* សំដៅលើពួកអ្នកជឿជាសាសន៍យូដាដែលមិនចូលប្រកបជាមួយក្រុមដែលប្រកាន់យកការកាត់ស្បែក ប៉ុន្តែពួកគេទាំងនោះក៏មានបញ្ហាជាមួយនឹងលោកពេត្រុសដែរ ។ *អំពើកំពុត* (មើលការពន្យល់ មថ ៦:២)។

**២:១៤** យោងតាមបទគម្ពីរ "កច ១៥:១៣–១៤,១៩" អ្នកដឹកនាំពួកជំនុំនៅទីក្រុងយេរូសាឡិមយល់ថា ការដែលតម្រូវឱ្យពួកអ្នកជឿជាសាសន៍ដទៃកាត់ស្បែកពុំមែនជាការសំខាន់ទេ ។ សេចក្ដីពិតនៃដំណឹងល្អ គឺសម្រាប់ទាំងពួកសាសន៍យូដា និងសាសន៍ដទៃ ហើយការសង្គ្រោះគឺកើតឡើងដោយសារព្រះគុណនៃព្រះអម្ចាស់ តាមរយៈសេចក្ដីជំនឿលើទ្រង់ប៉ុណ្ណោះ (ខ.១២)។

**២:១៦** ខនេះគឺជាខគន្លឹះនៅក្នុងកណ្ឌគម្ពីរកាឡាទី ។ មានបញ្ជាក់៣ដងថា មនុស្សមិនមែនបានរាប់ជាសុចរិតដោយសារក្រឹត្យវិន័យឡើយ និងបញ្ជាក់៣ដងទៀតថា មនុស្សបានរាប់ជាសុចរិត ដោយសារតែសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ ។ *មិនបានរាប់ជាសុចរិត ដោយប្រព្រឹត្តតាមក្រិត្យវិន័យនោះឡើយ* ឃ្លានេះលោកប៉ុលមិនបានបដិសេធចោលក្រិត្យវិន័យនោះទេ ពីព្រោះគាត់បានទទួលស្គាល់ថា ក្រិត្យវិន័យរបស់ព្រះអម្ចាស់គឺ "ល្អ បរិសុទ្ធ និងសុចរិត" (រម ៧:១២ និងការពន្យល់)។ គាត់និយាយយ៉ាងដូច្នេះ គឺសំដៅលើការដែលប្រើប្រាស់មិនត្រឹមត្រូវ នូវក្រិត្យវិន័យនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ *បានរាប់ជាសុចរិត ដោយសារសេចក្ដីជំនឿ* ឃ្លានេះគឺជាសេចក្ដីគន្លឹះនៃដំណឹងល្អ (រម ៣:២០,២៤,២៨ ភល ៣:៩)។ មានន័យថា មនុស្សត្រូវបានរាប់ជាសុចរិត គឺដោយសារតែជំនឿលើព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ (អភ ២:៨–៩ យក ២:១៤–២៦)។

**២:១៧** "មើលការពន្យល់ រម ៦:១"។

**២:១៩** *ខ្ញុំបានស្លាប់ខាងឯក្រិត្យវិន័យ* មានន័យថា អំណាចនៃក្រឹត្យវិន័យពុំអាចគម្រាមអ្នកជឿដល់ព្រះយេស៊ូវបានទេ (ខ.២០ រម ៧:៤ និងពន្យល់)។

**២:២០** *បានជាប់ឆ្កាងជាមួយនឹងព្រះគ្រីស្ទ* គឺឱ្យជីវិតចាស់របស់យើងដែលពេញដោយអំពើបាបបានស្លាប់ (៥:២៤ រម ៦:៤–៨–១០ ៧:៦ រម ៦:៧ និងការពន្យល់)។ *ក៏បានប្រគល់ព្រះអង្គទ្រង់ជំនួសខ្ញុំហើយ* មានន័យថា ព្រះយេស៊ូវគ្រីស្ទបានយាងមកសុគតដើម្បីលោះមនុស្សទាំងអស់ ប្រយោជន៍ឱ្យពួកគេបានសង្គ្រោះ និងមានជីវិតរស់អស់កល្បជានិច្ច (១:៤ ១ធថ ២:៦

ហើយ[ឡ] ២១ខ្ញុំមិនលើកព្រះគុណនៃព្រះចោលទេ ដ្បិតបើ
សិនជាសេចក្ដីសុចរិតមកដោយសារក្រិត្យវិន័យ[អ] នោះព្រះ
គ្រីស្ទបានសុគតជាឥតប្រយោជន៍សោះ ។

**ជំនឿ និងការប្រតិបត្តិតាមក្រឹត្យវិន័យ**

**៣** ១ឱពួកអ្នកស្រុកកាឡាទី[ក]ឥតបើគិតអើយ[ខ] ដែលបានបើក
សំដែងព្រះយេស៊ូវគ្រីស្ទមកយ៉ាងច្បាស់ នៅភ្នែកអ្នករាល់
គ្នា ហើយទាំងជាប់ឆ្កាងផង[គ] នោះតើអ្នកណាបានធ្វើអំពើ
ដាក់អ្នករាល់គ្នា ឱ្យលែងស្ដាប់តាមសេចក្ដីពិតវិញដូច្នេះ[ឃ]
២ខ្ញុំចង់សួរអ្នករាល់គ្នាតែប៉ុណ្ណេះថា តើអ្នករាល់គ្នាបាន
ទទួលព្រះវិញ្ញាណ[ង] ដោយប្រព្រឹត្តតាមក្រិត្យវិន័យ[ច] ឬដោយ
បានស្ដាប់ ទាំងមានសេចក្ដីជំនឿ[ឆ] ៣តើអ្នករាល់គ្នាជា
មនុស្សឥតបើគិតជាខ្លាំងដល់ម្ល៉េះឬអី ដែលបានចាប់ផ្ដើម
ដោយព្រះវិញ្ញាណហើយ តើឥឡូវនេះបានគ្រប់លក្ខណ៍
ឡើង ដោយសាច់ឈាមវិញឬ ៤តើបានរងទុក្ខច្រើនម្ល៉េះ
ជាឥតប្រយោជន៍ឬអី គឺបើជាឥតប្រយោជន៍មែន ៥ឯព្រះ
ដែលទ្រង់ប្រទានព្រះវិញ្ញាណមកអ្នករាល់គ្នា ហើយធ្វើការ
ឫទ្ធិបារមីក្នុងពួកអ្នករាល់គ្នា[ជ] នោះតើដោយអ្នករាល់គ្នា
ប្រព្រឹត្តតាមក្រិត្យវិន័យ ឬដោយស្ដាប់ ទាំងមានសេចក្ដី
ជំនឿវិញ[ឈ] ៦ដូចជាលោកអ័ប្រាហាំបានជឿដល់ព្រះ
ហើយសេចក្ដីនោះ បានរាប់ជាសេចក្ដីសុចរិតដល់លោក[ញ]
៧ដូច្នេះចូរដឹងថា ពួកអ្នកដែលមានសេចក្ដីជំនឿ[ដ] នោះជា
ពូជលោកអ័ប្រាហាំហើយ[ឋ] ៨ហើយដោយគម្ពីរបានដឹងជា
មុនថា ព្រះទ្រង់នឹងរាប់ពួកសាសន៍ដទៃជាសុចរិត ដោយសេច
ក្ដីជំនឿ បានជាមានសេចក្ដីប្រកាសប្រាប់មក ដល់លោកអ័
ប្រាហាំជាមុនថា «អស់ទាំងសាសន៍នឹងបានពរ ដោយសារ
ឯង»[ឌ] ៩ដូច្នេះ អស់អ្នកដែលមានសេចក្ដីជំនឿ[ឍ]នោះឈ្មោះថា
បានពរជាមួយនឹងលោកអ័ប្រាហាំ ដែលជាអ្នកជឿដែរ[ណ]
១០តែអស់អ្នកដែលអាងដល់ការប្រព្រឹត្តតាមក្រិត្យវិន័យ[ត]
នោះត្រូវបណ្ដាសាវិញ[ថ] ដ្បិតមានសេចក្ដីចែងទុកមកថា
«ត្រូវបណ្ដាសាហើយ អស់អ្នកណាដែលមិនកាន់ខ្ជាប់តាម
គ្រប់ទាំងសេចក្ដី ដែលកត់ទុកក្នុងគម្ពីរក្រិត្យវិន័យ ដើម្បីនិង
ប្រព្រឹត្តតាម»[ទ] ១១ហើយច្បាស់ជាគ្មានអ្នកណាបានរាប់
ជាសុចរិតនៅចំពោះព្រះ ដោយសារក្រិត្យវិន័យឡើយ[ធ]
ពីព្រោះ «មនុស្សសុចរិតនឹងរស់ ដោយអាងសេចក្ដីជំនឿ »[ន]
១២ឯក្រិត្យវិន័យ មិនអាងសេចក្ដីជំនឿទេ គឺអ្នកណាដែល

**២:២០** ឡ កទ ១:៤
**២:២១** អ កទ ៣:២១
**៣:១** ក កច ១៦:៦ ខ លក ២៤:២៥ គ ១កថ ១:២៣ ឃ កទ ៥:៧
**៣:២** ង យហ ២០:២២ ច ខ.៥,១០ កទ ២:១៦ ឆ រម ១០:១៧ ហព ៤:២
**៣:៥** ជ ១កថ ១២:១០ ឈ ខ.២,១០ កទ ២:១៦
**៣:៦** ញ លប ១៥:៦ រម ៤:៣
**៣:៧** ដ ខ.៩ ឋ លក ៣:៨
**៣:៨** ឌ លប ១២:៣ ១៨:១៨ ២២:១៨ ២៦:៤ កច ៣:២៥
**៣:៩** ឍ ខ.៧ រម ៤:១៦ ណ រម ៤:១៨–២២
**៣:១០** ត ខ.២,៥ កទ ២:១៦ ថ ខ.១៣ រម ៤:១៥ ទ ចទ ២៧:២៦ យរ ១១:៣
**៣:១១** ធ រម ៣:២៨ ន ហព ២:៤ រម ៩:៣០ ហព ១០:៣៨

ទត ២:១៤)។

**២:២១** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ច្បាប់ទម្លាប់ ឬវិន័យផ្សេងៗ គឺពុំអាចយកមកប្រៀបធៀប ឬយកមកលាយឡំជាមួយនឹងព្រះគុណបានទេ បើពុំដូច្នោះទេ វាធ្វើឱ្យការសុគតរបស់ព្រះយេស៊ូវគ្រីស្ទក្លាយជាឥតប្រយោជន៍វិញ ។

**៣:១** *ឥតបើគិត* ពួកជំនុំនៅទីក្រុងកាឡាទីមិនមែនពុំចេះគិតនោះទេ ប៉ុន្តែពួកគេមិនបានប្រើនូវការយល់ដឹងរបស់ខ្លួន (លក ២៤:២៥ រម ១:១៤ ១ធថ ៦:៩ ទត ៣:៣)។ *ជាប់ឆ្កាង* សំដៅលើការឆ្កាងនៅឯទីសាធារណៈដើម្បីឱ្យពួកបណ្ដាជនបានឃើញ (១កថ ១:២៣ ២:២)។ សូមប្រៀបធៀបនឹងរូបពស់លង្ហិន ដែលលោកម៉ូសេបានភ្ជាប់នៅលើបង្គោល នៅក្នុងបទគម្ពីរ "ជន ២១:៩"។

**៣:២** *ព្រះវិញ្ញាណ* គោលរឿងសំខាន់ក្នុងកណ្ឌគម្ពីរកាឡាទីចាប់ពីចំណុចនេះគឺនិយាយទាក់ទងនឹងព្រះវិញ្ញាណបរិសុទ្ធ (លោកប៉ុលនិយាយសំដៅលើព្រះវិញ្ញាណបរិសុទ្ធចំនួន១៦ដង)។

**៣:៣** *បានចាប់ផ្ដើម ដោយព្រះវិញ្ញាណ . . . បានគ្រប់លក្ខណ៍ឡើង* ត្រង់ចំណុចនេះបញ្ជាក់ថា ការសង្គ្រោះ និងការញែកជាបរិសុទ្ធ គឺជាព្រះរាជកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធ ។ លោកប៉ុលប្រកាសប្រាប់ពួកជំនុំ នៅទីក្រុងកាឡាទីថា ការដែលពួកគេបានរាប់ជាបរិសុទ្ធ គឺដោយសារតែសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ មិនមែនដោយសារការខំប្រឹងរបស់ពួកគេទេ ។

**៣:៤** បទគម្ពីរនេះបញ្ជាក់ថា ពួកជំនុំនៅទីក្រុងកាឡាទី បានទទួលការបៀតបៀន ដោយសារតែសេចក្ដីជំនឿលើព្រះយេស៊ូវ ។ ប្រសិនបើពួកគេលះចោលសេចក្ដីជំនឿរបស់ខ្លួននោះមានន័យថា អ្វីដែលពួកគេបានធ្វើក្លាយជាឥតប្រយោជន៍ ។ ដូច្នេះហើយបានជាលោកប៉ុលលើកទឹកចិត្តពួកគេ ឱ្យមានសេចក្ដីសង្ឃឹមដោយដឹងថា អ្វីដែលពួកគេខំប្រឹងមិនមែនឥតប្រយោជន៍ទេ ។

**៣:៧** លោកអ័ប្រាហាំគឺជាឪពុកខាងឯរូបកាយ និងវិញ្ញាណរបស់ពួកសាសន៍យូដា (យហ ៨:៣៣,៣៩,៥៣ កច ៧:២ រម ៤:១២)។ អស់អ្នកដែលជឿដល់ព្រះអម្ចាស់ ក៏ត្រូវបានហៅថា កូនចៅអ័ប្រាហាំដែរ (មើលការពន្យល់ រម ៤:១១–១២)។ ម្យ៉ាងទៀត ពួកគេត្រូវបានហៅថា ពូជលោកអ័ប្រាហាំ (ខ.១៦ ហព ២:១៦)។

**៣:៨** *គម្ពីរបានដឹងជាមុន* បញ្ជាក់ថា ព្រះអម្ចាស់បានប្រទានព្រះគម្ពីរមក (១ធថ ៥:១៨)។

**៣:៩** *លោកអ័ប្រាហាំដែលជាអ្នកជឿ* ត្រង់ចំណុចនេះបញ្ជាក់ថា លោកអ័ប្រាហាំបានរាប់ជាសុចរិត គឺដោយសារសេចក្ដីជំនឿ មិនមែនដោយសារការកាត់ស្បែកនោះទេ (រម ៤ ហព ១១:៨–៩)។

**៣:១០** *អ្នកដែលអាងដល់ការប្រព្រឹត្តតាមក្រិត្យវិន័យ* សំដៅលើពួកអ្នកដែលមិនព្រមទទួលយកព្រះគុណដែលព្រះអម្ចាស់ប្រទានមក ហើយនៅតែប្រកាន់ថា ការរាប់ជាសុចរិត គឺដោយសារការខំប្រឹងរបស់ខ្លួន ។ *ត្រូវបណ្ដាសា* មានន័យថា គ្មានមនុស្សណាម្នាក់ដែលនៅក្រោមក្រឹត្យវិន័យអាចប្រព្រឹត្តតាមឥតខ្ចោះទេ ។ *គ្រប់ទាំងសេចក្ដី* (យក ២:១០ និងពន្យល់)។

**៣:១១** *មនុស្សសុចរិតនឹងរស់* ឃ្លានេះមានន័យដូចគ្នានឹងការដែលបានញែកជាបរិសុទ្ធដែរ (ខ.១២)។

**៣:១២** "សូមមើល លវ ១៨:៥"។

អាចនឹងប្រព្រឹត្ត តាមសេចក្តីទាំងនោះបាន អ្នកនោះនឹង
រស់នៅ ដោយសារសេចក្តីទាំងនោះ[ប] ១៣ព្រះគ្រីស្ទទ្រង់
បានលោះយើងរាល់គ្នា ឱ្យរួចពីសេចក្តីបណ្តាសារបស់
ក្រិត្យវិន័យ[ផ] ដោយទ្រង់ត្រូវបណ្តាសាជំនួសយើងរាល់គ្នា
(ដ្បិតមានសេចក្តីចែងទុកមកថា «ត្រូវបណ្តាសាហើយ អ្នក
ណាដែលត្រូវព្យួរនៅលើឈើ»)[ព] ១៤ដើម្បីឱ្យពររបស់
លោកអ័ប្រាហាំបានមកដល់អស់ទាំងសាសន៍ក្នុងព្រះគ្រីស្ទ
យេស៊ូវ[ភ] ប្រយោជន៍ឱ្យយើងបានទទួលសេចក្តីសន្យា គឺជា
ព្រះវិញ្ញាណ ដោយសារសេចក្តីជំនឿ[ម]។

## ក្រឹត្យវិន័យ និងព្រះបន្ទូលសន្យា

១៥បងប្អូនអើយ[យ] ខ្ញុំនិយាយតាមបែបភាពមនុស្សថា
សូម្បីតែសេចក្តីសញ្ញារបស់មនុស្ស បើគេយល់ព្រមតាំងនឹង
គ្នាជាស្រេចហើយ នោះគ្មានអ្នកណានឹងលើកចោល ឬ
បន្ថែមបញ្ចូលអ្វីឡើយ ១៦រីឯសេចក្តីសន្យាទាំងប៉ុន្មាននោះ
បានតាំងនឹងលោកអ័ប្រាហាំ ហើយនិងពូជលោក[រ] តែទ្រង់
មិនបានមានបន្ទូលថា «នឹងពូជទាំងប៉ុន្មាន» ដូចជាមានពូជ
ជាច្រើននោះទេ គឺចំពោះពូជតែ១វិញ ដោយថា «នឹងពូជ
លោក១នោះឯង»[ល] គឺជាព្រះគ្រីស្ទ ១៧ខ្ញុំចង់និយាយដូច្នេះ
ថា សេចក្តីសញ្ញាដែលព្រះបានយល់ព្រមជាមុន នោះក្រិត្យ
វិន័យ ដែលកើតឡើង៤៣០ឆ្នាំ[វ]ជាក្រោយនឹងលើកចោល
ឱ្យសេចក្តីសញ្ញានោះទៅជាឥតប្រយោជន៍មិនបាន ១៨ដ្បិត
បើសិនជាមរដកនោះបានមក ដោយអាងក្រិត្យវិន័យ នោះ
មិនមែនអាងសេចក្តីសន្យាទៀតទេ[ស] តែព្រះទ្រង់បានប្រទាន
ដល់លោកអ័ប្រាហាំ តាមសេចក្តីសន្យាវិញ ១៩ដូច្នេះ តើហេតុ
អ្វីបានជាមានក្រិត្យវិន័យនោះគឺបានបន្ថែមបញ្ចូល ដោយ
ព្រោះសេចក្តីរំលងច្បាប់[ហ]ទាល់តែពូជបានកើតឡើង[ឡ]
ដែលទ្រង់តាំងសេចក្តីសន្យានោះឱ្យ ដោយសារពួកទេវតា[អ]
នៅដៃនៃអ្នកកណ្តាលម្នាក់[ក] ២០រីឯអ្នកកណ្តាល[ខ] នោះមិន
មែនបម្រួបបម្រួមអ្នកណាតែម្នាក់ឯងនោះឡើយ តែចំពោះ
ព្រះទ្រង់ជាព្រះតែ១ទេ ។
២១ដូច្នេះ តើក្រិត្យវិន័យទាស់ទទឹងនឹងសេចក្តីសន្យានៃ
ព្រះឬអី មិនមែនទេ[គ] ដ្បិតបើសិនជាមានក្រិត្យវិន័យណា
ប្រទានមក ដែលអាចនឹងធ្វើឱ្យរស់បាន នោះប្រាកដជា
សេចក្តីសុចរិតនឹងមក ដោយសារក្រិត្យវិន័យនោះហើយ[ឃ]
២២ប៉ុន្តែ គម្ពីរបានបង្ខាំងគ្រប់ទាំងអស់ក្នុងអំពើបាប[ង] ដើម្បី
ឱ្យសេចក្តីដែលទ្រង់សន្យា បានប្រទានមកដល់ពួកអ្នកជឿ
វិញ ដោយសារសេចក្តីជំនឿដល់ព្រះយេស៊ូវគ្រីស្ទ ២៣តែ
កាលមុនដែលមានសេចក្តីជំនឿចូលមក នោះយើងរាល់គ្នា
ត្រូវបង្ខាំងនៅក្រោមក្រិត្យវិន័យ[ច] គឺត្រូវឃុំទុកសំរាប់សេចក្តី

**៣:១២** ប លវ ១៨:៥ រម ១០:៥
**៣:១៣** ផ កទ ៤:៥ ព ចទ ២១:២៣ កច ៥:៣០
**៣:១៤** ភ រម ៤:៩,១៦ ម ឱ.២ យអ ២:២៨ យហ ២០:២២ កច ២:៣៣
**៣:១៥** យ រម ៧:១
**៣:១៦** រ លប ១៧:១៩ ទដ ១៣២:១១ មីក ៧:២០ លក ១:៥៥ រម ៤:១៣,១៦ ៩:៤,៨ កទ ៣:២៩ ៤:២៨ ល លប ១២:៧ ១៣:១៥ ១៧:៧,៨,១០ ២៤:៧
**៣:១៧** វ លប ១៥:១៣,១៤ នក ១២:៤០ កច ៧:៦
**៣:១៨** ស រម ៤:១៤
**៣:១៩** ហ រម ៥:២០ ឡ ឱ.១៦ អ ចទ ៣៣:២ កច ៧:៥៣

ក នក ២០:១៩ ចទ ៥:៥ **៣:២០** ខ ១ធថ ២:៥ ហព ៨:៦ ៩:១៥ ១២:២៤
**៣:២១** គ កទ ២:១៧ រម ៧:១២ ឃ កទ ២:២១ **៣:២២** ង រម ៣:៩–១៩
១១:៣២ **៣:២៣** ច រម ១១:៣២ ឆ ឱ.២៥

**៣:១៣** *ព្រះគ្រីស្ទទ្រង់បានលោះយើងរាល់គ្នា* (៤:៥ អភ ១:៧ និងការពន្យល់)។ *ឈើ* សំដៅលើឈើឆ្កាង (នអ ២:២៣ ១ពត ២:២៤ កច ៥:៣០ និងការពន្យល់)។

**៣:១៤** *ដើម្បីឱ្យពរដល់លោកអ័ប្រាហាំ* (ឱ.៨ រម ៤:១–៥ និងពន្យល់)។ *សេចក្តីសន្យា គឺជាព្រះវិញ្ញាណ* (អគ ៣៦:២៦ ៣៧:១៤ ៣៩:២៩ យហ ១៤:១៦, ១៧ អភ ១:១៣)។

**៣:១៥** *បងប្អូន* (មើលការពន្យល់ ១:២)។ *សេចក្តីសញ្ញារបស់មនុស្ស* លោកប៉ុលបង្ហាញនូវសេចក្តីសញ្ញា ដែលព្រះអម្ចាស់បានប្រទានមកលោកអ័ប្រាហាំ ដោយលើកយកសេចក្តីសញ្ញារបស់មនុស្សមកធ្វើជាឧទាហរណ៍ ។ មានន័យថា ពេលដែលសេចក្តីសញ្ញា (សេចក្តីសន្យា) បានតាំងឡើងហើយ វានឹងមិនផ្លាស់ប្តូរទេ (មថ ២៦:២៨ លក ១:៧២ កច ៣:២៥ ៧:៨ ២កថ ៣:១៤ ហព ៨:៩)។

**៣:១៦** *សេចក្តីសន្យា* (រម ៤:១៣ ៩:៤ និងការពន្យល់)។

**៣:១៧** *៤៣០ឆ្នាំ* សំដៅលើរយៈពេលដែលពួកអ៊ីស្រាអែលរស់នៅក្នុងប្រទេសអេស៊ីព្ទ ។ នៅក្នុង "លប ១៥:១៣ កច ៧:៦" (មើលការពន្យល់) បញ្ជាក់ថា មានរយៈពេល៤០០ឆ្នាំ ។

**៣:១៩** ចាប់ពីលោកអ័ប្រាហាំមក សេចក្តីសញ្ញាដែលព្រះអម្ចាស់បានតាំងនឹងលោក (លប ១២:២–៣,៧ ១៥:១៨–២០ ១៧:៤–៨) បានភ្ជាប់ទំនាក់ទំនងរវាងទ្រង់ និងរាស្ត្ររបស់ទ្រង់ ។ បន្ទាប់អំពីពួកអ៊ីស្រាអែលបានចាកចេញពីប្រទេសអេស៊ីព្ទ សេចក្តីសញ្ញានៅភ្នំស៊ីណាយ (លោកហោរាយេរេមាហៅថា សេចក្តីសញ្ញាចាស់) បានបន្ថែមលើសេចក្តីសញ្ញា ដែលទ្រង់មានចំពោះលោកអ័ប្រាហាំ (យរ ៣១:៣១–៣៤)។ *បានបន្ថែមបញ្ចូល* គឺបន្ថែមនូវក្រិត្យវិន័យ (រម ៤:១៥ ៧:៧–១១)។ *ទាល់តែពូជបានកើតឡើង* គឺទាល់តែព្រះយេស៊ូវគ្រីស្ទបានយាង មក (ឱ.១៦)។ *ដោយសារពួកទេវតា* (កច ៧:៣៨,៣៨ និងការពន្យល់)។ *អ្នកកណ្តាលម្នាក់* គឺសំដៅលើលោកម៉ូសេ (ឱ.២០ និងការពន្យល់)។

**៣:២០** សេចក្តីសញ្ញានៅភ្នំស៊ីណាយ គឺជាសេចក្តីសញ្ញាដែលបានតាំងឡើងរវាងព្រះអម្ចាស់ និងរាស្ត្រទ្រង់ ដោយមានលោកម៉ូសេជាអ្នកកណ្តាល ។ រីឯនៅក្នុងសេចក្តីសញ្ញា ដែលព្រះអម្ចាស់បានតាំងជាមួយនឹងលោកអ័ប្រាហាំ គឺគ្មានអ្នកកណ្តាលទេ (ចទ ៦:៤)។

**៣:២១** មូលហេតុដែលក្រិត្យវិន័យមិនប្រឆាំងនឹងសេចក្តីសន្យារបស់ព្រះ ពីព្រោះនៅក្រោមក្រិត្យវិន័យ គ្មានអ្នកណាអាចបានសង្គ្រោះទេ ។ ក្រិត្យវិន័យបង្ហាញឱ្យដឹងនូវអំពើបាប ដែលកាត់ផ្តាច់មនុស្សចេញពីព្រះអម្ចាស់ និងបង្ហាញនូវសេចក្តីសន្យា ស្តីអំពីការសង្គ្រោះដល់មនុស្សលោក ។

**៣:២៣** *សេចក្តីជំនឿ* គឺសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ (ឱ.២២)។ *ត្រូវបង្ខាំងនៅក្រោមក្រិត្យវិន័យ* ឃ្លានេះបញ្ជាក់ថា ការបង្ខាំងនៅក្រោមអំពើបាប និងក្រោមក្រិត្យវិន័យ គឺមានលក្ខណៈដូចគ្នា (ឱ.១៩ កល ២:២០ និងការពន្យល់)។

ជំនឿ ដែលត្រូវលេចមក[ឆ] ២៤បានជាក្រិត្យវិន័យធ្វើជាអ្នកដឹកនាំយើងរាល់គ្នាទៅដល់ព្រះគ្រីស្ទ[ជ] ដើម្បីឱ្យយើងបានរាប់ជាសុចរិត ដោយអាងសេចក្ដីជំនឿ[ឈ] ២៥តែលុះកាលសេចក្ដីជំនឿបានមកដល់ នោះយើងមិនមែននៅក្រោមអំណាច របស់អ្នកដឹកនាំនោះទៀតទេ[ញ]។

## កូននៃព្រះ

២៦ដ្បិតអ្នករាល់គ្នាសុទ្ធតែជាកូនព្រះ[ដ] ដោយសារសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទយេស៊ូវ ២៧ព្រោះអស់អ្នកដែលបានទទួលបុណ្យជ្រមុជក្នុងព្រះគ្រីស្ទ[ឋ] នោះឈ្មោះថាបានប្រដាប់កាយដោយព្រះគ្រីស្ទហើយ[ឌ] ២៨គ្មានសាសន៍យូដា ឬសាសន៍ក្រេក គ្មានបាវបំរើ ឬអ្នកជា[ឍ] គ្មានប្រុស និងស្រីទៀតទេ[ណ] ពីព្រោះអ្នករាល់គ្នាទាំងអស់រួមមកតែមួយ នៅក្នុងព្រះគ្រីស្ទយេស៊ូវ[ត] ២៩ហើយបើអ្នករាល់គ្នាជារបស់ផងព្រះគ្រីស្ទ[ថ] នោះក៏ពេញជាពូជរបស់លោកអ័ប្រាហាំហើយ[ទ] ក៏ជាអ្នកគ្រងមរដក[ធ]តាមសេចក្ដីសន្យាផង[ន]។

**៤** ១ខ្ញុំនិយាយដូច្នេះថា កាលអ្នកដែលត្រូវគ្រងមរដកនៅក្មេងនៅឡើយ នោះមិនផ្សេងពីបាវបំរើប៉ុន្មានទេ ទោះបើជាម្ចាស់លើទាំងអស់ក៏ដោយ ២ដ្បិតត្រូវនៅក្នុងអំណាចភីលៀង និងអ្នកត្រួតត្រា ដរាបដល់វេលា ដែលឪពុកបានកំណត់ជាមុន ៣ឯយើងរាល់គ្នាក៏ដូច្នោះដែរ កាលយើងនៅក្មេងនៅឡើយ នោះយើងត្រូវជាប់ចំណង[ប] ក្នុងអំណាចនៃអស់ទាំងបឋមសិក្សារបស់លោកីយ៍[ផ] ៤តែលុះវេលាកំណត់បានមកដល់[ព] នោះព្រះទ្រង់បានចាត់ព្រះរាជបុត្រាទ្រង់[ភ]ឱ្យមកចាប់កំណើតនឹងស្ត្រី[ម] គឺកើតក្រោមអំណាចនៃក្រិត្យវិន័យ[យ] ៥ដើម្បីនឹងលោះ[រ]ពួកអ្នកដែលនៅក្រោមក្រិត្យវិន័យ ប្រយោជន៍ឱ្យយើងបានទទួលសគុណ[ល] ទុកជាកូនចិញ្ចឹម[វ] ៦ហើយដោយព្រោះអ្នករាល់គ្នាជាកូន បានជាព្រះទ្រង់ចាត់ព្រះវិញ្ញាណនៃព្រះរាជបុត្រាទ្រង់[ស] ឱ្យមកក្នុងចិត្តអ្នករាល់គ្នា[ហ] ឱ្យបន្លឺឡើងថា អ័ប្បា ព្រះវរបិតាអើយ[ឡ] ៧ដូច្នេះអ្នករាល់គ្នាមិនមែនជាបាវបំរើទៀតទេ គឺជាកូនវិញ ហើយបើជាកូន នោះនឹងបានមរដកនៃព្រះ ដោយសារព្រះគ្រីស្ទដែរ[អ]។

## ការបារម្ភរបស់លោកប៉ុលចំពោះពួកជំនុំកាឡាទី

៨នៅវេលានោះ កាលអ្នករាល់គ្នាមិនទាន់ស្គាល់ព្រះ[ក]

**៣:២៤** ជ ខ.១៩ រម ១០:៤ ៤:១៥ ឈ កទ ២:១៦ **៣:២៥** ញ រម ៧:៤ **៣:២៦** ដ រម ៨:១៤ **៣:២៧** ឋ មថ ២៨:១៩ ឌ រម ១៣:១៤ **៣:២៨** ឍ ១កថ ១២:១៣ កល ៣:១១ ណ លប ១:២៧ ៥:២ យអ ២:២៩ ត យហ ១០:១៦ ១៧:១១ អភ ២:១៤,១៥ **៣:២៩** ថ ១កថ ៣:២៣ ទ ខ.១៦ ធ រម ៨:១៧ ន ខ.១៦ **៤:៣** ប ខ.៨,៩,២៤,២៥ កទ ២:៤ ផ កល ២:៨,២០ **៤:៤** ព មក ១:១៥ រម ៥:៦ អភ ១:១០ ភ យហ ៣:១៧ ម យហ ១:១៤ យ លក ២:២៧ **៤:៥** រ រម ៣:២៤ ល យហ ១:១២ វ រម ៨:១៤ **៤:៦** ស កច ១៦:៧ ហ រម ៥:៥ ឡ រម ៨:១៥,១៦ **៤:៧** អ រម ៨:១៧ **៤:៨** ក រម ១:២៨ ១កថ ១:២១ ១៥:៣៤ ១ថន ៤:៥ ២ថន ១:៨

**៣:២៤** គ្រួសារអ្នកមាននៅសម័យលោកប៉ុល តែងតែជួលគ្រូមកបង្ហាត់បង្រៀនដល់កូនរបស់ពួកគេ ហើយកូននោះគឺត្រូវស្ថិតនៅក្រោមអំណាចរបស់គ្រូ ។ ក្នុងរបៀបដូចគ្នានេះដែរ ក្រិត្យវិន័យត្រូវបានដាក់មក ដើម្បីណែនាំយើងឱ្យឈានទៅដល់ការស្គាល់ព្រះគ្រីស្ទ (១កថ ៤:១៥)។

**៣:២៥-២៦** ត្រង់ចំណុចនេះបញ្ជាក់ថា ដោយសារសេចក្ដីជំនឿលើព្រះយេស៊ូវ យើងត្រូវបានរាប់ជាសុចរិត និងបានចូលទៅក្នុងគ្រួសាររបស់ទ្រង់ (៤:១-៧ រម ៨:១៤-១៧)។

**៣:២៧** *ទទួលបុណ្យជ្រមុជក្នុងព្រះគ្រីស្ទ* (រម ៦:៣–១១ ១កថ ១២:១៣ និងការពន្យល់)។ *បានប្រដាប់កាយដោយព្រះគ្រីស្ទ* (ទដ ១០៩:២៩ និងការពន្យល់)។

**៣:២៨** បទគម្ពីរនេះបញ្ជាក់ថា ការរួបរួមនៅក្នុងព្រះគ្រីស្ទ ពុំគិតអំពីជាតិសាសន៍ សង្គម និងភេទប្រុស ឬស្រីទេ (រម ១០:១២ ១កថ ១២:១៣ ភព ២:១៥–១៦)។

**៣:២៩** *ពូជរបស់លោកអ័ប្រាហាំ* មានន័យថា អស់អ្នកដែលជឿដល់ព្រះអម្ចាស់ គឺជាពូជរបស់លោកអ័ប្រាហាំយ៉ាងពិតប្រាកដ ។

**៤:១** *ក្មេង* សំដៅលើពួកអ្នកដែលពុំទាន់ពេញវ័យនៅឡើយ ផ្ទុយនឹងមនុស្សពេញអាយុនៅក្នុង "១កថ ១៤:២០" (ភល ៣:១៥)។

**៤:២** *អ្នកត្រួតត្រា* ពាក្យនេះមានន័យទូលំទូលាយជាងពាក្យថា "អ្នកដឹកនាំយើង" នៅក្នុង "៣:២៤" (មថ ២០:៨ "នាយដំរួត" លក ៨:៣)។

**៤:៣** *ជាប់ចំណង* (៣:២៣ និងការពន្យល់)។ *បឋមសិក្សារបស់លោកីយ* លោកប៉ុលមានប្រសាសន៍យ៉ាងដូច្នេះ សំដៅលើប្រពៃណី ទំនៀមទម្លាប់ និងច្បាប់របស់មនុស្សជាតិទាំងឡាយ (កល ២:៨ និងការពន្យល់)។

**៤:៤** *លុះវេលាកំណត់បានមកដល់* សំដៅលើពេលវេលាដែលព្រះអម្ចាស់រៀបចំឱ្យរាស្ត្ររបស់ទ្រង់បានពេញវ័យ និងសម្រាប់ទទួលមរតក (ខ.២)។ *ព្រះទ្រង់បានចាត់ព្រះរាជបុត្រាទ្រង់* (យហ ១:១៤ ៣:១៦ រម ១:១–៦ ១យហ ៤:១៤)។ *មកចាប់កំណើតនឹងស្ត្រី* គឺដើម្បីបញ្ជាក់ថា ព្រះគ្រីស្ទគឺជាព្រះមួយរយភាគរយ និងជាមនុស្សមួយរយភាគរយ ។ *កើតក្រោមអំណាចនៃក្រិត្យវិន័យ* គឺស្ថិតនៅ ក្រោមក្រិត្យវិន័យរបស់សាសន៍យូដា ។

**៤:៥** *ពួកអ្នកដែលនៅក្រោមក្រិត្យវិន័យ* គឺពួកអ្នកដែលស្ថិតនៅក្រោមអំណាចនៃក្រិត្យវិន័យលោកម៉ូសេ (៥:១៨ រម ៦:១៤ ១កថ ៩:២០ និងការពន្យល់)។ *ទុកជាកូនចិញ្ចឹម* បញ្ជាក់ថា វិញ្ញាណនៃកូនចិញ្ចឹម គឺផ្ទុយពីវិញ្ញាណនៃបាវបម្រើ (រម ៨:១៥ អភ ១:៥ និងការពន្យល់)។ ព្រះអម្ចាស់រាប់ពួកអ្នកដែលទទួលជឿដល់ព្រះនាមទ្រង់ ថាជាកូននៅក្នុងគ្រួសាររបស់ទ្រង់យ៉ាងពិតប្រាកដ គឺទាំង សាសន៍យូដា និងសាសន៍ដទៃ ។

**៤:៦** *ព្រះវិញ្ញាណនៃព្រះរាជបុត្រាទ្រង់* គឺសំដៅលើព្រះវិញ្ញាណនៃព្រះអម្ចាស់ ឬ ព្រះវិញ្ញាណរបស់ព្រះគ្រីស្ទ (ខ.២ រម ៨:២,៩ អភ ១:១៣-១៤)។ *បន្លឺឡើង* នៅក្នុងភាសាក្រិក ពាក្យនេះសំដៅលើការបន្លឺសំឡេងយ៉ាងច្បាស់ និងភាគច្រើនសំដៅលើការទួញយំ ។ ក្នុងបទគម្ពីរ "មថ ២៧:៥០" ពាក្យនេះត្រូវបានប្រើនៅក្នុងការបន្លឺព្រះបន្ទូលជាចុងក្រោយបង្អស់របស់ព្រះយេស៊ូវនៅលើឈើឆ្កាង ។ *អ័ប្បា ព្រះវរបិតាអើយ* ឃ្លានេះសំដែងនូវទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយនឹងព្រះ ។

**៤:៨** *កាលអ្នករាល់គ្នាមិនទាន់ស្គាល់ព្រះ* (១កថ ១២:២ ១ថន ៤:៥)។ *មិនមែនជាព្រះពីកំណើតទេ* នៅពេលដែលពួកជំនុំនៅទីក្រុងកាឡាទីមិនទាន់បានស្គាល់ព្រះអម្ចាស់នៅឡើយ ពួកគេតែងតែគិតថា រូបព្រះដែល

នោះត្រូវជាប់បំរើ[ខ]ដល់អស់ទាំងរបស់ ដែលមិនមែនជា
ព្រះពីកំណើតទេ[គ] ៩តែឥឡូវនេះ លុះបានស្គាល់ព្រះហើយ
(តែស៊ូថា ព្រះបានស្គាល់អ្នករាល់គ្នាវិញជាជាង)[ឃ] នោះ
ធ្វើដូចម្តេចឱ្យអ្នករាល់គ្នាបានត្រឡប់ ទៅឯបឋមសិក្សា
ខ្សោយហើយទាបថោក ដែលអ្នករាល់គ្នាចង់ទៅជាប់បំរើ[ង]
ម្តងទៀតនោះ[ច] ១០អ្នករាល់គ្នាជាអ្នកកាន់ថ្ងៃ ខែ រដូវ និង
ឆ្នាំផ្សេងៗ[ឆ] ១១ខ្ញុំខ្លាចក្រែងខ្ញុំបានធ្វើការនឿយហត់ ក្នុងពួក
អ្នករាល់គ្នា ជាឥតប្រយោជន៍[ជ]។
១២បងប្អូនអើយ[ឈ] ខ្ញុំសូមអង្វរឱ្យអ្នករាល់គ្នាបានដូចខ្ញុំ
ដ្បិតខ្ញុំដូចអ្នករាល់គ្នាដែរ អ្នករាល់គ្នាមិនបានធ្វើអ្វីខុស
នឹងខ្ញុំទេ ១៣តែអ្នករាល់គ្នាដឹងថា ខ្ញុំបានផ្សាយដំណឹងល្អមក
អ្នករាល់គ្នាកាលពីដើម ដោយសេចក្តីកំសោយខាងសាច់
ឈាម[ញ] ១៤ហើយអ្នករាល់គ្នាមិនបានមើលងាយ ចំពោះ
សេចក្តីល្បងក្នុងសាច់ឈាមខ្ញុំ ឬចោលខ្ញុំចេញ ដោយខ្ពើម
នោះទេ គឺបានទទួលខ្ញុំទុកដូចជាទេវតានៃព្រះវិញ ហើយ
ដូចជាព្រះយេស៊ូវគ្រីស្ទផង[ដ] ១៥ដូច្នេះ សេចក្តីអំណរ ដែល
អ្នករាល់គ្នាមានកាលពីដើមនោះ តើនៅឯណា ដ្បិតខ្ញុំធ្វើ
បន្ទាល់ពីអ្នករាល់គ្នាថា កាលណោះអ្នករាល់គ្នានឹងខ្វេះ

**៤:៨** ខ ខ.៣
គ ២របា ១៣:៩ អស
៣៧:១៩ យរ ២:១១
៥:៧ ១៦:២០ ១កថ
៨:៤,៥
**៤:៩** ឃ ១កថ ៨:៣
ង ខ.៣ ច កល
២:២០
**៤:១០** ឆ រម ១៤:៥
កល ២:១៦
**៤:១១** ជ ១ថន ៣:៥
**៤:១២** ឈ រម ៧:១
កទ ៦:១៨
**៤:១៣** ញ ១កថ
២:៣
**៤:១៤** ដ មថ ១០:៤០
**៤:១៦** ឋ អម ៥:១០
**៤:១៧** ឌ កទ
២:៤,១២
**៤:១៨** ឍ ខ.១៣,១៤
**៤:១៩** ណ ១ថន
២:១១ ត រម ៨:២៩
អភ ៤:១៣

ភ្នែកចេញឱ្យមកខ្ញុំ បើសិនជាបាន ១៦ដូច្នេះ តើខ្ញុំបានត្រឡប់
ជាខ្មាំងសត្រូវនឹងអ្នករាល់គ្នាវិញ ដោយព្រោះតែនិយាយ
សេចក្តីពិតឬអី[ឋ] ១៧គេមានសេចក្តីឧស្សាហ៍ដល់អ្នករាល់គ្នា
ណាស់ តែមិនល្អទេ គឺគេចង់តែឱ្យអ្នករាល់គ្នាចោលយើង
ខ្ញុំចេញ ដើម្បីឱ្យអ្នករាល់គ្នាប្រឹងសង្វាតទៅតាមគេវិញ[ឌ]
១៨គួរឱ្យ មានសេចក្តីសង្វាត ខាងការល្អជាដរាបទៅ
មិនមែនតែក្នុង កាលដែលខ្ញុំនៅជាមួយប៉ុណ្ណោះឡើយ[ឍ]
១៩កូនចៅអើយ[ណ] ខ្ញុំលំបាកក្នុងចិត្តជាពន់ពេកដោយព្រោះ
អ្នករាល់គ្នាម្តងទៀត ទាល់តែព្រះគ្រីស្ទបានកមានរូបរាង
ក្នុងអ្នករាល់គ្នាឡើង[ត] ២០ហើយឥឡូវនេះ ខ្ញុំចង់នៅជាមួយ
នឹងអ្នករាល់គ្នា ដើម្បីឱ្យខ្ញុំបានផ្លាស់ពាក្យសំដីចេញ ដ្បិតខ្ញុំ
មានសេចក្តីសង្ស័យ ពីដំណើរអ្នករាល់គ្នាណាស់ ។

## នាងហាការ និង នាងសារ៉ា

២១អ្នករាល់គ្នា ដែលចង់នៅក្រោមបន្ទុកក្រិត្យវិន័យ
អើយ[ថ] សូមប្រាប់មកខ្ញុំ តើមិនឮសេចក្តីដែលក្រឹត្យវិន័យថា
ទេឬអី ២២ដ្បិតមានសេចក្តីចែងទុកមកថា លោកអ័ប្រាហាំ

**៤:២១** ថ រម ២:១២

ពួកគេថ្វាយបង្គំគឺជាព្រះ ។ បន្ទាប់ពីពួកគេបានស្គាល់ព្រះអម្ចាស់ហើយ ទើបពួកគេបានយល់ច្បាស់នូវសេចក្តីពិតរបស់ទ្រង់ (១កថ ៨:៥ និងពន្យល់) ។

**៤:៩** *ធ្វើដូចម្តេចឱ្យអ្នករាល់គ្នាបានត្រឡប់* (៣:១–៣ និងការពន្យល់)។ *បឋមសិក្សា ខ្សោយ ហើយទាបថោក* (ខ.៣ និងការពន្យល់)។ *ចង់ទៅជាប់បំរើម្តងទៀត* គឺបែរទៅទុកចិត្តលើជំនឿផ្សេងៗ ជឿលើការដឹងជាតិ ឬការចាប់ជាតិ ដូចកាលពួកគេមិនទាន់ស្គាល់ព្រះវិញ ។

**៤:១០** *ថ្ងៃ* អាចសំដៅលើថ្ងៃឈប់សម្រាក ឬថ្ងៃនៃការប្រោសលោះ (លវ ១៦:២៩–៣៤)។ *ខែ រដូវ* សំដៅលើបុណ្យចូលខែ (ជន ២៨:១១–១៥ អស ១:១៣–១៤) បុណ្យរំលង (នក ១២:១៨) និងបុណ្យថ្ងៃទី៥០ ឬបុណ្យចម្រូត ឬក៏បុណ្យផលដំបូង (លវ ២៣:១០)។ *ឆ្នាំផ្សេងៗ* សំដៅលើឆ្នាំឈប់សម្រាក (លវ ២៥:៤)។ ពួកផារិស៊ីតែងតែយកចិត្តទុកដាក់នឹងការទាំងអស់នេះ ក្នុងគោលបំណងចង់ទទួលមរតកនៅចំពោះព្រះអម្ចាស់ ។

**៤:១១** *ឥតប្រយោជន៍* មានន័យថា ការដែលពួកជំនុំខំប្រឹងប្រតិបត្តិតាមពួកផារិស៊ី គឺជាការឥតប្រយោជន៍ ។

**៤:១៣** *ខ្ញុំបានផ្សាយដំណឹងល្អមកអ្នករាល់គ្នាកាលពីដើម* គឺនៅពេលដែលលោកប៉ុលបានធ្វើដំណើរបេសកកម្មរបស់គាត់ មកទីក្រុងកាឡាទីជាលើកទីមួយ (កច ១៣:១៤–១៤:២៣)។

**៤:១៤** *បានទទួលខ្ញុំ* ត្រង់ចំណុចនេះបញ្ជាក់ថា ដោយព្រោះតែពួកជំនុំនៅទីក្រុងកាឡាទីបានទទួលឥទ្ធិពល និងសេចក្តីបង្រៀនរបស់ពួកគ្រូសាសនាយូដា ទើបធ្វើឱ្យពួកគេមានអាកប្បកិរិយាប្រែប្រួលចំពោះលោកប៉ុល ។ ក្រោយមកពួកគេបាន យល់នូវសេចក្តីពិត ក៏ទទួលយកសេចក្តីបង្រៀនរបស់លោកប៉ុលវិញ ។

**៤:១៥** *សេចក្តីអំណរ ដែលអ្នករាល់គ្នាមានកាលពីដើមនោះ តើនៅឯណា?* ឃ្លានេះបញ្ជាក់ថា ដោយព្រោះតែពួកគេគោរពប្រតិបត្តិតាមគ្រូសាសនាយូដា ទើបធ្វើឱ្យពួកគេបាត់បង់នូវព្រះពរ និងសេចក្តីអំណរដែលព្រះអម្ចាស់ប្រទានមកពួកគេ ។ *នឹងខ្វេះភ្នែកចេញ* នេះជាពាក្យសម្តីប្រៀបធៀប ដែលលោកប៉ុលមានប្រសាសន៍ទៅកាន់ពួកជំនុំនៅទីក្រុងកាឡាទី ដើម្បីឱ្យពួកគេបង្ហាញនូវការស្ម័គ្រចិត្ត ទទួលយកនូវសេចក្តីល្អ និងមានតម្លៃពិតប្រាកដសម្រាប់ខ្លួន ។

**៤:១៦** *ខ្មាំងសត្រូវនឹងអ្នករាល់គ្នា* ឃ្លានេះបញ្ជាក់ថា ពេលខ្លះការប្រកាសប្រាប់ដំណឹងល្អនៃសេចក្តីពិត ធ្វើឱ្យមនុស្សមិនសប្បាយចិត្តទេ ហើយអាចរហូតដល់បាត់បង់មិត្តភក្តិទៀតផង ។ *សេចក្តីពិត* គឺដំណឹងល្អអំពីព្រះគុណនៅក្នុងព្រះយេស៊ូវ ។

**៤:១៧** *គេមានសេចក្តីឧស្សាហ៍* សំដៅលើពួកគ្រូសាសនាយូដា (២:៤,១២)។

**៤:១៩** *កូនចៅអើយ* នេះជាពាក្យដែលលោកប៉ុលប្រើ ចំពោះពួកអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទតាមរយៈគាត់ (កច ២០:៣៧–៣៨ ភល ៤:១ ១ថន ២:៧–៨)។លោកយ៉ូហានច្រើនប្រើពាក្យនេះជាញឹកញាប់នៅក្នុងសំបុត្ររបស់គាត់ (យហ ១៣:៣៣ ១យហ ២:១ ៣:៧)។ *ទាល់តែព្រះគ្រីស្ទបានកមានរូបរាងក្នុងអ្នករាល់គ្នាឡើង* ឃ្លានេះគឺជាគោលបំណងដ៏សំខាន់របស់លោកប៉ុលនៅក្នុងបេសកកម្មរបស់គាត់ក្នុងការបម្រើព្រះអម្ចាស់ (រម ៨:២៩ អភ ៤:១៣,១៥ កល ១:២៧)។

**៤:២១** *ក្រោមបន្ទុកក្រិត្យវិន័យ* "មើលការពន្យល់ ខ.៥"។

**៤:២២** *លោកអ័ប្រាហាំមានកូន២* គឺអ៊ីសម៉ាអែល ជាកូនរបស់លោកអ័ប្រាហាំ និងបាវស្រីសាសន៍អេស៊ីព្ទឈ្មោះហាការ (លប ១៦:១–១៦)។

មានកូន ២ មួយកើតពីបាវស្រី[ទ] ហើយមួយពីស្រីអ្នកជា[ធ]
២៣ តែកូនដែលកើតពីបាវស្រី នោះបានកើតតាមសាច់ឈាម[ន]
ហើយ១ដែលកើតពីអ្នកជា បានកើតតាមសេចក្ដីសន្យាវិញ[ប]
២៤ នោះជាសេចក្ដីប្រៀបធៀប គឺស្ត្រីទាំង ២ នេះជាគំរូ
ពីសេចក្ដីសញ្ញា ២ ច្បាប់ មួយមកពីភ្នំស៊ីណាយ ក៏បង្កើត
សភាពជាបាវបំរើ នោះគឺជានាងហាការ ២៥ ដ្បិតនាង
ហាការទុកដូចជាភ្នំស៊ីណាយ នៅស្រុកអារ៉ាប់ ហើយក៏ត្រូវ
នឹងក្រុងយេរូសាឡិមសព្វថ្ងៃនេះ ជាក្រុងដែលជាប់បំរើ
ជាមួយនឹងកូនចៅផង ២៦ តែក្រុងយេរូសាឡិម ដែលនៅ
ស្ថានលើ[ផ] នោះជាស្រីអ្នកជាវិញ ដែលជាម្ដាយយើងទាំង
អស់គ្នា ២៧ ដ្បិតមានសេចក្ដីចែងទុកមកថា «ឱនាងអារ ដែល
មិនបង្កើតកូនអើយ ចូរអរសប្បាយឡើង ឱនាងដែលមិន
បានឈឺនឹងសំរាលអើយ ចូធ្លាយសំរែកឡើងចុះ ពីព្រោះ
កូនរបស់នាងដែលគ្មានគូ នោះច្រើនជាងកូននៃនាងដែល
មានប្ដីទៅហើយ»[ព] ២៨ តែបងប្អូនអើយ យើងរាល់គ្នាជា
កូនតាមសេចក្ដីសន្យា ដូចជាលោកអ៊ីសាកដែរ[ភ] ២៩ តែ
ឥឡូវនេះ ក៏ដូចជាកាលពីដើមដ្បិតកូនដែលកើតតាមសាច់
ឈាម[ម] បានធ្វើទុក្ខដល់កូនដែលកើតតាមព្រះវិញ្ញាណវិញ[យ]
៣០ តែគម្ពីរថាដូចម្ដេច គឺថា «ចូរដេញបាវស្រីនឹងកូនវាចេញ
ដ្បិតកូនរបស់បាវស្រី មិនត្រូវគ្រងមរដក ជាមួយនឹងកូន
របស់ស្រីអ្នកជាឡើយ»[រ] ៣១ ដូច្នេះ បងប្អូនអើយ យើងរាល់
គ្នាមិនមែនជាកូនរបស់បាវស្រីទេ[ល] គឺជាកូនរបស់ស្រីអ្នក
ជាវិញ[វ]។

**៤:២២** ទ លប ១៦:១៥ ធ លប ២១:២
**៤:២៣** ន ខ.២៨,២៩ រម ៩:៧,៨ ប លប ១៧:១៦-២១ ១៨:១០-១៤ ២១:១ ហេ ១១:១១
**៤:២៦** ផ ហេ ១២:២២ វវ ៣:១២ ២១:២,១០
**៤:២៧** ព អស ៥៤:១
**៤:២៨** ភ ខ.២៣ កទ ៣:១៦
**៤:២៩** ម ខ.២៣ យ លប ២១:៩
**៤:៣០** រ លប ២១:១០
**៤:៣១** ល រម ៧:៤ វ ខ.២២
**៥:១** ស ខ.១៣ យហ ៨:៣២ រម ៧:៤

## សេរីភាពនៅក្នុងព្រះគ្រីស្ទ

៥ ១ ព្រះគ្រីស្ទបានប្រោសយើងឱ្យរួចហើយ[ស] ដូច្នេះ ចូរអ្នក
រាល់គ្នាឈរឱ្យមាំមួន[ហ] ក្នុងសេរីភាពនោះចុះ កុំឱ្យត្រូវជាប់
ចំណងជាបាវបំរើទៀតឡើយ[ឡ] ២ នែ ប៉ុលខ្ញុំប្រាប់អ្នករាល់
គ្នាថា បើអ្នករាល់គ្នាទទួលកាត់ស្បែក[អ] នោះព្រះគ្រីស្ទគ្មាន
ប្រយោជន៍ដល់អ្នករាល់គ្នាសោះ ៣ ហើយខ្ញុំធ្វើបន្ទាល់ម្ដង
ទៀត ដល់អស់មនុស្សដែលកាត់ស្បែកហើយថា អ្នកនោះ
ឯងជាអ្នកជំពាក់ក្រិត្យវិន័យ នឹងត្រូវធ្វើតាមគ្រប់ជំពូក[ក]
៤ អ្នករាល់គ្នាណាដែលពឹងដល់ក្រិត្យវិន័យ ឱ្យបានរាប់ជា
សុចរិត[ខ] នោះត្រូវកាត់ចេញពីព្រះគ្រីស្ទ អ្នកបានធ្លាក់ចេញ

ហ ១កថ ១៦:១៣ ឡ មថ ២៣:៤ កទ ២:៤ **៥:២** អ ខ.៣,៦,១១,១២ កច ១៥:១ **៥:៣** ក រម ២:២៥ កទ ៣:១០ យក ២:១០ **៥:៤** ខ រម ៣:២៨

កូនម្នាក់ទៀតគឺ លោកអ៊ីសាកជាកូនគាត់ និងនាងសារ៉ា (លប ២១:២-៥)។

**៤:២៣** *សេចក្ដីសន្យា* "លប ១៧:១៩ ១៨:១០-១៥ រម ៩:៦-៩ និងការពន្យល់"។

**៤:២៤** *សេចក្ដីប្រៀបធៀប* លោកប៉ុលលើកយកស្ត្រី២នាក់គឺ សារ៉ា និង ហាការ មកប្រៀបធៀប ដើម្បីធ្វើការពន្យល់ដល់ពួកជំនុំនៅទីក្រុងកាឡាទី។ នៅក្នុងការប្រៀបធៀបនោះគឺ សារ៉ាតំណាងឱ្យព្រះគុណ ហើយហាការគឺតំណាងឱ្យក្រិត្យវិន័យ (នក ៣១:១៨)។ *សេចក្ដីសញ្ញា* (៣:១៥ និងការពន្យល់)។ *ភ្នំស៊ីណាយ* គឺជាកន្លែងដែលព្រះអម្ចាស់ប្រទាននូវក្រិត្យវិន័យមក ដើម្បីដឹកនាំពួកអ៊ីស្រាអែល (នក ១៩:២ ២០:១-១៧)។

**៤:២៦** *ក្រុងយេរូសាឡិម ដែលនៅស្ថានលើ* ក្រុងយេរូសាឡិមត្រង់ចំណុចនេះគឺសំដៅលើស្ថានសួគ៌ (វវ ២១:២) ដែលមានព្រះគ្រីស្ទសោយរាជ្យ ហើយមានគ្រីស្ទបរិស័ទជារាស្ត្ររបស់ទ្រង់ (ខ.២៥)។ *ម្ដាយយើង* មានន័យថា រាស្ត្រនៅស្ថានសួគ៌ គឺជាកូនរបស់សារ៉ាដែលជាស្រីអ្នកជា។

**៤:២៧** សេចក្ដីនៅក្នុងបទគម្ពីរនេះ លោកប៉ុលបានដកស្រង់ចេញពីបទគម្ពីរ "អស ៥៤:១"ដែលជាសេចក្ដីសន្យា ទាក់ទងនឹងការប្រែចិត្តរបស់ពួកសាសន៍ដទៃ ដែលមានចំនួនកើនឡើងជាលំដាប់ ដោយសារតែដំណឹងល្អនៃព្រះ។

**៤:២៨** *កូនតាមសេចក្ដីសន្យា* គឺជាកូនដែលកើតមកតាមសេចក្ដីសន្យារបស់ព្រះអម្ចាស់ (៣:២៩ រម ៩:៨)។

**៤:២៩** *ឥឡូវនេះ ក៏ដូចជាកាលពីដើម* "កច ១៣:៥០ ១៤:២-៥,១៩ ១ថស ២:១៤-១៦"។ *ដ្បិតកូនដែលកើតតាមសាច់ឈាម បានធ្វើទុក្ខដល់កូនដែលកើត តាមព្រះវិញ្ញាណ* "លប ២១:៩ ទដ ៨៣:៥-៦"។

**៤:៣០** *ចូរដេញបាវស្រី និងកូនវាចេញ* លោកប៉ុលបានលើកយកបទគម្ពីរ "លប ២១:១០" ដើម្បីធ្វើជាសេចក្ដីបង្រៀនដល់ពួកជំនុំ នៅទីក្រុងកាឡាទី និងក្នុងគោល បំណងឱ្យពួកគេបណ្ដេញពួកគ្រូសាសនាយូដាចេញពីពួកជំនុំ។

**៤:៣១** *យើងរាល់គ្នាមិនមែនជាកូនរបស់បាវស្រីទេ* មានន័យថា ពួកអ្នកជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ គឺលែងជាបាវបម្រើអំពើបាប និងក្រិត្យវិន័យទៀតហើយ ប៉ុន្តែ គឺជាកូននៃសេចក្ដីសន្យា ហើយរស់ដោយសេចក្ដីជំនឿវិញ (៣:៧,២៩)។

**៥:១** *សេរីភាព* គឺសេរីភាពចេញពីបន្ទុករបស់ក្រិត្យវិន័យ។ *កុំឱ្យត្រូវជាប់ចំណង ជាបាវបំរើទៀតឡើយ* សំដៅលើការដែលខំប្រឹងធ្វើតាមបញ្ញត្តិរបស់ក្រិត្យវិន័យ ក្នុងគោលបំណងដើម្បីឱ្យបានសេចក្ដីមេត្តារបស់ព្រះអម្ចាស់ (មថ ១១:២៨-៣០ និងការពន្យល់)។ ការទាំងនេះ គឺជាចំណងសម្រាប់មនុស្សដែលពេញដោយអំពើបាប (កច ១៥:១០-១១)។

**៥:២** លោកប៉ុលបញ្ជាក់យ៉ាងច្បាស់ថា ការកាត់ស្បែកគឺជាការរាំងស្ទះដល់ការរីកចម្រើននៃជីវិតរបស់គ្រីស្ទបរិស័ទនៅក្នុងព្រះគ្រីស្ទ។

**៥:៣** *ត្រូវធ្វើតាមគ្រប់ជំពូក* មានន័យថា បើអស់អ្នកណាប្រកាសថា ខ្លួនកាន់តាមក្រិត្យវិន័យ នោះគឺត្រូវតែកាន់តាមគ្រប់សេចក្ដីទាំងអស់ មិនអាចបោះបង់ចោលនូវចំណុចណាមួយឡើយ ទោះជាចំណុចដ៏តូចក៏ដោយ (យស ២:១០ និងការពន្យល់)។

**៥:៤** *បានធ្លាក់ចេញពីព្រះគុណហើយ* មានន័យថា បើអ្នកណាម្នាក់ព្យាយាមស្វែងរកសេចក្ដីមេត្តាករុណារបស់ព្រះអម្ចាស់ តាមរយៈការកាន់តាមក្រិត្យវិន័យនោះ គេកំពុងតែផ្ដាច់ខ្លួនចេញពីព្រះគុណរបស់ទ្រង់ហើយ។ ព្រះគុណរបស់ព្រះអម្ចាស់ ពុំមែនបានមកដោយការគោរពប្រតិបត្តិតាមក្រិត្យវិន័យនោះទេ (២:២ ៣:៣ និងការពន្យល់)។

ពីព្រះគុណហើយ[គ] ៥ដ្បិតយើង រាល់គ្នាអាងសេចក្តីជំនឿ
ដើម្បីនឹងរង់ចាំដោយនូវព្រះវិញ្ញាណ ឱ្យបានសេចក្តីសុច
រិតដែលយើងសង្ឃឹមចង់បាននោះ[ឃ] ៦ពីព្រោះក្នុងព្រះគ្រីស្ទ
យេស៊ូវ[ង] ដែលកាត់ស្បែកឬមិនកាត់ នោះមិនជាប្រយោជន៍
អ្វីទេ[ច] មានប្រយោជន៍តែសេចក្តីជំនឿ ដែលប្រព្រឹត្តដោយ
សេចក្តីស្រឡាញ់ប៉ុណ្ណោះ[ឆ] ៧អ្នករាល់គ្នាបានរត់យ៉ាងល្អហើយ[ជ]
តើអ្នកណាបានឃាត់[ឈ]មិនឱ្យស្តាប់តាមសេចក្តីពិតវិញ
៨ការបញ្ចុះបញ្ចូលនេះមិនមែនមកពីព្រះ ដែលទ្រង់ហៅ
អ្នករាល់គ្នាទេ[ញ] ៩ដំបែតែបន្តិច អាចធ្វើឱ្យម្សៅទាំងអស់
ដោរឡើងបាន[ដ] ១០ខ្ញុំទុកចិត្ត[ឋ]នឹងអ្នករាល់គ្នា ដោយនូវព្រះ
អម្ចាស់ថា អ្នករាល់គ្នានឹងគ្មានគំនិតណាផ្សេងទៀតឡើយ[ឌ]
តែអ្នកដែលបំភាន់អ្នករាល់គ្នា[ឍ] នោះនឹងត្រូវទោសវិញ
ទោះបើជាអ្នកណាក៏ដោយ ១១ប៉ុន្តែ បងប្អូនអើយបើសិន
ជាខ្ញុំនៅតែប្រដៅឱ្យគេកាត់ស្បែក នោះតើហេតុអ្វីបានជា
គេនៅតែបៀតបៀនដល់ខ្ញុំទៀត[ណ] បើប្រដៅដូច្នោះនោះ
សេចក្តីបង្អាក់បង្អន់[ត] ពីរឿងឈើឆ្កាង ត្រូវបាត់ហើយ
១២បើពួកអ្នកដែលបំភាន់អ្នករាល់ គ្នា[ថ] បានកាត់ខ្លួនគេចោល
ចេញ នោះខ្ញុំចូលចិត្តណាស់ ។
១៣បងប្អូនអើយ ព្រះទ្រង់បានហៅអ្នករាល់គ្នាមក ឱ្យ
មានសេរីភាព[ទ] តែកុំឱ្យប្រើសេរីនោះ ទុកជាឱកាសដល់
សាច់ឈាមឡើយ[ធ] គឺត្រូវឱ្យបំរើគ្នាទៅវិញទៅមក[ន] ដោយ
សេចក្តីស្រឡាញ់វិញ ១៤ដ្បិតក្រិត្យវិន័យទាំងមូល បាន
សំរេចមកក្នុងពាក្យតែ១ម៉ាត់នេះថា «ចូរឯងស្រឡាញ់
អ្នកជិតខាង ដូចខ្លួនឯង»[ប] ១៥បើអ្នករាល់គ្នាចេះតែប្រខាំ
ហើយហែកគ្នាស៊ីទៅវិញទៅមក នោះត្រូវប្រយ័ត្នចុះ ក្រែង
លោវិនាសអស់រលីងទៅ ។

## ការដើរក្នុងព្រះវិញ្ញាណ និងការដើរដោយសាច់ឈាម

១៦តែខ្ញុំប្រាប់ថា ចូរដើរក្នុងព្រះវិញ្ញាណ[ផ] នោះអ្នករាល់
គ្នានឹងមិនបំពេញសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាមទេ[ព]
១៧ដ្បិតសាច់ឈាមតែងតែប៉ងប្រាថ្នាទាស់នឹងព្រះវិញ្ញាណ
ឯព្រះវិញ្ញាណទ្រង់ក៏ទាស់នឹងសាច់ឈាមដែរ[ភ] សេចក្តីទាំង២

**៥:៤** គ ហព ១២:១៥ ២ពត ៣:១៧
**៥:៥** ឃ រម ៨:២៣,២៤
**៥:៦** ង រម ១៦:៣ ច ១កថ ៧:១៩ ឆ ១ថន ១:៣ យក ២:២២
**៥:៧** ជ ១កថ ៩:២៤ ឈ កទ ៣:១
**៥:៨** ញ រម ៨:២៨
**៥:៩** ដ ១កថ ៥:៦
**៥:១០** ឋ ២កថ ២:៣ ឌ ភល ៣:១៥ ឍ ខ.១២ កទ ១:៧
**៥:១១** ណ កទ ៤:២៩ ៦:១២ ត លក ២:៣៤
**៥:១២** ថ ខ.១០
**៥:១៣** ទ ខ.១ ធ ខ.២៤ ១កថ ៨:៩ ១ពត ២:១៦ ន ១កថ ៩:១៩ ២កថ ៤:៥ អភ ៥:២១
**៥:១៤** ប លវ ១៩:១៨ មថ ៥:៤៣ កទ ៦:២ **៥:១៦** ផ ខ.១៨,២៥ រម ៨:២,៤–៦,៩,១៤ ២កថ ៥:១៧ ព ខ.២៤ **៥:១៧** ភ រម ៨:៥–៨

**៥:៥** *សេចក្តីសុចរិត ដែលយើងសង្ឃឹមចង់បាន* នេះជាព្រះហឫទ័យព្រះអម្ចាស់ ក្នុងការធានាដល់ពួកអ្នកជឿលើព្រះនាមទ្រង់ថា ពួកគេត្រូវបានរាប់ជាសុចរិត និងបានញែកជាបរិសុទ្ធ គឺដោយសារព្រះរាជកិច្ចនៃព្រះវិញ្ញាណបរិសុទ្ធ ។

**៥:៦** *ដែលកាត់ស្បែកឬមិនកាត់ នោះមិនជាប្រយោជន៍អ្វីទេ* (ខ.២ ២:២១ ៦:១៥ ១កថ ៧:១៩)។ *សេចក្តីជំនឿ ដែលប្រព្រឹត្តដោយសេចក្តីស្រឡាញ់ប៉ុណ្ណោះ* សេចក្តីជំនឿមិនមែនគ្រាន់តែជាការយល់ព្រមនៅក្នុងគំនិតនោះទេ (យក ២:១៨–១៩) ប៉ុន្តែ គឺជាជីវិតដែលទុកចិត្តក្នុងព្រះគុណ និងសំដែងចេញដោយការប្រព្រឹត្តិដោយសេចក្តីស្រឡាញ់វិញ (១ថន ១:៣)។

**៥:៧** *បានរត់យ៉ាងល្អ* លោកប៉ុលបានពណ៌នាអំពីជីវិតរបស់គ្រីស្ទបរិស័ទដូចជាការរត់ប្រណាំងដូច្នោះដែរ (២:២ ភល ២:១៦ ២ធថ ៤:៧ ១កថ ៩:២៤–២៧ និងការពន្យល់)។

**៥:៨** *ការបញ្ចុះបញ្ចូល* សំដៅលើការបញ្ចុះបញ្ចូលដែលកើតឡើងពីសំណាក់ពួកអ្នកកាន់សាសនាយូដា ។

**៥:៩** បទគម្ពីរនេះសង្កត់ធ្ងន់លើផលអាក្រក់ ដែលកើតឡើងដោយពួកអ្នកកាន់សាសនាយូដា ។ នៅក្នុងព្រះគម្ពីរ ពាក្យថា "ដំបែ" ត្រូវបានប្រើដើម្បីបញ្ជាក់អំពីការអាក្រក់ ឬឥទ្ធិពលដ៏អាក្រក់ផ្សេងៗដែលបណ្តាលមកពីសេចក្តីបង្រៀនខុសឆ្គងទាំងឡាយ (មក ៨:១៥ មថ ១៣:៣៣ និងការពន្យល់)។

**៥:១១** *បងប្អូន* "មើលការពន្យល់ ១:២"។ *តើហេតុអ្វីបានជាគេ នៅតែបៀតបៀនដល់ខ្ញុំទៀត?* ដោយព្រោះតែសេចក្តីអំនួត ធ្វើឱ្យមនុស្សយល់ថាគេអាចធ្វើអ្វីម្យ៉ាង ដើម្បីបានទទួលការសង្គ្រោះ ។ ក្នុងសេចក្តីបង្រៀនរបស់លោកប៉ុលពុំបាននិយាយថា ការញែកជាបរិសុទ្ធបានមកដោយសារការកាត់ស្បែក និងការគោរពប្រតិបត្តិតាមក្រិត្យវិន័យទេ ប៉ុន្តែ គាត់តែងតែបញ្ជាក់យ៉ាងច្បាស់ថា ការនេះកើតឡើងដោយសារព្រះគុណរបស់ព្រះយេស៊ូវគ្រីស្ទ គឺក្នុងគ្រាដែលទ្រង់សុគតនៅលើឈើឆ្កាងវិញ ។ ម្យ៉ាងទៀត ដោយព្រោះតែគាត់បង្រៀនយ៉ាងដូច្នេះ ទើបធ្វើឱ្យពួកអ្នកកាន់សាសនាយូដាប្រឆាំងនឹងគាត់យ៉ាងខ្លាំង (រម ៩:៣២–៣៣ ១កថ ១:២៣ និងការពន្យល់)។

**៥:១២** លោកប៉ុលប្រើពាក្យសម្តីធ្ងន់ៗ ចំពោះពួកគ្រូខុសឆ្គង ដែលតែងតែនាំពួកជំនុំនៅទីក្រុងកាឡាទីឱ្យធ្វើតាមខ្លួន ដោយពួកគេនិយាយថា ដើម្បីបានសង្គ្រោះ គឺត្រូវតែកាត់ស្បែក ។ ដូច្នេះហើយបានជាលោកប៉ុលមានប្រសាសន៍ថា បើពួកគ្រូខុសឆ្គងទាំងនោះប្រកាសឱ្យគេកាត់ស្បែកទៀត នោះចូរឱ្យពួកគេក្រៀវខ្លួនគេតែម្តងទៅ (ភល ៣:២)។

**៥:១៣** បទគម្ពីរនេះបញ្ជាក់ថា គ្រីស្ទបរិស័ទពិតប្រាកដ មិនប្រើសេរីភាពរបស់ខ្លួន ដើម្បីបម្រើអំពើបាប និងនៅក្នុងផ្លូវអាក្រក់ទេ ប៉ុន្តែ គឺប្រើនៅក្នុងការបម្រើព្រះអម្ចាស់ ហើយនិងអ្នកដទៃដោយសេចក្តីស្រឡាញ់វិញ (១ពត ២:១៦ និងការពន្យល់)។

**៥:១៤** *ក្រិត្យវិន័យទាំងមូល* នៅក្នុងក្រឹត្យវិន័យ និងទំនាយរបស់ពួកហោរាបានចែងថា "អស់ទាំងការអ្វីដែលអ្នករាល់គ្នាចង់ឱ្យមនុស្សលោក ប្រព្រឹត្តនឹងខ្លួន នោះត្រូវឱ្យអ្នកប្រព្រឹត្តនឹងគេដូច្នោះដែរ" (មថ ៧:១២ មក ១២:៣១)។

**៥:១៥** *ប្រខាំ ហើយហែកគ្នាស៊ីទៅវិញទៅមក* ឃ្លានេះនិយាយសំដៅលើពួកអ្នកដែលចង់បានឋានៈនៅក្នុងព្រះអម្ចាស់និងក្នុងចំណោមមនុស្ស តាមរយៈការប្រតិបត្តិតាមក្រិត្យវិន័យ ដោយបានបង្កើតនូវការតម្កើងខ្លួន និងវិញ្ញាណនៃការរិះគន់ ។

**៥:១៦** *ចូរដើរក្នុងព្រះវិញ្ញាណ* សំដៅលើការរស់នៅមានការដឹកនាំនិងដោយអំណាចព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។ ការរស់នៅយ៉ាងដូច្នេះ នាំឱ្យជីវិតបានឈ្នះលើបំណងប្រាថ្នានៃអំពើបាប (ខ.២៥ រម ៨:២–៤ និងការពន្យល់)។

**៥:១៧** *សេចក្តីទាំង២នេះប្រឆាំងនឹងគ្នា* (សូមប្រៀបធៀប រម ៧:១៣–២៥

នេះប្រឆាំងនឹងគ្នា ដល់ម្ល៉េះបានជាអ្នករាល់គ្នារកធ្វើការ ដែល
ចង់ធ្វើទៅមិនកើត[ម] ១៨ បើព្រះវិញ្ញាណ[យ] ទ្រង់នាំអ្នករាល់គ្នា
វិញ នោះអ្នករាល់គ្នាមិននៅក្រោមបន្ទុកក្រិត្យវិន័យទៀត
ទេ[រ] ១៩ រីឯកិច្ចការខាងសាច់ឈាម នោះប្រាកដច្បាស់ហើយ
គឺជាសេចក្ដីកំផិត សហាយស្មន់[ល] ស្មោកគ្រោក អាសអាភាស
២០ ថ្វាយបង្គំរូបព្រះ មន្តអាគមសំអប់គ្នា ឈ្មោះប្រកែក
ឈ្នានីស កំហឹង ទាស់ទែងគ្នា បាក់បែក បក្សពួក
២១ ច្រណែន កាប់សំឡាប់ប្រមឹក ស៊ីផឹកជ្រុល និងការអ្វីទៀត
ដែលស្រដៀងនឹងសេចក្ដីទាំងនេះផង[វ] ហើយខ្ញុំប្រាប់អ្នក
រាល់គ្នាទុកជាមុនដូចជាបានប្រាប់រួចមកហើយថា អស់អ្នក
ដែលប្រព្រឹត្តដូច្នេះ នោះមិនបានគ្រងនគរព្រះ ទុកជាមរ
ដកឡើយ[ស] ២២ តែឯផលផ្លែ[ហ]នៃព្រះវិញ្ញាណវិញ នោះគឺ
សេចក្ដីស្រឡាញ់[ឡ] អំណរអរ មេត្រីភាព[អ] អត់ធ្មត់ សុភាព
សប្បុរស ស្មោះត្រង់ ២៣ ស្លូតបូត ហើយដឹងខ្នាត[ក] គ្មាន
ក្រិត្យវិន័យណាទាស់នឹងសេចក្ដីយ៉ាងនោះទេ[ខ] ២៤ ហើយអស់
អ្នកដែលជារបស់ផងព្រះគ្រីស្ទ នោះបានឆ្កាងសាច់ឈាម
ហើយ[គ] ព្រមទាំងសេចក្ដីរំជួល នឹងសេចក្ដីប៉ងប្រាថ្នា
ទាំងប៉ុន្មានផង[ឃ] ២៥ បើសិនជាយើងរស់ដោយនូវព្រះ
វិញ្ញាណ[ង] នោះត្រូវដើរដោយព្រះវិញ្ញាណដែរ ២៦ កុំឱ្យ
យើងរាល់គ្នារកកេរ្តិ៍ឈ្មោះដែលឥតប្រយោជន៍[ច] ទាំងចាក់
រុក ហើយឈ្នានីសគ្នាទៅវិញទៅមកឡើយ ។

**៥:១៧** ម រម ៧:១៥–២៣ **៥:១៨** យ ខ.១៦ រ រម ២:១២ ១ធថ ១:៩ **៥:១៩** ល ១កថ ៦:១៨ **៥:២១** វ មថ ១៥:១៩ រម ១៣:១៣ ស មថ ២៥:៣៤ **៥:២២** ហ មថ ៧:១៦–២០ អភ ៥:៩ ឡ កល ៣:១២–១៥ អ មឡ ២:៦ **៥:២៣** ក កច ២៤:២៥ ខ ខ.១៨ **៥:២៤** គ ខ.១៣ ១៦–២១ រម ៦:៦ ៧:៥,១៨ ៨:៣–៥, ៨,៩,១២,១៣ ១៣:១៤ កទ ៦:៨ កល ២:១១ ឃ ខ.១៦,១៧ **៥:២៥** ង ខ.១៦ **៥:២៦** ច ភល ២:៣ **៦:១** ឆ ១កថ ២:១៥ ៣:១ ជ មថ ១៨:១៥ ២កថ ២:៧

## ការធ្វើល្អចំពោះមនុស្សទាំងអស់

**៦** ១ ឱបងប្អូនអើយ បើបានទាន់ឃើញមនុស្សណាធ្វើខុសអ្វី
នោះអ្នករាល់គ្នាដែលដើរដោយព្រះវិញ្ញាណ[ឆ] ចូរដំរង់
អ្នកនោះ[ជ]ដោយចិត្តសុភាព ព្រមទាំងប្រយ័ត្នខ្លួនឯងផង
ក្រែងត្រូវសេចក្ដីល្បួងដែរ ២ ចូរយកអាសាគ្នាទៅវិញទៅ
មក យ៉ាងនោះទើបបានសំរេចតាមក្រិត្យវិន័យនៃព្រះ
គ្រីស្ទ[ឈ] ៣ ដ្បិតបើអ្នកណាគិតស្មានថាខ្លួនជាអ្វី ៗ[ញ] តែមិនជា
អ្វីសោះ អ្នកនោះឈ្មោះថាបញ្ឆោតខ្លួនឯងហើយ[ដ] ៤ ចូរឱ្យ
គ្រប់គ្នាល្បងលការ ដែលធ្វើរៀង ៗ ខ្លួន នោះនឹងមាន
សេចក្ដីអំនួតចំពោះតែខ្លួនឯង[ឋ] មិនមែនចំពោះអ្នកណា
ទៀតទេ[ឌ] ៥ ដ្បិតគ្រប់គ្នាត្រូវទទួលបន្ទុកជារបស់ខ្លួន[ឍ] ៦ អ្នក
ណាដែលមានគ្រូបង្រៀនខាងព្រះបន្ទូល នោះត្រូវចែកគ្រប់
ទាំងរបស់ល្អឱ្យដល់គ្រូនោះផង[ណ] ៧ កុំឱ្យច្រឡំឡើយ[ត] នឹង
បញ្ឆោតព្រះមិនបានទេ ដ្បិតពូជណាដែលមនុស្សព្រោះចុះ
នោះនឹងច្រូតបានពូជនោះឯងវិញ[ថ] ៨ អ្នកណាដែលព្រោះ
ខាងសាច់ឈាមរបស់ខ្លួន[ទ] នឹងច្រូតបានសេចក្ដីពុករលួយ

**៦:២** ឈ ១កថ ៩:២១ យក ២:៨ **៦:៣** ញ រម ១២:៣ ១កថ ៨:២ ដ ១កថ ៣:១៨ **៦:៤** ឋ ២កថ ១៣:៥ ឌ ២កថ ១០:១២ **៦:៥** ឍ ខ.២ យរ ៣១:៣០ **៦:៦** ណ ១កថ ៩:១១,១៤ ១ធថ ៥:១៧,១៨ **៦:៧** ត ១កថ ៦:៩ ថ សភ ២២:៨ យរ ៣៤:១៧ ហស ១០:១២,១៣ ២កថ ៩:៦ **៦:៨** ទ កទ ៥:២៤

១ពត ២:១១ និងមើលការពន្យល់)។

**៥:១៨** *ព្រះវិញ្ញាណទ្រង់នាំអ្នករាល់គ្នា* (សូមមើល រម ៨:១៤)។ *មិននៅក្រោមបន្ទុកក្រិត្យវិន័យ* គឺមិននៅក្រោមការព្យាយាមរកសេចក្ដីមេត្តាករុណារបស់ព្រះអម្ចាស់ ការសង្គ្រោះ និងការញែកជាបរិសុទ្ធ ដោយការខំប្រឹងប្រព្រឹត្តតាមក្រិត្យវិន័យទេ (រម ៦:១៤ និងការពន្យល់)។

**៥:១៩–២១** "មើលការពន្យល់ រម ១:២៩–៣១"។

**៥:២២–២៣** ត្រង់ចំណុចនេះបញ្ជាក់ថា អាកប្បកិរិយារបស់គ្រីស្ទបរិស័ទត្រូវបានបង្កើតឡើងដោយព្រះវិញ្ញាណ មិនមែនដោយការហ្វឹកហាត់ផ្នែកសីលធម៌ ដោយប្រតិបត្តិតាមក្រឹត្យវិន័យនោះទេ ។ លោកប៉ុលមានប្រសាសន៍យ៉ាងច្បាស់ថា ការញែកជាបរិសុទ្ធ គឺកើតឡើងដោយសារសេចក្ដីជំនឿ នៅក្នុងព្រះយេស៊ូវគ្រីស្ទ មិនមែនកើតឡើងដោយការប្រព្រឹត្តរបស់មនុស្សទេ ។ ព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងអ្នកជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ និងបង្កើតផលផ្លែខាងឯវិញ្ញាណនៅក្នុងជីវិតរបស់ពួកគេ (២កថ ៦:៦–១០ អភ ៤:២ ៥:៩ កល ៣:១២–១៥)។

**៥:២៣** *គ្មានក្រិត្យវិន័យណាទាស់នឹងសេចក្ដីយ៉ាងនោះទេ* "សូមមើល ១ធថ ១:៩"។

**៥:២៤** *បានឆ្កាងសាច់ឈាមហើយ* "សូមមើល ២:២០ ៦:១៤"។

**៦:១** *អ្នករាល់គ្នាដែលដើរដោយព្រះវិញ្ញាណ* គឺផ្ទុយនឹងសេចក្ដីដែលបានចែងនៅក្នុងបទគម្ពីរ "១កថ ៣:១–៣"។ *ចូរដំរង់* ត្រង់ចំណុចនេះបញ្ជាក់ថា អស់អ្នកដែលដើរដោយព្រះវិញ្ញាណ គឺត្រូវមាននាទីជួយដល់ពួកបងប្អូនរួមជំនឿឱ្យបានចម្រើនឡើង ។ ហើយនៅពេលឃើញបងប្អូនណាម្នាក់ធ្វើបាបនោះត្រូវកែតម្រង់គេដោយសេចក្ដីស្រឡាញ់ (មើលការពន្យល់ ១កថ ១:១០ ២កថ ១៣:៩)។

**៦:២** *ចូរយកអាសាគ្នាទៅវិញទៅមក* គឺជួយគ្នាទៅវិញទៅមកទាំងផ្នែកសម្ភារៈ និងផ្នែកសីលធម៌ (ខ.១ រម ១៥:១–៣)។ *ក្រិត្យវិន័យនៃព្រះគ្រីស្ទ* (មើលការពន្យល់ ១កថ ៩:២១)។

**៦:៤** *ចូរឱ្យគ្រប់គ្នាល្បងលការ ដែលធ្វើរៀងៗខ្លួន* គឺសំដៅលើការទទួលខុសត្រូវរបស់អ្នកជឿគ្រប់ៗគ្នា (សូមមើល ១កថ ១១:២៨ ២កថ ១៣:៥)។

**៦:៥** បទគម្ពីរនេះបញ្ជាក់អំពីភាពទទួលខុសត្រូវ របស់អ្នកជឿដល់ព្រះអម្ចាស់នៅចំពោះទ្រង់ ។ ម្យ៉ាងទៀត អាចសំដៅលើការជំនុំជម្រះ នៅពេលដែលព្រះគ្រីស្ទយាងមកជាលើកទីពីរ ជាពេលដែលគ្រប់ការទាំងអស់ នឹងសំដែងឱ្យឃើញនៅចំពោះទ្រង់ (ខ.៤ រម ១៤:១០,១២ ២កថ ៥:១០ និងពន្យល់)។

**៦:៦** *ត្រូវចែកគ្រប់ទាំងរបស់ល្អឱ្យដល់គ្រូ* "មើលការពន្យល់ ភល ៤:១៤–១៩ ១ធថ ៥:១៧"។

**៦:៧** *ពូជណាដែលមនុស្សព្រោះចុះ នោះនឹងច្រូតបានពូជនោះឯងវិញ* ឃ្លានេះសំដៅលើគ្រប់ការទាំងអស់ដែលមនុស្សធ្វើ ទាំងការល្អ និងការអាក្រក់ គឺគេនឹងបានផលពីការទាំងនោះ (ខ.៨–៩ ២កថ ៩:៦)។

**៦:៨** *សេចក្ដីពុករលួយ* "សូមមើល ៥:១៩–២១"។ *ជីវិតអស់កល្បជានិច្ច*

ពីសាច់ឈាមនោះឯង[ធ] តែអ្នកណាដែលព្រោះខាងឯព្រះ
វិញ្ញាណ នោះនឹងច្រូតបានជីវិតអស់កល្បជានិច្ច ពីព្រះ
វិញ្ញាណវិញ[ន] ៩កុំឱ្យយើងណាយចិត្ត នឹងធ្វើការល្អឡើយ[ប]
ដ្បិតបើមិនរសាយចិត្តទេ នោះដល់កំណត់យើងនឹងច្រូត
បានហើយ[ផ] ១០ដូច្នេះ កាលណាយើងមានឱកាស នោះ
ត្រូវធ្វើការល្អ[ព]ដល់មនុស្សទាំងអស់ ហើយគឺដល់ពួកអ្នក
ជឿ[ភ]ជាដើម ។

## ការកាត់ស្បែក និងជីវិតថ្មី

១១សូមមើលអក្សរធំទាំងម្ល៉េះនេះដែលខ្ញុំសរសេរដោយ
ដៃខ្ញុំ ផ្ញើមកអ្នករាល់គ្នា[ម] ១២អស់អ្នកណាដែលចង់បានបួក
ពាល្អខាងសាច់ឈាម[យ] នោះគេបង្ខំឱ្យអ្នករាល់គ្នាទទួលកាត់
ស្បែក[រ] ដើម្បីឱ្យតែខ្លួនគេបានរួចពីសេចក្ដីបៀតបៀន[ល]
ដោយព្រោះឈើឆ្កាងនៃព្រះគ្រីស្ទ ១៣ដ្បិតពួកអ្នកដែល
ទទួលពិធីកាត់ស្បែកនោះ គេមិនទាំងកាន់តាមក្រឹត្យវិន័យ
ផង[វ] តែគេចង់ឱ្យអ្នករាល់គ្នា កាត់ស្បែកវិញ ដើម្បីឱ្យគេ
បានអួតខ្លួន ខាងឯសាច់ឈាមរបស់អ្នករាល់គ្នាប៉ុណ្ណោះ[ស]
១៤ឯខ្ញុំ កុំបីឱ្យខ្ញុំអួតខ្លួនឡើយ អួតបានតែពីឈើឆ្កាងនៃព្រះ
យេស៊ូវគ្រីស្ទ[ហ] ជាព្រះអម្ចាស់នៃយើងរាល់គ្នាប៉ុណ្ណោះ
ដែលដោយសារទ្រង់ នោះលោកីយបានត្រូវជាប់ឆ្កាង
ខាងឯខ្ញុំ ហើយខ្ញុំខាងឯលោកីយដែរ[ឡ] ១៥ដ្បិតក្នុងព្រះគ្រីស្ទ
យេស៊ូវ ដែលកាត់ស្បែក ឬមិនកាត់ នោះមិនជាប្រយោជន៍
អ្វីទេ[អ] ដែលហៅថាមានប្រយោជន៍ នោះមានតែកើតជាថ្មី
វិញប៉ុណ្ណោះ[ក] ១៦សូមឱ្យអស់អ្នកដែលដើរតាមមាត្រានេះ
បានប្រកបដោយសេចក្ដីសុខសាន្ត និងសេចក្ដីមេត្តាករុណា
ចុះ ព្រមទាំងសាសន៍ អ៊ីស្រាអែលនៃព្រះផង ។
១៧អំពីនេះទៅមុខ កុំឱ្យអ្នកណារំខានចិត្តខ្ញុំទៀតឡើយ
ដ្បិតខ្ញុំជាប់មានស្នាមត្រា[ខ]របស់ព្រះអម្ចាស់យេស៊ូវនៅខ្លួនខ្ញុំ
ហើយ ១៨បងប្អូនអើយ សូមឱ្យព្រលឹងវិញ្ញាណរបស់អ្នក
រាល់គ្នា[គ] បានប្រកបដោយព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ[ឃ]
ជាព្រះអម្ចាស់នៃយើងរាល់គ្នា ។ អាម៉ែន ។

**៦:៨** ធ យប ៤:៨ ហស ៨:៧ រម៦:២៣ ន យក ៣:១៨ **៦:៩** ប ១កថ ១៥:៥៨ ២កថ ៤:១ ផ យប ៤២:១២ ទដ ១២៦:៥ ហព ១២:៣ វវ ២:១០ **៦:១០** ព សភ ៣:២៧ ទត ២:១៤ ភ អភ ២:១៩ ១ពត ៤:១៧ **៦:១១** ម ១កថ ១៦:២១ **៦:១២** យ មថ ២៣:២៥,២៦ រ កច ១៥:១ ល កទ ៥:១១ **៦:១៣** វ រម ២:២៥ ស ភល ៣:៣ **៦:១៤** ហ ១កថ ២:២ ឡ រម ៦:២,៦ **៦:១៥** អ ១កថ ៧:១៩ ក ២កថ ៥:១៧ **២:១៧** ខ អស ៤៤:៥ ២កថ ១:៥ ១១:២៣ **២:១៨** គ រម ១៦:២០ ឃ ភល ៤:២៣ ២ធថ ៤:២២ ភម ២៥

នៅក្នុង "កទ ៥:២១" លោកប៉ុលបានមានប្រសាសន៍ អំពីការទទួលមរតកនៅនគរស្ថានសួគ៌ ។ ហើយនៅក្នុងបទគម្ពីរនេះ គាត់និយាយអំពីការទទួលបាននូវជីវិតអស់កល្បជានិច្ច (យហ ៣:១៥ ប្រៀបធៀបនឹង រម ៨:១៣) ។

**៦:១០** "សូមប្រៀបធៀបនឹង ១ធថ ៥:៨ និងការពន្យល់" ។

**៦:១១** *អក្សរធំទាំងម្ល៉េះ* ត្រង់ចំណុចនេះមានមតិខ្លះយល់ថា លោកប៉ុលមានភ្នែកមើលមិនសូវច្បាស់ទេ ដូច្នេះហើយបានជាគាត់សរសេរអក្សរធំៗ (និងការពន្យល់ ៤:១៣) ។ មានមតិខ្លះទៀតយល់ថា ការដែលគាត់និយាយយ៉ាងដូច្នេះ គឺគ្រាន់តែចង់បញ្ជាក់នូវសារសំខាន់ នៃសេចក្ដីដែលគាត់សរសេរនោះប៉ុណ្ណោះ មិនមែនមានន័យថា ភ្នែកគាត់មើលមិនសូវច្បាស់នោះទេ ។ *ខ្ញុំសរសេរដោយដៃខ្ញុំ* ឃ្លានេះអាចបញ្ជាក់ថា សេចក្ដីនៅក្នុងសំបុត្រកាឡាទីចាប់ពីចំណុចនេះ រហូតទីបញ្ចប់នៃសំបុត្រ គឺលោកប៉ុលបានសរសេរដោយដៃគាត់ផ្ទាល់ (រម ១៦:២២ និងការពន្យល់) ។

**៦:១២** *បង្ខំឱ្យអ្នករាល់គ្នាទទួលកាត់ស្បែក* "សូមប្រៀបធៀបជាមួយនឹង ២:៣" ។ *ដើម្បីឱ្យតែខ្លួនបានរួចពីសេចក្ដីបៀតបៀន* ឃ្លានេះបញ្ជាក់ថា មានពួកជំនុំខ្លះបង្ខំចិត្តគោរពប្រតិបត្តិតាមពួកគ្រូសាសនាយូដា ដោយធ្វើពិធីកាត់ស្បែក និងកាន់តាមក្រឹត្យវិន័យរបស់ពួកគេ ដើម្បីឱ្យបានរួចខ្លួនពីការបៀតបៀនផ្សេងៗ ។ ការដែលពួកគេធ្វើដូច្នោះ គឺមានន័យថា ពួកគេគិតតែពីខ្លួនឯងប៉ុណ្ណោះ (៥:១១) ។

**៦:១៤** *អួតបានតែពីឈើឆ្កាង* "សូមមើល ១កថ ១:៣១ ២:២" ។ *លោកីយ* គឺសំដៅលើគ្រប់ការដែលប្រឆាំងនឹងព្រះអម្ចាស់ (យហ ១:៩ ១យហ ២:១៥ និងការពន្យល់) ។ *ត្រូវជាប់ឆ្កាងខាងឯខ្ញុំ ហើយខ្ញុំខាងឯលោកីយដែរ* "សូមមើល ២:១៩, ២០ ៥:២៤" ។

**៦:១៥** *កើតជាថ្មី* មានន័យថា ពួកអ្នកជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ គឺបានកើតជាថ្មី (២កថ ៥:១៧ និងការពន្យល់) ។

**៦:១៦,១៨** *សេចក្ដីសុខសាន្ត . . . ព្រះគុណ* "មើលការពន្យល់ រម ១:៧" ។

**៦:១៦** *មាត្រា* "សូមមើល ខ.១៤–១៥" ។ *សេចក្ដីសុខសាន្ត និងសេចក្ដីមេត្តាករុណា* "សូមប្រៀបធៀប ទដ ១២៥:៥ ១២៨:៦" ។ *សាសន៍អ៊ីស្រាអែលនៃព្រះ* នៅក្នុងព្រះគម្ពីរសញ្ញាថ្មី សាសន៍អ៊ីស្រាអែលនៃព្រះ គឺសំដៅលើពួកជំនុំដែលកើត ឡើងដោយពួកអ្នកជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ ទាំងពួកសាសន៍យូដា និងពួកសាសន៍ដទៃ ឬត្រូវបានហៅថា ពូជថ្មីរបស់លោកអ័ប្រាហាំ និងពូជនៃសេចក្ដីសន្យា (៣:២៩ ប្រៀបធៀបនឹង រម ៩:៦ ភល ៣:៣) ។

**៦:១៧** *ស្នាមត្រារបស់ព្រះអម្ចាស់យេស៊ូវ* នៅក្នុងសម័យកាលសញ្ញាចាស់ ស្នាមត្រាត្រូវបានប្រើដើម្បីសម្គាល់បាវបម្រើ ឬសត្វចិញ្ចឹមផ្សេងៗ ។ ត្រង់ចំណុចនេះបញ្ជាក់ថា ការឈឺចាប់របស់លោកប៉ុលបានសំដែងឱ្យឃើញថា គាត់គឺជាអ្នកបម្រើរបស់ព្រះយេស៊ូវគ្រីស្ទប្រាកដមែន (១:១០ កច ១៤:១៩ ១៦:២២ ២កថ ៤:១០ ១១:២៥ ២កថ ១២:៧ កទ ៤:១៣–១៤) ។

**៦:១៨** *បងប្អូន* "មើលការពន្យល់ រម ១:១៣" ។ *សូមឱ្យព្រលឹងវិញ្ញាណរបស់អ្នករាល់គ្នា បានប្រកបដោយព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ* មានន័យថា ឱ្យព្រះគុណនៃព្រះយេស៊ូវគ្រីស្ទនៅជាមួយពួកគេតែម្ដង (មើលការពន្យល់ ២កថ ១៣:១៤) ។ *អាម៉ែន* ពាក្យនេះមានប្រភពដើមមកពីភាសាហេព្រើរ ដែលមានន័យថា "ពិត" ឬ "មាំមួន" ឬ "ស្មោះត្រង់" (វវ ៣:១៤) ហើយក៏មានន័យផងដែរថា "សូមបានសម្រេចដូច្នេះចុះ" ។ នៅក្នុង "អស ៦៥:១៦" បានថែងថា "ព្រះនៃសេចក្ដីពិត" ដែលនៅក្នុងភាសាហេព្រើរសរសេរថា "ព្រះអាម៉ែន" ។ ព្រះយេស៊ូវគ្រីស្ទបាន ប្រើពាក្យនេះញឹកញាប់ ដើម្បីបង្ហាញឱ្យកាន់តែច្បាស់នូវព្រះបន្ទូលទ្រង់ (វវ ៣:១៤) ។ ជាទូទៅ រាល់សេចក្ដីអធិស្ឋានរបស់គ្រីស្ទបរិស័ទគឺតែងតែបញ្ចប់ដោយ ពាក្យថា "អាម៉ែន" (១កថ ១៤:១៦) ។

# សំបុត្ររបស់លោកប៉ុល
## មកដល់ពួកជំនុំ
# **អេភេសូរ**

សេចក្ដីផ្ដើម

### **អ្នកនិពន្ធ កាលបរិច្ឆេទ និងទីកន្លែងនៃការសរសេរ**

នៅក្នុងបទគម្ពីរនេះលោកប៉ុលបានប្រាប់យ៉ាងច្បាស់ថា គាត់គឺជាអ្នកសរសេរកណ្ឌគម្ពីរនេះ (១:១ ៣:១ ប្រៀបធៀប ៣:៧,១៣ ៤:១ ៦:១៩-២០) ។ ប៉ុន្ដែ នៅកន្លែងខ្លះគាត់ពុំបានប្រើពាក្យជម្រាបសួរជាបុគ្គលផ្ទាល់ខ្លួនដូចសំបុត្រផ្សេងៗទៀតដែលគាត់បានសរសេរនោះទេ ដូចជាសំបុត្រដែលគាត់បានសរសេរទៅកាន់ពួកជំនុំនៅទីក្រុងកូល៉ុសនោះជាដើម ។ ហេតុផលទាំងនេះហើយដែលបណ្ដាលឱ្យមានអ្នកខ្លះសង្ស័យអំពីឈ្មោះអ្នកនិពន្ធ ប៉ុន្ដែ ទោះជាយ៉ាងនេះក្ដី ក៏សំបុត្រទៅក្រុងអេភេសូរនេះ គឺសម្រាប់ផ្ញើទៅពួកជំនុំដទៃៗទៀតជាច្រើនដែរ ដោយបូករួមទាំងក្រុងអេភេសូរនេះផងដែរ (មើលការពន្យល់ ១:១,១៥ ៦:២១-២៣) ។ សំបុត្រនេះលោកប៉ុលអាចសរសេរនៅក្នុងអំឡុងពេលដូចគ្នា ក្នុងការដែលគាត់សរសេរទៅកាន់ពួកជំនុំ នៅក្រុងកូល៉ុសក្នុងឆ្នាំទី៦0គ.ស ក្នុងខណៈពេលដែលគាត់ជាប់គុកនៅទីក្រុងរ៉ូម (៣:១ ៤:១ ៦:២០) ។

### **អំពីទីក្រុងអេភេសូរ**

អេភេសូរជាទីក្រុងសំខាន់ជាងគេបំផុតមួយនៅតំបន់អាស៊ីមីន័រខាងលិច (សព្វថ្ងៃជាប្រទេសទួរគី) ដោយមានកំពង់ផែមួយតភ្ជាប់ទៅនឹងទន្លេខាយស្ទើ (Cayster River) ដែលមានទឹកហូរចាក់ទៅសមុទ្រអាជីន (Aegean Sea) ។ ដោយសារទីក្រុងនេះស្ថិតនៅត្រង់ចំណុចប្រសព្វនៃផ្លូវពាណិជ្ជកម្មនោះក៏បានធ្វើឱ្យក្រុងនេះក្លាយជាតំបន់ពាណិជ្ជកម្មដ៏សំខាន់មួយនាសម័យនោះ និងជាទីមោទនភាពដល់ព្រះវិហារពួកសាសន៍ដទៃ ដែលបង្ហាញពីព្រះរបស់ខ្លួនដូចជាព្រះឌីអាន (កច ១៩:២៣-៣១) ដល់ពួករ៉ូម៉ាំង ។ លោកប៉ុលបានយកទីក្រុងអេភេសូរធ្វើជាទីស្នាក់ការសម្រាប់ដំណឹងល្អអស់រយៈពេលប្រហែលបីឆ្នាំ (មើលការពន្យល់ កច ១៩:១០) បន្ទាប់មក ឃើញព្រះវិហាររីកចម្រើនបានមួយរយៈ តែក្រោយមកត្រូវបានទទួលការព្រមានវិញ (វវ ២:១-៧) ។

### **អំពីទេវសាស្ត្រ**

សំបុត្ររបស់លោកប៉ុលបានសរសេរទៅកាន់ទីក្រុងអេភេសូរមួយនេះ ពុំដូចគ្នានឹងសំបុត្រជាច្រើនដទៃទៀតដែលគាត់បានសរសេរនោះទេ គឺខុសត្រង់ដែលលោកពុំបានបញ្ជាក់អំពីកំហុសឆ្គង ឬក៏ការមិនចុះសម្រុងគ្នាពីសេចក្ដីជំនឿនោះឡើយ ។ លោកប៉ុលបានសរសេរសំបុត្រមួយនេះ ដើម្បីពង្រឹងពីអនាគតដល់អ្នកអានសំបុត្ររបស់លោក គឺឱ្យពួកគេយល់កាន់តែច្បាស់ខ្លាំងឡើងនូវបំណងផែនការដ៏ល្អ និងព្រះគុណរបស់ព្រះដែលមាន តាំងពីអស់កល្ប ជាបំណងព្រះហឫទ័យដ៏ខ្ពស់បំផុតដែលទ្រង់មានសម្រាប់ពួកជំនុំនាពេលបច្ចុប្បន្ន ។

សំបុត្រនេះបានចាប់ផ្ដើមឡើងដោយសេចក្ដីថ្លែងការជាច្រើនដែលបង្ហាញអំពីព្រះពររបស់ព្រះអម្ចាស់ ដោយមានលាយឡំគ្នានូវសេចក្ដីបញ្ជាក់ផ្សេងៗ ដែលឈានទៅរកការចាប់អារម្មណ៍ដល់ប្រាជ្ញា ការគិតទុកមុន និងផែនការរបស់ព្រះអម្ចាស់ ។ លោកប៉ុលបានសង្កត់ធ្ងន់បន្ដទៅទៀតថា យើងគ្រប់គ្នាបានទទួលសេចក្ដីសង្គ្រោះមិនមែនគ្រាន់តែជាប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះនោះទេ ប៉ុន្ដែ ថែមទាំងនាំមកនូវការសរសើរ និងថ្វាយសិរីរុងរឿងដល់ព្រះអម្ចាស់នៃយើងទៀតផង ។ កម្រិតខ្ពស់បំផុតនៃផែនការរបស់ព្រះអម្ចាស់ "ដល់ពេលកំណត់នោះនឹងបានសម្រេច" គឺដើម្បីនាំមកនូវគ្រប់យ៉ាងក្នុងពិភពលោកនេះ ឱ្យនៅក្រោមព្រះគ្រីស្ទ (១:១០) ។ ចំណុចសំខាន់បំផុតមួយដែលគ្រីស្ទបរិស័ទត្រូវដឹងនោះគឺ នៅក្នុង ១:១៥-២៣ និង ៣:១៤-២១ ដែលជាសេចក្ដីអធិស្ឋានទាំងពីរលើករបស់លោកប៉ុល ដើម្បីឱ្យពួកអ្នកអានបានយល់នូវព្រះហឫទ័យរបស់ព្រះ ។

ការពន្យល់ពីបំណងផែនការដ៏អស្ចារ្យរបស់ព្រះសម្រាប់ពួកជំនុំ នោះលោកប៉ុលបានបន្ដបង្ហាញជាជំហានៗឆ្ពោះទៅរកសេចក្ដីសម្រេចនៃជំហានទាំងនោះ ។ ជំហានទីមួយ : ព្រះអម្ចាស់បានផ្សះផ្សាជាលក្ខណៈបុគ្គលម្នាក់ៗផ្ទាល់ៗខ្លួនទៅចំពោះទ្រង់ដែលជាសកម្មភាពនៃព្រះគុណ (២:១-១០) ។ ជំហានទីពីរ : ព្រះអម្ចាស់បានផ្សះផ្សារវាងបុគ្គលម្នាក់ៗដែលបានទទួលសេចក្ដីសង្គ្រោះនោះ ឱ្យត្រូវគ្នានឹងអ្នកជឿដទៃៗទៀត ដោយការសុគតរបស់ព្រះគ្រីស្ទបានកំទេចអស់រនាំងខ័ណ្ឌទាំងឡាយចេញ (២:១១-២២) ។ ប៉ុន្ដែ ព្រះអម្ចាស់បានធ្វើលើសពីនេះទៅទៀតគឺទ្រង់បានបង្រួបបង្រួមអ្នកដែលទ្រង់បានផ្សះផ្សាម្នាក់ៗនោះឱ្យមានរូបកាយតែមួយនៅក្នុងព្រះគ្រីស្ទ នេះហើយជាបំណងព្រះហឫទ័យនៃព្រះដែលមានសម្រាប់ពួកជំនុំ ដើម្បីឱ្យបានស្គាល់ពីប្រាជ្ញានៃព្រះដ៏មានជាច្រើនយ៉ាងដល់ពួកអ្នកគ្រប់គ្រង និងពួកមានអំណាចនៅស្ថានសួគ៌ដ៏ខ្ពស់ (៣:៧-១៣) ។ ចំណុចទាំងអស់នេះ មានយ៉ាងច្បាស់ជាច្រើនដងដោយប្រើពាក្យ "ស្ថានសួគ៌ដ៏ខ្ពស់" (១:៣,២០

២:៦ ៣:១០ ៦:១២) ដែលគ្រីស្ទបរិស័ទយើងមាន មិនថានៅផែនដីនេះនោះឡើយ។ ការដែលទទួលអត្ថន័យ និងសារៈសំខាន់ពីស្ថានដ៏ខ្ពស់បំផុតដែលព្រះគ្រីស្ទត្រូវបានលើកតម្កើងឡើងនៅឯព្រះហស្តស្តាំនៃព្រះ (១:២០)។

ទោះជាយ៉ាងណាក៏ដោយ ជីវិតគ្រីស្ទបរិស័ទយើងនៅតែរស់លើផែនដីនេះនៅឡើយ ដូច្នេះការអនុវត្តន៍នៃជីវិតរស់នៅជាប្រចាំថ្ងៃរបស់យើងនាពេលបច្ចុប្បន្ន គឺត្រូវបន្តការងារដែលជាបំណងព្រះហឫទ័យព្រះ ។ ព្រះទ្រង់ប្រទាន "អំណោយទាន" ដល់សមាជិកនៃពួកជំនុំរបស់ទ្រង់ដើម្បីឱ្យពួកគេមានសមត្ថភាពបម្រើស្អាងរូបកាយ និងមានភាពពេញវ័យ(៤:១-១៦)។ ការរួបរួមនៃពួកជំនុំដោយនៅក្រោមការដឹកនាំរបស់ព្រះគ្រីស្ទ ដែលទ្រង់បានប្រាប់ទុកជាមុនថា "គ្រប់ទាំងរបស់នៅស្ថានសួគ៌ និងផែនដី " គឺនៅក្រោមព្រះគ្រីស្ទទាំងអស់ (១:១០)។ ជីវិតថ្មីនៃភាពបរិសុទ្ធគឺមានជំហរផ្ទុយពីជីវិតចាស់កាលដែលគ្មានព្រះគ្រីស្ទ (៤:១៧-៦:៩)។ អស់អ្នកណាដែលឈរមាំមួននៅក្នុងព្រះអម្ចាស់នោះនឹងមានជ័យជម្នះលើអស់ទាំងការអាក្រក់ ទាំងក្នុងជម្លោះខាងឯវិញ្ញាណដ៏ធំ ជាពិសេសឱ្យខ្ជាប់ខ្ជួនក្នុងអំណាចនៃសេចក្តីអធិស្ឋាន (៦:១០-២០ និងមើលការពន្យល់ ១:៣)។

**គម្រោងសង្ខេប**

**I. ពាក្យជម្រាបសួរ (១:១-២)**

**II. បំណងព្រះហឫទ័យព្រះអម្ចាស់: សិរីល្អ និងភាពដឹកនាំរបស់ព្រះគ្រីស្ទ (១:៣-១៤)**

**III. ការអធិស្ឋានឱ្យគ្រីស្ទបរិស័ទបានស្គាល់ពីបំណងព្រះហឫទ័យ និងព្រះចេស្តានៃព្រះ (១:១៥-២៣)**

**IV. ជំហានដែលឈានទៅរកការសម្រេចនៃបំណងព្រះហឫទ័យព្រះ (ជំពូក ២-៣)**

- ក. សេចក្តីសង្គ្រោះនៃបុគ្គលម្នាក់ៗដោយព្រះគុណ (២:១-១០)
- ខ. ការផ្សះផ្សាគ្នាឡើងវិញនៃសាសន៍យូដា និងសាសន៍ដទៃដោយសារឈើឆ្កាង (២:១១-១៨)
- គ. ការរួបរួមគ្នានៃសាសន៍យូដា និងសាសន៍ដទៃ ឱ្យចូលមកក្នុងដំណាក់តែមួយ (២:១៩-២២)
- ឃ. ការបើកសំដែងពីប្រាជ្ញារបស់ព្រះតាមរយៈពួកជំនុំ (៣:១-១៣)
- ង. ការអធិស្ឋានឱ្យមានបទពិសោធន៍កាន់តែជ្រៅថែមទៀតនៃភាពពេញលេញរបស់ព្រះ (៣:១៤-២១)

**V. មធ្យោបាយដែលធ្វើឱ្យបានសម្រេចផែនការរបស់ព្រះនៅក្នុងពួកជំនុំ (៤:១-៦:២០)**

- ក. ការរួបរួម (៤:១-៦)
- ខ. ភាពពេញវ័យ (៤:៧-១៦)
- គ. ការស្អាងឡើងវិញនៃជីវិតរបស់បុគ្គលម្នាក់ៗ (៤:១៧-៥:២០)
- ឃ. ភាពខុសប្លែកគ្នានៅក្នុងទំនាក់ទំនងផ្ទាល់ៗខ្លួន (៥:២១-៦:៩)
    - ១. គោលការនានា (៥:២១)
    - ២. ប្តី និងប្រពន្ធ (៥:២២-៣៣)
    - ៣. កូន និងឪពុកម្តាយ (៦:១-៤)
    - ៤. អ្នកបម្រើ និងចៅហ្វាយ (៦:៥-៩)
- ង. គ្រឿងសឹករបស់ព្រះ (៦:១០-២០)

**VI. ការសន្និដ្ឋាន ពាក្យជម្រាបសួរចុងក្រោយ និងពាក្យជូនពរ (៦:២១-២៤)**

**១** ១សំបុត្រប៉ុលខ្ញុំ ជាសាវក[ក]របស់ផងព្រះយេស៊ូវគ្រីស្ទ
ដោយនូវបំណងព្រះហឫទ័យព្រះ[ខ] ផ្ញើមកពួកបរិសុទ្ធ[គ]ដែល
នៅក្រុងអេភេសូរ[ឃ] ជាពួកអ្នកស្មោះត្រង់[ង]ក្នុងព្រះគ្រីស្ទ
យេស៊ូវ ២សូមឱ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ នឹង
សេចក្ដីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃយើង ហើយ
អំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ[ច]។

## ព្រះពរខាងឯវិញ្ញាណនៅក្នុងព្រះគ្រីស្ទ

៣សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវ
គ្រីស្ទ[ឆ] ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានប្រទាន
ពរមកយើងក្នុងព្រះគ្រីស្ទដោយគ្រប់ទាំងព្រះពរខាងព្រលឹង
វិញ្ញាណនៅស្ថានដ៏ខ្ពស់[ជ] ៤តាមដែលទ្រង់បានរើសយើង
រាល់គ្នា[ឈ]ក្នុងព្រះគ្រីស្ទ តាំងពីមុនកំណើតលោកីយមក[ញ]
ប្រយោជន៍ឱ្យយើងរាល់គ្នាបានបរិសុទ្ធ ហើយឥតកន្លែង
បន្ទោសបាន[ដ]នៅចំពោះទ្រង់ ដោយសេចក្ដីស្រឡាញ់[ឋ] ៥ពី

**១:១** ក ១កថ ១:១ ខ ២កថ ១:១ គ កច ៩:១៣ ឃ កច ១៨:១៩ ង កល ១:២
**១:២** ច រម ១:៧
**១:៣** ឆ ២កថ ១:៣ ១ពត ១:៣ ជ ខ.២០ អភ ២:៦ ៣:១០ ៦:១២
**១:៤** ឈ ២ថន ២:១៣ ញ មថ ២៥:៣៤ ដ លវ ១១:៤៤ ២០:៧ ២សយ ២២:២៤ ទដ ១៥:២ អភ ៥:២៧ កល ១:២២ ឋ អភ ៤:២,១៥,១៦

**១:១** *ប៉ុល* មើលការពន្យល់ រម ១:១ ។ *ជាសាវក . . . ដោយនូវបំណងព្រះហឫទ័យព្រះ* មើលការពន្យល់ ១កថ ១:១ ។ លោកប៉ុលមិនគ្រាន់តែបញ្ជាក់ពីអំណាចរបស់គាត់ដែលនៅក្រោមព្រះប៉ុណ្ណោះទេ តែថែមទាំងបានបញ្ជាក់ពីបំណងព្រះហឫទ័យ នៃអំណាចព្រះចេស្ដារបស់ព្រះអម្ចាស់នៅក្នុងខបន្ដបន្ទាប់ទៀតផង ។ *ពួកបរិសុទ្ធ* គឺអស់អ្នកណាដែលព្រះអម្ចាស់បានត្រាស់ហៅមកធ្វើជារាស្ដ្រផ្ទាល់របស់ទ្រង់ ដូចជា គ្រីស្ទបរិស័ទជាដើម(ខ.១៥,១៨) ពាក្យថាពួកបរិសុទ្ធនេះជាប់ទាក់ទងទៅនឹង អត្ថន័យនៃការបង្ហាញពីព្រះចេស្ដាព្រះ(មើលការពន្យល់ រម ១:៧)។ *នៅក្រុងអេភេសូរ* គឺជាទីកន្លែងដែលលោកប៉ុលបានសរសេរសំបុត្រផ្ញើមក ប៉ុន្ដែ តាមពិត គាត់សរសេរទៅកាន់ពួកជំនុំដែលរស់នៅទីក្រុងនោះតែម្ដង ដូចជាសំបុត្រជាច្រើនផ្សេងៗទៀតដែរ(មើលការពន្យល់ ខ.១៥ ៦:២១–២៣ កច ១៩:១០)។ *នៅក្នុងព្រះគ្រីស្ទយេស៊ូវ* ឃ្លានេះ(ឬពាក្យស្រដៀងនេះ)មានរហូតដល់ទៅ១០ដងគ្រាន់តែនៅក្នុងខ.១–១៣ ។ ពាក្យនេះមានជាប់ទាក់ទងទៅនឹងការរួបរួមខាងឯវិញ្ញាណនៃព្រះគ្រីស្ទជាមួយនឹងអ្នកជឿដែលលោកប៉ុលតែងតែប្រើជានិមិត្តរូប ដើម្បីប្រៀបធៀបអំពី "រូបកាយនៃព្រះគ្រីស្ទ"(ខ.២៣ ២:១៦ ៤:៤,១២,១៦ ៥:២៣,៣០)។

**១:២** *ព្រះគុណ នឹងសេចក្ដីសុខសាន្ត* មើលការពន្យល់ រម ១:៧ ។ លោកប៉ុលប្រើពាក្យថា "ព្រះគុណ"នេះមានចំនួន ១២ដង និងពាក្យថា "សុខសាន្ត"ចំនួន ៨ដង នៅក្នុងគម្ពីរអេភេសូរនេះ ។

**១:៣–១៤** គ្រប់ប្រយោគនីមួយៗនៅក្នុងភាសាក្រិកត្រូវបានគេហៅថា "ទំនុកសរសើរតម្កើង" ពីព្រោះជាបទដែលបានពិពណ៌នាអំពីអ្វីដែលព្រះអម្ចាស់បានធ្វើ និងជាការបញ្ជាក់ពីការថ្វាយបង្គំ និងការសរសើរតម្កើងដល់ព្រះ ។ លោកប៉ុលនិយាយលើក ដំបូងគឺអំពីព្រះពរ ដែលយើងបានទទួលពីព្រះវរបិតា (ខ.៣–៦) បន្ទាប់ពីនោះមកគឺតាមរយៈព្រះរាជបុត្រា(ខ.៧–១២) ហើយជាទីបញ្ចប់គឺតាមរយៈព្រះវិញ្ញាណបរិសុទ្ធ(ខ.១៣–១៤)។

**១:៣** *ព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ* គឺចង់និយាយថាព្រះយេស៊ូវ និងព្រះវរបិតា គឺព្រះតែមួយអង្គទេ(មើលការពន្យល់ យហ ២០:១៧)។ *បានប្រទានពរ. . .ព្រះពរ* ពួកសាសន៍យូដាបានប្រើពាក្យថា"ព្រះពរ" ដើម្បីសំដែងពីភាពសប្បុរសរបស់ព្រះអម្ចាស់ដល់យើង និងពីការអរព្រះគុណ ឬការសរសើររបស់យើងដល់ព្រះអម្ចាស់វិញ ។ *នៅស្ថានដ៏ខ្ពស់* ឃ្លានេះមាន៥ដងនៅក្នុងគម្ពីរអេភេសូរដែលបញ្ជាក់ពីគំនិតរបស់លោកប៉ុល ក្នុងការលើកតម្កើងដល់ព្រះគ្រីស្ទ(ការមានព្រះជន្មរស់ឡើងវិញ និងការគង់លើបល្ល័ង្កនៅខាងស្ដាំព្រះហស្ដរបស់ព្រះអម្ចាស់) និងលើកទឹកចិត្តឱ្យគ្រីស្ទបរិស័ទរួមគ្នាលើកតម្កើងព្រះគ្រីស្ទឱ្យសមជាព្រះដ៏ខ្ពស់បំផុតនេះ ហើយដែលជាបំណងដ៏ធំជាងគេបំផុតរបស់យើង ។ តាមគំនិតសម្រេចតាំងពី អស់កល្បរៀងមកនៃគោលបំណងរបស់ព្រះអម្ចាស់(៣:១១) ដែលបង្កឱ្យមានជម្លោះមួយដ៏ធំរវាងអ្នកដែលជឿលើព្រះ និងអ្នកដែលជឿលើអំណាចកម្លាំងវិញ្ញាណគោលបំណងនៃជម្លោះនេះ គឺផ្ដោតទៅលើប្រវត្តិសាស្ដ្រនៃការប្រោសលោះ ។ នៅក្នុងខ.៣នេះ លោកប៉ុលបានអះអាងថា តាមរយៈការរួបរួមគ្នាដើម្បីលើកតម្កើងព្រះគ្រីស្ទ នោះនាំឱ្យគ្រីស្ទបរិស័ទគ្រប់រូបទទួលបាននូវគ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណដែលជាកម្មសិទ្ធរបស់ស្ថានដ៏ខ្ពស់បំផុត (ស្ថានសួគ៌)។ នៅក្នុង ខ.២០–២២ លោកប៉ុលបានប្រកាសពីការលើកសរសើរតម្កើងព្រះគ្រីស្ទជាព្រះនៃស្ថានដ៏ខ្ពស់បំផុត ហើយនិងការលើកឡើងឱ្យលើសអស់ទាំងអំណាច អស់ទាំងនាម និងទ្រង់ជាអ្នកគ្រប់គ្រងលើទាំងអស់សម្រាប់ជាប្រយោជន៍ដល់ពួកជំនុំរបស់ទ្រង់ ។ បើយោងតាម ២:៦ បានថែងថា អស់អ្នកដែលបានប្រោសឱ្យរស់ឡើងវិញ នោះគឺរស់ជាមួយនឹងព្រះគ្រីស្ទ (២:៥) ដូច្នេះហើយបានជាយើងមានបំណែកនៅ ក្នុងការលើកសរសើរតម្កើង និងការគ្រងរាជ្យនៅស្ថានសួគ៌ ។ នៅក្នុង ៣:១០ ដោយការប្រមូលផ្ដុំនៃសាសន៍ដទៃ និងសាសន៍យូដាមកធ្វើជារូបកាយតែមួយ នៅក្នុងព្រះគ្រីស្ទ (ដោយសារពួកជំនុំ)។ ព្រះអម្ចាស់បានបង្ហាញភាពរុងរឿង របស់ទ្រង់តាមរយៈ "ប្រាជ្ញានៃព្រះដ៏មានជាច្រើនយ៉ាង" ដើម្បីឱ្យ "ពួកគ្រប់គ្រង និងពួកមានអំណាច" នៅស្ថានដ៏ខ្ពស់បំផុតបានស្គាល់ទ្រង់ ។ លទ្ធផលនៅក្នុងការតស៊ូខាងឯវិញ្ញាណនៃពួកបរិសុទ្ធនៅត្រង់កន្លែងនេះ គឺមិនមែនប្រឆាំងនឹងសាច់ឈាមនោះទេ តែប្រឆាំងនឹងកម្លាំងដ៏ធំសម្បើមខាងឯវិញ្ញាណដែលជាសង្គ្រាមទាស់នឹងព្រះដែលគង់នៅស្ថានសួគ៌(មើលការពន្យល់ ៦:១២)។

**១:៤** *បានរើស* ការជ្រើសរើសរបស់ព្រះអម្ចាស់គឺជាផ្ទៃរឿងដែលមានជាដ៏រាប នៅក្នុងសំបុត្ររបស់លោកប៉ុល(រម ៨:២៩–៣៣ ៩:៦–២៦ ១១:៥,៧,២៨ ១៦:១៣ កល ៣:១២ ១ថន ១:៤ ២ថន ២:១៣ ទត ១:១)។ នៅក្នុងជំពូកនេះបានសង្កត់ធ្ងន់ទៅលើចំណុចធំៗដូចតទៅ: (១)."ទ្រង់បានរើសយើងរាល់គ្នា(ខ.៤)" (២)."ទ្រង់ បានតម្រូវយើងរាល់គ្នាទុកជាមុន(ខ.៥)" (៣)."យើងរាល់គ្នាបានកេរ្ដិ៍អាករក្នុងទ្រង់(ខ.១១)" (៤)."ទ្រង់កំពុងតែតម្រូវយើងទុក (ខ.១១)"។ *តាំងពីមុនកំណើត លោកីយមក* សូមមើល យហ ១៧:២៤ ។ *បានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបាន* មើល ៥:២៧ ពាក្យទាំងពីរនេះគឺជាគូនឹងគ្នា ។ "ភាពបរិសុទ្ធ" គឺជាលទ្ធផលនៃដំណើរការ មិនមែនជាការចាប់ផ្ដើមក្នុងពេលព្រះជ្រើសរើសនោះទេ ។ ដំណើរនេះមានជាប់ទាក់ទងទាំងភាពបរិសុទ្ធដែលបានប្រទានមកដល់អ្នកជឿដោយព្រោះព្រះគ្រីស្ទ ហើយនិងការញែកជាបរិសុទ្ធជាបុគ្គលផ្ទាល់ខ្លួនរបស់អ្នកជឿម្នាក់ៗ (មើលការពន្យល់ នក ៣:៥ លវ ១១:៤៤ ១កថ ១:២)។ *ដោយសេច*

ព្រោះទ្រង់បានដំរូវយើងរាល់គ្នាទុកជាមុន[ឌ] សំរាប់ឱ្យទ្រង់
បានទទួលយើងជាកូនចិញ្ចឹម[ឍ] ដោយសារព្រះយេស៊ូវគ្រីស្ទ
តាមបំណងព្រះហឫទ័យទ្រង់[ណ] ៦ដើម្បីនឹងសរសើរដល់ព្រះ
គុណដ៏ឧត្ដមរបស់ទ្រង់[ត] ដែលបានផ្ដល់មកយើងរាល់គ្នា
ទទេ ក្នុងព្រះរាជបុត្រាស្ងួនភ្ងារបស់ទ្រង់[ថ] ៧ហើយយើងបាន
សេចក្ដីប្រោសលោះ[ទ]នៅក្នុងព្រះរាជបុត្រានោះដោយសា
ព្រះលោហិតទ្រង់[ធ] គឺជាសេចក្ដីប្រោសឱ្យរួចពីទោស តាម
ព្រះគុណដ៏ធ្ងន់ក្រៃលែង[ន]នៃទ្រង់ ៨ដែលបានផ្ដល់មកយើង
ជាបរិបូរ ដោយនូវប្រាជ្ញា និងដំរិះសព្វគ្រប់ ៩ព្រមទាំង
សំដែង ឱ្យយើងរាល់គ្នាស្គាល់សេចក្ដីអាថ៌កំបាំង[ប] នៃព្រះ
ហឫទ័យទ្រង់តាមគំនិត[ផ] ដែលទ្រង់បានគិតសំរេច ក្នុងព្រះអង្គ
ទ្រង់ ១០សំរាប់ការកាន់កាប់ត្រួតត្រា ក្នុងកាលដែលពេល
ពេញកំណត់បានមកដល់[ព] ដើម្បីនឹងបំព្រួមគ្រប់ទាំង អស់ក្នុង
ព្រះគ្រីស្ទ[ភ] ទាំងរបស់នៅស្ថានសួគ៌ នឹងរបស់នៅ ផែនដីផង
១១ឱ្យរួមគ្នាមកក្នុងទ្រង់ ដែលយើងរាល់គ្នាបានកេរ្ដិ៍អាករ
ក្នុងទ្រង់ដែរ ដោយទ្រង់បានដំរូវយើងទុកជាមុន[ម] តាមដំរិះ
សំរេចរបស់ព្រះ ដែលទ្រង់ធ្វើគ្រប់ការទាំងអស់ តាមដែល
គាប់ព្រះហឫទ័យ[យ]ទ្រង់ ១២ប្រយោជន៍ឱ្យយើងខ្ញុំ ដែល

**១:៥** ឌ ខ.១១ រម ៨:២៩,៣០ ឍ រម ៨:១៤,១៥ ណ លក ១២:៣២ ១កថ ១:២១ កល ១:១៩ **១:៦** ត ខ.១២,១៤ ថ មថ ៣:១៧ **១:៧** ទ ខ.១៤ រម ៣:២៤ ធ រម ៣:២៥ ន រម ២:៤ **១:៩** ប រម ១៦:២៥ ផ ខ.១១ **១:១០** ព មក ១:១៥ រម ៥:៦ កទ ៤:៤ ភ កល ១:២០ **១:១១** ម ខ.៥ រម ៨:២៩,៣០ យ ខ.៩ រម ៨:២៨ អភ ៣:១១ ហព ៦:១៧ **១:១២** រ ខ.៦,១៤ **១:១៣** ល អភ

បានទុកចិត្តជឿដល់ព្រះគ្រីស្ទជាមុន បានសំរាប់នឹងសរ
សើរដល់សិរីល្អទ្រង់[រ] ១៣ឯអ្នករាល់គ្នា ក៏បានឮព្រះបន្ទូល
នៃសេចក្ដីពិត[ល] គឺជាដំណឹងល្អពីសេចក្ដីសង្គ្រោះរបស់
អ្នករាល់គ្នាដោយសារទ្រង់[វ]ដែរ ហើយកាលអ្នករាល់គ្នា
បានជឿហើយ នោះទ្រង់ក៏ដៅចំណាំ[ស]ដោយព្រះវិញ្ញាណ
បរិសុទ្ធ[ហ] ដែលបានសន្យា ១៤ព្រះវិញ្ញាណនោះទ្រង់ជាទី
បញ្ចាំចិត្ត[ឡ] ពីដំណើរកេរ្ដិ៍អាកររបស់យើងរាល់គ្នា ទាល់
តែបានលោះ[អ]របស់កំណាន់ ដែលទ្រង់បានទិញទុកឱ្យយើង
នោះ សំរាប់ជាសេចក្ដីសរសើរដល់សិរីល្អនៃទ្រង់[ក]។

## ការអរព្រះគុណ និងការអធិស្ឋាន

១៥ដោយហេតុនោះ កាលខ្ញុំឮនិយាយពីសេចក្ដីជំនឿ
ដែលអ្នករាល់គ្នាមានដល់ព្រះអម្ចាស់យេស៊ូវ[ខ] ហើយនិងពី
សេចក្ដីស្រឡាញ់ ដែលមានដល់ពួកបរិសុទ្ធទាំងអស់គ្នា[គ]
១៦នោះខ្ញុំមិនដែលលែងអរព្រះគុណ ដោយព្រោះអ្នករាល់
គ្នាឡើយ[ឃ] គឺខ្ញុំតែងដំណាលពីអ្នករាល់គ្នា ក្នុងសេចក្ដី
អធិស្ឋានរបស់ខ្ញុំវិញ[ង] ១៧ដើម្បីនឹងសូមឱ្យព្រះនៃព្រះយេស៊ូវ

៤:២១ កល ១:៥ វ រម ១៦:៣ ស អភ ៤:៣០ ហ យហ ១៤:១៦,១៧ **១:១៤** ឡ កច ២០:៣២ ២កថ ៥:៥ អ ខ.៧ រម ៣:២៤ ក ខ.៦,១២ **១:១៥** ខ កច ២០:២១ គ កល ១:៤ **១:១៦** ឃ រម ១:៨ ង រម ១:១០

*ក្ដីស្រឡាញ់* មើលការពន្យល់ ខ.៤–៥ ៣:១៧ ៤:២,១៥–១៦ ៥:២ ។

**១:៥** *កូនចិញ្ចឹម* មើលការពន្យល់ រម ៨:២៣ ។

**១:៦** *ដើម្បីនឹងសរសើរ* មើលការពន្យល់ ខ.១២,១៤ ។ យើងទាំងអស់គ្នាត្រូវបានជ្រើសរើសមកដោយព្រះគុណរបស់ព្រះអម្ចាស់ ហើយក៏សម្រាប់នឹងថ្វាយសិរីរុងរឿងដល់ទ្រង់នោះផងដែរ ។

**១:៧** *សេចក្ដីប្រោសលោះ* មើល ខ.១៤ ៤:៣០ រម ៣:២៤ ទត ២:១៤ និងការពន្យល់ ។ ពួកអ្នកក្រុងអេភេសូរមានការអនុវត្តន៍នៃសេចក្ដីប្រោសលោះនេះ ស្រដៀងគ្នានឹងពួកសាសន៍រ៉ូម–ក្រេក នៅសម័យបុរាណនោះដែរថា ទាសករទាំងឡាយបានរួចខ្លួនមកវិញនោះគឺដោយសារយកប្រាក់ទៅលោះ ។ ការប្រោសលោះមនុស្សមានបាបឱ្យរួចពីចំណងនៃអំពើបាប និងរួចពីបណ្ដាសា ដែលបានធ្វើឡើងដោយក្រឹត្យវិន័យនោះ (កទ ៣:១៣) គឺការសុគតរបស់ព្រះគ្រីស្ទ (ឬហៅថា ព្រះលោហិតរបស់ទ្រង់)។ *ដោយសារព្រះលោហិតទ្រង់* មើល ២:១៣ ១ពត ១:១៨–១៩ ។

**១:៩** *សេចក្ដីអាថ៌កំបាំង* មើលការពន្យល់ រម ១១:២៥ កល ១:២៦ ។

**១:១០** *ដើម្បីនឹងបំព្រួម...នៅស្ថានសួគ៌... នៅផែនដី* លោកប៉ុលប្រើពាក្យសំខាន់មួយនៅទីនេះ ដែលមិនសំដៅលើតែគំនិតនៃភាពជាអ្នកដឹកនាំប៉ុណ្ណោះនោះទេ ប៉ុន្តែ ថែមទាំងបន្ថែមលើសពីនេះទៀតផង ។ បើយើងមើលមួយភ្លែតនៃការប្រើពាក្យនេះ អាចធ្វើឱ្យពិភពលោកយល់ច្រឡំបាន បើមិនបានពន្យល់ឱ្យច្បាស់ក្នុងការប្រើពាក្យថា "គ្រប់ទាំងអស់ក្នុងព្រះគ្រីស្ទទាំងរបស់នៅស្ថានសួគ៌ និងរបស់នៅផែនដី" នៅក្នុងអំឡុងពេលនោះ ។

**១:១១** *ក្នុងទ្រង់* មានន័យថា ព្រះគ្រីស្ទគឺជាចំណុចកណ្ដាលនៃផែនការរបស់ព្រះអម្ចាស់ ។ ទោះបីនៅក្នុងពិភពលោកនេះទាំងមូល ឬជាបុគ្គលក៏គ្រីស្ទបរិស័ទត្រូវមានគំនិតបែបយ៉ាងដូច្នេះថា មានតែការប្រកបជាមួយនឹងព្រះគ្រីស្ទទេ ទើបមានប្រយោជន៍ទៅអនាគត ។ លោកប៉ុលបានបន្តទៀតថា មិនត្រឹមតែមនុស្សក្នុងលោកទាំងមូលនោះទេ ប៉ុន្តែគឺអស់អ្នកណាដែលព្រះអម្ចាស់បានត្រាស់ហៅដែរ ។ *ដំរូវយើងទុកជាមុន* មើល ខ.៤–៥ និងការពន្យល់ រម ៨:២៩–៣០ ។

**១:១២** *យើងខ្ញុំ ដែលបានទុកចិត្តជឿដល់ព្រះគ្រីស្ទជាមុន* ឃ្លានេះប្រហែលសំដៅសាសន៍យូដាទាំងឡាយដែលចូលចិត្តលោកប៉ុល ហើយបានក្លាយជាគ្រីស្ទបរិស័ទមុនសាសន៍ដទៃផ្សេងៗទៀត ។

**១:១៣** *ឯអ្នករាល់គ្នា* ពាក្យនេះប្រហែលភាគច្រើនសំដៅលើសាសន៍ដទៃដែលរស់នៅក្រុងអេភេសូរ ។ *ព្រះបន្ទូលនៃសេចក្ដីពិត* មើលការពន្យល់ ២ធថ ២:១៥ ។ *ដៅចំណាំ* ពាក្យនេះមានន័យដូចនឹងពាក្យថាបោះត្រានោះដែរ ។ កាលណាគេបោះត្រាលើអ្វីមួយនោះគឺដើម្បីការពារសុវត្ថិភាព និងឱ្យដឹងថាមានម្ចាស់រួចហើយ ។

**១:១៤** *ជាទីបញ្ចាំចិត្ត* មើលការពន្យល់ រម ៨:២៣ ។ *កេរ្ដិ៍អាករ* មើល កល ១:១២ ហព ៩:១៥ និងមើលការពន្យល់ ១ពត ១:៤ ។

**១:១៥** *កាលខ្ញុំឮនិយាយ* ការប្រើឃ្លានេះហាក់បីដូចជាចម្លែកខ្លាំងណាស់ចំពោះមនុស្សម្នាក់ដែលបានចំណាយពេលរស់នៅក្រុងអេភេសូរអស់រយៈពេលពីពីរទៅបីឆ្នាំមកហើយនោះ ។ ត្រង់នេះលោកប៉ុលអាចនិយាយសំដៅលើការរីកចម្រើនរបស់ពួកជំនុំជាច្រើនកន្លែងផ្សេងទៀតនៅទីក្រុងនោះ ដែលគាត់មិនដែលបានដឹងឮពីមុន ឬអ្នកនៅក្រុងអេភេសូរបានដឹងពីអ្នកទទួលសំបុត្រនេះ (មើលការពន្យល់ ខ.១) ឬអាចសំដៅលើព័ត៌មានដែលគាត់បានទទួល ក្នុងពេលគាត់បានទៅសួរសុខទុក្ខនៅកន្លែងផ្សេងពីទីក្រុងនេះ។

គ្រីស្ទ ជាព្រះអម្ចាស់នៃយើង គឺជាព្រះវរបិតាដ៏មានសិរីល្អ[ច]
បានប្រទានឱ្យអ្នករាល់គ្នាបានព្រះវិញ្ញាណ ដែលប្រោសឱ្យ
មានប្រាជ្ញា[ឆ] ហើយក៏បើកសំដែង ឱ្យដឹងពីដំណើរស្គាល់
ទ្រង់ ១៨ដើម្បីឱ្យភ្នែកចិត្តរបស់អ្នករាល់គ្នា បានភ្លឺឡើង[ជ]
ប្រយោជន៍ឱ្យបានដឹងថា ដែលទ្រង់ហៅ[ឈ]អ្នករាល់គ្នា នោះ
មានសេចក្ដីសង្ឃឹមជាយ៉ាងណា ហើយថា សិរីល្អដ៏ប្រសើរ
ក្រៃលែង[ញ]នៃមរដកទ្រង់[ដ] ក្នុងពួកបរិសុទ្ធ[ឋ]ជាយ៉ាងណាផង
១៩ហើយថា ព្រះចេស្ដាដ៏ខ្លាំងលើសលន់របស់ទ្រង់ដល់
យើងរាល់គ្នាដែលជឿជាយ៉ាងណាដែរ តាមដែលកំឡាំង
ទ្រង់[ឌ]ដ៏មានឫទ្ធិបានពូកែនឹងធ្វើ[ឍ] ២០ជាព្រះចេស្ដាដែលទ្រង់
បានសំដែងចេញ ដោយប្រោសព្រះគ្រីស្ទ ឱ្យមានព្រះជន្ម
រស់ពីស្លាប់ឡើងវិញ[ណ] ព្រមទាំងតាំងឱ្យគង់ខាងស្ដាំទ្រង់[ត]
នៅស្ថានដ៏ខ្ពស់[ថ] ២១ឱ្យខ្ពស់ជាងអស់ទាំងពួកគ្រប់គ្រង[ទ] ពួក
មានអំណាច មានឫទ្ធិបារមី និងពួកមេទាំងប៉ុន្មាន ហើយ
គ្រប់ទាំងឈ្មោះ[ធ]ដែលបានតាំងឡើងដែរ មិនមែនតែក្នុង
បច្ចុប្បន្ននេះតែប៉ុណ្ណោះ គឺទៅក្នុងអនាគតខាងមុខទៀតផង[ន]
២២ហើយទ្រង់បានបង្ក្រាបគ្រប់ទាំងអស់ នៅក្រោមព្រះបាទ
នៃព្រះរាជបុត្រា[ប] ទាំងប្រទានទ្រង់មកធ្វើជាសិរសា[ផ] លើ
គ្រប់ទាំងអស់ដល់ពួកជំនុំ ដែលជារូបកាយទ្រង់[ព] ២៣គឺជា
សេចក្ដីពោរពេញរបស់ព្រះអង្គ[ភ] ដែលបំពេញគ្រប់ទាំង
អស់ក្នុងទាំងអស់[ម]។

## ត្រូវបានប្រោសឱ្យរស់ក្នុងព្រះគ្រីស្ទ

**២** ១ពីដើម អ្នករាល់គ្នាក៏ស្លាប់ក្នុងការរំលង ហើយក្នុង
អំពើបាបដែរ[យ] ២ជាការដែលអ្នករាល់គ្នាបានប្រព្រឹត្ត[រ]
តាមរបៀបលោកីយនេះ[ល] គឺតាមមេគ្រប់គ្រងរាជ្យលើ
អាកាស[វ] ជាវិញ្ញាណ ដែលសព្វថ្ងៃនេះ បណ្ដាលមកក្នុងពួក
មនុស្សរឹងចចេស[ស] ៣យើងរាល់គ្នាទាំងអស់ក៏បានប្រព្រឹត្ត

**១:១៧** ច យហ ២០:១៧ រម ១៥:៦ វវ ១:៦ ឆ នក ២៨:៣ អស ១១:២ ភល ១:៩ កល ១:៩
**១:១៨** ជ យប ៤២:៥ ២កថ ៤:៦ ហព ៦:៤ ឈ រម ៨:២៨ ញ ខ.៧ រម ២:៤ ដ ខ.១១ ឋ កល ១:១២
**១:១៩** ឌ អភ ៣:៧ កល ១:២៩ ឍ អស ៤០:២៦ អភ ៦:១០
**១:២០** ណ កច ២:២៤ ត មក ១៦:១៩ ថ ខ.៣
**១:២១** ទ អភ ៣:១០ កល ១:១៦ ធ ភល ២:៩,១០
ន មថ ១២:៣២ **១:២២** ប មថ ២២:៤៤ ២៨:១៨ ផ ១កថ ១១:៣ អភ ៤:១៥ ៥:២៣ កល ១:១៨ ២:១៩ ព ១កថ ១២:២៧ **១:២៣** ភ យហ ១:១៦ អភ ៣:១៩ ម អភ ៤:១០ **២:១** យ ខ.៥ កល ២:១៣
**២:២** រ ខ.៣,១១–១៣ រម ១១:៣០ ១កថ ៦:១១ ៥:៨ កល ៣:៧ ទត ៣:៣ ១ពត ៤:៣ ល រម ១២:២ វ យហ ១២:៣១ ស អភ ៥:៦

**១:១៧** *ព្រះនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង* មើលការពន្យល់ ខ.៣ *ទ្រង់* ជាសព្វនាមជំនួសឱ្យព្រះវរបិតា ។

**១:១៨** *ភ្នែកចិត្តរបស់អ្នករាល់គ្នា* គឺជាការយល់ដឹង ឬចិត្តគំនិត ឬក៏ភាពយល់ដឹងនូវអ្វីមួយចេញពីក្នុងខ្លួនមក ។ *សេចក្ដីសង្ឃឹម* គឺជាបំណងជាក់លាក់ និងពិតប្រាកដ (រម ៥:៥ និងការពន្យល់)។ សេចក្ដីសង្ឃឹមជាការធានាអះអាងនៃជីវិតអស់កល្ប ដែលបានធានាដោយអំណោយកម្មសិទ្ធិនៃព្រះវិញ្ញាណបរិសុទ្ធ(ខ.១៤)។ *ហៅ* មើល រម ៨:២៨ និងការពន្យល់ ភល ៣:១៤ ២ធថ ១:៩ ហព ៣:១ ។ *សិរីល្អដ៏ប្រសើរក្រៃលែង នៃមរដកទ្រង់* ឃ្លានេះអាចជាមរតកដែលយើងទទួលពីព្រះ (ខ.១៤ កល ១:១២) ឬជាមរតកដែលព្រះបានទទួលឧទាហរណ៍ភាពបរិសុទ្ធនៃអ្នកជឿ (ទដ ២:៨ អស ៥៣:១០)។ *ពួកបរិសុទ្ធ* មើលការពន្យល់ ខ.១ ។

**១:១៩** នៅក្នុងខនេះលោកប៉ុលបានត្រៀមលក្ខណៈជាពាក្យដើម្បីបញ្ជាក់ពីអំណាចព្រះអម្ចាស់ដោយលើកព្រះយេស៊ូវគ្រីស្ទឱ្យមានព្រះជន្មរស់ឡើងវិញ (ខ.២០) ហើយជាអំណាចតែមួយដែលបានធ្វើការតាមរយៈអ្នកជឿលើទ្រង់ផងដែរ(ភល ៣:១០ និងការពន្យល់)។

**១:២០** *គង់ខាងស្ដាំទ្រង់* គឺជានិមិត្តរូបនៃទីកន្លែង និងអំណាចដ៏ខ្ពស់បំផុត ។

**១:២១** *ឱ្យខ្ពស់ជាងអស់ទាំងពួកគ្រប់គ្រង ពួកមានអំណាច មានឫទ្ធិបារមី និងពួកមេទាំងប៉ុន្មាន ហើយគ្រប់ទាំងឈ្មោះដែលបានតាំងឡើងដែរ* នៅចំណុចនេះបាននិយាយពីគ្រប់អំណាចទាំងអស់ រួមទាំងអំណាចលើសពីមនុស្សលោកផងដែរ ។ នៅសម័យលោកប៉ុលមានមនុស្សជាច្រើន មិនត្រឹមតែជឿលើអំណាចរបស់ពួកទេវតា ឬអារក្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជឿលើអំណាចផ្សេងៗជាច្រើនទៀតផង ។ ព្រះគ្រីស្ទយេស៊ូវគឺជាព្រះដ៏ខ្ពស់លើអំណាចទាំងអស់នោះ ។ *មិនមែនតែក្នុងបច្ចុប្បន្ននេះតែប៉ុណ្ណោះ គឺទៅក្នុងអនាគតខាងមុខទៀតផង* មើល មថ ១២:៣២ ។ ដោយសារតែលោកប៉ុលបានស្គាល់គ្រូបង្រៀនសាសនាជាច្រើននៅសម័យនោះ បានជាគាត់ពន្យល់ថានៅពេលបច្ចុប្បន្ននេះគឺជាអំណាចរបស់វិញ្ញាណអាក្រក់ ហើយទៅថ្ងៃអនាគត គឺជាពេលវេលារបស់ព្រះមែស៊ីនឹងបំពេញនគររបស់ទ្រង់ ដោយភាពសុចរិតនៅលើផែនដីនេះទាំងមូល ។

**១:២២** *នៅក្រោមព្រះបាទ* ទដ ៨:៥–៦ បានបញ្ជាក់ពីវាសនានៃមនុស្សលោក និង ហព ២:៦–៩ បង្ហាញថា នៅទីចុងក្រោយបំផុត នោះកូនមនុស្សជាអ្នកគ្រប់គ្រងលើរបស់ទាំងអស់(ហព ១០:១៣)។ *សិរសា* ព្រះគ្រីស្ទមិនមែនត្រឹមតែជាសិរសាលើពួកជំនុំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាសិរសាលើគ្រប់របស់ទាំងអស់ផង(ខ.១០) *រូបកាយទ្រង់* មើល ២:១៦ ៤:៤,១២,១៦ ៥:២៣,៣០ ។

**១:២៣** *ពោរពេញ . . . បំពេញគ្រប់ទាំងអស់* ពួកជំនុំគឺជាសេចក្ដីពោរពេញនៃព្រះគ្រីស្ទ មានន័យថា គ្រប់របស់ទាំងអស់ត្រូវបានបំពេញដោយព្រះអង្គ ។

**២:១–១០** នៅក្នុងជំពូកមួយ លោកប៉ុលបានសរសេរអំពីបំណង និងផែនការដ៏អស្ចារ្យរបស់ព្រះអម្ចាស់ថា ព្រះគ្រីស្ទគឺជាអ្នកដឹកនាំកំពូលនៃពិភពលោក (១:១០,២២) ហើយគ្រប់របស់ទាំងអស់គឺសម្រាប់"សរសើរសិរីល្អដល់ទ្រង់" (១:១៤)។ ឥឡូវនេះគាត់បានបន្តពន្យល់ទៅជំហានបន្ទាប់ទៀតថា ព្រះអម្ចាស់នឹងបំពេញសព្វគ្រប់នូវគោលបំណងរបស់ទ្រង់ ដោយចាប់ផ្ដើមពីសេចក្ដីសង្គ្រោះនៃបុគ្គលម្នាក់ៗ ។

**២:១** នៅក្នុងខនេះគឺជាការពិពណ៌នាពីទង្វើអតីតកាលរបស់ពួកគេ ទាំងផ្នែកសីលធម៌ និងវិញ្ញាណដែលបណ្ដាលឱ្យដាច់ចេញពីព្រះអម្ចាស់(កល ១:២១)។

**២:២** *មេគ្រប់គ្រង* ពាក្យនេះគឺនិយាយពីសាតាំង(យហ ១៤:៣០"ចៅហ្វាយលោកិយ")។ *អាកាស* ពាក្យនេះក៏និយាយពី "សាតាំង" ដែរ ដោយបញ្ជាក់ថា វាគឺជាម្ចាស់នៃសេចក្ដីងងឹតនៅលោកីយនេះ(៦:១២)។ *ជាវិញ្ញាណ* មានន័យថា សាតាំងក៏ជាវិញ្ញាណមួយដែលត្រូវបានបង្កើតមកដែរ ប៉ុន្តែ វាមិនមែនជាមនុស្សទេ (យប ១:៦ អគ ២៨:១៥ មើលការពន្យល់ អស ១៤:១២–១៥)។

**២:៣** *យើងរាល់គ្នាទាំងអស់* គឺមានទាំងសាសន៍យូដា សាសន៍ក្រេក និងសាសន៍ដទៃ ។ *ជាមនុស្សជាប់ក្នុងសេចក្ដីខ្ញាល់* មើល រម ១:១៨–២០ ២:៣ ៩:២២

ក្នុងពួកនោះពីដើមដែរ[ហ] ដោយសេចក្តីប៉ងប្រាថ្នារបស់
សាច់ឈាម[ឡ]យើង ទាំងប្រព្រឹត្តសេចក្តីដែលសាច់ឈាម
និងគំនិតយើងចង់បានផង ហើយតាមកំណើតយើង នោះ
យើងជាមនុស្សជាប់ក្នុងសេចក្តីខ្ញាល់ ដូចជាមនុស្សឯទៀត
ដែរ ៤ប៉ុន្តែ ព្រះដែលទ្រង់មានសេចក្តីមេត្តាករុណាដ៏លើស
លប់ ដោយព្រោះសេចក្តីស្រឡាញ់ជាខ្លាំង ដែលទ្រង់មាន
ដល់យើងរាល់គ្នា[អ] ៥ក្នុងកាលដែលយើងនៅស្លាប់ក្នុងការ
រំលងនៅឡើយ[ក] នោះទ្រង់បានប្រោសឱ្យយើងរាល់គ្នាបាន
រស់ជាមួយនឹងព្រះគ្រីស្ទ គឺដោយព្រះគុណ ដែលអ្នករាល់
គ្នាបានសង្គ្រោះ[ខ] ៦ហើយទ្រង់បានប្រោសឱ្យយើងរស់ឡើង
វិញ ក៏ឱ្យយើងអង្គុយជាមួយនឹងព្រះគ្រីស្ទ[គ,ឃ] នៅស្ថានដ៏ខ្ពស់
ដែរ[ង] ៧ដើម្បីឱ្យទ្រង់បានសំដែងឱ្យអស់ទាំងកល្បខាងមុខ
បានឃើញព្រះគុណដ៏ធ្ងន់លើសលប់របស់ទ្រង់[ច] ដោយ
សេចក្តីសប្បុរស[ឆ] ដែលទ្រង់ផ្តល់មកយើង ក្នុងព្រះគ្រីស្ទ
យេស៊ូវ ៨ដ្បិតគឺដោយព្រះគុណ[ជ] ដែលអ្នករាល់គ្នាបាន
សង្គ្រោះ[ឈ] ដោយសារសេចក្តីជំនឿ[ញ] ហើយសេចក្តីនោះក៏
មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់
ព្រះវិញ ៩ក៏មិនមែនដោយការប្រព្រឹត្តដែរ[ដ] ក្រែងអ្នកណា
អួតខ្លួន[ឋ] ១០ដ្បិតយើងរាល់គ្នាជាស្នាដៃ[ឌ]ដែលទ្រង់បង្កើត[ឍ]
ក្នុងព្រះគ្រីស្ទយេស៊ូវ សំរាប់ការល្អ[ណ] ដែលព្រះបានរៀបចំ
ជាមុន ឱ្យយើងរាល់គ្នាប្រព្រឹត្តតាម ។

## មានតែមួយក្នុងព្រះគ្រីស្ទ

១១ដូច្នេះ ចូរនឹកចាំថា កាលពីដើម[ត]អ្នករាល់គ្នាជា
សាសន៍ដទៃខាងសាច់ឈាម ដែលពួកទទួលកាត់ស្បែកក្នុង
សាច់ ដោយដៃមនុស្ស[ថ] គេហៅអ្នករាល់គ្នាជាពួកមិនកាត់
ស្បែកវិញ ១២នៅវេលានោះ អ្នករាល់គ្នានៅទីទៃពីព្រះ
គ្រីស្ទ ក៏ឃ្លាតចេញពីអំណាចជាតិអ៊ីស្រាអែលផង ជាមនុស្ស
ដទៃ[ទ] ខាងឯសេចក្តីសញ្ញា[ធ] ដែលទ្រង់បានសន្យាទុក ក៏ឥត

**២:៣** ហ ខ.២ ឡ កទ ៥:២៤ **២:៤** អ យហ ៣:១៦ **២:៥** ក ខ.១ ទដ ១០៣:១២ ខ ខ.៨ យហ ៥:២៤ កច ១៥:១១ **២:៦** គ រម ៦:៥ ឃ អភ ១:២០ ង អភ ១:៣ **២:៧** ច រម ២:៤ ឆ ទត ៣:៤ **២:៨** ជ រម ៣:២៤ ឈ ខ.៥ ញ រម ៩:៣០ **២:៩** ដ ចទ ៩:៥ រម ៤:២ ២ធច ១:៩ ទត ៣:៥ ឋ ១កថ ១:២៩ **២:១០** ឌ អស ២៩:២៣ ៤៣:៧ ៦០:២១ ឍ អភ ៤:២៤ ណ ទត ២:១៤ **២:១១** ត ខ.២ ថ កល ២:១១ **២:១២** ទ អស ១៤:១ ៦៥:១ ធ កទ ៣:១៧

**២:៥** *ទ្រង់បានប្រោសឱ្យយើងរាល់គ្នាបានរស់ជាមួយនឹងព្រះគ្រីស្ទ* នេះជាសេចក្តីពិត ដែលត្រូវបានពន្យល់បន្ថែមទៀតនៅក្នុង រម ៦:១–១០(មើលពន្យល់ខទាំងនោះ)។

**២:៦** *នៅស្ថានដ៏ខ្ពស់* មើលការពន្យល់ ១:៣ ។ *អង្គុយជាមួយនឹងព្រះគ្រីស្ទ* គឺតាមរយៈការរួបរួមរបស់យើងជាមួយនឹងព្រះគ្រីស្ទ(មើលពន្យល់ ១:១)។

**២:៧** *អស់ទាំងកល្បខាងមុខ* បទគម្ពីរ ១:២១ គឺសំដៅលើព្រះពរដ៏អស់កល្បរបស់ព្រះគ្រីស្ទនាថ្ងៃអនាគត ។ *បានឃើញ* ស្មើនឹងពាក្យ"បានដាក់តាំង"ឬ"បានបង្ហាញ"។

**២:៨** នេះគឺជាបទគម្ពីរសំខាន់ដែលធ្វើឱ្យយល់ពីព្រះគុណរបស់ព្រះអម្ចាស់ ដូចជា: ភាពសប្បុរស ការអនុគ្រោះ ការអត់ទោស និងសេចក្តីស្រលាញ់របស់ទ្រង់ ។ *អ្នករាល់គ្នាបានសង្គ្រោះ* ពាក្យថា"បានសង្គ្រោះ" គឺមានអត្ថន័យធំទូលាយណាស់ ។ មានបូករួមទាំងសេចក្តីសង្គ្រោះដែលចេញពីសេចក្តីក្រោធរបស់ព្រះអម្ចាស់ ដែលយើងគ្រប់គ្នាបានទទួលរងដោយសារតែអំពើបាបរបស់ខ្លួនយើងផ្ទាល់នោះ ។ ប្រយោគនៃកិរិយាសព្ទនៅក្នុង(ខ.៥)បានសម្រេចសកម្មភាពរបស់ខ្លួនដោយសង្កត់ធ្ងន់នៅក្នុងខនេះ ជាសកម្មភាពនាពេលបច្ចុប្បន្នកាល ។ *ដោយសារសេចក្តីជំនឿ* (មើល រម ៣:២១–៣១ និងការពន្យល់) ដែលលើកឡើងពីសារសំខាន់នៃការជឿលើព្រះគ្រីស្ទតែមួយគត់ដែលនាំឱ្យមានសេចក្តីសុចរិតជាមួយនឹងព្រះឡើងវិញ ។ *មិនមែនកើតឡើងពីអ្នករាល់គ្នា* សេចក្តីសង្គ្រោះគឺមិនមែនបានមកដោយសារការខំប្រឹងប្រែងរបស់មនុស្ស ដើម្បីឱ្យបានវានោះទេ ប៉ុន្តែ វាជាអំណោយទានដែលបានមកពីព្រះអម្ចាស់វិញ (មើលការពន្យល់ ទត ៣:៥)។

**២:៩** *មិនមែនដោយការប្រព្រឹត្ត* មនុស្សមិនអាចទទួលសេចក្តីសង្គ្រោះ តាមរយៈ "ការប្រព្រឹត្តតាមក្រិត្យវិន័យនោះឡើយ"(រម ៣:២០,២៨ យក ២:១៤–២៦ និងការពន្យល់)។ មធ្យោបាយសមស្របមួយដែលនាំទៅរកសេចក្តីសង្គ្រោះ(ឬការរាប់ជាបរិសុទ្ធ) គឺការដាក់ទោសមួយដែលមិនចេះប្រែប្រួលនោះឡើយ(កទ ២:១៦និងការពន្យល់)។ *ក្រែងអ្នកណាអួតខ្លួន* គ្មាននរណាម្នាក់អាចមានកិត្តិយសរហូតដល់ទៅទទួលសេចក្តីសង្គ្រោះបានដោយខ្លួនឯងនោះឡើយ(២កថ ៥:១៧ និងការពន្យល់)។

**២:១០** *ជាស្នាដៃដែលទ្រង់បង្កើត* ពេលខ្លះ ពាក្យនេះជាភាសាក្រិកមានបង្កប់អត្ថន័យថា "កិច្ចការសិល្បៈ"។ *បានរៀបចំជាមុន* ឃ្លានេះបានបន្តប្រាប់ដល់យើងនូវដំណើរផែនការ និងគោលបំណងដ៏អស្ចារ្យរបស់ព្រះអម្ចាស់ ដូចដែលបានឃើញនៅក្នុងជំពូកទី១ (១:៤ និងការពន្យល់)។

**២:១១–២២** ក្រោយពីបានពន្យល់ពីសេចក្តីសង្គ្រោះរបស់ព្រះដល់បុគ្គលម្នាក់ៗរួចហើយ នោះលោកប៉ុលបានបន្តទៅគំនិតនៃសេចក្តីសង្គ្រោះមួយទៀតថា សេចក្តីសង្គ្រោះរបស់ទ្រង់បានផ្សះផ្សាសាសន៍យូដា និងសាសន៍ដទៃឱ្យបានជានានឹងគ្នាវិញ ដែលពីមុនជាសត្រូវនឹងគ្នាអស់រយៈពេលជាយូរមកហើយ ។ ការជានានឹងគ្នានេះ បានមកតាមរយៈព្រះគ្រីស្ទ(ខ.១១–១៦)ពុំមែនមកពីខ្លួនរបស់គាត់នោះទេ ។ លើសពីនេះទៅទៀត បច្ចុប្បន្ននេះព្រះអម្ចាស់បានបង្រួបបង្រួមបណ្តាជនទាំងឡាយឱ្យមក ជារូបកាយតែមួយដូចដែលចែងក្នុងខ.១៩–២២ និងការពន្យល់នៅក្នុងជំពូក៣ ។

**២:១១–១២** ខទាំងនេះនិយាយពីមនុស្សដែលគ្មានព្រះគ្រីស្ទ ដូចក្នុងខ.១–១០។

**២:១១** *អ្នករាល់គ្នាជាសាសន៍ដទៃ* អ្នកនៅក្រុងអេភេសូរភាគច្រើនជាសាសន៍ដទៃ (១:១៣ និងអ្នករាល់គ្នាផងដែរ)។ *ពួកទទួលកាត់ស្បែក . . .មិនកាត់ស្បែកវិញ* តាមប្រពៃណីនៃការកាត់ស្បែករបស់សាសន៍យូដាគឺធ្វើឡើងចំពោះតែទារកប្រុសៗ ផ្នែកខាងសាច់ឈាម(ដោយដៃរបស់មនុស្ស) ដែលអាចសំគាល់ឱ្យដឹងថាជាសាសន៍យូដា ឬជាសាសន៍ដទៃ នេះហើយជាទីអំនួតរបស់សាសន៍យូដាពីកំណើតរបស់ខ្លួននោះ ។

**២:១២** *នៅវេលានោះ* គឺជាពេលវេលាមុននឹងទទួលបានសេចក្តីសង្គ្រោះ ដែលផ្ទុយគ្នានឹងពេលនេះ(ខ.១៣)។ *ទីទៃពីព្រះគ្រីស្ទ . . . គ្មានព្រះក្នុងលោកីយនេះ* គ្រប់ទាំងសេចក្តីបញ្ជាក់ត្រង់ឃ្លានេះបានសង្កត់ធ្ងន់លើគម្លាតនៃការមិនជឿរបស់សាសន៍ដទៃ និងសាសន៍អ៊ីស្រាអែល ព្រមទាំងព្រះគ្រីស្ទផងដែរ។ *សេចក្តីសញ្ញា* ជាសេចក្តីសន្យា ថាផ្តល់ព្រះពរទៅដល់សាសន៍យូដា

មានទីសង្ឃឹម[ន] ហើយគ្មានព្រះក្នុងលោកីយនេះដែរ ១៣តែ
ឥឡូវនេះ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ នោះអ្នករាល់គ្នា
ដែលពីដើម[ប]នៅឆ្ងាយបានមកជិតវិញ[ផ] ដោយសារព្រះ
លោហិតទ្រង់[ព] ១៤ដ្បិតទ្រង់ជាស្ពានមេត្រី[ភ]នៃយើងរាល់គ្នា
ទ្រង់បានធ្វើឱ្យទាំង២រួមគ្នាតែ១[ម] ហើយបានរុះជញ្ជាំង
ដែលខាន់កណ្តាលចេញ ១៥ព្រមទាំងបំបាត់[យ]សេចក្តីសំអប់
គ្នា ដោយនូវរូបសាច់ទ្រង់ គឺបំបាត់ក្រិត្យវិន័យដែលមាន
បញ្ញត្ត[រ] នឹងសេចក្តីហាមប្រាមទាំងប៉ុន្មានចេញ ដើម្បីឱ្យ
បានយកទាំង២ មក បង្កើតជាមនុស្សថ្មីតែ១[ល]ក្នុងព្រះអង្គ
ទ្រង់ ដោយតាំងជាស្ពានមេត្រីឱ្យ ១៦ហើយឱ្យទ្រង់បានផ្សះ
ផ្សាទាំង២នឹងព្រះ ក្នុងរូបកាយតែ១ ដោយសារឈើឆ្កាង[វ]
ព្រមទាំងរំងាប់សេចក្តីសំអប់គ្នា ដោយឈើឆ្កាងនោះឯង
១៧ហើយកាលទ្រង់បានយាងមក នោះទ្រង់បានផ្សាយ
ដំណឹងល្អ គឺជាសេចក្តីមេត្រី[ស]ដល់អ្នករាល់គ្នាដែលនៅ
ឆ្ងាយ នឹងដល់ពួកអ្នកដែលនៅជិតផង[ហ] ១៨ដ្បិតដោយ
សារទ្រង់ នោះយើងទាំង២សាសន៍មានផ្លូវ[ឡ]ចូលទៅដល់
ព្រះវរបិតា[អ] ដោយព្រះវិញ្ញាណតែ១[ក] ១៩ដូច្នេះ អ្នករាល់គ្នា
មិនមែនជាអ្នកដទៃ ឬជាអ្នកគ្រាន់តែសំណាក់នៅទៀតទេ[ខ]
គឺជាជាតិតែ១[គ] នឹងពួកបរិសុទ្ធ ជាពួកដំណាក់ព្រះវិញ[ឃ]
២០ដែលបានស្អាងឡើង[ង]លើជើងជញ្ជាំង[ច]នៃពួកសាវក នឹង
ពួកហោរា[ឆ] ហើយព្រះយេស៊ូវគ្រីស្ទនោះឯង[ជ] ទ្រង់ជាថ្ម
ជ្រុងយ៉ាងឯក[ឈ] ២១ដែលដោយសារទ្រង់ ដំណាក់ទាំងមូល
នោះបានផ្គុំភ្ជាប់គ្នា ទាំងចំរើនឡើងជាវិហារបរិសុទ្ធ[ញ]ក្នុង
ព្រះអម្ចាស់ ហើយអ្នករាល់គ្នា ក៏បានស្អាងឡើងក្នុងទ្រង់ដែរ
សំរាប់ជាលំនៅនៃព្រះ ដោយ នូវព្រះវិញ្ញាណ[ដ]។

**២:១២** ន ១ថន ៤:១៣
**២:១៣** ប ខ.២ ផ ខ.១៧ ព កល ១:២០
**២:១៤** ភ ខ.១៥ យហ ១៤:២៧ ម ១កថ ១២:១៣ អភ ៣:៦
**២:១៥** យ កល ១:២១,២២ រ កល ២:១៤ ល កទ ៣:២៨
**២:១៦** វ ២កថ ៥:១៨ កល ១:២០, ២២
**២:១៧** ស លក ២:១៤ ហ ខ.១៣ ទដ ១៤៨:១៤ អស ៥៧:១៩
**២:១៨** ឡ អភ ៣:១២

អ កល ១:១២ ក ១កថ ១២:១៣ អភ ៤:៤ **២:១៩** ខ ខ.១២ គ ភល ៣:២០ ឃ កទ ៦:១០ **២:២០** ង ១កថ ៣:៩ ច មថ ១៦:១៨ ១កថ ៣:១០ វវ ២១:១៤ ឆ អភ ៤:១១ ជ ១កថ ៣:១១ ឈ កថ ៤:១១ ១ពត ២:៤–៨ **២:២១** ញ ១កថ ៣:១៦,១៧ ដ ១កថ ៣:១៦

និងតាមរយៈសាសន៍នេះទៅដល់អ្នកដទៃ (មើលការពន្យល់ រម ៩:៤)។

**២:១៣** *តែឥឡូវនេះ* មិនគ្រាន់តែផ្ទុយគ្នានឹងពាក្យថា"នៅវេលានោះ" (ខ.១២) ប៉ុន្តែ ថែមទាំងផ្ទុយគ្នារវាងពាក្យថា"ទីទៃពីព្រះគ្រីស្ទ ខ.១២"(ដាច់ចេញពីព្រះគ្រីស្ទ) និងពាក្យថា"នៅក្នុងព្រះគ្រីស្ទ"(ខ.១៣)នោះទៀតផង ។ *ព្រះលោហិតទ្រង់* គឺបញ្ជាក់ពី ការសុគតរបស់ព្រះដ៏ឈឺចុកចាប់បំផុតដូចដែលទ្រង់បានបង្ហូរឈាមរបស់ទ្រង់រហូត ដល់អស់ជីវិតដើម្បីលោះបាបរបស់យើង (១:៧ ហពា ៩:៩–១៣ និងការពន្យល់)។

**២:១៤** *ទាំង២* ពាក្យនេះសំដៅលើជំនឿរបស់សាសន៍យូដា និងជំនឿរបស់សាសន៍ដទៃ ។ *បានរុះជញ្ជាំង ដែលខាន់កណ្តាលចេញ* នេះប្រហែលជាសំដៅទៅលើការដាក់រនាំងនៅក្នុងបរិវេណព្រះវិហារក្រុងយេរូសាឡិម ដើម្បីកំណត់កន្លែងថាតើត្រង់ណាខ្លះដែលសាសន៍ដទៃអាចចូលបាន ។ រឿងនេះក៏ត្រូវបានគេធ្លាប់លើកយកមកពិពណ៌នា នូវបទពិសោធន៍នៃការដាច់ពីគ្នាទាំងស្រុង រវាងសាសន៍យូដា និងសាសន៍ដទៃនោះផងដែរ ។

**២:១៥** *ព្រមទាំងបំបាត់ក្រិត្យវិន័យ* តាមគម្ពីរ មថ ៥:១៧ និង រម ៣:៣១ បានឱ្យដឹងថា បទដ្ឋានក្រិត្យក្រមរបស់ព្រះអម្ចាស់បានបញ្ជាក់នៅក្នុងក្រិត្យវិន័យគម្ពីរសញ្ញាចាស់មិនត្រូវបានផ្លាស់ប្តូរដោយការយាងមករបស់ព្រះគ្រីស្ទនោះឡើយ ។ អ្វីដែលត្រូវបានបំបាត់ចោលនៅទីនេះ គឺជា"បញ្ញត្តិ និងសេចក្តីហាមប្រាមផ្សេងៗ" មានន័យថាជាបញ្ញត្តិដែលបានញែកសាសន៍យូដា និងសាសន៍ដទៃឱ្យដាច់ពីគ្នា ដូចជាអស់អ្នកណាដែលមិនប្រតិបត្តិតាមពិធីផ្សេងៗដែលមានចែងក្នុងក្រិត្យវិន័យរបស់ពួកយូដា នោះបណ្តាលឱ្យខ្លួនរបស់ពួកគេត្រឡប់ជាមិនស្អាត(កល ២:១៣–១៤)។ *ដោយនូវរូបសាច់ទ្រង់* ប្រហែលសំដៅទៅលើការសុគតរបស់ព្រះគ្រីស្ទ(មើលការពន្យល់ រម ៨:៣)។ *មនុស្សថ្មីតែ១* គឺរួបរួមជារូបកាយតែមួយរបស់ពួកជំនុំ ។

**២:១៦** *ក្នុងរូបកាយតែ១* ត្រង់នេះអាចនិយាយក្នុងខណៈដែលរូបកាយព្រះគ្រីស្ទបានបូជាលើឈើឆ្កាង(នៅក្នុងរូបសាច់របស់ទ្រង់ ខ.១៥) ប្រហែលជាទាក់ទងទៅនឹង "មនុស្សថ្មីតែ១" ដែលនិយាយពីរូបកាយរបស់អ្នកជឿ(ពួកជំនុំ)។

**២:១៧** *នៅឆ្ងាយ. . .នៅជិតផង* គឺជាគំនិតសាសន៍យូដា និងសាសន៍ដទៃរៀងៗខ្លួន ។

**២:១៩** *ដូច្នេះ* តាមពាក្យនេះ លោកប៉ុលបង្ហាញថា ការរួបរួមបានពិពណ៌នានៅក្នុង ខ.១៩–២២ ដោយពឹងលើព្រះគ្រីស្ទតាមរយៈការសុគតរបស់ទ្រង់ ដូចបានពណ៌នានៅក្នុង ខ.១៤–១៨ ។ *អ្នករាល់គ្នា* កាលណាឃើញពាក្យនេះ នោះគឺសំដៅទៅលើសាសន៍ដទៃនៅឯក្រុងអេភេសូរ ជាពិសេសនៅក្នុងខនេះ ។ *ជាជាតិតែ១. . . ជាពួកដំណាក់ព្រះវិញ* នេះគឺបង្ហាញពីរូបភាពជាមហាក្រុមគ្រួសារមួយ ។ ក្រុមគ្រួសារសម័យបុរាណខុសពីបច្ចុប្បន្ន ដែលយើងអាចហៅថា"គ្រួសារដែលមានឪពុកម្តាយ កូន ជីដូនជីតា មីង ពូ និង ក្មួយៗ។ល។

**២:២០** *លើជើងជញ្ជាំង* នេះជាផ្នែកភាសាបរមត្ថវិជ្ជាដែលនាំទៅរកគំនិតដ៏រឹងមាំ និងការប្រមូលផ្តុំរចនាសម្ព័ន្ធ ។ *ពួកសាវក និងពួកហោរា* ប្រហែលសំដៅទៅលើពួកអ្នកដែលធ្វើការដំបូងផ្នែកគ្រីស្ទបរិស័ទ ។ ពួកសាវក និងពួកហោរាគឺជាពួកអ្នកដែលប្រកាស និងបង្រៀនអំពីព្រះបន្ទូលព្រះ(មើលការពន្យល់ មថ ១៦:១៨ ១កថ ៣:១០–១១)។ *ថ្មជ្រុងយ៉ាងឯក* នៅក្នុងបទគម្ពីរ អស ២៨:១៦ ក៏បានប្រើពាក្យដូចគ្នានេះដែរ នៅសម័យគ្រីស្ទបរិស័ទដំបូងដែលបកប្រែជាភាសាក្រិក (the Septuagint) ដែលមានជាប់ទាក់ទងទៅនឹងការកសាងជញ្ជាំង ដោយយកថ្ម "សាកល្បង" មកដាក់ នឹងជ្រុងជើងជញ្ជាំង ។

**២:២១** *បានផ្គុំភ្ជាប់គ្នា* នៅក្នុង ៤:១៦ បានប្រើពាក្យដូចគ្នា។ អត្ថបទទាំងពីរវគ្គនេះ បាននិយាយពីភាពទំនាក់ទំនងយ៉ាងជិតស្និទ្ធក្នុងចំណោមអ្នកជឿ ។ *ចំរើនឡើង* នេះគឺជាការពណ៌នាអំពីសំណង់ដែលកំពុងសាងសង់ ដោយនាំទៅរកគំនិតនៃការរីកចម្រើនឡើងយ៉ាងឆាប់រហ័សនៃពួកជំនុំ ។ *ជាវិហារបរិសុទ្ធ* លោកប៉ុលលើករូប ភាពព្រះវិហារដើម្បីប្រៀបធៀបបង្ហាញពីបំណង "ដែលយើងត្រូវក្លាយជា" របស់ព្រះអម្ចាស់ ដែលទ្រង់បានដាំពួកជំនុំរបស់ទ្រង់ (១កថ ៣:១៦ និងការពន្យល់)។ *ជាលំនៅ* ពួកជំនុំនឹងត្រូវបានធ្វើជារាស្ត្រ ឬសហគមន៍ដែលមានព្រះវិញ្ញាណ បរិសុទ្ធសណ្ឋិតនៅខាងក្នុងចិត្ត(២កថ ៦:១៦ និងការពន្យល់)។

## ការផ្សាយដំណឹងល្អរបស់សាវ័កប៉ុលដល់សាសន៍ដទៃ

**៣** ១ហេតុនោះបានជាប៉ុលខ្ញុំ ជាសិស្សរបស់ព្រះយេស៊ូវ
គ្រីស្ទ ដែលខ្ញុំជាប់គុកនេះ[ឋ] ដើម្បីជាប្រយោជន៍ដល់អ្នករាល់
គ្នា ជាពួកសាសន៍ដទៃ ២[ឌ]គឺបើតិចណាស់ អ្នករាល់គ្នាបានឮ
និយាយពីការត្រួតត្រារបស់ព្រះគុណនៃព្រះ ដែលបាន
ប្រទានមកខ្ញុំ[ឍ]សំរាប់អ្នករាល់គ្នាថា ៣ទ្រង់បានធ្វើឱ្យខ្ញុំស្គាល់
ការអាថ៌កំបាំង[ឈ] ដោយការបើកសំដែង[ណ] ដូចជាខ្ញុំសរសេរ
យ៉ាងខ្លីពីកាលមុនដែរ ៤កាលណាអ្នករាល់គ្នាមើលសំបុត្រ
នោះ នោះនឹងអាចយល់ពីចំណេះខ្ញុំ[ត] ខាងឯការអាថ៌កំបាំង
របស់ព្រះគ្រីស្ទបាន ៥ជាការអាថ៌កំបាំងដែលកាលនៅអស់
ទាំងគ្រាជាន់មុន មិនបានប្រទានឱ្យពួកមនុស្សជាតិស្គាល់
ដូចជាបានសំដែងមកឱ្យពួកសាវក និងពួកហោរាបរិសុទ្ធ
ស្គាល់ ដោយសារព្រះវិញ្ញាណសព្វថ្ងៃនេះទេ[ថ] ៦[ទ]គឺដែលពួក
សាសន៍ដទៃ បានត្រឡប់ជាអ្នកគ្រងមរដក[ទ]ជាមួយគ្នា និងជា
រូបកាយជាមួយគ្នា[ធ] ហើយជាអ្នកទទួលចំណែកនៃសេចក្តី
សន្យារបស់ទ្រង់ ជាមួយគ្នាក្នុងព្រះគ្រីស្ទដែរ ដោយសារ
ដំណឹងល្អ[ន] ៧ខ្ញុំបានធ្វើជាអ្នកបំរើដំណឹងល្អនោះ[ប] តាមព្រះ
គុណនៃព្រះ ជាអំណោយទានដែលទ្រង់ប្រទានមកខ្ញុំ[ផ] តាម
ដែលព្រះចេស្តាទ្រង់ពូកែនឹងធ្វើ[ព] ៨ទ្រង់បានប្រទានព្រះ
គុណនេះ គឺជាសម្បត្តិរបស់ព្រះគ្រីស្ទដ៏ប្រមាណមិនបាន[ភ]
មកខ្ញុំដែលជាអ្នកតូចជាងបំផុត ក្នុងពួកបរិសុទ្ធទាំងអស់[ម]
ឱ្យខ្ញុំបានផ្សាយ ដំណឹងល្អក្នុងពួកសាសន៍ដទៃ[យ] ៩ហើយឱ្យ
ខ្ញុំបានបំភ្លឺដល់គ្រប់មនុស្សទាំងអស់ ពីសេចក្តីប្រកបក្នុង
ការអាថ៌កំបាំង[រ] ដែលលាក់ទុកក្នុងព្រះ តាំងពីអស់កល្ប
រៀងមក ជាព្រះដែលទ្រង់បង្កើតរបស់សព្វសារ ពើដោយ
សារព្រះយេស៊ូវគ្រីស្ទ ១០ដើម្បីឱ្យពួកគ្រប់គ្រង និងពួកមាន

**៣:១** ឋ កច ២៣:១៨
អភ ៤:១ ២ធថ ១:៨
អភ ៤:១ ២ធថ ១:៨
ភម ១,៩
**៣:២** ឌ កល ១:២៥
**៣:៣** ឈ រម ១៦:២៥
ណ ១កថ ២:១០
**៣:៤** ត ២កថ ១១:៦
**៣:៥** ថ រម ១៦:២៦
អភ ៤:១១
**៣:៦** ទ រម ៨:១៧
ធ អភ ២:១៥,១៦
ន អរ ៤៧:២២
**៣:៧** ប ១កថ ៣:៥
ផ រម ១២:៣
ព អភ ១:១៩
កល ១:២៩
**៣:៨** ភ កច ៩:១៥
ម រម ២:៤ យ ១កថ ១៥:៩ **៣:៩** រ រម ១៦:២៥

---

**៣:១-១៣** មនុស្សម្នាក់ៗបានទទួលសេចក្តីសង្គ្រោះគឺដោយសារព្រះគុណរបស់ព្រះ (២:១-១០) ហើយពួកគេម្នាក់ៗនោះក៏ស្រុះស្រួលនឹងគ្នាឡើងវិញ ព្រមទាំងជាមួយ និងព្រះអម្ចាស់ផងនោះ ក៏ដោយសារការសុគតរបស់ព្រះគ្រីស្ទនោះដែរ (២:១១-២២)។ ព្រះអម្ចាស់បង្រួបបង្រួមពួកគេឱ្យមានភាពស្មើគ្នានៅក្នុងរូបកាយរបស់ទ្រង់គឺជាពួកជំនុំ ។ នៅក្នុងជំហាននេះ គឺជាផែនការដ៏អស់កល្បរបស់ព្រះអម្ចាស់ដែលមិនទាន់បើកសំដែងឱ្យបានពេញលេញនៅឡើយ កាលពេលមុនដែលលោកប៉ុល ហៅថាជា "ការអាថ៌កំបាំង"។

**៣:១** *ដើម្បីជាប្រយោជន៍* គឺសំដៅទៅលើគ្រប់ការទាំងអស់ដែលព្រះអម្ចាស់បានធ្វើ (មានពន្យល់នៅខមុនៗ)។ *ដែលខ្ញុំជាប់គុក* តាមគម្ពីរ កច ២៨:១៦ និងមើលការពន្យល់ កច ២៨:១៦ បានឱ្យដឹងយ៉ាងច្បាស់ថា លោកប៉ុលត្រូវគេឃុំនៅក្នុងផ្ទះមួយនៅពេលគាត់សរសេរសំបុត្រនេះ ។ *របស់ព្រះយេស៊ូវគ្រីស្ទ* ការដែលសាច់ឈាមរបស់លោកប៉ុលជាប់គុកនេះ គឺដោយសារតែគាត់ស្តាប់បង្គាប់ដល់ព្រះយេស៊ូវគ្រីស្ទ ទោះបើមានគេជំទាស់ក៏ដោយ ។ បន្ទាប់ពីខនេះ លោកប៉ុលបានចែកចាយពីបទពិសោធន៍របស់គាត់"ពីការអាថ៌កំបាំង" (ខ.៤-១៤)។

**៣:២** *អ្នករាល់គ្នាបានឮនិយាយ* អ្នកក្រុងអេភេសូរភាគច្រើនបានឮ និងដឹងពីកិច្ចការរបស់លោកប៉ុល ដោយសារតែគាត់បានស្នាក់នៅទីនោះយ៉ាងយូរតាំងពីដំបូងមកម្ល៉េះ ។ តែទោះបីជាយ៉ាងនេះក៏ដោយ ក៏សំបុត្រមួយនេះបានផ្ញើមកដល់ពួកជំនុំ ផ្សេងទៀតដែលមិនទាន់បានស្គាល់គាត់ច្បាស់នោះដែរ (មើលការពន្យល់ ១:១)។ *ពីការត្រួតត្រា* លោកប៉ុលបានពន្យល់ពីផែនការត្រួតត្រារបស់ព្រះមកលើពួកជំនុំ និងលើពិភពលោកទាំងមូលនៅក្នុងសំបុត្រនេះ ជាពិសេសក្នុង "១:៣-១២" ទ្រង់ត្រូវបានប្រទាននូវការទទួលខុសត្រូវយ៉ាងសំខាន់ក្នុងការអនុវត្តន៍ផែនការនេះ ។

**៣:៣** *ការអាថ៌កំបាំង* មានសេចក្តីពិតមួយត្រូវបានបើកសំដែងឱ្យដឹងតាមតែរយៈព្រះអម្ចាស់តែមួយអង្គគត់ (ខ.៥ រម ១៦:២៥ និងមើលការពន្យល់ រម ១១:២៥ កល ១:២៦)។ ពាក្យ "អាថ៌កំបាំង" នេះបង្កប់ន័យពិសេសមួយ គឺថាជាផែនការដ៏ជាប្រាជ្ញាញាណរបស់ព្រះដែលចែងនៅក្នុងគម្ពីរអេភេសូរនេះ គឺបានបង្រួបបង្រួមអ្នកជឿសាសន៍យូដា និងអ្នកជឿសាសន៍ដទៃឱ្យមកជារូបកាយថ្មីតែមួយ នោះគឺជាពួកជំនុំ (មើល ខ.៦)។ វាអាចជាគំនិតនៃភាពសម្ងាត់មួយថា ជាការអាថ៌កំបាំង បណ្តោះអាសន្ន ប៉ុន្តែ លើសពីនេះទៀតនោះ វាជាផែនការរបស់ព្រះដែលទ្រង់ កំពុងតែបើកសំដែងម្តងមួយដំណាក់កាលៗ (១:៩-១០ វវ ១០:៧)។ *ការបើក សំដែង* មើល កល ១:១២ ។ *ខ្ញុំសរសេរយ៉ាងខ្លីពីកាលមុន* គឺនៅក្នុង ១:៩-១០ ។

**៣:៥** *នៅអស់ទាំងគ្រាជាន់មុន មិនបានប្រទានឱ្យពួកមនុស្សជាតិស្គាល់* មើលការពន្យល់ ខ.៦ ។ *បរិសុទ្ធ* មានន័យថា ញែកដោយឡែកសម្រាប់កិច្ចការព្រះអម្ចាស់ ។ *ពួកសាវក និងពួកហោរាបរិសុទ្ធ* មើលការពន្យល់ ២:២០ ។ ទោះជាលោកប៉ុលជាអ្នកទទួលកិច្ចការដ៏សំខាន់នេះក៏ដោយ ក៏អ្នកផ្សេងទៀតអាចទទួលពីព្រះអម្ចាស់បានដូចគ្នាផងដែរ ។

**៣:៦** *ជាមួយគ្នា . . . ជាមួយគ្នា . . . ជាមួយគ្នា* ការប្រើពាក្យដដែលៗនេះគឺបង្ហាញពីទិដ្ឋភាពតែមួយនៃភាពអាថ៌កំបាំងដែលមិនធ្លាប់បានដឹងឮពីមុនមក។ ការដែលមិនធ្លាប់បានដឹងពីមុននោះគឺ ភាពស្មើគ្នាទៅវិញទៅមករវាងសាសន៍យូដា និងសាសន៍ដទៃនៅក្នុងពួកជំនុំ ដែលជារូបកាយតែមួយក្នុងព្រះគ្រីស្ទ។ សាសន៍ដទៃទាំងឡាយណាបែរមករកព្រះរបស់អ៊ីស្រាអែលនោះនឹងបានសង្គ្រោះ នេះបើតាមសេចក្តីថ្លែងទំនាយនៅក្នុងគម្ពីរសញ្ញាចាស់ (មើល រ៉ូម ១៥:៩-១២)។ ត្រង់នេះបញ្ជាក់ថាពួកគេបានក្លាយជាសរីរាង្គនៃរូបកាយតែមួយជាមួយនឹងសាសន៍យូដា ដោយសារសេចក្តីជំនឿលើទ្រង់។ *អ្នកគ្រងមរដក* មើលការពន្យល់ ១:១៨ ។

**៣:៧** *ព្រះគុណនៃព្រះជាអំណោយទាន . . . ប្រទានមកខ្ញុំ* មើលពន្យល់ ខ.២។

**៣:៨** *ដែលជាអ្នកតូចជាងគេបំផុត* មើលការពន្យល់ ១ធថ ១:១៥ ។ លោកប៉ុលមិនដែលបោះបង់ការដ៏អស្ចារ្យណាមួយឱ្យត្រឡប់ទៅជាគ្មានប្រយោជន៍នោះទេ ឱ្យសមនឹងការដែលព្រះបានត្រាស់ហៅគាត់ឱ្យធ្វើការដ៏ធំ ។ ភាពរម្យទម (ការបន្ទាបខ្លួន) របស់គាត់នៅត្រង់នេះ សូម្បីតែយើងនៅបច្ចុប្បន្ននេះប្រហែលជាមិនអាចវាយតម្លៃលើខ្លួនឯងដូចនេះណាស់ ។ *ព្រះគុណ* ក្នុងករណីនេះជាទេយ្យទានពិសេសមួយ ដែលនាំមកនូវការទទួលខុសត្រូវសម្រាប់ការបម្រើ ។

**៣:៩** *ពីសេចក្តីប្រកបក្នុងការអាថ៌កំបាំង* មើលការពន្យល់ ខ.២ និង ខ.៣ ។

អំណាច[ល]នៅស្ថានដ៏ខ្ពស់[វ] បានស្គាល់[ស]ពីប្រាជ្ញានៃព្រះដ៏
មានជាច្រើនយ៉ាងណាស់[ហ] ដោយសារពួកជំនុំ ១១តាមគំ
និតសំរេចតាំងពីអស់កល្បរៀងមក[ឡ] ដែលទ្រង់បានគិត
ស្រេចក្នុងព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើង ១២ហើយ
ក្នុងទ្រង់ យើងរាល់គ្នាក៏មានសេចក្ដីក្លាហាន នឹងច្បាប់ចូល[អ]
ដោយទុកចិត្ត ដោយសារសេចក្ដីជំនឿជឿដល់ទ្រង់ដែរ[ក]
១៣ហេតុនោះបានជាខ្ញុំសូមអង្វរអ្នករាល់គ្នា កុំឱ្យរសាយ
ចិត្តដោយការដែលខ្ញុំរងទុក្ខលំបាក ជាការដែលមាន
ប្រយោជន៍ដល់អ្នករាល់គ្នានោះឡើយ ដ្បិតការនោះជា
សិរីល្អដល់អ្នករាល់គ្នាទេ។

## ការអធិស្ឋានសម្រាប់ពួកជំនុំនៅក្រុងអេភេសូរ

១៤ដោយហេតុនោះបានជាខ្ញុំលុតជង្គង់[ខ] នៅចំពោះព្រះ
វរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា
១៥ដែលគ្រប់ទាំងគ្រួនៅស្ថានសួគ៌ ហើយនៅផែនដី មាន
នាមត្រកូលពីទ្រង់មក ១៦ដើម្បីឱ្យទ្រង់បានប្រោសប្រទានឱ្យ
អ្នករាល់គ្នាបានព្រះចេស្ដា[គ] ចំរើនកំឡាំងនៃមនុស្សខាង
ក្នុង[ឃ] ដោយសារព្រះវិញ្ញាណទ្រង់ តាមសិរីល្អនៃទ្រង់
ដ៏ប្រសើរក្រៃលែង[ង] ១៧ឱ្យព្រះគ្រីស្ទបានសណ្ឋិតក្នុងចិត្តអ្នក
រាល់គ្នា[ច] ដោយសារសេចក្ដីជំនឿ ប្រយោជន៍ឱ្យអ្នករាល់គ្នា
បានចាក់ឫស[ឆ] ហើយតាំងមាំមួន ក្នុងសេចក្ដីស្រឡាញ់
១៨ដើម្បីឱ្យអាចនឹងយល់ ជាមួយនឹងពួកបរិសុទ្ធទាំងអស់គ្នា[ជ]
ពីទទឹង បណ្ដោយ ជំរៅ និងកំពស់នៃសេចក្ដីស្រឡាញ់
នោះ[ឈ] ១៩ហើយឱ្យបានស្គាល់សេចក្ដីស្រឡាញ់របស់ព្រះ
គ្រីស្ទដ៏រកគិតមិនយល់[ញ]ប្រយោជន៍ឱ្យអ្នករាល់គ្នាបានពេញ[ដ]
ដល់គ្រប់ទាំងសេចក្ដីពោរពេញរបស់ផងព្រះ[ឋ]។
២០ឯព្រះដែលទ្រង់អាច[ឌ]នឹងធ្វើហួសសន្ធឹក លើសជាង
អស់ទាំងសេចក្ដីដែលយើងសូម[ឍ] ឬគិតក្ដី តាមព្រះចេស្ដា[ណ]
ដែលបណ្ដាលក្នុងយើងរាល់គ្នា ២១នោះសូមឱ្យទ្រង់បាន
សិរីល្អ នៅក្នុងពួកជំនុំ ដោយសារព្រះគ្រីស្ទយេស៊ូវ រហូត
ដល់គ្រប់ទាំងដំណមនុស្ស នៅអស់កល្បជានិច្ចរៀងរាប
តទៅ ។ អាម៉ែន[ត]។

**៣:១០** ល អក ១:២១ ៦:១២ កល ២:១០,១៥ វ អក ១:៣ ស រម ១១:៣៣ ១កថ ២:៧ ហ ១ពត ១:១២ **៣:១១** ឡ អភ ១:១១ **៣:១២** អ អភ ២:១៨ ក ២កថ ៣:៤ ហព ៣:១៤ ៤:១៦ ១០:១៩,៣៥ ១យហ ២:២៨ ៣:២១ ៤:១៧ **៣:១៤** ខ ភល ២:១០ **៣:១៦** គ ខ.៨ រម ២:៤ ឃ ភល ៤:១៣ ង រម ៧:២២ **៣:១៧** ច រម ៨:១០ ឆ កល ២:៧ **៣:១៨** ជ អភ ១:១៥ ឈ យប ១១:៨,៩ ទដ ១០៣:១១ **៣:១៩** ញ ភល ៤:៧ ដ កល ២:១០ ឋ អភ ១:២៣ **៣:២០** ឌ រម ១៦:២៥ ២កថ ៩:៨ ឍ ១ពវ ៣:១៣ ណ ខ.៧ **៣:២១** ត រម ១១:៣៦ **៤:១** ថ អភ ៣:១ ទ ភល ១:២៧ កល ១:១០ ១ធថ ២:១២ ធ រម ៨:២៨

**៣:១០** *ដោយសារពួកជំនុំ* នេះជាការពិតដែលព្រះអម្ចាស់បានធ្វើ ដែលមើលទៅហាក់បីដូចជាមិនអាចទៅរួចក្នុងការផ្សះផ្សា និងការបង្រួបបង្រួមរូបកាយឱ្យមកតែមួយរវាងសាសន៍យូដា និងសាសន៍ដទៃដែលមាននៅក្នុងពួកជំនុំ គឺធ្វើឱ្យពួកជំនុំបានគ្រប់លក្ខណ៍ដើម្បីសំដែងពីប្រាជ្ញារបស់ព្រះអម្ចាស់ ។ *ដ៏មានជាច្រើនយ៉ាងណាស់* គឺជាស្នាមពណ៌ ឬមានជ្រុងច្រើន (ដូចជាពេជ្រមួយដុំដែលមានគ្រប់ជ្រុងមានពន្លឺភ្លឺព្រោងព្រាតចិញ្ចាចគ្រប់ទិស)។ *ពួកគ្រប់គ្រង នឹងពួកមានអំណាច* ព្រះគ្រីស្ទទ្រង់មានអំណាចលើពួកទាំងអស់នេះ (១:២០–២១)។នេះគឺជាគំនិតដែលសំដែងពីដំណាក់នៃពួកជំនុំនៅលើផែនដីដោយអំណាចខាងឯវិញ្ញាណ និងជាកម្រិតដែលបង្ហាញពីការរួបរួម និងជារូបភាពបង្ហាញពីប្រាជ្ញារបស់ព្រះ ។ នេះជាគំនិតសំខាន់មួយដែលធ្វើឱ្យយើងយល់ពីអត្ថន័យនៃការត្រាស់ហៅ (៤:១)។ *នៅស្ថានដ៏ខ្ពស់* មើលពន្យល់ ១:៣

**៣:១១** *តាមគំនិតសំរេចតាំងពីអស់កល្បរៀងមក* នេះបង្ហាញពីភាពដឹកនាំដ៏មានប្រសិទ្ធភាពរបស់ព្រះគ្រីស្ទ ដើម្បីឱ្យមានការរួបរួមក្នុងពួកជំនុំ ហើយនេះគឺជាការរៀបចំបម្រុងទុកមួយសម្រាប់ការកាន់កាប់ត្រួតត្រាលើពិភពនេះទាំងមូល ក្នុងកាលដែលពេលកំណត់របស់ទ្រង់បានមកដល់ (១:១០)។

**៣:១២** មើល ហព ៤:១៦ ១០:១៩–២២ និងការពន្យល់ ។

**៣:១៤–២១** នេះគឺជាសេចក្ដីអធិស្ឋានរបស់លោកប៉ុលដល់អ្នកក្រុងអេភេសូរឱ្យមានការធំលូតលាស់ និងឱ្យបានដឹងថាព្រះអម្ចាស់ទ្រង់កំពុងតែធ្វើការ នៅក្នុងចិត្តអ្នកជឿគ្រប់គ្នា ។ អំណោយទានសំខាន់របស់ព្រះអម្ចាស់ដែលបានប្រទានមកដល់អ្នកជឿនោះគឺ "ព្រះចេស្ដា (ខ.១៦,១៨,២០) និងសេចក្ដីស្រលាញ់ (ខ.១៧–១៩)"។

**៣:១៤** *ដោយហេតុនោះ* នេះគឺជាហេតុផលមួយដែលបាននិយាយក្នុងខ.១ ។ *ខ្ញុំលុតជង្គង់* គឺសំដែងពីសន្ដានចិត្ត និងការយកចិត្តទុកដាក់យ៉ាងខ្លាំងរបស់លោកប៉ុល ក្នុងខណៈដែលបណ្ដាជននៅសម័យនោះជាធម្មតា គេតែងតែឈរអធិស្ឋាន ។

**៣:១៥** *គ្រប់ទាំងគ្រួ* ពាក្យនេះជាភាសាក្រិកគឺមានន័យដូចគ្នានឹងពាក្យថា "ឪពុក" បើដូច្នេះអាចនិយាយបានថា "ជាគ្រួសារ" ដែលមាននាមត្រកូលមកពីខាង "ឪពុក"។ ព្រះអម្ចាស់នៃយើងរាល់គ្នាគឺជាឪពុករបស់យើង ដូច្នេះយើងអាចថ្វាយដាច់ដល់ទ្រង់នូវសេចក្ដីអធិស្ឋានរបស់យើងយ៉ាងកក់ក្ដៅ ។

**៣:១៦** *មនុស្សខាងក្នុង* មើលខ.១៧ និងការពន្យល់ ២កថ ៤:១៦ ។

**៣:១៧** *សណ្ឋិត* មានន័យថា តាំងលំនៅយ៉ាងពិតប្រាកដដូចជានៅផ្ទះដែរ ។ ព្រះគ្រីស្ទបានគង់នៅក្នុងជីវិតអ្នកជឿ នៅក្រុងអេភេសូរនោះរួចហើយ (រម ៨:៩)។ *ក្នុងចិត្ត* មានន័យថា ខាងក្នុងខ្លួនមនុស្សទាំងមូល ។

**៣:១៨** សូមមើលខយោង រម ៨:៣៥–៣៩ ។

**៣:១៩** *ដ៏រកគិតមិនយល់* ឃ្លានេះពុំមែនមានន័យថា មិនដឹងមិនយល់នោះទេ តែមានន័យថា ធំពេកក្រៃដែលមិនអាចយល់អស់បាន ។ *សេចក្ដីពោរពេញ* គ្មាននរណាម្នាក់ អាចកំណត់បានពីព្រះហឫទ័យរបស់ទ្រង់បានទេ ដូចជាសេចក្ដីស្រឡាញ់នេះជាដើម ។

**៣:២០** *ធ្វើហួសសន្ធឹក* ត្រង់នេះប្រហែលសំដៅទៅលើព្រឹត្តិការណ៍ជាក់លាក់ណាមួយដែលបានកើតឡើងនៅក្នុងក្រុងអេភេសូរ ប៉ុន្តែ មិនត្រូវបានដឹងថាដល់កម្រិតណានោះទេ ។ *តាមព្រះចេស្ដា* មើល ១:១៩–២១ ។

**៣:២១** *សូមឱ្យទ្រង់បានសិរីល្អ* នេះជាបំណងចុងក្រោយបំផុតរបស់យើង (មើលការពន្យល់ ១:៦)។ *នៅក្នុងពួកជំនុំ ដោយសារព្រះគ្រីស្ទយេស៊ូវ* នេះគឺជាការមួយដែលគួរឱ្យចាប់អារម្មណ៍ដោយឃើញពួកជំនុំ និងព្រះគ្រីស្ទនៅជាប់គ្នាជានិច្ចនោះ ។ ព្រះអម្ចាស់បានត្រាស់ហៅពួកជំនុំឱ្យមានតួនាទី និងកិច្ចការយ៉ាងពិសេសលើសពីធម្មតា (ខ.១០ ៤:១)។

## ការបង្រួបបង្រួមនៅក្នុងរូបកាយព្រះគ្រីស្ទ

**៤** 1 ដូច្នេះ ខ្ញុំជាអ្នកជាប់គុក[ថ]ក្នុងព្រះអម្ចាស់ ខ្ញុំទូន្មានអ្នក
រាល់គ្នាថា ចូរឱ្យអ្នករាល់គ្នាដើរបែបគួរ[ទ]នឹងការងារ
ដែលទ្រង់បានហៅ[ធ]មកធ្វើចុះ 2 ព្រមទាំងមានចិត្តសុភាព
ហើយស្លូតបូតគ្រប់ជំពូក ទាំងអត់ធ្មត់ ហើយទ្រាំទ្រគ្នាទៅ
វិញទៅមក[ន] ដោយស្រឡាញ់[ប] 3 ហើយខំប្រឹងរក្សាសេចក្តី
រួបរួមគ្នា[ផ]របស់ព្រះវិញ្ញាណ ដោយសេចក្តីមេត្រី ទុកជា
ចំណងផង[ព] 4 មានរូបកាយតែ១[ភ] ហើយព្រះវិញ្ញាណតែ១[ម]
ដូចជាទ្រង់បានហៅ[យ]អ្នករាល់គ្នាមក ក្នុងសេចក្តីសង្ឃឹម
តែ១ របស់ការងារអ្នករាល់គ្នាដែរ 5 មានព្រះអម្ចាស់
តែ១[រ] សេចក្តីជំនឿតែ១ បុណ្យជ្រមុជតែ១ 6 មានព្រះតែ១
គឺជា ព្រះវរបិតានៃទាំងអស់[ល] ដែលទ្រង់ខ្ពស់លើទាំងអស់
គង់ នៅកណ្តាលទាំងអស់ ហើយសណ្ឋិតនៅក្នុងទាំងអស់[វ]
7 តែមានព្រះគុណ[ស]ផ្តល់[ហ] មកយើងរាល់គ្នារៀងរាល់ ខ្លួន[ឡ]
តាមខ្នាតអំណោយទាននៃព្រះគ្រីស្ទ 8 បានជាទ្រង់មាន
បន្ទូលថា «ដែលបានយាងឡើងទៅស្ថានខ្ពស់ នោះទ្រង់
បាន ចាប់ពួកឈ្លើយនាំទៅជាឈ្លើយ[អ] ហើយបានប្រទាន
អំណោយទានដល់មនុស្ស»[ក] 9 តែដែលថា ទ្រង់យាងឡើង
ទៅនោះ តើមានន័យដូចម្តេច បើមិនមែនថា ទ្រង់បានយាង
ចុះទៅដល់ស្ថានទាបក្រោមដីជាមុនប៉ុណ្ណោះ 10 ឯព្រះដែល
យាងចុះទៅនោះ[ខ] គឺជាព្រះដដែល ដែលបានយាងឡើង
ផុតអស់ទាំងជាន់នៅស្ថានសួគ៌[គ] ដើម្បីឱ្យទ្រង់បានគង់នៅ
ពេញគ្រប់ទាំងអស់ 11 ហើយទ្រង់បានប្រទានឱ្យ[ឃ]អ្នកខ្លះបាន

**៤:២** ន កល ៣:១២,១៣ ប ៦.១៥,១៦ អភ ១:៤
**៤:៣** ផ រម ១៥:៥ ព កល ៣:១៥
**៤:៤** ភ រម ១២:៥ ម ១កថ ១២:១៣ អភ ២:១៨ យ រម ៨:២៨
**៤:៥** រ ១កថ ៨:៦
**៤:៦** ល ចទ ៦:៤ សក ១៤:៩ វ រម ១១:៣៦
**៤:៧** ស រម ៣:២៤ ហ រម ១២:៣ ឡ ១កថ ១២:៧,១១
**៤:៨** អ កល ២:១៥ ក ទដ ៦៨:១៨ **៤:១០** ខ សភ ៣០:១–៤ គ អភ ១:២៣ **៤:១១** ឃ ៦.៨

**៤:១–៣២** តាមពិតជំពូកនេះចាប់ផ្តើមឡើងពី៦.២ ហើយបញ្ចប់ទៅវិញនៅ ៦.៣២ ដោយពាក្យដាស់តឿនរំលឹកឱ្យចេះអត់ទោស និងស្រលាញ់ដល់គ្នាទៅវិញទៅមក ។

**៤:១–១៦** មកដល់ពេលនេះលោកប៉ុលបានបង្រៀនថា ព្រះអម្ចាស់បាននាំសាសន៍យូដា និងសាសន៍ដទៃ ឱ្យចូលមករកទំនាក់ទំនងថ្មីជាមួយគ្នានៅក្នុងពួកជំនុំ ។ ហេតុដូច្នេះហើយបានជាទ្រង់មានបន្ទូលថា ពួកជំនុំជាកន្លែងបង្ហាញពីប្រាជ្ញារបស់ទ្រង់ ។ លើសពីនេះទៅទៀត លោកប៉ុលនឹងបង្ហាញអំពីរបៀបដែលព្រះអម្ចាស់បានផ្គត់ផ្គង់ដល់ពួកអ្នកជឿ ដើម្បីឱ្យពួកជំនុំបានរស់ និងរួមគ្នាបន្តធ្វើការទៅមុខទៀតឱ្យបានធំ លូតលាស់ជាគ្រីស្ទបរិស័ទពេញវ័យខាងឯជំនឿ ។

**៤:១** *អ្នកជាប់គុក* មើលការពន្យល់ ៣:១។ *ហៅ* មើល ៣:១០,២១ និងការពន្យល់ ។

**៤:៣** *ខំប្រឹងរក្សាសេចក្តីរួបរួមគ្នា* នេះជាលទ្ធផលដែលព្រះអម្ចាស់ផ្សះផ្សាយើងគ្រប់គ្នា ដោយការសុគតរបស់ព្រះគ្រីស្ទនោះ(២:១៤–២២)។ វាជាការទទួលខុសត្រូវដ៏ធំធេងសម្រាប់គ្រីស្ទបរិស័ទ ដើម្បីរក្សានូវការរួបរួមគ្នាឱ្យរួចពីការបែកបាក់នោះ ។

**៤:៤** *ក្នុងសេចក្តីសង្ឃឹមតែ១* ត្រង់ចំណុចនេះមានទិដ្ឋភាពខុសៗគ្នា(១:៥,១០ ២:៧) ប៉ុន្តែវានៅតែមានសង្ឃឹមតែមួយដោយតភ្ជាប់ទៅនឹងសិរីរុងរឿងរបស់ព្រះគ្រីស្ទនាពេលអនាគត ក្នុងកាលដែលអ្នកជឿទាំងអស់បានចូលរួមចំណែកជាមួយនឹងគ្នា ។

**៤:៥** *បុណ្យជ្រមុជតែ១* ត្រង់នេះប្រហែលជាមិនជ្រមុជដោយព្រះវិញ្ញាណនោះទេ(១កថ ១២:១៣) តែជាការជ្រមុជផ្នែកខាងក្នុងចិត្ត បានជាមើលមិនឃើញ ប៉ុន្តែជាពិធីបុណ្យជ្រមុជទឹក(មើលការពន្យល់ រម ៦:៣–៤)។ ដោយសារលោកប៉ុលបានកំណត់យ៉ាងច្បាស់ថា នៅក្នុងចំណោមអ្នកជឿទាំងអស់គឺជាកម្មសិទ្ធិដល់គ្នាទៅវិញ ទៅមកដោយគាត់សំអាងទៅលើបទបញ្ញត្តិរបស់ពួកជំនុំថា អ្នកដែលទើបនឹងជឿថ្មី គ្រប់រូបត្រូវតែចូលរួមចំណែកកិច្ចការសាធារណៈ ។ នៅសម័យនោះគ្រីស្ទបរិស័ទបានធ្វើការងារសំខាន់ៗរួមគ្នាជាក់ស្តែងជាងគ្រីស្ទបរិស័ទនាពេលបច្ចុប្បន្ន ទោះបីជាគេធ្វើពិធីនោះផ្សេងៗពីគ្នាក៏ដោយ ក៏ធ្វើរួមគ្នានៅក្នុងតែពួកជំនុំនោះដែរ ។

**៤:៧** *ព្រះគុណ* មើល ៣:៧–៨ ។

**៤:៨** មើល ទដ ៦៨:១៨ (និងការពន្យល់នៅទីនោះ) បានថែងពីការប្រទាននូវជ័យជម្នះរបស់ព្រះអម្ចាស់ មកដល់បល្ល័ង្ករបស់ទ្រង់នៅក្នុងព្រះវិហារនៃក្រុងយេរូសាឡិម(នេះជានិមិត្តរូបនៃបល្ល័ង្ករបស់ទ្រង់នៅឯស្ថានសួគ៌)។ លោកប៉ុលបានបញ្ជាក់បន្ថែមថា នេះគឺជាការប្រទានមកនូវភាពជ័យជម្នះរបស់ព្រះគ្រីស្ទយេស៊ូវមកពីស្ថានសួគ៌។ នៅក្នុងបទគម្ពីរទំនុកដំកើងថែងបន្ថែមទៀតថា "ព្រមទាំងទទួលអំណោយទានសម្រាប់ចែកឱ្យដល់មនុស្ស" (លប ១៥:៩ ១៨:៥ ២៧:១៣ នក ២៥:២ ១ពវ ១៧:១០–១១)។ *ពួកឈ្លើយ* ត្រង់នេះប្រហែលជា លោកប៉ុលនិយាយសំដៅទៅលើសត្រូវខាងឯវិញ្ញាណដែលត្រូវបរាជ័យដោយការសុគតរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាង ។

**៤:៩** *យាងឡើង...យាងចុះ* នៅត្រង់នេះលោកប៉ុលបានដកស្រង់ចេញពីគម្ពីរទំនុកដំកើងមកដើម្បីណែនាំពីគំនិតដែលថា "អំណោយទានសម្រាប់មនុស្ស" ហើយ នេះក៏ជាឱកាសមួយដើម្បីរំលឹកដល់អ្នកអានរបស់លោកអំពីការយាងចុះមកលើ ផែនដីរបស់ព្រះយេស៊ូវគ្រីស្ទ(ការចាប់កំណើតជាមនុស្សរបស់ទ្រង់) និងការដែលទ្រង់មានព្រះជន្មរស់ឡើងវិញ ក៏ដូចជាការយាងឡើងទៅស្ថានសួគ៌វិញផងដែរ ។ នៅក្នុងបទគម្ពីរនេះប្រហែលជាមិនបង្រៀន ឬមានគំនិត ឬក៏ជាការបកប្រែដែលនិយាយអំពីព្រះគ្រីស្ទយាងចុះទៅស្ថាននរកនោះទេ ។

**៤:១១** *ហើយទ្រង់បានប្រទានឱ្យ អ្នកខ្លះបានធ្វើជា* ឃ្លានេះបានដកស្រង់ចេញពី ទដ ៦៨ ដែលមានអត្ថន័យចុងក្រោយសំដៅទៅលើព្រះគ្រីស្ទ ក្នុងខណៈពេលដែលព្រះអម្ចាស់បានលើកទ្រង់ឡើង នោះទ្រង់ក៏ប្រទានអំណោយទានដល់មនុស្ស ។ *សាវក* ហេតុផលដែលប្រើពាក្យសាវកនៅត្រង់នេះ គឺដោយសារតែពួកគេមានតួនាទីជាអ្នកបង្កើតពួកជំនុំ (២:២០)។ គុណសម្បត្តិនៃពួកសាវកមុនដំបូងនោះគឺ សូមមើល កច ១:២១–២២ និងការពន្យល់ មក ៦:៣០ រម ១:១ ១កថ ១:១ ហព ៣:១ ជាន័យធំទូលាយ ជាងនេះទៅទៀតនោះគឺលោកប៉ុលក៏ជាសាវកម្នាក់ដែរ (១:១)។ *គ្រូអធិប្បាយ* គឺជាមនុស្សដែលព្រះអម្ចាស់បានញែកសម្រាប់នាំនូវព្រះបន្ទូលមកដល់រាស្ត្ររបស់ទ្រង់ ទៅតាមពេលវេលា និងស្ថានភាពដ៏សមរម្យនៃសេចក្តីត្រូវការរបស់មនុស្សលោក (កច ១១:២៧ ១កថ ១២:១០ និងការពន្យល់)។ *គ្រូផ្សាយដំណឹងល្អ* សូម

ធ្វើជាសាវក[ង] ខ្លះជាគ្រូអធិប្បាយ[ច] ខ្លះជាគ្រូផ្សាយដំណឹងល្អ[ឆ]
ខ្លះជាគ្រូគង្វាល ហើយខ្លះជាគ្រូបង្រៀន[ជ] ១២ប្រយោជន៍នឹង
នាំឱ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើង សំរាប់ធ្វើការជំនួយ
ហើយនឹងស្អាងរូបកាយព្រះគ្រីស្ទ[ឈ]ឡើង[ញ] ១៣ទាល់តែយើង
រាល់គ្នាបានរួបរួម[ដ] ខាងឯសេចក្តីជំនឿរួចជាស្រេច ហើយ
បានស្គាល់ព្រះរាជបុត្រានៃព្រះ[ឋ] ដូចគ្នាទាំងអស់ គឺដល់បាន
ពេញជាមនុស្ស[ឌ] ហើយដល់ខ្នាតកំពស់នៃសេចក្តីពោរ
ពេញផងព្រះគ្រីស្ទ[ឍ] ១៤ដើម្បីកុំឱ្យយើងនៅជាកូនតូច
ទៀត[ណ] ទាំងត្រូវគ្រប់អស់ទាំងខ្យល់នៃសេចក្តីបង្រៀនបោក
ហើយផាត់យើងចុះឡើង[ត] ដោយសេចក្តីឆបោករបស់ផង
មនុស្ស ហើយដោយឧបាយកល ដែលគេប្រើនឹងនាំ
ឱ្យវង្វេងទៀតឡើយ[ថ] ១៥តែដោយកាន់តាមសេចក្តីពិត
ដោយសេចក្តីស្រឡាញ់វិញ[ទ] នោះឱ្យយើងបានធំឡើង ខាង
ឯគ្រប់ការទាំងអស់ក្នុងទ្រង់ ដែលទ្រង់ជាសិរសា[ធ] គឺជា
ព្រះគ្រីស្ទ ១៦ដែលរូបកាយទាំងមូលបានផ្គុំ ហើយភ្ជាប់គ្នា
មកអំពីទ្រង់ ដោយសារគ្រប់ទាំងសន្លាក់ដែលផ្គត់ផ្គង់ឱ្យ[ន]
តាមខ្នាតការងាររបស់អវយវៈនិមួយៗ នោះរូបកាយបាន
បង្កើនឡើង[ប] ដើម្បីនឹងស្អាងខ្លួន ក្នុងសេចក្តីស្រឡាញ់[ផ]។

**៤:១១** ង ១កថ ១២:២៨ អភ ២:២០ ៣:៥ ២ពត ៣:២ យជ ១៧ ច កច ១១:២៧ រម ១២:៦ ១កថ ១២:១០,២៨ ១៣:២,៨ ១៤:១,៣៩ អភ ២:២០ ៣:៥ ២ពត ៣:២ ឆ កច ២១:៨ ២ធម ៤:៥ ជ កច ១៣:១ រម ២:២១ ១២:៧ ១កថ ១២:២៨ ១៤:២៦ ១ធម ១:៧ យក ៣:១

**៤:១២** ឈ ១កថ ១២:២៧ ញ រម ១៤:១៩ **៤:១៣** ដ ខ.៣,៥ ឋ ភល ៣:៨ ឌ ១កថ ២:៦ កល ១:២៨ ឍ យហ ១:១៦ អភ ១:២៣ ៣:១៩
**៤:១៤** ណ ១កថ ១៤:២០ ត អស ៥៧:២០ យក ១:៦ ថ អភ ៦:១១
**៤:១៥** ទ ខ.២,១៦ អភ ១:៤ ធ អភ ១:២២ **៤:១៦** ន កល ២:១៩ ប ១កថ ១២:៧ ផ ខ.២,១៥ អភ ១:៤

មើល កច ២១:៨ ១កថ ១:១៧ ។ ក្នុងខណៈពេលដែល អំណោយទានបានប្រទានដល់មនុស្សដើម្បីជួយដល់ពួកជំនុំឱ្យរីកចម្រើន តាមរយៈការបន្ថែមគ្រូផ្សាយដំណឹងល្អ ដើម្បីជួយបង្កើនចំនួនសមាជិកភាពពួកជំនុំ ។ ដោយសារគោលបំណងដូចដែលបានពោលខាងលើក្នុងខ.១២ ថា "ប្រយោជន៍នឹងនាំឱ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើងសម្រាប់ធ្វើការជំនួយ ហើយនឹងស្អាងរូបកាយព្រះគ្រីស្ទឡើង" យើងអាចសន្និដ្ឋានបានថា នៅក្នុងចំណោមគ្រូផ្សាយដំណឹងល្អគឺមានភារកិច្ចផ្សេងៗជាច្រើនទៀតដូចជាជួយដល់គ្រីស្ទបរិស័ទដទៃថ្មីៗ ឱ្យចេះធ្វើទីបន្ទាល់ជាដើម ។ *គ្រូគង្វាល គ្រូបង្រៀន* ដោយសារតែទម្រង់នៃវេយ្យាករណ៍ភាសាក្រិក (បានប្រើពាក្យនេះភ្ជាប់គ្នា) គឺសម្រាប់ប្រើជាមួយនឹងក្រុមមនុស្សទាំងឡាយណា ដែលមានអំណោយប្រហាក់ប្រហែលគ្នាខ្លាំង ។ ចំពោះក្រុមអ្នកដែលទទួលបន្ទុកជាអ្នកគង្វាល សម្រាប់ថែរក្សាដល់រាស្ត្ររបស់ព្រះ (ជាគ្រូគង្វាល) ជាអ្នកផ្តល់ "ចំណីអាហារ" ខាងឯព្រលឹងវិញ្ញាណ តាមរយៈបទគម្ពីរនោះគឺជាការបង្រៀន (ជាគ្រូបង្រៀន)។ នោះពួកគេមានអំណោយទានយ៉ាងពិសេស ដែលធ្វើជាគ្រូបង្រៀនវិញ (១ធម ៣:២)។

**៤:១២** *សំរាប់ធ្វើការជំនួយ* ឃ្លានេះតភ្ជាប់ ខ.១១ គឺមិនមែនមានន័យថាធ្វើការសម្រាប់ពួកបណ្តាជននោះទេ ប៉ុន្តែ ជាអ្នកបង្ហាត់ដល់ពួកបណ្តាជនឱ្យចេះធ្វើដោយខ្លួនឯងវិញ ។ *ហើយនឹងស្អាងរូបកាយព្រះគ្រីស្ទឡើង* មើល ខ.១៦ ។ អំណោយទានខាងឯវិញ្ញាណនេះគឺសម្រាប់ស្អាងរូបកាយពួកជំនុំ និងមិនមែនសម្រាប់ប្រើជាប្រយោជន៍ផ្ទាល់ខ្លួននោះឡើយ ។ "ស្អាងរូបកាយ" គឺបញ្ជាក់ពីរូបភាពនៅក្នុង ២:១៩–២២ ។ គំនិតដែលនិយាយអំពីរូបកាយ និងការស្អាងឡើងនេះ តែងតែកើតឡើងរួមគ្នាដើម្បីបញ្ជាក់ពីគំនិតសំខាន់នៃការរីកចម្រើន

**៤:១៣** *ទាល់តែ* នៅត្រង់នេះមិនមែនគ្រាន់តែបញ្ជាក់ពីពេលវេលានោះទេ ប៉ុន្តែ សំដែងពីបំណងនៃការរួបរួមគ្នាទៀតផង ។ *រួបរួម* ពាក្យនេះបានបន្តគំនិតពីខ.១-៦ ។ *ខាងឯសេចក្តីជំនឿ* ពាក្យថា "សេចក្តីជំនឿ" នៅទីនេះគឺជាប់ទាក់ទងទៅនឹងការប្រែចិត្ត និងគោលលទ្ធិផ្សេងៗដែលទាក់ទងនឹងព្រះយេស៊ូវគ្រីស្ទរបស់គ្រីស្ទបរិស័ទ (ពួកសាវកក៏បង្រៀនយ៉ាងដូច្នេះដែរ កច ២:៤២)។ *ស្គាល់ព្រះរាជបុត្រានៃព្រះ* ការរួបរួមគ្នាគឺមិនមែនគ្រាន់តែជាព្រឹត្តិការណ៍នៃសេចក្តីស្រឡាញ់ ឬជាអារម្មណ៍ខាងឯសាសនានោះទេ តែនេះគឺសេចក្តីពិត និងជាការយល់ដឹងរួមគ្នាមួយនៅក្នុងព្រះរាជបុត្រានៃព្រះ ។ *ដល់បានពេញជាមនុស្ស . . . ពោរពេញផងព្រះគ្រីស្ទ* ការពេញជាមនុស្សត្រង់នេះពុំមែនមានន័យថាជាការពេញវ័យផ្នែកគោលលទ្ធិនៃការប្រែចិត្តនោះទេ ហើយក៏មិនមែនជាការពេញវ័យខាងឯរាងកាយផ្នែកសាច់ឈាមនោះដែរ ប៉ុន្តែ នេះគឺជាការពេញវ័យផ្នែកឯសេចក្តីគ្រប់លក្ខណ៍ដែលមានតម្លៃស្មើនឹងចរិតលក្ខណៈដូចនឹងព្រះគ្រីស្ទនោះដែរ ។

**៤:១៤** *កូនតូច* ពាក្យនេះគឺផ្ទុយទៅនឹងពាក្យថាមនុស្សពេញវ័យនៅក្នុងខ.១៣ (១កថ ៣:១)។ *បោក ហើយផាត់* ពាក្យនេះបានបង្ហាញជានិមិត្តរូបពីនាវាដែលធ្វើដំណើរចុះឡើងៗទៅដោយសារកម្លាំងនៃខ្យល់បក់គ្មានលំនឹងអ្វីសោះ ដែលប្រៀបដូចជា គ្រីស្ទបរិស័ទមិនរឹងមាំនោះដែរ (យក ១:៦)។ *សេចក្តីបង្រៀន* នៅសព្វថ្ងៃនេះមាន សេចក្តីបង្រៀនមិនត្រឹមត្រូវធ្វើឱ្យទុកចិត្តលើខ្លួនឯង បានធ្វើឱ្យពួកអ្នកដែលមិនពេញ វ័យខាងឯជំនឿនោះវង្វេងចេញពីលានប្រណាំងយ៉ាងងាយ ។ *ដោយសេចក្តីឆបោក . . . នាំឱ្យវង្វេង* ជួនកាលអស់ពួកអ្នកដែលព្យាយាមអូសទាញបណ្តាជនឱ្យចេញពីសេចក្តីជំនឿជាគ្រីស្ទបរិស័ទនោះ គឺដំបូងមើលទៅហាក់បីដូចជាមិនមែនជាមនុស្សអាក្រក់ដែលនាំទៅវង្វេងនោះទេ ប៉ុន្តែតាមពិតពួកនេះគឺជាអ្នកបង្ខូចដែលមានផែនការទុកជាមុន និងជាមនុស្សអាក្រក់ (១ធថ ៤:១–២)។

**៤:១៥** *កាន់តាមសេចក្តីពិត ដោយសេចក្តីស្រឡាញ់* ត្រង់នេះបញ្ជាក់ពីចរិតមាយាទនៃជីវិតដែលមានសេចក្តីពិត និងសេចក្តីស្រឡាញ់នៅក្នុងខ្លួននោះគឺចាំបាច់ត្រូវតែមានការអនុវត្តន៍ ។ *ឱ្យយើងបានធំឡើង . . . ដែលទ្រង់ជាសិរសា* នៅត្រង់នេះមានរបៀបថ្លែងឡើងវិញចេញពីខ.១៣ តែមានលក្ខណៈខុសគ្នាបន្តិចនៅត្រង់នេះបានផ្អែកទៅ លើតួអង្គព្រះគ្រីស្ទដែលជាសិរសានៃរូបកាយទាំងមូលនោះគឺជាពួកជំនុំនោះឯង ។ ចំណុចសំខាន់នៅត្រង់នេះ គឺលោកប៉ុលនិយាយអំពីការដែលមានទាក់ទងនឹងភាពពេញវ័យនៃគ្រីស្ទបរិស័ទ ។ នោះគឺជា "រូបកាយនៃព្រះគ្រីស្ទ" ដែលត្រូវបាន "ស្អាង ឡើង" (ខ.១២)។ នៅក្នុងខ.១៣ "យើងគ្រប់គ្នា" ត្រូវតែក្លាយជា "មនុស្សពេញវ័យ"។

**៤:១៦** នៅក្នុងខនេះបានពន្យល់បន្ថែមទៀតអំពីរូបភាពនៃការធំលូតលាស់របស់រូបកាយ នៅក្រោមការដឹកនាំរបស់សិរសា ។ បំណែកនៃរូបកាយនិមួយៗត្រូវចេះជួយគ្នាទៅវិញទៅមក នៅក្នុងដំណើរដែលកំពុងរីកចម្រើន ។ នេះហើយជាផ្ទាំងរូបភាព ដែលបាននិយាយពីភារកិច្ចនៃរាស្ត្ររបស់ព្រះអម្ចាស់ពីខ.១១–១៣ (រម ១២:៣–៨)។ *សេចក្តីស្រឡាញ់* ការដែលពេញវ័យ និងការដែលរួបរួមគឺមិនអាចទៅរួចទេ បើគ្មានសេចក្តីស្រឡាញ់នោះ (ខ.២,១៥)។

## ការរស់នៅជាកូននៃពន្លឺ

17 ដូច្នេះ ខ្ញុំនិយាយសេចក្ដីនេះ ហើយធ្វើបន្ទាល់ក្នុងព្រះ
អម្ចាស់ថា កុំបី[ព] ឱ្យអ្នករាល់គ្នាដើរដូចជាសាសន៍ដទៃឯទៀត
ដែលគេដើរតាមគំនិតឥតប្រយោជន៍របស់គេទៀតឡើយ[ភ]
18 គំនិតគេត្រូវបង្អាប់[ម] ហើយគេដាច់ចេញពីព្រះជន្មព្រះ[យ]
ដោយសារសេចក្ដីខ្លៅល្ងង់ក្នុងខ្លួនគេ ព្រោះចិត្តគេរឹង
ទទឹង[រ] 19 គេលែងខ្លាចបាប[ល] បានជាគេប្រគល់ខ្លួន[វ] ទៅខាង
សេចក្ដីអាសអាភាស[ស] ដើម្បីនឹងប្រព្រឹត្តសេចក្ដីស្មោគគ្រោក
គ្រប់យ៉ាងដោយចិត្តវក់វិញ 20 តែអ្នករាល់គ្នាមិនបានរៀន
ឱ្យស្គាល់ព្រះគ្រីស្ទយ៉ាងនោះទេ 21 នោះគឺបើតិចណាស់
អ្នករាល់គ្នាបានឮ ហើយរៀននឹងទ្រង់ តាមសេចក្ដីពិត
ដែលនៅក្នុងព្រះយេស៊ូវដែរ 22 ថាខាងឯកិរិយាប្រព្រឹត្ត
កាលពីដើម នោះត្រូវឱ្យអ្នករាល់គ្នាបានដោះ[ហ] មនុស្ស
ចាស់[ឡ] ដែលតែងតែខូចទៅ[អ] តាមសេចក្ដីប៉ងប្រាថ្នារបស់
សេចក្ដីឆបោកចោលចេញ 23 ហើយឱ្យគំនិតក្នុងចិត្តបាន
កែប្រែជាថ្មីឡើង[ក] 24 ព្រមទាំងប្រដាប់ខ្លួន[ខ] ដោយមនុស្ស
ថ្មីវិញ[គ] ដែលកើតមកក្នុងសេចក្ដីសុចរិត ហើយក្នុងសេចក្ដី
បរិសុទ្ធរបស់ផងសេចក្ដីពិត តាមភាពព្រះ[ឃ] ។
25 ដូច្នេះ ដែលបានដោះសេចក្ដីកំភូតចេញហើយ នោះ
ត្រូវឱ្យនិយាយសេចក្ដីពិត[ង] នឹងអ្នកជិតខាងរៀងខ្លួនវិញ
ដ្បិតយើងរាល់គ្នាជាអវយវៈផងគ្នាទៅវិញទៅមក[ច] 26 ចូរ
ខឹងចុះ តែកុំឱ្យធ្វើបាបឡើយ[ឆ] កុំឱ្យសេចក្ដីកំហឹងរបស់អ្នក
នៅដរាបដល់ថ្ងៃលិចឡើយ 27 [ជ] ក៏កុំឱ្យអារក្សមានឱកាសឱ្យ
សោះ[ឈ] 28 អ្នកណាដែលធ្លាប់លួច ត្រូវឈប់លួចទៅ ស៊ូឱ្យ
អ្នកនោះទ្រាំនឿយហត់ជាជាង[ឈ] ទាំងធ្វើការល្អដោយដៃខ្លួន
វិញ[ញ] ដើម្បីឱ្យមានអ្វីនឹងចែកដល់អ្នកណាដែលត្រូវការផង[ដ]
29 មិនត្រូវឱ្យមានពាក្យអាក្រក់ណាមួយ ចេញពីមាត់អ្នក

**៤:១៧** ព អភ ២:២ ភ រម ១:២១ **៤:១៨** ម ចទ ២៩:៤ រម ១:២១ យ អភ ២:១២ រ ២កថ ៣:១៤ **៤:១៩** ល ១ធថ ៤:២ វ រម ១:២៤ ស កល ៣:៥ ១ពត ៤:៣ **៤:២២** ហ ខ.២៥, ៣១ កល ៣:៥,៨,៩ យក ១:២១ ១ពត ២:១ ឡ រម ៦:៦ អ យរ ១៧:៩ ហាព ៣:១៣ **៤:២៣** ក រម ១២:២ កល ៣:១០ **៤:២៤** ខ រម ១៣:១៤ គ រម ៦:៤ ឃ អភ ២:១០ **៤:២៥** ង ទដ ១៥:២ លវ ១៩:១១ សក ៨:១៦ កល ៣:៩ ច រម ១២:៥ **៤:២៦** ឆ ទដ ៤:៤ មថ ៥:២២ **៤:២៧** ជ ២កថ ២:១០,១១ **៤:២៨** ឈ កច ២០:៣៥ ញ ១ថន ៤:១១ ដ កទ ៦:១០

**៤:១៧–៥:២០** លោកប៉ុលទើបតែបានពិភាក្សាអំពីការរួបរួម និងភាពពេញវ័យដូចជាគោលបំណងភ្លោះពីរសម្រាប់ពួកជំនុំ ដែលព្រះអម្ចាស់បាននាំពួកគេមកតាមរយៈការសុគតរបស់ព្រះគ្រីស្ទ ។ នៅវគ្គបន្តទៅទៀតនេះ លោកប៉ុលបានបង្ហាញពីភាពបរិសុទ្ធថា គឺជាការសំខាន់ផងដែរក្នុងចំណោមអស់អ្នកដែលនៅក្នុងព្រះគ្រីស្ទ ។

**៤:១៧** *គំនិតឥតប្រយោជន៍* ជីវិតគ្មានព្រះអម្ចាស់គឺជាប្រាជ្ញាដែលពុំបានសម្រេចឥតប្រយោជន៍ និងគ្មានន័យ (សស ១:២ និងមើលការពន្យល់ រម ១:២១) ។

**៤:១៨** *សេចក្ដីខ្លៅល្ងង់* ពាក្យនេះគឺជាការនិយាយបន្តពីពាក្យថា គំនិតឥតប្រយោជន៍ ។ *ចិត្តគេរឹងទទឹង* គឺបញ្ជាក់ពីគំនិតដែលមិនអើពើនឹងដំណឹងល្អទាល់តែសោះ ។

**៤:១៩** *បានជាគេប្រគល់ខ្លួនទៅ* នៅត្រង់នេះគឺមានន័យដូចគ្នានឹងទឹកចិត្តរបស់ស្ដេចផារ៉ោនដែលបានប្រគល់ខ្លួនរបស់ទ្រង់ទៅឱ្យព្រះដឹកនាំម្ដងទៀតខ្លួនគាត់ជាអ្នកដឹកនាំវិញម្ដង (នក ៧–១១ និងការពន្យល់ នក ៤:២១) ។ ដូច្នេះ នៅត្រង់កន្លែងនេះ ពួកសាសន៍ដទៃបានប្រគល់ខ្លួនរបស់ពួកគេឱ្យទៅអំពើបាបត្រួតត្រាលើជីវិតខ្លួនក្នុងកណ្ឌគម្ពីរ រម ១:២៤,២៦,២៨ ចែងថា ព្រះអម្ចាស់បានបណ្ដោយពួកគេទៅតាមជីវិតបែប ដូច្នោះចុះ ។

**៤:២១** *តាមសេចក្ដីពិត* ការប្រើពាក្យ និងការបញ្ចេញព្រះនាមថា ព្រះយេស៊ូវ (ដោយមិនប្រើព្រះនាមថាព្រះគ្រីស្ទ) នៅត្រង់នេះគឺដើម្បីបញ្ជាក់ថា លោកប៉ុលកំពុង តែនិយាយពីសេចក្ដីពិតនៃជីវិតរបស់ព្រះយេស៊ូវពីដំបូង ។

**៤:២២** *កិរិយាប្រព្រឹត្តកាលពីដើម* សូមមើលការពិពណ៌នានៅក្នុង ២:១–៣ ។ *មនុស្សចាស់* ប្រហែលជាមានន័យថា ជាប្រភេទមនុស្សដែលគ្រីស្ទបរិស័ទធ្លាប់ប្រព្រឹត្តពីមុនមក (១កថ ៦:១១ និងការពន្យល់) ។ ជាជីវិតបែបចាស់ដែលតែងតែមានគំនិតខូច ។

**៤:២៣** *គំនិត* គឺនិយាយពីគំនិតអាក្រក់របស់អ្នកមិនជឿ (ខ.១៧–១៨) ។

**៤:២៤** *មនុស្សថ្មី . . . តាមភាពព្រះ* ដោយមនុស្សថ្មីត្រូវបានបង្កើតមក នោះយើងមិនអាចរស់នៅបែបជាជីវិតចាស់ ដូចកាលដែលគ្មានព្រះគ្រីស្ទនោះទៀតទេ គឺត្រូវធ្វើជាមនុស្សបែបដែលទ្រង់បានបង្កើតថ្មីនោះវិញ (គ្រីស្ទបរិស័ទ) ។ និស្ស័យសំខាន់របស់អ្នកជឿថ្មីមិនត្រូវឱ្យមានការបែងចែកនោះទេ ពីព្រោះគ្រប់គ្នាបានចូលមកក្នុងកំណើតថ្មីតែមួយរបស់ទ្រង់ហើយ ។ ម្យ៉ាងទៀតនេះគឺជាវិធីថ្មីតែមួយនៃជីវិតដែលមិនមែនគ្រាន់តែ "ប្រដាប់ខ្លួន" មួយភ្លែតនៅពេលប្រែចិត្តនោះទេ (កល ៣:៩–១០) តែវាជាដំណើរបទពិសោធន៍នៃជីវិតគ្រីស្ទបរិស័ទ (មើលការពន្យល់ រម ៦:១២–១៣) ។

**៤:២៥** *សេចក្ដីពិត* មើលខ.១៥,២១ ។ *អ្នកជិតខាងរៀងខ្លួន* ន័យត្រង់នេះប្រហែលជា សំដៅទៅលើគ្រីស្ទបរិស័ទដូចគ្នា ។

**៤:២៦** *សេចក្ដីកំហឹងរបស់អ្នក* មានន័យថា គ្រីស្ទបរិស័ទមិនត្រូវបាត់បង់អារម្មណ៍នោះទេ នៅពេលដែលខ្លួនខឹងនឹងនរណាម្នាក់នោះ ដូច្នេះអារម្មណ៍របស់យើងត្រូវតែបរិសុទ្ធ ។ កំហឹងខ្លះគឺជាអំពើបាប ហើយខ្លះទៀតពុំមែនជាអំពើបាបទេ (ទដ ៤:៤ និងការពន្យល់) ។ *ដរាបដល់ថ្ងៃលិចឡើយ* មានន័យថា កុំឱ្យខឹងរហូតដល់ថ្ងៃលិច ។

**៤:២៧** *អារក្ស* ត្រង់នេះគឺសំដៅលើបាបផ្ទាល់ខ្លួន ជាផ្នែកមួយនៃបំណងអាក្រក់របស់មនុស្ស (យក ១:១៤) ជាជាងសេចក្ដីល្បួងមកពីអារក្សដោយផ្ទាល់ ។ តែទោះជាយ៉ាងណាក៏ដោយ សាតាំងអាចប្រើបាបទាំងនេះឱ្យមនុស្សបែកបាក់នឹងគ្នាបានជាពិសេស ក្នុងចំណោមគ្រីស្ទបរិស័ទ គឺដោយសារកំហឹងដែលខ្លួនមានរីកកាន់តែធំឡើងៗ ។

**៤:២៨** ខនេះមានន័យថា មនុស្សដែលធ្លាប់លួចគេ នោះត្រូវឈប់លួចនៅពេលដែលខ្លួនបានប្រែចិត្ត ហើយការដែលឈប់ធ្វើបាបនោះមិនទាន់គ្រប់គ្រាន់ទេ គឺត្រូវឱ្យអ្នកនោះខំប្រឹងធ្វើការល្អទៀត ។ ចំណុចនេះសំខាន់ណាស់ដែលពីដើមជាចោរ តែឥឡូវនេះជាអ្នកជួយដល់មនុស្សខ្វះខាតវិញ (១ថន ៤:១១–១២ ២ថន ៣:៦–១៣) ។

**៤:២៩** *បញ្ចេញតែពាក្យណាដែលល្អៗ* គឺជាពាក្យសម្រាប់លើកទឹកចិត្តដែលស្របទៅនឹងខខាងលើ ។ គ្រីស្ទបរិស័ទមិនមែនគ្រាន់តែឈប់និយាយពាក្យមិនល្អប៉ុណ្ណោះនោះទេ ប៉ុន្តែ ត្រូវនិយាយតែពាក្យណាដែលសម្រាប់នឹងស្អាងគ្នានោះ

រាល់គ្នាឡើយ[ឋ] ចូរបញ្ចេញតែពាក្យណាដែលល្អៗ សំរាប់
នឹងស្អាងចិត្ត[ឌ]តាមត្រូវការ ដើម្បីឱ្យបានផ្តល់ព្រះគុណដល់
អស់អ្នកដែលស្តាប់ ៣០កុំធ្វើឱ្យព្រះវិញ្ញាណបរិសុទ្ធនៃព្រះ
បានព្រួយព្រះហឫទ័យ[ឍ] ដែលទ្រង់ដៅចំណាំអ្នករាល់គ្នា[ណ]
ទុកសំរាប់ដល់ថ្ងៃប្រោសលោះនោះឡើយ[ត] ៣១ចូរខំដក[ថ]
គ្រប់ទាំងសេចក្តីជូរល្វីង ក្តៅក្រហាយ កំហឹង ឡូឡា ជេរ
ប្រមាថ និងគ្រប់ទាំងសេចក្តីអាក្រក់ ចេញពីពួកអ្នករាល់
គ្នាទៅ[ទ] ៣២ចូរមានចិត្តសប្បុរសនឹងគ្នាទៅវិញទៅមក[ធ]
ព្រមទាំងមានចិត្តទន់សន្តោស ហើយអត់ទោសគ្នា ដូចជា
ព្រះទ្រង់បានអត់ទោសឱ្យអ្នករាល់គ្នា ដោយព្រះគ្រីស្ទដែរ[ន]

**៥** ១ដូច្នេះ ចូរត្រាប់តាមព្រះ[ប] ដូចជាកូនស្ងួនភ្ងា[ផ] ២ហើយ
ដើរក្នុងសេចក្តីស្រឡាញ់ ដូចជាព្រះគ្រីស្ទបានស្រឡាញ់
យើង[ព] ព្រមទាំងប្រគល់ព្រះអង្គទ្រង់ជំនួសយើងផង[ភ] ទុកជា
ដង្វាយហើយជាយញ្ញបូជាសំរាប់ជាក្លិនឈ្ងុយថ្វាយដល់ព្រះ[ម]
៣ឯសេចក្តីកំផិត សេចក្តីស្មោកគ្រោកគ្រប់យ៉ាង[យ] នឹង
សេចក្តីលោភ[រ] នោះមិនត្រូវទាំងឱ្យឮឈ្មោះក្នុងពួកអ្នករាល់
គ្នាផង ដូចជាគួរគប្បីក្នុងពួកបរិសុទ្ធ ៤ព្រមទាំងរឿងគួរ
ខ្មាស ពាក្យសំដីចំកួត[ល] នឹងពាក្យកំប្លែង ដែលសេចក្តីទាំង
នោះមិនគួរគប្បីដែរ ស៊ូពោលតែពាក្យសំរាប់អរព្រះគុណ
វិញ[វ] ៥ដ្បិតអ្នករាល់គ្នាដឹងថា គ្មានមនុស្សកំផិត ឬស្មោក
គ្រោក ឬលោភ គឺជាមនុស្សថ្វាយបង្គំរូបព្រះ[ស] ដែលនឹង
គ្រងមរដក[ហ]ក្នុងនគរនៃព្រះគ្រីស្ទ ហើយនៃព្រះផងបាន
ឡើយ[ឡ] ៦កុំឱ្យអ្នកណាបញ្ឆោតអ្នករាល់គ្នា[អ] ដោយពាក្យ
សំដីឥតប្រយោជន៍ឡើយ ដ្បិតគឺដោយព្រោះសេចក្តីទាំង
នោះ បានជាសេចក្តីក្រោធរបស់ព្រះ[ក]បានមកលើមនុស្ស
រឹងចចេស[ខ] ៧ដូច្នេះ កុំឱ្យមានចំណែកជា១នឹងគេឡើយ
៨ដ្បិតកាលពីដើម[គ]អ្នករាល់គ្នាក៏ងងឹតដែរ តែឥឡូវនេះវិញ
បានភ្លឺក្នុងព្រះអម្ចាស់ ដូច្នេះ ចូរដើរដូចជាមនុស្សភ្លឺចុះ[ឃ]

**៤:២៩** ឋ មថ ១២:៣៦ អភ ៥:៤ កល ៣:៨ ឌ រម ១៤:១៩ **៤:៣០** ឍ អស ៦៣:១០ ១ថន ៥:១៩ ណ ២កថ ១:២២ អភ ១:១៣ ត រម ៨:២៣ **៤:៣១** ថ ខ.២២ ទ កល ៣:៨ ១ពត ២:១ **៤:៣២** ធ ១ពត ៣:៨ ន មថ ៦:១៤,១៥ កល ៣:១២,១៣ **៥:១** ប មថ ៥:៤៨ លក ៦:៣៦ ផ យហ ១:១២ **៥:២** ព យហ ១៣:៣៤ ភ ខ.២៥ កទ ១:៤ ២:២០ ម ហព ៧:២៧ **៥:៣** យ ១កថ ៦:១៨ រ កល ៣:៥ **៥:៤** ល អភ ៤:២៩ វ ខ.២០ **៥:៥** ស កល ៣:៥ ហ កច ២០:៣២ ឡ មថ ២៥:៣៤ **៥:៦** អ មក ១៣:៥ ក រម ១:១៨ ខ អភ ២:២ **៥:៨** គ អភ ២:២

វិញ (១កថ ១៤:៣) ។

**៤:៣០** *ព្រួយព្រះហឫទ័យ* គឺដោយសារតែអំពើបាប ដូចជា "ពាក្យអាក្រក់" (ខ.២៩) និងអំពើបាបដូចចែងនៅក្នុង ខ.៣១ នោះជាដើម ។ ការសំដែងពីសេចក្តីព្រួយនៅត្រង់នេះគឺបញ្ជាក់ថា ព្រះវិញ្ញាណបរិសុទ្ធគឺជាបុគ្គលម្នាក់ មិនមែនជាអំណាចណាមួយនោះទេ គឺមានតែមនុស្សទេដែលកើតទុក្ខព្រួយនោះ ។ *ដៅចំណាំ* មើលការពន្យល់ ១:១៣ ។ *ដល់ថ្ងៃប្រោសលោះ* មើល ១:១៤ ១ពត ១:៥ និងការពន្យល់ ។

**៤:៣១** *សេចក្តីជូរល្វីង . . . គ្រប់ទាំងសេចក្តីអាក្រក់* ចំណុចដែលបានរៀបរាប់នៅក្នុងខនេះហើយគឺជាការដែលធ្វើឱ្យព្រះវិញ្ញាណបរិសុទ្ធព្រួយព្រះហឫទ័យ ។ ខនេះក៏ជាការបង្រៀនបន្តពីសេចក្តីថ្លែងការនៅក្នុងខ.២៩ (មើលការពន្យល់ រម ១:២៩–៣១) ។

**៤:៣២** *មានចិត្តសប្បុរស . . . ចិត្តទន់សន្តោស* ត្រង់ចំណុចនេះគឺជាន័យផ្ទុយនៃពាក្យអវិជ្ជមាននៅក្នុងខ.៣១ ។ *អត់ទោស* អាកប្បកិរិយាដើមរបស់គ្រីស្ទបរិស័ទដែលបានទទួលមកពីព្រះគ្រីស្ទនោះគឺ ការអត់ទោស មានចិត្តសប្បុរស និងមានចិត្តទន់សន្តោស ទាំងនេះហើយដែលយើងត្រូវធ្វើដល់គ្នាទៅវិញទៅមកនោះ ។

**៥:១** *ចូរត្រាប់តាមព្រះ* មានវិធីមួយនៃការត្រាប់តាមព្រះនោះគឺត្រូវតែមានវិញ្ញាណនៃការអត់ទោស (៤:៣២) ។ មធ្យោបាយដែលយើងត្រាប់តាមព្រះអម្ចាស់របស់យើង នោះគឺគ្រាន់តែធ្វើឱ្យដូចដែលមានចែងក្នុង ខ.២ ៤:៣២ ។ វិធីដែលព្រះយេស៊ូវបូជា អង្គទ្រង់បានបញ្ជាក់ពីសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះយើងគ្រប់គ្នា គឺមិនមែនគ្រាន់តែសម្រាប់ឱ្យយើងបានសង្គ្រោះប៉ុណ្ណោះទេ (មើលជំពូក ២) ហើយថែមទាំងសម្រាប់ ធ្វើជាគំរូដល់យើងគ្រប់គ្នាក្នុងការរស់នៅជាប្រយោជន៍ដល់អ្នកដទៃទៀតផង ។

**៥:២** *ក្លិនឈ្ងុយថ្វាយដល់ព្រះ* ព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យនឹងការថ្វាយដង្វាយជាយញ្ញបូជាខ្លាំងណាស់នៅក្នុងគម្ពីរសញ្ញាចាស់ ដែលត្រូវបានគេពិពណ៌នាថា "ទ្រង់ធុំក្លិនឈ្ងុយ (លប ៨:២១ នក ២៩:១៨,២៥,៤១ លវ ១:៩,១៣,១៧)" ។

**៥:៣–៥** មើលការពន្យល់ រម ១:២៩–៣១ ។

**៥:៣** *មិនត្រូវទាំងឱ្យឮឈ្មោះ* មើលខ.១២ ។ *សេចក្តីស្មោកគ្រោកគ្រប់យ៉ាង និងសេចក្តីលោភ* ត្រង់ចំណុចនេះលោកប៉ុលបានបែរពីអំពើបាបខាងផ្លូវភេទ មកប្រាប់ពីអំពើបាបទូទៅវិញម្តង ដូចជាសេចក្តីលោភនេះជាដើម ។ *ក្នុងពួកបរិសុទ្ធ* មើល ២:២១ ១កថ ១:២ និងការពន្យល់ ។

**៥:៤** *ពាក្យសំដីចំកួត និងពាក្យកំប្លែង* គឺសំដៅលើមនុស្សដែលប្រព្រឹត្តអំពើអាសគ្រាម (អំពើមិនថ្លៃថ្នូរ) ពុំមែនជាពាក្យកំប្លែងសម្រាប់សើចធម្មតានោះទេ គឺជាពាក្យកំប្លែងសម្រាប់ប្រមាថមើលងាយដល់អ្នកដទៃ ដូច្នេះពាក្យទាំងនេះ មិនគួរឱ្យមាននៅក្នុងចំណោមគ្រីស្ទបរិស័ទនោះឡើយ ។ *អរព្រះគុណ* មើល ខ.២០ ១ថន ៥:១៨ ។ គឺជាការដឹងគុណគ្រប់កិច្ចការដែលព្រះអម្ចាស់បានប្រទានមកឱ្យយើង ដូចជាការដែលយើងអាចបោះបង់គំនិតនិងពាក្យអាក្រក់ៗចោលបាន ។

**៥:៥** *មនុស្សកំផិត ឬស្មោកគ្រោក ឬលោភ* មើល ខ.៣ ។ *មនុស្សថ្វាយបង្គំរូបព្រះ* មើលខយោង កល ៣:៥ ។ មនុស្សដែលមានចិត្តលោភ គេតែងតែស្វែងរកទ្រព្យសម្បត្តិច្រើនជាងស្វែងរកព្រះ ហើយគេចាត់ទុកវត្ថុទាំងនោះដូចជាព្រះរបស់ពួកគេ ហេតុនេះទើបហៅថា មនុស្សថ្វាយបង្គំរូបព្រះ ។ *គ្រងមរដក* គឺជាពួកមនុស្សកំផិត ហើយនិងជាមនុស្សលោភច្រើនប្រភេទទៀត ដែលបានបដិសេធព្រះហេតុដូច្នេះ ហើយបានជាត្រូវបដិសេធពួកនោះមិនឱ្យចូលនគររបស់ព្រះ (សូមមើលការពន្យល់ ១កថ ៦:៩,១១) ។

**៥:៦** *សេចក្តីក្រោធរបស់ព្រះ* មើល សក ១:២ រម ១:១៨ និងពន្យល់ ។

**៥:៧** *មានចំណែក* មានន័យថា គ្រីស្ទបរិស័ទក៏ជាមនុស្សដែលរស់នៅលាយឡំនឹងមនុស្សដទៃៗទៀត ដូចគ្នានឹងគ្រីស្ទបរិស័ទនៅសម័យនៃព្រះអម្ចាស់ព្រះយេស៊ូវនោះដែរ (លក ៥:៣០–៣២ ១៥:១–២) ប៉ុន្តែ ពួកគេពុំមានចំណែកចូលរួមធ្វើបាប ដូចជាពួកអ្នកមិនជឿនោះឡើយ (២កថ ៦:១៤ និងពន្យល់) ។

**៥:៨** *ងងឹត. . .ភ្លឺ* នៅក្នុងចំណុចនេះសង្កត់ធ្ងន់ទៅលើពាក្យពីរផ្ទុយគ្នាគឺ ងងឹត និងភ្លឺ ដែលបង្ហាញថា អស់អ្នកជារបស់ព្រះនោះគឺនៅខាងពន្លឺ (១យហ ១:៥)

៩ដ្បិតផលផ្លែ[ង]នៃពន្លឺ នោះមាននៅក្នុងគ្រប់ទាំងកិរិយា ល្អ[ច]
សេចក្តីសុចរិតនិងសេចក្តីពិត ១០ចូរលមើលឱ្យដឹង សេចក្តី
អ្វី ដែលព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យចុះ[ឆ] ១១កុំឱ្យប្រ
កបក្នុងការឥតផលប្រយោជន៍ របស់សេចក្តីងងឹតឡើយ[ជ]
ស៊ូបន្ទោសវិញ ១២ដ្បិតការទាំងប៉ុន្មានដែលគេប្រព្រឹត្តដោយ
សំងាត់ នោះបើគ្រាន់តែនិយាយពីការទាំងនោះ ក៏គួរខ្មាស
ទៅហើយ ១៣តែការទាំងនោះបានសំដែងមកយ៉ាងច្បាស់
ដោយពន្លឺភ្លឺបញ្ជាក់[ឈ] ដ្បិតគឺជាពន្លឺហើយ ដែលសំដែងឱ្យ
ឃើញទាំងអស់ ១៤ហេតុនោះបានជាទ្រង់មានបន្ទូលថា
« ឯងដែលដេកលក់អើយ ចូរភ្ញាក់ឡើង[ញ] ឱ្យក្រោកពី
ពួក មនុស្សស្លាប់ឡើង[ដ] នោះព្រះគ្រីស្ទនឹងភ្លឺមកលើឯង»[ឋ]

**៥:៨** ឃ យហ ៨:១២ លក ១៦:៨ កច ២៦:១៨ **៥:៩** ង មថ ៧:១៦-២០ កទ ៥:២២ ច រម ១៥:១៤ **៥:១០** ឆ ១ធថ ៥:៤ **៥:១១** ជ រម ១៣:១២ ២កថ ៦:១៤ **៥:១៣** ឈ យហ ៣:២០,២១ **៥:១៤** ញ រម ១៣:១១ ដ អស ២៦:១៩ យហ ៥:២៥ ឋ អស ៦០:១

១៥ដូច្នេះ ត្រូវប្រយ័ត្នដោយមធ្យ័ត ដែលអ្នករាល់គ្នាដើរ
យ៉ាងណា[ឌ] កុំឱ្យដើរដូចជាមនុស្សឥតប្រាជ្ញាឡើយ ត្រូវតែ
ដើរដោយមានប្រាជ្ញាវិញ ១៦ទាំងលៃយកឱកាសឱ្យទាន់
ពេលផង[ឍ] ពីព្រោះសម័យនេះអាក្រក់ណាស់[ណ] ១៧ដូច្នេះ
កុំឱ្យខ្លៅល្ងង់ឡើយ ត្រូវខំឱ្យយល់បំណងព្រះហឫទ័យព្រះ
អម្ចាស់វិញ[ត] ១៨កុំឱ្យស្រវឹងស្រា[ថ] ដែលនាំឱ្យព្រើលចិត្តឡើយ
តែចូរឱ្យបានពេញជាព្រះវិញ្ញាណវិញ[ទ] ១៩ហើយនិយាយគ្នា
ទៅវិញទៅមក ដោយបទទំនុកដំកើង ទំនុកបរិសុទ្ធ និង
ចំរៀងខាងឯវិញ្ញាណ[ធ] ទាំងច្រៀង ហើយសរសើរដល់

មឡ ៤:២ **៥:១៥** ឌ ខ.២ **៥:១៦** ឍ កល ៤:៥ ណ អភ ៦:១៣ **៥:១៧** ត រម ១២:២ កល ១:៩ ១ថន ៤:៣ **៥:១៨** ថ លវ ១០:៩ សភ ២០:១ អស ២៨:៧ រម ១៣:១៣ ទ លក ១:១៥ **៥:១៩** ធ ទដ ២៧:៦ ៩៥:២ កច ១៦:២៥ ១កថ ១៤:១៥,២៦ កល ៣:១៦

ឧទាហរណ៍ ព្រះអម្ចាស់មិនមែនគ្រាន់តែផ្តល់ភាពបរិសុទ្ធ និងសេចក្តីពិតមកបំភ្លឺតែក្នុងជីវិតរបស់គ្រីស្ទបរិស័ទនោះទេ គឺឱ្យពន្លឺដែលមានក្នុងជីវិតនេះ បានភ្លឺចែងចាំងដល់អ្នកដទៃទៀត (ជាកិរិយាប្រព្រឹត្តរបស់មនុស្សនៅខាងងងឹត) នោះដែរ (មថ ៥:១៤) ។

**៥:៩** *ផលផ្លែនៃពន្លឺ* នេះជាពាក្យប្រៀបធៀបដែលលាយឡំគ្នា ប៉ុន្តែមានអត្ថន័យច្បាស់លាស់ ដូចដែលមានពន្យល់តទៅនេះថា ពន្លឺគឺសម្រាប់ធ្វើឱ្យរុក្ខជាតិធំលូតលាស់ ហើយអស់អ្នកដែលរស់នៅក្នុងព្រះ នោះនឹងបានទទួលពន្លឺរបស់ព្រះដែលនាំឱ្យមានផលផ្លែល្អនៃកិរិយាមាយាទ (កទ ៥:២២-២៣) ក្នុងខណៈពេលដែលពួកអ្នក កំពុងរស់នៅក្នុងភាពងងឹតពុំមានផលផ្លែនៃពន្លឺនេះទេ (មើល ខ.១១) ។

**៥:១១** *កុំឱ្យប្រកបក្នុងការឥតផលប្រយោជន៍* មើល ខ.៧។ *បន្ទោស* ពាក្យបន្ទោសនៅត្រង់នេះមានន័យថា ពន្លឺដែលបានមកពីព្រះអម្ចាស់គឺសម្រាប់បំភ្លឺដល់សេចក្តីងងឹត គឺត្រូវបង្ហាញគេនូវអ្វីដែលជាសេចក្តីពិតពុំអាចយល់ព្រមនឹងសេចក្តីងងឹតបានទេ ។

**៥:១២** *គ្រាន់តែនិយាយ . . . គួរខ្មាស់ទៅហើយ* គ្រីស្ទបរិស័ទមិនត្រូវរស់នៅតាមបែបផ្លូវអាក្រក់នោះទេ ដែលបណ្តាលឱ្យជីវិតមានផលផ្លែមិនល្អដល់អ្នកដទៃ ។

**៥:១៣-១៤** *ការទាំងនោះ. . .សំដែងឱ្យឃើញទាំងអស់* ពាក្យទាំងនេះគឺជាការនិយាយឡើងវិញរបស់លោកប៉ុល ដើម្បីបញ្ជាក់ឱ្យអ្នកអានទាំងអស់បានជ្រួតជ្រាបអំពីលក្ខណៈនៃពន្លឺរបស់ព្រះ និងអំពីប្រសិទ្ធភាពរបស់ពន្លឺដែលពុំអាចអត់បាន ។

**៥:១៤** *ទ្រង់មានបន្ទូលថា* ពាក្យពេចន៍ដែលបានលើកមកនិយាយនៅក្នុងខនេះ អាច ជាបទចម្រៀងល្បីមួយដែលត្រូវបានគេធ្លាប់យកមកច្រៀងក្នុងសម័យកាលគ្រីស្ទបរិស័ទដំបូង (មើលការពន្យល់ កល ៣:១៦) ។ *ឯងដែលដេកលក់. . . មនុស្សស្លាប់* នេះគឺជាការពិពណ៌នាអំពីមនុស្សមានបាបទៅនឹងមនុស្សពីរប្រភេទគឺដេកលក់ និងមនុស្សស្លាប់ (២:១ និងការពន្យល់) ។ *ព្រះគ្រីស្ទនឹងភ្លឺមកលើឯង* គឺជាពន្លឺនៃជីវិតរបស់ទ្រង់ដែលបានប្រទានមកយើងរាល់គ្នា ។

**៥:១៥** *ឥតប្រាជ្ញា . . . មានប្រាជ្ញា* លោកប៉ុលប្រើពាក្យផ្ទុយគ្នាទាំងពីរនេះ គឺជា ការសង្កត់ធ្ងន់បន្ថែមទៀតរបស់គាត់ទៅលើពាក្យថា "ពន្លឺ" និងពាក្យថា "ងងឹត" ដែលគាត់បានលើកឡើងនៅក្នុងខគម្ពីរខាងលើ ។

**៥:១៦** *ទាំងលៃយកឱកាសឱ្យ* ពួកមនុស្សឥតប្រាជ្ញាគ្មានយុទ្ធសាស្ត្រអ្វីសម្រាប់ជីវិតរបស់ខ្លួននោះទេ ហើយជីវិតក៏បាត់បង់ឱកាសដើម្បីរស់នៅសម្រាប់ព្រះដោយរវល់ តែនឹងការអាក្រក់ដែលនៅជុំវិញខ្លួនគេ (កល ៤:៥) ។

**៥:១៧** *កុំឱ្យខ្លៅល្ងង់...ត្រូវខំឱ្យយល់* ការពន្យល់ដោយប្រើពាក្យផ្ទុយនៅតែមានបន្តទៀត ។ មនុស្សខ្លៅល្ងង់មិនមែនគ្រាន់តែបាត់បង់ឱកាសក្នុងការប្រើពេលឱ្យបានប្រាជ្ញាប៉ុណ្ណោះនោះទេ តែពួកគេថែមទាំងមានបញ្ហាជាច្រើនទៀតផងដូចជា ពួកគេមិនបានយល់នូវបំណងផែនការរបស់ព្រះដែលមានចំពោះមនុស្សលោក និងចំពោះគ្រីស្ទបរិស័ទនោះឡើយ ។ បំណងផែនការរបស់ព្រះជាសាច់រឿងសំខាន់ មួយដែលមានចែងនៅក្នុងបទគម្ពីរអេភេសូរនេះ (មើលជំពូកទី១) ។

**៥:១៨** *កុំឱ្យស្រវឹងស្រា. . .ចូរឱ្យបានពេញជាព្រះវិញ្ញាណវិញ* ប្រយោគនេះភាសាក្រិកគឺជាប្រយោគបច្ចុប្បន្នកាល ដែលត្រូវបានគេធ្លាប់លើកយកមកបង្ហាញពីការដែលពេញជាព្រះវិញ្ញាណបរិសុទ្ធ ។ ការពេញដោយព្រះវិញ្ញាណនេះពុំមែនជាកិច្ចការតែមួយភ្លែត ហើយបានពេញដោយព្រះវិញ្ញាណនោះទេ ប៉ុន្តែគឺជាបទពិសោធន៍នៃហេតុការណ៍ជាច្រើនដែលកើតឡើងបន្តបន្ទាប់ ដោយមានអំណាចព្រះចេស្តាពីព្រះវិញ្ញាណបរិសុទ្ធ តាមរយៈការថ្វាយបង្គំ ការបម្រើ និងការធ្វើ ទីបន្ទាល់ជាដើម ។ ការជោគជាំដោយស្រា និងការដែលពេញដោយព្រះវិញ្ញាណ បរិសុទ្ធគឺជារឿងពីរ ដែលមានលទ្ធផលផ្ទុយគ្នាស្រឡះ ប៉ុន្តែរឿងទាំងពីរមានឥទ្ធិពលលើមនុស្សដូចគ្នា ដូច្នេះមនុស្សជាអ្នកជ្រើសរើសផ្លូវ តើត្រូវនៅក្រោម ឥទ្ធិពលរបស់ស្រា ឬឥទ្ធិពលរបស់ព្រះវិញ្ញាណបរិសុទ្ធ ។ ដោយសារតែគម្ពីរ កល ៣:១៥-៤:១ ស្រដៀងគ្នានឹង អភ ៥:១៨-៦:៩ អាចធ្វើឱ្យយើងសន្និដ្ឋានថា លោកប៉ុលមានបំណងបញ្ជូនសេចក្តីបង្រៀនដ៏សំខាន់មួយនេះទៅកន្លែងផ្សេងៗគ្នា។ នៅពេលដែលលោកប៉ុលនិយាយនៅទីនេះថា ចូរឱ្យបានពេញជាព្រះវិញ្ញាណ ហើយគាត់និយាយនៅក្នុងគម្ពីរកូល៉ុសថា ចូរឱ្យសេចក្តីមេត្រីរបស់ព្រះគ្រីស្ទត្រួតត្រានៅក្នុងចិត្ត ។ ពាក្យដែលថា "របស់ព្រះគ្រីស្ទ" មានន័យថា នៅក្រោមការគ្រប់គ្រងរបស់ព្រះ ។ ការគ្រប់គ្រងដ៏មានប្រសិទ្ធភាពនេះ គឺមានសារៈសំខាន់ដូចគ្នា នៅក្នុងបទគម្ពីរទាំងពីរសម្រាប់ជាការលើកទឹកចិត្តដល់គ្នាទៅវិញទៅមកឱ្យចេះសរសើរដល់ព្រះ និងមានទំនាក់ទំនងល្អដល់គ្នាទៅវិញទៅមក ។

**៥:១៩** *ទំនុកដំកើង . . . ចំរៀង* គ្រប់ទាំងប្រភេទបទចម្រៀងមិនថាទំនុក

ព្រះអម្ចាស់ដោយចិត្ត [២០]ទាំងអរព្រះគុណ[ន]ដល់ព្រះដ៏ជាព្រះ
វរបិតាជាដរាប ក្នុងគ្រប់ការទាំងអស់ ដោយនូវព្រះនាម
ព្រះយេស៊ូវគ្រីស្ទ [២១]ហើយទាំងចំណុះគ្នាទៅវិញទៅមក[ប]
ដោយសេចក្ដី កោតខ្លាចដល់ព្រះគ្រីស្ទ ។

## ប្រពន្ធ និងប្ដី

*៥:២២–៦:៩ – កល ៣:១៨–៤:១*

[២២]ស្ត្រីរាល់គ្នាអើយ ចូរឱ្យចុះចូលចំពោះប្ដីខ្លួន[ផ] ដូចជា
ចុះចូលនឹងព្រះអម្ចាស់ដែរ[ព] [២៣]ដ្បិតប្ដីជាក្បាលនៃប្រពន្ធ
ដូចជាព្រះគ្រីស្ទទ្រង់ជាសិរសានៃពួកជំនុំដែរ[ភ] ក៏ជាព្រះអង្គ
សង្គ្រោះដល់រូបកាយផង [២៤]ហើយដូចជាពួកជំនុំចុះចូលនឹង
ព្រះគ្រីស្ទជាយ៉ាងណា នោះត្រូវឱ្យប្រពន្ធចុះចូលនឹងប្ដីខ្លួន[ម]
ក្នុងគ្រប់ការទាំងអស់យ៉ាងនោះដែរ ។
[២៥]បុរសរាល់គ្នាអើយ ចូរស្រឡាញ់ប្រពន្ធខ្លួន[យ] ដូចជា
ព្រះគ្រីស្ទបានស្រឡាញ់ដល់ពួកជំនុំ ហើយបានប្រគល់ព្រះ

**៥:២០** ន ខ.៤ យប ១:២១ ទដ ៣៤:១ កល ៣:១៧ ហាព ១៣:១៥ **៥:២១** ប កទ ៥:១៣ ១ពត ៥:៥ **៥:២២** ផ លប ៣:១៦ ១កថ ១៤:៣៤ កល ៣:១៨ ១ធថ ២:១២ ទត ២:៥ ១ពត ៣:១,៥,៦ ព អភ ៦:៥ **៥:២៣** ភ អភ ១:២២ **៥:២៤** ម ខ.២២ **៥:២៥** យ ខ.២៨, ៣៣ កល ៣:១៩ រ ខ.២

អង្គទ្រង់ជំនួសផង[រ] [២៦]ដើម្បីឱ្យទ្រង់បានញែកពួកជំនុំចេញ
ជាបរិសុទ្ធ[ល] ដោយបានលាងសំអាតនឹងទឹក[វ] គឺជាព្រះបន្ទូល
[២៧]ប្រយោជន៍ នឹងថ្វាយពួកជំនុំនេះដល់ព្រះអង្គទ្រង់[ស] ទុកជា
ពួកជំនុំដ៏ឧត្ដម ឥតប្រឡាក់ ឥតជ្រួញ ឬមានអ្វីឱ្យដូចឡើយ
គឺឱ្យបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបានវិញ[ហ] [២៨]ត្រូវ
ឱ្យប្ដីស្រឡាញ់ប្រពន្ធបែបយ៉ាងនោះឯង[ឡ] គឺដូចជាស្រឡាញ់
រូបកាយរបស់ខ្លួនដែរ អ្នកណាដែលស្រឡាញ់ប្រពន្ធខ្លួន
នោះក៏ឈ្មោះថាស្រឡាញ់ដល់ខ្លួនឯងហើយ [២៩]ដ្បិតមិន
ដែលមានអ្នកណាស្អប់រូបសាច់ខ្លួនឯងឡើយ គឺគេតែង
ចិញ្ចឹម ហើយថ្នាក់ថ្នមវិញ ដូចជាព្រះអម្ចាស់ដល់ពួកជំនុំ
ដែរ [៣០]ដ្បិតយើងរាល់គ្នាជាអវយវៈរបស់រូបអង្គ នឹងសាច់

**៥:២៦** ល យហ ១៧:១៩ ហាព ២:១១ ១០:១០,១៤ ១៣:១២ វ កច ២២:១៦ **៥:២៧** ស ២កថ ៤:១៤ ហ អភ ១:៤ **៥:២៨** ឡ ខ.២៥

តម្កើងដូចជានៅក្នុងគម្ពីរសញ្ញាចាស់ ឬបទថ្វាយបង្គំ ឬក៏បទផ្សេងៗទៀត ដែលគ្រីស្ទបរិស័ទធ្លាប់ច្រៀងនោះ អាចផ្ដល់ជាអត្ថន័យសម្រាប់លើកតម្កើង និងអរព្រះគុណដល់ព្រះ (ខ.២០)។ ទោះបីជាយ៉ាងណាក៏ដោយ តាមពិតពាក្យទាំងបីអាចជាប្រភេទផ្សេងៗគ្នានៃបទចម្រៀង (មើលការពន្យល់ កល ៣:១៦)។ *ចំរៀងខាងឯវិញ្ញាណ* គឺជាបទចម្រៀងដែលមានការជំរុញចិត្តដោយព្រះវិញ្ញាណ ។

**៥:២០** *ទាំងអរព្រះគុណដល់ព្រះ* មើល កល ២:៧ ៣:១៥ ៤:២ ១ថន ៥:១៨។

**៥:២១–៦:៩** នៅក្នុងជំពូក ២–៤ លោកប៉ុលបានបង្ហាញផ្លូវទៅឯព្រះដោយនាំអ្នកជឿជាសាសន៍យូដា និងសាសន៍ដទៃឱ្យមករួមគ្នាជារូបកាយតែមួយនៅក្នុងព្រះគ្រីស្ទ (៤:១–៦)។ ឥឡូវគាត់បានបង្ហាញនូវរបៀបដែលអ្នកជឿពេញដោយព្រះវិញ្ញាណ នោះគឺអាចចូលមករួមគ្នាតែមួយបាន ទោះជាក្រុមមនុស្សផ្សេងៗក៏ដោយ ។ តទៅនេះជាបញ្ជីនៃការទទួលខុសត្រូវដែលមានភាពស្រដៀងគ្នាទៅនឹងគំរូ ដែលបាន ឃើញនៅក្នុង កល ៣:១៨–៤:១ ១ពត ២:១៣–៣:១២ រម ១៣:១–១០ ។

**៥:២១** *ចំណុះគ្នាទៅវិញទៅមក* ត្រង់នេះបង្ហាញពីភាពស្មើគ្នាដូចដែលលោកប៉ុល បានពន្យល់ពីមុនៗហើយបន្តទៅទៀតនេះគាត់នឹងបង្ហាញពីរបៀបទំនាក់ទំនងគ្នា និងកិរិយានៃភាគីនីមួយៗដែលត្រូវសម្រុះសម្រួលគ្នា ។ ពាក្យថា "ចំណុះគ្នាទៅវិញ ទៅមក"នេះបើតាមវេយ្យាករណ៍ភាសាក្រិក គឺបញ្ជាក់ពីការពេញដោយព្រះវិញ្ញាណ(ខ.១៨)។ សេចក្ដីបង្គាប់ដែលថា"ចូរឱ្យបានពេញ"(ខ.១៨)ជាភាសា ក្រិកបានប្រើជាគុណនាមដែលក្លាយមកពីកិរិយាសព្ទ ដែលសំដៅទៅលើ: ការនិយាយ(ខ.១៩) ទំនុកបរិសុទ្ធ(ខ.១៩) ការច្រៀង(ខ.១៩) ទាំងអរព្រះគុណ(ខ.២០) ហើយទាំងការចំណុះគ្នាទៅវិញទៅមក(ខ.២១)។

**៥:២២** *ស្ត្រី . . . ចុះចូល* ត្រង់នេះគឺជាសេចក្ដីបង្រៀនអំពីការចុះចូលគ្នាទៅវិញទៅមកនៅក្នុង "ខ.២១" ជាពាក្យដែលមានបង្កប់ពីសេចក្ដីស្ដាប់បង្គាប់ (មើល ១ពត ៣:៥–៦) ប៉ុន្តែ ន័យចំមិនបាននិយាយនៅត្រង់វគ្គនេះទេ ។ *ដូច . . . ព្រះអម្ចាស់* ត្រង់នេះពុំមែនមានន័យថា ឱ្យដាក់ប្ដីរបស់ស្ត្រីទាំងនោះជំនួសកន្លែងរបស់ព្រះនោះទេ ចំណុចនេះគ្រាន់តែបង្ហាញថាស្ត្រីត្រូវតែចុះចូលនឹងប្ដីរបស់ខ្លួនឱ្យដូចជា ការដែលចុះចូលនឹងព្រះអម្ចាស់នោះដែរ ។

**៥:២៣** *ក្បាលនៃប្រពន្ធ* មើលការពន្យល់ ១កថ ១១:៣ ។ *ដូចជាព្រះគ្រីស្ទ* គឺជាភាពស្រដៀងនៃការទំនាក់ទំនងចំពោះព្រះគ្រីស្ទទៅនឹងពួកជំនុំ និងចំពោះប្ដីទៅនឹង ប្រពន្ធគឺផ្អែកលើបទគម្ពីរនេះទាំងមូល ។ *រូបកាយ* មើល ២:១៦ ៤:៤,១២,១៦ ។

**៥:២៥** *បុរសរាល់គ្នាអើយ* ត្រង់នេះលោកប៉ុលបង្ហាញពីការចុះចូលដោយពុំមែន ធ្វើឡើងតែម្ខាងៗនោះទេ គឺត្រូវតែចុះចូលគ្នាទៅវិញទៅមក ។ *ប្រគល់ព្រះអង្គទ្រង់ជំនួសផង* គឺមិនមែនគ្រាន់តែសំដែងពីសេចក្ដីស្រឡាញ់របស់ព្រះប៉ុណ្ណោះទេ នេះជាគំរូដល់ប្ដីគ្រប់រូប ដែលត្រូវតែស្រឡាញ់ប្រពន្ធខ្លួនឱ្យអស់ពីចិត្តព្រមទាំងប្រគល់ខ្លួនដល់នាងគ្រប់ទាំងការល្អ ។ ការលះបង់ជីវិតសម្រាប់មនុស្សដែលខ្លួន ស្រឡាញ់នោះជាការលះបង់ធំជាងការដែលប្រពន្ធខ្លួនស្រែកហៅឱ្យជួយ ។

**៥:២៦** *ដោយបានលាងសំអាតនឹងទឹក គឺជាព្រះបន្ទូល* សេចក្ដីប៉ងជាច្រើនត្រូវបានគេធ្វើឡើង ដើម្បីបង្ហាញពីប្រពៃណីអាពាហ៍ពិពាហ៍ ឬបង្ហាញពីនិមិត្តរូបអ្វីមួយនៅក្នុងកម្មវិធីរបស់ពួកជំនុំនៅសម័យនោះ ។ ការមួយដែលធ្វើឱ្យយើងបានដឹងច្បាស់នោះគឺព្រះអម្ចាស់ព្រះយេស៊ូវមិនមែនគ្រាន់តែសុគតដើម្បីនឹងអត់ទោសដល់យើងប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងមានឥទ្ធិពលលើជីវិតថ្មីនៃភាពបរិសុទ្ធ នៅក្នុងពួកជំនុំទៀតផង នោះគឺជា "កូនក្រមុំ"របស់ទ្រង់ ។ ការសិក្សាអំពីទស្សនៈនៃការសម្អាត ការប្រើទឹក និងព្រះបន្ទូលនោះ គឺមានដូចចែងក្នុង យហ ៣:៥ ១៥:៣ ទត ៣:៥ ហាព ១០:២២ យក ១:១៨ ១ពត ១:២៣ ៣:២១ និងការពន្យល់ ។

**៥:២៧** *ឱ្យបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបាន* មើលការពន្យល់ ១:៤ ។

**៥:២៨–២៩** *ដូចជាស្រឡាញ់រូបកាយរបស់ខ្លួន . . . ប្រពន្ធ . . . ស្រឡាញ់ដល់ខ្លួន* នេះគឺជាមូលដ្ឋានដើមនៃការបង្រៀន និងជាការបញ្ជាក់មួយដោយបានដកស្រង់ចេញពី លប ២:២៤(ខ.៣១)។ បើប្រពន្ធ និងប្ដីបានក្លាយជាសាច់តែមួយនោះ សម្រាប់បុរសត្រូវតែស្រឡាញ់ប្រពន្ធរបស់ខ្លួន ឱ្យដូចជាស្រឡាញ់

ឆ្អឹងទ្រង់[អ] ៣១«ដោយហេតុនោះបានជាមនុស្សប្រុស នឹងលា
ចេញពីឪពុកម្ដាយ ទៅនៅជាប់នឹងប្រពន្ធ ហើយអ្នកទាំង២
នោះនឹងត្រឡប់ជាសាច់តែ១វិញ»[ក] ៣២សេចក្ដីអាថ៌កំបាំង
នេះជ្រៅណាស់ តែខ្ញុំនិយាយខាងឯព្រះគ្រីស្ទនឹងពួកជំនុំ
វិញ ៣៣ប៉ុន្តែត្រូវឱ្យអ្នករាល់គ្នាទាំងអស់ស្រឡាញ់ប្រពន្ធខ្លួន[ខ]
ដូចជាខ្លួនឯង ហើយប្រពន្ធក៏ត្រូវកោតខ្លាចប្ដីដែរ ។

## កូន និងឪពុកម្ដាយ

**៦** ១ក្មេងរាល់គ្នាអើយ ចូរស្ដាប់បង្គាប់មាតាបិតាខ្លួនក្នុង
ព្រះអម្ចាស់ ដ្បិតធ្វើដូច្នោះទើបបានត្រូវ[គ] ២«ចូរគោរព
ប្រតិបត្តិដល់មាតាបិតាខ្លួន» នេះជាបញ្ញត្តិមុនដំបូង ដែល
ជាប់មានទាំងសេចក្ដីសន្យាផង ៣ដើម្បីឱ្យឯងរាល់គ្នាបាន
សេចក្ដីសុខ ហើយរស់នៅផែនដីជាយូរអង្វែងទៅ[ឃ]។
៤ឪពុករាល់គ្នាអើយ កុំឱ្យចាក់រុកកូនរបស់ខ្លួនឡើយ[ង]
ចូរបង្រៀនវាទៅតាមដំបូន្មាន និងសេចក្ដីដាស់តឿនរបស់
ព្រះអម្ចាស់វិញ[ច]។

## អ្នកបម្រើ និងចៅហ្វាយ

៥អ្នកបំរើរាល់គ្នាអើយ ចូរស្ដាប់បង្គាប់ចៅហ្វាយខ្លួនខាង
សាច់ឈាមដោយគោរពកោតខ្លាច[ឆ] ហើយញាប់ញ័រ ព្រម
ទាំងមានចិត្តទៀងត្រង់[ជ]ដូចជាដល់ព្រះគ្រីស្ទ[ឈ] ៦កុំបំរើតែក្នុង
កាលដែលគេមើលឃើញ ដូចជាចង់បំពេញដល់ចិត្តមនុស្ស
នោះឡើយ ចូរបំរើដូចជាបាវបំរើរបស់ព្រះគ្រីស្ទវិញ[ញ]
ទាំងធ្វើតាមព្រះហឫទ័យព្រះឱ្យអស់ពីចិត្ត ៧ទាំងបំរើដោយ
អំណរ ដូចជាបំរើដល់ព្រះអម្ចាស់ផង មិនមែនដូចជាបំរើ
មនុស្សឡើយ[ដ] ៨ដោយដឹងថាការល្អអ្វីដែលគ្រប់គ្នាធ្វើ[ឋ]នោះ
នឹងបានរង្វាន់ពីព្រះអម្ចាស់ ទោះបើជាបាវបំរើ ឬអ្នកជាក្ដី
៩ចៅហ្វាយរាល់គ្នាអើយ ចូរប្រព្រឹត្តនឹងបាវបំរើដូច្នោះ
ដែរ ទាំងលែងគំហកកំហែងទៅ ដោយដឹងថា ចៅហ្វាយ
របស់គេ ហើយរបស់អ្នករាល់គ្នាផង[ឌ] នោះទ្រង់គង់នៅ
ស្ថានសួគ៌ ហើយទ្រង់មិនចេះរើសមុខ[ឍ]អ្នកណាឡើយ ។

## គ្រឿងសឹករបស់ព្រះ

១០ឯសេចក្ដីឯទៀត បងប្អូនអើយ ចូរឱ្យមានកំឡាំងឡើង
ក្នុងព្រះអម្ចាស់[ណ] ដោយឫទ្ធិបារមីរបស់ព្រះចេស្ដាទ្រង់[ត]

**៥:៣០** អ រម ១២:៥ ១កថ ១២:២៧ **៥:៣១** ក លប ២:២៤ មថ ១៩:៥ ១កថ ៦:១៦ **៥:៣៣** ខ ខ.២៥ **៦:១** គ សភ ៦:២០ កល ៣:២០ **៦:៣** ឃ នក ២០:១២ ចទ ៥:១៦ **៦:៤** ង កល ៣:២១ ច លប ១៨:១៩ ចទ ៦:៧ សភ ១៣:២៤ ២២:៦ **៦:៥** ឆ ១ធថ ៦:១ ទត ២:៩ ១ពត ២:១៨ ជ កល ៣:២២ ឈ អភ ៥:២២ **៦:៦** ញ រម ៦:២២ **៦:៧** ដ កល ៣:២៣ **៦:៨** ឋ មថ ១៦:២៧ កល ៣:២៤ **៦:៩** ឌ យប ៣១:១៣,១៤ ឍ កច ១០:៣៤ **៦:១០** ណ ២សយ ១០:១២ ទដ ២៧:១៤ ហក ២:៤ ១កថ ១៦:១៣ ២ធថ ២:១ ត អភ ១:១៩

ផ្នែកមួយនៃរូបកាយរបស់ខ្លួននោះដែរ ។

**៥:៣២** *សេចក្ដីអាថ៌កំបាំង* មើលការពន្យល់ រម ១១:២៥ ។ នេះគឺជាអាថ៌កំបាំង ដែលនិយាយអំពីសេចក្ដីពិតដ៏ជ្រាលជ្រៅនៃការរួបរួមរបស់ព្រះគ្រីស្ទ ហើយនិងអំពីកូនក្រមុំរបស់ទ្រង់ដែលជាពួកជំនុំ ទាំងនេះហើយជាកិច្ចការអាថ៌កំបាំងដែលលើសពីការយល់ដឹងរបស់មនុស្ស ។ ចំណុចទាំងនេះមិនដូចជាការដែលបានលើកយកមកពន្យល់អំពីទំនាក់ទំនងគ្នារវាងប្ដី និងប្រពន្ធដែលត្រូវតែរួបរួមគ្នា ដូចជាព្រះគ្រីស្ទ និងពួកជំនុំនោះទេ ប៉ុន្តែ នេះជាកិច្ចការនៃសេចក្ដីពិតដ៏សំខាន់មួយដែល មនុស្សត្រូវធ្វើក្រោយពីរៀបការរួចមក ។

**៥:៣៣** *ស្រឡាញ់ប្រពន្ធខ្លួន ដូចជាខ្លួនឯង ហើយប្រពន្ធក៏ត្រូវកោតខ្លាចប្ដីដែរ* នេះ គឺជាឃ្លាមួយដែលបញ្ជាក់សារឡើងវិញ ហើយក៏ជាសេចក្ដីសង្ខេបនូវអ្វីដែលបានបង្រៀនអំពីប្ដី និងប្រពន្ធនៅក្នុងអត្ថបទនេះទាំងមូល ។

**៦:១** *ស្ដាប់បង្គាប់មាតាបិតា* មើល សភ ៣០:១៧ កល ៣:២០ និងការពន្យល់ ២ធថ ៣:២ ។ *ក្នុងព្រះអម្ចាស់* មានន័យថា ប្រកបជាមួយ និងស្ដាប់បង្គាប់ដល់ព្រះអម្ចាស់ ។

**៦:៣** *នៅផែនដី* បើតាមបទគម្ពីរ ចទ ៥:១៦ នក ២០:១២ ជាវគ្គដែលបានថែងពីបញ្ញត្តិ ដូចជា"សេចក្ដីសន្យា"(ខ.២) ដើម្បីបញ្ជាក់ពីការស្មានទុកមុនអំពីជីវិតនៅលើផែនដីនេះ ។ ឧទាហរណ៍ : នៅលើទឹកដីកាណាន ។ ការពិតទៅចំពោះក្រុងអេភេសូរមិនអាចថាជាទឹកដីកាណានបាននោះទេ ដូច្នេះពាក្យថា "នៅផែនដី" ត្រង់នេះគឺសំដៅលើជីវិតមនុស្សទូទៅ ពុំមែនសំដៅលើកន្លែងណាមួយនោះទេ ។

**៦:៤** *កុំឱ្យចាក់រុក* គឺចង់ប្រាប់ថា ឪពុកត្រូវតែផ្ដល់សិទ្ធិសេរីភាពដល់កូនរបស់ខ្លួន តាមការសមរម្យនោះផងដែរ បើមិនដូច្នេះទេ នោះពួកគេនិងមានអារម្មណ៍ថាខ្លួន បានធ្វើទង្វើមិនសមរម្យចំពោះកូនរបស់ខ្លួនឯងជាមិនខាន ។

**៦:៥** *អ្នកបំរើ* ចំពោះពាក្យនេះទាំងក្នុងគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី បូករួមទាំងបញ្ញត្តិផ្សេងៗសម្រាប់ស្ថានភាពសង្គមដូចជាភាពជាទាសករ និងការលែងលះគ្នាជាដើម(ចទ ២៤:១–៤)ដែលជាលទ្ធផលនៃភាពតានតឹងផ្លូវចិត្ត (មថ ១៩:៨) មានបញ្ញត្តិខ្លះពុំបានជួយកម្សាន្តចិត្ត ឬអត់ទោសឱ្យឡើយ ។ ប៉ុន្តែចំពោះព្រះអម្ចាស់ ទ្រង់បានប្រទានមធ្យោបាយសម្រាប់ដោះស្រាយដោយផ្អែកលើសេចក្ដីពិតវិញ ។

**៦:៨** *នឹងបានរង្វាន់ពីព្រះអម្ចាស់* ប្រហែលជានិយាយអំពីរង្វាន់របស់អ្នកជឿនៅថ្ងៃចុងក្រោយ(១កថ ៣:១០–១៥ ២កថ ៥:១០ និងការពន្យល់)។

**៦:៩** *ចៅហ្វាយ* លោកប៉ុលនិយាយបញ្ជាក់ម្ដងទៀតហើយអំពីអត្តចរិតគោរពដល់គ្នាទៅវិញទៅមក (៥:២១–៦:៤ មើល ទត ២:៩ និងការពន្យល់)។ *ចៅហ្វាយរបស់គេ ហើយរបស់អ្នករាល់គ្នាផង* "មើលការពន្យល់ រម ១៤:៤"។ *មិនចេះរើសមុខ* "មើល កច ១០:៣៤ និងការពន្យល់"។

**៦:១០–២០** នៅក្នុងខនេះគឺជាការសំឡឹងមើលបន្ថែមទៀតរបស់លោកប៉ុលនៅក្នុងក្រុងអេភេសូរកាន់តែច្បាស់ឡើង ។ ចាប់តាំងពីដើមដំបូងមក គាត់បានព្យាយាមធ្វើឱ្យភាពងងឹតនៅលោកីយនេះចាប់អារម្មណ៍ (មើលការពន្យល់ ១:៣ ១:១០,២០–២៣ ២:៦ ៦:១០) ហើយនៅពេលនេះ គាត់បានពណ៌នាអំពីសង្គ្រាមខាងឯវិញ្ញាណ តយុទ្ធនឹងវិញ្ញាណអាក្រក់ "ពួកម្ចាស់នៃសេចក្ដីងងឹតនាលោកីយនេះ"(ខ.១២)។

**៦:១០** *មានកំឡាំង...ដោយឫទ្ធិបារមី* ពាក្យនេះសំដែងពីកម្លាំងរបស់មនុស្សដែលគ្មានសមត្ថភាព ប៉ុន្តែ ឫទ្ធិបារមីរបស់ព្រះអម្ចាស់គឺមិនដែលបរាជ័យ

១១ចូរពាក់គ្រប់គ្រឿងសឹករបស់ព្រះ[ថ] ដើម្បីឱ្យអាចនឹងឈរ
មាំមួន ទាស់នឹងឧបាយកលទាំងអម្បាលម៉ានរបស់អារក្ស
១២ដ្បិតយើងរាល់គ្នាមិនមែនតយុទ្ធនឹងសាច់ឈាមទេ[ទ]
គឺនឹងពួកគ្រប់គ្រង ពួកមានអំណាច[ធ] និងពួកម្ចាស់[ន] នៃ
សេចក្ដីងងឹតនៅលោកីយនេះវិញ ហើយទាស់នឹងអំណាច
អាក្រក់ខាងវិញ្ញាណ នៅស្ថានដ៏ខ្ពស់ដែរ[ប]
១៣ហេតុនោះបាន
ជាត្រូវឱ្យយកគ្រប់គ្រឿងសឹករបស់ព្រះ[ផ] ដើម្បីឱ្យអ្នករាល់គ្នា
អាចនឹងទប់ទល់ក្នុងថ្ងៃអាក្រក់បាន រួចកាលណាបានតតាំង
សព្វគ្រប់ហើយ នោះឱ្យបាននៅតែឈរមាំមួនដដែល
១៤ដូច្នេះ ចូរឱ្យឈរមាំមួនចុះ ដោយក្រវាត់សេចក្ដីពិតនៅ
ចង្កេះ[ព] ហើយពាក់សេចក្ដីសុចរិតទុកជាប្រដាប់បាំងដើម
ទ្រូង[ភ]
១៥ទាំងពាក់សេចក្ដីប្រុងប្រៀបរបស់ដំណឹងល្អនៃ
សេចក្ដីសុខសាន្ត ទុកជាស្បែកជើង[ម]
១៦ថែមទាំងយកសេចក្ដី
ជំនឿទុកជាខែលផង[យ] ដែលអ្នករាល់គ្នានឹងអាចរំលត់ អស់
ទាំងព្រួញឆេះរបស់មេកំណាច ដោយសារខែលនោះបាន[រ]
១៧ចូរយកសេចក្ដីសង្គ្រោះទុកជាមួកសឹក[ល] និងដាវរបស់ព្រះ
វិញ្ញាណដែរ[វ] គឺជាព្រះបន្ទូល[ស]
១៨ព្រមទាំងប្រើសេចក្ដី
អធិស្ឋាន និងសេចក្ដីទូលអង្វរគ្រប់យ៉ាង[ហ] ដើម្បីអធិស្ឋាន
ដោយព្រះវិញ្ញាណ[ឡ]រាល់ពេលរាល់វេលា[អ] ហើយចាំយាម
ក្នុងសេចក្ដីនោះឯង ដោយនូវគ្រប់ទាំងសេចក្ដីខ្ជាប់ខ្ជួន នឹង
សេចក្ដីទូលអង្វរ[ក]ឱ្យពួកបរិសុទ្ធទាំងអស់
១៩ហើយឱ្យខ្ញុំផង[ខ]
ប្រយោជន៍ឱ្យព្រះបានប្រទានពាក្យសំដីមកខ្ញុំ ឱ្យខ្ញុំបានបើក
មាត់ដោយក្លាហាន[គ] នឹងសំដែងពីសេចក្ដីអាថ៌កំបាំង[ឃ]នៃ
ដំណឹងល្អ
២០ដែលខ្ញុំជាទូត[ង]ជាប់ច្រវាក់[ច] ដោយព្រោះដំ
ណឹងល្អនោះឯង ដើម្បីឱ្យខ្ញុំមានសេចក្ដីក្លាហានក្នុងដំណឹង
ល្អ ប្រយោជន៍ឱ្យខ្ញុំបាននិយាយ តាមដែលគួរគប្បី ។

## ការជម្រាបសួរចុងក្រោយ

២១តែអ្នកទីឃីកុស[ឆ] ជាបងប្អូនស្ងួនភ្ងា ហើយជាអ្នក
ជំនួយស្មោះត្រង់ក្នុងព្រះអម្ចាស់ គាត់នឹងប្រាប់គ្រប់ការ
ទាំងអស់ ឱ្យអ្នករាល់គ្នាដឹងពីដំណើរខ្ញុំ ដែលខ្ញុំធ្វើអ្វី ៗ
២២ខ្ញុំ
បានចាត់គាត់ឱ្យមកឯអ្នករាល់គ្នា សំរាប់សេចក្ដីនោះឯង
ដើម្បីឱ្យអ្នករាល់គ្នាបានដឹងពីដំណើរយើងខ្ញុំ[ជ] ហើយឱ្យគាត់

**៦:១១** ថ ខ.១៣ រម ១៣:១២ ១ថន ៥:៨
**៦:១២** ទ ១កថ ១៥:៥០ ហព ២:១៤ ធ អភ ១:២១ ៣:១០ ន រម ៨:៣៨ ប អភ ១:៣
**៦:១៣** ផ ខ.១១ ២កថ ៦:៧
**៦:១៤** ព អស ១១:៥ ភ ទដ ១៣២:៩ អស ៥៩:១៧ ១ថន ៥:៨
**៦:១៥** ម អស ៥២:៧ រម ១០:១៥
**៦:១៦** យ ១យហ ៥:៤ រ មថ ៥:៣៧
**៦:១៧** ល អស ៥៩:១៧ វ អស ៤៩:២ ស ហព ៤:១២
**៦:១៨** ហ រម ៨:២៦,២៧

ឡ លក ១៨:១ អ មថ ២៦:៤១ ភល ១:៤ ៤:៦ ក កច ១:១៤ កល ១:៣
**៦:១៩** ខ ១ថន ៥:២៥ គ កច ៤:២៩ ឃ រម ១៦:២៥ **៦:២០** ង ២កថ ៥:២០
ច កច ២១:៣៣ **៦:២១** ឆ កច ២០:៤ **៦:២២** ជ កល ៤:៧–៩

នោះឡើយ ។

**៦:១២** *មិនមែនតយុទ្ធនឹងសាច់ឈាមទេ* នេះគឺជាការដាស់តឿនមួយក្នុងការតយុទ្ធនឹងសត្រូវ ទាំងសត្រូវដែលមើលឃើញ និងមើលមិនឃើញ ទាំងក្នុងសមរភូមិ ឬក្រៅសមរភូមិ នោះគឺមិនមែនជាមនុស្សសុទ្ធសាតនោះទេ ។ *ពួកគ្រប់គ្រង ពួកមានអំណាច* ចំណុចនេះគឺលោកប៉ុលចង់និយាយភ្ជាប់ទៅនឹងសេចក្ដីពន្យល់ពីដំបូង របស់គាត់អំពីអំណាចនៃសេចក្ដីងងឹតនៅលោកិយនេះ (មើលការពន្យល់ ១:២១ ៣:១០) ។ *នៅស្ថានដ៏ខ្ពស់* មើលការពន្យល់ ១:៣។

**៦:១៣–១៤** *បានតតាំងសព្វគ្រប់ហើយ . . . នៅតែឈរមាំមួនដដែល* នេះគឺជារូបភាពអត្ថបទមួយ ពុំមែនជាទីលានប្រយុទ្ធដ៏ធំនៃវិញ្ញាណអាក្រក់នោះទេ ប៉ុន្តែវាគឺជា រូបភាពនៃការវាយប្រហារតទល់មកលើពួកទាហានជាលក្ខណៈបុគ្គលម្នាក់វិញ ។

**៦:១៤** *ដោយក្រវាត់សេចក្ដីពិត* នេះគឺជានិមិត្តរូបនៃសម្លៀកបំពាក់របស់ព្រះមែស៊ី (អស ១១:៥)។ ពុំមែនជាកម្លាំងកាយនោះទេ គឺជាជ័យជម្នះនៅក្នុងសមរភូមិដូចក្នុងករណីរបស់ព្រះមែស៊ីនោះជាដើម ។ *ពាក់សេចក្ដីសុចរិតទុកជាប្រដាប់បាំងដើមទ្រូង* នេះគឺជាចរិតលក្ខណៈនៃអ្នកធ្វើសង្គ្រាម គឺត្រូវតែមានប្រដាប់ការពារ ។ ដ្បិតព្រះអម្ចាស់ទ្រង់ផ្ទាល់ជាគំរូក្នុងការពាក់សេចក្ដីសុចរិតទុកជាប្រដាប់បាំងដើមទ្រូង នៅពេលទ្រង់ធ្វើដំណើរទៅនាំមកនូវយុត្តិធម៌(អស ៥៩:១៧ និងការពន្យល់)

**៦:១៥** *សេចក្ដីប្រុងប្រៀបរបស់ដំណឹងល្អ... ទុកជាស្បែកជើង* នេះគឺជាការពណ៌នានូវដំណើររបស់អ្នកប្រកាសដំណឹងល្អ (អស ៥២:៧) ដែលឆ្លុះបញ្ចាំងពីប្រពៃណីនៃការរត់ប្រណាំងដោយជើងទទេ ហើយក៏ជាអត្ថបទនៃដំណឹងល្អដែលជាគំរូមួយភ្ជាប់ ទៅនឹងទ្រនាប់ជើងនៃពួកទាហានរ៉ូម៉ាំង សម្រាប់ការពារ និងទ្រទ្រង់រាងកាយ ។ *ដំណឹងល្អនៃសេចក្ដីសុខសាន្ត* នេះគឺជាសេចក្ដីបញ្ជាក់តែមួយគត់ដែលគេបានរកក្នុងព្រះគម្ពីរ (២:១៤–១៦ រម ៥:១ និងការពន្យល់) ។

**៦:១៦** *យកសេចក្ដីជំនឿទុកជាខែល. . .អាចរំលត់. . .ព្រួញ. . .មេកំណាច* នេះគឺជា ការពិពណ៌នាអំពីខែលដ៏ធំរបស់ពួកទាហានរ៉ូម៉ាំងដែលមានស្រោបដោយស្បែក ជក់ទឹក អាចនឹងពន្លត់ចុងព្រួញភ្លើងរបស់សត្រូវបាន ។

**៦:១៧–១៨** *ដាវរបស់ព្រះវិញ្ញាណ . . . អធិស្ឋានដោយព្រះវិញ្ញាណ* ត្រង់នេះគឺរំឭកយើងបន្ថែមទៀតថា នេះគឺជាសង្គ្រាមខាងឯវិញ្ញាណ ដូច្នេះត្រូវតែប្រយុទ្ធដោយពឹងលើព្រះចេស្ដារបស់ព្រះ ពឹងលើព្រះបន្ទូល និងលើព្រះអង្គផ្ទាល់ តាមរយៈសេចក្ដីអធិស្ឋាន ។

**៦:១៧** *យកសេចក្ដីសង្គ្រោះទុកជាមួកសឹក* អស ៥៩:១៧ បានចែងស្រដៀងនឹងខនេះដែរ គឺឱ្យយកសេចក្ដីសង្គ្រោះនេះមកបាំងដើមទ្រូង (មើលការពន្យល់ខ.១៤) ។ មួកសឹកបានការពារទាហាន ហើយក្នុងករណីខ្លះមួកសឹកនេះបានផ្ដល់នូវនិមិត្តសញ្ញានៃ ជ័យជម្នះរបស់កងទ័ព ។

**៦:១៨** *អធិស្ឋានដោយព្រះវិញ្ញាណ* មានន័យថា អធិស្ឋានដោយមានជំនួយពីព្រះវិញ្ញាណបរិសុទ្ធ (រម ៨:២៦ និងការពន្យល់)។ *ពួកបរិសុទ្ធ* មើលការពន្យល់ ១:១ ។

**៦:១៩** *សេចក្ដីអាថ៌កំបាំង* "មើលការពន្យល់ ៣:៣"។

**៦:២០** *ជាប់ច្រវាក់* (ភល ១:៧,១៣ និងពន្យល់ កល ៤:៣ ភម ១០:១៣) ។

**៦:២១–២៣** នៅក្នុងខទាំងនេះគឺជាសេចក្ដីសរុបរបស់លោកប៉ុល ដោយពាក្យជម្រាបសួរ ប៉ុន្តែខ្វះខាតការរៀបរាប់ផ្ទាល់ខ្លួនរបស់គាត់ដូចសំបុត្រដទៃៗទៀត ។ ត្រង់នេះ យើងអាចយល់បានថា សំបុត្ររបស់គាត់ដែលផ្ញើទៅក្រុងអេភេសូរគឺជាសំបុត្រមួយដែលផ្ញើទៅពួកជំនុំច្រើន ។

**៦:២១** *អ្នកទីឃីកុស* គឺជាអ្នកជំនួយរបស់លោកប៉ុល ដែលធ្វើដំណើរទៅណា

បានកំឡាចិត្តអ្នករាល់គ្នាឡើងដែរ[ឈ]។
២៣សូមឱ្យពួកបងប្អូនបានប្រកបដោយនូវសេចក្តីសុខ
សាន្ត[ញ] និងសេចក្តីស្រឡាញ់ ព្រមទាំងសេចក្តីជំនឿ អំពីព្រះ
ដ៏ជាព្រះវរបិតា ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ ២៤សូម
ឱ្យព្រះគុណ បានសណ្ឋិតនៅជា ១ នឹងអស់អ្នកណាដែល

**៦:២២** ឈ កល ២:២ ៤:៨
**៦:២៣** ញ កទ ៦:១៦ ២ថន ៣:១៦ ១ពត ៥:១៤

ស្រឡាញ់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា
ដោយស្មោះត្រង់ ។ អាម៉ែន ។

មកណាជិនួសគាត់ (កល ៤:៧ ២ធថ ៤:១២ ទត ៣:១២)។
**៦:២៣-២៤** *សេចក្តីសុខសាន្ត . . . ព្រះគុណ* មើលការពន្យល់ រម ១:៧ ។
**៦:២៣** *បងប្អូន* មើលការពន្យល់ រម ១:១៣ ។
**៦:២៤** *ស្រឡាញ់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់* "មើលការពន្យល់ យហ ១៤:១៥,២១,២៣ ២១:១៥-១៧"។

សំបុត្ររបស់លោកប៉ុល
ដល់ពួកជំនុំ

# ភីលីព

## សេចក្ដីផ្ដើម

### អ្នកនិពន្ធ កាលបរិច្ឆេទ និងទីកន្លែង

ពួកជំនុំដំបូងបានធ្វើទីបន្ទាល់ជារួម ថាសំបុត្រភីលីពគឺជាស្នាដៃនិពន្ធរបស់លោកប៉ុល(១:១)។ តាមរយៈផ្ទៃសំបុត្រនេះផ្ទាល់ គេអាចដឹងច្បាស់ថាអ្នកនិពន្ធជានរណា ។ សេចក្ដីដែលអ្នកនិពន្ធនិយាយអំពីខ្លួនឯងនៅក្នុងសំបុត្រនេះ មានលក្ខណៈដូចជាសេចក្ដីផ្សេងទៀត ដែលយើងដឹងអំពីលោកប៉ុល តាមរយៈព្រះគម្ពីរសញ្ញាថ្មីឯទៀតៗដែរ ។

មានភស្តុតាងបញ្ជាក់ថា សាវ័កប៉ុលបានសរសេរសំបុត្រនេះផ្ញើពីក្នុងពន្ធនាគារមក(១:១៣-១៤)។ មានអ្នកខ្លះបានបដិសេធថាទីកន្លែងនៃការជាប់ឃុំនេះ គឺស្ថិតនៅឯក្រុងអេភេសូរ ប្រហែលជាក្នុងរវាងឆ្នាំ៥៣ ដល់៥៥គ.ស ។ រីឯអ្នកខ្លះទៀតបានអះអាងថា ការជាប់ឃុំនេះស្ថិតនៅក្រុងសេសារា ព្រមទាំងបានកំណត់យកឆ្នាំ៥៧-៥៩គ.ស ។ ទោះជាយ៉ាងនេះក៏ដោយ ក៏តាមរយៈភស្តុតាងដ៏ប្រសើរបំផុតមួយ គេបានកំណត់យកទីក្រុងរ៉ូមជាទីកន្លែងនិពន្ធ ដែលមានកាលបរិច្ឆេទនៅឆ្នាំ៦១គ.ស ។ ភស្តុតាងនេះពិតជាសមនឹងការអធិប្បាយអំពីការដែលពួករ៉ូមាំងឃុំខ្លួនសាវ័កប៉ុលនៅក្នុងផ្ទះ(កច ២៨:១៤-៣១)។ នៅពេលនិពន្ធព្រះគម្ពីរភីលីព លោកប៉ុលមិនមែនកំពុងជាប់ឃុំក្នុងគុកងងឹតម៉ាម៉ែរទីន(Mamertine) ដូចកាលនិពន្ធព្រះគម្ពីរធីម៉ូថេខ្សែទី២ឡើយ តាមពិតគឺនៅក្នុងផ្ទះដែលគាត់បានជួល ដែលក្នុងការរស់នៅរបស់គាត់ទីនោះរយៈពេលពីរឆ្នាំ គាត់មានសិទ្ធិសេរីភាពក្នុងការផ្សព្វផ្សាយដំណឹងល្អទៅដល់អស់អ្នកណាដែលបានមកឯគាត់ ។

### គោលបំណង

គោលបំណងជាចម្បងរបស់លោកប៉ុលក្នុងការសរសេរសំបុត្រនេះ គឺដើម្បីថ្លែងអំណរគុណដល់ពួកជំនុំក្រុងភីលីព ចំពោះអំណោយដែលពួកគេបានផ្ដល់ឱ្យគាត់ នៅពេលដែលពួកគេបានឮដំណឹងពីការជាប់ឃុំរបស់គាត់នៅក្រុងរ៉ូម(១:៥ ៤:១០-១៩)។ ទោះជាយ៉ាងណាក៏ដោយ លោកប៉ុលបានឆ្លៀតយកឱកាសនេះ ដើម្បីសម្រេចគោលបំណងឯទៀតៗដូចជា (១).ដើម្បីប្រាប់ពីស្ថានភាពផ្ទាល់ខ្លួន(១:១២-២៦ ៤:១០-១៩)។ (២).ដើម្បីលើកទឹកចិត្តពួកជំនុំភីលីពឱ្យឈរមាំមួនក្នុងការប្រឈមមុខនឹងការបៀតបៀន ឱ្យមានអំណរដោយគ្មានព្រួយបារម្ភពីស្ថានភាពអ្វីឡើយ(១:២៧-៣០ ៤:៤)។ (៣).ដើម្បីលើកទឹកចិត្តឱ្យពួកគេបន្ទាបខ្លួននិងសាមគ្គីគ្នា(២:១-១១ ៤:២-៥)។ (៤).ដើម្បីឱ្យចាត់លោកធីម៉ូថេ និងលោកអេប៉ាប្រូឌីតទៅ ឯពួកជំនុំភីលីព(២:១៩-៣០)។ (៥).ដើម្បីដាស់តឿនពួកភីលីពឱ្យប្រុងប្រយ័ត្ននឹងគ្រីស្ទបរិស័ទដែលនិយមជ្រុលខាងប្រពៃណីសាសនាយូដា(ពួកគ្រីស្ទបរិស័ទក្រឹត្យវិន័យនិយម) និងពួកអសីលធម៌ (ពួកសេរីនិយមជ្រុល)ដែលស្ថិតនៅក្នុងចំណោមពួកគេ(ជំពូក ៣)។

### អ្នកទទួល

ទីក្រុងភីលីពត្រូវបានគេដាក់ឈ្មោះឱ្យតាមលំនាំព្រះនាមស្ដេចភីលីពទី ២ នៃខេត្តម៉ាសេដូន ជាបិតាស្ដេចអ័ឡេក្សាន់ត្រុស-អធិរាជ ។ ទីក្រុងភីលីពជាទីក្រុងចំណុះមួយដ៏រុងរឿងនៃចក្រភពរ៉ូម ដែលមានន័យថាពលរដ្ឋក្រុងភីលីពក៏ជាពលរដ្ឋនៃទីក្រុងរបស់ចក្រភពរ៉ូមាំងដែរ ។ គឺយ៉ាងដូចនេះហើយ បានជាពួកក្រុងភីលីពបានអួតពួកខ្លួនថា ជាសាសន៍រ៉ូម(កច ១៦:២១) ស្លៀកពាក់តាមរបៀបសាសន៍រ៉ូម ហើយជាញឹកញាប់ពួកគេនិយាយភាសាឡាតាំងទៀតផង ។ បញ្ហានេះបាននាំលោកប៉ុលនិយាយអំពីអត្តសញ្ញាណពិតរបស់អ្នកជឿថា ជាសាសន៍ស្ថានសួគ៌(៣:២០-២១)។ អ្នកក្រុងភីលីពជាច្រើនជាពួកទាហានប្រុសៗចូលនិវត្តន៍ ដែលគេផ្ដល់ដីធ្លីនៅតាមដំបន់ជិតខាងទីក្រុងភីលីព ហើយជាពួកទាហានដែលផ្លាស់វេនគ្នាឈរជើងនៅតាមព្រំប្រទល់ទីក្រុងនេះ ។ ការដែលក្រុងភីលីពជាចំណុះឱ្យចក្រភពរ៉ូម៉ាំង ប្រហែលជាមូលហេតុដែលពួកសាសន៍យូដាពុំមានគ្នាគ្រប់គ្រាន់ ដើម្បីបង្កើតសាលាប្រជុំឱ្យបានមួយកន្លែងនៅក្រុងនេះ ហើយក៏ប្រហែលជាមូលហេតុដែលលោកប៉ុលមិនបានស្រង់យកបទគម្ពីរសញ្ញាចាស់ នៅក្នុងការសរសេរសំបុត្រទៅកាន់ពួកជំនុំក្រុងភីលីពផងដែរ ។

### ទម្រង់បែបបទ

១. ព្រះគម្ពីរភីលីពមិនមានសម្រង់បទគម្ពីរសញ្ញាចាស់(មើលការពន្យល់ យប ១៣:១៦)។

២. ព្រះគម្ពីរនេះជាលិខិតថ្លែងអំណរគុណ ដែលបេសកជនបានសរសេរប្រាប់ពីការរីកចម្រើននៃការងាររបស់ខ្លួនផងដែរ ។

៣. ព្រះគម្ពីរនេះបានចង្អុលបង្ហាញពីលក្ខណៈដ៏មាំមួននៃជីវិតគ្រីស្ទបរិស័ទដូចជា (១).ចេះបន្ទាបខ្លួន(២:១-៤)។ (២).ផ្ដោតឆ្ពោះគោលដៅ (៣:១៣-១៤)។ (៣).មិនព្រួយបារម្ភពីស្ថានភាពអ្វីទាំងអស់(៤:៦)។ (៤).អាចធ្វើគ្រប់ទាំងអស់បាន(៤:១៣)។

៤. ព្រះគម្ពីរនេះមានលក្ខណៈល្អប្រសើរនៅត្រង់ថា ជាសំបុត្រសញ្ញាថ្មីនៃក្ដីអំណរដែលមានពាក្យ"ក្ដីអំណរ"ចំនួន១៦ដង តាមទម្រង់

ផ្សេងៗពីគ្នា ។

៥. ព្រះគម្ពីរនេះមានការសិក្សាមួយ ក្នុងចំណោមការសិក្សាស៊ីជម្រៅបំផុតអំពីព្រះគ្រីស្ទ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី (២:៥-១១) ។ តែទោះជាស៊ីជម្រៅយ៉ាងណាក៏ដោយ សាវ័កប៉ុលបញ្ចូលការសិក្សានេះ ក្នុងគោលបំណងសំខាន់បំផុត ដើម្បីបង្ហាញពីការដែលគ្រីស្ទបរិស័ទត្រូវតែមានគំនិតគិតដូចព្រះគ្រីស្ទ ។

**ទីក្រុងភីលីពក្នុងសម័យលោកសាវ័កប៉ុល**

ទីក្រុងភីលីពដែលជាដែនដីចំណុះនៃចក្រភពរ៉ូម៉ាំង ជាទីក្រុងមួយដ៏សំខាន់នៃខេត្តម៉ាសេដូន ដែលតាមភូមិសាស្ត្រ មានផ្លូវជាតិដ៏ចម្បងមួយខ្សែកាត់តាម ទីក្រុងនេះដោយតភ្ជាប់ពីបណ្ដាខេត្តនានានៅភូមិភាគខាងលិចរហូតដល់ក្រុងរ៉ូម ។ ផ្លូវជាតិនេះឈ្មោះ "ផ្លូវអេកណាទា" (Via Egnatia) ដែលពុះចែកទីប្រជុំជន (មានសាលប្រជុំ ពាណិជ្ជកម្ម និងតុលាការរបស់ចក្រភពរ៉ូម៉ាំង) នៃទីក្រុងនេះជាពីរចំណែក ហើយជាប្រភពដ៏សំខាន់នៃភាពសំបូររុងរឿង និងសក្ដានុភាពនយោបាយ ។ តំបន់នាប៉ូលមានទីតាំងនៅលើឆ្នេរសមុទ្រ ចម្ងាយ ១៦,០៩គ.មពីទីក្រុងភីលីព និងជាទីកន្លែងដែលសាវ័កប៉ុលឡើងគោក បន្ទាប់ពីបានចុះសំពៅចេញពីទ្រអាសមក ដើម្បីឆ្លើយតបតាមទស្សនៈម៉ាសេដូន ។

ទីក្រុងភីលីពនៃខេត្តម៉ាសេដូននេះមានប្រវត្តិសាស្ត្រប្រកបដោយមោទនភាព ដោយសារជាទីក្រុងឈានមុខខាងផលិតផលមាស។ ដោយសារ គេបានដាក់ឈ្មោះឱ្យដំបូងបំផុតតាមលំនាំព្រះនាមស្ដេចភីលីពទី២ ដែលជាបិតាស្ដេចអ័ឡេក្សានគ្រុស-អធិរាជ ទីក្រុងនេះបានទទួលកិត្តិយសតាមរយៈព្រះនាមស្ដេច ជូលាសេសា និងស្ដេចអូគូសនៅសម័យក្រោយមកទៀត ។ ជនជាតិអ៊ីតាលីបានមកតាំងទីលំនៅតាមបណ្ដាកងពលនៃទាហានរ៉ូម៉ាំង ដែលបានចូលមកកាន់កាប់ទឹកដីនេះ ហើយបានធ្វើឱ្យពួកខ្លួនក្លាយជាពលរដ្ឋដែលមានថានៈខ្ពង់ខ្ពស់ ព្រមទាំងបានធ្វើឱ្យទីក្រុងភីលីពមានភាពរឹងមាំ និងមានភាសាចម្រុះទៀតផង ។ ក្រុងនេះបានរីកលូតលាស់ ដោយផ្លាស់ប្ដូរពីទីប្រជុំជនដ៏តូចតាចមួយទៅជាទីក្រុងមួយដ៏ល្បីល្បាញ និងមានអភ័យឯកសិទ្ធិ ។ សហគមន៍អ៊ីយូស អ៊ីតាលីយុម (Ius Italicum) មានកិត្តិយសខ្ពង់ខ្ពស់បំផុតនៅក្នុងទីក្រុងភីលីព ដោយច្បាប់បានផ្ដល់ឱ្យពួកនេះនូវសិទ្ធិសេរីភាពពេញលេញ ស្មើពួកអ្នកក្រុងឯទៀតៗរបស់អ៊ីតាលីដែរ ។

គេបានរកឃើញសំណង់បាក់បែកដែលមានដូចជា សាលមហោស្រព ទួលអាក្រូប៉ូល សាលប្រជុំ អាងទឹក និងក្លោងទ្វារជាទីវិញកខាងលិច (ប្រហែល ១៦,០៩ គ.ម ខាងលិចក្រុង) ។ នៅត្រង់ទន្លេកាងគីទីដែលនៅមិនឆ្ងាយពីខ្លោងទ្វារវិញក គឺជាទីកន្លែងដែលលោកប៉ុលបានលើកឡើងពីស្ត្រីកោតខ្លាចព្រះមួយចំនួន និងជាទីកន្លែងដែលស្ត្រីម្នាក់ឈ្មោះ "លីឌា" បានផ្លាស់ប្រែចិត្តទទួលជឿព្រះ (កច ១៦:១៣-១៥) ។

**គម្រោងសង្ខេប**

I. **ការគួរសម (១:១-២)**

II. **ការអរព្រះគុណ និងការអធិស្ឋានឱ្យពួកជំនុំក្រុងភីលីព (១:៣-១១)**

III. **ស្ថានភាពផ្ទាល់ខ្លួនរបស់សាវ័កប៉ុល (១:១២-២៦)**

IV. **ការលើកទឹកចិត្ត (១:២៧-២:១៨)**

ក. ការរស់នៅដែលស័ក្តិសមនឹងដំណឹងល្អ (១:២៧-៣០)

ខ. យកគំរូតាមការបម្រើរបស់ព្រះគ្រីស្ទ (២:១-១៨)

V. **គូកនការងាររបស់សាវ័កប៉ុលនៅក្នុងដំណឹងល្អ (២:១៩-៣០)**

ក. លោកធីម៉ូថេ (២:១៩-២៤)

ខ. លោកអេបាប្រូឌីត (២:២៥-៣០)

VI. **ការដាស់តឿនឱ្យប្រុងប្រយ័ត្នចំពោះពួកសាសនាយូដា និងពួកអសីលធម៌ (៣:១-៤:១)**

ក. ប្រយ័ត្ននឹងពួកគ្រីស្ទបរិស័ទនិយមជ្រុលខាងប្រពៃណីសាសនាយូដា ឬពួកក្រឹត្យវិន័យនិយម (៣:១-១៦)

ខ. ប្រយ័ត្ននឹងពួកអសីលធម៌ ឬពួកសេរីជ្រុលនិយម (៣:១៧-៤:១)

VII. **សេចក្ដីស្វាងទឹកចិត្តជាលើកចុងក្រោយ ការអរព្រះគុណ និងការសន្និដ្ឋាន (៤:២-២៣)**

ក. ការស្វាងទឹកចិត្តដោយផ្ដោតទៅលើទិដ្ឋភាពផ្សេងៗនៃជីវិតគ្រីស្ទបរិស័ទ (៤:២-៩)

ខ. ទីបន្ទាល់ជាសន្និដ្ឋាន និងការអរព្រះគុណម្ដងទៀត (៤:១០-២០)

គ. ការគួរសមជាបញ្ចប់ និងការជូនពរ (៤:២១-២៣)

១សំបុត្រប៉ុលនិងធីម៉ូថេ[ក] ជាបាវបំរើរបស់ព្រះយេស៊ូវ
គ្រីស្ទ យើងខ្ញុំផ្ញើមកពួកបរិសុទ្ធទាំងអស់[ខ] ក្នុងព្រះគ្រីស្ទ
យេស៊ូវ ដែលនៅក្រុងភីលីព[គ] ព្រមទាំងពួកអ្នកត្រួតត្រា[ឃ]
និងពួកជំនួយផង[ង]។ ២សូមឱ្យអ្នករាល់គ្នាបានប្រកបដោយ
ព្រះគុណនិង សេចក្ដីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃ
យើងរាល់គ្នា ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ[ច]។

## ការថ្លែងអំណរគុណ និងសេចក្ដីអធិស្ឋាន

៣ខ្ញុំអរព្រះគុណដល់ព្រះនៃខ្ញុំ ដោយព្រោះគ្រប់ទាំង
សេចក្ដីដែលខ្ញុំនឹកចាំពីអ្នករាល់គ្នា[ឆ] ៤ខ្ញុំក៏ទូលអង្វរ[ជ]ឱ្យអ្នក
រាល់គ្នា ដោយអំណរនៅគ្រប់វេលា ដែលខ្ញុំអធិស្ឋានជា
និច្ច ៥ដោយព្រោះចំណែកដែលអ្នករាល់គ្នាបានជួយ[ឈ] ក្នុង
ដំណឹងល្អ ចាប់តាំងពីថ្ងៃមុនដំបូង[ញ] ដរាបដល់ឥឡូវនេះ
៦ខ្ញុំជឿសេចក្ដីនេះជាយ៉ាងជាក់ថា ព្រះអង្គដែលទ្រង់បាន
ចាប់តាំងធ្វើការល្អក្នុងអ្នករាល់គ្នា ទ្រង់នឹងធ្វើឱ្យកាន់តែ
ពេញខ្នាតឡើង[ដ] ទាល់តែដល់ថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ[ឋ]។
៧គួរគប្បី[ឌ]ឱ្យខ្ញុំគិតពីអ្នករាល់គ្នាដូច្នេះដែរ ពីព្រោះអ្នក
រាល់គ្នានឹកពីខ្ញុំនៅជាប់ក្នុងចិត្តជានិច្ច[ឍ] ទោះបើខ្ញុំជាប់
ចំណង[ណ]ឬកំពុងតែដោះសា[ត] ហើយបញ្ជាក់ដំណឹងល្អក្ដី ដ្បិត
អ្នករាល់គ្នាមានសេចក្ដីប្រកប ក្នុងព្រះគុណជាមួយនឹងខ្ញុំ
ដែរ ៨ព្រះទ្រង់ជាស្មរបន្ទាល់[ថ]ពីខ្ញុំថា ខ្ញុំរឭកដល់អ្នករាល់
គ្នាជាខ្លាំង ដោយព្រះហឫទ័យសន្ដោសនៃព្រះយេស៊ូវគ្រីស្ទ
៩ខ្ញុំក៏អធិស្ឋានសូមសេចក្ដីនេះ គឺឱ្យសេចក្ដីស្រឡាញ់
របស់អ្នករាល់គ្នា[ទ] បានចំរើនកាន់តែច្រើនឡើង ដោយនូវ
សេចក្ដីចេះដឹង និងយោបល់គ្រប់ជំពូក[ធ] ១០ប្រយោជន៍ឱ្យអ្នក

**១:១** ក កច ១៦:១ ២កថ ១:១ ខ កច ៩:១៣ គ កច ១៦:១២ ឃ ១ធថ ៣:១ ង ១ធថ ៣:៨
**១:២** ច រម ១:៧
**១:៣** ឆ រម ១:៨
**១:៤** ជ រម ១:១០
**១:៥** ឈ កច ២:៤២ ភល ៤:១៥ ញ កច ១៦:១២–៤០
**១:៦** ដ ១៣៨:៨ ឋ ខ.១០ ១កថ ១:៨
**១:៧** ឌ ២ពត ១:១៣ ឍ ២កថ ៧:៣ ណ ខ.១៣,១៤,១៧ កច ២១:៣៣ ត ខ.១៦
**១:៨** ថ រម ១:៩ **១:៩** ទ ១ថន ៣:១២ ធ អភ ១:១៧

**១:១–២** លោកប៉ុលបានសរសេរសំបុត្រនីមួយៗ តាមរបៀបដែលគេនិយមប្រើនៅសម័យនោះ ដែលមានធាតុផ្សំបីយ៉ាង (១).អត្តសញ្ញាណរបស់អ្នកផ្ញើ (២).អត្តសញ្ញាណរបស់អ្នកទទួល (៣).ការគួរសម ។

**១:១** *ប៉ុល* មើលការពន្យល់ រម ១:១ ។ *ធីម៉ូថេ* មើលសេចក្ដីផ្ដើម ១ធីម៉ូថេ ត្រង់អ្នកទទួល ។ តាមសំបុត្រគេដឹងថា លោកធីម៉ូថេជាគូកនការងាររបស់លោកប៉ុល គឺមិនមែនជាអ្នកសរសេរសំបុត្ររួមគ្នាជាមួយនឹងគាត់ឡើយ ។ *បាវបំរើ* មើលការពន្យល់ រម ១:១ ទត ១:១ យក ១:១ ២ពត ១:១ យដ ១ វវ ១:១ ។ ការរៀបចំនេះបានបង្ហាញឱ្យឃើញពីអត្តសញ្ញាណជាធម្មតារបស់គាត់ជា "សាវ័ក"។ *ពួកបរិសុទ្ធ* មើលការពន្យល់ រម ១:៧ ។ *ក្រុងភីលីព* មើលសេចក្ដីផ្ដើមត្រង់អ្នកទទួល ។ *ពួកអ្នកត្រួតត្រា និងពួកជំនួយ* មានតែម្ដងគត់នៅក្នុងសំបុត្រនេះ ដែលពួកអ្នកបម្រើការងារព្រះវិហារ ដែលធ្វើការជាក្រុមមួយត្រូវបានរាប់ជាអ្នកទទួលសំបុត្រតែមួយ ។ *ពួកអ្នកត្រួតត្រា* មើលការពន្យល់ ១ធថ ៣:១ ។ *ពួកជំនួយ* មើលការពន្យល់ ១ធថ ៣:៨ ។

**១:២** *ព្រះគុណ និងសេចក្ដីសុខសាន្ត* មើលការពន្យល់ រម ១:៧ ។

**១:៣–៤** *ខ្ញុំអរព្រះគុណដល់ព្រះនៃខ្ញុំ . . . នឹកចាំពីអ្នករាល់គ្នា . . . ដោយអំណរ . . . ខ្ញុំអធិស្ឋានជានិច្ច* គឺជាសេចក្ដីអធិស្ឋានអរព្រះគុណដោយអំណរចំពោះការឆ្លើយតបរបស់ពួកក្រុងភីលីព ដោយការចេញផ្សាយដំណឹងល្អ ។ ការអធិស្ឋាននេះ គឺជាប្រយោគដែលសំគាល់ពីការចាប់ផ្ដើមនៃសំបុត្ររបស់លោកប៉ុល (រម ១:៨ ១កថ ១:៤ កល ១:៣ ១ថន ១:២ ២ថន ១:៣ ២ធថ ១:៣ ភម ៤)។

**១:៥** *ចំណែកដែលអ្នករាល់គ្នាបានជួយក្នុងដំណឹងល្អ* ការអរព្រះគុណក្នុងសេចក្ដីអធិស្ឋានរបស់លោកប៉ុលមិនមែនសំដៅចំពោះតែការទទួលដំណឹងល្អរបស់ពួកគេប៉ុណ្ណោះទេ តែក៏ចំពោះជំនួយដ៏សកម្មរបស់ពួកគេដល់ការងារបម្រើព្រះរបស់សាវកប៉ុលផងដែរ (មើលការពន្យល់ ភល ៤:១៥)។ *ចាប់តាំងពីថ្ងៃមុនដំបូង* គឺពេលដែលសាវកប៉ុលមកកាន់ក្រុងភីលីពជាលើកទី១ (មើលការពន្យល់ កច ១៦:១២)។ *ឥឡូវនេះ* គឺពេលដែលនៅគៀកនឹង (២:២៤) ការដែលពួករ៉ូម៉ាំងឃុំខ្លួនលោកសាវ័កប៉ុលជាលើកដំបូង (កច ២៨:១៦–៣១)។

**១:៦** *ធ្វើការល្អក្នុងអ្នករាល់គ្នា* សាវកប៉ុលមានការជឿជាក់មិនគ្រាន់តែចំពោះអ្វីដែលព្រះទ្រង់បានធ្វើ "សម្រាប់" អ្នកទទួលសំបុត្រ ដើម្បីអត់ទោសបាបឱ្យពួកគេប៉ុណ្ណោះទេ តែក៏ចំពោះអ្វីដែលទ្រង់បានធ្វើការ "ក្នុង" ពួកគេផងដែរ (ខ.១១) ពាក្យ "ធ្វើការ" បញ្ជាក់ពីព្រះរាជកិច្ចរបស់ព្រះក្នុងការសង្គ្រោះពួកគេ ។ *ថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ* គឺថ្ងៃនៃការយាងត្រឡប់មកវិញ ដែលសេចក្ដីសង្គ្រោះនឹងត្រូវបានបង្ហើយឱ្យចប់សព្វគ្រប់ (១:១០ ២:១៦ ១កថ ១:៨ ៥:៥ ២កថ ១:១៤) គឺជាព្រះដែលទ្រង់ជាអ្នកផ្ដើមឱ្យមាន និងបន្ត ហើយ និងបញ្ចប់សេចក្ដីសង្គ្រោះនៅថ្ងៃកំណត់របស់ទ្រង់ ។

**១:៧** *ជាប់ចំណង* មើលការពន្យល់ អភ ៦:២០ ។ *ប្រកប ក្នុងព្រះគុណ* សូម្បីតែការជាប់គុក និងការរងទុក្ខបៀតបៀន ក៏មិនអាចកែប្រែការប្រកបនេះបានដែរ ។ ហើយសូម្បីតែកាលដែលលោកប៉ុលនៅជាប់ឃុំ ពួកគេទទួលស្គាល់ថាខ្លួនពួកគេក៏ កំពុងជាប់ជាមួយនឹងលោកប៉ុលដែរ ដោយពួកគេបានបញ្ជូនលោកអេបាប្រាស់ និងជំនួយផ្នែកហិរញ្ញវត្ថុដល់គាត់ (២:២៥–៣០ ៤:១៨)។ ពួកគេបានក្លាយជាតែមួយនឹងលោកប៉ុលនៅក្នុងបេសកកម្មផ្សាយដំណឹងល្អនៃពួកសាវក (មើល ខ.៥)។

**១:៨** *ព្រះហឫទ័យសណ្ដោសនៃព្រះយេស៊ូវគ្រីស្ទ* ព្រះហឫទ័យដ៏ជ្រាលជ្រៅហើយទូលាយ ដែលជាសេចក្ដីស្រលាញ់ប្រកបដោយការអាណិតអាសូរនេះ បានបង្ហាញឱ្យឃើញដោយសារអង្គព្រះយេស៊ូវគ្រីស្ទ ហើយឥឡូវនេះបានចិញ្ចឹមនៅក្នុងសាវ័កប៉ុល តាមរយៈការប្រកបរបស់គាត់ជាមួយព្រះគ្រីស្ទ ។ ព្រះទ័យសណ្ដោសនេះ គឺមានសម្រាប់មនុស្សគ្រប់រូបស្មើៗគ្នាឥតមានរើសមុខឡើយ ។

**១:៩** *ចំរើនកាន់តែច្រើនឡើង* សេចក្ដីស្រឡាញ់ពិត គឺតម្រូវឱ្យមានការរីកលូតលាស់ និងភាពពេញខ្នាត (១ថន ៣:១២ ៤:១០ ២ថន ១:៣)។ *ដោយនូវសេចក្ដីចេះដឹង* ជារបៀបដែលសេចក្ដីស្រឡាញ់ធំធាត់ (កល ១:៩)។ *យោបល់គ្រប់ជំពូក* គឺការឆាប់ស្គាល់ខុសត្រូវ និងការឆាប់យល់ពីអារម្មណ៍អ្នកដទៃ ។ សេចក្ដីស្រឡាញ់នៃគ្រីស្ទបរិស័ទគឺលើសពីមនោសញ្ចេតនាទៅទៀត ព្រោះបានចាក់ឫសនៅក្នុងប្រាជ្ញា និងចំណេះខាងឯវិញ្ញាណ ។

**១:១០** *ស្គាល់អស់ទាំងសេចក្ដីដែលប្រសើរ* គ្រីស្ទបរិស័ទត្រូវទទួលស្គាល់

រាល់គ្នាបានលមើល ឱ្យស្គាល់អស់ទាំងសេចក្តីដែលប្រសើរ
ដើម្បីឱ្យបានជ្រះថ្លា ហើយឥតធ្វើឱ្យអ្នកណាអាក់អន់ចិត្ត
ឡើយ ដរាបដល់ថ្ងៃនៃព្រះគ្រីស្ទ[ន] ១១ព្រមទាំងមានពេញ
ជាផល នៃសេចក្តីសុចរិត[ប] ដែលមកដោយសារព្រះយេស៊ូវ
គ្រីស្ទសំរាប់ជាសិរីល្អ ហើយជាសេចក្តីសរសើរដល់ព្រះ
ផង ។

## ការជាប់ចំណងរបស់លោកប៉ុលចម្រើនដល់ដំណឹងល្អ

១២បងប្អូនអើយ ខ្ញុំចង់ឱ្យអ្នករាល់គ្នាដឹងថា ការទាំង
ប៉ុន្មានដែលកើតឡើងដល់ខ្ញុំ នោះបានប្រែទៅជាចំរើនដល់
ដំណឹងល្អវិញ ១៣ដល់ម្ល៉េះបានជានៅពេញក្នុងផ្ទៃវាំង និង
គ្រប់កន្លែងឯទៀត គេបានដឹងច្បាស់ថា ខ្ញុំជាប់ចំណង[ផ]នេះ
ដោយព្រោះព្រះគ្រីស្ទ ១៤ហើយពួកបងប្អូនច្រើនគ្នាក្នុងព្រះ
អម្ចាស់ ក៏បានសង្ឃឹមឡើងដោយសារចំណងខ្ញុំ[ព] ហើយ
គេហ៊ានផ្សាយព្រះបន្ទូលកាន់តែច្រើនឡើង ដោយឥតភ័យ
ខ្លាច[ភ] ១៥មានខ្លះសំដែងពីព្រះគ្រីស្ទ ដោយចិត្តឈ្នានីស
ហើយចង់ឈ្លោះប្រកែកមែន តែខ្លះដោយចិត្តស្មោះសរវិញ
១៦ឯពួកមួយ គេសំដែងពីព្រះគ្រីស្ទ ដោយចិត្តទទឹង[ម]មិន
មែនដោយចិត្តស្អាតទេ នោះគឺដោយស្មានថា គេនឹងបន្ថែម
សេចក្តីទុក្ខលំបាកដល់ចំណងខ្ញុំទៀត[យ] ១៧ឯពួកមួយទៀត
គេប្រព្រឹត្តដោយស្រឡាញ់វិញ ដោយដឹងថា ខ្ញុំបានតាំង
ឡើង សំរាប់ដោះសាពីដំណឹងល្អ[រ] ១៨ចុះតើអំពល់អ្វី ទោះ
បើយ៉ាងណាក៏ដោយ ទោះដោយពើ ឬដោយសេចក្តីស្មោះ
ក្តីគង់តែគេសំដែងពីព្រះគ្រីស្ទដែរ ដូច្នេះខ្ញុំមានសេចក្តី
អំណរណាស់ ក៏នឹងចេះតែមានអំណរតទៅមុខទៀត
១៩ដ្បិតខ្ញុំដឹងថា ការនេះនឹងបានត្រឡប់ជាសេចក្តីសង្គ្រោះ[ល]

**១:១០** ន ខ.៦ ១កថ ១:៨
**១:១១** ប យក ៣:១៨
**១:១៣** ផ ខ.៧,១៤,១៧ កច ២១:៣៣
**១:១៤** ព ខ.៧,១៣,១៧ កច ២១:៣៣
ភ កច ៤:២៩
**១:១៦** ម ភល ២:៣
យ ខ.៧,១៣,១៤ កច ២១:៣៣
**១:១៧** រ ខ.៧,១២
**១:១៩** ល ភម ២២

(ហើយអនុវត្តន៍) សេចក្តីអ្វីដែលខ្ពង់ខ្ពស់ជាងគេបំផុត ទាំងខាងចរិយាធម៌ និងខាងសីលធម៌ ។ *ជ្រះថ្លា* ហើយឥតធ្វើឱ្យអ្នកណាអាក់អន់ចិត្តឡើយ គោលដៅនៃជីវិតគ្រីស្ទបរិស័ទ ពោលគឺមិនត្រូវឱ្យមានល្បាយនៃសេចក្តីអាក្រក់ និងមិនត្រូវបណ្តោយចិត្តឱ្យបន្ទោស ដោយព្រោះតែបរាជ័យខាងឯសីលធម៌ ឬព្រលឹងវិញ្ញាណឡើយ ។ *ដរាបដល់ថ្ងៃនៃព្រះគ្រីស្ទ* ជាពេលបន្ទាប់មកទៀត ដែលយើងនឹងបានយល់ អំពីគោលដៅនោះយ៉ាងច្បាស់ឥតចន្លោះ (មើលការពន្យល់ ខ.៦) ហើយពេលនោះគ្រីស្ទបរិស័ទទាំងអស់គ្នានឹងត្រូវទៅនៅមុខទីជំនុំជម្រះ (២កថ ៥:១០) ។

**១:១១** *ពេញជាផលនៃសេចក្តីសុចរិត* ដែលគ្រីស្ទបរិស័ទគប្បីមាន (មថ ៥:២០-៤៨ ហេព ១២:១១ យក ៣:១៨ អម ៦:១២ កទ ៥:២២) ។ *ដោយសារព្រះយេស៊ូវគ្រីស្ទ* គឺបានបង្កើតឱ្យមានដោយសារព្រះគ្រីស្ទ (ក្នុងការប្រកបជាមួយទ្រង់) តាមរយៈការងារព្រះវិញ្ញាណបរិសុទ្ធ (យហ ១៥:៥ អភ ២:១០) ។ *សំរាប់ជាសិរីល្អ ហើយជាសេចក្តីសរសើរដល់ព្រះ* គោលដៅជាអវសាន្ត នៃគ្រប់ការទាំងអស់ដែលព្រះអម្ចាស់ទ្រង់ធ្វើនៅក្នុងអ្នកជឿ (អភ ១:៦,១២,១៤) ។

**១:១២** *ការទាំងប៉ុន្មានដែលកើតឡើងដល់ខ្ញុំ* គឺការឃុំខ្លួនក្នុងគុករបស់លោកសាវកប៉ុល ។ *ចំរើនដល់ដំណឹងល្អ* ជំនួសឱ្យការអង្អាក់ដល់ដំណឹងល្អ ការជាប់គុករបស់លោកប៉ុល គឺបានជួយឱ្យមានអ្នកឮដំណឹងល្អ ។

**១:១៣** *ច្បាស់ . . . ចំណងនេះដោយព្រោះព្រះគ្រីស្ទ* អ្នកដែលដឹងអំពីស្ថានភាពរបស់លោកប៉ុលអាចដឹងបានយ៉ាងងាយថា គាត់ជាប់គុកមិនមែនដោយសារតែគាត់មានទោសឧក្រិឌណាមួយនោះឡើយ ប៉ុន្តែ គឺដោយសារតែគាត់តស៊ូមិនព្រមលះបង់ចោលការផ្សាយដំណឹងល្អប៉ុណ្ណោះ ។ *ពេញក្នុងផ្ទៃវាំង* (ព្រះគម្ពីរមួយចំនួនប្រើពាក្យ "អ្នកយាមក្នុងវាំងទាំងមូល") គឺជាទាហានមួយកងពលធំ ដែលមានចំនួនដល់ទៅរាប់ពាន់នាក់ ហើយពួកនេះភាគច្រើនទំនងជាមានការទាក់ទងផ្ទាល់ខ្លួនជាមួយនឹងគាត់ ឬទំនងជាមានការដាក់វេនឱ្យពួកគេម្នាក់ៗយាមគាត់ (កច ២៨:១៦,៣០) ។ *ចំណង* ទោះតាមការពិតវាជាច្រវាក់ ឬចំណងដែលធំជាង ក៏វាបានសំដែងពីការរងទុក្ខ និងការជាប់គុករបស់គាត់ផងដែរ (ខ.១៤) ។

**១:១៤** *ហ៊ានផ្សាយព្រះបន្ទូល* ការជាប់គុករបស់សាវកប៉ុលនេះបានផ្តល់ជាប្រយោជន៍ ដែលមិននឹកស្មានដល់នៅត្រង់ថា ការនេះគឺជាគំរូមួយដ៏ប្រពៃ ដែលជំរុញទឹកចិត្តគ្រីស្ទបរិស័ទឯទៀតៗ ឱ្យឆេះឆួលនៅក្នុងការប្រកាសដំណឹងល្អ ។

**១:១៥** *ដោយចិត្តស្មោះសរ* ការផ្សាយដំណឹងល្អដែលបានជំរុញទឹកចិត្តដោយការជាប់គុករបស់សាវកប៉ុល គឺបានបណ្តាលមកពីចិត្តណាមួយ ក្នុងចំណោមចិត្តដែលផ្ទុយគ្នាទាំងពីរនោះ ។

**១:១៦** *គេសំដែងពីព្រះគ្រីស្ទ ដោយចិត្តទទឹង* គឺអ្នកមានចិត្តអាក្រក់ និងមិនស្មោះត្រង់ចំពោះការចែកចាយអំពីព្រះគ្រីស្ទ ដែលធ្វើបែបនេះ មិនមែនក្នុងន័យប្រកួតប្រជែងនឹងលោកប៉ុលទេ ប៉ុន្តែ ដើម្បីធ្វើឱ្យលោកប៉ុលកាន់តែលំបាកទ្រាំនឹងការជាប់គុកវិញប៉ុណ្ណោះ ។ *មិនមែនដោយចិត្តស្អាត* គឺមិនធ្វើចេញពីចិត្តបរិសុទ្ធ ។

**១:១៧** *គេប្រព្រឹត្តដោយស្រឡាញ់* អ្នកដែលចែកចាយដោយចិត្តទៀងត្រង់បានទទួលស្គាល់មូលហេតុដ៏ត្រឹមត្រូវ ដែលសាវកប៉ុលជាប់ឃុំ (ខ.១៣) ហើយការជាប់ឃុំនេះបានលើកទឹកចិត្តឱ្យពួកគេឈរមាំមួនដូចគាត់ដែរ ។

**១:១៨** *ទោះដោយពើ ឬដោយសេចក្តីស្មោះក្តី គង់តែគេសំដែងពីព្រះគ្រីស្ទដែរ* គាត់មិនបានថា ពួកអ្នកដែលចែកចាយទាំងនោះជាពួកខុសឆ្គងទេ ។ បង្រៀនរបស់ពួកគេ គឺត្រឹមត្រូវ ទោះជាចិត្តពួកគេមិនបរិសុទ្ធក៏ដោយ ។ ដំណឹងល្អមានមូលដ្ឋានជាសេចក្តីពិត ហើយអាចទទួលជឿបាន តែក៏មិនស្រេចលើតែអ្នកប្រកាសនោះដែរ ហើយការបង្រៀនវិញទៀតសោតក៏មិនមែនគ្រាន់តែជាចែកចាយដែរ ។ *ខ្ញុំមាន . . . ក៏នឹងចេះតែមានអំណរទៅមុខទៀត* គឺជាការដែលសាវកប៉ុលបង្ហាញអំពីគំរូនៃបទពិសោធន៍ល្អៗរបស់គ្រីស្ទបរិស័ទ ។ ពេលដែលគាត់កំពុងស្ថិតក្នុងការចាប់ខ្លួន មានគ្រីស្ទបរិស័ទខ្លះបានផ្សាយដំណឹងល្អ ដោយគ្មានចិត្តស្មោះសរ ក្នុងបំណងដើម្បីធ្វើឱ្យគាត់កាន់តែលំបាកថែមមួយកម្រិតទៀត ប៉ុន្តែ ទោះជាយ៉ាងនេះគាត់នៅតែបន្តការអរសប្បាយដដែល ។

**១:១៩** *ព្រះវិញ្ញាណនៃព្រះយេស៊ូវគ្រីស្ទ* ព្រះវិញ្ញាណបរិសុទ្ធទ្រង់មិនត្រឹមតែជាព្រះវិញ្ញាណនៃព្រះវរបិតាទេ (រម ៨:៩,១៤ ១កថ ២:១០–១១,១៤) ប៉ុន្តែ

ដល់ខ្ញុំវិញ ដោយអ្នករាល់គ្នាអធិស្ឋាន[វ]ឱ្យខ្ញុំ ហើយដោយ
ព្រះទ្រង់ប្រទានព្រះវិញ្ញាណ នៃព្រះយេស៊ូវគ្រីស្ទមកជួយ
ផង[ស] ២០តាមសេចក្ដីដែលខ្ញុំទន្ទឹងចាំ[ហ] ហើយសង្ឃឹមអស់ពី
ចិត្តថា ខ្ញុំមិនត្រូវខ្មាសក្នុងការអ្វីឡើយ គឺឱ្យតែខ្ញុំបានដំកើង
ព្រះគ្រីស្ទក្នុងរូបកាយខ្ញុំវិញ[ឡ] ដោយចិត្តក្លាហានគ្រប់ជំពូក[អ]
ក្នុងពេលឥឡូវនេះចុះ ដូចជាពីដើមរៀងមកដែរ ទោះរស់
ឬស្លាប់ក្ដី[ក] ២១ដ្បិតឯខ្ញុំ ដែលខ្ញុំរស់នៅ នោះគឺសំរាប់ព្រះ
គ្រីស្ទទេ[ខ] ហើយដែលស្លាប់ទៅនោះជាកំរៃវិញ ២២ប៉ុន្តែ
បើរស់ខាងឯសាច់ឈាម នឹងនាំឱ្យការខ្ញុំកើតផល នោះ
ខ្ញុំមិនដឹងរើសយកខាងណាទេ ២៣ខ្ញុំមានសេចក្ដីបណ្ដាល
ទាំងសងខាង ក៏មានចិត្តចង់ចេញទៅនៅ[គ]ជាមួយនឹងព្រះ
គ្រីស្ទ[ឃ] ដែលល្អជាជាងនោះផង ២៤តែបើខ្ញុំនៅក្នុងសាច់
ឈាមតទៅទៀត នោះមានប្រយោជន៍ដល់អ្នករាល់គ្នាជា
ជាង ២៥ហើយដោយហេតុដែលខ្ញុំជឿសេចក្ដីនោះយ៉ាងពិត
ប្រាកដ បានជាខ្ញុំដឹងថា ខ្ញុំនឹងនៅជាមួយនឹងអ្នករាល់គ្នា
តទៅទៀត ប្រយោជន៍ឱ្យអ្នករាល់គ្នាមានជំនឿនជឿនឡើង
ហើយឱ្យមានសេចក្ដីអំណរ ដោយសារសេចក្ដីជំនឿផង
២៦ដើម្បីឱ្យអ្នករាល់គ្នាបានអួតពីខ្ញុំ ក្នុងព្រះគ្រីស្ទយេស៊ូវកាន់
តែច្រើនឡើង ដោយខ្ញុំមកនៅជាមួយនឹងអ្នករាល់គ្នាម្ដងទៀត
២៧ប៉ុន្តែ ចូរឱ្យអ្នករាល់គ្នា ប្រព្រឹត្តបែបគួរ[ង] នឹងដំណឹងល្អ
របស់ព្រះគ្រីស្ទចុះ ដើម្បីកាលណាខ្ញុំមកសួរ ឬនៅឃ្លាតពី
អ្នករាល់គ្នាក្ដី នោះគង់តែនឹងបានឮនិយាយពីដំណើរអ្នក
រាល់គ្នាថា អ្នករាល់គ្នាបានឈរមាំមួនហើយ[ច] ព្រមទាំង
មានចិត្តមានគំនិត[ឆ]តែ១ ដើម្បីនឹងតតាំងជាមួយគ្នា ដោយ
នូវសេចក្ដីជំនឿខាងឯដំណឹងល្អផង ២៨ឥតមានភ័យខ្លាចចំ
ពោះពួកទាស់ទទឹងក្នុងការអ្វីឡើយ ដំណើរនោះឯង នឹង
សំដែងពីសេចក្ដីហិនវិនាសរបស់គេ តែពីសេចក្ដីសង្គ្រោះ
របស់អ្នករាល់គ្នាវិញ ដែលសេចក្ដីនោះបានមកពីព្រះផង

**១:១៩** វ ២កថ ១:១១
ស កច ១៦:៧
**១:២០** ហ រម ៨:១៩
ឡ ១កថ ៦:២០
អ ខ.១៤
ក រម ១៤:៨
**១:២១** ខ កទ ២:២០
**១:២៣** គ ២ធថ ៤:៦
ឃ យហ ១២:២៦
**១:២៧** ង អភ ៤:១
ច ១កថ ១៦:១៣
ឆ យដ ៣

ទ្រង់ក៏ជាព្រះវិញ្ញាណនៃព្រះយេស៊ូវគ្រីស្ទ ជាអង្គទីពីរនៃព្រះត្រៃឯកផងដែរ (កច ១៦:៧ រម ៨:៩ កទ ៤:៦)។ *ព្រះវរបិតា* (យហ ១៤:១៦–១៧,២៦ កទ ៤:៦) និង ព្រះរាជបុត្រា (យហ ១៥:២៦ ១៦:៧) បានបញ្ជូនព្រះវិញ្ញាណឱ្យចុះមក ។ *សេចក្ដីសង្គ្រោះ* សេចក្ដីសង្គ្រោះត្រង់ចំណុចនេះ គឺសំដៅទៅលើការដោះលែងលោកសាវ័កប៉ុលពីក្នុងគុក (ខ.២៥ ២:២៤) ឬជាសេចក្ដីសង្គ្រោះដែលផ្ដល់ឱ្យដល់អ្នកជឿ តាមរយៈការសុគតនៃព្រះយេស៊ូវ (រម ៨:២៨) តែទោះជាយ៉ាងណាក៏ដោយ ក៏នៅក្នុងខ.៥ ហាក់ដូចជាសំដៅលើការដោះលែងវិញ ។

**១:២០** *ខ្មាស . . . ដោយចិត្តក្លាហានគ្រប់ជំពូក* ស្ថានភាពនៅក្នុងគុកពោរពេញដោយការរងទុក្ខ និងការគាបសង្កត់ ដែលប្រៀបបីដូចជាសេចក្ដីល្បួងឱ្យគាត់បោះបង់ចោលដំណឹងល្អ និងការប្ដេជ្ញាចិត្តចំពោះការងារបម្រើព្រះគ្រីស្ទយ៉ាងពិតប្រាកដ ។ *រូបកាយខ្ញុំ* មានន័យថាព្រះគ្រីស្ទដ៏ខ្ពស់បំផុតទ្រង់សណ្ឋិតនៅដោយព្រះវិញ្ញាណទ្រង់ ព្រមទាំងធ្វើការក្នុងរូបកាយសាវកប៉ុលផង (រម ៨:៩–១០) ហើយទ្រង់ក៏បានតម្កើងឡើង តាមរយៈអ្វីដែលសាវកប៉ុលបានធ្វើផងដែរ ។ *ទោះរស់ ឬស្លាប់ក្ដី* គឺទោះការងារបម្រើព្រះរបស់គាត់ត្រូវបន្តទៅមុខទៀត ឬបញ្ចប់ត្រឹមសេចក្ដីស្លាប់ក៏ដោយ ។

**១:២១** *រស់នៅ នោះគឺសំរាប់ព្រះគ្រីស្ទ* ព្រះគ្រីស្ទទ្រង់ជាប្រភព និងជាអាថ៌កំបាំងនៃអំណរដ៏ជាប់ជានិច្ចរបស់លោកប៉ុល (ទោះស្ថិតក្នុងគុកក៏ដោយ) ពីព្រោះលោកប៉ុលបានរកឃើញ ពីអត្ថន័យនៃជីវិតគាត់គឺនៅក្នុងព្រះគ្រីស្ទយេស៊ូវ ។ *កំរៃ* ខ.២៣ បានបង្ហាញផងដែរថា កម្រៃដែលរកបានពីការស្លាប់គឺជា "ការបានទៅនៅជាប់ជាមួយនឹងព្រះគ្រីស្ទ" ហេតុនេះបានជាគាត់ពោលនៅត្រង់កន្លែងនេះថា ក្ដីបារម្ភចុងក្រោយ និងទ្រព្យសម្បត្តិមានតម្លៃដ៏មហិមារបស់គាត់ ទាំងនៅក្នុងពេលបច្ចុប្បន្ន ក៏ដូចជានិច្ចនិរន្តដែរនោះ គឺជាព្រះគ្រីស្ទ ព្រមទាំងការប្រកបទាក់ទងរបស់គាត់ជាមួយនឹងទ្រង់ ។

**១:២២** *ការខ្ញុំកើតផល* គឺការចម្រើនកើនឡើងនៃដំណឹងល្អ និងការកើនឡើងនៃចំនួនពួកជំនុំ ។

**១:២៣–២៤** *ចេញទៅជាមួយនឹងព្រះគ្រីស្ទ . . . នៅក្នុងសាច់ឈាមតទៅទៀត* ជម្រើសទាំងពីរនេះ គឺល្អដូចគ្នា ដែលក្នុងនោះមានអាថ៌កំបាំងមួយដែលសំដែងមកថា វគ្គនៃបទគម្ពីរនេះបង្រៀនយ៉ាងច្បាស់ ពីពេលដែលអ្នកជឿស្លាប់ទៅនោះ ពួកគេនឹងបាននៅជាមួយនឹងព្រះគ្រីស្ទ ដោយឈប់នៅជាមួយនឹងសាច់ឈាមតទៅទៀត (២កថ ៥:៦,៨–៩)។

**១:២៣** *ល្អជាជាងនោះផង* ពីព្រោះថានឹងមានការប្រកបជាមួយនឹងព្រះដែលជិតស្និទ្ធិ ហើយពេញលេញជាង។ ការឃ្លាតចេញទៅគឺល្អជាជាង ប៉ុន្តែការបានទៅនៅជាមួយនឹងព្រះគ្រីស្ទគឺកាន់តែល្អថែមទៀត (២កថ ៥:៦,៨, និងការពន្យល់ ៥:៨)។

**១:២៤** *មានប្រយោជន៍ដល់អ្នករាល់គ្នា* លោកប៉ុលបានដាក់តម្រូវការរបស់ពួកអ្នកដែលគាត់ផ្គត់ផ្គង់ នៅខាងមុខតម្រូវការផ្ទាល់ខ្លួនរបស់គាត់ ។

**១:២៥** *ខ្ញុំនឹងនៅ* ត្រង់នេះបញ្ជាក់ថា លោកប៉ុលប្រហែលជាអាចត្រូវគេដោះលែងពីក្នុងគុកនៅពេលក្រោយមកទៀត ។ *មានជំនឿនជឿនឡើង . . . សេចក្ដីជំនឿផង* ជីវិតជាគ្រីស្ទបរិស័ទត្រូវតែជាជីវិតដែលមានការរីកលូតលាស់ប្រកបដោយក្ដីអំណរ និងមានការចម្រើនទៅមុខ (ខ.៩ និងពន្យល់)។

**១:២៦** *អ្នករាល់គ្នាបានអួតពីខ្ញុំក្នុងព្រះគ្រីស្ទយេស៊ូវ* របៀបដែលលោកប៉ុលធ្វើការបម្រើព្រះ ក្នុងចំណោមពួកក្រុងភីលីពនឹងបានជាបុព្វហេតុដែលនាំឱ្យពួកគេមានអំណរក្នុងការអ្វីដែលព្រះគ្រីស្ទទ្រង់កំពុងធ្វើក្នុងចំណោមពួកគេ ។

**១:២៧** *បែបគួរ នឹងដំណឹងល្អ* គឺស័ក្តិសមនឹងមាត្រដ្ឋាន និងគោលដៅនៃដំណឹងល្អ។ *មានចិត្តមានគំនិតតែ១* គឺមានចរិយា និងគោលបំណងដូចគ្នា ។ *តតាំងជាមួយគ្នា* គឺជាពិសេសកាលណាការផ្សាយដំណឹងល្អជួបប្រទះនឹងបញ្ហា ឬការបៀតបៀនគ្រីស្ទបរិស័ទតែងតែត្រូវការនឹងគ្នា ហើយត្រូវរងទ្រាំទាំងអស់គ្នា ។

**១:២៨** *ដំណើរនោះឯង* ការស៊ូប្រឆាំងនឹងពួកជំនុំ និងដំណឹងល្អ គឺពិតជាដំណើរឆ្ពោះទៅរកសេចក្ដីហិនវិនាសនៅទីបញ្ចប់យ៉ាងប្រាកដ ដ្បិតការនេះជាផ្នែកនៃការបដិសេធន៍ផ្លូវតែមួយនៃសេចក្ដីសង្គ្រោះ ហេតុនេះគ្រាណា

២៩ដ្បិតមានឱកាសបើកឱ្យអ្នករាល់គ្នា[ជ] ហើយ មិនមែនឱ្យ
គ្រាន់តែជឿដល់ព្រះគ្រីស្ទតែប៉ុណ្ណោះទេ គឺឱ្យរងទុក្ខ[ឈ]
ដោយព្រោះទ្រង់ដែរ[ញ] ៣០ទាំងកើតមានសេចក្តីតតាំង[ដ]
ដដែល ដែលឃើញ[ឋ]ខ្ញុំមាន ហើយឥឡូវនេះ[ឌ]ឮថាខ្ញុំមាន
ទៀត ។

## គំរូនៃការបន្ទាបខ្លួននៃព្រះគ្រីស្ទ

**២** ១ដូច្នេះ បើសិនជាមានសេចក្តីដាស់តឿនណា ក្នុងព្រះ
គ្រីស្ទ ឬសេចក្តីកំសាន្តណារបស់ផងសេចក្តីស្រឡាញ់ ឬ
សេចក្តីប្រកបណាផងព្រះវិញ្ញាណ[ឍ] ឬសេចក្តីថ្មិតថ្នម និង
សេចក្តីអាណិតអាសូរណា[ណ] ២នោះចូរបំពេញសេចក្តី
អំណរ[ត]របស់ខ្ញុំ ដោយអ្នករាល់គ្នាមានគំនិត[ថ] មានសេចក្តី
ស្រឡាញ់តែ១[ទ] ទាំងរួបរួមចិត្តគ្នា ហើយគិតតែផ្លូវ១ដូចគ្នា
ចុះ ៣កុំឱ្យធ្វើអ្វី ដោយទាស់ទែងគ្នា[ធ] ឬដោយសេចក្តីអំ
នួតឥតប្រយោជន៍ឡើយ តែចូររាប់អានគេឱ្យលើសជាង
ខ្លួន[ន] ដោយចិត្តសុភាពវិញ ៤កុំឱ្យគ្រប់គ្នាស្វែងរកតែប្រ
យោជន៍ ផ្ទាល់ខ្លួនឡើយ ត្រូវស្វែងរកចំពោះអ្នកដទៃផង[ប]
៥ត្រូវតែមានគំនិតគិតដូចជាព្រះគ្រីស្ទយេស៊ូវវិញ[ផ]
៦ដែលទោះបើទ្រង់មានរូបអង្គជាព្រះក៏ដោយ[ព] គង់តែ

**១:២៩** ជ មថ ៥:១១, ១២ កច ៥:៤១ ឈ កច ១៤:២២ ញ កច ៥:៤១
**១:៣០** ដ ១ថន ២:២ ហព ១០:៣២ ឋ កច ១៦:១៩–៤០ ឌ ខ.១៣
**២:១** ឍ ២កថ ១៣:១៤ ណ កល ៣:១២
**២:២** ត យហ ៣:២៩ ថ ភល ៤:២ ទ រម ១៥:៥
**២:៣** ធ កទ ៥:២៦ ន រម ១២:១០ ១ពត ៥:៥ **២:៤** ប ១កថ ១០:២៤
**២:៥** ផ មថ ១១:២៩ **២:៦** ព យហ ១:១ ១៤:៩

ដែលគ្រីស្ទបរិស័ទទទួលរងនូវការបៀតបៀនដោយព្រោះសេចក្តីជំនឿ នោះមានន័យថាជាសញ្ញា នៃសេចក្តីសង្គ្រោះរបស់ពួកគេហើយ (២ធថ ១:៥) ។

**១:២៩** *បើកឱ្យ . . . រងទុក្ខដោយព្រោះទ្រង់ដែរ* គឺជាការប្រទានឱ្យជាអំណោយ ឬអភ័យឯកសិទ្ធ ។ ការរងទុក្ខរបស់គ្រីស្ទបរិស័ទ ព្រមទាំងសេចក្តីជំនឿរបស់ពួកគេ គឺសុទ្ធតែជាព្រះពររបស់ព្រះអម្ចាស់ (មថ ៥:១១–១២ កច ៥:៤១ យក ១:២ ១ពត ៤:១៤) ។ ជីវិតគ្រីស្ទបរិស័ទចាំបាច់ត្រូវមានប្រើទម្រង់ "មិនត្រឹមតែ . . . ប៉ុន្តែ ថែមទាំង . . ." ឧទាហរណ៍ "មិនត្រឹមតែជាការជឿប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងជាការរងទុក្ខផងដែរ" ។

**១:៣០** *សេចក្តីតតាំងដដែល* គឺជាការដែលពួកគេរួមចំណែកជាមួយនឹងលោកប៉ុលចំពោះការប៉ះទង្គិចគ្នាជាមួយនឹងអ្នកប្រឆាំងដំណឹងល្អ ។ *ដែលឃើញខ្ញុំ* គឺនៅពេលដែលលោកប៉ុល និងលោកស៊ីលវ៉ាន (ព្រះគម្ពីរពេត្រុសប្រើពាក្យនេះតែព្រះគម្ពីរកិច្ចការប្រើពាក្យ "ស៊ីឡាស" វិញ) បានមកលេងក្រុងភីលីព ជាលើកដំបូង ហើយក៏ត្រូវគេចាប់ខ្លួនអ្នកទាំងពីរដាក់គុក ។

**២:១** *ក្នុងព្រះគ្រីស្ទ* (ការប្រកបជាមួយ ឬក្នុងព្រះគ្រីស្ទ) នៅក្នុងសេចក្តីបង្រៀនរបស់លោកប៉ុល ការប្រកបផ្ទាល់ខ្លួននេះគឺជាសេចក្តីពិតជាមូលដ្ឋាននៃសេចក្តីសង្គ្រោះ ។ "ដែលនៅក្នុងព្រះគ្រីស្ទ នោះគឺពិតជាបានសង្គ្រោះហើយ" មានន័យថា ការប្រកបនេះជាការប្រកបស្និទ្ធស្នាលផ្ទាល់ខ្លួននៃមនុស្សម្នាក់ៗក្នុងព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទនៃយើង ។ ទំនាក់ទំនងនេះនឹងបង្ហូរចុះនូវគ្រប់ទាំងផលពិសេសៗ និងផលនៃសេចក្តីសង្គ្រោះដែលមានការលើកទឹកចិត្តជាដើម (ឧ.ភល ៣:៨–១០ រម ៨:១ ២កថ ៥:១៧ កទ ២:២០) ។ *សេចក្តីកំសាន្តណារបស់ផង សេចក្តីស្រឡាញ់* សេចក្តីចេះដឹងដែលនាំឱ្យក្សាន្តចិត្ត និងការធានាដែលចេញមកពីសេចក្តីស្រឡាញ់របស់ព្រះដែលមានក្នុងព្រះគ្រីស្ទបានបង្ហាញឱ្យឃើញជា ពិសេសនៅក្នុងការសុគតរបស់ផងព្រះគ្រីស្ទដើម្បីលោះបាបមនុស្ស និងដើម្បីជីវិតអស់កល្ប (យហ ៣:១៦ រម ៥:៨ ៨:៣៨–៣៩ ១យហ ៣:១៦ ៤:៩–១០,១៦) ។ *សេចក្តីប្រកបណាផងព្រះវិញ្ញាណ* (ឬជាមួយព្រះវិញ្ញាណ) ការប្រកបនៅក្នុងចំណោមអ្នកជឿ ដែលព្រះវិញ្ញាណបានបង្កើតឡើងនិងសណ្ឋិតក្នុងពួកគេនីមួយៗ (២កថ ១៣:១៤) ។ *សេចក្តីថ្មិតថ្នម និងសេចក្តីអាណិតអាសូរណា* គ្រីស្ទបរិស័ទត្រូវតែមានចិត្តដែលគិតដល់គ្នា និងអាណិតអាសូរគ្នាទៅវិញទៅមកជាពន់ពេក (១:៨ កល ៣:១២) ។ ការលើកទឹកចិត្ត សេចក្តីកម្សាន្តចិត្ត សេចក្តីប្រកបសេចក្តីថ្មិតថ្នម និងសេចក្តីអាណិតអាសូរ គឺសុទ្ធតែជាផលដែលលោកប៉ុលបានបង្ហាញឱ្យឃើញជាការពិតក្នុងបច្ចុប្បន្នដល់ពួកក្រុងភីលីព ។

**២:២** *ដោយអ្នករាល់គ្នាមានគំនិត . . . ចិត្តគ្នា . . . តែផ្លូវ១ដូចគ្នាចុះ* ត្រង់នេះគឺចង់សង្កត់ធ្ងន់ថាសាមគ្គីភាពគួរតែកើតមានក្នុងចំណោមគ្រីស្ទបរិស័ទ ។ *ដោយអ្នករាល់គ្នាមានគំនិត* (មានចិត្ត) គឺមិនមែនមានសណ្ឋាននៃចិត្តដូចគ្នាតែមួយនោះទេ ប៉ុន្តែការនេះគឺជាបំណងចិត្តដែលចង់ធ្វើការរួមគ្នា ព្រមទាំងបម្រើគ្នាទៅវិញទៅមកគឺ "គំនិតគិត" របស់ព្រះគ្រីស្ទ (ខ.៥ ៤:១២ រម ១២:១៦ ១៥:៥ ២កថ ១៣:១១) ។

**២:៣** *ដោយទាស់ទែងគ្នា ឬដោយសេចក្តីអំនួតឥតប្រយោជន៍* (ព្រះគម្ពីរខ្លះប្រើពាក្យដោយចិត្តអាត្មានិយម ឬសេចក្តីអំនួតឥតប្រយោជន៍) គឺជាសត្រូវជាអមតៈរបស់សាមគ្គីភាព និងការចុះសម្រុងគ្នាក្នុងចំណោមពួកជំនុំ (រម ១២:១០ កទ ៥:១៣ អភ ៥:២១ ១ពត ៥:៥) ។

**២:៤** *ប្រយោជន៍ផ្ទាល់ខ្លួន* យើងមិនត្រូវគិតតែប្រយោជន៍ផ្ទាល់ខ្លួនឡើយ គឺត្រូវគិតដល់ប្រយោជន៍របស់អ្នកដទៃផងដែរ ។ ប្រយោជន៍ទាំងនោះរួមមានតម្រូវការខាងឯសុខមាលភាពរបស់ពួកគេជាដើម (រម ១៥:២ ១កថ ១០:២៤ ៣៣ កទ ៦:២) តែមិនមែនមានន័យថា ត្រូវជ្រៀតជ្រែកចូលក្នុងកិច្ចការរបស់ពួកគេ ឬព្យាយាម ដើម្បីកាន់កាប់ពួកគេនោះទេ ផ្ទុយទៅវិញ យើងគប្បីស្វែងរកឱកាសជួយ និងលើកទឹកចិត្តពួកគេឱ្យបាន ទើបជាការគាប់ប្រសើរ ។

**២:៥** *មានគំនិតគិតដូចជាព្រះគ្រីស្ទយេស៊ូវ* មានន័យថា គ្រីស្ទបរិស័ទត្រូវមានគំនិត គិតដូចដែលមានចែងក្នុងបទគម្ពីរខាងលើ ព្រោះគំនិតគិតដូចនេះមាននៅក្នុងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។ គ្រីស្ទបរិស័ទក៏ត្រូវពឹងផ្អែកលើព្រះគ្រីស្ទនៅក្នុងការគិតផងដែរ ដោយអនុញ្ញាតិឱ្យទ្រង់ជួយដល់គំនិតគិតរបស់ខ្លួនដើម្បីជៀសវាងការគិតដែលខុសនឹងព្រះទ័យទ្រង់ (ខ.២–៤ មថ ១១:២៩ យហ ១៣:១២–១៧) ។

**២:៦–១១** វគ្គនៃបទគម្ពីរទាំងនេះប្រាកដជាមានលក្ខណៈជាអត្ថបទកំណាព្យបើទោះជាបទកាព្យមួយដ៏ខ្លីក៏ដោយ ។ មនុស្សជាច្រើនបានបកស្រាយថា បទនេះគឺជាទំនុកបរិសុទ្ធរបស់គ្រីស្ទបរិស័ទជាន់ដើម (កល ៣:១៦) ដែលសាវ័កប៉ុលបាននិពន្ធ ហើយគាត់ប្រហែលជាបានកែសម្រួលឡើងវិញទៀតផង ។ ប្រសិនបើដូច្នោះមែន ក៏ត្រូវឱ្យពួកអ្នកដែលបានបកស្រាយទាំងនោះនិយាយអំពីជំនឿរបស់សាវ័កប៉ុលដែរ ។ វគ្គនេះគឺបាននិយាយអំពីការបន្ទាបព្រះកាយ (៦–៨) និងការលើកតម្កើងអង្គព្រះគ្រីស្ទឡើង (៩–១១) ។

មិនបានរាប់សេចក្ដីដែលស្មើនឹងព្រះ[ភ] នោះ ទុកជាសេចក្ដី
ដែលគួរកាន់ខ្ជាប់ឡើយ ៧គឺទ្រង់បានលះបង់ព្រះអង្គទ្រង់[ម]
មកយករូបភាពជាបាវបំរើវិញ[យ] ព្រមទាំងប្រសូតមកមាន
រូបជាមនុស្សផង[រ] ៨ហើយដែលឃើញទ្រង់មានភាពជា
មនុស្សដូច្នោះ នោះក៏បន្ទាបព្រះអង្គទ្រង់ ទាំងចុះចូល
ស្ដាប់បង្គាប់ រហូតដល់ទីមរណៈ[ល]គឺទ្រង់ទទួលសុគត
ជាប់លើឈើឆ្កាងផង[វ] ៩ដោយហេតុនោះបានជាព្រះ
បានលើកទ្រង់ឡើងយ៉ាងខ្ពស់[ស] ហើយបានប្រទានឱ្យមាន
នាមដ៏ប្រសើរ លើសជាងអស់ទាំងនាមផង[ហ] ១០ដើម្បីកាល
ណាឮព្រះនាមព្រះយេស៊ូវ នោះឱ្យគ្រប់ទាំងជង្គង់នៅស្ថាន
សួគ៌ នៅផែនដី ហើយនៅក្រោមផែនដី[ឡ] ត្រូវលុតចុះ[អ]

**២:៦** ភ យហ ៥:១៨
**២:៧** ម ២កថ ៨:៩
យ មថ ២០:២៨
រ យហ ១:១៤
**២:៨** ល មថ ២៦:៣៩
យហ ១០: ១៨ រម
៥:១៩ ហព ៥:៨
វ ១កថ ១:២៣
**២:៩** ស អស
៥២:១៣ ៥៣:១២
ដយ ៧:១៤ កច
២:៣៣ ហព ២:៩
ហ អភ ១:២០,២១

១១ហើយឱ្យគ្រប់ទាំងអណ្ដាតបានថ្លែងប្រាប់ថា ព្រះយេស៊ូវ
គ្រីស្ទទ្រង់ជាព្រះអម្ចាស់[ក] សំរាប់ជាសិរីល្អដល់ព្រះដ៏ជាព្រះ
វរបិតា ។
១២បានជា ឱពួកស្ងួនភ្ងាអើយ ចូរបង្ហើយសេចក្ដីសង្គ្រោះ
របស់អ្នករាល់គ្នា ដោយកោតខ្លាច ហើយញាប់ញ័រចុះ[ខ]
ដូចជាបានស្ដាប់បង្គាប់ខ្ញុំជាដរាបរៀងមកដែរ មិនមែនតែ
កាលខ្ញុំនៅជាមួយប៉ុណ្ណោះទេ សូម្បីឥឡូវនេះដែលខ្ញុំមិននៅ
ជាមួយ នោះក៏ចូរខំប្រឹងឱ្យលើសទៅទៀតផង ១៣ដ្បិតគឺជា

**២:១០** ឡ មថ ២៨:១៨ អភ ១:១០ កល ១:២០ អ ទដ ៩៥:៦ អស ៤៥:២៣ រម ១៤:១១ **២:១១** ក យហ ១៣:១៣ **២:១២** ខ ២កថ ៧:១៥

**២:៦** *រូបអង្គជាព្រះ* គឺជាការបញ្ជាក់ថា ព្រះយេស៊ូវមានភាពជាព្រះទាំងស្រុង (មើល រម ៩:៥ និងការពន្យល់)។ *រូបអង្គ* គឺទ្រង់ទ្រាយជាចំបងដែលជាលក្ខណៈសម្បត្តិទាំងអស់នៃទ្រង់ ដែលរួមគ្នាមកតែមួយ ដើម្បីឱ្យព្រះអម្ចាស់ទ្រង់មានលក្ខណៈប្រាកដជាព្រះមែន ។ *សេចក្ដីដែលស្មើនឹងព្រះ* គឺអត្តសញ្ញាណ និងអភ័យឯកសិទ្ធិពិសេស ដែលជៀសមិនរួចពីការដែលតាមរូបអង្គជាព្រះនៃទ្រង់ឡើយ ។ *សេចក្ដីដែលគួរកាន់ខ្ជាប់* ប្រហែលជាសេចក្ដីអ្វីដែលត្រូវប្រកាន់ខ្ជាប់តាម ដោយកម្លាំងជិរុញចិត្ត ដែលនោះគឺសិរីល្អដែលព្រះយេស៊ូវទ្រង់មានជាមួយព្រះវបិតាទ្រង់ តាំងពីមុនដែលទ្រង់បានយាងមកយកកំណើតជាមនុស្ស ប៉ុន្ដែ ទ្រង់មិនបានចាត់ទុកឋានៈដ៏ខ្ពស់ឧត្ដមយ៉ាងនេះដូចជាអ្វីដែលទ្រង់មិនអាចលះបង់ចោលបាននោះឡើយ ម្យ៉ាងវិញទៀតសិរីល្អនោះនៅតែដូចជាអ្វីដែលត្រូវតែរកឱ្យបានដូចរង្វាន់ គឺហាក់បីដូចជាទ្រង់មិនទាន់មានសិរីល្អអញ្ចឹងដែរ ។

**២:៧** *លះបង់ព្រះអង្គទ្រង់* គឺ "ធ្វើឱ្យព្រះអង្គទ្រង់ត្រឡប់ទៅជាទទេ" ដោយមិនបានលះបង់ចោលភាពជាព្រះរបស់ទ្រង់នោះទេ ប៉ុន្ដែ ដោយលះបង់ចោលសិរីល្អរបស់ទ្រង់វិញ(យហ ១៧:៥) ព្រមទាំងបានចុះចូលព្រះអង្គទ្រង់នឹងការបន្ទាបខ្លួនមកយកកំណើតជាមនុស្ស(២កថ ៨:៩)។ ព្រះយេស៊ូវទ្រង់ពិតជាព្រះ ហើយពិតជាមនុស្ស ម្យ៉ាងទៀតព្រះអង្គបានធ្វើឱ្យអង្គទ្រង់ក្លាយទៅជាទទេ ដែលនោះមិនមែនធ្វើឱ្យអស់ភាពជាព្រះនោះឡើយ គឺឱ្យអស់អភ័យឯកសិទ្ធិនៃភាពជាព្រះដែលជាឋានៈដ៏ខ្ពស់បំផុតវិញ និងឱ្យអស់សិរីល្អនៃភាពជាព្រះ ។ *រូបភាពជាបាវបំរើ* គឺសង្កត់ធ្ងន់លើអត្តសញ្ញាណដ៏ពិតរបស់ទ្រង់ជាអ្នកបម្រើ(មថ ២០:២៨) ក្នុងការធ្វើជាអ្នកបម្រើនេះ ជានិច្ចជាកាលព្រះអង្គតែងបានចុះចូលនឹងព្រះទ័យព្រះវរបិតាទ្រង់ជានិច្ច ។

**២:៨** *មានភាពជាមនុស្ស* ព្រះយេស៊ូវទ្រង់មិនមែនគ្រាន់តែ "ដូច" មនុស្សជាតិប៉ុណ្ណោះទេ ប៉ុន្ដែ ទ្រង់ថែមទាំងបានយកលក្ខណៈសម្បត្តិជាសាច់ឈាមមនុស្សទៀតផង(យហ ១:១៤ រម ៨:៣ ហព ២:១៧)។ *បន្ទាបព្រះអង្គទ្រង់* ខ.៧ ២កថ ៨:៩ ចុះចូលស្ដាប់បង្គាប់ គឺជារបៀបដែលព្រះយេស៊ូវបន្ទាបព្រះកាយ (ហព ៥:៧-៨) *ស្ដាប់បង្គាប់រហូតដល់ទីមរណៈ* សង្កត់ធ្ងន់លើការស្ដាប់បង្គាប់ទាំងស្រុង ហើយខ្លាំងជាទីបំផុតរបស់ព្រះគ្រីស្ទ ។ *លើឈើឆ្កាង* គឺជាការបញ្ជាក់ពីការបន្ទាបខ្លួនឱ្យដល់កម្រិតទាបបំផុតនៃអង្គព្រះយេស៊ូវដោយសុគតដូចត្រូវបណ្ដាសា(កទ ៣:១៣ ហព ១២:២)។ ការឆ្កាងមនុស្សសម្លាប់ គឺជាទោសប្រហារជីវិតដែលធ្វើឱ្យអាប់ឱនបំផុតពីព្រោះវាអាចធ្វើឱ្យអ្នកទោសមានការឈឺចាប់រកថ្លែងពុំបាន ។

**២:៩** *លើកទ្រង់ឡើង* មើល មថ ២៨:១៨ កច ២:៣៣ អស ៥២:១៣ ។ *នាម . . . លើសជាងអស់ទាំងនាម* សំដៅទៅលើតំណែង ឬឋានៈដែលបានប្រទានមកដល់ព្រះយេស៊ូវជាឋានៈដែលប្រកបដោយសិរីរុងរឿង គឺមិនមែនសំដៅលើព្រះនាមដ៏សមរម្យរបស់ទ្រង់ឡើយ (អភ ១:២១ ហព ១:៤-៥)។

**២:១០-១១** *លុតចុះ . . . ថ្លែងប្រាប់ថា* (អស ៤៥:២៣)។ ការរៀបចំរបស់ព្រះ គឺមនុស្សនៅគ្រប់ទិសទីទាំងអស់ត្រូវតែថ្វាយបង្គំ ព្រមទាំងបម្រើព្រះយេស៊ូវឱ្យបានដូចជាព្រះអម្ចាស់ ។ នៅទីអវសាន ទោះព្រមក្ដី មិនព្រមក្ដីមនុស្សទាំងអស់គ្នានឹងទទួលស្គាល់ទ្រង់ជាព្រះអម្ចាស់(រម ១៤:៩)។

**២:១២** *បានជា* មានន័យថាពីព្រោះតែគំរូឥតខ្ចោះ ដែលគ្មានអ្វីប្រៀបរបស់ផងព្រះគ្រីស្ទ(ខ.៥-១១)។ *ស្ដាប់បង្គាប់* គឺស្ដាប់បង្គាប់តាមព្រះរាជបញ្ជារបស់ព្រះដែលទ្រង់បានដាក់ឱ្យពួកក្រុងភីលីពតាមរយៈសាវកប៉ុល(រម ១:៥ ១៥:១៨ ២កថ ១០:៥-៦)។ *នៅជាមួយ* ក្នុងអំឡុងពេលចុះបេសកកម្មលើកទីពីរ (កច ១៦:១២-៤០) និងទីបី(២០:១-៣,៦)របស់សាវកប៉ុល ។ *បង្ហើយសេចក្ដីសង្គ្រោះរបស់អ្នករាល់គ្នា* គឺបង្ហាញពីសេចក្ដីសង្គ្រោះ តាមរយៈការប្រព្រឹត្តរហូតដល់សេចក្ដីសង្គ្រោះត្រូវបញ្ចប់ ដែលនោះមិនមែនសំដៅលើការប្រព្រឹត្តដើម្បីឱ្យបានទទួលសេចក្ដីសង្គ្រោះនោះឡើយ តែក៏សំដៅទៅលើការបង្ហាញពីសេចក្ដីសង្គ្រោះ តាមរយៈការរីកចម្រើន និងការលូតលាស់ខាងឯវិញ្ញាណ ។ សេចក្ដីសង្គ្រោះមិនមែនគ្រាន់តែជាការប្រទានដែលទទួលបានម្ដង ហើយមានជារៀងរហូតប៉ុណ្ណោះទេ ប៉ុន្ដែគឺបានបង្ហាញខ្លួននៅក្នុងដំណើរការមួយដែលអ្នកជឿចូលរួមយ៉ាងខ្លាំងក្លា (សូមផ្ទៀបនឹង មថ ៤:១៣ ១កថ ៩:២៤-២៧ ហព ៣:១៤ ៦:៩-១១ ១ពត ១:៥-៨) ដោយការតស៊ូក្រាញនៀល ការបម្រើដោយបន្ទាបខ្លួន មានការរីកចម្រើន និងភាពពេញវ័យខាងឯព្រលឹងវិញ្ញាណ ។ *កោតខ្លាច ហើយញាប់ញ័រ* មិនមែនព្រោះតែមានមន្ទិលសង្ស័យ និងការថប់បារម្ភនោះឡើយ ផ្ទុយទៅវិញគឺសំដៅទៅលើការថ្វាយបង្គំយ៉ាងសកម្ម និងគោលបំណងដែលត្រូវនឹងព្រះគុណរបស់ព្រះ ។

**២:១៣** *ចំណង់ចង់ធ្វើ* ការមានបំណង ឬជំនឿ និងការស្ដាប់បង្គាប់របស់

ព្រះហើយ ដែលបណ្ដាលចិត្តអ្នករាល់គ្នា[គ] ឱ្យមានទាំង
ចំណង់ចង់ធ្វើ ហើយឱ្យបានប្រព្រឹត្តតាមបំណងព្រះហឫ
ទ័យទ្រង់ដែរ[ឃ] [១៤]ចូរធ្វើគ្រប់ការទាំងអស់ដោយឥតត្អូញ
ត្អែរ[ង] ឥតប្រកែក [១៥]ប្រយោជន៍ឱ្យអ្នករាល់គ្នាបានឥតសៅ
ហ្មង ឥតកិច្ចកល ជាកូនព្រះ[ច] ដែលរកបន្ទោសមិនបាន[ឆ] នៅ
ក្នុងដំណមនុស្សវៀច ហើយខិលខូច[ជ] ដែលអ្នករាល់គ្នាភ្លឺ
នៅកណ្ដាលគេ ដូចជាតួពន្លឺនៅក្នុងលោក [១៦]ទាំងហុចព្រះ
បន្ទូលនៃជីវិតដល់គេ ដើម្បីដល់ថ្ងៃនៃព្រះគ្រីស្ទ[ឈ] នោះឱ្យ
ខ្ញុំបានសេចក្ដីអំនួតអួតថា ខ្ញុំមិនបានរត់[ញ] ឬខំប្រឹងធ្វើការជា
ឥតប្រយោជន៍ឡើយ[ដ] [១៧]ប៉ុន្តែ បើសិនជាត្រូវច្រួច[ឋ]ខ្ញុំចេញ
លើយញ្ញបូជា[ឌ] និងការជំនួយរបស់សេចក្ដីជំនឿនៃអ្នក
រាល់គ្នា នោះខ្ញុំក៏អរ ហើយមានសេចក្ដីអំណរជាមួយនឹង
អ្នករាល់គ្នាទាំងអស់ដែរ[ឍ] [១៨]ចូរឱ្យអ្នករាល់គ្នាមានសេចក្ដី
អំណរយ៉ាងនោះ ហើយអរសប្បាយ ជាមួយនឹងខ្ញុំផង ។

## លោកធីម៉ូថេ និងលោកអេបាប្រាស

[១៩]ខ្ញុំសង្ឃឹមដោយនូវព្រះអម្ចាស់យេស៊ូវថាបន្តិចទៀត[ណ]
ខ្ញុំនឹងចាត់ធីម៉ូថេ[ត] មកឯអ្នករាល់គ្នា ដើម្បីឱ្យខ្ញុំបានក្សាន្តចិត្ត
ឡើង ដោយបានដឹងរឿងពីអ្នករាល់គ្នា [២០]ដ្បិតខ្ញុំគ្មានអ្នក

**២:១៣** គ អរ ១:៥ ១កថ ១២:៦ ១៥:១០ កទ ២:៨ ហព ១៣:២១ ឃ អភ ១:៥
**២:១៤** ង ១កថ ១០:១០ ១ពត ៤:៩
**២:១៥** ច មថ ៥:៤៥,៤៨ អភ ៥:១ ឆ ១ថន ៣:១៣ ជ កថ ២:៤០
**២:១៦** ឈ ១កថ ១:៨ ញ ១កថ ៩:២៤ ដ ១ថន ២:១៩
**២:១៧** ឋ ២កថ ១២:១៥ ២ធថ ៤:៦ ឌ រម ១៥:១៦ ឍ ២កថ ៦:១០

ណាមានគំនិតដូចជាគាត់[ថ] ដែលនឹងយកចិត្តទុកដាក់ក្នុង
ការរបស់អ្នករាល់គ្នាដោយស្មោះត្រង់នោះទេ [២១]ពីព្រោះ
មនុស្សទាំងអស់ គេរកតែប្រយោជន៍ផ្ទាល់ខ្លួន[ទ] មិនរកប្រ
យោជន៍ដល់ព្រះយេស៊ូវគ្រីស្ទទេ [២២]តែអ្នករាល់គ្នាស្គាល់
កិរិយារបស់គាត់ហើយ ថាគាត់បានបំរើនៅជាមួយនឹងខ្ញុំ
ក្នុងដំណឹងល្អ ដូចជាកូនបំរើឪពុក[ធ] [២៣]ដូច្នេះកាលណាខ្ញុំបាន
ឃើញថា រឿងខ្ញុំនឹងសំរេចជាយ៉ាងណា នោះខ្ញុំសង្ឃឹមថា
នឹងចាត់គាត់មកភ្លាម[ន] [២៤]ហើយខ្ញុំជឿប្រាកដ[ប] ដោយសារ
ព្រះអម្ចាស់ថា បន្តិចទៀតខ្លួនខ្ញុំនឹងមកដែរ ។
[២៥]ខ្ញុំបានយល់ឃើញថា ត្រូវចាត់អេបាប្រូឌីតមកឯអ្នករាល់
គ្នាដែរ គាត់ជាបងប្អូន ជាគូកនធ្វើការ[ផ] ហើយធ្វើទាហាន
ជាមួយនឹងខ្ញុំ[ព] ដែលអ្នករាល់គ្នាបានចាត់គាត់ទៅ ឱ្យជួយ
ផ្គត់ផ្គង់សេចក្ដីដែលខ្ញុំត្រូវការ[ភ] [២៦]គាត់រឭកដល់អ្នករាល់
គ្នា[ម]ជាខ្លាំង ហើយមានចិត្តព្រួយណាស់ ដោយព្រោះអ្នក
រាល់គ្នាបានឮថាគាត់ឈឺ [២៧]គាត់បានឈឺមែនស្ទើរតែនឹង

**២:១៩** ណ ខ.២៣ ត កថ ១៦:១ **២:២០** ថ ១កថ ១៦:១០
**២:២១** ទ ១កថ ១០:២៤ **២:២២** ធ ១កថ ៤:១៧ ១ធថ ១:២ **២:២៣** ន ខ.១៩
**២:២៤** ប ភល ១:២៥ **២:២៥** ផ រម ១៦:៣,៩,២១ ២កថ ៨:២៣ ភល ៤:៣
កល ៤:១១ ភម ១ ព ភម ២ ភ ភល ៤:១៨ **២:២៦** ម ភល ១:៨

យើងមិនអាចកាត់ផ្ដាច់ចេញពីគ្នាបានឡើយ (កទ ៥:៦ យក ២:១៨,២០, ២២) ។

**២:១៤** *ត្អូញត្អែរ* ការមិនពេញចិត្តនឹងបំណងព្រះហឫទ័យព្រះ គឺជាការបង្ហាញពីការមិនជឿ ដែលរារាំងបុគ្គលនោះ មិនឱ្យធ្វើអ្វីតាមព្រះទ័យព្រះ (ខ.១៣ ១កថ ១០:១០)។ *ប្រកែក* គឺការជជែកវែកញែកដែលគ្មានប្រយោជន៍អ្វីដល់ភាពល្អរបស់ពួកជំនុំ (២ធថ ២:២៣ ទត ៣:៩)។

**២:១៥** *ដែលរកបន្ទោសមិនបាន* គឺគ្រប់លក្ខណ៍ តែមិនមែនដាច់ខាត ហើយគ្មានបាបនោះឡើង ។ *ដំណមនុស្សវៀច ហើយខិលខូច* ជាការពិពណ៌នាអំពីលោកីយដែលមិនជឿ(កថ ២:៤០ អភ ២:១–៣ មថ ១៧:១៧)។ *ជាតួពន្លឺនៅក្នុងលោក* គឺជាពន្លឺនៅក្នុងភាពងងឹត ដែលគ្រីស្ទបរិស័ទត្រូវធ្វើជាពន្លឺដល់អ្នកដែលមិនជឿ (មថ ៥:១៥–១៦)។

**២:១៦** *សេចក្ដីអំនួត* លោកប៉ុលអួតដោយព្រោះអ្វី ដែលព្រះទ្រង់បានធ្វើតាមរយៈគាត់(១ថន ២:១៩) តែមិនមែនអួតពីខ្លួនគាត់ដែលបានសម្រេចកិច្ចការថ្វាយព្រះនោះឡើយ ។ *ថ្ងៃនៃព្រះគ្រីស្ទ* មើលការពន្យល់ ១:៦ ។ *ជាឥតប្រយោជន៍* ១កថ ៩:២៤–២៧ ។

**២:១៧–១៨** *ខ្ញុំក៏អរ. . .អ្នករាល់គ្នា. . . អរសប្បាយ. . .* គ្រីស្ទបរិស័ទអរសប្បាយ ត្រូវអរសប្បាយនឹងគ្នាទៅវិញទៅមក ។

**២:១៧** *ច្រួចខ្ញុំចេញលើយញ្ញបូជា* ប្រហែលជាការលះបង់មួយដ៏ធំធេងដោយធ្វើការបម្រើដើម្បីថ្វាយការអរព្រះគុណដល់ព្រះ ។ ជាងនេះទៅទៀត សាវ័កប៉ុលបានសំដៅទៅលើការជាប់ឃុំខ្លួនរបស់គាត់នៅពេលនោះ ដែលនឹងប្រហែលជាត្រូវបញ្ចប់ដោយការស្លាប់ដោយការបៀតបៀនដោយសារជំនឿលើព្រះគ្រីស្ទ ។ ជីវិតគាត់ពេលនោះនឹងបានច្រួចចេញជាមួយនឹងការបម្រើព្រះដែលពួកជំនុំក្រុងភីលីពបានបំពេញ ប្រកបដោយការលះបង់ ។ *ច្រួចខ្ញុំចេញ* តាមប្រវត្តិក្នុងគម្ពីរសញ្ញាចាស់នោះគឺជាសកម្មភាព នៃការច្រួចចេញដែលជាដង្វាយប្រចាំថ្ងៃនៅលើអសនា (នក ២៩:៣៨–៤១)។ *របស់សេចក្ដីជំនឿ នៃអ្នករាល់គ្នា* ជំនឿដែលពិត គឺសកម្មហើយបង្កើតផលផ្លែ (មើលការពន្យល់ ខ.១៣)។

**២:១៩–២៣** សាវកប៉ុលមានគម្រោងចាត់លោកធីម៉ូថេ(១:១)ឱ្យទៅមើល និងរាយការណ៍ពីស្ថានភាពពួកជំនុំក្រុងភីលីព ។

**២:២០** *ខ្ញុំគ្មានអ្នកណាមានគំនិតដូចជាគាត់* លោកធីម៉ូថេគឺជាគំរូដ៏ល្អសម្រាប់ការទូន្មានអ្នកឯទៀតនៅក្នុងខ.៤ ។

**២:២១** បទគម្ពីរនេះបានបញ្ជាក់ពីភាពខុសគ្នារវាងលោកធីម៉ូថេ និងគូកនការងារដទៃទៀតរបស់សាវកប៉ុល ហើយសាវកប៉ុលបានដាក់បញ្ហាដ៏សំខាន់មួយនេះដល់អ្នកដែលនៅខ្ចីក្នុងជំនឿនៅឡើយ ។

**២:២២** *ដូចជាកូនបំរើឪពុក* បើតាមព្រះគម្ពីរធីម៉ូថេខ្សែទី១ និង២ការរីកចម្រើនក្នុងទំនាក់ទំនងរវាងសាវ័កប៉ុល និងលោកធីម៉ូថេបានឆ្លងកាត់រយៈពេលដ៏យូរ ។ *បំរើ* ដូចព្រះយេស៊ូវ និងសាវកប៉ុលដែរ លោកធីម៉ូថេមានចរិតជាអ្នកបម្រើ ។

**២:២៤** សាវ័កប៉ុលបានប៉ាន់ប្រមាណថាគេនឹងដោះលែងគាត់ចេញពីគុកក្នុងពេលដ៏ខ្លីខាងមុខ(១:២៥)។

**២:២៥–៣០** អេបាប្រូឌីតក៏អញ្ចឹងដែរ គឺក្រោយពីគាត់ស្ទើរតែនឹងស្លាប់ទៅហើយនោះ(ខ.២៧,៣០) លោកប៉ុលនៅតែបញ្ជូនឱ្យគាត់ទៅឯក្រុងភីលីពដដែល ។

**២:២៥** *ដែលអ្នករាល់គ្នាបានចាត់គាត់* គឺពួកជំនុំក្រុងភីលីពបានចាត់គាត់

ស្លាប់ផង តែព្រះទ្រង់អាណិតមេត្តាដល់គាត់ មិនមែនដល់
គាត់តែ១ គឺដល់ខ្ញុំដែរ ដើម្បីមិនឱ្យខ្ញុំកើតទុក្ខជាខ្លាន់ៗ
ឡើយ ២៨ ដូច្នេះ ខ្ញុំបានចាត់គាត់ឱ្យមកជាប្រញាប់[យ] ដើម្បី
ឱ្យអ្នករាល់គ្នាមានសេចក្ដីអំណរ ដោយឃើញគាត់ ហើយ
ឱ្យខ្ញុំបានអន់ព្រួយដែរ ២៩ ចូរទទួលគាត់ក្នុងព្រះអម្ចាស់
ដោយអំណរគ្រប់ជំពូក ហើយរាប់អានមនុស្សយ៉ាងនោះ
ចុះ[រ] ៣០ ដ្បិតដែលគាត់ស្ទើរតែនឹងស្លាប់នោះ គឺដោយព្រោះ
តែការរបស់ព្រះគ្រីស្ទទេ គាត់បានប្រថុយជីវិត ដើម្បីនឹង
បំពេញសេចក្ដីណាដែលអ្នករាល់គ្នាត្រូវជួយដល់ខ្ញុំ[ល]។

## កុំទុកចិត្តលើសាច់ឈាម

**៣** ១ មួយសោតទៀត បងប្អូនអើយ ចូរអរសប្បាយក្នុងព្រះ
អម្ចាស់ចុះ ឯការដែលសរសេរសេចក្ដីដដែលៗ ផ្ញើមកអ្នក
រាល់គ្នា នោះមិនមែនធុញទ្រាន់ដល់ខ្ញុំទេ[ល] តែជាការមាន
ប្រយោជន៍ដល់អ្នករាល់គ្នាដែរ ២ ចូរប្រយ័ត្ននឹងពួកឆ្កែ[វ]
ហើយនិងពួកអ្នកដែលប្រព្រឹត្តអាក្រក់ ព្រមទាំងពួកកាត់
ស្បែកក្លែងក្លាយផង ៣ ដ្បិតយើងរាល់គ្នា ដែលបំរើព្រះ
ដោយវិញ្ញាណ ហើយអួតតែពីព្រះគ្រីស្ទយេស៊ូវ[ស] ឥតទុក
ចិត្តនឹងសាច់ឈាមឡើយ នោះយើងជាពួកកាត់ស្បែកដ៏
ពិត[ហ] ៤ ប៉ុន្តែ ខ្ញុំមានកន្លែងទុកខាងសាច់ឈាមខ្លះបានដែរ
បើមានអ្នកណាទៀតស្មានថា ខ្លួនទុកចិត្តខាងសាច់ឈាម
បាន នោះខ្ញុំក៏លើសទៅទៀត[ឡ] ៥ ដ្បិតខ្ញុំបានទទួលកាត់ស្បែក[អ]
នៅថ្ងៃទី៨ ខ្ញុំជាសាសន៍អ៊ីស្រាអែល[ក] ក្នុងពូជអំបូរបេនយ៉ា-
មីន[ខ] ជាអ្នកហេព្រើរ កើតពីពួកហេព្រើរ ឯខាងក្រិត្យវិន័យ
នោះខ្ញុំជាពួកផារិស៊ី[គ] ៦ ខាងឯសេចក្ដីឧស្សាហ៍[ឃ] នោះខ្ញុំជា
អ្នកដែលបានធ្វើទុក្ខបៀតបៀនដល់ពួកជំនុំ[ង] ចំណែកខាង
ឯសេចក្ដីសុចរិតក្នុងក្រិត្យវិន័យ[ច] នោះខ្ញុំគ្មានទោសសោះ

**២:២៨** យ ខ.២៥
**២:២៩** រ ១កថ ១៦:១៨ ១ធថ ៥:១៧
**២:៣០** ល ១កថ ១៦:១៧
**៣:១** ល ភល ២:១៨
**៣:២** វ ទដ ២២:១៦, ២០ វវ ២២:១៥
**៣:៣** ស រម ២:២៨, ២៩ កទ ៦:១៥ កល ២:១១ ហ រម ៥:១៧ កទ ៦:១៤
**៣:៤** ឡ ២កថ ១១:២១
**៣:៥** អ លក ១:៥៩ ក ២កថ ១១:២២ ខ រម ១១:១ គ កថ ២៣:៦
**៣:៦** ឃ កថ ២១:២០ ង កថ ៨:៣ ច ខ.៩ រម ១០:៥

ឱ្យធ្វើជាតំណាងពួកគេ (២កថ ៨:២៣) ។

**២:២៧** សូមមើល ភល ១:២១-២៦ ។

**២:២៨** *ព្រួយ* គឺការខ្វល់ខ្វាយ និងព្រួយបារម្ភអំពីការប្រឈមមុខនឹងការកៀបសង្កត់របស់ច្បាប់ដែលជាញ្ញា ឬជាឧបសគ្គដល់ជីវិតជាគ្រីស្ទបរិស័ទ និងការងារផ្សព្វផ្សាយដំណឹងល្អ (៤:៦ ២កថ ៤:៨ ១១:២៨ និងពន្យល់) ។

**៣:១** *មួយសោតទៀត* គឺសំគាល់ពីការនិយាយចូលដល់វគ្គថ្មីមួយទៀតដែលក្នុងដំណាក់កាលនេះ លោកប៉ុលកំពុងតែឈានទៅរកសេចក្ដីសន្និដ្ឋាន តែវាមិនមែនសំគាល់ពីទីបញ្ចប់នៃសំបុត្រនេះឡើយ (មើល ៤:៨) ។ *អរសប្បាយក្នុងព្រះអម្ចាស់* មើល៤:៤ ។ *សេចក្ដីដដែល* គឺជាបញ្ហាទាំងអស់ដែលមាននិយាយនៅក្នុងខគម្ពីរដែលមានជាបន្តបន្ទាប់ពីខ.១នេះ សេចក្ដីទាំងនោះគឺមាននៅ ក្នុងការចែកចាយរបស់គាត់ដោយផ្ទាល់ កាលពីមុននៅក្រុងភីលីព ឬប្រហែលជាមាននៅក្នុងសំបុត្រមួយច្បាប់មុន ។ *ការមានប្រយោជន៍* មានន័យថាគ្រប់ទាំងព្រះបន្ទូលព្រះជាសេចក្ដីពិត ហើយសុទ្ធតែមានប្រយោជន៍សម្រាប់មនុស្សគ្រប់គ្នាអាចប្រើបានគ្រប់សម័យកាល និងទីកន្លែង ហើយការរំឭកជាច្រើនដងគឺជាការចាំបាច់ណាស់ ។

**៣:២** *ពួកឆ្កែ* ជាពាក្យមួយដ៏សែនធ្ងន់ដែលលោកប៉ុលបានប្រើ ដើម្បីនិយាយប្រឆាំងនឹងពួកអ្នកដែលប្រឆាំងតទល់នឹងដំណឹងល្អ និងដើម្បីបង្ហាញពីភាពធ្ងន់ធ្ងរនៃកំហុសឆ្គងនេះ ក៏ដូចជាសេចក្ដីហិនវិនាសដែលកើតចេញពីការប្រឆាំងនេះដែលជាផលនាំឱ្យហិនវិនាសផងដែរ (កទ ៥:១៥) ។ ពួកនេះបានបង្រៀន នូវសេចក្ដីដែលស្ទើរតែស្រដៀងគ្នាទាំងស្រុង នឹងសេចក្ដីបង្រៀននៅក្នុងព្រះវិហាររបស់ពួកជំនុំកាឡាទី ដែលលោកប៉ុលត្រូវតែប្រឆាំង (មើលសេចក្ដីផ្ដើមកាឡាទី ត្រង់ឱកាស និងគោលបំណង) ។ *ពួកកាត់ស្បែកក្លែងក្លាយ* ជាពាក្យមួយទៀតដែលធ្ងន់ធ្ងរ និងបានបង្ហាញឱ្យកាន់តែងាយយល់ថែមទៀតពីសេចក្ដីអាក្រក់ដែល ពួកគ្រូបង្រៀនខុសឆ្គងទាំងនោះបានធ្វើឱ្យខូចដល់ពាក្យកាត់ស្បែកនេះ (ខ.៣) គឺបានធ្វើឱ្យពាក្យនេះគ្មានន័យអ្វីលើសពីការកាត់សរីរាង្គកាយដ៏ឥតប្រយោជន៍នោះឡើយ ។

**៣:៣** *កាត់ស្បែក* ភាពពិតនៃពាក្យនេះ គឺឃើញមានតែនៅក្នុងអ្នកជឿប៉ុណ្ណោះ ដែលពិតជាអ្នកថ្វាយបង្គំព្រះអម្ចាស់ដោយវិញ្ញាណ និងមានអំណរជាទីបំផុតចំពោះការទទួលព្រះគ្រីស្ទ ជាព្រះសង្គ្រោះរបស់ពួកគេ ជាជាងការពឹងផ្អែកលើកម្លាំងផ្ទាល់ខ្លួនរបស់ពួកគេម្នាក់ៗជាមនុស្ស (រម ២:២៨-២៩ កល ២:១២-១៣ ចទ ៣០:៦ អគ ៣៦:២៦) ។ *អួត...ឥតទុកចិត្ត* មនុស្សយើងសុទ្ធតែមានអំនួត គឺមិនថាតែនៅក្នុងព្រះគ្រីស្ទ ឬនៅក្នុងខ្លួនឯងឡើយ ។ *សាច់ឈាម* មានពេញដោយភាពកម្សោយ ។

**៣:៤-១៤** ទីបន្ទាល់ដែលលោកប៉ុលថ្លែងពីខ្លួនគាត់នេះ បានផ្ដល់ឱ្យជាគំរូដល់គ្រប់អ្នកជឿទាំងអស់ គឺដោយវាជាផ្នែកមួយក្នុងចំណោមផ្នែកជីវប្រវត្តិដែលសំខាន់ៗបំផុតរបស់សំបុត្រនេះ (កទ ១:១៣-២៤ ១ថធ ១:១២-១៦ កថ ២២:១-២១ ២៦:១-២៣) ។

**៣:៤-៦** ក្នុងវគ្គនេះលោកប៉ុលចង់បង្ហាញថា ទំនុកចិត្តដែលគាត់មានមុនពេលគាត់បានទទួលជឿព្រះបានកើតចេញពីឈាមជ័រ អភ័យឯកសិទ្ធិ និងចំណេះវិជ្ជារបស់គាត់ខាងសាសនាយូដា ។

**៣:៥** *ថ្ងៃទី៨* គឺថ្ងៃដែលគេរាប់ចាប់ពីថ្ងៃកំណើតរបស់គាត់ (លប ១៧:១២) ។ *ខ្ញុំជាសាសន៍អ៊ីស្រាអែល* លោកប៉ុលមានកំណើតជាសាសន៍យូដា ហើយធ្លាប់ជាអ្នកដែលមិនព្រមប្រែចិត្តជឿដល់ព្រះ ។ *ពូជអំបូរបេនយ៉ាមីន* មានន័យថាកាលមុនជឿព្រះ ជំនឿរបស់គាត់បានចាក់ឫសចូលជ្រៅ ហើយមានភាពប្រាកដប្រជានៅក្នុងសាសនាយូដា ។ ទីក្រុងបរិសុទ្ធយេរូសាឡិមមានទីតាំងនៅត្រង់ព្រំប្រទល់នៃទឹកដីកុលសម្ព័ន្ធឬពូជអំបូរបេនយ៉ាមីន ។ *អ្នកហេព្រើរកើតពីពួកហេព្រើរ* ពាក្យនេះមានន័យថាគាត់បានប្រើភាសា អាកប្បកិរិយា និងរបៀបនៃការរស់នៅរបស់ពួកហេព្រើរ (កថ ២២:២-៣ កទ ១:១៤) ។ *ផារិស៊ី* មើល កថ ២២:២ ២៣:៦ ២៦:៥ ។

**៣:៦** *សេចក្ដីសុចរិតក្នុងក្រិត្យវិន័យ* គឺសេចក្ដីសុចរិតដែលបានកើតចេញពីការយកច្បាប់មកប្រើឱ្យបានដូចជាចិត្តប៉ង ដើម្បីឱ្យសមនឹងទទួលបាននូវការបើកបង្ហាញ និងការប្រទានព្រះពរពីព្រះជាអម្ចាស់ (ខ.៩) ចំពោះការអនុវត្តន៍ក្រឹត្យវិន័យនេះ លោកប៉ុលបានផ្លាស់ប្រែមកជាប្រឆាំងយ៉ាងដាច់ខាតដោយហេតុថាវាទាស់ប្រឆាំងនឹងដំណឹងល្អ (រម ៣:២៧-២៨ ៤:១-៥ កទ ២:១៦ ៣:១០-១២) ។ *គ្មានទោស* គឺគ្មានទោសកំហុស ដោយព្រោះមិនបានបំពានលើក្រឹត្យវិន័យ ។

៧ប៉ុន្តែ សេចក្ដីអ្វីដែលមានប្រយោជន៍ដល់ខ្ញុំពីមុន នោះខ្ញុំ
បានរាប់ជាខាតវិញ[ឆ] ដោយព្រោះព្រះគ្រីស្ទ ៨ហើយខ្ញុំក៏រាប់
គ្រប់ទាំងអស់ទុកដូចជាខាត[ឆ]ដែរ ដោយព្រោះសេចក្ដីដែល
ប្រសើរជាង គឺដោយស្គាល់ព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់
នៃខ្ញុំ ដែលដោយយល់ដល់ទ្រង់ ខ្ញុំបានខាតគ្រប់ទាំងអស់
ហើយបានរាប់ទាំងអស់ទុកដូចជាសំរាម ប្រយោជន៍ឱ្យបាន
ព្រះគ្រីស្ទវិញ[ជ] ៩ហើយឱ្យគេបានឃើញខ្ញុំនៅក្នុងទ្រង់ ដោយ
សេចក្ដីសុចរិត ដែលមកពីសេចក្ដីជំនឿដល់ព្រះគ្រីស្ទ មិន
មែនដោយសេចក្ដីសុចរិតរបស់ខ្លួនខ្ញុំ ដែលមកពីក្រិត្យវិន័យ
នោះទេ[ឈ] គឺជាសេចក្ដីសុចរិត[ញ]ដែលមកពីព្រះ ដោយ
សេចក្ដីជំនឿវិញ[ដ] ១០ដើម្បីឱ្យខ្ញុំបានស្គាល់[ឋ]ទ្រង់ និងព្រះ
ចេស្ដានៃដំណើរ ដែលទ្រង់រស់ឡើងវិញ ហើយនិង
សេចក្ដីប្រកបក្នុងការរងទុក្ខរបស់ទ្រង់[ឌ] ព្រមទាំងត្រឡប់
ទៅដូចជាទ្រង់ក្នុងសេចក្ដីស្លាប់ផង[ឍ] ១១នោះគឺបើសិនជា
មានផ្លូវណា ឱ្យខ្ញុំបានមកដល់សេចក្ដីរស់ពីស្លាប់ឡើង
វិញ[ណ]។

**ការរត់តម្រង់ទៅឯទីប្រណាំង**

១២មិនមែនថា ខ្ញុំបានទទួល ឬថាខ្ញុំបានគ្រប់លក្ខណ៍
ហើយនោះទេ[ត] តែខ្ញុំកំពុងតែដេញតាម សង្ឃាតនឹងចាប់ឱ្យ
បាន[ថ]សេចក្ដីដែលព្រះគ្រីស្ទយេស៊ូវបានចាប់ខ្ញុំឱ្យបាននោះ
ដែរ[ទ] ១៣បងប្អូនអើយ ខ្ញុំមិនរាប់ថាខ្លួនខ្ញុំចាប់បានហើយ
នោះទេ តែមានសេចក្ដីនេះ១ គឺថា ខ្ញុំភ្លេចសេចក្ដីទាំង
ប៉ុន្មានដែលកន្លងទៅ[ធ]ហើយ ក៏ខំមមុលឈោងទៅឯសេចក្ដី
ខាងមុខទៀត ១៤ទាំងរត់ដំរង់[ន]ទៅឯទី ដើម្បីឱ្យបានរង្វាន់[ប]
នៃការងារដ៏ខ្ពស់របស់ព្រះ[ផ] ក្នុងព្រះគ្រីស្ទយេស៊ូវ។
១៥ដូច្នេះយើងទាំងអស់គ្នា ដែលគ្រប់លក្ខណ៍ហើយ[ព]

**៣:៧** ឆ មថ ១៣:៤៤ លក ១៤:៣៣
**៣:៨** ឆ ខ.១០ យរ ៩:២៣,២៤ យហ ១៧:៣ អភ ៤:១៣ ២ពត ១:២ ជ ទដ ៧៣:២៥
**៣:៩** ឈ ខ.៦ រម ១០:៥ ញ យរ ៣៣:១៦ ដ រម ៩:៣០
**៣:១០** ឋ ខ.៨ ឌ ២កថ ១:៥ ឍ រម ៦:៣-៥
**៣:១១** ណ យហ ១១:២៤ រម ៦:៥ វវ ២០:៥,៦
**៣:១២** ត ១កថ ១៣:១០ ថ ១ធថ ៦:១២ ទ កច ៩:៥,៦ **៣:១៣** ធ លក ៩:៦២ **៣:១៤** ន ហព ៦:១ ប ១កថ ៩:២៤ ផ រម ៨:២៨ **៣:១៥** ព ១ កថ ២:៦

**៣:៧-១៤** ទំនុកចិត្តថ្មីដែលលោកប៉ុលមានលើព្រះគ្រីស្ទ ។

**៣:៧** *សេចក្ដីអ្វី* គឺជាសេចក្ដីដែលបានបញ្ជាក់នៅក្នុងខ.៥-៦ ។ *ប្រយោជន៍. . .ខាតវិញ* គឺការប្រែចិត្តដ៏អស្ចារ្យ ដែលបានកើតមានចំពោះលោកប៉ុល ដោយបានផ្ដើមចាប់ពីកាលនៅលើដងផ្លូវឆ្ពោះទៅក្រុងដាម៉ាសរៀងរហូតមក (កច ៩:៣-១៦) គឺចាប់តាំងពីពេលដែលគាត់បានផ្លាស់ប្រែពីការដែលនិយមតែអាត្មាខ្លួនឯងទៅជាការដែលនិយមតែព្រះគ្រីស្ទវិញ ។

**៣:៨** *ដោយស្គាល់ព្រះគ្រីស្ទ* មានន័យថាមិនគ្រាន់តែជាចំណេះដឹងខាងឯសេចក្ដីពិតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាចំណេះដែលរកបានពីបទពិសោធន៍នៃការបំផ្លាស់បំប្រែមនុស្សម្នាក់ទាំងស្រុង ។ *សំរាម* ជីវិតរបស់គាត់កាលមិនទាន់មានព្រះ គឺគ្មានតម្លៃ ហើយមានភាពសាហាវព្រៃផ្សៃទៀតផង ។

**៣:៩** *គេបានឃើញខ្ញុំនៅក្នុងទ្រង់* គឺការប្រកបជាមួយនឹងព្រះគ្រីស្ទ (មើលការពន្យល់ ២:១ ១កថ ១:៣០) ដែលមិនគ្រាន់តែនៅកាលពីមុន តែក៏នៅក្នុងពេលបច្ចុប្បន្នផងដែរ គឺជាទំនាក់ទំនងដែលបន្តជាប់ជានិច្ច ។ *សេចក្ដីសុចរិត. . .មកពីក្រិត្យវិន័យ* មើលពន្យល់ខ.៦ ។ *សេចក្ដីសុចរិត. . . ដោយសេចក្ដីជំនឿ* ជាផលដែលត្រូវតែទទួលបានពីការប្រកបទាក់ទងជាមួយនឹងព្រះគ្រីស្ទ (រម ៣:២១-២២ ១កថ ១:៣០ កទ ២:១៦) ។

**៣:១០** *ស្គាល់ទ្រង់* ដូចនៅក្នុងខ.៨ ការយល់ដឹងនេះមិនមែនគ្រាន់តែជាការស្គាល់ការពិតប៉ុណ្ណោះទេ តែថែមទាំងបានរាប់បញ្ចូលការពិសោធន៍ជាមួយនឹងព្រះចេស្ដានៃការរស់ពីសុគតឡើងវិញផងដែរ (អភ ១:១៧-២០) និងការប្រកបនៅក្នុងការរងទុក្ខរបស់ផងទ្រង់(កច ៩:១៦) ហើយនិងការដែលបានដូចទ្រង់នៅក្នុងការសុគតផងដែរ (២កថ ៤:៧-១២ ១២:៩-១០)។ អ្នកជឿបានទទួលចំណែករួចរាល់ហើយនៅក្នុងការសុគត និងការមានព្រះជន្មឡើងវិញនៃអង្គព្រះយេស៊ូវគ្រីស្ទ(រម ៦:២-១៣ កទ ២:២០ ៥:២៤ ៦:១៤ អភ ២:៦ កល ២:១២-១៣ ៣:១)។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងខ.១០ លោកប៉ុលបាននិយាយពីការពិសោធន៍ជាក់ស្ដែង ជាមួយនឹងអំណាចនៃដំណើរពីការដែលទ្រង់រស់ឡើងវិញ ព្រមទាំងការរងទុក្ខជាមួយនិងសម្រាប់ទ្រង់ដែលសូម្បីតែហៀបនឹងស្លាប់ ។

**៣:១១** *បើសិនជាមានផ្លូវណា* មិនមែនជាការចង្អុលបង្ហាញពីការមានមន្ទិល ឬមិនច្បាស់ក្នុងចិត្តឡើយ តែពីការបន្ទាបខ្លួន ព្រោះមិនចង់ធ្វើកំហុសក្នុងការសន្និដ្ឋានទុកជាមុន ។ *រស់ពីស្លាប់ឡើងវិញ* អ្នកជឿព្រះមានការដឹងជាមុនអំពីការរស់ឡើងវិញរបស់ខ្លួនដោយក្ដីអំណរបំផុត(មើល ដយ ១២:២ យហ ៥:២៩ កច ២៤:១៥ ១កថ ១៥:២៣ ១ថន ៤:១៦)។

**៣:១២-១៤** ជីវិតគ្រីស្ទបរិស័ទប្រៀបបីដូចជាការប្រណាំងប្រជែង ។ នៅត្រង់កន្លែងផ្សេងៗទៀត សាវកប៉ុលបានប្រើការស្រមៃរបៀបស្រដៀងៗគ្នាដោយបានប្រដូចខ្លួនគាត់ទៅនឹងអ្នកអត្តពលកម្មម្នាក់ (១កថ ៩:២៤-២៧ ១ធថ ៦:១២ ២ធថ ៤:៧-៨ មថ ២៤:១៣ ហព ១២:១) ។

**៣:១២** *សង្ឃាតនឹងចាប់ឱ្យ. . .ចាប់ខ្ញុំឱ្យបាន* គោលដៅរបស់សាវកប៉ុល គឺជាគោលដៅ ដែលព្រះគ្រីស្ទទ្រង់មានសម្រាប់គាត់ ហើយព្រះគ្រីស្ទទ្រង់ក៏បានផ្គត់ផ្គង់ប្រភពធនធានដល់រូបគាត់ ដើម្បីឱ្យគាត់រត់តម្រង់ទៅឯទី(ឬគោលដៅ) (ខ.១៤ ២:១២ ១៣)។

**៣:១៣** *ភ្លេច* លោកប៉ុលមិនមែនបាត់បង់ការចងចាំពីបាប ដែលគាត់មានពីមុននោះទេ(មើល ខ.៤-៦) ប៉ុន្តែគាត់បានទុកវាចោលឱ្យនៅខាងក្រោយគាត់ដោយការស្រាយវាចេញ ដោយពឹងអាងលើព្រះគ្រីស្ទ ។

**៣:១៤** *រង្វាន់* អ្នកឈ្នះក្នុងការរត់ប្រណាំងរបស់ជនជាតិក្រិកតែងបានទទួលការបំពាក់កម្រងស្លឹកឈើមួយកម្រង ហើយជួនកាលបានទទួលរង្វាន់ជាប្រាក់កាក់ រីឯគ្រីស្ទបរិស័ទវិញមានរង្វាន់ដែលត្រូវបានប្រោសប្រទានឱ្យ ជាសិរីល្អដ៏អស់កល្បជានិច្ច។ *រង្វាន់នៃការងារដ៏ខ្ពស់របស់ព្រះ* ការប៉ងប្រាថ្នាចំពោះសេចក្ដីខាងមុខរបស់លោកប៉ុល គឺគាត់បានរកឃើញមិនមែននៅក្នុងជីវិតដែលគាត់កំពុង តែរស់នៅនោះទេ គឺនៅក្នុងស្ថានសួគ៌ដែលជាបល្ល័ង្ករបស់ផងព្រះតែប៉ុណ្ណោះ (កល ៣:១ -២)។

**៣:១៥** *គ្រប់លក្ខណ៍* ចំពោះអ្នកដែលបានរីកចម្រើនយ៉ាងប្រសើរខាងឯវិញ្ញាណ និងខាងការមានស្ថេរភាពក្នុងជំនឿ (១កថ ២:៦ ៣:១-៣ ហព ៥:១៤)។ *យ៉ាងនោះ* គឺសេចក្ដីដែលបានបង្ហាញក្នុងខ.១២-១៤ គឺកុំឆ្វេសប្រហែស ដោយអាងថា មានភាពគ្រប់លក្ខណ៍ ហើយនៅទ្រឹងមួយកន្លែង

យើងត្រូវមានគំនិតយ៉ាងនោះឯង[ភ] តែបើអ្នករាល់គ្នាមាន
គំនិតណាផ្សេងក្នុងការអ្វី នោះព្រះទ្រង់នឹងសំដែងឱ្យអ្នក
រាល់គ្នាបានឃើញសេចក្ដីនេះដែរ[ម] ១៦ប៉ុន្តែ ទោះបើបាន
ដល់ទីណាក៏ដោយ គង់តែត្រូវឱ្យយើងកាន់តាមច្បាប់នោះ
ឯង។

១៧បងប្អូនអើយ ចូរត្រាប់តាមខ្ញុំគ្រប់គ្នា[យ] ហើយពិចារ
ណាមើលឱ្យស្គាល់ពួកអ្នកដែលដើរដូចជាយើងខ្ញុំបានធ្វើ
ក្បួនឱ្យអ្នករាល់គ្នាហើយ[រ] ១៨ដ្បិតមានមនុស្សជាច្រើន ដែល
ខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាជាញយៗ ហើយឥឡូវនេះ ក៏
ប្រាប់ទាំងស្រក់ទឹកភ្នែកទៀតថា[ល] គេជាខ្មាំងសត្រូវនឹង
ឈើឆ្កាងព្រះគ្រីស្ទទេ[វ] ១៩ចុងបំផុត[ស]របស់គេជាសេចក្ដី
ហិនវិនាស គេយកពោះ[ហ]គេទុកជាព្រះ ហើយយកសេចក្ដី
គួរខ្មាសរបស់គេ ទុកជាសិរីល្អវិញ[ឡ] គេនឹកតែពីរបស់
នៅផែនដីនេះ[អ] ២០ឯយើងរាល់គ្នា យើងជាសាសន៍[ក]ស្ថាន
សួគ៌វិញ[ខ] ក៏នៅចាំព្រះអម្ចាស់យេស៊ូវគ្រីស្ទ[គ] ជាព្រះអង្គ
សង្គ្រោះ ទ្រង់យាងមកពីស្ថាននោះឯង ២១ដែលទ្រង់នឹង
បំផ្លាស់បំប្រែរូបកាយទាបថោករបស់យើង[ឃ] ឱ្យត្រឡប់
ដូចជារូបអង្គឧត្តមរបស់ទ្រង់[ង] តាមដែលព្រះចេស្ដាទ្រង់[ច]
ពូកែនឹងបញ្ចុះបញ្ចូលគ្រប់ទាំងអស់ នៅក្រោមអំណាចទ្រង់
ផង ។

៤ ១ដូច្នេះ បងប្អូនជាពួកស្ងួនភ្ងា ហើយជាទីរឭកជាទី
ត្រេកអរ[ឆ] ហើយជាមកុដរបស់ខ្ញុំអើយ ចូរឈរឱ្យមាំមួន[ជ]
ក្នុងព្រះអម្ចាស់ចុះ ឱពួកស្ងួនភ្ងាអើយ ។

## ការស្មោះទឹកចិត្ត

២ខ្ញុំសូមទូន្មានដល់នាងអើរ៉ូឌា និងនាងស៊ុនទីចដែរ ឱ្យ
មូលគំនិតតែ១[ឈ]ក្នុងព្រះអម្ចាស់ ៣ហើយខ្ញុំក៏សូមដល់អ្នក

**៣:១៥** ភ កទ ៥:១០ ម អភ ១:១៧ ១ថន ៤:៩ **៣:១៧** យ ១កថ ៤:១៦ រ ១ធថ ៤:១២ **៣:១៨** ល កច ២០:៣១ វ កទ ៦:១២ **៣:១៩** ស ទដ ៧៣:១៧ ហ រម ១៦:១៨ ឡ រម ៦:២១ យដ ១៣ អ រម ៨:៥,៦ កល ៣:២ **៣:២០** ក អភ ២:១៩ ខ កល ៣:១ ហព ១២:២២

គ ១កថ ១:៧ **៣:២១** ឃ ១កថ ១៥:៤៣–៥៣ ង រម ៨:២៩ កល ៣:៤ ច អភ ១:១៩ **៤:១** ឆ ភល ១:៨ ជ ១កថ ១៦:១៣ **៤:២** ឈ ភល ២:២

លែងមានសកម្មភាពទៅមុខទៀតនោះឡើយ គឺត្រូវឱ្យបានមមុលតទៅមុខទៀតផងទើបបាន ។

**៣:១៦** *ដល់ទីណា. . .កាន់តាមច្បាប់នោះឯង* គឺជាការដែលយកមកអនុវត្តនូវសេចក្ដីពិត ដែលពួកគេបានស្គាល់ហើយ គឺយើងត្រូវតែមានទំនួលខុសត្រូវចំពោះសេចក្ដីពិតដែលយើងបានទទួលហើយ ។

**៣:១៧** *ត្រាប់តាមខ្ញុំ* គឺដោយព្រោះលោកប៉ុលបានត្រាប់តាមព្រះគ្រីស្ទដែរ ។ *បានធ្វើក្បួនឱ្យអ្នករាល់គ្នា* គំរូនៃគ្រីស្ទបរិស័ទគួរតែស័ក្ដិសមនឹងយកតាម ។

**៣:១៨** *បានប្រាប់ដល់អ្នករាល់គ្នា* មើល ខ.១ ។ *ទាំងស្រក់ទឹកភ្នែក* (កច ២០:១៩,៣១)។ *គេជាខ្មាំងសត្រូវនឹងឈើឆ្កាងព្រះគ្រីស្ទ* គឺជាអ្នកដែលងាយនឹងកត់សំគាល់ថា បានប្រព្រឹត្តទាស់នឹងរបៀបនៃការប្រតិបត្តិរបស់លោកប៉ុល (ខ.១០) ព្រមទាំងទាស់នឹងសេចក្ដីពិតនៃដំណឹងល្អផងដែរ ។

**៣:១៩** *សេចក្ដីហិនវិនាស* គឺផ្ទុយនឹង"សេចក្ដីសង្គ្រោះ"។ *ពោះ . . . ព្រះ* គឺការយកអាត្មាខ្លួនឯងជាទីមួយ ដោយយកការស្រេកឃ្លាន និងសេចក្ដីប៉ងប្រាថ្នាខាងសាច់ឈាមជាធំ ។ *របស់នៅផែនដី* ពួកដែលដាក់ចិត្តលើអ្វីៗដែលពួកគេមាននៅក្នុងជីវិតរស់នៅ គឺពួកអសីលធម៌ក្នុងខ.២ ។

**៣:២០** *សាសន៍* គ្រីស្ទបរិស័ទគឺជាពួកក្រៅសាសន៍ ដែលមកស្នាក់នៅផែនដី ដែលទោះបីជាចំណែកមួយនៅក្នុងផែនដីនេះក្ដី ក៏គង់តែមិនមែនជារបស់ផែនដីដែរ (យហ ១៧:១៤–១៦ ១កថ ៧:២៩–៣១ ១ពត ២:១១)។ *ស្ថានសួគ៌* ជាកន្លែងព្រះគ្រីស្ទទ្រង់គង់ប្រថាប់នៅ ហើយជាកន្លែងដែលគ្រីស្ទបរិស័ទនៅប្រកបជាមួយនឹងទ្រង់ផងដែរ គឺផ្ទុយនឹង "របស់នៅផែនដី" ក្នុង ខ.១៩(អភ ២:៦ កល ៣:១–៤)។ *ក៏នៅ ចាំ. . .ស្ថាននោះឯង* (រម ៨:១៩ ១កថ ១:៧ ១ថន ១:៩–១០ ២ទត ៤:៨)។

**៣:២១** *ព្រះចេស្ដា. . .នៅក្រោមអំណាចទ្រង់* ព្រះចេស្ដាបច្ចុប្បន្នរបស់ផងព្រះគ្រីស្ទ ដែលទទួលបានពីការស្ដាប់បង្គាប់របស់ផងទ្រង់ រហូតដល់អស់ព្រះជន្ម (២:៨) ហើយបានទទួលនៅក្នុងការមានព្រះជន្មរស់ឡើងវិញ និងការយាងឡើងស្ថានសួគ៌របស់ទ្រង់ គឺមានអំណាចលើគ្រប់ទាំងអស់ និងមានជាសេចក្ដីពិត(មថ ២៨:១៨ ១កថ ១៥:២៧ អភ ១:២០–២) ។ *ឱ្យត្រឡប់ជា* គឺបានផ្លាស់ប្រែដោយព្រះវិញ្ញាណ នៅក្នុងការរស់ឡើងវិញ (រម ៨:១១ ១កថ ៦:១៤ ១៥:៥០–៥៣)។ *រូបកាយទាបថោករបស់យើង* ដែលមានពេញទៅដោយសេចក្ដីកម្សោយ ការពុកផុយ និងសេចក្ដីស្លាប់ ដោយសារតែមានបាប(រម ៨:១០,២០–២៣ ១កថ ១៥:៤២–៤៤)។ *ដូចជារូបអង្គឧត្ដមរបស់ទ្រង់* (រម ៨:២៩ ១យហ ៣:២) ព្រះគ្រីស្ទបានទទួលរូបកាយដែលមានព្រះជន្មរស់ពីស្លាប់ឡើងវិញ ហើយទ្រង់គឺជា "ផលដំបូង" ដែលអ្នកជឿនឹងទទួលបានក្នុង"ចម្រូត"នៃការរើបពីស្លាប់ឡើងវិញ នៅពេលអនាគត (១កថ ១៥:២០,៤៩) គឺរូបកាយដែលរស់ឡើងវិញខាងឯព្រលឹងវិញ្ញាណដែលមានន័យថា ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធបានបំផ្លាស់បំប្រែរូបកាយនោះ (១កថ ១៥:៤៤,៤៦)។

**៤:១** *ជាទីរឭក* (ឬម្យ៉ាងទៀតមានន័យថា "ជាទីស្រលាញ់ និងជាទីប្រាថ្នាដ៏លើសលប់")មើលការពន្យល់ ១:៨ ២:១ ។ *ជាទីត្រេកអរ ហើយជាមកុដរបស់ខ្ញុំ* វាមិនត្រឹមតែពិតក្នុងពេលហៅប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងពិតជាពិសេស នៅក្នុងពេលព្រះគ្រីស្ទយាងមកវិញជាលើកទីពីរផងដែរ (១ធថ ២:១៩)។ *ចូរ* (ឬអញ្ចឹង ហើយចូរ) សំដៅពីការបញ្ចប់សេចក្ដីថ្លែងនៅក្នុងជំពូក៣ ។ ចំពោះបញ្ហាពួក សីលធម៌ ដែលស្ថិតនៅចំពោះមុខនោះ(៣:១៨–១៩) ពួកជំនុំក្រុងភីលីពគប្បីគួរតែយកគំរូតាមលោកប៉ុល(៣:១៧) ដោយនឹកតែពីរបស់ដែលនៅឯស្ថានសួគ៌វិញ (៣:២០–២១)។ *ឈរឱ្យមាំមួន* គឺក្នុងខណៈពេលបច្ចុប្បន្នដែលកំពុងតែតស៊ូ ក្នុងបុព្វហេតុដំណឹងល្អ(១:២៧–៣០ ១កថ ១៥:៥៨)។

**៤:២–៣** ការមិនចុះសម្រុងគ្នារវាងនាងអើរ៉ូឌា និងនាងស៊ុនទីចមានសភាពធ្ងន់ធ្ងរល្មមនឹងត្រូវលើកមកនិយាយក្នុងសំបុត្រនេះ ហើយលោកប៉ុលមានជំនឿចិត្តថា "ស្ត្រីទាំងពីរ"(ខ.៣) នឹងបានជានាគ្នាឡើងវិញជាមិនខាន ។ ការដែលលោកប៉ុលគ្រប់គ្រងស្ថានភាពបែបនេះ គឺជាគំរូនៃយុទ្ធវិធីដោះស្រាយដ៏ល្អដែលក្នុងនោះគាត់មិនបានកាន់ជើងខាងណាឡើយ ផ្ទុយទៅវិញគាត់បានលើកទឹកចិត្តឱ្យអ្នកដទៃ ដែលនៅក្នុងសហគមន៍ជាមួយគ្នា ឬនៅក្បែរពួកគេ ផ្ដួចផ្ដើមឱ្យពួកគេមានការរួបរួមគ្នាឡើងវិញ(២:២)។

ឱគូកនស្មោះត្រង់របស់ខ្ញុំអើយ សូមជួយស្ត្រីទាំង២នោះ
ដែលបានតតាំងជា១នឹងខ្ញុំ ក្នុងដំណឹងល្អផង ហើយនិងអ្នក
ក្លេមេន និងគូកន[ញ]ខ្ញុំឯទៀត ដែលគេមានឈ្មោះកត់ទុកក្នុង
បញ្ជីជីវិតដែរ[ដ]។
៤ចូរអរសប្បាយ ក្នុងព្រះអម្ចាស់ជានិច្ច ខ្ញុំប្រាប់ម្តងទៀត
ថា ចូរអរសប្បាយឡើង[ឋ] ៥ចូរសំដែងឱ្យមនុស្សទាំងអស់
បានស្គាល់សេចក្តីសំឡូតរបស់អ្នករាល់គ្នាចុះ ព្រោះព្រះ
អម្ចាស់ទ្រង់ជិតដល់ហើយ[ឌ] ៦កុំឱ្យខ្វល់ខ្វាយអ្វីឡើយ[ឍ] ចូរ
ទូលដល់ព្រះ ឱ្យជ្រាបពីសេចក្តីសំណូម របស់អ្នករាល់គ្នា
ក្នុងគ្រប់ការទាំងអស់ ដោយសេចក្តីអធិស្ឋាន និងពាក្យទូល
អង្វរ ទាំងពោលពាក្យអរព្រះគុណផង[ណ] ៧យ៉ាងនោះសេច
ក្តីសុខសាន្តរបស់ព្រះ[ត] ដែលហួសលើសពីអស់ទាំងគំនិត[ថ]
នឹងជួយការពារចិត្ត ហើយនិងគំនិតរបស់អ្នករាល់គ្នា ក្នុង

**៤:៣** ញ ភល ២:២៥
ដ វវ ២០:១២
**៤:៤** ឋ ទដ ៨៥:៦
៩៧:១២ ហព ៣:១៨
មថ ៥:១២ រម
១២:១២ ភល ៣:១
**៤:៥** ឌ ទដ
១១៩:១៥១ ១៤៥:១៨
ហព ១០:៣៧
យក ៥:៨,៩
**៤:៦** ឍ មថ
៦:២៥–៣៤
**៤:៦** ណ អភ ៦:១៨
១ធថ ២:១
**៤:៧** ត អស ២៦:៣
យហ ១៤:២៧
ថ អភ ៣:១៩

ព្រះគ្រីស្ទយេស៊ូវ។
៨មួយទៀតបងប្អូនអើយ ឯសេចក្តីណាដែលពិត សេចក្តី
ណាដែលគួររាប់អាន សេចក្តីណាដែលសុចរិត សេចក្តី
ណាដែលបរិសុទ្ធ សេចក្តីណាដែលគួរស្រឡាញ់ សេចក្តី
ណាដែលមានឈ្មោះល្អ បើមានសគុណណា ឬជាសេចក្តី
សរសើរណា នោះចូរពិចារណាពីសេចក្តីទាំងនោះចុះ
៩ហើយសេចក្តីអ្វីដែលអ្នករាល់គ្នាបានរៀន បានទទួល បាន
ឮហើយឃើញក្នុងខ្ញុំ នោះចូរឱ្យប្រព្រឹត្តតាមសេចក្តីទាំង
នោះចុះ[ទ] ដូច្នេះព្រះនៃសេចក្តីសុខសាន្ត[ធ] ទ្រង់នឹងគង់នៅ
ជាមួយនឹងអ្នករាល់គ្នា ។

**ការអរព្រះគុណ ចំពោះអំណោយពួកជំនុំភីលីព**

១០ខ្ញុំមានសេចក្តីអំណរជាខ្លាំងក្នុងព្រះអម្ចាស់ ដោយ

**៤:៩** ទ ១ កថ ៤:១៦ ធ រម ១៥:៣៣

**៤:៣** *ជា១នឹងខ្ញុំ. . .គូកនខ្ញុំឯទៀត* ពួកអ្នកទាំងឡាយ(មិនថាប្រុស ឬស្រីឡើយ) ដែលមានទំនាក់ទំនងការងារដំណឹងល្អជាមួយនឹងពួកសាវក សុទ្ធតែជាអ្នកមាន ភាពស្មើគ្នានឹងប៉ុល គឺមិនមែនជាអ្នកនៅក្រោមដំណែងគាត់ឡើយ (ភល ២:២៥ រម ១៦:៣,២១ ភម ២៤) ។ *អ្នកក្លេមេន* មិនមានបញ្ជាក់នៅកន្លែងដទៃទៀតនៃព្រះគម្ពីរសញ្ញាថ្មីឡើយ ។ *គូកនខ្ញុំឯទៀត* គឺមិនបាននិយាយលំអិតពីម្នាក់ៗទេ ព្រោះព្រះទ្រង់ស្គាល់ពួកគេ ហើយឈ្មោះរបស់ពួកគេក៏បានកត់ចូលទៅក្នុងបញ្ជីជីវិត ដែលជាការចុះឈ្មោះរបស់ពួកអ្នករើសតាំងចូលក្នុងនគរព្រះ ។

**៤:៤** *ចូរអរសប្បាយក្នុងព្រះអម្ចាស់* មើល ៣:១ ។ *ជានិច្ច* គឺទោះជាស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ ដែលរួមមានការរងទុក្ខលំបាកជាដើម(ហព ៣:១៧–១៨ យក ១:២ ១ពត ៤:១៣)។

**៤:៥** *សេចក្តីសំឡូត* គឺជាលក្ខណៈនៃការមានគំនិតគិតដូចជាព្រះគ្រីស្ទចំពោះអ្នកដទៃ ដោយការពិចារណាមើលគ្នាទៅវិញទៅមកជាដើម (មើល ២កថ ១០:១ ហព ១០:២៤) ហើយការនោះមានសារៈប្រយោជន៍ណាស់ចំពោះអ្នកដឹកនាំពួកជំនុំ (១ធថ ៣:៣ ទត ៣:២ "ការពិចារណាមើលអ្នកដទៃ")។ *ជិតដល់ហើយ* (មើល រម ១៣:១១ យក ៥:៨–៩ វវ ២២:៧,១២,២០) គឺជាព្រឹត្តិការណ៍ដ៏អស្ចារ្យដែលនឹងកើតឡើងនៅពេលខាងមុខ និងមាននៅក្នុងការកំណត់ពេលរបស់ព្រះ ដែលមានជាទំនាយពីការយាងត្រឡប់នៃព្រះគ្រីស្ទ ។ មួយរយៈពេលពេញគឺចាប់តាំងពីការយាងមកជាលើកទីមួយនៃព្រះគ្រីស្ទរហូតដល់ការមកដល់នៃនគរព្រះដែលមានការបកស្រាយក្នុងព្រះគម្ពីរសញ្ញាថ្មីថា ជាពេលម៉ោងចុងក្រោយ(១យហ ២:១៨) សម្រាប់ព្រះពេលវេលាមួយពាន់ឆ្នាំ គឺប្រៀបបីដូចជារយៈពេលតែមួយថ្ងៃប៉ុណ្ណោះដូចនេះហើយ បានជាមានការបកស្រាយថា ចំពោះជំនាន់នីមួយៗរបស់មនុស្សជាតិការយាងត្រឡប់មកវិញនៃព្រះអម្ចាស់ គឺជិតដល់ហើយ ។

**៤:៦** *ខ្វល់ខ្វាយ* គឺការយកអាត្មាខ្លួនឯងជាទីមួយ ហើយដែលព្រួយបារម្ភនោះគឺឥតអាចជួយអ្វីបានដល់ខ្លួនអ្នកដែលខ្វល់ខ្វាយនោះឡើយ ព្រោះមិនមែនជាការព្រួយបារម្ភដែលត្រឹមត្រូវ និងការបារម្ភដល់ការផ្សាយនៃដំណឹងល្អ (ការពន្យល់ ២:២៨ ២កថ ១១:២៨ មថ ៦:២៥–៣១ ១ពត ៥:៧)។ *គ្រប់ការទាំងអស់ដោយ សេចក្តីអធិស្ឋាន* ការអធិស្ឋាននិងការខ្វល់ខ្វាយគឺជាមហាកម្លាំងប្រឆាំងគ្នាទាំងពីរ ដែលកើតឡើងក្នុងជីវិតគ្រីស្ទបរិស័ទ ។ *អរព្រះគុណ* (ទន្ទឹមគ្នានឹងការអធិស្ឋាន និងពាក្យទូលអង្វរ) គឺជាថ្នាំបន្សាបការព្រួយបារម្ភ ។

**៤:៧** *សេចក្តីសុខសាន្តរបស់ព្រះ* ជាសេចក្តីស្ងប់សុខខាងផ្លូវចិត្ត ដែលអាស្រ័យទៅលើសេចក្តីសុខសាន្ត ដែលមនុស្សយើងមានជាមួយព្រះអម្ចាស់ក្នុងកាលដែលបានទទួលការអត់ទោសបាបហើយ (យហ ១៤:២៧ រម ៥:១)។ គឺជាពាក្យផ្ទុយនឹងពាក្យខ្វល់ខ្វាយផងដែរ ដែលជាសេចក្តីស្ងប់សុខដែលមកដល់ នៅពេលដែលអ្នក ជឿបានថ្វាយដាច់គ្រប់បញ្ហាទាំងអស់ដែលធ្វើឱ្យព្រួយបារម្ភនោះទៅចំពោះព្រះ ដោយការអធិស្ឋាន ហើយលែងមានការព្រួយបារម្ភតទៅទៀត ។ *ហួសលើសពី អស់ទាំងគំនិត* (អភ ៣:១៨–២០)។ *ជួយការពារចិត្ត. . .គំនិត* គឺជាអត្ថន័យតាមទាហានដែលអធិប្បាយពីការចាត់អ្នកយាមឱ្យនៅការពារ ។ "ការថែរក្សាការពារ"របស់ផងព្រះចំពោះអ្នកដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ គឺពង្រីកចូលទៅដល់ស្នូលកណ្តាលនិងបំណងប្រាថ្នាដ៏ជ្រាលជ្រៅបំផុតរបស់ពួកគេម្នាក់ៗ (១ពត ១:៥)។

**៤:៨** *មួយទៀត* មើលការពន្យល់ ៣:១ ។ *ពិត. . .សេចក្តីសរសើរណា* លោកប៉ុល ស្គាល់ពីសេចក្តីដែលថា ការគិតរបស់មនុស្សម្នាក់ៗ មានឥទ្ធិពលមកលើជីវិតរបស់ពួកគេ ។ កាលណាមនុស្សម្នាក់បានអនុញ្ញាតិ ឱ្យសេចក្តីអ្វីមកកាន់កាប់ត្រួតត្រាចិត្តរបស់ខ្លួនឯងហើយ មិនយូរមិនឆាប់សេចក្តីនោះនឹងក្លាយទៅជាកត្តាកំណត់របស់ការនិយាយស្តី និងការប្រព្រិត្តរបស់អ្នកនោះជាប្រាកដ ។ បន្ទាប់ពីមានការលើកទឹកចិត្តឱ្យ "ពិចារណាពីសេចក្តីទាំងនោះ" ហើយលោកប៉ុលមានការលើកទឹកចិត្តទីពីរទៀត គឺ"ឱ្យប្រព្រឹត្តតាមសេចក្តីទាំងនោះ"ផង(ខ.៩)។ គុណធម៌ទាំងឡាយ ដែលមានរាយរាប់នៅក្នុង ខ.៨–៩ ពិតជានឹងនាំឱ្យមាននូវគំនិតដែលត្រឹមត្រូវ ហើយគំនិតនោះនឹងធ្វើឱ្យជីវិតរស់នៅមានសីលធម៌ និងគ្រប់លក្ខណ៍ខាងឯព្រលឹងវិញ្ញាណ ។

**៤:៩** *ឃើញក្នុងខ្ញុំ* មើលការពន្យល់ ៣:១៧ ។ *ព្រះនៃសេចក្តីសុខសាន្ត* មើលពន្យល់ ១ធថ ៥:២៣ ធៀបទៅនឹង"សេចក្តីសុខសាន្តនៃព្រះ"ក្នុងខ.៧ ។

**៤:១០** *ព្រោះឥឡូវនេះ. . .តែរកឱកាសគ្មាន* ការយឺតយាវក្នុងការបញ្ជូនអំណោយទៅសាវកប៉ុលពុំមែនជាកំហុសរបស់ពួកក្រុងភីលីព ឬដោយព្រោះពួកគេខ្វះការគិតគូរដល់គាត់នោះឡើយ(២កថ ១១:៩)។ ការដែលពួកក្រុង

ព្រោះឥឡូវនេះ អ្នករាល់គ្នាបាននឹកដល់ខ្ញុំឡើងវិញ អ្នក
រាល់គ្នាបាននឹកដល់ខ្ញុំជានិច្ចដែរ តែរកឱកាសគ្មាន[ន] ១១ ខ្ញុំ
និយាយដូច្នេះ មិនមែនដោយខ្ញុំខ្វះខាតទេ ដ្បិតខ្ញុំបានរៀនឱ្យ
មានសេចក្តីសន្តោសក្នុងសណ្ឋានគ្រប់យ៉ាង[ប] ១២ ខ្ញុំធ្លាប់ទ្រាំ
ឱ្យមានសេចក្តីចង្អៀតចង្អល់ ហើយក៏ធ្លាប់មានសេចក្តី
រីករាយដែរ ខ្ញុំធ្លាប់ទាំងឆ្អែត ទាំងឃ្លាន[ផ] ទាំងមាន ទាំងខ្វះ
ក្នុងសារពើទាំងអស់ហើយ[ព] ១៣ ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់
បានដោយសារព្រះគ្រីស្ទដែលទ្រង់ចំរើនកំឡាំងដល់ខ្ញុំ[ភ]
១៤ ប៉ុន្តែ ដែលអ្នករាល់គ្នាបានជួយដល់សេចក្តីកំសត់របស់ខ្ញុំ
នោះប្រពៃហើយ[ម]។
១៥ ឱពួកក្រុងភីលីពអើយ អ្នករាល់គ្នាក៏ដឹងថា កាលចាប់
ប្រារព្ធ[យ]ប្រកាសដំណឹងល្អ ដែលខ្ញុំទើបនឹងចេញពីស្រុក
ម៉ាសេដូនមក[រ] នោះគ្មានពួកជំនុំណាបានប្រកបនឹងខ្ញុំ អំពី
ដំណើរប្រាក់ចំណាយចំណូលឡើយ មានតែអ្នករាល់គ្នា
ប៉ុណ្ណោះ[ល] ១៦ ដ្បិតកាលខ្ញុំខ្វះខាតនៅថែស្សាឡូនីច[វ] នោះ
អ្នករាល់គ្នាបានផ្ញើទៅជួយខ្ញុំម្តងពីរដងផង[ស] ១៧ មិនមែន
ថាខ្ញុំរកចង់បានទានទេ ខ្ញុំរកតែផលដែលចំរើនប្រ
យោជន៍ដល់អ្នករាល់គ្នាវិញ[ហ] ១៨ ខ្ញុំមានគ្រប់គ្រាន់ទាំងអស់
ហើយក៏បរិបូរផង ខ្ញុំបានពោរពេញហើយ ដោយ
បានទទួលរបស់ទាំងប៉ុន្មានពីអេបាប្រូឌីត[ឡ] ដែលអ្នករាល់
គ្នាផ្ញើទៅខ្ញុំនោះ គឺជាក្លិនឈ្ងុយ[អ] ជាគ្រឿងបូជាដែល
ព្រះ ទ្រង់ទទួលហើយសព្វព្រះហឫទ័យដែរ ១៩ ព្រះនៃខ្ញុំ
ទ្រង់ នឹងបំពេញគ្រប់ទាំងអស់ ដែលអ្នករាល់គ្នាត្រូវការ[ក]
តាម ភោគសម្បត្តិនៃទ្រង់ដ៏ឧត្តម[ខ] ក្នុងព្រះគ្រីស្ទយេស៊ូវ
២០ សូមឱ្យព្រះដ៏ជាព្រះវរបិតា[គ]នៃយើងរាល់គ្នាបានសិរីល្អ

**៤:១០** ន ២កថ ១១:៩
**៤:១១** ប ១ធថ ៦:៦,៨ ហព ១៣:៥
**៤:១២** ផ ១កថ ៤:១១ ព ២កថ ១១:៩
**៤:១៣** ភ ២កថ ១២:៩ អភ ៣:១៦ កល ១:១១ ១ធថ ១:១២, ២ធថ ៤:១៧
**៤:១៤** ម ភល ១:៧
**៤:១៥** យ ភល ១:៥ រ កថ ១៦:៩
ល ២កថ ១១:៨,៩
**៤:១៦** វ កថ ១៧:១ ស ១ថន ២:៩ **៤:១៧** ហ ១កថ :១១,១២
**៤:១៨** ឡ ភល ២:២៥ អ ២កថ ២:១៤ **៤:១៩** ក ទដ ២៣:១ ២កថ ៩:៨
ខ រម ២:៤ **៤:២០** គ កទ ១:៤ ១ថន ១:៣ ៣:១១,៣ ឃ រម ១១:៣៦

ភីលីពមិនអាចបង្ហាញពីការគិតគូរនេះ ប្រហែលជាបណ្តាលមកពីគាត់មិនមានគម្រោងធ្វើដំណើរច្បាស់លាស់ មុនពេលដែលគាត់មកដល់ក្រុងរ៉ូម ឬប្រហែលមកពីខ្វះអ្នកនាំសារ ។

**៤:១១** *សេចក្តីសន្តោសក្នុងសណ្ឋានគ្រប់យ៉ាង* សាវកប៉ុលប្រាកដជាបានកោតសរសើរយ៉ាងខ្លាំងចំពោះអំណោយ ដែលពួកក្រុងភីលីពបានធ្វើសម្រាប់គាត់ (ខ.១៤:១៨) ប៉ុន្តែ គាត់មិនបានពឹងអាងលើជំនួយទាំងនោះជាទីមួយឡើយ(១ធថ ៦:៦–៨)។

**៤:១២** *ធ្លាប់មានសេចក្តីរីករាយ. . .ទាំងឆ្អែត. . .ក្នុងសារពើទាំងអស់* ភាពសម្បូរណ៍សប្បាយ ក៏អាចជាប្រភពនៃការមិនស្កប់ស្កល់ចិត្តផងដែរ ។

**៤:១៣** *គ្រប់ទាំងអស់* គឺគ្រប់អ្វីៗទាំងអស់ដែលព្រះទ្រង់សព្វព្រះទ័យឱ្យធ្វើ ។ *ព្រះគ្រីស្ទដែលទ្រង់ចំរើនកំលាំងដល់ខ្ញុំ* ការប្រកបជាមួយនឹងព្រះគ្រីស្ទ ជាព្រះដ៏មានព្រះជន្មរស់ ហើយបានដំកើងឡើង គឺជាអាថ៌កំបាំងនៃការដែលធ្វើឱ្យស្កប់ស្កល់ចិត្ត(ខ.១២) ហើយជាប្រភពនៃកម្លាំងដែលសាវ័កប៉ុល លោកមានជាប់ជានិច្ច(ជាពិសេសក្នុង ២កថ ១២:៩–១០ យហ ១៥:៥ អភ ៣:១៦–១៧ កល ១:១១)។

**៤:១៤** *ជួយដល់* អំណោយ និងការអធិស្ឋានរបស់ពួកជំនុំនៅក្រុងភីលីពគឺជាជំនួយនិងជាការរួមចំណែករបស់ពួកគេក្នុងសេចក្តីកំសត់របស់លោកប៉ុល (ហព ១០:៣៣)។

**៤:១៥** *កាលចាប់ប្រារព្ធ* ក្នុងអំឡុងពេលនៃដំណើរបេសកកម្មលើកទីពីររបស់លោកប៉ុល(កថ ១៦:១២–៤០)។ *ចេញពី* គឺចេញពីស្រុកម៉ាសេដូនទៅកាន់តំបន់ភាគខាងត្បូង(គឺស្រុកអាខៃ ដែលគេសំដៅទៅលើទឹកដីទាំងមូលនៃប្រទេសក្រិក សម័យចក្រភពរ៉ូម៉ាំង) ជាតំបន់ដែលក្រុងអាថែន និងក្រុងកូរិនថូសស្ថិតនៅ (កថ ១៧:១៤–១៦ ១៨:១–៤)។ *ម៉ាសេដូន* ស្ថិតនៅភូមិភាគខាងជើងនៃប្រទេសក្រិកបច្ចុប្បន្ន ជាទីតាំងរបស់ក្រុងបេរា ក្រុងថែស្សាឡូនីច ព្រមទាំងក្រុងភីលីពផង ។ *ប្រកបនឹងខ្ញុំ អំពីដំណើរ* លោកប៉ុលបានបកស្រាយអំពី "ប្រាក់ចំណាយចំណូល" រវាងខ្លួនគាត់ និងពួកជំនុំនៅក្រុងភីលីពដោយប្រើភាសាពាណិជ្ជកម្ម (មើល "ផលដែលចម្រើនប្រយោជន៍ដល់អ្នករាល់គ្នា" ក្នុង ខ.១៧) ប៉ុន្តែ ថ្វីត្បិតតែវាជាការនឹកគិតតាមបែបពាណិជ្ជកម្មក៏វានៅតែមានន័យលើសពីនោះទៅទៀត ដោយសារនៅក្នុងការប្រកបទាក់ទងរបស់ពួកគេ វាជាការគិតគូរដល់គ្នាទៅវិញទៅមក និងជាការលះបង់អាត្មាខ្លួនឯង ។ *មានតែអ្នករាល់គ្នាប៉ុណ្ណោះ* សេចក្តីសប្បុរសរបស់ពួកជំនុំក្រុងភីលីពមានលក្ខណៈពិសេសផ្សេងពីគេ ហើយល្អលើសលប់ជាងគេទៀតផង(២កថ ៨:១–៥)។

**៤:១៦** *កាលខ្ញុំខ្វះខាតនៅថែស្សាឡូនីច* (កថ ១៧:១–៩)។ *បានផ្ញើទៅជួយខ្ញុំម្តងពីរដងផង* អំណោយផ្ញើទៅក្រុងរ៉ូមតាមរយៈលោកអេបាប្រាសគឺជាគំរូនៃជំនួយសប្បុរសធម៌ដែលមានរយៈពេលវែងនិងឋិតថេរ (២កថ ៨:១-៥)។

**៤:១៧** *ផលដែលចំរើនប្រយោជន៍ដល់អ្នករាល់គ្នា* (មើលការពន្យល់ ខ.១៥) "តម្លៃ"នៃអំណោយរបស់ពួកក្រុងភីលីព មិនមែនជាអ្វីដែលលោកប៉ុលត្រូវតែទទួលបានទេ ប៉ុន្តែ វាបង្ហាញអំពី "ផលកម្រៃខាងវិញ្ញាណ" ដែលពួកគេបានទទួលបាននោះវិញ ។

**៤:១៨** *ជាក្លិនឈ្ងុយ* ជាគ្រឿងបូជាដែលព្រះទ្រង់ទទួល ហើយតាមអត្ថន័យព្រះគម្ពីរសញ្ញាចាស់ គឺជាការបូជាដែលមិនមែនជាដង្វាយលោះបាបឡើយ តែជាការថ្វាយការអរព្រះគុណ និងការសរសើរ (លវ ៧:១២–១៥ រម ១២:១ អភ ៥:១២ ហព ១៣:១៥–១៦)។ *ដែលព្រះទ្រង់ទទួល ហើយសព្វព្រះហឫទ័យ* គឺព្រោះតែព្រះរាជកិច្ចដែលព្រះគ្រីស្ទទ្រង់បានបំពេញ ដើម្បីយើងរាល់គ្នា(១ពត ២:៥) និងការដែលព្រះទ្រង់ធ្វើការក្នុងយើងរាល់គ្នា (ភល ២:៣)។

**៤:១៩** *នៃខ្ញុំ* គឺចង់បកស្រាយអំពីទំនាក់ទំនងផ្ទាល់ខ្លួនរបស់ប៉ុលជាមួយនឹងព្រះ (ធៀបនឹង "ព្រះនៃខ្ញុំ" ក្នុង ១:៣)។ *នឹងបំពេញ* គឺជាការសន្យានឹងពួកជំនុំដែលបានផ្គត់ផ្គង់ដល់តម្រូវការរបស់លោកប៉ុល ។ *ដែលអ្នករាល់គ្នាត្រូវការ* លោកប៉ុលបានគិតគូរមិនត្រឹមតែចំពោះស្ថានភាពរបស់គាត់ឡើយ គឺចំពោះស្ថានភាពរបស់ពួកជំនុំក្រុងភីលីពផងដែរ ។ *ភោគសម្បត្តិនៃទ្រង់ដ៏ឧត្តម ក្នុងព្រះគ្រីស្ទយេស៊ូវ* គឺការប្រទានព្រះពរដ៏ធំធេងដល់ពួកជំនុំក្រុងភីលីព (អភ ១:១៨ ៣:១៦–២០)។

**៤:២០** លោកប៉ុលមិនអាចលាក់ទុកនូវចិត្ត ដែលចង់តែសរសើរតម្កើងដល់ព្រះបានឡើយ ជាពិសេសពេលដែលគាត់បានគិតដល់សេចក្តីពិតក្នុងខ.១៩ ។

នៅអស់កល្បរៀងតទៅ អាម៉ែន[ឃ]។

## ការគួរសមជាលើកចុងក្រោយ

២១ សូមជិរាបសួរ មកពួកបរិសុទ្ធ ក្នុងព្រះគ្រីស្ទយេស៊ូវ
ផង ឯពួកបងប្អូនដែលនៅជាមួយនឹងខ្ញុំ[ង] គេសូមជិរាបសួរ
មកអ្នករាល់គ្នា ២២ ពួកបរិសុទ្ធទាំងអស់គ្នា[ច]មានពួកអ្នកនៅ
ដំណាក់សេសារជាដើម ក៏សូមជិរាបសួរមកអ្នករាល់គ្នា
ដែរ ២៣ សូមឱ្យព្រលឹងវិញ្ញាណអ្នករាល់គ្នា[ឆ] បានប្រកប
ដោយ ព្រះគុណនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ[ជ]។
អាម៉ែន ។

**៤:២១** ង កទ ១:២
**៤:២២** ច កថ ៩:១៣
**៤:២៣** ឆ រម ១៦:២០
ជ កទ ៦:១៨

**៤:២១-២២** ការគួរសមជាលើកចុងក្រោយ គឺជាលក្ខណៈពិសេសនៃការសរសេរសំបុត្ររបស់លោកប៉ុល (រម ១៦:៣-១៦ ២១-២៣ ១កថ ១៦:១៩-២០ ២កថ ១៣:១២-១៣ កល ៤:១០-១២,១៤-១៥,១៨)។

**៤:២១** *ពួកបរិសុទ្ធ* មើលការពន្យល់ ១:១ ។ *ឯពួកបងប្អូនដែលនៅជាមួយនឹងខ្ញុំ* គឺគូកនការងាររបស់សាវ័កប៉ុលនៅក្រុងរ៉ូមជាពិសេសគឺលោកធីម៉ូថេ (១:១,១៤,១៦)។

**៤:២២** *ពួកអ្នកនៅដំណាក់សេសារ* គឺជាពួកអ្នកដែលត្រូវបានជួល (ជាទាសករ ឬអ្នកដែលរួចពីទាសភាព) ឱ្យធ្វើការនៅក្នុង ឬជុំវិញបរិវេណវាំង ("អ្នកយាមវាំង" ១:១៣) គឺមិនមែនញាតិវង្សានុវង្សរបស់ស្តេចសេសារនោះឡើយ ។

**៤:២៣** ការដែលសាវ័កប៉ុលជូនពរនេះ គឺជារបៀបបញ្ចប់សំបុត្រទាំងមូលរបស់គាត់ ។ *ព្រះគុណ* មើលពន្យល់ រម ១:៧ ។ *ព្រលឹងវិញ្ញាណអ្នករាល់គ្នា* គឺសំដៅទៅលើជីវិតមនុស្សម្នាក់ៗទាំងមូល (គឺមានលក្ខណៈនៃមនុស្សម្នាក់ទាំងស្រុង) (កទ ៦:១៨ ២ធថ ៤:២២ ភម ២៥)។

# សំបុត្ររបស់លោកប៉ុល
## ដល់ពួក
# កូល៉ុស

សេចក្ដីផ្ដើម

**អ្នកនិពន្ធ កាលបរិច្ឆេទ និងទីកន្លែងនិពន្ធ**

កណ្ឌគម្ពីរកូល៉ុសគឺជាសំបុត្ររបស់លោកប៉ុលយ៉ាងពិតប្រាកដ (កល ១:១) ហើយក៏មិនមានការជជែកអំពីភាពជាអ្នកនិពន្ធរបស់គាត់ដែរ ។ ពួកជំនុំដំបូងបានបញ្ជាក់ថា លោកប៉ុលគឺជាអ្នកនិពន្ធកណ្ឌគម្ពីរកូល៉ុស ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅសតវត្សរ៍ទី១៩គ.ស អ្នកខ្លះគិតថា មានពួកអ្នកប្រឆាំងបានចោទថា បទគម្ពីរកូល៉ុសជំពូក២គឺជាសេចក្ដីនៃចំណេះនៅសតវត្សរ៍ទី២គ.សវិញ ។ ប៉ុន្ដែ បើធ្វើការវិភាគជំពូក២ដោយយកចិត្ដទុកដាក់បង្ហាញថា ការចោទប្រកាន់របស់ពួកប្រឆាំងនៅត្រង់ចំណុចនេះមិនត្រឹមត្រូវទេ ព្រោះថា សេចក្ដីបង្រៀននៃចំណេះរបស់ពួកគ្រូបង្រៀននាសតវត្សរ៍ទី២និងទី៣ មានការអភិវឌ្ឍន៍ជាង ។ ម្យ៉ាងទៀត ឫសគល់នៃការរីកដុះដាលនៃចំណេះ នាសតវត្សរ៍ទី២ ត្រូវបានចាប់ផ្ដើមឡើងនៅសតវត្សរ៍ ទី១ ហើយបានជ្រៀតចូលនៅក្នុងពួកជំនុំរួចស្រេចទៅហើយ ។ ជាលទ្ធផល ការដែលសន្មតថា កណ្ឌគម្ពីរកូល៉ុសត្រូវបានសរសេរឡើងនៅ សតវត្សរ៍ទី២មិនត្រឹមត្រូវទេ ។

ដូច្នេះ កណ្ឌគម្ពីរនេះត្រូវបានសរសេរឡើងក្នុងអំឡុងពេល២ឆ្នាំ ដែលលោកប៉ុលស្ថិតនៅក្នុងគុក នៅឯទីក្រុងរ៉ូម (កច ២៨:១៦-៣១) ។ មានអ្នកខ្លះជំទាស់ថា លោកប៉ុលសរសេរសំបុត្រកូល៉ុសនេះនៅឯទីក្រុងអេភេសូរ ឬសេសារា ប៉ុន្ដែ មានភស្ដុតាងជាច្រើនបញ្ជាក់ថា គាត់សរសេរ សំបុត្រនេះនៅឯទីក្រុងរ៉ូម ជាកន្លែងដែលគាត់សរសេរសំបុត្រជាច្រើនទៀតដោយបានបញ្ជាក់ថា គាត់ជាអ្នកជាប់គុក (អេភេសូរ កូល៉ុស ភីលីព និងភីលេម៉ូន)។ កណ្ឌគម្ពីរកូល៉ុសត្រូវបានកំណត់យកកាលបរិច្ឆេទឆ្នាំទី៦០គ.ស គឺដូចគ្នានឹងសំបុត្រអេភេសូរ និងសំបុត្រភីលេម៉ូនដែរ ។

**កូល៉ុសៈ ទីក្រុង និងពួកជំនុំ**

កាលពីពីរឬបីរយឆ្នាំមុនសម័យកាលលោកប៉ុល ទីក្រុងកូល៉ុសជាទីក្រុងសំខាន់មួយនៅអាស៊ីមីន័រ (Asia Minor សព្វថ្ងៃនៅប្រទេសទួរគី)។ ទីក្រុងនេះតាំងនៅតាមបណ្ដោយទន្លេលីគូស (Lycus River) និងស្ថិតនៅតាមបណ្ដោយផ្លូវពាណិជ្ជកម្មធំមួយ ភ្ជាប់ពីទីក្រុងអេភេសូរដែលស្ថិតនៅក្បែរសមុទ្រអេជីន (Aegean Sea)។ នៅសតវត្សរ៍ទី១ គ.ស ទីក្រុងកូល៉ុសត្រូវបានធ្លាក់មកនៅជាទីក្រុងលំដាប់ថ្នាក់ទីពីរ ផ្នែកទីផ្សារ ដែលពីមុន ធ្លាប់មានឥទ្ធិពលលើទីក្រុងជុំវិញដូចជា ទីក្រុងឡៅឌីសេ និងទីក្រុងហេរ៉ាប៉ូល (៤:១៣)។

ការដែលធ្វើឱ្យកណ្ឌគម្ពីរកូល៉ុសមានសារៈសំខាន់នៅក្នុងសញ្ញាថ្មី គឺនៅក្នុងអំឡុងពេលបីឆ្នាំ ដែលលោកប៉ុលបំពេញបេសកកម្ម នៅទីក្រុងអេភេសូរ លោកអេប៉ាប្រាសបានប្រែចិត្ដទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ ហើយបាននាំដំណឹងល្អទៅឯទីក្រុងកូល៉ុស (១:៧-៨ កច ១៩:១០)។ ជាលទ្ធផល ពួកជំនុំថ្មីមួយបានចាប់ផ្ដើម ហើយក៏បានក្លាយជាមុខសញ្ញាមួយនៃការបៀតបៀនពីសំណាក់ពួកប្រឆាំង ។ ដូច្នោះហើយបានជាធ្វើឱ្យ លោកអេប៉ាប្រាសធ្វើដំណើរទៅជួបលោកប៉ុលនៅទីក្រុងរ៉ូម ហើយលោកប៉ុលក៏សរសេរជាសំបុត្រកូល៉ុសនេះឡើង ។

អាចដោយសារលទ្ធផលនៃការខំប្រឹងរបស់លោកអេប៉ាប្រាស និងពួកអ្នកជឿដទៃទៀតតាមរយៈលោកប៉ុល ទើបធ្វើឱ្យពួកជំនុំនៅទីក្រុងឡៅឌីសេ និងទីក្រុងហេរ៉ាប៉ូលបានចាប់ផ្ដើមកើតឡើង ។ ពួកជំនុំមួយចំនួន គឺប្រជុំគ្នានៅតាមផ្ទះ (៤:១៥ ភម ២)។ ជាទូទៅ ពួកអ្នកជឿភាគច្រើន គឺជាសាសន៍ដទៃ ។

**ពួកអ្នកប្រឆាំងនៅទីក្រុងកូល៉ុស**

លោកប៉ុលមិនបានបញ្ជាក់ត្រង់ៗតែម្ដង អំពីការប្រឆាំងនៅក្នុងសំបុត្ររបស់គាត់ ចំពោះសេចក្ដីបង្រៀនខុសឆ្គងទេ ។ តាមការធ្វើវិភាគទៅលើការប្រឆាំងទាំងនោះបង្ហាញថា ពួកប្រឆាំងមានលក្ខណៈផ្សេងៗពីគ្នា មានដូចជាៈ

១. ការប្រតិបត្ដិតាមពិធីបុណ្យផ្សេងៗៈ គឺការប្រកាន់យកនូវបញ្ញត្ដិដ៏តឹងរ៉ឹងអំពីប្រភេទនៃអាហារ ពិធីបុណ្យសាសនា(២:១៦-១៧) និងការកាត់ស្បែក (២:១១ ៣:១១)។

២. ការឥតប្រណីដល់រូបកាយ (ការធ្វើទារុណកម្មលើរូបកាយ)ៈ "មិនឱ្យកាន់" "មិនឱ្យភ្លក់" និង "មិនឱ្យប៉ះ" (២:២១ ប្រៀបធៀប ២៣)។

៣. ការថ្វាយបង្គំទេវតា (២:១៨)។

៤. ការមិនឱ្យតម្លៃព្រះគ្រីស្ទៈ ការនេះបញ្ជាក់យ៉ាងច្បាស់ ត្រង់ចំណុចដែលលោកប៉ុលបញ្ជាក់អំពីភាពជាព្រះដ៏មានអំណាចព្រះចេស្ដារបស់ព្រះយេស៊ូវគ្រីស្ទ (១:១៥-២០ ២:២-៣,៩)។

៥. ចំណេះអាថ៌កំបាំងៈ ពួកអ្នកប្រឆាំងតែងតែអួតអំពីការនេះ ។ លោកប៉ុលបញ្ជាក់យ៉ាងច្បាស់ថា គ្រប់ទាំងផលផ្លែវិសេសនៃប្រាជ្ញា

និងសេចក្ដីចេះដឹង លាក់ទុកនៅក្នុងព្រះគ្រីស្ទ (២:២-៣,១៨)។

៦. ការពឹងអាងលើប្រាជ្ញា និងទំនៀមទម្លាប់របស់មនុស្ស (២:៤,៨)។

កត្តាទាំងនេះហាក់ដូចជាបែងចែកជាពីក្រុមទៀតគឺ ពួកសាសន៍យូដា និងពួកអ្នកប្រឆាំងដែលអាងលើចំណេះ ។ ដូច្នេះ បញ្ជាក់ថា ពួកអ្នកប្រឆាំងនៅទីក្រុងកូល៉ុស បានដាក់បញ្ចូលគ្នានូវគោលលទ្ធិសាសនាយូដា និងចំណេះដឹងថ្មីៗទៀត ដើម្បីប្រឆាំងនឹងពួកជំនុំនៅក្នុងទីក្រុងនេះ (សូមមើលសេចក្ដីផ្ដើម ១យហ និងការពន្យល់ ២យហ ៩)។

**គោលបំណង និងគោលរឿង**

គោលបំណងសំខាន់របស់លោកប៉ុលគឺ ប្រឆាំងនឹងពួកគ្រូខុសឆ្គងនៅទីក្រុងកូល៉ុស ។ ដើម្បីឱ្យបានជោគជ័យ លោកប៉ុលបានលើកព្រះគ្រីស្ទ ថាជារូបអង្គនៃព្រះដ៏ពិត (១:១៥) ជាព្រះអាទិករ (១:១៦) ជាព្រះដែលគង់នៅមុនទាំងអស់ (១:១៧) ជាសិរសាររបស់ពួកជំនុំ (១:១៨) បានរស់ពីស្លាប់ឡើងវិញមុនគេបង្អស់ (១:១៨) គ្រប់ទាំងសេចក្ដីពោរពេញបានស្ថិតនៅក្នុងទ្រង់ (១:១៩ ២:៩) និងបានផ្សះផ្សាគ្រប់ទាំងអស់ (១:២០-២២)។ ដូច្នេះព្រះគ្រីស្ទគឺគ្រប់គ្រាន់សម្រាប់ពួកគេ ។ មានន័យថា យើងបានទទួលនូវសេចក្ដីពោរពេញនៅក្នុងព្រះគ្រីស្ទ (២:១០)។ ផ្ទុយទៅវិញ សេចក្ដីបង្រៀនរបស់ពួកអ្នកប្រឆាំងនៅទីក្រុងកូល៉ុស គឺគ្មានប្រយោជន៍អ្វីទាំងអស់ គឺគ្រាន់តែជាទស្សនវិជ្ជាខុសឆ្គង និងគ្មានតម្លៃតែប៉ុណ្ណោះ (២:៨) ហើយ មិនអាចជួយឱ្យពួកគេបានរួចផុតពីនិស្ស័យនៃអំពើបាបទេ (២:២៣)។

គោលរឿងសំខាន់នៃសំបុត្រកូល៉ុស គឺភាពគ្រប់គ្រាន់ពេញលេញនៃព្រះគ្រីស្ទ ផ្ទុយពីទស្សនវិជ្ជារបស់មនុស្សដែលគ្មានអ្វីទាំងអស់ ។

**គម្រោងសង្ខេប**

**I. សេចក្ដីផ្ដើម (១:១-១៤)**

ក. ពាក្យជម្រាបសួរ (១:១-២)

ខ. ការអរព្រះគុណ (១:៣-៨)

គ. សេចក្ដីអធិស្ឋាន (១:៩-១៤)

**II. ព្រះចេស្ដារបស់ព្រះគ្រីស្ទ (១:១៥-២៣)**

**III. ការងាររបស់លោកប៉ុល សម្រាប់ពួកជំនុំ (១:២៤-២:៧)**

ក. ការបម្រើរបស់លោកប៉ុលសម្រាប់ពួកជំនុំ (១:២៤-២៩)

ខ. ការបារម្ភរបស់លោកប៉ុលចំពោះអ្នកអានសំបុត្ររបស់គាត់អំពីសង្គ្រាមខាងវិញ្ញាណ (២:១-៧)

**IV. សេរីភាពពីច្បាប់ទម្លាប់របស់មនុស្សតាមរយៈជីវិតនៅក្នុងព្រះគ្រីស្ទ (២:៨-២៣)**

ក. ការព្រមានឱ្យប្រុងប្រយ័ត្នចំពោះពួកគ្រូខុសឆ្គង (២:៨-១៥)

ខ. ការស្នើសូមឱ្យបដិសេធពួកគ្រូខុសឆ្គង (២:១៦-១៩)

គ. ការវិភាគអំពីពួកអ្នកប្រឆាំង (២:២០-២៣)

**V. បញ្ញត្តិសម្រាប់ការរស់នៅដោយបរិសុទ្ធ (៣:១-៤:៦)**

ក. មនុស្សចាស់ និងមនុស្សថ្មី (៣:១-១៧)

ខ. បញ្ញត្តិសម្រាប់គ្រីស្ទបរិស័ទ (៣:១៨-៤:១)

គ. សេចក្ដីទូន្មានផ្សេងៗ (៤:២-៦)

**VI. ការផ្ដាំផ្ញើចុងក្រោយ និងការសូមឱ្យព្រះអម្ចាស់ប្រទានព្រះពរ (៤:៧-១៨)**

**១** ១ សំបុត្រប៉ុលខ្ញុំ ជាសាវក[ក]នៃព្រះយេស៊ូវគ្រីស្ទ ដោយ
នូវព្រះហឫទ័យព្រះ[ខ] ២និងធីម៉ូថេ[គ] ជាបងប្អូនយើងខ្ញុំ ផ្ញើមក
ពួកបរិសុទ្ធ ជាពួកបងប្អូនស្មោះត្រង់ក្នុងព្រះគ្រីស្ទ ដែលនៅ
ក្រុងកូល៉ុស សូមឱ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ[ឃ]
និងសេចក្តីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតានៃយើងរាល់
គ្នា[ង]។

## ការអរព្រះគុណនិងការអធិស្ឋាន

៣យើងខ្ញុំអរព្រះគុណ ដល់ព្រះ[ច]ដ៏ជាព្រះវរបិតា របស់
ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ក៏អធិស្ឋាន
ឱ្យអ្នករាល់គ្នាជានិច្ច ៤ដោយបានឮដំណឹងពីសេចក្តីជំនឿ
ដែលអ្នករាល់គ្នាជឿដល់ព្រះគ្រីស្ទយេស៊ូវ ហើយពីសេចក្តី
ស្រឡាញ់[ឆ] ដែលអ្នករាល់គ្នាមានដល់ពួកបរិសុទ្ធទាំងអស់[ជ]
៥គឺអរព្រះគុណដោយព្រោះសេចក្តីសង្ឃឹម[ឈ] ដែលបំរុង
ទុក[ញ]ឱ្យអ្នករាល់គ្នានៅស្ថានសួគ៌ ជាសេចក្តីសង្ឃឹម ដែល
អ្នករាល់គ្នាបានឮនិយាយ ក្នុងព្រះបន្ទូលដ៏ពិត[ដ]នៃដំណឹងល្អ
៦ដែលបានផ្សាយ មកដល់អ្នករាល់គ្នាហើយ ដូចជាដល់
លោកីយទាំងមូលដែរ[ឋ] ក៏កំពុងតែបង្កើតផល[ឌ] ហើយចំរើន
ឡើងដូចក្នុងពួកអ្នករាល់គ្នា ចាប់តាំងពីថ្ងៃដែលអ្នករាល់គ្នា
បានឮ ហើយស្គាល់ព្រះគុណនៃព្រះជាប្រាកដ ៧តាមដែល
អ្នករាល់គ្នាបានរៀននឹងអេប៉ាប្រាស[ឍ]ជាបាវបំរើស្ងួនភ្ញា ជា
មួយនឹងយើងខ្ញុំ គាត់ជាអ្នកបំរើស្មោះត្រង់[ណ]របស់ព្រះគ្រីស្ទ
សំរាប់អ្នករាល់គ្នា ៨ហើយគាត់បានថ្លែងប្រាប់យើងខ្ញុំពី
សេចក្តីស្រឡាញ់ ដែលអ្នករាល់គ្នាមានដោយនូវព្រះវិញ្ញាណ[ត]

**១:១** ក ១កថ ១:១ ខ ២កថ ១:១ **១:២** គ កច ១៦:១ ឃ កល ៤:១៨ ង រម ១:៧ **១:៣** ច រម ១:៨ **១:៤** ឆ កទ ៥:៦ ជ កច ៩:១៣ អភ ១:១៥ ភម ៥ **១:៥** ឈ ខ.២៣ ១ថន ៥:៨ ទត ១:២ ញ ១ពត ១:៤ ដ ២ធថ ២:១៥ **១:៦** ឋ ខ.២៣ រម ១០:១៨ ឌ យហ ១៥:១៦
**១:៧** ឍ កល ៤:១២ ភម ២៣ ណ កល ៤:៧ **១:៨** ត រម ១៥:៣០

**១:១** *សំបុត្រប៉ុលខ្ញុំ* ត្រង់ចំណុចនេះបញ្ជាក់ថា នៅសម័យនោះ គេមានទម្លាប់ដាក់ឈ្មោះរបស់អ្នកសរសេរ នៅខាងដើមដំបូងនៃសំបុត្រ (សម្រាប់ព័ត៌មានលម្អិតផ្សេងទៀតសូមមើលនៅក្នុង"រម១:១"និងការពន្យល់)។ *ព្រះយេស៊ូវគ្រីស្ទ* លោកប៉ុលតែងតែយកព្រះយេស៊ូវគ្រីស្ទទុកជាទីមួយ នៅក្នុងជីវិតរបស់គាត់ ។ នៅក្នុងសំបុត្ររបស់គាត់ មានប្រើពាក្យថា "ព្រះយេស៊ូវគ្រីស្ទ" ចំនួន ២៩ដង ហើយមានប្រើពាក្យថា "ព្រះអម្ចាស់"ចំនួន៩ដង ។ *ជាសាវក . . . ដោយនូវព្រះហឫទ័យព្រះ* "សូមមើលការពន្យល់ ១កថ ១:១"។

**១:២** *ធីម៉ូថេ* លោកប៉ុលបានបញ្ជាក់ឈ្មោះលោកធីម៉ូថេនៅក្នុងសំបុត្ររបស់គាត់ ដូចជាសំបុត្រ ២កូរិនថូស ភីលីព ១និង២ថែស្សាឡូនីច និងសំបុត្រភីលេម៉ូន ។ ទោះជាឈ្មោះលោកធីម៉ូថេ ត្រូវបានសរសេររួមជាមួយនឹងឈ្មោះរបស់លោកប៉ុល នៅដើមសំបុត្រនេះក៏ដោយ ក៏អ្នកដែលសរសេរសំបុត្រនេះគឺជាលោកប៉ុលតែម្នាក់គត់ (៤:១៨)។ *បរិសុទ្ធ* បញ្ជាក់ថា ការដែលព្រះគ្រីស្ទទ្រង់សុគត គឺសម្រាប់ឱ្យពួកអ្នកដែលរស់នៅទីក្រុងកូល៉ុសបានបរិសុទ្ធដែរ ។ ម្យ៉ាងទៀត ដោយសារតែព្រះរាជកិច្ចនៃព្រះវិញ្ញាណបរិសុទ្ធបានធ្វើឱ្យពួកគេនៅបន្តរស់នៅដោយប្រកាន់ខ្ជាប់នូវភាពបរិសុទ្ធ នៅក្នុងជីវិតរបស់ខ្លួន (សូមមើលការពន្យល់ ភល ១:៣-៤)។ *ពួកបងប្អូនស្មោះត្រង់ក្នុងព្រះគ្រីស្ទ* លោកប៉ុលបានបញ្ជាក់អំពីការរួបរួមខាងឯ វិញ្ញាណនៅក្នុងព្រះគ្រីស្ទរបស់ពួកជំនុំនៅទីក្រុងកូល៉ុសចំនួន១២ដង (អភ ១:១ និងការពន្យល់)។ ដូច្នេះ បញ្ជាក់ថា ការរួបរួមគ្នាជាបងប្អូនមានសារៈសំខាន់ណាស់សម្រាប់ពួកអ្នកជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ ។ *ស្មោះត្រង់* (សូមមើល ១:៧ ៤:៧,៩ និងការពន្យល់)។ *ព្រះគុណ និងសេចក្តីសុខសាន្ត* "មើលការពន្យល់ រម ១:៧"។

**១:៣** *យើងខ្ញុំ* សំដៅលើលោកប៉ុល និងលោកធីម៉ូថេ (ខ.១–២)។ *អរព្រះគុណដល់ព្រះ* ត្រង់ចំណុចនេះបញ្ជាក់ថា គ្រប់សំបុត្ររបស់លោកប៉ុល សុទ្ធតែចាប់ផ្តើមឡើងដោយពាក្យអរព្រះគុណដល់ព្រះអម្ចាស់ (ភល ១:៣–៤) លើកលែងតែសំបុត្រផ្ញើទៅទីក្រុងកាឡាទី១ប៉ុណ្ណោះ ។ ក្នុងកណ្ឌគម្ពីរកូល៉ុស ការអរព្រះគុណគឺការសំខាន់ (ខ.១២ ២:៧ ៣:១៥–១៧ ៤:២)។ ម្យ៉ាងទៀត នៅក្នុងព្រះគម្ពីរបញ្ជាក់យ៉ាងច្បាស់ថា មានតែព្រះអម្ចាស់ប៉ុណ្ណោះដែលទ្រង់ស័ក្តិសមទទួលនូវការសរសើរ និងការអរព្រះគុណ ព្រោះទ្រង់គឺជាប្រភពនៃការទាំងអស់នេះ ។

**១:៤** *ពួកបរិសុទ្ធ* សំដៅលើពួកអ្នកដែលជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ រម ១:៧)។

**១:៥** សេចក្តីគ្រប់លក្ខណ៍បីយ៉ាងរួមមាន សេចក្តីជំនឿ សេចក្តីស្រលាញ់ និងសេចក្តីសង្ឃឹមរបស់គ្រីស្ទបរិស័ទក៏ត្រូវបានកត់ត្រាទុកនៅក្នុងបទគម្ពីរ "រម ៥:២–៥ ១កថ ១៣:១៣ កទ ៥:៥–៦ ១ថន ១:៣ ៥:៨ ហព ១០:២២–២៤"។ *សេចក្តីសង្ឃឹម* មិនមែនជាសេចក្តីសង្ឃឹមដែលមាននៅក្នុងការគិតទេ ប៉ុន្តែគឺជាសេចក្តីសង្ឃឹម ដែលមានការធានាពីព្រះអម្ចាស់ (រម ៥:៥ ទត ១:២ និងការពន្យល់)។ *ព្រះបន្ទូល ដ៏ពិត* សំដៅលើដំណឹងល្អ (អភ ១:១៣ ២ធថ ២:១៥)។

**១:៦** *ដូចជាដល់លោកិយទាំងមូល* ឃ្លានេះគឺជាសេចក្តីប្រៀបធៀប ដែលបញ្ជាក់ថាដំណឹងល្អគឺបានចម្រើនឡើងនៅក្នុងអំឡុងពេលបីទស្សវត្សរ៍ ចាប់ពីថ្ងៃបុណ្យទី៥០ ទៅគ្រប់ទីកន្លែង នៅក្នុងតំបន់គ្រប់គ្រងដោយចក្រភពរ៉ូម (ខ.២៣ រម១:៨ ១០:១៨ ១៦:១៩ និងការពន្យល់)។ លោកប៉ុលបានប្រកាសប្រឆាំងនឹងពួកគ្រូខុសឆ្គងដោយប្រកាសថា ដំណឹល្អមិនមែនគ្រាន់តែសម្រាប់មនុស្ស នៅក្នុងតំបន់របស់ខ្លួនប៉ុណ្ណោះទេ គឺសម្រាប់ពិភពលោកទាំងមូលតែម្តង ។

**១:៧** *អេប៉ាប្រាស* គាត់មានដើមកំណើតនៅទីក្រុងកូល៉ុស ហើយប្រហែលជាអ្នកចាប់ផ្តើមពួកជំនុំនៅក្នុងទីក្រុងនេះ និងជាអ្នកផ្សាយដំណឹងល្អ នៅក្រុងឡៅឌីសេ និងក្រុងហេរ៉ាប៉ូល (៤:១២)។ លោកប៉ុលស្រឡាញ់ពេញចិត្តគាត់ជាខ្លាំង ហើយបានហៅគាត់ថា ជាអ្នកជាប់គុកជាមួយនឹងគាត់ (ភម ២៣) ជាអ្នកបម្រើស្ងួនភ្ងា និងជាអ្នកស្មោះត្រង់របស់ព្រះគ្រីស្ទ ។ លោកអេប៉ាប្រាសអាចជាម្នាក់ដែលផ្តល់ដំណឹង ឱ្យលោកប៉ុលនៅឯទីក្រុងរ៉ូម អំពីបញ្ហាដែលបានកើតឡើងនៅក្នុងពួកជំនុំនៅ ទីក្រុងកាឡាទី ។ ដូច្នេះហើយបានជាលោកប៉ុលសរសរសំបុត្រកាឡាទីនេះ ទៅពួកជំនុំនៅទីក្រុងកាឡាទី (ខ.៤,៨)។ ឈ្មោះរបស់គាត់ គឺជាទម្រង់ខ្លីរបស់ពាក្យថា "អេប៉ាប្រូឌីតុស" (ជាទម្រង់ខ្លីរបស់ពាក្យ "អាប្រូឌីត" ដែលជារូបព្រះតំណាងឱ្យ សេចក្តីស្រឡាញ់របស់សាសន៍ក្រេក) ដូច្នេះអាចសន្មតថា គាត់គឺជាអ្នកជឿជា សាសន៍ដទៃម្នាក់ ។ គាត់មិនមែនម្នាក់នៅក្នុង "ភល ២:២៥ ៤:១៨"ទេ ។

**១:៨** *សេចក្តីស្រឡាញ់ ដែលអ្នករាល់គ្នាមានដោយនូវព្រះវិញ្ញាណ* មានន័យថា ព្រះវិញ្ញាណបរិសុទ្ធ គឺជាប្រភពនៃសេចក្តីស្រឡាញ់របស់គ្រីស្ទបរិស័ទ

៩ហេតុនោះ ចាប់តាំងពីថ្ងៃ ដែលយើងខ្ញុំឮនិយាយ[ថ] នោះ
យើងខ្ញុំក៏អធិស្ឋានឱ្យអ្នករាល់គ្នាឥតឈប់ឈរ[ទ] ហើយទូល
សូម ឱ្យអ្នករាល់គ្នាបានស្គាល់ព្រះហឫទ័យទ្រង់សព្វ គ្រប់[ធ]
ដោយគ្រប់ទាំងប្រាជ្ញា នឹងចំណេះខាងឯវិញ្ញាណ[ន]
១០ដើម្បីឱ្យបានដើរបែបគួរ[ប]នឹងព្រះអម្ចាស់ ទាំងគាប់ចិត្ត
ដល់មនុស្សទាំងអស់[ផ] ឱ្យបានបង្កើតផលក្នុងគ្រប់ទាំងការល្អ
ហើយឱ្យស្គាល់ព្រះកាន់តែច្បាស់ឡើង[ព] ១១ដោយបានគ្រប់
ទាំងព្រះចេស្ដា[ភ]ចំរើនកំឡាំង តាមឫទ្ធិបារមីដ៏ឧត្ដមរបស់
ទ្រង់ ដើម្បីឱ្យបានចេះទ្រាំទ្រ ហើយអត់ធន់គ្រប់យ៉ាង[ម]ដោយ
អំណរ ១២ព្រមទាំងអរព្រះគុណ ដល់ព្រះវរបិតា[យ]ដែលទ្រង់
បានប្រោស ឱ្យយើងបានគួរ និងទទួលចំណែកកេរ្ដិ៍អាករ[រ]
ក្នុងពួកបរិសុទ្ធនៅទីភ្លឺផង[ល] ១៣ទ្រង់បានប្រោសឱ្យយើងរួចពី
អំណាចនៃសេចក្ដីងងឹត[វ] ហើយផ្លាស់យើងមកក្នុងនគរ[ស]
របស់ព្រះរាជបុត្រាស្ងួនភ្ងានៃទ្រង់[ហ] ១៤យើងរាល់គ្នាមាន
សេចក្ដីប្រោសលោះ[ឡ]ក្នុងព្រះរាជបុត្រានោះ គឺជាសេចក្ដី
ផ្ដាច់បាប ដោយសារព្រះលោហិតទ្រង់[អ]។

**១:៩** ថ ខ.៤
អភ ១:១៥
ទ រម ១:១០
ធ អភ ៥:១៧
ន អភ ១:១៧
**១:១០** ប អភ ៤:១
ផ ២កថ ៥:៩ ព ខ.៦
ព ខ.៦
**១:១១** ភ ភល ៤:១៣
ម អភ ៤:២
**១:១២** យ អភ ៥:២០
រ កច ២០:៣២
ល កច ២៦:១៨
**១:១៣** វ កច ២៦:១៨
ស ២ពត ១:១១
ហ មថ ៣:១៧
**១:១៤** ឡ រម ៣:២៤
អ អភ ១:៧
**១:១៥** ក យហ ១៤:៩
ខ យហ ១:១៨
១ធថ ១:១៧

## ភាពខ្ពស់បំផុតនៃព្រះគ្រីស្ទ

១៥ដែលទ្រង់ជារូបអង្គ[ក]នៃព្រះដ៏មើលមិនឃើញ[ខ] ជាបង
ច្បង[គ]នៃគ្រប់ទាំងអស់ ដែលព្រះបានបង្កើតមក ១៦ដ្បិតគឺ
ទ្រង់ហើយដែលបង្កើតគ្រប់ទាំងអស់[ឃ] ទាំងរបស់នៅស្ថាន
សួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយ
ដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះ
អម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ[ង] នោះ
សុទ្ធតែកើតមកដោយសារទ្រង់ ហើយសំរាប់ទ្រង់ទាំងអស់
ផង[ច] ១៧ទ្រង់គង់នៅមុនទាំងអស់[ឆ] ហើយរបស់ទាំងអស់ក៏
នៅស្ថិតស្ថេរ ដោយសារទ្រង់ ១៨ទ្រង់ជាសិរសា[ជ]របស់រូប
កាយ[ឈ] គឺជាពួកជំនុំ ទ្រង់ជាដើម ក៏បានរស់ពីស្លាប់ឡើង
វិញមុន[ញ]គេ[ដ]បង្អស់ ដើម្បីឱ្យទ្រង់បានជាប្រធានក្នុងគ្រប់
ទាំងអស់ ១៩ដ្បិតព្រះបានសព្វព្រះហឫទ័យ[ឋ] ឱ្យគ្រប់ទាំង

ហព ១១:២៧ គ ខ.១៨ **១:១៦** ឃ យហ ១:៣ ង អភ ១:២០,២១
ច រម ១១:៣៦ **១:១៧** ឆ យហ ១:២ **១:១៨** ជ អភ ១:២២ ឈ ខ.២៤
១កថ ១២:២៧ ញ ខ.១៥ ទដ ៨៩:២៧ រម ៨:២៩ ហព ១:៦ ដ កច ២៦:២៣
វវ ១:៥ **១:១៩** ឋ អភ ១:៥

(រម ៥:៥ កទ ៥:២២–២៣ និងការពន្យល់)។

**១:៩** បទគម្ពីរនេះបញ្ជាក់ថា គ្រប់ទាំងប្រាជ្ញា និងចំណេះខាងឯវិញ្ញាណ គឺសំដៅលើការអនុវត្តនៃជីវិត ដែលរស់នៅដោយសុចរិត ស្មោះត្រង់ ប្រតិបត្តិ និងស្ដាប់បង្គាប់ព្រះអម្ចាស់ (ខ.១០–១២)។

**១:១០** *ដើរបែបគួរនឹងព្រះអម្ចាស់* ដើម្បីឱ្យជីវិតរបស់យើងបានគាប់ព្រះហឫទ័យព្រះអម្ចាស់ គឺត្រូវប្រតិបត្តិតាមព្រះបន្ទូលទ្រង់ ដោយធ្វើគ្រប់ទាំងការល្អដែលទ្រង់បង្គាប់មក (ខ.៦ ២:៧ ៣:៧ ៤:៥)។

**១:១២** *កេរ្ដិ៍អាករ* "សូមមើលការពន្យល់ ១ពត ១:៤"។ *ទីភ្លឺ* ពាក្យនេះច្រើនសំដៅលើភាពបរិសុទ្ធ (១យហ ១:៥ និងការពន្យល់) សេចក្ដីពិត (ទដ ១១៩:១០៥, ១៣០ ២កថ ៤:៦) សិរីរុងរឿង (អស ៦០:១–៣ ១ធថ ៦:១៦) និងជីវិត (យហ ១:៤)។ នៅក្នុងព្រះគម្ពីរ ពាក្យនេះក៏សំដៅលើព្រះគ្រីស្ទ (១យហ ១:៥ យហ ៨:១២) និងគ្រីស្ទបរិស័ទ (អភ ៥:៨) ផងដែរ ។ ម្យ៉ាងទៀត នគរនៃពន្លឺគឺផ្ទុយនឹងអាណាចក្រងងឹត (ខ.១៣ ទដ ២៧:១ និងការពន្យល់)។

**១:១៣** *នគរ* ពាក្យនេះពុំមែនសំដៅលើផ្ទៃដី ដែលគ្រប់គ្រងដោយស្ដេចណាមួយទេ ប៉ុន្តែ គឺសំដៅលើអំណាច និងការគ្រប់គ្រងរបស់ស្ដេចមួយអង្គ ។ មានន័យថា គ្រីស្ទបរិស័ទលែងស្ថិតនៅក្រោមអំណាចនៃវិញ្ញាណអាក្រក់ទៀតហើយ ប៉ុន្តែ ស្ថិតនៅក្រោមការដឹកនាំរបស់ព្រះរាជបុត្រានៃព្រះវិញ ។

**១:១៤** *សេចក្ដីប្រោសលោះ* គឺការប្រោសលោះ និងការឱ្យសេរីភាពចេញពីអំពើបាប ដោយសារការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ (រម ៣:២៤ និងការពន្យល់)។

**១:១៥–២០** ត្រង់ចំណុចនេះបង្ហាញពីសារសំខាន់នូវការពីរយ៉ាងគឺ (១). អំណាចព្រះចេស្ដារបស់ព្រះគ្រីស្ទ ក្នុងការបង្កើតពិភពលោក (ខ.១៥–១៧) (២). អំណាចព្រះចេស្ដារបស់ព្រះគ្រីស្ទ ក្នុងការប្រោសលោះមនុស្សលោក (ខ.១៨–២០)។

**១:១៥** *ទ្រង់ជារូបអង្គនៃព្រះ* នៅក្នុងបទគម្ពីរនេះ និងក្នុងបទគម្ពីរ "២កថ ៤:៤" (មើលការពន្យល់) ព្រះគ្រីស្ទត្រូវបានហៅថា "រូបអង្គនៃព្រះ"។ នៅក្នុងបទគម្ពីរ "ហព ១:៣" ព្រះគ្រីស្ទត្រូវបានហៅថា ជារស្មីភ្លឺមកពីសិរីល្អនៃព្រះ ហើយជារូបភាពនៃអង្គទ្រង់ ។ ការបង្ហាញនេះបញ្ជាក់នូវសេចក្ដីពិតពីរយ៉ាងគឺ (១). គ្មានអ្នកណាមើលឃើញព្រះអម្ចាស់ទេ (យហ ១:១៨) (២). ព្រះគ្រីស្ទជារូបអង្គ និងជាព្រះរាជបុត្រានៃព្រះ ដែលបានយាងមកយកកំណើតជាមនុស្ស ឱ្យមនុស្សលោកមើលឃើញទ្រង់ច្បាស់ (យហ ១:១៨ ១៤:៩)។ *ជាបងច្បងនៃគ្រប់ទាំងអស់* នៅក្នុងសម័យកាលព្រះគម្ពីរសញ្ញាចាស់ កូនច្បងមានសិទ្ធិ និងឱកាសលើសគេទាំងអស់ ដូចគ្នានេះដែរ ព្រះគ្រីស្ទគឺជាបងច្បងនៃគ្រប់ទាំងអស់ ហើយទ្រង់មានអំណាច ព្រះចេស្ដាលើគ្រប់ទាំងអស់ (ខ.១៦–១៨)។

**១:១៦** *នោះសុទ្ធតែកើតមកដោយសារទ្រង់* នៅក្នុង"ខ.១៥–២០"លោកប៉ុលបានលើកឡើងចំនួន៧ដងថា ព្រះគ្រីស្ទគ្រប់គ្រងលើគ្រប់ទាំងអស់ ។

**១:១៧** *ទ្រង់គង់នៅមុនទាំងអស់* បញ្ជាក់ថា ព្រះយេស៊ូវគ្រីស្ទគង់នៅតាំងពីអស់កល្បជានិច្ច (យហ ១:១–២ ៨:៥៨)។

**១:១៨** *សិរសា* មានន័យថា ពួកជំនុំទាំងអស់ដែលជឿដល់ព្រះយេស៊ូវគ្រីស្ទគឺស្ថិត នៅក្រោមការគ្រប់គ្រង និងការដឹកនាំរបស់ទ្រង់ (១កថ ១១:៣ អភ ១:២២)។ *បានរស់ពីស្លាប់ឡើងវិញមុនគេបង្អស់* មានន័យថា ព្រះគ្រីស្ទបានរស់ពីសុគតជាមួយនឹងរូបកាយដែលមិនចេះពុករលួយ ។ ពេលខ្លះ លោកប៉ុលហៅទ្រង់ថា ជាផលដំបូងពីពួកអ្នកដែលបានដេកលក់ទៅហើយ (១កថ ១៥:២០)។ ម្យ៉ាងទៀត បញ្ជាក់ថា ពួកអ្នកដែលទ្រង់ប្រោសឱ្យរស់ពីស្លាប់ឡើងវិញ ក្រោយមក រូបកាយរបស់គេក៏ត្រូវពុករលួយវិញដែរ (២ពវ ៤:៣៥ លក ៧:១៥ យហ ១១:៤៤ កច ៩:៣៦–៤១ ២០:៧–១២)។

**១:១៩** *សេចក្ដីពោរពេញ* មានន័យថា គ្រប់អំណាចព្រះចេស្ដា និងភាពជាម្ចាស់ គឺជារបស់ព្រះយេស៊ូវគ្រីស្ទ ។ អស់អ្នកដែលទទួលជឿដល់ព្រះនាម

សេចក្ដីពោរពេញ[ឌ]បានស្ថិតនៅក្នុងទ្រង់ ២០ ហើយឱ្យបាន
ផ្សះផ្សា[ឍ]គ្រប់ទាំងអស់ ឱ្យជានឹងអង្គទ្រង់ ដោយសារព្រះ
រាជបុត្រានោះ ទោះបើរបស់នៅស្ថានសួគ៌ ឬនៅផែនដីក្ដី[ណ]
ទាំងតាំងស្ពានមេត្រី[ត] ដោយសារព្រះលោហិត[ថ]នៃឈើឆ្កាង
ទ្រង់ ២១ រីឯអ្នករាល់គ្នា ដែលពីដើមត្រូវពង្រាត់ចេញ ហើយ
ជាខ្មាំងសត្រូវ[ទ]ក្នុងគំនិត[ធ] ដោយអំពើអាក្រក់នោះ ២២ ឥឡូវ
នេះវិញ ទ្រង់បានផ្សះផ្សា[ន]ក្នុងរូបសាច់ទ្រង់[ប] ដោយបាន
ទទួលសុគត ដើម្បីនឹងថ្វាយអ្នករាល់គ្នា[ផ]ជាដង្វាយបរិសុទ្ធ
ឥតសៅហ្មង ហើយឥតកន្លែងបន្ទោសបាននៅចំពោះទ្រង់[ព]
២៣ នោះគឺបើតិចណាស់អ្នករាល់គ្នាបានតាំងនៅ[ភ]ជាប់លាប់[ម]
ហើយមាំមួន ក្នុងសេចក្ដីជំនឿដែរ ឥតងាកបែរចេញពី
សេចក្ដីសង្ឃឹម[យ]របស់ដំណឹងល្អ ដែលអ្នករាល់គ្នាបានឮ ជា
ដំណឹងដែលបានផ្សាយ ទៅដល់គ្រប់ទាំងមនុស្ស ដែលកើត
ក្រោមមេឃផង[រ] ឯប៉ុលខ្ញុំ ជាអ្នកបំរើចំពោះដំណឹងល្អនោះ
ដែរ[ល]។

## ការបម្រើរបស់សាវ័កប៉ុលដល់ពួកជំនុំ

២៤ ឥឡូវនេះ ខ្ញុំមានចិត្តអំណរ[វ]ក្នុងការរងទុក្ខលំបាក
ដែលខ្ញុំទ្រាំដោយព្រោះអ្នករាល់គ្នា ហើយសេចក្ដីវេទនា
ណារបស់ព្រះគ្រីស្ទ[ស] ដែលខ្វះក្នុងរូបសាច់ខ្ញុំ នោះខ្ញុំកំពុង
តែបំពេញឡើង ដោយព្រោះរូបកាយទ្រង់ គឺជាពួកជំនុំ[ហ]
២៥ ខ្ញុំបានត្រឡប់ជាអ្នកបំរើ[ឡ]ដល់ពួកជំនុំនោះ តាមការកាន់
កាប់ត្រួតត្រារបស់ព្រះ ដែលបានប្រគល់មកខ្ញុំ[អ]សំរាប់អ្នក
រាល់គ្នា ដើម្បីនឹងបំពេញព្រះបន្ទូល[ក] ២៦ គឺជាសេចក្ដីអាថ៌
កំបាំង[ខ] ដែលលាក់ទុកតាំងពីអស់កល្បរៀងរាល់តែដំណ
តមក តែឥឡូវនេះបានបើកសំដែង ឱ្យពួកបរិសុទ្ធទ្រង់ស្គាល់
២៧ ព្រះទ្រង់បានសព្វព្រះហឫទ័យ នឹងសំដែង[គ]ឱ្យពួកបរិ
សុទ្ធនោះដឹងថា សិរីល្អដ៏បរិបូរ[ឃ]របស់សេចក្ដីអាថ៌កំបាំង
នេះជាយ៉ាងណា ក្នុងពួកសាសន៍ដទៃ គឺថា ព្រះគ្រីស្ទទ្រង់
សណ្ឋិតនៅក្នុងអ្នករាល់គ្នា[ង] ដែលជាទីសង្ឃឹមយ៉ាងឧត្ដម
២៨ យើងខ្ញុំប្រកាសប្រាប់ពីទ្រង់ទាំងទូន្មាន[ច]ដល់គ្រប់មនុស្ស
ហើយទាំងបង្រៀនដល់គ្រប់មនុស្ស ដោយគ្រប់ទាំងប្រាជ្ញា[ឆ]
ដើម្បីឱ្យបានថ្វាយគ្រប់មនុស្ស ជាដង្វាយគ្រប់លក្ខណ៍[ជ]ក្នុង
ព្រះគ្រីស្ទ ២៩ ខ្ញុំក៏ខំធ្វើការ[ឈ]នោះឯង ទាំងតយុទ្ធ[ញ]តាមឫទ្ធិ
បារមីទ្រង់ ដែលបណ្ដាលឡើងក្នុងខ្ញុំដោយព្រះចេស្ដា[ដ]។

**១:១៩** ឌ យហ ១:១៦
**១:២០** ឍ រម ៥:១០
ណ អភ ១:១០
ត លក ២:១៤
ថ អភ ២:១៣
**១:២១** ទ រម ៥:១០
ធ អភ ២:៣
**១:២២** ន ខ.២០
រម ៥:១០
ប រម ៧:៤
ផ ២កថ ៤:១៤
ព អភ ១:៤ ៥:២៧
**១:២៣** ភ រម ១១:២២
ម អភ ៣:១៧
យ ខ.៥ រ ខ.៦
រម ១០:១៨
ល ខ.២៥ ១កថ ៣:៥
**១:២៤** វ ២កថ ៦:១០
ស ២កថ ១:៥
ហ ១កថ ១២:២៧
**១:២៥** ឡ ខ.២៣
១កថ ៣:៥
អ អភ ៣:២
ក ហព ៤:១២
**១:២៦** ខ រម ១៦:២៥ **១:២៧** គ មថ ១៣:១១ ឃ រម ២:៤ ង រម ៨:១០
**១:២៨** ច កល ៣:១៦ ឆ ១កថ ២:៦,៧ ជ មថ ៥:៤៨ អភ ៥:២៧
**១:២៩** ឈ ១កថ ១៥:១០ ២កថ ១១:២៣ ញ កល ២:១ ដ អភ ១:១៩ ៣:៧

ព្រះយេស៊ូវគ្រីស្ទ មានព្រះវិញ្ញាណគង់នៅក្នុងគេ ហើយទ្រង់ប្រទានឱ្យគេនូវអំណាចព្រះចេស្ដារបស់ទ្រង់ (២:៩ និងការពន្យល់)។

**១:២០** *ឱ្យជានឹងអង្គទ្រង់* នៅពេលដែលលោកអ័ដាម និងនាងអេវ៉ាបានធ្លាក់ទៅក្នុងអំពើបាប គ្រប់អ្វីៗទាំងអស់បានផ្លាស់ប្ដូរ (រម ៨:១៩–២២)។ ព្រះគ្រីស្ទបានយាងមក និងសុគតនៅលើឈើឆ្កាង គឺដើម្បីឱ្យមនុស្សបានសង្គ្រោះ ហើយឱ្យបានជានឹងទ្រង់ (រម ៨:២១ និងការពន្យល់)។ ម្យ៉ាងទៀត បញ្ជាក់ថាអស់អ្នកដែលទទួលជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ គឺទទួលបានការសង្គ្រោះមកអំពីទ្រង់ ។

**១:២៣** *គ្រប់ទាំងមនុស្សដែលកើតក្រោមមេឃ* គឺសំដៅលើមនុស្សគ្រប់ជាតិសាសន៍ទាំងអស់នៅលើពិភពលោកនេះ (មើលការពន្យល់ ខ.៦)។

**១:២៤** *ការរងទុក្ខលំបាក* ក្នុងដំណើរបេសកកម្មរបស់លោកប៉ុលទៅឯពួកសាសន៍ដទៃ គាត់ទទួលនូវការរងទុក្ខជាច្រើន (២កថ ២៣–២៧)។ ការរងទុក្ខរបស់គាត់ត្រង់ចំណុចនេះ អាចសំដៅលើការដែលគាត់ជាប់នៅក្នុងពន្ធនាគារ ។ *សេចក្ដីវេទនាណារបស់ព្រះគ្រីស្ទ ដែលខ្វះក្នុងរូបសាច់ខ្ញុំ* ត្រង់ចំណុចនេះមិនមែនមានន័យថា ការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ មិនទាន់គ្រប់គ្រាន់ក្នុងការសង្គ្រោះមនុស្សលោកនោះទេ ។ លោកប៉ុលចង់មានន័យថា ការដែលគាត់ទទួលការឈឺចាប់ គឺពីព្រោះតែដំណឹងល្អរបស់ព្រះគ្រីស្ទដែលត្រូវប្រកាសដល់គ្រប់មនុស្សទាំងអស់វិញ ។ ការឈឺចាប់របស់ព្រះយេស៊ូវគ្រីស្ទ នៅលើឈើឆ្កាងគឺដើម្បីសង្គ្រោះមនុស្សឱ្យរួចពីបាប ។ រីឯការឈឺចាប់របស់លោកប៉ុលវិញ គឺដោយព្រោះការនាំដំណឹងល្អ ទៅពួកអ្នកដែលបាត់បង់ ។

**១:២៥** *តាមការកាន់កាប់ ត្រួតត្រារបស់ព្រះ* ឃ្លានេះអាចមានន័យថា តាមការរៀបចំរបស់ព្រះអម្ចាស់ គឺត្រូវនាំដំណឹងល្អទៅកាន់គ្រប់ទីកន្លែងទាំងអស់នៅក្នុងពិភពលោកនេះ (អស ៥៥:១១ រម ១៥:១៩ ១កថ ៩:១៧)។

**១:២៦** *សេចក្ដីអាថ៌កំបាំង* សំដៅលើព្រះហឫទ័យព្រះអម្ចាស់ ដែលគ្មានអ្នកណាអាចដឹងបានឡើយ លើកលែងតែមានការបើកសំដែងមកពីទ្រង់ប៉ុណ្ណោះ ។ ពាក្យនេះត្រូវបានប្រើនៅក្នុងចំណោមពួកសាសន៍ដទៃ នាសម័យកាលលោកប៉ុល ដោយពួកគេយល់ថា សេចក្ដីអាថ៌កំបាំង គឺអាចដឹងបានចំពោះតែក្រុមមនុស្សដោយឡែកណាមួយប៉ុណ្ណោះ ។ ក្នុងបទគម្ពីរនេះ លោកប៉ុលបញ្ជាក់យ៉ាងច្បាស់ថា សេចក្ដីអាថ៌កំបាំង ត្រូវបានបើកសំដែងដល់អស់អ្នកណា ដែលទទួលជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ (អភ ១:៩ ៣:៩ រម ១៦:២៥ និងការពន្យល់)។

**១:២៧** *សិរីល្អ* សំដៅលើសិរីល្អដែលព្រះអម្ចាស់បានរៀបចំសម្រាប់រាស្ត្ររបស់ទ្រង់ (៣:៤ រម ៥:២ ៨:១៧–១៨ ១កថ ២:៧ ១៥:៤២–៤៤ ២កថ ៤:១៧ ១ថន ២:១២ ២ថន ២:១៤ ២ធថ ២:១០ ហព ២:១០ ១ពត ៥:១,៤ និងការពន្យល់)។ *ក្នុងពួកសាសន៍ដទៃ គឺថា ព្រះគ្រីស្ទទ្រង់សណ្ឋិតនៅក្នុងអ្នករាល់គ្នា* ត្រង់ចំណុចនេះបញ្ជាក់ថា សេចក្ដីអាថ៌កំបាំងគឺ ព្រះគ្រីស្ទគង់សណ្ឋិតនៅក្នុងពួកសាសន៍ដទៃ ព្រោះនៅមុនពេលទ្រង់បានយាងមក ពួកគេមិនបានទទួលសិទ្ធិស្មើនឹងពួកសាសន៍អ៊ីស្រាអែលទេ (អភ ៣:៦)។

**១:២៨** *គ្រប់លក្ខណ៍* មានន័យថា នៅក្នុងព្រះគ្រីស្ទ មនុស្សគ្រប់រូបបានគ្រប់លក្ខណ៍ ឬបានពេញវ័យក្នុងសេចក្ដីជំនឿ ។ ម្យ៉ាងទៀត បញ្ជាក់ថា គោលបំណងដ៏សំខាន់នៃការប្រកាសដំណឹល្អគឺ ដើម្បីឱ្យមនុស្សគ្រប់រូបដែលទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ បានគ្រប់លក្ខណ៍នៅក្នុងទ្រង់ ។

**១:២៩** បទគម្ពីរនេះបង្ហាញយ៉ាងច្បាស់ នូវទំនាក់ទំនងរវាងការប្រឹងប្រែង

**២** ¹ខ្ញុំចង់ឱ្យអ្នករាល់គ្នាដឹងពីដំណើរខ្ញុំ ដែលខំតយុទ្ធជា
ខ្លាំងទាំងម្ល៉េះ[ឋ] ដោយយល់ដល់អ្នករាល់គ្នា និងពួកអ្នកនៅ
ក្រុងឡៅឌីសេ[ឌ] ព្រមទាំងអស់អ្នកណា ដែលមិនបានឃើញ
មុខខ្ញុំខាងសាច់ឈាមផង ²ដើម្បីឱ្យគេមានចិត្តក្សាន្ត[ឍ]ដោយ
បានរួបរួមគ្នាមកក្នុងសេចក្ដីស្រឡាញ់ ហើយឱ្យបានអស់
ទាំងផលប្រយោជន៍នៃប្រាជ្ញា ដែលជឿជាក់ផ្ដាច់ ដើម្បី
ឱ្យបានស្គាល់សេចក្ដីអាថ៌កំបាំង[ណ]នៃព្រះ គឺជាព្រះគ្រីស្ទ
³ដែលមានគ្រប់ទាំងផលថ្លៃវិសេសនៃប្រាជ្ញា និងសេចក្ដី
ចេះដឹងលាក់ទុកក្នុងទ្រង់[ត] ⁴ហើយដែលខ្ញុំថាដូច្នេះ នោះគឺ
ក្រែងលោមានអ្នកណាបញ្ឆោតអ្នករាល់គ្នា ដោយពាក្យ
លលួង[ថ] ⁵ដ្បិតទោះបើខ្ញុំមិននៅជាមួយខាងរូបសាច់ក៏ដោយ
គង់តែនៅជាមួយខាងវិញ្ញាណដែរ[ទ] ទាំងមានសេចក្ដីអំណរ
ដោយឃើញសណ្ដាប់ធ្នាប់[ធ]របស់អ្នករាល់គ្នានិងសេចក្ដី
ខ្ជាប់ខ្ជួន[ន]នៃសេចក្ដីជំនឿដែលអ្នករាល់គ្នាជឿដល់ព្រះគ្រីស្ទ
⁶ដូច្នេះ ដែលអ្នករាល់គ្នាបានទទួលព្រះគ្រីស្ទយេស៊ូវ ជា
ព្រះអម្ចាស់[ផ] បែបយ៉ាងណា នោះចូរដើរក្នុងទ្រង់តាមបែប
យ៉ាងនោះចុះ ⁷ដោយបានចាក់ឫស[ព] ហើយស្អាងឡើងក្នុង
ទ្រង់ ទាំងតាំងនៅខ្ជាប់ខ្ជួនក្នុងសេចក្ដីជំនឿ ដូចជាបាន
បង្រៀនដល់អ្នករាល់គ្នាហើយ[ភ] ព្រមទាំងអរព្រះគុណកាន់
តែច្រើនឡើងផង ។
⁸ចូរប្រយ័ត្ន ក្រែងមានអ្នកណាចាប់អ្នករាល់គ្នាធ្វើជារំពា
ដោយពាក្យបរមត្ថ[ម] និងពាក្យបញ្ឆោតជាអសារឥតការ
តាមសណ្ដាប់បុរាណរបស់មនុស្ស តាមបឋមសិក្សានៅនា
លោកីយ[យ] គឺមិនមែនតាមព្រះគ្រីស្ទទេ ⁹ដ្បិតមានគ្រប់ទាំង
សេចក្ដីពោរពេញ[រ]របស់ព្រះ សណ្ឋិតនៅក្នុងទ្រង់ទាំងមាន
រូបអង្គផង ¹⁰ហើយអ្នករាល់គ្នាក៏ពេញលេញក្នុងទ្រង់
ដែលទ្រង់ជាសិរសា[ល]លើអស់ទាំង ពួកគ្រប់គ្រង នឹងអំ
ណាចទាំងប៉ុន្មាន[វ] ¹¹អ្នករាល់គ្នាបានទទួលកាត់ស្បែក
ម្យ៉ាង[ស]ក្នុងទ្រង់ ដែលមិនបានធ្វើដោយដៃមនុស្សទេ គឺជា
ការដោះរូបកាយខាងសាច់ឈាមចេញ[ហ] ដោយទទួលការ
កាត់ស្បែករបស់ព្រះគ្រីស្ទវិញ ¹²ហើយអ្នករាល់គ្នាបានកប់
ជាមួយនឹងទ្រង់ក្នុងបុណ្យជ្រមុជ[ឡ] ក៏បានរស់ឡើងវិញជាមួយ
នឹងទ្រង់[អ] ដោយសារសេចក្ដីជំនឿជឿដល់ឫទ្ធិបារមីនៃព្រះ
ដែលទ្រង់បានប្រោសឱ្យព្រះយេស៊ូវ រស់ពីស្លាប់ឡើងវិញ[ក]

**២:១** ឋ កល ១:២៩ ៤:១២ ឌ កល ៤:១៣,១៥,១៦ វវ ១:១១ ៣:១៤ **២:២** ឍ អភ ៦:២២ កល ៤:៨ ណ រម ១៦:២៥ **២:៣** ត អភ ១១:២ យរ ២៣:៥ រម ១១:៣៣ ១កថ ១:២៤,៣០ **២:៤** ថ រម ១៦:១៨ **២:៥** ទ ១កថ ៥:៤ ១ថន ២:១៧ ធ ១កថ ១៤:៤០ ន ១ពត ៥:៩ ប កច ២០:២១ **២:៦** ផ យហ ១៣:១៣ កល ១:១០ **២:៧** ព អភ ៣:១៧ ភ អភ ៤:២១ **២:៨** ម ១ធថ ៦:២០ យ ខ.២០ កទ ៤:៣ **២:៩** រ យហ ១:១៦

**២:១០** ល អភ ១:២២ វ មថ ២៨:១៨ **២:១១** ស រម ២:២៩ ភល ៣:៣ ហ កទ ៥:២៤ **២:១២** ឡ មថ ២៨:១៩ អ រម ៦:៥ ក កច ២:២៤

របស់អ្នកជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ និងជំនួយមកអំពីទ្រង់ (ភល ២:១២–១៣) ។

**២:១** *ខំតយុទ្ធជាខ្លាំងទាំងម្ល៉េះ* លោកប៉ុលមានប្រសាសន៍យ៉ាងដូច្នេះ សំដៅលើការដែលគាត់ខំប្រឹងអធិស្ឋាន ហើយតយុទ្ធនឹងបញ្ហានៅក្នុងជីវិត ជាពិសេសគឺការបារម្ភចំពោះពួកជំនុំនៅទីក្រុងកូល៉ុសតែម្ដង ។ *ក្រុងឡៅឌីសេ* ទីក្រុងនេះស្ថិតនៅចម្ងាយ១៧,៦គ.ម ពីទីក្រុងកូល៉ុស ។ សំបុត្រដែលលោកប៉ុលផ្ញើទៅពួកជំនុំនៅទីក្រុងកូល៉ុស ក៏ត្រូវបានយកទៅអានឱ្យពួកជំនុំនៅទីក្រុងឡៅឌីសេបានស្ដាប់ដែរ (៤:១៦) ។

**២:២** *សេចក្ដីអាថ៌កំបាំង* "មើលការពន្យល់ ១:២៦ រម ១១:២៥"។

**២:៣** *សេចក្ដីចេះដឹង* លោកប៉ុលលើកយកសេចក្ដីនេះមកនិយាយនៅក្នុងសំបុត្ររបស់គាត់ ព្រោះចង់បញ្ជាក់ឱ្យពួកជំនុំដឹង និងចេះទប់ស្កាត់ចំពោះសេចក្ដីបង្រៀនរបស់ពួកគ្រូខុសឆ្គង ដែលតែងតែពោលថា សេចក្ដីចេះដឹងរបស់ពួកគេអាចនាំឱ្យបានសង្គ្រោះ (ខ.២ ១:៩–១០, សេចក្ដីផ្ដើម ១យហ) ។ លោកប៉ុលបានធ្វើការបញ្ជាក់យ៉ាងច្បាស់ដល់ពួកជំនុំនៅទីក្រុងកូល៉ុសថា ការសង្គ្រោះមិនអាចទទួលបានតាមរយៈចំណេះដឹងរបស់ពួកគេទេ ។

**២:៥–៧** "មើលការពន្យល់ ១កថ ៥:៣ អភ ៣:១៦–១៩"។

**២:៦** *ចូរដើរក្នុងទ្រង់តាមបែបយ៉ាងនោះចុះ* ត្រង់ចំណុចនេះបញ្ជាក់អំពីជីវិត និងការរស់នៅរបស់គ្រីស្ទបរិស័ទ ដែលដើរតាមព្រះយេស៊ូវគ្រីស្ទ (ខ.៧,១០–១៣, ២០ ១:២,២៧–២៨ ៣:១,៣) ។

**២:៧** *ព្រមទាំងអរព្រះគុណកាន់តែច្រើនឡើងផង* "អភ ៥:២០ និងការពន្យល់"។

**២:៨** *តាមបឋមសិក្សានៅនាលោកីយ* ឃ្លានេះសំដៅលើការបង្រៀនខុសឆ្គង សេចក្ដីបង្រៀនរបស់លោកិយ និងគោលលទ្ធិសាសនាផ្សេងៗ ។ ម្យ៉ាងទៀត លោកប៉ុលនិយាយដូច្នេះ គឺសំដៅលើពួកប្រឆាំង ដែលតែងតែដើរបង្រៀនពួកជំនុំនៅទីក្រុងកូល៉ុសថា ការសង្គ្រោះមិនមែនកើតឡើងដោយសារជំនឿលើព្រះគ្រីស្ទ តែប៉ុណ្ណោះទេ គឺត្រូវបន្ថែមនូវចំណេះដឹងអាថ៌កំបាំង និងច្បាប់ទម្លាប់របស់មនុស្សផ្សេងៗទៀត ដែលរួមមានការប្រតិបត្តិទាំងខាងឯរូបកាយ និងចិត្តគំនិត ការកាត់ស្បែក ការផឹកស៊ី និងការប្រតិបត្តិតាមពិធីបុណ្យសាសនាផ្សេងៗ ។

**២:៩** *សេចក្ដីពោរពេញរបស់ព្រះ* "មើលការពន្យល់ ១:១៩"។ ក្នុងបទគម្ពីរនេះ លោកប៉ុលបញ្ជាក់យ៉ាងច្បាស់ អំពីភាពជាមនុស្ស និងជាព្រះពិតរបស់ព្រះយេស៊ូវ ដើម្បីប្រឆាំងតបដោយផ្ទាល់ ទៅនឹងសេចក្ដីបង្រៀនរបស់ពួកប្រឆាំង ។

**២:១០–១៥** ត្រង់ចំណុចនេះ លោកប៉ុលបញ្ជាក់យ៉ាងច្បាស់ថា អស់អ្នកដែលទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ គឺពិតជាបានគ្រប់លក្ខណ៍នៅក្នុងទ្រង់ មិនដូចជាសេចក្ដីដែលពួកគ្រូខុសឆ្គងបានប្រកាសនោះទេ ។ សេចក្ដីគ្រប់លក្ខណ៍ទាំងនេះរួមមានការបានរួចអំពីនិស្ស័យបាប (ខ.១១) វិញ្ញាណបានរស់ពីស្លាប់វិញ (ខ.១២–១៣) ការអត់ទោសបាប (ខ.១៣) និងការប្រោសលោះឱ្យបានរួចអំពីសេចក្ដីតម្រូវរបស់ក្រឹត្យវិន័យ (ខ.១៤) ហើយនិងអំពីវិញ្ញាណអាក្រក់ (ខ.១៥) ។

**២:១០** *សិរសា* "១:១៨ អភ ១:១៩–២២ និងការពន្យល់"។

**២:១១–១២** *កាត់ស្បែក . . . បុណ្យជ្រមុជ* នៅក្នុងជំនឿរបស់ពួកសាសន៍អ៊ីស្រាអែល ការកាត់ស្បែកគឺជានិមិត្តរូបនៃសេចក្ដីសញ្ញារវាងពួកគេម្នាក់ៗ និងព្រះអម្ចាស់ ។ រីឯពាក្យថា "កាត់ស្បែក" ត្រង់ចំណុចនេះ មិនសំដៅលើការកាត់ស្បែកខាងឯរូបកាយនោះទេ ។ អ្នកកាត់ស្រាយខ្លះយល់ថា ពាក្យនេះសំដៅលើការជ្រមុជទឹក និងតំណាងឱ្យទំនាក់ទំនងនៃសេចក្ដីសញ្ញាថ្មី រវាង

[១៣]ឯអ្នករាល់គ្នាដែលបានស្លាប់ក្នុងការរំលង[ខ] ហើយក្នុង
សណ្ឋានមិនកាត់ស្បែកខាងសាច់ឈាម នោះទ្រង់បាន
ប្រោស ឱ្យរស់[គ]ជាមួយនឹងទ្រង់ ដោយបានអត់ទោសចំពោះ
អស់ទាំងការរំលងរបស់អ្នករាល់គ្នា[ឃ] [១៤]ទាំងលុបចោល
សេចក្តីដែលកត់ទុកទាស់នឹងយើងក្នុងសេចក្តីបញ្ញត្ត[ង] ដែល
ប្រទាំងនឹងយើង ហើយទ្រង់ក៏លើកចោល ដោយបោះភ្ជាប់
នៅឈើឆ្កាង[ច] [១៥]ទ្រង់បានទាំងទំលាក់ងារពីពួកគ្រប់គ្រង
និងពួកមានអំណាច[ឆ] ទាំងដាក់ពួកទាំងនោះនៅកណ្តាល
ជំនុំឱ្យគេមើល ហើយដឹកនាំគេទៅ ដោយមានជ័យជំនះ[ជ]
ដោយសារឈើឆ្កាងនោះឯង ។
[១៦]ដូច្នេះ កុំទុកឱ្យអ្នកណានិន្ទាអ្នករាល់គ្នា[ឈ] ពីរឿងចំណី
អាហារ ឬគ្រឿងផឹក[ញ] ឬពីរឿងថ្ងៃបុណ្យ[ដ] ថ្ងៃចូលខែ[ឋ] ឬថ្ងៃ
ឈប់សំរាកឡើយ[ឌ] [១៧]សេចក្តីទាំងនេះជាស្រមោលនៃការ
ដែលត្រូវមក[ឍ] តែតួរូបអង្គនោះ គឺជាព្រះគ្រីស្ទ [១៨]កុំឱ្យអ្នក
ណាបញ្ឆោតយករង្វាន់របស់អ្នករាល់គ្នា តាមតែចិត្តឡើយ
ដោយគេប្រព្រឹត្តបែបសុភាព[ណ] ទាំងថ្វាយបង្គំពួកទេវតា
ទាំងសៀតស៊កចូលទៅក្នុងការ ដែលខ្លួនមើលមិនឃើញ[ត]
ហើយមានចិត្តប៉ោងឡើង ដោយគំនិតខាងសាច់ឈាមគេ
នោះ [១៩]គេមិនកាន់ជាប់តាមសិរសាទេ[ថ] ដែលដោយសារ
សិរសានោះ រូបកាយទាំងមូលបានមានកំឡាំង[ទ] ហើយជាប់
គ្នា ដោយសារសន្លាក់ និងសរសៃទាំងប៉ុន្មាន ឱ្យបានចំរើន
ឡើង ដោយសេចក្តីចំរើនរបស់ព្រះ[ធ]។
[២០]ដូច្នេះ បើសិនជាអ្នករាល់គ្នាបានស្លាប់ទៅ ជាមួយ
នឹងព្រះគ្រីស្ទ[ន] ខាងឯបឋមសិក្សារបស់លោកីយនេះមែន[ប]
នោះតើហេតុអ្វីបានជាអ្នករាល់គ្នា ធ្វើដូចជារស់នៅជាប់
ក្នុងលោកីយនៅឡើយ ដោយចុះចូលនឹងសេចក្តីបញ្ញត្តិទាំង
ប៉ុន្មានវិញ[ផ] [២១]ដូចជាថា កុំឱ្យកាន់ កុំឱ្យភ្លក់ កុំឱ្យពាល់ឱ្យ
សោះ [២២]គឺតាមសេចក្តីហាមប្រាម និងសេចក្តីបង្រៀន
របស់មនុស្ស[ព] ដែលសេចក្តីទាំងនោះតែងតែវិនាសបាត់
ទៅ[ភ]ដោយការប្រើប្រាស់ [២៣]ជាសេចក្តីដែលមើលទៅដូច
ជាមានទំនងមែន ដោយមានការថ្វាយបង្គំស្ម័គ្រពីចិត្ត
ហើយមានសេចក្តីសុភាព ឥតប្រណីរូបសាច់[ម] តែគ្មាន
ប្រយោជន៍នឹងទប់ទល់សេចក្តីប៉ងប្រាថ្នារបស់សាច់ឈាម
ឡើយ ។

**២:១៣** ខ អភ ២:១,៥ គ អភ ២:៥ ឃ អភ ៤:៣២ **២:១៤** ង អភ ២:១៥ ច ១ពត ២:២៤ **២:១៥** ឆ ខ.១០ អផ ៦:១២ ជ មថ ១២:២៩ លក ១០:១៨ យហ ១២:៣១ **២:១៦** ឈ រម ១៤:៣,៤ ញ មក ៧:១៩ រម ១៤:១៧ ដ លវ ២៣:២ រម ១៤:៥ ឋ ១រប ២៣:៣១ ឌ មក ២:២៧,២៨ កទ ៤:១០ **២:១៧** ឍ ហព ៨:៥ ១០:១ **២:១៨** ណ ខ.២៣ ត ១កថ ៩:២៤ ភល ៣:១៤

**២:១៩** ថ អភ ១:២២ ទ ១កថ ១២:២៧ ធ អភ ៤:១៦ **២:២០** ន រម ៦:៦ ប ខ.៨ កទ ៤:៣,៩ ផ ខ.១៤,១៦ **២:២២** ព អស ២៩:១៣ មថ ១៥:៩ ទត ១:១៤ ភ ១កថ ៦:១៣ **២:២៣** ម ខ.១៨

អ្នកជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ និងព្រះអង្គទ្រង់ផ្ទាល់ ។

**២:១២** "មើលការពន្យល់ រម ៦:៣-៤"។

**២:១៣** "មើលការពន្យល់ អភ ២:១-៩"។

**២:១៤** *សេចក្តីដែលកត់ទុក* សំដៅលើក្រិត្យវិន័យលោកម៉ូសេ ដែលមានកត់ត្រានូវបញ្ញត្តិសម្រាប់អនុវត្តនៅក្នុងជីវិត ។

**២:១៥** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះអម្ចាស់បានរំដោះអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ឱ្យបានរួចពីអំណាចនៃក្រិត្យវិន័យ ។ ម្យ៉ាងទៀតទ្រង់បានទម្លាក់សាតាំង និងវិញ្ញាណអាក្រក់ (ពួកគ្រប់គ្រង និងពួកមានអំណាច ១:១៦ អភ ៦:១២) ដែលនាំមនុស្សឱ្យវង្វេង និងធ្វើតាមសេចក្តីបង្រៀនខុសឆ្គង។ ជាទូទៅ ពួកទាហានរ៉ូម៉ាំង តែងតែបណ្តើរពួកឈ្លើយសឹកនៅតាមផ្លូវ និងតាមទីសាធារណៈ ឱ្យពួកបណ្តាជនឃើញ ដើម្បីបង្ហាញនូវភស្តុតាងអំពីជ័យជម្នះទាំងស្រុងរបស់ពួកគេនៅក្នុងសង្គ្រាម (២កថ ២:១៤ និងការពន្យល់)។ ការដែលព្រះយេស៊ូវគ្រីស្ទមាន ជ័យជម្នះលើសាតាំង និងវិញ្ញាណអាក្រក់ត្រូវបានកត់ត្រាយ៉ាងច្បាស់នៅក្នុងបទ គម្ពីរ "មថ ១២:២៩ លក ១០:១៨ រម ១៦:២០"។

**២:១៦** "សូមប្រៀបធៀបនឹង រម ១៤:១-១៥:១៣"។

**២:១៧** *ស្រមោល* គ្រប់ពិធីបុណ្យផ្សេងៗដែលប្រារព្ធធ្វើនៅក្នុងសញ្ញាចាស់ គឺជាស្រមោល (ហព ៨:៥ ១០:១) ពីព្រោះពិធីទាំងនោះ ជានិមិត្តរូបនៃការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ ។ ពួកអ្នកប្រឆាំងនៅតែទទូចឱ្យមានការប្រារព្ធធ្វើពិធីបុណ្យទាំងនោះ ដោយពុំព្រមទទួលស្គាល់ថាការទាំងនោះបានសម្រេចហើយទេ ។ គ្រប់សេចក្តីដែលពួកគ្រូខុសឆ្គងតែងតែលើកយកមកបង្រៀន គឺត្រូវផ្សាផ្ជាប់ទៅនឹងការប្រតិបត្តិដ៏តឹងរ៉ឹងទៀតផង ដូចមានបញ្ជាក់នៅក្នុង "ខ.២០-២១"។

**២:១៨** *ដោយគេប្រព្រឹត្តបែបសុភាព* ឃ្លានេះសំដៅលើការដែលក្លែងធ្វើជាសុភាព ក្នុងគោលបំណងនាំពួកជំនុំ ឱ្យវង្វេងចេញពីសេចក្តីជំនឿលើព្រះអម្ចាស់ ។ ពួកអ្នកទាំងនោះតែងតែថ្លែងថា មានព្រះដែលមានអំណាចលើមនុស្សលោក ហើយពួកគេអាចថ្វាយបង្គំព្រះនោះតាមរយៈពួកទេវតា ។ នៅសតវត្សរ៍ទី២ មានពួកខុសឆ្គងបានដើរបោកបញ្ឆោត ដោយប្រើនូវតារាងឈ្មោះរបស់វិញ្ញាណមួយចំនួន ដែលពួកគេយល់ថា មនុស្សអាចចូលទៅព្រះបានតាមរយៈវិញ្ញាណទាំងនោះ ។ *ពួកទេវតា* ត្រង់ចំណុចនេះលោកប៉ុលចង់បញ្ជាក់ប្រាប់ពួកជំនុំនៅទីក្រុងកូល៉ុសថា មិនត្រូវអនុញ្ញាតឱ្យពួកគ្រូខុសឆ្គងមានឱកាសបង្រៀនពួកគេ នូវគោលទ្ធិខុសឆ្គង ដែលនាំមនុស្សឱ្យងាកចេញពីសេចក្តីជំនឿលើព្រះអម្ចាស់ទេ (ពួកគ្រូខុសឆ្គងទាំងនោះ តែងធ្វើឫកជាសុភាព និងនាំមនុស្សឱ្យថ្វាយបង្គំរូបទេវតា ឬវិញ្ញាណផ្សេងៗ)។

**២:១៩** *មិនកាន់ជាប់តាមសិរសាទេ* ឃ្លានេះបញ្ជាក់អំពីកំហុសឆ្គងនៃសេចក្តីបង្រៀនរបស់ពួកប្រឆាំងដែលពុំព្រមទទួលស្គាល់ថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះដ៏ពិតទេ (ខ.៩ ១:១៩)។

**២:២០** *បឋមសិក្សារបស់លោកីយ* "ខ.៨ និងការពន្យល់"។

**២:២១** បទគម្ពីរនេះបង្ហាញនូវសេចក្តីបង្រៀនរបស់ពួកគ្រូខុសឆ្គង (ពួកនេះតែងប្រកាន់នូវទំនៀមទម្លាប់ផ្សេងៗនៅក្នុងសញ្ញាចាស់) នៅឯទីក្រុងកូល៉ុស

**២:២៣** សេចក្តីនៅក្នុងបទគម្ពីរនេះ បញ្ជាក់អំពីលក្ខណៈរបស់ពួកប្រឆាំងនៅទីក្រុងកូល៉ុស (១).ជាប្រព័ន្ធនៃគោលលទ្ធិសាសនា និងទស្សនវិជ្ជា (២).ជាប្រព័ន្ធនៃសេចក្តីបង្រៀនខុសឆ្គង ដែលពួកគេបង្កើតឡើងដោយខ្លួនឯង និងមិនមែនមកពីព្រះទេ (៣).ពួកគ្រូខុសឆ្គងទាំងនោះព្យាយាមធ្វើឫកជាសុភាព និងបន្ទាបខ្លួន (៤).អាចឈានទៅដល់ការដាក់ទណ្ឌកម្មដ៏អាក្រក់លើរូបកាយ លោកប៉ុលបញ្ជាក់ថា ពួកគេធ្វើដូច្នោះ គឺជាការឥតប្រយោជន៍ ព្រោះពួកគេ

## ច្បាប់សម្រាប់ការរស់នៅជាបរិសុទ្ធ

**៣** ១ដូច្នេះ បើសិនជាអ្នករាល់គ្នាបានរស់ឡើងវិញ ជាមួយ
នឹងព្រះគ្រីស្ទ[យ] នោះចូរស្វែងរកអស់ទាំងសេចក្ដីដែលនៅ
ស្ថានលើវិញ ជាស្ថានដែលព្រះគ្រីស្ទគង់ខាងស្ដាំនៃព្រះ[រ]
២ចូរផ្ចង់ចិត្តទៅឯសេចក្ដីទាំងអស់ដែលនៅខាងលើ កុំឱ្យ
ផ្ចង់ទៅឯសេចក្ដីទាំងប៉ុន្មាន ដែលនៅផែនដីឡើយ[ល] ៣ដ្បិត
អ្នករាល់គ្នាបានស្លាប់ហើយ[វ] ជីវិតអ្នករាល់គ្នាក៏លាក់ទុកក្នុង
ព្រះជាមួយនឹងព្រះគ្រីស្ទ ៤កាលណាព្រះគ្រីស្ទដ៏ជាជីវិតនៃ
យើង[ស]បានលេចមក[ហ] នោះអ្នករាល់គ្នានឹងលេចមកក្នុង
សិរីល្អ ជាមួយនឹងទ្រង់ដែរ[ឡ]។
៥ដូច្នេះចូរសំឡាប់[អ]និស្ស័យសាច់ឈាមរបស់អ្នករាល់គ្នា
ដែលនៅផែនដីនេះចេញ[ក] គឺជាការសហាយស្មន់[ខ] ស្មោក
គ្រោក សំរើបសំរាល ប៉ងប្រាថ្នាអាក្រក់ និងសេចក្ដីលោភ[គ]
ដែលរាប់ទុកដូចជាការថ្វាយបង្គំរូបព្រះ[ឃ] ៦គឺដោយហេតុ
សេចក្ដីទាំងនោះ បានជាសេចក្ដីខ្ញាល់របស់ព្រះ[ង]មកលើពួក
មនុស្សរឹងចចេស ៧ហើយអ្នករាល់គ្នាបានប្រព្រឹត្តក្នុងពួក
នោះកាលពីដើម គឺពីកាលដែលនៅរស់ក្នុងកិរិយាទាំង
នោះដែរ[ច] ៨តែឥឡូវនេះ ចូរឱ្យអ្នករាល់គ្នាលះ[ឆ]អស់ទាំង
អំពើនោះ គឺសេចក្ដីកំហឹង គ្នាន់ក្នាញ់ គំរក់ ប្រមាថ[ជ]
និងពាក្យអព្វមង្គល ចេញពីមាត់ចោលទៅ[ឈ] ៩កុំឱ្យកុហក
គ្នាឡើយ[ញ] ដ្បិតអ្នករាល់គ្នាបានដោះមនុស្សចាស់[ដ] និងអំពើ
របស់វាចោលចេញហើយ ១០ចូរប្រដាប់ខ្លួនដោយមនុស្ស
ថ្មីវិញ[ឋ] ដែលកំពុងតែកែឡើង[ឌ]ខាងឯសេចក្ដីចេះដឹង ឱ្យ
បានត្រូវនឹងរូបអង្គព្រះ ដែលបង្កើតមនុស្សថ្មីនោះមក[ឍ]
១១ជាសណ្ឋានដែលគ្មានសាសន៍ក្រេក និងសាសន៍យូដា[ណ]
ការកាត់ស្បែក ហើយមិនកាត់ស្បែក[ត] មនុស្សប្រទេសដទៃ
ឬជាតិមនុស្សព្រៃ បាវបំរើ ឬអ្នកជាផងនោះទេ[ថ] គឺព្រះគ្រីស្ទ
ទ្រង់ជាគ្រប់ទាំងអស់វិញ[ទ] ហើយទ្រង់ក៏គង់នៅក្នុងគ្រប់ទាំង
អស់ផង ។
១២ដូច្នេះ ចូរប្រដាប់កាយ[ធ] ដោយចិត្តក្តួលអាណិត
សប្បុរស សុភាព[ន] សំឡូត និងចិត្តអត់ធ្មត់[ប] ទុកដូចជាពួកអ្នក
រើសតាំង ដែលបរិសុទ្ធ ហើយស្ងួនភ្ងាដល់ព្រះចុះ ១៣ហើយ
ទ្រាំទ្រគ្នា[ផ] ទាំងអត់ទោសទៅវិញទៅមក បើអ្នកណាមាន

**៣:១** យ រម ៦:៥ រ មក ១៦:១៩ **៣:២** ល ភល ៣:១៩,២០ **៣:៣** វ រម ៦:២ ២កថ ៥:១៤ **៣:៤** ស កទ ២:២០ ហ ១កថ ១:៧ ឡ ១ពត ១:១៣ ១យហ ៣:២ **៣:៥** អ រម ៦:២ អភ ៤:២២ ក កទ ៥:២៤ ខ ១កថ ៦:១៨ គ អភ ៥:៣ ឃ កទ ៥:១៩–២១ អភ ៥:៥ **៣:៦** ង រម ១:១៨ **៣:៧** ច អភ ២:២ **៣:៨** ឆ អភ ៤:២២ ជ អផ ៤:៣១ ឈ អភ ៤:២៩ **៣:៩** ញ អភ ៤:២២, ២៥ ដ រម ៦:៦ **៣:១០** ឋ រម ៦:៤ ១៣:១៤ ឌ រម ១២:២ ២កថ ៤:១៦ អភ ៤:២៣ ឍ អភ ២:១០ **៣:១១** ណ រម ១០:១២ ១កថ ១២:១៣ ត ១កថ ៧:១៩ ថ កទ ៣:២៨ ទ អភ ១:២៣ **៣:១២** ធ ខ.១០ ន ភល ២:៣ ប ២កថ ៦:៦ កទ ៥:២២,២៣ អភ ៤:២ **៣:១៣** ផ អភ ៤:២

ធ្លាក់ទៅក្នុងការគ្រប់គ្រងនៃបំណងប្រាថ្នារបស់អំពើបាប ។ ម្យ៉ាងទៀត ពួកគ្រូខុសឆ្គងទាំងនោះ បានបង្កើតដោយខ្លួនឯងនូវប្រព័ន្ធ និងច្បាប់ទម្លាប់ផ្សេងៗសម្រាប់ថ្វាយបង្គំ ។

**៣:១–១០** នៅក្នុងវគ្គនេះពិពណ៌នាអំពីជីវិតរបស់គ្រីស្ទបរិស័ទថា ពួកគេបានស្លាប់ (ខ.៣) បានរស់ឡើងវិញជាមួយនឹងព្រះគ្រីស្ទ (ខ.១) បាននៅជាមួយនឹងព្រះគ្រីស្ទនៅស្ថានសួគ៌ (ខ.៣) បានដោះមនុស្សចាស់ចេញ (ខ.៩) បានប្រដាប់ខ្លួនដោយមនុស្សថ្មីវិញ (ខ.១០)។ ម្យ៉ាងទៀត ក៏មាននូវការបង្គាប់បញ្ជាមួយចំនួនដែលគ្រីស្ទបរិស័ទត្រូវអនុវត្តនៅក្នុងជីវិតរបស់ខ្លួន គឺផ្ចង់ចិត្តទៅឯសេចក្ដីទាំងអស់ដែលនៅខាងលើ(ខ.១–២) កុំឱ្យផ្ចង់ទៅឯសេចក្ដីទាំងប៉ុន្មានដែលនៅផែនដីឡើយ (ខ.២,៥) លះបង់នូវសេចក្ដីកំហឹង គ្នាន់ក្នាញ់ គម្រក់ ប្រមាថ និងពាក្យ អព្វមង្គល (ខ.៨)។ ជាសង្ខេបមកគឺ ព្រះអម្ចាស់បានត្រាស់ហៅពួកគេឱ្យមកទទួល នូវបទពិសោធន៍ក្នុងទ្រង់ជារៀងរាល់ថ្ងៃ (រម ៦:១–១៣)។

**៣:៤** *បានលេចមក* សំដៅលើការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ (យហ ៣:២)។

**៣:៥,៨** "មើលការពន្យល់ រម ១:២៩–៣១"។

**៣:៦** *សេចក្ដីខ្ញាល់របស់ព្រះ* ត្រង់ចំណុចនេះបញ្ជាក់ថា ព្រះអម្ចាស់មានពេញដោយសេចក្ដីមេត្តាករុណា និងយុត្តិធម៌(សក ១:២ រម ១:១៨ និងពន្យល់)។

**៣:៩–១០** *ដោះមនុស្សចាស់ . . . ប្រដាប់ខ្លួនដោយមនុស្សថ្មី* មានន័យថា គ្រីស្ទបរិស័ទត្រូវលះបង់នូវផ្លូវអាក្រក់ ហើយមករស់នៅតាមព្រះបន្ទូលរបស់ព្រះគ្រីស្ទវិញ គឺដូចជាអ្នកដែលដោះអាវដែលប្រឡាក់ដោយធូលីចេញ ហើយពាក់អាវថ្មី ដែលគ្មានប្រឡាក់ធូលីដូច្នោះដែរ (ខ.១២–១៤ រម ១៣:១២ កទ ៣:២៧ អភ ៤:២២–២៤)។

**៣:១០** *កំពុងតែកែឡើង* "មើលការពន្យល់ ២កថ ៥:១៧"។ *សេចក្ដីចេះដឹង* "១:១០ ២:២–៣ និងការពន្យល់"។ *ឱ្យបានត្រូវនឹងរូបអង្គព្រះ ដែលបង្កើតមនុស្សថ្មីនោះមក* "សូមមើល លប ១:២៦ និងការពន្យល់"។

**៣:១១** *មនុស្សប្រទេសដទៃ* សំដៅលើពួកអ្នកដែលមិននិយាយភាសាក្រិក និងត្រូវបានគេចាត់ទុកថា ជាអ្នកដែលមិនមានអារ្យធម៌រុងរឿង (ឬមិនមានការរីកចម្រើន)។ *ជាតិមនុស្សព្រៃ* សំដៅលើជាតិសាសន៍មួយដែលត្រូវបានគេទទួលស្គាល់ថា មានភាពសាហាវឃោរឃៅ ប្រៀបបាននឹងសត្វសាហាវនៅក្នុងព្រៃ។ ពួកនេះមានដើមកំណើតពីតំបន់មួយ ដែលសព្វថ្ងៃស្ថិតនៅភាគខាងត្បូងនៃប្រទេសរុស្ស៊ី ។ *ព្រះគ្រីស្ទ ទ្រង់ជាគ្រប់ទាំងអស់វិញ* ព្រះយេស៊ូវទ្រង់បានបង្រួបបង្រួមមនុស្សមកពីគ្រប់ជាតិសាសន៍ គ្រប់វប្បធម៌ទាំងអស់ ឱ្យបានមករួមគ្នាវិញ ។ ម្យ៉ាងទៀត ការបែងចែក ការរើសអើងទាំងនោះ មិនត្រូវឱ្យមានជាបញ្ហាទៀតទេ គឺត្រូវយកព្រះគ្រីស្ទជាទីមួយវិញ (កទ ៣:២៨ និងការពន្យល់)។

**៣:១២** *ពួកអ្នករើសតាំង* ពួកអ៊ីស្រាអែលត្រូវបានហៅថា ពួកអ្នករើសតាំង (ចទ ៤:៣៧) ហើយគ្រីស្ទបរិស័ទក៏ត្រូវបានហៅដូច្នេះដែរ (១ពត ២:៩ និងពន្យល់)។ នៅក្នុងសំបុត្ររបស់លោកប៉ុលបានបញ្ជាក់អំពីការដែលព្រះអម្ចាស់ជ្រើសរើសរាស្ត្ររបស់ទ្រង់ (អភ ១:៤ និងការពន្យល់) ហើយនៅក្នុងព្រះគម្ពីរក៏បានបញ្ជាក់យ៉ាងច្បាស់ថា ការនេះមិនមែនជាភារកិច្ចរបស់មនុស្សលោកទេ ។ ម្យ៉ាងទៀត គ្រីស្ទបរិស័ទត្រូវបានជ្រើសរើសឱ្យបានទទួលនូវជីវិតអស់កល្បជានិច្ច ដូច្នេះពួកគេ ត្រូវខំប្រឹងរស់នៅតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ។ សម្រាប់លោកប៉ុល ការដឹកនាំមកពីព្រះអម្ចាស់ និងទំនួលខុសត្រូវរបស់មនុស្សលោក គឺមានទំនាក់ទំនងគ្នា ។ *ចូរប្រដាប់កាយដោយ . . .* មើល"ទដ ១០៩:២៩ និងការពន្យល់"។

ហេតុទាស់នឹងអ្នកណា នោះចូរអត់ទោសឱ្យគេចុះ ដូចជា
ព្រះគ្រីស្ទបានអត់ទោសឱ្យអ្នករាល់គ្នាដែរ[ព] ១៤ចូរបន្ថែម
ទាំងសេចក្តីស្រឡាញ់ថែមទៀត[ភ] ជាចំណងនៃសេចក្តីគ្រប់
លក្ខណ៍[ម] ១៥ចូរឱ្យសេចក្តីមេត្រី[យ] របស់ព្រះគ្រីស្ទ[រ] ត្រួតត្រា
នៅក្នុងចិត្ត ដែលទ្រង់បានហៅអ្នករាល់គ្នាមកក្នុងសេចក្តី
នោះឯង ឱ្យមានរូបកាយតែ១[ល] ហើយត្រូវដឹងគុណផង
១៦ចូរឱ្យព្រះបន្ទូលនៃព្រះគ្រីស្ទ[វ] បានសណ្ឋិតនៅក្នុងអ្នករាល់
គ្នាជាបរិបូរ ដោយប្រាជ្ញាគ្រប់យ៉ាង[ស] ទាំងបង្រៀនហើយ
ទូន្មានគ្នា ដោយនូវទំនុកដំកើង[ហ] ទំនុកបរិសុទ្ធ នឹងចំរៀង
ខាងឯវិញ្ញាណ ទាំងច្រៀងក្នុងចិត្តថ្វាយព្រះ[ឡ] ដោយព្រះ
គុណ ១៧ហើយក្នុងគ្រប់ការទាំងអស់ ទោះបើការអ្វីដែល
អ្នករាល់គ្នានឹងធ្វើ[អ] ដោយពាក្យសំដី ឬកិរិយាក៏ដោយចូរធ្វើ
ទាំងអស់ ដោយព្រះនាមនៃព្រះអម្ចាស់យេស៊ូវ ទាំងអរព្រះ
គុណ[ក]ដល់ព្រះដ៏ជាព្រះវរបិតា ដោយសារទ្រង់ផង ។

## ច្បាប់សម្រាប់ផ្ទះគ្រីស្ទបរិស័ទ

*៣:១៨–៤:១ – អផ ៥:២២–៦:៩*

១៨ពួកស្រីៗអើយ ចូរចុះចូលចំពោះប្តីខ្លួន[ខ] ដូចជាគួរ
គប្បីក្នុងព្រះអម្ចាស់ ១៩ពួកប្រុសៗអើយ ចូរស្រឡាញ់ប្រពន្ធ
ចុះ កុំឱ្យមានចិត្ត ជិនឆ្អន់ឡើយ ២០ក្មេងរាល់គ្នាអើយ ចូរស្តាប់
បង្គាប់ឪពុកម្តាយ ក្នុងគ្រប់ការទាំងអស់ដ្បិតព្រះអម្ចាស់
ទ្រង់សព្វព្រះហឫទ័យ យ៉ាងដូច្នោះឯង ២១ឱឪពុករាល់គ្នា
អើយ កុំឌុកដាន់កូនចៅឡើយ ក្រែងវារសាយចិត្តចេញ
២២ពួកបាវបំរើអើយ ចូរស្តាប់បង្គាប់ចៅហ្វាយនាយខាង
សាច់ឈាម ក្នុងគ្រប់ការទាំងអស់ចុះ មិនមែនតែកាលនៅ
មុខគេប៉ុណ្ណោះ ដូចជាចង់ផ្គាប់ចិត្តមនុស្សនោះទេ គឺដោយ
ចិត្តស្មោះត្រង់វិញ ទាំងកោតខ្លាចដល់ព្រះផង ២៣ហើយ
ការអ្វីដែលត្រូវធ្វើក៏ដោយ ចូរធ្វើឱ្យអស់ពីចិត្តទុកដូចជាធ្វើ
ថ្វាយដល់ព្រះអម្ចាស់ មិនមែនដល់មនុស្សទេ ២៤ដោយដឹង
ថា អ្នករាល់គ្នានឹងទទួល រង្វាន់[គ]ជាមរដក[ឃ]អំពីព្រះអម្ចាស់
មក ដ្បិតអ្នករាល់គ្នាជាអ្នក បំរើរបស់ព្រះគ្រីស្ទជាព្រះអម្ចាស់
២៥ឯអ្នកណាដែលប្រព្រឹត្តខុសឆ្គង នោះនឹងទទួលតាមការ
កំហុសរបស់ខ្លួន ហើយទ្រង់មិនរើសមុខអ្នកណាឡើយ[ង] ។

**៤** ១ពួកចៅហ្វាយរាល់គ្នាអើយ ចូរបើកឱ្យដល់អ្នកបំរើ
របស់អ្នក តាមត្រឹមត្រូវ ហើយទៀងត្រង់ចុះ[ច] ដោយដឹងថា
អ្នកក៏មានចៅហ្វាយ១ នៅស្ថានសួគ៌ដែរ ។
២ចូរព្យាយាមក្នុងសេចក្តីអធិស្ឋាន[ឆ] ទាំងចាំយាមក្នុងសេចក្តី

**៣:១៣** ព អក ៤:៣២
**៣:១៤** ភ ១កថ ១៣:១–១៣ ម រម ១៥:៥
**៣:១៥** យ រម ១៤:១៩ រ រម ១២:៥ ល យហ ១៤:២៧
**៣:១៦** វ រម ១០:១៧ ស កល ១:២៨ ហ ទដ ៤៧:៧ ឡ អក ៥:១៩
**៣:១៧** អ ១កថ ១០:៣១ ក អក ៥:២០
**៣:១៨** ខ អក ៥:២២
**៣:២៤** គ កច ២០:៣២ ឃ មថ ១៦:២៧
**៣:២៥** ង កច ១០:៣៤
**៤:១** ច លវ ២៥:៤៣,៥៣

**៣:១៤** "មើលការពន្យល់ ១កថ ១៣:១៣"។

**៣:១៥** *សេចក្តីមេត្រីរបស់ព្រះគ្រីស្ទ* ពាក្យថា "សេចក្តីមេត្រី" នៅត្រង់ចំណុចនេះ គឺទទួលបានមកអំពីព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ ដើម្បីជំនួសនូវលក្ខណៈឃោឃៅ និងលក្ខណៈឈ្លោះប្រកែកគ្នា ។ សេចក្តីមេត្រីរបស់ព្រះគ្រីស្ទគឺត្រូវតែគ្រប់គ្រងលើទំនាក់ទំនងរបស់មនុស្សលោកទាំងអស់ (មថ ១០:៣៤ និងការពន្យល់)។ *ត្រូវដឹងគុណផង* "មើលការពន្យល់ អក ៥:២០"។

**៣:១៦** *ព្រះបន្ទូលនៃព្រះគ្រីស្ទ* សំដៅលើគ្រប់សេចក្តីបង្រៀនរបស់ព្រះយេស៊ូវ ដែលនៅក្នុងសម័យកាលពួកជំនុំនៅទីក្រុងកូល៉ុស ត្រូវបានលើកយកមកបង្រៀនដោយផ្ទាល់មាត់តែម្តង ។ ទោះជាយ៉ាងណាក៏ដោយ ក៏សេចក្តីដែលមានចែងនៅក្នុងព្រះគម្ពីរសញ្ញាចាស់ និងសេចក្តីបង្រៀននៅក្នុងសញ្ញាថ្មី គឺមានទំនាក់ទំនងគ្នាជានិច្ច ។ *ទំនុកដំកើង ទំនុកបរិសុទ្ធ និងចំរៀងខាងឯវិញ្ញាណ* គោលលទ្ធិដ៏សំខាន់ មួយចំនួនត្រូវបានបើកសំដែងឱ្យគ្រីស្ទបរិស័ទបានដឹង តាមរយៈសំបុត្ររបស់លោកប៉ុល (១:១៥–២០ អក ៥:១៤ ភល ២:៦–១១ ១ធថ ៣:១៦)។ *ទំនុកដំកើង* សំដៅលើទំនុកតម្កើងនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលផ្នែកខ្លះត្រូវបានពួកជំនុំបញ្ចូលនូវទំនុកភ្លេង ។ ទំនុកតម្កើងក៏អាចរាប់បញ្ចូលផងដែរ នូវទំនុកនិពន្ធថ្មីៗ សម្រាប់ថ្វាយបង្គំ (១កថ ១៤:២៦)។ *ទំនុកបរិសុទ្ធ* ជាបទចម្រៀងសរសើរ ជា ពិសេសត្រូវបានប្រើក្នុងការសរសើរ (ហព ២:១២ និងការពន្យល់ មថ ២៦:៣០) និងមានលក្ខណៈដូចទំនុកតម្កើងក្នុងសញ្ញាចាស់ ដែលសរសើរដល់ព្រះអម្ចាស់ ។ *បទចំរៀង* រៀបរាប់នូវការអស្ចារ្យរបស់ព្រះអម្ចាស់ និងសរសើរទ្រង់ចំពោះការទាំងនោះ (វវ ៥:៩ និងពន្យល់) មានលក្ខណៈដូចទំនុកតម្កើងក្នុងគម្ពីរសញ្ញា ចាស់ និងពិពណ៌នានូវការអស្ចារ្យដែលទ្រង់បានធ្វើ (អភ ៥:១៩ និងការពន្យល់)។

**៣:១៨–៤:១** "មើលការពន្យល់ អក ៥:២២–៦:៩"។

**៣:២០** *ក្នុងគ្រប់ការទាំងអស់* គឺសំដៅលើគ្រប់ការទាំងអស់ដែលមិនមែនជាអំពើបាប (កច ៥:២៩)។

**៣:២២–៤:១** នៅក្នុងវគ្គនេះមិនមែនមានន័យថា លោកប៉ុលចង់ដោះលែងពួកបាវបម្រើឱ្យបានរួចខ្លួនទេ ហើយក៏មិនមែនឱ្យពួកគេប្រឆាំងនឹងម្ចាស់របស់ខ្លួនដែរ ។ ប៉ុន្តែ គាត់ចង់ឱ្យពួកគេទាំងអស់គ្នា បង្ហាញនូវសារសំខាន់នៃទំនាក់ទំនងរវាងពួកគេក្នុងនាមជាគ្រីស្ទបរិស័ទ និងឱ្យកែប្រែនូវការប្រព្រឹត្តផ្សេងៗ ដែលផ្ទុយនឹងព្រះបន្ទូលនៃព្រះអម្ចាស់ ។ មូលហេតុដែលលោកប៉ុលនិយាយអំពីបាវបម្រើ និងចៅហ្វាយ ច្រើនជាងនិយាយអំពីទំនាក់ទំនងរវាងប្តីនិងប្រពន្ធ ក្មេងៗនិងឪពុកម្តាយ អាចមកពីលោកអូនេស៊ីម ដែលជាបាវបម្រើរបស់លោកភីលេម៉ូន បានធ្វើដំណើរទៅទីក្រុងកូល៉ុសជាមួយនឹងលោកទីឃីកុសដែរ ដើម្បីនាំយកសំបុត្រកូល៉ុសនេះ និងសំបុត្រភីលេម៉ូនទៅប្រគល់ជូនលោកភីលេម៉ូន (លោកភីលេម៉ូន ជាចៅហ្វាយលោកអូនេស៊ីម) ដែលរស់នៅទីក្រុងកូល៉ុសនោះដែរ ។ ម្យ៉ាងទៀត ដោយលោកអូនេស៊ីមជាបាវបម្រើ ដែលបានរត់ចេញពីចៅហ្វាយរបស់ខ្លួន គឺលោកភីលេម៉ូន ដូច្នេះហើយបានជាលោកប៉ុលនិយាយអំពីបញ្ហាបាវបម្រើ និងចៅហ្វាយច្រើននៅក្នុងវគ្គនេះ ។

**៣:២៤** *មរដក* "១ពត ១:៤ ហព ៩:១៥ និងការពន្យល់"។

**៣:២៥** *ទ្រង់មិនរើសមុខអ្នកណាឡើយ* "មើលការពន្យល់ កច ១០:៣៤"។

នោះឯង ដោយពាក្យអរព្រះគុណ
៣ព្រមទាំង អធិស្ឋាន
ឱ្យយើងខ្ញុំផង ដើម្បីឱ្យព្រះបានបើកទ្វារ[ជ]ឱ្យយើងខ្ញុំផ្សាយ
ព្រះបន្ទូល ជាសេចក្តីអាថ៌កំបាំង[ឈ]នៃព្រះគ្រីស្ទ ដែលខ្ញុំ
ជាប់ចំណង ដោយព្រោះព្រះបន្ទូលនោះឯង[ញ]
៤ប្រយោជន៍
ឱ្យខ្ញុំបានសំដែងព្រះបន្ទូលតាមដែលគួរគប្បី
៥ចូរប្រព្រឹត្ត
នឹងពួកអ្នកក្រៅ[ដ]ដោយប្រាជ្ញា[ឋ] ទាំងលៃយកឱកាសឱ្យទាន់
ពេលផង[ឌ]
៦ចូរឱ្យពាក្យសំដីរបស់អ្នករាល់គ្នា បានប្រកប
ដោយព្រះគុណជានិច្ច[ឍ] ទាំងបង់អំបិលផង[ណ] ដើម្បីឱ្យដឹងជា
បែបយ៉ាងណា ដែលគួរឆ្លើយដល់មនុស្សនិមួយៗ[ត]។

## សេចក្តីគួរសមចុងក្រោយ

៧អ្នកទីឃីកុស[ថ] ជាបងប្អូនស្ងួនភ្ងា គឺជាអ្នកជំនួយដ៏ស្មោះ
ត្រង់ ហើយជាបាវបំរើជាមួយគ្នា[ទ]ក្នុងព្រះអម្ចាស់ គាត់នឹង
ប្រាប់ឱ្យអ្នករាល់គ្នាដឹងពីអស់ទាំងរឿងរបស់ខ្ញុំ
៨ខ្ញុំបានចាត់
គាត់មកឯអ្នករាល់គ្នា សំរាប់ការនោះឯង គឺឱ្យបានដឹងរឿង
ពីអ្នករាល់គ្នា ហើយឱ្យបានកំសាន្តចិត្តអ្នករាល់គ្នាផង[ធ]
៩ក៏ចាត់អ្នកអូនេស៊ីម[ន] ជាបងប្អូនស្ងួនភ្ងា ហើយស្មោះត្រង់
ដែលមកពីពួកអ្នករាល់គ្នាដែរ[ប] អ្នកទាំង២នេះនឹងប្រាប់
ឱ្យអ្នករាល់គ្នាដឹង ពីគ្រប់ការទាំងអស់ ដែលនៅខាងនាយ
នោះ ។
១០អ្នកអើរីស្តាក[ផ] ដែលជាប់គុកជាមួយនឹងខ្ញុំ ហើយ
ម៉ាកុស[ព] ជាក្មួយបាណាបាស[ភ] គាត់ជំរាបសួរមកអ្នករាល់គ្នា
អ្នករាល់គ្នាបានទទួលបង្គាប់ ពីរឿងគាត់រួចទៅហើយថា
បើគាត់មកឯអ្នករាល់គ្នា នោះត្រូវទទួលគាត់ចុះ
១១ឯអ្នក
យេស៊ូវ ដែលហៅថា យូស្ទុស គាត់ជំរាបសួរមកអ្នករាល់
គ្នាដែរ អ្នកទាំងនោះជាពួកកាត់ស្បែក ឯពួកអ្នកដែលធ្វើ
ការជាមួយនឹងខ្ញុំ[ម]ខាងឯនគរព្រះ មានតែប៉ុណ្ណឹងទេ ដែល
កំសាន្តចិត្តខ្ញុំ
១២អ្នកអេប៉ាប្រាស[យ] ជាបាវបំរើនៃព្រះគ្រីស្ទ
ដែលមកពីពួកអ្នករាល់គ្នា[រ] គាត់ សូមជំរាបសួរមកអ្នករាល់
គ្នាដែរ គាត់ខំប្រឹងអធិស្ឋានជានិច្ច[ល] ឱ្យអ្នករាល់គ្នាបានឈរ
ជាគ្រប់លក្ខណ៍[វ] ហើយពេញខ្នាត តាមព្រះហឫទ័យនៃព្រះ
គ្រប់ជំពូក
១៣ខ្ញុំធ្វើបន្ទាល់ពីគាត់ថា គាត់មានចិត្តឧស្សាហ៍
ដល់អ្នករាល់គ្នា នឹងពួកអ្នកនៅក្រុងឡៅឌីសេ[ស] ហើយពួក
អ្នកនៅក្រុងហេរ៉ាប៉ូលជាខ្លាំងណាស់
១៤លោកលូកា ជាគ្រូ

**៤:២** ឆ លក ១៨:១
**៤:៣** ជ កច ១៤:២៧
ឈ រម ១៦:២៥
ញ កច ២១:៣៣
**៤:៥** ដ មក ៤:១១
ឋ អភ ៥:១៥
ឌ អភ ៥:១៦
**៤:៦** ឍ អភ ៤:២៩
ណ មក ៩:៥០
ត ១ពត ៣:១៥
**៤:៧** ថ កច ២០:៤
ទ អភ ៦:២១,២២
កល ១:៧
**៤:៨** ធ អភ ៦:២១, ២២ កល ២:២
**៤:៩** ន ភម ១០
ប ខ.១២
**៤:១០** ផ កច ១៩:២៩
ព កច ១២:១២
ភ កច ៤:៣៦
**៤:១១** ម ភល ២:២៥
**៤:១២** យ កល ១:៧
ភម ២៣ រ ខ.៩
ល រម ១៥:៣០
វ ១កថ ២:៦ **៤:១៣** ស កល ២:១

**៤:២** *ចូរព្យាយាមក្នុងសេចក្តីអធិស្ឋាន* "មើលការពន្យល់ លក ១១:១ កច ២:៤២ រម ១២:១២ ១ថន ៥:១៧"។ *ចាំយាម* គឺសំដៅលើការប្រុងប្រយ័ត្ន និងវាងវៃ ខាងវិញ្ញាណ ។ *ដោយពាក្យអរព្រះគុណ* "មើលការពន្យល់ អភ ៥:២០"។

**៤:៣** *សេចក្តីអាថ៌កំបាំង* "មើលការពន្យល់ ១:២៦-២៧ រម ១១:២៥"។

**៤:៥** *ពួកអ្នកក្រៅ* សំដៅលើពួកអ្នកដែលពុំមែនជាគ្រីស្ទបរិស័ទ (១កថ ៥:១២-១៣ ១ថន ៤:១២ ១ធថ ៣:៧)។ *លៃយកឱកាសឱ្យទាន់ពេលផង* "មើលការ ពន្យល់ អភ ៥:១៦"។

**៤:៦** *ទាំងបង់អំបិល* អំបិលគឺត្រូវមានជាតិប្រៃ និងប្រើសម្រាប់ការពារវត្ថុមួយចំនួនមិនឱ្យខូចរលួយ ។ ដូចគ្នាដែរ ជីវិតរបស់គ្រីស្ទបរិស័ទ គឺត្រូវទាមទារនូវការការពារផងដែរ (៣:៨ អភ ៤:២៩)។

**៤:៧** *ទីឃីកុស* "មើលការពន្យល់ អភ ៦:២១"។

**៤:៩-១៧** នៅក្នុងវគ្គនេះមានលើកឡើងនូវឈ្មោះរបស់បុគ្គលមួយចំនួនដែលត្រូវបានលើកឡើងនៅក្នុងកណ្ឌគម្ពីរភីលេម៉ូនផងដែរគឺ អូនេស៊ីម (ខ.៩) អើរីស្តាក (ខ.១០) ម៉ាកុស (ខ.១០) អេប៉ាប្រាស (ខ.១២) លូកា (ខ.១៤) ដេម៉ាស (ខ.១៤) និងអើឃីព (ខ.១៧)។ដូច្នេះអាចសន្និដ្ឋានបានថា សំបុត្រកូល៉ុសនិងសំបុត្រភីលេម៉ូន ត្រូវបានសរសេរឡើងនៅក្នុងពេលតែមួយ និងកន្លែងតែមួយ ។

**៤:៩** *អូនេស៊ីម* "សូមមើលសេចក្តីផ្តើមកណ្ឌគម្ពីរភីលេម៉ូន ត្រង់ចំណុចអ្នកទទួល ប្រភព និងគោលបំណង"។

**៤:១០** *អើរីស្តាក* គាត់គឺជាអ្នកស្រុកម៉ាសេដូន ហើយឈ្មោះរបស់គាត់ត្រូវបានលើកឡើងបីដងនៅក្នុងកណ្ឌគម្ពីរកិច្ចការគឺ (១).គាត់បាននៅជាមួយលោកប៉ុលក្នុងអំឡុងពេលកើតវឹកវរនៅក្នុងពួកអ្នកក្រុងអេភេសូរ ដូច្នេះមានមនុស្សជាច្រើន នៅក្នុងក្រុងនេះបានស្គាល់គាត់ (កច ១៩:២៩) (២).គាត់ និងលោកទីឃីកុស (កច ២០:៤) បាននៅជាមួយនឹងលោកប៉ុលនៅប្រទេសក្រិក (៣).គាត់បាននៅជាមួយលោកប៉ុល ក្នុងដំណើរទៅទីក្រុងរ៉ូម (កច ២៧:២)។ *ម៉ាកុស* គាត់ជាអ្នកសរសេរកណ្ឌគម្ពីរម៉ាកុស ។ លោកប៉ុលបានទាស់សំដីនឹងលោកបាណាបាស និងមិនព្រមយកលោកម៉ាកុសទៅជាមួយ នៅក្នុងដំណើរបេសកកម្មរបស់គាត់លើកទីពីរ ព្រោះលោកម៉ាកុសបានចាកចោលពួកគាត់ នៅស្រុកប៉ាមភីលា (កច ១៥:៣៨ និងការពន្យល់)។ ប៉ុន្តែ ប្រហែលជា១២ឆ្នាំក្រោយមក បញ្ហាត្រូវបានដោះស្រាយ ព្រោះត្រង់ចំណុចនេះ និងក្នុងបទគម្ពីរ "ភម ២៤" លោកប៉ុលបានផ្ញើនូវការសួរសុខទុក្ខអំពីលោកម៉ាកុស ។ ប្រហែល៥ឆ្នាំក្រោយមកទៀត លោកប៉ុលបានបញ្ជាក់យ៉ាងច្បាស់ថា លោកម៉ាកុស គឺជាគូកន និងជាជំនួយដ៏ល្អរបស់គាត់ (២ធថ ៤:១១ មើលការពន្យល់ កច ១៥:៣៩)។

**៤:១៣** *ក្រុងហេរ៉ាប៉ូល* ជាទីក្រុងមួយនៅអាស៊ីមីន័រ (សព្វថ្ងៃគឺជាតំបន់មួយនៅប្រទេសទួរគី) មានចម្ងាយប្រហែល ៩,៦គ.ម ពីទីក្រុងឡៅឌីសេ និងមានចម្ងាយប្រហែល ២២,៤គ.ម ពីទីក្រុងកូល៉ុស ។ ពួកជំនុំនៅក្នុងក្រុងនេះប្រហែលបានចាប់ផ្តើមក្នុងអំឡុងពេល៣ឆ្នាំ ដែលលោកប៉ុលបានស្នាក់នៅទីក្រុងអេភេសូរ (កច ១៩) ប៉ុន្តែ ប្រហែលមិនមែនកើតឡើង ដោយសារលោកប៉ុលដោយផ្ទាល់ទេ (២:១)។

**៤:១៤** *លូកា* គាត់បានកត់ត្រាអំពីលោកប៉ុលនៅក្នុងកណ្ឌគម្ពីរកិច្ចការ និងបានធ្វើដំណើរជាមួយនឹងលោកប៉ុលញឹកញាប់ (កច ១៦:១០ និងការពន្យល់)។ គាត់បាននៅជាមួយនឹងលោកប៉ុល ក្នុងពេលគាត់ជាប់គុកនៅទីក្រុងរ៉ូម (កច ២៨) ដែលជាទីកន្លែងដែលគាត់សរសេរសំបុត្រកូល៉ុសនេះតែម្តង ។ *ដេម៉ាស* គាត់ម្នាក់នេះ ក្រោយមកបានចាកចោលលោកប៉ុល

ពេទ្យស្ងួនភ្ងា[ហ] និងអ្នកដេម៉ាស[ឡ] ក៏ជំរាបសួរមកអ្នករាល់
គ្នាដែរ ១៥សូមជំរាបសួរដល់ពួកបងប្អូននៅក្រុងឡៅឌីសេ[អ]
និងអ្នកនីមផាស ហើយពួកជំនុំដែលប្រជុំគ្នានៅផ្ទះគាត់[ក]
១៦កាលណាបានអានមើលសំបុត្រនេះ ក្នុងពួកបងប្អូនអ្នក
រាល់គ្នាហើយ នោះចូរឱ្យគេអានមើល[ខ]ក្នុងពួកជំនុំ នៅ
ក្រុងឡៅឌីសេដែរ រួចឱ្យអ្នករាល់គ្នាមើលសំបុត្រ ដែលផ្ញើ
ទៅពួកឡៅឌីសេផង ១៧សូមប្រាប់ដល់អ្នកអើឃីព[គ]ថា ចូរ
ប្រយ័ត្ននឹងការងារ ដែលបានទទួលក្នុងព្រះអម្ចាស់ហើយ
ចុះ ដើម្បីឱ្យបាន បំពេញការងារនោះ[ឃ]។
១៨ប៉ុលខ្ញុំសរសេរពាក្យជំរាបសួរនេះ ដោយដៃខ្លួនខ្ញុំ[ង]
សូមឱ្យអ្នករាល់គ្នានឹកចាំ[ច]ពីចំណងរបស់ខ្ញុំ[ឆ] សូមឱ្យអ្នករាល់
គ្នាបានប្រកបដោយព្រះគុណ[ជ]។ អាម៉ែន ។

**៤:១៤** ហ ២ធថ ៤:១១ ភម ២៤ ឡ ២ធថ ៤:១០ ភម ២៤
**៤:១៥** អ កល ២:១ ក រម ១៦:៥
**៤:១៦** ខ ២ថន ៣:១៤ ១ធថ ៤:១៣
**៤:១៧** គ ភម ២ ឃ ២ធថ ៤:៥
**៤:១៨** ង ១កថ ១៦:២១ ច ហព ១៣:៣ ឆ កច ២១:៣៣ ជ ១ធថ ៦:២១

(២ធថ ៤:១០)។

**៤:១៥** *ពួកជំនុំដែលប្រជុំគ្នានៅផ្ទះគាត់* ភាគច្រើនពួកជំនុំដំបូងតែងតែប្រជុំគ្នាថ្វាយបង្គំ និងប្រកបគ្នានៅតាមផ្ទះ ។ ជាទូទៅត្រូវបានប្រជុំគ្នា នៅក្នុងគ្រួសារណា មួយដូចជា នៅផ្ទះនាងព្រីស៊ីល និងអ័គីឡា (រម ១៦:៣–៥ ១កថ ១៦:១៩) នៅផ្ទះលោកភីលេម៉ូន (ភម ២) ផ្ទះនាងម៉ារា ជាម្ដាយលោកយ៉ូហាន (កច ១២:១២)។

**៤:១៦** *កាលណាបានអានមើលសំបុត្រនេះ* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកជំនុំដំបូងត្រូវអានសំបុត្ររបស់លោកប៉ុលដោយឮៗនៅក្នុងពួកជំនុំ ។

**៤:១៧** *អើឃីព* លោកប៉ុលហៅគាត់ថា"គូកនតយុទ្ធ"ជាមួយគាត់ (ភម ២)។

**៤:១៨** តាមទម្លាប់របស់លោកប៉ុល គឺគាត់បង្គាប់ឱ្យគូកនរបស់គាត់សរសេរ (រម ១៦:២២) ហើយចុងបញ្ចប់នៃសំបុត្រ គឺគាត់សរសេរដោយផ្ទាល់ដៃនូវការសួរសុខទុក្ខ (១កថ ១៦:២១ កទ ៦:១១ ២ថន ៣:១៧ ភម ១៩)។ ហត្ថលេខារបស់គាត់ គឺជាការធានាចំពោះសំបុត្ររបស់គាត់ ។ *ព្រះគុណ* "មើលការពន្យល់ រម ១:៧ ២កថ ១៣:១៤"។

សំបុត្រទី១របស់ប៉ុល

ដល់ពួកជំនុំ

# ថែស្សាឡូនីច

សេចក្តីផ្តើម

**ប្រភពនៃកណ្ឌគម្ពីរ ថែស្សាឡូនីច**

ជំនួយដ៏សំខាន់គឺការកំណត់នូវទីកន្លែងដែលលោកប៉ុល និងគូកនរបស់គាត់បានស្នាក់នៅ ដែលជាប់ទាក់ទងនឹងសំបុត្រថែស្សាឡូនីច នេះ ។ ដំណើរបេសកកម្មរបស់ពួកគាត់ទាំងនោះមាន:

១. លោកប៉ុល និងស៊ីលវ៉ាន (ស៊ីឡាស) បានធ្វើដំណើរពីទីក្រុងថែស្សាឡូនីចទៅឯក្រុងបេរា ។ ដោយព្រោះមិនបានបញ្ជាក់ឈ្មោះរបស់លោកធីម៉ូថេ (កច ១៧:១០ និងការពន្យល់) ដូច្នេះ គាត់ប្រហែលជាបានស្នាក់នៅក្នុងទីក្រុងថែស្សាឡូនីចតទៅទៀត ឬក៏ត្រឡប់ទៅឯទីក្រុងភីលីព ហើយបានមកជួបលោកប៉ុល និងស៊ីលវ៉ាននៅឯទីក្រុងបេរាវិញ (កច ១៧:១៤)។

២. លោកប៉ុលបានចាកចេញពីការបៀតបៀននៅក្រុងបេរា ទៅឯក្រុងអាថែន ដោយទុកឱ្យលោកធីម៉ូថេ និងស៊ីលវ៉ាននៅឯទីក្រុងបេរា (កច ១៧:១៤)។

៣. លោកប៉ុលផ្ញើសំបុត្រមកវិញ ប្រាប់ឱ្យលោកស៊ីលវ៉ាន និងលោកធីម៉ូថេ ត្រឡប់ទៅឯគាត់(ប៉ុល) នៅឯទីក្រុងអាថែនវិញ (កច ១៧:១៥ មើលការពន្យល់ ៣:១-២)។

៤. លោកធីម៉ូថេបានមកជួបលោកប៉ុលវិញនៅទីក្រុងអាថែន ហើយលោកប៉ុលបានបញ្ជូនគាត់ទៅឯទីក្រុងថែស្សាឡូនីច (៣:១-៥)។ ដោយព្រោះមិនបានបញ្ជាក់ឈ្មោះរបស់លោកស៊ីលវ៉ាន ដូច្នេះអាចសន្និដ្ឋានថា គាត់បានត្រឡប់ទៅឯទីក្រុងភីលីពវិញ ហើយលោកធីម៉ូថេបានត្រឡប់ទៅឯទីក្រុងថែស្សាឡូនីច (មើលការពន្យល់ ៣:១-២)។

៥. លោកប៉ុលបន្តទៅឯទីក្រុងកូរិនថូស (កច ១៨:១)។

៦. លោកធីម៉ូថេ និងលោកស៊ីលវ៉ានបានទៅឯលោកប៉ុលនៅឯទីក្រុងកូរិនថូស (៣:៦ កច ១៨:៥)។

៧. លោកប៉ុលសរសេរសំបុត្រទី១ថែស្សាឡូនីច ហើយផ្ញើទៅពួកជំនុំនៅទីនោះ ។

៨. ប្រហែល៦ខែក្រោយមក (ឆ្នាំទី៥១/៥២ គ.ស) លោកប៉ុលបានផ្ញើសំបុត្រទី២ទៅទីក្រុងថែស្សាឡូនីច ដោយឆ្លើយតបទៅនឹងព័ត៌មានដែលគាត់ទទួលបានពីពួកជំនុំនៅទីនោះ ។

**អ្នកនិពន្ធ កាលបរិច្ឆេទ និងទីកន្លែងនៃការសរសេរ**

តាមរយៈភស្តុតាង ទាំងខាងក្រៅ និងខាងក្នុងបទគម្ពីរផ្ទាល់បញ្ជាក់ថា លោកប៉ុលគឺជាអ្នកសរសេរសំបុត្រថែស្សាឡូនីចទីមួយនេះ (១:១ ២:១៨) ពីទីក្រុងកូរិនថូស (មើលការពន្យល់ ៣:១-២)។ អ្នកសរសេរសំបុត្រនៅក្នុងពួកជំនុំដំបូងបានយល់ស្របទៅនឹងការអះអាងនេះ ដោយមានទីបន្ទាល់ដែលចាប់ផ្តើមនៅឆ្នាំទី១៤០ គ.ស ។ ភាពជាអ្នកនិពន្ធរបស់លោកប៉ុលត្រូវបានបញ្ជាក់នៅក្នុងសំបុត្រនេះ (៣:១-២,៨-១១ ប្រៀបធៀបនឹង កច ១៥:៣៦ ២កច ១១:២៨)។ តាមរយៈការអះអាងប្រវិត្តិសាស្ត្រនៅក្នុងកណ្ឌគម្ពីរគឺតម្រូវទៅលើជីវិតរបស់លោកប៉ុល ដូចមានរៀបរាប់នៅក្នុង កណ្ឌគម្ពីរកិច្ចការ និងក្នុងសំបុត្រទាំងឡាយដែលគាត់បានសរសេរ (២:១៤-១៦ ប្រៀបធៀបនឹង កច ១៧:១៦)។

ដូច្នេះជាទូទៅ កាលបរិច្ឆេទត្រូវបានកំណត់យកឆ្នាំទី ៥១ គ.ស ។ ការគាំទ្រដ៏សំខាន់មួយចំពោះកាលបរិច្ឆេទនេះ ត្រូវបានរកឃើញនៅក្នុងសិលាចារឹកនៅឯឌែលភ្វី (Delphi) ប្រទេសក្រេក ដែលនៅក្នុងនោះបញ្ជាក់អំពីលោកកាលីយ៉ូ ជាអ្នកតំណាងសាសន៍រ៉ូមថា គាត់បានគ្រប់គ្រងនៅ ឆ្នាំទី៥១-៥២គ.ស និងបានបញ្ជាក់ថា លោកប៉ុលបានស្នាក់នៅឯទីក្រុងកូរិនថូសក្នុងឆ្នាំនោះដែរ (កច ១៨:១២-១៧ និងការពន្យល់ ១៨:១២)។ លើកលែងតែនៅក្នុងសំបុត្រកាឡាទីទេ ដែលត្រូវបានសរសេរមុន (ឆ្នាំទី ៤៨-៤៩ គ.ស?)។ សំបុត្រថែស្សាឡូនីចទី១ជាសំបុត្រមួយដែលលោកប៉ុលសរសេរមុនគេ ។

**ថែស្សាឡូនីច: ទីក្រុង និងពួកជំនុំ**

ថែស្សាឡូនីចជាទីក្រុងកំពង់ផែមួយដ៏មមាញឹក ស្ថិតនៅចុងឈូងសមុទ្រទែរម៉ាអ៊ិច (Thermaic Gulf)។ វាជាមជ្ឈមណ្ឌលទំនាក់ទំនង និងពាណិជ្ជកម្មដ៏សំខាន់មួយស្ថិតនៅទីប្រសព្វនៃផ្លូវ អ៊ិកណាធាន (Egnatian Way) និងផ្លូវដានូបេ (Danube) ទៅភាគខាងជើង ។

ម្យ៉ាងទៀត វាជាទីក្រុងធំជាងគេ នៅស្រុកម៉ាសេដូន និងជាទីក្រុងសំខាន់នៅក្នុងស្រុកនេះ ។

ប្រភពនៃពួកជំនុំនៅទីក្រុងថែស្សាឡូនីចមានរៀបរាប់នៅក្នុងបទគម្ពីរ "កច ១៧:១–៩"។ ដោយព្រោះលោកប៉ុលបានចាប់ផ្តើមបេសកកម្មរបស់គាត់នៅទីនោះ ក្នុងសាលាប្រជុំរបស់សាសន៍យូដា ដូច្នេះ អាចសន្និដ្ឋានថា ពួកជំនុំថ្មីគឺមានរួមបញ្ចូលនូវពួកយូដាផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅក្នុង "១:៩–១០ កច ១៧:៤" ហាក់ដូចជាបញ្ជាក់ថា សមាជិកពួកជំនុំភាគច្រើនជាពួកសាសន៍ដទៃ ។

**គោលបំណង**

លោកប៉ុលបានចាកចេញពីទីក្រុងថែស្សាឡូនីចយ៉ាងឆាប់រហ័ស (កច ១៧:៥-១០) បន្ទាប់ពីគាត់បានស្នាក់នៅទីនោះមួយរយៈមក។ ពួកអ្នកជឿដល់ព្រះអម្ចាស់មកពីពួកសាសន៍ដទៃ (១:៩) ត្រូវបានរស់នៅដោយមិនសូវមានការគាំទ្រនៅក្នុងពេលដែលមានការបៀតបៀន។ គោលបំណងរបស់លោកប៉ុលក្នុងការសរសេរសំបុត្រនេះ គឺដើម្បីលើកទឹកចិត្តពួកអ្នកជឿថ្មីៗ នៅក្នុងពេលដែលពួកគេជួបប្រទះនូវការលំបាក និងការបៀតបៀន (៣:៣–៥) និងដើម្បីផ្តល់នូវដំបូន្មានអំពីការរស់នៅក្នុងព្រះអម្ចាស់ (៤:១–១២) និងដើម្បីធានាអំពីអនាគតរបស់ពួកអ្នកដែលបានស្លាប់មុនពេលដែលព្រះគ្រីស្ទយាងមកជាលើកទីពីរ (៤:១៣–១៨ និងការពន្យល់)។

**គោលរឿង**

ទោះបីគោលរឿងដ៏សំខាន់នៃសំបុត្រនេះមានការប្រែប្រួលក៏ប្រធានបទនៃផ្នែកទេវសាស្ត្រ (គោលលទ្ធិ) ហាក់ដូចជាមាន លក្ខណៈសំខាន់នៅក្នុងសំបុត្រថែស្សាឡូនីចទាំងពីរ ។ គ្រប់ជំពូកនៃកណ្ឌគម្ពីរថែស្សាឡូនីចទី១ បញ្ចប់ដោយការអះអាងអំពីការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ ហើយជំពូកទី៤បានផ្តល់នូវការអះអាងដ៏សំខាន់ (១:៩–១០ ២:១៩–២០ ៣:១៣ ៤:១៣–១៨ ៥:២៣–២៤)។ ដូច្នេះ ការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទហាក់ដូចជាគោលគំនិតនៅក្នុងសំបុត្រនេះ និងជាគោលរឿងនៃសំបុត្រនេះតែម្តង ។ សំបុត្រថែស្សាឡូនីចទី១ និងទី២ត្រូវបានចាត់ទុកថា ជាសំបុត្រផ្នែកទេវសាស្ត្ររបស់លោកប៉ុល ។

**គម្រោងសង្ខេប**

**I. ការអរព្រះគុណសម្រាប់ពួកជំនុំនៅទីក្រុងថែស្សាឡូនីច (ជំពូក ១)**

ក. មូលហេតុនៃការអរព្រះគុណ (១:១–៤)

ខ. ភាពពិតនៃមូលហេតុ (១:៥–១០)

**II. ការការពារនៃសកម្មភាពសាវក និងពេលគ្មានវត្តមាន (ជំពូក ២–៣)**

ក. ការការពារនៃសកម្មភាពសាវក (២:១–១៦)

ខ. ការការពារនៅពេលអវត្តមាននៃសាវក (២:១៧–៣:១០)

គ. សេចក្តីអធិស្ឋាន (៣:១១–១៣)

**III. ការដាស់តឿនដល់ពួកជំនុំទីក្រុងថែស្សាឡូនីច (៤:១–៥:២២)**

ក. ការបារម្ភដំបូងនូវជីវិតផ្ទាល់ខ្លួន (៤:១–១២)

ខ. អំពីការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ (៤:១៣–៥:១១)

គ. ការបារម្ភដំបូងអំពីជីវិតពួកជំនុំ (៥:១២–២២)

**IV. សេចក្តីអធិស្ឋានសរុប ពាក្យជម្រាបសួរ និង ការសូមឱ្យព្រះអម្ចាស់ប្រទានព្រះពរ (៥:២៣–២៨)**

**១** ១ សំបុត្រប៉ុល សីលវ៉ាន[ក] និងធីម៉ូថេ[ខ] យើងខ្ញុំផ្ញើមកពួក
ជំនុំនៅក្រុងថែស្សាឡូនីច[គ] ដែលនៅក្នុងព្រះដ៏ជាព្រះវរបិតា
និងព្រះអម្ចាស់យេស៊ូវគ្រីស្ទ សូមឱ្យអ្នករាល់គ្នាបានប្រកប
ដោយព្រះគុណ និងសេចក្ដីសុខសាន្ត អំពីព្រះដ៏ជាព្រះ
វរបិតានៃយើង ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ[ឃ]។

## ការអរព្រះគុណសម្រាប់ជំនឿពួកជំនុំថែស្សាឡូនីច

២ យើងខ្ញុំអរព្រះគុណដល់ព្រះជានិច្ច ពីដំណើរអ្នករាល់
គ្នា[ង] ហើយកាលណាយើងខ្ញុំអធិស្ឋាន នោះក៏តែងដំណាលពី
អ្នករាល់គ្នា[ច] ៣ ដោយនឹកចាំជាដរាប ពីការដែលអ្នករាល់
គ្នាធ្វើ ដោយសេចក្ដីជំនឿ[ឆ] និងពីការនឿយហត់ ដែលធ្វើ
ដោយសេចក្ដីស្រឡាញ់[ជ] ហើយដែលអ្នករាល់គ្នាមានសេចក្ដី
សង្ឃឹមយ៉ាងមាំមួន ដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃ
យើងរាល់គ្នានៅចំពោះព្រះដ៏ជាព្រះវរបិតា នៃយើងផង ។

**១:១** ក កច ១៥:២២ ខ កច ១៦:១ ២ថន ១:១ គ កច ១៧:១ ឃ រម ១:៧
**១:២** ង រម ១:៨ អភ ៥:២០ ច រម ១:១០
**១:៣** ឆ កទ ៥:៦ ២ថន ១:១១ យក ២:១៤–២៦ ជ ១ថន ៣:៦ ២ថន ១:៣ ១កថ ១៣:១៣ ឈ រម ៨:២៥ ញ ភល ៤:២០
**១:៤** ដ កល ៣:១២ ២ថន ២:១៣

៤ ឱបងប្អូន ដែលព្រះទ្រង់ស្រឡាញ់អើយ[ដ] យើងខ្ញុំដឹងថា
ទ្រង់បានរើសតាំងអ្នករាល់គ្នាហើយ ៥ ដ្បិតដំណឹងល្អ[ឋ]របស់
យើងខ្ញុំ មិនបានផ្សាយមកដល់អ្នករាល់គ្នា ដោយពាក្យសំដី
តែប៉ុណ្ណោះទេ គឺដោយព្រះចេស្ដា[ឌ] និងព្រះវិញ្ញាណ
បរិសុទ្ធដែរ ហើយដោយសេចក្ដីជំនឿដ៏មោះមុតជាខ្លាំង
ថែមទៀតផង ដូចជាអ្នករាល់គ្នាដឹងហើយ[ឍ] ពីដំណើរយើង
ខ្ញុំ ដែលនៅក្នុងពួកអ្នករាល់គ្នាជាយ៉ាងណា សំរាប់នឹង
ជួយដល់អ្នករាល់គ្នា ៦ អ្នករាល់គ្នាក៏បានត្រាប់តាមយើងខ្ញុំ[ណ]
ហើយនឹងព្រះអម្ចាស់ ដោយបានទទួលព្រះបន្ទូល ដោយ
សេចក្ដីអំណរ[ត]របស់ព្រះវិញ្ញាណបរិសុទ្ធ[ថ] ក្នុងកាលដែល
កំពុងតែកើតទុក្ខលំបាកជាខ្លាំងផង[ទ] ៧ ដល់ម្ល៉េះបានជាអ្នក

**១:៥** ឋ ២កថ ២:១២ ២ថន ២:១៤ ឌ រម ១:១៦រម ១៥:១៣ ឍ ១ថន ២:១០
**១:៦** ណ ១កថ ៤:១៦ ត ២កថ ៦:១០ ថ កច ១៣:៥២ ទ កច ១៧:៥–១០

**១:១** *ប៉ុល* "មើលពន្យល់ រម ១:១"។ *សីលវ៉ាន* នេះគឺជាឈ្មោះជាភាសាក្រិករបស់លោកសីឡាស (មើលការពន្យល់ កច ១៥:២២)។ គាត់បានធ្វើដំណើរជាមួយលោកប៉ុល ភាគច្រើននៅក្នុងដំណើរបេសកកម្មលើកទីពីររបស់គាត់ (ប៉ុល)។ *ធីម៉ូថេ* លោកសីលវ៉ាន(សីឡាស) និងលោកធីម៉ូថេបានជួយលោកប៉ុលក្នុងការចាប់ផ្ដើមពួកជំនុំនៅទីក្រុងថែស្សាឡូនីច (កច ១៧:១–១៤ សូមមើលសេចក្ដីផ្ដើមកណ្ឌគម្ពីរធីម៉ូថេត្រង់ចំណុចអ្នកទទួល)។ *នៅក្នុងព្រះ* ត្រង់ចំណុចនេះបញ្ជាក់ អំពីការរស់នៅដោយមានការរួបរួម និងប្រកបជិតស្និទ្ធជាមួយគ្រីស្ទបរិស័ទដទៃទៀត នៅក្នុងព្រះអម្ចាស់ ដ៏ជាព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ (យហ ១៤:២៣ ១៧:២១)។ ទំនាក់ទំនងនៃព្រះវរបិតា និងព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធបញ្ជាក់អំពីទំនាក់ទំនងនៃព្រះត្រៃឯក (៣:១១ ២ថន ១:២,៨, ១២ ២:១៦ ៣:៥)។ *ព្រះអម្ចាស់យេស៊ូវគ្រីស្ទ* ពាក្យនេះមានលើកឡើងទៀតនៅចុងបញ្ចប់នៃសំបុត្រនេះ (៥:២៨)។ ចំពោះអត្ថន័យនៃពាក្យថា "ព្រះអម្ចាស់" "យេស៊ូវ" "គ្រីស្ទ" សូមមើលនៅក្នុងបទគម្ពីរ "មថ ១:១៧, ២១ លក ២:១១ រម ១០:៩ ១កថ ១២:៣ ភល ២:៩–១១"។ *ព្រះគុណ និងសេចក្ដីសុខសាន្ត* "មើលការពន្យល់ រម ១:៧"។

**១:២** *អរព្រះគុណ* "មើលការពន្យល់ ភល ១:៣–៤"។

**១:៣** សេចក្ដីបីយ៉ាងគឺ សេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់ ត្រូវបាន លើកឡើងជាច្រើនដងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី (៥:៨ រម ៥:២–៥ ១កថ ១៣:១៣ កទ ៥:៥–៦ កល ១:៤–៥ ហព ៦:១០–១២ ១០:២២–២៤ ១ពត ១:៣–៨។២១–២២)។ *ការដែលអ្នករាល់គ្នាធ្វើ ដោយសេចក្ដីជំនឿ* បញ្ជាក់ថាសេចក្ដីជំនឿបង្កើតចេញជាសកម្មភាព និងផលផ្លែ (រម ១:៥ ១៦:២៦ ២ថន ១:១១ យក ២:១៤–២៦ និងការពន្យល់ កទ ៥:៦)។ *សេចក្ដីសង្ឃឹម* មិនមែនសំដៅលើការ គិតដែលគ្មានហេតុផលនោះទេ ប៉ុន្តែ សំដៅលើការជឿជាក់ពិតប្រាកដក្នុងព្រះគ្រីស្ទ និងការយាងមកជាលើកទីពីររបស់ទ្រង់ (ឧ.១០ ហព ៦:១៨-២០ មើលការពន្យល់ រម ៥:៥ កល ១:៥)។

**១:៤** *បងប្អូន* សំដៅលើការរួបរួមគ្នា តាមរយៈការរួបរួមជាមួយព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ រម ១:១៣)។ ពាក្យនេះមានលើកឡើងចំនួន២៨ដងនៅក្នុងគម្ពីរថែស្សាឡូនីចទាំងពីរកណ្ឌ ។ *ស្រឡាញ់ . . . បានរើសតាំង* ពាក្យទាំងពីរនេះបញ្ជាក់អំពីការដែលព្រះអម្ចាស់ទ្រង់ជ្រើសរើសរាស្ត្ររបស់ទ្រង់ និងស្រឡាញ់រាស្ត្ររបស់ទ្រង់ (១ថន ២:១៣ មើលការពន្យល់ កល ៣:១២ អភ ១:៤)។

**១:៥** *ដំណឹងល្អរបស់យើងខ្ញុំ* សំដៅលើដំណឹងល្អដែលផ្សាយតាមរយៈលោកប៉ុលលោកសីលវ៉ាន(សីឡាស) និងលោកធីម៉ូថេ (មើលការពន្យល់ រម ១៦:២៥)។ ដំណឹងល្អនេះបានប្រទានមកពីព្រះអម្ចាស់តាមរយៈការសុគតរបស់ទ្រង់នៅលើឈើឆ្កាង (៣:២)។ *ព្រះចេស្ដា* សំដៅលើព្រះចេស្ដា ដែលប្រោសលោះមនុស្សលោកចេញពីភាពជាទាសករនៃអំពើបាប និងវិញ្ញាណអាក្រក់ ។ ម្យ៉ាងទៀតគឺសំដៅលើអំណាចព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ (រម ១៥:១៣,១៨–១៩ ១កថ ២:៤–៥) និងសំដៅលើដំណឹងល្អតែម្ដង (រម ១:១៦)។ *ដោយសេចក្ដីជំនឿ ដ៏មោះមុតជាខ្លាំង* សេចក្ដីជំនឿដ៏មោះមុតរបស់ពួកគ្រូបង្រៀនព្រះបន្ទូល និងពួក ជំនុំនៅទីក្រុងថែស្សាឡូនីច គឺត្រូវបានប្រទានមកពីព្រះវិញ្ញាណបរិសុទ្ធ ។

**១:៦** *ត្រាប់តាម* លំដាប់នៃការត្រាប់តាមរបស់គ្រីស្ទបរិស័ទនាសម័យកាលលោកប៉ុលមានដូចតទៅ (១).ពួកជំនុំនៅស្រុកម៉ាសេដូន និងស្រុកអាខៃបានត្រាប់តាមពួកជំនុំនៅទីក្រុងថែស្សាឡូនីច (ខ.៧) គឺដូចជាពួកជំនុំនៅទីក្រុងថែស្សាឡូនីច ដែលត្រាប់តាមពួកជំនុំនៅស្រុកយូដាដូច្នោះដែរ (២:១៤)។ (២).ពួកជំនុំនៅទីក្រុង ថែស្សាឡូនីចបានត្រាប់តាមលោកប៉ុល គឺដូចពួកជំនុំនៅឯទីក្រុងកូរិនថូសដែរ (១កថ ៤:៦ ១១:១) ហើយដូចជាគ្រីស្ទបរិស័ទត្រាប់តាមអ្នកដឹកនាំរបស់ខ្លួនដូច្នោះដែរ (២ថន ៣:៧,៩ ១ធថ ៤:១២ ទត ២:៧ ១ពត ៥:៣) (៣).លោកប៉ុលបានត្រាប់តាម ព្រះគ្រីស្ទ (១កថ ១១:១) គឺដូចពួកជំនុំនៅទីក្រុងថែស្សាឡូនីចដែរ (៤).គ្រប់គ្នាត្រូវតែត្រាប់តាមព្រះអម្ចាស់ (អភ ៥:១)។ *កាលដែលកំពុងតែកើតទុក្ខលំបាកជាខ្លាំងផង* ការនេះក៏មានកត់ត្រានៅក្នុងបទគម្ពីរ "កច ១៧:៥–១៤" (១ថន ២:១៤)។

**១:៧** *ស្រុកម៉ាសេដូន . . . អាខៃ* គឺជាខេត្តរបស់ចក្រភពរ៉ូម៉ាំង (កច ១៩:២១ រម ១៥:២៦)។ *ស្រុកម៉ាសេដូន* "មើលការពន្យល់ ភល ៤:១៥"។

រាល់គ្នាបានត្រឡប់ជាគំរូ[ធ] ដល់អស់អ្នកដែលជឿនៅស្រុក
ម៉ាសេដូន[ន] និងស្រុកអាខៃ[ប] ៨ ដ្បិតព្រះបន្ទូលនៃព្រះអម្ចាស់[ផ]
បានផ្សាយចេញពីអ្នករាល់គ្នា មិនមែនតែក្នុងស្រុកម៉ាសេ
ដូន និងស្រុកអាខៃប៉ុណ្ណោះទេ គឺរហូតដល់គ្រប់ទាំងកន្លែង[ព]
ដែលឮនិយាយពីសេចក្ដីជំនឿរបស់អ្នករាល់គ្នា ចំពោះព្រះ
ថែមទៀតផង បានជាមិនចាំបាច់ឱ្យយើងខ្ញុំនិយាយអ្វីទៀតទេ
៩ ដ្បិតគេថ្លែងប្រាប់ពីយើងខ្ញុំ ដែលអ្នករាល់គ្នាបានទទួល
យើងជាយ៉ាងណា ទាំងបែរ[ភ] ចេញពីរូបព្រះ[ម] មកឯព្រះដ៏ពិត
ឱ្យបានគោរពប្រតិបត្តិដល់ព្រះ ដ៏មានព្រះជន្មរស់នៅនោះ
វិញ[យ] ១០ ហើយឱ្យបានចាំព្រះរាជបុត្រាព្រះទ្រង់យាងមក
ពីស្ថានសួគ៌[រ] ដែលព្រះបានប្រោសឱ្យទ្រង់រស់ពីស្លាប់ឡើង
វិញ[ល] គឺជាព្រះយេស៊ូវ ដែលទ្រង់ប្រោសឱ្យយើងរួចពី
សេចក្ដីខ្ញាល់ទៅមុខ[វ]។

## ការងាររបស់លោកប៉ុលនៅក្រុងថែស្សាឡូនីច

**២** ១ ដ្បិតបងប្អូនអើយ អ្នករាល់គ្នាដឹងហើយ ពីបែបដែល
យើងខ្ញុំចូលមកឯអ្នករាល់គ្នា[ស] ថា មិនមែនជាឥតកើតផល
ទេ[ហ] ២ ឯក្រោយដែលយើងខ្ញុំបានរងទុក្ខ[ឡ] និងត្រូវគេជេរ
ប្រមាថ នៅក្រុងភីលីព[អ] ដូចជាអ្នករាល់គ្នាដឹងស្រាប់ហើយ

**១:៧** ធ ១ធថ ៤:១២
ន កច ១៦:៩
ប កច ១៨:១២
**១:៨** ផ ២ថន ៣:១
ព រម ១:៨
**១:៩** ភ កច ១៤:១៥
ម ១កថ ១២:២
កទ ៤:៨
យ មថ ១៦:១៦
**១:១០** រ ១កថ ១:៧
ល កច ២:២៤
វ រម ១:១៨
**២:១** ស ១ថន
១:៥,៩
ហ ២ថន ១:១០
**២:២** ឡ កច
១៤:១៩ ១៦:២២
ភល ១:៣០
អ កច ១៦:១២
ក កច ១៧:១–៩
**២:៣** ខ ២កថ
២:១៧
គ ២កថ ៤:២
**២:៤** ឃ កទ ២:៧
១ថន ១:១១
ង រម ២:២៩

នោះយើងខ្ញុំមានចិត្តក្លាហានដោយសារព្រះនៃយើងខ្ញុំ ដើម្បី
នឹងផ្សាយដំណឹងល្អពីព្រះ មកដល់អ្នករាល់គ្នាដែរ ទាំងមាន
សេចក្ដីតយុទ្ធជាច្រើនផង[ក] ៣ ដ្បិតសេចក្ដីដែលយើងខ្ញុំទូន្មាន
នោះមិនមែនកើតពីសេចក្ដីខុសឆ្គង ឬពីសេចក្ដីស្មោក
គ្រោក[ខ] ឬពីសេចក្ដីឆបោកនោះទេ[គ] ៤ តែតាមដែលព្រះ
ទ្រង់ល្បងលឃើញថា គួរនឹងផ្ញើព្រះបន្ទូលទុកនឹងយើងខ្ញុំ
ជាយ៉ាងណា[ឃ] នោះយើងខ្ញុំបានអធិប្បាយតាមបែបយ៉ាង
នោះឯង មិនមែនដូចជាចង់ផ្គាប់ដល់ចិត្តមនុស្សទេ[ង] គឺផ្គាប់
ដល់ព្រះហឫទ័យនៃព្រះវិញ ដែលទ្រង់ល្បងលចិត្តរបស់
យើងខ្ញុំ[ច] ៥ ដ្បិតយើងខ្ញុំមិនដែលប្រើពាក្យបញ្ចើច ដូចជាអ្នក
រាល់គ្នាដឹងស្រាប់ ឬប្រព្រឹត្តដោយចិត្តលោភឡើយ[ឆ] សឹង
មានព្រះទ្រង់ជាសាក្សីហើយ[ជ] ៦ ហើយទោះបើយើងខ្ញុំមាន
អំណាច និងនៅជាបន្ទុកលើអ្នករាល់គ្នា[ឈ] ទុកដូចជាសាវក
នៃព្រះគ្រីស្ទក៏ដោយ[ញ] គង់តែយើងខ្ញុំមិនរក ឱ្យមនុស្ស
គោរពប្រតិបត្តិដល់យើងខ្ញុំឡើយ[ដ] ទោះអ្នករាល់គ្នា ឬអ្នក
ណាទៀតក្តី ៧ យើងខ្ញុំបាននៅកណ្ដាលអ្នករាល់គ្នា ដោយ
ស្លូតបូតវិញ ប្រៀបដូចជាម្ដាយថ្នមកូន ដែលកំពុងនៅបៅ[ឋ]

ច វវ ២:២៣ **២:៥** ឆ កច ២០:៣៣ ជ ខ.១០ រម ១:៩ **២:៦** ឈ យហ ៥:៤១,៤៤ ញ ១កថ ៩:១,២ ដ ២កថ ១១:៧–១១ **២:៧** ឋ ខ.១១

**១:៨** *គ្រប់ទាំងកន្លែង* សំដៅលើគ្រប់ទីកន្លែងដែលពួកគេបានទៅដល់ (១កថ ១:២ ២កថ ២:១៤ ១ធថ ២:៨ និងការពន្យល់ រម ១:៨)។ ដំណឹងល្អបានផ្សាយចេញ ពីព្រោះតែតំបន់យុទ្ធសាស្ត្រនៃទីក្រុងថែស្សាឡូនីច (មើលសេចក្ដីផ្ដើមកណ្ឌ គម្ពីរថែស្សាឡូនីច ត្រង់ចំណុចទីក្រុង និងពួកជំនុំ)។

**១:៩–១០** មានការសំខាន់បីដែលបញ្ជាក់អំពីការប្រែចិត្ត (១).ការបែរចេញពីរូបព្រះ (២).គោរពប្រតិបត្តិដល់ព្រះអម្ចាស់ (៣).ការចាំយាមព្រះគ្រីស្ទយាងមកជាលើកទីពីរ ។ ក្នុងសំបុត្រទាំងពីររបស់លោកប៉ុលទៅពួកជំនុំនៅក្រុងថែស្សាឡូនីច គាត់បានបញ្ជាក់នូវសេចក្ដីយ៉ាងច្រើនទាក់ទងទៅនឹងការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ (ខ.១០ ២:១៩ ៣:១៣ ៤:១៣–៥:៤ ២ថន ១:៧–១០ ២:១–១២)។

**១:១០** *សេចក្ដីខ្ញាល់* អ្នកកាត់ស្រាយមួយចំនួនយល់ថា សេចក្ដីខ្ញាល់នេះសំដៅលើការជំនុំជម្រះនៅថ្ងៃចុងបំផុត (២:១៦ និងការពន្យល់ រម ១:១៨ ២:៥)។ មានអ្នកខ្លះទៀតយល់ថា ការនេះសំដៅលើទុក្ខវេទនានៅពេលអនាគតដូចមាន ពណ៌នានៅក្នុងបទគម្ពីរ "វវ ៦–១៨"។

**២:១–១២** ក្នុងវគ្គនេះបង្ហាញពីគំរូគ្រូអធិប្បាយ (១).សេចក្ដីអធិប្បាយរបស់គាត់គឺជាព្រះបន្ទូលនៃដំណឹងល្អរបស់ព្រះអម្ចាស់ (ខ.២) (២).ហេតុ–ផលរបស់គាត់គឺ ត្រូវបរិសុទ្ធ (ខ.៣) មិនដើម្បីផ្គាប់ចិត្តមនុស្ស (ខ.៤) មិនលោភលន់ (ខ.៥) ឬចង់បានការសរសើរពីមនុស្ស (ខ.៦) ប៉ុន្តែដើម្បីផ្គាប់ព្រះហឫទ័យព្រះវិញ (៣).មិនមានឧបាយកល (ខ.៣) មិនមែនជាការបញ្ឆោរ (ខ.៥) មិនលាក់បាំង សេចក្ដីពិត (ខ.៥) ប៉ុន្តែមានសេចក្ដីក្លាហាន (ខ.២) ស្លូតបូត (ខ.៧) សេចក្ដី ស្រឡាញ់ (ខ.៨,១១) ស៊ូទ្រាំ និងព្យាយាម (ខ.៩) ហើយនិងបរិសុទ្ធ (ខ.១០)។

**២:១** ពួកជំនុំនៅឯទីក្រុងថែស្សាឡូនីចបានដឹងថា ការងារដែលគាត់ធ្វើនៅក្នុងទីក្រុងនេះមិនមែនជាការបរាជ័យនោះទេ ព្រោះជាលទ្ធផលគឺពួកជំនុំថ្មីមួយត្រូវបានបង្កើតឡើងតាមរយៈគាត់ ។ ម្យ៉ាងទៀត ដោយសារតែទុក្ខលំបាកដែលលោក ប៉ុលជួបប្រទះបានធ្វើឱ្យពួកគេទាំងនោះដឹងយ៉ាងច្បាស់ថា ការដែលគាត់ធ្វើមិនមែនដើម្បីរកផលប្រយោជន៍ផ្ទាល់ខ្លួនទេ គឺដើម្បីដំណឹងល្អនៃព្រះអម្ចាស់វិញ ។

**២:២** *ជេរប្រមាថ* ត្រង់ចំណុចនេះបញ្ជាក់ថា លោកប៉ុលពិតជាទទួលនូវការឈឺចាប់ក្នុងអំឡុងពេលដែលគាត់បានស្នាក់នៅឯទីក្រុងភីលីព (កច ១៦:១៩–៤០)។

**២:៣** *សេចក្ដីឆបោក* ប្រភពដើមនៃពាក្យនេះគឺជាភាសាក្រិក ដែលសំដៅលើនុយដែលគេប្រើសម្រាប់ស្ទូចត្រី ហើយក្រោយមកត្រូវបានប្រើនៅក្នុងអត្ថន័យថា "ឧបាយកល" ដើម្បីយកប្រយោជន៍ពីអ្នកដទៃ ។

**២:៤** *ចិត្តរបស់យើងខ្ញុំ* មិនមែនសំដៅលើអារម្មណ៍ធម្មតាទេ ប៉ុន្តែ គឺសំដៅលើបញ្ញាចិត្ត និងឆន្ទៈ (ទដ ៤:៧ និងការពន្យល់)។

**២:៥** បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា លោកប៉ុលមិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួនឡើយ (កច ២០:៣៣)។

**២:៦** *បន្ទុក* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកសាវកត្រូវទទួលការផ្គត់ផ្គង់ ពីពួកជំនុំ (១កថ ៩:៣–១៤ ២កថ ១១:៧–១១)។ លោកប៉ុលមិនមែនធ្វើជាបន្ទុកដល់ពួកជំនុំរហូតទេ ប៉ុន្តែ គាត់មានសិទ្ធិបង្គាប់ដល់ពួកគេ ។ *សាវក* "មក ៦:៣០ និងពន្យល់"។

**២:៧** *ដូចជាម្ដាយ* នៅក្នុង "ខ.១១" លោកប៉ុលប្រៀបធៀបខ្លួនគាត់ដូចជាឪពុកម្នាក់ ដែរ ។

៨គឺយ៉ាងនោះហើយ ដែលយើងខ្ញុំបានស្រឡាញ់ដល់អ្នក
រាល់គ្នា ដល់ម្ល៉េះបានជាយើងខ្ញុំចូលចិត្តចែកដំណឹងល្អពី
ព្រះ[ឌ] មកអ្នករាល់គ្នា មិនត្រឹមតែប៉ុណ្ណោះ ក៏ចូលចិត្តចែក
ទាំងជីវិតយើងខ្ញុំផង[ឍ] ដោយព្រោះអ្នករាល់គ្នាបានត្រឡប់
ជាស្ងួនភ្ងាដល់យើងខ្ញុំ ៩ដ្បិតបងប្អូនអើយអ្នករាល់គ្នានឹកចាំ
ពីការយ៉ាងធ្ងន់ ហើយនឿយហត់ ដែលយើងខ្ញុំបានធ្វើ[ណ]
ដោយមិនចង់ឱ្យអ្នកណាព្រួយ ដោយសារយើងខ្ញុំទេ[ត] យើង
ខ្ញុំបានផ្សាយដំណឹងល្អពីព្រះ មកអ្នករាល់គ្នា ដោយខំធ្វើការ
ទាំងយប់ទាំងថ្ងៃ ១០អ្នករាល់គ្នាហើយព្រះផង[ថ]ជាស្មរបន្ទាល់
អំពីយើងខ្ញុំ[ទ] ដែលយើងខ្ញុំបាននៅជាមួយនឹងអ្នករាល់គ្នា
ជាពួកអ្នកជឿ បែបយ៉ាងណាដោយបរិសុទ្ធ[ធ] សុចរិត ហើយ
ឥតកន្លែងបន្ទោសបាន ១១ដូចជាអ្នករាល់គ្នាដឹងហើយថា
យើងខ្ញុំបានប្រព្រឹត្តនឹងអ្នករាល់គ្នានិមួយៗ ដូចជាឪពុកនឹង
កូន ទាំងទូន្មាន នឹងកំសាន្តចិត្តផង[ន] ១២ហើយទាំងធ្វើបន្ទាល់
ឱ្យអ្នករាល់គ្នាបានដើរយ៉ាងគួរ[ប]នឹងព្រះ ដែលទ្រង់ហៅ[ផ]
អ្នករាល់គ្នាមកក្នុងនគរ ហើយក្នុងសិរីល្អរបស់ទ្រង់ ។
១៣ដោយហេតុនេះទៀត បានជាយើងខ្ញុំអរព្រះគុណ
ដល់ព្រះ ឥតមានដាច់[ព] គឺដោយព្រោះកាលអ្នករាល់គ្នាបាន
ទទួលព្រះបន្ទូល[ភ] ជាដំណឹងពីព្រះ ដោយសារយើងខ្ញុំ នោះ
មិនបានទទួល ទុកដូចជាពាក្យរបស់មនុស្សទេ បានទទួល
តាមភាពដ៏ពិតនៃដំណឹងនោះវិញ គឺជាព្រះបន្ទូលនៃព្រះ
ដែលបណ្តាលមកក្នុងអ្នករាល់គ្នាជាពួកអ្នកជឿ ១៤ដ្បិតបង
ប្អូនអើយ អ្នករាល់គ្នាបានត្រាប់តាមអស់ទាំងពួកជំនុំ[ម]នៃព្រះ
ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ នៅស្រុកយូដា[យ] ពីព្រោះបាន
រងទុក្ខ នៅដៃនៃពួកអ្នកស្រុក[រ]របស់អ្នករាល់គ្នា ដូចជាពួក
ជំនុំទាំងនោះបានរងទុក្ខ នៅដៃនៃពួកសាសន៍យូដាដែរ
១៥ដែលគេបានសំឡាប់ទាំងព្រះអម្ចាស់យេស៊ូវ[ល] នឹងពួក
ហោរា[វ]ផង ក៏បានបណ្តេញយើងខ្ញុំទៀត ពួកនោះមិនជា
ទីគាប់ដល់ព្រះហឫទ័យរបស់ព្រះទេ ហើយក៏ទាស់ទទឹងនឹង
មនុស្សទាំងអស់ដែរ ១៦គេហាមមិនឱ្យយើងខ្ញុំថ្លែងប្រាប់ដល់
ពួកសាសន៍ដទៃ[ស] ប្រយោជន៍ឱ្យបានសង្គ្រោះឡើយ គឺដើម្បី
តែនឹងបំពេញអំពើបាបរបស់ខ្លួនគេជានិច្ចប៉ុណ្ណោះ[ហ] តែ
សេចក្តីក្រោធបានមកលើគេពេញទីហើយ ។
១៧បងប្អូនអើយ ក្រោយដែលយើងខ្ញុំត្រូវឃ្លាតមុខពីអ្នក
រាល់គ្នាបន្តិច[ឡ] តែមិនមែនឃ្លាតចិត្តឡើយ នោះយើងខ្ញុំ
មានចិត្តសង្វាត រឭកចង់ឃើញមុខអ្នករាល់គ្នាវិញជាខ្លាំង[អ]
១៨បានជាយើងខ្ញុំចង់មកសួរអ្នករាល់គ្នា គឺប៉ុលខ្ញុំចង់មកមួយ
ដងពីរទៅហើយ តែអារក្សសាតាំង[ក]បានឃាត់យើងខ្ញុំវិញ[ខ]
១៩ដ្បិតតើសេចក្តីសង្ឃឹម សេចក្តីអំណរ និងមកុដ[គ]ដែលនាំឱ្យ
យើងខ្ញុំរីករាយឡើង[ឃ] នោះជាអ្វី បើមិនមែនជាអ្នករាល់គ្នា
នៅចំពោះព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើង ក្នុងកាល

**២:៨** ឌ រម ១:១ ឍ ២កថ ១២:១៥ ១យហ ៣:១៦ **២:៩** ណ កច ១៨:៣ ត ២កថ ១១:៩ ២ថន ៣:៨ **២:១០** ថ ២កថ ១:១២ ទ ២.៥ រម ១:៩ ធ ១ថន ១:៥ **២:១១** ន ២.៧ ១កថ ៤:១៤ កទ ៤:១៩ ១ធថ ១:២ ភម ១០ ១យហ ២:១ **២:១២** ប អភ ៤:១ ផ រម ៨:២៨ **២:១៣** ព ១ថន ១:២ រម ១:៨ ភ ហព ៤:១២ **២:១៤** ម ១ថន ១:៦ យ កទ ១:២២ រ កច ១៧:៥ ២ថន ១:៤ **២:១៥** ល លក ២៤:២០ កច ២:២៣ វ មថ ៥:១២ **២:១៦** ស កច ១៣:៤៥,៥០ ១៧:៥ ២០:៣ ២១:២៧ ២៤:៩ ហ មថ ២៣:៣២ **២:១៧** ឡ ១កថ ៥:៣ កល ២:៥ អ ១ថន ៣:១០ **២:១៨** ក មថ ៤:១០ ខ រម ១:១៣ ៥:២២ **២:១៩** គ អស ៦២:៣ ភល ៤:១ ឃ ២កថ ១:១៤

**២:៩** *ការយ៉ាងធ្ងន់ ហើយនឿយហត់* នៅក្នុងភាសាក្រិក ឃ្លានេះត្រូវបានគេប្រើ តែចំពោះពួកបាវបម្រើ ឬទាសករប៉ុណ្ណោះ ប៉ុន្តែ លោកប៉ុលមិនខ្មាសនឹងការ ដែលគាត់បានធ្វើទេមានន័យថា គាត់ចង់ធ្វើយ៉ាងណាឱ្យតែដំណឹងល្អបានចម្រើន ឡើង ។ គាត់មិនចង់ធ្វើជាមនុស្សដែលពឹងអាស្រ័យលើអ្នកដទៃរហូត និងទាំងស្រុង ទេ (២ថន ៣:៨) ។
**២:១២** *បានដើរយ៉ាងគួរនឹងព្រះ* (សូមមើល អភ ៤:១) ។ *ទ្រង់ហៅ* "មើលការពន្យល់ ១:៤ រម ៨:២៨" ។ *នគរ* ពាក្យនេះជាប្រធានបទចម្បងនៃសេចក្តីបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ ។ លោកប៉ុលមិនបានប្រើពាក្យនេះញឹកញាប់ទេ ប៉ុន្តែ ច្រើនប្រើដោយភ្ជាប់ទៅនឹងសេចក្តីអធិប្បាយរបស់គាត់តែម្តង (មើលការ ពន្យល់ មថ ៣:២ លក ៤:៤៣ កច ២០:២៥ ២៨:៣១) ។ *សិរីល្អ* បញ្ជាក់ថា សិរីរុងរឿង និងព្រះចេស្តានៃព្រះអម្ចាស់ បានបើកសំដែងឱ្យយើងឃើញយ៉ាងពេញបរិបូរនៅក្នុងនគររបស់ទ្រង់ (មក ៨:៣៨ រម ៥:២ ៨:១៨ ១យហ ៣:២ អគ ៤៣:២ និងការពន្យល់) ។
**២:១៣** *មិនបានទទួល ទុកដូចជាពាក្យរបស់មនុស្សទេ* គឺមិនត្រូវបន្ថែមឬបន្ថយ ដើម្បីឱ្យបានល្បីល្បាញ ដូចជាចំណេះដឹងរបស់មនុស្សឡើយ ។
**២:១៤** *ត្រាប់តាម* "មើលការពន្យល់ ១:៦" ។ *បានរងទុក្ខនៅដៃនៃពួកអ្នកស្រុករបស់អ្នករាល់គ្នា* នៅពេលដែលលោកប៉ុលទៅឯទីក្រុងថែស្សាឡូនីច ការបៀតបៀនតែងតែត្រូវបានញុះញង់ដោយពួកសាសន៍យូដា ហើយសំដែងចេញជាសកម្មភាពដោយពួកសាសន៍ដទៃ (កច ១៧:៥–៩) ។ *សាសន៍យូដា* ទោះបីលោកប៉ុលមានចិត្តក្តួលអាណិត និងបារម្ភចំពោះសាសន៍យូដាស្តីអំពីការសង្គ្រោះរបស់ពួកគេ ដែលជាជាតិសាសន៍របស់ខ្លួន ក៏ដោយ (រម ៩:១-៣ ១០:១) ក៏គាត់បានស្តីបន្ទោសយ៉ាងខ្លាំងៗដល់ពួកសាសន៍យូដាដែលបៀតបៀនដល់ពួកជំនុំ ។
**២:១៥** *ពួកហោរា* ត្រង់ចំណុចនេះបញ្ជាក់ថាតាមរយៈរឿងរ៉ាវនៅក្នុងគម្ពីរសញ្ញាចាស់បានប្រាប់ថា ពួកអ៊ីស្រាអែលតែងតែធ្វើការបៀតបៀនដល់ពួកហោរារបស់ខ្លួន (កច ៧:៥២) ។ *បានបណ្តេញយើងខ្ញុំទៀត* "សូមមើល កច ៩:២៣–២៥,២៩–៣០ ១៣:៥០–៥១ ១៤:៥–៦,១៩ ១៧:១០,១៣–១៤" ។
**២:១៦** ក្នុងបទគម្ពីរនេះ លោកប៉ុលពិពណ៌នា ដោយសង្ខេបនូវហេតុការណ៍ដែលកើតឡើងនៅពេលដែលព្រះយេស៊ូវគ្រីស្ទយាងមកជាលើកទីពីរ (១៥:៥១–៥២ មក ១៣:២៤–២៧ យហ ៥:២៨–២៩) ។
**២:១៨** *អារក្សសាតាំង* (អភ ១:៣ និងការពន្យល់) ។
**២:១៩** *មកុដ* មិនមែនសំដៅលើមកុដរបស់ស្តេចទេ ប៉ុន្តែ គឺសំដៅលើភួងជ័យ ដែលត្រូវបានប្រគល់ជូនអ្នកណាម្នាក់នៅក្នុងពិធីដ៏ធំ ឬត្រូវបានប្រគល់ជូនជារង្វាន់ដល់អ្នកដែលទទួលបានជ័យជម្នះ នៅក្នុងការប្រកួតកីឡារបស់ជនជាតិក្រេក (២ធថ ៤:៨ យក ១:១២ ១ពត ៥:៤ វវ ២:១០ និងពន្យល់) ។ *ក្នុងកាលដែលទ្រង់យាងមក* សំដៅលើការយាងមកជា

ដែលទ្រង់យាងមកប៉ុណ្ណោះ[ង] [២០]ដ្បិតអ្នករាល់គ្នាជាសិរីល្អ[ច]
ហើយជាសេចក្តីអំណររបស់យើងខ្ញុំមែន ។
**៣** [១]ដូច្នេះ កាលទ្រាំមិនបានទៀត[ឆ] នោះយើងខ្ញុំបានគិតថា
គួរឱ្យយើងខ្ញុំនៅក្រុងអាថែនតែម្នាក់ឯងចុះ[ជ] [២]ដើម្បីនឹងចាត់
ធីម៉ូថេ[ឈ]ជាបងប្អូន គឺជាអ្នកបំរើនៃព្រះដែលបានធ្វើការជា
មួយនឹងយើងខ្ញុំ[ញ] ក្នុងដំណឹងល្អនៃព្រះគ្រីស្ទ[ដ] ឱ្យគាត់បានតាំង
អ្នករាល់គ្នាឡើងជាមាំមួន ហើយជួយចំរើនខាងឯសេចក្តី
ជំនឿផង [៣]ក្រែងអ្នកណាកើតមានចិត្តថប់ព្រួយ ដោយ
សេចក្តីទុក្ខលំបាកទាំងនេះ[ឋ] (ដ្បិតអ្នករាល់គ្នាដឹងហើយថា
យើងចៀសពីសេចក្តីយ៉ាងនេះមិនរួចទេ[ឌ] [៤]ព្រោះកាលយើង
ខ្ញុំនៅជាមួយនឹងអ្នករាល់គ្នានៅឡើយ នោះក៏បានប្រាប់ជា
មុនថា យើងរៀបនឹងរងទុក្ខលំបាក ដូចជាអ្នករាល់គ្នាដឹង
ស្រាប់ថា មានមកហើយ)[ឍ] [៥]ដោយហេតុនោះ កាលខ្ញុំទ្រាំ
មិនបានទៀត[ណ] នោះខ្ញុំបានចាត់គាត់មកឱ្យបានដឹងពីសេចក្តី
ជំនឿរបស់អ្នករាល់គ្នា[ត] ក្រែងមេល្បួងបានល្បួងនាំចិត្តអ្នក

**២:១៩** ង មថ ១៦:២៧ លក ១៧:៣០ ១កថ ១:៧ ៤:៥ ១ថន ៣:១៣ ២ថន ១:៨–១០ ១ពត ១:៧ ១យហ ២:២៨ វវ ១:៧ **២:២០** ច ២កថ ១:១៤ **៣:១** ឆ ឧ.៥ ជ កច ១៧:១៥ **៣:២** ឈ កច ១៦:១ ញ ១កថ ៣:៩ ដ ២កថ ២:១២ **៣:៣** ឋ មក ៤:១៧ យហ ១៦:៣៣ រម ៥:៣ ២កថ ១:៤ ៤:១៧ ២ធថ ៣:១២ ឌ កច ៩:១៦ ១៤:២២ **៣:៤** ឍ ១ថន ២:១៤ **៣:៥** ណ ឧ.១

រាល់គ្នា[ថ] ឱ្យការនឿយហត់របស់យើងខ្ញុំបានទៅជាឥតអំពើ
វិញ[ទ] ។

## របាយការណ៍លើកទឹកចិត្តរបស់លោកធីម៉ូថេ

[៦]តែឥឡូវនេះដែលធីម៉ូថេ[ធ]បានចេញពីអ្នករាល់គ្នាទៅ
ដល់យើងខ្ញុំ[ន] ព្រមទាំងនាំដំណឹងល្អពីសេចក្តីជំនឿ និងសេចក្តី
ស្រឡាញ់[ប] របស់អ្នករាល់គ្នាទៅប្រាប់យើងខ្ញុំវិញ ហើយពី
ដំណើរដែលអ្នករាល់គ្នានឹកចាំពីយើងខ្ញុំ ដោយអំណរជា
និច្ច ទាំងរឭកចង់ឃើញយើងខ្ញុំផង ដូចជាយើងខ្ញុំរឭកដល់
អ្នករាល់គ្នាដែរ[ផ] [៧]ដូច្នេះ បងប្អូនអើយ ក្នុងខណៈដែលយើង
ខ្ញុំកំពុងតែមានសេចក្តីទុក្ខព្រួយ និងសេចក្តីលំបាកជាច្រើន
នោះយើងខ្ញុំមានសេចក្តីក្សាន្តចិត្ត ពីដំណើរអ្នករាល់គ្នា
ឡើងវិញ ដោយសារសេចក្តីជំនឿរបស់អ្នករាល់គ្នា [៨]ដ្បិត
ឥឡូវនេះ បើអ្នករាល់គ្នាឈរនៅមាំមួន[ព]ក្នុងព្រះអម្ចាស់
នោះទើបយើងខ្ញុំនឹងរស់នៅ [៩]តើយើងខ្ញុំអាចនឹងអរព្រះ

ត ឧ.២ ថ មថ ៤:៣ ទ កទ ២:២ ភល ២:១៦ **៣:៦** ធ កច ១៦:១ ន កច ១៨:៥ ប ១ថន ១:៣ ផ ១ថន ២:១៧,១៨ **៣:៨** ព ១កថ ១៦:១៣

លើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ (៣:១៣ ៤:១៥ ៥:២៣ ២ថន ២:១,៨) ។

**២:២០** បទគម្ពីរនេះបញ្ជាក់ថា សេចក្តីអំណររបស់លោកប៉ុលមិនមែនកើតឡើង ដោយព្រោះគាត់ទទួលបានកិត្តិយសមាសប្រាក់ ឬរង្វាន់អ្វីផ្សេងៗទេ ប៉ុន្តែ គឺដោយសារគាត់ឃើញមានមនុស្សជាច្រើនបានផ្លាស់ប្រែ ទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ (ភល ៤:១) ។

**៣:១-២** ជាដំបូងលោកប៉ុលបានធ្វើដំណើរទៅទីក្រុងអាថែនតែម្នាក់ឯង បន្ទាប់មកគាត់បានផ្ញើសំបុត្រទៅឯទីក្រុងបេរា ដើម្បីឱ្យលោកស៊ីលវ៉ាន (ស៊ីឡាស) និងលោកធីម៉ូថេមកជួបគាត់ (កច ១៧:១៤–១៥)។ បន្ទាប់ពីលោកស៊ីលវ៉ានបានទទួលនូវ ការស្នើសូមរបស់លោកប៉ុល (កច ១៧:១៥) ហើយបានមកឯទីក្រុងអាថែនជាមួយនឹងលោកធីម៉ូថេ ពុំបានបញ្ជាក់ច្បាស់ទេ ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលលោកធីម៉ូថេបានត្រឡប់ពីទីក្រុងថែស្សាឡូនីច ទៅឯលោកប៉ុលដែលកំពុងស្នាក់នៅក្នុងទីក្រុងកូរិនថូស នោះលោកស៊ីលវ៉ានក៏ទៅជាមួយគាត់ (ធីម៉ូថេ) ដែរ (កច ១៨:៥ សូមមើលសេចក្តីផ្តើមកណ្ឌគម្ពីរថែស្សាឡូនីច)។

**៣:១** *យើងខ្ញុំ* ពាក្យ "យើងខ្ញុំ" ត្រង់ចំណុចនេះសំដៅលើលោកប៉ុលម្នាក់ប៉ុណ្ណោះ ។

**៣:២** *អ្នកបំរើនៃព្រះ ដែលបានធ្វើការជាមួយនឹងយើងខ្ញុំ* ចំពោះការបម្រើរបស់គ្រីស្ទបរិស័ទ សូមប្រៀបធៀបនឹងបទគម្ពីរ "១កថ ៣:៩"។ *ដំណឹងល្អនៃព្រះគ្រីស្ទ* "មើលការពន្យល់ ១:៥ មក ១:១"។ *តាំងអ្នករាល់គ្នាឡើងជាមាំមួន* ឃ្លានេះនៅក្នុងអក្សរសាស្ត្រក្រិកបុរាណ ជាទូទៅប្រើនៅក្នុងន័យសំដៅលើជន្ទល់ដែល គេប្រើសម្រាប់ទ្រអាគារ។ ព្រះគម្ពីរសញ្ញាថ្មីប្រើឃ្លានេះក្នុងអត្ថន័យប្រៀបធៀប ។

**៣:៣** *សេចក្តីលំបាក* សំដៅលើការប្រឆាំង និងការបៀតបៀន ដែលពួកអ្នកជឿដល់ព្រះអម្ចាស់នៅទីក្រុងថែស្សាឡូនីចជួបប្រទះ ។ *យើងចៀសពីសេចក្តីយ៉ាងនេះមិនរួចទេ* ត្រង់ចំណុចនេះបញ្ជាក់ថា ជីវិតជាគ្រីស្ទបរិស័ទត្រូវតែប្រឈមមុខនឹងឧបសគ្គ (មក ៤:១៧ យហ ១៦:៣៣ កច ១៤:២២ ភល ១:២៩ ២ធថ ៣:១២ ១ពត ២:២១ និងការពន្យល់) ប៉ុន្តែ ការទាំងអស់នោះពុំមែនជាមហន្តរាយដល់ពួកគេទេ ផ្ទុយទៅវិញធ្វើឱ្យព្រះហឫទ័យរបស់ព្រះអម្ចាស់បានសម្រេចវិញ (កច ១១:១៩ រម ៥:៣ ២កថ ១:៤ ៤:១៧ និងការពន្យល់) ។

**៣:៥** *ខ្ញុំ* លោកប៉ុលប្រើសព្វនាមថា "ខ្ញុំ" នៅក្នុងបទគម្ពីរនេះ គឺដើម្បីបង្ហាញនូវ ការបារម្ភរបស់គាត់ចំពោះពួកជំនុំ (២:១៨) ។ *មេល្បួង* សំដៅលើអារក្សសាតាំង ដែលត្រូវបានបញ្ជាក់ច្បាស់ នៅក្នុងព្រះគម្ពីរសញ្ញាថ្មីថា វាគឺជាមេនាំឱ្យមានការបែកបាក់ ។ វាជាមេនៃវិញ្ញាណអាក្រក់ (យហ ១២:៣១ ១៦:១១ អភ ២:២) ។ សកម្មភាពរបស់វាអាចមានឥទ្ធិពលលើរូបកាយ (២កថ ១២:៧) និងវិញ្ញាណ (មថ ១៣:៣៩ មក ៤:១៥ ២កថ ៤:៤ និងការពន្យល់) ។ វាបានល្បួងព្រះយេស៊ូវ (មថ ៤:១–១១) ហើយបន្តល្បួងអ្នកបម្រើទ្រង់ (លក ២២:៣ ១កថ ៧:៥) ។ វាបង្អាក់ និងរារាំងការងាររបស់អ្នកបម្រើព្រះអម្ចាស់ (២:១៨) ។ ប៉ុន្តែ វាទទួលនូវការបរាជ័យរួចហើយ (មថ ១២:២៩ កល ២:១៥ និងការពន្យល់) ដូច្នេះ គ្រីស្ទបរិស័ទមិនត្រូវមានការភ័យខ្លាចចំពោះវាឡើយ (អភ ៦:១៦) ។ ការដែលវាត្រូវធ្លាក់ចុះបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងព្រះគម្ពីរបរិសុទ្ធ (វវ ២០:១០) ។

**៣:៦** *ព្រមទាំងនាំដំណឹងល្អពីសេចក្តីជំនឿ* ឃ្លានេះត្រូវបានប្រើតែម្តងគត់នៅក្នុងភាសាក្រិកដោយលោកប៉ុល ។ មានការបីយ៉ាង ដែលធ្វើឱ្យលោកប៉ុលមានអំណរ (១).សេចក្តីជំនឿរបស់ពួកជំនុំចំពោះព្រះអម្ចាស់ (២).សេចក្តីស្រឡាញ់របស់ពួកគេរវាងគ្នានិងគ្នា (៣).ការដែលពួកគេរឭកចង់ជួបពួកគាត់ ។

**៣:៩** *អរព្រះគុណដល់ព្រះ* តាមរយៈសេចក្តីរៀបរាប់នៅក្នុងបទគម្ពីរមុនៗបានបញ្ជាក់ថា ការងារផ្សាយដំណឹងល្អរបស់លោកប៉ុល គឺទទួលបានជោគជ័យ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏លោកប៉ុលមិនមានមោទនភាពចំពោះខ្លួនគាត់ទេ ផ្ទុយទៅវិញ គឺគាត់អរព្រះគុណព្រះអម្ចាស់ចំពោះសេចក្តីអំណរដែលគាត់ទទួលបានតាមរយៈការដែលទ្រង់បានធ្វើវិញ ។

គុណដល់ព្រះ ពីដំណើរអ្នករាល់គ្នា[ភ] ដោយប្រការដូចម្ដេច
ឱ្យបានល្មមធួននឹងអស់ទាំងសេចក្ដីអំណរ ដែលយើងខ្ញុំមាន
នៅចំពោះព្រះនៃយើង ដោយព្រោះអ្នករាល់គ្នាបាន[ម]
10 យើងខ្ញុំទូលអង្វរ[យ]ដោយទទូចទាំងយប់ទាំងថ្ងៃ សូម
ឱ្យបានឃើញមុខអ្នករាល់គ្នា[រ] ហើយឱ្យបានបំពេញសេច
ក្ដីអ្វីដែលខ្វះ ខាងឯសេចក្ដីជំនឿរបស់អ្នករាល់គ្នាផង
11 សូមឱ្យព្រះដ៏ជាព្រះវរបិតា[ល] និងព្រះអម្ចាស់យេស៊ូវ
គ្រីស្ទនៃយើងខ្ញុំ ទ្រង់ដំរង់ផ្លូវយើងខ្ញុំឱ្យបានមកឯអ្នករាល់គ្នា
12 សូមឱ្យព្រះអម្ចាស់ចំរើនសេចក្ដីស្រឡាញ់របស់អ្នករាល់
គ្នាឱ្យបានពេញពោរហូរហៀរដល់គ្នាទៅវិញទៅមក[វ]
ព្រមទាំងដល់មនុស្សទាំងអស់ផង ដូចជាយើងខ្ញុំស្រឡាញ់
ដល់អ្នករាល់គ្នាដែរ 13 ប្រយោជន៍នឹងតាំងចិត្តអ្នករាល់គ្នា
ឱ្យបរិសុទ្ធ ឥតសៅហ្មង[ស] នៅចំពោះព្រះដ៏ជាព្រះវរបិតា
របស់យើងរាល់គ្នា[ហ] ក្នុងកាលដែលព្រះយេស៊ូវ ជាព្រះ
អម្ចាស់នៃយើង ទ្រង់យាងមក[ឡ] ជាមួយនឹងអស់ទាំងអ្នក
បរិសុទ្ធរបស់ទ្រង់[អ]។

## ការដើរតាមព្រះហឫទ័យព្រះ

**៣:៩** ភ ១ថន ១:២ ម ១ថន ២:១៩,២០
**៣:១០** យ ២ធថ ១:៣ រ ១ថន ២:១៧
**៣:១១** ល ខ.១៣ ភល ៤:២០
**៣:១២** វ ភល ១:៩ ១ថន ៤:៩,១០ ២ថន ១:៣
**៣:១៣** ស ទដ ១៥:២ ១កថ ១:៨ ភល ២:១៥ ១ថន ៥:២៣ ១ធថ ៦:១៤ ២ពត ៣:១៤ ហ ខ.១១ ភល ៤:២០ ឡ ១ថន ២:១៩ អ មថ ២៥:៣១ ២ថន ១:៧
**៤:១** ក ២កថ ១៣:១១ ២ថន ៣:១ ខ អភ ៤:១ គ ២កថ ៥:៩
**៤:៣** ឃ អភ ៥:១៧ ង ១កថ ៦:១៨

**៤** 1 មួយសោតទៀត បងប្អូនអើយ[ក] យើងខ្ញុំអង្វរ ហើយ
ទូន្មានដល់អ្នករាល់គ្នា ក្នុងព្រះអម្ចាស់យេស៊ូវថា ចូរ
ដើរ[ខ]តាមដែលគួរគប្បី ដើម្បីឱ្យបានគាប់ដល់ព្រះហឫទ័យ
ព្រះ[គ]កាន់តែខ្លាំងឡើង ដូចជាបានទទួលបង្គាប់ពីយើងខ្ញុំរួច
ហើយ 2 ដ្បិតអ្នករាល់គ្នាស្គាល់សេចក្ដីបញ្ញត្តដែលយើងខ្ញុំ
បានប្រគល់មកអ្នករាល់គ្នា ដោយនូវព្រះអម្ចាស់យេស៊ូវ
ហើយ 3 ដ្បិតព្រះទ្រង់សព្វព្រះហឫទ័យ[ឃ] ឱ្យអ្នករាល់គ្នាបាន
ញែកជាបរិសុទ្ធ ដើម្បីឱ្យបានចៀសពីសេចក្ដីកំផិតចេញ[ង]
4 ត្រូវឱ្យអ្នករាល់គ្នានិមួយៗ ចេះរក្សាអត្តភាពខ្លួន[ច] ដោយ
សេចក្ដីបរិសុទ្ធ និងសេចក្ដីប្រសើរ 5 មិនមែនដោយសេចក្ដី
រំជួលក្នុងតណ្ហា[ឆ] ដូចជាសាសន៍ដទៃ[ជ] ដែលមិនស្គាល់ព្រះ
នោះឡើយ[ឈ] 6 កុំឱ្យអ្នកណាបំពាន ឬធ្វើខុសនឹងបងប្អូនណា
មួយក្នុងការនោះឱ្យសោះ[ញ] ពីព្រោះព្រះអម្ចាស់ទ្រង់នឹងសង
សឹក[ដ] ក្នុងការទាំងនោះ[ឋ] ដូចជាយើងខ្ញុំបានប្រាប់ដល់អ្នក
រាល់គ្នាហើយ ព្រមទាំងធ្វើបន្ទាល់សព្វគ្រប់ផង 7 ដ្បិតព្រះ

**៤:៤** ច ១កថ ៧:២,៩ **៤:៥** ឆ រម ១:២៦ ជ អភ ៤:១៧ ឈ កទ ៤:៨
**៤:៦** ញ លវ ២៥:១៧ ១កថ ៦:៨ ដ ចទ ៣២:៣៥ ទដ ៩៤:១ រម ២:៥–១១ ១២:១៩ ហព ១០:៣០,៣១ ឋ ហព ១៣:៤

**៣:១០** *អង្វរ ដោយទទូច* ក្នុងភាសាក្រិកឃ្លានេះបញ្ជាក់អំពីបំណងចិត្តដ៏ខ្លាំងក្លារបស់លោកប៉ុល (៥:១៣ អភ ៣:២០)។ *ទាំងយប់ទាំងថ្ងៃ* សំដៅលើសេចក្ដីព្យាយាមជាប់ជានិច្ចរបស់ពួកគេនៅក្នុងការអធិស្ឋាន (១:២-៣)។ *ឱ្យបានបំពេញ សេចក្ដីអ្វីដែលខ្វះ* សេចក្ដីខ្វះទាំងនោះសំដៅលើការអនុវត្តន៍ជាក់ស្ដែងមានដូចជាផ្នែកសីលធម៌(៤:១–១២) វិន័យផ្សេងៗ(៥:១២–២៤) និងគោលលទ្ធិដ៏ត្រឹមត្រូវដែលមានដូចជា សេចក្ដីដែលទាក់ទងទៅនឹងការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ (៤:១៣–៥:១១)។ *សេចក្ដីជំនឿរបស់អ្នករាល់គ្នា* ត្រង់ចំណុច នេះជាលើកទីប្រាំហើយនៅក្នុងជំពូកនេះ ដែលលោកប៉ុលលើកឡើងអំពីសេចក្ដីជំនឿរបស់ពួកជំនុំនៅទីក្រុងថែស្សាឡូនីច (ខ.២,៥–៧)។

**៣:១១** នៅត្រង់វគ្គកណ្ដាលនៃសំបុត្ររបស់លោកប៉ុល គឺគាត់និយាយទាក់ទងនឹងសេចក្ដីអធិស្ឋាន (អភ ១:១៥–២៣ ៣:១៤–២១ ភល ១:៩–១១ កល ១:៩–១២)។ សម្រាប់សេចក្ដីដែលទាក់ទងនឹងព្រះវរបិតា និងព្រះរាជបុត្រា សូមមើល"១:១" និងការពន្យល់ ។

**៣:១២** *ព្រះអម្ចាស់* ពាក្យនេះនៅក្នុងសំបុត្ររបស់លោកប៉ុល ច្រើនសំដៅលើព្រះយេស៊ូវ ជាងព្រះវរបិតា ។

**៣:១៣** *តាំងចិត្ត* "មើលការពន្យល់ ខ.២"។ *បរិសុទ្ធ* សំដៅលើការញែកជាបរិសុទ្ធសម្រាប់ព្រះអម្ចាស់ (នក ៣:៥ លវ ១១:៤៤ រម ៦:២២ អភ ១:១ មើលការពន្យល់ ១កថ ១:២)។ *អ្នកបរិសុទ្ធ* ពាក្យនេះនៅក្នុងព្រះគម្ពីរសញ្ញាថ្មីត្រូវបានប្រើសំដៅលើគ្រីស្ទបរិស័ទ (រម ១:៧ និងការពន្យល់)។ ម្យ៉ាងទៀតអាចសំដៅលើពួកបរិសុទ្ធ ដែលត្រូវមកជាមួយនឹងព្រះយេស៊ូវក្នុងពេលដែលទ្រង់យាងមកជាលើកទីពីរ ឬអាចសំដៅលើពួកទេវតារបស់ទ្រង់ ឬក៏សំដៅលើទាំងពីរតែម្ដង (មក ៨:៣៨)។

**៤:១** វគ្គចម្បងនៃសំបុត្រនេះត្រូវបានបញ្ចប់ ទោះបីមានសេចក្ដីជាច្រើននៅបន្តទៀតក៏ដោយ (ភល ៣:១ និងការពន្យល់)។ *យើងខ្ញុំអង្វរ ហើយទូន្មាន* លោកប៉ុលមិនបានអួតអាងទេ ប៉ុន្តែគាត់មានប្រសាសន៍ដោយអំណាចក្នុងព្រះអម្ចាស់ ។ គាត់មានគំនិតរបស់ព្រះអម្ចាស់ (១កថ ២:១៦)។ *ចូរដើរ* អាចសរសេរថា"ចូររស់នៅ"។ លោកប៉ុលប្រើពាក្យប្រៀបធៀបនេះ គឺសំដៅលើរបៀបដែលគ្រីស្ទបរិស័ទត្រូវរស់នៅ និងការចម្រើនឡើងពិតប្រាកដរបស់ពួកគេ (រម ៦:៤ ២កថ ៥:៧ អភ ៤:១ ៥:១៥ កល ១:១០ ២:៦ ៤:៥)។

**៤:២** *សេចក្ដីបញ្ញត្តិ* ពាក្យនេះត្រូវបានប្រើនៅក្នុងន័យបង្គាប់បញ្ជា និងប្រកបដោយអំណាច ជាទូទៅគឺនៅក្នុងជួរកងទ័ព (កថ ៥:២៨ ១៦:២៤)។

**៤:៣** *ញែកជាបរិសុទ្ធ* "មើលការពន្យល់ ៣:១៣"។ *សេចក្ដីកំផិត* ជាទូទៅនៅសតវត្សរ៍ទីមួយ ផ្នែកសីលធម៌មានកម្រិតទាបណាស់ ហើយភក្ដីភាពរវាងប្ដី និងប្រពន្ធក៏បានថយចុះដែរ ។ ទោះជាយ៉ាងណា ក៏លោកប៉ុលពុំបានបញ្ជាក់នូវកម្រិតនៃសីលធម៌ និងការបង្គាប់បញ្ជាណាមួយទេ ប៉ុន្តែ ចំពោះការព្រមានសម្រាប់គ្រីស្ទបរិស័ទគឺត្រូវការជាចាំបាច់ ហើយមិនត្រូវបណ្ដោយតាមការល្បួងណាមួយទេ (១កថ ៥:១)។

**៤:៥** *ដូចសាសន៍ដទៃ* "មើលការពន្យល់ រម ១:២៤–២៧"។ ត្រង់ចំណុចនេះបញ្ជាក់ថា គ្រីស្ទបរិស័ទត្រូវមានការផ្លាស់ប្រែ ។ *មិនស្គាល់ព្រះ* "មើលការពន្យល់ ទដ ៧៩:៦–៧ ២ថន ១:៨ កទ ៤:៨"។

**៤:៦** *ធ្វើខុសនឹងបងប្អូន* បញ្ជាក់ថាអំពើផិតក្បត់មានឥទ្ធិពលអាក្រក់ដល់អ្នកដទៃ ។ ការថ្វាយបង្គំរូបព្រះតែងតែធ្វើឱ្យប្ដី ឬប្រពន្ធប្រព្រឹត្តខុស ។ ការរួមភេទមុនពេលរៀបការក៏ធ្វើឱ្យមានឥទ្ធិពលអាក្រក់ដល់អ្នកដទៃទៀតដែរ *ព្រះអម្ចាស់ទ្រង់នឹងសងសឹក ក្នុងការទាំងនោះ* ពាក្យថា"ការទាំងនោះ" សំដៅលើការដែលមិនបរិសុទ្ធ និងការដែលព្រះអម្ចាស់មិនសព្វព្រះហឫទ័យ ។

មិនបានហៅយើងរាល់គ្នា មកក្នុងសេចក្ដីស្មោកគ្រោកទេ
គឺមកក្នុងសេចក្ដីបរិសុទ្ធវិញ[ឌ] ៨ដូច្នេះ អ្នកណាដែលមិនព្រម
ទទួល នោះមិនមែនបោះបង់ចោលមនុស្ស ឈ្មោះថាបោះ
បង់ចោលព្រះវិញ ដែលទ្រង់បានប្រទានព្រះវិញ្ញាណ
បរិសុទ្ធនៃទ្រង់មកយើង[ឍ]។
៩រីឯសេចក្ដីស្រឡាញ់ជាបងប្អូន[ណ] នោះមិនចាំបាច់ឱ្យ
ខ្ញុំសរសេរមកអ្នករាល់គ្នាទេ[ត] ពីព្រោះព្រះទ្រង់បង្រៀន[ថ]
ឱ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមកហើយ[ទ] ១០អ្នក
រាល់គ្នាក៏ស្រឡាញ់ដល់អស់ទាំងពួកបងប្អូន នៅគ្រប់ក្នុង
ស្រុកម៉ាសេដូនដែរ[ធ] តែបងប្អូនអើយ យើងខ្ញុំសូមទូន្មាន ឱ្យ
អ្នករាល់គ្នាមានសេចក្ដីស្រឡាញ់នោះ កាន់តែខ្លាំងឡើង
ចុះ[ន] ១១ហើយខំប្រឹងឱ្យអស់ពីចិត្ត នឹងនៅដោយស្រគត់ស្រគំ
ទាំងប្រព្រឹត្តតែរឿងជារបស់ផងខ្លួន ហើយធ្វើការដោយ
ដៃខ្លួនឯងផង[ប] ដូចជាយើងខ្ញុំបានបង្គាប់ហើយ ១២ដើម្បីឱ្យ
អ្នករាល់គ្នាបានប្រព្រឹត្តដោយគួរគប្បី ដល់មនុស្សខាងក្រៅ[ផ]
ឥតត្រូវការអ្វីឡើយ ។

## ការយាងមកនៃព្រះអម្ចាស់

១៣បងប្អូនអើយ ខ្ញុំមិនចង់ឱ្យអ្នករាល់គ្នាឥតដឹង[ព] ពីពួក
អ្នកដែលដេកលក់ទៅហើយទេ[ភ] ក្រែងអ្នករាល់គ្នាកើតទុក្ខ
ព្រួយ ដូចជាអ្នកឯទៀត ដែលគ្មានសង្ឃឹម[ម] ១៤ដ្បិតបើយើង
ជឿថា ព្រះយេស៊ូវបានសុគត ព្រមទាំងរស់ឡើងវិញ
ហើយ[យ] នោះត្រូវជឿថា ព្រះទ្រង់និងនាំអស់អ្នកដែលដេក
លក់ទៅក្នុងព្រះយេស៊ូវ ឱ្យបានមកជាមួយនឹងទ្រង់ដែរ[រ]
១៥ដ្បិតយើងខ្ញុំប្រាប់មកអ្នករាល់គ្នា តាមព្រះបន្ទូលនៃព្រះ
អម្ចាស់ដូច្នេះថា យើងដែលរស់នៅជាប់ ដរាបដល់ព្រះ
អម្ចាស់យាងមក[ល] នោះយើងមិនទៅមុនពួកអ្នក ដែលបាន

**៤:៧** ឌ លវ ១១:៤៤ ១ពត ១:១៥
**៤:៨** ឍ អគ ៣៦:២៧ រម ៥:៥ ២កថ ១:២២ កទ ៤:៦ ១យហ ៣:២៤
**៤:៩** ណ រម ១២:១០ ត ១ថន ៥:១ ថ យហ ៦:៤៥ ទ យហ ១៣:៣៤
**៤:១០** ធ កថ ១៦:៩ ន ១ថន ៣:១២
**៤:១១** ប អភ ៤:២៨ ២ថន ៣:១០–១២
**៤:១២** ផ មក ៤:១១
**៤:១៣** ព រម ១១:២៥ ភ មថ ៩:២៤ ម អភ ២:១២
**៤:១៤** យ រម ១៤:៩ ១កថ ១៥:៣,៤ ២កថ ៥:១៥ រ ១កថ ១៥:១៨
**៤:១៥** ល ១កថ ១:៧ វ ១កថ ១៥:៥២

**៤:៧** មូលហេតុដែលតម្រូវឱ្យគ្រីស្ទបរិស័ទរស់នៅជាបរិសុទ្ធ ពីព្រោះព្រះអម្ចាស់បានត្រាស់ហៅគេមកឱ្យរស់នៅក្នុងភាពបរិសុទ្ធ ។

**៤:៨** *ទ្រង់បានប្រទានព្រះវិញ្ញាណបរិសុទ្ធនៃទ្រង់* ការមួយទៀតដែលតម្រូវឱ្យគ្រីស្ទបរិស័ទរស់នៅជាបរិសុទ្ធពីព្រោះថា អំពើផិតក្បត់គឺប្រឆាំងនឹងព្រះហឫទ័យព្រះអម្ចាស់ (លប ៣៩:៩ និងការពន្យល់) ដែលប្រទានព្រះវិញ្ញាណបរិសុទ្ធទ្រង់ដល់អស់អ្នកជឿដល់ព្រះនាមទ្រង់ទាំងអស់ ដើម្បីឱ្យពួកគេបានញែកជាបរិសុទ្ធ។ ការរស់នៅក្នុងអំពើផិតក្បត់ គឺជាការបដិសេធព្រះអម្ចាស់ ។

**៤:៩** *សេចក្ដីស្រឡាញ់ជាបងប្អូន* ឃ្លានេះនៅក្នុងភាសាក្រិក គឺសំដៅលើសេចក្ដីស្រឡាញ់ទៅវិញទៅមកជាបងប្អូន ទោះបីរវាងកូន និងឪពុកម្ដាយក៏ដោយ ។ ក្នុងព្រះគម្ពីរសញ្ញាថ្មី សំដៅលើសេចក្ដីស្រឡាញ់របស់ពួកបងប្អូនរួមជំនឿនៅក្នុងព្រះគ្រីស្ទ ដែលមានឪពុកតែមួយខាងឯវិញ្ញាណនៅស្ថានសួគ៌ ។ *ទ្រង់បង្រៀន* "មើល អស ៥៤:១៣ យហ ៦:៤៥ ១កថ ២:១៣"។

**៤:១១** *ទាំងប្រព្រឹត្តតែរឿងជារបស់ផងខ្លួន* លោកប៉ុលមានប្រសាសន៍ដូច្នេះ ពីព្រោះពួកជំនុំនៅទីក្រុងថែស្សាឡូនីចមួយចំនួន ដែលមានភាពខ្ជិលច្រអូស បានជ្រៀតជ្រែកដោយមិនត្រឹមត្រូវទៅក្នុងកិច្ចការរបស់អ្នកដទៃ (២ថន ៣:១១ និងការពន្យល់)។ *ធ្វើការដោយដៃខ្លួនឯងផង* ឃ្លានេះនៅក្នុងភាសាក្រិក គឺសំដៅលើកិច្ចការទាំងឡាយណាដែលស័ក្ដិសម និងមានលក្ខណៈជាអ្នកបម្រើ ។ ចំពោះគ្រីស្ទបរិស័ទក៏ដូច្នោះដែរ គឺត្រូវតែធ្វើការងារ ដើម្បីផ្គត់ផ្គង់ជីវភាព ប៉ុន្តែ ពួកជំនុំ នៅទីក្រុងថែស្សាឡូនីចមួយចំនួន ដោយព្រោះតែពួកគេចេះតែទន្ទឹងរង់ចាំការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ (២ថន ៣:១១) បានធ្វើឱ្យពួកគេធ្វេសប្រហែសនឹងការងារ ហើយមានចិត្តពឹងអាងលើជំនួយពីអ្នកដទៃទៅវិញ ។

**៤:១២** *ដល់មនុស្សខាងក្រៅ ឥតត្រូវការអ្វីឡើយ* នេះជាសេចក្ដីពិតនិងមានសារសំខាន់ណាស់ ។ ព្រះគ្រីស្ទទ្រង់ផ្គត់ផ្គង់គ្រប់តម្រូវការរបស់ពួកគេ ប៉ុន្តែពួកគេ បែរជាខ្ជិលច្រអូស និងមិនស្ដាប់បង្គាប់ទ្រង់ទៅវិញ (ទត ៣:១៤)។

**៤:១៣** *ពួកអ្នកដែលដេកលក់ទៅហើយ* សម្រាប់គ្រីស្ទបរិស័ទពាក្យថា "ដេកលក់" ជាពាក្យប្រៀបធៀប សំដៅលើការស្លាប់ខាងឯរូបកាយ ព្រោះថាសេចក្ដីស្លាប់ចុងក្រោយ និងការអាក្រក់នឹងត្រូវដកចេញ ដោយសារ ការធានាអំពីសេចក្ដីរស់ឡើងវិញ ។ ពួកជំនុំនៅទីក្រុងថែស្សាឡូនីច ហាក់ដូចជាមិនយល់នូវសេចក្ដីដែលលោកប៉ុលបានបង្រៀនដល់ពួកគេ ហើយនាំគ្នាយល់ថា អស់អ្នកជឿដល់ព្រះគ្រីស្ទនឹងរស់នៅរហូតដល់ទ្រង់យាងមកជាលើកទីពីរ ។ ដូច្នោះហើយ បានជានៅពេល ដែលមានអ្នកជឿបានស្លាប់ខាងឯរូបកាយ ធ្វើឱ្យពួកគេខ្លះចោទជាសំណួរឡើងថា "តើអ្នកដែលស្លាប់ទាំងនោះ មានចំណែកនៅក្នុងថ្ងៃព្រះគ្រីស្ទយាងមកដែរឬទេ ?" (ខ.១៥និងពន្យល់)។ *អ្នកដទៃទៀត ដែលគ្មានសង្ឃឹម* តាមរយៈសិលាចារឹកនៅលើផ្នូរ និងភស្តុតាងតាមរយៈអក្សរសាស្ត្របានបង្ហាញថា នៅសតវត្សរ៍ទីមួយពួកសាសន៍ដទៃមានការយល់ឃើញថា សេចក្ដីស្លាប់ និងសេចក្ដីអាក្រក់ គឺជាចុងបញ្ចប់សម្រាប់គ្រប់អ្វីៗទាំងអស់ ។ ចំពោះគ្រីស្ទបរិស័ទ គឺមានការយល់ឃើញផ្ទុយ ពីពួកគេទាំងស្រុង (១កថ ១៥:៥៥–៥៧ ភល ១:២១–២៣)។

**៤:១៤** *ព្រះយេស៊ូវបានសុគត* លោកប៉ុលមិនបានប្រើពាក្យថា "ដេកលក់" ចំពោះ ព្រះយេស៊ូវទេ ប្រហែលជាគាត់ចង់បញ្ជាក់ថា ការសុគតរបស់ទ្រង់ គឺដើម្បីទទួលគ្រប់ទាំងអំពើទាំងឡាយដែលមនុស្សលោកធ្វើ និងឱ្យអស់អ្នកណាជឿដល់ព្រះនាម ទ្រង់គឺបានការសង្គ្រោះ ។ *ព្រមទាំងរស់ឡើងវិញ* ចំពោះសារសំខាន់នៃការរស់ឡើងវិញ សូមមើល "១កថ ១៥"។ *អស់អ្នកដែលដេកលក់ទៅក្នុងព្រះយេស៊ូវ* សំដៅលើពួកអ្នកដែលបានស្លាប់ និងដែលបានទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ ។

**៤:១៥** *តាមព្រះបន្ទូលនៃព្រះអម្ចាស់* គោលលទ្ធិដែលលើកឡើងនៅត្រង់ចំណុចនេះ មិនមានលើកឡើងនៅក្នុងគម្ពីរដំណឹងល្អទាំងបួនទេ ដូច្នេះ អាចជាការបើកសំដែង ដែលលោកប៉ុលទទួលពីព្រះអម្ចាស់ដោយផ្ទាល់ ឬជាព្រះបន្ទូលដែលព្រះយេស៊ូវមានបន្ទូលទៅកាន់ពួកបណ្ដាជន ហើយពួកគេបានចេះចាំគ្រប់ៗគ្នា ។ *យើងដែលរស់នៅជាប់* សំដៅលើគ្រីស្ទបរិស័ទដែលមានជីវិតរស់នៅលើផែនដីក្នុងពេលព្រះគ្រីស្ទយាងមកជាលើកទីពីរ ។

ដេកលក់ទៅហើយនោះទេ[ស] ១៦ ព្រោះព្រះអម្ចាស់ទ្រង់នឹង
យាងចុះពីស្ថានសួគ៌មក[ស] ដោយស្រែកបង្គាប់ ១ព្រះឱស្ឋ
ទាំងមានឮសំឡេងមហាទេវតា[ហ] និងត្រែរបស់ព្រះផង[ឡ]
នោះពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់[អ]
១៧ រួចយើងរាល់គ្នាដែលកំពុងតែរស់នៅ[ក] ក៏នឹងបានលើក
ឡើងទៅក្នុងពពកជាមួយគ្នាទាំងអស់[ខ] ដើម្បីឱ្យបានចួបជុំនឹង
ព្រះអម្ចាស់[គ]នៅនាអាកាស យ៉ាងនោះ យើងនឹងនៅជាមួយ
នឹងព្រះអម្ចាស់ជាដរាបទៅ ១៨ ដូច្នេះ ចូរកំសាន្តចិត្តគ្នាទៅ
វិញទៅមក[ឃ]ដោយដំណើរនេះចុះ ។
**៥** ១ បងប្អូនអើយ ឯត្រង់ពេលវេលា[ង] នោះមិនបាច់ឱ្យខ្ញុំ
សរសេរប្រាប់មកអ្នករាល់គ្នាទេ[ច] ២ ដ្បិតអ្នករាល់គ្នាដឹង
ច្បាស់ហើយថា ថ្ងៃនៃព្រះអម្ចាស់[ឆ]នឹងមកដល់ ដូចជាចោរ
មកនៅពេលយប់[ជ] ៣ ដ្បិតកាលណាគេកំពុងតែនិយាយ
ថាមានសេចក្ដីសុខសាន្ត មានសេចក្ដីរៀបរយហើយ[ឈ]
នោះលោតែមានសេចក្ដីហិនវិនាសមកលើគេភ្លាម[ញ] ដូច
ជាស្ត្រីមានគភ៌ឈឺនឹងសំរាល ហើយគេចមិនរួចឡើយ[ដ]
៤ តែបងប្អូនអើយ អ្នករាល់គ្នាមិនមែននៅក្នុងសេចក្ដីងងឹត[ឋ]
ឱ្យថ្ងៃនោះបានមកដល់អ្នករាល់គ្នា ដូចជាចោរនោះទេ[ឌ]
៥ អ្នករាល់គ្នាសុទ្ធតែជាពួកនៃពន្លឺ[ឍ] ហើយជាពួកនៃថ្ងៃ

**៤:១៦** ស មថ ១៦:២៧ ហ យដ ៩ ឡ មថ ២៤:៣១ អ ១កថ ១៥:២៣ ២ថន ២:១ វវ ១៤:១៣
**៤:១៧** ក ១កថ ១៥:៥២ ខ កថ ១:៩ កថ ៨:៣៩ វវ ១:៧ ១១:១២ គ យហ ១២:២៦
**៤:១៨** ឃ ១ថន ៥:១១
**៥:១** ង កថ ១:៧ ច ១ថន ៤:៩
**៥:២** ឆ ១កថ ១:៨ ជ លក ១២:៣៩ **៥:៣** ឈ យរ ៤:១០ ៦:១៤ អគ ១៣:១០ ញ យប ១៥:២១ ទដ ៣៥:៨ ៥៥:១៥ អស ២៩:៥ ៤៧:៩,១១ ដ ២ថន ១:៩
**៥:៤** ឋ កថ ២៦:១៨ ១យហ ២:៨ ឌ ខ.២

ម្យ៉ាងទៀតសព្វនាម "យើង" នៅត្រង់ចំណុចនេះ មិនមែនត្រូវតែសំដៅលើលោកប៉ុលទេ ប៉ុន្តែ គាត់មានប្រសាសន៍យ៉ាងដូច្នេះ សំដៅលើអស់អ្នកដែលគាត់លើកយកមកនិយាយ ។ នៅចំណុចផ្សេងៗទៀត លោកប៉ុលមានប្រសាសន៍ថា "ព្រះទ្រង់បានទាំងប្រោសឱ្យព្រះអម្ចាស់រស់ឡើងវិញ ហើយនិងប្រោសឱ្យយើងរាល់គ្នារស់ឡើងវិញ" (១កថ ៦:១៤ ២កថ ៤:១៤)។ *យើងមិនទៅមុនពួកអ្នក ដែលបានដេកលក់ទៅហើយនោះទេ* ពួកជំនុំនៅទីក្រុងថែស្សាឡូនីច បានបារម្ភអំពីពួកអ្នក ដែលធ្លាប់រស់នៅក្នុងចំណោមពួកគេ ហើយដែលបានស្លាប់ហើយថា ប្រហែលជាពួកអ្នកដែលស្លាប់ទៅទាំង នោះបាត់បង់ឱកាស នៅពេលព្រះគ្រីស្ទយាងមកជាលើកទីពីរ ។ ដូច្នេះហើយបានជាលោកប៉ុលបញ្ជាក់ប្រាប់ពួកគេយ៉ាងច្បាស់ នូវសេចក្ដីដែលទាក់ទងនឹងការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ ។

**៤:១៦** *ព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក* "សូមមើល កថ ១:១១"។ *មហាទេវតា* នៅក្នុងព្រះគម្ពីរមានបញ្ជាក់ឈ្មោះមហាទេវតាចម្បាំង "មីកែល" (ដយ ១០:១៣ យដ ៩)។ ជាទូទៅនៅក្នុងព្រះគម្ពីរទេវតាកាព្រីយ៉ែលត្រូវបានហៅថា "ទេវតា" (លក ១:១៩,២៦)។ *ពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់* គឺមុនពេលការលើកឡើងនៃពួកអ្នកជឿ ដែលបញ្ជាក់នៅក្នុង បទគម្ពីរបន្ទាប់ ។

**៤:១៧** *យើងរាល់គ្នាដែលកំពុងតែរស់នៅ* "មើលការពន្យល់ ខ.១៥"។ *ក៏នឹង បានលើកឡើង* ត្រង់ចំណុចនេះបញ្ជាក់ច្បាស់អំពីការលើកឡើងនៃអ្នកជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ ។ អ្នកខ្លះយល់ថា ការនេះជាសេចក្ដីអាថ៌កំបាំង ប៉ុន្តែ លោកប៉ុលដូចជាពិពណ៌នាសេចក្ដីទាំងនេះដោយបើកចំហ និងនៅទីសាធារណៈ ដោយសំឡេងខ្លាំងៗតែម្ដង និងដូចជាមានសំឡេងត្រែបន្លឺឡើងជាមួយផង។ *ទៅក្នុងពពក* "សូមប្រៀបធៀបជាមួយនឹងបទគម្ពីរ កថ ១:៩ និងការពន្យល់"។ *ចួបជុំនឹងព្រះអម្ចាស់* នេះជាសេចក្ដីសង្ឃឹមធំបំផុតរបស់គ្រីស្ទបរិស័ទ (៥:១០ យហ ១៤:៣ ២កថ ៥:៨ ភល ១:២៣ កល ៣:៤)។

**៤:១៨** *ចូរកំសាន្តចិត្តគ្នាទៅវិញទៅមក* គោលបំណងធំជាងគេនៃ "ខ១៣–១៨" មិនមែនសម្រាប់តែហេតុការណ៍កើតឡើងនៅពេលអនាគតទេ ប៉ុន្តែគឺសំដៅលើការលើកទឹកចិត្តគ្នារបស់គ្រីស្ទបរិស័ទ នាពេលបច្ចុប្បន្ននេះតែម្ដង (ខ.១៣)។

**៥:១** *ពេលវេលា* "សូមមើល កថ ១:៦-៧"។ មានគ្រីស្ទបរិស័ទមួយចំនួនតែងតែ ព្យាយាមកំណត់ពេលវេលានៃការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ប៉ុន្តែ ជាទូទៅពួកជំនុំនៅទីក្រុងថែស្សាឡូនីចមិនមែននៅក្នុងចំណោមពួកនោះទេ។

**៥:២** *ថ្ងៃនៃព្រះអម្ចាស់* "សូមមើល ១កថ ៥:៥"។ ឃ្លានេះបានលើកឡើងនៅក្នុងបទគម្ពីរ "អេម៉ុស ៥:១៨"។ នៅក្នុងសញ្ញាចាស់និយាយអំពីពេលវេលាដែលព្រះអម្ចាស់ត្រូវយាងមក ហើយធ្វើអន្តរាគមន៍ដោយការជំនុំជម្រះ និងផ្ដល់នូវព្រះពរ (យអ ១:១៥ និងការពន្យល់)។ នៅក្នុងសញ្ញាថ្មី ការយល់ឃើញអំពីការជំនុំជម្រះនៅតែមានបន្ត (រម ២:៥ ២ពត ២:៩) ប៉ុន្តែ វាក៏ជា "ថ្ងៃនៃការប្រោសលោះ" (អភ ៤:៣០) "ថ្ងៃនៃព្រះអម្ចាស់" (២ពត ៣:១២) ឬ "ថ្ងៃរបស់ព្រះគ្រីស្ទ" (១កថ ១:៨ ភល ១:៦) និង "ថ្ងៃចុងក្រោយ" (យហ ៦:៣៩) "ថ្ងៃដ៏ធំ" (យដ ៦) ឬហៅជាទូទៅថា "ថ្ងៃនោះ" (២ថន ១:១០)។ នេះគឺជាសេចក្ដីពេញបរិបូរនៃគ្រប់ទាំងរបស់ទាំងអស់ ។ វានឹងមានទីសំគាល់ដំបូង (២ថន ២:៣) ប៉ុន្តែ សម្រាប់ពួកអ្នកមិនជឿការយាងមករបស់ព្រះយេស៊ូវគ្រីស្ទមិនអាចគិតស្មានដល់ គឺប្រៀបដូចជាចោរដែលចូលមកនៅពេលយប់ដូច្នោះដែរ (មថ ២៤:៤៣–៤៤ លក ១២:៣៩–៤០ ២ពត ៣:១០ វវ ៣:៣ ១៦:១៥)។

**៥:៣** *សេចក្ដីហិនវិនាស* មិនមែនមានន័យថា អ្វីៗទាំងអស់នឹងត្រូវវិនាសសូន្យនោះទេ ប៉ុន្តែសំដៅលើការទាំងឡាយណា ដែលមិនស្ថិតនៅក្នុងព្រះវត្តមានរបស់ព្រះអម្ចាស់ (២ថន ១:៩ និងការពន្យល់) ដូច្នេះ ការបំផ្លាញនៃ ជីវិត និងអំនួតនៃជីវិតត្រូវដល់កំណត់របស់វាហើយ ។ *មកលើគេភ្លាម* លោកប៉ុលបញ្ជាក់អំពីការភ្ញាក់ផ្អើលរបស់ពួកអ្នកមិនព្រមជឿដល់ព្រះអម្ចាស់ ។ គាត់ប្រើពាក្យដែលមាន តែនៅក្នុងបទគម្ពីរ "លក ២១:៣៤" ប៉ុណ្ណោះក្នុងព្រះគម្ពីរសញ្ញាថ្មី ។ *ដូចជាស្ត្រី មានគភ៌ឈឺនឹងសំរាល* ឃ្លានេះមិនសំដៅលើការឈឺចាប់ នៅពេលដែលសម្រាលកូននោះទេ ប៉ុន្តែ ចង់បញ្ជាក់អំពីការឈឺចាប់ដែលនឹងមកភ្លាមៗ ហើយមិនអាចជៀសផុតបានឡើយ ។ *ហើយគេចមិនរួចឡើយ* សំដៅលើការហិនវិនាស និងការជំនុំជម្រះ ។

**៥:៤** *សេចក្ដីងងឹត* បញ្ជាក់ថា អ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទ មិនរស់នៅក្នុងសេចក្ដីងងឹតទៀតទេ ហើយក៏មិនមែនជារបស់សេចក្ដីងងឹតទៀតដែរ (ខ.៥ កថ ២៦:១៨ ២កថ ៦:១៤ ១យហ ១:៥–៧ និងការពន្យល់)។ *ចោរ* "ខ.២ និងការពន្យល់"។

**៥:៥** *ពួកនៃពន្លឺ ហើយជាពួកនៃថ្ងៃ* បញ្ជាក់ថា គ្រីស្ទបរិស័ទមិនគ្រាន់តែជា

យើងមិនមែនជាពួកនៃយប់ ឬនៃសេចក្ដីងងឹតឡើយ ៦ដូច្នេះ
ត្រូវឱ្យយើងចាំយាម[ណ] ហើយដឹងខ្លួន[ត] មិនត្រូវឱ្យដេកលក់[ថ]
ដូចជាមនុស្សឯទៀតទេ ៧ដ្បិតពួកអ្នកដែលដេកលក់ នោះ
គេតែងដេកនៅពេលយប់ ហើយពួកអ្នកដែលស្រវឹងស្រា
ក៏តែងស្រវឹងនៅពេលយប់ដែរ[ទ] ៨តែយើងដែលជាពួកនៃ
ថ្ងៃ[ធ] យើងត្រូវដឹងខ្លួន ទាំងប្រដាប់កាយដោយសេចក្ដីជំនឿ
និងសេចក្ដីស្រឡាញ់ ទុកជាប្រដាប់បាំងដើមទ្រូង[ន] ហើយ
សេចក្ដីសង្ឃឹមរបស់ផងសេចក្ដីសង្គ្រោះ[ប] ទុកជាមួកសឹក[ផ]
៩ដ្បិតព្រះទ្រង់មិនបានដំរូវយើង ទុកសំរាប់សេចក្ដីក្រោធ
ទេ[ព] គឺសំរាប់ឱ្យបានសេចក្ដីសង្គ្រោះវិញ ដោយសារព្រះ
យេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង ដែលទ្រង់សុគត
ជំនួសយើង[ភ] ១០ដើម្បីឱ្យយើងរាល់គ្នាបានរស់នៅជាមួយនឹង
ទ្រង់ ទោះបើចាំយាម ឬដេកលក់ក្ដី[ម] ១១ដូច្នេះ ចូរកំសាន្ត[យ]
ហើយស្អាងចិត្តគ្នា[រ] ទៅវិញទៅមក ដូចជាអ្នករាល់គ្នាកំពុង
តែធ្វើហើយនោះដែរ ។

**៥:៥** ឈ លក ១៦:៨
**៥:៦** ណ កច ២៤:២៥ ត មថ ២៥:១៣ ថ កច ២៤:២៥
**៥:៧** ទ កច ២:១៥ រម ១៣:១៣ ២ពត ២:១៣
**៥:៨** ធ ខ.៥ ន អភ ៦:១៤ ប រម ៨:២៤ ផ អភ ៥៩:១៧ អភ ៦:១៧
**៥:៩** ព ១ថន ១:១០ ភ ២ថន ២:១៣,១៤
**៥:១០** ម រម ១៤:៩ ២កថ ៥:១៥
**៥:១១** យ ១ថន ៤:១៨ រ អភ ៤:២៩

## បណ្ដាំចុងក្រោយ

១២តែបងប្អូនអើយ យើងខ្ញុំអង្វរអ្នករាល់គ្នាថា ចូរ
ចំណាំឱ្យស្គាល់ពួកអ្នកដែលខំធ្វើកិច្ចការ[ល] ក្នុងពួកអ្នករាល់
គ្នា នឹងពួកអ្នកដែលនាំមុខអ្នករាល់គ្នាក្នុងព្រះអម្ចាស់[វ]
ហើយនិងពួកអ្នកដែលទូន្មានដែរ ១៣ដើម្បីឱ្យបានរាប់អាន
ជាខ្លាំង ចំពោះពួកអ្នកយ៉ាងនោះ ដោយសេចក្ដីស្រឡាញ់
ដោយព្រោះការដែលគេធ្វើ ចូរនៅជាមួយគ្នាដោយមេត្រី
ចុះ[ស] ១៤បងប្អូនអើយ យើងខ្ញុំទូន្មានឱ្យអ្នករាល់គ្នាបន្ទោស
ដល់ពួកអ្នកដែលគ្មានសណ្ដាប់ធ្នាប់[ហ] ហើយជួយកំសាន្តដល់
ពួកអ្នកណាដែលមានសេចក្ដីទន់ក្រំចិត្ត ទាំងគាំពារពួកអ្នក
ដែលខ្សោយ[ឡ] និងអត់ឱនចំពោះមនុស្សទាំងអស់ ១៥ចូរ
ប្រយ័ត្ន កុំឱ្យអ្នកណាធ្វើអំពើអាក្រក់ ស្នងនឹងអំពើអាក្រក់
ឡើយ[អ] ចូរដេញតាមការល្អជាដរាប ដល់គ្នាទៅវិញទៅ
មក[ក] ហើយដល់មនុស្សផងទាំងឡាយដែរ ១៦ចូរអរសប្បាយ

**៥:១២** ល រម ១៦:៦,១២ ១កថ ១៥:១០ វ ១ធថ ៥:១៧ ហព ១៣:១៧ **៥:១៣** ស មក ៩:៥០ **៥:១៤** ហ ២ថន ៣:៦,៧,១១ ឡ រម ១៤:១ ១កថ ៨:៧-១២

ពួកនៃពន្លឺប៉ុណ្ណោះទេ ប៉ុន្តែ ត្រូវបានទទួលស្គាល់ពន្លឺ (ព្រះអម្ចាស់)។

**៥:៦** *ត្រូវឱ្យយើងចាំយាម* ក្នុងន័យអក្សរសាស្ត្រ អាចនិយាយថា "ចាំមើល"។ លោកប៉ុលទូន្មានដល់ពួកជំនុំទាំងអស់ឱ្យចាំយាមជាប់ជានិច្ចសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវ (មថ ២៤:៤២,៤៣ ២៥:១៣ មក ១៣:៣៤-៣៧)។ *ហើយដឹងខ្លួន* គឺត្រូវមានលក្ខណៈខុសអំពីពួកអ្នកដែលត្រូវបានពណ៌នាក្នុងខ៧ ។ *ដេកលក់* ចំណុចនេះបង្ហាញថា ពួកអ្នកមិនជឿពុំបានប្រុងប្រយ័ត្នខាងឯវិញ្ញាណរបស់ពួកគេទេ ប៉ុន្តែ ចំពោះពួកអ្នករស់នៅក្នុងពន្លឺវិញមិនត្រូវធ្វើដូច្នោះទេ ។

**៥:៨** *ថ្ងៃ* សំដៅលើពន្លឺដែលបញ្ជាក់អំពីជីវិតរបស់គ្រីស្ទបរិស័ទ ហើយអាចសំដៅលើថ្ងៃដែលព្រះយេស៊ូវគ្រីស្ទទ្រង់យាងមកផងដែរ (ខ.២ និងមើលការពន្យល់)។ *ប្រដាប់បាំងដើមទ្រូង . . . មួកសឹក* លោកប៉ុលក៏បានប្រើពាក្យប្រៀបធៀបអំពីគ្រឿងសឹកនៅក្នុងបទគម្ពីរ "រម ១៣:១២ ២កថ ៦:៧ ១០:៤ អភ ៦:១៣-១៧ (និង មើលការពន្យល់)"ផងដែរ ។ គាត់មិនបានសំដៅលើគ្រឿងសព្វាវុធសម្រាប់ធ្វើសង្គ្រាមខាងឯសាច់ឈាមទេ ប៉ុន្តែគាត់ចង់បង្ហាញនូវគំនិតទូទៅ អំពីឧបករណ៍ដែលត្រូវប្រើប្រាស់នៅក្នុងការតយុទ្ធ ។ ចំពោះសេចក្ដីសំខាន់បីយ៉ាង រួមមានសេចក្ដីជំនឿសេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់ សូមមើល "១:៣ និងពន្យល់"។

**៥:៩** *ដំរូវ* សំដៅលើការដ៏សំខាន់ដែលព្រះអម្ចាស់តម្រូវទុកមក មិនមែនជាការជ្រើសរើសរបស់មនុស្សទេ ។ *សេចក្ដីក្រោធ* "មើលការពន្យល់ ១:១០"។ *សេចក្ដីសង្គ្រោះ* សំដៅលើសេចក្ដីសង្គ្រោះដ៏ពេញបរិបូរ ដែលត្រូវបានប្រទាន មកយើងរាល់គ្នាដែលជឿដល់ព្រះយេស៊ូវគ្រីស្ទ ។

**៥:១០** *នៅជាមួយនឹងទ្រង់* គឺរស់នៅជាមួយនឹងព្រះគ្រីស្ទ ដោយមានទំនាក់ទំនងជាមួយទ្រង់ ហើយគ្មានអ្វីអាចកាត់ផ្ដាច់បានឡើយ ។ *ទោះបើចាំយាម ឬដេកលក់ក្ដី* មានន័យថា ទោះបើនៅរស់ ឬបានស្លាប់ក្ដី ឬក៏ប្រើនៅក្នុងអត្ថន័យប្រព្រឹត្តខ្ជាប់ខ្ជួនល្អខាងសីលធម៌ ឬបណ្ដោយតាមលោកីយ (ខ.៦)។

**៥:១១** *ចូរកំសាន្ត ហើយនិងស្អាងចិត្តគ្នា* ឃ្លានេះលោកប៉ុលចង់សំដៅលើការស្អាងចិត្តគ្នារបស់គ្រីស្ទបរិស័ទ គឺដូចជាការសាងសង់ផ្ទះមួយឡើងដូច្នោះដែរ ។

**៥:១២** *ពួកអ្នកដែលខំធ្វើកិច្ចការក្នុងពួកអ្នករាល់គ្នា* នៅសម័យកាលនោះពុំបានបញ្ជាក់ច្រើនអំពីការរៀបចំ និងការដឹកនាំនៃពួកជំនុំទេ ប៉ុន្តែសេចក្ដីដែលចែងនៅត្រង់ចំណុចនេះ ជាទូទៅអាចសំដៅលើពួកចាស់ទុំ (ហព ១៣:៧,១៧)។

**៥:១៣** *ដោយព្រោះការដែលគេធ្វើ* ត្រង់ចំណុចនេះមិនមែនសំដៅលើឋានៈ ឬមុខងាររបស់ពួកគេទេ ប៉ុន្តែ គឺសំដៅលើការងារអនុវត្តផ្ទាល់របស់ពួកគេវិញ ។ *ចូរនៅជាមួយគ្នាដោយមេត្រីចុះ* ឃ្លានេះសំដៅលើការអនុវត្តន៍នៃទំនាក់ទំនងជាទូទៅរបស់គ្រីស្ទបរិស័ទ ប៉ុន្តែក៏សំដៅលើសិទ្ធិក្នុងការទំនាក់ទំនងរវាងអ្នកដឹកនាំ និងអ្នកដែលដើរតាមពួកគេដែរ (រម ១៤:១៧,១៩)។

**៥:១៤** *ពួកអ្នកដែលគ្មានសណ្ដាប់ធ្នាប់* ត្រង់ចំណុចនេះហាក់ដូចជាពួកជំនុំខ្លះនៅទីក្រុងថែស្សាឡូនីចបានយល់ថា ការយាងមករបស់ព្រះគ្រីស្ទជាលើកទីពីរ គឺនៅជិតបង្កើយ ដូច្នោះហើយទើបបណ្ដាលឱ្យពួក គេទាំងនោះមិនគិតធ្វើការងារអ្វីទេ បែរជាគិតតែរៀបចំខ្លួនសម្រាប់ការយាងមករបស់ទ្រង់តែប៉ុណ្ណោះ ។ ប៉ុន្តែ លោកប៉ុលបញ្ជាក់ប្រាប់ពួកគេយ៉ាងច្បាស់ថា ពួកគេត្រូវតែធ្វើការងារ (២ថន ៣:១០-១១ និងការពន្យល់)។ *ពួកអ្នកណាដែលមានសេចក្ដីទន់ក្រំចិត្ត . . . ខ្សោយ* សំដៅលើពួកអ្នកដែលត្រូវការជំនួយពីបងប្អូនដទៃទៀតដែលរឹងមាំ គឺមិនត្រូវឱ្យបោះបង់ពួកគេទេ (រម ១៤:១-១៥ ១កថ ៨:១៣ និងការពន្យល់)។

**៥:១៥** *កុំឱ្យអ្នកណាធ្វើអំពើអាក្រក់ ស្នងនឹងអំពើអាក្រក់ឡើយ* បញ្ជាក់ថាគ្រីស្ទបរិស័ទត្រូវបានព្រះអម្ចាស់ត្រាស់ហៅឱ្យអត់ទោសដល់អ្នកដទៃ (មថ ៥:៣៨-៤២ ១៨:២១-៣៥) ហើយមិនត្រូវធ្វើការសងសឹកដល់ពួកអ្នក

ជានិច្ច[ខ] ១៧ចូរអធិស្ឋានឥតឈប់ឈរ[គ] ១៨ចូរអរព្រះគុណក្នុង
គ្រប់ការទាំងអស់[ឃ] ពីព្រោះព្រះទ្រង់សព្វព្រះហឫទ័យឱ្យ
អ្នករាល់គ្នាធ្វើយ៉ាងដូច្នោះ ដោយនូវ ព្រះគ្រីស្ទយេស៊ូវ
១៩កុំឱ្យពន្លត់ព្រះវិញ្ញាណ[ង] ២០កុំឱ្យមើលងាយការអធិប្បាយ[ច]
ឡើយ ២១ចូរលមើលគ្រប់ទាំងអស់[ឆ] ហើយកាន់ខ្ជាប់តាម
សេចក្ដីដែលត្រឹមត្រូវ[ជ] ២២ចូរចៀសចេញពីសេចក្ដី អាក្រក់
គ្រប់យ៉ាង ។
២៣សូមឱ្យព្រះនៃសេចក្ដីសុខសាន្ត[ឈ] ញែកអ្នករាល់គ្នាចេញ
ជាបរិសុទ្ធសព្វគ្រប់ ហើយឱ្យទាំងព្រលឹងនិងវិញ្ញាណ[ញ]
ហើយរូបកាយទាំងមូលបានបំរុងទុកឥតសៅហ្មង[ដ] ដរាប
ដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង ទ្រង់យាងមក[ឋ]
២៤ព្រះដែលបានហៅ[ឌ] អ្នករាល់គ្នា ទ្រង់ស្មោះត្រង់[ឍ] ទ្រង់នឹង
ធ្វើសំរេចការនោះ[ណ] ។
២៥បងប្អូនអើយ សូមអធិស្ឋានឱ្យយើងខ្ញុំផង[ត] ២៦សូម
ជំរាបសួរដល់ពួកបងប្អូនទាំងអស់ ដោយថើបបរិសុទ្ធដែរ[ថ]
២៧ខ្ញុំផ្ដាំមកអ្នករាល់គ្នាដោយព្រះអម្ចាស់ថា សូមអានមើល
សំបុត្រនេះ ឱ្យពួកបងប្អូនបរិសុទ្ធគ្រប់គ្នាស្ដាប់ផង[ទ] ។
២៨សូមឱ្យអ្នករាល់គ្នា បានប្រកបដោយព្រះគុណរបស់
ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា[ធ] ។
អាម៉ែន ។

**៥:១៥** អ រម ១២:១៧ ១ពត ៣:៩ ក អភ ៤:៣២
**៥:១៦** ខ ភល ៤:៤
**៥:១៧** គ លក ១៨:១
**៥:១៨** ឃ អភ ៥:២០
**៥:១៩** ង អភ ៤:៣០
**៥:២០** ច ១កថ ១៤:១–៤០
**៥:២១** ឆ ១កថ ១៤:២៩ ១យហ ៤:១ ជ ១ថឌ ៣:១៣ ជ រម ១២:៩
**៥:២៣** ឈ រម ១៥:៣៣ ញ ហព ៤:១២ ឋ ១ថន ២:១៩
**៥:២៤** ឌ រម ៨:២៨ ឍ ១កថ ១:៩ ណ ជន ២៣:១៩ ភល ១:៦
**៥:២៥** ត អភ ៦:១៩ កល ៤:៣ ២ថន ៣:១ ហព ១៣:១៨
**៥:២៦** ថ រម ១៦:១៦ **៥:២៧** ទ ២ថន ៣:១៤ ២ធថ ៤:១៣
**៥:២៨** ធ រម ១៦:២០

ដែលធ្វើអាក្រក់លើខ្លួន ទេ (រម ១២:១៧ និងការពន្យល់)។

**៥:១៦** "មើលការពន្យល់ ភល ៤:៤"។

**៥:១៧** សម្រាប់ការអនុវត្តន៍ នៃការបន្តព្យាយាមនៅក្នុងសេចក្ដីអធិស្ឋាន សូមមើល "១:៣ ២:១៣ រម ១:៩–១០ អភ ៦:១៨ កល ១:៣ ២ធថ ១:៣"។

**៥:១៨** *ចូរអរព្រះគុណ* "សូមមើល អភ ៥:២០ និងការពន្យល់"។

**៥:១៩** *កុំឱ្យពន្លត់ព្រះវិញ្ញាណ* អាចសំដៅលើការធ្វេសប្រហែសចំពោះអំណោយទានដែលព្រះវិញ្ញាណប្រទានមក មិនត្រូវបញ្ឈប់ឬរារាំងអំណោយទានរបស់អ្នកដទៃឡើយ តែផ្ទុយទៅវិញត្រូវជួយស្អាងថែមទៀត(ខ.២០)។

**៥:២០** *ការអធិប្បាយ* ក្នុងព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសប្រើពាក្យថា "ការថ្លែងទំនាយ"។ សម្រាប់អំណោយទាននៃការថ្លែងទំនាយ សូមមើល "រម ១២:៦ ១កថ ១២:១០,២៨ ១៣:២ ១៤ អភ ៤:១១"។ សម្រាប់តួនាទីនៃការថ្លែងទំនាយ សូមមើល "១កថ ១៤:៣"។

**៥:២១** *ចូរលមើលគ្រប់ទាំងអស់* បញ្ជាក់ថា គ្រប់ទាំងសេចក្ដីដែលគេថ្លែងនៅក្នុងព្រះនាមព្រះអម្ចាស់ មិនមែនត្រូវតែទទួលយកដោយគ្មានការចោទសួរនោះទេ ។ លោកប៉ុលមិនបានបញ្ជាក់ថា យកអ្វីមកធ្វើពិសោធន៍ដើម្បីឱ្យដឹងនោះទេ ប៉ុន្តែ គាត់បានបញ្ជាក់ថា ត្រូវធ្វើពិសោធន៍ចំពោះការថ្លែងទំនាយ ។ ម្យ៉ាងទៀត គ្រប់ទាំងសេចក្ដីទំនាយ គឺត្រូវតែស្របនឹងព្រះបន្ទូលនៃព្រះអម្ចាស់ ។

**៥:២៣** បទគម្ពីរនេះបញ្ជាក់អំពីបែបបទនៃការអធិស្ឋាន ។ *ព្រះនៃសេចក្ដីសុខសាន្ត* សំដៅលើព្រះយេស៊ូវគ្រីស្ទ ។ លោកប៉ុលតែងតែ មានប្រសាសន៍យ៉ាងដូច្នេះ នៅចុងបញ្ចប់នៃសំបុត្ររបស់គាត់ (រម ១:៧ ១៥:៣៣ ១៦:២០ ១កថ ១៤:៣៣ ២កថ ១៣:១១ ភល ៤:៩ ២ថន ៣:១៦ និងការពន្យល់)។ *ញែកអ្នករាល់គ្នាចេញជាបរិសុទ្ធ* "មើលការពន្យល់ ១កថ ១:២"។ *ព្រលឹងនិងវិញ្ញាណ ហើយរូបកាយ* លោកប៉ុលមានប្រសាសន៍យ៉ាងដូច្នេះ គឺសំដៅលើបុគ្គលទាំងមូលតែម្ដងគ្មានលើកលែងនូវផ្នែកណាមួយទេ (ហព ៤:១២ និងការពន្យល់)។

**៥:២៤** បទគម្ពីរនេះបញ្ជាក់ថា លោកប៉ុលមានទំនុកចិត្តនៅក្នុងព្រះអម្ចាស់ (លប ១៨:២៥ និងការពន្យល់) ដែលទ្រង់ជាព្រះដែលសុចរិត ហើយអ្វីដែលទ្រង់បានចាប់ផ្ដើមទ្រង់នឹងបញ្ចប់ជាបរិបូរនិងគ្រប់លក្ខណ៍ (ជន ២៣:១៩ ភល ១:៦ និងការពន្យល់)។

**៥:២៦** *បងប្អូនទាំងអស់* លោកប៉ុលបានសរសេរសំបុត្រសួរសុខទុក្ខដល់ពួកជំនុំទាំងអស់ គឺទាំងពួកអ្នកដែលគាត់កែតម្រង់ផងដែរ ។ *ថើបបរិសុទ្ធ* គឺបុរសថើបបុរស ហើយស្ត្រីថើបស្ត្រី ដោយសេចក្ដីគោរព និងដោយសេចក្ដីស្រឡាញ់ក្នុងព្រះអម្ចាស់(រម១៦:១៦ ១កថ ១៦:២០ ២កថ ១៣:១២ ១ពត ៥:១៤ និងការ ពន្យល់)។

**៥:២៧** *ខ្ញុំផ្ដាំមកអ្នករាល់គ្នាដោយព្រះអម្ចាស់* ឃ្លានេះមានអត្ថន័យធ្ងន់ដែលមានលើកឡើងតែត្រង់ចំណុចនេះ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ លោកប៉ុលបញ្ជាក់យ៉ាងច្បាស់ថា ត្រូវឱ្យគ្រប់គ្នានៅក្នុងពួកជំនុំបានអាន និងស្ដាប់នូវសេចក្ដីដែលគាត់បានសរសេរទៅកាន់ពួកគេ ប្រយោជន៍ឱ្យពួកគេដឹងនូវការបារម្ភរបស់គាត់ចំពោះពួកគេ និងការទូន្មានផ្សេងៗ ។

**៥:២៨** លោកប៉ុលតែងតែបញ្ចប់សេចក្ដីនៅក្នុងសំបុត្ររបស់គាត់ដោយការទូលអង្វរដល់ព្រះអម្ចាស់ឱ្យប្រទានពរដល់អស់អ្នក ដែលអានសំបុត្ររបស់គាត់ (២កថ ១៣:១៤)។ *សូមឱ្យអ្នករាល់គ្នាបានប្រកប* "មើលការពន្យល់ ២កថ ១៣:១៤"។
*ព្រះគុណ* "មើលពន្យល់ រម ១:៧"។ *ព្រះយេស៊ូវគ្រីស្ទ* "មើលពន្យល់ ១:១"។

សំបុត្រទី២ របស់លោកប៉ុល

ដល់ពួក

# ថែស្សាឡូនីច

សេចក្ដីផ្ដើម

### អ្នកនិពន្ធ កាលបរិច្ឆេទ និងទីកន្លែងនិពន្ធ

សំបុត្រថែស្សាឡូនីចខ្សែទី ២នេះមានការ ចោទជាសំនួរ អំពីការ ដែលលោកប៉ុលជាអ្នកនិពន្ធ ច្រើនជាងសំបុត្រថែស្សាឡូនីចខ្សែទី១ ទោះបីជា តាមការពិត សំបុត្រនេះមានការគាំទ្រពីសំណាក់អ្នកនិពន្ធគ្រីស្ទបរិស័ទសម័យដើមច្រើនជាងយ៉ាងណាក៏ដោយ ។ ការបដិសេធន៍ទាំងនោះបណ្ដាលមកពីកត្តាខាងក្នុងរបស់សំបុត្រ ជាជាងប្រសាសន៍របស់អ្នកសរសេរ គោលលទ្ធិគ្រីស្ទបរិស័ទសម័យដើម ។ គេគិតថា មានភាពខុសគ្នាជាច្រើននៅក្នុងការប្រើប្រាស់ពាក្យ (មាន ១០ ពាក្យដែលមិនមានប្រើនៅក្នុងកណ្ឌព្រះគម្ពីរផ្សេងទៀត) នៅក្នុងរចនាបថ (មានគេនិយាយថា គ្មានការរំពឹងថាសំបុត្រនេះមានលក្ខណៈផ្លូវការទេ) និងនៅក្នុងវិជ្ជាអំពីព្រះទាក់ទងនឹងសេចក្ដីស្លាប់និងការបន្ទាប់នៃសេចក្ដីស្លាប់ (គោលទ្ធិអំពី "អាទទឹងច្បាប់" មិនមាន និយាយនៅក្នុងកណ្ឌគម្ពីរដទៃ) ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកកាត់ស្រាយសម័យនេះពុំមានការជឿជាក់ទៅលើពាក្យសំអាងខាងលើនេះទេ ។ ភាគច្រើននៃពួកគេនៅតែជឿថា សាវ័កប៉ុលគឺជាអ្នកនិពន្ធសំបុត្រនេះដដែល ។

ដោយសារលក្ខណៈប្រហាក់ប្រហែលគ្នារបស់សំបុត្រទាំងពីរ គេសន្និដ្ឋានថា សំបុត្រនេះប្រាកដជាត្រូវបានសរសេរក្នុងពេលបន្ទាប់មិនយូរប៉ុន្មាន ពីសំបុត្រទីមួយទេ គឺប្រហែលប្រាំមួយខែប៉ុណ្ណោះ ។ ស្ថានភាពពួកជំនុំតាមសំបុត្រទាំងពីរហាក់ដូចជាមានភាពដូចគ្នាច្រើន ។ គេ ជឿថាសាវ័កប៉ុលបានសរសេរសំបុត្រនេះ (មើល ១:១ ៣:១៧) នៅក្នុងឆ្នាំ ៥១ គ.ស. នៅទីក្រុងកូរិនថូស បន្ទាប់ពីលោកស៊ីឡាស និងលោកធីម៉ូថេបានត្រឡប់ពីបញ្ជូន សំបុត្រថែស្សាឡូនីចខ្សែទី១ (មើលសេចក្ដីផ្ដើម ១ថែស្សាឡូនីច) ។

### គោលបំណង

ដោយហេតុថា ស្ថានភាពនៅក្នុងពួកជំនុំថែស្សាឡូនីចមិនមានការផ្លាស់ប្ដូរ គោលបំណងដែលសាវ័កប៉ុលសរសេរសំបុត្រនេះគឺមិនខុស ពីសំបុត្រខ្សែទី១ទេ ។ លោកនិពន្ធសំបុត្រនេះគឺ (១) ដើម្បីលើកទឹកចិត្តដល់អ្នកជឿដែលគេបៀតបៀន (១:៤-១០) (២) ដើម្បីកុំឱ្យមានការ ភាន់ច្រឡំពីការយាងមករបស់ព្រះគ្រីស្ទ (២:១-១២) និង (៣) ដើម្បីលើកទឹកចិត្តពួកជំនុំថែស្សាឡូនីចឱ្យមានការប្រកាន់ខ្ជាប់ និងធ្វើការ ដោយស្រគត់ស្រគំ (២:១៣-៣:១៥) ។

### គោលរឿង

សំបុត្រនេះមានខ្លឹមសារសំខាន់មិនខុសពីសំបុត្រថែស្សាឡូនីចខ្សែទី១ទេ សំបុត្រនេះភាគច្រើននិយាយអំពីវិជ្ជាអំពីព្រះដែលទាក់ទងនឹងសេចក្ដីស្លាប់ និងសេចក្ដីបន្ទាប់ពីសេចក្ដីស្លាប់ (មើលសេចក្ដីផ្ដើម ១ថែស្សឡូនីច ត្រង់គោលរឿង) ។ ជាការពិតពិតណាស់ នៅក្នុងថែស្សាឡូនីចទី២ មាន ១៨ខក្នុងចំណោម៤៧ខបាននិយាយអំពីប្រធានបទនេះ ។

### គម្រោងសង្ខេប

**I. សេចក្ដីផ្ដើម (ជំពូក ១)**

ក. ការគួរសម (៣:១-៥)

ខ. ការអរព្រះគុណសម្រាប់សេចក្ដីជំនឿ សេចក្ដីស្រឡាញ់ និងការខ្ជាប់ខ្ជួនរបស់ពួកគេ (១:៣-១០)

គ. ការអធិស្ឋានសម្រាប់ការចម្រើនឡើងខាងឯវិញ្ញាណរបស់ពួកគេ (១:១១-១២)

**II. សេចក្ដីបង្រៀន (ជំពូក ២)**

ក. សេចក្ដីទំនាយអំពីថ្ងៃនៃព្រះអម្ចាស់ (២:១-១២)

ខ. ការអរព្រះគុណសម្រាប់ការរើសតាំង និងត្រាសហៅពួកគេ (២:១៣-១៥)

គ. ការអធិស្ឋានសម្រាប់ការបម្រើ និងទីបន្ទាល់របស់ពួកគេ (ការប្រព្រឹតតាម) (២:១៦-១៧)

**III. សេចក្ដីបណ្ដាំ (ជំពូក ៣)**

ក. សំណូមពរអធិស្ឋាន (ជំពូក ១០)

ខ. បណ្ដាំឱ្យប្រៀនប្រដៅពួកប្រព្រឹត្តខុសរបៀប និងពួកមនុស្សខ្ជិល (៣:៦-១៥)

គ. ការសន្និដ្ឋាន ការគួរសម និងការជូនពរជាបញ្ចប់ (៣:១៦-១៨)

**១** ១ សំបុត្រប៉ុល ស៊ីលវ៉ាន[ក] នឹងធីម៉ូថេ[ខ] យើងខ្ញុំផ្ញើមកពួក
ជំនុំនៅក្រុងថែស្សាឡូនីច[គ] ដែលនៅក្នុងព្រះដ៏ជាព្រះ
វរបិតានៃយើងរាល់គ្នា នឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ២ សូម
ឱ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ និងសេចក្ដីសុខ
សាន្ដ អំពីព្រះដ៏ជាព្រះវរបិតានៃយើង ហើយអំពីព្រះ
អម្ចាស់យេស៊ូវគ្រីស្ទ[ឃ]។

## ការអរព្រះគុណ និងការអធិស្ឋាន

៣ បងប្អូនអើយ យើងខ្ញុំត្រូវតែអរព្រះគុណដល់ព្រះ
ជានិច្ច ពីដំណើរអ្នករាល់គ្នា[ង] ដូចជាគួរគប្បីដែរ ពីព្រោះ
សេចក្ដីជំនឿរបស់អ្នករាល់គ្នា កំពុងតែចំរើនកាន់តែ
ច្រើនឡើង ហើយអ្នករាល់គ្នាមានសេចក្ដីស្រឡាញ់ ដល់គ្នា
ទៅវិញទៅមក រឹតតែខ្លាំងឡើងដែរ[ច] ៤ ដល់ម្ល៉េះបានជា
យើងខ្ញុំអួតពីអ្នករាល់គ្នា នៅក្នុងអស់ទាំងពួកជំនុំនៃព្រះ[ឆ]
ពីដំណើរសេចក្ដីខ្ជាប់ខ្ជួន នឹងសេចក្ដីជំនឿរបស់អ្នករាល់
គ្នា[ជ] ដែលមានក្នុងសេចក្ដីបៀតបៀន នឹងសេចក្ដីទុក្ខ
លំបាកទាំងប៉ុន្មាន ដែលអ្នករាល់គ្នារងទ្រាំ[ឈ] ៥ នោះជា
ភស្ដុតាង[ញ] ពីសេចក្ដីជំនុំជំរះដ៏សុចរិតរបស់ព្រះ ប្រយោជន៍
ឱ្យអ្នករាល់គ្នាបានរាប់ជាគួរ[ដ] នឹងនគរព្រះ ដែលអ្នករាល់
គ្នាកំពុងតែរងទុក្ខ ដោយព្រោះនគរនោះឯង ៦ ដ្បិតនេះ
ជាសេចក្ដីសុចរិតនៅចំពោះព្រះ[ឋ] គឺនឹងសងសេចក្ដីទុក្ខ
លំបាក ដល់ពួកអ្នកដែលធ្វើទុក្ខដល់អ្នករាល់គ្នា[ឌ] ៧ ហើយ
ឱ្យអ្នករាល់គ្នា ដែលត្រូវគេធ្វើទុក្ខនោះ បានសំរាក
ជាមួយនឹងយើងខ្ញុំវិញ ក្នុងកាលដែលព្រះអម្ចាស់យេស៊ូវ
ទ្រង់លេចមកពីស្ថានសួគ៌[ឍ] ជាមួយនឹងពួកទេវតានៃព្រះ
ចេស្ដាទ្រង់[ណ] ៨ នៅក្នុងអណ្ដាតភ្លើង[ត] ទាំងសងសឹក[ថ] នឹងពួក
អ្នកដែលមិនស្គាល់ព្រះ[ទ] ហើយនឹងពួកអ្នកដែលមិនស្ដាប់
តាមដំណឹងល្អពីព្រះយេស៊ូវគ្រីស្ទ[ធ] ជាព្រះអម្ចាស់នៃយើង
៩ គេនឹងរងទុក្ខទោស ជាសេចក្ដីហិនវិនាសអស់កល្បជានិច្ច[ន]
ឃ្លាតពីព្រះភក្ត្រនៃព្រះអម្ចាស់[ប] ហើយពីសិរីល្អនៃព្រះ

**១:១** ក កច ១៥:២២ ខ កច ១៦:១ ១ថន ១:១ គ កច ១៧:១ **១:២** ឃ រម ១:៧ **១:៣** ង រម ១:៨ អភ ៥:២០ ច ១ថន ៣:១២ **១:៤** ឆ ២កថ ៧:១៤ ជ ១ថន ១:៣ ឈ ១ថន ១:៦ ២:១៤ ៣:៣ **១:៥** ញ ភល ១:២៨ ដ លក ២០:៣៥ **១:៦** ឋ លក ១៨:៧,៨ ឌ រម ១២:១៩ កល ៣:២៥ វវ ៦:១០ **១:៧** ឍ លក ១៧:៣០ ណ យដ ១៤ **១:៨** ត ហព ១០:២៧ ១២:២៩ ២ពត ៣:៧ វវ ១:១៤ ថ ទដ ៧៩:៦ អស ៦៦:១៥ យរ ១០:២៥ ទ កទ ៤:៨ ធ រម ២:៨ ២កថ ២:១២ **១:៩** ន ភល ៣:១៩ ១ថន ៥:៣ ២ពត ៣:៧ ប ២ពវ ១៧:១៨

**១:១–២** មើលការពន្យល់ ១ថន ១:១ ។

**១:១** *ប៉ុល* មើលការពន្យល់ រម ១:១ ។ *ព្រះអម្ចាស់យេស៊ូវគ្រីស្ទ* នៅចុងបញ្ចប់នៃសំបុត្រនេះក៏ឃើញមានពាក្យនេះផង (៣:១៨) ។ មើលការពន្យល់ ១ថន ១:១ ។

**១:២** *ព្រះគុណ និងសេចក្ដីសុខសាន្ដ* មើលការពន្យល់ រម ១:៧ ។

**១:៣** *គួរគប្បី* មានន័យថា គ្រីស្ទបរិស័ទមានកាតព្វកិច្ចអរព្រះគុណដល់ព្រះ (សូមផ្ទៀបនឹង ១ថន ១:៧–៨, ការពន្យល់ ភល ១:៣–៤) ។ *អ្នករាល់គ្នា* មើលការពន្យល់ រម ១:១៣ ។ *សេចក្ដីជំនឿ . . . សេចក្ដីស្រឡាញ់* គឺជាសេចក្ដីខ្ពង់ខ្ពស់ទាំងពីរ ដែលធ្វើឱ្យលោកប៉ុលមានអំណរ (១ថន ៣:៦–៧ និងការពន្យល់ ៣:៦) ប៉ុន្ដែ សេចក្ដីទាំងពីរក៏មានការខ្វះខាតផងដែរ (១ថន ៣:១០ និងការពន្យល់,១២) ។ *រឹតតែខ្លាំងឡើង* មើល ១ថន ៣:១២ ។

**១:៤** *យើងខ្ញុំ* គឺលោកប៉ុល និងអ្នកដែលនៅជាមួយនឹងគាត់ ។ សាវកប៉ុលហាក់ដូចជាចង់និយាយពន្លយពាក្យថា ការដែលនរណាម្នាក់អួត ពីព្រះវិហារ ដែលខ្លួនបានបង្កើតគឺមិនមែនជារឿងធម្មតាទេ ទោះបីជាអាចមានអ្នកផ្សេងទៀតធ្វើដូចនេះក៏ដោយ (សូមផ្ទៀបនឹង ១ថន ១:៩) ។ ប៉ុន្ដែ ពួកជំនុំថែស្សាឡូនីចពិតជាមានលក្ខណៈ លេចធ្លោមែន ។ *សេចក្ដីបៀតបៀន និងសេចក្ដីទុក្ខលំបាកទាំងប៉ុន្មាន* មើល ១ថន ១:៦ ២:១៤ ៣:៣ ។

**១:៥** *ភស្ដុតាងពីសេចក្ដីជំនុំជំរះដ៏សុចរិតរបស់ព្រះ* ភស្ដុតាងនេះមាននៅក្នុងរបៀបដែលពួកជំនុំថែស្សាឡូនីចអត់ទ្រាំនឹងការលំបាក។ ការជំនុំជម្រះដែលពួកគេទទួលគឺសុចរិត ពីព្រោះព្រះអម្ចាស់ទ្រង់មិនយាងចោលដោយទុកឱ្យពួកគេពឹងអាងលើកម្លាំងខ្លួនឯងនោះឡើយ។ នៅក្នុងការអត់ទ្រាំនឹងការលំបាកនោះ ព្រះទ្រង់បានប្រទាននូវកម្លាំងដល់ពួកគេ ហើយការអត់ទ្រាំនេះបានបង្កើតឱ្យមានលក្ខណៈសម្បត្តិខាងឯវិញ្ញាណ និងសីលធម៌ ។ ការនេះក៏បង្ហាញផងដែរថា ព្រះទ្រង់ជួយដល់ពួកគេព្រមទាំងផ្ដល់នូវការព្រមានដល់អ្នកដែលធ្វើទុក្ខបៀតបៀនពួកគេ (សូមផ្ទៀប នឹង ភល ១:២៨ និងការពន្យល់) ។ *នគរព្រះ* មើលការ ពន្យល់ ១ថន ២:១២ មថ ៣:២ ។

**១:៦** *សេចក្ដីសុចរិតនៅចំពោះព្រះ* សេចក្ដីសុចរិតរបស់ព្រះនាំមកនូវការជំនុំជម្រះ មនុស្សមានបាបដែលមិនប្រែចិត្ត (សូមផ្ទៀប មក ៩:៤៧–៤៨ លក ១៣:៣–៥) ហើយការជំនុំជម្រះនេះអាចកើតមានក្នុងពេលបច្ចុប្បន្នក៏ដូចជានៅថ្ងៃជំនុំជម្រះ ។

**១:៧** *បានសំរាក* ការជំនុំជម្រះ គឺមិនគ្រាន់តែរាប់បញ្ចូលការកាត់ទោសពីសេចក្ដីអាក្រក់ប៉ុណ្ណោះទេ ប៉ុន្ដែថែមទាំងរាប់បញ្ចូលការសម្រាកសម្រាប់ពួកសុចរិតផងដែរ ។ *ជាមួយនឹងយើងខ្ញុំ* សាវកប៉ុលមិនមែនជាបណ្ឌិតវិជ្ជាសិក្សាអំពីព្រះដែលសរសេរសំបុត្រផ្ញើពីចម្ងាយមក ដោយសុខស្រួលនោះឡើយ ផ្ទុយទៅវិញលោកក៏កំពុងរងទុក្ខដូចពួកគេដែរ ។ *លេចមក* មានមនុស្សជាច្រើនបានបដិសេធ ព្រះវត្តមានរបស់ព្រះអម្ចាស់ ពីព្រោះពួកគេជឿតែលើការមើលឃើញប៉ុណ្ណោះ ប៉ុន្ដែ នៅគ្រាដែលទ្រង់យាងមកជាលើកទីពីរ មនុស្សគ្រប់រូបនឹងបានឃើញទ្រង់ ។ *ពួកទេវតានៃព្រះចេស្ដាទ្រង់* ប្រហែលជាទេវតាមួយក្រុម ដែលព្រះទ្រង់ប្រទាននូវអំណាចពិសេសដើម្បីធ្វើតាមព្រះហឫទ័យទ្រង់ (វវ ១៩:១៤ និងការពន្យល់) ។

**១:៨** *ពួកអ្នកដែលមិនស្គាល់ព្រះ* គឺពួកអ្នកដែលមិនជឿព្រះ ឬមិនប្រែចិត្តទទួលជឿព្រះ (សូមផ្ទៀបនឹង ២:១០ និងការពន្យល់ និងមើល ២:១២ រម ១:២៨) ។ *ពួកអ្នក ដែលមិនស្ដាប់តាមដំណឹងល្អ* គឺជាដំណឹងដែលអញ្ជើញឱ្យទទួលព្រះ ដូចនេះការបដិសេធនឹដំណឹងល្អជាការមិនស្ដាប់បង្គាប់តាមការអញ្ជើញរបស់ព្រះមហាក្សត្រ។

**១:៩** *សេចក្ដីហិនវិនាស* ដោយសារសេចក្ដីសង្គ្រោះមានន័យថា ជាការរស់ឡើងវិញនៃរូបកាយ ដូចនេះសេចក្ដីហិនវិនាសនៅក្នុងខនេះមិនមានន័យថាជាការបំផ្លេចបំផ្លាញឱ្យរលាយសូន្យនោះទេ (មើល ១ថន ៥:៣ និងការ

ចេស្តាទ្រង់[ផ] ១០ក្នុងកាល[ព]ដែលទ្រង់យាងមក ដើម្បីឱ្យបាន
ដំកើងឡើង[ភ]ក្នុងពួកបរិសុទ្ធរបស់ទ្រង់ ហើយនៅថ្ងៃនោះ
ឱ្យបានគេមើលទ្រង់ដោយអស្ចារ្យ ក្នុងពួកអ្នកដែលជឿ
ដ្បិតអ្នករាល់គ្នាបានជឿពាក្យបន្ទាល់របស់យើងខ្ញុំហើយ[ម]
១១ដូច្នេះ យើងខ្ញុំអធិស្ឋានឱ្យអ្នករាល់គ្នាជានិច្ច[យ] ដើម្បីឱ្យ
ព្រះនៃយើងខ្ញុំ បានរាប់អ្នករាល់គ្នាជាគួរ[រ] នឹងការដែល
ទ្រង់ហៅមកធ្វើ[ល] ហើយឱ្យទ្រង់បានបំពេញគ្រប់អស់ទាំង
សេចក្តីបំណងខាងឯការល្អ[វ] និងការដែលធ្វើដោយជំនឿ
ដោយព្រះចេស្តា[ស] ១២ដើម្បីឱ្យព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ
ជាព្រះអម្ចាស់នៃយើង បានដំកើងឡើងក្នុងអ្នករាល់គ្នា[ហ]
ហើយអ្នករាល់គ្នាក្នុងទ្រង់ផង តាមព្រះគុណរបស់ព្រះនៃ
យើង និងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។

## មនុស្សដែលជាតួបាប

**២** ១ឥឡូវនេះ បងប្អូនអើយ ដោយព្រោះព្រះយេស៊ូវគ្រីស្ទ[ឡ]
ជាព្រះអម្ចាស់នៃយើង ទ្រង់ត្រូវយាងមក ហើយយើងរាល់
គ្នាត្រូវប្រជុំគ្នានៅចំពោះទ្រង់[អ] នោះយើងខ្ញុំសូមអង្វរដល់
អ្នករាល់គ្នាថា ២កុំឱ្យអ្នករាល់គ្នាឆាប់មានគំនិត រវើរវាយ
ឬថប់ព្រួយអ្វី ទោះបើដោយសារវិញ្ញាណណា ឬពាក្យសំដី
ណា ឬសំបុត្រណា[ក] ដូចជាមកពីយើងខ្ញុំក្តី ដែលថាថ្ងៃនៃ
ព្រះអម្ចាស់[ខ]ជិតដល់ហើយនោះឡើយ[គ] ៣កុំឱ្យអ្នកណា
បញ្ឆោតអ្នករាល់គ្នា[ឃ]ជាយ៉ាងណាដែរ ដ្បិតថ្ងៃនោះមិនមក
ឡើយ ទាល់តែមានសេចក្តីក្បត់សាសនាមកជាមុន ហើយ
មនុស្សដែលជាតួបាបនោះ[ង]បានលេចមក[ច] គឺជាមនុស្ស
ដែលត្រូវហិនវិនាស ៤ដែលទាស់ទទឹង ហើយលើកខ្លួន
ឡើង ខ្ពស់លើសជាងអស់ទាំងអ្វីដែលហៅថាព្រះ[ឆ] ឬរបស់
អ្វីដែលគេគោរពប្រតិបត្តិផង ដល់ម្ល៉េះបានជាវានឹងអង្គុយ
នៅ ដូចជាព្រះក្នុងវិហារនៃព្រះទាំងសំដែងខ្លួនថាជាព្រះ
ផង[ជ] ៥តើអ្នករាល់គ្នាមិននឹកចាំទេឬអីថា ក្នុងគ្រាដែលខ្ញុំ

**១:៩** ផ អស ២:១០,១៩ ២ថន ២:៨
**១:១០** ព ១កថ ៣:១៣ ភ យហ ១៧:១០ ម ១កថ ១:៦
**១:១១** យ រម ១:១០ រ ខ.៥ ល រម ៨:២៨ វ រម ១៥:១៤ ស ១ថន ១:៣
**១:១២** ហ អស ២៤:១៥ ភល ២:៩–១១
**២:១** ឡ ១ថន ២:១៩ អ មក ១៣:២៧ ១ថន ៤:១៥–១៧
**២:២** ក ខ.១៥ ២ថន ៣:១៧ ខ ១កថ ១:៨ គ ២ធថ ២:១៨
**២:៣** ឃ មក ១៣:៥ ង មថ ២៤:១០–១២ ច ខ.៨ ដយ ៧:២៥ ៨:២៥ ១១:៣៦ វវ ១៣:៥,៦ **២:៤** ឆ ១កថ ៨:៥ ជ អស ១៤:១៣,១៤ អគ ២៨:២

ពន្យល់)។ នៅក្នុងខនេះសេចក្តីហិនវិនាសមានន័យថាជាការបង្ខាំងពីព្រះវត្តមានរបស់ព្រះ ។ ការដាច់ចេញអស់កល្បជានិច្ចនេះ គឺជាទោសនៃអំពើបាប និងលក្ខណៈនៃស្ថាននរក(សូមធៀបនឹង វវ ២០:១៤–១៥ ២១:៨,២៧)។

**១:១០** *ក្នុងកាល* មើលការពន្យល់ ១ថន ៥:២ ។ *ដំកើងឡើងក្នុងពួកបរិសុទ្ធរបស់ទ្រង់* គឺមិនមែននៅក្នុងចំណោមពួកគេទេ ប៉ុន្តែនៅក្នុងពួកគេ ។ សិរីល្អរបស់ទ្រង់ គឺឃើញមាននៅក្នុងការអ្វីដែលពួកគេជា ។ *ពួកបរិសុទ្ធ* មើលការពន្យល់ ១ថន ៣:១៣ ។ *ពាក្យបន្ទាល់របស់យើងខ្ញុំ* ការផ្សាយដំណឹងល្អគឺជាការធ្វើបន្ទាល់យ៉ាងសំខាន់បំផុត ពីព្រះរាជកិច្ចដែលព្រះទ្រង់បានធ្វើក្នុងព្រះគ្រីស្ទ ។

**១:១១** *អធិស្ឋានឱ្យអ្នករាល់គ្នាជានិច្ច* មើលការពន្យល់ ១ថន ៥:១៧ កល ៤:២ ។ *បំណងខាងឯការល្អ* គឺបំណងល្អ ។ ព្រះទ្រង់ជាអ្នកបណ្តាលឱ្យមានបំណងល្អសេចក្តីជំនឿជំរុញឱ្យមាននូវការប្រព្រឹត្ត ដែលតាមរយៈនេះ សាវកប៉ុលបានអធិស្ឋានសូមឱ្យព្រះទ្រង់បំពេញដល់ពួកគេ ។

**១:១២** *ព្រះនាម* ជាញឹកញាប់ នៅសម័យបុរាណ ឈ្មោះរបស់មនុស្សម្នាក់មិនគ្រាន់តែជាពាក្យដែលសន្មតសម្រាប់ហៅអ្នកនោះប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបានបង្ហាញពីអ្វីដែលអ្នកនោះជាផងដែរ ។ *ព្រះអម្ចាស់នៃយើងបានដំកើងឡើង ក្នុងអ្នករាល់គ្នា* សាវកប៉ុលសំឡឹងមើលសិរីល្អដែលព្រះគ្រីស្ទទ្រង់បណ្តាលឱ្យមាននៅក្នុងគ្រីស្ទបរិស័ទក្រុងថែស្សាឡូនីច តាមរយៈកិច្ចការដែលទ្រង់ធ្វើនៅក្នុងពួកគេ(មើល ខ.១០ និងការពន្យល់)។ *អ្នករាល់គ្នាក្នុងទ្រង់* គ្រីស្ទបរិស័ទនឹងមានចំណែកនៅក្នុងសិរីល្អរបស់ព្រះគ្រីស្ទដោយសារសេចក្តីល្អនៃការប្រកបរបស់ពួកគេជាមួយនឹងទ្រង់ (សូមធៀប យហ ១៥:៤ និងការពន្យល់ ១៧:២១)។

**២:១** *យាងមក* មើល ១ថន ២:១៩ និងការពន្យល់ ។ ការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ គឺជាប្រធានបទជាចំបងរបស់សំបុត្រថែស្សាឡូនីចខ្សែទី២នេះ ។ អ្វីដែលសាវកប៉ុលបានសរសេរក្នុងសំបុត្រនេះ គឺសម្រាប់បង្គ្រប់ការបង្រៀនផ្ទាល់មាត់របស់គាត់ និងការបង្រៀនដែលមាននៅក្នុងសំបុត្រមុនៗរបស់គាត់ ។ *ប្រជុំគ្នានៅចំពោះទ្រង់* មើល ១ថន ៤:១៧ និងការពន្យល់ ។

**២:២** *រវើរវាយ* ពាក្យនេះជាភាសាក្រិកច្រើនតែប្រើសម្រាប់ទូកដែលរសាតចេញពីច្រាំងដោយមិនមានជាប់ចំណង និងមានន័យថាមិននឹងនរ ។ *ថប់ព្រួយ* កាលព្រះយេស៊ូវទ្រង់មិនទាន់យាងឡើងស្ថានសួគ៌ ទ្រង់បានប្រទាននូវការបង្រៀន ដូចនេះ ដោយប្រើពាក្យដូចនេះផងដែរ(មក ១៣:៧)។ *ណា* ត្រង់ចំណុចនេះ សាវកប៉ុលនិយាយជាលក្ខណៈទូទៅ ។

**២:៣** *សេចក្តីក្បត់សាសនា* នៅគ្រាចុងបង្អស់ នឹងមានការរវាតចិត្តចេញពីសេចក្តីជំនឿ(មើល មថ ២៤:១០–១២ ១ធថ ៤:១) ប៉ុន្តែ ក្នុងខនេះសាវកប៉ុលនិយាយអំពីសេចក្តីក្បត់ ដែលមានការទាស់ទទឹងនៃសេចក្តីអាក្រក់ដែលលើកខ្លួនឡើងខ្ពស់លើសជាងអស់ទាំងអ្វី ដែលហៅថាព្រះ ។ *មនុស្សដែលជាតួបាប* គឺអ្នកដឹកនាំនៃកម្លាំងនៃសេចក្តីអាក្រក់នៅគ្រាចុងបង្អស់ ។ មានតែនៅក្នុងខនេះប៉ុណ្ណោះដែល មនុស្សនោះត្រូវបានហៅយ៉ាងដូចនេះ ។ លោកយ៉ូហានបាននិយាយអំពី "ពួកទទឹង នឹងព្រះគ្រីស្ទ"ជាច្រើនដង(១យហ ២:១៨) ហើយពួកដែលជាតួបាបនៅក្នុងខនេះ អាចជាពួកដែលអាក្រក់បំផុតគឺពួកដែលទទឹងនឹងព្រះគ្រីស្ទនៅក្នុង វវ ១៣ ។ អ្នក នោះមិនមែនជាអារក្សសាតាំងទេពីព្រោះខ.៩បានបង្ហាញយ៉ាង ច្បាស់អំពីភាពខុសគ្នានេះ ។ *លេចមក* ពាក្យនេះជាភាសាក្រិកមានឫសដូចជាពាក្យដែលប្រើសម្រាប់ព្រះយេស៊ូវគ្រីស្ទនៅក្នុង ១:៧ ដូចនេះពាក្យនេះប្រហែលជាសំដៅទៅលើសកម្មភាពដែលមានលក្ខណៈអធិធម្មជាតិ ។ *ដែលត្រូវហិនវិនាស* មនុស្សដែលជាតួបាបនោះនឹងត្រូវវិនាសជាប្រាកដ ដោយសារតែសេចក្តីអំណួតរបស់ខ្លួន ។ ពាក្យដូចនេះប្រើចំពោះលោកយូដាសអ៊ីស្ការីយ៉ុតផងដែរ (យហ ១៧:១២)។

**២:៤** *អស់ទាំងអ្វី ដែលហៅថាព្រះ ឬរបស់អ្វីដែលគេគោរពប្រតិបត្តិ* មនុស្សនោះមិនគ្រាន់តែជាអ្នកនយោបាយ ឬទាហានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងតាំងខ្លួនខ្ពស់លើសជាងព្រះទាំងអស់របស់លោកិយ និងជាងគ្រប់អ្វីៗទាំងអស់

នៅជាមួយ នោះខ្ញុំបានប្រាប់អ្នករាល់គ្នាពីសេចក្ដីទាំងនេះ
ដែរ[ឈ] 6 ហើយឥឡូវនេះ អ្នករាល់គ្នាស្គាល់សេចក្ដីដែល
ឃាត់វា[ញ] ប្រយោជន៍ឱ្យវាបានលេចមកតែក្នុងពេលវេលា
របស់វាប៉ុណ្ណោះ 7 ដ្បិតសេចក្ដីអាថ៌កំបាំងរបស់ការទទឹង
ច្បាប់ កំពុងតែបណ្ដាលឡើងហើយ ប៉ុន្តែ មាន១អង្គដែល
ឃាត់ឃាំងវាសព្វថ្ងៃនេះ[ដ] ទាល់តែបានដកទ្រង់ចេញទៅ
8 នោះទើបអាទទឹងច្បាប់នោះ នឹងលេចមក[ឋ] ដែលព្រះ
អម្ចាស់យេស៊ូវនឹងបំផ្លាញ ដោយខ្យល់ពីព្រះឱស្ឋទ្រង់[ឌ]
ហើយធ្វើឱ្យវិនាស ដោយរស្មីពន្លឺពីដំណើរទ្រង់យាងមក[ឍ]
9 អាទទឹងច្បាប់នោះនឹងមកទាំងធ្វើការ ដូចជាអារក្ស
សាតាំង[ណ] ដោយនូវគ្រប់ទាំងឫទ្ធិ ទីសំគាល់ និងការអស្ចារ្យ
ដ៏កំភូត[ត] 10 ហើយដោយគ្រប់ទាំងសេចក្ដីឆបោករបស់
សេចក្ដីទុច្ចរិត ក្នុងពួកអ្នកដែលត្រូវវិនាស[ថ] ដោយព្រោះគេ
មិនព្រមស្រឡាញ់ដល់សេចក្ដីពិត ដើម្បីឱ្យគេបានសង្គ្រោះ
នោះទេ[ទ] 11 ហេតុនោះបានជាព្រះ ទ្រង់នឹងឱ្យ[ធ] សេចក្ដីខុស
ឆ្គងមក[ន] បណ្ដាលឱ្យគេជឿតាមសេចក្ដីភូតភរវិញ[ប] 12 ដើម្បី
ឱ្យអស់មនុស្សណាដែលមិនជឿតាមសេចក្ដីពិត គឺពេញចិត្ត
នឹងសេចក្ដីទុច្ចរិត នោះបានជាប់មានទោសវិញ[ផ]។

**ការឈរមាំមួន**

13 ឱបងប្អូនដ៏ជាស្ងួនភ្ងានៃព្រះអម្ចាស់អើយ យើងខ្ញុំត្រូវ
តែអរព្រះគុណដល់ព្រះអង្គជានិច្ច ពីដំណើរអ្នករាល់គ្នា[ព]
ពីព្រោះព្រះទ្រង់បានរើសអ្នករាល់គ្នា[ភ] តាំងពីដើមដំបូងមក
ដើម្បីឱ្យបានសង្គ្រោះ[ម] ដោយព្រះវិញ្ញាណ[យ] ទ្រង់ញែកចេញ
ជាបរិសុទ្ធ ហើយដោយមានចិត្តជឿ តាមសេចក្ដីពិតផង
14 ទ្រង់បានហៅអ្នករាល់គ្នាមក[រ] ក្នុងសេចក្ដីទាំងនោះដោយ
សារដំណឹងល្អនៃយើងខ្ញុំ[ល] ប្រយោជន៍ឱ្យបានសិរីល្អរបស់
ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង 15 ដូច្នេះ បងប្អូន
អើយ ចូរឈរឱ្យមាំមួន[វ] ហើយកាន់ខ្ជាប់តាមសេចក្ដីបញ្ញត្តិ
ដែលយើងខ្ញុំបានបង្រៀនដល់អ្នករាល់គ្នាចុះ[ស] ទោះបើដោយ
ពាក្យសំដី ឬសំបុត្រក្ដី 16 សូមឱ្យព្រះយេស៊ូវគ្រីស្ទ ជាព្រះ

**២:៥** ឈ ១ថន ៣:៤
**២:៦** ញ ខ.៧
**២:៧** ដ ខ.៦
**២:៨** ឋ ខ.៣
ឌ អស ១១:៤ វវ
២:១៦ ១៩:១៥ ឍ
លក ១៧:១៣
**២:៩** ណ មថ ៤:១០
ត មថ ២៤:២៤ វវ
១៣:១៣ យហ ៤:៤៨
**២:១០** ថ ១កថ
១:១៨ ទ សក ៤:៦
យហ ៣:១៧–១៩
**២:១១** ធ រម ១:២៨
ន មថ ២៤:៥
មក ១៣:៥
ប រម ១:២៥
**២:១២** ផ រម ១:៣២
២:៨
**២:១៣** ព រម ១:៨
ភ អភ ១:៤
ម ១ថន ៥:៩
យ ១ពត ១:២

**២:១៤** រ រម ៨:២៨ ១១:២៩ ល ១ថន ១:៥ **២:១៥** វ ១កថ ១៦:១៣ ស ១កថ ១១:២

ដែលទាក់ទងនឹងការថ្វាយបង្គំ ។ មនុស្សនោះហ៊ានប្រកាសខ្លួនថាជាព្រះទៀតផង ។ *វិហារនៃព្រះ* គេជឿថា លោកសាវកប៉ុលប្រើពាក្យនេះ សំដៅទៅលើព្រះវិហារនៅទីក្រុងយេរូសាឡិម(សូមផ្ទៀប មថ ២៤:១៥ និងការពន្យល់)។

**២:៦** *សេចក្ដីដែលឃាត់វា* តាមមតិជាច្រើនសេចក្ដីដែលឃាត់នោះគឺ (១)ចក្រភពរ៉ូម៉ាំងនិងព្រះចៅអធិរាជ្យ (២)បេសកកម្មរបស់សាវ័កប៉ុល (៣)សាសន៍យូដា (៤)ច្បាប់និងរដ្ឋាភិបាលដែលគ្រប់គ្រងរដ្ឋ (៥)ព្រះវិញ្ញាណបរិសុទ្ធ ឬ(៦)ការឃាត់ឃាំងរបស់ព្រះវិញ្ញាណបរិសុទ្ធតាមរយៈពួកជំនុំ ។

**២:៧** *សេចក្ដីអាថ៌កំបាំង* មើលការពន្យល់ រម ១១:២៥ ។ ពាក្យនេះភាគច្រើនត្រូវបានប្រើសំដៅទៅលើដំណឹងល្អ ឬផ្នែកណាមួយនៃដំណឹងល្អ ។ ក្នុងខនេះសេចក្ដីអាថ៌កំបាំងគឺជាសេចក្ដីអាក្រក់ ដែលយើងដឹងតាមរយៈការបើកសំដែងរបស់ព្រះ ។ សេចក្ដីអាក្រក់នេះគឺបានចាប់ផ្ដើមធ្វើការរបស់វាហើយ ហើយវានឹងបន្តរហូតដល់សេចក្ដីឃាត់ឃាំងត្រូវបានដកចេញទៅនៅគ្រាបញ្ចប់ ។

**២:៨** *ព្រះអម្ចាស់យេស៊ូវនឹងបំផ្លាញ* អាទទឹងនោះនឹងត្រូវវិនាសទៅ ដោយព្រះបន្ទូលនៃជីវិតអស់កល្បជានិច្ច ដែលជាគោលលទ្ធិដ៏ត្រឹមត្រូវនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ អាទទឹងនោះនឹងមិនស្លាប់ទៅភ្លាមៗទេគឺនឹងស្លាប់ទៅបន្តិចម្ដងៗ ដោយសារការផ្សាយពីសេចក្ដីពិត ពីព្រោះវាត្រូវបង្ហាញខ្លួនត្រូវដួលរលំ និងត្រូវវិនាសនៅទីបញ្ចប់ ។

**២:៩** អារក្សសាតាំងជាអ្នកផ្ដល់អំណាចឱ្យអាទទឹងច្បាប់នោះ(សូមផ្ទៀបនឹង មថ ២៤:២៤)។

**២:១០** *សេចក្ដីឆបោក* គឺជាគោលបំណងនៃការឫទ្ធិបារមីនៃខ.៩ ។ *មិនព្រមមាន* ន័យថា ការមិនជឿរបស់ពួកគេគឺត្រូវបានធ្វើឡើង ដោយបំណងចិត្ត ។ *សេចក្ដីពិត* ជាសេចក្ដីដែលមានទំនាក់ទំនងនឹងព្រះយេស៊ូវ(មើល យហ ១៤:៦ និងការពន្យល់ អភ ៤:២១) និងដំណឹងល្អ(កទ ២:៥ អភ ១:១៣)។

**២:១១** *ហេតុនោះ* គឺពីព្រោះតែការបដិសេធន៍របស់ពួកគេចំពោះសេចក្ដីពិតដោយបំណងចិត្ត(ខ.១០)។ *ទ្រង់នឹងឱ្យសេចក្ដីខុសឆ្គងមកបណ្ដាលឱ្យគេជឿតាមសេចក្ដីភូតភរ* ព្រះទ្រង់ប្រើអំពើបាបដើម្បីកាត់ទោសអ្នកដែលមានបាប(មើល រម ១:២៤–២៨)។ *សេចក្ដីភូតភរ* គឺសេចក្ដីភូតភរគ្រប់យ៉ាងនិងសេចក្ដីភូតភរដែលអាក្រក់បំផុតដែលថាអាទទឹងនោះគឺជាព្រះ (ខ.៤)។

**២:១៣** *ដ៏ជាស្ងួនភ្ងានៃព្រះអម្ចាស់ . . . បានរើស* ចំពោះទំនាក់ទំនងរវាងសេចក្ដីស្រឡាញ់របស់ព្រះ និងពួករើសតាំង សូមមើល កល ៣:១២ ១ថន ១:៤ និងការពន្យល់ អភ ១:៤ ។ *តាំងពីដើមដំបូងមក* ការជ្រើសរើសគឺមានតាំងពីអស់កល្បជានិច្ច ។ *ញែកចេញជាបរិសុទ្ធ* គឺជាដំណើរនៃការលូតលាស់ខាងឯជំនឿរបស់គ្រីស្ទបរិស័ទ ដែលក្នុងនោះព្រះវិញ្ញាណបរិសុទ្ធទ្រង់ធ្វើឱ្យយើងបានត្រឡប់ដូចជារូបអង្គនៃព្រះគ្រីស្ទ(រម ៨:២៩)។ មើលការពន្យល់ ២ថន ១:១១,១២ ។

**២:១៤** *ទ្រង់បានហៅ . . . ដោយសារដំណឹងល្អនៃយើងខ្ញុំ* ព្រះទ្រង់ធ្វើការតាមរយៈសាវ័កប៉ុល និងគូរកនរបស់គាត់ ដើម្បីឱ្យដំណឹងល្អបានផ្សាយចេញទៅ ដើម្បីឱ្យមនុស្សយើងអាចមានចំណែកនៅក្នុងសិរីល្អរបស់ព្រះគ្រីស្ទ ។ ព្រះជាម្ចាស់ទ្រង់ បានប្រទានមកយើងនូវអភ័យឯកសិទ្ធិយ៉ាងពិសេសក្នុងការបំពេញមហាបេសកកម្មរបស់ទ្រង់ គឺការប្រាប់លោកីយពីរបៀបរកបានសេចក្ដីសង្គ្រោះ ។

**២:១៥** *សេចក្ដីបញ្ញត្តិដែលយើងខ្ញុំបានបង្រៀន* កាលព្រះគម្ពីរសញ្ញាថ្មីមិនទាន់បានសរសេរសេចក្ដីបង្រៀន សំខាន់ៗរបស់គ្រីស្ទបរិស័ទមានលក្ខណៈជាទំនៀមទម្លាប់ ដូចជាលក្ខណៈនៃសេចក្ដីបង្រៀនរបស់ពួកគ្រូក្រិត្យវិន័យយូដាដែរ(មថ ១៥:២ និងការពន្យល់) គឺអាចជាការសរសេរ ឬមាត់ទទេ ។ ក្នុង ១កថ ១៥:៣(មើលការពន្យល់) សាវកប៉ុលនិយាយអំពីការទទួល ហើយចែកចាយបន្តនូវទំនៀមទម្លាប់ ។

អម្ចាស់នៃយើង និងព្រះដ៏ជាព្រះវរបិតា[ហ] ដែលទ្រង់បាន
ស្រឡាញ់យើង[ឡ] ព្រមទាំងប្រទានឱ្យមានសេចក្ដីកំសាន្តអស់
កល្បជានិច្ច នឹងសេចក្ដីសង្ឃឹមយ៉ាងល្អ ដោយព្រះគុណទ្រង់
១៧ បានកំសាន្តចិត្ត[អ]អ្នករាល់គ្នាដែរ ហើយតាំងឱ្យអ្នករាល់
គ្នាបានមាំមួនឡើង[ក] ក្នុងគ្រប់ទាំងការ នឹងពាក្យសំដីដ៏ល្អ
ផង ។

## សំណូមពរអធិស្ឋាន

៣ ១ មួយសោតទៀត បងប្អូនអើយ[ខ] សូមអធិស្ឋានឱ្យយើងខ្ញុំ
ផង[គ] ដើម្បីឱ្យព្រះបន្ទូលនៃព្រះអម្ចាស់[ឃ]បានផ្សាយចេញទៅ
ហើយបានដំកើងឡើង ដូចនៅក្នុងពួកអ្នករាល់គ្នាដែរ[ង]
២ ហើយឱ្យយើងខ្ញុំបានរួចពីមនុស្សវៀច នឹងពីមនុស្សអាក្រក់
ចេញ[ច] ដ្បិតមិនមែនមនុស្សទាំងអស់ ដែលមានសេចក្ដីជំនឿ
ទេ ៣ តែព្រះអម្ចាស់ទ្រង់ស្មោះត្រង់[ឆ] ទ្រង់នឹងតាំងអ្នករាល់
គ្នា ឱ្យមាំមួនឡើង ហើយការពារអ្នករាល់គ្នាឱ្យរួចពីសេច
ក្ដីអាក្រក់ផង[ជ] ៤ យើងខ្ញុំក៏ទុកចិត្ត[ឈ]នឹងព្រះអម្ចាស់ ពីដំណើរ
អ្នករាល់គ្នាថា អ្នករាល់គ្នាកំពុងតែប្រព្រឹត្តហើយ នឹង
ប្រព្រឹត្តតទៅទៀត តាមអស់ទាំងសេចក្ដីដែលយើងខ្ញុំបានផ្តាំ
ទុកដែរ ៥ សូមឱ្យព្រះអម្ចាស់ដំរង់ចិត្តអ្នករាល់គ្នា[ញ] ទៅក្នុង
សេចក្ដី ស្រឡាញ់នៃព្រះ នឹងសេចក្ដីខ្ជាប់ខ្ជួនរបស់ព្រះគ្រីស្ទ
ចុះ ។

## បណ្ដាំឱ្យថយចេញពីពួកប្រព្រឹត្តខុសរបៀប

៦ ឥឡូវនេះ បងប្អូនអើយ យើងខ្ញុំសូមផ្តាំមកអ្នករាល់គ្នា
ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ[ដ] ជាព្រះអម្ចាស់នៃយើង
ថា ចូរថយចេញឱ្យផុតពី[ឋ]គ្រប់ទាំងបងប្អូនណា ដែលប្រ
ព្រឹត្តខុសរបៀប[ឌ] ហើយមិនស្ដាប់តាមបញ្ញត្តដែលបានទទួល
ពីយើងខ្ញុំ[ឍ] ៧ ដ្បិតខ្លួនអ្នករាល់គ្នាដឹងហើយ ដែលគួរត្រាប់
តាម យើងខ្ញុំជាយ៉ាងណា[ណ] ពីព្រោះយើងខ្ញុំមិនបានប្រព្រឹត្ត
ឥតរបៀប ក្នុងពួកអ្នករាល់គ្នាឡើយ ៨ ក៏មិនបានទទួលទាន
បាយ របស់អ្នកណាទទេដែរ យើងខ្ញុំបានធ្វើការ[ត]នឿយហត់
ហើយធ្ងន់ទាំងយប់ទាំងថ្ងៃ ដើម្បីកុំឱ្យអ្នករាល់គ្នាព្រួយនឹង
យើងខ្ញុំឡើយ ៩ មិនមែនថា យើងខ្ញុំគ្មានអំណាចនោះទេ[ថ] គឺ
យើងខ្ញុំចង់ធ្វើជាគំរូ ឱ្យអ្នករាល់គ្នាត្រាប់តាមយើងខ្ញុំវិញ
ទេតើ[ទ] ១០ កាលយើងខ្ញុំនៅជាមួយនឹងអ្នករាល់គ្នា[ធ] នោះក៏
បានផ្តាំថា បើអ្នកណាមិនចង់ធ្វើការ[ន] មិនត្រូវទាំងឱ្យអ្នក
នោះបរិភោគផង ១១ ដ្បិតយើងខ្ញុំឮថា មានអ្នកខ្លះក្នុងពួកអ្នក
រាល់គ្នា ដែលប្រព្រឹត្តឥតរបៀប ឥតមានធ្វើការអ្វីសោះ

**២:១៦** ហ ភល ៤:២០
ឡ យហ ៣:១៦
**២:១៧** អ ១ថន ៣:២
ក ២ថន ៣:៣
**៣:១** ខ ១ថន ៤:១
គ ១ថន ៥:២៥
ឃ ១ថន ១:៨
ង ១ថន ២:១៣
**៣:២** ច រម ១៥:១៣
**៣:៣** ឆ ១កថ ១:៩
ជ មថ ៥:៣៧
**៣:៤** ឈ ២កថ ២:៣
**៣:៥** ញ ១របា ២៩:១៨
**៣:៦** ដ ១កថ ៥:៤
ឋ ខ.១៤
រម ១៦:១៧
ឌ ខ.៧,១១
ឍ ១កថ ១១:១២
**៣:៧** ណ ខ.៩
១កថ ៤:១៦
**៣:៨** ត កច ១៨:៣
អភ ៤:២៨
**៣:៩** ថ ១កថ ៩:៤–១៤
ទ ខ.៧ ១កថ ៤:១៦ **៣:១០** ធ ១ថន ៣:៤ ន ១កថ ៤:១១

**២:១៦–១៧** មានសេចក្ដីអធិស្ឋានដូចនេះមួយទៀតនៅក្នុងសំបុត្រខ្សែទី១ (១ថន ៣:១១–១៣) ។

**២:១៧** *កំសាន្តចិត្ត . . . តាំងឱ្យអ្នករាល់គ្នាបានមាំមួនឡើង* ការទាំងពីរយ៉ាងនេះមានប្រើជាមួយគ្នានៅក្នុង "១ថន ៣:២" ផងដែរ ។ សេចក្ដីអធិស្ឋាននេះគឺដើម្បីឱ្យមានកម្លាំងផ្នែកខាងក្នុងឡើង ដែលនឹងបង្កើតផលនៅក្នុងទាំងការប្រព្រឹត្ត និងការនិយាយស្ដី ។

**៣:១** *មួយសោតទៀត* មើល ១ថន ៤:១ និងការពន្យល់ ។ នៅក្នុង ១ថន ៥:២៥ សាវកប៉ុលធ្វើសំណូមអធិស្ឋាន ហើយនៅក្នុងខនេះ គាត់បានបញ្ជាក់ឱ្យកាន់តែច្បាស់ ។ *ដូចនៅក្នុងពួកអ្នករាល់គ្នាដែរ* ឃ្លានេះប្រើសំដៅទៅលើទាំងកាលពីមុន និងពេលបច្ចុប្បន្ន (សូមធៀបនឹង ១ថន ២:១៣) ។

**៣:២** ចំពោះការលំបាកដែលគាត់ជួបប្រទះនៅទីក្រុងកូរិនថូស (ទីកន្លែងដែលគាត់សរសេរសំបុត្រនេះ) មើល កច ១៨:១២–១៣ ។

**៣:៣** *ស្មោះត្រង់* ពាក្យនេះក្នុងព្រះគម្ពីរភាសាក្រិកត្រូវបានសរសេរបន្ទាប់ពីពាក្យ "ជំនឿ" (ខ.២) ជាការបង្ហាញពីភាពផ្ទុយគ្នារវាងភាពស្មោះត្រង់របស់ព្រះ និងការខ្វះខាងឯជំនឿរបស់មនុស្ស (សូមធៀប ១កថ ១:៩ និងការពន្យល់ ១០:១៣ ២កថ ១:១៨) ។

**៣:៥** *ចិត្ត* មើលការពន្យល់ ១ថន ២:៤ ។ *សេចក្ដីស្រឡាញ់នៃព្រះ* សាវកប៉ុលបន្ទោសពួកប្រព្រឹត្តខុសរបៀបនៅក្នុងវគ្គខាងមុខ ហើយនៅក្នុងខនេះ គាត់កំពុងតែរំឭកពួកគេអំពីសេចក្ដីស្រឡាញ់របស់ព្រះ ។ មិនគួរឱ្យកំហឹងកើតមាននៅក្នុងចំណោមពួកអ្នកដែលជិពាក់ សេចក្ដីស្រឡាញ់របស់ព្រះនៅក្នុងគ្រប់អ្វីៗទាំងអស់ឡើយ ។ *សេចក្ដីខ្ជាប់ខ្ជួនរបស់ព្រះគ្រីស្ទ* គឺសេចក្ដីខ្ជាប់ខ្ជួនយ៉ាងអស្ចារ្យដែលទ្រង់ មានមុនពេលទ្រង់យាងឡើងស្ថានសួគ៌វិញ (ហព១២:១–៣ និងការពន្យល់) ។

**៣:៦** *ព្រះនាម* មើល ១:១២ និងការពន្យល់ ។ *ចូរ* គឺជាពាក្យបង្គាប់បញ្ជាតាមបែបទាហាន ។ *ថយចេញឱ្យផុតពី* មិនមែនឱ្យកាត់ផ្ដាច់ទំនាក់ទំនងទាំងស្រុងនោះទេ ប៉ុន្តែឱ្យជៀសវាងការប្រកបស្និទ្ធស្នាល ។ ការប្រព្រឹត្តឥតរ បៀបគឺជាអំពើបាប ហើយនាំឱ្យមានការរំខាន ប៉ុន្តែ អ្នកប្រព្រឹត្តនៅតែជាបងប្អូនក្នុងព្រះគ្រីស្ទដដែល (ខ.១៥) ។ *ប្រព្រឹត្តខុសរបៀប* បញ្ហានេះមានបញ្ជាក់នៅក្នុងសំបុត្រទី១ (១ថន ៤:១១–១២ ៥:១៤ និងការពន្យល់) ហើយជាបញ្ហាដែលកាន់តែអាក្រក់ឡើងៗ ។ សាវកប៉ុល បានបង្ហាញនូវការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះបញ្ហានេះ ។ *បញ្ញត្តិ* មើល ២:១៥ និងការពន្យល់ ។

**៣:៧** *ត្រាប់តាម យើងខ្ញុំ* មើល ១ថន ១:៦ និងការពន្យល់ ។

**៣:៨** *ទទួលទានបាយ* ភាសាហេព្រើរនិយមប្រើទម្រង់ពាក្យ ដូចនេះសំដៅទៅលើ "ការរកស៊ីចិញ្ចឹមជីវិត" (មើល ៣:១៩ អម ៧:១២) ។ ការដែលលោកប៉ុលប្រើពាក្យដូចនេះមិនមែនមានន័យថា គាត់មិនដែលទទួលការស្វាគមន៍ពីអ្នកដទៃនោះទេ ប៉ុន្តែមានន័យថា គាត់មិនបានពឹងពាក់ទៅលើអ្នកដទៃនៅក្នុងការចិញ្ចឹមជីវិតរបស់គាត់ឡើយ (១ថន ២:៩ និងការពន្យល់) ។

**៣:៩** *អំណាច* មើលការពន្យល់ ១ថន ២:៦ ។

**៣:១០** អ្នកមិនជឿ គេច្រើនតែនិយាយថា "អ្នកដែលមិនធ្វើការមិនត្រូវបរិភោគឡើយ" ប៉ុន្តែលោកប៉ុលបានប្រើពាក្យនោះជាលក្ខណៈបង្គាប់បញ្ជាថា "មិនត្រូវទាំងឱ្យអ្នកនោះបរិភោគផង" ។

**៣:១១** *រវល់តែចំពោះការឥតប្រយោជន៍* ការនេះអាក្រក់ជាងការប្រព្រឹត្តខុសរបៀបទៅទៀត ពីព្រោះពួកគេរវល់តែជ្រៀតជ្រែកកិច្ចការរបស់អ្នក

គឺគេរវល់តែចំពោះការឥតប្រយោជន៍វិញ[ប] ១២ដូច្នេះយើង
ខ្ញុំផ្ដាំមកមនុស្សយ៉ាងនោះ ហើយទូន្មានគេ ដោយព្រះយេស៊ូវ
គ្រីស្ទ[ផ] ជាព្រះអម្ចាស់នៃយើងថា ឱ្យគេបរិភោគបាយរបស់
ខ្លួនគេចុះ ទាំងធ្វើការដោយស្រគត់ស្រគំផង[ព] ១៣បងប្អូន
អើយកុំឱ្យរសាយចិត្តខាងឯការល្អឡើយ[ភ] ១៤បើអ្នកណាមិន
ស្ដាប់តាមពាក្យរបស់យើងខ្ញុំ ក្នុងសំបុត្រនេះទេ នោះចូរ
សំគាល់អ្នកនោះទុក ហើយកុំឱ្យភប់ប្រសព្វនឹងគេឱ្យសោះ[ម]
ដើម្បីឱ្យគេមានសេចក្ដីខ្មាស[យ] ១៥តែកុំឱ្យរាប់គេទុកដូចជា
ខ្មាំងសត្រូវឡើយ ចូរទូន្មានគេ ដូចជា បងប្អូនវិញ[រ]។

## ការជម្រាបសួរចុងក្រោយ

១៦សូមឱ្យព្រះអម្ចាស់ ដែលទ្រង់ផ្ដល់សេចក្ដីសុខសាន្ត[ល]
ទ្រង់ប្រទានឱ្យអ្នករាល់គ្នា បានសេចក្ដីសុខសាន្តគ្រប់យ៉ាង
ជានិច្ច សូមឱ្យព្រះអម្ចាស់គង់ជាមួយនឹងអ្នករាល់គ្នាទាំង
អស់[វ] ១៧ប៉ុលខ្ញុំសរសេរពាក្យជំរាបសួរនេះ ដោយដៃខ្លួនខ្ញុំ[ស]
នេះគឺជាទីសំគាល់ក្នុងគ្រប់សំបុត្ររបស់ខ្ញុំ គឺបែបយ៉ាងនេះ
ហើយ ដែលខ្ញុំសរសេរមក ១៨សូមឱ្យអ្នករាល់គ្នាទាំងអស់
បានប្រកបដោយព្រះគុណ របស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះ
អម្ចាស់នៃយើងរាល់ គ្នា[ហ]។ អាម៉ែន ។

**៣:១១** ប ខ.៦,៧ ១ធថ ៥:១៣
**៣:១២** ផ ១ថន ៤:១ ព ១ថន ៤:១១ អភ ៤:២៨
**៣:១៣** ភ កទ ៦:៩
**៣:១៤** ម ខ.៦ រម ១៦:១៧ យ ១កថ ៤:១៤
**៣:១៥** រ កទ ៦:១ ១ថន ៥:១៤ ភម ១៦
**៣:១៦** ល រម ១៥:៣៣ វ នរ ២:៤
**៣:១៧** ស ១កថ ១៦:២១ **៣:១៨** ហ រម ១៦:២០

ដទៃជាបញ្ហាដែលជាញឹកញាប់មានប្រភពពីការប្រព្រឹត្តខុសរបៀប ។
**៣:១២** *ដោយស្រគត់ស្រគំ* គឺផ្ទុយពីការ "រវល់តែចំពោះការឥតប្រយោជន៍" (ខ.១១)។
**៣:១៤** លោកប៉ុលដឹងថា អ្នកខ្លះប្រហែលជាមិនធ្វើតាមការបង្គាប់នៅក្នុងសំបុត្ររបស់គាត់ទេ ។ *ភប់ប្រសព្វនឹង* ពាក្យនេះមានប្រើនៅក្នុងកន្លែងផ្សេងទៀតនៅក្នុងព្រះគម្ពីរសញ្ញាថ្មីដូចជា ១កថ ៥:៩,១១ ដែលនិយាយដូចគ្នាអំពីការជៀសវាង ការប្រកបស្និទ្ធស្នាល ។ ការនេះបង្ហាញពីការឈប់ភប់ប្រសព្វដែលនឹងនាំឱ្យអ្នក នោះត្រឡប់មករកប្រព្រឹត្តដែលត្រឹមត្រូវវិញ ។ *មានសេចក្ដីខ្មាស* គឺមានសេចក្ដីខ្មាសហើយប្រែចិត្ត ។ គោលបំណងនៃការធ្វើបែបនេះគឺមិនមែន ដើម្បីដាក់ទោសអ្នកនោះទេ ប៉ុន្តែគឺ ដើម្បីឱ្យអ្នកនោះមានការប្រកបស្និទស្នាលឡើងវិញ ។
**៣:១៥** ការទូន្មានអ្នកប្រព្រឹត្តខុសនៅក្នុងព្រះវិហារត្រូវធ្វើឡើងតាមរបៀបបងប្អូន គឺមិនត្រូវធ្វើតាមរបៀបឃោរឃៅឡើយ ។ *ដូចជាបងប្អូន* មើលការពន្យល់ រម ១:១៣ ។
**៣:១៦,១៨** *សេចក្ដីសុខសាន្ត . . . ព្រះគុណ* មើលការពន្យល់ រម ១:៧ ។
**៣:១៦** *ព្រះអម្ចាស់ ដែលទ្រង់ផ្ដល់សេចក្ដីសុខសាន្ត* ទម្រង់ដែលគេប្រើច្រើនជាងគឺ "ព្រះនៃសេចក្ដីសុខសាន្តឬព្រះអម្ចាស់នៃសន្តិភាព" (ការពន្យល់ ១ថន ៥:២៣)។ *អ្នករាល់គ្នា* គឺរាប់បញ្ចូលទាំងអ្នកដែលប្រព្រឹត្តខុសរបៀបផង ។
**៣:១៧** តាមធម្មតាលោកប៉ុលហៅឱ្យគេកត់ចូលក្នុងសំបុត្រទាំងឡាយរបស់គាត់ (សូមផ្ទៀប រម ១៦:២២) ប៉ុន្តែនៅចុងបញ្ចប់នៃសំបុត្ររបស់គាត់មួយចំនួនគាត់បានផ្ញៀតសរសេរបន្ថែមយ៉ាងខ្លី ដោយដៃគាត់ផ្ទាល់ផងដែរ (មើល ១កថ ១៦:២១ និងការពន្យល់ កទ ៦:១១ កល ៤:១៨)។ ចំពោះសំបុត្រនេះ គាត់បានប្រាប់ថាការធ្វើដូចនេះគឺជាសញ្ញាសំគាល់របស់គាត់ ។
**៣:១៨** មើល ១ថន ៥:២៨ និងការពន្យល់ ។ សាវកប៉ុលបាននិយាយរិះគន់អ្នកដែលប្រព្រឹត្តខុសរបៀប ប៉ុន្តែ សេចក្ដីអធិស្ឋាននៅចុងបញ្ចប់នៃសំបុត្រនេះក៏ សម្រាប់ពួកនោះផងដែរ ។ *អ្នករាល់គ្នាទាំងអស់ បានប្រកប* មើលការពន្យល់ ២កថ ១៣:១៤ ។ *ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើងរាល់គ្នា* មើលការ ពន្យល់ ១:១ ។

# សំបុត្រដល់គ្រូគង្វាល

សំបុត្រដល់គ្រូគង្វាលមានដូចជា សំបុត្រធីម៉ូថេទី១ និងទី២ និងសំបុត្រទីតុស ។ សំបុត្រទាំងនេះផ្ដល់នូវការទូន្មានដោយផ្ដោតទៅលើការថែរក្សាពួកជំនុំ ។

អ្នកកាត់ស្រាយព្រះគម្ពីរបានលើកឡើងនូវចម្ងល់ជាច្រើនអំពីអំណាចនៃសំបុត្រគ្រូគង្វាល ជាងសំបុត្រផ្សេងៗទៀតរបស់លោកប៉ុល ។

១. ហេតុការណ៍ដែលលើកឡើងនៅក្នុងសំបុត្រគ្រូគង្វាលមិនបានតម្រូវទៅនឹងជីវិត និងការងាររបស់លោកប៉ុល ដែលបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរកិច្ចការ ទេ ។

២. ផ្នែកទេវសាស្ត្រមានភាពខុសប្លែកពីសំបុត្រផ្សេងៗទៀតរបស់លោកប៉ុល ហើយការរៀបចំពួកជំនុំក៏មានការរីកចម្រើនឡើងជាងមុន ។

៣. ផ្នែកវាក្យស័ព្ទ និងរបៀបនៃការសរសេរ មិនមែនជាលក្ខណៈរបស់លោកប៉ុល ។

ទោះជាយ៉ាងណាក៏មានការជំទាស់អំពីភាពជាអ្នកនិពន្ធរបស់លោកប៉ុល ហើយខាងក្រោមគឺជាចម្លើយ :

១. ការស្លាប់របស់លោកប៉ុលមិនបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរកិច្ចការជំពូក២៨ទេ ។ ដូច្នេះ អាចសន្និដ្ឋានថា លោកប៉ុលត្រូវបានគេដោះលែងពីពន្ធនាគារ ហើយគាត់បានបន្តដំណើរបេសកកម្មរបស់គាត់ ដែលនៅក្នុងដំណើរបេសកកម្មនោះគឺជាពេលវេលាដែលហេតុការណ៍ដែលបានកត់ត្រាទុកនៅក្នុងសំបុត្រគ្រូគង្វាល ។

២. ផ្នែកទេវសាស្ត្រមានភាពត្រូវគ្នានឹងសំបុត្រផ្សេងៗទៀតរបស់លោកប៉ុល ហើយការរៀបចំពួកជំនុំនៅក្នុងសំបុត្រគ្រូគង្វាលមិនមានភាពប្លែកគ្នាពីសំបុត្រផ្សេងៗទៀត ដូចជានៅក្នុងសំបុត្រភីលីពជាដើម ។

៣. ក្នុងពេលដែលសេចក្ដីរៀបរាប់នៅក្នុងសំបុត្រគ្រូគង្វាលមានដែនកំណត់ ដើម្បីធ្វើការសន្និដ្ឋានអំពីភាពជាអ្នកនិពន្ធ ដោយយោងទៅតាមវាក្យស័ព្ទ និងរបៀបនៃការសរសេរ ដូច្នេះបញ្ជាក់ថា សំបុត្រទាំងនេះពិតជាមានលក្ខណៈត្រឹមត្រូវ ដោយយោងទៅតាមស្ថានភាព ទីកន្លែង និងប្រធានបទដែលលោកប៉ុលបានជួបប្រទះ ។

គោលរឿង និងសេចក្ដីសំខាន់ៗទាំងឡាយត្រូវបានលើកឡើងផ្ទួនៗនៅក្នុងសំបុត្រគ្រូគង្វាលមានដូចជា (១).ព្រះដ៏ជាព្រះអង្គសង្គ្រោះ(ទត ១:៣) (២).គោលលទ្ធិ សេចក្ដីជំនឿ និងការបង្រៀន (មើលការពន្យល់ ទត ១:៩) (៣).ការគោរពប្រតិបត្តិដល់ព្រះ (មើលការពន្យល់ ១ធថ ២:២) (៤).រឿងក្ដី (១ធថ ១:៤ ៦:៤ ២ធថ ២:២៣ ទត ៣:៩) (៥).ពាក្យដែលគួរជឿ (មើលការពន្យល់ ១ធថ ១:១៥)។

សំបុត្រទី១របស់ប៉ុល

ដល់

# លោកធីម៉ូថេ

សេចក្ដីផ្ដើម

**អ្នកនិពន្ធ**

តាមរយៈទំនៀមទម្លាប់ និងសេចក្ដីផ្ដើមនៃសំបុត្រផ្ទាល់ (១,២ធថ និង ទត) បញ្ជាក់ថា លោកប៉ុលគឺជាអ្នកនិពន្ធកណ្ឌគម្ពីរធីម៉ូថេទី១នេះ (១:១ ២ធថ ១:១ ទត ១:១)។ មានការជំទាស់ខ្លះបានកើតឡើងស្ដីអំពីភាពជាអ្នកនិពន្ធកណ្ឌគម្ពីរនេះ ដោយសំអាងលើលក្ខណៈនៃវាក្យស័ព្ទ និងរបៀបនៃការសរសេរ (មើលការពន្យល់ ១:១៥ ២:២)។ ប៉ុន្ដែ ទោះជាយ៉ាងក៏ដោយ ក៏មានភស្ដុតាងជាច្រើនអះអាងថាលោកប៉ុលគឺជាអ្នកនិពន្ធកណ្ឌគម្ពីរនេះ ។

**ប្រភព និងគោលបំណង**

ក្នុងអំឡុងពេលនៃដំណើរបេសកកម្មលើកទីបួនរបស់លោកប៉ុល គាត់បានទូន្មានលោកធីម៉ូថេ ឱ្យថែរក្សាពួកជំនុំនៅទីក្រុងអេភេសូរ (១:៣) គឺក្នុងពេលដែលគាត់ធ្វើដំណើរទៅឯស្រុកម៉ាសេដូន ។ លោកប៉ុលយល់ថា គាត់មិនអាចត្រឡប់ទៅឯទីក្រុងអេភេសូរបានឆាប់ទេ (៣:១៤-១៥) ដូច្នោះគាត់ក៏សរសេរសំបុត្រទីមួយផ្ញើទៅលោកធីម៉ូថេ ដើម្បីអភិវឌ្ឍបន្ថែមនូវសេចក្ដីដែលគាត់បានបង្រៀនដល់អ្នកជំនួយរបស់គាត់ (១:៣,១៨) ក្នុងការទប់ស្កាត់សេចក្ដីបង្រៀនខុសឆ្គងទាំងឡាយ (១:៣-៧ ៤:១-៨ ៦:៣-៥,២០-២១) និងផ្ដល់នូវរបៀបគ្រប់គ្រងការងារ ក្នុងពេលមានការរីកចម្រើនឡើងនៃពួកជំនុំនៅទីក្រុងអេភេសូរ (ការថ្វាយបង្គំនៅក្នុងពួកជំនុំ ការតាំងពួកអ្នកដឹកនាំក្នុងពួកជំនុំ ៣:១-១៣ ៥:១៧-២៥)។

បញ្ហាដ៏ចម្បងដែលកើតឡើងក្នុងពួកជំនុំនៅទីក្រុងអេភេសូរ គឺពួកគ្រូខុសឆ្គង រួមជាមួយនឹងសេចក្ដីបង្រៀនខុសឆ្គងជាច្រើនទៀតដែលពុំមែនជាសេចក្ដីពិត(សូមមើលសេចក្ដីផ្ដើមកណ្ឌគម្ពីរ១យ៉ូហាន) ការធ្លាក់ចុះនៃសាសនាយូដា (១:៣-៧) និងការបង្រៀនខុសឆ្គងអំពីការតមប្រណីដល់រូបសាច់ (៤:១-៥)។

**កាលបរិច្ឆេទ**

កណ្ឌគម្ពីរធីម៉ូថេទី១ត្រូវបានសរសរឡើងបន្ទាប់ពីហេតុការណ៍កើតឡើងនៅក្នុងកណ្ឌគម្ពីរកិច្ចការជំពូក២៨ (ឆ្នាំទី ៦៣-៦៥ គ.ស) គឺយ៉ាងតិចបំផុត៨ឆ្នាំបន្ទាប់ពីលោកប៉ុលស្នាក់នៅទីក្រុងអេភេសូររយៈពេល៣ឆ្នាំ (កច ១៩:១០ និងការពន្យល់)។

**អ្នកទទួល**

ដូចដែលបានបញ្ជាក់នៅក្នុងសេចក្ដីផ្ដើម (១:២) លោកប៉ុលបានសរសេរសំបុត្រនេះទៅកាន់លោកធីម៉ូថេ ជាអ្នកក្រុងលីស្ដ្រា (សព្វថ្ងៃនៅប្រទេសទួរគី)។ ឪពុករបស់លោកធីម៉ូថេ ជាសាសន៍ក្រេក ហើយម្ដាយរបស់គាត់គឺជាគ្រីស្ទបរិស័ទសាសន៍យូដា (កច ១៦:១)។ លោកធីម៉ូថេបានរៀនបទគម្ពីរសញ្ញាចាស់តាំងពីក្មេងមក (២ធថ ១:៥ ៣:១៥)។ លោកប៉ុលហៅគាត់ថា "កូនពិតនៅក្នុងសេចក្ដីជំនឿ"(១:២ និងការពន្យល់) ប្រហែលមកពីគាត់បាននាំលោកធីម៉ូថេទទួលជឿដល់ព្រះគ្រីស្ទ ក្នុងដំណើរបេសកកម្មរបស់គាត់ទៅទីក្រុងលីស្ដ្រា ។ នៅក្នុងដំណើរបេសកកម្មលើកទីពីរ លោកប៉ុលបានសូមឱ្យលោកធីម៉ូថេរួមដំណើរជាមួយគាត់ ដោយបានធ្វើពិធីកាត់ស្បែកឱ្យដើម្បីឱ្យលោកធីម៉ូថេដែលជាសាសន៍ក្រេក អាចធ្វើការជាមួយនឹងពួកសាសន៍យូដា (កច ១៦:៣)។ លោកធីម៉ូថេបានជួយដល់លោកប៉ុលក្នុងការប្រកាសដំណឹងល្អនៅស្រុកម៉ាសេដូន និងស្រុកអាខៃ (កច ១៧:១៤-១៥ ១៨:៥) និងបាននៅជាមួយគាត់ក្នុងអំឡុងពេលគាត់អធិប្បាយព្រះបន្ទូលនៅទីក្រុងអេភេសូរ (កច ១៩:២២)។ លោក ធីម៉ូថេបានធ្វើដំណើរជាមួយលោកប៉ុលពីទីក្រុងអេភេសូរ ទៅឯស្រុកម៉ាសេដូនទីក្រុងកូរិនថូស (កច ២០:៣ និងការពន្យល់) និងបានត្រឡប់ទៅ ស្រុកម៉ាសេដូន និងទៅឯអាស៊ីមីន័រ (កច ២០:១-៦ Asia Minor)។ លោកធីម៉ូថេប្រហែលជាបានធ្វើដំណើររួមជាមួយលោកប៉ុលទៅឯទីក្រុងយេរូសាឡិម ។ គាត់បាននៅជាមួយលោកប៉ុលក្នុងពេលដែលលោកប៉ុលជាប់នៅក្នុងពន្ធនាគារជាលើកទីមួយ (ភល ១:១ កល ១:១ ភម ១)។

បន្ទាប់ពីលោកប៉ុលត្រូវបានដោះលែងពីពន្ធនាគារ (កច ២៨) លោកធីម៉ូថេបានចូលរួមជាមួយគាត់ម្ដងទៀត ប៉ុន្ដែ ក្រោយមកលោកធីម៉ូថេបានបន្ដស្នាក់នៅឯទីក្រុងអេភេសូរ ដើម្បីដោះស្រាយបញ្ហាកើតមានឡើងនៅទីនោះ ក្នុងពេលដែលលោកប៉ុលទៅឯស្រុកម៉ាសេដូន ។ ភាពជិតស្និទ្ធ និងការចូលចិត្តរបស់លោកប៉ុលចំពោះលោកធីម៉ូថេ ថាលោកធីម៉ូថេគឺជាអ្នកធ្វើការជាមួយគាត់ និងមានបញ្ជាក់នៅក្នុងសំបុត្រទាំង៦របស់គាត់ (២កថ ភល កល ១,២ថន ភម) ហើយលោកប៉ុលក៏បាននិយាយសរសើរអំពីលោកធីម៉ូថេ ដល់ពួក

ជំនុំនៅទីក្រុងភីលីពដែរ (ភល ២:១៩-២២)។ នៅចុងបញ្ចប់នៃជីវិតរបស់លោកប៉ុល គាត់បានស្នើសុំឱ្យលោកធីម៉ូថេធ្វើដំណើរជាមួយគាត់នៅទីក្រុងរ៉ូម (២ធម ៤:៩,២១)។ យោងតាមបទគម្ពីរហេព្រើរ ១៣:២៣ លោកធីម៉ូថេបានជាប់ពន្ធនាគា និងត្រូវបានដោះលែងវិញដោយមិនបានបញ្ជាក់អំពីទីកន្លែងទេ អាចនៅទីក្រុងរ៉ូម ឬកន្លែងដទៃទៀត ។ លោកធីម៉ូថេមិនមែនជាសាវកទេ តែជាការប្រសើរដែលចាត់ទុកគាត់ជាអ្នកតំណាងសាវក និងជាអ្នកទទួលអំណាច នៅក្នុងការបំពេញនូវការងារពិសេស (ទត ១:៥)។

គម្រោងសង្ខេប

**I. ពាក្យជម្រាបសួរ (១:១-២)**

**II. ការព្រមានប្រឆាំងនឹងគ្រូបង្រៀនខុសឆ្គង (១:៣-១១)**

ក. លក្ខណៈរបស់ពួកខុសឆ្គង (១:៣-៧)

ខ. គោលបំណងនៃក្រិត្យវិន័យ (១:៨-១១)

**III. ព្រះគុណរបស់ព្រះអម្ចាស់ចំពោះលោកប៉ុល (១:១២-១៧)**

**IV. គោលបំណងនៃការទូន្មានរបស់លោកប៉ុលចំពោះលោកធីម៉ូថេ (១:១៨-២០)**

**V. ការទូន្មានអំពីការរៀបចំពួកជំនុំ (ជំពូក ២-៣)**

ក. ការថ្វាយបង្គំនៅឯទីសាធារណៈ (ជំពូក ២)

ក.១.សេចក្តីអធិស្ឋានពេលថ្វាយបង្គំនៅទីសាធារណៈ (២:១-៨)

ក.២.ស្ត្រីនៅក្នុងការថ្វាយបង្គំនៅទីសាធារណៈ (២:៩-១៥)

ខ. សមត្ថភាពសម្រាប់អ្នកធ្វើការនៅក្នុងពួកជំនុំ (៣:១-១៣)

ខ.១.អ្នកត្រួតត្រា (៣:១-៧)

ខ.២.អ្នកជំនួយ (៣:៨-១៣)

គ. គោលបំណងនៃការទូន្មាន (៣:១៤-១៦)

**VI. ការទូន្មានស្តីអំពីការបង្រៀនខុសឆ្គង (ជំពូក ៤)**

ក. ការពណ៌នាអំពីសេចក្តីបង្រៀនខុសឆ្គង (៤:១-៥)

ខ. វិធីសាស្ត្រការពារចំពោះសេចក្តីបង្រៀនខុសឆ្គង (៤:៦-១៦)

**VII. ការទូន្មានស្តីអំពីក្រុមផ្សេងគ្នានៅក្នុងពួកជំនុំ (ជំពូក ៥:១-៦:២)**

ក. ពួកចាស់ទុំ និងពួកអ្នកនៅក្មេង (៥:១-២)

ខ. ស្ត្រីមេម៉ាយ (៥:៣-១៦)

គ. ពួកចាស់ទុំ (៥:១៧-២៥)

ឃ. ពួកបាវបម្រើ (៦:១-២)

**VIII. បញ្ហាបន្ទាប់បន្សំ (៦:៣-១៩)**

ក. ពួកគ្រូខុសឆ្គង (៦:៣-៥)

ខ. ការស្រលាញ់ប្រាក់ (៦:៦-១០)

គ. ទំនួលខុសត្រូវរបស់លោកធីម៉ូថេ (៦:១១-១៦)

ឃ. អ្នកមាន (៦:១៧-១៩)

**IX. សេចក្តីសន្និដ្ឋាន និងបណ្តាំចុងក្រោយ (៦:២០-២១)**

**១** ១ សំបុត្រប៉ុលខ្ញុំ ជាសាវកនៃព្រះយេស៊ូវគ្រីស្ទ តាមបង្គាប់
របស់ព្រះ[ក]ដ៏ជាព្រះអង្គសង្គ្រោះនៃយើង[ខ] នឹងព្រះយេស៊ូវ
គ្រីស្ទដ៏ជាទីសង្ឃឹមនៃយើងរាល់គ្នា[គ] ២ ខ្ញុំផ្ញើមកអ្នកធីម៉ូថេ[ឃ]
ជាកូនពិត[ង]ក្នុងសេចក្ដីជំនឿ សូមឱ្យអ្នកបានប្រកបដោយ
ព្រះគុណ សេចក្ដីមេត្តាករុណា នឹងសេចក្ដីសុខសាន្ត អំពី
ព្រះដ៏ជាព្រះវរបិតានៃយើង ហើយអំពីព្រះយេស៊ូវគ្រីស្ទ ជា
ព្រះអម្ចាស់នៃយើងរាល់គ្នា[ច] ។

## ការព្រមានអំពីពួកគ្រូក្រឹត្យវិន័យខុសឆ្គង

៣ កាលខ្ញុំរៀបនឹងទៅឯស្រុកម៉ាសេដូន[ឆ] នោះខ្ញុំបានសូម
ឱ្យអ្នកនៅតែក្នុងក្រុងអេភេសូរចុះ[ជ] ដើម្បីឱ្យអ្នកបានហាម
ប្រាមដល់អ្នកខ្លះ កុំឱ្យគេបង្រៀនពីសេចក្ដីណាផ្សេងទៀត[ឈ]
៤ ឬស្ដាប់តាមរឿងព្រេង[ញ] នឹងពង្សាវតា[ដ] ដែលមិនចេះអស់
មិនចេះហើយនោះឡើយ ដែលរឿងទាំងនោះតែងបង្កើត
ឱ្យមានសេចក្ដីដេញដោល[ឋ] ជាជាងចំរើនការនៃព្រះក្នុង
សេចក្ដីជំនឿ ៥ ហេតុដែលហាមយ៉ាងដូច្នោះ នោះគឺ
ប្រយោជន៍ចង់ឱ្យបានសេចក្ដីស្រឡាញ់ដែលកើតពីចិត្តស្អាត
ពីបញ្ញាចិត្តជ្រះថ្លា[ឍ] ហើយពីសេចក្ដីជំនឿដ៏ស្មោះត្រង់វិញ[ណ]
៦ ព្រោះអ្នកខ្លះបានជ្រួសចេញពីសេចក្ដីនោះទៅហើយ ព្រម
ទាំងបែរចេញ ទៅខាងពាក្យសំដី ដែលឥតប្រយោជន៍ផង
៧ គេចង់ធ្វើជាគ្រូ[ត]នៃក្រឹត្យវិន័យ តែគេមិនទាំងយល់សេចក្ដី
ដែលគេនិយាយ ឬពីសេចក្ដីដែលគេប្រកាន់នោះផង[ថ]
៨ រីឯយើងៗដឹងថា ក្រឹត្យវិន័យល្អមែន[ទ] បើអ្នកណាប្រើ
តាមត្រឹមត្រូវ ៩ ដោយដឹងថា ក្រឹត្យវិន័យមិនមែនតាំងសំរាប់
មនុស្សសុចរិតទេ[ធ] គឺសំរាប់មនុស្សទទឹងច្បាប់ នឹងមនុស្សរឹង
ចចេស[ន] មនុស្សទមិលល្មើស នឹងមនុស្សដែលមានបាប គឺជា
មនុស្សមិនបរិសុទ្ធ នឹងមនុស្សមិនរាប់ព្រះ មនុស្សដែលវាយ
ឪពុកម្ដាយ និងមនុស្សដែលសំឡាប់គេ ១០ មនុស្សកំផិត លេង
កូនជឹង ចាប់មនុស្សលក់ ភូតកុហក ហើយស្បថបំពានវិញ
ព្រមទាំងការអ្វីដែលទាស់ទទឹងនឹងសេចក្ដីបង្រៀនដ៏ត្រឹម
ត្រូវដែរ[ប] ១១ នោះគឺតាមដំណឹងពីសិរីល្អនៃព្រះដ៏មានពរ
ជាដំណឹង ដែលផ្ញើទុកនឹងខ្ញុំ[ផ] ។

## ព្រះគុណនៃព្រះផ្ដល់ដល់លោកប៉ុល

១២ ខ្ញុំអរព្រះគុណដល់ព្រះ ដែលទ្រង់ចំរើនកំឡាំងដល់

**១:១** ក ២កថ ១:១ ទត ១:៣ ខ លក ១:៤៧ គ កល ១:២៧ **១:២** ឃ កច ១៦:១ ង ខ.១៨ ១កថ ៤:១៧ ១ថន ២:១១ ២ធថ ១:២ ទត ១:៤ ច រម ១:៧ **១:៣** ឆ កច ១៦:៩ ជ កច ១៨:១៩ ឈ កទ ១:៦,៧ ១ធថ ៦:៣ **១:៤** ញ ១ធថ ៤:៧ ២ធថ ៤:៤ ទត ១:១៤ ដ ទត ៣:៩ ឋ ២ធថ ២:១៤ **១:៥** ឍ ២ធថ ២:២២ ឍ កច ២៣:១ ១ធថ ៤:២ ណ កទ ៥:៦ ២ធថ ១:៥ **១:៧** ត អភ ៤:១១ ថ យប ៣៨:២ **១:៨** ទ រម ៧:១២ **១:៩** ធ កទ ៥:២៣ ន កទ ៣:១៩ **១:១០** ប ១ធថ ៦:៣ ២ធថ ១:១៣ ៤:៣ ទត ១:៩ ២:១ **១:១១** ផ កទ ២:៧ ១ថន ២:៤ ទត ១:៣

**១:១** *ប៉ុល* "មើលការពន្យល់ រម ១:១"។ *សាវក* ជាមនុស្សពិសេសដែលព្រះអម្ចាស់ចាត់ឱ្យបំពេញបេសកកម្មថ្វាយទ្រង់ (១កថ ១:១ និងពន្យល់)។ *ព្រះអង្គសង្គ្រោះនៃយើង* "សូមមើល ទត ១:៣ និងការពន្យល់"។ *ព្រះយេស៊ូវគ្រីស្ទដ៏ជាទីសង្ឃឹមនៃយើងរាល់គ្នា* "សូមមើល ទត ២:១៣"។ *សង្ឃឹម* មិនមែនសំដៅលើបំណងប្រាថ្នាធម្មតាទេ ប៉ុន្តែគឺជាការសង្ឃឹមពិតប្រាកដ (អភ ១:១៨)។

**១:២** *ជាកូនពិតក្នុងសេចក្ដីជំនឿ* គឺជាកូនខាងឯវិញ្ញាណ (១:១៨ ១កថ ៤:១៧ ២ធថ ១:២ ២:១ ភម ១០)។ *ព្រះគុណ... សេចក្ដីសុខសាន្ត* "សូមមើល រម ១:៧ និងការពន្យល់"។ *សេចក្ដីមេត្តាករុណា* "សូមមើល រម ៩:២២–២៣ ២ធថ ១:២ និងការពន្យល់"។ ពាក្យនេះលោកប៉ុលច្រើនប្រើនៅក្នុងសំបុត្ររបស់គាត់ក្នុងការជម្រាបសួរដល់ពួកជំនុំ ។

**១:៣–១១** នៅក្នុងវគ្គនេះ ជាមួយនឹង "៤:១–៨ ៦:៣–៥,២០–២១" លោកប៉ុលព្រមានប្រឆាំងនឹងពួកគ្រូខុសឆ្គងនៅឯពួកជំនុំអេភេសូរ ។ ពួកគ្រូខុសឆ្គងទាំងនោះត្រូវបានសំដែងឱ្យឃើញដោយ (១).បង្រៀននូវគោលលទ្ធិខុសឆ្គង (ខ.៣ ៦:៣) (២).ប្រឌិតរឿងមិនសមហេតុផល និងមិនចេះចប់ដោយសំអាងលើពង្សាវតារមិនច្បាស់លាស់ (ខ.៤ ៤:៧) (៣).ចូលចិត្តជជែករកខុសត្រូវ (ខ.៤ ៦:៤) (៤).ប្រើប្រាស់ពាក្យសំដីដែលមិនមានប្រយោជន៍ (ខ.៦) (៥).ចង់ធ្វើខ្លួនជាគ្រូបង្រៀនក្រិត្យវិន័យសញ្ញាចាស់ (ខ.៧) (៦).មានអំនួត (ខ.៧ ៦:៤) (៧).មិនយល់អ្វីដែលពួកគេនិយាយ (ខ.៧ ៦:៤) (៨).បង្រៀនអំពីការឥតប្រណីដល់រូបសាច់ (៤:៣) (៩).ប្រើប្រាស់ឋានៈជាអ្នកដឹកនាំរបស់ពួកគេនៅក្នុងក្រុមសាសនា ដើម្បីបានចំណេញប្រាក់ (៦:៥)។ ទាំងអស់នេះជាសេចក្ដីបង្រៀនខុសឆ្គងរបស់ពួកអ្នក ប្រឆាំង (៦:២០ និងការពន្យល់)។

**១:៣** *កាលខ្ញុំរៀបនឹងទៅឯស្រុកម៉ាសេដូន* ដោយព្រោះតែហេតុការណ៍នេះមិនបានកត់ត្រាទុកនៅក្នុងកណ្ឌគម្ពីរកិច្ចការ ដូច្នេះ អាចបញ្ជាក់ថា ហេតុការណ៍នេះកើតឡើងបន្ទាប់ពីកិច្ចការជំពូក ២៨ គឺនៅចន្លោះពេលដែលលោកប៉ុលជាប់គុកលើកទី១ និងលើកទី២នៅរ៉ូម (សូមមើលសេចក្ដីផ្ដើមចំណុចអ្នកទទួល)។ *ស្រុកម៉ាសេដូន* "សូមមើលការពន្យល់ ភល ៤:១៥"។ *នៅតែក្នុងក្រុងអេភេសូរ* មានន័យថា ឱ្យស្នាក់នៅក្នុងក្រុងអេភេសូរ ហើយធ្វើការងារថ្វាយព្រះអម្ចាស់ នៅក្នុងពួកជំនុំដែលបានចាប់ផ្ដើមហើយនៅទីនោះ ។ លោកប៉ុលចាប់ផ្ដើមការងាររបស់គាត់នៅក្នុងទីក្រុងអេភេសូរ នៅក្នុងដំណើរបេសកកម្មលើកទីបីរបស់គាត់ ប្រហែលជា៨ឆ្នាំមុននោះ (កច ១៩:១–២០:១)។ *អេភេសូរ* "សូមមើលសេចក្ដី ផ្ដើមកណ្ឌគម្ពីរអេភេសូរ ត្រង់ចំណុចទីក្រុង"។

**១:៤** *រឿងព្រេង* ប្រហែលសំដៅលើរឿងព្រេងផ្សេងៗ ដែលពួកគ្រូខុសឆ្គងប្រឌិតឡើង ដោយប្រើរឿងរ៉ាវនៅក្នុងគម្ពីរសញ្ញាចាស់ (ពង្សាវតារ) ដែលក្រោយមកបានក្លាយទៅជាប្រព័ន្ធទស្សនវិជ្ជាខុសឆ្គងមួយ (សូមមើលសេចក្ដីផ្ដើម ១យហ)។

**១:៥** *ចិត្តស្អាត* "២ធថ ២:២២ ទដ ២៤:៤ ៥១:១០ មថ ៥:៨ និងពន្យល់"។

**១:៨** *ក្រិត្យវិន័យល្អមែន* "សូមមើល រម ៧:៧–១២ និងការពន្យល់"។

**១:៩–១០** "មើលការពន្យល់ រម ១:២៩–៣១"។

**១:១០** *សេចក្ដីបង្រៀនដ៏ត្រឹមត្រូវ* "សូមមើល ទត ១:៩ និងការពន្យល់"។

**១:១១** *ដំណឹង* សំដៅលើដំណឹងល្អ (សូមមើល មក ១:១ និងការពន្យល់)។ *ដំណឹងដែលផ្ញើទុកនឹងខ្ញុំ* "សូមមើល ៦:២០ ១កថ ៩:១៧ កទ ២:៧ ១ថន ២:៤ ២ធថ ១:១៤ និងការពន្យល់"។

**១:១២** *ចំរើនកំឡាំងដល់ខ្ញុំ គឺជាព្រះយេស៊ូវ* "សូមមើល ភល ៤:១៣ និង

ខ្ញុំ[ព] គឺជាព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា
ពីព្រោះទ្រង់បានរាប់ខ្ញុំទុកជាស្មោះត្រង់ ទាំងតាំងខ្ញុំឱ្យ
មានការងារ[ភ] ១៣ដែលពីដើមខ្ញុំជាអ្នកប្រមាថ ធ្វើទុក្ខ
បៀតបៀន[ម] ហើយព្រហើនឈ្លានពាន តែទ្រង់បាន
អាណិតមេត្តាដល់ខ្ញុំ[យ] ពីព្រោះខ្ញុំបានប្រព្រឹត្តដោយខ្លៅល្ងង់
ឥតមានសេចក្តីជំនឿ[រ] ១៤តែព្រះគុណរបស់ព្រះអម្ចាស់នៃ
យើងបានចំរើនជាបរិបូរហូរហៀរឡើង[ល] ព្រមទាំងសេចក្តី
ជំនឿ នឹងសេចក្តីស្រឡាញ់ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ
ផង[វ] ១៥ពាក្យនេះ[ស]គួរជឿ ហើយគួរទទួលគ្រប់យ៉ាង គឺថា
ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកិយ ដើម្បីនឹង
ជួយសង្គ្រោះមនុស្សមានបាប[ហ] ដែលខ្ញុំនេះជាលេខ ១ ក្នុង
ពួកគេ ១៦ដោយហេតុនោះបានជាទ្រង់អាណិតមេត្តាដល់ខ្ញុំ[ឡ]
ដើម្បីឱ្យព្រះយេស៊ូវគ្រីស្ទបានសំដែងចេញ គ្រប់ទាំងសេចក្តី
អត់ធន់របស់ទ្រង់ក្នុងខ្លួនខ្ញុំ[អ] ដែលជាអ្នកលេខ១នោះឱ្យខ្ញុំបាន
ធ្វើជាក្បួនដល់ពួកអ្នក ដែលនឹងជឿដល់ទ្រង់[ក] ប្រយោជន៍
ឱ្យគេបានជីវិតអស់កល្បជានិច្ច[ខ] ១៧រីឯស្តេច[គ] នៃអស់ទាំង
កល្ប ដែលទ្រង់មិនចេះសុគត[ឃ] ហើយមើលទ្រង់មិនឃើញ[ង]
គឺជាព្រះតែ ១ ព្រះអង្គ[ច] នោះសូមឱ្យទ្រង់បានល្បីព្រះនាម
និងសិរីល្អអស់កល្បជានិច្ចរៀងរាបតទៅ អាម៉ែន[ឆ]។

**១:១២** ព ភល ៤:១៣ ភ កច ៩:១៥
**១:១៣** ម កច ៨:៣ យ ខ.១៦ រ កច ២៦:៩
**១:១៤** ល ២កថ ៤:១៥ វ ២ធថ ១:១៣ ១ថន ១:៣
**១:១៥** ស ១ធថ ៣:១ ៤:៩ ២ធថ ២:១១ ទត ៣:៨ ហ មក ២:១៧ យហ ៣:១៧
**១:១៦** ឡ ខ.១៣ អ រម ២:៤ ក យហ ៣:១៥ ខ មថ ២៥:៤៦
**១:១៧** គ វវ ១៥:៣ ឃ ១ធថ ៦:១៦ ង កល ១:១៥ ច យដ ២៥ ឆ រម ១១:៣៦
**១:១៨** ជ ខ.២ ឈ ១ធថ ៤:១៤ ញ ១ធថ ៦:១២ ២ធថ ២:៣ ៤:៧

១៨ឱធីម៉ូថេ ជាកូនអើយ[ជ] ខ្ញុំប្រគល់ពាក្យបណ្តាំនេះទុក
នឹងអ្នក តាមសេចក្តីទំនាយដែលបានទាយពីអ្នកជាមុន[ឈ]
ដើម្បីឱ្យអ្នកបានច្បាំងជាចំបាំងយ៉ាងល្អ ដោយសារសេចក្តី
ទាំងនោះ[ញ] ១៩ព្រមទាំងរក្សាសេចក្តីជំនឿ និងបញ្ញាចិត្តជ្រះ
ថ្លា[ដ] ដែលមនុស្សខ្លះបានបោះបង់ចោល ហើយគេបានលិច
បាត់ខាងឯសេចក្តីជំនឿផង[ឋ] ២០ក្នុងពួកនោះ មានឈ្មោះ
ហ៊ីមេនាស[ឌ] និងអ័លេក្សានត្រុស[ឍ] ដែលខ្ញុំបានប្រគល់ទៅ
អារក្សសាតាំង[ណ] ឱ្យត្រូវវាយផ្ចាល ដើម្បីឱ្យគេរាងចាលកុំ
ឱ្យប្រមាថទៀត ។

## ការបង្រៀនអំពីការថ្វាយបង្គំ

**២** ១ដូច្នេះ ខ្ញុំទូន្មានសេចក្តីនេះជាមុនដំបូងថា ចូរពោល
ពាក្យអរព្រះគុណ ពាក្យទូលសូម ពាក្យអធិស្ឋាន[ត] នឹងពាក្យ
ទូលអង្វរឱ្យមនុស្សទាំងអស់ ២គឺឱ្យស្តេច ហើយឱ្យពួកនាម៉ឺន
ទាំងប៉ុន្មានផង[ថ] ដើម្បីឱ្យយើងរាល់គ្នាបាននៅជាសុខសាន្ត
ហើយស្រគត់ស្រគំ ដោយកោតខ្លាច[ទ] ហើយដោយនឹងធឹង
គ្រប់ជំពូក ៣ដ្បិតយ៉ាងនោះ ទើបបានល្អ ហើយគាប់[ធ]ព្រះ

**១:១៩** ដ ខ.៥ កច ២៣:១ ឋ ១ធថ ៦:២១ ២ធថ ២:១៨
**១:២០** ឌ ២ធថ ២:១៧ ឍ ២ធថ ៤:១៤ ណ ១កថ ៥:៥
**២:១** ត អភ ៦:១៨ **២:២** ថ អរ ៦:១០ រម ១៣:១ ទ ១ធថ ៣:១៦ ៤:៧,៨ ៦:៣,៥,៦,១១ ២ធថ ៣:៥ ទត ១:១ **២:៣** ធ ១ធថ ៥:៤

ការពន្យល់”។ *ទាំងតាំងខ្ញុំឱ្យមានការងារ* “សូមមើល ខ.១ និងពន្យល់”។

**១:១៣** *អ្នកប្រមាថ ធ្វើទុក្ខបៀតបៀន ហើយព្រហើនឈ្លានពាន* “សូមមើល កច ៩:១ ២២:៤–៥,១៩ ២៦:១០–១១ ២៦:១១ និងការពន្យល់”។

**១:១៤** *សេចក្តីជំនឿ និងសេចក្តីស្រឡាញ់ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ* “២ធថ ១:១៣ និងការពន្យល់”។

**១:១៥** *ពាក្យនេះគួរជឿ ហើយគួរទទួលគ្រប់យ៉ាង* ឃ្លានេះមិនមាននិយាយនៅកន្លែងផ្សេងទៀតទេ នៅក្នុងគម្ពីរសញ្ញាថ្មី ប៉ុន្តែ មានប្រើចំនួន៦ដងនៅក្នុងសំបុត្រអំពីភាពជាអ្នកគង្វាល (៣:១ ៤:៩ ២ធថ ២:១១ ទត ៣:៨) ដើម្បីបង្ហាញនូវការបង្រៀនជាគន្លឹះ ។

**១:១៦** *ជីវិតអស់កល្បជានិច្ច* “សូមមើល យហ ៣:១៥–១៦ និងពន្យល់”។

**១:១៧** *ហើយមើលទ្រង់មិនឃើញ* “សូមមើល កល ១:១៥ និងពន្យល់”។

**១:១៨** *កូន* “សូមមើល ខ.២ និងការពន្យល់”។ *សេចក្តីទំនាយដែលបានទាយពីអ្នកជាមុន* នៅក្នុងពួកជំនុំដំបូង ព្រះអម្ចាស់សំដែងឱ្យដឹងនូវព្រះហឫទ័យទ្រង់ តាមរយៈពួកអ្នកដែលមានអំណោយទានថ្លែងទំនាយ និងតាមរបៀបផ្សេងៗ (កច ១៣:១–៣ ពួកហោរាមាននាទីដ៏សំខាន់ក្នុងការបញ្ជូនលោកប៉ុល និងលោកបាណាបាសឱ្យទៅបំពេញបេសកកម្ម នៅក្នុងចំណោមសាសន៍ដទៃ)។ ក្នុងករណីលោកធីម៉ូថេ សេចក្តីទំនាយប្រហែលជាបានកើតឡើងនៅពេល ឬមុនពេលដែលគាត់ទទួលភារកិច្ច (៤:១៤) ប្រហែលជាកើតឡើងនៅ១២ឆ្នាំមុននោះ គឺក្នុងដំណើរបេសកកម្មលើកទី២របស់លោកប៉ុល (កច ១៦:១–៣)។ *បានច្បាំងជាចំបាំងយ៉ាងល្អ* “សូមមើល ៦:១២ ២ធថ ២:៣ ៤:៧ និងការពន្យល់”។

**១:២០** *ហ៊ីមេនាស* “សូមមើល ២ធថ ២:១៧,១៨”។ *អ័លេក្សានត្រុស* ប្រហែលជាលោកអ័លេក្សានត្រុស ដែលបានលើកឡើងនៅក្នុងបទគម្ពីរ “២ធថ ៤:១៤”។ *បានប្រគល់ទៅអារក្សសាតាំង ឱ្យត្រូវវាយផ្ចាល* សំដៅលើការហ៊ឹកហ្វឺននៅក្នុងពួកជំនុំ (មថ ១៨:១៧ និងការពន្យល់)។ លោកប៉ុលមិនរាប់បញ្ចូលអ្នកទាំងពីរនោះនៅក្នុងពួកជំនុំទេ ។ ពួកជំនុំត្រូវបានទទួលស្គាល់ថា ជាកន្លែងដែលមិនគ្រប់គ្រងដោយអំណាចអារក្សសាតាំងទេ ។ ការកាត់អ្នកទាំងពីរនោះចេញពីពួកជំនុំ គឺដើម្បីឱ្យពួកគេទទួលនូវមេរៀននៃជីវិត (ទទួលវិន័យ) មិនមែនដើម្បីឱ្យពួកគេធ្វើការអាក្រក់ទេ ។ សកម្មភាពដ៏តឹងតែងនេះ គឺដើម្បីកែតម្រង់ជាជាងការដាក់ទោស ។ សម្រាប់ស្ថានភាពស្រដៀងគ្នានេះសូមមើល “១កថ ៥:៥,១៣ និងការពន្យល់”។

**២:១–២** *អធិស្ឋាន . . .ឱ្យស្តេច ហើយពួកនាម៉ឺនទាំងប៉ុន្មានផង* “សូមមើល យរ ២៩:៧ ១ពត ២:១៣ និងការពន្យល់”។ នៅពេលលោកប៉ុលសរសេរសំបុត្រនេះ ស្តេចអធិរាជនេរ៉ូ ដែលជាអធិរាជនៃចក្រភពរ៉ូម៉ាំង (ឆ្នាំទី ៥៤–៦៨ គ.ស) កំពុងស្ថិតនៅក្នុងអំណាចនៅឡើយ ។ *កោតខ្លាច* ជាពាក្យគន្លឹះនៅក្នុងសំបុត្រស្តីអំពីភាពជាអ្នកគង្វាល និងមាននិយាយចំនួន១០ដង (៣:១៦ ៤:៧–៨ ៦:៣,៥–៦,១១ ២ធថ ៣:៥ ទត ១:១) ប៉ុន្តែ ពុំមាននិយាយនៅកន្លែងណាផ្សេងទៀតទេ ក្នុងសំបុត្រលោកប៉ុល ។ វាសំដែងនូវជីវិតល្អ និងបរិសុទ្ធជាមួយនឹងលក្ខណៈសំខាន់ និងការគោរពចុះចូលចំពោះព្រះ ។

**២:៣** *ព្រះដ៏ជាព្រះអង្គសង្គ្រោះនៃយើង* “មើលការពន្យល់ ទត ១:៣”។

ហឫទ័យ ដល់ព្រះដ៏ជាព្រះអង្គសង្គ្រោះនៃយើង[ន] ៤ដែលទ្រង់
សព្វព្រះហឫទ័យ[ប] ឱ្យមនុស្សទាំងអស់[ផ]បានសង្គ្រោះ[ព] ហើយ
ឱ្យបានស្គាល់សេចក្ដីពិត[ភ] ៥ពីព្រោះមានព្រះតែ១[ម] ហើយ
មានអ្នកសម្រុះសម្រួលតែ១[យ] នៅកណ្ដាលព្រះនឹងមនុស្ស
គឺជាមនុស្សដ៏ជាព្រះគ្រីស្ទយេស៊ូវនោះ[រ] ៦ទ្រង់បានថ្វាយព្រះ
អង្គទ្រង់ទុកជាថ្លៃលោះមនុស្សទាំងអស់[ល] ដែលត្រូវមានទី
បន្ទាល់[វ]នៅពេលកំណត់[ស] ៧ហើយទ្រង់បានតាំងខ្ញុំ ឱ្យធ្វើជា
អ្នកប្រកាសប្រាប់ និងជាសាវកពីការនោះឯង គឺជាគ្រូ
បង្រៀន[ហ]ដល់ពួកសាសន៍ដទៃ[ឡ] ដោយសេចក្ដីជំនឿ នឹង
សេចក្ដីពិត (ខ្ញុំនិយាយតាមសេចក្ដីពិត មិនកុហកទេ[អ]) ។
៨ដូច្នេះ ខ្ញុំចង់ឱ្យពួកប្រុសៗលើកដៃបរិសុទ្ធឡើង[ក] នឹង
អធិស្ឋាននៅគ្រប់ទីកន្លែង ដោយឥតខឹង ឬឈ្លោះប្រកែក
ឡើយ ៩ឯពួកស្រីៗនោះខ្ញុំក៏ចង់ឱ្យគេតែងខ្លួនតាមបែបគួរ
សម ឱ្យចេះអៀនខ្លួន ហើយដឹងប្រមាណខ្លួន មិនមែនជាអ្នក
តែងខ្លួនដោយក្រងសក់ ឬពាក់មាស កែវមុក្តា ឬសំលៀក បំ
ពាក់យ៉ាងថ្លៃពេកនោះឡើយ[ខ] ១០តែឱ្យសំណាំនឹងពួកស្ត្រីដែល
រាប់ខ្លួនជាអ្នកកោតខ្លាចដល់ព្រះ គឺដោយការប្រព្រឹត្តល្អ[គ]វិញ
១១ត្រូវឱ្យពួកស្រីៗរៀនដោយសំងាត់ ទាំងចុះចូលគ្រប់
ជំពូក[ឃ] ១២ខ្ញុំមិនបើកឱ្យស្ត្រីណាបង្រៀន ឬឱ្យមានអំណាច
លើបុរសទេ ត្រូវឱ្យគេនៅដោយស្រគត់ស្រគំចុះ[ង] ១៣ពីព្រោះ
ព្រះបានបង្កើតលោកអ័ដាមមកជាមុន រួចមកនាងអេវ៉ា[ច]
១៤ហើយមិនមែនលោកអ័ដាម ដែលចាញ់បញ្ឆោតទេ គឺជា

**២:៣** ន លក ១:៤៧ **២:៤** ប អគ១៨:២៣,៣២ ៣៣:១១ ផ ១ធថ ៤:១០ ទត ២:១១ ២ពត ៣:៩ ព យហ ៣:១៧ រម ១១:១៤ ភ ២ធថ ២:២៥ ទត ១:១ ហព ១០:២៦ **២:៥** ម ចទ ៦:៤ រម ៣:២៩,៣០ ១០:១២ យ កទ ៣:២០ រ រម ១:៣ **២:៦** ល មថ២០:២៨ វ ១កថ ១:៦ ស ១ធថ ៦:១៥ ទត១:៣ **២:៧** ហ ២ធថ ១:១១ ឡ កថ ៩:១៥

អ រម ៩:១ ១ធថ ១:១១ **២:៨** ក ទដ ២៤:៤ ៦៣:៤ ១៣៤:២ ១៤១:២ លក ២៤:៥០ **២:៩** ខ ១ពត ៣:៣ **២:១០** គ សភ ៣១:១៣ **២:១១** ឃ ១ពត ៣:៣,៤ **២:១២** ង អភ ៥:២២ **២:១៣** ច លប ២:៧,២២ ១កថ ១១:៨

**២:៤** *ទ្រង់សព្វព្រះហឫទ័យ ឱ្យមនុស្សទាំងអស់បានសង្គ្រោះ* ត្រង់ចំណុចនេះ បញ្ជាក់យ៉ាងច្បាស់ថា ព្រះអម្ចាស់មានព្រះហឫទ័យចង់ឱ្យមនុស្សទាំងអស់បានការសង្គ្រោះមកអំពីទ្រង់ ។ ក្នុងព្រះគម្ពីរបានបញ្ជាក់ផងដែរថា ព្រះទ្រង់ជ្រើសរើសមនុស្សសម្រាប់ព្រះរាជកិច្ចរបស់ទ្រង់ (៤:១០ រម ៨:២៩ និងការពន្យល់) ។

**២:៥** *មានព្រះតែ១* នេះមូលដ្ឋានជំនឿរបស់ពួកសាសន៍យូដា (ចទ ៦:៤ និងការពន្យល់) ដែលពួកគេលន់តួជារៀងរាល់ថ្ងៃ (មក ១២:២៩ និងការពន្យល់) ។ *អ្នកសម្រុះសម្រួលតែ១* សំដៅលើអ្នកដែលប្រាប់អំពីព្រះអម្ចាស់ដល់មនុស្ស និងនាំមនុស្សឱ្យស្គាល់ទ្រង់ ។ ម្យ៉ាងទៀត សំដៅលើព្រះយេស៊ូវដែលទ្រង់បានយករនាំងដែលរាំងរវាងមនុស្សនិងទ្រង់ចេញ ដោយប្រទានរូបអង្គទ្រង់ផ្ទាល់ ដើម្បីឱ្យមនុស្សបានទៅឯទ្រង់វិញ (ខ.៦ យហ ១៤:៦ ហព ៨:៦ និងការពន្យល់) ។

**២:៧** *អ្នកប្រកាសប្រាប់* សំដៅលើអ្នកដែលមានអំណាចក្នុងការប្រកាសដំណឹងល្អនៅទីសាធារណៈ (២ធថ ១:១១) ។ *សាវក* "សូមមើល ១កថ ១:១ និងពន្យល់" ។ *ការនោះឯង* តាមរយៈការសុគតរបស់ព្រះយេស៊ូវធ្វើឱ្យរនាំងដែលបាំងមនុស្ស និងព្រះត្រូវបានយកចេញ ហើយការសង្គ្រោះគឺបានប្រទានដល់មនុស្សទាំងអស់ ។

**២:៨** *ពួកប្រុសៗ* ត្រង់ចំណុចនេះមិនមែនមានន័យថា មានតែបុរសប៉ុណ្ណោះទេដែលមានសិទ្ធិអធិស្ឋាន ប៉ុន្តែ ស្ត្រីក៏មាននាទីនៅក្នុងការអធិស្ឋានដែរ (ខ.៥-៦ ១កថ ១១:៥ និងការពន្យល់) ។

**២:៩-១៤** មានមតិខ្លះយល់ថា ការបង្រៀនរបស់លោកប៉ុលនៅត្រង់ចំណុចនេះគឺសំដៅលើហេតុការណ៍ដែលបានកើតឡើងនាសម័យកាត់តែប៉ុណ្ណោះ ។ ប៉ុន្តែ មានមតិខ្លះទៀតយល់ថា បទគម្ពីរត្រង់ចំណុចនេះ គឺត្រូវអនុវត្តគ្រប់សម័យកាល ។

**២:៩** បទគម្ពីរនេះ លោកប៉ុលចង់ឱ្យពួកជំនុំចេះប្រុងប្រយ័ត្ន នូវទង្វើរបស់ខ្លួននៅក្នុងសង្គមដែលរួមមានការតុបតែងខ្លួនជាដើម ព្រោះថា ការដែលតុបតែងខ្លួនបែបមិនគួរសម និងហួសប្រមាណ គឺអាចសំដែងនូវការអួតអាងផងដែរ ។

**២:១០** "សូមមើល ១ពត ៣:៣-៥ និងការពន្យល់" ។

**២:១២** *មិនបើកឱ្យស្ត្រីណាបង្រៀន* ត្រង់ចំណុចនេះ មានមតិខ្លះយល់ថា ការដែលលោកប៉ុលមិនបើកឱ្យស្ត្រីបង្រៀន គឺសំដៅលើពួកស្ត្រីនៅឯទីក្រុងអេភេសូរនាសម័យកាត់តែប៉ុណ្ណោះ ព្រោះថាពួកស្រីៗទាំងនោះបានព្យាយាមប្រើអំណាចរបស់ខ្លួន ដើម្បីគាបសង្កត់អ្នកដទៃ ។ មតិខ្លះទៀតយល់ថា លោកប៉ុលមិនអនុញ្ញាត ឱ្យស្ត្រីធ្វើជាគ្រូបង្រៀនជាផ្លូវការ នៅក្នុងពួកជំនុំទេ ។ នេះបញ្ជាក់អំពីការព្យាយាមបន្ថែមនូវអំណាចរបស់ពួកស្ត្រីទាំងនោះ នៅក្នុងពួកជំនុំ (៣:១ និងការពន្យល់) ។

**២:១៣-១៤** បទគម្ពីរត្រង់ចំណុចនេះ លោកប៉ុលសំអាងលើ "លប ២-៣" ។ អ្នកខ្លះយល់ថា សេចក្ដីនៅត្រង់ចំណុចនេះ ពុំមែនជាមូលហេតុដែលតម្រូវឱ្យស្ត្រីនៅស្ងៀម និងចុះចូលនោះទេ ប៉ុន្តែ គឺប្រើដើម្បីភ្ជាប់សេចក្ដីជាមួយនឹងបទគម្ពីរនៅក្នុងខ.៥ ។ អត្ថន័យរួមគឺ ដោយព្រោះលោកអ័ដាមមានអាទិភាពសំខាន់នៅក្នុងចំណោមរបស់សព្វសារពើដែលព្រះអម្ចាស់បង្កើតមក ដូច្នេះការនេះបញ្ជាក់អំពីអាទិភាពជាចម្បងរបស់បុរស នៅក្នុងការបង្រៀនពួកជំនុំនៅក្រុងអេភេសូរ ។ ហើយការដែលនាងអេវ៉ាបានជ្រើសរើសផ្លូវខុស គឺបញ្ជាក់អំពីការប្រព្រឹត្តខុស របស់ពួកស្រីៗនៅទីក្រុងអេភេសូរដែលមិនបានរៀនសូត្រ និងមានលក្ខណៈទន្ទ្រាន ហើយពួកស្រីៗទាំងនោះបានទទួលនូវសេចក្ដីបង្រៀនខុសឆ្គងផ្សេងៗជាច្រើន ។ ការហាមប្រាមនេះ មិនមែនមានលក្ខណៈដាច់ខាត និងត្រូវអនុវត្តជាទូទៅនោះទេ ប៉ុន្តែ វាអាស្រ័យទៅលើស្ថានភាពជាក់ស្ដែងរបស់ពួកជំនុំ (សូមមើលសេចក្ដីផ្ដើមប្រភេទ និងគោលបំណង) ។ ដូច្នេះ ចំពោះស្ថានភាពខុសពីនេះ ការហាមប្រាមមិនត្រូវបានអនុវត្តទេ (១កថ ១១:១-៥) ។

អ្នកផ្សេងទៀតយល់ថា ដោយសារលក្ខណៈនៅក្នុងការបង្កើតលោក ធ្វើឱ្យការហាមប្រាមនេះត្រូវអនុវត្តជាទូទៅ និងជាអចិន្ត្រៃ (១).លោកអ័ដាមត្រូវបានបង្កើតជាមុន ។ លោកប៉ុលសំអាងលើអាទិភាពរបស់លោកអ័ដាម ។ ការយល់ឃើញយ៉ាងដូច្នេះ គឺសំដៅលើទំនាក់ទំនងរវាងបុរសនិងស្ត្រីតាំងពីការចាប់ផ្ដើមនៃពិភពលោកមកម្លេះ ។ (២).ស្ត្រីវិញទេតើដែលចាញ់បញ្ឆោត ។ លោកប៉ុលអះអាងយ៉ាងដូច្នេះគឺដោយព្រោះថា ស្ត្រីជាអ្នកចាញ់

ស្ត្រីវិញទេតើដែលចាញ់បញ្ឆោតនោះ ព្រមទាំងរំលងច្បាប់
ផង[ឆ] ១៥តែបើសិនជានាងនៅជាប់ក្នុងសេចក្ដីជំនឿ សេចក្ដី
ស្រឡាញ់[ជ] នឹងសេចក្ដីបរិសុទ្ធ ទាំងមានគំនិតមារយាទ
នោះនាងនឹងបានសង្គ្រោះក្នុងកាលដែលបង្កើតកូន ។

### អ្នកត្រួតត្រា និងអ្នកជំនួយ

៣ ១ពាក្យនេះគួរជឿដែលថា[ឈ] បើអ្នកណាប្រាថ្នាចង់ធ្វើជា
អ្នកត្រួតត្រា[ញ] នោះឈ្មោះថាចង់បានការល្អប្រសើរ ហើយ
២ដូច្នេះ ត្រូវឱ្យអ្នកត្រួតត្រាប្រព្រឹត្ត ដោយឥតកន្លែងចាប់
ទោសបានចុះ[ដ] ត្រូវជាមនុស្សមានប្រពន្ធតែ១[ឋ] ជាមនុស្សដឹង
ខ្នាត[ឌ] មានចិត្តធ្ងន់ធ្ង កាន់គំនិតមារយាទ ជាអ្នកចៅរ៉ៅ[ឍ]
ហើយប្រសប់នឹងការបង្រៀន[ណ] ៣មិនត្រូវជាអ្នកចំណូល
ស្រា[ត] ឬឈ្លោះប្រកែក[ថ] ឬស៊ីសំណូកឡើយ ត្រូវមានចិត្តស្លូត
បូត ឥតរករឿងរកហេតុ ឥតលោភចង់បានប្រាក់[ទ] ៤ត្រូវ
ត្រួតត្រាផ្ទះរបស់ខ្លួន ដោយស្រួលបួល ទាំងឱ្យកូនចៅស្ដាប់
បង្គាប់ដោយនឹងធឹង[ធ] ៥បើអ្នកណាមិនចេះត្រួតត្រាផ្ទះខ្លួន
ធ្វើដូចម្ដេចឱ្យថែរក្សាពួកជំនុំនៃព្រះបាន[ន] ៦មនុស្សណា
ដែលទើបនឹងជឿថ្មី នោះធ្វើពុំបានទេ ក្រែងកើតមានចិត្ត
ធំ[ប] ហើយធ្លាក់ទៅក្នុងទោស[ផ] របស់អារក្សវិញ ៧ត្រូវឱ្យអ្នក
នោះមានឈ្មោះល្អពីអ្នកដទៃផង[ព] ក្រែងគេត្មះតិះដៀល
ហើយធ្លាក់ទៅក្នុងអន្ទាក់របស់អារក្ស[ភ]។
៨ឯពួកអ្នកជំនួយ[ម] ក៏ដូច្នោះដែរ ត្រូវមានចិត្តនឹងធឹងឥត
និយាយសំដី ២ ឥតចំណូលស្រា[យ] ឬស៊ីសំណូកឡើយ ៩ត្រូវ
ជាអ្នកកាន់តាមសេចក្ដីអាថ៌កំបាំងរបស់សេចក្ដីជំនឿ ដោយ
បញ្ញាចិត្តដ៏ស្អាត[រ] ១០មួយទៀត ត្រូវល្បងលចំពោះពួកអ្នក
ជំនួយទាំងនោះជាមុនដំបូងដែរ[ល] រួចបើកាលណាឃើញថា
គ្មានកន្លែងចាប់ទោសបានហើយ នោះសឹមឱ្យគេជួយទៅចុះ
១១ឯប្រពន្ធរបស់គេ ក៏ត្រូវមានចិត្តនឹងធឹងដែរ ឥតចេះ
និយាយដើមគេ[វ] ជាអ្នកដឹងខ្នាត[ស] ហើយស្មោះត្រង់ក្នុងគ្រប់
ការទាំងអស់ ១២ត្រូវឱ្យអ្នកជំនួយមានប្រពន្ធតែ១[ហ] ទាំងត្រួត
ត្រាកូនចៅ និងផ្ទះខ្លួនដោយស្រួលបួល[ឡ] ១៣ដ្បិតពួកអ្នក
ដែលបានជួយយ៉ាងល្អ នោះនឹងបានថ្នាក់ល្អសំរាប់ខ្លួន និង
សេចក្ដីក្លាហានក្នុងសេចក្ដីជំនឿ ដោយសារព្រះគ្រីស្ទ
យេស៊ូវ។
១៤ខ្ញុំសង្ឃឹមថានឹងមកឯអ្នកជាយ៉ាងឆាប់ ប៉ុន្តែ ខ្ញុំសរ

**២:១៤** ឆ លប ៣:១–៦,១៣ ២កថ ១១:៣ **២:១៥** ជ ១ធថ ១:១៤ **៣:១** ឈ ១ធថ ១:១៥ ញ កច ២០:២៨ ភល ១:១ ទត ១:៧ **៣:២** ដ ទត ១:៦–៨ ឋ ខ.១២ ឌ ខ.១១ ទត ២:២ ឍ រម ១២:១៣ ណ ២ធថ ២:២៤ **៣:៣** ត ទត ១:៧ ថ ២ធថ ២:២៤ ទ លក ១៦:១៤ ១ធថ ៦:១០ ២ធថ ៣:២ ហព ១៣:៥ ១ពត ៥:២ **៣:៤** ធ ខ.១២ ទត ១:៦ **៣:៥** ន ១កថ ១០:៣២

**៣:៦** ប ១ធថ ៦:៤ ២ធថ ៣:៤ ផ ២ពត ២:៤ **៣:៧** ព មក ៤:១១ ភ ២ធថ ២:២៦ **៣:៨** ម ភល ១:១ យ ១ធថ ៥:២៣ ទត ១:៧ ២:៣ **៣:៩** រ កច ២៣:១ **៣:១០** ល ១ធថ ៥:២២ **៣:១១** វ ២ធថ ៣:៣ ទត ២:៣ ស ខ.២ **៣:១២** ហ ខ.២ ឡ ខ.៤

បញ្ឆោត (ហើយបាននាំលោកអ័ដាម ឱ្យធ្លាក់ទៅក្នុងសេចក្ដីបញ្ឆោតនោះដែរ ដូច្នោះហើយបានជាមតិនេះយល់ថា សេចក្ដីបង្រៀនរបស់ស្ត្រីដែលមានលក្ខណៈបំពាន និងខុសឆ្គងមិនត្រូវបានគេទុកចិត្តទេនៅក្នុងពួកជំនុំ ។

**២:១៥** *បានសង្គ្រោះក្នុងកាលដែលបង្កើតកូន* ឃ្លានេះអាចមានអត្ថន័យបីយ៉ាង (១).សំដៅលើស្ត្រីដែលគោរពកោតខ្លាចដល់ព្រះ និងបំពេញនាទីរបស់នាងនៅក្នុងនាមជាប្រពន្ធ និងជាម្ដាយដ៏ល្អនៅក្នុងផ្ទះរបស់ខ្លួន (២).សំដៅលើស្ត្រីដែលទទួលបានការសង្គ្រោះខាងឯវិញ្ញាណ តាមរយៈការកើតជាថ្មីនៅក្នុងព្រះគ្រីស្ទ (៣).សំដៅលើស្ត្រីដែលថែរក្សាខ្លួនបានល្អនៅក្នុងពេលប្រសូតបុត្រ ។

**៣:១** *ពាក្យនេះគួរជឿ* "មើលពន្យល់ ១:១៥"។ *អ្នកត្រួតត្រា* ពាក្យនេះនៅក្នុងវប្បធម៌ក្រិកសំដៅលើពួកប្រធានជាផ្លូវការ នៅក្នុងសង្គម ឬសាសនា ។ ម្យ៉ាងទៀត វាសំដៅលើមនុស្សដែលមើលការខុសត្រូវលើពួកជំនុំក្នុងតំបន់ ។ នៅក្នុងចំណោមគ្រីស្ទបរិស័ទជាតិយូដា មានប្រើពាក្យថា "ចាស់ទុំ" ដែលមានន័យដូចគ្នានឹងពាក្យនេះដែរ ។ ហើយជាទូទៅ ពាក្យទាំងពីរនេះត្រូវបានប្រើផ្លាស់ប្តូរគ្នា (កច ២០:១៧,២៨ ទត ១:៥–៧ ១ពត ៥:១–២ និងពន្យល់)។ ការងាររបស់អ្នកត្រួតត្រា ឬពួកចាស់ទុំ គឺបង្រៀន និងអធិប្បាយ (៣:២ ៥:១៧) កែតម្រង់កិច្ចការរបស់ពួកជំនុំ (៣:៥ ៥:១៧) ថែរក្សាហ្វូងចៀមរបស់ព្រះអម្ចាស់ (គ្រូគង្វាល កច ២០:២៨ និងការពន្យល់) និងដើម្បីការពារពួកជំនុំពីសេចក្ដីកំហុសផ្សេងៗ (កច ២០:២៨–៣១)។

**៣:២** *មនុស្សមានប្រពន្ធតែ១* ត្រង់ចំណុចនេះបញ្ជាក់អំពីគោលការជាទូទៅសម្រាប់អនុវត្តចំពោះពួកជំនុំរបស់ព្រះយេស៊ូវគ្រីស្ទ (មើលពន្យល់ ១:៦)។

**៣:៥** *ពួកជំនុំ* "មើលការពន្យល់ កច ៩:៣១ ២កថ ១:១"។

**៣:៧** *អន្ទាក់របស់អារក្ស* "២ធថ ២:២៦ ១ពត ៥:៨ និងការពន្យល់"។

**៣:៨** *ពួកអ្នកជំនួយ* ក្នុងការប្រើប្រាស់ធម្មតានៃភាសាក្រិក ឃ្លានេះមានន័យថា "អ្នកបម្រើ"។ ពួកអ្នកដែលត្រូវបានជ្រើសរើសនៅក្នុងបទគម្ពីរ "កច ៦:១–៦" ប្រហែលមិនមែនគ្រាន់តែជាអ្នកជំនួយ ដែលបានជ្រើសរើសក្នុងព្រះគម្ពីរសញ្ញាថ្មីប៉ុណ្ណោះទេ ប៉ុន្តែ ពួកគេគឺជាមនុស្សដែលត្រូវបានតែងតាំងឡើងនៅក្នុងពួកជំនុំតែម្តង (កច ៦:៦ និងការពន្យល់)។ ជាទូទៅ ការងាររបស់ពួកគេគឺ ជួយដល់ពួកចាស់ទុំ ឱ្យមានឱកាសក្នុងការអធិស្ឋាន និងការអធិប្បាយព្រះបន្ទូល (កច ៦:២,៤)។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី មានពួកជំនុំចំនួនពីរដែលមានបញ្ជាក់អំពីពួកអ្នកត្រួតត្រា (ឬពួកចាស់ទុំ) និងពួកអ្នកជំនួយ (ភល ១:១)។

**៣:៩** *សេចក្ដីជំនឿ* គឺជាសេចក្ដីដែលពួកសាវ័កតែងតែបង្រៀន (៤:១,៦ ៦:១០,១២,២១ ២ធថ ៤:៧ ទត ១:១៣ ១កថ ១៥:៣ ២ថន ២:១៥ និងការពន្យល់)។

**៣:១១** *ប្រពន្ធរបស់គេ* ឃ្លានេះនៅក្នុងភាសាក្រិកសរសេរថា "ពួកស្រីៗ" ដូច្នេះ អាចមានន័យពីរ (១).ប្រពន្ធរបស់ពួកអ្នកជំនួយ (២).ពួកស្រីៗដែលជាអ្នកជំនួយតែម្តង ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅក្នុងបទគម្ពីរ "១២–១៣" ហាក់ដូចជាបញ្ជាក់ថា តួនាទីពួកអ្នកជំនួយជាបុរសមានភាពប្លែកគ្នាពីពួកជំនួយជាស្ត្រី ។

**៣:១៤** *ខ្ញុំសរសេរសេចក្ដីទាំងនេះផ្ញើមក* ត្រង់ចំណុចនេះបញ្ជាក់នូវការសង្ខេបសេចក្ដីអំពីគោលបំណងនៃការសរសេររបស់លោកប៉ុល គឺដើម្បី

សេរសេចក្ដីទាំងនេះផ្ញើមកអ្នកសិន 15ដើម្បី ក្រែងខ្ញុំក្រមក
នោះឱ្យអ្នកបានដឹងពីរបៀបយ៉ាងណា ដែលគួរប្រព្រឹត្តក្នុង
ដំណាក់នៃព្រះ គឺក្នុងពួកជំនុំ[អ]នៃព្រះដ៏មានព្រះជន្មរស់[ក]
ដែលជាសសរ ហើយជាជើងថ្កល់របស់សេចក្ដីពិត 16ពិត
ប្រាកដជាសេចក្ដីអាថ៌កំបាំង[ខ]របស់សាសនានៃយើង[គ] នោះ
ជ្រាលជ្រៅណាស់ គឺដែលព្រះបានលេចមកក្នុងសាច់
ឈាម[ឃ] បានរាប់ជាសុចរិតដោយព្រះវិញ្ញាណ ពួកទេវតា
បានឃើញទ្រង់ មនុស្សបានប្រកាសប្រាប់ពីទ្រង់ដល់ពួក
សាសន៍ដទៃ[ង] មានគេជឿដល់ទ្រង់ក្នុងលោកីយនេះ រួចព្រះ
បានលើកទ្រង់ឡើងទៅក្នុងសិរីល្អវិញ[ច]។

## សេចក្ដីបង្រៀនដល់លោកធីម៉ូថេ

**៤** 1តែព្រះវិញ្ញាណ[ច] ទ្រង់មានបន្ទូលយ៉ាងជាក់ច្បាស់ថា
នៅគ្រាជាន់ក្រោយបង្អស់[ឆ] អ្នកខ្លះនឹងលាចាកចេញពីសេច
ក្ដីជំនឿ ដោយស្ដាប់តាមវិញ្ញាណបញ្ឆោត[ជ] និងសេចក្ដី
បង្រៀនរបស់ពួកអារក្ស 2ដោយសារពុតមាយារបស់
ពួកអ្នក ដែលពោលតែពាក្យកុហក ទាំងមានបញ្ញាចិត្ត
រលាក[ឈ] 3ព្រមទាំងហាមប្រាមមិនឱ្យយកប្ដីប្រពន្ធ[ញ] ហើយ
ឱ្យត្រូវតមអាហារ[ដ] ដែលព្រះបានបង្កើតមក[ឋ] សំរាប់ពួក
អ្នកជឿ នឹងពួកអ្នកដែលស្គាល់សេចក្ដីពិត ឱ្យបានទទួល
ដោយអរព្រះគុណ[ឌ] 4ដ្បិតសត្វទាំងអស់ដែលព្រះទ្រង់បង្កើត
មក នោះសុទ្ធតែល្អ[ឍ] ហើយមិនត្រូវចោល១ឡើយ[ណ] ឱ្យ
គ្រាន់តែទទួលដោយអរព្រះគុណប៉ុណ្ណោះ 5ដ្បិតបានញែក
ជាបរិសុទ្ធ ដោយសារព្រះបន្ទូល[ត] ហើយសេចក្ដីអធិស្ឋាន ។
6បើអ្នកសំដែងសេចក្ដីទាំងនេះ ដល់ពួកបងប្អូនឱ្យ
ស្គាល់ នោះអ្នកនឹងធ្វើជាជំនួយយ៉ាងល្អ របស់ព្រះយេស៊ូវ
គ្រីស្ទ ដែលព្រះបន្ទូលនៃសេចក្ដីជំនឿ[ថ] និងសេចក្ដីបង្រៀន
ដ៏ល្អបានចិញ្ចឹមអ្នក ដោយអ្នកបានកាន់តាមស្មោះចំពោះ
មែន[ទ] 7កុំឱ្យព្រមស្ដាប់អស់ទាំងរឿងល្បែងរបស់ស្រី
ចាស់ៗឡើយ[ធ]ចូរបង្ហាត់ខ្លួនខាងឯសេចក្ដីគោរពប្រតិបត្តិ
ដល់ព្រះវិញ[ន] 8ដ្បិតការបង្ហាត់ខ្លួនប្រាណ នោះមានប្រ
យោជន៍តែបន្តិចទេ តែសេចក្ដីគោរពប្រតិបត្តិដល់ព្រះ
នោះទើបមាន ប្រយោជន៍គ្រប់ជំពូកវិញ ក៏មានសេចក្ដី
សន្យាឱ្យបានជីវិត[ប]នៅជាន់ឥឡូវនេះ[ផ] ហើយទៅខាងនាយ
ផង[ព] 9ពាក្យនេះគួរជឿ[ភ] ហើយគួរទទួលគ្រប់យ៉ាង 10ដ្បិតគឺ
ដោយហេតុនោះបានជាយើងខ្ញុំខំធ្វើការ ទាំងត្រូវគេត្មះតិះ
ដៀល ពីព្រោះយើងខ្ញុំមានសេចក្ដីសង្ឃឹម ដល់ព្រះដ៏មាន
ព្រះជន្មរស់[ម] ដែលទ្រង់ជាព្រះអង្គសង្គ្រោះនៃមនុស្សទាំង

**៣:១៥** អ ខ.៥ ១កថ ១០:៣២
ក មថ ១៦:១៦
**៣:១៦** ខ រម១៦:២៥
គ ១ធថ ២:២
ឃ យហ ១:១៤
ង ទដ ៩:១១
កល ១:២៣
ច មក ១៦:១៩
**៤:១** ច យហ ១៦:១៣ កថ ៨:២៩ ១កថ ២:១០ ឆ ២ធថ ៣:១ ២ពត ៣:៣
ជ មក ១៣:៥
**៤:២** ឈ អភ ៤:១៩
**៤:៣** ញ ហព ១៣:៤
ដ កល ២:១៦
ឋ លប ១:២៩ ៩:៣
ឌ ខ.៤ ថ រម ១៤:៦ ១កថ ១០:៣០
**៤:៤** ឍ លប ១:១០, ១២,១៨,២១,២៥, ៣១ មក ៧:១៨,១៩ រម ១៤:១៤–១៨
ណ កថ ១០:១៥
**៤:៥** ត ហព ៤:១២
**៤:៦** ថ ១ធថ ១:១០ ទ ២ធថ ៣:១៥ **៤:៧** ធ ១ធថ ១:៤ ២ធថ ២:១៦ ន ១ធថ ២:២ **៤:៨** ប ១ធថ ៦:៦ ផ ទដ ៣៧:៩,១១ សភ ២២:៤ មថ ៦:៣៣ មក ១០:២៩,៣០ ព មក ១០:២៩,៣០ **៤:៩** ភ ១ធថ ១:១៥ **៤:១០** ម មថ ១៦:១៦

ផ្ដល់នូវការទូន្មានដែលទាក់ទងទៅនឹងការដឹកនាំពួកជំនុំ (ខ.១៥)។

**៣:១៥** *ដំណាក់នៃព្រះ* សំដៅលើគ្រួសារនៃព្រះអម្ចាស់ដែលបង្កើតឡើងដោយពួកអ្នកជឿដល់ទ្រង់ ។ *សសរ ហើយជាជើងថ្កល់របស់សេចក្ដីពិត* "មើលការពន្យល់ ២ធថ ២:១៩"។

**៣:១៦** *សេចក្ដីអាថ៌កំបាំង* "រម ១១:២៥ កល ១:២៦ និងការពន្យល់"។ ឃ្លានេះសំដៅលើការបើកសំដែងអំពីអាថ៌កំបាំងនៃសេចក្ដីពិត ដែលបង្កើតឱ្យមាននូវការចេះគោរពប្រតិបត្តិនៅក្នុងមនុស្សគ្រប់ៗរូប ។ សេចក្ដីអាថ៌កំបាំង ដូចដែលបានបញ្ជាក់នេះ គឺសំដៅលើព្រះយេស៊ូវគ្រីស្ទ ។ ការយាងមករបស់ព្រះអម្ចាស់ ជាពិសេសការសង្គ្រោះរបស់ទ្រង់ គឺជាប្រភពនៃការចេះគោរពប្រតិបត្តិ (២:២ កល ៣:១៦ ការពន្យល់)។ *បានរាប់ជាសុចរិតដោយព្រះវិញ្ញាណ* ព្រះវិញ្ញាណបរិសុទ្ធប្រទានឱ្យព្រះយេស៊ូវនូវអំណាចក្នុងការដេញវិញ្ញាណអាក្រក់ (មថ ១២:២៨) និងធ្វើការអស្ចារ្យជាច្រើន ។ ម្យ៉ាងទៀត ព្រះវិញ្ញាណបរិសុទ្ធបានប្រោសព្រះយេស៊ូវឱ្យរស់ពីសុគតឡើងវិញ (រម ១:៤ ១ពត ៣:១៨ និងពន្យល់) និងបង្ហាញថា ព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះ ។ *ពួកទេវតាបានឃើញទ្រង់* គឺនៅពេលដែលទ្រង់រស់ពីសុគតឡើងវិញ (មថ ២៨:២) និងពេលដែលទ្រង់យាងទៅស្ថានសួគ៌វិញ (កថ ១:១០ និងការពន្យល់)។

**៤:១,៦** *សេចក្ដីជំនឿ* "សូមមើល ៣:៩ និងការពន្យល់"។

**៤:១** *ព្រះវិញ្ញាណទ្រង់មានបន្ទូលយ៉ាងជាក់ច្បាស់* ត្រង់ចំណុចនេះប្រហែលជាលោកប៉ុលនិយាយសំដៅលើការបើកសំដែង ដែលគាត់ទទួលបានពីព្រះវិញ្ញាណ (មក ១៣:២២ កថ ២០:២៩-៣០ ២ថន ២:៣)។ *នៅជាន់ក្រោយបង្អស់* ឃ្លានេះសំដៅលើពេលវេលាដែលចាប់ផ្ដើមពីការយាងមកលើកទីមួយរបស់ព្រះយេស៊ូវ (យក ៥:៣ និងការពន្យល់)។ ម្យ៉ាងទៀត លោកប៉ុលមិននិយាយសំដៅលើពេលវេលាដែលព្រះយេស៊ូវជិតយាងមកជាលើកទីពីរតែប៉ុណ្ណោះទេ ព្រោះថា នៅសម័យដែលគាត់សរសេរសំបុត្រនេះ ការបង្រៀនខុសឆ្គងបានកើតមានរួចស្រេចទៅហើយ (ខ.៧)។

**៤:៣** បទគម្ពីរបញ្ជាក់យ៉ាងច្បាស់ថា ពួកគ្រូខុសឆ្គងតែងតែដើរបង្រៀននូវសេចក្ដីខុសឆ្គងជាច្រើន ដូចជាពួកគេបង្រៀនថា អ្វីៗទាំងអស់សុទ្ធតែអាក្រក់ (សូមមើលសេចក្ដីផ្ដើមកណ្ឌគម្ពីរ ១យហ)។

**៤:៤** *ព្រះទ្រង់បង្កើតមក នោះសុទ្ធតែល្អ* "មើល លប ១:៤,១០–៣១ ទត ១:១៥"។

**៤:៦** *សេចក្ដីបង្រៀនដ៏ល្អ . . . អ្នកបានកាន់តាមស្មោះចំពោះមែន* "សូមមើល ២ធថ ៣:១៥ និងការពន្យល់"។

**៤:៧** *រឿងល្បែង* "មើលការពន្យល់ ១:៤"។ *ចូរបង្ហាត់ខ្លួនខាងឯសេចក្ដីគោរពប្រតិបត្តិដល់ព្រះ* ចំណុចនេះបញ្ជាក់ថា ការគោរពប្រតិបត្តិ គឺទាមទារនូវការហ្វឹកហ្វាត់ផងដែរ (២:២ និងការពន្យល់)។

**៤:៩** *ពាក្យនេះគួរឱ្យជឿ* សំដៅលើសេចក្ដីដែលបានរៀបរាប់រួចមកហើយ និងនៅក្នុងបទគម្ពីរបន្ដបន្ទាប់ ។

**៤:១០** *សេចក្ដីសង្ឃឹម* "សូមមើល ១:១ និងការពន្យល់"។ *ព្រះអង្គសង្គ្រោះនៃមនុស្សទាំងឡាយ* ឃ្លានេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទគឺជា

ឡាយ[យ] មានមនុស្សដែលជឿជាដើម ១១ចូរផ្តាំគេពីសេចក្តី
ទាំងនេះហើយបង្ហាត់បង្រៀនចុះ[រ] ១២កុំឱ្យអ្នកណាមើល
ងាយអ្នក[ល] ដោយព្រោះនៅក្មេងនោះឡើយ ចូរធ្វើជាគំរូ[វ]
ដល់ពួកអ្នកជឿ ដោយពាក្យសំដី កិរិយាប្រព្រឹត្ត
សេចក្តីស្រឡាញ់ សេចក្តីជំនឿ[ស] នឹងសេចក្តីបរិសុទ្ធ
១៣ចូរឧស្សាហ៍មើលគម្ពីរ ហើយទូន្មាននឹងបង្រៀនគេដរាប
ដល់ខ្ញុំមក[ឡ] ១៤កុំឱ្យធ្វេសនឹងអំណោយទាន ដែលសណ្ឋិត
លើអ្នក ដែលបានប្រទានមកអ្នកដោយសេចក្តីទំនាយ[អ]
ក្នុងកាលដែលពួកចាស់ទុំ[ក]បានដាក់ដៃលើអ្នកឡើយ[ខ]
១៥ចូរឧស្សាហ៍ប្រព្រឹត្តតាមសេចក្តីទាំងនោះ ហើយកាន់
ខ្ជាប់ផង ដើម្បីឱ្យមនុស្សទាំងឡាយបានឃើញសេចក្តីជំនឿន
របស់អ្នក ១៦ចូរប្រុងប្រយ័ត្ននឹងខ្លួនអ្នក ហើយនឹងសេចក្តី
បង្រៀន ចូរកាន់ខ្ជាប់តាមសេចក្តីទាំងនេះ ដ្បិតដែលធ្វើ
ដូច្នោះ នោះអ្នកនឹងសង្គ្រោះ[គ]ខ្លួនអ្នកបាន ព្រមទាំងពួកអ្នក
ដែលស្តាប់អ្នកផង ។

## ការបង្រៀនអំពីស្ត្រីមេម៉ាយ ចាស់ទុំ និងអ្នកបម្រើ

**៥** ១កុំឱ្យស្តីបន្ទោស[ឃ] ដល់មនុស្សចាស់ៗ[ង] ឡើយ ចូរទូន្មាន
គាត់ទុកដូចជាឪពុកចុះ ហើយមនុស្សដែលក្មេងជាងអ្នក[ច]
នោះទុកដូចជាប្អូនវិញ ២ឯស្ត្រីចាស់ៗទុកដូចជាម្តាយ ហើយ
ពួកស្ត្រីដែលក្មេងជាងអ្នក ទុកដូចជាប្អូនដែរ ដោយសេចក្តី
បរិសុទ្ធសព្វគ្រប់ ៣ចូរគោរពដល់ពួកស្ត្រីដែលពិតជាមេ
ម៉ាយមែន[ឆ] ៤តែបើស្រីមេម៉ាយណាមានកូនចៅ នោះត្រូវ
ឱ្យកូនចៅនោះរៀនឱ្យចេះគោរពប្រតិបត្តិ ដល់ពួកផ្ទះ
ខ្លួនជាដើម ទាំងសងគុណឪពុកម្តាយ[ជ] ដ្បិតព្រះទ្រង់សព្វ
ព្រះហឫទ័យយ៉ាងដូច្នោះ[ឈ] ៥រីឯស្ត្រីណាដែលពិតជា
មេម៉ាយ[ញ]ហើយនៅតែឯង នោះសង្ឃឹមតែដល់ព្រះ[ដ] ក៏ព្យា
យាមក្នុងសេចក្តីទូលអង្វរ នឹងសេចក្តីអធិស្ឋាន[ឋ]ទាំងយប់
ទាំងថ្ងៃ ៦តែមេម៉ាយណាដែលនៅតែស្រើបស្រាល នោះ
ទោះបើរស់នៅក៏ដោយ ក៏ឈ្មោះថាស្លាប់ហើយ[ឌ] ៧ចូរ
ហាមគេពីសេចក្តីទាំងនេះ[ឍ] ដើម្បីកុំឱ្យគេមានកន្លែងបន្ទោស
បានឡើយ ៨បើមានអ្នកណា ដែលមិនផ្គត់ផ្គង់ឱ្យពួកញាតិ
សន្តានខ្លួន គឺឱ្យពួកអ្នកផ្ទះខ្លួនជាដើម អ្នកនោះឈ្មោះថា
បានបោះបង់ចោល[ណ]សេចក្តីជំនឿហើយ ក៏អាក្រក់ជាង
មនុស្សដែលមិនបានជឿទៅទៀត ៩ចូរឱ្យកត់ចុះក្នុងបញ្ជី
មេម៉ាយចំពោះតែឈ្មោះស្ត្រីណា ដែលមានអាយុពី៦០ ឆ្នាំ
ឡើងទៅលើប៉ុណ្ណោះ ហើយដែលបានមានប្តីតែមួយផង
១០ត្រូវមានគេធ្វើបន្ទាល់ពីការល្អរបស់ស្ត្រីនោះដែរ[ត] បើបាន

**៤:១០** យ លក ១:៤៧ ២:១១ **៤:១១** រ ១ធថ ៥:៧ ៦:២ **៤:១២** ល ២ធថ ១:៧ ទត ២:១៥ វ ភល ៣:១៧ ១ថន ១:៧ ២ថន ៣:៩ ទត ២:៧ ១ពត ៥:៣ ស ១ធថ ១:១៤ **៤:១៣** ហ លក ៤:១៦ កច ១៣:១៤–១៦ កល ៤:១៦ ១ថន ៥:២៧ ឡ ១ធថ ៣:១៤ **៤:១៤** អ ១ធថ ១:១៨ ក កច ១១:៣០ ខ កច ៦:៦ ២ធថ ១:៦ **៤:១៦** គ រម ១១:១៤ **៥:១** ឃ ទត ២:២ ង លវ ១៩:៣២ ច ទត ២:៦ **៥:៣** ឆ ខ.៥,១៦ **៥:៤** ជ ខ.៨ អភ ៦:១,២ ឈ រម ១២:២ អភ ៥:១០ ១ធថ ២:៣ **៥:៥** ញ ខ.៣,១៦ ដ ១កថ ៧:៣៤ ១ពត ៣:៥ ឋ លក ២:៣៧ រម ១:១០ **៥:៦** ឌ លក ១៥:២៤ **៥:៧** ឍ ១ធថ ៤:១១ ៦:២ **៥:៨** ណ ២ពត ២:១ យដ ៤

ព្រះអង្គសង្គ្រោះនៃមនុស្សនៅលើពិភពលោកនេះ ។ ដូច្នេះ អស់អ្នកណាដែលមកឯទ្រង់ និងទទួលជឿដល់ព្រះនាមទ្រង់ ពិតជាបានទទួលការសង្គ្រោះ ។

**៤:១២** *ដោយព្រោះនៅក្មេងនោះឡើយ* នៅពេលនោះលោកធីម៉ូថេប្រហែលជាមានអាយុ៣០ឆ្នាំ ឬក្មេងជាងនេះ ។ ម្យ៉ាងទៀត តួនាទីដ៏សំខាន់ដូច្នេះ មិនសូវមានឥទ្ធិពលសម្រាប់អស់អ្នកដែលមានវ័យក្មេងទេ ។ ដោយព្រោះតែមូលហេតុយ៉ាងដូច្នោះហើយ ទើបមានការចោទសួរអំពីភាពជាអ្នកដឹកនាំរបស់លោកធីម៉ូថេ (មើលការពន្យល់ ទត ២:៧–៨) ។

**៤:១៣** *ដរាបដល់ខ្ញុំមក* លោកប៉ុលបានចេញដំណើរបេសកកម្មរបស់គាត់ពីទីក្រុងអេភេសូរ ទៅឯស្រុកម៉ាសេដូន ប៉ុន្តែគាត់សង្ឃឹមថាបានជួបលោកធីម៉ូថេវិញយ៉ាងឆាប់នៅឯទីក្រុងអេភេសូរ (៣:១៤) ។

**៤:១៤** *សេចក្តីទំនាយ* "មើលការពន្យល់ ១:១៨"។ *ដាក់ដៃលើអ្នក* ការដែលពួកគេធ្វើយ៉ាងដូច្នោះ គឺជាសកម្មភាពបញ្ជូនអ្នកណាម្នាក់ឱ្យទៅធ្វើបេសកកម្ម (កច ៦:៦ ហព ៦:១–២ និងការពន្យល់) ។

**៤:១៦** *អ្នកនឹងសង្គ្រោះខ្លួនអ្នកបាន ព្រមទាំងពួកអ្នកដែលស្តាប់អ្នកផង* ចំណុចនេះបញ្ជាក់ថា មានតែព្រះយេស៊ូវទេដែលសង្គ្រោះមនុស្សលោក ហើយទ្រង់ក៏ប្រទានដំណឹងល្អអំពីសេចក្តីសង្គ្រោះនេះ តាមរយៈពួកអ្នកដែលជឿដល់ព្រះនាមទ្រង់ទៅអស់អ្នកផ្សេងៗទៀតដែរ ។

**៥:៣** *ចូរគោរពដល់ពួកស្ត្រីដែលពិតជាមេម៉ាយមែន* ឃ្លានេះអាចមានន័យថាឱ្យថែរក្សាពួកស្ត្រីមេម៉ាយចាស់ៗ ដែលគ្មានអ្នកណាមើលការខុសត្រូវរួមមានការផ្គត់ផ្គង់ផ្នែកសម្ភារៈផងដែរ ។ នៅសង្គមបុរាណ ពួកស្ត្រីមេម៉ាយមានការលំបាកខ្លាំងពីព្រោះមិនមានការជួយឧបត្ថមពីសំណាក់រដ្ឋាភិបាលខាងផ្នែកជីវភាពការធានានូវអាយុជីវិតនិងតម្រូវការផ្សេងៗជាច្រើនទៀត។

**៥:៤** *រៀនឱ្យចេះគោរពប្រតិបត្តិ* "មើលពន្យល់ យក ១:២២-២៧ ២:១៤-២៦"។

**៥:៥** គំរូសម្រាប់ស្ត្រីមេម៉ាយ សូមមើល "លក ២:៣៦–៣៨"។

**៥:៦** *ទោះបើនៅរស់ក៏ដោយ ក៏ឈ្មោះថាស្លាប់ហើយ* មានន័យថាស្លាប់ខាងឯវិញ្ញាណក្នុងពេលដែលរូបកាយនៅមានជីវិតនៅឡើយ ។

**៥:៨** *សេចក្តីជំនឿ* "មើលការពន្យល់ ៣:៩"។ សេចក្តីបង្រៀនរបស់ពួកសាវ័កច្រើនសង្កត់ធ្ងន់ទៅលើភាពទទួលខុសត្រូវផ្នែកសង្គម ។ *ក៏អាក្រក់ជាងមនុស្សដែលមិនបានជឿទៅទៀត* ជាទូទៅនៅក្នុងសង្គមរបស់ពួកសាសន៍ដទៃនាសម័យនោះ ពួកគេតែងតែថែរក្សាសមាជិកក្រុមគ្រួសាររបស់ខ្លួន ។ ដូច្នោះហើយ បើអ្នកណាមិនថែរក្សារក្រុមគ្រួសាខ្លួននោះគេយល់ថា អាក្រក់ជាងសាសន៍ដទៃទៅទៀត ។

**៥:៩** ពួកជំនុំនៅទីក្រុងអេភេសូរហាក់ដូចជាមានតារាងបញ្ជីរៀបរាប់ពីពួកស្ត្រីមេម៉ាយដែលបានទទួលការឧបត្ថម្ភពីព្រះវិហារ ។ ម្យ៉ាងទៀត ដោយព្រោះពួកស្ត្រីមេម៉ាយទាំងនោះមិនមានភាពរទូរទាំនឹងពួកអ្នកដឹកនាំ ដូច្នេះបញ្ជាក់ថា ពួកគេមានការប្រព្រឹត្តល្អ និងប្រហែលជាទទួលនូវភារកិច្ចក្នុងការអធិស្ឋាន (ខ.៥,១០) ។

**៥:១០** *លាងជើងពួកបរិសុទ្ធ* នេះជាការងាររបស់បាវបម្រើ ប៉ុន្តែវាមានសារសំខាន់នៅក្នុងសម័យកាលសញ្ញាថ្មី ព្រោះថាតាមផ្លូវមានធូលីច្រើន

ចិញ្ចឹមកូន ទទួលអ្នកដទៃឱ្យ ស្នាក់[ថ] លាងជើង[ទ]ពួកបរិសុទ្ធ
ជួយដោះទុក្ខ ដល់ពួកអ្នកដែល មានសេចក្ដីវេទនា[ធ]
បើបានឧស្សាហ៍តាមគ្រប់ទាំងការល្អ នោះទើបចុះបាន
១១ឯស្រីមេម៉ាយដែលក្មេងជាង នោះមិនត្រូវទទួលទេ ដ្បិត
បើកាលណាគេកើតមានចិត្តរឹងទទឹងនឹងព្រះគ្រីស្ទ នោះ
គេនឹងចង់យកប្ដីទៀត ១២គេនឹងមានទោស ដោយព្រោះ
បានបោះបង់ចោលសេចក្ដីជំនឿដើម ១៣ក៏នឹងទំលាប់
នៅដៃទំនេរ ទាំងដើរពីផ្ទះមួយទៅផ្ទះមួយមិនត្រឹមតែនៅដៃ
តែប៉ុណ្ណោះ[ន] គឺមានទាំងមាត់ប៉ប៉ាច់ប៉ប៉ោច ហើយបេះបួយ[ប]
ក៏និយាយសេចក្ដីដែលមិនគួរគប្បីថែមទៀតផង ១៤ដូច្នេះ
ខ្ញុំចង់ឱ្យស្រីមេម៉ាយដែលនៅក្មេងបានយកប្ដីទៅ[ផ] ដើម្បី
នឹងបង្កើតកូន ហើយគ្រប់គ្រងនៅទីផ្ទះ ឥតបើកឱកាសឱ្យ
ពួកអ្នកដែលរករឿងបានត្មះតិះដៀលឡើយ[ព] ១៥ដ្បិតមាន
អ្នកខ្លះ ងាកបែរទៅតាមអារក្សសាតាំងហើយ[ភ] ១៦បើមាន
អ្នកជឿណា ទោះប្រុសឬស្រីដែលមានម្ដាយមេម៉ាយ នោះ
ត្រូវជួយផ្គត់ផ្គង់ឱ្យផង កុំឱ្យផ្ទុកលើពួកជំនុំឡើយ ដើម្បីឱ្យ
ពួកជំនុំបានផ្គត់ផ្គង់ដល់ពួកអ្នកដែលពិតជា មេម៉ាយនោះ
វិញ[ម]។

១៧អ្នកចាស់ទុំណា[យ] ដែលជាអ្នកនាំមុខយ៉ាងល្អ នោះ
ត្រូវរាប់ជាគួរនឹងគោរពប្រតិបត្តិជាទ្វេគុណឡើង[រ] គឺមាន
ពួកដែលខំផ្សាយព្រះបន្ទូល ហើយនិងពួកដែលបង្រៀន
ជាដើម ១៨ដ្បិតគម្ពីរចែងទុកមកថា «មិនត្រូវឃ្លុំមាត់គោ
ដែលបញ្ជាន់ស្រូវឡើយ»[ល] ហើយថា «ជើងឈ្នួល គួរឱ្យបាន
ប្រាក់ឈ្នួលខ្លួន»[វ] ១៩កុំឱ្យស្ដាប់សេចក្ដីចោទប្រកាន់ទាស់នឹង
អ្នកចាស់ទុំណាឡើយ[ស] លើកតែមានស្មរបន្ទាល់២ ឬ៣នាក់[ហ]
២០ឯអ្នកណាដែលធ្វើបាប នោះចូរផ្ចាញ់ផ្ចាល[ឡ]គេ នៅមុខ
មនុស្សទាំងអស់ ដើម្បីឱ្យអ្នកឯទៀតបានកោតខ្លាចដែរ[អ]
២១ខ្ញុំផ្ដាំនឹងអ្នកអស់ពីចិត្ត នៅចំពោះព្រះ នឹងព្រះគ្រីស្ទ
យេស៊ូវ[ក] ហើយពួកទេវតារើសតាំងផងថា ឱ្យអ្នកកាន់តាម
សេចក្ដីទាំងនេះ ដោយឥតរើសមុខអ្នកណា ឬល្អៀងទៅ
ខាងណាឡើយ ២២កុំឱ្យប្រញាប់ដាក់ដៃ[ខ]លើអ្នកណា ក៏កុំ
ឱ្យមានសេចក្ដីប្រកបក្នុងបាបរបស់មនុស្សឯទៀតឱ្យសោះ[គ]
ចូររក្សាខ្លួនឱ្យ បរិសុទ្ធចុះ[ឃ] ២៣កុំឱ្យផឹកទឹកតែប៉ុណ្ណោះត្រូវ
ឱ្យផឹកស្រាទំពាំងបាយជូរបន្តិចផង[ង] ដោយព្រោះក្រពះអ្នក
និងរោគដែលអ្នក មានជាញយៗ ២៤អំពើបាបរបស់មនុស្ស
ខ្លះបានឃើញច្បាស់ ក៏នាំមុខគេទៅ ឱ្យត្រូវជំនុំជំរះឯបាប

**៥:១០** ត កច ៩:៣៦ ១ធថ ៦:១៨ ១ពត ២:១២ ថ រម ១២:១៣ ទ លក ៧:៤៤ ធ ខ.១៦ **៥:១៣** ន រម ១:២៩ ប ២ធថ ៣:១១ **៥:១៤** ផ ១កថ ៧:៩ ព ១ធថ ៦:១ **៥:១៥** ភ មថ ៤:១០ **៥:១៦** ម ខ.៣–៥ **៥:១៧** យ កច ១១:៣០ រ ភល ២:២៩ ១ថន ៥:១២ **៥:១៨** ល ចទ ២៥:៤ ១កថ ៩:៧–៩ វ លក ១០:៧ លវ ១៩:១៣ ចទ ២៤:១៤,១៥ មថ ១០:១០ ១កថ ៩:១៤ **៥:១៩** ស កច ១១:៣០ ហ មថ ១៨:១៦ **៥:២០** ឡ ២ធថ ៤:២ ទត ១:១៣ ២:១៥ អ ចទ ១៣:១១ **៥:២១** ក ១ធថ ៦:១៣ ២ធថ ៤:១ **៥:២២** ខ កច ៦:៦ គ អភ ៥:១១ ឃ ទដ ១៨:២៦ **៥:២៣** ង ១ធថ ៣:៨

ហើយពួកគេប្រើស្បែកជើងផ្ទាត់ (យហ ១៣:១៤)។ *ពួកបរិសុទ្ធ* "មើល រម ១:៧ អភ ១:១"។

**៥:១២** *បោះបង់ចោលសេចក្ដីជំនឿដើម* ប្រហែលនៅពេលនោះមានពួកស្ត្រីមេម៉ាយខ្លះដែលមានឈ្មោះនៅក្នុងតារាងឈ្មោះស្ត្រីមេម៉ាយ និងទទួលការផ្គត់ផ្គង់ពីព្រះវិហារ ពួកគេបានសន្យាប្រកាន់ខ្ជាប់ខ្ជួនក្នុងការបម្រើ និងក្នុងការអធិស្ឋាន ប៉ុន្តែក្រោយមកក៏ភ្លេចសេចក្ដីសន្យារបស់ខ្លួន បន្ទាប់ពីបានរៀបការម្ដងទៀត ។ ម្យ៉ាងទៀត លោកប៉ុលប្រហែលជាសំដៅលើគោលជំនឿជាមូលដ្ឋានរបស់គ្រីស្ទបរិស័ទ ដែលថាស្ត្រីមេម៉ាយអាចមានការធ្វេសប្រហែសនៅក្នុងសេចក្ដីជំនឿ ដោយសារតែការជ្រើសរើសគូស្រករៀបការម្ដងទៀតមិនបានត្រឹមត្រូវ ។

**៥:១៣** *បេះបួយ* "មើលការពន្យល់ ២ថន ៣:១១"។

**៥:១៥** *អារក្សសាតាំង* "សូមមើល យប ១:៦ មថ ១៦:២៣ ១ថន ៣:៥ ១យហ ៣:៨ វវ ១២:៩–១០ និងការពន្យល់"។

**៥:១៧** ពួកចាស់ទុំទាំងអស់ត្រូវតែហ្វឹកហ្វាត់នូវភាពជាអ្នកដឹកនាំ (៣:៤-៥) ការបង្រៀន និងការអធិប្បាយ (៣:២) ហើយទាំងអស់គ្នាបានទទួលការសរសើរ ។ ប៉ុន្តែ អស់អ្នកដែលអនុវត្តនូវភាពជាអ្នកដឹកនាំរបស់ខ្លួនបានប្រសើរជាងគេ នោះត្រូវទទួលការសរសើរទ្វេរដង ។ ហើយនេះជាការពិតជាពិសេសគឺចំពោះពួកអ្នកដែលបង្រៀន និងអធិប្បាយ (ខ.១៨)។

**៥:១៨** *គម្ពីរ* សំដៅលើគម្ពីរសញ្ញាចាស់ (ចទ ២៥:៤) និងគម្ពីរសញ្ញាថ្មី (លក ១០:៧ ២ពត ៣:១៦ និងការពន្យល់)។ *មិនត្រូវឃ្លុំមាត់គោដែលបញ្ជាន់ស្រូវឡើយ* "សូមមើល ១កថ ៩:៩–១០ និងការពន្យល់"។

**៥:១៩** *ស្មរបន្ទាល់២ ឬ៣នាក់* "សូមមើល ចទ ១៧:៦ និងការពន្យល់"។

**៥:២០** *អ្នកណាដែលធ្វើបាប* ឃ្លានេះបញ្ជាក់ថា លោកប៉ុលនិយាយសំដៅទៅលើការហ្វឹកហ្វឺនដល់ពួកចាស់ទុំ ។

**៥:២១** *ពួកទេវតារើសតាំង* សំដៅលើពួកទេវតារបស់ព្រះអម្ចាស់មិនមែនជាអារក្សសាតាំង និងពួកវិញ្ញាណអាក្រក់ទេ ។ *ដោយឥតរើសមុខអ្នកណា ឬល្អៀងទៅខាងណាឡើយ* "សូមមើល នក ២៣:៣ លវ ១៩:១៥ ចទ ១:១៧ ១៦:១៩ យប ១៣:១០ សភ ១៨:៥ ២៤:២៣ ២៨:២១ មឡ ២:១,៩ ៣:៧ និងការពន្យល់ កច ១០:៣៤"។

**៥:២២** *កុំឱ្យប្រញាប់ដាក់ដៃលើអ្នកណា* លោកប៉ុលនិយាយអំពីការតែងតាំងពួកចាស់ទុំ (៤:១៤ និងការពន្យល់) គឺធ្វើឡើងបាន ដរាបណាមានបញ្ជាក់នូវភស្តុតាងអំពីពួកគេសិន ។ *កុំឱ្យមានសេចក្ដីប្រកបក្នុងបាបរបស់មនុស្សឯទៀតឱ្យសោះ* បញ្ជាក់ថាមិនត្រូវតែងតាំងអ្នកមិនស្មោះត្រង់ទៅក្នុងការងាររបស់ពួកចាស់ទុំឡើយ ។ *ចូររក្សាខ្លួនឱ្យបរិសុទ្ធ* អាចសំដៅលើការបដិសេធមិនព្រមចូលរួមតែងតាំងពួកចាស់ទុំដែលមិនស្មោះត្រង់ ។

**៥:២៣** *កុំឱ្យផឹកតែទឹកប៉ុណ្ណោះ* ត្រង់ចំណុចនេះ ប្រហែលជាលោកធីម៉ូថេមានសុខភាពមិនសូវល្អ ហើយរូបកាយរបស់គាត់អាចមានជំងឺផ្សេងៗ ។ ម្យ៉ាងទៀត នៅសម័យកាលសញ្ញាថ្មី គេយល់ថា ការពិសារស្រាទំពាំងបាយជូរបន្តិចបន្តួចអាចមានប្រយោជន៍ជួយដល់ក្រពះ ។

**៥:២៤-២៥** លោកប៉ុលបានទូន្មានដល់ពួកជំនុំ កុំឱ្យធ្វេសប្រហែសចំពោះ

របស់អ្នកខ្លះទៀត បានមកតាមក្រោយ ២៥ឯការល្អវិញ
ក៏ឃើញច្បាស់ដូច្នោះដែរ បើមានការល្អណាដែលមិន
ច្បាស់ នោះនៅតែលាក់មិនកំបាំងដែរ ។
**៦** ១រីឯអស់អ្នកទាំងប៉ុន្មាន ដែលនៅក្រោមនឹមជាបាវបំរើ
គេ នោះត្រូវរាប់ចៅហ្វាយខ្លួន ទុកជាគួរនឹងគោរព
ប្រតិបត្តិគ្រប់យ៉ាងចុះ[ច] ដើម្បីកុំឱ្យគេប្រមាថដល់ព្រះនាមព្រះ
និងសេចក្ដីបង្រៀននេះឡើយ[ឆ] ២ហើយអ្នកណាដែលមាន
ចៅហ្វាយជាអ្នកជឿ នោះមិនត្រូវមានចិត្តមើលងាយដល់
ចៅហ្វាយនោះ ដោយព្រោះជាបងប្អូនគ្នាទេ[ជ] តែស៊ូបំរើ
វិញ ដោយព្រោះចៅហ្វាយនោះជាអ្នកជឿ ហើយជាស្ងួនភ្ងា
ដែរ ជាអ្នកដែលចំរើនឡើង ដោយការបំរើយ៉ាងល្អនោះ
ឯង ចូរឱ្យអ្នកបង្រៀនសេចក្ដីទាំងនេះ ហើយទូន្មានគេ
ចុះ[ឈ] ។

## ការស្រឡាញ់ប្រាក់

៣បើអ្នកណាបង្រៀនពីសេចក្ដីអ្វីផ្សេងទៀត[ញ] ហើយមិន
យល់ព្រមតាមពាក្យសំដីដែលត្រឹមត្រូវ[ដ]គឺជាព្រះបន្ទូលរបស់
ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង នឹងជាសេចក្ដី
បង្រៀនដែលត្រឹមត្រូវ តាមសេចក្ដីគោរពប្រតិបត្តិដល់
ព្រះទេ ៤អ្នកនោះឈ្មោះថាមានចិត្តធំ[ឋ] ហើយមិនដឹងអ្វី
សោះ គឺវក់តែនឹងជជែក ហើយដេញដោលពីន័យពាក្យ[ឌ]
ដែលនាំឱ្យកើតសេចក្ដីឈ្នានីស ឈ្លោះប្រកែក ជេរប្រមាថ
នឹងសេចក្ដីសង្ស័យដ៏អាក្រក់ប៉ុណ្ណោះ ៥ជាសេចក្ដីជំលោះឥត
ប្រយោជន៍របស់មនុស្សខូចគំនិត ហើយឥតស្គាល់សេចក្ដី
ពិត[ឍ] ដោយស្មានថា ការគោរពប្រតិបត្តិដល់ព្រះជាផ្លូវឱ្យ
បានកំរៃ ៦តែការគោរពប្រតិបត្តិដល់ព្រះ ដែលមានទាំង
ចិត្តស្កប់ស្កល់ផង[ណ] នោះជាកំរៃ១យ៉ាងធំមែន[ត] ៧ដ្បិតយើង
រាល់គ្នាមិនបានយកអ្វី ចូលមកក្នុងលោកិយនេះទេ ហើយ
ច្បាស់ជាយើងពុំអាចនឹងយកអ្វីចេញទៅវិញបានដែរ[ថ]
៨តែបើមានអាហារទទួលទាន នឹងសំលៀកបំពាក់ នោះក៏
ល្មមឱ្យយើងបានស្កប់ចិត្តហើយ[ទ] ៩ឯពួកអ្នកដែលចង់ធ្វើជា
អ្នកស្តុកស្តម្ភ[ធ] នោះនិងធ្លាក់ទៅក្នុងសេចក្ដីល្បួង នឹងអន្ទាក់
ហើយក្នុងបំណងជាច្រើន ដែលផ្ដេសផ្ដាស ហើយធ្វើទុក្ខ
ដល់ខ្លួន ក៏ពន្លិចមនុស្សទៅក្នុងសេចក្ដីហិនវិនាស នឹងសេចក្ដី
អន្តរធានវិញ[ន] ១០ដ្បិតការដែលស្រឡាញ់ប្រាក់[ប]នោះហើយ
ជាមេឬសនៃសេចក្ដីអាក្រក់គ្រប់យ៉ាង ដែលអ្នកខ្លះបាន
ឈោងតាម ហើយត្រូវល្បួងលោមឱ្យឃ្លាតចេញពីសេចក្ដី
ជំនឿ[ផ] ទាំងចាក់ទំលុះខ្លួនគេ ដោយសេចក្ដីព្រួយលំបាកជា
ច្រើន[ព] ។

## បណ្ដាំរបស់លោកប៉ុលដល់លោកធីម៉ូថេ

១១តែ ឱអ្នកសំណប់នៃព្រះអើយ[ភ] ចូរឱ្យអ្នករត់ចៀស
ចេញពីសេចក្ដីទាំងនោះ ហើយដេញតាមសេចក្ដីសុចរិត
សេចក្ដីគោរពប្រតិបត្តិដល់ព្រះ[ម] សេចក្ដីជំនឿ សេចក្ដី
ស្រឡាញ់[យ] សេចក្ដីខ្ជាប់ខ្ជួន នឹងសេចក្ដីសំឡូតវិញ ១២ចូរ
ខំប្រឹងតស៊ូ ដោយការតយ៉ាងល្អ[រ]នៃសេចក្ដីជំនឿ ចូរតោង
ចាប់[ល]ជីវិតអស់កល្បជានិច្ចឱ្យខ្ជាប់[វ] ដែលព្រះបានហៅ
អ្នកមកទទួល ហើយអ្នកក៏បានធ្វើបន្ទាល់យ៉ាងល្អ[ស] នៅ
មុខសាក្សីជាច្រើនដែរ ១៣ខ្ញុំផ្ដាំមកអ្នក[ហ]នៅចំពោះព្រះ
ដែលទ្រង់ប្រទានជីវិតដល់គ្រប់ទាំងអស់ ហើយនៅចំពោះ
ព្រះគ្រីស្ទយេស៊ូវ ដែលទ្រង់បានធ្វើបន្ទាល់យ៉ាងល្អ[ឡ] នៅ
មុខលោកប៉ុនទាស-ពីឡាត់ថា[អ] ១៤ឱ្យអ្នកកាន់តាមបញ្ញត្តិ
បែបដែលឥតសៅហ្មង ហើយឥតកន្លែងបន្ទោសបាន[ក]

**៦:១** ច អភ ៦:៥
ឆ ១ធថ ៥:១៤
ទត ២:៥,៨
**៦:២** ជ ភម ១៦
ឈ ១ធថ ៤:១១
**៦:៣** ញ ១ធថ ១:៣
ដ ១ធថ ១:១០
**៦:៤** ឋ ១ធថ ៣:៦
២ធថ ៣:៤
ឌ ២ធថ ២:១៤
**៦:៥** ឍ ២ធថ ៣:៨
ទត ១:១៥
**៦:៦** ណ ភល ៤:១១
ហព ១៣:៥
ត ១ធថ ៤:៨
**៦:៧** ថ យប ១:២១
ទដ ៤៩:១៧ សស
៥:១៥
**៦:៨** ទ សភ ៣០:៨
ហព ១៣:៥
**៦:៩** ធ សភ ១៥:២៧
២៨:២០
ន ១ធថ ៣:៧
**៦:១០** ប ១ធថ ៣:៣
ផ ខ.២១ យក ៥:១៩
ព យស ៧:២១
**៦:១១** ភ ២ធថ
៣:១៧ ម ខ.៣,៥,៦
១ធថ ២:២
យ ១ធថ ១:១៤
២ធថ ២:២៣ ៣:១០
**៦:១២** រ ១កថ
៩:២៥,២៦
១ធថ ១:១៨
ល ខ.១៩ ភល ៣:១២
វ មថ ២៥:៤៦
ស ហព ៣:១ **៦:១៣** ហ ១ធថ ៥:២១ ២ធថ ៤:១ ឡ ខ.១២
អ យហ ១៨:៣៣-៣៧ **៦:១៤** ក ១ថន ៣:១៣

អំពើបាបដែលលាក់កំបាំង និងគ្រប់ទាំងការល្អនៅក្នុងជីវិតរបស់បុគ្គលដែល
ត្រូវតែងតាំងឡើងធ្វើជាអ្នកដឹកនាំ ។

**៦:១** *បាវបំរើ* "សូមមើល អភ ៦:៥ កល ៣:២២-៤:១ ភម ១៦"។

**៦:២** *ទូន្មានគេចុះ* សំដៅលើសេចក្ដីទូន្មានដល់ពួកបាវបម្រើ ។

**៥:៣-៥** លោកប៉ុលបែរទៅនិយាយអំពីប្រធានបទនៅក្នុងបទគម្ពីរ "១:៣" វិញ (មើលការពន្យល់ ១:៣-១១)។

**៦:៥** *ឥតស្គាល់សេចក្ដីពិត* មានន័យថា ពួកគេបានស្គាល់សេចក្ដីពិតហើយ ប៉ុន្តែ បានបែរទៅរកសេចក្ដីកំហុសជាច្រើនវិញ ។ *ដោយស្មានថា ការគោរពប្រតិបត្តិដល់ព្រះជាផ្លូវឱ្យបានកំរៃ* "សូមមើល ២កថ ១១:៧ និងការពន្យល់"។

**៦:៨** "សូមមើល ភល ៤:១១-១២ និងការពន្យល់"។

**៦:៩** "សូមមើល លក ១២:១៣-២១ និងការពន្យល់"។

**៦:១០,១២,២១** *សេចក្ដីជំនឿ* "មើលការពន្យល់ ៣:៩"។

**៦:១២** *ដោយការតយ៉ាងល្អ* "មើលការពន្យល់ ១:១៨"។ *ចូរតោងចាប់ជីវិតអស់កល្បជានិច្ចឱ្យខ្ជាប់* លោកធីម៉ូថេបានទទួលនូវជីវិតអស់កល្បតាំងពីគាត់បានទទួលការសង្គ្រោះ ប៉ុន្តែ លោកប៉ុលបានទូន្មានឱ្យគាត់ (ធីម៉ូថេ) ប្រកាសអំពីជីវិតអស់កល្បនេះយ៉ាងពេញបរិបូរវិញ (ខ.១៧-១៩ ៤:១៦ និងការពន្យល់)។ *ហើយអ្នកក៏បានធ្វើបន្ទាល់យ៉ាងល្អ* អាចសំដៅលើការធ្វើបន្ទាល់របស់លោកធីម៉ូថេអំពីសេចក្ដីជំនឿ នៅថ្ងៃដែលគាត់ទទួលបុណ្យជ្រមុជទឹកក្នុងដំណើរបេសកកម្មលើកទីមួយរបស់លោកប៉ុល ។

**៦:១៣** *ដែលទ្រង់បានធ្វើបន្ទាល់យ៉ាងល្អ នៅមុខលោកប៉ុនទាស-ពីឡាត់* សំដៅលើព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ ដែលបានកត់ត្រាទុកនៅក្នុងបទគម្ពីរ "យហ ១៨:៣៤-៣៧ ១៩:១១"។

**៦:១៤** *បញ្ញត្តិ* ប្រហែលជាសំដៅលើបន្ទុកទាំងមូល ដែលលោកធីម៉ូថេបាន

ដរាបដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង ទ្រង់
លេចមក[ខ] ១៥ដែលព្រះនឹងសំដែងឱ្យឃើញទ្រង់ ក្នុងវេលា
កំណត់[គ] គឺជាស្ដេចចក្រតែ១[ឃ] ព្រះអង្គដ៏មានពរ[ង]ជាស្ដេច
លើអស់ទាំងស្ដេច ហើយជាព្រះអម្ចាស់ លើអស់ទាំង
ព្រះអម្ចាស់[ច] ១៦ក៏មានតែទ្រង់ប៉ុណ្ណោះដែលមិនចេះសុគត[ឆ]
ទ្រង់គង់នៅក្នុងពន្លឺ ដែលរកចូលទៅជិតមិនបាន[ជ] គ្មាន
មនុស្សណាដែលឃើញទ្រង់ឡើយ ក៏មើលទ្រង់មិនឃើញ
ផង[ឈ] សូមឱ្យទ្រង់បានល្បីព្រះនាម និងព្រះចេស្ដា នៅអស់
កល្បជានិច្ចអាម៉ែន[ញ]។

១៧ចូរហាមប្រាម ដល់ពួកអ្នកមាន[ដ] នៅលោកីយនេះ
ផង កុំឱ្យគេមានឫកខ្ពស់ ឬទុកចិត្តនឹងទ្រព្យសម្បត្តិ[ឋ] ដែល
មិនទៀងនោះឡើយ ត្រូវទុកចិត្តនឹងព្រះ[ឌ]ដ៏មានព្រះជន្មរស់
វិញ ដែលទ្រង់ប្រទានគ្រប់ទាំងអស់មកយើងរាល់គ្នាជា
បរិបូរ ឱ្យយើងបានអរសប្បាយ[ឍ] ១៨ចូរបង្គាប់ឱ្យគេធ្វើ
គុណ នឹងការល្អជាបរិបូរ[ណ] ព្រមទាំងចែកទានដោយសទ្ធា
ហើយប្រុងប្រៀបនឹងជួយគេផង[ត] ១៩យ៉ាងនោះឯង ទើប
ឈ្មោះថា គេនឹងប្រមូលទ្រព្យសម្បត្តិទុកជាគោលយ៉ាងល្អ
សំរាប់ខ្លួន[ថ]ដល់ថ្ងៃក្រោយវិញ ដើម្បីឱ្យគេចាប់បាន[ទ]ជីវិត
អស់កល្បជានិច្ច ។

២០ឱធីម៉ូថេអើយ ចូររក្សាសេចក្ដីដែលបានផ្ញើទុកនឹង
អ្នកចុះ[ធ] ហើយចៀសចេញពីសំដីឡេះឡោះឥតប្រយោជន៍[ន]
និងពាក្យទទឹងទទែងនៃសេចក្ដី ដែលក្លែងហៅថា ចំណេះ
វិជ្ជាផង ២១ដែលមានមនុស្សខ្លះប្រកាន់ ក៏បានជ្រួសពី
សេចក្ដីជំនឿចេញហើយ[ប] ។ សូមឱ្យអ្នកបានប្រកបដោយ
ព្រះគុណ[ផ] ។ អាម៉ែន ។

**៦:១៤** ខ ១កថ ១:៧ ២ថន ១:១០ ៤:១,៨
**៦:១៥** គ ១ធថ ២:៦ ទត ១:៣ ឃ ១ធថ ១:១៧ ង ១ធថ ១:១១ ច ចទ ១០:១៧ ទដ ១៣៦:៣ ដយ ២:៤៧ វវ ១:៥ ១៧:១៤ ១៩:១៦
**៦:១៦** ឆ ១ធថ ១:១៧ ជ ទដ ១០៤:២ ១យហ ១:៧ ឈ យហ ១:១៨ ញ រម ១១:៣៦
**៦:១៧** ដ ខ.៩ ឋ ទដ ៦២:១០ យរ ៤៩:៤ លក ១២:២០,២១ ឌ ១ធថ ៤:១០ ឍ កថ ១៤:១៧ **៦:១៨** ណ ១ធថ ៥:១០ ត រម ១២:៨,១៣ អភ ៤:២៨
**៦:១៩** ថ មថ ៦:២០ ទ ខ.១២ ភល ៣:១២ **៦:២០** ធ ២ធថ ១:១២ ន ២ធថ ២:១៦ **៦:២១** ប ខ.១០ ២ធថ ២:១៨ ផ កល ៤:១៨

ទទួលពីការអធិប្បាយព្រះបន្ទូលនិងការថែរក្សារពួកជំនុំ (ខ.២០)។ ទោះជាយ៉ាងណា ក៏សេចក្ដីនៅក្នុងបទគម្ពីរខាងលើ អាចបញ្ជាក់ថា លោកប៉ុលប្រើនូវសេចក្ដីបញ្ញត្តិមួយ ដោយសង្ខេបនូវសេចក្ដីទាំងឡាយដែលមាននៅក្នុង "ខ.១១–១២"។

**៦:១៥** *ក្នុងវេលាកំណត់* ពេលវេលាស្ដីអំពីការយាងមកជាលើកទីមួយរបស់ព្រះយេស៊ូវគ្រីស្ទគឺត្រូវបានកំណត់រួចជាស្រេច ហើយការយាងមកជាលើកទីពីររបស់ទ្រង់ ក៏ជាការកំណត់របស់ទ្រង់ដែរ ។ *ជាស្ដេចលើអស់ទាំងស្ដេច ហើយជា ព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់* "មើលពន្យល់ វវ ១៧:១៤ ១៩:១៦"។

**៦:១៦** *គ្មានមនុស្សណាដែលឃើញទ្រង់ឡើយ* "មើលពន្យល់ យហ ១:១៨"។

**៦:១៧–១៩** "សូមមើលការពន្យល់ ខ.១២"។

**៦:១៩** *គេនឹងប្រមូលទ្រព្យសម្បត្តិទុកជាគោលយ៉ាងល្អសំរាប់ខ្លួន* "សូមមើល មថ ៦:១៩–២១ ១៩:២១ លក ១២:៣៣ និងការពន្យល់"។

**៦:២០** *ចូររក្សាសេចក្ដីដែលបានផ្ញើទុកនឹងអ្នកចុះ* គឺសំដៅលើព្រះបន្ទូលនៃដំណឹងល្អ (២ធថ ១:១៤)។ *សេចក្ដីដែលក្លែងហៅថា ចំណេះវិជ្ជាផង* សំដៅលើសេចក្ដីបង្រៀនខុសឆ្គងទាំងឡាយរបស់ពួកប្រឆាំង នាសម័យកាលនោះ ដែលពួកគ្រូទាំងនោះបានបង្រៀនថា ពួកគេអាចបានសង្គ្រោះដោយសារចំណេះវិជ្ជារបស់ខ្លួន (សូមមើលសេចក្ដីផ្ដើម ១យហ)។

**៦:២១** *អ្នក* ពាក្យនេះ នៅក្នុងព្រះគម្ពីរបរិសុទ្ធជាភាសាក្រិកសរសេរជាទម្រង់ពហុវចនៈ ដូច្នេះបញ្ជាក់ថា សំបុត្រដែលលោកប៉ុលសរសេរផ្ញើទៅលោកធីម៉ូថេ គឺត្រូវឱ្យអាននៅមុខពួកជំនុំនៅទីក្រុងអេភេសូរទាំងមូលតែម្ដង (២ធថ ៤:២២)។ *ព្រះគុណ* "មើលការពន្យល់ រម ១:៧ ២កថ ១៣:១៤"។

សំបុត្រទី២របស់លោកប៉ុល

ដល់

# ធីម៉ូថេ

សេចក្តីផ្តើម

**អ្នកនិពន្ធ កាលបរិច្ឆេទ និងទីកន្លែងនៃការសរសេរ**

ក្រោយពីលោកប៉ុលបានត្រូវដោះលែងពីមន្ទីរឃុំឃាំងនៅក្រុងរ៉ូមក្នុងឆ្នាំ ៦២គ.ស (កច ២៨) និងបន្ទាប់ពីបញ្ចប់ដំណើរបេសកកម្មលើកទី៤របស់គាត់ នោះហើយជាអំឡុងពេលដែលគាត់សរសេរបទគម្ពីរធីម៉ូថេទី១ និងបទគម្ពីរទីតុស ។ លោកប៉ុលត្រូវបានគេចាប់ឃុំឃាំងម្តងទៀតនៅក្នុងសម័យស្តេចអធិរាជនេរ៉ូក្នុងឆ្នាំ៦៦-៦៧គ.ស ពេលនោះហើយដែលគាត់បានសរសេរបទគម្ពីរធីម៉ូថេទី២ ។ កាលដែលគាត់ជាប់ឃុំឃាំងលើកដំបូង គឺគាត់គ្រាន់តែរស់នៅក្នុងផ្ទះជួលមួយប៉ុណ្ណោះ (កច ២៨:៣០ និងមើលការពន្យល់) ។ ឥឡូវនេះគាត់កាន់តែល្វើយទៅៗ ដោយនៅក្នុងគុកត្រជាក់ (៤:១៣ និងមើលការពន្យល់) ព្រមទាំងគេដាក់ច្រវាក់គាត់ដូចជាជនឧក្រិដ្ឋ (១:១៦ ២:៩) ហើយសូម្បីតែមិត្តភ័ក្តិរបស់គាត់ក៏ពិបាកនឹងរកគាត់ឱ្យឃើញថា នៅទីណានោះពិតប្រាកដនោះដែរ (១:១៧) ។ លោកប៉ុលបានដឹងយ៉ាងច្បាស់ថាការងាររបស់គាត់បានសម្រេច ហើយជីវិតរបស់គាត់ក៏ជិតបានចូលមកដល់ទីបញ្ចប់ហើយដែរ (៤:៦-៨) ។

**ហេតុផលនៃការសរសេរ**

លោកប៉ុលមានហេតុផលបីយ៉ាងដែលបណ្តាលឱ្យគាត់សរសេរទៅកាន់លោកធីម៉ូថេនៅពេលនោះគឺ

១. បង្ហាញពីសេចក្តីស្រលាញ់របស់គាត់ចំពោះលោកភីកេលុស និងហើម៉ូនគេន"មនុស្សគ្រប់រូបនៅស្រុកអាស៊ី" (១:១៥) និងអ្នកដេម៉ាស (៤:១០) ដែលលះចោលគាត់ ។ អ្នកក្រេសេន អ្នកទីតុស និងអ្នកទីឃីកុសមិនបាននៅទីនោះទេ (៤:១០-១២) មានតែលោកលូកាតែម្នាក់ទេដែលនៅជាមួយគាត់ (៤:១១) ។ លោកប៉ុលចង់ឱ្យលោកធីម៉ូថេទៅជាមួយនឹងគាត់ខ្លាំងណាស់ ដោយព្រោះលោកធីម៉ូថេគឺជា "មិត្តរួមការងាររបស់គាត់" (រម ១៦:២១) ដែលប្រៀបដូចជា"ឪពុកចង់ឱ្យកូននៅជាមួយ" (ភម ២:២២ ការពន្យល់) បានបម្រើយ៉ាងជិតស្និទ្ធជាមួយនឹងលោកប៉ុល (១កថ ៤:១៧) ។ ចំពោះលោកប៉ុលគាត់អាចនិយាយទៅលោកធីម៉ូថេបានថា: "ខ្ញុំគ្មាននរណាទៀតក្រៅពីអ្នកឡើយ" (ភល ២:២០) ។ លោកប៉ុលបានរង់ចាំលោកធីម៉ូថេយ៉ាងយូរ (១:៤) ហើយបានសុំឱ្យលោកធីម៉ូថេមកឯគាត់ជាប្រញាប់រហូតដល់ទៅពីរដង (៤:៩,២១) ។ ចំពោះព័ត៌មានបន្ថែមអំពីលោក ធីម៉ូថេ សូមមើលសេចក្តីផ្តើមធីម៉ូថេទី១ ។

២. បង្ហាញពីការខ្វាយខ្វល់របស់គាត់ចំពោះសុខុមាលភាពរបស់ពួកជំនុំនៅក្នុងពេលមានការបៀតបៀនរបស់អធិរាជនេរ៉ូ (Nero) ហើយនិងដាស់តឿនលោកធីម៉ូថេឱ្យរក្សាបញ្ញើឱ្យបានល្អ (ដំណឹងល្អ"១:១៤") ឱ្យធីម៉ូថេនៅជាប់ក្នុងសេចក្តីដែលបានរៀន (៣:១៤) ហើយនៅតែផ្សាយព្រះបន្ទូល (៤:២) ទោះជាត្រូវរងទុក្ខលំបាកយ៉ាងណាក៏ដោយ (១:៨ ២:៣) ។

៣. បង្ហាញពីបំណងចិត្តដែលគាត់ចង់សរសេរសំបុត្រទៅកាន់ពួកជំនុំនៅក្រុងអេភេសូរ តាមរយៈសំបុត្ររបស់គាត់មកកាន់ធីម៉ូថេនេះ (៤:២២) ។

គម្រោងសង្ខេប

**I. សេចក្តីផ្តើម (១:១-៤)**

**II. ការខ្វាយខ្វល់របស់លោកប៉ុលចំពោះលោកធីម៉ូថេ (១:៥-១៤)**

**III. អំពីស្ថានភាពរបស់លោកប៉ុល (១:១៥-១៨)**

**IV. សេចក្តីបង្រៀនយ៉ាងពិសេសដល់លោកធីម៉ូថេ (ជំពូក ២)**

ក. ការដាស់តឿនឱ្យចេះអត់ធ្មត់ (២:១-១៣)

ខ. ការព្រមានអំពីពាក្យជជែកឥតប្រយោជន៍ (២:១៤-២៦)

**V. ការព្រមានអំពីថ្ងៃចុងក្រោយ (ជំពូក ៣)**

ក. ពេលលំបាកវេទនា (៣:១-៩) ខ. ការតយុទ្ធនឹងសេចក្តីបៀតបៀន (៣:១០-១៧)

**VI. បណ្តាំចុងក្រោយរបស់លោកប៉ុល (៤:១-៨)**

ក. ការលើកទឹកចិត្តឱ្យបន្តផ្សាយព្រះបន្ទូល (៤:១-៥) ខ. សេចក្តីសង្ឃឹមរបស់លោកប៉ុល (៤:៦-៨)

**VII. សំណូមពរចុងក្រោយរបស់លោកប៉ុល (៤:៩-២២)**

**១** ១ សំបុត្រប៉ុលខ្ញុំ ជាសាវក[ក]នៃព្រះយេស៊ូវគ្រីស្ទ ដោយ
ព្រះហឫទ័យនៃព្រះ[ខ] តាមសេចក្ដីសន្យាឱ្យបានជីវិត ដែល
នៅក្នុងព្រះគ្រីស្ទយេស៊ូវ[គ] ២ ខ្ញុំផ្ញើមកធីម៉ូថេ[ឃ] ជាកូនស្ងួនភ្ងា[ង]
សូមឱ្យអ្នកបានប្រកបដោយព្រះគុណ សេចក្ដីមេត្តាករុណា
និងសេចក្ដីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតា ហើយអំពី
ព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា[ច]។

### ការលើកទឹកចិត្តឱ្យមានភាពស្មោះត្រង់

៣ ខ្ញុំអរព្រះគុណដល់ព្រះ[ឆ] ដែលខ្ញុំបំរើដោយបញ្ញាចិត្ត
ដ៏បរិសុទ្ធ[ជ] ដូចជាពួកឰយុកោខ្ញុំដែរ ដោយព្រោះខ្ញុំនឹកចាំពី
អ្នកជានិច្ច ក្នុងកាលដែលខ្ញុំទូលអង្វរ ទាំងយប់ទាំងថ្ងៃ[ឈ] ៤ គឺ
នឹកចាំពីទឹកភ្នែករបស់អ្នក[ញ] បានជាខ្ញុំរឭកចង់ឃើញអ្នក[ដ]
ដើម្បីឱ្យខ្ញុំបានពេញជាសេចក្ដីអំណរឡើង ៥ ដ្បិតខ្ញុំនឹកចាំពី
សេចក្ដីជំនឿស្មោះត្រង់[ឋ] ដែលនៅក្នុងអ្នក សេចក្ដីជំនឿ
នោះបាននៅក្នុងយាយឡូអ៊ីស ជាជីដូនរបស់អ្នកជាមុនដំបូង
រួចក៏នៅក្នុងអ្នកអ៊ើនីស[ឌ] ជាម្ដាយអ្នកដែរ ហើយខ្ញុំជឿជាក់
ថា ក៏នៅក្នុងអ្នកផង ៦ ដោយហេតុនោះបានជាខ្ញុំរំឭកដល់
អ្នក ឱ្យដាស់តឿនអំណោយទានរបស់ព្រះ ដែលនៅក្នុងអ្នក
ដោយខ្ញុំដាក់ដៃលើ[ឍ] ៧ ដ្បិតព្រះទ្រង់មិនបានប្រទានឱ្យយើង
មានវិញ្ញាណ ដែលតែងតែខ្លាចឡើយ[ណ] គឺឱ្យមានវិញ្ញាណ
ដ៏មានអំណាច[ត] សេចក្ដីស្រឡាញ់ និងប្រាជ្ញានឹងធឹងវិញ ។
៨ ដូច្នេះ មិនត្រូវឱ្យអ្នកមានសេចក្ដីខ្មាស[ថ]ចំពោះការធ្វើ
បន្ទាល់ពីព្រះអម្ចាស់នៃយើង ឬដោយព្រោះខ្ញុំជាសិស្ស
របស់ទ្រង់ដែលជាប់គុកនោះឡើយ[ទ] ចូរទ្រាំទុក្ខលំបាកជា
មួយនឹងខ្ញុំ ក្នុងដំណឹងល្អ[ធ] តាមព្រះចេស្ដានៃព្រះចុះ ៩ ដែល
ទ្រង់បានជួយសង្គ្រោះយើង[ន] ហើយបានហៅ[ប]យើងមកក្នុង
ការងារបរិសុទ្ធ មិនមែនដោយការដែលយើងធ្វើទេ[ផ] គឺ
ដោយដំរិះ នឹងព្រះគុណនៃទ្រង់វិញ ដែលបានផ្ដល់មកយើង
ក្នុងព្រះគ្រីស្ទយេស៊ូវ មុនអស់ទាំងកល្ប ១០ តែឥឡូវនេះ ទើប
នឹងសំដែងមក[ព] ដោយដំណើរព្រះយេស៊ូវគ្រីស្ទ[ភ] ជាព្រះអង្គ
សង្គ្រោះនៃយើង ទ្រង់លេចមកដែលទ្រង់បានបំផ្លាញសេច
ក្ដីស្លាប់[ម] ហើយបានយកជីវិត និងសេចក្ដីមិនចេះស្លាប់មក
ដាក់នៅពន្លឺ ដោយសារដំណឹងល្អវិញ ១១ ហើយទ្រង់បាន

**១:១** ក ១កថ ១:១ ខ ២កថ ១:១ គ អភ ៣:៦ ទត ១:២ ១ធថ ៦:១៩
**១:២** ឃ កច ១៦:១ ង ១ធថ ១:២ ច រម ១:៧
**១:៣** ឆ រម ១:៨ ជ កច ២៣:១ ឈ រម ១:១០
**១:៤** ញ កច ២០:៣៧ ដ ២ធថ ៤:៩
**១:៥** ឋ ១ធថ ១:៥ ឌ កច ១៦:១ ២ធថ ៣:១៥
**១:៦** ឍ កច ៦:៦ ១ធថ ៤:១៤
**១:៧** ណ យរ ៤២:១១ រម ៨:១៥ ១កថ ១៦:១០,១១ ១ធថ ៤:១២ ហព ២:១៥ ត អស ១១:២
**១:៨** ថ ខ.១២,១៦ មក ៨:៣៨ ទ អភ ៣:១ ធ ២ធថ ២:៣,៩ ៤:៥
**១:៩** ន រម ១១:១៤ ប រម ៨:២៨ ផ អភ ២:៩
**១:១០** ព អភ ១:៩ ភ ១ធថ ៦:១៤ ម ១កថ ១៥:២៦,៥៤

**១:១** *ប៉ុល* មើលការពន្យល់ រម ១:១ ។ *សាវក* មើលពន្យល់ ១កថ ១:១ ។ *តាមសេចក្ដីសន្យាឱ្យបានជីវិត* ព្រះអម្ចាស់ទ្រង់បានជ្រើសរើសលោកប៉ុលឱ្យមកធ្វើជាសាវក ។ ការតែងតាំងលោកប៉ុលឱ្យធ្វើជាសាវកនេះ គឺដើម្បីនឹងប្រកាសដំណឹងល្អអំពីជីវិតអស់កល្បដល់មនុស្សគ្រប់រូប (ដែលគ្រប់គ្នាអាចនឹងទទួលបាន ) តាមរយៈការទទួលជឿលើព្រះគ្រីស្ទ ។

**១:២** *ធីម៉ូថេជាកូនស្ងួនភ្ងា* មើលការពន្យល់ ១ធថ ១:២ ។ *ព្រះគុណ . . . និងសេចក្ដីសុខសាន្ត* មើលការពន្យល់ រម ១:៧ ។ *សេចក្ដីមេត្តាករុណា* មើល ១ធថ ១:២ និងការពន្យល់ ។

**១:៣** *អរព្រះគុណដល់ព្រះ . . .ខ្ញុំទូលអង្វរ* មើលការពន្យល់ ភម ១:៣–៤ ។

**១:៤** *គឺនឹកចាំពីទឹកភ្នែករបស់អ្នក* ត្រង់នេះប្រហែលជាមានជាប់ទាក់ទងទៅនឹងទឹកភ្នែករបស់លោកធីម៉ូថេ នៅពេលដែលលោកប៉ុលបានចាកចេញពីស្រុកម៉ាសេដូន (១ធថ ១:៣ និងការពន្យល់)។ *បានជាខ្ញុំរឭកចង់ឃើញអ្នក* មើល ៤:៩,២១ ។

**១:៥** *យាយឡូអ៊ីស ជាជីដូន . . . អ្នកអ៊ើនីសជាម្ដាយអ្នក* ដោយយោងតាមបទគម្ពីរ "កច ១៦:១" បានឱ្យដឹងថា ម្ដាយរបស់លោកធីម៉ូថេគឺជាគ្រីស្ទបរិស័ទសាសន៍យូដាម្នាក់ ។ ហើយនៅក្នុងខនេះបានធ្វើឱ្យយើងដឹងថា ជីដូនរបស់គាត់ក៏ជាគ្រីស្ទបរិស័ទម្នាក់ដែរ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ក៏ឪពុករបស់គាត់គឺជាជនជាតិក្រេកម្នាក់ដែល ប្រហែលជាពុំមែនគ្រីស្ទបរិស័ទនោះទេ (កច ១៦:១)។

**១:៦** *ឱ្យដាស់តឿនអំណោយទានរបស់ព្រះ* អំណោយទានដែលបានប្រទានមកនេះពុំមែនដូចជាផ្ការីកអស់ក្រពុំនោះទេ គឺត្រូវការអភិវឌ្ឍន៍តាមរយៈការប្រើប្រាស់អំណោយទានទាំងនោះជាប្រចាំ ។ *ដែលនៅក្នុងអ្នកដោយខ្ញុំដាក់ដៃលើ* មើល ១ធថ ៤:១៤ និងការពន្យល់ ។ លោកប៉ុលគឺឧបករណ៍របស់ព្រះតាមរយៈអំណោយមកពីព្រះវិញ្ញាណបរិសុទ្ធដល់លោកធីម៉ូថេ (មើលការពន្យល់ ១ធថ ១:១៨)។

**១:៧** *វិញ្ញាណដែលតែងតែខ្លាចឡើយ* ឃ្លានេះធ្វើឱ្យយើងដឹងថា ភាពខ្វះខាតនៃទំនុកទុកចិត្តគឺជាបញ្ហាមួយដ៏ធ្ងន់ធ្ងរសម្រាប់លោកធីម៉ូថេ (មើល ១កថ ១៦:១០–១១ និង មើលការពន្យល់ ១៦:១០ ១ធថ ៤:១២)។

**១:៨** *មិនត្រូវឱ្យអ្នកមានសេចក្ដីខ្មាស* មើលខ.១២ រម ១:១៦ និងការពន្យល់ ។

**១:៩** *ហៅយើងមកក្នុងការងារបរិសុទ្ធ* មើលពន្យល់ អភ ១:៤ ១ថន ៤:៧ ។ *មិនមែនដោយការដែលយើងធ្វើទេ គឺដោយដំរិះ និងព្រះគុណនៃទ្រង់វិញ* សេចក្ដីសង្គ្រោះគឺបានមកដោយសារព្រះគុណតែមួយប៉ុណ្ណោះ គឺមិនអាស្រ័យលើការខំប្រឹងប្រែងរបស់មនុស្សនោះទេ ប៉ុន្តែ សេចក្ដីសង្គ្រោះនេះគឺជាផែនការសង្គ្រោះរបស់ព្រះ ហើយក៏ជាអំណោយទានព្រះគុណនៃព្រះរាជបុត្រា (រម ៣:២៨ អភ ២:៨–៩ ទត ៣:៥ និងការពន្យល់)។ *មុនអស់ទាំងកល្ប* នេះគឺជាផែនការសង្គ្រោះរបស់ព្រះអម្ចាស់សម្រាប់មនុស្សមានបាប គឺបានរៀបចំទុកតាំងពីអស់កល្បរៀងមក (អស ១:៤ ១ពត ១:២០ និងការពន្យល់ វវ ១៣:៨)។

**១:១០** *ព្រះយេស៊ូវគ្រីស្ទ. . .បានបំផ្លាញសេចក្ដីស្លាប់* មើល ១កថ ១៥:២៦, ៥៤–៥៧។ *បានយកជីវិត និងសេចក្ដីមិនចេះស្លាប់ មកដាក់នៅពន្លឺ* នេះគឺជាការថ្លែងបញ្ជាក់មុនដំណើរដែលព្រះយេស៊ូវយាងមក និងក្រោយពីទ្រង់សុគតនោះបានគ្របបាំងអស់ទាំងភាពខ្មៅងងឹត (ទដ ១១:៧ សស ៣:២១ អស ២៦:១៩ ដយ ១២:២ និងការពន្យល់)។ *ដំណឹងល្អ* មើលពន្យល់ មក ១:១ ។

**១:១១** *អ្នកប្រកាសប្រាប់ដំណឹងល្អនោះ និងជាសាវក* មើល ១ធថ ២:៧ ។

តាំងខ្ញុំ[យ] ឱ្យធ្វើជាអ្នកប្រកាសប្រាប់ដំណឹងល្អនោះ[រ] នឹងជា
សាវក ហើយជាគ្រូបង្រៀនដល់សាសន៍ដទៃ[ល] ១២គឺដោយ
ហេតុនោះ បានជាខ្ញុំរងទុក្ខទាំងនេះ តែខ្ញុំមិនខ្មាសទេ[វ] ដ្បិត
ខ្ញុំស្គាល់ព្រះដែលខ្ញុំបានជឿតាម ហើយខ្ញុំជឿពិតថា ទ្រង់
អាចនឹងថែរក្សាបញ្ញើ[ស] ដែលខ្ញុំបានផ្ញើទុកនឹងទ្រង់ ដរាប
ដល់ថ្ងៃនោះឯង[ហ] ។
១៣ចូរនឹកចាំពីអស់ទាំងពាក្យត្រឹមត្រូវ ដែលអ្នកបានឮពី
ខ្ញុំ[ឡ] ទុក[អ]ជាគំរូ[ក,ខ]ពីសេចក្តីជំនឿ នឹងសេចក្តីស្រឡាញ់ ដែល
នៅក្នុងព្រះគ្រីស្ទយេស៊ូវ[គ] ១៤ចូររក្សា[ឃ]បញ្ញើល្អដែលផ្ញើទុក
នឹងអ្នក ដោយសារព្រះវិញ្ញាណបរិសុទ្ធ ដែលសណ្ឋិតនៅ
ក្នុងយើង[ង] ។
១៥អ្នកដឹងដំណឹងថា ពួកអ្នកដែលនៅស្រុកអាស៊ីទាំង
ប៉ុន្មាន[ច] បានបោះបង់ចោលខ្ញុំហើយ[ឆ]ក្នុងពួកគេ មានឈ្មោះ
ភីកេលុស នឹងហើម៉ូគេន ។
១៦សូមឱ្យព្រះអម្ចាស់ផ្តល់សេចក្តីមេត្តាករុណា ដល់ពួក
ផ្ទះអូនេសិភ័រ[ជ] ដ្បិតគាត់បានលំហើយចិត្តខ្ញុំជាញឹកញយ ក៏
មិនបានខ្មាសគេ[ឈ]ដោយព្រោះចំណងរបស់ខ្ញុំដែរ[ញ] ១៧កាល
គាត់នៅក្រុងរ៉ូម នោះគាត់ខ្នះខ្នែងរកខ្ញុំ ទាល់តែឃើញផង
១៨សូមឱ្យព្រះអម្ចាស់ផ្តល់ឱ្យគាត់បានសេចក្តីមេត្តាករុណា
ពីព្រះអម្ចាស់នៅថ្ងៃនោះ[ដ] ហើយដែលគាត់បានជួយខ្ញុំ[ឋ]
នៅក្រុងអេភេសូរយ៉ាងណា នោះអ្នកក៏ដឹងលើសជាងគេ
ហើយ[ឌ] ។
**២** ១ដូច្នេះ កូនអើយ[ឍ] ចូរមានកំឡាំងឡើង[ណ] ដោយសារ
ព្រះគុណដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ ២ឯអស់ទាំងសេចក្តី
ដែលអ្នកបានឮអំពីខ្ញុំ[ត]នៅមុខស្មរបន្ទាល់ជាច្រើន[ថ] នោះក៏
ត្រូវផ្ញើទុកនឹងមនុស្សស្មោះត្រង់ ដែលអាចនឹងបង្វឹកបង្រៀន
តទៅអ្នកឯទៀតដែរ ៣ដូច្នេះ ចូរឱ្យអ្នកទ្រាំទ្រទុក្ខលំបាក[ទ]
ដូចជាទាហានយ៉ាងល្អ[ធ]របស់ព្រះយេស៊ូវគ្រីស្ទចុះ ៤ធម្មតា
អ្នកដែលធ្វើទាហាន នោះមិនដែលជាប់ទាក់ទិន នឹងការក្នុង
ជីវិតនេះទៀតទេ គឺដើម្បីឱ្យបានគាប់ចិត្តដល់អ្នក ដែល
កេណ្ឌខ្លួនទៅនោះវិញ ៥ហើយបើអ្នកណាប្រយុទ្ធគ្នាក្នុង
ព្រ៉ាត្រ នោះមិនបានពាក់ភួងជ័យទេ[ន] លើកតែប្រយុទ្ធតាម
ច្បាប់វិញ ៦ឯអ្នកធ្វើស្រែ ក៏ត្រូវនឿយហត់ជាមុនដែរ ទើប
នឹងទទួលផលបាន[ប] ៧ចូរពិចារណាសេចក្តីដែលខ្ញុំប្រាប់
ទាំងនេះចុះ ដ្បិតព្រះអម្ចាស់ទ្រង់នឹងប្រទានឱ្យអ្នកមាន
យោបល់ ក្នុងគ្រប់ការទាំងអស់ ។
៨ចូរនឹកចាំថា ព្រះយេស៊ូវគ្រីស្ទ ជាព្រះវង្សហ្លួងដាវីឌ[ផ]
ទ្រង់បានរស់ពីស្លាប់ឡើងវិញ[ព] តាមដំណឹងល្អដែលខ្ញុំផ្សាយ

**១:១១** យ កច ៩:១៥ រ ខ.៨ ល ១ធច ២:៧
**១:១២** វ ខ.៨,១៦ មក ៨:៣៨ ស ខ.១៤ ១ធច ៦:២០ ហ ខ.១៨ ១កច ១:៨ ២ធច ៤:៨
**១:១៣** ឡ ២ធច ២:២ អ ទត ១:៩ ក រម ៦:១៧ ខ ១ធច ១:១០ គ ១ធច ១:៣ ១ធច ១:១៤
**១:១៤** ឃ ខ.១២ ង រម ៨:៩
**១:១៥** ច កច ២:៩ ឆ ២ធច ៤:១០,១១,១៦
**១:១៦** ជ ២ធច ៤:១៩ ឈ ខ.៨,១២ មក ៨:៣៨ ញ កច ២១:៣៣
**១:១៨** ដ ខ.១២ ឋ ហព ៦:១០ ឌ កច ១៨:១៩
**២:១** ឍ ១ធច ១:២ ណ អភ ៦:១០
**២:២** ត ២ធច ១:១៣ ថ ១ធច ៦:១២ **២:៣** ទ ខ.៩ ២ធច ១:៨ ៤:៥ ធ ១ធច ១:១៨
**២:៥** ន ១កច ៩:២៥ **២:៦** ប ១កច ៩:១០ **២:៨** ផ មច ១:១ ព កច ២:២៤

**១:១២** *ខ្ញុំមិនខ្មាសទេ* មើលពន្យល់ខ.៨ ។ *ខ្ញុំស្គាល់ព្រះដែលខ្ញុំបានជឿតាម* ត្រង់នេះប្រហែលជាការប្តេជ្ញាចិត្តចំពោះព្រះគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់ (មើលខ.១៤ និងការពន្យល់ ១ធច ៦:២០) ។ *ដល់ថ្ងៃនោះឯង* នោះគឺជាថ្ងៃជំនុំជម្រះ ។

**១:១៣** *ពាក្យត្រឹមត្រូវដែលអ្នកបានឮពីខ្ញុំ* មើល ទត ១:៩ និងការពន្យល់ ។ *សេចក្តីជំនឿ និងសេចក្តីស្រឡាញ់* មើល ១ធច ១:១៤ ។ នេះគឺជាសេចក្តីជំនឿ និងសេចក្តីស្រឡាញ់ដែលមានរួមគ្នានៅក្នុងព្រះគ្រីស្ទ ឬអាចនិយាយម្យ៉ាងទៀតថាជាសេចក្តីជំនឿ និងសេចក្តីស្រឡាញ់របស់គ្រីស្ទបរិស័ទ ។

**១:១៤** *ចូររក្សាបញ្ញើល្អដែលផ្ញើទុកនឹងអ្នក* ឃ្លានេះគឺសំដៅលើដំណឹងល្អ (ខ.១២) លោកប៉ុលបានផ្តល់ដំបូន្មានយ៉ាងដូច្នេះក្នុងបទគម្ពីរ ១ធច ៦:២០ ។ *ព្រះវិញ្ញាណបរិសុទ្ធ ដែលសណ្ឋិតនៅក្នុងយើង* មើល រម ៥:៥ ១កច ៦:១៩ និងការពន្យល់ រម ៨:៩ ។

**១:១៥** *ក្នុងពួកគេ* ពាក្យនេះប្រហែលសំដៅទៅលើពួកអ្នកដែលមានគម្រោងនិយាយបំផ្លើសដល់សាធារណៈជន ពីដំណើរការដែលគេរត់ចោលលោកប៉ុល ។ *ស្រុកអាស៊ី* នៅពេលនេះគឺលោកធីម៉ូថេកំពុងស្ថិតនៅក្រុងអេភេសូរនៅឡើយ ។ ក្រុងអេភេសូរជារាជធានីនៃស្រុកអាស៊ី (មើលការពន្យល់សេចក្តីផ្តើមគម្ពីរអេភេសូរ) ។

**១:១៦** *ដល់ពួកផ្ទះអូនេសិភ័រ* ត្រង់ចំណុចនេះអាចបញ្ជាក់បានថា ក្រុមគ្រួសាររបស់លោកធីម៉ូថេក៏រស់នៅក្រុងអេភេសូរនោះដែរ (ខ.១៨ ៤:១៩) ។

**១:១៧** *ក្រុងរ៉ូម* មើលសេចក្តីផ្តើមត្រង់អ្នកនិពន្ធ កាលបរិច្ឆេទ និងមើលខ.៨ ២:៩ ។

**១:១៨** *នៅថ្ងៃនោះ* គឺនៅថ្ងៃជំនុំជម្រះ (ខ.១២) ។ *គាត់បានជួយខ្ញុំ* គឺនៅក្នុងអំឡុងពេលធ្វើដំណើរបេសកកម្មលើកទីបី ឬលើកទីបួនរបស់លោកប៉ុល ។

**២:១** *កូនអើយ* មើលការពន្យល់ ១ធច ១:២ ។ *ចូរមានកំឡាំងឡើងដោយសារព្រះគុណ . . . ក្នុងព្រះគ្រីស្ទ* នេះគឺជាសមត្ថភាពនៃអំណាចព្រះចេស្តាដែលបានមកពីការប្រកបជិតស្និទ្ធជាមួយនឹងព្រះគ្រីស្ទ (២កច ១២:៩–១០ អស ៦:១០ និងការពន្យល់) ។

**២:២** *នៅមុខស្មរបន្ទាល់ជាច្រើន* គឺសំដៅទៅលើការអធិប្បាយ និងការបង្រៀនរបស់លោកប៉ុល ដែលលោកធីម៉ូថេបានឮ ហើយត្រាប់តាម ។

**២:៣–៦** ខទាំងនេះគឺជាគំរូទាំងបីចំណុចរបស់លោកប៉ុលបានផ្តល់ឱ្យលោកធីម៉ូថេ (១).ជាទាហានម្នាក់ដែលចង់ផ្គាប់ចិត្តដល់អ្នកដែលកេណ្ឌខ្លួនមក ។ (២).ជាកីឡាករម្នាក់ដែលប្រកួតត្រឹមត្រូវតាមច្បាប់ ។ (៣).ជាកសិករដែលធ្វើយ៉ាងនឿយហត់ ។

**២:៥** *ភួងជ័យ* មើលការពន្យល់ ១កច ៩:២៥ ។

**២:៦** *ត្រូវនឿយហត់ជាមុនដែរ ទើបនឹងទទួលផលបាន* នេះគឺជាការបញ្ជាក់ពីការពន្យល់ខាងលើទាំងពីរ (ទាហាន ខ.៣–៤ កីឡាករ ខ.៥) បន្ថែមទៀត ។ មេរៀនសំខាន់នៅត្រង់នេះគឺបង្ហាញពីការខំប្រឹងប្រែង ដើម្បីឱ្យបានរង្វាន់ (១ធច ៥:១៧ និងការពន្យល់) ។

**២:៨** *ព្រះយេស៊ូវគ្រីស្ទជាព្រះវង្សហ្លួងដាវីឌ ទ្រង់បានរស់ពីស្លាប់ឡើងវិញ* ការរស់ឡើងវិញរបស់ព្រះគ្រីស្ទបានប្រកាស ពីភាពជាព្រះអម្ចាស់របស់ទ្រង់

ប្រាប់[ភ] ៩ហើយខ្ញុំរងទុក្ខ[ម] ទាំងជាប់ចំណងដូចជាមនុស្ស
អាក្រក់[យ] ដោយព្រោះដំណឹងល្អនោះឯង ប៉ុន្តែ ព្រះបន្ទូល[រ]
មិនបានជាប់ចំណងទេ ១០ហេតុនោះបានជាខ្ញុំទ្រាំទ្រនឹង
គ្រប់ការទាំងអស់[ល] ដើម្បីជាប្រយោជន៍ដល់ពួករើសតាំង[វ]
ឱ្យគេបានសេចក្ដីសង្គ្រោះ[ស] ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ
ព្រមទាំងមានសិរីល្អដ៏នៅអស់កល្បជានិច្ចផង[ហ] ១១ពាក្យ
នេះគួរជឿពិត[ឡ] ដ្បិតបើយើងបានស្លាប់ជាមួយ នឹងទ្រង់
នោះយើងនឹងរស់ជាមួយនឹងទ្រង់ដែរ[អ] ១២បើយើងទ្រាំ
ទ្រ នោះយើងនឹងសោយរាជ្យជាមួយនឹង ទ្រង់[ក] តែបើយើង
មិនព្រមទទួលស្គាល់ទ្រង់ទេ នោះទ្រង់ក៏ មិនព្រមទទួល
ស្គាល់យើងដែរ[ខ] ១៣បើទុកជាយើងមិនស្មោះត្រង់ក៏
ដោយគង់តែទ្រង់នៅស្មោះត្រង់ដដែល[គ] ទ្រង់ធ្វើជាមិន
ស្គាល់ព្រះអង្គទ្រង់មិនបាន ទេ ។

## អ្នកធ្វើការដែលមកពីព្រះ

១៤ចូររំឭកគេពីសេចក្ដីទាំងនេះ ហើយហាមប្រាមគេ
ដោយដាច់ខាត នៅចំពោះព្រះអម្ចាស់ថា កុំឱ្យជជែកគ្នាពី
ន័យពាក្យ[ឃ] ដែលជាការឥតប្រយោជន៍ ហើយក៏នាំពួកអ្នក

**២:៨** ភ រម ២:១៦ ១៦:២៥
**២:៩** ម កច ៩:១៦ យ កច ២១:៣៣ រ ហព ៤:១២
**២:១០** ល កល ១:២៤ វ ទត ១:១ ស ២កថ ១:៦ ហ ២កថ ៤:១៧ ១ពត ៥:១០
**២:១១** ឡ ១ធថ ១:១៥ អ រម ៦:២–១១
**២:១២** ក រម ៨:១៧ ១ពត ៤:១៣ ខ មថ ១០:៣៣
**២:១៣** គ រម ៣:៣ ១កថ ១:៩
**២:១៤** ឃ ខ.២៣ ១ធថ ១:៤ ៦:៤ ទត ៣:៩
**២:១៥** ង អភ ១:១៣ កល ១:៥

ដែលស្ដាប់ឱ្យវង្វេងផងនោះឡើយ ១៥ចូរខំប្រឹងនឹងថ្វាយខ្លួន
ដល់ព្រះ ទុកជាមនុស្សដែលបានល្បងលជាប់ហើយ ជាអ្នក
ធ្វើការ ដែលមិនត្រូវខ្មាសឡើយ ដោយកាត់ស្រាយព្រះ
បន្ទូលនៃសេចក្ដីពិតយ៉ាងត្រឹមត្រូវ[ង] ១៦តែត្រូវចៀសចេញពី
ពាក្យសំដីឡេះឡោះឥតប្រយោជន៍[ច] ដ្បិតពាក្យយ៉ាងនោះ
នឹងនាំឱ្យចំរើនសេចក្ដីទមិលល្មើស កាន់តែច្រើនឡើងទេ
១៧ហើយសំដីគេនឹងស៊ីរូងដូចជាដំបៅក្លាយ ក្នុងពួកនោះ
មានឈ្មោះ ហ៊ីមេនាស[ឆ] និងភីលេត ១៨ដែលបានជ្រួស
ហួសចេញពីសេចក្ដីពិតទាំងនិយាយថា សេចក្ដីរស់ឡើង
វិញបានកន្លងទៅហើយ[ជ] គេក៏បង្ខូចសេចក្ដីជំនឿរបស់អ្នក
ខ្លះដែរ[ឈ] ១៩ប៉ុន្តែ ឯឫសមាំមួនរបស់ព្រះ នោះធន់នៅវិញ[ញ]
ដោយបានបោះត្រាថា ព្រះអម្ចាស់ទ្រង់ស្គាល់អស់អ្នកដែល
ជារបស់ផងទ្រង់[ដ] ហើយថា ចូរឱ្យអស់អ្នកដែលចេញព្រះ
នាមព្រះអម្ចាស់[ឋ] ថយចេញពីសេចក្ដីទុច្ចរិតទៅ ២០នៅក្នុង

យក ១:១៨ **២:១៦** ច ទត ៣:៩ ១ធថ ៦:២០ **២:១៧** ឆ ១ធថ ១:២០
**២:១៨** ជ ២ថន ២:២ ឈ ១ធថ ១:១៩ ៦:២១ **២:១៩** ញ អស ២៨:១៦
ដ នក ៣៣:១២ ជន ១៦:៥ យហ ១០:១៤ ១កថ ៨:៣ កទ ៤:៩ ឋ ១កថ ១:២

ហើយការបង្ហាញពីតំណវង្សត្រកូលរបស់ហ្លួងដាវីឌ គឺបញ្ជាក់ពីភាពជាមនុស្ស ។ សេចក្ដីពិតទាំងពីរចំណុចនេះ គឺជាមូលដ្ឋានគ្រឹះនៃដំណឹងល្អ ។ ដោយសារតែព្រះគ្រីស្ទគឺជាព្រះ នោះការសុគតរបស់ទ្រង់គឺមានតម្លៃខ្លាំងឥតព្រំដែន ហើយដោយសារតែទ្រង់ជាមនុស្ស នោះទ្រង់ក៏ជាទីជំនួយដល់យើងផងដែរ ។

**២:៩** *ជាប់ចំណងដូចជាមនុស្សអាក្រក់* ក្នុងឃ្លានេះធ្វើឱ្យយើងឃើញយ៉ាងច្បាស់ថា លោកប៉ុលកំពុងតែរង់ចាំការប្រហារជីវិត(៤:៦ និងការពន្យល់)។

**២:១០** *ហេតុនោះបានជាខ្ញុំទ្រាំទ្រនឹងគ្រប់ការទាំងអស់ ដើម្បីជាប្រយោជន៍ដល់ពួករើសតាំង* ការរងទុក្ខលំបាកនោះគឺធំធេងណាស់ ប្រសិនបើវានាំមកនូវសេចក្ដីសង្គ្រោះនៃមនុស្សដែលបានជ្រើសរើស ដែលមិនទាន់បានជឿនៅឡើយ ។ *នៅក្នុងព្រះគ្រីស្ទយេស៊ូវ* មើលការពន្យល់ ១:១៣ អភ ១:១ ។ *សិរីល្អដ៏នៅអស់កល្ប* នេះគឺជាបំណងចុងក្រោយនៃសេចក្ដីសង្គ្រោះ ។

**២:១១–១៣** ត្រង់នេះប្រហែលជាបទចម្រៀងទំនុកតម្កើងរបស់គ្រីស្ទបរិស័ទនៅសម័យដំបូង ។ ចំណុចទាំងអស់នេះគឺជាការទូលអង្វររបស់លោកប៉ុលពីសេចក្ដីទុក្ខលំបាកសម្រាប់ព្រះគ្រីស្ទនោះនឹងបាននាំមកនូវសិរីល្អ(រម ៨:១៨)

**២:១១** *ពាក្យនេះគួរជឿពិត* មើលការពន្យល់ ១ធថ ១:១៥ ។ *បើយើងបានស្លាប់ជាមួយនឹងទ្រង់ នោះយើងនឹងរស់ជាមួយនឹងទ្រង់ដែរ* តាមទម្រង់វេយ្យាករណ៍របស់ភាសាក្រិកបានប្រាប់ឱ្យយើងដឹងថា "ស្លាប់ជាមួយនឹង" ព្រះគ្រីស្ទក្នុងអតីតកាល គឺជាពេលដែលទ្រង់បានសុគតនៅលើឈើឆ្កាងជំនួសបាបយើងនោះឯង រួចបីថ្ងៃក្រោយមក នោះទ្រង់ក៏មានព្រះជន្មរស់ឡើងវិញ ដូច្នេះយើងក៏ត្រូវរស់ឡើងវិញ ហើយមានជីវិតអស់កល្បជានិច្ច ដូចជាទ្រង់នោះផងដែរ (រម ៦:២–១១)។

**២:១២** *បើយើងទ្រាំទ្រនោះយើងនឹងសោយរាជ្យជាមួយនឹងទ្រង់* នេះគឺជាលទ្ធផលនៃសេចក្ដីជំនឿក្នុងការទ្រាំទ្រទុក្ខលំបាក និងការសាកល្បងផ្សេងៗចប់សព្វគ្រប់ ។ ការនោះនឹងបានទទួលរង្វាន់នៅពេលដែលព្រះគ្រីស្ទយាងមកម្ដងទៀត(រម ៨:១៧ និងការពន្យល់)។ *តែបើយើងមិនព្រមទទួលស្គាល់ទ្រង់ទេ* មើល មថ ១០:៣៣ ។

**២:១៣** *គង់តែទ្រង់នៅស្មោះត្រង់ដដែល* មើល រម ៣:៣–៤ និងពន្យល់ ។

**២:១៤–១៨** ការប្រើពាក្យនៅក្នុងខ.១៤–១៦ បានបង្ហាញពីសេចក្ដីជំនឿខុសឆ្គងជាលើកដំបូងនៃចំណេះដឹង ហើយក៏បាននិយាយដូចគ្នានេះដែរនៅក្នុងគម្ពីរ១ធីម៉ូថេ និងទីតុស (មើលការពន្យល់ ១ធថ ១:៣–១១ និងសេចក្ដីផ្ដើម)។ អ្នកដឹកនាំខុសឆ្គងទាំងពីរនាក់នេះគឺហ៊ីមេនាស (១ធថ ១:២០) និងភីលេត (ខ.១៧) បានបដិសេធការរស់ឡើងវិញខាងឯរូបកាយ (ខ.១៨) ហើយប្រហែលជាបានអះអាងថា មានតែវិញ្ញាណទេដែលរស់ឡើងវិញ (កំហុសនេះស្រដៀងគ្នានៅក្នុង ១កថ ១៥:១២–១៩ និងមើលការពន្យល់)។ ចំណេះដឹងដ៏អាថ៌កំបាំងនេះបានបកស្រាយពីការរស់ឡើងវិញជាពាក្យប្រៀបធៀបពុំមែនតាមន័យត្រង់នោះទេ ។

**២:១៥** *ដែលមិនត្រូវខ្មាស* មើលការពន្យល់ ១:៨ ។ *ព្រះបន្ទូលនៃសេចក្ដីពិត* នេះជាដំណឹងល្អ (អភ ១:១៣ កល ១:៥) ជាសេចក្ដីពិតដែលលោកធីម៉ូថេត្រូវជឿតាម និងស្ដាប់តាម និងត្រូវបង្រៀនបន្តទៀតផងដែរ (៤:២)។

**២:១៦** *ពាក្យសំដីឡេះឡោះឥតប្រយោជន៍* មើលពន្យល់ ១ធថ ១:៣–១១ ។

**២:១៩** *ឫសមាំមួនរបស់ព្រះ* គឺជាពួកជំនុំដែលឈរលើសេចក្ដីពិត(១ធថ ៣:១៥)។ តាមការបង្ហាញពីជំនឿខុសឆ្គងរបស់ហ៊ីមេនាស និងភីលេត (ខ.១៧) នោះបានលើកទឹកចិត្តដល់លោកធីម៉ូថេឱ្យបានដឹងថា ពួកជំនុំគឺជាឫសដ៏មាំមួនរបស់ព្រះ ។ ត្រង់នេះមានពីរករណីទី១បញ្ជាក់ពីជំនឿពិតប្រាកដរបស់ពួកជំនុំ (ព្រះអម្ចាស់ទ្រង់ស្គាល់អស់អ្នកដែលជារបស់ផងទ្រង់ "ពាក្យថា

ធំ មិនមែនមានសុទ្ធតែគ្រឿងប្រដាប់មាស ប្រាក់ម្យ៉ាង
ទេ គឺមានប្រដាប់ធ្វើពីឈើ ហើយពីដីដែរ ខ្លះសំរាប់
ការប្រសើរ ខ្លះសំរាប់ការអាប់ឱនវិញ[ឌ] ២១ដូច្នេះ បើអ្នក
ណាបានសំអាតខ្លួន ពីសេចក្តីទាំងនោះ អ្នកនោះនឹងបាន
ជាប្រដាប់សំរាប់ការប្រសើរ ដោយបានញែកជាបរិសុទ្ធ
ហើយ ក៏មានប្រយោជន៍ដល់ម្ចាស់ផង ទុកជាប្រដាប់
ដែលបានរៀបចំ សំរាប់ការល្អគ្រប់ជំពូក[ឍ]។
២២ចូរឱ្យរត់ពីសេចក្តីស្រើបស្រាលរបស់ក្មេងៗ ចេញ
ហើយដេញតាមសេចក្តីសុចរិត សេចក្តីជំនឿ សេចក្តី
ស្រឡាញ់[ណ] និងសេចក្តីមេត្រី ជាមួយនឹងអស់អ្នកដែលអំពាវ
នាវដល់ព្រះអម្ចាស់[ត] អំពីចិត្តដ៏បរិសុទ្ធវិញ[ថ] ២៣កុំឱ្យព្រម
ស្តាប់សេចក្តីដេញដោលចំកួត ហើយឥតច្បាប់នោះឡើយ
ដោយដឹងថា សេចក្តីទាំងនោះនាំឱ្យមានសេចក្តីឈ្លោះ
ប្រកែកគ្នាទេ[ទ] ២៤ក៏មិនគួរឱ្យបាវបំរើនៃព្រះអម្ចាស់ឈ្លោះ
ប្រកែកគ្នាឡើយ គួរឱ្យបានចិត្តសុភាពរាបសាដល់មនុស្ស
ទាំងអស់វិញ ត្រូវប្រសប់ក្នុងការបង្រៀន ទាំងមានចិត្តអត់
ធ្មត់ផង[ធ] ២៥ត្រូវប្រដៅដំរង់មនុស្សដែលទទឹងទទែង ដោយ
មានចិត្តសុភាព ក្រែងព្រះទ្រង់នឹងបណ្តាលឱ្យគេប្រែចិត្តឱ្យ
បានស្គាល់សេចក្តីពិតវិញ[ន] ២៦ហើយគេនឹងភ្ញាក់ដឹងខ្លួន
ឡើង ចេញផុតពីអន្ទាក់របស់អារក្ស[ប] ដែលវាបានចាប់គេ
ប្រើតាមចិត្តនោះ ។

**២:២០** ឌ រម ៩:២១
**២:២១** ឍ ២កថ ៩:៨ អភ ២:១០ ២ធថ ៣:១៧
**២:២២** ណ ១ធថ ១:១៤ ៦:១១ ត កថ ២:២១ ថ ១ធថ ១:៥
**២:២៣** ទ ខ.១៤
**២:២៤** ធ ១ធថ ៣:២,៣
**២:២៥** ន ១ធថ ២:៤
**២:២៦** ប ១ធថ ៣:៧
**៣:១** ផ ១ធថ ៤:១ ២ពត ៣:៣
**៣:២** ព ១ធថ ៣:៣ ភ រម ១:៣០ ម ២ពត ២:១០–១២ យ រម ១:៣០
**៣:៤** រ ទដ ២៥:៣ ល ១ធថ ៣:៦ ៦:៤
**៣:៥** វ ១ធថ ២:២ ស រម ១៦:១៧
**៣:៦** ហ យដ ៤
**៣:៧** ឡ ១ធថ ២:៤
**៣:៨** អ នក ៧:១១ ក កថ ១៣:៨ ខ ១ធថ ៦:៥
**៣:៩** គ នក ៧:១២ ៨:១៨ ៩:១១

## ការមិនគោរពប្រតិបត្តិដល់ព្រះនៅគ្រាក្រោយបង្អស់

៣ ១ចូរឱ្យដឹងថា នៅជាន់ក្រោយបង្អស់ និងមានគ្រាលំបាក
ណាស់[ផ] ២ដ្បិតនៅគ្រានោះ មនុស្សនឹងស្រឡាញ់តែខ្លួនឯង
ទាំងស្រឡាញ់ប្រាក់[ព] អួតអាងគឃរ មានឫកខ្ពស់[ភ] ប្រមាថ
មើលងាយ[ម] មិនស្តាប់បង្គាប់ឪពុកម្តាយ[យ] រមិលគុណ មាន
ចិត្តមិនបរិសុទ្ធ ៣មិនស្រឡាញ់តាមធម្មតាមនុស្ស គ្មានសេច
ក្តីអធ្យាស្រ័យ និយាយបង្កាច់គេ មិនចេះទប់ចិត្ត មានចិត្ត
សាហាវ មិនចូលចិត្តនឹងការល្អ ៤ក្បត់គេ[រ,ល] ឥតបើគិត មាន
ចិត្តធំ ហើយចូលចិត្តនឹងល្បែងលេងជាជាងព្រះ ៥គេមាន
ឫកពាជាអ្នកគោរពប្រតិបត្តិដល់ព្រះ[វ] ប៉ុន្តែ មិនព្រមទទួល
ស្គាល់ព្រះចេស្តា ដែលមកដោយការគោរពប្រតិបត្តិនោះ
ទេ ចូរបែរពីពួកមនុស្សយ៉ាងនោះចេញ[ស]។
៦ដ្បិតមនុស្សទាំងនោះ ជាពួកអ្នកដែលចូល[ហ]ទៅក្នុងផ្ទះ
គេ ទាំងល្បួងនាំពួកស្រីៗ ដែលល្ងង់ឱ្យឈ្លក់ចិត្ត ដែលស្ត្រី
ទាំងនោះផ្ទុកធ្ងន់ ដោយអំពើបាបហើយ ក៏បណ្តោយតាម
សេចក្តីប៉ងប្រាថ្នាផ្សេងៗ ៧គេរៀនជានិច្ច ប៉ុន្តែពុំអាចនឹង
ចេះដល់ថ្នាក់នៃសេចក្តីពិតឡើយ[ឡ] ៨គេជាអ្នកទាស់ទទឹងនឹង
សេចក្តីពិត[អ] បែបដូចជាយ៉ានេស នឹងយ៉ាមប្រេស បានទាស់
ទទឹងនឹងលោកម៉ូសេដែរ[ក] គឺជាមនុស្សមានគំនិតខូច[ខ]
ហើយឥតប្រយោជន៍ខាងឯសេចក្តីជំនឿ ៩ប៉ុន្តែ គេមិនមាន
សេចក្តីចំរើនជឿនឡើងទៅមុខទៀតទេ ដ្បិតមនុស្សទាំង
អស់នឹងឃើញសេចក្តីខ្លៅល្ងង់របស់គេជាយ៉ាងច្បាស់ ដូច
ជាបានឃើញសេចក្តីខ្លៅល្ងង់របស់អ្នកទាំង២នោះដែរ[គ]។

ស្គាល់ជាញឹកញាប់នៅក្នុងព្រះគម្ពីរ មានន័យថាស្គាល់ ឬដឹងច្បាស់លាស់")។ ករណីទី២បញ្ជាក់ពីការទទួលខុសត្រូវរបស់មនុស្សលោក (អ្នកណាលន់តួបាបដោយនូវព្រះនាមព្រះអម្ចាស់ នោះត្រូវបែរចេញពីសេចក្តីទុច្ចរិត)។ *បានបោះត្រា* មានន័យថា ពួកជំនុំគឺជារបស់ព្រះ ហើយព្រះអម្ចាស់ទ្រង់ជាអ្នកការពារដោយផ្ទាល់ (មើលការពន្យល់ អភ ១:១៣)។

**២:២១** *បានញែកជាបរិសុទ្ធ* គឺជាការត្រាស់ហៅឱ្យមកបម្រើដល់ព្រះ (១កថ ១:២ ១ពត ១:១៦ និងការពន្យល់)។

**២:២២** *ក្មេងៗ* មើលការពន្យល់ ១ធថ ៤:១២។ *សេចក្តីមេត្រី* មើល រម ១២:១៦។ *ចិត្តដ៏បរិសុទ្ធ* មើលការពន្យល់ ១ធថ ១:៥ ។

**២:២៣** នៅក្នុងខនេះគឺជាការរំលឹកពីចំណេះដឹងខុសឆ្គងម្តងទៀត(មើលការពន្យល់ ខ.១៤–១៨)។

**២:២៤** *បាវបំរើនៃព្រះអម្ចាស់* ពាក្យនេះហាក់បីដូចជាសំដៅទៅលើមនុស្សសំខាន់ៗដូចជាលោកធីម៉ូថេនេះជាដើម ដែលព្រះអម្ចាស់ទ្រង់បានញែកមកសម្រាប់កិច្ចការយ៉ាងពិសេស។ *ត្រូវប្រសប់ក្នុងការបង្រៀន* មើលការពន្យល់ ១ធថ ៣:១ ។

**២:២៥** *ប្រែចិត្ត* មើលការពន្យល់ មថ ៤:១៧។ *ស្គាល់សេចក្តីពិត* មើល ១ធថ ២:៤ ។

**២:២៦** *អន្ទាក់របស់អារក្ស* មើល ១ធថ ៣:៧ អភ ៦:១១ ១ពត ៥:៨ ។

**៣:១** *នៅជាន់ក្រោយបង្អស់* គឺជាសម័យកាលរបស់ព្រះមែស៊ីក្នុងកាលដែលព្រះគ្រីស្ទចាប់ផ្តើមយាងមក (១ធថ ៤:១ ហព ១:១–២ និងការពន្យល់ ១ពត ១:២០)។ នៅជាន់ក្រោយបង្អស់នៅក្នុងវគ្គនេះ មិនគ្រាន់តែសំដៅទៅលើមុនពេលវេលាដែលព្រះគ្រីស្ទយាងមកលើកទីពីរនោះទេ គឺសំដៅទៅលើសម័យកាលដែលលោកប៉ុលបានបង្គាប់ដល់លោកធីម៉ូថេ "ចូរបែរពីពួកមនុស្សយ៉ាងនោះចេញ"(ខ.៥)គឺចេញពីពួកមនុស្សមិនជឿ(ខាងឯកិរិយាមាយាទ)។

**៣:២–៥** នេះគឺជាការបញ្ជាក់បន្ថែមពីកិរិយាមាយាទរបស់អ្នកមិនជឿ(មើលការ ពន្យល់ ១:២៩–៣១)។

**៣:៥** *អ្នកគោរពប្រតិបត្តិដល់ព្រះ* មើល ១ធថ ២:២ និងការពន្យល់ ។

**៣:៦** *ពួកស្រីៗដែលល្ងង់* គឺសំដៅលើពួកមនុស្សដែលមានចិត្តមិននឹងនរ ហើយគិតតែពីការអាក្រក់ ដោយព្រោះតែអំពើបាប និងវិលវល់ក្នុងភាពស្រើបស្រាល ដោយទទួលបានពីគ្រូបង្រៀនខុសឆ្គងជាច្រើន(គេរៀនជានិច្ច "ខ.៧" ប៉ុន្តែ ពុំដែលបានទទួលចំណេះដឹងនៃសេចក្តីសង្គ្រោះរបស់ព្រះគ្រីស្ទនោះឡើយ)។

**៣:៨** *យ៉ានេស និងយ៉ាមប្រេស* បើយោងតាមប្រពៃណីរបស់សាសន៍យូដាបានឱ្យដឹងថា អ្នកទាំងពីរនាក់នេះគឺជាគ្រូមន្តអាគមប្រចាំរាជវាំងនៃជនជាតិ

## បណ្ដាំរបស់លោកប៉ុលដល់ធីម៉ូថេ

១០ តែចំណែកអ្នក អ្នកបានស្គាល់គ្រប់សេចក្ដីដែលខ្ញុំ
បង្រៀន[យ] កិរិយាដែលប្រព្រឹត្ត នឹងបំណងចិត្ត សេចក្ដីជំនឿ
សេចក្ដីអត់ធ្មត់ សេចក្ដីស្រឡាញ់ សេចក្ដីខ្ជាប់ខ្ជួនរបស់ខ្ញុំ
ហើយ ១១ ព្រមទាំងការដែលគេបៀតបៀនដល់ខ្ញុំនឹងសេចក្ដី
ទុក្ខលំបាករបស់ខ្ញុំដែរ ជាការដែលកើតដល់ខ្ញុំ នៅក្រុង
អាន់ទីយ៉ូក[ង] ក្រុងអ៊ីកូនាម[ច] នឹងក្រុងលីស្ត្រា[ឆ] ក៏ស្គាល់សេចក្ដី
បៀតបៀនជាយ៉ាងណាដែលខ្ញុំទ្រាំទ្រនោះដែរ[ជ] តែក្នុង
ការទាំងនោះ[ឈ] ព្រះអម្ចាស់ទ្រង់បានប្រោសឱ្យខ្ញុំរួចវិញ[ញ]
១២ ឯអស់អ្នកណាដែលចង់រស់ ដោយគោរព ប្រតិបត្តិដល់
ព្រះគ្រីស្ទយេស៊ូវ នោះនឹងត្រូវមានសេចក្ដីបៀតបៀនដែរ[ដ]
១៣ ហើយពួកអាក្រក់ នឹងពួកឆបោក គេនឹងមានជឿនជឿន
ទៅខាងសេចក្ដីអាក្រក់ កាន់តែខ្លាំងឡើង[ឋ] ទាំងនាំមនុស្សឱ្យ
វង្វេង ហើយត្រូវវង្វេងខ្លួនឯងផង[ឌ] ១៤ តែឯអ្នកចូរឱ្យអ្នកនៅ
ជាប់ក្នុងសេចក្ដីដែលអ្នកបានរៀន ហើយជឿប្រាកដវិញ
ដោយដឹងថា អ្នកបានរៀនសេចក្ដីនោះពីអ្នកណា[ឍ] ១៥ ហើយ
ថា តាំងពីក្មេងតូចមក[ណ] អ្នកបានស្គាល់បទគម្ពីរទាំងប៉ុន្មាន[ត]
ដែលអាចនឹងនាំឱ្យអ្នកមានប្រាជ្ញា[ថ]ដល់ទីសង្គ្រោះ ដែល
បានដោយសារសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទយេស៊ូវផង
១៦ គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណ
បណ្ដាលឱ្យតែងទេ[ទ] ក៏មានប្រយោជន៍សំរាប់ការបង្រៀន[ធ]
ការរំឭកឱ្យដឹងខ្លួន ការប្រដៅដំរង់ នឹងការបង្ហាត់ខាងឯ
សេចក្ដីសុចរិត[ន] ១៧ ដើម្បីឱ្យអ្នកសំណប់របស់ព្រះ[ប]បានគ្រប់
លក្ខណ៍ ហើយមានគ្រប់ទាំងចំណេះសំរាប់នឹងធ្វើការល្អ
គ្រប់មុខ[ផ] ។

**៤** ១ ដូច្នេះ ខ្ញុំផ្ដាំមកអ្នកយ៉ាងអស់ពីចិត្ត នៅចំពោះព្រះនឹង
ព្រះគ្រីស្ទយេស៊ូវ ដែលទ្រង់រៀបនឹងជំនុំជំរះ ទាំងមនុស្ស
រស់ និងមនុស្សស្លាប់ផង[ព] គឺផ្ដាំដោយអាងដំណើរទ្រង់យាង
មក[ភ] និងនគរទ្រង់ថា[ម] ២ ចូរឱ្យអ្នកផ្សាយ[យ] ព្រះបន្ទូលចុះ[រ]
ហើយទទួចជំរុញផង ទោះត្រូវពេល ឬខុសក្ដី ចូររំឭកគេ
ឱ្យដឹងខ្លួនព្រមទាំងបន្ទោស[ល] ហើយកំឡាចិត្ត[វ]គេ ដោយចិត្ត
អត់ធ្មត់ និងសេចក្ដីប្រៀនប្រដៅគ្រប់យ៉ាង ៣ ដ្បិតនឹងមាន
គ្រាមក ដែលគេមិនទ្រាំទ្រនឹងសេចក្ដីបង្រៀនដ៏ត្រឹមត្រូវ
ទេ[ស] គឺគេនឹងមានត្រចៀករមាស់ ហើយនឹងហៅគ្រូកាន់តែ
ច្រើនឡើង មកបង្រៀនឱ្យត្រូវចិត្ត[ហ] ៤ គេនឹងងាកត្រចៀក
ចេញពីសេចក្ដីពិត បែរទៅតាមរឿងព្រេងវិញ[ឡ] ៥ តែឯអ្នក
ចូរឱ្យមានគំនិតនឹងធឹងក្នុងគ្រប់ការទាំងអស់វិញ ចូរទ្រាំ
ទ្រនឹងសេចក្ដីលំបាក[អ] ចូរឱ្យអ្នកធ្វើការជាគ្រូផ្សាយដំណឹង

**៣:១០** យ ១ធថ ៤:៦
**៣:១១** ង កច ១៣:១៤,៥០ ច កច ១៣:៥១ ឆ កច ១៤:៦ ជ ២កថ ១១:២៣–២៧ ឈ ទដ ៣៤:១៩ ញ រម ១៥:៣១
**៣:១២** ដ យហ ១៥:២០ កច កច ១៤:២២
**៣:១៣** ឋ ២ធថ ២:១៦ ឌ មក ១៣:៥
**៣:១៤** ឍ ២ធថ ១:១៣
**៣:១៥** ណ ២ធថ ១:៥ ត យហ ៥:៣៩ ថ ចទ ៤:៦ ទដ ១១៩:៩៨,៩៩
**៣:១៦** ទ ២ពត ១:២០,២១ ធ រម ៤:២៣,២៤
ន ចទ ២៩:២៩
**៣:១៧** ប ១ធថ ៦:១១ ផ ២ធថ ២:២១

**៤:១** ព ខ.៨ កច ១០:៤២ ភ ១ធថ ៦:១៤ ម ១ធថ ៥:២១ ៦:១៣
**៤:២** យ ១ធថ ៤:១៣ រ កទ ៦:៦ ល ១ធថ ៥:២០ ទត ១:១៣ ២:១៥ វ ទត ២:១៥ **៤:៣** ស ១ធថ ១:១០ ហ អស ៣០:១០
**៤:៤** ឡ ១ធថ ១:៤ **៤:៥** អ ២ធថ ១:៨ ២:៣,៩

អេស៊ីព្ទ ហើយជាអ្នកដែលប្រឆាំងនឹងលោកម៉ូសេ (នក ៧:១១ និងពន្យល់) ។

**៣:១១** *ក្រុងអាន់ទីយ៉ូក ក្រុងអ៊ីកូនាម និងក្រុងលីស្ត្រា* ទីក្រុងទាំងបីនេះស្ថិតនៅក្នុងខេត្តរបស់រ៉ូម៉ាំងនៅស្រុកកាឡាទី ដែលលោកប៉ុលបានទៅសួរសុខទុក្ខក្នុងដំណើរលើកទីមួយ និងលើកទីពីររបស់គាត់ (កច ១៣:១៤,៥១ ១៤:៦ និងពន្យល់) ។ ដោយសារតែលោកធីម៉ូថេមកពីទីក្រុងលីស្ត្រា (កច ១៦:១) នោះគាត់ពិតជាបានដឹងពីទុក្ខលំបាករបស់លោកប៉ុលនៅទីនោះយ៉ាងច្បាស់ ។ *ព្រះអម្ចាស់ទ្រង់បាន ប្រោសឱ្យខ្ញុំរួចវិញ* គឺបូករួមទាំងការជួយសង្គ្រោះលោកប៉ុលឱ្យរួចពីការគប់ដុំថ្ម សម្លាប់នោះផងដែរ (មើល កច ១៤:១៩ –២០ និងការពន្យល់) ។

**៣:១២** មើល មថ ១០:២២ កច ១៤:២២ ភល ១:២៩ និងការពន្យល់ ១ពត ៤:១២ ។ *ព្រះគ្រីស្ទយេស៊ូវ* មើលការពន្យល់ ១:១៣ អភ ១:១ ។

**៣:១៤** *រៀនសេចក្ដីនោះពីអ្នកណា* គឺប្រហែលជាបានរៀនពីលោកប៉ុល ព្រមទាំងម្ដាយ និងជីដូនរបស់ធីម៉ូថេហើយមើលទៅ (មើលពន្យល់ ១:៥) ។

**៣:១៥** *តាំងពីក្មេងតូចមក អ្នកបានស្គាល់បទគម្ពីរ* ជាផ្លូវការក្មេងប្រុសរបស់សាសន៍យូដាត្រូវចាប់ផ្ដើមសិក្សាគម្ពីរសញ្ញាចាស់តាំងពីអាយុ៥ឆ្នាំ ។ ចំពោះលោកធីម៉ូថេត្រូវបានម្ដាយ និងជីដូនបង្រៀននៅផ្ទះតាំងពីមុនអាយុនេះទៅទៀត ។

**៣:១៦** *គ្រប់ទាំងបទគម្ពីរ* ពាក្យនេះសំខាន់សំដៅទៅលើគម្ពីរសញ្ញាចាស់ ពីព្រោះគម្ពីរសញ្ញាថ្មីមួយចំនួនមិនទាន់បានសរសេរនៅឡើយទេ (មើលការពន្យល់ ១ធថ ៥:១៨) នឹងបង្ហាញថា គម្ពីរសញ្ញាថ្មីខ្លះ ឬឯកសារមួយចំនួនត្រូវបានចាត់ទុកស្មើរនឹងបទគម្ពីរសញ្ញាចាស់ ។ *គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណ* លោកប៉ុលបានអះអាងពីសកម្មភាពរបស់ព្រះអម្ចាស់ក្នុងការចូលរួមសរសេរបទគម្ពីរ ដោយអំណាចព្រះចេស្ដារបស់ទ្រង់ដ៏ខ្លាំងពូកែដែលមិនចេះភ័ណ្ឌច្រឡំ ហើយបទគម្ពីរនេះឯងគឺជាព្រះបន្ទូលរបស់ព្រះ (២ពត ១:២០–២១ និងការពន្យល់) ។

**៤:១** លោកប៉ុលបានថ្លែងពីការផ្ដុកផ្ដាក់របស់គាត់ដល់លោកធីម៉ូថេឱ្យដឹងខ្លួនថាកិច្ចការដែលគាត់ធ្វើទាំងអស់នេះគឺនៅក្នុងព្រះវត្តមានរបស់ព្រះអម្ចាស់ព្រះវរបិតា និងព្រះគ្រីស្ទ ដែលទ្រង់នឹងជំនុំជម្រះមនុស្សគ្រប់ៗគ្នា ។ គាត់ក៏រឭកឱ្យដឹងពីការពិត ទាំងពីរនៃការយាងមកវិញរបស់ព្រះគ្រីស្ទ និងដំណើរមកដល់នៃនគរព្រះ ។ ត្រង់ចំណុចនេះ គឺជាបណ្ដាំចុងក្រោយដ៏សំខាន់របស់លោកប៉ុលដល់លោកធីម៉ូថេ ។ *ព្រះគ្រីស្ទយេស៊ូវដែលទ្រង់រៀបនឹងជំនុំជំរះ* មើល មថ ២៥:៣១–៣៣ យហ ៥:២២ យក ៥:៩ ១ពត ៤:៥ និងពន្យល់ ។

**៤:២** *ទទួចជំរុញ* ចំណុចនេះបញ្ជាក់ថា ត្រូវត្រៀមជាស្រេចគ្រប់កាលៈទេសៈ ដើម្បីប្រកាសព្រះបន្ទូល ដោយកែលំអរ បន្ទោស និងលើកទឹកចិត្ត ។

**៤:៣** *សេចក្ដីបង្រៀន* មើល ទត ១:៩ និងការពន្យល់ ។ *ត្រចៀករមាស់* គឺជាត្រចៀក ដែលត្រូវការឱ្យគេអេះដោយពាក្យ ដែលមានបំណងចិត្តអាក្រក់ជានិច្ច ។

**៤:៤** *រឿងព្រេង* មើល ១ធថ ១:៤ និងការពន្យល់ ។

ល្អចុះ[ក] ព្រមទាំងបំពេញការងាររបស់ខ្លួនគ្រប់ជំពូកផង ។
៦ដ្បិតខ្ញុំកំពុងតែត្រូវច្រួចចេញ[ខ] ឯពេលវេលាដែលខ្ញុំ
ត្រូវលាទៅ ក៏បានមកដល់ហើយ[គ] ៧ខ្ញុំបានតយុទ្ធយ៉ាងល្អ[ឃ] ខ្ញុំ
បានរត់ប្រណាំងជាស្រេច[ង] ខ្ញុំបានរក្សាសេចក្ដីជំនឿទៅ
ហើយ ៨ពីនេះទៅមុខ នឹងមានមកុដនៃសេចក្ដីសុចរិត[ច]
បំរុងទុកឱ្យខ្ញុំ[ឆ] ដែលព្រះអម្ចាស់ដ៏ជាចៅក្រមសុចរិត ទ្រង់
នឹងប្រទានមកខ្ញុំ នៅថ្ងៃនោះ[ជ] មិនមែនដល់ខ្ញុំតែម្នាក់
ប៉ុណ្ណោះ គឺដល់អស់អ្នកណា ដែលចូលចិត្តនឹងដំណើរទ្រង់
យាងមកវិញនោះដែរ[ឈ] ។

## កិច្ចការផ្ទាល់ខ្លួន

៩ចូរឱ្យខំប្រឹងទៅឯខ្ញុំជាប្រញាប់[ញ] ១០ដ្បិតអ្នកដេម៉ាស[ដ]បាន
លះចោលខ្ញុំហើយ ដោយគាត់ស្រឡាញ់លោកីយនេះ[ឋ] គាត់
បានទៅឯក្រុងថែស្សាឡូនីចហើយ[ឌ] អ្នកក្រេសេនបានទៅ
ឯស្រុកកាឡាទី[ឍ] ហើយអ្នកទីតុស[ណ]ក៏បានទៅឯស្រុកដាល់-
ម៉ាទា ១១មានតែលោកលូកាប៉ុណ្ណោះទេ[ត] ដែលនៅជាមួយ
នឹងខ្ញុំ[ថ] ចូរឱ្យអ្នកនាំម៉ាកុស[ទ]ទៅជាមួយផង ដ្បិតគាត់ជាអ្នក
មានប្រយោជន៍ក្នុងការងារខ្ញុំ ១២ខ្ញុំបានចាត់អ្នកទីឃីកុស[ធ]
ឱ្យទៅឯក្រុងអេភេសូរ[ន] ១៣ដល់កាលណាអ្នកទៅឯខ្ញុំ នោះ
សូមយកអាវធំ ដែលខ្ញុំផ្ញើទុកនឹងអ្នកកាប៉ុសនៅក្រុងទ្រអាស
ទៅផង[ប] នឹងសៀវភៅទាំងប៉ុន្មានដែរ តែសូមយកក្រាំង
ស្បែកជាដើម ។
១៤ឯអ័លេក្សានត្រុស[ផ] ជាជាងស្មិត គាត់បានធ្វើបាបខ្ញុំជា
ច្រើន តែព្រះអម្ចាស់ទ្រង់នឹងសងគាត់វិញ តាមការដែល
គាត់ធ្វើ[ព] ១៥ចូរឱ្យអ្នកប្រុងប្រយ័ត្ននឹងគាត់ដែរ ដ្បិតគាត់បាន
ទាស់ទទឹងនឹងពាក្យសំដីយើងជាខ្លាំងណាស់ ។
១៦កាលខ្ញុំបានដោះសាជាមុនដំបូង នោះគ្មានអ្នកណា
ឈរជាមួយនឹងខ្ញុំសោះ គេលះចោលខ្ញុំទាំងអស់គ្នា តែសូម
កុំឱ្យព្រះរាប់សេចក្ដីនោះ ជាទោសដល់គេឡើយ[ភ] ១៧ប៉ុន្តែ
ព្រះអម្ចាស់ទ្រង់បានគង់ជាមួយនឹងខ្ញុំវិញ[ម] ព្រមទាំងចំរើន
កំឡាំងផង[យ] ដើម្បីឱ្យដំណឹងល្អបានផ្សាយទៅសព្វគ្រប់ ឱ្យ

**៤:៥** ក កច ២១:៨ អភ ៤:១១
**៤:៦** ខ ជន ១៥:១–១២ ២៨:៧,២៤ ភល ២:១៧ គ ភល ១:២៣
**៤:៧** ឃ ១ធច ១:១៨ ង ១កថ ៩:២៤ កច ២០:២៤
**៤:៨** ច កល ១:៥ ១ពត ១:៤ ឆ ១កថ ៩:២៥ ជ ២ធច ១:១២ ឈ ១ធច ៦:១៤
**៤:៩** ញ ឌ.២១
**៤:១០** ដ កល ៤:១៤ ភម ២៤ ឋ ១យហ ២:១៥ ឌ កច ១៧:១ ឍ កច ១៦:៦ ណ ២កថ ២:១៣
**៤:១១** ត កល ៤:១៤ ភម ២៤
ថ ២ធថ ១:១៥ ទ កច ១២:១២ **៤:១២** ធ កច ២០:៤ ន កច ១៨:១៩
**៤:១៣** ប កច ១៦:៨ **៤:១៤** ផ កច ១៩:៣៣ ១ធថ ១:២០
ព ទដ ២៨:៤ ១០៩:២០ រម ២:៦ ១២:១៩ **៤:១៦** ភ កច ៧:៦០
**៤:១៧** ម កច ២៣:១១ យ ភល ៤:១៣

**៤:៦** *ច្រួចចេញ* គឺសំដៅទៅលើការចាក់ស្រាទំពាំងបាយជូរនៅថ្ងៃលៀងព្រះអម្ចាស់ (ជន ១៥:១–១២ ២៨:៧)។ ត្រង់នេះលោកប៉ុលបានបង្ហាញថា ជីវិតរបស់គាត់បានឈានដល់ចុងបញ្ចប់ហើយ ហើយដល់ពេលដែលត្រូវថ្វាយដល់ព្រះគ្រីស្ទវិញ(ភល ២:១៧ និងការពន្យល់)។ *ពេលវេលាដែលខ្ញុំត្រូវលា* គឺជាសេចក្ដីស្លាប់របស់គាត់ជិតមកដល់ហើយ(នៅឆ្នាំ ៦៧/៦៨ ភល ១:២៣)។

**៤:៧** នៅក្នុងខនេះលោកប៉ុលបានក្រឡេកទៅកាលពី៣០ឆ្នាំមុនក្នុងដំណើរជីវិតជាអ្នកបម្រើមាននាទីជាសាវ័ក (ឆ្នាំ៣៦–៦៧/៦៨) ដែលប្រៀបដូចជាកីឡាករម្នាក់បានទទួលជ័យជម្នះ នៅក្នុងទីលានប្រកួត (បានច្បាំងយ៉ាងល្អ មើល ១ធថ ១:១៨)។ គាត់បានបញ្ចប់ទីលានប្រណាំងហើយនៅតែរក្សាសេចក្ដីជំនឿមានន័យថា "គាត់រក្សាសេចក្ដីជំនឿជាគ្រីស្ទបរិស័ទបានល្អយ៉ាងពិតប្រាកដ"។ *សេចក្ដីជំនឿ* មើល ការពន្យល់ ១ធថ ៣:៩ ។

**៤:៨** *មកុដនៃសេចក្ដីសុចរិត* ត្រង់នេះនៅតែបន្តការពិពណ៌នា និងការប្រៀបធៀបរបស់លោកប៉ុលទៀតថា ភ្នួងជ័យគឺត្រូវបានប្រគល់ដល់អ្នកដែលឈ្នះនៅទីលានប្រកួត(មើលការពន្យល់ ១កថ ៩:២៥)។ គាត់អាចនិយាយសំដៅទៅលើ (១).មកុដទី១ ដែលបានប្រគល់ជូនទុកជារង្វាន់ បង្ហាញពីជីវិតសុចរិត (២).មកុដទី២ ដែលមានសេចក្ដីសុចរិត (៣).មកុដទី៣ដែលប្រគល់ឱ្យដោយសុចរិតពីចៅក្រមដ៏សុចរិត ។ *នៅថ្ងៃនោះ* គឺជាថ្ងៃដែលព្រះគ្រីស្ទយាងមកជាលើកទីពីរ (ឌ.១)។

**៤:១០** *អ្នកដេម៉ាស* មើលពន្យល់ កល ៤:១៤ ភម ២៤ ។ *ក្រុងថែស្សាឡូនីច* មើលការពន្យល់សេចក្ដីផ្ដើមថែស្សាឡូនីចទី១(មានពួកជំនុំនៅក្នុងទីក្រុង)។ *ស្រុកកាឡាទី* កន្លែងនេះអាចជាតំបន់អាស៊ីមីន័រ ឬជាខេត្តរបស់រ៉ូម៉ាំង ហើយសព្វថ្ងៃនេះ គឺជាប្រទេសទួរគី (កទ ១:២)។ *ទីតុស* មើលសេចក្ដីផ្ដើមគម្ពីរទីតុសត្រង់អ្នកទទួល ។ *ស្រុកដាល់ម៉ាទា* ស្រុកនេះត្រូវបានហៅថា ស្រុកអ៊ីលីរីកុននោះផងដែរ (រម ១៥:១៩)។

**៤:១១** *ម៉ាកុស* មើលសេចក្ដីផ្ដើមគម្ពីរម៉ាកុស ។ លោកម៉ាកុសនៅក្នុងគម្ពីរសញ្ញាថ្មីដែលគេហៅថា យ៉ូហាន–ម៉ាកុសដែលបានរត់ចោលលោកប៉ុល និងបាណាបាសនៅក្នុងដំណើរបេសកកម្មលើកទីមួយ (កច ១៣:១៣)។ ក្រោយពីលោកប៉ុលបានបដិសេធមិនឱ្យលោកម៉ាកុសទៅជាមួយ ក្នុងដំណើរបេសកកម្មលើកទីពីរ នោះលោកបាណាបាសក៏បានបែកផ្លូវពីលោកប៉ុល ទៅឯកោះគីប្រុស ដោយយកលោកម៉ាកុសទៅជាមួយផង(កច ១៥:៣៦–៤១)។ ប៉ុន្តែនៅទីបញ្ចប់លោកម៉ាកុសបានធ្វើឱ្យលោកប៉ុលពេញចិត្តនឹងខ្លួនគាត់វិញ ដោយបាននៅជាប់នឹងលោកប៉ុល ទោះជាលោកប៉ុលត្រូវបានពួករ៉ូម៉ាំងចាប់ដាក់គុកក្នុងពេលបំពេញបេសកកម្មលើកទីមួយ (កល ៤:១០ ភម ២៤) នោះក៏ដោយ ក៏លោកប៉ុលសំណូមពរឱ្យលោកធីម៉ូថេនាំលោកម៉ាកុសទៅឯទីក្រុងរ៉ូមជាមួយផង ។

**៤:១២** *អ្នកទីឃីកុស* មើល កច ២០:៤ អភ ៦:២១ និងពន្យល់ ។

**៤:១៣** *អាវធំ* សម្រាប់ការពារធាតុត្រជាក់(មើលសេចក្ដីផ្ដើមគម្ពីរធីម៉ូថេ)។ អាវនេះមានកម្រាស់ក្រាស់ គ្មានដៃមានតែករាងមូលដោយពាក់ស៊កពីលើមកវិញ ។ *ក្រុងទ្រអាស* មើលការពន្យល់ កច ១៦:៨ ។ *ក្រាំងស្បែក* គឺសម្រាប់សរសេរអក្សរផ្សេងៗ(មើលការពន្យល់ នក ១៧:១៤) ដែលធ្វើពីស្បែកសត្វ តួរអក្សនៅលើក្រាំងនោះគឺជាផ្នែកខ្លះនៃបទគម្ពីរសញ្ញាចាស់ ដែលត្រូវគេចម្លង ។

**៤:១៤** *អ័លេក្សានត្រុសជាជាងស្មិត* ម្នាក់នេះប្រហែលជាមនុស្សតែមួយដែលបាននិយាយនៅក្នុង ១ធថ ១:២០ ។

**៤:១៦** *កាលខ្ញុំបានដោះសាជាមុនដំបូង* ត្រង់នេះគឺនិយាយអំពីករណីដែលលោកប៉ុលមានវត្តមាននៅក្នុងតុលាការជាលើកដំបូង ពុំមែនក្នុងករណីដែលគាត់ជាប់គុកនោះទេ(កច ២៨)។

**៤:១៧** *ដំណឹងល្អបានផ្សាយទៅសព្វគ្រប់ ឱ្យអស់ទាំងសាសន៍បានដឹងដោយ*

អស់ទាំងសាសន៍បានដឹងដោយសារខ្ញុំ[រ] ហើយទ្រង់បាន
ប្រោសឱ្យខ្ញុំរួចពីមាត់សិង្ហដែរ[ល] ១៨ព្រះអម្ចាស់ទ្រង់នឹង
ប្រោស ឱ្យខ្ញុំរួចពីគ្រប់ការអាក្រក់ទៅទៀត[វ] ទ្រង់នឹង
ថែរក្សាខ្ញុំ ទុកសំរាប់នគរទ្រង់នៅស្ថានសួគ៌[ស] សូមឱ្យទ្រង់
បានសិរីល្អ នៅអស់កល្បជានិច្ចរៀងរាបតទៅ អាម៉ែន[ហ]។

## ការផ្តាំផ្ញើសួរសុខទុក្ខ

១៩សូមជិរាបសួរដល់នាងព្រីស៊ីល និងអ្នកអ័គីឡា[ឡ] ព្រម
ទាំងពួកអ្នកផ្ទះអូនេសិភ័រផង[អ] ២០អ្នកអេរ៉ាស្ទុស[ក]បាននៅ
ក្រុងកូរិនថូស ហើយខ្ញុំបានទុកអ្នកទ្រភីមចោល[ខ] ទាំងឈឺ
នៅក្រុងមីលេត[គ] ២១ចូរខំប្រឹងទៅឱ្យបានដល់មុនរដូវរងា[ឃ]
អ្នកអើប៊ូលុស អ្នកពូដេន អ្នកលីណុស អ្នកក្លូឌាស ហើយ
ពួកបងប្អូនទាំងអស់គ្នា សូមជិរាបសួរដល់អ្នក ។
២២សូមឱ្យព្រះអម្ចាស់យេស៊ូវគ្រីស្ទ បានគង់ជាមួយនឹង
វិញ្ញាណអ្នក[ង] សូមឱ្យអ្នករាល់គ្នាបានប្រកបដោយព្រះ
គុណ[ច]។ អាម៉ែន ។

**៤:១៧** រ កច ៩:១៥ ល ១សយ ១៧:៣៧ ទដ ២២:២១ ដយ ៦:២២ ១កថ ១៥:៣២
**៤:១៨** វ ទដ ១២១:៧ ២ពត ២:៩ ស ខ.១ ហ រម ១១:៣៦
**៤:១៩** ឡ កច ១៨:២ អ ២ធថ ១:១៦
**៤:២០** ក កច ១៩:២២ ខ កច ២០:៤ ២១:២៩ គ កច ២០:១៥,១៧
**៤:២១** ឃ ខ.៩ ទត ៣:១២ **៤:២២** ង កទ ៦:១៨ ច កល ៤:១៨

*សារខ្ញុំ* ទោះជានៅក្នុងស្ថានភាពនេះក៏ដោយ ក៏លោកប៉ុលបានឆ្លៀតឱកាសធ្វើទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ នៅក្នុងតុលាការដ៏ធំនេះ (កច ១៦:២៥ ភម ១:១២–១៤ និងការពន្យល់)។ *ប្រោសឱ្យខ្ញុំរួចពីមាត់សិង្ហ* ដោយសារតែលោកប៉ុលជាជនជាតិរ៉ូម នោះគេមិនអាចបោះគាត់ចូលទៅក្នុងរូងសិង្ហរោងមណ្ឌលនោះទេ ។ ត្រង់នេះគឺជាពាក្យប្រៀបធៀបមួយ ដែលគាត់បានឮពួកគេនិយាយជាលើកដំបូងជាលទ្ធផលល្អសម្រាប់តុលាការក្នុងការសម្រេចចិត្ត ។

**៤:១៨** *នឹងប្រោសឱ្យខ្ញុំរួចពីគ្រប់ការអាក្រក់* លោកប៉ុលយល់ថា ខ្លួនគាត់នឹងស្លាប់ក្នុងពេលឆាប់ៗ(ខ.៦ និងការពន្យល់)។ ការប្រើពាក្យថា នឹងប្រោសឱ្យខ្ញុំរួចពីគ្រប់ការអាក្រក់នៅទីនេះ គឺសំដៅទៅលើខាងឯព្រលឹងវិញ្ញាណពុំមែនសំដៅទៅលើខាងឯសាច់ឈាមនោះទេ ។

**៤:១៩** *នាងព្រីស៊ីល និងអ្នកអ័គីឡា* មើលការពន្យល់ កច ១៨:២,១៨ ១កថ ១៦:១៩ និងការពន្យល់ ។ *អូនេសិភ័រ* មើលការពន្យល់ ១:១៦ ។

**៤:២០** *អេរ៉ាស្ទុស* មើល រម ១៦:២៣ និងការពន្យល់ ។ *ក្រុងកូរិនថូស* មើលសេចក្តីផ្តើមនៅក្នុងកូរិនថូសទី១ ។ *អ្នកទ្រភីម* មើលពន្យល់ កច ២០:៤ ។ *ក្រុងមីលេត* គឺជាក្រុងកំពង់ផែមួយដែលស្ថិតនៅលើឆ្នេរសមុទ្រអាស៊ីមីន័រ មានចម្ងាយប្រហែលជា៦៦,៧១គ.ម ពីទីក្រុងអេភេសូរភាគខាងត្បូង (មើលការពន្យល់ កច ២០:១៥)។

**៤:២១** *អ្នកលីណុស* ម្នាក់នេះគឺជាគ្រូគង្វាលនៅក្រុងរ៉ូមបន្ទាប់ពីលោកពេត្រុស និងលោកប៉ុលបានស្លាប់ទៅ ។ *ពួកបងប្អូនទាំងអស់គ្នា* "មើល រម ១:១៣"។

**៤:២២** *គង់នៅជាមួយនឹងវិញ្ញាណអ្នក* មើលពន្យល់ កទ ៦:១៨ ។ *ព្រះគុណ* មើលការពន្យល់ រម ១:៧ ។ *បានប្រកបដោយ (បានគង់ជាមួយ)* មើលការពន្យល់ ២កថ ១៣:១៤ ។ *អ្នករាល់គ្នា* បើតាមវគ្គចុងក្រោយនៃគម្ពីរធីម៉ូថេទី១ (មើលការពន្យល់ ១ធថ ៦:២១) ពាក្យនេះគឺជាពហុវចនៈដោយសំបុត្រនេះមានបំណងចង់ប្រកាសជាសាធារណៈដោយប្រើពាក្យថា "អ្នករាល់គ្នា"។ តែទោះបីជាយ៉ាងណាក៏ដោយពាក្យ "អ្នក" នៅខាងដើមឃ្លាក្នុងខនេះ ក៏បានប្រើជាឯកវចនៈដែលសំដៅទៅលើលោកធីម៉ូថេតែម្នាក់ប៉ុណ្ណោះ ។

សំបុត្ររបស់ប៉ុល

ដល់

# ទីតុស

សេចក្ដីផ្ដើម

**អ្នកនិពន្ធ**

អ្នកនិពន្ធកណ្ឌគម្ពីរទីតុសនេះគឺលោកប៉ុល (សូមមើល ១:១ និងសេចក្ដីផ្ដើមកណ្ឌគម្ពីរធីម៉ូថេទី១ ត្រង់ចំណុចអ្នកនិពន្ធ)។

**អ្នកទទួល**

សំបុត្រនេះត្រូវបានសរសេរទៅកាន់លោកទីតុស ជាអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទតាមរយៈលោកប៉ុល (១:៤ និងការពន្យល់) និងបានជួយលោកប៉ុលក្នុងការងារបម្រើរបស់គាត់ ។ នៅពេលលោកប៉ុលចាកចេញពីទីក្រុងអាន់ទីយ៉ូក ដើម្បីទៅពិភាក្សាអំពីដំណឹងល្អជាមួយពួកអ្នកដឹកនាំនៅក្រុងយេរូសាឡិម គាត់បាននាំលោកទីតុសទៅជាមួយ (កទ ២:១-៣) ដោយលោកប៉ុលមានជំហរយ៉ាងល្អក្នុងការទទួលលោកទីតុសជាសាសន៍ដទៃ មិនកាត់ស្បែក និងគ្មានទោសកំហុសផង (កទ ២:៣-៥)។ អាចសន្មតថា ឈ្មោះរបស់លោកទីតុសមិនបានលើកឡើងនៅក្នុងកណ្ឌគម្ពីរកិច្ចការទេ (ប៉ុន្តែ មាននិយាយអំពីគាត់ចំនួន១៣ដងនៅក្នុងកណ្ឌគម្ពីរសញ្ញាថ្មី)។ គាត់បានធ្វើការជាមួយលោកប៉ុលនៅទីក្រុងអេភេសូរ ក្នុងដំណើរបេសកកម្មលើកទីបីរបស់លោកប៉ុល ។ វាហាក់ដូចជាបញ្ជាក់ថា លោកទីតុសជាអ្នកនាំសំបុត្ររបស់លោកប៉ុលទៅកាន់ពួកជំនុំនៅទីក្រុងកូរិនថូស (សូមមើលសេចក្ដីផ្ដើមកណ្ឌគម្ពីរកូរិនថូសទី២)។ លោកប៉ុលបានបារម្ភអំពីការឆ្លើយតបជាអវិជ្ជមានរបស់ពួកជំនុំក្រុងកូរិនថូស ចំពោះសំបុត្រដែលនិយាយពីសេចក្ដីធ្ងន់ធ្ងរ ដូច្នេះហើយគាត់ក៏រៀបចំពេលជួបជាមួយលោកទីតុសនៅក្រុងទ្រអាស(២កថ ២:១២-១៣)។ ពេលមិនបានឃើញលោកទីតុស លោកប៉ុលក៏បន្តដំណើរទៅស្រុកម៉ាសេដូន ។ នៅទីនោះគាត់បានជួបលោកទីតុស និងបានកម្សាន្តចិត្តយ៉ាងខ្លាំងដោយបានឮដំណឹងល្អ អំពីពួកជំនុំនៅទីក្រុងកូរិនថូសដែលធ្លាប់តែមានបញ្ហាពីមុន (២កថ ៧:៦-៧,១៣-១៤)។ លោកទីតុសដែលបានរួមដំណើរដោយពួកបងប្អូនពីរនាក់ទៀត ជាអ្នកនាំ សំបុត្រទីពីរទៅទីក្រុងកូរិនថូស និងទទួលបានទំនួលខុសត្រូវចុងក្រោយក្នុងការរៀបចំការចាត់ចែងសម្រាប់ការកែតម្រូវនៅទីក្រុងកូរិនថូស កាលពីមួយឆ្នាំមុន(២កថ ៨:៦,១៦-១៧ និងការពន្យល់)។

ក្រោយពេលលោកប៉ុលត្រូវបានដោះលែងពីពន្ធនាគារលើកទីមួយនៅទីក្រុងរ៉ូម (កថ ២៨) គាត់ និងលោកទីតុសបានធ្វើការនៅកោះក្រេត(១:៥) បន្ទាប់មកលោកប៉ុលបានតាំងលោកទីតុសឱ្យនៅកោះក្រេតនោះ ក្នុងនាមជាអ្នកតំណាងរបស់គាត់ និងបំពេញនូវការងារខ្លះនៅទីនោះ(១:៥ ២:១៥ ៣:១២-១៣)។ លោកប៉ុលបានស្នើរសុំឱ្យលោកទីតុសមកជួបគាត់នៅឯទីក្រុងនីកូប៉ូល (៣:១២ និងការពន្យល់)។ ក្រោយមកទៀត លោកទីតុសបានធ្វើដំណើរបេសកកម្មទៅឯស្រុកដាល់ម៉ាទា (២ធថ ៤:១០ និងការពន្យល់) និងជាពាក្យចុងក្រោយដែលយើងដឹងអំពីគាត់ នៅក្នុងគម្ពីរសញ្ញាថ្មី ។ យោងតាមការងារដែលលោកទីតុសបានទទួល បញ្ជាក់ថាគាត់ជាមនុស្សមានសមត្ថភាព និងជាអ្នកដឹកនាំម្នាក់មានភាពឈ្លាសវៃ ។

**កោះក្រេត**

ជាកោះធំលំដាប់ទី៤នៅក្នុងសមុទ្រមេឌីទែរ៉ាណេ និងលាតសន្ធឹងទៅភាគខាងត្បូងសមុទ្រអេជិន (Aegean Sea) (ប្រៀបធៀប១សយ ៣០:១៤ កថ ២៧:៧-១៣)។ នៅក្នុងសម័យកាលសញ្ញាថ្មី ជីវិតនៅលើកោះក្រេត កម្រិតសីលធម៌បានធ្លាក់ចុះយ៉ាងខ្លាំង ។ ភាពមិនស្មោះត្រង់ លោភ ស៊ីធីក និងភាពខ្ជិលច្រអូស រហូតដល់មានជាសុភាសិតដែលនិយាយអំពីពួកអ្នកនៅកោះនោះទៀតផង (១:១២)។

**ឱកាស និងគោលបំណង**

លោកប៉ុលបានចាប់ផ្ដើមប្រកាសដំណឹងល្អនៅកោះក្រេត ក្នុងពេលដែលគាត់ និងលោកទីតុសបានទៅទីនោះ ហើយបន្ទាប់មកលោកប៉ុល បានទុកឱ្យលោកទីតុសនៅទីនោះ ដើម្បីរៀបចំពួកអ្នកជឿនៅទីនោះ ។ លោកប៉ុលផ្ញើសំបុត្រតាមរយៈលោកសេន៉ាស និងលោកអ័ប៉ុឡូស ដែលធ្វើដំណើរទៅកោះក្រេតនោះ (៣:១៣) ដើម្បីផ្ដល់ឱ្យលោកទីតុសនូវសិទ្ធិក្នុងការដឹកនាំក្នុងពួកជំនុំ និងក្នុងពេលជួបប្រទះការប្រឆាំងផ្សេងៗ (១:៥ ២:១, ៧-៨ ៣:៩) ហើយនិងផ្ដល់ការទូន្មានអំពីសេចក្ដីជំនឿ និងការប្រព្រឹត្ត និងព្រមានដល់ពួកគ្រូបង្រៀនខុសឆ្គង ។ លោកប៉ុលក៏បានប្រាប់លោកទីតុស នូវគម្រោងការរបស់គាត់នាពេលអនាគតផងដែរ (៣:១២)។

**ទីកន្លែងនិពន្ធ**

លោកប៉ុលអាចសរសេរសំបុត្រទីតុសនេះពីស្រុកម៉ាសេដូន ព្រោះគាត់មិនទាន់បានមកដល់ទីក្រុងនីកូប៉ូលនៅឡើយ (៣:១២)។

សំបុត្រនេះ ត្រូវបានសរសេរឡើងបន្ទាប់ពីលោកប៉ុលត្រូវបានដោះលែងពីពន្ធនាគាររបស់រ៉ូម៉ាំងជាលើកទីមួយ(កច ២៨) អាចនៅចន្លោះឆ្នាំ៦៣គ.ស និង៦៥ គ.ស ឬអាចក្រោយមកទៀត ។

**លក្ខណៈផ្សេងៗ**

ការដែលសំខាន់បំផុត គឺការបារម្ភអំពីលក្ខណៈរបស់ពួកប្រឆាំង និងបង្ហាញនូវសេចក្តីស្រឡាញ់ ហើយធ្វើការ និងបង្រៀននូវអ្វីដែលល្អ (១:៨,១៦ ២:៣,៧,១៤ ៣:១,៨,១៤) និងគោលលទ្ធិរបស់គ្រីស្ទបរិស័ទនៅសម័យមុន (២:១១–១៤ ៣:៤–៧)។

**គម្រោងសង្ខេប**

**I. ពាក្យជម្រាបសួរ (១:១–៤)**

**II. ការបារម្ភពីពួកចាស់ទុំ (១:៥–៩)**

ក. មូលហេតុចាកចេញពីលោកទីតុសនៅកោះក្រេត (១:៥)

ខ. គុណសម្បត្តិរបស់ពួកចាស់ទុំ (១:៦–៩)

**III. ការបារម្ភពីគ្រូខុសឆ្គង (១:១០–១៦)**

**IV. បារម្ភពីក្រុមផ្សេងៗនៅក្នុងពួកជំនុំ (ជំពូក ២)**

ក. ការទូន្មានចំពោះក្រុមផ្សេងៗ (២:១–១០)

ខ. មូលដ្ឋានសម្រាប់ការរស់នៅរបស់គ្រីស្ទបរិស័ទ (២:១១–១៤)

គ. ភារកិច្ចរបស់លោកទីតុស (២:១៥)

**V. បារម្ភអំពីអ្នកជឿទូទៅ (៣:៨–៨)**

ក. កាតព្វកិច្ចក្នុងនាមជាអ្នកជឿ (៣:១–២)

ខ. ការជម្រុញសម្រាប់ការប្រព្រឹត្តតាមព្រះបន្ទូល (៣:៣–៨)

**VI. បារម្ភអំពីភាពទទួលខុសត្រូវចំពោះការកំហុសខាងឯវិញ្ញាណ (៣:៩–១១)**

**VII. សន្និដ្ឋាន និងបណ្តាំចុងក្រោយ (៣:១២–១៥)**

**១** ១សំបុត្រប៉ុលខ្ញុំ ជាបាវបំរើនៃព្រះ[ក] ហើយជាសាវក[ខ]
របស់ព្រះយេស៊ូវគ្រីស្ទ សំរាប់ជាសេចក្តីជំនឿដល់ពួករើស
តាំងនៃព្រះ និងសេចក្តីចេះដឹងខាងឯសេចក្តីពិត[គ] ដែលត្រូវ
នឹងសេចក្តីគោរពប្រតិបត្តិដល់ព្រះ[ឃ] ២ដោយសេចក្តីសង្ឃឹម
ដល់ជីវិតដ៏នៅអស់កល្បជានិច្ច[ង] ដែលព្រះដ៏មិនចេះភូត[ច]
ទ្រង់បានសន្យាមុនអស់ទាំងកល្ប[ឆ] ៣តែនៅពេលកំណត់[ជ]
នោះទើបបានសំដែងចេញឱ្យស្គាល់ព្រះបន្ទូលទ្រង់[ឈ] ដោយ
ការប្រកាសប្រាប់ដែលផ្ញើទុកនឹងខ្ញុំ[ញ] តាមបង្គាប់របស់ព្រះ[ដ]
ដ៏ជាព្រះអង្គសង្គ្រោះនៃយើង[ឋ]។
៤ខ្ញុំផ្ញើមកអ្នកទីតុស[ឌ] ជាកូនពិត[ឍ]តាមសេចក្តីជំនឿ ដែល
យើងកាន់ជាមួយគ្នា សូមឱ្យអ្នកបានប្រកបដោយព្រះគុណ
និងសេចក្តីសុខសាន្ត មកអំពីព្រះដ៏ជាព្រះវរបិតា ហើយអំពី
ព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃយើងរាល់គ្នា[ណ]។

**១:១** ក រម ១:១ យក ១:១ ខ ១កថ ១:១ គ ១ធថ ២:៤ ឃ ១ធថ ២:២ **១:២** ង ទត ៣:៧ ២ថន ១:១ ច ជន ២៣:១៩ ហព ៦:១៨ ឆ ២ធថ ១:៩ **១:៣** ជ ១ធថ ២:៦ ៦:១៥ ឈ ២ធថ ១:១០ ញ ១ធថ ១:១១ ដ ២កថ ១:១ ១ធថ ១:១ ឋ លក ១:៤៧

## កិច្ចការដែលលោកទីតុសធ្វើនៅកោះក្រេត

*១:៦–៨ – ១ធថ ៣:២–៤*

៥ខ្ញុំបានទុកឱ្យអ្នកនៅកោះក្រេត[ត] ដើម្បីនឹងរៀបចំការ
ដែលនៅខ្វះ ឱ្យស្រួលបួលឡើង ហើយនឹងតាំងឱ្យមានពួក
ចាស់ទុំ[ថ]នៅគ្រប់ទាំងទីក្រុង ៦គឺបើមានអ្នកណាដែលរក
ចាប់ទោសមិនបាន[ទ] ដែលមានប្រពន្ធតែ១ ហើយមានកូន
ចៅជឿដែរ ឥតមានអ្នកណាចោទប្រកាន់ ថាជាមនុស្សខូច
អាក្រក់ ឬរឹងចចេសអ្វីឡើយ នោះត្រូវតាំងគេចុះ ដូចជាខ្ញុំ
បានបង្គាប់អ្នកហើយ ៧ដ្បិតគួរឱ្យអ្នកដែលត្រួតត្រា[ធ] បានឥត
សៅហ្មង ដូចជាអ្នកជំនួយរបស់ព្រះដែរ[ន] មិនត្រូវមានចិត្ត
មានះ ឆាប់ខឹង ចំណូលស្រា ច្រឡោត ឬស៊ីសំណូកឡើយ[ប]

**១:៤** ឌ ២កថ ២:១៣ ឍ ១ធថ ១:២ ណ រម ១:៧ **១:៥** ត កច ២៧:៧ ថ កច ១១:៣០ **១:៦** ទ ១ថន ៣:១៣ ១ធថ ៣:២ **១:៧** ធ ១ធថ ៣:១ ន ១កថ ៤:១ ប ១ធថ ៣:៣,៨

**១:១** *ប៉ុល* "មើលការពន្យល់ រម ១:១"។ *ជាបាវបំរើនៃព្រះ* មានតែនៅត្រង់ចំណុចនេះប៉ុណ្ណោះ ដែលលោកប៉ុលហៅខ្លួនគាត់ថា "បាវបម្រើនៃព្រះ"។ នៅកន្លែងផ្សេងទៀត គាត់ហៅខ្លួនគាត់ថា "បាវបម្រើរបស់ព្រះគ្រីស្ទ" (រម ១:១ កទ ១:១០ ភល ១:១)។ លោកយ៉ាកុបបានប្រើពាក្យទាំងពីរនេះតែម្តង (យក ១:១)។ *បាវបំរើ* "មើលការពន្យល់ រម ១:១"។ *សាវក* "មើលពន្យល់ ១កថ ១:១"។ *សំរាប់ជាសេចក្តីជំនឿ... និងសេចក្តីចេះដឹងខាងឯសេចក្តីពិត* សម្រាប់ការជ្រើសរើស និងការតែងតាំងលោកប៉ុលឱ្យធ្វើជាអ្នកបម្រើ និងជាសាវ័ករបស់ព្រះគ្រីស្ទ សូមមើលនៅក្នុង "ខ.២" (កច ៩:១៥ ២២:១៥ ២៦:១៦–១៨ និងការពន្យល់)។ *សេចក្តីគោរពប្រតិបត្តិដល់ព្រះ* "មើលការពន្យល់ ១ធថ ២:២"។

**១:២** *សេចក្តីសង្ឃឹម* "មើលការពន្យល់ កល ១:៥"។ *ជីវិតដ៏នៅអស់កល្បជានិច្ច* "មើលការពន្យល់ យហ ៣:១៥–១៦"។ *ព្រះដ៏មិនចេះភូត* គឺផ្ទុយនឹងពួកសាសន៍ក្រេត (ខ.១២) និងវិញ្ញាណអាក្រក់ (យហ ៨:៤៤)។ *មុនអស់ទាំងកល្ប* "មើលការពន្យល់ ២ធថ ១:៩"។

**១:៣** *នៅពេលកំណត់* ត្រង់ចំណុចនេះបញ្ជាក់ថា ហេតុការណ៍សំខាន់ៗកើតឡើង នៅក្នុងផែនការរបស់ព្រះអម្ចាស់ ត្រូវកើតឡើងតាមពេលវេលាដែលទ្រង់កំណត់នៅក្នុងប្រវត្តិសាស្ត្រ (មើលការពន្យល់ ១ធថ ២:៦ ៦:១៥)។ *ព្រះបន្ទូលទ្រង់* សំដៅលើព្រះបន្ទូល ប្រកបដោយអំណាចព្រះចេស្ដា ដែលមាននៅក្នុងព្រះគ្រីស្ទ ។ *ព្រះដ៏ជាព្រះអង្គសង្គ្រោះនៃយើង* មានបីដងក្នុងសំបុត្រនេះ ដែលហៅព្រះវរបិតាថាព្រះអង្គសង្គ្រោះ (បទគម្ពីរនេះ ២:១០ ៣:៤ និងមើលការពន្យល់ ១ធថ ១:១ ២:៣ ៤:១០) និងបីដងដែលព្រះយេស៊ូវត្រូវបានហៅថា ព្រះអង្គសង្គ្រោះ (ខ.៤ ២:១៣ ៣:៦ និងមើលការពន្យល់ ២ធថ ១:១០)។

**១:៤** *ជាកូនពិត* លោកទីតុស ក៏ដូចជាលោកធីម៉ូថេដែរ (១ធថ ១:២) គឺជាកូនខាងឯវិញ្ញាណរបស់លោកប៉ុល ព្រោះបានទទួលជឿដល់ព្រះអម្ចាស់តាមរយៈលោកប៉ុល ។ លោកអូនេសីមក៏បានហៅថា កូនរបស់លោកប៉ុលដែរ (ភម ១០)។ *ពិតតាមសេចក្តីជំនឿ* ជាសេចក្តីជំនឿដែលត្រូវសំដែងឡើងតាមរយៈអ្នកជឿពិតប្រាកដដល់ព្រះអម្ចាស់ ។ *ព្រះគុណ និងសេចក្តីសុខសាន្ត* "មើលការពន្យល់ រម ១:៧"។ *ព្រះអង្គសង្គ្រោះ* នៅក្នុងសេចក្តីផ្តើមនៃសំបុត្ររបស់លោកប៉ុល តែងតែប្រើពាក្យថា ព្រះអម្ចាស់ ។ លោកប៉ុលប្រើពាក្យថា ព្រះអង្គសង្គ្រោះចំនួន១២ដង នៅក្នុងសំបុត្ររបស់គាត់ ។

**១:៥** *ខ្ញុំបានទុកឱ្យអ្នកនៅកោះក្រេត* ត្រង់ចំណុចនេះបញ្ជាក់ថា លោកប៉ុលនិងលោកទីតុសធ្លាប់បានទៅកោះក្រេតជាមួយគ្នា ក្នុងដំណើរបេសកកម្មរបស់គាត់ ប៉ុន្តែ ហេតុការណ៍នោះមិនបានបញ្ជាក់នៅក្នុងកណ្ឌគម្ពីរកិច្ចការទេ ។ ក្នុងដំណើររបស់លោកប៉ុលទៅឯទីក្រុងរ៉ូម ក្នុងនាមជាអ្នកទោស គាត់បានចូលទៅសួរសុខទុក្ខ ពួកអ្នកនៅកោះក្រេត (កច ២៧:៧–៨) ប៉ុន្តែនៅត្រង់ចំណុចនេះ លោកប៉ុលត្រូវ បានគេដោះលែងចេញពីពន្ធនាគារនៅទីក្រុងរ៉ូម ។ គាត់មានសេរីភាពធ្វើដំណើរ ទៅកន្លែងដែលគាត់ចង់ទៅ (មើលការពន្យល់ ៣:១២)។ *តាំងឱ្យមានពួកចាស់ទុំ* លោកប៉ុល និងលោកទីតុសធ្លាប់បានប្រកាសដំណឹងល្អ នៅកោះក្រេតរួចហើយ ទោះជាយ៉ាងណាក៏ដោយ ក៏ពួកគាត់មិនមានពេលសម្រាប់រៀបចំពួកជំនុំទេ ។ ការតាំងឱ្យមានពួកចាស់ទុំ តែងមានទំនាក់ទំនង ជាមួយនឹងការអនុវត្តជាក់ស្តែងរបស់លោកប៉ុល (មើលការពន្យល់ កច ១៤:២៣)។

**១:៦–៩** នៅក្នុងកណ្ឌគម្ពីរ "១ធថ ៣:១–៧" បានផ្តល់នូវតារាងនៃគុណសម្បត្តិសម្រាប់ពួកចាស់ទុំ និងអ្នកដឹកនាំ ។

**១:៦** *មានប្រពន្ធតែ១* ព្រោះពួកចាស់ទុំត្រូវបានជ្រើសរើសក្នុងចំណោមអស់អ្នកដែលមានវ័យចាស់ៗ ដូច្នេះបញ្ជាក់ថា ពួកចាស់ទុំទាំងនោះបានរៀបការ និងមានកូនចៅរួចហើយ ។ រីឯអស់អ្នកដែលមានសមត្ថភាព និងមិនមានប្រពន្ធ មិនត្រូវបានហាមឃាត់ទេ ។ ការនេះក៏ហាក់ដូចជាមិនហាមឃាត់ដល់ពួកអ្នកដែលរៀបការម្តងទៀត ក្រោយពេលដែលប្រពន្ធរបស់ខ្លួនបានស្លាប់ហើយនោះដែរ (រម ៧:២–៣ ១កថ ៧:៣៩)។ អត្ថន័យដែលសំខាន់បំផុតគឺត្រូវឱ្យមានភាពស្មោះត្រង់រវាងប្តីមួយ និងប្រពន្ធមួយ (មើលការពន្យល់ ១ធថ ៣:២)។

**១:៧** *អ្នកដែលត្រួតត្រា* ពាក្យថា "ពួកចាស់ទុំ" នៅក្នុង "ខ.៥" និងពាក្យថា "អ្នកដែលត្រួតត្រា" នៅក្នុង "ខ.៧" បញ្ជាក់ថា ពាក្យទាំងពីរនេះអាចប្រើប្រាស់ផ្លាស់ប្តូរគ្នាបាន (កច ២០:១៧,២៨ ១ពត ៥:១–២ និងការពន្យល់)។

៨ត្រូវមានចិត្តចៅរ៉ៅ[ផ] ស្រឡាញ់ការល្អ[ព] មានចិត្តធ្ងន់ធ្ងរ[ភ]
ហើយសុចរិត បរិសុទ្ធ ដឹងខ្នាតវិញ ៩ព្រមទាំងកាន់ខ្ជាប់តាម
ព្រះបន្ទូលដ៏ពិត[ម] ដូចជាបានបង្រៀនមកយើងហើយ ដើម្បី
ឱ្យអាចនឹងកំសាន្តចិត្តគេ ដោយសេចក្ដីបង្រៀនដ៏ត្រឹមត្រូវ[យ]
ហើយឱ្យបានផ្ចាញ់ដល់ពួកអ្នកដែលស្រដីទទឹង ។
១០ដ្បិតមានមនុស្សជាច្រើន គឺក្នុងពួកអ្នកកាត់ស្បែកជាដើម
ដែលរឹងរូស ជាពួកអ្នកដែលពោលពាក្យឥតប្រយោជន៍[រ]
ហើយបង្ខូចគំនិតមនុស្ស[ល] ១១ត្រូវតែបំបាត់មាត់គេ ដ្បិតគេ
ផ្ដួលពួកអ្នកផ្ទះទាំងមូល[វ] ដោយបង្រៀនសេចក្ដីដែលមិន
គួរគប្បី ឱ្យតែបានកំរៃដ៏លាមក ១២មានពួកគេម្នាក់ គឺជា
ហោរារបស់ផងគេ[ស]បានថា ពួកសាសន៍ក្រេត[ហ]ចេះតែភូត
កុហក ជាសត្វព្រៃកំណាច ជាពួកល្មោភហើយកំជិល
១៣សេចក្ដីបន្ទាល់នេះត្រូវណាស់ ដូច្នេះត្រូវរំឭក[ឡ]ឱ្យគេដឹង
ខ្លួនដោយតឹងរ៉ឹង ដើម្បីឱ្យគេមានសេចក្ដីជំនឿត្រឹមត្រូវវិញ[អ]
១៤ឥតស្ដាប់តាមរឿងទំនៀមនៃសាសន៍យូដា[ក] ឬតាមសេចក្ដី
បញ្ញត្តិ[ខ]របស់មនុស្ស ដែលបែរចេញពីសេចក្ដីពិតនោះ
ឡើយ[គ] ១៥គ្រប់ទាំងអស់ជាស្អាត[ឃ]ដល់អ្នកណាដែលស្អាត តែ
គ្មានអ្វីស្អាតសោះ[ង] ដល់ពួកអ្នកដែលស្មោកគ្រោក ហើយ
មិនជឿវិញនោះឡើយ គេស្មោកគ្រោកទាំងគំនិត ទាំង
បញ្ញាចិត្តដែរ[ច] ១៦គេប្រកាន់ថា គេស្គាល់ព្រះ តែកិរិយា
ប្រព្រឹត្តរបស់គេមិនព្រមស្គាល់ព្រះទេ[ឆ] ដ្បិតគេជាមនុស្ស
គួរខ្ពើម ហើយរឹងចចេស គឺជាមនុស្សឥតមានប្រយោជន៍អ្វី
ដល់ការល្អទាំងអស់[ជ] ។

## សេចក្ដីដែលត្រូវបង្រៀនដល់ក្រុមផ្សេងៗ

**២** ១ចូរឱ្យអ្នកនិយាយតែសេចក្ដីណា ដែលសំណាំនឹង
សេចក្ដីបង្រៀនដ៏ត្រឹមត្រូវ[ឈ] ២ត្រូវទូន្មានឱ្យពួកចាស់ៗ[ញ]ដឹង

**១:៨** ផ រម ១២:១៣ ព ២ធថ ៣:៣ ភ ទត ២:២,៥,៦,១២
**១:៩** ម ១កថ ១៦:១៣ ១ធថ ១:១៩ ២ធថ ១:១៣ ៣:១៤ យ ១ធថ ១:១០
**១:១០** រ ១ធថ ១:៦ ល កច ១០:៤៥ ១១:២
**១:១១** វ ១ធថ ៥:១៣
**១:១២** ស កច ១៧:២៨ ហ កច ២:១១
**១:១៣** ឡ ១ធថ ៥:២០ អ ទត ២:២
**១:១៤** ក ១ធថ ១:៤ ខ កល ២:២២ គ ២ធថ ៤:៤

**១:១៥** ឃ ទដ ១៨:២៦ មថ ១៥:១០,១១ មក ៧:១៤–១៩ កច ១០:៩–១៦,២៨ កល ២:២០–២២ ង រម ១៤:១៤,២៣ ច ១ធថ ៦:៥ **១:១៦** ឆ យរ ៥:២ ១២:២ ១យហ ២:៤ ជ ហស ៨:២,៣ **២:១** ឈ ១ធថ ១:១០
**២:២** ញ ១ធថ ៥:១ ដ ១ធថ ៣:២ ឋ ខ.៥,៦,១២ ទត ១:៨

ពួកចាស់ទុំត្រូវមានសមត្ថភាព (ពេញវ័យខាងជំនឿ និងបទពិសោធន៍) ហើយអ្នកត្រួតត្រាទាមទារនូវទំនួលខុសត្រូវ (មើលការខុសត្រូវលើហ្វូងចៀមរបស់ព្រះអម្ចាស់)។

**១:៨** *មានចិត្តធ្ងន់ធ្ងរ* ត្រង់ចំណុចនេះបញ្ជាក់ថា គុណធម៌មានសារសំខាន់ណាស់ ចំពោះពួកអ្នករស់នៅកោះក្រេត (ខ.១០–១៤)។ លោកប៉ុលនិយាយអំពីសេចក្ដីនេះចំនួន៥ដងនៅក្នុងពីរជំពូកដំបូង(២:២,៥–៦,១២)។ *ដឹងខ្នាត* គឺមានកម្លាំងខាងក្នុងដែលគ្រប់គ្រងលើបំណងប្រាថ្នា និងសកម្មភាពផ្សេងៗ។

**១:៩** *សេចក្ដីបង្រៀនដ៏ត្រឹមត្រូវ* ជាសេចក្ដីបង្រៀនពិតប្រាកដ ដែលពួកសាវកទទួលបានពីព្រះអម្ចាស់ (១ធថ ១:១០ ៦:៣ ២ធថ ១:១៣ ៤:៣)។ សេចក្ដីបង្រៀននេះត្រូវឈរនៅលើសេចក្ដីជំនឿ ព្រោះវាការពារប្រឆាំងនឹងភាពពុករលួយនៃសេចក្ដីបង្រៀនខុសឆ្គង ។ សេចក្ដីបង្រៀនដ៏ត្រឹមត្រូវ គឺជាសេចក្ដីដ៏សំខាន់ដែលមាននិយាយនៅគ្រប់សំបុត្ររបស់លោកប៉ុល (ខ.១៣ ២:១–២ ១ធថ ១:១០ ៦:៣ ២ធថ ១:១៣ ៤:៣)។

**១:១០** *ពួកអ្នកកាត់ស្បែកជាដើម ដែលរឹងរូស* គឺរឹងរូសប្រឆាំងព្រះបន្ទូលនៃព្រះអម្ចាស់ ហើយប្រឆាំងនឹងលោកប៉ុល និងលោកទីតុស ក្នុងនាមពួកគាត់ជាអ្នកបម្រើរបស់ទ្រង់ ។ ពួកអ្នករឹងរូសទាំងនោះ មានលក្ខណៈបីយ៉ាង (១).ពួកគេស្ថិតនៅក្នុងក្រុមដែលកាត់ស្បែក ដូចជាពួកអ្នកដែលមានបញ្ជាក់នៅក្នុង "កទ ២:១២" ដែលជឿថា ការសង្គ្រោះ ឬការញែកជាបរិសុទ្ធ គឺត្រូវធ្វើពិធីកាត់ស្បែក និងកាន់តាមក្រិត្យវិន័យនៃទំនៀមទម្លាប់ពួកសាសន៍យូដា (២).ពួកគេប្រកាន់យក នូវរឿងព្រេងរបស់ពួកសាសន៍យូដា (ខ.១៤) និងរឿងពង្សាវតារ ផ្សេងៗ (៣:៩ និងការពន្យល់ ១ធថ ១:៤) (៣).ពួកគេជាអ្នកដែលប្រតិបត្តិនូវការឥតប្រណីដល់រូបសាច់ (ខ.១៤–១៥) និងប្រឆាំងនឹងអ្វីដែលព្រះអម្ចាស់មានបន្ទូលថាល្អ ។ *ពួកអ្នកដែលពោលពាក្យឥតប្រយោជន៍* លោកប៉ុលប្រើពាក្យសម្ដីស្រដៀងគ្នានេះ ក្នុងសំបុត្ររបស់គាត់ទៅលោកធីម៉ូថេអំពីប្រភេទមនុស្សយ៉ាងដូច្នេះ (១ធថ ១:៦)។

**១:១៣** *សេចក្ដីជំនឿ* "មើលការពន្យល់ ១ធថ ៣:៩"។

**១:១៤** *រឿងទំនៀមនៃសាសន៍យូដា* "មើលការពន្យល់ ខ.១០"។

**១:១៥** *គ្រប់ទាំងអស់ជាស្អាត ដល់អ្នកណាដែលស្អាត* បញ្ជាក់ថា អស់អ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទ ត្រូវបានសម្អាតដោយការសុគតរបស់ទ្រង់ នោះគ្រប់អ្វីដែលទ្រង់ប្រទានឱ្យពួកគេគឺបរិសុទ្ធ បើគេទទួលដោយអរព្រះគុណទ្រង់ (១ធថ ៤:៤ និងការពន្យល់)។ *គ្មានអ្វីស្អាតសោះ ដល់ពួកអ្នកដែលស្មោកគ្រោក* មានន័យថា សម្រាប់អស់អ្នកមិនទទួលជឿដល់ព្រះយេស៊ូវ ជាពិសេសសំដៅលើពួកអ្នកដែលប្រតិបត្តិនូវការឥតប្រណីដល់រូបសាច់ ដែលប្រឆាំងនឹងការបរិភោគអាហារ ផ្សេងៗ ការរៀបអាពាហ៍ពិពាហ៍ និងការ ផ្សេងៗជាច្រើនទៀត (ប្រៀបធៀបកល ២:២១ ១ធថ ៤:៣ និងការពន្យល់) ហើយដែលមិនសប្បាយនឹងសេរីភាពនៃភាពជាគ្រីស្ទបរិស័ទពិតប្រាកដទេ ។ ផ្ទុយទៅវិញ ពួកគេបានបង្កើតឡើងនូវបម្រាម និងការបំពានដែលពួកគេគិតថាមិនបរិសុទ្ធ (មថ ១៥:១០–១១ ១៦–២០ កច ១០:៩–១៦ រម ១៤:២០)។ សេចក្ដីបង្រៀននៅក្នុងបទគម្ពីរនេះ មិនមានភាពផ្ទុយគ្នានឹងបទគម្ពីរដទៃទៀតនៅក្នុងព្រះគម្ពីរសញ្ញាថ្មីទេ គឺបង្រៀនអំពីការប្រឆាំងនឹងសេចក្ដីខុសឆ្គង ផ្នែកសីលធម៌ និងខាងវិញ្ញាណ ។ *បញ្ញាចិត្ត* "មើលពន្យល់ ១ធថ ៤:២–៣"។

**១:១៦** *តែកិរិយាប្រព្រឹត្តរបស់គេមិនព្រមស្គាល់ព្រះទេ* សំដៅលើពួកគ្រូខុសឆ្គង ដែលឈរបញ្ជាដោយចរិតលក្ខណៈរបស់ខ្លួន ។ *ការល្អ* ចំណេះដឹងត្រឹមត្រូវគឺជាការសំខាន់បំផុត ពីព្រោះវានាំទៅដល់ការ គោរពប្រតិបត្តិដល់ព្រះ (ខ.១)។ លោកប៉ុលបានបញ្ជាក់យ៉ាងច្បាស់អំពីតុល្យភាព រវាងគោលលទ្ធិនិងការអនុវត្ត ជាក់ស្តែង ។

**២:១** *ចូរឱ្យអ្នកនិយាយ* នេះជាពាក្យសង្កត់ធ្ងន់ដែលលោកប៉ុលផ្ដល់ដំបូន្មានដល់លោកទីតុស ដើម្បីបង្ហាញនូវភាពផ្ទុយគ្នារវាងការងាររបស់លោកទីតុស និងពួកគ្រូខុសឆ្គង ដូចបានរៀបរាប់នៅក្នុងបទគម្ពីរខាងលើ (១:១០–១៦)។ *សេចក្ដីបង្រៀនដ៏ត្រឹមត្រូវ* "មើលការពន្យល់ ១:៩"។

**២:២–១០** ការដឹកនាំត្រឹមត្រូវទាមទារនូវសេចក្ដីបង្រៀនដ៏ត្រឹមត្រូវ ដោយមិនគិតពីអាយុ ភេទ ឬឋានៈឡើយ ។

**២:២** ពួកអ្នកដែលមានវ័យចាស់ ដូចជាពួកចាស់ទុំ ត្រូវតែធ្វើជាគំរូដល់អ្នកដទៃទៀតផ្នែកសីលធម៌ និងខាងឯវិញ្ញាណ ។ *ដឹងខ្នាត* ជំនួសឱ្យភាពខ្ជិល

ខ្នាត[ដ] មានចិត្តនឹងធឹង[ឋ] ហើយធ្ងន់ធ្ងរ ឱ្យមានសេចក្ដីជំនឿ[ឌ]
សេចក្ដី ស្រឡាញ់ នឹងសេចក្ដីខ្ជាប់ខ្ជួនដ៏ត្រឹមត្រូវផង ៣ឱ្យ
ស្ត្រីចាស់ៗបានបែបដូចគ្នា ទាំងប្រព្រឹត្តបែបគួរនឹងពួក
ស្ត្រីបរិសុទ្ធ មិនត្រូវនិយាយដើមគេ[ឍ] ឬជាប់ស្រាទំពាំង
បាយជូរ[ណ]ឡើយ ត្រូវខំបង្រៀនសេចក្ដីត្រឹមត្រូវវិញ ៤ដើម្បី
នឹងបង្ហាត់ដល់ពួកស្ត្រីក្មេងៗ[ត] ឱ្យគេស្រឡាញ់ប្ដីនឹង កូនខ្លួន
៥ឱ្យមានចិត្តធ្ងន់ធ្ងរ[ថ] ហើយបរិសុទ្ធ ជាអ្នករវល់តែនឹង
ការនៅផ្ទះខ្លួន[ទ] ហើយមានចិត្តល្អ នឹងចុះចូលចំពោះប្ដី[ធ]
ដើម្បីកុំឱ្យមានអ្នកណាប្រមាថដល់ព្រះបន្ទូលបានឡើយ[ន]។
៦ចូរទូន្មានពួកបុរស ដែលក្មេងជាង[ប] បែបដូច្នោះដែរឱ្យ
គេមានចិត្តធ្ងន់ធ្ងរ[ផ] ៧ហើយត្រូវឱ្យអ្នកសំដែងខ្លួន ទុកជាគំរូ[ព]
ពីការល្អគ្រប់ជំពូក[ភ] ទាំងបង្រៀនគេ កុំឱ្យគេប្រព្រឹត្តខូច
អាក្រក់ឡើយ តែឱ្យមានចិត្តនឹងធឹងវិញ ៨ព្រមទាំងពាក្យសំដី
ត្រឹមត្រូវ ដែលរកចាប់ទោសមិនបានផង ដើម្បីឱ្យអ្នកណា
ដែលទទឹងទទែងបានអៀនខ្មាស ដោយគ្មានហេតុនឹង
និយាយអាក្រក់ពីអ្នកឡើយ[ម]។
៩ចូរឱ្យពួកបាវបំរើចុះចូលនឹងចៅហ្វាយខ្លួន ទាំងផ្គាប់
ចិត្ត ក្នុងគ្រប់ការទាំងអស់[យ] ឥតប្រកែក ១០ឥតលួចបំបាត់
ឡើយ ត្រូវសំដែងខ្លួនជាស្មោះត្រង់ល្អគ្រប់ជំពូក ដើម្បីឱ្យ
បានតាក់តែងសេចក្ដីបង្រៀនរបស់ព្រះ ដ៏ជាព្រះអង្គ
សង្គ្រោះ[រ] នៃយើងរាល់គ្នា ក្នុងគ្រប់ការទាំងអស់[ល]។
១១ព្រះគុណ[វ]នៃព្រះ ដែលនាំសេចក្ដីសង្គ្រោះមកដល់
មនុស្សទាំងឡាយ[ស] បានលេចមកហើយ[ហ] ១២ទាំងបង្ហាត់
បង្រៀនយើងរាល់គ្នា ឱ្យលះចោលសេចក្ដីទមិលល្មើស និង
សេចក្ដីប៉ងប្រាថ្នាក្នុងលោកនេះ[ឡ] ហើយឱ្យរស់នៅក្នុង
សម័យនេះ ដោយសេចក្ដីធ្ងន់ធ្ងរ[អ] សេចក្ដីសុចរិត[ក] ហើយ
ដោយគោរពប្រតិបត្តិដល់ព្រះវិញ ១៣ទាំងរង់ចាំសេចក្ដី
សង្ឃឹមដ៏មានពរ គឺឱ្យបានឃើញដំណើរលេចមក នៃ
សិរីល្អ[ខ]របស់ព្រះដ៏ជាធំ និងព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គ

**២:២** ឌ ទត ១:១៣
**២:៣** ឍ ១ធថ ៣:១១ ណ ១ធថ ៣:៨
**២:៤** ត ១ធថ ៥:២
**២:៥** ថ ខ.២,៦,១២ ទត ១:៨ ទ ១ធថ ៥:១៤ ធ អភ ៥:២២ ន ១ធថ ៦:១ ហព ៤:១២
**២:៦** ប ១ធថ ៥:១ ផ ខ.២,៥,១២ ទត ១:៨
**២:៧** ព ១ធថ ៤:១២ ភ ខ.១៤
**២:៨** ម ១ពត ២:១២
**២:៩** យ អភ ៦:៥
**២:១០** រ លក ១:៤៧ ល មថ ៥:១៦
**២:១១** វ រម ៣:២៤ ស ២ធថ ១:១០ ហ ១ធថ ២:៤
**២:១២** ឡ ទត ៣:៣ អ ខ.២,៥,៦ ទត ១:៨ ក ២ធថ ៣:១២
**២:១៣** ខ ១កថ ១:៧ ១ធថ ៦:១៤

ច្រអូស ដូចពួកអ្នករស់នៅកោះក្រេតជាទូទៅ (១:១២)។ ពួកអ្នកជឿជាចាស់ទុំត្រូវមានភាពទទួលខុសត្រូវ និងការយល់ដឹង ។

**២:៣** បទគម្ពីរនេះបញ្ជាក់ថា គំរូនៃសីលធម៌ត្រូវអនុវត្តចំពោះស្ត្រី ដូចគ្នានឹងបុរសដែរ ។ *មិនត្រូវនិយាយដើមគេ* បញ្ជាក់ថា ការនិយាយដើមគេ តែងតែកើតមានឡើងជាទូទៅនៅក្នុងចំណោមពួកស្រីៗសាសន៍ក្រេត ។ *ជាប់ស្រាទំពាំងបាយជូរឡើយ* "សូមប្រៀបធៀបនឹង ១:៧ ១ធថ ៣:៣,៨"។

**២:៤** *ឱ្យគេស្រឡាញ់ប្ដី* គឺដូចជាបុរសដែលត្រូវស្រឡាញ់ប្រពន្ធរបស់ខ្លួនដូច្នោះដែរ (អភ ៥:២៥)។

**២:៥** *ចុះចូលចំពោះប្ដី* "មើលការពន្យល់ អភ ៥:២២ កល ៣:១៨ ១ពត ៣:១"។ *កុំឱ្យមានអ្នកណាប្រមាថដល់ព្រះបន្ទូលឡើយ* នៅត្រង់ចំណុចនេះបញ្ជាក់អំពីការយក ចិត្តទុកដាក់ខាងឯវិញ្ញាណរបស់លោកប៉ុលនៅក្នុងការទូន្មាននេះ ។ សូមមើលនៅ ក្នុង ខ.៨,១០ ដែលបញ្ជាក់អំពីការដោះស្រាយទាក់ទងទៅនឹងជីវិតរស់នៅរបស់គ្រីស្ទបរិស័ទដែលគួរតែជួយ ជាជាងរារាំងការចម្រើនឡើងនៃដំណឹងល្អ ។

**២:៧–៨** ត្រង់ចំណុចនេះបញ្ជាក់ថា ប្រហែលជាលោកទីតុសនៅវ័យក្មេង និងមិនសូវទទួលបានការគោរព ពីសំណាក់ពួកជំនុំជាសាសន៍ក្រេតទេ ។ ការទូន្មានដល់ពួកអ្នកដឹកនាំ តម្រូវឱ្យមានមិនគ្រាន់តែពាក្យសំដីរបស់គេប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងទាក់ទងនឹងគំរូនៃជីវិតរបស់គាត់ទៀតផង(យក ៣:១ និងការពន្យល់)។

**២:៩–១០** ការទូន្មានសម្រាប់ក្រុមផ្សេងៗនៅក្នុងពួកជំនុំ ។ ភាពជាទាសករគឺជាកត្តាមូលដ្ឋាននៃសង្គមរ៉ូម៉ាំង ហើយឥទ្ធិពលរបស់គ្រីស្ទបរិស័ទ ទៅលើអ្នកបម្រើគឺការមួយគួរឱ្យចាប់អារម្មណ៍ ។ ការណែនាំចំពោះការប្រព្រឹត្តិរបស់គ្រីស្ទបរិស័ទដែលជាអ្នកបម្រើ មានសារសំខាន់ណាស់ (មើលការពន្យល់ អភ ៦:៥)។

**២:៩** *ចៅហ្វាយ* ពាក្យនេះនៅក្នុងភាសាក្រិកគឺសំដៅលើម្ចាស់ដែលមានអំណាចទាំងអស់លើបាវបម្រើ ។ បាវបម្រើសាសន៍រ៉ូម៉ាំងពុំមានសិទ្ធិស្របច្បាប់ទេ ហើយអនាគតរបស់ពួកគេ គឺអាស្រ័យលើចៅហ្វាយរបស់គេទាំងស្រុង (មើលការពន្យល់ កល ៣:២២–៤:១)។

**២:១០** អ្នកបម្រើជាគ្រីស្ទបរិស័ទអាចបង្ហាញនូវទីបន្ទាល់ដ៏ល្អ និងប្រកបដោយអំណាចក្នុងការឆ្លើយតបទៅនឹងដំណឹងល្អ ដោយភាពស្មោះត្រង់ និងការស្ដាប់បង្គាប់ចៅហ្វាយរបស់ពួកគេ ។

**២:១១–១៤** ត្រង់ចំណុចនេះបង្ហាញនូវលទ្ធផលនៃព្រះគុណ ដែលមានចំពោះអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទគ្រប់គ្នា ។ ដោយសារតែព្រះគុណធ្វើឱ្យពួកអ្នកដែលធ្លាប់តែមិនគោរពប្រតិបត្តិដល់ព្រះអម្ចាស់ បានវិលមកឯទ្រង់វិញ និងរស់នៅដោយគោរពប្រតិបត្តិដល់ទ្រង់វិញ ។ លោកប៉ុលមានប្រសាសន៍យ៉ាងទទូចថា អស់អ្នកដែលជារបស់ព្រះគ្រីស្ទ គឺត្រូវរស់នៅដោយគោរពប្រតិបត្តិដល់ទ្រង់ (ខ.១–២,៤–៥,១០ ៣:៨)។

**២:១១** ការប្រព្រឹត្តិត្រឹមត្រូវគឺទាមទារនូវគោលលទ្ធិដ៏ត្រឹមត្រូវ ។ *ព្រះគុណនៃព្រះ* សេចក្ដីស្រលាញ់របស់ព្រះអម្ចាស់ ដែលយើងមិនស័ក្តិសមនឹងទទួលត្រូវបានសំដែងឡើង តាមរយៈព្រះគ្រីស្ទ ក្នុងពេលដែលយើងស្ថិតនៅក្នុងអំពើបាបនៅឡើយ (រម ៥:៦–១០)។ ដោយសារតែព្រះគុណនេះហើយទើបយើងបានសង្គ្រោះ គឺមិនមែនដោយព្រោះការប្រព្រឹត្តិ និងការកាន់តាមសាសនានោះទេ (៣:៥ អភ ២:៨–៩ រម ៥:៦–១០ និងការពន្យល់)។ ប៉ុន្តែព្រះគុណដដែលនេះបង្រៀនយើងឱ្យដឹងថា ការសង្គ្រោះត្រូវបង្កើតការល្អ (ខ.១៤ អភ ២:១០ និងការពន្យល់)។

**២:១២** *បង្ហាត់បង្រៀនយើងរាល់គ្នា* ពាក្យថា "បង្រៀន" មិនមែនគ្រាន់តែសំដៅលើការទូន្មានប៉ុណ្ណោះទេ គឺមានរួមបញ្ចូលនូវដំណើរការហ្វឹកហ្វឺនទាំងមូល ដោយមានការលើកទឹកចិត្ត ការកែតម្រង់ និងការពិន័យផងដែរ ។ *នៅក្នុងសម័យនេះ* "មើលការពន្យល់ ២កថ ៤:៤"។

**២:១៣** *សេចក្ដីសង្ឃឹមដ៏មានពរ . . . ដំណើរលេចមកនៃសិរីល្អ* សំដៅលើការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ (១ធថ ៦:១៤ ២ធថ ៤:១ និងមើល ការពន្យល់ ៤:៨)។

សង្គ្រោះនៃយើង[ក] 14 ដែលទ្រង់បានថ្វាយព្រះអង្គទ្រង់ជំនួស
យើងរាល់គ្នា[ឃ] ដើម្បីនឹងលោះយើងឱ្យរួចពីគ្រប់ទាំង
សេចក្ដីទទឹងច្បាប់[ង] ហើយនឹងសំអាត[ច]មនុស្ស១ពួក ទុកដាច់
ជារាស្ត្ររបស់ផងទ្រង់[ឆ] ដែលឧស្សាហ៍ធ្វើការល្អ[ជ]។
15 ចូរប្រាប់សេចក្ដីទាំងនេះ ទាំងទូន្មាន ហើយរំឭកគេ
ឱ្យដឹងខ្លួន ដោយគ្រប់ទាំងអំណាច កុំឱ្យអ្នកណាមើលងាយ
អ្នកឡើយ ។

## ការធ្វើគ្រប់ទាំងការល្អ

**៣** 1 ចូររំឭកគេ ឱ្យចុះចូលនឹងពួកនាម៉ឺន ហើយនឹងពួកមាន
អំណាចទាំងអស់[ឈ] ព្រមទាំងស្ដាប់បង្គាប់ ហើយប្រុងប្រៀប
ធ្វើគ្រប់ទាំងការល្អ[ញ] 2 មិនត្រូវនិយាយអាក្រក់ពីអ្នកណា[ដ] ឬ
ឈ្លោះប្រកែកឡើយ ត្រូវមានចិត្តស្លូតបូត ទាំងសំដែង
សេចក្ដីសុភាពគ្រប់យ៉ាង ដល់មនុស្សទាំងអស់ផង 3 ដ្បិត
ពីដើម[ឋ] យើងរាល់គ្នាក៏ជាមនុស្សឥតប្រាជ្ញា រឹងចចេស
ហើយវង្វេងដែរ ទាំងបំរើសេចក្ដីប៉ងប្រាថ្នា នឹង
សេចក្ដីសំរើបផ្សេងៗ ទាំងរស់នៅដោយសេចក្ដីគំរក់ នឹង
សេចក្ដីឈ្នានីស យើងក៏គួរខ្ពើម ហើយបានស្អប់គ្នាទៅវិញ
ទៅមកដែរ 4 តែកាលសេចក្ដីសប្បុរស[ឌ] របស់ព្រះដ៏ជាព្រះ
អង្គសង្គ្រោះនៃយើង[ឍ] និងសេចក្ដីស្រឡាញ់របស់ទ្រង់ ដល់
មនុស្សបានលេចមកឱ្យឃើញ[ណ] 5 នោះទ្រង់បានជួយសង្គ្រោះ
យើង[ត] មិនមែនដោយការដែលយើងបានប្រព្រឹត្ត ដោយ
សុចរិតនោះទេ[ថ] គឺដោយសេចក្ដីមេត្តាករុណារបស់ទ្រង់
វិញ[ទ] ដោយសារការសំអាត[ធ]នៃសេចក្ដីកើតជាថ្មី ហើយការ
ប្រោសជាថ្មីឡើងវិញ[ន] នៃព្រះវិញ្ញាណបរិសុទ្ធ 6 ដែលទ្រង់
បានចាក់មកលើយើង[ប]ជាបរិបូរ ដោយសារព្រះយេស៊ូវ
គ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃយើង 7 ដើម្បីកាលណាយើង
បានរាប់ជាសុចរិត ដោយសារព្រះគុណទ្រង់[ផ] នោះឱ្យយើង
បានត្រឡប់ជាអ្នកគ្រងមរដក[ព] តាមសេចក្ដីសង្ឃឹម[ភ]ដល់
ជីវិតដ៏នៅអស់កល្បជានិច្ច[ម] 8 ពាក្យនេះគួរជឿ[យ] ហើយខ្ញុំចង់
បញ្ជាក់អ្នក ពីសេចក្ដីទាំងនេះឱ្យច្បាស់ ដើម្បីឱ្យពួកអ្នក
ដែលបានជឿដល់ព្រះ បានខំប្រឹងនឹងធ្វើការល្អ[រ]អស់ពីចិត្ត
នោះទើបល្អ ហើយមានប្រយោជន៍ដល់មនុស្ស 9 ប៉ុន្តែ
ចូរចៀសវាង[ល]ពីសេចក្ដីដេញដោលយ៉ាងល្ងីល្ងើ នឹងពី
រឿងពង្សាវតារ ហើយពីសេចក្ដីឈ្លោះប្រកែក នឹងសេចក្ដី
ជជែក[វ]ពីក្រឹត្យវិន័យចេញទៅ[ស] ដ្បិតសេចក្ដីទាំងនោះសុទ្ធ
តែឥតប្រយោជន៍ ហើយឥតអំពើទាំងអស់[ហ] 10 ឯមនុស្ស
ណាដែលបង្កើតបក្សពួក នោះត្រូវកាត់គេចោលចេញ ក្នុង
ពេលក្រោយដែលទូន្មានប្រដៅគេម្ដងពីរហើយ[ឡ] 11 ដោយ

**២:១៣** គ ២ពត ១:១
**២:១៤** ឃ មថ ២០:២៨ ង មថ ១:២១ ច ហព ១:៣ ១យហ ១:៧ ឆ នក ១៩:៥ ចទ ៤:២០ ១៤:២ ទដ ១៣៥:៤ មឡ ៣:១៧ ១ពត ២:៩ ជ ខ.៧ សភ ១៦:៧ មថ ៥:១៦ ២កថ ៨:២១ អភ ២:១០ ទត ៣:១,៨,១៤ ១ពត ២:១២,១៥ ៣:១៣
**៣:១** ឈ រម ១៣:១ ១ពត ២:១៣,១៤ ញ ២ធថ ២:២១ ទត ២:១៤
**៣:២** ដ អភ ៤:៣១
**៣:៣** ឋ អភ ២:២
**៣:៤** ឌ អភ ២:៧ ឍ លក ១:៤៧ ណ ទត ២:១១
**៣:៥** ត រម ១១:១៤ ថ អភ ២:៩ ទ ១ពត ១:៣ ធ កថ ២២:១៦ ន រម ១២:២
**៣:៦** ប រម ៥:៥
**៣:៧** ផ រម ៣:២៤ ព រម ៨:១៧ ភ រម ៨:២៤ ម មថ ២៥:៤៦ ទត ១:២
**៣:៨** យ ១ធថ ១:១៥ រ ទត ២:១៤
**៣:៩** ល ២ធថ ២:១៦ វ ២ធថ ២:១៤ ស ទត ១:១០–១៦ ហ ២ធថ ២:១៤
**៣:១០** ឡ រម ១៦:១៧

**២:១៤** ការសង្គ្រោះប្រោសយើងឱ្យរួចផុតពីសេចក្ដីអាក្រក់ និងការជំនុំជម្រះ (រម ៣:២៤ និងការពន្យល់) ហើយសម្អាតយើងឱ្យបានបរិសុទ្ធ និងសម្រាប់ជួយដល់អ្នកដទៃ ។

**២:១៥** បទគម្ពីរនេះសង្ខេបនូវទំនួលខុសត្រូវ និងអំណាចរបស់លោកទីតុស ។ *សេចក្ដីទាំងនេះ* សំដៅលើសេចក្ដីដែលរៀបរាប់នៅក្នុងជំពូកនេះតែម្ដង។

**៣:១–២** សេចក្ដីបង្រៀននៅក្នុងព្រះគម្ពីរសញ្ញាថ្មី មិនបានដាក់ដែនកំណត់ចំពោះការសង្គ្រោះផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗនោះទេ ប៉ុន្តែ តម្រូវឱ្យមានការទូន្មានអំពីការអនុវត្តន៍នៅក្នុងជីវិតផងដែរ ។ ទោះបីអ្នកជឿដល់ព្រះអម្ចាស់ជាសាសន៍ស្ថានសួគ៌ក៏ដោយ (ភល ៣:២០ និងការពន្យល់) ក៏ពួកគេត្រូវចុះចូលនឹងរដ្ឋាភិបាលនៅលើផែនដីនេះដែរ (រម ១៣:១–៧ ១ពត ២:១៣–១៧ និងការពន្យល់) ហើយជួយកសាងសហគមន៍ឱ្យបានល្អ ។

**៣:១** *ពួកនាម៉ឺន ហើយនិងពួកមានអំណាច* ឃ្លានេះសំដៅលើគ្រប់លំដាប់ថ្នាក់ និងទម្រង់នៃការគ្រប់គ្រងរបស់មនុស្ស (អភ ៣:១០ ៦:១២)។

**៣:៣** សូមប្រៀបធៀបនឹង "អភ ២:១–៣"។

**៣:៤** *សេចក្ដីសប្បុរស . . . និងសេចក្ដីស្រឡាញ់របស់ទ្រង់* ដោយព្រោះតែសេចក្ដីទាំងនេះហើយ ដែលព្រះអម្ចាស់មិនបោះបង់ចោលមនុស្សលោក ប៉ុន្តែ ទ្រង់បាន យាងមកសង្គ្រោះពួកគេវិញ (២:១១)។

**៣:៥** *ទ្រង់បានជួយសង្គ្រោះយើង . . . ដោយសេចក្ដីមេត្តាករុណារបស់ទ្រង់* ត្រង់ចំណុចនេះបញ្ជាក់ថា ការសង្គ្រោះមិនមែនកើតឡើងដោយសារការខំប្រឹង និងទង្វើរបស់មនុស្សទេ ប៉ុន្តែ គឺកើតឡើងដោយសារតែព្រះគុណរបស់ព្រះអម្ចាស់ប៉ុណ្ណោះ (អភ ២:៨–៩ និងការពន្យល់)។ *ដោយសារការសំអាតនៃសេចក្ដីកើតជាថ្មី* សំដៅលើការកើតជាថ្មីរបស់អ្នកជឿដល់ព្រះអម្ចាស់គ្រប់ៗគ្នា ។ម្យ៉ាងទៀត ការកើតជាថ្មីមិនមែនកើតឡើងដោយសារការធ្វើបុណ្យជ្រមុជទឹកនោះទេ ។ ការធ្វើពិធីនេះ គឺគ្រាន់តែជាការស្ដាប់បង្គាប់ និងជានិមិត្តរូបនៃការកើតជាថ្មីប៉ុណ្ណោះ ព្រោះការកើតជាថ្មីគឺជាព្រះរាជកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធ (យហ ៣:៥) និងពុំអាចទទួលបានដោយការធ្វើពិធីបុណ្យសាសនាណាមួយនោះទេ ។ *ប្រោសជាថ្មីឡើងវិញនៃព្រះវិញ្ញាណបរិសុទ្ធ* ឃ្លានេះសំដៅលើការកើតជាថ្មី ។

**៣:៦** *ទ្រង់បានចាក់មកលើយើងជាបរិបូរ* សូមប្រៀបធៀបនឹង រម ៥:៥។

**៣:៧** *បានរាប់ជាសុចរិតដោយសារព្រះគុណទ្រង់* "មើលការពន្យល់ រម ៣:២៤"។ *អ្នកគ្រងមរដក* "មើលការពន្យល់ រម ៨:១៧"។ *សេចក្ដីសង្ឃឹម* "មើលការពន្យល់ រម ៥:៥ កល ១:៥"។

**៣:៨** *ពាក្យនេះគួរជឿ* ឃ្លានេះនិយាយសំដៅលើគោលលទ្ធិដែលបានសង្ខេបនៅក្នុង "ខ.៤–៧" (មើលការពន្យល់ ១ធថ ១:១៥)។

**៣:៩** *រឿងពង្សាវតារ* "មើលពន្យល់ ១ធថ ១:៤"។ *សេចក្ដីជជែកពីក្រិត្យវិន័យ* សំដៅលើស្ថានភាពដែលបានពណ៌នានៅក្នុង"១:១០–១៦" ហើយវាក៏ជាបញ្ហាស្រដៀងគ្នានឹងពួកអ្នកនៅក្នុងទីក្រុងអេភេសូរដែរ (១:៣–១១ ១ធថ ១:៣–៧)។

**៣:១១** ភាពរឹងចចេស និងការប្រឆាំងមិនព្រមស្ដាប់សេចក្ដីកែតម្រូវ គឺបង្ហាញនូវការបដិសេធន៍ពីខាងក្នុង ។

ដឹងថា មនុស្សយ៉ាងនោះខូចអស់ហើយ ក៏ចេះតែធ្វើបាប
ព្រមទាំងកាត់ទោសខ្លួនគេផង ។

## បណ្ដាំចុងក្រោយ

១២ កាលណាខ្ញុំចាត់អ្នកអើតេម៉ាស ឬអ្នកទីឃីកុស[អ] មក
ឯអ្នក នោះត្រូវខំប្រឹងទៅឯខ្ញុំនៅក្រុងនីកូប៉ូលផង ដ្បិតខ្ញុំបាន
សំរេចនឹងនៅទីនោះ ក្នុងរដូវរងានេះ[ក]
១៣ ចូរខំជួយដំណើរ
ឱ្យលោកសេន៉ាស ជាស្មាក្ដី នឹងអ្នកអ័ប៉ុឡូស[ខ] ឱ្យបានទៅ
ខាងមុខ ដើម្បីមិនឱ្យខ្វះខាតអ្វីឡើយ
១៤ ហើយត្រូវឱ្យពួក
យើងហាត់ធ្វើការល្អឱ្យអស់ពីចិត្ត សំរាប់បំពេញកិច្ចដែល
ខ្វះខាត[គ] ដើម្បីកុំឱ្យគេនៅតែឥតផលប្រយោជន៍នោះឡើយ
១៥ ពួកអ្នកដែលនៅជាមួយនឹងខ្ញុំ គេសូមជំរាបសួរមក
អ្នក សូមឱ្យអ្នកជំរាបសួរ ដល់ពួកអ្នកដែលស្រឡាញ់យើងខ្ញុំ
ក្នុងសេចក្ដីជំនឿផង[ឃ] សូមឱ្យអ្នករាល់គ្នាបានប្រកបដោយ
ព្រះគុណ[ង]។ អាម៉ែន ។

**៣:១២** អ កច ២០:៤ ក ២ធថ ៤:៩,២១
**៣:១៣** ខ កច ១៨:២៤
**៣:១៤** គ ទត ២:១៤
**៣:១៥** ឃ ១ធថ ១:២ ង កល ៤:១៨

**៣:១២** *ទីឃីកុស* ជាម្នាក់ដែលលោកប៉ុលទុកចិត្តក្នុងការងារ និងបានធ្វើដំណើរជាមួយគាត់ (កច ២០:៤ អភ ៦:២១ និងការពន្យល់)។ *នីកូប៉ូល* មានន័យថា "ទីក្រុងនៃជ័យជម្នះ"។ មានទីក្រុងមួយចំនួនដែលមានឈ្មោះនេះ ប៉ុន្តែ ពាក្យនេះសំដៅលើទីក្រុងមួយនៅអេពីរូស (Epirus) ដែលស្ថិតនៅលើឆ្នេរភាគខាងលិចនៃប្រទេសក្រេក ។ *បានសំរេចនឹងនៅទីនោះ ក្នុងរដូវរងានេះ* បញ្ជាក់ថា លោកប៉ុលមិនបាននៅទីនោះទេពេលគាត់សរសេរសំបុត្រនេះ ហើយគាត់នៅមានសេរីភាពធ្វើដំណើរបាន និងមិនទាន់ជាប់ពន្ធនាគារជាលើកទីពីរ នៅឯទីក្រុងរ៉ូមនៅឡើយទេ ។

**៣:១៣** *សេន៉ាស ជាស្មាក្ដី* ប្រសិនបើគាត់ជាសាសន៍យូដាដែលបានជឿ អាចបញ្ជាក់ថា គាត់គឺជាអ្នកជំនាញខាងក្រឹត្យវិន័យលោកម៉ូសេ ។ ប្រសិនបើគាត់ជាសាសន៍ដទៃ នោះបញ្ជាក់ថា គាត់គឺជាចៅក្រមរ៉ូម៉ាំង ។ *អ័ប៉ូឡូស* គាត់គឺជាអ្នកមកពីអ័លេក្សានទ្រា និងជាគូកនម្នាក់របស់លោកប៉ុល ដែលមានគេស្គាល់ច្រើន (កច ១៨:២៤–២៨ ១៩:១ ១កថ ១:១២ ៣:៤–៦,២២ ១៦:១២)។

**៣:១៤** "សូមមើល ១ធថ ៥:៨ ហើយប្រៀបធៀបនឹង ២ថន ៣:១០–១២"។

**៣:១៥** *ព្រះគុណ* "មើលការពន្យល់ រម ១:៧ ២កថ ១៣:១៤"។

សំបុត្ររបស់ប៉ុល

ដល់

# ភីលេម៉ូន

សេចក្ដីផ្ដើម

### អ្នកនិពន្ធ កាលបរិច្ឆេទ និងទីកន្លែង

លោកសាវកប៉ុលបានសរសេរសំបុត្រខ្លីមួយនេះឡើង (ខ.១,៩,១៩) នៅពេលដំណាលគ្នានឹងសំបុត្រដែលគាត់បានសរសេរទៅកាន់ពួកជំនុំនៅក្រុងកូល៉ុសដែរ (ក្នុងឆ្នាំ៦០គ.ស) (មើលសេចក្ដីផ្ដើមព្រះគម្ពីរកូល៉ុសត្រង់ "អ្នកនិពន្ធ កាលបរិច្ឆេទ និងទីកន្លែង") ហើយបានផ្ញើសំបុត្រនេះទៅកាន់ទីក្រុងកូល៉ុស តាមរយៈអ្នកដំណើរដដែល គឺលោកអូនេស៊ីម និងលោកទីឃីកុស ។ គេជឿថា គាត់បានសរសេរ ហើយផ្ញើសំបុត្រទាំងពីរច្បាប់នេះពីក្នុងគុកនៅក្រុងរ៉ូម (មើលសេចក្ដីផ្ដើមព្រះគម្ពីរភីលីព ត្រង់ "អ្នកនិពន្ធ កាលបរិច្ឆេទ និងទីកន្លែង")។

### អ្នកទទួល ប្រភព និងគោលបំណង

លោកសាវកប៉ុលបានសរសេរសំបុត្រនេះទៅកាន់លោកភីលេម៉ូន ជាគ្រីស្ទបរិស័ទម្នាក់ដែលមានទីលំនៅក្នុងទីក្រុងកូល៉ុស និងជាចៅហ្វាយម្នាក់ក្នុងចំណោមចៅហ្វាយឯទៀតៗ (ប្រៀបធៀប កល ៤:១ "ភាពជាអ្នកបម្រើ" មើលការពន្យល់ អភ ៦:៥)។ ក្នុងចំណោមអ្នកបម្រើរបស់គាត់មានម្នាក់ឈ្មោះ អូនេស៊ីមបានលួចរត់ចេញពីគាត់ (ប្រៀបធៀប ខ.១៨) ហើយបានបន្ដរត់គេចខ្លួនបាត់ ។ បើយោងតាមច្បាប់ចក្រភពរ៉ូម៉ាំង ការដែលគាត់បានប្រព្រឹត្ដបែបនេះអាចឈានទៅដល់ទោសប្រហារជីវិត ។ ប៉ុន្ដែ លោកអូនេស៊ីមបានជួបលោកប៉ុល ហើយតាមរយៈការងារ បម្រើព្រះរបស់សាវករូបនេះ លោកអូនេស៊ីមក៏បានក្លាយទៅជាគ្រីស្ទបរិស័ទម្នាក់ (ខ.១០)។ បន្ទាប់ពីនោះមកគាត់បានព្រមវិលត្រឡប់ទៅ ឯចៅហ្វាយរបស់គាត់វិញជាមួយគ្នានោះ លោកប៉ុលក៏បានសរសេរសំបុត្រផ្ទាល់ខ្លួនមួយច្បាប់នេះឡើង ដើម្បីសូមឱ្យលោកភីលេម៉ូនទទួល លោកអូនេស៊ីមដូចជាបងប្អូនស្ងួនភ្ងាម្នាក់ វិញ (ខ.១៦)។

### ដំណោះស្រាយ និងរចនាបថ

ដើម្បីជោគជ័យក្នុងការធ្វើឱ្យលោកភីលេម៉ូនព្រមទទួលលោកអូនេស៊ីម លោកប៉ុលបានសរសេរយ៉ាងប៉ិនប្រសប់ណាស់ គឺគាត់បានប្រើពាក្យពេចន៍យ៉ាងពិរោះរណ្ដំ ដោយការលេងពាក្យជាដើម (មើលការពន្យល់ ខ.១១)។ ការស្នើសុំនេះ (ខ.៤–២១) បានរៀបចំឡើងតាមលំនាំវិធីបង្ហាប់ បញ្ជោររបស់ពួកក្រេក្រិក និងគ្រូរ៉ូម៉ាំងដើម្បីបង្កើតភាពស្និទ្ធស្នាល (ខ.៤–១០) លួងលោមចិត្ត (ខ.១១–១៩) និងប្ដូរអារម្មណ៍ (ខ.២០–២១)។ លោកប៉ុលមិនបានបញ្ចេញឈ្មោះលោកអូនេស៊ីម រហូតដល់ពេលដែលការនិយាយដើម្បីបង្កើតភាពស្និទ្ធស្នាលបានបញ្ចប់រួចជាស្រេចហើយសិន (ខ.១០) ហើយដើម្បីលួងលោមចិត្ត (ខ.១៧) លោកប៉ុលបានលើកសំណើឱ្យទទួលលោកអូនេស៊ីមនៅជិតចុងបញ្ចប់នៃសំបុត្រនេះ។

### គម្រោងសង្ខេប

**I. ពាក្យជម្រាបសួរ (១–៣)**

**II. ការអរព្រះគុណ និងសេចក្ដីអធិស្ឋាន (៤–៧)**

**III. ការអង្វររបស់លោកប៉ុលជំនួសលោកអូនេស៊ីម (៨–២១)**

**IV. សំណើចុងក្រោយ ពាក្យជម្រាបសួរ និងការជូនពរ (២២–២៥)**

១សំបុត្រប៉ុល ជាសិស្សរបស់ព្រះគ្រីស្ទយេស៊ូវ ដែលខ្ញុំ
ជាប់គុក[ក]នេះ និងធីម៉ូថេ[ខ]ជាបងប្អូនយើងខ្ញុំ[គ] ផ្ញើមកអ្នក
ភីលេម៉ូន ជាសំឡាញ់ស្ងួនភ្ងា ដែលធ្វើការជាមួយនឹងយើង
ខ្ញុំ[ឃ] ២ហើយមកនាងអាប់ភាជាអ្នកស្ងួនភ្ងា និងអ្នកអើឃីព[ង]
ជាគូកនតយុទ្ធ[ច]ជាមួយនឹងយើងខ្ញុំ ព្រមទាំងពួកជំនុំដែល
ប្រជុំនៅផ្ទះអ្នកដែរ[ឆ] ៣សូមឱ្យអ្នករាល់គ្នាបានប្រកបដោយ
ព្រះគុណនិងសេចក្តីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតា
នៃយើង ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ[ជ]។

## ការអរព្រះគុណ និងការអធិស្ឋាន

៤ខ្ញុំអរព្រះគុណដល់ព្រះ[ឈ]នៃខ្ញុំ ទាំងដំណាលពីអ្នកជា
និច្ចក្នុងកាលដែលខ្ញុំអធិស្ឋានផង[ញ] ៥ដោយបានឮនិយាយពី
សេចក្តីស្រឡាញ់ និងសេចក្តីជំនឿដែលអ្នកមានដល់
ព្រះអម្ចាស់យេស៊ូវ[ដ]ហើយដល់ពួកបរិសុទ្ធទាំងអស់គ្នាដែរ[ឋ]
៦ខ្ញុំសូមឱ្យសេចក្តីប្រកបនៃសេចក្តីជំនឿរបស់អ្នក បានកើត
ការឡើង ឱ្យបានយល់ព្រមតាមគ្រប់ទាំងការល្អដែលនៅ
ក្នុងខ្លួនយើង សំរាប់ព្រះគ្រីស្ទយេស៊ូវ ៧ដ្បិត ឱប្អូនអើយ
យើងខ្ញុំមានសេចក្តីអំណរ នឹងសេចក្តីក្សាន្តចិត្តជាខ្លាំងដែរ[ឌ]
ដោយ សារសេចក្តីស្រឡាញ់របស់អ្នក ពីព្រោះចិត្តនៃពួក
បរិសុទ្ធ បានស្បើយល្ហែ[ឍ] ដោយសារអ្នក ។

## ការអង្វររបស់លោកប៉ុល ជំនួសលោកអូនេស៊ីម

៨ដូច្នេះ ទោះបើខ្ញុំមានអំណាចជាច្រើន ក្នុងព្រះគ្រីស្ទ នឹង
អាចបង្គាប់ឱ្យអ្នកធ្វើការដែលគួរគប្បីនេះក៏ដោយ ៩គង់
តែខ្ញុំ ឈ្មោះប៉ុល ជាអ្នកមានវ័យចាស់ហើយ ដែលឥឡូវ
នេះបានជាប់គុក[ណ] ដោយព្រោះព្រះយេស៊ូវគ្រីស្ទផង ខ្ញុំសូម
ទូន្មានដល់អ្នក[ត]ដោយសេចក្តីស្រឡាញ់វិញ ១០ខ្ញុំអង្វរអ្នក
ជំនួសកូនខ្ញុំ[ថ] គឺឈ្មោះអូនេស៊ីមនេះ[ទ] ដែលខ្ញុំបានបង្កើតក្នុង
វេលាជាប់ចំណង[ធ] ១១ពីដើមជាអ្នកគ្មានប្រយោជន៍ដល់អ្នក
ទេ តែឥឡូវនេះមានប្រយោជន៍ដល់ទាំងអ្នកនឹងខ្ញុំផង ខ្ញុំ
ចាត់គាត់មកឯអ្នកវិញ ១២សូមអ្នកទទួលគាត់ចុះ ព្រោះជា
ដួងចិត្តរបស់ខ្ញុំហើយ ១៣ខ្ញុំចង់ទុកគាត់ឱ្យនៅជាមួយនឹងខ្ញុំ
ណាស់ ដើម្បីឱ្យគាត់បំរើខ្ញុំជំនួសអ្នក ដែលខ្ញុំនៅជាប់
ចំណង[ន] ដោយព្រោះដំណឹងល្អ ១៤តែខ្ញុំមិនចង់ធ្វើអ្វីទេ
លើកតែអ្នកយល់ព្រមដែរ ដើម្បីកុំឱ្យអ្នកធ្វើគុណទាំងបង្ខំ
ឡើយ គឺចង់ឱ្យបានធ្វើដោយស្ម័គ្រពីចិត្តវិញ[ប] ១៥ដ្បិត
ប្រហែលជាដោយហេតុនោះ បានជាគាត់ឃ្លាតចេញពី
អ្នកទៅជាយូរបន្តិច ដើម្បីឱ្យអ្នកបានគាត់វិញ ឱ្យនៅជាប់
ជាដរាបទៅ ១៦តែមិនមែនដូចជាបាវបំរើ[ផ]ទៀតឡើយ
គឺលើសជាងបាវបំរើទៅទៀត ទុកដូចជាប្អូនស្ងួនភ្ងាវិញ[ព]
គឺដល់ខ្ញុំជាដើម ហើយដល់អ្នក តើលើសជាងយ៉ាង
ណាទៅ ទាំងខាងសាច់ឈាម នឹងក្នុងព្រះអម្ចាស់ផង
១៧ដូច្នេះបើអ្នករាប់ខ្ញុំទុកជាគូកន[ភ] នោះចូរទទួលគាត់ទុក
ដូចជាខ្លួនខ្ញុំចុះ ១៨បើគាត់បានធ្វើអ្វីខុសឆ្គងនឹងអ្នក ឬជំពាក់
អ្នក នោះត្រូវគិតលើខ្ញុំវិញ[ម] ១៩ប៉ុលខ្ញុំសរសេរដោយដៃខ្លួន[យ]
ថា ខ្ញុំនឹងសងអ្នកតែដែលអ្នកជំពាក់ខ្ញុំទាំងខ្លួនអ្នកផងនោះ
មិនថាទេ ២០អើ ប្អូនអើយ សូមឱ្យខ្ញុំបានផលនេះអំពីអ្នកក្នុង
ព្រះអម្ចាស់ សូមលំហែ[រ]ចិត្តខ្ញុំក្នុងព្រះគ្រីស្ទផង ២១ខ្ញុំបាន
សរសេរសំបុត្រនេះផ្ញើមកអ្នក ដោយមានចិត្តជឿ[ល]ថា អ្នក
នឹងស្តាប់តាមខ្ញុំ ហើយខ្ញុំក៏ដឹងជាក់ថា អ្នកនឹងធ្វើលើសអំពី
សេចក្តីដែលខ្ញុំសូមនេះទៅទៀត ។
២២សូមរៀបកន្លែងឱ្យខ្ញុំបាននៅផង ដ្បិតខ្ញុំសង្ឃឹមថា[វ]
ព្រះទ្រង់នឹងប្រគល់ខ្ញុំមកឯអ្នកវិញ ដោយអ្នកអធិស្ឋានឱ្យ

**១:១** ក ខ.៩,២៣ អភ ៣:១ ខ កថ ១៦:១ គ ២កថ ១:១ ឃ ភល ២:២៥ **១:២** ង កល ៤:១៧ ច ភល ២:២៥ ឆ រម ១៦:៥ **១:៣** ជ រម ១:៧ **១:៤** ឈ រម ១:៨ ញ រម ១:១០ **១:៥** ដ កថ ២០:២១ ឋ កល ១:៤ ១ថន ៣:៦ **១:៧** ឌ ២កថ ៧:៤,១៣ ឍ ខ.២០ រម ១៥:៣២ ១កថ ១៦:១៨ **១:៩** ណ ខ.១,២៣ អភ ៣:១ ត ១កថ ១:១០ **១:១០** ថ ១ថន ២:១១ ទ កល ៤:៩ ធ កថ ២១:៣៣ **១:១៣** ន ខ.១០ កថ ២១:៣៣ **១:១៤** ប ២កថ ៩:៧ ១ពត ៥:២ **១:១៦** ផ ១កថ ៧:២២ ព មថ ២៣:៨ កថ ១:១៦ ១ធថ ៦:២ **១:១៧** ភ ២កថ ៨:២៣ **១:១៨** ម លប ៤៣:៩ **១:១៩** យ ១កថ ១៦:២១ **១:២០** រ ខ.៧ ១កថ ១៦:១៨ **១:២១** ល ២កថ ២:៣ **១:២២** វ ភល ១:២៥ ២:២៤ ហព ១៣:១៩

**១–២** សាវកប៉ុលសរសេរសំបុត្រនេះរួមគ្នាជាមួយនឹងលោកធីម៉ូថេ ហើយផ្ញើមកពួកជំនុំកូល៉ុស ។ តែក្នុងផ្នែកសំបុត្រផ្ទាល់ខ្លួនដល់លោកភីលេម៉ូន លោកប៉ុលប្រើពាក្យ "ខ្ញុំ" ជាជាង"ពួកយើង" និង"អ្នក"(ឯកវចនៈ លើកលែងតែ ខ.២២,២៥ ប៉ុណ្ណោះ)។

**១** *ប៉ុល* មើលការពន្យល់ រម ១:១ ។ *ខ្ញុំជាប់គុក* ការពន្យល់ អភ ៣:១ ភល ១:១៣ ។ *ធីម៉ូថេ* មើលការពន្យល់ កល ១:១ និងសេចក្តីផ្តើម ១ធីម៉ូថេត្រង់ អ្នកទទួល ។ *ភីលេម៉ូន* ជាគ្រីស្ទបរិស័ទនៅក្រុងកូល៉ុស ឬតំបន់ជិតខាងក្រុងនេះ និងជាចៅហ្វាយលោក អូនេស៊ីម (មើលការពន្យល់ ខ.១០)។

**២** *អាប់ភា* ជាប្រពន្ធលោកភីលេម៉ូន ។ *អើឃីព* សូមមើល កល ៤:១៧ ។

**៣** *ព្រះគុណ . . . សុខសាន្ត* មើលការពន្យល់ រម ១:៧ ។

**៤** *អរព្រះគុណ . . . ខ្ញុំ អធិស្ឋានផង* មើលការពន្យល់ ភល ១:៣–៤ ។

**៥** *ពួកបរិសុទ្ធ* រម ១:៧, អភ ១:១ ។

**៧** *ចិត្ត* គឺជាលក្ខណៈពិសេសនៃសេចក្តីអាណិត និងស្រឡាញ់(ខ.១២,២០)។

**១០** *អូនេស៊ីម* មានន័យថា"មានប្រយោជន៍"(មើលសេចក្តីផ្តើមត្រង់ "អ្នកទទួល ប្រភព និងគោលបំណង")។ *កូនខ្ញុំ* មើលការពន្យល់ ១ធថ ១:២ ។

**១១** *គ្មាន . . . មានប្រយោជន៍* នេះជាន័យធៀបរបស់ឈ្មោះលោកអូនេស៊ីម

**១៣** *ជាប់ចំណងដោយព្រោះដំណឹងល្អ* មើលការពន្យល់ ខ.១ ។

**១៧–១៩** លោកម៉ាទីន លូធើ(Martin Luther)បានពោលទុកថា "ព្រះគ្រីស្ទទ្រង់បានផ្សះផ្សាយើងឱ្យទៅឯព្រះវរបិតាវិញ ដូចនេះលោកសាវកប៉ុលក៏បានផ្សះផ្សាលោកអូនេស៊ីមឱ្យទៅឯលោកភីលេម៉ូនផងដែរ"។

**១៩** *ខ្ញុំសរសេរដោយដៃខ្លួន* មើលការពន្យល់ ១កថ ១៦:២១ ។ *ជំពាក់ខ្ញុំទាំងខ្លួនអ្នកផង* គេជឿថា លោកប៉ុលបាននាំលោកភីលេម៉ូនឱ្យបានជឿព្រះគ្រីស្ទ

**២០** *ខ្ញុំ . . . ចិត្តខ្ញុំ* (របស់ខ្ញុំ)ជាពាក្យសង្កត់ន័យ ដែលបង្កើតឱ្យមានការយោងដល់ ខ.៧ ។ *ផល* ការលេងន័យរបស់ឈ្មោះលោកអូនេស៊ីមម្តងទៀត ។

**២១** *លើសពីអំពីសេចក្តីដែលខ្ញុំសូម* នេះជាសំណើរសុំឱ្យលោកភីលេម៉ូនដោះលែងលោកអូនេស៊ីមឱ្យមានសេរីភាព ហើយរាប់ជាបងប្អូនក្នុងព្រះគ្រីស្ទវិញ។

**២២** បញ្ហានោះគឺត្រូវដោះស្រាយ ថាតើអ្នកសរសេរគ្រោងមកជួបអ្នកទទួលរូបនេះ ដោយវិធីណា និងនៅពេលណា ។

ខ្ញុំផង[ស] ។
២៣ អ្នកអេបា៉ប្រាស[ហ] ជាអ្នកជាប់គុក[ឡ] ជាមួយនឹងខ្ញុំ ដោយព្រោះ
ព្រះគ្រីស្ទយេស៊ូវ គាត់ជំរាបសួរមកអ្នកដែរ ២៤ ព្រមទាំង
អ្នកម៉ាកុស[អ] អ្នកអើរីស្តាក[ក] អ្នកដេម៉ាស[ខ] នឹងអ្នកលូកា ជាគូ
កនធ្វើការជាមួយនឹងខ្ញុំ[គ] គេក៏សូមជំរាបសួរមក អ្នកផង ។
២៥ សូមឱ្យវិញ្ញាណអ្នកបានប្រកបដោយព្រះគុណនៃ
ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង[ឃ] ។ អាម៉ែន ។

**១:២២** ស ២កថ ១:១១ ភល ១:១៩
**១:២៣** ហ កល ១:៧ ឡ ខ.១ រម ១៦:៧ កល ៤:១០
**១:២៤** អ កច ១២:១២ ក កច ១៩:២៩ ខ កល ៤:១៤ ២ធថ ៤:១០ គ ខ.១
**១:២៥** ឃ កទ ៦:១៨

**២៣** *អ្នកអេបា៉ប្រាស* កល ១:៧ និងការពន្យល់ ៤:១២ ។
**២៤** *អ្នកម៉ាកុស អ្នកអើរីស្តាក* មើលការពន្យល់ កល ៤:១០ ។ *អ្នកដេម៉ាស និងអ្នកលូកា* មើលការពន្យល់ កល ៤:១៤ ។
**២៥** *ព្រះគុណ* មើលការពន្យល់ រម ១:៧ ។ *វិញ្ញាណអ្នកបានប្រកប* មើលការពន្យល់ កទ ៦:១៨ ។

# សំបុត្រផ្ញើរទៅពួកសាសន៍ហេព្រើរ

សេចក្ដីផ្ដើម

**អ្នកនិពន្ធ**

អ្នកនិពន្ធកណ្ឌគម្ពីរ ហេព្រើរ មិនបានបញ្ជាក់ឈ្មោះរបស់ខ្លួនទេ ប៉ុន្តែគាត់ត្រូវបានអ្នកទទួលសំបុត្រនេះដំបូងស្គាល់យ៉ាងច្បាស់ ។ ក្នុងអំឡុងពេលប្រហែលជា១២០០ឆ្នាំ (៤០០គ.ស ដល់ ១៦០០គ.ស) កណ្ឌគម្ពីរ នេះត្រូវបានហៅថា សំបុត្ររបស់សាវកប៉ុលទៅកាន់ពួកជំនុំហេព្រើរ ប៉ុន្តែ មិនមានការយល់ស្របណាមួយចំពោះភាពជាអ្នកនិពន្ធរបស់កណ្ឌគម្ពីរ នេះទេ ។ ចាប់តាំងពីមានការកែទម្រង់របស់គ្រីស្ទបរិស័ទមក កណ្ឌគម្ពីរ នេះត្រូវបានគេយល់ថាមិនមែនជាសំបុត្ររបស់លោកប៉ុលទៀតទេ ។ សេចក្ដីបង្រៀននៃកណ្ឌគម្ពីរ នេះ និងសេចក្ដីបង្រៀននៅក្នុងសំបុត្ររបស់លោកប៉ុលមាន លក្ខណៈស្របគ្នា ប៉ុន្តែ ចំណុចសំខាន់ និងរបៀបសរសេរ មានភាពខុសគ្នា ។ អ្នកនិពន្ធមិនបានបញ្ជាក់ឈ្មោះនៅក្នុងសំបុត្រនេះទេ គឺគ្រាន់តែបានបញ្ជាក់ថា គាត់ជាបុរសប៉ុណ្ណោះ (១១:៣២ និងការព្យល់) ផ្ទុយពីសំបុត្រផ្សេងៗរបស់លោកប៉ុល ។ ជាងនេះទៅទៀត ឃ្លាថា "នោះធ្វើដូចម្ដេចឱ្យយើងរួចបាប បើយើងធ្វេសនឹងសេចក្ដីសង្គ្រោះដ៏ធំម្ល៉េះ ដែលព្រះអម្ចាស់បានចាប់ផ្ដើមផ្សាយមករួចពួកអ្នកដែលឮ ក៏បានបញ្ជាក់មកយើងរាល់គ្នាដែរ" (២:៣) បញ្ជាក់ថា អ្នកនិពន្ធមិនធ្លាប់រស់នៅជាមួយនឹងព្រះយេស៊ូវទេ ហើយក៏មិនធ្លាប់បានស្ដាប់សេចក្ដីបង្រៀនរបស់ទ្រង់ដោយផ្ទាល់ដែរ ។ ដូច្នេះ អ្នកនិពន្ធកណ្ឌគម្ពីរ នេះមិនអាចជាសាវកប៉ុលទេ (កទ ១:១១-១២) ។

សេចក្ដីស្នើឡើងដំបូងគេអំពីភាពជាអ្នកនិពន្ធ ត្រូវបានរកឃើញនៅក្នុងសៀវភៅរបស់លោកធើទូលលានឈ្មោះ "ដឺពុយឌីស៊ីធា,២០" (Tertullian´s De Pudicitia,20 ប្រហែលឆ្នាំ២០០គ.ស) ដែលនៅក្នុងនោះគាត់បានបញ្ជាក់ថា សំបុត្រហេព្រើរ មានអ្នកនិពន្ធឈ្មោះថាបាណាបាស ។ នៅក្នុងសំបុត្រនេះផ្ទាល់ក៏បញ្ជាក់យ៉ាងច្បាស់ថា អ្នកនិពន្ធកណ្ឌគម្ពីរ ហេព្រើរ មានអំណាចជាសាវកនៅក្នុងពួកជំនុំ ហើយជាគ្រីស្ទបរិស័ទហេព្រើរម្នាក់ ដែលមានចំណេះដឹងច្រើនអំពីព្រះគម្ពីរសញ្ញាចាស់ ។ ដូច្នេះលោកបាណាបាសស័ក្តិសមជាអ្នកនិពន្ធកណ្ឌគម្ពីរ នេះ ។ លោកបាណាបាសជាសាសន៍យូដា នៅក្នុងត្រកូលពួកសង្ឃលេវី (កច ៤:៣៦) ហើយបានក្លាយជាគូកនជិតស្និទ្ធនឹងលោកប៉ុលបន្ទាប់ពីបានជឿដល់ព្រះអម្ចាស់ ។ ក្រោមការដឹកនាំនៃព្រះវិញ្ញាណបរិសុទ្ធ ពួកជំនុំនៅទីក្រុងអាន់ទីយ៉ូកបានតាំងលោកបាណាបាស និងលោកប៉ុលសម្រាប់ការងារដំណឹងល្អ ហើយបានបញ្ជូនពួកគាត់ទៅក្នុងដំណើរបេសកកម្មទីមួយ (កច ១៣:១-៤) ។

បុគ្គលម្នាក់ទៀតដែលស័ក្តិសមជាអ្នកនិពន្ធកណ្ឌគម្ពីរ ហេព្រើរ នេះដែរគឺលោកអ័ប៉ុឡូស ជាម្នាក់ដែលលោកម៉ាទីនលូធើលើកឡើង (Martin Luther) និងមានការនិយមចូលចិត្តច្រើនពីសំណាក់អ្នកបកស្រាយនាពេលបច្ចុប្បន្ន ។ លោកអ័ប៉ុឡូសកើតនៅអ័លេក្សានទ្រាគាត់ជាគ្រីស្ទបរិស័ទជាតិយូដា ហើយជាអ្នកមានបញ្ញា ភាពថ្លៃថ្នូរ និងសមត្ថភាពខាងថ្លែងព្រះបន្ទូល ។ លោកលូកាមានប្រសាសន៍ថា លោកអ័ប៉ុឡូសជាអ្នកដែលរៀនឆាប់ចេះផ្នែកខាងឯព្រះបន្ទូល (កច ១៨:២៤) ។ យើងក៏ដឹងទៀតថា លោកអ័ប៉ុឡូសតែងធ្វើដំណើរជាមួយនឹងលោកប៉ុល ក្នុងអំឡុងឆ្នាំដំបូងនៅពួកជំនុំនៅទីក្រុងកូរិនថូស (១កថ ១:១២ ៣:៤-៦,២២) ។

ភស្តុតាងមួយទៀតគឺ អ្នកនិពន្ធកណ្ឌគម្ពីរ ហេព្រើរ ជាមនុស្សមានជំនាញផ្នែកភាសាក្រិក នាសម័យកាលគាត់នោះតែម្ដង ដោយសារតែគាត់បានប្រើប្រាស់ នូវបទគម្ពីរដកស្រង់ចេញពីព្រះគម្ពីរបកប្រែជាភាសាក្រិកដំបូង នៅក្នុងកណ្ឌគម្ពីរ នេះ ។

**កាលបរិច្ឆេទ**

កណ្ឌគម្ពីរ នេះត្រូវបានសរសេរ ឡើងនៅមុនពេលការវិនាសព្រះវិហារ នៅទីក្រុងយេរូសាឡិម និងទីក្រុងយេរូសាឡិម នៅឆ្នាំទី៧០គ.ស ពីព្រោះ (១). ប្រសិនបើកណ្ឌគម្ពីរ នេះត្រូវសរសេរ ឡើងក្រោយឆ្នាំទី៧០គ.ស នោះអ្នកនិពន្ធពិតជានិយាយពីការវិនាសព្រះវិហារ នៅទីក្រុងយេរូសាឡិម និងចុងបញ្ចប់នៃប្រព័ន្ធថ្វាយយញ្ញបូជារបស់ពួកសាសន៍យូដាជាមិនខាន ។ (២). អ្នកនិពន្ធបានប្រើភាសាក្រិកក្នុងទម្រង់ជាបច្ចុប្បន្នកាល នៅពេលនិយាយអំពីព្រះវិហារ និងសកម្មភាពរបស់ពួកសង្ឃនៅក្នុងព្រះវិហារ នោះ (៥:១-៣ ៧:២៣,២៧ ៨:៣-៥ ៩:៦-៩,១៣,២៥ ១០:១,៣-៤,៨,១១ ១៣:១០-១១) ។

**អ្នកទទួល**

សំបុត្រនេះត្រូវបានសរសេរ ទៅកាន់ពួកអ្នកជឿដល់ព្រះអម្ចាស់ជាសាសន៍យូដា ដែលមានការយល់ដឹងផ្នែកព្រះគម្ពីរសញ្ញាចាស់ ហើយពួកគេកំពុងជួបប្រទះសេចក្ដីល្បួងឱ្យដើរតាមគោលលទ្ធិសាសនាយូដា (កទ ២:១៤) ។ មានអ្នកខ្លះយល់ថា គ្រីស្ទបរិស័ទទាំងនោះមានគំនិតចង់ចូលរួមទៅក្នុងក្រុមនៃពួកសាសនាយូដា ដូចជាពួកអ្នកនៅឯគូមរ៉ាន់ (Qumran) នៅជិតសមុទ្រស្លាប់ ។ មានមតិស្នើឡើងផ្សេងទៀត ថា

ពួកអ្នកទទួលសំបុត្រនេះ គឺមកពីចំណោមពួកសង្ឃដែលបានទទួលជឿដល់ព្រះយេស៊ូវគ្រីស្ទ (កថ ៦:៧) ។

**គោលរឿង**

គោលរឿងនៅក្នុងកណ្ឌគម្ពីរហេព្រើរគឺនិយាយអំពីភាពពិតប្រាកដ និងភាពគ្រប់គ្រាន់នៃព្រះយេស៊ូវគ្រីស្ទ ជាតួអង្គត្រូវបានបើកសំដែង និងជាតួអង្គនៃព្រះគុណនៃព្រះ ។ សេចក្តីផ្តើម(១:១-៤)បង្ហាញអំពីព្រះគ្រីស្ទ ជាសេចក្តីសម្រេច និងការបើកសំដែងចុងក្រោយបង្អស់ ឆ្លើយតបនឹងការបើកសំដែងដែលបានប្រទានមកនៅក្នុងសញ្ញាចាស់ ។ សេចក្តីទំនាយនៅក្នុងសញ្ញាចាស់បានសម្រេចនៅក្នុងសេចក្តី សញ្ញាថ្មីដែលមានព្រះគ្រីស្ទជាអ្នកកណ្តាល ។ ក្នុងសញ្ញាចាស់បានបង្ហាញអំពីព្រះគ្រីស្ទធំឧត្តមលើពួកហោរា ពួកទេវតា លោកម៉ូសេ លោក អើរ៉ុន និងពួកសង្ឃដែលចេញពីគាត់ ។

កណ្ឌគម្ពីរហេព្រើរអាចត្រូវបានហៅថា "សំបុត្រនៃការប្រសើរ" ដោយព្រោះមានពាក្យក្រិកពីរ ដែលប្រើនៅកណ្ឌគម្ពីរនេះ គឺពាក្យ "ប្រសើរ" និង ពាក្យ "ឧត្តម" ចំនួន១៥ដង ។ ការគួរឱ្យកត់សម្គាល់ ដែលបង្ហាញនៅក្នុងកណ្ឌគម្ពីរនេះគឺ អ្នកនិពន្ធបានលើកយកអត្ថបទគម្ពីរ ៨នៅក្នុងសញ្ញាចាស់:

| | | |
|---|---|---|
| (១). ២:៥-៩ | ដកស្រង់ចេញពី | "ទដ ៨:៤-៦" |
| (២). ៣:៧-៤:១៣ | ដកស្រង់ចេញពី | "ទដ ៩៥:៧-១១" |
| (៣). ៤:១៤-៧:២៨ | ដកស្រង់ចេញពី | "ទដ ១១០:៤" |
| (៤). ៨:១-១០:១៨ | ដកស្រង់ចេញពី | "យរ ៣១:៣១-៣៤" |
| (៥). ១០:១-១០ | ដកស្រង់ចេញពី | "ទដ ៤០:៦-៨" |
| (៦). ១០:៣២-១២:៣ | ដកស្រង់ចេញពី | "ហាប ២:៣-៤" |
| (៧). ១២:៤-១៣ | ដកស្រង់ចេញពី | "សភ ៣:១១-១២" |
| (៨). ១២:១៨-២៤ | ដកស្រង់ចេញពី | "នក ១៩:១០-២៣" |

ការអនុវត្តន៍ជាក់ស្តែងនៃគោលរឿងនេះត្រូវបានបញ្ជាក់តាមរយៈកណ្ឌគម្ពីរនេះទាំងមូល ។ ម្យ៉ាងទៀត បញ្ជាក់ថា អ្នកទទួលសំបុត្រនេះមិនអាចបែរក្រោយ ឬត្រឡប់ទៅដើរតាមប្រព័ន្ធនៃគោលលទ្ធិសាសនាយូដាទៀតទេ ព្រោះការទាំងអស់ត្រូវបានសម្រេចនៅក្នុងភាពជាសង្ឃរបស់ព្រះគ្រីស្ទរួចហើយ ។ រាស្ត្ររបស់ព្រះអម្ចាស់ទាំងអស់ត្រូវសម្លឹងមើលទៅឯទ្រង់តែមួយគត់ដោយព្រោះ ការសុគត ការរស់ឡើងវិញ និងការ លើកឡើងទៅឯស្ថានសួគ៌វិញរបស់ទ្រង់ បានបើកទ្វារទៅកាន់សេចក្តីពិត និងព្រះវត្តមានរបស់ទ្រង់នៅឯស្ថានសួគ៌ ។ ការបដិសេធសេចក្តីសង្គ្រោះដ៏ធំ (២:៣) ឬមិនទទួលស្គាល់ភាពបរិសុទ្ធរបស់ទ្រង់ (១២:១០,១៤) គឺកំពុងប្រឈមមុខនឹងសេចក្តីក្រោធនៃព្រះដ៏មានព្រះជន្មរស់ហើយ (១០:៣១) ។ អ្នកនិពន្ធបានលើកឡើងចំនួន៥ដង នូវការព្រមាន និងរំឭកពួកអ្នកទទួលសំបុត្រនេះអំពីការជំនុំ ជំរះនៃព្រះអម្ចាស់ ដែលបានកើតឡើងចំពោះ ពួកអ៊ីស្រាអែលដែលបះបោរនៅទីរហោស្ថាន ។

**ទម្រង់អក្សរសាស្ត្រ**

កណ្ឌគម្ពីរហេព្រើរជាទូទៅត្រូវបានហៅថាសំបុត្រ ទោះបីមិនមានទម្រង់ជាសំបុត្រក៏ដោយ ។ សេចក្តីបញ្ចប់នៃកណ្ឌគម្ពីរនេះមានលក្ខណៈដូចសំបុត្រ (១៣:២២-២៥) ប៉ុន្តែ សេចក្តីផ្តើមមានលក្ខណៈដូចជាសេចក្តីពង្រាង ឬការអធិប្បាយវិញ (១:១-៤) ។ អ្នកនិពន្ធមិនបានបញ្ជាក់អំពីខ្លួនគាត់ផ្ទាល់ ឬអ្នកដទៃទៀត ដូចជាអ្នកនិពន្ធសំបុត្រផ្សេងៗទៀតតែងតែធ្វើនោះទេ ។ ម្យ៉ាងទៀត គាត់ពុំបានបញ្ជាក់អំពីការស្វាគមន៍ ដូចដែលបានប្រើនៅសំបុត្រនាសម័យនោះទេ ។ អ្នកនិពន្ធកណ្ឌគម្ពីរនេះបានផ្តើមនិយាយអំពីព្រះយេស៊ូវគ្រីស្ទ ហើយបានហៅសេចក្តីអធិប្បាយរបស់គាត់ថា "ព្រះបន្ទូលទូន្មាន" (១៣:២២ កថ ១៣:១៥) ។ ដូចគ្នានឹងការអធិប្បាយដែរ កណ្ឌគម្ពីរហេព្រើរពេញដោយការលើកទឹកចិត្ត ការទូន្មាន និងការ ព្រមាន ។ ម្យ៉ាងទៀត កណ្ឌគម្ពីរនេះ អ្នកនិពន្ធប្រើជាសេចក្តីអធិប្បាយ ហើយផ្ញើទៅពួកអ្នកទទួលក្នុងទម្រង់ជាសំបុត្រ ។

**គម្រោងសង្ខេប**

**I. បុព្វកថា: ភាពធំឧត្តមនៃការបើកសំដែងថ្មីរបស់ព្រះអម្ចាស់ (១:១-៤)**

**II. ភាពធំឧត្តមរបស់ព្រះគ្រីស្ទ ឆ្លើយតបនឹងសេចក្តីសញ្ញាចាស់ (១:៥-៧:២៨)**

**ក. ព្រះគ្រីស្ទទ្រង់ធំលើសជាងពួកទេវតា (១:៥-២:១៨)**

១. ភស្តុតាងនៅក្នុងបទគម្ពីរអំពីភាពធំឧត្តមរបស់ព្រះគ្រីស្ទ (១:៥–១៤)
២. ការទូន្មានមិនឱ្យបដិសេធការបើកសំដែងរបស់ព្រះនៅក្នុងព្រះរាជបុត្រា (២:១–៤)
៣. ព្រះយេស៊ូវទ្រង់បន្ទាបព្រះអង្គទ្រង់ (២:៥–៩)
៤. ព្រះយេស៊ូវទ្រង់សង្គ្រោះយើង ដោយមានរូបកាយដូចយើងរាល់គ្នា (២:១០–១៨)

**ខ. ព្រះគ្រីស្ទទ្រង់ធំលើសជាងលោកម៉ូសេ (៣:១–៤:១៣)**
១. ការបង្ហាញនៃភាពធំឧត្តមរបស់ព្រះគ្រីស្ទ (៣:១–៦)
២. ការទូន្មានចូលទៅរកការសម្រាកនៃសង្គ្រោះ (៣:៧–៤:១៣)

**គ. ព្រះគ្រីស្ទទ្រង់ធំលើសជាងពួកសង្ឃរបស់លោកអើរ៉ុន (៤:១៤–៧:២៨)**
១. ព្រះយេស៊ូវជាសម្តេចសង្ឃដ៏ធំ (៤:១៤–១៦)
២. សមត្ថភាពនៃពួកសង្ឃ (៥:១–១០)
៣. ការទូន្មានឱ្យបានពេញវ័យខាងជំនឿ (៥:១១–៦:១២)
៤. ភាពច្បាស់លាស់នៃសេចក្តីសន្យារបស់ព្រះអម្ចាស់ (៦:១៣–២០)
៥. លំដាប់នៃភាពជាសង្ឃរបស់ព្រះគ្រីស្ទ (ជំពូក ៧)

**III. យញ្ញបូជាដ៏ឧត្តមរបស់សម្តេចសង្ឃនៃយើង (៨:១–១០:១៨)**
ក. ទីបរិសុទ្ធថ្មី និងសេចក្តីសញ្ញាថ្មី (ជំពូក ៨)
ខ. ទីបរិសុទ្ធចាស់ (៩:១–១០)
គ. យញ្ញបូជាដ៏ប្រសើរ (៩:១១–១០:១៨)

**IV. ការត្រាស់ហៅឱ្យដើរតាមព្រះយេស៊ូវដោយស៊ូទ្រាំ និងស្មោះត្រង់ (១០:១៩–១២:២៩)**
ក. មានជំនឿជាក់ចូលទៅក្នុងទីបរិសុទ្ធ (១០:១៩–២៥)
ខ. ស៊ូទ្រាំក្នុងជំនឿពេលមានទុក្ខលំបាក (១០:៣២–១២:៣)
១. ពេលអនាគត ដូចជាអតីត (១០:៣២–៣៩)
២. ជំនឿ និងគំរូដ៏ល្អ (ជំពូក ១១)
៣. ព្រះយេស៊ូវជាគំរូដ៏ល្អ (១២:១–៣)
គ. ការលើកទឹកចិត្តឱ្យស៊ូទ្រាំ និងប្រឈមមុខនឹងទុក្ខលំបាក (១២:៤–១៣)
ឃ. ការទូន្មាននៅក្នុងការរស់នៅបរិសុទ្ធ (១២:១៤–១៧)
ង. ការចម្រើនឡើង ការជំរុញទឹកចិត្ត និងការព្រមាន (១២:១៨–២៩)

**V. សេចក្តីសន្និដ្ឋាន (ជំពូក ១៣)**
ក. វិន័យសម្រាប់គ្រីស្ទបរិស័ទ (១៣:១–១៧)
ខ. សំណូមពរអធិស្ឋាន (១៣:១៨–១៩)
គ. ការទូលសូមព្រះពរពីព្រះអម្ចាស់ (១៣:២០–២១)
ឃ. ការសង្កេតផ្ទាល់ខ្លួន (១៣:២២–២៣)
ង. ពាក្យបណ្តាំចុងក្រោយ (១៣:២៤–២៥)

## ព្រះរាជបុត្រាប្រសើរជាងពួកទេវតា

**១** ១ ឯព្រះ ដែលពីដើម ទ្រង់មានបន្ទូល[ក] នឹងពួកព្ធយុកោ
ដោយពួកហោរា[ខ] ជាច្រើនដងច្រើនបែប[គ] ២ នៅជាន់
ក្រោយបង្អស់នេះ[ឃ] ទ្រង់បានមានបន្ទូលនឹងយើងរាល់គ្នា
ដោយសារព្រះរាជបុត្រាវិញ[ង] ដែលទ្រង់បានដំរូវឱ្យបាន
គ្រងរបស់ទាំងអស់ ទុកជាមរដក[ច] ព្រមទាំងបង្កើតលោកិយ
ដោយសារព្រះរាជបុត្រា[ឆ] នោះដែរ[ជ] ៣ គឺទ្រង់ជារស្មីភ្លឺមក
ពីសិរីល្អនៃព្រះ[ឈ] ហើយជារូបភាពនៃអង្គទ្រង់[ញ] ទាំង
ទ្រទ្រង់គ្រប់របស់ទាំងអស់[ដ] ដោយសារព្រះបន្ទូលដ៏មានព្រះ
ចេស្តានៃទ្រង់ ហើយក្រោយដែលបានសំអាតអំពើបាប[ឋ]
របស់យើងរាល់គ្នាទាំងប៉ុន្មាន នោះក៏គង់នៅខាងស្តាំនៃ
ឫទ្ធានុភាពនៅលើស្ថានដ៏ខ្ពស់[ឌ] ៤ ហើយដែលទ្រង់បានទទួល
នាម១ ទុកជាមរដក ជានាមដែលប្រសើរជាងនាមរបស់
ពួកទេវតាប៉ុណ្ណា នោះទ្រង់ក៏បានត្រឡប់ជាវិសេសជាងពួក
ទេវតាប៉ុណ្ណោះដែរ[ឍ]។
៥ ដ្បិតតើព្រះដែលមានបន្ទូលនឹងទេវតាណាមួយថា
«ឯងជាកូនអញ អញបានបង្កើតឯងនៅថ្ងៃនេះ»[ណ] ឬថា
«អញនឹងបានជាឪពុកដល់វា ហើយវានឹងបានជាកូនរបស់
អញ»[ត] ដូច្នេះឬទេ ៦ ហើយម្តងទៀត កាលទ្រង់ឱ្យព្រះរាជ
បុត្រា[ថ] មកក្នុងលោកិយ[ទ] នោះទ្រង់មានបន្ទូលថា «ចូរឱ្យអស់
ទាំងទេវតានៃព្រះថ្វាយបង្គំចុះ»[ធ] ៧ ខាងឯពួកទេវតា នោះ
ទ្រង់មានបន្ទូលថា «ទ្រង់យកពួកទេវតារបស់ទ្រង់ ធ្វើជា

**១:១** ក យហ ៩:២៩ ហព ២:៣,៣ ៤:៨ ១២:២៥ ខ ក ១:៧០ កថ ២:៣០ គ ជន ១២:៦,៨ **១:២** ឃ ចទ ៤:៣០ ហព ៩:២៦ ១ពត ១:២០ ង ខ.៥ មថ ៣:១៧ ហព ៣:៦ ៥:៨ ៧:២៨ ច ទដ ២:៨ មថ ១១:២៧ ២៨:១៨ ឆ យហ ១:៣ ជ ហព ១១:៣ **១:៣** ឈ យហ ១:១៤ ញ យហ ១៤:៩ ដ កល ១:១៧

ឋ ទត ២:១៤ ហព ៧:២៧ ៩:១១–១៤ ឌ មក ១៦:១៩ **១:៤** ឍ អភ ១:២១ ភល ២:៩,១០ ហព ៨:៦ **១:៥** ណ ទដ ២:៧ មថ ៣:១៧ ត ២សយ ៧:១៤ **១:៦** ថ យហ ៣:១៦ កល ១:១៨ ទ ហព ១០:៥ ធ ចទ ៣២:៤៣ ទដ ៩៧:៧ **១:៧** ន ទដ ១០៤:៤

---

**១:១** *ពីដើម* ពាក្យនេះមានន័យផ្ទុយគ្នានឹងពាក្យថា "ជាន់ក្រោយបង្អស់នេះ" នៅក្នុង ខ.២ ដែលជាយុគសម័យនៃព្រះមែស៊ី ដោយការកើតជាថ្មី (កថ ២:១៧ ១ធថ ៤:១ ១យហ ២:១៨ និងការពន្យល់)។ *ទ្រង់មានបន្ទូល* ត្រង់ចំណុចនេះបញ្ជាក់ថា ព្រះអម្ចាស់គឺជាអ្នកនិពន្ធទាំងគម្ពីរសញ្ញាចាស់ និងគម្ពីរសញ្ញាថ្មី។ *នឹងពួកព្ធយុកោ* គឺផ្ទុយនឹងពាក្យថា "នឹងយើងរាល់គ្នា" នៅក្នុងខ.២។ *ដោយពួកហោរា* បញ្ជាក់ថា អ្នកនិពន្ធគម្ពីរសញ្ញាចាស់ត្រូវបានហៅថា "ហោរា" ដែលថ្លែងអំពីការយាងមករបស់ព្រះគ្រីស្ទ (សូមប្រៀបធៀបនឹងឃ្លាថា ដោយសារព្រះរាជបុត្រាក្នុងខ.២)។ *ជាច្រើនដងច្រើនបែប* មានន័យថា ការបើកសំដែងនៅក្នុងគម្ពីរសញ្ញាចាស់គឺ ទៅតាមពេលវេលា និងបញ្ចប់ដោយបែបផែនផ្សេងៗ។

**១:២–៣** ការបើកសំដែងដ៏អស្ចារ្យរបស់ព្រះអម្ចាស់ត្រូវបានពណ៌នាដោយសេចក្តី៧យ៉ាង (១).*ទ្រង់បានដំរូវឱ្យបានគ្រងរបស់ទាំងអស់* ជាកូនដែលកើតជាថ្មីដែលបានបំពេញព្រះរាជកិច្ចនៃការប្រោសលោះ និងត្រូវបានតម្កើងឡើងជាកូនច្បងបង្អស់នៃព្រះ (រម ៨:១៧)។ (២).*ព្រមទាំងបង្កើតលោកីយ ដោយសារព្រះរាជបុត្រានោះដែរ* "មើលការពន្យល់ យហ ១:៣ ១កថ ៨:៦ កល ១:១៦"។ (៣).*ទ្រង់ជារស្មីភ្លឺមកពីសិរីល្អនៃព្រះ* បញ្ជាក់ថា ព្រះយេស៊ូវគ្រីស្ទជាពន្លឺដែលមកពីព្រះ និងជាអង្គទីពីរនៃព្រះត្រៃឯក ប្រៀបដូចជាកាំរស្មីរបស់ព្រះអាទិត្យ មិនអាចផ្តាច់ចេញពីព្រះអាទិត្យដូច្នោះដែរ (យហ ១:១៤,១៨ និងពន្យល់)។ (៤).*ជារូបភាព នៃអង្គទ្រង់* ព្រះយេស៊ូវជារូបអង្គនៃព្រះ និងជាព្រះដ៏ពិត (យហ ១៤:៩ កល ១:១៥ និងពន្យល់)។ (៥).*ទាំងទ្រទ្រង់គ្រប់របស់ទាំងអស់* គឺទ្រង់គ្រប់គ្រងគ្រប់សារពើដែលបានបង្កើតមកតាមរយៈទ្រង់ (កល ១:១៧)។ (៦).*បានសំអាតអំពើបាប* តាមរយៈការប្រោសលោះរបស់ទ្រង់ ដោយការសុគតនៅលើឈើឆ្កាង (៧:២៧ ៩:១២ ទត ២:១៤ និងពន្យល់)។ (៧).*គង់នៅខាងស្តាំនៃឫទ្ធានុភាពនៅលើស្ថានដ៏ខ្ពស់* ដោយព្រោះព្រះយេស៊ូវជាព្រះ និងគង់នៅខាងស្តាំនៃព្រះវរបិតា ដូច្នេះបញ្ជាក់ថាទ្រង់កំពុងគ្រប់គ្រងលើគ្រប់ទាំងអស់ (ខ.១៣ ៨:១ ១០:១២ មថ ២៦:៦៤ កថ ២:២៣ ៥:៣៤ រម ៨:៣៤ អភ ១:២០ កល ៣:១ ១ពត ៣:២២)។

**១:២** *នៅជាន់ក្រោយបង្អស់នេះ* សំដៅលើពេលវេលាដែលគ្រប់សេចក្តីសន្យា នៅក្នុងគម្ពីរសញ្ញាចាស់ត្រូវបានសម្រេច (ខ.១ យក ៥:៣ ១ពត ១:២០ យដ ១៨ និង ការពន្យល់ ២ពត ៣:៣)។

**១:៤** *ប្រសើរជាងនាមរបស់ពួកទេវតា* សម្រាប់ពួកសាសន៍យូដា ពួកទេវតាគឺត្រូវបានតម្កើងឡើងខ្ពស់ ជាពិសេសពួកទេវតាទាំងនោះមានការចូលរួមក្នុងការប្រទានក្រឹត្យវិន័យនៅលើភ្នំស៊ីណាយ (២:២) ហើយសម្រាប់ពួកនេះ ក្រិត្យវិន័យគឺជាការបើកសំដែងរបស់ព្រះ ។ យោងតាមសិលាចារិកសមុទ្រស្លាប់ (Dead Sea Scrolls) យល់ថា ទេវតាចម្បាំងមីកែលគួរតែជារូបភាពអស្ចារ្យនៃនគររបស់ព្រះមែស៊ី ។ *នាម* យោងតាមបទគម្ពីរបន្តបន្ទាប់បញ្ជាក់ថាជានាមរបស់ព្រះរាជបុត្រា គឺពុំមែនជានាមដែលពួកទេវតាអាចទទួលបានទេ (ភល ២:៩ និងពន្យល់)។

**១:៥–១៤** ភាពអស្ចារ្យរបស់ព្រះគ្រីស្ទលើពួកទេវតា ត្រូវបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរសញ្ញាចាស់ និងបញ្ជាក់ថា ទ្រង់ជាព្រះរាជបុត្រានៃព្រះ ដែលទទួលការថ្វាយបង្គំពីពួកទេវតា ។

**១:៥** *ឯងជាកូនអញ អញបានបង្កើតឯងនៅថ្ងៃនេះ* បទគម្ពីរនេះ (ទដ ២:៧) ត្រូវបានលើកមកនិយាយនៅក្នុងគម្ពីរ "កថ ១៣:៣៣" ជាការសម្រេចក្នុងការរស់ពីសុគតឡើងវិញរបស់ព្រះគ្រីស្ទ (រម ១:៤)។ *អញនឹងបានជាឪពុកដល់វា ហើយវានឹងបានជាកូនរបស់អញ* ពួកសាសន៍យូដាទទួលស្គាល់ថាបទគម្ពីរ "២សយ ៧:១៤ និង ទដ ២" គឺនិយាយអំពីព្រះមែស៊ី (លក ១:៣២–៣៣ និងការពន្យល់)។

**១:៦** *ព្រះរាជបុត្រា* "មើលពន្យល់ កល ១:១៥"។ *ចូរឱ្យអស់ទាំងទេវតានៃព្រះថ្វាយបង្គំចុះ* ឃ្លានេះក្នុងព្រះគម្ពីរសញ្ញាចាស់ និយាយសំដៅលើព្រះអម្ចាស់ដ៏ជាព្រះ (ព្រះយេហូវ៉ា) ហើយនៅត្រង់ចំណុចនេះសំដៅលើព្រះគ្រីស្ទ ដោយបញ្ជាក់នូវភាពជាព្រះដ៏ពិតប្រាកដរបស់ទ្រង់ ។ ម្យ៉ាងទៀត បទគម្ពីរនេះបញ្ជាក់យ៉ាងច្បាស់ថា អស់ទាំងទេវតាថ្វាយបង្គំព្រះគ្រីស្ទ ។

**១:៧** *ទ្រង់យកពួកទេវតារបស់ទ្រង់ធ្វើជាវិញ្ញាណ ហើយពួកអ្នកបំរើទ្រង់ធ្វើជាអណ្តាតភ្លើង* នៅក្នុងបទគម្ពីរ "ទដ ១០៤:៤" បានចែងថា "ទ្រង់យកខ្យល់ធ្វើអ្នកជូនដំណើររបស់ទ្រង់ ហើយយកអណ្តាតភ្លើងធ្វើជាពួកបម្រើទ្រង់"។ *ទេវតា* ពាក្យនេះនៅក្នុងភាសាក្រិក និងភាសាហេព្រើរ មានន័យថា "អ្នកនាំសារ"។

វិញ្ញាណ ហើយពួកអ្នកបំរើទ្រង់ធ្វើជាអណ្តាតភ្លើង»[ន] ៨តែ
ខាងឯព្រះរាជបុត្រាវិញ នោះទ្រង់មានបន្ទូលថា «ឱព្រះ
អើយ បល្ល័ង្កទ្រង់នៅជាប់អស់កល្បជានិច្ចរៀងរាបតទៅ[ប]
ព្រះដំបងពេជ្ររបស់រាជ្យទ្រង់ នោះជាដំបងសុចរិត ៩ទ្រង់
បានស្រឡាញ់សេចក្តីសុចរិត ហើយស្អប់ការទទឹងច្បាប់
ហេតុនោះបានជាព្រះ គឺជាព្រះនៃទ្រង់ បានចាក់ប្រេង[ផ]
ថ្វាយទ្រង់ ជាប្រេងនៃសេចក្តីត្រេកអរសាទរ[ព] លើសជាង
ពួកសំឡាញ់នៃទ្រង់»[ភ] ១០ហើយថា «ឱព្រះអម្ចាស់អើយ
កាលដើមដំបូង ទ្រង់បានបង្កប់ឫសផែនដី ហើយផ្ទៃមេឃក៏ជា
ការដែលព្រះហស្តទ្រង់ធ្វើដែរ[ម] ១១ឯរបស់ទាំងនោះនឹង
សាបសូន្យទៅ តែទ្រង់នឹងគង់នៅជាប់ដដែល របស់ទាំង
នោះនឹងចាស់ទៅ ដូចជាសំលៀកបំពាក់[យ] ១២ទ្រង់នឹងឆ្នូល
ទៅដូចជាអាវ ហើយរបស់ទាំងនោះក៏នឹងប្រែក្លាយទៅ តែ
ទ្រង់នៅតែដដែល[រ] ព្រះជន្មទ្រង់មិនចេះផុតឡើយ»[ល] ១៣តើ
ទ្រង់ដែលមានបន្ទូលទៅទេវតាណាមួយថា «ចូរអង្គុយខាង
ស្តាំអញ[វ] ទាល់តែអញដាក់ពួកខ្មាំងសត្រូវឯង ទុកជា
កំណល់[ស]កល់ជើងឯង»[ហ] ដូច្នេះឬទេ ១៤តើពួកទេវតាទាំង
នោះមិនមែនជាវិញ្ញាណបំរើ[ឡ] ដែលទ្រង់បានចាត់មក
សំរាប់ការងារជួយដល់ពួកដែលត្រូវទទួល[អ]សេចក្តីសង្គ្រោះ
ជាមរដកទេឬអី[ក]?

**១:៨** ប លក ១:៣៣
**១:៩** ផ អស ៦១:១,៣ ព ទដ ៤៥:៦,៧ ភ ភល ២:៩
**១:១០** ម ទដ ៨:៦ សក ១២:១
**១:១១** យ អស ៣៤:៤ ៥១:៦ ហាព ១២:២៧
**១:១២** រ ហាព ១៣:៨ ល ទដ ១០២:២៥–២៧
**១:១៣** វ ខ.៣ មក ១៦:១៩ ស យស ១០:២៤ ហាព ១០:១៣ ហ ទដ ១១០:១ មថ ២២:៤៤
**១:១៤** ឡ ទដ ៩១:១១ ១០៣:២០ ដយ ៧:១០ អ មថ ២៥:៣៤ មក ១០:១៧ កច ២០:៣២ ក រម ១១:១៤ ហាព ២:៣ ៥:៩ ៩:២៨
**២:១** ខ រម ១១:២២
**២:២** គ ហាព ១:១

## ការព្រមានឱ្យប្រុងប្រយ័ត្ន

២ ១ដោយហេតុនោះ បានជាគួរឱ្យយើងរាល់គ្នាប្រុង
ប្រយ័ត្នលើសទៅទៀត ចំពោះសេចក្តីដែលយើងរាល់គ្នា
បានឮ ក្រែងយើងរសាត់ចេញពីសេចក្តីទាំងនោះ[ខ] ២ដ្បិត
បើសិនជាគ្រប់ទាំងព្រះបន្ទូល[គ]ដែលពួកទេវតាបានពោល[ឃ]
នោះបានឃើញថាពិតមែន ហើយគ្រប់ទាំងអំពើរំលង និង
សេចក្តីរឹងចចេសក៏ត្រូវទោសចំពោះ[ង] ៣នោះធ្វើដូចម្តេចឱ្យ
យើងរួចបាន បើយើងធ្វេសនឹងសេចក្តីសង្គ្រោះដ៏ធំម្ល៉េះ?[ច]
ដែលព្រះអម្ចាស់បានចាប់ផ្តើមផ្សាយមក[ឆ] រួចពួកអ្នកដែល
ឮ ក៏បានបញ្ជាក់មកយើងរាល់គ្នាដែរ[ជ] ៤ទាំងមានព្រះធ្វើ
បន្ទាល់ជាមួយផង ដោយទីសំគាល់ ការអស្ចារ្យ និងការឫទ្ធិ
បារមីជាច្រើនយ៉ាង[ឈ] ទាំងចែកព្រះវិញ្ញាណបរិសុទ្ធ[ញ] មក
តាមព្រះហឫទ័យទ្រង់ផង[ដ]។

## បងប្អូនរបស់ព្រះយេស៊ូវ

៥រីឯនៅខាងបរលោក ដែលយើងខ្ញុំនិយាយនេះ ទ្រង់
មិនបានបញ្ចុះបញ្ចូល មកក្រោមអំណាចនៃពួកទេវតាទេ

ឃ ចទ ៣៣:២ កច ៧:៥៣ កទ ៣:១៩ ង ហាព ១០:២៨ **២:៣** ច ហាព ១០:២៩ ១២:២៥ ឆ ហាព ១:២ ជ លក ១:២ **២:៤** ឈ មក ១៦:២០ យហ ៤:៤៨ ញ ១កថ ១២:៤ ដ អភ ១:៥

**១:៨** *តែខាងឯព្រះរាជបុត្រា . . . ឱព្រះអើយ បល្ល័ង្កទ្រង់នៅជាប់អស់កល្បជានិច្ចរៀងរាបតទៅ* អ្នកនិពន្ធបញ្ជាក់អំពីភាពជាស្តេចរបស់ព្រះមែស៊ី ហើយបន្ទាប់ ទៀតបញ្ជាក់ថាព្រះរាជបុត្រាទ្រង់មានអំណាចលើពួកទេវតា (ទដ ៤៥:៦)។

**១:១០** បទគម្ពីរនេះ ក៏ដូចគ្នានឹងខ.៦ដែរ គឺនិយាយសំដៅលើព្រះអម្ចាស់ជាព្រះលើគ្រប់ទាំងអស់ ។ ត្រង់ចំណុចនេះនិយាយសំដៅលើព្រះរាជបុត្រា ។

**១:១៣** *ចូរអង្គុយខាងស្តាំអញ* នៅក្នុងបទគម្ពីរ "ទដ ១១០" គឺនិយាយសំដៅលើព្រះយេស៊ូវ (ខ.២–៣,១៣ ៥:៦ ៦:២០ ៧:៣,១១,១៧,២១ ៨:១ ១០:១២–១៣ ១២:២)។

**១:១៤** *ជាវិញ្ញាណបំរើ* ព្រះគ្រីស្ទទ្រង់សោយរាជ្យ ហើយពួកទេវតាទ្រង់ប្រទានមកដើម្បីបម្រើ ។

**២:១** *សេចក្តីដែលយើងរាល់គ្នាបានឮ* គឺដំណឹងល្អ ដែលរួមបញ្ចូលនូវភាពជាព្រះរបស់ព្រះគ្រីស្ទ និងការប្រោសលោះរបស់ទ្រង់ ដោយការសុគតនៅលើឈើឆ្កាង ។ *ក្រែងយើងរសាត់ចេញពីសេចក្តីទាំងនោះ* គឺចេញពីការបើកសំដែង ដែលព្រះទ្រង់បានប្រទានមក តាមរយៈព្រះរាជបុត្រា ។

**២:២** *គ្រប់ទាំងព្រះបន្ទូលដែលពួកទេវតាបានពោល* សំដៅលើក្រិត្យវិន័យដែលព្រះបានប្រទានមកលោកម៉ូសេនៅភ្នំស៊ីណាយ (មើល កច ៧:៣៨ និងការពន្យល់)។

**២:៣** *នោះធ្វើដូចម្តេចឱ្យយើងរួចបាន* "សូមមើល ១២:២៥"។ *សេចក្តីសង្គ្រោះដ៏ធំម្ល៉េះ* សេចក្តីសង្គ្រោះនេះត្រូវបានប្រកាសជាដំបូង ដោយព្រះយេស៊ូវគ្រីស្ទ ។ ពួកហោរានៅក្នុងសញ្ញាចាស់បានថ្លែងអំពីការយាងមករបស់ព្រះគ្រីស្ទ ប៉ុន្តែ ព្រះគ្រីស្ទដែលបានប្រកាសអំពីសេចក្តីសម្រេចនៃទំនាយទាំងនោះ ។ ម្យ៉ាងទៀត ទ្រង់មិនគ្រាន់តែថ្លែងអំពីការសម្រេចនៃសេចក្តីទំនាយរបស់ពួកហោរា នៅក្នុងសញ្ញាចាស់ប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គទ្រង់ផ្ទាល់ គឺជាសេចក្តីសម្រេចនោះតែម្តង ។ *រួចពួកអ្នកដែលឮ ក៏បានបញ្ជាក់មកយើងរាល់គ្នាដែរ* ឃ្លានេះសំដៅលើសាក្សី ដែលបានឃើញដោយផ្ទាល់ មានដូចជាពួកសាវកជាដើម (កច ១:២១–២២ ១យហ ១:១ ២ពត ១:១៦ និងការពន្យល់)។

**២:៤** *ទីសំគាល់ ការអស្ចារ្យ និងការឫទ្ធិបារមី* ត្រង់ចំណុចនេះបញ្ជាក់ថាព្រះអម្ចាស់សំដែងការអស្ចារ្យបន្ថែមលើព្រះបន្ទូលនៃដំណឹងល្អ ដោយទ្រង់ប្រទាននូវការប្រោសឱ្យជាពីជំងឺ ឬការអស្ចារ្យផ្សេងៗទៀត (កច ៣:៧–៩,១១–១២,១៦ ៥:១២ ៩:៣២–៤១ ១៤:៣,៨,៩ ១៩:១១,១២ ២៨:៨,៩)។ *ទាំងចែកព្រះវិញ្ញាណបរិសុទ្ធមក* គឺចែកនូវអំណោយទានខាងឯវិញ្ញាណដល់អស់អ្នកណាដែលទទួល ជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ (កច ២:៤–១២ ១កថ ១២:៤–១១)។

**២:៥–៩** សេចក្តីរៀបរាប់នៅក្នុងបទគម្ពីរ "ទដ ៨:៤–៦" បានបង្ហាញនូវការអស្ចារ្យពីព្រះគ្រីស្ទគ្រប់គ្រងលើអស់ពួកទេវតា ហើយអស់អ្នកណា នៅក្នុងទ្រង់នោះមានអំណាចលើអ្វីៗដែលទ្រង់បានបង្កើត(លប ១:២៦,២៨)។

**២:៥** *ទ្រង់មិនបានបញ្ចុះបញ្ចូល មកក្រោមអំណាចនៃពួកទេវតាទេ* ឃ្លានេះ និយាយសំដៅលើព្រះគ្រីស្ទ ដែលនាំមកនូវការបើកសំដែងថ្មី (១:២–៣ និងការពន្យល់)។ ទ្រង់មានអំណាចលើពួកទេវតាទាំងអស់ ដែលបានចូលរួមក្នុងការប្រទាននូវក្រិត្យវិន័យនៅឯភ្នំស៊ីណាយ (២:២ និងការពន្យល់)។

៦តែមានមនុស្សម្នាក់[ឋ]បានធ្វើបន្ទាល់ នៅកន្លែងណាមួយថា
«តើមនុស្សជាអ្វី បានជាទ្រង់យកចិត្តទុកដាក់នឹងគេ ឬកូន
មនុស្សបានជាទ្រង់ប្រោសដូច្នេះ[ឌ] ៧ទ្រង់បានធ្វើឱ្យគេទាប
ជាងពួកទេវតាតែបន្តិចទេ ក៏បានបំពាក់សិរីល្អ និងកេរ្តិ៍
ឈ្មោះឱ្យ ទុកជាមកុដ ទ្រង់បានតាំងឡើងឱ្យត្រួតត្រាលើអស់
ទាំងការនៃព្រះហស្តទ្រង់» ៨ទ្រង់បានបញ្ចុះបញ្ចូលគ្រប់
ទាំងអស់ នៅក្រោមជើងគេ»[ឍ] ហើយដែលទ្រង់បានបញ្ចុះ
បញ្ចូលគ្រប់ទាំងអស់ នោះគឺមិនបានទុកអ្វី ដែលមិនចុះ
ចូលសោះឡើយ តែសព្វថ្ងៃនេះ យើងមិនទាន់ឃើញគ្រប់
ទាំងអស់ចុះចូលនៅឡើយទេ ៩តែយើងឃើញព្រះយេស៊ូវ
វិញ ដែលព្រះបានធ្វើឱ្យទាបជាងពួកទេវតាបន្តិចទ្រង់ពាក់
សិរីល្អ និងល្បីព្រះនាម ទុកជាមកុដ[ណ] ដោយព្រោះទ្រង់បាន
រងទុក្ខសុគត[ត] ដើម្បីនឹងភ្លក់សេចក្តីស្លាប់ជំនួសមនុស្សទាំង
អស់ ដោយនូវព្រះគុណនៃព្រះ[ថ] ១០ដ្បិតឯព្រះដែលគ្រប់
របស់ទាំងអស់សំរាប់ទ្រង់ ហើយដោយសារទ្រង់[ទ] កាល
ទ្រង់ចង់នាំកូនជាច្រើនមកក្នុងសិរីល្អ នោះគួរគប្បីឱ្យ
ទ្រង់បានធ្វើឱ្យមេនៃសេចក្តីសង្គ្រោះគេ បានគ្រប់លក្ខណ៍
ដោយរងទុក្ខលំបាក[ធ] ១១ពីព្រោះព្រះអង្គ ដែលញែកជា
បរិសុទ្ធ[ន] និងពួកអ្នកដែលទ្រង់ញែកជាបរិសុទ្ធ[ប] នោះសុទ្ធ
តែកើតមកពីព្រះតែ១ បានជាទ្រង់មិនខ្មាសនឹងហៅគេ
ជាបងប្អូនទេ[ផ] ១២ទ្រង់មានបន្ទូលថា «ទូលបង្គំនឹងប្រកាស
ប្រាប់ពីព្រះនាមទ្រង់ ដល់ពួកបងប្អូន ទូលបង្គំនឹងច្រៀង
សរសើរពីទ្រង់ នៅកណ្តាលពួកជំនុំ»[ព] ១៣ហើយ១ទៀតថា
«ទូលបង្គំនឹងទុកចិត្តដល់ទ្រង់»[ភ] ហើយ ១ទៀតថា «មើល
ទូលបង្គំនេះ នឹងពួកកូនចៅ ដែលព្រះ បានប្រទានមកទូល
បង្គំ»[ម] ១៤ដូច្នេះ ដែលកូនចៅបានប្រកបដោយសាច់
ឈាមព្រមគ្នា[យ] នោះទ្រង់ក៏ទទួលចំណែកជាសាច់ឈាម
ដូច្នោះដែរ[រ] ដើម្បីឱ្យទ្រង់បានបំផ្លាញអានោះ[ល] ដែលមាន
អំណាចលើសេចក្តីស្លាប់ គឺជាអារក្ស ដោយទ្រង់សុគត[វ]
១៥ហើយឱ្យបានប្រោសដល់ពួកអ្នកនោះ ដែលជាប់ជាបាវ
បំរើគ្រប់១ជីវិត ដោយខ្លាច[ស]ស្លាប់ ឱ្យបានរួចចេញវិញ
១៦ដ្បិតច្បាស់ជាទ្រង់មិនបានយកពួកទេវតាទេ គឺបានយក

**២:៦** ឋ ហាព ៤:៤ ឌ យប ៧:១៧ ទដ ១៤៤:៣ **២:៨** ឍ ទដ ៨:៤-៦ មថ ២២:៤៤ **២:៩** ណ ខ.៧ កច ៣:១៣ ភល ២:៩ ត ភល ២:៧-៩ ថ ២កថ ៥:១៥ **២:១០** ទ រម ១១:៣៦ ធ លក ២៤:២៦ ហាព ៥:៨,៩ ៧:២៨ **២:១១** ន ហាព ១៣:១២ ប អភ ៥:២៦ ផ មថ ២៨:១០ **២:១២** ព ទដ ២២:២២ ៦៨:២៦ **២:១៣** ភ យក ៨:១៧ ម អស ៨:១៨ យហ ១០:២៩ **២:១៤** យ ១កថ ១៥:៥០ អភ ៦:១២ រ យហ ១:១៤ ល លប ៣:១៥ ១កថ ១៥:៥៤-៥៧ ២ធថ ១:១០ វ ១យហ ៣:៨ **២:១៥** ស ២ធថ ១:៧

**២:៦-៨** ទោះបីព្រះគ្រីស្ទជាព្រះរាជបុត្រានៃព្រះ និងមានអំណាចលើពួកទេវតា ហើយគ្រប់សារពើទាំងអស់ក៏ដោយ ក៏នៅពេលដែលទ្រង់ត្រូវបានបញ្ជូនមកនៅលើផែនដី យកកំណើតជាមនុស្ស ហើយមានឋានៈទាបជាងពួកទេវតាបន្តិចក៏ពិតមែន (ខ.៧) ប៉ុន្តែ បន្ទាប់ពីទ្រង់រស់ពីសុគតឡើងវិញ ទ្រង់បានទទួលគ្រប់ទាំង សិរីល្អ និងមានអំណាចលើគ្រប់ទាំងអស់វិញ (លប ១:២៦-២៨ អភ ១:២០-២២ ហាព ១:១៣)។

**២:៨** *គ្រប់ទាំងអស់* ផែនការរបស់ព្រះសម្រាប់មនុស្សកាលដើមដំបូង គឺឱ្យពួកគេគ្រប់គ្រងលើគ្រប់ទាំងអស់បន្ទាប់ពីទ្រង់ ។ ប៉ុន្តែ ដោយព្រោះការមិនស្តាប់បង្គាប់ ទើបធ្វើឱ្យមនុស្សធ្លាក់ទៅក្នុងអំពើបាប ហើយបានក្លាយទៅជាបាវបម្រើនៃអំពើបាបវិញ (ខ.១៥)។ ទោះជាយ៉ាងក៏ដោយ ដោយសារតែព្រះគុណនៃព្រះអម្ចាស់ អស់អ្នកណាដែលទទួលជឿដល់ព្រះនាមទ្រង់ នោះមិនមែនជាបាវបម្រើនៃអំពើបាបទៀតទេ ។

**២:៩** *ទ្រង់ពាក់សិរីល្អ និងល្បីព្រះនាម ទុកជាមកុដ* បទគម្ពីរ "ទដ ៨" គឺនិយាយសំដៅលើព្រះយេស៊ូវគ្រីស្ទតែម្តង ។ ក្នុងនាមទ្រង់ជាព្រះប្រោសលោះមនុស្សនៅលើពិភពលោកនេះ ទ្រង់ត្រូវបានធ្វើឱ្យទាបជាងពួកទេវតាបន្តិច (ខ.៧ ១០:១៣ និងការពន្យល់) ប៉ុន្តែ បន្ទាប់ពីទ្រង់រស់ពីសុគតឡើងវិញទ្រង់បានទទួលនូវសិរីល្អ និងការសរសើរតម្កើង និងគង់នៅខាងស្តាំនៃព្រះវរបិតា ។ ដោយព្រោះព្រះជន្មដ៏គ្រប់លក្ខណ៍ ការសុគតនៅលើឈើឆ្កាង និងការលើកឡើងទៅស្ថានសួគ៌វិញរបស់ព្រះយេស៊ូវ នោះបញ្ជាក់ថាទ្រង់មានសមត្ថភាពប្រោសលោះមនុស្សលោកយ៉ាងពិតប្រាកដ ដូចមានចែងទុកនៅក្នុងបទគម្ពីរ "ទដ ៨" រួចជាស្រេច អំពីនគរដ៏គ្រប់លក្ខណ៍របស់ទ្រង់ដែលនឹងត្រូវមកដល់នាពេលអនាគត ។

**២:១០** *កូនជាច្រើនមកក្នុងសិរីល្អ* អ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទត្រូវបានជាកូនព្រះ (យហ ១:១២-១៣ រម ៨:១៤-២៣ កទ ៣:២៦ ៤:៥ អភ ៤:៥ ៥:១ ១យហ ៣:១-២ និងការពន្យល់)។ *មេ* ពាក្យនេះ នៅក្នុងភាសាក្រិកសំដៅលើ "អ្នកចាប់ផ្តើម ឬអ្នកបង្កើត"។ ពាក្យនេះក៏ប្រើចំពោះអ្នកដឹកនាំ អ្នកត្រួតត្រា ឬស្តេចដែរ ។ តាមទស្សនៈបច្ចុប្បន្ន ពាក្យនេះអាចសំដៅលើ"អ្នកជើងឯក" ដែលមានអំណាចលើសេចក្តីស្លាប់ និងជាជំនួយដល់អស់អ្នកដែលជាប់ជាទាសភាពនៃសេចក្តីស្លាប់នោះ (ខ.១៤,១៥ ១២:២ កច ៣:១៥ ៥:៣១ និងពន្យល់)។ *បានគ្រប់លក្ខណ៍ដោយរងទុក្ខលំបាក* មានន័យថា តាមរយៈការរងទុក្ខលំបាករបស់ព្រះគ្រីស្ទ ទើបទ្រង់ត្រូវបានប្រទាននូវមហាបេសកកម្មប្រោសលោះមនុស្សលោក (ខ.១៧ ៥:៩ ៧:២៨)។

**២:១១** *ព្រះអង្គដែលញែកជាបរិសុទ្ធ និងពួកអ្នកដែលទ្រង់ញែកជាបរិសុទ្ធ* ដោយសារការសុគតនៅលើឈើឆ្កាងរបស់ព្រះយេស៊ូវគ្រីស្ទ នោះទ្រង់បានញែកជាបរិសុទ្ធដល់ពួកអ្នកជឿដល់ព្រះនាមទ្រង់ (១កថ ១:២ និងពន្យល់)។

**២:១២** *ទូលបង្គំនឹងប្រកាសប្រាប់ពីព្រះនាមទ្រង់ ដល់ពួកបងប្អូន* ឃ្លានេះបានដកស្រង់ចេញពី "ទដ ២២:២២" ដែលពិពណ៌នាអំពីទុក្ខលំបាក និងការប្រោសលោះ នៃអ្នកបម្រើរបស់ព្រះអម្ចាស់ ។ *ពួកបងប្អូន* ឃ្លានេះដូចជាចេញពីព្រះឱស្ឋរបស់ព្រះមែស៊ី ។

**២:១៣** *ទូលបង្គំនឹងទុកចិត្តដល់ទ្រង់* គំរូនៃការទុកចិត្តដល់ព្រះ គឺសំដែងនៅក្នុងព្រះយេស៊ូវគ្រីស្ទ ។ *ទូលបង្គំនេះ និងពួកកូនចៅ ដែលព្រះបានប្រទានមកទូលបង្គំ* ឃ្លានេះជាព្រះបន្ទូលមកពីព្រះរាជបុត្រា។កូនរបស់ព្រះត្រូវបានប្រទានទៅ ព្រះរាជបុត្រាក្នុងនាមជាបងប្អូនប្រុសស្រីរបស់ទ្រង់ (ខ.១១ មថ ១២:៥០)។

**២:១៤** *អានោះដែលមានអំណាចលើសេចក្តីស្លាប់* គឺអារក្សសាតាំងដែលកាន់អំណាចនៃសេចក្តីស្លាប់ ដោយគ្រាន់តែនាំមនុស្សឱ្យធ្វើបាប និងធ្លាក់ទៅក្នុងទោសរបស់អំពើបាប ដែលជាសេចក្តីស្លាប់ (រម ៥:១២ និងពន្យល់)។

**២:១៥** *ឱ្យបានរួចចេញវិញ* "ការពន្យល់ ១កថ ១៥:៥៤-៥៧ វវ ១:១៨"។

ពូជលោក អ័ប្រាហាំវិញ[ហ] 17ហេតុនោះបានជាគួរឱ្យទ្រង់
បានដូចបងប្អូនទ្រង់គ្រប់ជំពូកដែរ[ឡ] ដើម្បីឱ្យបានធ្វើជា
សំដេចសង្ឃ[អ] ដែលមានព្រះទ័យមេត្តាករុណា[ក] ហើយក៏
ស្មោះត្រង់ក្នុងការទាំងប៉ុន្មានខាងឯព្រះ[ខ]ប្រយោជន៍នឹងថ្វាយ
ដង្វាយឱ្យធួន[គ] នឹងបាបរបស់ប្រជាជនទាំងឡាយ 18ដ្បិត
ដែលទ្រង់បានរងទុក្ខលំបាក ទាំងត្រូវសេចក្ដីល្បួង នោះ
ទ្រង់ក៏អាចនឹងជួយ ដល់អស់អ្នក ដែលត្រូវសេចក្ដីល្បួង
បានដែរ[ឃ]។

## ព្រះយេស៊ូវធំជាងលោកម៉ូសេ

៣ 1ដូច្នេះ បងប្អូនបរិសុទ្ធ[ង] ដែលមានចំណែកក្នុងការងារ
ស្ថានសួគ៌អើយ[ច] ចូរពិចារណាពីព្រះយេស៊ូវ ជាសាវក នឹង
ជាសំដេចសង្ឃ[ឆ] ដែលយើងថា យើងជឿតាមនោះចុះ[ជ]
2គឺដែលទ្រង់ស្មោះត្រង់ដល់ព្រះដែលតាំងទ្រង់ ដូចជា
លោកម៉ូសេក៏ស្មោះត្រង់ ក្នុងដំណាក់នៃព្រះទាំងមូលដែរ[ឈ]
3ដ្បិតដែលមនុស្សសង់ផ្ទះតែងមានកេរ្តិ៍ឈ្មោះ លើសជាង

**២:១៦** ហ លក ៣:៸
**២:១៧** ឡ ឧ.១៤ ភល ២:៧ អ ហព ៣:១ ៤:១៤,១៥ ៥:៥,១០ ៧:២៦,២៨ ៨:១,៣ ៩:១១ ក ហព ៥:២ ខ ហព ៥:១ គ រម ៣:២៥
**២:១៨** ឃ ហព ៤:១៥
**៣:១** ង ហព ២:១១ ច រម ៨:២៨ ឆ ហព ២:១៧ ជ ១ធថ ៦:១២ ហព ៤:១៤,១៥ ១០:២៣ ២កថ ៩:១៣
**៣:២** ឈ ឧ.៥ ជន ១២:៧
**៣:៣** ញ ចទ ៣៤:១២
**៣:៤** ដ លប ១:១

ផ្ទះនោះយ៉ាងណា នោះទ្រង់ក៏បានរាប់ជាគួរនឹងសិរីល្អ
លើសជាងលោកម៉ូសេយ៉ាងនោះដែរ[ញ] 4ព្រោះគ្រប់ទាំងផ្ទះ
តែងមានគេធ្វើ តែឯអ្នកដែលបានធ្វើគ្រប់របស់ទាំងអស់
នោះគឺជាព្រះវិញ[ដ] 5ហើយលោកម៉ូសេក៏ស្មោះត្រង់ នៅក្នុង
ដំណាក់នៃទ្រង់ទាំងមូលមែន[ឋ] ទុកដូចជាអ្នកបំរើ[ឌ] សំរាប់ជា
ទីបន្ទាល់ ពីការដែលត្រូវថ្លែងប្រាប់មកតាមក្រោយ 6តែ
ព្រះគ្រីស្ទ ទ្រង់ស្មោះត្រង់ ទុកដូចជាព្រះរាជបុត្រា[ឍ] ដែល
ត្រួតលើដំណាក់ទ្រង់វិញ គឺយើងរាល់គ្នានេះជាដំណាក់
នោះ[ណ] បើយើងកាន់ចិត្តមោះមុត[ត] នឹងសេចក្ដីអំនួតចំពោះ
សេចក្ដីសង្ឃឹមនេះ[ថ]យ៉ាងខ្ជាប់ខ្ជួនដរាបដល់ចុងបំផុតមែន ។

## សេចក្ដីព្រមានចំពោះការមិនជឿ

7ដូច្នេះ ចូរប្រយ័ត្នបងប្អូនអើយ ក្រែងមានពួកអ្នករាល់
គ្នាណាមួយ មានចិត្តអាក្រក់ ដោយមិនជឿ ព្រមទាំងបោះ

**៣:៥** ឋ ឧ.២ ជន ១២:៧ ឌ នក ១៤:៣១ **៣:៦** ឍ ហព ១:២ ណ ១កថ ៣:១៦ ១ធថ ៣:១៥ ត ឧ.១៤ រម ១១:២២ ហព ៤:១៤ ថ រម ៥:២ ហព ៦:១១,១៨,១៩ ៧:១៩ ១១:១

**២:១៦** *ពូជលោកអ័ប្រាហាំ* ព្រះគ្រីស្ទយាងមកសង្គ្រោះពួកកូនចៅលោកអ័ប្រាហាំ គឺពួកអ្នកមានជំនឿតាមលោកអ័ប្រាហាំ (លប ១២:២–៣ រម ៤:១១,១៦ ៩:៨ កទ ៣:២៩ និងការពន្យល់)។

**២:១៧** *សំដេចសង្ឃ ដែលមានព្រះទ័យមេត្តាករុណា ហើយក៏ស្មោះត្រង់* "សូមមើល ឧ.១៨ ៥:២"។ *សំដេចសង្ឃ* សំដៅលើម្នាក់ដែលមានសិទ្ធិចូលទៅក្នុងទីដ៏បរិសុទ្ធបំផុតនៅក្នុងព្រះវិហារ ដើម្បីផ្ទេរនូវអំពើបាបរបស់រាស្ត្រនៃព្រះ (៩:៧ ១៣:១១ លវ ១៦:១–៣៤ និងពន្យល់)។ *ថ្វាយដង្វាយឱ្យធួននឹងបាប* ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្ស ដើម្បីឱ្យពួកគេបានរួចផុតពីសេចក្ដីក្រោធរបស់ព្រះ (លវ ១៦:២០–២២ ១៧:១១ រម ៣:២៥ ១យហ ២:២ និងការពន្យល់)។

**២:១៨** *ទាំងត្រូវសេចក្ដីល្បួង* "មើលការពន្យល់ ៤:១៥"។

**៣:១–៦** ព្រះគ្រីស្ទជាសម្ដេចសង្ឃស្មោះត្រង់ ដែលគួរទទួលនូវការសរសើរពីយើងរាល់គ្នា ព្រោះទ្រង់ធំជាងលោកម៉ូសេ ។

**៣:១** *បងប្អូន* "មើលពន្យល់ រម ១:១៣"។ *បរិសុទ្ធ* "មើលពន្យល់ ១កថ ១:២"។ *មានចំណែកក្នុងការងារស្ថានសួគ៌* សំដៅលើការចូលរួមក្នុងព្រះវត្តមាន និងសេចក្ដីអំណរនៃព្រះអម្ចាស់ (ឧ.១៤ ១១:១៦ ១២:២២ និងការពន្យល់)។ *សាវក* សំដៅលើម្នាក់ ដែលត្រូវបានបញ្ជូនឱ្យទៅបំពេញបេសកកម្ម (មើលការពន្យល់ មក ៦:៣០)។ ព្រះយេស៊ូវមានបន្ទូលពីព្រះអង្គទ្រង់ថា ទ្រង់ត្រូវបានបញ្ជូនទៅក្នុង លោកីយដោយព្រះវរបិតា (មថ ១០:៤០ ១៥:២៤ មក ៩:៣៧ លក ៩:៤៨ យហ ៤:៣៤ ៥:២៤,៣០,៣៦–៣៨ ៦:៣៨)។ ព្រះគ្រីស្ទជាមេសាវ័កដ៏ធំបំផុតដែល ហើយទ្រង់ជាគំរូដល់សិស្សរបស់ទ្រង់ ។ *សំដេចសង្ឃ* មើលការពន្យល់ ២:១៧ ។

**៣:២** បទគម្ពីរនេះបង្ហាញនូវការប្រៀបធៀបរវាងព្រះយេស៊ូវគ្រីស្ទ និងលោកម៉ូសេ ។ លោកម៉ូសេត្រូវបានព្រះបញ្ជូនមក ដើម្បីនាំរាស្ត្ររបស់ទ្រង់ចេញពីភាពជាទាសកររបស់ស្ដេចនៃប្រទេសអេស៊ីព្ទឱ្យចូលទៅឯទឹកដីដែលទ្រង់បានសន្យាប្រទានឱ្យពួកគេវិញ ។ ព្រះយេស៊ូវត្រូវបានប្រទានមកដើម្បីដោះមនុស្សឱ្យរួចផុតពីអំណាចនៃសេចក្ដីស្លាប់(២:១៤,១៥) និងឱ្យសម្រាកក្នុងទ្រង់វិញ (៤:៣,៩)។

**៣:៣** *មនុស្សសង់ផ្ទះតែងមានកេរ្តិ៍ឈ្មោះ លើសជាងផ្ទះ* ឃ្លានេះ ប្រៀបធៀបព្រះយេស៊ូវគ្រីស្ទទៅនឹងអ្នកសង់ផ្ទះ ហើយលោកម៉ូសេគឺគ្រាន់តែជាចំណែកមួយនៃផ្ទះប៉ុណ្ណោះ ។

**៣:៤** *ឯអ្នកដែលបានធ្វើគ្រប់របស់ទាំងអស់ នោះគឺជាព្រះវិញ* ឃ្លានេះនិយាយសំដៅលើព្រះយេស៊ូវគ្រីស្ទ និងបញ្ជាក់ថា ទ្រង់ធំជាងលោកម៉ូសេ ។

**៣:៥–៦** *ជាអ្នកបំរើ សំរាប់ជាទីបន្ទាល់ . . . ទុកដូចជាព្រះរាជបុត្រា* លក្ខណៈ ដែលព្រះគ្រីស្ទធំជាងលោកម៉ូសេមានដូចជា (១).លោកម៉ូសេជាអ្នកបម្រើ ប៉ុន្តែ ព្រះគ្រីស្ទជាព្រះរាជបុត្រានៃព្រះ (២).លោកម៉ូសេជាអ្នកស្មោះត្រង់ក្នុងដំណាក់នៃព្រះ ប៉ុន្តែព្រះគ្រីស្ទត្រួតលើដំណាក់ទ្រង់ ។

**៣:៥** *ស្មោះត្រង់ . . . នៅក្នុងដំណាក់ទ្រង់* "សូមមើល ជន ១២:៧"។

**៣:៦** *គឺយើងរាល់គ្នាជាដំណាក់នោះ* បញ្ជាក់ថា ដំណាក់ព្រះត្រូវបង្កើតឡើងដោយរាស្ត្ររបស់ទ្រង់ (អភ ២:១៩ ១ពត ២:៥ និងការពន្យល់)។ *បើយើងកាន់ចិត្តមោះមុត* ត្រង់ចំណុចនេះបញ្ជាក់ថា កូនរបស់ព្រះត្រូវមានចិត្តព្យាយាម និងខ្ជាប់ខ្ជួន (១០:៣៥–៣៦)។ *សេចក្ដីអំនួត* សំដៅលើសេចក្ដីអំណរដ៏ពេញបរិបូរ (កទ ៦:១៤ ១កថ ១:២៩,៣១ ២កថ ១០:១៧ អភ ២:៩)។ *សេចក្ដីសង្ឃឹម* ជា ការធានារបស់ព្រះអម្ចាស់ (ឧ.១ ៦:១៨–១៩ ១១:១ រម ៥:២ និងការពន្យល់)។

**៣:៧–៤:១៣** សេចក្ដីពណ៌នានៅក្នុង "ទដ ៩៥:៧–១១" បញ្ជាក់នូវភាពធំឧត្ដមរបស់ព្រះគ្រីស្ទលើសលោកម៉ូសេ និងបង្ហាញនូវការព្រមានចំពោះពួកអ្នកមិនស្ដាប់បង្គាប់ និងពួកអ្នកមិនជឿ (២:១–៤ និងការពន្យល់)។

**៣:៧–១១** សេចក្ដីដកស្រង់ចេញពីបទគម្ពីរ "ទដ ៩៥:៧–១១" បានសង្ខេបនូវឱនភាពពួកអ៊ីស្រាអែល ក្រោមការដឹកនាំរបស់លោកម៉ូសេនៅទីរហោស្ថាន ។ គំរូនៃពួកអ៊ីស្រាអែល ស្ថិតនៅក្រោមការដឹកនាំរបស់លោកម៉ូសេត្រូវបានអ្នកនិពន្ធបទគម្ពីរទំនុកដំកើង យកមកធ្វើជាការព្រមានដល់ពួកអ្នក

បង់ចោលព្រះដ៏មានព្រះជន្មរស់នៅ ៨ដូចជាព្រះវិញ្ញាណ
បរិសុទ្ធបានមានបន្ទូលថា[ទ] «នៅថ្ងៃនេះ បើឯងរាល់គ្នាឮ
សំឡេងទ្រង់ ៨នោះកុំឱ្យតាំងចិត្តរឹងរូសឡើយ[ធ] ដូចកាល
គ្រាបះបោរ នៅថ្ងៃដែលមានសេចក្ដីល្បួង នៅក្នុងទីរហោ
ស្ថាន ១០ជាកន្លែងដែលពួកឰយុកោឯងរាល់គ្នាបានល្បួង
អញ ទាំងសាកអញមើល ហើយក៏ឃើញការអញធ្វើ
នៅរវាង៤០ឆ្នាំផងនោះ ១១ដូច្នេះ អញក៏គ្នាន់គ្នាញ់នឹង
មនុស្សជំណាន់នោះ[ន] ហើយនិយាយថា វារាល់គ្នាចេះតែមាន
ចិត្តវង្វេងជាដរាប ហើយមិនបានស្គាល់ផ្លូវរបស់អញសោះ[ប,ផ]
១២បានជាអញស្បថទាំងកំហឹងថា វារាល់គ្នាមិនត្រូវ
ចូលទៅក្នុងសេចក្ដីសំរាករបស់អញសោះឡើយ»[ព] ១៣តែ
ចូរកំឡាចិត្តគ្នាទៅវិញទៅមកជារាល់ថ្ងៃវិញ[ភ] ក្នុងកាល
ដែលនៅតែហៅថា «ថ្ងៃនេះ» នៅឡើយ ក្រែងអ្នករាល់គ្នា
ណាមួយមានចិត្តរឹងរូស ដោយសេចក្ដីបញ្ឆោតរបស់អំពើ
បាប[ម] ១៤ដ្បិតបើយើងរាល់គ្នាកាន់ខ្ជាប់[យ] តាមសេចក្ដី
ជំនឿ[រ]ដើម ដរាបដល់ចុងបំផុតមែន នោះពិតជាយើងបាន
ត្រឡប់ជាអ្នកមានចំណែកជាមួយនឹងព្រះគ្រីស្ទ ហើយ
១៥កំពុងដែលនៅមានសេចក្ដីថា «នៅថ្ងៃនេះ បើឯងរាល់
គ្នាឮសំឡេងទ្រង់ នោះកុំឱ្យតាំងចិត្តរឹងរូស ដូចកាលគ្រា
បះបោរនោះឡើយ»[ល] ១៦ចុះតើអ្នកណាដែលឮ រួចកើត
បះបោរ នោះតើមិនមែនជាអស់អ្នក ដែលលោកម៉ូសេ
បាននាំចេញពីស្រុកអេស៊ីព្ទទេឬអី[វ] ១៧តើទ្រង់គ្នាន់គ្នាញ់
នឹងអ្នកណា នៅរវាង៤០ឆ្នាំនោះ តើមិនមែននឹងអស់
អ្នកដែលបានធ្វើបាបដែលសាកសពរបស់គេបានដួល នៅ

**៣:៨** ទ ខ.១៥ ហាព ៤:៧ **៣:៩** ធ ជន ១៤:៣៣ ចទ ១:៣ កច ៧:៣៦ **៣:១១** ន ចទ ១:៣៤,៣៥ ប ហាព ៤:៣,៥ ផ ទដ ៩៥:៧-១១ **៣:១២** ព មថ ១៦:១៦ **៣:១៣** ភ ហាព ១០:២៤,២៥ ម យរ ១៧:៩ អភ ៤:២២ **៣:១៤** យ ខ.៦ ល អភ ៣:១២ **៣:១៥** រ ខ.៧,៨ ទដ ៩៥:៧,៨ ហាព ៤:៧ **៣:១៦** ល ជន ១៤:២ **៣:១៧** ស ជន ១៤:២៩ ទដ ១០៦:២៦ ១កថ ១០:៥ **៣:១៨** ហ ជន ១៤:២០–២៣ ចទ ១:៣៤,៣៥ ឡ ហាព ៤:៦ អ ទដ ៧៨:២២ ១០៦:២៤ យហ ៣:៣៦ **៤:១** ក ហាព ១២:១៥ **៤:២** ខ ១ថន ២:១៣ **៤:៣** គ ទដ ៩៥:១១ ចទ ១:៣៤,៣៥

ទីរហោស្ថានទេឬអី[ស] ១៨ហើយតើទ្រង់បានស្បថនឹងអ្នក
ណាថា «វារាល់គ្នាមិនត្រូវចូល ទៅក្នុងសេចក្ដីសំរាក របស់
អញសោះឡើយ»[ហ] បើមិនមែននឹងអស់អ្នក ដែលមិនស្ដាប់
បង្គាប់ទេ[ឡ] ដូច្នេះយើងឃើញថា អ្នកទាំងនោះពុំអាចនឹង
ចូលបានទេ ដោយព្រោះគេមិនជឿ[អ]។

## ថ្ងៃឈប់សម្រាកជាព្រះពរសម្រាប់រាស្ត្ររបស់ព្រះ

**៤** ១ដូច្នេះ ដែលនៅមានសេចក្ដីសន្យាទុកមក ឱ្យបានចូល
ក្នុងសេចក្ដីសំរាករបស់ទ្រង់ នោះត្រូវឱ្យយើងរាល់គ្នាខ្លាច
ចុះ ក្រែងអ្នករាល់គ្នាណាមួយមើលទៅដូចជាឈោងទៅ
មិនដល់[ក] ២ដ្បិតដំណឹងល្អបានផ្សាយមកយើងរាល់គ្នា ដូចជា
ដល់គេដែរ ប៉ុន្តែ ព្រះបន្ទូលដែលគេឮនោះគ្មានប្រយោជន៍
ដល់គេសោះ ដោយព្រោះមិនបានលាយនឹងសេចក្ដីជំនឿ
ក្នុងចិត្តនៃពួកអ្នកដែលឮនោះ[ខ] ៣តាមសេចក្ដីដែលទ្រង់មាន
បន្ទូលថា «អញបានស្បថទាំងកំហឹងថា វារាល់គ្នាមិនត្រូវ
ចូល ទៅក្នុងសេចក្ដីសំរាក របស់អញសោះឡើយ»[គ] តែ
យើងរាល់គ្នាដែលជឿ យើងចូលក្នុងសេចក្ដីសំរាកនោះ
វិញ ទោះបើការទាំងប៉ុន្មានបានសំរេច តាំងពីកំណើត
លោកីយមកក៏ដោយ ៤ដ្បិតនៅកន្លែងណាមួយនោះទ្រង់
មានបន្ទូលពីថ្ងៃទី៧ ដូច្នេះថា «ព្រះទ្រង់បានឈប់សំរាក ពី
អស់ទាំងការរបស់ទ្រង់នៅថ្ងៃទី៧»[ឃ] ៥ហើយនៅកន្លែងនេះ
ទៀតថា «វារាល់គ្នាមិនត្រូវចូល ទៅក្នុងសេចក្ដីសំរាក
របស់អញសោះឡើយ»[ង] ៦ដូច្នេះ ដែលនៅតែបើកឱ្យអ្នកខ្លះ

ហាព ៣:១១ **៤:៤** ឃ លប ២:២,៣ នក ២០:១១ **៤:៥** ង ទដ ៩៥:១១ ខ.៣

មិនជឿ និងមិនស្ដាប់បង្គាប់ដែលរស់នៅក្នុងសម័យនោះ ។ ដូចគ្នាដែរ អ្នកនិពន្ធគម្ពីរហេព្រើរបានលើកយកបទគម្ពីរទំនុកដំកើងនេះ ដើម្បីធ្វើជាការព្រមានដល់អស់អ្នកដែលអានសំបុត្ររបស់គាត់ ។

**៣:៧** *ព្រះវិញ្ញាណបរិសុទ្ធ* សម្រាប់សេចក្ដីបញ្ជាក់ដែលថា ព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលនៅក្នុងបទគម្ពីរ សូមមើល "៩:៨ ១០:១៥ មក ១២:៣៦ កច ១:១៦ ៤:២៥ ២១:១១ ២៨:២៥ ១ពត ១:១២ ២ពត ១:២០–២១ ២ធថ ៣:១៦"។

**៣:១៤** *កាន់ខ្ជាប់ . . . ដរាបដល់ចុងបំផុត* "ប្រៀបធៀប ៦:១១ មថ ១០:២២ ២៤:១៣ មក ១៣:១៣ រម ២:២៦ ១កថ ១:៨"។ *មានចំណែកនៅក្នុងព្រះគ្រីស្ទ* គឺក្លាយជារបស់ទ្រង់ និងរួមចំណែកនៅក្នុងការទទួលព្រះពរដែលទ្រង់ប្រទាន មក (ខ.១)។

**៣:១៦–១៩** ការជជែកបានបន្តដោយមានសំនួរជាច្រើន ។ សេចក្ដីពិតសំខាន់គឺពួកអ៊ីស្រាអែលដែលមិនបានចូលទៅក្នុងទឹកដីសន្យា គឺពួកអ្នកបានឮព្រះបន្ទូលនៃព្រះហើយ ប៉ុន្តែ មិនព្រមទទួលស្គាល់ និងមិនព្រមជឿ (ខ.១៩) ព្រមទាំង បង្ហាញនូវសកម្មភាពបះបោរប្រឆាំង (ខ.១៦) អំពើបាប (ខ.១៧) និងការមិន ស្ដាប់បង្គាប់ (ខ.១៨)(ជន ១៤:២១–៣៥)។

**៤:១** *សេចក្ដីសន្យាទុកមក ឱ្យបានចូលទៅក្នុងសេចក្ដីសំរាករបស់ទ្រង់* "សូមមើល នក ៣៣:១៤ ចទ ៣:២០"។ សេចក្ដីសន្យារបស់ព្រះក្នុងការនាំរាស្ត្រទ្រង់ចូលទៅក្នុងសេចក្ដីសម្រាករបស់ទ្រង់គឺនៅតែបើកចំហ ។ សេចក្ដីសន្យានេះគឺបានតាំងនៅជាមួយលោកអ័ប្រាហាំ (លប ១៥:១២–២១ ១៧:១–៨ ២២:១៥–១៨) បន្ទាប់មក គឺជាមួយស្ដេចដាវីឌ (២សយ ៧:៥–១៦ ១ពវ ៥:៤) ហើយចុងបញ្ចប់គឺជាពេលវេលារបស់ព្រះមែស៊ី (អស ១១:១–៩)។ សេចក្ដីសន្យារបស់ព្រះត្រូវបានសម្រេច តាមរយៈការសោយរាជ្យរបស់ព្រះមែស៊ី (អស ៦៥:១៧ ៦៦:២២ វវ ២១:៤)។

**៤:៣** *យើងរាល់គ្នាដែលជឿ យើងចូលក្នុងសេចក្ដីសំរាកនោះ* ការទៅក្នុងទឹកដីសន្យាទាមទារនូវសេចក្ដីជំនឿ ដូចគ្នាដែរ ការទទួលសេចក្ដីសម្រាកនៃសេចក្ដីសង្គ្រោះគឺទាមទារនូវជំនឿលើព្រះយេស៊ូវគ្រីស្ទ ។ *ការទាំងប៉ុន្មានបានសំរេចតាំងពីកំណើតលោកិយមក* ព្រះអម្ចាស់បានសម្រាកនៅថ្ងៃទី៧ បន្ទាប់ពីទ្រង់បានបង្កើតលោកិយនេះឡើង (ខ.៤ លប ២:២) ដូច្នេះ ទ្រង់ក៏ហៅមនុស្សលោកឱ្យបានទទួលនូវចំណែកនៃការសម្រាកនោះដែរ (ខ.១០–១១)។

បានចូលទៅក្នុងសេចក្ដីសំរាកនោះ ហើយពួកអ្នកដែលឮ
ដំណឹងល្អពីដើម គេមិនបានចូលទេ ដោយព្រោះមិនជឿ[ច]
៧នោះបានជាទ្រង់ ដាក់កំណត់ថ្ងៃ១ទៀតថា «នៅថ្ងៃនេះ»
ដូច្នេះវិញ ទាំងមានបន្ទូលដោយសារហ្លួងដាវីឌជាយូរ
ក្រោយមក តាមពាក្យអម្បាញ់មិញ ដែលថា «នៅថ្ងៃនេះ
បើឯងរាល់គ្នាឮសំឡេងទ្រង់ នោះកុំឱ្យតាំងចិត្តរឹងរូស
ឡើយ»[ឆ] ៨បើសិនជាលោក យ៉ូស្វេបានឱ្យគេឈប់
សំរាក[ជ] នោះក្រោយមក ទ្រង់មិនមានបន្ទូល[ឈ]ពីថ្ងៃ ១
ទៀតទេ ៩ដូច្នេះ មានសេចក្ដីឈប់សំរាក ទុកសំរាប់រាស្ត្រ
របស់ព្រះនៅខាងមុខ ១០ដ្បិតអ្នកណាដែលចូលទៅក្នុង
សេចក្ដីសំរាករបស់ទ្រង់ហើយ នោះក៏បានឈប់សំរាក
ពីការខ្លួនប្រព្រឹត្តទាំងប៉ុន្មាន[ញ] ដូចជាព្រះបានឈប់ ពី
ការដែលទ្រង់ធ្វើដែរ[ដ] ១១ដូច្នេះ ត្រូវឱ្យយើងរាល់គ្នា
សង្វាតនឹងចូល ទៅក្នុងសេចក្ដីសំរាកនោះ ក្រែងលោអ្នក
ណាដួលទៅ តាមក្បួនមិនជឿ ដូចជាគេដែរ[ឋ] ១២ពីព្រោះ
ឯព្រះបន្ទូលនៃព្រះ[ឌ]នោះរស់នៅ[ឍ] ហើយពូកែផង[ណ] ក៏មុត
ជាងដាវណាមានមុខ ២[ត] ទាំងធ្លុះចូលទៅ ទាល់តែកាតព្រ

**៤:៦** ច ខ.១១ ហាព ៣:១៨
**៤:៧** ឆ ទដ ៩៥:៧,៨ ហាព ៣:៧,៨,១៥
**៤:៨** ជ យស ២២:៤ ឈ ហាព ១:១
**៤:១០** ញ លវ ២៣:៣ វវ ១៤:១៣ ដ ខ.៤
**៤:១១** ឋ ខ.៦ ហាព ៣:១៨
**៤:១២** ឌ មក ៤:១៤ លក ៥:១ ១១:២៨ យហ ១០:៣៥ កច ១២:២៤ ១ថន ២:១៣ ២ធថ ២:៩ ១ពត ១:២៣ ១យហ ២:១៤ វវ ១:២,៩ ឍ កច ៧:៣៨ ១ណត ១:២៣ ណ អស ៥៥:១១ យរ ២៣:២៩ ១ថន ២:១៣

លីងនឹងវិញ្ញាណ ហើយសន្លាក់ នឹងខួរឆ្អឹងដាច់ពីគ្នា ទាំង
ពិចារណាអស់ទាំងគំនិតដែលចិត្តគិត ហើយដែលសំរេច
ដែរ[ថ] ១៣គ្មានអ្វីកើតមក ដែលទ្រង់ទតមិនឃើញនោះឡើយ[ទ]
គឺគ្រប់ទាំងអស់នៅជាអាក្រាត ហើយចំហនៅចំពោះព្រះ
នេត្រនៃព្រះ ដែលយើងរាល់គ្នាត្រូវរាប់រៀបទាំងអស់ទូល
ថ្វាយទ្រង់ ។

## ព្រះយេស៊ូវជាសម្ដេចសង្ឃយ៉ាងធំ

១៤ដូច្នេះដែលមានសំដេចសង្ឃយ៉ាងធំ ១ អង្គ[ធ]ដែលទ្រង់
បានយាងកាត់អស់ទាំងជាន់ស្ថានសួគ៌[ន] គឺព្រះយេស៊ូវជាព្រះ
រាជបុត្រានៃព្រះ[ប] នោះត្រូវតែឱ្យយើងមានចិត្តដាច់ស្រឡះ
នឹងជឿតាមចុះ[ផ] ១៥ដ្បិតសំដេចសង្ឃនៃយើង[ព] ទ្រង់មិនមែន
មិនអាចនឹងអាណិតអាសូរ ដល់សេចក្ដីកំសោយរបស់យើង
រាល់គ្នានោះទេ ព្រោះទ្រង់បានត្រូវសេចក្ដីល្បួងគ្រប់យ៉ាង
ដូចជាយើងរាល់គ្នាដែរ[ភ] តែឥតធ្វើបាបឡើយ[ម] ១៦ដូច្នេះ

ត អភ ៦:១៧ វវ ១:១៦ ថ ១កថ ១៤:២៤,២៥ **៤:១៣** ទ ទដ ៣៣:១៣–១៥ សភ ៥:២១ យរ ១៦:១៧ ២៣:២៤ ដយ ២:២២ **៤:១៤** ធ ហាព ២:១៧ ន ហាព ៦:២០ ៨:១ ៩:២៤ ប មថ ៤:៣ ផ ហាព ៣:១ **៤:១៥** ព ហាព ២:១៧ ភ ហាព ២:១៨ ម ២កថ ៥:២១

**៤:៦-៨** ពួកអ៊ីស្រាអែលចូលទៅក្នុងទឹកដីសន្យាក្រោមការដឹកនាំរបស់លោកយ៉ូស្វេ គឺគ្រាន់តែជាផ្នែកមួយ និងជាការសម្រាកតែមួយគ្រាប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយ ក៏វាមិនមែនជាការសម្រាកចុងក្រោយ ដូចដែលបានថែងនៅក្នុងបទគម្ពីរ "ទដ ៩៥:៧–៨" នោះទេ ។

**៤:៩** *មានសេចក្ដីសំរាក ទុកសំរាប់រាស្ត្ររបស់ព្រះ* សេចក្ដីសម្រាករបស់ព្រះគឺ ទទួលបានដោយជំនឿលើព្រះរាជបុត្រាទ្រង់ (លប ២:២ នក ២០:១១ ២៣:១២ ៣១:១៤ ចទ ៣:២០ ទដ ៩៥:១១ ១៣២:៨,១៤ អស ៦៦:១) ។

**៤:១០** *សេចក្ដីសំរាករបស់ទ្រង់* អ្នកជឿដល់ព្រះអម្ចាស់ត្រូវឈប់ពឹងអាងលើការប្រព្រឹត្តរបស់ខ្លួនក្នុងការទទួលបានសេចក្ដីសង្គ្រោះ ហើយត្រូវសម្រាកនៅក្នុងព្រះរាជកិច្ចរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាងវិញ ។ សេចក្ដីសម្រាកចុងក្រោយរបស់គ្រីស្ទបរិស័ទក៏បានបញ្ជាក់នៅត្រង់ចំណុចនេះដែរ (វវ ១៤:១៣) ។

**៤:១១** *សង្វាត* គឺមិនមែនមានន័យថា ការត្រាស់ហៅឱ្យខំប្រឹងប្រព្រឹត្តដើម្បីឱ្យបានការសង្គ្រោះនោះទេ ប៉ុន្តែ ជាសេចក្ដីដាស់តឿនឱ្យចូលទៅក្នុងការសម្រាកនៃសេចក្ដីសង្គ្រោះដោយជំនឿ និងមិនឱ្យយកគំរូតាមពួកអ៊ីស្រាអែលកាលនៅឯទីរហោស្ថាននោះទេ ។

**៤:១២** *ព្រះបន្ទូលនៃព្រះ* សេចក្ដីពិតរបស់ព្រះអម្ចាស់ត្រូវបានបើកសំដែងឱ្យដឹងតាមរយៈព្រះយេស៊ូវគ្រីស្ទ (យហ ១:១,១៤) ។ ព្រះចេស្ដានៃព្រះបន្ទូលគឺមានសកម្មភាពក្នុងការសម្រេចបំណងព្រះហឫទ័យព្រះ (ទដ ១៩:៧–១១ ១០៧:២០ ១៤៧:១៥,១៨ អស ៤០:៨ ៥៥:១១ កទ ៣:៨ អភ ៥:២៦ យក ១:១៨ ១ពត ១:២៣) ។ អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរពណ៌នាព្រះបន្ទូលនៃព្រះថាជាអំណាចដ៏រស់ ដែលជំនុំជម្រះដោយការមើលឃើញ និងចាក់ទម្លុះចូលទៅក្នុងជីវិតមនុស្សម្នាក់ៗ ។ *ព្រលឹង និងវិញ្ញាណ ហើយសន្លាក់* គឺសំដៅលើមនុស្សទាំងមូល និងជីវិតរបស់គេតែម្ដង (១ថន ៥:២៣ និងការពន្យល់) ។

**៤:១៣** *គ្មានអ្វីកើតមក ដែលទ្រង់ទតមិនឃើញនោះឡើយ* អ្នកនិពន្ធកណ្ឌគម្ពីរនេះ បានភ្ជាប់ទំនាក់ទំនងរវាងសកម្មភាពនៃព្រះបន្ទូល និងសកម្មភាពព្រះអម្ចាស់ដោយបញ្ជាក់អំពីលក្ខណៈដូចគ្នា ។

**៤:១៤–៧:២៨** វគ្គនេះរៀបរាប់អំពីភាពធំឧត្តមរបស់ព្រះគ្រីស្ទ លើលោកអើរ៉ុន (ទដ ១១០:៤) ។

**៤:១៤** *សំដេចសង្ឃយ៉ាងធំ* "សូមមើល ២:៧ និងការពន្យល់"។ *ទ្រង់បានយាងកាត់អស់ទាំងជាន់ស្ថានសួគ៌* សម្ដេចសង្ឃសាសន៍យូដាត្រូវចូលទៅទីដ៏បរិសុទ្ធបំផុតនៃព្រះវិហារម្ដងក្នុងមួយឆ្នាំ (៩:៧) ។ លោកប៉ុលបានមានប្រសាសន៍ថា យើងមានសម្ដេចសង្ឃដ៏ធំ នៅឯស្ថានសួគ៌ និងបានអធិស្ឋានទូលអង្វរសម្រាប់យើង ហើយបានបង្ហូរព្រះលោហិតទ្រង់សម្រាប់យើង (៩:២៤–២៥ លវ ១៦:១៥,១៧ កច ១:៩–១១) ។ *ត្រូវឱ្យយើងមានចិត្តដាច់ស្រឡះ និងជឿតាមចុះ* ត្រង់ចំណុចនេះ បញ្ជាក់ថា ពួកអ្នកទទួលសំបុត្រហេព្រើរនេះកំពុងជួបប្រទះនូវគ្រោះថ្នាក់ ក្នុងការ បណ្ដោយឱ្យសេចក្ដីជំនឿរបស់ខ្លួនធ្លាក់ចុះ (២:១ ៣:៦,១៤) ។

**៤:១៥** *ទ្រង់បានត្រូវសេចក្ដីល្បួងគ្រប់យ៉ាង ដូចជាយើងរាល់គ្នាដែរ* អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរ បញ្ជាក់អំពីភាពស្រដៀងគ្នានៃសេចក្ដីល្បួង ដែលព្រះយេស៊ូវ និងយើងរាល់គ្នាជួបប្រទះ ។ *តែឥតធ្វើបាបឡើយ* ឃ្លានេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវបានជួបប្រទះនូវសេចក្ដីល្បួង ដូចជា យើងដែរ ប៉ុន្តែ ទ្រង់មិនដែលធ្វើ បាបឡើយ គឺផ្ទុយពីយើងរាល់គ្នា (មថ ៤:១–១១ និងការពន្យល់) ។

**៤១៦** *ត្រូវឱ្យយើងរាល់គ្នាមកដល់បល្ល័ង្កនៃព្រះគុណ* ដោយព្រោះព្រះគ្រីស្ទជាសម្ដេចសង្ឃរបស់យើង បានជួបនូវបទពិសោធន៍នៃការល្បួង ដែលយើងជួបប្រទះ ដូច្នេះ ទ្រង់គង់ចាំជួយយើងជានិច្ច ពេលជួបនូវសេចក្ដីល្បួងទាំង

ត្រូវឱ្យយើងរាល់គ្នា មកដល់[យ]បល្ល័ង្ក នៃព្រះគុណដោយ
ក្លាហាន[រ] ដើម្បីនឹងទទួលសេចក្ដីមេត្តា ហើយរកបានព្រះ
គុណសំរាប់នឹងជួយដល់ពេលត្រូវការចុះ ។
**៥** ១ពីព្រោះអស់ទាំងសំដេចសង្ឃ ដែលគេរើសយកពីពួក
មនុស្ស នោះបានតាំងសំរាប់មនុស្ស ក្នុងអស់ទាំងការខាងឯ
ព្រះ[ល] ដើម្បីនឹងថ្វាយដង្វាយ និងយញ្ញបូជា[វ] ដោយព្រោះ
បាប[ស] ២ជាអ្នកដែលមានអធ្យាស្រ័យ ដល់មនុស្សខ្លៅល្ងង់
និងមនុស្សវង្វេងផង[ហ] ដោយព្រោះលោកក៏មានសេចក្ដី
កំសោយ នៅព័ទ្ធជុំវិញខ្លួនដែរ[ឡ] ៣ហើយដោយហេតុនោះ
បានជាលោកត្រូវថ្វាយដង្វាយ ដោយព្រោះបាបរបស់ខ្លួន
លោក ដូចជាតែងថ្វាយ ដោយព្រោះបាបនៃបណ្ដាជន
ដែរ[អ] ៤គ្មានអ្នកណាលើកខ្លួនដល់ងារដ៏ប្រសើរនោះឡើយ
មានតែអ្នកដែលព្រះទ្រង់ហៅប៉ុណ្ណោះ តួយ៉ាងដូចជាលោក
អើរ៉ុន[ក] ៥ដូច្នេះ ព្រះគ្រីស្ទក៏មិនបានដំកើងព្រះអង្គទ្រង់ឡើង[ខ]
ធ្វើជាសំដេចសង្ឃដែរ[គ] គឺជាព្រះវិញទេតើ ដែលមាន
បន្ទូល[ឃ]ទៅទ្រង់ថា «ឯងជាកូនអញ ៗ បានបង្កើតឯងនៅថ្ងៃ
នេះ»[ង] ៦ដូចក្នុងបទ ១ ទៀត ព្រះក៏មានបន្ទូលថា «ឯងជា
សង្ឃនៅអស់កល្បជានិច្ច តាមរបៀបលោកម៉ិលគីស្សា-
ដែក»[ច,ឆ] ៧ហើយកាលទ្រង់គង់នៅក្នុងសាច់ឈាមនៅ
ឡើយនោះទ្រង់បានពោលពាក្យអធិស្ឋាន នឹងពាក្យទូល
អង្វរ[ជ] ដោយសំឡេងជាខ្លាំង ទាំងទឹកភ្នែក[ឈ] ដល់ព្រះដែល
អាចនឹងប្រោសឱ្យទ្រង់រួចពីស្លាប់ ហើយ[ញ]ដោយព្រោះទ្រង់
កោតខ្លាច បានជាព្រះព្រមទទួលទ្រង់[ដ] ៨ហើយទោះបើ
ទ្រង់ជាព្រះរាជបុត្រាក៏ដោយ[ឋ] គង់តែទ្រង់បានរៀនស្ដាប់
បង្គាប់ ដោយសារការដែលទ្រង់រងទុក្ខលំបាកទាំងប៉ុន្មាន
នោះដែរ[ឌ] ៩រួចកាលទ្រង់បានគ្រប់លក្ខណ៍ហើយ[ឍ] នោះទ្រង់
បានត្រឡប់ជាមេបង្កើត នៃសេចក្ដីសង្គ្រោះដ៏នៅអស់កល្ប
ជានិច្ច ដល់អស់អ្នកណាដែលស្ដាប់បង្គាប់ទ្រង់ ១០ដោយព្រះ
បានតាំងងារទ្រង់ជាសំដេចសង្ឃ[ណ] តាមរបៀបលោក ម៉ិល
គីស្សាដែក[ត] ។

## ការព្រមានប្រឆាំងផ្លូវខុសឆ្គង

*៦:៤–៦ = ហេព ១០:២៦–៣១*

១១យើងខ្ញុំមានសេចក្ដីជាច្រើននឹងអធិប្បាយពីលោក
នោះ ដែលពិបាកពន្យល់ ដ្បិតអ្នករាល់គ្នាបានត្រឡប់ជា
ព្រងើយនឹងការស្ដាប់ ១២គួរឱ្យអ្នករាល់គ្នាបានធ្វើជាគ្រូ

**៤:១៦** យ ហេព ៧:១៩ រ អភ ៣:១២ **៥:១** ល ហេព ២:១៧ វ ហេព ៨:៣ ៩:៩ ស ហេព ៧:២៧ **៥:២** ហ អស ២៩:២៤ ហេព ២:១៨ ៤:១៥ ឡ ហេព ៧:២៨ **៥:៣** អ លវ ៩:៧ ១៦:៦ ហេព ៧:២៧ ៩:៧ **៥:៤** ក នក ២៨:១ ជន ១៤:៤០ ១៨:៧ **៥:៥** ខ យហ ៨:៥៤ គ ហេព ២:១៧ ឃ ហេព ១:១ ង ទដ ២:៧ មថ ៣:១៧ **៥:៦** ច ខ.១០ លប ១៤:១៨ ហេព ៦:២០ ៧:១–២២ ឆ ទដ ១១០:៤ ហេព ៧:១៧,២១ **៥:៧** ជ លក ២២:៤១–៤៤
ឈ មថ ២៧:៤៦,៥០ លក ២៣:៤៦ ញ ទដ ២២:២៤ ដ មក ១៤:៣៦
**៥:៨** ឋ ហេព ១:២ ឌ ភល ២:៨ **៥:៩** ឍ ហេព ២:១០ **៥:១០** ណ ខ.៥ ហេព ២:១៧ ត ខ.៦

ឡាយ (២:២ និងការពន្យល់) ។

**៥:១–៤** សម្ដេចសង្ឃមានលក្ខណៈសម្បត្តិសំខាន់ៗពីរយ៉ាង (១).ត្រូវជ្រើសរើសពីចំណោមបុរស (ខ.១) ដែលជាអ្នកតំណាងនៅចំពោះព្រះ (២).ត្រូវតែជាមនុស្ស ដែលព្រះជ្រើសរើស (ខ.៤) ។

**៥:១** *សំដេចសង្ឃ* "មើលការពន្យល់ ២:៧"។ *ដង្វាយ និងយញ្ញបូជា* "សូមមើល ៨:៣ ៩:៩ លវ ១:២ ២:១ និងការពន្យល់"។

**៥:២** *មនុស្សខ្លៅល្ងង់ និងមនុស្សវង្វេងផង* ត្រង់ចំណុចនេះបញ្ជាក់អំពីអំពើបាបអចេតនា និងការប្រឆាំងបះបោរនឹងព្រះ (៦:៤–៦ ១០:២៦–៣១ ទដ ១១៩:១៧៦ លវ ៤ ជន ១៥:២២–៣១) ។

**៥:៤** *គ្មានអ្នកណាលើកខ្លួនដល់ងារដ៏ប្រសើនោះឡើយ* ក្នុងសម័យកាលព្រះគ្រីស្ទយាងមក ការងារជាសម្ដេចសង្ឃគឺស្ថិតនៅក្នុងកណ្ដាប់ដៃរបស់គ្រួសារមួយ ។

**៥:៥** *ព្រះគ្រីស្ទក៏មិនបានដំកើងព្រះអង្គទ្រង់ឡើងជាសំដេចសង្ឃដែរ* ព្រះរាជបុត្រាត្រូវបានតាំងឡើងដោយព្រះវរបិតា ដូចដែលបានបញ្ជាក់នៅក្នុងបទគម្ពីរនេះ (ទដ ២:៧ ១១០:៤) ។ *ឯងជាកូនអញៗបានបង្កើតឯងនៅថ្ងៃនេះ* "សូមមើល ១:៥ ទដ ២:៧–៩ រម ១:៤ និងការពន្យល់"។

**៥:៦** *តាមរបៀបលោកម៉ិលគីស្សាដែក* "មើលការពន្យល់ ៧:៣ លប ១៤:២០ ទដ ១១០:៤"។

**៥:៧** *អធិស្ឋាន . . . ទឹកភ្នែក* សំដៅលើការឈឺចាប់របស់ព្រះយេស៊ូវគ្រីស្ទនៅឯច្បារគែតសេម៉ានី និងទីគាល់កូថា ។ *ដល់ព្រះដែលអាចនឹងប្រោសឱ្យទ្រង់រួចពីស្លាប់* សំដៅលើព្រះវរបិតា ។ ទុក្ខលំបាក និងសេចក្ដីស្លាប់ខាងឯរូបកាយ មិនត្រូវបានយកចេញពីព្រះយេស៊ូវគ្រីស្ទទេ ប៉ុន្តែ ដោយសារតែការទាំងនេះ ទ្រង់បាន ទទួលអំពើបាបរបស់មនុស្សដាក់លើព្រះកាយទ្រង់ (មថ ២៧:៤៦) ។ ទោះបីទ្រង់អាចទូលសូមដល់ព្រះវរបិតា ឱ្យយកពែងនៃសេចក្ដីទុក្ខលំបាកចេញពីទ្រង់ក៏ដោយ ក៏ទ្រង់មិនបានរុញរានឹងទទួលយក និងបំពេញបំណងព្រះហឫទ័យព្រះវរបិតាដែរ (មថ ២៦:៣៦–៤៦ និងការពន្យល់) ។ *បានជាព្រះព្រមទទួលទ្រង់* បញ្ជាក់ថា សេចក្ដីអធិស្ឋានរបស់ព្រះយេស៊ូវគ្រីស្ទបានឮដល់ព្រះវរបិតា ដែលប្រោសទ្រង់ឱ្យ មានព្រះជន្មរស់ពីសុគតឡើងវិញ ។

**៥:៨** *ទ្រង់ជាព្រះរាជបុត្រា* គឺទ្រង់ជាព្រះរាជបុត្រានៃព្រះ (១:២–៣) ។ *បានរៀនស្ដាប់បង្គាប់* គឺរៀនស្ដាប់បង្គាប់ទាំងស្រុងចំពោះបំណងព្រះហឫទ័យព្រះសម្រាប់មនុស្សដែលបានតម្រូវទុកសម្រាប់ទ្រង់ ។ *ដោយសារការដែលទ្រង់រងទុក្ខលំបាកទាំងប៉ុន្មាន* ជាពិសេសគឺការដែលទ្រង់សុគត ហើយដោយសារការសុគតនោះធ្វើ ឱ្យទ្រង់គឺជាប្រភពនៃសេចក្ដីសង្គ្រោះសម្រាប់អស់អ្នកស្ដាប់បង្គាប់ទ្រង់ (ខ.៩) ។

**៥:៩** *ទ្រង់បានគ្រប់លក្ខណ៍* "មើលការពន្យល់ ២:១០"។

**៥:១១** *មានសេចក្ដីជាច្រើននឹងអធិប្បាយពីលោកនោះ* គឺសេចក្ដីដែលនិយាយអំពីសង្ឃដ៏អស់កល្បរបស់ព្រះគ្រីស្ទ តាមរបៀបលោកម៉ិលគីស្សាដែក (ខ.១០) ។ *ព្រងើយនឹងការស្ដាប់* ជំនួសឱ្យការចម្រើនឡើងនៅក្នុងជីវិតជាគ្រីស្ទបរិស័ទ ពួកអ្នកទទួលសំបុត្រហេព្រើរនេះបែរជាស្លឹក និងខ្ជិលខាងឯវិញ្ញាណ (៦:១២) ។

**៥:១២** បទគម្ពីរនេះបញ្ជាក់ថា ពួកអ្នកទទួលសំបុត្រហេព្រើរ មិនមែនជាអ្នក

ដោយព្រោះជឿជាយូរមកហើយ តែអ្នករាល់គ្នាត្រូវការ
ឱ្យគេបង្រៀនទាំងខ្លឹមរបស់បឋមសិក្សា នៃព្រះបន្ទូលម្ដង
ទៀត[ច] ហើយមិនត្រូវការនឹងអាហាររឹង គឺត្រូវការនឹងទឹក
ដោះវិញ[ទ] ១៣ដ្បិតអស់អ្នកណាដែលទទួលទានទឹកដោះ នោះ
មិនប្រសប់ខាងឯព្រះបន្ទូលនៃសេចក្ដីសុចរិតទេ ពីព្រោះ
អ្នកនោះជាកូនតូចនៅឡើយ[ធ] ១៤ឯអាហាររឹង នោះសំរាប់
តែមនុស្សធំ[ន] ដែលបានបង្ហាត់ឥន្ទ្រិយ ដោយធ្លាប់ខ្លួនហើយ
ដើម្បីឱ្យបានដឹងខុសត្រូវ[ប] ។
៦ ១ដូច្នេះ ចូរឱ្យយើងឈប់[ផ] ខាងឯសេចក្ដីបឋមសិក្សា[ព] នៃ
ព្រះបន្ទូលព្រះគ្រីស្ទ ហើយខំឱ្យបានជឿនទៅមុខ ដរាបដល់
ពេញខ្នាតចុះ មិនត្រូវតាំងសេចក្ដីដើមនោះជាថ្មីឡើងវិញ
ដូចជាសេចក្ដីប្រែចិត្តចេញពីការស្លាប់[ភ] និងសេចក្ដីជំនឿ
ជឿដល់ព្រះ ២ហើយនិងសេចក្ដីបង្រៀនពីបុណ្យជ្រមុជ[ម]
ការដាក់ដៃ[យ] សេចក្ដីរស់ពីស្លាប់ឡើងវិញ[រ] និងសេចក្ដីជំនុំ
ជំរះកាត់ទោស ដល់អស់កល្បជានិច្ចនោះឡើយ ៣បើសិនជា
ព្រះទ្រង់អនុញ្ញាតឱ្យ[ល] នោះយើងរាល់គ្នានឹងធ្វើការ នោះ
ឯង ៤ដ្បិតឯពួកអ្នកដែលបានភ្លឺម្ដង[វ] ទាំងភ្លក់អំណោយទាន
នៃស្ថានសួគ៌[ស] ក៏បានចំណែកនៃព្រះវិញ្ញាណបរិសុទ្ធ[ហ]
៥ហើយភ្លក់[ឡ]ព្រះបន្ទូលដ៏ល្អនៃព្រះ[អ] នឹងការឫទ្ធិបារមីរបស់
បរលោកនាយ ៦រួចធ្លាក់ទៅវិញ នោះគ្មានផ្លូវណានឹងនាំឱ្យ
គេប្រែចិត្តម្ដងទៀតទេ[ក] ដោយព្រោះគេបានឆ្កាងព្រះរាជ
បុត្រានៃព្រះ[ខ] ខាងឯខ្លួនគេរួចទៅហើយ ព្រមទាំងធ្វើឱ្យ
ទ្រង់ហាលមុខនៅកណ្ដាលជំនុំផង ៧ដ្បិតដីណាបានបឿម
ទឹកភ្លៀង ដែលធ្លាក់មកជាញយៗ រួចបង្កើតជាបន្លែមានប្រ
យោជន៍ដល់អ្នកដែលភ្ជួររាស់ នោះបានទទួលព្រះពរហើយ
៨តែដីណាដែលបង្កើតសុទ្ធតែបន្លា នឹងអញ្ចាញវិញ ដីនោះ
ត្រូវបោះបង់ចោលចេញ ក៏ជិតនឹងត្រូវបណ្ដាសាហើយ[គ]
លុះដល់ចុងបំផុតនឹងត្រូវដុតចោលផង ។

**៥:១២** ច ហព ៦:១ ទ ១កថ ៣:២ ១ពត ២:២
**៥:១៣** ធ ១កថ ១៤:២០
**៥:១៤** ន ១កថ ២:៦ ប អស ៧:១៥
**៦:១** ផ ភល ៣:១២–១៤ ព ហព ៥:១២ ភ ហព ៩:១៤
**៦:២** ម យហ ៣:២៥ យ កច ៦:៦ រ កច ២:២៤ កច ១៧:១៨,៣២
**៦:៣** ល កច ១៨:២១
**៦:៤** វ ហព ១០:៣២ ស អភ ២:៨ ហ កទ ៣:២
**៦:៥** ឡ ទដ ៣៤:៨ អ ហព ៤:១២
**៦:៦** ក ២ពត ២:២១ ១យហ ៥:១៦ ខ មថ ៤:៣
**៦:៨** គ លប ៣:១៧,១៨ អស ៥:៦ ២៧:៤

ជឿថ្មីទេ ។ *ខ្លឹមរបស់បឋមសិក្សា នៃព្រះបន្ទូល* គឺដូចជាពួកអ្នកដែលបានលើកឡើងនៅក្នុង ៦:១–២ (មើលការពន្យល់)។ ពួកគេបានឈាននូវជំហានទីមួយទៅក្នុងជីវិតជាគ្រីស្ទបរិស័ទ ប៉ុន្តែពួកគេបានត្រឡប់ទៅថយក្រោយវិញ។ *អាហាររឹង* សំដៅលើសេចក្ដីបង្រៀន ដែលមានការរីកចម្រើន ដូចមានចែងនៅក្នុងជំពូក៧ ។

**៥:១៤** *មនុស្សធំ* គឺសំដៅលើពួកអ្នកដែលបានចម្រើនឡើង នៅក្នុងជីវិតជាគ្រីស្ទបរិស័ទ និងឈានដល់កម្រិតនៃការចេះពិចារណា និងដឹងខុសត្រូវ ។ *ដឹងខុសត្រូវ* គឺអ្វីដែលកូនតូចៗខាងវិញ្ញាណមិនអាចធ្វើបាន ។

**៦:១–២** *មិនត្រូវតាំងសេចក្ដីដើមនោះជាថ្មីឡើងវិញ* ត្រង់ចំណុចនេះបង្ហាញនូវគោលលទ្ធិគ្រឹះ៦យ៉ាង (១).*ប្រែចិត្ត* គឺផ្លាស់គំនិតចេញពីអំពើបាប (មថ ៤:១៧ និងការពន្យល់)។ (២).*ជំនឿនៅក្នុងព្រះអម្ចាស់* ជាផ្នែកមួយនៃការប្រែចិត្ត ។ ការប្រែចិត្តគឺការបែរចេញពីអំពើបាប រីឯសេចក្ដីជំនឿវិញ គឺការងាកមកឯព្រះ (ប្រៀបធៀប ១ថន ១:៩)។ (៣).*ការទូន្មានអំពីបុណ្យជ្រមុជទឹក* សំដៅលើការជ្រមុជផ្សេងៗពីគ្នាដែលអ្នកអានអាចយល់បាន ដូចជាពិធីជ្រមុជរបស់ពួកយូដា ពិធីជ្រមុជរបស់លោកយ៉ូហាន–បាទីស្ទ និងពិធីបុណ្យជ្រមុជដែលជាព្រះរាជបញ្ជារបស់ព្រះយេស៊ូវ (មថ ២៨:១៩ និងការពន្យល់)។(៤).*ការដាក់ដៃលើ* ពេលខ្លះ កើតឡើងបន្ទាប់ពីពិធីបុណ្យជ្រមុជទឹក (កច ៨:១៧)។ ពេលខ្លះទៀត ការដាក់ដៃលើអ្នកណាម្នាក់ ធ្វើឡើងដើម្បីតាំងគេឱ្យចេញទៅបំពេញបេសកកម្ម (កច ៦:៦ និងពន្យល់) ឬការអធិស្ឋានប្រោសជំងឺ (មក ៦:៥ លក ៤:៤០ កច ២៨:៨) ការទូលសូមព្រះពរ (មថ ១៩:១៣–១៥)។ (៥).*សេចក្ដីរស់ពីស្លាប់ឡើងវិញ* គឺការរស់ឡើងវិញរបស់មនុស្សទាំងអស់នៅថ្ងៃគ្រាចុងក្រោយ (យហ ៥:២៥–២៩ ១១:២៥ ២កថ ៤:១៤)។ (៦).*សេចក្ដីជំនុំជំរះ* អាចជាសេចក្ដីជំនុំជម្រះនៃព្រះ ។

**៦:១** *សេចក្ដីបឋមសិក្សានៃព្រះបន្ទូលព្រះគ្រីស្ទ* "មើលការពន្យល់ ៥:១២"។ *ការស្លាប់* សំដៅលើការងារដែលនាំទៅរកសេចក្ដីស្លាប់ ឬក្បួនច្បាប់ទាំងឡាយណាដែលមិនបាននាំទៅរកជីវិត (៩:១៤)។

**៦:៣** បទគម្ពីរនេះបង្ហាញនូវសេចក្ដីដែលពឹងអាងទៅលើព្រះហឫទ័យព្រះអម្ចាស់ (ប្រៀបធៀប ១កថ ១៦:៧)។ មានតែព្រះអម្ចាស់ប៉ុណ្ណោះដែលបើកចិត្ត គំនិត និងប្រទានឱ្យយើងនូវភាពពេញវ័យខាងឯវិញ្ញាណ ។

**៦:៤–៨** ជាការព្រមានលើកទីបី (មើលការពន្យល់ ២:១–៤)។

**៦:៤-៦** ការបកស្រាយផ្សេងៗគ្នានៃបទគម្ពីរដ៏លំបាកនេះមាន (១).សំដៅលើគ្រីស្ទបរិស័ទដែលបាត់បង់សេចក្ដីសង្គ្រោះ (២).ជាសេចក្ដីប្រៀបធៀបដើម្បីព្រមាន ដល់ពួកអ្នកជឿជាតិហេព្រើរ ដែលនៅខ្ចីខាងឯជំនឿ (៥:១១–១៤) ដែលពួកគេត្រូវតែឱ្យបានចម្រើនឡើងខាងជំនឿ (ខ.១) ឬជាការបង្ហាញអំពីវិន័យ និងការជំនុំជម្រះរបស់ព្រះអម្ចាស់ (ខ.៧–៨)។ (៣).សំដៅលើអ្នកដែលហៅខ្លួនឯងថាគ្រីស្ទបរិស័ទ ប៉ុន្តែ មិនមានជំនឿដល់ព្រះអម្ចាស់ (១យហ ២:១៩)។ ទស្សនៈនេះយល់ ឃើញថា បទគម្ពីរហេព្រើរជំពូក៣–៤ គឺជាការព្រមាន ដោយយោងតាមការបះបោររបស់ពួកអ៊ីស្រាអែលនៅឯទីរហោស្ថាន ។ ពួកអ៊ីស្រាអែលដែលប្រឆាំង នឹងព្រះអម្ចាស់មិនបានចូលទៅក្នុងទឹកដីសន្យាទេ ។ ដូចគ្នានេះដែរ ពួកហេព្រើរដែលមិនជឿដល់ព្រះអម្ចាស់ ហើយទាស់ប្រឆាំងនឹងពន្លឺរបស់ទ្រង់ ក៏មិនអាចទទួលបានការសង្គ្រោះពីទ្រង់ដែរ ។ យោងតាមការបកស្រាយនេះ ការដែលបង្ហាញអំពីពន្លឺការទទួលយកអំណោយទានពីស្ថានសួគ៌ និងការទទួលបាននូវព្រះវិញ្ញាណ គឺបញ្ជាក់ថា អ្នកនោះបានចូលមកក្រោមឥទ្ធិពលនៃព្រះពរ និងបានងាកចេញពីសេចក្ដីងងឹតមកឯពន្លឺ ប៉ុន្តែ គេកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់គ្រប់ពេលវេលា ហើយទីបំផុត ក៏បដិសេធព្រះគ្រីស្ទ ដែលជាភស្តុតាងបញ្ជាក់ថា គេមិនបានកើតជាថ្មីទេ (១០:២៦–៣១ ២ពត ២:២០–២២ និងពន្យល់)។

**៦:៥** *បរលោកនាយ* "មើលការពន្យល់ មក ១០:៣០ ១ធថ ៦:១៩"។

**៦:៧–៨** ត្រង់ចំណុចនេះជាសេចក្ដីប្រៀបធៀបស្ដីអំពីការព្រមានដែលលើកឡើង នៅបទគម្ពីរខាងលើ (មថ ១៣:៣–២៣)។

៩ ពួកស្ងួនភ្ងាអើយ[ឃ] ទោះបើយើងខ្ញុំនិយាយដូច្នេះក៏ដោយ
គង់តែយើងខ្ញុំទុកចិត្តខាងឯអ្នករាល់គ្នាថា បានសេចក្ដី
ប្រសើរជាង គឺជាសេចក្ដីដែលត្រូវខាងសេចក្ដីសង្គ្រោះវិញ
១០ ដ្បិតព្រះទ្រង់មិនមែនជាអ្នករមិលគុណដែលទ្រង់នឹងភ្លេច
ការអ្នករាល់គ្នាធ្វើ នឹងសេចក្ដីស្រឡាញ់ ដែលអ្នករាល់គ្នា
បានសំដែងដល់ព្រះនាមទ្រង់ ដោយបានបំរើពួកបរិសុទ្ធ
ហើយក៏នៅតែបំរើទៀតនោះទេ[ង] ១១ តែយើងខ្ញុំចង់ឱ្យអ្នក
រាល់គ្នានិមួយៗបានសំដែងចេញជាចិត្តឧស្សាហ៍ដូចគ្នាទាំង
អស់ ប្រយោជន៍ឱ្យបានសេចក្ដីជំនឿដ៏ពេញលេញរបស់
សេចក្ដីសង្ឃឹម[ច] ដរាបដល់ចុងបំផុត ១២ ដើម្បីកុំឱ្យអ្នករាល់
គ្នាធ្វើព្រងើយកន្តើយឡើយ គឺឱ្យត្រាប់តាម[ឆ]ពួកអ្នកដែល
គ្រងបានសេចក្ដីសន្យា[ជ]ទុកជាមរដកដោយចិត្តជឿ ហើយ
អត់ធន់[ឈ]វិញ ។

## ភាពច្បាស់លាស់នៃព្រះបន្ទូលសន្យា

១៣ ដ្បិតកាលព្រះបានសន្យានឹងលោកអ័ប្រាហាំ នោះ
ពីព្រោះគ្មានអ្នកណាធំជាង សំរាប់ឱ្យទ្រង់បានស្បថដោយ
អ្នកនោះទេ បានជាទ្រង់ស្បថដោយព្រះអង្គទ្រង់វិញថា[ញ]
១៤ «ដែលឱ្យពរ នោះអញនឹងឱ្យដល់ឯងមែន ហើយដែល
ចំរើន នោះអញនឹងចំរើនពូជឯងមែន»[ដ] ១៥ ហើយលោក
បានទទួលសេចក្ដីសន្យានោះ ដោយព្រោះលោកមាន
សេចក្ដីអត់ធន់ជាយូរ[ឋ] ១៦ ដ្បិតឯមនុស្ស គេតែងតែស្បថ
ដោយអ្នកណាដែលធំជាងខ្លួន ហើយពាក្យសម្បថ នោះក៏
រាំងរាគ្រប់ទាំងផ្លូវទាស់ទែងគ្នា ដើម្បីឱ្យការនោះបាន
សំរេច[ឌ] ១៧ ដូច្នេះ ចំណែកខាងព្រះ ដែលទ្រង់មានព្រះ
ហឫទ័យសង្វាតលើសទៅទៀត[ឍ] ចង់សំដែងឱ្យពួកអ្នកគ្រង
សេចក្ដីសន្យាទុកជាមរដក[ណ] បានឃើញព្រះទ័យសំរេច
របស់ទ្រង់ថា មិនចេះប្រែប្រួលឡើយ នោះទ្រង់ក៏បញ្ចូល
ពាក្យសម្បថដូច្នោះដែរ ១៨ ដើម្បីឱ្យយើងរាល់គ្នា ដែលបាន
រត់មកចាប់កាន់សេចក្ដីសង្ឃឹម[ត] ដែលដាក់នៅមុខយើង
ទុកជាទីជ្រកកោន បានសេចក្ដីកំឡាចិត្តឡើងជាខ្លាំង ដោយ
សារសេចក្ដីទាំង២មុខនេះដ៏មិនចេះប្រែប្រួល ដែលខាង
ឯសេចក្ដីទាំង២នោះ ព្រះទ្រង់កុហកពុំបានទេ[ថ] ១៩ យើងខ្ញុំ
មានសេចក្ដីសង្ឃឹមនោះ ទុកដូចជាយុថ្កានៃព្រលឹងដ៏ជាប់
លាប់មាំមួន ដែលចូលទៅខាងក្នុងនៃវាំងនន[ទ] ២០ ជាកន្លែង
ដែលព្រះយេស៊ូវទ្រង់បានយាងចូលទៅ ជំនួសយើងរាល់
គ្នា[ធ] ទុកដូចជាអ្នកនាំមុខ ដោយទ្រង់បានត្រឡប់ជាសំដេច
សង្ឃ[ន]នៅអស់កល្បជានិច្ច តាមរបៀបលោកម៉ិលគីស្សាដែក[ប]។

## លោកម៉ិលគីស្សាដែកជាសង្ឃ

**៧** ១ រីឯលោកម៉ិលគីស្សាដែក ស្ដេចក្រុងសាឡិម[ផ] ជាសង្ឃ
របស់ព្រះដ៏ខ្ពស់បំផុតនេះ[ព] ដែលបានទៅចួបនឹងលោក

**៦:៩** ឃ ១កថ ១០:១៤
**៦:១០** ង មថ
ង មថ ១០:៤០,៤២
១ថន ១:៣
**៦:១១** ច ហាព ៣:៦
**៦:១២** ឆ ហាព ១៣:៧
ជ ហាព ១០:៣៦
ឈ ២ថន ១:៤
យក ១:៣ វវ ១៣:១០
១៤:១២
**៦:១៣** ញ លប
២២:១៦ លក ១:៧៣
**៦:១៤** ដ លប
២២:១៧
**៦:១៥** ឋ លប ២១:៥
**៦:១៦** ឌ នក ២២:១១
**៦:១៧** ឍ ខ.១៨
ទដ ១១០:៤
ណ រម ៤:១៦
ហាព ១១:៩
**៦:១៨** ត ហាព ៣:៦
ថ ជន ២៣:១៩
ទត ១:២
**៦:១៩** ទ លវ ១៦:២
ហាព ៩:២,៣,៧
**៦:២០** ធ ហាព ៤:១៤
ន ហាព ២:១៧

ប ហាព ៥:៦ **៧:១** ផ ទដ ៧៦:២ ព មក ៥:៧

**៦:៨** *ត្រូវដុតចោល* "សូមប្រៀបធៀប ១០:២៧ និងការពន្យល់"។

**៦:៩** *គង់តែយើងខ្ញុំមានទំនុកចិត្ត . . . ជាសេចក្ដីដែលត្រូវខាងសេចក្ដីសង្គ្រោះវិញ* ទោះជាអ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរសន្និដ្ឋានថា អ្នកអានសំបុត្ររបស់គាត់ មានខ្លះមិនទាន់បានទទួលការសង្គ្រោះនៅឡើយ ក៏គាត់នៅតែមានទំនុកចិត្តថា ព្រះអម្ចាស់ កំពុងធ្វើការអស្ចារ្យនៅក្នុងចំណោមពួកគេដែរ ។ ដោយសារជីវិតបានផ្លាស់ប្រែ និងទង្វើនៃសេចក្ដីស្រលាញ់ (ខ.១០) បញ្ជាក់ថា ពួកគេបានកើតជាថ្មី ។

**៦:១១** *សេចក្ដីជំនឿដ៏ពេញលេញរបស់សេចក្ដីសង្ឃឹម* "មើលការពន្យល់ ៣:៦ ១១:១ ២ពត ១:១០"។ *ដរាបដល់ចុងបំផុត* ការត្រាស់ហៅឱ្យមានសេចក្ដីស៊ូទ្រាំក្នុងជំនឿ គឺជាភស្តុតាងនៃការសង្គ្រោះ ។

**៦:១២** *ព្រងើយ* "មើលការពន្យល់ ៥:១១"។ *ពួកអ្នកគ្រងបានសេចក្ដីសន្យាទុកជាមរដកដោយចិត្តជឿ ហើយអត់ធ្មត់វិញ* "សូមមើលឧទាហរណ៍ក្នុងជំពូក ១១"។

**៦:១៣** *ព្រះបានសន្យានឹងលោកអ័ប្រាហាំ* សេចក្ដីសន្យាបានប្រទានដល់មនុស្សលោក ដោយព្រះទ្រង់ស្បថដោយព្រះអង្គទ្រង់ផ្ទាល់ ដើម្បីបង្ហាញនូវភាពមិនប្រែប្រួលរបស់ទ្រង់ (លប ២២:១៦–១៨)។ ពាក្យស្បថស្បែររបស់មនុស្សតែងតែប្រែប្រួល និងមិនអាចទុកចិត្តបាន (មថ ៥:២៣–២៦ និងការពន្យល់)។ រីឯសេចក្ដីសន្យារបស់ព្រះវិញ គឺទ្រង់បានស្បថដោយព្រះអង្គទ្រង់ ហើយជាសេចក្ដីពិតមិនប្រែប្រួល (ខ.១៨ និងការពន្យល់)។

**៦:១៥** *លោកបានទទួលសេចក្ដីសន្យា* គឺកំណើតរបស់លោកអ៊ីសាក (លប ១៧:២ ១៨:១០ ២១:៥)។ *សេចក្ដីអត់ធន់ជាយូរ* គឺ២៥ឆ្នាំ (លប ១២:៣,៤ ២១:៥) ។

**៦:១៨** *សេចក្ដីកំឡាចិត្តឡើងជាខ្លាំង* សេចក្ដីសន្យាបានសម្រេចនៅពេលដែលលោកអ័ប្រាហាំចូលរួមប៉ុណ្ណោះ (១១:១៣ យហ ៨:៥៦ និងមើលការពន្យល់)។ *សេចក្ដីទាំង២មុខនេះដ៏មិនចេះប្រែប្រួល* គឺសេចក្ដីសន្យារបស់ព្រះ ដែលទុកចិត្តបានទាំងស្រុង និងសេចក្ដីសម្បថរបស់ទ្រង់ដែលធានានូវសេចក្ដីសន្យានោះ ។

**៦:១៩** *ទុកដូចជាយុថ្កានៃព្រលឹងដ៏ជាប់លាប់មាំមួន* សេចក្ដីសង្ឃឹមរបស់យើងនៅក្នុងព្រះគ្រីស្ទត្រូវបានធានា គឺដូចជាយុថ្កាដែលជួយឱ្យនាវាមានលំនឹងដូច្នោះដែរ ។ *ចូលទៅខាងក្នុងនៃវាំងនន* ដូចដែលយុថ្កាត្រូវទម្លាក់ចុះទៅក្នុងទឹកសមុទ្រ នោះគ្រីស្ទបរិស័ទត្រូវចូលទៅក្នុងសេចក្ដីពិត និងស្ថានសួគ៌វិញ ។

**៦:២០** *ជាសំដេចសង្ឃ នៅអស់កល្បជានិច្ច តាមរបៀបលោកម៉ិលគីស្សាដែក* ឃ្លានេះជាគោលរឿងដ៏សំខាន់ ដែលត្រូវបានសង្ខេបនៅក្នុង ៥:៦–១០ ហើយបានបន្តពណ៌នាបន្ថែមនៅក្នុងជំពូក៧ ។ *សំដេចសង្ឃ* "មើលការពន្យល់ ២:១៧"។

**៧:១** *លោកម៉ិលគីស្សាដែក* "លប ១៤:១៨–២០ ទដ ១១០:៤ និងការពន្យល់"។ *ស្ដេច...សង្ឃ* នេះជាទំនួលខុសត្រូវរបស់លោកម៉ិលគីស្សាដែក

អ័ប្រាហាំ ក្នុងកាលដែលត្រឡប់ពីវាយបំផ្លាញពួកស្តេចវិញ
ក៏បានប្រទានពរដល់លោក[ភ] ២ហើយលោកអ័ប្រាហាំបាន
យក ១ ភាគក្នុង ១០ ពីរបស់ទាំងអស់ជូនលោក នាមស្តេច
នោះ ដើមដំបូងស្រាយថា ស្តេចនៃសេចក្តីសុចរិតរួចមកជា
ស្តេចក្រុងសាឡិម គឺថាជាស្តេចនៃសេចក្តីសុខសាន្ត ៣លោក
គ្មានមាតាបិតា គ្មានពង្សាវតារទេ[ម] ក៏គ្មានថ្ងៃកំណើត ឬថ្ងៃ
ស្លាប់ដែរ លោកមានភាពដូចជាព្រះរាជបុត្រានៃព្រះ[យ] ក៏
នៅជាសង្ឃជារៀងរាបដរាបតទៅ ៤ចូរពិចារណាពី
លោកនោះ ដែលជាធំដល់ម្ល៉េះ បានជាលោកអ័ប្រាហាំ
ជាព្ទយុកោ[រ] បានជូនរបឹប ១ ភាគក្នុង ១០ផង[ល] ៥រីឯខាង
ឯពួកកូនចៅលេវី ដែលទទួលការងារជាសង្ឃ គេបាន
ទទួលបង្គាប់តាមក្រឹត្យវិន័យ ឱ្យហូតយក ១ ភាគក្នុង ១០ ពីប្រ
ជាជនដែរ[វ] គឺពីពួកបងប្អូនគេទាំងប៉ុន្មាន ទោះបើពួក
នោះកើតអំពីពូជពង្សលោកអ័ប្រាហាំក៏ដោយ ៦តែលោក
ម៉ិលគីស្សាដែកនេះ ដែលមិនបានរាប់ជាវង្សាគេទេ នោះ
បានទទួល ១ ភាគក្នុង ១០ ពីលោកអ័ប្រាហាំវិញ ហើយ
ក៏ឱ្យពរ[ស] ដល់លោកដែលបានទទួលសេចក្តីសន្យាទាំង
ប៉ុន្មានផង[ហ] ៧ហើយច្បាប់នេះដែលថា គឺអ្នកធំតែងឱ្យពរ
ដល់អ្នកតូច នោះប្រកែកមិនបានឡើយ ៨រីឯនៅទីនេះ
មនុស្សដែលតែងតែស្លាប់ គេទទួល ១ ភាគក្នុង ១០ តែនៅទី
នោះមានសេចក្តីបន្ទាល់ថា លោកនេះរស់នៅ[ឡ] ៩ហើយ
លោកលេវី ដែលទទួលដង្វាយ ១ ភាគក្នុង ១០ នោះលោក
ឧប្បមាដូចជាបានថ្វាយ ១ ភាគក្នុង ១០ ដែរ ដោយសារ
លោកអ័ប្រាហាំ ១០ដ្បិតកាលលោកម៉ិលគីស្សាដែកបានទៅ
ចួបនឹងលោកអ័ប្រាហាំ នោះលោកលេវីនៅជាពូជ ក្នុងខ្លួន
នៃព្ទយុកោលោកនៅឡើយ ។

**៧:១** ភ ខ.៦
លប ១៤:១៨–២០
**៧:៣** ម ខ.៦
យ មថ ៤:៣
**៧:៤** រ កច ២:២៩
ល លប ១៤:២០
**៧:៥** វ ជន
១៨:២១,២៦
**៧:៦** ស លប
១៤:១៩,២០
ហ រម ៤:១៣
**៧:៨** ឡ ហព ៥:៦
៦:២០
**៧:១១** អ ខ.១៨,១៩
ហព ៨:៧
ក ហព ១០:១
ខ ខ.១៧ ហព ៥:៦
**៧:១៣** គ ខ.១១
ឃ ខ.១៤
**៧:១៤** ង អស ១១:១
មថ ១៣:២,២:៦
លក ៣:៣៣ វវ ៥:៥
**៧:១៧** ច ទដ ១១០:៤
ខ.២១ ហព ៥:៦
**៧:១៨** ឆ រម ៨:៣

## ព្រះយេស៊ូវជាសង្ឃតាមរបៀបលោកម៉ិលគីស្សាដែក

១១ដូច្នេះ បើសិនជាមនុស្សបានគ្រប់លក្ខណ៍ ដោយសារ
ការងារជាសង្ឃ ខាងពួកលេវី ដ្បិតគឺក្រោមការងារនោះ
ដែលប្រជាជនបានទទួលក្រិត្យវិន័យទៅហើយ[អ] នោះតើត្រូវ
ការអ្វីឱ្យមានសង្ឃ ១ ទៀត[ក] ដែលមិនបានតាំងឡើងតាម
របៀបលោកអើរ៉ុន គឺតាមរបៀបលោកម៉ិលគីស្សាដែក
វិញធ្វើអី[ខ] ១២ពីព្រោះ បើការងារជាសង្ឃបានផ្លាស់ប្រែទៅ
នោះក្រិត្យវិន័យក៏ត្រូវផ្លាស់ប្រែដែរ ១៣ដ្បិតឯព្រះអង្គ ដែល
គេបានទាយសេចក្តីទាំងនេះពីទ្រង់ ទ្រង់កើតពីពូជអំបូរ ១
ទៀត[គ] ដែលគ្មានអ្នកណាមួយបានធ្វើការបំរើនៅអាសនា
ឡើយ[ឃ] ១៤ដ្បិតច្បាស់ជាព្រះអម្ចាស់នៃយើង ទ្រង់បានកើតពី
ពូជអំបូរយូដា[ង] ហើយលោកម៉ូសេមិនបានមានប្រសាសន៍ពី
ពូជអំបូរនោះ ខាងឯការងារជាសង្ឃឡើយ ១៥សេចក្តីនេះ
ក៏រឹងរឹតតែច្បាស់ជាងទៅទៀត ដោយមានសង្ឃ ១ ផ្សេង
ទៀតកើតឡើង តាមបែបលោកម៉ិលគីស្សាដែក ១៦សង្ឃ
នោះមិនបានតាំងឡើងតាមក្រឹត្យវិន័យ ដែលមានសេចក្តី
បញ្ញត្តខាងសាច់ឈាមទេ គឺតាមព្រះចេស្តារបស់ជីវិតដ៏មិន
ចេះសូន្យឡើយនោះវិញ ១៧ដ្បិតមានសេចក្តីបន្ទាល់ពីទ្រង់
ថា «ឯងជាសង្ឃនៅអស់កល្បជានិច្ច តាមរបៀបលោក
ម៉ិលគីស្សាដែក »[ច] ១៨ឯសេចក្តីបញ្ញត្តិដែលមានពីមុនមក
នោះត្រូវលើក ចោលវិញ ដោយព្រោះខ្សោយ ហើយឥត
ប្រយោជន៍[ឆ] ១៩(ពីព្រោះក្រិត្យវិន័យ មិនដែលនាំឱ្យបាន

និងជាសេចក្តីប្រៀបធៀបទៅនឹងព្រះគ្រីស្ទ (សក ៤:១៤ ៦:១៣)។ *ក្រុងសាឡិម* គឺទីក្រុងយេរូសាឡិម (លប ១៤:១៨ និងការពន្យល់)។

**៧:២** *ស្តេចនៃសេចក្តីសុចរិត . . . ស្តេចនៃសេចក្តីសុខសាន្ត* ទាំងនេះជាងាររបស់ព្រះមែស៊ី (អស ៩:៦–៧ យរ ២៣:៥–៦ និងការពន្យល់)។

**៧:៣** *លោកគ្មានមាតាបិតា . . . ឬថ្ងៃស្លាប់ដែរ* ក្នុងបទគម្ពីរ "លប ១៤:១៨-២០" មានភាពផ្ទុយគ្នានឹងបទគម្ពីរនៅក្នុងជំពូកខាងដើមនៃកណ្ឌគម្ពីរលោកុប្បត្តិ ដោយពុំបានបញ្ជាក់អំពីឪពុកម្តាយ ការចម្រើនវ័យកំណើត និងថ្ងៃស្លាប់របស់គាត់ទេ ។ ទាំងនេះជារឿងពិត ប៉ុន្តែ អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបាននិយាយអំពីលោកម៉ិលគីស្សាដែក ដើម្បីធ្វើការប្រៀបធៀបទៅនឹងព្រះគ្រីស្ទ ។ ភាពជាសង្ឃរបស់លោកម៉ិលគីស្សាដែក បានបង្ហាញនូវភាពមិនប្រែប្រួល និងគ្មានទីបញ្ចប់នៃភាពជាសង្ឃរបស់គ្រីស្ទ ។

**៧:៤** *ចូរគិតពិចារណាពីលោកនោះ ដែលជាធំដល់ម្ល៉េះ* អ្នកដែលទារពន្ធគឺធំជាងអ្នកដែលបង់ពន្ធ ហើយអ្នកតូចតែងទទួលការសរសើរពីអ្នកធំ (ខ.៧)។ ដូច្នេះបញ្ជាក់ថា លោកម៉ិលគីស្សាដែកគឺធំជាងលោកអ័ប្រាហាំ ។

**៧:១១** *ប្រជាជនបានទទួលក្រិត្យវិន័យទៅហើយ* ក្រឹត្យវិន័យលោកម៉ូសេ និងភាពជាសង្ឃត្រូវបានប្រទានមកព្រមគ្នា ។ មនុស្សទាំងអស់សុទ្ធតែមានបាប បើតាមក្រិត្យវិន័យ ដូច្នោះហើយទើបភាពជាសង្ឃត្រូវប្រទានមក ដើម្បីនៅជាកណ្តាលរវាងមនុស្ស និងព្រះ ។ *មិនបានតាំងឡើងតាមរបៀបលោកអើរ៉ុន គឺតាមរបៀបលោកម៉ិលគីស្សាដែក* បញ្ជាក់ថា ភាពជាសង្ឃរបស់លោកអើរ៉ុនមិនគ្រប់លក្ខណ៍ទេ ដូចភាពជាសង្ឃរបស់លោកម៉ិលគីស្សា–ដែកទេ ។ ទាំងនេះបង្ហាញ នូវការយាងមកនៃសម្តេចសង្ឃដែលនៅរស់អស់កល្បជានិច្ច (ទដ ១១០:៤)។

**៧:១៦** *សង្ឃនោះមិនបានតាំងឡើងតាមក្រិត្យវិន័យ ដែលមានសេចក្តីបញ្ញត្តខាងសាច់ឈាមទេ* នៅក្នុងក្រិត្យវិន័យរបស់លោកម៉ូសេ តួនាទីរបស់សង្ឃត្រូវតែជ្រើសរើសចេញពីគ្រួសារលោកអើរ៉ុនជាពួកលេវី (នក ២៨:១–៤ ៤០:១២–១៥ ជន ៣:១០) ប៉ុន្តែ ព្រះយេស៊ូវទ្រង់ប្រសូតមកពីពួកយូដា ដែលមិនមែនជាពួកសង្ឃ (ខ.១៤–១៥)។ *ព្រះចេស្តារបស់ជីវិតដ៏មិនចេះសូន្យ* យោងតាមបទគម្ពីរ "ទដ ១១០:៤" ភាពជាសង្ឃតាមរបៀបរបស់លោកម៉ិលគីស្សាដែក គឺនៅអស់កល្បជានិច្ច ។ នេះជារបៀបមួយបញ្ជាក់ថា ព្រះយេស៊ូវជាលទ្ធផលនៃព្រះចេស្តារបស់ ព្រះដែលប្រោសទ្រង់ឱ្យមានព្រះជន្មរស់ពីសុគតឡើងវិញ ហើយឱ្យមានអំណាចឈ្នះលើសេចក្តីស្លាប់ ។

**៧:១៨** *សេចក្តីបញ្ញត្តិដែលមានពីមុនមក . . . ដោយព្រោះខ្សោយ ហើយឥត*

គ្រប់លក្ខណ៍ ឡើយ)[ជ] ក៏មានសេចក្ដីសង្ឃឹមដ៏ប្រសើរជាង
បានចូលមកផង[ឈ] ដែលយើងរាល់គ្នានឹងចូលទៅជិតព្រះ
បានដោយសារ សេចក្ដីសង្ឃឹមនោះ[ញ]។
២០ ពួកសង្ឃទាំងនោះ គេបានតាំងឱ្យមានងារ ដោយឥត
មានសម្បថទេ ២១ តែទ្រង់វិញ មានទាំងពាក្យសម្បថផង
ដោយសារព្រះដែលមានបន្ទូលពីទ្រង់ថា «ព្រះអម្ចាស់ទ្រង់
បានស្បថ ហើយមិនដែលផ្លាស់គំនិតឡើយថា[ដ] ឯងជាសង្ឃ
នៅអស់កល្បជានិច្ច តាមរបៀបលោកម៉ិលគីស្សាដែក»[ឋ]
២២ ហើយដោយព្រោះការងារនោះដែលមិនមែនឥតពាក្យ
សម្បថដូច្នោះ បានជាព្រះយេស៊ូវទ្រង់ជាអ្នកធានា ពីសេចក្ដី
សញ្ញា១ដ៏ប្រសើរជាង[ឌ] ២៣ មួយទៀត ពួកសង្ឃទាំងនោះ
មានគ្នាជាច្រើន ពីព្រោះគេតែងតែស្លាប់ មិននៅជាប់ស្ថិត
ស្ថេរទេ ២៤ តែទ្រង់មាន ការងារជាសង្ឃឥតផ្ទេរឡើយ ពី
ព្រោះទ្រង់នៅជាប់អស់កល្បជានិច្ចវិញ[ឍ] ២៥ ដោយហេតុ
នោះបានជាទ្រង់អាចនឹងជួយសង្គ្រោះ[ណ] សព្វគ្រប់បានដល់
មនុស្សទាំងអស់ ដែលចូលទៅឯព្រះ[ត] ដោយសារទ្រង់
ដ្បិតទ្រង់មានព្រះជន្មរស់នៅជានិច្ច ដើម្បីនឹងជួយអង្វរ
ជំនួសគេ[ថ]។
២៦ គួរឱ្យមានសំដេចសង្ឃយ៉ាងនោះ[ទ] សំរាប់យើងដែល
ទ្រង់បរិសុទ្ធ ឥតពុតមាយា ឥតសៅហ្មង ដែលបានញែក
ចេញពីមនុស្សបាប[ធ] ហើយបានត្រឡប់ជាខ្ពស់ជាងស្ថាន
សួគ៌ទៅទៀត[ន] ២៧ ទ្រង់មិនចាំបាច់នឹងថ្វាយយញ្ញបូជា[ប] ជា
រាល់ថ្ងៃ ដូចជាសំដេចសង្ឃ ដែលថ្វាយដោយព្រោះបាប
ខ្លួនជាមុនដំបូង[ផ] រួចមក ដោយព្រោះបាបរបស់ជនទាំង
ឡាយនោះទេ[ព] ដ្បិតទ្រង់បានថ្វាយយញ្ញបូជានោះ ១ ដងជា
សំរេច គឺក្នុងកាលដែលទ្រង់ថ្វាយព្រះអង្គទ្រង់នោះឯង[ភ]
២៨ ព្រោះឯក្រិត្យវិន័យ នោះតែងតាំងមនុស្សឱ្យធ្វើជាសំដេច
សង្ឃ ដែលគេមានសេចក្ដីកំសោយ[ម] តែសេចក្ដីសម្បថដែល
មកក្រោយក្រិត្យវិន័យ នោះបានតាំងព្រះរាជបុត្រាវិញ[យ]
ដែលទ្រង់បានគ្រប់លក្ខណ៍[រ] នៅអស់កល្បជានិច្ច ។

## សម្ដេចសង្ឃនៃសេចក្ដីសញ្ញាថ្មី

**៨** ១ រីឯដែលបង្រួមសេចក្ដីអធិប្បាយទាំងប៉ុន្មានអម្បាញ់
មិញនេះ នោះគឺថា យើងរាល់គ្នាមានសំដេចសង្ឃ ១ អង្គ
យ៉ាងនោះ[ល] ដែលទ្រង់បានគង់ខាងស្តាំបល្ល័ង្កនៃឫទ្ធានុភាព

**៧:១៩** ជ ខ.១១ រម ៣:២០ ៧:៧,៨ កទ ៣:២១ ហេ ៩:៩ ១០:១ ឈ ហេ ៣:៦ ញ ខ.២៥ ហេ ៤:១៦ ១០:១,២២ យក ៤:៨ **៧:២១** ដ ជន ២៣:១៩ ១សម ១៥:២៩ មទ្ទ ៣:៦ រម ១១:២៩ ឋ ទដ ១១០:៤ ហេ ៥:៦ **៧:២២** ឌ លក ២២:២០ **៧:២៤** ឍ ខ.២៨ **៧:២៥** ណ រម ១១:១៤ ត ខ.១៩ ថ រម ៨:៣៤ **៧:២៦** ទ ហេ ២:១៧ ធ ២កថ ៥:២១ ន ហេ ៤:១៤

**៧:២៧** ប ហេ ៥:១ ផ ហេ ៥:៣ ព រម ៦:១០ ហេ ៩:១២,២៦,២៨ ១០:១០ ១ពត ៣:១៨ ភ អភ ៥:២ ហេ ៩:១៤,២៨ **៧:២៨** ម ហេ ៥:២ យ ហេ ១:២ រ ហេ ២:១០ **៨:១** ល ហេ ២:១៧

ប្រយោជន៍ ក្រិត្យវិន័យគឺល្អ និងបរិសុទ្ធ (រម ៧:១២) ប៉ុន្តែ មិនអាចផ្ដល់នូវការប្រោសលោះ ឬមិនអាចអត់ទោសឱ្យអ្នក ដែលប្រឆាំងនឹងក្រឹត្យវិន័យនោះបានទេ (ខ.១៩)។

**៧:១៩** ក្រិត្យវិន័យអាចសម្អាតមនុស្សម្នាក់ឱ្យស្អាតបានតែផ្នែកខាងក្រៅ ប៉ុន្តែ មិនអាចធ្វើឱ្យចិត្តគំនិតរបស់គេបានស្អាតទេ ។ ហើយក្រិត្យវិន័យមិនអាចធ្វើមនុស្សបានសុចរិតទេ (មថ ៥:១៧ រម ៧:១២ ៨:១–៣ កទ ៣:២៣–២៤ និងការពន្យល់)។ *សេចក្ដីសង្ឃឹមដ៏ប្រសើរជាង* សេចក្ដីសញ្ញាថ្មីគឺប្រសើរជាង ព្រោះបានធានានូវការប្រោសលោះដ៏គ្រប់លក្ខណ៍ដល់យើង និងនាំយើងឱ្យបានចូលទៅក្នុងព្រះវត្តមានព្រះអម្ចាស់ (៣:៦ និងការពន្យល់)។

**៧:២០** ព្រះយេស៊ូវជាតំណាងយើងរាល់គ្នា ទ្រង់គង់នៅស្ថានសួគ៌ ហើយទ្រង់ជាសេចក្ដីសង្ឃឹមរបស់យើងរាល់គ្នា ។ ទ្រង់បានបើកផ្លូវសម្រាប់យើងរាល់គ្នាឱ្យបានចូលទៅក្នុងព្រះវត្តមានព្រះ ។

**៧:២១** *ពាក្យសម្បថ* សម្រាប់សេចក្ដីសំខាន់នៃពាក្យនេះ សូមមើល "៦:១៧"។

**៧:២២** *សេចក្ដីសញ្ញា១ដ៏ប្រសើរជាង* "សូមមើល ជំពូក ៨–១០"។

**៧:២៣–២៤** ចាប់ពីលោកអើរ៉ុនជាសម្ដេចសង្ឃទីមួយ រហូតដល់អំឡុងពេលនៃការសរសេរសំបុត្រហេព្រើរនេះ មានសម្ដេចសង្ឃចំនួន៨៣នាក់ ។ អ្នកទាំងអស់នេះសុទ្ធតែបានស្លាប់អស់ហើយ ។ ប៉ុន្តែ ព្រះយេស៊ូវទ្រង់ជាសម្ដេចសង្ឃដែលគង់នៅអស់កល្បជានិច្ច ។

**៧:២៥** *មានព្រះជន្មរស់នៅជានិច្ច ដើម្បីនឹងជួយអង្វរជំនួសគេ* ត្រង់ចំណុចនេះបញ្ជាក់ថា រាស្ត្ររបស់ព្រះអម្ចាស់មិនអាចគ្មានសម្ដេចសង្ឃជាអ្នកតំណាងនៅក្នុងព្រះវត្តមានរបស់ទ្រង់បានទេ (យហ ១៧:៦–២៦ ១យហ ២:១–២ និងពន្យល់)។ *សព្វគ្រប់* អាចរួមបញ្ចូល នូវគំនិតពេញលេញ និងមិនប្រែប្រួល ។

**៧:២៦** *សំដេចសង្ឃ* "មើលការពន្យល់ ២:១៧"។ *សំរាប់យើង* គឺសម្រាប់ឱ្យយើងបានសង្គ្រោះពីអំពើបាប និងផលផ្លែរបស់អំពើបាប ។

**៧:២៧** *ថ្វាយយញ្ញបូជាជារាល់ថ្ងៃ* សំដៅលើការដែលបន្តថ្វាយយញ្ញបូជាជារៀងរាល់ឆ្នាំ (នក ២៩:៣៦–៤២) ជាភស្តុតាងបញ្ជាក់ថា យញ្ញបូជាទាំងនោះមិនមានប្រសទ្ធិភាព និងមិនអាចជួយគេឱ្យរួចពីបាបទេ ។ *សំដេចសង្ឃដែលថ្វាយ ដោយព្រោះបាបខ្លួនជាមុនដំបូង* ភាពជាសង្ឃរបស់ព្រះគ្រីស្ទគឺគ្រប់លក្ខណ៍ ព្រោះទ្រង់គ្មានបាបសោះ ផ្ទុយពីពួកសង្ឃនៅសញ្ញាចាស់ (លវ ៩:៨ និងការពន្យល់)។ *១ដងជាសំរេច* ឃ្លានេះគឺជាឃ្លាគន្លឹះនៅក្នុងកណ្ឌគម្ពីរហេព្រើរ (៩:១២,២៦ ១០:២,១០)។ *ទ្រង់ថ្វាយព្រះអង្គទ្រង់* ពួកសង្ឃនៅក្នុងសញ្ញាចាស់បានថ្វាយសត្វ ជាយញ្ញបូជា ប៉ុន្តែ ព្រះគ្រីស្ទបានថ្វាយព្រះអង្គទ្រង់ផ្ទាល់ជាយញ្ញបូជាសម្រាប់ប្រោសលោះយើងរាល់គ្នា ។

**៧:២៨** *មនុស្ស . . . មានសេចក្ដីកំសោយ* ពីព្រោះ (១).ពួកគេត្រូវស្លាប់ និងប្រែប្រួល (ខ.២៣) (២).ពួកគេមានបាប (ខ.២៧) (៣).ពួកគេគ្រាន់តែថ្វាយសត្វជាយញ្ញបូជាប៉ុណ្ណោះ និងមិនអាចផ្ដល់នូវការប្រោសលោះសម្រាប់ពួកគេដែលព្រះបង្កើតមកទេ (លប ១:២៦–២៨ និងការពន្យល់)។ *គ្រប់លក្ខណ៍នៅអស់កល្បជានិច្ច* សំដៅលើការតាំងមហាបេសកកម្មរបស់ទ្រង់ (មើលការពន្យល់ ២:១០ ៥:៩)។

**៨:១–១០:១៨** ការជជែកបកស្រាយនៅក្នុងវគ្គនេះបានដកស្រង់ចេញពីបទគម្ពីរ "យរ ៣១:៣១–៣៤" និងបញ្ជាក់ថា ព្រះគ្រីស្ទទ្រង់ជាអ្នកកណ្ដាលនៃសេចក្ដីសញ្ញាថ្មីដ៏ប្រសើរ (៧:២២)។

**៨:១** "មើលពន្យល់ ១:២–៣"។ *សំដេចសង្ឃ* "មើលការពន្យល់ ២:១៧"។

នៅស្ថានសួគ៌[វ] ២ជាអ្នកមានការងារក្នុងទីបរិសុទ្ធ ហើយក្នុង
រោងឧបោសថដ៏ពិត[ស] ដែលព្រះអម្ចាស់បានដំឡើង មិន
មែនជាមនុស្សទេ ។
៣ឯសំដេចសង្ឃទាំងប៉ុន្មាន[ហ] នោះបានតាំងឱ្យមានងារ
សំរាប់នឹងថ្វាយដង្វាយ ហើយយញ្ញបូជា[ឡ] បានជាត្រូវឱ្យព្រះ
អង្គនេះ បានអ្វីនឹងថ្វាយដែរ[អ] ៤ដ្បិតបើសិនជាទ្រង់គង់
នៅផែនដី នោះទ្រង់មិនបានធ្វើជាសង្ឃទេ ពីព្រោះមាន
ពួកសង្ឃ ដែលថ្វាយដង្វាយ តាមក្រិត្យវិន័យហើយ[ក] ៥ដែល
គេជាគំរូ[ខ] ហើយជាស្រមោល[គ] ពីរបស់នៅស្ថានសួគ៌វិញ
ដូចជាព្រះបានបង្គាប់លោកម៉ូសេ[ឃ] ក្នុងកាលដែលលោក
រៀបនឹងធ្វើរោងឧបោសថថា «ចូរប្រយ័តនឹងធ្វើគ្រប់ទាំង
អស់ តាមគំរូដែលអញបានបង្ហាញឯងនៅលើភ្នំ»[ង] ៦តែ
ឥឡូវនេះវិញដែលទ្រង់ជាអ្នកកណ្តាលរបស់សេចក្តីសញ្ញា
១[ច] ដ៏ប្រសើរជាងប៉ុណ្ណា ដែលសេចក្តីសញ្ញានោះបានតាំង
ឡើង[ឆ] លើពាក្យសន្យាប្រសើរជាងផង នោះទ្រង់ក៏បាន
ទទួលការងារដ៏ប្រសើរជាងប៉ុណ្ណោះដែរ ៧ដ្បិតបើសិន
ជាសញ្ញាចាស់ឥតមានកំហុស នោះមិនបានរកកន្លែងឱ្យ
បានតាំង១ទៀតឡើយ[ជ] ៨ពីព្រោះ ដែលទ្រង់ចាប់សេចក្តីកំ
ហុស នោះទ្រង់មានបន្ទូលទៅគេថា «មើល ព្រះអម្ចាស់មាន
បន្ទូលថា នឹងមានថ្ងៃមក ដែលអញនឹងតាំងសញ្ញាថ្មី[ឈ]
ដល់វង្សានុវង្សនៃពួកអ៊ីស្រាអែល និងពួកយូដា ៩មិនមែន
តាមសេចក្តីសញ្ញា ដែលអញបានតាំង នឹងពួកឰយុកោគេ[ញ]
នៅថ្ងៃដែលអញបានចាប់ដៃ នាំគេចេញពីស្រុកអេស៊ីព្ទ
នោះទេ ព្រោះគេមិនបានកាន់ខ្ជាប់តាមសេចក្តីសញ្ញារបស់
អញនោះឡើយ ហើយអញបានបែរចេញពីគេដែរ នេះជា
ព្រះបន្ទូលនៃព្រះអម្ចាស់ ១០ព្រះអម្ចាស់ មានបន្ទូលថា
ឯសេចក្តីសញ្ញា[ដ] ដែលអញនឹងតាំងដល់វង្សានុវង្ស នៃពួក
អ៊ីស្រាអែលក្រោយគ្រានោះ គឺថា អញនឹងដាក់ក្រិត្យវិន័យ
អញ នៅក្នុងគំនិតគេ ហើយនិងកត់ទុកនៅក្នុងចិត្តគេផង[ឋ]
អញនឹងធ្វើជាព្រះដល់គេ ហើយគេនឹងធ្វើជារាស្ត្ររបស់
អញ[ឌ] ១១នោះមិនចាំបាច់ឱ្យគ្រប់គ្នាបង្រៀនអ្នកជិតខាង និង
បងប្អូនខ្លួនថា ចូរស្គាល់ព្រះអម្ចាស់នោះទេ ដ្បិតក្នុងពួកគេ
មនុស្សនឹងស្គាល់អញគ្រប់គ្នា[ឍ] តាំងពីអ្នកតូចរហូតដល់
អ្នកធំហើយ ១២ពីព្រោះអញនឹងអាណិតមេត្តាចំពោះសេចក្តី
ទុច្ចរិតរបស់គេ ហើយអញនឹងលែងនឹកចាំពីអំពើបាប
និងសេចក្តីទទឹងច្បាប់របស់គេទៀត»[ណ,ត] ១៣រីឯពាក្យដែល
ថា «ថ្មី»[ថ] នោះគឺថា ព្រះទ្រង់បានធ្វើឱ្យ សេចក្តីមុនទៅជា
ចាស់ហើយ[ទ] ឯរបស់ណាដែលត្រឡប់ជាចាស់ ហើយមាន
វ័យកន្លង នោះក៏ជិតនឹងសូន្យបាត់ដែរ ។

**៨:១** វ មក ១៦:១៩ ហាព ៤:១៤ **៨:២** ស ហាព ៩:១១, ២៤ **៨:៣** ហ ហាព ២:១៧ ឡ ហាព ៥:១ ៩:៩ អ ហាព ៩:១៤ **៨:៤** ក ហាព ៥:១ ៩:៩ **៨:៥** ខ ហាព ៩:២៣ គ កល ២:១៧ ហាព ១០:១ ឃ ហាព ១១:៧ ១២:២៥ ង នក ២៥:៤០ **៨:៦** ច កទ ៣:២០ ឆ ខ.៨,១៣ លក ២២:២០ **៨:៧** ជ ហាព ៧:១១, ១៨ ១០:១ **៨:៨** ឈ ខ.៦,១៣ លក ២២:២០ **៨:៩** ញ នក ១៩:៥,៦ ២០:១–១៧ **៨:១០** ដ រម ១១:២៧ ឋ ២កថ ៣:៣ ហាព ១០:១៦ ឌ អគ ១១:២០ សក ៨:៨ **៨:១១** ឍ អស ៥៤:១៣ យហ ៦:៤៥ **៨:១២** ណ ហាព ១០:១៧ ត រម ១១:២៧ **៨:១៣** ថ ខ.៦,៨ លក ២២:២០ ទ ២កថ ៥:១៧

**៨:២** *រោងឧបោសថដ៏ពិត* គឺផ្ទុយនឹងរោងឧបោសថសង់ឡើងដោយលោកម៉ូសេ ដែលជារោងឧបោសថមិនគ្រប់លក្ខណ៍ និងមិនចម្លងតាមរោងឧបោសថនៅឯស្ថានសួគ៌ទាំងស្រុងទេ ។ *ព្រះអម្ចាស់បានដំឡើង* ទីបរិសុទ្ធនៅឯស្ថានសួគ៌ គឺសាងឡើងដោយព្រះអម្ចាស់ ដែលត្រូវគ្នានឹងទីបរិសុទ្ធបំផុតដែលនៅក្នុងសញ្ញាចាស់ មានតែសម្តេចសង្ឃប៉ុណ្ណោះ ទើបអាចចូលបានម្តងក្នុងមួយឆ្នាំ ដើម្បីថ្វាយដង្វាយលោះបាប (លវ ១៦:១៣–១៥,៣៤)។ រីឯទីបរិសុទ្ធនៅស្ថានសួគ៌វិញ សម្តេចសង្ឃដ៏ធំរបស់យើង ទ្រង់គង់នៅអស់កល្បជានិច្ច និងអធិស្ឋានលន់តួឱ្យយើងគ្រប់ពេលទាំងអស់ (៧:២៥)។

**៨:៣** *ដង្វាយ ហើយយញ្ញបូជា* "មើលការពន្យល់ ៥:១"។

**៨:៤** *ពួកសង្ឃដែលថ្វាយដង្វាយ* ពាក្យថា "ថ្វាយ" ត្រង់ចំណុចនេះ ព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេស ប្រើទម្រង់កិរិយាសព្ទជាបច្ចុប្បន្នកាល ដូច្នេះបញ្ជាក់ថា សំបុត្រហេព្រើរត្រូវបានសរសេរឡើងនៅមុនពេលព្រះវិហារក្រុងយេរូសាឡិមមិនទាន់បានបំផ្លាញក្នុងឆ្នាំទី៧០គ.សនៅឡើយ (សូមមើលសេចក្តីផ្តើម)។

**៨:៥** *ជាគំរូ ហើយជាស្រមោល ពីរបស់នៅស្ថានសួគ៌វិញ* សេចក្តីរៀបរាប់របស់អ្នកនិពន្ធត្រង់ចំណុចនេះ មានជាប់ទាក់ទងទៅនឹងសេចក្តី ដែលបានចែងទុកនៅក្នុងបទគម្ពីរ "នក ២៥:៤០"។ *ធ្វើគ្រប់ទាំងអស់ តាមគំរូដែលអញបានបង្ហាញឯង* ព្រោះទាំងរោងឧបោសថ និងការងារនៅក្នុងរោងឧបោសថ បញ្ជាក់អំពីរបៀបដែលមនុស្សមានបាបចូលទៅឯព្រះដ៏បរិសុទ្ធ និងទូលសូមការអត់ទោសបាបពីទ្រង់ ។

**៨:៦** *អ្នកកណ្តាល* "មើលការពន្យល់ ១ធថ ២:៥"។ តួនាទីរបស់អ្នកកណ្តាលនៅ ត្រង់ចំណុចនេះពុំមែនជាអ្នកបង្កើតសេចក្តីសញ្ញាទេ ប៉ុន្តែជាអ្នកធានាថា សេចក្តីសញ្ញានេះត្រូវបានសម្រេចជាបរិបូរ (៧:២២) ហើយសេចក្តីសន្យានៃការប្រោសលោះក៏បានបង្កើតឡើងដែរ (នក ៣២:៣១–៣២ ៣៣:១២–២៣ ៣៤:៥–១០ ជន ១៤:១៣–២០)។

**៨:៧** ការជដែកនៅក្នុងបទគម្ពីរនេះមានភាពប្រហាក់ប្រហែលគ្នានឹងសេចក្តីដែលចែងនៅក្នុងបទគម្ពីរ "៧:១១" ដែលបញ្ជាក់ថា ភាពជាសង្ឃរបស់ពួកលេវី គឺទាបជាងភាពជាសង្ឃរបស់លោកម៉ិលគីស្សាដែក ។ ដូចគ្នានេះដែរ ប្រសិនបើសេចក្តីសញ្ញាដែលបានប្រទានមកនៅភ្នំស៊ីណាយគ្រប់គ្រាន់ហើយ នោះពុំចាំបាច់ ត្រូវការសេចក្តីសញ្ញាថ្មីទេ ។

**៨:៨–១២** សេចក្តីដកស្រង់ចេញពីបទគម្ពីរ "យរ ៣១:៣១–៣៤" និយាយអំពីការប្រកាស និងអត្ថន័យរបស់សេចក្តីសញ្ញាថ្មី ខុសប្លែកពីសេចក្តីសញ្ញាចាស់ដែលបានប្រទាននៅភ្នំស៊ីណាយ (ខ.៩)។ លក្ខណៈសំខាន់ៗរួមមាន (១).ក្រិត្យវិន័យរបស់ព្រះនឹងក្លាយជាគោលការណ៍នៅក្នុងចិត្តគំនិតមនុស្ស (ខ.១០) ដែលធ្វើឱ្យពួកគេរីករាយធ្វើតាមព្រះហឫទ័យទ្រង់ (អគ ៣៦:២៦–២៧ រម ៨:២–៤ និងការពន្យល់)។ (២).ព្រះអម្ចាស់ និងរាស្ត្ររបស់ទ្រង់នឹងមានទំនាក់ទំនងដ៏ជិតស្និទ្ធ (ខ.១០)។ (៣).អ្នកដែលមិនព្រមទទួលស្គាល់ព្រះអម្ចាស់នឹងត្រូវញែកចេញ (ខ.១១)។ (៤).ការអត់ទោសបាបគឺជាសេចក្តីពិតរហូត (ខ.១២)។

**៨:១៣** *របស់ណាដែលត្រឡប់ជាចាស់ ហើយមានវ័យកន្លង* សំដៅលើសេចក្តី

## របៀបថ្វាយបង្គំក្នុងរោងឧបោសថនៅលោកីយនេះ

**៩** ១ចំណែកសេចក្ដីសញ្ញាមុននោះ គឺមានរបៀបថ្វាយបង្គំ
ព្រះ ក៏មានទីបរិសុទ្ធ ដែលនៅលោកីយនេះដែរ[ធ] ២ដ្បិត
គេបានធ្វើរោងឧបោសថ[ន] ដែលប៉ែកខាងមុខហៅថា ទី
បរិសុទ្ធ[ប] ជាកន្លែងមានជើងចង្កៀង[ផ] នឹងតុ[ព] ហើយនំបុ័ង
តាំងទុក[ភ] ៣ខាងក្រោយវាំងននទី២ មានកន្លែងហៅថា ទី
បរិសុទ្ធបំផុត[ម] ៤ទីនោះមានជើងពានមាស សំរាប់ដុតគ្រឿង
ក្រអូប[យ] នឹងហឹបនៃសេចក្ដីសញ្ញា[រ] ដែលស្រោបដោយ
មាសជុំវិញទាំងអស់ នៅក្នុងហឹបនោះមានចានមាសដាក់
នំម៉ាន៉ា[ល] ក៏មានដំបងរបស់លោកអើរ៉ុនដែលបុិចឡើង[វ]
នឹងបន្ទះថ្មនៃសេចក្ដីសញ្ញាផង[ស] ៥ឯខាងលើហឹបនោះ មាន
រូបចេរូប៊ីនដ៏មានសិរីល្អ[ហ] ដែលបាំងទីសន្ដោសប្រោស[ឡ] តែ
យើងខ្ញុំថ្លែងពីរបស់ទាំងនោះដោយពិស្ដារ ក្នុងពេលឥឡូវ
នេះមិនបានទេ ។

៦កាលរបស់ទាំងនេះបានរៀបជាស្រេចហើយ នោះ
ពួកសង្ឃក៏ចូលទៅ សំរេចការងារក្នុងរោងឧបោសថផ្នែក
ខាងមុខជានិច្ច[អ] ៧តែឯផ្នែកខាងក្នុង[ក] នោះមានតែសំដេច
សង្ឃតែឯងប៉ុណ្ណោះ ដែលចូលទៅបាន[ខ] ក្នុង១ឆ្នាំ១ដង[គ]
ក៏មិនមែនឥតយកឈាម[ឃ] ដែលលោកថ្វាយដោយព្រោះខ្លួន
លោក[ង] នឹងអំពើបាបដែលប្រជាជនប្រព្រឹត្ត ដោយឥតដឹង
នោះដែរ[ច] ៨យ៉ាងនោះ ព្រះវិញ្ញាណបរិសុទ្ធសំដែងថា[ឆ]
កាលរោងឧបោសថមុននោះនៅៗឡើយ នោះផ្លូវចូល[ជ]ទៅ
ក្នុងទីបរិសុទ្ធបំផុតមិនទាន់បើកទេ ៩នេះជាសេចក្ដីប្រៀប
ពន្យល់[ឈ]ដល់ជាន់ឥឡូវនេះ ជាគ្រាដែលគេនៅតែថ្វាយ
ដង្វាយ[ញ] នឹងយញ្ញបូជានៅឡើយ[ដ] ដែលដង្វាយទាំងនោះ
ពុំអាចនឹងធ្វើឱ្យអ្នកដែលថ្វាយបានគ្រប់លក្ខណ៍ខាងឯបញ្ញា
ចិត្តបានឡើយ ១០ដ្បិតមានតែសេចក្ដីបញ្ញត្តខាងសាច់ឈាម
ទេ ដែលសំដែងពីម្ហូបម្ហា[ឋ] និងគ្រឿងផឹក[ឌ] ហើយការលាង
សំអាតផ្សេងៗ[ឍ] ដែលបង្គាប់មក[ណ] ដរាបដល់វេលាដែល
រៀបចំឱ្យត្រឹមត្រូវឡើងវិញ ។

## ព្រះលោហិតនៃព្រះគ្រីស្ទ

១១ប៉ុន្តែ កាលព្រះគ្រីស្ទបានយាងមក ធ្វើជាសំដេចសង្ឃ[ត]
ខាងឯសេចក្ដីល្អដែលត្រូវមក[ថ] គឺធ្វើដោយសាររោង
ឧបោសថដ៏វិសេសជាង ហើយគ្រប់លក្ខណ៍ជាង[ទ] ដែលមិន
បានធ្វើដោយដៃ[ធ]គឺថា មិនមែនជារបស់ផងលោកិយនេះទេ

**៩:១** ធ នក ២៥:៨ **៩:២** ប នក ២៥:៨,៩ ផ នក ២៦:៣៣,៣៤ ព នក ២៥:៣១–៣៩ ភ នក ២៥:២៣–២៩ ម នក ២៥:៣០ លវ ២៤:៥–៨ **៩:៣** យ នក ២៦:៣១–៣៣ **៩:៤** រ នក ៣០:១–៥ ល នក ២៥:១០–២២ វ នក ១៦:៣២,៣៣ ស ជន ១៧:១០ **៩:៥** ហ នក ២៥:១៧–១៩ ឡ នក ២៥:២០–២២ ២៦:៣៤ **៩:៦** អ ជន ២៨:៣ **៩:៧** ក ខ.២,៣ ខ លវ ១៦:១១–១៩ គ លវ ១៦:៣៤ ឃ លវ ១៦:១១,១៤ ង លវ ១៦:១១ ហព ៥:២,៣ ច ហព ៥:២,៣ **៩:៨** ឆ ហព ៣:៧ ជ យហ ១៤:៦ ហព ១០:១៩,២០ **៩:៩** ឈ ហព ១០:១ ញ ហព ៥:១ ៨:៣ ដ ហព ៧:១៩ **៩:១០** ឋ លវ ១១:២–២៣ ឌ ជន ៦:៣ កល ២:១៦ ឍ លវ ១១:២៥,២៨,៤០ ណ ហព ៧:១៦ **៩:១១** ត ហព ២:១៧ ថ ហព ១០:១ ទ ខ.២៤ ហព ៨:២ ធ យហ ២:១៩

---

សញ្ញាដែលព្រះប្រទានមកនៅឯភ្នំស៊ីណាយ មិនមែនជាសេចក្ដីសញ្ញាដែលទ្រង់បានតាំងជាមួយលោកអ័ប្រាហាំទេ (រម ៤:១៦–១៧ ជីពូក ៩–១១ កទ ៣:៧–៩,១៤,១៦–១៨ អភ ២:១២)។

**៩:១** *សេចក្ដីសញ្ញាមុននោះ* សំដៅលើសេចក្ដីសញ្ញាដែលបានប្រទានមកនៅឯភ្នំស៊ីណាយ (មើលការពន្យល់ ៨:១៣)។

**៩:២** *គេបានធ្វើរោងឧបោសថ* គឺរោងឧបោសថដែលបានសង់ឡើងក្រោមការមើលខុសត្រូវរបស់លោកម៉ូសេ ។ *ជើងចង្កៀង* ធ្វើអំពីមាស និងតាំងនៅភាគខាងត្បូងនៃទីបរិសុទ្ធ (នក ៤០:២៤) មានចង្កៀងចំនួន៧ ដែលដុតឱ្យឆេះរាល់យប់ (នក ២៥:៣១–៤០ ២៧:២១)។ *តុ ហើយនំបុ័ងតាំងទុក* តុនោះធ្វើអំពីឈើនាងនួន ស្រោបដោយមាស (នក ២៥:២៣–៣០) និងតាំងនៅភាគខាងជើងនៃទីបរិសុទ្ធ (នក ៤០:២២)។ នៅលើតុមាននំបុ័ងម្សៅឱកចំនួន១២ តម្រៀបជា ៦ជួរ (លវ ២៤:៥–៨)។

**៩:៤** *ជើងពានមាស សំរាប់ដុតគ្រឿងក្រអូប* ជើងពានមាសសម្រាប់ដុតគ្រឿងក្រអូបគឺស្ថិតនៅទីបរិសុទ្ធ ប៉ុន្តែ អ្នកនិពន្ធពណ៌នាថា ជើងពាននោះគឺស្ថិតនៅក្នុងទីបរិសុទ្ធបំផុតវិញ ។ គោលបំណងរបស់អ្នកនិពន្ធគឺបង្ហាញពីទំនាក់ទំនងជិតស្និទ្ធរវាងជើងពានមាស និងទីបរិសុទ្ធបំផុត ហើយនិងហឹបនៃសេចក្ដីសញ្ញា (នក ៣០:១–៦)។ នៅថ្ងៃនាំដង្វាយលោះបាបសម្ដេចសង្ឃនាំយកគ្រឿងក្រអូប និងដង្វាយឈាមលោះបាបទៅទីបរិសុទ្ធបំផុត (លវ ១៦:១២–១៤)។ *ហឹបនៃសេចក្ដីសញ្ញា* ជាហឹបមួយដែលធ្វើអំពីឈើនាងនួន ផ្ទៃខាងក្រៅ និងខាងក្នុងបិទដោយ មាស (នក ២៥:១០–១៦)។ *នំម៉ាន៉ា . . . ដំបង. . . បន្ទះថ្ម* "មើល ការពន្យល់ នក ១៦:៣៣–៣៤ ជន ១៧:៨–១០"។

**៩:៧** *ក្នុង១ឆ្នាំ១ដង* នៅថ្ងៃធួននឹងបាប ជាថ្ងៃទី១០ នៃខែទី៧ (លវ ១៦:២៩, ៣៤ ២៣:២៧–២៨)។ សម្រាប់សេចក្ដីពណ៌នាអំពីពិធីនេះសូមមើល "លវ ១៦ និងការពន្យល់"។ *អំពើបាប. . . ប្រព្រឹត្ត ដោយឥតដឹង* "មើលការពន្យល់ ៥:២"។

**៩:៨** *ព្រះវិញ្ញាណបរិសុទ្ធ* "មើលការពន្យល់ ៣:៧"។ *កាលណារោងឧបោសថមុននោះនៅៗឡើយ* គឺកាលដែលប្រព័ន្ធនៃក្រឹត្យវិន័យរបស់លោកម៉ូសេ ភាពជាសង្ឃមិនគ្រប់លក្ខណ៍ និងយញ្ញបូជានៅតែមាននៅឡើយ (៨:៧–៨,១៣)។

**៩:៩** *ជាសេចក្ដីប្រៀបពន្យល់ដល់ជាន់ឥឡូវនេះ* ទោះបីរោងឧបោសថ និងព្រះវិហារត្រូវបានផ្លាស់ប្ដូរក៏ដោយ ក៏វានៅតែជាជំនួយដែលផ្ដល់នូវការទូន្មាន តាមរយៈការសំខាន់ៗ និងការរំឭកថា ការដែលត្រឡប់ទៅប្រតិបត្តិតាមរបៀបចាស់ នោះជាការឥតប្រយោជន៍ ព្រោះមិនអាចដោះស្រាយដោយមានប្រសិទ្ធភាពចំពោះអំពើបាបទេ ។ *ដង្វាយ និងយញ្ញបូជា* "មើលការពន្យល់ ៥:១"។

**៩:១០** *រៀបចំឱ្យត្រឹមត្រូវឡើងវិញ* សំដៅលើសេចក្ដីសញ្ញាថ្មី រួមជាមួយនឹងភាពជាសង្ឃថ្មី ទីបរិសុទ្ធថ្មី និងយញ្ញបូជាថ្មី ដែលទាំងអស់បានប្រទានមកដោយព្រះយេស៊ូវគ្រីស្ទ ។

**៩:១១** *មិនមែនជារបស់ផងលោកីយនេះទេ* មិនមែនជារោងឧបោសថនៅលើផែនដីនេះទេ ប៉ុន្តែ ជារោងឧបោសថនៃព្រះវត្តមានព្រះអម្ចាស់វិញ (ខ.២៤ ៨:១២)។

១២ នោះទ្រង់បានយាងចូលទៅក្នុងទីបរិសុទ្ធបំផុត[ន] ១ ដងជា
សំរេច[ប] ទាំងបានសេចក្តីប្រោសលោះ នៅអស់កល្បជានិច្ច
មិនមែនដោយយកឈាមពពែឈ្មោល ឬឈាមកូនគោទេ[ផ]
គឺដោយយកព្រះលោហិតនៃអង្គទ្រង់វិញ[ព] ១៣ ដ្បិតបើសិន
ជាឈាមគោឈ្មោល នឹងឈាមពពែឈ្មោល[ភ] ហើយផេះ
គោក្រមុំ[ម] ដែលគេប្រោះលើមនុស្សស្មោកគ្រោក បានញែក
អ្នកនោះចេញជាបរិសុទ្ធ ខាងសាច់ឈាមបានទៅហើយ
១៤ ចំណង់បើព្រះលោហិតរបស់ព្រះគ្រីស្ទ ដែលទ្រង់បាន
ថ្វាយព្រះអង្គទ្រង់[យ] ឥតសៅហ្មងដល់ព្រះ ដោយសារព្រះ
វិញ្ញាណដ៏គង់នៅអស់កល្បជានិច្ច[រ] នោះនឹងសំអាតទាំង
បញ្ញាចិត្តអ្នករាល់គ្នា[ល] ពីអស់ទាំងការស្លាប់ផង[វ] ដើម្បីឱ្យ
បានបំរើព្រះដ៏មានព្រះជន្មរស់ តើជាជាងអម្បាលម៉ានទៅ
ទៀត[ស] ១៥ ដោយហេតុនោះបានជាទ្រង់ជាអ្នកកណ្តាល[ហ]
នៃសញ្ញាថ្មី[ឡ] ដើម្បីឱ្យពួកអ្នកដែលទ្រង់ហៅ[អ] បានទទួល
សេចក្តីសន្យា[ក] ទុកជាមរដកដ៏នៅអស់កល្បជានិច្ច[ខ] ដោយ
ទ្រង់សុគត ប្រយោជន៍នឹងប្រោសលោះគេឱ្យរួចពីការ
រំលង ដែលគេប្រព្រឹត្តពីកាលនៅក្រោមសញ្ញាចាស់នៅ
ឡើយ[គ] ១៦ ដ្បិតដែលមានសំបុត្រសញ្ញាចែកមរដក នោះ
ត្រូវចាំដល់ម្ចាស់សំបុត្រស្លាប់ទៅសិន ទើបចែកបាន

៩:១២ ន ខ.១៩
លវ ១៦:៦,១៥
ហព ១០:៤ ប ខ.២៤
ផ ខ.២៦,២៨
ហព ៧:២៧ ព
ខ.១៤ រម ៣:២៥
៩:១៣ ភ ហព ១០:៤
ម ជន ១៩:៩,១៧,១៨
៩:១៤ យ ១ពត
៣:១៨ រ អភ ៥:២
ល ទដ ៥១:២ ៦៥:៣
យរ ៣៣:៨
សក ១៣:១
ទត ២:១៤
ហព ១០២,២២
វ ហព ៦:១
ស មថ ១៦:១៦
៩:១៥ ហ កទ ៣:២០
ឡ លក ២២:២០
អ រម ៨:២៨
១១:២៩
ក ហព ៦:១៥
១០:៣៦
ខ កច ២០:៣២
គ ហព ៧:២២
៩:១៨ ឃ នក
២៤:៦-៨

១៧ ពីព្រោះ សំបុត្រសញ្ញានោះមានប្រយោជន៍ តែកាលណា
ម្ចាស់បាន ស្លាប់ទៅហើយទេ កាលម្ចាស់កំពុងរស់នៅឡើយ
នោះគ្មានអំណាចសោះ ១៨ ដូច្នេះ សេចក្តីសញ្ញាចាស់ក៏មិន
បានតាំងឡើង ដោយឥតឈាមដែរ[ឃ] ១៩ ពីព្រោះ កាល
លោកម៉ូសេបានមានប្រសាសន៍[ង] ប្រាប់ពីបញ្ញត្តិទាំងប៉ុន្មាន
តាមក្រិត្យវិន័យ ដល់ប្រជាជនទាំងឡាយហើយ នោះលោក
ក៏យកឈាមកូនគោ[ច] នឹងឈាមពពែ ព្រមទាំងទឹក នឹង
រោមចៀមជ្រលក់ក្រហម ហើយនិងមែកហ៊ីសុបមកប្រោះ
លើគម្ពីរនោះឯង ព្រមទាំងលើប្រជាជនទាំងអស់ដែរ[ឆ]
២០ ដោយមានប្រសាសន៍ថា «នេះជាឈាមនៃសញ្ញា ដែល
ព្រះទ្រង់បង្គាប់មកអ្នករាល់គ្នា»[ជ] ២១ លោកក៏ប្រោះឈាម
ទៅលើរោងឧបោសថ នឹងគ្រឿងប្រដាប់ដែលសំរាប់ការ
ងារទាំងប៉ុន្មានបែបដូច្នោះដែរ ២២ ហើយតាមក្រឹត្យវិន័យ
សឹងតែគ្រប់របស់ទាំងអស់បានស្អាត ដោយសារឈាម[ឈ]
បើគ្មានខ្ចាយឈាមទេ នោះគ្មានផ្លូវណាឱ្យបានរួចពីបាប
ឡើយ[ញ]។

២៣ ដូច្នេះ អស់ទាំងគំរូ[ដ]ពីរបស់នៅស្ថានសួគ៌បានត្រូវ

**៩:១៩** ង ហព ១:១ ច ខ.១២ ឆ នក ២៤:៦-៨ **៩:២០** ជ នក ២៤:៨ មថ ២៦:២៨ **៩:២២** ឈ នក ២៩:២១ លវ ៨:១៥ ញ លវ ១៧:១១ **៩:២៣** ដ ហព ៨:៥

**៩:១២** *មិនមែនដោយយកឈាមពពែឈ្មោល ឬឈាមកូនគោទេ* "មើលការពន្យល់ លវ ១៧:១១"។ *គឺដោយយកព្រះលោហិតនៃអង្គទ្រង់វិញ* គឺមិនមែនដោយសារយញ្ញបូជាដែលត្រូវថ្វាយរៀងរាល់ឆ្នាំ ដូចដែលពួកសង្ឃលេវីធ្លាប់ធ្វើនោះទេ ។ យញ្ញបូជារបស់ព្រះគ្រីស្ទគឺគ្រប់លក្ខណ៍ ព្រោះមានប្រសិទ្ធភាព និងមិនត្រូវការធ្វើម្តងហើយម្តងទៀតនោះទេ ។ ព្រះយេស៊ូវគ្រីស្ទបានយាងទៅឯទីបរិសុទ្ធ នៅស្ថានសួគ៌វិញ បន្ទាប់ពីទ្រង់បានបំពេញមហាបេសកកម្មប្រោសលោះដ៏អស់កល្បរួចហើយ ។

**៩:១៣** *ឈាមគោឈ្មោល ឈាមពពែឈ្មោល* គឺដូចជានៅថ្ងៃធួននឹងបាបដែរ ។ *ហើយផេះគោក្រមុំ* ដូចដែលបានពណ៌នានៅក្នុងបទគម្ពីរ "ជន ១៩" ចំពោះពួកអ្នកដែលរាប់ជាមិនបរិសុទ្ធ ដោយព្រោះបានប៉ះពាល់សាកសព ។ *បរិសុទ្ធ ខាងសាច់ឈាម* ការដែលយកឈាមសត្វទាំងនោះប្រោះលើមនុស្សមិនអាចសម្អាត គេឱ្យបានបរិសុទ្ធទេ ព្រោះជាទង្វើតែពីខាងក្រៅប៉ុណ្ណោះ ។

**៩:១៤** *ព្រះវិញ្ញាណដ៏គង់នៅអស់កល្បជានិច្ច* ឃ្លានេះមានការជជែកច្រើន ប៉ុន្តែ អាចសំដៅលើព្រះវិញ្ញាណបរិសុទ្ធ ដែលប្រទានឱ្យព្រះយេស៊ូវគ្រីស្ទនូវអំណាចក្នុងការបំពេញមហាបេសកកម្មរបស់ទ្រង់ (មថ ៣:១៦ និងការពន្យល់)។ *ទ្រង់បានថ្វាយព្រះអង្គទ្រង់* មានន័យថា ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកថ្វាយដង្វាយលោះបាប ហើយទ្រង់ជាដង្វាយនោះតែម្តង ។ *ឥតសៅហ្មង* "មើល លវ ២២:១៩-២១"។ *សំអាតទាំងបញ្ញាចិត្តអ្នករាល់គ្នា* គឺដកយកជាបន្តបន្ទាប់នូវអំពើបាបចេញ ពីខាងក្នុងយើងរាល់គ្នា ។ *ពីអស់ទាំងការដែលស្លាប់ផង* "៦:១ និងការពន្យល់"។

**៩:១៥** *អ្នកកណ្តាល* "មើលការពន្យល់ ៨:៦"។ *សញ្ញាថ្មី* "មើលការពន្យល់ ៧:២២ ៨:៦,១៣"។ *បានទទួលសេចក្តីសន្យា ទុកជាមរដកដ៏នៅអស់កល្បជានិច្ច* សេចក្តីសន្យាទាំងនោះមានចែងនៅក្នុងបទគម្ពីរ "យរ ៣១:៣១-៣៤" (មើលការពន្យល់ ៨:៨-១២)។ ដោយសំអាងលើការសុគតរបស់ព្រះគ្រីស្ទ មរដកទាំងនោះបានកើតឡើងពិតចំពោះអស់អ្នកណាដែលទ្រង់ហៅ (រម ៨:២៨)។ *ប្រយោជន៍ នឹងប្រោសលោះគេ* "សូមមើល ១០:៤៥ និងការពន្យល់"។

**៩:១៦** *សំបុត្រសញ្ញា* ពាក្យនេះជាភាសាក្រិកមានន័យដូចគ្នានឹងពាក្យថា សេចក្តីសញ្ញាដែរ (ខ.១៥) ប៉ុន្តែ នៅក្នុង "ខ.១៧"វិញ សំដៅលើសំបុត្រ និងសេចក្តីសញ្ញាចុងក្រោយ ។ អ្នកទទួលមរដកមិនអាចទទួលសេចក្តីទាំងនោះបានទេ លុះណាតែម្ចាស់សំបុត្រនោះបានសុគតសិន (ខ.១៧)។ ដោយព្រោះតែការសុគតរបស់ព្រះយេស៊ូវគ្រីស្ទត្រូវបានបញ្ជាក់យ៉ាងច្បាស់ ដូច្នេះ សេចក្តីសន្យាអំពីការប្រទាននូវមរដកដ៏នៅអស់កល្បជានិច្ច ពិតជាត្រូវបានផ្តល់មកពួកអ្នកដែលទទួល ។

**៩:១៨-២០** ចំពោះពិធីបុណ្យទាក់ទងនឹងបទគម្ពីរនេះ មើល "នក ២៤:៤-៨"។

**៩:១៨** *ដោយឥតឈាម* គឺដោយឥតបាត់បង់ជីវិត ។ លោកម៉ូសេបានយកឈាមកូនគោមកប្រើនៅក្នុងសេចក្តីសញ្ញាចាស់ ។

**៩:២១** សូមមើលបទគម្ពីរ "លវ ១៧:១១"។

**៩:២២** "សូមមើល លវ ១៧:១១ និងការពន្យល់"។

**៩:២៣** *អស់ទាំងគំរូពីរបស់នៅស្ថានសួគ៌* "សូមមើល ៨:៥"។ យញ្ញបូជាជាសត្វមានសារសំខាន់សម្រាប់រោងឧបោសថនៅលើផែនដី ដូច្នេះ រោង

សំអាត ដោយសាររបស់ទាំងនោះ តែរបស់នៅស្ថានសួគ៌
វិញ នោះត្រូវសំអាតដោយយញ្ញបូជាប្រសើរជាងទៅទៀត
២៤ដ្បិតព្រះគ្រីស្ទទ្រង់មិនបានយាងចូល ទៅក្នុងទីបរិសុទ្ធធ្វើ
ដោយដៃ ដែលជាគំរូពីទីបរិសុទ្ធពិតនោះទេ[ឋ] គឺបានចូល
ទៅក្នុងស្ថានសួគ៌នោះឯង[ឌ] ដើម្បីនឹងលេចមកក្នុងពេល
ឥឡូវនេះ នៅចំពោះព្រះភក្ត្រនៃព្រះ ដំណាងយើងរាល់
គ្នា[ឍ] ២៥ក៏មិនមែននឹងថ្វាយព្រះអង្គទ្រង់ជាញឹកញយ ដូចជា
សំដេចសង្ឃ ដែលចូលទៅក្នុងទីបរិសុទ្ធ[ណ] រាល់តែឆ្នាំ ទាំង
យកឈាមដទៃនោះដែរ[ត] ២៦ដ្បិតបើយ៉ាងដូច្នោះ នោះត្រូវ
ឱ្យទ្រង់រងទុក្ខជាច្រើនដង តាំងពីកំណើតលោកីយមក[ថ] តែ
ជាន់ឥឡូវនេះ ដែលជាចុងបំផុតអស់ទាំងកល្ប នោះទ្រង់
បានលេចមក១ដង[ទ] ដើម្បីនឹងលើកអំពើបាបចោល[ធ] ដោយ
ថ្វាយព្រះអង្គទ្រង់វិញ ទុកជាយញ្ញបូជា[ន] ២៧ហើយដោយ
ព្រោះបានដំរូវត្រូវឱ្យមនុស្សទាំងអស់ស្លាប់១ដង[ប] រួចសឹម
ជាប់សេចក្ដីជំនុំជំរះ[ផ] ២៨ដូច្នេះ ព្រះគ្រីស្ទក៏បែបយ៉ាងនោះ
ដែរ ដែលទ្រង់បានថ្វាយព្រះអង្គទ្រង់១ដងហើយ[ព] ដោយ
ព្រោះបាបរបស់មនុស្សជាច្រើន នោះទ្រង់នឹងលេចមកម្ដង
ទៀត[ភ] ក្រៅពីរឿងអំពើបាប[ម] គឺសំរាប់នឹងជួយសង្គ្រោះ[យ]
ដល់អស់អ្នកដែលរង់ចាំទ្រង់[រ] ។

## យញ្ញបូជារបស់ព្រះគ្រីស្ទសម្រាប់មនុស្សទាំងអស់

**១០** ១ដ្បិតឯក្រិត្យវិន័យ ដែលមានតែស្រមោល[ល] ពីសេចក្ដី
ល្អ[វ]ដែលត្រូវមក មិនមែនជាតួរូបរបស់សេចក្ដីទាំងនេះទេ[ស]
នោះពុំអាចនឹងធ្វើឱ្យពួកអ្នក ដែលចូលមកថ្វាយយញ្ញបូជា
ដដែល ៗ រាល់តែឆ្នាំជានិច្ច បានគ្រប់លក្ខណ៍[ហ] ឡើយ[ឡ]
២ដ្បិតបើបាន តើគេមិនបានលែងថ្វាយទេឬអី ពីព្រោះ
បញ្ញាចិត្តនៃពួកអ្នកដែលថ្វាយបង្គំ នោះមិនបានដឹងថាមាន
បាបទៀតទេ ដោយព្រោះបានញែកសំអាតម្ដងហើយ[អ] ៣តែ
យញ្ញបូជាទាំងនោះនាំឱ្យរឭកឃើញ ពីអំពើបាបរបស់គេ
រាល់តែឆ្នាំវិញ[ក] ៤ដ្បិតឈាមគោឈ្មោល នឹងពពែឈ្មោល[ខ]
នោះពុំអាចនឹងដោះបាបបានឡើយ[គ] ៥ហេតុនោះបានជា
កាលទ្រង់យាងមកក្នុងលោកីយ[ឃ] ទ្រង់មានបន្ទូលថា «ព្រះអង្គ
មិនចង់បានយញ្ញបូជា នឹងដង្វាយទេ តែទ្រង់បានរៀប
ចំរូបកាយឱ្យទូលបង្គំវិញ[ង] ៦ទ្រង់ក៏មិនសព្វព្រះហឫទ័យ
នឹងដង្វាយដុត ឬនឹងដង្វាយ លោះបាបដែរ ៧បានជាទូល
បង្គំទូលថា មើល ឱព្រះអង្គអើយ ទូលបង្គំមកនឹងធ្វើតាម
ព្រះហឫទ័យទ្រង់[ច] (សេចក្ដីនេះបានកត់ទុកពីទូលបង្គំ នៅ
ក្នុងគម្ពីរហើយ[ឆ])» ៨ក្រោយដែលមានបន្ទូលថា យញ្ញ
បូជា នឹងដង្វាយ ហើយដង្វាយដុតនឹងដង្វាយលោះ
បាប ទ្រង់មិនចង់បានទេ ក៏មិនសព្វ ព្រះហឫទ័យដែរ[ជ]

**៩:២៤** ឋ ហព ៨:២ ឌ ខ.១២ ហព ៤:១៤ ឍ រម ៨:៣៤ **៩:២៥** ណ ហព ១០:១៩ ត ខ.៧,៨ **៩:២៦** ថ ហព ៤:៣ ទ ១យហ ៣:៥ ធ ខ.១២,២៨ ហព ៧:២៧ ន ខ.១២ **៩:២៧** ប លប ៣:១៩ ផ ២កថ ៥:១០ **៩:២៨** ព ខ.១២,២៦ ហព ៧:២៧ ភ មថ ១៦:២៧ ម ១ពត ២:២៤ យ ហព ៥:៩ រ ១កថ ១:៧ **១០:១** ល កល ២:១៧ ហព ៨:៥ វ ហព ៩:១១ ស ហព ៩:២៣ ហ ខ.៤,១១ ហព ៧:១៩ ឡ ហព ៧:១៩ **១០:២** អ ហព ៩:៩ **១០:៣** ក លវ ១៦:៣៤ ហព ៩:៧ **១០:៤** ខ ហព ៩:១២,១៣ គ ខ.១,១១ **១០:៥** ឃ ហព ១:៦ ង ហព ២:១៤ ១ពត ២:២៤ **១០:៧** ច ទដ ៤០:៦–៨ មថ ២៦:៣៩ ឆ អរ ៦:២ យរ ៣៦:២

ឧបោសថនៅឯស្ថានសួគ៌គឺត្រូវការយញ្ញបូជារបស់អង្គព្រះយេស៊ូវគ្រីស្ទ ។

**៩:២៤** *លេចមកក្នុងពេលឥឡូវនេះ* "សូមមើល ៧:២៥ ១យហ ២:១ និងការពន្យល់"។ ព្រះគ្រីស្ទលេចមក (ខ.២៦) ហើយទ្រង់នឹងលេចមកទៀត (ខ.២៨) ។

**៩:២៦** *ចុងបំផុតអស់ទាំងកល្ប* ការយាងមករបស់ព្រះយេស៊ូវត្រូវបានបើកសំដែងឱ្យដឹងនៅយុគសម័យព្រះមែស៊ី និងបន្តរហូតនៅក្នុងប្រវត្តិសាស្ត្រ (មើលការពន្យល់ ១:១–២) ។

**៩:២៨** *ទ្រង់នឹងលេចមកម្ដងទៀត* "សូមមើល មថ ២៤:៣–២១ ២៥:៣១–៤៦ យហ ១៤:៣ ១កថ ១:៧ ១៥:២៣ ១ថន ២:១៩ ៤:១៣–១៨ ២ថន ១:៧ ទត ២:១៣ ២ពត ៣:៤ វវ ៣:១១ ១៩:១១–១៦"។ *សំរាប់នឹងជួយសង្គ្រោះ* សេចក្ដីសម្រេចនៃការសង្គ្រោះ បានប្រទានមកយើងនៅលើឈើឆ្កាង (រម ៨:២៩–៣០ ភល ៣:២០–២១ ១យហ ៣:២)។ *រង់ចាំទ្រង់* គឺរង់ចាំដូចដែលពួកអ៊ីស្រាអែលរង់ចាំសម្ដេចសង្ឃចេញមកពីទីបរិសុទ្ធបំផុត ដោយនាំមកនូវការធានាថាអំពើបាបរបស់ ពួកគេត្រូវបានអត់ទោសឱ្យ (២ធថ ៤:៨ ទត ២:១៣) ។

**១០:១–១០** ក្នុងវគ្គនេះគឺជាសេចក្ដីពណ៌នានៃបទគម្ពីរ "ទដ ៤០:៦–៨" (មើលការ ពន្យល់) ។

**១០:១** *ក្រិត្យវិន័យ* ក្រឹត្យវិន័យនិងភាពជាសង្ឃរបស់ពួកលេវីមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងស្ថិតនៅក្រោមប្រព័ន្ធក្រឹត្យវិន័យលោកម៉ូសេ (មើលការពន្យល់ ៧:១១)។ *មានតែស្រមោល* យញ្ញបូជាដែលបានលើកឡើងនៅក្នុងក្រឹត្យវិន័យ គឺជានិមិត្តរូបបញ្ជាក់អំពីយញ្ញបូជាដ៏ពិតប្រាកដរបស់ព្រះគ្រីស្ទ ។ ដោយព្រោះតែយញ្ញបូជា ដែលលើកឡើងនៅក្នុងក្រឹត្យវិន័យ ត្រូវធ្វើជាបន្តបន្ទាប់ជារៀងរាល់ឆ្នាំ ដូច្នេះ មានន័យថា យញ្ញបូជានោះមិនគ្រប់លក្ខណ៍ និងមិនអាចដោះមនុស្សឱ្យរួចផុតពីអំពើបាបបានទេ ។ *គ្រប់លក្ខណ៍* "សូមមើលបទគម្ពីរ ហព ១០:១៤ និងការពន្យល់"។

**១០:៤** បទគម្ពីរនេះបញ្ជាក់ថា សត្វដែលយកមកធ្វើជាយញ្ញបូជាមិនអាចយកមកជំនួសបាបមនុស្ស ដែលបង្កើតឡើងដូចជារូបអង្គនៃព្រះអម្ចាស់ទេ ។

**១០:៥–៦** ត្រង់ចំណុចនេះជារបៀបផ្សេងទៀត ដែលប្រើសម្រាប់យញ្ញបូជាបួនប្រភេទក្នុងចំណោមយញ្ញបូជាប្រាំយ៉ាង ថ្វាយដោយពួកលេវីដែលបានចែងនៅក្នុងក្រឹត្យវិន័យលោកម៉ូសេ (លវ ១–៧) មានដូចជា ការប្រកបគ្រាប់ធញ្ញជាតិ ដង្វាយដុត និងដង្វាយលោះបាបជាដើម ។

**១០:៥** *កាលទ្រង់យាងមកក្នុងលោកីយ* ឃ្លានេះជាព្រះបន្ទូលនៅក្នុងបទគម្ពីរទំនុកដំកើង ជាសម្ដីរបស់ស្ដេចដាវីឌ និយាយអំពីការចុះចូលរបស់ព្រះគ្រីស្ទចំពោះព្រះវបិតាក្នុងការយាងមកផែនដី ។ យញ្ញបូជានៅក្នុងក្រឹត្យវិន័យលោកម៉ូសេត្រូវបានជំនួសដោយការស្ដាប់បង្គាប់ទៅនឹងព្រះហឫទ័យព្រះអម្ចាស់ (ខ.៧) ។

**១០:៦** *ទ្រង់ក៏មិនសព្វព្រះហឫទ័យ* "១សយ ១៥:២២ ទដ ៤០:៦ និងពន្យល់"។

**១០:៧** *ធ្វើតាមព្រះហឫទ័យទ្រង់* បញ្ជាក់ថា ព្រះរាជបុត្រាទ្រង់តែងតែធ្វើតាមបំណងព្រះហឫទ័យព្រះវរបិតាជានិច្ច (លក ២២:៤២ យហ ៤:៣៤ និងការពន្យល់"។

ជារបស់ដែលគេថ្វាយតាមក្រិត្យវិន័យ ៩នោះទ្រង់ក៏ថែព្រះ
បន្ទូលនេះទៀតថា «មើល ឱព្រះអង្គអើយ ទូលបង្គំមកនឹង
ធ្វើតាមព្រះហឫទ័យទ្រង់[ឈ]» ដូច្នេះ ទ្រង់បានលើកចោល
សេចក្តីមុន ដើម្បីនឹងតាំងសេចក្តីក្រោយវិញ ១០គឺដោយ
សារចំណង់ព្រះហឫទ័យនោះ ដែលយើងរាល់គ្នាបានញែក
ជាបរិសុទ្ធ[ញ] ដោយសារដង្វាយថ្វាយរូបអង្គ[ដ]ព្រះយេស៊ូវ
គ្រីស្ទ១ដងជាសំរេច[ឋ]។

១១ឯអស់ទាំងសង្ឃក៏ឈរធ្វើការងាររាល់តែថ្ងៃ ទាំង
ថ្វាយយញ្ញបូជាដដែលជាញឹកញយ[ឌ] ដែលពុំអាចនឹងដោះ
បាបបានឡើយ[ឍ] ១២តែទ្រង់វិញ ក្រោយដែលទ្រង់បានថ្វាយ
យញ្ញបូជាតែ១ ដោយព្រោះបាប[ណ] នោះទ្រង់បានគង់ខាង
ស្តាំព្រះ នៅជារៀងរាបដរាបទៅ[ត] ១៣ទាំងចាំទំរាំដល់បាន
ដាក់ពួកខ្មាំងសត្រូវ ឱ្យធ្វើជាកំណាល់កល់ព្រះបាទទ្រង់[ថ]
១៤ដ្បិតទ្រង់ធ្វើឱ្យពួកអ្នក ដែលបានញែកជាបរិសុទ្ធហើយ
បានគ្រប់លក្ខណ៍អស់កល្បជានិច្ច[ទ] ដោយសារដង្វាយតែ ១
នោះ[ធ] ១៥ហើយព្រះវិញ្ញាណបរិសុទ្ធ ក៏ធ្វើបន្ទាល់[ន]ដល់យើង
ដែរ ដ្បិតក្រោយដែលទ្រង់មានបន្ទូលថា ១៦«ឯសេចក្តី
សញ្ញាដែលអញនឹងតាំងដល់គេ ក្រោយគ្រានោះ គឺថាអញ
នឹងដាក់ក្រឹត្យវិន័យអញនៅក្នុងចិត្តគេ ហើយនឹងកត់ទុកនៅ
ក្នុងគំនិតគេផង»[ប] ១៧នោះទ្រង់បានបន្ថែមនូវព្រះបន្ទូលនេះ
ទៀតថា «អញនឹងលែងនឹកចាំពីអំពើបាប នឹងសេចក្តីទទឹង
ច្បាប់របស់គេទៀត»[ផ] ១៨ដូច្នេះ ដែលបានប្រោសឱ្យរួចពី
សេចក្តីទាំងនោះរួចហើយ នោះមិនចាំបាច់ថ្វាយដង្វាយ
ដោយព្រោះបាបទៀតទេ ។

## ការព្រាស់ហៅឱ្យខ្ជាប់ខ្ជួន

១៩ដូច្នេះ បងប្អូនអើយ ដែលយើងមានសេចក្តីក្លៀវក្លា[ព]
នឹងចូលទៅក្នុងទីបរិសុទ្ធ[ភ] ដោយសារព្រះលោហិតនៃព្រះ
យេស៊ូវ ២០តាមផ្លូវដែលទ្រង់ បានតាំងសំរាប់យើងរាល់គ្នា
ជាផ្លូវថ្មី ហើយរស់[ម] ដែលចូលកាត់វាំងនន[យ] គឺជារូបសាច់
របស់ទ្រង់ ២១ហើយដែលមានសំដេចសង្ឃដ៏ធំ១អង្គ[រ]ត្រួត
លើដំណាក់ព្រះ[ល] ២២នោះត្រូវឱ្យយើងចូលទៅជិត[វ]ទាំងមាន
ចិត្តស្មោះត្រង់ នឹងចិត្តដឹងពិតប្រាកដ ហើយសេចក្តីជំនឿ[ស]
ព្រមទាំងមានចិត្តប្រោះញែកជាស្អាត រួចពីបញ្ញាចិត្តដែល

**១០:៨** ជ ខ.៥,៦ មក ១២:៣៣ **១០:៩** ឈ ខ.៧ **១០:១០** ញ ខ.១៤ អភ ៥:២៦ ដ ហាព ២:១៤ ១ពត ២:២៤ ឋ ហាព ៧:២៧ **១០:១១** ឌ ហាព ៥:១ ឍ ខ.១,៤ **១០:១២** ណ ហាព ៥:១ ត មក ១៦:១៩ **១០:១៣** ថ យស ១០:២៤ ហាព ១:១៣ **១០:១៤** ទ ខ.១ ធ ខ.១០ អភ ៥:២៦ **១០:១៥** ន ហាព ៣:៧ **១០:១៦** ប យរ ៣១:៣៣ ហាព ៨:១០ **១០:១៧** ផ យរ ៣១:៣៤ ហាព ៨:១២ **១០:១៩** ព អភ ៣:១២ ភ លវ ១៦:២ អភ ២:១៨ ហាព ៩:៨,១២,២៥ **១០:២០** ម ហាព ៩:៨ យ ហាព ៦:១៩ ៩:៣ **១០:២១** រ ហាព ២:១៧ ល ហាព ៣:៦ **១០:២២** វ ខ.១ ហាព ៧:១៩ ស អភ ៣:១២

**១០:៩** *ទ្រង់បានលើកចោលសេចក្តីមុន ដើម្បីនឹងតាំងសេចក្តីក្រោយវិញ* យញ្ញបូជាដ៏គ្រប់លក្ខណ៍របស់ព្រះគ្រីស្ទ បានថ្វាយដោយចុះចូលទាំងស្រុងចំពោះព្រះហឫទ័យព្រះវរបិតា ដើម្បីជំនួសគ្រប់យញ្ញបូជាពីមុនប្រយោជន៍ឱ្យមនុស្សមានបាបបានជាបរិសុទ្ធ ។

**១០:១០,១៤** *បានញែកជាបរិសុទ្ធ* គឺបានលាងសម្អាតពីគ្រប់អំពើបាបទាំងអស់(បានអត់ទោស និងលាងសម្អាត) ញែកសម្រាប់ព្រះរាជកិច្ចរបស់ព្រះអម្ចាស់ (១កថ ១:២ និងការពន្យល់)។

**១០:១១-១២** ចំណុចនេះបញ្ជាក់ពីភាពផ្ទុយគ្នារវាងការឈរ និងការអង្គុយ។ ភាពជាសង្ឃរបស់ពួកលេវីតែងតែឈរជានិច្ច ពីព្រោះការងាររបស់ពួកគេគឺចេះតែបន្តរហូត (៧:២៧ និងការពន្យល់)។

**១០:១២** *នោះទ្រង់បានគង់ខាងស្តាំព្រះ* "មើលការពន្យល់ ១:១៣"។ *នៅជារៀងរាបដរាបទៅ* "មើលការពន្យល់ ៧:២៧"។

**១០:១៣** ព្រះយេស៊ូវជាស្តេចគង់នៅលើបល្ល័ង្ក ថ្វាយនូវដង្វាយគ្រប់លក្ខណ៍ហើយ ទ្រង់មានជ័យជម្នះ លើពួកអ្នកប្រឆាំងនឹងអំណាចរបស់ទ្រង់ (១:៣ វវ ៥:៦–១៤ ៧:១០,១៧ ១១:១៥ ១៩:១១–២១ ២០:៤ និងការពន្យល់)។

**១០:១៤** *គ្រប់លក្ខណ៍* ព្រះយេស៊ូវជាព្រះគ្រប់លក្ខណ៍ (៥:៩ ៧:២៨ ២:១០ និងការពន្យល់) ទ្រង់បានប្រទានពរឱ្យមនុស្សមានបាបបានគ្រប់លក្ខណ៍ ទៅតាមបំណងព្រះហឫទ័យទ្រង់សម្រាប់ភាពបរិសុទ្ធ ។

**១០:១៥** *ព្រះវិញ្ញាណបរិសុទ្ធ* "មើលការពន្យល់ ៣:៧"។

**១០:១៦–១៨** សេចក្តីដែលលើកឡើងនៅត្រង់ចំណុចនេះត្រូវបានដកស្រង់ចេញពីបទគម្ពីរ "យរ ៣១:៣១–៣៤"។ ជាសេចក្តីសញ្ញាថ្មីដែលធានាថាមនុស្សត្រូវបានអត់ទោសពីបាប(ខ.១៧) ហើយមិនចាំបាច់ត្រូវការយញ្ញបូជាណាបន្ថែមទៀតទេ (ខ.១៨)។

**១០:១៩** *មានសេចក្តីក្លៀវក្លានឹងចូលទៅក្នុងទីបរិសុទ្ធ* "មើលពន្យល់ ខ.១៣, ១៤"។

**១០:២០** *វាំងននគឺជារូបសាច់របស់ទ្រង់* ព្រះគ្រីស្ទបានថ្វាយព្រះកាយទ្រង់នៅលើឈើឆ្កាង ហើយទ្រង់ជាសម្តេចសង្ឃរបស់យើង ដែលគង់នៅក្នុងទីដ៏បរិសុទ្ធបំផុត (៩:១១ និងការពន្យល់) និងប្រទានឱ្យមនុស្សមានបាបបានបរិសុទ្ធ (ខ.១៤ និងការពន្យល់) ដើម្បីឱ្យគេអាចឆ្លងកាត់វាំងនន ដែលជារូបកាយដែលរស់ឡើងវិញដ៏គ្រប់លក្ខណ៍ សម្រាប់យើងរាល់គ្នានូវរបៀបរស់នៅថ្មី (មើលការពន្យល់ មថ ២៧:៥១ មក ១៥:៣៨)។

**១០:២២–២៥** សេចក្តីទូន្មានប្រាំយ៉ាងដែលចេញពីការប្រទាននៃព្រះយេស៊ូវសម្រាប់ការផ្សះផ្សាររបស់យើងទៅឯព្រះវរបិតា (១).ចូរឱ្យយើងចូលទៅជិតព្រះអម្ចាស់ (២).ចូរឱ្យយើងកាន់ខ្ជាប់នូវសេចក្តីសង្ឃឹមមិនប្រែប្រួល (៣).ចូរឱ្យយើងគិតពិចារណារពីរបៀបជួយគ្នាទៅវិញទៅមកឱ្យបានចម្រើនឡើង (៤).ចូរកុំឱ្យយើងបោះបង់ការជួបប្រជុំគ្នាឡើយ (៥).ចូរឱ្យយើងលើកទឹកចិត្តគ្នាទៅវិញ ទៅមក ។ សម្រាប់សេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ សូមមើល បទគម្ពីរ "១ថន ១:៣" និងការពន្យល់ ។

**១០:២២** ត្រង់ចំណុចនេះមានលក្ខ័ណ្ឌ៤យ៉ាងសម្រាប់ចូលទៅជិតព្រះអម្ចាស់ (១).ចិត្តស្មោះត្រង់ដោយគ្មានបែងចែកនូវភក្តីភាពនៅក្នុងចិត្ត។ (២).ពេញដោយការធានានៃសេចក្តីជំនឿ ជាសេចក្តីជំនឿដែលគ្មានការស្ទាក់ស្ទើនៅក្នុងការទុកចិត្តដល់ព្រះគ្រីស្ទ ។ (៣).ចិត្តប្រោះញែកជាស្អាត រួចពីបញ្ញាចិត្ត ដែលសៅហ្មងដែលជាការមានសេរីភាពរួចពីភាពសៅហ្មង និងជាសេរីភាព ដែលអាស្រ័យលើយញ្ញបូជាមួយសម្រាប់មនុស្សទាំងអស់របស់ព្រះគ្រីស្ទ។ (៤).បានលាងរូបកាយដោយទឹកដ៏ស្អាត ។ ចំពោះការលាងសម្អាតចិត្ត និងការលាងសម្អាតរូបកាយ (មថ ២៨:១៩) ប្រៀបទៅនឹងការ

សៅហ្មងផង[ហ] ហើយបានលាងរូបកាយនឹងទឹកដ៏ស្អាតដែរ[ឡ]
២៣ត្រូវឱ្យយើងរាល់គ្នាកាន់ខ្ជាប់ តាមសេចក្ដីបន្ទាល់របស់
សេចក្ដីសង្ឃឹមនោះ[អ] ឥតរវើរវាយ[ក] ដ្បិតព្រះដែលបាន
សន្យានោះ ទ្រង់ស្មោះត្រង់[ខ] ២៤ហើយត្រូវឱ្យយើង ពិចារ
ណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីនឹងបណ្ដាលឱ្យមាន
សេចក្ដីស្រឡាញ់ ហើយឱ្យប្រព្រឹត្តការល្អផង[គ] ២៥ឥតលែង
ប្រជុំគ្នា[ឃ] ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ត្រូវឱ្យកំឡាចិត្តគ្នា
វិញ[ង] ឱ្យកាន់តែខ្លាំងឡើងផង តាមដែលឃើញថាថ្ងៃនោះ
ជិតមកដល់ហើយ[ច] ២៦ដ្បិតក្រោយដែលយើងបានទទួល
ស្គាល់សេចក្ដីពិត[ឆ] ហើយបើយើងធ្វើបាបស្ម័គ្រពីចិត្ត
ទៀត[ជ]នោះគ្មានយញ្ញបូជាណា សំរាប់នឹងលោះបាបទៀត
ទេ ២៧មានតែរង់ចាំ ដោយស្ញែងខ្លាចចំពោះសេចក្ដីជំ
នុំជំរះ នឹងសេចក្ដីសហ័សនៃភ្លើង[ឈ] ដែលរៀបនឹងឆេះដល់
អស់ទាំងពួកទាស់ទទឹងផងប៉ុណ្ណោះ ២៨ឯអ្នកណាដែលក្បត់
ក្រិត្យវិន័យលោកម៉ូសេ នោះបានត្រូវស្លាប់ឥតគេប្រណី
ដោយសេចក្ដីបន្ទាល់របស់ មនុស្ស២ឬ៣នាក់[ញ] ២៩ចុះតើ
អ្នករាល់គ្នាស្មានថា គេគួរមានទោសជាធ្ងន់ជាងយ៉ាងណា
ទៅ ដែលគេជាន់ឈ្លី[ដ] ព្រះរាជបុត្រានៃព្រះ[ឋ] ទាំងរាប់ព្រះ
លោហិតនៃសេចក្ដីសញ្ញា[ឌ] ដែលបានញែកគេចេញជាបរិ
សុទ្ធ[ឍ] ទុកដូចជារបស់ប្រើធម្មតា ហើយត្មះតិះដៀលដល់
ព្រះវិញ្ញាណ[ណ]ដ៏មានព្រះ គុណផងនោះ[ត] ៣០ដ្បិតយើងស្គាល់
ព្រះអង្គដែលទ្រង់មានបន្ទូលថា «សេចក្ដីសងសឹកជារបស់
ផងអញ អញនឹងសងគេ[ថ] នេះជាព្រះបន្ទូលនៃព្រះអម្ចាស់»
ហើយ១ទៀតថា «ព្រះ អម្ចាស់ទ្រង់នឹងជំនុំជំរះរាស្ត្រទ្រង់»[ទ]
៣១ឯការដែលធ្លាក់ ទៅក្នុងកណ្ដាប់ព្រះហស្ត[ធ] នៃព្រះដ៏
មានព្រះជន្មរស់នៅ[ន] នោះគួរស្ញែងខ្លាចណាស់[ប]។
៣២ចូរនឹកចាំពីជាន់មុន គឺពីកាលដែលអ្នករាល់គ្នា ទើប
នឹងបានភ្លឺឡើង[ផ] នោះក៏ទ្រាំនឹងទុក្ខលំបាក ទាំងតតាំងជា
ខ្លាំងដែរ[ព] ៣៣ដោយសារគេយកអ្នករាល់គ្នាទុកជាល្បែង
មើលលេង ទាំងត្មះតិះដៀល ហើយធ្វើទុក្ខដល់អ្នករាល់គ្នា
នោះម្យ៉ាង[ភ] ហើយមួយទៀត ដោយអ្នករាល់គ្នាបានភប់
ប្រសព្វនឹងពួកអ្នក ដែលត្រូវទុក្ខលំបាកដូច្នោះម្យ៉ាងផង[ម]
៣៤ដ្បិតអ្នករាល់គ្នាមានចិត្តអាណិតអាសូរ ដល់ពួកអ្នកដែល
ជាប់ចំណង[យ] ក៏ទ្រាំឱ្យមនុស្សប្លន់យករបស់ទ្រព្យខ្លួន ដោយ
អំណរ ដោយដឹងថា ខ្លួនមានទ្រព្យសម្បត្តិ ដែលប្រសើរ
ជាង ហើយក៏នៅជាប់លាប់ផង នៅឯស្ថានសួគ៌[រ]។
៣៥ដូច្នេះ កុំឱ្យបោះបង់ចោលសេចក្ដីក្លាហាន[ល]របស់អ្នក
រាល់គ្នា ដែលមានរង្វាន់ជាធំនោះឡើយ ៣៦ដ្បិតអ្នករាល់គ្នា
ត្រូវការនឹងសេចក្ដីអត់ធ្មត់[វ] ដើម្បីឱ្យបានទទួលសេចក្ដីដែល
បានសន្យា ដោយធ្វើតាមព្រះហឫទ័យព្រះ[ស] ៣៧ពីព្រោះនៅ

**១០:២២** ហ អគ ៣៦:២៥ ហាព ៩:១៤ ១២:២៤ ១ពត ១:២ ឡ កច ២២:១៦ **១០:២៣** អ ហាព ៣:៦ ក ហាព ៣:១ ខ ១កថ ១:៩ **១០:២៤** គ ទត ២:១៤ **១០:២៥** ឃ កច ២:៤២ ង ហាព ៣:១៣ ច ១កថ ៣:១៣ **១០:២៦** ឆ ១ធថ ២:៤ ជ នក ២១:១៤ ជន ១៥:៣០ ហាព ៥:២ ៦:៤–៨ ២ពត ២:២០ **១០:២៧** ឈ អស ២៦:១១ ២ថន ១:៧ ហាព ៩:២៧ ១២:២៩ **១០:២៨** ញ ចទ ១៧:៦,៧ មថ ១៨:១៦ ហាព ២:២ **១០:២៩** ដ ហាព ៦:៦ ឋ មថ ៤:៣ ឌ មថ ២៦:២៨ ឍ ១កថ ៦:១១ វវ ១:៥ ណ អភ ៤:៣០ ហាព ៦:៤

ត ហាព ២:៣ ១២:២៥ **១០:៣០** ថ ចទ ៣២:៣៥ រម ១២:១៩ ទ ចទ ៣២:៣៦ ទដ ១៣៥:១៤ **១០:៣១** ធ មថ ១៦:១៦ ន ២កថ ៥:១១ ប អស ១៩:១៦ **១០:៣២** ផ ហាព ៦:៤ ព ភល ១:២៩,៣០ **១០:៣៣** ភ ១កថ ៤:៩ ម ភល ៤:១៤ ១ថន ២:១៤ **១០:៣៤** យ ហាព ១៣:៣ រ ហាព ១១:១៦ ១ពត ១:៤,៥ **១០:៣៥** ល អភ ៣:១២ **១០:៣៦** វ រម ៥:៣ ហាព ១២:១ យក ១:៣,៤,១២ ៥:១១ ២ពត ១:៦ ស ហាព ៦:១៥ ៩:១៥

ជ្រមុជទឹករបស់គ្រីស្ទបរិស័ទ និងការលាងជម្រះពី អំពើបាបដោយការសុគត របស់ព្រះគ្រីស្ទនោះដែរ (លវ ១៤:៩ ១៥:១៣ ១៦:៤, ២៤,២៦ ជន ១៩:១៩ សក ១៣:១ រម ៦:៣–១១ និងការពន្យល់)។

**១០:២៣** *សេចក្ដីបន្ទាល់របស់សេចក្ដីជំនឿ* "មើលពន្យល់ ៣:៦ ៦:១៨–១៩"។

*ព្រះដែលសន្យានោះ ទ្រង់ស្មោះត្រង់* "សូមមើល ២ធថ ២:១៣"។

**១០:២៥** *ឥតលែងប្រជុំគ្នា* នៅក្នុងភាសាក្រិកសំដៅលើការរត់ចោល និងការបោះបង់ចោល (មថ ២៧:៤៦ ២កថ ៤:៩ ២ធថ ៤:១០,១៦)។ *ថ្ងៃ* សំដៅលើថ្ងៃព្រះគ្រីស្ទយាងមកជាលើកទីពីរ (១ថន ៥:២,៤ ២ថន ១:១០ ២:២ ២ពត ៣:១០)។

**១០:២៦–៣១** ត្រង់ចំណុចនេះជាការព្រមានលើកទីបួន (មើលពន្យល់ ២:១–៤)។ ការព្រមាននេះជាពិសេសចំពោះពួកអ្នកដែលរត់ចោលពួកជំនុំ (ខ.២៥)។ សូមមើល ៦:៤–៨ (និងការពន្យល់) សម្រាប់ការពិភាក្សានូវលក្ខ័ណ្ឌខាងឯវិញ្ញាណ ដែលស្រដៀងគ្នា ។

**១០:២៦** *បើយើងធ្វើបាបដោយស្ម័គ្រពីចិត្តទៀត* ការប្រព្រឹត្តអំពើបាបដែលបែកចេញពីសេចក្ដីជំនឿ (ខ.១៩ មើលការពន្យល់ ៥:២)។ ព្រះគម្ពីរសញ្ញាចាស់ជាមូលដ្ឋានគ្រឹះគឺនៅក្នុង "ជន ១៥:២៧–៣១"។ *គ្មានយញ្ញបូជាណា* ការបដិសេធន៍យញ្ញបូជារបស់ព្រះគ្រីស្ទ សម្រាប់លោះបាបមនុស្សទាំងអស់ គឺជាការបដិសេធន៍យញ្ញបូជាតែមួយគត់ គឺគ្មានយញ្ញបូជាណាទៀតទេ។

**១០:២៧** *សេចក្ដីជំនុំជំរះ . . . និងសេចក្ដីសហ័សនៃភ្លើង* "សូមមើលការពន្យល់ ១២:២៩ ២ថន ១:៦–៩"។ សម្រាប់ភ្លើងដែលប្រៀបទៅនឹងសេចក្ដីជំនុំជម្រះរបស់ព្រះអម្ចាស់ សូមមើល "បទ ១:១៣"។

**១០:២៨** "សូមមើល ចទ ១៧:៦ និងការពន្យល់"។

**១០:២៩** *ព្រះលោហិតនៃសេចក្ដីសញ្ញា* "មើលការពន្យល់ ៩:១៨ ១៣:២០ មថ ២៦:២៨ មថ ១៤:២៤"។

**១០:៣១** "សូមមើល ១២:២៩"។

**១០:៣២–១២:៣** ចំណុចនេះជាសេចក្ដីពិណនានៅក្នុងវគ្គ "ហាប ២:៣–៤"។

**១០:៣២** *ចូរនឹកចាំពីជាន់មុន គឺពីកាលដែលអ្នករាល់គ្នាទើបនឹងបានភ្លឺឡើង* បញ្ជាក់ថា ការទាំងនេះកើតឡើង បន្ទាប់ពីពួកគេឆ្លើយតបជាទីមួយទៅនឹងដំណឹងល្អ គឺនៅពេលដែលពួកគេជួបប្រទះនឹងការលំបាក និងការបៀតបៀន ហើយស្ថិតនៅក្នុងស្ថានភាពមួយដែលបារម្ភចំពោះគ្នាទៅវិញទៅមក ។

**១០:៣៤** *ទ្រព្យសម្បត្តិដែលប្រសើរជាង ហើយក៏នៅជាប់លាប់ផង នៅឯស្ថានសួគ៌* មានដូចជាការសង្គ្រោះនៅក្នុងព្រះគ្រីស្ទ និងព្រះពរដែលទ្រង់ប្រទានឱ្យ (១១:១០, ១៦,៣៥ ១៣:១៤ និងការពន្យល់)។

តែបន្តិចទៀត «នោះព្រះអង្គដែលត្រូវមក[ហ] ទ្រង់នឹងយាង
មកមែន ឥតបង្អង់ឡើយ[ឡ] ៣៨តែពួកមនុស្សសុចរិតនឹងរស់
នៅ ដោយអាងសេចក្ដីជំនឿ[អ] បើអ្នកណាថយទៅវិញ នោះ
ចិត្តអញគ្មានសេចក្ដីអំណរចំពោះអ្នកនោះទេ»[ក] ៣៩តែយើង
រាល់គ្នាមិនមែនជាពួកអ្នកដែលថយទៅវិញ ឱ្យត្រូវវិនាស
នោះឡើយ គឺជាពួកអ្នកដែលមានសេចក្ដីជំនឿសំរាប់ឱ្យ
ព្រលឹងបានសង្គ្រោះវិញ ។

## ដោយជំនឿ

**១១** ១រីឯសេចក្ដីជំនឿ នោះគឺជាចិត្តដែលដឹងជាក់ថានឹង
បានដូចសង្ឃឹម[ខ] ជាសំគាល់ពីការដែលមើលមិនឃើញ[គ]
២ព្រះទ្រង់បានធ្វើបន្ទាល់ពីមនុស្សចាស់បុរាណ ដោយព្រោះ
គេមានសេចក្ដីជំនឿនោះឯង[ឃ] ៣យើងរាល់គ្នាក៏យល់ដោយ
សារសេចក្ដីជំនឿនោះថា លោកីយបានកើតមកដោយសារ
ព្រះបន្ទូលនៃព្រះ បានជារបស់ដែលមើលឃើញទាំងប៉ុន្មាន
នោះមិនមែនកើតអំពីរបស់ដែលមើលឃើញទេ[ង]។
៤ដោយសារសេចក្ដីជំនឿ នោះអេបិលបានថ្វាយយញ្ញ
បូជាដល់ព្រះ ដែលប្រសើរជាងដង្វាយរបស់កាអ៊ីន ហើយ
មានសេចក្ដីបន្ទាល់ពីគាត់[ច] ដោយព្រោះយញ្ញបូជានោះថា
គាត់សុចរិត ទាំងមានព្រះធ្វើបន្ទាល់ពីដង្វាយគាត់ផង[ឆ] បាន
ជាទោះបើគាត់ស្លាប់ក៏ដោយ គង់តែនៅមាននិយាយទៅ
ទៀត ដោយសារដង្វាយនោះឯង[ជ]។
៥ដោយសារសេចក្ដីជំនឿ នោះហេណុកបានឡើងទៅ
លើ មិនបានឃើញសេចក្ដីស្លាប់ឡើយ ហើយគេរកគាត់មិន
ឃើញទៀត ពីព្រោះព្រះបានយកគាត់ទៅ[ឈ] ដ្បិតកាលមុន
ដែលលើកយកគាត់ទៅ នោះមានសេចក្ដីបន្ទាល់ពីគាត់ថា
ព្រះទ្រង់សព្វព្រះហឫទ័យនឹងគាត់ណាស់ ៦តែបើឥតមាន
សេចក្ដីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះ
បានឡើយ ដ្បិតអ្នកណាដែលចូលទៅឯព្រះ[ញ] នោះត្រូវតែ
ជឿថា មានព្រះមែន ហើយថា ទ្រង់ប្រទានរង្វាន់ ដល់អស់
អ្នកដែលស្វែងរកទ្រង់ ។
៧ដោយសារសេចក្ដីជំនឿ នោះព្រះបានមានបន្ទូល
ពន្យល់លោកណូអេ ពីការដែលមើលមិនទាន់ឃើញនៅ
ឡើយ[ដ] ហើយដោយលោកមានសេចក្ដីកោតខ្លាច បានជា
លោកធ្វើទូក ១ យ៉ាងធំ[ឋ] សំរាប់នឹងជួយសង្គ្រោះដល់ពួក
គ្រួសាររបស់លោក[ឌ] ហើយលោកបានកាត់ទោសលោកីយ
ដោយការនោះ ក៏ត្រឡប់ជាអ្នកគ្រងសេចក្ដីសុចរិត ដែល
ត្រូវខាងសេចក្ដីជំនឿ ទុកជាមរដកដែរ[ឍ]។
៨ដោយសារសេចក្ដីជំនឿ កាលព្រះបានហៅលោក
អ័ប្រាហាំ នោះលោកក៏បានស្ដាប់បង្គាប់ លោកចេញទៅ[ណ]
ឯកន្លែងដែលត្រូវទទួលជាមរដក[ត] គឺចេញទៅឥតមានដឹង
ជាទៅឯណាទេ ៩ដោយសារសេចក្ដីជំនឿ នោះលោកបាន
ស្នាក់នៅក្នុងស្រុក ដែលទ្រង់សន្យាឱ្យ[ថ] ដូចជានៅប្រទេស
ដទៃ ក៏នៅតែក្នុងត្រសាល[ទ] ជាមួយនឹងអ៊ីសាក់ ហើយនិង

**១០:៣៧** ហ មថ ១១:៣ ឡ វវ ២២:២០
**១០:៣៨** អ រម ១:១៧ កទ ៣:១១ ក ហព ២:៣,៤
**១១:១** ខ ហព ៣:៦ គ ២កថ ៤:១៨
**១១:២** ឃ ខ.៤,៣៩
**១១:៣** ង លប ១ យហ ១:៣ ហព ១:២ ២ពត ៣:៥
**១១:៤** ច ខ.២,៣៩ ឆ លប ៤:៤ ១យហ ៣:១២ ជ ហព ១២:២៤
**១១:៥** ឈ លប ៥:២១-២៤
**១១:៦** ញ ហព ៧:១៩
**១១:៧** ដ ខ.១ ឋ លប ៦:១៣-២២ ឌ ១ពត ៣:២០ ឍ លប ៦:៩ អគ ១៤:១៤,២០ រម ៩:៣០
**១១:៨** ណ លប ១២:៧ ត លប ១២:១-៤ កច ៧:២-៤
**១១:៩** ថ កច ៧:៥ ទ លប ១២:៨ ១៨:១,៩

**១០:៣៨** *ពួកមនុស្សសុចរិតនឹងរស់នៅ ដោយអាងសេចក្ដីជំនឿ* "ហប ២:៤ និងការពន្យល់"។

**១០:៣៩** *ដែលថយទៅវិញ ឱ្យត្រូវវិនាសនោះឡើយ* គឺផ្ទុយនឹងពួកអ្នកដែលជឿ ហើយទទួលបានការសង្គ្រោះ ។ អ្នកនិពន្ធកណ្ឌគម្ពីរនេះមានជំនឿថា ពួកអ្នកដែលទទួលសំបុត្រគាត់ គឺនៅក្នុងចំណោមអ្នកដែលបានទទួលការសង្គ្រោះ (៦:៩ និងការពន្យល់) ។

**១១:១-១២:៣** វគ្គនេះនិយាយផ្តោតទៅលើការលើកទឹកចិត្ត ឱ្យព្យាយាមនៅក្នុងសេចក្ដីជំនឿ ។

**១១:២** *មនុស្សចាស់បុរាណ* សំដៅលើវីរបុរសនៃសេចក្ដីជំនឿ នៅយុគសម័យមុនព្រះគ្រីស្ទយាងមក ដូចមានរៀបរាប់ឈ្មោះនៅក្នុងជំពូកនេះ ។

**១១:៤** សូមមើលបទគម្ពីរ "លប ៤:២-៥"។ *មានសេចក្ដីបន្ទាល់ពីគាត់ . . .ថាគាត់សុចរិត* ហេតុផលដែលដង្វាយរបស់លោកអេបិលត្រូវបានគាប់ព្រះហឫទ័យព្រះ គឺព្រោះគាត់ថ្វាយដោយសេចក្ដីជំនឿ ។ ដង្វាយរបស់កាអ៊ីនមិនគាប់ព្រះហឫទ័យព្រះ ព្រោះគាត់ថ្វាយដោយគ្មានជំនឿ (លប ៤:៣-៤ ១យហ ៣:១២ និងការពន្យល់) ។

**១១:៥** *ហេណុក* "សូមមើល លប ៥:១៨-២៤"។ *បានឡើងទៅលើ* គឺទៅឯទីដែលព្រះគង់នៅ (លប ៥:២៤ ប្រៀបធៀប ទដ ៤៩:១៥ ៧៣:២៤) ។

**១១:៦** *បើឥតមានសេចក្ដីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ* ការដែលលោកហេណុកបានគាប់ព្រះហឫទ័យដល់ព្រះ គឺបង្ហាញដោយសេចក្ដីជំនឿរបស់គាត់ ។ *នោះត្រូវតែជឿថា មានព្រះមែន* សេចក្ដីជំនឿគឺត្រូវមានកម្មបទ ហើយកម្មបទដែលត្រឹមត្រូវនៃសេចក្ដីជំនឿគឺព្រះអម្ចាស់ ។ *អ្នកដែលស្វែងរកទ្រង់* សូមប្រៀបធៀបនឹងបទគម្ពីរ "យរ ២៩:១៣"។

**១១:៧** *ដោយសារសេចក្ដីជំនឿ* នៅពេលដែលទឹកជំនន់មកដល់ ព្រះបន្ទូលព្រះត្រូវបានបញ្ជាក់នូវការពិត គឺលោកណូអេបានរួចផុតពីសេចក្ដីស្លាប់ រីឯអស់អ្នកដែលមិនព្រមជឿនោះត្រូវវិនាស ។ *លោកណូអេ* "មើល លប ៥:២៨-៩:២៩"។ *សេចក្ដីសុចរិតដែលត្រូវខាងសេចក្ដីជំនឿ* លោកណូអេបានបង្ហាញនូវការទុកចិត្តដល់ព្រះអម្ចាស់ និងព្រះបន្ទូលទ្រង់ ទោះបីគាត់មិនបានឃើញការទាំងនោះជាមុនក៏ដោយ (ខ.១) ដូចជាទឹកជំនន់ជាដើម ។ ដូច្នោះហើយទើបលោកណូអេក៏ត្រូវបានរាប់ជាសុចរិត ដោយសេចក្ដីជំនឿលើព្រះអម្ចាស់ដែរ (១០:៣៨) ។

**១១:៨** *ព្រះបានត្រាស់ហៅ* "សូមមើល លប ១២:១-៣"។ *លោកអ័ប្រាហាំ* ឈ្មោះរបស់គាត់ត្រូវបានលើកមកនិយាយ នៅក្នុងគម្ពីរសញ្ញាថ្មីជាគំរូដ៏ប្រសើរ សម្រាប់ពួកអ្នករស់ដោយជំនឿ និងជាឪពុករបស់ពួកអ្នកដែលជឿដល់ព្រះអម្ចាស់ (រម ៤:១១-១២ កទ ៣:៧,៩,២៩)។ សេចក្ដីជំនឿរបស់លោកអ័ប្រាហាំ សំដែងចេញនូវការស្ដាប់បង្គាប់ (លប ១២:១-៣) ។ *កន្លែង*

យ៉ាកុប ជាអ្នកគ្រងសេចក្ដីសន្យាដដែល ទុកជាមរដកជា
មួយគ្នា[ធ] ១០ពីព្រោះលោករង់ចាំក្រុង១[ន] ដែលមានឫស
ជញ្ជាំង[ប] ដែលព្រះទ្រង់ជាអ្នកគូរ ហើយជាជាងសង់[ផ]។
១១ដោយសារសេចក្ដីជំនឿ នោះនាងសារ៉ាក៏ទទួល
អំណាច ឱ្យមានគភ៌បង្កើតកូនបាន ហើយនាងបង្កើតកូន
មក[ព] ក្នុងកាលដែលហួសអាយុហើយ[ភ] ពីព្រោះនាងបានរាប់
ព្រះដែលសន្យានោះ ទុកជាស្មោះត្រង់[ម] ១២ដូច្នេះ ក៏មាន
មនុស្ស១ហ្វូង ដូចផ្កាយនៅលើមេឃ ហើយដូចខ្សាច់នៅ
មាត់សមុទ្រ[យ] ដែលរាប់មិនចេះអស់ បានកើតមកអំពីមនុស្ស
តែម្នាក់ ដែលអ្នកនោះក៏ទុកដូចជាស្លាប់[រ] ហើយដែរ។
១៣ពួកអ្នកទាំងនោះបានស្លាប់ក្នុងសេចក្ដីជំនឿ ឥតទទួល
សេចក្ដីដែលបានសន្យាទាំងប៉ុន្មានទេ[ល] តែគេបានឃើញពី
ចំងាយ[វ] ហើយក៏ទទួលគំនាប់ដែរ ទាំងយល់ព្រមថា ខ្លួនគេ
ជាអ្នកដទៃ ដែលគ្រាន់តែសំណាក់នៅផែនដីប៉ុណ្ណោះ[ស]
១៤ពួកអ្នកដែលនិយាយដូច្នោះ នោះសំដែងច្បាស់ថា គេជា
អ្នករកស្រុកសំរាប់ខ្លួនគេពិត ១៥ហើយបើសិនជាគេរឭក
ស្រុក ដែលគេទើបនឹងចេញមកនោះ នោះគេនឹងមាន
ឱកាសត្រឡប់ទៅវិញបាន[ហ] ១៦តែឥឡូវនេះ គេសង្វាតចង់
បានស្រុក១ដ៏ប្រសើរជាង គឺខាងស្ថានសួគ៌វិញ[ឡ] បានជា
ព្រះទ្រង់គ្មានសេចក្ដីខ្មាស[អ] ដោយគេហៅទ្រង់ជាព្រះនៃគេ
នោះឡើយ[ក] ដ្បិតទ្រង់បានរៀបចំទីក្រុង១[ខ]ឱ្យគេហើយ ។
១៧ដោយសារសេចក្ដីជំនឿ នោះអ័ប្រាហាំបានថ្វាយ
អ៊ីសាក[គ] ក្នុងកាលដែលទ្រង់ល្បងលលោក គឺអ្នកដែលបាន
ទទួលសេចក្ដីសន្យាទាំងប៉ុន្មាន លោកបានថ្វាយកូនលោក
តែមួយ ១៨ដែលមានសេចក្ដីចែងទុកពីដំណើរកូននោះថា
«ពូជឯងនឹងបានរាប់តាមអ៊ីសាក់»[ឃ] ១៩លោកបានរាប់ថា
ព្រះទ្រង់អាចនឹងប្រោសកូន ឱ្យរស់ពីស្លាប់ឡើងវិញបាន
ផង[ង] ហើយលោកបានទទួលវាមកវិញមែនធៀបដូចជារស់
ពីស្លាប់ឡើងវិញ[ច] ។
២០ដោយសារសេចក្ដីជំនឿ នោះអ៊ីសាកបានឱ្យពរដល់
យ៉ាកុប នឹងអេសាវ ពីដំណើរការទៅខាងមុខ[ឆ]។
២១ដោយសារសេចក្ដីជំនឿ នោះយ៉ាកុបបានឱ្យពរដល់
កូនយ៉ូសែបទាំង២[ជ] ហើយក៏ថ្វាយបង្គំព្រះ ទាំងច្រត់លើចុង
ឈើច្រត់ ក្នុងកាលដែលលោកហៀបនឹងស្លាប់ ។
២២ដោយសារសេចក្ដីជំនឿ នោះយ៉ូសែបបានប្រាប់ពី
ដំណើរពួកជនជាតិអ៊ីស្រាអែល ដើរចេញពីស្រុកអេស៊ីព្ទ ក៏
ផ្ដាំពីដំណើរសពរបស់ខ្លួន ក្នុងកាលដែលហៀបនឹងផុត
ដង្ហើមទៅផង[ឈ]។
២៣ដោយសារសេចក្ដីជំនឿ កាលម៉ូសេបានកើតមក
នោះឪពុកម្ដាយបានលាក់ទុក៣ខែ[ញ] ឥតមានខ្លាចដល់
បញ្ញត្តិរបស់ស្ដេចឡើយ ពីព្រោះបានឃើញថាជាកូនថ្លោស

**១១:៩** ធ ហព ៦:១៧
**១១:១០** ន ហព ១២:២២ ១៣:១៤
ប វវ ២១:២,១៤
ផ ខ.១៦
**១១:១១** ព លប ២១:២
ភ លប ១៧:១៧–១៩ ១៨:១១–១៤
ម ១កថ ១:៩
**១១:១២** យ រម ៤:១៩
រ លប ២២:១៧
**១១:១៣** ល ខ.៣៩
វ មថ ១៣:១៧
ស លប ២៣:៤ លវ ២៥:២៣ ភល ៣:២០ ១ពត ១:១៧ ២:១១
**១១:១៥** ហ លប ២៤:៦–៨
**១១:១៦** ឡ ២ធថ ៤:១៨ អ មក ៨:៣៨
ក លប ២៦:២៤ ២៨:១៣ នក ៣:៦,១៥
ខ ខ.១០ ហព ១៣:១៤
**១១:១៧** គ លប ២២:១–១០ យក ២:២១
**១១:១៨** ឃ លប ២១:១២ រម ៩:៧ **១១:១៩** ង រម ៤:២១ យហ ៥:២១
**១១:២០** ច លប ២៧:២៧–២៩,៣៩, ៤០ **១១:២១** ឆ លប ៤៨:១,៨–២២
**១១:២២** ជ លប ៥០:២៤,២៥ នក ១៣:១៩ យក ២៤:៣២
**១១:២៣** ឈ នក ២:២ ញ នក ១:១៦,២២

*ដែលត្រូវទទួលជាមរដក* គឺទឹកដីកាណាន ។
**១១:១០** *ក្រុង១ដែលមានឫសជញ្ជាំង* សំដៅលើក្រុងមួយដែលស្ថិតស្ថេរ និង ផ្ទុយពីលំនៅរបស់ពួកព្រឹទ្ធាចារ្យ (ខ.៩)។ ទីក្រុងនេះជាទីក្រុងយេរូសាឡិម នៅឯស្ថានសួគ៌ (១២:២២) ជាទីក្រុងដែលនឹងប្រទានមក (១៣:១៤) និងជាទីក្រុងយេរូសាឡិមថ្មី (វវ ២១:២–៤, ៩–២៧)។ *ជាងសង់* "សូមមើល ខ.១៦ ប្រៀបធៀប អភ ២:១៩–២២ ១ពត ២:៤–៥ ទដ ១៤៧:២ អស ៦២:៥ និងការពន្យល់)។
**១១:១១** *សារ៉ា . . . បង្កើតកូនបាន* "មើល លប ១១:៣០ ១៨:១១–១២"។
**១១:១២** *ក៏ទុកដូចជាស្លាប់ហើយដែរ* ពីព្រោះលោកអ័ប្រាហាំមានអាយុ ១០០ឆ្នាំហើយ (លប ២១:៥ រម ៤:១៩)។ *ដូចផ្កាយនៅលើមេឃ ហើយដូចខ្សាច់នៅមាត់សមុទ្រ* "មើលការពន្យល់ លប ១៣:១៦ ១៥:៥ ២២:១៧ ២៦:៤ ១ពវ ៤:២០"។
**១១:១៣** *គេបានឃើញពីចំងាយ ហើយក៏ទទួលគំនាប់ដែរ* គឺពួកគេបានឃើញ ដោយសេចក្ដីជំនឿ ឃើញព្រិលៗ ចំពោះការពិត ដែលជាសេចក្ដីសន្យា និងមានភាពច្បាស់លាស់ថា សេចក្ដីសង្ឃឹមរបស់ពួកគេនឹងក្លាយជារបស់ពួកគេ (ខ.១)។ *ជាអ្នកដទៃ ដែលគ្រាន់តែសំណាក់នៅផែនដីប៉ុណ្ណោះ* បញ្ជាក់ថាទីលំនៅពិត ប្រាកដរបស់ពួកគេគឺជាទីក្រុងរបស់ព្រះអម្ចាស់ (ខ.១០,១៦)។
**១១:១៤** *ស្រុកសំរាប់ខ្លួនគេពិត* ជាស្រុកមួយដែលពួកគេនឹងលែងជាជនបរទេស និងជាជនចម្លែកទៀតហើយ (ខ.១៣)។
**១១:១៦** *ទ្រង់បានរៀបចំទីក្រុង១ឱ្យគេ* "មើល ខ.១០ និងការពន្យល់"។
**១១:១៧** សូមមើលបទគម្ពីរ "លប ២២"។ *កូនលោកតែមួយ* "សូមមើល លប ២២:២,១២,១៦ និងការពន្យល់"។
**១១:១៩** សូមប្រៀបធៀបជាមួយនឹងបទគម្ពីរ "លប ២២:១៣" និងពន្យល់ ។
**១១:២០** សូមមើលបទគម្ពីរ "លប ២៧:២៧–៤០"។
**១១:២១** សូមមើលបទគម្ពីរ "លប ៤៨:៩–២០"។ *ថ្វាយបង្គំព្រះ ទាំងច្រត់លើចុងឈើច្រត់* "សូមមើល លប ៤៧:៣១ និងការពន្យល់"។
**១១:២២** សូមមើលបទគម្ពីរ "លប ៥០:២៤–២៥"។ លោកយ៉ាកុប (ខ.២១) និងលោកយ៉ូសែប គឺជាគំរូបន្ថែមអំពីពួកអ្នកដែលមានសេចក្ដីជំនឿកាន់តែខ្លាំងនៅពេលដែលជិតអស់ជីវិតនៅលើផែនដីនេះ (ខ.១៣)។
**១១:២៣** សូមមើល "នក ២:២-៣ កថ ៧:២០-៤៤"។ *ឪពុកម្ដាយបានលាក់លោក* សូមមើល "នក ៦:២០ ជន ២៦:៥៨–៥៩"។ *ឥតមានទឹកខ្លាច* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកគេបង្ហាញនូវគំនិតមិនព្រមធ្វើតាមបញ្ញត្តិរបស់ស្ដេចផារ៉ោនទេ ។ *បញ្ញត្តិរបស់ស្ដេច* បញ្ញត្តិរបស់ស្ដេចផារ៉ោន គឺឱ្យសម្លាប់ក្មេងប្រុសជាតិយូដាទាំងអស់ចោល (នក ១:១៦,២២)។ *ជាកូនថ្លោសល្អ* សូមមើល "នក ២:២"។

ល្អ[ដ] ។
២៤ ដោយសារសេចក្ដីជំនឿ លុះលោកធំហើយ នោះ
លោកមិនព្រមឱ្យគេហៅខ្លួន ជាកូនរបស់បុត្រីផារ៉ោនទេ[ឋ]
២៥ លោកស៊ូរងទុក្ខលំបាក[ឌ]ជាមួយនឹងរាស្ត្ររបស់ព្រះ ជា
ជាងមានសេចក្ដីអំណរខាងអំពើបាប ដែលនៅតែ១ភ្លែត
នោះវិញ ២៦ ដោយបានរាប់សេចក្ដីដំនៀល ដែលគេតិះ
ដៀលដល់ព្រះគ្រីស្ទ[ឍ] ទុកជាទ្រព្យសម្បត្តិប្រសើរជាងអស់
ទាំងរបស់ថ្លៃវិសេសនៅស្រុកអេស៊ីព្ទ ដ្បិតលោកសំឡឹង
ចំទៅឯរង្វាន់វិញ[ណ] ២៧ ដោយសារសេចក្ដីជំនឿ នោះលោក
ក៏ចេញពីស្រុកអេស៊ីព្ទទៅ[ត] ឥតកោតខ្លាចដល់សេចក្ដីកំហឹង
នៃស្ដេចឡើយ ដ្បិតលោកបានកាន់យ៉ាងខ្ជាប់ខ្ជួន ហាក់ដូច
ជាឃើញព្រះដ៏មើលមិនឃើញដែរ ២៨ ដោយសារសេចក្ដី
ជំនឿ នោះលោកបានធ្វើបុណ្យរំលង ទាំងរលាស់ឈាម
ដើម្បីកុំឱ្យមេបំផ្លាញ[ថ]ពួកកូនច្បង បានមកពាល់ដល់គេ
ឡើយ[ទ] ។

**១១:២៤** ដ នក ២:១០,១១
**១១:២៥** ឋ ខ.៣៧
**១១:២៦** ឌ ហព ១៣:១៣ ឍ លក ១៤:៣៣ ណ ហព ១០:៣៥
**១១:២៧** ត នក ១២:៥០,៥១
**១១:២៨** ថ ១កថ ១០:១០ ទ នក ១២:២១-២៣
**១១:២៩** ធ នក ១៤:២១-៣១
**១១:៣០** ន យស ៦:១២-២០
**១១:៣១** ប យស ២:១,៩-១៤ ៦:២២-២៥ យក ២:២៥

២៩ ដោយសារសេចក្ដីជំនឿ នោះគេបានដើរកាត់
សមុទ្រក្រហម ដូចជាដើរលើដីគោក តែកាលពួកសាសន៍
អេស៊ីព្ទបានល្បងល នោះគេក៏ត្រូវលេបបាត់ទៅ[ធ] ៣០ ដោយ
សារសេចក្ដីជំនឿ លុះគេដើរព័ទ្ធជុំវិញក្រុង យេរីខូរ អស់៧
ថ្ងៃហើយ នោះកំផែងទីក្រុងក៏រលំទៅ[ន] ។
៣១ ដោយសារសេចក្ដីជំនឿ នោះនាងរ៉ាហាប ជាស្រី
សំផឹង មិនបានវិនាសទៅ ជាមួយនឹងពួកអ្នករឹងចចេស
ឡើយ ពីព្រោះនាងបានទទួលពួកឈ្លបលប ដោយមេត្រី
ចិត្ត[ប] ។
៣២ តើត្រូវឱ្យខ្ញុំនិយាយអ្វីទៀត ដ្បិតគ្មានពេលវេលានឹង
ថ្លែងប្រាប់រឿងពីគេឌាន[ផ] បារ៉ាក[ព] សាំសុន[ភ] យែបថា[ម]
ដាវីឌ[យ] សាំយូអែល[រ] នឹងពួកហោរាទេ ៣៣ ដែលដោយសារ
សេចក្ដីជំនឿ នោះគេបានឈ្នះនគរដទៃ[ល] បានសំរេចការ

**១១:៣២** ផ ពច ៦-៨ ព ពច ៤-៥ ភ ពច ១៣-១៦ ម ពច ១១-១២ យ ១សយ ១៦:១,១៣ រ ១សយ ១:២០ **១១:៣៣** ល ២សយ ៨:១-៣

**១១:២៤** *កូនរបស់បុត្រីផារ៉ោន* "សូមមើល នក ២:១០"។

**១១:២៥** *សេចក្ដីអំណរខាងអំពើបាប* សំដៅលើភាពប្រណិត និងកិត្តិនាមនៃវាំងស្ដេចអេស៊ីព្ទ ។

**១១:២៦** *សេចក្ដីដំនៀល ដែលគេតិះដៀលដល់ព្រះគ្រីស្ទ* ទោះបីការយល់ដឹងរបស់លោកម៉ូសេអំពីសេចក្ដីសន្យា ចំពោះពួកអ៊ីស្រាអែលមានដែនកំណត់ក៏ដោយ ក៏គាត់យល់ស្របជាមួយនឹងពួកគេ ដែលថាអនាគតនឹងត្រូវបានសំដែងឱ្យឃើញយ៉ាងច្បាស់ ។ ត្រង់ចំណុចនេះ អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបញ្ជាក់ថា អនាគតគឺនៅក្នុងតួអង្គព្រះមែស៊ីដែលជាសេចក្ដីសន្យា ដែលត្រូវបានធានាចំពោះអនាគតពិតប្រាកដ ។ *របស់ថ្លៃវិសេសនៅស្រុកអេស៊ីព្ទ* គឺរបស់ដែលមានតម្លៃរកអ្វីប្រៀបផ្ទឹមពុំបាន ។ គ្រាន់តែនៅក្នុងផ្នូររបស់ស្ដេចទូតានខាមួន (Tutankhamun) គឺមានរួមបញ្ចូលនូវ មាសសុទ្ធរាប់ពាន់គីឡូក្រាម ។

**១១:២៧** *ដោយសារសេចក្ដីជំនឿ នោះលោកក៏ចាកចេញពីស្រុកអេស៊ីព្ទ* សំដៅលើពេលវេលា ដែលលោកម៉ូសេបានចាកចេញពីស្រុកអេស៊ីព្ទ ទៅឯស្រុកម៉ាឌាន ពេលដែលគាត់មានវ័យ៤០ឆ្នាំ (នក ២:១១-១៥ កច ៧:២៣-២៩ និងពន្យល់)។ *ឥតកោតខ្លាចដល់សេចក្ដីកំហឹងនៃស្ដេចឡើយ* កណ្ឌគម្ពីរនិក្ខមនំបានបញ្ជាក់ថា លោកម៉ូសេមានការភ័យខ្លាច (នក ២:១៤) ប៉ុន្តែមិនបានប្រាប់ថាគាត់ខ្លាចអ្នកណាទេ ។ ម្យ៉ាងទៀតក្នុងកណ្ឌគម្ពីរនិក្ខមនំបញ្ជាក់ថា ស្ដេចផារ៉ោនព្យាយាមសម្លាប់លោកម៉ូសេ (នក ២:១៥) ប៉ុន្តែ មិនបង្ហាញថាគាត់រត់គេចដោយភ័យខ្លាចនោះទេ ។ អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរចង់បង្ហាញថា ការដែលលោកម៉ូសេរត់ចេញពីការ តាមសម្លាប់របស់ស្ដេច-ផារ៉ោន គឺគាត់បានដាក់សេចក្ដីទុកចិត្តរបស់គាត់ទៅលើ ព្រះអម្ចាស់ ដោយទុកចិត្តថា ទ្រង់នឹងរំដោះអ៊ីស្រាអែលឱ្យមានសេរីភាពវិញ ហើយ គាត់ក៏បានរួមចំណែកដែរ ។ *ដ្បិតលោកបានកាន់យ៉ាងខ្ជាប់ខ្ជួន* គឺក្នុងរយៈពេល ៤០ឆ្នាំនៅស្រុកម៉ាឌាន (កច ៧:៣០)។ *ឃើញព្រះដ៏មើលមិនឃើញដែរ* សូមមើល "ខ.១,៦ រម ១:២០ កល ១:១៥ ១ធថ ១:១៧ និងការពន្យល់"។

**១១:២៨** សូមមើលបទគម្ពីរ "នក ១២:១-៣០"។

**១១:២៩** ជាលើកទីបី និងជាគ្រា៤០ឆ្នាំចុងក្រោយនៃជីវិតរបស់លោកម៉ូសេ ដែលចំណាយពេលដឹកនាំសាសន៍អ៊ីស្រាអែលឆ្លងកាត់ទីរហោស្ថាន ។ ពេលគាត់មានវ័យ១២០ឆ្នាំ ជីវិតរបស់គាត់នៅលើផែនដីត្រូវបានបញ្ចប់នៅស្រុកម៉ូអាប់ (ចទ ៣៤:១-៧)។

**១១:៣០-៣១** សូមមើល "យស ២,៦"។

**១១:៣០** *ក្រុងយេរីខូរ* ត្រង់ចំណុចនេះបញ្ជាក់អំពីឧបសគ្គទីមួយចំពោះជ័យជម្នះរបស់ពួកអ៊ីស្រាអែល ក្រោមការដឹកនាំរបស់លោកយ៉ូស្វេ ដែលទទួលបានទឹកដីដោយសេចក្ដីជំនឿ និងមិនបាច់ច្បាំង ។

**១១:៣១** *ដោយសារសេចក្ដីជំនឿ* សូមមើល"យស ៦:៩-១១"។ *ស្រីសំផឹង* នេះ ជាការពណ៌នាអំពីរបៀបនៃជីវិតរស់នៅរបស់ពួកសាសន៍កាណាន នៅក្នុងសង្គមរបស់ពួកគេ ។ *នាងបានទទួលពួកឈ្លបលប* "សូមមើល យស ២:២៥"។

**១១:៣២-៣៨** មានវីរបុរសនៃសេចក្ដីជំនឿជាច្រើន មុនពេលដែលព្រះគ្រីស្ទបានយាងមក ហើយដែលគួរកត់ត្រាអំពីពួកគេ ។ មានគំរូតិចតួចដែលបង្ហាញនូវគ្រប់ប្រភេទបុរស និងស្ត្រីនៃសេចក្ដីជំនឿ ។ គុណសម្បត្តិដ៏ធំដែលពួកគេមានជាទូទៅគឺ ពួកគេមានជ័យជម្នះតាមរយៈសេចក្ដីជំនឿ (ខ.៣៥)។

**១១:៣២** *ថ្លែងប្រាប់* ពាក្យនេះនៅក្នុងភាសាក្រិកជាកិរិយាសព្ទមានទម្រង់ជាភេទប្រុស ដូច្នេះបញ្ជាក់ថា អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរគឺជាបុរស (សូមមើលសេចក្ដីផ្ដើម)។ *គេឌាន បារ៉ាក សាំសុន យែ៉បថា* "សូមមើល ពច ៤-៨ ១១-១៦ ១សយ ១២:១១"។ *សាំយូអែល និងពួកហោរា* ចំពោះការដែលលោកសាំយូអែលត្រូវបានរាប់ជាហោរាទីមួយ ក្នុងចំណោមពួកហោរា សូមមើល "កច ៣:២៤ ១៣:២០ ទដ ៩៩:៦ យរ ១៥:១ និងការពន្យល់"។

**១១:៣៣** *បានឈ្នះនគរដទៃ* សូមមើលឧទាហរណ៍អំពីជ័យជំនះរបស់ស្ដេចដាវីឌ (២សយ ៥:៦-២៥ ៨:១-១៤ ១០:១-១៩ ១២:២៦-៣១)។ *បានសំរេចការសុចរិត* សូមមើលឧទាហរណ៍អំពីលោកសាំយូអែល (១សយ

សុចរិត បានទទួលសេចក្ដីសន្យា បានបិទមាត់សិង្ហ[វ] ៣៤បាន
ពន្លត់អំណាចភ្លើង[ស] បានរួចពីមុខដាវ[ហ] បានមានកំឡាំងក្នុង
កាលដែលកំពុងតែខ្សោយ[ឡ] ក៏ត្រឡប់ជាពូកែក្នុងចំបាំង
ទាំងកំចាត់ពលទ័ពសាសន៍ដទៃផង[អ] ៣៥ពួកស្រីៗបានទទួល
មនុស្សស្លាប់របស់ខ្លួនមក ដោយរស់ពីស្លាប់ឡើងវិញ[ក] ខ្លះ
ត្រូវគេធ្វើទុក្ខវេទនា ឥតទទួលការប្រោសលោះឱ្យរួច
ឡើយ គឺដើម្បីឱ្យបានរស់ឡើងវិញបែបប្រសើរជាង ៣៦ខ្លះ
ទៀតត្រូវសេចក្ដីល្បង ដោយមានគេចំអកឱ្យទាំងវាយនឹង
រំពាត់[ខ] ក៏ទ្រាំទាំងជាប់ចំណង និងជាប់គុកផង[គ] ៣៧ត្រូវគេ
ចោលនឹងថ្ម[ឃ] ល្បួង ហើយអារបណ្ដាច់ ក៏ត្រូវស្លាប់នឹងដាវ[ង]
ត្រូវដើរវីមវាម ទាំងស្លៀកស្បែកចៀម និងស្បែកពពែ[ច]
ត្រូវកំសត់ទុគ៌ត ត្រូវគេសង្កត់សង្កិន ហើយធ្វើបាប ៣៨ក៏ដើរ
សាត់ព្រាត់នៅក្នុងទីរហោស្ថាន ហើយនៅទីភ្នំ ទាំងនៅក្នុង
រអាង[ឆ] ហើយនឹងរូងក្នុងដីលោកីយមិនគួរនឹងពួកអ្នកទាំង
នោះទេ ៣៩ពួកអ្នកទាំងនោះ ទោះបើមានសេចក្ដីបន្ទាល់[ជ]
ពីគេថា គេមានសេចក្ដីជំនឿក៏ដោយ គង់តែគេមិនបាន
ទទួលសេចក្ដីដែលបានសន្យានោះទេ[ឈ] ៤០ដ្បិតព្រះបានផ្គត់
ផ្គង់សេចក្ដីប្រសើរជាង សំរាប់យើងរាល់គ្នា[ញ] ដើម្បីមិនឱ្យ
អ្នកទាំងនោះបានគ្រប់លក្ខណ៍ ក្រៅពីយើងឡើយ[ដ]។

**ព្រះអម្ចាស់វាយផ្ចាលកូនរបស់ទ្រង់**

**១២** ១ដូច្នេះ ដែលមានស្មរបន្ទាល់ ១ ហ្វូងធំម្ល៉េះ នៅព័ទ្ធ
ជុំវិញយើង នោះត្រូវឱ្យយើងចោលអស់ទាំងបន្ទុក នឹងអំពើ
បាប ដែលរុំយើងជុំវិញជាងាយម្ល៉េះនោះចេញ ហើយត្រូវ
រត់ក្នុងទីប្រណាំង[ឋ] ដែលនៅមុខយើង ដោយអំណត់[ឌ] ២ទាំង
រំពឹងមើលដល់ព្រះយេស៊ូវ[ឍ]ដ៏ជាមេផ្តើម[ណ] ហើយជាមេ
សំរេចសេចក្ដីជំនឿរបស់យើង ដែលទ្រង់បានរងទ្រាំនៅ
ឈើឆ្កាង[ត] ទាំងមើលងាយចំពោះសេចក្ដីអាមាស់ខ្មាស
នោះ[ថ] ឱ្យតែបានសេចក្ដីអំណរដែលនៅចំពោះទ្រង់ រួច

**១១:៣៣** វ ដយ ៦:២២ **១១:៣៤** ស ដយ ៣:១៩-២៧ ហ នក ១៨:៤ ឡ ២ពវ ២០:៧ អ ពច ១៥:៨ **១១:៣៥** ក ១ពវ ១៧:២២,២៣ ២ពវ ៤:៣៦,៣៧ **១១:៣៦** ខ យរ ២០:២ ៣៧:១៥ គ លប ៣៩:២០ **១១:៣៧** ឃ ២រប ២៤:២១ ង ១ពវ ១៩:១០ យរ ២៦:២៣ ច ២ពវ ១:៨ **១១:៣៨** ឆ ១ពវ ១៨:៤ ១៩:៩ **១១:៣៩** ជ ខ.២,៤ ឈ ខ.១៣ ហាព ១០:៣៦ **១១:៤០** ញ វវ ៦:១១ ដ ហាព ២:១០ **១២:១** ឋ ១កថ ៩:២៤ ឌ ហាព ១០:៣៦ **១២:២** ឍ ទដ ២៥:១៥ ណ ហាព ២:១០ ត ភល ២:៨,៩ ហាព ២:៩ ថ ហាព ១៣:១៣

១២:៣-៥) ដាវីឌ (២សយ ៨:១៥) សាឡូម៉ូន (១ពវ ៣:៩,១២,១៦-២៨)។ *បានទទួលសេចក្ដីសន្យា* អាចសំដៅលើស្ថានភាពនៃការសម្រាករបស់ពួកអ៊ីស្រាអែល នៅលើទឹកដីសន្យា ដូចមានចែងនៅក្នុងបទគម្ពីរ "១ពវ ៥:៤" អំពីស្ដេចសាឡូម៉ូន (សូមមើល យស ២៣:១៤ ២៤:៨-១៣ ២រប ២០:៣០ និងការពន្យល់)។ *បានបិទមាត់សឹង្ហ* សូមមើលឧទាហរណ៍អំពីលោកដានីយ៉ែលនៅក្នុងរូងសឹង្ហ (ដយ ៦)។

**១១:៣៤** *បានពន្លត់អំណាចភ្លើង* សូមមើលឧទាហរណ៍អំពីមិត្តភក្តិរបស់លោកដានីយ៉ែល ដែលមានលោកសាដ្រាក់ មែសាក់ និង អ័បេឌនេកោ ដែលត្រូវគេបោះចូលទៅក្នុងគុកភ្លើង (ដយ ៣)។ *បានរួចពីមុខដាវ* មើលឧទាហរណ៍ដាវីឌ (១សយ ១៧:៤៥-៤៩) អេលីយ៉ា (២ពវ ១) អេលីសេ (២ពវ ៦:៣១) យេរេមា (យរ ២៦:៧-២៤)។ *បានមានកំឡាំងក្នុងកាលដែលកំពុងតែខ្សោយ* មើលឧទាហរណ៍ លោកសាំសុន (ពច ១៦:២១-៣០) ហាណា (១សយ ១) យេរេមា (១:៦-១០)។

**១១:៣៥** *ពួកស្រីៗបានទទួលមនុស្សស្លាប់របស់ខ្លួនមក* សូមប្រៀបធៀបជាមួយនឹងស្ត្រីមេម៉ាយនៅឯសារិបតា (១ពវ ១៧:៩,១៧-២៩) និងស្ត្រីនៅស្រុកស៊ូណែម (២ពវ ៤:៨-៣៦)។

**១១:៣៦** *ចំអកឱ្យ ទាំងវាយនឹងរំពាត់* សូមមើលឧទាហរណ៍អំពីលោកយេរេមា (យរ ២០:២,៧-៨)។ *ជាប់គុក* មើល "យរ ៣៧:១៥-១៦"។

**១១:៣៧** *ត្រូវគេចោលនឹងថ្ម* សូមមើលឧទាហរណ៍ លោកសាការី ជាកូនរបស់សង្ឃយេហូយ៉ាដា និងត្រូវបានគេចោលនឹងថ្មសម្លាប់ ដោយព្រោះប្រកាសសេចក្ដីពិត (២រប ២៤:២១)។ *អារបណ្ដាច់* ប្រហែលសំដៅលើលោកអេសាយ ដែលតាមទំនៀមទម្លាប់យល់ថា ត្រូវគេសម្លាប់ដោយរបៀបនេះ ដោយស្ដេចអាក្រក់ឈ្មោះម៉ាណាសេ ។

**១១:៣៩** *មានសេចក្ដីបន្ទាល់ពីគេថា គេមានសេចក្ដីជំនឿ* គឺដោយព្រះវិញ្ញាណបរិសុទ្ធ (៣:៧ និងការពន្យល់)។

**១១:៤០** *ព្រះបានផ្គត់ផ្គង់សេចក្ដីប្រសើរ* គឺជាសេចក្ដីសម្រេចសម្រាប់ពួកគេ និងយើងរាល់គ្នា នៅក្នុងព្រះគ្រីស្ទ ដែលបានរស់ពីសុគតឡើងវិញ ហើយដែលទ្រង់ជាជីវិត (យហ ១១:២៥-២៦)។ *ដើម្បីមិនឱ្យអ្នកទាំងនោះបានគ្រប់លក្ខណ៍ ក្រៅពីយើងឡើយ* វីរបុរសនៃសេចក្ដីជំនឿ គឺអស់អ្នកដែលដាក់សេចក្ដីជំនឿរបស់ពួកគេលើព្រះអម្ចាស់ និងសេចក្ដីសន្យារបស់ទ្រង់ ។ សេចក្ដីសន្យាដែលទ្រង់មានចំពោះពួកគេ គឺបានសម្រេចនៅក្នុងអង្គព្រះយេស៊ូវគ្រីស្ទ ហើយការប្រោសលោះសម្រាប់ ពួកគេក៏នៅក្នុងទ្រង់ដែរ ។

**១២:១** *មានស្មរបន្ទាល់១ហ្វូងធំម្ល៉េះ នៅព័ទ្ធជុំវិញយើង* ឃ្លានេះនិយាយប្រៀបធៀបទៅនឹងការប្រកួតកីឡាអត្តពលកម្មនៅក្នុងរោងមហោស្រពដ៏ធំមួយ ។ ស្មរបន្ទាល់គឺពួកវីរបុរសនាសម័យដើមដូចបានរៀបរាប់ឈ្មោះខាងលើ (ជំពូក ១១)។ ពួកគេមិនមែនជាអ្នកទស្សនាទេ ប៉ុន្តែ ជាគំរូនៃការលើកទឹកចិត្ត ។ នៅក្នុងភាសាក្រិក ពាក្យថា "ស្មរបន្ទាល់" សំដៅលើ "អ្នករងទុក្ខ" និងមានន័យថា "អ្នកធ្វើបន្ទាល់ ឬសាក្សី"។ ពួកគេធ្វើបន្ទាល់ចំពោះអំណាចនៃសេចក្ដីជំនឿ និងសេចក្ដីសុចរិត របស់ព្រះអម្ចាស់ ។ *រត់ក្នុងទីប្រណាំង . . . ដោយអំណត់* "សូមមើល កច ២០:២៤ ១កថ ៩:២៤-២៦ កទ ២:២ ៥:៧ ភល ២:១៦ ២ធថ ៤:៧"។ ជីវិតគ្រីស្ទបរិស័ទ ប្រៀបដូចនឹងការរត់ប្រណាំងមួយវែងឆ្ងាយ មិនមែនជាការរត់នៅក្នុងទីដ៏ឆ្ងាយ នៅក្នុងរយៈពេលដ៏ខ្លីនោះទេ ។

**១២:២** *ជាមេផ្តើម ហើយជាមេសំរេចសេចក្ដីជំនឿ* គឺជាម្នាក់ដែលបានទៅមុនអ្នកជឿទាំងអស់នៅក្នុងសេចក្ដីជំនឿ និងឈានទៅដល់គោលដៅពិតប្រាកដ ហើយជាអ្នកតំណាង និងគំរូនៃសេចក្ដីជំនឿ ។ *សេចក្ដីអំណរដែលនៅចំពោះទ្រង់* សំដៅលើសិរីល្អដែលទ្រង់មាននៅខាងស្ដាំព្រះវរបិតា (មើលការពន្យល់ ១:២-៣ អស ៥៣:១០-១២)។ *ទ្រង់បានរងទ្រាំនៅឈើឆ្កាង* "មើលពន្យល់ ភល ២:៨"។ *ទាំងមើលងាយចំពោះសេចក្ដីអាមាស់ខ្មាសនោះ* គឺដូចជាព្រះគ្រីស្ទដែរ ការឈឺចាប់ និងទុក្ខវេទនារបស់

ទ្រង់ក៏គង់ខាងស្ដាំបល្ល័ង្កនៃព្រះ[ទ] 3ដូច្នេះ ចូរពិចារណា
មើលទ្រង់ ដែលទ្រង់បានទ្រាំទ្រនឹងពួកមនុស្សមានបាប
ដែលធ្វើទទឹងទទែងនឹងទ្រង់ជាខ្លាំងម្ល៉េះ ក្រែងលោអ្នក
រាល់គ្នាត្រូវនឿយហត់[ធ] ហើយរសាយចិត្តចេញ 4ដ្បិតអ្នក
រាល់គ្នាមិនទាន់តយុទ្ធនឹងអំពើបាប ដល់ទៅហូរឈាមនៅ
ឡើយទេ[ន] 5តែអ្នករាល់គ្នាបានភ្លេចសេចក្ដីដំបូន្មានអស់
រលីងទៅ ដែលទ្រង់បានទូន្មានដល់អ្នករាល់គ្នា ទុកដូចជា
កូនថា «កូនអើយ កុំឱ្យមើលងាយសេចក្ដីផ្ចាញ់ផ្ចាលរបស់
ព្រះអម្ចាស់ឡើយ ក៏កុំឱ្យរសាយចិត្ត[ប]ក្នុងកាលដែលទ្រង់
បន្ទោសឯងដែរ 6ដ្បិតព្រះអម្ចាស់ទ្រង់ផ្ចាញ់ផ្ចាលចំពោះ
អស់អ្នកណាដែលទ្រង់ស្រឡាញ់[ផ] ហើយទ្រង់វាយប្រដៅ
ដល់អស់ទាំងកូនដែលទ្រង់ទទួល»[ព] 7បើសិនជាអ្នក
រាល់គ្នាត្រូវសេចក្ដីផ្ចាញ់ផ្ចាល នោះគឺព្រះអង្គទ្រង់ប្រ
ព្រឹត្តនឹងអ្នករាល់គ្នា ដូចជាកូនហើយ[ភ] ដ្បិតតើមានកូន
ឯណាដែលឪពុកមិនវាយផ្ចាលនោះ 8តែបើសិនជាអ្នក
រាល់គ្នាមិនដែលត្រូវផ្ចាញ់ផ្ចាលសោះ ជាសេចក្ដីដែល
គ្រប់គ្នាត្រូវរងទ្រាំ[ម] នោះអ្នករាល់គ្នាជាកូនឥតខាន់ស្លាទេ
មិនមែនជាកូនពិតប្រាកដឡើយ 9មួយទៀតយើងរាល់គ្នា
មានឪពុកខាងសាច់ឈាមដែលវាយផ្ចាលយើង ហើយយើង
ក៏កោតខ្លាចដល់គាត់ដែរ ដូច្នេះ តើមិនត្រូវឱ្យយើងចុះ
ចូល ចំពោះព្រះវរបិតាខាងវិញ្ញាណ[យ]ជាជាងទៅទៀត
ដើម្បីឱ្យបានរស់នៅទេឬអី[រ] 10ដ្បិតឪពុកយើងតែវាយ
ប្រដៅយើង តាមតែខណៈចិត្តរបស់គាត់ប៉ុណ្ណោះ តែមិនមែន
ជាយូរឆ្នាំទេ ចំណែកព្រះដែលទ្រង់វាយផ្ចាល នោះសំរាប់
ជាប្រយោជន៍ដល់យើងវិញ ដើម្បីឱ្យយើងបានសេចក្ដីបរិសុទ្ធ
របស់ទ្រង់[ល] 11កាលណាយើងត្រូវសេចក្ដីផ្ចាញ់ផ្ចាល នោះ
មើលទៅដូចជាព្រួយណាស់ មិនមែនសប្បាយទេ តែក្រោយ
មក នោះទើបបង្កើតផលដ៏សុខសាន្ត[វ] នៃសេចក្ដីសុចរិត ដល់
អស់អ្នកណាដែលត្រូវរងទ្រាំនោះវិញ ។
12ដូច្នេះ ចូរលើកដៃដែលស្រពន់ឡើង និងជង្គង់ដែល
ស្កុតដែរ[ស] 13ហើយធ្វើផ្លូវឱ្យត្រង់ សំរាប់ជើងអ្នករាល់គ្នា[ហ]
ក្រែងអ្នកណាដែលខ្ចើចត្រូវបង្វែរចេញទៅ ស៊ូឱ្យបានជា
ឡើងវិញ[ឡ]។

## ការព្រមានចំពោះការបដិសេធន៍ព្រះ

14ចូរដេញតាមសេចក្ដីមេត្រី ចំពោះមនុស្សទាំងអស់ចុះ[អ]
ហើយឱ្យបានញែកជាបរិសុទ្ធដែរ[ក] បើអ្នកណាគ្មានសេចក្ដី
បរិសុទ្ធ នោះមិនដែលឃើញព្រះអម្ចាស់ឡើយ[ខ] 15ហើយត្រូវ
ប្រយ័ត្នឱ្យមែនទែន ក្រែងមានអ្នកណាខ្វះខាងឯព្រះគុណនៃ
ព្រះ[គ] ហើយមានឫសជូរចត់ណា[ឃ]ពន្លកឡើង នាំឱ្យទំនាស់ចិត្ត
រួចមានមនុស្សជាច្រើនបានស្មោកគ្រោក ដោយសារសេចក្ដី
នោះ 16ក្រែងមានអ្នកកំផិត[ង] ឬមនុស្សទមិលណា ដូចជា
អេសាវ ដែលលក់ច្បាប់បងច្បងរបស់ខ្លួន សង្វាតឱ្យបានតែ
ម្ហូប១មុខប៉ុណ្ណោះដែរ[ច] 17ដ្បិតអ្នករាល់គ្នាដឹងថា ក្រោយមក

**១២:២** ទ មក ១៦:១៩
**១២:៣** ធ កទ ៦:៩ វវ ២:៣
**១២:៤** ន ហព ១០:៣២–៣៤ ១៣:១៣
**១២:៥** ប ខ.៣
**១២:៦** ផ ទដ ៩៤:១២ ១១៩:៧៥ វវ ៣:១៩ ព សភ ៣:១១,១២
**១២:៧** ភ ចទ ៨:៥ ២សយ ៧:១៤ សភ ១៣:២៤
**១២:៨** ម ១ពត ៥:៩
**១២:៩** យ ជន ១៦:២២ ២៧:១៦ វវ ២២:៦ រ អស ៣៨:១៦
**១២:១០** ល ២ពត ១:៤
**១២:១១** វ អស ៣២:១៧ យក ៣:១៧,១៨
**១២:១២** ស អស ៣៥:៣
**១២:១៣** ហ សភ ៤:២៦ ឡ កទ ៦:១
**១២:១៤** អ រម ១៤:១៩ ក រម ៦:២២ ខ មថ ៥:៨ **១២:១៥** គ កទ ៥:៤ ហព ៣:១២ ៤:១ ឃ ចទ ២៩:១៨ **១២:១៦** ង ១កថ ៦:១៨ ច លប ២៥:២៩–៣៤

គ្រីស្ទបរិស័ទដោយព្រោះដំណឹងល្អ នឹងនាំមកនូវរង្វាន់ នៃសិរីរុងរឿងដ៏គ្រប់លក្ខណ៍ (មថ ៥:១០–១២ រម ៨:១៨ ២កថ ៤:១៧ ១ពត ៤:១៣ ៥:១,១០)។

**១២:៣** *ចូរពិចារណាមើលទ្រង់* ព្រះគ្រីស្ទបានទទួលនូវការឈឺចាប់ខ្លាំងបំផុតលើសពួកសិស្សរបស់ទ្រង់ទៅទៀត ដូច្នេះ នៅពេលយើងជួបនូវការបៀតបៀន និងទុក្ខវេទនាផ្សេងៗ ចូរកុំឱ្យមានការបារម្ភ និងបាក់ទឹកចិត្តឡើយ ។ *នឿយហត់* "សូមមើល កទ ៦:៩ វវ ២:៣ អស ៤០:២៨–៣១"។

**១២:៤–១៣** ក្នុងវគ្គនេះនិយាយផ្ដោតទៅលើការលើកទឹកចិត្តក្នុងពេលដែលមានការលំបាក ដូចមានពណ៌នានៅក្នុងបទគម្ពីរ "ទដ ៣:១១–១២"។

**១២:៥** *សេចក្ដីផ្ចាញ់ផ្ចាលរបស់ព្រះអម្ចាស់* ការឈឺចាប់ និងការបៀតបៀនគួរតែជាការកែតម្រូវ និងការហ្វឹកហ្វឺនទូន្មាន សម្រាប់ឱ្យលូតលាស់ខាងឯវិញ្ញាណ ក្នុងនាមយើងជាកូនរបស់ព្រះ ។

**១២:៦** *ផ្ចាញ់ផ្ចាល* ពាក្យនេះនៅក្នុងភាសាក្រិកមានន័យថា "វាយ"។ ព្រះអម្ចាស់ព្រមានយើង គឺដើម្បីកែតម្រូវកំហុសរបស់យើង ។

**១២:៧** *ទ្រង់ប្រព្រឹត្តនឹងអ្នករាល់គ្នាដូចជាកូនហើយ* ការព្រមានរបស់ព្រះអម្ចាស់ គឺជាភស្តុតាងបញ្ជាក់ថា យើងជាកូនរបស់ទ្រង់ ។ ផ្ទុយអំពីការអស់សង្ឃឹម ការព្រមានរបស់ព្រះគឺជាមូលដ្ឋាននៃការលើកទឹកចិត្ត និងការទ្រាំទ្រ (ខ.១០)។

**១២:១១** *នោះទើបបង្កើតផលដ៏សុខសាន្ត* នៅពេលទទួលការស្ដាប់បង្គាប់ (ខ.៩) ការព្រមាន នោះគឺជាសេចក្ដីល្អ និងផលកម្រៃ ។

**១២:១២** សូមមើល អស ៣៥:៣ ។

**១២:១៣** *ធ្វើផ្លូវឱ្យត្រង់* ការត្រាស់ហៅសម្រាប់ការប្រព្រឹត្តសុចរិតដែលជួយជាជាងការរារាំងបង្អាក់ គឺជាជំនួយខាងសីលធ៌ម និងវិញ្ញាណដល់អ្នកដទៃជា ពិសេសគឺពួកអ្នកដែលខ្សោយ និងវេរាខាងឯសេចក្ដីជំនឿ ។

**១២:១៤–១៧** ក្នុងវគ្គនេះពិពណ៌នាអំពីការរស់នៅក្នុងភាពបរិសុទ្ធ (៤:១ ៦:៤–៨ កទ ៥:៤ និងការពន្យល់)។

**១២:១៤** *គ្មានសេចក្ដីបរិសុទ្ធ នោះមិនដែលឃើញព្រះអម្ចាស់ឡើយ* "សូមប្រៀបធៀបនឹង ១ពត ១:១៥–១៦ ១កថ ១:២ ១យហ ៣:២–៣ និងការពន្យល់"។

**១២:១៥** *ខ្វះខាងឯព្រះគុណនៃព្រះ* "ខ្វះមិនដល់ព្រះគុណ" "បរាជ័យក្នុងការចាប់យកព្រះគុណ" (៦:៤–៨ និងការពន្យល់)។ *ឫសជូរចត់* សំដៅលើអំនួត សម្ពប់ ការប្រជែង និងការដែលធ្វើឱ្យមានទុក្ខទោសដល់អ្នកដទៃ ។

**១២:១៦** *មនុស្សទមិលណា ដូចជាអេសាវ* "សូមមើល លប ២៥:២៩–៣៤"។ អេសាវមិនមានការអបអរចំពោះតម្លៃពិតប្រាកដទេ (ភល ៣:១៩)។ គាត់បង្អាប់តម្លៃសិទ្ធិជាកូនច្បងរបស់គាត់ (លប ២៥:៣៤) អន់ជាងតម្លៃអាហារមួយចម្អែតទៅទៀត ។

**១២:១៧** *គាត់ត្រូវចោលចេញវិញ* ពីព្រោះអេសាវគ្រាន់តែសោកស្ដាយ

គាត់សង្វាតចង់បានពរ តែគាត់ត្រូវចោលចេញវិញ ដ្បិតទោះ
បើគាត់ខំស្វែងរកទាំងស្រក់ទឹកភ្នែកក៏ដោយ គង់តែរកផ្លូវ
ប្រែចិត្តមិនឃើញទេ[ឆ]។
១៨ អ្នករាល់គ្នាមិនមែនមកដល់ភ្នំ ដែលនឹងពាល់បាន
ហើយដែលមានភ្លើងឆេះនោះទេ ឬដល់សេចក្ដីងងឹត ឬ
ស្រអាប់ ឬខ្យល់ព្យុះ[ជ] ១៩ ឬសូរផ្លុំត្រែ[ឈ] ឬព្រះសៀងនៃព្រះ
ដែលមានបន្ទូលមក[ញ] ជាសូរសៀង ដែលពួកអ្នកឮ ក៏អង្វរ
កុំឱ្យព្រះបន្ទូលបានមកដល់ខ្លួនទៀតឡើយ[ដ] ២០ ដ្បិតគេទ្រាំនឹង
សេចក្ដីដែលបង្គាប់មកមិនបាន គឺជាសេចក្ដីថា «សូម្បីសត្វ
ណាដែលពាល់ភ្នំ នោះនឹងត្រូវចោលនឹងថ្ម ឬបាញ់ទំលុះ
ដោយព្រួញ»[ឋ] ២១ ហើយការដែលគេឃើញនោះ ក៏គួរស្ញែង
ខ្លាចណាស់ ដល់ម្ល៉េះបានជាម៉ូសេ លោកមានប្រសាសន៍ថា
«ខ្ញុំភ័យញ័រជាខ្លាំង»[ឌ] ២២ គឺអ្នករាល់គ្នាបានមកដល់ភ្នំស៊ី
យ៉ូនវិញ[ឍ] ជាទីក្រុង[ណ]នៃព្រះដ៏មានព្រះជន្មរស់[ត] គឺក្រុងយេ
រូសាឡិម[ថ]នៃស្ថានសួគ៌ ហើយដល់ពួកទេវតាទាំងសល់សែន

**១២:១៧** ឆ លប ២៧:៣០–៤០
**១២:១៨** ជ នក ១៩:១២–២២ ២០:១៨ ចទ ៤:១១
**១២:១៩** ឈ នក ២០:១៨ ញ ចទ ៤:១២ ដ នក ២០:១៩ ចទ ៥:៥,២៥ ១៨:១៦
**១២:២០** ឋ នក ១៩:១២,១៣
**១២:២១** ឌ ចទ ៩:១៩
**១២:២២** ឍ អស ២៤:២៣ ៦០:១៤ វវ ១៤:១ ណ ហព ១១:១០ ១៣:១៤

២៣ ដល់ទីប្រជុំរបស់មនុស្សទាំងឡាយ[ទ] នឹងជំនុំពួកកូន
ច្បងដែលកត់ទុកនៅស្ថានសួគ៌[ធ] ដល់ព្រះដ៏ជាចៅក្រមនៃ
មនុស្សទាំងអស់[ន] ដល់អស់ទាំងវិញ្ញាណនៃពួកសុចរិត
ដែលបានគ្រប់លក្ខណ៍ហើយ[ប] ២៤ ដល់ព្រះយេស៊ូវ ដែល
ជាអ្នកកណ្ដាល[ផ]នៃសេចក្ដីសញ្ញាថ្មី ហើយដល់ព្រះលោហិត[ព]
ដែលសំរាប់នឹងប្រោះ ជាព្រះលោហិតដែលសំដែងពី
សេចក្ដីប្រសើរ ជាជាងឈាមរបស់អេបិលទៅទៀតផង[ភ]។
២៥ ចូរប្រយ័ត្ន កុំឱ្យប្រកែកមិនព្រមស្ដាប់តាម[ម]ព្រះអង្គ
ដែលទ្រង់មានបន្ទូលឡើយ[យ] ដ្បិតបើសិនជាអ្នកទាំងនោះ
ដែលមិនព្រមស្ដាប់តាមលោកម៉ូសេ ក្នុងកាលដែលលោក
សំដែងព្រះបន្ទូល[រ] ឱ្យស្ដាប់នៅផែនដី គេមិនបានរួចទោស

ត មថ ១៦:១៦ ថ កទ ៤:២៦ **១២:២៣** ទ នក ៤:២២ ធ វវ ២០:១២ ន លប ១៨:២៥ ទដ ៩៤:២ ប ភល ៣:១២ **១២:២៤** ផ កទ ៣:២០ ប ហព ៩:១៩ ១០:២២ ១ពត ១:២ ភ លប ៤:១០ ហព ១១:៤ **១២:២៥** ម ហព ៣:១២ យ ហព ១:១ រ ហព ៨:៥ ១១:៧

ចំពោះការបរាជ័យរបស់ខ្លួនប៉ុណ្ណោះ និងមិនបានប្រែចិត្តចេញពីអំពើបាបរបស់ខ្លួនទេ (លប ២៧)។ ទុក្ខព្រួយរបស់គាត់មិនមែនជាទុក្ខព្រួយនៃសេចក្ដីសុចរិត ដែលនាំមកនូវការប្រែចិត្ត និងនាំទៅរកសេចក្ដីសង្គ្រោះនោះទេ ប៉ុន្ដែ ជាសេចក្ដីទុក្ខព្រួយ របស់លោកិយដែលនាំទៅរកសេចក្ដីស្លាប់វិញ (២កថ ៧:១០)។ *គង់តែរកផ្លូវ ប្រែចិត្តមិនឃើញទេ* គឺមិនអាចកែប្រែនូវអ្វីដែលខ្លួនបានធ្វើហើយ (៦:៤–៦ និង ការពន្យល់)។ *គាត់ចង់បានពរ* គឺគាត់ចង់បានសិទ្ធិជាកូនច្បង ។ ពួកអ្នកទទួលសំបុត្រហេព្រើរអាចគិតចុះចូលសេចក្ដីជំនឿរបស់ខ្លួន ដើម្បីឱ្យបានរួចផុងពីការបៀតបៀន ។ ការឈប់សម្រាករបស់ពួកគេក្នុងរយៈពេលខ្លីនៅលើផែនដីនេះ អាចប៉ះពាល់ដល់ការទទួលព្រះពរពីព្រះអម្ចាស់ ។ *ទាំងស្រក់ទឹកភ្នែក* មិនមែនសំដៅលើទឹកភ្នែកនៃការប្រែចិត្តនោះទេ (លប ២៧:៣៤–៣៨)។

**១២:១៨–២៩** ក្នុងវគ្គនេះផ្ដោតទៅលើការជំរុញទឹកចិត្ត និងការព្រមាន (២:១–៤ និងការពន្យល់ រួមនឹងការពណ៌នានៅក្នុង នក ១៩:១០–២៥ ចទ ៤:១១–១២ ៥:២២–២៦)។

**១២:២២** *ភ្នំស៊ីយ៉ូន* មិនមែនសំដៅលើភ្នំស៊ីយ៉ូននៅលើផែនដីនេះទេ ប៉ុន្ដែសំដៅលើទីក្រុងនៃព្រះអម្ចាស់នៅឯស្ថានសួគ៌ និងពួកអ្នកដែលនៅជាមួយទ្រង់ (១១:១០, ១៣–១៦ ១៣:១៤ ភល ៣:២០)។ ស្ថានភាពនៃការប្រទាននូវសេចក្ដីសញ្ញាចាស់(ខ.១៨–២១) និងលក្ខណៈនៃសេចក្ដីសញ្ញាថ្មី (ខ.២២–២៤) បានបង្ហាញនូវភាព ខុសគ្នាទាំងស្រុងរវាងសេចក្ដីទាំងពីរនេះ ហើយបានបង្កើតនូវគ្រឹះមួយសម្រាប់ព្រមាន និងទូន្មានដាស់តឿនចំពោះពួកអ្នកដែលនៅតែគិតចង់បែរទៅរកលទ្ធិនៃសាសនាយូដាវិញ ។ *ពួកទេវតាទាំងសល់សែន* "សូមមើល វវ ៥:១១–១២"។

**១២:២៣** *ជំនុំពួកកូនច្បង* សំដៅលើអ្នកជឿដល់ព្រះអម្ចាស់ដែលជាពួកជំនុំទ្រង់ ។ អត្ថន័យនៃឃ្លានេះ (១).មិនសំដៅលើពួកទេវតាទេ ព្រោះទើបតែបានលើកឡើងក្នុងបទគម្ពីរខាងលើ(ខ.២២)។ (២).ពាក្យថា"កូនច្បង"ត្រង់ចំណុចនេះមិនសំដៅលើព្រះគ្រីស្ទទេ (ទោះបីព្រះគ្រីស្ទត្រូវបានហៅថាជាកូនច្បងក៏ដោយ ១:៦ រម ៨:២៩ កល ១:១៥–១៨ វវ ១:៥) ព្រោះពាក្យនេះជាភាសាក្រិកសរសេរជាពហុវចនៈ ។ (៣).ឈ្មោះនៃពួកកូនច្បងត្រូវបានកត់ទុកនៅស្ថានសួគ៌រំឭកយើងឱ្យដឹង ពីពួកអ្នកដែលបានទទួលនូវការប្រោសលោះ (វវ ៣:៥ ១៣:៨ ១៧:៨ ២០:១២ ២១:២៧)។ ការបង្ហាញនូវពួកអ្នកដែលបានទទួលការប្រោសលោះថាជា "ពួកកូនច្បង" គឺសំដែងនូវឋានៈជាឯកសិទ្ធិ និងជាអ្នកទទួលមរតកជាមួយនឹងព្រះគ្រីស្ទ ដែលទ្រង់ជាកូនច្បង និងទទួលនូវមរតកទាំងអស់ (ហព ១:២)។ *ព្រះដ៏ជាចៅក្រមនៃមនុស្សទាំងអស់* "សូមមើល ៤:១៣ រម ១៤:១០–១២ ១កថ ៣:១០–១៥ ២កថ ៥:១០ វវ ២០:១១–១៥"។ *អស់ទាំងវិញ្ញាណនៃពួកសុចរិត ដែលបានគ្រប់លក្ខណ៍ហើយ* ដូចជាលោកអេបិល(១១:៤)និងលោកណូអេជាដើម(១១:៧)។ ពួកគេត្រូវបានរាប់ជាសុចរិតដោយសារសេចក្ដីជំនឿ គឺដូចជាលោកអ័ប្រាហាំដែរ (លប ១៥:៦ រម ៤:៣ និងការពន្យល់)។ ទោះជាយ៉ាងណា ក៏ការរាប់ជាសុចរិតមិនទាន់បានគ្រប់លក្ខណ៍នៅឡើយទេ ដរាបដល់ព្រះគ្រីស្ទយាងមកសុគតនៅលើឈើឆ្កាងហើយរស់ឡើងវិញ (១១:៤០ រម ៣:២៤-២៦ និងការពន្យល់ ៤:២៣-២៥)។

**១២:២៤** *ជាអ្នកកណ្ដាលនៃសេចក្ដីសញ្ញាថ្មី* "សូមមើល ៨:៦ និងការពន្យល់"។ *សេចក្ដីប្រសើរ ជាជាងឈាមរបស់អេបិលទៅទៀត* ឈាមរបស់អេបិលស្រែករកសេចក្ដីយុត្តិធម៌ និងការដាក់ទោស (លប ៤:១០ និងការពន្យល់) រីឯព្រះលោហិតរបស់ព្រះគ្រីស្ទវិញ គឺបានបង្ហូរនៅលើឈើឆ្កាងដើម្បីអត់ទោសបាប និងការផ្សះផ្សា (៩:១២ ១០:១៩ កល ១:២០ ១យហ ១:៧ និងការពន្យល់)។

**១២:២៥–២៦** វគ្គនេះជាការព្រមានលើកទីប្រាំ (មើលពន្យល់ ២:១–៤)។

**១២:២៥** *ព្រះអង្គដែលទ្រង់មានបន្ទូល* សំដៅលើព្រះអម្ចាស់ ។ *សំដែងព្រះបន្ទូលឱ្យស្ដាប់នៅផែនដី* គឺនៅភ្នំស៊ីណាយ ។ *មានបន្ទូលពីស្ថានសួគ៌មក* សំដៅលើព្រះគ្រីស្ទដែលយាងមកពីស្ថានសួគ៌ និងគង់នៅស្ថានសួគ៌ (១:១–៣ ៤:១៤ ៦:២០ ៧:២៦ ៩:២៤)។ ដោយព្រោះយើងទទួលបានការបើកសំដែងច្រើនមកពីព្រះអម្ចាស់ ដូច្នេះ យើងមានទំនួលខុសត្រូវច្រើន (២:២–៣ និងការពន្យល់)។

ទៅហើយ នោះចំណង់បើយើងរាល់គ្នា ដែលងាកបែរចេញ
ពីព្រះ ដែលមានបន្ទូលពីស្ថានសួគ៌មក តើតឹងជាងយ៉ាងណា
ទៅ[ល] ២៦សំឡេងទ្រង់បានធ្វើឱ្យផែនដីកក្រើករញ្ជួយ[វ]នៅ
វេលានោះ តែឥឡូវនេះ ទ្រង់សន្យាថា «អញនឹងធ្វើឱ្យកក្រើក
ម្តងទៀត មិនត្រឹមតែផែនដីប៉ុណ្ណោះ គឺទាំងផ្ទៃមេឃថែម
ទៀតផង»[ស] ២៧រីឯពាក្យដែលថា «ម្តងទៀត» នោះសំដែងថា
របស់ដែលត្រូវកក្រើក នោះត្រូវរើចេញ[ហ] ទុកដូចជារបស់
ដែលបានធ្វើហើយ ដើម្បីឱ្យរបស់ដែលមិនបានកក្រើកទាំង
ប៉ុន្មាន បានធន់នៅវិញ ២៨ដូច្នេះ ដែលទទួលនគរ១ដ៏កក្រើក
រញ្ជួយពុំបាន[ឡ] នោះត្រូវឱ្យយើងដឹងគុណ ដែលដោយសារ
សេចក្តីនោះ យើងនឹងបំរើព្រះបែបឱ្យទ្រង់សព្វព្រះហឫទ័យ
ទាំងមានចិត្តគោរពប្រតិបត្តិ ហើយកោតខ្លាចដល់ទ្រង់[អ]
២៩ដ្បិតព្រះនៃយើងរាល់ គ្នាទ្រង់ជាភ្លើងដែលឆេះបន្សុស[ក]។

## ពាក្យលើកទឹកចិត្តចុងក្រោយ

**១៣** ១ចូរឱ្យមានសេចក្តីស្រឡាញ់គ្នា ជាបងប្អូនជានិច្ច[ខ]
២កុំឱ្យភ្លេចសេចក្តីចៅរ៉ៅឡើយ[គ] ដ្បិតមនុស្សខ្លះបានទទួល
ទាំងទេវតា ឱ្យសំណាក់នៅឥតដឹងផង ដោយមានសេចក្តីនោះ
ឯង[ឃ] ៣ចូរនឹកចាំពីពួកអ្នកជាប់គុក[ង] ទុកដូចជាជាប់ចំណងជា
មួយគ្នា ហើយពីពួកអ្នកដែលត្រូវគេធ្វើបាបផង ដ្បិតអ្នករាល់
គ្នាក៏នៅក្នុងរូបកាយដែរ ។

**១២:២៥** ល ចទ ១៨:១៩ ហាព ២:២,៣ ១០:២៩
**១២:២៦** វ នក ១៩:១៨ ស ហាក ២:៦
**១២:២៧** ហ អស ៣៤:៤ ៥៤:១០ ១កថ ៧:១៣ ហាព ១:១១,១២ ២ពត ៣:១០ ១យហ ២:១៧
**១២:២៨** ឡ ទដ ១៥:៥ ដយ ២:៤៤ អ មឡ ២:៥ ៤:២ ហាព ១៣:១៥
**១២:២៩** ក នក ២៤:១៧ ចទ ៤:២៤ ៩:៣ ទដ ៩៧:៣ អស ៣៣:១៤ ២ថន ១:៧
**១៣:១** ខ រម ១២:១០
**១៣:២** គ យប ៣១:៣២ មថ ២៥:៣៥ រម ១២:១៣ ឃ លប ១៨:១–៣៣ ១៩:១–៣

៤ការវិវាហមង្គលជាការប្រសើរដល់គ្រប់គ្នា[ច] ហើយ
ដែលរួមដំណេក នោះក៏ជាការឥតសៅហ្មងដែរ តែព្រះទ្រង់
នឹងជំនុំជំរះមនុស្សកំផិត ហើយនិងមនុស្សសហាយស្មន់គ្នា
វិញ[ឆ]។
៥ចូរឱ្យកិរិយាដែលអ្នករាល់គ្នាប្រព្រឹត្ត បានឥតលោភ ឡើយ[ជ]
ឱ្យស្កប់ចិត្តនឹងរបស់ដែលមានហើយប៉ុណ្ណោះចុះ[ឈ] ដ្បិតទ្រង់
មានបន្ទូលថា «អញនឹងមិនចាកចេញពីឯង ក៏មិនបោះបង់
ចោលឯងឡើយ»[ញ] ៦បានជាយើងរាល់គ្នាអាចនឹងនិយាយ
ដោយក្លាហានថា «ខ្ញុំមិនព្រមខ្លាចឡើយ ព្រោះព្រះអម្ចាស់
ទ្រង់ជាជំនួយខ្ញុំ តើមនុស្សនឹងធ្វើដល់ខ្ញុំជាយ៉ាងណាបាន»[ដ]។
៧ចូរនឹកចាំពីពួកអ្នកនាំមុខ[ឋ] ដែលបានផ្សាយព្រះបន្ទូល[ឌ]
មកអ្នករាល់គ្នា ត្រូវតែត្រាប់តាម[ឍ]សេចក្តីជំនឿរបស់អ្នកទាំង
នោះ ទាំងពិចារណាមើលចុងបំផុតនៃកិរិយាគេផង ៨ដ្បិត
ព្រះយេស៊ូវគ្រីស្ទទ្រង់នៅតែដដែល គឺពីថ្ងៃម្សិល ថ្ងៃនេះ
ហើយទៅដល់អស់កល្បជានិច្ចតទៅ[ណ]។

**១៣:៣** ង មថ ២៥:៣៦ កល ៤:១៨ ហាព ១០:៣៤ **១៣:៤** ច មឡ ២:១៥ ១កថ ៧:៣៨ ១ធថ ៤:៣ ឆ ចទ ២២:២២ ១កថ ៦:៩ វវ ២២:១៥ **១៣:៥** ជ ១ធថ ៣:៣ ឈ ភល ៤:១១ ១ធថ ៦:៦,៨ ញ ចទ ៣១:៦,៨ យស ១:៥ **១៣:៦** ដ ទដ ១១៨:៦,៧ **១៣:៧** ឋ ខ.១៧,២៤ ១កថ ១៦:១៦ ឌ ហាព ៤:១២ ឍ ហាព ៦:១២ **១៣:៨** ណ ទដ ១០២:២៧ ហាព ១:១២

**១២:២៦** *ផែនដីកក្រើករញ្ជួយ* "មើល នក ១៩:១៨ ពច ៥:៤–៥ ទដ ៦៨:៧-៨"។

**១២:២៧** *ម្តងទៀត* ត្រង់ចំណុចនេះបញ្ជាក់ថា ទុក្ខវេទនានៅក្នុងអំឡុងពេលចុងបញ្ចប់នៃពិភពលោកមានជាប់ទាក់ទងទៅនឹងការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ (មថ ២៤:២៩ មក ១៣:២៤–២៥ លក ២១:១១ កថ ២:២០ និងការពន្យល់)។ *របស់ដែលមិនបានកក្រើកទាំងប៉ុន្មាន* សំដៅលើនគរមួយដែលលើកឡើងនៅក្នុងខ.២៨ ។

**១២:២៨** *បំរើព្រះបែបឱ្យទ្រង់សព្វព្រះហឫទ័យ* "យហ ៤:១៩-២៤ រម ១២:១"។

**១២:២៩** សូមមើល ១០:២៧ នក ២៤:១៧ ចទ ៩:៣ ។

**១៣:២** *កុំឱ្យភ្លេចសេចក្តីចៅរ៉ៅឡើយ* "សូមមើល មថ ២៥:៣៥"។ *មនុស្សខ្លះបានទទួលទាំងទេវតាឱ្យសំណាក់នៅឥតដឹងផង* គឺដូចជាលោកអ័ប្រាហាំ (លប ១៨) លោកគេឌាន (ពច ៦) និង ម៉ាណូអា (ពច ១៣)។

**១៣:៣** *ពួកអ្នកជាប់គុក . . . ពួកអ្នកដែលត្រូវគេធ្វើបាបផង* ពិសេសគឺពួកអ្នកជឿរួមទាំងមនុស្សទាំងអស់ផងដែរ (១០:៣២–៣៤ មថ ២៥:៣៦ ១កថ ១២:២៦)។

**១៣:៤** "មើលការពន្យល់ នក ២០:១៤"។ *ការវិវាហមង្គលជាការប្រសើរដល់គ្រប់គ្នា* "សូមមើល ១កថ ៦:១៣–១៨ ៧:១–១៥ អភ ៥:២៦–៣១ ១ធថ ៤:៣"។ *មនុស្សកំផិត . . . មនុស្សសហាយស្មន់គ្នាវិញ* "សូមមើល ១កថ ៦:៩"។

**១៣:៥** *ឥតលោភឡើយ* "សូមមើល លក ១២:១៥,២១ ភល ៤:១០–១៣ ១ធថ ៦:៦–១០, ១៧–១៩"។ *ឱ្យស្កប់ចិត្ត* "សូមមើល ភល ៤:១១–១២ ១ធថ ៦:៨"។

**១៣:៧–១៧** ក្នុងវគ្គនេះជួយរំឭកឱ្យចងចាំនូវពួកអ្នកដឹកនាំពីអតីតកាល និងមើលពីគំរូនៃសេចក្តីជំនឿរបស់ពួកគេ ហើយទូន្មានឱ្យស្តាប់បង្គាប់ និងចុះចូលដល់ពួកអ្នកដឹកនាំបច្ចុប្បន្ន ។

**១៣:៧** *ពួកអ្នកនាំមុខ ដែលបានផ្សាយព្រះបន្ទូលមកអ្នករាល់គ្នា* សូមមើល ២:៣ ៥:១២ ។ *ត្រាប់តាមសេចក្តីជំនឿរបស់អ្នកទាំងនោះ* "សូមមើល ៦:១២ អភ ៥:១ ១ថន ១:៦ ១កថ ៤:១៦ និងការពន្យល់"។ *ទាំងពិចារណាមើលចុងបំផុតនៃកិរិយាគេផង* គឺពិចារណាមើលពីរបៀបរក្សានូវសេចក្តីជំនឿ និងការចូលនៅក្នុងមរដកដែលព្រះបានសន្យា (៦:១២)។

**១៣:៨** *ព្រះយេស៊ូវគ្រីស្ទទ្រង់នៅតែដដែល* នេះជាការប្រកាសអំពីភាពមិនប្រែប្រួលរបស់ព្រះគ្រីស្ទ ដែលទាក់ទងនឹងបទគម្ពីរខាងលើ ។ សាច់រឿងនៅក្នុងបទគម្ពីរខាងលើ អំពីសេចក្តីជំនឿរបស់ពួកអ្នកដឹកនាំទាំងនោះ គឺពួកគេមានជំនឿថា ព្រះគ្រីស្ទទ្រង់មិនប្រែប្រួលឡើយ ។ *ថ្ងៃម្សិល* ត្រង់ចំណុចនេះប្រហែលសំដៅលើពេលព្រះគ្រីស្ទយាងមកសុគត និងរស់ឡើងវិញហើយមានស្មរបន្ទាល់ ជាច្រើនបានឃើញទ្រង់ (២:៣)។ *ថ្ងៃនេះ* បញ្ជាក់ថាព្រះគ្រីស្ទដែលមានពួកស្មរបន្ទាល់ជាច្រើនបានឃើញ ហើយទ្រង់គង់នៅដដែល មិនប្រែប្រួល និងពិតជានិច្ច ។ *អស់កល្បជានិច្ចតទៅ* ជាសេចក្តីពិតរហូត ។ ការមិនយកចិត្តទុកដាក់ លើភាពជាព្រះដ៏ពិតរបស់ព្រះគ្រីស្ទ ហើយបែរទៅគោរពប្រតិបត្តិតាមភាពជាសង្ឃរបស់លោលអ័រ៉ុន និងយញ្ញបូជា

[៩]ដូច្នេះ កុំឱ្យបណ្តែតបណ្តោយតាមសេចក្តីបង្រៀនប្លែកៗ
ឡើយ[ត] ដ្បិតគួរឱ្យចិត្តបានតាំងនៅខ្ជាប់ខ្ជួន[ថ] ដោយព្រះគុណ
មិនមែនដោយចំណីអាហារទេ[ទ] ដែលពួកអ្នកប្រព្រឹត្តតាម
សេចក្តីទាំងនោះ មិនបានប្រយោជន៍អ្វីពីនោះមកឡើយ[ធ]
[១០]យើងរាល់គ្នាមានអាសនា១ ដែលពួកអ្នកបំរើក្នុងរោង
ឧបោសថ[ន] គេគ្មានច្បាប់នឹងចូលមកបរិភោគពីអាសនានោះ
ទេ[ប] [១១]ដ្បិតឯសត្វទាំងប៉ុន្មាន ដែលសំដេចសង្ឃនាំយក
ឈាមចូលទៅក្នុងទីបរិសុទ្ធ ដោយព្រោះបាប[ផ] នោះត្រូវដុត
នៅខាងក្រៅទីដំឡើងត្រសាលវិញ[ព] [១២]ដូច្នេះព្រះយេស៊ូវ
ទ្រង់ក៏បានរងទុក្ខ នៅខាងក្រៅទ្វារក្រុងដែរ[ភ] ដើម្បីនឹង
ញែកប្រជាជនឱ្យបរិសុទ្ធ[ម] ដោយសារព្រះលោហិតនៃអង្គ
ទ្រង់[យ] [១៣]ហេតុនោះបានជាត្រូវឱ្យយើងរាល់គ្នាចេញទៅឯ
ទ្រង់[រ] នៅខាងក្រៅទីដំឡើងត្រសាលដែរ ទាំងផ្ទុកសេចក្តី
ដំនៀលរបស់ទ្រង់ ចុះ[ល] [១៤]ដ្បិតនៅស្ថាននេះ យើងរាល់គ្នា
គ្មានទីក្រុងណា ដែលស្ថិតនៅជាប់ជានិច្ចទេ[វ] តែយើង
កំពុងតែស្វែងរកក្រុងនោះ ដែលត្រូវមក[ស] [១៥]ដូច្នេះ ត្រូវឱ្យ
យើងរាល់គ្នាថ្វាយពាក្យសរសើរ ដោយសារទ្រង់ ទុកជា
គ្រឿងបូជាដល់ព្រះជានិច្ច[ហ] គឺជាផលនៃបបូរ មាត់[ឡ] ដែល
ថ្លែងប្រាប់ពីព្រះនាមទ្រង់ [១៦]កុំឱ្យភ្លេចនឹងធ្វើគុណ ហើយ
ចែកចាយឡើយ[អ] ដ្បិតព្រះទ្រង់សព្វព្រះហឫទ័យនឹងគ្រឿង
បូជាយ៉ាងនោះ[ក]។

[១៧]ចូរស្តាប់តាម ហើយចុះចូលនឹងពួកអ្នក ដែលនាំមុខ
អ្នករាល់គ្នាចុះ[ខ] ដើម្បីឱ្យអ្នកទាំងនោះបានថែរក្សាព្រលឹងអ្នក
រាល់គ្នាដោយអំណរ[គ] មិនមែនដោយស្រែកថ្ងូរទេ ដ្បិតបើ
ត្រូវស្រែកថ្ងូរ នោះបង់ប្រយោជន៍ដល់អ្នករាល់គ្នាហើយ
ពីព្រោះអ្នកទាំងនោះថែរក្សា ហាក់ដូចជានឹងត្រូវរាប់រៀប
ទូលដល់ទ្រង់វិញ ។

[១៨]សូមជួយអធិស្ឋានឱ្យយើងខ្ញុំផង[ឃ] ដ្បិតយើងខ្ញុំជឿជាក់
ថា យើងខ្ញុំមានបញ្ញាចិត្តជ្រះថ្លា[ង] ហើយក៏ប្រាថ្នាចង់ប្រព្រឹត្តល្អ
ក្នុងគ្រប់ការទាំងអស់ [១៩]ខ្ញុំក៏សូមជាលើសទៅទៀតថា ចូរឱ្យ
អ្នករាល់គ្នាអធិស្ឋាន សូមឱ្យខ្ញុំបានត្រឡប់មកឯអ្នករាល់គ្នា
វិញជាឆាប់ៗ[ច]។

[២០]សូមឱ្យព្រះនៃសេចក្តីសុខសាន្ត[ឆ] ដែលទ្រង់ប្រោស
ព្រះយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ឱ្យត្រឡប់ពីពួក

**១៣:៩** ត អភ ៤:១៤ ថ កល ២:៧ ទ កល ២:១៦ ធ ហាព ៩:១០ **១៣:១០** ន ហាព ៨:៥ ប ១កថ ៩:១៣ ១០:១៨ **១៣:១១** ផ លវ ១៦:១៥ ព នក ២៩:១៤ លវ ៤:១២,២១ ៩:១១ ១៦:២៧ **១៣:១២** ភ យហ ១៩:១៧ ម អភ ៥:២៦ យ រម ៣:២៥ **១៣:១៣** រ លក ៩:២៣ ល ហាព ១១:២៦ **១៣:១៤** វ ហាព ១២:២៧ ស ភល ៣:២០ ហាព ១១:១០, ២៧ ១២:២២ **១៣:១៥** ហ ១ពត ២:៥ ឡ អស ៥៧:១៩ ហស ១៤:២ **១៣:១៦** អ រម ១២:១៣ ក ភល ៤:១៨ **១៣:១៧** ខ ខ.៧,២៤ គ អស ៦២:៦ កថ ២០:២៨ **១៣:១៨** ឃ ១ថន ៥:២៥ ង កថ ២៣:១ **១៣:១៩** ច ភម ២២ **១៣:២០** ឆ រម ១៥:៣៣ លប ៩:១៦ ១៧:៧,១៣,១៩ អស ៥៥:៣ ១៦:៨ អគ ៣៧:២៦ ជ កថ ២:២៤ ឈ យហ ១០:១១

ទាំងនោះ (ជំពូក ៥–១០) គឺមានន័យថា បង្អាប់ដល់ដំណឹងល្អហើយ ។

**១៣:៩** *មិនមែនដោយចំណីអាហារទេ* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកអ្នកនិយមជ្រុលខាងក្រឹត្យវិន័យសាសន៍យូដាមានការបង្រៀនយ៉ាងដូច្នេះ ។ គ្រប់ក្រឹត្យវិន័យទាំងអស់ត្រូវបានសម្រេចនៅឈើឆ្កាង ហើយមិនអាចកែប្រែបានឡើយ ។

**១៣:១០** *យើងរាល់គ្នាមានអាសនា១* អាចសំដៅលើឈើឆ្កាង ដែលជាសញ្ញានៃចុងបញ្ចប់នៃភាពជាសង្ឃរបស់លោកអើរ៉ុន ហើយដែលត្រូវជំនួសដោយលោកម៉ិលគីស្សាដែក និងបញ្ជាក់ថា ព្រះគ្រីស្ទគឺជាសម្តេចសង្ឃតែមួយគត់ ។ *គ្មានច្បាប់ នឹងចូលមកបរិភោគពីអាសនានោះទេ* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកសង្ឃនៅ សម័យសញ្ញាចាស់មិនអាចបរិភោគអាហារនៅថ្ងៃប្រោះលោះបានទេ ប៉ុន្តែ យើងអាចបរិភោគបានដោយសេចក្តីជំនឿក្នុងព្រះគ្រីស្ទ (យហ ៦:៤៨–៥៨)។ ដូច្នេះ បញ្ជាក់យ៉ាងច្បាស់ថា យើងមានឱកាសច្រើនជាងពួកសង្ឃ ក្រោមសេចក្តីសញ្ញាចាស់ ។

**១៣:១១** *ត្រូវដុតនៅខាងក្រៅទីដំឡើងត្រសាល* "មើល លវ ៤:១២ ១៦:២៧"។

**១៣:១២** *ព្រះយេស៊ូវទ្រង់ក៏បានរងទុក្ខនៅខាងក្រៅទ្វារក្រុងដែរ* ការសុគតរបស់ព្រះគ្រីស្ទនៅក្រៅទីក្រុងយេរូសាឡិម តំណាងឱ្យការដោះនូវអំពើបាប និង ជំនួសឱ្យការយកសត្វធ្វើជាយញ្ញបូជា ចេញពីពួកអ៊ីស្រាអែល ។

**១៣:១៣** *ចេញទៅឯទ្រង់ នៅខាងក្រៅទីដំឡើងត្រសាលដែរ* ការត្រាស់ហៅឱ្យបែរចេញពីគោលលទ្ធិសាសនាយូដាទៅឯព្រះគ្រីស្ទ ។ ព្រះគ្រីស្ទទ្រង់ត្រូវបានគេធ្វើគុត និងបង្អាប់កិត្តិយសនៅខាងក្រៅទីក្រុង ដូច្នេះ អ្នកទទួលសំបុត្រហេព្រើរនេះ មិនត្រូវខ្មាស់ ក្នុងការងាកបែរ ចេញពីគោលលទ្ធិ នៃសាសនាយូដា ទៅឯព្រះគ្រីស្ទ ។

**១៣:១៤** *ក្រុងនោះដែលត្រូវមក* "មើលការពន្យល់ ១១:១០,១៤,១៦"។

**១៣:១៥** *ថ្វាយពាក្យសរសើរ* សូមប្រៀបធៀប រម ១២:១ ។ សម្រាប់ប្រភពនៃសញ្ញាចាស់សូមមើល លវ ៣:១ ដទ ៧:១៧ ៥១:១៧ និងការពន្យល់ ។

**១៣:១៦** *គ្រឿងបូជា* សូមមើល ភល ៤:១៨ និងការពន្យល់ ។

**១៣:១៧** *ពួកអ្នកដែលនាំមុខ* សំដៅលើពួកអ្នកដឹកនាំនាពេលបច្ចុប្បន្ន ដែលមានលក្ខណៈផ្សេងពីពួកអ្នកដឹកនាំរបស់ពួកគេនាពេលមុន ដែលបានស្លាប់ហើយ ដូចមានបញ្ជាក់នៅក្នុងខ.៧ (មើលការពន្យល់ ខ.៧–១៧)។ *ចុះចូល* ត្រង់ចំណុច នេះមិនសំដៅលើមេដឹកនាំផ្តាច់ការនោះទេ ប៉ុន្តែ គោរពចុះចូលនឹងអំណាច បញ្ញត្តិ និងវិន័យនៅក្នុងពួកជំនុំ ដែលពួកគេបានទទួលពីការបង្រៀនក្នុងសញ្ញាថ្មី (២កថ ១០:៨ និងការពន្យល់)។

**១៣:១៩** *ត្រឡប់មកឯកអ្នករាល់គ្នាវិញជាឆាប់* អត្តសញ្ញាណ និងទីលំនៅរបស់អ្នកនិពន្ធមិនបានបញ្ជាក់ទេ ប៉ុន្តែការដែលគាត់មានប្រសាសន៍ថា ត្រឡប់មកពួកគេវិញ នេះបញ្ជាក់ថា គាត់កំពុងតែធ្វើការងារបម្រើដំណឹងល្អ ។ ម្យ៉ាងទៀត គាត់មិនស្ថិតនៅក្រោមការឃុំខ្លួនទេ (ខ.២៣)។

**១៣:២០,២៥** *សេចក្តីសុខសាន្ត . . . ព្រះគុណ* "មើលពន្យល់ រម ១:៧"។

**១៣:២០–២១** សេចក្តីក្នុងវគ្គនេះបញ្ជាក់អំពីសេចក្តីសន្និដ្ឋាននៃសំបុត្រនេះ ។

**១៣:២០** *ព្រះនៃសេចក្តីសុខសាន្ត* នេះជាងារនៃព្រះអម្ចាស់ ដែលប្រើញឹកញាប់ នៅក្នុងការទូលសូមឱ្យទ្រង់ប្រទានព្រះពរដល់អ្នកណាម្នាក់ (រម ១៥:៣៣ ១៦:២០ ភល ៤:៩ ១ថន ៥:២៣ និងការពន្យល់)។ *អ្នកគង្វាលដ៏ធំនៃហ្វូងចៀម* សូមមើល ឧទាហរណ៍នៅក្នុងបទគម្ពីរ "ទដ ២៣ អស

ស្លាប់មកវិញ[ជ] គឺជាអ្នកគង្វាលដ៏ធំនៃហ្វូងចៀម[ឈ] ២១ទ្រង់
ប្រោសឱ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ក្នុងការល្អគ្រប់ជំពូក
ដោយសារព្រះលោហិត នៃសញ្ញាដ៏នៅអស់កល្បជានិច្ច[ញ]
ប្រយោជន៍ឱ្យអ្នករាល់គ្នា បានធ្វើតាមបំណងព្រះហឫទ័យ
របស់ទ្រង់[ដ] ដោយទ្រង់ធ្វើការក្នុងអ្នករាល់គ្នា[ឋ] ដែលគាប់ដល់
ព្រះហឫទ័យនៃទ្រង់[ឌ] ដោយសារព្រះយេស៊ូវគ្រីស្ទ សូមឱ្យទ្រង់
បានសិរីល្អ នៅអស់កល្បជានិច្ច រៀងរាបតទៅ អាម៉ែន[ឍ]។
២២តែបងប្អូនអើយ ចូរទ្រាំទ្រនឹងសេចក្ដីប្រដៅទូន្មាននេះ
ចុះ ដ្បិតខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នាយ៉ាងខ្លីៗទេ[ណ]។

**១៣:២១** ញ ២កថ ៩:៨ ដ កល ២:១៣ ឌ រម ១១:៣៦ ឍ មថ ២៦:២៨
**១៣:២២** ណ ១ពត ៥:១២
**១៣:២៣** ត កច ១៦:១
**១៣:២៤** ថ ខ.៧,១៧ ទ កច ១៨:២
**១៣:២៥** ធ កល ៤:១៨

២៣សូមឱ្យដឹងថា គេបានលែងធីម៉ូថេ[ត] ជាបងប្អូនយើង
ហើយ បើគាត់មកយ៉ាងឆាប់ នោះខ្ញុំនឹងបានមកសួរអ្នករាល់
គ្នា ជាមួយនឹងគាត់ដែរ ២៤សូមជំរាបសួរដល់ពួកអ្នកនាំមុខ
អ្នករាល់គ្នា[ថ] និងពួកបរិសុទ្ធទាំងអស់គ្នាដែរ ពួកអ្នកនៅ
ស្រុកអ៊ីតាលី[ទ] ក៏សូមជំរាប សួរមកអ្នករាល់គ្នា ។
២៥សូមឱ្យអ្នករាល់គ្នា បានប្រកបដោយព្រះគុណទាំងអស់
គ្នា[ធ]។ អាម៉ែន ។

៤០:១១ អគ ៣៤:១១–១៦,២៣ ៣៧:២៤ យហ ១០:២–៣,១១,១៤,២៧ ១ពត ២:២៥ ៥:៤"។

**១៣:២១** *ព្រះលោហិត* "មើលការពន្យល់ ១០:២៩"។ *ការល្អគ្រប់ជំពូក* ដូចជា សេចក្ដីជំនឿ សេចក្ដីសុចរិត ការស្ដាប់បង្គាប់ និងការទ្រាំទ្រ ។ *សញ្ញាដ៏នៅអស់កល្បជានិច្ច* សំដៅលើសេចក្ដីសញ្ញាថ្មី (មើលការពន្យល់ ៨:៨–១២)។ អ្វីដែលលោកយេរេមាបានលើកឡើងអំពីសេចក្ដីសញ្ញាថ្មីក្នុង ៣១:៣១ គឺលោកពិពណ៌នា នូវសេចក្ដីសញ្ញាដែលស្ថិតនៅអស់កល្បជានិច្ចនៅក្នុង ៣២:៤០ (អស ៥៥:៣ ៦១:៨ និងការពន្យល់)។

**១៣:២២–២៥** វគ្គនេះជាសេចក្ដីបន្ថែមរបស់អ្នកនិពន្ធកណ្ឌគម្ពីរនេះ ។

**១៣:២២** *បងប្អូន* "មើលការពន្យល់ រម ១:១៣"។ *សេចក្ដីប្រដៅទូន្មាន* សេចក្ដីពិតដ៏សំខាន់នៅក្នុងកណ្ឌគម្ពីរនេះគឺផ្ដល់ទៅពួកអ្នកពេញវ័យខាងឯជំនឿ និងកុំឱ្យ

# សំបុត្ររបស់យ៉ាកុប

សេចក្ដីផ្ដើម

### អ្នកនិពន្ធ

តាមបទគម្ពីរអ្នកនិពន្ធមានឈ្មោះយ៉ាកុប(១:១) ។ គេជឿថា លោកគឺជាប្អូនរបស់ព្រះយេស៊ូវ និងជាអ្នកដឹកនាំក្រុមជំនុំក្រុងយេរូសាឡិម (កច១៥) ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មីមានអ្នកមានឈ្មោះយ៉ាកុបបួននាក់ ។ អ្នកនិពន្ធនៃសំបុត្រនេះមិនអាចជាលោកសាវ័កយ៉ាកុបទេ ព្រោះលោកសាវកយ៉ាកុបបានស្លាប់នៅមុនពេលដែលសំបុត្រនេះត្រូវបានសរសេរទៅទៀត(គ.ស.៤៤) ។ ចំណែកឯអ្នកដែលមានឈ្មោះយ៉ាកុបពីរនាក់ទៀតមិនមានលក្ខណៈសម្បត្តិ ឬឥទ្ធិពលដូចអ្នកនិពន្ធសំបុត្រនេះឡើយ ។

លោកយ៉ាកុបគឺជាប្អូនប្រុសម្នាក់ ក្នុងចំណោមប្អូនប្រុសទាំងឡាយរបស់ព្រះយេស៊ូវគ្រីស្ទ ។ គេជឿថាលោកជាកូនប្រុសច្បងបន្ទាប់ពីព្រះយេស៊ូវ ព្រោះឈ្មោះគាត់ត្រូវបាននិយាយមុនគេក្នុង មថ ១៣:៥៥ ។ ដំបូងឡើយលោកមិនជឿលើព្រះយេស៊ូវទេ ហើយថែមទាំងល្បងសមត្ថភាពរបស់ទ្រង់ និងភាន់ច្រឡំពីព្រះរាជបេសកកម្មរបស់ទ្រង់ទៀតផង(យហ ៧:២-៥) តែក្រោយមកលោកក៏បានក្លាយជាអ្នកមានតួនាទីសំខាន់ នៅក្នុងពួកជំនុំ:

១. លោកជាបុគ្គលដែលព្រះគ្រីស្ទទ្រង់ជ្រើសរើសឱ្យបានឃើញព្រះអង្គទ្រង់ បន្ទាប់ពីទ្រង់មានព្រះជន្មឡើងវិញ (១កច ១៥:៧ និងការពន្យល់) ។

២. លោកសាវ័កប៉ុលបានហៅលោកយ៉ាកុបថា "សសរទ្រូង" នៃពួកជំនុំ (កទ ២:៩) ។

៣. នៅពេលលោកសាវ័កប៉ុលទៅសួរសុខទុក្ខពួកជំនុំនៅក្រុងយេរូសាឡិមលើកទីមួយបន្ទាប់ពីបានប្រែចិត្តទទួលជឿព្រះ លោកបានជួបលោក យ៉ាកុប (កទ ១:១៩) ។

៤. នៅពេលលោកប៉ុលទៅសួរសុខទុក្ខពួកជំនុំនៅក្រុងយេរូសាឡិមលើកក្រោយបង្អស់ ក៏បានជួបលោកយ៉ាកុបម្ដងទៀត (កច ២១:១៨) ។

៥. នៅពេលសាវ័កពេត្រុសត្រូវបានរំដោះចេញពីគុក លោកបានផ្ដាំមិត្តភ័ក្ដិលោកឱ្យប្រាប់លោកយ៉ាកុប (កច ១២:១៧) ។

៦. លោកយ៉ាកុបជាអ្នកដឹកនាំនៅក្នុងក្រុមជំនុំដ៏សំខាន់នៃក្រុងយេរូសាឡិម (កច ១៥:១៣) ។

៧. លោកយូដាសក៏បានហៅខ្លួនលោកថា "ប្អូនយ៉ាកុប"(យដ ១:១) ដូច្នេះហើយលោកយ៉ាកុបក៏ល្បីឈ្មោះផងដែរ ។ លោកយ៉ាកុបត្រូវស្លាប់ដោយការបៀតបៀនក្នុងឆ្នាំ ៦២ គ.ស.។

### ការបរិច្ឆេទ

អ្នកខ្លះបានកំណត់យកទសវត្សរ៍នៃឆ្នាំ៦០នៃសតវត្សរ៍ទី១នៃគ.ស. ។ ទោះជាយ៉ាងណាក៏ដោយ មានការចង្អុលបង្ហាញថា កាលសរសេរសំបុត្រនេះបានធ្វើឡើងនៅមុនឆ្នាំ៥០គ.ស. ពីព្រោះ :

១. លក្ខណៈយូដាសុទ្ធសាធនៃសំបុត្រនេះបង្ហាញថា សំបុត្រនេះត្រូវបានសរសេរឡើង នៅពេលដែលពួកជំនុំនៅមានលក្ខណៈយូដាភាគច្រើន ។

២. សំបុត្រនេះឆ្លុះបញ្ចាំងពីសណ្ដាប់ធ្នាប់ធម្មតារបស់ពួកជំនុំ ដែលមាន "ចាស់ទុំ"(៥:១៤) និង "ពួកគ្រូ"(៣:១)ជាអ្នកធ្វើការក្នុងពួកជំនុំ ។

៣. សំបុត្រនេះមិនមាននិយាយយោងដល់បញ្ហាកាត់ស្បែករបស់សាសន៍ដទៃទេ ។

៤. សំបុត្រនេះមានប្រើពាក្យសាលាប្រជុំ ដែលត្រូវបានបង្កើតសម្រាប់ជួបប្រជុំគ្នា ឬជាកន្លែងជួបប្រជុំគ្នារបស់ពួកជំនុំ(២:២) ។

ប្រសិនបើការកំណត់យកកាលបរិច្ឆេទនេះត្រឹមត្រូវ សំបុត្រនេះគឺជាសំបុត្រ ឬព្រះគម្ពីរដំបូងបំផុតក្នុងចំណោមព្រះគម្ពីរសញ្ញាថ្មីទាំងអស់ ។

### អ្នកទទួល

មានតែ ១:១ ប៉ុណ្ណោះ ដែលប្រាប់យ៉ាងច្បាស់ថា អ្នកទទួលជានរណា ។ ពួកគេគឺ "ពូជអំបូរទាំង១២ ដែលត្រូវខ្ចាត់ខ្ចាយ"។ អ្នកខ្លះជឿថាពាក្យនេះគឺត្រូវបានប្រើសំដៅទៅលើអ្នកជឿជាទូទៅ ប៉ុន្តែពាក្យពូជអំបូរទាំង១២ ត្រូវប្រើជាធម្មតាជាងសម្រាប់គ្រីស្ទបរិស័ទដែលជា

សាសន៍យូដា ។ ជាងនេះទៅទៀត អ្នកទទួលជាសាសន៍យូដាមានភាពស្និទ្ធស្នាលនឹងសំបុត្រដែលមានលក្ខណៈយូដានេះជាងសាសន៍ដទៃ ។ ការដែលអ្នកទទួលជាគ្រីស្ទ បរិស័ទ គឺមានបង្ហាញយ៉ាងច្បាស់ក្នុង ២:១ ៥:៧–៨ ។ ពួកគេគឺជាអ្នកជឿដែលចេញពីពួកជំនុំដំបូងនៅក្រុងយេរូសាឡិម ដែលបន្ទាប់ពីលោកស្ទេផានត្រូវបានសម្លាប់ ពួកគេត្រូវខ្ចាត់ខ្ចាយទៅនៅឯទីឆ្ងាយ រហូតដល់ស្រុកភេនីស ស្រុកគីប្រុស និងក្រុងអាន់ទីយ៉ូក(កច ៨:១ ១១:១៩ និងការពន្យល់)។ ការនេះបង្ហាញថា លោកយ៉ាកុបបាននិយាយអំពីការល្បួងល និងការគាបសង្កត់ដែលអ្នកអានរបស់គាត់ជួបប្រទះ ។ ក្នុងនាមជាអ្នកដឹកនាំម្នាក់ នៅទីក្រុងយេរូសាឡិម លោកយ៉ាកុបបានសរសេរសំបុត្រនេះ ប្រៀបដូចជាគ្រូគង្វាលដែលបង្រៀននិងលើកទឹកចិត្តពួកជំនុំរបស់ខ្លួនដែលត្រូវខ្ចាត់ ខ្ចាយ នៅពេលជួបប្រទះនឹងការលំបាក ។

**លក្ខណៈផ្សេងពីគេ**

លក្ខណៈដែលធ្វើឱ្យសំបុត្រនេះខុសពីព្រះគម្ពីរផ្សេងៗទៀតគឺ (១).មានលក្ខណៈសាសន៍យូដាឥតខ្ចោះ ។ (២).និយាយសង្កត់ធ្ងន់លើសេចក្តីសង្គ្រោះដែលបានដោយសេចក្តីជំនឿដែលមានការប្រព្រឹត្តតាម ។ (៣).មានការរៀបចំដែលសាម័ញ្ញ ។ (៤).មាននិយាយពីសេចក្តីដែលយោងដល់សេចក្តីបង្រៀននៅលើទីទួលរបស់ព្រះយេស៊ូវ(សូមធៀប ២:៥ នឹង មថ ៥:៣ ៣:១០–១២ មថ ៧:១៥–២០ ៣:១៨ មថ ៥:៩ ៥:២–៣ មថ ៦:១៩–២០ ៥:១២ មថ ៥:៣៣–៣៧)។ (៥).មានលក្ខណៈស្រដៀងគ្នានឹងលក្ខណៈនៃការសរសេររបស់ព្រះគម្ពីរសុភាសិត ។ (៦).ប្រើភាសាក្រេក ក្នុងការសរសេរបានយ៉ាងល្អប្រសើរ ។

**គម្រោងសង្ខេប**

I. **ពាក្យជម្រាបសួរ (១:១)**

II. **សេចក្តីល្បួង និងការល្បងល (១:២–១៨)**
  - ក. ការសាកល្បងជំនឿ (១:២–១២)
  - ខ. ប្រភពនៃសេចក្តីល្បួង (១:១៣–១៨)

III. **ការស្តាប់ និងការប្រព្រឹត្ត (១:១៩–២៧)**

IV. **ការហាមប្រាមពីការរើសមុខ (២:១–១៣)**

V. **សេចក្តីជំនឿ និងការប្រព្រឹត្តតាម (២:១៤–២៦)**

VI. **ការផ្សាំងអណ្តាត (៣:១–១២)**

VII. **ប្រាជ្ញាពីរប្រភេទ (៣:១៣–១៨)**

VIII. **ការព្រមានពីនិស្ស័យលោកីយ (ជំពូក ៤)**
  - ក. សេចក្តីឈ្លោះប្រកែក (៤:១–៣)
  - ខ. ភាពមិនស្មោះត្រង់ខាងវិញ្ញាណ (៤:៤)
  - គ. ការមានឫកធំ(៤:៥–១០)
  - គ. ការនិន្ទាគ្នា (៤:១១–១២)
  - ឃ. សេចក្តីអំណួត (៤:១៣–១៧)

IX. **ការព្រមានដល់ពួកអ្នកមានដែលសង្កត់សង្កិន (៥:១–៦)**

X. **ការលើកទឹកចិត្ត (៥:៧–២០)**
  - ក. ពីការអត់ធ្មត់ក្នុងការរងទុក្ខ (៥:៧–១១)
  - ខ. ពីសេចក្តីសម្បថ (៥:១២)
  - គ. ពីការអធិស្ឋានដោយជំនឿ (៥:១៣–១៨)
  - ឃ. ពីអ្នកដែលវង្វេងចេញពីសេចក្តីពិត (៥:១៩–២០)

**១** ១សំបុត្រយ៉ាកុប[ក] ជាបាវបំរើរបស់ព្រះ[ខ] ហើយរបស់ព្រះ
អម្ចាស់យេស៊ូវគ្រីស្ទ ខ្ញុំផ្ញើមកជំរាបសួរ[គ]ដល់ពូជអំបូរទាំង
១២[ឃ] ដែលត្រូវខ្ចាត់ខ្ចាយ[ង]។

## សេចក្តីល្បួង និងល្បងល

២បងប្អូនអើយ កាលណាអ្នករាល់គ្នាមានសេចក្តីល្បួង
ផ្សេងៗ នោះត្រូវរាប់ជាសេចក្តីអំណរសព្វគ្រប់វិញ[ច]
៣ដោយដឹងថា ការល្បងលមើលសេចក្តីជំនឿនៃអ្នករាល់
គ្នា[ឆ] នោះនាំបង្កើតឱ្យមានសេចក្តីខ្ជាប់ខ្ជួន[ជ] ៤ចូរទុកឱ្យសេច
ក្តីខ្ជាប់ខ្ជួននោះ បានធ្វើការឱ្យសំរេចពេញលេញចុះ ដើម្បី
ឱ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍[ឈ] ហើយពេញខ្នាតឥតខ្វះ
អ្វីឡើយ ៥តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូម
ដល់ព្រះ[ញ] ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ ដោយ
សទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឱ្យ[ដ] ៦តែត្រូវឱ្យ
អ្នកនោះសូមដោយចិត្តជឿ ឥតសង្ស័យអ្វីសោះ[ឋ] ដ្បិតអ្នកណា
ដែលសង្ស័យ នោះប្រៀបដូចជារលកសមុទ្រ ដែលត្រូវផាត់
ដោយខ្យល់ ទាំងរំពើកចុះឡើង ៧កុំឱ្យមនុស្សយ៉ាងនោះនឹក
ស្មានថា ខ្លួននឹងបានអ្វីពីព្រះអម្ចាស់ឡើយ ៨ដ្បិតអ្នកនោះជា
មនុស្សមានចិត្ត២[ឌ] ចេះតែសាវ៉ា[ឍ]ក្នុងគ្រប់ទាំងផ្លូវ ។
៩ត្រូវឱ្យបងប្អូនណា ដែលមានសណ្ឋានទាបថោក បាន
ត្រេកអរ ដោយបានដំកើងឡើង[ណ] ១០ហើយអ្នកមានត្រូវអរ
សប្បាយ ដោយត្រូវបន្ទាបចុះវិញ ដ្បិតគេនឹងបាត់ទៅដូចជា
ផ្កាស្មៅ[ត] ១១ពីព្រោះថ្ងៃរះឡើង មានចំហាយក្តៅវេលា
ណា[ថ] នោះធ្វើឱ្យស្មៅក្រៀមស្វិត[ទ] ហើយផ្កាក៏រោយរុះ ឯ
លំអក៏វិនាសសូន្យទៅ[ធ] ដូច្នេះ អ្នកមានក៏នឹងត្រូវស្រពោន
ទៅក្នុងផ្លូវខ្លួនយ៉ាងនោះដែរ ១២មានពរហើយមនុស្សណា
ដែលស៊ូទ្រាំនឹងសេចក្តីល្បួង[ន] ដ្បិតកាលណាត្រូវល្បងល
ឃើញថាខ្ជាប់ខ្ជួនហើយ នោះនឹងទទួលបានមកុដជីវិត[ប]
ដែលព្រះអម្ចាស់ទ្រង់សន្យា នឹងប្រទានឱ្យដល់អស់អ្នកណា
ដែលស្រឡាញ់ទ្រង់[ផ]។
១៣កាលណាមានសេចក្តីល្បួង នោះកុំឱ្យអ្នកណានិយាយ
ថា ព្រះទ្រង់ល្បួងខ្លួនឡើយ ដ្បិតសេចក្តីអាក្រក់ ពុំអាចនឹង
ល្បួងនាំព្រះហឫទ័យព្រះបានឡើយ ហើយព្រះក៏មិនដែល
ល្បួងអ្នកណាដែរ ១៤តែដែលគ្រប់គ្នាកើតមានសេចក្តីល្បួង
នោះ គឺដោយសារតែសេចក្តីប៉ងប្រាថ្នារបស់ខ្លួន[ព] នាំ
ប្រទាញ ហើយលួងលោមទេ ១៥រួចកាលណាសេចក្តីប៉ង
ប្រាថ្នាជាប់មានជាផ្ទៃ នោះសំរាលចេញមកជាអំពើបាប[ភ]

**១:១** ក កច ១៥:១៣ ខ រម ១:១ ទត ១:១ គ ចទ ៣២:២៦ យហ ៧:៣៥ ១ពត ១:១ ឃ កច ១៥:២៣ ង កច ២៦:៧ **១:២** ច ខ.១២ មថ ៥:១២ ហព ១០:៣៤ ១២:១១ **១:៣** ឆ ១ពត ១:៧ ជ ហព ១០:៣៦ **១:៤** ឈ ១កថ ២:៦ **១:៥** ញ ១ពវ ៣:៩,១០ សភ ២:៣–៦ ដ ទដ ៥១:៦ ដយ ១:១៧ ២:២១ មថ ៧:៧ **១:៦** ឋ មថ ២១:២១ មក ១១:២៤ **១:៨** ឌ ទដ ១១៩:១១៣ យក ៤:៨ ឍ ២ពត ២:១៤ ៣:១៦ **១:៩** ណ មថ ២៣:១២
**១:១០** ត យប ១៤:២ ទដ ១០៣:១៥,១៦ អស ៤០:៦,៧ ១កថ ៧:៣១ ១ពត ១:២៤ **១:១១** ថ មថ ២០:១២ ទ ទដ ១០២:៤,១១ ធ អស ៤០:៦–៨ **១:១២** ន ខ.២ លប ២២:១ យក ៥:១១ ១ពត ៣:១៤ ប ១កថ ៩:២៥ ផ នក ២០:៦ ១កថ ២:៩ ៨:៣ យក ២:៥ **១:១៤** ព សភ ១៩:៣ **១:១៥** ភ លប ៣:៦ យប ១៥:៣៥ ទដ ៧:១៤ អស ៥៩:៤

**១:១** *យ៉ាកុប* មើលសេចក្តីផ្តើមត្រង់អ្នកនិពន្ធ ។ *បាវបំរើ* មើលការពន្យល់ រម ១:១ ។ *ពូជអំបូរទាំង ១២* មើលសេចក្តីផ្តើមត្រង់អ្នកទទួល ។

**១:២–៣** *សេចក្តីល្បួង . . . ការល្បងល . . . បង្កើតឱ្យមានសេចក្តីខ្ជាប់ខ្ជួន* មួយវគ្គនេះ និងខ.១២បានបង្កើតជាទម្រង់នៃពាក្យពេចន៍របស់លោកយ៉ាកុបអំពីសេចក្តីល្បួងល្បង ។

**១:២** *បងប្អូន* សូមធៀបនឹង ការពន្យល់ រម ១:១៣ ។ លោកយ៉ាកុបបានហៅអ្នកអានថា "បងប្អូន" ចំនួន ១៥ ដង នៅក្នុងសំបុត្រដ៏ខ្លីមួយនេះ ។ គាត់បានស្តីបន្ទោសឱ្យពួកគេជាច្រើន ប៉ុន្តែក្នុងសេចក្តីស្រលាញ់ជាបងប្អូនទេ ។ *សេចក្តីល្បួងផ្សេងៗ* គឺសេចក្តីល្បងលដែលមាននិយាយក្នុង ខ.៣ ។ *សេចក្តីអំណរ* មើល មថ ៥:១១–១២ កច ៥:៤១ រម ៥:៣ និងការពន្យល់ ភល ៤:៤ និងការពន្យល់ ១ពត ១:៦ ។

**១:៥** *ប្រាជ្ញា* ជួយឱ្យអាចប្រឈមមុខនឹងការល្បងល ដោយ"សេចក្តីអំណរសព្វគ្រប់"(ខ.២)។ ប្រាជ្ញាគឺជាចំណេះដឹងជ្រៅជ្រះ ដែលបង្ហាញឱ្យឃើញតាមរយៈការប្រព្រឹត្តល្អ(៣:១៣–១៨ សភ ១:២–៤ និងការពន្យល់ ១:២ ២:១០–១៥ ៤:៥–៩ ៩:១០–១២)។

**១:៦** *រលកសមុទ្រ* មើល អភ ៤:១៤ និងការពន្យល់ ។

**១:៩–១០** *បងប្អូនណា ដែលមានសណ្ឋានទាបថោក . . . អ្នកមាន* គ្រីស្ទបរិស័ទដែលជួបប្រទះនឹងភាពក្រខ្សត់ ត្រូវមានអំនួតនៅក្នុងការដែលបានតម្កើងឡើង ជាអ្នកមានខាងសេចក្តីជំនឿ(មើល ២:៥)។ ចំពោះអ្នកជឿព្រះដែលជាអ្នកមានវិញ ពួកគេមិនត្រូវមានអំនួតនៅក្នុងទ្រព្យសម្បត្តិឡើយ ប៉ុន្តែត្រូវមានអំនួតនៅក្នុងសេចក្តីពិតដែលថាព្រះទ្រង់បានបន្ទាបពួកគេចុះ ហើយប្រទានឱ្យពួកគេមាននូវការកោតខ្លាចព្រះដើម្បីឱ្យពួកគេដឹងថា តើជីវិតនិងទ្រព្យសម្បត្តិមានភាពមិនស្ថិតស្ថេរយ៉ាងណានោះ(ខ.១០)។

**១:១០** *បាត់ទៅដូចជាផ្កាស្មៅ* មើល យប ១៤:២ ទដ ១០៣:១៥ អស ៤០:៦–៧ ១ពត ១:២៤ ធៀបនឹង លក ១២:១៥ ២០–២១ ១ធថ ៦:៨–១០ ១៧–១៩។

**១:១១** *ក្រៀមស្វិត* សូមធៀប ៤:១៤ និងការពន្យល់ ។

**១:១២** *មានពរហើយ* មើល យរ ១៧:៧–៨ មថ ៥:៣–១២ មើលការពន្យល់ ទដ ១:១ មថ ៥:៣ វវ ១:៣ ។ *មកុដ* ចំពោះពាក្យនេះព្រះគម្ពីរក្រិកប្រើពាក្យកម្រងផ្កាឬស្លឹកឈើដែលគេបំពាក់លើក្បាលអ្នកអត្តពលកម្ម ឬអ្នកដឹកនាំទាហានដែលទទួលបានជ័យជម្នះ(២ធថ ៤:៨ ១ពត ៥:៤ វវ ២:១០ និងការពន្យល់)។ *ជីវិត* គឺ ជីវិតអស់កល្បជានិច្ច ។

**១:១៣** *សេចក្តីល្បួង* សេចក្តីល្បួងដែលមាននិយាយក្នុង ខ.១៣–១៤ គឺជាការល្បងលកម្លាំងខាងឯសីលធម៌ដែលមនុស្សម្នាក់មានក្នុងការទប់ទល់នឹងអំពើបាប(ពន្យល់ មថ ៤:១)។ *ពុំអាចនឹងល្បួងនាំព្រះហឫទ័យព្រះ* ពីព្រោះព្រះទ្រង់បរិសុទ្ធ និងគ្មានបាប ។ *ព្រះក៏មិនដែលល្បួងអ្នកណា* មើលការពន្យល់ លប ២២:១ ។

**១:១៤** *សេចក្តីប៉ងប្រាថ្នា* គឺចិត្តពីកំណើតដែលដឹកនាំទៅរកអំពើបាប(សូមធៀប នឹង យរ ១៧:៩)។ *នាំប្រទាញ ហើយលួងលោម* នៅក្នុងខនេះ ពាក្យនេះប្រើជាន័យធៀបពីរបៀបដែលសេចក្តីប៉ងប្រាថ្នាដឹកនាំ (សូមធៀបនឹង ២ពត ២:១៤ និងការពន្យល់)។

ហើយកាលណាបាបបានពោរពេញឡើង នោះក៏បង្កើតជា
សេចក្ដីស្លាប់[ម] ។
១៦បងប្អូនស្ងួនភ្ងារបស់ខ្ញុំអើយ[យ] កុំឱ្យត្រូវបំភាន់ឡើយ[រ]
១៧គ្រប់ទាំងរបស់ដ៏ល្អ ដែលព្រះប្រទានមក នឹងអស់ទាំង
អំណោយទានដ៏គ្រប់លក្ខណ៍ នោះសុទ្ធតែមកពីស្ថានលើ[ល] គឺ
មកពីព្រះវរបិតានៃពន្លឺ[វ] ដែលទ្រង់មិនចេះប្រែប្រួល[ស] សូម្បី
តែស្រមោលនៃសេចក្ដីផ្លាស់ប្រែក៏គ្មានដែរ ១៨ទ្រង់បាន
បង្កើតយើងរាល់គ្នា[ហ]មកតាមព្រះហឫទ័យទ្រង់ ដោយសារ
ព្រះបន្ទូលដ៏ពិត[ឡ] ប្រយោជន៍ឱ្យយើងបានបែបដូចជាផល
ដំបូង[អ] ក្នុងរបស់ទាំងប៉ុន្មានដែលទ្រង់បង្កើតមក ។

## ការស្ដាប់ និងការប្រព្រឹត្ត

១៩ដូច្នេះ បងប្អូនស្ងួនភ្ងាអើយ[ក] ចូរឱ្យគ្រប់គ្នាបានឆាប់
នឹងស្ដាប់ ក្រនឹងនិយាយ[ខ] ហើយយឺតនឹងខឹងដែរ ២០ដ្បិត
សេចក្ដីកំហឹងរបស់មនុស្ស[គ] មិនដែលសំរេចតាមសេចក្ដី
សុចរិតរបស់ព្រះទេ ២១បានជាចូរទទួលព្រះបន្ទូលដែល
បានដាំក្នុងចិត្តអ្នករាល់គ្នា[ឃ] ដោយចិត្តសុភាពចុះ ទាំងលះ
ចោល[ង]អស់ទាំងសេចក្ដីស្មោកគ្រោកចេញ នឹងសេចក្ដីគំរក់
ដ៏មានច្រើនម្ល៉េះចេញផង ដ្បិតព្រះបន្ទូលនោះអាចនឹងជួយ
សង្គ្រោះព្រលឹងអ្នករាល់គ្នាបាន ២២ចូរឱ្យអ្នករាល់គ្នា
ប្រព្រឹត្តតាមព្រះបន្ទូលទៅ កុំឱ្យគ្រាន់តែស្ដាប់ប៉ុណ្ណោះ

**១:១៥** ម រម ៦:២៣
**១:១៦** យ ១កថ ៦:៩ រ ខ.១៩ យក ២:៥
**១:១៧** ល ទដ ៨៥:១២ យហ ៣:២៧ យក ៣:១៥,១៧ វ លប ១:១៦ ទដ ១៣៦:៧ ដយ ២:២២ ១យហ ១:៥ ស ជន ២៣:១៩ ទដ ១០២:២៧ មឡ ៣:៦
**១:១៨** ហ យហ ១:១៣ ឡ ២ធថ ២:១៥ អ យរ ២:៣ វវ ១៤:៤
**១:១៩** ក ខ.១៦ យក ២:៥ ខ សភ ១០:១៩ យក ៣:៣–១២
**១:២០** គ មថ ៥:២២
**១:២១** ឃ អភ ១:១៣ ង អភ ៤:២២
**១:២២** ច មថ ៧:២១ យក ២:១៤–២០
**១:២៥** ឆ ទដ ១៩:៧ យហ ៨:៣២

ហើយបញ្ឆោតខ្លួនវិញនោះឡើយ[ច] ២៣ដ្បិតបើអ្នកណាស្ដាប់
ព្រះបន្ទូលហើយ តែមិនប្រព្រឹត្តតាម អ្នកនោះធៀបដូចជា
មនុស្សដែលឆ្លុះមុខក្នុងកញ្ចក់ ២៤អ្នកនោះគ្រាន់តែមើលខ្លួន
រួចចេញបាត់ទៅ ហើយក៏ភ្លេចពីបែបភាពខ្លួនជាយ៉ាង
ណាភ្លាម ២៥តែអ្នកណាដែលពិនិត្យ មើលក្នុងក្រិត្យវិន័យ
ដ៏គ្រប់លក្ខណ៍ គឺជាក្រិត្យវិន័យខាងឯសេរីភាព[ឆ] ហើយក៏
ជាប់ចិត្តចំពោះ ឥតមានភ្លេចសេចក្ដីដែលស្ដាប់នោះឡើយ
គឺបានប្រព្រឹត្តតាមវិញ អ្នកនោះនឹងមានពរក្នុងគ្រប់ការ
ដែលខ្លួនធ្វើទាំងប៉ុន្មាន[ជ] ។
២៦បើអ្នកណាស្មានថា ខ្លួនជាអ្នកកាន់សាសនា តែមិន
ចេះទប់អណ្ដាតសោះ[ឈ] អ្នកនោះឈ្មោះថា បញ្ឆោតចិត្ត
ខ្លួនហើយ ឯសាសនារបស់អ្នកនោះជាឥតប្រយោជន៍ទទេ
២៧ឯសាសនាដែលបរិសុទ្ធ ហើយឥតសៅហ្មង នៅចំពោះ
ព្រះដ៏ជាព្រះវរបិតា នោះគឺឱ្យទៅសួរពួកកំព្រា និងពួក
មេម៉ាយ[ញ] ក្នុងកាលដែលគេមានសេចក្ដីវេទនា ហើយឱ្យ
រក្សាខ្លួន[ដ] មិនឱ្យប្រឡាក់ដោយលោកិយនេះឡើយ[ឋ] ។

## ការហាមប្រាមពីការរើសមុខ

**២** ១បងប្អូនអើយ កុំឱ្យមានសេចក្ដីជំនឿ ជឿដល់ព្រះ

កទ ២:៤ យក ២:១២ ជ យហ ១៣:១៧ **១:២៦** ឈ ទដ ៣៤:១៣ ៣៩:១ ១៤១:៣ យក ៣:២–១២ ១ពត ៣:១០ **១:២៧** ញ មថ ២៥:៣៦ ដ រម ១២:២ យក ៤:៤ ២ពត ១:៤ ២:២០ ឋ ចទ ១៤:២៩ យប ៣១:១៦,១៧,២១ ទដ ១៤៦:៩ អស ១:១៧,២៣

**១:១៥** ខនេះនិយាយអំពីដំណាក់កាលទាំងបីដែលមានដូចជា សេចក្ដីប៉ងប្រាថ្នា អំពើបាប និងសេចក្ដីស្លាប់ ដែលឃើញមាននៅក្នុងសេចក្ដីល្បួងនាងអេវ៉ា (លប ៣:៦–២២) និងស្ដេចដាវីឌ (២សយ ១១:២–១៧)។

**១:១៧** *គ្រប់ទាំងរបស់ដ៏ល្អ ដែលព្រះប្រទានមក និងអស់ទាំងអំណោយទានដ៏គ្រប់លក្ខណ៍ នោះសុទ្ធតែមកពីស្ថានលើ* មើល ខ.៥ ៣:១៧ ។ *ព្រះវរបិតានៃពន្លឺ* ជាញឹកញាប់ព្រះគម្ពីរប្រៀបធៀបសេចក្ដីល្អទៅនឹងពន្លឺ ហើយសេចក្ដីអាក្រក់ទៅនឹងភាពងងឹត (សូមមើល ទដ ២៧:១ អស ៦០:១៩–២២ យហ ១:១–១៤)។

**១:១៨** *បង្កើត* ការបង្កើតក្នុងខនេះគឺសំដៅទៅលើការបង្កើតជាថ្មីខាងឯវិញ្ញាណ (មើល យហ ៣:៣,៥,៧ និងការពន្យល់)។ ពួកជំនុំដំបូងគឺជាពួកអ្នកជំនាន់ទីមួយ ដែលជឿលើព្រះយេស៊ូវគ្រីស្ទថាជាព្រះមែស៊ី ។ លោកយ៉ាកុបបានហៅពួកគេថា"ផលដំបូងក្នុងរបស់ទាំងប៉ុន្មានដែលទ្រង់បង្កើត"។ ពួកមេដឹកនាំសាសន៍យូដាប្រាកដជាដឹងច្បាស់អំពីការថ្វាយផលដំបូងដែលជាការថ្វាយបង្គំ និងព្រះពរ សម្រាប់ការប្រមូលផលខាងមុខទៀត(ចទ ២៦:៩–១១)។ ក្នុង ១កថ ១៥:២០ លោកប៉ុលបានបង្រៀនថា ព្រះយេស៊ូវទ្រង់ជាផលដំបូងពីពួកអ្នកដែលដេកលក់ទៅហើយ ។

**១:១៩** *ចូរឱ្យគ្រប់គ្នា . . . ក្រនឹងនិយាយ* មើល ខ.២៦ ។

**១:២១** *ព្រះបន្ទូល* សូមធៀបនឹង ១ពត ១:២៣ ។ លោកយ៉ាកុបបានបង្រៀននៅក្នុងខនេះឱ្យយើងលះចោលគ្រប់ទាំងការដែលស្មោគគ្រោក និងគម្រក់ចេញពីជីវិតរបស់យើងម្នាក់ៗ ហើយបន្ទាបខ្លួនទទួលព្រះបន្ទូលនៃសេចក្ដីសង្គ្រោះ("ព្រះបន្ទូលដែលដាំក្នុងចិត្តយើង")ពីព្រោះមានតែទ្រង់ទេ ដែលអាចជួយសង្គ្រោះយើងបាន។

**១:២៥** *ក្រិត្យវិន័យដ៏គ្រប់លក្ខណ៍* គឺក្រឹត្យវិន័យអំពីសីលធម៌របស់គ្រីស្ទបរិស័ទដែលមានមូលដ្ឋាននៅក្នុងក្រឹត្យវិន័យអំពីសីលធម៌នៃព្រះគម្ពីរសញ្ញាចាស់ដែលមានដូចជាក្រឹត្យវិន័យទាំងដប់ប្រការ (មើល ទដ ១៩:៧) ប៉ុន្តែ ត្រូវបានធ្វើឱ្យសម្រេចដោយព្រះយេស៊ូវគ្រីស្ទ (មើលការពន្យល់ មថ ៥:១៧ រម ១០:៤)។

**១:២៦–២៧** វគ្គនេះជាឧទាហរណ៍ពីអ្នកដែលធ្វើតាម និងអ្នកដែលមិនធ្វើតាមព្រះបន្ទូល ។

**១:២៦** *កាន់សាសនា* គឺសំដៅទៅលើការប្រព្រឹត្តតាមសាសនា ដែលមានការឱ្យទានដល់អ្នកក្រ ការតម ការអធិស្ឋាន និងការថ្វាយបង្គំជាសាធារណៈ (មថ ៦:១–១៨ និងការពន្យល់ ៦:១)។ *ទប់អណ្ដាត* មើល ៣:១–១២ ។

**១:២៧** មើល យរ ២២:១៦ និងការពន្យល់ ។ *ពួកកំព្រា និងពួកមេម៉ាយ* មើលការពន្យល់ នក ២២:២១–២៧ អស ១:១៧ ។ *លោកិយនេះ* គឺលោកិយដែលជាពួកមនុស្ស ទាស់ប្រឆាំង និងដាច់ចេញពីព្រះ(១យហ ២:១៥ និងការពន្យល់)។

**២:១** *មានសេចក្ដីជំនឿ . . . រើសមុខអ្នកណាឡើយ* ព្រះទ្រង់មិនរើសមុខអ្នកណាឡើយ(មើលការពន្យល់ កច ១០:៣៤) ហើយគ្រីស្ទបរិស័ទក៏មិនត្រូវរើសមុខអ្នកណាដែរ (មើលការពន្យល់ ខ.៥–១៣ ១ធថ ៥:២១)។ *ដ៏ឧត្ដម*

យេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់ដ៏ឧត្តម[ឌ]នៃយើង ដោយរើសមុខ
អ្នកណាឡើយ[ឍ] ២ដ្បិតបើសិនជាមានអ្នកណាចូលមកក្នុង
សាលាប្រជុំរបស់អ្នករាល់គ្នា ទាំងពាក់ចិញ្ចៀនមាស និង
សំលៀកបំពាក់ដ៏មានដំឡៃ ហើយមានអ្នកក្រម្នាក់ស្លៀក
ពាក់កក្វក់ចូលមកដែរ ៣រួចអ្នករាល់គ្នាមើលទៅអ្នកដែល
ស្លៀកពាក់មានដំឡៃនោះ ក៏អញ្ជើញគេថា សូមអង្គុយនៅ
ទីល្អនេះ រួចប្រាប់ទៅអ្នកក្រថា ចូរឈរនៅទីនុ៎ះចុះ ឬ
អង្គុយ នៅទៀបកំណល់ជើងខ្ញុំនេះដូច្នេះ ៤នោះតើមិនមែន
ឈ្មោះថាបានយោគយល់ នៅក្នុងពួកអ្នករាល់គ្នាហើយ
បានត្រឡប់ជាអ្នករើសមុខ[ណ] ដែលមានគំនិតអាក្រក់ទេឬអី។
៥ចូរស្តាប់ចុះ បងប្អូនស្ងួនភ្ងាអើយ[ត] តើព្រះមិនបានរើស
ពួកអ្នកក្រនៅលោកីយនេះ[ថ] ដែលជាអ្នកមានខាងសេចក្តី
ជំនឿ[ទ] ហើយជាអ្នកគ្រងមរដកក្នុងនគរ[ធ] ដែលទ្រង់បាន
សន្យាទុក ឱ្យពួកអ្នកដែលស្រឡាញ់ទ្រង់ទេឬអី[ន] ៦តែអ្នក
រាល់គ្នាបន្តុះបង្អាប់អ្នកក្រនោះវិញ[ប] តើពួកអ្នកមានមិន
សង្កត់សង្កិន ហើយអូសអ្នករាល់គ្នាទៅនៅមុខទីជំនុំជំរះ
ទេឬអី[ផ] ៧តើគេមិនប្រមាថដល់ព្រះនាមល្អ ដែលបានឱ្យដល់
អ្នករាល់គ្នាទេឬអី ៨បើអ្នករាល់គ្នាកាន់តាមក្រិត្យវិន័យ
ដ៏ប្រសើរ ដូចមាន បទគម្ពីរថា «ចូរឱ្យឯងស្រឡាញ់អ្នក
ជិតខាង ដូចជាខ្លួនឯង»[ព] នោះឈ្មោះថាប្រព្រឹត្តល្អហើយ
៩តែបើអ្នករាល់គ្នារើសមុខគេ[ភ] នោះមានបាបវិញ ហើយ
ក្រិត្យវិន័យក៏កាត់ទោសអ្នក ទុកដូចជាបានប្រព្រឹត្តរំលង
ដែរ[ម] ១០ដ្បិតអ្នកណាដែលកាន់ក្រិត្យវិន័យទាំងមូល តែភ្លាត់
ជំពប់នឹងបទណាមួយ[យ] នោះក៏ត្រឡប់ជាមានទោសចំពោះ
ក្រិត្យវិន័យទាំងមូលនោះហើយ[រ] ១១ពីព្រោះព្រះដែលមាន
បន្ទូលថា «កុំឱ្យ ផិតគ្នាឱ្យសោះ»[ល] ទ្រង់ក៏មានបន្ទូលថា «កុំឱ្យ
សំឡាប់មនុស្ស» ដែរ[វ] ដូច្នេះ បើអ្នកមិនបានប្រព្រឹត្តសេចក្តី
កំផិតទេ តែបានសំឡាប់វិញ នោះឈ្មោះថា អ្នកបានប្រព្រឹត្ត
អំពើរំលងក្រិត្យ វិន័យហើយ ១២ចូរឱ្យអ្នករាល់គ្នានិយាយ
ព្រមទាំងប្រព្រឹត្តបែបដូចជាក្រិត្យវិន័យ នៃសេចក្តីសេរី
ភាព[ស] រៀបនឹងជំនុំជំរះ[ហ]អ្នកហើយចុះ ១៣ដ្បិតអ្នកណា
ដែលប្រព្រឹត្តដោយឥតមេត្តា[ឡ] នោះនឹងត្រូវទោសឥតគេ
មេត្តាដែរ រីឯសេចក្តីមេត្តា នោះរមែងឈ្នះសេចក្តីជំនុំជំរះ
វិញ ។

## សេចក្តីជំនឿ និងការប្រព្រឹត្ត

១៤បងប្អូនអើយ បើអ្នកណាថាខ្លួនមានសេចក្តីជំនឿ តែ
មិនប្រព្រឹត្តតាម នោះតើមានប្រយោជន៍អ្វី[អ] តើសេចក្តី
ជំនឿអាចនឹងជួយសង្គ្រោះអ្នកនោះបានដែរឬ ១៥ចុះបើ

**២:១** ឌ កច ៧:២ ១កថ ២:៨ ឍ ខ.៩ ចទ ១:១៧ លវ ១៩:១៥ សភ ២៤:២៣ កច ១០:៣៤ **២:៤** ណ យហ ៧:២៤ **២:៥** ត យក ១:១៦,១៩ ថ យប ៣៤:១៩ ១កថ ១:២៦–២៨ ទ លក ១២:២១ វវ ២:៩ ធ មថ ២៥:៣៤ ន យក ១:១២ ប ១កថ ១១:២២ **២:៦** ផ កច ៨:៣ ១៦:១៩ **២:៨** ព លវ ១៩:១៨ មថ ៥:៤៣ **២:៩** ភ ខ.១ ម ចទ ១:១៧ **២:១០** យ យក ៣:២ រ មថ ៥:១៩ កទ ៣:១០ ៥:៣ **២:១១** ល នក ២០:១៤ ចទ ៥:១៨ វ នក ២០:១៣ ចទ ៥:១៧ **២:១២** ស យក ១:២៥ ហ មថ ១៦:២៧ **២:១៣** ឡ មថ ៥:៧ ៩:១៣ ១២:៧ ១៨:៣២–៣៥ លក ៦:៣៧ **២:១៤** អ មថ ៧:២៦ យក ១:២២–២៥ **២:១៥** ក មថ ២៥:៣៥,៣៦

មើល យហ ១:១៤ ហព ១:៣ និងការពន្យល់ ។

**២:៤** *អ្នករើសមុខ ដែលមានគំនិតអាក្រក់* សូមផ្ទៀបនឹង លវ ១៩:១៥ ។

**២:៥–១៣** ក្នុងវគ្គនេះលោកយ៉ាកុបនិយាយសេចក្តីបីយ៉ាងប្រឆាំងនឹងការរើសមុខ (១).ពួកអ្នកមានធ្វើទុក្ខពួកអ្នកក្រដែលជាពួកអ្នកជឿព្រះ (ខ.៥–៧) (២).ការរើសមុខគឺជាការបំពានក្រឹត្យវិន័យកំពូលរបស់សេចក្តីស្រលាញ់ និងជាអំពើបាប (ខ.៨–១១)។ (៣).ការរើសមុខនឹងត្រូវជាប់ជំនុំជម្រះ (ខ.១២–១៣)។

**២:៥** *តើព្រះមិនបានរើសពួកអ្នកក្រ . . . ?* សូមផ្ទៀបនឹង លក ៦:២០ និងការពន្យល់ ៦:២០–២៣ ១កថ ១:២៦–៣១ ។ *នគរ* គឺនគរសម្រាប់ពួកអ្នកកើតជាថ្មី (ការពន្យល់ ១:១៨) ហើយនឹងត្រូវទទួលបាននៅពេលអនាគត(មថ ២៥:៣៤,៤៦ និងការពន្យល់ មថ ៣:២)។

**២:៨** *ក្រិត្យវិន័យដ៏ប្រសើរ* គឺក្រិត្យវិន័យនៃសេចក្តីស្រលាញ់(លវ ១៩:១៨ និងការពន្យល់) ហៅថា"ដ៏ប្រសើរ" ពីព្រោះជាក្រឹត្យវិន័យកំពូលដែលសរុបក្រិត្យវិន័យទាំងអស់(មថ ២២:៣៦–៤០ រម ១៣:៨–១០ និងការពន្យល់ ១៣:៨–៩)។

**២:១០** *មានទោសចំពោះក្រិត្យវិន័យទាំងមូល* ក្រិត្យវិន័យជាការបង្ហាញពីលក្ខណៈ និងបំណងព្រះហឫទ័យរបស់ព្រះ ដូចនេះ ការបំពានផ្នែកណាមួយនៃក្រិត្យវិន័យ គឺជាការបំពានបំណងព្រះហឫទ័យព្រះ ព្រមទាំងក្រិត្យវិន័យទាំងអស់របស់ទ្រង់ផងដែរ (សូមផ្ទៀប មថ ៥:១៨–១៩ ២៣:២៣)។

**២:១១** មូលហេតុដែលលោកយ៉ាកុបបានជ្រើសរើសក្រិត្យវិន័យទាំងពីរ មកពីការប្រព្រឹត្តខុសនឹងក្រឹត្យវិន័យទាំងពីរ គឺខុសនឹងក្រឹត្យវិន័យនៃសេចក្តីស្រលាញ់ដល់អ្នកជិតខាង(ខ.៨)។

**២:១២** *ក្រិត្យវិន័យនៃសេចក្តីសេរីភាព* គឺក្រឹត្យវិន័យដ៏ប្រសើរខ្ពង់ខ្ពស់បំផុត។ *ជំនុំជំរះ* គឺជំនុំជម្រះដោយពុំមានរើសមុខ ។

**២:១៣** មានតែព្រះទេ ដែលទ្រង់អាចអត់ទោសបាបយើងបាន ដោយសេចក្តីមេត្តាករុណារបស់ទ្រង់ ។ បើយើងបានទទួលការអត់ទោសមកពីព្រះហើយ តែមិនអត់ទោសឱ្យអ្នកដទៃទេ នោះមានន័យថាយើងមិនយល់ ឬទទួលស្គាល់សេចក្តីមេត្តាករុណាដែលព្រះមានចំពោះយើងឡើយ(មថ ៦:១៤,១៥ ១៨:២១ អភ ៤:១៣, ៣២)។

**២:១៤–២៦** នៅក្នុងខ.១៤–២០,២៤ សេចក្តីជំនឿដែលគ្មានការប្រព្រឹត្តមានដូចជា(១).ជំនឿរបស់អារក្ស(ខ.២០) (២).ជំនឿស្លាប់(ខ.២០,២៦)។ ជំនឿទាំងនោះ គឺគ្រាន់តែជាការទទួលស្គាល់នូវសេចក្តីពិត តែមិនទទួលព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះទេ ។ លោកយ៉ាកុបមិនមែនមានន័យថា មនុស្សបានសង្គ្រោះដោយសារការប្រព្រឹត្ត ទោះជាគ្មានជំនឿក៏ដោយ ផ្ទុយទៅវិញ គាត់ចង់មានន័យថា មនុស្សបានសង្គ្រោះដោយសារជំនឿដែលរស់ ។ ជំនឿដែលពិតប្រាកដបង្កើតឱ្យមានការប្រព្រឹត្តល្អ ជំនឿលើព្រះគ្រីស្ទនាំឱ្យបានសេចក្តីសង្គ្រោះ ។

**២:១៥–១៦** ការបកស្រាយអំពីសេចក្តីជំនឿខុសឆ្គង មានលក្ខណៈស្រដៀង

មានបងប្អូនប្រុសស្រីណានៅអាក្រាត ព្រមទាំងខ្វះអាហារ
បរិភោគរាល់តែថ្ងៃ[ក] ១៦ ហើយអ្នករាល់គ្នាណាមួយនិយាយ
ទៅអ្នកនោះថា អញ្ជើញទៅឱ្យសុខសាន្ត សូមឱ្យបានកក់ក្ដៅ
ហើយឆ្អែតចុះ តែគ្មានឱ្យអ្វីដល់អ្នកដែលត្រូវការខាងរូប
សាច់នោះសោះ នោះតើមានប្រយោជន៍អ្វី[ខ] ១៧ ឯសេចក្ដី
ជំនឿក៏បែបដូច្នោះដែរ បើគ្មានការប្រព្រឹត្តតាមទេ នោះក៏
ស្លាប់នៅតែឯង[គ] ១៨ តែអ្នកខ្លះនឹងនិយាយថា អ្នកមាន
សេចក្ដីជំនឿ ហើយខ្ញុំមានការប្រព្រឹត្ត ដូច្នេះ ចូរអ្នកបង្ហាញ
សេចក្ដីជំនឿរបស់អ្នក ក្រៅពីការដែលអ្នកប្រព្រឹត្ត ឱ្យខ្ញុំ
ឃើញផង[ឃ] នោះខ្ញុំនឹង បង្ហាញសេចក្ដីជំនឿខ្ញុំ[ង] ដោយសារ
ការដែលខ្ញុំប្រព្រឹត្តដែរ[ច] ១៩ អ្នកជឿថា មានព្រះតែ ១[ឆ]
នោះត្រូវហើយ ទោះទាំងពួកអារក្សក៏ជឿដូច្នោះ[ជ] ព្រម
ទាំងព្រឺខ្លាចដែរ ២០ ឱមនុស្សកំឡៅអើយ អ្នកចង់ដឹងពិត
ឬទេថា សេចក្ដីជំនឿដែលឥតមានការប្រព្រឹត្តតាម នោះ
ឈ្មោះថាស្លាប់ហើយ[ឈ] ២១ ចុះលោកអ័ប្រាហាំ ជាឰយុកោ
យើង តើមិនបានរាប់ជាសុចរិត ដោយការលោកប្រព្រឹត្ត
ក្នុងកាលដែលលោកបានថ្វាយអ៊ីសាក ជាកូនលោក នៅ
លើអាសនាទេឬអី[ញ] ២២ ដូច្នេះ អ្នកឃើញថា សេចក្ដីជំនឿ
បានរួមជាមួយនឹងការដែលលោកប្រព្រឹត្ត[ដ] ហើយសេចក្ដី
ជំនឿបានគ្រប់លក្ខណ៍ ដោយសារការនោះឯង[ឋ] ២៣ នោះ
ទើបបានសំរេច បទគម្ពីរ ដែលថា «អ័ប្រាហាំបានជឿដល់
ព្រះ ហើយសេចក្ដីនោះ បានរាប់ជាសេចក្ដីសុចរិតដល់
លោក»[ឌ] ព្រះក៏ហៅលោកជាសំឡាញ់របស់ទ្រង់ដែរ[ឍ]
២៤ ដូច្នេះ អ្នករាល់គ្នាឃើញថា មនុស្សបានរាប់ជាសុចរិត
មិនមែនដោយសារតែសេចក្ដីជំនឿប៉ុណ្ណោះទេ គឺដោយ
សារការប្រព្រឹត្តដែរ ២៥ ឯនាងរ៉ាហាប ជាស្រីសំផឹង
ក៏ដូច្នោះដែរ តើនាងមិនបានរាប់ជាសុចរិត ដោយសារ
ការនាងប្រព្រឹត្តទេឬអី គឺក្នុងកាលដែលនាងទទួលពួកអ្នក
ដែលគេចាត់មកនោះ ហើយនាងបានឱ្យគេចេញទៅវិញ
តាមផ្លូវ ១ ទៀត[ណ] ២៦ ពីព្រោះសេចក្ដីជំនឿ បើគ្មានការប្រ
ព្រឹត្តតាម នោះឈ្មោះថាស្លាប់ហើយ ប្រៀបដូចជារូបកាយ
បើឥតមានព្រលឹងវិញ្ញាណទេ នោះក៏ស្លាប់ហើយដែរ[ត]។
**៣** ១ បងប្អូនអើយ កុំឱ្យធ្វើជាគ្រូច្រើនគ្នាពេកឡើយ[ថ] ពី
ព្រោះដឹងហើយថា យើងនឹងត្រូវទោស[ទ]ធ្ងន់ជាងគេ[ធ] ២ ដ្បិត
យើងទាំងអស់គ្នាក៏ជំពប់ជាញយៗដែរ[ន] បើអ្នកណាមិនបាន
ជំពប់ដោយពាក្យសំដី[ប] នោះជាមនុស្សគ្រប់លក្ខណ៍ហើយ[ផ]
ដែលអាចនឹងទប់រូបកាយទាំងមូលបានដែរ[ព] ៣ មើលយើង
ដាក់ដែកបង្ហៀចុះក្នុងមាត់សេះ ឱ្យវាស្ដាប់បង្គាប់តាម ហើយ
យើងញាក់រូបកាយវាទាំងមូលទៅបាន[ភ] ៤ សូមគិតមើលពី

**២:១៦** ខ លក ៣:១១ ១យហ ៣:១៧,១៨ **២:១៧** គ ខ.២០,២៦ កទ ៥:៦ **២:១៨** ឃ រម ៣:២៨ ង ហព ១១ ច មថ ៧:១៦,១៧ យក ៣:១៣ **២:១៩** ឆ ចទ ៦:៤ មក ១២:២៩ ជ មថ ៨:២៩ លក ៤:៣៤ **២:២០** ឈ ខ.១៧, ២៦ **២:២១** ញ លប ២២:៩,១២ **២:២២** ដ ហព ១១:១៧ ឋ ១ថន ១:៣ **២:២៣** ឌ លប ១៥:៦ រម ៤:៣ ឍ ២របា ២០:៧ អស ៤១:៨ **២:២៥** ណ ហព ១១:៣១ **២:២៦** ត ខ.១៧,២០ **៣:១** ថ អភ ៤:១១ ទ មថ ៧:១ ធ រម ២:២១ **៣:២** ន ១ពវ ៨:៤៦ រម ៣:៩–២០ យក ២:១០ ១យហ ១:៨ ប ទដ ៣៩:១ សភ ១០:១៩ ១ពត ៣:១០ ផ មថ ១២:៣៧ ព យក ១:២៦ **៣:៣** ភ ទដ ៣២:៩

គ្នានឹងការបកស្រាយអំពីសេចក្ដីស្រលាញ់ខុសឆ្គង នៅក្នុង ១យហ ៣:១៧ (មើលការពន្យល់ខនេះ)។ វគ្គនោះនិយាយអំពីសេចក្ដីស្រលាញ់ដែលមានការប្រព្រឹត្ត ហើយវគ្គនេះនិយាយអំពីសេចក្ដីជំនឿដែលមានការប្រព្រឹត្ត ។

**២:១៨** *អ្នកមានសេចក្ដីជំនឿ ហើយខ្ញុំមានការប្រព្រឹត្ត* ការដែលថា សេចក្ដីជំនឿ និងការប្រព្រឹត្តមិនត្រូវការនឹងគ្នាគឺមិនត្រឹមត្រូវទេ ហើយក៏មិនត្រូវមានគ្រីស្ទបរិស័ទខាងសេចក្ដីជំនឿ និងគ្រីស្ទបរិស័ទខាងការប្រព្រឹត្តដែរ ។ *ចូរអ្នកបង្ហាញ សេចក្ដីជំនឿរបស់អ្នកក្រៅពីការដែលអ្នកប្រព្រឹត្ត* លោកយ៉ាកុបមិនបានជឿថា ការនេះអាចកើតឡើងបានឡើយ ។

**២:១៩** *មានព្រះតែ១* គឺជាការប្រកាសនៃជំនឿដែលជឿថាមានព្រះតែមួយអង្គ ។ ក្នុងជំនឿដ៏ល្បីល្បាញរបស់ពួកសាសនាយូដា គេហៅការប្រកាសនេះជាភាសាហេព្រើរថា"សេម៉ា" ដែលប្រែថា"ឮ"(ចទ ៦:៤ មើលការពន្យល់ ចទ ៦:៤–៩ មក ១២:២៩ និងការពន្យល់)។

**២:២១** ន័យរបស់ខនេះមិនមែនផ្ទុយនឹងសេចក្ដីបង្រៀន ក្នុងព្រះគម្ពីរដែលថា មនុស្សបានសង្គ្រោះដោយសារជំនឿ ហើយមិនមែនការប្រព្រឹត្តនោះទេ(រម ៣:២៨ និងការពន្យល់ កទ ២:១៥–១៦ និងការពន្យល់ ២:១៦) ។ ការប្រព្រឹត្តដោយសុចរិត ជាភស្តុតាងនៃសេចក្ដីជំនឿដ៏ពិត គឺមិនមែនអាចលាងបាបបាននោះទេ ពីព្រោះតាមខ.២៣ (មើល លប ១៥:៦ និងការពន្យល់) "អ័ប្រាហាំបានជឿដល់ព្រះ ហើយសេចក្ដីនោះបានរាប់ជាសេចក្ដីសុចរិតដល់លោក"។ ជាងនេះទៅទៀត លប ១៥:៦ លោកអ័ប្រាហាំមានសេចក្ដីជំនឿមុនពេលថ្វាយអ៊ីសាក់ ដែលគ្រាន់តែជាភស្តុតាងពីភាពពិតនៃសេចក្ដីជំនឿប៉ុណ្ណោះ ។ តាមសេចក្ដីបង្រៀនរបស់លោកប៉ុល សេចក្ដីដែលមានប្រយោជន៍ គឺសេចក្ដីជំនឿដែលប្រព្រឹត្តដោយស្រលាញ់(កទ ៥:៦ និងការពន្យល់)។ សេចក្ដីជំនឿដែលនាំឱ្យបានសេចក្ដីសង្គ្រោះ បង្កើតឱ្យមានការប្រព្រឹត្តល្អ ។

**២:២៣** *សំឡាញ់របស់ទ្រង់* ការហៅដូចនេះ(២របា ២០:៧ និងការពន្យល់) គឺបង្ហាញពីការទទួលស្គាល់ក្នុងទំនាក់ទំនង(សូមធៀប យហ ១៥:១៣–១៥)

**២:២៤** *មិនមែនដោយសារតែសេចក្ដីជំនឿប៉ុណ្ណោះទេ* គឺមិនមែនដោយការយល់ពីសេចក្ដីពិតនោះឡើយ(ការពន្យល់ ២:១៤–២៦)។

**២:២៥** *នាងរ៉ាហាប ជាស្រីសំផឹង* កាលដែលលោកយ៉ាកុបនិយាយពីការងាររបស់នាងរ៉ាហាប មិនមែនមានន័យថា គាត់គាំទ្រការងាររបស់នាងឡើយ ។ គាត់គ្រាន់តែសរសើរនាង ដោយសារតែសេចក្ដីជំនឿរបស់នាង (ហព ១១:៣១ និងការពន្យល់) ដែលនាងបង្ហាញ ដោយការជួយដល់ពួកស៊ើបការ (យស ២)។

**៣:១** *ត្រូវទោសធ្ងន់ជាង* ពីព្រោះគ្រូមានឥទ្ធិពលច្រើន ការទទួលខុសត្រូវក៏ត្រូវមានច្រើនផងដែរ (មថ ២៣:១–៣៣ លក ២០:៤៦–៤៧ ហព ១៣:១៧)

**៣:២** *មនុស្សគ្រប់លក្ខណ៍* បញ្ជាក់ថាមនុស្សពិបាកក្នុងការគ្រប់គ្រងអណ្ដាតណាស់ ហើយអ្នកណាដែលអាចគ្រប់គ្រងអណ្ដាតឱ្យគ្រប់លក្ខណ៍បាន នោះក៏អាចគ្រប់គ្រងខ្លួនឯងនៅក្នុងផ្នែកទាំងអស់នៃជីវិតរបស់ខ្លួនផងដែរ ។

សំពៅដែរ វាធំដល់ម្ល៉េះ ហើយមានខ្យល់គំហុកបក់ផាត់
ទៅផង តែតៃកុងបើកទៅមកបានតាមចិត្ត ក៏ដោយសារ
តែចង្កូតយ៉ាងតូចប៉ុណ្ណោះ ៥ឯអណ្ដាតក៏ជា អវយវៈ១
យ៉ាងតូចដូច្នោះដែរ ប៉ុន្តែ ចេះអួតអាងយ៉ាង សំបើម
ណាស់[ម] មើលចុះ ភ្លើងតែបន្តិចទេ អាចនឹងឆេះព្រៃធំៗទៅ
បាន ៦ហើយអណ្ដាតក៏ជាភ្លើងដែរ[យ] គឺជាលោកីយដ៏
ពេញដោយសេចក្ដីទុច្ចរិត ជាគ្រឿងរាប់បញ្ចូលជា១នឹង
អវយវៈឯទៀតរបស់យើង ជារបស់ដែលធ្វើឱ្យរូបកាយ
ទាំងមូលស្មោកគ្រោក ក៏បញ្ឆេះទាំងផ្លូវជីវិតផង[រ] ហើយ
ភ្លើងឆេះនោះមកពីស្ថាននរកដែរ[ល] ៧រីឯគ្រប់ទាំងពូជ
សត្វព្រៃ សត្វស្លាប សត្វលូនវារ នឹងសត្វនៅក្នុងសមុទ្រ
នោះគេអាចនឹងផ្សាំងបាន ក៏មានមនុស្សបានផ្សាំងហើយ
ដែរ ៨តែឯអណ្ដាតវិញ នោះគ្មានអ្នកណាអាចនឹងផ្សាំង
បានឡើយ គឺជារបស់អាក្រក់ដែលទប់មិនបាន ក៏មាន
ពេញដោយពិសដែលនាំឱ្យស្លាប់[វ] ៩ដោយសារអណ្ដាត
នោះយើងសរសើរដំកើងដល់ព្រះអម្ចាស់ដ៏ជាព្រះវរបិតា
ផង ហើយដាក់បណ្ដាសាដល់មនុស្ស ដែលកើតមកតាមរូប
អង្គព្រះផង[ស] ១០មានទាំងពាក្យសរសើរ នឹងពាក្យប្រទេច
ផ្ដាសា ចេញមកពីមាត់តែ១នោះឯង បងប្អូនអើយ មិន
គួរគប្បីឱ្យមានដូច្នោះឡើយ ១១តើរន្ធទឹកតែ១នឹងអាច
ចេញជាទឹកសាប ហើយភ្លាវផងបានឬទេ ១២បងប្អូនអើយ
តើដើមល្វាអាចនឹងបង្កើតផ្លែជាអូលីវ ឬដើមទំពាំងបាយ
ជូរបង្កើតផ្លែជាល្វាបានឬទេ[ហ] ដូច្នេះគ្មានរន្ធទឹកណាចេញ
ទឹក ជាប្រៃផងសាបផងបានឡើយ ។

## ប្រាជ្ញាពីរយ៉ាង

**៣:៥** ម ទដ ១២:៣,៤ ៧៣:៨,៩
**៣:៦** យ សភ ១៦:២៧ រ មថ ១៥:១១,១៨,១៩ ល មថ ៥:២២
**៣:៨** វ ទដ ១៤០:៣ រម ៣:១៣
**៣:៩** ស លប ១:២៦,២៧ ១កថ ១១:៧
**៣:១២** ហ មថ ៧:១៦
**៣:១៣** ឡ យក ២:១៨ អ ១ពត ២:១២
**៣:១៤** ក ខ.១៦ ២កថ ១២:២០ ខ យក ៥:១៩
**៣:១៥** គ ខ.១៧ យក ១:១៧ ឃ ១ធថ ៤:១
**៣:១៦** ង ខ.១៤ កទ ៥:២០,២១
**៣:១៧** ច ១កថ ២:៦ យក ១:១៧ ឆ ហព ១២:១១ ជ លក ៦:៣៦ ឈ រម ១២:៩
**៣:១៨** ញ មថ ៥:៩ រម ១៤:១៩ ដ សភ ១១:១៨ អស ៣២:១៧ ហស ១០:១២ ភល ១:១១

១៣ក្នុងពួកអ្នករាល់គ្នា បើមានអ្នកណាមានប្រាជ្ញានឹង
យោបល់ ត្រូវឱ្យអ្នកនោះសំដែងចេញជាកិរិយាល្អ[ឡ] ដោយ
សារការដែលខ្លួនប្រព្រឹត្ត[អ] ដោយសេចក្ដីសុភាពនៃប្រាជ្ញា
ចុះ ១៤បើមានសេចក្ដីច្រណែនដ៏ជូរល្វីង និងសេចក្ដីគំនុំក្នុង
ចិត្ត[ក] នោះកុំឱ្យអួតខ្លួន ឬកុហកទទឹងនឹងសេចក្ដីពិតឡើយ[ខ]
១៥ប្រាជ្ញាយ៉ាងនោះមិនមែនមកពីស្ថានលើទេ[គ] គឺជារបស់
ផងលោកីយនេះ ហើយក៏ខាងសាច់ឈាម នឹងខាងអារក្ស
វិញទេតើ[ឃ] ១៦ដ្បិតកន្លែងណាដែលមានសេចក្ដីច្រណែន
និងសេចក្ដីគំនុំ[ង] នោះក៏មានវឹកវរ និងសេចក្ដីអាក្រក់គ្រប់
យ៉ាងដែរ ១៧តែប្រាជ្ញាដែលមកពីស្ថានលើ[ច] នោះមុន
ដំបូងហៅថាបរិសុទ្ធ រួចមកមានមេត្រីចិត្ត[ឆ] សេចក្ដីសំឡូត
ចិត្តទន់ ក៏ពេញដោយសេចក្ដីមេត្តាករុណា[ជ] នឹងផលល្អ
ឥតរើសមុខ ហើយឥតពុតមាយាផង[ឈ] ១៨រីឯផលនៃសេចក្ដី
សុចរិត នោះបានព្រោះចុះដោយសេចក្ដីមេត្រី[ញ] សំរាប់ពួក
អ្នកដែលរក សេចក្ដីមេត្រីនោះឯង[ដ] ។
**៤** ១ឯសេចក្ដីទាស់ទែង និងសេចក្ដីឈ្លោះប្រកែក[ឋ] ក្នុងពួក
អ្នករាល់គ្នា នោះមកពីណា តើមិនមែនមកពីសេចក្ដីសំរើប
ដែលច្បាំង[ឌ]ក្នុងអវយវៈរបស់អ្នករាល់គ្នាទេឬអី ២អ្នករាល់
គ្នាសង្វាតចង់បាន តែមិនបានទេ អ្នករាល់គ្នាសំឡាប់គេ[ឍ]
ហើយមានចិត្តច្រណែន តែពុំអាចនឹងបានឡើយ ក៏ឈ្លោះ
ប្រកែក ហើយតយុទ្ធគ្នា តែមិនបានអ្វីសោះ ពីព្រោះមិនសូម
៣អ្នករាល់គ្នាក៏សូមដែរ តែមិនបានទេ[ណ]ដ្បិតសេចក្ដីសំណូម
នោះបែបអាក្រក់[ត] សំរាប់នឹងចាយបំពេញសេចក្ដីសំរើប
របស់អ្នករាល់គ្នាវិញ ៤ឱពួកកំផិត[ថ]ទាំងប្រុសទាំងស្រីអើយ

**៤:១** ឋ ទត ៣:៩ ឌ រម ៧:២៣ **៤:២** ឍ មថ ៥:២១,២២ យក ៥:៦ ១យហ ៣:១៥ **៤:៣** ណ ទដ ១៨:៤១ មថ ៧:៧ ត ទដ ៦៦:១៨ ១យហ ៣:២២ ៥:១៤

**៣:៦** *លោកិយដ៏ពេញដោយសេចក្ដីទុច្ចរិត* គឺលោកិយដែលមានពេញដោយអំពើបាប ហើយអណ្ដាតជាបុព្វហេតុនៃអំពើបាបជាច្រើន (សូមធៀប មក ៧:២០–២៣) ។ *ភ្លើងឆេះនោះមកពីស្ថាននរក* គឺជាពាក្យប្រៀបប្រដូច ក្នុងន័យថា ប្រភពនៃសេចក្ដីអាក្រក់របស់អណ្ដាតគឺអារក្សសាតាំង(យហ ៨:៤៤ និងពន្យល់)។ *ស្ថាននរក* មើលការពន្យល់ មថ ៥:២២ លក ១៦:២៣ ។

**៣:៩** *តាមរូបអង្គព្រះ* ដោយសារមនុស្សត្រូវបានបង្កើតមកតាមរូបអង្គព្រះ (មើល លប ១:២៦–២៧ និងការពន្យល់) ការជេរប្រទេចដល់មនុស្សជាតិ គឺបង្ហាញពីការមើលងាយដល់ព្រះអម្ចាស់(មើល លប ៩:៦ និងការពន្យល់)

**៣:១១–១២** មានតែចិត្តដែលបានផ្លាស់ប្រែជាថ្មីប៉ុណ្ណោះ ដែលអាចបង្កើតឱ្យមាននូវពាក្យសម្ដីដែលបរិសុទ្ធ ។

**៣:១៣** *ប្រាជ្ញា* មើលការពន្យល់ ១:៥ ។

**៣:១៥** *មិនមែនមកពីស្ថានលើ* គឺមិនមកពីព្រះ(មើល ១:៥ ១កថ ២:៦–២៦ និង ដយ ៤:២៦ និងការពន្យល់)។

**៣:១៦** *មានវឹកវរ* សូមធៀបនឹងឃ្លា "ដ្បិតព្រះទ្រង់មិនមែនជាព្រះនៃសេចក្ដីវឹកវរទេ តែទ្រង់ជាព្រះនៃសេចក្ដីសុខសាន្តវិញ"(១កថ ១៤:៣៣ និងការពន្យល់)។

**៣:១៧** *ឥតរើសមុខ* មើល ២:១–១៣ និងការពន្យល់ ១ធថ ៥:១២ ។

**៣:១៨** *អ្នកដែលរកសេចក្ដីមេត្រីនោះឯង* គឺផ្ទុយនឹងខ.១៦ ។ ភាពវឹកវរមិនអាចបង្កើតផលដែលសព្វព្រះទ័យព្រះឡើយ ។

**៤:២** *សំឡាប់* អ្នកខ្លះយល់ថា ពាក្យនេះត្រូវបានប្រើជាតាមបែបប្រៀបប្រដូច (សូមធៀប មថ ៥:២១–២២)ទៅនឹងពាក្យ "ស្អប់" ។ អ្នកខ្លះទៀតយល់ថា ពាក្យនេះគួរតែមានន័យដូចជា ការដែលនឹងកើតឡើងនៅពេលដែលចំណង់កើនឡើងខ្លាំង រហូតដល់ទប់លែងបាន(ឧ.អ័ហាប់សម្លាប់ណាបោត ១ពវ ២១:១–១៦ ស្ដេចដាវីឌសម្លាប់អ៊ូរី ២សយ ១១)។

**៤:៤** *ពួកកំផិត* សំដៅពួកអ្នកដែលគ្មានភាពស្មោះត្រង់ខាងឯវិញ្ញាណចំពោះព្រះ ពោលគឺពួកអ្នកដែលស្រលាញ់លោកិយជាជាងស្រឡាញ់ព្រះ ។ ចំពោះការកំផិត ខាងវិញ្ញាណ សូមមើល នក ៣៤:១៥ និងការពន្យល់ ។ *លោកិយ* មើលការពន្យល់ ១:២៧ ។

តើមិនដឹងទេឬអីថា ដែលស្រឡាញ់ដល់លោកីយ៍[ទ] នោះគឺ
ជាស្អប់ដល់ព្រះហើយ[ធ] ដូច្នេះ អ្នកណាដែលចូលចិត្តចង់
ធ្វើជាមិត្រសំឡាញ់នឹងលោកីយ នោះឈ្មោះថា បានតាំង
ខ្លួនជាខ្មាំងសត្រូវនឹងព្រះវិញ[ន] ៥ឬតើអ្នករាល់គ្នាស្មានថា
គម្ពីរសំដែងចេញជាឥតប្រយោជន៍ឬអី រីឯព្រះវិញ្ញាណ
ដែលបានសណ្ឋិតនៅក្នុងយើង[ប] ទ្រង់រំឭកដល់យើង ដោយ
មានព្រះហឫទ័យប្រចណ្ឌ ៦តែទ្រង់ផ្តល់ព្រះគុណមកកាន់
តែខ្លាំងឡើង ហេតុនោះបានជាទ្រង់មានបន្ទូលថា «ព្រះទ្រង់
ទាស់ទទឹងនឹងពួកមានឫកធំ តែទ្រង់ផ្តល់ព្រះគុណមកពួក
រាបសាវិញ»[ផ] ៧ដូច្នេះ ត្រូវចុះចូលចំពោះព្រះ ហើយតស៊ូ
នឹងអារក្សវិញចុះ[ព] នោះវានឹងរត់ចេញពីអ្នករាល់គ្នាទៅ
៨ត្រូវចូលទៅជិតព្រះ នោះទ្រង់នឹងចូលមកជិតអ្នករាល់គ្នា
ដែរ[ភ] ឱពួកមានបាបអើយ ចូរលាងដៃឱ្យស្អាតចុះ[ម] ឱពួកអ្នក
មានចិត្ត២អើយ[យ] ចូរសំអាតចិត្តឡើង[រ] ៩ចូរឱ្យមាន សេចក្តី
ទុក្ខ ហើយយំសោក ទាំងស្រក់ទឹកភ្នែកចុះ សូមឱ្យសំណើច
របស់អ្នករាល់គ្នាត្រឡប់ជាដំងូរ ហើយឱ្យសេចក្តីអំណរ
ទៅជាសេចក្តីព្រួយវិញ[ល] ១០ចូរបន្ទាបខ្លួន នៅចំពោះព្រះ
អម្ចាស់ នោះទ្រង់នឹងដំកើងអ្នករាល់គ្នាឡើង[វ]។
១១បងប្អូនអើយ កុំឱ្យនិន្ទាគ្នាឡើយ[ស] អ្នកណាដែលនិន្ទា
ហើយថ្កោលទោសបងប្អូនខ្លួន[ហ] នោះក៏និន្ទា ហើយថ្កោល
ទោសចំពោះក្រិត្យវិន័យដែរ[ឡ] បើអ្នកថ្កោលទោសក្រិត្យ
វិន័យ នោះអ្នកមិនមែនកាន់តាមក្រិត្យវិន័យទេ[អ] គឺឈ្មោះ

៤:៤ ថ អស ៥៤:៥ យរ ៣:២០ ហស ២:២-៥ ៣:១ ៩:១ ទ យក ១:២៧ ធ រម ៨:៧ ១យហ ២:១៥ ន យហ ១៥:១៩
៤:៥ ប ១កថ ៦:១៩
៤:៦ ផ សភ ៣:៣៤ មថ ២៣:១២
៤:៧ ព អក ៤:២៧ ៦:១១ ១ពត ៥:៦-៩
៤:៨ ភ ទដ ៧៣:២៨ សក ១:៣ មឡ ៣:៧ ហព ៧:១៩ ម អស ១:១៦ យ ទដ ១១៩:១១៣ យក ១:៨ រ ទដ ២៤:៤ យរ ៤:១៤
៤:៩ ល លក ៦:២៥
៤:១០ វ ខ.៦ យប ៥:១១ ១ពត ៥:៦
៤:១១ ស រម ១:៣០ ២កថ ១២:២០ ១ពត ២:១ ហ មថ ៧:១ ឡ យក ២:៨ អ យក ១:២២
៤:១២ ក អស ៣៣:២២ យក ៥:៩ ខ មថ ១០:២៨

ថាជាអ្នកថ្កោលទោសវិញ ១២ឯអ្នកដែលតែងក្រឹត្យវិន័យ
ហើយជំនុំជំរះផង នោះមានតែ១ទេ[ក] គឺ ជាព្រះដែលទ្រង់
អាចនឹងជួយសង្គ្រោះ ឬបំផ្លាញក៏បាន[ខ] ចុះតើអ្នកជាអ្វីដែល
ថ្កោលទោសអ្នកដទៃនោះ[គ]។

## ការអួតពីថ្ងៃស្អែក

១៣ឥឡូវនេះ[ឃ] ឯពួកអ្នកដែលថា ថ្ងៃនេះ ឬថ្ងៃស្អែក
យើងនឹងទៅឯក្រុងណាមួយ ហើយនឹងនៅស្រុកនោះ អស់ ១
ឆ្នាំ ដើម្បីនឹងរកស៊ីឱ្យបានចំណេញ[ង] ១៤អ្នករាល់គ្នាមិន
ដឹងជានឹងកើតមានយ៉ាងណាដល់ថ្ងៃស្អែកទេ ដ្បិតជីវិតអ្នក
រាល់គ្នាជាអ្វី គឺជាចំហាយទឹកទេតើ ដែលឃើញ តែ១ភ្លែត
រួចបាត់ទៅ[ច] ១៥គួរតែបាននិយាយដូច្នេះវិញថា បើយើង
រស់នៅ ហើយព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យ[ឆ] នោះ
យើងនឹងធ្វើការនេះ ឬការនោះ ១៦តែឥឡូវនេះ អ្នករាល់
គ្នាមានសេចក្តីអំនួត អំពីពាក្យអួតអាងរបស់ខ្លួនដូច្នោះ
ហើយគ្រប់ទាំងសេចក្តីអំនួតយ៉ាងនោះ សុទ្ធតែអាក្រក់
ទាំងអស់[ជ] ១៧ដូច្នេះ ឯអ្នកណាដែលចេះធ្វើល្អ តែមិនធ្វើ
សោះនោះរាប់ជាបាបដល់ អ្នកនោះវិញ[ឈ]។
**៥** ១ឥឡូវនេះ[ញ] ពួកអ្នកមានអើយ[ដ] ចូរយំសោកចុះ ព្រម
ទាំងស្រែកទ្រហោផង[ឋ] ដោយព្រោះសេចក្តីវេទនា ដែល

គ មថ ៧:១ **៤:១៣** ឃ យក ៥:១ ង សភ ២៧:១ កល ១២:១៨-២០
**៤:១៤** ច យប ៧:៧ ទដ ៣៩:៥ ១០២:៣ ១៤៤:៤ អស ២:២២
**៤:១៥** ឆ កថ ១៨:២១ **៤:១៦** ជ ១កថ ៥:៦ **៤:១៧** ឈ លក ១២:៤៧ យហ ៩:៤១ **៥:១** ញ យក ៤:១៣ ដ លក ៦:២៤ ១ធថ ៦:៩ យក ២:២-៦ ឋ អស ១៣:៦ អក ៣០:២

**៤:៥** *ព្រះវិញ្ញាណ . . . មានព្រះហឫទ័យប្រចណ្ឌ* (សូមមើល កទ ៥:១៧) គឺផ្ទុយពីគ្រប់ទាំងចិត្តដែលគ្មានសេចក្តីស្រឡាញ់របស់លោកិយ ។

**៤:៦** មើល ១ពត ៥:៥ ដែលដកស្រង់ចេញពី សភ ៣:៣៤ ។

**៤:៧–១០** លោកយ៉ាកុបបានបង្ហាញពីវិធីប្រាំយ៉ាងដើម្បីឱ្យអាចចូលទៅជិតព្រះគឺ (១).ចុះចូលចំពោះព្រះ(ខ.៧)។(២).តស៊ូនឹងអារក្ស ។(៣).លាងដៃឱ្យស្អាត . . . សម្អាតចិត្ត(ដើម្បីរស់ក្នុងជីវិតបរិសុទ្ធ) (ខ.៨)។ (៤).មានសេចក្តីទុក្ខ ហើយយំសោក ទាំងស្រក់ទឹកភ្នែក ។ (៥).បន្ទាបខ្លួននៅចំពោះព្រះអម្ចាស់ នោះទ្រង់នឹងតម្កើងអ្នករាល់គ្នាឡើង(យក ៤:១០ ១ពត ៥:៦)។

**៤:៧** *តស៊ូនឹងអារក្ស* មើលការពន្យល់ អក ៦:១០–២០ ១ពត ៥:៨–៩ ។

**៤:៨** *លាងដៃឱ្យស្អាត* មុនពេលពួកសង្ឃសម័យសញ្ញាចាស់ចូលទៅចំពោះព្រះក្នុងត្រសាលជំនុំ ពួកគេត្រូវតែលាងដៃ និងជើងនៅក្នុងចានក្លាំ និងជើងធ្វើពីលង្ហិន ដែលជានិមិត្តរូបនៃការលាងសម្អាតខាងឯវិញ្ញាណ(នក ៣០:១៧–២១)។ ចំពោះការលាងដៃ និងចិត្តដែលបរិសុទ្ធ សូមមើល ទដ ២៤:៤ និងការពន្យល់ ។

**៤:៩** *សេចក្តីទុក្ខ ហើយយំសោក ទាំងស្រក់ទឹកភ្នែក* គឺចំពោះសេចក្តីកំហុសដែលខ្លួនបានប្រព្រឹត្ត ។

**៤:១០** មើល មថ ២៣:១២ លក ១៤:១១ និងការពន្យល់ ១ពត ៥:៦ ។

**៤:១១** *និន្ទា ហើយថ្កោលទោសបងប្អូនខ្លួន . . . ចំពោះក្រិត្យវិន័យ* មើលការពន្យល់ ២:៨, នក ២០:១៦ និងការពន្យល់, ទដ ១៥:៣ ៥០:១៩–២០ សភ ៦:១៦,១៩ និងការពន្យល់ ។ ចំពោះការនិន្ទា ហើយថ្កោលទោសដល់បងប្អូនគ្រីស្ទបរិស័ទ គឺជាការនិន្ទា ហើយថ្កោលទោសក្រឹត្យវិន័យនៃសេចក្តីស្រឡាញ់

**៤:១៣–៥:៦** យក ៤:១៣–១៧ ជាវគ្គដែលនិយាយអំពីអ្នករកស៊ីដែលត្រូវធ្វើដំណើរ និងសេចក្តីអំនួតដែលខុសឆ្គង ហើយ ៥:១–៦ ជាវគ្គដែលនិយាយព្រមានដល់ពួកអ្នកមាន ដែលមិនចេះប្រើទ្រព្យសម្បត្តិឱ្យបានត្រឹមត្រូវ ។

**៤:១៤** *ចំហាយទឹក* សូមធៀបនឹង "ស្រមោល"(១របា ២៩:១៥) "ខ្យល់"(យប ៧:៧) "ពពក"(យប ៧:៩) "ស្រមោលដែលជ្រេទៅ"(ទដ ១០២:១)

**៥:១** ក្នុងខនេះលោកយ៉ាកុបបានប្រកាសពីភាពគ្មានតម្លៃនៃពួកអ្នកមាន មិនមែនពីភាពគ្មានតម្លៃនៃភាពមានបាននោះទេ ។ មាសប្រាក់ក្នុងថ្ងៃនេះនឹងប្រែជាគ្មានតម្លៃនៅពេលព្រះគ្រីស្ទយាងមកជាលើកទីពីរ មានតែទ្រព្យសម្បត្តិដែលនៅក្នុង នគរព្រះប៉ុណ្ណោះដែលស្ថិតស្ថេរនៅអស់កល្បជានិច្ច ។ ប្រាក់មិនមែនជាបញ្ហាទេ ព្រោះគ្រីស្ទបរិស័ទក៏ត្រូវការប្រាក់សម្រាប់ផ្គត់ផ្គង់ជីវភាព និងដំណើរការការងារបម្រើព្រះផងដែរ ។ ម្យ៉ាងវិញទៀតការស្រលាញ់ប្រាក់ប៉ុណ្ណោះដែលជាបញ្ហា ព្រោះការនេះជាមេឫសនៃការអាក្រក់គ្រប់យ៉ាង(១ធថ ៦:១០)។

ត្រូវមកលើអ្នករាល់គ្នា ២ទ្រព្យសម្បត្តិរបស់អ្នក រាល់គ្នាបាន
ពុករលួយ ហើយសំលៀកបំពាក់អ្នករាល់គ្នា ត្រូវកន្លាត
កាត់អស់ហើយ[ឌ] ៣មាសប្រាក់របស់អ្នករាល់គ្នាបានដុះស្នឹម
ឯស្នឹមនោះ នឹងបានទុកសំរាប់ជាទីបន្ទាល់ ទាស់នឹងអ្នក
រាល់គ្នា ហើយនឹងស៊ីសាច់អ្នករាល់គ្នាដូចជាភ្លើង ដ្បិត
អ្នករាល់គ្នាបានខំប្រមូលបង្គរទ្រព្យសម្បត្តិឡើង នៅជាន់
ក្រោយបង្អស់នេះ[ឍ] ៤មើល ប្រាក់ឈ្នួល ដែលអ្នករាល់គ្នា
បានបង្ខានចំពោះពួកដើងឈ្នួល[ណ] ជាអ្នកច្រូតនៅស្រែ
របស់អ្នករាល់គ្នា នោះក៏ស្រែកឡើង ហើយសំរែក[ត]នៃពួក
អ្នកដែលច្រូតនោះ បានឮដល់ព្រះកាណ៌របស់ព្រះអម្ចាស់
នៃពួកពលបរិវារដែរ[ថ] ៥អ្នករាល់គ្នាបាននៅលើផែនដី
បែបប្រសើររុងរឿង តាមតែចិត្តសំរើបស្រើប ទាំងចំអែត
ចិត្ត[ទ]ដូចជានៅថ្ងៃសំឡាប់សត្វ[ធ] ៦អ្នករាល់គ្នាបានកាត់
ទោសក៏បានសំឡាប់[ន]មនុស្សសុចរិត[ប] តែគេមិនបានតយុទ្ធ
នឹងអ្នករាល់គ្នាវិញសោះ ។

## ការអត់ធ្មត់នៅក្នុងការរងទុក្ខលំបាក

៧បងប្អូនអើយ ចូរមានចិត្តអត់ធ្មត់ ដរាបដល់ព្រះអម្ចាស់
ទ្រង់យាងមក[ផ] មើល អ្នកធ្វើស្រែ គេរង់ចាំផល វិសេស
ដែលកើតពីដីមក ដោយសេចក្ដីអត់ធ្មត់[ព] ទាល់តែបានភ្លៀង
ធ្លាក់មកខាងដើមរដូវ នឹងចុងរដូវផង[ភ] ៨ចូរឱ្យអ្នករាល់គ្នា
អត់ធ្មត់ដូច្នោះដែរ ទាំងតាំងចិត្តឱ្យខ្ជាប់ខ្ជួនឡើង ដ្បិតព្រះ
អម្ចាស់ជិត[ម]យាង[យ]មកហើយ ៩បងប្អូនអើយ[រ] កុំឱ្យរទូររទាំ
ទាស់នឹងគ្នាទៅវិញទៅមកឡើយ ក្រែងមានទោស មើល
ចៅក្រម[ល] លោកឈរនៅមាត់ ទ្វារហើយ[វ] ១០បងប្អូនអើយ
ចូរយកពួកហោរា[ស] ដែលបានទាយដោយនូវព្រះនាមព្រះ
អម្ចាស់ ទុកជាគំរូពីសេចក្ដីទុក្ខលំបាក នឹងពីសេចក្ដីអត់ធ្មត់
ចុះ ១១មើល យើងហៅពួកអ្នកដែលទ្រាំទ្រ ថាជាអ្នកមាន
ពរ[ហ] ចុះអ្នករាល់គ្នាបានឮនិយាយ ពីសេចក្ដីអត់ធន់[ឡ]របស់
លោកយ៉ូបទៅហើយ ក៏បានឃើញថាដល់ចុងបំផុត[អ] នោះ
ព្រះអម្ចាស់ទ្រង់មានព្រះហឫទ័យមេត្តាករុណា នឹងសេចក្ដី
អាណិតអាសូរពោរពេញដែរ[ក] ១២តែបងប្អូនអើយ កុំឱ្យ
ស្បថជាដើម ទោះបើនឹងស្ថានសួគ៌ ឬនឹងផែនដីក្ដី ក៏កុំឱ្យ
ស្បថយ៉ាងណាឱ្យសោះតែឱ្យពាក្យ «បាទ »របស់អ្នករាល់គ្នា
បាននៅតែ «បាទ » ហើយពាក្យ «ទេ »នៅតែ «ទេ »
ដដែល ក្រែងអ្នករាល់គ្នាធ្លាក់ទៅជាមានទោស[ខ] ។

## ការអធិស្ឋានដោយជំនឿ

១៣តើមានពួកអ្នករាល់គ្នាណា កើតទុក្ខលំបាកឬទេ ត្រូវ
ឱ្យអ្នកនោះអធិស្ឋាន[គ] តើមានអ្នកណាអរសប្បាយ ឬទេ ត្រូវ
ឱ្យគេច្រៀងសរសើរដល់ព្រះចុះ[ឃ] ១៤តើមានពួកអ្នករាល់

**៥:២** ឌ យប ១៣:២៨ ទដ ៣៩:១១ អស ៥០:៩ មទ្បូ ៦:១៩,២០ **៥:៣** ឍ ខ.៧,៨ **៥:៤** ណ លវ ១៩:១៣ យរ ២២:១៣ មទ្បូ ៣:៥ ត ចទ ២៤:១៥ ថ រម ៩:២៩ **៥:៥** ទ អគ ១៦:៤៩ អម ៦:១ លក ១៦:១៩ ធ យរ ១២:៣ ២៥:៣៤ **៥:៦** ន យក ៤:២ ប ហព ១០:៣៨ **៥:៧** ផ ១កថ ១:៧ ព កទ ៦:៩ ភ ចទ ១១:១៤ យរ ៥:២៤ យអ ២:២៣ **៥:៨** ម ១កថ ១:៧ យ រម ១៣:១១ **៥:៩** រ យក ៤:១១ ល ទដ ៩៤:២ ១កថ ៤:៥ យក ៤:១២ ១ពត ៤:៥

វ មថ ២៤:៣៣ **៥:១០** ស មថ ៥:១២ **៥:១១** ហ មថ ៥:១០ ឡ យប ១:២១,២២ ២:១០ ហព ១០:៣៦ អ យប ៤២:១០ ១២–១៧ ក នក ៣៤:៦ ជន ១៤:១៨ ទដ ១០៣:៨ **៥:១២** ខ មថ ៥:៣៤–៣៧ **៥:១៣** គ ទដ ៥០:១៥

**៥:២** *សំលៀកបំពាក់* គឺជាទម្រង់នៃទ្រព្យសម្បត្តិសម័យបុរាណ(ពច ១៤:១២–១៣ និងការពន្យល់ ១៤:១២ កច ២០:៣៣)។

**៥:៣** *ស្នឹម* គឺកើតឡើងពីការគរលាក់ទុក ហើយវានឹងក្លាយជាបន្ទាល់ទាស់ និងកាត់ទោសពួកអ្នកមានដែលអាត្មានិយម ។ *ជាន់ក្រោយបង្អស់* មើលការពន្យល់ កច ២:១៧ ១ធថ ៤:១ ២ធថ ៣:១ ហព ១:១–២ ១យហ ២:១៨ ។

**៥:៤** *ព្រះអម្ចាស់នៃពួកពលបរិវារ* មើលពន្យល់ លប ១៧:១ ១សយ ១:៣ ។

**៥:៥** *បែបប្រសើររុងរឿង តាមតែចិត្តសំរើបស្រើប* មើល លក ១៦:១៩–៣១ *ថ្ងៃសំឡាប់សត្វ* គឺថ្ងៃជំនុំជម្រះ ។ ពួកអ្នកមានដែលអាក្រក់គឺដូចជាហ្វូងសត្វ ដែលខំបំប៉នខ្លួនឱ្យធំធាត់ជារៀងរាល់ថ្ងៃ ដោយពុំដឹងថាត្រូវសម្លាប់នៅពេលខាងមុខទេ ។

**៥:៦** *កាត់ទោស* គឺប្រហែលជាតាមរយៈការគ្រប់គ្រងតុលាការ ដោយប្រើមាសប្រាក់ និងអំណាច ។

**៥:៧** អ្នកជឿដែលត្រូវរងទុក្ខក្នុងកណ្ដាប់ដៃពួកអ្នកមានដែលអាក្រក់នោះ ត្រូវទន្ទឹងរង់ចាំការយាងមករបស់ព្រះអម្ចាស់ដោយអត់ធ្មត់ ។ *ភ្លៀងធ្លាក់មកខាងដើមរដូវ និងចុងរដូវ* ព្រះគ្រីស្ទទ្រង់នឹងយាងមកតាមពេលកំណត់របស់ទ្រង់ ។

**៥:៩** *កុំឱ្យរទូររទាំ* អ្នកជឿត្រូវមានការអត់ធ្មត់ចំពោះទាំងអ្នកជឿ និងអ្នកមិនជឿ (ខ.៧–៨)។ *ចៅក្រម លោកឈរនៅមាត់ទ្វារហើយ* គឺឃ្លានេះគឺនិយាយសំដៅទៅលើការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ(មើល ខ.៧–៨) ដើម្បីជំនុំជម្រះលោកិយ ។ ការយាងមកជាលើកទីពីរគឺប្រាកដជានឹងកើតឡើងក្នុងពេលឆាប់ៗ (រម ១៣:១២ និងការពន្យល់ ហព ១០:៥ ១ពត ៤:៧ វវ ២២:២០)។ មនុស្សយើងបានរស់នៅក្នុងជាន់ក្រោយបង្អស់(ខ.៣) គឺចាប់តាំងពីពេលដែលព្រះគ្រីស្ទយាងមកយកកំណើតជាមនុស្ស(មើល ហព ១:១–២)។ មហាព្រឹត្តិការណ៍នៅក្នុងគ្រាព្រះគុណ គឺការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ ។ ព្រះគម្ពីរពុំបានប្រាប់ ថាទ្រង់នឹងយាងមកនៅថ្ងៃណាទេ ហើយគ្រីស្ទបរិស័ទត្រូវតែរង់ចាំព្រះរាជដំណើរ ទ្រង់ ។

**៥:១០** *ចូរយកពួកហោរា . . . ទុកជាគំរូពីសេចក្ដីទុក្ខលំបាក និងពីសេចក្ដីអត់ធ្មត់* សូមធៀបនឹង មថ ៥:១២ ២៣:៣១ កច ៧:៥២ ។

**៥:១១** ពួកហោរាជាច្រើនត្រូវរងទុក្ខពីការបៀតបៀន ដូចជា លោកម៉ូសេ លោកអេលីយ៉ា និងលោកយេរេមា ។ ចំពោះសេចក្ដីអំពីការរងទុក្ខសូមមើល យប ១:១ ២:១០ ៣:២៣–២៦ ៤:៧,៨ ៤២:១៧ និង យប ២ ។

**៥:១២** *កុំឱ្យស្បថ* សូមមើល មថ ៥:៣៣–៣៧ និងការពន្យល់ ។ ខនេះមិនមែននិយាយផ្ទុយនឹងសេចក្ដីសម្បថដែលព្រះទ្រង់មានជាមួយនឹងលោកអ័ប្រាហាំ (ហព ៦:១៣ និងការពន្យល់) ឬជាសេចក្ដីសម្បថដែលព្រះយេស៊ូវមានជាមួយនឹងលោកកៃផា(មថ ២៦:៦៣–៦៤) ឬមួយជាសេចក្ដីសម្បថលោកប៉ុល(រម ១:៩ ៩:១) នោះឡើយ ។ ផ្ទុយទៅវិញខនេះហាមឃាត់ចំពោះការប្រើព្រះនាមព្រះមិនបានត្រឹមត្រូវ ឬប្រើវត្ថុសក្ដិសិទ្ធអ្វីមួយ ដើម្បីធានាពាក្យសម្ដី(ខ.១៥ មក ៦:១៣ និងការពន្យល់) ។

គ្នាណាឈឺឬទេ ត្រូវឱ្យអ្នកនោះហៅពួកចាស់ទុំក្នុងពួក
ជំនុំ[ង] មកអធិស្ឋានឱ្យចុះ ព្រមទាំងលាបប្រេងឱ្យ[ច] ដោយនូវ
ព្រះនាមព្រះអម្ចាស់ផង ១៥នោះពាក្យអធិស្ឋាននៃសេចក្ដី
ជំនឿ[ឆ] នឹងជួយសង្គ្រោះដល់មនុស្សហេវនោះ ហើយព្រះ
អម្ចាស់ទ្រង់នឹងប្រោសឱ្យគាត់បានជាឡើង បើគាត់បានធ្វើ
បាបអ្វី នោះនឹងបានអត់ទោសឱ្យផង ១៦ដូច្នេះ ចូរឱ្យអ្នក
រាល់គ្នាលន់តួទោសនឹងគ្នា[ជ] ហើយអធិស្ឋានឱ្យគ្នាទៅវិញ
ទៅមក ដើម្បីឱ្យបានជាចុះ[ឈ] ដ្បិតសេចក្ដីទូលអង្វរដ៏អស់ពី
ចិត្តរបស់មនុស្សសុចរិត នោះពូកែណាស់[ញ] ១៧ឯហោរា
អេលីយ៉ា លោកមានចិត្តដូចជាយើងដែរ[ដ] តែលោកបាន
អធិស្ឋាន សូមកុំឱ្យមានភ្លៀង នោះនៅផែនដីក៏រាំងអស់
រវាង៣ឆ្នាំ៦ខែ[ឋ] ១៨រួចលោកបានអធិស្ឋានម្ដងទៀត នោះ
មេឃក៏បង្អុរភ្លៀងធ្លាក់មក ហើយដីបានបង្កើតផលផ្លែ
ឡើង[ឌ]។
១៩បងប្អូនអើយ បើមានអ្នកណាក្នុងពួកអ្នករាល់គ្នាគេ
វង្វេងចេញពីសេចក្ដីពិត[ឍ] ហើយមានអ្នកណានាំអ្នក នោះឱ្យ
ត្រឡប់មកវិញ[ណ] ២០នោះត្រូវដឹងថា អ្នកណាដែលនាំមនុស្ស
បាប ឱ្យត្រឡប់ពីផ្លូវវង្វេងមកវិញ នោះឈ្មោះថាបានជួយ
សង្គ្រោះ[ត] ព្រលឹង១ឱ្យរួចពីសេចក្ដីស្លាប់ ហើយក៏គ្របបាំង
អំពើបាបជាអនេកអនន្តផង[ថ]។

**៥:១៣** ឃ កល ៣:១៦
**៥:១៤** ង កច ១១:៣០ ច ទជ ២៣:៥ អស ១:៦ មក ៦:១៣ ១៦:១៨ លក ១០:៣៤
**៥:១៥** ឆ យក ១:៦
**៥:១៦** ជ មថ ៣:៦ កច ១៩:១៨
**៥:១៦** ឈ ហព ១២:១៣ ១ពត ២:២៤ ញ មថ ៧:៧ យហ ៩:៣១ **៥:១៧** ដ កច ១៤:១៥ ឋ ១ពវ ១៧:១ លក ៤:២៥
**៥:១៨** ឌ ១ពវ ១៨:៤១–៤៥ **៥:១៩** ឍ យក ៣:១៤ ណ មថ ១៨:១៥
**៥:២០** ត រម ១១:១៤ ថ ១ពត ៤:៨

**៥:១៤** *ពួកចាស់ទុំ* មើលការពន្យល់ ១ធថ ៣:១ ៥:១៧ ។ *ពួកជំនុំ* មើលការពន្យល់ មថ ១៦:១៨ ។ *ប្រេង* គឺថ្នាំ(នៅសម័យលោកយ៉ាកុប ពាក្យនេះមានន័យថា ឱសថបុរាណដ៏ល្បីឈ្មោះ សូមមើល អស ១:៦ និងការពន្យល់ លក ១០:៣៤)។ អ្នកខ្លះជឿថា លោកយ៉ាកុបប្រហែលប្រើពាក្យនេះសំដៅទៅលើថ្នាំ ។ អ្នកខ្លះទៀត ជឿថា គាត់សំដៅទៅលើថ្នាំដែលប្រើរួមផ្សំជាមួយសេចក្ដីជំនឿ មានន័យថា ព្រះទ្រង់ឆ្លើយតបចំពោះការអធិស្ឋានដោយជំនឿ រួមជាមួយនឹងការព្យាបាលជម្ងឺដោយប្រើថ្នាំ(ឧ.៥ មក ៦:១៣ និងការពន្យល់)។

**៥:១៧** *ហោរាអេលីយ៉ា . . . បានអធិស្ឋាន* សូមមើល ១ពវ ១៨ ។ គេជឿថា រយៈពេលបីឆ្នាំកន្លះ(លក ៤:២៥) គឺជាចំនួនគត់(ពាក់កណ្ដាលនៃចំនួនប្រាំពីរ) បើតាម ១ពវ ១៨:១(មើលការពន្យល់ខនេះ, សូមផ្ទៀប វវ ១១:១–៦ និងការពន្យល់)។

**៥:១៩** *បងប្អូនអើយ* មើលការពន្យល់ រម ១:១៣ ។ *វង្វេងចេញពីសេចក្ដីពិត* ការវង្វេងចេញនេះ សំដៅចំពោះគ្រីស្ទបរិស័ទដែលមានជំនឿខុសឆ្គង គឺជំនឿមិនពិតប្រាកដ (សូមផ្ទៀប ហព ៦:៤–៨ និងការពន្យល់ ៦:៤–៦ ២ពត ២:២០–២២ និងការពន្យល់) ឬគ្រីស្ទបរិស័ទដែលនៅតែបន្តធ្វើអំពើបាប ជាអ្នកដែលត្រូវនាំមកវិញ ។

**៥:២០** *គ្របបាំងអំពើបាបជាអនេកអនន្ត* អ្នកដែលវង្វេងនឹងបានទទួលការអត់ទោសបាបពីព្រះអម្ចាស់ បើគេប្រែចិត្ត( សភ ១០:១២ និងការពន្យល់)។

# សំបុត្រទី ១
របស់
# ពេត្រុស

សេចក្ដីផ្ដើម

## អ្នកនិពន្ធ និងកាលបិរច្ឆេទ

អ្នកនិពន្ធបានបង្ហាញពីអត្តសញ្ញាណរបស់ខ្លួនថា ជាលោកសាវ័កពេត្រុស (១:១) ហើយមាតិការ និងលក្ខណៈនៃសំបុត្រនេះក៏បានបង្ហាញថាលោកពេត្រុសជាអ្នកនិពន្ធផងដែរ (មើលការពន្យល់ ១:១២ ៤:១៣ ៥:១–២,៥,១៣)។ ជាងនេះទៅទៀត សំបុត្រនេះបានឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រ និងការប្រើប្រាស់ពាក្យដែលមាននៅក្នុងព្រះគម្ពីរដំណឹងល្អ និងព្រះគម្ពីរកិច្ចការ (ការដកស្រង់ពាក្យសម្ដីរបស់លោកពេត្រុស)។ ខ្លឹមសាររបស់សំបុត្រនេះបានឆ្លុះបញ្ចាំងពីបទពិសោធន៍ និងទំនាក់ទំនងរបស់លោកពេត្រុស នៅក្នុងរយៈពេលដែលព្រះអម្ចាស់ទ្រង់នៅបំពេញព្រះរាជកិច្ចរបស់ទ្រង់នៅលើផែនដី និងនៅសម័យពួកសាវក ឧទាហរណ៍ លោកពេត្រុសបានជួបគ្នាជាមួយនឹងសាវកប៉ុល ហើយការដែលសាវកប៉ុលសរសេរសំបុត្រត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុង ២ពត ៣:១៥–១៦ (មើលការពន្យល់វគ្គនេះ) កទ ១:១៨ ២:១–២១ និងបទគម្ពីរផ្សេងៗទៀត ។ ដូចនេះ ការដែលលោកពេត្រុសមានគំនិតយល់ស្របនឹងសំបុត្ររបស់លោកសាវកប៉ុលមិនមែនជាការគួរឱ្យភ្ញាក់ផ្អើលនោះទេ ។ នៅដើមសំបុត្រគេអាចដឹងបានថា សំបុត្រនេះគឺជាស្នាដៃនិពន្ធរបស់សាវកពេត្រុស ។ តាម ២ពត ៣:១ (មើលការពន្យល់) លោកពេត្រុសបានប្រាប់ថា គាត់បានសរសេរសំបុត្រពេត្រុសទាំងពីរខ្សែ ។

ពួកគ្រូបង្រៀនគោលទ្ធិគ្រីស្ទបរិស័ទល្បីៗនៅសម័យបុរាណបានធ្វើបន្ទាល់ផងដែរថា លោកពេត្រុសជាអ្នកនិពន្ធនៃសំបុត្រនេះ ដែលមានដូចជាលោកអ៊ីរ៉ាន៉េស (Irenaeus) (គ.ស.១៤០–២០៣) លោកទ័រទូលាន (Tertullian) (គ.ស.១៥០–២២២) លោកក្លេមិននៃក្រុងអឡេក្សានទ្រា (Clement of Alexandria) (១៥៥–២១៥) និងលោកអូរីហ្គេន (Origen) (១៨៥–២៥៣)។

ទោះជាយ៉ាងណាក៏ដោយ មានអ្នកខ្លះអះអាងថា លោកពេត្រុសមិនមានលទ្ធភាពប្រើសំនួនវោហាស័ព្ទរបស់ភាសាក្រេកនៅក្នុងសំបុត្រនេះបានឡើយ ។ ប៉ុន្តែនៅក្នុងសម័យដែលគាត់រស់នៅ គេប្រើភាសាអ៊ើរ៉ាម ហេព្រើ និងក្រេកនៅក្នុងទឹកដីបរិសុទ្ធ ដូចនេះគាត់ប្រហែលជាចេះលើសពីមួយភាសា ។ ការដែលគាត់មិនបានរៀនសូត្រច្រើន (កច ៤:១៣) មិនមានន័យថា គាត់មិនចេះភាសាក្រេកនោះឡើយ តាមការពិតគាត់ជាអ្នកនេសាទ នៅស្រុកកាលីឡេ ដូចនេះគាត់ទំនងជាចេះភាសាក្រេក ។ បើគាត់មិនចេះភាសាក្រេកនៅពេលដែលពួកជំនុំទើបនឹងចាប់ផ្ដើមទេ នោះប្រហែលជាគាត់រៀនភាសាក្រេកជាជំនួយនៅក្នុងការងារបម្រើព្រះ ដែលនាំឱ្យគាត់អាចចេះប្រើសំនួនវោហាស័ព្ទភាសាក្រេកនៅក្នុងសំបុត្រពេត្រុសខ្សែទី១នេះ ។

ជាការពិតណាស់ អក្សរសាស្ត្រក្រេកត្រូវបានប្រើនៅក្នុងការសរសេរសំបុត្រពេត្រុសខ្សែទី១យ៉ាងប្រសើរ ហើយទោះជាលោកពេត្រុសពិតជាចេះនិយាយភាសាក្រេកដូចមនុស្សជាច្រើនទៀតនៅតំបន់សមុទ្រមេឌីទែរ៉ាណេក៏ដោយ ក៏គាត់មិនទំនងជាអាចប្រើភាសាក្រេកបានយ៉ាងល្អដូចនេះទេ ។ តាម ៥:១២ លោកពេត្រុសបាននិយាយថា "ខ្ញុំបានសរសេរយ៉ាងខ្លី ផ្ញើមកអ្នករាល់គ្នា ដោយសារអ្នកស៊ីលវ៉ាន" ។ ឃ្លា "ដោយសារអ្នក ស៊ីលវ៉ាន" មានន័យថា លោកស៊ីលវ៉ានមិនគ្រាន់តែជាអ្នកនាំសំបុត្រនេះប៉ុណ្ណោះទេ តែថែមទាំងជាអ្នកជំនួយនៅក្នុងការសរសេរផងដែរ ។ អ្នកខ្លះបានអះអាងថា បទគម្ពីរ កច ១៥:២២–២៩ ក៏អាចបង្ហាញផងដែរថា លោកស៊ីលវ៉ាន (ឬស៊ីឡាស) ជាអ្នកជំនួយនៅក្នុងការប្រើអក្សរសាស្ត្រក្រេកក្នុងសំបុត្រនេះ ។ នៅសម័យនោះ អ្នកកត់ត្រាច្រើនតែជាអ្នកដែលពូកែប្រើភាសាក្រេកនៅក្នុងការចងក្រងឯកសារ ឱ្យអ្នកដែលមិនអាចប្រើភាសាក្រេកបាន ។ ដូចនេះ ការប្រើអក្សរសាស្ត្រក្រេកក្នុងការសរសេរសំបុត្រពេត្រុសខ្សែទី១នេះអាចជាជំនួយរបស់លោកស៊ីលវ៉ាន រីឯនៅក្នុងការសរសេរសំបុត្រពេត្រុសខ្សែទី២វិញ លោកពេត្រុសប្រហែលជាប្រើអក្សរសាស្ត្រក្រេកតាមបែបសាមញ្ញដោយខ្លួនឯង ។

កាលបរិច្ឆេទនៃការសរសេរសំបុត្រនេះ គឺនៅដើមទសវត្សរ៍ទី៦០នៃស.វ.ទី១ ហើយមិនអាចនៅមុនដើមទសវត្សរ៍ទី៦០បានឡើយ ព្រោះសំបុត្រនេះមានលក្ខណៈប្រហាក់ប្រហែលនឹងសំបុត្រដែលលោកសាវ័ប៉ុលសរសេរក្នុងគុក (សំបុត្រកូល៉ុស និងអេភេសូរមិនមានកាលបរិច្ឆេទនៅមុនទសវត្សរ៍ទី៦០ទេ)។ សូមធៀប ១:១–៣ នឹង អភ ១:១–៣ ២:១៨ នឹង កល ៣:២២ ៣:១–៦ នឹង អភ ៥:២២–២៤ ។ ជាងនេះទៅទៀត កាលបរិច្ឆេទនៃសំបុត្រនេះ មិនអាចនៅក្រោយឆ្នាំ ៦៧ ឬ៦៨ ឡើយ ព្រោះលោកពេត្រុសត្រូវគេបៀតបៀនសម្លាប់នៅក្នុងរាជ្យស្ដេចនេរ៉ូ ។

## ទីកន្លែង

នៅក្នុង ៥:១៣ លោកពេត្រុសបានបង្ហាញថា នៅ"ក្រុងបាប៊ីឡូន" នៅពេលដែលលោកនិពន្ធព្រះគម្ពីរពេត្រុសទី១នេះ ។ មានការកាត់

ស្រាយជាច្រើនថា លោកពេត្រុសសរសេរសំបុត្រនេះនៅ (១).ក្រុងបាប៊ីឡូននៃប្រទេសអេស៊ីព្ទ ដែលជាទីតាំងទ័ព (២).ក្រុងបាប៊ីឡូននៅតំបន់មេសូប៉ូតាមា (៣).ក្រុងយេរូសាឡិម និង(៤).ក្រុងរ៉ូម ។ លោកពេត្រុសប្រហែលជាប្រើពាក្យ "បាប៊ីឡូន" ក្នុងន័យប្រៀបប្រដូចដូចនៅក្នុងព្រះគម្ពីរវិវរណៈ(វវ ១៤:៨ ១៧:៩-១០ និងការពន្យល់)។ អ្នកដែលបានកំណត់យកទីក្រុងរ៉ូមជាកន្លែងដែលគាត់សរសេរសំបុត្រនេះ ដោយសារផ្នែកចុងក្រោយនៃជីវិតរបស់គាត់គឺនៅទីក្រុងរ៉ូម ហើយអ្នកនិពន្ធនៅក្នុងពួកជំនុំដំបូងក៏បានជឿផងដែរថា គាត់សរសេរសំបុត្រពេត្រុសខ្សែទី១នៅក្រុងនេះ ។ អ្នកខ្លះទៀតបានចង្អុលបង្ហាញថា (១).នៅ ស.វ.ទី១ ក្រុងបាប៊ីឡូនត្រូវបានគេស្គាល់ថាជាក្រុងដ៏តូចមួយនៅតាមដងទន្លេអឺប្រាត (២).មុនការនិពន្ធព្រះគម្ពីរវិវរណៈ(ប្រហែលឆ្នាំ ៩៥ គ.ស.) គ្មានភ័ស្តុតាងណាមួយបញ្ជាក់ថាពាក្យ"ក្រុងបាប៊ីឡូន" គឺជាន័យធៀបរបស់ពាក្យ "ក្រុងរ៉ូម"ឡើយ (៣).បរិបទនៃ ៥:១៣ ហាក់ដូចជាគ្មានបង្កប់ន័យប្រៀបធៀបអ្វីឡើយ ។

**អ្នកទទួល** មើលការពន្យល់ ១:១ ។

**ខ្លឹមសារ**

ទោះសំបុត្រពេត្រុសខ្សែទីមួយជាសំបុត្រខ្លីក៏ដោយ ក៏សំបុត្រនេះបាននិយាយជាច្រើនអំពីគោលទ្ធិ និងជីវិត និងកាតព្វកិច្ចរបស់គ្រីស្ទបរិស័ទដែរ ។ ដូចនេះគ្រីស្ទបរិស័ទអាចរកឃើញខ្លឹមសារសំខាន់ៗជាច្រើននៅក្នុងសំបុត្រនេះ ។ ឧទាហរណ៍ សំបុត្រនេះមានលក្ខណៈជាសំបុត្រនៃការញែកចេញការរងទុក្ខ និងការបៀតបៀន ការរងទុក្ខនឹងសិរីល្អ សេចក្ដីសង្ឃឹម សេចក្ដីក្លាហាន និងព្រះគុណដ៏ពិតនៃព្រះ ។ លោកពេត្រុសបានមានប្រសាសន៍ថា លោកបានសរសេរសំបុត្រនេះ "ដើម្បីនឹងទូន្មាន ហើយធ្វើបន្ទាល់ថា ព្រះគុណនៃព្រះដែលអ្នករាល់គ្នាកាន់ខ្ជាប់តាម នោះជាព្រះគុណពិតប្រាកដហើយ"(៥:១២)។ សំបុត្រនេះបានរាប់បញ្ចូលការលើកទឹកចិត្តជាបន្តបន្ទាប់(ជាលក្ខណៈបង្គាប់) ដោយចាប់ផ្ដើមពី ១:១៣ ដល់ ៥:១១ ។

**គម្រោងសង្ខេប**

**I. ពាក្យជម្រាបសួរ (១:១-២)**

**II. ការសរសើរដល់ព្រះចំពោះព្រះគុណ និងសេចក្ដីសង្គ្រោះរបស់ទ្រង់(១:៣-១២)**

**III. ការលើកទឹកចិត្តពីជីវិតដែលបរិសុទ្ធ (១:១៣-៥:១១)**

- ក. សេចក្ដីត្រូវការនៃភាពបរិសុទ្ធ(១:១៣-២:៣)
- ខ. ឋានៈរបស់គ្រីស្ទបរិស័ទ(២:៤-១២)
  - ១. ផ្ទះខាងឯវិញ្ញាណ(២:៤-៨)
  - ២. រាស្ត្រជ្រើសតាំង(២:៩-១០)
  - ៣. អ្នកមកសំណាក់នៅ(២:១១-១២)
- គ. ការចុះចូលនឹងរដ្ឋអំណាច(២:១៣-៣:៧)
  - ១. ការចុះចូលនឹងអ្នកដឹកនាំ(២:១៣-៣:១៧)
  - ២. ការចុះចូលនឹងចៅហ្វាយនាយ(២:១៨-២០)
  - ៣. គំរូរបស់ព្រះគ្រីស្ទពីការចុះចូល(២:២១-២៥)
  - ៤. ការចុះចូលរបស់ប្រពន្ធចំពោះប្ដី(៣:១-៦)
  - ៥. កាតព្វកិច្ចរបស់ប្ដីចំពោះប្រពន្ធ(៣:៧)
- ឃ. កាតព្វកិច្ចដែលគ្រប់គ្នាត្រូវមាន(៣:៨-១៧)
- ង. គំរូរបស់ព្រះគ្រីស្ទ(៣:១៨-៤:៦)
- ច. ការប្រព្រឹត្តដោយដឹងថារបស់ទាំងអស់ជិតដល់ទីបញ្ចប់ហើយ(៤:៧-១១)
- ឆ. ការប្រព្រឹត្តរបស់អ្នកដែលរងទុក្ខថ្វាយព្រះគ្រីស្ទ(៤:១២-១៩)
- ជ. ការប្រព្រឹត្តរបស់មនុស្សចាស់(៥:១-៤)
- ឈ. កាប្រព្រឹត្តរបស់អ្នកនៅក្មេង(៥:៥-១១)

**IV. គោលបំណងចុងក្រោយនៃសំបុត្រ(៥:១២)**

**V. សេចក្ដីផ្ដាំផ្ញើ ពាក្យជម្រាបសួរ និងការឱ្យពរ (៥:១៣-១៤)**

**១** ១សំបុត្រពេត្រុស ជាសាវកនៃព្រះយេស៊ូវគ្រីស្ទ[ក] ខ្ញុំផ្ញើមក
ពួកអ្នកខ្ចាត់ខ្ចាយ[ខ] ដែលសំណាក់[គ]នៅស្រុកប៉ុនតុស[ឃ] ស្រុក
កាឡាទី[ង] ស្រុកកាប៉ាដូគា ស្រុកអាស៊ី និងស្រុកប៊ីធូនា[ច] ២ជា
ពួកអ្នករើសតាំង[ឆ] តាមបុព្វញ្ញាណ[ជ]នៃព្រះដ៏ជាព្រះវរបិតា
ដោយព្រះវិញ្ញាណទ្រង់ញែកជាបរិសុទ្ធ[ឈ] ដើម្បីឱ្យបានស្តាប់
បង្គាប់[ញ] ព្រមទាំងបានព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ
ប្រោះលើខ្លួន[ដ] សូមឱ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ
និងសេចក្តីសុខសាន្ត កាន់តែច្រើនឡើង[ឋ]។

### សរសើរដល់ព្រះដែលប្រទានសង្ឃឹមដ៏រស់

៣សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវ
គ្រីស្ទ[ឌ]ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានបង្កើត
យើងឡើងជាថ្មី[ឍ] តាមសេចក្តីមេត្តាករុណាដ៏ធំរបស់ទ្រង់[ណ]
ដើម្បីឱ្យយើងរាល់គ្នាបានសេចក្តីសង្ឃឹមដ៏រស់[ត] ដោយសារ
ព្រះយេស៊ូវគ្រីស្ទ ទ្រង់រស់ពីស្លាប់ឡើងវិញ[ថ] ៤ហើយឱ្យ
យើងបានមរដក[ទ] ដែលមិនចេះពុករលួយ ក៏ឥតសៅហ្មង
ហើយមិនដែលស្រពោនឡើយ[ធ] ជាមរដកដែលបំរុងទុកឱ្យ
យើងរាល់គ្នា នៅស្ថានសួគ៌[ន] ៥គឺឱ្យយើងរាល់គ្នា ដែលព្រះ
ចេស្តា[ប]នៃព្រះកំពុងតែថែរក្សា ដោយសារសេចក្តីជំនឿ
សំរាប់ឱ្យបានសេចក្តីសង្គ្រោះ[ផ] ដែលប្រុងប្រៀបនឹងសំដែង
មក[ព]នៅជាន់ក្រោយបង្អស់នោះ ៦អ្នករាល់គ្នាក៏មានសេចក្តី
អំណរជាខ្លាំង[ភ] ក្នុងសេចក្តីសង្គ្រោះនោះ ទោះបើសព្វថ្ងៃ
នេះត្រូវរងទុក្ខព្រួយជាយូរបន្តិច[ម] ដោយកើតមានសេចក្តី
ល្បួងផ្សេងៗក៏ដោយ[យ] ៧ដើម្បីឱ្យការសាកលសេចក្តីជំនឿ
នៃអ្នករាល់គ្នា ដ៏វិសេសជាងមាសដែលតែងតែខូច ទោះ
បើបានសាកនឹងភ្លើងក៏ដោយ[រ] នោះបានឃើញ[ល]សំរាប់ជា
សេចក្តីសរសើរ កេរ្តិ៍ឈ្មោះ[វ] និងសិរីល្អក្នុងកាលដែល

**១:១** ក ២ពត ១:១ ខ យក ១:១ គ ហព ១១:១៣ ឃ កថ ២:៩ ១៨:២ ង កថ ១៦:៦ ច កថ ១៦:៧ **១:២** ឆ មថ ២៤:២២ ជ រម ៨:២៩ ឈ ២ថន ២:១៣ ញ ខ.១៤,២២ ដ ហព ១០:២២ ១២:២៤ ឋ រម ១:៧ **១:៣** ឌ ២កថ ១:៣ ឍ អភ ១:៣ ណ ខ.២៣ យហ ១:១៣ ត ខ.១៣,២១ ហព ៣:៦ ថ ១កថ ១៥:២០ ១ពត ៣:២១

**១:៤** ទ កថ ២០:៣២ រម ៨:១៧ ធ ១ពត ៥:៤ ន កល ១:៥ ២ធថ ៤:៨ **១:៥** ប ១សយ ២:៩ យហ ១០:២៨ ផ រម ១១:១៤ ព រម ៨:១៨ **១:៦** ភ រម ៥:២ ម ១ពត ៥:១០ យ យក ១:២ ១ពត ៤:១២ **១:៧** រ យប ២៣:១០ ទដ ៦៦:១០ សភ ១៧:៣ អស ៤៨:១០ ល យក ១:៣ វ ២កថ ៤:១៧

**១:១** *ពេត្រុស* មើលសេចក្តីផ្តើមត្រង់អ្នកនិពន្ធ និងកាលបរិច្ឆេទ និងការពន្យល់ មថ ១៦:១៨ យហ ១:៤២ ។ *សាវក* មើលការពន្យល់ មក ៦:៣០ ១កថ ១:១ ហព ៣:១ ។ *ដែលសំណាក់* មានន័យថាមានទីលំនៅបណ្តោះអាសន្ននៅលើផែនដី ប៉ុន្តែ មានផ្ទះអស់កល្បជានិច្ចនៅស្ថានសួគ៌(សូមធៀប ១របា ២៩:១៥ ទដ ៣៩:១២ និង ការពន្យល់ ហព ១៣:១៤)។ *ខ្ចាត់ខ្ចាយដែលសំណាក់នៅស្រុកប៉ុនតុស . . . ប៊ីធូនា* គឺគ្រីស្ទបរិស័ទសាសន៍យូដា និងសាសន៍ដទៃដែលខ្ចាត់ខ្ចាយ ភាគច្រើននៅក្នុង ទឹកដីនៃតំបន់អាស៊ីមីន័រ ។ ពួកគេមានវត្តមាននៅក្រុងយេរូសាឡិមនៅថ្ងៃបុណ្យ ទី៥០(កថ ២:៩–១១)។ លោកប៉ុលបានចែកចាយ និងបង្រៀននៅក្នុងស្រុកដែលមាននិយាយក្នុងខនេះ(កថ ១៦:៦ ១៨:២៣ និងការពន្យល់ ១៩:១០,២៦)។

**១:២** *រើសតាំង* មើលការពន្យល់ អភ ១:៤ ។ *បុព្វញ្ញាណ* មើលការពន្យល់ រម ៨:២៩ ។ *ព្រះដ៏ជាព្រះវរបិតា... ព្រះវិញ្ញាណ... ព្រះយេស៊ូវ* គឺអង្គទាំងបីនៃព្រះត្រៃឯក(ការពន្យល់ មថ ២៨:១៩) ដែលមានចំណែកនៅក្នុងការសង្គ្រោះពួករើសតាំង ។ *ញែកជាបរិសុទ្ធ* មើលការពន្យល់ ១កថ ១:២ ២ថន ២:១៣ ។ ព្រះវិញ្ញាណបរិសុទ្ធទ្រង់ធ្វើការក្នុងចិត្តមនុស្ស ដើម្បីឱ្យបានទទួលជឿលើព្រះគ្រីស្ទ ហើយញែកពួកគេចេញជាបរិសុទ្ធសម្រាប់ការងារបម្រើព្រះ(២ថន ២:១៣)។ *បានស្តាប់បង្គាប់* មានន័យថា ព្រះទ្រង់សព្វព្រះទ័យឱ្យការញែកចេញជាបរិសុទ្ធ នេះកើតមានដល់រាស្ត្ររបស់ទ្រង់ ដើម្បីឱ្យពួកគេបានស្តាប់បង្គាប់ដល់ទ្រង់ ។ *ព្រមទាំងព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទប្រោះលើខ្លួន* ផលនៃសេចក្តីប្រោសលោះនៃព្រះគ្រីស្ទគឺសម្រាប់រាស្ត្ររបស់ទ្រង់(សូមធៀប នក ២៤:៤–៨ អស ៥២:១៥ ហព ៩:១១–១៤ ១៨–២៨)។ *ព្រះគុណ និងសេចក្តីសុខសាន្ត* មើលការពន្យល់ រម ១:៧ ។

**១:៣** *បង្កើតយើងឡើងជាថ្មី* មើល យហ ៣:៣–៨ និងការពន្យល់ ៣:៣ ។ *សេចក្តីមេត្តាករុណា* មើលការពន្យល់ រម ៩:២២–២៣ ។ *សេចក្តីសង្ឃឹមដ៏រស់* មានន័យថា ទោះបីជាត្រូវរងទុក្ខលំបាក និងការបៀតបៀនជាញឹកញាប់ក៏ដោយ(ខ.៦ ២:១២ ១៨–២៥ ៣:១៣–១៨ ៤:១,៤,១២–១៩ ៥:១,៧–១០) ក៏សេចក្តីសង្ឃឹមនៅតែរស់ក្នុងចិត្តជានិច្ច (មើលសេចក្តីផ្តើមត្រង់ខ្លឹមសារ)។ សេចក្តីសង្ឃឹមតាមព្រះគម្ពីរគឺជាសេចក្តីសង្ឃឹមដែលមានការធានាដោយសេចក្តីពិត(មើលការពន្យល់ អភ ១:១៨)។ *ព្រះយេស៊ូវគ្រីស្ទទ្រង់រស់ពីស្លាប់ឡើងវិញ* គឺជាសេចក្តីធានាដល់រាស្ត្ររបស់ព្រះថាពួកគេនឹងបានរស់ឡើងវិញផងដែរ(១កថ ១៥:២០–២៣ និងការពន្យល់ ១៥:២០,២៣)។

**១:៤** *ឱ្យយើងបានមរដក* អ្នកជឿព្រះមិនគ្រាន់តែកើតជាថ្មី ដោយមានសេចក្តីសង្ឃឹមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនឹងបានទទួលនូវមរតកដ៏អស់កល្បជានិច្ច ដែលពួកគេត្រូវសង្ឃឹមថានឹងបានជាប្រាកដមែន (មើល ហព ៩:១៥ និងការពន្យល់)។

**១:៥** *ព្រះចេស្តា . . .ដោយសារសេចក្តីជំនឿ* ការតស៊ូរបស់គ្រីស្ទបរិស័ទត្រូវបានការពារដោយ (១).អំណាចព្រះចេស្តាព្រះ និង(២).ជំនឿរបស់ពួកគេដែលមិនបណ្តាលឱ្យពួកគេធ្វើខុសនឹងឆន្ទៈរបស់ខ្លួន ឬឃ្លាតចេញពីព្រះរាជកិច្ចរបស់ព្រះឡើយ ។ *សេចក្តីសង្គ្រោះ* មើលការពន្យល់ ២ធថ ១:៩ ។ តាមព្រះគម្ពីរសេចក្តីសង្គ្រោះរបស់មនុស្សម្នាក់ (១).ក្នុងអតីតកាលជាពេលដែលអ្នកនោះទទួលជឿព្រះជាលើកដំបូង(ទត៣:៥) (២).ក្នុងពេលបច្ចុប្បន្នជាពេលដែលសេចក្តីសង្គ្រោះ និងការសម្អាតជាបរិសុទ្ធកំពុងតែធ្វើការក្នុងជីវិតអ្នកនោះ(ខ.២ និងការពន្យល់ ខ.៩ លវ ១១:៤៤ និងការពន្យល់ ១កថ ១:១៨) និង(៣).ក្នុងអនាគតកាលជាពេលដែលព្រះគ្រីស្ទទ្រង់យាងត្រឡប់មកវិញ ហើយសេចក្តីសង្គ្រោះ ឬការជម្រះជាបរិសុទ្ធត្រូវចប់សព្វគ្រប់ ដោយការលើកឡើងនូវពួកបរិសុទ្ធ (មើលក្នុង ខនេះ និង រម ៨:២៣,៣០ ១៣:១១ ហព ៩:២៨ យក ១:២១ និងការពន្យល់)។

**១:៧** *ដើម្បីឱ្យការសាកលសេចក្តីជំនឿនៃអ្នក... នោះបានឃើញ* មើល រម ៥:៣ យក ១:២–៤ ។ សេចក្តីជំនឿពិតជាមានតម្លៃណាស់ ប៉ុន្តែ គ្រីស្ទបរិស័ទត្រូវឆ្លងកាត់ការសាកលមើលសេចក្តីជំនឿ ដែលជាការមានតម្លៃណាស់ ។ អ្នកជឿនឹងមានចំណែកនៅក្នុង"ការសរសើរ"ពីព្រះ (៥:៤ ១កថ ៤:៥)។

ព្រះយេស៊ូវគ្រីស្ទទ្រង់លេចមក[ស] ៨ដែលអ្នករាល់គ្នាមិនបាន
ឃើញទ្រង់ទេ តែបានស្រឡាញ់ទ្រង់ ហើយទោះបើនៅជាន់
ឥឡូវនេះ អ្នករាល់គ្នានៅតែមិនឃើញទ្រង់ទៀត គង់តែ
មានចិត្តជឿដែរ[ហ] ហើយក៏ត្រេកអរសាទរក្នុងទ្រង់ ដោយ
សេចក្ដីអំណរដ៏ប្រសើរ ដែលរកថ្លែងមិនបាន ៩ដោយបាន
ទទួលចុងបំផុត នៃសេចក្ដីជំនឿរបស់អ្នករាល់គ្នា គឺជា
សេចក្ដីសង្គ្រោះដល់ព្រលឹង[ឡ] ១០ឯពួកហោរា ជាអ្នកបាន
ទាយ[អ]ពីព្រះគុណ ដែលផ្ដល់មកអ្នករាល់គ្នា[ក] គេបានស៊ើប
សួរ ហើយខំរកឱ្យដឹងពី សេចក្ដីសង្គ្រោះនោះ[ខ] ១១ទាំង
ស្វែងរកឱ្យដឹងពេលវេលាណា ឬគ្រាយ៉ាងណា ដែលព្រះ
វិញ្ញាណនៃព្រះគ្រីស្ទ[គ]ដ៏សណ្ឋិតក្នុងគេ ទ្រង់ចង្អុលបង្ហាញ[ឃ]
ក្នុងកាលដែលទ្រង់ធ្វើបន្ទាល់ជាមុន អំពីព្រះគ្រីស្ទត្រូវ
រងទុក្ខលំបាក ហើយពីសិរីល្អទាំងប៉ុន្មាន ដែលត្រូវមក
តាមក្រោយ ១២តែទ្រង់បានសំដែងឱ្យគេដឹងថា សេចក្ដី
ទាំងនោះមិនមែនសំរាប់គេទេ គឺសំរាប់យើងរាល់គ្នាវិញ[ង]
គឺជាសេចក្ដីទាំងប៉ុន្មាន ដែលឥឡូវនេះ ពួកអ្នកផ្សាយដំណឹង
ល្អបានប្រាប់មកអ្នករាល់គ្នា[ច] ដោយព្រះវិញ្ញាណបរិសុទ្ធ
ដែលទ្រង់បានចាត់ពីស្ថានសួគ៌មក[ឆ] ហើយពួកទេវតាក៏ចូល
ចិត្តចង់ពិនិត្យមើលសេចក្ដី ទាំងនោះដែរ ។

## ចូរបានបរិសុទ្ធ

១៣ដូច្នេះ ចូរក្រវាត់គំនិតអ្នករាល់គ្នាឱ្យមាំមួនចុះ ទាំង
ដឹងខ្លួន[ជ] ហើយឱ្យមានសេចក្ដីសង្ឃឹមគ្រប់ជំពូក[ឈ] ដល់ព្រះ
គុណដែលត្រូវផ្ដល់មកដល់អ្នករាល់គ្នា[ញ] ក្នុងកាលដែលព្រះ
យេស៊ូវគ្រីស្ទទ្រង់លេចមកផង[ដ] ១៤ឱ្យដូចជាពួកកូនដែល
ស្តាប់បង្គាប់[ឋ] ឥតបណ្ដោយ[ឌ]តាមសេចក្ដីប៉ងប្រាថ្នា ដែលអ្នក
រាល់គ្នាមាន ពីកាលនៅល្ងង់ពីដើមនោះឡើយ[ឍ] ១៥តែចូរឱ្យ
អ្នករាល់គ្នាបានបរិសុទ្ធក្នុងគ្រប់កិរិយាទាំងអស់ ដូចជាព្រះ
ដែលហៅអ្នករាល់គ្នាទ្រង់បរិសុទ្ធដែរ[ណ] ១៦ដ្បិតមានសេចក្ដី
ចែងទុកមកថា «ចូរឱ្យឯងរាល់គ្នាបានបរិសុទ្ធ ដ្បិតអញជា
បរិសុទ្ធ»[ត] ១៧ហើយបើសិនជាអ្នករាល់គ្នាអំពាវនាវដល់
ទ្រង់ ទុកដូចជាព្រះវរបិតា[ថ]ដែលទ្រង់ជំនុំជំរះ តាមកាដែល
គេប្រព្រឹត្តរៀងខ្លួន[ទ] ឥតរើសមុខអ្នកណា[ធ] នោះត្រូវតែប្រ
ព្រឹត្តដោយកោតខ្លាច[ន] ក្នុងកាលដែលនៅសំណាក់[ប]ក្នុង
ជីវិតនេះនៅឡើយចុះ ១៨ដោយដឹងថា ទ្រង់បានលោះ

**១:៧** ស ខ.១៣ ១ថន ២:១៩ ១ពត ៤:១៣ **១:៨** ហ យហ ២០:២៩ **១:៩** ឡ រម ៦:២២ **១:១០** អ មថ ២៦:២៤ ក ច.១៣ ខ មថ ១៣:១៧ **១:១១** គ កច ១៦:៧ ២ពត ១:២១ ឃ មថ ២៦:២៤ **១:១២** ង រម ៤:២៤ ច ខ.២៥ ឆ លក ២៤:៤៩ **១:១៣** ជ កច ២៤:២៥ ឈ ខ.៣,២១ ហព ៣:៦ ញ ខ.១០ ដ ខ.៧ ១កថ ១:៧ **១:១៤** ឋ ខ.២,២២ ឌ រម ១២:២ ឍ អភ ៤:១៨ **១:១៥** ណ អស ៣៥:៨ ១ថន ៤:៧ ១យហ ៣:៣

**១:១៦** ត លវ ១១:៤៤,៤៥ ១៩:២ ២០:៧ **១:១៧** ថ មថ ៦:៩ ទ មថ ១៦:២៧ ធ កច ១០:៣៤ ន ហព ១១:១៣ ប ហព ១២:២៨

**១:៨** *អ្នករាល់គ្នានៅតែមិនឃើញទ្រង់ទៀត គង់តែមានចិត្តជឿ* មើលព្រះបន្ទូលព្រះយេស៊ូវក្នុង យហ ២០:២៩ ដែលពេលនោះ លោកពេត្រុសក៏មានវត្តមាននៅជាមួយនឹងទ្រង់ផងដែរ ។

**១:៩** *ព្រលឹង* គឺសំដៅទៅលើលក្ខណៈទាំងមូលរបស់មនុស្សជាអ្នកដែលបានសង្គ្រោះ ។

**១:១០** *ពួកហោរា . . . ស៊ើបសួរ ហើយខំរកឱ្យដឹងពីសេចក្ដីសង្គ្រោះ* ព្រះវិញ្ញាណទ្រង់បណ្ដាលឱ្យពួកហោរាទាយ ប៉ុន្តែទ្រង់មិនបានប្រទានឱ្យពួកគេមានសព្វញ្ញុតញ្ញាណ ដែលអាចដឹងអ្វីៗគ្រប់ទាំងអស់នោះឡើយ ។ *ព្រះគុណដែលផ្ដល់មកអ្នករាល់គ្នា* ពាក្យព្រះគុណក្នុងខនេះគឺសំដៅទៅលើសេចក្ដីសង្គ្រោះ ដែលពួកគេមានការពិសោធន៍រួចហើយ(មើល ខ.៩)។ ចំពោះព្រះគុណដែលត្រូវប្រទានមកជាអវសាន សូមមើល ខ.១៣ និងការពន្យល់ ។

**១:១១** *ព្រះវិញ្ញាណនៃព្រះគ្រីស្ទ* ព្រះវិញ្ញាណទ្រង់ត្រូវបានហៅដូចនេះ ព្រោះព្រះគ្រីស្ទបានចាត់ទ្រង់ឱ្យមក(យហ ១៦:៧) និងបានបំពេញព្រះរាជកិច្ចតាមរយៈទ្រង់(លក ៤:១៤,១៨)។ *ព្រះគ្រីស្ទត្រូវរងទុក្ខលំបាក ហើយពីសិរីល្អទាំងប៉ុន្មាន* គឺជាខ្លឹមសារសំខាន់នៃព្រះគម្ពីរបរិសុទ្ធ(មើល ទដ ២២ អស ៥២:១៣–៥៣:១២ សក ៩:៩–១០ ១៣:៧ មថ ១៦:២១–២៣ ១៧:២២ ២០:១៩ លក ២៤:២៦,៤៦ យហ ២:១៩ កច ៣:១៧–២១) និងជាអត្ថន័យ ជាមូលដ្ឋាននៃសំបុត្រនេះ(ខ.១៨–២១ ៣:១៧–២២ ៤:១២–១៦ ៥:១,៤,៩–១០)។ បន្ទាប់ពីរងទុក្ខពួកអ្នក ដែលរួបរួមជាមួយព្រះគ្រីស្ទក៏នឹងបានសិរីល្អ ហើយនឹងបានទទួលផលល្អនៅក្នុងការរងទុក្ខនៅពេលបច្ចុប្បន្ន ដោយសារពួកគេបានចូលទៅក្នុងសិរីល្អរួចជាស្រេចហើយ (៣:២១–២២)។

**១:១២** *ព្រះវិញ្ញាណបរិសុទ្ធ ដែលទ្រង់បានចាត់ពីស្ថានសួគ៌មក* ន័យរបស់ឃ្លានេះគឺព្រះគ្រីស្ទទ្រង់បានចាត់ព្រះវិញ្ញាណឱ្យមកនៅថ្ងៃបុណ្យទី៥០ (កច ២:៣៣) ដែលលោកពេត្រុសក៏បានទទួលព្រះវិញ្ញាណនៅពេលនោះផងដែរ ។ ព្រះវរបិតាទ្រង់ក៏បានប្រទានព្រះវិញ្ញាណបរិសុទ្ធឱ្យមកផងដែរ (យហ ១៤:១៦,២៦)។

**១:១៣** *ចូរក្រវាត់គំនិតអ្នករាល់គ្នាឱ្យមាំមួនចុះ ទាំងដឹងខ្លួន* ឃ្លានេះជាការលើកទឹកចិត្ត(ជារបៀបបង្គាប់)ទីមួយ ហើយមានការលើកទឹកចិត្តជាបន្តបន្ទាប់ទៀតរហូតដល់ ៥:១១(មើលសេចក្ដីផ្ដើមត្រង់ខ្លឹមសារ)។ *ព្រះគុណដែលត្រូវផ្ដល់មកដល់អ្នករាល់គ្នា* ឃ្លានេះសំដៅទៅលើស្ថានភាពចុងក្រោយនៃការប្រទានព្រះពរនៅលើផែនដី និងការលោះពីអំពើបាប ។ គោលបំណងសំខាន់បំផុតនៃសំបុត្រនេះគឺដើម្បីលើកទឹកចិត្ត និងធ្វើបន្ទាល់ពី "ព្រះគុណដ៏ពិតនៃព្រះ"(៥:១២ និងសូម ធៀបនឹង ៥:១០)។

**១:១៤** *ពួកកូន* ពាក្យនេះគឺសំដៅទៅលើគ្រីស្ទបរិស័ទ ដែលកើតនៅក្នុងគ្រួសារនៃព្រះ(ខ.២៣) ពួកគេគឺជាពួកកូននៃព្រះវរបិតា ដែលគង់នៅស្ថានសួគ៌(ខ.១៧) ហើយអាចអធិស្ឋានថា "ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌"(មថ ៦:៩)។ មានការពិពណ៌នាថា អ្នកជឿបានទទួលនិស្ស័យជាកូនចិញ្ចឹមនៅក្នុងគ្រួសារនៃព្រះផងដែរ (រម ៨:១៥ និងការពន្យល់)។

**១:១៦** *ចូរឱ្យឯងរាល់គ្នាបានបរិសុទ្ធ ដ្បិតអញជាបរិសុទ្ធ* ការបានបរិសុទ្ធគឺមានន័យ ថាបានញែកចេញពីអំពើបាប និងភាពមិនបរិសុទ្ធ និងញែកចេញសម្រាប់ព្រះ(មើលការពន្យល់ នក ៣:៥ លវ ១១:៤៤ រម ៦:២២ ១កថ ១:២)។ សំបុត្រពេត្រុសខ្សែទីមួយនេះជាសំបុត្រ ដែលមានទៅដោយការកម្សាន្ត និងលើកទឹកចិត្ត ។

**១:១៧** *ឥតរើសមុខអ្នកណា* មើល កច ១០:៣៤ និងការពន្យល់ ។ *ដោយ*

អ្នករាល់គ្នា[ផ] ឱ្យរួចពីកិរិយាឥតប្រយោជន៍[ព] ដែលបានតពី
ពួកឰយុកោមក នោះមិនមែនដោយរបស់ពុករលួយ ដូច
ជាប្រាក់ឬមាសនោះទេ ១៩ គឺបានលោះដោយសារព្រះលោ
ហិតដ៏វិសេសរបស់ព្រះគ្រីស្ទវិញ[ភ] ទុកដូចជាឈាមនៃកូន
ចៀម[ម]ឥតខ្ចោះ ឥតស្លាកស្នាម[យ] ២០ ដែលបានស្គាល់តាំងពី
មុនកំណើតលោកីយមក[រ] តែទើបនឹងលេចមកនៅជាន់
ក្រោយបង្អស់នេះ[ល] ដើម្បីជាប្រយោជន៍ដល់អ្នករាល់គ្នា
២១ ដែលដោយសារទ្រង់ នោះអ្នករាល់គ្នាក៏ជឿដល់ព្រះ[វ]
ដែលប្រោសឱ្យទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ[ស] ព្រម
ទាំងប្រទានឱ្យមានសិរីល្អ[ហ] ដើម្បីឱ្យសេចក្ដីជំនឿ ហើយនឹង
សេចក្ដីសង្ឃឹម[ឡ]របស់អ្នករាល់គ្នាបានជាប់នៅនឹងព្រះ ។
២២ អ្នករាល់គ្នាបានជំរះសំអាត[អ]ចិត្ត ដោយស្ដាប់តាម[ក]
សេចក្ដីពិត សំរាប់ឱ្យបានសេចក្ដីស្រឡាញ់ជាបងប្អូនឥតពុត
មាយា ដូច្នេះ ចូរស្រឡាញ់គ្នាទៅវិញទៅមកជាយ៉ាងខ្លាំង[ខ]
ដោយចិត្តដ៏ស្អាតចុះ ២៣ ដ្បិតព្រះបានបង្កើតអ្នករាល់គ្នាជា

**១:១៨** ផ មថ ២០:២៨ ១កថ ៦:២០ ព កទ ៤:៣
**១:១៩** ភ រម ៣:២៥ ម យហ ១:២៩ យ នក ១២:៥
**១:២០** រ អភ ១:៤ មថ ២៥:៣៤ ល ហព ៩:២៦
**១:២១** វ រម ៤:២៤ ១០:៩ ស កថ ២:២៤ ហ ភល ២:៧–៩ ហព ២:៩ ឡ ខ.៣,១៣ ហព ៣:៦
**១:២២** អ យក ៤:៨ ក ខ.២,១៤ ខ យហ ១៣:៣៤ រម ១២:១០
**១:២៣** គ ខ.៣ យហ ១:១៣ ឃ យហ

ថ្មី[គ] មិនមែនពីពូជដែលតែងតែពុករលួយនោះទេ[ឃ] គឺពីពូជ
ដែលមិនចេះពុករលួយវិញ គឺជាព្រះបន្ទូលដ៏រស់ ហើយនៅ
ជាប់លាប់[ង] ២៤ ព្រោះគ្រប់ទាំងមនុស្សប្រៀបដូចជាស្មៅ
ហើយសិរីល្អទាំងប៉ុន្មានរបស់មនុស្សក៏ដូចជាផ្កាស្មៅ រីឯ
ធម្មតាស្មៅនោះតែងតែក្រៀមស្វិត ហើយផ្កាក៏រោយរុះ ទៅ
២៥ តែឯព្រះបន្ទូលនៃព្រះអម្ចាស់ នោះនៅជាប់អស់កល្បជា
និច្ចវិញ[ច] គឺជាព្រះបន្ទូលនេះ ដែលបានផ្សាយមកអ្នករាល់
គ្នាហើយ ។

**២** ១ ដូច្នេះ ដែលអ្នករាល់គ្នា[ឆ]បានលះបង់ចោលអស់ទាំង
សេចក្ដីគំរក់ និងកិច្ចកលទាំងប៉ុន្មាន ព្រមទាំងពុតមាយា ចិត្ត
ច្រណែន ហើយពាក្យនិយាយដើមគេ[ជ]ទាំងអស់ចេញ ២ នោះ
ត្រូវឱ្យសង្វាតរកទឹកដោះសុទ្ធ[ឈ] ខាងឯព្រលឹងវិញ្ញាណវិញ
ដូចជាទារកដែលទើបនឹងកើត ដើម្បីឱ្យអ្នករាល់គ្នាបាន

១:១៣ ង ហព ៤:១២ **១:២៥** ច អស ៤០:៦–៨ យក ១:១០,១១
**២:១** ឆ អភ ៤:២២ ជ យក ៤:១១ **២:២** ឈ ១កថ ៣:២ ហព ៥:១២,១៣

*កោតខ្លាច* មានន័យថាមិនមែនភ័យតក់ស្លុតទេ ប៉ុន្តែថ្វាយការគោរពកោតខ្លាចដល់ព្រះនៅក្នុងជីវិតរស់នៅ(សូមធៀប សភ ១:៧ និងការពន្យល់)។ *ដែលនៅសំណាក់* មើល ខ.១ ។

**១:១៨** *បានលោះ* នៅក្នុងព្រះគម្ពីរពាក្យថា "លោះ" មានន័យថា ដោះអ្នកណាម្នាក់ពីការអាក្រក់អ្វីមួយ ដោយបង់ប្រាក់ជាជំនួស(នក ២១:៣០ និងការពន្យល់ និង នក ១៣:១៣)។ នៅក្នុងសង្គមប្រទេសក្រេកបុរាណទាសករអាចត្រូវបានលោះ ដោយការបង់ប្រាក់ដោយទាសករខ្លួនឯង ឬអ្នកដទៃ ។ ចំពោះបញ្ហាបាបរបស់មនុស្សវិញ ព្រះយេស៊ូវទ្រង់បានលោះអ្នកជឿដល់ទ្រង់ពី "បណ្ដាសានៃក្រិត្យវិន័យ"(លប ៣:១៣) និង"សេចក្ដីទទឹងច្បាប់" (ទត ២:១៤) មិនមែនដោយបង់មាស ឬប្រាក់ឡើយ ប៉ុន្តែដោយព្រះលោហិតទ្រង់(ខ.១៩ អភ ១:៧ និងការពន្យល់ វវ ៥:៩) គឺការសុគត(មថ ២០:២៨ ហព ៩:១៥ និងការពន្យល់) និងព្រះកាយទ្រង់(កទ ៣:១៣)។ ផលនៃការលោះនេះគឺ "ការអត់ទោសបាប"(កល ១:១៤) និង "សម្អាតឱ្យបានសុចរិត"(រម ៣:២៤ និងការពន្យល់)។ *កិរិយាឥតប្រយោជន៍ដែលបានតពីពួកឰយុកោ* ត្រង់ចំណុចនេះអ្នកខ្លះអះអាងថា អ្នកទទួលប្រាកដជាពួកសាសន៍ដទៃ ពីព្រោះគម្ពីរសញ្ញាថ្មីមានការសង្កត់ធ្ងន់ទៅលើកិរិយាឥតប្រយោជន៍របស់ពួកសាសន៍ដទៃ(រម ១:២១ អភ ៤:១៧ និងការពន្យល់)។ អ្នកខ្លះទៀតយល់ថា អ្នកទទួលជាពួកសាសន៍យូដា ព្រោះពួកគេជាសាសន៍ដែលប្រកាន់តឹងរឹងខាងប្រពៃណី ពួកគេសង្កត់ធ្ងន់ទៅលើឥទ្ធិពលរបស់ឪពុកដែលជាគ្រូបង្រៀននៅផ្ទះ ។ តែតាមបរិបទនៃបទគម្ពីរនេះគេជឿថាសំបុត្រនេះទាំងមូលមានអ្នកទទួលជាសាសន៍យូដា និងសាសន៍ដទៃ ។

**១:១៩** *កូនចៀម* ព្រះយេស៊ូវទ្រង់គឺជាកូនចៀមនៃថ្ងៃបុណ្យរំលង(១កថ ៥:៧ និងការពន្យល់) ដែលលាងសំអាតអំពើបាបនៃលោកីយទាំងមូល(មើល យហ ១:២៩ និងការពន្យល់)។ *ឥតខ្ចោះ ឥតស្លាកស្នាម* មើល ហព ៩:១៤ និងការ ពន្យល់ សេចក្ដីផ្ដើមលេវីវិន័យត្រង់ ខ្លឹមសារខាងឯវិជ្ជាអំពីព្រះ ។

**១:២០** *ស្គាល់តាំងពីមុនកំណើតលោកីយ* មានន័យថា ព្រះទ្រង់បានជ្រាបជាមុនថាការប្រោសលោះបាបរបស់មនុស្ស គឺជាការចាំបាច់(សូមធៀប វវ ១៣:៨) ហើយបានចាត់ព្រះគ្រីស្ទឱ្យមកនៅគ្រាចុងក្រោយនេះ ។ ការកាត់ស្រាយដទៃទៀត គឺព្រះទ្រង់បានរើសព្រះគ្រីស្ទឱ្យធ្វើជាព្រះអង្គសង្គ្រោះតាំងពីអស់កល្បជានិច្ច ។ *ជាន់ក្រោយបង្អស់* មើលការពន្យល់ យក ៥:៣ ។

**១:២២** *សេចក្ដីស្រឡាញ់. . . ឥតពុតមាយា* មើល រម ១២:៩ និងការពន្យល់ *បងប្អូន* មើលពន្យល់ រម ១:១៣ ។ *ស្រឡាញ់គ្នាទៅវិញទៅមក* យហ ១៣:៣៤–៣៥ ១ថន ៤:៩–១០ និងការពន្យល់ ៤:៩ ជាវគ្គដែលលោកប៉ុល ក៏បានបង្គាប់ដល់អ្នកអានដូចលោកពេត្រុសផងដែរថាឱ្យស្រឡាញ់គ្នា ហើយស្រឡាញ់កាន់តែខ្លាំង ។

**១:២៣** *ព្រះបានបង្កើតអ្នករាល់គ្នាជាថ្មី . . ព្រះបន្ទូលដ៏រស់* មានន័យថាការកើតជាថ្មីជាការចាប់កំណើតតាមរយៈ ការធ្វើការរបស់ព្រះវិញ្ញាណ (ទត ៣:៥ និងការពន្យល់) ហើយព្រះបន្ទូលក៏មានតួនាទីសំខាន់ផងដែរ ព្រោះព្រះបន្ទូលមានទៅ ដោយដំណឹងល្អដែលផ្សាយទៅដល់មនុស្សមានបាបឱ្យប្រែចិត្តទទួលជឿព្រះគ្រីស្ទ (ខ.២៥)។ *ពូជដែលតែងតែពុករលួយ. . . មិនចេះពុករលួយ* នៅក្នុងបរិបទនេះ ពូជដែលមិនចេះពុករលួយ គឺព្រះបន្ទូលនៃព្រះ ដែលមិនចេះពុករលួយ ហើយស្ថិតស្ថេរនៅអស់កល្បជានិច្ច ។

**១:២៥** *ព្រះបន្ទូល . . . អស់កល្បជានិច្ច* ចំណុចសំខាន់នៃខនេះគឺព្រះបន្ទូលទ្រង់គង់នៅអស់កល្បជានិច្ច ។

**២:១** *ដូច្នេះ* ជាពាក្យដែលតភ្ជាប់ការលើកទឹកចិត្តពីបទគម្ពីរ ១:២៣–២៥ ។ សូមធៀបនឹង"បង្កើតជាថ្មី"(១:២៣)និង"ទារកដែលទើបនឹង កើត"(២:២)

**២:២** *សង្វាត* ពាក្យនេះមានន័យថាការស្រេកឃ្លានជាធម្មតារបស់ទារកដែលមានសុខភាពល្អ ដែលដូចជាសេចក្ដីស្រេកឃ្លានអាហារខាងឯវិញ្ញាណជាបឋមរបស់គ្រីស្ទបរិស័ទដែលនៅក្មេងខាងវិញ្ញាណ ។ *ទឹកដោះសុទ្ធខាងឯវិញ្ញាណ* ពាក្យនេះ ជាន័យធៀបរបស់ពាក្យ "ព្រះបន្ទូល"(១:២៣,២៥

ចំរើនធំឡើង[ញ] ដរាបដល់បានសង្គ្រោះ ៣គឺបើអ្នករាល់គ្នា
បានភ្លក់ឱ្យដឹងថា ព្រះអម្ចាស់ទ្រង់ល្អមែន[ដ] ។

## ថ្មរស់ និងមនុស្សដែលព្រះបានជ្រើសរើស

៤ឯអ្នករាល់គ្នា ដែលកំពុងតែមកឯទ្រង់ដ៏ជាថ្មរស់[ឋ]
ដែលមនុស្សបានបោះបង់ចោលចេញ តែព្រះបានជ្រើស
រើស[ឌ] ហើយរាប់ជាវិសេសវិញ ៥នោះអ្នករាល់គ្នាក៏បាន
ស្អាងឡើង[ឍ] ដូចជាថ្មរស់ដែរ ឱ្យបានធ្វើជាផ្ទះខាងឯ
វិញ្ញាណ[ណ] ជាពួកសង្ឃបរិសុទ្ធ[ត] សំរាប់នឹងថ្វាយគ្រឿងបូជា
ខាងព្រលឹងវិញ្ញាណ ដែលព្រះទ្រង់សព្វព្រះហឫទ័យទទួល
ដោយព្រះយេស៊ូវគ្រីស្ទ[ថ] ៦ពីព្រោះមានសេចក្តីចែងទុកមក
ក្នុងគម្ពីរថា «មើលអញដាក់ថ្មជ្រុង១[ទ] នៅក្រុងស៊ីយ៉ូន ជាថ្ម
ដែលជ្រើសរើស ហើយវិសេសវិសាល អ្នកណាដែលជឿ
ដល់ទ្រង់ នោះនឹងគ្មានហេតុនាំឱ្យខ្មាសឡើយ»[ធ] ៧ដូច្នេះ
ដែលទ្រង់វិសេស នោះគឺវិសេសដល់អ្នករាល់ គ្នាដែលជឿ
តែដល់ពួកអ្នកមិនជឿវិញ នោះ[ន]«ថ្មដែលពួកជាងសង់ផ្ទះ
បាន ចោលចេញ[ប] បានត្រឡប់ជាថ្មជ្រុងយ៉ាងឯក»[ផ] ៨«ជាថ្ម
ជំពប់ ហើយជាថ្មដាដែលនាំឱ្យរវាតចិត្ត»[ព] គេជំពប់នឹងព្រះ
បន្ទូលដោយព្រោះតែមិនជឿ ហើយគេក៏ត្រូវដំរូវទុកសំ
រាប់ការនោះឯង[ភ] ៩តែអ្នករាល់គ្នាជាពូជជ្រើសរើស[ម]
ជាពូជសង្ឃហ្លួង[យ] ជាសាសន៍បរិសុទ្ធ[រ] ជារាស្ត្រដ៏ជាកេរ្តិ៍
អាករនៃព្រះ[ល] ដើម្បីឱ្យអ្នករាល់គ្នាបានសំដែងចេញ ឱ្យ
ឃើញអស់ទាំងលក្ខណៈរបស់ព្រះ ដែលទ្រង់បានហៅអ្នក
រាល់គ្នាចេញពីសេចក្តីងងឹត មកក្នុងពន្លឺអស្ចារ្យរបស់ទ្រង់[វ]

**២:២** ញ អភ ៤:១៥,១៦ **២:៣** ដ ទដ ៣៤:៨ ហាព ៦:៥ **២:៤** ឋ ខ.៧ ឌ អស ៤២:១ **២:៥** ឍ សភ ៩:១ ១កថ ៣:៩ អភ ២:២០–២២ ណ ១ធថ ៣:១៥ ត ខ.៩ នក ១៩:៦ អស ៦១:៦ វវ ១:៦ ៥:១០ ២០:៦ ថ ភល ៤:១៨ ហាព ១៣:១៥ **២:៦** ទ អភ ២:២០ ធ អស ២៨:១៦ រម ៩:៣២,៣៣ ១០:១១ **២:៧** ន ២កថ ២:១៦ ប ខ.៤ ផ ទដ ១១៨:២២ កច ៤:១១ **២:៨** ព អស ៨:១៤ លក ២:៣៤ ភ រម ៩:២២ **២:៩** ម ចទ ១០:១៥ ១សយ ១២:២២ យ ខ.៥ រ នក ១៩:៦ ចទ ៧:៦ អស ៦២:១២ ល ទត ២:១៤

១កថ ៣:២ ហាព ៥:១២–១៤) ហើយផ្ទុយនឹងអាហាររឹងដែលទារកមិនអាចទទួលបាន ។ *ចំរើនធំឡើង* ពាក្យ នេះតាមព្រះគម្ពីរក្រិកមានន័យថា ត្រូវការចម្រើនធំឡើងពីទារកតូច(សូមធៀបនឹង ២ពត ៣:១៨) ។

**២:៣** *បានភ្លក់ឱ្យដឹង* តាមព្រះគម្ពីរក្រិកពាក្យនេះគឺសំដៅទៅលើការភ្លក់ចាប់ពីអាហារកម្រិតដំបូងឡើងទៅ ។ ដោយសារការភ្លក់ ដូចនេះបង្ហាញពីការស្កប់ស្កល់ចិត្តអ្នកជឿត្រូវមានការស្រេកឃ្លានអាហារខាងឯវិញ្ញាណជាបន្ថែម ។

**២:៤** *ថ្មរស់* ត្រង់ចំណុចនេះព្រះគ្រីស្ទទ្រង់ជាថ្មរស់(មើល ខ.៦–៨ សូមធៀបនឹង មថ ២១:៤២ មក ១២:១០–១១ លក ២០:១៧ កច ៤:១១ រម ៩:៣៣) ។ ទ្រង់ជាថ្មដែលប្រទានជីវិត ។ នៅក្នុងព្រះគ្រីស្ទដ៏ជាព្រះរាជបុត្រានៃព្រះគឺមានជីវិត(យហ ១:៤ ៥:២៦ និងការពន្យល់) ។ សូមមើល "ទឹករស់" ក្នុង យហ ៤:១០–១៤ (មើល ការពន្យល់ ៤:១០) និង យហ ៧:៣៨ "នំបុ័ងដ៏រស់" ក្នុង យហ ៦:៥១ (មើលការ ពន្យល់ ៦:៣៥) និង "ផ្លូវដ៏រស់" ក្នុង ហាព ១០:២០ ។ *មនុស្សបានបោះបង់ចោលចេញ តែព្រះបានជ្រើសរើស* លោកពេត្រុសបាននិយាយជាច្រើនដងនៅក្នុងព្រះគម្ពីរកិច្ចការអំពីភាពផ្ទុយគ្នារវាងការទាស់ប្រឆាំងរបស់អ្នកមិនជឿចំពោះព្រះគ្រីស្ទ និងការដែលព្រះវរបិតាលើកទ្រង់ឡើង(កច ២:២២–៣៦ ៣:១៣–១៥ ៤:១០–១១ ១០:៣៩–៤២) ។

**២:៥** *ថ្មរស់* ជីវិតរបស់គ្រីស្ទបរិស័ទគឺកើតឡើងពីព្រះគ្រីស្ទ ដ៏ជាថ្មរស់ដំបូង និង "ព្រលឹងរស់"(១កថ ១៥:៤៥)ដល់អស់អ្នកណាដែលមកឯទ្រង់(ខ.៤) ។ ការនិយាយអំពីថ្មនេះ អាចឆ្លុះបញ្ចាំងពីព្រះបន្ទូលដែលព្រះយេស៊ូវទ្រង់មានដល់ពេត្រុសក្នុង មថ ១៦:១៨ (មើលការពន្យល់ខនេះ) ។ *ផ្ទះខាងឯវិញ្ញាណ* គឺផ្ទះខាងឯវិញ្ញាណក្នុងន័យធៀប ប៉ុន្តែ ក៏ជាផ្ទះដែលព្រះវិញ្ញាណនៃព្រះទ្រង់បង្កើត និងសណ្ឋិតនៅផងដែរ ។ ថ្មដែលមានក្នុងផ្ទះនោះត្រូវបានធ្វើឱ្យមានជីវិតឡើង ដោយព្រះវិញ្ញាណ ដែលព្រះគ្រីស្ទដ៏ជាថ្មរស់ដ៏ខ្ពស់បំផុតទ្រង់បានចាត់មក(សូមធៀប កច ២:៣៣) ។ ព្រះវិហារនៃសញ្ញាចាស់ក៏បានផ្តល់ជាសេចក្តីពន្យល់បន្ថែមសម្រាប់ ការនិយាយពីថ្មក្នុងវគ្គនេះផងដែរ(សូមធៀប យហ ២:១៩ ១កថ ៣:១៦ អភ ២:១៩–២២ និងការពន្យល់) ។ *ពួកសង្ឃបរិសុទ្ធ* គឺសំដៅអ្នកជឿរាល់រូប ។ ក្នុងនាមជាពួកសង្ឃអ្នកជឿត្រូវ (១).បង្ហាញពីភាពបរិសុទ្ធនៃព្រះ និងរបស់ពួកសង្ឃតាមរយៈការប្រព្រឹត្តរបស់ខ្លួន(១:១៥ ហាព ៧:២៦ ១០:១០ និងការពន្យល់) (២).ថ្វាយគ្រឿងបូជាខាងព្រលឹងវិញ្ញាណ(ក្នុងខនេះ) (៣).ទូលសូមឱ្យព្រះអត់ទោសដល់អ្នកដទៃ និង(៤).ធ្វើបន្ទាល់ពីព្រះដល់ពួកគេ ។ *គ្រឿងបូជាខាងព្រលឹងវិញ្ញាណ* ព្រះគម្ពីរសញ្ញាថ្មីប្រើពាក្យនេះសំដៅទៅលើគ្រឿងបូជាជាច្រើន–ប្រភេទដូចជា ការថ្វាយដល់ព្រះនូវរូបកាយ (រម ១២:១) ការថ្វាយប្រាក់ និងសម្ភារៈផ្សេងៗ(ភល ៤:១៨ ហាព ១៣:១៦) ការថ្វាយការសរសើរដល់ព្រះ(ហាព ១៣:១៥) និងការថ្វាយការប្រព្រឹត្តល្អ(ហាព ១៣:១៦) ។ *ដែលព្រះទ្រង់សព្វព្រះហឫទ័យទទួល* គឺតាមរយៈព្រះយេស៊ូវគ្រីស្ទដ៏ជាអ្នកផ្សះផ្សា (សូមធៀបនឹង ១៤:៦) ។ អ្នកជឿគឺជាថ្មរស់សម្រាប់សង់ព្រះវិហារខាងឯវិញ្ញាណ ដែលជាពួកសង្ឃបរិសុទ្ធ ដែលត្រូវថ្វាយគ្រឿងបូជាខាងព្រលឹងវិញ្ញាណ ។

**២:៦** *ថ្មដែលជ្រើសរើសហើយវិសេសវិសាល* មើល ទដ ១១៨:២២ និងការពន្យល់ មថ ២១:៤២ មក ១២:១០ លក ២០:១៧ កច ៤:១១ និងការពន្យល់ពាក្យនេះគឺសំដៅទៅលើព្រះយេស៊ូវគ្រីស្ទ ដូចដែលមាននិយាយយ៉ាងច្បាស់ក្នុង ខ.៦–៨ ។ ថ្មជ្រុងជាថ្មដែលសំខាន់ជាងគេបំផុតនៅក្នុងចំណោមថ្មសំណង់ទាំងអស់ ។ តាមបទគម្ពីរនេះអ្នកជឿគឺជាផ្ទះខាងឯវិញ្ញាណ (ខ.៥) ដែលមានព្រះគ្រីស្ទដ៏ជាថ្មរស់ទ្រង់ជាគ្រឹះ ។ *អ្នកណាដែលជឿដល់ទ្រង់* ត្រង់ចំណុចនេះមានមនុស្សពីរប្រភេទប្រព្រឹត្តចំពោះថ្មជ្រុង: (១).មនុស្សដែលជឿលើទ្រង់ (២).មនុស្សដែលបដិសេធទ្រង់(ខ.៧) ហើយត្រូវជំពប់ដួលនឹងថ្មជ្រុងនោះ ។

**២:៨** *ដំរូវទុកសំរាប់ការនោះ* អ្នកកាត់ស្រាយខ្លះយល់ថា ន័យរបស់ខនេះគឺអ្នកខ្លះត្រូវបានតម្រូវទុកជាមុនឱ្យត្រូវដួលចុះ និងបាត់បង់ ។ អ្នកដទៃទៀតនិយាយថា អ្នកមិនជឿត្រូវបានតម្រូវទុកជាមុនឱ្យត្រូវបាត់បង់ ព្រោះព្រះទ្រង់បានជ្រាបជាមុន ថាពួកគេនឹងមិនជឿទ្រង់ឡើយ ។ ប៉ុន្តែនៅមានអ្នកខ្លះជឿថា លោកពេត្រុសចង់មានន័យថា ការមិនជឿព្រះត្រូវកំណត់ជាមុនឱ្យនាំមកនូវសេចក្តីហិនវិនាសអស់កល្បជានិច្ច ។

**២:៩** *ពូជជ្រើសរើស* មើល អភ ១:៤ និងការពន្យល់ អស ៤៣:១០,២០ ៤៤:១–២ ។ អ៊ីស្រាអែលត្រូវបានរាប់ជារាស្ត្រជ្រើសតាំងនៅ ក្នុងសញ្ញា

១០ពីដើមអ្នករាល់គ្នាមិនមែនជាសាសន៍ណាមួយទេ តែ
ឥឡូវនេះជាសាសន៍របស់ព្រះវិញ[ស] ពីដើមមិនបានទទួល
សេចក្ដីមេត្តាករុណាទេ តែឥឡូវនេះបានទទួលហើយ ។
១១ឱពួកស្ងួនភ្ងាអើយ[ហ] ខ្ញុំទូន្មានអ្នករាល់គ្នាទុកដូចជា
ពួកប្រទេសក្រៅ ហើយដូចជាពួកអ្នក ដែលគ្រាន់តែសំ
ណាក់នៅ[ឡ]ថា ចូរឱ្យអ្នករាល់គ្នាចៀសពីសេចក្ដីប៉ងប្រាថ្នា
ខាងសាច់ឈាម[អ] ដែលតយុទ្ធនឹងព្រលឹងវិញ្ញាណចេញ[ក]
១២ទាំងប្រព្រឹត្តដោយទៀងត្រង់ នៅក្នុងពួកសាសន៍ដទៃ
ដើម្បីនៅកន្លែងណា ដែលគេនិយាយដើម ពីអ្នករាល់គ្នា
ទុកដូចជាមនុស្សប្រព្រឹត្តអាក្រក់ នោះឱ្យគេបានសរសើរ
ដល់ព្រះ[ខ] នៅថ្ងៃដែលទ្រង់យាងមកប្រោស ដោយគេឃើញ
ការល្អ[គ]របស់ អ្នករាល់គ្នាវិញ ។

### ការចុះចូលនឹងអ្នកដឹកនាំ និងម្ចាស់

១៣ចូរឱ្យចុះចូលនឹងគ្រប់ទាំងច្បាប់នៃមនុស្សលោក[ឃ]
ដោយយល់ដល់ព្រះអម្ចាស់ ទោះបើនឹងស្ដេច ទុកជាធំ
បណ្ដាច់ ១៤ឬនឹងចៅហ្វាយ ទុកដូចជាអ្នកដែលស្ដេចចាត់
ចែងផង ដែលលោកទាំងនោះសំរាប់ធ្វើទោសដល់ពួកអ្នក
ដែលប្រព្រឹត្តអាក្រក់[ង] ហើយនិងសរសើរដល់ពួកអ្នក ដែល
ប្រព្រឹត្តល្អវិញ[ច] ១៥ដ្បិតព្រះទ្រង់សព្វព្រះហឫទ័យ[ឆ]ឱ្យបំបាត់
ពាក្យសំដីចំកួតរបស់មនុស្សខ្លៅល្ងង់ចេញ ដោយសារកិ
រិយាល្អ[ជ] ១៦គឺត្រូវចុះចូលទុកដូចជាមនុស្សមានសេរីភាព[ឈ]
តែមិនមែនដោយប្រើសេរីនោះ ដើម្បីនឹងបំបិតបំបាំង
សេចក្ដីអាក្រក់ឡើយ[ញ] ត្រូវចុះចូលដូចជាអ្នកបំរើរបស់
ព្រះវិញ[ដ] ១៧ចូររាប់អានដល់មនុស្សទាំងអស់ ហើយស្រ
ឡាញ់បងប្អូន[ឋ] កោតខ្លាចដល់ព្រះ ព្រមទាំងគោរពប្រតិបត្តិ
ដល់ស្ដេចផង[ឌ]។
១៨ឱពួកអ្នកបំរើអើយ ចូរចុះចូលចំពោះចៅហ្វាយ
ដោយកោតខ្លាចគ្រប់យ៉ាង[ឍ] មិនមែនត្រឹមតែចៅហ្វាយណា
ដែលស្លូតបូតល្អប៉ុណ្ណោះ[ណ] ទោះទាំងចៅហ្វាយដែលកាច

**២:៩** វ កច ២៦:១៨ **២:១០** ស ហស ១:៩,១០ ២:២៣ រម ៩:២៥,២៦ **២:១១** ហ ១កថ ១០:១៤ ឡ ហព ១១:១៣ អ រម ១៣:១៤ កទ ៥:១៦ ក យក ៤:១ **២:១២** ខ មថ ៩:៨ គ ភល ២:១៥ ទត ២:៨ ទត ២:១៤ ១ពត ៣:១៦ **២:១៣** ឃ រម ១៣:១ ទត ៣:១ **២:១៤** ង រម ១៣:៤ ច រម ១៣:៣ **២:១៥** ឆ ១ពត ៣:១៧ ៤:១៩ ជ ខ.១២ **២:១៦** ឈ យហ ៨:៣២ ញ កទ ៥:១៣ ដ រម ៦:២២ **២:១៧** ឋ រម ១២:១០ ឌ សភ ២៤:២១ រម ១៣:៧ **២:១៨** ឍ អភ ៦:៥ ណ យក ៣:១៧

ចាស់ដូចនេះនៅក្នុងសញ្ញាថ្មី អ្នកជឿព្រះត្រូវបានតម្រូវឱ្យធ្វើជាពួករើសតាំង ។ *ពួកសង្ឃហ្លួង* មើលការពន្យល់ ខ.៥ នក ១៩:៦ សូមផ្ទៀប អស ៦១:៦ ។ *ជាសាសន៍បរិសុទ្ធ* សូមផ្ទៀប ចទ ២៨:៩ ។ *រាស្ត្រដ៏ជាកេរ្តិ៍* មើល នក ១៩:៥ និងការពន្យល់ ។ ទោះជាពីមុនមិនបានធ្វើជារាស្ត្ររបស់ព្រះក៏ឥឡូវនេះពួកគេគឺជាអ្នកទទួលសេចក្ដីមេត្តាករុណារបស់ព្រះ (មើល ១:៦–១០ និងការពន្យល់ ១:១០ រម ៩:២៥–២៦ និងការពន្យល់ ១០:១៩)។ *សំដែងចេញ. . .ទាំងលក្ខណៈរបស់ព្រះ* មើល អស ៤៣:២១ កច ២:១១ ។

**២:១០** មើលការពន្យល់ ហស ១:៦,៩ ២:១,២២ រម ៩:២៥–២៦ ។ តាមគម្ពីរហូសេ គឺអ៊ីស្រាអែលត្រូវបានឈប់រាប់ជារាស្ត្ររបស់ព្រះតាមគម្ពីររ៉ូមលោកប៉ុលប្រើព្រះបន្ទូល ក្នុងព្រះគម្ពីរហូសេចំពោះសាសន៍ដទៃ ហើយនៅក្នុង១ពេត្រុស ព្រះបន្ទូលនេះត្រូវបានប្រើចំពោះសាសន៍ទាំងពីរ ។

**២:១១** *ពួកប្រទេសក្រៅ ហើយដូចជាពួកអ្នកដែលគ្រាន់តែសំណាក់នៅ* មើលការពន្យល់ ១:១ ។ ដូចជាពួកប្រទេសក្រៅ និងអ្នកដែលគ្រាន់តែសំណាក់នៅ ដែលមានសញ្ជាតិនៅស្ថានសួគ៌ ហើយត្រូវញែកចេញពីសេចក្ដីពុករលួយនៃលោកីយ តែមិនមែនជិន្នួសដោយសេចក្ដីប៉ងប្រាថ្នារបស់លោកីយប្រកបដោយអំពើបាប ដែលនាំទៅរកសេចក្ដីហិនវិនាសនោះទេ ។

**២:១២** *ថ្ងៃដែលទ្រង់យាងមកប្រោស* ថ្ងៃនោះប្រហែលជាថ្ងៃដែលទ្រង់យាងមកកាត់ទោសលោកីយឬអាចជាថ្ងៃ ដែលព្រះទ្រង់យាងមកប្រោសអ្នកដែលមានសេចក្ដីសង្គ្រោះ។ ជីវិតផ្លាស់ប្រែរបស់អ្នកជឿអាចមានឥទ្ធិពលលើអ្នកមិនជឿ គឺអាចនាំឱ្យពួកគេប្រែចិត្តទទួលជឿព្រះ ។ *គេឃើញការល្អរបស់អ្នករាល់គ្នា* សូមផ្ទៀបនឹង មថ ៥:១៦ ។ ពាក្យ "ឃើញ" ក្នុងព្រះគម្ពីរភាសាក្រិក គឺសំដៅទៅលើការឃើញ ដោយមើលយ៉ាងប្រុងប្រយ័ត្នក្នុងមួយរយៈពេល ។ ការវាយតម្លៃរបស់អ្នកមិនជឿក្នុងខនេះមិនមែនជា "ការវិនិច្ឆ័យងាយៗ" នោះឡើយ ។

**២:១៣–៣:៦** ក្នុងវគ្គនេះគ្រីស្ទបរិស័ទត្រូវចុះចូលចំពោះរដ្ឋអំណាចដែលត្រឹមត្រូវ ទោះជាពួកគេមិនមែនជាអ្នកជឿព្រះក៏ដោយ ។

**២:១៣** *គ្រប់ទាំងច្បាប់នៃមនុស្សលោក* ច្បាប់ទាំងនោះកើតមានឡើងដោយ អាស្រ័យទៅលើព្រះអម្ចាស់(រម ១៣:១–២ និងការពន្យល់ ១៣:១)។ ពេលដែលមនុស្សមិនគោរពច្បាប់ដ៏ត្រឹមត្រូវរបស់មនុស្ស ដែលព្រះទ្រង់បានតាំងឱ្យមាននោះទេ មានន័យថាពួកគេមិនស្ដាប់បង្គាប់ព្រះ ដោយប្រយោល(រម ១៣:២)។ *ស្ដេច* លោកពេត្រុសសរសេរសំបុត្រនេះ នៅពេលដែលចក្រភពរ៉ូម៉ាំងស្ថិតនៅក្នុងរាជ្យស្ដេចទមិល ហើយសាហាវឈ្មោះនេរ៉ូ ដែលកាន់កាប់អំណាចពីឆ្នាំ៥៤ ដល់ ៦៨ គ.ស.(មើលសេចក្ដីផ្ដើមត្រង់អ្នកនិពន្ធ និងកាលបរិច្ឆេទ)។ លោកពេត្រុសមិនបានប្រាប់ឱ្យគ្រីស្ទបរិស័ទចុះចូលសូម្បីតែច្បាប់ដែលខុសនឹងជំនឿលើព្រះគ្រីស្ទទេ ព្រោះគាត់បាននិយាយកាលពីមុនថា "ត្រូវតែស្ដាប់បង្គាប់ដល់ព្រះជាជាងមនុស្ស"(កច ៤:១៩, ៥:២៩)។

**២:១៥** *បំបាត់ពាក្យសំដីចំកួតរបស់មនុស្សខ្លៅល្ងង់* ពាក្យសំដីចំកួតគឺការចោទប្រកាន់មិនសមហេតុផលមកលើគ្រីស្ទបរិស័ទ ហើយក្នុងរឿងនេះគ្រីស្ទបរិស័ទត្រូវផ្សាយដំណឹងល្អដល់អ្នកមិនជឿវិញ(សូមមើល ទត ២:៧–៨)។

**២:១៦** *ទុកដូចជាមនុស្សមានសេរីភាព* ខនេះមិនមែនបង្គាប់ឱ្យធ្វើការបះបោរ ប្រឆាំងនឹងរដ្ឋអំណាចនោះទេ ប៉ុន្តែ គឺឱ្យអ្នកជឿចុះចូលចំពោះព្រះ និងរដ្ឋអំណាចនៃលោកិយដោយស្ម័គ្រចិត្ត (លុះណាតែការចុះចូលនោះមិនប្រឆាំងនឹងក្រឹត្យវិន័យរបស់ព្រះ)។ *ដើម្បីនឹងបំបិទបំបាំងសេចក្ដីអាក្រក់* សេរីភាពពិតប្រាកដ គឺជាសេរីភាពក្នុងការបម្រើព្រះ ដែលជាសេរីភាពដែលព្រះបានកំណត់ឱ្យ ។

**២:១៧** *រាប់អានដល់មនុស្សទាំងអស់* បានជាត្រូវរាប់អានដល់មនុស្សទាំងអស់ព្រោះមនុស្សគ្រប់រូបមានរូបកាយដែលព្រះទ្រង់បង្កើតតាមរូបអង្គទ្រង់ ។ *កោតខ្លាចដល់ព្រះ* មើលការពន្យល់ ១:១៧ ។

**២:១៨** *អ្នកបំរើ* គឺអ្នកបម្រើក្នុងផ្ទះ ទោះជាពួកគេបានទទួលការហ្វឹកហាត់ ឬ

ក៏ដែរ ១៩ដ្បិតបើអ្នកណាត្រូវព្រួយលំបាក ទាំងរងទុក្ខឥត
ហេតុ ដើម្បីឱ្យបានបញ្ញាចិត្តជ្រះថ្លានៅចំពោះព្រះ នោះគួរ
សរសើរហើយ[ត] ២០បើអ្នកទ្រាំឱ្យគេវាយដោយអំណត់
ដោយព្រោះបានធ្វើបាប នោះតើនឹងមានសេចក្ដីប្រសើរអ្វី
តែបើអ្នកបានប្រព្រឹត្តល្អ ហើយទ្រាំឱ្យគេធ្វើទុក្ខដោយអត់
ទ្រាំវិញ នោះទើបជាការដែលគាប់ព្រះហឫទ័យនៅចំពោះ
ព្រះមែន[ថ] ២១ដ្បិតទ្រង់បានហៅអ្នករាល់គ្នា[ទ] មកឯសេចក្ដី
នោះឯង[ធ] ពីព្រោះព្រះគ្រីស្ទក៏បានរងទុក្ខជំនួសយើងដែរ[ន]
ទាំងទុកដំរាប់ ឱ្យយើងរាល់គ្នាដើរតាមលំអានដាន[ប]នៃទ្រង់
២២ទ្រង់មិនបានធ្វើបាបអ្វីសោះ[ផ] ក៏មិនឃើញមានកិច្ចកលអ្វី
នៅព្រះឱស្ឋទ្រង់ឡើយ[ព] ២៣កាលគេបានជេរប្រមាថដល់
ទ្រង់[ភ] នោះទ្រង់មិនបានជេរតបវិញទេ ខណៈដែលទ្រង់រង
ទុក្ខ នោះក៏មិនបានគំហកកំហែងដល់គេដែរ[ម] គឺបានប្រគល់
ព្រះអង្គទ្រង់[យ]ទៅព្រះ ដែលជំនុំជំរះដោយសុចរិតវិញ[រ]
២៤ទ្រង់បានផ្ទុកអំពើបាបរបស់យើងរាល់គ្នា[ល] នៅលើ
រូបអង្គទ្រង់ ជាប់លើឈើឆ្កាង[វ] ដើម្បីឱ្យយើងបានរស់ខាង
ឯសេចក្ដីសុចរិត ដោយបានស្លាប់ខាងឯអំពើបាបហើយ[ស]
គឺដោយស្នាមជាំរបស់ទ្រង់ ដែលអ្នករាល់គ្នាបានជា[ហ]
២៥ដ្បិតពីដើមអ្នករាល់គ្នាប្រៀបដូចជាចៀមដែលវង្វេង[ឡ]
តែឥឡូវនេះបានត្រឡប់មកឯអ្នកគង្វាល[អ] ជាអ្នកថែទាំព្រលឹងអ្នករាល់គ្នាវិញហើយ[ក]។

## ប្ដីនិងប្រពន្ធ

៣ ១ឯពួកស្រីៗត្រូវចុះចូល[ខ]ចំពោះប្ដីខ្លួន[គ]បែបដូច្នោះដែរ
ដើម្បីបើមានអ្នកណា ដែលមិនព្រមស្ដាប់បង្គាប់ តាមព្រះ
បន្ទូល នោះប្រពន្ធនឹងទាញចិត្តមកបាន[ឃ] ដោយសារកិរិយា

**២:១៩** ត ១ពត ៣:១៤,១៧ **២:២០** ថ ១ពត ៣:១៧ **២:២១** ទ រម ៨:២៨ ធ កច ១៤:២២ ភល ១:២៩ ១ពត ៣:៩ ន ១ពត ៣:១៨ ៤:១,១៣ ប មថ ១១:២៩ ១៦:២៤ **២:២២** ផ ២កថ ៥:២១ ព អស ៥៣:៩ **២:២៣** ភ ហព ១២:៣ ១ពត ៣:៩ ម អស ៥៣:៧ យ លក ២៣:៤៦ រ ទដ ៩:៤

**២:២៤** ល អស ៥៣:៤,១១ ហព ៩:២៨ វ កច ៥:៣០ ស រម ៦:២ ហ ចទ ៣២:៣៩ ទដ ១០៣:៣ អស ៥៣:៥ ហព ១២:១៣ យក ៥:១៦ **២:២៥** ឡ អស ៥៣:៦ អ យហ ១០:១១ ក យប ១០:១២ **៣:១** ខ ១ពត ២:១៨ គ អភ ៥:២២ ឃ ១កថ ៧:១៦ ៩:១៩

តួនាទីជាអ្វីក៏ដោយ ។ តាមបរិបទនេះ លោកពេត្រុសកំពុងនិយាយដល់ទាសករដែលជឿព្រះ ។ ក្នុងព្រះគម្ពីរសញ្ញាថ្មីអ្នកនិពន្ធមិនសរសេរវាយប្រហារពួកទាសករឡើយ(ការពន្យល់ អភ ៦:៥) ផ្ទុយទៅវិញ ព្រះគម្ពីរសញ្ញាថ្មីមានសរសេរពីគោលការសំដៅផ្ដួលរំលំរបបទាសភាព(មើល ភម ១៦)។ ការបង្រៀនជាមូលដ្ឋានរបស់ លោកពេត្រុសអំពីបញ្ហានេះ ក៏អាចយកមកប្រើនៅក្នុងទំនាក់ទំនងរវាងនិយោជក និងនិយោជិកបច្ចុប្បន្នផងដែរ (អភ ៦:៥–៨ កល ៣:២២–២៥ ១ធថ ៦:១–២ ទត ២:៩–១០)។

**២:១៩** *បញ្ញាចិត្តជ្រះថ្លានៅចំពោះព្រះ* ដោយសារការចុះចូលចំពោះរដ្ឋអំណាចដែលកើតចេញពីច្បាប់ដ៏ត្រឹមត្រូវនោះគឺ"ដោយយល់ដល់ព្រះ"(ខ.១៣ សូមធៀបនឹង អភ ៦:៧–៨) នោះការដែលអាចចុះចូល ដោយរងទុកយ៉ាងអយុត្តិធម៌តាមព្រះហឫទ័យព្រះ គឺជាការដែលគួរឱ្យសរសើរ ។

**២:២១** *ទ្រង់បានហៅអ្នករាល់គ្នា មកឯសេចក្ដីនោះឯង* ការរងទុក្ខដោយអត់ទ្រាំចំពោះសេចក្ដីអយុត្តិធម៌ គឺជាផ្នែកមួយនៅក្នុងផែនការព្រះសម្រាប់គ្រីស្ទបរិស័ទ និងជាការប្រកាន់ខ្ជាប់តាមព្រះគុណដ៏ពិតប្រាកដ(៥:១២)។ *ព្រះគ្រីស្ទក៏បានរងទុក្ខជំនួសយើង* សូមធៀប អស ៥២:១៣–៥៣:១២ ។ ព្រះគ្រីស្ទទ្រង់ជាគំរូដ៏ល្អបំផុតអំពីការអត់ទ្រាំនឹងការអាក្រក់ ដើម្បីការល្អ ហើយទ្រង់បំផ្លាស់បំប្រែការរងទុក្ខរបស់អ្នកដើរតាមទ្រង់ ពីសេចក្ដីវេទនាទៅជាអភ័យឯកសិទ្ធិ(កច ៥:៤១)។

**២:២២** បទគម្ពីរនេះប្រកាសពីភាពគ្មានបាបទាស់តែសោះនៃព្រះគ្រីស្ទ(១:១៩ កច ៣:១៤ និងការពន្យល់ ២កថ ៥:២១ ហព ៤:១៥ ៧:២៥ ១យហ ៣:៥)។ *មិនឃើញមានកិច្ចកលអ្វី* សូមធៀបនឹង ខ.១ ៣:១០ ។

**២:២៣** ខនេះនិយាយពីគំរូនៃការចុះចូលរបស់ព្រះគ្រីស្ទ ដោយពុំមានបន្ទូលអ្វីទាំងអស់ដែលមាននៅក្នុង មថ ២៧:១២–១៤,៣៤–៤៤ ។ *ប្រគល់ព្រះអង្គទ្រង់* សូមធៀប ៤:១៩ ។

**២:២៤** *ផ្ទុកអំពើបាបរបស់យើងរាល់គ្នា* មើល អស ៥៣:១២ ។ ព្រះគ្រីស្ទបានសុគតដើម្បីលោះបាបមនុស្ស ដូចជាកូនចៀមដែលគេធ្វើយញ្ញបូជានៅសម័យសញ្ញាចាស់(រម ៥:៦ ១យហ ២:២ និងពន្យល់)។ *ឈើឆ្កាង* មើលការពន្យល់ កច ៥:៣០ និង កច ១០:៣៩ ១៣:២៩ កទ ៣:១៣ និងពន្យល់ ។ *ដើម្បីឱ្យយើងបានរស់ខាងឯសេចក្ដីសុចរិត ដោយបានស្លាប់ខាងឯអំពើបាប* សូមធៀបនឹង រម ៦:៣–១៤ ។ ក្នុងខនេះលោកពេត្រុសបាននិយាយសង្កត់ធ្ងន់ពីការសុគតលើឈើឆ្កាងរបស់ព្រះគ្រីស្ទដើម្បីឱ្យមនុស្សយើងបានរស់ខាងឯសេចក្ដីសុចរិត ។ ដោយសារព្រះគ្រីស្ទបានសុគតនៅលើឈើឆ្កាង អ្នកជឿក៏បានស្លាប់ខាងឯអំពើបាប ដើម្បីឱ្យយើងបានរស់នៅក្នុងជីវិតថ្មី ហើយត្រូវថ្វាយរូបកាយរបស់ខ្លួនដល់ព្រះ ដូចជាឧបករណ៍នៃសេចក្ដីសុចរិត (មើលការពន្យល់ រម ៦:១១–១៣)។ *អ្នករាល់គ្នាបានជា* មើល អស ៥៣:៥ និងការពន្យល់ ។ ការប្រោសនេះមិនមែនសំដៅទៅលើការប្រោសខាងឯរូបកាយទេ ទោះបីជាមានអ្នកខ្លះជឿថា ការប្រោសឱ្យជាមានរាប់បញ្ចូលនៅក្នុងការលោះបាបក៏ដោយ (សូមធៀប អស ៥៣:៤ និងការពន្យល់ មថ ៨:១៦–១៧)។ អ្នកខ្លះជឿថា ការប្រោសឱ្យបានជានៅក្នុងវគ្គនេះជាការប្រោសឱ្យជាខាងឯវិញ្ញាណ ។

**២:២៥** *អ្នកគង្វាល* ពាក្យនេះមានទំនាក់ទំនងនឹងចៀមដែលបែរចេញតាមផ្លូវរៀងៗខ្លួន ក្នុង អស ៥៣ ។ មើលការពន្យល់ ទដ ២៣:១ មើល យហ ១០:១១,១៤ និងការពន្យល់ ហព ១៣:២០ ។ *អ្នកថែទាំ* មានន័យថាព្រះគ្រីស្ទ (សូមធៀបនឹង ៥:២,៤ កច ២០:២៨)។ ពួកចាស់ទុំត្រូវធ្វើទាំងអ្នកគង្វាល និងអ្នកថែទាំមានន័យថា ពួកគេត្រូវថែទាំសុខុមាលភាពរបស់ហ្វូងចៀម ។

**៣:១–៦** វគ្គនេះគឺជាសេចក្ដីបង្រៀនដល់ស្ត្រីជាប្រពន្ធ(សូមធៀបនឹង លប ៣:១៦–១កថ ១១:៣ និងការពន្យល់ អភ ៥:២២–២៤ និងការពន្យល់ ៥:២២ កល ៣:១៨ ១ធថ ២:៩–១០ ទត ២:៥)។

**៣:១** *ត្រូវចុះចូល* ព្រះគម្ពីរក្រិកប្រើកិរិយាសព្ទដូចនៅក្នុង ២:១៣,១៨ ជាពាក្យដែលបង្គាប់ឱ្យចុះចូលចំពោះអំណាចដែលត្រឹមត្រូវ ។ ខនេះមិនមានន័យថាប្រពន្ធត្រូវបន្ទាបតម្លៃនៃខ្លួនឯងឱ្យទាបជាងប្ដីនោះឡើយ ។ ការចុះចូលមានតួនាទីយ៉ាងសំខាន់នៅក្នុងការធ្វើឱ្យមានសណ្ដាប់ធ្នាប់ក្នុងគ្រួសារ ។ *បែបដូច្នោះដែរ* គឺដូចដែលអ្នកជឿត្រូវតែចុះចូលចំពោះរដ្ឋអំណាច (២:១៣–១៧) និងដូចដែលអ្នក បម្រើត្រូវតែចុះចូលចំពោះចៅហ្វាយដែរ

ល្អក្រៅពីព្រះបន្ទូល ២ដោយអ្នកនោះឃើញកិរិយាបរិសុទ្ធ
ដែលប្រពន្ធប្រព្រឹត្តយ៉ាងកោតខ្លាចដល់ព្រះ ៣ទាំងតែងខ្លួន
មិនមែនដោយបែបខាងក្រៅ ដូចជាក្រងសក់ ពាក់មាស ឬ
សំលៀកបំពាក់ផ្សេង ៗ ឡើយ[ង] ៤គឺតែងចំពោះមនុស្សលាក់
កំបាំងក្នុងចិត្តវិញ[ច] ដោយគ្រឿងដ៏មិនចេះពុករលួយរបស់
វិញ្ញាណសំឡូត ហើយរម្យទម នោះឯងជាសេចក្តី ដែល
មានដំឡៃវិសេសនៅចំពោះព្រះ[ឆ] ៥ដ្បិតពីដើម ពួកស្រី ៗ
បរិសុទ្ធដែលសង្ឃឹមដល់ព្រះ[ជ] ក៏បានតែងខ្លួនយ៉ាងដូច្នោះ[ឈ]
ទាំងចុះចូលចំពោះប្តីខ្លួនដែរ ៦ដូចជានាងសារ៉ាបាន
ចុះចូលនឹងលោកអ័ប្រាហាំ ព្រមទាំងហៅលោកជាម្ចាស់
ផង[ញ] ឯអ្នករាល់គ្នា ក៏បានត្រឡប់ជាពូជនាងនោះ ដោយ
បានប្រព្រឹត្តល្អ ឥតភិតភ័យនឹងសេចក្តីស្ញែងខ្លាចណាឡើយ
៧ឯពួកប្រុស ៗ[ដ] នោះក៏ត្រូវនៅជាមួយនឹងប្រពន្ធដោយ
ប្រាជ្ញាដែរ ដូចនឹងគ្រឿងភាជនៈដែលខ្សោយជាងគឺជា
មនុស្សស្រី ព្រមទាំងរាប់អាននាង ទុកដូចជាអ្នកគ្រងព្រះ
គុណនៃជីវិត ទុកជាមរដកជាមួយគ្នា ដើម្បីកុំឱ្យមានអ្វីបង្អាក់
ដល់សេចក្តីអធិស្ឋានរបស់អ្នករាល់គ្នាឡើយ ។

**៣:៣** ង អស ៣:១៨–២៣ ១ធថ ២:៩
**៣:៤** ច រម ៧:២២ អភ ៣:១៦
ឆ រម ២:២៩
**៣:៥** ជ ១ធថ ៥:៥
ឈ នអ ២:១៥
**៣:៦** ញ លប ១៨:១២
**៣:៧** ដ អភ ៥:២៥–៣៣ កល ៣:១៩
**៣:៨** ឋ រម ១៥:៥ ឌ រម ១២:១០ ឍ អភ ៤:២ ១ពត ៥:៥
**៣:៩** ណ រម ១២:១៧ ១ថន ៥:១៥
ត ១ពត ២:២៣ ថ មថ ៥:៤៤ ទ រម ៨:២៨
ធ ១ពត ២:២១
**៣:១២** ប ទដ ៣៤:១២–១៦

## ការរងទុក្ខដោយសារទង្វើល្អ

៨ក្រោយបង្អស់នេះ ចូរឱ្យគ្រប់គ្នាមានគំនិតតែ១[ឋ] ព្រម
ទាំងមានចិត្តអាណិតអាសូរ ហើយស្រឡាញ់គ្នាជាបងប្អូន[ឌ]
នឹងមានចិត្តទន់សន្តោស ហើយសុភាព[ឍ] ៩ឥតធ្វើការអាក្រក់
ស្នងនឹងការអាក្រក់[ណ] ឬពាក្យប្រមាថស្នងនឹងពាក្យប្រមាថ
ឡើយ[ត] គឺត្រូវឱ្យពរវិញ[ថ] ដោយដឹងថា ទ្រង់បានហៅអ្នក
រាល់គ្នា[ទ] មកឯសេចក្តីនោះឯង[ធ] ដើម្បីឱ្យបានព្រះពរទុកជា
មរដក[ន] ១០ដ្បិត «អ្នកណាដែលចូលចិត្តចង់ស្រឡាញ់ជីវិត
ហើយចង់ឃើញគ្រាដ៏ល្អ នោះត្រូវបញ្ឈៀសអណ្តាត ពី
សេចក្តីអាក្រក់ចេញ ហើយបបូរមាត់ក៏ដែរ កុំឱ្យពោល
ពាក្យប្រកបដោយឧបាយកលឡើយ ១១ត្រូវឱ្យអ្នកនោះបែរ
ចេញពីការអាក្រក់ ប្រយោជន៍ឱ្យបានធ្វើការល្អវិញ ត្រូវ
ស្វែងរក ហើយដេញតាមសេចក្តីមេត្រីភាព ១២ពីព្រោះព្រះ
នេត្រនៃព្រះអម្ចាស់ តែងទតមកលើមនុស្សសុចរិត ឯព្រះ
កាណ៌ទ្រង់ក៏ផ្ទៀងស្តាប់ពាក្យទូលអង្វររបស់គេ តែព្រះភក្ត្រ
ព្រះអម្ចាស់ តែងទាស់ទទឹងនឹងពួកអ្នកដែលប្រព្រឹត្តអាក្រក់
វិញ»[ប] ។

(២:១៨–២៥) ។ *ព្រះបន្ទូល* គឺដំណឹងល្អ ។ *ក្រៅពីព្រះបន្ទូល* បើបុរសជាប្តីមិនស្តាប់បង្គាប់តាមព្រះបន្ទូល ឬការផ្សាយដំណឹងល្អទេ ស្ត្រីជាប្រពន្ធត្រូវរស់នៅជាទីបន្ទាល់ល្អ ព្រោះការប្រព្រឹត្តបញ្ចេញ សំឡេងខ្លាំងជាងពាក្យសម្តី ។

**៣:២** *កិរិយាបរិសុទ្ធ . . . កោតខ្លាចដល់ព្រះ* ស្ត្រីជាប្រពន្ធត្រូវរស់នៅប្រកបដោយកិរិយាធម៌បរិសុទ្ធ ដែលជាលទ្ធផលនៃការកោតខ្លាចដល់ព្រះ ។

**៣:៣** *ក្រងសក់ ពាក់មាស* (មើលការពន្យល់ ១ធថ ២:៩) ពាក្យនេះសំដៅទៅលើការតុបតែងសក់ខ្លាំងពេក និងពាក់គ្រឿងអលង្កាឆើតឆាយ ។ ស្ត្រីដែលជឿព្រះមិនត្រូវរំពឹងទៅលើការសម្អិតសម្អាងកាយដើម្បីធ្វើជាបន្ទាល់ដល់អ្នកដទៃទេ ។ *សំលៀកបំពាក់* គឺសម្លៀកបំពាក់ថ្លៃៗហើយឆើតឆាយ ។

**៣:៥** *ដ្បិតពីដើម* មានន័យថាសេចក្តីបង្គាប់ក្នុងវគ្គនេះអាចប្រើបានគ្រប់សម័យកាល ។

**៣:៦** *ព្រមទាំងហៅលោកជាម្ចាស់ផង* គឺជារបៀបនៃការចុះចូលដែលបាននិយាយចាប់ពីខ.១ (មើល លប ១៨:១២) ។ *ពូជនាងនោះ . . . ឥតភិតភ័យ* ស្ត្រីជាគ្រីស្ទបរិស័ទក្លាយជាកូនស្រីរបស់នាងសារ៉ា នៅពេលដែលពួកគេបានត្រឡប់ដូចជានាងនៅក្នុងការធ្វើល្អ និងមិនភ័យខ្លាចគ្រោះមហន្តរាយអ្វីមួយនោះ ប៉ុន្តែ មានជំនឿលើព្រះ (សូមផ្ទៀប សភ ៣:២៥–២៧) ។

**៣:៧** *គ្រឿងភាជនៈដែលខ្សោយជាង* ពាក្យនោះមិនសំដៅទៅលើភាពអន់ខ្សោយជាងខាងផ្នែកសីលធម៌ និងបញ្ញាទេ ប៉ុន្តែសំដៅទៅលើភាពទន់ខ្សោយខាងផ្នែក កាយសម្បទារបស់ស្ត្រី ។ *អ្នកគ្រងព្រះគុណនៃជីវិតទុកជាមរដកជាមួយគ្នា* ព្រះគុណរបស់ព្រះគឺមានស្មើគ្នាសម្រាប់ជីវិតមនុស្សទាំងពីរភេទ (កទ ៣:២៨ និងការពន្យល់) ។ *បង្អាក់ ដល់សេចក្តីអធិស្ឋានរបស់អ្នករាល់គ្នា* មានន័យថា ការប្រកបខាងឯវិញ្ញាណជាមួយនឹងព្រះ និងរវាងប្តីនិងប្រពន្ធអាចត្រូវបង្អាក់ដោយការព្រងើយកន្តើយនឹងសេចក្តីបង្រៀនរបស់ព្រះអំពីទំនាក់ទំនងប្តីប្រពន្ធ ។

**៣:៨–១២** នៅក្នុងវគ្គ ២:១១–១៧ សាវកពេត្រុសបាននិយាយដល់អ្នកអានរបស់គាត់ទាំងអស់ដោយមិនចំពោះ ហើយនៅក្នុង ២:១៨–២៥ គាត់បាននិយាយដល់ ពួកអ្នកបម្រើដោយផ្ទាល់តែម្តង ក្នុង ៣:១–៦ គាត់បាននិយាយដល់ស្ត្រីជាប្រពន្ធ និង ក្នុង ៣:៧ ដល់ប្តី ។ នៅក្នុងវគ្គនេះគាត់បានលើកទឹកចិត្តអ្នកអានរបស់គាត់ទាំងអស់ ឱ្យចម្រើនផ្នែកគុណធម៌នៅក្នុងទំនាក់ទំនងរបស់ពួកគេជាមួយនឹងអ្នកដទៃ (មើលពាក្យ "គ្រប់គ្នា"ក្នុងខ.៨) ។

**៣:៨** *ចូរឱ្យគ្រប់គ្នាមានគំនិតតែ១* មើល រម ១២:១៦ ភល ២:២ និងការពន្យល់។ *មានចិត្តអាណិតអាសូរ* មើល រម ១២:១៥ ១កថ ១២:២៦ និងការពន្យល់ ។ *ស្រឡាញ់គ្នាជាបងប្អូន* មើល កល ៣:១២ ។ *សុភាព* មើល ភល ២:៦–៨ និងការ ពន្យល់ ។

**៣:៩** មើល ២:២៣ រម ១២:១៧–២១ និងការពន្យល់ ។

**៣:១០–១២** វគ្គនេះមានការដកស្រង់ចេញពី ទដ ៣៤ ។ តាមបទគម្ពីរនេះ (១).អ្នកប្រតិបត្តិតាមព្រះរាជបញ្ញានេះ នឹងបានការស្កប់ចិត្តនៅក្នុងការរស់នៅ (២).នឹងបានឃើញគ្រាដ៏ល្អ (៣).ព្រះនេត្រនៃព្រះអម្ចាស់នឹងទតមកលើអ្នកនោះ ជានិច្ច (ខ.១២) និង (៤).ព្រះកាណ៌ទ្រង់ក៏នឹងផ្ទៀងស្តាប់ពាក្យទូលអង្វររបស់គេ (ខ.១២) ។ ចំពោះសេចក្តីយោងពីការគ្រប់គ្រងអណ្តាត សូមមើល យក ៣:២–១៨ ។

**៣:១១** ជាញឹកញាប់មនុស្សយើងយល់ថា សន្តិភាពគឺគ្រាន់តែជាអវត្តមាននៃជម្លោះតែប៉ុណ្ណោះ ហើយយល់ថា ការចងសេចក្តីមេត្រីជាតួនាទី ដែលអ្នកដទៃត្រូវចាប់ផ្តើមមុន ប៉ុន្តែនៅក្នុងបទគម្ពីរនេះ សេចក្តីមេត្រីភាពគឺជាការដែលត្រូវដេញតាម ការបង្កើតសេចក្តីមេត្រីអាចជាការពិបាកធ្វើជាងការបង្កជម្លោះ ប៉ុន្តែមិននាំមកនូវសេចក្តីស្លាប់ទេ តែនាំមកនូវជីវិត និងសុភមង្គលវិញ ។

**៣:១២** *ព្រះភក្ត្រព្រះអម្ចាស់* មើល ទដ ១៣:១ និងការពន្យល់ ។

១៣បើអ្នករាល់គ្នាឧស្សាហ៍នឹងប្រព្រឹត្តការល្អ នោះតើ
មានអ្នកណានឹងធ្វើបាបដល់អ្នករាល់គ្នា[ផ] ១៤តែបើអ្នករាល់
គ្នាត្រូវរងទុក្ខ ដោយព្រោះសេចក្តីសុចរិតវិញ នោះអ្នក
រាល់គ្នាមានពរពិត[ព] មិនត្រូវឱ្យអ្នកខ្លាចចំពោះសេចក្តីស្ញែង
ខ្លាចរបស់គេឡើយ ក៏កុំឱ្យថប់បារម្ភដែរ[ភ] ១៥ចូរឱ្យតាំង
ព្រះគ្រីស្ទឡើង ជាបរិសុទ្ធ នៅក្នុងចិត្តអ្នករាល់គ្នា ទុកជា
ព្រះអម្ចាស់ចុះ ហើយឱ្យប្រុងប្រៀបជានិច្ច ដោយសុភាព
ហើយកោតខ្លាច ដើម្បីនឹងតបឆ្លើយដល់អ្នកណាដែលសួរ[ម]
ពីហេតុនៃសេចក្តីសង្ឃឹម[យ]របស់អ្នករាល់គ្នា ១៦ព្រមទាំង
មានបញ្ញាចិត្តជ្រះថ្លា[រ] ដើម្បីឱ្យពួកអ្នកដែលនិយាយដើមពី
អ្នករាល់គ្នា ទុកដូចជាមនុស្សប្រព្រឹត្តអាក្រក់ បានអៀន
ខ្មាសវិញ ដោយព្រោះគេនិយាយបង្កាច់ពីកិរិយាល្អ ដែល
អ្នករាល់គ្នាប្រព្រឹត្តក្នុងព្រះគ្រីស្ទ[ល] ១៧ដ្បិតបើព្រះទ្រង់សព្វ
ព្រះហឫទ័យ[វ]ឱ្យអ្នករាល់គ្នារងទុក្ខ នោះស៊ូរងដោយព្រោះ
ការល្អ[ស]ជាជាងការអាក្រក់ ១៨ព្រោះព្រះគ្រីស្ទទ្រង់បានរង
ទុក្ខម្តង[ហ] ដោយព្រោះបាប[ឡ]ដែរ គឺជាព្រះដ៏សុចរិត ទ្រង់រង
ទុក្ខជំនួសមនុស្សទុច្ចរិត ដើម្បីនឹងនាំយើងរាល់គ្នាទៅដល់
ព្រះ[អ] ដោយទ្រង់ត្រូវគេធ្វើគុតខាងសាច់ឈាម[ក] តែបានព្រះ
វិញ្ញាណប្រោសឱ្យរស់វិញ[ខ] ១៩ហើយដោយនូវព្រះវិញ្ញាណ
នោះឯង ទ្រង់បានយាងទៅប្រដៅដល់ពួកវិញ្ញាណដែល
ជាប់ឃុំ ជាពួកអ្នកដែលពីដើមមិនព្រមជឿ[គ] ២០គឺក្នុងខណៈ
ដែលសេចក្តីអត់ធ្មត់របស់ព្រះ[ឃ] បានរង់ចាំនៅជំនាន់លោក
ណូអេ កាលលោកកំពុងតែធ្វើទូកធំ[ង] ហើយនៅក្នុងទូកនោះ
មានមនុស្សតែបន្តិច គឺ៨នាក់ប៉ុណ្ណោះ[ច] ដែលបានរួចដោយ

**៣:១៣** ផ ទត ២:១៤
**៣:១៤** ព ខ.១៧ ១ពត ២:១៩,២០ ៤:១៥,១៦ ភ អស ៨:១២,១៣
**៣:១៥** ម កល ៤:៦ យ ហព ៣:៦
**៣:១៦** រ ខ.២១ កច ២៣:១ ល ១ពត ២:១២,១៥
**៣:១៧** វ ១ពត ២:១៥ ៤:១៩ ស ១ពត ២:២០ ៤:១៥,១៦
**៣:១៨** ហ ហព ៧:២៧ ឡ ១ពត ២:២១ ៤:១,១៣ អ រម ៥:២ ក កល ១:២២ ១ពត ៤:១ ខ ១ពត ៤:៦ **៣:១៩** គ ១ពត ៤:៦ **៣:២០** ឃ រម ២:៤ ង លប ៦:៣,៥,១៣, ១៤ ច លប ៨:១៨

**៣:១៣** *តើមានអ្នកណានឹងធ្វើបាបដល់អ្នករាល់គ្នា?* បុគ្គលដែលសាបព្រោះពូជល្អ និងបានទទួលផលល្អ(កទ ៦:៧) ។

**៣:១៤** *បើអ្នករាល់គ្នាត្រូវរងទុក្ខ ដោយព្រោះសេចក្តីសុចរិត* ព្រះទ្រង់អនុញ្ញាតឱ្យមានការល្បងល និងការបៀតបៀនដល់អ្នកជឿ ដើម្បីសេចក្តីសុចរិត ប៉ុន្តែការ សំខាន់មិនមែនដើម្បីឱ្យអ្នកជឿរងទុក្ខតែម៉្យាងនោះឡើយ ព្រោះទ្រង់នឹងឱ្យការ នោះកើតឡើងសូម្បីតែនៅក្នុងការបម្រើទ្រង់ ដើម្បីឱ្យមានការចម្រើនឡើងខាងឯសេចក្តីល្អដល់អ្នកដើរតាមទ្រង់ ។

**៣:១៥** *តាំងព្រះគ្រីស្ទឡើង ជាបរិសុទ្ធ* ពាក្យនេះគឺជាការលើកទឹកចិត្តដល់គ្រីស្ទបរិស័ទឱ្យមានការប្តេជ្ញាចិត្តចំពោះព្រះគ្រីស្ទ ។ នៅពេលដែលមានការត្រាស់ហៅឱ្យការពារជំនឿ អ្នកជឿព្រះមិនត្រូវមានសេចក្តីក្លាហានក្នុងការនិយាយ ដោយការប្រុងប្រៀបខ្លួនជានិច្ច ។ *ដោយសុភាពហើយកោតខ្លាច* គ្រីស្ទបរិស័ទ ត្រូវធ្វើជាសុភាពបុរស និងសុភាពនារីជានិច្ច ទោះជាត្រូវអ្នកដទៃបៀតបៀនក៏ដោយ ។ ការឆ្លើយតបគឺត្រូវផ្តល់ឱ្យដោយសេចក្តីស្រឡាញ់ មិនមែនពាក្យមិនសមរម្យនោះទេ ។ *សេចក្តីសង្ឃឹម* មើល រម ៥:៥ និងការពន្យល់ ។

**៣:១៦** *បានអៀនខ្មាសវិញ ដោយព្រោះគេនិយាយបង្កាច់ពីកិរិយាល្អ* ពីព្រោះការនិយាយបង្កាច់មិនមែនជាការពិត ហើយព្រោះការប្រព្រឹត្តដោយសេចក្តីស្រឡាញ់របស់គ្រីស្ទបរិស័ទ នាំឱ្យអ្នកប្រឆាំងមានសេចក្តីអាម៉ាសពីទង្វើអាក្រក់របស់ខ្លួន ។

**៣:១៨** *បានរងទុក្ខម្តង* មើល ហព ៩:២៨ ។ *ព្រះដ៏សុចរិត ទ្រង់រងទុក្ខជំនួសមនុស្សទុច្ចរិត* លោកពេត្រុសនិយាយដូចលោកប៉ុលក្នុង ភល ២:៥-១១ ពីគំរូ ដែលព្រះគ្រីស្ទទ្រង់បានប្រទានសម្រាប់ឱ្យគ្រីស្ទបរិស័ទយកតាម ។ អ្នកផ្ទុកឈើឆ្កាង ដើរតាមព្រះគ្រីស្ទត្រូវមានការត្រៀមខ្លួនជានិច្ចសម្រាប់ ការរងទុក្ខដោយសារការប្រព្រឹត្តល្អ(ខ.១៣-១៤,១៧)។ ទោះជាយ៉ាងណាក៏ដោយការនិយាយពីការរងទុក្ខ និងការសុគតរបស់ព្រះគ្រីស្ទបាននាំ លោកពេត្រុសពន្យល់ពីហេតុការណ៍ ដែលកើតឡើងបន្ទាប់ ពីការសុគត របស់ព្រះគ្រីស្ទ ដែលមានការយាងទៅប្រដៅដល់ពួកវិញ្ញាណដែលជាប់ឃុំ និងការធ្វើបុណ្យជ្រមុជទឹក(មើល ខ.១៩-២១)។ *តែបានព្រះវិញ្ញាណប្រោសឱ្យរួចវិញ* សំដៅលើការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទ ។ បទគម្ពីរផ្សេងទៀតនិយាយពីការប្រោសព្រះគ្រីស្ទឱ្យមានព្រះជន្ម ឡើងវិញដោយព្រះវរបិតា(កច ២:៣២ កទ ១:១ អភ ១:២០) និងព្រះរាជបុត្រា ដែលព្រះវរបិតាប្រទានអំណាចឱ្យទ្រង់អាចយកជីវិតដែលបានដាក់មកវិញបាន (យហ ១០:១៧-១៨) តែទោះជាយ៉ាងណាក៏ដោយអង្គទាំងបីរួមគ្នាមកតែមួយជាព្រះត្រៃឯក ។

**៣:១៩-២០ក** មានការកាត់ស្រាយសំខាន់ៗបីអំពីវគ្គនេះគឺ (១).អ្នកខ្លះយល់ថា មុនពេលយាងមកយកកំណើតជាមនុស្ស ព្រះគ្រីស្ទទ្រង់បានយាងហើយផ្សាយតាម រយៈលោកណូអេទៅដល់ដំណមនុស្សអាក្រក់នៅសម័យនោះ។ (២).អ្នកខ្លះទៀតយល់ថា នៅចន្លោះពេលនៃការសុគត និងការមានព្រះជន្មឡើងវិញ ព្រះគ្រីស្ទទ្រង់យាងទៅប្រដៅដល់ពួកទេវតាដែលជាប់ឃុំ និងដល់ពួកទេវតាដែលបានលះ ចោលសភាពពិតរបស់ខ្លួនមករៀបការជាមួយមនុស្សស្រីសម័យលោកណូអេ (សូមផ្ទៀប លប ៦:១-៤ ២ពត ២:៤ យដ ៦)។ មានការកាត់ស្រាយថា ពាក្យ "ពួកកូនប្រុសរបស់ព្រះ" នៅក្នុង លប ៦:២,៤ គឺជាពួកទេវតារបស់ព្រះ ដូចពួក ទេវតាក្នុង យក ១:៦ ២:១ ។ គេជឿថា ព្រះបន្ទូលដែលទ្រង់មានដល់ពួកទេវតា អាក្រក់ទាំងនេះគឺការប្រកាសពីជ័យជម្នះ ។ (៣).មានអ្នកខ្លះទៀតនិយាយថា នៅចន្លោះពេលនៃការសុគត និងការមានព្រះជន្មឡើងវិញ ព្រះយេស៊ូវទ្រង់យាងទៅស្ថានឃុំព្រលឹងមនុស្សស្លាប់ ហើយប្រដៅដល់ពួកវិញ្ញាណដែលស្លាប់ជំនាន់លោកណូអេ ។ ព្រះបន្ទូលដែលទ្រង់ផ្សាយប្រហែលជាដំណឹងល្អ ឬការប្រកាសពីជ័យជម្នះរបស់ព្រះគ្រីស្ទ និងសេចក្តីហិនវិនាសដែលនឹងកើតឡើងដល់អ្នកដែលព្ទ ទាំងអស់នោះ ។

ចំណុចខ្សោយរបស់ទស្សនៈទីមួយគឺ មិនជាប់ទាក់ទងនឹងការសុគតនឹងរស់ឡើងវិញរបស់ព្រះគ្រីស្ទទេ ។ បញ្ហាចម្បងនៅក្នុងទស្សនៈទីពីរគឺការស្មានខុសពីទំនាក់ទំនងផ្លូវភេទរវាងមនុស្សស្រីនឹងពួកទេវតា ហើយទំនាក់ទំនងខាងសាច់ឈាមដូចនោះមិនអាចកើតមានចំពោះ ពួកទេវតាឡើយ ព្រោះពួកទេវតា ជាវិញ្ញាណ(ការពន្យល់ លប ៦:២)។ ការលំបាកបំផុតនៅក្នុងទស្សនៈទីបី គឺការប្រើពាក្យ"វិញ្ញាណ" សំដៅលើតែមនុស្ស ។

សារទឹក[ឆ] ២១ដែលទឹកនោះហើយ ជាគំរូពីបុណ្យជ្រមុជ
ដែលជួយសង្គ្រោះអ្នករាល់គ្នាសព្វថ្ងៃនេះ[ជ] មិនមែនជាការ
សំអាតក្អែលរបស់រូបសាច់ចេញទេ គឺជាសេចក្ដីសន្មតិ
របស់បញ្ញាចិត្តដ៏ជ្រះថ្លា[ឈ]ចំពោះព្រះវិញ ដោយសារព្រះ
យេស៊ូវគ្រីស្ទទ្រង់មានព្រះជន្មរស់ឡើងវិញ[ញ] ២២ដែលទ្រង់
បានយាងចូលទៅក្នុងស្ថានសួគ៌[ដ] គង់នៅខាងស្ដាំនៃព្រះ[ឋ]
ទាំងមានពួកទេវតា ពួកមានអំណាច នឹងពួកមានឥទ្ធិឫទ្ធិ
ទាំងប៉ុន្មាន ចុះចូលនឹងទ្រង់ដែរ[ឌ]។

## ការរស់នៅថ្វាយព្រះ

**៤** ១ដូច្នេះ ដែលព្រះគ្រីស្ទទ្រង់បានរងទុក្ខក្នុងសាច់ឈាម
ជំនួសយើងរួចហើយ[ឍ] នោះត្រូវឱ្យអ្នករាល់គ្នាមានគំនិត
ដូច្នោះដែរ ទុកជាគ្រឿងការពារខ្លួន ដ្បិតអ្នកណាដែលបាន
រងទុក្ខក្នុងសាច់ឈាម នោះបានឈប់ខាងឯអំពើបាប
ហើយ[ណ] ២ដើម្បីកុំឱ្យបង់ពេលដែលសល់ នឹងរស់នៅខាង
សាច់ឈាម តាមតែសេចក្ដីប៉ងប្រាថ្នារបស់មនុស្សទៀត
ឡើយ[ត] គឺតាមបំណងព្រះហឫទ័យនៃព្រះវិញ ៣ដ្បិតដែលពី
ដើម[ថ] យើងរាល់គ្នាបានធ្វើតាមបំណងចិត្តរបស់សាសន៍
ដទៃ ទាំងដើរក្នុងសេចក្ដីអាសអាភាស ការស្រើបស្រាល
ការចំណូលស្រា ស៊ីផឹកជ្រុល ការប្រមឹក នឹងការថ្វាយបង្គំ
រូបព្រះ ដែលសុទ្ធតែខុសច្បាប់ នោះល្មមដល់យើងហើយ[ទ]
៤គេក៏ឆ្ងល់ ដែលអ្នករាល់គ្នាមិនរត់ទៅ តាមសេចក្ដីខូច
អាក្រក់ដ៏ហូរហៀរ ជាមួយនឹងគេដែរ បានជាគេប្រមាថ
ដល់អ្នករាល់គ្នា[ធ] ៥តែគេនឹងត្រូវរាប់រៀបទូលដល់ព្រះវិញ
ដែលទ្រង់រៀបនឹងជំនុំជំរះ ទាំងមនុស្សរស់នឹងមនុស្ស
ស្លាប់[ន] ៦ហេតុនោះបានជា បានផ្សាយដំណឹងល្អទៅមនុស្ស
ដែលស្លាប់ហើយដែរ[ប] ដើម្បីឱ្យគេត្រូវជាប់ជំនុំជំរះខាង
ឯសាច់ឈាម តាមបែបមនុស្ស តែឱ្យគេបានរស់ខាង
ឯវិញ្ញាណតាមព្រះវិញ ។

**៣:២០** ឆ ហព ១១:៧
**៣:២១** ជ កច ២២:១៦
ឈ ខ.១៦ កច ២៣:១
ញ ១ពត ១:៣
**៣:២២** ដ ហព ៤:១៤ ឋ មក ១៦:១៩
ឌ មក ២៨:១៨ រម ៨:៣៨
**៤:១** ឍ ១ពត ២:២១ ណ រម ៦:១៨
**៤:២** ត រម ៦:២ ១ពត ១:១៤
**៤:៣** ថ អភ ២:២
ទ រម ១៣:១៣
**៤:៤** ធ ១ពត ៣:១៦
**៤:៥** ន កច ១០:៤២
**៤:៦** ប ១ពត ៣:១៩

ទស្សនៈដែលល្អបំផុតគឺ វិញ្ញាណដែលជាប់ឃុំជាវិញ្ញាណដែលមិនស្ដាប់បង្គាប់ ("ពួកទេវតា ពួកមានអំណាច និងពួកមានឥទ្ធិឫទ្ធិ"ខ.២២) ហើយការដែលទ្រង់យាងឡើង "ស្ថានសួគ៌"(ខ.២២) គឺជាការប្រកាសពីជ័យជម្នះដល់ពួកទេវតាទាំងនោះ ។

**៣:២១** *ទឹកនោះហើយ ជាគំរូពីបុណ្យជ្រមុជ* នៅក្នុងខនេះ មាននិមិត្តរូបពីរយ៉ាង ។ ទឹកជំនន់ជានិមិត្តរូបនៃបុណ្យជ្រមុជទឹក ហើយបុណ្យជ្រមុជទឹកជានិមិត្តរូបនៃសេចក្ដីសង្គ្រោះ ។ ទឹកជំនន់គឺជានិមិត្តរូបនៃបុណ្យជ្រមុជទឹកមានន័យថា ទឹកដែលបង្ហាញពីការជំនុំជម្រះ (ការសម្លាប់មនុស្សអាក្រក់ក្នុងទឹកជំនន់ ការសុគតនៃព្រះគ្រីស្ទ និងការស្លាប់របស់អ្នកជឿក្នុង បុណ្យជ្រមុជទឹក) គឺជាទឹកដែលជួយសង្គ្រោះ ។ បុណ្យជ្រមុជទឹកគឺជានិមិត្តរូបនៃសេចក្ដីសង្គ្រោះមានន័យថាបុណ្យជ្រមុជទឹក បង្ហាញពីការសុគត ការបញ្ចុះព្រះសព និងការមានព្រះជន្មឡើងវិញនៃព្រះគ្រីស្ទ និងការប្ដេជ្ញាចិត្តរបស់អ្នកជឿក្នុងការដើរតាមព្រះគ្រីស្ទ(រម ៦:៤)។ *ដែលជួយសង្គ្រោះអ្នករាល់គ្នាសព្វថ្ងៃនេះ* តាមការពិតអ្នកជឿបានសេចក្ដីសង្គ្រោះ ដោយការអ្វីដែលបុណ្យជ្រមុជជានិមិត្តរូបឱ្យ ដែលជាការសុគត និងមានព្រះជន្មឡើង វិញនៃព្រះគ្រីស្ទ ។ និមិត្តរូបនិងការពិតមានទំនាក់ទំនងជិតស្និទ្ធនឹងគ្នាយ៉ាងខ្លាំង (មើលការពន្យល់ រម ៦:៣–៤)។ *ជាសេចក្ដីសន្មតិរបស់បញ្ញាចិត្តដ៏ជ្រះថ្លា ចំពោះព្រះ* ការទទួលបុណ្យជ្រមុជទឹកគឺជាការប្ដេជ្ញារបស់អ្នកជឿ នៅក្នុងការដើរតាម និងធ្វើតាមព្រះហឫទ័យដឹកនាំរបស់ព្រះ ហើយដើម្បីបញ្ជាក់ពីការ ដែលអ្នកជឿបានកប់ជាមួយនឹងទ្រង់ក្នុងបុណ្យជ្រមុជ និងការបានរស់ឡើងវិញជាមួយនឹងទ្រង់(កល ២:១២)។ *ដោយសារព្រះយេស៊ូវគ្រីស្ទទ្រង់មានព្រះជន្ម រស់ឡើងវិញ* មនុស្សមិនមែនបានសង្គ្រោះដោយសារការធ្វើបុណ្យសន្សំកុសលអ្វីឡើយ ប៉ុន្តែ ដោយអំណាចនៃសេចក្ដីរស់ឡើងវិញ។

**៤:២** *តាមតែសេចក្ដីប៉ងប្រាថ្នារបស់មនុស្ស . . . បំណងព្រះហឫទ័យនៃព្រះ* ព្រះគ្រីស្ទទ្រង់បានផ្ដល់គំរូនៃការចុះចូលនឹងតាមបំណង ព្រះហឫទ័យព្រះវរបិតា ដែលនាំឱ្យទ្រង់បានទទួលនូវជ័យជម្នះ ដូចនេះគ្រីស្ទបរិស័ទក៏ត្រូវទទួលយកនូវបំណងព្រះហឫទ័យព្រះជាកត្តាកំណត់នៃជីវិតរបស់ខ្លួនផងដែរ

**៤:៣** *ពីដើម* គឺកាលមិនទាន់បានប្រែចិត្តទទួលជឿព្រះ(អភ ២:១–៣ និងការពន្យល់ ២:១)។ *សាសន៍ដទៃ* តាមពាក្យនេះគេអាចសន្និដ្ឋានបានថា យ៉ាងហោច ណាស់ក៏មានអ្នកទទួលសំបុត្រនេះជាសាសន៍ដទៃមួយចំនួនផងដែរ (មើលការពន្យល់ ១:១)។

**៤:៤** *គេក៏ឆ្ងល់ . . . គេប្រមាថដល់អ្នករាល់គ្នា* ការរស់នៅដោយកោតខ្លាចដល់ព្រះក៏អាចមាននូវការបៀតបៀនដែរ(មើល ២ធថ ៣:១២ និងការពន្យល់)។

**៤:៥** *ត្រូវរៀបរាប់ទូល* មើល មថ ១២:៣៦ កច ១៧:៣១ រម ២:៥ និងការពន្យល់ និង ខ.១៦ ។ *ដែលទ្រង់រៀបនឹងជំនុំជំរះ* នៅក្នុងព្រះគម្ពីរសញ្ញាថ្មីមាន និយាយថា ព្រះវរបិតាក៏ដូចជាព្រះរាជបុត្រាដែរ គឺនឹងធ្វើការជំនុំជម្រះនៅថ្ងៃធំ និងចុងក្រោយបំផុត ។ ព្រះវរបិតាទ្រង់រៀបចំឱ្យមានការជំនុំជម្រះ ប៉ុន្តែទ្រង់នឹងប្រគល់ការជំនុំជម្រះនេះទៅដល់ព្រះរាជបុត្រាទ្រង់ (សូមផ្ទៀបនឹង យហ ៥:២៧ កច ១៧:៣១ និងការពន្យល់)។

**៤:៦** *ហេតុនោះបានជា* ពាក្យហេតុនោះគឺសំដៅទៅលើមូលហេតុដែលមានបង្ហាញនៅខាងចុងខនេះ(ក្នុងអនុប្រយោគដែលចាប់ផ្ដើមដោយពាក្យ "ដើម្បី") ប៉ុន្តែមិនមែននៅក្នុងខខាងមុខនោះទេ ។ *ផ្សាយដំណឹងល្អទៅមនុស្សដែលស្លាប់ ហើយដែរ* មនុស្សដែលស្លាប់ ដែលមាននិយាយក្នុងខនេះ គឺអ្នកដែលមិនជឿ ដែលនៅស្លាប់ខាងឯវិញ្ញាណ តែនៅរស់ខាងឯសាច់ឈាមនៅឡើយ ជាឱកាសដែលត្រូវផ្សាយដំណឹងល្អដល់ពួកគេ (បើស្លាប់ទាំងខាងសាច់ឈាមដែរ នោះនឹងគ្មាន ឱកាសនឹងទទួលជឿលើព្រះគ្រីស្ទទៀតឡើយ មើល ហព ៩:២៧ និងការពន្យល់) *ដើម្បីឱ្យគេត្រូវជាប់ជំនុំជំរះខាងឯសាច់ឈាម តាមបែបមនុស្ស* ពួកជំនុំដំបូងជា ច្រើនមានការបារម្ភពីការដែលត្រូវមកដល់បន្ទាប់ ពីការស្លាប់ខាងឯសាច់ឈាមនៅលើផែនដី ។ នៅក្រុងថែស្សាឡូនីច គ្រីស្ទបរិស័ទមានការបារម្ភថា មនុស្សជាទីស្រឡាញ់របស់ពួកគេដែលបានស្លាប់មុនពេលដែលព្រះ គ្រីស្ទទ្រង់យាងមកវិញ នឹងមិនដែលអាចឃើញទ្រង់ទេ(៤:១៣–១៨)។ នៅក្នុងព្រះគម្ពីរពេត្រុសមាន ការបញ្ជាក់ថា អ្នកដែលបានស្លាប់ទៅហើយ(ទាំងពួកសុចរិត

៧រីឯចុងបំផុតនៃរបស់ទាំងអស់ នោះជិតដល់ហើយ[ផ] ដូច្នេះ
ចូរឱ្យមានគំនិតនឹងធឹង[ព] ហើយចាំយាមក្នុងសេចក្តីអធិស្ឋាន
ចុះ ៨តែមុនដំបូងបង្អស់ ត្រូវឱ្យអ្នករាល់គ្នាមានសេចក្តី
ស្រឡាញ់គ្នាឱ្យអស់ពីចិត្ត[ភ] ដ្បិតសេចក្តីស្រឡាញ់ នឹងគ្រប
បាំងអំពើបាបជាអនេកអនន្ត[ម] ៩ចូរប្រព្រឹត្តនឹងគ្នាដោយ
សេចក្តីចៅរ៉ៅ[យ] ឥតមានត្អូញត្អែរឡើយ[រ] ១០គឺដោយខំបំរើ
គ្នាទៅវិញទៅមក តាមអំណោយទានដែលគ្រប់គ្នាបាន
ទទួលមក[ល] ទុកដូចជាអ្នកចែកចាយយ៉ាងល្អ[វ] នៃព្រះគុណដ៏
បែកជាច្រើនផ្លូវវិញ ១១បើអ្នកណាអធិប្បាយ នោះត្រូវតែ
អធិប្បាយ ដូចជាអ្នកដែលបញ្ចេញព្រះបន្ទូលនៃព្រះ[ស]
ហើយបើអ្នកណាបំរើ នោះត្រូវបំរើដោយកំឡាំងដែល
ព្រះប្រទានឱ្យ[ហ] ដើម្បីឱ្យព្រះបានថ្កើងឡើងក្នុងគ្រប់ការ
ទាំងអស់[ឡ] ដោយសារព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់មាន
សិរីល្អ និងព្រះចេស្តានៅអស់កល្បជានិច្ចរៀងរាបតទៅ
អាម៉ែន[អ]។

## ការរងទុក្ខដោយសារជាគ្រីស្ទបរិស័ទ

១២ពួកស្ងួនភ្ងាអើយ កុំឱ្យមានប្លែកក្នុងចិត្ត ដោយភ្លើងដ៏
ក្តៅក្រហាយ ដែលកំពុងតែល្បងអ្នករាល់គ្នា [ក]ទុកដូចជា
កើតមានសេចក្តីចំឡែកនោះឡើយ ១៣ត្រូវអរសប្បាយវិញ[ខ]
ដោយព្រោះមានចំណែកក្នុងការរងទុក្ខរបស់ព្រះគ្រីស្ទ[គ]
ដើម្បីឱ្យអ្នករាល់គ្នាបានត្រេកអររីករាយជាខ្លាំង ក្នុងកាល
ដែលសិរីល្អទ្រង់លេចមក[ឃ] ១៤បើសិនជាគេតិះដៀលអ្នក
រាល់គ្នា ដោយព្រោះព្រះគ្រីស្ទ[ង] នោះមានពរហើយ[ច]
ពីព្រោះព្រះវិញ្ញាណដ៏មានសិរីល្អ គឺជាព្រះវិញ្ញាណនៃព្រះ
ទ្រង់សណ្ឋិតលើអ្នករាល់គ្នាហើយ ១៥កុំបីឱ្យអ្នករាល់គ្នាណា
មួយរងទុក្ខទោស ដោយព្រោះសំឡាប់គេ ឬលួចគេ ឬធ្វើ
ការអាក្រក់ ឬសៀតចូលក្នុងការរបស់អ្នកដទៃឡើយ ១៦តែ
បើរងទុក្ខ ដោយព្រោះជាពួកគ្រីស្ទានវិញ នោះកុំឱ្យខ្មាស
ឱ្យសោះ ចូរសរសើរដំកើងដល់ព្រះ ដោយព្រោះនាមនោះ
វិញ[ឆ] ១៧ដ្បិតពេលវេលាដែលសេចក្តីជំនុំជំរះត្រូវចាប់ផ្តើម
ពីដំណាក់នៃព្រះទៅ[ជ] នោះបានមកដល់ហើយ បើសិនជា
ចាប់តាំងពីយើងរាល់គ្នាជាមុនដូច្នេះ នោះតើចុងបំផុត
របស់ពួកអ្នក ដែលមិនជឿតាមដំណឹងល្អនៃព្រះ នឹងបាន
ជាយ៉ាងដូចម្តេចទៅ[ឈ] ១៨បើមនុស្សសុចរិតបានរួចដោយ
ពិបាកផង នោះពួកទមិលល្មើស នឹងពួកមានបាបនឹង
លេចមកនៅឯណា[ញ] ១៩ដូច្នេះ ពួកអ្នកដែលរងទុក្ខតាម
ព្រះហឫទ័យនៃព្រះ[ដ] នោះត្រូវផ្ញើព្រលឹងខ្លួន ទុកនឹងព្រះដ៏
បង្កបង្កើត ដែលទ្រង់ស្មោះត្រង់ ដោយខ្លួនប្រព្រឹត្តការល្អចុះ។

**៤:៧** ផ រម ១៣:១១ ព កច ២៤:២៥ **៤:៨** ភ ១ពត ១:២២ ម សភ ១០:១២ យក ៥:២០ **៤:៩** យ រម ១២:១៣ រ ភល ២:១៤ **៤:១០** ល រម ១២:៦,៧ វ ១កថ ៤:២ **៤:១១** ស ១ថន ២:៤ ហ អភ ៦:១០ ឡ ១កថ ១០:៣១ អ រម ១១:៣៦ **៤:១២** ក ១ពត ១:៦,៧ **៤:១៣** ខ មថ ៥:១២ គ ២កថ ១:៥ ឃ រម ៨:១៧ ១ពត ១:៧ ៥:១ **៤:១៤** ង យហ ១៥:២១ ច មថ ៥:១១ **៤:១៦** ឆ កច ៥:៤១ **៤:១៧** ជ យរ ២៥:២៩ អគ ៩:៦ អម ៣:២ ១ទត ៣:១៥ ឈ ២ថន ១:៨

**៤:១៨** ញ សភ ១១:៣១ លក ២៣:៣១ **៤:១៩** ដ ១ពត ២:១៥ ៣:១៧

និងពួកទុច្ចរិត) នឹងត្រូវជាប់ជំនុំជម្រះ ។ ការជំនុំជម្រះនឹងត្រូវបានធ្វើឡើងដោយមានយុត្តិធម៌ ព្រោះមានព្រះអម្ចាស់ទ្រង់ជាចៅក្រមដ៏សុចរិតយុត្តិធម៌ ។ ដំណឹងល្អបានចាប់ផ្តើមប្រកាស នៅពេលព្រះយេស៊ូវទ្រង់យាងមកយកកំណើតនៅលើផែនដី ប៉ុន្តែ ដំណឹងល្អមានកំណើតតាំងពីមុនកំណើតលោកិយ(អភ ១:៤) ហើយមានឥទ្ធិពល លើមនុស្សគ្រប់ រូបគឺទាំងមនុស្សរស់ និងមនុស្សស្លាប់ ។

**៤:៧** *ចុងបំផុត . . . ជិតដល់ហើយ* មើលការពន្យល់ យក ៥:៩ ។ *ដូច្នេះ* ត្រង់ចំណុចនេះមានន័យថា ក្នុងការប្រមើលមើលពីទីអវសាន ដែលព្រះយេស៊ូវទ្រង់ យាងត្រឡប់មកវិញ គ្រីស្ទបរិស័ទត្រូវរៀបចំ ចរិត ការប្រព្រឹត្តសកម្មភាព និង ទំនាក់ទំនងឱ្យបានល្អ(២ពត ៣:១១–១៤ និងការពន្យល់)។ *គំនិតនឹងធឹង* គ្រីស្ទបរិស័ទត្រូវមានលក្ខណៈសម្បត្តិជាអ្នកនឹងធឹងខាងប្រាជ្ញាភាពពេញវ័យខាងឯការសម្រេចចិត្ត និងគោលបំណងច្បាស់លាស់ និងបានជ្រើសរើសយ៉ាងត្រឹមត្រូវនៅក្នុងជីវិតរស់នៅ ។ *ហើយចាំយាមក្នុងសេចក្តីអធិស្ឋាន* សូមធៀបនឹង ៣:៧ និងការពន្យល់ ១កថ ៧:៥ ។

**៤:៨** *សេចក្តីស្រឡាញ់គ្នា* មើល ១ថន ៤:៩ ២ពត ១:៧ និងការពន្យល់ និង ១យហ ៤:៧–១១ ។ *សេចក្តីស្រឡាញ់ នឹងគ្របបាំងអំពើបាបជាអនេកអនន្ត* មើល យក ៥:២០ និងការពន្យល់ ។ សេចក្តីស្រឡាញ់នាំឱ្យមានការអត់ទោសឱ្យម្តង ហើយម្តងទៀត(មថ ១៨:២១ និងការពន្យល់ ១៨:២២ ១កថ ១៣:៥ អភ ៤:៣២ និងការពន្យល់)។

**៤:៩** *ដោយសេចក្តីចៅរ៉ៅ* មើល រម ១២:១៣ និងការពន្យល់ ១ធថ ៣:២ ៥:១០ ទត ១:៨ ហព ១៣:២ និងការពន្យល់ ៣យហ ៥–៨ ។

**៤:១០** *តាមអំណោយទានដែលគ្រប់គ្នាបានទទួលមក* មើល រម ១២:៤–៨ ១កថ ១២:៧–១១ និងការពន្យល់ ។

**៤:១១** *ព្រះបន្ទូលនៃព្រះ* មើល កច ៧:៣៨ រម ៣:២ និងពន្យល់ ។ *ដើម្បីឱ្យព្រះបានថ្កើងឡើង* មើល ១កថ ១:២៦–៣១ និងពន្យល់ យក ២៤–២៥។

**៤:១២** *កុំឱ្យមានប្លែកក្នុងចិត្ត . . . កំពុងតែល្បងអ្នករាល់គ្នា* មើល ១:៦–៧ និង ការពន្យល់ ១:៧ ២:២០–២១ និងការពន្យល់ ២:២១ ។

**៤:១៣** *ត្រូវអរសប្បាយវិញ ដោយព្រោះមានចំណែកក្នុងការរងទុក្ខរបស់ព្រះគ្រីស្ទ* មើល កល ១:២៤ និងការពន្យល់ ។ លោកពេត្រុសធ្លាប់ប្រឆាំងនឹងការដែលព្រះយេស៊ូវទ្រង់នឹងរងទុក្ខ(មើល មថ ១៦:២១–២៣)។

**៤:១៤** *តិះដៀលអ្នករាល់គ្នា ដោយព្រោះព្រះគ្រីស្ទ* មើល មថ ៥:១១–១២ យហ ១៥:១៨–២០ កច ៥:៤១ ១៤:២២ រម ៨:១៧ និងការពន្យល់ ២កថ ១:៥ ភល ៣:១០ និងការពន្យល់ ២ធថ ៣:១២ និងការពន្យល់ ។

**៤:១៦** *គ្រីស្ទបរិស័ទ* មើលការពន្យល់ កច ១១:២៦ ។

**៤:១៧** *ពេលវេលាដែលសេចក្តីជំនុំជំរះត្រូវចាប់ផ្តើមពីដំណាក់នៃព្រះ* មានន័យថា ការបៀតបៀនដែលគ្រីស្ទបរិស័ទត្រូវទទួលរង គឺជាការជំនុំជម្រះដែលមក ពីព្រះដើម្បីធ្វើឱ្យពួកគេបានបរិសុទ្ធ ។ *ចុងបំផុតរបស់ពួកអ្នក ដែលមិនជឿតាម ដំណឹងល្អនៃព្រះ និងបានដូចម្តេចទៅ* ព្រះទ្រង់ជំនុំជម្រះរាស្ត្ររបស់ទ្រង់ ដូចនេះការជំនុំជម្រះពួកអ្នកមិនជឿនឹងបានធ្ងន់ជាងអ្នកជឿទៅទៀត ។

## ចំពោះពួកចាស់ទុំ និងអ្នកនៅក្មេង

**៥** ១ឯពួកចាស់ទុំក្នុងពួកអ្នករាល់គ្នា នោះខ្ញុំ ដែលជាអ្នក
ចាស់ទុំដែរ[ឋ] ហើយជាស្មរបន្ទាល់[ឌ] ពីការរងទុក្ខរបស់
ព្រះគ្រីស្ទ ជាអ្នកមានចំណែកក្នុងសិរីល្អដែលត្រូវលេចមក[ឍ]
ខ្ញុំសូមទូន្មានថា ២ចូរឃ្វាលហ្វូងចៀមរបស់ព្រះ[ណ] ដែលនៅ
ជាមួយនឹងអ្នករាល់គ្នាចុះ ទាំងគ្រប់គ្រង ដោយស្ម័គ្រពីចិត្ត
មិនមែនដោយបង្ខំទេ[ត] ក៏មិនមែនដោយចង់បានកំរៃដែរ[ថ]
គឺដោយគាប់ចិត្តវិញ ៣មិនមែនបែបដូចជាមានអំណាច
លើ[ទ]របស់ទ្រព្យទេ គឺដើម្បីឱ្យបានធ្វើជាគំរូ[ធ]ដល់ហ្វូងចៀម
វិញប៉ុណ្ណោះ ៤រួចកាលណាមេពួកអ្នកគង្វាល[ន]បានលេចមក
នោះអ្នករាល់គ្នានឹងទទួលភួងជ័យ[ប] ដែលមិនចេះស្រពោន
ឡើយ[ផ]។
៥ឯអ្នករាល់គ្នាដែលនៅក្មេង នោះត្រូវចុះចូល[ព]នឹងពួក
ចាស់ទុំដែរ ហើយត្រូវឱ្យគ្រប់គ្នាមានចិត្តសុភាព[ភ] ដល់គ្នា
ទៅវិញទៅមក ពីព្រោះព្រះទ្រង់តែងតតាំងនឹងមនុស្សអួត
អាង តែផ្តល់ព្រះគុណដល់ពួករាបសាវិញ[ម] ៦ដូច្នេះ ចូរឱ្យ
អ្នករាល់គ្នាបន្ទាបខ្លួន នៅក្រោមព្រះហស្តដ៏ពូកែរបស់ព្រះ
ចុះ ដើម្បីឱ្យទ្រង់បានដំកើងអ្នករាល់គ្នាឡើង នៅវេលា
កំណត់[យ] ៧ហើយចូរផ្ទេរគ្រប់ទាំងសេចក្ដីទុក្ខព្រួយរបស់អ្នក
រាល់គ្នាទៅលើទ្រង់[រ] ដ្បិតទ្រង់តែងយកព្រះទ័យទុកដាក់នឹង
អ្នករាល់គ្នា[ល]។
៨ចូរឱ្យដឹងខ្លួន[វ] ហើយចាំយាមចុះ ព្រោះអារក្សដែលជា
ខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល[ស] ទាំង
គ្រហឹមដូចជាសឹង្ហ[ហ] ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់

**៥:១** ឋ កច ១១:៣០ ឌ លក ២៤:៤៨ ឍ ១ពត ១:៥,៧ ៤:១៣ វវ ១:៩ **៥:២** ណ យហ ២១:១៦ ត ២កថ ៩:៧ ភម ១៤ ថ ១ធថ ៣:៣ **៥:៣** ទ អគ ៣៤:៤ មថ ២០:២៥-២៨ ធ ១ធថ ៤:១២ **៥:៤** ន យហ ១០:១១ ប ១កថ ៩:២៥ ផ ១ពត ១:៤ **៥:៥** ព អភ ៥:២១ ភ ១ពត ៣:៨ ម សភ ៣:៣៤ មថ ២៣:១២
**៥:៦** យ យប ៥:១១ យក ៤:១០ **៥:៧** រ ទដ ៣៧:៥ មថ ៦:២៥ ល ទដ ៥៥:២២ ហព ១៣:៥ **៥:៨** វ កច ២៤:២៥ ស យប ១:៧ ហ ២ធថ ៤:១៧ **៥:៩** ឡ យក ៤:៧ អ កល ២:៥ ក កច ១៤:២២

**៥:១** *ពួកចាស់ទុំ* មើលការពន្យល់ នក ៣:១៦ ២សយ ៣:១៧ កច ២០:១៧ ១ធថ ៣:១ ៥:១៧ ។ ក្នុងសំបុត្រពេត្រុសនេះក៏មាននិយាយ ដោយឡែកទៅកាន់ពួកចាស់ទុំផងដែរ (សូមធៀប ២យហ ១ ៣យហ ១) ដើម្បីលើកទឹកចិត្តដល់ពួកគេ ដែលមានការទទួលខុសត្រូវខ្ពស់ចំពោះពួកជំនុំ ដែលជាពួកអ្នកខ្ចាត់ខ្ចាយទៅដល់តំបន់ជា ច្រើននៃតំបន់អាស៊ីមីន័រ (១:១ និងមើលការពន្យល់) ដូចនេះ បើសិនជាលោក ពេត្រុសជាអ្នកធ្វើការ នៅក្នុងពួកជំនុំក្នុងតំបន់ នោះគាត់ប្រាកដជាមានទំនាក់ទំនងជាមួយនឹងពួកគេ ។ *ស្មរបន្ទាល់ពីការរងទុក្ខរបស់ព្រះគ្រីស្ទ* លោកពេត្រុសបាននៅក្បែរព្រះគ្រីស្ទតាំង ពីពេលដែលទ្រង់ទើបនឹងចាប់ផ្តើមបេសកកម្មរបស់ទ្រង់ ហើយជាស្មរបន្ទាល់ពីគ្រប់ទាំងការដែលទ្រង់ធ្វើ ដែលរួមមានការរងទុក្ខរបស់ទ្រង់ផងដែរ (សូមធៀបនឹង មថ ២៦:៥៨ មក ១៤:៥៤ លក ២២:៦០-៦២ យហ ១៨:១០-១១,១៥-១៦)។ នៅក្នុងការសរសេរសំបុត្រនេះ គាត់ក៏បាធ្វើស្មរបន្ទាល់ពីការរងទុក្ខរបស់ព្រះគ្រីស្ទ (២:២១-២៤) និងស្តាប់បង្គាប់តាមព្រះរាជបញ្ជារបស់ទ្រង់នៅក្នុង កច ១:៨ ។ *ចំណែកក្នុងសិរីល្អ ដែលត្រូវលេចមក* មើល រម ៨:១៨ ។ លោកពេត្រុសបានធ្វើបន្ទាល់ពីសិរីល្អ នៃព្រះគ្រីស្ទនៅក្នុងការងារជាទូទៅរបស់គាត់(យហ ១:១៤ ២:១១) ហើយគាត់ជាអ្នក ដែលមានវត្តមាននៅកន្លែងដែលព្រះគ្រីស្ទប្រែព្រះកាយផងដែរ (២ពត ១:១៦ និងពន្យល់ មថ ១៦:២៧ ១៧:៨) ដូចនេះគាត់បានឃើញសិរីល្អនៃនគរព្រះហើយ ។ ព្រះគ្រីស្ទទ្រង់បានរងទុក្ខ ហើយបានចូលទៅក្នុងសិរីល្អនៃទ្រង់ហើយ ដូចនេះរាស្ត្ររបស់ទ្រង់ និងមានចំណែកនៅក្នុងសិរីល្អនៅពេលខាងមុខ បន្ទាប់ពីពួកគេរងទុក្ខហើយនោះ ។

**៥:២** *ចូរឃ្វាលហ្វូងចៀមរបស់ព្រះ* គឺជាពាក្យប្រៀបប្រដូច ដែលព្រះអម្ចាស់នៃយើងបានប្រើសម្រាប់អង្គទ្រង់ផងដែរ (យហ ១០:១-១៨ យក ១៥:៣-៧) ហើយលោកពេត្រុសច្បាស់ជាមានការប៉ះពាល់ចិត្ត (យហ ២១:១៥-១៧ សូមធៀប ១ពត ២:២៥)។ ការដែលលោកពេត្រុសសរសេរសំបុត្រនេះ ក៏ជាការអនុវត្តតាមព្រះរាជបញ្ជាដែលព្រះគ្រីស្ទទ្រង់បង្គាប់ថាឱ្យចំណីដល់ចៀមរបស់ទ្រង់ផងដែរ ។ ពាក្យ "ឃ្វាលហ្វូងចៀម" ក៏ជាពាក្យប្រៀបធៀបដែលមានប្រើនៅក្នុងព្រះគម្ពីរសញ្ញាចាស់ផងដែរ (អគ ៣៤:១-១០ ព្រះអម្ចាស់ទ្រង់បានដាក់ទោសឱ្យអ្នកដឹកនាំសាសន៍អ៊ីស្រាអែលទទួលខុសត្រូវចំពោះការមិនឃ្វាលហ្វូងចៀមអ៊ីស្រាអែល)។ *ទាំងគ្រប់គ្រង* លក្ខណៈនៃពាក្យ"គ្រប់គ្រង"នេះ មានប្រើនៅក្នុង កច ២០:២៨ ភល ១:១ ១ធថ ៣:២ ទត ១:៧ មើលការពន្យល់ ១ធថ ៣:១ ។ ក្នុងបរិបទនៃវគ្គនេះក៏ដូចជាក្នុង កច ២០:១៧,២៨ លក្ខណៈនៃពាក្យទាំងបីដែលមាន "ពួកចាស់ទុំ" "គ្រប់គ្រង" និង"ឃ្វាលហ្វូងចៀម"(គ្រូគង្វាល) សុទ្ធតែប្រើជាមួយគ្នានៅក្នុងមុខនាទីតែមួយ(ការពន្យល់ ទត ១:៧)។

**៥:៣** *មិនមែនបែបដូចជាមានអំណាចលើរបស់ទ្រព្យ* សូមធៀបនឹង មថ ១៦:២៤-២៧ មក ១០:៤២-៤៥ ភល ២:៦-១១ ២ថន ៣:៩ ។ ទោះបីជាលោកពេត្រុស មានសិទ្ធិអំណាចជាសាវ័កពេញទីក៏ដោយ(មើល ឧ.១) ក៏លោកមិនបានប្រើវា ដើម្បីបង្គាប់អ្នកដទៃតាមចិត្តទេ ប៉ុន្តែលោកបានប្រើវាជាគំរូដល់អ្នកឯទៀត ។

**៥:៤** *មេពួកអ្នកគង្វាល* ពាក្យនេះគឺប្រើសម្រាប់ "ព្រះគ្រីស្ទ" ។ នៅពេលដែលព្រះ គ្រីស្ទដ៏ជាមេគង្វាលយាងត្រឡប់មកវិញ ទ្រង់នឹងប្រទានរង្វាន់ដល់អស់អ្នកដែលបានបម្រើជាអ្នកគង្វាលនៅក្រោមបង្គាប់ទ្រង់ ។ *ដែលមិនចេះស្រពោន* មើល ១:៤ និងការពន្យល់ ។

**៥:៥** សេចក្ដីបង្រៀនរបស់លោកពេត្រុសមានប្រយោជន៍សម្រាប់ទាំងពួកនៅក្មេង និងពួកចាស់ទុំ ។ សេចក្ដីអំនួតតែងនាំឱ្យពួកចាស់ទុំមិនខិតខំយល់ចិត្តពួកនៅក្មេង ហើយក៏នាំឱ្យពួកនៅក្មេងមិនស្តាប់ពួកចាស់ទុំផងដែរ ។ លោកពេត្រុសបានបង្រៀនឱ្យពួកចាស់ទុំ និងពួកនៅក្មេងបន្ទាបខ្លួន ហើយបម្រើគ្នាទៅវិញទៅមក ។

**៥:៦** មើល លក ១៤:១១ និងការពន្យល់ ។ *ដំកើងអ្នករាល់គ្នាឡើង នៅវេលាកំណត់* ជំនួយរបស់ទ្រង់នឹងមកដល់នៅពេលដែលបានកំណត់ទុក (សូមធៀបនឹង ហព ៤:១៦ និងការពន្យល់)។

**៥:៧** មើល ភល ៤:៦-៧ និងការពន្យល់ សូមធៀបនឹង ទដ ៥៥:២២ ។

**៥:៨** *ចូរឱ្យដឹងខ្លួន* មើល កទ ៥:២៣ ១ថន ៥:៦,៨ ។ *ចាំយាមចុះ* ការចាំយាម គឺជាការដែលគ្រីស្ទបរិស័ទត្រូវ ប្រកាន់ខ្ជាប់ជានិច្ចរហូតដល់ព្រះទ្រង់យាងមក ។ *អារក្ស* មើល ២កថ ៤:៤ ១យហ ៣:៨ និងការពន្យល់ ។

លេបបាន ៩ចូរតស៊ូនឹងវា[ឡ] ដោយមានចិត្តជឿមាំមួន[អ]
ទាំងដឹងថា ពួកបងប្អូនរបស់អ្នករាល់គ្នា ដែលនៅក្នុង
លោកីយនេះ គេកំពុងតែរងទុក្ខលំបាកដូចគ្នាដែរ[ក] ១០រីឯ
ព្រះដ៏មានព្រះគុណសព្វគ្រប់ ដែលទ្រង់បានហៅ យើងរាល់
គ្នា[ខ] មកក្នុងសិរីល្អនៃទ្រង់[គ] ដ៏នៅអស់កល្បជានិច្ចដោយព្រះ
គ្រីស្ទយេស៊ូវ នោះសូមទ្រង់មេត្តាប្រោសឱ្យអ្នក រាល់គ្នាបាន
គ្រប់លក្ខណ៍ ទាំងចំរើនកំឡាំង ហើយតាំងអ្នករាល់គ្នាឱ្យ
មាំមួនឡើង[ឃ] ក្នុងខណៈក្រោយដែលបានរងទុក្ខបន្តិច[ង]
១១សូមឱ្យទ្រង់បានសិរីល្អ នឹងព្រះចេស្តា នៅអស់កល្ប
ជានិច្ច ជារៀងរាបតទៅ អាម៉ែន[ច]។

**៥:១០** ខ រម ៨:២៨ គ ២កថ ៤:១៧ ២ធថ ២:១០ ឃ ១ពត ១:៦ ង ទដ ១៨:៣២ ២ថន ២:១៧
**៥:១១** ច រម ១១:៣៦
**៥:១២** ឆ ហព ១៣:២២ ជ កច ១៥:២២ ឈ ១កថ ១៦:១៣
**៥:១៣** ញ កច ១២:១២
**៥:១៤** ដ រម ១៦:១៦ ឋ អភ ៦:២៣

## ពាក្យជម្រាបសួររបស់ពួកបងប្អូន

១២ខ្ញុំបានសរសេរយ៉ាងខ្លី[ឆ] ផ្ញើមកអ្នករាល់គ្នា ដោយសារ
អ្នកស៊ីលវ៉ាន[ជ] ដែលខ្ញុំរាប់ទុកជាបងប្អូនស្មោះត្រង់ពិត ដើម្បី
នឹងទូន្មាន ហើយធ្វើបន្ទាល់ថា ព្រះគុណនៃព្រះដែលអ្នក
រាល់គ្នាកាន់ខ្ជាប់តាម[ឈ] នោះជាព្រះគុណពិតប្រាកដហើយ ។
១៣ពួកជំនុំនៅក្រុងបាប៊ីឡូន ដែលទ្រង់បានរើស តាំងជា
មួយនឹងអ្នករាល់គ្នាដែរ ព្រមទាំងអ្នកម៉ាកុស[ញ] ជាកូនខ្ញុំផង
គេជំរាបសួរមកអ្នករាល់គ្នា ១៤សូមជំរាបសួរគ្នាទៅវិញ
ទៅមក ដោយថើបដ៏កើតអំពីចិត្តស្រឡាញ់[ដ] សូមឱ្យអ្នករាល់
គ្នា ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ បានប្រកបដោយសេចក្តី
សុខសាន្ត[ឋ]ចុះ ។ អាម៉ែន ។

**៥:៩** *ចូរតស៊ូនឹងវា* មើល យក ៤:៧ និងការពន្យល់ ។ *ពួកបងប្អូនរបស់អ្នករាល់គ្នា* មើលការពន្យល់ កច ១១:១ ។ គ្រីស្ទបរិស័ទមិនត្រូវគ្មានទំនាក់ទំនងនឹងគ្នាឡើយ ព្រោះត្រូវមករួមសុខរួមទុក្ខជាមួយគ្នានៅក្នុងគ្រួសារនៃព្រះគ្រីស្ទ ។

**៥:១០,១២,១៤** *ព្រះគុណ . . . ព្រះគុណ . . . សេចក្តីសុខសាន្ត* មើល រម ១:៧

**៥:១០** *ព្រះដ៏មានព្រះគុណសព្វគ្រប់* សូមមើល ១:១០,១៣ និងការពន្យល់ ។

**៥:១២** *ដោយសារអ្នកស៊ីលវ៉ាន* តាមបទគម្ពីរនេះលោកស៊ីលវ៉ាន (ឬស៊ីឡាស) អាចជាអ្នកនាំសំបុត្រនេះ ។ គាត់ប្រហែលជាអ្នកសរសេរចូលក្នុងសំបុត្រនូវសម្តី លោកពេត្រុសប្រាប់ឱ្យសរសេរ និងជាអ្នកជំនួយខាងអក្សរសាស្ត្រក្រិក (មើលសេចក្តីផ្តើមត្រង់អ្នកនិពន្ធ និងកាលបរិច្ឆេទ) ។ *ដើម្បីនឹងទូន្មាន . . . ព្រះគុណ* មើលសេចក្តីផ្តើមត្រង់ខ្លឹមសារ ។

**៥:១៣** *ក្រុងបាប៊ីឡូន* មើលសេចក្តីផ្តើមត្រង់ ទីកន្លែង ។ *ដែលទ្រង់បានរើស* មើលការពន្យល់ អភ ១:៤ ។ *អ្នកម៉ាកុស ជាកូនខ្ញុំ* ការហៅលោកម៉ាកុសថាកូនដូចនេះបង្ហាញពីទឹកចិត្តស្រឡាញ់ ដែលលោកពេត្រុសមានចំពោះ គាត់ ហើយអាចបង្ហាញថា លោកពេត្រុសជាអ្នកនាំឱ្យលោកម៉ាកុសទទួលជឿព្រះ (សូមផ្ទៀប ១ធថ ១:២ និងការពន្យល់) ។ តាមពួកជំនុំសម័យដើម លោកទាំងពីរមានទំនាក់ទំនងជិតស្និទ្ធនឹងគ្នា (មើលសេចក្តីផ្តើមព្រះគម្ពីរម៉ាកុស ត្រង់អ្នកនិពន្ធ) ។

**៥:១៤** *ថើប* មើលការពន្យល់ ១កថ ១៦:២០ ។ *សូមឱ្យអ្នករាល់គ្នា . . . ប្រកប ដោយសេចក្តីសុខសាន្ត* សេចក្តីសុខសាន្តគឺជាព្រះពរខាងឯវិញ្ញាណ ដែលកើតមានអស់អ្នកដែលមានការប្រកបស្និទ្ធស្នាលជាមួយនឹងព្រះគ្រីស្ទ (សូមមើលការពន្យល់ អភ ១:១) ។ លោកពេត្រុសបានបញ្ចប់សំបុត្រនេះ ដោយពាក្យសេចក្តីសុខសាន្ត ជាការនិយាយយោងដល់ការប្រកបស្និទ្ធស្នាលរបស់អ្នកជឿជាមួយនឹងព្រះគ្រីស្ទ ដែលជាខ្លឹមសារសំខាន់នៃសំបុត្រនេះ ។

សំបុត្រទី២

# **របស់ពេត្រុស**

សេចក្ដីផ្ដើម

### **អ្នកនិពន្ធ**

លោកស៊ីម៉ូន–ពេត្រុសបានបញ្ជាក់យ៉ាងច្បាស់ថា គាត់គឺជាអ្នកនិពន្ធកណ្ឌគម្ពីរពេត្រុសទី២នេះ ។ គាត់បានប្រើសព្វនាមទម្រង់ជាបុរសទីមួយ ឯកវចនក្នុងសំបុត្ររបស់គាត់ (១:១២–១៥) ហើយបានអះអាងថា គាត់គឺស្មបន្ទាល់បានឃើញព្រះយេស៊ូវគ្រីស្ទដោយផ្ទាល់ (១:១៦–១៨ ១:១៦ ធៀប មថ ១៧:១–៥ និងការពន្យល់)។ លោកពេត្រុសបញ្ជាក់ថា កណ្ឌគម្ពីរនេះជាសំបុត្រទី២របស់គាត់ ទៅពួកអ្នកដែលទទួលសំបុត្រទី១របស់គាត់ និងបានអះអាងថា លោកប៉ុលគឺជាបងប្អូនស្ងួនភ្ងា (មើលការពន្យល់ ៣:១៥)។ សរុបមក កណ្ឌគម្ពីរនេះគឺជាសំបុត្ររបស់លោកពេត្រុស ។

ទោះបីកណ្ឌគម្ពីរពេត្រុសទី២មិនសូវមានពួកជំនុំដំបូងស្គាល់ច្រើនក៏ដោយ ក៏មានពួកគេជាច្រើនបានទទួលយក និងប្រើប្រាស់សំបុត្រនេះ នៅសតវត្សរ៍១ និងទី២ (១៨៥គ.ស–២៥៣ គ.ស)។ ម្យ៉ាងទៀត កណ្ឌគម្ពីរនេះមិនត្រូវបានពណ៌នាចំពោះលោកពេត្រុសទេ ដោយព្រោះពេលវេលា (១៨៥គ.ស–២៥៣គ.ស) ហើយមានការសង្ស័យខ្លះដែលទាក់ទងនឹងកណ្ឌគម្ពីរនេះ ។ អឺសីបឺស (២៦៥គ.ស–៣៤០គ.ស) បានចាត់ទុកកណ្ឌគម្ពីរនេះ នៅក្នុងចំណោមកណ្ឌគម្ពីរដែលត្រូវជជែកពីភាក្យាយោបល់ ទោះបីមានមតិជាច្រើនបានទទួលស្គាល់ថា ជាសំបុត្ររបស់លោកពេត្រុសក៏ដោយ។ ក្រោយមក ហាក់ដូចជាមានការទទួលស្គាល់ជាទូទៅថា លោកពេត្រុសគឺជាអ្នកនិពន្ធ ។

ទោះជាយ៉ាងណា ក៏នៅសតវត្សរ៍ថ្មីៗនេះ ភាពជាអ្នកនិពន្ធរបស់លោកពេត្រុសត្រូវបំភ្លឺ ហើយបានទទួលទទួលស្គាល់ពីពួកអ្នកកាត់ស្រាយជាច្រើន ។ មានបញ្ហាមួយបានកើតឡើង គឺថា កណ្ឌគម្ពីរពេត្រុសទី២មានទម្រង់ខុសប្លែកពីកណ្ឌគម្ពីរពេត្រុសទី១ ។ ប៉ុន្តែ ភាពខុសប្លែកគ្នានេះមិនមែនទាំងស្រុងទេ គឺមានភាពស្រដៀងគ្នាច្រើន ទាំងការប្រើប្រាស់ពាក្យពេចន៍ និងលក្ខណៈផ្សេងៗទៀត ។ ម្យ៉ាងទៀត គ្មានសំបុត្រណាផ្សេងទៀត ដែលមានភាពដូចគ្នា ជាងដែលកណ្ឌគម្ពីរពេត្រុសទី១ និងកណ្ឌគម្ពីរពេត្រុសទី២នេះទេ ។ ភាពខុសប្លែកគ្នាកើតឡើងអាចបណ្ដាលមកពីកត្តាផ្សេងៗ ដែលមានដូចជា ប្រធានបទ ទម្រង់នៃការសរសេរ និងគោលបំណងនៃសំបុត្រ ពេលវេលា និងស្ថានភាពនៃការការសរសេរ ប្រភព គំរូ និងអ្នកនិពន្ធ ។ ប្រហែលជាកណ្ឌគម្ពីរពេត្រុសទី១ លោកស៊ីឡាសជាអ្នកជំនួយក្នុងការសរសេរ ដូចមានបញ្ជាក់នៅក្នុងបទគម្ពីរ "១ពត ៥:១២"។ ចំណែកឯកណ្ឌ គម្ពីរពេត្រុសទី២វិញពុំមានលក្ខណៈទាំងអស់នេះទេ ដែលអាចបញ្ជាក់អំពីខុសប្លែកគ្នានៃរបៀបនៃការសរសេរ (មើលសេចក្ដីផ្ដើម ពេត្រុសទី១)។

មានការជំទាស់ផ្សេងទៀតបានកើតឡើង តាមរយៈប្រវត្តិសាស្ត្រពួកជំនុំដំបូង ឬការយល់ច្រឡំ ឬក៏ទិន្នន័យមិនប្រក្រតី ។ ឧទាហរណ៍ មតិមួយចំនួនយល់ថា ការអះអាងនៅក្នុង "៣:១៥–១៦" បញ្ជាក់ថា កណ្ឌគម្ពីរនេះបានសរសេរឡើងមុនសំបុត្រលោកប៉ុល ។ ម្យ៉ាងទៀត អាចបញ្ជាក់ថា សំបុត្ររបស់លោកបុលត្រូវបានគេប្រមូលផ្ដុំមុនសំបុត្ររបស់លោកពេត្រុស ដោយសំអាងលើការស្លាប់នៃលោកពេត្រុស ។ សេចក្ដីដែលលោកពេត្រុសបានលើកឡើង បង្ហាញថាគាត់បានដឹងអំពីសេចក្ដីនៅក្នុងសំបុត្រលោកប៉ុល និងពុំមែនមានន័យថា លោកពេត្រុសប្រើប្រាស់អត្ថបទរបស់លោកប៉ុលនោះទេ ។

### **កាលបរិច្ឆេទ**

កណ្ឌគម្ពីរនេះត្រូវបានសរសេរឡើងនៅមុនចុងបញ្ចប់នៃជីវិតរបស់លោកពេត្រុស (១:១២–១៥) គឺបន្ទាប់ពីការសរសេរសំបុត្រទី១របស់គាត់ (៣:១) ទៅកាន់ពួកអ្នកទទួលសំបុត្រទី១របស់គាត់ (ពេត្រុសទី១)។ លោកពេត្រុសត្រូវបានស្ដេចអធិរាជនេរ៉ូ (Nero) សម្លាប់ ដូច្នេះការស្លាប់របស់គាត់អាចកើតឡើងនៅមុនឆ្នាំទី៦៨គ.ស ។ ម្យ៉ាងទៀត អាចបញ្ជាក់ថា កណ្ឌគម្ពីរពេត្រុសទី២ប្រហែលត្រូវបានសរសេរឡើងនៅចន្លោះឆ្នាំទី ៦៥ គ.ស ទៅឆ្នាំទី ៦៨ គ.ស ។

មានមតិខ្លះជំទាស់ថា កាលបរិច្ឆេទនៃការសរសេរកណ្ឌគម្ពីរពេត្រុសទី២ ដែលបានលើកលើងខាងលើ ហាក់ដូចជាឆាប់ពេក ប៉ុន្តែ គ្មានការអះអាងនៅក្នុងអត្ថបទគម្ពីរពេត្រុសទី២ ដែលបញ្ជាក់ថាការសរសេរកណ្ឌគម្ពីរនេះ ត្រូវបានសរសេរឡើងក្នុងអំឡុងពេលក្រោយមកទៀតនោះទេ ។ កំហុសដែលបានលើកយកមកជជែក គឺអាចប្រៀបធៀបទៅនឹងប្រភេទនៃវត្តមានរបស់ពួកខុសឆ្គងនៅសតវត្សរ៍ទី១ ។ ការដែលអះអាងថា បទគម្ពីរ "២ពត ២" ជាការសរសេរប្រឆាំងដោយផ្ទាល់ចំពោះពួកគ្រូខុសឆ្គងនៅសតវត្សរ៍ទី២ គឺជាការសន្និតមួយលើសពីសេចក្ដីដែលបានលើកឡើងនៅក្នុងជំពូក២នេះទៅទៀត ។ គ្មានការបញ្ជាក់អះអាងណាដែលថា គ្មានពួកគ្រូខុសឆ្គងរស់នៅក្នុងសម័យកាលរបស់លោកពេត្រុសទេ ។

មតិផ្សេងទៀតទទួលយកកាលបរិច្ឆេទទី២ ព្រោះពួកគេកាត់ស្រាយថា ពួកព្ទយុកោនៅក្នុងបទគម្ពីរ "៣:៤" គឺជាគ្រីស្ទបរិស័ទជំនាន់មុនគេបង្អស់ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ពាក្យថា "ពួកព្ទយុកោ"នេះ ជាទូទៅអាចត្រូវបានគេកាត់ស្រាយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ថា "ពួកសង្ឃ" (ប្រៀបធៀប យហ ៦:៣១ "ព្ទយុកោ" កច ៣:១៣ ហព ១:១)។ ដូចគ្នានេះដែរ ទោះបីមានការសំអាងលើលោកប៉ុល និងសំបុត្ររបស់លោកក៏ដោយ (៣:១៥-១៦) ក៏កាលបរិច្ឆេទនៃការសរសេរកណ្ឌគម្ពីរពេត្រុសទី២ មិនអាចកើតឡើងក្រោយការស្លាប់របស់លោកពេត្រុសបានឡើយ ។

**ពេត្រុសទី២ និងយូដាស**

កណ្ឌគម្ពីរពេត្រុសទី២ និងកណ្ឌគម្ពីរយូដាសមានភាពស្រដៀងគ្នាគួរឱ្យកត់សម្គាល់ (ប្រៀបធៀប ២ពត ២ និង យដ ៤-១៨) ប៉ុន្តែ ក៏ភាពខុសប្លែកគ្នាយ៉ាងពិសេសផងដែរ ។ អ្នកខ្លះយល់ថា កណ្ឌគម្ពីរទាំងពីរនេះបានចម្លងចេញពីគ្នា ឬកើតឡើងដោយប្រើប្រភពដើមតែមួយ ។ ប្រសិនបើចម្លងចេញពីគ្នា ក៏វាមិនមែនជាការចម្លងទាំងស្រុងទេ គឺគ្រាន់តែជាការយល់ស្របទៅនឹងគោលបំណងរបស់អ្នកនិពន្ធតែប៉ុណ្ណោះ ។ ក្នុងពេលជាមួយគ្នានោះដែរមានមតិផ្សេងទៀតយល់ថា កណ្ឌគម្ពីរយូដាសត្រូវបានដកស្រង់ចេញពីកណ្ឌគម្ពីរពេត្រុស ព្រោះកណ្ឌគម្ពីរយូដាសខ្លីជាងកណ្ឌគម្ពីរពេត្រុស ។ ម្យ៉ាងទៀត ការចម្លងយ៉ាងដូច្នោះ តែងតែកើតមានជាទូទៅចំពោះការនិពន្ធនៅសម័យដើម ។ ឧទាហរណ៍ មតិមួយចំនួនជឿថាលោកប៉ុល ប្រើប្រាស់បទចម្រៀងសរសើរនៅក្នុងបទគម្ពីរ "ភល ២:៦-១១ និង ១ធថ ៣:១៦"។

**គោលបំណង**

នៅក្នុងសំបុត្រទីមួយរបស់លោកពេត្រុស បានចម្អែតពួកចៀមរបស់ព្រះគ្រីស្ទ ដោយផ្តល់ឱ្យពួកគេនូវការទូន្មាន អំពីរបៀបដោះស្រាយចំពោះការបៀតបៀនកើតឡើងពីពួកអ្នកដែលនៅខាងក្រៅពួកជំនុំ (១ពត ៤:១២)។ រីឯនៅក្នុងសំបុត្រទី២វិញ លោកពេត្រុសបានបង្រៀនពួកគេ ពីរបៀបដោះស្រាយចំពោះពួកគ្រូខុសឆ្គង និងពួកមនុស្សអាក្រក់ដែលបានចូលមកក្នុងពួកជំនុំ (២:១ ៣:៣-៤ និងការពន្យល់)។ ស្ថានភាពជាក់ស្តែងចំពោះមតិការរឿង និងសេចក្តីបញ្ជាក់ផ្សេងៗ ជាទូទៅមានការប្រែប្រួល ក្នុងសំបុត្រទាំងពីររបស់លោកពេត្រុសក្នុងនាមជាអ្នកគង្វាលចៀមនៃព្រះ (យហ ២១:១៥-១៧) ដោយគាត់ព្យាយាមផ្តល់ឱ្យពួកគេ នូវបណ្តាំនៃសេចក្តីជំនឿ និងការអនុវត្តន៍ជាក់ស្តែងរបស់គ្រីស្ទបរិស័ទ ។ ជាងនេះទៅទៀត គោលបំណងរបស់គាត់មានបីសំខាន់ៗគឺ (១).ស្វាងឱ្យគ្រីស្ទបរិស័ទបានចម្រើនឡើង (២).ប្រឆាំងតបនឹងការបង្រៀនខុសឆ្គង(ជំពូក២) (៣).លើកទឹកចិត្តឱ្យចាំយាមជានិច្ច រង់ចាំការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ (ជំពូក ៣)។

**គម្រោងសង្ខេប**

- **I. ពាក្យជម្រាបសួរ (១:១២)**
- **II. ការទូន្មានឱ្យចម្រើនឡើងនៃគុណធម៌របស់គ្រីស្ទបរិស័ទ (១:៣-១១)**
  - ក. ជំនួយមកពីព្រះអម្ចាស់ (១:៣-៤)
  - ខ. ការត្រាស់ហៅឱ្យចម្រើនឡើង (១:៥-៧)
  - គ. តម្លៃនៃការចម្រើនឡើង (១:៨-១១)
- **III. គោលបំណង និងអត្តសញ្ញាណនៃសំបុត្ររបស់លោកពេត្រុស (១:១២-២១)**
  - ក. គោលរឿងនៃការសរសេរ (១:១២-១៥)
  - ខ. មូលដ្ឋាននៃអំណាចរបស់លោកពេត្រុស (១:១៦-២១)
- **IV. ការព្រមានប្រឆាំងនឹងពួកគ្រូខុសឆ្គង (ជំពូក ២)**
  - ក. ការមករបស់ពួកគ្រូខុសឆ្គងត្រូវបានបើកសំដែងឱ្យដឹងជាមុន (២:១-៣)
  - ខ. ការជំនុំជំរះរបស់ពួកគ្រូខុសឆ្គង (២:៣-៩)
  - គ. លក្ខណៈរបស់ពួកគ្រូខុសឆ្គង (២:១០-២២)
- **V. កត្តានៃការយាងមករបស់ព្រះគ្រីស្ទ (៣:១-២)**
  - ក. គោលបំណងរបស់នៃការសរសេររបស់លោកពេត្រុស (៣:១-២)

ខ. ការមកដល់នៃពួកអ្នកចំអក (៣:៣–៧)

គ. ភាពពិតប្រាកដនៃយាងមករបស់ព្រះគ្រីស្ទ (៣:៨–១០)

ឃ. ការទូន្មានអាស្រ័យលើកត្តានៃការយាងមករបស់ព្រះគ្រីស្ទ (៣:១១–១៦)

ង. ពាក្យបណ្តាំចុងក្រោយ (១៣:២៤–២៥)

**VI. សេចក្តីសន្និដ្ឋាន និងការសរសើរ (៣:១៧–១៨)**

**១** ១សំបុត្រស៊ីម៉ូន–ពេត្រុសជាបាវបំរើ[ក] ហើយជាសាវក
របស់ព្រះយេស៊ូវគ្រីស្ទ[ខ] ខ្ញុំផ្ញើមកពួកអ្នក ដែលបានទទួល
សេចក្ដីជំនឿដ៏វិសេស ត្រូវគ្នានឹងយើងខ្ញុំដែរ ដោយសេចក្ដី
សុចរិត[គ]របស់ព្រះយេស៊ូវគ្រីស្ទ[ឃ] ដ៏ជាព្រះ ហើយជាព្រះអង្គ
សង្គ្រោះនៃយើងរាល់គ្នា ២សូមឱ្យព្រះគុណ និងសេចក្ដីសុខ
សាន្តបានចំរើន[ង]ដល់អ្នករាល់គ្នាឱ្យបានស្គាល់ព្រះ នឹងព្រះ
យេស៊ូវ ជាព្រះអម្ចាស់នៃយើង[ច]។

## ភាពច្បាស់លាស់នៃការត្រាស់ហៅ និងការរើសតាំង

៣ដ្បិតព្រះចេស្ដានៃព្រះ[ឆ] បានផ្ដល់ឱ្យយើងរាល់គ្នាមាន
គ្រប់របស់ទាំងអស់ ខាងឯជីវិត និងសេចក្ដីគោរពប្រតិបត្តិ
ដល់ព្រះ ដោយយើងបានស្គាល់ព្រះអង្គ[ជ] ដែលទ្រង់ហៅ
យើងរាល់គ្នាមក[ឈ] ដោយសារសិរីល្អ និងសគុណរបស់ទ្រង់
៤ដែលដោយសារសេចក្ដីទាំងនោះ ទ្រង់បានប្រទានសេចក្ដី
សន្យាដ៏ធំបំផុត ហើយវិសេសផង[ញ] មកយើងរាល់គ្នា ដើម្បី
ឱ្យអ្នករាល់គ្នាបានចំណែកជានិស្ស័យនៃព្រះ[ដ] ដោយសារ
សេចក្ដីសន្យានោះឯង ដោយបានរួចពីសេចក្ដីពុករលួយ
នៅក្នុងលោកិយនេះ ដែលកើតអំពីសេចក្ដីប៉ងប្រាថ្នា[ឋ]
៥ហើយដោយហេតុនោះបានជាត្រូវឱ្យអ្នករាល់គ្នា បន្ថែម
ឱ្យមានសេចក្ដីឧស្សាហ៍ដែរ ដើម្បីឱ្យសេចក្ដីជំនឿបាន
ទៀងត្រង់ ឱ្យសេចក្ដីទៀងត្រង់បានដំរិះ[ឌ] ៦ឱ្យដំរិះបាន
ចេះអត់សង្កត់[ឍ] ឱ្យសេចក្ដីអត់សង្កត់បានខ្ជាប់ខ្ជួន[ណ] ឱ្យ
សេចក្ដីខ្ជាប់ខ្ជួនបានចេះគោរពប្រតិបត្តិដល់ព្រះ[ត] ៧ឱ្យសេច
ក្ដីគោរពប្រតិបត្តិ បានចេះរាប់អានគ្នាជាបងប្អូន ហើយឱ្យ
សេចក្ដីរាប់អានគ្នា បានសេចក្ដីស្រឡាញ់ថែមទៀត[ថ] ៨ដ្បិត
បើមានសេចក្ដីទាំងនោះចំរើនឡើង ក្នុងចិត្តអ្នករាល់គ្នា

**១:១** ក រម ១:១ ខ ១ពត ១:១ គ រម ៣:២១–២៦ ឃ ទត ២:១៣ **១:២** ង រម ១:៧ ច ខ.៣,៨ ២ពត ២:២០ ៣:១៨ ភល ៣:៨ **១:៣** ឆ ១ពត ១:៥ ជ ខ.២ ឈ រម ៨:២៨ **១:៤** ញ ២កថ ៧:១ ដ អភ ៤:២៤ ហព ១២:១០ ១យហ ៣:២ ឋ យក ១:២៧ ២ពត ២:១៨–២០ **១:៥** ឌ ខ.២ កល ២:៣ **១:៦** ឍ កថ ២៤:២៥ ណ ហព ១០:៣៦ ត ខ.៣ **១:៧** ថ រម ១២:១០ ១ថន ៣:១២ **១:៨** ទ យហ ១៥:២ កល ១:១០ ទត ៣:១៤ ធ ខ.២

**១:១** *ស៊ីម៉ូ–ពេត្រុស* "សូមមើលសេចក្ដីផ្ដើមកណ្ឌគម្ពីរពេត្រុសទី១ និងការពន្យល់ មថ ១៦:១៨ យហ ១:៤២"។ *បាវបំរើ* "មើលការពន្យល់ រម ១:១"។ *សាវក* "មើលការពន្យល់ មក ៦:៣០ ១កថ ១:១ ហព ៣:១"។ *ផ្ញើមកពួកអ្នក* អាចសំដៅលើពួកអ្នកទទួល ដូចដែលបានបញ្ជាក់នៅក្នុង "១ពត ១:១"។ *បានទទួលសេចក្ដី ជំនឿ* បញ្ជាក់ថា ព្រះអម្ចាស់យុត្តិធម៌ និងប្រទានពរដល់រាស្ត្រទ្រង់ នូវសមត្ថភាពជឿជាក់ដល់ទ្រង់ ។ *សេចក្ដីជំនឿ* សំដៅលើសមត្ថភាពដែលព្រះអម្ចាស់ប្រទាន មក ដើម្បីទុកចិត្តដល់ទ្រង់ និងសម្រាប់សេចក្ដីសង្គ្រោះ ។ *ព្រះយេស៊ូវគ្រីស្ទ . . . ព្រះអង្គសង្គ្រោះ* បញ្ជាក់ថា ព្រះយេស៊ូវគឺជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះ ។ សម្រាប់បទគម្ពីរផ្សេងទៀត ដែលនិយាយអំពីភាពជាព្រះរបស់ព្រះគ្រីស្ទ សូមមើលការពន្យល់ រម ៩:៥ ។

**១:២** *ព្រះគុណ និងសេចក្ដីសុខសាន្ត* "មើលការពន្យល់ រម ១:៧"។ *បានចំរើនដល់អ្នករាល់គ្នាឱ្យបានស្គាល់ព្រះ និងព្រះយេស៊ូវ* ទស្សនៈនៃចំណេះរបស់គ្រីស្ទបរិស័ទបានបញ្ជាក់ច្បាស់ នៅក្នុងកណ្ឌគម្ពីរពេត្រុសទី២នេះ (មើលការពន្យល់ ខ.៣,៥,៨ ៣:១៨)។ លោកពេត្រុសបានតយុទ្ធនឹងសេចក្ដីបង្រៀនរបស់ពួកខុសឆ្គង ហើយគ្រឿងការពារដ៏មានប្រសិទ្ធភាពសម្រាប់ប្រឆាំងនឹងពួកនេះ គឺចំណេះនៃសេចក្ដីពិត ។

**១:៣** *បានផ្ដល់ឱ្យយើងរាល់គ្នាមានគ្រប់របស់ទាំងអស់ ខាងឯជីវិតនិងសេចក្ដីគោរពប្រតិបត្តិដល់ព្រះ* ព្រះអម្ចាស់ប្រទានឱ្យយើងនូវតម្រូវការខាងឯវិញ្ញាណ តាមរយៈចំណេះដែលយើងមាននៅក្នុងទ្រង់ ។ ប្រសិនបើកណ្ឌគម្ពីរនេះសរសេរទៅពួកអ្នកអាងចំណេះ នោះលោកពេត្រុសអាច បញ្ជាក់ថា ចំណេះដឹងទទួលតាមរយៈពួកសាវករបស់ព្រះអម្ចាស់ គឺគ្រប់គ្រាន់សម្រាប់តម្រូវការខាងឯវិញ្ញាណ ។ ដូច្នេះគ្មានការអាថ៌កំបាំង ឬចំណេះដែលដឹងបានតែមនុស្សមួយចំនួនតិច ដើម្បីឱ្យបានការសង្គ្រោះទៀតហើយ (សូមមើលសេចក្ដីផ្ដើម ១យហ)។ *សេចក្ដីគោរពប្រតិបត្តិដល់ព្រះ* នេះជាភស្ដុតាងពិតប្រាដកចំពោះព្រះអម្ចាស់ ដែលគ្រប់គ្រងលើអាកប្បកិរិយារបស់អ្នកជឿដល់ទ្រង់គ្រប់ៗគ្នា និងគ្រប់ផ្នែកនៃជីវិតរបស់ពួកគេ ម្នាក់ៗ (១ធថ ២:២ និងពន្យល់)។ *សិរីល្អ និងសគុណរបស់ទ្រង់* ភាពប្រសើរនៃព្រះ ។ សិរីល្អសំដែងនូវភាពប្រសើររបស់ព្រះអម្ចាស់ ។ ព្រះអម្ចាស់បង្ហាញនូវការទាំងពីរនេះ ដើម្បីប្រទានការសង្គ្រោះដល់យើងរាល់គ្នា ។

**១:៤** *ដោយសារសេចក្ដីទាំងនោះ* គឺដោយសារសិរីល្អនៃព្រះតាមសេចក្ដីសន្យា ដែលទ្រង់បានប្រទានមកយើង ។ លក្ខណៈនៃសេចក្ដីសន្យានេះសំដែងនូវភាពជាព្រះរបស់ព្រះអម្ចាស់ និងការគេចចេញពីភាពពុករលួយរបស់លោកីយ ។ *ដើម្បីឱ្យ អ្នករាល់គ្នាបានចំណែកជានិស្ស័យនៃព្រះ* មានន័យថាអស់អ្នកដែលទទួលជឿដល់ព្រះគ្រីស្ទ នោះព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងគេ (យហ ១៤:១៦,១៧ និងពន្យល់)។ ភាពជាមនុស្ស និងភាពជាព្រះ គឺផ្ទុយគ្នាទាំងស្រុង ។ *លោកិយ* "មើលការពន្យល់ យហ ១:៩"។ *សេចក្ដីប៉ងប្រាថ្នា* "មើលការពន្យល់ ២:១០"។

**១:៥–៩** ក្នុងវគ្គនេះបង្ហាញនូវផលផ្លែនៃគុណធម៌ នៅក្នុងជីវិតរបស់គ្រីស្ទបរិស័ទ (កទ ៥:២២–២៣ និងការពន្យល់)។

**១:៥** *សេចក្ដីជំនឿ* ជាឫសកែវនៃជីវិតរបស់គ្រីស្ទបរិស័ទ (មើលពន្យល់ ខ.១)។ *ទៀងត្រង់* "មើលពន្យល់ ខ.៣"។ *ដំរិះ* "មើលពន្យល់ ខ.២–៣"។

**១:៦** *អត់សង្កត់* តាមរយៈសម្ដីរបស់លោកពេត្រុសបញ្ជាក់ថា ចំណេះដឹងរបស់គ្រីស្ទបរិស័ទឈានទៅរកការអត់ធ្មត់ គឺផ្ទុយនឹងសេចក្ដីបង្រៀនរបស់ពួកគ្រូខុសឆ្គង ដែលថា ការអត់ធ្មត់មិនសំខាន់ (សូមប្រៀបធៀប សភ ២៥:២៨ កទ ៥:២៣)។

**១:៧** *រាប់អានគ្នាជាបងប្អូន* នៅត្រង់ចំណុចនេះបញ្ជាក់ពីសេចក្ដីរាប់អានសេចក្ដីស្រឡាញ់ ដែលមានក្នុងសេចក្ដីជំនឿដល់ព្រះអម្ចាស់ ។ *សេចក្ដីស្រឡាញ់* នេះជា ការលះចោលនូវអាកប្បកិរិយាផ្ទាល់ខ្លួន ហើយដឹកនាំការល្អថ្វាយជាយញ្ញបូជា ដល់អ្នកដទៃទៀត (១ពត ៤:៨)។

**១:៨** *ដ្បិតបើមានសេចក្ដីទាំងនោះចំរើនឡើង* ត្រង់ចំណុចនេះលោកពេត្រុសមិនបានបញ្ជាក់ថា ពួកអ្នកជឿជាអ្នកដាំសេចក្ដីជំនឿ ដើម្បីចាក់បំពេញគ្នារហូតម្នាក់ៗបានគ្រប់លក្ខណ៍ឡើងនោះទេ ។ ជំនួសឱ្យការទាំងអស់នេះពួកអ្នកទាំងអស់នោះ ក៏ត្រូវបានដាំឡើងក្នុងពេលដំណាលៗគ្នាដែរ ។ *ចំរើន–*

ហើយនោះអ្នករាល់គ្នាមិននៅទំនេរ ឬឥតផល[ទ]ខាងឯ
ដំណើរស្គាល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង
រាល់គ្នាឡើយ[ធ] ៩ពីព្រោះអ្នកណាដែលគ្មានសេចក្តីទាំង
នោះគឺឈ្មោះថាជាអ្នកខ្វាក់[ន] មើលទៅឆ្ងាយមិនឃើញ ព្រម
ទាំងភ្លេចថា ព្រះបានសំអាតបាបដែលខ្លួនធ្វើពីដើមផង[ប]
១០ដូច្នេះ បងប្អូនអើយ គួរឱ្យអ្នករាល់គ្នាមានចិត្តឧស្សាហ៍
វិញ ដើម្បីនឹងធ្វើឱ្យដំណើរដែលទ្រង់ហៅ[ផ] ហើយរើសតាំង
អ្នករាល់គ្នា បានពិតប្រាកដឡើង បើប្រព្រឹត្តដូច្នោះ នោះ
អ្នករាល់គ្នាមិនដែលជំពប់ឡើយ[ព] ១១ដ្បិតយ៉ាងនោះនឹងមាន
ផ្លូវបើកចំហ ឱ្យអ្នករាល់គ្នាចូលទៅក្នុងនគរដ៏នៅអស់កល្ប
ជានិច្ច[ភ]របស់ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ ហើយជាព្រះ
អង្គសង្គ្រោះនៃយើងរាល់គ្នា[ម]។

### បទទំនាយនៃព្រះគម្ពីរ

១២ដូច្នេះ ខ្ញុំប្រុងប្រៀបនឹងរំឭកដល់អ្នករាល់គ្នាអំពី
សេចក្តីទាំងនេះជានិច្ច[យ] ទោះបើអ្នករាល់គ្នាស្គាល់ ហើយ
បានតាំងខ្ជាប់ខ្ជួនក្នុងសេចក្តីពិត[រ]ដែលមានហើយក៏ដោយ
១៣ហើយកាលខ្ញុំនៅក្នុងត្រសាលនេះនៅឡើយ[ល] នោះខ្ញុំគិត
ថា ត្រូវឱ្យខ្ញុំដាស់តឿនរំឭក[វ] ដល់អ្នករាល់គ្នាជាដរាប
១៤ដោយដឹងថា វេលាដែលខ្ញុំត្រូវដោះត្រសាលនេះចេញ[ស]
នោះដល់ឆាប់ហើយ ដូចជាព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់
នៃយើង ទ្រង់បានបង្ហាញខ្ញុំ[ហ] ១៥មួយទៀតខ្ញុំនឹងខំប្រឹង
រំឭករាល់ពេលវេលា ឱ្យអ្នករាល់គ្នាបាននឹកចាំពីសេច
ក្តីទាំងនេះ ក្រោយដែលខ្ញុំទៅបាត់[ឡ]ដែរ ១៦ដ្បិតដែលយើង
ខ្ញុំបានឱ្យអ្នករាល់គ្នាស្គាល់ដល់ព្រះ ចេស្តានៃព្រះយេស៊ូវ
គ្រីស្ទ ជាព្រះអម្ចាស់នៃយើង[អ] នឹងដំណើរដែលទ្រង់យាង
មក នោះមិនមែនតាមរឿងព្រេង ប្រឌិតដោយដំរិះនោះទេ
គឺយើងខ្ញុំជាស្មរបន្ទាល់ ដែលបានឃើញឫទ្ធានុភាពរបស់
ទ្រង់ជាក់នឹងភ្នែកវិញ[ក] ១៧ដ្បិតទ្រង់បានល្បីព្រះនាម នឹង
សិរីល្អពីព្រះដ៏ជាព្រះវរបិតា ក្នុងកាលដែលមានឮសំឡេង
ពីសិរីល្អដ៏ប្រសើរឧត្តម មានបន្ទូលមកទ្រង់ថា «នេះជាកូន
ស្ងួនភ្ងាអញ ជាទីគាប់ចិត្តអញណាស់»[ខ] ១៨យើងខ្ញុំបានឮ

**១:៩** ន ១យហ ២:១១ ប អភ ៥:២៦ មថ ១:២១
**១:១០** ផ រម ៨:២៨ ព ទដ ១៥:៥ ២ពត ៣:១៧ យដ ២៤
**១:១១** ភ ទដ ១៤៥:១៣ ២ធថ ៤:១៨ ម ២ពត ២:២០ ៣:១៨
**១:១២** យ ភល ៣:១ ១យហ ២:២១ យដ ៥ រ ២យហ ២
**១:១៣** ល អស ៣៨:១២ ២កថ ៥:១,៤ វ ២ពត ៣:១
**១:១៤** ស ២ធថ ៤:៦ ហ យហ ១៣:៣៦ ២១:១៨,១៩ **១:១៥** ឡ លក ៩:៣១
**១:១៦** អ មក ១៣:២៦ ១៤:៦២ ក មថ ១៧:១–៨ **១:១៧** ខ មថ ៣:១៧

*ឡើង* ត្រង់ចំណុចនេះសេចក្តីជំនឿខាងឯព្រលឹងវិញ្ញាណរបស់លោកពេត្រុសបានរីកលូតលាស់ឡើងថែមទៀត (ប្រៀបធៀប ១:១៨ ១ពត ២:២ ភល ៣:១០ ១ថន ៣:១២) ។ *ផល ខាងឯ . . . ដំណើរស្គាល់* ត្រង់នេះបញ្ជាក់ថា ចំណេះដឹងរបស់គ្រីស្ទបរិស័ទគឺអាចមានឥទ្ធិពលលើផ្លូវជីវិត ដែលពួកគេរស់នៅ ។ ម្យ៉ាងទៀតក៏មិនបានបញ្ជាក់ថា ពួកគេរួចផុតពីការបង្ខាំងនៃសីលធម៌ ដូចជាពួកប្រឆាំងបានបង្រៀននោះឡើយ (មើលសេចក្តីផ្តើម ១យហ)។ ជាមួយគ្នានេះដែរ វាក៏ផ្តល់នូវភាពជាបរិសុទ្ធ និងគ្រប់គុណធម៌ទាំងអស់ផងដែរ (ប្រៀបធៀប កល ១:៩–១២ ) ។

**១:៩** *ជាអ្នកខ្វាក់មើលទៅឆ្ងាយមិនឃើញ* ឃ្លានេះមិនមែនមានន័យថា ការទាំងពីរ នេះកើតឡើងក្នុងពេលតែមួយទេ ហើយលោកពេត្រុសបានបញ្ជាក់ ដោយខ្លួនគាត់ផ្ទាល់ថា អត្ថន័យនៃឃ្លាថា "មើលទៅឆ្ងាយមិនឃើញ" ប្តូរទៅជា "បិទភ្នែក"វិញ ។ ដូច្នេះ មនុស្សងងឹត គឺពីព្រោះតែពួកគេបានបិទភ្នែកនៅចំពោះសេចក្តីពិត ( ១យហ ២:១១)។

**១:១០** *បងប្អូន* "មើលការពន្យល់ រម ១:១៣"។ *ហើយរើសតាំង អ្នករាល់គ្នាបានពិតប្រាកដឡើងវិញ* តាមរយៈសេចក្តីបញ្ជាក់នៅក្នុង"ខ.៥–៧" ពួកគេ និងអ្នកផ្សេងៗទៀតអាចត្រូវបានធានាថា ព្រះអម្ចាស់បានជ្រើសរើស និងត្រាស់ហៅពួកគេ (មថ ៧:២០ កទ ៥:៦ យក ២:១៨ និងការពន្យល់)។ នៅពេលព្រះអម្ចាស់ជ្រើសរើស និងត្រាស់ហៅ គឺទ្រង់ត្រាស់ហៅឱ្យស្តាប់បង្គាប់ និងចូលទៅក្នុងភាពបរិសុទ្ធ (១ពត ១:២ អភ ១:៣–៦ និងការពន្យល់) ហើយផលផ្លែទាំងនេះធានានូវប្រភពមកអំពីទ្រង់។ *មិនដែលជំពប់ឡើយ* ត្រង់ចំណុចនេះបញ្ជាក់ថា អស់អ្នកដែលដើរនៅក្នុងផ្លូវរបស់ព្រះអម្ចាស់ នោះសេចក្តីជំនឿរបស់ពួកគេនឹងមិនដែលជំពប់ដួលឡើយ ។

**១:១១** *នឹងមានផ្លូវបើកចំហ* គឺតាមរយៈការបង្កើតផលផ្លែដែលលោកពេត្រុសបានបង្គាប់ដល់ពួកគេ (ខ.៥–១០)។ *នគរដ៏នៅអស់កល្បជានិច្ច* អាចសំដៅលើ ជីវិតដ៏នៅអស់កល្បជានិច្ច (មថ ២៥:៤៦)។

**១:១២** សូមមើល រម ១៥:១៥ ភល ៣:១ ១យហ ២:២១ ។

**១:១៣** *ដាស់តឿនរំឭកដល់អ្នករាល់គ្នា* (យហ ១:១៤ ២កថ ៥:១)។

**១:១៤** *ព្រះយេស៊ូវគ្រីស្ទ . . . ទ្រង់បង្ហាញដល់ខ្ញុំ* អាចតាមរយៈការបើកសំដែងដែលបានកត់ត្រាទុកនៅក្នុងបទគម្ពីរ "យហ ២១:១៨–១៩" (មើលការពន្យល់) ឬ តាមរយៈការបើកសំដែងក្រោយមកទៀត ។

**១:១៥** *បាននឹកចាំពីសេចក្តីទាំងនេះ* សំដៅលើសេចក្តីពិត និងកិច្ចការដែលពួកគេបានធ្វើថ្វាយព្រះអម្ចាស់ ។ ម្យ៉ាងទៀត លោកពេត្រុសបានរំឭកដល់ពួកគេឱ្យចងចាំនូវការមួយដ៏សំខាន់ គឺនាំមនុស្សឱ្យបានស្គាល់សេចក្តីពិតប្រយោជន៍ឱ្យពួកគេមានជីវិតរស់អស់កល្បជានិច្ចនៅក្នុងព្រះអម្ចាស់ ។

**១:១៦** *រឿងព្រេងប្រឌិតដោយដំរិះ* ត្រង់ចំណុចនេះបញ្ជាក់ថា សេចក្តីបង្រៀនរបស់លោកពេត្រុស គឺសំអាងលើការដែលគាត់ឃើញ ដោយផ្ទាល់ភ្នែកនូវការអស្ចារ្យដែលព្រះយេស៊ូវបានធ្វើ ។ សេចក្តីបង្រៀនរបស់គាត់មិនមែនអាស្រ័យលើ រឿងព្រេងដែលបានប្រឌិតឡើង ដូចពួកគ្រូខុសឆ្គងទាំងនោះទេ (២:៣ និងមើល ការពន្យល់)។ *ដំណើរដែលទ្រង់យាងមក* ការបង្ហាញព្រះកាយរបស់ព្រះគ្រីស្ទដល់ពួកសិស្សរបស់ទ្រង់ នៅពេលដែលទ្រង់យាងមកជាលើកទីមួយ ហើយបានសុគត និងរស់ឡើងវិញ បានធ្វើឱ្យពួកសិស្សទ្រង់ដឹងជាមុនថា ការយាងមកជាលើកទីពីររបស់ទ្រង់ មានលក្ខណៈដូចកាលដែលទ្រង់យាងទៅស្ថានសួគ៌ដែរ (មើលការពន្យល់ មថ ១៦:២៨)។ *យើងខ្ញុំជាស្មរបន្ទាល់ ដែលបានឃើញឫទ្ធានុភាពរបស់ ទ្រង់ជាក់នឹងភ្នែកវិញ* មានន័យថា ពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទពិតជាបានឃើញទ្រង់រស់ពីសុគតឡើងវិញពិតប្រាកដ (ខ.១៧–១៨ មថ ១៦:២៨–១៧:៨)។

សំឡេងនោះមកពីលើមេឃ ក្នុងកាលដែល នៅលើភ្នំ
បរិសុទ្ធជាមួយនឹងទ្រង់[ក] ១៩ហើយយើងខ្ញុំមានពាក្យទំនាយ
ដ៏ពិតជាង[ឃ] ដែលគួរឱ្យអ្នករាល់គ្នាយកចិត្តទុកដាក់តាម
ដូចជាតាមចង្កៀងដែល ភ្លឺ[ង]ក្នុងទីងងឹត ទាល់តែថ្ងៃភ្លឺឡើង[ច]
ហើយផ្កាយព្រឹក[ឆ]រះ ឡើងក្នុងចិត្តអ្នករាល់គ្នា[ជ] ២០ដោយ
ដឹង[ឈ]សេចក្ដីនេះជាមុនដំបូងថា គ្មានពាក្យទំនាយណា
ក្នុងគម្ពីរ ដែលស្រាយបានតាមតែចិត្តនោះឡើយ ២១ដ្បិត
សេចក្ដីទំនាយមិនដែលមក ដោយបំណងចិត្តមនុស្សទេ
គឺជាមនុស្សបរិសុទ្ធរបស់ព្រះ[ញ] ដែលបានទាយ ដោយសារ
ព្រះវិញ្ញាណបរិសុទ្ធទ្រង់ បណ្ដាលវិញ[ដ]។

## ពួកគ្រូខុសឆ្គង និងគ្រោះថ្នាក់របស់ពួកគេ

**២** ១តែកាលពីដើម មានហោរាក្លែងក្លាយ[ឋ] នៅក្នុងពួកជន
ដូចជានឹងមានគ្រូក្លែងក្លាយក្នុងពួកអ្នករាល់គ្នាដែរ[ឌ] គេនឹង
លួចនាំបញ្ចូលបក្សពួកដែលបង្ខូចបំផ្លាញ គេមិនព្រមស្គាល់
ព្រះដ៏ជាម្ចាស់[ឍ] ដែលបានលោះគេនោះឡើយ[ណ] ក៏នាំ
សេចក្ដីវិនាសដ៏ឆាប់រហ័សឱ្យមកលើខ្លួនផង ២នឹងមាន
មនុស្សជាច្រើនទៅតាមផ្លូវវិនាសរបស់គេ[ត] នោះផ្លូវពិតនឹង
ត្រូវសេចក្ដីប្រមាថមើលងាយ ដោយព្រោះគេដែរ ៣ហើយ
ដោយគេមានចិត្តលោភ[ថ] នោះគេនឹងប្រើអ្នករាល់គ្នាឱ្យ
បានចំណេញ[ទ] ដោយពោលពាក្យបញ្ឆោតបំពោត តែតាំង
ពីយូរមកហើយ សេចក្ដីជំនុំជំរះគេមិននៅស្ងៀមស្ងាត់ទេ
ហើយសេចក្ដីហិនវិនាសរបស់គេក៏មិនងុយងោកដែរ ។
៤ដ្បិតបើសិនជាព្រះមិនបានប្រណី ដល់ពួកទេវតាដែល

**១:១៨** គ មថ ១៧:៦
**១:១៩** ឃ ១ពត ១:១០,១១ ង ទដ ១១៩:១០៥ ច លក ១:៧៨ ឆ វវ ២២:១៦ ជ ២កថ ៤:៦
**១:២០** ឈ ២ពត ៣:៣
**១:២១** ញ ២ធថ ៣:១៦ ដ ២សយ ២៣:២ កច ១:១៦ ៣:១៨ ១ពត ១:១១
**២:១** ឋ ចទ ១៣:១–៣ យរ ៦:១៣ មថ ៧:១៥
ឌ ១ធថ ៤:១ ឍ យដ ៤ ណ ១កថ ៦:២០

**២:២** ត យដ យដ៤ **២:៣** ថ ខ.១៤ ទ ២កថ ២:១៧ ១ថន ២:៥ **២:៤** ធ លប ៦:១-៤ ន ១ធថ ៣:៦ យដ ៦ វវ ២០:១,២

**១:១៨** *ភ្នំបរិសុទ្ធ* "មើលការពន្យល់ លក ៩:២៨"។

**១:១៩–២១** សេចក្ដីអធិប្បាយរបស់លោកពេត្រុសមានមូលដ្ឋានគ្រឹះពីរយ៉ាងគឺ (១).ជាព្រះបន្ទូលមកពីព្រះអម្ចាស់នៅពេលដែលទ្រង់យាងមកសុគតលើឈើឆ្កាង (ខ.១៦–១៨) (២).ទីបន្ទាល់សំខាន់ៗជាច្រើននៃព្រះបន្ទូលព្រះ (ខ.១៩,២១)។ ម្យ៉ាងទៀត មានទស្សនៈខ្លះយល់ថា ទីបន្ទាល់របស់ពួកសាវក អំពីការយាងមករបស់ព្រះយេស៊ូវគ្រីស្ទធ្វើឱ្យសម្រេច និងអះអាងបន្ថែមនូវបទគម្ពីរទាំងពីរខាងលើ ។

**១:១៩** *ផ្កាយព្រឹករះឡើង* "មើលការពន្យល់ ជន ២៤:១៧ វវ ២២:១៦"។

**១:២០** ត្រង់ចំណុចនេះមានទស្សនៈធំៗពីរគឺ (១).គ្មានការថ្លែងទំនាយណាមួយ ដែលមានការបកស្រាយជាលក្ខណៈដាច់ដោយឡែក និងជាលក្ខណៈឯកជនឡើយ (៣:១៦) គឺត្រូវតែមានការចូលរួមពីព្រះវិញ្ញាណព្រះគម្ពីរ និងពួកជំនុំ ។ (២). គ្មានការថ្លែងទំនាយណា ដែលកើតចេញពីការកាត់ស្រាយរបស់អ្នកថ្លែងទំនាយ ដោយផ្ទាល់ទេ ។ អត្ថបទខាងលើ និងបន្ទបន្ទាប់ទៀតបញ្ជាក់ថា ទស្សនៈដែលលើក ឡើងខាងលើត្រូវបានគេនិយមចូលចិត្ត ។ បទគម្ពីរ "ខ.១៦–១៨" ជាប្រភពដើមនៃសេចក្ដីបង្រៀនរបស់ពួកសាវក ។ ម្យ៉ាងទៀតត្រូវចងចាំថា ការថ្លែងទំនាយ នោះ កើតឡើងដោយសារមនុស្ស ឬកើតមកអំពីព្រះ? នៅក្នុង"ខ.២១" បញ្ជាក់យ៉ាងច្បាស់ពីប្រភពដើមនៃសេចក្ដីទំនាយ ។ សេចក្ដីទំនាយមិនអាចកើតឡើងដោយសារគំនិតស្រមើស្រមៃរបស់មនុស្សទេ (ខ.២១)។

**១:២១** *បានទាយដោយសារព្រះវិញ្ញាណបរិសុទ្ធទ្រង់បណ្ដាលវិញ* "មើលការពន្យល់ ២ធថ ៣:១៦"។ ក្នុងការប្រទាននូវព្រះគម្ពីរ គឺមានព្រះអម្ចាស់ជាប្រភព ហើយមានការចូលរួមចំណែកពីមនុស្សដែលទ្រង់បានជ្រើសរើស ។

**២:១** *ហោរាក្លែងក្លាយ* "សូមមើល ១ពវ ១៨:១៩ អស ៩:១៣–១៧ យរ ៥:៣១ ១៤:១៤ ២៣:៣០–៣២ ២៣:៣១ មីក ៣:៥,៧ និងការពន្យល់"។ *នឹងមានគ្រូក្លែង ក្លាយក្នុងពួកអ្នករាល់គ្នាដែរ* ត្រង់ចំណុចនេះបញ្ជាក់ថា មានបទគម្ពីរជាច្រើនដែលព្រមានអំពីពួកគ្រូក្លែងក្លាយ ដែលកើតឡើងនាពេលបច្ចុប្បន្ន និងនៅពេលអនាគត (មថ ២៤:៤–៥,១១ កច ២០:២៩–៣០ កទ ១:៦–៩ ភល ៣:២ កល ២:៤,៨,១៨, ២០-២៣ ២យហ ៧-១១ យដ ៣,៤)។ *បក្សពួកដែលបង្ខូចបំផ្លាញ* សេចក្ដីបង្រៀនខុសឆ្គងនាំឱ្យមានការបាក់បែក នឹងសំដែងចេញនូវលទ្ធផលនៃការវិនាស ចំពោះ ពួកអ្នកដែលទទួលយក ។ *ព្រះដ៏ជាម្ចាស់ ដែលបានលោះគេ* "មើលការពន្យល់ យដ ៤"។ ការដែលថាពួកទាំងនោះជាអ្នកជឿ ឬមិនជឿមិនមែនជាការសំខាន់ទេ ។ ការសុគតរបស់ព្រះគ្រីស្ទបានបង់ថ្លៃលោះមនុស្សទាំងអស់ ដូច្នេះអស់អ្នកណាដែលទទួលជឿដល់ទ្រង់ នោះនឹងបានសង្គ្រោះ (ខ.២០–២២)។ *សេចក្ដីវិនាសដ៏ឆាប់រហ័ស* មិនសំដៅលើសេចក្ដីវិនាសដែលកើតឡើងចំពោះរូបកាយភ្លាមៗនោះទេ ប៉ុន្តែ អាចសំដៅលើសេចក្ដីវិនាសនៅពេលស្លាប់ ឬនៅពេលព្រះគ្រីស្ទយាងមកជាលើកទីពីរ (មថ ២៤:៥០–៥១ ២ថន ១:៩ និងការពន្យល់)។

**២:២** *ផ្លូវវិនាស* អាចសំដៅលើគោលលទ្ធិខុសឆ្គង រួមជាមួយនឹងការប្រព្រឹត្តមិនបរិសុទ្ធ ។ *ផ្លូវពិត* "សូមមើល ទដ ១១៩:៣០"។ ជំនឿរបស់គ្រីស្ទបរិស័ទមិនមែនគ្រាន់តែសំដៅលើគោលលទ្ធិត្រឹមត្រូវប៉ុណ្ណោះទេ គឺសំដៅលើការរស់នៅក្នុងជីវិតត្រឹមត្រូវផងដែរ ។

**២:៣** *គេមានចិត្តលោភ* ពួកគេបានទាក់ទាញដោយបំណងចិត្តស្រឡាញ់ប្រាក់ និងប្រើប្រាស់ជំនឿរបស់គ្រីស្ទបរិស័ទទៅធ្វើជំនួញ ដើម្បីបម្រើមហិច្ឆតាលោភលន់របស់ខ្លួន ។ *ពោលពាក្យបញ្ឆោតបំពោត* "មើលការពន្យល់ ១:១៦"។ *តាំងពីយូរមកហើយ* គឺតាំងពីសម័យកាលសញ្ញាចាស់ដែលទោសកំហុសទាំងឡាយត្រូវបានបើកចំហ (ការជំនុំជម្រះនឹងត្រូវមកលើពួកមនុស្សអាក្រក់ សូមមើល ខ.៤–៩)។ *សេចក្ដីជំនុំជំរះគេមិននៅស្ងៀមស្ងាត់ទេ* ការពន្យាពេលរបស់ព្រះអម្ចាស់ធ្វើឱ្យពួកគេគិតថាខ្លួនអាចគេចផុតពីការជំនុំជម្រះរបស់ទ្រង់ ប៉ុន្តែ សេចក្ដីវិនាសគឺជាការពិតដែលនឹងត្រូវកើតឡើងចំពោះពួកគេ ។

**២:៤–៨** ត្រង់ចំណុចនេះ បង្ហាញនូវឧទាហរណ៍បី ដែលអះអាងថា ព្រះអម្ចាស់នឹងបំបាត់មនុស្សអាក្រក់ ហើយសង្គ្រោះមនុស្សសុចរិត ។

**២:៤** *ព្រះមិនបានប្រណី ដល់ពួកទេវតាដែលបានធ្វើអំពីបាប* មានមតិខ្លះយល់ថា ឃ្លានេះសំដៅលើសេចក្ដីបានចែងនៅក្នុង "លប ៦:២" ដែលថាកូនប្រុសរបស់ព្រះ គឺពួកទេវតាទាំងនោះ បានយកកូនស្រីរបស់មនុស្សធ្វើជាប្រពន្ធ ។ ហើយពួកកូនៗរបស់ពួកគេត្រូវបានគេយល់ថា ជាមនុស្សខ្លាំងពូកែ (លប ៦:២,៤ និងការពន្យល់)។ ប៉ុន្តែ មានមតិខ្លះទៀតយល់ថា

បានធ្វើអំពើបាប[ធ] គឺទ្រង់បោះទំលាក់ទៅក្នុងជង្ហុកជ្រៅបំផុត
ឱ្យជាប់ច្រវាក់នៃសេចក្ដីងងឹត ទាំងឃុំទុកសំរាប់នឹងជំនុំ
ជំរះវិញ[ន] ៥ហើយបើទ្រង់មិនបានប្រណីដល់លោកីយពីចាស់
បុរាណ[ប] ក្នុងកាលដែលទ្រង់បានធ្វើឱ្យទឹកជន់លិចពួក
មនុស្ស[ផ] ទមិលល្មើស តែបានជួយសង្គ្រោះលោកណូអេ
ទាំងអស់គ្នាមាន ៨ នាក់ ដែលលោកជាអ្នកប្រកាសប្រាប់ពី
សេចក្ដីសុចរិត[ព] ៦ហើយបើទ្រង់បានបញ្ឆោះក្រុងសូដុំម នឹង
ក្រុងកូម៉ូរ៉ាឱ្យទៅជាផេះ[ភ] ទាំងកាត់ទោស ឱ្យត្រូវហិនវិនាស
សាបសូន្យទៅ ទុកជាគំរូ[ម]ដល់ពួកមនុស្សតទៅមុខ ដែលគិត
រស់នៅដោយសេចក្ដីទមិលល្មើស[យ] ៧តែបានប្រោសលោក
ឡុត[រ] ជាអ្នកសុចរិតឱ្យរួចវិញ ដែលលោកមានចិត្តព្រួយ
លំបាក ដោយព្រោះកិរិយាខូចអាក្រក់របស់មនុស្សទទឹង
ច្បាប់ទាំងនោះ[ល] ៨ដ្បិតអ្នកសុចរិតនោះ[វ] ដែលនៅជាមួយ
នឹងគេ ក៏កើតទុក្ខក្នុងចិត្តសុចរិតរបស់លោករាល់តែថ្ងៃ
ដោយបានឮ ហើយឃើញការទទឹងច្បាប់ ដែលគេប្រព្រឹត្ត
ធ្វើ ៩បើដូច្នេះឃើញថា ព្រះអម្ចាស់ទ្រង់ចេះប្រោសមនុស្ស
ដែលគោរពប្រតិបត្តិដល់ទ្រង់ ឱ្យរួចពីសេចក្ដីល្បួង[ស] ហើយ
នឹងឃុំទុកមនុស្សទុច្ចរិត សំរាប់នឹងធ្វើទោសក្នុងថ្ងៃជំនុំជំរះ
វិញ[ហ] ១០គឺពួកអស់អ្នកដែលដើរតាមសាច់ឈាមជាដើម
ដែលគេមានសេចក្ដីប៉ងប្រាថ្នាខាងឯការស្មោកគ្រោក[ឡ]
ហើយក៏មើលងាយដល់អស់ទាំងអំណាចត្រួតត្រាដែរ គេ
ជាពួកព្រហើន មានក្បាលរឹង ដែលមិនខ្លាចនឹងជេរប្រ
មាថដល់ទាំងពួកប្រសើរឧត្ដមផង[អ] ១១ដែលពួកទេវតាដ៏
មានកំឡាំង មានឫទ្ធិលើសជាងគេទៅទៀត ក៏មិនហ៊ានប្រ
មាថដល់ពួកនោះនៅចំពោះព្រះអម្ចាស់ឡើយ[ក] ១២តែ
ដោយ ព្រោះគេជេរប្រមាថដល់ការដែលគេមិនស្គាល់
នោះគេនឹងត្រូវវិនាសបាត់ក្នុងការខូចអាក្រក់របស់គេអស់
រលីង ដូចជាសត្វតិរច្ឆាន ដែលកើតមកសំរាប់តែឱ្យគេចាប់
ហើយកាប់សំឡាប់ប៉ុណ្ណោះដែរ[ខ] ១៣គេហៀបនឹងទទួល
រង្វាន់នៃការទុច្ចរិត គេជាពួកអ្នកដែលរាប់ការស្រើប
ស្រាលនៅពេលថ្ងៃ[គ] ទុកជាការត្រេកអរសប្បាយ គេជា
ស្នាមប្រឡាក់ ហើយជាសេចក្ដីស្មោកគ្រោក គេត្រេកអរ
ដោយសេចក្ដីបញ្ឆោតរបស់ខ្លួន ក្នុងពេលកំពុងដែលគេ

**២:៥** ប ២ពត ៣:៦ ផ លប ៦:៥–៨:១៩ ព ហព ១១:៧ ១ពត ៣:២០ **២:៦** ភ លប ១៩:២៤,២៥ ម ជន ២៦:១០ យដ ៧ យ មថ ១០:១៥ ១១:២៣,២៤ រម ៩:២៩ **២:៧** រ លប ១៩:១៦ ល ២ពត ៣:១៧ **២:៨** វ ហព ១១:៤ **២:៩** ស ទដ ៣៧:៣៣ រម ១៥:៣១ វវ ៣:១០ ហ មថ ១០:១៥ **២:១០** ឡ ២ពត ៣:៣ យដ ១៦,១៨ អ យដ ៨ **២:១១** ក យដ ៩

**២:១២** ខ ទដ ៤៩:១២ យដ ១០ **២:១៣** គ រម ១៣:១៣ ១ថន ៥:៧ ឃ ១កថ ១១:២០, ២១ យដ ១២

ពួកទេវតាទាំងនេះបានធ្វើបាបតាំងពីមុនពេលលោកអ័ដាម និងនាងអេវ៉ា បានប្រព្រឹត្តបាបទៅទៀត ។ ពួកទេវតាដែលបានប្រព្រឹត្តបាបទាំងនោះ បានក្លាយទៅជាទេវតាអាក្រក់ និងវិញ្ញាណអាក្រក់ ។ *ជង្ហុកជ្រៅបំផុត* សំដៅលើទីកន្លែងដែលពួកវិញ្ញាណអាក្រក់ត្រូវទម្លាប់ចុះទៅ ។ *ជំនុំជំរះ* ពាក្យនេះអាចសំដៅលើការជំនុំជម្រះ ដែលលើកឡើងនៅក្នុងបទគម្ពីរ "វវ ២០:១១–១៥"។

**២:៥** *មនុស្សទមិលល្មើស* "សូមមើល លប ៦:៥,១១–១២"។ *អ្នកប្រកាសប្រាប់ពីសេចក្ដីសុចរិត* សំដៅលើលោកណូអេ ។ *ទាំងអស់គ្នាមាន៨នាក់* រួមមានលោកណូអេប្រពន្ធគាត់កូនប្រុសគាត់៣នាក់ និងកូនប្រសារស្រីគាត់៣នាក់ទៀត (១ពត ៣:២០)។

**២:៦** *បានបញ្ឆេះក្រុងសូដុំម និងក្រុងកូម៉ូរ៉ា* "សូមមើលបទគម្ពីរ លប ១៩"។

**២:៧** *លោកមានចិត្តព្រួយលំបាក ដោយព្រោះកិរិយាខូចអាក្រក់របស់មនុស្សទទឹងច្បាប់ទាំងនោះ* សូមមើលបទគម្ពីរ លប ១៩:៤–៩ ។ ត្រង់ចំណុចនេះបញ្ជាក់អំពីទុក្ខលំបាករបស់លោកឡុត និងការដែលគាត់បង្ខំចិត្តចង់ប្រគល់កូនស្រីទាំងពីររបស់ខ្លួនទៅពួកមនុស្សអាក្រក់ ដែលជារឿងមួយពិបាកនឹងយល់ ហើយនិងរបៀបដែលលោកត្រូវបានព្រះអម្ចាស់រាប់ថា ជាមនុស្សសុចរិត (លប ១៩:៨)។

**២:៩** ត្រង់ចំណុចនេះ លោកពេត្រុសបញ្ជាក់ថា សេចក្ដីដែលបានលើកឡើងនៅ ក្នុង"ខ.៤–៨" គឺពួកមនុស្សអាក្រក់នឹងត្រូវទទួលជំនុំជម្រះ ។

**២:១០** ពួកគ្រូខុសឆ្គងនៅសម័យលោកពេត្រុស តែងតែសំដែងខ្លួនឱ្យឃើញយ៉ាងច្បាស់ថា ពួកគេនឹងត្រូវជាប់នៅក្នុងសេចក្ដីជំនុំជម្រះ ដោយព្រោះមូលហេតុពីរយ៉ាងគឺ (១). ពួកគេប្រតិបត្តិតាមបំណងប្រាថ្នា ដ៏ពុករលួយនៃអំពើបាប (សំដៅលើការប្រព្រឹត្តអំពើផិតក្បត់ ខ.១៨ ១:៤ ៣:៣)។ (២). ពួកគេមិនឱ្យតម្លៃចំពោះអំណាចដែលព្រះប្រទានមកទេ ។ *មិនខ្លាចនឹងជេរប្រមាថដល់ទាំងពួកប្រសើរឧត្ដម* ត្រង់ចំណុចជាភស្ដុតាងមួយបញ្ជាក់ថា ពួកគ្រូខុសឆ្គង ទាំងនោះមិនបានឱ្យតម្លៃ ចំពោះអំណាចដែលមកអំពីព្រះអម្ចាស់ទេ ។ *ពួកប្រសើរឧត្ដម* អាចសំដៅលើពួកអ្នកដែលបានរាប់ថា ជាមនុស្សប្រសើរនៅលើផែនដីនេះ ដែលរួមមានដូចជាពួកអ្នកដឹកនាំពួកជំនុំជាដើម។ ម្យ៉ាងទៀតឃ្លានេះក៏អាចសំដៅលើពួកទេវតា ។ មតិនេះហាក់ដូចជាបានទទួលការគាំទ្រច្រើន ដោយព្រោះបទគម្ពីរនៅក្នុង "យដ ៨–១០" បាននិយាយសំដៅលើពួកទេវតាដែលបានប្រព្រឹត្តបាប ។

**២:១១** *ពួកទេវតា . . . មិនហ៊ានប្រមាថដល់ពួកនោះ* ត្រង់ចំណុនេះបញ្ជាក់ថា ទោះបីពួកទេវតារបស់ព្រះអម្ចាស់ ដែលមានអំណាចយ៉ាងធំក៏ដោយ ក៏មិនហ៊ានពោលពាក្យប្រមាថដល់ពួកទេវតា ដែលប្រព្រឹត្តបាបនៅចំពោះព្រះភ័ក្ត្ររបស់ព្រះអម្ចាស់ដែរ ។

**២:១២** *ការដែលគេមិនស្គាល់* សេចក្ដីបង្រៀនខុសឆ្គងដែលលោកពេត្រុសនិយាយនៅត្រង់ចំណុចនេះ អាចជាទម្រង់នៃសេចក្ដីបង្រៀនខុសឆ្គងនៅសតវត្សរ៍ទី២ដែលអះអាងថា គេអាចទទួលបាននូវចំណេះនៃការអាថ៌កំបាំងពិសេសដែលមនុស្សធម្មតាមិនអាចយល់បាន ។ ដូច្នេះ បញ្ជាក់ថា ពួកគ្រូខុសឆ្គងទាំងនោះមានពេញទៅដោយសេចក្ដីអំនួត ហើយជាលទ្ធផលគឺពួកគេបានក្លាយទៅជាមនុស្សព្រហើន ។ *ដូចសត្វតិរច្ឆាន* នេះជាឃ្លាដែលមានលក្ខណៈធ្ងន់ធ្ងរបំផុត ។ ពួកគ្រូខុសឆ្គងទាំងនោះ មានលក្ខណៈដូចជាសត្វដែលគ្មានវិចារណញ្ញាណ ហើយជីវិតរបស់ពួកគេត្រូវបានដឹកនាំតាមសភាវគតិ ហើយរស់នៅសម្រាប់តែទទួលនូវការស្លាប់វិញប៉ុណ្ណោះ ។ ជាលទ្ធផលសេចក្ដីវិនាសនឹងធ្លាក់មកលើពួកគេ ។

**២:១៣** *ការស្រើបស្រាលនៅពេលថ្ងៃ* "សូមមើល ១ថន ៥:៧"។ ត្រង់

ស៊ីលៀងជាមួយនឹងអ្នករាល់គ្នា[ឃ] ១៤ គេមានចិត្តនឹកឃើញ
តែស្រីសំផឹង គេមិនចេះលែងធ្វើបាបឡើយ ក៏បិទនុយ[ង]
ចាប់ព្រលឹងមនុស្សដែលមិនខ្ជាប់ខ្ជួន[ច] ហើយមានចិត្ត
ធ្លាប់ខាងឯសេចក្ដីលោភ[ឆ] គឺជាមនុស្សដែល ត្រូវបណ្ដាសា[ជ]
១៥ គេបានបោះបង់ចោលផ្លូវទៀងត្រង់ ហើយវង្វេងទៅ
តាមផ្លូវរបស់ហោរាបាឡាម[ឈ] ជាកូនបេអ៊័រ ដែលស្រ
ឡាញ់កំរៃនៃការទុច្ចរិត ១៦ តែគាត់ត្រូវបន្ទោស ដោយ
ព្រោះការរំលងរបស់គាត់ ដោយសត្វព្រនាក់គ បាន
និយាយជាសំឡេងមនុស្ស ទាំងឃាត់ឃាំងសេចក្ដីចំកួត
របស់គាត់[ញ] ១៧ ពួកអ្នកទាំងនោះសុទ្ធតែជារន្ធទឹកខ្សោះ[ដ]
ជាពពកដែលខ្យល់ព្យុះបក់ផាត់ ដែលសេចក្ដីងងឹតសូន្យ
ឈឹង បានបំរុងទុកឱ្យគេអស់កល្បជានិច្ច[ឋ] ១៨ ដ្បិតគេ
និយាយសេចក្ដីអំនួតអួតយ៉ាងសំបើម[ឌ] ទាំងបិទនុយដែល
ប្រកបដោយសេចក្ដីសំរើបខាងសាច់ឈាម នឹងសេចក្ដី
ខូចអាក្រក់ទាំងប៉ុន្មាន ដើម្បីចាប់ពួកអស់អ្នក ដែលទើប
តែនឹងរួចចេញ[ឍ]ពីពួកវង្វេង ១៩ ទាំងសន្យាឱ្យអ្នកទាំង
នោះបានសេរីភាពផង តែខ្លួនគេក៏នៅជាប់ជាបាវបំរើ
របស់សេចក្ដីពុករលួយវិញ ដ្បិតបើអ្នកណាត្រូវគេបង្ក្រាប
ខ្លួន នោះត្រូវនៅជាប់ជាបាវ របស់អ្នកនោះហើយ[ណ]
២០ ពីព្រោះក្រោយដែលបានរួចពីសេចក្ដីស្មោកគ្រោក
របស់លោកីយនេះ ដោយបានស្គាល់[ត]ព្រះអម្ចាស់យេស៊ូវ
គ្រីស្ទ[ថ] ជាព្រះអង្គសង្គ្រោះហើយ បើអ្នកណាត្រឡប់
ទៅជាជាប់ទាក់ទិន ឱ្យសេចក្ដីទាំងនោះបានបង្ក្រាបខ្លួន
វិញ នោះសណ្ឋានក្រោយរបស់អ្នកនោះ បានអាក្រក់
ជាងមុនទៅទៀត[ទ] ២១ ដ្បិតបើមិនបានស្គាល់ផ្លូវសុច
រិតសោះ នោះជាជាងឱ្យបានស្គាល់រួចបែរចេញពីសេច
ក្ដីបញ្ញត្តបរិសុទ្ធ ដែលបានប្រគល់មកហើយនោះវិញ

**២:១៤** ង ខ.១៨ ច យក ១:៨ ២ពត ៣:១៦ ឆ ខ.៣ ជ អភ ២:៣
**២:១៥** ឈ ជន ២២:៤-២០ ៣១:១៦ ចទ ២៣:៤ យដ ១១ វវ ២:១៤
**២:១៦** ញ ជន ២២:២១-៣០
**២:១៧** ដ យដ ១២ ឋ យដ ១៣
**២:១៨** ឌ យដ ១៦ ឍ ខ.២០ ២ពត ១:៤
**២:១៩** ណ រម ៦:១៦
**២:២០** ត ២ពត ១:២ ថ ២ពត ១:១១ ៣:១៨ ទ មថ ១២:៤៥

ចំណុចនេះបញ្ជាក់ថា សូម្បីតែពួកសាសន៍ដទៃ ក៏ពួកគេតែងប្រព្រឹត្តការទាំងនេះដោយលាក់កំបាំងដែរ ប៉ុន្តែ ពួកគ្រូខុសឆ្គងទាំងនោះបានប្រព្រឹត្តការទាំងនេះដោយមិនចេះអៀនខ្មាសទាល់តែសោះ ។ *គេត្រេកអរដោយសេចក្ដីបញ្ឆោតរបស់ខ្លួនក្នុងពេលកំពុងដែលគេ ស៊ីលៀងជាមួយនឹងអ្នករាល់គ្នា* ពួកគ្រូខុសឆ្គងទាំងនោះ ហាក់ដូចជាបានចូលរួមជាមួយនឹងពួកជិនុំដំបូង ក្នុងពិធីលៀងព្រះអម្ចាស់ ហើយបានបញ្ចូលនូវការស៊ីផឹករបស់ខ្លួនទៅក្នុងពិធីដ៏បរិសុទ្ធនេះ និងបានសំដែងចេញនូវសកម្មភាពដែលមិនចេះអៀនខ្មាសរបស់ខ្លួនទៀតផង (១កថ ១១:១៧-២២, ២៧-៣៤ និងការពន្យល់ ១១:២០-២២)។

**២:១៤** *គេមានចិត្តនឹកឃើញតែស្រីសំផឹង* បញ្ជាក់ថា ភ្នែកពួកគេពេញទៅដោយសេចក្ដីកំផិត ។ *គេមិនចេះលែងធ្វើបាបឡើយ* ពួកគេប្រើភ្នែករបស់ខ្លួនទុកដូចជាឧបករណ៍សម្រាប់ប្រព្រឹត្តបាប ។ *បិទនុយចាប់ព្រលឹងមនុស្សដែលមិនខ្ជាប់ខ្ជួន* ចំពោះសេចក្ដីប្រៀបធៀបនឹងឃ្លានេះ សូមមើលបទគម្ពីរ "យក ១:១៤ និងការពន្យល់"។ ត្រង់ចំណុចនេះបង្ហាញថា ពួកគេមានភាពស្រដៀងគ្នាទៅនឹងពួកអ្នកនេសាទ ដែលប្រើនុយដើម្បីទាក់ទាញក្នុងបំណងចង់ចាប់ត្រីយ៉ាងដូច្នោះដែរ ។ *មានចិត្តធ្លាប់ខាងឯសេចក្ដីលោភ* ឃ្លានេះនៅក្នុងភាសាក្រិកសំដៅលើពួកអ្នក ដែលហ្វឹកហាត់ខ្លួនខាងឯសេចក្ដីលោភ ។

**២:១៥** *ហោរាបាឡាម ជាកូនបេអ៊័រ* "សូមមើល ជន ២២-២៤"។ ហោរាបាឡាមត្រូវបានគេបញ្ចុះបញ្ចូល ឱ្យដាក់បណ្ដាសាលើរាស្ត្រអ៊ីស្រាអែល ប៉ុន្តែព្រះអម្ចាស់មិនសព្វព្រះហឫទ័យនឹងការនោះទេ ។ គាត់ចង់បានប្រាក់ដែលគេឱ្យដល់គាត់ ។ ពួកគ្រូខុសឆ្គងនៅសម័យលោកពេត្រុសក៏មានលក្ខណៈស្រដៀងគ្នានេះដែរ គឺតែងតែចង់បានប្រាក់ពីពួកអ្នកស្ដាប់ដែលស្មោះត្រង់ ។ រីឯការដែលសត្វនិយាយបន្ទោសហោរាបាឡាម(ខ.១៦) មិនមែនគ្រាន់តែបង្ហាញនូវគំនិតដ៏ល្ងង់ខ្លៅ របស់គាត់ប៉ុណ្ណោះទេ គឺថែមទាំងសំដៅលើពួកគ្រូខុសឆ្គងនៅសម័យកាលលោកពេត្រុសទៀតផង ។

**២:១៧** *រន្ធទឹកខ្សោះ* ត្រង់ចំណុចនេះបង្ហាញឱ្យឃើញនូវគំនិតកុហកបោកប្រាស់របស់ពួកគ្រូខុសឆ្គង ។ ពួកអ្នកដំណើរដែលស្រេកទឹកសង្ឃឹមថា នឹងបានទឹកផឹក ប៉ុន្តែ បែរជាប្រទះនឹងកន្លែងគ្មានទឹកវិញ (យរ ១៥:១៨ និងការពន្យល់)។ ដូចគ្នានេះដែរ ពួកគ្រូខុសឆ្គងទាំងនោះបានសន្យាផ្ដល់នូវសេចក្ដីពិតដល់ពួកអ្នកស្ដាប់ខ្លួន ប៉ុន្តែ ផ្ទុយទៅវិញ ពួកគេគ្មានអ្វីផ្ដល់ដល់ពួកអ្នកដែលស្ដាប់ខ្លួនទាល់តែសោះ ។ *ពពកដែលខ្យល់ព្យុះបក់ផាត់* គឺត្រូវរលាយមុនពេលដែលអាចបង្កជាទឹកភ្លៀង ។ *សេចក្ដីងងឹតសូន្យឈឹង* ឃ្លានេះបញ្ជាក់ពីលទ្ធផលចុងបញ្ចប់របស់ពួកគ្រូខុសឆ្គងទាំងអស់នោះ ។

**២:១៨** *គេនិយាយសេចក្ដីអំនួតអួតយ៉ាងសំបើម* បញ្ជាក់ថា ពាក្យសម្ដីរបស់ពួកគ្រូខុសឆ្គងទាំងនោះ ធ្វើឱ្យពួកអ្នកជឿដល់ព្រះអម្ចាស់ថ្មីៗមានការភាន់ច្រឡំ ប៉ុន្តែតាមការពិត ពួកគ្រូខុសឆ្គងទាំងនោះ មិនមានសេចក្ដីពិតអ្វីផ្ដល់ដល់ពួកគេទេ ។ *សេចក្ដីសំរើបខាងសាច់ឈាម* "មើលការពន្យល់ ខ.១០"។ *សេចក្ដីខូចអាក្រក់* "មើលការពន្យល់ ខ.១៤"។ *ពួកអស់អ្នកដែលទើបតែនឹងរួចចេញពីពួកវង្វេង* សំដៅលើពួកអ្នកជឿថ្មីៗ ដែលទើបតែបានងាកបែរចេញពីផ្លូវដែលនាំឱ្យវង្វេង ។ ដូច្នេះហើយបានជាពួកគ្រូខុសឆ្គងទាំង នោះឆក់យកឱកាសនោះទាក់ទាញពួកអ្នកជឿថ្មីៗ ដែលមិនទាន់បានទទួលនូវការបង្ហាត់បង្រៀនឱ្យលូតលាស់ខាងឯព្រលឹងវិញ្ញាណបានរឹងមាំនៅឡើយ ។

**២:១៩** *ទាំងសន្យាឱ្យអ្នកទាំងនោះបានសេរីភាពផង* ប្រហែលជាសំដៅទៅលើសេរីភាព ដែលនាំឱ្យបែកចេញពីការប្រព្រឹត្តត្រឹមត្រូវ (១កថ ៦:១២-១៣ កទ ៥:១៣ និងការពន្យល់)។ ម្យ៉ាងទៀត ពួកគេបានសន្យានូវសេរីភាពចេញពីភាព ជាទាសករទៅក្នុងការគ្រប់គ្រងដោយច្បាប់ទម្លាប់វិន័យផ្សេងៗ ដែលធ្វើឱ្យពួកគេធ្លាក់ទៅក្នុងភាពជាទាសករនៃសេចក្ដីពុករលួយ ។ សេរីភាពណាដែលនាំឱ្យបែកចេញពីក្រិត្យវិន័យរបស់ព្រះអម្ចាស់ សេរីភាពនោះនឹង នាំទៅរកភាពជាទាសកររបស់បាប ។

**២:២០-២២** មានមតិខ្លះយល់ថា ត្រង់ចំណុចនេះគឺជាភស្តុតាង បញ្ជាក់អំពីមនុស្សដែលទទួលបានការសង្គ្រោះហើយ អាចបាត់សេចក្ដីសង្គ្រោះ នោះទៅវិញ ។ ពួកគេស្គាល់ព្រះអម្ចាស់ និងព្រះបន្ទូលនៃសេចក្ដីសុចរិតហើយបានបែរចេញពីលោកិយ ។ បន្ទាប់មកពួកគេបែរចេញពីព្រះបន្ទូល ហើយត្រឡប់ទៅផ្លូវជីវិតចាស់របស់ខ្លួនវិញ ។ ម្យ៉ាងទៀតពួកគេត្រូវបានទទួលស្គាល់ថា បានទទួលចំណេះពិតប្រាកដមកអំពីព្រះអម្ចាស់ ហើយជីវិតរបស់ពួកគេបានផ្លាស់ប្រែ រីឯការងាកបែរទៅរកជីវិតចាស់របស់ខ្លួនវិញ

នោះសណ្ឋានក្រោយរបស់អ្នកនោះវិញ[ធ] ២២តែមានការ
កើតមកដល់គេ ដូចជាពាក្យទំនៀមពិតដែលថា «ឆ្កែបាន
ត្រឡប់ទៅស៊ីកំអួតវា[ន] ឯជ្រូកញីដែលគេលាងស្អាតហើយ
បានទៅននៀលនៅក្នុងខ្នាចវិញ»។

## ថ្ងៃនៃព្រះអម្ចាស់

**៣** ១ឥឡូវនេះ ពួកស្ងួនភ្ងាអើយ[ប] ខ្ញុំផ្ញើសំបុត្រទី ២ នេះផ្ញើ
មកអ្នករាល់គ្នា ដែលក្នុងសំបុត្រទាំង ៣ ច្បាប់ ខ្ញុំបានរំឮក[ផ]
ដាស់តឿនសតិស្មារតីដ៏ស្អាតរបស់អ្នករាល់គ្នាហើយ ២ដើម្បី
ឱ្យបាននឹកចាំ ពីអស់ទាំងសេចក្តី ដែលពួកហោរាបរិសុទ្ធ
បានទាយកាលពីដើម[ព] នឹងពីសេចក្តីបញ្ញត្តិរបស់ព្រះអម្ចាស់
ដ៏ជាព្រះអង្គសង្គ្រោះ ដែលបងប្អូនបានឮដោយសារយើងខ្ញុំ
ជាពួកសាវក[ភ] ៣ដោយដឹងសេចក្តីនេះជាមុនថានៅជាន់
ក្រោយ[ម] នឹងមានមនុស្សចំអកមក ដែលគេដើរតាមសេចក្តី
ប៉ងប្រាថ្នារបស់គេ[យ] ទាំងចំអកឡកឡឺយថា ៤តើសេចក្តី
សន្យា[រ]ពីព្រះអង្គយាងមកនៅឯណា ដ្បិតតាំងពីពួកឰយុកោ
ដេកលក់ទៅ នោះគ្រប់ទាំងអស់នៅតែដដែល ដូចជាពី
កំណើតលោកីយរៀងមកដែរ[ល] ៥ពីព្រោះគេចង់បំភ្លេច
ថា ពីចាស់បុរាណមានផ្ទៃមេឃ ក៏មានដីដុះចេញពីទឹក
ហើយនៅក្នុងទឹកផង[វ] ដោយសារព្រះបន្ទូលនៃព្រះ[ស]
៦រួចមកលោកិយ[ហ]ត្រូវទឹកនោះជន់លិចបំផ្លាញទៅ[ឡ]

**២:២១** ធ អគ ១៨:២៤ ហព ៦:៤–៦ ១០:២៦,២៧
**២:២២** ន សភ ២៦:១១
**៣:១** ប ១កថ ១០:១៤ ផ ២ពត ១:១៣
**៣:២** ព លក ១:៧០ កច ៣:២១
ភ អភ ៤:១១
**៣:៣** ម ១ធថ ៤:១ ២ធថ ៣:១ យ ២ពត ២:១០ យដ ១៨
**៣:៤** រ អស ៥:១៩ អគ ១២:២២ មថ ២៤:៤៨ លក ១៧:៣០ ល មក ១០:៦
**៣:៥** វ ទដ ២៤:២ ស លប ១:៦,៩ ហព ១១:៣ **៣:៦** ហ ២ពត

មិនមានភាពស្មោកស្មើរទេ ។ មតិខ្លះទៀតយល់ថា ពួកគេមិនបានទទួលព្រះបន្ទូល និងសេចក្តីសុចរិតរបស់ព្រះអម្ចាស់ពិតប្រាកដទេ។ ប្រសិនបើពួកគេទាំងនោះបានទទួលការកើតជាថ្មីពិតមែន នោះពួកគេពិតជាឈរមាំនៅក្នុងសេចក្តីជំនឿជាមិនខាន ។ មានសេចក្តីអះអាងនៅក្នុងបទគម្ពីរ "យហ ១០:២៧–៣០ និង រម ៨:២៨–២៩" ដែលបញ្ជាក់យ៉ាងច្បាស់ថា ពួកអ្នកដែល ទទួលបានការសង្គ្រោះពីព្រះអម្ចាស់ហើយ នោះនឹងមិនត្រូវវិនាសឡើយ ។ ដូច្នេះ ពួកអ្នកដែលបានរៀបរាប់នៅត្រង់ចំណុចនេះ អាចមិនមែនជាមនុស្សដែលបានទទួលការសង្គ្រោះនៅឡើយទេ (១យហ ២:១៩)។

**២:២០** *ក្រោយដែលបានរួចពីសេចក្តីស្មោកគ្រោករបស់លោកីយនេះ* ឃ្លានេះ សំដៅលើពួកគ្រូខុសឆ្គង ដែលបានប្រែចិត្តជឿដល់ព្រះអម្ចាស់ ដោយបង្ហាញឱ្យឃើញ ដោយសារទង្វើនៃការប្រព្រឹត្តនៅក្នុងជីវិតរបស់ពួកគេ ។ *ត្រឡប់ទៅជាជាប់ទាក់ទិន ឱ្យសេចក្តីទាំងនោះបានបង្ក្រាបខ្លួនវិញ* មានន័យថា ពួកគេបានធ្លាក់ចូលទៅក្នុងផ្លូវនៃជីវិតចាស់វិញ ។

**២:២១** បទគម្ពីរនេះបញ្ជាក់ថា ពួកអ្នកដែលបានស្គាល់សេចក្តីពិតហើយ បន្ទាប់មកងាកបែរចេញទៅវិញ នោះចិត្តរបស់ពួកគេនឹងកាន់តែរឹងឡើង នៅសម័យពួកជំនុំដំបូង គ្រីស្ទបរិស័ទត្រូវបានគេហៅថា "ផ្លូវ" (កច ៩:២ ១៨:២៥ ១៩:៩, ២៣ ២២:៤ ២៤:១៤,២២ និងការពន្យល់)។ *សេចក្តីបញ្ញត្តិបរិសុទ្ធ* សំដៅលើបញ្ញត្តិនៃដំណឹងល្អសម្រាប់ឱ្យមនុស្សទាំងអស់ទទួលយក ដើម្បីបានសង្គ្រោះ (មើលការពន្យល់ យដ ៣)។

**២:២២** *ឆ្កែ... ជ្រូកញី... បានទៅននៀលនៅក្នុងខ្នាចវិញ* ត្រង់ចំណុចនេះ បញ្ជាក់អំពីលក្ខណៈរបស់សត្វគឺមិនប្រែប្រួល ។ សត្វជ្រូកត្រូវត្រឡប់ទៅដេកនៅក្នុងភក់វិញ ព្រោះថាវានៅតែជាជ្រូកដដែល ។ ការផ្លាស់ប្រែឱ្យមានភាពស្អាត គឺមានដែនកំណត់ ។

**៣:១** *សំបុត្រទី២* គឺសំបុត្រទីពីររបស់លោកពេត្រុស ។ សំបុត្រទីមួយរបស់គាត់អាចជាកណ្ឌគម្ពីរពេត្រុសទី១ ។ *រំឭកដាស់តឿន* "សូមមើល ១:១២–១៣,១៥"។

**៣:២** *ពួកហោរាបរិសុទ្ធ* សំដៅលើពួកហោរារបស់ព្រះអម្ចាស់នៅសម័យកាលសញ្ញាចាស់ ។ *សេចក្តីបញ្ញត្តិរបស់ព្រះអម្ចាស់* "មើលការពន្យល់ ២:២១"។ *ដោយសារយើងខ្ញុំជាពួកសាវក* ត្រង់ចំណុចនេះ លោកពេត្រុសបានហៅពួកហោរានៅក្នុងសម័យកាលសញ្ញាចាស់ស្មើគ្នានឹងពួកសាវកនៅសម័យកាលសញ្ញាថ្មីដែរ។ ទាំងពួកហោរា និងពួកសាវកគឺជាអ្នកនាំនូវសេចក្តីពិតរបស់ព្រះអម្ចាស់ដល់រាស្ត្រទ្រង់ ។ ម្យ៉ាងទៀតលោកពេត្រុសបានមានប្រសាសន៍ដោយបង្ហាញនូវចំណេះដឹង និងអំណាចជាអ្នកតំណាងពួកសាវក។

**៣:៣** *ដោយដឹងសេចក្តីនេះជាមុន* លោកពេត្រុសប្រើឃ្លានេះដើម្បីផ្តល់នូវចំណាប់អារម្មណ៍ និងបង្ហាញនូវសារសំខាន់នៃសេចក្តីដែលគាត់បានលើកឡើង(១:២០)។ *នៅជាន់ក្រោយ* ឃ្លានេះសំដៅលើអំឡុងពេលនៃការយាងមកជាលើកទីមួយរបស់ព្រះគ្រីស្ទ ។ ក្នុងអំឡុងពេលនៃការយាងមកលើកទីមួយរបស់ព្រះគ្រីស្ទ គឺជារយៈពេលចុងក្រោយនៃសម័យកាលសញ្ញាចាស់ និងជាការចាប់ផ្តើមនៃសម័យកាលសញ្ញាថ្មី (មើលពន្យល់ ហព ១:១–២)។ ម្យ៉ាងទៀត គឺជាពេលវេលាដែលសេចក្តីទំនាយរបស់ពួកហោរានៅក្នុងសញ្ញាចាស់ត្រូវបានសម្រេចផងដែរ។ *នឹងមានមនុស្សចំអកមក* អាចសំដៅលើពួកគ្រូខុសឆ្គង ដែលបានលើកឡើងនៅក្នុងជំពូក២ (សូមប្រៀបធៀប ២:១០,១៨–១៩)។ ទោះជាយ៉ាងក៏ដោយ បទគម្ពីរនៅក្នុងជំពូក៣នេះច្រើននិយាយសំដៅទៅលើការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ ។ ដូច្នេះ ពួកអ្នកប្រឆាំងទាំងនោះ អាចជាពួកខុសឆ្គងដែលមិនព្រមទទួលស្គាល់ថាមានការជំនុំជម្រះដែលនឹងត្រូវមក ហើយអ្វីៗនឹងបើកសំដែងទាំងអស់ ។ *សេចក្តីប៉ងប្រាថ្នា* "មើលការពន្យល់ ២:១០"។

**៣:៤** *ព្រះអង្គ* សំដៅលើព្រះយេស៊ូវគ្រីស្ទ ។ *តាំងពីពួកឰយុកោដេកលក់ទៅ* ឃ្លានេះអាចសំដៅលើគ្រីស្ទបរិស័ទដំបូងបង្អស់ (លោកស្ទេផាន លោកយ៉ាកុប បងប្អូនរបស់លោកយ៉ូហាន និងពួកអ្នកដឹកនាំពួកជំនុំព្រះអម្ចាស់ដំបូងដែលបានស្លាប់អស់ហើយ) (សូមប្រៀបធៀប ហព ១៣:៧ និងការពន្យល់) ឬអាចសំដៅលើពួកឰយុកោនៅក្នុងសម័យកាលសញ្ញាចាស់ ។ *នោះគ្រប់ទាំងអស់នៅតែដដែល* ត្រង់ចំណុចនេះ មានមតិប្រឆាំងមួយយល់ថា ការយាងមករបស់ព្រះគ្រីស្ទមិនមែនជាការពិតទេ ពីព្រោះគេយល់ថាទ្រង់មិនបានបង្ហាញអង្គទ្រង់ឱ្យពួកគេឃើញ ។

**៣:៥** *ពីព្រោះពួកគេចង់បំភ្លេច* ការបដិសេធន៍នូវអន្តរាគមន៍មកពីព្រះអម្ចាស់ ដូចជាទឹកជំនន់ជាដើមមិនមែនដោយព្រោះពួកគេភ្លេចទេ ប៉ុន្តែ គឺពួកគេមានចេតនាធ្វើជាភ្លេចតែម្តង ។ ពួកគេមិនព្រមប្រឈមមុខនឹងកំហុសរបស់ពួកគេទេ ។ *ក៏មានដីដុះចេញពីទឹក* "សូមមើល លប ១:៦–១០"។ *ព្រះបន្ទូលនៃព្រះ* គឺបញ្ញត្តិនៃព្រះ ឬជាការបង្គាប់បញ្ជារបស់ទ្រង់ដូចដែលទ្រង់មានបន្ទូលថា "ចូរឱ្យមាន ពន្លឺឡើង" (លប ១:៣)។

**៣:៦** *រួចមកលោកយត្រូវទឹកនោះជន់លិចបំផ្លាញទៅ* លោកពេត្រុសចង្អុល

៧តែផ្ទៃមេឃ នឹងផែនដីនៅជាន់នេះ បានបំរុងទុកដល់ថ្ងៃ
ជំនុំជំរះ[អ]ដោយសារព្រះបន្ទូលនៃទ្រង់ សំរាប់ឱ្យភ្លើងឆេះ
វិញ[ក] ហើយបំផ្លាញមនុស្សទមិលល្មើសចេញ ៨តែពួក
ស្ងួនភ្ងាអើយ កុំឱ្យភ្លេចសេចក្តី១នេះឡើយ គឺថា នៅចំពោះ
ព្រះអម្ចាស់ ១ ថ្ងៃទុកដូចជា ១ ពាន់ថ្ងៃ ហើយ១ ពាន់ឆ្នាំក៏
ទុកដូចជា ១ ថ្ងៃដែរ[ខ] ៩ព្រះអម្ចាស់មិនផ្អាកសេចក្តីសន្យា
របស់ទ្រង់[គ] ដូចជាមានអ្នកខ្លះគិតស្មាននោះទេ គឺទ្រង់
មានព្រះហឫទ័យអត់ធ្មត់[ឃ]នឹងយើងរាល់គ្នាវិញ ដោយមិន
ចង់ឱ្យអ្នកណាមួយវិនាសឡើយ គឺចង់ឱ្យមនុស្សទាំងអស់
បានប្រែចិត្តវិញ[ង] ១០រីឯថ្ងៃនៃព្រះអម្ចាស់ នោះនឹង
មកដូចជាចោរប្លន់[ច] នៅថ្ងៃនោះផ្ទៃមេឃនឹងបាត់ទៅ
ដោយសូរគ្រាំគ្រេង[ឆ] ឯធាតុសព្វសារពើនឹងរលាយទៅ
ដោយកំដៅដ៏ក្រៃលែង[ជ] ហើយផែនដីនឹងការសព្វសារពើ
នឹងត្រូវឆេះអស់រលីងទៅ[ឈ]។

**៣:៦** ឡ លប ៧:២១,២២
**៣:៧** អ មថ ១០:១៥ ក ខ.១០,១២ ២ថន ១:៧
**៣:៨** ខ ទដ ៩០:៤
**៣:៩** គ ហព ២:៣ ហព ១០:៣៧ ឃ រម ២:៤ ង ១ធម ២:៤ វវ ២:២១
**៣:១០** ច លក ១២:៣៩ ឆ អស ៣៤:៤ ជ ខ.៧,១២ ២ថន ១:៧ ឈ មថ ២៤:៣៥ ហព ១២:២៧ វវ ២១:១

១១ចុះដែលរបស់ទាំងនោះនឹងត្រូវរលាយទៅ នោះតើ
គួរឱ្យអ្នករាល់គ្នាប្រព្រឹត្តបែបយ៉ាងណាវិញ ក្នុងកិរិយា
បរិសុទ្ធ នឹងសេចក្តីគោរពប្រតិបត្តិ ១២ទាំងទន្ទឹងចាំ[ញ]
ហើយខំជួយឱ្យថ្ងៃនៃព្រះឆាប់មកដល់ផង[ដ] ដែលនៅថ្ងៃ
នោះផ្ទៃមេឃនឹងឆេះរលាយអស់ ហើយធាតុសព្វសារពើ
នឹងរលាយទៅ ដោយកំដៅដ៏ក្រៃលែងដូច្នេះ[ឋ] ១៣តែ
តាមសេចក្តីសន្យារបស់ទ្រង់ នោះយើងរាល់គ្នាទន្ទឹងចាំផ្ទៃ
មេឃថ្មី នឹងផែនដីថ្មី[ឌ] ដែលមានសុទ្ធតែសេចក្តីសុចរិតវិញ
១៤ដូច្នេះ ឱពួកស្ងួនភ្ងាអើយ ដែលទន្ទឹងចាំសេចក្តីទាំងនោះ
ចូរមានចិត្តឧស្សាហ៍ ឱ្យទ្រង់បានឃើញអ្នករាល់គ្នា ជា
ឥតសៅហ្មង ហើយឥតកន្លែងបន្ទោសបាន[ឍ] ទាំងមាន
សេចក្តីមេត្រីផង ១៥ហើយត្រូវរាប់សេចក្តីអត់ធ្មត់របស់

**៣:១២** ញ ១កថ ១:៧ ដ ទដ ៥០:៣ ឋ ខ.១០ **៣:១៣** ឌ អស ៦៥:១៧ ៦៦:២២ វវ ២១:១ **៣:១៤** ឍ ១ថន ៣:១៣

បង្ហាញនូវកំហុសនៃពួកអ្នកប្រឆាំង ។ មានន័យថា អន្តរាគមន៍របស់ព្រះអម្ចាស់គឺមានតាំងពីពេល ដែលទ្រង់បានបង្កើតពិភពលោកនេះម្ល៉េះ ដូចជាមានទឹកជំនន់ជាដើម (មើលការពន្យល់ លប ៦:១៧)។

**៣:៧** *ដោយសារព្រះបន្ទូលនៃទ្រង់* ព្រះបន្ទូលបានបង្កើតពិភពលោកនេះ (ខ.៥) និងបានបង្កើតឱ្យមានទឹកជំនន់ឱ្យជន់លិចផែនដី និងបំផ្លាញពួកមនុស្សអាក្រក់នាសម័យលោកណូអេ ។ ព្រះបន្ទូលដដែលនេះនឹងនាំមកនូវការបំផ្លាញពិភពលោកនេះ និងពួកមនុស្សអាក្រក់ដោយភ្លើង ។

**៣:៨** *១ថ្ងៃទុកដូចជា១ពាន់ឆ្នាំ* "សូមមើល ទដ ៩០:៤–៥ និងការពន្យល់"។ ការដែលព្រះអម្ចាស់គិតអំពីពេលវេលា គឺខុសអំពីរបៀបមនុស្សគិត ។ ព្រះអម្ចាស់គ្រប់គ្រងពេលវេលា ។ មានន័យថា ពេលវេលាគឺនៅក្នុងទ្រង់ ។

**៣:៩** ក្នុងបទគម្ពីរនេះ ហាក់ដូចជាព្រះអម្ចាស់ពន្យាពេល នៃសេចក្តីវិនាសរបស់ពិភពលោក ប៉ុន្តែ គឺទ្រង់មានព្រះហឫទ័យអត់ធ្មត់ជាប្រយោជន៍ឱ្យមនុស្សទាំងអស់បានប្រែចិត្តវិញ ។ ដូច្នេះហើយបានជាពួកខុសឆ្គងបានយល់ថា គ្រប់ការទាំងអស់ លែងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះអម្ចាស់ទៀតហើយ ។ ម្យ៉ាងទៀត ពួកគ្រូខុសឆ្គងទាំងនោះ មិនបានទទួលស្គាល់អំពីការពន្យាពេលនៃសេចក្តីវិនាសដែលត្រូវមកដល់នោះទេ ។ *បានប្រែចិត្ត* "មថ ៤:១៧ មក ១:៤ និងការពន្យល់"។

**៣:១០** *ថ្ងៃនៃព្រះអម្ចាស់* "មើលការពន្យល់ អស ២:១១,១៧,២០ យអ ១:១៥ អម ៥:១៨ ១ថន ៥:២"។ *មកដូចជាចោរប្លន់* គឺមកក្នុងមួយពព្រិចភ្នែក និងគ្មានអ្នកណាអាចគិតដល់ឡើយ ។ *នៅថ្ងៃនោះផ្ទៃមេឃនឹងបាត់ទៅដោយសូរគ្រាំគ្រេង* "សូមមើល ខ.១២"។ *ធាតុសព្វសារពើ* អាចសំដៅលើធាតុផ្សេងៗនៅក្នុងពិភព លោកនេះ ។ *កំដៅ* "សូមមើល ខ.៧,១២"។ *ផែនដី . . . ត្រូវឆេះអស់រលីងទៅ* អាចសំដៅលើការរលាយបាត់នៃផែនដី និងការសព្វសារពើនៅថ្ងៃចុងបំផុត ។

**៣:១១** *របស់ទាំងនោះនឹងត្រូវរលាយទៅ* គ្រប់សារពើទាំងអស់នៅ លើពិភពលោកនេះនឹងត្រូវផ្លាស់ប្តូរ ។ ជាលទ្ធផលគឺជីវិតនឹងទៅជាបរិសុទ្ធ (ញែកចេញជាបរិសុទ្ធ) និងពេញដោយការល្អ (សម្រាប់ថ្វាយបង្គំ និងបម្រើដល់ព្រះអម្ចាស់) (សូមប្រៀបធៀប ១:១៣–១៦ មថ ២៥:១៣ ១ថន ៥:៦,៨,១១)។

**៣:១២** *ថ្ងៃនៃព្រះ* "សូមមើល ខ.១០ វវ ១៦:១៤ និងការពន្យល់"។ *ថ្ងៃនៃព្រះបានជិតមកដល់ផង* ត្រង់ចំណុចនេះបញ្ជាក់ថា ថ្ងៃនៃព្រះអម្ចាស់នឹងឆាប់មកដល់ក្នុងពេលដែលបំណងព្រះហឫទ័យទ្រង់បានសម្រេច ។ ព្រះអម្ចាស់រង់ចាំឱ្យមនុស្សទាំងអស់បានប្រែចិត្ត (ខ.៩) និងឱ្យអ្នកជឿដល់ព្រះនាមទ្រង់បាននាំសេចក្តីសង្គ្រោះទៅដល់អ្នកដទៃទៀតកាន់តែឆាប់ នោះថ្ងៃនៃព្រះអម្ចាស់ក៏មកកាន់តែឆាប់ដែរ (ប្រៀបធៀប កច ៣:១៩–២០)។ សេចក្តីអធិស្ឋាន និងជីវិតបរិសុទ្ធក៏ធ្វើឱ្យថ្ងៃនៃព្រះអម្ចាស់បានឆាប់មកដល់ដែរ (ខ.១១ មថ ១៦:២០)។ *ផ្ទៃមេឃនឹងឆេះរលាយ អស់* "សូមមើល ខ.១០"។ *ធាតុសព្វសារពើនឹងរលាយទៅ ដោយកំដៅដ៏ក្រៃលែង* "សូមមើល ខ.១០ អស ៣៤:៤ និងការពន្យល់"។

**៣:១៣** *សេចក្តីទាំងនោះ* សំដៅលើសេចក្តីសន្យាអំពីការប្រទាននូវស្ថានសួគ៌ និងផែនដីថ្មីតាមរយៈលោកហោរាអេសាយ (អស ៦៥:១៧ ៦៦:២២)។ សេចក្តីសន្យា នោះបានបញ្ជាក់បន្ថែមនៅក្នុងបទគម្ពីរ"វវ ២១:១"។ *ដែលមានសុទ្ធតែសេចក្តីសុចរិត* បញ្ជាក់ថា ពួកមនុស្សសុចរិតនឹងរស់នៅក្នុងស្ថានសួគ៌ និងផែនដីថ្មីអស់កល្បជានិច្ច (អស ១១:៤–៥ ៤៥:៨ ដយ ៩:២៤ និងការពន្យល់"។

**៣:១៤,១៨** *សេចក្តីមេត្រី . . . ព្រះគុណ* "មើលការពន្យល់ រម ១:៧"។

**៣:១៤** *ឥតសៅហ្មង ហើយឥតកន្លែងន្ទោសបាន* (សូមប្រៀបធៀប ១ពត ១:១៩)។ *សេចក្តីមេត្រី* ដោយសារសេចក្តីជំនឿ អ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទបានជាមេត្រីនឹងទ្រង់ (ប្រៀបធៀប ១កថ ៣:១០–១៥ ២កថ ៥:១០ និងការពន្យល់)។

**៣:១៥** *សេចក្តីអត់ធ្មត់របស់ព្រះអម្ចាស់នៃយើង* "មើលការពន្យល់ ខ.៩"។ *ប៉ុល ជាបងប្អូនស្ងួនភ្ងារបស់យើងខ្ញុំ* លោកពេត្រុសសំដែងនូវភាពកក់ក្តៅ

ព្រះអម្ចាស់នៃយើង[ណ] ទុកជាសេចក្ដីសង្គ្រោះ[ត] ដូចជាប៉ុល
ជាបងប្អូនស្ងួនភ្ងារបស់យើងខ្ញុំ បានសរសេរមកអ្នករាល់គ្នា
តាមប្រាជ្ញាដែលព្រះបានប្រទានមកលោកដែរ[ថ] ១៦ដូចជា
ក្នុងគ្រប់ទាំងសំបុត្ររបស់លោក ដែលសុទ្ធតែសំដែងពី
សេចក្ដីទាំងនេះ នោះមានសេចក្ដីខ្លះដែលពិបាកយល់
ហើយពួកអ្នកខ្លៅល្ងង់ នឹងពួកមិនខ្ជាប់ខ្ជួន[ទ] គេបង្វែរន័យ
សេចក្ដីទាំងនោះ[ធ] ដូចជាគេបង្វែរបទគម្ពីរឯទៀតដែរ[ន]
ឱ្យខ្លួនគេត្រូវវិនាស ។
១៧ដូច្នេះ ពួកស្ងួនភ្ងាអើយ ចូរប្រយ័ត្ន[ប] ដោយព្រោះអ្នក
រាល់គ្នាដឹងសេចក្ដីនោះជាមុនហើយ ក្រែងលោធ្លាក់ពី
សេចក្ដីខ្ជាប់ខ្ជួនរបស់អ្នករាល់គ្នាចេញ[ផ] ដែលបណ្ដោយតាម
សេចក្ដីវង្វេង[ព]របស់ពួកទទឹងច្បាប់[ភ]នោះ ១៨ចូរឱ្យអ្នករាល់
គ្នាចំរើនឡើងក្នុងព្រះគុណ[ម] ហើយក្នុងការស្គាល់[យ]ដល់
ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់[រ] ហើយក្នុងការស្គាល់ដល់
ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ ជាព្រះអង្គសង្គ្រោះនៃយើង
រាល់គ្នា សូមឱ្យទ្រង់បានសិរីល្អនៅជាន់ឥឡូវនេះ ដរាប
ដល់អស់កល្បជានិច្ច ។ អាម៉ែន[ល]។

**៣:១៥** ណ រម ២:៤ ត ខ.៩ ថ អភ ៣:៣ **៣:១៦** ទ យក ១:៨ ២ពត ២:១៤ ធ ទដ ៥៦:៥ យរ ២៣:៣៦ ន ខ.២ **៣:១៧** ប ១កថ ១០:១២ ផ វវ ២:៥ ព ២ពត ២:១៨ ភ ២ពត ២:៧

**៣:១៨** ម រម ៣:២៤ យ ២ពត ១:២ រ ២ពត ១:១១ ២:២០ ល រម ១១:៣៦

ដែលលោក ប៉ុលមាន ។ ភាពត្រូវគ្នារវាងការបង្រៀនរបស់លោកពេត្រុស និងការបង្រៀនរបស់លោកប៉ុល ដែលមានបញ្ជាក់នៅសំបុត្ររបស់លោកប៉ុល និងក្នុងកណ្ឌគម្ពីរកិច្ចការបានបញ្ជាក់យ៉ាងច្បាស់នៅត្រង់ចំណុចនេះ ដោយលោកពេត្រុស (មើលពន្យល់ ១ពត ១:១ និងសេចក្ដីផ្ដើមគម្ពីររ៉ូម)។

**៣:១៦** *ដូចជានៅក្នុងគ្រប់ទាំងសំបុត្ររបស់លោក* ត្រង់ចំណុចនេះលោកពេត្រុស ប្រហែលជាសំដៅលើសេចក្ដីដែលលើកឡើងនៅក្នុង "ខ.១១–១៤" ដែលនិយាយ ស្របគ្នាទៅនឹងអត្ថបទជាច្រើនរបស់លោកប៉ុល ។ *អ្នកខ្លៅល្ងង់ នឹងពួកមិនខ្ជាប់ខ្ជួន* ពួកខ្លៅល្ងង់ គឺអាចសំដៅលើពួកអ្នក ដែលមិនបានទទួលការបង្រៀនមកពីពួកសាវ័ក ដូច្នោះហើយបានជាពួកគេជាច្រើនបានបែរចេញពីសេចក្ដីជំនឿ (ប្រៀបធៀប ២:១៤ និងការពន្យល់)។ *បទគម្ពីរឯទៀតដែរ* លោកពេត្រុសបង្ហាញនូវ ការគាំទ្រ ចំពោះសេចក្ដីដែលលោកប៉ុលបានសរសេរ ដូចជាបទគម្ពីរដែលព្រះអម្ចាស់បានប្រទានមកនៅក្នុងសញ្ញាចាស់ដែរ (មើលការពន្យល់ ១:២១ ២ធថ ៣:១៦)។

**៣:១៧** *ដឹងសេចក្ដីនោះជាមុនហើយ* មានន័យថា ពួកគេដឹងថា មានពួកគ្រូខុសឆ្គងជាច្រើនបានមកឯពួកគេ (ប្រៀបធៀបនឹងជំពូក ២)។

**៣:១៨** *ចំរើនឡើង . . . ក្នុងការស្គាល់ដល់ព្រះយេស៊ូវ* លោកពេត្រុសបានសង្ខេបសេចក្ដីដែលគាត់បាននិយាយ ដោយសង្កត់ធ្ងន់ទៅលើចំណេះដឹងនៃការស្គាល់ព្រះអម្ចាស់ (មើលការពន្យល់ ១:២–៣,៥) និងដើម្បីឆ្លើយតបចំពោះពួកគ្រូបង្រៀនខុសឆ្គងដែលតែងតែអួតអាងអំពីចំណេះ ដែលខ្លួនគិតថា មានតែពួកគេទេទើបមាន ។

# សំបុត្រទី ១ របស់
# យ៉ូហាន

សេចក្ដីផ្ដើម

**អ្នកនិពន្ធ**

អ្នកនិពន្ធគឺលោកយ៉ូហាន ដែលត្រូវជាកូនលោកសេបេដេ (មើល មថ ១:១៩-២០) ជាសាវក និងជាអ្នកនិពន្ធនៃព្រះគម្ពីរដំណឹងល្អយ៉ូហាន និងព្រះគម្ពីរវិវរណៈ (មើលសេចក្ដីផ្ដើមនៃព្រះគម្ពីរទាំងពីរ ត្រង់អ្នកនិពន្ធ) ។ គាត់គឺជាអ្នកនេសាទម្នាក់ក្នុងចំណោមអ្នកនេសាទទាំងឡាយ (លោកយ៉ាកុប និលោកពេត្រុស) ដែលព្រះយេស៊ូវទ្រង់បានត្រាស់ហៅធ្វើជាសាវក ហើយគាត់ជា "សិស្សម្នាក់ដែលព្រះយេស៊ូវស្រឡាញ់" (យហ ១៣:២៣ និងការពន្យល់) ។ គាត់ប្រហែលត្រូវជាបងប្អូនជីដូនមួយរបស់ព្រះយេស៊ូវ (ម្ដាយរបស់គាត់ប្រហែលជានាងសាឡូមេ ដែលអាចជាបងប្អូនស្រីរបស់នាងម៉ារា សូមធៀបនឹង មថ ២៧:៥៦ មក ១៥:៤០ និងការពន្យល់ ១៦:១ យហ ១៩:២៥ ពាក្យ "ប្អូនស្រីមាតាព្រះយេស៊ូវ" នៅក្នុង យហ ១៩:២៥ គឺសំដៅទៅលើនាងសាឡូមេ ។

សំបុត្រយ៉ូហានខ្សែទីមួយនេះ មិនបាននិយាយថា អ្នកនិពន្ធជានរណាទេ គឺដូចសំបុត្រភាគច្រើននៃព្រះគម្ពីរសញ្ញាថ្មីដែរ ។ អ្នកដឹកនាំពួកជំនុំសម័យដើមដូចជា លោកអ៊ីរ៉ានាស (ប្រហែលឆ្នាំ ១៤០-២០៣ គ.ស.) លោកក្លេមិននៅក្រុងអ័ឡេក្សានឌ្រា (ប្រហែលឆ្នាំ ១៥០-២១៥ គ.ស.) លោកទ័រទូលាន (ប្រហែលឆ្នាំ ១៥៥-២២២) និងលោកអូរីហ្គែន (ប្រហែល ឆ្នាំ ១៨៥-២៥៣ គ.ស.) បានទទួលស្គាល់ថា លោកយ៉ូហានជាអ្នកនិពន្ធនៃសំបុត្រនេះ ហើយក៏មិនមានការទទួលស្គាល់អ្នកអ្នកនិពន្ធដទៃទៀតពីអ្នកដឹកនាំពួកជំនុំសម័យដើមដែរ ។

ការទទួលស្គាល់នេះគឺបានធ្វើឡើងដោយមានភស្តុតាងបញ្ជាក់នៅក្នុងសំបុត្រនេះដូចជា

១. គួរឱ្យកត់សំគាល់ថា ព្រះគម្ពីរដំណឹងល្អយ៉ូហានមានរចនាបថនៃការនិពន្ធដូចសំបុត្រនេះដែរ ។ ព្រះគម្ពីរទាំងពីរត្រូវបាននិពន្ធឡើងជាភាសាក្រេកបែបសាមញ្ញ និងប្រើពាក្យផ្ទុយគ្នាដូចជា ពន្លឺនិងសេចក្ដីងងឹត ជីវិតនិងសេចក្ដីស្លាប់ សេចក្ដីពិតនិងសេចក្ដីភូតភរ ហើយសេចក្ដីស្រឡាញ់ និងសេចក្ដីសម្អប់ ។

២. ព្រះគម្ពីរដំណឹងល្អយ៉ូហាន និងសំបុត្រនេះមានខយោងដែលគួរឱ្យកត់សំគាល់ដូចជា

| ១ យ៉ូហាន | ព្រះគម្ពីរដំណឹងល្អយ៉ូហាន |
|---|---|
| ១:១ | ១:១,១៤ |
| ១:៤ | ១៦:២៤ |
| ១:៦-៧ | ៣:១៩-២១ |
| ២:៧ | ១៣:៣៤-៣៥ |
| ៣:៨ | ៨:៤៤ |
| ៣:១៤ | ៥:២៤ |
| ៤:៦ | ៨:៤៧ |
| ៤:៩ | ១:១៤,១៨ ៣:១៦ |
| ៥:៩ | ៥:៣២,៣៧ |
| ៥:១២ | ៣:៣៦ |

៣. មានការបញ្ជាក់នៃស្មរបន្ទាល់ (១:១-៤) ជាមួយនឹងការពិតថា លោកយ៉ូហានគឺជាអ្នកដើរតាមព្រះគ្រីស្ទតាំងពីពេលដែលទ្រង់ទើបតែចាប់ផ្ដើមព្រះរាជកិច្ចទ្រង់ ។

៤. សំបុត្រនេះមានលក្ខណៈនៃការនិពន្ធរបស់ពួកសាវក (លក្ខណៈបង្គាប់នៅក្នុង ២:១៥,២៤,២៨ ៤:១ ៥:២១ ការនិយាយសង្កត់ធ្ងន់ ២:៦ ៣:១៤ ៤:១២ និងការនិយាយពីការកុហកនិងបញ្ឆោត ១:៦,៨ ២:៤,២២) ។

៥. លក្ខណៈនៃការប្រើពាក្យបង្ហាញពីវ័យចំណាស់ (ការហៅអ្នកអានរបស់គាត់ថា "កូនតូចៗរាល់គ្នា" ២:១,២៨ ៣:៧) ដែលជាប្រពៃណីរបស់ពួកជំនុំដំបូង ។

៦. ការនិយាយប្រឆាំងនឹងពួកទទឹងព្រះគ្រីស្ទ (២:១៨) អ្នកកុហក (២:២២) និងពួកកូនអារក្ស (៣:១០) ដែលត្រូវនឹងការដែល

ព្រះយេស៊ូវទ្រង់ហៅលោកយ៉ូហានថា "កូនផ្គរលាន់" (មក ៣:១៧) ។

៧. ការបង្ហាញពីទំនាក់ទំនងជិតស្និទ្ធជាមួយនឹងព្រះអម្ចាស់ (១:១ ២:៥-៦,២៤,២៧-២៨) ដែលសក្តិសមនឹងពាក្យថា "សិស្សដែលព្រះយេស៊ូវស្រឡាញ់" និងពាក្យថា គាត់អង្គុយនៅគុ "ផ្អែកលើព្រះឱរាទ្រង់" (យហ ១៣:២៣) ។

**កាលបរិច្ឆេទ**

មានការលំបាកនៅក្នុងការកំណត់កាលបរិច្ឆេទនៃសំបុត្រនេះឱ្យបានជាក់លាក់ ប៉ុន្តែមានការកំណត់យកចុងសតវតស្សរ៍ទីមួយជាកាលបរិច្ឆេទ ដោយកត្តាជាច្រើនដូចជា (១).ភស្តុតាងពីអ្នកនិពន្ធគ្រីស្ទបរិស័ទសម័យដើម (លោកអ៊ីរ៉ានាស និងលោកក្លេមិននៅក្រុងអ័លេក្សានឌ្រា) (២).ការនិយាយឆ្លុះបញ្ចាំងនៅក្នុងសំបុត្រអំពីពួកគ្រូបង្រៀនខុសឆ្គងអំពីព្រលឹងវិញ្ញាណ និង (៣).ការនិយាយដែលឆ្លុះបញ្ចាំងពីវ័យចំណាស់របស់លោកយ៉ូហាន ។ ដោយសារសំបុត្រយ៉ូហានខ្សែទីមួយនេះមាននិយាយអំពីព្រះគម្ពីរដំណឹងល្អទីបួន (១យហ ២:៧-១១) ការកំណត់យកកាលបរិច្ឆេទនៅចន្លោះឆ្នាំ៨៥ ដល់៩៥គ.ស. ដែលនៅក្រោយកាលបរិច្ឆេទនៃការនិពន្ធដំណឹងល្អទីបួន (ប្រហែលនៅឆ្នាំ ៨៥ គ.ស.) គឺជាការសមហេតុផល (មើល សេចក្តីផ្តើមព្រះគម្ពីរដំណឹងល្អយ៉ូហានត្រង់កាលបរិច្ឆេទ) ។

**អ្នកទទួល**

តាម ១យហ ២:១២-១៤,១៩ ៣:១ ៥:១៣ លោកយ៉ូហានបានសរសេរសំបុត្រនេះផ្ញើដល់អ្នកជឿ ។ ប៉ុន្តែសំបុត្រនេះមិនបានបង្ហាញថាអ្នកអានជានរណា និងនៅកន្លែងណាទេ ។ ការដែលសំបុត្រនេះមិនបាននិយាយអំពីឈ្មោះអ្នកទទួលក៏បានបង្ហាញផងដែរថា សំបុត្រនេះគឺជាសំបុត្រសម្រាប់ផ្ញើដល់ពួកជំនុំនៅកន្លែងផ្សេងៗមួយចំនួន ។ អ្នកនិពន្ធគ្រីស្ទបរិស័ទសម័យដើមបានធ្វើបន្ទាល់ថា សំបុត្រនេះត្រូវបានសរសេរផ្ញើទៅទីក្រុងអេភេសូរ ក្នុងរយៈពេលចុងក្រោយនៃការរស់នៅរបស់គាត់នៅផែនដីនេះ (ប្រហែលឆ្នាំ ៧០-១០០ គ.ស.) ។ មានការអះអាងដំបូងបំផុតមួយថា សំបុត្រនេះត្រូវបានសរសេរផ្ញើទៅស្រុកអាស៊ីដែលជាចំណុះនៃចក្រភពរ៉ូម៉ាំង (ប្រទេសទួរគីសព្វថ្ងៃ) និងជាទីតាំងនៃទីក្រុងអេភេសូរ ។ លោកក្លេមិននៃក្រុងអ័ឡេក្សានឌ្រាក៏បានបង្ហាញផងដែរថា លោកយ៉ូហានបានធ្វើការបម្រើព្រះជាមួយនឹងព្រះវិហារផ្សេងៗជាច្រើនដែលត្រូវខ្ចាត់ខ្ចាយនៅទូទាំងស្រុកអាស៊ី ។ ដូចនេះគេអាចសន្និដ្ឋានបានថា សំបុត្រយ៉ូហានខ្សែទីមួយនេះត្រូវបានសរសេរផ្ញើទៅកាន់ពួកជំនុំនៅស្រុកអាស៊ី ។

**ពួកគ្រូបង្រៀនខុសឆ្គង**

មានពួកគ្រូបង្រៀនខុសឆ្គងជាច្រើន ដែលសេចក្តីបង្រៀនរបស់ពួកគេបាននាំឱ្យមានគ្រោះថ្នាក់បំផុតដល់ពួកជំនុំនៅសតវត្សត៍ទី១ និងទី២ ។ ពួកគេបានបង្រៀនថា វិញ្ញាណសុទ្ធតែល្អ ហើយរូបធាតុសុទ្ធតែអាក្រក់ ។ សេចក្តីបង្រៀនរបស់ពួកគេមិនបានយកព្រះគម្ពីរជាគោលទេ ហើយបង្រួមមកមានចំនុចខុសឆ្គង ៥ យ៉ាងគឺ

១. ខ្លួនរបស់មនុស្សជារូបធាតុដូចនេះខ្លួនមនុស្សអាក្រក់ ផ្ទុយពីព្រះដែលជាវិញ្ញាណ ហើយទ្រង់ល្អ ។

២. សេចក្តីសង្គ្រោះគឺជាការគេចចេញពីរូបកាយ ហើយមិនអាចទទួលបានដោយជំនឿលើព្រះគ្រីស្ទទេ ប៉ុន្តែអាចទទួលបានដោយការមានចំណេះពិសេស (ពាក្យចំណេះជាភាសាក្រេកគឺ "ក្នូស៊ីស") ។

៣. ពួកគេបានបដិសេធភាពជាមនុស្សនៃព្រះគ្រីស្ទដោយវិធីពីរយ៉ាង (១).អ្នកខ្លះនិយាយថា ព្រះគ្រីស្ទទ្រង់គ្រាន់តែហាក់ដូចជាមានរូបកាយប៉ុណ្ណោះ (២).អ្នកខ្លះទៀតនិយាយថា ព្រះគ្រីស្ទដែលជាព្រះបានយាងមកសណ្ឋិតព្រះយេស៊ូវដែលជាមនុស្សលោកនៅពេលទ្រង់ទទួលបុណ្យជ្រមុជទឹក ហើយបានយាងចេញពីទ្រង់មុនពេលទ្រង់សុគត ហើយអ្នកដឹកនាំការបង្រៀននេះឈ្មោះ សេរីនធូស ។ សូមមើល ១យហ ១:១ ២:២២ ៤:២-៣ និងការពន្យល់ ។

៤. រូបកាយត្រូវចាត់ទុកថាអាក្រក់ ដូចនេះត្រូវប្រព្រឹត្តអំពើឃោរឃៅមកលើរូបកាយ ។ សូមមើលនៅក្នុងសំបុត្រកូឡុសផងដែរ (កល ២:២១, ២៣ និងការពន្យល់) ។

៥. ការបង្រៀនខុសឆ្គងនេះក៏បានបណ្តាលឱ្យមានអំពើអសីលធម៌ជាច្រើនផងដែរ ។

ចំពោះបញ្ហាពួកគ្រូបង្រៀនខុសឆ្គងផ្សេងទៀត សូមមើលនៅក្នុងព្រះគម្ពីរ កូឡុស ១,២ធីម៉ូថេ ទីតុស ២ពេត្រុស និង១កូរិនថូស ។

**ឱកាស និងគោលបំណង**

អ្នកអានសំបុត្ររបស់លោកយ៉ូហានបានជួបប្រទះនឹងគ្រោះថ្នាក់ដែលបង្ករឡើងដោយពួកគ្រូបង្រៀនខុសឆ្គង ដែលនាំឱ្យមានការប្រព្រឹត្តខុសនឹងបំណងព្រះហឫទ័យព្រះ ។

លោកយ៉ូហានបានសរសេរសំបុត្រនេះដោយគោលបំណងជាបឋមពីរយ៉ាង (១).ដើម្បីប្រាប់ឱ្យពួកជំនុំដឹងអំពីពួកគ្រូបង្រៀនខុសឆ្គង

(២:២៦ និងការពន្យល់) និង (២).ដើម្បីឱ្យអ្នកជឿមានការដឹងច្បាស់អំពីសេចក្តីសង្គ្រោះ (៥:១៣ និងការពន្យល់) ។ លោកយ៉ូហានបានបង្ហាញពីមុខមាត់ពិតរបស់របស់ពួកគ្រូខុសឆ្គងទាំងនោះ ដោយនិយាយអំពីការប្រព្រឹត្តអំពើបាប (៣:៨–១០) និងដោយធ្វើបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទដែលបានយាងមកយកកំណើតជាមនុស្ស (១:៣) ។ សំបុត្រនេះបានផ្តល់ឱ្យអ្នកទទួលនូវសេចក្តីអំណរ (១:៤) ។

**គម្រោងសង្ខេប**

**I. សេចក្តីផ្តើម: សេចក្តីពិតនៃការយាងមកយកកំណើតនៃព្រះគ្រីស្ទ (១:១–៤)**

**II. ការរបស់នៅរបស់គ្រីស្ទបរិស័ទដោយមានការប្រកបជាមួយនឹងព្រះវរបិតា និងព្រះរាជបុត្រា (១:៥–២:២៨)**

ក. សេចក្តីប្រកបដ៏ត្រឹមត្រូវ (១:៥–២:១១)

១. ការដើរក្នុងពន្លឺ (១:៥–៧)

២. ការលន់តួបាប (១:៨–២:២)

៣. ការស្តាប់បង្គាប់ (២:៣–៦)

៤. សេចក្តីស្រឡាញ់នៃអ្នកជឿ (២:៧–១១)

ខ. ការឈ្នះមេកំណាច និងលោកីយ (២:១២–១៧)

គ. អាទទឹងនឹងព្រះគ្រីស្ទដែលត្រូវលេចមក (២:១៨–២៨)

១. អ្នកដែលចេញពីគ្រីស្ទបរិស័ទ និងគ្រីស្ទបរិស័ទ (២:១៨–២១)

២. ភាពជាមនុស្សនៃព្រះគ្រីស្ទជារឿងពិត (២:២២–២៣)

៣. ជំនឿខ្ជាប់ខ្ជួន: គន្លឹះនៃការបន្តការប្រកប (២:២៤–២៨)

**III. ការរស់នៅរបស់គ្រីស្ទបរិស័ទដូចជាកូនព្រះ (២:២៩–៤:៦)**

ក. លក្ខណៈនៃកូនព្រះ (២:២៩–៣:២៤)

១. សេចក្តីសុចរិត (២:២៩–៣:១០ក)

២. សេចក្តីស្រឡាញ់ (៣:១០កខ–២៤)

ខ. អ្នកមកពីព្រះ (៤:១–៦)

**IV. ការរស់នៅរបស់គ្រីស្ទបរិស័ទដោយស្រឡាញ់គ្នាទៅវិញទៅមក (៤:៧–៥:១២)**

ក. លក្ខណៈនៃសេចក្តីស្រឡាញ់ (៤:៧–៥:៥)

១. ប្រភពនៃសេចក្តីស្រឡាញ់ (៤:៧–១៦)

២. ផលផ្លែនៃសេចក្តីស្រឡាញ់ (៤:១៧–១៩)

៣. ការស្រឡាញ់ដល់ព្រះ និងស្រឡាញ់ដល់បងប្អូន (៤:២០–៥:១)

៤. ការស្តាប់បង្គាប់: ភស្តុតាងនៃសេចក្តីស្រឡាញ់ដល់កូនព្រះ (៥:២–៥)

ខ. សាក្សីរបស់ព្រះគ្រីស្ទ (៥:៦–១២)

**V. សេចក្តីបញ្ចប់: ការដឹងជាក់ច្បាស់របស់គ្រីស្ទបរិស័ទ (៥:១៣–២១)**

## ព្រះបន្ទូលនៃជីវិត

**១** ១ឯសេចក្ដីដែលមានតាំងពីដើមមក[ក] ដែលយើងខ្ញុំបានឮ
ហើយភ្នែកបានឃើញ[ខ] ក៏បានមើល ហើយដៃបានប៉ះពាល់[គ]
ខាងឯព្រះបន្ទូលនៃជីវិត ២(ដ្បិតព្រះដ៏ជាជីវិត ទ្រង់បាន
លេចមកហើយ[ឃ] យើងខ្ញុំបានឃើញទ្រង់ ក៏ធ្វើជាទីបន្ទាល់[ង]
ប្រាប់ដល់អ្នករាល់គ្នាពីជីវិតនោះដ៏រស់នៅអស់កល្បជានិច្ច[ច]
ដែលពីដើមស្ថិតនៅនឹងព្រះវរបិតា ហើយបានលេចមកឱ្យ
យើងខ្ញុំឃើញ) ៣ដូច្នេះ សេចក្ដីដែលយើងខ្ញុំបានឃើញ
ហើយឮនោះ[ឆ] យើងខ្ញុំប្រាប់មកអ្នករាល់គ្នា ដើម្បីឱ្យអ្នក
រាល់គ្នាមានសេចក្ដីប្រកបនឹងយើងខ្ញុំដែរ រីឯសេចក្ដីប្រកប
របស់យើងខ្ញុំ នោះគឺប្រកបនឹងព្រះវរបិតា ហើយនិង
ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រាទ្រង់[ជ] ៤យើងខ្ញុំក៏សរសេរ
សេចក្ដីទាំងនេះ[ឈ] ផ្ញើមកអ្នករាល់គ្នា ដើម្បីឱ្យសេចក្ដីអំណរ
របស់អ្នករាល់គ្នាបានពោរពេញឡើង[ញ]។

## ការដើរក្នុងពន្លឺ

៥នេះជាដំណឹង ដែលយើងខ្ញុំបានឮពីទ្រង់[ដ] ហើយក៏
ប្រាប់មកអ្នករាល់គ្នា គឺថា ព្រះទ្រង់ជាពន្លឺភ្លឺ[ឋ] គ្មានសេចក្ដី
ងងឹតណា នៅក្នុងទ្រង់សោះ ៦បើសិនជាយើងរាល់គ្នាថា
យើងមានសេចក្ដីប្រកបនឹងទ្រង់ តែដើរក្នុងសេចក្ដីងងឹត
វិញ[ឌ] នោះឈ្មោះថាយើងកុហក ហើយមិនប្រព្រឹត្តតាម
សេចក្ដីពិតទេ[ឍ] ៧តែបើយើងរាល់គ្នាដើរក្នុងពន្លឺវិញ[ណ] ដូច
ជាទ្រង់ក៏គង់ក្នុងពន្លឺដែរ នោះយើងមានសេចក្ដីប្រកបនឹង
គ្នា ទៅវិញទៅមក ហើយព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ
ជាព្រះរាជបុត្រានៃទ្រង់ ក៏សំអាតយើងរាល់គ្នា ពីគ្រប់អំពើ
បាបទាំងអស់[ត] ៨បើសិនជាយើងថា យើងគ្មានបាបសោះ[ថ]
នោះឈ្មោះថាយើងបញ្ឆោតដល់ខ្លួន ហើយសេចក្ដីពិត
មិនស្ថិតនៅក្នុងយើងទេ[ទ] ៩បើយើងលន់តួបាបវិញ នោះ
ទ្រង់មានព្រះហឫទ័យ ស្មោះត្រង់ ហើយសុចរិត ប្រយោជន៍
នឹងអត់ទោសបាបឱ្យយើង[ធ] ហើយនឹងសំអាតយើង ពីគ្រប់
អំពើទុច្ចរិតទាំងអស់ផង[ន] ១០បើយើងថា យើងមិនដែល

**១:១** ក យហ ១:២ ខ លក ២៤:៤៨ យហ ១:១៤ ១៩:៣៥ កច ៤:២០ ២ពត ១:១៦ ១យហ ៤:១៤ គ យហ ២០:២៧ **១:២** ឃ យហ ១:១–៤ ១១:២៥ ១៤:៦ ១ធថ ៣:១៦ ១ពត ១:២០ ១យហ ៣:៥,៨ ង យហ ១៥:២៧ ច មថ ២៥:៤៦ **១:៣** ឆ ខ.១ ជ ១កថ ១:៩ **១:៤** ឈ ១យហ ២:១ ញ យហ ៣:២៩ **១:៥** ដ ១យហ ៣:១១ ឋ ១ធថ ៦:១៦ **១:៦** ឌ យហ ៣:១៩–២១ ៨:១២ ២កថ ៦:១៤ អភ ៥:៨ ១យហ ២:១១ ឍ យហ ៣:១៩–២១ ១យហ ២:៤ ៤:២០ **១:៧** ណ អស ២:៥ ត ហព ៩:១៤ វវ ១:៥ ៧:១៤ **១:៨** ថ សភ ២០:៩ យរ ២:៣៥ រម ៣:៩–១៩ យក ៣:២ ទ យហ ៨:៤៤ ១យហ ២:៤ **១:៩** ធ ទដ ៣២:៥ ៥១:២ សភ ២៨:១៣ ន ខ.៧ មីក ៧:១៨–២០ ហព ១០:២២ **១:១០** ប ខ.៨

**១:១–៤** សេចក្ដីផ្ដើមនៃសំបុត្រនេះ និងសេចក្ដីផ្ដើមនៃព្រះគម្ពីរដំណឹងល្អយ៉ូហាននិយាយផ្ដោតទៅលើប្រធានបទ និងប្រើពាក្យដូចៗគ្នា (១:១–៤) ដូចជា "កាលដើមដំបូង" "ព្រះបន្ទូល" "ជីវិត" និង "នឹង" (ឬ "ជាមួយ")។

**១:១** *យើងខ្ញុំ* ពាក្យនេះប្រើសំដៅទៅលើលោកយ៉ូហាន និងពួកសាវ័កដទៃទៀត ។ *បានឮ . . . ឃើញ . . . មើល . . . ពាល់* មានន័យថា ពួកសាវ័កបានសិក្សាពីព្រះបន្ទូលនៃជីវិតយ៉ាងប្រុងប្រយ័ត្ន ។ លោកយ៉ូហានបានធ្វើបន្ទាល់ថា ព្រះបន្ទូលដែល ទ្រង់មានតាំងពីអស់កល្បជានិច្ច "បានត្រឡប់ជាសាច់ឈាម" (យហ ១:៤ និងពន្យល់) មានន័យថា ទ្រង់បានយាងមកយកកំណើតជាមនុស្សដែលមានសាច់មានឈាម ។ ទ្រង់ពិតប្រាកដជាព្រះ និងមនុស្សមួយរយភាគរយ ។ ក្នុងដើមសំបុត្រនេះ លោកយ៉ូហានបាននិយាយផ្ទុយនឹងសេចក្ដីបង្រៀនខុសឆ្គងអំពីព្រលឹងវិញ្ញាណ (មើលសេចក្ដីផ្ដើមត្រង់ពួកគ្រូបង្រៀនខុសឆ្គង)។ *ព្រះបន្ទូលនៃជីវិត* ព្រះបន្ទូលនៃជីវិតទ្រង់ ាជីវិត ហើយបានបើកសំដែងជីវិតនោះ (ខ.២ និងការពន្យល់)។ ក្នុងខនេះ "ព្រះបន្ទូល" មានន័យថា ព្រះបន្ទូលនៃការបើកសំដែង (ការពន្យល់ យហ ១:១)។

**១:២** *ជីវិត . . . ជីវិតនោះដ៏រស់នៅអស់កល្បជានិច្ច* ព្រះគ្រីស្ទទ្រង់ជាជីវិត ព្រោះ ទ្រង់មានព្រះជន្មគង់នៅជានិច្ច ហើយនៅក្នុងទ្រង់មានជីវិត (យហ ១១:២៥ ១៤:៦ និងការពន្យល់)។ ទ្រង់ក៏ជាប្រភពនៃជីវិត ហើយមានអំណាចលើសេចក្ដីស្លាប់ (៥:១១)។ សំបុត្រនេះចាប់ផ្ដើម និងបញ្ចប់ទៅវិញដោយពាក្យ "ជីវិតអស់កល្បជានិច្ច"។

**១:៣** *សេចក្ដីប្រកបនឹងយើងខ្ញុំ* មានន័យថា មានចំណែកជាមួយនឹងយើងខ្ញុំនៅក្នុងការឮឃើញ និងពាល់ព្រះគ្រីស្ទដែលទ្រង់បានត្រឡប់ជាសាច់ឈាម (ខ.១)។ ការ ប្រកប (ជាភាសាក្រិកគឺ ខយណូនីអា "Koinonia") គឺជាការរួបរួម របស់អ្នកជឿ និងព្រះគ្រីស្ទ ។ ការប្រកបនេះត្រូវបានប្រៀបធៀបនឹងដើមទំពាំងបាយជូរជាមួយនឹងខ្នែង (យហ ១៥:១–៥) និងរូបកាយជាមួយនឹងក្បាល (១កថ ១២:១២ កល ១:១៨)។ ហើយការប្រកបនេះក៏ជាការប្រកបរវាងព្រះវរបិតានិងអ្នកជឿផងដែរ (មើល ខ.៦–៧)។

**១:៤** *សេចក្ដីអំណររបស់អ្នករាល់គ្នាបានពោរពេញ* សេចក្ដីអំណររបស់លោកយ៉ូហានមិនអាចពោរពេញបានទេ បើអ្នកអានរបស់គាត់មិនមានការយល់ដឹងដ៏ពិតប្រាកដពីព្រះគ្រីស្ទទេ (២យហ ១២ សូមធៀបនឹងភល ២:២)។

**១:៥** *ពីទ្រង់* មានន័យថា ពីព្រះគ្រីស្ទ ។ *ពន្លឺ . . . ងងឹត* ពន្លឺគឺជាតំណាងឱ្យការអ្វីដែលល្អពិត និងបរិសុទ្ធចំណែកឯងងឹតវិញ ជាតំណាងឱ្យការអាក្រក់ និងមិនពិត (យហ ៣:១៩–២១)។

**១:៦–៧** *ដើរក្នុងសេចក្ដីងងឹត . . . ក្នុងពន្លឺ* មានន័យថា មានការរស់នៅពីរប្រភេទគឺប្រភេទទីមួយមានលក្ខណៈអាក្រក់ ហើយខុសឆ្គងប្រភេទទីពីរមានលក្ខណៈបរិសុទ្ធ និងមានសេចក្ដីពិត ។

**១:៧** *អំពើបាប* គឺជាពាក្យគន្លឹះនៃ១យ៉ូហាន ដែលឃើញមាន២៧ដងនៅក្នុងអត្ថបទដើមជាភាសាក្រិក ។

**១:៩** *ស្មោះត្រង់ ហើយសុចរិត* ពាក្យទាំងពីរនេះច្រើនតែត្រូវបានប្រើក្នុងន័យរួមតែមួយ ដែលមានន័យថាព្រះទ្រង់នឹងឆ្លើយតបចំពោះអ្នកដែលលន់តួបាបតាមលក្ខណៈ និងព្រះគុណនៃទ្រង់ (ទដ ១៤៣:១ សក ៨:៨ និងការពន្យល់)។ *ស្មោះត្រង់* ព្រះទ្រង់មានភាពស្មោះត្រង់នឹងព្រះបន្ទូលសន្យាថាទ្រង់នឹងអត់ទោសបាបឱ្យដល់អ្នកដែលលន់តួបាប (យរ ៣១:៣៤ មីក ៧:១៨–២០ ហព ១០:២២–២៣ និងការពន្យល់)។ *ប្រយោជន៍នឹងអត់ទោសបាបឱ្យយើង* ព្រះទ្រង់នឹងប្រទាននូវការអត់ទោសបាប ដែលនាំឱ្យមានទំនាក់ទំនងឡើងវិញជាមួយនឹងទ្រង់ដែលទំនាក់ទំនងនេះត្រូវបានកាត់ផ្ដាច់ ដោយអំពើបាប (ដូចដែលមាននៅក្នុងសេចក្ដីអធិស្ឋាននៃព្រះអម្ចាស់ក្នុង មថ ៦:១២)។

**១:១០** *យើងមិនដែលធ្វើបាបសោះ* ការដែលថាខ្លួនមិនដែលធ្វើបាបសោះ គឺជាអំពើបាប ។

ធ្វើបាបសោះ[ប] នោះឈ្មោះថាយើងធ្វើឱ្យទ្រង់ទៅជាអ្នក
កុហកវិញ[ផ] ហើយព្រះបន្ទូលទ្រង់មិននៅក្នុងយើងទេ[ព]។
**២** ១ [ភ]កូនតូចៗរាល់គ្នាអើយ[ភ] ដែលខ្ញុំសរសេរសេចក្ដីទាំង
នេះផ្ញើមក នោះដើម្បីកុំឱ្យអ្នករាល់គ្នាធ្វើបាបទៀត តែបើ
សិនជាអ្នកណាភ្លាត់ធ្វើបាបវិញ នោះយើងមានព្រះដ៏ជា
ជំនួយ១អង្គហើយ[ម] ដែលទ្រង់គង់នៅចំពោះព្រះវរបិតា គឺ
ជាព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏សុចរិត ២ ដែលទ្រង់ជាដង្វាយ
ធួននឹងបាបយើងរាល់គ្នា[យ] មិនត្រឹមតែបាបរបស់យើងរាល់
គ្នាតែប៉ុណ្ណោះ គឺនឹងបាបរបស់លោកីយទាំងមូលដែរ[រ]។
៣ យើងរាល់គ្នាដឹងថា[ល] យើងស្គាល់ទ្រង់[វ] ដោយសារ
សេចក្ដីនេះ គឺដោយយើងកាន់តាមបញ្ញត្តិរបស់ទ្រង់[ស] ៤ អ្នក
ណាដែលថា បានស្គាល់ទ្រង់[ហ] តែមិនកាន់តាមបញ្ញត្តិទ្រង់
ទេ អ្នកនោះឈ្មោះថាជាអ្នកកុហក ហើយសេចក្ដីពិតមិននៅ
ក្នុងអ្នកនោះឡើយ[ឡ] ៥ តែអ្នកណាដែលកាន់តាមព្រះបន្ទូល
ទ្រង់វិញ[អ] នោះប្រាកដជាសេចក្ដីស្រឡាញ់នៃព្រះបានពេញ
ខ្នាត[ក] នៅក្នុងអ្នកនោះហើយ គឺដោយសេចក្ដីនោះឯង ដែល
យើងដឹងថា[ខ] យើងនៅក្នុងទ្រង់ ៦ អ្នកណាដែលថាខ្លួននៅ
ក្នុងទ្រង់ នោះត្រូវតែប្រព្រឹត្តដូចជាទ្រង់ដែរ[គ]។
៧ ពួកស្ងួនភ្ងាអើយ[ឃ] សេចក្ដីដែលខ្ញុំសរសេរ ផ្ញើមកអ្នក
រាល់គ្នា នោះមិនមែនជាបញ្ញត្តិថ្មីទេ គឺជាបញ្ញត្តចាស់
ដដែល ដែលអ្នករាល់គ្នាមានតាំងពីដើមមក[ង] ឯបញ្ញត្តិ
ចាស់នោះ គឺជាព្រះបន្ទូល ដែលអ្នករាល់គ្នាបានឮហើយ
៨ ខ្ញុំក៏សរសេរបញ្ញត្ត១ថ្មីទៀត[ច] ផ្ញើមកអ្នករាល់គ្នាជាសេចក្ដី
ពិតដែលនៅក្នុងទ្រង់ ហើយក្នុងអ្នករាល់គ្នាដែរ ដ្បិតសេច
ក្ដីងងឹតកំពុងតែបាត់ទៅ[ឆ] ហើយពន្លឺដ៏ពិត[ជ]បានភ្លឺឡើង[ឈ]
៩ អ្នកណាដែលថា ខ្លួននៅក្នុងពន្លឺ តែស្អប់ដល់បងប្អូន[ញ]
នោះឈ្មោះថានៅក្នុងសេចក្ដីងងឹត ដរាបដល់សព្វថ្ងៃនេះ[ដ]
១០ ឯអ្នកណាដែលស្រឡាញ់ដល់បងប្អូនខ្លួន នោះតែងនៅ

**១:១០** ផ ១យហ ៥:១០ ព យហ ៥:៣៨ ១យហ ២:១៤
**២:១** ភ ខ.១២,១៣, ២៨ ១យហ ៣:៧, ១៨ ៤:៤ ៥:២១ ១យហ ២:១១ ម រម ៨:៣៤ ១ធថ ២:៥
**២:២** យ រម ៣:២៥ ១យហ ៤:១០ រ មថ ១:២១ យហ ៣:១៧
**២:៣** ល ខ.៥ ១យហ ៣:២៤ ៤:១៣ ៥:២ វ ខ.៤ ស យហ ១៤:១៥
**២:៤** ហ ខ.៣ ទត ១:១៦ ១យហ ៣:៦ ៤:៧,៨ ឡ ១យហ ១:៦,៨
**២:៥** អ យហ ១៤:១៥

ក ១យហ ៤:១២ ខ ខ.៣ **២:៦** គ មថ ១១:២៩ **២:៧** ឃ ១កថ ១០:១៤ ង ខ.២៤ ១យហ ៣:១១,២៣ ៤:២១ ២យហ ៥,៦ **២:៨** ច យហ ១៣:៣៤ ឆ រម ១៣:១២ ហព ១០:២៥ ជ យហ ១:៩ ឈ អភ ៥:៨ ១ថន ៥:៥ **២:៩** ញ ខ.១១ លវ ១៩:១៧ ១យហ ៣:១០,១៥,១៦ ៤:២០,២១ ដ ១យហ ១:៥

**២:១** *កូនតូចៗរាល់គ្នាអើយ* លោកយ៉ូហានជាសាវ័កដែលមានវ័យចាស់ ហើយលោកប្រើពាក្យដែលបង្ហាញពីសេចក្ដីស្រឡាញ់ ដ៏ជ្រាលជ្រៅ (ខ.១២–១៣,២៨ ៣:៧,១៨ ៤:៤ ៥:២១)។ *ព្រះដ៏ជាជំនួយ១អង្គ* ព្រះគម្ពីរក្រិកប្រើពាក្យអ្នកការពារក្ដី(ការពន្យល់ យហ ១៤:១៦)។ *ជាព្រះដ៏សុចរិត* នៅទីជំនុំជម្រះក្ដីរបស់ព្រះអ្នកការពារក្ដីត្រូវតែជាអ្នក ដែលគ្មានបាប (សូមធៀប កច ៣:១៤ និងការពន្យល់)។

**២:២** *ដង្វាយធួននឹងបាបយើងរាល់គ្នា* មើល ៤:១០ ។ សេចក្ដីបរិសុទ្ធរបស់ព្រះទាមទាឱ្យមានការដាក់ទោសដល់មនុស្សមានបាបដូចនេះ ព្រះដែលពេញ ដោយក្ដីស្រឡាញ់ទ្រង់បានចាត់ព្រះរាជបុត្រា ទ្រង់ឱ្យមកដើម្បីធ្វើជាដង្វាយធួននឹងបាបរបស់អ្នកដែលទទួលជឿទ្រង់ ។ តាមរយៈការនេះ សេចក្ដីក្រោធរបស់ទ្រង់ក៏បានបាត់ទៅមានន័យថា សេចក្ដីក្រោធរបស់ទ្រង់ចំពោះអំពើបាបរបស់គ្រីស្ទបរិស័ទបានបាត់ទៅ ហើយត្រឡប់ជាមាន ចំពោះព្រះគ្រីស្ទវិញ ។ មើលការពន្យល់ រម ៣:២៥ ។ *នឹងបាបរបស់លោកីយទាំងមូល* មានន័យថា ព្រះគ្រីស្ទទ្រង់បានសុគតមិនមែនដើម្បីលោះបាបតែក្រុមមនុស្សណាមួយនោះទេ ប៉ុន្ដែ ដល់មនុស្សទាំងអស់នៅលើលោកីយនេះ (មើល យហ ១:២៩) ហើយពួកគេអាចទទួលបាននូវសេចក្ដីសង្គ្រោះនេះដោយសេចក្ដីជំនឿលើព្រះនាមទ្រង់(យហ ៣:១៦)។ ដូចនេះខនេះមិនបានបង្រៀនថា មនុស្សគ្រប់រូបនឹងបានសង្គ្រោះនោះទេ ប៉ុន្ដែបានបង្រៀនថា ព្រះទ្រង់គ្មានភាពលំអៀងឡើយ ។

**២:៣** *ដឹង* នៅក្នុងសំបុត្រនេះមានប្រើកិរិយាសព្ទ"ដឹង" ឬ"ស្គាល់"ចំនួន៥២ដង ។ *កាន់តាមបញ្ញត្តិទ្រង់* ត្រង់ចំណុចនេះមិនមានន័យថាអ្នកដែលមិនដែលមិនស្ដាប់បង្គាប់ព្រះទើបជាអ្នកដែលស្គាល់ព្រះនោះឡើយ (១:៨–៩) ប៉ុន្ដែមានន័យថាអ្នកដែលរស់នៅដោយស្ដាប់បង្គាប់ព្រះគឺជាអ្នក ដែលស្គាល់ព្រះ។

**២:៥** *សេចក្ដីស្រឡាញ់នៃព្រះបានពេញខ្នាតនៅក្នុងអ្នក* មានន័យថា សេចក្ដីស្រឡាញ់នៃព្រះបានពេញខ្នាត នៅពេលដែលសេចក្ដីស្រឡាញ់នេះនាំឱ្យអ្នកជឿប្រព្រឹត្តដោយស្ដាប់បង្គាប់(៤:១២) ឬសេចក្ដីស្រឡាញ់របស់អ្នកជឿចំពោះព្រះបានពេញខ្នាតនៅពេលដែលពួកគេ ប្រព្រឹត្តដោយស្ដាប់បង្គាប់ដល់ទ្រង់(៣:១៦–១៨)។ *យើងនៅក្នុងទ្រង់* មានន័យថា ប្រកបស្និទ្ធស្នាលខាងឯវិញ្ញាណជាមួយនឹងទ្រង់(យហ ១៧:២១ អភ ១:១ និងការពន្យល់)។

**២:៧–៨** *បញ្ញត្តិថ្មី* មើល យហ ១៣:៤៣–៣៥ និងការពន្យល់ ។ បញ្ញត្តិនៃសេចក្ដីស្រឡាញ់មានចែងនៅក្នុងព្រះគម្ពីរតាំងពីយូរណាស់មកហើយ (លវ ១៩:១៨ និង មថ ២២:៣៩–៤០) ប៉ុន្ដែ ភាពថ្មីនៃបញ្ញត្តិនេះ ត្រូវបានបង្ហាញឱ្យឃើញនៅក្នុង (១).ការបង្ហាញសេចក្ដីស្រឡាញ់របស់ព្រះអម្ចាស់នៅលើឈើឆ្កាង (២).សេចក្ដីបង្រៀនរបស់ព្រះអម្ចាស់អំពីក្រឹត្យវិន័យសញ្ញាចាស់ (មើល មថ ៥) ដែលហាក់ដូច ជាថ្មីសម្រាប់អ្នកស្ដាប់ការបង្រៀន របស់ទ្រង់ និង(៣).ការដែលអ្នកជឿពិសោធនសេចក្ដីស្រឡាញ់ជារៀងរាល់ថ្ងៃនៅក្នុងការចម្រើនខាងឯសេចក្ដីស្រឡាញ់ ។

**២:៧** *ពួកស្ងួនភ្ងាអើយ* ពាក្យនេះមានការប្រើប្រាស់ដូចពាក្យ "កូនតូចៗរាល់គ្នាអើយ"ផងដែរ លោកយ៉ូហានចូលចិត្តប្រើពាក្យនេះណាស់ (មានប្រើ១០ដង ក្នុង សំបុត្រពីរ ៣:២,២១ ៤:១,៧,១១ ៣យហ ១–២,៥,១១)។ *តាំងពីដើមមក* មានន័យថាតាំងពីបានចាប់ផ្ដើមពិសោធនជីវិតជាគ្រីស្ទបរិស័ទនៅពេលដែលបានឮ ដំណឹងល្អជាលើកដំបូង ។

**២:៨** *ពន្លឺដ៏ពិត* ពាក្យនេះឃើញមានប្រើតែនៅក្នុងខនេះ និង យហ ១:៩ ប៉ុណ្ណោះ (មើលការពន្យល់ យហ ១:៤)។ ពាក្យនេះប្រើសំដៅទៅលើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់ជាពន្លឺនៃជីវិត(យហ ៨:១២ និងការពន្យល់)។

**២:៩–១០** *ស្អប់... ស្រឡាញ់* តាមន័យព្រះគម្ពីរសេចក្ដីស្រឡាញ់ និងសេចក្ដីស្អប់ គឺមិនគ្រាន់តែមាននៅក្នុងចិត្តប៉ុណ្ណោះទេ ប៉ុន្ដែថែមទាំងសម្ដែងចេញមកតាមរយៈ ការប្រព្រឹត្តទៀតផង(៣:១៥–១៦)។

**២:៩** *ពន្លឺ... ងងឹត* មើលការពន្យល់ ១:៥ ។ *បងប្អូន* មើលការពន្យល់ រម ១:១៣ ។

**២:១០** *បង្អាក់បង្អន់ចិត្ត* មានន័យថា រវាតចិត្ត ។

ក្នុងពន្លឺវិញ[ឋ] ហើយនៅក្នុងអ្នកនោះគ្មានហេតុណា នឹង
បង្អាក់បង្អន់ចិត្តគេឡើយ[ឌ] ១១តែអ្នកណាដែលស្អប់ដល់បង
ប្អូន[ឍ] នោះឈ្មោះថា នៅក្នុងសេចក្ដីងងឹតវិញ ក៏ដើរក្នុង
សេចក្ដីងងឹត[ណ] ហើយមិនដឹងជាខ្លួនទៅឯណាផង ពីព្រោះ
សេចក្ដីងងឹតនោះបានបំបាំងភ្នែកហើយ[ត]។
១២កូនតូចៗរាល់គ្នាអើយ ខ្ញុំសរសេរផ្ញើមកអ្នករាល់ គ្នា[ថ]
ពីព្រោះទ្រង់បានអត់ទោសបាបរបស់អ្នករាល់គ្នាហើយ
ដោយយល់ដល់ព្រះនាមទ្រង់[ទ] ១៣ឱពុករាល់គ្នាអើយ ខ្ញុំ
សរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះបានស្គាល់ព្រះ ដែល
ទ្រង់គង់នៅតាំងពីដើមរៀងមក[ធ] កំឡោះរាល់គ្នាអើយ ខ្ញុំ
សរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះបានឈ្នះ[ន]មេកំណាច
ហើយ[ប] ក្មេងរាល់គ្នាអើយ ខ្ញុំបានសរសេរផ្ញើមកអ្នករាល់
គ្នា[ផ] ពីព្រោះបានស្គាល់ព្រះវរបិតា ១៤ឱពុករាល់គ្នាអើយ ខ្ញុំ
បានសរសេរផ្ញើរមកអ្នករាល់គ្នា ពីព្រោះបានស្គាល់ព្រះ
ដែលគង់នៅតាំងពីដើមរៀងមក[ព] កំឡោះរាល់គ្នាអើយ
ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះមានកំឡាំង[ភ]
ហើយព្រះបន្ទូល[ម]ក៏ស្ថិតនៅក្នុងអ្នករាល់គ្នា[យ] អ្នករាល់គ្នា
បានឈ្នះមេកំណាចហើយ[រ]។

## កុំស្រឡាញ់លោកីយ

១៥កុំឱ្យស្រឡាញ់លោកីយ ឬរបស់អ្វីដែលនៅក្នុងលោកីយ
នេះឱ្យសោះ[ល] បើអ្នកណាស្រឡាញ់លោកីយ អ្នកនោះ
គ្មានសេចក្ដីស្រឡាញ់របស់ព្រះវរបិតានៅក្នុងខ្លួនឡើយ[វ]
១៦ដ្បិតអស់ទាំងសេចក្ដី ដែលនៅក្នុងលោកីយនេះ គឺជា
សេចក្ដីប៉ងប្រាថ្នារបស់សាច់ឈាម[ស] និងសេចក្ដីប៉ងប្រាថ្នា
របស់ភ្នែក[ហ] ហើយសេចក្ដីអំនួតរបស់ជីវិត នោះមិនកើតមក
ពីព្រះវរបិតាទេ គឺមកតែពីលោកិយនេះវិញ ១៧ឯលោកីយ
នេះ នឹងសេចក្ដីប៉ងប្រាថ្នារបស់វា នោះកំពុងកន្លងទៅ[ឡ] តែ
អ្នកណាដែលធ្វើតាមព្រះហឫទ័យព្រះ[អ] នោះនឹងនៅជាប់
អស់កល្បជានិច្ចវិញ ។

## ការព្រមានពីពួកទទឹងនឹងព្រះគ្រីស្ទ

១៨ក្មេងរាល់គ្នាអើយ នេះជាពេលម៉ោងក្រោយបង្អស់
ហើយ[ក] សព្វថ្ងៃនេះកើតមានពួកទទឹងនឹងព្រះគ្រីស្ទជាច្រើន[ខ]
ដូចជាអ្នករាល់គ្នាបានឮហើយថា អាទទឹងនឹងព្រះគ្រីស្ទត្រូវ
មក[គ] ហេតុនោះបានជាយើងដឹងថា នោះជាពេលម៉ោង
ក្រោយបង្អស់ ១៩គេបានចេញពីពួកយើងទៅ[ឃ] តែមិនមែន
ជាពួកយើងទេ ដ្បិតបើគេជាពួកយើងមែន នោះនឹងបាននៅ
ជាប់ជាមួយនឹងយើងហើយ តែដែលគេបានចេញទៅ នោះ
ដើម្បីនឹងសំដែងពីគេថា គ្រប់គ្នាមិនមែនជាពួកយើងទេ[ង]
២០រីឯអ្នករាល់គ្នាបានព្រះដ៏បរិសុទ្ធចាក់លាប[ច]ឱ្យហើយ[ឆ]
ក៏ចេះគ្រប់ទាំងអស់ផង[ជ] ២១ខ្ញុំសរសេរផ្ញើមក មិនមែន
ដោយព្រោះអ្នករាល់គ្នាមិនស្គាល់សេចក្ដីពិតទេ គឺដោយ
ព្រោះបានស្គាល់ហើយ[ឈ] ក៏ដឹងថា គ្មានសេចក្ដីភូតភរណា
កើតពីសេចក្ដីពិតនោះឡើយ ២២តើអ្នកណាជា អ្នកកុហក

**២:១០** ឋ ១យហ ៣:១៤ ឌ ខ.១១ ទដ ១១៩:១៦៥
**២:១១** ឍ ខ.៩ ណ ១យហ ១:៦ ត យហ ១១:៩ ១២:៣៥
**២:១២** ថ ខ.១ ទ ១យហ ៣:២៣
**២:១៣** ធ យហ ១:១ ន យហ ១៦:៣៣ ប ខ.១៤ មថ ៥:៣៧ ផ ខ.១
**២:១៤** ព យហ ១:១ ភ អភ ៦:១០ ម ហព ៤:១២ យ យហ ៥:៣៨ ១យហ ១:១០ រ ខ.១៣
**២:១៥** ល រម ១២:២ វ យក ៤:៤
**២:១៦** ស លប ៣:៦ រម ១៣:១៤ អភ ២:៣ ហ សភ ២៧:២០
**២:១៧** ឡ ហព ១២:២៧ អ មថ ១២:៥០
**២:១៨** ក រម ១៣:១១ ខ ១យហ ៤:១ គ ខ.២២ ១យហ ៤:៣ ២យហ ៧
**២:១៩** ឃ ១កថ ១១:១៩ ង កច ២០:៣០ **២:២០** ច ខ.២៧ ២កថ ១:២១ ឆ មក ១:២៤ ជ យរ ៣១:៣៤ មថ ១៣:១១ យហ ១៤:២៦ **២:២១** ឈ ២ពត ១:១២ យដ ៥

**២:១២-១៤** *ខ្ញុំសរសេរផ្ញើ... ពីព្រោះ* លោកយ៉ូហានប្រើទម្រង់ដូចនេះជាច្រើនដងនៅក្នុងវគ្គនេះ ដើម្បីបញ្ជាក់ដល់អ្នកអានរបស់គាត់ថា ទោះជានៅក្នុងសំបុត្រនេះមានទៅដោយបញ្ញត្តិទឹងរឹងក៏ដោយក៏គាត់នៅ តែមានការជឿជាក់សេចក្ដីសង្គ្រោះដែលព្រះទ្រង់បានសន្យាដល់ពួកគេ ។ *កូនតូចៗរាល់គ្នា . . . ឪពុក រាល់គ្នា . . . កំឡោះរាល់គ្នាអើយ* គេជឿថា នៅក្នុងបទដទៃៗទៀតនៃសំបុត្រ នេះលោកយ៉ូហានប្រើពាក្យ "កូនតូចៗ រាល់គ្នា" សំដៅទៅលើអ្នកអានរបស់គាត់ទាំងអស់(ការពន្យល់ ខ.១)។ ការប្រើពាក្យ "ឪពុក"និង"កំលោះ" ប្រហែលជាដើម្បីបង្ហាញពីកម្រិតពីរខុសគ្នានៃភាពពេញវ័យខាងវិញ្ញាណ ហើយពាក្យទាំងបីសុទ្ធតែប្រើសំដៅទៅលើកម្រិតនៃភាពពេញវ័យខាងវិញ្ញាណ ។

**២:១៨** *ពេលម៉ោងក្រោយបង្អស់* កណ្ឌគម្ពីរនេះក៏បានបង្ហាញ ពីរយៈពេលដែលចាប់ផ្ដើមពីការយាងមកជាលើកទីមួយរបស់ព្រះគ្រីស្ទថា ជារយៈពេលចុងក្រោយ ដូចជាព្រះគម្ពីរសញ្ញាថ្មីដទៃៗទៀតផងដែរ(កច ២:១៧ ២ធថ ៣:១ និងការពន្យល់)។ ពាក្យ "ពេលម៉ោងក្រោយបង្អស់" ក៏ត្រូវបានប្រើក្នុងន័យភាពបន្ទាន់ និងការដែលត្រូវមកជាឆាប់ផងដែរ ។ គ្រីស្ទបរិស័ទត្រូវចាំយាមការយាងត្រឡប់មកវិញនៃព្រះគ្រីស្ទ(មថ ២៥:១-១៣)។ *អាទទឹងនឹងព្រះគ្រីស្ទជាច្រើន. . . ត្រូវមក* ពាក្យនេះមានសរសេរថា "អាទទឹងនឹងព្រះគ្រីស្ទ"(ខ.១៨) "ពួកក្បត់សាសនា" (២ថន ២:៣ និងការពន្យល់) និង "សត្វសាហាវ"(វវ ១៣:១-១០)។ មុនពេលទ្រង់យាងមកម្ដងទៀតពួកនោះនឹងមានចំនួនយ៉ាងច្រើន ហើយមានលក្ខណៈ ដូចជា (១).បដិសេធថា ព្រះគ្រីស្ទមិនបានមកក្នុងសាច់ឈាម(៤:២ និងការពន្យល់ និង ២យហ ៧) ហើយព្រះយេស៊ូវមិនមែនជាព្រះគ្រីស្ទ(ខ.២២)។ (២).បដិសេធព្រះវរបិតា(ខ.២២)។ (៣).គ្មានព្រះវរបិតា(ខ.២៣)។ (៤).ជា អ្នកកុហក(ខ.២២) និងអ្នកប្រវញ្ចបញ្ឆោត(២យហ ៧)។ (៥).មានគ្នាច្រើន (ខ.១៨)។ (៦).បានចេញពីពួកជំនុំ ដោយសារគ្មានលក្ខណៈដូចពួកជំនុំ(ខ.១៩)។ ពួកទទឹងនឹងព្រះគ្រីស្ទនៅសម័យលោកយ៉ូហានគឺពួកគ្រូបង្រៀនខុសឆ្គងអំពីព្រលឹងវិញ្ញាណ ។

**២:២០** *ព្រះដ៏បរិសុទ្ធ* មានន័យថា ព្រះយេស៊ូវគ្រីស្ទ(មក ១:២៤ យហ ៦:៣៩ កច ២:២៧ ៣:១៤ ២២:១៤) ឬព្រះវរបិតា(២ពវ ១៩:២២ យប ៦:១០)។ *ចាក់លាបឱ្យ* មានន័យថា ប្រទានឱ្យមានព្រះវិញ្ញាណបរិសុទ្ធ (ខ.២៧ យហ ១៤:១៦-១៧ ១៥:២៦ ១៦:១៣ កច ១០:៣៨)។

**២:២២** *ព្រះយេស៊ូវមិនមែនជាព្រះគ្រីស្ទ* ភាពជាមនុស្សរបស់ព្រះគ្រីស្ទគ្មានអំពើបាបឡើយគឺមានភាពបរិសុទ្ធ ដែលគ្មាននរណាអាចរកចាប់កំហុសទ្រង់បានឡើយ(មើល ៥:៥ និងសេចក្ដីផ្ដើមត្រង់ពួកគ្រូបង្រៀនខុសឆ្គង

បើមិនមែនជាអ្នកដែលប្រកែកថា ព្រះយេស៊ូវមិនមែនជា
ព្រះគ្រីស្ទនោះទេ អ្នកណាដែលមិនព្រមទទួលស្គាល់ទាំង
ព្រះវរបិតា នឹងព្រះរាជបុត្រាផង អ្នកនោះ ហើយជាអ្នក
ដែលទទឹងនឹងព្រះគ្រីស្ទ[ញ] ២៣ឯអស់អ្នកណា ដែលមិនព្រម
ទទួលស្គាល់ព្រះរាជបុត្រា នោះក៏គ្មានព្រះវរបិតាដែរ
តែអ្នកណាដែលព្រមទទួលស្គាល់ព្រះរាជបុត្រា នោះក៏មាន
ទាំងព្រះវរបិតាផង[ដ] ២៤ដូច្នេះ ចូរឱ្យសេចក្ដីដែលអ្នក
រាល់គ្នាបានឮពីដើមមក[ឋ] បាននៅជាប់ក្នុងខ្លួនចុះ បើសិន
ជាសេចក្ដីដែលឮតាំងពីដើមមក បាននៅជាប់ក្នុងអ្នក
រាល់គ្នាមែន នោះអ្នករាល់គ្នានឹងនៅជាប់ក្នុងព្រះរាជ
បុត្រា ហើយក្នុងព្រះវរបិតា ដែរ[ឌ] ២៥នេះហើយ ជាសេចក្ដី
ដែលទ្រង់បានសន្យានឹងយើងរាល់គ្នា គឺជាជីវិតដ៏រស់នៅ
អស់កល្បជានិច្ច[ឍ]។

២៦ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា ពីដំណើរនៃពួក
អ្នកដែលនាំអ្នករាល់គ្នាឱ្យវង្វេង[ណ] ២៧រីឯដំណើរដែលទ្រង់
ចាក់លាបឱ្យ[ត] នោះក៏នៅជាប់នឹងអ្នករាល់គ្នាពិត ហើយអ្នក
រាល់គ្នាមិនត្រូវការ ឱ្យអ្នកណាបង្រៀនពីការអ្វីទេ[ថ] ប៉ុន្តែ
ដូចជាដំណើរចាក់លាបនោះ បានបង្រៀនពីគ្រប់ការទាំង
អស់ ហើយមិនមែនជាសេចក្ដីកំភូតទេ គឺជាសេចក្ដីពិតវិញ
នោះត្រូវឱ្យអ្នករាល់គ្នានៅជាប់ក្នុងទ្រង់ចុះ តាមដែល
ដំណើរនោះបានបង្រៀនមក[ទ]។

## កូននៃព្រះ

២៨ហើយឥឡូវនេះ ពួកកូនតូចៗអើយ[ធ] ចូរនៅជាប់ក្នុង
ទ្រង់ចុះ ដើម្បីកាលណាទ្រង់លេចមក[ន] នោះយើងខ្ញុំនឹងមាន
ចិត្តក្លាហាន[ប] ឥតត្រូវការនឹងខ្មាសនៅចំពោះទ្រង់ ក្នុងកាល
ដែលទ្រង់យាងមកនោះឡើយ[ផ] ២៩បើអ្នករាល់គ្នាដឹងថា
ទ្រង់សុចរិត[ព] នោះត្រូវតែយល់ឃើញថា អស់អ្នកណាដែល
ប្រព្រឹត្តតាមសេចក្ដីសុចរិតនោះ គេបានកើតពីទ្រង់មក
ដែរ[ភ]។

**៣** ១មើល សេចក្ដីស្រឡាញ់យ៉ាងណាហ្ន៎[ម] ដែលព្រះវរបិតា
បានផ្ដល់មកយើងរាល់គ្នា ឱ្យយើងបានហៅថាជាកូនរបស់
ព្រះដូច្នេះ[យ] គឺដោយហេតុនោះបានជាលោកីយមិនស្គាល់
យើងទេ ពីព្រោះមិនស្គាល់ទ្រង់ដែរ[រ] ២ពួកស្ងួនភ្ងាអើយ[ល]
ឥឡូវនេះ យើងរាល់គ្នាជាកូនព្រះហើយ[វ] តែដែលយើង
រាល់គ្នានឹងបានទៅជាយ៉ាងណាទៀត នោះមិនទាន់សំដែង
មកនៅឡើយ ប៉ុន្តែ យើងដឹងថា កាលណាទ្រង់លេចមក[ស]
នោះយើងនឹងបានដូចជាទ្រង់[ហ] ដ្បិតដែលទ្រង់យ៉ាងណា
នោះយើងនឹងឃើញទ្រង់យ៉ាងនោះឯង[ឡ] ៣អស់អ្នកណា
ដែលមានសេចក្ដីសង្ឃឹមយ៉ាងនេះដល់ទ្រង់ នោះក៏តែងជិះ
សំអាតចិត្តខ្លួន[អ] ឱ្យដូចទ្រង់ដែលស្អាតដែរ[ក] ៤ឯអស់អ្នក
ណាដែលប្រព្រឹត្តអំពើបាបវិញ នោះក៏ឈ្មោះថាប្រព្រឹត្ត
រំលងក្រិត្យវិន័យដែរ ដ្បិតអំពើបាបជាការរំលងក្រិត្យ
វិន័យហើយ[ខ] ៥អ្នករាល់គ្នាដឹងហើយ ថាទ្រង់បានលេច
មក ដើម្បីនឹងដោះបាបយើងចេញ[គ] ហើយក៏នៅក្នុងទ្រង់

**២:២២** ញ ១យហ ៤:៣ ២យហ ៧ **២:២៣** ដ យហ ៨:១៩ ១៤:៧ ១យហ ៤:១៥ ៥:១ ២យហ ៩ **២:២៤** ឋ ខ.៧ ឌ យហ ១៤:២៣ ១៥:៤ ១យហ ១:៣ ២យហ ៩ **២:២៥** ឍ មថ ២៥:៤៦ **២:២៦** ណ ១យហ ៣:៧ **២:២៧** ត ខ.២០ ថ ១កថ ២:១២ ទ យហ ១៥:៤ **២:២៨** ធ ខ.១ ន កល ៣:៤ ១យហ ៣:២ ប អភ ៣:១២ ផ ១ថន ២:១៩ **២:២៩** ព ១យហ ៣:៧ ភ យហ ១:១៣ **៣:១** ម យហ ៣:១៦ យ ខ.២,១០ យហ ១:១២ រ យហ ១៥:២១ ១៦:៣ **៣:២** ល ១កថ ១០:១៤ វ ខ.១,១០ យហ ១:១២ ស កល ៣:៤ ១យហ ២:២៨ ហ រម ៨:២៩ ២ពត ១:៤ ឡ ទដ ១៧:១៥ យហ ១៧:២៤ ២កថ ៣:១៨ **៣:៣** អ ២កថ ៧:១ ២ពត ៣:១៣,១៤ ក ទដ ១៨:២៦ **៣:៤** ខ ១យហ ៥:១៧ **៣:៥** គ ខ.៨ យហ ៣:១៧ ឃ ២កថ ៥:២១

និងការពន្យល់ ៥:៦)។

**២:២៣** ចំពោះន័យដូចគ្នា សូមមើល ២យហ ៩ ។

**២:២៥** *ជីវិតដ៏រស់នៅអស់កល្បជានិច្ច* មើល យហ ៣:១៥ និងការពន្យល់ សូម ធៀបនឹង មថ ១៩:១៦ និងការពន្យល់ ។

**២:២៦** ខនេះនិយាយពីគោលបំណងរបស់សំបុត្រនេះ (មើលសេចក្ដីផ្ដើមត្រង់ឱកាស និងគោលបំណង)។

**២:២៧** *ចាក់លាបឱ្យ* មើលការពន្យល់ ខ.២០ ។ *មិនត្រូវការឱ្យអ្នកណាបង្រៀនពីការអ្វី* ត្រង់ចំណុចនេះមិនមានន័យថា លោកយ៉ូហានហាមមិនឱ្យទទួលការបង្រៀនពីមនុស្សនោះទេ ព្រោះព្រះគម្ពីរក៏លើកតម្កើងការបង្រៀនផងដែរ (មថ ២៨:២០ ១កថ ១២:២៨ អភ ៤:១១ កល ៣:១៦ ១ធថ ៤:១១ ២ធថ ២:២,២៤)។ នៅពេលដែលលោកយ៉ូហាន សរសេរសំបុត្រនេះពួកគ្រូខុសឆ្គងបានអះអាងថា ពួកខ្លួនមានចំណេះខាងឯវិញ្ញាណដែលខ្ពស់ជាងពួកសាវក ការបង្រៀនរបស់ពួកសាវកត្រូវបន្ថែមដោយការបង្រៀន ដោយចំណេះរបស់ពួកខ្លួន ។ លោកយ៉ូហានបានឆ្លើយតបថា សេចក្ដីបង្រៀនរបស់ពួកសាវកមានភាពគ្រប់គ្រាន់ ហើយជាសេចក្ដីពិតដែលអាចជឿជាក់បាន ព្រោះជាការដែលព្រះវិញ្ញាណទ្រង់បណ្ដាល ។ *គ្រប់ការទាំងអស់* មានន័យថា គ្រប់ការដែលចាំបាច់ត្រូវដឹង ដើម្បីសេចក្ដីសង្គ្រោះ និងការរស់នៅជាគ្រីស្ទបរិស័ទ។ *ដំណើរនោះបានបង្រៀន* ពាក្យនេះប្រើសំដៅទៅលើការបង្រៀននៃព្រះវិញ្ញាណ អំពីព្រះបន្ទូលដែលមានបើកសំដែងនៅក្នុងព្រះគម្ពីរដល់អ្នកជឿព្រះ ដើម្បីឱ្យពួកគេយល់អត្ថន័យ ហើយទុកដាក់ក្នុងចិត្ត និងយកទៅអនុវត្តក្នុងជីវិតរស់នៅរាល់ថ្ងៃ ។

**២:២៨** *ចិត្តក្លាហាន* មើល ៣:២១ ៤:១៧ ៥:១៤ ។

**២:២៩** *ទ្រង់* មានន័យថាព្រះដ៏ជាព្រះវរបិតា ។ *ប្រព្រឹត្តតាមសេចក្ដីសុចរិត* លក្ខណៈនៃអ្នកកើតជាថ្មីត្រូវបង្ហាញចេញមកតាមរយៈការប្រព្រឹត្តអំពើសុចរិត ។

**៣:១** *កូនរបស់ព្រះ* មើលការពន្យល់ យហ ១:១២ ។

**៣:២** *ទ្រង់ . . . ទ្រង់* ពាក្យទ្រង់ក្នុងខនេះគឺសំដៅទៅលើព្រះគ្រីស្ទ ។ *យើងនឹងបានដូចជាទ្រង់* សូមធៀបនឹង រម ៨:២៩ ១កថ ១៥:៤៩ ភល ៣:២១ ។

**៣:៣** *សេចក្ដីសង្ឃឹម* គឺជាការសង្ឃឹមដែលមានជានិច្ច (រម ៥:៥ និងពន្យល់)។ *ទ្រង់* គឺព្រះគ្រីស្ទ។ *ជិះសំអាតចិត្ត* ដោយបែរចេញពីអំពើបាប។

**៣:៥** *ដោះយើងចេញពីបាប* មើល យហ ១:២៩ និងការពន្យល់ ។ *ក្នុងទ្រង់នោះគ្មានបាបសោះ* ក្នុងគម្ពីរសញ្ញាថ្មី ពាក្យនេះមានប្រើនៅក្នុងបទគម្ពីរ

នោះគ្មានបាបសោះ[ឃ] ៦ឯអស់អ្នកណាដែលនៅជាប់ក្នុងទ្រង់
នោះមិនដែលធ្វើបាបទេ[ង] តែពួកអ្នកដែលធ្វើបាបវិញ គេ
មិនបានឃើញទ្រង់ឡើយ[ច] ក៏មិនស្គាល់ទ្រង់ផង[ឆ]។
៧កូនតូចៗរាល់គ្នាអើយ[ជ] ចូរកុំឱ្យអ្នកណានាំអ្នករាល់គ្នា
ឱ្យវង្វេងឡើយ[ឈ] អ្នកណាដែលប្រព្រឹត្តសេចក្តីសុចរិត នោះ
ឈ្មោះថាសុចរិតហើយ ដូចជាទ្រង់ក៏សុចរិតដែរ[ញ] ៨តែអ្នក
ណាដែលប្រព្រឹត្តអំពើបាបវិញ នោះគឺមកពីអារក្សទេ[ដ] ពី
ព្រោះអារក្សបានធ្វើបាប ចាត់តាំងពីដើមរៀងមក ដោយ
ហេតុនោះបានជាព្រះរាជបុត្រានៃព្រះ[ឋ]បានលេចមក គឺ
ដើម្បីនឹងបំផ្លាញការរបស់អារក្សចេញ[ឌ] ៩អស់អ្នកណា
ដែលកើតពីព្រះ[ឍ] នោះមិនដែលប្រព្រឹត្តអំពើបាបទេ[ណ]
ពីព្រោះពូជព្រះ[ត]នៅក្នុងអ្នកនោះឯង បានជាពុំអាចនឹងធ្វើ
បាបឡើយ ដ្បិតបានកើតពីព្រះមក ១០គឺយ៉ាងនោះហើយ
ដែលនឹងសំគាល់ថាជាពួកកូនព្រះ[ថ] ឬពួកកូនអារក្សទៅ
បាន[ទ] ឯអ្នកណាដែលមិនប្រព្រឹត្តសេចក្តីសុចរិត ហើយមិន
ស្រឡាញ់[ធ]ដល់បងប្អូន[ន] នោះមិនមែនមកពីព្រះទេ ។

## ចូរស្រឡាញ់គ្នាទៅវិញទៅមក

១១ដ្បិតនេះឯងជាសេចក្តី ដែលអ្នករាល់គ្នាបានឮ[ប]ពី
ដើមរៀងមក[ផ]គឺថា ត្រូវឱ្យយើងស្រឡាញ់គ្នាទៅវិញទៅ
មក[ព] ១២មិនមែនដូចជាកាអ៊ីន ដែលកើតពីមេកំណាចមក[ភ]
ហើយបានសំឡាប់ប្អូនខ្លួននោះឡើយ[ម] ចុះតើហេតុអ្វីបាន
ជាសំឡាប់ប្អូន គឺពីព្រោះតែការរបស់គាត់សុទ្ធតែអាក្រក់
ហើយការរបស់ប្អូនសុទ្ធតែល្អវិញប៉ុណ្ណោះ[យ]។

**៣:៦** ង ខ.៩ ១យហ ៥:១៨ ច ៣យហ ១១ ឆ ១យហ ២:៤ **៣:៧** ជ ១យហ ២:១ ឈ ១យហ ២:២៦ ញ ១យហ ២:២៩ **៣:៨** ដ ខ.១០ យហ ៨:៤៤ ឋ មថ ៤:៣ ឌ ហព ២:១៤ **៣:៩** ឍ យហ ១:១៣ ណ ខ.៦ ទដ ១១៩:៣ ១យហ ៥:១៨ ត ១ពត ១:២៣ **៣:១០** ថ ខ.១,២ យហ ១:១២ ទ ខ.៨ ធ ១យហ ៤:៨ ន ១យហ ២:៩ **៣:១១** ប ១យហ ១:៥ ផ ១យហ ២:៧ ព យហ ១៣:៣៤,៣៥ ១៥:១២ ១យហ ៤:៧,១១,២១ ២យហ ៥ **៣:១២** ភ មថ ៥:៣៧ ម លប ៤:៨ យ ទដ ៣៨:២០ សភ ២៩:១០ **៣:១៣** រ យហ ១៥:១៨,១៩ ១៧:១៤ **៣:១៤** ល យហ ៥:២៤ វ ១យហ ២:៩ **៣:១៥** ស ១យហ ២:៩

១៣បងប្អូនអើយ បើលោកីយស្អប់អ្នករាល់គ្នា[រ] នោះកុំឱ្យ
ឆ្ងល់ឡើយ ១៤យើងរាល់គ្នាដឹងថា យើងបានកន្លងផុតពី
សេចក្តីស្លាប់ ទៅដល់ជីវិតហើយ[ល] ពីព្រោះយើងស្រឡាញ់
ដល់ពួកបងប្អូន ឯអ្នកណាដែលមិនស្រឡាញ់បងប្អូន អ្នក
នោះជាអ្នកនៅជាប់ក្នុងសេចក្តីស្លាប់នៅឡើយ[វ] ១៥អ្នកណា
ដែលមានចិត្តស្អប់ដល់បងប្អូន[ស] នោះឈ្មោះថា ជាអ្នក
សំឡាប់គេ[ហ] ហើយអ្នករាល់គ្នាដឹងហើយ ថាគ្មានអ្នក
សំឡាប់គេណាមួយ ដែលមានជីវិតដ៏រស់អស់កល្បជានិច្ច
នៅក្នុងខ្លួនឡើយ[ឡ] ១៦ដោយសារសេចក្តីនេះ យើងរាល់
គ្នាបានស្គាល់សេចក្តីស្រឡាញ់ គឺដោយទ្រង់បានស៊ូប្តូរ
ព្រះជន្មទ្រង់ជំនួសយើង[អ] ដូច្នេះ គួរឱ្យយើងប្តូរជីវិតយើង
ជំនួសបងប្អូនដែរ[ក] ១៧បើអ្នកណាមានភោគសម្បត្តិរបស់
លោកីយនេះ ហើយឃើញបងប្អូនណាដែលខ្វះខាត តែមិន
ចេះអាណិតមេត្តាសោះ[ខ] នោះធ្វើដូចម្តេច ឱ្យសេចក្តីស្រ
ឡាញ់នៃព្រះ បានស្ថិតនៅក្នុងអ្នកនោះបាន[គ]។
១៨ពួកកូនតូចៗអើយ[ឃ] យើងមិនត្រូវស្រឡាញ់ ដោយ
ពាក្យសំដី ឬដោយបបូរមាត់ប៉ុណ្ណោះឡើយ គឺដោយការ
ប្រព្រឹត្ត នឹងសេចក្តីពិតវិញ[ង] ១៩គឺយ៉ាងនោះឯងដែលយើង
នឹងដឹងថា យើងកើតមកពីសេចក្តីពិត ហើយយើងនឹងបាន
កំឡាចិត្ត នៅចំពោះទ្រង់ផង ២០ដ្បិតបើសិនជាចិត្តយើង
ចោទប្រកាន់ខ្លួន នោះព្រះទ្រង់ធំជាងចិត្តយើងទៅទៀត

ហ មថ ៥:២១,២២ យហ ៨:៤៤ ឡ កទ ៥:២០,២១ វវ ២១:៨ **៣:១៦** អ យហ ១០:១១ ក យហ ១៥:១៣ ភល ២:១៧ ១ថន ២:៨ **៣:១៧** ខ ចទ ១៥:៧,៨ យក ២:១៥,១៦ គ ១យហ ៤:២០ **៣:១៨** ឃ ១យហ ២:១ ង អគ ៣៣:៣១ រម ១២:៩

ដទៃៗទៀតផងដែរ (២កថ ៥:២១ ហព ៤:១៥ និងពន្យល់ ១ពត ៣:១៨)។

**៣:៦** *ពួកអ្នកដែលធ្វើបាប* ក្នុងខនេះមិនមានន័យថា អ្នកដែលមិនធ្វើបាបសោះ ទើបជាគ្រីស្ទបរិស័ទដែលនៅជាប់នឹងព្រះគ្រីស្ទនោះទេ (១:៨–១០ ២:១) ប៉ុន្តែ មានន័យថា គ្រីស្ទបរិស័ទមិនត្រូវធ្វើបាបសោះឡើយ គឺត្រូវធ្វើតែអំពើល្អវិញ ។

**៣:៨** *អារក្ស* ក្នុងព្រះគម្ពីរនេះ មានការនិយាយជាច្រើនដងអំពីអារក្សដូចជា (១).វាត្រូវបានហៅថា "អារក្ស"(ខនេះ) ហើយថា "អាមេកំណាច"(ក្នុង ខ.១២ ២:១៣–១៤ ៥:១៨–១៩)។ (២).វាបានធ្វើបាបតាំងពីដើម គឺចាប់តាំងពីពេល ដែលវាដឹកនាំការបះបោរប្រឆាំងនឹងព្រះ (មុនពេលល្បួងលោកអ័ដាម និងនាងអេវ៉ា)(មើល យហ ៨:៤៤ និងការពន្យល់)។ (៣).វាជាអ្នកបណ្តាលឱ្យមនុស្សធ្វើអំពើបាប ហើយអ្នកដែលនៅតែបន្តធ្វើអំពើបាបគឺជាកម្មសិទ្ធិរបស់វា(ខ.៨,១២) ហើយជាកូនរបស់វា(ខ.១០)។ (៤).វានៅក្នុងលោកិយ(៤:៣) ហើយវាមាន "លោកីយទាំងមូល" ជាកម្មសិទ្ធិព្រមទាំងគ្រប់គ្រងអ្នកដែលមិនជឿព្រះផងដែរ(៥:១៩)។ (៥).ប៉ុន្តែ វាមិនអាចពាល់អ្នកដែលកើតពីព្រះបានឡើយ(៥:១៨)។ (៦).អ្នកជឿព្រះមានជ័យជម្នះលើវា(២:១៣–១៤ ៤:៤) ហើយព្រះគ្រីស្ទទ្រង់នឹងបំផ្លាញកិច្ចការរបស់វា ។

**៣:៩** *ពូជព្រះ* មានន័យថា អ្នកដែលកើតពីព្រះ គឺជាពូជរបស់ព្រះ ។ *ពុំអាចនឹងធ្វើបាបបានឡើយ* ត្រង់ចំនុចនេះមិនមែនមានន័យថា គ្រីស្ទបរិស័ទគ្មានបាបនោះឡើយ តែត្រូវឈប់ប្រព្រឹត្តអំពើបាប ។

**៣:១១** *ពីដើមរៀងមក* មើលការពន្យល់ ២:៧ ។

**៣:១២** *កាអ៊ីន* មើល ហព ១១:៤ និងការពន្យល់ ។

**៣:១៣** *បងប្អូន* មើលការពន្យល់ រម ១:១៣ ។

**៣:១៥** *ស្អប់* មើលការពន្យល់ ២:៩–១០ ។ *អ្នកសំឡាប់គេ* មើល យក ៤:២ និងការពន្យល់ ។

**៣:១៧–១៨** មើល យក ២:១៤–១៧ និងការពន្យល់ ២:១៥–១៦ ។

**៣:១៧** *សេចក្តីស្រឡាញ់នៃព្រះ* គឺសេចក្តីស្រឡាញ់ដែលព្រះទ្រង់បានបង្ហូរចូលទៅក្នុងចិត្តអ្នកជឿ(រម ៥:៥ និងការពន្យល់) ហើយនាំឱ្យអ្នកជឿមានសេចក្តីស្រឡាញ់ដល់អ្នកឯទៀត និងស្រឡាញ់ដល់ទ្រង់ ។

**៣:២០** *ព្រះទ្រង់ធំជាងចិត្តយើង* សេចក្តីស្រឡាញ់របស់ព្រះអាចធ្វើឱ្យមនុស្សបន្ទាបខ្លួន ហើយថ្វាយចិត្ត និងជីវិតដល់ទ្រង់ ។ ព្រះទ្រង់ជ្រាបពីចិត្តរបស់មនុស្សម្នាក់ៗ ព្រោះពួកគេជាស្នាព្រះហស្តទ្រង់ ។

ហើយក៏ជ្រាបគ្រប់ទាំងអស់ផង ២១ពួកស្ងួនភ្ងាអើយ[ច] បើចិត្ត
យើងមិនចោទប្រកាន់ចំពោះខ្លួនទេ នោះយើងមានសេចក្ដី
ក្លាហាននៅចំពោះព្រះ[ឆ] ២២ហើយទោះបើយើងសូមអ្វីពី
ទ្រង់ក៏ដោយ គង់តែនឹងបានសំរេច[ជ] ពីព្រោះយើងកាន់
តាមបញ្ញត្តទ្រង់[ឈ] ហើយក៏ប្រព្រឹត្តការដែលគាប់ព្រះ
ហឫទ័យដល់ទ្រង់ដែរ[ញ] ២៣ឯបញ្ញត្តទ្រង់នោះ គឺថា ត្រូវឲ្យ
យើងជឿ[ដ]ដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ[ឋ] ជាព្រះរាជបុត្រា
នៃទ្រង់ ហើយត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចជាទ្រង់
បានបង្គាប់មកហើយ[ឌ] ២៤អ្នកណាដែលកាន់តាមបញ្ញត្ត
ទ្រង់[ឍ] នោះឈ្មោះថានៅជាប់ក្នុងទ្រង់[ណ] ហើយទ្រង់ក៏គង់នៅ
ក្នុងអ្នកនោះដែរ យើងដឹងថា ទ្រង់គង់នៅក្នុងយើង ដោយ
សារព្រះវិញ្ញាណដែលទ្រង់ប្រទានមក[ត]។

## ការល្បងវិញ្ញាណ

**៤** ១ពួកស្ងួនភ្ងាអើយ[ថ] កុំឲ្យជឿគ្រប់ទាំងវិញ្ញាណឡើយ[ទ]
ចូរល្បងវិញ្ញាណទាំងអស់វិញ ដើម្បីឲ្យបានដឹងជាមកពីព្រះ
ឬមិនមែន ដ្បិតមានហោរាក្លែងក្លាយជាច្រើនកើតមក ក្នុង
លោកីយនេះហើយ[ធ] ២យើងនឹងសំគាល់ព្រះវិញ្ញាណនៃព្រះ
បានដូច្នេះ គឺអស់ទាំងវិញ្ញាណណាដែលថ្លែងប្រាប់ថា ព្រះ
យេស៊ូវគ្រីស្ទបានមកក្នុងសាច់ឈាម[ន] គឺវិញ្ញាណនោះហើយ
ដែលមកពីព្រះ[ប] ៣តែវិញ្ញាណណាដែលមិនព្រមថា ព្រះ
យេស៊ូវគ្រីស្ទបានមកក្នុងសាច់ឈាមទេ នោះមិនមែនមក
ពីព្រះឡើយ គឺជាវិញ្ញាណរបស់អាទទឹងនឹងព្រះគ្រីស្ទវិញ[ផ]
ដែលអ្នករាល់គ្នាបានឮនិយាយថា ត្រូវមកតែឥឡូវនេះ ក៏
នៅក្នុងលោកីយហើយ[ព] ៤ពួកកូនតូចៗអើយ[ភ] អ្នករាល់គ្នា
មកពីព្រះហើយក៏ឈ្នះវិញ្ញាណទាំងនោះដែរ[ម] ពីព្រោះព្រះ
ដែលគង់ក្នុងអ្នករាល់គ្នា[យ] នោះទ្រង់ធំជាងអានោះដែលនៅ
ក្នុងលោកីយផង[រ] ៥ពួកនោះមកពីលោកីយទេ[ល] ដោយហេតុ
នោះបានជាគេនិយាយតាមភាពលោកីយ ហើយលោកីយ
ក៏ស្តាប់គេដែរ ៦ឯយើងរាល់គ្នា ជាអ្នកមកពីព្រះវិញ ហើយ
អ្នកណាដែលស្គាល់ព្រះ នោះក៏ស្តាប់យើងខ្ញុំ តែអ្នកណា
ដែលមិនមកពីព្រះទេ នោះមិនព្រមស្តាប់យើងខ្ញុំឡើយ[វ]
គឺយ៉ាងនោះឯងដែលយើងនឹងស្គាល់វិញ្ញាណនៃសេចក្ដី
ពិត[ស] នឹងវិញ្ញាណ នៃសេចក្ដីខុសឆ្គងទៅបាន[ហ]។

## សេចក្ដីស្រឡាញ់របស់ព្រះ និងរបស់យើង

៧ពួកស្ងួនភ្ងាអើយ យើងត្រូវស្រឡាញ់គ្នាទៅវិញទៅ
មក[ឡ] ដ្បិតសេចក្ដីស្រឡាញ់មកពីព្រះ ឯអស់អ្នកណាដែល
មានសេចក្ដីស្រឡាញ់ នោះឈ្មោះថាមកពីព្រះ[អ] ហើយក៏
ស្គាល់ទ្រង់ដែរ[ក] ៨តែអ្នកណាដែលគ្មានសេចក្ដីស្រឡាញ់

**៣:២១** ច ១កថ ១០:១៤ ឆ អភ ៣:១២ ១យហ ៥:១៤ **៣:២២** ជ មថ ៧:៧ ឈ យហ ១៤:១៥ ញ យហ ៨:២៩ ហព ១៣:២១ **៣:២៣** ដ យហ ៦:២៩ ឋ លក ២៤:៤៧ យហ ១:១២ ៣:១៨ ២០:៣១ ១កថ ៦:១១ ១យហ ៥:១៣ ឌ យហ ១៣:៣៤ **៣:២៤** ឍ ១យហ ២:៣ ណ ១យហ ២:៦ ៤:១៥ ត ១ថន ៤:៨ ១យហ ៤:១៣ **៤:១** ថ ១កថ ១០:១៤ ទ យរ ២៩:៨ ១កថ ១២:១០ ២ថន ២:២ ធ មថ ៧:១៥ ១យហ ២:១៨ **៤:២** ន យហ ១:១៤ ១យហ ២:២៣ ប ១កថ ១២:៣

**៤:៣** ផ ១យហ ២:២២ ២យហ ៧ ព ២យហ ២:១៨ **៤:៤** ភ ១យហ ២:១ ម យហ ១៦:៣៣ យ រម ៨:៣១ រ ២ពរ ៦:១៦ យហ ១២:៣១ **៤:៥** ល យហ ១៥:១៩ ១៧:១៤,១៦ **៤:៦** វ យហ ៨:៤៧ ស យហ ១៤:១៧ ហ មក ១៣:៥ **៤:៧** ឡ ១យហ ៣:១១ អ យហ ១:១៣ ក ១យហ ២:៤

**៣:២៣** តាមខនេះ បញ្ញត្តិមានពីផ្នែកគឺ (១).ត្រូវជឿលើព្រះគ្រីស្ទ(យហ ៦:២៩ និងការពន្យល់) និង (២).ស្រឡាញ់គ្នាទៅវិញទៅមក(យហ ១៣:៣៤–៣៥ និងការពន្យល់)។ ផ្នែកទីមួយមានការបកស្រាយនៅក្នុង ៤:១–៦ និង ផ្នែកទីពីរមាន នៅក្នុង ៤:៧–១២ ។

**៣:២៤** *យើងដឹងថា ទ្រង់គង់នៅក្នុងយើង ដោយសារព្រះវិញ្ញាណ* មើល រម ៨:១៦ និងការពន្យល់ ។

**៤:១** *វិញ្ញាណ* ពាក្យវិញ្ញាណក្នុងខនេះសំដៅទៅលើមនុស្ស ដែលត្រូវបានដឹកនាំដោយព្រះវិញ្ញាណ និងមនុស្សដែលត្រូវបានដឹកនាំដោយវិញ្ញាណអាក្រក់ ។ *ចូរល្បងវិញ្ញាណទាំងអស់វិញ* សូមធៀបនឹង ១ថន ៥:២១ និងការពន្យល់ ។ *ហោរា ក្លែងក្លាយ* ហោរាដែលពិតប្រាកដថ្លែងទំនាយដោយសារអំណាចព្រះវិញ្ញាណបរិសុទ្ធនៃព្រះ(២ពត ១:២១ និងការពន្យល់)។ ពួកហោរាក្លែងក្លាយដែលមាន ដូចជាពួកគ្រូបង្រៀន ខុសឆ្គងនៅសម័យលោកយ៉ូហានបាននិយាយដោយអំណាច នៃវិញ្ញាណដែលមិនមែនមកអំពីព្រះ ។ គ្រីស្ទបរិស័ទត្រូវមានការប្រុងប្រយ័ត្នចំពោះពួកហោរាក្លែងក្លាយ(មថ ៧:១៥ និងការពន្យល់ មក ១៣:២២ ១ធថ ៤:១ និងការពន្យល់ ២ពត ២:១ និងការពន្យល់)។

**៤:២** *សំគាល់* មានន័យថា អាចស្គាល់វិញ្ញាណអាក្រក់(យក ២:១៩ សូមធៀបនឹង មក ១:២៤) ហើយប្រកាសជាសាធារណៈ ។ *ព្រះយេស៊ូវគ្រីស្ទបានមកក្នុងសាច់ ឈាម* មើលការពន្យល់ ១:១ ។ មើលការពន្យល់ ១:១ ដែលនៅក្នុងនោះ លោកយ៉ូហានបានបង្រៀនផ្ទុយនឹងពួកគ្រូបង្រៀនខុសឆ្គងជាពិសេសពួកដែលនៅក្រុងកូរិនថូស ដែលបង្រៀនថាព្រះគ្រីស្ទ ដែលជាព្រះវិញ្ញាណបានយាងមកសណ្ឋិតព្រះយេស៊ូវដែលជាមនុស្ស នៅពេលដែលទ្រង់ទទួលបុណ្យជ្រមុជទឹក ហើយបានយាងចេញពីព្រះយេស៊ូវវិញនៅពេលដែលទ្រង់ជាប់ឆ្កាង គឺពួកគេចង់មានន័យថា នៅក្នុងការឆ្កាងនោះ ព្រះយេស៊ូវដែលជាមនុស្សបានស្លាប់ តែព្រះគ្រីស្ទដ៏ជាព្រះវិញ្ញាណទ្រង់មិនបានស្លាប់ទេ(មើលសេចក្ដីផ្ដើមត្រង់ពួកគ្រូបង្រៀនខុសឆ្គង)។

**៤:៣** *ដែលមិនព្រមថា ព្រះយេស៊ូវគ្រីស្ទបានមកក្នុងសាច់ឈាម* មើលការពន្យល់ ២:១៨ ។

**៤:៤** *ដែលមកពីព្រះ* មានន័យថា "កើតពីព្រះ"(២:២៩ ៣:៩–១០)។ *វិញ្ញាណទាំងនោះ* គឺពួកហោរាក្លែងក្លាយ(ខ.១)ដែលត្រូវបានដឹកនាំដោយវិញ្ញាណរបស់អាទទឹងនឹងព្រះគ្រីស្ទ(ខ.៣)។ *អានោះដែលនៅក្នុងលោកីយ* មានន័យថាពួក អារក្ស(មើល យហ ១២:៣១ និងការពន្យល់)។ នៅក្នុង ខ.៤–៥ ពាក្យ "លោកីយ" មានន័យថា សង្គមឬប្រព័ន្ធនៃពួកអ្នក ដែលមិនមែនកើតពីព្រះគ្រីស្ទ ដែលមានពួកទទឹងនឹងព្រះគ្រីស្ទជាដើម (មើលការពន្យល់ យហ ១:៩)។

**៤:៦** *វិញ្ញាណនៃសេចក្ដីខុសឆ្គង* សូមធៀបនឹង ៥:៦ យហ ១៤:១៧ និងមើលការពន្យល់ ។

**៤:៧–៥:៣** នៅក្នុងសំបុត្រនេះទាំងមូល មានការប្រើប្រាស់ពាក្យ "សេចក្ដីស្រឡាញ់" ចំនួន៤៣ដង ហើយនៅក្នុងវគ្គដ៏ខ្លីមួយនេះ មានប្រើ៣២ដង ។

**៤:៨** *មិនស្គាល់ទ្រង់* មានន័យថា អ្នកដែលមានសេចក្ដីស្រឡាញ់នៃព្រះទើប

នោះមិនស្គាល់ព្រះវិញ ពីព្រោះព្រះទ្រង់ជាសេចក្ដីស្រឡាញ់
នោះឯង[ខ] ៩សេចក្ដីស្រឡាញ់របស់ព្រះបានសំដែងមក ឱ្យ
យើងខ្ញុំស្គាល់ ដោយទ្រង់ចាត់ព្រះរាជបុត្រាទ្រង់តែ១[គ] ឱ្យ
មកក្នុងលោកីយ ដើម្បីឱ្យយើងរាល់គ្នាបានរស់ដោយសារ
ទ្រង់[ឃ] ១០នេះហើយជាសេចក្ដីស្រឡាញ់ មិនមែនជាយើង
បានស្រឡាញ់ព្រះនោះទេ គឺទ្រង់បានស្រឡាញ់យើងវិញ
ទេតើ[ង] ហើយបានចាត់ព្រះរាជបុត្រាទ្រង់ឱ្យមក ទុកជា
ដង្វាយឱ្យធួននឹងបាបយើងរាល់គ្នាផង[ច] ១១ពួកស្ងួនភ្ងាអើយ[ឆ]
បើព្រះបានស្រឡាញ់យើងរាល់គ្នាជាខ្លាំងទាំងម្ល៉េះ[ជ] នោះ
ត្រូវឱ្យយើងស្រឡាញ់គ្នាទៅវិញទៅមកដែរ[ឈ] ១២គ្មាន
អ្នកណាដែលឃើញព្រះឡើយ[ញ] តែបើយើងស្រឡាញ់
គ្នាទៅវិញទៅមក នោះព្រះទ្រង់គង់នៅក្នុងយើងហើយ
សេចក្ដី ស្រឡាញ់របស់ទ្រង់ បានពេញខ្នាតក្នុងយើងដែរ[ដ]
១៣គឺយ៉ាងនោះឯងដែលយើងដឹងថា[ឋ] យើងនៅជាប់ក្នុង
ទ្រង់ ហើយទ្រង់ក៏គង់នៅក្នុងយើង ពីព្រោះទ្រង់បានប្រទាន
ព្រះវិញ្ញាណទ្រង់មកយើងរាល់គ្នា[ឌ] ១៤ហើយយើងបាន
ឃើញ ក៏ធ្វើបន្ទាល់ថា[ឍ] ព្រះវរបិតាបានចាត់ព្រះរាជបុត្រា
មកធ្វើជាព្រះអង្គសង្គ្រោះនៃមនុស្សលោក[ណ] ។
១៥អ្នកណាដែលយល់ព្រមថា ព្រះយេស៊ូវ ជាព្រះរាជ
បុត្រានៃព្រះ[ត] អ្នកនោះឈ្មោះថា មានព្រះគង់នៅក្នុងខ្លួនពិត
ហើយខ្លួនក៏នៅក្នុងព្រះដែរ[ថ] ១៦យើងរាល់គ្នាបានស្គាល់
ហើយក៏ជឿចំពោះសេចក្ដីស្រឡាញ់ ដែលព្រះទ្រង់មាន
ដល់យើង ព្រះទ្រង់ជាតួសេចក្ដីស្រឡាញ់[ទ] ឯអ្នកណាដែល
នៅជាប់ក្នុងសេចក្ដីស្រឡាញ់ នោះក៏បាននៅជាប់ក្នុងព្រះ
ហើយព្រះទ្រង់គង់នៅក្នុងអ្នកនោះដែរ[ធ] ១៧គឺយ៉ាងនោះ
ហើយ ដែលសេចក្ដីស្រឡាញ់បានពេញខ្នាតក្នុងយើង[ន]
ដើម្បីឱ្យយើងមានសេចក្ដីក្លាហាន[ប]នៅថ្ងៃជំនុំជំរះ[ផ] ដ្បិត
ដែលព្រះទ្រង់ជាយ៉ាងណា នោះយើងរាល់គ្នាក៏យ៉ាងនោះ
នៅក្នុងលោកីយនេះដែរ ១៨គ្មានសេចក្ដីភ័យខ្លាចណា នៅ
ក្នុងសេចក្ដីស្រឡាញ់ឡើយ សេចក្ដីស្រឡាញ់ដែលពេញខ្នាត
នោះបណ្ដេញសេចក្ដីភ័យខ្លាចចេញ[ព] ពីព្រោះសេចក្ដីភ័យ
ខ្លាចតែជាប់មានសេចក្ដីវេទនា ហើយអ្នកណាដែលមាន
សេចក្ដីភ័យខ្លាច នោះមិនទាន់បានពេញខ្នាត ខាងឯសេចក្ដី
ស្រឡាញ់នៅឡើយទេ ១៩ឯយើងរាល់គ្នា យើងស្រឡាញ់
ទ្រង់ ពីព្រោះទ្រង់បានស្រឡាញ់យើងជាមុន[ភ] ។
២០បើអ្នកណាថា ខ្លួនស្រឡាញ់ព្រះ តែស្អប់ដល់បងប្អូន
វិញ[ម] អ្នកនោះជាអ្នកកុហក[យ] ដ្បិតអ្នកណាដែលមិនស្រឡាញ់
បងប្អូនដែលបានមើលឃើញទៅហើយ[រ] នោះធ្វើដូចម្ដេច
ឡើយ ឱ្យស្រឡាញ់ដល់ព្រះ ដែលមើលមិនឃើញទៅបាន[ល]
២១មួយទៀត យើងបានទទួលបញ្ញត្តិនេះ[វ]ពីព្រះមកថា អ្នក
ណាដែលស្រឡាញ់ដល់ព្រះ នោះត្រូវតែស្រឡាញ់ដល់បង
ប្អូនដែរ[ស] ។

## សេចក្ដីជំនឿលើព្រះរាជបុត្រានៃព្រះ

**៥** ១អស់អ្នកណាដែលជឿថា[ហ] ព្រះយេស៊ូវជាព្រះគ្រីស្ទ[ឡ]
អ្នកនោះបានកើតពីព្រះមក[អ] ហើយអស់ទាំងអ្នកណាដែល

**៤:៨** ខ ខ.៧,១៦
**៤:៩** គ យហ ១:១៨
ឃ យហ ៣:១៦,១៧
១យហ ៥:១១
**៤:១០** ង រម
៥:៨,១០
ច រម ៣:២៥
**៤:១១** ឆ ១កថ
១០:១៤
ជ យហ ៣:១៦
ឈ យហ ១៥:១២
១យហ ៣:១១
**៤:១២** ញ យហ
១:១៨ ដ ខ.១៧
១យហ ២:៥
**៤:១៣** ឋ ១យហ
២:៣
ឌ ១យហ ៣:២៤
**៤:១៤** ឍ យហ
១៥:២៧ ណ លក
២:១១
យហ ៣:១៧
**៤:១៥** ត ១យហ
២:២៣ ៥:៥
ថ ១យហ ៣:២៤
**៤:១៦** ទ ខ.៨
ធ ខ.១២,១៣
១យហ ៣:២៤
**៤:១៧** ន ខ.១២
១យហ ២:៥ ប អភ
៣:១២ ផ មថ
១០:១៥

**៤:១៨** ព រម ៨:១៥ **៤:១៩** ភ ខ.១០ **៤:២០** ម ១យហ ១:៦ ២:៤ យ ១យហ
២:៩ រ ១យហ ៣:១៧ **៤:២០** ល ខ.១២ យហ ១:១៨ **៤:២១** វ ១យហ ២:៧
ស មថ ៥:៤៣ ១យហ ២:៩ **៥:១** ហ យហ ៣:១៥ ឡ ១យហ ២:២២
៤:២,១៥ អ យហ ១:១៣ ១យហ ២:២៣

ជាអ្នកដែលពិតជាស្គាល់ទ្រង់ ។ *ព្រះទ្រង់ជាសេចក្ដីស្រឡាញ់* ព្រះទ្រង់ ជាសេចក្ដីស្រឡាញ់ ហើយទ្រង់ធ្វើគ្រប់ការទាំងអស់ដោយសេចក្ដីស្រឡាញ់ ។ ព្រះគម្ពីរ យ៉ូហានក៏បានបង្ហាញផងដែរថា ព្រះទ្រង់ជាវិញ្ញាណ (យហ ៤:២៤ និងការពន្យល់) ពន្លឺ (១:៥ និងការពន្យល់) ទ្រង់បរិសុទ្ធមានអំណាចចេស្ដា ស្មោះត្រង់ ទ្រង់ជាសេចក្ដីពិត ហើយទ្រង់មានយុត្តិធម៌ ។

**៤:៩** *ព្រះរាជបុត្រាទ្រង់តែ១* មើល យហ ១:១៨ ៣:១៦ និងការពន្យល់ ។

**៤:១០** *ដង្វាយឱ្យធួននឹងបាបយើងរាល់គ្នា* មើលការពន្យល់ ២:២ ។

**៤:១២** *គ្មានអ្នកណាដែលឃើញព្រះ* មើលការពន្យល់ យហ ១:១៨ ។ ដោយសារសេចក្ដីស្រឡាញ់របស់យើង មានប្រភពពីសេចក្ដីស្រឡាញ់នៃព្រះ នោះយើងអាចបង្ហាញសេចក្ដីស្រឡាញ់នៃទ្រង់ឱ្យបានពេញលេញដោយស្រឡាញ់អ្នកដទៃ ។ ដូចនេះគេអាចមើលឃើញ ព្រះដែល" មនុស្សគ្រប់គ្នាមិនអាចឃើញ" តាមរយៈអ្នក ជឿដែលស្រឡាញ់ដល់អ្នកដទៃ ពីព្រោះទ្រង់គង់ក្នុងពួកគេ ។

**៤:១៣–១៤** *ព្រះវិញ្ញាណ . . . ព្រះវរបិតា . . . ព្រះរាជបុត្រា* មើលការពន្យល់ មថ ២៨:១៩ ។

**៤:១៣** *ប្រទានព្រះវិញ្ញាណ* មើល ៣:២៤ និងការពន្យល់ ។

**៤:១៦** *ព្រះទ្រង់ជាតួសេចក្ដីស្រឡាញ់* មើលការពន្យល់ ខ.៨ ។

**៤:១៧** *ក៏យ៉ាងនោះ* មានន័យថា បានដូចព្រះគ្រីស្ទដែរ ។ ការដែលអ្នកជឿបាន ដូចព្រះគ្រីស្ទនៅក្នុងសេចក្ដីស្រឡាញ់មានន័យថា ព្រះដ៏ជាសេចក្ដីស្រឡាញ់ទ្រង់គង់ក្នុងពួកគេ ដូចនេះពួកគេអាចជឿជាក់ថា ពួកគេនឹងបានសេចក្ដីសង្គ្រោះនៅថ្ងៃជំនុំជម្រះ ។

**៤:១៨** *គ្មានសេចក្ដីភ័យខ្លាចណា នៅក្នុងសេចក្ដីស្រឡាញ់* មានន័យថា ឱ្យតែគ្រីស្ទបរិស័ទមានសេចក្ដីស្រឡាញ់ដែលពេញខ្នាតចំពោះព្រះ ពួកគេនឹងមិនមានសេចក្ដីភ័យខ្លាចចំពោះការអ្វីទាំងអស់ ហើយពួកគេនឹងមិនភ័យខ្លាចនៅពេលការជំនុំជម្រះមកដល់ឡើយ ។

**៤:១៩** ព្រះទ្រង់ជាប្រភពនៃសេចក្ដីស្រឡាញ់ ហើយមានតែទ្រង់ទេដែលអាចប្រទានសេចក្ដីស្រឡាញ់ពេញខ្នាតបាន ដូចនេះសេចក្ដីស្រឡាញ់ ដែលពេញខ្នាតមិនអាចកើតឡើងពីមនុស្ស ដែលជាស្នាព្រះហស្តរបស់ទ្រង់ឡើយ ។

**៤:២១** *បញ្ញត្តិនេះ* មើល យហ ១៣:៣៤ និងការពន្យល់ ។

**៥:១** *អ្នកណាដែលជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទ អ្នកនោះបានកើតពីព្រះមក* ការមានជំនឿថា ព្រះគ្រីស្ទគឺជាព្រះមែស៊ីបង្ហាញពីការមានកំណើតថ្មី ។ *ព្រះគ្រីស្ទ* មើលការពន្យល់ ២:២២ ។ *អស់ទាំងអ្នកណាដែល*

ស្រឡាញ់ព្រះដ៏បង្កើតខ្លួនមក នោះក៏រមែងស្រឡាញ់ដល់
អស់អ្នកឯទៀត ដែលកើតពីទ្រង់មកដែរ[ក] ២កាលណាយើង
ស្រឡាញ់ដល់ព្រះ ហើយកាន់តាមអស់ទាំងបញ្ញត្តរបស់ទ្រង់
នោះយើងដឹងថា[ខ] យើងស្រឡាញ់ដល់ពួកកូនរបស់ព្រះដែរ[គ]
៣ដ្បិតនេះហើយជាសេចក្ដីស្រឡាញ់ដល់ព្រះ គឺឱ្យយើងកាន់
តាមអស់ទាំងបញ្ញត្តិរបស់ទ្រង់[ឃ] ឯបញ្ញត្តទ្រង់នោះមិនមែន
ជាបន្ទុកដ៏ធ្ងន់ទេ[ង] ៤ពីព្រោះគ្រប់ទាំងអស់ដែលកើតពី
ព្រះមក[ច] នោះបានឈ្នះលោកីយហើយ ឯជ័យជំនះដែល
ឈ្នះ[ឆ]លោកីយ នោះគឺជាសេចក្ដីជំនឿរបស់យើង ៥តើអ្នក
ណាជាអ្នកឈ្នះលោកីយ បើមិនមែនជាអ្នកដែលជឿថា
ព្រះយេស៊ូវ ជាព្រះរាជបុត្រានៃព្រះ[ជ]។

៦គឺព្រះយេស៊ូវគ្រីស្ទនេះហើយ ដែលយាងមកដោយទឹក
ហើយនឹងឈាម[ឈ] មិនមែនដោយទឹកតែប៉ុណ្ណោះ គឺទាំងទឹក
ទាំងឈាមផង គឺជាព្រះវិញ្ញាណដែលធ្វើបន្ទាល់ ដ្បិតព្រះ
វិញ្ញាណទ្រង់ជាសេចក្ដីពិត[ញ] ៧មានសាក្សី ៣ អង្គ[ដ]ដែលធ្វើ
បន្ទាល់នៅស្ថានសួគ៌ គឺជាព្រះវរបិតា ១ ព្រះបន្ទូល ១ នឹង

**៥:១** ក យហ ៨:៤២
**៥:២** ខ ១យហ ២:៣
គ ១យហ ៣:១៤
**៥:៣** ឃ យហ ១៤:១៥
ង មថ ១១:៣០ ២៣:៤
**៥:៤** ច យហ ១:១៣
ឆ យហ ១៦:៣៣
**៥:៥** ជ ខ.១ ១យហ ២:២៣
**៥:៦** ឈ យហ ១៩:៣៤
ញ យហ ១៤:១៧
**៥:៧** ដ មថ ១៨:១៦
**៥:៩** ឋ យហ ៥:៣៤
ឌ មថ ៣:១៦,១៧ យហ ៥:៣២,៣៧ ៨:១៧,១៨

ព្រះវិញ្ញាណបរិសុទ្ធ ១ តែទាំង៣អង្គនេះរួមមកតែ ១ ទេ
៨ហើយមាន ៣ មុខទៀត ដែលធ្វើបន្ទាល់នៅផែនដីដែរ
គឺជាព្រះវិញ្ញាណ១ ទឹក១ និងឈាម១ ទាំង៣ នេះក៏ត្រូវគ្នា
ដែរ ៩បើសិនជាយើងបានទទួលសេចក្ដីបន្ទាល់របស់មនុស្ស
ទៅហើយ[ឋ] នោះសេចក្ដីបន្ទាល់របស់ព្រះ ក៏ប្រសើរជាង
ទៅទៀត ដ្បិតសេចក្ដីបន្ទាល់របស់ព្រះ[ឌ] គឺជាសេចក្ដីដែល
ទ្រង់ថ្លែងប្រាប់ ពីព្រះរាជបុត្រានៃទ្រង់ ១០អ្នកណាដែលជឿ
ដល់ព្រះរាជបុត្រានៃព្រះ នោះមានសេចក្ដីបន្ទាល់ នៅក្នុង
ខ្លួនហើយ[ឍ] តែអ្នកណាដែលមិនជឿដល់ព្រះសោះ នោះ
ឈ្មោះថា បានធ្វើឱ្យទ្រង់ទៅជាអ្នកកុហកវិញ[ណ] ពីព្រោះ
មិនបានជឿដល់សេចក្ដីបន្ទាល់ ដែលទ្រង់បានធ្វើពីដំណើរ
ព្រះរាជបុត្រានៃទ្រង់ ១១នេះហើយជាសេចក្ដីបន្ទាល់នោះ
គឺថា ព្រះទ្រង់បានប្រទានជីវិតដ៏នៅអស់កល្បជានិច្ចមក
យើងរាល់គ្នា[ត] ហើយជីវិតនោះ គឺនៅក្នុងព្រះរាជបុត្រា

**៥:១០** ឍ រម ៨:១៦ កទ ៤:៦ ណ យហ ៣:៣៣ ១យហ ១:១០
**៥:១១** ត មថ ២៥:៤៦

*ស្រឡាញ់ព្រះដ៏បង្កើតខ្លួនមក នោះក៏រមែងស្រឡាញ់ដល់អស់អ្នកឯទៀត ដែលកើតពីទ្រង់មកដែរ* មានន័យថា អ្នកដែលស្រឡាញ់ព្រះតែងស្ដាប់បង្គាប់តាមព្រះ ហើយស្រឡាញ់ដល់កូនរបស់ ទ្រង់ផងដែរ ។

**៥:៣** *នេះហើយជាសេចក្ដីស្រឡាញ់ដល់ព្រះ គឺឱ្យយើងកាត់តាមអស់ទាំងបញ្ញត្តិ របស់ទ្រង់* សូមផ្ទៀបនឹង យក ១៤:១៥,២១ និងការពន្យល់ ។ *ឯបញ្ញត្តិទ្រង់ នោះមិនមែនជាបន្ទុកដ៏ធ្ងន់* មិនមែនព្រោះតែបញ្ញត្តិរបស់ព្រះជាបន្ទុកដ៏ស្រាល ដែលងាយកាត់តាមនោះទេ ប៉ុន្តែ ដោយសារ ព្រះវិញ្ញាណទ្រង់ជួយដល់អ្នកដែលបាន កើតជាថ្មីឱ្យអាចកាន់តាមបញ្ញត្តិរបស់ព្រះ ។

**៥:៤** *បានឈ្នះ . . . ឈ្នះលោកីយ* ការឈ្នះលោកីយមានន័យថាឈ្នះការរស់នៅ ប្រកបដោយអំពើបាបរបស់លោកីយ ដោយស្ដាប់បង្គាប់ព្រះ(ខ.៣)។ ការស្ដាប់បង្គាប់នេះមិនជាការដែលអ្នកជឿព្រះមិនអាចធ្វើបាននោះទេ ព្រោះពួកគេបានកើតជាថ្មី ហើយព្រះវិញ្ញាណទ្រង់គង់ក្នុងពួកគេ ហើយប្រទានពួកគេនូវកម្លាំង ។ តាមព្រះគម្ពីរយ៉ូហាន មានជ័យជម្នះពីរប្រភេទ (១).ជ័យជម្នះដែលកើតឡើងពីការឈប់មានជំនឿលើលោកិយ ហើយផ្លាស់ ប្រែជាមានជំនឿលើព្រះវិញ(“បាន ឈ្នះ”) (២).ជ័យជម្នះរបស់គ្រិស្ទបរិស័ទនៅក្នុងជីវិតរស់នៅ ដែលបន្តមានពីថ្ងៃមួយទៅថ្ងៃមួយទៀត(“ឈ្នះ”)។ *លោកីយ* មើលការពន្យល់ ២:១៥ ។

**៥:៥** *ព្រះរាជបុត្រានៃព្រះ* សូមមើល ២:២២ ៤:២ ៥:១ និងការពន្យល់ ។

**៥:៦** ទឹកជានិមិត្តរូបនៃការទទួលបុណ្យជ្រមុជទឹករបស់ព្រះគ្រីស្ទ ហើយព្រះលោហិតជានិមិត្តរូបនៃការសុគតរបស់ទ្រង់ ។ នៅក្នុងសម័យលោកយ៉ូហានមានការបង្រៀនខុសឆ្គងថា ចាប់តាំងពីពេលព្រះយេស៊ូវទ្រង់ប្រសូត្រ ទ្រង់គ្រាន់តែជាមនុស្សប៉ុណ្ណោះ ហើយទាល់តែដល់ពេល ទទួលបុណ្យ ជ្រមុជទឹក ទើបទ្រង់បានក្លាយជាព្រះផងមនុស្សផង ។ ពួកគ្រូខុសឆ្គងទាំងនោះបានអះអាងថាព្រះមែស៊ី(ព្រះរាជបុត្រានៃព្រះ) បានយាងមកសណ្ឋិតព្រះយេស៊ូវដែលគ្រាន់តែជាមនុស្ស ហើយបានយាងចេញពីទ្រង់វិញ នៅមុនពេលទ្រង់រងទុក្ខនៅលើឈើឆ្កាង ដូចនេះព្រះយេស៊ូវដែលជាមនុស្សបានសុគតតែមួយអង្គឯងប៉ុណ្ណោះ ។ តាមព្រះគម្ពីរនេះព្រះ យេស៊ូវទ្រង់ជាព្រះហើយក៏ជាមនុស្សផងដែរ(១:១–៤ ៤:២ ៥:៥) ហើយទ្រង់ បានយាងមកក្នុងលោកិយនេះ ទ្រង់បានទទួលបុណ្យជ្រមុជទឹក ហើយទ្រង់បានសុគត ។ ព្រះយេស៊ូវទ្រង់ទ្រង់ជាព្រះរាជបុត្រានៃព្រះ មិនគ្រាន់តែនៅពេលទ្រង់ទទួលបុណ្យជ្រមុជទឹកប៉ុណ្ណោះទេ ប៉ុន្តែថែមនៅពេលដែលទ្រង់សុគតផងដែរ (ខ.៦)។ សេចក្ដីពិតនេះសំខាន់ណាស់ ព្រោះថាបើព្រះយេស៊ូវបានសុគតក្នុងភាពជាមនុស្សតែម្យ៉ាង ដង្វាយឱ្យធួននឹងបាបរបស់ទ្រង់(២:២ ៤:១០)មិនមាន លក្ខណៈគ្រប់គ្រាន់នៅក្នុងការលោះបាបមនុស្សបានឡើយ ។ *ព្រះវិញ្ញាណដែលធ្វើបន្ទាល់* ព្រះវិញ្ញាណទ្រង់ធ្វើបន្ទាល់ថាព្រះយេស៊ូវទ្រង់ជាព្រះរាជបុត្រានៃព្រះតាមវិធីពីរយ៉ាង (១).ព្រះវិញ្ញាណទ្រង់បានយាងមកសណ្ឋិតព្រះយេស៊ូវនៅពេល ទ្រង់ទទួលបុណ្យជ្រមុជទឹក(យហ ១:៣២–៣៤) ហើយ (២).ព្រះវិញ្ញាណទ្រង់ បានបន្តធ្វើការបញ្ជាក់នៅក្នុងចិត្តរបស់អ្នកជឿ ហើយការធ្វើបន្ទាល់របស់ពួកសាវកថាការទទួលបុណ្យជ្រមុជទឹកនិងការសុគតនៃព្រះយេស៊ូវបានបញ្ជាក់ ថា ទ្រង់ជាព្រះមែស៊ីឬព្រះរាជបុត្រានៃព្រះ(២:២៧ ១កថ ១២:៣ និងការពន្យល់)។

**៥:៧** *៣អង្គ* តាមច្បាប់ក្នុងសញ្ញាចាស់ សាក្សីត្រូវមានចំនួន “ពីរឬបីនាក់” (ចទ ១៧:៦ និងការពន្យល់)។ សាក្សីទាំងបីអង្គដែលធ្វើបន្ទាល់នៅស្ថានសួគ៌ គឺជាសាក្សីដែលមិនអាចខ្វះបានឡើយ ។

**៥:៩** *សេចក្ដីបន្ទាល់របស់ព្រះ ក៏ប្រសើរជាងទៅទៀត* មានន័យថា ជាសេចក្ដីបន្ទាល់ ដែលមានអំណាចជាង ហើយគួរឱ្យទទួលយកជាង គឺជាសេចក្ដីបន្ទាល់ដែលព្រះវរបិតារួមជាមួយនឹងព្រះបន្ទូល និងព្រះវិញ្ញាណបានធ្វើបន្ទាល់ពីព្រះរាជបុត្រាថា ទ្រង់ជាព្រះអង្គសង្គ្រោះនៃពិភពលោក ។

**៥:១១** *ប្រទានជីវិតដ៏នៅអស់កល្បជានិច្ច* មានន័យថាប្រទានឱ្យមានជីវិតអស់កល្បចាប់ពីពេលទទួលជឿព្រះ(ការពន្យល់ យហ ៣:១៥,៣៦)។

នៃទ្រង់[ថ] ១២ឯអ្នកណាដែលមានព្រះរាជបុត្រា នោះក៏មាន
ជីវិតដែរ តែអ្នកណាដែលគ្មានព្រះរាជបុត្រានៃព្រះទេ
នោះគ្មានជីវិតឡើយ[ទ] ។

## សេចក្ដីបញ្ចប់

១៣ខ្ញុំបានសរសេរសេចក្ដីទាំងនេះ ផ្ញើមកអ្នករាល់គ្នា
ដែលជឿដល់ព្រះនាមព្រះរាជបុត្រានៃព្រះ[ធ] ដើម្បីឱ្យអ្នក
រាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ច
ហើយ[ន] ១៤យើងក៏មានសេចក្ដីក្លាហាន[ប] ដល់ទ្រង់យ៉ាងដូច្នេះ
ដែរ គឺថា បើយើងនឹងសូមអ្វី ដែលត្រូវតាមព្រះហឫទ័យ
ទ្រង់ នោះទ្រង់នឹងទទួលព្រម[ផ] ១៥បើយើងដឹងថាទ្រង់ទទួល
ព្រមតាមយើង ក្នុងការអ្វីដែលយើងសូមដូច្នេះ នោះយើង
ក៏ដឹងថា[ព] យើងបានអ្វីដែលយើងសូមពីទ្រង់ហើយដែរ[ភ] ។
១៦បើអ្នកណាឃើញបងប្អូនកំពុងតែធ្វើបាប គឺជាបាប
ដែលមិនមានទោសដល់ស្លាប់ទេ នោះត្រូវសូមចុះទ្រង់នឹង
ប្រទានជីវិតមកដល់អស់អ្នកធ្វើបាប[ម] ដែលមិនមែនមាន
ទោសដល់ស្លាប់នោះជាពិត តែមានបាបម្យ៉ាងដែលមាន
ទោសដល់ស្លាប់វិញ[យ] ឯបាបនោះខ្ញុំមិនថា ឱ្យសូមអង្វរឱ្យ

**៥:១១** ថ យហ ១:៤
**៥:១២** ទ យហ ៣:១៥,១៦,៣៦
**៥:១៣** ធ ១យហ ៣:២៣ ន ខ.១១ មថ ២៥:៤៦
**៥:១៤** ប អភ ៣:១២ ១យហ ៣:២១ ផ មថ ៧:៧
**៥:១៥** ព ខ.១៨,១៩,២០ ភ ១ពរ ៣:១២
**៥:១៦** ម យក ៥:១៥ យ នក ២៣:២១ ហព ៦:៤-៦ ១០:២៦ រ យរ ៧:១៦ ១៤:១១
**៥:១៧** ល ១យហ ៣:៤ វ ខ.១៦ ១យហ ២:១
**៥:១៨** ស យហ ១:១៣

ទេ[រ] ១៧គ្រប់ទាំងអំពើទុច្ចរិត សុទ្ធតែជាបាបទាំងអស់[ល]
ហើយក៏មានបាបខ្លះ ដែលមិនមានទោសដល់ស្លាប់ដែរ[វ]
១៨យើងដឹងថា អ្នកណាដែលកើតពីព្រះមក[ស] នោះមិន
ចេះធ្វើបាបទេ អ្នកនោះឯងជាអ្នករក្សាខ្លួនវិញ ហើយ
មេកំណាច[ហ]នឹងពាល់អ្នកនោះមិនបានឡើយ[ឡ] ១៩យើងដឹង
ថា យើងមកពីព្រះពិត[អ] តែលោកីយទាំងមូលដេកនៅក្នុង
ឱវាទនៃមេកំណាចវិញ[ក] ២០យើងក៏ដឹងថា ព្រះរាជបុត្រា
នៃព្រះបានយាងមកហើយ[ខ] ក៏បានប្រទានឱ្យយើងរាល់គ្នា
ប្រាជ្ញា[គ] ដើម្បីឱ្យបានស្គាល់ព្រះដ៏ពិតប្រាកដ[ឃ] យើងរាល់គ្នា
ជាអ្នកនៅក្នុងព្រះដ៏ពិតប្រាកដនោះ គឺក្នុងព្រះយេស៊ូវគ្រីស្ទ
ជាព្រះរាជបុត្រានៃទ្រង់ ព្រះអង្គនោះឯងជាព្រះពិតប្រាកដ
ហើយជាជីវិតអស់កល្បជានិច្ចផង[ង] ។
២១កូនតូចៗរាល់គ្នាអើយ[ច] ចូរឱ្យអ្នករាល់គ្នារក្សាខ្លួន
ឱ្យផុតពីរូបព្រះចេញ[ឆ] ។ អាម៉ែន ។

ហ មថ ៥:៣៧ ឡ យហ ១៤:៣០ **៥:១៩** អ ១យហ ៤:៦ ក យហ ១២:៣១ ១៤:៣០ ១៧:១៥ **៥:២០** ខ ខ.៥ គ លក ២៤:៤៥ ឃ យហ ១៧:៣ ង ខ.១១ មថ ២៥:៤៦ **៥:២១** ច ១យហ ២:១ ឆ ១កថ ១០:១៤ ១ថន ១:៩

**៥:១៣** ខនេះបានបញ្ជាក់ម្ដងទៀតអំពីគោលបំណងនៃសំបុត្រនេះ (២:២៦ និងការ ពន្យល់) ។ មើលសេចក្ដីផ្ដើមត្រង់ ឱកាស និងគោលបំណង ។

**៥:១៤** *បើយើងនឹងសូមអ្វី ដែលត្រូវតាមព្រះហឫទ័យទ្រង់* សូមធៀបនឹង លក ២២:២៤ ។ ចំពោះសេចក្ដីអធិស្ឋានសូមមើល ៣:២១-២២ ។

**៥:១៦** ខ.១៦-១៧ និយាយអំពីការអធិស្ឋានទូលសូម ដែលព្រះទ្រង់នឹងឆ្លើយតប (ខ.១៤-១៥) ។ *បងប្អូន* មានន័យថា អ្នកណាក៏ដោយឱ្យ តែកំពុងតែធ្វើបាប ។ *ដែលមានទោសដល់ស្លាប់* បាបដែលមានទោសដល់ស្លាប់អាចជាបាបដែលព្រះ ទ្រង់សម្រេចព្រះទ័យដាក់ទោសដោយតម្រូវឱ្យអ្នកប្រព្រឹត្តនោះស្លាប់ ។

**៥:១៨-២០** *យើងដឹង* សំបុត្រនេះបានបញ្ចប់ទៅវិញ ដោយពាក្យដែលគួរឱ្យគត់សំគាល់ដែលបញ្ជាក់ការពិតថា "យើងដឹង" និងសង្ខេបខ្លឹមសារសំខាន់ៗ មួយចំនួនរបស់សំបុត្រនេះ ។

**៥:១៨** *អ្នកណាដែលកើតពីព្រះមក* មានន័យថាអ្នកដែលជឿ និងស្រឡាញ់ទ្រង់ ។

**៥:២០** *ព្រះដ៏ពិតប្រាកដ* ព្រះយេស៊ូវទ្រង់ជាព្រះពិតដ៏មានព្រះជន្មគង់នៅជានិច្ច ។ *ជីវិតអស់កល្បជានិច្ច* សំបុត្រនេះបានចាប់ផ្ដើម(១:១-២) និងបញ្ចប់ទៅវិញ ដោយពាក្យនេះ ។

**៥:២១** *ឱ្យផុតពីរូបព្រះ* មានន័យថា ឱ្យផុតពីការថ្វាយបង្គំព្រះក្លែងក្លាយពីការថ្វាយបង្គំរូបសត្វ ហើយឱ្យផុតពីចិត្តដែលស្រឡាញ់ ស្រេកឃ្លាន និងកោតខ្លាចដល់អ្វីមួយ ជាជាងដល់ព្រះអម្ចាស់ ។

# សំបុត្រទី២
# របស់យ៉ូហាន

សេចក្ដីផ្ដើម

**អ្នកនិពន្ធ**

អ្នកនិពន្ធកណ្ឌគម្ពីរយ៉ូហានទី២នេះគឺលោកយ៉ូហានជាសាវករបស់ព្រះយេស៊ូវគ្រីស្ទ ។ ភាពដូចគ្នារវាងកណ្ឌគម្ពីរយ៉ូហានទី១ និងយ៉ូហានទី២ ហើយនិងគណ្ឌគម្ពីរដំណឹងល្អយ៉ូហានបានអះអាងថា អ្នកនិពន្ធកណ្ឌគម្ពីរទាំងបីនេះគឺជាមនុស្សតែមួយ ។ សូមប្រៀបធៀបចំណុចខាងក្រោម:

| | | |
|---|---|---|
| ២យហ ៥ | ១យហ ២:៧ | យហ ១៣:៣៤–៣៥ |
| ២យហ ៦ | ១យហ ៥:៣ | យហ ១៤:២៣ |
| ២យហ ៧ | ១យហ ៤:២–៣ | |
| ២យហ ១២ | ១យហ ១:៤ | យហ ១៥:១១ ១៦:២៤ |

សូមមើលសេចក្ដីផ្ដើមកណ្ឌគម្ពីរយ៉ូហានទី១ និងកណ្ឌគម្ពីរដំណឹងល្អយ៉ូហាន ត្រង់ចំណុចអ្នកនិពន្ធ ។

**កាលបរិច្ឆេទ**

តាមរយៈការប្រៀបធៀបខាងលើ សំបុត្រនេះអាចត្រូវបានសរសេរឡើងដំណាលគ្នានឹងសំបុត្រយ៉ូហានទី១ដែរ គឺនៅឆ្នាំទី៨៥–៩៥គ.ស (សូមមើលសេចក្ដីផ្ដើម ១យហ ត្រង់ចំណុចកាលបរិច្ឆេទ)។

**ឱកាស និងគោលបំណង**

ក្នុងអំឡុងពេលសតវត្សរ៍ទីមួយ និងទីពីរ ដំណឹងល្អត្រូវបានផ្សាយពីកន្លែងមួយទៅកន្លែងមួយទៀត តាមរយៈអ្នកផ្សាយដំណឹងល្អ និងគ្រូបង្រៀនព្រះបន្ទូលនៃព្រះអម្ចាស់ ។ តាមទម្លាប់របស់ពួកអ្នកជឿនាសម័យនោះ គឺតែងទទួលបេសកជនឱ្យចូលស្នាក់នៅផ្ទះរបស់ពួកគេ និងផ្គត់ផ្គង់ម្ហូបអាហារ ហើយឧបត្ថមនូវសេចក្ដីត្រូវការផ្សេងៗ នៅពេលដែលពួកគ្រូទាំងនោះបានចាកចេញ ។ ដោយព្រោះតែមានពួកគ្រូខុសឆ្គងបានអនុវត្តនូវការទាំងនេះដែរ (មើលការពន្យល់ ៣យហ ៥) ទើបកណ្ឌគម្ពីរយ៉ូហានទី២នេះត្រូវបានសរសេរឡើង ដើម្បីឱ្យពួកជំនុំមានការប្រុងប្រយ័ត្នក្នុងការទំនុកបម្រុងពួកគ្រូទាំងឡាយ ដែលធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ បើមិនដូច្នោះទេនឹងមានកំហុសអចេតនាចំពោះការផ្គត់ផ្គង់ដល់ពួកគ្រូខុសឆ្គង ជាជាងការផ្គត់ផ្គង់ដល់ពួកគ្រូដែលបង្រៀនសេចក្ដីពិត ។

**គម្រោងសង្ខេប**

**I. ពាក្យជម្រាបសួរ (១:១២)**

**II. ការសរសើរ (៤)**

**III. ការទូន្មាន និងការព្រមាន (៥–១១)**

**IV. សេចក្ដីសន្និដ្ឋាន និងពាក្យបណ្ដាំចុងក្រោយ (១២–១៣)**

១សំបុត្រអ្នកចាស់ទុំ[ក] ផ្ញើមកលោកស្រីរើសតាំង[ខ] និងកូន
ចៅរបស់លោកស្រី ដែលខ្ញុំស្រឡាញ់ពិតប្រាកដ[គ] មិនមែន
តែខ្ញុំ១ គឺព្រមទាំងអស់អ្នកដែលស្គាល់សេចក្ដីពិតផងដែរ[ឃ]
២ដោយព្រោះសេចក្ដីពិត[ង] ដែលនៅក្នុងយើងរាល់គ្នា[ច]
ហើយក៏នៅជាមួយនឹងយើងជាដរាប ៣សូមឱ្យអ្នករាល់គ្នា
បានប្រកបដោយព្រះគុណ និងសេចក្ដីមេត្តាករុណា ហើយ
និងសេចក្ដីសុខសាន្ត អំពីព្រះដ៏ជាព្រះវរបិតា ហើយអំពី
ព្រះអម្ចាស់យេស៊ូវគ្រីស្ទ[ឆ] ជាព្រះរាជបុត្រានៃព្រះវរបិតា គឺ
ដោយសេចក្ដីពិត និងសេចក្ដីស្រឡាញ់ ។

៤ខ្ញុំមានសេចក្ដីអំណរជាខ្លាំងណាស់ ដោយបានឃើញ
កូនចៅខ្លះរបស់លោកស្រី ដែលប្រព្រឹត្តតាមសេចក្ដីពិត[ជ]
ដូចជាព្រះវរបិតាបានបង្គាប់មកយើងរាល់គ្នា ៥ឥឡូវនេះ
លោកស្រីអើយ ដែលខ្ញុំសរសេរផ្ញើមកនេះ មិនមែនដូចជា
បង្គាប់ដល់លោកស្រីទេ គឺខ្ញុំសូមអង្វរវិញថា ឱ្យយើងរាល់
គ្នាមានសេចក្ដីស្រឡាញ់ដល់គ្នាទៅវិញទៅមកចុះ ដូចជាតាំង
ពីដើមរៀងមក[ឈ] ៦នេះហើយជាសេចក្ដីស្រឡាញ់[ញ]គឺឱ្យ
យើងរាល់គ្នាប្រព្រឹត្តតាមបញ្ញត្តទ្រង់[ដ] ឯសេចក្ដីបញ្ញត្តិ នោះ
គឺដូចជាបានឮតាំងតែពីដើមរៀងមក[ឋ] ដើម្បីឱ្យបាន ប្រព្រឹត្ត
តាម ៧ពីព្រោះមានអ្នកប្រវ័ញ្ចបញ្ឆោត ជាច្រើនបានមកក្នុង
លោកីយហើយ[ឌ] ជាពួកអ្នកដែលមិនព្រមទទួលថា ព្រះ
យេស៊ូវគ្រីស្ទ[ឍ]បានមកក្នុងសាច់ឈាមទេ[ណ] នោះហើយជា
អ្នកប្រវ័ញ្ចបញ្ឆោត ហើយជាអ្នកទទឹងនឹងព្រះគ្រីស្ទផង[ត]
៨ត្រូវឱ្យអ្នករាល់គ្នាប្រយ័ត្ន ក្រែងបាត់ផលការដែលបានធ្វើ
ហើយនោះ គឺឱ្យបានទទួលរង្វាន់ដ៏ពេញលេញវិញ[ថ] ៩អ្នក
ណាដែលប្រព្រឹត្តរំលង ហើយមិនកាន់ខ្ជាប់ក្នុងសេចក្ដី
បង្រៀនរបស់ព្រះគ្រីស្ទ[ទ] អ្នកនោះជាអ្នកគ្មានព្រះទេ តែអ្នក
ណាដែលកាន់ខ្ជាប់ ក្នុងសេចក្ដីបង្រៀនរបស់ព្រះគ្រីស្ទវិញ
អ្នកនោះមានទាំងព្រះវរបិតា នឹងព្រះរាជបុត្រាផង[ធ] ១០បើ
អ្នកណាមកឯអ្នករាល់គ្នា តែមិនបង្រៀនចំពោះសេចក្ដីនេះ
នោះកុំឱ្យទទួលអ្នកនោះនៅក្នុងផ្ទះឡើយ កុំឱ្យទាំងជំរាបសួរ
ដល់អ្នកនោះផង[ន] ១១ដ្បិតបើអ្នកណាជំរាបសួរ នោះក៏តែង
មានសេចក្ដីប្រកបគ្នា[ប] ក្នុងការអាក្រក់របស់អ្នកនោះដែរ ។

១២ខ្ញុំមានសេចក្ដីជាច្រើន នឹងសរសេរផ្ញើមកអ្នករាល់
គ្នា តែមិនចង់សរសេរនៅក្រដាស ដោយទឹកខ្មៅនោះទេ
ដ្បិតខ្ញុំសង្ឃឹមថា នឹងមកសួរអ្នករាល់គ្នា ហើយនិងនិយាយ
ផ្ទាល់មាត់វិញ[ផ] ដើម្បីឱ្យសេចក្ដីអំណររបស់យើងរាល់គ្នា
ចំរើនបានពោរពេញឡើង[ព] ១៣ឯកូនចៅរបស់ប្អូនស្រីរើសត
រាំង[ភ]របស់លោកស្រី ក៏សូមជំរាបសួរមកលោកស្រីដែរ។
អាម៉ែន ។

**១:១** ក កច ១១:៣០ ៣យហ ១ ខ ខ.១៣ រម ១៦:១៣ ១ពត ៥:១៣ គ ខ.៣ ឃ យហ ៨:៣២ ១ធថ ២:៤
**១:២** ង ២ពត ១:១២ ច យហ ១៤:១៧ ១យហ ១:៨
**១:៣** ឆ រម ១:៧
**១:៤** ជ ២យហ ៣,៤
**១:៥** ឈ ១យហ ២:៧
**១:៦** ញ ១យហ ២:៥ ដ យហ ១៤:១៥ ឋ ១យហ ២:៧
**១:៧** ឌ ១យហ ៤:១ ឍ ១យហ ២:២២ ៤:២,៣ ណ យហ ១:១៤ ត ១យហ ២:១៨
**១:៨** ថ មថ ១០:៤២ មក ១០:២៩,៣០ ១កថ ៣:៨ ហព ១០:៣៥,៣៦ ១១:២៦
**១:៩** ទ យហ ៨:៣១ ធ ១យហ ២:២៣
**១:១០** ន រម ១៦:១៧
**១:១១** ប ១ធថ ៥:២២
**១:១២** ផ ៣យហ ១៣,១៤ ព យហ ៣:២៩ **១:១៣** ភ ខ.១

**ខ.១** *អ្នកចាស់ទុំ* "មើលការពន្យល់ ១ធថ ៣:១"។ ក្រោយមកលោកយ៉ូហានមាន តួនាទីជាចាស់ទុំម្នាក់ ប្រហែលនៅក្នុងពួកជំនុំទីក្រុងអេភេសូរ ។ លោកពេត្រុសមានតួនាទីស្រដៀងគ្នានេះដែរ (១ពត ៥:១ និងការពន្យល់)។ *លោកស្រីរើសតាំង* អាចសំដៅលើស្ត្រីម្នាក់ ដែលមិនបានបញ្ជាក់ឈ្មោះឱ្យដឹង ឬអាចជាពាក្យសម្ដី ប្រៀបធៀបសំដៅលើពួកជំនុំនៅក្នុងតំបន់ដែលបានទទួលសំបុត្រទី២របស់លោកយ៉ូហាន (ខ.១៣)។ *កូនចៅរបស់លោកស្រី* អាចសំដៅលើកូនចៅរបស់ស្ត្រីដែល មិនបានស្គាល់ឈ្មោះម្នាក់នោះ ឬជាពាក្យប្រៀបធៀបសំដៅលើសមាជិកពួកជំនុំនៅក្នុងតំបន់ដែលទទួលសំបុត្ររបស់លោកយ៉ូហាន។ *សេចក្ដីពិត* "មើលពន្យល់ យហ ១:១៤"។

**ខ.៣** *ព្រះគុណ... សេចក្ដីសុខសាន្ត* "មើលការពន្យល់ រម ១:៧"។ *សេចក្ដីមេត្តាករុណា* "មើលការពន្យល់ រម ៩:២២-២៣"។

**ខ.៥** *បង្គាប់* "មើលការពន្យល់ ១យហ ២:៧-៨"។

**ខ.៦** *តាំងតែពីដើមរៀងមក* "មើលការពន្យល់ ១យហ ២:៧"។

**ខ.៧-១១** ត្រង់ចំណុចនេះជាសេចក្ដីបង្រៀនការពារ និងប្រឆាំងនឹងសេចក្ដីបង្រៀនរបស់ពួកគ្រូខុសឆ្គងដែលបានបង្រៀនថា ព្រះយេស៊ូវមិនបានយាងមក កើតជាសាច់ឈាមទេ (យហ ១:១៤ និងការពន្យល់) ប៉ុន្តែ ពួកគេបាននិយាយថាព្រះរាជបុត្រានៃព្រះគឺគ្រាន់តែបានយាងមកសណ្ឋិតលើបុរសម្នាក់ឈ្មោះយេស៊ូវ គឺនៅចន្លោះពេលដែលបុរសនោះទទួលពិធីបុណ្យជ្រមុជទឹក និងពេលដែលត្រូវគេ ឆ្កាងតែប៉ុណ្ណោះ (សូមមើលសេចក្ដីផ្ដើម ១យហ)។

**ខ.៧** *អ្នកប្រវ័ញ្ចបញ្ឆោត* "មើលការពន្យល់ ១យហ ២:១៨"។ *ព្រះយេស៊ូវគ្រីស្ទបានមកក្នុងសាច់ឈាម* "មើលការពន្យល់ ១យហ ៤:២-៤"។

**ខ.៨** *ក្រែងបាត់ផលការដែលបានធ្វើហើយ* ត្រង់ចំណុចនេះបញ្ជាក់ច្បាស់ថា ភាពស្មោះត្រង់ចំពោះការងារនៅលើផែនដីនេះ នាំឱ្យទទួលបានរង្វាន់នៅពេលអនាគត (មក ៩:៤១ ១០:២៩-៣០ លក ១៩:១៦-១៩ ហព ១១:២៦)។

**ខ.៩** *អ្នកណាដែលប្រព្រឹត្តរំលង* សំដៅលើពួកខុសឆ្គងដែលជឿថា ពួកគេអាច មានការចម្រើនឡើងខ្លាំងជាងពួកសាវ័កទៅទៀត។ *សេចក្ដីបង្រៀនរបស់ព្រះគ្រីស្ទ* ត្រង់ចំណុចនេះមានភាពដូចគ្នានឹងសំបុត្រទីមួយរបស់លោកយ៉ូហាន គឺនិយាយប្រឆាំងនឹងពួកគ្រូខុសឆ្គងដូចគ្នា ។ ម្យ៉ាងទៀតលោកយ៉ូហានបានបញ្ជាក់យ៉ាងច្បាស់ថា សេចក្ដីបង្រៀនរបស់គាត់គឺជាសេចក្ដីបង្រៀនពិតប្រាកដ អំពីព្រះគ្រីស្ទជាព្រះរាជបុត្រានៃព្រះ ។

**ខ.១០** *កុំទទួលអ្នកនោះនៅក្នុងផ្ទះឡើយ* ត្រង់ចំណុចនេះសំដៅលើការទទួលស្វាគមន៍ និងផ្គត់ផ្គង់ពួកគ្រូទាំងឡាយដែលតែងតែធ្វើដំណើរ (សូមមើលសេចក្ដីផ្ដើម)។ ទោះជាយ៉ាងណាក៏ដោយ ឃ្លានេះមិនហាមឃាត់ក្នុងការទទួលភ្ញៀវ ឬការអញ្ជើញភ្ញៀវឱ្យចូលទៅក្នុងផ្ទះនោះទេ ។ លោកយ៉ូហានបានព្រមានប្រឆាំងនឹងការផ្គត់ផ្គង់អាហារ និងទីកន្លែងស្នាក់នៅដល់ពួកគ្រូខុសឆ្គងសម្រាប់ធ្វើការអាក្រក់ដែលជះឥទ្ធិពលអាក្រក់ផ្សេងៗ (ខ.១១)។

**ខ.១២** *ក្រដាស* សំដៅលើស្លឹកប៉ាពីរូស (Papyrus)។ *ទឹកខ្មៅ* ធ្វើអំពីល្បាយធ្យូងលាយជាមួយទឹក ការ ជ័រ ឬក៏ប្រេង ។ *ដើម្បីឱ្យសេចក្ដីអំណររបស់យើងរាល់គ្នាចំរើនបានពេញឡើង* "មើលការពន្យល់ ១យហ ១:៤"។

**ខ.១៣** *ប្អូនស្រីរើសតាំង* ត្រង់ចំណុចនេះអាចនិយាយជាន័យត្រង់ដែលសំដៅលើ គ្រីស្ទបរិស័ទជាស្ត្រីម្នាក់ទៀត ឬជាភាសាប្រៀបធៀបដែលសំដៅលើពួកជំនុំផ្សេងទៀតនៅក្នុងតំបន់ជាមួយគ្នា (មើលការពន្យល់ ខ.១)។

# សំបុត្រទី ៣
# របស់យ៉ូហាន

សេចក្ដីផ្ដើម

**អ្នកនិពន្ធ**

អ្នកនិពន្ធកណ្ឌគម្ពីរយ៉ូហានទី៣នេះគឺលោកយ៉ូហានជាសាវ័ករបស់ព្រះយេស៊ូវគ្រីស្ទ ។ នៅក្នុងបទគម្ពីរទីមួយនៃកណ្ឌគម្ពីរយ៉ូហានទី២ និងទី៣ អ្នកនិពន្ធបានបញ្ជាក់នូវអត្តសញ្ញាណរបស់គាត់ថា គាត់គឺជាចាស់ទុំម្នាក់ ។ សូមកត់សម្គាល់ភាពដូចគ្នាផ្សេង២ទៀត ដូចជា "ខ្ញុំស្រឡាញ់ពិតប្រាកដ"(ខ.១ ក្នុងកណ្ឌគម្ពីរទាំងពីរ) "ប្រព្រឹត្តតាមសេចក្ដីពិត" (ខ.៤ ក្នុងកណ្ឌគម្ពីរទាំងពីរ) និងភាពដូចគ្នានៃសេចក្ដីសន្និដ្ឋាន ។ សូមមើលសេចក្ដីផ្ដើមកណ្ឌគម្ពីរ យ៉ូហានទី១ និងកណ្ឌគម្ពីរដំណឹងល្អយ៉ូហាន ។

**កាលបរិច្ឆេទ**

សំបុត្រនេះអាចត្រូវបានសរសេរឡើងដំណាលគ្នានឹងសំបុត្រយ៉ូហានទី១ និងទី២ដែរ គឺនៅក្នុងឆ្នាំទី៨៥-៩៥គ.ស (សូមមើលសេចក្ដីផ្ដើម ១យហ ត្រង់ចំណុចកាលបរិច្ឆេទ)។

**ឱកាស និងគោលបំណង**

សូមមើលសេចក្ដីផ្ដើមកណ្ឌគម្ពីរយ៉ូហានទី២ ត្រង់ចំណុច ឱកាស និងគោលបំណង ។ លោកយ៉ូហានបានបញ្ជូនគ្រូបង្រៀនព្រះបន្ទូលជាច្រើន ប៉ុន្ដែពួកគេទាំងនោះបានត្រូវអ្នកដឹកនាំពួកជំនុំម្នាក់ឈ្មោះឌីអូត្រេពនៅស្រុកអាស៊ីបដិសេធ ហើយថែមទាំងបដិសេធដល់អស់សមាជិកពួកជំនុំ ណាម្នាក់ដែលទទួលពួកគ្រូដែលលោកយ៉ូហានបានបញ្ជូនមក ។ លោកយ៉ូហានបានសរសេរសំបុត្រនេះឡើងដើម្បីទូន្មានដល់កៃយុស ឱ្យជួយផ្គត់ផ្គង់ដល់ពួកគ្រូទាំងឡាយដែលគាត់បានបញ្ជូនឱ្យទៅ ហើយជាការព្រមានដល់ឌីអូត្រេពដោយប្រយោលផងដែរ ។

**គម្រោងសង្ខេប**

**I. ពាក្យជម្រាបសួរ (១-២)**

**II. ការបង្គាប់ដល់កៃយុស (៣-៨)**

**III. ការព្រមានដល់ឌីអូត្រេព (៩-១០)**

**IV. ការទូន្មានដល់កៃយុស (១១)**

**V. គំរូល្អរបស់ដេមេទ្រាស (១២)**

**VI. សេចក្ដីសន្និដ្ឋាន ពាក្យទូលសូមឱ្យព្រះអម្ចាស់ប្រទានព្រះពរ និងពាក្យបណ្ដាំចុងក្រោយ (១៣-១៤)**

¹សំបុត្រអ្នកចាស់ទុំ[ក] ផ្ញើមកអ្នកកៃយុស ជាអ្នកស្ងួនភ្ងា
ដែលខ្ញុំស្រឡាញ់ពិតប្រាកដ ²អ្នកស្ងួនភ្ងាអើយ ខ្ញុំប្រាថ្នាចង់
ឱ្យអ្នកបានចំរើនឡើងគ្រប់ជំពូក ហើយឱ្យបានសុខសប្បាយ
ខាងរូបសាច់ ដូចជាព្រលឹងអ្នកបានចំរើនឡើងដែរ ³ដ្បិត
ខ្ញុំបានអរជាខ្លាំងណាស់ ដោយមានបងប្អូន[ខ]មកធ្វើបន្ទាល់
ពីសេចក្ដីពិតដែលនៅក្នុងអ្នក ដូចជាអ្នកធ្លាប់ប្រព្រឹត្ត
តាមសេចក្ដីពិតនោះ[គ] ⁴គ្មានសេចក្ដីណាដែលនាំឱ្យខ្ញុំ
អរសប្បាយ លើសជាងសេចក្ដីនេះទេ គឺដែលឮនិយាយ
ថាពួកកូនខ្ញុំ[ឃ] កំពុងតែប្រព្រឹត្តតាមសេចក្ដីពិតនោះឯង[ង]
⁵អ្នកស្ងួនភ្ងាអើយ ការអ្វីដែលអ្នកធ្វើ សំរាប់ពួកបង ប្អូន[ច]
នឹងពួកដទៃដែរ[ឆ] នោះអ្នកក៏ធ្វើដោយស្មោះត្រង់គ្រប់
ទាំងអស់ហើយ ⁶គេក៏បានធ្វើបន្ទាល់ពីសេចក្ដីស្រឡាញ់
របស់អ្នក នៅមុខពួកជំនុំផង បើអ្នកនឹងជួយដំរង់អ្នកទាំង
នោះ[ជ] តាមបែបគួរ[ឈ]នឹងព្រះ នោះបានល្អហើយ ⁷ដ្បិតគេ
បានចេញដើរទៅ ដោយព្រោះព្រះនាមទ្រង់[ញ] ឥតមាន
ទទួលអ្វីពីសាសន៍ដទៃឡើយ[ដ] ⁸ដូច្នេះ យើងរាល់គ្នាត្រូវ
ជួយទំនុកបំរុងដល់មនុស្សយ៉ាងនោះ ដើម្បីឱ្យយើងបានធ្វើ
ការជាមួយនឹងគេក្នុងសេចក្ដីពិត ។
⁹ខ្ញុំបានធ្វើសំបុត្រផ្ញើមកពួកជំនុំ ប៉ុន្តែ អ្នកឌីអូត្រេព
ដែលចូលចិត្តចង់ធ្វើធំក្នុងពួកនោះ គាត់មិនទទួលយើងទេ
¹⁰ដូច្នេះ បើខ្ញុំមក[ឋ] ខ្ញុំនឹងនឹកចាំពីការដែលអ្នកនោះធ្វើ
ដោយគាត់ពោលពាក្យអាក្រក់ និយាយដើមយើង ហើយមិន
ស្កប់ចិត្តនឹងសេចក្ដីនោះតែប៉ុណ្ណោះ ថែមទាំងមិនព្រម
ទទួលពួកបងប្អូនទៀតផង[ឌ] ហើយបើមានអ្នកណាចង់ទទួល
គេ នោះគាត់ក៏ហាមឃាត់មិនឱ្យទទួលវិញ ព្រមទាំងកាត់គេ
ចេញពីពួកជំនុំផង[ឍ]។
¹¹អ្នកស្ងួនភ្ងាអើយ ចូរត្រាប់តាមសេចក្ដីល្អ[ណ] កុំឱ្យតាម
សេចក្ដីអាក្រក់ឱ្យសោះ អ្នកណាដែលប្រព្រឹត្តល្អ នោះមកពី
ព្រះ[ត] តែអ្នកណាដែលប្រព្រឹត្តអាក្រក់ នោះមិនបានឃើញ
ព្រះឡើយ[ថ] ¹²មនុស្សទាំងអស់[ទ] ព្រមទាំងសេចក្ដីពិត ក៏ធ្វើ
បន្ទាល់យ៉ាងល្អពីអ្នកដេមេទ្រាស យើងខ្ញុំក៏ធ្វើបន្ទាល់ដែរ
ហើយអ្នករាល់គ្នាដឹងថា សេចក្ដីបន្ទាល់របស់យើង នោះ
ពិតប្រាកដមែន[ធ]។
¹³ខ្ញុំមានសេចក្ដីជាច្រើននឹងសរសេរផ្ញើមក តែខ្ញុំមិន
ចង់សរសេរដោយស្លាបប្រកា នឹងទឹកខ្មៅទេ ¹⁴ដោយខ្ញុំ
សង្ឃឹមថា នឹងមកសួរអ្នករាល់គ្នាយ៉ាងឆាប់ ហើយនឹង
និយាយដោយផ្ទាល់មាត់វិញ[ន] ¹⁵សូមឱ្យអ្នកបានប្រកប
ដោយសេចក្ដីសុខ[ប] ពួកសំឡាញ់ខាងណោះ គេជំរាបសួរ
មកអ្នក សូមជំរាបសួរដល់ពួកសំឡាញ់ខាងណេះ តាម
ឈ្មោះគេរៀងខ្លួនផង[ផ]។

**១:១** ក កច ១១:៣០ ២យហ ១
**១:៣** ខ ខ.៥,១០ កច ១:១៦ គ ២យហ ៤
**១:៤** ឃ ១យហ ២:១ ង ខ.៣
**១:៥** ច ខ.៣ ឆ រម ១២:១៣ ហប ១៣:២
**១:៦** ជ ១កថ ១៦:១១ ២កថ ១:១៦ ឈ អភ ៤:១
**១:៧** ញ យហ ១៥:២១ ដ កច ២០:៣៣,៣៥
**១:១០** ឋ ខ.១៤ ២យហ ១២ ឌ ខ.៥ ឍ យហ ៩:២២,៣៤
**១:១១** ណ ទដ ៣៤:១៤ ៣៧:២៧ ត ១យហ ២:២៩ ថ ១យហ ៣:៦,៩,១០
**១:១២** ទ ១ធថ ៣:៧ ធ យហ ១៩:៣៥ ២១:២៤
**១:១៤** ន ២យហ ១២ **១:១៥** ប រម ១:៧ អភ ៦:២៣ ផ យហ ១០:៣

**ខ.១** *អ្នកចាស់ទុំ* "មើលការពន្យល់ ២យហ ១"។ *អ្នកកៃយុស* ជាអ្នកជឿដល់ព្រះអម្ចាស់ម្នាក់ក្នុងពួកជំនុំនៅអាស៊ីមីន័រ ។ ពាក្យថា "កៃយុស"នេះ គឺជាឈ្មោះដែលពួកសាសន៍រ៉ូមនិយមចូលចិត្តប្រើ ។ សំបុត្រយ៉ូហានទី៣នេះបានបង្ហាញនូវគំរូល្អរបស់មនុស្សពីរនាក់ (កៃយុស ខ.៣-៨ ដេមេទ្រាស ខ.១២) និងគំរូអាក្រក់របស់មនុស្សម្នាក់ (ឌីអូត្រេព ខ.៩-១០)។ *ជាអ្នកស្ងួនភ្ងា* នេះជាពាក្យដែលលោកយ៉ូហានចូលចិត្តប្រើនៅក្នុងសំបុត្ររបស់គាត់ (មើលការពន្យល់ ១យហ ២:៧)។ *ពិតប្រាកដ* "មើលការពន្យល់ យហ ១:១៤)។

**ខ.៣-៤** *ប្រព្រឹត្តតាមសេចក្ដីពិត... សេចក្ដីពិត* "មើលពន្យល់ ២យហ ៤"។

**ខ.៤** *ពួកកូនខ្ញុំ* ប្រហែលសំដៅលើពួកអ្នកដែលបានទទួលជឿដល់ព្រះអម្ចាស់តាមរយៈគាត់ ឬសំដៅលើពួកអ្នកដែលស្ថិតនៅក្រោមការមើលខុសត្រូវរបស់គាត់ខាងឯវិញ្ញាណ (មើល ការពន្យល់ ១យហ ២:១)។

**ខ.៥** *ការអ្វីដែលអ្នកធ្វើ សំរាប់ពួកបងប្អូន* ត្រង់ចំណុចនេះបញ្ជាក់ថា ពួកជំនុំដំបូងតែងតែផ្គត់ផ្គង់ និងជួយដល់បេសកជនដែលធ្វើដំណើរផ្សាយដំណឹងល្អ ។ សូមមើលសេចក្ដីផ្ដើមកណ្ឌគម្ពីរយ៉ូហានទី២ ត្រង់ចំណុចអ្នកឱកាស និងគោលបំណង និងពន្យល់ ២យហ ១០ ។

**ខ.៧** *ព្រះនាមទ្រង់* "មើលការពន្យល់ កច ៤:១២"។

**ខ.៨** *ជួយទំនុកបំរុង* "មើលការពន្យល់ ខ.៥ ១ពត ៤:៩"។

**ខ.៩** *ខ្ញុំបានផ្ញើសំបុត្រ* សំដៅលើសំបុត្ររបស់លោកយ៉ូហានដែលបានផ្ញើទៅពួកជំនុំនោះ ពីមុន ហើយដែលឌីអូត្រេពបដិសេធចោល ។ *ពួកជំនុំ* ត្រង់ចំណុចនេះ មានមតិខ្លះយល់ថា សំដៅលើស្ត្រីម្នាក់ ដែលបានទទួលសំបុត្រទីពីររបស់លោកយ៉ូហាន (២យហ ១)។ *ឌីអូត្រេព* ជាអ្នកដឹកនាំពួកជំនុំម្នាក់ ដែលបានអនុវត្តនូវអំណាចផ្ដាច់ការ នៅក្នុងពួកជំនុំ។ ឌីអូត្រេពម្នាក់នេះពិតជាមានឥទ្ធិពលខ្លាំងនៅក្នុងពួកជំនុំ ព្រោះគាត់មានសិទ្ធិដេញសមាជិកណាម្នាក់ ឱ្យចេញពីការប្រកបគ្នានៃពួកជំនុំក៏បាន (ខ.១០)។ សូមមើលសេចក្ដីផ្ដើម ត្រង់ចំណុចឱកាស និងគោលបំណង ។

**ខ.១០** *ពោលពាក្យអាក្រក់ និយាយដើម* "មើលការពន្យល់ សភ ១៨:៨ ២ថន ៣:១១ ១ធថ ៥:១៣"។

**ខ.១១** *ចូរត្រាប់តាមសេចក្ដីល្អ* សំដៅលើការបន្តប្រព្រឹត្តការល្អជារៀងរហូតមិនមែនសំដៅលើការប្រព្រឹត្តិតែក្នុងខណៈពេលណាមួយនោះទេ (រម ១២:២១)។ *មិនបានឃើញព្រះ* "មើលការពន្យល់ ១យហ ៣:៦"។

**ខ.១២** *បន្ទាល់យ៉ាងល្អពីអ្នកដេមេទ្រាស* គឺផ្ទុយពីឌីអូត្រេព (មើលពន្យល់ ខ.១,៩, ១០)។ ដេមេទ្រាសម្នាក់នេះអាចជាអ្នកនាំសំបុត្រនេះទៅកាន់ពួកជំនុំ ។ *សេចក្ដីបន្ទាល់... នោះពិតប្រាកដមែន* ឃ្លានេះអាចសំដៅលើព្រះបន្ទូលនៃដំណឹងល្អ ។

**ខ.១៣-១៤** សម្រាប់សេចក្ដីសន្និដ្ឋានស្រដៀងគ្នានេះ "សូមមើល ២យហ ១២-១៣" (មើលការពន្យល់ ២យហ ១២-១៣)។

**ខ.១៥** *សូមឱ្យអ្នកបានប្រកបដោយសេចក្ដីសុខ* គឺឱ្យបានទទួលនូវគ្រប់ទាំងការល្អទាំង ខាងវិញ្ញាណ និងសេចក្ដីត្រូវការប្រចាំថ្ងៃ (មើលការពន្យល់ រម ១:៧)។

# សំបុត្រ
# របស់យូដាស

សេចក្តីផ្តើម

### អ្នកនិពន្ធ

អ្នកនិពន្ធបានបញ្ជាក់ថា ឈ្មោះរបស់គាត់គឺ យូដាស (ខ.១)។ ក្នុងភាសាហេព្រើរសរសេរថា "យូដា"។ ភាសាក្រេកប្រើពាក្យថា "យូដាស" ជាឈ្មោះដែលពួកហេព្រើរចូលចិត្ត ។ នៅក្នុងសម័យកាលសញ្ញាថ្មី មានមនុស្សជាច្រើនប្រើឈ្មោះថា"យូដាស"នេះ ។ ទោះជាយ៉ាងណាក៏ដោយ ក៏មនុស្សដែលស័ក្តិសមជាអ្នកនិពន្ធរបស់កណ្ឌគម្ពីរនេះគឺ (១). យូដាស ជាសាវក (លក ៦:១៦ កច ១:១៣ និងពន្យល់) មិនមែន យូដាស–អ៊ីស្ការីយ៉ុត នោះទេ ។ (២).យូដាស ជាប្អូនរបស់ព្រះយេស៊ូវ និងជាកូនរបស់លោកយ៉ូសែប (មថ ១៣:៥៥ មក ៦:៣)។ ចម្លើយទីពីរហាក់ដូចជាស័ក្តិសមជាង ។ ឧទាហរណ៍: អ្នកនិពន្ធមិនបានប្រកាសថាខ្លួនជាសាវកទេ គ្រាន់តែបង្ហាញពីភាពជិតស្និទ្ធជាមួយនឹងពួកសាវកតែប៉ុណ្ណោះទៀតផង (ខ.១៧)។ លើសពី នេះទៅទៀត គាត់បានរាប់ខ្លួនគាត់ថា ជាបងប្អូនរបស់លោកយ៉ាកុប (ខ.១)។ ជាទូទៅនៅសម័យកាលលោកយូដាស មនុស្សភាគច្រើនហៅខ្លួនឯងថា ជាកូនរបស់អ្នកណាម្នាក់ ជាជាងហៅថាជាប្អូន ។ ករណីរលើកលែងនៅត្រង់ចំណុចនេះ អាចមកពីលោកយ៉ាកុបគឺជាអ្នកដឹកនាំមានឥទ្ធិពលម្នាក់ ក្នុងពួកជំនុំនៅក្រុងយេរូសាឡិម (សូមមើលសេចក្តីផ្តើមគម្ពីរយ៉ាកុប ត្រង់ចំណុចអ្នកនិពន្ធ)។

ទោះបីលោកយូដាស និងលោកយ៉ាកុបមិនបានហៅខ្លួនថា ជាប្អូនរបស់ព្រះអម្ចាស់ក៏ដោយ ក៏អ្នកដទៃទៀតមិនស្ទាក់ស្ទើរនឹងហៅពួកគាត់ជាប្អូនរបស់ទ្រង់ដែរ (មថ ១៣:៥៥ យហ ៧:៣–១០ កច ១:១៤ ១កថ ៩:៥ កទ ១:១៩)។ ម្យ៉ាងទៀត ពួកគាត់ក៏មិនបានសូមឱ្យគេហៅខ្លួនដូច្នេះ ដោយព្រោះតែខ្លួនមានឯកសិទ្ធិពិសេស និងបានកើតមកក្នុងត្រកូលរបស់លោកយ៉ូសែប និងនាងម៉ារានោះដែរ ។

ភស្តុតាងដែលចាត់ទុកជាបានការ ចំពោះសំបុត្ររបស់លោកយ៉ូដាស ឬសេចក្តីដកស្រង់ចេញពីសំបុត្រនេះ ត្រូវបានរកឃើញនៅសម័យកាលដំបូងដូចជានៅក្នុងក្លេមិនរ៉ូម (Clement of Rome ប្រហែលឆ្នាំ៩៦គ.ស)។ ក្លេមិនអ័លេក្សាន់ទ្រា (Clement of Alexandria ១៥៥–២១៥គ.ស) ទើរទូលលៀន (Tertullian ១៥០–២២២គ.ស) និងអូរីគែន (Origen ១៨៥–២៥៣គ.ស) បានទទួលស្គាល់យ៉ាងដូច្នេះ ។ សំបុត្រនេះត្រូវបានរាប់បញ្ចូលនៅក្នុងមុយរាតូរាន កាណុន (Muratorian Canon ប្រហែលឆ្នាំ ១៧០គ.ស) និងបានទទួលស្គាល់ដោយអាថាណាស៊ីស (Athanasius ២៩៨–៣៧៣ គ.ស) ហើយនិងទទួលស្គាល់ដោយក្រុមប្រឹក្សា កាថាច (Carthage ៣៧៩)។ លោកអឺសឺប៊ីស (Eusebius ២៦៥–៣៤០) បានដាក់សំបុត្រនេះ ក្នុងចំណោមសៀវភៅដែលមិនបានស្គាល់ឈ្មោះអ្នកនិពន្ធច្បាស់ ទោះជាគាត់ទទួលស្គាល់ថាសំបុត្រនេះអាចជាសំបុត្ររបស់លោកយូដាសក៏ដោយ ។

យោងតាមយេរ៉ូម (Jerome) និង ឌីឌីមីស (Didymus) មានអ្នកខ្លះយល់ថា សំបុត្រនេះមិនមែនជាក្រឹត្យវិន័យទេ ពីព្រោះវាមិនមានលក្ខណៈអក្សរសាស្ត្រ (មើលការពន្យល់ ខ.៩,១៤)។ ប៉ុន្តែ មានមតិលើកឡើងថា អ្នកនិពន្ធអាចទទួលការបើកសំដែងឱ្យប្រើទម្រង់អក្សរសាស្ត្រយ៉ាងដូច្នោះ (អាចសម្រាប់បង្ហាញនូវគោលបំណងជាក់លាក់ណាមួយ ឬអាស្រ័យលើប្រវត្តិសាស្ត្រ ឬក៏សម្ភារៈដែលទុកចិត្តបាន ។ ការប្រើប្រាស់យ៉ាងដូច្នោះមិនមែនមានន័យថា ទម្រង់នៃការសរសេរត្រូវបានបើកសំដែងនោះទេ)។ ក្រោមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ ពួកជំនុំបានទទួលស្គាល់ថា អំណាចព្រះចេស្តារបស់ព្រះអម្ចាស់គឺមាននៅក្នុងសំបុត្ររបស់លោកយូដាស ។ សំបុត្រនេះត្រូវបានចោទសួរ និងធ្វើពិសោធ ប៉ុន្តែយ៉ាងណាក៏ដោយ នៅទីបញ្ចប់ ក៏ត្រូវបានគេទទួលស្គាល់ជាចុងក្រោយ ដោយមានពួកជំនុំបញ្ជាក់ពីចំណុចខ្លាំងនៃការអះអាងពីភាពជាអ្នកនិពន្ធរបស់សំបុត្រនេះ ។

### កាលបរិច្ឆេទ

គ្មានចំណុចណានៅក្នុងសំបុត្រនេះដែលបញ្ជាក់អំពីកាលបរិច្ឆេទ ក្រោយពេលដំណើរជីវិតលោកយូដាស ជាប្អូនរបស់ព្រះអម្ចាស់ឡើយ ។ កំហុសអំពីភាពជាអ្នកនិពន្ធត្រូវបានជជែកពិភាក្សា ដូចនៅក្នុងកណ្ឌគម្ពីរពេត្រុសទីពីរដែរ គឺសំបុត្រនេះអាចត្រូវបានសរសេរឡើងនៅសម័យកាលដំបូង (ប្រៀបធៀប កច ២០:២៩–៣០ រម ៦:១ ១កថ ៥:១–១១ ២កថ ១២:២១ កទ ៥:១៣ អភ ៥:៣–១៧ ១ថន ៤:៦ និងមើលសេចក្តីផ្តើម ២ពត ចំណុចកាលបរិច្ឆេទ)។ ជាងនេះទៅទៀត គ្មានចំណុចណានៅក្នុងសំបុត្រដែលបញ្ជាក់អំពីកាលបរិច្ឆេទថាក្រោយពេលរបស់ពួកសាវក ដូចមតិខ្លះបានលើកឡើងនោះទេ ។ ម្យ៉ាងទៀត អាចបញ្ជាក់ថា អ្នកទទួលសំបុត្រយូដាស ធ្លាប់បានឮសេចក្តីបង្រៀនរបស់ពួកសាវក (ខ.១៧–១៨)។ ដូចគ្នា ចំពោះការប្រើប្រាស់ពាក្យថា "សេចក្តីជំនឿ" នៅក្នុងប្រធានបទនៃរូបកាយរបស់ព្រះគ្រីស្ទ (ខ.៣) មិនបញ្ជាក់អំពីកាលបរិច្ឆេទក្រោយមកទៀតនៃសំបុត្រ ។ ពាក្យថា "សេចក្តីជំនឿនេះ" ត្រូវបានប្រើក្នុងអំឡុងពេលប្រហាក់ប្រហែលគ្នានឹង"កទ ១:២៣"ដែរ ។

សំណួរអំពីទំនាក់ទំនងរវាងសំបុត្រយូដាស និងពេត្រុសទី២ មានជាប់ទាក់ទងទៅនឹងកាលបរិច្ឆេទនៃសំបុត្រយូដាស។ ប្រសិនបើ "២ពត ២" ប្រើសេចក្ដីនៅក្នុងកណ្ឌគម្ពីរយូដាស (ការយល់ឃើញដែលទទួលស្គាល់ជាទូទៅ សូមមើលសេចក្ដីផ្ដើមពេត្រុសទី២) ដូច្នេះ កណ្ឌគម្ពីរយូដាសត្រូវបានកំណត់យកកាលបរិច្ឆេទនៅមុនពេត្រុសទី២ គឺប្រហែលនៅឆ្នាំទី ៦៥គ.ស ។ ម្យ៉ាងទៀត កាលបរិច្ឆេទអាចនៅឆ្នាំទី ៨០គ.ស ។

**អ្នកទទួល**

ការពណ៌នាអំពីអ្នកទទួលសំបុត្រដែលលោកយូដាសបានលើកឡើងមានលក្ខណៈទូទៅខ្លាំងមែនទែន(ខ.១)។ វាអាចសំដៅលើគ្រីស្ទបរិស័ទសាសន៍យូដា ឬគ្រីស្ទបរិស័ទសាសន៍ដទៃ ឬក៏ទាំងពីរតែម្ដង ។ ទីកន្លែងដែលអ្នកទទួលរស់នៅនោះពុំបានបញ្ជាក់ទេ ។ ទោះបីបទគម្ពីរ "២ពត ២" និង "យដ ៤-៨" ហាក់ដូចជា ពិពណ៌នាអំពីស្ថានភាពដូចគ្នាក៏ដោយ ក៏មិនអាចសន្និដ្ឋានបានថា សំបុត្រទាំងពីរនេះត្រូវបានសរសេរទៅ កាន់មនុស្សដូចគ្នានោះទេ ។ ពួកគ្រូខុសឆ្គងដែលបានលើកឡើងនៅក្នុងសំបុត្រទាំងពីរបានកើតឡើងច្រើនកន្លែង ។

**ឱកាស និងគោលបំណង**

ទោះបីលោកយូដាសមានបំណងយ៉ាងខ្លាំងក្នុងការសរសេរអំពីសេចក្ដីសង្គ្រោះ ទៅកាន់ពួកអ្នកទទួលសំបុត្ររបស់គាត់ក៏ដោយ ក៏គាត់មានអារម្មណ៍ថា គាត់ត្រូវព្រមានពួកគេអំពីពួកមនុស្សអសីលធម៌ ដែលរស់នៅក្នុងចំណោមពួកគេ និងបានបង្ខូចដល់ព្រះគុណរបស់ព្រះអម្ចាស់ (ខ.៤ និងការពន្យល់)។ ប្រហែលជាពួកគ្រូខុសឆ្គងទាំងនោះបានព្យាយាមទាក់ទាញពួកអ្នកជឿដល់ព្រះអម្ចាស់ ដោយនិយាយថា ពួកគេបានសង្គ្រោះតាមរយៈព្រះគុណ ដូច្នេះ ពួកគេមានសិទ្ធិប្រព្រឹត្តអំពើបាប ព្រោះអំពើបាបមិនអាចប្រឆាំងតបនឹងពួកគេបានទេ ។ លោកយូដាសយល់ថា ពួកអ្នកទទួលសំបុត្ររបស់គាត់ត្រូវតែប្រុងប្រយ័ត្នចំពោះពួកគ្រូខុសឆ្គងទាំងនោះ ហើយត្រៀមខ្លួនប្រឆាំងនឹងសេចក្ដីបង្រៀនរបស់ពួកអ្នកទាំងនោះ ដោយប្រើនូវសេចក្ដីពិតអំពីព្រះគុណនៃការសង្គ្រោះរបស់ព្រះអម្ចាស់ ។

ជាទូទៅគេសន្និដ្ឋានថា ពួកគ្រូខុសឆ្គងទាំងនោះត្រូវបានហៅថា "ណូស្ទិក" (Gnostics)។ ទោះបីលក្ខណៈរបស់ពួកគ្រូខុសឆ្គងដែលបានលើកឡើងត្រូវបានគេស្គាល់ច្បាស់ក៏ដោយ ក៏ពួកគេជាប្រភពនៃសេចក្ដីបង្រៀនខុសឆ្គងនៅសតវត្សរ៍ទីពីរដែរ (មើលសេចក្ដីផ្ដើមពេត្រុសទី២ ចំណុចកាលបរិច្ឆេទ)។

**គម្រោងសង្ខេប**

**I. ពាក្យជម្រាបសួរ (១-២)**

**II. ឱកាសសម្រាប់សំបុត្រ (៣-៤)**

ក. ការផ្លាស់ប្ដូរប្រធានបទ (៣)

ខ. មូលហេតុនៃការផ្លាស់ប្ដូរ: វត្តមាននៃពួកគ្រូខុសឆ្គង (៤)

**III. ការព្រមានប្រឆាំងនឹងពួកគ្រូខុសឆ្គង (៥-១៦)**

ក. គំរូជាប្រវត្តិសាស្ត្រនៃទោសកំហុសរបស់ពួកមនុស្សអាក្រក់ (៥-៧)

១. ពួកអ៊ីស្រាអែលដែលមិនជឿ (៥)

២. ពួកទេវតាដែលធ្លាក់ចុះ (៦)

៣. ក្រុងសូដុំម និងក្រុងកូម៉ូរ៉ា (៧)

ខ. ការពណ៌នាអំពីពួកគ្រូខុសឆ្គងនៅសម័យកាលលោកយូដាស (៨-១៦)

១. ពាក្យសំដីប្រមាថរបស់ពួកគ្រូខុសឆ្គង (៨-១០)

២. ចរិតលក្ខណៈរបស់ពួកគេត្រូវបានសំដែងឱ្យឃើញ (១១-១៣)

៣. ការវិនាសរបស់ពួកគេត្រូវបានថ្លែងទុក (១៤-១៦)

៤. ការកើនឡើងចំពោះពួកអ្នកជឿ (១៧-២៣)

**IV. ការបញ្ចប់សេចក្ដី និងការសរសើរតម្កើងដល់ព្រះអម្ចាស់ (២៤-២៥)**

[១]សំបុត្រយូដាស[ក] ជាបាវបំរើរបស់ព្រះយេស៊ូវគ្រីស្ទ[ខ]
ហើយជាប្អូនយ៉ាកុប ខ្ញុំផ្ញើមកពួកអ្នកដែលព្រះបានហៅ[គ] ជា
ពួកអ្នកស្ងួនភ្ងាក្នុងព្រះដ៏ជាព្រះវរបិតា ដែលបំរុងទុកក្នុង
ព្រះយេស៊ូវគ្រីស្ទ[ឃ] [២]សូមឱ្យអ្នករាល់គ្នាបានប្រកបដោយ
សេចក្តីមេត្តាករុណា សេចក្តីសុខសាន្ត[ង] និងសេចក្តី
ស្រឡាញ់កាន់តែច្រើនឡើង[ច] ។

## អំពើបាប និងការវិនាសនៃមនុស្សទមិឡល្មើស

[៣]ពួកស្ងួនភ្ងាអើយ[ឆ] កំពុងដែលខ្ញុំខ្មីឃ្មាតសរសេរពីសេចក្តី
សង្គ្រោះ ដែលសំរាប់យើងទាំងអស់គ្នា[ជ] នោះខ្ញុំមានសេចក្តី
បង្ខំនឹងសរសេរ ផ្ញើមកអ្នករាល់គ្នា ទាំងទូន្មានឱ្យខំតយុទ្ធ
ដើម្បីការពារ[ឈ]សេចក្តីជំនឿ[ញ] ដែលបានប្រគល់មកពួក
បរិសុទ្ធ១ដងជាសំរេច[ដ] [៤]ដ្បិតមានមនុស្សខ្លះបានលួចចូល[ឋ]
គឺជាពួកអ្នកដែលមានទោសកត់ទុក តាំងពីដើមមក ជា
មនុស្សទមិឡល្មើស ដែលបំផ្លាស់ព្រះគុណរបស់ព្រះនៃ
យើងរាល់គ្នា ឱ្យទៅជាសេចក្តីអាសអាភាស ហើយគេមិន
ព្រមទទួលព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើង ដែលទ្រង់ជា
ម្ចាស់តែ១ផងទេ[ឌ] ។
[៥]ខ្ញុំចង់រំឭកដល់អ្នករាល់គ្នា[ឍ] ដែលបានជ្រាបសេចក្តី
ទាំងនេះម្តងហើយថា[ណ] ក្រោយដែលព្រះអម្ចាស់បានជួយ
សង្គ្រោះរាស្ត្រទ្រង់ ឱ្យរួចពីស្រុកអេស៊ីព្ទមក នោះទ្រង់បាន
បំផ្លាញពួកអ្នកដែលមិនជឿវិញ[ត] [៦]ទោះទាំងពួកទេវតា
ដែលមិនបានរក្សាសណ្ឋានដើមរបស់ខ្លួន គឺជាទេវតាដែល
បោះបង់ចោលទីលំនៅចេញ នោះទ្រង់បានឃុំក្នុងសេចក្តី
ងងឹត ទាំងជាប់ចំណងអស់កល្បជានិច្ច ទុកសំរាប់នឹង
ជំនុំជំរះនៅថ្ងៃដ៏ធំនោះ[ថ] [៧]ដូចជាក្រុងសូដុំម និងក្រុងកូម៉ូ
រ៉ា[ទ] ហើយអស់ទាំងទីក្រុងនៅជុំវិញដែរ[ធ] ដែលគេបានប្រ
គល់ខ្លួនទៅប្រព្រឹត្តសេចក្តីកំផិតដូចគ្នា ទាំងបណ្តោយទៅ
តាមសាច់ដទៃ ហើយទ្រង់បានតាំងអ្នកទាំងនោះទុក
ជាក្បួន ឱ្យគេរងទុក្ខ ទោសក្នុងភ្លើងដ៏ឆេះអស់កល្បជានិច្ច[ន]

**១:១** ក មថ ១៣:៥៥ យហ ១៤:២២ កច ១:១៣ ខ រម ១:១ គ រម ១:៦,៧ ឃ យហ ១៧:១២ **១:២** ង កទ ៦:១៦ ១ធថ ១:២ ច រម ១:៧ **១:៣** ឆ ១កថ ១០:១៤ ជ ទត ១:៤ ឈ ១ធថ ៦:១២ ញ ខ.២០ កច ៦:៧ ដ កច ៩:១៣ **១:៤** ឋ កទ ២:៤ ឌ ទត ១:១៦ ២ពត ២:១ ១យហ ២:២២ **១:៥** ឍ ២ពត ១:១២,១៣ ៣:១,២ ណ ១យហ ២:២០ ត ជន ១៤:២៩ ចទ ១:៣២ ២:១៥ ទដ ១០៦:២៦ ១កថ ១០:១–៥ ហព ៣:១៦,១៧ **១:៦** ថ ២ពត ២:៤,៩ **១:៧** ទ មថ ១០:១៥ ធ ចទ ២៩:២៣ ន មថ ២៥:៤១ ២ពត ៣:៧

**ខ.១** *បាវបំរើ* "មើលការពន្យល់ រម ១:១"។ *ជាប្អូនយ៉ាកុប* សូមមើលការពន្យល់ សេចក្តីផ្តើម ត្រង់ចំណុចអ្នកនិពន្ធ ។ *ព្រះបានហៅ* "មើលពន្យល់ រម ៨:២៨"។ *ជាពួកអ្នកស្ងួនភ្ងាក្នុងព្រះ* "មើលការពន្យល់ យហ ៣:១៦ រម ៨:២៨–៣៩"។ *បំរុងទុកក្នុងព្រះយេស៊ូវគ្រីស្ទ* ព្រះដែលបានបង្កើត និងគ្រប់គ្រងពិភពលោក (កល ១:១៧ ហព ១:៣) ទ្រង់នឹងឃើញកូនរបស់ទ្រង់ឈរមាំនៅក្នុងសេចក្តីជំនឿ ដើម្បីជាប្រយោជន៍ឈានទៅទទួលបាននូវមរតកអស់កល្បជានិច្ច (យហ ៦:៣៧–៤០ ១៧:១១–១២ ១ពត ១:៣–៥)។

**ខ.២** *សេចក្តីមេត្តាករុណា* "សូមមើល លប ១៩:១៦ រម ៩:២២–២៣ ទត ៣:៥ និងការពន្យល់"។ *សេចក្តីសុខសាន្ត* "មើលការពន្យល់ ១:៧"។

**ខ.៣** *ពួកស្ងួនភ្ងាអើយ* "សូមមើល ខ.១៧–២០ និងការពន្យល់ ២ពត ៣:១"។ *សេចក្តីសង្គ្រោះ ដែលសំរាប់យើងទាំងអស់គ្នា* គោលបំណងដំបូងរបស់លោកយូដាសក្នុងការសរសេរកណ្ឌគម្ពីរនេះ គឺដើម្បីបង្ហាញនូវគោលលទ្ធិទូទៅអំពីសេចក្តីសង្គ្រោះ ដែលទាក់ទងទៅនឹងអំពើបាប ការអាក្រក់របស់មនុស្ស សេចក្តីស្រឡាញ់ ព្រះគុណ ការអត់ទោសបាប និងការផ្លាស់ប្រែនៃជីវិត បន្ទាប់ពីបានកើតជាថ្មី ។ *ដើម្បីការពារសេចក្តីជំនឿ* ត្រង់ចំណុចនេះបញ្ជាក់ថា រូបកាយនៃសេចក្តីពិតដែលជាដំណឹងល្អ និងអ្វីៗដែលជាប់ទាក់ទងនឹងដំណឹងល្អត្រូវបានការពារ ដោយពួកអ្នកជឿដល់ព្រះអម្ចាស់នៅគ្រប់ទីកន្លែង (សូមមើលសេចក្តីផ្តើម និងការពន្យល់ ១ធថ ៤:៦)។ សេចក្តីពិតទាំងនេះត្រូវបានគេវាយប្រហារ ហើយទាមទារឱ្យមាននូវការការពារ ។ *ប្រគល់មកពួកបរិសុទ្ធ១ដងជាសំរេច* បញ្ជាក់ថាសេចក្តីពិតនឹងមិនប្រែប្រួលឡើយ ។ *ពួកបរិសុទ្ធ* "មើល រម ១:៧ អភ ១:១"។

**ខ.៤** *ពួកអ្នកដែលមានទោសកត់ទុក* អាចសំដៅលើការប្រកាសបដិសេធន៍នៅក្នុងគម្ពីរសញ្ញាចាស់របស់ពួកមនុស្សអាក្រក់ ឬសំដៅលើសេចក្តីទំនាយរបស់លោកហេណុក (ខ.១៤–១៥)។ ម្យ៉ាងទៀត លោកយូដាសអាចនិយាយសំដៅលើការជំនុំ ជម្រះដែលនឹងត្រូវធ្លាក់លើពួកគេដោយ ព្រោះតែអំពើបាបរបស់ខ្លួន (មើលការពន្យល់ ២ពត ២:៣)។ *មនុស្សទមិឡល្មើស* "សូមមើល ខ.១៥,១៨"។ *បំផ្លាស់ ព្រះគុណរបស់ព្រះ . . . ឱ្យទៅជាសេចក្តីអាសអាភាស* ពួកគេទាំងនោះយល់ថា ការសង្គ្រោះដោយព្រះគុណបានផ្តល់ឱ្យពួកគេនូវសិទ្ធិសេរីភាពដើម្បីធ្វើបាបឥតឈប់ឈរ (រម ៥:២០ ៦:១ និងការពន្យល់)។ *មិនព្រមទទួលព្រះអម្ចាស់ . . . ជាម្ចាស់តែ១ផង* នៅក្នុងភាសាក្រិកពាក្យថា "អម្ចាស់តែមួយ" សំដៅលើព្រះដែលមានអំណាចព្រះចេស្តា គ្មានដែនកំណត់ និងគ្រប់គ្រងលើអ្វីៗទាំងអស់ ។ ម្យ៉ាងទៀតនៅក្នុងសំណង់ប្រយោគជាភាសាក្រិក ឃ្លានេះសំដៅលើព្រះតែមួយ ហើយនៅក្នុងបទគម្ពីរនេះ គឺនិយាយសំដៅលើព្រះគ្រីស្ទតែម្តង (២ពត ២:១)។

**ខ.៥–៧** ត្រង់វគ្គនេះបង្ហាញអំពីគំរូនៃការជំនុំជម្រះរបស់ព្រះអម្ចាស់ ។

**ខ.៥** *បំផ្លាញពួកអ្នកដែលមិនជឿ* ពួកគេមិនជឿថាព្រះអម្ចាស់ប្រទានទឹកដីកាណានដល់ពួកគេទេ ជាលទ្ធផល ពួកអ្នកពេញវ័យដែលមិនជឿទាំងអស់បានស្លាប់នៅក្នុងទីរហោស្ថាន និងមិនបានចូលទៅក្នុងទឹកដីសន្យាឡើយ (ជន ១៤:២៩–៣០ ចទ ១:៣២–៣៦ ២:១៥ ១កថ ១០:១–៥ ១០:៥ ហព ៣:១៦–១៩ និងការពន្យល់)។

**ខ.៦** *ពួកទេវតា* "មើលការពន្យល់ ២ពត ២:៤"។ *សណ្ឋានដើមរបស់ខ្លួន* "មើលការពន្យល់ ២ពត ២:៤"។ ព្រះអម្ចាស់បានរៀបឱ្យពួកទេវតានូវទំនួលខុសត្រូវ និងអំណាចផ្សេងៗគ្នា (ដយ ១០:២០–២១)។ ពួកទេវតាខ្លះប្រកែកមិនព្រមរក្សានូវតំណែងរបស់ខ្លួន ដូច្នោះក៏ក្លាយទៅជាអាក្រក់ (មថ ២៥:៤១)។ *ទីលំនៅ* ពួកទេវតាត្រូវបានរៀបចំឱ្យមានតួនាទី និងកន្លែងណាមួយច្បាស់លាស់ ។ មានមតិខ្លះ យល់ថាពួកទេវតាទាំងនោះ បានចាកចេញពីស្ថានសួគ៌មកកាន់ផែនដី (មើលការពន្យល់ ២ពត ២:៤)។ *បានឃុំ . . . ជាប់ចំណង . . . ទុកសំរាប់នឹងជំនុំជំរះ* "មើលការពន្យល់ ២ពត ២:៤"។ *ថ្ងៃដ៏ធំនោះ* សំដៅលើថ្ងៃជំនុំជម្រះចុងក្រោយ ។

**ខ.៧** *ប្រព្រឹត្តសេចក្តីកំផិតដូចគ្នា* ត្រង់ចំណុចនេះមិនមានន័យថាអំពើបាបរបស់ពួកអ្នកនៅទីក្រុងសូដុំម និងក្រុងកូម៉ូរ៉ា ដូចគ្នានឹងអំពើបាបរបស់ពួកទេវតាទាំងនោះទេ ។ ឃ្លានេះត្រូវបានប្រើដើម្បីចាប់ផ្តើមនូវ ការបង្ហាញជា

៨ទោះបើមានក្បួនដូច្នោះហើយ គង់តែមនុស្សទាំងនេះ
ធ្វើឱ្យខ្លួនស្មោកគ្រោកវិញ ដោយនឹកតែពីផ្លូវខូចអាក្រក់
ទាំងមើលងាយដល់អស់ទាំងអំណាចគ្រប់គ្រង ហើយជេរ
ប្រមាថដល់ពួកប្រសើរឧត្តមផង[ប] ៩រីឯមីកែល[ផ] ជាមហា
ទេវតា[ព] លោកមិនហ៊ានប្តឹងប្រមាថដល់អារក្ស ក្នុងកាល
ដែលកំពុងតែជជែកនឹងវា ទាំងប្រកែកពីដំណើរសពរបស់
លោកម៉ូសេនោះទេ[ភ] គឺបាននិយាយដូច្នេះវិញថា សូមឱ្យ
ព្រះអម្ចាស់បន្ទោសឯងចុះ[ម] ១០តែពួកនោះ គេហ៊ានជេរ
ប្រមាថដល់ទាំងអ្វីៗដែលគេមិនស្គាល់ផង ព្រមទាំងបង្ខូច
ខ្លួន ក្នុងការអ្វីដែលគេយល់ដោយធម្មតាវិញ ហាក់ដូចជា
សត្វតិរច្ឆាន[យ] ១១វេទនាដល់មនុស្សទាំងនោះ ពីព្រោះគេ
បានទៅតាមផ្លូវរបស់កាអ៊ីន[រ] ក៏ស្ទុះទៅក្នុងសេចក្តីខុស
ឆ្គងរបស់បាឡាម[ល] ឱ្យតែបានកំរៃ ហើយគេត្រូវវិនាស
ក្នុងការបះបោរ របស់កូរេទៅ[វ] ១២ពួកនោះជាដុំស្មោក
គ្រោក ក្នុងពេលដែលអ្នករាល់គ្នាបរិភោគ ជាមួយគ្នា
ដោយស្រឡាញ់[ស] គេបរិភោគជាមួយឥតខ្លាច ទាំងចិញ្ចឹម
តែខ្លួនគេ[ហ] គេជាពពកឥតទឹក[ឡ] ដែលត្រូវខ្យល់បង់ផាត់
ទៅមក[អ] ជាដើមឈើឥតផ្លែក្នុងរដូវកាល[ក] ដែលស្លាប់២
ដងរួចហើយ ក៏ត្រូវរលើងផង ១៣គេជារលកសមុទ្រ
យ៉ាងសំបើម[ខ] ដែលបែកពពុះចេញ ជាសេចក្តីអាមាស់
ខ្មាសរបស់គេ[គ] ក៏ជាផ្កាយមិនទៀង ដែលសេចក្តីងងឹតសូន្យ
ឈឹងអស់កល្បជានិច្ចបានបំរុងទុកឱ្យគេ[ឃ] ១៤ឯហេណុក[ង]
ជាដំណទី៧ពីលោកអ័ដាមមក គាត់បានទាយពីមនុស្សទាំង
នោះថា មើល ព្រះអម្ចាស់ទ្រង់យាងមក[ច] នៅកណ្តាលពួក
បរិសុទ្ធទ្រង់ទាំងសល់សែន[ឆ] ១៵ដើម្បីនឹងកាត់ទោស[ជ]ដល់

**១:៨** ប ២ពត ២:១០ **១:៩** ផ ដយ ១០:១៣,២១ ១២:១ វវ ១២:៧ ព ១ថឧ ៤:១៦ ភ ចទ ៣៤:៦ ម សក ៣:២ **១:១០** យ ២ពត ២:១២ **១:១១** រ លប ៤:៣-៨ ហព ១១:៤ ១យហ ៣:១២ ល ២ពត ២:១៥ វ ជន ១៦:១–៣ ៣១–៣៥ **១:១២** ស ២ពត ២:១៣ ១កថ ១១:២០,២២ ហ អគ ៣៤:២,៨,១០ ឡ សភ ២៥:១៤ ២ពត ២:១៧ អ អភ ៤:១៤ ក មថ ១៥:១៣ **១:១៣** ខ អស ៥៧:២០ គ ភល ៣:១៩ ឃ ២ពត ២:១៧ **១:១៤** ង លប ៥:១៨ ២១–២៤ ច មថ ១៦:២៧ ឆ ចទ ៣៣:២ ដយ ៧:១០ សក ១៤:៥ ហព ១២:២២

លើកទីបីនៃសេចក្តីដែលថា ពួកមនុស្សអាក្រក់នឹងត្រូវទទួលទណ្ឌកម្មនៅថ្ងៃជំនុំជម្រះ ។ *បណ្តោយទៅ តាមសាច់ដទៃ* ឃ្លានេះភាគច្រើនសំដៅលើការអនុវត្តន៍ ការរួមភេទដូចគ្នា (លប ១៩:៥ និងការពន្យល់)។ *បានតាំងអ្នកទាំងនោះទុកជាក្បួន ឱ្យគេរងទុក្ខទោសក្នុងភ្លើងដ៏ឆេះអស់កល្បជានិច្ច* ព្រះអម្ចាស់បានបំផ្លាញទីក្រុងសូដុំម និងក្រុងកូម៉ូរ៉ា ដោយទម្លាក់ភ្លើងពីលើមេឃ (លប ១៩:២៤) ដែលជាការព្រមានទុកជាមុនអំពីភ្លើងឆេះដ៏អស់កល្បនឹងត្រូវមកនៅថ្ងៃចុងក្រោយ ។

**ខ.៨** *ធ្វើឱ្យខ្លួនស្មោកគ្រោក* ឃ្លានេះអាចសំដៅលើការរួមភេទដូចគ្នា ដែលបានអនុវត្តនៅទីក្រុងសូដុំម និងកូម៉ូរ៉ា(មើល ខ.៤,៧ ១កថ ៦:៩,១៨ និងការពន្យល់)។ *ដោយនឹកតែពីផ្លូវខូចអាក្រក់* សំដៅលើពួកមនុស្សអាក្រក់ដោយព្រោះតែ (១).ពួកគេប្រកាសថាបានទទួលនូវការបើកសំដែងជាច្រើន។ (២).បំណងប្រាថ្នារបស់ពួកគេឃ្លាតចាកពីសេចក្តីពិតនិងការពិត។ *មើលងាយដល់អស់ទាំងអំណាចគ្រប់គ្រង* "មើលការពន្យល់ ២ពត ២:១០"។ *ជេរប្រមាថដល់ពួកប្រសើរឧត្តមផង* "មើលការពន្យល់ ២ពត ២:១០"។

**ខ.៩** សូមមើល កថ ១៧:២៨ ទត ១:១២ និងការពន្យល់ ។

**ខ.១០** *អ្វីៗដែលគេមិនស្គាល់ផង* "មើលពន្យល់ ២ពត ២:១២ ប្រៀបធៀប ១កថ ២:១៤"។ *ហាក់ដូចជាសត្វតិរច្ឆាន* "មើលពន្យល់ ២ពត ២:១២"។

**ខ.១១** ត្រង់ចំណុចនេះ លោកយូដាសបានលើកឡើងនូវគំរូនៃមនុស្សបីប្រភេទ ដើម្បីព្រមានដល់ពួកអ្នកអានសំបុត្ររបស់គាត់ ។ *វេទនាដល់មនុស្សទាំងនោះ* ជាការព្រមានថា ការជំនុំជម្រះគឺកំពុងតែមកដល់ហើយ (មថ ២៣:១៣,១៥–១៦, ២៣,២៥,២៧,២៩)។ *ផ្លូវរបស់កាអ៊ីន* គឺផ្លូវនៃការគិតតែប្រយោជន៍ផ្ទាល់ខ្លួន និង សេចក្តីលោភ (មើលការពន្យល់ លប ៤:៣–៤) និងផ្លូវនៃសេចក្តីសម្អប់ ហើយនិងការកាប់សម្លាប់ (១យហ ៣:១២)។ *សេចក្តីខុសឆ្គងរបស់បាឡាម* គឺកំហុសឆ្គងក្នុងសេចក្តីលោភ (មើលការពន្យល់ ២ពត ២:១៥)។ *ការបះបោររបស់កូរេ* សំដៅលើការបះបោររបស់កូរេប្រឆាំងនឹងមនុស្សដែលព្រះអម្ចាស់បានរើសតាំង (ជន ១៦)។ លោកយូដាសប្រហែលជាបង្ហាញថា ពួកគ្រូខុសឆ្គងនៅសម័យគាត់បានបះបោរប្រឆាំងនឹងអ្នកដឹកនាំពួកជំនុំ ដែលព្រះអម្ចាស់បានរើសតាំងឡើង (ប្រៀបធៀបនឹង ៣យហ ៩–១០)។

**ខ.១២–១៣** ត្រង់ចំណុចនេះមានសេចក្តីប្រៀបធៀប ចំនួន៦ត្រូវបានលើកឡើងគឺ (១).*ដុំស្មោកគ្រោកក្នុងពេលដែលអ្នករាល់គ្នាបរិភោគ* "មើលការពន្យល់ ២ពត ២:១៣"។ (២).*គេបរិភោគជាមួយឥតខ្លាចទាំងចិញ្ចឹមតែខ្លួនគេ* គឺគេមិនបានចិញ្ចឹមហ្វូងចៀមដែលខ្លួនមានទំនួលខុសត្រូវទេ (អគ ៣៤:៨–១០)។ (៣).*គេជា ពពកឥតទឹក* ពួកគ្រូខុសឆ្គងទាំងនោះដូចជាពពកឥតមានទឹក ដែលសន្យាផ្តល់ទឹកដល់ដីកំពុងស្ងួតហែងដូច្នោះដែរ គឺពួកគេបានសន្យាបំពេញសេចក្តីត្រូវការខាងសេចក្តីពិត ប៉ុន្តែ ជាក់ស្តែងពួកគេគ្មានអ្វីសម្រាប់ផ្តល់ឱ្យពួកជំនុំទេ ។ (៤). *គេជាដើមឈើឥតផ្លែក្នុងរដូវកាល ដែលស្លាប់២ដងរួចហើយ* មានន័យថា ពួកគេមិនមែនជាមនុស្សដែលបង្កើតផលផ្លែទេ ។ (៥).*គេជារលកសមុទ្រ* ពួកគ្រូខុសឆ្គងទាំងនោះបានបន្តបញ្ចូលសីលធម៌អាក្រក់ទៅក្នុងពួកជំនុំ (អស ៥៧:២០) ដូចជាខ្យល់ដែលរុញច្រានរលកសមុទ្រមិនចេះឈប់ឈរដូច្នោះដែរ។ (៦).*ជាផ្កាយមិនទៀង* បញ្ជាក់ថា ទីបញ្ចប់ពួកគ្រូខុសឆ្គងទាំងនោះ គឺស្ថិតនៅក្នុងទីងងឹតគឺ ដូចជាពន្លឺអាចម៌ផ្កាយដែលភ្លឺតែមួយភ្លែត ហើយងងឹតបាត់ទៅវិញដូច្នោះដែរ ។

**ខ.១៤** *ហេណុក ជាដំណទី៧ពីលោកអ័ដាម* មិនមែនជាលោកហេណុក នៅក្នុងពូជអំបូររបស់កាអ៊ីនទេ (លប ៤:១៧) ប៉ុន្តែ គឺលោកហេណុកដែលជាពូជអំបូររបស់លោកសេត (លប ៥:១៨–២៤ ១រប ១:១–៣)។ ប្រសិនបើលោកអ័ដាមត្រូវបានរាប់ជាតំណទីមួយ នោះលោកហេណុកត្រូវជាតំណទី៧ *ព្រះអម្ចាស់ទ្រង់យាងមក* លោកយូដាសប្រើប្រាស់សេចក្តីដកស្រង់នេះ សំដៅលើការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទនិងការមកដល់នៃការជំនុំជម្រះសម្រាប់ពួកមនុស្សអាក្រក់ (មើល ២ថឧ ១:៦–១០)។ *ពួក បរិសុទ្ធ* អាចសំដៅលើពួកទេវតារបស់ព្រះ(ដយ ៤:១៣–១៧ ២ថឧ ១:៧)។ ទោះជាយ៉ាងណាក៏ដោយមានមតិខ្លះយល់ថាឃ្លានេះ សំដៅលើពួកបរិសុទ្ធដែលបានលើកឡើងទៅជាមួយព្រះអម្ចាស់ ហើយបានធ្វើដំណើរមកជាមួយទ្រង់ក្នុងកាលដែលទ្រង់យាងមកជាលើកទីពីរ (មើលការពន្យល់ ១ថឧ ៣:១៣)។

**ខ.១៥** *ពួកទមិលល្មើស . . . ការទមិលល្មើស . . . ចិត្តល្មើស . . . ពួកទមិលល្មើស* ការលើកឡើងនូវសេចក្តីដដែលៗទាំងនេះ គឺដើម្បីពណ៌នាអំពីទោស

គ្រប់មនុស្សទាំងឡាយ ហើយនិងរំឭកពួកទមិឡល្មើស
ទាំងអម្បាលម៉ាន ឱ្យដឹងខ្លួនពីគ្រប់ទាំងការទមិឡល្មើស
ដែលគេបានប្រព្រឹត្តធ្វើ ដោយចិត្តល្មើសហើយពីអស់ទាំង
សេចក្ដីរឹងទទឹងទាំងប៉ុន្មាន ដែលអស់ពួកទមិឡល្មើសដ៏
មានបាបទាំងនោះ បានពោលទាស់នឹងទ្រង់[ឈ] ១៦មនុស្ស
ទាំងនោះជាពួកដែលចេះតែរទូរទាំ[ញ] ហើយត្អូញត្អែរ
ដែលដើរតាមតែសេចក្ដីប៉ងប្រាថ្នារបស់ខ្លួន[ដ] ហើយមាត់
គេពោលសុទ្ធតែពាក្យអំនួតអួតយ៉ាងសំបើម[ឋ] គេរាប់អាន
មនុស្ស ឱ្យតែបានកំរៃទេ ។

## ការព្រាសហៅឱ្យស៊ូទ្រាំ

១៧ពួកស្ងួនភ្ងាអើយ ចូរនឹកចាំពីព្រះបន្ទូល ដែលពួក
សាវក[ឱ]របស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងបាន
ផ្សាយប្រាប់ពីដើមរៀងមកចុះ[ឍ] ១៨គេបានប្រាប់មកអ្នករាល់
គ្នាថានៅជាន់ក្រោយបង្អស់[ណ]នឹងមានមនុស្សចំអកដែលនឹង
ប្រព្រឹត្តតាមតែសេចក្ដីប៉ងប្រាថ្នាទមិឡល្មើសរបស់ខ្លួន[ត]
១៩ពួកនោះជាអ្នកដែលបង្កើតបក្សពួក គឺជាមនុស្សដែល
នៅដោយវិស័យសាច់ឈាម ដែលគ្មានព្រះវិញ្ញាណទេ[ថ]
២០ប៉ុន្តែ ឯអ្នករាល់គ្នា ជាពួកស្ងួនភ្ងាអើយ ចូររក្សាខ្លួន
ក្នុងសេចក្ដីស្រឡាញ់របស់ព្រះចុះ ព្រមទាំងរង់ចាំ[ទ]សេចក្ដី
មេត្តាករុណារបស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង
ឱ្យបានជីវិតអស់កល្បជានិច្ចវិញ[ធ] ២១ដោយស្អាងចិត្តឡើង[ន]
ក្នុងសេចក្ដីជំនឿដ៏បរិសុទ្ធបំផុតរបស់អ្នករាល់គ្នា[ប] ហើយ
ទាំងអធិស្ឋាន ដោយនូវព្រះវិញ្ញាណបរិសុទ្ធផង[ផ] ២២ចូរ
មានចិត្តអាណិតដល់ពួកអ្នកខ្លះ ដែលមានសេចក្ដីសង្ស័យ
ផង ២៣ហើយជួយសង្គ្រោះដល់អ្នកដទៃ[ព] ទាំងឆក់យកគេ
ចេញពីភ្លើង ហើយត្រូវមានចិត្តមេត្តាដល់មនុស្សឯទៀត
ដោយភ័យខ្លាច ហើយស្អប់ដល់ទាំងអាវ ដែលត្រូវស្មោក
គ្រោក ដោយសាច់ឈាមផង[ភ]។

## សេចក្ដីសរសើរដល់ព្រះ

២៤រីឯព្រះ ដែលអាច[ម]នឹងថែរក្សា មិនឱ្យអ្នករាល់គ្នា
ជំពប់ដួល ហើយនិងដាក់អ្នករាល់គ្នា នៅចំពោះសិរីល្អ
ទ្រង់[យ] ដោយឥតមានកន្លែងបន្ទោសបាន[រ] ព្រមទាំងមានចិត្ត
ត្រេកអរផង ២៥គឺជាព្រះអង្គដ៏ជាព្រះតែមួយ[ល] ជាព្រះអង្គ
សង្គ្រោះនៃយើងរាល់គ្នា ដោយសារព្រះយេស៊ូវគ្រីស្ទ ជា
ព្រះអម្ចាស់នៃយើង នោះសូមឱ្យទ្រង់បានសិរីល្អឫទ្ធានុភាព
ព្រះចេស្ដា និងអំណាច តាំងពីមុនអស់កល្ប នៅជាន់ឥឡូវ
នេះ ហើយទៅដល់អស់កល្បជានិច្ចតទៅ[វ]។ អាម៉ែន[ស]។

**១:១៥** ដ ២ពត ២:៦-៩ ឈ ១ធថ ១:៩
**១:១៦** ញ ១កថ ១០:១០ ដ ខ.១៨ ២ពត ២:១០ ឋ ២ពត ២:១៨
**១:១៧** ឌ អភ ៤:១១ ឍ ហព ២:៣ ២ពត ៣:២
**១:១៨** ណ ១ធថ ៤:១ ២ធថ ៣:១ ២ពត ៣:៣ ត ខ.១៦ ២ពត ២:១ ៣:៣
**១:១៩** ថ ១កថ ២:១៤,១៥
**១:២០** ទ ទត ២:១៣ ហព ៩:២៨ ២ពត ៣:១២ ធ មថ ២៥:៤៦
**១:២១** ន កល ២:៧ ២ថន ៥:១១ ប ខ.៣ ផ អភ ៦:១៨
**១:២៣** ព អម ៤:១១ សក ៣:២-៥ ១កថ ៣:១៥ ភ វវ ៣:៤
**១:២៤** ម រម ១៦:២៥ យ ២កថ ៤:១៤ រ កល ១:២២
**១:២៥** ល យហ ៥:៤៤ ១ធថ ១:១៧ វ ហព ១៣:៨ ស រម ១១:៣៦

កំហុសដែលពួកគ្រូខុសឆ្គងទាំងនោះ (ខ.៤) ត្រូវទទួល ។

**ខ.១៦** *មនុស្សទាំងនោះ* សំដៅលើពួកមនុស្សដែលបានរៀបរាប់នៅក្នុងខ.៤ (ខ.៨,១០,១២,១៤,១៩)។ ពួកគេជាគ្រូខុសឆ្គងខិលខូចដែលធ្វើខូច ដល់ព្រះគុណរបស់ព្រះអម្ចាស់ ។

**ខ.១៧** *ចូរនឹកចាំពីព្រះបន្ទូល ដែលពួកសាវក . . . បានផ្សាយប្រាប់ពីដើមរៀងមក* ត្រង់ចំណុចនេះបញ្ជាក់ថា ការដែលពួកគ្រូខុសឆ្គងបានកើតឡើង មិនត្រូវឱ្យពួកជំនុំមានការភ្ញាក់ផ្អើលឡើយ ព្រោះការទាំងនេះបានថ្លែងប្រាប់ជាមុនដោយពួកសាវករបស់ព្រះអម្ចាស់រួចជាស្រេចហើយ (កច ២០:២៩ ១ធថ ៤:១ ២ធថ ៣:១-៥ ២ពត ២:១-៣ ៣:២-៣)។

**ខ.១៨** *គេបានប្រាប់មកអ្នករាល់គ្នា* ជាភាសាក្រិកឃ្លានេះបញ្ជាក់ថាពួកសាវកបន្តទូន្មានដល់ពួកជំនុំថា នឹងមានពួកគ្រូខុសឆ្គងដែលត្រូវមក ។ *នៅជាន់ក្រោយបង្អស់* "មើលពន្យល់ យក ៥:៣"។ *មនុស្សចំអក* ក្នុងគម្ពីរពេត្រុស (២ពត ៣:៣) ក៏ដូចជានៅក្នុងគម្ពីរយូដាសនេះដែរ បញ្ជាក់ថាពួកចំអកគឺសំដៅលើពួកអ្នកប្រព្រឹត្តតាមសេចក្ដីប៉ងប្រាថ្នារបស់ខ្លួនឯង (គិតតែខ្លួនឯង)។

**ខ.១៩** *ពួកនោះជាអ្នកដែលបង្កើតបក្សពួក* បញ្ជាក់ថាពួកគ្រូខុសឆ្គង ជាមនុស្សដែលបង្ករឱ្យមានបញ្ហា និងការបែកបាក់នៅក្នុងពួកជំនុំ ។ *មនុស្សដែលនៅដោយវិស័យសាច់ឈាម* គឺជាការពណ៌នាអំពីពួកគ្រូខុសឆ្គង ដែលរស់នៅតាមសេចក្ដីប៉ងប្រាថ្នាលោភលន់ (១កថ ២:១៤ និងមើលពន្យល់)។ *គ្មានព្រះវិញ្ញាណទេ* លោកយូដាសបានបញ្ជាក់ថា ពួកគ្រូខុសឆ្គង ទាំង នោះមិនគ្រាន់តែគ្មានព្រះវិញ្ញាណទេ គឺពួកគេថែមទាំងមានវិញ្ញាណអាក្រក់ទៀតផង ។ មនុស្សដែលគ្មានព្រះវិញ្ញាណមិនបានសង្គ្រោះទេ (រម ៨:៩)។

**ខ.២០** *ប៉ុន្តែ ឯអ្នករាល់គ្នាជាពួកស្ងួនភ្ងាអើយ* សំដៅលើពួកជំនុំដែលត្រូវបានរើសតាំងឡើង ផ្ទុយពីពួកគ្រូខុសឆ្គងដែលបានលើកឡើងខាងលើ។ *ចូររក្សាខ្លួនក្នុងសេចក្ដីស្រឡាញ់របស់ព្រះ* បញ្ជាក់ថា ព្រះអម្ចាស់ទ្រង់ ថែរក្សាពួកអ្នកជឿ ដោយសេចក្ដីស្រឡាញ់របស់ទ្រង់ (មើលពន្យល់ រម ៨:៣៥-៣៩) ហើយប្រទានឱ្យពួកគេថែររក្សាខ្លួននៅក្នុងសេចក្ដីស្រឡាញ់ ។ *ជីវិតអស់កល្បជានិច្ច* "មើលការ ពន្យល់ យហ ៣:១៥"។

**ខ.២១** *សេចក្ដីជំនឿដ៏បរិសុទ្ធ* "មើលការពន្យល់ ខ.៣"។ *ដោយនូវព្រះវិញ្ញាណ* គឺតាមការដឹកនាំរបស់ព្រះវិញ្ញាណ និងដោយមានអំណាចមកពីទ្រង់ (មើលការ ពន្យល់ រម ៨:២៦-២៧ កទ ៤:៦ អភ ៦:១៧-១៨)។

**ខ.២២-២៣** *អ្នកខ្លះដែលមានសេចក្ដីសង្ស័យ . . . ហើយជួយសង្គ្រោះដល់អ្នកដទៃ* ប្រហែលសំដៅលើពួកអ្នកស្ថិតនៅក្រោមឥទ្ធិពលរបស់ពួកគ្រូខុសឆ្គង។

**ខ.២៣** *ឆក់យកគេចេញពីភ្លើង* គឺជួយសង្គ្រោះពួកគេឱ្យរួចផុតអំពីផ្លូវនៃសេចក្ដីវិនាស (អម ៤:១១ សក ៣:២ ១កថ ៣:១៥ និងការពន្យល់)។ *ចិត្តមេត្តាដល់មនុស្សឯទៀតដោយភ័យខ្លាច* បញ្ជាក់ថា ទោះជាក្នុងការបង្ហាញនូវចិត្តមេត្តា ក៏មានអ្នកខ្លះអាចធ្លាក់ចូល ទៅក្នុងអន្ទាក់នៃអំពើបាបផងដែរ ។ *ហើយស្អប់ដល់ទាំងអាវ ដែលត្រូវស្មោកគ្រោកដោយសាច់ឈាមផង* ពួកមនុស្សអាក្រក់ត្រូវបានហៅថា ជាមនុស្សស្អុយរលួយ គឺសូម្បីតែសម្លៀកបំពាក់របស់ពួកគេ ក៏ត្រូវស្មោកគ្រោក ដោយអំពើបាបរបស់ពួកគេដែរ ។

**ខ.២៤-២៥** ជាសរុបសេចក្ដីចំពោះការចាប់អារម្មណ៍អំពីពួកមនុស្សអាក្រក់ និងទង្វើនៃសេចក្ដីអាក្រក់របស់ពួកគេ ដែលមានចែងនៅក្នុងសំបុត្រនេះ លោកយូដាសបានធ្វើការសន្និដ្ឋានរបស់គាត់ ដោយឱ្យផ្ដោតអារម្មណ៍ទៅឯព្រះអម្ចាស់ ដែលទ្រង់មានអំណាចថែររក្សាពួកអ្នក ដែលទុកចិត្តដល់ទ្រង់ដោយសេចក្ដីជំនឿ ។

# វិវរណៈ
# នៃ
# ព្រះយេស៊ូវគ្រីស្ទ

សេចក្ដីផ្ដើម

**អ្នកនិពន្ធ**

អ្នកសរសេរកណ្ឌគម្ពីរនេះ គឺលោកយ៉ូហាន ដែលបានបង្ហាញឈ្មោះរបស់គាត់ចំនួនបួនដងនៅក្នុងបទគម្ពីរនេះ (១:១,៤,៩ ២២:៨) ។ តាមឯកសារដំបូងៗដូចជាឯកសាររបស់លោកយើស្ទីន ម៉ាធី (Justin Martyr) នៅសតវត្សរ៍ទីពីរបានឱ្យដឹងថាលោកយ៉ូហានម្នាក់ នេះគឺជាសាវក និងត្រូវជាកូនប្រុសរបស់លោកសេបេដេ (មថ ១០:២) ។ តាមរយៈអត្ថបទគម្ពីរយ៉ូហាននេះបានបង្ហាញថា អ្នកនិពន្ធម្នាក់នេះ គឺជាសាសន៍យូដា ជាអ្នកដែលពូកែសរសេរកំណាព្យ ជាអ្នកដឹកនាំពួកជំនុំ ហើយល្បីក្នុងចំណោមពួកជំនុំទាំងប្រាំពីរនៅអាស៊ីមីន័រ ហើយនិងជាគ្រីស្ទបរិស័ទម្នាក់ដែលមាន ជំនឿយ៉ាងរឹងមាំ រហូតបានជ័យជម្នះលើអំណាចរបស់អារក្សនៅក្នុងកិច្ចការនាលើលោកីយនេះ ។

ទោះបីជាយ៉ាងនេះក៏ដោយ ក៏នៅក្នុងសតវត្សរ៍ទីបី មានសង្ឃរាជជនជាតិអាហ្វ្រិចម្នាក់ឈ្មោះឌីអូនីស៊ីយូស (Dionysius) បានប្រៀបធៀបចំពោះ ការប្រើភាសារចនាបទ និងគំនិតនៃទីអវសាន (វិវរណៈ) ជាមួយនឹងការសរសេរអត្ថបទផ្សេងៗទៀតរបស់លោកយ៉ូហានបានធ្វើឱ្យសង្ឃរាជរូប នេះសម្រេចចិត្តថា គម្ពីរនេះពុំមែនជាការសរសេររបស់លោកសាវកយ៉ូហាននោះទេ ។ គាត់បានផ្ដល់យោបល់ថា អ្នកនិពន្ធបទគម្ពីរនេះ គឺប្រាកដជា លោកចន ប្រិសបិនធើ (John the Presbyter) ដែលឈ្មោះម្នាក់នេះត្រូវបានគេឃើញក្នុងសៀវភៅផ្សេងៗទៀតនៅសម័យពីបុរាណ ។ ដូច្នេះហើយបានជាមានមនុស្សជាច្រើនយល់ស្របគំនិតនេះ ដោយបែរទៅជាយកភស្តុតាងពីខាងក្រៅគម្ពីរដ៏ច្រើនលើសលុបនៃគំនិតទំនៀមទម្លាប់នោះ មកអនុវត្តទៅវិញនៅសព្វថ្ងៃនេះ ។

**កាលបរិច្ឆេទ**

កណ្ឌគម្ពីរវិវរណៈនេះត្រូវបានសរសេរឡើងនៅពេលដែលគ្រីស្ទបរិស័ទស្ថិតនៅក្នុងអំឡុងពេលនៃការបៀតបៀន ។ ភាគច្រើននៃវេលានោះ មានរយៈពេលពីរផ្នែកដែលគេតែងតែលើកមកនិយាយ គឺសម័យក្រោយស្ដេចនេរ៉ូ (Nero) នៅគ.ស៥៤-៦៨ និងសម័យក្រោយស្ដេចដូមីថាន (Domitian) នៅគ.ស ៨១-៩៦ ។ អ្នកកាត់ស្រាយភាគច្រើនបានយល់ថា គម្ពីរនេះបានសរសេរនៅគ.ស ៩៥ "អ្នកកាត់ស្រាយចំនួនតិចផ្សេងទៀតបាន ឱ្យយោបល់បន្ថែមថាគម្ពីរនេះបានសរសេរឡើងនៅក្នុងរាជ្ជកាលនៃការសោយរាជ្យរបស់ស្ដេចវេសប៉ាសៀន (Vespasian) នៅគ.ស ៦៩-៧៩" ។

**កាលៈទេសៈ**

នៅខណៈនេះ អំណាចរបស់ចក្រភពរ៉ូម៉ាំងបានកំពុងចាប់ផ្ដើមគាប់សង្កត់ដល់គ្រីស្ទបរិស័ទដែលបានថ្វាយបង្គំដល់ព្រះគ្រីស្ទ ដោយបដិសេធការថ្វាយបង្គំស្ដេចសេសារកាន់តែខ្លាំងឡើងៗ ។ ពួកអ្នកជឿនៅទីក្រុងស្មឺនាត្រូវបានព្រមានកុំឱ្យខ្លាចពីសេចក្ដីរងទុក្ខនោះឡើយ (២:១០) និងពួកជំនុំ នៅក្រុងភីឡាដិលភាត្រូវបានប្រាប់ដែលរក្សាឱ្យរួចពីវេលាល្បួងដែលត្រូវមកលើលោកីយទាំងមូល (៣:១០) ។ ស្ដេចអាន់ទីប៉ាសបានលះបង់ជីវិតរបស់ខ្លួន (២:១៣) ជាមួយនឹងមនុស្សផ្សេងៗទៀត (៦:៩) ។ លោកយ៉ូហានត្រូវបានគេនិរទេសទៅកោះមួយឈ្មោះថាប៉ាត់ម៉ុស (ប្រហែលជាទីតាំងសម្រាប់ដាក់ទោសរបស់អាណានិគមរ៉ូម៉ាំង) ហើយនៅទីនោះលោកមានសកម្មភាពដូចជាបេសកជន (១:៩) ។ មានអ្នកខ្លះនៅក្នុងពួកជំនុំបានធ្វើខុសនឹងសេចក្ដីជំនឿ (២:១៤-១៥,២០) ដែលចាំបាច់ត្រូវតែកែតម្រង់ ដើម្បីឱ្យអ្នកជឿទាំងឡាយអាចតាំងចិត្តឡើងក្នុងការទប់ទល់ឥទ្ធិពលនៃការគាប សង្កត់របស់ពួករ៉ូម៉ាំងនឹងមកដល់ក្នុងពេលឆាប់ៗខាងមុខនេះ ។

**គោលបំណង**

លោកយ៉ូហានសរសេរសំបុត្រនេះ ដើម្បីជំរុញទឹកចិត្តដល់គ្រីស្ទបរិស័ទឱ្យនៅតែស្មោះត្រង់នឹងសេចក្ដីជំនឿក្នុងពេលតស៊ូប្រយុទ្ធជាមួយនឹងវិញ្ញាណអាក្រក់ដ៏ខ្លាំងក្លានេះ ។ គាត់បានជូនដំណឹងដល់អ្នកអានរបស់គាត់ថា ពេលចុងក្រោយរវាងព្រះ ហើយនិងសាតាំងបានជិតមកដល់ណាស់ហើយ ។ សាតាំងនឹងបង្កើតការបៀតបៀនរបស់វាមន្ថែមទៀតដល់អ្នកជឿ ដូច្នេះហើយគ្រីស្ទបរិស័ទត្រូវតែឈរឱ្យរឹងមាំ ទោះជាត្រូវស្លាប់ក៏ដោយ ។ គ្រីស្ទបរិស័ទត្រូវបានធ្វើជាត្រាសម្រាប់តយុទ្ធនឹងវិញ្ញាណបៀតបៀន និងសម្រាប់បង្ហាញជាភស្តុតាងនៅពេលព្រះគ្រីស្ទយាងត្រឡប់មកម្ដងទៀត ជាពេលដែលមនុស្សអាក្រក់ត្រូវបានបំផ្លាញ ហើយក៏ជាពេលដែលរាស្ត្ររបស់ព្រះបានទទួលសិរីល្អនៃជីវិត និងព្រះពរដ៏អស់កល្ប ។

**ទម្រង់នៃអក្សរសាស្ត្រ**

ដើម្បីឱ្យកាន់តែយល់ច្បាស់នៅក្នុងគម្ពីរវិវរណៈ អ្នកអានត្រូវតែដឹងថា អក្សរសាស្ត្រនៅក្នុងគម្ពីរមានលក្ខណៈខុសប្លែកពីគេ ។ គម្ពីរ

វិវរណៈ គឺជាគម្ពីរមួយដែលនិយាយអំពីទីអវសាននៃពិភពលោក សំណេរប្រភេទបែបនេះគឺជាការប្រើរូបារម្មណ៍ខ្ពស់ខ្លាំងណាស់ ។ ទោះជាយ៉ាងណាក៏ដោយ ការបើកសំដែងនៅក្នុងគម្ពីរនេះ ជារឿយៗហាក់បីដូចជាប្លែកចំពោះអ្នកអាននៅប៉ែកលោកខាងលិច ប៉ុន្តែ ក៏មាននិមិត្តរូបមួយចំនួនបានបកស្រាយប្រាប់ដែរ នៅក្នុងអត្ថបទគម្ពីរនេះ (ដូចជា: ផ្កាយ គឺជាពួកទេវតា ជើងចង្កៀងគឺជាពួកជំនុំ "១:២០" ស្រីសំផឹងដ៏ធំគឺជាក្រុងបាប៊ីឡូន ឬ "រ៉ូម?" ១៧:៥,១៨ ហើយនិងក្រុងយេរូសាឡិមថ្មីចុះពីស្ថានសួគ៌គឺជាភរិយាថ្មោងថ្មីរបស់កូនចៀម "២១:៩–១០") ។

**លក្ខណៈពិសេស**

កណ្ឌគម្ពីរនេះ ជាញឹកញយឃើញមានប្រើលេខប្រាំពីរចំនួន៥២ដង ។ ដូចជា: មានព្រះពរប្រាំពីរ (មើលការពន្យល់ ១:៣) មានពួកជំនុំប្រាំពីរ (១:៤,១១) មានវិញ្ញាណប្រាំពីរ (១:៤) មានជើងចង្កៀងមាសប្រាំពីរ (១:១២) មានផ្កាយប្រាំពីរ (១:១៦) មានត្រាប្រាំពីរ (៥:១) មានស្នែងប្រាំពីរ និងភ្នែកប្រាំពីរ (៥:៦) មានត្រែប្រាំពីរ (៨:២) មានសំឡេងផ្គរលាន់ប្រាំពីរ (១០:៣) មានទីសំគាល់ប្រាំពីរ (១២:១,៣ ១៣:១៣–១៤ ១៥:១ ១៦:១៤ ១៩:២០) មានមកុដប្រាំពីរ (១៥:៦) មានសេចក្តីវេទនាប្រាំពីរ (១៥:៦) មានចានកន្ទោងមាសប្រាំពីរ (១៥:៧) មានភ្នំប្រាំពីរ (១៧:៩) មានស្តេចប្រាំពីរអង្គ (១៧:១០) ព្រមទាំងមានចំនួនប្រាំពីរផ្សេងទៀត ។ អត្ថន័យនៃនិមិត្តរូបរបស់លេខប្រាំពីរនេះ គឺជានិមិត្តរូបឱ្យចំនួនគ្រប់លក្ខណ៍ ។

**ការបកស្រាយ**

អ្នកកាត់ស្រាយអត្ថន័យរបស់គម្ពីរវិវរណៈនេះជាធម្មតាចែកជាបួនក្រុម :

*១. អ្នករស់នៅសម័យនោះ* មនុស្សនៅក្នុងសតវត្សរ៍ទី១បានយល់ថា ពាក្យពេចន៍ ការប្រកាសនៃព្រឹត្តិការណ៍ផ្សេងៗបានកើតរួចមកហើយ ។

*២. អ្នកប្រវត្តិសាស្ត្រ* យល់ថា នេះគឺជាការពិពណ៌នាពីហេតុការណ៍នៅលើកោះប៉ាតម៉ុស (Patmos) រហូតចុងបំផុតនៃប្រវត្តិសាស្ត្រ ។

*៣. អ្នកអនាគតកាល* យល់ថា ព្រឹត្តិការណ៍ទាំងនេះនឹងកើតនាពេលចុងបញ្ចប់ ។

*៤. អ្នកគំនិតនិយម* យល់ថា ព្រឹត្តិការណ៍ទាំងនេះគឺជារូបភាពនិម្មិតមួយ ដែលនឹងគ្មានពេលមកដល់ទេ ដូចជាអំពើល្អឈ្នះអំពើអាក្រក់ជាដើម ។

គោលការណ៍ដ៏សំខាន់ ហើយល្អប្រសើរបំផុតនៃសេចក្តីពិតនៅក្នុងគម្ពីរវិវរណៈនេះ គឺមិនអាស្រ័យលើការបកស្រាយរបស់ក្រុមណាមួយនោះឡើយ ។ ចំណុចទាំងនេះគឺជាមធ្យោបាយមួយដែលអាចផ្តល់ដល់អ្នកអានទាំងឡាយឱ្យចេះទប់ទល់នឹងសេចក្តីល្បួង ទុកដូចជាការបើកសំដែងដោយសេចក្តីស្រឡាញ់ដ៏ពិស្តារបំផុតមួយ ។

**គម្រោងសង្ខេប**

**I. សេចក្តីផ្តើម (១:១–៨)**

ក. បុព្វកថា (១:១–៣)

ខ. ការជម្រាបសួរ និងការសរសើរ (១:៤–៨)

**II. ព្រះយេស៊ូវគង់ក្នុងចំណោមពួកជំនុំទាំងប្រាំពីរ (១:៩–២០)**

**III. សំបុត្រជូនដល់ពួកជំនុំទាំងប្រាំពីរ (២–៣)**

ក. ក្រុងអេភេសូរ (២:១–៧)

ខ. ក្រុងស្មឺនា (២:៨–១១)

គ. ក្រុងពើកាម៉ុស (២:១២–១៧)

ឃ. ក្រុងធាទេរ៉ា (២:១៨–២៩)

ង. ក្រុងសើដេស (៣:១–៦)

ច. ក្រុងភីឡាដិលភា (៣:៧–១៣)

ឆ. ក្រុងឡៅឌីសេ (៣:១៤–២២)

**IV. បល្ល័ង្ក ក្រាំង និងកូនចៀម (៤–៥)**

ក. បល្ល័ង្កនៅស្ថានសួគ៌ (៤)

ខ. ត្រារបស់ក្រាំងទាំងប្រាំពីរ (៥:១–៥)

គ. កូនចៀមដូចជាបានសម្លាប់ហើយ (៥:៦–១៤)

**V. ត្រាទាំងប្រាំពីរ (៦:១–៨:១)**

ក. ត្រាទីមួយ : សេះស (៦:១–២)

ខ. ត្រាទីពីរ : សេះក្រហម (៦:៣–៤)

គ. ត្រាទីបី : សេះខ្មៅ (៦:៥–៦)

ឃ. ត្រាទីបួន : សេះសម្បុរស្លាំង (៦:៧–៨)

ង. ត្រាទីប្រាំ : ព្រលឹងនៅក្រោមអាសនា (៦:៩–១១)

ច. ត្រាទីប្រាំមួយ : កក្រើកដីជាខ្លាំង (៦:១២–១៧)

ឆ. ត្រានៅលើមនុស្ស ១៤៤ 000 (៧:១–៨)

ជ. គ្មានអ្នកណាអាចនឹងរាប់បាន (៧:៩–១៧)

ឈ. ត្រាទី៧: ស្ងាត់ច្រៀប (៨:១)

**VI. ត្រែទាំងប្រាំពីរ (៨:២–១១:១៩)**

ក. សេចក្តីផ្តើម (៨:២–៥)

ខ. ត្រែទីមួយ: ព្រឹល និងភ្លើងលាយដោយឈាម (៨:៦–៧)

គ. ត្រែទីពីរ : ភ្នំមួយត្រូវបានបោះទៅក្នុងសមុទ្រ (៨:៨–៩)

ឃ. ត្រែទីបី : ផ្កាយដែលមានជាតិស្លែង (៨:១0–១១)

ង. ត្រែទីបួន : ព្រះអាទិត្យ ព្រះច័ន្ទ និងផ្កាយត្រូវងងឹត១ភាគ៣ (៨:១២–១៣)

ច. ត្រែទីប្រាំ : សេចក្តីវេទនាដោយសារសត្វកណ្តូប (៩:១–១២)

ឆ. ត្រែទីប្រាំមួយ : ការស្រាយទេវតាទាំងបួន (៩:១–១២)

ជ. ទេវតា និងក្រាំងតូច (១0)

ឈ. ស្មរបន្ទាល់ទាំងពីរនាក់ (១១:១–១៤)

ញ. ត្រែទាំងប្រាំពីរ : ការជំនុំជម្រះ ហើយនិងរង្វាន់ (១១:១៥–១៩)

**VII. ឥស្សរជន និងព្រឹត្តិការណ៍ផ្សេងៗ (១២–១៤)**

ក. ស្ត្រី និងនាគ (១២)

ខ. សត្វសាហាវពីរ (១៣)

គ. កូនចៀម និងមនុស្ស១៤៤ 000នាក់ (១៤:១–៥)

ឃ. រដូវចំរូវរបស់ផែនដី (១៤:៦–២0)

**VIII. ចានទីប្រាំពីរ (១៥–១៦)**

ក. សេចក្តីផ្តើម: ចម្រៀងលោកម៉ូសេ និងទេវតាទាំងប្រាំពីរមានសេចក្តីវេទនាប្រាំពីរ (១៥)

ខ. ចានទីមួយ: ដំបៅ និងការឈឺចុកចាប់ (១៦:១–២)

គ. ចានទីពីរ: សមុទ្រក្លាយជាឈាម (១៦:៣)

ឃ. ចានទីបី: ទន្លេ និង រន្ធទឹកប្រែជាឈាម (១៦:៤–៧)

ង. ចានទីបួន: ព្រះអាទិត្យធ្វើឱ្យមនុស្សខ្លោច (១៦:៨–៩)

ច. ចានទីប្រាំ: ភាពងងឹត (១៦:១0–១១)

ឆ. ចានទីប្រាំមួយ: ភាពរីកស្ងួតនៃទឹកទន្លេអើប្រាត (១៦:១២–១៦)

ជ. ចានទីប្រាំពីរ: កក្រើកដីយ៉ាងខ្លាំង (១៦:១៧–២១)

**IX. ក្រុងបាប៊ីឡូនៈ ស្រីសំផឹងដ៏ធំ (១៧:១–១៩:៥)**

ក. ការពិពណ៌នាអំពីក្រុងបាប៊ីឡូន (១៧)

ខ. ការរលំចុះរបស់ក្រុងបាប៊ីឡូន (១៨)

គ. ការអរសប្បាយចំពោះការធ្លាក់ចុះនៃក្រុងបាប៊ីឡូន (១៩:១-៥)

**X. អរសប្បាយចំពោះវិវាហមង្គលនៃកូនចៀម (១៩:៦-១០)**

**XI. ការយាងត្រឡប់មកវិញរបស់ព្រះគ្រីស្ទ (១៩:១១-២១)**

**XII. រយៈពេល១ពាន់ឆ្នាំ (២០:១-៦)**

**XIII. សេចក្តីហិនវិនាសរបស់សាតាំង (២០:៧-១០)**

**XIV. សេចក្តីជំនុំជម្រះចេញពីបល្ល័ង្កស១យ៉ាងធំ (២០:១១-១៥)**

**XV. ស្ថានសួគ៌ថ្មី ផែនដីថ្មី ក្រុងយេរូសាឡិមថ្មី (២១:១-២២:៥)**

**XVI. សេចក្តីបញ្ចប់ និងការអធិស្ឋានជូនពរ (២២:៦-២១)**

## បុព្វកថា

**១** ១នេះជាសេចក្ដីដែលព្រះយេស៊ូវគ្រីស្ទ បានបើកឱ្យ
ឃើញ ជាសេចក្ដីដែលព្រះបានប្រទាន[ក]មកទ្រង់ ដើម្បីនឹង
បង្ហាញដល់ពួកបាវបំរើទ្រង់ ឱ្យដឹងពីអស់ទាំងការដែល
បន្តិចទៀតត្រូវកើតមានមក[ខ] ទ្រង់ក៏បានសំដែងឱ្យឃើញ
ដោយចាត់ទេវតា[គ]ទ្រង់មកឯយ៉ូហាន ជាបាវបំរើទ្រង់[ឃ]
២គាត់បានធ្វើបន្ទាល់ប្រាប់តាមព្រះបន្ទូល[ង] នឹងសេចក្ដី
បន្ទាល់នៃព្រះយេស៊ូវគ្រីស្ទ[ច] គឺពីគ្រប់ទាំងសេចក្ដីដែលគាត់
បានឃើញ ៣មានពរហើយ អ្នកណាដែលមើល និងអស់អ្នក
ដែលស្ដាប់ពាក្យទំនាយទាំងនេះ ហើយប្រព្រឹត្តតាមសេចក្ដី
ទាំងប៉ុន្មាន ដែលកត់ទុកនេះដែរ[ឆ] ដ្បិតឯពេលវេលា នោះ
ជិតដល់ហើយ[ជ]។

## ការជម្រាបសួរ និងការសរសើរតម្កើងព្រះ

៤សំបុត្រយ៉ូហានខ្ញុំ ផ្ញើមកពួកជំនុំទាំង៧[ឈ]នៅស្រុកអាស៊ី
សូមឱ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ[ញ] និងសេចក្ដី
សុខសាន្ត អំពីព្រះដ៏គង់នៅ ក៏គង់នៅតាំងតែពីដើម ហើយ
ត្រូវយាងមកទៀត[ដ] និងអំពីព្រះវិញ្ញាណទាំង៧[ឋ] ដែលនៅ
ចំពោះបល្ល័ង្កទ្រង់ ៥ហើយអំពីព្រះយេស៊ូវគ្រីស្ទ ជាស្មរ
បន្ទាល់ស្មោះត្រង់[ឌ] ដែលកើតពីពួកស្លាប់មកមុនគេបង្អស់[ឍ]
ជាអធិបតីលើអស់ទាំងស្តេចនៅផែនដី[ណ] រីឯព្រះអង្គដែល
ទ្រង់ស្រឡាញ់យើងរាល់គ្នា[ត] ហើយបានលាងយើង ដោយ
ព្រះលោហិតទ្រង់[ថ]ឱ្យបានរួចពីបាប ៦ព្រមទាំងតាំងយើង
រាល់គ្នាឡើងជានគរ ហើយជាពួកសង្ឃ[ទ]ថ្វាយព្រះដ៏ជា
ព្រះវរបិតា[ធ] នោះសូមឱ្យទ្រង់បានសិរីល្អ នឹងព្រះចេស្ដា
នៅអស់កល្បជានិច្ចរៀងរាបតទៅ អាម៉ែន[ន]។
៧មើល ទ្រង់យាងមកតាមពពក[ប] នោះគ្រប់ទាំងភ្នែកនឹង
ឃើញទ្រង់ ព្រមទាំងពួកអ្នកដែលចាក់ទ្រង់ផង[ផ] រួចគ្រប់
ទាំងពូជមនុស្សនៅផែនដីនឹងយំសោក[ព] ដោយព្រោះទ្រង់
អើ មែនហើយ អាម៉ែន ។
៨ព្រះអម្ចាស់ដ៏ជាព្រះ ដែលទ្រង់គង់នៅ ក៏គង់នៅតាំង
តែពីដើម ហើយត្រូវយាងមកទៀត[ភ] គឺជាព្រះដ៏មានព្រះ
ចេស្ដាបំផុត[ម] ទ្រង់មានបន្ទូលថា អញជាអាលផា និងជា
អូមេកា[យ] គឺជាដើម ហើយជាចុង ។

**១:១** ក យហ ១២:៤៩ ១៧:៨ ខ ខ.១៩ ដយ ២:២៨,២៩ វវ ២២:៦ គ វវ ២២:១៦ ឃ ខ.៤,៩ វវ ២២:៨
**១:២** ង ខ.៩ ហព ៤:១២ ច ខ.៩ ១២:១៧ ១:៦ វវ ៦:៩ ២:១៧ ១៩:១០
**១:៣** ឆ លក ១១:២៨ វវ ២២:៧ ជ រម ១៣:១១
**១:៤** ឈ ខ.១១,២០ ញ រម ១:៧ ដ ខ.៨ វវ ៤:៨ ១១:១៧ ១៦:៥ ឋ អស ១១:២ វវ ៣:១ ៤:៥ ៥:៦
**១:៥** ឌ អស ៥៥:៤ យហ ១៨:៣៧ វវ ៣:១៤ ឍ ទដ ៨៩:២៧ កល ១:១៨ ណ ១ធថ ៦:១៥ ត រម ៨:៣៧ ថ រម ៣:២៥
**១:៦** ទ ១ពត ២:៥ វវ ៥:១០ ២០:៦ ធ រម ១៥:៦ ន រម ១១:៣៦
**១:៧** ប ដយ ៧:១៣ មថ ១៦:២៧ ២៤:៣០ ២៦:៦៤ លក ១៧:៣០ ១កថ ១:៧ ១ថន ២:១៩ ៤:១៦,១៧ ផ យហ ១៩:៣៤,៣៧ ព សក ១២:១០ មថ ២៤:៣០
**១:៨** ភ ខ.៤ ម ខ.១៧ វវ ២១:៦ ២២:១៣ យ វវ ៤:៨ ១៥:៣ ១៩:៦

**១:១** *បានបើកឱ្យឃើញ* គឺជាការដាក់ឱ្យឃើញ ឬការផ្សាយបង្ហាញឱ្យដឹងពីទីអវសាននៃលោកីយ ។ *នេះជាសេចក្ដីដែលព្រះយេស៊ូវគ្រីស្ទ* ឃ្លានេះចង់បញ្ជាក់ថា (១).ការបើកសំដែងទាំងនេះគឺមកពីព្រះយេស៊ូវគ្រីស្ទ (២).អំពីព្រះយេស៊ូវគ្រីស្ទ (៣).ឬក៏អាចទាំងពីរ ។ *បាវបំរើ* គឺជាអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទ ។ *ដែលបន្តិចទៀតត្រូវកើតមានមក* មើល ខ.៣ ២២:៦-៧, ១០,២០ ។ *ទេវតា* គឺជាអ្នកនាំសាររបស់ព្រះអម្ចាស់ ។ នៅក្នុងគម្ពីរវិវរណៈមានពាក្យទេវតានេះរហូតដល់៨០ដង ។ *យ៉ូហាន* មើលសេចក្ដីផ្ដើមត្រង់ចំណុចអ្នកនិពន្ធ ។
**១:៣** *មានពរហើយ* នេះគឺជាសុភមង្គលមួយនៅក្នុងចំណោមសុភមង្គលទាំងប្រាំពីរ (មើល ១៤:១៣ ១៦:១៥ ១៩:៩ ២០:៦ ២២:៧,១៤)។ ពាក្យថា "*មានពរ* " មានន័យលើសពី "ភាពសប្បាយ"។ ពាក្យនេះបានពិពណ៌នាពីកាលៈទេសៈដែលព្រះអម្ចាស់បានអនុគ្រោះដល់មនុស្ស (មើលការពន្យល់ ទដ ១:១ មថ ៥:៣)។ *ពាក្យទំនាយទាំងនេះ* គឺមិនមែនគ្រាន់តែប្រាប់ពីហេតុការណ៍ពីអនាគតនោះទេ ប៉ុន្តែ ថែមទាំងប្រកាសប្រាប់ពីព្រះបន្ទូលនោះផងដែរទាំងការបង្គាប់ទាំងបង្រៀនប្រវត្តិសាស្ត្រ ឬក៏ជាទំនាយ (១កថ ១៤:៣ និងពន្យល់)។ *ពេលវេលា នោះជិតដល់ហើយ* មើលពន្យល់ យក ៥:៩ ។
**១:៤** *ពួកជំនុំទាំង៧* មានទីតាំងចម្ងាយប្រមាណ៨០គ.មពីគ្នាជារង្វង់មូលទ្រនិចនាឡិកា ដោយចាប់ពីក្រុងអេភេសូរភាគខាងកើត រហូតដល់ក្រុងឡៅឌីសេនៅក្នុងស្រុកអាស៊ី ។ ក្រុងអេភេសូរ និងក្រុងឡៅឌីសេគឺជាទីក្រុងសំខាន់នៃការផ្តល់ទីតាំងភូមិសាស្ត្រ ។ នៅក្នុងខ.១១បានប្រាប់យ៉ាងច្បាស់ថាអ្វីៗដែលបានបើកសំដែងនៅក្នុងគម្ពីរវិវរណៈនេះ គឺសម្រាប់ផ្ញើទៅពួកជំនុំទាំង៧នេះ (ដោយមាន៧សំបុត្រ)។ *ស្រុកអាស៊ី* ស្រុកនេះកាលពីសម័យមុនគឺជាខេត្តរបស់ចក្រភពរ៉ូម៉ាំងដែលលាតសន្ធឹងរហូតដល់ភាគខាងលិចប្រទេសទួរគីសព្វថ្ងៃ ។ *ព្រះគុណ និងសេចក្ដីសុខសាន្ត* មើលការពន្យល់ រម ១:៧ ។ *អំពីព្រះដ៏គង់នៅ . . . គង់នៅតាំងតែពីដើម ហើយត្រូវយាងមកទៀត* ឃ្លានេះគឺដកស្រង់ចេញពី នក ៣:១៤–១៥ ហព ១៣:៨ ដែលនិយាយពីព្រះនាមរបស់ព្រះអម្ចាស់។ *ព្រះវិញ្ញាណទាំង៧* "សក ៤:២ ៤:១០ និងពន្យល់"។
**១:៥–៦** *ឱ្យបានរួចពីបាប...ព្រមទាំងតាំងយើងរាល់គ្នា* ឃ្លានេះបានបញ្ជាក់ពីព្រះពរមួយដែលបានប្រទានមកដល់គ្រីស្ទបរិស័ទ ទុកជាទ្រព្យសម្បត្តិដ៏សែនអំណរនាពេលបច្ចុប្បន្ននេះ (មើល ៥:៩–១០)។
**១:៦** *ជានគរ ហើយជាពួកសង្ឃ* នេះហើយគឺជាការជ្រើសរើសទុកជាមុនចំពោះជនជាតិអ៊ីស្រាអែលនៅក្នុងគម្ពីរសញ្ញាចាស់ (មើលការពន្យល់ នក ១៩:៦ សក ៣) ហើយត្រូវបានយកមកអនុវត្តនៅក្នុងគម្ពីរសញ្ញាថ្មីគឺសំដៅលើពួកជំនុំ (១ពត ២:៥,៩)។
**១:៧** *យាងមកតាមពពក* មើលការពន្យល់ មថ ២៤:៣០ ។ *ចាក់* មើល ទដ ២២:១៦ អស ៥៣:៥ សក ១២:១០ យហ ១៩:៣៤,៣៧ ។ *អើ មែនហើយ អាម៉ែន* នេះគឺជាប្រយោជន៍មួយដែលស្របអត្ថន័យខាងលើ ។
**១:៨** *ជាអាលផា និងជាអូមេកា* នេះគឺជាតួអក្សរដំបូងគេ ហើយនិងជាតួអក្សរចុងក្រោយគេនៃព្យញ្ជនៈភាសាក្រិក ។ ព្រះអម្ចាស់ទ្រង់គឺជាដើម ហើយជាចុង (មើល ២១:៦)។ ទ្រង់គឺជាព្រះដែលគ្រប់គ្រងលើប្រវត្តិសាស្ត្ររបស់មនុស្សទាំងមូល ។ នៅក្នុង "២២:១៣" ព្រះយេស៊ូវទ្រង់បានបញ្ជាក់ពីព្រះនាមទ្រង់យ៉ាងដូចនេះដែរ "ជាដើម ហើយជាចុង" (ខ.៧ ២:៨ ២២:១៣)។ *ព្រះចេស្ដា* ពាក្យនេះមានចំនួន៩ដងក្នុងគម្ពីរវិវរណៈ ក្នុងចំណោមទាំង១២ពាក្យដែលមាននៅក្នុងគម្ពីរសញ្ញាថ្មីទាំងមូល (៤:៨ ១១:១៧ ១៥:៣ ១៦:៧

## ព្រះដែលមានសណ្ឋានដូចជាកូនមនុស្ស

៩ យ៉ូហាន[រ] ខ្ញុំ ដែលជាបងប្អូននៃអ្នករាល់គ្នា ហើយជា
អ្នកមានចំណែកក្នុងសេចក្តីទុក្ខលំបាក[ល] នឹងក្នុងនគរ[វ] ហើយ
ក្នុងសេចក្តីអត់ធ្មត់[ស] របស់ព្រះយេស៊ូវគ្រីស្ទ ជាមួយនឹងអ្នក
រាល់គ្នាដែរ ខ្ញុំបាននៅឯកោះឈ្មោះប៉ាត់ម៉ុស ដោយព្រោះ
ព្រះបន្ទូល[ហ] នឹងសេចក្តីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ[ឡ] ១០ ហើយ
នៅថ្ងៃនៃព្រះអម្ចាស់[អ] ខ្ញុំបានត្រឡប់ជានៅដោយវិញ្ញាណ[ក]
នោះក៏ឮសំឡេងបន្លឺឡើង ដូចជាសូរត្រែ[ខ] នៅខាងក្រោយខ្ញុំ
ថា ១១ "ការអ្វីដែលឯងឃើញ[គ] នោះចូរកត់ទុកក្នុងសៀវភៅ
ចុះ រួចផ្ញើទៅពួកជំនុំទាំង៧[ឃ] ដែលនៅស្រុកអាស៊ីផង គឺនៅ
ក្រុងអេភេសូរ[ង] ក្រុងស្មឺនា[ច] ក្រុងពើកាម៉ុស[ឆ] ក្រុងធាទេរ៉ា[ជ]
ក្រុងសើដេស[ឈ] ក្រុងភីឡាដិលភា[ញ] ហើយនៅក្រុងឡៅឌីសេ
ដែរ[ដ]។

១២ ខ្ញុំក៏បែរខ្លួនទៅមើលសំឡេង ដែលមានបន្ទូលមកខ្ញុំ
នោះ លុះបែរខ្លួនទៅហើយ នោះក៏ឃើញជើងចង្កៀង
មាស ៧[ឋ] ១៣ នៅត្រង់កណ្តាលជើងចង្កៀងទាំង ៧ នោះ[ឌ]
ឃើញមាន១អង្គ ដូចជាកូនមនុស្ស[ឍ] ទ្រង់ព្រះពស្ត្រវែងដល់
ព្រះបាទ[ណ] ហើយមានខ្សែមាសរឹតត្រង់ព្រះឧរា[ត] ១៤ ព្រះ
សិរសានឹងព្រះកេសាទ្រង់ស ដូចជារោមចៀមដែលស គឺ
ដូចហិមៈ ព្រះនេត្រទ្រង់ដូចជាអណ្តាតភ្លើង[ថ] ១៥ ព្រះបាទទ្រង់
ដូចជាលង្ហិនរលីង ដែលភ្លឺផ្លេកៗដូចជាដុតក្នុងគុកភ្លើង[ទ]
ព្រះសូរសៀងទ្រង់ដូចជាសូរនៃទឹកច្រើន[ធ] ១៦ នៅព្រះហស្ត
ស្តាំទ្រង់កាន់ផ្កាយ ៧[ន] ក៏មានដាវមុខ ២ ដ៏មុត[ប] ចេញពី
ព្រះឱស្ឋទ្រង់មក ហើយព្រះភក្ត្រទ្រង់ ដូចជាថ្ងៃ[ផ] ភ្លឺពេញអំ
ណាច ១៧ កាលខ្ញុំឃើញទ្រង់នោះខ្ញុំដួលនៅទៀបព្រះបាទទ្រង់
[ព] ដូចជាស្លាប់ តែទ្រង់ដាក់ព្រះហស្តស្តាំលើខ្ញុំ[ភ] ដោយបន្ទូល
ថា កុំខ្លាចអ្វីឡើយ[ម] អញជាដើម ហើយជាចុង[យ] ១៨ ជាព្រះដ៏

**១:៩** រ ខ.១ ល កច ១៤:២២ ២កថ ១:៧ ភល ៤:១៤ វ ខ.៦ ស ២ធថ ២:១២ ហ ខ.២ ហព ៤:១២ ឡ ខ.២
**១:១០** អ កច ២០:៧ ក វវ ៤:២ ១៧:៣ ២១:១០ ខ នក ២០:១៨ វវ ៤:១
**១:១១** គ ខ.១៩ ឃ ខ.៤,២០ ង កច ១៨:១៩ ច វវ ២:៨ ឆ វវ ២:១២ ជ កច ១៦:១៤ វវ ២:១៨ ឈ វវ ៣:១ ញ វវ ៣:៧ ដ កល ២:១ វវ ៣:១៤
**១:១២** ឋ ខ.២០ នក ២៥:៣១-៤០ សក ៤:២ វវ ២:១
**១:១៣** ឌ វវ ២:១ ឍ អគ ១:២៦ ដយ ៧:១៣ ១០:១៦ វវ ១៤:១៤ ណ អស ៦:១ ត ដយ ១០:៥ វវ ១៥:៦ **១:១៤** ថ ដយ ៧:៩ ១០:៦ វវ ២:១៨ ១៩:១២ **១:១៥** ទ អគ ១:៧ ដយ ១០:៦ វវ ២:១៨ ធ អគ ៤៣:២ វវ ១៤:២ ១៩:៦ **១:១៦** ន ខ.២០ វវ ២:១ ៣:១ ប អស ១:២០ ៤៩:២ ហព ៤:១២ វវ ២:១២,១៦ ១៩:១៥,២១ ផ ពច ៥:៣១ មថ ១៧:២
**១:១៧** ព អគ ១:២៨ ដយ ៨:១៧,១៨ ភ ដយ ៨:១៨ ម មថ ១៤:២៧ យ អស ៤១:៤ ៤៤:៦ ៤៨:១២ វវ ២:៨ ២២:១៣

១៩:៦,១៥ ២១:២២ រម ៩:២៩ ២កថ ៦:១៨ យក ៥:៤)។

**១:៩** *សេចក្តីទុក្ខលំបាក . . . ក្នុងនគរ . . . ក្នុងសេចក្តីអត់ធ្មត់* ទាំងបីពាក្យនេះគឺជាផ្នែករឿងសំខាន់នៅក្នុងគម្ពីរវិវរណៈ (១).ពាក្យថា "ទុក្ខលំបាក" (២:៩-១០,២២ ៧:១៤)។ (២).ពាក្យថា "នគរ" (១១:១៥ ១២:១០ ១៦:១០ ១៧:១២,១៧-១៨) (៣)."អត់ធ្មត់" (២:២-៣,១៩ ៣:១០ ១៣:១០ ១៤:១២)។ *ប៉ាត់ម៉ុស* គឺជាឈ្មោះកោះតូចមួយមានទំហំប្រហែល១២,៨០ គ.ម² នៅក្នុងសមុទ្រអាជីន (Aegean Sea) ដែលមានសុទ្ធតែថ្មចម្ងាយប្រហែលជា៨០គ.មពីក្រុងអេភេសូរភាគខាងត្បូងដោយចេញពីឆ្នេរសមុទ្រនៃប្រទេសទួរគីនាពេលបច្ចុប្បន្ន ។ កោះនោះអាចជាកន្លែងសម្រាប់ពួករ៉ូម៉ាំងដាក់អ្នកទោសផងដែរ ដោយសំអាងលើប្រវត្តិសាស្ត្ររបស់ពួកជំនុំដើមក្នុងឆ្នាំទី ២៦៥-៣៤០គ.ស បានឱ្យដឹងថា លោកយ៉ូហានម្នាក់នេះត្រូវបានរួចពីការឃុំខ្លួននៅកោះប៉ាត់ម៉ុសក្រោមការគ្រប់គ្រប់របស់អធិរាជនេវ៉ា (Nerva) នៅឆ្នាំទី ៩៦-៩៨គ.ស ។

**១:១០** *នៅថ្ងៃនៃព្រះអម្ចាស់* គឺជាពាក្យបច្ចេកទេសមួយដែលមានន័យថា ជាថ្ងៃដំបូងនៃសប្តាហ៍ ពីព្រោះនៅថ្ងៃនោះព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទទ្រង់មានព្រះជន្មរស់ពីសុគតឡើងវិញ ហើយនៅថ្ងៃនោះក៏ជាថ្ងៃដែលគ្រីស្ទបរិស័ទ (កច ២០:៧) បានប្រមូលផ្តុំគ្នាដែរ (១កថ ១៦:២)។ *នៅដោយវិញ្ញាណ* នេះគឺជាការថ្លែងមួយនៃការលើកឡើងខាងវិញ្ញាណ ដោយអំណាចរបស់ព្រះវិញ្ញាណពុំមែនជាការយល់សប្តិ គឺជានិម្មិតដូចជាពេត្រុសនោះដែរ (កច ១០:១០)។

**១:១១** *សៀវភៅ* តាមពិតទៅពុំមែនជាសៀវភៅធម្មតាដូចសព្វថ្ងៃនេះទេ គឺជាឧបករណ៍ម្យ៉ាងធ្វើពីដើមរុក្ខជាតិ ឬពីស្បែកសត្វ ដេរភ្ជាប់គ្នា ហើយយកមករុំនឹងដុំឈើមួយ (មើលការពន្យល់ នក ១៧:១៤)។ នេះគឺជាសៀវភៅដំបូងដែលគេបានប្រើនៅសតវត្សរ៍ទីពីរ ។

**១:១២** *៧* មើលសេចក្តីផ្តើមពន្យល់គម្ពីរវិវរណៈ ។ សម្រាប់សំគាល់លក្ខណៈពិសេសអ្វីមួយ ។ *ជើងចង្កៀងមាស* គឺសំដៅលើពួកជំនុំទាំង៧ (ខ.២០)។

**១:១៣** *កូនមនុស្ស* មើលការពន្យល់ ដយ ៧:១៣ មក ៨:៣១ ។ *ព្រះពស្ត្រវែងដល់ព្រះបាទ* ដូចជាសម្តេចសង្ឃនោះដែរ គឺពាក់អាវស៊ីកវែងដល់ជើង (នក ២៨:៤ ២៩:៥)។ ត្រង់ចំណុចនេះគឺសំដៅទៅលើតួអង្គព្រះយេស៊ូវ ដែលទ្រង់គឺជាសម្តេចសង្ឃដែលមានខ្សែមាសរឹតត្រង់ព្រះឱរា (ពាក់ឆៀងនៅនាដើមទ្រូង)។

**១:១៤** *ស ដូចជារោមចៀម* មើល ដយ ៧:៩ អស ១:១៨ ។ ព្រះកេសាទ្រង់ស្កូវ គឺសំដែងពីប្រាជ្ញា និងកិត្តិសព្ទរបស់ទ្រង់ (លវ ១៩:៣២ សភ ១៦:៣១)។ *ព្រះនេត្រទ្រង់ដូចជាអណ្តាតភ្លើង* មានន័យថា ព្រះអង្គមានប្រាជ្ញាយល់គ្រប់ហេតុការណ៍ និងទតមើលធ្លុះគ្រប់ទាំងចិត្តគំនិតរបស់មនុស្ស (៤:៦)។

**១:១៦** *ដាវមុខពីរដ៏មុតចេញពីព្រះឱស្ឋទ្រង់* គឺជាដាវម្យ៉ាងវែងដូចជាអ្នកស្រុកទ្រេស (Thracian) ដែលរស់នៅតាមឆ្នេរសមុទ្រខ្មៅពីបុរាណយកមកប្រើ (២:១២,១៦ ៦:៨ ១៩:១៥,២១)។ ដាវនៅក្នុង ៦:៤ ១៣:១០,១៤ គឺជាដាវតូច១ ឬក៏កាំបិតស្នៀត ។ ដាវគឺជានិមិត្តរូបនៃការជំនុំជម្រះរបស់ព្រះ (អស ៤៩:២ ហព ៤:១២)។

**១:១៧** *ដួលនៅទៀបព្រះបាទ* គឺជាសញ្ញានៃការគោរព និងកោតខ្លាចដ៏ខ្លាំង (៤:១០ ៥:៨ ៧:១១ ១៩:១០ ២២:៨)។ *អញជា* មើលការពន្យល់ យហ ៦:៣៥ ។ *ជាដើមហើយជាចុង* មានអត្ថន័យដូចនឹងពាក្យថា "ជាអាលផា និងជាអូមេកា" (ខ.៨ អស ៤៤:៦ ៤៨:១២)។

**១:១៨** *ជាព្រះដ៏រស់នៅ* គឺជាព្រះដ៏មានព្រះជន្ម (យស ៣:១០ ទដ ៤២:២ ៨៤:២) ដែលផ្ទុយនឹងព្រះរបស់សាសន៍ដទៃជាព្រះស្លាប់នោះ ព្រះគ្រីស្ទទ្រង់ជាម្ចាស់លើជីវិតដែលមានលក្ខណៈតាំងពីដើមមកម៉្លេះ ។ *កូនសោនៃសេចក្តី*

រស់នៅ អញបានស្លាប់[វ] តែមើល អញរស់នៅអស់កល្បជា
និច្ចរៀងរាបតទៅវិញ[ល] អញក៏មានកូនសោនៃសេចក្ដីស្លាប់
និងស្ថានឃុំព្រលឹងមនុស្សស្លាប់ដែរ[វ] ១៩ដូច្នេះ ចូរឱ្យឯង
កត់អស់ទាំងសេចក្ដីដែលឯងបានឃើញ[ស] ព្រមទាំងសេចក្ដី
ដែលមានសព្វថ្ងៃនេះ នឹងសេចក្ដីទាំងប៉ុន្មាន ដែលត្រូវ
កើតមកតាមក្រោយទៀតផង ២០ឯសេចក្ដីអាថ៌កំបាំង ពី
ផ្កាយទាំង ៧ ដែលឯងបានឃើញនៅដៃស្តាំអញ[ហ] ហើយពី
ជើងចង្កៀងមាសទាំង៧[ឡ] នោះស្រាយថា ផ្កាយទាំង៧នោះ
គឺជាទេវតារបស់ពួកជំនុំទាំង ៧[អ] ហើយជើងចង្កៀងទាំង៧
នោះគឺជាពួកជំនុំទាំង៧នោះឯង[ក] ។

## ពួកជំនុំនៅក្រុងអេភេសូរ

**២** ១ចូរសរសេរផ្ញើទៅទេវតានៃពួកជំនុំ ដែលនៅក្រុង
អេភេសូរ[ខ]ថា ព្រះអង្គដែលកាន់ផ្កាយទាំង៧ នៅព្រះហស្ត
ស្តាំ[គ]ហើយយាងនៅកណ្ដាលជើងចង្កៀងមាសទាំង ៧ នោះ
ទ្រង់មានបន្ទូលសេចក្ដីទាំងនេះថា[ឃ] ២អញស្គាល់អស់ទាំង
ការដែលឯងធ្វើ[ង] និងសេចក្ដីនឿយហត់ ហើយសេចក្ដីអត់
ធ្មត់របស់ឯងហើយ ក៏ដឹងថា ឯងទ្រាំនឹងមនុស្សអាក្រក់ពុំ
បានផង គឺឯងបានល្បងល[ច]ពួកអ្នកដែលហៅខ្លួនជាសា
វកតែមិនមែនជាសាវកទេ ក៏បានឃើញថា អ្នកទាំងនោះ
ជាពួកភូតភរវិញ[ឆ] ៣ឯងបានអត់ធន់ ហើយទ្រាំទ្រទាំងធ្វើ
ការដោយនឿយហត់ ឥតណាយចិត្តឡើយ ដោយព្រោះ
ឈ្មោះអញ[ជ] ៤តែអញប្រកាន់សេចក្ដីនេះនឹងឯង គឺថា ឯង
បានបោះបង់ចោលសេចក្ដីស្រឡាញ់ដើមចេញ[ឈ] ៥ដូច្នេះ
ចូរនឹកចាំ ដែលឯងបានធ្លាក់ចេញពីសណ្ឋានណានោះ
ហើយប្រែចិត្តចុះ[ញ] រួចប្រព្រឹត្តតាមការដើមដំបូងនោះវិញ
ពុំនោះសោត អញនឹងមកឯឯង ហើយនិងហូតយកជើង
ចង្កៀងឯង[ដ]ពីកន្លែងចេញ លើកតែឯងប្រែចិត្តឡើងវិញ
៦ប៉ុន្តែ ឯងមាន សេចក្ដី១នេះ គឺថា ឯងស្អប់ការរបស់ពួក
នីកូឡាស[ឋ] ដែលអញក៏ស្អប់ដែរ ៧អ្នកណាដែលមានត្រ
ចៀក ឱ្យអ្នកនោះស្តាប់[ឌ]សេចក្ដី ដែលព្រះវិញ្ញាណមាន
បន្ទូល ដល់ពួកជំនុំទាំងប៉ុន្មានចុះ ឯអស់អ្នកណាដែលឈ្នះ[ឍ]

**១:១៨** វ រម ៦:៩ វវ ២:៨ ល ដយ ៣២:៤០ ដយ ៤:៣៤ ១២:៧ វវ ៤:៩,១០ ១០:៦ ១៥:៧ វ វវ ៩:១ ២០:១
**១:១៩** ស ខ.១១ ហព ២:២
**១:២០** ហ ខ.១៦ ឡ ខ.១២ អ ខ.៤,១១ ក មថ ៥:១៤,១៥
**២:១** ខ កច ១៨:១៩ គ វវ ១:១៦
**២:១** ឃ វវ ១:១២,១៣
**២:២** ង ខ.១៩ វវ ៣:១,៨,១៥ ច ១យហ ៤:១ ឆ ២កថ ១១:១៣
**២:៣** ជ យហ ១៥:២១
**២:៤** ឈ យរ ២:២ មថ ២៤:១២
**២:៥** ញ ខ.១៦,២២ វវ ៣:៣,១៩ ដ វវ ១:២០ **២:៦** ឋ ខ.១៥
**២:៧** ឌ មថ ១១:១៥ ខ.១១,១៧,២៩ វវ ៣:៦,១៣,២២ ១៣:៩

*ស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់* ត្រង់នេះគឺបង្ហាញពីដែននៃអំណាចគ្រប់គ្រង(មថ ១៦:១៨ និងសេចក្ដីពន្យល់)។

**១:១៩** នៅក្នុងខនេះបានបែកចែកជាបីផ្នែកដែលជាគំរូនៃរចនាសម្ព័ន្ធនៅក្នុងគម្ពីរវិវរណៈនេះទាំងមូល ។ *"ចូរឱ្យឯងកត់អស់ទាំងសេចក្ដីដែលឯងបានឃើញ"* នេះគឺជានិម្មិតដំបូងនៅក្នុងជំពូកទី១ ។ "ព្រមទាំងសេចក្ដីដែលមានសព្វថ្ងៃនេះ" ត្រង់នេះគឺជាសេចក្ដីសំបុត្រសម្រាប់ផ្ញើទៅកាន់ពួកជំនុំទាំង៧(ជំពូក ២–៣)។ "សេចក្ដីទាំងប៉ុន្មាន ដែលត្រូវកើតមកតាមក្រោយទៀត" គឺជាអ្វីៗដែលមាននៅក្នុងជំពូកទី៤តទៅ ។ ការជ្រើសរើសយករបៀបបកស្រាយបែបនេះដោយសំអាងលើ ខ.១១នោះផងដែរ ។

**១:២០** នេះគឺជាកន្លែងដំបូងគេក្នុងកន្លែងជាច្រើនដែលជានិមិត្តរូបត្រូវយកមកបកស្រាយ(១៧:១៥,១៨)។ *ទេវតា* ពាក្យនេះអាចមានន័យពីរ (១).ជាអ្នកនាំសារមកពីស្ថានសួគ៌ (២).គឺជាអ្នកនាំសារនៅលើផែនដីគឺជាអ្នកបម្រើព្រះ ។

**២:១–៣:២២** មានអ្នកខ្លះបានយកសំបុត្រទាំង៧នេះ មកធ្វើជាសេចក្ដីសង្ខេបនៃប្រវត្តិរបស់ពួកជំនុំដោយចាប់ផ្ដើមពីក្រុងឡៅឌីសេជាដើមដំបូង ។ មានមនុស្សមួយចំនួនទៀតបានចាត់ទុកពួកជំនុំទាំង៧នេះថា ជាអត្តសញ្ញាណនៃចរិតលក្ខណៈផ្សេងៗគ្នារបស់ពួកជំនុំគ្រីស្ទបរិស័ទនីមួយៗ នៅសម័យលោកយ៉ូហាន ហើយបានបន្តរហូតមកដល់សព្វថ្ងៃនេះ ។ តាមករណីទាំងពីរខាងលើនេះ ធ្វើឱ្យយើងដឹងថាពួកជំនុំទាំង៧នេះគឺជាប្រវត្តិសាស្ត្ររបស់ពួកជំនុំនៅអាស៊ីមីន័រ ។ ជាទូទៅអត្ថន័យនៅក្នុងសំបុត្រនេះគឺនិយាយអំពីការកោតសរសើរការរអ៊ូរទាំ និងអំពីការកែតម្រង់ ។

**២:១** *ទេវតា* មើលការពន្យល់ ១:២០ ។ *ក្រុងអេភេសូរ* មើលសេចក្ដីផ្ដើមគម្ពីរអេភេសូរ ។ *កាន់ផ្កាយទាំង៧* មើល ១:១៦,២០ ។ *ជើងចង្កៀងមាសទាំង៧* មើល ១:១២,២០ ។

**២:២** *ល្បងល* នេះគឺជាការល្បងលអំពីគោលលទ្ធិ និងសេចក្ដីបង្រៀនដែលជាកិច្ចការចាំបាច់ ហើយត្រូវបានគេទទួលស្គាល់ជាទូទៅ នៅក្នុងសម័យពួកជំនុំដំបូង(១កថ ១៤:២៩ ១ថន ៥:២១ ១យហ ៤:១)។

**២:៤** *សេចក្ដីស្រឡាញ់ដើម* គឺជាសេចក្ដីស្រឡាញ់ដែលពួកគេមានចំពោះគ្នាទៅវិញទៅមក និងចំពោះព្រះគ្រីស្ទជាដំបូង ។

**២:៥** *ហូតយកជើងចង្កៀងឯងពីកន្លែងចេញ* ឃ្លានេះសំដៅលើការជំនុំជម្រះជាបន្ទាន់ ។

**២:៦** *ពួកនីកូឡាស* គឺជាប្រភេទមនុស្សអាក្រក់មួយក្រុមនៅក្នុងព្រះវិហារដែលបានធ្វើការសម្របសម្រួលជាមួយនឹងសង្គមអ្នកមិនជឿព្រះ ។ ពួកនេះបានបង្រៀនថា វិញ្ញាណនៃសិទ្ធិសេរីភាពបានផ្ដល់ឱ្យពួកគេមានសិទ្ធិគ្រប់គ្រាន់ ដើម្បីនឹងប្រព្រឹត្តអំពើកំផិត និងអំពើអសីលធម៌ ។ តាមប្រពៃណីនៅសម័យនោះបានឱ្យដឹងថា នីកូឡាសជាអ្នកស្រុកនៅអាន់ទីយ៉ូក គឺជាមនុស្សដំបូងគេក្នុងចំណោមអ្នក ជំនួយទាំង៧ក្នុងពួកជំនុំនៅក្រុងយេរូសាឡិម(កថ ៦:៥) ប៉ុន្តែ ទាំងអស់នេះគ្រាន់តែជាការបង្ហាញពីដំណើរហេតុការណ៍ប៉ុណ្ណោះ ។ មានមនុស្សមួយក្រុមទៀត ស្រដៀងនឹងនេះដែរនៅក្រុងពើកាម៉ុស ដែលបានកាន់តាមសេចក្ដីបង្រៀនរបស់បាឡាម (ខ.១៤–១៥) ហើយមួយក្រុមទៀតនៅក្រុងធាទេរ៉ា ដែលកាន់តាមសេចក្ដីបង្រៀនរបស់ស្ត្រីម្នាក់ឈ្មោះយេសិបិល(ខ.២០)។ ដោយសារនិន្នាការរបស់ក្រុមទាំងបីនេះបានបង្កើតឱ្យមានក្រុមមួយថា ពួកនីកូឡាសនេះឯង ។

**២:៧** *ឈ្នះ* ត្រង់នេះគឺជាការជំរុញទឹកចិត្តឱ្យមានជ័យជម្នះ នៅក្នុងសមរភូមិប្រឆាំងនឹងវិញ្ញាណអាក្រក់(១២:១១) ដែលមានកត់ចុះនៅក្នុងសំបុត្រនីមួយៗ (ខ.១១,១៧,២៦ ៣:៥,១២,២១)។ *ស្ថានបរមសុខ* ពាក្យនេះគឺ

នោះអញនឹងឱ្យបរិភោគផ្លែរបស់ដើមជីវិត[ណ] ដែលនៅ
ស្ថានបរមសុខ[ត]របស់ព្រះ ។

## ចំពោះពួកជំនុំនៅក្រុងស្មឺន៉ា

៨ចូរសរសេរផ្ញើទៅទេវតានៃពួកជំនុំ ដែលនៅក្រុង
ស្មឺន៉ាថា[ថ] ព្រះដ៏ជាដើម ហើយជាចុង[ទ] ដែលបានសុគត
រួចមានព្រះជន្មរស់ឡើងវិញ[ធ] ទ្រង់មានបន្ទូលសេចក្ដីទាំង
នេះថា ៩អញស្គាល់សេចក្ដីទុក្ខលំបាក នឹងសេចក្ដីកំសត់
របស់ឯងហើយ ប៉ុន្តែ ឯងជាអ្នកមានវិញ[ន] ក៏ស្គាល់សេចក្ដី
ប្រមាថរបស់ពួកអ្នក ដែលហៅខ្លួនជាសាសន៍យូដាដែរ
តែគេមិនមែនសាសន៍យូដាទេ[ប] គឺជាពួកជំនុំរបស់អារក្ស
សាតាំងវិញ[ផ] ១០កុំឱ្យឯងខ្លាចសេចក្ដីដែលឯងត្រូវរងទុក្ខ
នោះឡើយ មើល អារក្សវារៀបនឹងបោះពួកឯងខ្លះទៅក្នុង
គុកហើយ ដើម្បីនឹងល្បងលមើលឯង[ព] នោះឯងរាល់គ្នានឹង
ត្រូវរងវេទនាអស់ ១០ ថ្ងៃ[ភ] ដូច្នេះ ចូរនៅជាស្មោះត្រង់[ម]
ដរាបដល់ស្លាប់ចុះ នោះអញនឹងឱ្យមកុដនៃជីវិតដល់ឯង[យ]
១១អ្នកណាដែលមានត្រចៀក ឱ្យអ្នកនោះស្ដាប់[រ]សេចក្ដី
ដែលព្រះវិញ្ញាណមានបន្ទូលដល់ពួកជំនុំទាំងប៉ុន្មានចុះ
ឯអ្នកណាដែលឈ្នះ នោះសេចក្ដីស្លាប់ទី២ នឹងធ្វើទុក្ខដល់
អ្នកនោះមិនបានឡើយ[ល] ។

**២:៧** ឈ យហ ១៦:៣៣ ណ លប ២:៩ ៣:២២–២៤ វវ ២២:២,១៤,១៩ ត លក ២៣:៤៣
**២:៨** ថ វវ ១:១១ ទ វវ ១:១៧ ធ វវ ១:១៨
**២:៩** ន ២កថ ៦:១០ យក ២:៥ ប វវ ៣:៩ ផ ខ.១៣,២៤ មថ ៤:១០
**២:១០** ព វវ ៣:១០ ភ ដយ ១:១២,១៤ ម ខ.១៣ វវ ១៧:១៤ យ មថ ១០:២២ ១កថ ៩:២៥
**២:១១** រ ខ.៧ ល វវ ២០:៦,១៤ ២១:៨
**២:១២** វ វវ ១:១១ ស ខ.១៦ វវ ១:១៦
**២:១៣** ហ វវ ១៤:១២ ឡ វវ ១:៥ ១១:៣ អ ខ.៩,២៤ មថ ៤:១០

## ចំពោះពួកជំនុំនៅក្រុងពើកាម៉ុស

១២ចូរសរសេរផ្ញើទៅទេវតានៃពួកជំនុំ ដែលនៅក្រុង
ពើកាម៉ុស[វ]ថា ព្រះដែលមានដាវមុខ ២ ដ៏មុត[ស] ទ្រង់មាន
បន្ទូលសេចក្ដីទាំងនេះថា ១៣អញស្គាល់ទីលំនៅរបស់ឯង
ហើយ គឺជាកន្លែងដែលមានបល្ល័ង្ករបស់អារក្សសាតាំង
នោះ តែឯងកាន់ខ្ជាប់តាមឈ្មោះអញ ហើយមិនបានលះ
ចោលសេចក្ដីជំនឿដល់អញចេញឡើយ[ហ] ទោះក្នុងគ្រា
ដែលគេបាន សំឡាប់អាន់ទីប៉ាស ជាស្មរបន្ទាល់ស្មោះត្រង់
របស់អញ[ឡ] នៅកណ្ដាលពួកឯងរាល់គ្នា ជាកន្លែងដែល
អារក្សសាតាំងនៅនោះផង[អ] ១៤ប៉ុន្តែ អញប្រកាន់សេចក្ដី
ខ្លះនេះនឹងឯង[ក] ពីព្រោះនៅទីនោះ ឯងមានអ្នកខ្លះ ដែល
កាន់តាមសេចក្ដីបង្រៀនរបស់បាឡាម[ខ] ជាអ្នកដែលបង្រៀន
ឱ្យបាឡាមដាក់អន្ទាក់នៅមុខ ពួកជនជាតិអ៊ីស្រាអែល
ដើម្បីនឹងនាំឱ្យគេបរិភោគដង្វាយ ដែលថ្វាយទៅរូបព្រះ[គ]
ហើយឱ្យប្រព្រឹត្តសេចក្ដីកំផិតផង[ឃ] ១៥ឯងក៏មានអ្នកខ្លះ
ដែលកាន់តាមសេចក្ដីបង្រៀន របស់ពួកនីកូឡាសដែរ[ង]
១៦ដូច្នេះ ចូរប្រែចិត្តចុះ[ច] ពុំនោះសោតអញនឹងមកឯឯង

**២:១៤** ក ខ.២០ ខ ២ពត ២:១៥ គ កច ១៥:២០ ឃ ១កថ ៦:១៣
**២:១៥** ង ខ.៦ **២:១៦** ច ខ.៥

មានដើមកំណើតមកពីភាសាពើស៊ី ដែលមានន័យថា សួនឧទ្យានដ៏រីករាយ (លក ២៣:៤៣) ។ នៅក្នុងការ បើកសំដែងនេះ គឺជានិមិត្តរូបមួយប្រាប់អំពីទីកន្លែងដែលព្រះអម្ចាស់ និងអ្នកជឿបានរស់នៅព្រមទាំងប្រកបគ្នាយ៉ាងជិតស្និទ្ធតាំងពីមុនអំពើបាបបានចូលមកក្នុងពិភពលោកនេះ ។

**២:៨** *ស្មឺន៉ា* ជាទីក្រុងមួយដែលមានភាពឆើតឆាយ និងជាទីមោទកភាពនៅក្នុងតំបន់អាស៊ី ហើយជាសម្ព័ន្ធមិត្តយ៉ាងជិតស្និតជាមួយនឹងទីក្រុងរ៉ូម ដោយសារទីក្រុងមួយនេះ បានឆ្លើយតបនឹងសេចក្ដីត្រូវការរបស់រ៉ូម៉ាំង ។ ចំណុចនេះហើយ ដែលជាឧបសគ្គយ៉ាងធំដល់ប្រជាជនយូដាដែលជាគ្រីស្ទបរិស័ទនៅទីក្រុងនោះ ។ លោកប៉ូលីខាប (Polycarp ) គឺជាសម្ដេចសង្ឃម្នាក់នៅក្រុងស្មឺន៉ាដែលល្បីខាងឯរងទុក្ខលំបាកជាងគេ ។

**២:៩** *ហៅខ្លួនជាសាសន៍យូដា* មើល រម ២:២៨–២៩ ។ *សាតាំង* មើលការពន្យល់ មថ ១៦:២៣ ១យហ ៣:៨ ។

**២:១០** *អារក្ស* ជាភាសាក្រិកមានន័យថា"មេចោទប្រកាន់"។ *វេទនា* មើលការព្រមានរបស់ព្រះយេស៊ូវ (យហ ១៥:២០) ហើយនិងការព្រមានរបស់លោកប៉ុល (២ធថ ៣:១២)។ *១០ថ្ងៃ* ត្រង់នេះប្រហែលជាបង្ហាញរយៈពេលនៃការរងទុក្ខ ។ *មកុដនៃជីវិត* គឺជាមកុដដែលមានជីវិតអស់កល្បជានិច្ច ។ "មកុដ" នៅត្រង់នេះពុំទាក់ទងទៅនឹងមកុដរបស់ស្ដេចនោះទេ (១២:៣ ១៣:១ ១៩:១២) គឺសំដៅទៅលើកម្រងផ្កា ឬភួងជ័យដែលសម្រាប់ផ្ដល់រង្វាន់ក្នុងការប្រកួតកីឡា (៣:១១ ៤:៤,១០ ៦:២ ៩:៧ ១២:១ ១៤:១៤) ។

**២:១១** *ឈ្នះ* មើលការពន្យល់ ខ.៧ ។ សេចក្ដីស្លាប់ទី២ គឺជាបឹងភ្លើង (២០:៦,១៤ ២១:៨) ។

**២:១២** *ក្រុងពើកាម៉ុស* បច្ចុប្បន្នមានឈ្មោះថា បើហ្គាម៉ា (Bergama ) ជារាជធានីបុរាណរបស់ស្រុកអាស៊ី ដែលត្រូវបានគេសង់ឡើងមានរាងមូលដូចជាប្រាក់កាក់ នៅលើកំពូលកូនភ្នំមួយមានកំពស់ប្រហែល៣០,៤៨ម៉ែត្រជុំវិញជ្រលងភ្នំនោះ ។ ទីក្រុងនេះមានឈ្មោះមួយផ្សេងទៀតជាសាភាក្រិកថា "ស៊ីតាដែល" (citadel ) ។

**២:១៣** *កន្លែងដែលមានបល្ល័ង្ករបស់អារក្សសាតាំង* សាតាំងបានចាប់យកក្រុងពើកាម៉ុស ធ្វើជាមូលដ្ឋានធំសម្រាប់ដឹកនាំអាណាចក្ររបស់វានៅស្រុកអាស៊ី ។ *អាន់ទីប៉ាស* ជាជនរងគ្រោះទីមួយនៅក្នុងស្រុកអាស៊ី ។ តាមការនិយាយតៗគ្នាមកបានឱ្យដឹងថា គាត់ត្រូវបានដុតសម្លាប់បន្តិចម្ដងៗនៅក្នុងឆ្នាំងស្ពាន់មួយក្នុងអំឡុងពេលនៃស្ដេចដូមីទាន (Domitian ) សោយរាជ្យ (ឆ្នាំ៨១–៩៦គ.ស) ។ *ស្មរបន្ទាល់ ស្មោះត្រង់* ពាក្យនេះគឺសំដៅទៅលើងារ ឬព្រះនាមរបស់ព្រះអម្ចាស់ (១:៥) ។

**២:១៤** *កាន់តាមសេចក្ដីបង្រៀនរបស់បាឡាម* បាឡាមម្នាក់នេះបានទទួលការណែនាំពីស្ត្រីសាសន៍ម៉ាឌានជាច្រើននាក់ ក្នុងការដឹកនាំអ៊ីស្រាអែលទៅរកផ្លូវខុស (ជន ២៥:១–២ ៣១:១៦ យដ ១១) ។ គាត់ម្នាក់នេះ ហើយដែលជាគ្រូបង្រៀនខុសឆ្គងមុនដំបូងគេ ក្នុងការបង្ខូចដល់អ្នកជឿទាំងឡាយឱ្យប្រព្រឹត្តអំពើអាក្រក់ជាមួយនឹងពួកលោកីយ ។ *ដង្វាយដែលថ្វាយទៅរូបព្រះ . . . សេចក្ដីកំផិត* មើល កច ១៥:២០,២៩ ។

**២:១៥** *ពួកនីកូឡាស* មើលការពន្យល់ ខ.៦ ។

**២:១៦** *ដាវដែលនៅមាត់អញ* នេះគឺជាដាវវែងមួយ (១:១៦ និងពន្យល់) ។

ជាឆាប់ នោះអញនឹងយកដាវ ដែលនៅមាត់អញ ច្បាំងនឹង
គេ[ឆ] ១៧អ្នកណាដែលមានត្រចៀក ឱ្យអ្នកនោះស្តាប់[ជ]
សេចក្តីដែលព្រះវិញ្ញាណមានបន្ទូល ដល់ពួក ជំនុំទាំង
ប៉ុន្មានចុះ ឯអ្នកណាដែលឈ្នះ[ឈ] នោះអញនឹងឱ្យបរិភោគ
នំម៉ាន៉ាដ៏លាក់កំបាំង[ញ] ហើយនឹងឱ្យគ្រួសស ១ដល់អ្នកនោះ
នៅគ្រួសនោះមានឆ្លាក់ជាឈ្មោះថ្មី[ដ] ដែល គ្មានអ្នកណា
ស្គាល់ឡើយ ស្គាល់បានតែអ្នកដែលទទួល ប៉ុណ្ណោះ[ឋ] ។

## ចំពោះពួកជំនុំធាទេរ៉ា

១៨ចូរសរសេរផ្ញើទៅទេវតានៃពួកជំនុំ ដែលនៅក្រុង
ធាទេរ៉ាថា[ឌ] ព្រះរាជបុត្រានៃព្រះ[ឍ] ដែលមានព្រះនេត្រដូច
ជាអណ្តាតភ្លើង ហើយព្រះបាទដូចជាលង្ហិនរលីង[ណ] ទ្រង់
មានបន្ទូលសេចក្តីទាំងនេះថា ១៩អញស្គាល់ការដែលឯង
ធ្វើហើយ[ត] ព្រមទាំងសេចក្តីស្រឡាញ់ សេចក្តីជំនួយ សេចក្តី
ជំនឿ សេចក្តីអត់ធ្មត់របស់ឯងដែរ ហើយថា ការដែលឯង
ធ្វើជាន់ក្រោយ បានច្រើនលើសជាងជាន់មុនទៅទៀត
២០តែអញប្រកាន់សេចក្តីខ្លះនឹងឯង ដ្បិតឯងបណ្តោយឱ្យស្ត្រី
ឈ្មោះយេសិបិល[ថ] ដែលហៅខ្លួនជាហោរា បានទៅបង្ហាត់
បង្រៀន ហើយនាំពួកបាវបំរើរបស់អញ ឱ្យវង្វេងទៅ
ប្រព្រឹត្តសេចក្តីកំផិត ហើយបរិភោគដង្វាយដែលថ្វាយទៅ
រូបព្រះផង[ទ] ២១អញបានឱ្យវាមានឱកាស[ធ]នឹងប្រែចិត្តចេញ
ពីការកំផិតរបស់វាដែរ តែវាមិនព្រមសោះ[ន] ២២មើលអញ

**២:១៦** ឆ ២ថន ២:៨ វវ ១:១៦
**២:១៧** ជ ខ.៧ ឈ យហ ១៦:៣៣ ញ យហ ៦:៤៩,៥០ ដ អស ៥៦:៥ ៦២:២ ៦៥:១៥ ឋ វវ ១៩:១២
**២:១៨** ឌ ខ.២៤ កច ១៦:១៤ វវ ១:១១ ឍ មថ ៤:៣ ណ វវ ១:១៤,១៥
**២:១៩** ត ខ.២
**២:២០** ថ ១ពវ ១៦:៣១ ២១:២៥ ២ពវ ៩:៧ ទ ខ.១៤ កច ១៥:២០
**២:២១** ធ រម ២:៤ ២ពត ៣:៩ ន រម ២:៥ វវ ៩:២០ ១៦:៩,១១
**២:២២** ប វវ ១៧:២ ១៨:៩
**២:២៣** ផ ១សយ ១៦:៧ ១ពវ ៨:៣៩ ទដ ១៣៩:១,២,២៣ សភ ២១:២ យរ ១៧:១០ លក ១៦:១៥

នឹងបោះវាទៅលើគ្រែ ហើយបោះពួកអ្នក ដែលប្រព្រឹត្ត
សេចក្តីកំផិត[ប]ជាមួយនឹងវា ឱ្យទៅក្នុងសេចក្តីវេទនាជាខ្លាំង
លើកតែគេប្រែចិត្តលះបង់ការ ដែលគេប្រព្រឹត្តនោះចេញ
២៣ហើយអញនឹងសំឡាប់កូនចៅវាចោល[ផ] នោះគ្រប់ទាំង
ពួកជំនុំនឹងដឹងថា គឺអញនេះហើយ ដែលស្ទង់មើលចិត្ត នឹង
ថ្លើម រួចអញនឹងសងការដល់ឯងរាល់គ្នា តាមការដែល
គ្រប់គ្នាបានប្រព្រឹត្ត[ព] ២៤តែអញប្រាប់ដល់ឯងរាល់គ្នា ហើយ
ដល់ពួកអ្នកឯទៀត នៅក្រុងធាទេរ៉ាដែរ គឺដល់ពួកអ្នក
ដែលមិនកាន់តាមសេចក្តីបង្រៀននោះ ក៏មិនស្គាល់សេចក្តី
ជំរៅរបស់អារក្សសាតាំង ដូចជាពាក្យដែលគេថានោះ
ឡើយ តែអញ ៗមិនផ្ទុកបន្ទុកអ្វីទៀតលើឯងរាល់គ្នាទេ[ភ]
២៥ប៉ុន្តែ សេចក្តីដែលឯងមាន[ម] នោះឱ្យកាន់ខ្ជាប់ ដរាបដល់
អញមកចុះ[យ] ២៦ឯអ្នកណាដែលឈ្នះ[រ] ហើយកាន់តាមការ
អញដរាបដល់ចុងបំផុត[ល] នោះអញនឹងឱ្យមានអំណាចលើ
ពួកសាសន៍ដទៃ[វ] ២៧អ្នកនោះនឹងឃ្វាលគេដោយដំបងដែក[ស]
ដូចជាគេបំបែកភាជន៍ដីឱ្យខ្ទេចខ្ទី[ហ] តាមអំណាចដែលអញ
បានទទួលពីព្រះវរបិតាមក ២៨អញនឹងឱ្យផ្កាយព្រឹកដល់អ្នក
នោះ[ឡ] ២៩អ្នកណាដែលមានត្រចៀកឱ្យអ្នកនោះស្តាប់[អ] សេច
ក្តីដែលព្រះវិញ្ញាណមានបន្ទូលដល់ពួកជំនុំទាំងប៉ុន្មានចុះ ។

រម ៨:២៧ ១ថន ២:៤ ព មថ ១៦:២៧ **២:២៤** ភ កច ១៥:២៨
**២:២៥** ម វវ ៣:១១ យ មថ ១៦:២៧ **២:២៦** រ យហ ១៦:៣៣
ល មថ ១០:២២ វ ទដ ២:៨ វវ ៣:២១ **២:២៧** ស វវ ១២:៥ ១៩:១៥ ហ ទដ
២:៩ អស ៣០:១៤ យរ ១៩:១១ **២:២៨** ឡ វវ ២២:១៦ **២:២៩** អ ខ.៧

**២:១៧** *ឈ្នះ* មើលការពន្យល់ ខ.៧ ។ *នំម៉ាន៉ាដ៏លាក់កំបាំង* គឺសំដៅទៅលើម្ហូបអាហារនៅស្ថានសួគ៌ ដែលបម្រុងទុកឱ្យអ្នកជឿ ដែលមានជ័យជម្នះ (ទដ ៧៨:២៤) ម្ហូបអាហារនេះគឺផ្ទុយគ្នានឹងអាហារមិនស្អាតរបស់ពួកបាឡាម ។ *គ្រួសស* គឺជាដុំគ្រួសមួយប្រភេទដែលត្រូវបានគេធ្លាប់យកមកប្រើធ្វើកាក់សំប៉ែតៗមកប្រើជាច្រើនប្រភេទ ។ គ្រួសសត្រង់នេះ អាចជាវត្ថុមួយសម្រាប់បង្ហាញពីការដែលអាចចូលរួមបរិភោគពិធីស៊ីលៀងរបស់ព្រះមែស៊ីបាន ។ *ឈ្មោះថ្មី* គឺជាឈ្មោះអ្នកដែលមានជ័យជម្នះ (អស ៦២:២ ៦៥:១៥) ។

**២:១៨** *ក្រុងធាទេរ៉ា* បច្ចុប្បន្ននេះមានឈ្មោះថា អាគីសា (Akhisar) ។ បានស្ថាបនាដោយស្តេចសេឡើគូសទី១ (Seleucus I) ឆ្នាំ៣១១–២៨០មុន គ.ស ជាបន្ទាយជួរមុខរបស់ពួកយោធា ហើយទីនេះត្រូវបានគេស្គាល់ថា ដោះដូរទំនិញជាច្រើនប្រភេទនោះផងដែរ ។ លីឌា គឺជាអ្នករកស៊ីជួញដូរក្រណាត់ពណ៌ស្វាយម្នាក់មកពីក្រុងធាទេរ៉ានេះឯង (មើលការពន្យល់ កច ១៦:១៤) ។ *ព្រះនេត្រដូចជា អណ្តាតភ្លើង* មើលការពន្យល់ ១:១៤ ដយ ១០:៦ ។ *ព្រះបាទ* គឺជាជើង ។

**២:២០** *ស្ត្រីឈ្មោះយេសិបិល* "១ពវ ១៦:៣១ ២ពវ ៩:២២,៣០–៣៧"។ ឈ្មោះនេះត្រូវធ្លាប់បានគេប្រើសម្រាប់បញ្ជាក់ពីស្ត្រីម្នាក់នៅក្នុងពួកជំនុំដែលជាមនុស្សខ្វះភាពស្មោះត្រង់ចំពោះព្រះអម្ចាស់របស់ខ្លួន ដោយបែរទៅតាមការប្រព្រឹត្តរបស់ពួកសាសន៍ដទៃវិញ ។

**២:២២** *គ្រែ . . .សេចក្តីវេទនា* ពាក្យនេះគឺតែងតែសំដៅលើជំងឺផ្សេងៗដែលជាការដាក់ទោសសម្រាប់អ្នកដែលបានធ្វើបាប (សូមមើល ១កថ ១១:២៩,៣០) ។

**២:២៣** *កូនចៅវា* យេសិបិលគឺជាម្តាយខាងឯវិញ្ញាណនៃពួកអ្នកកាន់តាមគោលលទ្ធិនៃសេចក្តីកំផិត ។ *គឺអញនេះហើយ ដែលស្ទង់មើលចិត្ត និងថ្លើម* (ទដ ៧:៩ សភ ២៤:១២ យរ ១១:២០ ១៧:១០) ។ "ចិត្ត" គឺសំដៅលើឆន្ទៈ និងមនោសញ្ចេតនា ។ *តាមការដែលគ្រប់គ្នាបានប្រព្រឹត្ត* ការជំនុំជម្រះ គឺផ្អែកទៅលើទង្វើរបស់មនុស្ស (មថ ១៦:២៧ រម ២:៦ វវ ១៨:៦ ២០:១២–១៣ ២២:១២) ។

**២:២៤** *សេចក្តីជំរៅរបស់អារក្សសាតាំង* មើលសេចក្តីផ្តើម យ៉ូហានទី១ ។ ក្នុងសេចក្តីពន្យល់នោះបានប្រាប់យើងថា ដើម្បីយកជ័យជម្នះលើសាតាំងនោះត្រូវតែចូលឱ្យដល់ចំណុចខ្លាំងរបស់វា ។

**២:២៧** *ឃ្វាល* នេះគឺជាពាក្យប្រៀបធៀបទៅនឹងពាក្យថា "ត្រួតត្រា" ។ *ដំបងដែក* គឺជានិមិត្តរូបពីអំណាចរបស់ទ្រង់ (១២:៥ ១៩:១៥) ។

**២:២៨** *ផ្កាយព្រឹក* ប្រៀបធៀប ២២:១៦ ដយ ១២:៣ ។

## ចំពោះពួកជំនុំនៅក្រុងសើដេស

**៣** ១ចូរសរសេរផ្ញើទៅទេវតានៃពួកជំនុំ ដែលនៅក្រុង
សើដេស[ក]ថា ព្រះដ៏មានព្រះវិញ្ញាណទាំង៧[ខ] នឹងផ្កាយទាំង
៧[គ] ទ្រង់មានបន្ទូលសេចក្តីទាំងនេះថា អញស្គាល់ការដែល
ឯងប្រព្រឹត្តហើយ[ឃ] គឺដែលឯងមានឈ្មោះថារស់ តែឯង
ស្លាប់ទេ[ង] ២ចូរប្រុងប្រយ័ត្ន ហើយចំរើនកំឡាំងដល់អ្វីៗ
ដែលនៅសល់ ដែលរៀបនឹងស្លាប់នោះដែរ ដ្បិតអញមិន
បានឃើញការដែលឯងប្រព្រឹត្តនោះ ជាពេញខ្នាតនៅ
ចំពោះព្រះនៃអញទេ ៣ដូច្នេះ ចូរនឹកចាំដែលឯងបាន
ទទួល ហើយបានឮជាយ៉ាងណា រួចឱ្យកាត់តាម ហើយប្រែ
ចិត្តចុះ[ច] បើឯងមិនចាំយាមទេ នោះអញនឹងមកឯងដូចជា
ចោរ[ឆ] ហើយឯងនឹងមិនដឹងជាវេលាណា[ជ] ដែលអញមកឯ
ឯងឡើយ ៤ប៉ុន្តែ នៅក្រុងសើដេស ឯងក៏មានអ្នកខ្លះ ដែល
មិនបានធ្វើឱ្យសំលៀកបំពាក់ខ្លួនស្មោកគ្រោកដែរ[ឈ] អ្នក
ទាំងនោះនឹងស្លៀកពាក់ស[ញ] ដើរជាមួយនឹងអញដ្បិតគេ
បានគួរហើយ ៥អ្នកណាដែលឈ្នះ[ដ] នោះនឹងបានស្លៀក
ពាក់ស[ឋ] ហើយអញមិនដែលលុបឈ្មោះអ្នកនោះ ចេញពី
បញ្ជីជីវិតឡើយ[ឌ] អញនឹងថ្លែងប្រាប់ពីឈ្មោះអ្នកនោះ នៅ
ចំពោះព្រះវរបិតា អញ[ឍ] នឹងចំពោះពួកទេវតាទ្រង់ដែរ
៦អ្នកណាដែលមានត្រចៀក ឱ្យអ្នកនោះស្តាប់[ណ]សេចក្តីដែល
ព្រះវិញ្ញាណមានបន្ទូល ដល់ពួកជំនុំទាំងប៉ុន្មានចុះ ។

## ចំពោះពួកជំនុំនៅក្រុងភីឡាដិលភា

៧ចូរសរសេរផ្ញើទៅទេវតានៃពួកជំនុំ ដែលនៅក្រុង
ភីឡាដិលភា[ត]ថា ព្រះអង្គដ៏បរិសុទ្ធ[ថ] ហើយពិតប្រាកដ[ទ] ដែល
ទ្រង់កាន់កូនសោររបស់ហ្លួងដាវីឌ[ធ] ដែលទ្រង់បើក ហើយ
គ្មានអ្នកណាបិទ ក៏បិទ ហើយគ្មានអ្នកណាបើកបានទ្រង់មាន
បន្ទូលសេចក្តីទាំងនេះថា ៨អញស្គាល់ការដែលឯងធ្វើ
ហើយ[ន] មើល អញបានបើកទ្វារចំហ[ប]នៅមុខឯង គ្មានអ្នក
ណាអាចនឹងបិទបានទេ ពីព្រោះទោះបើឯងមានអំណាចតែ
បន្តិចក៏ដោយ គង់តែបានកាន់តាមពាក្យអញដែរ ហើយមិន
បានលះបង់ឈ្មោះអញទេ[ផ] ៩មើល អញប្រគល់ពួកជំនុំរបស់
អារក្សសាតាំងខ្លះដល់ឯង[ព] ដែលពួកនោះអួតខ្លួនថាជា
សាសន៍យូដា តែមិនមែនទេ[ភ] គឺគេកុហកវិញ មើល អញនឹង
ឱ្យគេមកក្រាបសំពះ នៅទៀបជើងឯង[ម] ព្រមទាំងឱ្យគេដឹង
ថា អញបានស្រឡាញ់ដល់ឯងផង[យ] ១០ហើយដោយព្រោះ
ឯងបានកាន់តាមរឿង ពីសេចក្តីអត់ធ្មត់របស់អញ នោះអញ

**៣:១** ក វវ ១:១១ ខ វវ ១:៤ គ វវ ១:១៦ ឃ វវ ២:២ ង ១ធថ ៥:៦
**៣:៣** ច វវ ២:៥ ឆ លក ១២:៣៩ ជ លក ១២:៣៩
**៣:៤** ឈ យដ ២៣ ញ ខ.៥,១៨ វវ ៤:៤,៦ ៦:១១ ៧:៩, ១៣,១៤ ១៩:១៤
**៣:៥** ដ យហ ១៦:៣៣ ឋ ខ.៤ ឌ វវ ២០:១២ ឍ មថ ១០:៣២
**៣:៦** ណ វវ ២:៧
**៣:៧** ត វវ ១:១១ ថ មក ១:២៤ ទ ១យហ ៥:២០ វវ ៦:១០ ១៩:១១ ធ អស ២២:២២ មថ១៦:១៩
**៣:៨** ន វវ ២:២ ប កច ១៤:២៧ ផ វវ ២:១៣
**៣:៩** ព វវ ២:៩ ភ វវ ២:៩ ម អស ៤៩:២៣ យ អស ៤៣:៤ រម ៨:៣៧

**៣:១** *ក្រុងសើដេស* ទីក្រុងនេះបច្ចុប្បន្នមានឈ្មោះថា សាត (Sart ) ជារាជធានីនៃអាណាចក្របុរាណរបស់ប្រទេសលីឌា ដែលមានកិត្តិនាមល្បីល្បាញ ហើយនិងមានទ្រព្យសម្បត្តិដ៏ច្រើនមហាសាល ។ ទីក្រុងនេះស្ថិតនៅលើទីទួលពីធម្មជាតិដ៏សំខាន់មួយ នៅភាគខាងជើងនៃភ្នំធ្មូលូស (Tmolus ) មានកំពស់ប្រហែល៤៥,៧២ម ពីជ្រលងភ្នំនេះ ។

**៣:៣** *មកឯងដូចជាចោរ* ពុំមែនជាការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទនោះទេ ពីព្រោះការយាងមកត្រង់ចំណុចនេះ គឺអាស្រ័យលើការមិនព្រមប្រែចិត្តរបស់ពួកជំនុំ ។ មានប្រយោគផ្សេងៗទៀតដែលនិយាយអំពីការយាងត្រឡប់មករបស់ព្រះគ្រីស្ទនោះគឺ (១៦:១៥ មថ ២៤:៤២–៤៤ ១ថន ៥:២ ២ពត ៣:១០) ។

**៣:៤** *ស្លៀកពាក់ស* ពាក្យនេះគឺជាការពិពណ៌នាអំពីសេចក្តីប្រោសលោះ (៣:១៨ ៦:១១ ៧:៩,១៣–១៤ ៤:៤ ១៩:១៤) ។

**៣:៥** *បញ្ជីជីវិត* គឺជាសៀវភៅរបស់ព្រះអម្ចាស់ ។ សៀវភៅនេះបាននិយាយដំបូងគេនៅក្នុង នក ៣២:៣២–៣៣ (មើលការពន្យល់ ទដ ៦៩:២៨ ដយ ១២:១) ។ ជាសៀវភៅមួយសម្រាប់ចុះឈ្មោះរាស្ត្រទាំងអស់នៅក្នុងនគររបស់ទ្រង់ ។ *មិនដែលលុបឈ្មោះចេញ* ចង់បញ្ជាក់ថា ឈ្មោះទាំងឡាយណាដែលបានកត់ចុះហើយ នោះនឹងមិនត្រូវលុបចេញពីបញ្ជីជីវិតនេះវិញឡើយ នេះគឺជាការធានាអះអាងពីព្រះអម្ចាស់ (១៣:៨ ២០:១២,១៥ ២១:២៧ ភម ៤:៣) ។

**៣:៧** *ក្រុងភីឡាដិលភា* ទីក្រុងនេះបច្ចុប្បន្នមានឈ្មោះថា អាឡាសីហ៊ី (Ala-shehir ) ជាក្រុងពាណិជកម្មមួយដ៏សំខាន់ មានទីតាំងក្នុងស្រុកអាស៊ីនៅអាស៊ីមីន័រ ជាអាណាខេត្តនៃចក្រភពរ៉ូម៉ាំង ។ ទីក្រុងនេះត្រូវបានកសាងឡើងដោយស្តេចអាតាលូសទី២ (Attalus II នៅឆ្នាំ២២០–១៣០មុនគ.ស) សម្រាប់រំឭក និងឧទ្ទិសដល់វីរភាពបងប្រុសរបស់ទ្រង់ឈ្មោះអ៊ីមីណេសទី២ (Eumenes II) ដូច្នេះហើយ បានជាឈ្មោះទីក្រុងនេះមានន័យថា "បងប្រុសជាទីស្រឡាញ់"។ *បរិសុទ្ធ ហើយពិតប្រាកដ* មើល ៦:១០ ។ ព្រះអម្ចាស់ទ្រង់ជាព្រះដ៏បរិសុទ្ធ មើល អស ៤០:២៥ ហព ៣:២–៣ មក ១:២៤ មើលការពន្យល់ នក ៣:៥ លវ ១១:៤៤ ។ *កូនសោររបស់ហ្លួងដាវីឌ* ព្រះគ្រីស្ទទ្រង់គឺជាព្រះមែស៊ីតាមវង្សស្តេចដាវីឌ ដែលទ្រង់មានអំណាចព្រះចេស្តា ដើម្បីគ្រប់គ្រងទ្វារចូលនគរស្ថានសួគ៌ (អស ២២:២២ មថ ១៦:១៩) ។

**៣:៨** *ទ្វារចំហ* មានន័យថា ជាទ្វារនៃឱកាសក៏បាន ឬជាទ្វារចូលនគរស្ថានសួគ៌ក៏បាន ។ បរិបទនេះនឹងមានពន្យល់លំអិតនៅពេលក្រោយទៀត ។

**៣:៩** *ពួកជំនុំរបស់អារក្សសាតាំង* នេះគឺជាការប្រៀបធៀបចំៗមួយបានបង្ហាញពីការប្រឆាំងពីពួកអ្នកមិនជឿ និងពួកសត្រូវរបស់សាសន៍យូដា ។ ព្រះយេស៊ូវបន្ទោសយ៉ាងដំណំក្នុងគម្ពីរ យហ ៨:៤៤ ២កថ ១១:១៤–១៥ ។ ពួកជំនុំសាសន៍យូដា គឺជាកន្លែងប្រមូលផ្តុំគ្នាមួយសម្រាប់ថ្វាយបង្គំសិក្សា និងធ្វើសកម្មភាពរួម ។ *អួតខ្លួនថាជាសាសន៍យូដា* មើល រម ២:២៨–២៩ ។ *ក្រាបសំពះនៅទៀបជើងឯង* មើល អស ៤៥:១៤ ៦០:១៤ កច ១០:២៥ ភម ២:១០ និងការពន្យល់ វវ ១:១៧ ។

**៣:១០** *រក្សាឯងឱ្យរួចពី* ជាភាសាក្រិកឃ្លានេះអាចមានន័យថា "រួចខ្លួនពីទុក្ខទោសក៏បាន" ឬ "រួចផុតពីទុក្ខហើយក៏បាន"។ *វេលាល្បួង* គឺជារយៈពេលនៃការល្បួង មុននឹងទទួលបានជីវិតពេញបរិបូរ នៃនគរស្ថានសួគ៌

នឹងរក្សាឯង[រ] ឱ្យរួចពីវេលាល្បងដែលត្រូវមកលើលោកីយ
ទាំងមូល[ល] ដើម្បីនឹងល្បងល[វ]ដល់ពួកអ្នក ដែលនៅលើ
ផែនដីទាំងប៉ុន្មាន[ស] ១១មើល អញមកជាឆាប់ហើយ[ហ] ចូរ
កាន់ខ្ជាប់តាមសេចក្តីដែលឯងមានហើយចុះ[ឡ] ដើម្បីកុំឱ្យ
អ្នកណាយកមកុដរបស់ឯងបានឡើយ[អ] ១២អ្នកណាដែល
ឈ្នះ[ក] អញនឹងយកអ្នកនោះធ្វើជាសសរទ្រូង[ខ] ក្នុងវិហារ
របស់ព្រះនៃអញ រួចអ្នកនោះនឹងមិនចេញពីទីនោះទៀត
ឡើយ ហើយអញនឹងកត់ព្រះនាមនៃព្រះរបស់អញ[គ] នឹង
ឈ្មោះក្រុងរបស់ព្រះនៃអញ[ឃ] នៅលើអ្នកនោះ គឺជាឈ្មោះ
ក្រុងយេរូសាឡិមថ្មី[ង] ដែលចុះពីស្ថានសួគ៌មកអំពីព្រះនៃ
អញ ហើយនឹងកត់ឈ្មោះថ្មីរបស់ អញដែរ ១៣អ្នកណាដែល
មានត្រចៀក ឱ្យអ្នកនោះស្តាប់[ច]សេចក្តី ដែលព្រះវិញ្ញាណ
មានបន្ទូល ដល់ពួកជំនុំទាំងប៉ុន្មាន ចុះ ។

## ចំពោះពួកជំនុំនៅក្រុងឡៅឌីសេ

១៤ចូរសរសេរផ្ញើទៅទេវតានៃពួកជំនុំ ដែលនៅក្រុង
ឡៅឌីសេ[ឆ]ថា ព្រះដ៏ជា «អាម៉ែន » ជាស្មរបន្ទាល់ស្មោះត្រង់
ហើយពិតប្រាកដ[ជ] ជាដើមការដែលព្រះទ្រង់បង្កើតមក[ឈ]
ទ្រង់មានបន្ទូលសេចក្តីទាំងនេះថា ១៥អញស្គាល់ការដែល
ឯងធ្វើ[ញ] ហើយថា ឯងមិនត្រជាក់ ក៏មិនក្តៅផង[ដ] អញចូល
ចិត្តឱ្យឯងបាន ទោះត្រជាក់ឬក្តៅក្តី ១៦ដូច្នេះ ដោយព្រោះ
ឯងគ្រាន់តែស្ទើរ ៗ ប៉ុណ្ណោះ គឺមិនមែនត្រជាក់ក៏មិនក្តៅផង
នោះអញនឹងខ្ជាក់ឯងចេញពីមាត់អញទៅ ១៧ដោយព្រោះ
ឯងអួតថា ឯងជាអ្នកមានបានកាន់តែស្តុកស្តម្ភឡើងហើយ
ក៏មិនត្រូវការនឹងអ្វីសោះ[ឋ] តែឯងមិនដឹងថា ឯងវេទនា
លំបាក ទ័លក្រ ខ្វាក់ភ្នែក ហើយអាក្រាតវិញនោះទេ[ឌ]
១៨បានជាអញទូន្មានឱ្យឯងទិញមាស ដែលសិរងក្នុងភ្លើង
ពីអញ[ឍ] ដើម្បីឱ្យបានធ្វើជាអ្នកមានពិតមែន ហើយទិញ
សំលៀកបំពាក់ស[ណ] ឱ្យបានស្លៀកពាក់ កុំឱ្យគេឃើញកេរ្តិ៍
ខ្មាស ដែលឯងនៅអាក្រាតនោះឡើយ[ត] ព្រមទាំងថ្នាំលាប
ភ្នែកផង ឱ្យឯងបានមើលឃើញវិញ ១៩អញបន្ទោស ហើយ
ផ្ចាញ់ផ្ចាល ដល់អស់អ្នកណា ដែលអញស្រឡាញ់[ថ] ដូច្នេះ
ចូរមានចិត្តឧស្សាហ៍ ហើយប្រែចិត្តចុះ[ទ] ២០មើល អញឈរ
នៅមាត់ទ្វារ[ធ]ទាំងគោះ បើអ្នកណាឮសំឡេងអញ ហើយ
បើកទ្វារឱ្យ[ន] នោះអញនឹងចូលទៅឯអ្នកនោះ[ប] អញនឹង
បរិភោគជាមួយនឹងអ្នកនោះ ហើយអ្នកនោះជាមួយនឹងអញ
ដែរ ២១ឯអ្នកណាដែលឈ្នះ[ផ] នោះអញនឹងឱ្យអង្គុយលើ
បល្ល័ង្កជាមួយនឹងអញ[ព] ដូចជាអញបានឈ្នះ[ភ] ហើយបាន
អង្គុយជាមួយនឹងព្រះវរបិតា លើបល្ល័ង្កទ្រង់ដែរ ២២អ្នក

**៣:១០** រ ២ពត ២:៩ ល មថ ២៤:១៤ វ វវ ២:១០ ស វវ ៦:១០ ៨:១៣ ១១:១០ ១៣:៨,១៤ ១៧:៨ **៣:១១** ហ មថ ១៦:២៧ ឡ វវ ២:២៥ អ ១កថ ៩:២៥ ក យហ ១៦:៣៣ **៣:១២** ខ កទ ២:៩ គ វវ ១៤:១ ២២:៤ ឃ អគ ៤៨:៣៥ ង កទ ៤:២៦ វវ ២១:២,១០ **៣:១៣** ច វវ ២:៧ **៣:១៤** ឆ កល ២:១ វវ ១:១១ ជ យហ ១៨:៣៧ វវ ១:៥ ឈ សភ ៨:២២ យហ ១:៣ កល ១:១៦,១៨ **៣:១៥** ញ វវ ២:២ ដ រម ១២:១១ **៣:១៧** ឋ ហស ១២:៨ ១កថ ៤:៨ ឌ សភ ១៣:៧
**៣:១៨** ឍ ១ពត ១:៧ ណ ឧ.៤ ត វវ ១៦:១៥ **៣:១៩** ថ ចទ ៨:៥ សភ ៣:១២ ១កថ ១១:៣២ ហព ១២:៥,៦ ទ វវ ២:៥ **៣:២០** ធ មថ ២៤:៣៣ យក ៥:៩ ន លក ១២:៣៦ ប រម ៨:១០ **៣:២១** ផ យហ ១៦:៣៣ ព មថ ១៩:២៨ ភ វវ ៥:៥

(១៣:៥–១០ មថ ២៤:៤–២៨ ដយ ១២:១ មក ១៣:១៩ ២ថន ២:១–១២) ។ *នៅលើផែនដីទាំងមូល* មើល ៦:១០ និងការពន្យល់ ។

**៣:១១** *អញមកជាឆាប់* មើល ១:១ ២២:៧,១២,២០ និងការពន្យល់ ៥:៩ ។ *មកុដ* មើលការពន្យល់ ២:១០ ។

**៣:១២** *ដែលឈ្នះ* មើលពន្យល់ ២:៧ ។ *វិហារ* មើលការពន្យល់ ៧:១៥ ។ *ព្រះនាមនៃព្រះរបស់អញ* មើល ១៤:១ ២២:៤ ។ *យេរូសាឡិមថ្មី* មើល ២១:២,១០។ *កត់ឈ្មោះថ្មីរបស់អញ* ឈ្មោះបានបើកសំដែងពីចរិតលក្ខណៈរបស់ទ្រង់ ។ ព្រះនាមថ្មីរបស់ព្រះគ្រីស្ទសំគាល់ថា ទ្រង់មានតម្លៃលើសគ្រប់របស់ទាំងអស់ ដោយព្រោះកិច្ចការប្រោសលោះរបស់ទ្រង់គឺសម្រាប់មនុស្សលោកទាំងមូល នេះគឺជាការយាងមកលើកទីពីររបស់ព្រះគ្រីស្ទ ។

**៣:១៤** *ក្រុងឡៅឌីសេ* ទីក្រុងនេះបច្ចុប្បន្នមានឈ្មោះថា ឌិនីសលី (Denizli ) ជាទីក្រុងមួយដែលមានទ្រព្យសម្បត្តិជាងគេបំផុតនៅស្រុកភ្រីជៀ (Phrygia ) នៅក្នុងសម័យរ៉ូម៉ាំង ហើយជាក្រុងមួយដែលត្រូវបានស្គាល់ជាទូទៅថាពូកែខាងធានាគារ សាលាពេទ្យ និងឧស្សាហកម្មតម្បាញ ប៉ុន្តែមានចំណុចខ្សោយមួយនៅក្នុងទីក្រុងនេះគឺពុំមានទឹកប្រើប្រាស់គ្រប់គ្រាន់ ។ ចំណុចនីមួយៗនៃចរិតលក្ខណៈទាំងនេះគឺ បានឆ្លុះបញ្ចាំងនៅក្នុងសំបុត្រផ្ញើមកក្រុងឡៅឌីសេ ។ *អាម៉ែន* បើនៅក្នុងគម្ពីរ អស ៦៥:១៦ គឺនិយាយដល់ "ព្រះដ៏ជាអាម៉ែន" បញ្ជាក់ពី "ព្រះដ៏ជាសេចក្តីពិត"។ ត្រង់ចំណុចនេះគឺជាការបង្ហាញពីព្រះនាមរបស់ព្រះមួយអង្គដែលមានន័យថា ជាព្រះនាមដ៏ស្មោះត្រង់ ឬដ៏ពិតត្រង់យ៉ាងសុក្រិត ។ *ជាស្មរបន្ទាល់ស្មោះត្រង់ ហើយពិតប្រាកដ* មើល ១:៥ ៩:១១ ។

**៣:១៦** *គ្រាន់តែស្ទើរៗប៉ុណ្ណោះ គឺមិនមែនត្រជាក់ ក៏មិនក្តៅផង* "ក្តៅ"ពាក្យនេះអាចសំដៅលើទឹកក្តៅមួយកន្លែងសម្រាប់ធ្វើថ្នាំនៅជិតក្រុងហេរ៉ាប៉ូល ។ ពួកជំនុំនៅក្រុងឡៅឌីសេមិនបានជួយព្យាបាលវិញ្ញាណដែលឈឺ ហើយថែមទាំងពុំបានកែវិញ្ញាណខូចខ្ទេចខ្ទាំនោះឱ្យល្អប្រសើរឡើងវិញផងដែរ ។ *ខ្ជាក់* នៅត្រង់នេះ អាចមានន័យថា ក្អួត ។

**៣:១៨** ក្នុងខនេះនិយាយពីចំណុចទាំងបី ដែលធ្វើឱ្យក្រុងឡៅឌីសេមានមោទនភាពនោះគឺ ភាពសម្បូរហូរហៀរផ្នែករូបិយវត្ថុ ឧស្សាហកម្មវាយនភណ្ឌដ៏ធំធេង និងភាពល្បីល្បាញផ្នែកឱសថលាបភ្នែក ។

**៣:១៩** *អញបន្ទោស . . . ដែលស្រឡាញ់* មើល យប ៥:១៧ ទដ ៩៤:១២ សភ ៣:១១–១២ ១កថ ១១:៣២ ហព ១២:៥–១១ ។

**៣:២០** *មើល អញឈរនៅមាត់ទ្វារ ទាំងគោះ* ឃ្លានេះជាធម្មតាគឺនិយាយអំពីតួអង្គព្រះគ្រីស្ទដែលកំពុងតែគោះទ្វារចិត្តរបស់អ្នកមិនជឿម្នាក់ៗ ។ តែទោះបីជាយ៉ាងនេះក៏ដោយ ក៏បរិបទនេះនិយាយសំដៅទៅលើសមាជិកនៃពួកជំនុំខ្លះដែលត្រូវបានគេបោកបញ្ឆោតនោះផងដែរ ។

**៣:២១** *ឈ្នះ* មើលការពន្យល់ ២:៧ ។ *អង្គុយជាមួយនឹងព្រះវរបិតាលើបល្ល័ង្កទ្រង់* មើល ២០:៤,៦ មថ ១៩:២៨ ២ធថ ២:១២ ។

ណាដែលមានត្រចៀក ឱ្យអ្នកនោះស្ដាប់[ម] សេចក្ដីដែលព្រះ
វិញ្ញាណមានបន្ទូលដល់ពួកជំនុំទាំងប៉ុន្មានចុះ ។

## បល្ល័ង្កនៅស្ថានសួគ៌

**៤** [១] ក្រោយនោះមក ខ្ញុំក្រឡេកទៅឃើញមានទ្វារ ១ ចំហ[យ]
នៅស្ថានសួគ៌ ហើយសំឡេងដែលខ្ញុំបានឮ ដូចជាសូរត្រែ[រ]
ជាមុនដំបូងនោះ ក៏មានបន្ទូលមកខ្ញុំថា ចូរឡើងមកឯ
ណេះ[ល] អញនឹងបង្ហាញឱ្យឯងឃើញការ ដែលត្រូវមក
ខាងក្រោយទៀត[វ] [២] ស្រាប់តែខ្ញុំបានត្រឡប់ជានៅដោយ
វិញ្ញាណ[ស] ហើយឃើញមានបល្ល័ង្ក១ដាក់នៅលើស្ថានសួគ៌[ហ]
ក៏មាន១អង្គគង់នៅលើបល្ល័ង្កនោះ [៣] ឯព្រះអង្គដែលគង់នៅ
នោះ មើលទៅមានភាពដូចជាត្បូងមណីជោតិ[ឡ] នឹងត្បូង
ទទឹម[អ] ក៏មានឥន្ទធនូ[ក]នៅព័ទ្ធជុំវិញបល្ល័ង្ក ដែលមើលទៅ
ដូចជាត្បូងមរកត[ខ] ។
[៤] នៅព័ទ្ធជុំវិញបល្ល័ង្កនោះ ក៏មានបល្ល័ង២៤ទៀត ហើយខ្ញុំ
ឃើញអ្នកចាស់ទុំ ២៤ នាក់[គ] អង្គុយលើបល្ល័ង្កទាំងនោះ ទាំង
ស្លៀកពាក់ស[ឃ] ហើយមានមកុដមាសនៅលើក្បាល [៥] មាន
ផ្លេកបន្ទោរ សៀងសំឡេង នឹងផ្គរលាន់[ង] ចេញពីបល្ល័ង្ក ១
នោះមក ក៏មានចង្កៀង ៧[ច] ឆេះនៅពីខាងមុខ នោះគឺជា
វិញ្ញាណទាំង ៧[ឆ] របស់ព្រះ [៦] ឯនៅខាងមុខបល្ល័ង្កនោះមាន
សមុទ្រកែវ[ជ] ដូចជាកែវចរណៃ ហើយនៅកណ្ដាលនិង
ជុំវិញនៃបល្ល័ង្កនោះ ក៏មានតួមានជីវិត ៤[ឈ] ដែលមានភ្នែក
ពេញទាំងមុខទាំងក្រោយ[ញ] [៧] ឯតួទី១ស្រដៀងនឹងសត្វសិង្ហ តួ
ទី២ស្រដៀងនឹងកូនគោ តួទី៣មានមុខដូចជាមនុស្ស ហើយ
តួទី៤ ស្រដៀងនឹងឥន្ទ្រីដែលហើរ[ដ] [៨] តួមានជីវិតទាំង៤
នោះ[ឋ] មានស្លាប៦[ឌ] គ្រប់រូប ក៏មានភ្នែកពេញខ្លួននៅជុំវិញ[ឍ]
ហើយទាំងខាងក្នុងដែរ ក៏ចេះតែពោលពាក្យឥតឈប់ឈរ
ទាំងយប់ទាំងថ្ងៃ[ណ] ថា បរិសុទ្ធ បរិសុទ្ធ បរិសុទ្ធ គឺព្រះ

**៣:២២** ម វវ ២:៧
**៤:១** យ មថ ៣:១៦ រ វវ ១:១០ ល វវ ១១:១២ វ វវ ១:១៩ ២២:៦
**៤:២** ស វវ ១:១០ ហ ខ.៩,១០ ១ពវ ២២:១៩ អស ៦:១ អគ ១:២៦–២៨ ដយ ៧:៩ វវ ២០:១១
**៤:៣** ឡ វវ ២១:១១ អ វវ ២១:២០ ក អគ ១:២៨ វវ ១០:១ ខ វវ ២១:១៩
**៤:៤** គ ខ.១០ វវ ៥:៦,៨,១៤ ១១:១៦ ១៩:៤ ឃ វវ ៣:៤,៥
**៤:៥** ង នក ១៩:១៦ វវ ៨:៥ ១១:១៩ ១៦:១៨ ច សក ៤:២ ឆ វវ ១:៤
**៤:៦** ជ វវ ១៥:២ ឈ ខ.៨,៩ អគ ១:៥ វវ ៥:៦ ៦:១ ៧:១១ ១៤:៣ ១៥:៧ ១៩:៤ ញ អគ ១:១៨ ១០:១២
**៤:៧** ដ អគ ១:១០ ១០:១៤
**៤:៨** ឋ ខ.៦ ឌ អស ៦:២ ឍ អគ ១:១៨

**៤:១–៥:១៤** នៅក្នុងជំពូកទាំងពីរនេះ គឺជាសេចក្ដីផ្ដើមនៃសេចក្ដីដែលមានថែងនៅក្នុងជំពូក៦–២០ ។ ពាក្យថា បល្ល័ង្កនៅស្ថានសួគ៌ និងកូនចៀមគឺជាពាក្យមួយ សម្រាប់ប្រើនៅក្នុងមហាជម្លោះចុងក្រោយជាមួយនឹងអំណាចអាក្រក់ ។ នៅទីបញ្ចប់នឹងឃើញកូនចៀមទទួលបានជ័យជម្នះ ហើយវិញ្ញាណអាក្រក់ត្រូវបានបោះទៅក្នុងបឹងភ្លើង ។

**៤:១** *ចូរឡើងមកឯណេះ* សំឡេងនេះគឺដូចគ្នានឹងសំឡេងដែលព្រះអម្ចាស់បានហៅលោកម៉ូសេ ឱ្យមកទទួលការណែនាំពីទ្រង់នៅលើភ្នំស៊ីណាយនោះដែរ (នក ១៩:២០,២៤) ហើយក៏ដូចគ្នានឹងសំឡេងដែលពីរនាក់ទៀតបានឮពីស្ថានសួគ៌នោះដែរ (១១:១២) ។ មានអ្នកបកស្រាយខ្លះយល់ថានៅក្នុងខនេះ គឺគ្រាន់តែជាការអណ្ដែតអណ្ដូងរបស់ពួកជំនុំទេ ។ *ដែលត្រូវមកខាងក្រោយទៀត* មើល ១:១,១៩ ដយ ២:២៨–២៩,៤៥ ។

**៤:២** *នៅដោយវិញ្ញាណ* នេះគឺជាសេចក្ដីថ្លែងនៃភាពដឹងខ្លួនយ៉ាងច្បាស់ខាងឯវិញ្ញាណដោយមានការបើកសំដែងពីព្រះវិញ្ញាណបរិសុទ្ធ (មើលការពន្យល់ ១:១០ ១៧:៣ ២១:១០) ។ *មានបល្ល័ង្ក១ ដាក់នៅលើស្ថានសួគ៌* ត្រង់នេះគឺជាការពិពណ៌នាអំពីការគ្រប់គ្រងរបស់ព្រះដោយចេញពីរាជបល្ល័ង្ករបស់ទ្រង់នៅឯស្ថានសួគ៌ ដែលជាលក្ខណៈពិសេសមួយមានតាំងពីនៅក្នុងគម្ពីរសញ្ញាចាស់ (ទដ ៤៧:៨) ។

**៤:៣** *ត្បូងមណីជោតិ . . . ត្បូងទទឹម . . . ត្បូងមរកត* ដោយព្រោះតែព្រះទ្រង់គង់នៅ "កន្លែងមួយដែលពុំមានពន្លឺទៅដល់នោះ" ហើយនិងជាកន្លែងមួយដែលពុំធ្លាប់នរណាបានឃើញ ឬក៏អាចឃើញបាននោះ" (១ធថ ៦:១៦) បានជានៅត្រង់នេះមានការពិពណ៌នាពីរស្មីពន្លឺនៃត្បូងដ៏មានតម្លៃដូចជាពន្លឺឥន្ទធនូនៅព័ទ្ធជុំវិញបល្ល័ង្ក (សូមផ្ទៀបនឹង អគ ១:២៦–២៨) ។

**៤:៤** *ចាស់ទុំ២៤នាក់* អ្នកទាំងនេះតំណាងឱ្យក្រុមអ្នកជឿទាំងមូលនៅឯស្ថានសួគ៌ក៏បាន ឬអ្នកតំណាងឱ្យក្រុមទេវតាផ្នែកថ្វាយបង្គំ និងសរសើរតម្កើងដល់ព្រះនោះក៏បាន (ខ.៩–១១ ៥:៥–១៤ ៧:១១–១៧ ១១:១៦–១៨ ១៤:៣ ១៩:៤) ។ លេខ២៤ ជាញឹកញាប់ត្រូវបានគេពន្យល់ថា ជាលេខដែលឆ្លុះបញ្ចាំងពីអំបូរអ៊ីស្រាអែលទាំង១២នៅក្នុងគម្ពីរសញ្ញាចាស់ និងសាវកទាំង១២នាក់នៅក្នុងគម្ពីរសញ្ញាថ្មី ។

**៤:៥** *មានផ្លេកបន្ទោរ សៀងសំឡេង និងផ្គរលាន់* ទាំងនេះគឺជានិមិត្តរូបនៃភាពអស្ចារ្យ និងព្រះចេស្ដារបស់ព្រះអម្ចាស់ (ដូចជាការបើកសំដែងនៅលើភ្នំស៊ីណាយ នក ១៩:១៦–១៩ ហើយក៏ដូចគ្នានឹងការតាំងសញ្ញានៅក្នុងសញ្ញាចាស់នោះដែរ ។ ទាំងអស់នេះសុទ្ធតែជាការពិពណ៌នាអំពីការយាងមកដ៏មានអំណាចព្រះចេស្ដារបស់ព្រះ ដើម្បីរំដោះរាស្ត្ររបស់ទ្រង់ ទដ ១៨:១២–១៥ ៧៧:១៨) ។ *វិញ្ញាណ ទាំង៧របស់ព្រះ* មើលការពន្យល់ ១:៤ ។ "លេខ៧" ជានិមិត្តរូបពីសេចក្ដីពេញបរិបូរ សេចក្ដីសម្រេច ឬសេចក្ដីគ្រប់លក្ខណ៍ ។

**៤:៦** *សមុទ្រកែវ* មើល ១៥:២ ។ ជាប្រភពនៃរូបភាពដែលមាននៅក្នុង អគ ១:២២ នក ២៤:១០ ប៉ុន្តែ ត្រង់នេះអាចជាកម្រាលនៃព្រះវិហារនៅស្ថានសួគ៌នោះផងដែរ (១១:១៩ ១៤:១៥,១៧ ១៥:៥–៦,៨ ១៦:១,១៧) ។ មានគំនិតដូចគ្នានៅក្នុងព្រះវិហារដំបូងក៏ត្រូវបាននិយាយពីសមុទ្រនោះផងដែរ (១ពវ ៧:២៣–២៥ ២ពវ ១៦:១៧ ២រប ៤:២,៤,១០,១៥ យរ ២៧:១៩) ។ មានលក្ខណៈពិសេសផ្សេងទៀត នៃព្រះវិហារនៅឯស្ថានសួគ៌ មានដូចតទៅៈ ចង្កៀង (ខ.៥) អាសនា (៦:៩) អាសនា . . . មានគ្រឿងក្រអូប (៨:៣) និងហឹបនៃសេចក្ដីសញ្ញា (១១:១៩) ។ *មានតួមានជីវិត៤* គឺជាពួកទេវតាដែលមានតួនាទីការពារបល្ល័ង្កនៅឯស្ថានសួគ៌ ហើយនិងជាអ្នកដឹកនាំថ្វាយបង្គំ និងថ្វាយគ្រឿងបូជាដល់ព្រះ ។ *មានភ្នែកពេញ ទាំងមុខទាំងក្រោយ* គឺគ្មានអ្វីជាអាថ៌កំបាំងនោះឡើយ ។

**៤:៧** មាននិម្មិតអំពីតួជីវិត៤នៅក្នុងគម្ពីរអេសេគាល ដូចគ្នានឹងនិម្មិតនៅត្រង់នេះដែរ គឺថា តួជីវិតនោះមានមុខ៤ តួមនុស្សនៅខាងមុខសត្វតោនៅខាងស្ដាំ កូនគោ នៅខាងឆ្វេង សត្វឥន្ទ្រីនៅខាងក្រោយ (អគ ១:៦,១០) ។ នៅក្នុងនិម្មិតរបស់លោកយ៉ូហាននេះគឺមានតួជីវិតជាទម្រង់សត្វតោមួយ គោមួយ និងសត្វឥន្ទ្រីមួយកំពុងតែហើរ ហើយមុខដូចជាមនុស្សម្នាក់នោះដែរ ។

**៤:៨** *មានស្លាប៦* ចំណុចនេះគឺជាលក្ខណៈរបស់តួជីវិត ហើយពួកគេនិយាយ

អម្ចាស់ ជាព្រះដ៏មានព្រះចេស្ដាបំផុត[ត] ដែលទ្រង់គង់នៅ
តាំងតែពីដើម ក៏នៅឥឡូវនេះ ហើយត្រូវយាងមកទៀត[ថ]
៩កាលណាតួមានជីវិតទាំង៤ នោះបានថ្វាយសិរីល្អ ល្បីព្រះ
នាម និងពាក្យអរព្រះគុណ ដល់ព្រះអង្គដែលគង់នៅលើ
បល្ល័ង្ក[ទ] ជាព្រះដ៏មានព្រះជន្មរស់អស់កល្បជានិច្ច រៀងរាប
ដរាបទៅរួចហើយ[ធ] ១០នោះពួកចាស់ទុំទាំង ២៤ នាក់[ន] ក៏
ទំលាក់ខ្លួនក្រាបចុះនៅចំពោះព្រះអង្គ[ប] ដែលគង់លើបល្ល័ង្ក[ផ]
ទាំងថ្វាយបង្គំដល់ព្រះដ៏មានព្រះជន្មរស់អស់កល្បជានិច្ច
រៀងរាបតទៅនោះ ហើយក៏ដាក់មកុដខ្លួនចុះថ្វាយនៅមុខ
បល្ល័ង្ក ដោយទូលថា ១១ឱព្រះអម្ចាស់ ជាព្រះនៃយើង
រាល់គ្នាអើយ ទ្រង់គួរនឹងទទួលសិរីល្អ កិត្តិនាម នឹងព្រះ
ចេស្ដា[ព] ដ្បិតទ្រង់បានបង្កើតរបស់សព្វសារពើមក ហើយគឺ
ដោយបំណងព្រះហឫទ័យទ្រង់ហើយ ដែលរបស់ទាំងនោះ
បានកើតមក ហើយមាននៅផង[ភ]។

## ក្រាំង និងកូនចៀម

**៥** ១រីឯនៅព្រះហស្តស្តាំនៃព្រះអង្គដែលគង់លើបល្ល័ង្ក[ម]
នោះខ្ញុំឃើញមានក្រាំង ដែលសរសេរទាំងខាងក្នុង នឹង
ខាងក្រៅ[យ] ព្រមទាំងមានបិទត្រា[រ] ៧ផង ២រួចឃើញទេវតា
១ដ៏ខ្លាំងពូកែ[ល] ប្រកាសសួរដោយសំឡេងយ៉ាងខ្លាំងថា តើ
អ្នកណាគួរនឹងបកត្រា ហើយបើកក្រាំងនោះ ៣តែគ្មានអ្នក
ណានៅស្ថានសួគ៌ នៅផែនដី ឬនៅក្រោមដី ដែលអាចនឹង
បើកក្រាំងនោះបានឡើយ សូម្បីតែក្រឡេកមើលក៏ពុំបាន
ផង ៤នោះខ្ញុំយំជាខ្លាំង ដោយព្រោះគ្មានអ្នកណាគួរនឹង
បើក ឬក្រឡេកមើលក្រាំងនោះទេ ៥រួចមានចាស់ទុំម្នាក់
និយាយមកខ្ញុំថា កុំយំថ្វី មើលន៏ សត្វសិង្ហ[វ]ដែលកើតពីពូជ
អំបូរយូដា[ស] គឺជាឫសកែវនៃហ្លួងដាវីឌ[ហ] ទ្រង់បានឈ្នះ
ហើយអាចនឹងបកត្រាទាំង៧ បើកក្រាំងនោះបាន។
៦ខ្ញុំក្រឡេកទៅឃើញមានកូនចៀម១[ឡ] ដែលមើលទៅ
ដូចជាបានសំឡាប់ហើយ មានទាំងស្នែង៧ នឹងភ្នែក៧[អ]
កំពុងតែឈរនៅកណ្ដាលបល្ល័ង្ក នឹងតួមានជីវិតទាំង ៤[ក]
ហើយនៅកណ្ដាលពួកចាស់ទុំទាំងប៉ុន្មាន[ខ] ឯភ្នែកទាំងនោះ
គឺជាវិញ្ញាណទាំង ៧[គ] របស់ព្រះ ដែលទ្រង់ចាត់ទៅពេញ
លើផែនដី ៧កូនចៀមនោះក៏មកយកក្រាំង ពីព្រះហស្តស្តាំ
របស់ព្រះអង្គដែលគង់លើបល្ល័ង្កទៅ[ឃ] ៨លុះបានយកក្រាំង

**៤:៨** ណ វវ ១៤:១១ ត អស ៦:៣ វវ ១:៨ ថ វវ ១:៤
**៤:៩** ទ ខ.២ ទដ ៤៧:៨ វវ ៥:១ ធ វវ ១:១៨
**៤:១០** ន ខ.៤ ប ចទ ៣៣:៣ វវ ៥:៨,១៤ ៧:១១ ១១:១៦ ផ ខ.២
**៤:១១** ព វវ ១:៦ ៥:១២ ភ កច ១៤:១៥ វវ ១០:៦
**៥:១** ម ខ.៧,១៣ វវ ៤:២,៩ ៦:១៦ យ អគ ២:៩,១០ រ អស ២៩:១១ ដយ ១២:៤
**៥:២** ល វវ ១០:១
**៥:៥** វ លប ៤៩:៩ ស ហព ៧:១៤ ហ អស ១១:១,១០ រម ១៥:១២ វវ ២២:១៦
**៥:៦** ឡ ខ.៨,៩,១២, ១៣ អ យហ ១:២៩
ក វវ ៤:៦ ខ វវ ៤:៤ គ វវ ១:៤ **៥:៧** ឃ ខ.១

តាមលំនាំដូចជាពួកទេវតាដែលមានចែងនៅក្នុង អស ៦:២–៣ ។ តួជីវិតទាំងនេះមានភិនភាគដូចនឹងចេរូប៊ីន ដែលមានចែងនៅក្នុងអេសេគាលជំពូក១ និងជំពូក១០ (មើលការពន្យល់ ខ.៧) និងលក្ខណៈរបស់ពួកទេវតាក្នុងអេសាយជំពូក៦ ។ *បរិសុទ្ធ បរិសុទ្ធ បរិសុទ្ធ* មើលការពន្យល់ អស ៦:៣ ។ *ទ្រង់គង់នៅតាំងពីដើម . . . ក៏នៅឥឡូវនេះ ហើយត្រូវយាងមកទៀត* ត្រង់នេះគឺពង្រីកពីព្រះនាមរបស់ព្រះអម្ចាស់(នក ៣:១៤–១៥ និងការពន្យល់ វវ ១:៤)។ អំណាចព្រះចេស្ដារបស់ព្រះ និងភាពបរិសុទ្ធបានពង្រីកពីភាពអស់កល្បពីអតីតរហូតដល់យាងមកអស់កល្បជានិច្ច(អស ៤១:៤)។

**៤:១០** *ដាក់មកុដខ្លួនចុះ* ត្រង់ចំណុចនេះបញ្ជាក់ពីការទទួលស្គាល់ថា មានតែព្រះមួយអង្គគត់ដែលសមនឹងលើកតម្កើង និងថ្វាយបង្គំ ។

**៤:១១** *ទ្រង់បានបង្កើតរបស់សព្វសារពើមក* មើលលោកុប្បត្តិ ជំពូក១ ។

**៥:១** *ក្រាំង* មើលពន្យល់ ១:១១ ។ មានក្រាំងតូចនៅក្នុង ១០:២,៨–១០ ។ *ដែលសរសេរទាំងខាងក្នុង និងខាងក្រៅ* ត្រង់នេះមានរាងដូចជាផ្ទាំងថ្មនៃការតាំងសញ្ញាក្រិត្យវិន័យក្នុងគម្ពីរសញ្ញាចាស់(នក ៣២:១៥ និងការពន្យល់ អគ ២:៩–១០)។ នេះគឺជាក្រាំងម្យ៉ាងដែលអាចបត់បានងាយស្រួលនៅក្នុងការសរសេរទាំងសងខាង ហើយអាចសរសេរទទឹងនិងបណ្ដោយបាន ។ *មានបិទត្រា៧* ត្រង់ចំណុចនេះបង្ហាញពីភាពមិនចេះចាញ់ជាដាច់ខាត(អស ២៩:១១ ដយ ១២:៤)។

**៥:២** *ទេវតាដ៏ខ្លាំងពូកែ* ជាអំណាចដ៏គ្រប់គ្រាន់ដើម្បីបញ្ជាក់ពីការបង្កើតពិភពលោក(១០:១ ១៨:២១ បញ្ជាក់ពីអំណាចដ៏អស្ចារ្យ និងសិរីល្អ ១៨:២)

**៥:៣** *ស្ថានសួគ៌នៅផែនដី ឬនៅក្រោមដី* នេះគឺជាឃ្លាសាមញ្ញមួយដែលត្រូវបានគេធ្លាប់យកមកបញ្ជាក់ជាទូទៅនៃសេចក្ដីប្រកាសថា គ្មាននរណាម្នាក់សមនឹងទទួលនោះឡើយ ។ ត្រង់ចំណុចនេះ ពុំមានបំណងបង្រៀនអំពីការបែងចែកពិភពលោកនេះជាបីផ្នែកនោះទេ(នក ២០:៤ ភម ២:១០)។

**៥:៥** *សត្វសិង្ហ ដែលកើតពីពូជអំបូរយូដា* ពាក្យនេះគឺជាងាររបស់ព្រះមែស៊ីដែលបានដកស្រង់ចេញពី លប ៤៩:៨–១០ ។ នៅក្នុងចំណុចនេះ យូដាត្រូវបានដាក់ឈ្មោះថា "កូនតោ" ហើយនិងត្រូវបានសន្យាថានឹងប្រគល់សិទ្ធិឱ្យគ្រប់គ្រង "ដរាបដល់អ្នកនោះកើតឡើង ដែលមានច្បាប់នឹងទទួល" (អគ ២១:២៧)។ *ជាឫសកែវនៃ ហ្លួងដាវីឌ* បើមើល អស ១១:១,១០ នោះធ្វើឱ្យយើងដឹងថា ព្រះមែស៊ីមានខ្សែលោហិតចេញមកពីហ្លួង ដាវីឌនេះឯង(រម ១៥:១២)។

**៥:៦** *កូនចៀម* និមិត្តរូបមួយសម្រាប់ធ្វើយញ្ញបូជាសងនឹងថ្លៃអំពើបាប ("សម្លាប់" អស ៥៣:៧ យហ ១:២៩) និងជានិមិត្តរូបពីអំណាចនៃជ័យជម្នះ (១៧:១៤)។ ពាក្យថា "កូនចៀម" គឺជាពាក្យយ៉ាងពិសេសនៅក្នុងគម្ពីរវិវរណៈនេះ ដែលមានរហូតទៅដល់២៩ដង តែមានម្ដងទៀតគត់នៅក្នុងគម្ពីរសញ្ញាថ្មីគឺ យហ ២១:១៥ ។ អត្ថន័យនៃពាក្យថាកូនចៀម គឺជាការយកជ័យជម្នះរបស់មេទ័ពនៅទីបញ្ចប់នៃពិភពលោក ។ *មើលទៅដូចជាបានសំឡាប់ហើយ* នេះគឺជាដំណើរដែលនាំព្រះយេស៊ូវទៅធ្វើគុត ទ្រង់បានយាងមកដោយអំណាចព្រះចេស្ដា ។ *មានទាំងស្នែង៧* ដោយយោងតាមនិមិត្តរូបពីបុរាណរបស់សាសន៍យូដាបានឱ្យដឹងថា ស្នែងតំណាងឱ្យអំណាច ឬកម្លាំង(ចទ ៣៣:១៧)។ តួមានជីវិត ទាំង៤នេះ នៅក្នុងគម្ពីរ ដយ ៧:៧,២០ គឺមានស្នែង១០(ដយ ៨:៣,៥)។ ស្នែង៧អាចជានិមិត្តរូបពីកម្លាំងពេញ ។ *វិញ្ញាណទាំង៧* មើលការពន្យល់ ៤:៥ ។

**៥:៨** *ស៊ុង* ជាឧបករណ៍ភ្លេងម្យ៉ាងដែលមានខ្សែ(ពុំដូចស៊ុងនាពេលបច្ចុប្បន្ន

ទៅហើយ នោះតួមានជីវិតទាំង៤[ង] នឹងពួកចាស់ទុំ ២៤
នាក់[ច] ក៏ទំលាក់ខ្លួនក្រាបចុះនៅមុខកូនចៀម ទាំងកាន់ស៊ុង[ឆ]
នឹងពានមាស ដែលពេញដោយគ្រឿងក្រអូបរៀងខ្លួន ឯ
គ្រឿងក្រអូប នោះជាសេចក្ដីអធិស្ឋានរបស់ពួកបរិសុទ្ធ[ជ]
៩ពួកទាំងនោះក៏ច្រៀងទំនុក១ថ្មី[ឈ]ថា ទ្រង់គួរ[ញ]នឹងយក
ក្រាំងនេះ ហើយនឹងបកត្រាផង ដ្បិតទ្រង់បានត្រូវគេធ្វើគុត
ហើយទ្រង់បានលោះយើងរាល់គ្នា[ដ] ដោយព្រះលោហិត
ទ្រង់[ឋ] ចេញពីគ្រប់ទាំងពូជមនុស្ស គ្រប់ភាសា គ្រប់នគរ
ហើយពីគ្រប់ទាំងសាសន៍ ថ្វាយដល់ព្រះ[ឌ] ១០ក៏តាំងយើង
រាល់គ្នាឡើងជានគរ ហើយជាពួកសង្ឃ[ឍ] ថ្វាយដល់ព្រះនៃ
យើងរាល់គ្នា ឱ្យយើងបានសោយរាជ្យលើផែនដី[ណ]។
១១នោះខ្ញុំឃើញ ហើយក៏ឮសំឡេងទេវតាជាច្រើន នៅ
ជុំវិញបល្ល័ង្ក ព្រមទាំងតួមានជីវិត[ត] នឹងពួកចាស់ទុំផង[ថ] ឯ
ចំនួននៃទេវតានោះ មានទាំងម៉ឺនទាំងសែន ហើយទាំង
ពាន់រាប់ជាពាន់[ទ] ១២គ្រប់គ្នាក៏បន្លឺសំឡេងថា កូនចៀម[ធ]
ដែលគេបានសំឡាប់[ន] នោះគួរនឹងបានព្រះចេស្ដា ទ្រព្យ
សម្បត្តិ ប្រាជ្ញា ឥទ្ធិឫទ្ធិ កិត្តិនាម សិរីល្អ នឹងព្រះពរ[ប]
១៣នោះខ្ញុំក៏ឮគ្រប់ទាំងអស់ ដែលមានជីវិត នៅស្ថានសួគ៌
នៅផែនដី នៅក្រោមដី[ផ] ហើយនៅក្នុងសមុទ្រ នឹងគ្រប់ទាំង
អស់ដែលនៅស្ថានទាំងនោះនិយាយថា សូមថ្វាយព្រះពរ
កិត្តិនាម សិរីល្អ នឹងព្រះចេស្ដា ដល់ព្រះអង្គដែលគង់លើ
បល្ល័ង្ក[ព] ហើយដល់កូនចៀម[ភ] នៅអស់កល្បជានិច្ចរៀងរាប
តទៅ[ម] ១៤រួចតួមានជីវិតទាំង៤[យ] ក៏ទទួលថា អាម៉ែន[រ]
ហើយពួកចាស់ទុំ[ល]ក៏ទំលាក់ខ្លួនក្រាបចុះថ្វាយបង្គំ[វ]។

## ត្រា

**៦** ១កាលកូនចៀម[ស]បកត្រាទី១[ហ] នោះខ្ញុំក៏ឃើញ រួចខ្ញុំឮតួ
មានជីវិត១[ឡ] បន្លឺសំឡេងឡើងដូចផ្គរលាន់[អ]ថា ចូរមកមើល
ចុះ ២ខ្ញុំក៏ក្រឡេកទៅឃើញសេះស១[ក] ឯអ្នកដែលជិះក៏កាន់ធ្នូ
ហើយមានគេឱ្យមកុដ[ខ]ដល់អ្នកនោះ រួចអ្នកនោះចេញទៅ
ទាំងមានជ័យជំនះ ហើយឱ្យបានឈ្នះតទៅ[គ]។
៣លុះបកត្រាទី២ នោះខ្ញុំឮតួមានជីវិតទី២[ឃ] ថា ចូរមក
មើលចុះ ៤នោះមានសេះ១ទៀតចេញមក មានសម្បុរ
ក្រហម[ង] ហើយគេឱ្យអ្នកដែលជិះ មានអំណាចអាចនឹងដក
យកសេចក្ដីសុខសាន្តពីផែនដីចេញ[ច] ឱ្យមនុស្សលោកបាន
សំឡាប់គ្នា គេក៏ប្រគល់ដាវ១ យ៉ាងធំ ដល់អ្នកនោះដែរ។
៥លុះបកត្រាទី៣ នោះខ្ញុំឮតួមានជីវិតទី៣[ឆ]ថា ចូរមក

**៥:៨** ង វវ ៤:៦ ច វវ ៤:៤ ឆ វវ ១៤:២ ១៥:២ ជ ទដ ១៤១:២ វវ ៨:៣,៤ **៥:៩** ឈ ទដ ៤០:៣ ៩៨:១ ១៤៩:១ អស ៤២:១០ វវ ១៤:៣,៤ ញ វវ ៤:១១ ដ ហព ៩:១២ ឋ ១កថ ៦:២០ ឌ វវ ១៣:៧ **៥:១០** ឍ ១ពត ២:៥ ណ វវ ៣:២១ ២០:៤ ត វវ ៤:៦ ថ វវ ៤:៤ **៥:១១** ទ ដយ ៧:១០ ហព ១២:២២ យដ ១៤ **៥:១២** ធ ខ.៣ ភល ២:១០ ន ខ.១៣ ប ខ.៩ **៥:១៣** ផ វវ ១:៦ ៤:១១ ព ខ.១,៧ ភ ខ.៦ វវ ៦:១៦ ៧:១០ ម ១របា ២៩:១១ មឡ ១:៦ ២:២ រម ១១:៣៦ **៥:១៤** យ វវ ៤:៦ រ វវ ៤:៩ ល វវ ៤:៤ វ វវ ៤:១០ **៦:១** ស វវ ៥:៦ ហ វវ ៥:១ ឡ វវ ៤:៦,៧ អ វវ ១៤:២ ១៩:៦ **៦:២** ក សក ១:៨ ៦:៣ វវ ១៩:១១ ខ សក ៦:១១ វវ ១៤:១៤ ១៩:១២ គ ទដ ៤៥:៤ **៦:៣** ឃ វវ ៤:៧ **៦:៤** ង សក ១:៨ ៦:២ ច មថ ១០:៣៤ **៦:៥** ឆ វវ ៤:៧

នេះទេ) សម្រាប់លេង ជាពិសេសជាមួយនឹងបទចម្រៀង(ទដ ៣៣:២)។ *ឯគ្រឿង ពានមាសដែលពេញដោយគ្រឿងក្រអូប* ពាក្យថា "ពាន" មានន័យថា ថាស ។ គ្រឿងក្រអូប គឺជាវត្ថុធម្មតាមួយដែលពួកហេព្រើរយកមកប្រើនៅក្នុងពិធីបុណ្យ (ចទ ៣៣:១០ ទដ ១៤១:២ វវ ៨:៣–៤)។ *សេចក្ដីអធិស្ឋានរបស់ពួកបរិសុទ្ធ* ពួកយូដាដែលថ្វាយបង្គំរូបព្រះបានគិតថា ទេវតាតែងតែបង្ហាញខ្លួននៅពេលពួកបរិសុទ្ធអធិស្ឋានទៅរកព្រះ ។ *ពួកបរិសុទ្ធ* មើលការពន្យល់ រម ១:៧ អភ ១:១ ។

**៥:៩** *ទំនុក១ថ្មី* មើល ១៤:៣ ទដ ៣៣:៣ ៩៦ :១ ១៤៤:៩ អស ៤២:១០ ។ នៅក្នុងគម្ពីរសញ្ញាចាស់ទំនុក១ថ្មី (ចម្រៀង១ថ្មី) នេះបានអបអរសាទរនូវការប្រោសលោះ ឬការទទួលបានព្រះពរថ្មីៗថែមទៀត ហើយនេះក៏ជាអត្ថន័យរបស់ពាក្យនេះផងដែរ ដោយយោងតាមដំណើររឿងនៅត្រង់ចំណុចនេះ ។ *ទ្រង់បានលោះ យើងរាល់គ្នាដោយព្រះលោហិតទ្រង់* ការសុគតរបស់ព្រះគ្រីស្ទគឺជាចំណុចសំខាន់ នៃសេចក្ដីបង្រៀននៅក្នុងគម្ពីរសញ្ញាថ្មីទាំងមូល (មក ១០:៤៥ ១កថ ៦:២០)។

**៥:១០** *តាំងយើងរាល់គ្នាឡើង* មើលការពន្យល់ ១:៦ ។ *ជានគរ ហើយជាពួកសង្ឃ* មើលការពន្យល់ ១:៦ ។ *បានសោយរាជ្យលើផែនដី* មើល ២:២៦–២៧ ២០:៤,៦ ២២:៥ ។

**៥:១១** *ទាំងពាន់រាប់ជាពាន់* ត្រង់ចំណុចនេះបញ្ជាក់អំពីចំនួនដ៏ច្រើន (មើល ដយ ៧:១០ ហព ១២:២២)។

**៥:១២** *ព្រះចេស្ដា . . . ព្រះពរ* ត្រង់ចំណុចនេះគឺដូចនឹងសេចក្ដីអធិស្ឋានចុងក្រោយរបស់ស្ដេចដាវីឌនៅក្នុង ១របា ២៩:១០–១៩ ។ មានការកំណត់ទុកជាមុនក្នុងការដំឡើងចំនួននៃពាក្យសរសើរ ដោយដំបូងមានបីពាក្យនៅក្នុង ៤:១១ បួនពាក្យនៅ ក្នុង ៥:១៣ និងមានប្រាំពីរពាក្យក្នុង ៥:១២ ៧:១២ ។

**៥:១៣** *នៅស្ថានសួគ៌ នៅផែនដី នៅក្រោមដី* មើលការពន្យល់ ខ.៣ ។

**៦:១** *កូនចៀម* មើល ខ.១៦ និងមើលការពន្យល់ ៥:៦ ។ *តួមានជីវិត* មើល ៤:៦–៧ និងការពន្យល់ ។

**៦:២** *សេះស* នេះគឺជារូបភាពមួយក្នុងចំណោម "មនុស្សសេះទាំងបួននៃទីអវសានពិភពលោក" ដែលបានដកស្រង់ពី សក ១:៨–១៧ ៦:១–៨(មើលការពន្យល់ សក ៦:២–៣)។ ពណ៌សនៅក្នុងគម្ពីរវិវរណៈនេះ គឺឆ្លើយតបទៅនឹងបុគ្គលិកលក្ខណៈរបស់អ្នកជិះ ហើយពណ៌សនេះ ក៏ជានិមិត្តរូបពីជ័យជម្នះផងដែរ ។ មានការបកស្រាយសំខាន់មួយចំនួនអំពីអ្នកជិះសេះសនេះថា (១).គឺជាព្រះគ្រីស្ទ(១៩:១១)។ (២).គឺជាអ្នកទាស់នឹងព្រះគ្រីស្ទ (៣).គឺជាវិញ្ញាណនៃជ័យជម្នះ ។ ក្រោយមកមាន ការបកស្រាយបន្ថែមទៀតពីសណ្ឋានរបស់អ្នកជិះទាំងបីនេះថា "ជានិមិត្តរូបពីការបង្ហូរឈាម គ្រាអំណត់ និងការសុគត)។ *ធ្នូ* គឺជាអាវុធសម្រាប់ធ្វើសង្គ្រាម ។

**៦:៤** *មានសេះ១ទៀតចេញមក មានសម្បុរក្រហម* គឺជានិមិត្តរូបអំពីការបង្ហូរឈាមគ្នា ហើយនិងការធ្វើសង្គ្រាម(សក ១:៨ ៦:២)។ *ឱ្យមនុស្សលោកបានសំឡាប់គ្នា* ត្រង់នេះបើសេះសមានជ័យជម្នះ ដោយគ្មានសេះក្រហមនោះអាច ជាការបម្រែបម្រួលផ្នែកខាងក្នុង ។ *ដាវ* មើលពន្យល់ ១:១៦ ។

**៦:៥** *សេះខ្មៅ* ជានិមិត្តរូបអំពីគ្រាមានអំណត់(សក ៦:២,៦) ហើយនិងជា

មើលចុះ ខ្ញុំក៏ក្រឡេកទៅឃើញសេះខ្មៅ១[ជ] ឯអ្នកដែលជិះក៏
កាន់ជញ្ជីង១ នៅដៃ ៦ រួចខ្ញុំឮសំឡេង១ នៅកណ្ដាលតួមាន
ជីវិតទាំង៤[ឈ] ពោលដូច្នេះថា អង្ករស្រូវសាលី១នាលិ ថ្លៃ
២ កាក់ ហើយអង្ករស្រូវឱក ៣ នាលិថ្លៃ ២ កាក់[ញ] តែកុំឱ្យ
បង្ខូច[ដ] ប្រេង នឹងស្រាទំពាំងបាយជូរឡើយ។
៧ លុះបកត្រាទី ៤ នោះខ្ញុំឮតួមានជីវិតទី ៤[ឋ] ថា ចូរមក
មើលចុះ ៨ ខ្ញុំក៏ក្រឡេកមើលទៅឃើញសេះ១សម្បុរស្លាំង[ឌ]
ឯអ្នកដែលជិះមានឈ្មោះថា «សេចក្ដីស្លាប់» ហើយស្ថានឃុំ
ព្រលឹងមនុស្សស្លាប់[ឍ] ក៏តាមអ្នកនោះទៅ គេឱ្យទាំង២នោះ
មានអំណាចលើផែនដី ១ភាគក្នុង៤ ដើម្បីនឹងសំឡាប់ដោយ
ដាវ អំណត់អត់ នឹងសេចក្ដីវេទនា ហើយដោយសត្វព្រៃ
នៅផែនដីផង[ណ]។
៩ លុះបកត្រាទី ៥ នោះនៅក្រោម[ត] អាសនា[ថ] ខ្ញុំក៏ឃើញ
មានអស់ទាំងព្រលឹងរបស់មនុស្ស ដែលគេបានសំឡាប់[ទ]
ដោយព្រោះកាន់តាមព្រះបន្ទូល[ធ] នឹងសេចក្ដីបន្ទាល់ ១០ ឯ
ព្រលឹងទាំងនោះក៏បន្លឺសំឡេងថា ឱព្រះដ៏ជាម្ចាស់[ន] ជាព្រះ
បរិសុទ្ធ ហើយពិតប្រាកដអើយ[ប] តើទ្រង់ចាំដល់កាលណា
ទៀត[ផ] បានជំនុំជំរះ ហើយសងសឹកដល់ពួកមនុស្សនៅលើ
ផែនដី[ព] ដោយព្រោះឈាមយើងខ្ញុំរាល់គ្នា[ភ] ១១ នោះមានគេ

**៦:៥** ជ សក ៦:២
**៦:៦** ឈ វវ ៤:៦,៧
ញ អគ ៤:១៦
ដ វវ ៧:១,៣ ៩:៤
**៦:៧** ឋ វវ ៤:៧
**៦:៨** ឌ សក ៦:៣
ឍ ហស ១៣:១៤
វវ ១:១៨ ២០:១៣,
១៤ ណ យរ
១៥:២,៣ ២៤:១០
អគ ៥:១២,១៧
**៦:៩** ត នក ២៩:១២
លវ ៤:៧ ថ វវ
១៤:១៨ ១៦:៧ ទ វវ
២០:៤ ធ រម ១:២
ហព ៤:១២
**៦:១០** ន លក ២:២៩
២ពត ២:១
ប វវ ៣:៧
ផ ទដ ១៩:៨៤
សក ១:១២
ព វវ ៣:១០
ភ ចទ ៣២:៤៣
២ពវ ៩:៧
ទដ ៧៩:១០

ឱ្យអាវសវែង[ម] ដល់អ្នកទាំងនោះ ហើយក៏ប្រាប់ឱ្យឈប់
សំរាកបន្តិចសិន ទាល់តែពួកបាវបំរើ ជាគូកន ហើយជា
បងប្អូន ដែលត្រូវសំឡាប់បែបដូចគ្នាបានគ្រប់ចំនួន[យ]។
១២ លុះបកត្រាទី ៦ នោះខ្ញុំក្រឡេកទៅ ឃើញមានកក្រើក
ដីជាខ្លាំង[រ] ថ្ងៃក៏ត្រឡប់ទៅជាខ្មៅ[ល] ដូចសំពត់រោមខ្មៅ[វ]
ហើយខែក៏ត្រឡប់ប្រែទៅដូចជាឈាម ១៣ ផ្កាយនៅលើ
មេឃក៏ធ្លាក់មកលើផែនដី[ស] ដូចជាដើមល្វា[ហ] ដែលត្រូវខ្យល់
ធំ គ្រវាត់បណ្ដាច់ផ្លែខ្ចីចោលចេញដែរ ១៤ ផ្ទៃមេឃក៏បាត់
ទៅ ដូចជាក្រាំងដែលគេមូរទៅវិញ[ឡ] ហើយគ្រប់ទាំងភ្នំ
នឹងកោះទាំងប៉ុន្មាន ក៏ត្រូវរើចេញពីកន្លែងផង[អ] ១៥ អស់ទាំង
ស្តេចនៅផែនដី នឹងពួកអ្នកធំ ពួកអ្នកមាន ពួកមេទ័ព ពួក
ខ្លាំងពូកែ ហើយគ្រប់ទាំងបាវបំរើ នឹងអ្នកជា[ក] ទាំងប៉ុន្មាន
គេ ពួននៅក្នុងរអាង ហើយក្នុងក្រហែងភ្នំទាំងអស់គ្នា[ខ]
១៦ គេអង្វរទៅភ្នំ ហើយទៅថ្មថា សូមធ្លាក់មកលើយើង[គ]

វវ ១៦:៦ ១៨:២០ ១៩:២ **៦:១១** ម វវ ៣:៤ យ ហព ១១:៤០ **៦:១២** រ ទដ ៩៧:៤ អស ២៩:៦ អគ ៣៨:១៩ វវ ៨:៥ ១១:១៣ ១៦:១៨ ល មថ ២៤:២៩ វ អស ៥០:៣ **៦:១៣** ស មថ ២៤:២៩ វវ ៨:១០ ៩:១ ហ អស ៣៤:៤ **៦:១៤** ឡ ២ពត ៣:១០ វវ ២០:១១ ២១:១ អ ទដ ៤៦:២ អស ៥៤:១០ យរ ៤:២៤ អគ ៣៨:២០ ណាហ ១:៥ វវ ១៦:២០ ២១:១ **៦:១៥** ក វវ ១៩:១៨ ខ អស ២:១០,១៩,២១ **៦:១៦** គ ហស ១០:៨ លក ២៣:៣០

និមិត្តរូបនៅក្នុងលក្ខណៈទាំងបីគឺការយកជ័យជម្នះ ការបង្ហូរឈាម និងគ្រាមានអំណត់ ។

**៦:៦** *ស្រូវសាលី . . . ស្រូវឱក* ស្រូវសាលី១នាលិគឺសម្រាប់តែមនុស្សម្នាក់ប៉ុណ្ណោះ ។ ស្រូវឱក៣នាលិគឺមិនគ្រប់សម្រាប់គ្រួសារតូចមួយទេ ។ ការនិយាយពីគ្រាមានអំណត់នៅត្រង់នេះ បានបង្កើតតម្លៃរហូតដល់១០ដង ជាងគ្រាអំណត់ធម្មតា ។ *ប្រេង និងស្រា* ត្រង់នេះគឺបញ្ជាក់ពីភាពអន្តរាយដោយអ្នកជិះសេះខ្មៅ ។ ឫសនៃដើមអូលីវ និងដើមទំពាំងបាយជូរពុំអាចចាក់ជ្រៅឬដុះបានទេ បើពុំមានទឹកគ្រប់គ្រាន់ ។

**៦:៨** *សេះ១សម្បុរស្លាំង* ត្រង់នេះគឺជាការពិពណ៌នាអំពីទិដ្ឋភាពនៃកម្មេចផេះរបស់មនុស្សស្លាប់ (វាជានិមិត្តរូបនៃសេចក្ដីស្លាប់)។ *ស្ថានឃុំព្រលឹងមនុស្សស្លាប់* ជាភាសាហេព្រើរថា សេអូល (Sheol) "សូមមើល ១:១៨ ២០:១៣–១៤ និងមើលការពន្យល់ មថ ១៦:១៨"។ *ដាវ អំណត់អត់ និងសេចក្ដីវេទនា ហើយដោយសត្វព្រៃ នៅផែនដី* មើល អគ ៥:១៦–១៧ និងការពន្យល់ ។

**៦:៩** *នៅក្រោមអាសនា* នៅក្នុងគម្ពីរសញ្ញាចាស់មានពិធីបុណ្យមួយ យកឈាមសត្វដែលបានសម្លាប់រួច មកចាក់នៅលើជើងអាសនា (នក ២៩:១២ លវ ៤:៧)។

**៦:១០** *មនុស្សនៅលើផែនដី* ត្រង់នេះគឺជាការកំណត់ទុកជាមុនសម្រាប់មនុស្សជាតិដែលបានទាស់ទទឹងនឹងព្រះ (៣:១០ ៨:១៣ ១១:១០ ១៣:៨,១២ ១៧:២,៨)។

**៦:១១** *អាវសវែង* គឺជានិមិត្តរូបអំពីព្រះពរ និងភាពបរិសុទ្ធ (៣:៥,១៨ ៤:៤ ៧:៩,១៣ ១៩:១៤)។ *បានគ្រប់ចំនួន* ពាក្យនេះចំពោះសាសន៍យូដាបានយល់ថាជាតារាងនៃពេលវេលាដែលព្រះបានកំណត់ទុកជាមុន សម្រាប់គ្រប់គ្រងពិភពលោក ហើយនិងការរង់ចាំមនុស្សសុចរិតបានស្លាប់គ្រប់ចំនួនសិន នោះហើយជាពេលចុងក្រោយរបស់លោកិយនេះ ។ *គូកន* មើលការពន្យល់ រម ១:១៣ ។

**៦:១២** *កក្រើកដី* ពាក្យនេះជាទូទៅបង្ហាញពីព្រះវត្តមានរបស់ព្រះ (នក ១៩:១៨ អស ២:១៩ ហក ២:៦)។ *ខែក៏ត្រឡប់ប្រែទៅដូចជាឈាម* មើល យអ ២:៣១ ។ ត្រង់ចំណុចនេះបានដកស្រង់ឡើង ដោយលោកពេត្រុសសម្រាប់សេចក្ដីអធិប្បាយរបស់គាត់នៅថ្ងៃបុណ្យទី៥០ (កច ២:២០)។

**៦:១៣** *ផ្កាយនៅលើមេឃក៏ធ្លាក់មក* នេះគឺជាសញ្ញាប្រាប់ទុកជាមុនមួយមុននឹងការយាងមករបស់កូនមនុស្ស (មក ១៣:២៥–២៦)។ *ផ្លែខ្ចី* គឺជាដើមល្វាដែលទើបនឹងមានផ្លែនៅរដូវលំហើយ ហើយត្រូវបានខ្យល់មកផ្ដាច់ផ្លែនោះបាត់ទៅក្នុងរដូវដើមល្វាគ្មានស្លឹក ។

**៦:១៤** *ផ្ទៃមេឃក៏បាត់ទៅដូចជាក្រាំងដែលគេមូរទៅវិញ* អស ៣៤:៤ ។ *គ្រប់ទាំងភ្នំ និងកោះទាំងប៉ុន្មាន ក៏ត្រូវរើចេញពីកន្លែងផង* មើល ១៦:២០ ២០:១១ ។ ត្រង់ចំណុចនេះប្រហែលជាដកស្រង់ចេញពី យរ ៤:២៤ ឬ ណាហ ១:៥ ។

**៦:១៥** *ពួកមេទ័ព* បើមេទ័ពរបស់ពួករ៉ូម៉ាំងវិញ ក្នុងម្នាក់មានកូនទាហានប្រហែល១000នាក់ ។ *ពួននៅក្នុងរអាង* មើល យរ ៤:២៩ ។

**៦:១៦** *សេចក្ដីក្រោធរបស់កូនចៀម* គឺដូចគ្នានឹងពាក្យថា សេចក្ដីក្រោធរបស់ព្រះ (ខ.១៧)។ សេចក្ដីក្រោធរបស់ព្រះគឺជាប្រធានបទដែលបានលើកយកមកបង្រៀននៅក្នុងគម្ពីរសញ្ញាថ្មីទាំងបច្ចុប្បន្ន (រម ១:១៨ និងមើលការ

ដើម្បីបំបាំងយើងពីព្រះភក្ត្រព្រះអង្គ ដែលគង់លើបល្ល័ង្ក[ឃ]
នឹងពីសេចក្ដីក្រោធរបស់កូនចៀមចេញ ១៧ដ្បិតថ្ងៃធំ[ង]នៃ
សេចក្ដីក្រោធរបស់ទ្រង់បានមកដល់ហើយ តើអ្នកណាអាច
នឹងឈរនៅបាន[ច]។

## អ្នកទាំង១៤៤000នាក់ត្រូវបានបោះត្រា

**៧** ១ក្រោយនោះមក ខ្ញុំឃើញទេវតា៤រូប ឈរនៅជ្រុង
ផែនដីទាំង៤[ឆ] ទាំងទប់ខ្យល់នៅផែនដីទាំង៤ទិស[ជ]មិនឱ្យ[ឈ]
បក់មកលើផែនដី ឬសមុទ្រ ឬដើមឈើណាឡើយ ២រួចខ្ញុំ
ឃើញទេវតា១ទៀត ដែលឡើងមកពីទិសថ្ងៃរះ មានទាំង
ត្រា[ញ]របស់ព្រះដ៏មានព្រះជន្មរស់[ដ] ទេវតានោះក៏បន្លឺសំឡេង
ទៅទេវតាទាំង៤នោះ ដែលមានអំណាចនឹងធ្វើទុក្ខផែនដី
ហើយនឹងសមុទ្រ[ឋ]ថា ៣កុំឱ្យធ្វើទុក្ខ[ឌ]ផែនដី ឬសមុទ្រ ឬដើម
ឈើណាក្ដី ទាល់តែបោះត្រានៅត្រង់ថ្ងាស[ឍ] នៃពួកបាវបំរើ
របស់ព្រះនៃយើងសិន ៤ខ្ញុំក៏ឮចំនួន[ណ]ពួកអ្នកដែលបានបោះ
ត្រានោះថា មាន១សែន៤ម៉ឺន៤ពាន់នាក់[ត] ដែលមកពីគ្រប់
ទាំងពូជអំបូរនៃជនជាតិអ៊ីស្រាអែល ៥គឺពីពូជអំបូរយូដា
បានបោះត្រា១ម៉ឺន២ពាន់នាក់ ពីពូជអំបូររូបេនមាន១ម៉ឺន
២ពាន់នាក់ពីពូជអំបូរកាឌ់ មាន១ម៉ឺន២ពាន់នាក់ ៦ពីពូជ
អំបូរអាសើរ មាន១ម៉ឺន២ពាន់នាក់ ពីពូជអំបូរណែបថាលី
មាន១ម៉ឺន២ពាន់នាក់ ពីពូជអំបូរម៉ាន៉ាសេ មាន១ម៉ឺន
២ពាន់នាក់ ៧ពីពូជអំបូរស៊ីម្មាន មាន១ម៉ឺន២ពាន់នាក់ ពីពូជ
អំបូរលេវី មាន១ម៉ឺន២ពាន់នាក់ ពីពូជអំបូរ អ៊ីសាខារ
មាន១ម៉ឺន២ពាន់នាក់ ៨ពីពូជអំបូរសាប់យូល៉ូន មាន១ម៉ឺន
២ពាន់នាក់ ពីពូជអំបូរយ៉ូសែប មាន១ម៉ឺន២ពាន់នាក់ ហើយ
ពីពូជអំបូរបេនយ៉ាមីន មាន១ម៉ឺន២ពាន់នាក់ ដែល
បានបោះត្រា ។

## មនុស្ស១ហ្វូងធំពាក់អាវសវែង

៩ក្រោយនោះមក ខ្ញុំក្រឡេកទៅឃើញមនុស្ស១ហ្វូង
យ៉ាងធំ ដែលគ្មានអ្នកណាអាចនឹងរាប់បានឡើយ គេមកពី
គ្រប់ទាំងសាសន៍ គ្រប់ទាំងពូជមនុស្ស គ្រប់ទាំងគ្រួសារ
ហើយគ្រប់ទាំងភាសា[ថ] ក៏ឈរនៅមុខបល្ល័ង្ក[ទ] នឹងកូនចៀម
ទាំងពាក់អាវសវែង[ធ] ហើយកាន់ធាងចាកនៅដៃ ១០គេបន្លឺ
សំឡេងថា សេចក្ដីសង្គ្រោះស្រេចនូវព្រះនៃយើងរាល់គ្នា[ន]
ដែលគង់លើបល្ល័ង្ក[ប] ហើយស្រេចនឹងកូនចៀមផង ១១រួច

**៦:១៦** ឃ វវ ៥:១
**៦:១៧** ង យអ ១:១៥ ២:១,២,១១,៣១ សផ ១:១៤,១៥ វវ ១៦:១៤ ច ទដ ៧៦:៧ ណហ ១:១៦ មឡ ៣:២
**៧:១** ឆ អស ១១:១២ ជ យរ ៤៩:៣៦ អគ ៣៧:៩ ដយ ៧:២ សក ៦:៥ មថ ២៤:៣១ ឈ វវ ៦:៦
**៧:២** ញ វវ ៩:៤ ដ មថ ១៦:១៦ ឋ ខ.១
**៧:៣** ឌ វវ ៦:៦ ឍ អគ ៩:៤ វវ ៩:៤ ១៤:១ ២២:៤
**៧:៤** ណ វវ ៩:១៦ ត រម ១៤:១,៣
**៧:៩** ថ វវ ១៣:៧ ទ ខ.១៥ ធ វវ ៣:៤
**៧:១០** ន ទដ ៣:៨ វវ ១២:១០ ១៩:១ ប វវ ៥:១

ពន្យល់) និងអនាគត(១៩:១៥)។ ចំណុចនេះក៏ត្រូវបានទាយទុកនៅក្នុងគម្ពីរសញ្ញាចាស់នោះផងដែរ (សផ ១:១៤–១៨ ណហ ១:៦ មឡ ៣:២)។

**៧:១–១៧** ត្រង់ចំណុចនេះ គឺនិយាយអំពីព្រឹត្តិការណ៍ដាច់ដោយឡែកពីត្រាចុងក្រោយ(៨:១) ក្នុងចំណោមត្រាទាំង៦ដែលបានពិពណ៌នាពីខាងដើមមក (មានលក្ខណៈដូចគ្នាក្នុងករណីពេលផ្លុំត្រែនោះដែរ សូមមើល ១០:១–១១:១៣)។ នៅក្នុងអត្ថបទនេះមានការបើកសំដែងពីរគឺ (១).ចំនួននៃការបោះត្រាមាន ១៤៤ 000 (ខ.១–៨) និង (២).ជាចំនួនច្រើនដែលពុំអាចរាប់អស់(ខ.៩–១៧)។

**៧:១** *ខ្យល់ . . .ទាំង៤ទិស* គឺជាភ្នាក់ងារសម្រាប់បំផ្លាញរបស់ព្រះ(យរ ៤៩:៣៦)។

**៧:២** *ត្រារបស់ព្រះដ៏មានព្រះជន្មរស់* ឯកសារពីបុរាណត្រូវបានគេបត់និងចងទុក ដោយមានដីឥដ្ឋមួយដុំសង្កត់ពីលើចំណងផង ។ បន្ទាប់មកអ្នកបញ្ជូនបានបោះត្រាលើដីឥដ្ឋរឹងនេះ ហើយត្រានោះអាចជាចិញ្ចៀនត្រា ឬជាត្រាមានដងធម្មតា ដែលត្រូវបានគេទទួលស្គាល់ត្រឹមត្រូវតាមផ្លូវច្បាប់ ហើយនិងសម្រាប់ការពារឯកសារនោះផងដែរ ។ បំណងសំខាន់នៃការបោះត្រាលើថ្ងាសរបស់អ្នកជឿ នៅក្នុងព្រះនាមព្រះអម្ចាស់ត្រង់ជំពូក៧នេះ (៩:៤ ១៤:១ ២២:៤) គឺដើម្បីការពារដល់រាស្ត្ររបស់ទ្រង់នៅពេលជំនុំជម្រះ ។ មានសេចក្ដីលំអិតបន្ថែមទៀតនៅក្នុង"អគ ៩:៤ និងការពន្យល់"។ សញ្ញានៃការបោះត្រាលើថ្ងាសនេះ គឺជាលំដាប់តួអក្សរទី២២នៃភាសាហេព្រើរថា"ថូ (Taw) ដែលមានរាងជា "x" ឬ "+"។

**៧:៤** *១សែន៤ម៉ឺន៤ពាន់នាក់* មានអ្នកខ្លះយល់ថា ត្រង់ចំណុចនេះគឺនិយាយអំពីសមាជិកនៃពូជអំបូររបស់សាសន៍អ៊ីស្រាអែល ដែលនៅតែមានជំនឿស្មោះត្រង់ក្នុងគ្រា"មានទុក្ខលំបាកខ្លាំង"(ខ.១៤)។ តែមានអ្នកផ្សេងទៀតយល់ថាអត្ថបទនេះជានិមិត្តរូបនៃអ្នកជឿទាំងអស់ ដែលនៅតែស្មោះត្រង់នៅក្នុងគ្រាមានទុក្ខលំបាក ។

**៧:៥** *ពូជអំបូរយូដា* ត្រង់នេះបានជាពូជអំបូររបស់លោកយូដាត្រូវបានសរសេរមុនពូជអំបូររបស់លោករូបេន ដែលជាបងប្រុសរបស់គាត់នោះ គឺដោយសារតែព្រះមែស៊ី ជាខ្សែលោហិតចេញពីពូជអំបូររបស់លោកយូដា (ប៉ុន្តែ សូមមើលការពន្យល់ លប ៣៧:២១)។

**៧:៦** *ម៉ាន៉ាសេ* ជាពូជអំបូរ១នៅក្នុងអំបូរទាំងពីររបស់លោកយ៉ូសែប (អេប្រាអ៊ីម និងម៉ាន៉ាសេ) ហេតុផលដែលត្រូវបានបែងចែកនេះ ប្រហែលដើម្បីឱ្យបានគ្រប់ចំនួន១២ ពីព្រោះលោកដាន់ត្រូវបានគេលុបចោល ។ ការលុបចោលនេះ ប្រហែលមកពីកាលដំបូង គាត់មានជាប់ទាក់ទងទៅនឹងការថ្វាយបង្គំរូបព្រះ(ពច ១៨:៣0) ឬតាមប្រពៃណីបានឱ្យដឹងថា ពួកអ្នកដែលប្រឆាំងនឹងព្រះគ្រីស្ទគឺអាចចេញពីពូជអំបូរនេះតែម្ដង ។

**៧:៩** *១ហ្វូងយ៉ាងធំ* ឃ្លានេះបានបញ្ជាក់ពីខ.១៤ អំពីអស់អ្នកណាដែលបានទទួល"រងទុក្ខលំបាកយ៉ាងខ្លាំង"។ *គ្រប់ទាំងសាសន៍គ្រប់ទាំងពូជមនុស្ស គ្រប់ទាំងគ្រួសារ ហើយគ្រប់ទាំងភាសា* ចំណុចដែលបានពោលទាំងបួននេះ គឺមាននៅក្នុង ៥:៩ ១១:៩ ១៣:៧ ១៤:៦ ១0:១១ ១៧:១៥ ប៉ុន្តែមានមួយនៅក្នុងចំណោមទាំងបួននេះត្រូវបានផ្លាស់ប្ដូរ ។ *ធាងចាក* ជាមែកឈើមួយដែលធ្លាប់បានគេយកមកប្រើនៅក្នុងពិធីបុណ្យផ្សេងៗ (លវ ២៣:៤0 យហ ១២:១៣)។

**៧:១0** *សេចក្ដីសង្គ្រោះស្រេចនូវព្រះនៃយើង* មើល លប ៤៩:១៨ (សេចក្ដីប្រោសលោះ មើល យហ ២:៩)។

**៧:១១** *ពួកចាស់ទុំ* មើលការពន្យល់ ៤:៤ ។ *តួមានជីវិតទាំង៤* មើលការពន្យល់ ៤:៦ ។

អស់ទាំងទេវតាដែលឈរនៅជុំវិញបល្ល័ង្ក ព្រមទាំងពួក
ចាស់ទុំ[ផ] នឹងតួមានជីវិតទាំង៤[ព] ក៏ទំលាក់ខ្លួនក្រាបចុះ[ផ]នៅ
ចំពោះបល្ល័ង្ក ថ្វាយបង្គំដល់ព្រះ ១២ទាំងទូលថា អាម៉ែន
សូមថ្វាយព្រះពរ សិរីល្អ ប្រាជ្ញា ពាក្យអរព្រះគុណ កិត្តិនាម
ព្រះចេស្ដា នឹងឥទ្ធិឫទ្ធិ ដល់ព្រះនៃយើងរាល់គ្នា នៅអស់
កល្បជានិច្ចរៀងរាបតទៅ អាម៉ែន[ម]។
១៣នោះពួកចាស់ទុំម្នាក់សួរមកខ្ញុំថា តើអស់អ្នកដែល
ពាក់អាវសនោះ[យ]ជាពួកណា ហើយមកពីណា ១៤ខ្ញុំក៏
ឆ្លើយទៅថា លោកម្ចាស់អើយ លោកជ្រាបហើយ រួចអ្នក
នោះនិយាយមកខ្ញុំថា អ្នកទាំងនោះជាពួកអ្នកដែលបាន
ចេញពីគ្រាវេទនាយ៉ាងធំមក គេបានបោកអាវ[រ] ហើយធ្វើ
ឱ្យឡើងសក្នុងឈាមរបស់កូនចៀម[ល] ១៥ហេតុនោះ បានជា
គេស្ថិតនៅចំពោះបល្ល័ង្កព្រះ[វ] ព្រមទាំងបំរើទ្រង់[ស]នៅក្នុង
ព្រះវិហារទាំងយប់ទាំងថ្ងៃ[ហ] ហើយព្រះអង្គដែលគង់នៅ
លើបល្ល័ង្កនោះ[ឡ] ទ្រង់នឹងធ្វើជាត្រសាលបាំងឱ្យគេ[អ] ១៦គេ
នឹងមិនឃ្លាន ឬស្រេកទៀត[ក] ក៏មិនត្រូវថ្ងៃចាំងមកលើគេ
ឬចំហាយណាទៀតឡើយ[ខ] ១៧ពីព្រោះ កូនចៀមដែលនៅ
កណ្ដាលបល្ល័ង្ក ទ្រង់នឹងឃ្វាល[គ] ហើយនាំគេ ទៅដល់រន្ធទឹក
នៃជីវិត[ឃ] ហើយព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែកពីភ្នែក
គេចេញ[ង]។

## ត្រាទី៧ និងអាសនាមាស

**៨** ១កាលកូនចៀមបកត្រាទី ៧[ច] នោះនៅស្ថានសួគ៌បាន
ស្ងាត់ច្រៀបប្រហែលជាកន្លះម៉ោង ២រួចខ្ញុំឃើញទេវតា
ទាំង ៧[ឆ]ដែលឈរនៅចំពោះព្រះ ក៏មានត្រែ ៧[ជ]បាន
ប្រគល់ទៅឱ្យ ៣មានទេវតា១ទៀត[ឈ] បានចេញមកឈរនៅ
ចំពោះអាសនាទាំងកាន់ពានមាស ហើយមានគ្រឿងក្រអូប
ជាច្រើនបានប្រគល់ឱ្យទេវតានោះ ដើម្បីនឹងថ្វាយជាមួយ
នឹងសេចក្ដីអធិស្ឋានរបស់ពួកបរិសុទ្ធ[ញ] នៅលើអាសនា
មាស[ដ]ដែលនៅមុខបល្ល័ង្ក ៤នោះផ្សែងនៃគ្រឿងក្រអូបក៏
ផ្សាយឡើង ជាមួយនឹងសេចក្ដីអធិស្ឋានរបស់ពួកបរិសុទ្ធ
ចេញអំពីដៃនៃទេវតានៅចំពោះព្រះ[ឋ] ៥រួចទេវតាក៏យក
ពាន ទៅដាក់ពេញដោយភ្លើង ពីលើអាសនា[ឌ] បោះទៅលើ
ផែនដី នោះកើតមានសំឡេងផ្គរលាន់[ឍ] ផ្លេកបន្ទោរ និង
កក្រើកដី[ណ]។

**៧:១១** ផ វវ ៤:៤ ព វវ ៤:៦ ភ វវ ៤:១០
**៧:១២** ម រម ១១:៣៦ វវ ៥:១២-១៤
**៧:១៣** យ វវ ៣:៤
**៧:១៤** រ វវ ២២:១៤ ល ហព ៩:១៤ ១យហ ១:៧ វវ ១២:១១
**៧:១៥** វ ខ.៩ ស វវ ២២:៣ ហ វវ ១១:១៩ ឡ វវ ៥:១ អ អស ៤:៥,៦ វវ ២១:៣
**៧:១៦** ក យហ ៦:៣៥ ខ អស ៤៩:១០
**៧:១៧** គ យហ ១០:១១ ឃ យហ ៤:១០ ង អស ២៥:៨ ៣៥:១០ ៥១:១១ ៦៥:១៩ វវ ២១:៤
**៨:១** ច វវ ៦:១
**៨:២** ឆ ខ.៦-១៣ វវ ៩:១,១៣ ១១:១៥ ជ មថ ២៤:៣១
**៨:៣** ឈ វវ ៧:២ ញ វវ ៥:៨ ដ ខ.៥ នក ៣០:១-៦ ហព ៩:៤ វវ ៩:១៣ **៨:៤** ឋ ទដ ១៤១:២ **៨:៥** ឌ លវ ១៦:១២,១៣ ឍ វវ ៤:៥ ណ វវ ៦:១២

**៧:១២** *សូមថ្វាយព្រះពរ . . . ឥទ្ធិឫទ្ធិ* ពាក្យទាំង៧ចំណុចនៃសេចក្ដីទុក្ខវេទនាបានបញ្ជាក់យ៉ាងពេញលេញ ឬបរិបូរនៃការសរសើរ (មើលការពន្យល់ ៥:១២)។

**៧:១៣** *អ្នកដែលពាក់អាវស* មើលការពន្យល់ ៦:១១ ។

**៧:១៤** *វេទនាយ៉ាងធំ* គឺជាគ្រានៃសង្គ្រាម (ភាពប្រទូសរ៉ាយ) ចុងក្រោយមុននឹងព្រះគ្រីស្ទយាងមកលើកទី២ ។ អ្នកខ្លះយល់ថា ការចាប់ផ្ដើមនៃភាពប្រទូសរ៉ាយដល់ពួកជំនុំនេះ គឺត្រូវបានកន្លងផុតទៅហើយ ក្នុងសម័យលោកយ៉ូហាន ។

**៧:១៥** *ព្រះវិហារ* ក្នុងគម្ពីរវិវរណៈមានពាក្យចំនួន១៦ដែលជាប់ទាក់ទងទៅនឹងពាក្យថាព្រះវិហារ ជាជាងគ្រាន់តែសំដៅទៅលើបរិវេណព្រះវិហារ គឺជាកន្លែងមួយដែលព្រះវត្តមានរបស់ព្រះគង់នៅ ។ កន្លែងព្រះគង់ប្រថាប់នោះពុំមែនមានតែពួជអ័បូរលេវីប៉ុណ្ណោះនោះទេ ដែលអាចចូលបាននោះតែជាកន្លែងមួយ សម្រាប់អ្នកជឿទាំងអស់អាចចូលមកបម្រើទ្រង់បាន ពីព្រោះពួកអ្នកជឿទាំងអស់ ត្រូវបានត្រឡប់ជាសង្ឃរបស់ព្រះ (១:៦ ៥:១០ ២០:៦)។ *ត្រសាលបាំងឱ្យគេ* ត្រង់នេះគឺជារូបភាពមួយដែលនិយាយទៅដល់ត្រសាលនៅក្នុងទីហោរស្ថាន (លវ ២៦:១១-១៣)។

**៧:១៧** *ឃ្វាល* មានន័យថា ស្ដេចពីបុរាណតែងតែចាត់ទុកខ្លួនរបស់ពួកគេទៅនឹងអ្នកឃ្វាលដល់រាស្ត្ររបស់ខ្លួន (ដទ ២៣:១ និងការពន្យល់)។

**៨:១** *នៅស្ថានសួគ៌បានស្ងាត់ច្រៀប* ត្រង់នេះបញ្ជាក់ពីរយៈពេលសម្រាកមួយរយៈនៃវិនាសកម្ម មុននឹងសេចក្ដីហិនវិនាសទាំងអស់បានចូលមកដល់ ។ នៅទីបញ្ចប់នៃសកកម្មភាពនៃវិនាសកម្មនេះ គឺពុំត្រូវបានបើកសំដែងឱ្យដឹងទេនៅពេលនោះ គឺទុកបើកសំដែងនៅពេលក្រោយ ។

**៨:២** *ត្រែ៧* នៅក្នុងសម័យគម្ពីរសញ្ញាចាស់ត្រែត្រូវបានប្រើសម្រាប់ប្រកាសព័ត៌មានសំខាន់ៗ និងសម្រាប់ឱ្យសញ្ញានៅពេលមានសង្គ្រាម ។ ត្រែទាំង៧នៅក្នុងគម្ពីរវិវរណៈជំពូក ៨-៩,១១:១៥-១៩ បានប្រកាសអំពីគ្រោះមហន្តរាយធ្ងន់ធ្ងរជាងនិមិត្តរូបនៃការបោះត្រានោះទៅទៀត ប៉ុន្តែពុំមែនជាការបង្ហិនបង្ហោចទាំងស្រុងដ៏ហួសនិស្ស័យនោះទេ (វវ ១៦)។

**៨:៣** *ពាន* គឺជាចានដែកមួយត្រូវបានគេធ្លាប់ប្រើដើម្បីដាក់ធ្យូងសម្រាប់ដុតគ្រឿងក្រអូប (នក ២៧:៣ ១ពវ ៧:៥០)។ *ជាមួយនឹងសេចក្ដីអធិស្ឋាន* មានការបកស្រាយជាច្រើនបានចាត់ទុកគ្រឿងក្រអូបជាផ្នែកមួយដែលបូកបញ្ចូល "ជាមួយនឹង" សេចក្ដីអធិស្ឋាន ។ ឃ្លានេះជាភាសាក្រិកវិញ កាលណាគេយកគ្រឿងក្រអូបមកថ្វាយដល់ព្រះនោះ "ត្រូវតែមាន" សេចក្ដីអធិស្ឋានជានិច្ច (គ្រឿងក្រអូប. . . ជាមួយនឹងសេចក្ដីអធិស្ឋាន)។

**៨:៤** នៅត្រង់ខនេះបានប្រាប់ថា សូម្បីតែទេវតាក៏ត្រូវបង្ហាញវត្តមានជាមួយនឹងពួកបរិសុទ្ធក្នុងការអធិស្ឋាននេះដែរ ប៉ុន្តែ ពុំមែនមានន័យថា ទាល់តែមានទេវតាទើបព្រះទ្រង់ព្រមទទួលការអធិស្ឋាននោះទេ ។ ពួកសាសន៍យូដាបានយល់ថា នៅទីអវសាននៃពិភពលោកគឺពួកទេវតាជាអ្នកទូលអង្វរជំនួសយើងចំណុចនេះ ពុំមានចែងទេ នៅក្នុងគម្ពីរសញ្ញាថ្មីនោះ ។ ពួកទេវតាមានតួនាទីជាអ្នកទូលអង្វរជំនួសមែននៅក្នុងគ្រាតាំងសញ្ញាចាស់ (កច ៧:៣៨ និងការពន្យល់) ប៉ុន្តែ ពុំមានចែងសោះឡើយថា ទេវតាជាអ្នកទូលអង្វរជំនួសនៅក្នុងគ្រាតាំងសញ្ញាថ្មីនោះ ។

**៨:៥** *ផ្គរលាន់ . . . កក្រើកដី* មើលការពន្យល់ ៤:៥ ។

**ត្រែទាំង៧**

៦រួចទេវតាទាំង៧ ដែលកាន់ត្រែ៧[ត]នោះ ក៏រៀបនឹង
ផ្លុំឡើង ។
៧ទេវតាទី១[ថ]ក៏ផ្លុំឡើង នោះកើតមានព្រឹល ហើយភ្លើង[ទ]
លាយដោយឈាម បោះទៅលើផែនដី រួចផែនដី១ភាគ
ក្នុង៣[ធ] បានឆេះអស់ទៅ ព្រមទាំងដើមឈើ ១ភាគក្នុង៣
ដែរ នឹងស្មៅទាំងអស់ផង[ន]។
៨ទេវតាទី២ក៏ផ្លុំឡើង នោះមានដូចជាភ្នំយ៉ាងធំ[ប] កំពុង
តែឆេះជាភ្លើង បានបោះទំលាក់នៅក្នុងសមុទ្រ រួចសមុទ្រ
១ភាគក្នុង៣[ផ] ក៏ត្រឡប់ទៅជាឈាម[ព] ៩ហើយអស់ទាំងសត្វ
នៅក្នុងសមុទ្រ ដែលមានជីវិតរស់ ក៏ស្លាប់អស់១ភាគក្នុង
៣[ភ] ហើយអស់ទាំងនាវា ក៏ត្រូវបំផ្លាញ ១ភាគក្នុង៣ដែរ ។
១០ទេវតាទី៣ក៏ផ្លុំឡើង នោះមានផ្កាយ១យ៉ាងធំធ្លាក់ចុះ
ពីលើមេឃ[ម] ទាំងឆេះដូចជាចន្លុះ ក៏ធ្លាក់ទៅលើអស់ទាំង
ទន្លេ១ភាគក្នុង៣ ហើយនឹងលើអស់ទាំងរន្ធទឹក[យ] ១១ផ្កាយ
នោះឈ្មោះហៅថា «ស្លែង» ហើយទឹក១ភាគក្នុង៣[រ] បាន
ត្រឡប់ទៅជាពុល មានមនុស្សជាច្រើនស្លាប់ ដោយសារទឹក
នោះ ដ្បិតបានត្រឡប់ជាល្វីងអស់ហើយ[ល]។
១២ទេវតាទី៤ក៏ផ្លុំឡើង នោះព្រះអាទិត្យ ព្រះចន្ទនិង
ផ្កាយទាំងប៉ុន្មានបានត្រូវងងឹត[វ]ទៅ ១ ភាគក្នុង ៣[ស] នៅ
ពេលថ្ងៃ គ្មានពន្លឺ១ភាគក្នុង៣ ពេលយប់ក៏ដូច្នោះដែរ[ហ]។
១៣រួចខ្ញុំឃើញ ហើយឮសត្វឥន្ទ្រីហើរកាត់កណ្ដាលមេឃ[ឡ]
ទាំងបន្លឺដោយសំឡេងយ៉ាងខ្លាំងថា វេទនា វេទនា វេទនា
ហើយ[អ] ដល់អស់មនុស្សដែលនៅលើផែនដី[ក] ដោយព្រោះ
សូរត្រែរបស់ទេវតាទាំង៣ដែលរៀបនឹងផ្លុំទៀត។
**៩** ១ទេវតាទី៥ ក៏ផ្លុំឡើង នោះខ្ញុំឃើញផ្កាយ១ធ្លាក់ចុះពីលើ
មេឃមកលើផែនដី[ខ] មានគេឱ្យកូនសោ[គ]ទីជ្រៅនៃជង្ហុកធំ
ដល់ផ្កាយនោះ[ឃ] ២ផ្កាយនោះក៏បើកទីជ្រៅនៃជង្ហុកធំ រួច
មានផ្សែងហុយឡើងពីទីនោះ ដូចជាផ្សែងពីគុកភ្លើងយ៉ាង
ធំ[ង]ហើយព្រះអាទិត្យ និងអាកាសក៏ងងឹត[ច] ដោយព្រោះផ្សែង
ដែលហុយពីទីនោះមក[ឆ] ៣ក៏មានកណ្ដូប[ជ]ជាច្រើនចេញ ពី
ផ្សែងមកលើផែនដី វាបានទទួលអំណាច ដូចអំណាចខ្យា

**៨:៦** ត ខ.២
**៨:៧** ថ ខ.២ ទ អក ៣៨:២២ ធ ខ.៧-១២ វវ ៩:១៥,១៨ ១២:៤ ន វវ ៩:៤
**៨:៨** ប យរ ៥១:២៥ ផ ខ.៧ ព វវ ១៦:៣
**៨:៩** ភ ខ.៧
**៨:១០** ម អស ១៤:១២ វវ ៦:១៣ ៩:១ យ វវ ១៤:៧ ១៦:៤
**៨:១១** រ ខ.៧ ល យរ ៩:១៥ ២៣:១៥
**៨:១២** វ នក ១០:២១–២៣ វវ ៦:១២,១៣ ស ខ.៧ ហ អគ ៣២:៧
**៨:១៣** ឡ វវ ១៤:៦ ១៩:១៧ អ វវ ៩:១២ ១១:១៤ ១២:១២ ក វវ ៣:១០

**៩:១** ខ វវ ៨:១០ គ វវ ១:១៨ ឃ ខ.២,១១ លក ៨:៣១ **៩:២** ង លប ១៩:២៨ នក ១៩:១៨ ច យអ ២:២,១០ ឆ ខ.១,១១ លក ៨:៣១

**៨:៦** អត្ថន័យនៃការផ្លុំត្រែនៅត្រង់នេះមានបីយ៉ាងគឺ (១).ដើម្បីព្រមានថាការជំនុំជម្រះមានពិតប្រាកដមែន (២).ដើម្បីប្រកាសហៅកម្លាំងទាំងល្អនិងអាក្រក់ដើម្បីធ្វើសង្គ្រាម និង(៣).ការប្រកាសពីការយាងត្រឡប់មកវិញរបស់ស្ដេចដែលជាព្រះមែស៊ី ។ សេចក្ដីព្រមានទាំងនេះគឺជាការលើកទឹកចិត្តមួយដល់យើងគ្រប់គ្នា ធ្វើយ៉ាងណាឱ្យប្រាកដពីសេចក្ដីជំនឿរបស់យើងម្នាក់ៗឱ្យបានរឹងមាំឡើងថែមទៀតលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។
**៨:៨** *សមុទ្រ . . . ត្រឡប់ទៅជាឈាម* ត្រង់ចំណុចនេះគឺសំដៅទៅលើគ្រោះកាចទីមួយដែលបានកើតឡើងនៅស្រុកអេស៊ីព្ទ(នក ៧:២០–២១)។ នៅត្រង់នេះគឺជាសេចក្ដីជំនុំជម្រះចុងបញ្ចប់នៃពិភពលោក ជាជាងគ្រោះមហន្តរាយធម្មជាតិដោយកំអែរនៃបន្ទុះភ្នំភ្លើង ។
**៨:១០** *ផ្កាយ១យ៉ាងធំ . . . ធ្លាក់ចុះ* មើលការពន្យល់ ៦:១៣ ៩:១ ។
**៨:១១** *ស្លែង* គឺជារុក្ខជាតិមួយដើមដែលរសជាតិល្វីងយ៉ាងខ្លាំង ។ រុក្ខជាតិនេះត្រូវបានគេធ្លាប់ប្រើជាពាក្យប្រៀបប្រដូចជាមួយនឹងសេចក្ដីទុក្ខវេទនានិងភាពទុក្ខសោក(សភ ៥:៣–៤ យរ ៩:១៥ បទ ៣:១៩)។ រុក្ខជាតិនេះពុំមែនជារុក្ខជាតិពុលនោះទេ ប៉ុន្តែភាពល្វីងរបស់វាអាចធ្វើឱ្យស្លាប់បាន ។ *បានត្រឡប់ទៅជាពុល* ត្រង់ចំណុចនេះមានជាប់ទាក់ទងនឹងការអស្ចារ្យនៅជំរុំម៉ារ៉ាដែលមានទឹកល្វីង ហើយត្រឡប់ទៅជាផ្អែមវិញ(នក ១៥:២៥)។
**៨:១២** *នៅពេលថ្ងៃគ្មានពន្លឺ១ភាគក្នុង៣* ត្រង់ចំណុចនេះគឺជាគ្រោះកាចទី៩នៅស្រុកអេស៊ីព្ទ ភាពខ្មៅងងឹតក្រាស់ខ្មឹកគ្របដណ្ដប់ពេញផ្ទៃដីអស់រយៈពេលបីថ្ងៃ(នក ១០:២១–២៣)។ ភាពជាប់ទាក់ទងគ្នារវាងគ្រោះកាចនៅស្រុកអេស៊ីព្ទបានឱ្យយល់គ្រោះកាចនៅក្នុងគម្ពីរវិវរណៈនោះថា រាស្ត្ររបស់ព្រះត្រូវបានអនុញ្ញាតឱ្យចេញពីអំណាចគ្រប់គ្រងរបស់ខ្មាំងសត្រូវ ។
**៨:១៣** *វេទនា វេទនា វេទនាហើយ . . .* សេចក្ដីវេទនាទាំងបីនេះមានជាប់ទាក់ទងទៅនឹងគ្រោះកាចទាំងបីចុងក្រោយ (៩:១២ ១១:១៤ "១០:១–១១:១៣ ត្រង់នេះគឺជារយៈពេលចន្លោះ"។ សេចក្ដីជំនុំជម្រះដ៏ហួសហេតុនៅក្នុងជំពូក ១៥–១៦ គឺជាសេចក្ដីវេទានទីបី)។ សេចក្ដីវេទនាទាំងនេះនឹងធ្លាក់មកលើអ្នកមិនជឿនៅក្នុង ពិភពលោកនេះ(ជាពួកមនុស្សអាក្រក់ "មើលការពន្យល់ ៦:១០") ពុំមែនជាមនុស្សសុចរិតនោះទេ(៩:៤)។
**៩:១** *ផ្កាយ១ធ្លាក់ចុះពីលើមេឃមក* គឺជាផ្កាយដែលបាននិយាយនៅក្នុង ៨:១០ជាផ្នែកមួយនៃការរំខានដោយការធ្លាក់ចុះនៃផ្នែកលោហធាតុ ។ ផ្កាយនៅត្រង់ចំណុចនេះគឺជាភ្នាក់ងាររបស់ព្រះអាចជាទេវតា(២០:១)។ *ទីជ្រៅ* ពាក្យនេះសំដៅទៅលើការបង្ករហេតុនៅខាងក្រោមដី ដែលជាទីលំនៅរបស់សាតាំង(២០:១ លក ៨:៣១)។ ពាក្យនេះជាភាសាក្រិកមានន័យថា "យ៉ាងជ្រៅ" ឬ "ជ្រៅពុំអាចវាស់បាន" ហើយត្រូវបានគេយកមកប្រើនៅក្នុងគម្ពីរសញ្ញាចាស់(គម្ពីរបកប្រែជាភាសាក្រិកដំបូងរបស់គ្រីស្ទបរិស័ទ) ដើម្បីបកប្រែជាសាភាហេព្រើរ សម្រាប់អត្ថន័យជ្រៅៗកាលពីដំបូង (លប ១:២ ៧:១១ សភ ៨:២៨)។ មានពាក្យប្រាំបីនៅក្នុងចំណោមពាក្យទាំងប្រាំបួននៅក្នុងគម្ពីរសញ្ញាថ្មី ជាភាសាក្រិកដែលបានប្រើពាក្យថា "ទីជម្រៅ" នៅក្នុងគម្ពីរវិវរណៈ ។
**៩:៣** *កណ្ដូប* មានប្រវត្តិចេញពីគ្រោះកាចមួយនៅក្នុងចំណោមគ្រោះកាចទាំង១០ ដែលបានចែងក្នុងគម្ពីរ នក ១០:១–២០ យអ ១:២–២:១១ ។ ពាក្យថា "កណ្ដូប"ត្រង់ចំណុចនេះគឺប្រាប់អំពីប្រថ្នូលនៃការបំផ្លាញនៅពេលថ្ងៃនៃព្រះអម្ចាស់មកដល់ ។ សត្វកណ្ដូបបានធ្វើដំណើរជាហ្វូងៗ ហើយអាចស៊ីបំផ្លាញដំណាំទាំងអស់បាន ។ នៅឆ្នាំ១៨៦៦មានប្រជាជនចំនួន២០០ ០០០នាក់បានស្លាប់ដោយសារភាពអំណត់នៅស្រុកអាលហ្គឺ(Algiers) ក្រោយពីសត្វកណ្ដូបបានបំផ្លាញដំណាំ ។ *ខ្យាដំរី* ជាសត្វមានពិសនៅត្រង់ចុងកន្ទុយរបស់

ដំរី[ឈ]ដែលនៅផែនដី ៤ហើយមានគេបង្គាប់ដល់វាថា កុំឱ្យ
បំផ្លាញ[ញ]ស្មៅនៅផែនដី ឬរបស់ណាខ្ចី ឬដើមឈើ[ដ]ណា
ឡើយ ត្រូវធ្វើទុក្ខដល់តែមនុស្សណា ដែលគ្មានត្រា
របស់ព្រះនៅថ្ងាសវិញប៉ុណ្ណោះ[ឋ] ៥ដែលវាបានទទួល
អំណាចនោះ មិនមែននឹងសំឡាប់មនុស្សទេ គឺឱ្យបានគ្រាន់
តែធ្វើទុក្ខក្នុង រវាង៥ខែវិញប៉ុណ្ណោះ[ឌ] ហើយដែលវាធ្វើទុក្ខ
នោះសោត ក៏បែបដូចជាខ្យាដំរី[ឍ]ធ្វើទុក្ខ ក្នុងកាលដែល
វាទិចមនុស្សដែរ ៦នៅគ្រានោះ មនុស្សនឹងរកចង់បាន
សេចក្ដីស្លាប់ ប៉ុន្តែមិនប្រទះឡើយ គេនឹងចង់ស្លាប់ តែ
សេចក្ដីស្លាប់នឹងរត់ចេញពីគេទៅ[ណ] ៧កណ្ដូបទាំងនោះ
មើលទៅដូចជាសេះ ដែលរៀបនឹងចូលទៅច្បាំង[ត] នៅលើ
ក្បាលវាមានដូចជាមកុដ ដែលស្រដៀងនឹងមាស ហើយ
មានមុខវាដូចជាមុខមនុស្ស[ថ] ៨ឯសក់វា នោះដូចជាសក់
របស់ស្រីៗ ហើយធ្មេញវាដូចជា ធ្មេញរបស់សត្វសិង្ហ[ទ] ៩វា
ពាក់អាវសឹក ដូចជាអាវសឹកដែក ហើយសូរស្លាបវា ឮដូច
ជាសូរទេះចំបាំង ដែលទឹមដោយ សេះជាច្រើនបរជិះរត់
ទៅច្បាំង[ធ] ១០វាក៏មានកន្ទុយ ហើយនឹងទ្រនិចដូចជាខ្យាដំរី
ឯអំណាចវាក៏នៅក្នុងកន្ទុយនោះ សំរាប់នឹងធ្វើទុក្ខដល់
មនុស្សអស់រវាង ៥ ខែ[ន] ១១វាមានស្តេចត្រួតលើវាដែរ
គឺជាទេវតានៃជង្ហុកធំ[ប] ដែលតាមភាសាហេព្រើរ[ផ] មាន
ឈ្មោះហៅថា «អាបាដូន»[ព] តែតាមភាសាក្រេកហៅថា

៩:៣ ជ នក ១០:១២–១៥ ឈ ខ.៥,១០
៩:៤ ញ វវ ៦:៦ ដ វវ ៨:៧ ឋ វវ ៧:២,៣
៩:៥ ឌ ខ.១០ ឍ ខ.៣
៩:៦ ណ យប ៣:២១ ៧:១៥ យរ ៨:៣ វវ ៦:១៦
៩:៧ ត យអ ២:៤ ថ ដយ ៧:៨
៩:៨ ទ យអ ១:៦
៩:៩ ធ យអ ២:៥
៩:១០ ន ខ.៣,៥,១៩
៩:១១ ប ខ.១,២ លក ៨:៣១ ផ វវ ១៦:១៦ ព យប ២៦:៦ ២៨:២២ ៣១:១២ ទដ ៨៨:១១
៩:១២ ភ វវ ៨:១៣
៩:១៣ ម នក ៣០:១–៣ យ វវ ៨:៣
៩:១៤ រ វវ ៧:១ ល លប ១៥:១៨ ចទ ១:៧ យស ១:៤ អស ១១:១៥ វវ ១៦:១២

«អាប៉ុលីយ៉ូន» វិញ ១២សេចក្ដីវេទនាទី ១បានកន្លងទៅ
ហើយមើល មានសេចក្ដីវេទនា ២ យ៉ាងមកតាមក្រោយ
ទៀត[ភ] ។
១៣ទេវតាទី៦ក៏ផ្លុំឡើង នោះខ្ញុំឮសំឡេង១ ចេញពីស្នែង
ទាំង៤[ម] របស់អាសនាមាស ដែលនៅចំពោះព្រះ[យ] ១៤ក៏
និយាយទៅទេវតាទី ៦[រ]ដែលកាន់ត្រែថា ចូរស្រាយទេវតា
ទាំង៤ ដែលចងទុកនៅទន្លេអើប្រាតដ៏ជាធំទៅ[ល] ១៥នោះក៏
ស្រាយ[វ]ទេវតាទាំង៤ដែលប្រុងប្រៀបសំរាប់ពេលកំណត់
ថ្ងៃ ខែ និងឆ្នាំដើម្បីនឹងសំឡាប់មនុស្ស១ភាគក្នុង៣[ស]ចោល[ហ]
១៦ឯចំនួនពលសេះ នោះមាន ២០ កោដិ ខ្ញុំក៏ឮចំនួនពលទ័ព
ទាំងនោះ[ឡ] ១៧ហើយក្នុងការជាក់ស្តែងនេះ ខ្ញុំឃើញសេះ
ទាំងនោះ នឹងអ្នកដែលជិះដែរ គេមានពាក់អាវសឹកសម្បុរ
ភ្លើង ស្វាយខ្ចី និងស្ពាន់ធ័រ ឯក្បាលសេះនោះដូចជាក្បាល
សិង្ហ មានភ្លើង ផ្សែង ហើយស្ពាន់ធ័រចេញពីមាត់[អ]វាមក[ក]
១៨មនុស្សលោក ១ ភាគក្នុង ៣[ខ]បានស្លាប់[គ] ដោយសេចក្ដី
វេទនាទាំង ៣ មុខនេះ គឺដោយភ្លើងផ្សែង នឹងស្ពាន់ធ័រ[ឃ]
ដែលចេញពីមាត់វាមកនោះឯង ១៩ពីព្រោះអំណាចរបស់
សេះទាំងនោះ គឺមាននៅក្នុងមាត់ នឹងក្នុងកន្ទុយវា ដ្បិត
កន្ទុយវាដូចជាពស់ដែលមានក្បាល ហើយវាក៏ធ្វើទុក្ខដោយ
សារកន្ទុយនោះ ២០រីឯសំណល់មនុស្សដែលមិនបានស្លាប់

**៩:១៥** វ វវ ២០:៧ ស វវ ៨:៧ ហ ខ.១៨ **៩:១៦** ឡ វវ ៥:១១ ៧:៤
**៩:១៧** អ វវ ១១:៥ ក ខ.១៨ ទដ ១១:៦ អស ៣០:៣៣ អគ ៣៨:២២ វវ ១៤:១០ ១៩:២០ ២០:១០ ២១:៨ **៩:១៨** ខ វវ ៨:៧ គ ខ.១៥ ឃ ខ.១៧

វាដែលអាចធ្វើមនុស្សដែលវាទិចនោះរបួស ឬស្លាប់បាន ។

**៩:៤** *មនុស្សណា ដែលគ្មានត្រារបស់ព្រះ* ទុក្ខសោកដំបូងពុំបានប៉ះពាល់ដល់ "អ្នកបម្រើព្រះ"(មើល ៧:៣)។ នៅត្រង់ចំណុចនេះមានន័យថា រាស្ត្រអ៊ីស្រាអែលត្រូវបានទទួលការពារ ពីការធ្វើទុក្ខបៀតបៀនពីពួកអេស៊ីព្ទ (នក ៨:២២ ៩:៤,២៦ ១០:២៣ ១១:៧)។

**៩:៥** *៥ខែ* ពាក្យនេះមានន័យថា ជារយៈពេលមួយនៃវដ្តជីវិតរបស់សត្វកណ្ដូបតែងតែមាន ឬជារដូវប្រាំង (ពីនិទាឃរដូវរហូតដល់ផុតរដូវក្តៅ) ហើយជាគ្រាមួយ គ្រោះថ្នាក់បំផុតដោយសារការបំផ្លាញរបស់សត្វកណ្ដូប ។

**៩:៦** *ចង់បានសេចក្ដីស្លាប់ ប៉ុន្តែមិនប្រទះឡើយ* បើតាមគម្ពីរ ហស ១០:៨ (លក ២៣:៣០)។ នៅក្នុងសតវត្សទី១មុនគ.ស លោកមេទ័ពកូនេលាសបាននិពន្ធកំណាព្យមួយឃ្លាថា "គ្មានអ្វីឈឺចុកចាប់ជាងការដែលចង់ស្លាប់ ហើយស្លាប់មិនបាននោះទេ" លោកប៉ុលក៏ធ្លាប់បាននិយាយប្រហាក់ប្រហែលបែបនេះផងដែរ (ភល ១:២៣–២៤)។

**៩:៧** *មុខមនុស្ស* ត្រង់ចំណុចនេះគឺជាកណ្ដូបដែលបង្ហាញពីភាពប៉ិនប្រសប់នៃប្រាជ្ញារបស់វាពុំមែនបង្ហាញពីកម្លាំងរបស់សត្វកំណាចនោះទេ ។

**៩:៨** *សក់របស់ស្រីៗ* ពាក្យនេះប្រហែលជានិយាយអំពីព្រុយវែងៗរបស់កណ្ដូប ។ *ធ្មេញរបស់សត្វសិង្ហ* ត្រង់នេះបង្ហាញអំពីភាពព្រៃផ្សៃ និងភាពឥតមេត្តារបស់វា ។

**៩:៩** *អាវសឹក* នេះគឺជាអាវក្រោះម្យ៉ាងសម្រាប់ការពារសត្រូវពីខាងមុខ ។ *ដូចជាអាវសឹកដែក* គឺជាអាវក្រោះម្យ៉ាងដែលធ្វើអំពីដែកបន្ទះស្តើងៗផ្នែកខាងក្រៅ ហើយទ្រាប់ស្បែកនៅខាងក្នុង ។

**៩:១១** *អាបាដូន* គឺជានិមិត្តរូបនៃការបំផ្លាញ (សភ ១៥:១១)។

**៩:១៣** *ស្នែងទាំង៤របស់អាសនាមាស* មើល ៨:៣–៥ ។ ស្នែងទាំងនេះត្រូវបានដាក់នៅតាមជ្រុងអាសនាទាំងបួន(នក ២៧:២)។ អស់អ្នកណាដែលរត់ចេញពីការជំនុំជម្រះអាចស្វែងរកសេចក្ដីមេត្តាករុណាបាន ដោយកាន់ស្នែងទាំងនេះ (១ពវ ១:៥០–៥១ ២:២៨ និងការពន្យល់ អម ៣:១៤)។

**៩:១៤** *ទេវតាទាំង៤* នេះគឺជាទេវតារបស់អារក្សសាតាំងដែលទទួលបន្ទុកទ័ពសេះ (ខ.១៥–១៩)។ *អើប្រាត* មើលការពន្យល់ លក ១៥:១៨ ។

**៩:១៥** *ពេល...ថ្ងៃ...ខែ...និងឆ្នាំ* ត្រង់ចំណុចនេះគឺជាវេលានៃទីអវសានរបស់លោកិយដែលព្រះអម្ចាស់បានកំណត់ទុកពេលមួយដ៏ជាក់លាក់បំផុត ។

**៩:១៦** *២កោដិ* ពាក្យនេះភាគច្រើនផ្តោតទៅលើមេទ័ព ដែលកូនទាហានដ៏ច្រើនលើសលប់ពិបាកនឹងរាប់អស់ (ទដ ៦៨:១៧ ដយ ៧:១០ វវ ៥:១១)។

**៩:១៧** *ភ្លើង . . . ចេញពីមាត់វា* មានសាក្សីពីរនាក់នៅក្នុង ១១:៥ ។

**៩:១៩** *កន្ទុយវាដូចជាពស់ ដែលមានក្បាល* ចំណុចនេះបញ្ជាក់ពីរូបរាងសេះរបស់អារក្សសាតាំង (១២:៩)។

**៩:២០** *នៅតែមិនព្រមប្រែចិត្ត* ត្រង់ចំណុចនេះបានបង្ហាញពីបំណងនៃភាព

ដោយសារសេចក្ដីវេទនាទាំងនោះ ក៏នៅតែមិនព្រមប្រែ
ចិត្ត[ង]ចេញពីការដែលស្នាដៃគេធ្វើ[ច] ដើម្បីនឹងលះចោល
ការគោរពដល់អារក្ស[ឆ]នឹងរូបព្រះធ្វើពីមាស ប្រាក់ លង្ហិន
ថ្ម ឬពីឈើក្ដី ដែលមើលមិនឃើញ ស្ដាប់មិនឮ ហើយដើរ
មិនរួចនោះឡើយ[ជ] ២១ក៏មិនបានប្រែចិត្តចោល[ឈ]ការកាប់
សំឡាប់ មន្តអាគម[ញ] កំផិត[ដ] នឹងការលួចប្លន់ ដែលគេ
ប្រព្រឹត្តផងដែរ ។

## ទេវតា និងក្រាំងតូច

**១០** ១ខ្ញុំក៏ឃើញទេវតា[ឋ]ដ៏ខ្លាំងពូកែ១ទៀត ចុះមកពីលើ
មេឃ[ឌ] មានពពកហ៊ុម ហើយមានឥន្ទធនូ[ឍ]នៅលើក្បាលមុខ
នៃទេវតានោះដូចជាថ្ងៃ[ណ] ហើយជើងដូចជាបង្គោលភ្លើង[ត]
២មានកាន់ក្រាំង១តូច[ថ]បើកនៅដៃ ក៏ឈានជើងស្ដាំទៅលើ
សមុទ្រ ហើយជើងឆ្វេងទៅលើដីគោក[ទ] ៣រួចបន្លឺឡើង
ដោយសំឡេងយ៉ាងខ្លាំង ដូចជាសំឡេងនៃសត្វសិង្ហដែល
គ្រហឹម[ធ] លុះបានបន្លឺស្រេចហើយ នោះក៏មានឮសំឡេងផ្គរ
លាន់៧[ន] ៤កាលបានឮផ្គរលាន់ទាំង៧នោះរួចហើយ នោះ
ខ្ញុំរៀបនឹងសរសេរ[ប] តែមានសំឡេងចេញពីលើមេឃ[ផ]
ប្រាប់ខ្ញុំថា ចូរបំបិទសេចក្ដីដែលផ្គរលាន់ទាំង៧ បានថ្លែង
នោះទៅ កុំឱ្យកត់សេចក្ដីទាំងនោះឡើយ[ព] ៥រួចទេវតា
ដែលខ្ញុំឃើញឈរលើសមុទ្រ ហើយលើដីគោក[ភ] ក៏លើក
ដៃស្ដាំទៅលើមេឃ[ម] ៦ទាំងស្បថ[យ]នឹងព្រះដ៏មានព្រះជន្មរស់
អស់កល្បជានិច្ចរៀងរាបតទៅ[រ] ជាព្រះដែលបង្កើតមេឃ ដី
សមុទ្រ នឹងរបស់ទាំងប៉ុន្មាន ដែលនៅស្ថានទាំងនោះ[ល]ថា
គ្មានពេលបង្អង់ទៀតឡើយ[វ] ៧តែនៅគ្រាដែលឮសំឡេង
ទេវតាទី ៧ ក្នុងកាលដែលរៀបនឹងផ្លុំត្រែ[ស] នោះសេចក្ដី

**៩:២០** ង វវ ២:២១
ច ចទ ៤:២៨
៣១:២៩ យរ ១:១៦
មីក ៥:១៣ កច
៧:៤១ ឆ ១កថ
១០:២០ ជ ទដ
១១៥:៤–៧
១១៣:១៥–១៧
ដយ ៥:២៣
**៩:២១** ឈ វវ
២:២១ ញ អស
៤៧:៩,១២
វវ ១៨:២៣ ដ វវ
១៧:២,៥
**១០:១** ឋ វវ ៥:២
ឌ វវ ១៨:១ ២០:១
ឍ អគ ១:២៨ វវ
៤:៣ ណ មថ ១៧:២
វវ ១:១៦
ត វវ ១:១៥

**១០:២** ថ ខ.៨–១០ វវ ៥:១ ទ ខ.៥,៨ **១០:៣** ធ ហស ១១:១០ ន វវ ៤:៥
**១០:៤** ប វវ ១:១១,១៩ ផ ខ.៨ ព ដយ ៨:២៦ ១២:៤,៩ វវ ២២:១០
**១០:៥** ភ ខ.១,២ ម ចទ ៣២:៤០ ដយ ១២:៧ **១០:៦** យ លប ១៤:២២
នក ៦:៨ ជន ១៤:៣០ រ វវ ១:១៨ ល ទដ ១១៥:១៥ ១៤៦:៦ វវ ៤:១១
១៤:៧ វ វវ ១៦:១៧ **១០:៧** ស មថ ២៤:៣១

ឈើចាប់ដ៏ខ្លាំងបំផុត របស់អ្នកប្រកាសដំណឹងល្អមួយចំនួន បានប្រកាសឱ្យមនុស្សផ្សេងប្រែចិត្ត តែអ្នកទាំងនោះមិនព្រមប្រែចិត្តសោះ (ខ.២១ ២:២១ ១៦:៩,១១ និងការពន្យល់ អម ៤:៦–១១) ។ *អារក្ស* គឺជាវិញ្ញាណទាំងឡាយណាដែលមានសម្ព័ន្ធមិត្តជាមួយនឹងវិញ្ញាណសាតាំង ហើយមានឥទ្ធិពលលើកិច្ចការរបស់មនុស្សលោក (ចទ ៤:២៨ ទដ ១១៥:៥–៧ លក ៤:៣៣ និងការពន្យល់ ១កថ ១០:២០) ។

**៩:២១** *ក៏មិនបានប្រែចិត្តចោល* មើល ១៦:៩,១១ ។ ត្រង់ចំណុចនេះមានន័យថា ទោះបីជាឈើខាងរូបរាងកាយយ៉ាងណាក៏ដោយ ក៏នៅតែមិនព្រមផ្លាស់ចិត្តរឹងទទឹងនោះដដែល ។ *មន្តអាគម* ពាក្យថា មន្តអាគមនៅត្រង់នេះគឺមានជាប់ទាក់ទងទៅនឹងការផ្សំពីរុក្ខជាតិ (ពាក្យនេះមកពីភាសាក្រិកមានន័យថា "ឱសថស្ថាន" ប៉ុន្តែនេះសម្រាប់កន្លែងពិសោធន៍មន្តអាគមប៉ុណ្ណោះ) ។ អ្នកជឿនៅក្រុងអេភេសូរបានដុតសៀវភៅមន្តអាគមនោះចោល ដែលសៀវភៅនីមួយៗមានតម្លៃស្មើនឹងកម្លាំងពលកម្មមួយថ្ងៃ (កច ១៩:១៩) ។

**១០:១** *ទេវតាដ៏ខ្លាំងពូកែ* ទេវតារូបនេះប្រហែលជាទេវតាតែមួយនៅក្នុង ៥:២ ។ *មានពពកហ៊ុំ* មើល មថ ១៧:៥ ២៤:៣០ និងការពន្យល់ ។ *ឥន្ទធនូ* មើល អគ ១:២៦–២៨ ។ ឥន្ទធនូ គឺជានិមិត្តសញ្ញានៃការសន្យារបស់ព្រះថានឹងមិនបំផ្លាញ ផែនដីដោយសារទឹកជំនន់ម្ដងទៀតឡើយ (លប ៩:៨–១៧ និងការពន្យល់ ៩:១៣) ។ *ជើងដូចជាបង្គោលភ្លើង* ពាក្យនេះបានរំឭកពីប្រវត្តិដើមក្នុងកាលដែលរាស្ត្រអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទ ដោយមានការដឹកនាំពីព្រះអម្ចាស់ជាបង្គោលភ្លើង និងបង្គោលពពក (នក ១៣:២១–២២) ហើយបានការពារអ៊ីស្រាអែល ក្នុងអំឡុងពេលធ្វើដំណើរកាត់ទីហោរស្ថានទៀតផង (នក ១៤:១៩,២៤) ហើយក៏ជាពាក្យសំខាន់នៅក្នុងគម្ពីរវិវរណៈនេះផងដែរ (មើលការពន្យល់ ៨:១២) ។

**១០:២** *ក្រាំង១តូច* ក្រាំងនេះពុំមែនដូចជាក្រាំងនៅក្នុងជំពូក៥នោះទេ ដោយសារតែក្រាំងនេះត្រូវបានបើកសំដែង អំពីអត្ថន័យទាំងអស់នៅក្នុងនោះ ហើយក៏ត្រូវបានគេបរិភោគ ។ លើសពីនេះទៅទៀត ពាក្យថា "ក្រាំង១តូច" នេះមានលក្ខណៈពិសេសដាច់ដោយឡែកពីក្រាំងផ្សេងៗដទៃទៀត ។ *ជើងស្ដាំទៅលើសមុទ្រ ហើយជើងឆ្វេងទៅលើដីគោក* ឃ្លានេះបង្ហាញពីភាពធំឧត្ដមរបស់ព្រះអម្ចាស់ជានិមិត្តសញ្ញានៃការយាងមករបស់ព្រះអាទិករ (ខ.៦) ។

**១០:៣** *សំឡេងផ្គរលាន់* មើល ៨:៥ ១១:១៩ ១៦:១៨ ។ ផ្គរលាន់គឺមានជាប់ទាក់ទាក់គ្នាទៅនឹងការជំនុំជម្រះរបស់ព្រះ ។ នៅទីនេះក៏ដូចគ្នាផងដែរ គឺជាការជំនុំជម្រះ ដល់អ្នកដែលបដិសេធសេចក្ដីស្រឡាញ់ និងព្រះគុណរបស់ទ្រង់ ។

**១០:៤** *ចូរបំបិទសេចក្ដី* មើលខយោងក្នុងព្រះគម្ពីរ ដយ ៨:២៦ ១២:៤,៩ ដែលបានទាយអំពីបិទត្រានេះទុកសិនរហូតដល់ពេលចុងក្រោយ ដល់ពេលថ្ងៃមួយនឹងត្រូវបានបើកសំដែង ។ អត្ថន័យនៃផ្គរលាន់ទាំង៧នឹងមិនត្រូវបានបើកសំដែងទេរហូតដល់ពេលកំណត់ទើបបើកសំដែង ។ បើតាម ២២:១០ ទេវតាបានប្រាប់ថាកុំឱ្យបំបិទសេចក្ដីទំនាយនៅក្នុងគម្ពីរវិវរណៈនេះឡើយ ។

**១០:៥** *លើកដៃស្ដាំទៅលើមេឃ* គឺជានិមិត្តសញ្ញានៃពាក្យសម្បថ (លប ១៤:២២–២៣ ចទ ៣២:៤០) ។

**១០:៦** *ព្រះដ៏មានព្រះជន្មរស់អស់កល្បជានិច្ចរៀងរាបតទៅ* ត្រង់នេះគឺជាឃ្លាសម្រាប់លើកទឹកចិត្ត ជាពិសេសដល់អស់អ្នកដែលត្រូវបានគេគំរាមធ្វើបាបដោយសារតែសេចក្ដីជំនឿ (១:១៨ ៤:៩–១០ ១៥:៧) ។ *គ្មានពេលបង្អង់ទៀតឡើយ* អ្នកដែលទទួលរងទុក្ខដោយសារសេចក្ដីជំនឿនៅក្នុង ៦:៩–១១ ត្រូវបានគេប្រាប់ឱ្យសម្រាកសិន ប៉ុន្តែ ឥឡូវនេះពេលចុងបញ្ចប់បានមកដល់ហើយ (ដយ ១២:១ មក ១៣:១៩) ។

**១០:៧** *សេចក្ដីអាថ៌កំបាំងនៃព្រះ* ចំពោះពួកហោរាសាស្ត្របានយល់ពីសេចក្ដីអាថ៌កំបាំងនៃព្រះនេះថា គឺជាការសម្ងាត់ដែលបានលាក់ទុកនៅឯស្ថានសួគ៌ ហើយនឹងត្រូវបានបើកសំដែងមកដល់ពួកហោរា ។ សេចក្ដីអាថ៌កំបាំងនៅត្រង់នេះ គឺថាព្រះអម្ចាស់បានយកជ័យជម្នះ លើអំណាចនៃវិញ្ញាណអាក្រក់ ហើយទ្រង់នឹងសោយរាជ្យអស់កល្បជានិច្ច (១១:១៥) ។

អាថ៌កំបាំង[ហ]នៃព្រះនឹងបានសំរេច ដូចជាទ្រង់បានផ្សាយ
ដំណឹងល្អមកប្រាប់ពួកហោរា ជាពួកបាវបំរើរបស់ទ្រង់
ដែរ[ឡ]។

8 ឯសំឡេងដែលខ្ញុំឮពីលើមេឃ[អ] នោះក៏និយាយមកខ្ញុំ
ម្តងទៀតថា ចូរទៅយកក្រាំងតូច[ក]ដែលបើកនៅដៃទេវតា
ដែលឈរលើសមុទ្រ ហើយលើដីគោកនោះចុះ
9 ខ្ញុំក៏ទៅ
ឯទេវតានោះ និយាយថា សូមឱ្យក្រាំងតូចនោះមកខ្ញុំ
ទេវតាឆ្លើយថា ចូរយកទៅបរិភោគចុះ ក្រាំងនេះនឹងធ្វើ
ឱ្យពោះឯងល្វីង តែនៅក្នុងមាត់នឹងបានផ្អែមដូចទឹកឃ្មុំទេ[ខ]
10 នោះខ្ញុំក៏យកក្រាំងតូចពីដៃទេវតាមកទទួលទាន ឯនៅក្នុង
មាត់ខ្ញុំ[គ] ក៏ផ្អែមដូចទឹកឃ្មុំមែន តែកាលខ្ញុំបានទទួលទានរួច
ទៅហើយ នោះពោះខ្ញុំបានទៅជាល្វីងវិញ
11 រួចទេវតា
ប្រាប់ខ្ញុំថា ឯងត្រូវទាយម្តងទៀត[ឃ] គឺទាយពីដំណើរ
គ្រួសារ នឹងពីពួកសាសន៍ ពីភាសាផ្សេងៗ ហើយពីស្តេច
ជាច្រើន[ង]។

**១០:៧** ហ រម ១៦:២៥ ឡ អម ៣:៧
**១០:៨** អ ខ.៤ ក ខ.២
**១០:៩** ខ យរ ១៥:១៦ អក ២:៨–៣:៣
**១០:១០** គ ខ.៩
**១០:១១** ឃ អគ ៣៧:៤,៩ ង ដយ ៣:៤ វវ ១៣:៧
**១១:១** ច អគ ៤០:៣ វវ ២១:១៥
**១១:២** ឆ អគ ៤០:១៧,២០ ជ លក ២១:២៤ ឈ វវ ២១:២ ញ ខ.៣ ដយ ៧:២៥ ១២:៧ វវ ១២:៦,១៤ ១៣:៥
**១១:៣** ដ វវ ១:៥ ២:១៣

## ស្មរបន្ទាល់ទាំង២

**១១** 1 មានគេឱ្យដើមបបុសទុកជាខ្នាត[ច]មកខ្ញុំ ដោយថា
ចូរក្រោកឡើងទៅវាស់ព្រះវិហារនៃព្រះ នឹងអាសនា
ហើយនឹងពួកអ្នកដែលថ្វាយបង្គំក្នុងព្រះវិហារផង
2 តែ
ទីលានដែលនៅខាងក្រៅ[ឆ] នោះត្រូវចោលចេញ កុំឱ្យវាស់
ឡើយ ដ្បិតបានឱ្យទីនោះដល់សាសន៍ដទៃហើយ[ជ] គេនឹងជាន់
ទីក្រុងបរិសុទ្ធ[ឈ]អស់រវាង ៤២ ខែ[ញ]
3 អញនឹងឱ្យអំណាច
ដល់ស្មរបន្ទាល់អញទាំង ២ នាក់[ដ] គេនឹងទាយក្នុងរវាង
១២៦០ ថ្ងៃ[ឋ] ទាំងស្លៀកពាក់សំពត់ធ្មៃផង[ឌ]
4 អ្នក ២ នាក់
នោះ គេជាដើមអូលីវទាំង ២[ឍ] ហើយជាចង្កៀងទាំង ២
ដែលឈរនៅចំពោះព្រះអម្ចាស់នៃផែនដី[ណ]
5 បើអ្នកណា
ចង់ធ្វើទុក្ខដល់អ្នក ២ នាក់នោះ នឹងមានភ្លើងចេញពីមាត់គេ
មកបញ្ឆោះបំផ្លាញពួកខ្មាំងសត្រូវវិញ[ត] បើសិនជាអ្នកណាចង់
ធ្វើទុក្ខគេ នោះត្រូវស្លាប់ទៅយ៉ាងដូច្នោះ[ថ]
6 អ្នកទាំង២ នោះ

ឋ ខ.២ ឌ លប ៣៧:៣៤ ២សយ ៣:៣១ នហ ៩:១ យហ ៣:៥ **១១:៤** ឍ ទដ ៥២:៨ យរ ១១:១៦ សក ៤:៣,១១ ណ សក ៤:១៤ **១១:៥** ត ២សយ ២២:៩ ២ពវ ១:១០ យរ ៥:១៤ វវ ៩:១៧,១៨ ថ ជន ១៦:២៩,៣៥

**១០:៩** *ចូរយកទៅបរិភោគចុះ* មានន័យថា ទទួល ហើយសញ្ជឹងគិតឱ្យគ្រប់ជ្រុងជ្រោយនូវអត្ថបទខាងក្នុងនៃក្រាំងនោះ (ទដ ១១៩:១០៣)។ *ធ្វើឱ្យពោះឯងល្វីង* នេះគឺជាអត្ថន័យនៃអត្ថបទនៅក្នុងក្រាំងតូចនោះ (១១:១–១៣) ដែលបញ្ជាក់ពីសេចក្តីទុក្ខវេទនា។ *ក្នុងមាត់នឹងបានផ្អែមដូចទឹកឃ្មុំ* មានន័យថាបំណងព្រះហឫទ័យដែលមានតាំងពីដើមមក នោះនឹងមិនពន្យាពេលទៀតឡើយ (ដំណឹងល្អ)។

**១០:១១** *ត្រូវទាយម្តងទៀត* ទំនាយទាំងនេះបានកើតឡើងក្រោយពីឮសំឡេងត្រែទី៧បានបន្លឺឡើង ។ *គ្រួសារ . . . ស្តេចជាច្រើន* មើលពន្យល់ ៧:៩ ។

**១១:១** *ដើមបបុស* ជារុក្ខជាតិម្យ៉ាងមានថ្នាំងៗដូចជាដើមឫស្សី មានកំពស់ប្រហែល0,៦0ម៉ែត្រ ដែលតែងតែដុះនៅមាត់ទឹកតាមដងទន្លេយ័រដាន់ ។ ដើមបបុសនេះមានរាងត្រង់ស្រាល ងាយស្រួលយកមកធ្វើបន្ទាត់វាស់ (អគ ៤0:៣ សក ២:១–២)។ *ព្រះវិហារ* មើលការពន្យល់ ៧:១៥ ។ ព្រះវិហារត្រូវបានគេឱ្យនិយមន័យជាច្រើនដូចតទៅនេះ អ្នកខ្លះចាត់ទុកថាជាទីសក្ការៈបូជានៅលើផែនដី អ្នកខ្លះចាត់ទុកថា ជានិមិត្តរូបដំណាងឱ្យអ្នកជឿលើព្រះគ្រីស្ទ អ្នកខ្លះទៀតថាជានិមិត្តរូបដំណាងឱ្យពួកអ៊ីស្រាអែលជាអ្នកជឿលើព្រះ ហើយមានអ្នកខ្លះយល់ថាគឺជាអ្នកជឿព្រះនាពេលបច្ចុប្បន្ន ដែលត្រូវតែស្អាងព្រះវិហារនេះបន្តទៅមុខទៀត ។ *អាសនា* គឺបង្ហាញពីទីកន្លែងសម្រាប់ថ្វាយបង្គំ ហើយអាសនានៅទីនេះគឺជាអាសនាធំបំផុត ។

**១១:២** *ទីលានដែលនៅខាងក្រៅ* គឺជាទីលានសម្រាប់សាសន៍ដទៃ ។ *ជាន់ទីក្រុងបរិសុទ្ធ* មើល ទដ ៧៩:១ អស ៦៣:១៨ លក ២១:២៤ ។ *៤២ ខែ* គឺស្មើនឹងបីឆ្នាំកន្លះ ។ មានអ្នកខ្លះបានរកឃើញប្រវត្តិនៃរយៈពេលនេះថា ជាពេលដែលសាសន៍យូដារងទុក្ខវេទនា នៅក្រោមអំណាចរបស់ពួកស៊ីរី ទីរ៉ាន អង់ទីយ៉ូក អេភីហ្វាន (Syrian tyrant, Antiochus Epiphanes) នៅក្នុងអំឡុងឆ្នាំ១៦៨–១៦៥មុនស.គ ។ ដោយហេតុតែព្រះវិហារបានរងទុក្ខអស់រយៈពេលបីឆ្នាំនៅក្រោមអង់ទីយ៉ូក បានជាមានអ្នកខ្លះបង្ហាញតួលេខដែលត្រូវបានប្រើនៅក្នុងគម្ពីរវិវរណៈដែលមានរយៈពេលបីឆ្នាំកន្លះនេះដោយគ្មានការសង្ស័យថា គឺជាការចែកនៃការបែកបាក់ព្រះវិហារនៅឆ្នាំទី៧0 ជាពីរផ្នែកស្មើៗគ្នា ដែលមានរយៈពេលរងទុក្ខ "១អាទិត្យ" (ដយ ៩:២៧)។ រយៈពេលការចែកជាពីរផ្នែកស្មើៗគ្នានេះ ក៏ត្រូវបានកំណត់ជាចំនួន១២៦0ថ្ងៃ (ខ.៣ ១២:៦) គឺជាពេលពាក់កណ្តាលមួយ ក្នុងចំណោមពេលទាំងពីរនោះ (១២:១៤ ដយ ៧:២៥ ១២:៧)។ នៅក្នុងអំឡុងនៃរយៈពេលខាងលើនេះ បានក្លាយជានិមិត្តរូប នៃភស្តុតាងមួយ សម្រាប់កំណត់រយៈពេលនៃការបណ្តោយតាមមនុស្សអាក្រក់ ។

**១១:៣** *ស្មរបន្ទាល់* ត្រង់នេះគឺស្មរបន្ទាល់ផ្សេងទៀតដែលមានលំនាំគំរូដូចជាលោកម៉ូសេ និងអេលីយ៉ា (ខ.៥–៦)។ លោកទាំងពីរនាក់នេះជានិមិត្តរូបតំណាង ឱ្យអ្នកជឿក្នុងអំឡុងពេលចុងក្រោយ មុននឹងព្រះគ្រីស្ទយាងមក ។ ឬលោកទាំងពីរនាក់នេះ អាចជាអ្នករងទុក្ខវេទនា ដោយសារតែប្រកាសដំណឹងល្អនៃសេចក្តីពិត ។ *១២៦0ថ្ងៃ* មើលការពន្យល់ ខ.២ ។ ត្រង់នេះមានន័យថា ១ខែមាន៣0ថ្ងៃ (៤២ខែ x ៣0ថ្ងៃ = ១២៦0ថ្ងៃ)។ *សំពត់ធ្មៃ* គឺជាក្រណាត់ពណ៌ខ្មៅគ្រើមៗម្យ៉ាងដែលធ្វើអំពីរោមចៀម ឬរោមអូដ្ឋ ។ វាត្រូវបានគេហែកទុកជាសញ្ញានៃទុក្ខសោក និងសោកសង្រេង (យអ ១:១៣ យហ ៣:៥–៦ មថ ១១:២១)។

**១១:៤** ក្នុងខនេះគឺជារូបភាពមួយ ដែលបញ្ជាក់អំពីអំណាចសម្រាប់ធ្វើទីបន្ទាល់ឱ្យមានប្រសិទ្ធភាព ដែលត្រូវបានប្រទានមកដោយព្រះវិញ្ញាណរបស់ព្រះ (មើលការពន្យល់ សក ៤)។

**១១:៥** *ភ្លើងចេញពី . . . ធ្វើទុក្ខ* ត្រង់នេះគឺសំដៅទៅលើការដែលលោកអេលីយ៉ាបានជួបប្រទះ ជាមួយនឹងអ្នកនាំសាររបស់ស្តេចអ័ហាស៊ីយ៉ា (២ពវ ១:១0,១២)។

**១១:៦** *មានអំណាចនឹងធ្វើឱ្យមេឃរាំង* នៅត្រង់នេះសំដៅលើកាលដែលពុំមានភ្លៀងនៅក្នុងសម័យរបស់លោកអេលីយ៉ា (១ពវ ១៧:១ លក ៤:២៥ យក

មានអំណាចនឹងធ្វើឱ្យមេឃ[ទ]រាំង មិនឱ្យភ្លៀងធ្លាក់មកក្នុង
គ្រាដែលគេទាយ[ធ] ក៏មានអំណាចនឹងបំផ្លាស់ទឹកឱ្យទៅជា
ឈាម[ន]ហើយនឹងធ្វើឱ្យផែនដីកើតមានសេចក្ដីវេទនាគ្រប់
យ៉ាង ក្នុងវេលាណាក៏ដោយ តាមតែចិត្តបាន ។
៧ កាលណាអ្នក ២ នាក់នោះ បានធ្វើបន្ទាល់របស់ខ្លួន
ស្រេចហើយ នោះសត្វសាហាវ[ប]ដែលឡើងមកពីជង្ហុកធំ[ផ]
នឹងច្បាំងនឹងគេ[ព] ទាំងឈ្នះ ហើយសំឡាប់គេផង ៨ ខ្មោចគេ
ទាំង ២ នាក់ នឹងដេកនៅផ្លូវទីក្រុងធំ[ភ] ដែលខាងព្រលឹង
វិញ្ញាណហៅថាក្រុងសូដុំម[ម] ហើយស្រុកអេស៊ីព្ទ គឺនៅក្រុង
នោះឯង ដែលមនុស្សបានឆ្កាងព្រះអម្ចាស់នៃអ្នកទាំង ២
នោះដែរ[យ] ៩ នោះនឹងមានមនុស្សពីគ្រប់ទាំងគ្រួសារ ពូជ
មនុស្ស ភាសា នឹងសាសន៍ទាំងប៉ុន្មាន[រ] បានឃើញខ្មោចគេ
នៅអស់ ៣ ថ្ងៃកន្លះ មិនព្រមឱ្យអ្នកណាកប់ឡើយ[ល] ១០ ហើយ
មនុស្សនៅផែនដីទាំងប៉ុន្មាន[វ] គេនឹងមានសេចក្ដីអំណរ
ហើយលេងសប្បាយ ពីដំណើរអ្នកទាំង ២ បានស្លាប់ហើយ
ក៏នឹងជូនជំនូនគ្នាទៅវិញទៅមក[ស] ពីព្រោះហោរាទាំង ២
នោះបានធ្វើទុក្ខដល់មនុស្ស ដែលនៅផែនដីទាំងប៉ុន្មាន
ជាខ្លាំងណាស់ ។
១១ ក្រោយ ៣ ថ្ងៃកន្លះនោះមក[ហ] ព្រះវិញ្ញាណនៃជីវិត
ដែលមកពីព្រះក៏ចូលក្នុងខ្មោចទាំង ២[ឡ] រួចគេក្រោកឈរ
ឡើង ហើយពួកអ្នកដែលឃើញក៏មានសេចក្ដីភ័យខ្លាចជា
ខ្លាំង ១២ នោះអ្នកទាំង ២ បានឮសំឡេងពីលើមេឃថា
ចូរឡើងមកឯណេះ[អ] គេក៏ឡើងទៅលើមេឃពួដ៏ពពក[ក]
ពួកខ្មាំងសត្រូវរបស់គេក៏ឃើញដែរ ១៣ នៅវេលានោះឯង
មានកក្រើកដីជាខ្លាំង[ខ] ទីក្រុងនោះ ១ ភាគក្នុង១០ ក៏រលំអស់
ទៅហើយមានមនុស្ស ៧ ពាន់នាក់ស្លាប់ ក្នុងខណៈដែល
កក្រើកដីនោះ ឯពួកមនុស្សដែលសល់ គេមានចិត្តភ័យខ្លាច
ក៏សរសើរដំកើង[គ]ដល់ព្រះនៃស្ថានសួគ៌[ឃ] ១៤ សេចក្ដីវេទនាទី
២ បានកន្លងទៅហើយ មើល សេចក្ដីវេទនាទី ៣ ត្រូវមកជា
ឆាប់[ង] ។

## ត្រែទី៧

១៥ ទេវតាទី៧ក៏ផ្លុំឡើង[ច] នោះមានឮសំឡេងជាច្រើនបន្លឺ
ឡើង[ឆ] នៅលើមេឃថា នគរទាំងប៉ុន្មាននៅលើលោកីយ
បានត្រឡប់ជានគររបស់ព្រះអម្ចាស់នៃយើងរាល់គ្នា នឹងជា
របស់ផងព្រះគ្រីស្ទនៃទ្រង់ហើយ[ជ] ទ្រង់នឹងសោយរាជ្យ នៅ
អស់កល្បជានិច្ចរៀងរាបតទៅ[ឈ] ១៦ នោះពួកចាស់ទុំទាំង
២៤ នាក់[ញ] ដែលអង្គុយនៅលើបល្ល័ង្ករបស់ខ្លួន នៅចំពោះ
ព្រះ ក៏ទំលាក់ខ្លួន[ដ]ក្រាបចុះថ្វាយបង្គំដល់ទ្រង់ ១៧ ទូលថា
ឱព្រះអម្ចាស់ ជាព្រះដ៏មានព្រះចេស្ដាបំផុត ដែលគង់នៅ

**១១:៦** ទ លក ៤:២៥ ធ ខ.៣ ន នក ៧:១៧,១៩ វវ ៨:៨
**១១:៧** ប វវ ១៣:១–៤ ផ លក ៨:៣១ ព ដយ ៧:២១ វវ ១៣:៧
**១១:៨** ភ វវ ១៦:១៩ ម អស ១:៩ យរ ២៣:១៤ អគ ១៦:៤៦ យ ហព ១៣:១២
**១១:៩** រ វវ ១៣:៧ ល ទដ ៧៩:២,៣
**១១:១០** វ វវ ៣:១០ ស នហ ៨:១០,១២ នអ ៩:១៩,២២
**១១:១១** ហ ខ.៩ ឡ អគ ៣៧:៥,៩ ១០,១៤
**១១:១២** អ វវ ៤:១ ក ២ពវ ២:១១ កច ១:៩
**១១:១៣** ខ វវ ៦:១២ គ វវ ១៤:៧ ១៦:៩ ១៩:៧ ឃ វវ ១៦:១១
**១១:១៤** ង វវ ៨:១៣
**១១:១៥** ច មថ ២៤:៣១ ឆ វវ ១៦:១៧ ១៩:១ ជ វវ ១២:១០ ឈ ទដ ១៤៥:១៣ ដយ ២:៤៤ ៧:១៤,២៧ មីក ៤:៧ សក ១៤:៩ លក ១:៣៣
**១១:១៦** ញ វវ ៤:៤ ដ វវ ៤:១០

៥:១៧) ។ *ទឹកឱ្យទៅជាឈាម* គ្រោះកាចមួយនេះនឹងកើតដូចគ្នាក្នុងកាលដែលព្រះបានប្រើលោកម៉ូសេ ឱ្យនាំរាស្ត្រអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទ (នក ៧:១៧–២១) ។

**១១:៧** *សត្វសាហាវ* នៅត្រង់នេះគឺជាលើកទីមួយហើយដែលបានពោលពីអ្នកប្រឆាំងនឹងរាស្ត្ររបស់ព្រះដ៏សំខាន់នៅថ្ងៃចុងក្រោយ (មើលជំពូក ១៣, ១៧) ។ សត្វសាហាវនោះនឹងចេញមកពីជង្ហុកធំ (មើលការពន្យល់ ៩:១) បង្ហាញពីចរិតលក្ខណៈរបស់អារក្សសាតាំង ។ *សំឡាប់គេ* ត្រង់ចំណុចនេះបានបញ្ជាក់ថា ពួកគេនឹងរងទុក្ខវេទនាដូចនឹងព្រះអម្ចាស់របស់ពួកគេដែរ (ខ.៨) ។

**១១:៨** *ខ្មោចគេទាំងពីរនាក់នឹងដេកនៅផ្លូវ* ការដែលមិនព្រមបញ្ចុះសពរបស់អ្នកស្រុកនៅក្នុងតំបន់សមុទ្រមេឌីទែរ៉ាណេខាងកើត គឺបង្ហាញពីការរំលោភបំពានយ៉ាងឃោរឃៅបំផុតដល់សព ។ *ទីក្រុងធំ* ទីក្រុងនេះប្រហែលជាក្រុងយេរូសាឡិម តែមានអ្នកខ្លះថា ទីក្រុងរ៉ូម បាប៊ីឡូន ឬក៏អាចជាទីក្រុងផ្សេងៗទៀត ។ ទីក្រុងនេះអាចជានិមិត្តរូបនៃការប្រឆាំងរបស់លោកិយនេះជាមួយនឹងព្រះ (មើល ១៦:១៩, ១៧:១៨ ១៨:១០,១៦,១៨–១៩,២១) ។ *ក្រុងសូដុំម* មើល អស ១:១០ ។ ឈ្មោះនេះសំដៅទៅលើមនុស្ស ដែលមានសីលធម៌រស់នៅទាប (លប ១៩:៤–១១) ។ *ស្រុកអេស៊ីព្ទ* ពាក្យនេះបញ្ជាក់ពីការគាបសង្កត់ និងភាពជាទាសករ ។ មានខ្លះនិយាយថា ព្រះយេស៊ូវត្រូវបានគេឆ្កាងនៅឯក្រុងរ៉ូម ក្នុងន័យនេះចង់បញ្ជាក់ថា អំណាចរបស់ទ្រង់ត្រូវបានពង្រីកឱ្យមនុស្សបានដឹងពេញទាំងពិភពលោក ហើយការនេះអាចសម្រេចទៅបានគឺដោយសារការសុគតរបស់ព្រះគ្រីស្ទ ។

**១១:៩** *៣ថ្ងៃកន្លះ* រយៈពេលនេះគឺខ្លីណាស់បើប្រៀបធៀបទៅនឹងរយៈពេលនៃការបំពេញភារកិច្ចរបស់ពួកគាត់ រយៈពេល៣ឆ្នាំកន្លះនោះ ។

**១១:១១** *ព្រះវិញ្ញាណនៃជីវិតដែលមកពីព្រះក៏ចូលក្នុងខ្មោចទាំង២* ចំណុចនេះជាការបញ្ជាក់កាន់តែច្បាស់ឡើងពីសេចក្ដីជំនឿដ៏ពិត (អគ ៣៧:៥,១០) ។

**១១:១២** *ឡើងទៅលើមេឃពួដ៏ពពក* មើល ១ថន ៤:១៧ ។ *ពួកខ្មាំងសត្រូវរបស់គេក៏ឃើញដែរ* មើល ១:៧ ។

**១១:១៣** *កក្រើកដី* មើលការពន្យល់ ៦:១២ អគ ៣៨:១៩ ។ *សរសើរដំកើងដល់ព្រះនៃស្ថានសួគ៌* នៅត្រង់ចំណុចនេះពុំមែនជាសកម្មភាពនៃការប្រែចិត្តនោះទេ វាគ្រាន់តែជាការបង្ហាញពីការភ័យខ្លាច និងការឈប់ប្រឆាំងនឹងព្រះគ្រីស្ទរបស់មនុស្សលោកតែប៉ុណ្ណោះ ។

**១១:១៤** *សេចក្ដីវេទនាទី២* មើល ៩:១២ ។

**១១:១៥** *ទេវតាទី៧ . . .ឮសំឡេង* ត្រង់នេះគឺជាលំដាប់លំដោយនៃសំឡេងត្រែដែលត្រូវបានគេកំពុងតែផ្លុំត្រែបន្ត (៩:១៣) ហើយត្រូវបានបញ្ចប់ ។ *នគររបស់ព្រះអម្ចាស់នៃយើងរាល់គ្នា* មើល នក ១៥:១៨ ទដ ១០:១៦ សក ១៤:៩ ។ *ជារបស់ផងព្រះគ្រីស្ទនៃទ្រង់* មើល ទដ ២:២ ។

**១១:១៦** *ពួកចាស់ទុំទាំង២៤នាក់* មើលការពន្យល់ ៤:៤ ។

**១១:១៧** *ដែលគង់នៅ ក៏បានគង់នៅតាំងតែពីដើម ហើយត្រូវយាងមកទៀត*

ក៏បានគង់នៅតាំងតែពីដើម ហើយត្រូវយាងមកទៀតអើយ[ឋ]
យើងខ្ញុំអរព្រះគុណ[ឌ]ដល់ទ្រង់ ព្រោះទ្រង់បានយកព្រះ
ចេស្តាដ៏ធំរបស់ទ្រង់[ឍ]ហើយបានសោយរាជ្យឡើង[ណ] ១៨អស់
ទាំងសាសន៍បានមានសេចក្ដីកំហឹង[ត] ហើយសេចក្ដីខ្ញាល់
ទ្រង់ក៏មកដល់ ជាពេលកំណត់ ដែលត្រូវជំនុំជំរះពួកមនុស្ស
ស្លាប់[ថ] ហើយប្រទានរង្វាន់ដល់ពួកហោរា[ទ] ពួកបរិសុទ្ធ នឹង
អស់អ្នកដែលកោតខ្លាចដល់ព្រះនាមទ្រង់ គឺជាពួកបាវបំរើ
ទ្រង់ទាំងតូចទាំងធំដែរ[ធ] ហើយជាពេលត្រូវបំផ្លាញពួកអ្នក
ដែលបង្ខូចផែនដីផង។

១៩នោះមានគេបើកព្រះវិហារនៃព្រះ[ន]នៅស្ថានសួគ៌
ហើយឃើញមានហិបនៃសេចក្ដីសញ្ញារបស់ទ្រង់[ប]នៅក្នុង
ព្រះវិហារនោះ រួចមានផ្លេកបន្ទោរ[ផ] សៀងសំឡេងផ្គរ
លាន់ កក្រើកដី នឹងព្រឹលយ៉ាងធំៗ[ព]។

### ស្ត្រី និងនាគ

**១២** ១រួចមានទីសំគាល់១យ៉ាងធំ[ភ] នៅលើមេឃ[ម] គឺជា
ស្ត្រីម្នាក់ប្រដាប់ខ្លួនដោយព្រះអាទិត្យ មានព្រះចន្ទនៅក្រោម
ជើង ក៏មានមកុដធ្វើពីផ្កាយ១២[យ]នៅលើក្បាលដែរ ២នាង
មានគភ៌ ក៏ស្រែកដោយរៀបនឹងសំរាលចេញ ទាំងឈឺ
ចាប់[រ] នឹងបង្កើតកូនមក ។

៣ឃើញមកទីសំគាល់១ទៀត នៅលើមេឃ[ល] គឺនាគដ៏ធំ
មានសម្បុរក្រហម[វ] ដែលមានក្បាល៧[ស] និងស្នែង១០[ហ] ឯ
នៅលើក្បាលវាមានមកុដ ៧[ឡ] ៤កន្ទុយវាក៏ទាញផ្កាយនៅ
លើមេឃ១ភាគក្នុង៣[អ]គ្រវាត់ចោលទៅផែនដី[ក] នាគនោះក៏
ស្ថិតនៅត្រង់មុខស្ត្រី ដែលរៀបនឹងសំរាលកូននោះ ដើម្បី
នឹងលេបកូននាង[ខ] ក្នុងកាលដែលសំរាលចេញមក ៥នាង
សំរាលបានកូនប្រុស ដែលត្រូវឃ្វាលគ្រប់អស់ទាំងសាសន៍
ដោយដំបងដែក[គ] តែព្រះទ្រង់លើក[ឃ]កូននាងទៅឯទ្រង់ នឹង
ដល់បល្ល័ង្កទ្រង់វិញ ៦រួចស្ត្រីនោះក៏រត់ទៅឯទីរហោស្ថាន
នៅទីនោះព្រះបានរៀបកន្លែងឱ្យនាង ដើម្បីនឹងចិញ្ចឹមនាង
នៅទីនោះ អស់រវាង១២៦០ថ្ងៃ[ង]។

៧នោះមានចំបាំងនៅលើមេឃ គឺមីកែល[ច] និងពួក
ទេវតារបស់លោកច្បាំងនឹងនាគ[ឆ] ហើយនាគ និងទេវតា
វា[ជ]ក៏ច្បាំងនឹងលោកដែរ ៨តែមិនបានឈ្នះទេ ក៏មិនឃើញ
មានកន្លែងណាឱ្យវានៅលើមេឃទៀតផង ៩នោះនាគធំ

**១១:១៧** ឋ វវ ១៩:៦ ឌ ទដ ៣០:១២ ឍ វវ ១:៨ ណ វវ ១:៤
**១១:១៨** ត ទដ ២:១ ថ វវ ២០:២១ ទ វវ ១០:៧ ធ វវ ១៩:៥
**១១:១៩** ន វវ ១៥:៥,៨ ប នក ២៥:១០–២២ ២រប ៥:៧ ហព ៩:៤ ផ វវ ៤:៥ ព វវ ១៦:២១
**១២:១** ភ ខ.៣ ម វវ ១១:១៩ យ លប ៣៧:៩
**១២:២** រ អស ២៦:១៧ កទ ៤:១៩
**១២:៣** ល ខ.១ វវ ១៥:១ វ ខ.៩,១៣,១៦,១៧ វវ ១៣:១ ស វវ ១៣:១ ១៧:៣,៧,៩ ហ ដយ ៧:៧,២០ វវ ១៣:១ ១៧:៣,៧,១២,១៦ ឡ វវ ១៩:១២
**១២:៤** អ វវ ៨:៧ ក ដយ ៨:១០ ខ មថ ២:១៦
**១២:៥** គ ទដ ២:៩ វវ ២:២៧ ១៩:១៥ ឃ កច ៨:៣៩
**១២:៦** ង វវ ១១:២ **១២:៧** ច យដ ៩ ឆ ខ.៣ ច មថ ២៥:៤១

មើល ១:៤,៨ ៤:៨ ហើយទ្រង់ក៏នឹងយាងមកម្ដងទៀត ។

**១១:១៨** *អស់ទាំងសាសន៍មានសេចក្ដីកំហឹង* មើល ទដ ៤៨:៤ ។ *សេចក្ដីខ្ញាល់ទ្រង់* មើលការពន្យល់ ៦:១៦ ។ សេចក្ដីក្រោធរបស់ទ្រង់បានទទួលជ័យជម្នះនៅក្នុង "១៤:១០–១១ ១៦:១៥–២១ ២០:៨–៩"។ *ជំនុំជំរះពួកមនុស្សស្លាប់* ចំណុចនេះត្រូវបានព្រៀងទុកនៅក្នុង ៦:១០ ហើយយកមកអនុវត្តនៅក្នុង ២០:១១–១៥ ។ *ពួក ហោរា . . . បាវបំរើ* មើល ដយ ៩:៦,១០ អម ៣:៧ សក ១:៦ ។

**១១:១៩** *ព្រះវិហារនៃព្រះនៅស្ថានសួគ៌* ជាទីលានបរិសុទ្ធនៅឯស្ថានសួគ៌ (៣:១២ ៧:១៥ ១៥:៥–៨) មានលក្ខណៈខុសគ្នាពីទីបរិសុទ្ធ (ព្រះវិហារ) នៅផែនដី (១១:១)។ *ហិបនៃសេចក្ដីសញ្ញា* នៅក្នុងព្រះគម្ពីរសញ្ញាចាស់បានប្រាប់ថាហិបនេះបានធ្វើឡើងពីឈើនាងនួន (ចទ ១០:១–២)។ ហិបនេះជានិមិត្តរូបតំណាងពីបល្ល័ង្ក ឬវត្តមានរបស់ព្រះអម្ចាស់ដែលបានគង់នៅក្នុងចំណោមរាស្ត្ររបស់ទ្រង់ ។ ហិបនេះប្រហែលត្រូវបានបំផ្លាញដោយចោលនៅពេលដែលស្ដេចនាបូសារាដាន់បានបំផ្លាញព្រះវិហារទីក្រុងយេរូសាឡិម (២ពវ ២៥:៨–១០)។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មីហិបនេះជានិមិត្តរូបអំពីភាពស្មោះត្រង់របស់ព្រះចំពោះការរក្សាការតាំងសញ្ញាជាមួយនឹងរាស្ត្ររបស់ទ្រង់ ។ *ផ្លេកបន្ទោរ . . . និងព្រឹលយ៉ាងធំ* មើលការពន្យល់ ៤:៥ ។

**១២:១** *ទីសំគាល់* ត្រង់នេះគឺជាទស្សនីយភាព ឬជាព្រឹត្តិការណ៍ដ៏អស្ចារ្យមួយដែលនឹងកើតឡើងហួសពីការស្មាន (លក ២១:១១,២៥ កច ២:១៩)។ *ស្ត្រីម្នាក់ប្រដាប់ដោយព្រះអាទិត្យ* ត្រង់នេះប្រហែលសំដៅទៅលើពួកអ្នកជឿព្រះមែស៊ី (ខ.៥)។ *ផ្កាយទាំង១២* គឺតំណាងឱ្យពូជអំបូរអ៊ីស្រាអែលទាំង ១២នាក់ ។

**១២:២** *ស្រែក . . . ទាំងឈឺចាប់* មានភាសាស្រដៀងគ្នានឹងត្រង់ចំណុចនេះដែរដែលបានពណ៌នាអំពីការកើតឡើងវិញរបស់ក្រុងយេរូសាឡិមនៅក្នុង អស ៦៦:៧ (មីក ៤:១០)។

**១២:៣** *នាគដ៏ធំមានសម្បុរក្រហម* ត្រង់នេះគឺជានិមិត្តរូបរបស់អារក្សសាតាំងដែលបាននិយាយនៅក្នុងខ.៩ (២០:២)។ បើនិយាយពីសត្វនាគនោះមានច្រើនណាស់ នៅក្នុងរឿងទេវកថារបស់មនុស្សពីបុរាណ (ដូចជាជំនឿរឿងព្រេងរបស់ពួកលេវីនៅស្រុកកាណាន ហើយនិងសិត–ទីហ្វូន អំពីក្រពើក្រហមនៅស្រុកអេស៊ីព្ទ)។ ជាធម្មតានៅគម្ពីរសញ្ញាចាស់ សត្វនាគនេះត្រូវបានគេប្រើសម្រាប់ប្រៀបធៀប ដើម្បីពណ៌នាពីខ្មាំងសត្រូវរបស់ព្រះ ហើយនិងសាសន៍អ៊ីស្រាអែល (ទដ ៧៥:១៤ អស ២៧:១ អគ ២៩:៣)។ *ក្បាល៧* ជានិមិត្តរូបពីប្រាជ្ញាដ៏ធំធេង (១៣:១)។ *ស្នែក១០* ជានិមិត្តរូបពីអំណាចដ៏អស្ចារ្យ ។

**១២:៥** *កូនប្រុស* គឺជាព្រះមែស៊ី ។ *ដំបងដែក* មើលការពន្យល់ ២:២៧ ។ *ទ្រង់លើកកូនាង* គឺជាការយាងឡើងទៅឯស្ថានសួគ៌របស់ព្រះគ្រីស្ទ ។

**១២:៦** *ទីរហោស្ថាន* នៅត្រង់នេះគឺពុំមែនចង់និយាយអំពីដីឥតប្រយោជន៍នោះទេ គឺនិយាយអំពីទីជម្រកខាងឯវិញ្ញាណវិញ (ហស ២:១៤)។ *១២៦០ថ្ងៃ* គឺជារយៈពេលនៃការការពាររបស់ព្រះវិញ្ញាណ នៅក្នុងអំឡុងពេលរងទុក្ខបៀតបៀន (មើលការពន្យល់ ១១:២ ១៣:៥)។

**១២:៧** *មីកែល* គឺជាប្រធានទេវតាដែលផ្ចាញ់សាតាំងក្នុងសង្គ្រាមនៅស្ថានសួគ៌ ។ នៅក្នុងបទគម្ពីរ ដយ ១២:១ ទេវតានេះគឺជាអ្នកការពារដល់រាស្ត្រអ៊ីស្រាអែលនៅពេលរំដោះរាស្ត្រនេះចេញពីទុក្ខលំបាកនៅថ្ងៃចុងក្រោយ ។

**១២:៩** *នាគធំត្រូវបោះទំលាក់ទៅ . . . ផែនដី* ការបោះទំលាក់សាតាំងចេញ

ត្រូវបោះទំលាក់ទៅ គឺជាពស់ពីបុរាណ[ឈ] ដែលឈ្មោះ
ហៅថាអារក្ស[ញ] ហើយសាតាំងផង[ដ] ដែលបាននាំលោកីយ
ទាំងមូលឱ្យវង្វេងចេញ[ឋ] វាត្រូវបោះទំលាក់ទៅផែនដីវិញ[ឌ]
ព្រមទាំងពួកទេវតារបស់វាផង ។
១០ នោះខ្ញុំឮសំឡេង១យ៉ាងខ្លាំង នៅលើមេឃ[ឍ]ថា ឥឡូវ
នេះ សេចក្ដីសង្គ្រោះ[ណ] ព្រះចេស្ដា នឹងរាជ្យរបស់ព្រះនៃ
យើងរាល់គ្នា ហើយអំណាចរបស់ព្រះគ្រីស្ទនៃទ្រង់ បានមក
ដល់ហើយ ដ្បិតអានោះដែលចោទប្រកាន់ពីពួកបងប្អូន
យើងរាល់គ្នា[ត] ដែលចេះតែចោទពីគេ នៅចំពោះព្រះ
ទាំងយប់ទាំងថ្ងៃ វាត្រូវបោះទំលាក់ទៅហើយ ១១ គេបាន
ឈ្នះ[ថ]វា ដោយសារឈាមនៃកូនចៀម[ទ] ហើយដោយសារ
សេចក្ដីបន្ទាល់របស់គេ[ធ] ក៏មិនបានស្ដាយជីវិតខ្លួនដរាបដល់
ស្លាប់[ន] ១២ ដោយហេតុនោះ ឱស្ថានសួគ៌ នឹងពួកអ្នកដែលនៅ
ស្ថាននោះអើយ ចូរអរសប្បាយឡើង[ប] តែវេទនា[ផ]ដល់
ផែនដី និងសមុទ្រវិញ[ព] ពីព្រោះអារក្សបានចុះមកឯអ្នក
រាល់គ្នា ទាំងមានសេចក្ដីឃោរឃៅជាខ្លាំង ដោយវាដឹងថា
ពេលវេលាវាខ្លីណាស់ហើយ។
១៣ លុះនាគ[ភ]ឃើញថា វាត្រូវបោះទំលាក់ទៅផែនដី
ហើយ នោះវាក៏ធ្វើទុក្ខដល់ស្ត្រីដែលសំរាលកូនប្រុសនោះ[ម]
១៤ តែព្រះទ្រង់ប្រទានឱ្យស្ត្រីនោះមានស្លាប ២ ដូចជាស្លាប
នៃសត្វឥន្ទ្រី[យ] ដើម្បីឱ្យនាងបានហើរទៅនៅកន្លែងរបស់
នាង នៅទីរហោស្ថាន ជាកន្លែងដែលទ្រង់ចិញ្ចឹមនាងអស់
១ខួប ២ខួប ហើយកន្លះខួបផង[រ] ឱ្យឃ្លាតពីមុខសត្វពស់នោះ
ចេញ ១៥ រួចពស់[ល]វាព្រួសទឹកចេញពីមាត់វាដូចជាទន្លេឱ្យ
ហូរទៅតាមស្ត្រីនោះ ដើម្បីនឹងបន្សាត់នាងឱ្យបាត់តាមទន្លេ
នោះទៅ ១៦ តែផែនដីបានជួយនាង ដោយហាឡើងលេប
ទន្លេ ដែលនាគព្រួសចេញពីមាត់វាទៅបាត់ ១៧ នាគក៏ខឹង
នឹងស្ត្រីនោះ ហើយចេញទៅច្បាំង[វ]នឹងសំណល់ពូជនាង
ទាំងប៉ុន្មាន[ស] ជាពួកអ្នកដែលកាន់តាមបញ្ញត្តព្រះ[ហ] ហើយ
មានសេចក្ដីបន្ទាល់ពីព្រះយេស៊ូវ[ឡ]។

**១២:៩** ឈ ខ.១៥ លប ៣:១-៧ ញ មថ ២៥:៤១ វវ ២០:២ ដ មថ ៤:១០ ឋ វវ ២០:៣,៨,១០ ឌ លក ១០:១៨ យហ ១២:៣១
**១២:១០** ឍ វវ ១១:១៥ ណ វវ ៧:១០ ត យប ១:៩-១១ សក ៣:១ ១ពត ៥:៨
**១២:១១** ថ យហ ១៦:៣៣ វវ ១៥:២ ទ វវ ៧:១៤ ធ វវ ៦:៩ ន លក ១៤:២៦ វវ ២:១០
**១២:១២** ប ទដ ៩៦:១១ អស ៤៤:២៣ ៤៩:១៣ វវ ១៨:២០ ផ វវ ៨:១៣ ព វវ ១០:៦
**១២:១៣** ភ ខ.៣ ម ខ.៥
**១២:១៤** យ នក ១៩:៤ រ វវ ១១:២
**១២:១៥** ល ខ.៩

## សត្វសាហាវដែលឡើងពីសមុទ្រ

**១៣** ១ ខ្ញុំក៏ឈរលើខ្សាច់ នៅមាត់សមុទ្រ ហើយខ្ញុំឃើញ
សត្វសាហាវ១ឡើងចេញពីសមុទ្រមក[អ] ដែលមានស្នែង១០
និងក្បាល៧[ក] រីឯនៅលើស្នែងវា មានមកុដ១០ ហើយនៅ
លើក្បាលទាំងប៉ុន្មាន នោះមានឈ្មោះជាពាក្យប្រមាថ[ខ]
២ សត្វដែលខ្ញុំឃើញនោះ មើលទៅដូចជាខ្លារខិន[គ] ជើងវា
ដូចជាជើងនៃខ្លាឃ្មុំ[ឃ] ហើយមាត់វាដូចជាមាត់សិង្ហ[ង] នាគក៏
ឱ្យឫទ្ធិ នឹងបល្ល័ង្ករបស់វាដល់សត្វនោះ ព្រមទាំងអំណាច
យ៉ាងធំដែរ[ច] ៣ ខ្ញុំឃើញក្បាលវា១ ដូចជាបានកាប់សំឡាប់
ហើយ តែរបួសដល់ស្លាប់នោះបានសះជាឡើងវិញ[ឆ] ហើយ

**១២:១៧** វ វវ ១:១៧ ១៣:៧ ស លប ៣:១៥ ហ យហ ១៤:១៥ ឡ វវ ១:២
**១៣:១** អ ដយ ៧:១-៦ វវ ១៥:២ ១៦:១៣ ក វវ ១២:៣ ខ ដយ ១១:៣៦ វវ ១៧:៣ **១៣:២** គ ដយ ៧:៦ ឃ ដយ ៧:៥ ង ដយ ៧:៤ ច វវ ២:១៣ ១៦:១០ **១៣:៣** ឆ ខ.១២,១៤

ពីស្ថានសួគ៌នៅត្រង់នេះគឺ ពុំមែនជាការបោះទំលាក់លើកដំបូងនោះទេ តែនៅត្រង់នេះគឺជាការបណ្ដេញចេញជាលើកចុងក្រោយហើយ ជាពួកអ្នកប្រឆាំងនឹងរាស្ត្ររបស់ព្រះនៅថ្ងៃចុងក្រោយ(ខ.១២-១៧)។ *អារក្ស ហើយសាតាំង* មើលការពន្យល់ ២:៩-១០ ។ *នាំ . . . ឱ្យវង្វេងចេញ* មើល ២កថ ១១:៣ លក ២២:៣១ យហ ១៣:២ ។

**១២:១០** *ចោទប្រកាន់* មើល យប ១:៩-១១ និងពន្យល់ ១:៦ មថ ១៦:២៣ ១យហ ៣:៨ សក ៣:១ ។ សាតាំង(ខ.៩)ជាភាសាហេព្រើរមានន័យថា "មេចោទប្រកាន់"។

**១២:១១** *ឈាមនៃកូនចៀម* មើលការពន្យល់ ៥:៩ និង ១:៥ ៧:១៤ ។

**១២:១២** *ពេលវេលាវាខ្លីណាស់* នេះគឺជាពេលចុងក្រោយរបស់សាតាំងក្នុងការទាស់ប្រឆាំងនឹងរាស្ត្ររបស់ព្រះកាន់តែខ្លាំងឡើង ។

**១២:១៣-១៦** អត្ថន័យនៅក្នុងខនេះគឺស្រដៀងគ្នាទៅនឹងស្ថានភាពរបស់អ៊ីស្រាអែលក្នុងកាលពេលចេញដំណើរពីស្រុកអេស៊ីព្ទ ។

**១២:១៤** *ទីរហោស្ថាន* មើលការពន្យល់ ខ.៦ ។ *១ខួប ២ខួប ហើយកន្លះខួបផង* មើលការពន្យល់ ១១:២ ។

**១២:១៦** *ផែនដីបានជួយនាង ដោយហាឡើង* មើល ជន ១៦:៣០-៣៣ ដែលនិយាយអំពីព្រឹត្តិការណ៍នៃដីហារឡើងលេបពួកកូនចៅកូរេ ។

**១២:១៧** *សំណល់ពូជនាងទាំងប៉ុន្មាន* គឺសំដៅទៅលើអ្នកជឿព្រះក្រៅពីព្រះគ្រីស្ទ (ក្រៅពីកូនប្រុស ខ.៥,១៣)។ *មានសេចក្ដីបន្ទាល់ពីព្រះយេស៊ូវ* នេះគឺជាបន្ទាល់ពីកំណើតរបស់ព្រះយេស៊ូវ(១:២,៩ ១៩:១០)។

**១៣:១** *សត្វសាហាវ១ឡើងចេញពីសមុទ្រមក* យើងឃើញពាក្យនេះដំបូងនៅក្នុង១១:៧ ។ចំពោះសត្វសាហាវនេះមានមតិប្លែកៗពីគ្នាជាច្រើនថាវាជានិមិត្តរូបនៃចក្រភពរ៉ូម៉ាំងដែលបានគំរាមកំហែងពិភពលោក ខ្លះថា វាជានិមិត្តរូបនៃពួកអ្នក ប្រឆាំងនឹងព្រះគ្រីស្ទនៅថ្ងៃចុងក្រោយ ហើយខ្លះទៀតថាវាជានិមិត្តរូបនៃពួកអ្នកមានអំណាចនយោបាយ (ពួកចក្រភពរ៉ូម៉ាំង) បានគាបសង្កត់លើគ្រីស្ទបរិស័ទ តាមវិធីផ្សេងៗជាច្រើននៅក្នុងសម័យលោកយ៉ូហាន ហើយបន្តរហូតដល់បច្ចុប្បន្ននេះ (មើលពន្យល់ ១៤:៨)។ ចំណុចនេះមើលទៅហាក់បីដូចជាដកស្រង់ចេញពីនិម្មិតរបស់លោកដានីយ៉ែលអំពីសត្វដ៏សាហាវទាំងបួន(ដយ ៧:២-៧)។ មើល ១៧:៨-១១ ដែលបានបកស្រាយពន្យល់អំពីសត្វសាហាវ ។ *មានស្នែង១០* មើល ១៧:១២ ។ *មានឈ្មោះជាពាក្យប្រមាថ* ពួករ៉ូម៉ាំងបានព្យាយាមប្រើព្រះនាមនៃព្រះ ។

**១៣:២** *ខ្លារខិន . . . ខ្លាឃ្មុំ . . . សិង្ហ* សត្វសាហាវដែលយ៉ូហានបាននិយាយនៅត្រង់នេះ គឺត្រូវបានភ្ជាប់ជាមួយនឹងចរិតលក្ខណៈនៃសត្វសាហាវទាំងបួនដែលបាននិយាយនៅក្នុងគម្ពីរដានីយ៉ែល(ដយ ៧:៤-៦)។

**១៣:៣** *របួសដល់ស្លាប់នោះបានសះជាឡើងវិញ* ត្រង់នេះចង់បញ្ជាក់ពីអំណាចនៃការប្រោសលោះដ៏អស្ចារ្យ ។ *ផែនដីក៏អស្ចារ្យ* មើល ១៧:៨ ការ

ផែនដីក៏អស្ចារ្យ[ង]នឹងសត្វនោះ ៤ គេក្រាបថ្វាយបង្គំដល់នាគ
ដែលឱ្យសត្វនោះមានអំណាច ព្រមទាំងក្រាបថ្វាយបង្គំដល់
សត្វនោះដែរ ដោយនិយាយថា តើមានអ្នកណាដូច[ឈ]សត្វ
នេះ មានអ្នកឯណាដែលអាចច្បាំងនឹងវាបាន ៥ នាគក៏ឱ្យវា
មានមាត់ចេះនិយាយជាពាក្យសំដីដ៏ធំ នឹងពាក្យប្រមាថ[ញ]
ក៏ឱ្យមានអំណាចនឹងធ្វើការវា ក្នុងរវាង៤២ខែ[ដ] ៦ វាបើក
មាត់ ប្រមាថដល់ទាំងព្រះ និងព្រះនាម ហើយព្រះវិហារនៃ
ទ្រង់ដែរ ព្រមទាំងដល់ពួកអ្នកដែលនៅស្ថានសួគ៌ផង[ឋ] ៧ ក៏
មានអំណាចបានប្រគល់ដល់វា ឱ្យច្បាំង[ឌ]ឈ្នះពួកបរិសុទ្ធ
បាន ហើយនិងអំណាចលើគ្រប់ទាំងពូជមនុស្ស គឺអស់ទាំង
គ្រួសារ និងភាសា ហើយនិងអស់ទាំងសាសន៍ផង[ឍ] ៨ ឯ
អស់មនុស្សទាំងប៉ុន្មាននៅផែនដី[ណ] ដែលគ្មានឈ្មោះកត់ទុក
ក្នុងបញ្ជីជីវិត[ត]របស់កូនចៀម[ថ] ដែលត្រូវគេសំឡាប់ តាំងពី
កំណើតលោកិយមក[ទ] នោះនឹងក្រាបថ្វាយបង្គំចំពោះសត្វ
នោះ ៩ បើអ្នកណាមានត្រចៀកឱ្យអ្នកនោះស្តាប់ចុះ[ធ] ១០ បើ
អ្នកណាដឹកនាំគេឱ្យទៅជាឈ្លើយ អ្នកនោះឯងនឹងត្រូវគេ
ដឹកនាំខ្លួនទៅជាឈ្លើយដែរ បើអ្នកណាកាប់សំឡាប់គេ
ដោយដាវ នោះនឹងត្រូវស្លាប់ដោយដាវដែរ[ន] នេះហើយជា
សេចក្តីអត់ធ្មត់[ប] និងសេចក្តីជំនឿរបស់ពួកបរិសុទ្ធ[ផ]។

**១៣:៣** ដ វវ ១៧:៨
**១៣:៤** ឈ នក ១៥:១១
**១៣:៥** ញ ដយ ៧:៨,១១,២០,២៥ ១១:៣៦ ២ថន ២:៤ ដ វវ ១១:២
**១៣:៦** ឋ វវ ១២:១២
**១៣:៧** ឌ ដយ ៧:២១ វវ ១១:៧ ឍ វវ ៥:៩ ៧:៩ ១០:១១ ១៧:១៥
**១៣:៨** ណ ខ.១២, ១៤ វវ ៣:១០ ត វវ ២០:១២ ថ យហ ១:២៩ ទ មថ ២៥:៣៤
**១៣:៩** ធ វវ ២:៧
**១៣:១០** ន យរ ១៥:២ ៤៣:១១ ប ហព ៦:១២ ផ វវ ១៤:១២
**១៣:១១** ព ខ.១,២ ភ វវ ១៦:១៣
**១៣:១២** ម ខ.៤ យ ខ.១៤ វវ ១៩:២០

## សត្វសាហាវឡើងចេញពីដី

១១ ខ្ញុំក៏ឃើញសត្វសាហាវ១ទៀត ឡើងចេញពីដីមក[ព] វា
មានស្នែង២ ដូចជាកូនចៀម តែពោលពាក្យដូចជានាគ
វិញ[ភ] ១២ ក៏ប្រព្រឹត្តដោយនូវគ្រប់ទាំងអំណាច[ម]របស់សត្វទី១
នៅមុខនាគនោះ[យ] ទាំងបណ្តាលឱ្យផែនដី និងអស់អ្នកដែល
នៅផែនដីបានក្រាបថ្វាយបង្គំ ដល់សត្វទី១[រ] ដែលមានរបួស
ដល់ស្លាប់នោះ តែបានសះជាវិញនោះផង[ល] ១៣ វាក៏ធ្វើទី
សំគាល់យ៉ាងធំ[វ] ដល់ម៉្លេះបានជាធ្វើឱ្យធ្លាក់ទាំងភ្លើង ពី
លើមេឃ[ស]មកលើផែនដី នៅមុខមនុស្សលោកផង ១៤ វា
បញ្ឆោតពួកមនុស្សនៅផែនដីដោយសារទីសំគាល់[ហ] ដែល
វាមានអំណាចនឹងធ្វើ នៅមុខសត្វនោះ ក៏ប្រាប់[ឡ]ដល់ពួកអ្នក
នៅផែនដី[អ] ឱ្យធ្វើរូបសត្វនោះ ដែលត្រូវរបួសនឹងដាវ តែ
បានរស់វិញដែរ[ក] ១៥ ក៏មានអំណាចបានប្រគល់ឱ្យវា និងធ្វើ
ឱ្យរូបសត្វនោះមានខ្យល់ដង្ហើម ដើម្បីឱ្យបានចេះនិយាយ
ហើយអំណាចនឹងធ្វើឱ្យពួកអ្នក ដែលមិនព្រមក្រាបថ្វាយ
បង្គំ[ខ]រូបសត្វនោះ ត្រូវស្លាប់ផង[គ] ១៦ វាក៏បង្ខំមនុស្សទាំងអស់
ទាំងធំ ទាំងតូច[ឃ] ទាំងមាន ទាំងក្រ ហើយទាំងអ្នកជា និង

រ ខ.១៥ វវ ១៤:៩,១១ ១៦:២ ១៩:២០ ២០:៤ ល ខ.៣
**១៣:១៣** វ មថ ២៤:២៤ ស ១ពវ ១៨:៣៨ ២ពវ ១:១០ លក ៩:៥៤ វវ ២០:៩ **១៣:១៤** ហ ២ថន ២:៩,១០ ឡ វវ ១២:៩ អ វវ ៣:១០ ក ខ.៣,១២ **១៣:១៥** ខ ខ.១២ គ ដយ ៣:៣–៦ **១៣:១៦** ឃ វវ ១៩:៥

ដែលមានប្រតិកម្មដូចដើមឡើងវិញ ។

**១៣:៥** *ឱ្យវាមាន* ភាសាក្រិកពាក្យនេះមានប្រើបួនដងក្នុងខ.៥–៧ ដែលមានទម្រង់ជាកិរិយាអកម្ម ដែលបញ្ជាក់ពីតួនាទីរបស់សត្វសាហាវនេះ ស្ថិតនៅក្រោមអំណាចអ្វីមួយ(ខ.២,៤)។ ចំណុចនេះចង់បញ្ជាក់ថា សូម្បីតែសត្វដ៏សាហាវនេះ ក៏ត្រូវការគេផ្តល់អំណាចឱ្យវាដែរ ។ អំណាចដ៏ធំបំផុត ហើយអស់កល្បនោះគឺជារបស់ព្រះ (ខ.២,៤)។ *៤២ខែ* មើលពន្យល់ ១១:២ ។

**១៣:៧** *ឱ្យច្បាំងឈ្នះ* មើល ១២:១៧ ដយ ៧:៧ ។

**១៣:៨** *បញ្ជីជីវិត* មើលការពន្យល់ ៣:៥ ២០:១២,១៥ ។ *កូនចៀមដែលត្រូវគេសំឡាប់* មើលការពន្យល់ ៥:៦ អស ៥៣:៧ យហ ១:២៩,៣៦ ។ *តាំងពីកំណើតលោកីយមក* ការសុគតរបស់ព្រះយេស៊ូវគឺជាព្រឹត្តិការណ៍នៃសេចក្តីសង្គ្រោះមួយដែលត្រូវបានសម្រេចតាំងពីអស់កល្បមក(១៧:៨)។

**១៣:១១** *សត្វសាហាវ១ទៀតឡើងចេញពីដីមក* នៅត្រង់នេះមានអ្នកខ្លះថា វាជានិមិត្តរូបពីអំណាចខាងសាសនា ដែលកំពុងតែបម្រើប្រយោជន៍ឱ្យលោកិយ ។ មានអ្នកខ្លះទៀតថា វាជាហោរាក្លែងក្លាយ (១៦:១៣ ១៩:២០ ២០:១០)។ *ស្នែង២ដូច ជាកូនចៀម* មានន័យថា សត្វនេះវាប៉ុនប៉ងធ្វើខ្លួនរបស់វាឱ្យដូចសត្វមួយដែលចរិតស្លូតបូត ហើយនិងគ្មានគ្រោះថ្នាក់ដល់អ្នកដទៃ ។ *ពោលពាក្យដូចជានាគ* ឃ្លាននេះជាប់ទាក់ទងទៅនឹងសេចក្តីព្រមានរបស់ព្រះយេស៊ូវ ឱ្យប្រយ័ត្ននឹងឆ្កែចចកដ៏ស្រេកឃ្លានមួយហ្វូងបានពាក់រោមចៀមបន្លំចូលមកហើយ(មថ ៧:១៥)។

**១៣:១២** *ក៏ប្រព្រឹត្តដោយនូវគ្រប់ទាំងអំណាចរបស់សត្វទី១* ត្រង់នេះបានបង្ហាញអំពីត្រៃឯកនៃវិញ្ញាណអាក្រក់ ។ សត្វសាហាវទី១គឺនៅលើគោកដែលមានអំណាចនៅក្រោមសត្វសាហាវទី២មកពីសមុទ្រ ហើយសត្វសាហាវទី៣ដែលជាសត្វចុងក្រោយគេនោះ គឺជាសត្វនាគនេះឯង ។ សាតាំង អំណាចលោកិយ និងសាសនានានា(ឬថា សាតាំង ពួកអ្នកប្រឆាំងនឹងព្រះគ្រីស្ទ និងពួកហោរាក្លែងក្លាយ)បានព្រមព្រៀងរួមគ្នាទាស់ប្រឆាំងនឹងព្រះដែលមានៈព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ ។

**១៣:១៣** *ទីសំគាល់យ៉ាងធំ* មើលការព្រមាននៅក្នុង ចទ ១៣:១–៣ មថ ២៤:២៤ ២ថន ២:៩ វវ ១៩:២០។ *ភ្លើងពីលើមេឃ* មើលការពន្យល់ ១ពវ ១៨:២៤–៣៩។

**១៣:១៤** *ឱ្យធ្វើរូបសត្វនោះ* មើល ដយ ៣:១–១១ ២ថន ២:៤ ។

**១៣:១៥** *ឱ្យបានចេះនិយាយ* មានជំនឿមួយជឿថា រូបចម្លាក់អាចនិយាយបានដែលត្រូវបានគេបង្ហាញភស្តុតាងជាទូទៅ តាមឯកសារពីបុរាណកាល ។ ដូចជាការនិយាយមិនកំរើកបបូរមាត់ ហើយតាមរបៀបបន្លំផ្សេងៗទៀតជាច្រើន ។

**១៣:១៦** *ទីសំគាល់* ដើមកំណើតនៃពាក្យនេះមកពីការធ្វើសញ្ញាសំគាល់នៅលើប្រភេទមនុស្សដូចជាៈ ពួកទាសករ ឬពួកទាហាន ហើយក៏មានអ្នកខ្លះក៏បានបោះត្រាលើឯកសារ ឬធ្វើសញ្ញាឈើឆ្កាងនៅលើថ្ងាសដល់អ្នកជឿថ្មីជាផ្លូវការ ។ ទីសំគាល់ ឬផ្លាកសញ្ញារបស់សត្វសាហាវនេះ គឺជានិមិត្តរូបនៃភក្តីភាពចំពោះការថ្វាយបង្គំដល់អារក្សសាតាំង ។ ពួកអ្នកប្រឆាំងនឹងត្រូវបានធ្វើការសាកល្បង អំពីភាពស្មោះត្រង់របស់ខ្លួន នៅថ្ងៃចុងក្រោយបំផុត

បាវគេ ឱ្យទទួលទីសំគាល់នៅដៃស្តាំ ឬនៅថ្ងាសគេរៀង
ខ្លួន[ង] ១៧ហើយមិនបើកឱ្យអ្នកណាមានច្បាប់នឹងទិញ ឬលក់
អ្វីបានឡើយ លើកតែអ្នកដែលមានទីសំគាល់នោះចេញ[ច]
គឺជាឈ្មោះរបស់សត្វនោះ ឬជាលេខឈ្មោះរបស់វា[ឆ]
១៨នេះហើយជាប្រាជ្ញា[ជ] អ្នកណាដែលមានយោបល់ ឱ្យអ្នក
នោះរាប់លេខ[ឈ] នៃសត្វនោះចុះ ដ្បិតលេខនោះជាលេខ
របស់មនុស្ស គឺ៦៦៦ ។

## កូនចៀម និងមនុស្សទាំង១សែន៤ម៉ឺន៤ពាន់នាក់

**១៤** ១ខ្ញុំក្រឡេកទៅឃើញកូនចៀម[ញ] ឈរនៅលើភ្នំ
ស៊ីយ៉ូន[ដ] ហើយមានមនុស្ស១សែន៤ម៉ឺន៤ពាន់នាក់[ឋ] ដែល
មានព្រះនាមទ្រង់ នឹងព្រះនាមព្រះវរបិតាទ្រង់[ឌ]កត់លើ
ថ្ងាស[ឍ] គេបានឈរជាមួយដែរ ២រួចខ្ញុំឮសំឡេងមកពីលើ
មេឃ ដូចជាសូរទឹកច្រើន[ណ] ហើយដូចផ្គរលាន់យ៉ាងខ្លាំង[ត]
រីឯសំឡេងដែលខ្ញុំឮនោះ ក៏ដូចជាសូរសព្ទរបស់ពួកជន្ត្រី
ដែលកំពុងតែចាប់ស៊ុង[ថ] ៣គេច្រៀងបទ១ថ្មី[ទ] នៅមុខបល្ល័ង្ក
ហើយមុខតួមានជីវិតទាំង៤[ធ] នឹងពួកចាស់ទុំដែរ[ន] គ្មានអ្នក
ណាអាចនឹងរៀនបទនោះបានទេ មានតែមនុស្ស១សែន៤
ម៉ឺន៤ ពាន់នាក់[ប] ដែលទ្រង់លោះពីផែនដីចេញប៉ុណ្ណោះ
៤នោះជាពួកព្រហ្មចារី[ផ] ដែលមិនបានបង្ខូចខ្លួននឹងស្រី
ឡើយ គេតាមកូនចៀមទៅគ្រប់កន្លែងដែលទ្រង់យាងទៅ[ព]

**១៣:១៦** ង វវ ៧:៣ ១៤:៩ ២០:៤ **១៣:១៧** ច វវ ១៤:៩ ឆ ខ.១៨ វវ ១៤:១១ ១៥:២ **១៣:១៨** ជ វវ ១៧:៩ ឈ វវ ១៥:២ ២១:១៧ **១៤:១** ញ វវ ៥:៦ ដ ទដ ២:៦ ហព ១២:២២ ឋ ខ.៣ វវ ៧:៤ ឌ វវ ៣:១២ ២២:៤ ឍ វវ ៧:៣ **១៤:២** ណ វវ ១:១៥ ត វវ ៦:១ ថ វវ ៥:៨ ១៥:២ **១៤:៣** ទ វវ ៥:៩ ធ វវ ៤:៦ ន វវ ៤:៤ ប ខ.១ **១៤:៤** ផ ២កថ ១១:២ វវ ៣:៤ ព វវ ៧:១៧ ភ វវ ៥:៩ ម យរ ២:៣ យក ១:១៨ **១៤:៥** យ ទដ ៣២:២ សផ ៣:១៣

ទ្រង់បានលោះគេចេញពីពួកមនុស្សលោក[ភ] ទុកជាផ្លែដំបូង[ម]
ថ្វាយដល់ព្រះ ហើយនឹងកូនចៀម ៥មិនឃើញមានសេចក្តី
ភូតភរ នៅក្នុងមាត់គេឡើយ[យ] ដ្បិតគេឥតសៅហ្មង[រ] ។

## ទេវតាទាំងបី

៦ខ្ញុំក៏ឃើញទេវតា ១ ទៀត កំពុងហោះកាត់កណ្តាល
មេឃ[ល] ទាំងមានដំណឹងល្អដ៏នៅអស់កល្បជានិច្ច សំរាប់
នឹងថ្លែងប្រាប់ដល់មនុស្សនៅផែនដី[វ] គឺដល់គ្រប់អស់ទាំង
សាសន៍ គ្រប់ពូជអំបូរ គ្រប់ភាសា ហើយគ្រប់ទាំងគ្រួសារ
ដែរ[ស] ៧ទេវតានោះបន្លឺសំឡេងយ៉ាងខ្លាំងថា ចូរកោត
ខ្លាចដល់ព្រះ[ហ] ហើយសរសើរសិរីល្អរបស់ទ្រង់ចុះ[ឡ] ដ្បិត
ពេលដែលទ្រង់ត្រូវជំនុំជំរះ នោះបានមកដល់ហើយ ចូរ
ក្រាបថ្វាយបង្គំដល់ព្រះដ៏បង្កើត[អ]ផ្ទៃមេឃ ផែនដី សមុទ្រ
នឹងរន្ធទឹកទាំងប៉ុន្មានចុះ[ក]។
៨មានទេវតា ១ទៀតមកតាមក្រោយប្រាប់ថា ក្រុង
បាប៊ីឡូនដ៏ជាធំ[ខ] បានរលំហើយ បានរលំហើយ ដ្បិតវាបាន
ឱ្យគ្រប់ទាំងសាសន៍ផឹកស្រានៃសេចក្តីឃោរឃៅរបស់ការ

យហ ១:៤៧ ១ពត ២:២២ រ អភ ៥:២៧ **១៤:៦** ល វវ ៨:១៣ ១៩:១៧ វ វវ ៣:១០ ស វវ ១៣:៧ **១៤:៧** ហ ទដ ៣៤:៩ វវ ១៥:៤ ឡ វវ ១១:១៣ អ វវ ១០:៦ ក វវ ៨:១០ ១៦:៤ **១៤:៨** ខ អស ២១:៩ យរ ៥១:៨ វវ ១៦:១៩ ១៧:៥ ១៨:២,១០

(ខ.១៧ ១៤:៩,១១ ១៥:២ ១៦:២ ១៩:២០ ២០:៤) ដោយយកតម្រាប់តាមគំរូអ្នកបម្រើរបស់ព្រះនៅក្នុងជំពូក៧ ។

**១៣:១៧** *ទិញ ឬលក់* ត្រង់នេះគឺជាការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច ដើម្បីប្រឆាំងនឹងសេចក្តីជំនឿរបស់អ្នកជឿ ។ *ជាឈ្មោះរបស់សត្វនោះ* នៅសម័យបុរាណតួនៃអក្ខរក្រមត្រូវបានជំនួសដោយតួលេខផងដែរ ។ អត្ថន័យក្នុងការដាក់ឈ្មោះមនុស្ស ក៏ត្រូវបានគេនិយមប្រើជាចំនួនលេខនោះផងដែរ ។

**១៣:១៨** *៦៦៦* លេខនេះគឺជាវិធីផ្សេងៗជាច្រើនសម្រាប់បកស្រាយលទ្ធផលនៃតួលេខរបស់ឈ្មោះមនុស្ស ដូចជាឈ្មោះអើអានថាស ឡាថៃនណូស និងនេរ៉ូសេសា (Euanthas, Lateinos, and Nero Caesar ) ។ មានអ្នកខ្លះទៀតបានចាត់ទុកលេខ ៦៦៦ ថាជានិមិត្តនៃត្រៃឯកខាងឯវិញ្ញាណអាក្រក់ ហើយនិងភាពមិនគ្រប់លក្ខណ៍ ព្រោះតួលេខនីមួយៗមិនគ្រប់ចំនួន លេខដែលគ្រប់លក្ខណ៍នោះគឺលេខ៧ ។

**១៤:១** *កូនចៀម* មើលការពន្យល់ ៥:៦ ។ *ភ្នំស៊ីយ៉ូន* នៅក្នុងគម្ពីរសញ្ញាចាស់បានឱ្យដឹងថា ទីកន្លែងនោះគឺជាបន្ទាយដំបូងរបស់អ៊ីស្រាអែល មុនការចាប់ផ្តើមក្រុងយេរូសាឡិម (២សយ ៥:៧) ដែលត្រូវបានវាយដណ្តើមយកដោយស្តេចដាវីឌ ហើយបានស្ថាបនាជាទីក្រុងសម្រាប់ព្រះអង្គផ្ទាល់ ។ ក្រោយមកទីក្រុងនេះក៏បានក្លាយជាមូលដ្ឋានសំខាន់សម្រាប់ក្រុងយេរូសាឡិម ។ ក្នុងគម្ពីរវិវរណៈ និងគម្ពីរហេព្រើរត្រង់នេះ "១២:២២–២៤" គឺនិយាយអំពីក្រុងយេរូសាឡិមនៅឯស្ថានសួគ៌ ដែលជាដំណាក់ដ៏អស់កល្បជានិច្ចរបស់ព្រះ និងរាស្ត្ររបស់ទ្រង់ (កទ ៤:២៦) ជាទីក្រុងយេរូសាឡិមនៅឯស្ថានសួគ៌ចុះមកតាំងលើផែនដីថ្មី (២១:២–៣) ។ *១សែន៤ ម៉ឺន៤ពាន់នាក់* មើលការពន្យល់ ៧:៤ ។ *ព្រះនាម* ត្រង់នេះផ្ទុយនឹង ១៣:១៦–១៨។

**១៤:២** *ស៊ុង* មើលការពន្យល់ ៥:៨ ។

**១៤:៣** *ច្រៀងបទ១ថ្មី* និយាយអំពីការប្រោសលោះ (មើលពន្យល់ ៥:៩) ។

**១៤:៤** *ពួកព្រហ្មចារីដែលមិនបានបង្ខូចខ្លួននឹងស្រី* ត្រង់នេះប្រហែលជានិមិត្តរូប នៃការពណ៌នាពីពួកអ្នកជឿ ដែលនៅតែរក្សាខ្លួនប្រាណរបស់ពួកគេបានយ៉ាងល្អដោយមិនជាប់ប្រឡាក់នឹងព្រះដទៃនៃលោកិយនេះឡើយ។ *តាមកូនចៀម* គឺនិយាយពីការដើរតាមសិស្សរបស់ទ្រង់ (មថ ១៩:២១ មក ៨:៣៤) ។ *ជាផលដំបូង* មើល លវ ២៣:៩-១៤ ។ ពាក្យនេះប្រើនៅក្នុងគម្ពីរសញ្ញាថ្មី គឺសម្រាប់ប្រៀបធៀបចំពោះអ្នកជឿដំបូងគេនៅទីកន្លែងណាមួយ (រម ១៦:៥) និងអ្នកដែលរស់ពីស្លាប់ឡើងវិញដំបូងគេ (១កថ ១៥:២០) ។ នៅក្នុងគម្ពីរវិវរណៈអ្នកជឿទាំងអស់ ត្រូវបានចាត់ទុកថា ជាជម្រើសមួយទុកជាដង្វាយថ្វាយដល់ព្រះ និងកូនចៀម ។

**១៤:៥** *មិនឃើញមានសេចក្តីភូតភរ* ត្រង់នេះគឺផ្ទុយនឹង ១:២៥ ២ថន ២:៩–១២ និងការពន្យល់ ២:១១ អស ៥៣:៩ ។

**១៤:៦** *ដំណឹងល្អ. . .ជានិច្ច* បរិបទនៃ "ដំណឹងល្អ" ប្រហែលជាមាននៅក្នុង ខ.៧ ។

**១៤:៧** *ព្រះដ៏បង្កើតផ្ទៃមេឃ* មើល នក ២០:១១ ទដ ១៤៦:៦ ។

**១៤:៨** *ក្រុងបាប៊ីឡូនដ៏ជាធំ* ជាទីក្រុងមួយក្នុងស្រុកម៉េសូប៉ូតាមៀ (Mesopotamia ) ដែលជាមជ្ឈមណ្ឌលនយោបាយ ពាណិជ្ជកម្ម និងសាសនារបស់

កំផិតខ្លួន[គ]។
៩រួចមានទេវតាទី៣មកតាមក្រោយទៀត ទាំងបន្លឺដោយ
សំឡេងយ៉ាងខ្លាំងថា បើអ្នកណាក្រាបថ្វាយបង្គំដល់សត្វ
នោះ[ឃ] នឹងរូបវា[ង] ហើយទទួលទីសំគាល់វានៅលើថ្ងាស[ច]
ឬនៅដៃ ១០អ្នកនោះនឹងត្រូវផឹកស្រាផងសេចក្ដីឃោរឃៅ
របស់ព្រះ[ឆ] ជាស្រាឥតលាយ ដែលចាក់ទៅក្នុងពែងនៃ
សេចក្ដីក្រោធរបស់ទ្រង់[ជ] ព្រមទាំងត្រូវរងទុក្ខវេទនា នៅ
ក្នុងភ្លើង នឹងស្ពាន់ធ័រ[ឈ] ចំពោះមុខនៃពួកទេវតាបរិសុទ្ធ នឹង
កូនចៀមផង ១១ឯផ្សែងនៃសេចក្ដីទុក្ខលំបាករបស់គេ នឹង
ហុយឡើងអស់កល្បជានិច្ចរៀងរាបតទៅ[ញ] គេនឹងឥតមាន
សេចក្ដីស្រាកស្រាន្តឡើយ ទាំងយប់ទាំងថ្ងៃ[ដ] គឺពួកអ្នកដែល
ក្រាបថ្វាយបង្គំដល់សត្វនោះ នឹងរូបវា[ឋ] ឬអ្នកណាដែល
ទទួលទីសំគាល់នៃឈ្មោះវាផង[ឌ] ១២នេះហើយជាសេចក្ដី
អត់ធ្មត់[ឍ]របស់ពួកបរិសុទ្ធ[ណ]ដែលកាន់តាមបញ្ញត្ត[ត]របស់ព្រះ
ហើយមានសេចក្ដីជំនឿដល់ព្រះយេស៊ូវ ។
១៣ខ្ញុំក៏ឮសំឡេងពីលើមេឃថា ចូរកត់ទុកដូច្នេះថា ពី
នេះទៅមុខ អស់អ្នកណាដែលស្លាប់ក្នុងព្រះអម្ចាស់[ថ] នោះ
មានពរហើយ ព្រះវិញ្ញាណទ្រង់មានបន្ទូល[ទ]ថា ហ្នឹង
ហើយ គឺដើម្បីឱ្យគេបានឈប់សំរាក ពីគ្រប់ទាំងការនឿយ
ហត់របស់គេ ដ្បិតការគេធ្វើ ក៏តាមគេជាប់។

## ចម្រូតនៅផែនដី

១៤នោះខ្ញុំក្រឡេកឃើញពពកស១[ធ]ហើយមាន១អង្គ ដូច
ជាកូនមនុស្ស[ន] គង់នៅលើពពកនោះ ទាំងពាក់មកុដមាស[ប]
ហើយកាន់កណ្ដៀវដ៏មុត ១៥រួចមានទេវតា១ ទៀតចេញពី
ព្រះវិហារមក[ផ] បន្លឺដោយសំឡេងយ៉ាងខ្លាំង ដល់ព្រះអង្គ
ដែលគង់លើពពកថា សូមលូកកណ្ដៀវទ្រង់ទៅច្រូតចុះ[ព]
ដ្បិតជាវេលាត្រូវច្រូតហើយ[ភ] ពីព្រោះនៅផែនដីបានទុំជា
ស្រេច ១៦នោះព្រះអង្គ ដែលគង់នៅលើពពកទ្រង់លូក
កណ្ដៀវទៅឯផែនដី ដូច្នេះ ផែនដីក៏បានច្រូតរួចហើយ ។
១៧រួចមានទេវតា១ទៀត ចេញពីព្រះវិហារនៅស្ថាន
សួគ៌មក ទាំងកាន់ថែយ៉ាងមុតដែរ[ម] ១៨ហើយមានទេវតា១
ទៀត ដែលមានអំណាចលើភ្លើង ក៏ចេញពីអាសនាមក[យ]
បន្លឺដោយសំឡេងយ៉ាងខ្លាំង ដល់ទេវតាដែលកាន់ថែដ៏មុត

**១៤:៨** គ វវ ១៧:២,៤ ១៨:៣,៩
**១៤:៩** ឃ វវ ១៣:១២ ង វវ ១៣:១៤ ច វវ ១៣:១៦
**១៤:១០** ឆ អស ៥១:១៧ យរ ២៥:១៥ ជ យរ ៥១:៧ វវ ១៨:៦ ឈ វវ ៩:១៧
**១៤:១១** ញ អស ៣៤:១០ វវ ១៩:៣ ដ វវ ៤:៨ ឋ ខ.៩ វវ ១៣:១២ ឌ វវ ១៣:១៧
**១៤:១២** ឍ ហព ៦:១២ ណ វវ ១៣:១០ ត យហ ១៤:១៥
**១៤:១៣** ថ ១កថ ១៥:១៨ ១ថន ៤:១៦

ទ វវ ២:៧ ២២:១៧ **១៤:១៤** ធ មថ ១៧:៥ ន ដយ ៧:១៣ វវ ១:១៣
ប វវ ៦:២ **១៤:១៥** ផ ខ.១៧ វវ ១១:១៩ ព ខ.១៨ យអ ៣:១៣ មក ៤:២៩
ភ យរ ៥១:៣៣ **១៤:១៧** ម ខ.១៥ **១៤:១៨** យ វវ ៦:៩ ៨:៥ ១៦:៧

ពិភពលោក ។ ទីក្រុងនេះត្រូវបានគេសំគាល់ថា ជាទីក្រុងល្អប្រណិត តែមានភាពអាប់ឱនផ្នែកសីលធម៌ ។ ទីក្រុងតូចនេះមានងារថា “បាប៊ីឡូនដ៏ធំ” ត្រូវបានគេដកស្រង់ចេញពី ដយ ៤:៣០ ។ យោងតាមមតិខ្លះថា ទីក្រុងនេះត្រូវបាន គេប្រើនៅក្នុងគម្ពីរវិវរណៈ “១៦:១៩ ១៧:៥ ១៨:២,១០,២១”ត្រង់នេះសំដៅទៅលើក្រុងរ៉ូម ដែលជាចំណុចសំខាន់នៃការប្រឆាំងនឹងព្រះ ហើយនិងរាស្ត្ររបស់ទ្រង់ ។ តែមានមតិខ្លះទៀតថា ទីក្រុងនេះតំណាងឱ្យប្រព័ន្ធនយោបាយ និងសាសនានៃពិភពលោក ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកអ្នកប្រឆាំងនឹងព្រះគ្រីស្ទ(មើលការពន្យល់ ១៣:១)។ នៅមានមតិផ្សេងៗដទៃទៀតបានយល់ថា ឈ្មោះទីក្រុងនេះបានធ្វើឱ្យយើងយល់ពីន័យរបស់ពាក្យនេះថា ស្អាងឡើងវិញ និងកសាងឡើងវិញ ។ ការធ្លាក់ចុះរបស់ក្រុងបាប៊ីឡូនគឺត្រូវប្រកាសនៅក្នុង អស ២១:៩ យរ ៥១:៨ ។ *ស្រានៃសេចក្ដីឃោរឃៅរបស់ការកំផិតខ្លួន* ពាក្យនេះសំដៅទៅលើក្រុងបាប៊ីឡូន(ឬក្រុងរ៉ូម) គឺជារូបភាពដូចជាស្ត្រីពេស្យាដែលជាការរួមភេទខុសសីលធម៌ គឺបានធ្វើឱ្យសម្រេចដោយគ្រឿងស្រវឹង (មើលការពន្យល់ នក ៣៤:១៥)។

**១៤:១០** *ពែងនៃសេចក្ដីក្រោធ* នៅក្នុងគម្ពីរសញ្ញាចាស់ពែងនៃ សេចក្ដីក្រោធនៃព្រះត្រូវបានគេបង្ហាញជារូបភាពមួយដ៏សាមញ្ញថា ជាពែងស្រាដែលអាចធ្វើឱ្យស្រវឹងបាន (ទដ ៧៥:៨ អស ៥១:១៧ យរ ២៥:១៥)។ ចំណុចនេះពុំមែននិយាយត្រង់ៗ ចំពោះការដាក់ទោសដោយច្បាប់នោះទេ ប៉ុន្តែ ជាការឆ្លើយតបរបស់ព្រះដ៏សុចរិត ចំពោះអស់អ្នកណាដែលបានបដិសេធព្រះគុណ និងសេចក្ដីស្រឡាញ់របស់ទ្រង់ ។ *ក្នុងភ្លើង និងស្ពាន់ធ័រ* គឺសំដៅទៅលើព្រឹត្តិការណ៍នៃការ បំផ្លាញក្រុងសូដុំម និងកូម៉ូរ៉ាដោយសារការបង្អុរភ្លៀងជាស្ពាន់ធ័រ និងភ្លើង( លប ១៩:២៤)។ ក្នុងគម្ពីរ ទដ ១១:៦ បាននិយាយពីជោគវាសនាមួយស្រដៀងនឹង ហេតុការណ៍នេះមកលើមនុស្សអាក្រក់ ។ ហេតុការណ៍បែបនេះមានកត់ចុះនៅ កន្លែងផ្សេងៗទៀតក្នុងគម្ពីរសញ្ញាចាស់និងក្នុងជំពូកចុងក្រោយនៃគម្ពីរវិវរណៈនេះផងដែរ (វវ ១៩:២០ ២០:១០ ២១:៨)។

**១៤:១១** *សេចក្ដីទុក្ខលំបាក . . . អស់កល្បជានិច្ច* ត្រង់នេះគឺជាសេចក្ដីទុក្ខលំបាកចុងក្រោយបំផុតសម្រាប់មនុស្សអាក្រក់(១៩:២០ ២០:១០)។

**១៤:១៣** *មានពរហើយ* នេះគឺជាសុភមង្គលទីពីរ (មើលការពន្យល់ ១:៣)។

**១៤:១៤** *គង់នៅលើពពក* មើល មថ ១៧:៥ និងការពន្យល់ មថ ២៤:៣០ ។ *កូនមនុស្ស* មើល ១:១៣ និងការពន្យល់ ដយ ៧:១៣ មក ៨:៣១ ។ *មកុដ–មាស* គឺជាមកុដនៃជ័យជម្នះធ្វើអំពីមាស(មើលការពន្យល់ ២:១០ សម្រាប់ការប្រៀបធៀបរវាងមកុដជ័យជម្នះ និងមកុដស្ដេច ។ *កណ្ដៀវ* នៅស្រុកអ៊ីស្រាអែលកណ្ដៀវត្រូវបានគេធ្វើអំពីថ្មរឹងម្យ៉ាងពណ៌ប្រផេះ ឬអំពីដែកមានរាងសំប៉ែត កុក មានដង ធ្វើអំពីឈើ ឬឆ្អឹង សម្រាប់កាត់ ឬច្រូតពពួកធញ្ញជាតិ(មានស្រូវ ស្មៅជាដើម)។

**១៤:១៥** *ច្រូត . . . នៅផែនដីបានទុំជាស្រេច* ជានិមិត្តរូបទូទៅនៃដំណើរចូលមកនៃការជំនុំជម្រះ(មថ ១៣:៣០,៤០–៤២)។ អ្នកបកស្រាយគម្ពីរខ្លះគិតថា ឃ្លានេះសំដៅលើការប្រមូលផ្ដុំនៃមនុស្សសុចរិត នៅពេលព្រះគ្រីស្ទយាងមកម្ដងទៀត ។

**១៤:១៨** *មានទេវតា១ទៀត ដែលមានអំណាចលើភ្លើង* នេះគឺជាទេវតាដែលបាននិយាយនៅក្នុង ៨:៣–៥ ។ ជាធម្មតាភ្លើងជាប់ទាក់ទង់ទៅនឹងការជំនុំជម្រះ(ការពន្យល់ បទ ១:១៣ មថ ១៨:៨ លក ៩:៥៤ ២ថន ១:៧)។ *ថែដ៏មុត* ថែគឺកាំបិតកុកម្យ៉ាងសម្រាប់កាត់ចង្កោមផ្លែទំពាំងបាយជូរចេញ

នោះថា ចូរលូកថែដ៏មុតរបស់ឯង[រ] ទៅកាត់ចង្កោមទំពាំង
បាយជូរ នៅផែនដីទៅ ដ្បិតផ្លែទុំហើយ ១៩ទេវតា នោះក៏
លូកថែទៅឯផែនដី ហើយកាត់ផ្លែទំពាំងបាយជូរ នៅផែន
ដីទាំងអស់ រួចបោះទៅក្នុងធុងជាន់ផ្លែយ៉ាងធំ របស់ផង
សេចក្តីក្រោធនៃព្រះ[ល] ២០នោះមានគេជាន់ក្នុងធុងនោះ[វ]
នៅខាងក្រៅទីក្រុង[ស] ហើយមានឈាម[ហ]ចេញពីធុងឡើង
ទៅត្រឹមដែកបង្ហៀសេះ ចំងាយ ៣០០ គីឡូម៉ែត្រទៅ ។

## ទេវតាទាំង៧ដែលមានសេចក្តីវេទនាទាំង៧

**១៥** ១ខ្ញុំក៏ឃើញទីសំគាល់ ១ ទៀត ដែលធំហើយអស្ចារ្យ[ឡ]
នៅលើមេឃ គឺមានទេវតា៧[អ]ដែលកាន់សេចក្តីវេទនាទាំង
៧[ក] ក្រោយបង្អស់ ដ្បិតសេចក្តីឃោរឃៅរបស់ព្រះបាន
សំរេច ដោយសេចក្តីវេទនាទាំងនោះ ។
២រួចខ្ញុំមើលទៅឃើញដូចជាសមុទ្រកែវ[ខ] លាយនឹងភ្លើង
ហើយពួកអ្នកដែលបានឈ្នះ[គ]សត្វនោះ[ឃ] នឹងរូបវា[ង] ហើយ
លេខឈ្មោះវាផង[ច] គេឈរលើសមុទ្រនោះ ទាំងកាន់ស៊ុង[ឆ]
របស់ព្រះគ្រប់គ្នា ៣គេច្រៀងទំនុករបស់លោកម៉ូសេ[ជ]ជា
បាវបំរើនៃព្រះ[ឈ] នឹងទំនុករបស់កូនចៀម[ញ]ថា ឱព្រះ
អម្ចាស់ជាព្រះដ៏មានព្រះចេស្តាបំផុតអើយ[ដ] ការទ្រង់សុទ្ធតែ
ធំ ហើយអស្ចារ្យ[ឋ] ឱស្តេចនៃអស់ទាំងសាសន៍អើយ ផ្លូវទ្រង់
សុទ្ធតែសុចរិត ហើយពិតត្រង់[ឌ] ៤ឱព្រះអម្ចាស់អើយ តើ
មានអ្នកឯណាដែលមិនត្រូវកោតខ្លាចដល់ទ្រង់[ឍ] ហើយ
សរសើរដំកើងដល់ព្រះនាមទ្រង់[ណ] ដ្បិតមានតែទ្រង់១ដែល
បរិសុទ្ធ គ្រប់ទាំងសាសន៍នឹងមកក្រាបថ្វាយបង្គំនៅចំពោះ
ទ្រង់[ត] ដ្បិតការសុចរិត[ថ]របស់ទ្រង់ បានសំដែងមកឱ្យឃើញ
ហើយ។
៥ក្រោយនោះ ខ្ញុំក្រឡេកទៅឃើញថា ទ្វារទីបរិសុទ្ធ[ទ]
របស់រោងឧបោសថនៃសេចក្តីបន្ទាល់[ធ]នៅស្ថានសួគ៌ ក៏នៅ
ចំហ[ន] ៦ហើយទេវតា ៧ ដែលកាន់សេចក្តីវេទនាទាំង ៧[ប] ក៏
ចេញពីព្រះវិហារមក[ផ] ទាំងស្លៀកពាក់ជាសំពត់ទេសយ៉ាង
ស្អាត[ព] ហើយភ្លឺ មានទាំងខ្សែមាសរឹតនៅដើមទ្រូងផង[ភ] ៧តួ
មានជីវិត១[ម] ក៏ឱ្យចានកន្ទោងមាស៧ ទៅទេវតាទាំង៧[យ]
ដែលចានទាំងនោះពេញទៅដោយសេចក្តីឃោរឃៅ
របស់ព្រះដ៏មានព្រះជន្មរស់អស់កល្បជានិច្ចរៀងរាបតទៅ[រ]
៨នោះព្រះវិហារមានពេញដោយផ្សែង[ល]ពីសិរីល្អ ហើយពី
ព្រះចេស្តានៃព្រះ គ្មានអ្នកណាអាចនឹងចូលទៅក្នុងព្រះ
វិហារបានទេ[វ] ទាល់តែសេចក្តីវេទនាទាំង៧របស់ទេវតា៧
នោះបានសំរេចស្រេច ។

**១៤:១៨** រ ខ.១៥ **១៤:១៩** ល វវ ១៩:១៥ **១៤:២០** វ ខ.១៩ អស ៦៣:៣ យអ ៣:១៣ វវ ១៩:១៥ ស ហព ១៣:១២ វវ ១១:៨ ហ លប ៤៩:១១ ចទ ៣២:១៤ **១៥:១** ឡ វវ ១២:១, ៣ អ ខ.៦–៨ វវ ១៦:១ ១៧:១ ២១:៩ ក លវ ២៦:២១ វវ ៩:២០ **១៥:២** ខ វវ ៤:៦ គ វវ ១២:១១ ឃ វវ ១៣:១ ង វវ ១៣:១៤ ច វវ ១៣:១៧ ឆ វវ ៥:៨ ១៤:២ **១៥:៣** ជ នក ១៥:១ ឈ យស ១:១ ញ វវ ៥:៩ ដ វវ ១:៨ ឋ ទដ ១១១:២ ឌ ទដ ១៤៥:១៧ **១៥:៤** ឍ យរ ១០:៧ ណ ទដ ៨៦:៩

**១៥:៤** ត អស ៦៦:២៣ ថ វវ ១៩:៨ **១៥:៥** ទ វវ ១១:១៩ ធ នក ៣៨:២១ ជន ១:៥០ ន មថ ៣:១៦ **១៥:៦** ប ខ.១ ផ វវ ១៤:១៥ ព អគ ៩:២ ដយ ១០:៥ ភ វវ ១:១៣ **១៥:៧** ម វវ ៤:៦ យ ខ.១ រ វវ ១:១៨ **១៥:៨** ល អស ៦:៤ វ នក ៤០:៣៤,៣៥ ១ពវ ៨:១០,១១ ២របា ៥:១៣,១៤

ពីដើមរបស់វា (ថែខុសប្លែកពីកណ្តៀវនៅក្នុង ខ.១៤) ។

**១៤:១៩** *ធុងជាន់ផ្លែ* ពាក្យបានបញ្ជាក់ពីរបៀបដែលគេយកទឹកទំពាំងបាយជូរយ៉ាងដូច្នេះថា ផ្លែទំពាំងបាយជូរត្រូវបានគេបោះចូលទៅក្នុងធុងឈើធំមួយដែលមានមនុស្សកំពុងតែជាន់ផ្លែទាំងនោះឱ្យចេញទឹក រួចបង្ហូរតាមទុយោមកដាក់ក្នុងធុងតូចៗនៅទីទាបជាងកន្លែងដែលគេជាន់នោះ (មើលការពន្យល់ ហាក ២:១៦) តែពេលក្រោយៗមកទៀតនោះត្រូវបានគេគាបវាវិញ ។ ការជាន់ផ្លែទំពាំងបាយជូរគឺជាការប្រៀបធៀបមួយទៅនឹងការដាក់ទោស ដោយព្រោះសេចក្តីក្រោធរបស់ព្រះ (អស ៦៣:៣ បទ ១:១៥ យអ ៣:១៣) ។

**១៤:២០** *នៅខាងក្រៅទីក្រុង* មានន័យថាឈាមដែលបានហូរចេញមកនោះនឹងធ្វើឱ្យកង្វក់ដល់ទីក្រុង ដូច្នេះហើយបានជាត្រូវនៅក្រៅទីក្រុង (យអ ៣:១២–១៤ សក ១៤:១–៤ ហព ១៣:១២) ។ *៣០០គីឡូម៉ែត្រ* ត្រង់ចំណុននេះប្រហែលជាប្រវែងនៃទឹកដីបរិសុទ្ធពីទិសខាងជើងទៅទិសខាងត្បូង ។

**១៥:១–៨** ត្រង់នេះគឺជាសេចក្តីផ្តើមចុងក្រោយនៃសេចក្តីវេទនាទី៧នៃការជំនុំជម្រះ និងពាននៃសេចក្តីក្រោធ (មើលការពន្យល់ ៨:២) ។

**១៥:១** *សេចក្តីឃោរឃៅរបស់ព្រះ* មើលការពន្យល់ ៦:១៦ ។

**១៥:២** *សមុទ្រកែវ* មើលការពន្យល់ ៤:៦ ។ *ដែលបានឈ្នះសត្វ* គឺនិយាយអំពីពួកបរិសុទ្ធបានឈ្នះលើអារក្សសាតាំង (១២:១១) ។ *លេខឈ្មោះវា* មើលការពន្យល់ ១៣:១៦–១៨ ។ *ស៊ុង* មើលការពន្យល់ ៥:៨ ។

**១៥:៣** *ច្រៀងទំនុករបស់លោកម៉ូសេ* មើល នក ១៥ ចទ ៣២ នក ១៥:១–១៨ គឺជាចម្រៀងដែលគេលើកយកមកច្រៀង នៅល្ងាចថ្ងៃឈប់សម្រាកនៅក្នុងព្រះវិហារ ដើម្បីអបអរសាទរក្នុងការដែលព្រះបានប្រោសលោះរាស្ត្រអ៊ីស្រាអែល ។ *ទំនុករបស់កូនចៀម* គឺជាចម្រៀងដែលនិយាយពីជ័យជម្នះរបស់ព្រះគ្រីស្ទលើខ្មាំងសត្រូវរបស់ទ្រង់ ក្នុងកាលដែលទ្រង់មានព្រះជន្មរស់ឡើងវិញ (១:១៨ ទដ ២២) ។ *ការទ្រង់សុទ្ធតែធំ ហើយអស្ចារ្យ* មើល នក ១៥:១១ ទដ ៩២:៥ ១១១:២ ។ *ជាព្រះដ៏មានព្រះចេស្តាបំផុតអើយ* មើលការពន្យល់ ១:៨ ។ *ស្តេចនៃអស់ទាំងសាសន៍* មើល យរ ១០:១០ ១ធថ ១:១៧ ។

**១៥:៤** ក្នុងខនេះគឺជាការទទួលស្គាល់ព្រះជាទូទៅមួយ ដែលត្រូវបានគេបង្រៀនទាំងនៅក្នុងគម្ពីរសញ្ញាចាស់ (ទដ ៨៦:៩ អស ៤៥:២២–២៣ មឡ ១:១១) ហើយនិងគម្ពីរសញ្ញាថ្មី (ភល ២:៩–១១) ។

**១៥:៥** *រោងឧបោសថនៃទីបន្ទាល់* គឺជាទីកន្លែងដែលព្រះបានគង់នៅក្នុងខណៈពេលរាស្ត្រអ៊ីស្រាអែលធ្វើដំណើរឆ្លងកាត់ទីរហោស្ថាន (នក ៤០:៣៤-៣៥) ។ ឈ្មោះនេះដែលត្រូវបានគេហៅយ៉ាងដូច្នេះ ពីព្រោះនៅក្នុងរោងឧបោសថនោះមានផ្ទាំងថ្មពីរ ដែលយកមកពីភ្នំស៊ីណាយ (នក ៣២:១៥ ៣៨:២១ ចទ ១០:៥) ។

**១៥:៦** *សេចក្តីវេទនាទាំង៧* នេះគឺជាសេចក្តីវេទនាចុងក្រោយគេ (មើល ខ.១) ។ *ខ្សែមាស* ជានិមិត្តរូបនៃតួនាទីរបស់ស្តេច និងសង្ឃ ។

**១៥:៧** *សេចក្តីឃោរឃៅរបស់ព្រះ* មើល ២ថន ១:៧–៩ ។

**១៥:៨** *ពេញដោយផ្សែង* មើល នក ៤០:៣៤ ១ពវ ៨:១០–១១ អគ ៤៤:៤ ។

## ចានទាំង៧នៃសេចក្តីឃោរឃៅរបស់ព្រះ

**១៦** ១ខ្ញុំក៏ឮសំឡេង១យ៉ាងខ្លាំង ចេញពីព្រះវិហារ[ស] ប្រាប់
ទៅទេវតាទាំង៧[ហ] ថា ចូរចាក់សេចក្តីឃោរឃៅរបស់ព្រះ
ដែលនៅក្នុងចានទាំង៧ទៅលើផែនដីទៅ[ឡ]។
២ទេវតាទី១ក៏ចេញទៅ ចាក់ពីចានខ្លួនទៅលើផែនដី[អ]
នោះមនុស្សដែលមានទីសំគាល់របស់សត្វ នឹងអស់ពួកអ្នក
ដែលក្រាបថ្វាយបង្គំដល់រូបវា[ក] គេក៏កើតដំបៅកាចអាក្រក់
ណាស់[ខ]។
៣ទេវតាទី២ក៏ចាក់ពីចានខ្លួន ទៅក្នុងសមុទ្រ រួចសមុទ្រ
ត្រឡប់ទៅជាឈាម ដូចជាឈាមខ្មោច ហើយគ្រប់ទាំងសត្វ
នៅក្នុងសមុទ្រក៏ស្លាប់អស់[គ]។
៤ទេវតាទី៣ ក៏ចាក់ពីចានខ្លួន ទៅក្នុងទន្លេ នឹងរន្ធទឹក
ទាំងប៉ុន្មាន[ឃ] នោះក៏ប្រែទៅជាឈាមទាំងអស់ដែរ[ង] ៥រួចខ្ញុំ
ឮទេវតានៃទឹកនិយាយថា ឱព្រះ[ច]ដ៏គង់នៅ ហើយបានគង់
នៅតាំងពីដើមរៀងមកអើយ[ឆ] ដែលទ្រង់បានជំនុំជំរះកាត់
ទោស[ជ]ដូច្នេះ នោះសុចរិតហើយ[ឈ] ៦ដ្បិតគេបានកំចាយ
ឈាមនៃពួកបរិសុទ្ធ នឹងពួកហោរា[ញ] ហើយទ្រង់បាន
ប្រទានឈាមឱ្យគេផឹក[ដ] គេគួរមានទោសដូច្នេះហើយ
៧រួចខ្ញុំឮអាសនា[ឋ]ទទួលថា មែនហើយ ឱព្រះអម្ចាស់ ជា
ព្រះដ៏មានព្រះចេស្តាបំផុតអើយ[ឌ] សេចក្តីជំនុំជំរះរបស់ទ្រង់
សុទ្ធតែសុចរិត ហើយពិតត្រង់ទាំងអស់[ឍ]។
៨ទេវតាទី៤[ណ]ក៏ចាក់ពីចានខ្លួន ទៅលើព្រះអាទិត្យ[ត]
រួចព្រះអាទិត្យបានអំណាចនឹងធ្វើឱ្យមនុស្សត្រូវខ្លោច
ដោយសារភ្លើង[ថ] ៩មនុស្សលោកក៏ត្រូវខ្លោចទៅ ដោយ
អំណាចក្តៅជាខ្លាំង តែគេមិនបានប្រែចិត្ត[ទ] ដើម្បីនឹងលើក
សរសើរដល់សិរីល្អនៃព្រះទេ[ធ] គឺគេប្រមាថដល់ព្រះនាម
ព្រះ[ន] ដែលមានអំណាចលើសេចក្តីវេទនាទាំងនោះវិញ ។
១០ឯទេវតាទី៥ក៏ចាក់ពីចានខ្លួន ទៅលើបល្ល័ង្ករបស់
សត្វនោះ[ប] រួចនគរវាត្រឡប់ទៅជាងងឹតសូន្យសុង[ផ] ហើយ
គេខាំអណ្តាត ដោយមានសេចក្តីទុក្ខលំបាក ១១ក៏ប្រមាថ[ព]
ដល់ព្រះនៃស្ថានសួគ៌[ភ] ដោយព្រោះទុក្ខលំបាក នឹងដំបៅ
របស់គេ[ម] តែមិនបានប្រែចិត្តលះចោលពីការដែលគេ
ប្រព្រឹត្តឡើយ[យ]។
១២ទេវតាទី៦ក៏ចាក់ពីចានខ្លួន ទៅលើទន្លេធំ គឺជាទន្លេ
អ៊ើប្រាត[រ] រួចទឹកទន្លេនោះក៏រីងទៅ ដើម្បីឱ្យបានរៀបចំផ្លូវ[ល]
របស់ពួកស្តេចពីទិសខាងថ្ងៃរះ[វ] ១៣រួចខ្ញុំឃើញវិញ្ញាណ

**១៦:១** ស វវ ១១:១៩ ហ វវ ១៥:១ ឡ ខ.២-២១ ទដ ៧៩:៦ សផ ៣:៨ **១៦:២** អ វវ ១៣:១៥-១៧ ១៤:៩ ក ខ.១១ នក ៩:៩-១១ ចទ ២៨:៣៥ ខ វវ ៨:៧ **១៦:៣** គ នក ៧:១៧-២១ វវ ៨:៨,៩ វវ ១១:៦ **១៦:៤** ឃ វវ ៨:១០ ង នក ៧:១៧-២១ **១៦:៥** ច វវ ១៥:៤ ឆ វវ ១:៤ ជ វវ ៦:១០ ឈ វវ ១៥:៣ **១៦:៦** ញ លក ១១:៤៩-៥១ ដ អស ៤៩:២៦ វវ ១៧:៦ ១៨:២៤ **១៦:៧** ឋ វវ ៦:៩ ១៤:១៨ ឌ វវ ១:៨ ឍ វវ ១៥:៣ ១៩:២ **១៦:៨** ណ វវ ៨:១២ ត វវ ៦:១២ ថ វវ ១៤:១៨ **១៦:៩** ទ វវ ១១:១៣ ធ វវ ២:២១ ន ខ.១១,២១ **១៦:១០** ប វវ ១៣:២ ផ នក ១០:២១-២៣ អស ៨:២២ វវ ៨:១២ ៩:២ **១៦:១១** ព ខ.៩,២១ ភ វវ ១១:១៣ ម ខ.២ យ វវ ២:២១ **១៦:១២** រ វវ ៩:១៤ ល អស ១១:១៥,១៦ វ អស ៤១:២ ៤៦:១១

---

ផ្សេងតំណាងឱ្យអំណាចព្រះចេស្តា និងសិរីល្អរបស់ព្រះ ។ *គ្មានអ្នកណាអាចនឹងចូលទៅក្នុងព្រះវិហារបានទេ* មានន័យថា ទាំងព្រះវិហារ និងរោងឧបោសថ គឺជានិមិត្តរូបមួយ ដែលជាប់ទាក់ទងទៅនឹងលោកម៉ូសេ (នក ៤០:៣៥) បង្ហាញពីអត្តសញ្ញាណរបស់លោកថាជាសង្ឃ (២រប ៥:១៤) ។

**១៦:២** *លើផែនដី* ត្រង់នេះគឺជាការប្រៀបធៀបចានទាំងបួនលើកដំបូង (ខ.២-៩) ជាមួយទៅនឹងការផ្លុំត្រែទាំងបួន (៨:៧-១២) ។ *ដំបៅកាចអាក្រក់* គឺជាដំបៅបូសដែលក្លាយពីកន្លែងមួយទៅកន្លែងមួយទៀតនៅលើខ្លួនមនុស្សបានកើតនៅក្នុងគ្រោះកាចទី៦នៅក្នុងស្រុកអេស៊ីព្ទ (នក ៩:៩-១១ យប ២:៧-៨,១៣) ។ *ទីសំគាល់របស់សត្វ* មើលការពន្យល់ ១៣:១៦ ។

**១៦:៤** *ទន្លេ និងរន្ធទឹកទាំងប៉ុន្មាន* មើល ៨:១០-១១ ទដ ៧៨:៤៤ ។

**១៦:៥** *ព្រះដ៏គង់នៅ ហើយបានគង់នៅតាំងតែពីរៀងមក* មើលការពន្យល់ ១១:១៧ នក ៣:១៤ ។

**១៦:៦** *ប្រទានឈាមឱ្យគេផឹក* គឺជាសេចក្តីជំនុំជម្រះដែលត្រូវបានគេបញ្ចេញបញ្ចូល ដើម្បីឱ្យសមនឹងបទឧក្រិដ្ឋរបស់ពួកគេ (អស ៤៩:២៦ និងការពន្យល់ កទ ៦:៧) ។

**១៦:៧** *អាសនា* ពាក្យនេះតំណាងឱ្យមនុស្ស ។

**១៦:៨** *ភ្លើង* ពាក្យនេះនៅក្នុងបទគម្ពីរជារឿយៗតែងតែជាប់ទៅនឹងសេចក្តីជំនុំជម្រះ (មើលពន្យល់ ១៤:១៨ ចទ ២៨:២២ ១កថ ៣:១៣ ២ពត ៣:៧) ។

**១៦:៩** *គេមិនបានប្រែចិត្ត* នៅក្នុង "១១:១៣" ជាតិសាសន៍ទាំងឡាយត្រូវបានស្រវាំងភ្នែកដោយសារភាពអំនួតរបស់គេ ទោះជាឃើញកក្រើកដីយ៉ាងណាក៏ដោយ ។

**១៦:១០** *បល្ល័ង្ករបស់សត្វ* គឺជាបល្ល័ង្ករបស់អារក្សសាតាំង (២:១៣) ។ ពាក្យថា "បល្ល័ង្ក" មានចំនួន៤២ដងនៅក្នុងគម្ពីរវិវរណៈនេះ ហើយមាន៤០ពាក្យផ្សេងទៀតគឺនិយាយពីបល្ល័ង្ករបស់ព្រះអម្ចាស់ ។ *ងងឹតសូន្យសុង* "សូមមើល នក ១០:២១-២៣។ *គេខាំអណ្តាត* ជារូបភាពមួយដែលមាននៅក្នុង (មើល ១៦:១៥-១៧) ។

**១៦:១១** *ព្រះនៃស្ថានសួគ៌* ឃ្លានេះក៏បានប្រើនៅក្នុង ដយ ២:៤៤ នោះផងដែរដោយថែងថា "រីឯនៅគ្រានៃស្តេចទាំងនោះ ព្រះនៃស្ថានសួគ៌ទ្រង់នឹងតាំងនគរ១ឡើង ដែលមិនត្រូវបំផ្លាញឡើយ ហើយអំណាចហ្លួងក៏មិនត្រូវផ្ទេរដល់សាសន៍ដទៃណាដែរ នគរនោះនឹងស្ថិតស្ថេរនៅអស់កល្បជានិច្ច ហើយនគរនោះនឹងបំបាក់បំបែក ហើយលេបបំបាត់នគរលោកិយទាំងអស់នេះចោលចេញវិញ"។

**១៦:១២** *ទន្លេអ៊ើប្រាត* មើលការពន្យល់ លប ១៥:១៨ ។ *ពួកស្តេចពីទិសខាងថ្ងៃរះ* គឺសំដៅទៅលើពួកអ្នកគ្រប់គ្រងនៃសាសន៍ផារថុស (១៧:១៥-១៨:២៤) ដែលការគ្រប់គ្រងខុសប្លែកពីស្តេចដទៃ (ខ.១៤) ហើយជាអ្នកដែលធ្វើសង្គ្រាមចុងក្រោយប្រឆាំងនឹងព្រះគ្រីស្ទ ហើយក៏ជាទាហាននៃស្ថានសួគ៌ (១៩:១១-២១) ។

**១៦:១៣** *កង្កែប* គឺជាសត្វមួយប្រភេទដែលត្រូវបានគេចាត់ទុកថាជាសត្វមិនស្អាត (លវ ១១:១០) ។ សត្វកង្កែបនេះក៏ជានិមិត្តរូបនៃការក្លែងបន្លំ និងពីគោលបំណង នាថ្ងៃចុងក្រោយដែលបណ្តាលឱ្យមនុស្សទៅទទួល និងគាំទ្រ

អសោចិ៍៣[ស] ដូចជាកង្កែប[ហ] ចេញពីមាត់នាគ[ឡ] មាត់សត្វ[អ]នឹង
ពីមាត់ហោរាក្លែងក្លាយមក[ក] ១៤ដ្បិតវិញ្ញាណទាំងនោះ ជា
វិញ្ញាណនៃពួកអារក្ស[ខ] ដែលចេញទៅឯអស់ទាំងស្ដេចនៅ
ផែនដីទាំងមូល[គ] ទាំងធ្វើទីសំគាល់[ឃ] ដើម្បីនឹងប្រមូលស្ដេច
ទាំងនោះមកក្នុងចំបាំង[ង]នៅថ្ងៃដ៏ធំ[ច]របស់ព្រះដ៏មានព្រះ
ចេស្ដាបំផុត ១៥(មើលអញមកដូចជាចោរប្លន់[ឆ] មានពរ
ហើយអ្នកណាដែលនៅចាំ[ជ] ហើយរក្សាសំលៀកបំពាក់ខ្លួន
ដើម្បីមិនឱ្យដើរអាក្រាត ឱ្យអ្នកណាឃើញកេរ្ដិ៍ខ្មាសខ្លួន
ឡើយ)[ឈ] ១៦រួចវិញ្ញាណទាំងនោះ ក៏ប្រមូលគេ[ញ]ទៅឯ
កន្លែង ដែលភាសាហេព្រើរ[ដ]ហៅថា អើម៉ាគេដូន[ឋ]។
១៧ទេវតាទី៧ក៏ចាក់ពីចានខ្លួន ទៅក្នុងអាកាស[ឌ]រួចមាន
ឮសំឡេងខ្លាំង[ឍ] ចេញពីបល្ល័ង្កក្នុងព្រះវិហារ[ណ]នៅស្ថាន
សួគ៌មកថា ស្រេចហើយ[ត] ១៨រួចមានផ្លេកបន្ទោរស្នូរ
សំឡេង និងផ្គរលាន់[ថ] ហើយមានកក្រើកដីជាខ្លាំងដែរ[ទ]ដល់
ម្ល៉េះបានជាតាំងពីមានមនុស្សនៅផែនដី[ធ]រៀងមក នោះមិន
ដែលមានកក្រើកដីយ៉ាងខ្លាំង ហើយសំបើមដូច្នោះឡើយ
១៩ទីក្រុងដ៏ធំ[ន]ក៏ញែកចេញជា៣ភាគ អស់ទាំងទីក្រុងរបស់
សាសន៍ដទៃទាំងប៉ុន្មានក៏រលំ ហើយព្រះទ្រង់នឹកចាំ[ប]ពី
ក្រុងបាប៊ីឡូនដ៏ជាធំ[ផ] ដើម្បីនឹងឱ្យពែងស្រារបស់សេចក្ដី
ឃោរឃៅផង សេចក្ដីខ្ញាល់ទ្រង់ដល់គេ[ព] ២០នោះគ្រប់ទាំង
កោះក៏បាត់ទៅ ហើយមិនឃើញមានភ្នំណាទៀតសោះ
ឡើយ[ភ] ២១ក៏មានព្រឹលយ៉ាងធំៗ[ម] គ្រាប់១ទំងន់១ហាប ធ្លាក់
ចុះពីផ្ទៃមេឃមកលើមនុស្សលោក ហើយមនុស្សលោកក៏
ប្រមាថដល់ព្រះ[យ]ដោយព្រោះសេចក្ដីវេទនា នឹងព្រឹលនោះ[រ]
ពីព្រោះសេចក្ដីវេទនាជាខ្លាំងក្រៃលែង ។

**១៦:១៣** ស វវ ១៨:២ ហ នក ៨:៦ ឡ វវ ១២:៣ អ វវ ១៣:១ ក វវ ១៩:២០ ២០:១០ **១៦:១៤** ខ ១ធថ ៤:១ គ មថ ២៤:២៤ ឃ មថ ២៤:១៤ ង វវ ១៧:១៤ ១៩:១៩ ២០:៨ ច វវ ៦:១៧ **១៦:១៥** ឆ លក ១២:៣៩ ជ លក ១២:៣៧ ឈ វវ ៣:១៨ **១៦:១៦** ញ ខ.១៤ ដ វវ ៩:១១ ឋ ពច ៥:១៩ ២ពវ ២៣:២៩,៣០ សក ១២:១១ **១៦:១៧** ឌ អភ ២:២ ឍ វវ ១៤:១៥ ណ វវ ១១:១៥ ត វវ ២១:៦ **១៦:១៨** ថ វវ ៤:៥ ទ វវ ៦:១២ ធ ដយ ២១:១ មថ ២៤:២១ **១៦:១៩** ន វវ ១៧:១៨ ប វវ ១៨:៥ ផ វវ ១៤:៨ ព វវ ១៤:១០ **១៦:២០** ភ វវ ៦:១៤ **១៦:២១** ម អក ១៣:១៣ ៣៨:២២ វវ ៨:៧ ១១:១៩ យ ខ.៩,១១

## ស្ត្រីដែលជិះលើសត្វសាហាវ

**១៧** ១ទេវតា ១ ក្នុងពួកទាំង ៧ នោះ[ល] ដែលកាន់ចាន
កន្ទោង៧[វ] ក៏មកនិយាយមកខ្ញុំថា ចូរមកឯណេះ ខ្ញុំនឹង
បង្ហាញឱ្យអ្នកឃើញទោស[ស]នៃស្រីសំផឹងដ៏ធំ[ហ] ដែលស្ថិតនៅ
លើទឹកច្រើន[ឡ] ២ដែលពួកស្ដេចនៅផែនដីបានសហាយស្មន់
នឹងវាហើយអស់អ្នកនៅផែនដីបានស្រវឹង ដោយស្រារបស់
សេចក្ដីកំផិតនៃវា[អ] ៣ទេវតានោះក៏នាំវិញ្ញាណខ្ញុំ[ក]ទៅឯ
ទីរហោស្ថាន[ខ] នោះខ្ញុំឃើញមានស្ត្រីម្នាក់ ជិះនៅលើសត្វ
សម្បុរក្រហម[គ] ដែលពេញជាឈ្មោះប្រមាថ[ឃ] មានក្បាល៧
ហើយស្នែង១០[ង] ៤សំលៀកបំពាក់របស់ស្ត្រីនោះមានពណ៌
ស្វាយ ហើយក្រហម ក៏តែងដោយមាស ត្បូងមានដំឡៃ
ហើយនឹងកែវមុក្ដា[ច] ព្រមទាំងកាន់ពែងមាស[ឆ]ដែលពេញ
ដោយសេចក្ដីស្មោកគ្រោក របស់ការកំផិតដ៏គួរខ្ពើមរបស់
វាផង[ជ] ៥ហើយនៅថ្ងាសវា មានកត់ឈ្មោះថា សេចក្ដីអាថ៌
កំបាំង[ឈ] ក្រុងបាប៊ីឡូនដ៏ជាធំ[ញ] ជាម្ដាយនៃពួកស្រីសំផឹង[ដ] និង
អស់ទាំងសេចក្ដីគួរខ្ពើមនៅផែនដី ៦ខ្ញុំក៏ឃើញស្ត្រីនោះ
ស្រវឹងនឹងឈាមនៃពួកបរិសុទ្ធ[ឋ] ហើយនិងឈាមពួកអ្នក
ដែលធ្វើបន្ទាល់ពីព្រះយេស៊ូវ លុះខ្ញុំឃើញវាហើយ ក៏មាន
សេចក្ដីអស្ចារ្យជាខ្លាំង ។
៧នោះទេវតាសួរខ្ញុំថា ហេតុអ្វីបានជាអ្នកមានសេចក្ដី
អស្ចារ្យដូច្នេះ ខ្ញុំនឹងប្រាប់ឱ្យអ្នកដឹងពីសេចក្ដីអាថ៌កំបាំង[ឌ]
របស់ស្ត្រីនោះ ហើយនិងសត្វដែលវាជិះនោះ ដែលមាន

រ នក ៩:២៣–២៥ **១៧:១** ល វវ ១៥:១ វ វវ ១៥:៧ ស វវ ១៦:១៩ ហ ខ.៥,១៥,១៦ អស ២៣:១៧ វវ ១៩:២ ឡ យរ ៥១:១៣ **១៧:២** អ វវ ១៤:៨ **១៧:៣** ក វវ ១:១០ ខ វវ ១២:៦,១៤ គ វវ ១៨:១២,១៦ ឃ វវ ១៣:១ ង វវ ១២:៣ **១៧:៤** ច អក ២៨:១៣ វវ ១៨:១៦ ឆ យរ ៥១:៧ វវ ១៨:៦ ជ ខ.២ វវ ១៤:៨ **១៧:៥** ឈ ខ.៧ ញ វវ ១៤:៨ ដ ខ.១,២ **១៧:៦** ឋ វវ ១៦:៦ ១៨:២៤ **១៧:៧** ឌ ខ.៥

វិញ្ញាណអាក្រក់ ។

**១៦:១៤** *ធ្វើទីសំគាល់* មើល ១៣:១៣ ។ *នៅផែនដីទាំងមូល* មើល ៦:១៥ ។ *នៅថ្ងៃដ៏ធំរបស់ព្រះ* មើល ១៩:១១–២១ គឺនៅថ្ងៃចំបាំងចុងក្រោយ ។

**១៦:១៦** *អើម៉ាគេដូន* ពាក្យនេះប្រហែលសំដៅទៅលើភ្នំ"មេគីដោ"(ពច ៥:១៩)។ មានមនុស្សជាច្រើនបានកំណត់ថា អើម៉ាគេដូន និងមេគីដោគឺជាកន្លែងតែមួយប៉ុណ្ណោះនៅក្នុងឯកសារភូមិសាស្ត្រនោះ ហើយវាជានិមិត្តរូបនៃការដែលព្រះបានផ្ចាញ់វិញ្ញាណអាក្រក់ ។

**១៦:១៧** *ព្រះវិហារ* មើល ១៥:៥–៦ ។ *ស្រេចហើយ* មានន័យថា ការចាក់ពីចាននៃសេចក្ដីក្រោធរបស់ព្រះបានដល់ទីបញ្ចប់ហើយ ។

**១៦:១៩** *ទីក្រុងដ៏ធំ* មើលការពន្យល់ ១៧:១៨ ។

**១៦:២១** *មានព្រឹលយ៉ាងធំ* មើល នក ៩:១៨–២៦ ។

**១៧:១–១៨:២៤** មើលការពន្យល់ ១៤:៨ ។

**១៧:១** *ពួកទាំង៧* មើល ១៥:១,១៦ ។ *ស្រីសំផឹងដ៏ធំ* មើល ខ.១៨ គឺជាទីសំគាល់ពីនិមិត្តរូបរបស់ទេវតា ។ នៅក្នុង ខ.៥ បានឱ្យដឹងថាក្រុងបាប៊ីឡូនដ៏ជាធំនោះ គឺជាម្ដាយរបស់ស្រីសំផឹង ។ *ទឹកច្រើន* មើល ខ.១៥ ទដ ១៣៧:១ យរ ៥១:១៣ ។

**១៧:២** *ស្រារបស់សេចក្ដីកំផិត* មើលពន្យល់ ១៤:៨ ១៨:៣ អស ២៣:១៧ យរ ៥១:៧ ។

**១៧:៣** *វិញ្ញាណ* ត្រង់ចំណុចនេះគឺជាការសញ្ជឹងគិតមួយដែលដឹកនាំដោយព្រះវិញ្ញាណ (មើលការពន្យល់ ១:១០ ៤:២ ២១:១០)។ *សត្វសម្បុរក្រហម* គឺជាសត្វដែលចេញមកពីសមុទ្រនៅក្នុងជំពូកទី១៣ ។ សត្វពណ៌ក្រហមត្រង់នេះគឺស្រដៀងនឹងសត្វនាគក្រហមដែលនិយាយនៅក្នុង ១២:៣,៤ នោះដែរ។ *ឈ្មោះប្រមាថ* មើលការពន្យល់ ១៣:១ ។

**១៧:៥** *សេចក្ដីអាថ៌កំបាំង* ពាក្យនេះប្រហែលពុំមែនជាផ្នែកមួយនៃចំណងជើងនោះទេ។ វាគ្រាន់តែជាពាក្យមួយដែលត្រូវបានគេបកប្រែនៅដើមខនេះសម្រាប់សរសេរនៅលើថ្ងាសតែប៉ុណ្ណោះ (មើលការពន្យល់ ១៤:៨)។

**១៧:៦** *ពួកបរិសុទ្ធ . . . ធ្វើបន្ទាល់* មើល ៦:៩ ។

**១៧:៧** *សេចក្ដីអាថ៌កំបាំង* មើលការពន្យល់ ១០:៧ ។

ក្បាល ៧ នឹងស្នែង ១០ដែរ[ល] ៨ឯសត្វដែលអ្នកបានឃើញ
នោះ ពីដើមវានៅ ឥឡូវនេះបាត់ទៅហើយ ក៏រៀប
នឹងឡើងចេញពីជង្ហុកធំមកវិញ[ណ] រួចវានឹងត្រូវវិនាសបាត់
ទៅ[ត] ឯអស់អ្នកនៅផែនដី[ថ] ដែលគ្មានឈ្មោះកត់ទុកក្នុងបញ្ជី
ជីវិត[ទ] តាំងពីកំណើតលោកីយមក គេនឹងមានសេចក្ដី
អស្ចារ្យ[ធ] ដោយឃើញសត្វដែលពីដើមនៅ ឥឡូវនេះបាត់
តែនឹងត្រឡប់មានឡើងវិញនោះ ៩នេះហើយជាគំនិតដ៏
មានប្រាជ្ញា[ន] ឯក្បាលទាំង៧[ប] នោះជាភ្នំ៧ គឺជាកន្លែងដែល
ស្ត្រីនោះអង្គុយនៅ ១០ក៏មានស្ដេច៧អង្គ ឯ៥អង្គបានដួល
ហើយ មាន១អង្គនៅសព្វថ្ងៃ ហើយ១អង្គទៀតមិនទាន់
មកដល់ទេ កាលណាស្ដេចនោះបានមកហើយ នោះនឹង
នៅមិនយូរប៉ុន្មានទេ ១១រីឯសត្វដែលពីដើមមាន តែឥឡូវ
នេះបាត់[ផ] នោះជាស្ដេចទី ៨ ដែលកើតមកពីស្ដេច ៧ អង្គ
នោះ ហើយត្រូវវិនាសបាត់ទៅវិញ ១២ឯស្នែង ១០[ព] ដែល
អ្នកឃើញ នោះជាស្ដេច ១០អង្គ ដែលមិនទាន់ទទួលរាជ្យ
នៅឡើយ តែនឹងទទួលអំណាចជាស្ដេច នៅតែ ១ ម៉ោង
ប៉ុណ្ណោះ[ភ] ជាមួយនឹងសត្វនោះ ១៣ស្ដេចទាំងនោះនឹងមាន
គំនិតតែ១ ដើម្បីនឹងប្រគល់កំឡាំង នឹងអំណាចខ្លួនដល់សត្វ
នោះ[ម] ១៤គេនឹងច្បាំង[យ]ទាស់នឹងកូនចៀម តែកូនចៀមនឹង
ឈ្នះគេ[រ] ពីព្រោះទ្រង់ជាព្រះអម្ចាស់លើអស់ទាំងព្រះ
អម្ចាស់[ល] ហើយជាស្ដេចលើអស់ទាំងស្ដេច ឯពួកអ្នកដែល
នៅជាមួយនឹងទ្រង់ នោះជាអ្នកដែលទ្រង់បានហៅបាន
រើស[វ] ហើយជាអ្នកស្មោះត្រង់ទាំងអស់គ្នា ។
១៥ទេវតាក៏ប្រាប់ខ្ញុំថា ឯទឹក[ស]ដែលអ្នកបានឃើញ ជា
កន្លែងដែលស្រីសំផឹងអង្គុយនោះ គឺជាប្រជាជន នឹងមនុស្ស
ផងទាំងឡាយ គ្រប់សាសន៍ គ្រប់ភាសា[ហ] ១៦ស្នែងទាំង ១០[ឡ]
ដែលអ្នកឃើញ ព្រមទាំងសត្វនោះផង នោះនឹងស្អប់ដល់
ស្រីសំផឹង[អ] ហើយនឹងបំផ្លាញវាទៅ[ក] ទាំងធ្វើឱ្យវានៅ
អាក្រាត[ខ] រួចនឹងស៊ីសាច់វា[គ] ហើយដុតវានៅក្នុងភ្លើង[ឃ]
១៧ដ្បិតព្រះទ្រង់បានបណ្ដាលចិត្តគេ[ង] ឱ្យធ្វើតាមគំនិតទ្រង់
ហើយឱ្យគេមូលគំនិត នឹងប្រគល់រាជ្យគេដល់សត្វនោះ[ច]
ទាល់តែព្រះបន្ទូលនៃព្រះបានសំរេច[ឆ] ១៨ឯស្ត្រីដែលអ្នក
បានឃើញ នោះគឺជាទីក្រុងដ៏ធំ[ជ] ដែលមានអំណាចលើ
ស្ដេចទាំងប៉ុន្មាននៅផែនដី ។

## ការដួលរលំនៃទីក្រុងបាប៊ីឡូន

**១៨** ១ក្រោយនោះមក ខ្ញុំឃើញទេវតា១[ឈ]ទៀតចុះពីស្ថាន
សួគ៌មក[ញ] មានអំណាចយ៉ាងធំ ហើយសិរីល្អរបស់ទេវតា
នោះក៏បំភ្លឺផែនដី[ដ] ២ទេវតានោះបន្លឺឡើង ដោយសំឡេង
យ៉ាងខ្លាំងថា ក្រុងបាប៊ីឡូនដ៏ជាធំ[ឋ]បានរលំហើយ បានរលំ
ហើយ ក៏ត្រឡប់ជាលំនៅនៃពួកអារក្ស[ឌ] ជាកន្លែងរបស់អស់
ទាំងវិញ្ញាណអសោចិ៍ និងអស់ទាំងសត្វស្លាបអសោចិ៍គួរ

**១៧:៧** ល ខ.៣ វវ ១២:៣
**១៧:៨** ណ លក ៨:៣១ ត វវ ១៣:១០ ថ វវ ៣:១០ ទ វវ ២០:១២ ធ វវ ១៣:៣
**១៧:៩** ន វវ ១៣:១៨ ប ខ.៣
**១៧:១១** ផ ខ.៨
**១៧:១២** ព វវ ១២:៣ ភ វវ ១៨:១០,១៧,១៩
**១៧:១៣** ម ខ.១៧
**១៧:១៤** យ វវ ១៦:១៤ រ យហ ១៦:៣៣ ល ១ធថ ៦:១៥ វ មថ ២២:១៤
**១៧:១៥** ស ខ.១ អស ៨:៧ យរ ៤៧:២ ហ វវ ១៣:៧
**១៧:១៦** ឡ វវ ១២:៣ អ ខ.១ ក វវ ១៨:១៧,១៩ ខ អគ ១៦:៣៧,៣៩ គ វវ ១៩:១៨ ឃ វវ ១៨:៨
**១៧:១៧** ង ២កថ ៨:១៦ ច ខ.១៣ ឆ យរ ៣៩:១៦ វវ ១០:៧ **១៧:១៨** ជ វវ ១៦:១៩ ១៨:១០,១៨,១៩,២១
**១៨:១** ឈ វវ ១៧:១ ញ វវ ១០:១ ២០:១ ដ អគ ៤៣:២
**១៨:២** ឋ វវ ១៤:៨ ឌ វវ ១៦:១៣

**១៧:៨** *ពីដើមវានៅ... ឥឡូវនេះបាត់ តែនឹងត្រឡប់មានឡើងវិញ* ត្រង់នេះគឺជា ការត្រាប់តាមមួយយ៉ាងពិតប្រាកដនៃការពិពណ៌នាអំពីកូនចៀម(១:១៨ ២:៨)និងការពិពណ៌នាអំពីព្រះ(១:៤,៨ ៤:៨)។ ឃ្លានេះហាក់បីដូចជាមានន័យថាសត្វនោះបានលេចចេញរួចហើយ ពុំមែនពេលបច្ចុប្បន្ននេះទេ ហើយវានឹងមកម្ដងទៀត ។ តាមពិតវិញ្ញាណអាក្រក់នេះមានជារៀងរហូតតមក ។ *ជង្ហុកធំ* មើលការពន្យល់ ៩:១។ *បញ្ជីជីវិត* មើលការពន្យល់ ៣:៥ ។ *វានឹងត្រូវវិនាសបាត់ទៅ* ទោះជាវានឹងត្រូវវិនាសបាត់ទៅនៅពេលមួយក៏ដោយ ក៏ពេលនេះវាមានពិតប្រាកដមែន ហើយពុំកំណត់ថាពេលណាជាពេលចុងក្រោយរបស់វានោះដែរ ។

**១៧:៩** *ភ្នំ៧* ត្រង់កន្លែងនេះប្រហែលជាទីតាំងសំខាន់ដែលក្រុងរ៉ូមបានចាប់ផ្ដើមចងជាបណ្ដាញនៃភ្នំទាំង៧ ដើម្បីដោះស្រាយបញ្ហានៅតំបន់ទន្លេទីបេ (Tiber) ខាងកើត ។ លើភ្នំទាំង៧នេះមានទីក្រុងរួមមួយជាកន្លែង សម្រាប់ពួកអ្នកនិពន្ធជាតិរ៉ូម៉ាំងដូចជា វើហ្គីល ម៉ាតថៃល និងស៊ីសើរ៉ូ (Virgil Martial, Cicero) ។

**១៧:១០** *ស្ដេច៧អង្គ* គឺជាមេដឹកនាំទាំង៧រូបនៅលើភ្នំទាំង៧ ដែលប្រៀបដូចជាវត្ថុរំអិល សម្រាប់ជួយឱ្យលោកិយនេះរលាយទៅយ៉ាងឆាប់រហ័ស (ភ្នំតំណាងឱ្យអំណាចរបស់ស្ដេចលោកិយ ឬតំណាងឱ្យខាងនយោបាយ)។ *៥អង្គ . . . ១អង្គនៅសព្វថ្ងៃ . . . ១អង្គទៀត* ឃ្លានេះអាចមានន័យថា (១).ជាអាណាចក្ររបស់រ៉ូម៉ាំងទាំង៧ពិតៗ (២).ជាអាណាចក្រទាំង៧របស់លោកិយ ឬ(៣).ជានិមិត្តរូបតំណាងឱ្យចក្រភពរ៉ូម៉ាំងនៅលើផែនដីនេះទាំងមូលតែមួយ ។

**១៧:១១** *តែឥឡូវនេះបាត់* មើល ១៣:៣ ។ *ស្ដេចទី៨* គឺជាម្នាក់ដែលប្រឆាំងនឹងព្រះគ្រីស្ទដែលមានតួនាទីជាស្ដេច(ជាកម្មសិទ្ធិរបស់ស្ដេចទី៧)ប៉ុន្តែ វាជាផ្នែកមួយនៃអ្នកប្រយុទ្ធយ៉ាងខ្លាំងក្លារវាងព្រះ និងសាតាំង ។

**១៧:១២** *ស្ដេច១០អង្គ* គឺជាស្ដេចដែលមិនទាន់បានទទួលអំណាចតែនឹងទទួលអំណាចក្នុងពេលអនាគត ។ ស្ដេចទាំងនេះជានិមិត្តរូបតំណាងឱ្យអំណាចខាងនយោបាយដែលមានសម្ព័ន្ធមិត្ត ជាមួយនឹងសត្វសាហាវនោះ ។ *១ម៉ោង* គឺជារយៈពេលខ្លីបំផុត ។

**១៧:១៤** *ព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់ ស្ដេចលើអស់ទាំងស្ដេច* ត្រង់នេះគឺបានបញ្ជាក់អំពីមហិទ្ធិរិទ្ធដ៏ខ្ពស់បំផុតនៃកូនចៀម(មើលពន្យល់ ៥:៦ ១៩:១៦ ចទ ១០:១៧ ទដ ១៣៦:២–៣ ដយ ២:៤៧ ១ធថ ៦:១៥)។

**១៧:១៨** *ទីក្រុងដ៏ធំ* មើល ១៦:១៩ ១៧:១ និងការពន្យល់ ១១:៨ ១៤:៨ ។

**១៨:១** *អំណាចយ៉ាងធំ* មើលការពន្យល់ ៥:២ ។ *សិរីល្អរបស់ទេវនោះក៏បំភ្លឺផែនដី* មើល នក ៣៤:២៩–៣៥ ទដ ១០៤:២ អគ ៤៣:១–៥ ១ធថ ៦:១៦ ។

**១៨:២** *បាប៊ីឡូនដ៏ជាធំ* មើល អស ២១:៩ យរ ៥១:៨ និងពន្យល់ ១១:៨ ១៤:៨ ។

ខ្ពឹម[ឍ] ៣ពីព្រោះគ្រប់ទាំងសាសន៍បានផឹកស្រារបស់សេចក្តី
ឃោរឃៅផងសេចក្តីកំផិតវា[ណ] ពួកស្តេចនៅផែនដីបាន
សហាយស្មន់នឹងវា[ត] ហើយពួកជំនួញនៅផែនដី បានត្រឡប់
ជាមានឡើង[ថ] ដោយអំណាចនៃការហ៊ឺហារបស់វាដែរ[ទ]។
៤ខ្ញុំក៏ឮសំឡេង១ទៀតពីលើមេឃ ពោលថា រាស្ត្រ
អញអើយ ចូរចេញពីទីក្រុងនោះមក[ធ] ដើម្បីកុំឱ្យត្រូវមាន
ចំណែកក្នុងអំពើបាបវាឡើយ ក្រែងត្រូវវេទនាដូចជាវា
ដែរ[ន] ៥ដ្បិតអំពើបាបវាបានគរជាគំនរឡើងដល់ផ្ទៃមេឃ[ប]
ហើយព្រះទ្រង់បាននឹកចាំ[ផ]ពីការទុច្ចរិតរបស់វា ៦ចូរសងវា
តាមការដែលវាបានធ្វើដល់ឯងចុះ[ព] ទាំងទ្វេ១ជា២[ភ] ឱ្យវា
ផង ចូរចាក់១ជា២ ទៅក្នុងពែង ដែលវាបានចាក់ឱ្យឯង[ម]
៧ដែលវាបានដំកើងខ្លួន ហើយរស់ដោយហ៊ឺហាយ៉ាងណា
នោះត្រូវឱ្យវាមានសេចក្តីទុក្ខលំបាក និងសេចក្តីសោក
សង្រេងយ៉ាងនោះដែរ[យ] ដ្បិតវាគិតក្នុងចិត្តថា អញអង្គុយ
ជាមហាក្សត្រី មិនមែនជាមេម៉ាយទេ ក៏មិនត្រូវមានសេចក្តី
សោកសង្រេងឡើយ[រ] ៨ដោយហេតុនោះបានជាសេចក្តី
វេទនារបស់វា នឹងមកដល់ក្នុងថ្ងៃតែ១វិញ[ល] គឺជាសេចក្តី
ស្លាប់សោកសង្រេង និងអំណត់អត់ ហើយវានឹងត្រូវភ្លើង
ឆេះទៅ[វ] ដ្បិតព្រះអម្ចាស់ដ៏ជាព្រះ ដែលជំនុំជំរះវា ទ្រង់
ខ្លាំងពូកែណាស់ ៩នោះពួកស្តេចនៅផែនដីដែលសហាយ
ស្មន់[ស] ហើយរស់ដោយហ៊ឺហារជាមួយនឹងវា[ហ] គេនឹងយំទួញ
ហើយសោកសង្រេង[ឡ] ក្នុងកាលដែលឃើញផ្សែងហុយ
ឡើង ពីភ្លើងដែលកំពុងតែឆេះវានោះ[អ] ១០គេនឹងឈរពី
ចំងាយ[ក] ដោយខ្លាចសេចក្តីវេទនារបស់វា ទាំងនិយាយថា
វេទនា ៗ ហើយ ក្រុងបាប៊ីឡូនដ៏ជាធំ[ខ] ហើយខ្លាំងពូកែ

**១៨:២** ឍ អស ១៣:២១,២២ ៣៤:១១,១៣–១៥ យរ ៥០:៣៩ ៥១:៣៧ សផ ២:១៤,១៥
**១៨:៣** ណ វវ ១៤:៨ ត វវ ១៧:២ ថ ខ.១១,១៥,២៣ អគ ២៧:៩–២៥ ទ ខ.៧,៩
**១៨:៤** ធ អស ៤៨:២០ យរ ៥០:៨ ៥១:៦,៩,៤៥ ២កថ ៦:១៧ ន លប ១៩:១៥
**១៨:៥** ប ២របា ២៨:៩ អរ ៩:៦ យរ ៥១:៩ ផ វវ ១៦:១៩
**១៨:៦** ព ទដ ១៣៧:៨ យរ ៥០:១៥,២៩ ភ អស ៤០:២ ម វវ ១៤:១០ ១៦:១៩ ១៧:៤
**១៨:៧** យ អគ ២៨:២–៨ រ ទដ ១០:៦ អស ៤៧:៧,៨ សផ ២:១៥
**១៨:៨** ល ខ.១០ អស ៩:១៤ ៤៧:៩ យរ ៥០:៣១,៣២ វ វវ ១៧:១៦
**១៨:៩** ស ខ.៣ វវ ១៤:៨ ១៧:២,៤

អើយ ដ្បិតសេចក្តីជំនុំជំរះឯងបានសំរេចក្នុងខណៈតែ១
ម៉ោង[គ]ទេ។
១១ឯពួកជំនួញ[ឃ]នៅផែនដី គេយំទួញ ហើយសោក
សង្រេង[ង]នឹងវា ដោយព្រោះគ្មានអ្នកណាទិញទំនិញរបស់
គេទៀតឡើយ[ច] ១២ឯទំនិញនោះ គឺជាមាស ប្រាក់
ត្បូងមានដំឡៃ កែវមុក្តា សំពត់ទេស ព្រៃ ល័ខពណ៌ស្វាយ
ពណ៌ក្រហម ឈើក្រអូបគ្រប់យ៉ាង អស់ទាំងគ្រឿងធ្វើពីភ្លុក
ហើយពីឈើមានដំឡៃ ពីលង្ហិន ពីដែក ហើយពីថ្មកែវ[ឆ]
១៣សម្បុរល្វែង ជ័រល្វីងទេស ទឹកអប់ កំញានគ្រឿងក្រអូប
ស្រាទំពាំងបាយជូរ ប្រេង ម្សៅម៉ដ្ឋ ស្រូវសាលី គោ ចៀម
សេះ រទេះ ហើយទាំងខ្លួនប្រាណ នឹងព្រលឹងមនុស្សផង[ជ]
១៤ឯអស់ទាំងផលផ្លែ ដែលចិត្តឯងប្រាថ្នាចង់បាន នោះ
បានថយចេញពីឯងហើយ ព្រមទាំងរបស់ថ្លៃវិសេស នឹង
របស់ភ្លឺរុងរឿងដែរ ឯងនឹងមិនឃើញទៀតឡើយ ១៥ពួក
ជំនួញ ដែលជួញរបស់ទាំងនោះ ហើយបានត្រឡប់ជាមាន
ដោយសារក្រុងនោះ[ឈ] គេយំទួញ ទាំងសោកសង្រេង[ញ]
ហើយឈរពីចំងាយ[ដ] ដោយខ្លាចសេចក្តីវេទនារបស់វា
១៦ក៏និយាយថា វេទនា ៗ ហើយ ទីក្រុងដ៏ធំ[ឋ]ដែលបានស្លៀក
ពាក់ ដោយសំពត់ទេស ពណ៌ស្វាយ នឹងពណ៌ក្រហម ទាំង
តែងខ្លួនដោយមាស នឹងត្បូងមានដំឡៃ ហើយកែវមុក្តាផង[ឌ]
១៧ដ្បិតទ្រព្យសម្បត្តិដ៏ច្រើនម្ល៉េះនេះ បានវិនាសបាត់ទៅ[ឍ]

ហ ខ.៣,៧ ឡ យរ ៥១:៨ អគ ២៦:១៧,១៨ អ ខ.១៨ វវ ១៤:១១ ១៩:៣
**១៨:១០** ក ខ.១៥ ខ ខ.១៦,១៩ គ ខ.១៧ វវ ១៧:១២ **១៨:១១** ឃ អគ ២៧:២៧ ង ខ.១៥,១៩ អគ ២៧:៣១ ច ខ.៣ **១៨:១២** ឆ អគ ២៧:១២–២២ វវ ១៧:៤ **១៨:១៣** ជ អគ ២៧:១៣ ១ធថ ១:១០ **១៨:១៥** ឈ ខ.៣ ញ ខ.១១,១៩ អគ ២៧:៣១ ដ ខ.១០,១៧ **១៨:១៦** ឋ ខ.១០,១៩ ឌ វវ ១៧:៤ **១៨:១៧** ឍ វវ ១៧:១៦

**១៨:៣** *ស្រារបស់សេចក្តីឃោរឃៅផងសេចក្តីកំផិត* មើលពន្យល់ ១៤:៨ ។
**១៨:៤** *ចូរចេញពីទីក្រុងនោះ* ត្រង់ចំណុចនេះគឺជាសេចក្តីថ្លែងព្រមាន (អស ៥២:១១ យរ ៥១:៤៥ ២កថ ៦:១៧) ។
**១៨:៦** *ទាំងទ្វេ១ជា២* និយាយអំពីសេចក្តីវេទនាយ៉ាងពេញទី ឬពេញបន្ទុកនៅក្នុងទីក្រុងបាប៊ីឡូន (មើលពន្យល់ អស ៤០:២) ។ *ពែង* មើល ១៧:៤ ។
**១៨:៧** *មិនមែនជាមេម៉ាយទេ* ត្រង់នេះជាសេចក្តីប្រកាសដែលមានន័យថា បុរស ៗ នៅក្រុងបាប៊ីឡូនមិនទាន់ស្លាប់នៅក្នុងសមរភូមិអស់នោះទេ ។
**១៨:៩–២០** នៅត្រង់នេះមានមនុស្សបីក្រុមដែលយំទួញ និងសោកសង្រេងនោះគឺ (១).ស្តេច (ខ.៩) (២).ពួកជំនួញ (ខ.១១) (៣).ពួសំពៅ (ខ.១៧) ។ វគ្គនេះត្រូវបានប្រាប់ពីគំរូនៃការថ្លែងទំនាយពីក្រុងទីរ៉ុស (អគ ២៧) របស់ហោរាអេសេគាលអំពីសេចក្តីទួញយំ ។ វត្ថុមានតម្លៃ១៥មុខនៅក្នុងចំណោម ២៩មុខដែលបានចែងនៅក្នុង ខ.១២–១៣ ហើយក៏បានចែងនៅក្នុង អគ ២៧:១២–២២ ។
**១៨:៩** *ពួកស្តេច . . . យំទួញ ហើយសោកសង្រេង* នៅត្រង់នេះប្រហែលជានិយាយអំពីវិបត្តិហិរញ្ញវត្ថុផ្ទាល់របស់ពួកគេ (ខ.១១) ។
**១៨:១០** *តែ១ម៉ោង* ត្រង់នេះគឺជាការនិយាយម្តងទៀតនៅក្នុងខ.១៧,១៩ និងមើលការពន្យល់ ១៧:១២ ។
**១៨:១២** *ពណ៌ស្វាយ* គឺជាពណ៌មួយដែលត្រូវបានគេយកមកពីតំណក់នៃការស្រក់នៃខ្យងម្យ៉ាងដែលមានបន្លា ៗ ហេតុនេះហើយបានជាវាមានតម្លៃថ្លៃ ។ *ឈើមានដំឡៃ* គឺជាឈើពណ៌ខ្មៅម្យ៉ាង ដែលត្រូវបានគេយកមកពីអាហ្វ្រិកខាងជើង សម្រាប់ឆ្លាក់ធ្វើគ្រឿងសង្ហារឹមថ្លៃ ៗ ។ *កែវមុក្តា* គឺជាវត្ថុមួយសម្រាប់តែងលំអរអាគារសាធារណៈនិងវិមាន ឬគេហដ្ឋានរបស់ពួកអ្នកមាន ។
**១៨:១៣** *ជ័រល្វីងទេស* គឺជាអំណោយដែលហោរនាំមកថ្វាយដល់បុត្រតូចព្រះយេស៊ូវ (មថ ២:១១) ។ *ទាំងខ្លួនប្រាណ និងព្រលឹងមនុស្ស* ត្រង់នេះនិយាយអំពីការទិញដូរទាសករ ។
**១៨:១៧** *តៃកុង* គឺសំដៅអ្នកបើកបរកប៉ាល់ គឺពុំប្រាកដថាជាម្ចាស់កប៉ាល់នោះទេ (កថ ២៧:១១) ។

ក្នុងខណៈតែ ១ ម៉ោងប៉ុណ្ណោះ[ណ] អស់ទាំងតៃកុង នឹងពួក
សំពៅទាំងអស់ ពួកជើងឈ្នួល នឹងអស់អ្នកដែលរកស៊ីខាង
ជើងទឹក[ត] គេក៏ឈរពីចំងាយ[ថ] ១៨ទាំងស្រែកឡើង ដោយ
ឃើញផ្សែងហុយឡើងពីភ្លើង[ទ] ដែលឆេះវានោះថា តើមាន
ទីក្រុងណាឱ្យដូចជាក្រុងធំ[ធ]នេះ[ន] ១៩ហើយគេបាចធូលីដីទៅ
លើក្បាលខ្លួនគេ[ប] ទាំងស្រែកឡើង ដោយយំទួញ ហើយ
សោកសង្រេងថា[ផ] "វេទនា ៗ ហើយ ទីក្រុងដ៏ធំ[ព] ដែលអស់
ពួកអ្នកមាននាវាដើរសមុទ្របានមានឡើង ដោយសារ
សេចក្ដីប្រសើររុងរឿងរបស់វា ពីព្រោះវាត្រូវចោលស្ងាត់
ទៅ ក្នុងខណៈតែ១ម៉ោង[ភ] ។
២០ឱស្ថានសួគ៌ ពួកសាវក នឹងពួកហោរាបរិសុទ្ធអើយ[ម]
ចូរអរសប្បាយនឹងទីក្រុងនោះឡើង ដ្បិតព្រះទ្រង់បានកាត់
ទោស តាមសេចក្ដីជំនុំជំរះរបស់ឯងរាល់គ្នាហើយ[យ]
២១នោះមានទេវតាខ្លាំងពូកែ១រូប[រ] បានលើកថ្ម ដូចជាថ្ម
ត្បាល់កិនយ៉ាងធំ ទំលាក់ចុះទៅក្នុងសមុទ្រ[ល] ដោយពោលថា
ទីក្រុងបាប៊ីឡូនដ៏ជាធំ[វ] នឹងត្រូវបោះទំលាក់ទៅ ដោយ
គំហុកយ៉ាងដូច្នេះ គេនឹងរកទៀតមិនឃើញឡើយ ២២ក៏នឹង
គ្មានឮសំឡេងនៃពួកអ្នកចាប់ស៊ុង ច្រៀងចំរៀង ផ្លុំខ្លុយ នឹង
ត្រែនៅក្នុងឯងទៀតឡើយ[ស] ហើយមិនឃើញមានជាងណា
ដែលធ្វើការអ្វីក៏ដោយនៅក្នុងឯង ឬឮសូរត្បាល់កិននៅ
ក្នុងឯងទៀតឡើយ[ហ] ២៣នឹងគ្មានពន្លឺចង្កៀង ណាភ្លឺនៅក្នុង
ឯង ឬឮសំឡេងប្ដីប្រពន្ធថ្មោងថ្មី នៅក្នុងឯងទៀតឡើយ[ឡ]
ដ្បិតពួកជំនួញរបស់ឯង នោះជាអ្នកធំនៅផែនដី[អ] ពីព្រោះ
អស់ទាំងសាសន៍បានវង្វេង ដោយសារការមន្តអាគម
របស់ឯង[ក] ២៤រីឯនៅក្នុងទីក្រុងនោះ ឃើញមានសុទ្ធតែ
ឈាមនៃពួកហោរា នឹងពួកបរិសុទ្ធ[ខ] ហើយនឹងឈាមនៃ
អស់អ្នក ដែលត្រូវគេសំឡាប់នៅផែនដីដែរ[គ] ។

**១៨:១៧** ណ ខ.១០ វវ ១៧:១២
ត អគ ២៧:២៨–៣០
ថ ខ.១០,១៥
**១៨:១៨** ទ ខ.៩ វវ ១៩:៣ ធ វវ ១៧:១៨
ន អគ ២៧:៣២ វវ ១៣:៤
ប យស ៧:៦ បទ ២:១០
អគ ២៧:៣០ ផ ខ.១១,១៥ អគ ២៧:៣១ ព ខ.១០,១៦ វវ ១៧:១៨
**១៨:១៩** ភ វវ ១៧:១៦
**១៨:២០** ម យរ ៥១:៤៨ វវ ១២:១២
យ វវ ១៩:២
**១៨:២១** រ វវ ៥:២ ១០:១ ល យរ ៥១:៦៣ វ វវ ១៧:១៨
**១៨:២២** ស អស ២៤:៨ អគ ២៦:១៣
ហ យរ ២៥:១០
**១៨:២៣** ឡ យរ ៧:៣៤ ១៦:៩ ២៥:១០
អ ខ.៣ អស ២៣:៨
ក ណហ ៣:៤
**១៨:២៤** ខ វវ ១៦:៦ ១៧:៦
គ យរ ៥១:៤៩ មថ ២៣:៣៥
**១៩:១** ឃ ខ.៦ វវ ១១:១៥

## ហាលេលូយ៉ា

**១៩** ១ក្រោយនោះមក ខ្ញុំឮសំឡេងយ៉ាងខ្លាំង របស់មនុស្ស
១ ហ្វូងដ៏ធំ[ឃ] នៅលើស្ថានសួគ៌ថា ហាលេលូយ៉ា[ង] សេចក្ដី
សង្គ្រោះ[ច] សិរីល្អ នឹងព្រះចេស្តា[ឆ] នោះជារបស់ផងព្រះនៃ
យើងរាល់គ្នាហើយ ២ដ្បិតសេចក្ដីជំនុំជំរះរបស់ទ្រង់សុទ្ធ
តែពិតត្រង់[ជ] ហើយសុចរិតទាំងអស់ ពីព្រោះទ្រង់បានកាត់
ទោសស្រីសំផឹងដ៏ធំនោះ[ឈ] ដែលបង្ខូចផែនដី ដោយការ
កំផិតរបស់វា ទ្រង់ក៏សងសឹក ដោយព្រោះឈាមពួកបាវ
បំរើរបស់ទ្រង់ ដែលវាបានកំចាយ[ញ] ៣ពួកនោះក៏ពោល
ពាក្យម្ដងទៀតថា ហាលេលូយ៉ា[ដ] ហើយផ្សែងវាក៏ហុយ
ឡើងនៅអស់កល្បជានិច្ចរៀងរាបតទៅ[ឋ] ៤ពួកចាស់ទុំទាំង
២៤ នាក់[ឌ] នឹងតួមានជីវិតទាំង ៤[ឍ] ក៏ទំលាក់ខ្លួនក្រាបចុះ[ណ]
ថ្វាយបង្គំចំពោះព្រះ ដែលគង់លើបល្ល័ង្ក ដោយនិយាយថា
អាម៉ែន ហាលេលូយ៉ា[ត] ៥រួចមានសំឡេងចេញពីបល្ល័ង្ក
មកថា អស់ទាំងបាវបំរើទ្រង់[ថ]នឹងពួកអ្នកដែលកោតខ្លាច
ទ្រង់ ទាំងធំទាំងតូចអើយ ចូរសរសើរដល់ព្រះនៃយើង
រាល់គ្នាចុះ[ទ] ៦នោះខ្ញុំឮសូរដូចជាសំឡេងនៃមនុស្ស ១ ហ្វូង
យ៉ាងធំ[ធ] ដូចសូរទឹកច្រើន[ន] ហើយដូចសូរផ្គរលាន់យ៉ាងខ្លាំង
ថា ហាលេលូយ៉ា[ប] ដ្បិតព្រះអម្ចាស់ដ៏ជាព្រះ ដែលមានព្រះ
ចេស្តាបំផុត[ផ] ទ្រង់សោយរាជ្យឡើងហើយ[ព] ៧ចូរឱ្យយើង
អរសប្បាយ ហើយរីករាយឡើង ទាំងថ្វាយសិរីល្អដល់ទ្រង់
ចុះ[ភ] ដ្បិតបានដល់ពេលរៀបវិវាហមង្គលនៃកូនចៀម

ង ខ.៣,៤,៦ ច វវ ៧:១០ ១២:១០ ឆ វវ ៤:១១ ៧:១២
**១៩:២** ជ វវ ១៦:៧ ឈ វវ ១៧:១ ញ វវ ៦:១០ **១៩:៣** ដ ខ.១,៤,៦
ឋ អស ៣៤:១០ វវ ១៤:១១ **១៩:៤** ឌ វវ ៤:៤ ឍ វវ ៤:៦ ណ វវ ៤:១០
ត ខ.១,៣,៦ **១៩:៥** ថ ទដ ១៣៤:១ ទ ខ.១៨ ទដ ១១៥:១៣ វវ ១១:១៨
១៣:១៦ ២០:១២ **១៩:៦** ធ ខ.១ វវ ១១:១៥ ន វវ ១:១៥ ប ខ.១,៣,៤
ផ វវ ១:៨ ព វវ ១១:១៥ **១៩:៧** ភ វវ ១១:១៣

**១៨:១៩** *បាចធូលីដីទៅលើក្បាល* ចំណុចនេះគឺជាសកម្មភាពនៃភាពសោកស្ដាយ និងភាពស្រងាកចិត្ត (អគ ២៧:៣០) ។ *១ម៉ោង* មើល ខ.១០,១៧ ។

**១៨:២០** *ព្រះទ្រង់បានកាត់ទោស តាមសេចក្ដីជំនុំជំរះរបស់ឯងរាល់គ្នា* មានន័យថា ជញ្ជីងនៃសេចក្ដីយុត្តិធម៌ត្រូវតែមានលំនឹង ។

**១៨:២១** *ត្បាល់កិនយ៉ាងធំ* ត្បាល់កិននៅក្នុងខនេះគឺស្រដៀងនឹងត្បាល់កិននៅក្នុងគម្ពីរម៉ាកុស (មក ៩:៤២) ម្យ៉ាងទៀតត្រូវបានគេហៅថា "ត្បាល់កិនសត្វលា" ដោយយកសត្វលាមកអូស ។

**១៨:២៤** *ឈាមនៃពួកហោរា* មើល ៦:១០ ១៧:៦ ១៩:២ អគ ២៤:៧ ។ *ហោរា . . . ពួកបរិសុទ្ធ* ត្រង់នេះពុំមែនជាមនុស្សពីរក្រុមខុសគ្នានោះទេ ។ ពួកហោរាក៏អាចជាមនុស្សពិសេស នៅក្នុងចំណោមពួកបរិសុទ្ធនោះដែរ (១៦:៦) ។

**១៩:១** *មនុស្ស១ហ្វូងដ៏ធំ* មើលការពន្យល់ ៧:៩ ។ *ហាលេលូយ៉ា* ពាក្យនេះមានរហូតដល់ទៅចំនួន៤ដងនៅក្នុង ខ.១–៦ គ្មានកន្លែងណាផ្សេងទៀតឡើយនៅក្នុងគម្ពីរសញ្ញាថ្មី ។ ពាក្យនេះមានប្រភពមកពីភាសាហេព្រើរ ពីរព្យាង្គដែលមានន័យថា "សរសើរព្រះអម្ចាស់" (មើលពន្យល់ ទដ ១៣៥:១) ។

**១៩:២** *ស្រីសំផឹងដ៏ធំ* មើល ១៧:១,៥,១៨ និងការពន្យល់ ១៤:៨ ។ *សងសឹកដោយ ព្រោះ . . . បំរើរបស់ទ្រង់* មើលសេចក្ដីអធិស្ឋាននៅក្នុង ៦:១០ ១៦:៦ ១៨:២០ ។

**១៩:៤** *ពួកចាស់ទុំទាំង២៤នាក់ និងពួកមានជីវិតទាំង៤* មើលការពន្យល់ ៤:៤,៦ ។

**១៩:៧** *វិវាហមង្គលនៃកូនចៀម* ត្រង់នេះគឺជារូបភាពនៃការរៀបការមួយដែលបានបញ្ជាក់អំពីទំនាក់ទំនងដ៏ជិតស្និទ្ធរវាងព្រះអម្ចាស់ ហើយនិងរាស្ត្ររបស់ទ្រង់ (ជាកូនមុំ) ដែលមានឫសគល់របស់វាចេញមកពីទំនាយនៅក្នុងគម្ពីរសញ្ញាចាស់ (អស ៥៤:៥–៧ ហាស ២:១៩) និងក្នុងគម្ពីរសញ្ញាថ្មី (មថ

ហើយ[ម] ភរិយាទ្រង់[យ]បានរៀបខ្លួនជាស្រេច ៨ទ្រង់ប្រទានឱ្យ
នាងបានស្លៀកពាក់សំពត់ទេសយ៉ាងម៉ដ្ឋ[រ]ស្អាតហើយភ្លឺ
ដ្បិតសំពត់ទេសយ៉ាងម៉ដ្ឋ នោះជាសេចក្ដីសុចរិត[ល]របស់
ពួកបរិសុទ្ធ ៩ទេវតាក៏ប្រាប់មកខ្ញុំថា[វ] ចូរសរសេរថា[ស]
មានពរហើយ អស់អ្នកដែលព្រះបានហៅមកបរិភោគការ
កូនចៀម[ហ] ក៏និយាយមកខ្ញុំទៀតថា នេះជាព្រះបន្ទូលពិត
របស់ព្រះ[ឡ] ១០នោះខ្ញុំទំលាក់ខ្លួនចុះ នៅទៀបជើងទេវតា
នោះ ដើម្បីថ្វាយបង្គំ[អ] តែទេវតាប្រាប់ខ្ញុំថា កុំឱ្យធ្វើដូច្នេះ
ឡើយ ដ្បិតខ្ញុំជាបាវបំរើជាមួយនឹងអ្នក ហើយនឹងបងប្អូន
អ្នក ដែលមានសេចក្ដីបន្ទាល់ពីព្រះយេស៊ូវដែរ ចូរថ្វាយ
បង្គំដល់ព្រះវិញ[ក] ដ្បិតការធ្វើបន្ទាល់ពីព្រះយេស៊ូវ[ខ] នោះ
ហើយជាវិញ្ញាណនៃសេចក្ដីទំនាយ ។

## ព្រះអង្គដែលគង់នៅលើសេះសរ

១១ខ្ញុំក៏ឃើញមេឃបើកចំហឡើង[គ]នោះឃើញមានសេះ
ស១ នឹងព្រះអង្គដែលគង់លើវា[ឃ] ទ្រង់មានព្រះនាមថា
«ស្មោះត្រង់ ហើយពិតប្រាកដ»[ង] ទ្រង់ជំនុំជំរះ ហើយច្បាំង
ដោយសុចរិត[ច] ១២ព្រះនេត្រទ្រង់ដូចជាអណ្ដាតភ្លើង[ឆ] ហើយ
នៅលើព្រះសិរសា មានមកុដជាច្រើន[ជ] ទ្រង់មានព្រះនាម
កត់ទុក[ឈ] ដែលគ្មានអ្នកណាស្គាល់ឡើយ លើកតែអង្គទ្រង់
ប៉ុណ្ណោះ[ញ] ១៣ទ្រង់ក៏ទ្រង់ព្រះពស្ត្រជ្រលក់ដោយឈាម[ដ]
ហើយព្រះនាមទ្រង់ហៅថា «ព្រះបន្ទូលនៃព្រះ»[ឋ] ១៤អស់
ទាំងពលបរិវារនៅស្ថានសួគ៌ ក៏ជិះសេះសដង្ហែទ្រង់ ទាំង
ស្លៀកពាក់សំពត់ទេស[ឌ] ហើយស្អាតផង[ឍ] ១៥មានដាវយ៉ាង
មុត[ណ]ចេញពីព្រះឱសទ្រង់ ដើម្បីនឹងកាប់[ត]អស់ទាំងសាសន៍
ហើយទ្រង់នឹងឃ្វាលគេ ដោយដំបងដែក[ថ] ទ្រង់ក៏ជាន់ក្នុង
ធុងឃ្នាបនៃស្រាទំពាំងបាយជូរ[ទ] ជាសេចក្ដីឃោរឃៅ
របស់សេចក្ដីខ្ញាល់នៃព្រះដ៏មានព្រះចេស្ដាបំផុត ១៦ទ្រង់
មានព្រះនាមកត់នៅព្រះពស្ត្រ ហើយនៅព្រះឧរូទ្រង់ថា[ធ]
«ស្ដេចលើអស់ទាំងស្ដេច ជាព្រះអម្ចាស់លើអស់ទាំង
ព្រះអម្ចាស់»[ន] ។

១៧ខ្ញុំក៏ឃើញទេវតា១ឈរនៅលើព្រះអាទិត្យបន្លឺដោយ
សំឡេងយ៉ាងខ្លាំង ដល់គ្រប់ទាំងសត្វដែលហើរ[ប]លើ
អាកាស[ផ]ថា ចូរមក[ព]ប្រជុំគ្នា នឹងស៊ីលៀងដ៏ធំរបស់ព្រះ
ចុះ[ភ] ១៨ដើម្បីនឹងស៊ីសាច់នៃពួកស្ដេច ពួកមេទ័ព ពួកមនុស្ស
ខ្លាំងពូកែ ព្រមទាំងសេះ ហើយនឹងពួកអ្នកដែលជិះដែរ គឺ
ជាសាច់នៃមនុស្សទាំងអស់[ម] ទាំងអ្នកជា នឹងខ្ញុំគេ[យ]ទាំងអ្នក
ធំ និងអ្នកតូចផង[រ] ។

១៩ខ្ញុំក៏ឃើញសត្វនោះ[ល] នឹងពួកស្ដេចនៅផែនដី[វ] ព្រម
ទាំងពលទ័ពគេ បានប្រមូលគ្នា ដើម្បីច្បាំងនឹងព្រះអង្គ
ដែលគង់នៅលើសេះសនោះ[ស] នឹងពួកពលទ័ពរបស់ទ្រង់
ផង ២០សត្វនោះក៏ត្រូវចាប់បាន ព្រមទាំងហោរាក្លែង
ក្លាយ[ហ] ដែលនៅជាមួយផង ជាអ្នកដែលធ្វើទីសំគាល់[ឡ]នៅ
មុខវា[អ] ដើម្បីនឹងបញ្ឆោតពួកអ្នក[ក] ដែលទទួលទីសំគាល់
របស់សត្វ[ខ] នឹងពួកអ្នកដែលក្រាបថ្វាយបង្គំដល់រូបវា[គ]

**១៩:៧** ម ខ.៩ មថ ២២:២ ២៥:១០ អភ ៥:៣២ យ វវ ២១:២,៩ ២២:១៧ **១៩:៨** រ ខ.១៤ វវ ១៥:៦ ល អស ៦១:១០ អគ ៤៤:១៧ សក ៣:៤ វវ ១៥:៤ **១៩:៩** វ ខ.១០ ស វវ ១:១៩ ហ លក ១៤:១៥ ឡ វវ ២១:៥ ២២:៦ **១៩:១០** អ វវ ២២:៨ ក កច ១០:២៥,២៦ វវ ២:៩ ខ វវ ១:២ **១៩:១១** គ មថ ៣:១៦ ឃ ខ.១៩,២១ វវ ៦:២ ង វវ ៣:១៤ ច នក ១៥:៣ ទដ ៩៦:១៣ អស ១១:៤ **១៩:១២** ឆ វវ ១:១៤ ជ វវ ៦:២ ១២:៣ ឈ ខ.១៦ ញ វវ ២:១៧ **១៩:១៣** ដ អស ៦៣:២,៣ ឋ យហ ១:១ **១៩:១៤** ឌ ខ.៨ ឍ វវ ៣:៤ **១៩:១៥** ណ ខ.២១ វវ ១:១៦
ត អស ១១:៤ ២ថស ២:៨ ថ ទដ ២:៩ វវ ២:២៧ ១២:៥ ទ វវ ១៤:២០ **១៩:១៦** ធ ខ.១២ ន ១ធម ៦:១៥ **១៩:១៧** ប ខ.២១ ផ វវ ៨:១៣ ១៤:៦ ព យរ ១២:៩ អគ ៣៩:១៧ ភ អស ៣៤:៦ យរ ៤៦:១០ **១៩:១៨** ម អគ ៣៩:១៨–២០ យ វវ ៦:១៥ រ ខ.៥ **១៩:១៩** ល វវ ១៣:១ វ វវ ១៦:១៤,១៦ ស ខ.១១,២១ **១៩:២០** ហ វវ ១៦:១៣ ឡ មថ ២៤:២៤ អ វវ ១៣:១២ ក វវ ១៣:១៤ ខ វវ ១៣:១៦

២២:២–១៤ អភ ៥:៣២) ។

**១៩:៩** *មានពរ* គឺជាសុភមង្គលទីបួន (មើលពន្យល់ ១:៣) ។ *បរិភោគការ* មើល មថ ៨:១១ លក ១៤:១៥ និងការពន្យល់ ២២:១៦ ។

**១៩:១០** *ទំលាក់ខ្លួនចុះនៅទៀបជើង* មើលពន្យល់ ១:១៧ កច ១០:២៥ ។ *ជាវិញ្ញាណនៃសេចក្ដីទំនាយ* ត្រង់នេះអាចមានន័យទាំងពីរថា ឃ្លានេះបានបញ្ជាក់ដោយព្រះយេស៊ូវ គឺជាសារសំខាន់នៃសេចក្ដីប្រកាសទំនាយ ឬក៏បញ្ជាក់ដោយព្រះយេស៊ូវគឺជាវិញ្ញាណដែលដាក់ និងចេញពីមាត់របស់ហោរាគ្រីស្ទបរិស័ទ ។

**១៩:១១** *សេះស១* សេះត្រង់នេះប្រហែលពុំមែនជាសេះដែលនិយាយនៅក្នុង ៦:២ នោះទេ ។ អត្ថន័យបន្ថែមរបស់ពាក្យនេះគឺបង្ហាញថា អ្នកជិះសេះនេះគឺជាព្រះគ្រីស្ទ ដែលយាងត្រឡប់មកវិញ ធ្វើជាអ្នកចម្បាំង ព្រះមែស៊ី និងជាស្ដេច ។

**១៩:១២** *ព្រះនាមកត់ទុក* ជាព្រះនាមសម្ងាត់មួយដែលជាអត្ថន័យរបស់ព្រះនាមនេះត្រូវបានគេលាក់កំបាំងពីរបស់ដែលត្រូវបានបង្កើតមក ។

**១៩:១៣** *ជ្រលក់ដោយឈាម* ឈាមនៅត្រង់នេះអាចជាឈាមរបស់ពួកសត្រូវដែលខ្ចាយនៅក្នុងជម្លោះ (១៤:១៤–២០ អស ៦៣:១–៣) ឬអាចជាឈាមរបស់ព្រះគ្រីស្ទដែលបានខ្ចាយមកសម្រាប់មនុស្សមានបាប ។

**១៩:១៤** *ពលបរិវារនៅស្ថានសួគ៌* ជាពួកទេវតា (ចទ ៣៣:២ ទដ ៦៨:១៧) ហើយអាចពួកអ្នកជឿព្រះផងដែរ (១៧:១៤) ។

**១៩:១៥** *ដាវយ៉ាងមុត* មើលការពន្យល់ ១:១៦ ។ *ដំបងដែក* មើលការពន្យល់ ២:២៧ ។ *ជាន់ក្នុងធុងឃ្នាបនៃ . . . សេចក្ដីឃោរឃៅរបស់សេចក្ដីខ្ញាល់នៃព្រះ* មើលការពន្យល់ អស ៦៣:៣ ។ *ធុងឃ្នាបនៃស្រាទំពាំងបាយជូរ* មើលការពន្យល់ ១៤:១៩ ។

**១៩:១៦** *ស្ដេចលើអស់ទាំងស្ដេច* មើលការពន្យល់ ១៧:១៩ ។

**១៩:១៧** *ស៊ីលៀងដ៏ធំរបស់ព្រះ* ត្រង់នេះខុសគ្នាយ៉ាងខ្លាំងទៅនឹង"បរិភោគការកូនចៀម" (ខ.៩ អគ ៣៩:១៧–២០) ។

**១៩:១៩** មើលការពន្យល់ ១៦:១៦ ។

**១៩:២០** *សត្វ . . . ហោរាក្លែងក្លាយ* មើលពន្យល់ ១៣:១,១១ ។ *បឹងភ្លើងដែលឆេះដោយស្ពាន់ធ័រ* មើល ២០:១០,១៤–១៥ ២១:៨ ។ ត្រង់នេះគឺជាការដាក់ទោសដោយភ្លើង ដែលត្រូវបានបង្ហាញនៅក្នុងគម្ពីរ (មើលការ

ហើយវាទាំង២ ក៏ត្រូវបោះទាំងរស់ ទៅក្នុងបឹងភ្លើង[ឃ]
ដែលឆេះដោយស្ពាន់ធ័រ[ង] 21 ហើយពួកដែលសល់នៅ
ក៏ត្រូវស្លាប់ដោយដាវ[ច]របស់ព្រះអង្គ ដែលគង់លើសេះ ជា
ដាវដែលចេញពីព្រះឱស្ឋទ្រង់មក[ឆ] នោះអស់ទាំងសត្វ
ស្លាប[ជ] បានឆ្អែត ដោយសាច់នៃពួកទាំងនោះ ។

## រយៈពេល១ពាន់ឆ្នាំ

**២០** 1 ខ្ញុំក៏ឃើញទេវតា ១ ចុះពីស្ថានសួគ៌មក[ឈ] ទាំងកាន់
កូនសោរ[ញ]ជង្ហុកធំ[ដ]នឹងច្រវាក់១យ៉ាងធំនៅដៃ 2 ទេវតានោះ
ក៏ចាប់នាគចងវាទុក ១ ពាន់ឆ្នាំ គឺជាពស់ពីចាស់បុរាណ
ដែលជាអារក្សឈ្មោះថា សាតាំង[ឋ,ឌ] 3 ក៏បោះវាចោលទៅ
ក្នុងជង្ហុកធំ[ឍ]ទាំងខ្ទប់ ហើយបិទត្រាពីលើ[ណ] ដើម្បីកុំឱ្យវានាំ
អស់ទាំងសាសន៍ឱ្យវង្វេងទៀត[ត] ទាល់តែផុតពី ១ ពាន់ឆ្នាំ
នោះទៅ ក្រោយនោះត្រូវតែស្រាយវាលែងបន្តិច ។
4 ខ្ញុំក៏ឃើញបល្ល័ង្កជាច្រើន[ថ] នឹងពួកអ្នកដែលអង្គុយលើ
ហើយមានអំណាចបានប្រគល់ ដល់អ្នកទាំងនោះ ឱ្យ
ជំនុំជំរះ[ទ] នោះព្រលឹងមនុស្សទាំងប៉ុន្មានដែលត្រូវគេកាត់
ក្បាល[ធ] ដោយព្រោះធ្វើបន្ទាល់ពីព្រះយេស៊ូវ[ន] ហើយដោយ
ព្រោះព្រះបន្ទូលនៃព្រះ[ប] ព្រមទាំងពួកអ្នកដែលមិនបាន
ក្រាបថ្វាយបង្គំដល់សត្វនោះ[ផ] ឬរូបវា ក៏មិនបានទទួល
ទីសំគាល់វា នៅលើថ្ងាស ឬនៅលើដៃឡើយ[ព] អ្នកទាំង
នោះបានរស់វិញ ហើយក៏សោយរាជ្យ[ភ]ជាមួយនឹងព្រះ
គ្រីស្ទ នៅ១ពាន់ឆ្នាំ 5 តែមនុស្សស្លាប់ឯទៀត មិនបានរស់
វិញទេ ទាល់តែផុតពី១ពាន់ឆ្នាំនោះទៅ នេះហើយជាខណៈ
រស់ឡើងវិញទី១[ម] 6 មានពរហើយ[យ] ក៏បរិសុទ្ធផង អស់អ្នក
ណាដែលមានចំណែក ក្នុងខណៈរស់ឡើងវិញជាន់មុន
ដំបូងនេះ សេចក្ដីស្លាប់ទី២[រ]គ្មានអំណាចលើអ្នកទាំងនោះ
ឡើយ អ្នកទាំងនោះនឹងធ្វើជាពួកសង្ឃ[ល]នៃព្រះ និងព្រះ
គ្រីស្ទ ហើយនិងសោយរាជ្យជាមួយនឹងទ្រង់[វ]អស់១ពាន់ឆ្នាំ

## សាតាំងនាំឱ្យគេវង្វេង

7 លុះផុតពី១ពាន់ឆ្នាំនោះហើយ[ស] ទើបទ្រង់នឹងស្រាយ
អារក្សសាតាំងលែងពីគុកចេញ 8 នោះវានឹងចេញទៅខំ

**១៩:២០** គ វវ ១៣:១៥ ឃ ដយ ៧:១១ វវ ២០:១០, ១៤,១៥ ២១:៨ ង វវ ៩:១៧ **១៩:២១** ច ខ.១៥ វវ ១:១៦ ឆ ខ.១១,១៩ ជ ខ.១៧ **២០:១** ឈ វវ ១០:១ ១៨:១ ញ វវ ១:១៨ ដ លក ៨:៣១ **២០:២** ឋ មថ ៤:១០ ឌ អស ២៤:២២ ២ពត ២:៤ **២០:៣** ឍ ខ.១ ណ ដយ ៦:១៧ មថ ២៧:៦៦ ត ខ.៨,១០ វវ ១២:៩ **២០:៤** ថ ដយ ៧:៩ ទ មថ ១៩:២៨ វវ ៣:២១ ធ វវ ៦:៩ ន វវ ១:២

ប ហព ៤:១២ ផ វវ ១៣:១២ ព វវ ១៣:១៦ ភ ខ.៦ វវ ២២:៥ **២០:៥** ម ខ.៦ លក ១៤:១៤ ភល ៣:១១ ១ថន ៤:១៦ **២០:៦** យ វវ ១៤:១៣ រ វវ ២:១១ ល ១ពត ២:៥ វ ខ.៤ វវ ២២:៥ **២០:៧** ស ខ.២

ពន្យល់ បទ ១:១៣) និងសំណេរក្រៅពីគម្ពីររបស់សាសន៍យូដា ។ ការដាក់ទោសនៅត្រង់នេះ លោកយ៉ូហានពុំបាននិយាយត្រង់ៗអំពីការធ្លាក់ទៅស្ថាននរកនោះឡើយ (មើលការពន្យល់ មថ ៥:២២)។ ដើមកំណើតដំបូងរបស់បរិវេណនៃចេតិយស្ថាននោះ គឺជាកន្លែងដែលគេយកមនុស្សទៅបូជា(២ពវ ១៦:៣ ២៣:១០ យរ ៧:៣១) ក្រោយមកតំបន់នោះក៏ត្រឡប់ទៅជាមានអត្ថន័យស្មើនឹងពាក្យ "ស្ថាននរក" ដែលជាកន្លែងសម្រាប់ទទួលទោសក្រោយជំនុំជម្រះនៅថ្ងៃចុងក្រោយ ។

**១៩:២១** *អស់ទាំងសត្វស្លាបបានឆ្អែត* ត្រង់នេះសំដៅទៅលើពិធី"លៀងព្រះអម្ចាស់ដ៏ធំអស្ចារ្យ"(មើល ខ.១៧–១៨)។

**២០:១–២២:២១** បីជំពូកចុងក្រោយនៅត្រង់នេះបានឆ្លុះបញ្ចាំងដល់ប្រធានបទ និងសាច់រឿងជាច្រើនទៅនឹងគម្ពីរលោកុប្បត្តិបីជំពូកដំបូង (មើលការពន្យល់ សេចក្ដីផ្ដើមរបស់លោកុប្បត្តិ)។

**២០:១** *ជង្ហុកធំ* មើលការពន្យល់ ៩:១ ។

**២០:២** *នាគ* មើលពន្យល់ ១២:៣ ។ *ពស់ពីបុរាណ* សូមមើល ១២:១៥ លប ៣:១–៥ ។ *១ពាន់ឆ្នាំ* មានការបកស្រាយបីចំណុចដែលជាប់ទាក់ទងទៅនឹងរយៈពេល១ពាន់ឆ្នាំនេះគឺ (១).ការសោយរាជ្យនាពេលបច្ចុប្បន្ននៃព្រះគ្រីស្ទនៅនគរស្ថានសួគ៌(មថ ២៨:១៨–២០) ជាមួយនឹងព្រលឹងនៃអ្នកជឿដែលបានស្លាប់ទៅហើយនោះ ហើយនៅក្នុងចិត្ត និងជីវិតរបស់អ្នកជឿដែលកំពុងតែរស់នៅផែនដីនេះ(មើលការពន្យល់ ១កថ ១៥:២៥)។ រយៈពេល១ពាន់ឆ្នាំនៃនគររបស់ព្រះគ្រីស្ទនេះ នឹងភ្ជាប់មកជាមួយនូវការយាងត្រឡប់មកម្ដងទៀតរបស់ទ្រង់ អ្នកជឿទូទៅបានរស់ឡើងវិញ ការជំនុំជម្រះចុងក្រោយ និងការបន្តសោយរាជ្យរបស់ទ្រង់ នៅលើទឹកដីថ្មីដ៏គ្រប់លក្ខណ៍អស់កល្បជានិច្ច ។ (២).ទម្រង់បច្ចុប្បន្នកាលនៃនគរព្រះកំពុងតែធ្វើដំណើរឆ្ពោះទៅរកការយាងត្រឡប់មកជាលើកទីពីររបស់ព្រះគ្រីស្ទ នេះបើតាមន័យត្រង់ ។ ការរស់ឡើងវិញជាលើកដំបូងនឹងមកដល់ ហើយនគររបស់ទ្រង់ក៏នឹងត្រូវបានបើកសំដែង នៅពេលនោះសេចក្ដីសុចរិត និងសន្តិភាពនឹងមាននៅលើផែនដីនេះ បើវិភាគតាមប្រវត្តិសាស្ត្រ ។ បន្ទាប់ពីការរស់ឡើងវិញនៅថ្ងៃចុងក្រោយការជំនុំជម្រះចុងក្រោយ ហើយនិងការផ្លាស់ប្រែថ្មីនៃស្ថានសួគ៌ និងផែនដី នោះនគរនាពេលអនាគត និងនគរបណ្ដោះអាសន្ននឹងរួមបញ្ចូលគ្នាទៅជានគរតែមួយ ហើយព្រះអម្ចាស់នឹងសោយរាជ្យលើនគរនោះអស់កល្បជានិច្ចដរាបតទៅនៅលើផែនដីថ្មី ។ (៣).នៅក្នុងពិភពលោកនេះ ជាទូទៅមនុស្សដែលបានក្លាយជាគ្រីស្ទបរិស័ទនោះ គឺដោយសារការប្រកាសដំណឹងល្អ ដែលនឹងមានរយៈពេល១ពាន់ឆ្នាំនៃសេចក្ដីសុខសាន្ត និងភាពជោគជ័យ ។ ក្នុងពេលអនាគតឆាប់ៗខាងមុខនេះនឹងមានហេតុការណ៍នៃការយាងត្រឡប់មកជា លើកទីពីររបស់ព្រះគ្រីស្ទ មនុស្សស្លាប់នឹងរស់ឡើងវិញ សេចក្ដីជំនុំជម្រះចុងក្រោយ ហើយនិងមាននគរមួយស្ថិតនៅអស់កល្បជានិច្ច ។

**២០:៣** *ស្រាយវាលែងបន្តិច* មើល ខ.៧–១០ ។

**២០:៤** *ព្រលឹងមនុស្សទាំងប៉ុន្មាន ដែលត្រូវគេកាត់ក្បាល* មើល ៦:៩–១១ ។ *ទី សំគាល់* មើលការពន្យល់ ១៣:១៦ ។ *អ្នកនោះបានរស់វិញ* នេះគឺជារស់ឡើងវិញជាលើកដំបូង(ខ.៥)។

**២០:៥** *មនុស្សស្លាប់ឯទៀត មិនបានរស់វិញទេ* ត្រង់នេះគឺជាមនុស្សអាក្រក់ ឬក៏មនុស្សគ្រប់គ្នា លើកលែងតែអ្នករងគ្រោះ(ខ.៤)។

**២០:៦** *មានពរហើយ* នេះគឺជាព្រះពរទី៥(មើលការពន្យល់ ១:៣)។ *សេចក្ដីស្លាប់ទី២* មើលអត្ថន័យនៃពាក្យនេះនៅក្នុងខ.៤ ដូចជា"បឹងភ្លើង"(២១:៨)។

**២០:៧** *១ពាន់ឆ្នាំ* មើលការពន្យល់ ខ.២ ។

**២០:៨** *សាសន៍កុក និងសាសន៍ម៉ាកុក* ជានិមិត្តរូបនៃជាតិសាសន៍ទាំងឡាយនៅក្នុងលោកិយនេះ ដែលពួកគេរួមគ្នាប្រឆាំងនឹងព្រះ នាថ្ងៃចុងក្រោយ

នាំអស់ទាំងសាសន៍[ហ] ដែលនៅផែនដីទាំង៤ទិស[ឡ] ឱ្យវង្វេង
គឺទាំងសាសន៍កុក នឹងសាសន៍ម៉ាកុក[អ] ដើម្បីនឹងប្រមូលគេ
មកច្បាំង[ក] ចំនួនគេដូចជាខ្សាច់នៃសមុទ្រ[ខ] ៩នោះគេក៏ឡើង
ទៅពេញពាសលើផែនដី ទាំងឡោមព័ទ្ធ[គ]ទីដំឡើងត្រសាល
របស់ពួកបរិសុទ្ធ ហើយនឹងទីក្រុងស្ងួនភ្ងាដែរ[ឃ] តែមាន
ភ្លើងធ្លាក់ពីលើមេឃ[ង]មកអំពីព្រះ បញ្ឆេះគេទាំងអស់ទៅ
១០រួចអារក្សដែលនាំគេឱ្យវង្វេង[ច] បានត្រូវបោះទៅក្នុងបឹង
ដែលឆេះជាភ្លើង នឹងស្ពាន់ធ័រ[ឆ] ជាកន្លែងដែលសត្វនោះ[ជ]
នឹងហោរាក្លែងក្លាយនៅហើយ[ឈ] នោះវារាល់គ្នាត្រូវរង
ទុក្ខវេទនាទាំងយប់ទាំងថ្ងៃ នៅអស់កល្បជានិច្ចរៀងរាប
តទៅ[ញ]។

## ការជំនុំជម្រះមនុស្សស្លាប់

១១ខ្ញុំក៏ឃើញបល្ល័ង្កស ១[ដ]យ៉ាងធំ នឹងព្រះអង្គដែល
គង់លើ ឯផែនដី នឹងផ្ទៃមេឃ ក៏រត់ពីចំពោះទ្រង់ចេញ[ឋ]
ឥតឃើញមានកន្លែងណាឱ្យនៅទៀតឡើយ ១២នោះខ្ញុំ
ឃើញមនុស្សស្លាប់ ទាំងអ្នកធំ ទាំងអ្នកតូច[ឌ] គេឈរនៅ
ចំពោះព្រះ បញ្ជីក៏បានបើកឡើង[ឍ] ហើយបញ្ជី១ទៀត គឺ
ជាបញ្ជីជីវិត[ណ]បានបើកឡើងដែរ រួចមនុស្សស្លាប់ទាំង
អស់ត្រូវជំនុំជំរះ[ត] ពីសេចក្ដីដែលកត់ទុកក្នុងបញ្ជីទាំងនោះ
តាមអំពើដែលគេបានប្រព្រឹត្ត[ថ]រៀងខ្លួន ១៣ឯសមុទ្រនោះ
បានប្រគល់ពួកមនុស្សស្លាប់ ដែលនៅក្នុងទឹកមកវិញ ហើយ
សេចក្ដីស្លាប់ នឹងស្ថានឃុំព្រលឹងមនុស្សស្លាប់[ទ] ក៏ប្រគល់ពួក
មនុស្សស្លាប់[ធ] ដែលនៅឯណោះមកវិញដែរ រួចគេត្រូវជំនុំ
ជំរះ តាមអំពើដែលគេបានប្រព្រឹត្តរៀងខ្លួន[ន] ១៤ចំណែក
សេចក្ដីស្លាប់[ប] នឹងស្ថានឃុំព្រលឹងមនុស្សស្លាប់[ផ] នោះត្រូវ
បោះទៅក្នុងបឹងភ្លើងដែរ[ព] នេះជាសេចក្ដី ស្លាប់ទី ២[ភ] ១៥បើ
អ្នកណាគ្មានឈ្មោះកត់ទុកក្នុងបញ្ជីជីវិត[ម] អ្នកនោះត្រូវបោះ

**២០:៨** ហ ខ.៣,១០ វវ ១២:៩ ឡ អស ១១:១២ អគ ៧:២ វវ ៧:១ អ អគ ៣៨:២ ៣៩:១ ក វវ ១៦:១៤ ខ អគ ៣៨:៩,១៥ ហព ១១:១២
**២០:៩** គ អគ ៣៨:៩,១៦ ឃ ទដ ៨៧:២ ង អគ ៣៨:២២ ៣៩:៦ វវ ១៣:១៣
**២០:១០** ច ខ.៣,៨ វវ ១២:៩ ១៩:២០ ឆ វវ ៩:១៧ ជ វវ ៦:១៣ ឈ វវ ១៦:១៣ ញ វវ ១៤:១០,១១
**២០:១១** ដ វវ ៤:២ ឋ វវ ៦:១៤
**២០:១២** ឌ វវ ១៩:៥ ឍ ដយ ៧:១០ ណ ខ.១៥ នក ៣២:៣២ ចទ ២៩:២០ ដយ ១២:១ មឡ ៣:១៦ លក ១០:២០ វវ ៣:៥ ២១:២៧ ត វវ ១១:១៨ ថ យរ ១៧:១០ មថ ១៦:២៧
**២០:១៣** ទ វវ ១:១៨ ៦:៨ ធ អស ២៦:១៩ ន មថ ១៦:២៧
**២០:១៤** ប ១កថ ១៥:២៦ ផ ខ.១៣ ព វវ ១៩:២០

ទៅក្នុងបឹងភ្លើង ។

## ទីក្រុងយេរូសាឡិមថ្មី

**២១** ១រួចខ្ញុំឃើញផ្ទៃមេឃថ្មី នឹងផែនដីថ្មី[យ] ដ្បិតផ្ទៃមេឃ
មុន នឹងផែនដីមុនបានកន្លងបាត់ទៅហើយ[រ] ក៏គ្មានសមុទ្រ
ទៀតឡើយ ២ហើយយ៉ូហានខ្ញុំ ក៏ឃើញទីក្រុងដ៏បរិសុទ្ធ[ល] គឺ
ជាក្រុងយេរូសាឡិមថ្មី ចុះពីស្ថានសួគ៌មកអំពីព្រះ[វ] តាក់តែង
ដូចជាប្រពន្ធថ្មោងថ្មី[ស]តែងខ្លួនទទួលប្ដី ៣ខ្ញុំមានឮសំឡេង១
យ៉ាងខ្លាំង ចេញពីស្ថានសួគ៌មកថា មើលរោងឧបោសថ
របស់ព្រះ បាននៅជាមួយនឹងមនុស្សហើយ ទ្រង់នឹងគង់នៅ
ជាមួយនឹងគេ[ហ] គេនឹងធ្វើជារាស្ត្ររបស់ទ្រង់ ហើយព្រះអង្គ
ទ្រង់ក៏នឹងធ្វើជាព្រះដល់គេ[ឡ] ៤ព្រះទ្រង់នឹងជូតអស់ទាំងទឹក
ភ្នែក ពីភ្នែកគេចេញ[អ] នឹងគ្មានសេចក្ដីស្លាប់[ក] ឬសេចក្ដី
សោកសង្រេង ឬសេចក្ដីយំទួញ ឬទុក្ខលំបាកណាទៀត
ឡើយ[ខ] ដ្បិតសេចក្ដីមុខទាំងប៉ុន្មានបានកន្លងបាត់ទៅហើយ[គ]។
៥ឯព្រះអង្គ ដែលគង់លើបល្ល័ង្ក[ឃ] ទ្រង់មានបន្ទូលថា
មើល អញធ្វើទាំងអស់ឡើងជាថ្មី[ង] រួចទ្រង់មានបន្ទូលមកខ្ញុំ
ថា ចូរសរសេរទុកចុះ ដ្បិតពាក្យទាំងនេះពិតប្រាកដ ហើយ
គួរជឿ[ច] ៦ទ្រង់ក៏មានបន្ទូលមកខ្ញុំថា ស្រេចហើយ[ឆ]អញ
ជាអាលផា នឹងអូមេកា[ជ] គឺជាដើម ហើយជាចុង បើអ្នក
ណាស្រេក អញនឹងឱ្យអ្នកនោះផឹកពីរន្ធទឹកនៃជីវិត[ឈ] ឥត
យកថ្លៃ[ញ] ៧ឯអ្នកណាដែលឈ្នះ[ដ] នោះនឹងបានគ្រងសេចក្ដី

ភ វវ ២:១១ **២០:១៥** ម ខ.១២ **២១:១** យ ២ពត ៣:១៣ រ វវ ៦:១៤
**២១:២** ល ខ.១០ នហ ១១:១៨ អស ៥២:១ វវ ១១:២ ២២:១៩ វ ខ.១០ ហព ១១:១០ ១២:២២ វវ ៣:១២ ស វវ ១៩:៧ **២១:៣** ហ នក ២៥:៨ ២របា ៦:១៨ អគ ៤៨:៣៥ សក ២:១០ ឡ ២កថ ៦:១៦ **២១:៤** អ វវ ៧:១៧ ក អស ២៥:៨ ១កថ ១៥:២៦ វវ ២០:១៤ ខ អស ៣៥:១០ ៦៥:១៩ គ ២កថ ៥:១៧ **២១:៥** ឃ វវ ៤:៩ ២០:១១ ង ខ.៤ ច វវ ១៩:៩ ២២:៦
**២១:៦** ឆ វវ ១៦:១៧ ជ វវ ១:៨ ២២:១៣ ឈ អស ៥៥:១ ញ យហ ៤:១០
**២១:៧** ដ យហ ១៦:៣៣

(អគ ៣៨–៣៩) ។

**២០:១០** *រងទុក្ខវេទនាទាំងយប់ទាំងថ្ងៃ* មើល ១៤:១០ និងពន្យល់ ១៤:១១ ។

**២០:១២** *បញ្ជីជីវិត* មើលពន្យល់ ៣:៥ ។ *តាមអំពើ . . . ប្រព្រឹត្តរៀងខ្លួន* គោលការនៃសេចក្ដីជំនុំជម្រះ គឺឈរនៅលើមូលដ្ឋាននៃការងារត្រូវបានបង្រៀនក្នុង "ទដ ៦២:១២ យរ ១៧:១០ រម ២:៦ ១ពត ១:១៧" និងកន្លែងផ្សេងៗទៀត ។

**២០:១៣** *សេចក្ដីស្លាប់ និងស្ថានឃុំព្រលឹង* មើលការពន្យល់ ៦:៨ ។

**២០:១៤–១៥** *បឹងភ្លើង* មើលការពន្យល់ ១៩:២០ ។

**២១:២–២២:៥** "ទីក្រុងដ៏បរិសុទ្ធ" រួមទាំងធាតុផ្សេងៗនៃក្រុងយេរូសាឡិម ព្រះវិហារ និងសួនច្បារអេដែន(មើលសេចក្ដីផ្ដើមលោកុប្បត្តិ)។

**២១:២** *ក្រុងយេរូសាឡិមថ្មី* មើលការពន្យល់ កទ ៤:២៦ ។ *ប្រពន្ធថ្មោងថ្មី* មានន័យថា កូនក្រមុំទើបនឹងរៀបការរួច(មើលការពន្យល់ ១៩:៧)។

**២១:៣** *ទ្រង់នឹងគង់នៅជាមួយនឹងគេ* មើល ២៦:១១–១២ អគ ៣៧:២៧ ២កថ ៦:១៦ អភ ២:២១–២២ ។ *នៅជាមួយ . . . នៅជាមួយ* ត្រង់នេះបានបញ្ជាក់អំពីការប្រើវោហារស័ព្ទដ៏ប៉ិនប្រសប់របស់អត្ថន័យនៃពាក្យ "អេម៉ាញូអែល (មើលការពន្យល់ ២កថ ១៣:១៤)។ *ជារាស្ត្ររបស់ទ្រង់ . . . ព្រះដល់គេ* ត្រង់នេះគឺជាសេចក្ដីបញ្ជាក់ដ៏ជ្រៅបំផុតនៃការប្រកបគ្នា ដែលព្រះអម្ចាស់បានសន្យានៅក្នុងការតាំងសញ្ញានឹងរាស្ត្ររបស់ទ្រង់ (មើលការពន្យល់ អគ ៨:៨)។

**២១:៤** *ជូតអស់ទាំងទឹកភ្នែក* មើល ៧:១៧ អស ២៥:៨ ។

**២១:៦** *អាលផា និងអូមេកា* មើលការពន្យល់ ១:៨ ។ *រន្ធទឹកនៃជីវិត* មើល ទដ ៣៦:៩ និងការពន្យល់ យហ ៤:១០,១៤ ។

**២១:៧** *អ្នកណាដែលឈ្នះ* គឺសំដៅទៅលើការឈ្នះនៅក្នុងសេចក្ដីសំបុត្រទាំង៧ (២:៧,១១,១៧,២៦ ៣:៥,១២,២១)។

ទាំងនេះទុកជាមរដក អញនឹងធ្វើជាព្រះដល់អ្នកនោះ
ហើយអ្នកនោះនឹងធ្វើជាកូនរបស់អញ[ឋ] ៨តែត្រង់ពួកខ្លាច
ពួកមិនជឿ ពួកគួរខ្ពើម ពួកកាប់សំឡាប់គេ ពួកកំផិត ពួក
មន្តអាគម ពួកថ្វាយបង្គំរូបព្រះ ហើយគ្រប់ទាំងមនុស្ស
កំភូត[ឌ] គេនឹងមានចំណែក នៅក្នុងបឹងដែលឆេះជាភ្លើងនឹង
ស្ពាន់ធ័រ[ឍ] គឺជាសេចក្ដីស្លាប់ទី២វិញ[ណ]។
៩ក្នុងទេវតាទាំង៧ មានទេវតា១ ដែលកាន់ចានកន្ទោង
ដ៏ពេញដោយសេចក្ដីវេទនាទាំង៧[ត] ក្រោយបង្អស់ទេវតា
នោះបានមកនិយាយនឹងខ្ញុំថា ចូរមកឯណេះ ខ្ញុំនឹងបង្ហាញ
ឱ្យអ្នកឃើញប្រពន្ធថ្មោងថ្មី[ថ] ជាភរិយារបស់កូនចៀម
១០នោះទេវតាក៏នាំយក[ទ]វិញ្ញាណខ្ញុំ[ធ] ទៅលើភ្នំធំហើយខ្ពស់
បង្ហាញឱ្យខ្ញុំឃើញទីក្រុងបរិសុទ្ធ គឺជាក្រុងយេរូសាឡិម
ដែលកំពុងតែចុះពីស្ថានសួគ៌[ន]មកអំពីព្រះ ១១ទាំងមាន
សិរីល្អនៃព្រះ[ប] ហើយពន្លឺរស្មីរបស់ទីក្រុងនោះ ក៏ដូចជាត្បូង
មានដំឡៃថ្លៃវិសេស គឺដូចជាត្បូងមណីជោតិ[ផ] ហើយថ្លាដូច
ជាកែវចរណៃ[ព] ១២ក្រុងនោះមានកំផែងធំ ហើយខ្ពស់មាន
ទ្វារ១២[ភ] ឯត្រង់ទ្វារទាំងនោះមានទេវតា១២ ហើយមាន
ឈ្មោះឆ្លាក់ទុក ដែលជាឈ្មោះរបស់ពូជអំបូរជនជាតិ
អ៊ីស្រាអែលទាំង១២[ម] ១៣នៅទិសខាងកើតមានទ្វារ៣ ខាង
ជើងមានទ្វារ៣ ខាងត្បូងមានទ្វារ៣ ហើយខាងលិចមាន
ទ្វារ៣ដែរ ១៤កំផែងនៃទីក្រុងក៏មានជើង១២[យ] ដែលមាន
ឆ្លាក់ឈ្មោះ ជាឈ្មោះពួកសាវក[រ]របស់កូនចៀមទាំង១២
នាក់ ។
១៥ឯទេវតា ដែលនិយាយមកខ្ញុំ នោះក៏មានកាន់រង្វាស់[ល]
មាស ដើម្បីនឹងវាស់ទីក្រុង នឹងទ្វារ[វ] ហើយកំផែងក្រុងដែរ
១៦ទីក្រុងនោះមានរាង៤ជ្រុង បណ្ដោយនឹងទទឹងស្មើគ្នា
ទេវតាក៏យករង្វាស់ទៅវាស់ទីក្រុង ឃើញមាន១២ពាន់
ស្តាដ ឯបណ្ដោយ ទទឹង ហើយកំពស់ក៏ស្មើគ្នាទាំងអស់ ១៧ក៏
វាស់កំផែងឃើញ១៤៤ហត្ថ តាមរង្វាស់មនុស្សជាតិ[ស]ដែល

**២១:៧** ឋ ខ.៣ ២សយ ៧:១៤ ២កថ ៦:១៦ រម ៨:១៤
**២១:៨** ឌ ខ.២៧ ទជ ៥:៦ ១កថ ៦:៩ ហព ១២:១៤ វវ ២២:១៥ ឍ វវ ៩:១៧ ណ វវ ២:១១
**២១:៩** ត វវ ១៥:១,៦,៧ ថ វវ ១៩:៧
**២១:១០** ទ អគ ៤០:២ វវ ១៧:៣ ធ វវ ១:១០ ន ខ.២
**២១:១១** ប ខ.២៣ អស ៦០:១,២ អគ ៤៣:២ វវ ១៥:៨ ២២:៥ ផ ខ.១៨,១៩ វវ ៤:៣ ព វវ ៤:៦
**២១:១២** ភ ខ.១៥,២១,២៥ វវ ២២:១៤ ម អគ ៤៨:៣០–៣៤
**២១:១៤** យ អភ ២:២០ ហព ១១:១០ រ កច ១:២៦ អភ ២:២០
**២១:១៥** ល អគ ៤០:៣ វវ ១១:១ វ ខ.១២
**២១:១៧** ស វវ ១៣:១៨
**២១:១៨** ហ ខ.១១ ឡ ខ.២១
**២១:១៩** អ នក ២៨:១៧–២០ អស ៥៤:១១,១២ អគ ២៨:១៣ ក ខ.១១

ទេវតាប្រើ ១៨កំផែងនោះបានធ្វើពីត្បូងមណីជោតិ[ហ] ហើយ
ទីក្រុងក៏ធ្វើពីមាសសុទ្ធ ដូចជាកែវថ្លាល្អ[ឡ] ១៩ជើងកំផែងបាន
តាក់តែង ដោយត្បូងមានដំឡៃគ្រប់យ៉ាង[អ] ជើងទី១មាន
ត្បូងមណីជោតិ[ក] ទី២មានត្បូងកណ្ដៀង ទី៣មានត្បូងមោរ៉ា
ទី៤មានត្បូងមរកត ២០ទី៥មានត្បូងសាមសី ទី៦មានត្បូង
ពិទាយ[ខ] ទី៧មានត្បូងប៊ុតលឿង ទី៨មានត្បូងបេរីល ទី៩
មានត្បូងទោប៉ាត់ ទី១០មានត្បូងយក់ ទី១១មានត្បូងនិល ទី
១២មានត្បូងត្របែក ២១ទ្វារទាំង១២[គ] ជាកែវមុក្តា១២[ឃ]
គឺទ្វារ១ធ្វើពីកែវមុក្តា១ ហើយផ្លូវក្រុងក៏ធ្វើពីមាសសុទ្ធ ថ្លា
ដូចជាកែវ[ង]។
២២ខ្ញុំមិនឃើញមានព្រះវិហារណា[ច] នៅក្នុងក្រុងនោះ
ទេ ដ្បិតព្រះអម្ចាស់ ជាព្រះដ៏មានព្រះចេស្ដាបំផុត[ឆ] ព្រម
ទាំងកូនចៀមដែរ[ជ] ទ្រង់ជាព្រះវិហារនៃទីក្រុងនោះ ២៣ក្រុង
នោះមិនត្រូវការនឹងព្រះអាទិត្យ ឬព្រះចន្ទ សំរាប់នឹងបំភ្លឺទេ
ដ្បិតសិរីល្អ[ឈ]នៃព្រះបានបំភ្លឺហើយ[ញ] ឯកូនចៀម[ដ]ក៏ជា
ចង្កៀងនៃក្រុងនោះដែរ ២៤អស់ទាំងសាសន៍នឹងដើរក្នុង
ពន្លឺក្រុងនោះ អស់ទាំងស្តេចនៅផែនដី ក៏យកសិរីនៃខ្លួន
មកទុកក្នុងក្រុងនោះដែរ[ឋ] ២៥ទ្វារក្រុង[ឌ]នោះទាំងប៉ុន្មានមិន
ដែលបិទ[ឍ]នៅពេលថ្ងៃទេ ហើយនៅឯណោះគ្មានយប់
ឡើយ[ណ] ២៦មនុស្សលោកនឹងយកសិរីល្អ នឹងកេរ្តិ៍ឈ្មោះ
របស់សាសន៍ទាំងប៉ុន្មានមកទុកក្នុងក្រុងនោះ[ត] ២៧ក៏គ្មានអ្វី
ស្មោកគ្រោក ឬអ្នកណាដែលប្រព្រឹត្តបែបគួរខ្ពើម ឬ
សេចក្ដីកំភូតណា[ថ]ចូលទៅក្នុងទីក្រុងនោះបានឡើយ ចូល
បានតែអ្នកណា ដែលមានឈ្មោះកត់ទុក ក្នុងបញ្ជីជីវិត
របស់កូនចៀមប៉ុណ្ណោះ[ទ]។

**២១:២០** ខ វវ ៤:៣ **២១:២១** គ ខ.១២ ឃ អស ៥៤:១២ ង ខ.១៨
**២១:២២** ច យហ ៤:២១,២៣ ឆ វវ ១:៨ ជ វវ ៥:៦ **២១:២៣** ឈ ខ.១១
ញ អស ២៤:២៣ ៦០:១៩,២០ វវ ២២:៥ ដ វវ ៥:៦ **២១:២៤** ឋ ខ.២៦
អស ៦០:៣,៥ **២១:២៥** ឌ ខ.១២ ឍ អស ៦០:១១ ណ សក ១៤:៧
វវ ២២:៥ **២១:២៦** ត ខ.២៤ **២១:២៧** ថ អស ៥២:១ យអ ៣:១៧
វវ ២២:១៤,១៥ ទ វវ ២០:១២

**២១:៨** *ពួកខ្លាច ... មនុស្សកំភូត* មើលការពន្យល់ ១:២៩–៣១ ។ បានជាពាក្យថា “ពួកខ្លាច” នេះបានរៀបមុនគេនៅក្នុងបញ្ជីនេះគឺដោយសារតែពួកនេះជាមនុស្សខ្វះភាពស្មោះត្រង់ដល់ព្រះដ៏មានជ័យជម្នះ (ខ.៧) ។ *ពួកមន្តអាគម* មើល កច ១៩:១៩ ។ នៅសម័យមុន ឱសថបុរាណដែលធ្វើពីរុក្ខជាតិនានានោះត្រូវបានគេបន្ថែមមន្តអាគម របស់វិញ្ញាណអាក្រក់ទៀតផង ។ *បឹងដែលឆេះជាភ្លើង និងស្ពាន់ធ័រ* មើលការពន្យល់ ១៩:២០ ។

**២១:៩** *សេចក្ដីវេទនាទាំង៧* មើល ១៥:១ ។

**២១:១០** *វិញ្ញាណខ្ញុំ* មើលការពន្យល់ ១:១០ ៤:២ ១៧:៣ ។

**២១:១២** *ទ្វា១២* មើល អគ ៤៨:៣០–៣៥ ។ លេខ១២ប្រហែលជាបញ្ជាក់ពីពួកជំនុំទាំង១២ខាងមុខទៀតនៅក្នុងសញ្ញាថ្មី និងមនុស្សរបស់ព្រះទាំង១២នាក់នៅក្នុងសញ្ញាចាស់ ។ នៅក្នុង ខ.១៤ ក៏បានបញ្ជាក់ពីកំផែងនៃទីក្រុងក៏មានឆ្លាក់ឈ្មោះពួកសាវ័កទាំង១២ ។

**២១:១៥** *វាស់ទីក្រុង* មើល អគ ៤០–៤១ ។ នៅក្នុងបទគម្ពីរ “វវ ១១” បានបង្ហាញអំពីការវាស់នេះថា គឺដើម្បីអះអាងពីតំបន់ដែលត្រូវការពារ ។ ចំណុចនេះបានបង្ហាញអំពីទំហំ និងភាពស៊ីគ្នានៃសេចក្ដីជំនឿដែលមាននៅទីកន្លែងនោះ ។

**២១:១៦** *បណ្ដោយ . . . ទទឹង . . . កំពស់* គឺជារាងគូប (បួនជ្រុងស្មើ) ជាកន្លែងមួយដែលបរិសុទ្ធបំផុតនៅក្នុងរោងឧបោសថ និងក្នុងព្រះវិហារ ។

### ទន្លេជីវិត

**២២** ១ទេវតាក៏បង្ហាញ ឱ្យខ្ញុំឃើញទន្លេ[ធ]ទឹកជីវិត[ន] ថ្លាដូច
ជាកែវចរណៃ[ប] ដែលហូរចេញ[ផ]ពីបល្ល័ង្កនៃព្រះ នឹងកូន
ចៀម ២ឯនៅកណ្ដាលផ្លូវក្រុងនោះ ហើយនៅមាត់ទន្លេ
ទាំងសងខាង នោះមានដើមជីវិត[ព] ដែលបង្កើតផ្លែ ១២ ដង
គឺ ១ ខែម្ដងៗ ហើយស្លឹកឈើនោះ ក៏សំរាប់នឹងមើលអស់
ទាំងសាសន៍ឱ្យជា[ភ] ៣គ្រានោះ នឹងគ្មានសេចក្ដីបណ្ដាសា
ទៀតឡើយ[ម] ហើយបល្ល័ង្កនៃព្រះ នឹងកូនចៀម ក៏នឹងនៅក្នុង
ក្រុងនោះ ឯពួកបាវរបស់ទ្រង់ គេនឹងបំរើទ្រង់[យ] ៤គេនឹង
ឃើញព្រះភក្ត្រទ្រង់[រ] ហើយព្រះនាមទ្រង់នឹងនៅលើថ្ងាស
គេ[ល] ៥ក៏នឹងឥតមានយប់ទៀតឡើយ[វ] ហើយគេមិនត្រូវការ
នឹងចង្កៀងណា ឬពន្លឺព្រះអាទិត្យទេ ពីព្រោះព្រះអម្ចាស់ដ៏
ជាព្រះទ្រង់នឹងបំភ្លឺគេ[ស] ហើយគេនឹងសោយរាជ្យ នៅអស់
កល្បជានិច្ចរៀងរាបតទៅ[ហ]។
៦ទេវតាក៏និយាយមកខ្ញុំថា[ឡ] ពាក្យទាំងនេះពិតប្រាកដ
ហើយគួរជឿ[អ]ឯព្រះអម្ចាស់ដ៏ជាព្រះនៃវិញ្ញាណពួកហោរា[ក]
ទ្រង់ក៏ចាត់ទេវតាទ្រង់មក[ខ]បង្ហាញឱ្យពួកបាវបំរើទ្រង់ឃើញ
ការដែលបន្តិចទៀតត្រូវកើតមក។

### ព្រះយេស៊ូវមកជាឆាប់

៧មើល អញមកជាឆាប់[គ] មានពរហើយ[ឃ] អ្នកណា
ដែលកាន់តាមសេចក្ដីទំនាយក្នុងគម្ពីរនេះ[ង]។
៨គឺយ៉ូហានខ្ញុំ ដែលបានឃើញ ហើយឮសេចក្ដីទាំងនេះ[ច]
លុះខ្ញុំឮ ហើយឃើញ នោះខ្ញុំក៏ទំលាក់ខ្លួនរៀបនឹងថ្វាយបង្គំ
នៅទៀបជើង[ឆ]នៃទេវតា ដែលបង្ហាញឱ្យខ្ញុំឃើញសេចក្ដី
ទាំងនេះ ៩តែទេវតាប្រាប់ខ្ញុំថា កុំឱ្យធ្វើដូច្នេះឡើយ ខ្ញុំក៏ជា
បាវបំរើជាមួយនឹងអ្នកដែរ ហើយជាមួយនឹងពួកហោរា
ជាបងប្អូនអ្នក និងពួកអ្នកដែលកាន់តាមព្រះបន្ទូលក្នុងគម្ពីរ
នេះផង[ជ] ចូរថ្វាយបង្គំដល់ព្រះវិញចុះ[ឈ]។
១០រួចទេវតាប្រាប់មកខ្ញុំថា កុំឱ្យបំបិទ[ញ]សេចក្ដីទំនាយ
នៅក្នុងគម្ពីរនេះឡើយ[ដ] ពីព្រោះពេលកំណត់ជិតដល់
ហើយ[ឋ] ១១អ្នកណាដែលទុច្ចរិត ឱ្យអ្នកនោះនៅតែទុច្ចរិត
អ្នកដែលស្មោគគ្រោក ឱ្យអ្នកនោះនៅតែស្មោគគ្រោកចុះ
តែអ្នកណាដែលសុចរិតវិញ ត្រូវឱ្យអ្នកនោះចេះតែប្រព្រឹត្ត
ផ្លូវសុចរិតទៅ ហើយអ្នកណាដែលបរិសុទ្ធ ឱ្យអ្នកនោះនៅ
តែបរិសុទ្ធដដែល[ឌ] ១២មើល អញមកជាឆាប់[ឍ] ទាំងនាំ
យករង្វាន់មកជាមួយ[ណ] ដើម្បីនឹងចែកឱ្យគ្រប់គ្នា តាមការ
ដែលខ្លួនបានធ្វើ[ត] ១៣អញជាអាលផា និងអូមេកា[ថ] គឺជា
មុនគេ ហើយក្រោយ[ទ]គេ ជាដើម ហើយជាចុង[ធ] ១៤មាន
ពរហើយអស់អ្នកណាដែលលាងអាវខ្លួន[ន] ដើម្បីឱ្យបាន
ច្បាប់ដល់ដើមជីវិត[ប] ហើយឱ្យបានចូលទៅក្នុងក្រុង[ផ]តាម
ទ្វារ[ព] ១៥ខាងក្រៅ[ភ]មានសុទ្ធតែពួកឆ្កែ[ម] ពួកមន្តអាគម ពួក
កំផិត ពួកកាប់សំឡាប់គេ ពួកថ្វាយបង្គំរូបព្រះ ហើយគ្រប់

**២២:១** ធ ទដ ៣៦:៨ ៤៦:៤ ន ខ.១៧ យហ ៤:១០ ប វវ ៤:៦ ផ អគ ៤៧:១ សក ១៤:៨ **២២:២** ព វវ ២:៧ ភ អគ ៧:១៥ **២២:៣** ម សក ១៤:១១ យ វវ ៧:១៥ **២២:៤** រ មថ ៥:៨ ល វវ ៧:៣ **២២:៥** វ វវ ២១:២៥ សក ១៤:៧ ស អស ៦០:១៩,២០ វវ ២១:២៣ ហ ដយ ៧:២៧ វវ ២០:៤ **២២:៦** ឡ វវ ១:១ អ វវ ២១:៥ ក ១កថ ១៤:៣២ ហព ១២:៩ ខ ខ.១៦ វវ ១:១ **២២:៧** គ ខ.១២,២០ មថ ១៦:២៧ ឃ វវ ១:៣ ១៦:១៥ ង ខ.១០,១៨,១៩ **២២:៨** ច វវ ១:១ ឆ វវ ១៩:១០ **២២:៩** ជ ខ.១០, ១៨,១៩ ឈ វវ ១៩:១០ **២២:១០** ញ ដយ ៨:២៦ វវ ១០:៤ ដ ខ.៧,១៨,១៩ ឋ រម ១៣:១១ **២២:១១** ឌ អគ ៣:២៧ ដយ ១២:១០ **២២:១២** ឍ ខ.៧,២០ មថ ១៦:២៧ ណ អស ៤០:១០ ៦២:១១ ត មថ ១៦:២៧ **២២:១៣** ថ វវ ១:៨ ទ វវ ១:១៧ ធ វវ ២១:៦ **២២:១៤** ន វវ ៧:១៤ ប វវ ២:៧ ផ វវ ២១:២៧ ព វវ ២១:១២ **២២:១៥** ភ ដយ ២៣:១៨ ១កថ ៦:៩,១០ កទ ៥:១៩–២១ កល ៣:៥,៦ វវ ២១:៨ ម ភល ៣:២

**២២:១** *ទន្លេទឹកជីវិត* សេចក្ដីបរិយាយនៃទន្លេនៅត្រង់នេះហាក់បីដូចជាដើម្បីភ្ជាប់វត្ថុធាតុសំខាន់ៗជាច្រើនដែលមាននៅក្នុងសួនច្បារអេដែន (លប ២:៨–១៤) និងទន្លេដែលមានទឹកហូរមកពីព្រះវិហារថ្មី ក្នុងគម្ពីរអេសេគាល (អគ ៤៧:១–១២) ហើយព្រមទាំងភ្ជាប់នឹងវត្ថុធាតុថ្មីៗផ្សេងដទៃទៀតផងដែរ ។

**២២:២** *ដើមជីវិត* មើល ខ.១៤ លប ២:៩ ៣:២២ អគ ៤៧:១២ ។

**២២:៤** *គេនឹងឃើញព្រះភក្ត្រទ្រង់* ឃ្លានេះសំដៅលើជនឧក្រិដ្ឋនៅសម័យបុរាណដែលត្រូវបានគេបណ្ដេញចេញពីព្រះភក្ត្រស្ដេច (អគ ៧:៨ ២សយ ១៤:២៤) ។ ព្រះពរមួយនៃជីវិតអស់កល្ប នោះពួកគេនឹងឃើញព្រះភក្ត្រព្រះអម្ចាស់មុខទល់នឹងមុខ (១កថ ១៣:១២ ១យហ ៣:២) ។ *ព្រះនាមទ្រង់* មើលការពន្យល់ ៣:១២ ។

**២២:៥** *គេនឹងសោយរាជ្យ* មើល ៥:១០ ២០:៦ ដយ ៧:១៨,២៧ ។

**២២:៦** *បាវបំរើរបស់ទ្រង់* មើល ខ.៣ ។ *បន្តិចទៀតត្រូវកើតមក* មើល ១:១,១៩ ។

**២២:៧** *អញមកជាឆាប់* មើល ខ.១២,២០ ២:១៦ ៣:១១ ។

**២២:៨** *ទំលាក់ខ្លួនរៀបនឹងថ្វាយបង្គំ* មើលការពន្យល់ ១:១៧ ។

**២២:៩** *កុំឱ្យធ្វើដូច្នេះ* ត្រង់នេះគឺជាព្រឹត្តិការណ៍ដែលបានកើតឡើងដដែលៗ (១៩:១០) ដើម្បីរំលឹកដល់អ្នកអាន អ្នកស្ដាប់ថា មិនត្រូវថ្វាយបង្គំនូវអ្វីដែលព្រះបានបង្កើតនោះទេ ទោះជាមានរូបភាពជាអភិជន ទេវតា រូបចម្លាក់ ឬអ្វីផ្សេងពីនេះយ៉ាងណានោះក៏ដោយ ក៏ត្រូវហាមយ៉ាងដាច់ខាតដែរ (ខ.១៥ ២១:៨ នក ៣៤:១៥ និងការពន្យល់ លប ២០:៩) ។

**២២:១០** *កុំឱ្យបំបិទសេចក្ដីទំនាយនៅក្នុងគម្ពីរ* ត្រង់នេះគឺផ្ទុយគ្នាទៅនឹង "ដយ ១២:៤" ។ *ពេលកំណត់ជិតដល់ហើយ* មើល ខ.១០ មានន័យថាហួសពេល ហើយចំពោះពួកអ្នកដែលមិនបានប្រែចិត្តពីមុននោះ ។ ពួកអ្នកដែលមិនបានប្រែចិត្ត នោះត្រូវតែប្រឈរមុខនឹងទង្វើរបស់ពួកគេ (ខ.១២) ។

**២២:១២** *អញមកជាឆាប់* មើល ខ.៧,២០ ២:១៦ ៣:១១ ។ *តាមការដែលខ្លួនបានធ្វើ* មើលការពន្យល់ ២:២៣ ២០:១២ ។

**២២:១៣** *អាលផា និងអូមេកា* មើលការពន្យល់ ១:៨ ។

**២២:១៤** *មានពរហើយ* នេះគឺជាព្រះពរទី៧ចុងក្រោយ (មើលការពន្យល់ ១:៣) ។ *លាងអាវខ្លួន* គឺលាងឈាមនៃកូនចៀម (៧:១៤) ។

**២២:១៥** *ពួកឆ្កែ . . . កំភូត* មើលពន្យល់ រម ១:២៩–៣១ ។ *ពួកឆ្កែ* ពាក្យមួយនេះសម្រាប់ប្រើចំពោះប្រភេទមនុស្សមិនល្អ ដែលមានចិត្តមិនស្មោះ ។

ទាំងអ្នកណាដែលស្រឡាញ់ ហើយប្រព្រឹត្តសេចក្ដីកំភូត ។
១៦អញ ឈ្មោះយេស៊ូវ[យ] បានចាត់ទេវតារបស់អញ[រ]
មកធ្វើបន្ទាល់ ប្រាប់ឱ្យឯងរាល់គ្នាដឹងពីសេចក្ដីទាំងនេះ
នៅក្នុងពួកជំនុំទាំងប៉ុន្មាន[ល] អញជាឫស[វ] ហើយជាពូជហ្លួង
ដាវីឌ[ស] ជាផ្កាយព្រឹកដ៏ភ្លឺចិញ្ចែង[ហ] ១៧ព្រះវិញ្ញាណ[ឡ]នឹង
ប្រពន្ធថ្មោងថ្មី[អ]ពោលថា អញ្ជើញមក ហើយអ្នកណាដែល
ឮ ក៏ថា អញ្ជើញមកដែរ អ្នកណាដែលស្រេក នោះមានតែ
មក ហើយអ្នកណាដែលចង់បាន មានតែយកទឹកជីវិតនោះ
ចុះ ឥតចេញថ្លៃទេ[ក] ។
១៨ខ្ញុំធ្វើបន្ទាល់ ដល់អស់អ្នកណា ដែលឮសេចក្ដីទំនាយ
ក្នុងគម្ពីរនេះថា[ខ] បើអ្នកណាបញ្ចូលអ្វីក្នុងសេចក្ដីទាំងនេះ[គ]
នោះព្រះទ្រង់នឹងបន្ថែមអស់ទាំងសេចក្ដីវេទនាដែលកត់ទុក
ក្នុងគម្ពីរនេះ ដល់អ្នកនោះផង[ឃ] ១៩ហើយបើអ្នកណាដកអ្វី[ង]
ពីព្រះបន្ទូលក្នុងគម្ពីរនៃសេចក្ដីទំនាយនេះ[ច]ចេញ នោះព្រះ
ទ្រង់នឹងដកចំណែក ដែលអ្នកនោះមានដល់ដើមជីវិត[ឆ]
និងទីក្រុងបរិសុទ្ធ ហើយនិងសេចក្ដីទាំងប៉ុន្មាន ដែល
កត់ទុកក្នុងគម្ពីរនេះចេញដែរ ។
២០ព្រះអង្គ ដែលធ្វើបន្ទាល់ពីសេចក្ដីទាំងនេះ[ជ] ទ្រង់មាន
បន្ទូលថា អើ អញមកជាឆាប់[ឈ]។ អាម៉ែន ព្រះអម្ចាស់
យេស៊ូវអើយ សូមយាងមក[ញ]។ ២១សូមឱ្យអ្នករាល់គ្នាបាន
ប្រកបដោយព្រះគុណនៃ ព្រះយេស៊ូវគ្រីស្ទ[ដ]ជាព្រះអម្ចាស់
នៃយើងរាល់គ្នា ។ អាម៉ែន ។

**២២:១៦** យ វវ ១:១ រ ខ.៦ ល វវ ១:៤ វ វវ ៥:៥ ស មថ ១:១ ហ ២ពត ១:១៩ វវ ២:២៨
**២២:១៧** ឡ វវ ២:៧ ១៤:១៣ អ វវ ១៩:៧ ក យហ ៤:១០
**២២:១៨** ខ ខ.៧,១០, ១៩ គ ចទ ៤:២ ១២:៣២ សភ ៣០:៦ ឃ វវ ១៥:៦–១៦:២១
**២២:១៩** ង ចទ ៤:២ ១២:៣២ សភ ៣០:៦ ច ខ.៧,១០,១៨ ឆ វវ ២:៧
**២២:២០** ជ វវ ១:២ ឈ ខ.៧,១២ មថ ១៦:២៧ ញ ១កថ ១៦:២២
**២២:២១** ដ រម ១៦:២០

ពាក្យនេះដដែល នៅក្នុង "ដយ ២៣:១៨" គឺសំដៅទៅលើពួកសំផឹងប្រុស ។
**២២:១៦** *ទេវតារបស់អញ* មើល ១:១ ។ *ជាឫស ហើយជាពូជហ្លួងដាវីឌ* មើលការពន្យល់ ៥:៥ អស ១១:១,១០ រម ១:៣ ។ *ជាផ្កាយព្រឹកដ៏ភ្លឺចិញ្ចែង* មើលការពន្យល់ ជន ២៤:១៧ ។
**២២:១៨–១៩** ត្រង់ចំណុចនេះគឺជាបទបញ្ញាដែលបានចែងនៅក្នុង ចទ ៤:២ ១២:៣២ ។ ប៉ុន្តែ ការព្រមានត្រង់នេះទាក់ទងតែក្នុងគម្ពីរវិវរណៈប៉ុណ្ណោះ ។
**២២:២០** *អញមកជាឆាប់* មើល ខ.៧,១២ ២:១៦ ៣:១១ ។ *ព្រះអម្ចាស់យេស៊ូវអើយ សូមយាងមក* មើលការពន្យល់ ១កថ ១៦:២២ ។
**២២:២១** *ព្រះគុណ* មើលការពន្យល់ រម ១:៧ ។ *បានប្រកប* មើលការពន្យល់ ២កថ ១៣:១៤ ។ *អាម៉ែន* មើលពន្យល់ ចទ ២៧:១៥ រម ១:២៥ ។